បើកមាត់ក្នុងការទទួលឈាមរបស់ប្អូនរបស់អ្នក
ព្រះមានបន្ទូលអំពីផែនដីដូចជាមនុស្សដែលអាចផឹកឈាមរបស់អេបិល។ ការបកប្រែផ្សេងទៀត៖ «ដែលត្រាំជាមួយឈាមរបស់បងប្អូនអ្នក»
ពីដៃរបស់អ្នក
ព្រះជាម្ចាស់មានបន្ទូលអំពីដៃរបស់កាអ៊ីនដូចជាបានចាក់ឈាមរបស់អេបិលចូលទៅក្នុងមាត់ដី។ ការបកប្រែផ្សេងទៀត៖ «ដែលបានកំពប់ពេលអ្នកសម្លាប់គាត់» ឬ «ពីអ្នក»
ភ្ជួររាស់ដី
នេះមានន័យថាធ្វើអ្វីគ្រប់យ៉ាងចាំបាច់ដើម្បីធ្វើឱ្យរុក្ខជាតិលូតលាស់បានល្អ។ សូមមើលពីរបៀបដែល« ការដាំដុះ» ជំពូក ២: ៤
វាលែងបង្កើតផលច្រើនដូចមុនទៀតហើយ
ដីមានលក្ខណៈដូចជាមនុស្សដែលបាត់បង់កម្លាំង។ ការបកប្រែផ្សេងទៀត៖ «ដីនឹងមិនផ្តល់ផលច្រើនសម្រាប់អ្នកទេ»
ស្មៅព្រាត់
អ្នកអាចចូលរួមជាមួយពាក្យទាំងនេះជាមួយគ្នា។ ការបកប្រែផ្សេងទៀត៖ «អ្នកសាត់ព្រាត់គ្មានផ្ទះសម្បែង»
Genesis 4:13
ទូលបង្គំនឹងលាក់ខ្លួននៅចំពោះព្រះភក្ត្ររបស់ព្រះអង្គ
នៅទីនេះ «ព្រះភ័ក្ត្រ» គឺតំណាងព្រះវត្តមានព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត៖ «ទូលបង្គំនឹងមិនអាចនិយាយជាមួយទ្រង់បានទេ»
សាត់ព្រាត់ ហើយអណ្តែតត្រសែត
ព្រះអម្ចាស់មានបន្ទូលទៅកាអ៊ីនថា៖ «តើអ្នកបានធ្វើអ្វីដូច្នេះ? ឈាមរបស់ប្អូនប្រុសរបស់អ្នកកំពុងតែស្រែករកយើងពីដីមក»។
នឹងត្រូវសងសឹកមួយជាប្រាំពីរ
នេះបានបង្ហាញក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖ «ខ្ញុំនឹងសងសឹកដល់គាត់ប្រាំពីរដង» ឬ «ខ្ញុំនឹងដាក់ទណ្ឌកម្មលើគាត់៧ដងដូចខ្ញុំដាក់ទណ្ឌកម្មអ្នក»
មិនអាចប្រហារគាត់បានឡើយ
«មិនត្រូវសម្លាប់ដល់កាអ៊ីនឡើយ»
Genesis 4:16
បានចេញពីព្រះវត្តមានរបស់ព្រះអម្ចាស់
ទោះបីជាព្រះអម្ចាស់គង់នៅគ្រប់ទីកន្លែងក៏ដោយ ប៉ុន្តែកាអ៊ីនដូចជាគាត់បានទៅឆ្ងាយ។ ការបកប្រែផ្សេងទៀត៖ «ដែលគាត់បានចាកចេញពីកន្លែងដែលព្រះអម្ចាស់បានមានបន្ទូលទៅគាត់»
ណូឌ
អាចប្រែថា «ពាក្យណូឌ»មានន័យថា «កំពង់ រង្វេង»។
បានគេងជាមួយ
អាចនិយាយគួរសម។ ជំនាន់មុនខ្លះនិយាយថា «ស្គាល់»
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង៤: ១
បុរសបានគេងជាមួយនាងអេវ៉ាភរិយារបស់គាត់។ នាងមានផ្ទៃពោះ ហើយបង្កើតបានកាអ៊ីន។ នាងនិយាយថា៖ «ខ្ញុំបានបង្កើតបុរសម្នាក់ដោយសារព្រះអម្ចាស់ជួយ»។
គាត់បានសង់ទីក្រុង
«កាអ៊ីនបានកសាងទីក្រុងមួយ»
Genesis 4:18
លោកអេណុកបង្កើតអ៊ីរ៉ាដ
វាបញ្ជាក់ថាអេណុកធំឡើងហើយរៀបការជាមួយស្ត្រីម្នាក់។ ការបកប្រែផ្សេងទៀត៖ «អេណុកបានធំឡើងហើយរៀបការ ហើយបានក្លាយជាឪពុករបស់កូនប្រុសដែលគាត់ដាក់ឈ្មោះអ៊ីរ៉ាដ»
លោកអ៊ីរ៉ាដជាឪពុករបស់មហ៊ូយ៉ែល
«លោកអ៊ីរ៉ាដបានបង្កើតកូនប្រុសមួយដែលបានដាក់អោយមហ៊ូយ៉ែល»
អដា .....ស៊ីឡា
ឈ្មោះរបស់ស្ត្រីទាំងពីរនោះ។
Genesis 4:20
នាងអដា.....នាងស៊ីឡា
បកប្រែឈ្មោះទាំងនេះនៅក្នុង ៤:១៩។
គាត់ជាឪពុករបស់អស់អ្នកដែលរស់នៅក្នុងជំរុំ
អត្ថន័យទី១) «គាត់គឺជាមនុស្សទី១ដែលរស់នៅក្នុងជំរុំ ឬទី២)គាត់ហើយនិងពូជពង្សគាត់ជាអ្នកដែលបានរស់នៅក្នុងជំរុំ»
អ្នកដែលរស់នៅក្នុងជំរុំនៃអ្នកដែលមានហ្វូងសត្វ
មនុស្សណាដែលរស់នៅក្នុងជំរុំហើយក៏ជាអ្នកដែលត្រូវមើលថែទាំសត្វដែរ។
គាត់ជាឪពុកនៃអស់អ្នកលេងពិណ និងចាប៉ី
អត្ថន័យទី១) «គាត់គឺជាបុគ្គលដំបូងដែលលេងពិណនិងចាប៉ី» ឬទី២) «គាត់ហើយនិងពូជអំបូររបស់គាត់ជាអ្នកលេងពិណនិងចាប៉ី»
ជាឪពុកនៃពួកជាងលង្ហិន និងដែក
«ទូបាកាអ៊ីន។ គាត់គឺជាជាងលង្ហិន និងជាងដែក»
ដែក
នេះគឺជាប្រភេទដែកដែលរឹងដែលប្រើសម្រាប់ធ្វើគ្រឿងសាស្ត្រាវុធ។
Genesis 4:23
អដា និងស៊ីឡា
៤:១៩លោកឡាម៉េកមានភរិយាពីរនាក់ ម្នាក់ឈ្មោះ នាងអដា ហើយម្នាក់ទៀតឈ្មោះនាងស៊ីឡា។

generated on Wed Sep 10 16:16:32 2025

ចូរស្តាប់សម្លេងរបស់ខ្ញុំ .....ស្តាប់អ្វីដែលខ្ញុំនិយាយ
ឡាមេកបាននិយាយដូចគ្នាពីរដងសម្រាប់ការសង្កត់ធ្ងន់។
សម្លេងរបស់គាត់គឺជាពាក្យសំដីសម្រាប់មនុស្សទាំងមូលរបស់គាត់។
ការបកប្រែផ្សេងទៀត៖ «ស្តាប់ខ្ញុំដោយយកចិត្តទុកដាក់»
បុរសម្នាក់.....យុវជនម្នាក់
ឡាមេកបានសម្លាប់មនុស្សម្នាក់។
ឲ្យខ្ញុំរងរបួស.....បានវាយដំខ្ញុំ
«ដោយព្រោះគាត់បានធ្វើអោយខ្ញុំរបួស...ដោយព្រោះតែគាត់បានវាយដំខ្ញុំ»
ឬ«ពីព្រោះតែគាត់បានធ្វើអោយខ្ញុំឈឺចាប់»
ប្រសិនបើ គេសងសឹងចំពោះលោកកាអ៊ីនមួយជាប្រាំពីរ ,ចុះឡាម៉េក
ឡាមេកបានដឹងថា ព្រះនឹងសងសឹកកាអ៊ីនប្រាំពីរដង។ ការបកប្រែផ្សេងទៀត៖ «
ព្រោះព្រះនឹងដាក់ទោសដល់អ្នកណាដែលសម្លាប់កាអ៊ីន ដល់ទៅ៧ ដង ឡាមេក»
ដូច្នេះ ត្រូវសងសឹកដល់ឡាម៉េកមួយជាចិតសិបដងវិញ
ប្រាំពីរដង - នេះអាចនៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«អ្នកណាដែលសម្លាប់ខ្ញុំ ព្រះជាម្ចាស់នឹងដាក់ទណ្ឌកម្មដល់ទៅចិតសិបប្រាំពីរដង»
៧៧
ជាលេខ - ៧៧
Genesis 4:25
បានគេងជាមួយ
នៅក្នុងភាសាដែលគួរសម។នៅសម័យមុនគេនិយាយថា «ស្គាល់»
សូមមើលនៅក្នុងជំពូក៤:១
ព្រះជាម្ចាស់បានប្រទានកូនប្រុសមួយទៀតដល់ខ្ញុំ
នេះគឺជាហេតុផលដែលបានដាក់ឈ្មោះអោយថាសេថ។
នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត៖ «ហើយបានពន្យល់ថា»
ព្រះជាម្ចាស់បានផ្តល់ឱ្យខ្ញុំនូវកូនមួយទៀត។ (សូមមើល:figs-explicit)
សេថ
អ្នកបកប្រែបានបន្ថែមថា «នេះគឺជាឈ្មោះដែលមាន»
ឈ្មោះនេះស្តាប់មើលទៅដូចជាពាក្យហេព្រើរមានន័យថា «បានផ្តល់ឱ្យហើយ»
លោកសេថមានកូនប្រុសម្នាក់
នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត៖
«ប្រពន្ធរបស់សេថបង្កើតបានកូនប្រុសមួយ» (សូមមើល:figs-explicit)
អំពាវនាវរកព្រះនាមរបស់ព្រះអម្ចាស់
នេះជាលើកទីមួយដែលមនុស្សបានហៅព្រះជាម្ចាស់តាមព្រះនាមយេហូវ៉ា។
នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត៖ «ថ្វាយបង្គំព្រះ ដោយ
ប្រើព្រះនាមព្រះអម្ចាស់»

---

5 [1]នេះគឺជាបញ្ជីពូជពង្សរបស់លោកអដាំ។ នៅថ្ងៃដែលព្រះជាម្ចាស់បានបង្កើតមនុស្សលោក ព្រះអង្គបានបង្កើតពួកគេឲ្យដូចជារូបភាពរបស់ព្រះអង្គ។
[2]ព្រះអង្គបង្កើតពួកគេជាប្រុស ជាស្រី។ នៅពេលព្រះអង្គបង្កើតពួកគេ ព្រះអង្គបានប្រទានពរដល់ពួកគេ ហើយដាក់ឈ្មោះឲ្យពួកគេថាជាមនុស្សលោក។
[3]នៅពេលលោកអដាំរស់បាន ១៣០ឆ្នាំ គាត់មានកូនប្រុសមួយដែលមានលក្ខណដូចជាគាត់ ដូចជារូបរបស់គាត់ ហើយគាត់បានដាក់ឈ្មោះកូនប្រុសនោះថា សេថ។
[4]បន្ទាប់ពីមានសេថជាកូនប្រុសហើយ គាត់រស់បានប្រាំបីរយឆ្នាំទៀត។ គាត់មានកូនប្រុស និងកូនស្រីជាច្រើនទៀត។[5]លោកអដាំរបស់បាន៩៣០ឆ្នាំ
បន្ទាប់គាត់ក៏ស្លាប់ទៅ។
[6]នៅពេលលោកសេថរស់បាន១៥០ឆ្នាំ គាត់បង្កើតបានកូនមួយឈ្មោះ អេណុស។[7]បន្ទាប់ពីគាត់បង្កើតលោកអេណុស គាត់រស់បាន៨០៧ឆ្នាំ ហើយគាត់មានកូនប្រុស
និងស្រីជាច្រើនទៀត។[8]លោកសេថរស់បាន៩១២ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[9]នៅពេលលោក អេណុសរស់បានកៅសិបឆ្នាំ គាត់បង្កើតបានកូនប្រុសមួយឈ្មោះកែណាន។[10]បន្ទាប់ពីគាត់បង្កើតបានកែណាន លោកអេណុសរបស់បាន ៨១៥។
[11]គាត់មានកូនប្រុស និងកូនស្រីជាច្រើនទៀត។ លោកអេណុសរបស់បាន ៩០៥ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[12]នៅពេលលោកកែណានរស់បានចិតសិបឆ្នាំ គាត់បង្កើតបានម៉ាលេលាល់។[13]បន្ទាប់ពីបង្កើតលោកម៉ាលេលាល់ លោកកែណានរស់បាន ៨៤០ឆ្នាំទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[14]លោកកែណានរស់បាន៩១០ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[15]នៅពេលលោកម៉ាលេលាល់រស់បានហុកសិបប្រាំឆ្នាំ គាត់បង្កើតបានយ៉ារ៉ែឌ។[16]បន្ទាប់មក គាត់បានបង្កើតលោកយ៉ារ៉ែឌហើយ លោកម៉ាលេលាស់រស់បាន ៨៣០ទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[17]លោកម៉ាលេលាល់រស់បាន៨៩៥ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[18]នៅពេលលោកយ៉ារ៉ែឌរស់បាន១៦១ឆ្នាំ គាត់បង្កើតបានហេណុក។[19]បន្ទាប់ពីលោកយ៉ារ៉ែឌបង្កើតលោកហេណុកមក លោកយ៉ារ៉ែឌរស់បានប្រាំបីរយឆ្នាំទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[20]លោកយ៉ារ៉ែឌរស់បាន ៩៦២ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[21]នៅពេលលោកហេណុករស់បានហុកសិបប្រាំឆ្នាំ គាត់បង្កើតបានមធូសាឡា។[22]បន្ទាប់មកគាត់បង្កើតបានមធូសាឡា លោកអេណុកដើរនៅចំពោះព្រះជាម្ចាស់បីរយឆ្នាំ។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[23]លោកហេណុករស់នៅបាន៣៦៥ឆ្នាំ។[24]លោកហេណុកដើរនៅចំពោះព្រះជាម្ចាស់ ហើយបន្ទាប់មក
គេលែងឃើញគាត់ទៀត ដ្បិត ព្រះជាម្ចាស់បានយកគាត់ទៅ។
[25]នៅពេលលោកមធូសាឡារស់បាន ១៨៧ឆ្នាំ គាត់បង្កើតបានឡាម៉េក។[26]បន្ទាប់ពីគាត់បង្កើតលោកឡាម៉េកមក លោកមធូសាឡារស់បាន ៧៨២ឆ្នាំទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[27]លោកមធូសាឡារបស់បាន ៩៦៩ឆ្នាំ។ បន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[28]នៅពេលលោកឡាម៉េករស់បាន ១៨២ឆ្នាំ គាត់បង្កើតបានកូនប្រុសមួយ។[29]គាត់ដាក់ឈ្មោះកូនរបស់គាត់ថា ណូអេ ដោយនិយាយថា៖
«ម្នាក់នេះនឹងជួយឲ្យយើងបានសម្រាកពីកិច្ចការរបស់យើង ហើយពីការធ្វើការដ៏ឈឺចាប់ដែលចេញពីដៃរបស់យើង ដែលយើងត្រូវធ្វើ
ដោយសារតែព្រះអម្ចាស់បានដាក់បណ្តាសាដល់ដី»។
[30]បន្ទាប់ពីគាត់បង្កើតបានលោកណូអេមក លោកឡាម៉េករស់បាន ៥៩៥ឆ្នាំទៀត។ គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[31]លោកឡាម៉េករស់បាន ៧៧៧ឆ្នាំ។
បន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[32]បន្ទាប់ពីលោកណូអេរស់បានប្រាំរយឆ្នាំ គាត់បង្កើតបាន សិម ហាំ និងយ៉ាផេត។

Genesis 5:1
ព័ត៌មានទូទៅ
នេះគឺជាការចាប់ផ្តើមនៃពូជអំបូររបស់អដាំ។
ឲ្យដូចជារូបភាពរបស់ព្រះអង្គ
ឃ្លានេះមានន័យថាព្រះបានធ្វើឲ្យមនុស្សមានលក្ខណដូចជាទ្រង់។
ខគម្ពីរនេះមិនបានប្រាប់តាមរបៀបណាដែលព្រះបានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់នោះទេ ដោយសារ
ព្រះមិនមានរូបរាងទេ ដូច្នេះវាមិនមានន័យថា មនុស្សមើលទៅដូចជាព្រះនោះទេ។
ការបកប្រែផ្សេងទៀត៖ «ធ្វើឱ្យដូចយើងយ៉ាងពិតប្រាកដ»។
សូមមើលពីរបៀបដែល «បន្ទាប់ពីមានភាពដូចយើង» សូមមើលនៅជំពូក ១:២៦
នៅពេលព្រះអង្គបង្កើតពួកគេ
នេះបានធ្វើអោយទៅជាសកម្ម។ ការបកប្រែផ្សេងទៀត៖
«នៅពេលដែលទ្រង់បង្កើតពួកគេ»

Genesis 5:3
១៣០.....ប្រាំបីរយឆ្នាំទៀត
អ្នកបកប្រែបានបកប្រែ«១៣០» និង«៨០០» ឬជាពាក្យ«មួយរយសាមសិប» និង
«ប្រាំបីរយ»។
គាត់បានក្លាយទៅជាឪពុកនៃកូនប្រុសមួយ
ការបកប្រែ
ដូចជារូបរបស់គាត់,បន្ទាប់ពីរូបគាត់
ត្រង់ចំណុចនេះមានអត្ថន័យពីរ។
ពួកគេបាននឹកចាំពីព្រះជាម្ចាស់ដែលបានមនុស្សមកក្នុងរូបភាពអង្គទ្រង់។
សូមមើលនៅក្នុងជំពូក១:២៦។
សេថ
ឈ្មោះដែលបានដាក់នៅក្នុងជំពូក៤:២៥។

generated on Wed Sep 10 16:16:32 2025

គាត់មានកូនប្រុស និងកូនស្រីជាច្រើនទៀត
«គាត់បានបង្កើតប្រុសកូនស្រីជាច្រើនទៀត»
បន្ទាប់គាត់ក៏ស្លាប់ទៅ
នៅឃ្លាត្រង់នេះបានរម្លឹកសារឡើងវិញម្តងទៀតនៅពេញមួយជំពូក។
លោកអាដាំរបស់បាន៩៣០ឆ្នាំ
មនុស្សរស់នៅដែលមានអាយុវែង។ ប្រើពាក្យធម្មតារបស់អ្នកសម្រាប់ «ឆ្នាំ» ។
ការបកប្រែផ្សេងទៀត៖ អាដាំរស់នៅសរុប ៩៣០ ឆ្នាំ»
Genesis 5:6
គាត់ជាឪពុករបស់អេណុស
នៅទីនេះ ពាក្យនេះមានន័យថា ជាឪពុកពិតប្រាដក នេះមិនមែនជាជីតាទេ។
ការបកប្រែផ្សេងទៀត៖ «គាត់មានកូនប្រុសមួយឈ្មោះថាអេណុស»
អេណុស
នេះគឺជាឈ្មោះបុគ្គលម្នាក់។
ហើយគាត់មានកូនប្រុស និងស្រីជាច្រើនទៀត
«ហើយគាត់មានកូនប្រុស និងស្រីជាច្រើនទៀត»
លោកសេថរស់បាន៩១២ឆ្នាំ
«លោកសេថសរុបអាយុរបស់គាត់គឺមាន៩១២ឆ្នាំ»
ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ
នៅត្រង់ចំនុចនេះជាជំពូកដែលបញ្ជាក់ពីការស្លាប់របស់គាត់។
Genesis 5:9
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ៥: ៦-២៧ មានទ្រង់ទ្រាយដូចគ្នា។
បកប្រែពួកវាយោងទៅតាមកំណត់ចំណាំក្នុង ៥: ៦ ។
Genesis 5:12
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ៥: ៦-២៧ មានទ្រង់ទ្រាយដូចគ្នា។
បកប្រែពួកវាយោងទៅតាមកំណត់ចំណាំក្នុង ៥: ៦ ។
Genesis 5:15
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ៥: ៦-២៧ មានទ្រង់ទ្រាយដូចគ្នា។
បកប្រែពួកវាយោងទៅតាមកំណត់ចំណាំក្នុង ៥: ៦ ។
Genesis 5:18
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ៥: ៦-២៧ មានទ្រង់ទ្រាយដូចគ្នា។
បកប្រែពួកវាយោងទៅតាមកំណត់ចំណាំក្នុង ៥: ៦ ។
Genesis 5:21
គាត់បង្កើតបានមធូសាឡា
«គាត់បានដាក់ឈ្មោះអោយកូនប្រុសរបស់គាត់ថាមធូសាឡា»
មធូសាឡា
នេះគឺជាឈ្មោះរបស់បុរសម្នាក់។
លោកហេណុកដើរនៅចំពោះព្រះជាម្ចាស់
ការដើរជាមួយនរណាម្នាក់គឺជាការប្រៀបធៀបមួយសម្រាប់ការមានទំនាក់ទំនងជិតស្និទ្ធជាមួយគាត់។
ការបកប្រែផ្សេងទៀត «ហេណុកមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់» ឬ
«ហេណុករស់នៅក្នុងការរួបរួមជាមួយព្រះជាម្ចាស់»
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត
«គាត់មានកូនប្រុសកូនស្រីជាច្រើនទៀត»
លោកហេណុករស់នៅបាន៣៦៥ឆ្នាំ
«លោកហេណុកគាត់រស់នៅបានអាយុ៣៦៥ឆ្នាំ»
បន្ទាប់មក គេលែងឃើញគាត់ទៀត
ចំពោះពាក្យថា «គាត់» គឺសំដៅទៅកាន់លោកហេណុក។
គាត់មិនបានរស់នៅយូរនៅលើផែនដីឡើយ។
ព្រះជាម្ចាស់បានយកគាត់ទៅ
នេះគឺមានន័យថា
ព្រះជាម្ចាស់បានលើកគាត់ឡើងជាមួយនិងទ្រង់ផ្ទាល់(ព្រះជាម្ចាស់)។
Genesis 5:25
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ៥: ៦-២៧ មានទ្រង់ទ្រាយដូចគ្នា។
បកប្រែយោងទៅតាមកំណត់ចំណាំក្នុង ៥: ៦ ។
ឡាម៉េក
ឈ្មោះឡាម៉េកនៅត្រង់នេះខុសពីឡាម៉េកនៅក្នុងលោកុប្បត្តិ៤:១៨។
Genesis 5:28
គាត់បង្កើតបានកូនប្រុសមួយ
គាត់មានកូនប្រុសមួយ
ណូអេ
អ្នកបកប្រែប្រហែលចង់និយាយថា «ឈ្មោះនេះដូចជាភាសាហេព្រើរ គឺមានន័យថា
ពីការធ្វើការដ៏ឈឺចាប់ដែលចេញពីដៃរបស់យើង
ឡាម៉េកបាននិយាយត្រង់ចំនុចនេះដូចគ្នា២ដង
ដែលសង្កត់ធ្ងន់ទៅលើពាក្យការងារដ៏លំបាក។ ការបកប្រែផ្សេងទៀត៖
«គឺត្រូវធ្វើការដោយហត់នឿយចេញពីដៃរបស់យើង»
Genesis 5:30
លោកឡាម៉េករស់បាន ៧៧៧ឆ្នាំ
<<លោកឡាម៉េកគាត់រស់នៅសរុបមានអាយុ៧៧៧ឆ្នាំ>>
Genesis 5:32
គាត់បានក្លាយជាឪពុករបស់
«គឺគាត់មានកូនប្រុស»
ត្រង់នេះមិនប្រាប់យើងថាតើកូនប្រុសកើតនៅថ្ងៃតែមួយឬឆ្នាំខុសគ្នាទេ។
សិម ហាំ និងយ៉ាផេត
កូនប្រុសៗមិនអាចត្រូវបានចុះក្នុងបញ្ជីកំណើតរបស់ពួកគេឡើយ។
ពីព្រោះមានការខ្វែងគំនិតគ្នាថាតើមួយណាកើតមកមុនគេ។
ជៀសវាងការបកប្រែនេះតាមរបៀបដែលបង្កប់ន័យថា
បញ្ជីគឺស្ថិតនៅក្នុងលំដាប់នៃអាយុរបស់ពួកគេ។

---

6 [1]នៅពេលមនុស្សកើនជាច្រើនឡើងនៅលើផែនដី
ហើយពួកគេបង្កើតបានកូនស្រីៗជាច្រើន[2]កូនប្រុសៗរបស់ព្រះជាម្ចាស់ឃើញថាពួកកូនស្រីៗរបស់មនុស្សមានការទាក់ទាញ។
ពួកគេបានយកកូនស្រីៗទាំងនោះមកធ្វើជាភរិយារបស់ពួកគេ ពួកគេបានជ្រើសរើសក្នុងចំណោមពួកស្រីៗទាំងនោះ។[3]ព្រះអម្ចាស់មានបន្ទូលថា៖
«វិញ្ញាណរបស់យើងនឹងមិននៅជាមួយមនុស្សលោករហូតទេ ដ្បិត ពួកគេជាសាច់ឈាម។ ពួកគេនឹងរស់នៅបាន១២០ឆ្នាំប៉ុណ្ណោះ»។
[4]នៅសម័យនោះ មនុស្សមានមាឌធំៗនៅលើផែនដី ហើយក្រោយមកក៏មានដែរ។ ការនេះកើតឡើងនៅពេលបុត្ររបស់ព្រះជាម្ចាស់រៀបការជាមួយកូនស្រីរបស់មនុស្ស
ហើយពួកគេមានកូនជាមួយគ្នា។ អ្នកទាំងនេះហើយគឺជាមនុស្សដ៏ខ្លាំងពូកែ និងមានឈ្មោះល្បីនៅសម័យបូរាណ។
[5]ព្រះជាម្ចាស់ឃើញថាអំពើអាក្រក់របស់មនុស្សកាន់តែច្រើនឡើងនៅលើផែនដី ហើយនៅក្នុងគំនិតនៃដួងចិត្តរបស់ពួកគេរេទៅរកតែការអាក្រក់ជាបន្តបន្ទាប់។
[6]ព្រះអម្ចាស់សោកស្តាយដែលព្រះអង្គបានបង្កើតមនុស្សនៅលើផែនដី ហើយវាបានធ្វើឲ្យទ្រង់ព្រួយនៅក្នុងព្រះទ័យរបស់ព្រះអង្គ។
[7]ដូច្នេះ ព្រះអម្ចាស់មានបន្ទូលថា៖ «យើងនឹងលុបបំបាត់មនុស្សលោកដែលយើងបានបង្កើតចេញពីផ្ទៃនៃផែនដី ទាំងមនុស្ស និងសត្វស្រុក សត្វលូនវា
ព្រមទាំងសត្វស្លាបដែលហើយនៅលើអាកាស ដើម្បីយើងសោកស្តាយដែលយើងបានបង្កើតពួកគេមក»។[8]ប៉ុន្តែ ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងលោកណូអេ។
[9]នេះគឺជាព្រឹត្តិការណ៍ទាក់ទងជាមួយលោកណូអេ។ លោកណូអេជាមនុស្សសុចរិត ហើយគ្មានកន្លែងបន្ទោសបាននៅក្នុងចំណោមមនុស្សនៅសម័យនោះ។
[10]លោកណូអេបានដើរជាមួយព្រះជាម្ចាស់។ លោកណូអេមានកូនប្រុសបីនាក់គឺឈ្មោះសិម ហាំ និងយ៉ាផេត។
[11]ផែនដីបានខូចអាក្រក់នៅចំពោះព្រះជាម្ចាស់ និងពេញដោយអំពើឃោរឃៅ។[12]ព្រះជាម្ចាស់បានឃើញផែនដី មើល៍ ផែនដីបានខូច ដ្បិត
គ្រប់ទាំងមនុស្សបានប្រព្រឹត្តអាក្រក់នៅគ្រប់ទាំងផ្លូវរបស់ពួកគេនៅលើផែនដី។
[13]ព្រះជាម្ចាស់មានបន្ទូលទៅលោកណូអេថា៖ «យើងឃើញថា ដល់ពេលដែលត្រូវបញ្ចប់ដល់មនុស្សលោកទាំងអស់ហើយ ដ្បិត
ផែនដីបានពេញទៅដោយអំពើឃោឃៅដោយសារពួកគេ។ ពិតណាស់ យើងនឹងបំផ្លាញពួកគេជាមួយនិងផែនដីដែរ។[14]ចូរធ្វើទូកពីដើមស្រល់សម្រាប់អ្នក។

generated on Wed Sep 10 16:16:32 2025

ចូរធ្វើបន្ទប់នៅក្នុងទូកនោះ ហើយបិទជ័រនៅខាងក្នុង និងខាងក្រៅផង។[15]នេះជារបៀបដែលអ្នកត្រូវធ្វើវា៖ ទូកនោះត្រូវមានប្រវែងបីរយហត្ថ ទទឹងហាសិបហត្ថ
និងកំពស់សាមសិបហត្ថ។
[16]ចូរធ្វើដំបូលគ្របពីលើទូកមានកំពស់មួយហត្ថ។ ចូរដាក់ទ្វារនៅចំហៀងទូក ហើយដាក់នៅជាន់ក្រោម ជាន់ទីពីរ និងជាន់ទីបី។[17]ចូរស្តាប់
យើងនឹងនាំឲ្យមានទឹកជំនន់នៅលើផែនដី ដើម្បីបំផ្លាញមនុស្សលោកទាំងអស់ដែលមានជីវិតរស់នៅក្រោមស្ថានសួគ៌។ អ្វីៗទាំងអស់ដែលនៅលើផែនដីនឹងស្លាប់។
[18]ប៉ុន្តែ យើងនឹងបង្កើតសម្ពន្ធមេត្រីរបស់យើងជាមួយអ្នក។ អ្នកត្រូវចូលទៅក្នុងទូក គឺអ្នក និងកូនប្រុសៗ ព្រមទាំងភរិយា ហើយនិងកូនប្រសារស្រីៗរបស់អ្នក។
[19]អ្នកក៏ត្រូវនាំសត្វលោកទាំងអស់ មួយគូពីចំណោមសត្វទាំងអស់ចូលទៅក្នុងទូក ឲ្យពួកវារស់នៅជាមួយអ្នក ទាំងញីទាំងឈ្មោល។
[20]អ្នកត្រូវនាំសត្វស្លាបគ្រប់ប្រភេទ ហើយសត្វធំៗតាមពូជរបស់វា ពីសត្វលូនវាតាមពូជរបស់វា ចូរយកមួយគូៗទៅជាមួយអ្នក ឲ្យពួកវារស់នៅជាមួយអ្នក។
[21]ចូរប្រមូលអាហារសម្រាប់អ្នក និងពួកវាដែរ»។[22]ដូច្នេះ លោកណូអេក៏ធ្វើការនេះ។ ទៅតាមអ្វីៗដែលព្រះជាម្ចាស់បានបង្គាប់ដល់គាត់ ដូច្នេះ គាត់ក៏ធ្វើតាម។

Genesis 6:1

នៅពេល

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ពីការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។

ពួកគេបង្កើតបានកូនស្រីៗ

នេះជាទម្រង់សកម្ម«ស្ត្រីអោយកំណើតកូនស្រី»

ប្រុសៗរបស់ព្រះជាម្ចាស់

ត្រង់ចំណុចនេះ គឺមិនបានបញ្ជាក់អោយច្បាស់ថាសំដៅទៅលើស្ថានបរមសុខ ឬ
សំដៅទៅមនុស្សឡើយ «ក្នុងការចាប់ផ្តើមដំបូង គឺពួកគេត្រូវបានបង្កើតឡើង
ដោយព្រះជាម្ចាស់ជាអ្នកបង្កើតពួកគេមក»

អ្នកខ្លះជឿពាក្យទាំងនេះសំដៅទៅលើពួកទេវតាដែលបះបោរប្រឆាំង
នឹងព្រះពោលគឺវិញ្ញាណអាក្រក់ ឬ ពួកបិសាច។

អ្នកខ្លះទៀតគិតថារឿងនេះអាចសំដៅទៅលើមេដឹកនាំនយោបាយដែលមានអំណាចហើយ[illegible]

ព្រះវិញ្ញាណរបស់យើង

នៅត្រង់នេះគឺ ព្រះអម្ចាស់ និយាយអំពីអង្គទ្រង់ផ្ទាល់
ហើយនិងព្រះវិញ្ញាណបរស់ព្រះអង្គ នោះគឺជាព្រះវិញ្ញារបស់ព្រះជាម្ចាស់។

សាច់ឈាម

ត្រង់ចំណុចនេះសំដៅទៅលើរូបកាយ ដែលថ្ងៃមួយ និង ស្លាប់ទៅវិញ។

ពួកគេនឹងរស់នៅបាន១២០ឆ្នាំ

មានន័យថា១) អាយុកាលធម្មតារបស់មនុស្សនឹងថយចុះដល់ ១២០ ឆ្នាំ។
ការបកប្រែផ្សេងទៀត៖ «ពួកគេនឹងមិនរស់នៅលើសពី ១២០ ឆ្នាំ» ឬ ២)
ក្នុងរយៈពេល ១២០ ឆ្នាំមនុស្សគ្រប់គ្នានឹងស្លាប់។ ការបកប្រែផ្សេងទៀត៖
«ពួកគេនឹងរស់នៅបានតែ ១២០ ឆ្នាំប៉ុណ្ណោះ»

Genesis 6:4

មនុស្សមានមាឌធំៗ

ខ្ពស់មាឌធំៗ

ការនេះកើតឡើងនៅពេល

«យក្សកើតពីព្រោះ»

បុត្ររបស់ព្រះជាម្ចាស់

លោកុប្បត្តិ៦:១ នៅពេលមនុស្សកើនជាច្រើនឡើងនៅលើផែនដី
ហើយពួកគេបង្កើតបានកូនស្រីៗជាច្រើន។

កទាំងនេះហើយគឺជាមនុស្សដ៏ខ្លាំងពូកែ

«យក្សទាំងនេះគឺជាបុរសខ្លាំងពូកែដែលបានរស់នៅជាយូរមកហើយ» ឬ
«កុមារទាំងនេះបានក្លាយជាអ្នកប្រយុទ្ធដ៏មានឥទ្ធិពលដែលបានរស់នៅជាយូរមកហើយ»

មនុស្សដ៏ខ្លាំងពូកែ

បុរសដែលមានភាពក្លាហាន និងជ័យជម្នះក្នុងការប្រយុទ្ធ

នៅសម័យបុរាណ

«បុរសល្បី»

Genesis 6:5

រេទៅ

«ទំនោរ» ឬ «ទម្លាប់»

គំនិតនៃដួងចិត្ត

អ្នកនិពន្ធនិយាយពីបេះដូងហាក់ដូចជាផ្នែកនៃរាងកាយដែលគិត។ « បេះដូង»
ដើម្បីនិយាយអំពីផ្នែករបស់មនុស្សដែលគិត។ ការបកប្រែផ្សេងទៀត៖
«គំនិតអាថ៌កំបាំងខាងក្នុងនិងខាងក្នុងរបស់ពួកគេ»

ឲ្យទ្រង់ព្រួយនៅក្នុងព្រះទ័យរបស់ព្រះអង្គ

អ្នកនិពន្ធនិយាយពីបេះដូងហាក់ដូចជាផ្នែកនៃរាងកាយដែលមានអារម្មណ៍សោកសៅ។
« បេះដូង» គឺនិយាយអំពីអារម្មណ៍។ ការបកប្រែផ្សេងទៀត៖
«ទ្រង់ពិតជាសោកសៅចំពោះវាណាស់»

Genesis 6:7

យើងនឹងលុបបំបាត់មនុស្សលោក.....ចេញពីផ្ទៃនៃផែនដី

អ្នកនិពន្ធនិយាយពីព្រះជាម្ចាស់ដែលសម្លាប់មនុស្សដូចជាព្រះជាម្ចាស់កំពុងតែជូតភាពកខ្វក់ចេញពីផ្ទៃរាប
ការបកប្រែផ្សេងទៀត៖ «យើងនឹងបំផ្លាញមនុស្សជាតិ ...
ដូច្នេះដើម្បីកុំអោយមានមនុស្សនៅលើផែនដីទៀត»

យើងនឹងលុបបំបាត់មនុស្សលោកដែលយើងបានបង្កើត

ភាសាខ្លះត្រូវការបកប្រែឃ្លានេះជាពីរប្រយោគ។ ការបកប្រែផ្សេងទៀត៖
«យើងបានបង្កើតមនុស្សជាតិ។ យើងនឹងលុបចោលពួកគេ»

លុបបំបាត់

«បំផ្លាញទាំងស្រុង»

ត្រង់នេះ«ជូតចេញ»ត្រូវបានប្រើក្នុងន័យអវិជ្ជមានត្បិតព្រះជាម្ចាស់កំពុងមានបន្ទូលអំពីការបំផ្លាញប្រជាជ

ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងលោកណូអេ

[illegible]

«ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងលោកណូអេ»

ព្រះអម្ចាស់គាប់ព្រះហឫទ័យ

នៅទីនេះ «ភ្នែក» តំណាងឱ្យការមើលឃើញ ឬ គំនិត ការបកប្រែផ្សេងទៀត៖
«ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់» ឬ «ព្រះហឫទ័យរបស់ព្រះអម្ចាស់»

Genesis 6:9

ព័ត៌មានទូទៅ

នេះគឺជាការចាប់ផ្តើមដំណើររឿងណូអេដែលបន្តដល់ជំពូក ៩

នេះគឺជាព្រឹត្តិការណ៍ទាក់ទងជាមួយលោកណូអេ

«នេះជាដំណើររឿងរបស់លោកណូអេ»

ដើរជាមួយព្រះជាម្ចាស់

លោកុប្បត្តិ៥:២១ នៅពេលលោកហេណុករស់បានហុកសិបប្រាំឆ្នាំ
គាត់បង្កើតបានមធូសាឡា។

លោកណូអេមានកូនប្រុស៣នាក់

«លោកណូអេមានកូនប្រុសបីនាក់»
ឬ«ប្រពន្ធរបស់លោកណូអេបានបង្កើតកូនប្រុសបីនាក់»

សិម ហាំ និង យ៉ាផេត

អ្នកបកប្រែអាចបន្ថែមលេខយោងខាងក្រោម៖
«កូនប្រុសមិនត្រូវបានចុះបញ្ជីតាមលំដាប់ដែលពួកគេបានកើតទេ»

Genesis 6:11

ផែនដី

អត្ថន័យដែលមានគឺ ១) ប្រជាជនដែលរស់នៅលើផែនដីឬ ២) «ផែនដីខ្លួនឯង»

បានខូចអាក្រក់

មនុស្សធ្វើអំពើអាក្រក់ត្រូវបានគេនិយាយដូចជាពួកគេជាអាហារដែលស្អុយរលួយ។
ការបកប្រែផ្សេងទៀត៖ «រលួយ» ឬ «ខូចអាក្រក់ទាំងស្រុង»

ចំពោះព្រះជាម្ចាស់

អត្ថន័យដែលអាចមានគឺ ១) «ចំពោះព្រះនេត្ររបស់ព្រះ»ឬ ២) «
នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់» ដូចនៅក្នុង ៤:១៦

និង ពេញដោយអំពើឃោរឃៅ

អ្នកនិពន្ធនិយាយពីអំពើឃោរឃៅហាក់ដូចជាអ្វីមួយដែលអាចដាក់ចូលទៅក្នុងកុងតឺន័រ
និង ផែនដីជាធុងមួយ។ ការបកប្រែផ្សេងទៀត៖
«ហើយមានមនុស្សឃោរឃៅជាច្រើននៅលើផែនដី» ឬ
«ពីព្រោះវាពេញទៅដោយមនុស្សដែលបានធ្វើអំពើអាក្រក់ដាក់គ្នាទៅវិញទៅមក»

មើល៍

នៅទីនេះការដាស់តឿនយើងឱ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលកើតឡើង។

គ្រប់ទាំងមនុស្ស

អត្ថន័យដែលមានគឺ ១) មនុស្សទាំងអស់ឬ ២)

generated on Wed Sep 10 16:16:32 2025

រូបធាតុទាំងអស់រួមទាំងមនុស្សនិងសត្វ។
ប្រព្រឹត្តអាក្រក់នៅគ្រប់ទាំងផ្លូវរបស់ពួកគេ
របៀបដែលមនុស្សម្នាក់មានអាកប្បកិរិយាត្រូវបានគេនិយាយដូចជាវាជាផ្លូវឬផ្លូវ។ ការបកប្រែផ្សេងទៀត៖ «បានឈប់រស់នៅតាមរបៀបដែលព្រះសព្វព្រះហឫទ័យ» ឬ«បានរស់នៅប្រព្រឹត្តអាក្រក់»
Genesis 6:13
មនុស្សលោក
លោកុប្បត្តិ៦:១១ ផែនដីបានខូចអាក្រក់នៅចំពោះព្រះជាម្ចាស់ និងពេញដោយអំពើឃោរឃៅ។
ផែនដីបានពេញទៅដោយអំពើឃោរឃៅដោយសារពួកគេ
«មនុស្សសព្វទិសទីនៅលើផែនដីបានប្រព្រឹត្តិនៅអំពើឃោរឃៅ»
យើងនឹងបំផ្លាញពួកគេជាមួយនិងផែនដីដែរ
«យើងនឹងបំផ្លាញពួកគេទៅជាមួយនិងផែនដី» ឬ«យើងនឹងបំផ្លាញពួកគេនៅពេលដែលយើងនឹងបំផ្លាញផែនដី»
ទូក
នេះសំដៅទៅលើប្រអប់មួយដែលមានទំហំធំណាស់ដែលអាចអណ្តែតលើទឹកសូម្បីតែក្នុងមនុស្សអាក្រក់ក៏ដោយ។ «ទូកធំ» ឬ «កប៉ាល់» ឬ «ទូក»
ដើមស្រល់
មនុស្សមិនដឹងច្បាស់ថាដើមឈើប្រភេទនេះជាឈើប្រភេទអ្វីនោះទេ។ «ឈើប្រើសម្រាប់សាងសង់ទូក» ឬ «ឈើល្អ»
បិទជ័រ
«បាងសាចខាងលើ» ឬ «លាបជ័រពីលើវា» ហេតុផលសម្រាប់ការធ្វើបែបនេះអាចត្រូវបានធ្វើឱ្យជិត «ដើម្បីមិនអោយមានជ្រាបទឹក»
ជ័រ
នេះគឺជាអង្គធាតុរាវក្រាស់ស្អិតឬខ្លាញ់ដែលមនុស្សដាក់នៅខាងក្រៅទូកដើម្បីបញ្ឈប់ទឹក
ហត្ថ
មួយហត្ថគឺជាឯកតារង្វាស់ដែលមានប្រវែងតិចជាងកន្លះម៉ែត្រ។
បីរយហត្ថ
«១៣៨ ម៉ែត្រ» អ្នកអាចប្រើឯកតាវាស់ភាសាហេព្រើរពី ULB ឬ ឯកតាម៉ែត្រពី UDB ឬឯកតាវប្បធម៌ផ្ទាល់ខ្លួនរបស់អ្នកប្រសិនបើអ្នកដឹងពីរបៀបដែលវាប្រៀបធៀបទៅនឹងឯកតាម៉ែត្រ។ អ្នកក៏អាចនិយាយថា៖ «បីរយហត្ថគឺប្រហែល ១៣៨ ម៉ែត្រ»
ហាសិបហត្ថច
«២៣ម៉ែត្រ»
សាមសិបហត្ថ
«១៤ម៉ែត្រ»
Genesis 6:16
ដំបូលគ្របពីលើទូក
នេះប្រហែលជាដំបូលកំពូលឬអិល។ គោលបំណងគឺដើម្បីការពារអ្វីៗទាំងអស់នៅក្នុងទូកពីទឹកភ្លៀង។
ហត្ថ
មួយហត្ថមានប្រវែងតិចជាងកន្លះម៉ែត្រ។ សូមមើលនៅក្នុង ៦:១៣
នៅជាន់ក្រោម ជាន់ទីពីរ និងជាន់ទីបី
«ជាន់ទាបមួយជាន់កណ្តាលនិងជាន់ខាងលើ» ឬ «ចំនួនបីនៅខាងក្នុង»
ជាន់
«ជាន់» ឬ «កម្រិត»
ចូរស្តាប់
ព្រះជាម្ចាស់មានបន្ទូលដូច្នេះដើម្បីបញ្ជាក់ថាទ្រង់នឹងធ្វើអ្វីដែលទ្រង់ហៀបនឹងបន្ទូល «ចូរយកចិត្តទុកដាក់» ឬ «ស្តាប់នូវអ្វីដែលអញកំពុងមានបន្ទូល»
យើងនឹងនាំឲ្យមានទឹកជំនន់នៅលើផែនដី
«យើងហៀបនឹងបញ្ជូនទឹកជន់លិច» ឬ «យើងហៀបនឹងបង្កជាទឹកជំនន់ឡើង»
មនុស្សលោក
នៅទីនេះ «មុនស្សលោក» តំណាងឱ្យរូបវន្តបុគ្គលទាំងអស់រួមទាំងមនុស្សនិងសត្វ។
ដែលមានជីវិតរស់
នៅត្រង់នេះ«ដង្ហើម»គឺសំដៅជីវិត។ ការបកប្រែផ្សេងទៀត៖ «រស់នៅ»
Genesis 6:18
បង្កើតសម្ពន្ធមេត្រីរបស់យើងជាមួយអ្នក
«បង្កើតសម្ព័ន្ធមេត្រីរវាងអ្នកហើយនិងយើង»
ជាមួយណូអេ
អ្នកត្រូវចូលទៅក្នុងទូក
«អ្នកនឹងចូលទៅក្នុងទូកធំ» ។ ការបកប្រែខ្លះនិយាយថា «អ្នកនឹងចូលទៅក្នុងទូកធំ»។
ត្រូវនាំសត្វលោកទាំងអស់ មួយគូពីចំណោមសត្វទាំងអស់ចូលទៅក្នុងទូក
«អ្នកត្រូវតែនាំយកសត្វគ្រប់ប្រភេទ១គូរចូលទៅក្នុងទូកធំ»
សត្វ
ព្រះជាម្ចាស់ជាអ្នកបង្កើតសត្វគ្រប់មុខ។
លោកទាំងអស់
ព្រះជាម្ចាស់
និងពេញដោយអំពើឃោរឃៅ។
Genesis 6:20
តាមពូជរបស់វា
«នៃប្រភេទនីមួយៗ»
សត្វលូនវា
ដែលវាមានទៅលើប្រភេទសត្វដែលវានៅលើដី។
មួយគូរៗ
នេះសំដៅទៅ១គូរៗលើសត្វគ្រប់ប្រភេទរហូតដល់សត្វស្លាប។
ឲ្យពួកវារស់នៅ
«ដូច្នេះអ្នកអាចមើលថែពួកវាបាន»
ដល់អ្នក.....ខ្លួនអ្នក.....អ្នក
នេះគឺសំដៅលើលោកណូអេ និងជាឯកវចនៈ។
ប្រមូលអាហារ
«អាហារសម្រាប់មនុស្សនិងសត្វសម្រាប់បរិភោគ»
លោកណូអេក៏ធ្វើការនេះ ទៅតាមអ្វីៗដែលព្រះជាម្ចាស់បានបង្គាប់ដល់គាត់ ដូច្នេះ គាត់ក៏ធ្វើតាម ប្រយោគទាំងពីរនេះមានន័យដូចគ្នា។ ប្រយោគទី ២ ពន្យល់អំពីទីមួយហើយសង្កត់ធ្ងន់ថាណូអេបានស្តាប់បង្គាប់ព្រះជាម្ចាស់។ ប្រយោគប៉ារ៉ាឡែលទាំងនេះអាចត្រូវបានផ្សំជាមួយ។ ការបកប្រែផ្សេងទៀត៖ «ដូច្នេះណូអេបានធ្វើអ្វីគ្រប់យ៉ាងដែលព្រះបានបញ្ជាគាត់ឱ្យធ្វើ»

---

7 [1]ព្រះអម្ចាស់មានបន្ទូលទៅលោកណូអេថា៖ «ចូរចូលទៅក្នុងទូក អ្នក និងគ្រួសាររបស់អ្នក ដ្បិត យើងបានឃើញថា អ្នកជាមនុស្សសុចរិត
នៅចំពោះយើងនៅក្នុងជំនាន់នេះ។[2]ចូរនាំសត្វដែលស្អាតៗទៅជាមួយអ្នក ញីប្រាំពីរ និងឈ្មោលប្រាំពីរផង។[3]ចំណែកសត្វដែលមិនស្អាត ចូរនាំតែមួយគូបានហើយ
ឈ្មោល និងមេញីរបស់វា។ ព្រមទាំងសត្វស្លាបនៅលើមេឃ ចូរនាំឈ្មោលប្រាំពីរ និងញីប្រាំពីរ ដើម្បីបន្តពូជនៅលើផ្ទៃនៃផែនដីទាំងមូលផង។
[4]ដ្បិត នៅថ្ងៃទីប្រាំពីរ យើងនឹងធ្វើឲ្យមានភ្លៀងធ្លាក់មកលើផែនដីក្នុងរយៈពេលសែសិបថ្ងៃសែសិបយប់។
យើងនឹងបំផ្លាញអ្វីៗដែលមានជីវិតនៅលើផ្ទៃផែនដីដែលយើងបានបង្កើតទាំងអស់»។[5]លោកណូអេបានធ្វើតាមព្រះអម្ចាស់បានបង្គាប់ដល់គាត់ទាំងអស់។
[6]ពេលទឹកជំនន់នៅលើផែនដី លោកណូអេមានអាយុប្រាំមួយរយឆ្នាំ។[7]លោកណូអេ កូនប្រុសៗ និងភរិយា ព្រមទាំងកូនប្រសាស្រីរបស់គាត់បានចូលទៅក្នុងទូកជាមួយគ្នា
ដោយសារទឹកជំនន់។
[8]សត្វស្អាត និងសត្វដែលមិនស្អាត សត្វស្លាប និងសត្វលូនវានៅលើផែនដីទាំងអស់[9]មួយគូៗ ទាំងឈ្មោល ទាំងញី បានមករកលោកណូអេ ហើយបានចូលទៅក្នុងទូក
ដូចដែលព្រះជាម្ចាស់បានបង្គាប់ដល់លោកណូអេ។[10]នៅពេលភ្លៀងបានប្រាំពីរថ្ងៃ ទឹកបានជន់លិចផែនដី។
[11]នៅពេលលោកណូអេមានអាយុប្រាំមួយរយឆ្នាំ នៅខែទីពីរ គឺនៅថ្ងៃទីដប់ប្រាំ ខែនោះ ថ្ងៃដដែលនោះ ប្រភពទឹកនៅក្នុងទីជម្រៅទាំងអស់បានបើកឡើង
ហើយបង្ហួចស្ថានសួគ៌បានបើកដែរ។[12]ភ្លៀងបានចាប់ផ្តើម ហើយធ្លាក់ចុះមកផែនដីសែសិបថ្ងៃសែសិបយប់។

generated on Wed Sep 10 16:16:32 2025

[13]នៅថ្ងៃដដែលនោះឯង លោកណូអេ និងកូនប្រុសៗរបស់លោក គឺសិម ហាំ និងយ៉ាផេត ព្រមទាំងភរិយារបស់លោកណូអេ និងភរិយាទាំងបីរបស់កូនប្រុសៗរបស់លោក
បានចូលទៅក្នុងទូកជាមួយពួកគេដែរ។[14]ពួកគេបានចូលទៅជាមួយសត្វ តាមពូជរបស់វា ហើយសត្វស្រុកក៏តាមពូជរបស់វារៀងៗខ្លួនដែរ
ព្រមទាំងសត្វលូនវានៅលើផែនដីតាមពូជរបស់វា និងសត្វបក្សាបក្សីតាមពូជរបស់វា ព្រមទាំងសត្វស្លាបតាមពូជរបស់វាដែរ។
[15]សត្វដែលមានជីវិតមួយគូៗបានចូលមកឯលោកណូអេ ហើយបានចូលទៅក្នុងទូក។[16]សត្វទាំងអស់ដែលចូលទៅក្នុងទូកនោះមានឈ្មោល មានញី
ពួកគេបានចូលទៅក្នុងទូកដូចដែលព្រះជាម្ចាស់បានបង្គាប់ដល់លោក។ បន្ទាប់ពីពួកគេចូលអស់ហើយ ព្រះអម្ចាស់បានបិទទ្វារ។
[17]បន្ទាប់ពីទឹកជំនន់មកនៅលើផែនដីសែសិបថ្ងៃរួចហើយ ទឹកក៏កាន់តែចម្រើនឡើង ហើយបានលើកទូក ហើយបានអណ្តែតផុតពីដី។[18]ទឹកមានពេញពាសផែនដីទាំងមូល
ហើយទូកបានអណ្តែតនៅលើផ្ទៃនៃទឹកនោះ។
[19]ទឹកកាន់ខ្ពស់ឡើងកាន់តែខ្លាំងនៅលើផែនដី ដូច្នេះ សូម្បីតែនៅលើភ្នំខ្ពស់ៗទាំងឡាយដែលនៅក្រោមមេឃក៏លិចអស់ដែរ។
[20]ទឹកបានឡើងខ្ពស់ផុតពីកំពូលភ្នំដប់ប្រាំហត្ថថែមទៀត។
[21]គ្រប់ទាំងសត្វមានជីវិតទាំងឡាយដែលរស់នៅលើផែនដីបានស្លាប់ ទាំងសត្វបក្សាបក្សី សត្វស្រុក សត្វព្រៃ
និងសត្តនិករដែលរស់នៅលើផែនដីយ៉ាងសន្ធឹកសន្ធាប់ទាំងអស់បានស្លាប់ និងមនុស្សលោកទាំងអស់ផងដែរ។[22]គ្រប់ទាំងសត្វដែលមានជីវិតទាំងអស់នៅលើដី
ដែលមានជីវិតរបស់នៅ ហើយដកដង្ហើមតាមច្រមុះរបស់ពួកគេបានស្លាប់ទាំងអស់។
[23]ដូច្នេះ អ្វីៗដែលមានជីវិតទាំងអស់ ដែលរស់នៅលើផ្ទៃនៃផែនដីត្រូវបានលុបបំបាត់ចោលទាំងអស់ តាំងពីតូចរហូតដល់ធំ ចាប់តាំងពីសត្វលូនវា
និងសត្វដែលហើរលើអាកាស។[24]ពួកគេត្រូវបានបំផ្លាញទាំងអស់ពីផែនដី។ មានតែលោកណូអេ និងអស់អ្នកដែលនៅក្នុងទូកជាមួយគាត់ទេ។
ទឹកមិនបានជ្រាបចូលទៅក្នុងផែនដីវិញ អស់រយៈពេលមួយរយហាសិបថ្ងៃ។

Genesis 7:1
ព័ត៌មានទូទៅ
ព្រឹត្តិការណ៍ក្នុងជំពូកនេះកើតឡើងបន្ទាប់ពីណូអេបានសង់ទូកធំ
ប្រមូលអាហារហើយដាក់ក្នុងទូក។
ចូរ.....ចូលទៅក្នុងទូក....យក
«បញ្ជូល ... ចូលទៅក្នុងទូក ... យក» ការបកប្រែជាច្រើនអានថា«ទៅ ...
ចូលទៅក្នុងទូក ... យកទៅ»
អ្នក
ពាក្យថា«អ្នក»គឺសំដៅទៅលើណូអេជាឯកវចនៈ។
គ្រួសាររបស់អ្នក
«គ្រួសារអ្នក»
អ្នកជាមនុស្សសុចរិត នៅចំពោះយើង
នេះមានន័យថាព្រះជាម្ចាស់ទតឃើញលោកណូអេជាមនុស្សដែលសុចរិតនៅចំពោះទ្រង់។
ចំពោះយើងនៅក្នុងជំនាន់នេះ
នេះគឺសំដៅទៅលើមនុស្សទាំងអស់ដែលរស់នៅអំឡុងពេលនោះ។
ការបកប្រែផ្សេងទៀត៖ ក្នុងចំណោមទាំងអស់ដែលកំពុងរស់នៅ»
សត្វដែលស្អាត
នេះគឺជាសត្វមួយដែលព្រះបានអនុញ្ញាតឱ្យប្រជាជនរបស់ទ្រង់សម្រាប់ទទួលទាននិងសម្រាប់ធ្វើយញ្ញបូជា។
សំរាប់សត្វដែលមិនស្អាត
ទាំងនេះជាសត្វដែលព្រះមិនអនុញ្ញាតឱ្យមនុស្សបរិភោគឬយកមកធ្វើយញ្ញបូជាឡើយ។
ដើម្បីបន្តពូជ
«ដូច្នេះពួកគេនឹងមានកូនចៅដែលនឹងរស់នៅ» ឬ
«ដូច្នេះបន្ទាប់ពីទឹកជំនន់សត្វនឹងបន្តរស់នៅ»
Genesis 7:4
សែសិបថ្ងៃនិងសែសិបយប់
នេះគឺជារយៈពេលសែសិបថ្ងៃពេញ។ វាមិនមែនជាចំនួនសរុបប៉ែតសិបថ្ងៃទេ។
ការបកប្រែផ្សេងទៀត៖ «សែសិបថ្ងៃនិងយប់»
ជីវិត
គឺសំដៅទៅលើជីវិតលើរាងកាយ។
Genesis 7:6
ព័ត៌មានទូទៅ
ខ ៦-១២
រំលឹកម្តងទៀតជាលើកទីពីរហើយប្រាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលណូអេចូលក្នុងទូក
៧: ១ ។ នេះមិនមែនជាព្រឹត្តិការណ៍ថ្មីទេ។
នៅលើផែនដី
«បានកើតឡើង»ឬ«បានមកលើផែនដី»
ដោយសារទឹកជំនន់
«ដោយសារតែទឹកជំនន់ដែលនឹងមក» ឬ «ដើម្បីគេចចេញពីទឹកជំនន់»
Genesis 7:8
ព័ត៌មានទូទៅ
ខ ៦-១២
រំលឹកម្តងទៀតជាលើកទីពីរហើយប្រាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលណូអេចូលក្នុងទូក
៧: ១ ។ នេះមិនមែនជាព្រឹត្តិការណ៍ថ្មីទេ។
សត្វស្អាត
ទាំងនេះគឺជាសត្វដែលព្រះបានអនុញ្ញាតឱ្យមនុស្សបរិភោគនិងផ្តល់ឱ្យគាត់សម្រាប់ធ្វើយញ្ញបូជា។
សត្វដែលមិនស្អាត
ទាំងនេះជាសត្វដែលព្រះមិនអនុញ្ញាតឱ្យមនុស្សបរិភោគឬថ្វាយជាយញ្ញបូជាឡើយ។
មួយគូៗ
សត្វបានចូលទូកជាគូមានឈ្មោល ១ ញី១ ។
នៅពេលភ្លៀង
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង៖
ការចាប់ផ្តើមនៃទឹកជំនន់។
បន្ទាប់បានប្រាំពីរថ្ងៃ
«បន្ទាប់ពីបាន៧ថ្ងៃ»ឬ«៧ថ្ងៃក្រោយមក»
ទឹកបានជន់លិចផែនដី
ព័ត៌មានច្បាស់លាស់ «វាចាប់ផ្តើមភ្លៀង» អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖
«វាបានចាប់ផ្តើមមានភ្លៀងហើយទឹកជំនន់បានលិចមកលើផែនដី»
Genesis 7:11
ព័ត៌មានទូទៅ
៦-១២
រំលឹកម្តងទៀតជាលើកទីពីរហើយប្រាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលណូអេចូលក្នុងទូក
៧: ១ ។ នេះមិនមែនជាព្រឹត្តិការណ៍ថ្មីទេ។
លោកណូអេមានអាយុប្រាំមួយរយឆ្នាំ
«នៅពេលដែលលោកណូអេមានអាយុ៦០០ឆ្នាំ»។
នៅខែទីពីរ គឺនៅថ្ងៃទីដប់ប្រាំ
ចាប់តាំងពីលោកម៉ូសេបានសរសេរសៀវភៅនេះមកគាត់អាចនិយាយអំពីខែទី ២
នៃប្រតិទិនហេព្រើរ។ ប៉ុន្តែនេះមិនច្បាស់ទេ។
ថ្ងៃដដែលនោះ
នេះសំដៅទៅលើថ្ងៃជាក់លាក់នៅពេលភ្លៀងចាប់ផ្តើម។
ឃ្លានេះសង្កត់ធ្ងន់ទៅលើរបៀបដែលព្រឹត្តិការណ៍សំខាន់ៗទាំងអស់នេះកើតឡើងយ៉ាងឆាប់រហ័សនៅពេល
ប្រភពទឹកនៅក្នុងទីជម្រៅទាំងអស់បានបើកឡើង
«ទឹកពីក្រោមដីប្រញាប់ឡើងដល់ផ្ទៃផែនដី»
ក្នុងទីជម្រៅ
[illegible]
បង្ហួចស្ថានសួគ៌បានបើកដែរ
នេះសំដៅទៅលើទឹកភ្លៀង។
វាពិពណ៌នាអំពីមេឃជាពិដានមួយដែលធ្វើឱ្យទឹកនៅពីលើវាធ្លាក់មកលើផែនដី។
នៅពេលដែលបង្ហួចឬទ្វារនៅលើមេឃត្រូវបានបើកទឹកបានហូរកាត់ពួកគេ។
ការបកប្រែផ្សេងទៀត៖ «មេឃបានបើក» ឬ «ទ្វារនៅលើមេឃបានបើក»
ភ្លៀង
ប្រសិនបើភាសារបស់អ្នកមានពាក្យសម្រាប់ទឹកភ្លៀងច្រើនវានឹងសមរម្យនៅទីនេះ។
Genesis 7:13
ព័ត៌មានទូទៅ
[illegible]

generated on Wed Sep 10 16:16:32 2025

ខ៦-១២
រម្លឹកម្តងទៀតជាលើកទីពីរហើយប្រាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលណូអេចូលក្នុងទូកធំជាមួយគ្រួសារ
និង សត្វក្នុង ៧: ១ ។ នេះមិនមែនជាព្រឹត្តិការណ៍ថ្មីទេ។
នៅថ្ងៃដដែលនោះឯង
«នៅថ្ងៃជាក់លាក់នោះ»។ នេះសំដៅទៅលើថ្ងៃដែលទឹកភ្លៀងបានចាប់ផ្តើម។ ខ
១៣-១៦ គឺបានប្រាប់ពីអ្វីដែលណូអេបានធ្វើភ្លាមៗមុនពេលមានភ្លៀងធ្លាក់មក។
សត្វព្រៃ.....សត្វស្រុក.....សត្វលូនវា....សត្វបក្សាបក្សី
ក្រុមសត្វទាំងបួននេះត្រូវបានចុះបញ្ជីដើម្បីបង្ហាញថាសត្វគ្រប់ប្រភេទត្រូវបានបញ្ចូល។
ប្រសិនបើភាសារបស់អ្នកមានវិធីមួយផ្សេងទៀតនៃការដាក់ជាក្រុមសត្វទាំងអស់អ្នកអាចប្រើវា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១:២៤
ព្រមទាំងសត្វលូនវា
នេះសំដៅទៅលើសត្វដែលវារនៅលើដីដូចជាសត្វកកេរ សត្វល្អិត សត្វជីកចក់
និងពស់។
តាមពូជរបស់វារៀងៗខ្លួនដែ
«ដូច្នេះសត្វនីមួយៗនឹងបង្កើតបានជាប្រភេទរបស់វាបន្ថែមទៀត»។
សូមមើលនៅក្នុង លោកុប្បត្តិ១:២៤ ។
Genesis 7:15
ព័ត៌មានទូទៅ
ខ ១៣-១៨
រម្លឹកម្តងទៀតជាលើកទីបីហើយប្រាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលណូអេចូលក្នុងទូកធំជាមួយគ្រួសារ
៧: ១ ។ នេះមិនមែនជាព្រឹត្តិការណ៍ថ្មីទេ។
សត្វដែលមានជីវិតមួយគូៗ
ទីនេះ«រូប»គឺតំណាងអំពីពពួកសត្វ។
ដែលមានជីវិត
ទីនេះ«ដង្ហើម»គឺតំណាងអំពីជីវិត។ ការបកប្រែផ្សេងទៀត៖ «ដែលបានរស់នៅ»
មកឯលោកណូអេ
ចំពោះពាក្យ«មក»អាចបកប្រែថា«បានទៅ»
សត្វទាំងអស់
នេះ«រូប»តំណាងអំពីសត្វគ្រប់ប្រភេទទាំងអស់។ការបកប្រែផ្សេងទៀត៖
«គឺសត្វគ្រប់ប្រភេទទាំងអស់»
បន្ទាប់ពីពួកគេ
អត្ថន័យពេញលេញអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«បន្ទាប់ពីពួកគេបានចូលទៅក្នុងទូកធំ»
Genesis 7:17
ព័ត៌មានទូទៅ
ខ ១៣-១៨
រម្លឹកម្តងទៀតជាលើកទីបីហើយប្រាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលណូអេចូលក្នុងទូកធំជាមួយគ្រួសារ
៧: ១ ។ នេះមិនមែនជាព្រឹត្តិការណ៍ថ្មីទេ។
ទឹកក៏កាន់តែចម្រើនឡើង
ហេតុការណ៍នេះកើតឡើងក្នុងអំឡុងពេលសែសិបថ្ងៃខណៈពេលទឹកនៅតែបន្តឡើង។
«ហើយទឹកកាន់ជ្រៅៗ»
ទូកធំជាមួយគ្រួសារ
«ហើយទូកចាប់ផ្តើមអណ្តែតឡើង»
បានអណ្តែតផុតពីដី
«ទូកធំអណ្តែតលើកំពូលទឹកជ្រៅ»ឬ«ទូកធំនោះអណ្តែតលើទឹកជ្រៅ»
Genesis 7:19
ទឹកកាន់ខ្ពស់ឡើងកាន់តែខ្លាំងនៅលើផែនដី
«សរុបមកទឹកបានលិចគ្របដណ្តប់លើផែនដីទាំងមូល»
ប្រើរបៀបដែលអ្នកអាចប្រើក្រុមទាំងនេះ។
«ខម៉ែត្រ»សូមមើលនៅក្នុងលោកុប្បត្តិ៦:១៣
Genesis 7:21
ដែលរស់នៅលើ
«បានផ្លាស់ប្តូរអំពី» ឬ «គ្រហឹមៗ»
គ្រប់ទាំងសត្វមានជីវិតទាំងឡាយដែលរស់នៅលើផែនដី
នេះសំដៅទៅលើសត្វទាំងអស់ដែលធ្វើដំណើរជុំវិញដីជាក្រុមធំៗ។
ដែលមានជីវិតរបស់នៅ ហើយដកដង្ហើមតាមច្រមុះ
នៅទីនេះ «ច្រមុះ» តំណាងឱ្យសត្វឬមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត៖
«មនុស្សគ្រប់គ្នាដែលដកដង្ហើម»
ដង្ហើមនៃជីវិត
តំណាងឱ្យថាមពលដែលបណ្តាលឱ្យមនុស្សនិងសត្វមានជីវិត។
បានស្លាប់
នេះគឺសំដៅទៅលើរូបរាងកាយដែលបានស្លាប់។
Genesis 7:23
ដូច្នេះ អ្វីៗដែលមានជីវិតទាំងអស់.....ត្រូវបានលុបបំបាត់ចោល
បើចាំបាច់នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះរាល់ភាវៈរស់ ... បានវិនាស» ឬ
«ដូច្នេះទឹកជំនន់បានបំផ្លាញអ្វីៗទាំងអស់ដែលមានជីវិត»
ពួកគេត្រូវបានបំផ្លាញទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់បានបំផ្លាញពួកគេទាំងអស់»
អស់ពីផែនដី
«ដូច្នេះពួកគេមិនបានរស់នៅបានយូរនៅលើផែនដីឡើយ»
អស់អ្នកដែលនៅក្នុងទូកជាមួយគាត់
«គឺអស់ទាំងសត្វនិងមនុស្សដែលបាននៅជាមួយនិងគាត់»
បានចេញ
ទឹកបានគ្រប់ដណ្តប់ពេញផែនដី
« ជម្រៅទឹកបានគ្របដណ្តប់លើផែនដីទាំងមូល» ឬ«
ទឹកនៅតែមានទឹកជំនន់ពេញផែនដី»

---

8 [1]ព្រះជាម្ចាស់បាននឹកចាំពីលោកណូអេ និងសត្វព្រៃទាំងអស់ ព្រមទាំងសត្វស្រុកដែលនៅក្នុងទូកជាមួយគាត់។ ព្រះជាម្ចាស់បានធ្វើឲ្យមានខ្យល់បក់នៅលើផែនដី
ហើយឲ្យទឹកចាប់ផ្តើមស្រក់ចុះ។[2]ប្រភពទឹកដែលផុតចេញពីជម្រៅ ហើយទ្វារនៃស្ថានសួគ៌បានបិទ ហើយភ្លៀងក៏រាំង។[3]ទឹកជំនន់បានស្រក់ចុះពីផែនដីយ៉ាងយឺតៗ
ហើយបន្ទាប់ពីផុតមួយរយហាសិបថ្ងៃមកទឹកបានស្រក់ចុះអស់។
[4]ទូកបានជាប់កៀងនៅក្នុងខែទីប្រាំពីរ នៅថ្ងៃទីដប់ប្រាំពីរនៃខែនោះ នៅលើភ្នំអារ៉ារ៉ាត។[5]ទឹកបានបន្តស្រក់ចុះរហូតដល់ខែទីដប់។ នៅថ្ងៃទីមួយនៃខែនោះ
កំពូលភ្នំផ្សេងៗបានលេចឡើង។
[6]សែសិបថ្ងៃក្រោយមក លោកណូអេបានបើកបង្អួចទូកដែលលោកបានធ្វើនោះ។[7]លោកបានប្រលែងសត្វក្អែកមួយ វាក៏ហើរទៅហើយមក រហូតទាល់តែទឹកស្ងួតពីផែនដី។
[8]បន្ទាប់មក លោកបានប្រលែងសត្វព្រាបមួយទៀត ដើម្បីឲ្យដឹងថា តើទឹកបានស្ងួតពីផ្ទៃនៃផែនដីហើយឬនៅ[9]ប៉ុន្តែ សត្វព្រាបរកកន្លែងទំមិនបាន
វាបានត្រឡប់មករកលោកដែលនៅក្នុងទូកវិញ ដ្បិត ទឹកនៅគ្របដណ្តប់ផែនដីទាំងមូលនៅឡើយ។ គាត់បានឈោងដៃចាប់វា
ហើយយកវាត្រឡប់ចូលមកនៅក្នុងទូកជាមួយគាត់វិញ។
[10]គាត់បានរង់ចាំប្រាំពីរថ្ងៃក្រោយទៀត ហើយគាត់បានប្រលែងព្រាបនោះពីទូកម្តងទៀត។[11]សត្វព្រាបបានត្រឡប់មកឯគាត់វិញនៅពេលល្ងាច។ មើល៍!
នៅមាត់របស់វាមានត្រួយអូលីវមកជាមួយផង។ ដូច្នេះ លោកណូអេបានដឹងថា ទឹកបានស្ងួតពីផែនដីអស់ហើយ។[12]គាត់បានរង់ចាំប្រាំពីរថ្ងៃទៀត
ហើយគាត់បានប្រលែងសត្វព្រាបម្តងទៀត។ វាមិនបានត្រឡប់មករកគាត់វិញទេ។
[13]នៅថ្ងៃទីមួយ ខែទីមួយ និងឆ្នាំទីមួយ នៅពេលលោកណូអេមានអាយុប្រាំមួយរយមួយឆ្នាំ ទឹកបានរីងស្ងួតពីផែនដីទាំងអស់។ លោកណូអេបានរើដំបូលទូកចេញ
សម្លឹងមើលទៅក្រៅ ហើយលោកបានឃើញថា ផ្ទៃនៃផែនដីបានស្ងួត។[14]នៅខែទីពីរ ថ្ងៃទីម្ភៃប្រាំពីរនៃខែនោះ ផែនដីបានស្ងួតអស់។
[15]ព្រះជាម្ចាស់មានបន្ទូលទៅលោកណូអេថា៖[16]«ចូរចេញពីទូក អ្នក ភរិយារបស់អ្នក និងកូនប្រុសៗរបស់អ្នក ព្រមទាំងភរិយារបស់កូនប្រុសៗអ្នកផង។
[17]ចូរយកសត្វមានជីវិតទាំងអស់ដែលនៅជាមួយអ្នកចេញពីទូក គឺសត្វបក្សាបក្សី ហ្វូងសត្វ ហើយសត្វលូនវាទាំងអស់ដែលលូនវានៅលើផែនដី
ដើម្បីឲ្យពួកគេបានបង្កើតពូជនៅពាសពេញផែនដីវិញ ចូរបង្កើតផល និងបានចម្រើនឡើងនៅពេញផែនដីចុះ»។

generated on Wed Sep 10 16:16:32 2025

[18]ដូច្នេះ លោកណូអេ កូនប្រុសៗ និងភរិយារបស់គាត់ ព្រមទាំងភរិយាកូនប្រុសរបស់គាត់បានចេញពីទូកជាមួយគាត់។[19]សត្វដែលមានជីវិត សត្វលូនវា
និងសត្វបក្សាបក្សីទាំងអស់ ដែលមានចលនានៅលើផែនដី តាមពូជ តាមគ្រួសាររៀងៗខ្លួន បានចាកចេញពីទូក។
[20]លោកណូអេបានសង់អាសនៈថ្វាយព្រះអម្ចាស់។ គាត់បានយកសត្វខ្លះពីសត្វស្អាត និងសត្វបក្សាបក្សីខ្លះពីសត្វបក្សាបក្សីដែលស្អាត
ហើយបានថ្វាយជាតង្វាយដុតនៅលើអាសនៈ។[21]ព្រះអម្ចាស់បានធំក្លិនឆ្ងុយគាប់ព្រះទ័យដល់ព្រះអង្គ ហើយព្រះអង្គមានបន្ទូលក្នុងព្រះទ័យរបស់ព្រះអង្គថា
ទោះបីជានៅក្នុងដួងចិត្តរបស់ពួកគេអាក្រក់តាំងពីតូចមកក្តី។ យើងនឹងមិនបំផ្លាញអ្វីៗដែលមានជីវិតទៀត ដូចយើងបានធ្វើនេះទេ។[22]ដរាបណាផែនដីនៅមាន
នឹងមានពេលសាបព្រោះ និងច្រូតកាត់ នឹងមានក្តៅ និងត្រជាក់ នឹងមានរដូវក្តៅ និងរដូវរងា និងមានថ្ងៃ មានយប់ មិនអាក់ខានឡើយ។

Genesis 8:1
បាននឹកចាំ
«នឹកចាំ»ឬ«បានគិតអំពី»
ទូកធំ
នេះសំដៅទៅលើប្រអប់មួយដែលមានទំហំធំណាស់ដែលអាចអណ្តែតលើទឹកសូម្បីតែក្នុងអាកប្បកិរិយាដែលធ្ងន់ធ្ងរក៏ដោយ។ សូមមើលការបកប្រែផ្សេងទៀត៖ «ទូកធំ» ឬ «កប៉ាល់» ឬ «ទូក» ដូចនៅក្នុង ៦:១៣
ប្រភពទឹកដែលផុតចេញពីជម្រៅ ហើយទ្វារនៃស្ថានសួគ៌បានបិទ
ទឹកឈប់ហូរចេញពីដីហើយភ្លៀងក៏ឈប់ធ្លាក់ចុះមក។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់បានបិទប្រភពទឹកជ្រៅនិងបង្ហួចនៃស្ថានបរមសុខ»
ប្រភពទឹកដែលផុតចេញពីជម្រៅ
«ទឹកពីក្រោមផែនដី» ។ សូមមើលនៅក្នុង ៧:១១
ហើយទ្វារនៃស្ថានសួគ៌បានបិទ
នេះសំដៅទៅលើភ្លៀងបញ្ឈប់។
វាពិពណ៌នាអំពីមេឃជាពិដានមួយដែលធ្វើឱ្យទឹកនៅពីលើវាធ្លាក់មកលើផែនដី។
នៅពេលដែលបង្ហួចឬទ្វារនៅលើមេឃត្រូវបានបិទទឹកឈប់ហូរឆ្លងកាត់ពួកគេ។
ការបកប្រែផ្សេងទៀត៖ «មេឃបិទ» ឬ «ទ្វារនៅលើមេឃបានបិទ» ។
សូមមើលពីរបៀបដែល «បង្ហួចនៃស្ថានសួគ៌» ត្រូវបានបកប្រែនៅក្នុង ៧:១១ ។
Genesis 8:4
បានជាប់ភ្នែង
«ចុះចត» ឬ «ឈប់នៅលើដីរឹង»
ក្នុងខែទីប្រាំពីរ, នៅថ្ងៃទីដប់ប្រាំពីរនៃខែនោះ .....ខែទីដប់
ដោយសារម៉ូសេបានសរសេរសៀវភៅនេះវាអាចថាគាត់កំពុងសំដៅទៅលើខែទីប្រាំពីរ
និងខែទីដប់នៃប្រតិទិនហេព្រើរប៉ុន្តែនេះមិនច្បាស់ទេ។
នៅថ្ងៃទីមួយនៃខែនោះ
«នៅថ្ងៃដំបូងនៃខែទីដប់»
បានលេចឡើង
អាចត្រូវបានធ្វើឱ្យកាន់តែច្បាស់៖ «បានបង្ហាញខ្លួននៅខាងលើផ្ទៃទឹក។ »
Genesis 8:6
ក្រោយមក
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
ការបកប្រែផ្សេងទៀត៖ «វាបានកើតឡើងថា»
ក្រោយមក.....បានបើកបង្ហួចទូកដែលលោកបានធ្វើនោះ
ឃ្លា « គាត់បានបង្កើត» ប្រាប់អំពីបង្ហួច។
ភាសាខ្លះប្រហែលជាត្រូវបង្កើតឃ្លានេះជាប្រយោគដាច់ដោយឡែកមួយ៖
«ណូអេបានធ្វើបង្ហួចនៅលើទូក។
វាបានកើតឡើងបន្ទាប់ពីសែសិបថ្ងៃដែលគាត់បានបើកបង្ហួច»
សត្វក្អែក
បក្សីខ្មៅមួយដែលស៊ីសាច់សត្វងាប់ភាគច្រើន។
វាក៏ហើរទៅហើយមក
មានន័យថាសត្វក្អែកនៅតែចាកចេញពីទូកហើយត្រឡប់មកវិញ។
រហូតទាល់តែទឹកស្ងួតពីផែនដី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«រហូតដល់ខ្យល់ស្ងួតទឹក» ឬ «រហូតដល់ទឹកស្ងួត»
Genesis 8:8
រកកន្លែងទំមិនបាន
«ដើម្បីចុះ» ឬ «ដើម្បី ទំ »
វាមានន័យថាចុះចតលើអ្វីមួយដើម្បីសម្រាកពីការហោះហើរ។
ទំមិនបាន....វាត្រលប់មកវិញ.....ហើយយកវាត្រឡប់ចូលមក
ពាក្យថា« ព្រាប» គឺមានលក្ខណៈជាភាសារបស់អ្នកនិពន្ធ។
អ្នកអាចបកប្រែឃ្លាទាំងនេះជាមួយសព្វនាម «វា ... វា ... វា» ឬ «របស់គាត់ ...
គាត់ ... គាត់» អាស្រ័យលើភាសារបស់អ្នកសំដៅទៅលើសត្វព្រាប។
គាត់.....គាត់
ប្រសិនបើអ្នកប្រើសព្វនាមបុរសសម្រាប់ពាក្យ «ព្រាប»
អាក្រក់ក្តីវាយបង្ហូរឈ្មោះរបស់ណូអេនៅទីនេះដើម្បីជៀសវាងការភាន់ច្រលំ៖
«ណូអេបានបញ្ចោញសត្វព្រាប» «ណូអេលាតដៃ» ។ ល។
Genesis 8:10
មើល!
«យកចិត្តទុកដាក់» ឬ «នេះគឺសំខាន់»
នៅមាត់របស់វាមានត្បួយអូលីវ
«ស្លឹកឈើដែលវាទើបតែបេះពីដើមអូលីវ»
ពាំ
«ខូច»
គាត់បានរង់ចាំប្រាំពីរថ្ងៃទៀត
«គាត់បានរង់ចាំ៧ថ្ងៃម្តងទៀត»
វាមិនបានត្រឡប់មករកគាត់វិញទេ
ប្រសិនបើមនុស្សមិនយល់អ្នកអាចបញ្ជាក់ពីហេតុផលយ៉ាងច្បាស់ថា
«វាមិនបានវិលត្រឡប់មករកគាត់ម្តងទៀតទេពីព្រោះវារកកន្លែងទំបានហើយ»
Genesis 8:13
នៅថ្ងៃ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
នៅអាយុ៦០០ឆ្នាំនៃឆ្នាំទី១
«គឺនៅពេលដែលលោកណូអេមានអាយុ៦០០ឆ្នាំ»
នៅខែទីមួយ,នៅក្នុងថ្ងៃទី១ក្នុងខែ
ដោយសារម៉ូសេបានសរសេរសៀវភៅនេះវាអាចទៅរួចដែលគាត់កំពុងសំដៅទៅលើខែដំបូងនៃប្រតិទិនហេ
ទឹកបានរីងស្ងួតពីផែនដីទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ទឹកដែលគ្របលើផែនដីរីងស្ងួត» ឬ«
ខ្យល់បានធ្វើអោយទឹករីងស្ងួតដែលគ្របលើផែនដី»
ដំបូលទូក
នេះគឺសំដៅទៅលើដំបូលគ្របទូកដែលការពារកុំអោយទូកត្រូវទឹកភ្លៀង។
សម្លឹងមើល
ពាក្យ«សម្លឹងមើល»គឺកំពុងតែប្រាប់ពីការដែលត្រូវយកចិត្តទុកដាក់និងពត៌មានសំខាន់ដែលនិងត្រូវមកប
នៅខែទីពីរ ថ្ងៃទីម្ភៃប្រាំពីរនៃខែ
នៅថ្ងៃទី៧នៃខែនោះ«នៅ២៧ថ្ងៃនៃខែទី២»នេះគឺសំដៅទៅនិងខែទី២នៃភាសាហេព្រើរក្នុងប្រតិទិន
ប៉ុន្តែវាមិនបានបញ្ជាក់ច្បាស់ទេ។
ផែនដីបានស្ងួតអស់
«គឺដីទាំងមូលបានស្ងួតទាំងអស់»
Genesis 8:15
ចូរចេញ.....ចូរយក
«ចេញ ... យកទៅ» ការបកប្រែខ្លះអានថា « ចេញមក...នាំចេញមក»
សត្វមានជីវិតទាំងអស់ដែលនៅ
«សត្វមានជីវិតគ្រប់ប្រភេទ» សូមមើលពីរបៀបដែល « សត្វទាំងអស់» នៅក្នុង
៦:១១
ចូរបង្កើតផល,និងបានចម្រើនឡើង
សូមមើលនៅក្នុង ១:២៨ ។
ព្រះចង់ឲ្យមនុស្សនិងសត្វបង្កើតឡើងវិញដូច្នេះវានឹងមានច្រើន។
Genesis 8:18
លោកណូអេបានចេញក្រៅ
នៅត្រង់នេះបកប្រែថា «លោកណូអេបានចេញមកខាងក្រៅ»

generated on Wed Sep 10 16:16:32 2025

តាមគ្រួសាររៀងៗខ្លួន
«នៅក្នុងក្រុមនៃប្រភេទផ្ទាល់ខ្លួនរបស់ពួកគេ»
Genesis 8:20
បានសង់អាសនៈថ្វាយព្រះអម្ចាស់
«បានបានសង់អាសនៈថ្វាយព្រះអម្ចាស់ថ្វាយព្រះអម្ចាស់»
ឬ«សង់អាសនៈសម្រាប់ថ្វាយបង្គំព្រះអម្ចាស់»
គាត់ប្រហែលជាសាងសង់ឡើងជាមួយថ្ម។
សត្វស្អាត.....បក្សាបក្សីដែលស្អាត
ត្រង់នេះ« ស្អាត» មានន័យថាព្រះអនុញ្ញាតអោយប្រើសត្វទាំងនេះក្នុងការបូជា។
សត្វខ្លះមិនត្រូវបានប្រើសម្រាប់ការធ្វើបូជាឡើយត្រូវបានគេហៅថាមិនស្អាត។
ថ្វាយជាតង្វាយដុត
ណូអេបានសម្លាប់សត្វហើយដុតវាជាតង្វាយថ្វាយដល់ព្រះ។
ការបកប្រែផ្សេងទៀត៖ «ដុតសត្វជាតង្វាយថ្វាយព្រះអម្ចាស់»
គាប់ព្រះទ័យដល់ព្រះអង្គ
នេះគឺសំដៅទៅលើក្លិនឈ្ងុយនៃដង្វាយដុត។
មានបន្ទូលក្នុងព្រះទ័យ
ពាក្យ«ព្រះទ័យ» សំដៅទៅលើគំនិតនិងអារម្មណ៍របស់ព្រះអង្គ។
បំផ្លាញដី
«ធ្វើបាបធ្ងន់ធ្ងរដល់ផែនដី»
ដោយសារតែមនុស្សជាតិ
នេះអាចត្រូវបានបញ្ជាក់ឱ្យកាន់តែច្បាស់៖
«ពីព្រោះមនុស្សជាតិមានពេញដោយអំពើបាប» ។
ទំនោរចិត្តរបស់គេគឺអាក្រក់តាំងពីក្មេងមក
«តាំងពីឆ្នាំដំបូងពួកគេមានទំនោរធ្វើរឿងអាក្រក់» ឬ
«នៅពេលពួកគេនៅក្មេងពួកគេចង់ធ្វើអ្វីដែលអាក្រក់»
ទំនោរចិត្តរបស់គេ
ត្រង់នេះពាក្យ «ដួងចិត្ត» សំដៅទៅលើគំនិតអារម្មណ៍បំណងប្រាថ្នា
និងឆន្ទៈរបស់មនុស្ស។ ការបកប្រែផ្សេងទៀត៖ «ទំនោររបស់ពួកគេ» ឬ
«ទម្លាប់របស់ពួកគេ»
តាំងពីក្មេង
នេះគឺសំដៅទៅលើក្មេងចាស់។ ការបកប្រែផ្សេងទៀត៖
«ចាប់តាំងពីពួកគេជាយុវវ័យ»
ខណៈពេលដែលផែនដីនៅសល់
«ខណៈពេលដែលផែនដីមានរយៈពេល» ឬ «ដរាបណាផែនដីមាន»
ពេលសាបព្រោះ
«ជារដូវសម្រាប់ដាំដុះ»
មានក្តៅ និងត្រជាក់ នឹងមានរដូវក្តៅ និងរដូវរងា
កន្សោមទាំងពីរនេះសំដៅទៅលើលក្ខខណ្ឌអាកាសធាតុធំពីរនៅក្នុងឆ្នាំ។
អ្នកបកប្រែអាចប្រើឃ្លាក្នុងតំបន់។
រដូវក្តៅ
ក្តៅ ពេលស្ងួតហួតហែងនៃឆ្នាំ
រដូវរងារ
រដូវត្រជាក់ សើមឬមានធ្លាក់ព្រឹលនៃឆ្នាំ។
មិនដែលអាក់ខាន
«នឹងមិនឈប់មានទេ» ឬ «នឹងមិនបញ្ឈប់ការកើតឡើងទេ» ។
នេះអាចត្រូវបានបង្ហាញក្នុងលក្ខណៈវិជ្ជមាន។ ការបកប្រែផ្សេងទៀត៖ «នឹងបន្ត»

9 [1]បន្ទាប់មក ព្រះជាម្ចាស់បានប្រទានពរដល់លោកណូអេ និងកូនប្រុសៗរបស់គាត់ ដោយមានបន្ទូលទៅពួកគេថា៖ «ចូរបង្កើតផល
ឲ្យបានចម្រើនឡើងបានពេញផែនដី។[2]សត្វដែលរស់នៅលើផែនដី ទាំងសត្វបក្សាបក្សីនៅលើមេឃ និងអ្វីៗដែលនៅក្រោមដី
ហើយនិងត្រីសមុទ្រទាំងអស់នឹងភ័យខ្លាចអ្នករាល់គ្នា។ យើងនឹងប្រគល់ពួកគេនៅក្នុងកណ្តាប់ដៃអ្នករាល់គ្នា។
[3]អ្វីៗទាំងអស់ដែលធ្វើចលនា ដែលមានជីវិតនឹងត្រូវធ្វើជាអាហារដល់អ្នករាល់គ្នា។ យើងឲ្យអ្វីៗទាំងអស់នេះដល់អ្នករាល់គ្នា
ដូចយើងបានឲ្យតិណជាតិទាំងឡាយដល់អ្នករាល់គ្នាដែរ។[4]ប៉ុន្តែ អ្នកមិនត្រូវហូបសាច់ដែលមានជីវិតនៅក្នុងវាទេ នោះឈាមដែលនៅក្នុងវានោះឯង។
[5]ដោយព្រោះឈាមរបស់អ្នក មានជីវិតនៅក្នុងឈាមរបស់អ្នកនោះ យើងនឹងទាមទារឲ្យបង់ថ្លៃវិញ។ ពីគ្រប់ទាំងសត្វណាដែលបង្ហូរឈាមអ្នក យើងនឹងទាមទារមកវិញ។
ហើយបើដៃរបស់មនុស្សណាម្នាក់ គឺដៃដែលរបស់អ្នកដែលបានសម្លាប់បងប្អូនរបស់គេ យើងនឹងទាមទារស្របទៅតាមជីវិតរបស់អ្នកនោះវិញ។
[6]អស់អ្នកដែលណាដែលបង្ហូរឈាមមនុស្ស អ្នកនោះនឹងត្រូវស្លាប់ដែរ ដ្បិត គេគឺជារូបភាពរបស់ព្រះជាម្ចាស់ គឺព្រះអង្គបានបង្កើតគេមក។[7]អ្នករាល់គ្នាក៏ដូចគ្នាដែរ
ចូរបង្កើតផល ហើយបានចម្រើនឡើង នៅពាសពេញផែនដី និងបានចម្រុងចម្រើនឡើង។
[8]បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកណូអេ និងកូនប្រុសៗដែលនៅជាមួយគាត់ថា ដោយបន្ទូលថា៖[9]«រីឯយើងវិញ ចូរស្តាប់!
យើងនឹងតាំងសម្ពន្ធមេត្រីរបស់យើងជាមួយអ្នករាល់គ្នា
និងពូជពង្សរបស់អ្នកដែលនៅបន្ទាប់ពីអ្នករាល់គ្នា[10]ព្រមទាំងតាំងជាមួយនឹងសត្តនិករមានជីវិតទាំងឡាយដែលនៅជាមួយអ្នក ពីអ្វីៗទាំងអស់ដែលចេញពីទូកមក
និងជាមួយនឹងសត្តនិករទាំងអស់ដែលនៅផែនដី។
[11]យើងតាំងសម្ពន្ធមេត្រីជាមួយនឹងអ្នករាល់គ្នាថា យើងនឹងមិនបំផ្លាញជីវិតទាំងអស់ដោយសារទឹកជំនន់ទៀតទេ។ នឹងមិនមានទឹកជំនន់បំផ្លាញផែនដីទៀតទេ»។
[12]ព្រះជាម្ចាស់មានបន្ទូលថា៖ «នេះគឺជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីដែលយើងបានតាំងរវាងយើង និងអ្នករាល់គ្នា
ព្រមទាំងសត្តនិករដែលមានជីវិតទាំងឡាយដែលនៅជាមួយអ្នករាល់គ្នា នៅគ្រប់ជំនាន់តរៀងទៅ។[13]យើងបានដាក់ឥន្ទធនូនៅលើពពក
ហើយវាជាទីសម្គាល់នៃសម្ពន្ធមេត្រីរវាងយើង និងផែនដី។
[14]វានឹងកើតឡើងនៅពេលយើងដាក់ពពកនៅលើផែនដី ហើយនឹងឃើញឥន្ទធនូនៅលើពពកនោះ[15]ពេលនោះ យើងនឹងរំលឹកខ្លួនយើងពីសម្ពន្ធមេត្រីរបស់យើង
ដែលបានតាំងរវាងយើង និងអ្នករាល់គ្នា ហើយនិងសត្តនិករដែលមានជីវិតទាំងឡាយ។ ទឹកនឹងមិនត្រឡប់ទៅជាទឹកជំនន់បំផ្លាញជីវិតរបស់មនុស្សទៀតទេ។
[16]ឥន្ទធនូនឹងនៅលើពពក ហើយយើងនឹងឃើញវា ដើម្បីរំលឹកពីសម្ពន្ធមេត្រីដ៏នូវអស់កល្ប រវាងព្រះជាម្ចាស់ និងសត្តនិករដែលមានជីវិតទាំងឡាយ ដែលនៅលើផែនដី។
[17]នៅពេលព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកណូអេថា៖ «នេះគឺជាទីសម្គាល់នៃសម្ពន្ធមេត្រីដែលយើងបានតាំងរវាងយើង
និងគ្រប់ទាំងជីវិតដែលនៅរស់នៅលើផែនដីទាំងមូល»។
[18]កូនប្រុសៗរបស់លោកណូអេដែលបានចេញពីទូកមកមានឈ្មោះដូចជា សិម ហាំ និងយ៉ាផេត។ លោកហាំជាឪពុករបស់កាណាន។
[19]នេះគឺជាកូនប្រុសៗទាំងបីរបស់លោកណូអេ ហើយកូនចៅទាំងនេះហើយ បានបានចេញទៅពាសពេញពិភពលោកទាំងមូល។
[20]លោកណូអេបានចាប់ផ្តើមធ្វើស្រែចម្ការ ហើយគាត់បានដាំដើមទំពាំងបាយជូរ។[21]គាត់បានផឹកស្រាខ្លះ ហើយបានស្រវឹង។ គាត់ដេកអាក្រាតនៅក្នុងរោងរបស់គាត់។
[22]លោកហាំជាឪពុករបស់លោកកាណាន បានឃើញភាពអាក្រាតរបស់ឪពុកគាត់ ហើយបានប្រាប់ដល់បងទាំងពីរនាក់ដែលនៅខាងក្រៅ។[23]ដូច្នេះ លោកសិម និង
លោកយ៉ាផេតបានយកសំពត់មួយ ហើយដាក់វាគ្របនៅលើស្មារបស់ពួកគេ ហើយដើរថយក្រោយ ហើយបានគ្របបាំងភាពអាម៉ាសឪពុករបស់ពួកគេ។
ពួកគេបានបានបែរភ្នែកទៅកន្លែងផ្សេង ដើម្បីកុំឲ្យពួកគេបានឃើញភាពអាក្រាតរបស់ឪពុកពួកគេឡើយ។
[24]នៅពេលលោកណូអេភ្ញាក់ឡើងពីភាពស្រវឹងរបស់គាត់ គាត់បានដឹងពីអ្វីដែលកូនប្រុសពៅរបស់គាត់បានធ្វើចំពោះគាត់។ ដូច្នេះ[25]គាត់បាននិយាយថា៖
«កាណានត្រូវបណ្តាសាហើយ។ សូមឲ្យវាបានក្លាយជាអ្នកបម្រើ អ្នកបម្រើរបស់បងៗរបស់វា»។
[26]គាត់និយាយថា៖ «ព្រះអម្ចាស់អើយ និងជាព្រះជាម្ចាស់របស់លោកសិមអើយ សូមឲ្យព្រះអង្គបានប្រកបដោយព្រះពរ
ហើយសូមឲ្យកាណានបានក្លាយជាអ្នកបម្រើរបស់គាត់។[27]សូមព្រះជាម្ចាស់ពង្រីកទឹកដីរបស់លោកយ៉ាផេត ហើយឲ្យគាត់បានធ្វើផ្ទះនៅក្នុងរោងរបស់លោកសិម។
សូមឲ្យកាណានបានក្លាយជាអ្នកបម្រើវិញ»។
[28]បន្ទាប់ពីទឹកជំនន់រួចហើយ លោកណូអេរស់បានមួយរយហាសិបឆ្នាំទៀត។[29]លោកណូអេរស់បានទាំងអស់ប្រាំបួនរយហាសិបឆ្នាំ ហើយបន្ទាប់មក គាត់ក៏ស្លាប់ទៅ។

generated on Wed Sep 10 16:16:32 2025

Genesis 9:1

ចូរបង្កើតផល ឲ្យបានចម្រើនឡើងបានពេញផែនដី

នេះគឺជាព្រះពររបស់ព្រះជាម្ចាស់។ ព្រះអង្គបានប្រាប់ណូអេ និង
ក្រុមគ្រួសាររបស់គាត់ឲ្យបង្កើតមនុស្សជាច្រើនដូចជាពួកគេដែរដូច្នេះនឹងមានមនុស្សជាច្រើន។
ពាក្យថា «ចម្រើនឡើង» ពន្យល់ពីរបៀបដែលពួកគេអាច«បង្កើតផលបាន»។
សូមមើលនៅក្នុង ១:២៨ ។

ការភ័យខ្លាចរបស់អ្នកនិងការភ័យខ្លាចរបស់អ្នកនឹងកើតមានលើសត្វមានជីវិតទាំងអស់.....និងត្រីសមុទ្រទាំងអស់

អ្នកនិពន្ធនិយាយពីការភ័យខ្លាចនិងការភ័យខ្លាចខ្លាំង មានន័យជារួមដូចគ្នា
ហើយនឹងរបៀបភ័យខ្លាចលើសត្វយ៉ាងណា។ ការបកប្រែផ្សេងទៀត៖
«សត្វមានជីវិតទាំងអស់ ... និងត្រីសមុទ្រទាំងអស់នឹងខ្លាចអ្នក»

ការភ័យខ្លាចរបស់អ្នកនិងការភ័យខ្លាចរបស់អ្នក

ពាក្យថា «ការភ័យខ្លាច» និង «ខ្លាច»
មានន័យថាជារួមដូចគ្នានិងបញ្ជាក់ពីការភ័យខ្លាចរបស់សត្វនឹងមនុស្សជាតិ។
ការបកប្រែផ្សេងទៀត៖ «ការភ័យខ្លាចដ៏គួរឱ្យខ្លាចចំពោះអ្នក» ឬ
«ការភ័យខ្លាចដ៏គួរឱ្យភ័យខ្លាចចំពោះអ្នក»

សត្វដែលរស់នៅលើផែនដី

នេះជាប្រភេទសត្វទីមួយក្នុងចំណោម ៤
ប្រភេទដែលអ្នកនិពន្ធបានចុះបញ្ជីហើយមិនមែនជាសេចក្តីសង្ខេបនៃសត្វដែលនៅសល់ទេ។
គាត់និងលើកឡើងបន្ទាប់ទៀត។

សត្វបក្សាបក្សី

នេះគឺជាពាក្យទូទៅសម្រាប់អ្វីដែលហោះហើរ។ សូមមើលនៅក្នុង ១:២០

នៅលើមេឃ និងអ្វីៗដែលនៅក្រោមដី

នេះរួមបញ្ចូលទាំងសត្វតូចៗគ្រប់ប្រភេទ។ សូមមើលនៅក្នុង ១:២៤

ប្រគល់ពួកគេនៅក្នុងកណ្តាប់ដៃអ្នករាល់គ្នា

ដៃគឺជាឈ្មោះហៅក្រៅសម្រាប់វត្ថុបញ្ជាដែលដៃមាន។
នេះអាចត្រូវបានធ្វើឱ្យសកម្ម។ ការបកប្រែផ្សេងទៀត៖
«ពួកគេត្រូវបានប្រគល់ទៅក្នុងការគ្រប់គ្រងរបស់អ្នក» ឬ
«ខ្ញុំបានដាក់ពួកគេនៅក្រោមការគ្រប់គ្រងរបស់អ្នក» (សូមមើល និងfigs-activepassive)

Genesis 9:3

ព័ត៌មានទូទៅ

ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកណូអេនិងកូនប្រុសរបស់គាត់។

ជីវិត.....ឈាម

អ្នកបកប្រែអាចបន្ថែមដូចតទៅនេះ៖ «ឈាមគឺជានិមិត្តរូបសម្រាប់ជីវិត»
ពួកគេក៏អាចបន្ថែមលេខយោងដែលនិយាយអ្វីមួយដូចនេះដែរថា៖
«ព្រះជាម្ចាស់បានបញ្ជាប្រជាជនមិនឱ្យបរិភោគសាច់ខណៈពេលឈាមនៅតែមាន។
ពួកគេត្រូវបង្ហូរឈាមចេញជាមុនសិន»។

Genesis 9:5

ព័ត៌មានទូទៅ

ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកណូអេនិងកូនប្រុសរបស់គាត់។

ក្នុងឈាមរបស់អ្នក

នេះផ្ទុយពីឈាមរបស់មនុស្សនិងឈាមរបស់សត្វ (៩: ១)

ដោយព្រោះឈាមរបស់អ្នក, មានជីវិតនៅក្នុងឈាមរបស់អ្នកនោះ

មានន័យថាឈាមស្រក់ឬបង្ហូរចេញឬកំពប់ចេញ។ ការបកប្រែផ្សេងទៀត៖
«ប្រសិនបើនរណាម្នាក់ធ្វើឱ្យឈាមរបស់អ្នកហូរចេញ» ឬ
«ប្រសិនបើនរណាម្នាក់ហៀរឈាមរបស់អ្នក» ឬ
«ប្រសិនបើនរណាម្នាក់សម្លាប់អ្នក»

ជីវិត

នេះគឺសំដៅទៅលើជីវិតរូបកាយ

យើងនឹងទាមទារ

ការបង់ប្រាក់នេះសំដៅទៅលើការស្លាប់របស់ឃាតករមិនមែនដើម្បីលុយទេ។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំនឹងតម្រូវឱ្យអ្នកដែលសម្លាប់អ្នកបង់ប្រាក់»

ពីដៃ

ពាក្យត្រង់នេះ«ដៃ»គឺសំដៅទៅលើនរណាដែលទទួលខុសត្រូវទៅលើអ្វីដែលនិងកើតឡើង។
(សូមមើលfigs-synecdoche)

ពីគ្រប់ទាំងសត្វណាដែលបង្ហូរឈាមអ្នក យើងនឹងទាមទារ

«យើងនឹងតម្រូវឱ្យមានសត្វណាដែលយកជីវិតរបស់អ្នកបង់"

ហើយបើដៃរបស់មនុស្សណាម្នាក់, គឺដៃដែលរបស់អ្នកដែលបានសម្លាប់បងប្អូនរបស់អ្នក,
យើងនឹងទាមទារស្របទៅតាមជីវិតរបស់អ្នកនោះវិញ

«យើងនិងតម្រូវអោយមាននរណា យកជីវិតអ្នកផ្សេងទៅបង់ជំនួសវិញ»

ពីដៃនៃ

ឃ្លានេះសំដៅទៅលើបុគ្គលតាមរបៀបផ្ទាល់ខ្លួន។ ការបកប្រែផ្សេងទៀត៖
«ពីមនុស្សម្នាក់នោះ» (សូមមើលfigs-synecdoche)

បងប្អូន

នៅទីនេះ «បងប្អូន»

ត្រូវមាន

អស់អ្នកដែលណាដែលបង្ហូរឈាមមនុស្ស អ្នកនោះនឹងត្រូវស្លាប់ដែរ

ការបង្ហូរឈាមគឺជាការប្រៀបធៀបសម្រាប់ការសម្លាប់នរណាម្នាក់។
នេះមានន័យថាប្រសិនបើមនុស្សម្នាក់សម្លាប់នរណាម្នាក់
អ្នកផ្សេងត្រូវសម្លាប់ឃាតករ។ ទោះជាយ៉ាងណាក៏ដោយ «ឈាម»
គឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងអត្ថបទនេះ។ «ស្រក់ឈាម»
ដោយពាក្យដែលបង្ហាញពីការបាត់បង់ឈាមដ៏ធំមួយដែលបណ្តាលឱ្យស្លាប់។

គេគឺជារូបភាពរបស់ព្រះជាម្ចាស់ គឺព្រះអង្គបានបង្កើតគេមក

«ពីព្រោះព្រះជាម្ចាស់បង្កើតមនុស្សអោយដូចរូបអង្គទ្រង់» ឬ
«ពីព្រោះយើងបានបង្កើតមនុស្សអោយដូចរូបយើង»

ចូរបង្កើតផល ហើយបានចម្រើនឡើង

ដែលគឺជាការប្រទានពររបស់ព្រះ។
ទ្រង់បានប្រាប់ដល់ណូអេនិងក្រុមគ្រួសាររបស់គាត់ឲ្យបង្កើតមនុស្សជាច្រើនដូចជាពួកគេដែរ។
ដូច្នេះនឹងមានមនុស្សជាច្រើន។ ពាក្យថា «ចម្រើនឡើង»
ពន្យល់ពីរបៀបដែលពួកគេអាចបង្កើតផលបាន។ សូមមើលនៅក្នុង ១:២៨

Genesis 9:8

បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកណូអេ និងកូនប្រុសៗដែលនៅជាមួយគាត់

ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់ពួកគាត់រួចហើយ។
ឃ្លានេះសម្គាល់ការផ្លាស់ប្តូរអ្វីដែលព្រះជាម្ចាស់នឹងត្រូវនិយាយ។
ការបកប្រែផ្សេងទៀត៖ « ព្រះជាម្ចាស់បានបន្តមានបន្ទូលទៅកាន់ណូអេនិងកូន ៗ
របស់គាត់» ឬ«បន្ទាប់មកព្រះបានបន្តបន្ទូលទៅ»

រីឯយើងវិញ

ឃ្លានេះត្រូវបានប្រើជាភាសាអង់គ្លេសដើម្បីសម្គាល់ការផ្លាស់ប្តូរពីព្រះជាម្ចាស់ដែលបានមានបន្ទូលអំពីអ្វីដែ

យើងនឹងតាំងសម្ពន្ធមេត្រីរបស់យើងជាមួយអ្នករាល់គ្នា

«ធ្វើកិច្ចព្រមព្រៀងរវាងអ្នកនិងយើង»។ ដូចនៅក្នុង ៦:១៨ ។

Genesis 9:11

ព័ត៌មានទូទៅ

ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកណូអេ និងកូនប្រុសរបស់គាត់

យើងតាំងសម្ពន្ធមេត្រីជាមួយនឹងអ្នករាល់គ្នា

«ដោយនិយាយបែបនេះ យើងតាំងសម្ពន្ធមេត្រីជាមួយអ្នក»
សូមមើលពីរបៀបដែលពាក្យស្រដៀងគ្នានេះត្រូវបានបកប្រែនៅក្នុង ៦:១៨ ។

ជីវិតទាំងអស់

អាចមានអត្ថន័យ១)សម្រាប់មនុស្សទាំងអស់ឬ២)សម្រាប់មនុស្សនិងសត្វទាំងអស់។

មិនបំផ្លាញជីវិតទាំងអស់ដោយសារទឹកជំនន់ទៀតទេ

« នឹងលែងមានទឹកជំនន់បំផ្លាញផែនដីទៀតហើយ» វានឹងមានទឹកជំនន់
ប៉ុន្តែពួកគេនឹងមិនបំផ្លាញផែនដីទាំងមូលឡើយ។

សញ្ញាសម្គាល់

នេះមានន័យថាការរំលឹកពីអ្វីមួយដែលបានសន្យា។

សម្ពន្ធមេត្រី.....នៅគ្រប់ជំនាន់តរៀងទៅ

កាតាំងសម្ព័ន្ធមេត្រីនេះសម្រាប់លោកណូអេនិងគ្រួសាររបស់គាត់និងចំពោះមនុស្សគ្រប់ជំនាន់ទាំងអស់ផង

Genesis 9:14

ព័ត៌មានទូទៅ

ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកណូអេ និងកូនរបស់គាត់។

វានឹងកើតឡើងនៅពេល

«នៅពេលណា » គឺជាអ្វីដែលនឹងកើតឡើងច្រើនដង។

ឃើញឥន្ទនូ

គឺមិនច្បាស់ទេថាតើអ្នកណានឹងឃើញឥន្ទនូនោះទេប៉ុន្តែដោយសារតែការតាំងសម្ព័ន្ធមេត្រីរវាងព្រះអម្ចាស់
និងប្រជាជន
ប្រសិនបើអ្នកចង់និយាយថានរណាជានរណាដែលនឹងឃើញឥន្ទធនូវាជាការល្អបំផុតដែលដាក់ឈ្មោះទាំង
និងមនុស្ស។ នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«មនុស្សនិងយើងឃើញឥន្ទនូ»

ឥន្ទនូ

ឆ្នូតចម្រុះពណ៌នៃពន្លឺដែលលេចចេញជាទឹកភ្លៀងនៅពេលព្រះអាទិត្យរះពីខាងក្រោយអ្នកមើល។

generated on Wed Sep 10 16:16:32 2025

យើងនឹងរំលឹកខ្លួនយើងពីសម្ពន្ធមេត្រីរបស់យើង
នេះមិនបានន័យថាព្រះជាម្ចាស់នឹងភ្លេចមុនគេទេ។ ការបកប្រែផ្សេងទៀត៖
«យើងនឹងគិតអំពីការតាំងសម្ព័ន្ធមេត្រីរបស់យើង»
យើងនិងអ្នក
ពាក្យត្រង់នេះ«អ្នក»គឺជាពហុវចៈ។
គឺព្រះជាម្ចាស់បានមានព្រះបន្ទូលទៅកាន់លោកណូអេ និង កូនៗរបស់គាត់។
និងសត្តនិករដែលមានជីវិតទាំងឡាយ
«គ្រប់សត្តនិករដែលមានជីវិតរស់ទាំងអស់»
ជីវិតទាំងឡាយ
មានអត្ថន័យ១) មនុស្សឬ២)
គ្រប់មនុស្សទាំងអស់,រួមបញ្ចូលទាំងមនុស្សហើយនិងសត្វ។ ដូចនៅក្នុង៦:១១
Genesis 9:16
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកណូអេ និងកូនរបស់គាត់។
ដើម្បីរំលឹក
«ដូច្នេះយើងនឹងនឹកចាំ» ឬ «ដូច្នេះយើងនឹងគិតអំពី»
រវាងព្រះជាម្ចាស់ និង សត្តនិករដែលមានជីវិតទាំងឡាយ
ព្រះជាម្ចាស់មានបន្ទូលត្រង់នេះ។ ការបកប្រែផ្សេងទៀត៖
«រវាងព្រះជាម្ចាស់នឹងសព្វសត្វមានជីវិតទាំងឡាយ»
មានជីវិតទាំងឡាយ
«សព្វសត្វមានជីវិតទាំងអស់» ដូចនៅក្នុង៩:១៤
ពេលព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកណូអេ
ព្រះជាម្ចាស់បាននិយាយជាមួយណូអេរួចហើយ។
ឃ្លានេះសម្គាល់ផ្នែកចុងក្រោយនៃអ្វីដែលព្រះកំពុងមានបន្ទូល។
ការបកប្រែផ្សេងទៀត៖ « ព្រះជាម្ចាស់បានបញ្ចប់ដោយនិយាយទៅកាន់ណូអេ»
ឬ« ដូច្នេះព្រះជាម្ចាស់បានមានបន្ទូលទៅកាន់ណូអេ»
Genesis 9:18
ព័ត៌មានទូទៅ
នៅក្នុងខ១៨-១៩គឺណែនាំពីកូនប្រុសទាំងបីរបស់កាណូអេក៏ជាបុគ្គលដ៏សំខាន់ដែរ
និងនិយាយនៅសាច់រឿងខាងមុខបន្ត។
ឪពុក
ហាំគឺជាឪពុករបស់កាណាន។
Genesis 9:20
ចម្ការ
«មនុស្សនៃដី»
ហើយបានស្រវឹង
«ស្រវឹងដោយព្រោះតែស្រាទំពាំងបាយជូរ»
អាក្រាត
អត្ថបទរបស់គាត់មិនបានបញ្ជាក់ច្បាស់ថាតើខ្លួនលោកណូអេត្រូវបានអាក្រាតនៅពេលដែលគាត់ស្រវឹង
ប្រតិកម្មរបស់កូនប្រុសគាត់បង្ហាញយើងថាគួរឱ្យខ្មាសណាស់។
Genesis 9:22
ឪពុករបស់គាត់
នេះគឺសំដៅទៅកាន់លោកណូអេ។
Genesis 9:24
ព័ត៌មានទូទៅ
នៅក្នុងខ២៥-២៧ណូអេចាប់ផ្តើមដាក់បណ្តាសាលើហាំ
ហើយប្រទានពរអោយប្អូនរបស់ហាំវិញ។ លោកណូអេនិយាយអ្វីទៅពួកគេ
ហើយឆ្លើយតបទៅ៣តំណរនៃពូជពង្សគេដូចប្រាប់នៅ
ព័ត៌មានទូទៅ
ឃ្លាជំនួសនៅក្នុងខទាំងនេះត្រូវបានចូលបន្ទាត់ដើម្បីបង្ហាញថានេះគឺជាកំណាព្យ។
ប្រសិនបើអ្នកអាចធ្វើទ្រង់ទ្រាយខទាំងនេះដូចដែលពួកវាត្រូវបានធ្វើទ្រង់ទ្រាយនៅទីនេះដើម្បីបង្ហាញអ្នកអ
ភ្ញាក់ឡើងពីភាពស្រវឹងរបស់គាត់
«ដឹងខ្លួនហើយ»
កូនប្រុសពៅរបស់គាត់
នេះសំដៅទៅកាន់ហាំ។ ការបកប្រែផ្សេងទៀត៖ «កូនប្រុសពៅ ហាំ»
កាណានត្រូវបណ្តាសាហើយ
«អញដាក់បណ្តាសាកាណាន»
ឬ«សូមអោយការអាក្រក់បានកើតឡើងដល់កាណាន»
កាណាន
នេះគឺជាកូនហាំម្នាក់។ ការបកប្រែផ្សេងទៀត៖ «កាណានកូនរបស់ហាំ»
អ្នកបម្រើ អ្នកបម្រើរបស់បងៗរបស់វា
«គឺជាអ្នកបម្រើដ៏ទាបរបស់បងប្រុសរបស់គាត់»
ឬ«អ្នកបម្រើសំខាន់បំផុតរបស់បងប្អូនប្រុសៗរបស់គាត់»
បងរបស់គាត់
នេះអាចសំដៅទៅលើបងប្អូនរបស់កាណានឬសាច់ញាតិរបស់គាត់ជាទូទៅ។
Genesis 9:26
ព័ត៌មានទូទៅ
ប្រសិនបើអ្នកប្រើទ្រង់ទ្រាយខទាំងនេះដូចដែលពួកគេបានធ្វើទ្រង់ទ្រាយនៅទីនេះដើម្បីបង្ហាញអ្នកអានថា
ព្រះអម្ចាស់អើយ និងជាព្រះជាម្ចាស់របស់លោកសិមអើយ
«ចូរសរសើរដល់ព្រះជាព្រះអម្ចាស់របស់សិម»ឬ«ព្រះអម្ចាស់ជាព្រះនៃសិម
សមនឹងទទួលបានការសរសើរ»ឬ«ខ្ញុំសូមសរសើរដំកើងដល់ព្រះជាព្រះអម្ចាស់នៃសិម»
សូមឲ្យកាណានបានក្លាយជាអ្នកបម្រើរបស់គាត់
«ហើយសូមអោយកាណានបានក្លាយជាអ្នកបម្រើដល់សិម»
នេះគឺភ្ជាប់ទៅដល់ពូជពង្សកាណាននិងសិម។
សូមព្រះជាម្ចាស់ពង្រីកទឹកដីរបស់លោកយ៉ាផេត
អាចមានអត្ថន័យ១) «សូមព្រះជាម្ចាស់ពង្រីកព្រះពរដល់យ៉ាផេតអោយច្រើនឡើង»
ឬ២)«សូមព្រះជាម្ចាស់បានប្រទានព្រះពរដល់ពូជពង្សរបស់លោកយ៉ាផេតអោយចម្រើនឡើង»
ហើយឲ្យគាត់បានធ្វើផ្ទះនៅក្នុងរោងរបស់លោកសិម
«ហើយសូមអោយគាត់បញ្ចេញសន្តិភាពហូរហៀរដល់សិម»
នេះរួមបញ្ចូលទាំងអ្នកប្រើប្រាស់ដែលមានជីវិតទាំងអស់ផងដែរ។
ដែលបានក្លាយជាអ្នកបម្រើវិញ
«សូមអោយកាយណានបានត្រលប់ទៅជាបាវបម្រើដល់យ៉ាផេតវិញ»
នេះរួមបញ្ចូលទាំងពូជពង្សកាណានរបស់យ៉ាផេតហើយនិងយ៉ាផេតដែរ។

---

10 [1]នេះគឺជាពូជពង្សកូនៗរបស់លោកណូអេ មានសិម ហាំ និងយ៉ាផេត។ ក្រោយពីទឹកជំនន់ ពួកគេបានបង្កើតកូនទាំងនេះ។

[2]កូនប្រុសៗរបស់លោកយ៉ាផេត គឺកូមើរ ម៉ាកុក ម៉ាដាយ យ៉ាវ៉ាន ទូបាល ម៉េសេក និងទីរ៉ាស។[3]កូនប្រុសៗរបស់លោកកូមើរគឺអ័សកាណាស រីផាត និងតូការម៉ា។
[4]កូនប្រុសៗរបស់លោកយ៉ាវ៉ានគឺអេលីសា តើស៊ីស គីទីម និងដូដានីម។[5]ពីមនុស្សដែលរស់នៅតាមមាត់សមុទ្រនេះហើយដែលបានបែកខ្ញែក
ហើយចេញទៅក្នុងទឹកដីរបស់ពួកគេ ពួកគេមានភាសារៀងៗខ្លួន ទៅតាមអំបូរ និងប្រជាជាតិរៀងខ្លួន។
[6]កូនប្រុសៗរបស់លោកហាំគឺគូស មីសរ៉ែម ពូថ និងកាណាន។[7]កូនប្រុសៗរបស់គូសគឺសេបា ហាវីឡា សាបតា រ៉ាម៉ា និងសាបតិកា។ កូនប្រុសៗរបស់លោករ៉ាម៉ាគឺសេបា
និងដេដាន់។
[8]លោកគូសជាឪពុករបស់លោកនីមរ៉ូដ លោកនីមរ៉ូដនេះហើយជាវីរបុរសទីមួយនៅលើផែនដី។[9]លោកគឺជាអ្នកប្រម៉ាញ់ដ៏ខ្លាំងពូកែនៅចំពោះព្រះអម្ចាស់។
ហេតុនេះហើយបានជាមានពាក្យថា «លោកនីមរ៉ូដ គឺជាអ្នកប្រម៉ាញ់ដ៏ខ្លាំងពូកែនៅចំពោះព្រះអម្ចាស់»។[10]អាណាចក្រទីមួយរបស់លោកគឺបាប៊ិល អេរេក អាកាឌ និង
កាលនេ ជាទីក្រុងដែលនៅទឹកដីស៊ីណើរ។
[11]ក្រៅពីទឹកដីទាំងនោះ លោកបានទៅទឹកដីអាសស៊ើរ ហើយបានសង់ក្រុងនីនីវេ ក្រុងរេហូបុត ក្រុងកាឡាស[12]និងក្រុងរេសែនដែលជាក្រុងមួយនៅចន្លោះក្រុងនីនីវេ និង
ក្រុងកាឡាស។ វាជាទីក្រុងដ៏ធំមួយ។[13]លោកមីសរ៉ែមបង្កើតជនជាតិលូឌ ជនជាតិអណាមីម ជនជាតិលេហាប៊ីម ជនជាតិណាប់ធូហ៊ីម។[14]ជនជាតិប៉ាត្រូស៊ីម ជនជាតិ
កាសលូហ៊ីម (ដែលជាដូនតារបស់ជនជាតិភីលីស្ទីន) និងជនជាតិកាប់ថោរីម។
[15]លោកកាណានបង្កើតបានស៊ីដូន ជាកូនច្បងរបស់គាត់ និងហេត[16]ព្រមទាំងជនជាតិយេប៊ូស ជនជាតិអាម៉ូរី ជនជាតិគើកាស៊ី[17]ជនជាតិហេវី ជនជាតិអើគី ជនជាតិ
ស៊ីនី[18]ជនជាតិអើវ៉ាឌីតសេម៉ារីត ជនជាតិសេម៉ារី ជនជាតិហាម៉ាធីតផងដែរ។ ហើយក្រោយមកអំបូរកាណានបានបែកខ្ញែកគ្នា។

generated on Wed Sep 10 16:16:32 2025

[19]ព្រំប្រទល់ទឹកដីជនជាតិកាណានចាប់ពីក្រុងស៊ីដូន ឆ្ពោះទៅក្រុងកេរ៉ា រហូតដល់ក្រុងកាសា និងរហូតដល់ក្រុងសូដុម ក្រុងកូម៉ូរ៉ា ក្រុងអាដម៉ា និងក្រុងសេបោម និងរហូតទៅដល់ក្រុងឡាសាថែមទៀតផង។[20]អ្នកទាំងនេះគឺជាពូជពង្សរបស់លោកហាំ និងអំបូររបស់ពួកគេ តាមភាសារបស់ពួកគេ នៅក្នុងទឹកដីរបស់ពួកគេ
និងនៅក្នុងប្រទេសរបស់ពួកគេដែរ។
[21]លោកសិមជាបងប្រុសច្បងរបស់លោកយ៉ាផេតក៏មានកូនប្រុសៗផងដែរ។ លោកសិមជាបុព្វបុរសរបស់មនុស្សទាំងអស់របស់ជនជាតិហេប៊ើរ។[22]កូនប្រុសៗរបស់លោកសិមគឺអេឡាំ អាសស៊ើរ អើប៉ាក សាឌលូឌ និងអើរ៉ាម។[23]កូនប្រុសៗរបស់លោកអើរ៉ាមគឺ អ៊ូស ហ៊ូល កេធើរ និងម៉ាស។
[24]លោកអើប៉ាកសាឌជាឪពុករបស់សេឡា ហើយសេឡាជាឪពុករបស់ហេប៊ើរ។[25]លោកហេប៊ើរមានកូនប្រុសពីរនាក់។ កូនប្រុសមួយឈ្មោះផាឡេក ដ្បិត នៅជំនាន់នោះមនុស្សនៅលើផែនដីបានបែកខ្ញែកគ្នា។ ប្អូនរបស់គាត់ឈ្មោះ យ៉ុកថាន។
[26]លោកយ៉ុកថានជាឪពុករបស់អាល់ម៉ូដាដ សេឡេប ហាសារ៉ម៉ាវ៉ែត យេរ៉ា[27]ហាដូរ៉ាម អ៊ូសាល ឌីកឡា[28]អ៊ូបាល អប៊ីម៉ែល សេបា[29]អ៊ូភារ ហាវីឡា និងយ៉ូបាប។ អ្នកទាំងនេះគឺជាកូនប្រុសៗរបស់លោកយ៉ុកថានទាំងអស់។
[30]ទឹកដីរបស់ពួកគេចាប់តាំងពីក្រុងមេសា រហូតទៅដល់ក្រុងសេផារ នៅតំបន់ភ្នំខាងកើត។[31]ពួកគេគឺជាពូជពង្សរបស់លោកសិម តាមពូជអំបូរ តាមភាសា តាមទឹកដី និង
តាមជនជាតិរបស់គេ។
[32]អ្នកទាំងនេះគឺជាអំបូរកូនប្រុសៗរបស់លោកណូអេ តាមពង្សាវតារបស់ពួកគេ តាមប្រជាជាតិរបស់ពួកគេ។ ពីប្រជាជាតិទាំងនេះហើយដែលបែកខ្ញែកទៅពាសពេញផែនដីបន្ទាប់ពីទឹកជំនន់។

Genesis 10:1

នេះគឺជាពូជពង្សកូនៗរបស់លោកណូអេ

នេះជាដំណើររឿងរបស់កូនប្រុសណូអេ។

ប្រយោគនេះបង្ហាញពីដំណើររឿងនៃកូនចៅរបស់ណូអេនៅក្នុងលោកុប្បត្តិ ១០:
១-១១: ៩

Genesis 10:2

ពីមនុស្សដែលរស់នៅតាមមាត់សមុទ្រនេះហើយដែលបានបែកខ្ញែក

«កូនប្រុសនិងកូនចៅរបស់យ៉ាវ៉ានបានបែកគ្នា
ហើយបានផ្លាស់ទៅតំបន់ឆ្នេរនិងកោះ»

មនុស្សដែលរស់នៅតាមមាត់សមុទ្រ

នេះសំដៅទៅលើមនុស្សដែលរស់នៅតាមឆ្នេរ និង នៅលើកោះ។

ទឹកដីរបស់ពួកគេ

«ស្រុកកំណើតរបស់ពួកគេ» ។
ទាំងនេះជាកន្លែងដែលប្រជាជនផ្លាស់ប្តូរទៅរស់នៅ។

ពួកគេមានភាសារៀងៗខ្លួន

« ក្រុមមនុស្សនីមួយៗនិយាយភាសារបស់ខ្លួនគេ» ឬ«
ក្រុមប្រជាជនបែងចែកខ្លួនគេយោងទៅតាមភាសារបស់ពួកគេ»

Genesis 10:6

មីសរ៉ែម

មីសរ៉ែមឈ្មោះនៅក្នុងភាសាហេព្រើរគឺ «អេស៊ីប»

Genesis 10:8

ជារឹរបុរស

អត្ថន័យដែលអាចមានគឺ ១)« អ្នកចម្បាំងដ៏ពូកែ» ឬ ២)« បុរសខ្លាំង» ឬ ៣)«
អ្នកមានអំណាច» ។

នៅចំពោះព្រះអម្ចាស់

អត្ថន័យដែលមានគឺ ១)« ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់» ឬ
២)«ដោយមានជំនួយពីព្រះអម្ចាស់»

ហេតុនេះហើយបានជាមានពាក្យថា

នេះណែនាំសុភាសិតមួយ។
ភាសារបស់អ្នកអាចណែនាំសុភាសិតនិងពាក្យសំដីតាមរបៀបផ្សេង។
ការបកប្រែផ្សេងទៀត៖ « នេះជាហេតុផលដែលមនុស្សនិយាយ»

អាណាចក្រទីមួយ

អត្ថន័យដែលអាចមានគឺ ១) មជ្ឈមណ្ឌលទី ១ ដែលគាត់បង្កើតឬ ២)
ទីក្រុងសំខាន់ៗ។

Genesis 10:11

លោកបានទៅទឹកដីអាសស៊ើរ

«លោកនីមរ៉ុដបានចូលទៅក្នុងទឹកដីអាសស៊ើរ»

លោកមីសរ៉ែមបង្កើត

បញ្ជីឈ្មោះរបស់ពូជពង្សលោកណូអេចាប់ផ្តើមបន្ត។

មីសរ៉ែម

មីសរ៉ែម ជាកូនប្រុសម្នាក់របស់ ហាំ ។
កូនចៅរបស់គាត់បានក្លាយជាប្រជាជននៅស្រុកអេស៊ីប។
មីសរ៉ែមគឺជាឈ្មោះរបស់ហេព្រើរថាអេស៊ីប។

Genesis 10:15

យេប៊ូស. ....អាម៉ូរី.....គើកាស៊ី

ឈ្មោះទាំងអស់នេះគឺសំដៅទៅមនុស្សមួយក្រុមធំគឺជាពូជពង្សដែលចេញពីលោកកាណាន។

Genesis 10:19

ព្រំប្រទល់

«ទឹកដី» ឬ «ព្រំប្រទល់នៃទឹកដីរបស់ពួកគេ»

ពីក្រុងស៊ីដូន ឆ្ពោះទៅក្រុងកេរ៉ា រហូតដល់ក្រុងកាសា

ទិសខាងត្បូងអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ប្រសិនបើចាំបាច់។
ការបកប្រែផ្សេងទៀត៖
«មកពីទីក្រុងស៊ីដូននៅភាគខាងជើងឆ្ងាយពីខាងត្បូងក្រុងកាសាដែលនៅជិតកេរ៉ា»

រហូតដល់ក្រុងសូដុម ក្រុងកូម៉ូរ៉ា ក្រុងអាដម៉ា និងក្រុងសេបោម និងរហូតទៅដល់ក្រុង
ឡាសាថែមទៀតផង

ពីទិស«ខាងកើត» ឬ «ផ្លូវទឹក» អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ប្រសិនបើចាំបាច់។
ការបកប្រែផ្សេងទៀត៖ «បន្ទាប់មកឆ្ពោះទៅខាងកើតក្រុងសូដុម កូម៉ូរ៉ា អាដម៉ា
និងក្រុងសេបោម និងរហូតដល់ឡាសា។ (សូមមើល Assumed Knowledge
និង Implicit Information)

អ្នកទាំងនេះគឺជាពូជពង្សរបស់លោកហាំ

ពាក្យ"ទាំងនេះ «គឺសំដៅទៅលើពួកមនុស្សមួយក្រុមដែលបានកត់ត្រាចុះ»
នៅក្នុងខ១០:៦។

តាមភាសារបស់ពួកគេ

«បានបែងចែកទៅតាមភាសាគេរៀងៗខ្លួន»

នៅក្នុងទឹកដីរបស់ពួកគេ

«នៅក្នុងទឹកដីរបស់ពួកគេ»

Genesis 10:24

លោកអើប៉ាកសាឌ

លោកអើប៉ាកសាឌក៏ជាកូនប្រុសរបស់សិមម្នាក់ដែរ។

ផាឡេក

អ្នកបកប្រែអាចបន្ថែមកំណត់ចំណាំលេខយោងដែលនិយាយថា
«ឈ្មោះផាឡេកមានន័យថា ការបែងចែក»

ផែនដីបានបែកខ្ញែកគ្នា

នេះអាចត្រូវបានធ្វើឱ្យសកម្ម។ ការបកប្រែផ្សេងទៀត៖
«ប្រជាជននៅលើផែនដីបានបែងខ្ញែកគ្នា» ឬ
«ប្រជាជននៅលើផែនដីបំបែកពីគ្នាទៅវិញទៅមក» ឬ
«ព្រះបានបែងចែកប្រជាជននៅលើផែនដី»

Genesis 10:26

យ៉ុកថាន

យ៉ុកថានគឺជាកូនប្រុសរបស់អេប៊ើរ។

ទាំងអស់

«ទាំងអស់»នៅទីនេះគឺនិយាយពីកូនប្រុសរបស់យ៉ុកថាន។

Genesis 10:30

ទឹកដីរបស់ពួកគេ

«គឺជាទឹកដីដែលពួកគ្រប់គ្រង»ឬ«ទឹកដីដែលពួកគេរស់នៅ»

ពួកគេគឺជាពូជពង្សរបស់លោកសិម

ពាក្យ«ទាំងអស់»គឺសំដៅទៅលើពូជពង្សរបស់សិម។(១០:២១)

Genesis 10:32

generated on Wed Sep 10 16:16:32 2025

អ្នកទាំងនេះគឺជាអំបូរ
នេះគឺសំដៅទៅលើប្រជាជនដែលបានចុះទៅក្នុងបញ្ជីដូចនៅក្នុងលោកុប្បត្តិ១០:១
តាមពង្សាវតារ
«បញ្ជីឈ្មោះដែលបានចុះ»
ពីប្រជាជាតិទាំងនេះហើយដែលបែកខ្ញែកទៅពាសពេញផែនដី
«ពីអំបូរទាំងនេះជាតិសាសន៍ទាំងអស់បែកខ្ញែកគ្នាទៅពាសពេញលើផែនដី» ឬ
«អំបូរទាំងនេះបែកចេញពីគ្នាហើយបង្កើតជាតិសាសន៍នានានៅលើពេញផែនដី»
បន្ទាប់ពីទឹកជំនន់
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ឬច្បាស់ជាងនេះ។ ការបកប្រែផ្សេងទៀត៖
«បន្ទាប់ពីទឹកជំនន់បានបំផ្លាញផែនដី»

---

11 [1]ឥឡូវនេះ ផែនដីទាំងមូលបានប្រើភាសាតែមួយ ហើយមានសំដីតែមួយ។[2]ក្នុងការដែលពួកគេធ្វើដំណើរឆ្ពោះទៅប៉ែកខាងកើតនោះ
ពួកគេបានជួបទីវាលរាបមួយនៅក្នុងទឹកដីស៊ីណើរ ហើយពួកគេក៏តាំងលំនៅនៅទីនោះ។
[3]ពួកគេបាននិយាយទៅកាន់គ្នាទៅវិញទៅមកថា៖ «មក ចូរយើងធ្វើឥដ្ឋ ហើយដុតវា»។ ពួកគេមានដីឥដ្ឋជំនួសឲ្យថ្ម និងប្រើជ័រខ្មៅជាបាយអ។[4]ពួកគេនិយាយថា៖ «ចូរមក
តោះយើងសង់ទីក្រុងមួយ និងប៉មមួយសម្រាប់ខ្លួនយើង ដែលមានកំពូលរហូតដល់មេឃ ហើយយើងធ្វើវាដើម្បីកេរ្តិ៍ឈ្មោះពួកយើង។ ប្រសិនបើ យើងមិនធ្វើទេ
យើងនឹងបែកខ្ញែកគ្នាទៅពេញផ្ទៃនៃផែនដីទាំងមូលហើយ»។
[5]ដូច្នេះ ព្រះអម្ចាស់បានយាងចុះមក ដើម្បីទតមើលទីក្រុង ហើយនិងប៉មដែលកូនចៅរបស់លោកអាដាំបានសង់។[6]ព្រះអម្ចាស់មានបន្ទូលថា៖ «មើល៍
ពួកគេជាមនុស្សតែមួយ ជាមួយនឹងភាសាតែមួយ ហើយពួកគេចាប់ផ្តើមធ្វើការនេះ គ្មានអ្វីអាចហាមពីបំណងចិត្តដែលពួកគេចង់ធ្វើបានឡើយ។[7]មក ចូរយើងចុះទៅ
ហើយបំភាន់ភាសារបស់ពួកគេ ដើម្បីកុំឲ្យពួកគេយល់គ្នាទៅវិញទៅមកបានឡើយ»។
[8]ដូច្នេះ ព្រះអម្ចាស់បានបំបែកពួកគេចេញពីផ្ទៃនៃផែនដីទាំងមូល ហើយពួកគេបានឈប់សង់ទីក្រុងនោះទៀយ។[9]ហេតុដូច្នេះហើយ គេបានហៅទីក្រុងនោះថា បាបិល ព្រោះ
ព្រះអម្ចាស់បានបំភាន់ភាសានៅលើផែនដីទាំងមូល ហើយព្រះអម្ចាស់បានបំបែកពួកគេពីទីនោះឲ្យបែកខ្ញែកទៅពេញផ្ទៃនៃផែនដីទាំងមូល។
[10]អ្នកទាំងនេះគឺជាពូជពង្សរបស់លោកសិម។ លោកសិមមានអាយុមួយរយឆ្នាំ ហើយក្រោយទឹកជំនន់ពីរឆ្នាំ គាត់មានកូនប្រុសមួយឈ្មោះអើប៉ាក់សាឌ ។
[11]លោកសិមរស់បានប្រាំរយឆ្នាំ បន្ទាប់មកគាត់បង្កើតបានលោកអើប៉ាក់សាឌ។ គាត់ក៏មានកូនប្រុស និងកូនស្រីជាច្រើនទៀតដែរ។
[12]ពេលលោកអើប៉ាក់សាឌរស់បានសាមសិបឆ្នាំ គាត់បង្កើតបានសេឡា។[13]លោកអើប៉ាក់សាឌរស់បាន៤០៣ឆ្នាំ បន្ទាប់ពីគាត់បង្កើតបានលោកសេឡារួចហើយ។
គាត់ក៏បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀតដែរ។
[14]លោកសេឡារស់បានសាមសិបឆ្នាំ គាត់បង្កើតបានហេប៊ើរ។[15]លោកសេឡារបស់បាន៤០៣ឆ្នាំ បន្ទាប់ពីគាត់បង្កើតបានលោកហេប៊ើរ។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
[16]លោកហេប៊ើរស់បានសាមសិបបួនឆ្នាំ គាត់បង្កើតបានផាលេក។[17]បន្ទាប់ពីលោកហេប៊ើររស់បាន៤៣០ឆ្នាំ គាត់បង្កើតបានផាលេក។ គាត់បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
[18]លោកផាលេករស់បានសាមសិបឆ្នាំ គាត់បង្កើតបានរេហ៊ូវ។[19]លោកផាលេករស់បាន២០៩ឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតលោករេហ៊ូវ។ គាត់បានបង្កើតកូនប្រុស
និងកូនស្រីជាច្រើនទៀត។
[20]លោករេហ៊ូវរស់បានសាមសិបពីរឆ្នាំ គាត់បង្កើតបានសេរូក។[21]លោករេហ៊ូវរស់បាន២០៧ឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតបានលោកសេរូក។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
[22]លោករេហ៊ូវរស់បានសាមសិបឆ្នាំ គាត់បង្កើតបានណាឃរ។[23]លោករេហ៊ូវរស់បានពីររយឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតបានលោកណាឃរ។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
[24]លោកណាឃររស់បានម្ភៃប្រាំបួនឆ្នាំ គាត់បង្កើតបានថេរ៉ា។[25]លោកណាឃររស់បាន១១៩ឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតលោកថេរ៉ា។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។[26]បន្ទាប់មក លោកថេរ៉ារបស់បានចិតសិបឆ្នាំទៀត គាត់បង្កើតបានអាប់រ៉ាម ណាឃរ និងហារ៉ាន។
[27]ហើយនេះគឺជាពូជពង្សរបស់លោកថេរ៉ា។ លោកថេរ៉ាបង្កើតបានលោកអាប់រ៉ាម លោកណាឃរ និងលោកហារ៉ាន ហើយលោកហារ៉ានបង្កើតបានឡុត។
[28]លោកហារ៉ានបានស្លាប់នៅចំពោះមុខថេរ៉ាជាឪពុករបស់គាត់ នៅក្នុងទឹកដីកំណើតរបស់គាត់ នៅក្នុងក្រុងអ៊ើរនៃទឹកដីខាល់ដេ។
[29]លោកអាប់រ៉ាម និងលោកណាឃរបានរៀបការ។ ភរិយារបស់លោកអាប់រ៉ាមឈ្មោះនាងសារ៉ាយ ហើយភរិយារបស់លោកណាឃរឈ្មោះនាងមីលកា
ត្រូវជាកូនស្រីរបស់លោកហារ៉ាន ដែលជាឪពុករបស់មីលកា និងយីសកា។[30]នាងសារ៉ាយជាស្ត្រីអារ នាងគ្មានកូនទេ។
[31]លោកថេរ៉ាបាននាំលោកអាប់រ៉ាមកូនប្រុសរបស់គាត់ លោកឡុតត្រូវជាកូនប្រុសរបស់កូនប្រុសគាត់គឺលោកហារ៉ាន ហើយពួកគេបានចេញទៅពីក្រុងអ៊ើរនៃទឹកដីខាល់ដេ
ទៅក្នុងទឹកដីកាណាន។ ប៉ុន្តែ ពួកគេបានទៅហារ៉ាន ហើយស្នាក់នៅទីនោះ។[32]លោកថេរ៉ារស់នៅបាន២០៥ឆ្នាំ ហើយបន្ទាប់គាត់ក៏បានស្លាប់នៅក្នុងក្រុងហារ៉ាន។

Genesis 11:1
ឥឡូវនេះ
ពាក្យនេះបង្ហាញថាអ្នកនិពន្ធកំពុងចាប់ផ្តើមផ្នែកថ្មីនៃរឿង។
ផែនដីទាំងមូល
មនុស្សទាំងអស់នៅលើផែនដី។
ប្រើភាសាតែមួយ ហើយមានសំដីតែមួយ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចៗគ្នា
ហើយបញ្ជាក់ថាប្រជាជនទាំងអស់និយាយភាសាដូចគ្នា។
ដំណើរឆ្ពោះ
«បានធ្វើចំណាកស្រុក» ឬ «បានផ្លាស់ប្តូរលំនៅ»
ទៅប៉ែកខាងកើត
អត្ថន័យដែលមានគឺ ១) «នៅទិសខាងកើត» ឬ ២) «ពីខាងកើត» ឬ ៣)
«ទៅខាងកើត» ជម្រើសដែលពេញចិត្តគឺ «នៅភាគខាងកើត»
ពីព្រោះស៊ីណើរស្ថិតនៅទិសខាងកើតដែលអ្នកប្រាជ្ញជឿថាទូកធំបានឈប់នៅទីនោះ។
តាំងលំនៅនៅទីនោះ
ឈប់ប្តូរពីកន្លែងមួយទៅកន្លែងមួយហើយចាប់ផ្តើមរស់នៅទីតាំងមួយនោះ។
Genesis 11:3
មក
ប្រសិនបើភាសារបស់អ្នកមានវិធីជម្រុញឬបញ្ជាឱ្យមនុស្សចាប់ផ្តើមធ្វើការដូចជាភាសាអង់គ្លេស
«ចូលមក!» អ្នកអាចប្រើវានៅទីនេះ។
ហើយដុតវា
មនុស្សធ្វើឥដ្ឋពីដីឥដ្ឋហើយកំដៅវាក្នុងឡក្តៅខ្លាំងដើម្បីឱ្យវារឹងនិងរឹងមាំ។
ជ័រ
រាវខ្មៅស្អិតក្រាស់ដែលកើតចេញពីដីមក។
បាយអ
នេះគឺជាសារធាតុក្រាស់ធ្វើពីម្សៅកំបោរដីឥដ្ឋដីខ្សាច់និងទឹកដែលប្រើដើម្បីធ្វើថ្មឬឥដ្ឋធ្វើអោយនៅជាប់គ្នា។
ហើយយើងធ្វើវាដើម្បីកេរ្តិ៍ឈ្មោះពួកយើង
«ចូរយើងធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់យើងល្បីល្បាញ»
ឈ្មោះ
«កេរ្តិ៍ឈ្មោះ»
យើងនឹងបែកខ្ញែក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«យើងនឹងញែកចេញពីគ្នាហើយរស់នៅកន្លែងផ្សេងៗគ្នា»
Genesis 11:5
កូនចៅរបស់លោកអាដាំ
«គឺប្រជាជន»
ចុះមក
អ៊ីតាលេស
អំពីកន្លែងដែលគាត់ចុះមកពីណាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់៖

generated on Wed Sep 10 16:16:32 2025

«ចុះមកពីស្ថានសួគ៌» នេះមិនប្រាប់ពីរបៀបដែលគាត់ចុះមកទេ។
ប្រើពាក្យទូទៅមានន័យថា «ចុះមក» ។
ទតមើល
«ដើម្បីអង្កេត»ឬ«ដើម្បីពិនិត្យមើលអោយបានជិត»
មនុស្សតែមួយ ជាមួយនឹងភាសាតែមួយ
មនុស្សទាំងអស់ទៅជាក្រុមតែមួយ ហើយពួកគេនិយាយភាសាតែមួយដូចគ្នា។
ហើយពួកគេចាប់ផ្តើមធ្វើការនេះ
អត្ថន័យដែលអាចមានគឺ ១) «ពួកគេបានចាប់ផ្តើមធ្វើ»
មានន័យថាពួកគេបានចាប់ផ្តើមសាងសង់ប៉មតែមិនទាន់បានបញ្ចប់ឬ ២)
«នេះគ្រាន់តែជារឿងដំបូងដែលពួកគេបានធ្វើ
«មានន័យថានៅពេលអនាគតពួកគេនឹង ធ្វើអ្វីដែលធំជាងនេះ»។
គ្មានអ្វីអាចហាមពីបំណងចិត្តដែលពួកគេចង់ធ្វើបានឡើយ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត៖
«អ្វីដែលពួកគេចង់ធ្វើនឹងអាចធ្វើបានសម្រាប់ពួកគេ»
មក
ប្រសិនបើភាសារបស់អ្នកមានវិធីជម្រុញឬបញ្ជាឱ្យមនុស្សចាប់ផ្តើមធ្វើការដូចជាភាសាអង់គ្លេស
«ចូលមក!» អ្នកអាចប្រើវានៅទីនេះ។ សូមមើលនៅក្នុង ១១: ៣
ចូរយើងចុះទៅ
ពាក្យថា «យើង» មានពហុវចនៈទោះបីជាវាសំដៅទៅលើតួអង្គព្រះក៏ដោយ។
អ្នកខ្លះបកប្រែវាថា «អោយខ្ញុំទៅចុះ» ឬ «ខ្ញុំនឹងចុះ» ។
ប្រសិនបើអ្នកធ្វើដូចនេះពិចារណាបន្ថែមលេខយោងដើម្បីនិយាយថាសព្វនាមគឺពហុវចនៈ
សូមមើលកំណត់សំគាល់នៅលើ« ចូរយើងធ្វើ» នៅក្នុង ១:២៦
បំភាន់ភាសារបស់ពួកគេ
នេះមានន័យថាព្រះអម្ចាស់នឹងធ្វើអោយប្រជាជននៅលើផែនដីឈប់និយាយភាសាតែមួយ។
ការបកប្រែផ្សេងទៀត៖ «បញ្ឈប់ភាសារបស់ពួកគេ»
ដើម្បីកុំឲ្យពួកគេយល់គ្នាទៅវិញទៅមកបានឡើយ
នេះគឺជាគោលបំណងនៃការបំភាន់ភាសារបស់ពួកគេ។ ការបកប្រែផ្សេងទៀត៖
«ដើម្បីកុំអោយពួកគេអាចយល់ពីអ្វីដែលកំពុងនិយាយ»
Genesis 11:8
ចេញពី
«ចេញពីទីក្រុង»
គេបានហៅទីក្រុងនោះថា បាបិល ព្រោះ ព្រះអម្ចាស់បានបំភាន់
ឈ្មោះ «បាបិល» សូរអត្ថន័យដូចពាក្យ«បំភាន់»
បានបំភាន់ភាសានៅលើផែនដីទាំងមូល
វាមានន័យថាព្រះអម្ចាស់ធ្វើអោយប្រជាជននៅលើផែនដីលែងនិយាយភាសាដដែល។
ការបកប្រែផ្សេងទៀត៖ «លាយបញ្ឈូលភាសានៃផែនដីទាំងមូល»
Genesis 11:10
ព័ត៌មានទូទៅ
នៅក្នុងជំពូកទាំងមូលគឺនិយាយអំពីពូជអំបូររបស់សិមរហូតដល់អាប់រ៉ាម
ទាំងនេះគឺជាពូជពង្សរបស់លោកសិម
នេះគឺចាប់ផ្តើមកត់ត្រាពីពូជពង្សរបស់សិមទាំងអស់។
ទឹកជំនន់
នេះគឺជាទឹកជំនន់តាំងពីជំនាន់លោកណូអេនៅពេលដែលមនុស្សអាក្រក់ដូច្នេះព្រះបានបញ្ជូន
គាត់មានកូនប្រុសមួយឈ្មោះអើប៉ាក់សាឌ
«មានកូនប្រុសរបស់គាត់ឈ្មោះអើប៉ាក់សាឌ» ឬ
«កូនប្រុសរបស់គាត់ឈ្មោះអើប៉ាក់សាឌ»
អើប៉ាក់សាឌ
គឺជាឈ្មោះរបស់មនុស្ស
មួយរយ .....ពីរ.....ប្រាំរយ
អ្នកបកប្រែអាចសរសេរពាក្យឬលេខ «១០០» ២ «និង ៥០០ »
Genesis 11:12
គាត់បង្កើតបានសេឡា
«គាត់គឺជាកូនប្រុសរបស់សេឡាដែលបានកើតមក»
សេឡា
គឺជាឈ្មោះរបស់មនុស្ស។

Genesis 11:14
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ១១: ១២-២៥ មានទ្រង់ទ្រាយដូចគ្នា។ សូមមើល ១១:១២ ។
Genesis 11:16
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ១១: ១២-២៥ មានទ្រង់ទ្រាយដូចគ្នា។ សូមមើល ១១:១២ ។
Genesis 11:18
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ១១: ១២-២៥ មានទ្រង់ទ្រាយដូចគ្នា។ សូមមើល ១១:១២ ។
Genesis 11:20
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ១១: ១២-២៥ មានទ្រង់ទ្រាយដូចគ្នា។ សូមមើល ១១:១២ ។
Genesis 11:22
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ១១: ១២-២៥ មានទ្រង់ទ្រាយដូចគ្នា។ សូមមើល ១១:១២ ។
Genesis 11:24
ព័ត៌មានទូទៅ
កំណត់ត្រានៅក្នុងលោកុប្បត្តិ ១១: ១២-២៥ មានទ្រង់ទ្រាយដូចគ្នា។ សូមមើល ១១:១២ ។
អាប់រ៉ាម,ណាឃរ,ហើយនិងហារ៉ាន
យើងមិនដឹងពីបញ្ជីកំណើតរបស់កូនប្រុសគាត់ទេ។
Genesis 11:27
នេះគឺជាពូជពង្សរបស់លោកថេរ៉ា
ប្រយោគនេះបង្ហាញពីដំណើររឿងនៃកូនចៅរបស់ថេរ៉ា។ លោកុប្បត្តិ ១១: ២៧-២៥: ១១ ប្រាប់អំពីកូនចៅរបស់ថេរ៉ាជាពិសេសអ័ប្រាហាំជាកូនប្រុសរបស់គាត់។
ការបកប្រែផ្សេងទៀត៖ «នេះគឺជាកំណត់ហេតុនៃកូនចៅរបស់ថេរ៉ា»
លោកហារ៉ានបានស្លាប់នៅចំពោះមុខថេរ៉ាជាឪពុករបស់គាត់
នេះមានន័យថាលោកហារ៉ានបានស្លាប់ពេលឪពុករបស់គាត់នៅរស់។
ការបកប្រែផ្សេងទៀត៖
«ហារ៉ានបានស្លាប់នៅពេលដែលឪពុករបស់គាត់ឈ្មោះថេរ៉ានៅជាមួយគាត់»
Genesis 11:29
យកភរិយា
«រៀបការ»
យីសកា
នេះគឺជាឈ្មោះរបស់ស្ត្រី
ឥឡូវ
ពាក្យនេះត្រូវបានប្រើដើម្បីណែនាំព័ត៌មានថ្មីអំពីសារ៉ាយដែលនឹងក្លាយជារឿងសំខាន់នៅក្នុងជំពូកបន្ទាប់។
ទឹកជំនន់ទាំងមូល
ពាក្យនេះពិពណ៌នាអំពីស្ត្រីម្នាក់ដែលមានកាយសម្បទាមិនអាចមានគភ៌ឬបង្កើតកូនបាន។
Genesis 11:31
គាត់
ពាក្យនៅត្រង់នេះ «គាត់» គឺសំដៅទៅកាន់ថេរ៉ា។
សារ៉ាយគឺជាកូនប្រសារស្រី,ជាប្រពន្ធអាប់រ៉ាមកូនប្រុសគាត់
កូនប្រសារជាប្រពន្ធកូនប្រុសគាត់។ «សារ៉ាយជាកូនប្រសារស្រីរបស់គាត់
គឺជាប្រពន្ធអាប់រ៉ាមកូនប្រុសរបស់គាត់»
ហារ៉ាន.....ហារ៉ាន
ទាំងនេះគឺជាឈ្មោះពីរផ្សេងគ្នាហើយសរសេរខុសគ្នាតាមភាសាហេព្រើរ។
មួយសំដៅទៅលើមនុស្សម្នាក់ហើយម្នាក់ទៀតសំដៅទៅលើទីក្រុង។ (សំឡេង «ហ»
នៅក្នុងឈ្មោះទីក្រុងគឺលឺជាងសំឡេង «ហ» នៅក្នុងឈ្មោះរបស់មនុស្ស។)
អ្នកអាចជ្រើសរើសតួអក្សរខុសគ្នានៅក្នុងភាសារបស់អ្នកដើម្បីបង្ហាញវា។

---

12 [1]ព្រះអម្ចាស់មានបន្ទូលទៅលោកអាប់រ៉ាមថា៖ «ចូរចេញពីប្រទេស ពីសាច់ញាតិ និងពីគ្រួសាររបស់អ្នក ទៅកាន់ទឹកដីដែលយើងបានបង្ហាញដល់អ្នក។
[2]យើងនឹងធ្វើឲ្យអ្នកត្រឡប់ទៅជាប្រទេសមួយដ៏ធំ ហើយយើងនឹងប្រទានពរដល់អ្នក ហើយធ្វើឲ្យអ្នកមានឈ្មោះល្បី

generated on Wed Sep 10 16:16:32 2025

ព្រមទាំងឲ្យអ្នកបានត្រឡប់ទៅជាពរដល់អ្នកដទៃ។[3]យើងនឹងឲ្យពរដល់អស់អ្នកដែលឲ្យពរដល់អ្នក ប៉ុន្តែ អស់អ្នកណាដែលមើលងាយដល់អ្នក
យើងនឹងដាក់បណ្តាសាដល់អ្នកនោះវិញ។ គ្រួសារទាំងអស់ដែលនៅផែនដីនឹងបានពរតាមរយៈអ្នក»។
[4]ដូច្នេះ លោកអាប់រ៉ាមបានចេញទៅ តាមដែលព្រះអម្ចាស់បង្គាប់ដល់គាត់ឲ្យធ្វើ ហើយលោកឡុតបានទៅជាមួយគាត់ដែរ។ លោកអាប់រ៉ាមមានអាយុចិតសិបប្រាំ
ពេលគាត់ចេញពីហារ៉ាន។[5]លោកអាប់រ៉ាមបាននាងសារ៉ាយជាភរិយារបស់គាត់ និងលោកឡុត ក្មួយប្រុសរបស់គាត់ និងទ្រព្យសម្បត្តិទាំងអស់ដែលពួកគេមាន
ហើយនិងទាសករដែលពួកគេបានទិញនៅក្នុងទឹកដីហារ៉ាន។ ពួកគេបានចាកចេញ ដើម្បីធ្វើដំណើរទៅទឹកដីកាណាន ហើយបានមកដល់ទឹកដីរបស់កាណាន។
[6]លោកអាប់រ៉ាមបានឆ្លងកាត់ទឹកដីកាណានមកដល់ ស៊ីគែម នៅត្រង់ដើមដើមជ្រៃរបស់លោកម៉ូរេ។ នៅសម័យនោះ ជនជាតិកាណានជាម្ចាស់ទឹកដីដែលគេរស់នៅ។
[7]ព្រះអម្ចាស់បានយាងមកឲ្យលោកអាប់រ៉ាមឃើញ ហើយមានបន្ទូលថា៖ «យើងនឹងប្រគល់ទឹកដីនេះ ដល់ពូជពង្សរបស់អ្នក»។ នៅទីនោះ
លោកអាប់រ៉ាមបានសង់អាសនៈមួយថ្វាយព្រះអម្ចាស់ ដែលបានយាងមកឲ្យគាត់ឃើញ។
[8]គាត់បានចាកចេញពីទីនោះទៅប្រទេសដែលមានភ្នំគឺភាគខាងកើតនៃបេតអែល គាត់បានសង់ត្រសាលរបស់គាត់នៅទីនោះ បេតអែលនៅខាងលិចគឺនៅចន្លោះ នឹងក្រុង
អៃ ដែលនៅខាងកើត។ គាត់បានសង់អាសនៈថ្វាយព្រះអម្ចាស់ ហើយអំពាវនាវរកព្រះនាមព្រះរបស់ព្រះអម្ចាស់នៅទីនោះ។[9]បន្ទាប់មក លោកអាប់រ៉ាមបានបន្តដំណើរ
ឆ្ពោះទៅក្នុងក្រុងណេកិប។
[10]នៅពេលនោះ មានគ្រោះទុរភិក្សកើតឡើងនៅក្នុងទឹកដីរបស់គាត់ ដូច្នេះ លោកអាប់រ៉ាមបានចុះទៅរស់នៅអេស៊ីប ដ្បិត
មានគ្រោះទុរភិក្សយ៉ាងខ្លាំងកើតឡើងនៅក្នុងទឹកដីរបស់គាត់។[11]នៅពេលគាត់ជិតចូលទៅក្នុងទឹកដីរបស់អេស៊ីបហើយ
គាត់បាននិយាយទៅកាន់សារ៉ាយភរិយារបស់គាត់ថា៖ «មើល៍ បងដឹងថា អូនជាស្ត្រីម្នាក់ដែលស្អាត។[12]នៅពេលជនជាតិអេស៊ីបឃើញអូន ពួកគេនឹងនិយាយថា
នេះជាភរិយារបស់គាត់ ហើយគេនឹងសម្លាប់បងហើយ តែគេនឹងទុកឲ្យអូនរស់វិញ។[13]ចូរនិយាយថា អូនជាប្អូនស្រីរបស់បង
ដើម្បីឲ្យពួកគេបានធ្វើល្អជាមួយបងដោយសារអូន ហើយអូនបានការពារជីវិតបងផងដែរ»។
[14]នៅពេលលោកអាប់រ៉ាមបានចូលទៅក្នុងទឹកដីអេស៊ីប ជនជាតិអេស៊ីបបានឃើញថា នាងសារ៉ាយស្អាតខ្លាំងណាស់។[15]ពួកមន្ត្រីរបស់ស្តេចផារ៉ោនបានឃើញនាង
ហើយបានសរសើរនាងចំពោះស្តេចផារ៉ោន ហើយគេបាននាំនាងទៅក្នុងដំណាក់របស់ស្តេចផារ៉ោន។
[16]ស្តេចផារ៉ោនបានប្រព្រឹត្តជាមួយលោកអាប់រ៉ាមយ៉ាងល្អដោយព្រោះនាង ហើយបានប្រទានចៀម គោ និងសត្វលាឈ្មោលៗ អ្នកបម្រើទាំងប្រុស និងអ្នកបម្រើស្រី
សត្វលាញីៗ និងសត្វអូដ្ឋជាច្រើនផង។
[17]បន្ទាប់មក ព្រះអម្ចាស់បានធ្វើឲ្យស្តេចផារ៉ោន និងញាតិវង្សរបស់ស្តេចជួបគ្រោះកាចយ៉ាងខ្លាំង ដោយសារនាងសារ៉ាយ ភរិយារបស់អាប់រ៉ាម។
[18]ស្តេចផារ៉ោនបានកោះហៅលោកអាប់រ៉ាម ហើយមានបន្ទូលថា៖ «ហេតុអ្វីបានជាអ្នកធ្វើចំពោះយើងយ៉ាងដូច្នេះ?
ហេតុអ្វីបានជាអ្នកមិនប្រាប់យើងថានាងជាភរិយារបស់អ្នក?[19]ហេតុអ្វីបានជាអ្នកនិយាយថានាងជាប្អូនស្រីរបស់អ្នកទៅវិញ
ធ្វើឲ្យយើងយកនាងទៅជាមហេសីរបស់យើងដូច្នេះ? ឥឡូវនេះ មើល៍ នេះ ភរិយារបស់អ្នក។ ចូរយកនាង ហើយចេញទៅ?»។[20]បន្ទាប់មក
ស្តេចផារ៉ោនបានបង្គាប់ដល់ពួកប្រុសៗរបស់ព្រះអង្គទាំងអស់ទាក់ទងនឹងលោក ហើយពួកគេបានចាត់លោកឲ្យទៅ ជាមួយភរិយារបស់លោក
និងជាមួយអ្វីៗទាំងអស់ដែលគាត់មាន។

Genesis 12:1

ឥឡូវ

ពាក្យនេះត្រូវបានប្រើដើម្បីសម្គាល់ផ្នែកថ្មីនៃរឿង។

ចូរចេញពីប្រទេស ពីសាច់ញាតិ

«ចេញពីទឹកដីអ្នកពីក្រុមគ្រួសាររបស់អ្នក»

យើងនឹងធ្វើឲ្យអ្នកត្រឡប់ទៅជាប្រទេសមួយដ៏ធំ

នៅទីនេះ «អ្នក» មានលក្ខណៈឯកវចនៈហើយសំដៅទៅលើលោកអាប់រ៉ាម
ប៉ុន្តែលោកអាប់រ៉ាមតំណាងឱ្យកូនចៅរបស់គាត់។ ការបកប្រែផ្សេងទៀត៖
«យើងនឹងចាប់ផ្តើមជាប្រជាជាតិដ៏អស្ចារ្យមួយតាមរយៈអ្នក» ឬ
«យើងនឹងធ្វើឱ្យកូនចៅរបស់អ្នកក្លាយជាប្រជាជាតិដ៏អស្ចារ្យមួយ»

ហើយធ្វើឲ្យអ្នកមានឈ្មោះល្បី

ពាក្យ «ឈ្មោះ» តំណាងឱ្យកេរ្តិ៍ឈ្មោះរបស់មនុស្ស។ ការបកប្រែផ្សេងទៀត៖
«និងធ្វើឱ្យអ្នកល្បីល្បាញ»

អ្នកបានត្រឡប់ទៅជាពរ

ពីពាក្យ «ទៅកាន់មនុស្សផ្សេងទៀត» ។ ការបកប្រែផ្សេងទៀត៖
«អ្នកនឹងក្លាយជាព្រះពរដល់មនុស្សផ្សេងទៀត»

អ្នកណាដែលមើលងាយដល់អ្នក យើងនឹងដាក់បណ្តាសាដល់អ្នកនោះវិញ

«យើងនឹងដាក់បណ្តាសាអ្នកណាដែលធ្វើបាបអ្នកតាមរបៀបគួរឱ្យអាម៉ាស់» ឬ
«ប្រសិនបើនរណាម្នាក់ធ្វើបាបអ្នកដូចជាគ្មានតម្លៃ
យើងនឹងដាក់បណ្តាសាអ្នកនោះ»

គ្រួសារទាំងអស់ដែលនៅផែនដីនឹងបានពរតាមរយៈអ្នក

នេះអាចត្រូវបានធ្វើឱ្យសកម្ម។ ការបកប្រែផ្សេងទៀត៖
«យើងនឹងប្រទានពរដល់ក្រុមគ្រួសារទាំងអស់នៅលើផែនដីតាមរយៈអ្នក»

តាមរយៈអ្នក

«ពីព្រោះអ្នក» ឬ«ពីព្រោះតែយើងបានអោយពរដល់អ្នក»

Genesis 12:4

ទ្រព្យសម្បត្តិ

នេះបូកបញ្ចូលទាំងសត្វនិងទ្រព្យសម្បត្តិ និង ដីធ្លី។

ហើយនិងទាសករដែលពួកគេបានទិញ

អត្ថន័យដែលមានគឺ ១)« ទាសករដែលពួកគេបានប្រមូល» ឬ« ២)
ដែលជាមនុស្សដែលពួកគេបានប្រមូលមកនៅជាមួយ»

Genesis 12:6

លោកអាប់រ៉ាមបានឆ្លងកាត់ទឹកដី

មានតែឈ្មោះរបស់លោកអាប់រ៉ាមប៉ុណ្ណោះដែលត្រូវបានលើកឡើងព្រោះគាត់ជាមេគ្រួសារ។
ព្រះបានបញ្ជាគាត់ឱ្យនាំក្រុមគ្រួសារគាត់ទៅទីនោះ។ ការបកប្រែផ្សេងទៀត៖ «ដូច្នេះ
លោកអាប់រ៉ាម និង ក្រុមគ្រួសាររបស់គាត់បានឆ្លងកាត់ទឹកដីនេះ»

ទឹកដី

«ទឹកដីនៃស្រុកកាណាន»

ដើមជ្រៃរបស់លោកម៉ូរេ

លោកម៉ូរេប្រហែលជាអ្នកដាក់ឈ្មោះអោយទីកន្លែងមួយ។

ព្រះអម្ចាស់, ដែលបានយាងមកឲ្យគាត់ឃើញ

«ព្រះអម្ចាស់ ពីព្រោះទ្រង់បានលេចមកអោយគាត់ឃើញ»

Genesis 12:8

គាត់បានសង់ត្រសាលរបស់គាត់

លោកអាប់រ៉ាមនិងអ្នកធ្វើដំណើរទៅជាមួយគាត់។
មនុស្សដែលផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយរស់នៅក្នុងតង់។
ការបកប្រែផ្សេងទៀត៖ «ពួកគេបានរៀបចំតង់របស់ពួកគេ»

អំពាវនាវរកព្រះនាមព្រះរបស់ព្រះអម្ចាស់

«អធិស្ឋានរកព្រះនាមនៃព្រះនាមព្រះអម្ចាស់»ឬ«ថ្វាយបង្គំដល់ព្រះនាមនៃព្រះអម្ចាស់»

បន្ទាប់មក លោកអាប់រ៉ាមបានបន្តដំណើរ

«លោកអាប់រ៉ាមបោះជំរុំហើយបន្តដំណើរទៅមុខទៀត»

ឆ្ពោះទៅក្នុងក្រុងណេកិប

«ឆ្ពោះទៅតំបន់ ណេកិប» ឬ «ឆ្ពោះទៅភាគខាងត្បូង» ឬ «ខាងត្បូងទៅវាលខ្សាច់
ណេកិប»

Genesis 12:10

នៅពេលនោះ មានគ្រោះទុរភិក្ស

ដំណាំមិនលូតលាស់ល្អទេនៅរដូវនោះ។ ការបកប្រែផ្សេងទៀត៖
«មានកង្វះខាតស្បៀងអាហារ»

នៅក្នុងទឹកដី

«នៅក្នុងតំបន់» ឬ «នៅលើទឹកដីដែលអាប់រ៉ាមកំពុងរស់នៅ»

បានចុះទៅ

អត្ថន័យដែលមានគឺ ១) «ទៅខាងត្បូងទៀត» ឬ ២) បានទៅឆ្ងាយពីកាណាន។

generated on Wed Sep 10 16:16:32 2025

វាជាការល្អបំផុតដើម្បីបកប្រែវាដោយប្រើពាក្យធម្មតារបស់អ្នកសម្រាប់ការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ។ «គ្រួសាររបស់ផារ៉ោន» ពោលគឺជាប្រពន្ធឬ ២)«
ហើយគេនឹងសម្លាប់បងហើយ..... តែគេនឹងទុកឲ្យអ្នករស់វិញ
ដំណាក់របស់ស្តេចផារ៉ោន» ឬ«វាំងផារ៉ោន»
មូលហេតុដែលពួកគេនឹងសម្លាប់លោកអាប់រ៉ាមអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា៖
ដែលជាការត្រេកអរសម្រាប់ស្តេចផារ៉ោនធ្វើឱ្យនាងក្លាយជាភរិយារបស់គាត់។
«ពួកគេនឹងសម្លាប់ខ្ញុំដើម្បីពួកគេអាចរៀបការជាមួយអ្នក»
ដោយព្រោះនាង
ហើយអូនបានការពារជីវិតបងផងដែរ
«គឺសម្រាប់នាងសារ៉ាយ» ឬ«ពីព្រោះសារ៉ាយ»
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
Genesis 12:17
«ដូច្នេះដោយសារតែអ្នក ពួកគេនឹងមិនសម្លាប់ខ្ញុំទេ»
ដោយសារនាងសារ៉ាយ ភរិយារបស់អាប់រ៉ាម
Genesis 12:14
នេះអាចត្រូវបានធ្វើឱ្យកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត៖ «
នៅពេល
ព្រោះស្តេចផារ៉ោនមានបំណងយកសារ៉ាយដែលជាភរិយារបស់អាប់រ៉ាមធ្វើជាប្រពន្ធរបស់គាត់»
អត្ថន័យដែលមានគឺ ១)
ស្តេចផារ៉ោនបានកោះហៅលោកអាប់រ៉ាម
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់កន្លែងដែលសកម្មភាពចាប់ផ្តើមហើយប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះឬ
បានហៅអាប់រ៉ាម»ឬ«ស្តេចផារ៉ោនបញ្ជាអោយអាប់រ៉ាមចូលមកជួបគាត់»
២)«ហើយនោះគឺជាអ្វីដែលបានកើតឡើង»។
ហេតុអ្វីបានជាអ្នកធ្វើចំពោះយើងយ៉ាងដូច្នេះ?
ពួកមន្ត្រីរបស់ស្តេចផារ៉ោនបានឃើញនាង
ស្តេចផារ៉ោនបានប្រើសំនួរនេះដើម្បីបង្ហាញពីកំហឹងរបស់គាត់ចំពោះអ្វីដែលអាប់រ៉ាមបានធ្វើចំពោះគាត់។
«ពួកមន្ត្រីរបស់ស្តេចផារ៉ោនបានឃើញសារ៉ាយ»ឬ«ស្តេចក្នុងបរម្យារាជវាំងបានឃើញនាង»
បាននាំនាងទៅក្នុងដំណាក់របស់ស្តេចផារ៉ោន
វាក៏អាចត្រូវបានបញ្ជាក់ថាជាឧទាន។ ការបកប្រែផ្សេងទៀត៖
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«អ្នកបានធ្វើរឿងដ៏គួរឱ្យភ័យខ្លាចចំពោះខ្ញុំ!»
«ផារ៉ោនបាននាំនាងចូលក្នុងដំណាក់បស់គាត់» ឬ
ស្តេចផារ៉ោនបានបង្គាប់ដល់ពួកប្រុសៗរបស់ព្រះអង្គទាំងអស់ទាក់ទងនឹងលោក
«ផារ៉ោនបានអោយទាហាននាំនាងចូលក្នុងដំណាក់របស់គាត់»
«ស្តេចផារ៉ោនបញ្ជាអោយមន្ត្រីរបស់លោកទាក់ទងនឹងលោកអាប់រ៉ាម»
ស្ត្រី
ហើយពួកគេបានចាត់លោកឲ្យទៅ ជាមួយភរិយារបស់លោក និងជាមួយអ្វីៗទាំងអស់ដែលគាត់មាន
«សារ៉ាយ»
«ហើយពួកមន្ត្រីបានបណ្តេញលោកអាប់រ៉ាមចេញពីផារ៉ោនជាមួយប្រពន្ធ
ដំណាក់ស្តេចផារ៉ោន
និងទ្រព្យសម្បត្តិទាំងអស់របស់គាត់»

---

13 [1]ដូច្នេះ លោកអាប់រ៉ាមបានចេញពីអេស៊ីប ហើយធ្វើដំណើរទៅណេកិប ជាមួយភរិយា និងអ្វីៗទាំងអស់ដែលគាត់មាន។ លោកឡុតក៏ទៅជាមួយពួកគេដែរ។
[2]លោកអាប់រ៉ាមមានហ្វូងសត្វ ប្រាក់ និងមាសជាច្រើន។
[3]គាត់បានបន្តធ្វើដំណើរពីណេកិតទៅបេតអែល ទៅកន្លែងដែលគាត់បានសង់ត្រសាលកាលពីមុន នៅចន្លោះបេតអែល និងក្រុងអៃ។
[4]គាត់បានទៅដល់កន្លែងដែលមានអាសនៈ ដែលគាត់បានសង់ពីមុន។ នៅទីនេះ គាត់អំពាវនាវព្រះនាមព្រះជាម្ចាស់។
[5]លោកឡុតបានធ្វើដំណើរជាមួយលោកអាប់រ៉ាម គាត់មានហ្វូងសត្វ ហ្វូងចៀម ហ្វូងគោ និងមានត្រសាលជាច្រើនដែរ។
[6]ទឹកដីនោះមិនអាចផ្គត់ផ្គង់ពួកគេទាំងពីរនាក់ឲ្យរស់នៅជាមួយគ្នាបានទេ ដោយសារពួកគេមានទ្រព្យសម្បត្តិយ៉ាងច្រើន ដូច្នេះ ពួកគេមិនអាចនៅជាមួយគ្នាបានទេ។
[7]ក៏មានជម្លោះរវាងអ្នកគង្វាលសត្វរបស់លោកអាប់រ៉ាម និងអ្នកគង្វាលសត្វរបស់លោកឡុត។ ជនជាតិកាណាន និងជនជាតិពេរិស៊ីត ក៏រស់នៅក្នុងស្រុកនោះដែរ។
[8]ដូច្នេះ លោកអាប់រ៉ាមនិយាយទៅកាន់លោកឡុតថា៖ «កុំឲ្យមានជម្លោះរវាងឯងនិងអ៊ំ និងអ្នកគង្វាលសត្វរបស់ឯង និងអ្នកគង្វាលសត្វរបស់អ៊ំដែរ
ព្រោះយើងជាគ្រួសារតែមួយទេ។[9]តើទឹកដីនៅខាងមុខឯងទាំងអស់នេះ មិនមែនជារបស់ឯងទេឬអី? ចូរទៅចុះ ហើយយើងបែកផ្លូវគ្នាចុះ។ ប្រសិនបើ ឯងទៅខាងឆ្វេង
អ៊ំនឹងទៅខាងស្តាំ។ ឬ ប្រសិនបើ ឯងទៅខាងស្តាំ អ៊ំនឹងទៅខាងឆ្វេង»។
[10]ដូច្នេះ លោកឡុតក៏សម្លឹងមើលជុំវិញ ហើយគាត់បានឃើញទឹកដីទាំងអស់នៅវាលទន្លេយ័រដាន់មានទឹកច្រើនល្អ រហូតដល់ក្រុងសូអារ ស្អាតដូចជាសួនរបស់ព្រះអម្ចាស់
ដូចជាទឹកដីរបស់អេស៊ីប។ ការនេះ នៅមុនព្រះអម្ចាស់បំផ្លាញក្រុងសូដុម និងក្រុងកូម៉ូរ៉ា។[11]ដូច្នេះ លោកឡុតក៏ជ្រើសរើសវាលរបស់ទន្លេយ័រដាន់
ហើយបានធ្វើដំណើរទៅភាគខាងកើត ហើយពួកគេបានបែកខ្ញែកពីសាច់ញាតិរបស់ពួកគេ។
[12]លោកអាប់រ៉ាមបានរស់នៅក្នុងទឹកដីកាណាន ហើយលោកឡុតរស់នៅក្នុងចំណោមទីក្រុងដែលមានវាលទំនាប។
គាត់បានសង់ត្រសាលនៅពេលដែលគាត់មកដល់ក្រុងសូដុម។[13]មនុស្សនៅក្នុងក្រុងសូដុមជាមនុស្សបាប អាក្រក់ជាខ្លាំងទាស់នឹងព្រះអម្ចាស់។
[14]ព្រះអម្ចាស់មានបន្ទូលទៅកាន់លោកអាប់រ៉ាម បន្ទាប់ពីលោកឡុតចេញពីគាត់ «ចូរមើលពីកន្លែងដែលអ្នកឈរនេះ ទៅជើង ទៅត្បូង ទៅកើត និងទៅលិច។
[15]ទឹកដីទាំងអស់ដែលអ្នកឃើញ យើងនឹងប្រគល់ឲ្យអ្នក និងពូជពង្សរបស់អ្នករហូតតទៅ។
[16]យើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកបានចម្រើនឡើងដូចជាធូលីនៅលើផែនដី ប្រសិនបើ មនុស្សអាចរាប់ធូលីដីបាន នោះគេក៏អាចរាប់ពូជពង្សរបស់អ្នកបានដែរ។
[17]ចូរក្រោកឡើង ចូរដើរឲ្យពេញទឹកដីនេះ ដ្បិត យើងបានប្រគល់ឲ្យអ្នកហើយ»។[18]ដូច្នេះ លោកអាប់រ៉ាមបានដំឡើងត្រសាលរបស់គាត់
ហើយមករស់នៅជិតដើមជ្រៃរបស់លោកម៉ាមរ៉េ ដែលនៅក្រុងហេប្រុន ហើយបានសង់កន្លែងថ្វាយតង្វាយថ្វាយដល់ព្រះអម្ចាស់នៅទីនោះ។

Genesis 13:1
«ពួកគេបានបន្តដំណើររបស់ពួកគេ»
បានចេញពី
ទៅកន្លែងដែលគាត់បានសង់ត្រសាលកាលពីមុន
«ចាកចេញ» ឬ«បានចេញដំណើរពី»
អ្នកបកប្រែខ្លះបានប្រែដូចនៅក្នុងលោកុប្បត្តិ១២:៨
ធ្វើដំណើរទៅណេកិប
«ពេលវេលាដែលគាត់បានធ្វើដំណើរនោះត្រូវបញ្ជាក់យ៉ាងច្បាស់។
ណេកិបគឺជាតំបន់វាលខ្សាច់ក្នុងទឹកដីកាណានភាគខាងត្បូង
ការបកប្រែផ្សេងទៀត៖
ខាងលិចនៃស្រុកអេស៊ីប។នេះត្រូវបានបញ្ជាក់ច្បាស់លាស់។
«គឺជាកន្លែងដែលគាត់បានសង់ត្រសាលពីមុនដែលគាត់ធ្វើដំណើរទៅទឹកដីអេស៊ីប»
ការបកប្រែផ្សេងទៀត៖ «ត្រលប់ទៅឯវាលខ្សាច់នៃណេកិប»
គាត់អំពាវនាវព្រះនាមព្រះជាម្ចាស់
លោកអាប់រ៉ាមមានហ្វូងសត្វ ប្រាក់ និងមាសជាច្រើន
«អធិស្ឋានអំពាវនាវរកព្រះនាមនៃព្រះអម្ចាស់»ឬ«ថ្វាយបង្គំព្រះជាម្ចាស់»
«អាប់រ៉ាមមានសត្វជាច្រើន ប្រាក់ជាច្រើន ហើយនិងមាសយ៉ាងច្រើន»
Genesis 13:5
សត្វ
បានធ្វើដំណើរ
«សត្វចិញ្ចឹម» ឬ «សត្វគោក្របី»
ពាក្យនេះត្រូវបានប្រើដើម្បីបង្ហាញអ្វីដែលជាព័ត៌មានអោយដឹងពីប្រវត្តិដើម្បីជួយអ្នកអានឱ្យយល់ពីព្រឹត្តិកា
Genesis 13:3
ទឹកដីនោះមិនអាចផ្គត់ផ្គង់ពួកគេ
គាត់បានបន្តធ្វើដំណើរ
មិនមានដីនិងទឹកគ្រប់គ្រាន់សម្រាប់សត្វទាំងអស់របស់ពួកគេទេ។
លោកអាប់រ៉ាមនិងក្រុមគ្រួសាររបស់គាត់បានបន្តដំណើរដោយដំណាក់កាលពីមួយកន្លែងទៅមួយទៀត
ទ្រព្យសម្បត្តិ
នេះត្រូវបានបញ្ជាកយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
នេះរួមបញ្ចូលទាំងសត្វចិញ្ចឹម,ដែលត្រូវការវាលស្មៅនិងទឹក។

generated on Wed Sep 10 16:16:32 2025

ពួកគេមិនអាចនៅជាមួយគ្នាបានទេ
«មិនអាចរស់នៅជាមួយគ្នាបាន»
ជនជាតិកាណាន និងជនជាតិពេរិស៊ីត ក៏រស់នៅក្នុងស្រុកនោះដែរ
នេះជាហេតុផលមួយទៀតដែលដីមិនអាចទ្រទ្រង់ពួកគេបានទាំងអស់។
Genesis 13:8
កុំឲ្យមានជម្លោះរវាងឯងនិងអំ
«កុំឈ្លោះគ្នា»
ជម្លោះ
«អរិភាព» ឬ «ការប្រយុទ្ធគ្នា» ឬ «ការឈ្លោះប្រកែកគ្នា»
និងអ្នកគង្វាលសត្វរបស់ឯង និង អ្នកគង្វាលសត្វរបស់អ៊ីដែរ
«ហើយសូមបញ្ឈប់មនុស្សដែលថែរក្សាសត្វរបស់យើងពីការឈ្លោះប្រកែកគ្នា»
ព្រោះយើងជាគ្រួសារតែមួយទេ
«ពីព្រោះពួកយើងគឺជាគ្រួសារ»
គ្រួសារ
«ញាតិសន្តាន» ឬ «សាច់ញាតិ» ។ ឡុតជាកូនរបស់អ័ប្រាហាំ។
តើទឹកដីនៅខាងមុខឯងទាំងអស់នេះ មិនមែនជារបស់ឯងទេឬអី?
សំណួរពាក្យនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍វិជ្ជមាននៅត្រង់ប្រយោគនេះ៖
ការបកប្រែផ្សេងទៀត៖ «ដីទាំងមូលនេះសំរាប់អោយអ្នកប្រើប្រាស់វា»។
ចូរទៅចុះ ហើយយើងបែកផ្លូវគ្នាចុះ
លោកអ័ប្រាហាំនិយាយដោយសុភាពទៅកាន់ឡុត
ហើយបានលើកទឹកចិត្តដល់ឡុតដើម្បីអោយធ្វើការនេះដើម្បីសម្រួលដល់ពួកគេទាំងពីរ
«ចូរបែកគ្នា»
ប្រសិនបើអ្នកទៅខាងឆ្វេង,នោះខ្ញុំនិងទៅខាងស្តាំ
អត្ថន័យដែលមានគឺ ១) «ប្រសិនបើអ្នកទៅផ្លូវមួយ ខ្ញុំនឹងទៅផ្លូវមួយទៀត» ឬ ២)
ប្រសិនបើអ្នកទៅខាងជើង ខ្ញុំនឹងទៅភាគខាងត្បូង។
អាប់រ៉ាមអនុញ្ញាតឱ្យឡុតជ្រើសរើសដីដែលគាត់ចង់បានហើយ
លោកអាប់រ៉ាមនឹងយកអ្វីដែលនៅសល់។
Genesis 13:10
ទន្លេយ័រដាន់មានទឹកច្រើនល្អ
នេះគឺសំដៅទៅតំបន់ទូទៅនៅទន្លេយ័រដាន់។
មានទឹកច្រើន
«គឺមានទឹកយ៉ាងច្រើន»
ស្អាតដូចជាសួនរបស់ព្រះអម្ចាស់ ដូចជាទឹកដីរបស់អេស៊ីប
«ដូចជាសួនច្បាររបស់ព្រះយេហូវ៉ាឬដូចជាស្រុកអេស៊ីបដែរ»។
ទាំងនេះជាកន្លែងពីរផ្សេងគ្នា។
សួនរបស់ព្រះអម្ចាស់
នេះគឺជាឈ្មោះផ្សេងទៀតសម្រាប់ក្នុងសួនច្បារអេដែន។
សួនច្បារ
ប្រើពាក្យដូចគ្នា«សួនច្បារ»ដូចក្នុងលោកុប្បត្តិ២:៧។
មុនព្រះអម្ចាស់បំផ្លាញក្រុងសូដុម និងក្រុងកូម៉ូរ៉ា
នេះស្មានទុកមុននូវអ្វីដែលនឹងកើតឡើងនៅពេលក្រោយ។
វាមានសារៈសំខាន់ណាស់នៅទីនេះព្រោះវាពន្យល់ពីមូលហេតុដែលឡុតបានតាំងទីលំនៅក្នុងតំបន់មួយដែ
សាច់ញាតិ
«ញាតិសន្តាន» ឬ «គ្រួសារ» ។
នេះសំដៅទៅលើឡុតនិងអាប់រ៉ាមជាមួយគ្រួសាររបស់ពួកគាត់។
Genesis 13:12
រស់នៅ
«ទូទាត់» ឬ «ស្នាក់នៅ»
ទឹកដីកាណាន
«គឺជាទឹកដីរបស់ពួកកូនចៅកាណាន»
គាត់បានសង់ត្រសាលនៅពេលដែលគាត់មកដល់ក្រុងសូដុម
អត្ថន័យដែលអាចមានគឺ ១)
«គាត់បានរៀបចំត្រសាលរបស់គាត់នៅជិតក្រុងសូដុម» ឬ ២)
គាត់បានផ្លាស់ទីជម្រករបស់គាត់នៅជុំវិញតំបន់មួយដែលទៅដល់ផ្លូវទៅក្រុងសូដុម។
Genesis 13:14
បន្ទាប់ពីលោកឡុតចេញពីគាត់
«បន្ទាប់ពីលោកឡុតបានចាកចេញពីលោកអប្រាហាំ»
Genesis 13:16
ដើរកាត់ប្រវែងនិងទទឹងដី
«បានដើរកាត់នៅលើទឹកដីទាំងមូល»
ម៉ាមរ៉ែ
នេះជាឈ្មោះមនុស្សដែលជាម្ចាស់ដើមជ្រៃ។
ហេប្រុន
គឺជាឈ្មោះទីកន្លែង។
សង់អាសនាថ្វាយព្រះអម្ចាស់
«គឺជាកន្លែងអាសនាសម្រាប់ថ្វាយបង្គំព្រះជាម្ចាស់»

---

14 [1]កាលនោះ ព្រះបាទអាំរ៉ាផែលជាស្តេចរបស់ប្រទេសស៊ីណើរ ព្រះបាទអើយ៉ុកជាស្តេចរបស់ប្រទេសអេឡាសារ ព្រះបាទកេដូឡោមើរជាស្តេចប្រទេសអេឡាំ និង
ព្រះបាទធីដាលជាស្តេចរបស់ប្រទេសកូយីម[2]ពួកគេបានធ្វើសង្គ្រាមទាស់នឹងព្រះបាទបេរ៉ាជាស្តេចក្រុងសូដុម ព្រះបាទប៊ីសារជាស្តេចក្រុងកូម៉ូរ៉ា ព្រះបាទស៊ីណាបជា
ស្តេចក្រុងអាដម៉ា ព្រះបាទសេមេប៊ើរជាស្តេចក្រុងសេបោម និងស្តេចក្រុងបេឡា (ដែលហៅថាក្រុងសូអារផងដែរ)។
[3]ក្រោយមក ស្តេចទាំងប្រាំបានរួមគ្នានៅជ្រលងភ្នំស៊ីឌីម (ដែលហៅថាសមុទ្រប្រៃ)។[4]ស្តេចទាំងនេះបានបម្រើព្រះបាទកេដូឡោមើរ អស់រយៈពេលដប់ពីរឆ្នាំ ប៉ុន្តែ នៅឆ្នាំទីដប់
បីពួកគេបាននាំគ្នាបះបោរ។[5]បន្ទាប់មក នៅឆ្នាំទីដប់បួន ព្រះបាទកេដូឡោមើរ និងស្តេចផ្សេងៗ ដែលនៅជាមួយព្រះអង្គ បាននាំគ្នាមកវាយលុកជនជាតិរេផែម នៅក្រុង
អាសថារ៉ូតកើណែម ជនជាតិស៊ូស៊ីម នៅក្រុងហាំ ជនជាតិអេមីម នៅក្រុងគារយ៉ាថែម[6]និងជនជាតិហូរី នៅតំបន់ភ្នំសៀរ រហូតដល់តំបន់អែលបារ៉ាន ដែលនៅជិតទី
រហោស្ថាន។
[7]បន្ទាប់មក ពួកគេបានត្រឡប់ ហើយមកឯក្រុងអេនមីសផាត (ដែលហៅថាក្រុងកាដេស) វិញ ហើយបានវាយយករបស់ជនជាតិអាម៉ាឡេក ព្រមទាំងជនជាតិអាម៉ូរី ដែល
រស់នៅទឹកដីហាសាសូនតាម៉ារផង។[8]បន្ទាប់មក ស្តេចក្រុងសូដុម ស្តេចក្រុងកូម៉ូរ៉ា និងស្តេចបេឡា (ដែលហៅថាក្រុងសូអារ)[9]បានចេញទៅធ្វើសង្គ្រាមតទល់នឹងព្រះបាទ
កេដូឡោមើរជាស្តេចរបស់ទឹកដីអេឡាំ ព្រះបាទធីដាលជាស្តេចទឹកដីកូយីម ព្រះបាទអាំរ៉ាផែលជាស្តេចរបស់ទឹកដីស៊ីណើរ និងព្រះបាទអើរយ៉ុកជាស្តេច
របស់ទឹកដីអេឡាសារ គឺស្តេចបួនអង្គតទល់នឹងស្តេចប្រាំអង្គ។
[10]ឥឡូវនេះ នៅជ្រលងភ្នំស៊ីឌីមពេញទៅដោយអណ្តូងប្រេងជាច្រើន ហើយស្តេចក្រុងសូដុម និងក្រុងកូម៉ូរ៉ា បានរត់ ហើយពួកគេបានធ្លាក់ទៅក្នុងអណ្តូងនោះ។
ហើយពួកអ្នកដែលនៅសល់បានរត់ទៅតាមភ្នំផ្សេងៗ។[11]ដូច្នេះ ពួកសត្រូវបានយករបស់របរនៅក្រុងសូដុម និងក្រុងកូម៉ូរ៉ាទាំងអស់
ព្រមទាំងទ្រព្យសម្បត្តិរបស់ពួកគេទៅជាមួយដែរ។[12]នៅពេលពួកគេនាំចេញទៅ ពួកគេបាននាំលោកឡុត
ក្មួយរបស់លោកអាប់រ៉ាមដែលរស់នៅក្នុងក្រុងសូដុមទៅជាមួយដែរ រួមទាំងទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ផងដែរ។
[13]មានម្នាក់ដែលបានគេចរួចបានមកប្រាប់លោកអាប់រ៉ាមជាជនជាតិហេព្រើរ។ លោករស់នៅក្បែរដើមជ្រៃដែលជាកម្មសិទ្ធិរបស់លោកម៉ាមរ៉ែជាជនជាតិអាម៉ូរី ដែលត្រូវជា
បងប្អូនរបស់លោកអែសកុល និងលោកអាន់នើរ ដែលជាសម្ពន្ធមិត្តរបស់លោកអាប់រ៉ាម។[14]នៅពេលនេះ លោកអាប់រ៉ាមបានឮថា
ពួកសត្រូវបានចាប់យកសាច់ញាតិរបស់គាត់ លោកបាននាំអ្នកបម្រើដែលកើតនៅក្នុងផ្ទះរបស់គាត់ ដែលគាត់បានបង្វឹកចំនួន៣១៨នាក់
ហើយគាត់បានដេញតាមពួកគេរហូតដល់ក្រុងដាន់។
[15]គាត់បានបែងចែកគ្នារបស់គាត់ដើម្បីប្រយុទ្ធជាមួយពួកគេនៅពេលយប់ ហើយបានវាយលុកពួកគេ និងដេញតាមពួកគេរហូតដល់ក្រុងហូបា ដែលនៅខាងជើងក្រុង
ដាម៉ាស។[16]បន្ទាប់មក គាត់បាននាំទ្រព្យសម្បត្តិទាំងអស់ ហើយបាននាំលោកឡុតដែលជាសាច់ញាតិរបស់គាត់ ព្រមទាំងរបស់របរ រួមទាំងភរិយា
និងអ្នកផ្សេងទៀតផងដែរ។
[17]បន្ទាប់ពីលោកអាប់រ៉ាមបានត្រឡប់ពីវាយលុកព្រះបាទកេដូឡោមើរ និងស្តេចទាំងឡាយដែលនៅជាមួយរួចមក ស្តេចក្រុងសូដុមក៏ចេញមកទទួលគាត់នៅជ្រលងភ្នំសាវេ
(ដែលហៅថាជ្រលងភ្នំហ្គួងផងដែរ)។[18]ព្រះបាទម៉ិលគីស្សាដែកជាស្តេចនៅក្រុងសាឡិម បានឲ្យគេយកនំប៉័ង និងស្រាទំពាំងបាយជូរមកជូនលោកអាប់រ៉ាម។
គាត់គឺជាមហាបូជាចារ្យរបស់ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត។

[19]គាត់បានឲ្យពរដល់លោកដោយថ្លែងថា៖ «សូមព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ជាព្រះដែលបានបង្កើតស្ថានសួគ៌ និងផែនដី បានប្រទានពរដល់លោកអាប់រ៉ាម។
[20]សូមព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ជាព្រះដែលបានប្រគល់ខ្មាំងសត្រូវមកក្នុងកណ្តាប់ដៃរបស់លោក ប្រទានពរដល់លោក»។ បន្ទាប់មក
លោកអាប់រ៉ាមបានថ្វាយមួយភាគដប់ដល់ស្តេចពីអ្វីៗទាំងអស់។
[21]ស្តេចក្រុងសូដុមមានបន្ទូលទៅលោកអាប់រ៉ាមថា៖ «ចូរប្រគល់មនុស្សមកឲ្យយើងវិញ ហើយយកទ្រព្យសម្បត្តិសម្រាប់លោកទៅចុះ»។
[22]លោកអាប់រ៉ាមទូលទៅស្តេចក្រុងសូដុមថា៖ «ទូលបង្គំសូមលើកដៃរបស់ទូលបង្គំនៅចំពោះព្រះអម្ចាស់ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ជាព្រះដែលបានបង្កើតស្ថានសួគ៌ និង
ផែនដីថា[23]ទូលបង្គំនឹងមិនយកអំបោះមួយសរសៃ ឬខ្សែស្បែកជើងមួយ ឬអ្វីៗដែលជាសម្បត្តិរបស់ព្រះករុណាសោះឡើយ ដើម្បីកុំឲ្យព្រះករុណាមានបន្ទូលថា៖ «យើង
បានធ្វើឲ្យអាប់រ៉ាមទៅជាអ្នកមាន»។[24]ទូលបង្គំនឹងមិនយកអ្វីឡើយ លើកលែងតែអ្វីៗដែលសម្រាប់យុវជនហូប ហើយចែករំលែកជាមួយអ្នកដែលទៅជាមួយទូលបង្គំ
ប៉ុណ្ណោះបានហើយ សូមឲ្យលោកអាន់នើរ លោកអេសកុល និងលោកម៉ាមរ៉េបានយកចំណែករបស់ពួកគេផង»។

Genesis 14:1

ព័ត៌មានទូទៅ

គឺជាទីកន្លែងក្នុង១៤:១ទាំងអស់នោះគឺជាទីក្រុងឯករាជ្យ។

កាលនោះ

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។

នៅក្នុងថ្ងៃនៃ

«គឺក្នុងពេលនៃ»

ពួកគេបានធ្វើសង្គ្រាម

«ពួកគេបានទៅធ្វើសង្គ្រាម» ឬ «ពួកគេបានចាប់ផ្តើមធ្វើសង្គ្រាម» ឬ
«ពួកគេបានត្រៀមលក្ខណៈសម្រាប់សង្គ្រាម»

Genesis 14:3

ស្តេចទាំងប្រាំបានរួមគ្នា

ព័ត៌មានដែលកងទ័ពរបស់ពួកគេនៅជាមួយពួកគេអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖ « ស្តេចប្រាំអង្គនិងកងទ័ពរបស់ពួកគេបានរួមគ្នា»

ដប់ពីរឆ្នាំដែលពួកគេបានបំរើ

ព្រឹត្តិការណ៍នេះនៅក្នុង៤-៧តែបានកើតឡើងនៅមុន៣។

បានបម្រើព្រះបាទកេដូឡោមើរ

ពួកគេប្រហែលជាត្រូវបង់ពន្ធឱ្យគាត់ហើយបម្រើក្នុងជួរកងទ័ពរបស់គាត់។
ការបកប្រែផ្សេងទៀត៖ «ពួកគេស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះបាទ
កេដូឡោមើរ»

ពួកគេបាននាំគ្នាបះបោរ

«ពួកគេបដិសេធន៏ដើម្បីបម្រើគាត់» ឬ«ពួកគេបានឈប់បម្រើគាត់»

បាននាំគ្នាមកវាយលុក

ពួកគេបានយ៉ាងនេះពីព្រោះដោយសារមានស្តេចផ្សេងទៀតបះបោរ។

រ៉េផែម.....ស៊ូស៊ីម.....អេមីម....ហូរី

ទាំងនេះគឺជាឈ្មោះរបស់មនុស្សមួយក្រុម។

អាសថារ៉ូត..កើណែម...ហាំ....យ៉ាថែម..សៀរ..អែលបារ៉ាន

ទាំងអស់នេះគឺជាឈ្មោះរបស់ទីកន្លែង។

អែលបារ៉ាន ដែលនៅជិតទីរហោស្ថាន

ឃ្លានេះជួយឱ្យអ្នកអានយល់ពីកន្លែងដែលអែលបារ៉ាន។
វាអាចត្រូវបានបកប្រែជាប្រយោគដាច់ដោយឡែកប្រសិនបើចាំបាច់។
ការបកប្រែផ្សេងទៀត៖ «អែលបារ៉ាន ។ អែលបារ៉ាន នៅជិតវាលខ្សាច់»

Genesis 14:7

ព័ត៌មានទូទៅ

ខ៨និងខ៩ រំលឹកឡើងវិញពីអ្វីដែលបាននិយាយនៅក្នុងជំពូក១៤:៣
ហើយបន្តរៀបរាប់ពីអ្វីដែលបានកើតឡើងនៅពេលស្តេចទាំងអស់នេះប្រយុទ្ធគ្នា។

ពួកគេបានត្រឡប់ ហើយមក

ពាក្យថា « ពួកគេ»
សំដៅទៅលើស្តេចបរទេសទាំងបួនអង្គដែលកំពុងវាយប្រហារតំបន់កាណាន។
ឈ្មោះរបស់ស្តេចទាំងអស់នោះគឺអាំរ៉ាផែល អើរយ៉ុក កេដូឡាមើរ និងទីដាល។
ការបកប្រែផ្សេងទៀត៖ «ពួកគេបានត្រឡប់ហើយទៅ»

អាម៉ូរី ដែលរស់នៅទឹកដីហាសាសូនតាម៉ារ

ឃ្លានេះប្រាប់ថាតើប្រជាជនអាម៉ូរីត្រូវបានចាញ់។
មានប្រជាជនអាម៉ូរីដែលរស់នៅកន្លែងផ្សេងទៀត។

និងស្តេចបេឡា (ដែលហៅថាក្រុងសូអារ)

ទីក្រុងបេឡាក៏ត្រូវបានគេហៅថាសូអារដែរ។
ព័ត៌មាននេះក៏អាចត្រូវបានដាក់នៅចុងបញ្ចប់នៃអត្ថបទ។
«ហើយស្តេចបេឡាបានចេញទៅរៀបចំត្រៀមសម្រាប់ប្រយុទ្ធ។
បេឡាក៏ត្រូវបានគេហៅថាសូអារដែរ»

រៀបចំសម្រាប់សង្គ្រាម

«បានចូលរួមក្នុងសង្គ្រាម» ឬ«បានបង្កើតខ្សែប្រយុទ្ធ»។
អ្នកបកប្រែខ្លះប្រហែលជាត្រូវនិយាយផងដែរថាកងទ័ពបានប្រយុទ្ធដូចជាធ្វើនៅក្នុងខ
៩ ។

គឺស្តេចបួនអង្គតទល់នឹងស្តេចប្រាំអង្គ

ចាប់តាំងពីស្តេចទាំង ៥ ត្រូវបានចុះបញ្ជីដំបូង ភាសាខ្លះអាចបកប្រែថា «ស្តេចទាំង
៥ ប្រឆាំងនឹងបួនអង្គ»។

Genesis 14:10

ឥឡូវនេះ

ពាក្យនេះណែនាំព័ត៌មានប្រវត្តិអំពីជ្រលងភ្នំស៊ីឌីម។

ពេញទៅដោយអណ្តូងប្រេង

«មានអណ្តូងជាច្រើន» ទាំងនេះគឺជារណ្តៅនៅក្នុងដីដែលមានជ័រ។

ជ័រ

រាវ ខ្មៅស្និត ក្រាស់ដែលកើតចេញពីដី។ សូមមើលនៅក្នុង ១១: ៣។

ស្តេចក្រុងសូដុម និងក្រុងកូម៉ូរ៉ា

នេះជាពាក្យប្រៀបធៀបសម្រាប់ស្តេច និងកងទ័ពរបស់ពួកគេ។
ការបកប្រែផ្សេងទៀត៖ «ស្តេចក្រុងសូដុម និងកូម៉ូរ៉ា និងកងទ័ពរបស់ពួកគេ»

ពួកគេបានធ្លាក់ទៅក្នុងនោះ

អត្ថន័យគឺ ១) ទាហានរបស់ពួកគេខ្លះបានធ្លាក់ចូលរណ្តៅជ័រឬ ២)
ស្តេចខ្លួនឯងបានធ្លាក់ចូលរណ្តៅជ័រ។ ចាប់តាំងពី ១៤:១៧
និយាយថាស្តេចសូដុមបានទៅជួបអាប់រ៉ាម អត្ថន័យដំបូងទំនងជាត្រឹមត្រូវ។

ហើយពួកអ្នកដែលនៅសល់

«អស់អ្នកដែលមិនបានស្លាប់ក្នុងពេលប្រយុទ្ធ
ហើយក៏មិនបានធ្លាប់ទៅក្នុងរណ្តៅជ័រ!»

សត្រូវ

នេះគឺសំដៅទៅស្តេចកេតដូឡោម
និងស្តេចដទៃទៀតនិងកងទ័ពរបស់ពួកគេជាមួយគាត់ដែលកំពុងវាយប្រហារក្រុងសូដុមនិងកូម៉ូរ៉ា។

របស់របនៅក្រុងសូដុម និងក្រុងកូម៉ូរ៉ា

ពាក្យ«សូដុម»និង«កូម៉ូរ៉ា»គឺជាពាក្យប្រៀបប្រដូចសម្រាប់ប្រជាជនដែលរស់នៅក្នុងទីក្រុងទាំងនោះ។
ការបកប្រែផ្សេងទៀត៖ «ទ្រព្យសម្បត្តិរបស់ប្រជាជនក្រុងសូដុមនិងកូម៉ូរ៉ា» ឬ«
ទ្រព្យសម្បត្តិរបស់ប្រជាជនក្រុងសូដុមនិងកូម៉ូរ៉ា»

ទ្រព្យសម្បត្តិរបស់ពួកគេ

«គឺគ្រឿងបរិភោគរបស់ពួកគេ»

ទៅជាមួយដែរ

«ពួកគេបានចេញទៅ»

នៅពេលពួកគេនាំចេញទៅ ពួកគេបាននាំលោកឡុត
ក្មួយរបស់លោកអាប់រ៉ាមដែលរស់នៅក្នុងក្រុងសូដុមទៅជាមួយដែរ
រួមទាំងទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ផងដែរ
ឃ្លា «កូនប្អូនប្រុសរបស់លោកអាប់រ៉ាម» និង «ដែលកំពុងរស់នៅក្នុងក្រុងសូដុម»
រំលឹកដល់អ្នកអាននូវអ្វីដែលត្រូវបានសរសេរមុនអំពីឡុត។ ការបកប្រែផ្សេងទៀត៖
« ពួកគេក៏បានយកឡុតរួមជាមួយទ្រព្យសម្បត្តិទាំងអស់របស់គាត់ដែរ។
ឡុតគឺជាកូនប្អូនប្រុសរបស់លោកអាប់រ៉ាមហើយរស់នៅក្នុងក្រុងសូដុមនាពេលនោះ»

Genesis 14:13

មានម្នាក់ដែលបានគេចរួច

«មានបុរសម្នាក់ដែលបានគេចរួចពីការប្រយុទ្ធនោះ»

លោករស់នៅ

«លោកអាប់រ៉ាមបានរស់នៅ» នេះគឺបានរៀបរាប់ពីសាច់រឿងដែលបានកើតឡើង។

ជាសម្ពន្ធមិត្តរបស់លោកអាប់រ៉ាម

«ជាដៃគូសន្ធិសញ្ញាជាមួយអាប់រ៉ាម» ឬ

generated on Wed Sep 10 16:16:32 2025

«មានកិច្ចព្រមព្រៀងសន្តិភាពជាមួយលោកអាប់រ៉ាម»
សាច់ញាតិរបស់គាត់
នេះគឺសំដៅពីលោកឡុតក្មួយរបស់លោកអាប់រ៉ាម។
បង្វឹកពួកគេ
«គឺមនុស្សដែលបង្វឹកដើម្បីទៅច្បាំង»
កើតនៅក្នុងផ្ទះរបស់គាត់
«ពួកអ្នកដែលបានកើតនៅក្នុងផ្ទះរបស់លោកអាប់រ៉ាម»។
ពួកគេគឺជាកូនពួកអ្នកបម្រើនៅផ្ទះរបស់លោកអាប់រ៉ាម។
ដេញតាមពួកគេ
«ដេញពួកគេ»
ក្រុងដាន់
នេះជាទីក្រុងមួយនៅភាគខាងជើងឆ្ងាយនៃស្រុកកាណាន
ឆ្ងាយពីជំរុំរបស់លោកអាប់រ៉ាម។
Genesis 14:15
គាត់បានបែងចែកគ្នារបស់គាត់ដើម្បីប្រយុទ្ធជាមួយពួកគេនៅពេលយប់ ហើយបានវាយលុកពួកគេ
នេះប្រហែលជាសំដៅទៅលើយុទ្ធសាស្ត្រប្រយុទ្ធ។
«អាប់រ៉ាមបានបែងចែកបុរសជាក្រុមជាច្រើនហើយពួកគេបានវាយប្រហារសត្រូវរបស់ពួកគេពីទិសផ្សេងៗ»
ទ្រព្យសម្បត្តិទាំងអស់
នេះសំដៅទៅលើរបស់ដែលសត្រូវបានលួចពីទីក្រុងសូដុម និងកូម៉ូរ៉ា។
ទាំងរបស់របរ
«និងទ្រព្យសម្បត្តិរបស់ឡុតដែលសត្រូវបានលួចពីឡុត»
រួមទាំងស្ត្រីៗ និង អ្នកផ្សេងទៀតផងដែរ
«ក៏ដូចជាស្ត្រី និង ប្រជាជនដទៃទៀតដែលស្តេចទាំងបួនបានចាប់យក»
Genesis 14:17
បានត្រឡប់
ព័ត៌មានដែលបញ្ជាក់អំពីកន្លែងដែលគាត់កំពុងវិលត្រឡប់អាចត្រូវបានបញ្ជាក់ឱ្យច្បាស់ប៉ុន្តែបានទទួលស្គាល់ថាទាហានបានបរិភោគរបស់ខ្លះក្នុងអំឡុងពេលធ្វើដំណើរត្រឡប់ទៅក្រុងសូដុមបន្ទា
ការបកប្រែផ្សេងទៀត៖ «ត្រឡប់ទៅកន្លែងដែលគាត់កំពុងរស់នៅ»
ព្រះបាទម៉ិលគីស្សាដែក ជាស្តេចនៅក្រុងសាឡឹម
នេះគឺជាលើកដំបូងបំផុតដែលនិយាយអំពីស្តេចនេះ។
នំប៉័ង និងស្រាទំពាំងបាយជូរ
មនុស្សជាទូទៅបរិភោគនំប៉័ង និង ស្រាទំពាំងបាយជូរ។
សូមមើលពីរបៀបដែលអ្នកបកប្រែ « នំប៉័ង» នៅ ៣:១៧ និង«
ស្រាទំពាំងបាយជូរ» ក្នុង ៩:២០ ។
Genesis 14:19
គាត់បានឲ្យពរដល់លោក
ស្តេចមីលគីស្សាដែកអោយពរដល់លោកអាប់រ៉ាម។
សូមព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ជាព្រះដែលបានបង្កើតស្ថានសួគ៌ និងផែនដី
នេះត្រូវបានបញ្ជាក់ទំរង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«សូមព្រះជាម្ចាស់ដែលគង់នៅទីខ្ពស់បំផុត ជាម្ចាស់នៃស្ថានបរមសុខ
ហើយនិងផែនដី ប្រទានពរដល់លោកអាប់រ៉ាម»
ស្ថានសួគ៌
នេះគឺសំដៅទីកន្លែងដែលព្រះជាម្ចាស់ទ្រង់គង់នៅ។
ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ជាព្រះដែលបានប្រគល់
«ព្រះជាម្ចាស់ដែលខ្ពស់បំផុត ពីព្រោះទ្រង់បានប្រទានពរ»
ត្រង់ចំណុះនេះបានបញ្ជាក់ជាមួយ «អ្នកដែលបានប្រគល់»
គឺបានប្រាប់យើងបន្ថែមអំពីអ្វីដែលព្រះជាម្ចាស់ដ៏ខ្ពស់។
សូមព្រះជាម្ចាស់ដ៏ខ្ពស់បំផុត
នេះគឺជាអ្វីដែលបានសរសើរដំកើងដល់ព្រះ។ សូមមើលពីការបកប្រែ «ព្រះពរ»
នៅក្នុង៩:២៦
មកក្នុងកណ្តាប់ដៃ
«ទៅក្នុងការគ្រប់គ្រងរបស់អ្នក» ឬ «ទៅក្នុងអំណាចរបស់អ្នក»
Genesis 14:21
ប្រគល់មនុស្សមកឲ្យយើងវិញ
នៅឃ្លា«មនុស្ស»ប្រហែលសំដៅទៅមនុស្សនៅក្រុងសូដុមដែលសត្រូវបានចាបយកពួកគេ។
លោកអាប់រ៉ាមបានរំដោះពួកគេពេលដែលលោករំដោះលោកឡុត។
ទូលបង្គំសូមលើកដៃរបស់ទូលបង្គំ
នេះមានន័យថា «ខ្ញុំបានស្បថ» ឬ«ខ្ញុំបានបង្កើតសេចក្តីសន្យា»
ទូលបង្គំនឹងមិនយកអ្វីឡើយ លើកលែងតែអ្វីៗដែលសម្រាប់យុវជនហូប
«ខ្ញុំយកពីអ្នកនូវអ្វីដែលបុរសវ័យក្មេងរបស់ខ្ញុំបានបរិភោគរួចហើយ»។
លោកអាប់រ៉ាមបានបដិសេធមិនទទួលយកអ្វីសម្រាប់ខ្លួនគាត់ទេ
ហើយចែករំលែកជាមួយអ្នកដែលទៅជាមួយទូលបង្គំ
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖
«ចំណែកនៃទ្រព្យសម្បត្តិដែលបានរកឃើញដែលជាកម្មសិទ្ធិរបស់បុរសដែលបានជួយខ្ញុំឱ្យទទួលបានមក
លោកអាន់នើរ លោកអេសកុល និងលោកម៉ាមរ៉េ
ទាំងនេះគឺជាសម្ព័ន្ធមិត្តរបស់អាប់រ៉ាម (សូមមើល៖ ១៤:១៣) ។
ដោយសារពួកគេជាសម្ព័ន្ធមិត្តរបស់អាប់រ៉ាមពួកគេបានច្បាំងនឹងគាត់។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖ «សម្ព័ន្ធមិត្តរបស់ខ្ញុំគឺអាន់នើរ អេសកុល និងម៉ាមរ៉េ»

---

15 [1]បន្ទាប់ការទាំងនេះកើតឡើង ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកអាប់រ៉ាមនៅក្នុងនិមិត្តថា៖ «អាប់រ៉ាមអើយ! កុំខ្លាចអី យើងជាខែល
និងជារង្វាន់ដ៏ធំរបស់អ្នក»។[2]លោកអាប់រ៉ាមទូលថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គនឹងប្រទានអ្វីដល់ទូលបង្គំ? បើទូលបង្គំគ្មានកូនដូច្នេះ ហើយអ្នកដែលនឹងទទួល
កេរមត៌កនៅក្នុងផ្ទះរបស់ទូលបង្គំ គឺអេលាស៊ើរជាអ្នកក្រុងដាម៉ាសឯណោះវិញទេ»។[3]លោកអាប់រ៉ាមបន្តទៀតថា៖ «ព្រះអង្គមិនបានប្រទានឲ្យទូលបង្គំមានកូន មើល
មានតែអ្នកបម្រើនៅក្នុងផ្ទះរបស់ទូលបង្គំទេ នឹងទទួលកេរមត៌ករបស់ទូលបង្គំ»។
[4]មើល៍ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់គាត់ ថា៖ «បុរសនេះនឹងមិនទទួលកេរមត៌ករបស់អ្នកឡើយ ប៉ុន្តែ ម្នាក់ដែលកើតចេញពីរូបកាយរបស់អ្នកទេ
ដែលនឹងទទួលកេរមត៌ករបស់អ្នក»។[5]បន្ទាប់មក ព្រះអង្គបាននាំគាត់ចេញមកក្រៅ ហើយមានបន្ទូលថា៖ «ចូរមើលទៅស្ថានសួគ៌ ហើយរាប់ចំនួនផ្កាយ ប្រសិនបើ
អ្នកអាចរាប់ចំនួនវាបាន»។ បន្ទាប់មកព្រះអង្គមានបន្ទូលទៅគាត់ថា៖ «ដូច្នេះ អ្នកនឹងរាប់ពូជពង្សរបស់អ្នកបានហើយ»។
[6]គាត់បានជឿលើព្រះអម្ចាស់ ហើយគាត់ត្រូវបានរាប់ជាសុចរិត។[7]ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «យើងគឺព្រះអម្ចាស់ ដែលបាននាំអ្នកចេញពីក្រុងអ៊ើរ ទឹកដីខាល់ដេ
យើងនឹងប្រគល់ទឹកដីនេះជាកេរមត៌កដល់អ្នក»។[8]គាត់ទូលថា៖ «ព្រះអម្ចាស់ដ៏ជាព្រះអើយ តើទូលបង្គំដឹងបានយ៉ាងដូចម្តេចថា ទូលបង្គំនឹងបានទទួលវានោះ?»
[9]បន្ទាប់មក ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «មើល៍ ចូរយកគោញីមួយអាយុបីឆ្នាំ ពពែញីមួយអាយុបីឆ្នាំ និងកូនចៀមឈ្មោលមួយអាយុបីឆ្នាំ ព្រាបមួយ
និងលលកដំទើរមួយមក»។[10]គាត់បានយកសត្វទាំងអស់នោះមកថ្វាយព្រះអង្គ ហើយកាត់ពួកវាជាពីរ និងយកមកពាក់កណ្តាលមកដាក់ផ្ទុយគ្នា ប៉ុន្តែ
គាត់មិនបានពុះសត្វស្លាបទេ។[11]ពេលនោះ មានត្មាតមកឆាបសាច់សត្វ លោកអាប់រ៉ាមបានដេញវា។
[12]បន្ទាប់មក នៅពេលថ្ងៃជិតលិច លោកអាប់រ៉ាមងងុយគេងជាខ្លាំង ហើយមើល មានភាពងងឹត និងគួរឲ្យភ័យខ្លាចជាខ្លាំងចំពោះគាត់។[13]បន្ទាប់ពី
ព្រះអម្ចាស់មានបន្ទូលមកលោកអាប់រ៉ាមថា៖ «ចូរដឹងជាប្រាកដថា ពូជពង្សរបស់អ្នកនឹងក្លាយជាជនបរទេសនៅក្នុងទឹកដីសាសន៍ដទៃដែលមិនមែនជាទឹកដីរបស់ខ្លួន
ហើយនឹងក្លាយជាទាសករ ហើយត្រូវគេជិះជាន់អស់រយៈពេលបួនរយឆ្នាំ។
[14]យើងនឹងជំនុំជម្រះប្រជាជាតិដែលពួកគេនឹងបម្រើនោះ ហើយបន្ទាប់មកពួកគេនឹងចេញពីប្រទេសនោះជាមួយនឹងទ្រព្យសម្បត្តិយ៉ាងច្រើនសន្ធឹក។[15]ប៉ុន្តែ
អ្នកនឹងត្រឡប់ទៅឯឪពុករបស់ដោយសេចក្តីសុខសាន្ត ហើយអ្នកនឹងត្រូវបញ្ចុះក្នុងផ្នូរក្នុងអាយុវែងល្អហើយ។[16]នៅក្នុងជំនាន់ទីបួន ពួកគេនឹងមកទីនេះម្តងទៀត
ដើម្បីអំពើរំលងរបស់អាម៉ូរីមិនទាក់កម្រិតរបស់វានៅឡើយ»។
[17]នៅពេលថ្ងៃជិតលិច ហើយសេចក្តីងងឹតក៏មកដល់ មើល៍ មានឆ្នាំងភ្លើងហុយផ្សែង ហើយនិងអណ្តាតភ្លើងឆេះនៅចន្លោះដុំសាច់ទាំងនោះ។[18]នៅថ្ងៃនោះ
ព្រះអម្ចាស់បានធ្វើសម្ពន្ធមេត្រីជាមួយលោកអាប់រ៉ាម ដោយមានបន្ទូលថា៖ «យើងនឹងប្រគល់ទឹកដីនេះ ដល់ពូជពង្សរបស់អ្នក ពីទន្លេអេស៊ីប
រហូតដល់ទន្លេធំអឺប្រាត[19]ជនជាតិកែន ទឹកដីកេនិស៊ីត ទឹកដីកាត់ម៉ូន[20]ទឹកដីហេត ទឹកដីពេរិស៊ីត ទឹកដីរេផែម[21]ទឹកដីអាម៉ូរី ទឹកដីកាណាន ទឹកដីគើកាស៊ី និងទឹកដី
យេប៊ូស»។

generated on Wed Sep 10 16:16:32 2025

Genesis 15:1

បន្ទាប់ការទាំងនេះកើតឡើង

«ការទាំងនេះ» សំដៅទៅពេលស្តេចទាងបួនអង្គរកឃើញ
ហើយលោកអាប់រ៉ាមបានជួយរំដោះលោកឡុត។

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក

ពាក្យនេះមានន័យថាព្រះអម្ចាស់មានព្រះបន្ទូល។ ការបកប្រែផ្សេងទៀត៖
«ព្រះអម្ចាស់មានព្រះបន្ទូលមកលោក»

ព្រះបន្ទូលរបស់ព្រះអម្ចាស់

ទីនេះ «ព្រះបន្ទូល» គឺបង្ហាញពីព្រះបន្ទូលនៃព្រះអម្ចាស់។ការបកប្រែផ្សេងទៀត៖
«ព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា»

ខែល.....រង្វាន់

ព្រះជាម្ចាស់បានប្រើពាក្យប្រៀបធៀបអំពីលក្ខណសម្បត្តិរបស់ទ្រង់ហើយពីការទំនាក់ទំនងរបស់ទ្រង់ជាមួយប្រជារាស្ត្ររបស់ទ្រង់ដែលទ្រង់ធ្វើជាម៉ាក់ការពារ

យើងជាខែល

ទាហានប្រើខែលការពារខ្លួនពីសត្រូវរបស់ពួកគេ។ ការបកប្រែផ្សេងទៀត៖
«យើងនឹងការពារអ្នកដូចខែល» ឬ «យើងជាខែលការពារអ្នក»

ជារង្វាន់

«ការទូទាត់។ »
នេះសំដៅទៅលើការបង់ប្រាក់ដែលមនុស្សម្នាក់សមនឹងទទួលបាន។
អត្ថន័យពីរដែលអាចទៅរួចគឺ ១) «យើងជាអ្វីទាំងអស់ដែលអ្នកត្រូវការ» ឬ ២)
«យើងនឹងផ្តល់ឱ្យអ្នកនូវអ្វីដែលអ្នកត្រូវការ»។

លោកអាប់រ៉ាមបន្តទៀតថា៖ «ព្រះអង្គមិនបានប្រទានឲ្យទូលបង្គំ

លោកអាប់រ៉ាមបន្តទូលសូមនិងនិយាយថា៖ «តាំងពីទ្រង់បានប្រទានមកទួលបង្គំ»

Genesis 15:4

មើល៍

ពាក្យថា « មើល»
បញ្ជាក់ពីការពិតដែលថាព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់អប្រាហាំម្តងទៀត។

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក

នេះមានន័យថាព្រះជាម្ចាស់មានបន្ទូល។ សូមមើលនៅក្នុង ១៥: ១ ។
ការបកប្រែផ្សេងទៀត៖ «ព្រះអម្ចាស់មានព្រះបន្ទូលមកលោក»

ព្រះបន្ទូលរបស់ព្រះអម្ចាស់

នៅទីនេះ «ព្រះបន្ទូល» តំណាងអោយសាររបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត៖ «ជាសាររបស់ព្រះអម្ចាស់»

បុរសនេះ

នេះគឺសំដៅទៅលោកអេលាស៊ើរអ្នកស្រុកដាម៉ាស។

ម្នាក់ដែលកើតចេញពីរូបកាយរបស់អ្នក

«ម្នាក់នេះអ្នកនិងក្លាយជាឪពុក» ឬ«គឺកូនប្រុសរបស់អ្នកផ្ទាល់»
កូនប្រុសរបស់អាប់រ៉ាមនឹងក្លាយជាអ្នកស្នងមរតករបស់គាត់។

ចំនួនផ្កាយ

«រាប់ចំនួនផ្កាយ»

ដូច្នេះ អ្នកនឹងរាប់ពូជពង្សរបស់អ្នកបានហើយ

ដូចលោកអាប់រ៉ាមមិនអាចរាប់ផ្កាយទាំងអស់បានដែរគាត់នឹងមិនអាចរាប់កូនចៅទាំងអស់របស់គាត់បានទេ

Genesis 15:6

គាត់បានជឿលើព្រះអម្ចាស់

នេះគឺមានន័យថាគាត់បានជឿនិងទុកចិត្តទៅលើអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលហើយធ្វើតាម

គាត់ត្រូវបានរាប់ជាសុចរិត

«ព្រះជាម្ចាស់បានរាប់ជំនឿលោកអាប់រ៉ាមថាសុចរិត»
ឬ«ព្រះអម្ចាស់ចាត់ទុកលោកអាប់រ៉ាមថាសុចរិតព្រោះលោកអាប់រ៉ាមជឿព្រះអង្គ»

យើងគឺព្រះអម្ចាស់, ដែលបាននាំអ្នកចេញពីក្រុងអ៊ើរ

ព្រះអម្ចាស់បានរម្លឹកលោកអប្រាហាំពីអ្វីដែលគាត់បានធ្វើរួចហើយដើម្បីឱ្យអប្រាហាំដឹងថាព្រះអម្ចាស់មានអំណាចផ្តល់ឱ្យលោកអាប់រ៉ាមនូវអ្វីដែលព្រះអង្គបានសន្យាជាមួយគាត់។

ជាកេរមត៌ក

«ដើម្បីទទួលវា» ឬ «ដូច្នេះអ្នកនឹងកាន់កាប់វា»

តើទូលបង្គំដឹងបានយ៉ាងដូចម្តេចថា

លោកអាប់រ៉ាមបានស្នើសុំភស្តុតាងថែមទៀតដែលថាព្រះអម្ចាស់នឹងប្រគល់ទឹកដីនេះដល់គាត់

Genesis 15:9

គ្រោងឆ្អឹង

«គឺជាសរីរាង្គស្លាប់របស់សត្វចិញ្ចឹមនិងសត្វស្លាប»

លោកអាប់រ៉ាមបានដេញវា

«លោកអាប់រ៉ាមដេញសត្វបក្សីទៅឆ្ងាយ»។
គាត់បានធ្វើឱ្យប្រាកដថាបក្សីមិនបរិភោគសត្វដែលងាប់។

Genesis 15:12

លោកអាប់រ៉ាមងងុយគេងជាខ្លាំង

នេះគឺបញ្ជាក់។ ការបកប្រែផ្សេងទៀត៖ «លោកអាប្រាហាំលង់លុកយ៉ាងខ្លាំង។»

មានភាពងងឹត និងគួរឲ្យភ័យ

«ភាពងងឹតខ្លាំងដែលធ្វើឱ្យគាត់ភ័យខ្លាច»

ជាខ្លាំងចំពោះគាត់

«ព័ទ្ធគាត់»

ជនបរទេស

«ជនចម្លែក» ឬ «ជនបរទេស»

ហើយនឹងក្លាយជាទាសករ ហើយត្រូវគេជិះជាន់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ហើយអ្នកស្រុកនោះនឹងធ្វើជាម៉ាក់ការ

Genesis 15:14

ព័ត៌មានទូទៅលើជំនាន់

ព្រះអម្ចាស់បន្តមានបន្ទូលអំឡុងពេលលោកអាប់រ៉ាមនិងការសុបិន្តរបស់លោកអាប់រ៉ាម។

យើងនឹងជំនុំជម្រះ

នៅទីនេះ «ចៅក្រម»
គឺជាពាក្យសំដីសម្រាប់អ្វីដែលនឹងកើតឡើងបន្ទាប់ពីព្រះធ្វើការវិនិច្ឆ័យ។
ការបកប្រែផ្សេងទៀត៖ «យើងនឹងដាក់ទណ្ឌកម្ម»

ពួកគេនឹងបម្រើ

អត្ថន័យពេញលេញវគ្គនេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត៖
«កូនចៅរបស់អ្នកនឹងបម្រើ»

ទ្រព្យសម្បត្តិយ៉ាងច្រើនសន្ធឹក

នេះគឺជាលេខសម្គាល់។ ការបកប្រែផ្សេងទៀត៖ «ទ្រព្យសម្បត្តិជាច្រើន» ឬ
«ទ្រព្យសម្បត្តិដ៏អស្ចារ្យ»

អ្នកនឹងត្រឡប់ទៅឯឪពុក

នេះជាវិធីគួរសមក្នុងការនិយាយថា «អ្នកនឹងត្រូវស្លាប់»។

ឪពុក

ពាក្យថា« ឪពុក» គឺជាពាក្យរួមមួយសម្រាប់បុព្វបុរសទាំងអស់។
ការបកប្រែផ្សេងទៀត៖ «បុព្វបុរស» ឬ «បុព្វបុរសដូនតា»

អ្នកនឹងត្រូវបញ្ចុះក្នុងផ្នូរក្នុងអាយុវែងល្អ

«អ្នកនឹងចាស់ណាស់ពេលអ្នកស្លាប់ហើយគ្រួសារជាអ្នកបញ្ចុះសពអ្នក»

នៅក្នុងជំនាន់ទីបួន

នៅទីនេះជំនាន់មួយសំដៅទៅលើអាយុកាល ១០០ ឆ្នាំ។ «បន្ទាប់ពីបួនរយឆ្នាំ»

ពួកគេនឹងមកទីនេះម្តងទៀត

«កូនចៅរបស់អ្នកនឹងត្រឡប់មកទីនេះវិញ»
កូនចៅរបស់អ័ប្រាហាំនឹងមកដល់ទឹកដីដែលអាប់រ៉ាមរស់នៅ
ទឹកដីដែលព្រះអម្ចាស់បានសន្យាថានឹងប្រទានដល់គាត់។

នៅមិនទាន់ដល់កំរិតកំណត់នៅឡើយទេ

«មិនទាន់រួចរាល់ទេ» ឬ «នឹងកាន់តែអាក្រក់មុនពេលយើងដាក់ទោសពួកគេ»

ដ្បិតរហូតដល់ពេលនោះ

ព្រោះនឹងមានចំនួនច្រើន។

Genesis 15:17

មើល៍

ចំពោះពាក្យ «មើល៍»
នៅទីនេះដាស់តឿនយើងឱ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលមាននៅខាងក្រោម។

មានឆ្នាំងភ្លើងហុយផ្សែង ហើយនិងអណ្តាតភ្លើងឆេះនៅចន្លោះដុំសាច់ទាំងនោះ

ព្រះជាម្ចាស់បានធ្វើការនេះដើម្បីបង្ហាញដល់លោកអាប់រ៉ាមពីការដែលទ្រង់បានធ្វើពីការតាំងសញ្ញាជាមួយគ

នៅចន្លោះដុំសាច់ទាំងនោះ

«ឆ្លងកាត់ចន្លោះពីរជួរនៃបំណែកសត្វ»

ព្រះអម្ចាស់មានអំណាចផ្តល់ឱ្យលោកអាប់រ៉ាមនូវអ្វីដែលព្រះអង្គបានសន្យាជាមួយគាត់។

នៅក្នុងសម្ពន្ធមេត្រីនេះព្រះសន្យាថានឹងប្រទានពរដល់លោកអាប់រ៉ាមហើយទ្រង់នឹងបន្តប្រទានពរដល់គាត់

យើងនឹងប្រគល់ទឹកដីនេះ

តាមរយៈការនិយាយនេះ

ព្រះជាម្ចាស់កំពុងប្រទានទឹកដីដល់កូនចៅរបស់លោកអាប់រ៉ាម។ ព្រះកំពុងធ្វើដូច្នេះ

ប៉ុន្តែកូនចៅនឹងមិនចូលទៅក្នុងទឹកដីនោះទេរហូតដល់ច្រើនឆ្នាំក្រោយ។

ទន្លេដ៏អស្ចារ្យគឺទន្លេអឺប្រាត

«ទន្លេធំគឺទន្លេអឺប្រាត» ទាំងនេះគឺជាវិធីពីរយ៉ាងក្នុងការសំដៅទៅលើទន្លេតែមួយ។

ជនជាតិកែន ទឹកដីកេនីស៊ីត ទឹកដីកាត់ម៉ូនី ទឹកដីហេត ទឹកដីពេរិស៊ីត ទឹកដីរេផែម ទឹកដីអាម៉ូរី
ទឹកដីកាណាន ទឹកដីគើកាស៊ី និងទឹកដីយេប៊ូស

ទាំងនេះគឺជាឈ្មោះក្រុមមនុស្សដែលបានរស់នៅលើទឹកដីនោះ។

generated on Wed Sep 10 16:16:32 2025

ព្រះជាម្ចាស់នឹងអនុញ្ញាតឱ្យកូនចៅរបស់អប្រាហាំយកឈ្នះលើប្រជាជនទាំងនេះហើយកាន់កាប់ទឹកដីរបស់ពួកគេ។

16 [1]ឥឡូវនេះ នាងសារ៉ាយ ភរិយារបស់លោកអាប់រ៉ាម មិនបានបង្កើតកូនណាមួយឲ្យលោកអាប់រ៉ាមទេ ប៉ុន្តែ នាងមានអ្នកបម្រើស្រីម្នាក់ ជាជនជាតិអេស៊ីប
នាងឈ្មោះហាកា។[2]ដូច្នេះ នាងសារ៉ាយបានប្រាប់លោកអាប់រ៉ាមថា៖ «មើល៍ ព្រះអម្ចាស់បានបង្ខាំងខ្ញុំមិនឲ្យមានកូន។ ចូរទៅគេងជាមួយអ្នកបម្រើស្រីរបស់ខ្ញុំចុះ។
ខ្ញុំប្រហែលជាមានកូនដោយសារនាង»។ លោកអាប់រ៉ាមបានស្តាប់តាមសំដីរបស់នាងសារ៉ាយ។[3]ការនេះកើតឡើងបន្ទាប់ពីលោកអាប់រ៉ាមមករស់នៅទឹកដីកាណានដប់ឆ្នាំ
ដែលនាងសារ៉ាយភរិយារបស់លោកអាប់រ៉ាមប្រគល់នាងហាកា ជាអ្នកបម្រើស្រីរបស់នាង ទៅឲ្យស្វាមីរបស់នាងធ្វើជាភរិយា។[4]ដូច្នេះ លោកក៏បានរួមរស់ជាមួយនាងហាកា
ហើយនាងក៏មានផ្ទៃពោះ។ នៅពេលនាងឃើញថា នាងមានកូនដូច្នេះ នាងចាប់ផ្តើមមើលងាយម្ចាស់ស្រីរបស់នាង។
[5]បន្ទាប់មក នាងសារ៉ាយប្រាប់លោកអាប់រ៉ាមថា៖ «នេះជាកំហុសរបស់អ្នកគឺដោយសារតែបង។ អ្នកបានប្រគល់អ្នកបម្រើស្រីរបស់អ្នកទៅឲ្យបងឱប
ហើយនៅពេលនាងដឹងថា នាងមានផ្ទៃពោះ នាងបែរជាមើលងាយអ្នកទៅវិញ។ សូមឲ្យព្រះអម្ចាស់វិនិច្ឆ័យ រវាងអ្នកនិងបងចុះ»។[6]ប៉ុន្តែ
លោកអាប់រ៉ាមនិយាយទៅនាងសារ៉ាយថា៖ «មើល៍ អ្នកបម្រើស្រីរបស់អ្នកនៅក្នុងអំណាចរបស់អ្នកហើយ ចូរធ្វើតាមតែចិត្តអ្នកចុះ»។ ដូច្នេះ
នាងសារ៉ាយបានប្រព្រឹត្តនឹងនាងយ៉ាងគ្រោតគ្រាត ហើយនាងហាកាក៏រត់ចេញពីនាង។
[7]ទេវតារបស់ព្រះអម្ចាស់បានមកជួបនាងនៅក្បែរប្រភពទឹកមួយនៅទីរហោស្ថាន ប្រភពទឹកនោះនៅតាមផ្លូវទៅទឹកដីស៊ើរ។[8]លោកនិយាយនឹងនាងថា៖ «ហាកា
អ្នកបម្រើរបស់នាងសារ៉ាយអើយ តើអ្នកមកពីណា ហើយទៅណា?» បន្ទាប់មក នាងក៏តបថា៖ «នាងខ្ញុំរត់ចេញពីលោកស្រីសារ៉ាយម្ចាស់ស្រីរបស់ខ្ញុំ»។
[9]ទេវតារបស់ព្រះអម្ចាស់ប្រាប់ទៅនាងថា៖ «ចូរត្រឡប់ទៅម្ចាស់ស្រីរបស់អ្នកវិញចុះ ហើយចុះចូលនឹងសិទ្ធិអំណាចរបស់នាង»។[10]បន្ទាប់មក
ទេវតារបស់ព្រះអម្ចាស់និយាយទៅនាងថា៖ «យើងនឹងធ្វើឲ្យពូជពង្សរបស់នាងបានចម្រើនច្រើនឡើង គ្មាននរណាអាចរាប់បានឡើយ»។
[11]ទេវតារបស់ព្រះអម្ចាស់ក៏ប្រាប់ទៅនាងផងដែរថា៖ «មើល អ្នកមានផ្ទៃពោះ ហើយនាងនឹងបង្កើតបានកូនប្រុសមួយ ហើយអ្នកត្រូវដាក់ឈ្មោះថា អ៊ីស្មាអែល
ដោយសារព្រះអម្ចាស់បានឮទុក្ខលំបាករបស់នាង។[12]គាត់នឹងបានដូចជាសត្វលាព្រៃ។ គាត់នឹងវាយមនុស្សទាំងអស់ ហើយមនុស្សទាំងអស់នឹងវាយវាវិញ
ហើយវានឹងរស់នៅដោយឡែកពីបងប្អូនទាំងអស់របស់វា»។
[13]បន្ទាប់មក នាងបានថ្វាយព្រះនាមដល់ព្រះអម្ចាស់ដែលមានបន្ទូលជាមួយនាងថា៖ «ព្រះអង្គជាព្រះជាម្ចាស់ដែលទតឃើញខ្ញុំម្ចាស់» ដ្បិតនាងនិយាយថា៖
«តើខ្ញុំពិតជាមើលឃើញ សូម្បីតែព្រះអង្គបានទតឃើញខ្ញុំ»?[14]ដូច្នេះ អណ្តូងនោះត្រូវបានហៅថា អណ្តូងឡាហាយរយ មើល វាស្ថិតនៅចន្លោះភូមិកាដេស និងភូមិបារ៉ែដ។
[15]នាងហាកាបង្កើតបានកូនប្រុសមួយឲ្យលោកអាប់រ៉ាម ហើយលោកអាប់រ៉ាមបានដាក់ឈ្មោះកូនប្រុសរបស់គាត់ ដែលនាងហាកាបង្កើតនោះថា អ៊ីស្មាអែល។
[16]លោកអាប់រ៉ាមមានអាយុប៉ែតសិបប្រាំមួយឆ្នាំ ពេលនាងហាកាបង្កើតអ៊ីស្មាអែលដល់លោកអាប់រ៉ាម។

Genesis 16:1

ឥឡូវនេះ

ពាក្យនេះត្រូវបានប្រើជាភាសាអង់គ្លេសដើម្បីណែនាំផ្នែកថ្មីនៃសាច់រឿងនិងព័ត៌មានផ្ទៃខាងក្រោយសំខាន់ៗ។

អ្នកបម្រើស្រី

«ទាសកស្រី » អ្នកបម្រើប្រភេទនេះបម្រើស្ត្រីកិច្ចការក្នុងផ្ទះ។

ឲ្យមានកូន

«ពីការផ្តល់កំណើតដល់កុមារ»

ខ្ញុំប្រហែលជាមានកូនដោយសារនាង

«ខ្ញុំនឹងកសាងក្រុមគ្រួសាររបស់ខ្ញុំតាមរយៈនាង»

លោកអាប់រ៉ាមបានស្តាប់តាមសំដីរបស់នាងសារ៉ាយ

«លោកអាប់រ៉ាមបានធ្វើតាមអ្វីដែលសារ៉ាយបាននិយាយ»

នាងចាប់ផ្តើមមើលងាយម្ចាស់ស្រីរបស់នាង

«នាងមើលងាយម្ចាស់ស្រីរបស់នាង» ឬ
«នាងគិតថានាងមានតម្លៃច្រើនជាងម្ចាស់ស្រី»

ម្ចាស់ស្រីរបស់នាង

ត្រង់នេះគឺសំដៅទៅកាន់សារ៉ាយ។

គឺចៅហ្វាយមានអំណាចគ្រប់គ្រងទៅលើទាសកររបស់នាង។ការបកប្រែផ្សេងទៀត៖
«គាត់គឺជាម្ចាស់» ឬ«សារ៉ាយ»

Genesis 16:5

នេះជាកំហុសរបស់អូន

«នេះគឺអយុត្តិធម៌លើខ្ញុំ»

គឺដោយសារតែបង

«គឺជាទំនួលខុសត្រូវរបស់អ្នក» ឬ «គឺជាកំហុសរបស់អ្នក»

អូនបានប្រគល់អ្នកបម្រើស្រីរបស់អូនទៅឲ្យបងឱប

សារ៉ាយបានប្រើពាក្យ «ឱប»
នៅទីនេះដើម្បីសំដៅលើលោកអាប់រ៉ាមដេកជាមួយនាង។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំអោយអ្នកបម្រើរបស់ខ្ញុំអោយអ្នកគេងជាមួយនាង»

នាងបែរជាមើលងាយអូនទៅវិញ

នេះអាចសកម្ម។ ការបកប្រែផ្សេងទៀត៖ «នាងស្អប់ខ្ញុំ» ឬ «នាងចាប់ផ្តើមស្អប់ខ្ញុំ»
ឬ «នាងគិតថានាងប្រសើរជាងខ្ញុំ»

សូមឲ្យព្រះអម្ចាស់វិនិច្ឆ័យ រវាងអូននិងបងចុះ

«ខ្ញុំចង់អោយព្រះអម្ចាស់មានបន្ទូលថា តើនេះជាកំហុសរបស់អ្នក» ឬ
«ជាកំហុសរបស់អ្នកឬខ្ញុំចង់អោយព្រះអម្ចាស់សំរេចថាតើមួយណាត្រឹមត្រូវ?» ឃ្លា
«ដើម្បីវិនិច្ឆ័យរវាង»
មានន័យថាត្រូវសម្រេចចិត្តថាតើបុគ្គលណាម្នាក់ដែលមានជម្លោះនៅក្នុងជម្លោះរវាងពួកគេ។

មើល៍ នេះ

«ស្តាប់ខ្ញុំ» ឬ «យកចិត្តទុកដាក់»

«នៅក្រោមសិទ្ធិអំណាចរបស់អ្នក»

នាងសារ៉ាយបានប្រព្រឹត្តនឹងនាងយ៉ាងគ្រោតគ្រាត

«សារ៉ាយបានធ្វើបាបហាការយ៉ាងធ្ងន់ធ្ងរ»

ក៏រត់ចេញពីនាង

«ហើយហាការក៏បានរត់ចេញពីសារ៉ាយ»

Genesis 16:7

ទេវតារបស់ព្រះអម្ចាស់

អត្ថន័យអាចមានគឺ ១) ព្រះអម្ចាស់បានធ្វើខ្លួន ឲ្យ ដូចទេវតាឬ ២)
នេះគឺជាទេវតារបស់ព្រះអម្ចាស់ ឬ ៣)
នេះគឺជាអ្នកនាំសារពិសេសមកពីព្រះជាម្ចាស់ (អ្នកសិក្សាខ្លះគិតថាជាព្រះយេស៊ូ) ។
ដោយសារឃ្លាមិនត្រូវបានយល់ច្បាស់វាជាការល្អបំផុតដើម្បីបកប្រែជា
«ទេវតារបស់ព្រះអម្ចាស់» ដោយប្រើពាក្យធម្មតាដែលអ្នកប្រើសម្រាប់ «ទេវតា»។

ទីរហោស្ថាន

តំបន់វាលរហោស្ថានដែលនាងបានទៅគឺវាលខ្សាច់។ ការបកប្រែផ្សេងទៀត៖
«វាលខ្សាច់»

ទឹកដីស៊ើរ

នេះជាឈ្មោះទីកន្លែងខាងត្បូងនៃស្រុកកាណាននិងខាងកើតនៃស្រុកអេស៊ីប។

ម្ចាស់ស្រីរបស់ខ្ញុំ

ត្រង់នេះសំដៅទៅលើលោកស្រីសារ៉ាយ។
ម្ចាស់ស្រីមានសិទ្ធិអំណាចលើខ្ញុំបម្រើរបស់នាង។ ការបកប្រែផ្សេងទៀត៖
«ម្ចាស់របស់ខ្ញុំ»។ សូមមើលពីរបៀបដែល «ម្ចាស់ស្រីរបស់នាង»
ត្រូវបានបកប្រែនៅក្នុង ១៦: ១ ។

Genesis 16:9

ទេវតារបស់ព្រះអម្ចាស់ប្រាប់ទៅនាងថា

«ទេវតានៃព្រះជាម្ចាស់បាននិយាយទៅកាន់នាងហាការ»

ទេវតារបស់ព្រះអម្ចាស់

សូមមើលឃ្លានេះនៅក្នុង១៦:៧

ម្ចាស់ស្រីរបស់អ្នក

លោកស្រីសារ៉ាយ។ «ម្ចាស់ស្រីរបស់នាង» សូមមើលក្នុង ១៦: ១

ទេវតារបស់ព្រះអម្ចាស់និយាយទៅនាងថាយើង

នៅពេលដែលគាត់និយាយថា« យើង» គាត់កំពុងសំដៅទៅលើព្រះអម្ចាស់។
នៅពេលបកប្រែអ្វីដែលមាននៅក្នុងពាក្យដកស្រង់ចូរធ្វើដូចទេវតារបស់ព្រះអម្ចាស់បានធ្វើនិងប្រើពាក្យ

generated on Wed Sep 10 16:16:32 2025

«យើង» នៅពេលនិយាយដល់ព្រះអម្ចាស់។
យើងនឹងធ្វើឲ្យពូជពង្សរបស់នាងបានចម្រើនច្រើនឡើង
«យើងនឹងផ្តល់ឱ្យអ្នកនូវកូនចៅជាច្រើន»
យើងនឹងផ្តល់ឱ្យអ្នកនូវកូនចៅជាច្រើន
«ច្រើនណាស់ដែលគ្មាននរណាម្នាក់អាចរាប់ពួកគេបាន»
Genesis 16:11
ទេវតារបស់ព្រះអម្ចាស់
សូមមើលឃ្លានេះនៅក្នុង១៦:៧
មើល
«មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់»
បង្កើតបានកូនប្រុសមួយ
«បង្កើតបានកូនប្រុសមួយៗ»
ហើយអ្នកត្រូវដាក់ឈ្មោះថា
«អ្នក និង ដាក់ឈ្មោះគាត់ថា» ពាក្យ«អ្នក»គឺសំដៅទៅកាន់នាងហាការ។
អ៊ីស្មាអែល ដោយសារព្រះអម្ចាស់បានឮ
ឈ្មោះ «អ៊ីស្មាអែល» មានន័យថា «ព្រះជាម្ចាស់បានឮ»។
ទុក្ខលំបាក
នាងត្រូវបានរងទុក្ខដោយទុក្ខព្រួយ និង ទុក្ខវេទនា។
គាត់នឹងបានដូចជាសត្វលាព្រៃ
នេះមិនមែនជាការប្រមាថទេ។
វាអាចមានន័យថាអ៊ីស្មាអែលនឹងមានឯករាជ្យនិងរឹងមាំដូចសត្វលាព្រៃ។
ការបកប្រែផ្សេងទៀត៖ «គាត់នឹងដូចជាសត្វលាព្រៃក្នុងចំណោមមនុស្ស»
គាត់នឹងរាយមនុស្សទាំងអស់
«គាត់នឹងក្លាយជាសត្រូវរបស់មនុស្សគ្រប់គ្នា»
ហើយមនុស្សទាំងអស់នឹងរាយវាវិញ
«មនុស្សគ្រប់គ្នានឹងក្លាយជាសត្រូវរបស់គាត់»
ហើយវានឹងរស់នៅដោយឡែកពី
នេះក៏អាចមានន័យថា «គាត់នឹងរស់នៅក្នុងអរិភាពជាមួយ»។
បងប្អូន
«សាច់ញាតិ» ឬ «ញាតិ»
Genesis 16:13
ព្រះអម្ចាស់ដែលមានបន្ទូលជាមួយនាង
«ព្រះជាម្ចាស់ពីព្រោះទ្រង់បានមានបន្ទូលទៅនាង»
តើខ្ញុំពិតជាមើលឃើញ ,.....ខ្ញុំ?
ហាការបានប្រើសំណួរនេះដើម្បីសម្តែងការងឿងឆ្ងល់ថានាងនៅតែមានជីវិត
សូម្បីតែបន្ទាប់ពីនាងបានជួបព្រះជាម្ចាស់។
ប្រជាជនរំពឹងថាប្រសិនបើពួកគេបានជួបព្រះជាម្ចាស់ ពួកគេនឹងស្លាប់។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំពិតជាភ្ញាក់ផ្អើលដែលខ្ញុំនៅរស់ ... ខ្ញុំ»។
ដូច្នេះ អណ្តូងនោះត្រូវបានហៅថា អណ្តូងឡាហាយរយ
ឡាហាយរយ មានន័យថា «មានអណ្តូងទឹករស់មួយដែលបានឃើញខ្ញុំ»។
មើល វាស្ថិតនៅចន្លោះភូមិកាដេស និងភូមិបារ៉ែដ
ពាក្យថា «មើល»
នៅទីនេះទាញចំណាប់អារម្មណ៍ពីការពិតដែលថាអណ្តូងទឹកស្ថិតនៅកន្លែងដែលអ្នកនិពន្ធនិងអ្នកអានរប
ការបកប្រែផ្សេងទៀត៖ «តាមពិតវាស្ថិតនៅចន្លោះកាដេសនិងបារ៉ែដ»
Genesis 16:15
នាងហាកាបង្កើតបានកូន
ហាការបានវិលត្រឡប់កាន់ទៅលោកស្រីសារ៉ាយ និងលោកអាប់រ៉ាម
គឺបញ្ជាក់យ៉ាងច្បាស់។ អ្នកអាចធ្វើឱ្យវាកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះហាការបានត្រឡប់មកវិញហើយផ្តល់កំណើត»
ដាក់ឈ្មោះកូនប្រុសរបស់គាត់, ដែលនាងហាកាបង្កើតនោះ
«ដាក់ឈ្មោះកូនប្រុសរបស់គាត់ដោយហាការ» ឬ «ដាក់ឈ្មោះគាត់
និងកូនប្រុសរបស់ហាការ»
លោកអាប់រ៉ាមបាន
នេះណែនាំពីប្រវត្តិអាយុរបស់អាប់រ៉ាមនៅពេលដែលរឿងទាំងនេះបានកើតឡើង។
បង្កើតបានកូនប្រុសមួយឲ្យលោកអាប់រ៉ាម
នេះមានន័យថា «បានបង្កើតកូនប្រុសអោយលោកអាប់រ៉ាម គឺអ៊ីស្មាអែល»
ការយកចិត្តទុកដាក់គឺលោកអាប់រ៉ាមមានកូនប្រុស។

---

17 [1]ពេលលោកអាប់រ៉ាមមានអាយុកៅសិបប្រាំបួនឆ្នាំ ព្រះអម្ចាស់បានយាងមកជួបលោក ហើយមានបន្ទូលទៅគាត់ថា៖ «យើងគឺជាព្រះអម្ចាស់ដ៏មានព្រះចេស្តា។
[2]ចូរដើរនៅចំពោះយើង ហើយឲ្យបានគ្រប់លក្ខណ៍ចុះ។ បន្ទាប់មក យើងនឹងចងសម្ពន្ធមេត្រីរវាងយើងនិងអ្នក
ហើយយើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកបានកើតចំនួនច្រើនឡើង»។
[3]លោកអាប់រ៉ាមបានក្រាបមុខដល់ដី ហើយព្រះជាម្ចាស់មានបន្ទូលជាមួយគាត់ថា៖[4]«ចំណែកយើង មើល យើងនឹងចងសម្ពន្ធមេត្រីជាមួយអ្នក។
អ្នកនឹងក្លាយជាឪពុកនៃប្រជាជាតិជាច្រើន។[5]ឈ្មោះរបស់អ្នកលែងជាអាប់រ៉ាមទៀតហើយ ប៉ុន្តែ ឈ្មោះរបស់អ្នកនឹងទៅជាអប្រាហាំវិញ ដ្បិត យើងបានរើសតាំងអ្នក
ដើម្បីឲ្យធ្វើជាឪពុកនៃប្រជាជាតិជាច្រើន។[6]យើងនឹងធ្វើឲ្យអ្នកបានចម្រុងចម្រើនឡើង ហើយយើងនឹងធ្វើឲ្យអ្នកក្លាយជាប្រជាជាតិជាច្រើន ហើយស្តេចនឹងកើតចេញពីអ្នក។
[7]យើងនឹងចងសម្ពន្ធមេត្រីរបស់យើង រវាងយើងនិងអ្នក ព្រមទាំងជាមួយពូជពង្សរបស់អ្នកដែលមកតាមក្រោយអ្នក គ្រប់ទាំងតំណរតទៅ ដ្បិត សម្ពន្ធមេត្រីនេះស្ថិតស្ថេរ
នៅអស់កល្បជានិច្ច ឲ្យយើងបានធ្វើជាព្រះជាម្ចាស់របស់អ្នក និងពូជពង្សដែលនៅក្រោយអ្នក។[8]យើងនឹងប្រគល់ទឹកដីដែលអ្នកកំពុងរស់នៅនេះ ដល់អ្នក
និងដល់កូនចៅបន្ទាប់ពីអ្នក គឺទឹកដីកាណានទាំងអស់ សម្រាប់ជាសម្បត្តិដ៏នៅអស់កល្បជានិច្ច ហើយយើងនឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ»។
[9]បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលមកលោកអ័ប្រាហាំថា៖ «ចំណែកអ្នកវិញ អ្នកត្រូវកាន់តាមសម្ពន្ធមេត្រីរបស់យើង អ្នកនិងកូនចៅនៅបន្ទាប់ពីអ្នក
និងគ្រប់ទាំងតំណរបស់ពួកគេតទៅ។[10]នេះគឺជាសម្ពន្ធមេត្រីរបស់យើង ដែលអ្នកត្រូវកាន់តាម រវាងយើង និងអ្នក ព្រមទាំងពូជពង្សនៅបន្ទាប់ពីអ្នក
អ្នកត្រូវកាត់ស្បែកភេទប្រុសដែលនៅក្នុងចំណោមអ្នកទាំងអស់។[11]អ្នកត្រូវកាត់ស្បែកចុងលឹង្គរបស់មនុស្សទាំងអស់ ហើយនេះគឺជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីរវាងយើង
និងអ្នក។
[12]គ្រប់ទាំងភេទប្រុសទាំងអស់នៅក្នុងចំណោមអ្នកដែលមានអាយុប្រាំបីថ្ងៃ គឺមនុស្សគ្រប់ទាំងតំណរបស់អ្នក។ ការនេះ បូករួមទាំងអស់អ្នកដែលបានកើតនៅក្នុងគ្រួសារ
និងអស់អ្នកដែលបានទិញពីសាសន៍ដទៃដែលមិនមែនជាពូជពង្សរបស់អ្នក។[13]អស់អ្នកដែលកើតមកនៅក្នុងគ្រួសាររបស់អ្នក
និងអស់អ្នកដែលអ្នកបានទិញត្រូវតែកាត់ស្បែក។ ដូច្នេះ សម្ពន្ធមេត្រីរបស់យើងនឹងចងជាមួយអ្នក ដ្បិត សម្ពន្ធមេត្រីនេះ ស្ថិតស្ថេរនៅអស់កល្បជានិច្ច។[14]ប្រសិនបើ
បុរសមិនកាត់ស្បែកណាដែលមិនបានកាត់ស្បែកខាងសាច់ឈាម ចុងលឹង្គរបស់គាត់ទេ ចូរកាត់កាល់គាត់ចេញពីមនុស្សរបស់គាត់ទៅ។
គាត់បានបំបែកសម្ពន្ធមេត្រីរបស់យើង»។
[15]ព្រះជាម្ចាស់មានបន្ទូលមកលោកអ័ប្រាហាំថា៖ «ចំណែក នាងសារ៉ាយ ភរិយារបស់អ្នក កុំហៅនាងថាសារ៉ាយទៀត។ ផ្ទុយទៅវិញ ត្រូវហៅនាងថាសារ៉ាវិញ។
[16]យើងនឹងឲ្យពរដល់នាង ហើយយើងនឹងឲ្យកូនប្រុសមួយដល់នាង។ យើងនឹងឲ្យពរដល់នាង ហើយនាងនឹងក្លាយជាម្តាយនៃប្រជាជាតិជាច្រើន ស្តេចរបស់ប្រជារាស្ត្រ
នឹងកើតចេញមកពីនាង»។
[17]ពេលនោះ លោកអប្រាហាំបានក្រាបចុះ ឱនមុខទៅដី ហើយបានសើច ហើយគាត់និយាយនៅក្នុងចិត្តរបស់គាត់ថា៖ «តើមនុស្សមានអាយុមួយរយឆ្នាំហើយ
អាចមានកូនបានដែរឬ? តើនាងសារ៉ា ដែលមានអាយុកៅសិបឆ្នាំហើយ អាចមានកូនបានដែរឬ?»[18]លោកអប្រាហាំទូលទៅព្រះជាម្ចាស់ថា៖ «ព្រះអង្គអើយ
សូមឲ្យអ៊ីស្មាអែលបានរស់នៅចំពោះព្រះអង្គទៅបានហើយ!»។
[19]ព្រះជាម្ចាស់មានបន្ទូលថា៖ «អត់ទេ គឺសារ៉ា ភរិយារបស់អ្នកទេ ដែលបង្កើតកូនប្រុសនោះ ហើយអ្នកត្រូវដាក់ឈ្មោះថា អ៊ីសាក។ យើងនឹងចងសម្ពន្ធមេត្រីជាមួយកូននោះ
ជាសម្ពន្ធមេត្រីដ៏នូវអស់កល្បជានិច្ចជាមួយនឹងពូជពង្សបន្ទាប់ពីគាត់ដែរ។[20]ចំណែកអ៊ីស្មាអែលវិញ យើងបានឮអ្នក។ មើល៍ យើងនឹងឲ្យពរដល់គាត់
ហើយនឹងធ្វើឲ្យគាត់បង្កើតផល ហើយបានចម្រើនច្រើនឡើងជាបរិបូរ។ គាត់នឹងធ្វើជាឪពុកនៃអ្នកដឹកនាំកុលសម្ពន្ធទាំងដប់ពីរ
ហើយយើងនឹងធ្វើឲ្យគាត់ក្លាយជាប្រជាជាតិមួយដ៏ធំ។[21]ប៉ុន្តែ សម្ពន្ធមេត្រីដែលយើងនឹងចងជាមួយអ៊ីសាក ជាកូនដែលសារ៉ាបានបង្កើតដល់អ្នកនៅឆ្នាំក្រោយនេះ»។

generated on Wed Sep 10 16:16:32 2025

[22]នៅពេលព្រះអង្គមានបន្ទូលជាមួយលោកចប់ ព្រះជាម្ចាស់យាងចេញពីលោកអប្រាហាំ។[23]បន្ទាប់មក លោកអប្រាហាំបានយកអ៊ីស្មាអែលកូនប្រុសរបស់គាត់
និងអស់អ្នកដែលបានកើតនៅក្នុងគ្រួសាររបស់គាត់ទាំងអស់ ព្រមទាំងអស់ដែលបានទិញដោយលុយ និងគ្រប់ទាំងប្រុសៗនៅក្នុងគ្រួសាររបស់លោកអប្រាហាំទាំងអស់
មកកាត់ស្បែកចុងលឹង្គនៅថ្ងៃតែមួយនោះឯង ដូចព្រះជាម្ចាស់បានមានបន្ទូលទៅគាត់។
[24]លោកអប្រាហាំមានអាយុកៅសិបប្រាំបួនឆ្នាំ នៅពេលលោកកាត់ស្បែកចុងលឹង្គរបស់គាត់។[25]អ៊ីស្មាអែលកូនប្រុសរបស់កាត់មានអាយុដប់បីឆ្នាំ
ពេលគាត់កាត់ស្បែកចុងលឹង្គរបស់គាត់។[26]នៅថ្ងៃដដែលនោះ លោកអប្រាហាំ និងអ៊ីស្មាអែលកូនប្រុសរបស់គាត់កាត់ស្បែកទាំងពីរនាក់។
[27]ប្រុសៗទាំងអស់នៅក្នុងគ្រួសាររបស់គាត់ត្រូវបានកាត់ស្បែកជាមួយគាត់ រួមទាំងអស់អ្នកដែលកើតនៅក្នុងគ្រួសាររបស់គាត់
និងអស់អ្នកដែលបានទិញដោយលុយពីជនបរទេស។

Genesis 17:1
ពេលលោកអាប់រ៉ាមមានអាយុកៅសិបប្រាំបួនឆ្នាំ
អាយុប្រាំបួនឆ្នាំ -
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ព្រះអម្ចាស់ដ៏មានព្រះចេស្តា
«ព្រះជាម្ចាស់ដែលមានគ្រប់ព្រះជាម្ចាស់ចេស្តា»ឬ«ព្រះជាម្ចាស់ដែលមានអំណាចទាំងអស់»
ដើរនៅចំពោះយើង
ការដើរគឺជាពាក្យប្រៀបធៀបសម្រាប់ការរស់នៅហើយ «មុខយើង» ឬ
«នៅចំពោះមុខយើង» នៅទីនេះគឺជាពាក្យប្រៀបធៀបសម្រាប់ការគោរពប្រតិបត្តិ។
ការបកប្រែផ្សេងទៀត៖ «រស់នៅតាមរបៀបដែលយើងចង់អោយអ្នក» ឬ
«គោរពយើង»
បន្ទាប់មកយើងនិងបញ្ជាក់
«ប្រសិនបើអ្នកធ្វើនេះ បន្ទាប់មកយើងនិងបញ្ជាក់»
បន្ទាប់មក យើងនឹងចងសម្ពន្ធមេត្រី
«យើងនិងអោយសេចក្តីសម្ព័ន្ធមេត្រី» ឬ «យើងនិងបង្កើតសម្ព័ន្ធមេត្រី»
សម្ពន្ធមេត្រី
នៅក្នុងការតាំងសម្ពន្ធមេត្រីនេះព្រះសន្យាថានឹងប្រទានពរដល់លោកអាប់រ៉ាម
ប៉ុន្តែទ្រង់ក៏តម្រូវឱ្យលោកអាប់រ៉ាមស្តាប់បង្គាប់ទ្រង់ដែរ។
ធ្វើឲ្យពូជពង្សរបស់អ្នកបានកើតចំនួនច្រើនឡើង
«បង្កើនចំនួនកូនចៅរបស់អ្នក» ឬ «ផ្តល់ឱ្យអ្នកមាននូវកូនចៅជាច្រើន»
Genesis 17:3
លោកអាប់រ៉ាមបានក្រាបមុខដល់ដី
«លោកអាប់រ៉ាមក្រាបមុខចុះដល់ដី»ឬ«អប្រាហាំក៏ក្រាបមុខគាត់ចុះដល់ដីភ្លាម»។
គាត់បានធ្វើដូច្នេះដើម្បីបង្ហាញថាគាត់គោរពព្រះហើយនឹងធ្វើតាមព្រះ។
ចំណែកយើង
ព្រះជាម្ចាស់បានប្រើឃ្លានេះដើម្បីបង្ហាញពីអ្វីដែលគាត់នឹងធ្វើចំពោះអាប់រ៉ាមដែលជាផ្នែកនៃការតាំងសម្ពន្ធមេត្រីរបស់ទ្រង់
មើល យើងនឹងចងសម្ពន្ធមេត្រីជាមួយអ្នក
ពាក្យថា « មើល»
នៅទីនេះនិយាយថាអ្វីដែលនឹងកើតឡើងបន្ទាប់គឺប្រាកដណាស់ថា
«ការតាំងសម្ពន្ធមេត្រីរបស់យើងពិតជានៅជាមួយអ្នកមែន» ។
ឪពុកនៃប្រជាជាតិជាច្រើន
«ឪពុកនៃប្រជាជាតិជាច្រើន» ឬ
«ប្រទេសមួយដែលប្រទេសជាច្រើនដាក់ឈ្មោះខ្លួនឯង»
អប្រាហាំ
ឈ្មោះ «អាប់រ៉ាម» មានន័យថា «ឪពុកដែលលើកតម្កើង» ហើយឈ្មោះ
«អប្រាហាំ» ស្តាប់ទៅដូចជា «ឪពុករបស់ហ្វូងមនុស្ស» ។
យើងនឹងធ្វើឲ្យអ្នកបានចម្រុងចម្រើនឡើង
«យើងនឹងធ្វើអោយអ្នកមានកូនចៅជាច្រើន»
យើងនឹងធ្វើឲ្យអ្នកក្លាយជាប្រជាជាតិជាច្រើន
«យើងនឹងធ្វើអោយកូនចៅរបស់អ្នកក្លាយទៅជាប្រជាជាតិនានា»
ស្តេចនឹងកើតចេញពីអ្នក
«ក្នុងចំណោមកូនចៅរបស់អ្នកនឹងមានស្តេច» ឬ
«កូនចៅខ្លះរបស់អ្នកនឹងក្លាយជាស្តេច»
Genesis 17:7
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអប្រាហាំ។
ព្រមទាំងជាមួយពូជពង្សរបស់អ្នក
«សម្រាប់គ្រប់ជំនាន់គេនីមួយៗ»
សម្ពន្ធមេត្រីនេះស្ថិតស្ថេរនៅអស់កល្បជានិច្ច
«ជាការតាំងសម្ពន្ធមេត្រីដែលនឹងស្ថិតស្ថេរជារៀងរហូត»
ធ្វើជាព្រះជាម្ចាស់របស់អ្នក និងពូជពង្សដែលនៅក្រោយអ្នក
«ធ្វើជាព្រះជាម្ចាស់របស់អ្នកនិងជាព្រះជាម្ចាស់របស់ពូជពង្សអ្នក» ឬ«
ការតាំងសម្ពន្ធមេត្រី»
ទឹកដីកាណានទាំងអស់ សម្រាប់ជាសម្បត្តិដ៏នៅអស់កល្បជានិច្ច
«កាណានជាសម្បត្តិដែលស្ថិតស្ថេរ» ឬ«កាណានសម្បត្តិជារៀងរហូត»
Genesis 17:9
ចំណែកអ្នកវិញ
ព្រះជាម្ចាស់ប្រើឃ្លានេះដើម្បីបង្ហាញនូវអ្វីដែលលោកអាប់រ៉ាមនឹងត្រូវធ្វើដែលជាផ្នែកនៃការតាំងសម្ពន្ធមេត្រ
ត្រូវកាន់តាមសម្ពន្ធមេត្រីរបស់យើង
« គោរពតាមសេចក្តីសញ្ញារបស់យើង» ឬ« គោរពសេចក្តីសញ្ញារបស់យើង» ឬ«
ស្តាប់តាមសេចក្តីសញ្ញារបស់យើង»
នេះគឺជាសម្ពន្ធមេត្រីរបស់យើង
«នេះគឺជាតម្រូវការនៃសម្ពន្ធមេត្រីរបស់យើង» ឬ
«នេះគឺជាផ្នែកនៃការតាំងសម្ពន្ធមេត្រីរបស់យើង»
ប្រយោគនេះណែនាំពីផ្នែកនៃសម្ពន្ធមេត្រីដែលលោកអាប់រ៉ាមត្រូវធ្វើ។
នៅក្នុងចំណោមអ្នកទាំងអស់ត្រូវកាត់ស្បែក
ការបកប្រែផ្សេងទៀត៖ «អ្នករាល់គ្នាត្រូវកាត់ស្បែកប្រុសៗក្នុងចំណោមអ្នករាល់គ្នា»
មនុស្សប្រុសទាំងអស់
នេះគឺសំដៅទៅកាន់មនុស្សប្រុសទាំងអស់។
អ្នកត្រូវកាត់ស្បែកភេទប្រុសដែលនៅក្នុងចំណោមអ្នកទាំងអស់
សហគមន៍ខ្លះអាចចូលចិត្តការបញ្ចេញមតិដែលមិនសូវពិពណ៌នាដូចជា
«អ្នកត្រូវតែកាត់ស្បែក» ។ ប្រសិនបើការបកប្រែ «កាត់ស្បែក»
របស់អ្នករួមបញ្ចូលពាក្យ «ស្បែកគ្របក្បាលលិង្គ»
រួចហើយអ្នកមិនចាំបាច់និយាយម្តងទៀតទេ។ ការបកប្រែផ្សេងទៀត៖
«អ្នករាល់គ្នាត្រូវកាត់ស្បែកប្រុសៗក្នុងចំណោមអ្នករាល់គ្នា»
[illegible]
មើល
«សញ្ញាដែលបង្ហាញថាមានការតាំងសម្ពន្ធមេត្រី»
សញ្ញាសម្គាល់
អត្ថន័យគទី ១) «សញ្ញា» ឬ ២) «សញ្ញា»។
ទីមួយមានន័យថាមានសញ្ញាសំគាល់មួយហើយទី ២
មានន័យថាអាចមានសញ្ញាសំគាល់ច្រើនជាងមួយ។ ត្រង់នេះពាក្យ
«សញ្ញាសំគាល់» មានន័យថាជាការរម្លឹកពីអ្វីមួយដែលព្រះជាម្ចាស់បានសន្យា។
Genesis 17:12
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអប្រាហាំ។
គ្រប់ទាំងភេទប្រុសទាំងអស់
«គឺសំដៅទៅលើបុរសទាំងអស់»
គឺមនុស្សគ្រប់ទាំងតំណរបស់អ្នក
«គឺគ្រប់តំណរទាំងអស់»
អស់អ្នកដែលបានទិញ
នេះគឺសំដៅទៅលើទាសករ។ ការបកប្រែផ្សេងទៀត៖
«គឺគ្រប់ទាំងមនុស្សដែលឯងបានទិញ»
សម្ពន្ធមេត្រីរបស់យើងនឹងចងជាមួយអ្នក
ការបកប្រែផ្សេងទៀត៖
«អ្នកនិងសំគាល់សម្ពន្ធមេត្រីរបស់យើងនៅក្នុងខ្លួនរបស់អ្នក»
សម្ពន្ធមេត្រីនេះ ស្ថិតស្ថេរនៅអស់កល្បជានិច្ច
«ជាការតាំងសម្ពន្ធមេត្រីអចិន្ត្រៃយ៍»
ដោយសារតែវាត្រូវបានសម្គាល់នៅក្នុងសាច់ឈាមគ្មាននរណាម្នាក់អាចលុបបំបាត់វាបានយ៉ាងងាយស្រួល
បុរសមិនកាត់ស្បែកណាដែលមិនបានកាត់ស្បែក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម

generated on Wed Sep 10 16:16:32 2025

ហើយអ្នកអាចទុកពាក្យដែលនឹងផ្តល់អត្ថន័យមិនត្រឹមត្រូវនៅក្នុងភាសារបស់អ្នក។
ការបកប្រែផ្សេងទៀត៖ «បុរសដែលអ្នកមិនបានកាត់ស្បែក»
ប្រសិនបើ បុរសមិនកាត់ស្បែកណា.....ចុងលឹង្ករបស់គាត់ទេ ចូរកាត់កាលគាត់ចេញពីមនុស្ស
អត្ថន័យដែលមានគឺ ១) « ខ្ញុំនឹងកាត់បុរសដែលកាត់ស្បែក ចេញពីមនុស្ស» ឬ
២)« ខ្ញុំចង់ឲ្យ អ្នកកាត់បុរសដែលកាត់ស្បែកចេញពីមនុស្សរបស់គាត់»
កាត់កាល់គាត់ចេញពីមនុស្សរបស់គាត់
អត្ថន័យដែលអាចមានគឺ ១)« សម្លាប់» ឬ
២)«ត្រូវបានគេបញ្ជូនទៅឆ្ងាយពីសហគមន៍» (សូមមើល:figs-euphemism)
គាត់បានបំបែកសម្ពន្ធមេត្រីរបស់យើង
«គាត់មិនបានគោរពតាមច្បាប់នៃសម្ពន្ធមេត្រីរបស់យើងទេ»
នេះជាហេតុផលដែលគាត់នឹងត្រូវកាត់ចេញពីប្រជាជនរបស់គាត់។
Genesis 17:15
ចំណែក នាងសារ៉ាយ
ពាក្យ«ចំណែក» ជាសេចក្តីណែនាំពីបុគ្គលម្នាក់ទៀតដែលព្រះនិងនិយាយអំពី។
យើងនឹងឲ្យកូនប្រុសមួយដល់នាង
«យើងនិងបង្កើតកូនប្រុសមួយសម្រាប់អ្នក»
ហើយនាងនឹងក្លាយជាម្តាយនៃប្រជាជាតិជាច្រើន
«នាងនឹងក្លាយជាបុព្វបុរសនៃប្រជាជាតិជាច្រើន» ឬ
«កូនចៅរបស់នាងនឹងក្លាយជាប្រជាជាតិជាច្រើន»
ស្តេចរបស់ប្រជារាស្ត្រ នឹងកើតចេញមកពីនាង
«ស្តេចនៃប្រជាជននឹងចុះមកពីនាង» ឬ
«កូនចៅខ្លះរបស់នាងនឹងក្លាយជាស្តេចរបស់ប្រជាជនជាច្រើន»
Genesis 17:17
គាត់និយាយនៅក្នុងចិត្តរបស់គាត់
«គិតដោយខ្លួនឯង» ឬ «និយាយទៅកាន់ខ្លួនឯងដោយស្ងាត់ស្ងៀម»
តើមនុស្សមានអាយុមួយរយឆ្នាំហើយ អាចមានកូនបានដែរឬ
អ្រាហាំបានប្រើសំណួរនេះពីព្រោះគាត់មិនជឿថារឿងនេះអាចកើតឡើងទេ។
ការបកប្រែផ្សេងទៀត៖
«ប្រាកដណាស់បុរសដែលមានអាយុមួយរយឆ្នាំមិនអាចមានកូនបានទេ!»
តើនាងសារ៉ាដែលមានអាយុកៅសិបឆ្នាំហើយ អាចមានកូនបានដែរឬ?
ជាថ្មីម្តងទៀតលោកអ្រាហាំបានប្រើសំណួរពាក្យនេះពីព្រោះគាត់មិនជឿថារឿងនេះអាចកើតឡើងបាន។
ឃ្លាដែលថា «មានអាយុកៅសិបឆ្នាំ»
ប្រាប់ពីមូលហេតុដែលអ្រាហាំមិនជឿថាលោកស្រីសារ៉ាអាចបង្កើតកូនប្រុសបាន?
« ការបកប្រែផ្សេងទៀត៖
«លោកស្រីសារ៉ាមានអាយុកៅសិបឆ្នាំហើយតើនាងអាចបង្កើតកូនប្រុសបានទេ?»
ឬ «លោកស្រីសារ៉ាមានអាយុកៅសិបឆ្នាំ។
ពិតជាមិនអាចបង្កើតបានកូនប្រុសមួយទេ!»
សូមឲ្យអ៊ីស្មាអែលបានរស់នៅចំពោះព្រះអង្គ
«សូមឱ្យអ៊ីស្មាអែលទទួលមរតកសម្ពន្ធមេត្រីដែលទ្រង់បានធ្វើជាមួយខ្ញុំ» ឬ
«ប្រហែលជាអ៊ីសម៉ាអែលអាចទទួលបានពរជ័យនៃសម្ពន្ធមេត្រីរបស់ទ្រង់»
លោកអ្រាហាំបានស្នើអ្វីមួយដែលគាត់ជឿថាពិតជាអាចកើតឡើងរួចហើយ។

Genesis 17:19
អត់ទេ គឺសារ៉ា ភរិយារបស់អ្នកទេ ដែលបង្កើត
ព្រះជាម្ចាស់មានបន្ទូលដូច្នេះដើម្បីកែជំនឿលោកអ្រាហាំ
ដែលគាត់ថាលោស្រីសារ៉ាអាចបង្កើតកូនបាន។
ហើយអ្នកត្រូវដាក់ឈ្មោះ
ពាក្យ«លោក»គឺសំដៅទៅលោកអ្រាហាំ។
ចំណែកអ៊ីស្មាអែល
ពាក្យ «ចំណែក»
បង្ហាញថាព្រះកំពុងប្តូរពីការនិយាយអំពីទារកដែលនឹងកើតមកដើម្បីនិយាយអំពីអ៊ីស្មាអែលវិញ។
មើល៍
«មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលទ្រង់រៀបនឹងប្រាប់អ្នក»
ហើយនឹងធ្វើឲ្យគាត់បង្កើតផល
នេះគឺជាសំណួរពាក្យដែលមានន័យថា «នឹងធ្វើឱ្យគាត់មានកូនច្រើន»
ហើយបានចម្រើនច្រើនឡើងជាបរិបូរ
«យើងនឹងធ្វើអោយគាត់មានកូនចៅជាច្រើន»
អ្នកដឹកនាំកុលសម្ពន្ធ
«ប្រធាន» ឬ «អ្នកគ្រប់គ្រង» ។
មេដឹកនាំទាំងនេះមិនមែនជាកូនប្រុសនិងចៅប្រុសរបស់យ៉ាកុបដែលនឹងដឹកនាំកុលសម្ព័ន្ធអ៊ីស្រាអែលទាំង
ប៉ុន្តែ សម្ពន្ធមេត្រីដែលយើងនឹងចងជាមួយអ៊ីសាក
ព្រះជាម្ចាស់វិលត្រឡប់មកនិយាយអំពីសម្ពន្ធមេត្រីរបស់លោកជាមួយលោកអ័ប្រាហាំវិញ
ហើយបញ្ជាក់ថាលោកនឹងបំពេញតាមការសន្យារបស់លោកជាមួយអ៊ីសាកមិនមែនជាមួយអ៊ីសម៉ាអែលទេ
Genesis 17:22
នៅពេលព្រះអង្គមានបន្ទូលជាមួយគាត់ចប់
«នៅពេលដែលព្រះជាម្ចាស់បានមានបន្ទូលជាមួយលោកអ្រាហាំចប់។
ព្រះជាម្ចាស់យាងចេញពីលោកអ្រាហាំ
«ព្រះជាម្ចាស់បានយាងចេញពីលោកអ្រាហាំ»
គ្រប់ទាំងប្រុសៗនៅក្នុងគ្រួសាររបស់លោកអ្រាហាំទាំងអស់
«មនុស្សប្រុសៗទាំងអស់នៅក្នុងគ្រួសាររបស់លោកអ្រាហាំ» ឬ
«មនុស្សប្រុសៗទាំងអស់នៅក្នុងគ្រួសាររបស់លោកអ្រាហាំ» ។
គឺសំដៅទៅលើមនុស្សគ្រប់វ័យ: ទារក ក្មេងប្រុស និងមនុស្សប្រុស។
Genesis 17:24
រួមទាំងអស់អ្នកដែលកើតនៅក្នុងគ្រួសាររបស់គាត់
និងអស់អ្នកដែលបានទិញដោយលុយពីជនបរទេស
«នេះរាប់បញ្ចូលទាំងអ្នកដែលកើតនៅក្នុងគ្រួសាររបស់គាត់
ហើយនិងអស់អ្នកដែលគាត់បានទិញពីជនបរទេស»
អស់អ្នកដែលបានទិញដោយលុយពីជនបរទេស
នេះគឺសំដៅទៅលើអ្នកបម្រើ និងពួកទាសករ។
អស់អ្នកដែលបានទិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«អ្នកដែលគាត់បានទិញ»

---

18 [1]ព្រះអម្ចាស់បានយាងមកឲ្យលោកអ្រាហាំឃើញនៅក្បែរនៅដើមជ្រៃលោកម៉ាមរ៉ែ។
គឺក្នុងកាលដែលគាត់អង្គុយនៅច្រកទ្វារត្រសាលរបស់គាត់នៅក្នុងពេលថ្ងៃកំពុងពេញកម្តៅ។[2]គាត់បានសម្លឹងមើល ហើយមើល៍
គាត់បានឃើញបុរសម្នាក់កំពុងឈរនៅទល់មុខគាត់។ ពេលគាត់បានឃើញពួកគេ គាត់បានរស់ទៅជួបពួកគេពីច្រកទ្វារត្រសាល ហើយក្រាបផ្កាប់មុខទៅនឹងដី។
[3]គាត់ទូលថា៖ «ព្រះអម្ចាស់អើយ ប្រសិនបើ ទូលបង្គំគាប់ព្រះហឫទ័យដល់ព្រះអង្គ សូមមេត្តាកុំយាងហួស ដោយទុកចោលអ្នកបម្រើព្រះអង្គឡើយ។
[4]សូមឲ្យគេបានយកទឹកមកលាងព្រះបាទរបស់ព្រះអង្គ ហើយសម្រាកនៅក្រោមដើមឈើនេះសិនហើយ។[5]សូមឲ្យទូលបង្គំនាំអាហារបន្តិចបន្ទួចមកថ្វាយ
ដើម្បីឲ្យព្រះអង្គបានសោយ។ បន្ទាប់មក ព្រះអាចយាងចេញពីទូលបង្គំបានហើយ ព្រោះព្រះអង្គបានយាងមកជួបអ្នកបម្រើព្រះអង្គរួចហើយ»។ ពួកគេឆ្លើយថា៖
«ចូរតាមសម្តីរបស់អ្នកចុះ»។
[6]បន្ទាប់មក លោកអ្រាហាំទៅរកនាងសារ៉ាយ៉ាងលឿននៅក្នុងត្រសាល ហើយនិយាយថា៖ «ចូរប្រញាប់ឡើង យកម្សៅយ៉ាងម៉ដ្តបីរង្វាល់មក ច្របាច់វា
ហើយធ្វើជានំប៉័ង»។[7]បន្ទាប់មក លោកអ្រាហាំរត់ទៅឯអ្នកឃ្វាលសត្វ ហើយបានយកកូនគោ ដែលស្ទាវ ហើយល្អមួយ ហើយប្រគល់វាទៅឲ្យអ្នកបម្រើ
ហើយគាត់ក៏ប្រញាប់ទៅចម្អិនវា។[8]គាត់បានយកខ្លាញ់ និងទឹកដោះគោ ព្រមទាំងសាច់កូនគោដែលគេបានចម្អិននោះ មកដាក់នៅមុខរបស់ពួកគេ
ហើយគាត់ឈរនៅក្បែរពួកគេនៅក្នុងដើមឈើ នៅពេលពួកគេកំពុងហូប។
[9]ពួកគេនិយាយទៅកាន់គាត់ថា៖ «តើសារ៉ាភរិយារបស់លោកនៅឯណា?» គាត់ឆ្លើយថា៖ «នៅក្នុងត្រសាលឯណោះ»។[10]ព្រះអង្គមានបន្ទូលថា៖
«យើងនឹងត្រឡប់មកវិញជាប្រាកដនៅក្នុងរដូវលំហើយ ហើយមើល៍ សារ៉ាយភរិយារបស់លោកនឹងមានកូនប្រុសមួយ»។ នាងសារ៉ាយកំពុងស្តាប់នៅមាត់ទ្វារក្នុងត្រសាល
ដែលនៅពីក្រោយគាត់។
[11]ឥឡូវ លោកអ្រាហាំ និងនាងសារ៉ាមានវ័យចាស់ណាស់ហើយ នាងសារ៉ាមានអាយុហួសក្នុងការមានកូនហើយ។[12]នាងសារ៉ាសើចនឹងខ្លួនឯង
ហើយនិយាយមកកាន់ខ្លួននាងថា៖ «ខ្ញុំចាស់ចំណាស់នេះហើយ ស្វាមីខ្ញុំក៏ចាស់ណាស់ដែរ យើងខ្ញុំនៅមានតម្រេកអ្វីទៀត?»

generated on Wed Sep 10 16:16:32 2025

[13]ព្រះអម្ចាស់មានបន្ទូលទៅលោកអប្រាហាំថា៖ «ហេតុអ្វីបានជានាងសារ៉ាសើច ហើយនិយាយថា តើខ្ញុំអាចមានកូនបាន ក្នុងការដែលខ្ញុំចាស់ហើយនោះ?
[14]តើមានអ្វីដែលពិបាកពេកសម្រាប់ព្រះអម្ចាស់ទេ? នៅពេលកំណត់ យើងនឹងត្រឡប់មកឯអ្នកវិញ គឺនៅក្នុងរដូវលំហើយ។ នៅឆ្នាំក្រោយ នៅក្នុងរដូវនេះ
នាងសារ៉ានឹងមានកូនប្រុសមួយ»។[15]បន្ទាប់មក នាងសារ៉ាបដិសេធរា ហើយនិយាយថា៖ «ខ្ញុំម្ចាស់មិនបានសើចទេ» ដ្បិត នាងខ្លាច។ គាត់ឆ្លើយថា៖ «អត់ទេ
នាងបានសើចមែន»។
[16]បន្ទាប់មក ពួកគេបានក្រោកឡើងដើម្បីចាកចេញហើយសម្លឹងមើលទៅក្រុងសូដុម។ លោកអប្រាហាំបានចេញទៅជាមួយពួកគេ ដើម្បីជូនដំណើរពួកគេ។[17]ប៉ុន្តែ
ព្រះអម្ចាស់មានបន្ទូលថា៖ «តើគួរឲ្យយើងលាក់ជាមួយលោកពីអ្វីដែលខ្ញុំនឹងធ្វើដែរឬទេ?[18]លោកអប្រាហាំនឹងក្លាយជាប្រជាជាតិមួយដ៏ធំ ហើយខ្លាំងពូកែ
ហើយប្រជាជាតិទាំងអស់នៅលើផែនដីនឹងបានពរដោយសារគាត់។[19]ដ្បិត យើងបានជ្រើសរើសគាត់ ដើម្បីឲ្យគាត់បានបង្រៀនដល់កូន
និងគ្រួសាររបស់គាត់ដែលមកតាមក្រោយឲ្យកាន់តាមផ្លូវរបស់ព្រះអម្ចាស់ ឲ្យប្រព្រឹត្តសេចក្តីសុចរិត និងយុត្តធម៌ ដើម្បីឲ្យព្រះអម្ចាស់បានសម្រេចដល់លោកអប្រាហាំ តាម
សេចក្តីដែលព្រះអង្គបានមានបន្ទូលនឹងគាត់»។
[20]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលថា៖ «ដោយព្រោះមានសម្រែកយំទាស់នឹងក្រុងសូដុម និងក្រុងកូម៉ូរ៉ាខ្លាំងពេក
ហើយបាបរបស់ពួកគេក៏ខ្លាំងណាស់ដែរ[21]យើងនឹងចុះទៅទីនោះ ហើយមើលពីសម្រែកទាស់នឹងក្រុងនោះបានមកដល់យើង
ថាតើពួកគេពិតជាបានធ្វើការនោះមែនឬយ៉ាងណា។ ប្រសិនបើ មិនបានធ្វើទេ យើងនឹងបានដឹង»។
[22]ដូច្នេះ បុរសទាំងនោះបានចេញពីទីនោះ ហើយធ្វើដំណើរឆ្ពោះទៅក្រុងសូដុម ប៉ុន្តែ លោកអប្រាហាំឈរនៅចំពោះព្រះអម្ចាស់។[23]បន្ទាប់មក លោកអប្រាហាំបានចូលទៅជិត
ហើយទូលថា៖ «តើព្រះអង្គបំផ្លាញមនុស្សសុចរិត ជាមួយនឹងមនុស្សទុច្ចរិតមែនឬ?
[24]ប្រហែលជាមានមនុស្សសុចរិតហាសិបនាក់នៅក្នុងទីក្រុង។ តើព្រះអង្គនឹងបំផ្លាញទីក្រុងនោះចោល
ហើយមិនទុកកន្លែងសម្រាប់មនុស្សដែលសុចរិតហាសិបអ្នកដែលនៅទីនោះដែរទេឬ?[25]ព្រះអង្គមិនធ្វើដូច្នោះទេ
ព្រះអង្គមិនសម្លាប់មនុស្សសុចរិតជាមួយមនុស្សទុច្ចរិតឡើយ ដូច្នេះមនុស្សសុចរិតនឹងទទួលរងដូចមនុស្សទុច្ចរិតដែរ។ ព្រះអង្គមិនធ្វើដូច្នោះទេ!
តើចៅក្រមរបស់ផែនដីទាំងមូលមិនធ្វើអ្វីដែលយុត្តិធម៌ទេឬ?»[26]ព្រះអម្ចាស់មានបន្ទូលថា៖ «ប្រសិនបើ យើងរកឃើញមនុស្សសុចរិតហាសិបនាក់នៅក្នុងក្រុងសូដុម
យើងនឹងមិនបំផ្លាញទីនោះទេ ដោយយល់ដល់ពួកគេ»។
[27]លោកអប្រាហាំឆ្លើយ ហើយទូលថា៖«មើល៍ សូមអត់ទោសដល់ទូលបង្គំផង ដែលទូលបង្គំគ្រាន់តែជាធូលីដី និងជាផេះ ហ៊ាននិយាយតវ៉ាជាមួយព្រះអម្ចាស់!
[28]ចុះបើមានមនុស្សសុចរិតតែសែសិបប្រាំនាក់? តើព្រះអង្គនឹងបំផ្លាញទីក្រុងទាំងមូលដោយខ្វះតែប្រាំនាក់មែនទេ?» នោះព្រះអង្គមានបន្ទូលថា៖ «យើងមិនបំផ្លាញទេ
ប្រសិនបើមានសែសិបប្រាំនាក់»។
[29]គាត់ទូលព្រះអង្គសារជាថ្មីទៀតថា៖ «ចុះបើមានតែសែសិបនាក់នៅទីនោះ?» ព្រះអង្គតបថា៖ «យើងនឹងមិនបំផ្លាញទេ ដោយព្រោះអ្នកសែសិបនាក់នោះ»។
[30]គាត់ទូលទៀតថា៖ «សូមកុំព្រះពិរោធនឹងទូលបង្គំធ្វើអ្វី ព្រះអម្ចាស់អើយ ដែលទូលបង្គំនិយាយដូច្នេះ។ ប្រហែលជាមានមនុស្សសុចរិតតែសាមសិបនាក់នៅទីនោះ»។
ព្រះអង្គតបថា៖ «មើល៍ យើងមិនបំផ្លាញក្រុងនោះទេ ប្រសិនបើ យើងរកឃើញមនុស្សសុចរិតសាមសិបនាក់នៅទីនោះ»។[31]គាត់ទូលទៀតថា៖ «មើល៍
សូមអត់ទោសដល់ទូលបង្គំផងដែលហ៊ានទូលទៅព្រះអម្ចាស់បែបនេះ! ប្រហែលជាមានមនុស្សសុចរិតតែម្ភៃនាក់នៅទីនោះ»។ ព្រះអង្គតបថា៖
«យើងមិនបំផ្លាញទីក្រុងនោះទេ ដោយយល់ដល់អ្នកម្ភៃនាក់នោះ»។
[32]គាត់ទូលថា៖ «សូមព្រះអង្គកុំព្រះពិរោធនឹងទូលបង្គំធ្វើអ្វី ព្រះអម្ចាស់អើយ ទូលបង្គំសូមនិយាយបែបនេះជាលើកចុងក្រោយ។
ប្រហែលជារកឃើញមនុស្សសុចរិតតែដប់នាក់ទេ នៅទីនោះ»។ បន្ទាប់មក ព្រះអង្គមានបន្ទូលថា៖ «យើងមិនបំផ្លាញវាទេ ដោយយល់ដល់អ្នកទាំងដប់នាក់នោះ»។
[33]ព្រះអម្ចាស់បានយាងចេញភ្លាម បន្ទាប់ពីព្រះអង្គបានបញ្ចប់ការសន្ទនាជាមួយលោកអប្រាហាំ ហើយលោកអប្រាហាំក៏ត្រឡប់ទៅផ្ទះរបស់គាត់វិញ។

Genesis 18:1
ម៉ាមរេ
នេះគឺឈ្មោះដែលបុរសម្នាក់ដែលបានធ្វើជាម្ចាស់នៃដើមជ្រៃ។
នៅច្រកទ្វារត្រសាល
«នៅពេលបើកចូលត្រសាល» ឬ «នៅច្រកទ្វារចូលទៅត្រសាល»
នៅក្នុងពេលថ្ងៃកំពុងពេញកម្តៅ
«នៅថ្ងៃដែលក្តៅយ៉ាងខ្លាំង»
គាត់បានសម្លឹងមើល ហើយមើល៍ គាត់បានឃើញបុរស៣នាក់កំពុងឈរ
«លោកក្រឡេកមើលទៅឃើញបុរសបីនាក់កំពុងតែឈរ»
មើល៍
«រំពេចនឹនោះ» ពាក្យថា« មើល»
នៅទីនេះបង្ហាញយើងថាអ្វីដែលគួរអោយភ្ញាក់ផ្អើលដល់លោកអប្រាហាំ។
នៅទល់មុខគាត់
«នៅក្បែរ» ឬ «នៅទីនោះ»
ពួកគេនៅជិតគាត់ប៉ុន្តែនៅឆ្ងាយល្មមសម្រាប់គាត់ដើម្បីរត់ទៅរកពួកគេ។
ក្រាប
នេះមានន័យថាត្រូវពត់ខ្លួនដើម្បីបង្ហាញការគោរពនិងផ្តល់កិត្តិយសដោយរាបសារដល់នរណាម្នាក់។
Genesis 18:3
ព្រះអម្ចាស់
នេះគឺជាចំណងជើងនៃការគោរព។ អត្ថន័យដែលអាចមានគឺ ១) អ្នកបម្រើព្រះអង្គ
អប្រាហាំដឹងថាបុរសម្នាក់នោះក្នុងចំណោមពួកគេគឺជាព្រះឬ ២) «ខ្ញុំ » លោកអប្រាហាំ
អប្រាហាំដឹងថាបុរសទាំងនេះមកជំនួសព្រះជាម្ចាស់។ សំដៅទៅលើខ្លួនគាត់តាមរបៀបនេះដើម្បីបង្ហាញការគោរពដល់ភ្ញៀវរបស់គាត់។
ក្នុងការមើលឃើញរបស់ទ្រង់ សូមឲ្យគេបានយកទឹក
លោកអប្រាហាំកំពុងនិយាយជាមួយបុរសម្នាក់ក្នុងចំណោមបុរសទាំងនោះ។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
(សូមមើល:figs-you) «សូមឱ្យខ្ញុំយកទឹកមកឱ្យអ្នក» ឬ «អ្នកបម្រើខ្ញុំនឹងនាំទឹកឱ្យអ្នក»
សូមមេត្តាកុំយាងហួស ទឹកបន្តិចបន្តួច.....មួយបន្តិចបន្តួច
«សូមកុំបន្ត» «ទឹកខ្លះ ... អាហារខ្លះ» ការនិយាយថា «តិចតួច»
គឺជាវិធីគួរសមក្នុងការបង្ហាញពីភាពសប្បុរស។
អាប្រាហាំនឹងផ្តល់ទឹកនិងអាហារគ្រប់គ្រាន់ដល់ពួកគេ។
លាងព្រះបាទរបស់ព្រះអង្គ
ទំនៀមទម្លាប់នេះបានជួយអ្នកធ្វើដំណើរដែលនឿយហត់ឱ្យមានកម្លាំងចិត្តឡើងវិញបន្ទាប់ពីដើរផ្លូវឆ្ងាយ។
របស់អ្នក.....អ្នក
អប្រាហាំនិយាយទៅកាន់បុរសទាំងបីនាក់ដូច្នេះ «អ្នក» និង «របស់អ្នក»
មានពហុវចនៈ។
Genesis 18:6
ម៉ាមរេ
ប្រហែល២លីត្រ
នំបុ័ង
នំបុ័ងនេះប្រហែលជាត្រូវបានចម្អិនយ៉ាងលឿននៅលើដុំថ្មក្តៅ។
ប្រហែលអាចមានរាងសំប៉ែត ឬ មូលដូចនំបុ័ងឬ មូល។
គាត់ក៏ប្រញាប់
«អ្នកបម្រើប្រញាប់ប្រញាល់»
ដើម្បីរៀបចំ
«កាត់វាហើយក៏អាំងវា»
ខ្លាញ់
នេះសំដៅទៅលើផ្នែករឹងនៃទឹកដោះគោដែលមានជាតិមេ។ វាអាចជាទឹកដោះគោជូរ

generated on Wed Sep 10 16:16:32 2025

ឬ ឈឺស។
ព្រមទាំងសាច់កូនគោដែលបានរៀបចំ
«សាច់គោដែលបានអាំង»
នៅមុខរបស់ពួកគេ
«គឺនៅមុខភ្ញៀវទាំងបីនាក់នោះ»
Genesis 18:9
ពួកគេនិយាយទៅកាន់គាត់
«ហើយពួកគេក៏និយាយទៅកន់លោកអប្រាហាំ»
ព្រះអង្គមានបន្ទូល «យើងនឹងត្រឡប់មកវិញជាប្រាកដ»
ពាក្យ«ទ្រង់»គឺសំដៅទៅកាន់បុរសម្នាក់ដែលលោកអប្រាហាំហៅថា«ព្រះអម្ចាស់»នៅក្នុងខគម្ពីរ
នៅក្នុងរដូវលំហើយ
«នៅពេលវេលាដដែលនិងមកនៅឆ្នាំក្រោយ»ឬ«ប្រហែលនៅពេលវេលានេះឆ្នាំក្រោយ»
ហើយមើល៍
ពាក្យ «មើល»
នៅទីនេះជូនដំណឹងយើងឱ្យយកចិត្តទុកដាក់លើព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលកើតឡើង
នៅមាត់ទ្វារក្នុងត្រសាល
«នៅពេលបើកត្រសាល» ឬ «នៅច្រកចូលក្នុងត្រសាល»
Genesis 18:11
ខ្ញុំចាស់ចំណាស់នេះហើយ ស្វាមីខ្ញុំក៏ចាស់ណាស់ដែរ យើងខ្ញុំនៅមានតម្រេកអ្វីទៀត?
ចាស់ហើយចៅហ្វាយខ្ញុំចាស់ តើខ្ញុំនឹងមានអារម្មណ៍តម្រេកអី? -
អ្នកប្រហែលជាចង់បន្ថែម« ការមានកូន»
លោកស្រីសារ៉ាបានប្រើសំនួរនេះពីព្រោះនាងមិនជឿថានាងអាចមានកូនបានទេ។
ការបកប្រែផ្សេងទៀត៖
«ខ្ញុំមិនជឿថាខ្ញុំនឹងទទួលបាននូវសេចក្តីអំណរនៃការមានកូនទេ។
ចៅហ្វាយរបស់ខ្ញុំក៏ចាស់ដែរ»
ចៅហ្វាយខ្ញុំគឺចាស់ណាស់ហើយ
នេះមានន័យថា «ចាប់តាំងពីប្តីរបស់ខ្ញុំក៏ចាស់ដែរ»
ចៅហ្វាយខ្ញុំ
នេះគឺជាចំណងជើងនៃការគោរពដែលសារ៉ាបានផ្តល់ឱ្យអ័ប្រាហាំប្តីរបស់គាត់។
Genesis 18:13
ហេតុអ្វីបានជានាងសារ៉ាសើច ហើយនិយាយថា តើខ្ញុំអាចមានកូនបាន
ក្នុងការដែលខ្ញុំចាស់ហើយនោះ?
ព្រះបានប្រើសំណួរនេះដើម្បីបង្ហាញថាទ្រង់ដឹងពីអ្វីដែលសារ៉ាកំពុងគិតហើយថាគាត់មិនត្រូវ
ទ្រង់មានបន្ទូលឡើងវិញនូវសំណួរនេះដល់សារ៉ា
តើមានអ្វីដែលពិបាកពេកសម្រាប់ព្រះអម្ចាស់ទេ?
តើមានអ្វីដែលព្រះអម្ចាស់មិនអាចធ្វើបានទេ?
ព្រះអម្ចាស់និយាយអំពីអង្គទ្រង់ផ្ទាល់ដូចជាទ្រង់កំពុងមានបន្ទូលអំពីនរណាម្នាក់ដើម្បីរៀនពីរបៀប
ការបកប្រែផ្សេងទៀត៖
«គ្មានអ្វីដែលទ្រង់ជាព្រះអម្ចាស់មិនអាចធ្វើបានទេ!» (សូមមើល និងfigs-
rquestion)
នៅពេលកំណត់ យើងនឹងត្រឡប់មកឯអ្នកវិញ គឺនៅក្នុងរដូវលំហើយ
«នៅពេលដែលយើងបានកំណត់ដែលជាពេលរដូវលំហើយ»
ន្ទាប់មក នាងសារ៉ាបដិសេធន៏ ហើយនិយាយថា
«លោកស្រីសារ៉ាបានបដិសេធន៏ដោយការនិយាយ»
ទ្រង់ឆ្លើយតប
«ព្រះជាម្ចាស់បានឆ្លើយតប»
ទេ អ្នកបានសើច
«មែនហើយអ្នកបានសើច»។ នេះមានន័យថា «ទេនោះមិនពិតទេ
អ្នកពិតជាបានសើច»
Genesis 18:16
ដើម្បីជូនដំណើរពួកគេ
«ដើម្បីជូនដំណើរពួកគេ» ឬ «ដើម្បីនិយាយថាលា ទៅកាន់ពួកគេ» ។
វាជាការគួរសមក្នុងការធ្វើដំណើរឆ្ងាយជាមួយភ្ញៀវនៅពេលពួកគេកំពុងចាកចេញ។
តើគួរឲ្យយើងលាក់ជាមួយលោកពីអ្វីដែលខ្ញុំនឹងធ្វើដែរឬទេ?
ព្រះជាម្ចាស់បានប្រើសំណួរនេះដើម្បីមានបន្ទូលថាទ្រង់នឹងមានបន្ទូលជាមួយលោកអប្រាហាំ
ការបកប្រែផ្សេងទៀត៖
«យើងមិនគួរហើយនឹងមិនលាក់ពីលោកអប្រាហាំនូវអ្វីដែលយើងនឹងធ្វើ ... គាត់»។
ឬ «យើងគួរតែប្រាប់លោកអប្រាហាំនូវអ្វីដែលយើងនឹងធ្វើ ... គាត់»
តើគួរឲ្យយើង....ធ្វើ,ចាប់តាំង.....គាត់?
«យើងមិនគួរ.....ធ្វើ។នេះគឺព្រោះ.....គាត់»
ហើយប្រជាជាតិទាំងអស់នៅលើផែនដីនឹងបានពរដោយសារគាត់
នេះត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«យើងនឹងប្រទានពរដល់ប្រជាជាតិទាំងអស់នៅលើផែនដីតាមរយៈលោកអប្រាហាំ»
បានពរដោយសារគាត់
«នឹងទទួលពរដោយសារលោកអប្រាហាំ» ឬ
«នឹងទទួលពរដោយសារទ្រង់បានឲ្យពរដល់លោកអប្រាហាំ» «នៅក្នុងគាត់»
«តាមរយៈអ្នក» សូមមើល ១២: ១
ដើម្បីឲ្យគាត់បានបង្រៀន
ដែលគាត់នឹងដឹកនាំ» ឬ «ដូច្នេះគាត់នឹងបញ្ជា»
ឲ្យកាន់តាមផ្លូវរបស់ព្រះអម្ចាស់...ព្រះជាម្ចាស់និងនាំ...ទ្រង់បានមានបន្ទូល
ព្រះអម្ចាស់កំពុងមានបន្ទូលអំពីព្រះអង្គដូចជាទ្រង់ជាមនុស្សម្នាក់ផ្សេងទៀត។
ការបកប្រែផ្សេងទៀត៖ « គោរពតាមអ្វីដែលយើងជាព្រះអម្ចាស់តម្រូវឲ្យ... ទ្រង់
ព្រះអម្ចាស់នឹងនាំ ... ទ្រង់បានមានបន្ទូលហើយ»
ឲ្យកាន់តាមផ្លូវរបស់ព្រះអម្ចាស់
«ដើម្បីស្តាប់បង្គាប់បញ្ជាព្រះជាម្ចាស់»
ឲ្យប្រព្រឹត្តសេចក្តីសុចរិត និងយុត្តធម៌
«ដោយប្រព្រឹត្តិសេចក្តីសុចរិតនិងយុត្តិធម៌»
នេះប្រាប់ពីរបៀបដែលរក្សាមាគ៌ារបស់ព្រះអម្ចាស់។
ដើម្បីឲ្យព្រះអម្ចាស់បានសម្រេចដល់លោកអប្រាហាំ តាមសេចក្តីដែលព្រះអង្គបានមានបន្ទូលនឹង
គាត់
«ដូច្នេះព្រះអម្ចាស់នឹងប្រទានពរដល់លោកអប្រាហាំដូចអ្វីដែលទ្រង់បានមានបន្ទូលថាទ្រង់នឹងធ្វើ»
នេះសំដៅទៅលើការសន្យានៃសម្ពន្ធមេត្រីដែលនឹងប្រទានពរដល់អប្រាហាំនិងធ្វើឱ្យគាត់ក្លាយជាប្រជាជាតិ
Genesis 18:20
មានសម្រែកយំទាស់នឹងក្រុងសូដុម និងក្រុងកូម៉ូរ៉ាខ្លាំង
នេះអាចត្រូវបានប្រើឡើងវិញដូច្នេះនាមអរូបី «ស្រែក»
ត្រូវបានបង្ហាញជាកិរិយាស័ព្ទ «ចោទប្រកាន់»។ ការបកប្រែផ្សេងទៀត៖
«មានមនុស្សជាច្រើនបានចោទប្រកាន់ប្រជាជនក្រុងសូដុមនិងកូម៉ូរ៉ាថាពីការធ្វើអំពើអាក្រក់»
ហើយបាបរបស់ពួកគេក៏ខ្លាំងណាស់ដែរ
«ពួកគេមានបាបយ៉ាងច្រើន»
យើងនឹងចុះទៅទីនោះ
«យើងនិងចុះទៅក្រុងសូដុម និង កូម៉ូរ៉ាឥឡូវ»
«ចុះទៅទីនោះដើម្បីស្វែងរកមើល» ឬ «ចុះទៅទីនោះដើម្បីសម្រេច»
មើលឃើញសម្រែកយំ.....ដែលបានចូលមកខ្ញុំ
ព្រះអម្ចាស់មានព្រះបន្ទូលដូចព្រះអង្គជ្រាបអំពីបញ្ហានេះ
ការចោទប្រកាន់របស់ប្រជាជនដែលរងទុក្ខលំបាក។ នេះអាចត្រូវបានប្រើឡើងវិញ
ដូច្នេះនាមអរូបី «ស្រែក» ត្រូវបានបង្ហាញជាកិរិយាស័ព្ទ «ចោទប្រកាន់»។
ការបកប្រែផ្សេងទៀត៖ «អាក្រក់ដូចអ្នកដែលចោទប្រកាន់ពួកគេនិយាយថាពួកគេ»
សូមមើល
Genesis 18:22
បានចេញពីទីនោះ
«បានចេញពីជំរុំរបស់លោកអប្រាហាំ»
លោកអប្រាហាំឈរនៅចំពោះព្រះអម្ចាស់
«លោកអប្រាហាំ ហើយនិងព្រះជាម្ចាស់បានឈរនៅជាមួយគ្នា»
ចូលទៅជិត
«ចូលទៅជិតព្រះជាម្ចាស់» ឬ«ឈរនៅជិតព្រះជាម្ចាស់»
បំផ្លាញចេញ
លោកអប្រាហាំនិយាយអំពីការបំផ្លាញមនុស្សដូចជាកំពុងបោសធូលីដីដោយអំបោស។
ការបកប្រែផ្សេងទៀត៖ «បំផ្លាញ»
មនុស្សសុចរិត ជាមួយនឹងមនុស្សទុច្ចរិត
«មនុស្សសុចរិតនិងមនុស្សទុច្ចរិត»
Genesis 18:24
ព្រះអម្ចាស់នឹងធ្វើអ្វីដែលសំខាន់ហើយវាជាការល្អបំផុតសម្រាប់ទ្រង់។
លោកអប្រាហាំបន្តនិយាយទៅកាន់ព្រះជាម្ចាស់។
ប្រហែលជាមាន
«ឧបមាថាមាន»
តើព្រះអង្គនឹងបំផ្លាញទីក្រុងនោះចោល

generated on Wed Sep 10 16:16:32 2025

ហើយមិនទុកកន្លែងសម្រាប់មនុស្សដែលសុចរិតហាសិបអ្នកដែលនៅទីនោះដែរទេឬ?
លោកអប្រាហាំសង្ឃឹមថាព្រះអម្ចាស់នឹងមានព្រះបន្ទូលថា
«យើងនឹងមិនបំផ្លាញចេញទេ» ការបកប្រែផ្សេងទៀត៖
«ខ្ញុំគិតថាទ្រង់នឹងមិនបំផ្លាញទេ។
ផ្ទុយទៅវិញ,ទ្រង់នឹងទុកកន្លែងនេះសម្រាប់ជាប្រយោជន៍ដល់មនុស្សសុចរិតហាសិបនាក់ដែលអាចរស់នៅទីនេះ»។
បំផ្លាញទីក្រុងនោះចោល
«បំផ្លាញវា»
អាប្រាហាំនិយាយអំពីការបំផ្លាញមនុស្សដូចជាកំពុងបោសធូលីដីដោយអំបោស។
ការបកប្រែផ្សេងទៀត៖ «បំផ្លាញប្រជាជនណាដែលរស់នៅទីនោះ»
ហើយមិនទុកកន្លែងសម្រាប់មនុស្សដែលសុចរិតហាសិបអ្នកដែលនៅទីនោះដែរទេឬ?
លោកអប្រាហាំសង្ឃឹមថាព្រះជាម្ចាស់នឹងមានព្រះបន្ទូលថា
«យើងនឹងទុកកន្លែងនេះសម្រាប់ជាប្រយោជន៍ដល់ប្រជាជនសុចរិតហាសិបនាក់»។
ទុកកន្លែង
«ទុកអោយមនុស្សរស់នៅ»
សម្រាប់ជាប្រយោជន៍នៃ
«ពីព្រោះនៃការ»
ព្រះអង្គមិនធ្វើដូច្នោះទេ
«យើងនឹងមិនចង់អោយអ្នកធ្វើដូចនោះទេ» ឬ «អ្នកមិនគួរធ្វើអ្វីដូចនោះទេ»
ធ្វើដូច្នោះសម្លាប់
«ដូចជារឿងការសម្លាប់» ឬ «រឿងបែបនេះគឺជាការសម្លាប់»
មនុស្សសុចរិតនឹងទទួលរងដូចមនុស្សទុច្ចរិត
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«អ្នកគួរតែប្រព្រឹត្តចំពោះមនុស្សសុចរិតដូចអ្នកបានធ្វើចំពោះមនុស្សអាក្រក់»
តើចៅក្រមរបស់ផែនដីទាំងមូលមិនធ្វើអ្វីដែលយុត្តិធម៌ទេឬ?
អប្រាហាំបានប្រើសំនួរនេះដើម្បីនិយាយអ្វីដែលគាត់រំពឹងថាព្រះនឹងធ្វើ។
ការបកប្រែផ្សេងទៀត៖ «ចៅក្រមនៃផែនដីទាំងមូលនឹងធ្វើអ្វីដែលត្រឹមត្រូវ» ឬ
«ចាប់តាំងពីទ្រង់ជាចៅក្រមនៃផែនដី ទ្រង់ប្រាកដជាធ្វើអ្វីដែលត្រឹមត្រូវ!»
ចៅក្រម
ជារឿយៗព្រះជាម្ចាស់ត្រូវបានគេហៅថាចៅក្រមពីព្រោះទ្រង់គឺជាចៅក្រមដ៏ល្អឥតខ្ចោះម្នាក់ដែលធ្វើការសម្រេចចិត្តត្រឹមត្រូវ។
Genesis 18:27
មើល៍
ឃ្លា «មើល»
នៅទីនេះទាក់ទាញការយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យចាប់អារម្មណ៍ដែលមានខាងក្រោម។
សូមអត់ទោសដល់ទូលបង្គំផងដើម្បីទួល
«លើកលែងទោសអោយទូលបង្គំដែលហ៊ាននិយាយជាមួយទ្រង់» ឬ
«សូមទោសដែលខ្ញុំក្លាហាននិយាយ»
ជាមួយព្រះអម្ចាស់
លោកអប្រាហាំបង្ហាញការគោរពដល់ព្រះជាម្ចាស់ដោយនិយាយទៅកាន់ព្រះយេហូវ៉ាដូចជាទ្រង់ជាស្តេច។
ការបកប្រែផ្សេងទៀត៖ «ចំពោះទ្រង់ ព្រះអម្ចាស់របស់ខ្ញុំ»
គ្រាន់តែជាធូលីដី និងជាផេះ
ការប្រៀបធៀបនេះពិពណ៌នាអំពីលោកអ័ប្រាហាំជាមនុស្សម្នាក់ដែលនឹងត្រូវស្លាប់ហើយរូបកាយរបស់គាត់
ការបកប្រែផ្សេងទៀត៖ «មានតែមនុស្សរមែងស្លាប់» ឬ
«មិនសំខាន់ដូចធូលីនិងផេះ»
មានមនុស្សសុចរិតហាសិបនាក់ខ្វះប្រាំ
«តើមានមនុស្សសុចរិតតែសែសិបប្រាំនាក់»
ខ្វះតែប្រាំនាក់
«ប្រសិនបើមានមនុស្សសុចរិតតិចជាងប្រាំនាក់»
យើងមិនបំផ្លាញទេ
«យើងនិងមិនបំផ្លាញទីក្រុងសូដុមឡើយ»
Genesis 18:29
គាត់ទូលព្រះអង្គ
«លោកអប្រាហាំនិយាយទៅកាន់ព្រះជាម្ចាស់»
ចុះបើមានតែសែសិបនាក់នៅទីនោះ
នេះមានន័យថា
«ប្រសិនបើអ្នករកឃើញមនុស្សសុចរិតសែសិបនាក់នៅសូដុមនិងកូម៉ូរ៉ា »
ព្រះអង្គតបថា
«ព្រះជាម្ចាស់បានឆ្លើយតប»
យើងនឹងមិនបំផ្លាញទេ ដោយព្រោះអ្នកសែសិបនាក់នោះ
«យើងនឹងមិនបំផ្លាញទីក្រុងទេប្រសិនបើយើងរកឃើញមនុស្សសុចរិតចំនួនសែសិបនាក់នៅទីនោះ»
សាមសិប
«មនុស្សសុចរិត ៣០ នាក់» ឬ «មនុស្សល្អ ៣០ នាក់»
មើល៍
ឃ្លា «មើល»
នៅទីនេះទាក់ទាញការយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលមាននៅខាងក្រោម។
សូមអត់ទោសដល់ទូលបង្គំផងដែលហ៊ានទូល
«សូមទោសខ្ញុំចំពោះភាពក្លាហានក្នុងការនិយាយទៅកាន់អ្នក» ឬ
«សូមទោសដែលខ្ញុំមិនហ៊ាននិយាយ» សូមមើល ១៨:២៧
ម្ភៃនាក់
ដោយសារតែការអធិស្ឋានរបស់លោកអ័ប្រាហាំ ព្រះអម្ចាស់បានសន្យាថានឹងមិនបំផ្លាញទីក្រុងសូដុមទេ ប្រសិនបើមានមនុស្សសុចរិតតែ ២០ នាក់ប៉ុណ្ណោះរស់នៅទីនោះ។
Genesis 18:32
ប្រហែលជារកឃើញមនុស្សសុចរិតតែដប់នាក់ទេ
«ប្រហែលជាអ្នកនឹងឃើញមនុស្សសុចរិត ១០ នាក់នៅទីនោះ»
«មនុស្សសុចរិត ១០ នាក់» ឬ «មនុស្សល្អ ១០ នាក់»
បន្ទាប់មក ព្រះអង្គមានបន្ទូលថា
«ហើយព្រះជាម្ចាស់បានឆ្លើយតប»
ដោយយល់ដល់អ្នកទាំងដប់នាក់នោះ
ដោយសារតែការអធិស្ឋានរបស់លោកអ័ប្រាហាំ ព្រះអម្ចាស់បានសន្យាថានឹងមិនបំផ្លាញទីក្រុងសូដុមទេ ប្រសិនបើមានមនុស្សសុចរិតតែ ២០ នាក់ប៉ុណ្ណោះរស់នៅទីនោះ»
ព្រះអម្ចាស់បានយាងចេញភ្លាម
«ព្រះអម្ចាស់បានចេញដំណើរទៅ» ឬ «ព្រះអម្ចាស់បានចាកចេញ»

19 [1]ទេវតាទាំងពីរបានមកដល់ក្រុងសូដុមនៅពេលល្ងាច លោកឡុតកំពុងអង្គុយនៅទ្វារក្រុងសូដុម។ លោកឡុតបានឃើញទេវតាទាំងពីរ ក៏ក្រោកឡើងទៅជួបពួកគេ
ហើយក្រាបចុះមុខទល់ដី។[2]គាត់និយាយថា៖ «សូមលោកម្ចាស់ សូមមេត្តាចូរទៅផ្ទះខ្ញុំ ជាអ្នកបម្រើរបស់លោក ហើយស្នាក់នៅទីមួយយប់សិន
ព្រមតាំងបានលាងជើងជូនដល់លោកផង។ បន្ទាប់មក លោកអាចក្រោកឡើងពីព្រលឹម ហើយបន្តដំណើរទៅមុខទៀតចុះ»។ ពួកគេឆ្លើយថា៖ «អត់ទេ
យើងនឹងគេងនៅតាមទីធ្លាក្រុងយប់នេះ»។[3]ប៉ុន្តែ លោកឡុតអង្វរពួកគេជាខ្លាំង ពួកគេក៏ទៅជាមួយគាត់ ហើយចូលទៅក្នុងផ្ទះរបស់គាត់។ គាត់បានចម្អិនអាហារ
ហើយដុតនំប៉័ងឥតមេ ហើយពួកគេក៏ហូប។
[4]ប៉ុន្តែ មុនពេលពួកគេគេង ពួកប្រុសៗនៅក្នុងទីក្រុង គឺពួកប្រុសៗនៅក្នុងទីក្រុងសូដុម បានព័ទ្ធជុំវិញផ្ទះ ទាំងក្មេងទាំងចាស់ ប្រុសៗទាំងនោះមកពីគ្រប់ទិសទីនៃទីក្រុង។
[5]ពួកគេបានហៅលោកឡុត ហើយនិយាយទៅគាត់ថា៖ «តើបុរសដែលមកឯលោកនៅឯណា? ចូរនាំពួកគេចេញមកឲ្យពួកយើង ដើម្បីឲ្យយើងបានគេងជាមួយពួកគេ»។
[6]ដូច្នេះ លោកឡុតបានចេញពីទ្វារទៅរកពួកគេ ហើយបិទទ្វារនៅក្រោយខ្នងគាត់។[7]គាត់និយាយថា៖ «ខ្ញុំសូមអង្វរ បងប្អូនខ្ញុំអើយ សូមកុំប្រព្រឹត្តអាក្រក់អី។[8]មើល៍
ខ្ញុំមានកូនស្រីពីរនាក់ មិនទាន់គេងជាមួយបុរសណាឡើយ។ ខ្ញុំសូមអង្វរអ្នកទាំងអស់គ្នា ចូរនាំពួកគេទៅជាមួយអ្នករាល់គ្នាទៅ
ហើយអ្នករាល់គ្នាអាចធ្វើអ្វីដល់ពួកគេតាមតែអ្វីដែលអ្នករាល់គ្នាគិតថាល្អនៅចំពោះភ្នែករបស់អ្នករាល់គ្នាចុះ។ តែសូមកុំធ្វើអ្វីជាមួយបុរសពីរនាក់នេះឡើយ
ព្រោះពួកគេបានមកជ្រកនៅក្រោមដំបូលផ្ទះរបស់ខ្ញុំ»។
[9]ពួកគេនិយាយថា៖ «ចយចេញទៅ!» ហើយពួកគេក៏បន្តទៀតថា៖ «ម្នាក់នេះជាជនបរទេសមករស់នៅទីនោះសោះ ហើយឥឡូវ វាបានក្លាយជាចៅក្រមរបស់យើងហើយ!
ឥឡូវនេះ យើងនឹងប្រព្រឹត្តអាក្រក់ជាមួយអ្នកខ្លាំងជាងពួកគេទេ»។ ពួកគេបានរុញយ៉ាងខ្លាំងទាស់នឹងលោកឡុត ហើយចូលមកជិតដើម្បីទម្លោះទ្វារ។
[10]ប៉ុន្តែ បុរសពីនាក់នោះបានលូកដៃរបស់ពួកគេ ហើយបាននាំលោកឡុតចូលមកក្នុងផ្ទះជាមួយពួកគេ ហើយបិទទ្វារវិញ។[11]បន្ទាប់មក
ទេវតាបានពួកប្រុសៗដែលនៅមាត់ទ្វារផ្ទះឲ្យខ្វាក់ភ្នែក ទាំងក្មេងទាំងចាស់ ដើម្បីឲ្យពួកគេអស់កម្លាំង នៅពេលពួកគេព្យាយាមរកទ្វារ។
[12]បន្ទាប់មកបុរសទាំងពីរនាក់បាននិយាយទៅកាន់លោកឡុតថា៖ «តើលោកមានអ្នកផ្សេងទៀតនៅទីនេះទេ? កូនប្រសារប្រុសៗ កូនៗ និងកូនស្រីៗរបស់លោក
និងអ្នកផ្សេងៗដែលអ្នកមាននៅក្នុងទីក្រុងនេះ ចូរយកពួកគេចេញពីទីនេះ។[13]ដ្បិត យើងនឹងបំផ្លាញទីនេះហើយ ដោយសារការចោទប្រកាន់ទាស់នឹងទីក្រុងនេះ
នៅចំពោះព្រះអម្ចាស់បានឮយ៉ាងខ្លាំងបានជាព្រះជាម្ចាស់ចាត់យើងមកឲ្យបំផ្លាញទីក្រុងនេះ»។

generated on Wed Sep 10 16:16:32 2025

[14]លោកឡុតបានចេញទៅ ហើយបានហៅកូនប្រសារប្រុសៗរបស់គាត់ គឺពួកប្រុសៗដែលបានរៀបការជាមួយកូនស្រីៗរបស់លោក ហើយប្រាប់ថា៖ «ចូរចេញពីទីនេះ
ជាប្រញាប់ ដ្បិត ព្រះអម្ចាស់នឹងបំផ្លាញទីក្រុងនេះហើយ»។ ប៉ុន្តែ កូនប្រសារប្រុសៗរបស់លោក គិតថាគាត់និយាយលេង។[15]នៅពេលព្រឹកព្រលឹម
ទេវតាទាំងពីរបានបង្ខំលោកឡុត ដោយនិយាយថា៖ «ចូរចេញទៅ យកភរិយា និងកូនស្រីទាំងពីររបស់លោកដែលនៅទីនេះចេញទៅ
ដើម្បីកុំឲ្យលោកត្រូវបំផ្លាញជាមួយទីក្រុងដោយដោយសារការជំនុំជម្រះឡើយ»។
[16]ប៉ុន្តែ គាត់នៅបង្អែបង្អង់។ ដូច្នេះ ទេវតាទាំងពីរបានចាប់ដៃលោក ហើយដៃភរិយារបស់លោក ព្រមទាំងដៃកូនស្រីទាំងពីររបស់លោក
ដោយសារព្រះអម្ចាស់ផ្តល់មេត្តាដល់ពួកគេ។ ទេវតាទាំងពីរបាននាំពួកគេចេញ ហើយនាំចេញទៅទុកនៅខាងក្រៅក្រុង។[17]បន្ទាប់មក ទេវតាទាំងពីរបាននាំពួកគេចេញ
ហើយមានម្នាក់និយាយថា៖ «ចូររត់ដើម្បីឲ្យអ្នកបានរស់! កុំមើលក្រោយឡើយ ឬ ស្នាក់នៅទីវាលណាមួយឡើយ។ ចូររត់គេចទៅឯភ្នំ ដើម្បីកុំឲ្យអ្នកត្រូវបំផ្លាញឡើយ»។
[18]លោកឡុតនិយាយទៅទេវតាទាំងពីរថា៖ «អត់ទេ លោកម្ចាស់អើយ![19]ខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់បានទទួលព្រះគុណនៅចំពោះលោកម្ចាស់ ហើយ
លោកម្ចាស់បានផ្តល់ក្តីមេត្តាយ៉ាងធំក្នុងការសង្គ្រោះជីវិតរបស់យើងខ្ញុំ ប៉ុន្តែ ខ្ញុំមិនអាចរត់គេចទៅឯភ្នំបានទេ ព្រោះគ្រោះមហន្តរាយនឹងបំផ្លាញខ្ញុំ និងខ្ញុំនឹងស្លាប់ហើយ។
[20]មើល៍ ទីក្រុងនៅទីនោះ វាជិតល្មមដែលអាចរត់ទៅដល់ ហើយវាក៏តូចដែរ។ សូមឲ្យខ្ញុំរត់គេចទៅទីនោះចុះ (តើវាមិនតូចទេឬអី?) ហើយខ្ញុំនឹងមានជីវិតរស់នៅទីនោះ»។
[21]ទេវតាទាំងពីរនិយាយទៅគាត់ថា៖ «មិនអីទេ ខ្ញុំយល់ព្រមតាមសំណើនេះ ថាយើងនឹងមិនបំផ្លាញក្រុងដែលលោកបាននិយាយទេ។[22]ប្រញាប់ឡើង!
ចូររត់គេចចេញពីទីនេះទៅ ព្រោះយើងមិនអាចធ្វើអ្វីបានឡើយ ទាល់តែលោកទៅដល់ទីនោះសិន»។ ហេតុដូច្នេះហើយបានជាគេហៅទីក្រុងនោះថា សូអារ។
[23]ពេលលោកឡុតទៅដល់ក្រុងសូអារ ថ្ងៃបានរះឡើងមកលើផែនដី។[24]បន្ទាប់មក ព្រះអម្ចាស់បានធ្វើឲ្យភ្លៀងធ្លាក់ជាស្ពាន់ធ័រ និងភ្លើងធ្លាក់ចុះមកលើក្រុងសូដុម
និងក្រុងកូម៉ូរ៉ាពីព្រះអម្ចាស់មកគឺធ្លាក់ចេញពីលើមេឃមក។[25]ព្រះអង្គបំផ្លាញទីក្រុងទាំងនោះ ហើយគ្រប់ទាំងទីវាល ហើយនិងប្រជាជនដែលរស់នៅទីក្រុងនោះ
ហើយទីវាលដែលមានស្មៅដុះដែរ។
[26]ប៉ុន្តែ ភរិយារបស់លោកឡុត ដែលដើរតាមក្រោយគាត់ បានសម្លឹងក្រោយ ហើយនាងបានក្លាយជាសសរអំបិល។[27]លោកអប្រាហាំក្រោកតាំងពីព្រលឹម
ហើយចេញទៅកន្លែងដែលគាត់បានឈរជាមួយនៅចំពោះព្រះអម្ចាស់។[28]គាត់បានសម្លឹងមើលទៅឯក្រុងសូដុម និងក្រុងកូម៉ូរ៉ា
និងសម្លឹងមើលទៅឯទីវាលនៅក្នុងទឹកដីនោះ។ គាត់បានសម្លឹងមើល ឃើញផ្សែងហុយឡើងពីដីដូចជាផ្សែងរបស់គុកភ្លើង។
[29]ដូច្នេះ នៅពេលព្រះជាម្ចាស់បំផ្លាញទីក្រុងទាំងប៉ុន្មាន នៅទីវាល ព្រះជាម្ចាស់បាននឹងចាំពីលោកអប្រាហាំ។ ព្រះអង្គបានបញ្ជូនលោកឡុតចេញពីគ្រោះមហន្តរាយ
នៅពេលព្រះអង្គបំផ្លាញទីក្រុងផ្សេងៗ ដែលលោកឡុតបានរស់នៅ។
[30]ប៉ុន្តែ លោកឡុតបានឡើងទៅក្រុងសូអារ ទៅរស់នៅតាមតំបន់ភ្នំ ជាមួយកូនស្រីពីរនាក់ ដោយព្រោះគាត់មានការភ័យខ្លាចក្នុងការរស់នៅក្នុងក្រុងសូអារ។ ដូច្នេះ
គាត់និងកូនស្រីទាំងពីររបស់គាត់ បានទៅរស់នៅក្នុងរូងភ្នំវិញ ។
[31]កូនស្រីច្បងនិយាយទៅកូនស្រីប្អូនថា៖ «ឪពុករបស់យើងចាស់ហើយ ហើយគ្មានប្រុសណាមកគេងជាមួយយើង ដូចគេដូចឯងនៅក្នុងលោកនេះទេ។[32]មក
តោះយើងទៅបង្អកស្រាឪពុករបស់យើង ហើយយើងនឹងគេងជាមួយគាត់ ដូច្នេះយើងអាចបន្តពូជឪពុករបស់យើង»។[33]ដូច្នេះ
ពួកគេបានធ្វើឲ្យឪពុករបស់ពួកគេស្រវឹងនៅយប់នោះ។ បន្ទាប់មក កូនស្រីច្បងបានចូលទៅក្នុង ហើយគេងជាមួយឪពុងរបស់នាង
ហើយគាត់មិនដឹងថានាងចូលទៅគេងជាមួយគាត់នៅពេលណា ឬពេលណានាងក្រោកឡើងទេ។
[34]នៅថ្ងៃបន្ទាប់ បងស្រីច្បងនិយាយទៅកាន់ប្អូនស្រីពៅថា៖ «សូមស្តាប់ យប់មិញ បងបានទៅគេងជាមួយឪពុករួចហើយ។ តោះ យើងធ្វើឲ្យគាត់ស្រវឹងនៅយប់នេះទៀត
ហើយអូនត្រូវទៅក្នុងហើយគេងជាមួយគាត់ ដើម្បីឲ្យយើងអាចបន្តពូជពីឪពុករបស់យើង»។[35]ដូច្នេះ ពួកគេបានធ្វើឲ្យឪពុករបស់ពួកគេស្រវឹងនៅយប់នោះ
ហើយប្អូនស្រីពៅបានចូលទៅ ហើយគេងជាមួយគាត់។ គាត់មិនដឹងពេលណានាងគេង ឬពេលណានាងចេញពីគាត់នោះទេ។
[36]ដូច្នេះ កូនស្រីទាំងពីររបស់លោកឡុតក៏មានកូនដោយសារឪពុករបស់ពួកគេ។[37]កូនស្រីច្បងបង្កើតបានកូនប្រុសមួយ ហើយដាក់ឈ្មោះថា ម៉ូអាប់។ គាត់បានក្លាយជា
បុព្វបុរសរបស់ជនជាតិម៉ូអាប់សព្វថ្ងៃនេះ។[38]ចំណែក ប្អូនស្រីពៅក៏បង្កើតបានកូនប្រុសមួយដែរ ហើយ ដាក់ឈ្មោះកូននោះថា បេន អាំមី។ គាត់បានក្លាយជាបុព្វបុរសរបស់
ជនជាតិអាំម៉ូនសព្វថ្ងៃនេះ។

Genesis 19:1
ទេវតាទាំងពីរ
លោកុប្បត្តិ ១៨ និយាយថាបុរសពីរនាក់បានទៅក្រុងសូដុម។
នៅទីនេះយើងរៀនថាពួកគេពិតជាទេវតា។ (សូមមើល ១៨:២២)
ទ្វារក្រុងសូដុម
«ច្រកចូលទីក្រុងសូដុម» ទីក្រុងនេះមានជញ្ជាំងព័ទ្ធជុំវិញ,
ហើយមនុស្សត្រូវឆ្លងកាត់ច្រកទ្វារដើម្បីចូលទៅក្នុងនោះ។
នេះជាកន្លែងសំខាន់ណាស់នៅក្នុងទីក្រុង។
មនុស្សសំខាន់តែងតែចំណាយពេលនៅទីនោះ។
ហើយក្រាបចុះមុខទល់ដី
គាត់ដាក់ជង្គង់របស់គាត់លើដីបន្ទាប់មកប៉ះថ្ងាសនិងច្រមុះរបស់គាត់ដល់ដី។
លោកម្ចាស់
នេះគឺជាពាក្យគោរពដែលលោកឡុតបានប្រើសម្រាប់ពួកទេវតា។
សូមមេត្តាចូរទៅផ្ទះខ្ញុំ ជាអ្នកបម្រើរបស់លោក
«សូមអញ្ជើញស្នាក់នៅផ្ទះអ្នកបម្រើរបស់លោកសិន»
ជាអ្នកបម្រើរបស់លោក
លោកឡុតចាត់ទុកខ្លួនគាត់ជាអ្នកបម្រើដើម្បីបង្ហាញការគោរពដល់ពួកគេ។
បានលាងជើងជូនដល់លោក
មនុស្សចូលចិត្តការលាងជើងពួកគេបន្ទាប់ពីពួកគេធ្វើដំណើរ
ក្រោកឡើងពីព្រលឹម
«ភ្ញាក់ពីព្រលឹម»
យើងនឹងគេងនៅតាមទីធ្លាក្រុងយប់
នៅពេលដែលទេវតាទាំងពីរនិយាយដូច្នេះ
ពួកគេសំដៅទៅលើតែខ្លួនឯងប៉ុណ្ណោះមិនមែនទៅឡុតទេ។
ពួកគេទាំងពីរនាក់មានគម្រោងចំណាយពេលពេលយប់នៅទីលាន។
ភាសាខ្លះប្រើទម្រង់ផ្តាច់មុខ «យើង» នៅទីនេះ។
ទីធ្លាក្រុង
នេះគឺជាទីសាធារណគឺជាទីធ្លានៅក្នុងទីក្រុង។
ពួកគេក៏ទៅជាមួយគាត់
«ពួកគេត្រឡប់ទៅវិញជាមួយគាត់»
Genesis 19:4
មុនពេលពួកគេគេង
«មុនពេលមនុស្សដែលនៅក្នុងផ្ទះលោកឡុតចូលទៅគេង»
ពួកប្រុសៗនៅក្នុងទីក្រុង គឺពួកប្រុសៗនៅក្នុងទីក្រុងសូដុម
«បុរសនៃទីក្រុងនោះ,នោះគឺបុរសនៃក្រុងសូដុម» ឬគ្រាន់តែជា
«បុរសនៃទីក្រុងសូដុម»
ផ្ទះ
«ផ្ទះរបស់លោកឡុត»
ទាំងក្មេងទាំងចាស់
«ចាប់ទីពីក្មេងជាងគេរហូតដល់ចាស់ជាងគេ» នេះមានន័យថា «មនុស្សគ្រប់វ័យ»
ហើយសំដៅទៅលើបុរសនៅក្រុងសូដុមដែលនៅជុំវិញផ្ទះរបស់លោកឡុត។
មកក្នុងពួកយើង
«ដែលបានចូលក្នុងផ្ទះរបស់អ្នក»
គេងជាមួយពួកគេ
« រួមភេទជាមួយពួកគេ» អ្នកអាចប្រើពាក្យរបស់អ្នកអាចគួរសមជាងនេះ។
ការបកប្រែផ្សេងទៀត៖ «ស្គាល់ពួកគេជិតស្និទ្ធឬរួមភេទ»
Genesis 19:6
ក្រោយខ្នងគាត់
«នៅម្ខាងគាត់» ឬ«បន្ទាប់ពីគាត់បានចេញទៅ»
ខ្ញុំសូមអង្វរ, បងប្អូនខ្ញុំអើយ

generated on Wed Sep 10 16:16:32 2025

«ខ្ញុំសូមអង្វរអ្នក បងប្អូនខ្ញុំ»
បងប្អូនខ្ញុំអើយ
ឡុតបាននិយាយយ៉ាងរាក់ទាក់ទៅកាន់បុរសនៃទីក្រុងដោយសង្ឃឹមថាពួកគេនឹងស្តាប់គាត់។
ការបកប្រែផ្សេងទៀត៖ «មិត្តភក្តិរបស់ខ្ញុំ»
សូមកុំប្រព្រឹត្តអាក្រក់អី
« កុំធ្វើអ្វីដែលអាក្រក់» ឬ« កុំធ្វើអំពើអាក្រក់បែបនេះ»
មើល៍
«យកចិត្តទុកដាក់» ឬ «មើលនៅទីនេះ»
មិនទាន់គេងជាមួយ
«មិនបានរួមភេទជាមួយ» អ្នកអាចមានអាចនិយាយគួរសមជាងនេះក្នុងភាសាអ្នក។
ការបកប្រែផ្សេងទៀត៖ «មិនបានដឹង»
គិតថាល្អនៅចំពោះភ្នែករបស់អ្នករាល់គ្នាចុះ
«អ្វីក៏ដោយដែលអ្នកចង់បាន» ឬ «អ្វីដែលអ្នកគិតថាត្រឹមត្រូវ»
នៅក្រោមដំបូលផ្ទះរបស់ខ្ញុំ
បុរសទាំងពីរនាក់ជាភ្ញៀវនៅក្នុងផ្ទះឡុត ដូច្នេះគាត់ត្រូវការការពារពួកគេ។ ពាក្យថា« ដំបូល»
គឺជានិមិត្តរូបនៃផ្ទះទាំងមូលនិងពាក្យប្រៀបធៀបសម្រាប់ឡុតការពារពួកគេ។
ការបកប្រែផ្សេងទៀត៖ «ចូលក្នុងផ្ទះខ្ញុំ
ហើយព្រះជាម្ចាស់រំពឹងថាខ្ញុំនឹងការពារពួកគេ»
Genesis 19:9
ថយចេញទៅ!
«ថយចេញ!» ឬ «ចេញពីផ្លូវរបស់យើង!»
ម្នាក់នេះជាជនបរទេសមករស់នៅទីនោះ
«ម្នាក់នេះមកទីនេះក្នុងនាមជាអ្នកក្រៅ» ឬ «ជនបរទេសនេះបានមករស់នៅទីនេះ»
ម្នាក់នេះ
«លោកឡុត» ។ បុរសកំពុងនិយាយគ្នា។
ប្រសិនបើវាមិនច្បាស់នៅក្នុងភាសារបស់អ្នក
អ្នកអាចឱ្យបុរសនិយាយទៅកាន់ឡុតនៅទីនេះដូចជានៅUDB។
ឥឡូវ វាបានក្លាយជាចៅក្រមរបស់យើងហើយ
«ហើយឥឡូវនេះគាត់គិតថាគាត់មានសិទ្ធិប្រាប់យើងថាអ្វីដែលត្រូវនិងអ្វីដែលខុស» ឬ«
ប៉ុន្តែយើងនឹងមិនអនុញ្ញាតឱ្យគាត់បញ្ឈប់យើងពីការធ្វើអ្វីដែលយើងចង់ធ្វើនោះទេ»
ហើយឥឡូវគាត់
«ហើយទោះបីគាត់គ្មានហេតុផលត្រឹមត្រូវក៏ដោយ គាត់នៅតែ»
ឥឡូវយើង
«ពីព្រោះអ្នកកំពុងប្រាប់យើងថាអ្វីដែលយើងកំពុងធ្វើគឺខុស យើង»
ឥឡូវនេះ យើងនឹងប្រព្រឹត្តអាក្រក់ជាមួយអ្នកខ្លាំងជាងពួកគេទេ
បុរសទាំងនោះខឹងនឹងលោកឡុតបាននិយាយថា «កុំធ្វើអំពើអាក្រក់» (១៩: ៦)
ដូច្នេះពួកគេកំពុងតែគំរាមធ្វើអាក្រក់ជាងលោកឡុតដែលបានខ្លាចកាលពីដើម។
ការបកប្រែផ្សេងទៀត៖
«យើងនឹងធ្វើអាក្រក់ជាមួយអ្នកជាងយើងនឹងធ្វើជាមួយពួកគេ»
ពួកគេបានរុញយ៉ាងខ្លាំងទាស់នឹងលោកឡុត ហើយចូលមកជិតដើម្បីទម្លោះទ្វារ
អត្ថន័យមានគឺ ១)«
ពួកគេបានខិតទៅជិតបុរសនោះដល់ឡុតរហូតដល់ពួកគេជិតទម្លោះទ្វារ» ឬ ២)
ពួកគេបានរុញច្រានឡុតទៅនឹងជញ្ជាំងឬទ្វារផ្ទះហើយរៀបនឹងបំបែកទ្វារចុះ។
បុរស.....ឡុត
នេះគឺជាវិធីដែលសំដៅទៅកាន់លោកឡុត។
Genesis 19:10
ប៉ុន្តែ បុរស
«ប៉ុន្តែភ្ញៀវពីរនាក់របស់ឡុត» ឬ «ប៉ុន្តែទេវតាទាំងពីរ»
បុរសពីនាក់នោះបានលូកដៃរបស់ពួកគេ ហើយបាននាំ.....ពួកគេ ហើយបិទ
ភាសារបស់អ្នកប្រហែលជាត្រូវការបន្ថែមថាបុរសបានបើកទ្វារជាមុនសិន។
ការបកប្រែផ្សេងទៀត៖ «បុរសបានបើកទ្វារអោយចំហរ
ដូច្នេះពួកគេអាចចាប់ដៃពួកគេទាញ...ពួកគេ ហើយពួកគេបានបិទ »
ទេវតាបានពួកប្រុសៗដែលនៅមាត់ទ្វារផ្ទះឲ្យខ្វាក់ភ្នែក
ឃ្លា «វាយដោយងងឹតភ្នែក» គឺជាពាក្យប្រៀបធៀប
ភ្ញៀវមិនបានធ្វើបាបបុរសឡើយ។ ការបកប្រែផ្សេងទៀត៖
«ភ្ញៀវរបស់ឡុតធ្វើឱ្យបុរសងងឹតភ្នែក» ឬ «ពួកគេបានមើលឃើញឆ្ងាយ»
ទាំងក្មេងទាំងចាស់
«បុរសគ្រប់វ័យ» នេះបញ្ជាក់ថាភ្ញៀវបានធ្វើឱ្យបុរសទាំងអស់ងងឹតភ្នែក។
នេះអាចបង្ហាញពីជំហរសង្គមជាជាងអាយុ។ ការបកប្រែផ្សេងទៀត៖
គ្រប់ទាំងតូចទាំងធំ»
Genesis 19:12
បន្ទាប់មកបុរសទាំងពីរនាក់បាននិយាយ
«បន្ទាប់មកបុរសទាំងពីបានរនិយាយថា» ឬ«បន្ទាប់មកទេវតាបាននិយាយ»
តើលោកមានអ្នកផ្សេងទៀតនៅទីនេះទេ?
«តើមានសមាជិកផ្សេងទៀតនៃគ្រួសាររបស់អ្នកនៅក្នុងទីក្រុងទេ?» ឬ
«តើអ្នកមានសមាជិកគ្រួសារផ្សេងទៀតនៅក្នុងកន្លែងនេះទេ?»
អ្នកណាដែលអ្នកមាននៅក្នុងទីក្រុង
«មានសមាជិកផ្សេងទៀតក្នុងគ្រួសាររបស់អ្នកនៅក្នុងទៅទីក្រុង»
យើងនឹងបំផ្លាញ
ពាក្យថា «យើង» នៅទីនេះគឺផ្តាច់មុខ។
មានតែទេវតាពីរទេដែលអាចបំផ្លាញទីក្រុងបាន ឡុតនឹងមិនបំផ្លាញឡើយ។
ប្រសិនបើភាសារបស់អ្នកមានទម្រង់ «យើង» ផ្តាច់មុខសូមប្រើវានៅទីនេះ។
ការចោទប្រកាន់ទាស់នឹងទីក្រុងនេះ នៅចំពោះព្រះអម្ចាស់បានឮយ៉ាងខ្លាំង
នេះអាចត្រូវបានប្រើឡើងវិញដូច្នេះថា «ការចោទប្រកាន់»
នាមអរូបីត្រូវបានបង្ហាញជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត៖
«មានមនុស្សជាច្រើនបានប្រាប់ដល់ព្រះអម្ចាស់ថាប្រជាជននៅទីក្រុងនេះកំពុងធ្វើអំពើអាក្រក់»
Genesis 19:14
លោកឡុតបានចេញទៅ
«ដូច្នេះលោកឡុតបានចាកចេញពីផ្ទះ»
កូនប្រសារប្រុសៗរបស់គាត់,គឺពួកប្រុសៗដែលបានសន្យារៀបការជាមួយកូនស្រីៗរបស់លោក
នៅក្នុងច្បាប់ បុរសដែលបានសន្យាថានឹងរៀបការជាមួយកូនស្រីរបស់គាត់ - ឃ្លា
«បុរសដែលបានសន្យាថានឹងរៀបការជាមួយកូនស្រីរបស់គាត់» ពន្យល់ពីអ្វី
«កូនប្រសារប្រុស» ទីនេះមានន័យ។ ការបកប្រែផ្សេងទៀត៖
«បុរសដែលនឹងរៀបការជាមួយកូនស្រីរបស់គាត់» ឬ «គូដណ្តឹងកូនស្រីរបស់គាត់»
នៅពេលព្រឹកព្រលឹម
«មុនពេលដែលព្រះអាទិត្យរះឡើង»
ចូរចេញទៅ
«ចេញទៅឥឡូវ»
លោកត្រូវបំផ្លាញជាមួយទីក្រុងដោយដោយសារការជំនុំជម្រះឡើយ
គាត់អាចត្រូវបានថ្លែងនៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះព្រះអម្ចាស់ក៏មិនបំផ្លាញអ្នកដែរនៅពេលដែលទ្រង់ដាក់ទណ្ឌកម្មប្រជាជនទីក្រុងនេះ»
មិនត្រូវបានបំផ្លាញចោលក្នុងការជំនុំជំរះ
ព្រះបានបំផ្លាញប្រជាជននៃទីក្រុងនេះគឺដូចជាមនុស្សម្នាក់កំពុងបោសធូលីដី។
នៃទីក្រុង
ត្រង់នេះ«ទីក្រុង»តំណាងពីប្រជាជន។
Genesis 19:16
ប៉ុន្តែ គាត់នៅបង្អែបង្អង់
«ប៉ុន្តែឡុតស្ទាក់ស្ទើរ» ឬ «ប៉ុន្តែលោកឡុតមិនបានចាប់ផ្តើមចាកចេញទេ»
ទេវតាទាំងពីរបានចាប់
«ដូច្នេះបុរសទាំងពីរចាប់យក» ឬ «ដូច្នេះពួកទេវតាចាប់យក»
ផ្តល់មេត្តាដល់ពួកគេ
«មានសេចក្តីអាណិតអាសូរចំពោះលោកឡុត»
ព្រះអម្ចាស់ត្រូវបានពិពណ៌នាថា«មេត្តាករុណា»ពីព្រោះទ្រង់បានជួយសង្គ្រោះជីវិតលោកឡុត
និង
គ្រួសាររបស់គាត់ជាជាងបំផ្លាញពួកគេនៅពេលដែលទ្រង់បានបំផ្លាញប្រជាជននៅក្រុងសូដុមដោយសារព
បន្ទាប់មក ទេវតាទាំងពីរបាននាំពួកគេចេញ
«នៅពេលបុរសទាំងពីរនាក់បាននាំគ្រួសារឡុតចេញ»
ចូររត់ដើម្បីឲ្យអ្នកបានរស់!
នេះជាវិធីប្រាប់អោយគេអោយរត់ដើម្បីកុំអោយគេងាប់។ ការបកប្រែផ្សេងទៀត៖
«រត់ទៅឆ្ងាយហើយជួយសង្គ្រោះជីវិតអ្នក!»
កុំមើលក្រោយឡើយ
ឃ្លា «នៅទីក្រុង» ត្រូវបានយល់។ ការបកប្រែផ្សេងទៀត៖
«សូមកុំមើលត្រលប់ទៅទីក្រុងវិញ» ឬ «កុំមើលត្រលប់ទៅក្រុងសូដុម»
នៅលើទីវាល
នេះមានន័យថាវាលទំនាបទន្លេយ័រដាន់។
នេះសំដៅទៅលើតំបន់ទូទៅនៃទន្លេយ័រដាន់។

generated on Wed Sep 10 16:16:32 2025

ដើម្បីកុំឲ្យអ្នកត្រូវបំផ្លាញឡើយ
វាត្រូវបានគេយល់ថាពួកគេនឹងបោសសំអាតជាមួយប្រជាជននៃទីក្រុង។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ឬផ្សេងទៀតដែលព្រះនឹងបំផ្លាញអ្នករួមជាមួយប្រជាជននៃទីក្រុង»
កុំអោយអ្នកត្រូវបំផ្លាញឡើយ
ព្រះជាម្ចាស់បានបំផ្លាញប្រជាជននៃទីក្រុងនេះគឺដូចជាមនុស្សម្នាក់កំពុងបោសធូលីដី។
Genesis 19:18
ខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់បានទទួលព្រះគុណនៅចំពោះលោកម្ចាស់
ដើម្បីផ្គាប់ចិត្តនរណាម្នាក់ត្រូវបានគេនិយាយដូចជា «ការពេញចិត្ត»
គឺជាវត្ថុដែលត្រូវបានរកឃើញ។ គួរបញ្ជាក់ផងដែរថា« ការមើលឃើញ»
គឺជាការប្រៀបធៀបដែលតំណាងឱ្យគំនិត ឬ យោបល់របស់មនុស្សម្នាក់។
ការបកប្រែផ្សេងទៀត៖ «អ្នកពេញចិត្តនឹងខ្ញុំ»
អ្នកបម្រើរបស់លោកម្ចាស់
ឡុតបានបង្ហាញការគោរពដោយសំដៅទៅលើខ្លួនគាត់ថាជា «អ្នកបម្រើរបស់អ្នក»
ការបកប្រែផ្សេងទៀត៖ «ខ្ញុំជាអ្នកបម្រើលោកមាន»
លោកម្ចាស់បានផ្តល់ក្តីមេត្តាយ៉ាងធំក្នុងការសង្គ្រោះជីវិតរបស់យើងខ្ញុំ
នាមអរូបី « សេចក្តីសប្បុរស» អាចត្រូវបានបញ្ជាក់ថាជា« ចិត្តល្អ»
ការបកប្រែផ្សេងទៀត៖ «ទ្រង់មានចិត្តល្អចំពោះខ្ញុំដោយជួយសង្គ្រោះជីវិតខ្ញុំ»
ខ្ញុំមិនអាចរត់គេចទៅឯភ្នំបានទេ ព្រោះគ្រោះមហន្តរាយនឹងបំផ្លាញខ្ញុំ និងខ្ញុំនឹងស្លាប់ហើយ
ការមិនអាចនៅឆ្ងាយពីក្រុងសូដុមបាននៅពេលដែលព្រះជាម្ចាស់បំផ្លាញទីក្រុងត្រូវបានគេនិយាយថាជា
«គ្រោះមហន្តរាយ» គឺជាមនុស្សម្នាក់ដែលនឹងដេញតាមចាប់លោកឡុត។
ការបកប្រែផ្សេងទៀត៖ «គ្រួសារខ្ញុំនិងខ្ញុំប្រាកដជាស្លាប់នៅ
ពេលដែលព្រះបំផ្លាញប្រជាជនក្រុងសូដុម
ពីព្រោះភ្នំនៅឆ្ងាយពីយើងដើម្បីអោយយើងទទួលបានសុវត្ថិភាព»
ជីវិតខ្ញុំ....ខ្ញុំមិនអាចរត់គេច...មកលើខ្ញុំ, ហើយនិងខ្ញុំនឹងស្លាប់
នេះបញ្ជាក់ថាគ្រួសាររបស់ឡុតនឹងស្លាប់ជាមួយគាត់។ ការបកប្រែផ្សេងទៀត៖
«ជីវិតរបស់យើង ... យើងមិនអាចរត់គេចបានទេ ... មកលើយើង.
ហើយយើងនឹងស្លាប់»
សូមឲ្យខ្ញុំរត់គេចទៅទីនោះចុះ (តើវាមិនតូចទេឬអី?) ហើយខ្ញុំនឹងមានជីវិតរស់នៅទីនោះ
ឡុតបានប្រើសំណួរនេះដើម្បីឱ្យពួកទេវតាកត់សម្គាល់ថាទីក្រុងនេះពិតជាតូចមែន។
ការបកប្រែផ្សេងទៀត៖ «សូមឱ្យខ្ញុំរត់គេចខ្លួននៅទីនោះ។
អ្នកអាចដឹងថាវាតូចប៉ុណ្ណា។
ប្រសិនបើអ្នកអនុញ្ញាតឱ្យយើងទៅទីនោះយើងនឹងរស់នៅ»
សូមឲ្យខ្ញុំរត់គេចទៅទីនោះចុះ
សំណូមពររបស់ឡុតអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«ជំនួសឱ្យការបំផ្លាញទីក្រុងនោះខ្ញុំសូមរត់គេចពីទីនោះ»
ខ្ញុំនឹងមានជីវិតរស់នៅ
នេះបញ្ជាក់ថាជីវិតគ្រួសារឡុតនឹងត្រូវបានសង្គ្រោះរួមជាមួយគាត់។
នេះក៏អាចត្រូវបានបញ្ជាក់ជាទម្រង់សកម្មផងដែរ។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះយើងនឹងរស់នៅ» ឬ «ដូច្នេះយើងនឹងអាចសង្គ្រោះបាន»
Genesis 19:21
ខ្ញុំយល់ព្រមតាមសំណើនេះ
«ខ្ញុំនឹងធ្វើតាមអ្វីដែលអ្នកសុំ»
មិនអាចធ្វើអ្វីបាន
នេះអាចត្រូវបានធ្វើឱ្យកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត៖
«មិនអាចបំផ្លាញទីក្រុងផ្សេងទៀតបានទេ»
សូអារ
អ្នកបកប្រែអាចបន្ថែមលេខយោងដែលនិយាយថា
«ឈ្មោះសូអារស្តាប់ទៅដូចជាពាក្យហេព្រើរដែលមានន័យថា«តិចតួច» ។
ឡុតបានហៅទីក្រុងនេះថា« តូច» នៅក្នុងលោកុប្បត្តិ ១៩:២០»
Genesis 19:23
ថ្ងៃបានរះឡើងមកលើផែនដី
«ព្រះអាទិត្យបានរះនៅលើផែនដី» ឃ្លា «នៅលើផែនដី»
អាចត្រូវបានទុកចោលយ៉ាងច្បាស់ដូចដែលវាមាននៅក្នុងយូឌីបីដែលវាមិនត្រូវបានបកប្រែ
ពេលលោកឡុតទៅដល់ក្រុងសូអារ
នេះគឺបញ្ជាក់ថាគ្រួសាររបស់លោកឡុតនៅជាមួយគាត់។ ការបកប្រែផ្សេងទៀត៖
«នៅពេលដែលលោកឡុត និង គ្រួសាររបស់គាត់ទៅដល់ទីក្រុងសូអារ»
ព្រះអម្ចាស់បានធ្វើឲ្យភ្លៀងធ្លាក់ជាស្ពាន់ធ័រ និងភ្លើងធ្លាក់ចុះមកលើក្រុងសូដុម
និងក្រុងកូម៉ូរ៉ាពីព្រះអម្ចាស់មកគឺធ្លាក់ចេញពីលើមេឃមក
ឃ្លាថា«មកពីយេហូវ៉ា»តំណាងឱ្យព្រះចេស្តារបស់ព្រះជាម្ចាស់ដែលធ្វើឱ្យស្ពាន់ធ័រនិងភ្លើងធ្លាក់មកលើទីក្រុ
ការបកប្រែផ្សេងទៀត៖
«ព្រះអម្ចាស់បានធ្វើអោយស្ពាន់ធ័រនិងភ្លើងធ្លាក់ចុះពីលើមេឃមកលើក្រុងសូដុមនិងកូម៉ូរ៉ា។
ស្ពាន់ធ័រ និងភ្លើង
ពាក្យទាំងពីរនេះត្រូវបានប្រើជាមួយគ្នាដើម្បីពិពណ៌នាអំពីប្រធានបទមួយ។
ការបកប្រែផ្សេងទៀត៖ «ដុតស្ពាន់ធ័រ» ឬ «ភ្លើងភ្លៀង»
ទីក្រុងនោះ
នេះសំដៅទៅលើក្រុងសូដុមនិងកូម៉ូរ៉ា
ប៉ុន្តែក៏សំដៅទៅលើក្រុងចំនួនបីផ្សេងទៀតដែរ។
ប្រជាជននៅទីក្រុង
«សម្រាប់ប្រជាជនណាដែលរស់នៅក្នុងទីក្រុង»
Genesis 19:26
នាងបានក្លាយជាសសរអំបិល
«នាងបានក្លាយជារូបសំណាក់អំបិល» ឬ
«រាងកាយរបស់នាងបានក្លាយជាដុំថ្មអំបិលខ្ពស់»។
ដោយសារនាងមិនស្តាប់បង្គាប់ទេវតាដែលបានប្រាប់ពួកគេកុំ ឲ្យ
ក្រឡេកមើលទីក្រុងវិញ
ព្រះជាម្ចាស់បានធ្វើអោយនាងក្លាយជារូបសំណាក់ដូចរូបចម្លាក់ធ្វើពីអំបិលថ្ម។
សម្លឹងមើល
គេនិយាយថាមើលដូចជា
ទាក់ទាញការចាប់អារម្មណ៍ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលមានជាបន្តបន្ទាប់។
ដូចជាផ្សែងរបស់គុកភ្លើង
នេះបង្ហាញថាវាជាចំនួនផ្សែងច្រើនណាស់។ ការបកប្រែផ្សេងទៀត៖
«ដូចជាផ្សែងចេញពីអណ្តាតភ្លើងធំណាស់»
Genesis 19:29
ព័ត៌មានទូទៅ
នៅក្នុងខ២៩គឺសង្ខេបនៅក្នុងជំពូកនេះ។
ព្រះជាម្ចាស់បាននឹងចាំពីលោកអប្រាហាំ
នេះប្រាប់ពីមូលហេតុដែលព្រះបានជួយសង្គ្រោះលោកឡុត។ ដើម្បី «ហៅឱ្យចាំ»
គឺជាវិធីនៃការនិយាយថា «ចងចាំ» ។
នេះមិនបានន័យថាព្រះជាម្ចាស់ភ្លេចអំពីលោកអប្រាហាំទេ។
មានន័យថាទ្រង់បានចាត់ទុកលោកអប្រាហាំថាមានចិត្តមេត្តាករុណាចំពោះគាត់។
ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់បានគិតអំពីលោកអប្រាហាំហើយមានព្រះហឫទ័យអាណិតអាសូរដល់គាត់»
បញ្ជូនចេញពីការបំផ្លាញ
«ឆ្ងាយពីការបំផ្លាញ» ឬ «ឆ្ងាយពីគ្រោះថ្នាក់»
Genesis 19:30
លោកឡុតបានឡើងទៅក្រុងសូអារ ទៅរស់នៅតាមតំបន់ភ្នំ
ឃ្លា «បានចេញពី»
ត្រូវបានគេប្រើពីព្រោះលោកឡុតបានទៅកន្លែងខ្ពស់ជាងនៅលើភ្នំ។
Genesis 19:31
កូនច្បង
«លោកឡុតបានកូនស្រីដំបូង» ឬ«កូនស្រីច្បង»
កូនស្រីប្អូន
«កូនស្រីប្អូន» ឬ«ប្អូនស្រីនាង»
ដូចគេដូចឯងនៅក្នុងលោកនេះ
នៅទីនេះ «លោកនេះ» គឺតំណាងអោយមនុស្ស។ការបកប្រែផ្សេងទៀត៖
«ដូចមនុស្សគ្រប់កន្លែងដែលគេធ្វើ»
បង្កកស្រា
ត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាគោលដៅរបស់ពួកគេគឺធ្វើឱ្យគាត់ស្រវឹង។
ការបកប្រែផ្សេងទៀត៖ «ផឹកស្រាហូតដល់គាត់ស្រវឹង» ឬ «ស្រវឹងជាមួយស្រា»
ដូច្នេះយើងអាចបន្តពូជឪពុករបស់យើង
នេះនិយាយអំពីការផ្តល់កូនចៅដល់ឡុតដូចជាគ្រួសាររបស់គាត់ជាខ្សែដែលពួកគេធ្វើឱ្យវែងជាងមុន។
ការបកប្រែផ្សេងទៀត៖
«ដូច្នេះយើងអាចបង្កើតកូនដែលនឹងក្លាយជាកូនចៅឪពុករបស់យើង»
គាត់មិនដឹងថានាងចូលទៅគេងជាមួយគាត់នៅពេលណា ឬពេលណានាងក្រោកឡើងទេ
«គាត់មិនដឹងអ្វីទាំងអស់អំពីវា» ឬ «គាត់មិនដឹងថានាងបានដេកជាមួយគាត់ទេ»
Genesis 19:34
យើងធ្វើឲ្យគាត់ស្រវឹង.....ឬពេលណានាងចេញពីគាត់នោះ

generated on Wed Sep 10 16:16:32 2025

នៅក្នុង១៩:៣១កូនស្រីច្បងនិយាយទៅកូនស្រីប្អូនថា៖
«ឪពុករបស់យើងចាស់ហើយ ហើយគ្មានប្រុសណាមកគេងជាមួយយើង
ដូចគេដូចឯងនៅក្នុងលោកនេះទេ។
គាត់ស្រវឹង
ត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាគោលដៅរបស់ពួកគេគឺធ្វើឱ្យគាត់ស្រវឹង។
ការបកប្រែផ្សេងទៀត៖ «ផឹកស្រាហូតដល់គាត់ស្រវឹង» ឬ «ស្រវឹងជាមួយស្រា»
ដើម្បីឲ្យយើងអាចបន្តពូជពីឪពុករបស់យើង
នេះនិយាយអំពីការផ្តល់កូនចៅដល់ឡុតដូចជាគ្រួសាររបស់គាត់ជាខ្សែដែលពួកគេធ្វើឱ្យ
ការបកប្រែផ្សេងទៀត៖
«ដូច្នេះយើងអាចបង្កើតកូនដែលនឹងក្លាយជាកូនចៅឪពុករបស់យើង»
គាត់មិនដឹងពេលណានាងគេង ឬពេលណានាងចេញពីគាត់នោះទេ
«គាត់មិនដឹងអ្វីទាំងអស់អំពីវា» ឬ «គាត់មិនដឹងថានាងបានដេកជាមួយគាត់ទេ»
Genesis 19:36
កូនស្រីទាំងពីររបស់លោកឡុតក៏មានកូនដោយសារឪពុករបស់ពួកគេ
«មានផ្ទៃពោះដោយឪពុករបស់ពួកគេ» ឬ «មានផ្ទៃពោះជាមួយឪពុករបស់ពួកគេ»
គាត់បានក្លាយ
«គឺគាត់»
ជនជាតិម៉ូអាប់សព្វថ្ងៃនេះ
«ប្រជាជនម៉ូអាប់ដែលកំពុងរស់នៅសព្វថ្ងៃ»
ថ្ងៃនេះ
ពាក្យថា «ថ្ងៃនេះ»
ពេលដែលអ្នក
ពេលវេលាដែលអ្នកនិពន្ធសៀវភៅលោកុប្បត្តិកំពុងរស់នៅ។
អ្នកនិពន្ធបានកើតមកហើយបានសរសេររឿងនេះជាច្រើនឆ្នាំបន្ទាប់ពីគ្រួសាររបស់ឡុតរស់នៅនិងស្លាប់។
បេន អាំមី
នេះគឺជាឈ្មោះមនុស្សប្រុស។
ជនជាតិអាំម៉ូន
«កូនចៅអាំម៉ូន» ឬ «ប្រជាជនអាំម៉ូន»

---

20 [1]លោកអប្រាហាំបានធ្វើដំណើរពីទីនោះ ឆ្ពោះទៅទឹកដីណេកិប ហើយគាត់រស់នៅចន្លោះក្រុងកាដេស និងក្រុងស៊ើរ។ បន្ទាប់មក គាត់បានទៅនៅក្រុង
កេរ៉ាក្នុងនាមជាជនបរទេស។[2]លោកអប្រាហាំនិយាយទាក់ទងនឹងភរិយារបស់គាត់ថា៖ «នាងជាប្អូនស្រីរបស់ខ្ញុំ»។ ដូច្នេះ ព្រះបាទអប៊ីម៉ាឡិច ជាស្តេចនៅក្រុងកេរ៉ា
បានចាត់អ្នកបម្រើឲ្យទៅ ហើយយកនាងសារ៉ាមក។[3]ប៉ុន្តែ ព្រះជាម្ចាស់បានមកជួបព្រះបាទអប៊ីម៉ាឡិចនៅក្នុងសុបិនយប់នោះ ដោយមានបន្ទូលថា៖ «មើល
អ្នកនឹងត្រូវស្លាប់ ដោយព្រោះស្ត្រីដែលអ្នកបានយកមក ដ្បិតនាងជាភរិយារបស់គេទេ»។
[4]ព្រះបាទអប៊ីម៉ាឡិចមិនទាន់បានចូលទៅជិតនាងនៅឡើយទេ ហើយស្តេចបានមានបន្ទូលថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គសម្លាប់ សូម្បីតែប្រជាជាតិសុចរិត?
[5]តើមិនមែនគាត់ខ្លួនឯងទេឬអីដែលនិយាយមកទូលបង្គំថា នាងជាប្អូនស្រីរបស់ខ្ញុំ? សូម្បីតែនាងខ្លួនឯងផ្ទាល់និយាយថា គាត់គឺជាបងប្រុសរបស់ខ្ញុំ។
ទូលបង្គំបានធ្វើការនេះដោយស្មោះត្រង់ចេញពីចិត្តរបស់ទូលបង្គំ និងពីដៃរបស់អ្នកដែលឥតកំហុស»។
[6]បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលទៅស្តេចនៅក្នុងសុបិនថា៖ «ពិតមែនហើយ យើងក៏ដឹងដែរថា ដួងចិត្តរបស់ទ្រង់ស្មោះត្រង់ក្នុងការធ្វើការនេះ
ហើយយើងក៏បានការពារទ្រង់មិនឲ្យធ្វើបាបទាស់នឹងយើងដែរ។ ហេតុដូច្នេះហើយ បានជាយើងហាមមិនឲ្យអ្នកប៉ះពាល់នាងឡើយ។[7]ដូច្នេះ
ចូរប្រគល់នាងទៅស្វាមីរបស់នាងវិញចុះ ដ្បិត គាត់គឺជាព្យាការីម្នាក់។ គាត់នឹងអធិស្ឋានឲ្យអ្នក ហើយអ្នកនឹងបានរស់។ ប៉ុន្តែ ប្រសិនបើ ទ្រង់មិនប្រគល់នាងឲ្យគាត់វិញទេ
ចូរដឹងថា ទ្រង់និងអស់អ្នកដែលនៅជាមួយទ្រង់ស្លាប់»។
[8]ព្រះបាទអប៊ីម៉ាឡិចបានក្រោកតាំងពីព្រលឹម ហើយកោះហៅអ្នកបម្រើរបស់ស្តេចទាំងអស់មកគាល់ព្រះអង្គ។ ព្រះអង្គបានប្រាប់ការទាំងអស់នេះទៅកាន់ពួកគេ
ហើយពួកគេមានការភ័យខ្លាចជាខ្លាំង។[9]បន្ទាប់មក ព្រះបាទអប៊ីម៉ាឡិចបានហៅលោកអប្រាហាំមក ហើយមានរាជឱង្ការទៅគាត់ថា៖
«ហេតុអ្វីបានជាលោកធ្វើដូច្នេះជាមួយយើង? តើយើងបានធ្វើបាបអ្វីដល់លោក បានជាលោកនាំយើង និងអាណាចក្ររបស់យើងទៅធ្វើបាបយ៉ាងធំដូច្នេះ?
អ្វីដែលលោកបានធ្វើចំពោះយើងនេះ គឺជាអ្វីដែលលោកមិនគួរធ្វើទេ»។
[10]ព្រះបាទអប៊ីម៉ាឡិចមានបន្ទូលទៅកាន់លោកអប្រាហាំថា៖ «តើលោកមានគោលបំណងអ្វីបានជាធ្វើការនេះ?[11]លោកអប្រាហាំទូលថា៖ «ដោយព្រោះទូលបង្គំគិតថា
ប្រហែលជាគ្មានការកោតខ្លាចព្រះទេនៅទីនេះ ហើយថា គេនឹងសម្លាប់ទូលបង្គំ ដោយសារតែភរិយាទូលបង្គំមិនខាន។[12]ម្យ៉ាងវិញទៀត នាងគឺជាប្អូនស្រីរបស់ទូលបង្គំមែន
នាងគឺជាកូនស្រីរបស់ឪពុកទូលបង្គំ ប៉ុន្តែមិនមែនជាកូនស្រីម្តាយរបស់ទូលបង្គំទេ ហើយទូលបង្គំបានរៀបការជាមួយនាង។
[13]នៅពេលដែលព្រះជាម្ចាស់បានឲ្យទូលបង្គំចាកចេញពីផ្ទះឪពុករបស់ទូលបង្គំហើយធ្វើដំណើរចេញពីកន្លែងមួយទៅកន្លែងមួយ ទូលបង្គំបានប្រាប់នាងថា៖
«អ្នកត្រូវបង្ហាញពីភាពស្មោះត្រង់ក្នុងនាមជាភរិយារបស់បង គឺនៅទីណាដែលយើងទៅ សូមប្រាប់គេថា៖ «គាត់ជាបងប្រុសរបស់ខ្ញុំ»។[14]បន្ទាប់មក
ព្រះបាទអប៊ីម៉ាឡិចបានយកចៀម និងគោ ព្រមទាំងអ្នកបម្រើប្រុសស្រីជាច្រើន ហើយប្រគល់ពួកគេឲ្យទៅលោកអប្រាហាំ។ បន្ទាប់មក ព្រះអង្គបានប្រគល់នាងសារ៉ា
ភរិយារបស់លោកអប្រាហាំទៅគាត់វិញ។
[15]ព្រះបាទអប៊ីម៉ាឡិចមានរាជឱង្ការថា៖ «មើល៍ ទឹកដីរបស់យើងនៅចំពោះលោកហើយ។[16]ចូរនៅកន្លែងណាតាមតែលោកចូលចិត្តចុះ»។
ព្រះអង្គមានរាជឱង្ការទៅនាងសារ៉ាថា៖ «មើល៍ យើងប្រគល់ដល់បងប្រុសដែលជាស្វាមីរបស់នាងប្រាក់ចំនួនមួយពាន់តម្លឹង។
ដើម្បីគ្រប់បាំងកំហុសដែលបានធ្វើទាស់នឹងនាងនៅក្នុងភ្នែករបស់មនុស្សគ្រប់គ្នាដែលនៅជាមួយនាង និងនៅចំពោះមុខរបស់មនុស្សគ្រប់គ្នា
អ្នកមិនបានបាត់បង់កិត្តិយសអ្វីឡើយ»។
[17]លោកអប្រាហាំអធិស្ឋានទៅព្រះជាម្ចាស់ ហើយព្រះជាម្ចាស់បានប្រោសព្រះបាទអប៊ីម៉ាឡិច មហេសីរបស់ព្រះអង្គ និងអ្នកបម្រើប្រុសស្រី
ដើម្បីឲ្យពួកគេបានបង្កើតកូនចៅបាន។[18]ដ្បិត ព្រះអម្ចាស់បានធ្វើឲ្យស្ត្រីទាំងអស់នៅក្នុងព្រះរាជវង្សរបស់ព្រះបាទអប៊ីម៉ាឡិចទាំងមូល ក្លាយទៅជាស្ត្រីអារ ព្រោះតែនាង
សារ៉ាជាភរិយារបស់លោកអប្រាហាំ។

Genesis 20:1
ក្រុងស៊ើរ
នេះគឺជាតំបន់វាលខ្សាច់មួយនៅព្រំដែនខាងកើតនៃប្រទេសអេស៊ីប។
បានចាត់អ្នកបម្រើឲ្យទៅ ហើយយកនាងសារ៉ាមក
«ចាត់បុរសរបស់គាត់ឲ្យទៅទទួលសារ៉ាហើយនាំនាងទៅគាត់»
ព្រះជាម្ចាស់បានមកជួបព្រះបាទអប៊ីម៉ាឡិច
«ព្រះជាម្ចាស់លេចមកឲ្យស្តេចអេប៊ីម៉ាឡិចឃើញ»
មើល
នៅទីនេះពាក្យ «មើល» បន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
«ស្តាប់ខ្ញុំ»
អ្នកនឹងត្រូវស្លាប់
នេះគឺជាវិធីដ៏រឹងមាំក្នុងការនិយាយថាស្តេចនឹងសោយទិវង្គត។
ការបកប្រែផ្សេងទៀត៖ «អ្នកនឹងស្លាប់ឆាប់ៗ» ឬ «ខ្ញុំនឹងសម្លាប់អ្នក»
ភរិយារបស់គេ
«នាងជាស្ត្រីដែលរៀបការរួចហើយ»
Genesis 20:4
ឥឡូវ.....នាង
ពាក្យរបស់គាត់ត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាព័ត៌មានអំពីស្តេចអប៊ីម៉ាឡិច
ព្រះបាទអប៊ីម៉ាឡិចមិនទាន់បានចូលទៅជិតនាងនៅឡើយទេ
នេះជាវិធីគួរសមក្នុងការនិយាយថាគាត់មិនបានរួមភេទជាមួយនាងទេ។
ការបកប្រែផ្សេងទៀត៖ «លោកអប៊ីម៉ាឡិចមិនបានដេកជាមួយលោកស្រីសារ៉ាទេ»
ឬ «លោកអប៊ីម៉ាឡិចមិនបានប៉ះលោកស្រីសារ៉ា»
សូម្បីតែប្រជាជាតិសុចរិត
នៅទីនេះ« ប្រជាជាតិ» តំណាងឱ្យប្រជាជន។
ស្តេចអប៊ីម៉ាឡិចបារម្ភថាព្រះនឹងមិនដាក់ទណ្ឌកម្មតែគាត់ប៉ុណ្ណោះទេ
តែប្រជាជនរបស់គាត់ក៏នឹងទទួលទោសដែរ។ ការបកប្រែផ្សេងទៀត៖

generated on Wed Sep 10 16:16:32 2025

«សូម្បីតែប្រជាជនដែលគ្មានកំហុស»
តើមិនមែនគាត់ខ្លួនឯងទេឬអីដែលនិយាយមកទូលបង្គំថា នាងជាបួនស្រីរបស់ខ្ញុំ?
សូម្បីតែនាងខ្លួនឯងផ្ទាល់និយាយថា គាត់គឺជាបងប្រុសរបស់ខ្ញុំ
នេះមានសម្រង់នៅក្នុងសម្រង់មួយ។
ពួកគេអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖
«តើគាត់ផ្ទាល់មិនបានប្រាប់ខ្ញុំថានាងជាបួនស្រីរបស់គាត់ទេ?
សូម្បីតែនាងផ្ទាល់ក៏ប្រាប់ខ្ញុំថាគាត់គឺជាបងប្រុសរបស់នាងដែរ»។
តើមិនមែនគាត់ខ្លួនឯងទេឬអីដែលនិយាយមកទូលបង្គំថា នាងជាបួនស្រីរបស់ខ្ញុំ?
លោកអប៊ីម៉ាឡិចបានប្រើសំណួរនេះដើម្បីរំលឹកព្រះអំពីអ្វីដែលព្រះបានជ្រាប។
ការបកប្រែផ្សេងទៀត៖ «លោកអប្រាហាំផ្ទាល់បានប្រាប់ខ្ញុំថា
នាងគឺជាបួនស្រីរបស់ខ្ញុំ» ឬ «អប្រាហាំបាននិយាយថានាងគឺជាបួនស្រីរបស់គាត់»
តើមិនមែនគាត់ខ្លួនឯងទេឬអីដែលនិយាយមកទូលបង្គំ.....សូម្បីតែនាងខ្លួនឯង
ពាក្យថា «ខ្លួនគាត់ផ្ទាល់» និង «នាងខ្លួនឯង»
ត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់ដើម្បីទាក់ទាញចំណាប់អារម្មណ៍ដល់អប្រាហាំនិងសារៈ
ហើយដើម្បីស្តីបន្ទោសពួកគេចំពោះអ្វីដែលបានកើតឡើង។
ទូលបង្គំបានធ្វើការនេះដោយស្មោះត្រង់ចេញពីចិត្តរបស់ទូលបង្គំ និងពីដៃរបស់អ្នកដែលឥតកំហុស
នៅទីនេះ« ចិត្ត» តំណាងឱ្យគំនិតឬចេតនារបស់គាត់។ ដូចគ្នា «ដៃ»
តំណាងឱ្យសកម្មភាពរបស់គាត់។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំបានធ្វើរឿងនេះដោយចេតនានិងសកម្មភាពល្អ» ឬ
«ខ្ញុំបានធ្វើរឿងនេះដោយគ្មានគំនិតឬសកម្មភាពអាក្រក់ឡើយ»
Genesis 20:6
ព្រះជាម្ចាស់មានបន្ទូលទៅស្តេច
«ព្រះជាម្ចាស់មានបន្ទូលទៅកាន់ស្តេចអប៊ីម៉ាឡិច»
ដួងចិត្តរបស់ទ្រង់ស្មោះត្រង់ក្នុងការធ្វើការនេះ
នៅទីនេះ« ចិត្ត» តំណាងឱ្យគំនិតឬចេតនារបស់គាត់។ ការបកប្រែផ្សេងទៀត៖
«អ្នកបានធ្វើរឿងនេះដោយចេតនាល្អ» ឬ
«អ្នកបានធ្វើរឿងនេះដោយគ្មានចេតនាអាក្រក់»
ប៉ះពាល់នាង
នេះគឺជាការត្រេកត្រអាលចំពោះការរួមភេទជាមួយសារ៉ា។ ការបកប្រែផ្សេងទៀត៖
«ដេកជាមួយនាង»
ស្វាមីរបស់នាង
«ភរិយាលោកអប្រាហាំ»
អ្នកនឹងបានរស់
«យើងនិងអោយអ្នកបានរស់»
អស់អ្នកដែលនៅជាមួយទ្រង់
«ប្រជាជនរបស់អ្នកទាំងអស់»
Genesis 20:8
ព្រះអង្គបានប្រាប់ការទាំងអស់នេះទៅកាន់ពួកគេ
«ស្តេចប្រកាសប្រាប់ពួកគេគ្រប់រឿងទាំងអស់ ដែលព្រះជាម្ចាស់បានប្រាប់ទ្រង់»
ហេតុអ្វីបានជាលោកធ្វើដូច្នេះជាមួយយើង?
លោកអប៊ីម៉ាឡិចបានប្រើសំណួរនេះដើម្បីចោទប្រកាន់លោកអប្រាហាំ។
ការបកប្រែផ្សេងទៀត៖ «អ្នកបានធ្វើអ្វីមិនល្អចំពោះយើង!» ឬ
«មើលអ្វីដែលអ្នកបានធ្វើចំពោះពួកយើង!»
យើង
ពាក្យថា «យើង» នៅទីនេះគឺផ្តាច់ចេញមិនរាប់បញ្ចូលលោកអប្រាហាំ និង
លោកស្រីសារ៉ាទេ។ «យើង» ឬ «យើងផ្តាច់» សូមប្រើវានៅទីនេះ។
តើយើងបានធ្វើបាបអ្វីដល់លោក, បានជាលោកនាំយើង .....បាប?
អប៊ីម៉ាឡេកបានប្រើសំនួរនេះដើម្បីរំលឹកអប្រាហាំថាគាត់មិនបានធ្វើបាបប្រឆាំងនឹងអប្រាហាំ
ការបកប្រែផ្សេងទៀត៖ « ខ្ញុំមិនបានធ្វើអ្វីប្រឆាំងនឹងអ្នកទេ
ដែលបណ្តាលឱ្យអ្នកនាំ ... អំពើបាប» ។
បានជាលោកនាំយើង និងអាណាចក្ររបស់យើងទៅធ្វើបាបយ៉ាងធំដូច្នេះ
ដើម្បីធ្វើឱ្យនរណាម្នាក់មានទោសពីអំពើបាបត្រូវបានគេនិយាយដូចជា «អំពើបាប»
គឺជារឿងដែលអាចដាក់លើមនុស្សម្នាក់។ ការបកប្រែផ្សេងទៀត៖
«អ្នកគួរតែធ្វើឱ្យខ្ញុំនិងនគររបស់ខ្ញុំមានទោសចំពោះអំពើបាបដ៏អាក្រក់បែបនេះ»
លើអាណាចក្ររបស់យើង
នៅទីនេះ « អាណាចក្រ» តំណាងឱ្យប្រជាជន។ ការបកប្រែផ្សេងទៀត៖
«លើប្រជាជននៃអាណាចក្ររបស់ខ្ញុំ»
លោកបានធ្វើចំពោះយើងនេះ គឺជាអ្វីដែលលោកមិនគួរធ្វើទេ
«អ្នកមិនគួរណាធ្វើរឿងបែបនេះចំពោះខ្ញុំទេ»
Genesis 20:10
តើលោកមានគោលបំណងអ្វីបានជាធ្វើការនេះ?
«តើអ្វីដែលបណ្តាលឱ្យអ្នកធ្វើបែបនេះ?» ឬ «ហេតុអ្វីបានជាអ្នកធ្វើបែបនេះ?»
អ្វីដែលលោកអប្រាហាំបានធ្វើអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត៖
«ហេតុអ្វីបានជាអ្នកប្រាប់ខ្ញុំថាលោកស្រីសារ៉ាគឺជាបួនស្រីរបស់អ្នក?»
ដោយព្រោះទូលបង្គំគិតថា ប្រហែលជាគ្មានការកោតខ្លាចព្រះទេនៅទីនេះ ហើយថា គេនឹងសម្លាប់
ទូលបង្គំ ដោយសារតែភរិយាទូលបង្គំមិនខាន
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ អេធី:
«ដោយសារតែខ្ញុំគិតថាដោយសារតែគ្មាននរណាម្នាក់នៅទីនេះកោតខ្លាចព្រះទេ
មានគេអាចសម្លាប់ខ្ញុំដូច្នេះពួកគេអាចយកប្រពន្ធរបស់ខ្ញុំ»
គ្មានការកោតខ្លាចព្រះទេនៅទីនេះ
នៅទីនេះ «កន្លែង» សំដៅលើប្រជាជន។ ការបកប្រែផ្សេងទៀត៖
«គ្មាននរណាម្នាក់នៅទីនេះក្នុង លោកកេរ៉ា កោតខ្លាចព្រះជាម្ចាស់ទេ»
កោតខ្លាចព្រះ
នេះមានន័យថាយើងគោរពព្រះជាម្ចាស់យ៉ាងជ្រាលជ្រៅហើយបង្ហាញការគោរពនោះដោយការស្តាប់បង្គាប់
ម្យ៉ាងវិញទៀត, នាងគឺជាបួនស្រីរបស់ទូលបង្គំមែន
«ក៏ដឹងដែរថា លោកស្រីសារ៉ាពិតជាបួនស្រីខ្ញុំមែន» ឬ
«លោកស្រីសារ៉ាពិតជាបួនស្រីរបស់ខ្ញុំ»
នាងគឺជាកូនស្រីរបស់ឪពុកទូលបង្គំ ប៉ុន្តែមិនមែនជាកូនស្រីម្តាយរបស់ទូលបង្គំទេ
«យើងមានឪពុកតែមួយ ប៉ុន្តែយើងមានម្តាយផ្សេងគ្នាវិញ»
Genesis 20:13
ព័ត៌មានទូទៅ
នៅក្នុងខ១៣គឺលោកអប្រាហាំបានឆ្លើយតបទៅកាន់ស្តេចអប៊ីម៉ាឡិច។
ផ្ទះឪពុករបស់ទូលបង្គំ
នៅទីនេះ «ផ្ទះ» តំណាងឱ្យគ្រួសាររបស់លោកអប្រាហាំ។ ការបកប្រែផ្សេងទៀត៖
«ឪពុកខ្ញុំនិងគ្រួសារខ្ញុំផ្សេងទៀត» ឬ «គ្រួសារឪពុកខ្ញុំ»
ទូលបង្គំបានប្រាប់នាងថា៖ «អូនត្រូវបង្ហាញពីភាពស្មោះត្រង់ក្នុងនាមជាភរិយារបស់បង
គឺនៅទីណាដែលយើងទៅ សូមប្រាប់គេថា៖ «គាត់ជាបងប្រុសរបស់ខ្ញុំ»
នេះមានដកស្រង់នៅក្នុងសម្រង់សម្តី។
ពួកគេអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំបាននិយាយទៅកាន់សារ៉ាថា ខ្ញុំចង់អោយនាងស្មោះត្រង់នឹងខ្ញុំ
ដោយប្រាប់មនុស្សគ្រប់ទីកន្លែងដែលយើងទៅ ថាខ្ញុំជាបងរបស់នាង»
ព្រះបាទអប៊ីម៉ាឡិចបានយក
«ស្តេចអប៊ីម៉ាឡិចបាននាំយករបស់ខ្លះ»
Genesis 20:15
ព្រះបាទអប៊ីម៉ាឡិចមានរាជឱង្ការថា
«ស្តេចអប៊ីម៉ាឡិចបាននិយាយទៅលោកអប្រាហាំ»
មើល៍
នៅទីនេះនិងនៅក្នុងខ ១៦ ពាក្យ «មើល»
បន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ទឹកដីរបស់យើងនៅចំពោះលោកហើយ
នេះគឺជាវិធីនៃការនិយាយថា «ខ្ញុំអោយដីរបស់ខ្ញុំទាំងអស់សម្រាប់អ្នក»
ចូរនៅកន្លែងណាតាមតែលោកចូលចិត្តចុះ
«នៅទីណាដែលអ្នកចង់បាន»
មួយពាន់
«ដើម្បីគ្រប់បាំងកំហុសដែលបានធ្វើទាស់នឹងនាងនៅក្នុងភ្នែករបស់មនុស្សគ្រប់គ្នា
ឱ្យលុយដើម្បីបង្ហាញដល់អ្នកដទៃថា
សារ៉ាគ្មានទោសត្រូវបានគេនិយាយដូចជាគាត់កំពុងបិទបាំងលើបទល្មើសដូច្នេះគ្មាននរណាម្នាក់អាចមើល
ការបកប្រែផ្សេងទៀត៖ «ខ្ញុំកំពុងផ្តល់រឿងនេះទៅគាត់
ដូច្នេះអ្នកដែលនៅជាមួយអ្នកនឹងដឹងថា អ្នកមិនបានធ្វើអ្វីខុសទេ»
នៅក្នុងភ្នែក
នៅទីនេះ «ភ្នែក» តំណាងឱ្យគំនិតឬយោបល់របស់មនុស្សម្នាក់។
នៅចំពោះមុខរបស់មនុស្សគ្រប់គ្នា, អ្នកមិនបានបាត់បង់កិត្តិយសអ្វីឡើយ
ឃ្លាអកម្ម «ត្រូវបានធ្វើឱ្យត្រឹមត្រូវ» អាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត៖ «អ្នករាល់គ្នាគ្មានកំហុស»
Genesis 20:17

generated on Wed Sep 10 16:16:32 2025

ទៅជាស្ត្រីអារ
«សរុបសេចក្តីទៅគឺគ្មានកូន»
ព្រោះតែនាងសារ៉ា ជាភរិយារបស់លោកអប្រាហាំ

អត្ថន័យពេញអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«ពីព្រោះព្រះបាទអ័ប៊ីម៉ាឡេកបានយកប្រពន្ធរបស់លោកអប្រាហាំគឺសារ៉ា»

21

[1]ព្រះអម្ចាស់យកព្រះទ័យទុកដាក់ជាមួយនាងសារ៉ា ដូចដែលព្រះអង្គបានមានបន្ទូលថាព្រះអង្គនឹងធ្វើ ហើយព្រះអម្ចាស់បានធ្វើសម្រាប់នាងសារ៉ា
ដូចដែលព្រះអង្គបានសន្យា។[2]នាងសារ៉ាមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយឲ្យលោកអប្រាហាំក្នុងការដែលគាត់ចាស់ណាស់ហើយ
តាមពេលកំណត់ដែលព្រះអង្គបានមានបន្ទូលជាមួយគាត់។[3]លោកអប្រាហាំដាក់ឈ្មោះកូនប្រុសនោះថា អ៊ីសាក។
[4]លោកអប្រាហាំបានកាត់ស្បែកអ៊ីសាកកូនប្រុសរបស់គាត់ នៅពេលគាត់មានអាយុបានប្រាំបីថ្ងៃ ដូចដែលព្រះជាម្ចាស់បានបង្គាប់ដល់គាត់។
[5]លោកអប្រាហាំមានអាយុមួយរយឆ្នាំ ពេលគាត់មានអ៊ីសាកកូនប្រុសរបស់គាត់។[6]នាងសារ៉ានិយាយថា៖ «ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំសើច
មនុស្សគ្រប់គ្នាដែលឮនឹងសើចជាមួយខ្ញុំ»។[7]នាងក៏និយាយផងដែរថា៖ «តើអ្នកណាអាចនិយាយជាមួយលោកអប្រាហាំថា នាងសារ៉ាបំបៅកូន មិនត្រឹមតែប៉ុណ្ណោះ
ខ្ញុំបានបង្កើតកូនប្រុសមួយនៅក្នុងកាលដែលគាត់មានវ័យចាស់ណាស់ហើយដែរ»។
[8]កូនបានធំឡើង ហើយបានផ្តាច់ដោះ លោកអប្រាហាំបានធ្វើពិធីជប់លៀងយ៉ាងធំនៅថ្ងៃដែលអ៊ីសាកបានផ្តាច់ដោះនោះ។[9]នាងសារ៉ាឃើញកូននាងហាកាជនជាតិអេស៊ីប
ដែលនាងបានបង្កើតឲ្យលោកអប្រាហាំ កំពុងចំអកដល់កូននាង។
[10]ដូច្នេះ នាងបានប្រាប់លោកអប្រាហាំថា៖ «ចូរបណ្តេញស្ត្រីបម្រើ និងកូនប្រុសរបស់នាងចេញទៅ ដើម្បីកូនប្រុសរបស់ស្រីបម្រើនោះ
មិនអាចគ្រងមរតកជាមួយអ៊ីសាកបានទេ»។[11]ការនេះ បានធ្វើឲ្យលោកអប្រាហាំពិបាកចិត្តយ៉ាងខ្លាំងដោយព្រោះកូនប្រុសរបស់គាត់។
[12]ប៉ុន្តែ ព្រះជាម្ចាស់មានបន្ទូលជាមួយលោកអប្រាហាំថា៖ «កុំពិបាកចិត្តដោយព្រោះក្មេង និងអ្នកបម្រើស្រីរបស់អ្នកឡើយ។
ចូរស្តាប់តាមសម្តីទាំងអស់ដែលនាងប្រាប់អ្នកពីបញ្ហាចុះ ពីព្រោះ តាមរយៈអ៊ីសាកដែលពូជពង្សរបស់ដែលនឹងស្នងត្រកូលពីនាក់។
[13]យើងនឹងធ្វើឲ្យកូនស្រីបម្រើបានក្លាយជាប្រជាជាតិមួយ ព្រោះគាត់គឺជាពូជពង្សរបស់អ្នក»។
[14]លោកអប្រាហាំបានក្រោកឡើងតាំងពីព្រលឹម យកនំបុ័ង និងថង់ស្បែកមានទឹក ហើយប្រគល់វាទៅឲ្យនាងហាកា ដាក់លើស្មារបស់នាង។
គាត់បានប្រគល់កូនប្រុសទៅនាង ហើយក៏ចាត់នាងឲ្យចេញទៅ។ នាងបានចាកចេញ ហើយបានវង្វេងនៅទីរហោស្ថានបៀរសេបា។
[15]នៅពេលទឹកនៅក្នុងថង់ស្បែកអស់ទៅ នាងបានទុកកូនប្រុសចោលនៅក្រោមដើមឈើតូចមួយ។[16]បន្ទាប់មក នាងក៏ចេញទៅ ហើយបានអង្គុយឆ្ងាយបន្តិចពីគាត់
ប្រហែលជាមួយសន្ទុះព្រួញ នាងនិយាយថា៖ «ខ្ញុំមិនចង់ឃើញកូនស្លាប់នៅចំពោះមុខខ្ញុំទេ»។ ក្នុងកាលដែលនាងអង្គុយទល់មុខនឹងកូននោះ នាងបានស្រែក
ហើយយំជាខ្លាំង។
[17]ព្រះជាម្ចាស់បានឮសម្លេងក្មេងនោះ ហើយទេវតារបស់ព្រះជាម្ចាស់បានហៅនាងហាកាពីស្ថានសួគ៌មក ហើយនិយាយទៅនាងថា៖ «ហាកាអើយ តើនាងមានរឿងអ្វី?
កុំខ្លាចអ្វីឡើយ ដ្បិត ព្រះជាម្ចាស់បានឮសម្លេងរបស់ក្មេងពីកន្លែងរបស់វាហើយ។[18]ចូរក្រោកឡើង លើកក្មេងនោះ ហើយលើកទឹកចិត្តគាត់ ដ្បិត
យើងនឹងធ្វើឲ្យគាត់ក្លាយជាប្រជាជាតិមួយដ៏ធំ»។
[19]បន្ទាប់មក ព្រះជាម្ចាស់បានបើកភ្នែករបស់នាង ហើយនាងបានឃើញអណ្តូងទឹកមួយ។ នាងបានទៅ ហើយដងទឹកដាក់ក្នុងថង់ស្បែកដាក់ទឹក
ហើយបានឲ្យទៅក្មេងនោះផឹក។[20]ព្រះជាម្ចាស់គង់ជាមួយក្មេងនោះ ហើយគាត់បានធំឡើង។ គាត់រស់នៅក្នុងទីវាលរហោស្ថាន ហើយបានក្លាយជាអ្នកពូកែបាញ់ធ្នូ។
[21]គាត់រស់នៅក្នុងទីរហោស្ថាននៅក្នុងទឹកដីប៉ារ៉ាន ហើយម្តាយរបស់គាត់បានការប្រពន្ធឲ្យគាត់ជាមួយនឹងជនជាតិអេស៊ីប។
[22]នៅគ្រានោះ ព្រះបាទអប៊ីម៉ាឡិច និងលោកភីកុល ជាមេទ័ពរបស់ព្រះអង្គពោលទៅលោកអប្រាហាំថា៖ «ព្រះជាម្ចាស់គង់ជាមួយលោកនៅក្នុងគ្រប់ការទាំងលោកធ្វើ។
[23]ឥឡូវនេះ ចូរស្បថជាមួយយើងនៅទីនេះក្នុងនាមព្រះជាម្ចាស់ថា អ្នកនឹងមិនប្រព្រឹត្តមិនត្រឹមត្រូវជាមួយយើង ឬជាមួយកូនចៅរបស់យើង
ឬជាមួយពូជពង្សរបស់យើងឡើយ។ ចូរប្រព្រឹត្តជាមួយយើង
និងជាមួយទឹកដីដែលលោកស្នាក់នៅដោយសម្ពន្ធមេត្រីដ៏ស្មោះត្រង់ដែលយើងបានប្រព្រឹត្តជាមួយនឹងលោកដែរ។[24]លោកអប្រាហាំពោលថា៖ «ខ្ញុំស្បថ»។
[25]លោកអប្រាហាំបានប្តឹងព្រះបាទអប៊ីម៉ាឡិចទាក់ទងនឹងអណ្តូងទឹកដែលអ្នកបម្រើរបស់ព្រះបាទអប៊ីម៉ាឡិចបានយកពីគាត់។[26]ព្រះបាទអប៊ីម៉ាឡិចមានបន្ទូលថា៖
«យើងមិនដឹងថា អ្នកណាជាអ្នកធ្វើការនេះទេ។ ព្រោះលោកមិនបានប្រាប់ឲ្យយើងដឹងផង យើងមិនបានដឹងរហូតដល់សព្វថ្ងៃនេះ»។[27]ដូច្នេះ លោកអប្រាហាំបានយកចៀម
និងគោ ហើយថ្វាយដល់ព្រះបាទអប៊ីម៉ាឡិច ហើយអ្នកទាំងពីរបានធ្វើសម្ពន្ធមេត្រីនឹងគ្នា។
[28]បន្ទាប់មក លោកអប្រាហាំបានរៀបចំចៀមញីពីហ្វូងសត្វទុកដោយឡែក។[29]ព្រះបាទអប៊ីម៉ាឡិចមានបន្ទូលទៅលោកអប្រាហាំថា៖ «តើសត្វចៀមញីទាំងប្រាំពីរនេះ
មានន័យយ៉ាងដូចម្តេច ដែលលោកបានញែកដោយឡែកបែបនេះ?»[30]គាត់ឆ្លើយថា៖ «ព្រះអង្គនឹងទទួលចៀមញីទាំងប្រាំពីរនេះ ពីដៃរបស់ទូលបង្គំ
ដើម្បីធ្វើជាសាក្សីសម្រាប់ទូលបង្គំ ថាទូលបង្គំជាអ្នកជីកអណ្តូងនេះ»។
[31]ដូច្នេះ គាត់បានហៅកន្លែងនោះថា បៀរសេបា ព្រោះអ្នកទាំងពីរបានស្បថសច្ចានៅទីនោះ។[32]ពួកគេបានចងសម្ពន្ធមេត្រីនៅបៀរសេបា ហើយបន្ទាប់មកព្រះបាទអប៊ីម៉ាឡិច
និងលោកភីកុល ជាមេទ័ពរបស់ព្រះអង្គ បានត្រឡប់ទៅទឹកដីភីលីស្ទីនវិញ។
[33]លោកអប្រាហាំបានដាំដើមអំពិលមួយដើមនៅបៀរសេបា។ គាត់ថ្វាយបង្គំព្រះជាអម្ចាស់ ជាព្រះដ៏នូវអស់កល្បនៅទីនោះ។
[34]លោកអប្រាហាំនៅជាជនបរទេសនៅក្នុងទឹកដីភីលីស្ទីនជាច្រើនឆ្នាំ។

Genesis 21:1
ព្រះអម្ចាស់យកព្រះទ័យទុកដាក់ជាមួយនាងសារ៉ា
ឃ្លានៅទីនេះ « យកចិត្តទុកដាក់ចំពោះ»
សំដៅទៅលើព្រះអម្ចាស់ដែលជួយសារ៉ាមានកូនមួយ។ ការបកប្រែផ្សេងទៀត៖
«ព្រះអម្ចាស់បានជួយលោកស្រីសារ៉ា»
បង្កើតបានកូនប្រុសមួយឲ្យលោកអប្រាហាំ
«បង្កើតកូនប្រុសមួយអោតលោកអប្រាហាំ»
ក្នុងការដែលគាត់ចាស់ណាស់ហើយ
«គឺនៅពេលដែលលោកអប្រាហាំចាស់ណាស់ហើយ»
តាមពេលកំណត់ដែលព្រះអង្គបានមានបន្ទូលជាមួយគាត់
«នៅពេលជាក់លាក់មួយ ដែលព្រះបានប្រាប់គាត់ថា វានឹងកើតឡើង»
លោកអប្រាហាំដាក់ឈ្មោះកូនប្រុសម្នាក់ដែលកើតមកដើម្បីគាត់
អ្នកដែលសារ៉ាបានបង្កើតអោយគាត់គឺលោកអ៊ីសាក
«លោកអប្រាហាំដាក់ឈ្មោះកូនប្រុសដែលទើបនឹងកើតមករបស់គាត់ដែលសារ៉ាបានបង្កើតលោកអ៊ីសាក»
ឬ
«លោកអប្រាហាំដាក់ឈ្មោះកូនប្រុសដែលទើបនឹងកើតរបស់ពួកគេថាឈ្មោះលោកអ៊ីសាក»
លោកអប្រាហាំបានកាត់ស្បែកអ៊ីសាកកូនប្រុសរបស់គាត់ នៅពេលគាត់មានអាយុបានប្រាំបីថ្ងៃ
«ពេលអ៊ីសាកជាកូនប្រុសរបស់គាត់មានអាយុប្រាំបីថ្ងៃ
លោកអប្រាហាំបានធ្វើពិធីកាត់ស្បែកអោយ»
ប្រាំបីថ្ងៃ
«៨ថ្ងៃ»
បានបង្គាប់ដល់គាត់
«បានបង្គាប់ដល់លោកអប្រាហាំត្រូវធ្វើ»
Genesis 21:5
មួយរយ
«១០០»

generated on Wed Sep 10 16:16:32 2025

ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំសើច
សារ៉ាបានសើចព្រោះនាងភ្ញាក់ផ្អើលនិងរីករាយ។ នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖ «ព្រះបានធ្វើអោយខ្ញុំសើចសប្បាយ»
មនុស្សគ្រប់គ្នាដែលឮ
អ្វីដែលមនុស្សបានលឺ អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«មនុស្សគ្រប់គ្នាដែលបានលឺអំពីអ្វី ដែលព្រះបានធ្វើសម្រាប់ខ្ញុំ»
តើអ្នកណាអាចនិយាយជាមួយលោកអប្រាហាំថា នាងសារ៉ាបំបៅកូន
សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត៖
«គ្មាននរណាម្នាក់ធ្លាប់និយាយទៅកាន់លោកអប្រាហាំថាសារ៉ានឹងបំបៅកូន»
បំបៅកូន
នេះជាវិធីគួរសមក្នុងការសំដៅទៅលើទារកដែលបំបៅដោះ។
ការបកប្រែផ្សេងទៀត៖ «ចិញ្ចឹមទារកដោយទឹកដោះគាត់»
Genesis 21:8
កូនបានធំឡើងហើយ.....អ៊ីសាកបានផ្តាច់ដោះ
«ផ្តាច់» គឺជាវិធីគួរសមក្នុងការនិយាយថាកូនបានបញ្ចប់ការបំបៅដោះ។
ការបកប្រែផ្សេងទៀត៖
«លោកអ៊ីសាកបានធំឡើងមិនយូរប៉ុន្មានគាត់លែងត្រូវការទឹកដោះរបស់ម្តាយគាត់
អប្រាហាំមានពិធីជប់លៀងដ៏ធំមួយ»
កូននាងហាកាជនជាតិអេស៊ីប, ដែលនាងបានបង្កើតឲ្យលោកអប្រាហាំ
ឈ្មោះកូនប្រុសរបស់ហាការត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«អ៊ីសម៉ាអែលជាកូនរបស់ហាការដែលជាជនជាតិអេស៊ីប និង លោកអប្រាហាំ»
ចំអក
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាគាត់កំពុងសើចចំអកឬសើចចំអកឱ្យអ៊ីសាក។
ការបកប្រែផ្សេងទៀត៖ «សើចអ៊ីសាក»
Genesis 21:10
នាងបានប្រាប់លោកអប្រាហាំថា
«លោកស្រីសារ៉ាបានប្រាប់ដល់លោកអប្រាហាំ»
ចូរបណ្តេញ
«បញ្ជូនទៅឆ្ងាយ» ឬ «កម្ចាត់»
ស្ត្រីបម្រើ និងកូនប្រុសរបស់នាងចេញទៅ
នេះសំដៅទៅលើហាការនិងអ៊ីស្មាអែល។ សារ៉ាមិនបានប្រាប់ពួកគេតាមឈ្មោះទេ
ពីព្រោះនាងខឹងនឹងពួកគេ។
ជាមួយកូនប្រុសខ្ញុំ, ជាមួយអ៊ីសាក
«ជាមួយកូនប្រុសខ្ញុំអ៊ីសាក»
ការនេះ បានធ្វើឲ្យលោកអប្រាហាំពិបាកចិត្តយ៉ាងខ្លាំង
«លោកអប្រាហាំពិតជាមិនសប្បាយយ៉ាងខ្លាំង អំពីអ្វីដែលសារ៉ាបាននិយាយ»
ដោយព្រោះកូនប្រុសរបស់គាត់
«ពីព្រោះនិយាយអំពីកូនប្រុសរបស់គាត់» បញ្ជាក់យ៉ាងច្បាស់ថា
នេះមានន័យថាកូនប្រុសរបស់គាត់គឺអ៊ីស្មាអែល។
Genesis 21:12
កុំពិបាកចិត្តដោយព្រោះក្មេង និងអ្នកបម្រើស្រីរបស់អ្នកឡើយ
«កុំអោយពិបាកចិត្តដោយព្រោះតែក្មេងនិងស្ត្រីជាអ្នកបម្រើរបស់អ្នកឡើយ»
ចូរស្តាប់តាមសម្តីទាំងអស់ដែលនាងប្រាប់អ្នកពីបញ្ហាចុះ
នៅទីនេះ «ពាក្យ» តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។ ការបកប្រែផ្សេងទៀត៖
«ធ្វើអ្វីគ្រប់យ៉ាងដែលលោកស្រីសារ៉ានិយាយទៅកាន់អ្នកអំពីពួកគេ» (សូមមើល:figs-
metonymy)
តាមរយៈអ៊ីសាកដែលពូជពង្សរបស់ដែលនឹងស្នងត្រកូល
ឃ្លា « នឹងមានឈ្មោះ»
មានន័យថាអស់អ្នកដែលកើតមកតាមអ៊ីសាកគឺជាមនុស្សដែលព្រះចាត់ទុកថាជាកូនចៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«អ៊ីសាកគឺជាអ្នកដែលនឹងក្លាយជាបុព្វបុរសនៃកូនចៅដែលព្រះជាម្ចាស់បានសន្យាថានឹង
activepassive)
យើងនឹងធ្វើឲ្យកូនស្រីបម្រើបានក្លាយជាប្រជាជាតិមួយ
ពាក្យថា « ប្រជាជាតិ»
មានន័យថាព្រះជាម្ចាស់នឹងប្រទានកូនចៅអោយគាត់ដើម្បីអោយពួកគេក្លាយជាប្រជាជាតិដ៏អស្ចារ្យ
ការបកប្រែផ្សេងទៀត៖
«យើងនឹងធ្វើឱ្យកូនប្រុសរបស់ស្ត្រីជាអ្នកបម្រើក៏ក្លាយជាឪពុកនៃប្រជាជាតិដ៏អស្ចារ្យ»
Genesis 21:14
យកនំបុ័ង
អត្ថន័យដែលអាចមានគឺ ១) នេះសំដៅទៅលើអាហារជាទូទៅឬ ២)
នេះសំដៅទៅលើនំបុ័ងពិសេស។
ថង់ស្បែកមានទឹក
«គឺជាថង់ទឹក» ជាប្រដាប់ដាក់ទឹក ដែលបានធ្វើឡើងពីស្បែកសត្វ
នៅពេលទឹកនៅក្នុងថងស្បែកអស់ទៅ
«នៅពេលថង់ទឹកទទេរ ឬ «នៅពេលដែលពួកគេបានផឹកទឹកទាំងអស់»
ហើយបានអង្គុយឆ្ងាយបន្តិច
នេះសំដៅទៅលើចម្ងាយដែលមនុស្សម្នាក់អាចបាញ់ព្រួញដោយធ្នូ។ នេះគឺប្រហែល
១០០ ម៉ែត្រ។
ខ្ញុំមិនចង់ឃើញកូនស្លាប់នៅចំពោះមុខខ្ញុំទេ
នាមអរូបី «ការស្លាប់» អាចត្រូវបានគេនិយាយថា៖ «ស្លាប់»។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំមិនចង់មើលក្មេងប្រុសស្លាប់ទេ»
នាងបានស្រែក ហើយយំជាខ្លាំង
នៅទីនេះ «សំឡេង» តំណាងឱ្យសំឡេងយំរបស់នាង។ ដើម្បី «
សំឡេងជីវិតរបស់នាង» មានន័យថាយំខ្លាំង ៗ ។ ការបកប្រែផ្សេងទៀត៖
«នាងស្រែកយំខ្លាំង ៗ ហើយយំ» ឬ «នាងយំយ៉ាងខ្លាំង»
Genesis 21:17
ឮសម្លេងក្មេងនោះ
«សំឡេងក្មេងប្រុស»។ នៅទីនេះ «សំឡេង» តំណាងអោយសំឡេងក្មេងប្រុសយំ
ឬនិយាយ។ សំឡេងរបស់អ៊ីស្មាអែល (សូមមើល:figs-metonymy)
ទេវតារបស់ព្រះជាម្ចាស់
«អ្នកនាំសារមកពីព្រះជាម្ចាស់» ឬ «អ្នកនាំសាររបស់ព្រះ»
ពីស្ថានសួគ៌មក
ទីនេះ «ស្ថានបរមសុខ» មានន័យថាជាកន្លែងដែលព្រះគង់នៅ។
តើនាងមានរឿងអ្វី?
«តើកើតអ្វី» ឬ «ហេតុអ្វីបានជាអ្នកយំ»
បានឮសម្លេងរបស់ក្មេងពីកន្លែង
នៅទីនេះ « សំឡេង» តំណាងអោយសំឡេងក្មេងប្រុសយំឬនិយាយ។
ការបកប្រែផ្សេងទៀត៖ «សំឡេងក្មេងប្រុសដេកនៅទីនោះ»
លើកក្មេងនោះ
«ជួយក្មេងប្រុសអោយក្រោកឡើង»
យើងនឹងធ្វើឲ្យគាត់ក្លាយជាប្រជាជាតិមួយដ៏ធំ
ដើម្បីធ្វើឱ្យអ៊ីស្មាអែលទៅជាប្រជាជាតិដ៏ធំមួយមានន័យថាព្រះជាម្ចាស់នឹងប្រទានឱ្យគាត់នូវកូនចៅជាច្រើ
ការបកប្រែផ្សេងទៀត៖ «យើងនឹងធ្វើឱ្យកូនចៅរបស់គាត់ក្លាយជាប្រជាជាតិដ៏ធំ» ឬ
«ខ្ញុំនឹងធ្វើឱ្យគាត់ក្លាយជាបុព្វបុរសរបស់ប្រជាជាតិដ៏អស្ចារ្យ»
Genesis 21:19
ព្រះជាម្ចាស់បានបើកភ្នែករបស់នាង ហើយនាងបានឃើញ
ព្រះជាម្ចាស់ធ្វើឱ្យហាការដឹងអណ្តូងអាចនិយាយមួយទៀតទ្រង់បានបើកភ្នែកនាងអោយឃើញ។
ការបកប្រែផ្សេងទៀត៖ «ព្រះជាម្ចាស់បណ្តាលឱ្យហាការមើលឃើញ»
ឬ«ព្រះជាម្ចាស់បានបង្ហាញនាង»
ស្បែក
«ធុងធ្វើពីស្បែក» ឬ «កាបូប»
ក្មេង
«ក្មេងប្រុស» ឬ«អ៊ីស្មាអែល»
ព្រះជាម្ចាស់គង់ជាមួយក្មេងនោះ
នៅឃ្លានេះថា «គង់ជាមួយ» គឺជាការសំគាល់មានន័យថាព្រះបានជួយ
ឬប្រទានពរដល់ក្មេងប្រុស។ ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់បានដឹកនាំក្មេងប្រុស» ឬ
(សូមមើល:figs-idiom)
ក្លាយជាអ្នកពូកែបាញ់ធ្នូ
(សូមមើល:figs-និងព្រួញ»
គាត់បានការប្រពន្ធ
«បានប្រពន្ធ»
Genesis 21:22
វគ្គនេះគឺចាប់ផ្តើមនូវរឿងថ្មី។
លោកភីកុល
នេះគឺជាឈ្មោះរបស់បុរសម្នាក់
ជាមេទ័ព

generated on Wed Sep 10 16:16:32 2025

«គឺជាមេបញ្ជាការនៅក្នុងកងទ័ពរបស់គាត់»
មេទ័ពរបស់ព្រះអង្គ
ពាក្យ «ព្រះអង្គ» គឺសំដៅទៅលើស្តេចអប៊ីម៉ាឡិច។
ព្រះជាម្ចាស់គង់ជាមួយលោកនៅក្នុងគ្រប់ការទាំងលោកធ្វើ
នៅទីនេះឃ្លាថា «គង់ជាមួយអ្នក»
គឺជាពាក្យសំដីដែលមានន័យថាព្រះជាម្ចាស់ជួយឬប្រទានពរដល់អាប្រាហាំ។
ការបកប្រែផ្សេងទៀត៖ «ព្រះប្រទានពរដល់អ្វីៗទាំងអស់ដែលអ្នកធ្វើ»
ឥឡូវនេះ
ពាក្យថា «ឥឡូវនេះ» មិនមានន័យថា «នៅពេលនេះទេ»
ប៉ុន្តែត្រូវបានប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍ទៅចំណុចសំខាន់ដែលនៅខាងក្រោម។
ការបកប្រែផ្សេងទៀត៖ «ដូច្នេះ»
ចូរស្បថជាមួយយើងនៅទីនេះក្នុងនាមព្រះជាម្ចាស់
នេះគឺជាន័យពិសេសមួយដើម្បីធ្វើសម្បថដ៏ឧឡារិកដែលធ្វើជាសាក្សីដោយអ្នកមានអំណាចខ្លាំងជាងមុន។
ការបកប្រែផ្សេងទៀត៖ «សន្យាជាមួយខ្ញុំ ដែលព្រះជាម្ចាស់ជាសាក្សីរបស់អ្នក»
អ្នកនឹងមិនប្រព្រឹត្តមិនត្រឹមត្រូវជាមួយយើង
«គឺអ្នកនិងមិនកុហកដល់យើង»
នឹងមិនប្រព្រឹត្តមិនត្រឹមត្រូវ.....ជាមួយកូនចៅរបស់យើង
គាត់អាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត៖ «
នឹងដោះស្រាយដោយស្មោះត្រង់ជាមួយខ្ញុំនិងកូនចៅ»
ចូរប្រព្រឹត្តជាមួយយើង.....សម្ពន្ធមេត្រីដ៏ស្មោះត្រង់ដែលយើងបានប្រព្រឹត្តជាមួយនឹងលោកដែរ
បុរសទាំងពីរនាក់បានធ្វើកិច្ចព្រមព្រៀងជាមួយគ្នា។ នាមអរូបី «ភាពស្មោះត្រង់»
អាចត្រូវបានបញ្ជាក់ថា «ស្មោះត្រង់» ឬ «ស្មោះត្រង់» ។ ការបកប្រែផ្សេងទៀត៖
«ស្មោះត្រង់នឹងខ្ញុំនិងដីដូចខ្ញុំបានធ្វើចំពោះអ្នក»
ជាមួយទឹកដី
នៅទីនេះ « ដី» តំណាងឱ្យប្រជាជន។ ការបកប្រែផ្សេងទៀត៖
«ទៅកាន់ប្រជាជននៅលើដី»
ខ្ញុំស្បថ
នេះអាចត្រូវបានបញ្ជាក់ដោយព័ត៌មានដែលយល់។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំបានស្បថថានឹងស្មោះត្រង់ចំពោះអ្នកនិងប្រជាជនរបស់អ្នកដូចដែលអ្នកបានធ្វើចំពោះខ្ញុំ»
Genesis 21:25
លោកអប្រាហាំបានតួញតែ្ពរព្រះបាទអប៊ីម៉ាឡិច
អត្ថន័យដែលអមានគឺ ១) អប្រាហាំបានតួញតែ្ពរអំពីអ្វីដែលបានកើតឡើងឬ ២)
«អប្រាហាំក៏ស្តីបន្ទោសព្រះបាទអប៊ីម៉ាឡិច»
ទាក់ទងនឹងអណ្តូងទឹកដែលពួកអ្នកបំរើរបស់ស្តេចអប៊ីម៉ាឡេកបានយកពីគាត់
«ពីព្រោះពួកអ្នកបម្រើរបស់អប៊ីម៉ាឡិចបានយកអណ្តូងរបស់អប្រាហាំ។»
បានយកពីគាត់
«បានយកពីលោកអប្រាហាំ» ឬ«បានគ្រប់គ្រង»
យើងមិនបានដឹងរហូតដល់សព្វថ្ងៃនេះ
«នេះគឺជាលើកទីមួយដែលយើងបានលឺអំពីរឿងនេះ»
លោកអប្រាហាំបានយកចៀម និងគោ ហើយថ្វាយដល់ព្រះបាទអប៊ីម៉ាឡិច
នេះគឺជាសញ្ញានៃមិត្តភាពរបស់អប្រាហាំបានធ្វើកិច្ចព្រមព្រៀងជាមួយព្រះបាទអប៊ីម៉ាឡិច។
Genesis 21:28
លោកអប្រាហាំបានរៀបចំចៀមញីៗ៧ពីហ្វូងសត្វទុកដោយឡែក
«អប្រាហាំបានញែកកូនចៀមញីប្រាំពីរចេញពីហ្វូងចៀម»
ប្រាំពីរ
«៧»
តើសត្វចៀមញីទាំងប្រាំពីរនេះ មានន័យយ៉ាងដូចម្តេច ដែលលោកបានញែកដោយឡែកបែបនេះ?
«ហេតុអ្វីបានជាអ្នកបំបែកកូនចៀមទាំងប្រាំពីរចេញពីហ្វូង?»
ព្រះអង្គនឹងទទួល
«ព្រះអង្គនិងយក»
ការបកប្រែផ្សេងទៀត៖ «ការចង្អុលបង្ហាញនេះ
ទីនេះ«ដៃ»តំណាងអោយលោកអប្រាហាំ។ ការបកប្រែផ្សេងទៀត៖ «ពីទូលបង្គំ»
ដើម្បីធ្វើជាសាក្សី
ពាក្យ«វា»គឺសំដៅទៅលើអំណោយនៃចៀមទាំងប្រាំពីរ។
ដូច្នេះដើម្បីធ្វើជាសាក្សីសម្រាប់ទូលបង្គំ
នាមអរូបី «សាក្សី» អាចត្រូវបានបញ្ជាក់ថាជា «ដើម្បីបង្ហាញ»។
ការបកប្រែផ្សេងទៀត៖ «ដើម្បីបង្ហាញដល់មនុស្សគ្រប់គ្នា»
Genesis 21:31
គាត់បានហៅកន្លែងនោះថា
«លោកអប្រាហាំហៅទីកន្លែងនោះ»
បៀរសេបា
អ្នកអាចហៅថា បៀរសេបាអាចមានន័យថា«អណ្តូងនៃសម្បថ» ឬ «អណ្តូង ៧ »
អ្នកទាំងពីរ
«លោកអប្រាហាំនិងស្តេចអប៊ីម៉ាឡិច»
លោកភីកុល
នេះគឺជាឈ្មោះរបស់បុរសម្នាក់។ នៅក្នុង២១:២២
ត្រឡប់ទៅទឹកដីភីលីស្ទីនវិញ
«បានវិលត្រលប់ទៅទឹកដីភីលីស្ទីនវិញ។»
Genesis 21:33
ដើមអំពិលមួយ
នេះគឺជាដើមឈើបៃតងដែលអាចដុះនៅវាលខ្សាច់។ វាត្រូវបានបញ្ជាក់ជាទូទៅ។
ការបកប្រែផ្សេងទៀត៖ «ដើមឈើ» (សូមមើល:translate-unknown)
ព្រះជាម្ចាស់ដ៏នូវអស់កល្ប
«គឺជាព្រះជាម្ចាស់ដែលគង់នៅរហូត»
ជាច្រើនថ្ងៃ
នេះគឺសំដៅពេលវេលាដែលយូរ។

---

22 [1]បន្ទាប់ពីការទាំងនោះមក ព្រះជាម្ចាស់បានល្បងលលោកអប្រាហាំ។ ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «អប្រាហាំ!» លោកអប្រាហាំទូលថា៖ «ទូលបង្គំនៅទីនេះ»។
[2]បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរយកកូនប្រុស គឺកូនប្រុសតែមួយគត់របស់អ្នក ជាកូនដែលអ្នកស្រឡាញ់ ហើយទៅទឹកដីម៉ូរីយ៉ា។
ថ្វាយគាត់ជាយញ្ញបូជាដុតនៅលើភ្នំមួយនៅទីនោះ ដែលយើងនឹងប្រាប់ដល់អ្នក»។[3]ដូច្នេះ លោកអប្រាហាំបានក្រោកតាំងពីព្រលឹម ចងកែបលារបស់គាត់
ហើយយកអ្នកបម្រើរបស់គាត់ពីរនាក់ទៅជាមួយគាត់ រួមទាំងអ៊ីសាកកូនប្រុសរបស់គាត់។ គាត់បានកាប់អុសដើម្បីជាតង្វាយដុត បន្ទាប់មក
រៀបចំចេញដំណើរទៅកន្លែងដែលបានប្រាប់ដល់គាត់។
[4]នៅថ្ងៃទីបី លោកអប្រាហាំបានងើយទៅលើ ហើយមើលឃើញកន្លែងនោះពីចម្ងាយ។[5]គាត់បាននិយាយទៅកាន់អ្នកបម្រើរបស់គាត់ថា៖
«ចូរនៅទីនេះជាមួយនឹងសត្វលាហើយ យើង និងក្មេងនឹងទៅទីនោះ។ យើងនឹងទៅថ្វាយបង្គំព្រះ ហើយនឹងត្រឡប់មករកអ្នកវិញ»។[6]បន្ទាប់មក
លោកអប្រាហាំបានយកអុសសម្រាប់ជាតង្វាយដុត ហើយដាក់វាឲ្យអ៊ីសាកកូនប្រុសរបស់គាត់លី។ គាត់បានកាន់ភ្លើង និងកាំបិតដោយដៃរបស់គាត់ផ្ទាល់ ហើយទាំងឪពុក
ទាំងកូនដើរទៅជាមួយគ្នា ហើយពួកគេទាំងពីរបានទៅជាមួយគ្នា។
[7]អ៊ីសាកនិយាយទៅកាន់លោកអប្រាហាំជាឪពុករបស់គាត់ថា៖ «ពុក» ហើយគាត់ឆ្លើយថា៖ «មានការអីកូន»។ គាត់និយាយថា៖ «មើល៍ នៅទីនេះ មានអុស និងភ្លើង ប៉ុន្តែ
តើកូនចៀមសម្រាប់ជាតង្វាយដុតនៅឯណា?»[8]លោកអប្រាហាំប្រាប់ថា៖ «កូនអើយ ព្រះជាម្ចាស់នឹងផ្គត់ផ្គង់កូនចៀមសម្រាប់ជាតង្វាយដុត»។ ដូច្នេះ
ពួកគេក៏បន្តដំណើរទៅមុខទៀត ជាមួយគ្នា។
[9]នៅពេលពួកគេទៅដល់កន្លែងដែលព្រះជាម្ចាស់បានប្រាប់ដល់គាត់ លោកអប្រាហាំបានសង់អាសនៈមួយនៅទីនោះ ហើយដាក់អុសនៅលើវា។ បន្ទាប់មក
ចងអ៊ីសាក់កូនប្រុសរបស់គាត់ ហើយផ្តេកគាត់នៅលើអាសនៈនៅលើអុសនោះ។[10]លោកអប្រាហាំបានលូកដៃរបស់គាត់យកកំបិត ដើម្បីសម្លាប់កូនប្រុសរបស់គាត់។
[11]បន្ទាប់មក ទេវតារបស់ព្រះអម្ចាស់បានហៅកាត់ពីស្ថានសួគ៌ ដោយមានបន្ទូលថា៖ «អប្រាហាំ អប្រាហាំអើយ! ហើយគាត់បានទូលឆ្លើយថា៖ «ទូលបង្គំនៅទីនេះហើយ»។
[12]ព្រះអង្គមានបន្ទូលថា៖ «កុំលូកដៃរបស់អ្នកលើក្មេង ឬធ្វើអ្វីឲ្យគាត់មានរបួសឡើយ ដ្បិត ឥឡូវនេះ យើងដឹងហើយថា អ្នកកោតខ្លាចព្រះជាម្ចាស់ មើល
អ្នកមិនបានសំចៃសូម្បីតែកូនប្រុសរបស់អ្នក គឺកូនប្រុសតែមួយរបស់អ្នក ពីយើងទេ»។
[13]លោកអប្រាហាំងើយទៅលើ ហើយមើល៍ នៅខាងក្រោយគាត់មានចៀមមួយ ដោយស្នែងរបស់វានៅជាប់នឹងព្រៃ។ លោកអប្រាហាំបានទៅ ហើយយកចៀម
ហើយថ្វាយចៀមនោះជាតង្វាយដុត ជំនួសឲ្យកូនរបស់គាត់។[14]ដូច្នេះ លោកអប្រាហាំបានហៅកន្លែងនោះថា៖ «ព្រះអម្ចាស់ផ្គត់ផ្គង់»។
ហើយគេបានហៅកន្លែងនោះរហូតមកដល់សព្វថ្ងៃនេះថា នៅលើភ្នំរបស់ព្រះអម្ចាស់ ព្រះអង្គនឹងផ្គត់ផ្គង់»។

generated on Wed Sep 10 16:16:32 2025

[15]ទេវតារបស់ព្រះអម្ចាស់បានហៅលោកអប្រាហាំពីស្ថានសួគ៌ជាលើកទីពីរ ហើយមានបន្ទូលថា[16]នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
យើងស្បថនឹងខ្លួនយើងដោយព្រោះអ្នកបានធ្វើការនេះ ហើយអ្នកមិនបានសំចៃ សូម្បីតែកូនប្រុស គឺកូនប្រុសតែមួយរបស់អ្នក[17]យើងនឹងឲ្យពរដល់អ្នក
ហើយយើងនឹងធ្វើឲ្យពូជពង្សរបស់បានចម្រើនកើនឡើងដូចជាផ្កាយនៅលើមេឃ ហើយដូចជាខ្សាច់នៅមាត់សមុទ្រ
ហើយពូជពង្សរបស់អ្នកនឹងគ្រប់គ្រងលើទ្វារខ្មាំងសត្រូវរបស់ពួកគេ។
[18]តាមរយៈពូជពង្សរបស់អ្នក ប្រជាជាតិនៅលើផែនដីទាំងមូលនឹងបានពរ ព្រោះអ្នកបានស្តាប់តាមសម្លេងរបស់យើង»។[19]ដូច្នេះ
លោកអប្រាហាំបានត្រឡប់ទៅអ្នកបម្រើរបស់គាត់វិញ ហើយពួកគេបានចាកចេញ ហើយឆ្ពោះទៅបៀរសេបាជាមួយគ្នា។
[20]បន្ទាប់ពីការទាំងអស់នេះហើយ មានគេមកប្រាប់លោកអប្រាហាំថា៖ «នាងមីលកាក៏បង្កើតបានកូនឲ្យលោកណាឃរ ជាប្អូនរបស់លោកដែរ»។[21]គឺអ៊ូសជាកូនច្បង ប៊ូសជា
ប្អូនប្រុសរបស់គាត់ កេមូអែលជាឪពុករបស់អើរ៉ាម[22]កេសែឌ ហាសួរ ពីលដាស យីដឡាប និងបេធូអែល។
[23]លោកបេធូអែលបង្កើតបាននាងរេបិកា។ ទាំងនេះគឺជាកូនៗទាំងប្រាំបីដែលនាងមីលកាបង្កើតឲ្យលោកណាឃរ ជាប្អូនប្រុសរបស់លោកអប្រាហាំ។[24]ចំណែក ប្រពន្ធទីពីរ
របស់លោកណាឃរ ឈ្មោះនាងរេយូម៉ា ក៏មានកូនដែរ គឺធេបា កាហាំ ថាហាស និងម្អាកា។

Genesis 22:1

បន្ទាប់ពីការ

ឃ្លានៅទីនេះដើម្បីបញ្ជាក់ពីការចាប់ផ្តើមនៃសាច់រឿងថ្មី។

បន្ទាប់ពីការទាំងនោះ

នេះគឺសំដៅទៅលើព្រឹត្តិការណ៍ដែលមាននៅក្នុងជំពូក២១។

ព្រះជាម្ចាស់បានល្បងលលោកអប្រាហាំ

គឺបញ្ជាក់ថាព្រះជាម្ចាស់កំពុងសាកល្បងលលោកអប្រាហាំដើម្បីដឹងថាលោកអប្រាហាំនឹងស្តាប់បង្គាប់ឬអត់។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖ «
ព្រះជាម្ចាស់បានសាកល្បងភាពស្មោះត្រង់របស់លោកអប្រាហាំ »

ទូលបង្គំនៅទីនេះ

«ក្រាបទូល ទូលបង្គំកំពុងតែស្តាប់» ឬ«ក្រាបទូល តើមានអ្វី?»

កូនប្រុសតែមួយគត់របស់អ្នក

គឺបញ្ជាក់ថាព្រះជាម្ចាស់ដឹងថាលោកអប្រាហាំមានកូនប្រុសមួយទៀតគឺអ៊ីស្មាអែល។
នេះបញ្ជាក់ថាអ៊ីសាកជាកូនប្រុសដែលព្រះព្រះជាម្ចាស់បានសន្យាថានឹងឲ្យលោកអប្រាហាំ
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖ «កូនប្រុសតែមួយរបស់អ្នកដែលខ្ញុំបានសន្យា»

ដែលអ្នកស្រឡាញ់

នេះបញ្ជាក់ពីសេចក្តីស្រឡាញ់របស់លោកអប្រាហាំចំពោះកូនប្រុសរបស់គាត់
អ៊ីសាក។

ទឹកដីម៉ូរីយ៉ា

«ទឹកដីដែលបានហៅថាម៉ូរីយ៉ា»

ចងកែបលារបស់គាត់

«ផ្ទុកលើសត្វលារបស់គាត់ » ឬ
«ដាក់លើលារបស់គាត់នូវអ្វីដែលគាត់ត្រូវការសម្រាប់ការធ្វើដំណើរ »

ក្មេងប្រុសៗ

«អ្នកបម្រើ»

រៀបចំចេញដំណើររបស់គាត

«បានចាប់ផ្តើមដំណើររបស់គាត់» ឬ «ចាប់ផ្តើមធ្វើដំណើរ»

Genesis 22:4

នៅថ្ងៃទីបី

ពាក្យ «ទីបី» គឺជាលេខដើមសម្រាប់លេខ៣។ ការបកប្រែផ្សេងទៀត៖
«បន្ទាប់ពីធ្វើដំណើរអស់រយៈពេលបីថ្ងៃ»

មើលឃើញកន្លែងនោះពីចម្ងាយ

«ឃើញកន្លែងដែលព្រះបានមានបន្ទូលមក»

ក្មេងប្រុសៗ

«អ្នកបម្រើ»

យើងនឹងថ្វាយបង្គំ

ពាក្យ«យើង»គឺសំដៅទៅលោកអប្រាហាំនិងអ៊ីសាក។

នឹងត្រឡប់មករកអ្នកវិញ

«ត្រឡប់មករកអ្នក»

ដាក់លើអ៊ីសាកកូនប្រុសរបស់គាត់

«មានអ៊ីសាក កូនគាត់ លីវ៉ា»

គាត់បានយកនៅក្នុងដៃរបស់គាត់ផ្ទាល់

នៅទីនេះ«ដៃរបស់គាត់ផ្ទាល់»បញ្ជាក់ថា លោកអប្រាហាំបានកាន់របស់ទាំងនេះ។
ការបកប្រែផ្សេងទៀត៖ «លោកអប្រាហាំផ្ទាល់បានដឹក»

ភ្លើង

នៅទីនេះ «ភ្លើង» តំណាងឱ្យខ្ទះដែលផ្ទុកធ្យូងឬពិលឬចង្កៀង។
ការបកប្រែផ្សេងទៀត៖ «អ្វីមួយសម្រាប់ការចាប់ផ្តើមឆេះ»

ហើយពួកគេទាំងពីរបានទៅជាមួយគ្នា

«ពួកគេបានចាកចេញទៅទាំងអស់គ្នា»ឬ«ទាំងពីរបានទៅជាមួយគ្នា»

Genesis 22:7

លោកឪពុករបស់ខ្ញុំ

[illegible]

ខ្ញុំនៅទីនេះ

«បាទ ខ្ញុំកំពុងស្តាប់» ឬ «បាទ តើមានអ្វី?» សូមមើលនៅក្នុង ២២: ១

កូនអើយ

នេះជាវិធីដែលគួរឱ្យស្រឡាញ់សម្រាប់ឪពុកនិយាយជាមួយកូនប្រុសរបស់គាត់។

ភ្លើង

នៅទីនេះ «ភ្លើង» តំណាងឱ្យខ្ទះដែលផ្ទុកធ្យូង ឬពិល ឬចង្កៀង។ សូមមើលនៅក្នុង ២២: ៤

កូនចៀមសម្រាប់ជាតង្វាយដុត

«កូនចៀមដែលអ្នក នឹងថ្វាយជាតង្វាយដុត»

ព្រះជាម្ចាស់ផ្ទាល់

នៅទីនេះ «ទ្រង់ផ្ទាល់» សង្កត់ធ្ងន់គឺជាព្រះជាម្ចាស់ដែលនឹងផ្តល់សាច់ចៀម។

នឹងផ្តត់ផ្គង់

«និងផ្តល់អោយយើង»

Genesis 22:9

នៅពេលពួកគេទៅដល់កន្លែង

«ពេលលោកអប្រាហាំនិងអ៊ីសាកមកដល់កន្លែង»

គាត់ចង

«គាត់បានចង»

លើអាសនៈនៅលើអុសនោះ

«នៅលើឈើ ដែលមាននៅលើអាសនៈ»

បានលូកដៃរបស់គាត់យកកំបិត

«បានយកកាំបិត»

Genesis 22:11

ទេវតារបស់ព្រះអម្ចាស់

អត្ថន័យដែលមានគឺ ១) ព្រះអម្ចាស់បានធ្វើទ្រង់ ដូចទេវតាឬ ២)
នេះគឺជាទេវតារបស់ព្រះអម្ចាស់ ឬ ៣)
នេះគឺជាអ្នកនាំសារពិសេសមកពីព្រះជាម្ចាស់ (អ្នកសិក្សាខ្លះគិតថាជាព្រះយេស៊ូ) ។
ដោយសារឃ្លាមិនត្រូវបានយល់ច្បាស់ វាជាការល្អបំផុតដើម្បីបកប្រែថា
«ទេវតារបស់ព្រះអម្ចាស់» ដោយប្រើពាក្យធម្មតា «ទេវតា» សូមមើលឃ្លានេះក្នុង ១៦: ៧

ពីស្ថានសួគ៌

នេះគឺសំដៅទីកន្លែងដែលព្រះជាម្ចាស់គង់នៅ។

ទូលបង្គំនៅទីនេះ

«បាទ ទូលបង្គំកំពុងស្តាប់» ឬ «បាទ តើជាអ្វី?» សូមមើលនៅក្នុង ២២: ១

កុំលូកដៃរបស់អ្នកលើក្មេង ឬធ្វើអ្វីឲ្យគាត់មានរបួសឡើយ

ឃ្លាថា «កុំដាក់ដៃអ្នកលើ» គឺជាវិធីនិយាយថា «កុំធ្វើបាប»
ព្រះជាម្ចាស់បានមានបន្ទូលដូចគ្នានឹងពីរដងដើម្បីបញ្ជាក់ថាលោកអប្រាហាំមិនគួរធ្វើបាបអ៊ីសាកឡើយ។
ការបកប្រែផ្សេងទៀត៖
«កុំធ្វើបាបក្មេងប្រុសមិនថាតាមរបៀបណាមួយោឡើយ» (សូមមើល និងfigs-parallelism)

generated on Wed Sep 10 16:16:32 2025

ដ្បិត ឥឡូវនេះ យើងដឹង.....ពីយើង
ពាក្យ «យើង» និង «យើង» សំដៅទៅលើព្រះអម្ចាស់។
នៅពេលបកប្រែអ្វីដែលមាននៅក្នុងពាក្យដកស្រង់ចូរធ្វើដូចទេវតារបស់ព្រះអម្ចាស់បានធ្វើ
«យើង» និង «យើង» នៅពេលនិយាយគឺសំដៅទៅព្រះអម្ចាស់។
អ្នកកោតខ្លាចព្រះជាម្ចាស់
នេះសំដៅទៅលើការគោរពព្រះយ៉ាងជ្រាលជ្រៅហើយបង្ហាញការគោរពនោះដោយស្តាប់
មើលន៏
«ពីព្រោះយើងបានឃើញ»
អ្នកមិនបានសំចៃសូម្បីតែកូនប្រុសរបស់អ្នក គឺកូនប្រុសតែមួយរបស់អ្នក..... ពីយើងទេ
«អ្នកមិនបានឃាត់កូនប្រុសរបស់អ្នក....ពីយើងទេ»
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត៖
«អ្នកសុខចិត្តផ្តល់ជូនកូនប្រុសរបស់អ្នក ... ដល់យើង»
កូនប្រុសអ្នក,កូនប្រុសរបស់អ្នកតែមួយ
បញ្ជាក់ថាព្រះជាម្ចាស់ដឹងថាលោកអប្រាហាំមានកូនប្រុសមួយទៀតគឺអ៊ីស្មាអែល។
នេះបញ្ជាក់ថាអ៊ីសាកជាកូនប្រុសដែលព្រះជាម្ចាស់បានសន្យាថានឹងឲ្យលោកអប្រាហាំ
សូមមើលនៅក្នុង ២២: ១
Genesis 22:13
មើល៍
ពាក្យ «មើល»
នៅទីនេះពញ្ជាក់យើងឱ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលមាននៅ
គឺចៀមឈ្មោលដែលជាប់នៅក្នុងគុម្ពោតដោយស្នែងរបស់វា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«គឺជាចៀមឈ្មោលដែលមានស្នែងនៅជាប់នឹងគុម្ពោត» ឬ
«ជាចៀមដែលជាប់នៅក្នុងគុម្ពោត»
បានទៅ ហើយយកចៀម
«លោកអប្រាហាំបានទៅឯចៀមនោះហើយចាប់យកវា»
នឹងផ្គត់ផ្គង់.....និងបានផ្គត់ផ្គង់
ប្រើពាក្យដូចគ្នាសម្រាប់ «ផ្គត់ផ្គង់» ដូចដែលអ្នកបានប្រើក្នុង ២២: ៧
ល់សព្វថ្ងៃនេះ
«សូម្បីតែឥឡូវនេះ»
នេះមានន័យថាសូម្បីតែពេលវេលាដែលអ្នកនិពន្ធកំពុងសរសេរសៀវភៅនេះ។
ព្រះអង្គនឹងផ្គត់ផ្គង់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ទ្រង់នឹងផ្គត់ផ្គង់»
Genesis 22:15
ទេវតារបស់ព្រះអម្ចាស់
អត្ថន័យដែលមានគឺ ១) ព្រះអម្ចាស់បានធ្វើឲ្យទ្រង់ ដូចទេវតាឬ ២)
នេះគឺជាទេវតារបស់ព្រះអម្ចាស់ ឬ ៣) នេះគឺជាអ្នកនាំសារពិសេសមកពីព្រះជា
ម្ចាស់ (អ្នកសិក្សាខ្លះគិតថាជាព្រះយេស៊ូវ)។
ដោយសារឃ្លាមិនត្រូវបានយល់ច្បាស់វាជាការល្អបំផុតដើម្បីបកប្រែថា
«ទេវតារបស់ព្រះអម្ចាស់» ដោយប្រើពាក្យធម្មតាដែលអ្នកប្រើសម្រាប់ «ទេវតា»។
សូមមើលក្នុង ១៦: ៧
លើកទីពីរ
ពាក្យ«ទីពីរ»ជាលេខពីរ។ ការបកប្រែផ្សេងទៀត៖ «ម្តងទៀត»
ពីស្ថានសួគ៌
ពាក្យត្រង់នេះ«ស្ថានបរមសុខ»សំដៅទីកន្លែងដែលព្រះជាម្ចាស់គង់នៅ។
បន្ទូលថា - នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
«ហើយនិយាយថាព្រះបន្ទូលនេះពីព្រះអម្ចាស់» ឬ
«ហើយប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់»។
នេះជាវិធីនិយាយជាផ្លូវនូវពាក្យដែលមកតាមក្រោយគឺមកពីព្រះអម្ចាស់ផ្ទាល់។
យើងស្បថនឹងខ្លួនយើង
«ខ្ញុំបានសន្យាហើយខ្ញុំជាសាក្សីរបស់ខ្ញុំ»។
ពាក្យ«ស្បថដោយ»មានន័យថាប្រើឈ្មោះអ្វីមួយឬនរណាម្នាក់ជាមូលដ្ឋានឬអំណាចលើ
គ្មានអ្វីអាចប្រៀបផ្ទឹមនឹងព្រះអម្ចាស់បានឡើយក្រៅពីព្រះអង្គផ្ទាល់។
អ្នកបានធ្វើការនេះ
«អ្នកបានស្តាប់បង្គាប់យើង»
ហើយអ្នកមិនបានសំចៃ សូម្បីតែកូនប្រុស
«មិនបានរក្សាកូនប្រុសអ្នកទេ»។ នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។
ការបកប្រែផ្សេងទៀត៖ «សុខចិត្តប្រគល់កូនប្រុសរបស់អ្នកមកយើង»
កូនប្រុសអ្នក,កូនប្រុសតែមួយរបស់អ្នក
បញ្ជាក់ថាព្រះដឹងថាអប្រាហាំមានកូនប្រុសមួយទៀតគឺអ៊ីស្មាអែល។
ធ្វើនិយ
នេះបញ្ជាក់ថាអ៊ីសាកជាកូនប្រុសដែលព្រះបានសន្យាថានឹងឲ្យលោកអប្រាហាំ។
សូមមើលនៅក្នុង ២២: ១
ព្រះពរពិតប្រាកដ
«ប្រាកដ
យើងនឹងធ្វើឲ្យពូជពង្សរបស់បានចម្រើនកើន
«យើងនឹងធ្វើអោយកូនចៅរបស់អ្នកកើនចំនួនច្រើនដង» ឬ
«យើងនឹងធ្វើអោយកូនចៅរបស់អ្នកកើនចំនួនច្រើន»
កើនឡើងដូចជាផ្កាយនៅលើមេឃ ហើយដូចជាខ្សាច់នៅមាត់សមុទ្រ
ព្រះជាម្ចាស់បានប្រៀបធៀបកូនចៅរបស់អប្រាហាំទៅនឹងផ្កាយនិងខ្សាច់។
ដូចជាមនុស្សមិនអាចរាប់ផ្កាយបានច្រើនឬគ្រាប់ខ្សាច់ដែរ
ដូច្នេះកូនចៅរបស់អ័ប្រាហាំជាច្រើនមិនអាចរាប់ពួកគេបានឡើយ។
ការបកប្រែផ្សេងទៀត៖ «លើសពីអ្វីដែលអ្នកអាចរាប់បាន»
ដូចជាផ្កាយនៅលើមេឃ
នៅទីនេះពាក្យថា« មេឃ»
សំដៅទៅលើអ្វីៗដែលយើងឃើញនៅខាងលើផែនដី,រួមទាំងព្រះអាទិត្យ
ព្រះចន្ទនិងផ្កាយ។
នឹងគ្រប់គ្រងលើទ្វារខ្មាំងសត្រូវរបស់ពួកគេ
ទ្វារ» តំណាងឱ្យទីក្រុងទាំងមូល។ ដើម្បី«
កាន់កាប់ទ្វារសត្រូវរបស់ពួកគេ» មានន័យថាបំផ្លាញសត្រូវរបស់ពួកគេ។
ការបកប្រែផ្សេងទៀត៖ «នឹងទទួលបានជ័យជម្នះទាំងស្រុងលើសត្រូវរបស់ពួកគេ»
Genesis 22:18
ព័ត៌មានទូទៅ
ទេវតារបស់ព្រះជាម្ចាស់បន្តសន្ទនាជាមួយលោកអប្រាហាំ។
ប្រជាជាតិនៅលើផែនដីទាំងមូលនឹងបានពរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«យើងជាព្រះអម្ចាស់នឹងប្រទានពរដល់ប្រជាជនទាំងអស់ដែលរស់នៅគ្រប់ទីកន្លែង»
ប្រជាជាតិនៅលើផែនដី
ទីនេះ«ប្រជាជាតិ»តំណាងអោយប្រជាជននៃប្រជាជាតិនានា។
ព្រោះអ្នកបានស្តាប់តាមសម្លេងរបស់យើង
នៅទីនេះ« សម្លេង» តំណាងអោយអ្វីដែលព្រះបានមានបន្ទូល។
ការបកប្រែផ្សេងទៀត៖ «អ្នកបានធ្វើតាមអ្វីដែលយើងបាននិយាយ» ឬ
«អ្នកបានស្តាប់តាមយើង»
លោកអប្រាហាំបានត្រឡប់
មានតែលោកអប្រាហាំទេដែលត្រូវបានគេដាក់ឈ្មោះព្រោះគាត់ជាឪពុក
ប៉ុន្តែមានន័យថាកូនប្រុសរបស់គាត់បានទៅជាមួយគាត់។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖
«លោកអប្រាហាំនិងកូនប្រុសរបស់គាត់បានត្រលប់មកវិញ»
ក្មេងប្រុសៗ
«អ្នកបម្រើ»
ពួកគេបានចាកចេញ
«ពួកចាកចេញពីកន្លែងនោះ»
គាត់រស់នៅឯបៀរសេបា
មានតែលោកអប្រាហាំទេដែលត្រូវបានគេលើកឡើងដោយសារតែគាត់ជាមេដឹកនាំក្រុមគ្រួសារនិងអ្នកប
ប៉ុន្តែត្រូវបានបញ្ជាក់ថាពួកគេនៅជាមួយគាត់។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖
«លោកអប្រាហាំនិងប្រជាជនរបស់គាត់បានស្នាក់នៅបៀរសេបា»
Genesis 22:20
បន្ទាប់ពីការទាំងអស់នេះហើយ
ឃ្លា«ការទាំងនេះ»សំដៅទៅលើព្រឹត្តិការណ៍នៅលោកុប្បត្តិ ២២: ១-១៩
មកប្រាប់លោកអប្រាហាំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«មានគេមកប្រាប់លោកអប្រាហាំ»
នាងមីលកាក៏បង្កើតបានកូន
«មីលកាក៏បង្កើតកូន»

generated on Wed Sep 10 16:16:32 2025

មីលកា
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
គឺអ៊ូសជាកូនច្បង ប៊ូសជាប្អូនប្រុសរបស់គាត់
ឈ្មោះរបស់កូនច្បងគឺអ៊ូស ហើយឯឈ្មោះរបស់ប៊ូសជាប្អូនរបស់គាត់។
អ៊ូស..ប៊ូស...អើរ៉ាម...កេសែឌ,ហាសួរ,ពីលដាស,យីដឡាប,និងបេធូអែល
ទាំងនេះជាឈ្មោះប្រុសៗ។
បកប្រែវាដូច្នេះវាច្បាស់ថាទាំងអស់នេះលើកលែងតែអើរ៉ាម
គឺជាកូនរបស់ណាឃរនិងមីលកា។
Genesis 22:23
លោកបេធូអែលបង្កើតបាននាងរេបិកា
«បន្ទាប់មកបេអែលបានក្លាយទៅជាឪពុកនៃរេបេកា»
ទាំងនេះគឺជាកូនៗទាំងប្រាំបីដែលនាងមីលកាបង្កើតឲ្យលោកណាឃរ
ជាប្អូនប្រុសរបស់លោកអប្រាហាំ
«ទាំងនេះគឺជាកូនទាំងប្រាំបីនាក់របស់មីលកានិងណាឃរដែលជាប្អូនរបស់លោកអប្រាហាំ»។
នេះសំដៅទៅលើកូនដែលត្រូវបានចុះបញ្ជីនៅ ២២ ៖ ២០
ប្រាំបី
«៨»
ប្រពន្ធចុងរបស់គាត់
«លោកណាឃរមានប្រពន្ធចុង»
រេយូម៉ា
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
ក៏មានកូនដែរ
«ដូចគ្នាក៏បានបង្កើតកូន»
ធេបា កាហាំ ថាហាស និងម្អាកា
ទាំងអស់នេះគឺជាឈ្មោះរបស់មនុស្សប្រុស។

---

23 [1]នាងសារ៉ារស់បានមួយរយម្ភៃប្រាំពីរឆ្នាំ។ ទាំងនេះគឺចំនួនឆ្នាំនៃជីវិតរបស់នាងសារ៉ា។[2]នាងសារ៉ាបានស្លាប់នៅក្រុងគារយ៉ាត់ អើបា គឺនៅក្រុងហេប្រូន ក្នុងទឹកដីកាណាន។ លោកអប្រាហាំបានកាត់ទុក្ខ និងយំសោកចំពោះនាងសារ៉ា។
[3]បន្ទាប់មក លោកអប្រាហាំក្រោកឡើង ហើយចេញពីសេចក្តីស្លាប់របស់ភរិយារបស់គាត់ ហើយបាននិយាយទៅកូនចៅប្រុសលោកហេត ពោលថា៖
[4]«ខ្ញុំជាជនបរទេសនៅក្នុងចំណោមអ្នករាល់គ្នា។ សូមចែកដីសម្រាប់កន្លែងបញ្ចុះសពនៅក្នុងចំណោមអ្នករាល់គ្នា ដើម្បីឲ្យខ្ញុំអាចបញ្ចុះសពខ្ញុំផង។
[5]កូនចៅរបស់លោកសេតឆ្លើយទៅលោកអប្រាហាំដោយនិយាយថា៖[6]«លោកម្ចាស់ សូមស្តាប់យើងខ្ញុំ។ លោកគឺជាព្រះអង្គម្ចាស់របស់ព្រះជាម្ចាស់នៅចំណោមយើង។ សូមបញ្ចុះសាកសពរបស់លោកនៅក្នុងផ្នូរដែលល្អបំផុតរបស់យើង។ នៅក្នុងចំណោមយើងគ្មាននរណាបដិសេធមិនឲ្យផ្នូររបស់គេឡើយ ដូច្នេះលោកអាចបញ្ចុះសាកសពរបស់លោកហើយ។
[7]លោកអប្រាហាំក្រោកឡើយ ហើយលុតជង្គង់ចុះចំពោះម្ចាស់ទឹកដី គឺចំពោះកូនចៅរបស់លោកសេត។[8]គាត់បាននិយាយទៅពួកគេ ដោយពោលថា៖ «ប្រសិនបើអ្នករាល់គ្នាយល់ព្រម ឲ្យខ្ញុំបានបញ្ចុះសពរបស់ខ្ញុំមែន ដូច្នេះ សូមស្តាប់ខ្ញុំ ហើយជួយនិយាយជាមួយលោកអេប្រូន ជាកូនរបស់លោកសូហារឲ្យខ្ញុំផង។[9]សូមឲ្យគេលក់រូងភ្នំម៉ាកពេឡារបស់គាត់ឲ្យខ្ញុំមក។ សូមឲ្យគាត់លក់ក្នុងតម្លៃពេញដល់ខ្ញុំជាសាធារណៈ ជាទ្រព្យសម្បត្តិសម្រាប់ជាកន្លែងបញ្ចុះសព»។
[10]លោកអេប្រូនអង្គុយនៅក្នុងចំណោមកូនចៅរបស់លោកហេត ហើយលោកអេប្រូន ជាជនជាតិបានឆ្លើយទៅលោកអប្រាហាំនៅចំពោះមុខរបស់កូនចៅហេត នៃអស់អ្នកដែលមកក្នុងទ្វារក្រុង និយាយថា៖[11]«អត់ទេ លោកម្ចាស់ សូមស្តាប់ខ្ញុំសិន។ ខ្ញុំប្រគល់ដី និងរូងភ្នំនៅក្នុងនោះឲ្យលោក។ ខ្ញុំនឹងប្រគល់វាឲ្យលោកនៅចំពោះមុខប្រជាជនរបស់ខ្ញុំទាំងអស់។ ខ្ញុំនឹងប្រគល់វាជូនលោក ដើម្បីបញ្ចុះសពរបស់លោក»។
[12]បន្ទាប់មក លោកអប្រាហាំលុតជង្គង់ចុះនៅចំពោះអ្នកស្រុកនោះ។[13]គាត់និយាយទៅលោកអេប្រូន ហើយអ្នកស្រុកទាំងអស់ក៏បានឮផងដែរ ថា៖ «សូមស្តាប់ខ្ញុំ ប្រសិនបើលោកព្រម ខ្ញុំនឹងបង់ថ្លៃសម្រាប់ដីនេះ។ សូមយកលុយពីខ្ញុំចុះ ហើយខ្ញុំនឹងបញ្ចុះសពខ្ញុំនៅទីនោះ»។
[14]លោកអេប្រូនឆ្លើយទៅលោកអប្រាហាំថា៖[15]«លោកម្ចាស់ សូមមេត្តាស្តាប់ខ្ញុំសិន។ ដីមួយដុំនេះមានតម្លៃប្អូនរយសេកែល តើតម្លៃនេះមានអ្វីសំខាន់រវាងលោកម្ចាស់ និងខ្ញុំ? សូមលោកម្ចាស់បញ្ចុះសពចុះ!»។[16]លោកអប្រាហាំបានស្តាប់លោកអេប្រូន ហើយលោកអប្រាហាំបានថ្លឹងប្រគល់ឲ្យលោកអេប្រូននូវចំនួនប្រាក់ដែលគាត់បាននិយាយ ហើយអ្នកស្រុកហេតបានឮទាំងអស់គ្នា គឺប្រាក់ចំនួនបួនរយសេកែល គិតតាមតម្លៃដែលគេលក់ដីនៅសម័យនោះ។
[17]ដូច្នេះ ដីរបស់លោកអេប្រូន ដែលនៅម៉ាកពេឡា ហើយនៅជិតម៉ាមរ៉ែ គឺទាំងដីចម្ការ ដែលមានរូងភ្នំ និងដើមឈើទាំងប៉ុន្មាននៅក្នុងចម្ការ ព្រមទាំងដើមឈើដែលនៅព័ទ្ធជុំវិញចម្ការផង[18]បានប្រគល់ឲ្យលោកអប្រាហាំដែលគាត់បានទិញ នៅចំពោះមុខអស់អ្នកដែលនៅទ្វារក្រុងរបស់គាត់ផង។
[19]បន្ទាប់ពីនេះ លោកអប្រាហាំបានបញ្ចុះនាងសារ៉ាភរិយារបស់គាត់នៅក្នុងដីរូងភ្នំម៉ាកពេឡា ដែលនៅក្បែរម៉ាមរ៉ែ គឺក្នុងក្រុងហេប្រុន ក្នុងទឹកដីកាណាន។[20]ដូច្នេះ ដី និងរូងភ្នំបានប្រគល់ទៅឲ្យលោកអប្រាហាំធ្វើជាទ្រព្យសម្បត្តិសម្រាប់ជាកន្លែងបញ្ចុះសព ពីកូនចៅរបស់លោកហេត។

Genesis 23:1
នាងសារ៉ារស់បានមួយរយម្ភៃប្រាំពីរឆ្នាំ
ប្រាំពីរឆ្នាំ - «សារ៉ារស់នៅ ១២៧ ឆ្នាំ»
ទាំងនេះគឺចំនួនឆ្នាំនៃជីវិតរបស់នាងសារ៉ា
ការបកប្រែខ្លះមិនរាប់បញ្ចូលប្រយោគនេះទេ។
គារយ៉ាត់ អើបា
នេះគឺជាឈ្មោះនៃទីក្រុងមួយ។
លោកអប្រាហាំបានកាត់ទុក្ខ និងយំសោកចំពោះនាងសារ៉ា
«លោកអប្រាហាំពិបាកចិត្តណាស់ហើយយំព្រោះលោកស្រីសារ៉ាបានស្លាប់»
Genesis 23:3
ហើយចេញពីការស្លាប់របស់ភរិយារបស់គាត់
«គាត់បានក្រោកចេញពីសាកសពភរិយារបស់គាត់»
ប្រុសលោកហេត
នៅទីនេះ «កូនប្រុស» តំណាងឱ្យពូជអំបូរលោកហេត។ ការបកប្រែផ្សេងទៀត៖ «កូនចៅហេត» ឬ «ហិតធីត»
ក្នុងចំណោមអ្នក
គំនិតនេះអាចត្រូវបានបង្ហាញនៅក្នុងទីតាំង។ «នៅក្នុងប្រទេសរបស់អ្នក» ឬ «នៅទីនេះ»
សូមចែកដីដល់ខ្ញុំ
«លក់ដីខ្ញុំខ្លះ» ឬ «អនុញ្ញាតឱ្យខ្ញុំទិញដីមួយដុំ»
សពខ្ញុំ
គុណនាមនាម « ស្លាប់» អាចត្រូវបានបញ្ជាក់ជាគុណនាម ឬ កិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត៖ «ប្រពន្ធស្លាប់របស់ខ្ញុំ» ឬ «ប្រពន្ធខ្ញុំដែលបានស្លាប់»
Genesis 23:5
កូនប្រុសរបស់លោកហេត
នៅទីនេះ «កូនប្រុស» តំណាងឱ្យពូជអំបូររបស់លោកហេត។ សូមមើលនៅក្នុង ២៣: ៣។ ការបកប្រែផ្សេងទៀត៖ «កូនចៅហេត»
លោកម្ចាស់របស់ខ្ញុំ
នៅឃ្លានេះប្រើដើម្បីបង្ហាញពីការគោរពដល់លោកអប្រាហាំ។
ព្រះអង្គម្ចាស់របស់ព្រះជាម្ចាស់
នេះគឺជាការសម្គាល់។ នេះប្រហែលជាមានន័យថា «បុរសមានអំណាច» ឬ «មេដឹកនាំដ៏ខ្លាំងម្នាក់»
សពរបស់លោក
គុណនាមបន្ទាប់បន្សំ «ស្លាប់» អាចត្រូវបានបញ្ជាក់ជាកិរិយាសព្ទឬគ្រាន់តែជា «ប្រពន្ធ»។ ការបកប្រែផ្សេងទៀត៖ «ប្រពន្ធរបស់អ្នកដែលបានស្លាប់» ឬ «ប្រពន្ធរបស់អ្នក»
ផ្នូរដែលល្អបំផុតរបស់យើង
«កន្លែងបញ្ចុះសពល្អបំផុតរបស់យើង»
បដិសេធមិនឲ្យផ្នូររបស់គេឡើយ
«បដិសេធកន្លែងបញ្ចុះសពរបស់គាត់ពីអ្នក» ឬ «បដិសេធមិនផ្តល់ឱ្យអ្នកនូវផ្នូររបស់គាត់»
Genesis 23:7

generated on Wed Sep 10 16:16:32 2025

លុតជង្គង់ចុះ
នេះមានន័យថាឱនលុតជង្គង់ឬបន្ទាបខ្លួនទាបបំផុតដើម្បីបង្ហាញការគោរពនិងកិត្តិយសចំពោះ
ចំពោះម្ចាស់ទឹកដី គឺចំពោះកូនចៅរបស់លោកហេត
«ដល់កូនចៅហេតដែលរស់នៅតំបន់នោះ»
កូនចៅរបស់លោកហេត
នៅទីនេះ «កូនប្រុស» តំណាងឱ្យកូនចៅដែលកើតពីលោកហេត។
សូមមើលនៅក្នុង ២៣: ៣ ។ ការបកប្រែផ្សេងទៀត៖ «កូនចៅហេត»
សូមមើលបដែលអ្នកបកប្រែនៅក្នុង ២៣: ៣
សពរបស់ខ្ញុំ
គុណនាមបន្ទាប់បន្សំ «ស្លាប់» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទឬជា «ប្រពន្ធ» ។
ការបកប្រែផ្សេងទៀត៖ «ប្រពន្ធរបស់ខ្ញុំដែលបានស្លាប់» ឬ «ប្រពន្ធរបស់ខ្ញុំ»
អេប្រូន.....សូហារ
នេះគឺជាឈ្មោះរបស់បុរស
រូងភ្នំម៉ាកពេឡា,របស់គាត់,ដែលនៅចុងបញ្ចប់នៃវាលរបស់គាត់
«រូងភ្នំរបស់គាត់ដែលនៅចុងបញ្ចប់នៃចម្ការរបស់គាត់នៅម៉ាក់ពេឡា»
រូងភ្នំនៃម៉ាក់ពេឡា
«រូងភ្នំនៅម៉ាក់ពេឡា។ » ម៉ាក់ពេឡា គឺជាឈ្មោះនៃតំបន់ ឬតំបន់មួយ។
អេប្រុនជាម្ចាស់ចំការមួយនៅម៉ាក់ពេឡា និងរូងភ្នំដែលស្ថិតនៅក្នុងវាលស្រែ។
របស់គាត់
នេះគឺបានប្រាប់អំពីរូងភ្នំរបស់គាត់។ លោកអេប្រុនដែលជាម្ចាស់នៃរូងភ្នំនោះ។
នៅចុងបញ្ចប់នៃវាលរបស់គាត់
នេះក៏ប្រាប់អ្វីមួយអំពីរូងភ្នំ។ រូងភ្នំស្ថិតនៅខាងចុងវាលស្រែរបស់អេប្រុន។
លក់ក្នុងតម្លៃពេញដល់ខ្ញុំជាសាធារណៈ
«លក់វាអោយខ្ញុំនៅចំពោះមុខអ្នកទាំងអស់គ្នា» ឬ
«លក់វាអោយខ្ញុំនៅចំពោះមុខអ្នក»
ជាទ្រព្យសម្បត្តិ
«ជាដីមួយកន្លែងដែលខ្ញុំអាចកាន់កាប់និងប្រើប្រាស់»
Genesis 23:10
លោកអេប្រូនអង្គុយនៅក្នុងចំណោមកូនចៅរបស់លោកហេត
ទីនេះ «ឥឡូវនេះ»
ត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាព័ត៌មានកន្លងទៅអំពីអេប្រុន
លោកអេប្រុន
នេះគឺឈ្មោះនៃបុរសម្នាក់។ សូមមើល៖២៣:៧
កូនចៅរបស់លោកហេត
នៅទីនេះ «កូនប្រុស» តំណាងឱ្យកូនចៅលោកហេត។ សូមមើលនៅក្នុង ២៣: ៣
។ ការបកប្រែផ្សេងទៀត៖ «កូនចៅហេត» សូមមើលនៅក្នុង ២៣: ៣
កូនចៅរបស់លោកហេតដែលបានស្តាប់លឺ
នាមអរូបី «បានឮ» អាចត្រូវបានបញ្ជាក់ថាជា «លឺ» ឬ «ស្តាប់»។
ការបកប្រែផ្សេងទៀត៖ «ដើម្បីឱ្យកូនប្រុសហេតទាំងអស់អាចស្តាប់គាត់» ឬ
«ខណៈពេលដែលកូនប្រុសរបស់ហេតទាំងអស់កំពុងស្តាប់»
នៃអស់អ្នកដែលមកក្នុងទ្វារក្រុង
នេះប្រាប់ថាកូន ៗ របស់ហេតកំពុងតែស្តាប់។ អេធី:
«អស់អ្នកដែលបានប្រមូលផ្តុំគ្នានៅខ្លោងទ្វារក្រុងរបស់គាត់»
ក្នុងទ្វារក្រុងរបស់អ្នក
ច្រកទ្វារទីក្រុងគឺជាកន្លែងដែលមេដឹកនាំទីក្រុងនឹងជួបប្រជុំគ្នាដើម្បីធ្វើការសម្រេចចិត្តសំខាន់ៗ
ទីក្រុងគាត់
«ទីក្រុងដែលគាត់រស់នៅ» ។ ឃ្លានេះបង្ហាញថាអេប្រុនជាកម្មសិទ្ធិរបស់ទីក្រុងនោះ។
វាមិនមានន័យថាគាត់ជាម្ចាស់វាទេ។
លោកម្ចាស់របស់ខ្ញុំ
ឃ្លានេះបង្ហាញពីការគោរពទៅដល់លោកអាប្រាហាំ។
នៅចំពោះមុខប្រជាជនរបស់ខ្ញុំទាំងអស់
នៅទីនេះ« នៅចំពោះមុខ»តំណាងឱ្យប្រជាជនដែលធ្វើជាសាក្សី។
ការបកប្រែផ្សេងទៀត៖ «ជាមួយមិត្តរួមជាតិរបស់ខ្ញុំជាសាក្សីរបស់ខ្ញុំ»
នៅមុខប្រជាជនរបស់ខ្ញុំ
នេះមានន័យថា« ជនរួមជាតិរបស់ខ្ញុំ» ឬ « មិត្តរបស់ខ្ញុំ»
ប្រជាជនរបស់ខ្ញុំ
ប្រជាជានរបស់ខ្ញុំ,
ឃ្លានេះបង្ហាញថាអេប្រុនក៏ជាសមាជិកនៅក្នុងក្រុមនៃប្រជាជននោះដែរ។
វាមិនមានន័យថាគាត់ជាមេដឹកនាំរបស់ពួកគេទេ។
ខ្ញុំនឹងប្រគល់វាជូនលោក ដើម្បីបញ្ចុះសពរបស់លោក
ខ្ញុំនឹងប្រគល់ជូនលោក។ កប់សពរបស់លោក»
សពរបស់លោក
គុណនាមបន្ទាប់បន្សំ «ស្លាប់» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទឬជា«ប្រពន្ធ» ។
ការបកប្រែផ្សេងទៀត៖ «ប្រពន្ធរបស់លោកដែលបានស្លាប់» ឬ
«ប្រពន្ធរបស់លោក»
Genesis 23:12
លុតជង្គង់ចុះ
នេះមានន័យថាឱនលុតជង្គង់ឬបន្ទាបខ្លួនទាបបំផុតដើម្បីបង្ហាញការគោរពនិងអោយកិត្តិយសចំពោះនរណ
ប្រជាជាននៃស្រុក
«ប្រជាជនដែលរស់នៅក្នុងតំបន់នោះ»
អ្នកស្រុកទាំងអស់ក៏បានឮផងដែរ
នាមអរូបី«ដែលលឺ» អាចត្រូវបានគេនិយាយថា «ស្តាប់» ឬ
«កំពុងស្តាប់»ការបកប្រែផ្សេងទៀត៖ ការបកប្រែផ្សេងទៀត៖
ការបកប្រែផ្សេងទៀត៖ «ដើម្បីឱ្យប្រជាជនដែលរស់នៅតំបន់នោះអាចស្តាប់ឮ» ឬ
«ខណៈពេលដែលប្រជាជនដែលរស់នៅតំបន់នោះកំពុងស្តាប់»
ប៉ុន្តែ ប្រសិនបើ លោកព្រម
ពាក្យ «ប៉ុន្តែ» បង្ហាញភាពផ្ទុយគ្នា។ លោកអេប្រុនចង់ផ្តល់ដីដល់លោកអាប្រាហាំ។
អាប្រាហាំចង់បង់ថ្លៃ។ ការបកប្រែផ្សេងទៀត៖ «ទេ ប៉ុន្តែប្រសិនបើលោកយល់ព្រម»
ឬ «ទេប៉ុន្តែប្រសិនបើអ្នកព្រមព្រៀងជាមួយនេះ»
ខ្ញុំនិងបង់លុយសំរាប់ដីនេះ
«ខ្ញុំនិងបង់លុយទៅអោយអ្នកសំរាប់ដីនេះ»
សពរបស់ខ្ញុំ
គុណនាមបន្ទាប់បន្សំ «ស្លាប់» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទឬជា «ប្រពន្ធ។
»ការបកប្រែផ្សេងទៀត៖ «ប្រពន្ធរបស់ខ្ញុំដែលបានស្លាប់» ឬ «ប្រពន្ធរបស់ខ្ញុំ»
Genesis 23:14
លោកអេប្រូន
នេះគឺជាឈ្មោះរបស់ម្នាក់ម្នាក់។សូមមើលនៅក្នុង:២៣:៧
លោកម្ចាស់ សូមមេត្តាស្តាប់ខ្ញុំសិន
"សូមស្តាប់ខ្ញុំ,លោកម្ចាស់"ឬ""សូមស្តាប់ខ្ញុំលោកអើយ"
លោកម្ចាស់
នៅឃ្លានេះគឺដើម្បីបង្ហាញពីការគោរពទៅដល់លោកអាប្រាហាំ។
ដីមួយដុំនេះមានតម្លៃបួនរយសេកែល តើតម្លៃនេះមានអ្វីសំខាន់រវាងលោកម្ចាស់ និងខ្ញុំ?
លោកអេប្រុនបានន័យថាចាប់តាំងពីគាត់
និងលោកអាប្រាហាំមានទ្រព្យស្តុកស្តម្ភណាស់នោះប្រាក់ចំនួន ៤០០
ដុំជាចំនួនតិចតួច។ សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត៖ «ដីនេះមានតម្លៃត្រឹមតែបួនរយតម្លឹងប្រាក់។
សម្រាប់អ្នកនិងខ្ញុំមិនជាអ្វីទេ» (សូមមើលសូមមើលfigs-rquestion)
តម្លៃបួនរយសេកែល នៃប្រាក់
នេះគឺប្រហែល៤.៥គីឡូនៃប្រាក់
បួនរយ
«៤០០»
សូមលោកម្ចាស់បញ្ចុះសពចុះ
គុណនាមបន្ទាប់បន្សំ «ស្លាប់» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទឬជា «ប្រពន្ធ» ។
ការបកប្រែផ្សេងទៀត៖ «ទៅបញ្ចុះប្រពន្ធរបស់អ្នកដែលបានស្លាប់» ឬ
«ទៅបញ្ចុះប្រពន្ធរបស់អ្នក»
លោកអប្រាហាំបានថ្លឹងប្រគល់ឲ្យលោកអេប្រូននូវចំនួនប្រាក់
«អាប្រាហាំបានថ្លឹងប្រាក់ហើយ ឲ្យ
អេប្រុនមនូវចំនួនទឹកប្រាក់នោះ»ឬ«អាប្រាហាំបានរាប់ចំនួនប្រាក់ក៏អោយទៅអេប្រុន»
នូវចំនួនប្រាក់ដែលគាត់បាននិយាយ
«គឺចំនួនប្រាក់ដែលអេប្រុនបាននិយាយ»
នូវចំនួនប្រាក់ដែលគាត់បាននិយាយ
នាមអរូបី «ឮ» អាចត្រូវបានបញ្ជាក់ថាជា «ឮ» ឬ «ស្តាប់» ។
ការបកប្រែផ្សេងទៀត៖ «ដើម្បីឱ្យកូនប្រុសហេតទាំងអស់អាចស្តាប់គាត់» ឬ
«ខណៈពេលដែលកូនប្រុសរបស់ហេតទាំងអស់កំពុងស្តាប់»
កូនប្រុសហេត
នៅទីនេះ «កូនប្រុស»តំណាងឱ្យអ្នកដែលបានកើតពីហេត។ សូមមើលនៅក្នុង
២៣: ៣ ។ ការបកប្រែផ្សេងទៀត៖«កូនចៅហេត»
គិតតាមតម្លៃដែលគេលក់ដីនៅសម័យនោះ

generated on Wed Sep 10 16:16:32 2025

«ប្រើការវាស់ស្តង់ទម្ងន់ដែលឈ្មួញបានប្រើ។ »
នេះអាចត្រូវបានបញ្ជាក់ជាប្រយោគថ្មី។ ការបកប្រែផ្សេងទៀត៖
«គាត់ថ្លឹងប្រាក់តាមរបៀបដែលឈ្មួញប្រើដើម្បីថ្លឹងទម្ងន់»
Genesis 23:17
ម៉ាកពេឡា
ម៉ាក់ពេឡាគឺជាឈ្មោះនៃតំបន់មួយ។បាននិយាយនៅក្នុង២៣:៧
ម៉ាមរេ
នេះគឺជាឈ្មោះនៃទីក្រុងមួយរបស់អេប្រុន។អាចហៅឈ្មោះនេះបន្ទាប់ពីម៉ាមរេ
មិត្តភ័ក្ររបស់លោកអប្រាហាំរស់នៅទីនោះ។
គឺទាំងដីចម្ការ ដែលមានរូងភ្នំ និងដើមឈើទាំងប៉ុន្មាននៅក្នុងចម្ការ ព្រមទាំងដើមឈើ
ឃ្លានេះពន្យល់ពីអត្ថន័យរបស់អ្នកនិពន្ធនៅពេលគាត់សរសេរ «វាលអេប្រុន» ។
វាមិនត្រឹមតែជាវាលស្រែប៉ុណ្ណោះទេប៉ុន្តែក៏ជារូងភ្នំនិងដើមឈើនៅក្នុងវាលផងដែរ។
បានប្រគល់ឲ្យលោកអប្រាហាំដែលគាត់បានទិញ
«បានក្លាយជាកម្មសិទ្ធិរបស់លោកអប្រាហាំនៅពេលដែលគាត់បានទិញវា» ឬ
«ជាកម្មសិទ្ធិរបស់លោកអប្រាហាំបន្ទាប់ពីគាត់បានទិញវា»
នៅចំពោះមុខកូនចៅហេត
នៅទីនេះ« ចំពោះមុខ» តំណាងឱ្យប្រជាជនដែលធ្វើជាសាក្សី។
ការបកប្រែផ្សេងទៀត៖ «ជាមួយប្រជាជនហេតមើលជាសាក្សី»
មុខអស់អ្នកដែលនៅទ្វារក្រុងរបស់គាត់ផង
ត្រង់នេះបានប្រាប់ពីកូនចៅរបស់ហេតបានឃើញលោកអប្រាហាំបានទិញដីនេះ។
សូមនៅ២៣:១០
នៅទ្វារក្រុងរបស់គាត់
ច្រកទ្វារទីក្រុងគឺជាកន្លែងដែលមេដឹកនាំទីក្រុងនឹងជួបប្រជុំគ្នាដើម្បីធ្វើការសម្រេចចិត្តរឿងសំខាន់ៗ។
ទីក្រុងរបស់គាត់
«ទីក្រុងដែលគាត់រស់នៅ» ។ ឃ្លានេះបង្ហាញថាអេប្រុនជាកម្មសិទ្ធិរបស់ទីក្រុងនោះ។
វាមិនមានន័យថាគាត់ជាម្ចាស់វាទេ។
Genesis 23:19
បន្ទាប់ពីនេះ
«បន្ទាប់ពីគាត់ទិញដី»
ដីនៃរូងភ្នំ
«រូងភ្នំដែលនៅក្នុងទឹកដី»
ទឹកដីនៃម៉ាក់ពេឡា
«គឺជាទឹកដីនៅក្នុងម៉ាក់ពេឡា»
គឺក្នុងក្រុងហេប្រុន
អត្ថន័យដែលមានគឺ ១) ម៉ាមរេរសគឺជាឈ្មោះមួយផ្សេងទៀតសម្រាប់ហេប្រុនឬ ២)
ហេប្រុនពីមុនត្រូវបានគេហៅថាម៉ាមរេឬ ៣)
ម៉ាមរេរសគឺស្ថិតនៅជិតទីក្រុងធំនៃហេប្រុនដូច្នេះមនុស្សជាទូទៅហៅវាថាហេប្រុន។
បានប្រគល់ទៅឲ្យលោកអប្រាហាំធ្វើជាទ្រព្យសម្បត្តិសម្រាប់ជាកន្លែងបញ្ចុះសព
ពីកូនចៅរបស់លោកហេត
«បានក្លាយជាទ្រព្យសម្បត្តិរបស់អាប្រាហាំសម្រាប់ការបញ្ចុះសពនៅពេលគាត់បានទិញវាពីកូនចៅ
ហេត»
ពីកូនចៅរបស់លោកហេត
នៅទីនេះ «កូនចៅ» តំណាងឱ្យអ្នកដែលកើតពីហេត។ សូមមើលនៅក្នុង ២៣: ៣
។ ការបកប្រែផ្សេងទៀត៖ «កូនចៅហេត»

---

24 [1]ឥឡូវ លោកអប្រាហាំក៏ចាស់ណាស់ហើយ ហើយព្រះអម្ចាស់បានប្រទានពរដល់លោកអប្រាហាំនៅក្នុងគ្រប់ការទាំងអស់។
[2]លោកអប្រាហាំនិយាយទៅអ្នបម្រើរបស់គាត់ ជាម្នាក់ដែលចាស់ទុំជាងគេនៅក្នុងគ្រួសាររបស់គាត់
ហើយជាម្នាក់ដែលមើលខុសត្រូវលើអ្វីៗទាំងអស់ដែលគាត់មានថា៖ «ចូរដាក់ដៃរបស់ឯងនៅលើភ្លៅរបស់យើង[3]ហើយយើងសូមឲ្យឯងស្បថដោយជាមួយព្រះអម្ចាស់
ជាព្រះជាម្ចាស់នៃស្ថានសួគ៌ និងជាព្រះជាម្ចាស់នៃផែនដីថា ឯងនឹងមិនយកភរិយាឲ្យកូនប្រុសយើងពីកូនស្រីរបស់ជនជាតិកាណាន
គឺនៅក្នុងចំណោមអស់អ្នកដែលយើងបានសង់ផ្ទះនៅជាមួយឡើយ។[4]ប៉ុន្តែ ឯងត្រូវទៅប្រទេសរបស់យើង ហើយទៅរកសាច់ញាតិរបស់យើង
ហើយរកភរិយាឲ្យកូនប្រុសរបស់យើងនៅទីនោះ»។
[5]អ្នកបម្រើបាននិយាយទៅគាត់ថា៖ «ចុះប្រសិនបើស្រីនោះមិនព្រមតាមខ្ញុំមកទឹកដីនេះ?
តើគួរឲ្យខ្ញុំយកកូនប្រុសរបស់លោកម្ចាស់ត្រឡប់ទៅទឹកដីដែលលោកម្ចាស់បានចេញមកដែរទេ?»[6]លោកអប្រាហាំនិយាយទៅគាត់ថា៖
«សូមកុំនាំកូនប្រុសរបស់ខ្ញុំទៅទីនោះឡើយ![7]ព្រះអម្ចាស់ គឺជាព្រះជាម្ចាស់នៃស្ថានសួគ៌ ព្រះអង្គដែលនាំខ្ញុំមកទីនេះ ពីផ្ទះឪពុកម្តាយរបស់ខ្ញុំ
និងពីទឹកដីនៃញាតិសន្តានរបស់ខ្ញុំ ព្រះអង្គបានសន្យាជាមួយខ្ញុំដោយស្បថថា៖ «ព្រះអង្គនឹងប្រគល់ទឹកនេះដល់ពូជពង្សរបស់ខ្ញុំ
ហើយព្រះអង្គនឹងចាត់ទេវតារបស់ព្រះអង្គទៅមុនអ្នក ហើយអ្នកនឹងរកភរិយាសម្រាប់កូនប្រុសរបស់ខ្ញុំនៅទីនោះ។
[8]ប៉ុន្តែប្រសិនបើ ស្ត្រីនោះមិនព្រមមកជាមួយអ្នកទេ ដូចនេះអ្នកបានរួចពីសម្បថជាមួយខ្ញុំហើយ។ តែសូមកុំយកកូនប្រុសរបស់ខ្ញុំទៅទីនោះឡើយ។[9]ដូច្នេះ
អ្នកបម្រើបានយកដៃដាក់នៅលើភ្លៅរបស់លោកអប្រាហាំជាម្ចាស់របស់គាត់ ហើយបានស្បថជាមួយគាត់ទាក់ទងនឹងរឿងនេះ។
[10]អ្នកបម្រើបានយកសត្វអូដ្ឋរបស់ចៅហ្វាយគាត់ដប់ក្បាល ហើយបានចាកចេញទៅ។ គាត់បានយកអំណោយជាច្រើនផ្សេងទៀតពីចៅហ្វាយរបស់គាត់ទៅជាមួយគាត់។
គាត់បានចេញដំណើរ ហើយទៅតំបន់អើរ៉ាម ណាហារ៉ាម គឺទៅទីក្រុងរបស់លោកណាឃរ។[11]គាត់បានឲ្យសត្វអូដ្ឋលុតជង្គង់នៅខាងក្រៅក្រុង នៅក្បែរអណ្តូងទឹក។
គឺនៅពេលល្ងាច ពេលនោះពួកស្រីៗបានចេញមកដងទឹក។
[12]បន្ទាប់មក គាត់អធិស្ឋានថា៖ «ឱព្រះអម្ចាស់ ជាព្រះរបស់លោកអប្រាហាំចៅហ្វាយទូលបង្គំអើយ សូមឲ្យទូលបង្គំបានជោគជ័យនៅថ្ងៃនេះ
ហើយសូមបង្ហាញពីភាពស្មោះត្រង់នៃសម្ពន្ធមេត្រីចំពោះចៅហ្វាយរបស់ទូលបង្គំផង។[13]មើល៍ ទូលបង្គំឈរនៅទីនេះ ក្បែរអណ្តូងទឹក
ហើយពួកស្រីៗនៅក្នុងក្រុងនេះមកចេញមកដងទឹកពីអណ្តូងនេះ។ សូមឲ្យវាកើតឡើងយ៉ាងដូច្នេះ។[14]នៅពេល ទូលបង្គំនិយាយទៅកាន់ស្ត្រីណាថា៖ «សូមនាងដាក់ក្អមចុះ
មកឲ្យខ្ញុំបានផឹកផង» ហើយនាងនិយាយមកទូលបង្គំថា៖ «ចូរផឹកចុះ ហើយខ្ញុំនឹងដងទឹកឲ្យសត្វអូដ្ឋរបស់លោកផឹកដែរ»
នោះសូមឲ្យនាងគឺជាម្នាក់ដែលព្រះអង្គបានចាត់ត្រៀមសម្រាប់អ្នកបម្រើព្រះអង្គឈ្មោះអ៊ីសាក។ នោះ ទូលបង្គំនឹងដឹងថា
ព្រះអង្គបានបង្ហាញពីភាពស្មោះត្រង់ចំពោះសម្ពន្ធមេត្រីដល់ចៅហ្វាយរបស់ទូលបង្គំ»។
[15]កាលគាត់អធិស្ឋានមិនទាន់ចប់ផង មើល៍ នាងរេបិកា កាន់ក្អមលើនៅលើស្មារបស់នាង។ នាងរេបេកាជាកូនស្រីរបស់លោកបេធូអែល ចៅរបស់លោកស្រីមីលកា និង
លោកណាឃរ ដែលជាប្អូនរបស់លោកអប្រាហាំ។[16]នាងជាក្មេងស្រីដែលមានរូបស្រស់ស្អាតណាស់ ហើយជាស្រីក្រមុំផង។ គ្មានបុរសណារស់នៅជាមួយនាងនៅឡើយ។
នាងបានចុះទៅប្រភពទឹក ហើយដងទឹកដាក់ក្អមរបស់នាង ហើយត្រឡប់មកវិញ។
[17]បន្ទាប់មក អ្នកបម្រើនោះបានរត់ទៅជួបនាង ហើយនិយាយថា៖ «សូមឲ្យទឹកនៅក្នុងក្អមរបស់អ្នកឲ្យខ្ញុំផឹកបន្តិចមក»។[18]នាងឆ្លើយថា៖ «លោកម្ចាស់អើយ
សូមពិសាចុះ»។ ហើយនាងបានដាក់ក្អមពីលើស្មារបស់នាងយ៉ាងលឿនមកដាក់លើដៃរបស់នាង ហើយប្រគល់ឲ្យគាត់ផឹក។
[19]នៅពេលនាងបានឲ្យទឹកគាត់ផឹករួចហើយ នាងនិយាយថា៖ «ខ្ញុំនឹងដងទឹកឲ្យសត្វអូដ្ឋរបស់លោកផឹកដែរ រហូតទាល់តែអូដ្ឋឈប់ផឹក»។[20]ដូច្នេះ នាងបានទៅជាប្រញាប់
ហើយចាក់ទឹកអស់ពីក្អមទៅក្នុងស្នូក បន្ទាប់មក នាងបានរត់ម្តងទៀតទៅឯអណ្តូង ដើម្បីដងទឹក ហើយដងទឹកឲ្យសត្វអូដ្ឋទាំងអស់របស់គាត់ផឹក។
[21]បុរសនោះបានមើលនាងពីទីស្ងាត់ មើល៍ដើម្បីឲ្យដឹងថា តើព្រះអម្ចាស់ប្រោសឲ្យដំណើររបស់គាត់បានជោគជ័យឬយ៉ាងណា។[22]បន្ទាប់ពីសត្វអូដ្ឋផឹករួចហើយ
បុរសនោះបានយកមាសមកពាក់នៅនឹងច្រមុះរបស់នាងមានទម្ងន់កន្លះសេកែល និងកងដៃមាសពីរពាក់នៅដៃរបស់នាងមានទំងន់ ដប់សេកែល[23]ហើយសួរថា៖
«តើនាងជាកូនស្រីរបស់អ្នកណា? សូមប្រាប់ខ្ញុំមើល៍ តើនៅផ្ទះឪពុករបស់នាងមានកន្លែងសម្រាប់ឲ្យយើងបានសម្រាកមួយយប់ទេ?
[24]នាងនិយាយទៅគាត់ថា៖ «ខ្ញុំជាកូនស្រីរបស់លោកបេធូអែល ជាកូនរបស់នាងមីលកា បង្កើតឲ្យលោកណាឃរ»។[25]នាងក៏និយាយទៅគាត់ទៀតថា៖ «យើងមានទាំង
ចំបើង និងស្មៅស្ងួតយ៉ាងច្រើនបរិបូរ ហើយក៏មានកន្លែងសម្រាប់អស់លោកស្នាក់នៅដែរ»។

generated on Wed Sep 10 16:16:32 2025

[26]បន្ទាប់មក បុរសនោះបានលុតជង្គង់ ហើយថ្វាយបង្គំព្រះអម្ចាស់។[27]គាត់និយាយថា៖ «សូមថ្វាយព្រះពរដល់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំ
ជាចៅហ្វាយរបស់ទូលបង្គំ ព្រះអង្គមិនបានបោះបង់ចោលសម្ពន្ធមេត្រីដ៏ស្មោះត្រង់ និងគួរឲ្យទុកចិត្ត ចំពោះលោកម្ចាស់ទូលបង្គំជានិច្ច។ ចំណែក ទូលបង្គំវិញ
ព្រះអម្ចាស់បាននាំទូលបង្គំ រហូតមកដល់ផ្ទះសាច់ញាតិរបស់ចៅហ្វាយរបស់ទូលបង្គំ»។
[28]បន្ទាប់មក នាងក្រមុំបានរត់ ហើយទៅប្រាប់ក្រុមគ្រួសារម្តាយរបស់នាងអំពីការទាំងអស់នេះ។[29]នាងរេបិកាមានបងប្រុសម្នាក់ ហើយគាត់ឈ្មោះថា ឡាបាន់។
លោកឡាបាន់រត់ទៅបុរសនោះ ដែលនៅខាងក្រៅតាមផ្លូវ ក្បែរប្រភពទឹក។[30]នៅពេលគាត់បានឃើញក្រវិលនៅនឹងច្រមុះ ហើយកងដៃនៅលើកដៃប្អូនស្រីរបស់គាត់
ហើយនៅពេលគាត់បានឮពាក្យរបស់នាងរេបេកាប្អូនស្រីរបស់លោកថា៖ «គឺបុរសនេះហើយដែលនិយាយមកកាន់ខ្ញុំ»។ គាត់បានទៅជួបបុរសនោះ ហើយមើល
គាត់បានឈរនៅក្បែរអូដ្ឋនៅជិតអណ្តូង។
[31]បន្ទាប់មក លោកឡាបាន់និយាយថា៖ «សូមអញ្ជើញចូលមក ឱអ្នកដែលប្រកបដោយព្រះពរនៃព្រះអម្ចាស់អើយ ហេតុអ្វីបានជាឈរនៅខាងក្រៅដូច្នេះ? ខ្ញុំបានត្រៀមផ្ទះ
និងកន្លែងសម្រាប់អូដ្ឋរួចហើយ»។[32]ដូច្នេះ បុរសនោះក៏ចូលទៅផ្ទះ ហើយគាត់បានដោះយកឥវ៉ានចេញពីអូដ្ឋ។ ហើយបានឲ្យចំបើង និងស្មៅទៅអូដ្ឋស៊ី
ហើយយកទឹកមកលាងជើងគាត់ និងលាងជើងប្រុសៗដែលមកជាមួយគាត់។
[33]ពួកគេបានរៀបចំអាហារដាក់នៅចំពោះមុខគាត់ដើម្បីឲ្យពួកគាត់ហូប ប៉ុន្តែ គាត់និយាយថា៖ «ខ្ញុំនឹងមិនហូបទេ ទាល់តែខ្ញុំបាននិយាយអ្វីដែលខ្ញុំត្រូវនិយាយសិន»។
[34]ដូច្នេះ លោកឡាបាន់និយាយថា៖ «សូមនិយាយមកចុះ»។ គាត់និយាយថា៖ «ខ្ញុំជាអ្នកបម្រើរបស់លោកអប្រាហាំ។
[35]ព្រះអម្ចាស់បានប្រទានពរដល់ចៅហ្វាយរបស់ខ្ញុំយ៉ាងខ្លាំង ហើយគាត់បានក្លាយជាអ្នកមាន។ គាត់បានប្រគល់ហ្វូងចៀម និងហ្វូងគោ ប្រាក់ និងមាស អ្នកបម្រើប្រុស
និងអ្នកបម្រើស្រី ព្រមទាំងសត្វអូដ្ឋ និងសត្វលាផង។
[36]លោកស្រីសារ៉ា ជាភរិយាចៅហ្វាយរបស់ខ្ញុំ បានបង្កើតកូនប្រុសមួយជូនចៅហ្វាយរបស់ខ្ញុំ នៅពេលនាងមានអាយុចាស់ណាស់ហើយ
ចៅហ្វាយរបស់ខ្ញុំបានប្រគល់អ្វីៗទាំងអស់ដែលគាត់មានឲ្យទៅគាត់។[37]ចៅហ្វាយរបស់ខ្ញុំបានឲ្យខ្ញុំស្បថជាមួយគាត់ ដោយនិយាយថា៖
«អ្នកមិនត្រូវយកភរិយាឲ្យកូនប្រុសខ្ញុំ ពីពួកកូនស្រីរបស់ជនជាតិកាណាន គឺនៅក្នុងទឹកដីដែលខ្ញុំរស់នៅ។[38]ផ្ទុយទៅវិញ អ្នកត្រូវទៅរកក្រុមគ្រួសារឪពុករបស់ខ្ញុំ
ហើយទៅរកសាច់ញាតិរបស់ខ្ញុំ ព្រមទាំងរកភរិយាឲ្យកូនប្រុសរបស់ខ្ញុំពីទីនោះ»។
[39]ខ្ញុំបាននិយាយទៅចៅហ្វាយរបស់ខ្ញុំថា៖ «ប្រហែលជាស្ត្រីនោះមិនមកតាមខ្ញុំទេ»។[40]ប៉ុន្តែ គាត់បានប្រាប់ខ្ញុំថា៖ «ព្រះអម្ចាស់នឹងយាងទៅមុនខ្ញុំ
ព្រះអង្គនឹងចាត់ទេវតារបស់ព្រះអង្គទៅជាមួយខ្ញុំ ហើយព្រះអង្គនឹងធ្វើឲ្យដំណើររបស់ខ្ញុំបានជោគជ័យ
ដើម្បីឲ្យអ្នកអាចរកភរិយាសម្រាប់កូនប្រុសខ្ញុំពីចំណោមសាច់ញាតិរបស់ខ្ញុំ និងពីវង្សត្រកូលក្រុមគ្រួសាររបស់ខ្ញុំ។[41]ប៉ុន្តែ អ្នកនឹងរួចផុតពីសម្បថរបស់ខ្ញុំ ប្រសិនបើ
អ្នកបានទៅដល់សាច់ញាតិរបស់ខ្ញុំហើយ ហើយពួកគេមិនប្រគល់នាងឲ្យមកអ្នក។ នោះអ្នកនឹងរួចផុតពីសម្បថរបស់ខ្ញុំហើយ»។
[42]នៅថ្ងៃនេះ ខ្ញុំបានធ្វើដំណើរមកដល់ប្រភពទឹក ហើយខ្ញុំអធិស្ឋានថា៖ «ឱព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំចៅហ្វាយរបស់ទូលបង្គំអើយ សូមមេត្តា
ប្រសិនបើ ព្រះអង្គប្រោកដជាចង់ឲ្យដំណើររបស់ទូលបង្គំបានជោគជ័យមែន[43]ទូលបង្គំនៅទីនេះហើយ កំពុងឈរនៅក្បែរអណ្តូងទឹក សូមឲ្យក្មេងស្រី ដែលបានមកដងទឹក
គឺជាកូនស្រី ដែលទូលបង្គំនិយាយទៅកាន់នាងថា៖ «សូមឲ្យទឹកពីក្អមរបស់នាងឲ្យខ្ញុំផឹកបន្តិចមក»។[44]ហើយក្មេងស្រីណាដែលនិយាយមកទូលបង្គំថា៖
«សូមអញ្ជើញពិសាចុះ ហើយខ្ញុំនឹងទៅដងទឹកឲ្យអូដ្ឋរបស់លោកផឹកដែរនោះ សូមឲ្យក្មេងស្រីម្នាក់នោះ ជាអ្នកដែលព្រះអម្ចាស់
បានជ្រើសរើសសម្រាប់កូនប្រុសចៅហ្វាយរបស់ទូលបង្គំ»។
[45]ខ្ញុំអធិស្ឋាននៅក្នុងចិត្តរបស់ខ្ញុំមិនទាន់ចប់ផង មើល៍ នាងរេបិកាបានចេញមកជាមួយនឹងក្អមនៅលើស្មារបស់នាង ហើយនាងបានចុះទៅប្រភពទឹក ព្រមទាំងដងទឹកនោះ។
ដូច្នេះ ខ្ញុំបាននិយាយទៅនាងថា៖ «សូមឲ្យទឹកខ្ញុំផឹកបន្តិចមក»។[46]នាងឆ្លើយយ៉ាងលឿនថា ហើយបានដាក់ក្អមពីលើស្មានាង ហើយនិយាយថា៖ «សូមអញ្ជើញពិសាចុះ
ហើយខ្ញុំនឹងឲ្យអូដ្ឋរបស់លោកផឹកដែរ»។ ដូច្នេះ ខ្ញុំក៏ផឹក ហើយនាងបានដងទឹកឲ្យអូដ្ឋខ្ញុំផឹកដែរ។
[47]ខ្ញុំបានសួរនាង ហើយនិយាយថា៖ «តើអ្នកជាកូនរបស់នរណា?» នាងឆ្លើយថា៖ «កូនស្រីរបស់លោកបេធូអែល ជាកូនរបស់លោកណាឃរ និងនាងមីលកា»។ បន្ទាប់មក
ខ្ញុំបានបំពាក់ក្រវិលនៅនឹងច្រមុះរបស់នាង ហើយបំពាក់កងដៃនៅនឹងដៃរបស់នាង។[48]បន្ទាប់មក ខ្ញុំបានក្រាបចុះ ហើយថ្វាយបង្គំព្រះអម្ចាស់
ហើយថ្វាយព្រះពរដល់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំចៅហ្វាយរបស់ខ្ញុំ ដែលបាននាំខ្ញុំឲ្យដើរតាមផ្លូវត្រូវ
ដើម្បីស្វែងរកកូនស្រីសាច់ញាតិចៅហ្វាយរបស់ខ្ញុំឲ្យទៅកូនប្រុសរបស់គាត់។
[49]ឥឡូវនេះ ប្រសិនបើ លោកបានរៀបចំ ដើម្បីប្រព្រឹត្តដល់ក្រុមគ្រួសារចៅហ្វាយរបស់ខ្ញុំនូវភក្តីភាព និង ទឹកចិត្តស្មោះត្រង់ចំពោះចៅហ្វាយខ្ញុំ នោះសូមប្រាប់ខ្ញុំមកចុះ។ ប៉ុន្តែ
ប្រសិនបើ មិនព្រមទេ នោះខ្ញុំអាចនឹងងាកទៅខាងស្តាំ ឬខាងឆ្វេងទៀត»។
[50]បន្ទាប់មក លោកឡាបាន់ និងលោកបេធូអែលបានឆ្លើយ ហើយនិយាយថា៖ «អ្វីដែលមកព្រះអម្ចាស់ យើងមិនអាចនិយាយទៅកាន់អ្នកថាអាក្រក់ ឬល្អបានឡើយ។
[51]មើល៍ នាងរេបិកានៅចំពោះអ្នកហើយ។ ចូរយកនាង ហើយចេញទៅ ដូច្នេះ នាងអាចធ្វើជាភរិយាកូនប្រុសចៅហ្វាយរបស់លោកហើយ ដូចព្រះអម្ចាស់មានបន្ទូល»។
[52]នៅពេលអ្នកបម្រើរបស់លោកអប្រាហាំបានឮពាក្យរបស់ពួកគេហើយ គាត់លុតជង្គង់ហើយក្រាបចុះដល់ដីចំពោះព្រះអម្ចាស់។[53]អ្នកបម្រើនោះបានយកគ្រឿងអលង្ការ ជា
ប្រាក់ ជាមាស ព្រមទាំងសម្លៀកបំពាក់ចេញមក ហើយជូននាងរេបិកា។ ហើយគាត់ក៏ជូនអំណោយដ៏មានតម្លៃផ្សេងៗទៀត ទៅបងប្រុស និងទៅម្តាយរបស់នាងដែរ។
[54]បន្ទាប់មក គាត់និងពួកប្រុសៗដែលនៅជាមួយគាត់បានហូបបាយទឹក។ ពួកគេស្នាក់នៅទីនោះមួយយប់ ហើយនៅពេលពួកគេក្រោកឡើងតាំងពីព្រលឹម គាត់និយាយថា៖
«ខ្ញុំសូមលាត្រឡប់ទៅចៅហ្វាយរបស់ខ្ញុំវិញហើយ»។[55]បងប្រុស និងម្តាយរបស់នាងនិយាយថា៖ «សូមឲ្យនាងនៅជាមួយយើងបន្តិចទៀតសិនចុះ
យ៉ាងហោចណាស់ដប់ថ្ងៃ។ បន្ទាប់មក នាងអាចទៅបានហើយ»។
[56]ប៉ុន្តែ គាត់និយាយទៅពួកគេថា៖ «កុំឃាត់ខ្ញុំឡើយ ដ្បិតព្រះអម្ចាស់បានធ្វើឲ្យដំណើររបស់ខ្ញុំជោគជ័យ។[57]ពួកគេនិយាយថា៖ «យើងនឹងហៅនាង ហើយសួរនាង»។
[58]ពួកគេក៏ហៅនាងរេបិកាមក ហើយសួរនាងថា៖ «តើនាងព្រមទៅជាមួយបុរសនេះទេ?» នាងឆ្លើយថា៖ «ខ្ញុំព្រម»។
[59]ដូច្នេះ ពួកគេក៏ជូនដំណើរនាងរេបិកាប្អូនស្រីរបស់ពួកគេ ជាមួយនឹងអ្នកបម្រើស្រីរបស់នាង ដើម្បីធ្វើដំណើរជាមួយអ្នកបម្រើរបស់លោកអប្រាហាំ
និងពួកដែលមកជាមួយគាត់។[60]ពួកគេឲ្យពរដល់នាងរេបិកា ហើយនិយាយទៅនាងថា៖ «ប្អូនស្រីរបស់បងអើយ សូមឲ្យប្អូនជាម្តាយនៃមនុស្សរាប់ពាន់រាប់ម៉ឺន
ហើយសូមឲ្យពូជពង្សរបស់ប្អូនគ្រប់គ្រងទ្វាររបស់ពួកអ្នកដែលស្អប់ពួកគេ»។
[61]បន្ទាប់មក នាងរេបិកាបានក្រោកឡើង ហើយនាង និងអ្នកបម្រើស្រីរបស់នាងឡើងជិះអូដ្ឋ ហើយទៅតាមអ្នកបម្រើនោះ។ អ្នកបម្រើនោះបានយកនាងរេបិកា
ហើយចេញដំណើរទៅ។[62]លោកអ៊ីសាកកំពុងតែរស់នៅក្នុងក្រុង ណេកិប ហើយទើបតែត្រឡប់មកពីអណ្តូងទឹកឡាហាយរយ។
[63]លោកអ៊ីសាកបានចេញក្រៅ ដើម្បីជញ្ជឹងគិតនៅឯវាលនាពេលល្ងាច។ នៅពេលគាត់ងើយមុខឡើង ហើយឃើញ មើល៍ ហ្វូងអូដ្ឋកំពុងតែមក។[64]នាងរេបិកាបានមើល
ហើយពេលនាងឃើញលោកអ៊ីសាក នាងបានលោតចុះពីអូដ្ឋ។[65]នាងសួរទៅកាន់អ្នកបម្រើថា៖ «តើបុរសដែលកំពុងដើរនៅឯវាលមកជួបយើងនោះជានរណា?»
អ្នកបម្រើឆ្លើយថា៖ «គាត់គឺជាចៅហ្វាយរបស់ខ្ញុំ»។ ដូច្នេះ នាងក៏យកស្បៃរបស់នាងមក ហើយគ្របមុខនាង។
[66]អ្នកបម្រើបានរៀបរាប់ប្រាប់លោកអ៊ីសាកគ្រប់រឿងរ៉ាវទាំងអស់ដែលគាត់បានធ្វើ។[67]បន្ទាប់មក
លោកអ៊ីសាកបាននាំនាងរេបិកាចូលទៅនាងសារ៉ាជាម្តាយរបស់គាត់នៅក្នុងត្រសាល ហើយនាងបានក្លាយជាភរិយារបស់លោក ហើយលោកបានស្រឡាញ់នាង។ ដូច្នេះ
លោកអ៊ីសាកបានទទួលការកម្សាន្តចិត្ត បន្ទាប់ពីម្តាយរបស់គាត់ស្លាប់ទៅ។

generated on Wed Sep 10 16:16:32 2025

Genesis 24:1

ឥឡូវ

ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់ៗ
នៅទីនេះអ្នកនិពន្ធចាប់ផ្តើមប្រាប់ផ្នែកថ្មីនៃរឿង។

ចូរដាក់ដៃរបស់ឯងនៅលើភ្លៅរបស់យើង

លោកអប្រាហាំហៀបនឹងសុំអ្នកបម្រើស្បថឲ្យធ្វើអ្វីមួយ។
ការដាក់ដៃនៅក្រោមភ្លៅរបស់លោកអប្រាហាំនឹងបង្ហាញថាគាត់ពិតជានឹងធ្វើអ្វីដែលគាត់ស្បថ។

យើងសូមឲ្យឯងស្បថ

នេះអាចត្រូវបានបង្ហាញជាពាក្យបញ្ជា។ ការបកប្រែផ្សេងទៀត៖
«ស្បថ» (សូមមើល [[;en:ta:vol2:translate]])

ស្បថដោយជាមួយព្រះអម្ចាស់

ពាក្យ«ស្បថដោយ»មានន័យថាប្រើឈ្មោះអ្វីមួយឬនរណាម្នាក់ជាមូលដ្ឋានឬអំណាចដើម្បីធ្វើ។
«សន្យានឹងខ្ញុំជាមួយព្រះអម្ចាស់ក្នុងនាមជាសាក្សីរបស់អ្នក»

ជាព្រះជាម្ចាស់នៃស្ថានសួគ៌ និងជាព្រះជាម្ចាស់នៃផែនដី

ហើយលោកអេសាវក៏ត្រឡប់ពីការបរបាញ់វិញផងដែរ។[31]គាត់ក៏បានធ្វើម្ហូបយ៉ាងឆ្ងាញ់ ហើយយកមកជូនឪពុករបស់គាត់ដែរ។ គាត់និយាយទៅឪពុករបស់គាត់ថា៖
«លោកឪពុក សូមក្រោកឡើង ហើយពិសាម្ហូបដែលកូនធ្វើ ហើយសូមលោកឪពុកឲ្យពរដល់កូន»។
[32]លោកអ៊ីសាក ឪពុករបស់គាត់និយាយទៅគាត់ថា៖ «តើឯងជានរណា?» គាត់ឆ្លើយថា៖ «ខ្ញុំជាអេសាវ កូនប្រុសច្បងរបស់លោកឪពុក»។[33]លោកអ៊ីសាកញ័រខ្លួនជាខ្លាំង
ហើយនិយាយថា៖ «តើនរណាបានបរបាញ់សត្វ ហើយយកសាច់មកឲ្យឪពុក? ឪពុកបានហូបវាអស់ហើយ មុនពេលកូនឯងមកដល់ ហើយឪពុកបានឲ្យពរដល់គាត់ផង។
ហើយគាត់នឹងបានពរជាប្រាកដ»។
[34]ពេលលោកអេសាវឮពាក្យរបស់ឪពុកគាត់បែបនេះ គាត់បានស្រែកយំ ហើយឈឺផ្សាជាខ្លាំង ព្រមទាំងនិយាយទៅកាន់ឪពុករបស់គាត់ថា៖ «លោកឪពុកអើយ
សូមឲ្យពរខ្ញុំផង»។[35]លោកអ៊ីសាកនិយាយថា៖ «ប្អូនប្រុសរបស់កូនបានមកទីនេះបោកប្រាស់ ហើយបានយកពររបស់កូនអស់ហើយ»។
[36]លោកអេសាវនិយាយថា៖ «តើមិនត្រឹមត្រូវទេឬអី ដែលគេដាក់ឈ្មោះថា យ៉ាកុប? ដ្បិត វាបានបោកប្រាស់ខ្ញុំ ពីរលើកហើយ។ វាបានដណ្តើមយកសិទ្ធិកូនច្បង
ហើយមើល៍ ឥឡូវនេះ វាបានយកពរព្រះខ្ញុំទៀត»។ បន្ទាប់មក គាត់និយាយថា៖ «តើលោកឪពុកមិនបានត្រៀមពរអ្វីផ្សេងទៀតឲ្យកូនទេឬអី?»[37]លោកអ៊ីសាកឆ្លើយ
ហើយនិយាយទៅលោកអេសាវថា៖ «មើល៍ ឪពុកបានធ្វើឲ្យវាក្លាយជាចៅហ្វាយរបស់ឯង ហើយឪពុកបានឲ្យបងប្អូនទាំងអស់របស់វា ក្លាយជាអ្នកបម្រើរបស់វា
ហើយឪពុកបានឲ្យវាមានស្រូវ និងស្រាទំពាំងបាយជូរថ្មី។ កូនអើយ តើឪពុកមានអ្វីច្រើនជាងនេះឲ្យកូន?»
[38]លោកអេសាវនិយាយទៅឪពុករបស់គាត់ថា៖ «លោកឪពុកអើយ តើលោកឪពុក អត់មានសល់ពរណាមួយឲ្យកូនទេឬ? សូមឲ្យពរដល់កូនផង លោកឪពុកអើយ»។
លោកអេសាវយំជាខ្លាំង។
[39]លោកអ៊ីសាក ឪពុករបស់គាត់ឆ្លើយ ហើយនិយាយថា៖ «មើល៍ ទីកន្លែងដែលកូនរស់នៅនឹងគ្មានជីជាតិនៅលើផែនដី នឹងមិនមានសន្សើមធ្លាក់ពីលើមេឃ។
[40]កូននឹងរស់នៅដោយដាវរបស់កូន ហើយកូននឹងបម្រើប្អូនប្រុសរបស់កូន។ ប៉ុន្តែ នៅពេលកូនប្រឆាំងបះបោរ កូននឹងអង្រួននឹមរបស់វាពីករបស់កូន»។
[41]លោកអេសាវស្អប់លោកយ៉ាកុប ដោយសារតែពរដែលឪពុករបស់គាត់បានឲ្យដល់គាត់។ លោកអេសាវនិយាយនៅក្នុងចិត្តរបស់គាត់ថា៖
«ថ្ងៃកាន់ទុក្ខរបស់ឪពុកខ្ញុំជិតមកដល់ហើយ បន្ទាប់ពីនោះ ខ្ញុំនឹងសម្លាប់យ៉ាកុប ប្អូនប្រុសរបស់ខ្ញុំ»។[42]ពាក្យរបស់លោកអេសាវ កូនច្បងរបស់នាងរេបិកា

generated on Wed Sep 10 16:16:32 2025

ត្រូវបានគេយកទៅប្រាប់ដល់នាង។ ដូច្នេះ នាងបានចាត់គេ ហើយទៅហៅលោកយ៉ាកុប កូនប្រុសពៅរបស់នាង ហើយប្រាប់គាត់ថា៖ «មើល៍ អេសាវ បងប្រុសរបស់កូន
មានផែនការចង់សម្លាប់កូន ដើម្បីរំសាយកំហឹង»។
[43]ដូច្នេះហើយ កូនអើយ ស្តាប់ម្តាយ ចូររត់ទៅឡាបាន ជាបងប្រុសរបស់ម្តាយ នៅទឹកដីខារ៉ានទៅ។
[44]ចូររស់នៅជាមួយគាត់មួយរយៈ[45]រហូតទាល់តែបងប្រុសរបស់កូនរសាយកំហឹង ហើយភ្លេចអ្វីដែលកូនបានធ្វើជាមួយវាហើយ។
នោះម្តាយនឹងចាត់គេឲ្យទៅនាំកូនពីទីនោះមកវិញ។ តើត្រូវឲ្យម្តាយបាត់បង់កូនទាំងពីរនៅថ្ងៃតែមួយឬអី?
[46]នាងរេបិកានិយាយទៅកាន់លោកអ៊ីសាកថា៖ «ខ្ញុំធុញនឹងជីវិតនេះណាស់ ដោយសារកូនស្រីរបស់ជនជាតិហេតនេះ។ ប្រសិនបើ យ៉ាកុបយកកូនស្រីរបស់ជនជាតិ
ហេតមកធ្វើជាភរិយានៅក្នុងទឹកដីនេះ នោះជីវិតខ្ញុំនឹងលែងមានន័យអ្វីទៀតហើយ»។

Genesis 27:1
ហើយភ្នែករបស់គាត់ក៏ស្រអាប់
នេះនិយាយអំពីភ្នែកងងឹត ហាក់ដូចជាភ្នែកជាចង្កៀង ហើយពន្លឺជិតអស់ហើយ។
ការបកប្រែផ្សេងទៀត៖ «គាត់ស្ទើរតែងងឹតភ្នែក» ឬ «គាត់ស្ទើរតែពិការភ្នែក»
គាត់ ហើយនិយាយទៅកាន់គាត់ថា
«ហើយអេសាវក៏ឆ្លើយតប»
បាទ លោកឪពុក
«បាទលោកឪពុក» ឬ«ខ្ញុំកំពុងស្តាប់។»សូមមើលរវានៅក្នុង ២២: ១ ។
គាត់ឆ្លើយ
«បន្ទាប់មកលោកអ៊ីសាកក៏និយាយ»
មើលនេះ
ឃ្លា «មើលនេះ» បន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែផ្សេងទៀត៖ «ស្តាប់ដោយយកចិត្តទុកដាក់»
ឪពុកមិនដឹងថា ឪពុកស្លាប់ពេលណាទេ
នេះបញ្ជាក់ថាអ៊ីសាកដឹងថាគាត់នឹងស្លាប់ឆាប់ៗ។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំអាចនឹងស្លាប់នៅថ្ងៃណាមួយឆាប់ៗ»
ស្លាប់
នេះគឺសំដៅទៅលើរូបកាយ។
Genesis 27:3
ព័ត៌មានទូទៅ
លោកអ៊ីសាកបន្តណែនាំដល់កូនប្រុសច្បងរបសគាត់។
ចូរយកប្រដាប់បរបាញ់របស់កូ
«គឺជាសម្ភារៈបរបាញ់»
ព្រួញរបស់កូន
ព្រួញគឺជាករណីសម្រាប់កាន់ព្រួញ។ការបកប្រែផ្សេងទៀត៖
«ព្រួញរបស់អ្នកបាញ់ព្រួញ»
បរបាញ់សត្វមកឲ្យឪពុក
«បាញ់សត្វព្រៃមកអោយពុក»
ចូរធ្វើម្ហូបឲ្យឆ្ងាញ់ឲ្យឪពុក ជាម្ហូបដែលឪពុកចូលចិត្ត
ពាក្យថា«ឆ្ងាញ់»គឺសំដៅទៅលើអ្វីមួយដែលមានរសជាតិឆ្ងាញ់។
ការបកប្រែផ្សេងទៀត៖ «ចំអិនសាច់អោយដែលពុកចូលចិត្ត»
ឲ្យពរដល់កូន
នៅសម័យព្រះគម្ពីរ ឪពុកតែងតែប្រកាសអោយពរជាផ្លូវការដល់កូន ៗ របស់គាត់។
Genesis 27:5
ឥឡូវ
ពាក្យថា «ឥឡូវនេះ» បង្ហាញពីការផ្លាស់ប្តូរការសង្កត់ធ្ងន់ទៅលើរេបិកានិងយ៉ាកុប។.
នាងរេបិកាបានឮ ពេលលោកអ៊ីសាកប្រាប់លោកអេសាវ កូនប្រុសរបស់គាត់
«នាងរេបិកាបានលឺអ្វីដែលអ៊ីសាកបាននិយាយជាមួយកូនប្រុសរបស់គាត់អេសាវ»
លោកអេសាវបានចេញ.....ហើយយកមក
ពាក្យ «ដូច្នេះពេល»
អាចត្រូវបានបន្ថែមដើម្បីបង្ហាញថារេបិកានិយាយទៅកាន់យ៉ាកុបដោយសារអ្វីដែលនាងបានលឺ ហើយនាងកំពុងនិយាយជាមួយគាត់នៅពេលអេសាវចេញបាត់។
ការបកប្រែផ្សេងទៀត៖ «ដូច្នេះនៅពេលអេសាវទៅ ... នាំវាមកវិញ»
ដល់អេសាកូនប្រុសគាត់.....ដល់យ៉ាកុបកូនប្រុសនាង
អេសាវនិងយ៉ាកុបគឺជាកូនប្រុសរបស់អ៊ីសាកនិងរេបិកា។ ពួកគេត្រូវបានគេហៅថា «កូនប្រុសរបស់គាត់»
និង«កូនប្រុសរបស់នាង»ដើម្បីបញ្ជាក់ថាឪពុកម្តាយម្នាក់ចូលចិត្តកូនប្រុសម្នាក់ជាងកូនប្រុសម្នាក់ទៀត។
មើល៏នេះ
ឃ្លា «មើល៏នេះ» បន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែផ្សេងទៀត៖ «ស្តាប់ដោយយកចិត្តទុកដាក់»
គាត់ប្រាប់ថា «ចូរទៅបរបាញ់សត្វនៅវាលយកមក ហើយធ្វើម្ហូបយ៉ាងឆ្ងាញ់ ឲ្យឪពុកហូប
ហើយឪពុកនឹងឲ្យពរកូននៅមុខព្រះអម្ចាស់ មុនពេលឪពុកស្លាប់»
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖
ជ«គាត់បានប្រាប់អេសាវ ឲ្យទៅ បរបាញ់សត្វព្រៃមួយ
ហើយធ្វើម្ហូបដែលគាត់ចូលចិត្ត មុននឹងគាត់ស្លាប់ អ៊ីសាកនឹង ឲ្យ
ពរដល់អេសាវនៅចំពោះមុខព្រះជាម្ចាស់។
ចូរទៅបរបាញ់
«នាំសត្វព្រៃដែលអ្នកបានបរបាញ់និងសម្លាប់មកអោយខ្ញុំ»
ចំអិនម្ហូបឆ្ងាញ់អោយពុក
«ចំអិនឱ្យពុកនូវសាច់ដែលពុកចូលចិត្ត។» សូមមើលនៅក្នុង ២៧: ៣ ។
អោយពរដល់កូននៅចំពោះមុខព្រះជាម្ចាស់
«អោយពរនៅចំពោះមុខព្រះជាម្ចាស់»
មុនពេលពុកស្លាប់
«មុនពុកស្លាប់»
Genesis 27:8
ព័ត៌មានទូទៅ
រេបិកាបន្តនិយាយទៅកាន់កូនប្រុសពៅរបស់គាត់គឺយ៉ាកុប។
ដូច្នេះ
នេះមិនមានន័យថា «នៅពេលនេះទេ»
ប៉ុន្តែត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះចំណុចសំខាន់ដែលនៅខាងក្រោម។
ចូរស្តាប់ពាក្យម្តាយ ដែលបានបង្គាប់ដល់កូន
រេបិកាបាននិយាយថា« សំលេងរបស់ម្តាយ»
សំដៅទៅលើអ្វីដែលនាងកំពុងតែនិយាយ។ ការបកប្រែផ្សេងទៀត៖ «ស្តាប់ម្តាយ
ហើយធ្វើអ្វីដែលម្តាយប្រាប់កូនចុះ»
ម្តាយនឹងធ្វើម្ហូបយ៉ាងឆ្ងាញ់ពីសត្វនោះ ឲ្យឪពុករបស់កូន តាមដែលគាត់ចូលចិត្ត
ពាក្យថា«ឆ្ងាញ់» គឺសំដៅទៅលើអ្វីមួយដែលមានរសជាតិឆ្ងាញ់។
សូមមើលប្រយោគស្រដៀងគ្នាត្រូវបានបកប្រែនៅក្នុង ២៧: ៣ ។
កូននឹងយកម្ហូបនោះទៅជូនឪពុករបស់កូន
«បន្ទាប់មកកូនយកវាទៅអោយឪពុកកូន»
ដើម្បីឲ្យគាត់បានហូប ហើយគាត់នឹងឲ្យពរដល់កូន
«ហើយឪពុកនិងបរិភោគវា គាត់និងអោយពរកូន»
គាត់នឹងឲ្យពរដល់កូន
ពាក្យថា«អោយពរ»គឺសំដៅទៅលើពរជ័យជាផ្លូវការដែលឪពុកម្នាក់ប្រកាសលើកូន
ៗ របស់គាត់។
មុនពេលគាត់ស្លាប់
«មុនគាត់ស្លាប់»
Genesis 27:11
ខ្ញុំអត់មានរោមសោះ
«ខ្ញុំគឺជាមនុស្សដែលមានស្បែករលោង» ឬ «ខ្ញុំអត់មានរោមទេ»
ហើយគាត់នឹងដឹងថា កូនជាអ្នកបោកប្រាសគាត់
«ហើយគាត់នឹងគិតថាខ្ញុំជាអ្នកកុហក» ឬ««គាត់នឹងដឹងថាខ្ញុំកំពុងបញ្ឆោតគាត់»
កូននឹងនាំបណ្តាសាមកដាក់ខ្លួនកូន ជំនួសឲ្យព្រះពរ
ការដាក់បណ្តាសាឬប្រទានពរត្រូវបានគេនិយាយថាដូចជាបណ្តាសានិងពរដែលត្រូវបានដាក់ទៅលើមនុស
ការបកប្រែផ្សេងទៀត៖
«បន្ទាប់មកដោយសារតែរឿងនេះគាត់នឹងដាក់បណ្តាសាខ្ញុំហើយមិនឱ្យពរដល់ខ្ញុំទេ»
Genesis 27:13
កូនអើយ សូមឲ្យបណ្តាសាធ្លាក់លើម្តាយចុះ
«សូមឱ្យបណ្តាសាមកលើខ្ញុំ,ជំនួសអោយកូនប្រុសរបស់ខ្ញុំវិញចុះ។
»ការដាក់បណ្តាសាត្រូវបានគេនិយាយថាដូចជាការដាក់បណ្តាសាដាក់លើមនុស្ស។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត៖
«សូម់ពុកឱ្យឪពុកអ្នកដាក់បណ្តាសាលើខ្ញុំ,ជំនួសកូនប្រុសខ្ញុំចុះ»
ស្តាប់តាមពាក្យម្តាយ
រេបិកាបាននិយាយថា« ស្តាប់ម្តាយ»សំដៅទៅលើអ្វីដែលនាងកំពុងតែនិយាយ។
ការបកប្រែផ្សេងទៀត៖ «ធ្វើតាមអ្វីដែលម្តាយប្រាប់កូន» ឬ «ស្តាប់ម្តាយ»
យកវាមកឲ្យម្តាយ
«ចូរយកពពែស្ទាវមកអោយម្តាយ»
ធ្វើម្ហូបយ៉ាងឆ្ងាញ់,តាមដែលឪពុកចូលចិត្ត
ពាក្យថា«ឆ្ងាញ់»គឺសំដៅទៅលើអ្វីមួយដែលមានរសជាតិឆ្ងាញ់។
សូមមើលស្រដៀងគ្នាត្រូវបានបកប្រែនៅក្នុង ២៧: ៣ ។
Genesis 27:15
នាងពាក់រោមពពែស្ទាវនៅនឹងដៃរបស់គាត់
«ស្បែកពពែដែលមានរោម»
នាងបានដាក់ម្ហូបដ៏ឆ្ងាញ់ ហើយនិងនំប៉័ងដែលនាងបានរៀបចំទៅឲ្យយ៉ាកុបកូនប្រុសរបស់នាង
«នាងបានអោយអាហារទៅកូនប្រុសរបស់គាត់គឺយ៉ាកុប
និងម្ហូបយ៉ាងឆ្ងាញ់និងនំប៉័ងដែលនាងបានរៀបចំ»
Genesis 27:18
គាត់បាននិយាយថា
«ហើយឪពុករបស់គាត់បានឆ្លើយ» ឬ «អ៊ីសាកឆ្លើយតប»(UDB)
ឪពុកនៅទីនេះ
«បាទ ខ្ញុំកំពុងស្តាប់» ឬ«បាទ តើមានអ្វី?»សូមមើលនៅក្នុង ២២: ១ ។
កូនបានធ្វើតាម លោកឪពុកប្រាប់ដល់កូនហើយ
«កូនបានធ្វើអ្វីដែលលោកឪពុកបានប្រាប់ខ្ញុំអោយធ្វើហើយ»
សាច់ដែលកូនបានបាញ់
ពាក្យថា« ប្រដាប់ប្រដា»
សំដៅទៅលើសត្វព្រៃដែលមនុស្សម្នាក់បរបាញ់និងសម្លាប់។
សូមមើលពីរបៀបដែល« ប្រសាប់ប្រដា»បានបកប្រែនៅក្នុង ២៧: ៣ ។
Genesis 27:20
គាត់ឆ្លើយថា
«លោកយ៉ាកុបបានឆ្លើយតប»
បានយកវាមកឲ្យកូន
នេះគឺជាអត្ថន័យពិសេសមួយដែលព្រះបណ្តាលឱ្យវាកើតឡើង។
ការបកប្រែផ្សេងទៀត៖«ជួយខ្ញុំឱ្យទទួលបានជោគជ័យខណៈពេលបរបាញ់»(សូមមើលនិមិត្តរូប idiom)
បានដឹងថា កូនឯងពិតជាអេសាវកូនឪពុក ឬយ៉ាងណា
«ប្រសិនបើកូនឯងពិតជាអេសាវកូនពុកកមែន»
Genesis 27:22
លោកយ៉ាកុបបានចូលទៅជិតលោកអ៊ីសាកជាឪពុក
«យ៉ាកុបបានចូលទៅជិតអ៊ីសាកឪពុករបស់គាត់»
សម្លេងគឺជាសម្លេងរបស់យ៉ាកុប
អ៊ីសាកប្រៀបបាននឹងសំឡេងរបស់លោកយ៉ាកុបជាមួយលោកយ៉ាកុបផ្ទាល់។
ការបកប្រែផ្សេងទៀត៖«អ្នកស្តាប់ទៅដូចជាយ៉ាកុប»
ប៉ុន្តែ ដៃជាដៃរបស់អេសាវ
អ៊ីសាកកំពុងតែប្រៀបធៀបដៃរបស់អេសាវជាមួយអេសាវផ្ទាល់។
ការបកប្រែផ្សេងទៀត៖ «ប៉ុន្តែដៃរបស់អ្នកមានអារម្មណ៍ដូចជាដៃអេសាវ»
Genesis 27:24
គាត់និយាយថា
អ៊ីសាកសួរសំណួរនេះមុនពេលជូនពរកូនប្រុសរបស់គាត់។ ការបកប្រែផ្សេងទៀត៖
«ប៉ុន្តែអ៊ីសាកដំបូងបានសួរ» (UDB)(សូមមើល:figs-events)
ឪពុកនឹងហូបម្ហូបនោះ
ពាក្យថា« ម្ហូប» សំដៅទៅលើសត្វព្រៃមួយប្រភេទដែលមនុស្សបរបាញ់និងសម្លាប់។
សូមមើលពីរបៀបដែល «ម្ហូប» ត្រូវបានបកប្រែនៅក្នុង ២៧: ៥ ។
ហើយគាត់ក៏ពិសាដែរ
«ហើយអ៊ីសាកក៏ពិសាវា»
Genesis 27:26
គាត់បានធំក្លិនសម្លៀកបំពាក់របស់គាត់ ហើយបានឲ្យពរដល់គាត់
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាសម្លៀកបំពាក់មានក្លិនដូចសម្លៀកបំពាក់របស់អេសាវ
ការបកប្រែផ្សេងទៀត៖
«គាត់ធុំក្លិនសម្លៀកបំពាក់របស់គាត់ហើយពួកគេមានក្លិនដូចសម្លៀកបំពាក់អេសាវ
ដូច្នេះអ៊ីសាកអោយពរគាត់»
ហើយគាត់បានធំក្លិន
«ហើយអ៊ីសាកបានធំក្លិន»
ក្លិន
«ក្លិនក្រអូប»
ហើយគាត់បានអោយពរ
«ហើយបន្ទាប់មកគាត់បានប្រទានពរដល់គាត់។
»នេះសំដៅទៅលើការអោយពរជាផ្លូវការដែលឪពុកម្នាក់ប្រកាសលើកូន ៗ
របស់គាត់។
មើល៍ ក្លិនកូនប្រុសខ្ញុំ
ពាក្យថា« មើល» ត្រូវបានប្រើជាតួលេខនៃការនិយាយដែលមានន័យថា«
វាជាការពិត។ » «ពិតជាក្លិនកូនប្រុសរបស់ខ្ញុំ»
ដែលព្រះអម្ចាស់បានប្រទានពរ
ត្រង់នេះពាក្យថា« ប្រទានពរ» មានន័យថាព្រះយេហូវ៉ាបានបណ្តាល ឲ្យ
មានរឿងល្អកើតឡើងនៅលើវាជាម្ចាស់លហើយបានបង្កើតផល។
ការបកប្រែផ្សេងទៀត៖ «ដែលព្រះអម្ចាស់បានបង្កើតផលយ៉ាងច្រើន»
Genesis 27:28
ព័ត៌មានទូទៅ
នេះគឺជាពររបស់អ៊ីសាក។
គាត់គិតថាគាត់កំពុងតែនិយាយទៅកាន់អេសាវប៉ុន្តែគាត់កំពុងតែនិយាយទៅកាន់យ៉ាកុប
ប្រទានអ្នក
នៅទីនេះ «អ្នក» គឺមានលក្ខណៈឯកឯងហើយសំដៅទៅលើយ៉ាកុប។
ប៉ុន្តែព្រះពរនេះក៏នឹងត្រូវអនុវត្តចំពោះកូនចៅរបស់យ៉ាកុបដែរ។
ទឹកសន្សើមពីលើមេឃ
«ទឹកសន្សើម» គឺជាដំណក់ទឹកដែលបង្កើតនៅលើរុក្ខជាតិក្នុងពេលយប់។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។
ការបកប្រែផ្សេងទៀត៖«អ័ព្ទពេលយប់ពីលើមេឃដើម្បីស្រោចទឹកដំណាំរបស់អ្នក»
មានជីជាតិដល់ផែនដី
មានដីមានជីជាតិត្រូវបានគេនិយាយថាផែនដីមានខ្លាញ់ឬសំបូរបែប។
ការបកប្រែផ្សេងទៀត៖«ដីល្អសម្រាប់ផលិតដំណាំ»
មានស្រូវ និងមានស្រាទំពាំងបាយជូរថ្មីយ៉ាងបរិបូរ
ប្រសិនបើ «គ្រាប់ធញ្ញជាតិ» និង«ស្រា»
មិនមានទេនេះអាចត្រូវបានបញ្ជាក់ជាទូទៅ។ ការបកប្រែផ្សេងទៀត៖
«មានអាហារនិងភេសជ្ជៈច្រើន»
Genesis 27:29
កូន.....របស់កូន
នៅទីនេះសព្វនាមទាំងនេះមានលក្ខណៈឯកវចនៈហើយសំដៅទៅលើយ៉ាកុប។
ប៉ុន្តែពរនេះក៏អនុវត្តចំពោះកូនចៅរបស់យ៉ាកុបដែរ។
ប្រជាជាតិជាច្រើនលុតជង្គង់
នៅទីនេះ «ប្រជាជាតិ» សំដៅទៅលើប្រជាជន។ ការបកប្រែផ្សេងទៀត៖
«ប្រជាជនមកពីគ្រប់ជាតិសាសន៍»
លុតជង្គង់
នេះមានន័យថាត្រូវពត់ខ្លួនដើម្បីបង្ហាញការគោរពនិងកិត្តិយសដោយរាបសារដល់នរណាម្នាក់។
(សូមមើល:translate-symaction)
ចូរធ្វើជាចៅហ្វាយលើបងប្អូនរបស់កូន
«និងធ្វើជាចៅហ្វាយលើបងប្អូនរបស់កូន»
បងប្អូនរបស់កូន.....ម្តាយរបស់កូន
លើោកអ៊ីសាកកំពុងតែនិយាយពីពរនេះដល់យ៉ាកុបដោយផ្ទាល់។
ប៉ុន្តែវាក៏អនុវត្តចំពោះកូនចៅរបស់លោកយ៉ាកុបដែលនឹងគ្រប់គ្រងលើកូនចៅអេសាវនិងកូនចៅនៃបងប្អូន
ហើយសូមឲ្យម្តាយរបស់កូនបានលុតជង្គង់ចំពោះកូនដែរ
«ហើយកូន ៗ របស់ម្តាយអ្នកនឹងក្រាបលុតជង្គង់ចំពោះអ្នក»
សូមឲ្យមនុស្សគ្រប់គ្នា ដែលដាក់បណ្តាសាកូន ត្រូវបណ្តាសា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«សូមអោយព្រះជាម្ចាស់ដាក់បណ្តាសាអ្នកដែលជេរប្រមាថកូន»
សូមឲ្យមនុស្សគ្រប់គ្នាដែលឲ្យពរដល់កូន បានពរដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«សូមព្រះប្រទានពរដល់មនុស្សគ្រប់គ្នាដែលប្រទានពរកូន»
Genesis 27:30
មានការភ័យខ្លាច ហើយបានចេញពីវត្តមានលោកអ៊ីសាកជាឪពុករបស់ខ្លួន

generated on Wed Sep 10 16:16:32 2025

«ទើបតែចេញពីត្រសាលរបស់អ៊ីសាកជាឪពុករបស់គាត់»
ធ្វើម្ហូបយ៉ាងឆ្ងាញ់
«សាច់ដែលពុកចូលចិត្ត។» សូមមើលបានបកប្រែនៅក្នុង ២៧: ៣
ម្ហូបពីកូនលោកឪពុក
នៅទីនេះ
«កូនប្រុសរបស់លោកពុក»គឺជាវិធីគួរសមដែលអេសាវសំដៅទៅលើអាហារផ្ទាល់ខ្លួនដែលគាត់ចង់ឱ្យឪពុករបស់គាត់រៀបចំ។
ម្ហូបកូនពុក
ពាក្យថា«ម្ហូប»គឺសំដៅទៅលើសត្វព្រៃដែលមនុស្សបរបាញ់ដើម្បីស៊ី។
សូមមើលពីរបៀបដែល «ម្ហូប» ត្រូវបានបកប្រែនៅក្នុង ២៧: ៥
ឲ្យពរដល់កូន
នេះសំដៅទៅលើព្រះពរជាផ្លូវការដែលឪពុកម្នាក់ប្រកាសលើកូន ៗ របស់គាត់។
Genesis 27:32
និយាយទៅគាត់ថា
«និយាយទៅអេសាវ»
លោកអ៊ីសាកញ័រខ្លួន
«លោកអ៊ីសាកចាប់ផ្តើមញ័រ»
បានបរបាញ់សត្វ
បរបាញ់សំដៅទៅលើសត្វព្រៃមួយប្រភេទដែលមនុស្សប្រមាញ់និងសម្លាប់។
សូមមើលពីរបៀបដែល "បរបាញ់" ត្រូវបានបកប្រែនៅក្នុង ២៧: ៥ ។
Genesis 27:34
គាត់បានស្រែកយំ ហើយឈឺផ្សាជាខ្លាំង
អេសាវឈឺចិត្តនឹងរសជាតិនៃអ្វីដែលឈឺផ្សា។ ការបកប្រែផ្សេងទៀត៖
«គាត់ស្រែកយំខ្លាំងៗ»(សូមមើល:figs-metaphor)
ហើយបានយកពររបស់កូនអស់ហើយ
នេះគឺជាតួលេខនៃការនិយាយមានន័យថាយ៉ាកុបបានយកអ្វីដែលជារបស់អេសាវ។
ការបកប្រែផ្សេងទៀត៖ «ពុកបានអោយពរគាត់ជំនួសកូនហើយ»
Genesis 27:36
តើមិនត្រឹមត្រូវទេឬអី ដែលគេដាក់ឈ្មោះថា យ៉ាកុប?
អេសាវប្រើសំណួរដើម្បីបញ្ជាក់កំហឹងរបស់គាត់ចំពោះយ៉ាកុប។
ការបកប្រែផ្សេងទៀត៖ «យ៉ាកុបពិតជាឈ្មោះត្រឹមត្រូវសម្រាប់បងប្រុសរបស់ខ្ញុំ!»
យ៉ាកុប
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា៖ «ឈ្មោះយ៉ាកុបមានន័យថា
គាត់ចាប់កែងជើង› នៅក្នុងភាសាដើមឈ្មោះ«យ៉ាកុប» ក៏ស្តាប់ទៅដូចជាពាក្យថា
«គាត់បោកបញ្ឆោត»
គាត់បានទទួល.....ព្រះពរ
នេះនិយាយអំពីសិទ្ធិកូនច្បងដូចជាវាជាវត្ថុដែលមនុស្សម្នាក់អាចយកទៅបាន។
ការបកប្រែផ្សេងទៀត៖ «គាត់បានបោកបញ្ឆោតខ្ញុំ
ឱ្យផ្តល់ឱ្យគាត់នូវមរតកទ្វេដែលខ្ញុំគួរតែទទួលបានជាកូនប្រុសច្បង!»
ឥឡូវនេះ វាបានយកពរព្រះខ្ញុំទៀត
នេះនិយាយអំពីព្រះពរមួយដូចជាវត្ថុដែលមនុស្សម្នាក់អាចដកហូតបាន។
ការបកប្រែផ្សេងទៀត៖ «ឥឡូវនេះគាត់បានបោកបញ្ឆោតលោកពុក
ឱ្យផ្តល់ពរដល់គាត់ជំនួសខ្ញុំ»
តើលោកឪពុកមិនបានត្រៀមពរអ្វីផ្សេងទៀតឲ្យកូនទេឬអី
អេសាវដឹងថាឪពុករបស់គាត់មិនអាចអោយពរគាត់ដូចគ្នានឹងអ្វីដែលគាត់បានអោយពរ
អេសាវកំពុងតែសួរថាតើមានអ្វីដែលត្រូវនិយាយទៅកាន់គាត់ថា
អ៊ីសាកមិនបាននិយាយទេពេលដែលកំពុងអោយពរដល់យ៉ាកុប។
តើឪពុកមានអ្វីច្រើនជាងនេះឲ្យកូន?
លោកអ៊ីសាកប្រើសំណួរដើម្បីបញ្ជាក់ថាគ្មានអ្វីផ្សេងទៀតដែលគាត់អាចធ្វើបានទេ។
ការបកប្រែផ្សេងទៀត៖ «មិនមានអ្វីផ្សេងទៀតដែលខ្ញុំអាចធ្វើបានសម្រាប់អ្នកទេ!»
Genesis 27:38
តើលោកឪពុក អត់មានសល់ពរណាមួយឲ្យកូនទេឬ,លោកឪពុកអើយ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ «ឪពុកខ្ញុំ
តើអ្នកមានពរមួយទៀតសម្រាប់ខ្ញុំទេ»
Genesis 27:39
និយាយទៅគាត់ថា
«និយាយទៅកាន់អេសាវ»
មើល៏
នេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលអ៊ីសាកនិយាយបន្ទាប់។
ការបកប្រែផ្សេងទៀត៖ «ស្តាប់» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក»
គ្មានជីជាតិនៅលើផែនដី
នេះគឺជាតួលេខនៃការនិយាយសំដៅទៅលើេជីជាតិរបស់ផែនដី។
ការបកប្រែផ្សេងទៀត៖ «ឆ្ងាយពីដីមានជីជាតិ»
របស់កូន.....កូន
ដោតុអាចារៀបចំ
សព្វនាមទាំងនេះគឺមានលក្ខណៈឯកវចនហើយសំដៅទៅលើអេសាវ
ប៉ុន្តែអ្វីដែលអ៊ីសាកនិយាយក៏អនុវត្តចំពោះកូនចៅអេសាវដែរ។.
សន្សើមធ្លាក់ពីលើមេឃ
«ទឹកសន្សើម»គឺជាដំណក់ទឹកដែលបង្កើតនៅលើរុក្ខជាតិក្នុងពេលយប់។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ការបកប្រែផ្សេងទៀត៖
«អ័ព្ទពេលយប់ពីលើមេឃដើម្បីស្រោចទឹកដំណាំរបស់អ្នក»(សូមfigs-explicit)
រស់នៅដោយដាវរបស់កូន
ត្រង់នេះ« ដាវ» តំណាងឱ្យអំពើហឹង្សា។ ការបកប្រែផ្សេងទៀត៖
«អ្នកនឹងប្លន់និងសម្លាប់មនុស្សដើម្បីទទួលបានអ្វីដែលអ្នកត្រូវការដើម្បីរស់នៅ» (UDB)
(សូមមើល:figs-metonymy)
កូននឹងអង្រួននឹមរបស់វាពីករបស់កូន
នេះនិយាយអំពីនរណាម្នាក់ដែលមានចៅហ្វាយដូចជាការគ្រប់គ្រងរបស់ចៅហ្វាយលើបុគ្គលនោះគឺជានឹម
ការបកប្រែផ្សេងទៀត៖
«អ្នកនឹងដោះលែងខ្លួនអ្នកពីការគ្រប់គ្រងរបស់គាត់»(UDB)
Genesis 27:41
លោកអេសាវនិយាយនៅក្នុងចិត្តរបស់គាត់ថា
នៅទីនេះ« ចិត្ត» តំណាងឱ្យអេសាវខ្លួនឯង។ ការបកប្រែផ្សេងទៀត៖
«អេសាវនិយាយដោយខ្លួនឯង»
ថ្ងៃកាន់ទុក្ខរបស់ឪពុកខ្ញុំជិតមកដល់ហើយ
នេះសំដៅទៅលើចំនួនថ្ងៃដែលមនុស្សម្នាក់សោកសៅនៅពេលសមាជិកគ្រួសារស្លាប់។
ពាក្យរបស់លោកអេសាវ កូនច្បងរបស់នាងរេបិកា ត្រូវបានគេយកទៅប្រាប់ដល់នាង
នៅទីនេះ «ពាក្យ» តំណាងឱ្យអ្វីដែលអេសាវបាននិយាយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«មានគេប្រាប់រេបិកាអំពីផែនការរបស់អេសាវ»
មើល៏
«ស្តាប់» ឬ «សូមយកចិត្តទុកដាក់»
ដើម្បីរំសាយកំហឹង
«ធ្វើអោយខ្លួនគាត់មានអារម្មណ៍ធូរស្បើយ»
Genesis 27:43
ដូច្នេះ
នេះមិនមានន័យថា «នៅពេលនេះទេ»
ប៉ុន្តែត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះចំណុចសំខាន់ដែលនៅខាងក្រោម។
រត់ទៅឡាបាន់
«ចាកចេញពីទីនេះអោយរហ័ស ហើយទៅឯឡាបាន់»
មួយរយៈពេល
«សម្រាប់មួយរយៈពេល»
រហូតទាល់តែកំហឹងបងប្រុសបានធូរស្បើយ
រហូតទាល់តែបងប្រុសរបស់កូនរសាយកំហឹងពីកូន
លែងមានការខឹងត្រូវបានគេនិយាយដូចជាកំហឹងបែទៅទិសដៅផ្សេងឆ្ងាយពីមនុស្ស។
ការបកប្រែផ្សេងទៀត៖ «រហូតដល់គាត់លែងខឹងនឹងកូន»
តើត្រូវឲ្យម្តាយបាត់បង់កូនទាំងពីរនៅថ្ងៃតែមួយឬអី
រេបិកាប្រើសំណួរដើម្បីបញ្ជាក់ពីកង្វល់របស់នាង។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំមិនចង់បាត់បង់កូនទាំងពីរក្នុងមួយថ្ងៃទេ!»
បាត់បង់កូនទាំងពីរនៅថ្ងៃតែមួយ
នេះបញ្ជាក់ថាប្រសិនបើអេសាវសម្លាប់យ៉ាកុប,នោះពួកគេនឹងសម្លាប់អេសាវជាឃាតករ។
(សូមមើលfigs-explicit)
ខ្ញុំបាត់បង់
នេះជាវិធីគួរសមក្នុងការសំដៅទៅលើកូនប្រុសរបស់គាត់ដែលបានស្លាប់។
Genesis 27:46
ខ្ញុំធុញនឹងជីវិតនេះណាស់
រេបិកាកំពុងនិយាយបំផ្លើសដើម្បីបញ្ជាក់ពីការដែលនាងមិនសប្បាយចិត្តចំពោះស្ត្រីជនជាតិហេតដែលអេ
ការបកប្រែផ្សេងទៀត៖ «ខ្ញុំតូចចិត្តណាស់»

generated on Wed Sep 10 16:16:32 2025

កូនស្រីរបស់ជនជាតិហេត
«អស់ទាំងកូនស្រីសាសន៏ហេត» ឬ «កូនចៅនៃជនជាតិហេត»
យកកូនស្រីរបស់ជនជាតិហេតមកធ្វើជាភរិយានៅក្នុងទឹកដីនេះ
ឃ្លាថា «កូនស្រីនៃទឹកដី» មានន័យថាស្ត្រីក្នុងស្រុក។ ការបកប្រែផ្សេងទៀត៖
«ដូចស្ត្រីទាំងនេះដែលរស់នៅលើទឹកដីនេះ»
នោះជីវិតខ្ញុំនឹងលែងមានន័យអ្វីទៀតហើយ
រេបិកាប្រើសំនួរមួយដើម្បីបញ្ជាក់ថានាងនឹងពិបាកចិត្តយ៉ាងណាបើយ៉ាកុបរៀបការជាមួយស្ត្រីជនជាតិហេត
ការបកប្រែផ្សេងទៀត៖ «ជីវិតរបស់ខ្ញុំនឹងអាក្រក់ណាស់!»

---

28 [1]លោកអ៊ីសាកបានហៅលោកយ៉ាកុប ឲ្យពរដល់គាត់ ហើយបង្គាប់គាត់ថា៖ «កូនមិនត្រូវយកភរិយាពីស្ត្រីជនជាតិកាណានឡើយ។[2]ចូរក្រោកឡើង
ទៅប៉ាដាន់អើរ៉ាមគឺទៅផ្ទះរបស់លោកបេធូអែល ជាឪពុករបស់ម្តាយរបស់កូន ហើយយកភរិយាពីទីនោះ ពីកូនស្រីម្នាក់ក្នុងចំណោមកូនស្រីរបស់លោកឡាន
បងប្រុសម្តាយរបស់កូន។
[3]សូមព្រះជាម្ចាស់ដ៏មានគ្រប់ព្រះចេស្តាប្រទានពរដល់កូន ធ្វើឲ្យកូនបង្កើតផលផ្លែជាបរិបូរ ហើយចម្រើនច្រើនឡើង ដើម្បីឲ្យកូនមានគ្នាជាច្រើន។
[4]សូមព្រះអង្គប្រទានពររបស់លោកអប្រាហាំដល់កូន និងដល់ពូជពង្សបន្ទាប់ពីកូន នោះកូននឹងទទួលទឹកដីជាមរតក នៅកន្លែងដែលកូនរស់នៅ
ដែលព្រះជាម្ចាស់បានប្រទានដល់លោកអប្រាហាំ»។
[5]ដូច្នេះ លោកអ៊ីសាកបានឲ្យលោកយ៉ាកុបចេញទៅ។ លោកយ៉ាកុបបានទៅទឹកដីប៉ាដាន់អើរ៉ាម ទៅរកលោកឡាបាន់ជាកូនរបស់លោកបេធូអែល ជនជាតិអារ៉ាម ដែលត្រូវ
ជាបងប្រុសរបស់នាងរេបិកា ជាម្តាយរបស់លោកយ៉ាកុប និងលោកអេសាវ។
[6]លោកអេសាវបានឃើញលោកអ៊ីសាកឲ្យពរដល់លោកយ៉ាកុប ហើយចាត់ឲ្យគាត់ទៅទឹកដីប៉ាដាន់អើរ៉ាម ដើម្បីយកភរិយានៅទីនោះ។ គាត់ក៏បានឃើញថា
លោកអ៊ីសាកឲ្យពរដល់គាត់ ហើយបានបង្គាប់ដល់គាត់ ដោយនិយាយថា៖ «កូនមិនត្រូវយកភរិយាពីពួកកូនស្រីរបស់ជនជាតិកាណានឡើយ»។
[7]លោកអេសាវក៏បានឃើញថា លោកយ៉ាកុបបានស្តាប់បង្គាប់ឪពុក និងម្តាយរបស់គាត់ ហើយបានចេញទៅទឹកដីប៉ាដាន់អើរ៉ាម។
[8]លោកអេសាវបានឃើញថា លោកអ៊ីសាកមិនពេញចិត្តនឹងស្ត្រីជនជាតិកាណានឡើយ។[9]ដូច្នេះ គាត់បានទៅរកលោកអ៊ីស្មាអែល ហើយយកភរិយា
ក្រៅពីភរិយាដែលគាត់មាន គឺនាងម៉ាហាឡាត ជាបងរបស់នាងនេបាយ៉ូត ជាកូនស្រីរបស់លោកអ៊ីស្មាអែលដែលកូនរបស់លោកអប្រាហាំ មកធ្វើជាភរិយារបស់គាត់។
[10]លោកយ៉ាកុបបានចាកចេញពីបៀរសេបា ហើយឆ្ពោះដំណើរទៅទឹកដីខារ៉ាន។ គាត់បានទៅដល់កន្លែងមួយ ហើយបានសម្រាកនៅទីនោះពេញមួយយប់
ដោយសារថ្ងៃបានលិចបាត់ហើយ។[11]គាត់បានយកថ្មមួយនៅកន្លែងនោះ មកកើយនៅក្រោមក្បាលរបស់គាត់ ហើយបានដេកលក់នៅកន្លែងនោះទៅ។
[12]គាត់បានយល់សុបិន ហើយឃើញមានជណ្តើរមួយបញ្ឈរលើផែនដី។ ចុងវាខ្ពស់រហូតដល់មេឃ ហើយពួកទេវតារបស់ព្រះជាម្ចាស់បានហោះចុះ ហោះឡើងនៅពីលើវា។
[13]មើល៍ ព្រះអម្ចាស់បានឈរនៅពីលើវា ហើយមានបន្ទូលថា៖ «យើងគឺជាព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំឪពុករបស់អ្នក
ហើយជាព្រះជាម្ចាស់របស់លោកអ៊ីសាកដែរ។ យើងនឹងប្រគល់ទឹកដីដែលអ្នកកំពុងតែគេងនេះឲ្យទៅអ្នក និងពូជពង្សរបស់អ្នក។
[14]ពូជពង្សរបស់អ្នកនឹងដូចជាធូលីដីនៅលើផែនដី ហើយទឹកដីរបស់អ្នកនឹងលាតសន្ធឹងពីលិច ទៅកើត ហើយពីជើងទៅត្បូង។ តាមរយៈអ្នក និងតាមរយៈពូជពង្សរបស់អ្នក
គ្រប់ទាំងគ្រួសារទាំងអស់នៅលើផែនដីនឹងបានពរ។[15]មើល៍ យើងនៅជាមួយអ្នក ហើយយើងនឹងការពារអ្នក នូវគ្រប់កន្លែងដែលអ្នកទៅ។
យើងនឹងនាំអ្នកមកទឹកដីនេះម្តងទៀត ដើម្បីយើងមិនបោះបង់អ្នកចោលឡើយ។ យើងនឹងធ្វើការទាំងអស់ ដែលយើងបានសន្យាដល់អ្នក»។
[16]លោកយ៉ាកុបបានក្រោកពីគេងឡើង ហើយគាត់និយាយថា៖ «ប្រាកដណាស់ ព្រះអម្ចាស់គង់នៅកន្លែងនេះ ហើយខ្ញុំមិនបានដឹងសោះ»។[17]គាត់មានការភ័យខ្លាច
ហើយនិយាយថា៖ «ទីកន្លែងនេះគួរឲ្យភ័យខ្លាចណាស់! ទីនេះគ្មានអ្វីផ្សេងទៀតទេ គឺក្រៅពីដំណាក់របស់ព្រះជាម្ចាស់។ នេះគឺជាទ្វាររបស់ស្ថានសួគ៌ពិតប្រាកដមែន»។
[18]លោកយ៉ាកុបបានក្រោកឡើងនៅពេលព្រឹក ហើយគាត់បានយកថ្មដែលគាត់បានដាក់កើយនៅក្រោមក្បាលគាត់នោះ។[19]ហើយបានបញ្ឈរដូចជាសសរ
ហើយបានចាក់ប្រេងនៅពីលើថ្មនោះ។ គាត់បានហៅកន្លែងនោះ បេតអែល ប៉ុន្តែពីដើមឈ្មោះរបស់ទីក្រុងនេះគឺ លូស។
[20]លោកយ៉ាកុបបានស្បថសម្បថដោយនិយាយថា៖ «ប្រសិនបើ ព្រះជាម្ចាស់គង់ជាមួយទូលបង្គំ ហើយការពារទូលបង្គំនៅតាមផ្លូវដែលខ្ញុំកំពុងដើរនេះ
ហើយប្រទានអាហារនិងសម្លៀកបំពាក់ឲ្យខ្ញុំពាក់ បើខ្ញុំត្រឡប់ទៅផ្ទះរបស់ឪពុកខ្ញុំវិញដោយសុខសាន្ត[21]ដូច្នេះ ព្រះអម្ចាស់នឹងត្រូវជាព្រះរបស់ទូលបង្គំ។
[22]បន្ទាប់មកថ្មដែលគាត់បានបញ្ឈរដូចជាសសរនោះបានត្រឡប់ទៅជាថ្មសក្ការៈ។ ទូលបង្គំប្រាកដជាថ្វាយមួយភាគដប់
ពីអ្វីៗដែលព្រះអង្គប្រទានដល់ទូលបង្គំទៅព្រះអង្គវិញ។

Genesis 28:1
កូនមិនត្រូវយក
«កុំយក»
ចូរក្រោកឡើង ទៅ
«ចូរចេញភ្លាមទៅ»
ប៉ាដាន់ អើរ៉ាម
នេះគឺជាឈ្មោះមួយទៀតនៅតំបន់មេសូប៉ូតាមៀ
ដែលមានទីតាំងដូចគ្នានឹងប្រទេសអ៊ីរ៉ាក់ទំនើបដែរ។
សូមមើលការបកប្រែនេះនៅក្នុង ២៥:១៩
ផ្ទះរបស់
នេះគឺសំដៅទៅដល់បុគ្គលដែលមានសាច់ញាតិ ពូជអំបូរ។ការបកប្រែផ្សេងទៀត៖
«គ្រួសារ»
បេធូអែល
លោកបេធូអែលដែលជាឪពុករបស់រេបិកា។
ដែលមានឈ្មោះនៅក្នុង២២:២០(សូមមើលtranslate-names)
ជាឪពុករបស់ម្តាយរបស់កូន
«ដែលជាជីតារបស់កូន»
ពីកូនស្រីម្នាក់
«យកពីកូនស្រី»
បងប្រុសម្តាយរបស់កូន
«ត្រូវជាអ៊ំរបស់កូន»
Genesis 28:3
ព័ត៌មានទូទៅ
លោកអ៊ីសាកបន្តការសន្ទនាទៅលោកយ៉ាកុប
ធ្វើឲ្យកូនបង្កើតផលផ្លែជាបរិបូរ ហើយចម្រើនច្រើនឡើង
ពាក្យ«ចម្រើនឡើង»ពន្យល់អំពីរបៀបដែលព្រះនឹង ធ្វើឲ្យ យ៉ាកុប«បង្កើតផល»។
ការបកប្រែផ្សេងទៀត៖ «ផ្តល់ឱ្យអ្នកនូវកូនចៅនិងកូនចៅជាច្រើន»
សូមព្រះអង្គប្រទានពររបស់លោកអប្រាហាំ,ដល់កូន,និងដល់ពូជពង្សបន្ទាប់ពីកូន
នេះនិយាយអំពីការផ្តល់ពរដល់នរណាម្នាក់ដូចជាពរគឺជាវត្ថុមួយដែលមនុស្សម្នាក់អាចផ្តល់។
នាមអរូបី «ព្រះពរ» អាចត្រូវបានបញ្ជាក់ថាជា «ប្រទានពរ» ។
ការបកប្រែផ្សេងទៀត៖ «សូមព្រះប្រទានពរដល់អ្នក
និងកូនចៅរបស់អ្នកដូចដែលទ្រង់ បានអោយពរដល់លោកអប្រាហាំ» ឬ«
សូមអោយព្រះជាម្ចាស់ប្រទានដល់អ្នកនិងកូនចៅរបស់អ្នកនូវអ្វីដែលទ្រង់បានសន្យាជាមួយលោកអប្រាហ
នោះកូននឹងទទួលទឹកដីជាមរតក
ព្រះជាម្ចាស់បានឲ្យដីកាណានដល់យ៉ាកុបនិងកូនចៅរបស់គាត់ដូចជាកូននិងទទួលមរតកលុយឬទ្រព្យស
នៅកន្លែងដែលកូនរស់នៅ
«គឺជាទឹកដីដែលកូននិងរស់នៅ»
ដែលព្រះជាម្ចាស់បានប្រទានដល់លោកអប្រាហាំ
«គឺជាសេចក្តីសន្យាដែលព្រះជាម្ចាស់បានធ្វើទៅលោកអប្រាហាំ»
Genesis 28:5
ប៉ាដាន់អើរ៉ាម
នេះគឺជាឈ្មោះមួយទៀតសម្រាប់តំបន់មេសូប៉ូតាមៀដែលមានទីតាំងដូចគ្នានឹងប្រទេសអ៊ីរ៉ាក់ទំនើបដែរ។
សូមមើលបកប្រែនៅក្នុង ២៥:១៩ (សូមមើល ranslate-names)
លោកបេធូអែល
បេធូអែលជាឪពុករបស់រេបិកា។ សូមមើលបានបកប្រែឈ្មោះនេះនៅក្នុង ២២:២០
Genesis 28:6

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ

សាច់រឿងបានផ្លាស់ផ្តូរពីលោកយ៉ាកុបទៅលោកអេសាវ។

ដូច្នេះ

ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាព័ត៌មានបន្ទាប់អំពីអេសាវ

ប៉ាដាន់-អើរ៉ាម

នេះគឺជាឈ្មោះមួយទៀតនៅតំបន់មេសូប៉ូតាមៀដែលមានទីតាំងដូចគ្នានឹងប្រទេសអ៊ីរ៉ាក់ដែរសព្វថ្ងៃ

សូមមើលបានបកប្រែនៅក្នុង ២៥:១៩ (សូមមើល:translate-names)

ដើម្បីយកភរិយានៅទីនោះ

«គឺយកប្រពន្ធសំរាប់ខ្លួនគាត់»

គាត់ឃើញលោកអ៊ីសាកឲ្យពរដល់គាត់

«អេសាវក៏បានឃើញលោកអ៊ីសាកអោយពរដល់លោកយ៉ាកុប»

កូនមិនត្រូវយក

«សូមកុំយក»

ស្ត្រីនៃសាសន៏កាណាន

«កូនស្រីនៃពយកកាណាន"ឬ"ស្ត្រីសាសនីកាណាន»

Genesis 28:8

ព័ត៌មានទូទៅ

នេះគឺបន្តពីប្រវត្តិពត៌មានអំពីអេសាវ។

អេសាវឃើញ

«អេសាវបានដឹង»

លោកអ៊ីសាកមិនពេញចិត្តនឹងស្ត្រីជនជាតិកាណានឡើយ

«អ៊ីសាកជាឪពុករបស់គាត់មិនពេញចិត្តនឹងស្ត្រីកាណានទេ»

ស្ត្រីជនជាតិកាណាន

«កូនស្រីរបស់ស្រុកកាណាន» ឬ «ស្ត្រីជនជាតិកាណាន»

ដូច្នេះ

«ដោយព្រោះយ៉ាងនោះ»

ក្រៅពីភរិយាដែលគាត់មាន

«ក្រៅពីប្រពន្ធដែលគាត់មាន»

ម៉ាហាឡាត់

នេះគឺជាកូនស្រីរបស់អ៊ីស្មាអែល។

នេបាយ៉ូត

នេះជាឈ្មោះកូនប្រុសម្នាក់របស់អ៊ីស្មាអែល។

Genesis 28:10

ព័ត៌មានទូទៅ

ប្តូរទៅរឿងរបស់លោកយ៉ាកុបវិញម្តង។

គាត់បានទៅដល់កន្លែងមួយ ហើយបានសម្រាកនៅទីនោះពេញមួយយប់

ដោយសារថ្ងៃបានលិចបាត់ហើយ។

«គាត់បានមកដល់កន្លែងជាក់លាក់មួយ,
ហើយដោយសារតែព្រះអាទិត្យបានលេច,គាត់ក៏បានសំរេចចិត្តស្នាក់នៅពេលយប់»

Genesis 28:12

គាត់បានយល់សុបិន

«លោកយ៉ាកុបបានយល់សប្តិ»

បញ្ឈរលើផែនដី

«ជាមួយនឹងបាតរបស់វាប៉ះនឹងដី»

រហូតដល់មេឃ

នេះសំដៅទីកន្លែងដែលព្រះជាម្ចាស់គង់នៅ។

មើល៏

ពាក្យថា« មើល៏»

នៅទីនេះដាស់តឿនយើងឱ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលកើតឡើង

ព្រះអម្ចាស់បានឈរនៅពីលើវា

អត្ថន័យដែលមានគឺ ១) «ព្រះអម្ចាស់បានឈរនៅកំពូលជណ្តើរ»ឬ ២)

«ព្រះអម្ចាស់បានឈរក្បែរយ៉ាកុប»

លោកអប្រាហាំឪពុក

នៅទីនេះ «ឪពុក»មានន័យថា «បុព្វបុរស។

»ការបកប្រែផ្សេងទៀត៖«លោកអប្រាហាំជាបុព្វបុរសរបស់អ្នក»ឬ«លោកអប្រាហាំជាជីតារបស់អ្នក»

Genesis 28:14

ព័ត៌ទូទៅ

ព្រះជាម្ចាស់បន្តការសន្ទនាក្នុងយល់សប្តិជាមួយលោកយ៉ាកុប។

ពូជពង្សរបស់អ្នកនឹងដូចជាធូលីដីនៅលើផែនដី

ព្រះប្រៀបធៀបកូនចៅរបស់យ៉ាកុបទៅនឹងធូលីដីដើម្បីបញ្ជាក់ពីចំនួនដ៏ច្រើនរបស់ពួកគេ។

ការបកប្រែផ្សេងទៀត៖

«អ្នកនឹងមានកូនចៅច្រើនជាងអ្នកអាចរាប់បាន»(សូមមើលFigs-simile)

ពីលិច ទៅកើត ហើយពីជើងទៅត្បូង

នៅទីនេះពាក្យ «អ្នក»គឺមានលក្ខណៈឯកវចនៈ

និយាយពីយ៉ាកុបទេព្រោះគាត់ជាមេដឹកនាំក្រុមគ្រួសារ។ ការបកប្រែផ្សេងទៀត៖

«ហើយកូនចៅរបស់អ្នកនឹងរីករាលដាលទៅភាគខាងលិច»

អ្នកនឹងលាតសន្ធឹង

នេះមានន័យថាប្រជាជននឹងពង្រីកព្រំប្រទល់ដីរបស់ពួកគេនិងកាន់កាប់ទឹកដីបន្ថែមទៀត។

ពីលិច ទៅកើត ហើយពីជើងទៅត្បូង

ឃ្លានេះត្រូវបានប្រើរួមគ្នាដើម្បីមានន័យថា «ទិសដៅទាំងអស់។

»ការបកប្រែផ្សេងទៀត៖ «នៅគ្រប់ទិសដៅ»

តាមរយៈពូជពង្សរបស់អ្នក គ្រប់ទាំងគ្រួសារទាំងអស់នៅលើផែនដីនឹងបានពរ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖

«យើងនឹងប្រទានពរដល់ក្រុមគ្រួសារទាំងអស់នៅលើផែនដីតាមរយៈអ្នកនិងកូនចៅរបស់អ្នក»

មើល៏

នេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលត្រូវនិយាយបន្ទាប់។ ការបកប្រែផ្សេងទៀត៖

«មើល» ឬ «ស្តាប់»ឬ«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងនឹងប្រាប់អ្នក»

ដើម្បីយើងមិនបោះបង់អ្នកចោលឡើយ។ យើងនឹងធ្វើការទាំងអស់

«សម្រាប់យើងនឹងមិនចាកចេញពីអ្នក រហូតដល់យើងបានធ្វើអ្វីទាំងអស់»

យើងនឹងការពារអ្នក

«យើងនឹងរក្សាអ្នកឱ្យមានសុវត្ថិភាព» ឬ «យើងនឹងការពារអ្នក»

យើងនឹងនាំអ្នកមកទឹកដីនេះម្តងទៀត

«យើងនឹងនាំអ្នកត្រឡប់ទៅទឹកដីនេះវិញ»

Genesis 28:16

បានក្រោកពីគេងឡើង

«គាត់បានភ្ញាក់ពីការគេងរបស់គាត់»

ដំណាក់របស់ព្រះជាម្ចាស់.....ជាទ្វាររបស់ស្ថានសួគ៌

ឃ្លាដែលថា«ទ្វារនៃស្ថានស្ថាសួគ៌»ពន្យល់ថាកន្លែងនេះគឺជាច្រកចូលទៅក្នុង«ដំណាក់របស់ព្រះ»និង«ច្រក

នេះគឺជាទ្វាររបស់ស្ថានសួគ៌

នេះនិយាយអំពីផ្លូវចូលទៅកន្លែងដែលព្រះគង់នៅដូចជានគរដែលមានខ្លោងទ្វារដែលមាននរណាម្នាក់ត្រូវ

Genesis 28:18

សសរ

នេះគឺជាសសរស្លាករំលឹក,គឺដុំថ្មធំឬផ្ទាំងថ្មមួយដែលបានតំឡើងនៅចុងរបស់វា។

បានចាត់ប្រេងនៅពីលើថ្មនោះ

សកម្មភាពនេះបង្ហាញថាលោកយ៉ាកុបកំពុងតែសម្ភោធថ្វាយសសរដល់ព្រះ។

អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។

ការបកប្រែផ្សេងទៀត៖

«ចាក់ប្រេងលើកំពូលរបស់វាដើម្បីថ្វាយសសរដល់ព្រះជាម្ចាស់»សូមមើល និង

បេតអែល

អ្នកបកប្រែបន្ថែមលេខយោងដែលនិយាយថា

ឈ្មោះបេតអែលមានន័យថា«ដំណាក់របស់ព្រះជាម្ចាស់»

លូស

នេះគឺជាឈ្មោះនៃទីក្រុង។

Genesis 28:20

បានស្បថសម្បថ

«បានស្បថ»ឬ«សន្យាជាមួយព្រះយ៉ាងខ្លាំង»

ប្រសិនបើ ព្រះជាម្ចាស់.....ព្រះអម្ចាស់នឹងត្រូវជាព្រះរបស់ទូលបង្គំ

យ៉ាកុបកំពុងតែនិយាយទៅកាន់ព្រះនៅក្នុងមនុស្សទីបី។

នេះអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីពីរ។ ការបកប្រែផ្សេងទៀត៖

«ប្រសិនបើព្រះអង្គនឹង ... ពេលនោះទ្រង់នឹងក្លាយជាព្រះ ដែលខ្ញុំនឹងថ្វាយបង្គំ»

នៅតាមផ្លូវដែលខ្ញុំកំពុងដើរនេះ

នេះតំណាងឱ្យដំណើររបស់យ៉ាកុបដើម្បីស្វែងរកប្រពន្ធហើយត្រលប់មកផ្ទះវិញ។

»ការបកប្រែផ្សេងទៀត៖ «ក្នុងដំណើរនេះ»

ហើយប្រទាននំបុ័ងឲ្យខ្ញុំហូប

នៅទីនេះ «នំបុ័ង»តំណាងឱ្យអាហារទូទៅ។

ទៅផ្ទះរបស់ឪពុកខ្ញុំវិញ

នៅទីនេះ «ផ្ទះ» តំណាងឱ្យក្រុមគ្រួសាររបស់យ៉ាកុប។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត៖«ទៅឪពុកខ្ញុំនិងគ្រួសារខ្ញុំទាំងអស់»
ថ្មសក្ការៈ
នេះមានន័យថាថ្មនឹងសម្គាល់កន្លែងដែលព្រះបានលេចមកឱ្យគាត់ហើយ
នឹងជាកន្លែងដែលមនុស្សអាចថ្វាយបង្គំព្រះបាន។ ការបកប្រែផ្សេងទៀត៖
«ដំណាក់របស់ព្រះជាម្ចាស់» ឬ «កន្លែងរបស់ព្រះជាម្ចាស់»

---

29 [1]បន្ទាប់មក លោកយ៉ាកុបបានធ្វើដំណើរ ហើយទៅដល់ទឹកដីរបស់ប្រជាជនដែលនៅភាគខាងកើត។[2]នៅពេលគាត់សម្លឹងមើល គាត់បានឃើញអណ្តូងនៅឯវាល
ហើយមើល៍ មានសត្វចៀមបីហ្វូងដេកនៅក្បែរអណ្តូងនោះ។ ព្រោះហ្វូងសត្វទាំងអស់នោះ ផឹកទឹកពីអណ្តូងនោះ ហើយមានថ្មមួយយ៉ាងធំបិទមាត់អណ្តូងនោះ។
[3]នៅពេលហ្វូងសត្វបានមកជុំគ្នានៅទីនោះហើយ ពួកអ្នកគង្វាលនឹងរមៀលថ្មចេញពីមាត់អណ្តូងនោះ ហើយដងទឹកឲ្យចៀមផឹក ហើយ
រមៀលថ្មមកដាក់នៅមាត់អណ្តូងទៅកន្លែងរបស់វាវិញ។
[4]លោកយ៉ាកុបនិយាយទៅកាន់ពួកគេថា៖ «បងប្អូនអើយ តើបងប្អូនមកពីណា?» ពួកគេឆ្លើយថា៖ «យើងមកពីខារ៉ាន»។[5]គាត់និយាយទៅកាន់ពួកគេថា៖
«តើបងប្អូនស្គាល់លោកឡាបាន់ កូនប្រុសរបស់លោកណាឃរទេ?»។[6]គាត់និយាយទៅកាន់ពួកគេថា៖ «តើគាត់សុខសប្បាយជាទេ?» ពួកគេឆ្លើយថា៖
«គាត់សុខសប្បាយទេ ហើយមើល៍នោះ នាងរ៉ាជែល កូនស្រីរបស់គាត់មកជាមួយចៀមផង?»។
[7]លោកយ៉ាកុបឆ្លើយថា៖ «មើល៍ ឥឡូវនេះថ្ងៃត្រង់ហើយ។ វាមិនមែនជាពេលដែលហ្វូងសត្វត្រូវប្រមូលផ្តុំឡើយ។ អ្នកគួរតែឲ្យចៀមផឹកទឹក ហើយបន្ទាប់មក
លែងពួកវាឲ្យទៅស៊ីស្មៅចុះ»។[8]ពួកគេនិយាយថា៖ «យើងមិនអាចឲ្យពួកវាផឹកទឹក លុះត្រាតែពួកវាជួបជុំគ្នាសិន។ បន្ទាប់មក ពួកប្រុសៗបានរមៀលថ្មចេញពីមាត់អណ្តូង
ហើយ យើងនឹងឲ្យទឹកចៀមផឹក»។
[9]កាលលោកយ៉ាកុបកំពុងនិយាយជាមួយពួកគេនៅឡើយ នាងរ៉ាជែល បានដើរមកជាមួយហ្វូងចៀមឪពុកនាង ដ្បិតនាងឃ្វាលពួកវា។
[10]ពេលលោកយ៉ាកុបឃើញនាងរ៉ាជែល កូនស្រីរបស់លោកឡាបាន់ ត្រូវជាប្អូនប្រុសម្តាយរបស់គាត់ និងហ្វូងចៀមរបស់លោកឡាបាន់ ប្អូនប្រុសម្តាយរបស់គាត់
គាត់បានចូលទៅជិត ហើយរមៀលថ្មចេញពីមាត់អណ្តូង ហើយបានដងទឹកឲ្យហ្វូងចៀមរបស់លោកឡាបាន់ ប្អូនប្រុសម្តាយរបស់គាត់។
[11]លោកយ៉ាកុបបានថើបនាងរ៉ាជែល ហើយយំខ្លាំងៗ។[12]លោកយ៉ាកុបបានប្រាប់នាងរ៉ាជែលថា គាត់គឺជាសាច់ញាតិឪពុករបស់នាង ហើយថា
គាត់គឺជាកូនប្រុសរបស់នាងរេបិកា។ បន្ទាប់មក នាងបានរត់ ហើយទៅប្រាប់ឪពុករបស់នាង។
[13]ពេលលោកឡាបាន់បានឮដំណឹងពីលោកយ៉ាកុប កូនប្រុសបងស្រីរបស់គាត់ គាត់បានរត់ទៅជួប ហើយឱប ថើប ព្រមទាំងនាំគាត់មកផ្ទះរបស់គាត់ផង។
លោកយ៉ាកុបប្រាប់លោកឡាបាន់ពីគ្រប់រឿងរ៉ាវទាំងអស់។[14]លោកឡាបាន់និយាយទៅគាត់ថា៖ «ក្មួយពិតជាជាប់សាច់ឈាមរបស់អ៊ំមែន។ បន្ទាប់មក
លោកឡាបាន់បានស្នាក់នៅជាមួយគាត់អស់រយៈពេលមួយខែ។
[15]បន្ទាប់មក លោកឡាបាន់និយាយទៅកាន់លោកយ៉ាកុបថា៖ «តើក្មួយមិនត្រូវធ្វើការឲ្យអ៊ំ ដោយមិនបានកម្រៃឬអី? ប្រាប់អ៊ំមក
តើក្មួយចង់បានថ្លៃឈ្នួលប៉ុន្មាន?»[16]លោកឡាបាន់មានកូនស្រីពីរនាក់។ កូនស្រីច្បងឈ្មោះនាងលេអា ហើយកូនស្រីពៅឈ្មោះនាងរ៉ាជែល។[17]នាងលេអាមានភ្នែកស្រទន់
ប៉ុន្តែ នាងរ៉ាជែលវិញមានរូបឆោមស្រស់ស្អាតណាស់។[18]លោកយ៉ាកុបស្រឡាញ់នាងរ៉ាជែល ដូច្នេះ គាត់និយាយថា៖ «ខ្ញុំនឹងបម្រើអ៊ំប្រាំពីរឆ្នាំ ដើម្បីឲ្យបាននាងរ៉ាជែល
កូនស្រីពៅរបស់អ៊ំ»។
[19]លោកឡាបាន់និយាយថា៖ «អ៊ំលើកកូនឲ្យឯង ប្រសើរជាអ៊ំលើកកូនឲ្យអ្នកផ្សេង។ នៅជាមួយអ៊ំហើយ»។[20]ដូច្នេះ លោកយ៉ាកុបបានបម្រើប្រាំពីរឆ្នាំ
ដើម្បីឲ្យបាននាងរ៉ាជែល ហើយប្រាំពីរឆ្នាំ ហាក់បីដូចជាប៉ុន្មានថ្ងៃប៉ុណ្ណោះ ដ្បិត គាត់ស្រឡាញ់នាងជាខ្លាំង។
[21]បន្ទាប់មក លោកយ៉ាកុបនិយាយកាន់លោកឡាបាន់ថា៖ «ខ្ញុំបានបម្រើអ៊ំគ្រប់ប្រាំពីរឆ្នាំហើយ សូមប្រគល់នាងឲ្យខ្ញុំមក ដើម្បីឲ្យខ្ញុំអាចរៀបការជាមួយនាង!»[22]ដូច្នេះ
លោកឡាបាន់បានប្រមូលពួកប្រុសៗទាំងអស់នៅកន្លែងរបស់គាត់ ហើយធ្វើពិធីជប់លៀង។
[23]នៅពេលល្ងាច លោកឡាបាន់បានយកនាងលេអា កូនស្រីច្បងរបស់គាត់ ហើយយកនាងទៅឲ្យលោកយ៉ាកុប ដើម្បីគេងជាមួយនាង។
[24]លោកឡាបាន់បានប្រគល់អ្នកបម្រើស្រីរបស់គាត់ឲ្យទៅកូនស្រីរបស់គាត់ ឈ្មោះនាងស៊ីលផា ដើម្បីបម្រើនាង។[25]នៅពេលព្រឹក មើល៍ នាងជាលេអាទៅវិញ
លោកយ៉ាកុបបាននិយាយទៅកាន់លោកឡាបាន់ថា៖ «តើអ៊ំធ្វើដូច្នេះដាក់ខ្ញុំធ្វើអ្វី? តើខ្ញុំមិនបានបម្រើអ៊ំ ដើម្បីឲ្យបាននាងរ៉ាជែលជាឬ?
ហេតុអ្វីបានជាអ៊ំបោកប្រាស់ខ្ញុំដូច្នេះ?»។
[26]លោកឡាបាន់និយាយថា៖ «នេះមិនមែនជាទម្លាប់របស់យើងទេ ដែលប្អូនស្រីពៅរៀបការមុនបងស្រីច្បងនោះ។[27]ចូរនៅជាមួយកូនស្រីនេះមួយសប្តាហ៍សិនទៅ
ហើយយើងនឹងប្រគល់កូនស្រីមួយទៀតឲ្យ ទុកដូចជាថ្លៃឈ្នួលនៃការបម្រើអ៊ំប្រាំពីរឆ្នាំទៀត»។
[28]លោកយ៉ាកុបក៏ធ្វើតាម ហើយបាននៅជាមួយនាងលេអាគ្រប់មួយសប្តាហ៍។ បន្ទាប់មក លោកឡាបាន់បានប្រគល់នាងរ៉ាជែល កូនស្រីរបស់គាត់
ឲ្យធ្វើជាភរិយារបស់គាត់ផងដែរ។[29]លោកឡាបាន់បានប្រគល់នាងប៊ីលហាដល់នាងរ៉ាជែលជាកូនស្រីរបស់គាត់ ដើម្បីបម្រើនាង។[30]ដូច្នេះ
លោកយ៉ាកុបបានគេងជាមួយនាងរ៉ាជែលផងដែរ ប៉ុន្តែ គាត់ស្រឡាញ់នាងរ៉ាជែលខ្លាំងជាងនាងលេអា។ ដូច្នេះ
លោកយ៉ាកុបបានបម្រើលោកឡាបាន់អស់រយៈពេលប្រាំពីឆ្នាំទៀត។
[31]ព្រះអម្ចាស់បានឃើញថា នាងលេអាមិនបានទទួលសេចក្តីស្រឡាញ់ ដូច្នេះ ព្រះអង្គបានធ្វើឲ្យនាងមានកូន ប៉ុន្តែ នាងរ៉ាជែលវិញគ្មានកូនទេ។[32]នាងលេអាមានផ្ទៃពោះ
ហើយបង្កើតបានកូនប្រុសមួយ ហើយនាងដាក់ឈ្មោះកូនប្រុសនោះថា រូបេន។ នាងបាននិយាយថា៖ «ព្រះអម្ចាស់បានឃើញពីទុក្ខលំបាករបស់ខ្ញុំ ដូច្នេះ
ស្វាមីរបស់ខ្ញុំមុខជាស្រឡាញ់ខ្ញុំមិនខាន»។
[33]បន្ទាប់មក នាងក៏មានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយទៀត។ នាងនិយាយថា៖ «ព្រះជាម្ចាស់ជ្រាបថា ស្វាមីខ្ញុំមិនស្រឡាញ់ខ្ញុំទេ ហេតុដូច្នេះហើយ
បានជាព្រះអង្គប្រទានកូនប្រុសមួយទៀតឲ្យខ្ញុំ» ហើយនាងបានដាក់ឈ្មោះកូនប្រុសនោះថា ស៊ីម្មាន។[34]បន្ទាប់មក នាងក៏មានផ្ទៃពោះ
ហើយបង្កើតបានកូនប្រុសមួយទៀត។ នាងនិយាយថា៖ «ឥឡូវនេះ ដល់ពេលដែលស្វាមីរបស់ខ្ញុំ ជាប់ចិត្តនឹងខ្ញុំវិញហើយ ព្រោះខ្ញុំបានបង្កើតកូនប្រុសបីដល់គាត់»។
ដូច្នេះហើយបានជាដាក់ឈ្មោះឲ្យកូនប្រុសនោះថា លេវី។
[35]នាងមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយទៀត។ នាងនិយាយថា៖ «ខ្ញុំនឹងសរសើរព្រះអម្ចាស់នៅពេលនេះ»។
ហេតុដូច្នេះហើយបានជានាងដាក់ឈ្មោះកូនប្រុសនោះថា យូដា។ បន្ទាប់មក នាងលែងមានកូនទៀត។

Genesis 29:1
ប្រជាជនដែលនៅភាគខាងកើត
នេះមានន័យថាប្រជាជនប៉ាដាន-អើរ៉ាមដែលជាទឹកដីនៅខាងកើតស្រុកកាណាន។
ហើយ មើល៍ មានសត្វចៀមបីហ្វូងដេក
ពាក្យថា«មើល៍» សម្គាល់ការចាប់ផ្តើមនៃព្រឹត្តិការណ៍មួយទៀតនៅក្នុងរឿងធំ។
ចេញពីមាត់អណ្តូងនោះ
«យកចេញពីអណ្តូងនោះ»
ឃ្លានេះសម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាពត៌មានខាងក្រោយអំពីរបៀបដែលពួកគង្វាលធ្វើការជាមួយគ្នា
ទាំងអស់នោះ ផឹកទឹក
«ពួកគង្វាលនឹងស្រោចទឹក»ឬ«អ្នកដែលថែរក្សាចៀមនឹងស្រោចទឹក»
មាត់អណ្តូង
នៅទីនេះ «មាត់» គឺជាមធ្យោបាយនៃការសំដៅទៅលើការបើក។
ការបកប្រែផ្សេងទៀត៖ «ការបើកអណ្តូងទឹក»
Genesis 29:4
លោកយ៉ាកុបនិយាយទៅកាន់ពួកគេ
លោកជ្រោះ[illegible]ចៀមរបស់អ្នកគង្វាល»

generated on Wed Sep 10 16:16:32 2025

បងប្អូនអើយ
នេះជាវិធីគួរសមដើម្បីស្វាគមន៍ជនចម្លែក។
លោកឡាបាន់ កូនប្រុសរបស់លោកណាឃរ
នៅទីនេះ «កូនប្រុស» សំដៅទៅលើកូនចៅប្រុស។
អត្ថន័យដែលអាចទៅរួចមួយទៀតគឺ «ឡាបាន់ចៅប្រុសរបស់ណាឃរ។ » (UDB)
ហើយមើល៍នោះ នាងរ៉ាជែល កូនស្រីរបស់គាត់មកជាមួយចៀម
ឥឡូវនេះមើល! រ៉ាជែលកូនស្រីរបស់គាត់កំពុងមកជាមួយចៀម។
Genesis 29:7
នេះថ្ងៃត្រង់ហើយ
«ព្រះអាទិត្យនៅតែខ្ពស់នៅលើមេឃ» (UDB)
ឬ«ព្រះអាទិត្យនៅតែមានពន្លឺចែងចាំង»
ហ្វូងសត្វត្រូវប្រមូលផ្តុំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«សម្រាប់អ្នកដើម្បីប្រមូលហ្វូងសត្វ»
ត្រូវប្រមូលផ្តុំ
នេះមានន័យថាប្រមូលផ្តុំពួកគេនៅខាងក្នុងរបងសម្រាប់ពួកគេស្នាក់នៅពេលយប់។
លែងពួកវាឲ្យទៅស្មៅ
«ឱ្យពួកគេស៊ីស្មៅនៅឯវាល»
យើងមិនអាចឲ្យពួកវាផឹកទឹក
«យើងត្រូវរង់ចាំទឹកពួកគេ ។»
នេះត្រូវធ្វើជាមួយពេលវេលាមិនមែនការអនុញ្ញាតទេ។
លុះត្រាតែពួកវាជួបជុំគ្នាសិន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«រហូតដល់អ្នកគង្វាលផ្សេងទៀតប្រមូលហ្វូងសត្វរបស់ពួកគេ»
ចេញពីមាត់អណ្តូង
នៅទីនេះ «មាត់» គឺជាមធ្យោបាយនៃការសំដៅទៅលើការបើក។
ការបកប្រែផ្សេងទៀត៖ «ពីអណ្តូងទឹក» ឬ«ពីការបើកអណ្តូងទឹក»
យើងនឹងឲ្យទឹកចៀមផឹក
«បន្ទាប់មកយើងនឹងអោយទឹកចៀម»
Genesis 29:9
ត្រូវជាបងប្រុសម្តាយរបស់គាត់
«អ៊ុំគាត់»
ចេញពីមាត់អណ្តូង
នៅទីនេះ «មាត់» គឺសំដៅទៅលើការបើក។ ការបកប្រែផ្សេងទៀត៖ «អណ្តូងទឹក»
ឬ«ការបើកអណ្តូងទឹក»
Genesis 29:11
លោកយ៉ាកុបបានថើបនាងរ៉ាជែល
នៅពីបុរាណវាជិតទិសខាងកើត ការសួរសុខទុក្ខសាច់ញាតិដោយការថើប។
ទោះជាយ៉ាងណាក៏ដោយជាធម្មតាវាត្រូវបានធ្វើឡើងរវាងបុរស។
ប្រសិនបើភាសារបស់អ្នក ការស្វាគមន៍ជាទីរាប់អានសម្រាប់សាច់ញាតិសូមប្រើវា។
ប្រើអ្វីដែលសមស្រប។
យំខ្លាំងៗ
យ៉ាកុបយំព្រោះគាត់សប្បាយចិត្តណាស់។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
គឺជាសាច់ញាតិឪពុករបស់នាង
«មានទំនាក់ទំនងទៅឪពុករបស់នាង »
Genesis 29:13
កូនប្រុសបួនស្រីរបស់គាត់
«កួយប្រុសគាត់»
ឱប គាត់
«បានឱបគាត់»
ថើបគាត់
នៅពីបុរាណជិតទិសខាងកើត,ការសួរសុខទុក្ខសាច់ញាតិដោយការថើប។
ទោះជាយ៉ាងណាក៏ដោយជាធម្មតាវាត្រូវបានធ្វើឡើងរវាងបុរស។
ប្រសិនបើភាសារបស់អ្នក,ការស្វាគមន៍ជាទីរាប់អានសម្រាប់សាច់ញាតិសូមប្រើវា។
ប្រើអ្វីដែលសមស្រប។
លោកយ៉ាកុបប្រាប់លោកឡាបាន់ពីគ្រប់រឿងរ៉ាវទាំងអស់
«លោកយ៉ាកុបបានប្រាប់ឡាបាន់នូវអ្វីៗទាំងអស់ដែលលោកបានប្រាប់រ៉ាជែល»
កួយពិតជាជាប់សាច់ឈាមរបស់អ៊ំមែន
ឃ្លានេះមានន័យថាពួកគេពិតជាមានទាក់ទង។ ការបកប្រែផ្សេងទៀត៖
«សាច់ញាតិរបស់ខ្ញុំ» ឬ «សមាជិកគ្រួសាររបស់ខ្ញុំ» ។ (មើលfigs-metonymy)
Genesis 29:15
តើក្មួយមិនត្រូវធ្វើការឲ្យអ៊ំ ដោយមិនបានកម្រៃឬអី....សាច់ញាតិខ្ញុំ?
ឡាបាន់ប្រើសំនួរមួយដើម្បីបញ្ជាក់ថាគាត់គួរតែអោយយ៉ាកុបសំរាប់ធ្វើការអោយគាត់។
សំណួរអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
នេះក៏អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមានផងដែរ។ ការបកប្រែផ្សេងទៀត៖
«វាពិតជាត្រឹមត្រូវដែលខ្ញុំគួរតែបង់ប្រាក់ឱ្យអ្នកសម្រាប់ធ្វើការឱ្យខ្ញុំទោះបីអ្នកជាសាច់ញាតិរបស់ខ្ញុំក៏ដោយ»
ឥឡូវនេះ លោកឡាបាន់មាន
ពាក្យ «ឥឡូវនេះ»
ត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាព័ត៌មាននៅខាងក្រោយអំពីឡាបាន់និងកូនស្រ
(មើល:writing-background)
នាងលេអាមានភ្នែកស្រទន់
អត្ថន័យដែលមានគឺ ១)« ភ្នែករបស់លេអាស្អាតណាស់»ឬ ២)«
ភ្នែករបស់លេអាស្អាត»
លោកយ៉ាកុបស្រឡាញ់នាងរ៉ាជែល
នៅទីនេះពាក្យថា «ស្រឡាញ់»
សំដៅទៅលើការទាក់ទាញមនោសញ្ចេតនារវាងបុរសនិងស្ត្រី។
Genesis 29:19
អ៊ំលើកកូនឲ្យឯង ប្រសើរជាអ៊ំលើកកូនឲ្យអ្នកផ្សេង
«ជាជាងឱ្យនាងទៅបុរសផ្សេង»
ហាក់បីដូចជាប៉ុន្មានថ្ងៃប៉ុណ្ណោះ
«ប៉ុន្តែពេលវេលាហាក់ដូចជាគាត់នៅសល់តែពីរបីថ្ងៃប៉ុណ្ណោះ»
ដ្បិត គាត់ស្រឡាញ់នាងជាខ្លាំង
«ដោយសារសេចក្តីស្រឡាញ់ដែលគាត់មានចំពោះនាង»ឬ
«ដោយសារសេចក្តីស្រឡាញ់របស់គាត់ចំពោះនាង»
Genesis 29:21
ខ្ញុំបានបម្រើអ៊ំគ្រប់ប្រាំពីរឆ្នាំហើយ សូមប្រគល់នាងឲ្យខ្ញុំមក ដើម្បីឲ្យខ្ញុំអាចរៀបការជាមួយនាង!
នៅទីនេះ «ថ្ងៃ» តំណាងឱ្យរយៈពេលយូរជាងនេះ។ ឃ្លា
«ត្រូវបានបញ្ចប់»អាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
សេចក្តីថ្លែងការណ៍គឺគួរឱ្យទុកចិត្ត។ ការបកប្រែផ្សេងទៀត៖
«ផ្តល់ឱ្យខ្ញុំរ៉ាជែលដើម្បីឱ្យខ្ញុំរៀបការជាមួយនាង
ព្រោះខ្ញុំបានធ្វើការអស់រយៈពេលប្រាំពីរឆ្នាំសម្រាប់អ្នក!»
ធ្វើពិធីជប់លៀង
«បានរៀបចំពិធីមង្គលការ។»
ឡាបាន់ទំនងជាអ្នកអ្នកផ្សេងទៀតរៀបចំពិធីជប់លៀងអោយ។
ការបកប្រែផ្សេងទៀត៖ «មានអ្នកផ្សេងទៀតរៀបចំពិធីមង្គលការ» ។
Genesis 29:23
ដើម្បីគេងជាមួយនាង
នេះបញ្ជាក់ថាយ៉ាកុបមិនដឹងថាគាត់នៅជាមួយលេអាទេពីព្រោះវាងងឹតហើយគាត់មិនអាចមើលឃើញ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
លោកឡាបាន់បានអោយអ្នកបំរើរបស់គាត់គឺស៊ីលផា.....អ្នកបំរើនាង
នៅទីនេះអ្នកនិពន្ធបានផ្តល់ព័ត៌មាននៅខាងក្រោយអំពីឡាបាន់ឱ្យស៊ីលផាដល់លេអា។
ភាគច្រើនគាត់បានអោយស៊ីលផាដល់លេអានៅមុនថ្ងៃរៀបអាពាហ៍ពិពាហ៍។
(សូមមើលwriting-background)
ស៊ីលផា
នេះគឺជាឈ្មោះអ្នកបម្រើស្រីរបស់នាងលេអា។(សូមមើលtranslate-names)
មើល៍ នេះគឺជាលេអា
លោកយ៉ាកុបបានភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលឃើញនាងលេអាកំពុងដេកជាមួយគាត់។
ពាក្យថា«
មើល»នៅទីនេះបង្ហាញថាយ៉ាកុបមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។
តើអ៊ំធ្វើដូច្នេះដាក់ខ្ញុំធ្វើអ្វី?
យ៉ាកុបប្រើសំណួរដើម្បីបង្ហាញកំហឹងនិងការភ្ញាក់ផ្អើលរបស់គាត់។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំមិនជឿថាអ៊ំបានធ្វើបែបនេះចំពោះខ្ញុំទេ!»
តើខ្ញុំមិនបានបម្រើអ៊ំ ដើម្បីឲ្យបាននាងរ៉ាជែលជាឬ?
លោកយ៉ាកុបប្រើសំនួរទាំងនេះដើម្បីបង្ហាញពីការឈឺចាប់របស់គាត់ដែលឡាបាន់បានបញ្ឆោតគាត់។
សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំបានបម្រើអ្នកអស់រយៈពេលប្រាំពីរឆ្នាំដើម្បីរៀបការជាមួយរ៉ាជែល!»(សូមមើល៍figs-
rquestion)

generated on Wed Sep 10 16:16:32 2025

Genesis 29:26
នេះមិនមែនជាទម្លាប់របស់យើងទេ
«នៅក្នុងគ្រួសាររបស់យើងមិនអោយ»
ចូរនៅជាមួយកូនស្រីនេះមួយសប្តាហ៍សិន
«បញ្ចប់ការអបអរមួយសប្តាហ៍ជាមួយលេអាកូនក្រមុំ»
ហើយយើងនឹងប្រគល់កូនស្រីមួយទៀតឲ្យ
អត្ថន័យពេញលេញអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត៖
«ហើយសប្តាហ៍ក្រោយយើងនឹងផ្តល់ឱ្យអ្នករ៉ាជែលផងដែរ»
Genesis 29:28
លោកយ៉ាកុបក៏ធ្វើតាម ហើយបាននៅជាមួយនាងលេអាគ្រប់មួយសប្តាហ៍
លោកយ៉ាកុបបានធ្វើតាមពាក្យដែលលោកឡាបាន់បានស្នើសុំ,ហើយបានបញ្ចប់ពិធីអបអរសាទរមួយសប្តាហ៍
ប៊ីលហា
នេះគឺជាឈ្មោះអ្នកបម្រើស្រីរបស់រ៉ាជែល។(សូមមើល:translate-names)
លោកយ៉ាកុបបានគេងជាមួយនាងរ៉ាជែល
នេះជាវិធីគួរសមក្នុងការនិយាយថាពួកគេមានទំនាក់ទំនងអាពាហ៍ពិពាហ៍។
ការបកប្រែផ្សេងទៀត៖ «យ៉ាកុបរៀបការជាមួយរ៉ាជែល»
គាត់ស្រឡាញ់នាងរ៉ាជែល
នេះសំដៅទៅលើស្នេហារ៉ូមែនទិករវាងបុរសនិងស្ត្រី។
Genesis 29:31
នាងលេអាមិនបានទទួលសេចក្តីស្រឡាញ់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត៖«យ៉ាកុបមិនបានស្រឡាញ់លេអា»
មិនបានទទួលសេចក្តីស្រឡាញ់
នេះគឺជាការបំផ្លើសមួយដើម្បីបញ្ជាក់ថាយ៉ាកុបស្រឡាញ់រ៉ាជែលច្រើនជាងលេអា។
ការបកប្រែផ្សេងទៀត៖ «ស្រឡាញ់តិចជាងរ៉ាជែល»
ដូច្នេះ ព្រះអង្គបានធ្វើឲ្យនាងមានកូន
ព្រះជាម្ចាស់បាន បណ្តាលឲ្យ
លេអាមានគភ៌គឺដូចជាព្រះកំពុងតែបើកស្បូនរបស់នាង។
គ្មានកូនទេ
«មិនអាចមានផ្ទៃពោះបានទេ»
នាងលេអាមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយ
«លេអាមានផ្ទៃពោះហើយសំរាលបានកូនប្រុសមួយ»
នាងដាក់ឈ្មោះកូនប្រុសនោះថា រូបេន
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា៖« ឈ្មោះរូបេនមានន័យថា មើលកូនប្រុស»
ព្រះអម្ចាស់បានឃើញពីទុក្ខលំបាករបស់ខ្ញុំ
លេអាកំពុងមានអារម្មណ៍ឈឺចាប់ដោយសារយ៉ាកុបបានបដិសេធនាង។
នាមអរូបី«ទុក្ខវេទនា» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត៖
«ព្រះអម្ចាស់បានឃើញខ្ញុំរងទុក្ខវេទនា»
Genesis 29:33
បន្ទាប់មក នាងក៏មានផ្ទៃពោះ
«នាងលេអាក៏ចាប់ផ្តើមមានផ្ទៃពោះ»
បង្កើតបានកូនប្រុសមួយ
«នាងបានសំរាលបានកូនប្រុសមួយ»
ព្រះជាម្ចាស់ជ្រាបថា ស្វាមីខ្ញុំមិនស្រឡាញ់ខ្ញុំទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ព្រះអម្ចាស់បានឮថាប្តីខ្ញុំមិនស្រឡាញ់ខ្ញុំទេ»
នាងបានដាក់ឈ្មោះកូនប្រុសនោះថា ស៊ីម្មាន
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា«
ឈ្មោះស៊ីម្មានមានន័យថា«បានលឺ»(សូមមើលtranslate-names)
ស្វាមីរបស់ខ្ញុំ ជាប់ចិត្តនឹងខ្ញុំវិញហើយ
«ប្តីខ្ញុំនឹងឱបខ្ញុំ»
ព្រោះខ្ញុំបានបង្កើតកូនប្រុសបីដល់គាត់
«ខ្ញុំបានផ្តល់កំណើតឱ្យកូនប្រុសបីនាក់សម្រាប់គាត់»
ដាក់ឈ្មោះឲ្យកូនប្រុសនោះថា លេវី
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា៖
ឈ្មោះលេវីមានន័យថា«ភ្ជាប់»(សូមមើលtranslate-names)
Genesis 29:35
នាងមានផ្ទៃពោះម្តងទៀត
«លេអាក៏មានផ្ទៃពោះម្តងទៀត»
បង្កើតបានកូនប្រុសមួយ
«នាងសំរាលបានកូនប្រុសមួយ»
នាងដាក់ឈ្មោះកូនប្រុសនោះថា យូដា
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា៖
ឈ្មោះយូដាមានន័យថា«ការសរសើរ» (សូមមើលtranslate-names)

---

30 [1]នៅពេលនាងរ៉ាជែលឃើញថា មិនបានបង្កើតកូនឲ្យលោកយ៉ាកុបសោះ នាងរ៉ាជែលបានច្រណែននឹងបងស្រីរបស់នាង។ នាងនិយាយទៅលោកយ៉ាកុបថា៖
«បើមិនឲ្យខ្ញុំមានកូនផង ខ្ញុំនឹងស្លាប់»។[2]លោកយ៉ាកុបខឹងជាមួយនឹងនាងរ៉ាជែលជាខ្លាំង។ គាត់និយាយថា៖ «តើបងព្រះជាម្ចាស់មែនទេ
ដែលបង្ខាំងអូនមិនឲ្យមានកូន?»។
[3]នាងនិយាយថា៖ «មើល៍នែ ប៊ីលហា ជាអ្នកបម្រើស្រីរបស់អូន ចូរគេងជាមួយនាងទៅ ដើម្បីឲ្យនាងអាចបង្កើតកូនមកដាក់លើជង្គង់អូន ហើយអូននឹងមានកូន
ដោយសារនាង»។[4]ដូច្នេះ នាងបានប្រគល់នាងប៊ីលហា ជាអ្នកបម្រើស្រីរបស់នាង ឲ្យធ្វើជាភរិយា ហើយលោកយ៉ាកុបក៏គេងជាមួយនាង។
[5]នាងប៊ីលហាមានផ្ទៃពោះ ហើយបង្កើតកូនប្រុសមួយឲ្យលោកយ៉ាកុប។[6]បន្ទាប់មក នាងរ៉ាជែលនិយាយថា៖ «ព្រះជាម្ចាស់រកយុត្តិធម៌ឲ្យខ្ញុំ។
ព្រះអង្គបានស្តាប់សេចក្តីអធិស្ឋានរបស់ខ្ញុំ ហើយប្រទានកូនប្រុសមួយឲ្យខ្ញុំ»។ ដោយហេតុនេះ បានជានាងដាក់ឈ្មោះកូនប្រុសនោះថា ដាន់។
[7]នាងប៊ីហា ជាអ្នកបម្រើស្រីរបស់នាងរ៉ាជែល មានផ្ទៃពោះម្តងទៀត ហើយបង្កើតប្រុសទីពីរឲ្យលោកយ៉ាកុប។[8]នាងរ៉ាជែលនិយាយថា៖ «ខ្ញុំខំប្រឹងតទល់យ៉ាងខ្លាំងជាមួយ
នឹងបងស្រីខ្ញុំ ហើយខ្ញុំបានឈ្នះ»។ នាងបានដាក់ឈ្មោះកូនប្រុសនោះថា ណែបថាលី។
[9]នៅពេលនាងលេអាឃើញថា នាងលែងមានកូនបានទៀត នាងបាននាងស៊ីលផា ជាអ្នកបម្រើស្រីរបស់នាង ហើយប្រគល់នាងឲ្យលោកយ៉ាកុប ធ្វើជាភរិយា។
[10]នាងស៊ីលផា អ្នកបម្រើស្រីរបស់នាងលេអា បានបង្កើតកូនប្រុសមួយឲ្យលោកយ៉ាកុប។[11]នាងលេអានិយាយថា៖ «មានសំណាងហើយ!» ដូច្នេះ
នាងបានដាក់ឈ្មោះកូនប្រុសនោះថា កាដ។
[12]បន្ទាប់មកនាងស៊ីលផា អ្នកបម្រើរបស់នាងលេអា បានបង្កើតកូនទីពីរឲ្យលោកយ៉ាកុប។[13]នាងលេអានិយាយថា៖ «ខ្ញុំរីករាយហើយ! ដ្បិតស្ត្រីទាំងឡាយនឹងហៅខ្ញុំថា
រីករាយ»។ ដូច្នេះ នាងបានដាក់ឈ្មោះកូនប្រុសនោះថា អេស៊ើរ។
[14]លោករូបេនបានចេញទៅចម្ការនៅក្នុងរដូវច្រូតស្រូវ ហើយបេះបានផ្លែស្នេហ៍នៅក្នុងចម្ការ។ កាត់បានយកផ្លែឈើទាំងនោះមកជូននាងលេអាជាម្តាយរបស់គាត់។
បន្ទាប់មក នាងរ៉ាជែលបាននិយាយទៅនាងលេអាថា៖ «សូមឲ្យផ្លែស្នេហ៍កូនប្រុសបងមកខ្ញុំខ្លះមក»។[15]នាងលេអានិយាយទៅនាងថា៖
«តើវាជារឿងតូចតាចសម្រាប់ឯងមែនទេ ដែលឯងមកយកប្តីរបស់យើងទៅ? ហើយឥឡូវ ឯងចង់មកយកផ្លែស្នេហ៍ពីកូនប្រុសយើងទៀត?» នាងរ៉ាជែលនិយាយថា៖
«អ៊ីចឹង ខ្ញុំនឹងឲ្យគាត់ទៅគេងជាមួយបងយប់នេះ ដើម្បីប្តូរយកផ្លែស្នេហ៍កូនប្រុសរបស់បងនេះ»។
[16]លោកយ៉ាកុបមកដល់ពីស្រែនៅពេលល្ងាច។ នាងលេអាបានចេញទៅជួបគាត់ ហើយនិយាយថា៖ «បងត្រូវគេងជាមួយអូនយប់នេះ
ព្រោះអូនបានជួលបងដោយថ្លៃផ្លែស្នេហ៍កូនប្រុសរបស់អូន»។ ដូច្នេះ លោកយ៉ាកុបក៏ទៅគេងជាមួយនាងលេអានៅយប់នោះ។[17]ព្រះជាម្ចាស់ស្តាប់តាមនាងលេអា
ហើយនាងក៏មានផ្ទៃពោះ ហើយបានបង្កើតកូនប្រុសទីប្រាំឲ្យលោកយ៉ាកុប។[18]នាងលេអានិយាយថា៖ «ព្រះជាម្ចាស់ប្រទានរង្វាន់ដល់ខ្ញុំ
ព្រោះខ្ញុំបានប្រគល់អ្នកបម្រើស្រីរបស់ខ្ញុំឲ្យទៅស្វាមីរបស់ខ្ញុំ»។ នាងបានដាក់ឈ្មោះកូនប្រុសនោះថា អ៊ីសាខា។
[19]នាងលេអាមានផ្ទៃពោះម្តងទៀត ហើយបង្កើតបានកូនប្រុសទីប្រាំមួយ ឲ្យលោកយ៉ាកុប។ នាងលេអានិយាយថា៖ «ព្រះជាម្ចាស់បានប្រទានអំណោយយ៉ាងល្អដល់ខ្ញុំ»។
[20]ឥឡូវនេះ ស្វាមីខ្ញុំនឹងគោរពខ្ញុំ ដោយសារខ្ញុំបានបង្កើតកូនប្រុសទីប្រាំមួយឲ្យគាត់»។[21]នាងដាក់ឈ្មោះកូនប្រុសនោះថា សាប់យូឡូន។ បន្ទាប់មក
នាងបានបង្កើតបានកូនស្រីមួយ ហើយនាងបានដាក់ឈ្មោះកូនស្រីនោះថា ឌីណា។

generated on Wed Sep 10 16:16:32 2025

[22]ព្រះជាម្ចាស់បាននឹកចាំពីនាងរ៉ាជែល ហើយបានស្តាប់តាមនាង។ ព្រះអង្គបានធ្វើឲ្យនាងមានផ្ទៃពោះ។[23]នាងមានកូន ហើយបង្កើតបានកូនប្រុសមួយ។ នាងនិយាយថា៖ «ព្រះជាម្ចាស់បានដកភាពអាម៉ាសចេញរបស់ខ្ញុំចេញ»។[24]នាងដាក់ឈ្មោះកូនប្រុសនោះថា យ៉ូសែប ដោយនិយាយថា៖ «ព្រះអម្ចាស់បានបន្ថែមកូនប្រុសមួយទៀតដល់ខ្ញុំ»។
[25]បន្ទាប់ពីនាងរ៉ាជែលបង្កើតយ៉ូសែបហើយ លោកយ៉ាកុបបាននិយាយទៅកាន់លោកឡាបាន់ថា៖ «សូមឲ្យខ្ញុំបានចេញទៅ ដើម្បីខ្ញុំអាចចេញទៅផ្ទះរបស់ខ្ញុំ និងប្រទេសរបស់ខ្ញុំវិញ។[26]សូមប្រគល់ភរិយា និងកូនៗ ព្រោះខ្ញុំបានបម្រើលោកឪពុក ហើយសូមអនុញ្ញាតឲ្យខ្ញុំទៅ
ដើម្បីលោកឪពុកដឹងពីកិច្ចការដែលខ្ញុំបានធ្វើជូនលោកឪពុកហើយ»។
[27]លោកឡាបាន់តបទៅគាត់ថា៖ «ប្រសិនបើកូនយោគយល់ដល់ពុក ឪពុកបានដឹងដោយសារការទស្សន៍ទាយថាព្រោះតែកូន ព្រះអម្ចាស់បានប្រទានពរពុក»។[28]ដូច្នេះ គាត់បាននិយាយថា៖ «កូនចង់បានថ្លៃឈ្នួលប៉ុន្មាន ពុកនឹងប្រគល់ឲ្យ»។
[29]លោកយ៉ាកុបនិយាយទៅគាត់ថា៖ «លោកឪពុកជ្រាបពីការដែលកូនបានបម្រើឲ្យឪពុក និងពីហ្វូងសត្វរបស់លោកឪពុកបានកើនចំនួនច្រើនយ៉ាងណានោះ។[30]ដ្បិត មុនពេលខ្ញុំមក លោកឪពុកមានតែបន្តិចទេ ហើយឥឡូវ វាចម្រើនច្រើនឡើងជាបរិបូរ។ ព្រះអម្ចាស់បានប្រទានពរដល់លោកឪពុក នៅគ្រប់ពេលដែលខ្ញុំធ្វើការ។ ឥឡូវនេះ តើពេលណាទើបខ្ញុំអាចផ្គត់ផ្គង់គ្រួសាររបស់ខ្ញុំម្តង?»
[31]ដូច្នេះ លោកឡាបាន់និយាយថា៖ «តើកូនត្រូវការថ្លៃឈ្នួលប៉ុន្មាន?» លោកយ៉ាកុបឆ្លើយថា៖ «លោកឪពុក មិនចាំបាច់ឲ្យថ្លៃឈ្នួលកូនអ្វីទេ។ ប្រសិនបើលោកឪពុកធ្វើការមួយនេះជាមួយខ្ញុំ ខ្ញុំនឹងមើលថែទាំហ្វូងសត្វរបស់លោកឪពុកតទៅមុខទៀត។[32]សូមឲ្យខ្ញុំបានដើរកាត់ហ្វូងសត្វនៅថ្ងៃនេះ ដើម្បីញែកសត្វចៀមពព្លាក់ពពាល និងសត្វខ្មៅទាំងអស់ក្នុងកូនចៀមទាំងអស់ ព្រមទាំងសត្វដែលពពាល ពព្លាក់ក្នុងហ្វូងពពែផង។ ទាំងនឹងទុកជាថ្លៃឈ្នួលសម្រាប់ខ្ញុំ។
[33]ភាពស្មោះត្រង់របស់ខ្ញុំនឹងធ្វើបន្ទាល់ពីខ្ញុំនៅពេលក្រោយ នៅពេលលោកឪពុកទៅពិនិត្យពីថ្លៃឈ្នួលរបស់ខ្ញុំ។ ចៀមណាដែលមិនពពាល ពព្លាក់ក្នុងហ្វូងពពែ ហើយដែលមិនខ្មៅក្នុងហ្វូងចៀម នោះចាត់ទុកថាខ្ញុំបានលួចហើយ»។[34]លោកឡាបាន់និយាយថា៖ «យល់ព្រម។ សូមធ្វើតាមសម្តីរបស់កូនចុះ»។
[35]នៅថ្ងៃនោះ លោកឡាបាន់បានយកពពែឈ្មោលដែលឆ្នូតៗ ពពាល និងពពែញីដែលពព្លាក់ និងពពាល គ្រប់ទាំងសត្វដែលមានសម្បុរសដុំៗ និងអស់ទាំងសត្វខ្មៅក្នុងហ្វូងចៀមទាំងអស់ ប្រគល់ទៅឲ្យកូនៗរបស់គាត់មើលថែ។[36]លោកឡាបាន់បានធ្វើដំណើរអស់រយៈពេលបីថ្ងៃពីកន្លែងគាត់ទៅលោកយ៉ាកុប។ ដូច្នេះ លោកយ៉ាកុបបានឃ្វាលហ្វូងសត្វដែលនៅសល់ទាំងអស់របស់លោកឡាបាន់។
[37]លោកយ៉ាកុបបានកាត់យកមែករួស និងមែកចំបក់ ព្រមទាំងក្រចៅស្រស់ៗ និងមកបកសំបកជាកង់ៗ ឲ្យឃើញសាច់សៗ។[38]បន្ទាប់មក គាត់យកមែកដែលមានឆ្នូតៗនោះ ទៅដាក់នៅក្នុងចង្ហុរ និងស្នូកជាកន្លែងដែលសត្វតែងមកផឹកទឹក ដើម្បីឲ្យសត្វទាំងនោះឃើញ ដ្បិត វាតែងតែពាក់គ្នានៅពេលផឹកទឹក។
[39]ហ្វូងសត្វដែលពាក់គ្នានៅមុខមែកឈើ ហើយហ្វូងសត្វនឹងបង្កើតកូនមានសម្បុរឆ្នូតៗ ពពាល និងពព្លាក់។ លោកយ៉ាកុបបានញែកកូនចៀមទាំងនោះ ប៉ុន្តែ តម្រង់ឈ្មោលទាំងអស់បែរមុខទៅឯពួកចៀមឆ្នូត និងចៀមខ្មៅទាំងអស់ក្នុងហ្វូងសត្វរបស់ឡាបាន់។[40]បន្ទាប់មកគាត់ញែកហ្វូងសត្វរបស់គាត់ឲ្យនៅដោយឡែក ហើយមិនបានដាក់ពួកគេឲ្យនៅជាមួយហ្វូងសត្វរបស់លោកឡាបាន់ឡើយ។
[41]នៅពេលណាចៀមណាខ្លាំងជាងនៅក្នុងហ្វូងដោយពាក់គ្នា ដូច្នេះ លោកយ៉ាកុបបានដាក់មែកឈើទាំងនោះនៅក្នុងប្រឡាយ មុនចំពោះភ្នែករបស់ហ្វូងសត្វនោះ ដើម្បីពួកវាអាចពាក់គ្នានៅចំពោះមុខមែកឈើទាំងនោះ។[42]ប៉ុន្តែ នៅពេលសត្វណាខ្សោយចូលមកនៅក្នុងហ្វូងសត្វ គាត់មិនបានដាក់មែកឈើនៅចំពោះមុខពួកវាឡើយ។ ដូច្នេះ សត្វណាដែលខ្សោយជារបស់លោកឡាបាន់ ហើយសត្វណាដែលខ្លាំងជារបស់លោកយ៉ាកុប។
[43]លោកយ៉ាកុបបានក្លាយជាអ្នកមានយ៉ាងខ្លាំង។ គាត់មានហ្វូងសត្វយ៉ាងធំ មានអ្នកបម្រើស្រី និងអ្នកបម្រើប្រុស ហើយនិងសត្វអូដ្ឋ និងសត្វលាជាច្រើនផង។

Genesis 30:1
នៅពេលនាងរ៉ាជែលឃើញថា មិនបានបង្កើតកូនឲ្យលោកយ៉ាកុបសោះ
«នៅពេលរ៉ាជែលដឹងថានាងមិនអាចមានផ្ទៃពោះ»
ខ្ញុំនឹងស្លាប់
រ៉ាជែលកំពុងប្រើពាក្យសំដីបំផ្លើសដើម្បីបង្ហាញពីអារម្មណ៍មិនសប្បាយចិត្តដែលនាងមិនអាចមានកូន។ ការបកប្រែផ្សេងទៀត៖ «ខ្ញុំមានអារម្មណ៍ថាគ្មានតំលៃទាំងស្រុង»(មើលៈfigs-hyperbole)
បើមិនឲ្យខ្ញុំមានកូន
«ធ្វើអោយខ្ញុំមានផ្ទៃពោះ»
លោកយ៉ាកុបខឹងជាមួយនឹងនាងរ៉ាជែលជាខ្លាំង
កំហឹងរបស់យ៉ាកុបត្រូវបានគេនិយាយដូចជាភ្លើង។ ការបកប្រែផ្សេងទៀត៖ «យ៉ាកុបខឹងនឹងរ៉ាជែល»
តើបងព្រះជាម្ចាស់មែនទេ ដែលបង្ខាំងអូនមិនឲ្យមានកូន?
នេះគឺជាសំណួរដែលយ៉ាកុបប្រើដើម្បីស្តីបន្ទោសរ៉ាជែល។ វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត៖ «ខ្ញុំមិនមែនជាព្រះទេ! ខ្ញុំមិនមែនជាអ្នកដែលរារាំងអ្នកមិនឱ្យមានកូនទេ!»
Genesis 30:3
នាងនិយាយថា
«គឺនាងរ៉ាជែលនិយាយ»
មើល៏
«ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក។ » នេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលរ៉ាជែលនិងនិយាយបន្ទាប់។
នោះបីលហាជាអ្នកបំរើខ្ញុំ....ខ្ញុំនិងមានកូនដោសារនាង
នៅពេលនោះ,នេះគឺជាមធ្យោបាយដែលអាចទទួលយកបានសម្រាប់ស្ត្រីដែលគ្មានកូនដើម្បីឱ្យនាងមានកូនសម្រាប់ប្តីរបស់នាង។ អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានធ្វើឱ្យច្បាស់។
នាងបីលហា
នេះគឺជាឈ្មោះអ្នកបំរើស្រីរបស់រ៉ាជែល។ដែលបានបកប្រែនៅក្នុង២៩:២៨
នៅលើភ្លៅខ្ញុំ
នេះជាអាចនិយាយថាកូនដែលបីលហាបង្កើតបាននឹងត្រូវជាកម្មសិទ្ធិរបស់រ៉ាជែល។ ការបកប្រែផ្សេងទៀត៖ «សម្រាប់ខ្ញុំ»
ខ្ញុំនិងមានកូនដោយសារនាង
«ហើយតាមរបៀបនេះនាងនឹងធ្វើអោយខ្ញុំមានកូន»
Genesis 30:5
នេះគឺជាឈ្មើរបស់អ្នកបំរើស្រីរបស់រ៉ាជែល។បានបកប្រែនៅក្នុង២៩:២៨។
បានបង្កើតប្រុសមួយអោយយ៉ាកុប
«បានសំរាលកូនប្រុសមួយអោយយ៉ាកុប»
នាងបានដាក់ឈ្មោះអោយ
«នាងរ៉ាជែលជាអ្នកដាក់ឈ្មោះអោយកូនប្រុសនោះ»
ដាក់ឈ្មោះថាដាន់
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា «ឈ្មោះដាន់មានន័យថា"គាត់បានវិនិច្ឆ័យ»។ (សូមមើលtranslate-names)
Genesis 30:7
នាងបីលហា.....មានផ្ទៃពោះម្តងទៀត
«នាងបីលហា....ក៏មានទំងន់ម្តងទៀត»
បានបង្កើតកូនប្រុសទី២អោយលោកយ៉ាកុប
«នាងបានសំរាលកូនប្រុសទី២អោយលោកយ៉ាកុប»
ខ្ញុំខំប្រឹងតទល់យ៉ាងខ្លាំងជាមួយនឹងបងស្រីខ្ញុំ
ឃ្លាថា«ចំបាប់ដែលខ្ញុំបានចំបាប់» គឺជាពាក្យដែលប្រើសម្រាប់ការសង្កត់ធ្ងន់។ វាក៏ជាពាក្យប្រៀបធៀបមួយដែលនិយាយពីការប៉ុនប៉ងរបស់រ៉ាជែលដើម្បីមានកូនដូចបងស្រីរបស់នាងដែរ ការបកប្រែផ្សេងទៀត៖ «ខ្ញុំមានការតស៊ូយ៉ាងខ្លាំងដើម្បីមានកូនដូចបងស្រីខ្ញុំឈ្មោះលេអា»
ដើម្បីយកឈ្នះ
«ហើយខ្ញុំបានឈ្នះ» ឬ «ខ្ញុំបានទទួលជោគជ័យ»
ដាក់ឈ្មោះកូនប្រុសនោះថា ណែបថាលី
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា ឈ្មោះណែបថាលីមានន័យថា« ការតស៊ូរបស់ខ្ញុំ»
Genesis 30:9

generated on Wed Sep 10 16:16:32 2025

នៅពេលនាងលេអាឃើញថា
«នៅពេលដែលនាងលេអាដឹងថា»
នាងបានយកនាងស៊ីលផា ជាអ្នកបម្រើស្រីរបស់នាង ហើយប្រគល់នាងឲ្យលោកយ៉ាកុប
«នាងអោយស៊ីលផាជាអ្នកបំរើរបស់នាងអោយទៅធ្វើជាប្រពន្ធរបស់យ៉ាកុប»
ស៊ីលផា
នេះគឺជាឈ្មោះអ្នកបំរើស្រីរបស់លេអា។មើលក្នុការបកប្រែ២៩:២៣។
បានបង្កើតកូនប្រុសមួួយអោយយ៉ាកុប
«នាងសំរាលបានកូនប្រុសមួយអោយលោកយ៉ាកុប
មានសំណាងហើយ!
«ពិតជាសំណាងណាស់!» ឬ«អ្វីដែលសំណាងល្អ!»
ដាក់ឈ្មោះកូនប្រុសនោះថា កាឌ់
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា៖ ឈ្មោះកាឌ់មានន័យថា« សំណាង។»
Genesis 30:12
នាងស៊ីលផា
នេះគឺជាឈ្មោះអ្នកបម្រើស្រីរបស់លេអា។មើលក្នុការបកប្រែ២៩:២៣។
(សូមមើលtranslate-names)
បានបង្កើតកូនទីពីរឲ្យលោកយ៉ាកុប
«បង្កើតបានកូនប្រុសទី ២ សំរាប់លោកយ៉ាកុប»
ខ្ញុំរីករាយហើយ!
«ខ្ញុំពិតជាមានពរណាស់!» ឬ «ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់!»
ដ្បិតស្ត្រីទាំងឡាយ
«ស្ត្រី» ឬ «ស្ត្រីវ័យក្មេង»
ដាក់ឈ្មោះកូនប្រុសនោះថា អេស៊ើរ
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា៖ ឈ្មោះអេស៊ើរមានន័យថា« រីករាយ»
Genesis 30:14
លោករូបេនបានចេញទៅ
«លោករូបេនបានចេញទៅក្រៅ»
នៅក្នុងរដូវច្រូតស្រូវ
នៅទីនេះឃ្លា «នៅជំនាន់»
គឺជាលេខពិសេសដែលសំដៅទៅលើរដូវកាលឬពេលវេលានៃឆ្នាំ។
ការបកប្រែផ្សេងទៀត៖ «នៅពេលនៃឆ្នាំប្រមូលផលស្រូវសាលី» ឬ «កំឡុងពេលប្រមូលផលស្រូវសាលី»
ផ្លែស្នេហ៍
នេះគឺជាផ្លែឈើដែលត្រូវបានគេនិយាយថាដើម្បីបង្កើនភាពមានកូននិងបំណងប្រាថ្នាចង់
ការបកប្រែផ្សេងទៀត៖ «ផ្លែឈើស្រឡាញ់»
តើវាជារឿងតូចតាចសម្រាប់ឯងមែនទេ.....ប្តីរបស់យើងទៅ?
«តើអ្នកមិនខ្វល់ទេ ... ប្តីរបស់ខ្ញុំ?»
នេះគឺជាសំនួរដែលត្រូវបានប្រើដើម្បីស្តីបន្ទោសរ៉ាជែល។
សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត៖ «វាមិនល្អគ្រប់គ្រាន់ទេ ... ប្តីរបស់ខ្ញុំ»
ឥឡូវឯងចង់មកយក.....មែនទេ?
នេះគឺជាសំនួរដែលប្រើដើម្បីស្តីបន្ទោសរ៉ាជែល។
សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត៖ «ឥឡូវនេះអ្នកចង់បាន ... ដែរ!»
គាត់ទៅគេងជាមួយ
«បន្ទាប់មកយ៉ាកុបនឹងដេក» ឬ «បន្ទាប់មកខ្ញុំនឹងឱ្យយ៉ាកុបដេក»
Genesis 30:16
ផ្លែស្នេហ៍កូនប្រុសរបស់អូន
«សម្រាប់តម្លៃនៃផ្លែស្នេហ៍កូនប្រុសរបស់ខ្ញុំ។» សូមមើលបានបកប្រែពាក្យ«បង្ខំ» ក្នុង ៣០:១៤
នាងក៏មានផ្ទៃពោះ
«បានចាប់ផ្តើមមានផ្ទៃពោះ»
ហើយបានបង្កើតកូនប្រុសទីប្រាំឲ្យលោកយ៉ាកុប
«ហើយបង្កើតបានកូនប្រុសទីប្រាំសំរាប់លោកយ៉ាកុប»
ព្រះជាម្ចាស់ប្រទានរង្វាន់ដល់ខ្ញុំ
ព្រះបាន ឲ្យ រង្វាន់ដល់លេអាគឺដូចជាគាត់ជាចៅកែបើកប្រាក់ឈ្នួល ឲ្យ អ្នកដែលធ្វើការជំនួសគាត់។ ការបកប្រែផ្សេងទៀត៖ «
ព្រះបានអោយពេលវេលារបស់ខ្ញុំ» ឬ« ព្រះជាម្ចាស់បានប្រទានរង្វាន់ដល់ខ្ញុំ»
នាងបានដាក់ឈ្មោះកូនប្រុសនោះថា អ៊ីសាខា
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា ៖ឈ្មោះអ៊ីសាខាថាមានន័យថា «មានរង្វាន់។»
Genesis 30:19
នាងលេអាមានផ្ទៃពោះម្តងទៀត
«លេអាមានផ្ទៃពោះម្តងទៀត»
ហើយបង្កើតបានកូនប្រុសទីប្រាំមួយ ឲ្យលោកយ៉ាកុប
«ហើយបង្កើតបានកូនប្រុសទី ៦ សំរាប់លោកយ៉ាកុប»
នាងដាក់ឈ្មោះកូនប្រុសនោះថា សាប់យូល៉ូន
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា“
ឈ្មោះសាប់យូល៉ូនមានន័យថា« កិត្តិយស»
ហើយនាងបានដាក់ឈ្មោះកូនស្រីនោះថា ឌីណា
នេះគឺជាឈ្មោះកូនស្រីរបស់នាងលេអា
Genesis 30:22
ព្រះជាម្ចាស់បាននឹកចាំពីនាងរ៉ាជែល ហើយបានស្តាប់តាមនាង
ឃ្លាថា« នឹកចាំ» មានន័យថាត្រូវចាំ។ នេះមិនមានន័យថាព្រះភ្លេចរ៉ាជែលទេ។ នេះមានន័យថាទ្រង់ពិចារណាសំណើរបស់នាង។ ការបកប្រែផ្សេងទៀត៖ «ព្រះជាម្ចាស់បានពិចារណារ៉ាជែល ហើយផ្តល់ឱ្យនាងនូវអ្វីដែលនាងចង់បាន»
ព្រះជាម្ចាស់បានដកភាពអាម៉ាសចេញរបស់ខ្ញុំចេញ
ព្រះបណ្តាលឱ្យរ៉ាជែលលែងមានអារម្មណ៍ខ្មាស់អៀនត្រូវបានគេនិយាយដូចជា «ខ្មាស់អៀន» គឺជាវត្ថុដែលមនុស្សអាចដកហូតពីអ្នកដទៃ។ នាមអរូបី «ខ្មាស់អៀន» អាចត្រូវបានគេនិយាយថា «ខ្មាស់អៀន។»ការបកប្រែផ្សេងទៀត៖ «ព្រះជាម្ចាស់បានធ្វើអោយខ្ញុំលែងខ្មាសអៀន»
នាងដាក់ឈ្មោះកូនប្រុសនោះថា យ៉ូសែប
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា៖ «ឈ្មោះយ៉ូសែបមានន័យថា ទ្រង់នឹងបន្ថែម› »
ព្រះអម្ចាស់បានបន្ថែមកូនប្រុសមួយទៀតដល់ខ្ញុំ
កូនប្រុសដំបូងរបស់រ៉ាជែលគឺតាមរយៈអ្នកបម្រើស្រីឈ្មោះប៊ីលហា។
Genesis 30:25
បន្ទាប់ពីនាងរ៉ាជែលបង្កើតយ៉ូសែបហើយ
«បន្ទាប់ពីរ៉ាជែលសំរាលបានយ៉ូសែប»
សូមឲ្យខ្ញុំបានចេញទៅ
«ដូច្នេះសុំមអោយខ្ញុំទៅ»
លោកឪពុកដឹងពីកិច្ចការដែលខ្ញុំបានធ្វើជូនលោកឪពុកហើយ
យ៉ាកុបបានរៀបការជាមួយនឹងកូនស្រីទាំងពីរនាក់ និងបានមានកូនជាច្រើនជាមួយនឹងប្រពន្ធទាំងពីរនាក់ និងបានធ្វើការជាមួយនឹងសត្វរបស់ពួកគេ
Genesis 30:27
លោកឡាបាន់តបទៅគាត់ថា
«លោកឡាបាន់បាននិយាយទៅលោកយ៉ាកុប»
ប្រសិនបើកូនយោគយល់ដល់ពុក
ឃ្លា«នៅក្នុងភ្នែករបស់អ្នក»
គឺជាពាក្យប្រៀបធៀបដែលតំណាងឱ្យគំនិតឬយោបល់របស់យ៉ាកុប។
ការបកប្រែផ្សេងទៀត៖ «ប្រសិនបើកូនពេញចិត្តនឹងពុក»
ឬ«ប្រសិនបើកូនពេញចិត្តនឹងពុក» (UDB) (សូមមើលfigs-metonymy)
យោគយល់
នេះគឺជាពាក្យដែលមានន័យថាមាននរណាម្នាក់ត្រូវបានយល់ព្រមដោយអ្នកដទៃ។
ចាំ,ពីព្រោះ
«សូមស្នាក់នៅ ពីព្រោះ»
ឪពុកបានដឹងដោយសារការទស្សន៍ទាយ
«ពិកបានរកឃើញដោយការអនុវត្តខាងវិញ្ញាណនិងវេទមន្តផ្ទាល់ខ្លួនរបស់ពុក»
សំរាប់ប្រយោជន៏កូន
«ពីព្រោះកូន»
កូនចង់បានថ្លៃឈ្នួលប៉ុន្មាន
នេះអាចធ្វើឱ្យកាន់តែច្បាស់។
ការបកប្រែផ្សេងទៀត៖«ប្រាប់ពុកថាពុកត្រូវចំណាយប៉ុន្មានដើម្បីរក្សាកូននៅទីនេះ» ។
Genesis 30:29
លោកយ៉ាកុបនិយាយទៅគាត់ថា
«លោកយ៉ាកុបនិយាយទៅកាន់លោកឡាបាន់»

generated on Wed Sep 10 16:16:32 2025

និងពីហ្វូងសត្វរបស់លោកឪពុកបានកើនចំនួនច្រើនយ៉ាងណានោះ
«តើសត្វចិញ្ចឹមរបស់ពុកធ្វើបានល្អប៉ុណ្ណាតាំងពីខ្ញុំចាប់ផ្តើមមើលថែទាំពួកវា»
មុនពេលខ្ញុំមក លោកឪពុកមានតែបន្តិចទេ
«ហ្វូងរបស់លោកពុកតិចទេ មុនពេលដែលខ្ញុំធ្វើការឱ្យពុក»
ហើយឥឡូវ វាចម្រើនច្រើនឡើយជាបរិបូរ
មើលរបៀបដែលអ្នកបកប្រែនេះគឺ ៤១:៤៤ ។
ជាកូនរបស់លោកប៉ូទីផេរ៉ា
«ប៉ូទីផេរា»គឺជាឪពុករបស់អាសណាត់។ សូមមើលបានបកប្រែវានៅក្នុង ៤១:៤៤ ។
(សូមមើល
បូជាចារ្យនៅក្រុងអូន
អូន គឺជាទីក្រុងមួយដែលត្រូវបានគេហៅថា ហ៊ីលីអូប៉ូលីស ដែលជា«
ទីក្រុងនៃព្រះអាទិត្យ» និង ជាមជ្ឈមណ្ឌលនៃការថ្វាយបង្គំព្រះព្រះអាទិត្យរ៉ា ។
សូមមើលបានបកប្រែវានៅក្នុង ៤១:៤៤ ។
ដែលនឹងមក
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា
«ឈ្មោះ»ម៉ាណាសេមានន័យថា «បណ្តាលឱ្យភ្លេច»
ញាតិសន្តានទាំងប៉ុន្មានរបស់ឪពុក
នេះសំដៅទៅលើយ៉ាកុបឪពុករបស់យ៉ូសែបនិងក្រុមគ្រួសាររបស់គាត់។
អេប្រាអ៊ីម
អ្នកបកប្រែក៏អាចបន្ថែមលេខយោងដែលនិយាយថា«
ឈ្មោះអេប្រាអ៊ីម»មានន័យថា« បង្កើតផល» ឬ« មានកូន»
ប្រទានឲ្យខ្ញុំមានកូនចៅ
ត្រង់នេះ" មានផ្លែផ្កា" មានន័យថារីកចំរើនរឺមានកូន។
ក្នុងទឹកដីដែលខ្ញុំបានរងទុក្ខវេទនានេះ
នាមអរូបី «ទុក្ខវេទនា» អាចត្រូវបានគេនិយាយថា «ខ្ញុំបានរងទុក្ខ។»
ការបកប្រែផ្សេងទៀត៖ « នៅក្នុងទឹកដីនេះដែលខ្ញុំបានរងទុក្ខ»
Genesis 41:53
ក្នុងទឹកដី
នៅគ្រប់ប្រទេសដែលនៅជុំវិញប្រទេសអេស៊ីបរួមទាំងទឹកដីកាណានផង។
ប៉ុន្តែ មានស្បៀងនៅក្នុងទឹកដីអេស៊ីបទាំងមូល
បញ្ជាក់ថាមានស្បៀងអាហារដោយសារតែយ៉ូសែបបានបញ្ជាប្រជាជនរបស់គាត់ឱ្យទុកស្បៀងអាហារក្នុងអំ
Genesis 41:55
នៅពេលគ្រោះទុរ្ភិក្សនៅក្នុងទឹកដីអេស៊ីប
នៅទីនេះ«ដី» តំណាងឱ្យប្រជាជន។ ការបកប្រែផ្សេងទៀត៖ «
នៅពេលប្រជាជនអេស៊ីបទាំងអស់កំពុងអត់ឃ្លាន» សូមមើល
គ្រោះទុរ្ភិក្សបានកើតឡើងនៅពាសពេញទឹកដីទាំងមូល
ពាក្យ« មុខ» សំដៅទៅលើផ្នែកដី។ ការបកប្រែផ្សេងទៀត៖ «
ទុរ្ភិក្សបានរាលដាលពាសពេញទឹកដី»
លោកយ៉ូសែបបានបើកឃ្លាំងទាំងអស់របស់លោក ហើយលក់ឲ្យជនជាតិអេស៊ីប
នៅទីនេះ «យ៉ូសែប» តំណាងឱ្យអ្នកបំរើរបស់យ៉ូសែប។ ការបកប្រែផ្សេងទៀត៖ «
យ៉ូសែបបានអោយអ្នកបម្រើរបស់គាត់បើកឃ្លាំងទាំងអស់ហើយលក់ស្រូវ ឲ្យ
ជនជាតិអេស៊ីប»
ពិភពលោកទាំងមូលបានចូលមកអេស៊ីប
នៅទីនេះ «ផែនដី»តំណាងឱ្យប្រគ្រប់តំបន់។ ការបកប្រែផ្សេងទៀត៖ «
មនុស្សទាំងអស់ធ្វើដំណើរទៅអេស៊ីបនិងអ្នកអ្នកនៅជុំវិញតំបន់នោះដែរ»
នៅលើផែនដីទាំងមូល
«ពាសពេញផ្ទៃដី។
»ដៃគូពាណិជ្ជកម្មនិងប្រទេសផ្សេងៗគ្នាទាំងអស់ដែលជាផ្នែកនៃផ្លូវពាណិជ្ជកម្មអេស៊ីបដែលរងផលប៉ះពាព

---

42 [1]លោកយ៉ាកុបបានដឹងថា មានស្រូវនៅក្នុងអេស៊ីប។ គាត់បានប្រាប់ទៅកូនប្រុសៗរបស់គាត់ថា៖
«ហេតុអ្វីបានជាកូនៗមើលមុខគ្នាទៅវិញទៅមកដូច្នេះ?»[2]គាត់ប្រាប់ថា៖ «មើល៍ យើងបានឮថាមានស្រូវនៅអេស៊ីប។ ចូរចុះទៅអេស៊ីប ហើយទិញស្រូវពីនោះមក
ដើម្បីកុំឲ្យយើងស្លាប់ តែដើម្បីឲ្យយើងបានរស់វិញ»។[3]បងប្រុសទាំងដប់របស់លោកយ៉ូសែបបានចុះទៅទិញស្រូវពីអេស៊ីប។[4]ប៉ុន្តែ បេនយ៉ាមីន
ជាប្អូនប្រុសរបស់លោកយ៉ូសែប លោកយ៉ាកុបមិនឲ្យទៅជាមួយបងៗរបស់គាត់ទេ ព្រោះគាត់ខ្លាចថា មានគ្រោះថ្នាក់ដល់គាត់។
[5]កូនប្រុសៗរបស់លោកអ៊ីស្រាអែលបានមកទិញស្រូវជាមួយអ្នកផ្សេងៗទៀត ដ្បិត មានគ្រោះទុរ្ភិក្សនៅក្នុងទឹកដីកាណានដែរ។[6]លោកយ៉ូសែបជាអ្នកគ្រប់គ្រងនៅលើទឹកដី។
គាត់ជាម្ចាស់ដែលបានលក់ដល់មនុស្សគ្រប់គ្នានៅក្នុងប្រទេស។ បងៗរបស់លោកយ៉ូសែបបានមក ហើយលុតជង្គង់ចុះចំពោះគាត់ ហើយឱនមុខរបស់ពួកគេទល់នឹងដី។
[7]លោកយ៉ូសែបបានឃើញបងៗរបស់គាត់ ហើយស្គាល់ពួកគេ ប៉ុន្តែ គាត់ធ្វើជាមិនស្គាល់ពួកគេ ហើយនិយាយគំរោះគំរើយជាមួយពួកគេថា៖
«តើអ្នកទាំងអស់គ្នាមកពីណា?» ពួកគេឆ្លើយថា៖ «មកពីទឹកដីកាណាន ដើម្បីទិញអាហារ»។[8]លោកយ៉ូសែបស្គាល់បងៗ ប៉ុន្តែ ពួកគេមិនស្គាល់លោកទេ។
[9]នោះ លោកយ៉ូសែបបានចាំពីសុបិនដែលគាត់បានសុបិនពីពួកគេ ហើយគាត់និយាយទៅពួកគេថា៖ «តើអស់លោកជាអ្នកស៊ើបការណ៍មែនទេ?»។[10]ពួកគេឆ្លើយថា៖
«អត់ទេ លោកម្ចាស់។ យើងខ្ញុំមកទីនេះ ដើម្បីទិញស្បៀងតែប៉ុណ្ណោះ។ យើងមានឪពុកតែមួយ។[11]យើងជាមនុស្សស្មោះត្រង់។ យើងខ្ញុំមិនមែនជាអ្នកស៊ើបការណ៍ទេ»។
[12]គាត់និយាយទៅពួកគេថា៖ «អត់ទេ អ្នករាល់គ្នាមកដើម្បីមកស៊ើបការណ៍ទឹកដីនេះមែន!»។[13]ពួកគេនិយាយថា៖ «យើងខ្ញុំមានបងប្អូនដប់ពីរនាក់
ជាកូនរបស់បុរសម្នាក់ដែលរស់នៅទឹកដីកាណាន។ មើល ប្អូនប្រុសពៅរបស់យើងនៅជាមួយឪពុករបស់យើង ហើយម្នាក់ទៀតបានស្លាប់បាត់ហើយ»។
[14]លោកយ៉ូសែបនិយាយទៅពួកគេថា៖ «នោះជាអ្វីដែលអ្នករាល់គ្នានិយាយ អ្នករាល់គ្នាគឺជាអ្នកស៊ើបការណ៍។[15]ដោយហេតុនេះ ខ្ញុំនឹងល្បងលអ្នករាល់គ្នា។ ដរាបណា
ផារ៉ោននៅមានព្រះជន្ម នោះអ្នករាល់គ្នានឹងមិនអាចចេញពីទីនេះបានឡើយ។[16]ចូរចាត់នរណាម្នាក់ឲ្យទៅហើយនាំប្អូនពៅរបស់អ្នករាល់ឯងមកដល់ទីនេះសិន។
អ្នកនឹងត្រូវជាប់គុក រហូតទាល់តែបានល្បងលមើលដឹងថា ពាក្យរបស់អ្នករាល់គ្នាពិតមែន»។[17]គាត់បានឃុំខ្លួនអ្នកទាំងអស់នោះអស់រយៈពេលបីថ្ងៃ។
[18]លោកយ៉ូសែបនិយាយទៅពួកគេនៅថ្ងៃទីបីថា៖ «ចូរធ្វើដូច្នេះ ហើយអ្នករាល់គ្នានឹងបានរស់ ដ្បិត ខ្ញុំក៏ជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់ដែរ។[19]ប្រសិនបើ
អ្នករាល់គ្នាជាសមនុស្សស្មោះត្រង់មែន ចូរឲ្យបងប្អូនរបស់អ្នករាល់គ្នាណាម្នាក់នៅជាប់ក្នុងគុកនេះហើយ ប៉ុន្តែ អ្នករាល់គ្នាអាចទៅ

generated on Wed Sep 10 16:16:32 2025

នាំយកស្រូវទៅផ្ទះរបស់អ្នករាល់គ្នាព្រោះមានភាពអត់ឃ្លាននៅទីនោះ។[20]ហើយនាំប្អូនប្រុសពៅរបស់អ្នកមកឲ្យខ្ញុំ ដើម្បីបញ្ជាក់ថាអ្នករាល់គ្នាស្មោះត្រង់
ហើយអ្នករាល់គ្នាមិនត្រូវស្លាប់ឡើយ»។ ដូច្នេះ ពួកគេក៏ធ្វើតាម។
[21]ពួកគេនិយាយគ្នានឹងគ្នាថា៖ «យើងពិតជាមានកំហុសមែន ទាក់ទងនឹងប្អូនប្រុសរបស់យើង ដែលយើងឃើញពីទុក្ខកង្វល់នៃព្រលឹងរបស់គាត់
នៅពេលយើងគាត់អង្វរយើង ហើយយើងមិនស្តាប់គាត់ទេ។ ដូច្នេះហើយ បានជាទុក្ខកង្វល់របស់គាត់បានធ្លាក់មកលើយើង»។[22]លោករូបេនឆ្លើយទៅពួកគេថា៖
«តើបងមិនបានប្រាប់អ្នកទាំងអស់គ្នាទេឬអីថា កុំធ្វើបាបទាស់នឹងប្អូនប្រុសឡើយ ប៉ុន្តែ អ្នករាល់គ្នាមិនស្តាប់សោះ? ឥឡូវមើល
ឈាមរបស់វាបានទាមទារពីយើងវិញហើយ»។
[23]ពួកគេមិនបានដឹងថា លោកយ៉ូសែបយល់សម្តីពួកគេទេ ដើម្បីមានអ្នកបកប្រែឲ្យពួកគេ។[24]គាត់បានបែរមុខពីពួកគេ ហើយយំ។ គាត់បានត្រឡប់មកវិញ
ហើយនិយាយទៅកាន់ពួកគេ។ គាត់បានយកលោកស៊ីម្មានពីចំណោមពួកគេ ហើយចងគាត់នៅចំពោះមុខពួកគេ។[25]បន្ទាប់មក
លោកយ៉ូសែបបានបង្គាប់ដល់អ្នកបម្រើរបស់គាត់ឲ្យដាក់ស្រូវពេញបាវរបស់ពួកគេរៀងៗខ្លួន ហើយបានដាក់ប្រាក់ត្រឡប់ទៅថង់លុយរបស់ពួកគេគ្រប់គ្នាវិញ
ហើយផ្តត់ផ្គង់ដល់ដំណើររបស់ពួកគេដែរ។ គាត់បានធ្វើដូច្នេះជាមួយបងៗគាត់។
[26]បងៗបានលើកស្រូវរបស់ពួកគេដាក់លើសត្វលា ហើយបានចេញពីទីនោះទៅ។[27]ម្នាក់ក្នុងចំណោមពួកគេបានបើកបាវរបស់គាត់ដើម្បីឲ្យស្មៅលាស៊ីនៅពេលសម្រាក
គាត់បានឃើញលុយរបស់គាត់។ មើល៍ ឃើញលុយនៅក្នុងបាវរបស់គាត់។[28]គាត់ប្រាប់បងៗរបស់គាត់ថា៖ «គេដាក់លុយខ្ញុំមកវិញ។ មើលនែ៎ វានៅក្នុងបាវខ្ញុំឯនេះ»។
ពួកគេមានការភ័យខ្លាចជាខ្លាំង ហើយពួកគេរត់រកគ្នាទាំងញាប់ញ័រ ដោយនិយាយថា៖ «ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើដាក់យើងដូច្នេះ?»។
[29]ពួកគេបានទៅជួបលោកយ៉ាកុប ឪពុករបស់ពួកគេរស់នៅក្នុងទឹកដីកាណាន ហើយបានប្រាប់គាត់ នូវអ្វីៗដែលបានកើតឡើងជាមួយពួកគេ។ ពួកគេប្រាប់ថា៖
[30]«លោកដែលជាចៅហ្វាយរបស់ទឹកដីនោះ បាននិយាយសម្លុតយើង ហើយគិតថា យើងគឺជាអ្នកស៊ើបការណ៍នៅក្នុងទឹកដីរបស់គេ។[31]យើងប្រាប់គាត់ថា៖
«យើងជាមនុស្សស្មោះត្រង់។ យើងមិនមែនជាអ្នកស៊ើបការណ៍ទេ។[32]យើងមានបងប្អូនដប់ពីរនាក់ ជាកូនដែលចេញពីឪពុកតែមួយ។ ម្នាក់បានស្លាប់បាត់ហើយ
ហើយប្អូនប្រុសពៅនៅជាមួយឪពុករបស់យើង នៅក្នុងទឹកដីកាណានឯណោះ»។
[33]បុរសដែលជាម្ចាស់ទឹកដីនោះ និយាយមកយើងថា៖ «ទុកប្អូនប្រុសម្នាក់របស់អ្នករាល់គ្នានៅជាមួយយើងម្នាក់ បើធ្វើដូច្នេះ យើងដឹងថាអ្នកពិតជាមនុស្សស្មោះត្រង់មែន
ហើយយកស្រូវទៅដោយព្រោះគ្រោះអត់ឃ្លាននៅក្នុងផ្ទះរបស់អ្នក ហើយចាកចេញទៅ។[34]ចូរនាំប្អូនប្រុសពៅរបស់អ្នកមកឲ្យខ្ញុំ។ បន្ទាប់មក ខ្ញុំនឹងដឹងថា
អ្នករាល់គ្នាប្រាកដជាមិនមែនអ្នកស៊ើបការណ៍ទេ ហើយដឹងថាអ្នកគឺជាមនុស្សស្មោះត្រង់មែន។ បន្ទាប់មក យើងនឹងដោះលែងប្អូនរបស់អ្នករាល់គ្នា
ហើយអ្នករាល់គ្នាអាចប្រកបរបរនៅក្នុងទឹកដីនេះបាន»។
[35]នៅពេលពួកគេបានចាក់ស្រូវចេញពីបាវហើយ មើល៍ នៅក្នុងបាវរបស់ម្នាក់ៗមានប្រាក់នៅក្នុងបាវនោះ។ នៅពេលពួកគេ
និងឪពុករបស់ពួកគេបានឃើញបាវមានប្រាក់នោះ ពួកគេភ័យខ្លាចយ៉ាងខ្លាំង។[36]លោកយ៉ាកុប ឪពុករបស់ពួកគេបាននិយាយទៅពួកគេថា៖
«ឯងរាល់គ្នាបានធ្វើឲ្យឪពុកបាត់កូនអស់ហើយ។ ឯងរាល់គ្នាបានធ្វើឲ្យយ៉ូសែប និងស៊ីម្មានបានស្លាប់ ហើយឥឡូវនេះ
ឯងរាល់គ្នាចង់យកបេនយ៉ាមីនចេញពីយើងទៀតមែនទេ។ ការទាំងអស់នេះទាស់នឹងឪពុកហើយ»។
[37]លោករូបេនបាននិយាយទៅកាន់ឪពុករបស់គាត់ថា៖ «លោកឪពុកអាចសម្លាប់កូនប្រុសទាំងពីររបស់ខ្ញុំ ប្រសិនបើ ខ្ញុំមិននាំបេនយ៉ាមីនមកឲ្យលោកឪពុកវិញ។
សូមឲ្យវាមកក្នុងដៃរបស់ខ្ញុំចុះ ហើយខ្ញុំនឹងនាំវាត្រឡប់មករកឪពុកវិញ»។[38]លោកយ៉ាកុបនិយាយថា៖ «យើងមិនឲ្យកូនរបស់យើងទៅជាមួយឯងទេ។ ដ្បិត
បងប្រុសរបស់វាបានស្លាប់ហើយ នៅសល់តែវាទេ។ ប្រសិនបើ វាមានគ្រោះថ្នាក់អ្វីនៅតាមផ្លូវដែលទៅជាមួយឯង ដូច្នេះ
ឯងរាល់គ្នាមុខជានាំសក់ស្កូវរបស់ឪពុកជាមួយនឹងភាពសោកសៅទៅស្ថានឃុំព្រលឹងហើយ»។

Genesis 42:1

ឥឡូវលោកយ៉ាកុបបានដឹង

ពាក្យថា« ឥឡូវ» សម្គាល់ផ្នែកថ្មីនៃរឿង។

ហេតុអ្វីបានជាកូនៗមើលមុខគ្នាទៅវិញទៅមកដូច្នេះ?

យ៉ាកុបប្រើសំនួរមួយដើម្បីស្តីបន្ទោសកូនប្រុសរបស់គាត់ដែលមិនបានធ្វើអ្វីអំពីស្រូវអង្ករ។

ការបកប្រែផ្សេងទៀត៖ « កុំអង្គុយនៅទីនេះ!»

ចូរចុះទៅ.....ចេញទៅ

វាជារឿងធម្មតាទេដែលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីបដូចជាការដើរចុះ

ពីអេស៊ីប

នៅទីនេះ «អេស៊ីប» សំដៅទៅលើប្រជាជនដែលលក់ស្រូវ។ ការបកប្រែផ្សេងទៀត៖
« ពីអ្នកលក់ស្រូវនៅស្រុកអេស៊ីប»

បេនយ៉ាមីន ប្អូនប្រុសយ៉ូសែប យ៉ាកុបមិនបានបញ្ជូនទេ

បេនយ៉ាមីននិងយ៉ូសែបមានឪពុកនិងម្តាយដូចគ្នា។

យ៉ាកុបមិនចង់ប្រថុយបញ្ជូនកូនប្រុសចុងក្រោយរបស់វ៉ាដែលទេ។

Genesis 42:5

កូនប្រុសៗរបស់លោកអ៊ីស្រាអែលបានមកទិញស្រូវជាមួយអ្នកផ្សេងៗទៀត

ពាក្យ «បានមក» អាចត្រូវបានបកប្រែជា «បានទៅ។» ដូចគ្នានេះផងដែរពាក្យ
«ស្រូវ» និង «អេស៊ីប» ត្រូវបានគេយល់។ ការបកប្រែផ្សេងទៀត៖
«កូនចៅអ៊ីស្រាអែលបានទៅធ្វើទិញស្រូវរួមជាមួយប្រជាជនផ្សេងទៀតដែលបានទៅស្រុកអេស៊ីប»

ឥឡូវលោកយ៉ូសែប

«ឥឡូវនេះ» សម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាព័ត៌មានផ្ទៃខាងក្រោមអំពីយ៉ូសែប។

គ្រប់គ្រងនៅលើទឹកដី

នៅទីនេះ «ដី» សំដៅទៅលើប្រទេសអេស៊ីប។ការបកប្រែផ្សេងទៀត៖ «លើអេស៊ីប»

មនុស្សគ្រប់គ្នានៅក្នុងប្រទេស

នៅទីនេះ«ដី» រួមមានអេស៊ីបនិងប្រទេសជុំវិញផ្សេងទៀត។ការបកប្រែផ្សេងទៀត៖
« ប្រជាជនទាំងអស់នៃប្រជាជាតិទាំងអស់ដែលមកទិញស្រូវ»

បងៗរបស់លោកយ៉ូសែបបានមក

នៅទីនេះ «បានមក»អាចត្រូវបានបកប្រែជា«បានទៅ។»

លុតជង្គង់ចុះចំពោះគាត់ ហើយឱនមុខរបស់ពួកគេទល់នឹងដី

នេះជារបៀបបង្ហាញពីការគោរព។

Genesis 42:7

លោកយ៉ូសែបបានឃើញបងៗរបស់គាត់ ហើយស្គាល់ពួកគេ

ពេលយ៉ូសែបបានឃើញបងប្អូនរបស់គាត់ គាត់ក៏ស្គាល់ពួកគេ»

គាត់គំរោះគំរើយជាមួយពួកគេ

«គាត់បានធ្វើដូចជាគាត់មិនមែនជាបងប្អូនរបស់ពួកគេ»ឬ
«គាត់មិនបានអោយពួកគេដឹងថាគាត់ជាបងប្អូនរបស់ពួកគេ»

តើអ្នកទាំងអស់គ្នាមកពីណា?

នេះមិនមែនជាសំនួរចំលើយទេទោះបីជាយ៉ូសែបដឹងចម្លើយក៏ដោយ។
វាជាផ្នែកមួយនៃជម្រើសរបស់គាត់ដើម្បីរក្សាអត្តសញ្ញាណរបស់គាត់ពីបងប្អូនរបស់គាត់។

Genesis 42:9

អស់លោកជាអ្នកស៊ើបការណ៍

អ្នកស៊ើបការណ៍គឺជាមនុស្សដែលព្យាយាមយកព័ត៌មានអំពីប្រទេសមួយដោយសម្ងាត់ដើម្បីជួយប្រទេសម

អ្នកបានមកមើលផ្នែកដែលមិនមានសុវត្ថិភាពនៃទឹកដី

អត្ថន័យពេញលេញអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«អ្នកបានមករកកន្លែងដែលយើងមិនបានយាមដីរបស់យើង
ដើម្បីអ្នកអាចវាយប្រហារយើង»

ការមើលឃើញ

នេះគឺជាវិធីដើម្បីសំដៅទៅលើនរណាម្នាក់ដើម្បីផ្តល់កិត្តិយសដល់ពួកគេ។

យើងខ្ញុំមកទីនេះ

បងប្អូនបានចាត់ទុកខ្លួនឯងថាជា« អ្នកបម្រើរបស់អ្នក។
»នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
ការបកប្រែផ្សេងទៀត៖ «យើង ដែលជាអ្នកបំរើរបស់លោកន» ឬ «យើងមាន»

Genesis 42:12

គាត់និយាយទៅពួកគេ

«យ៉ូសែបនិយាយទៅបងៗប្រុសរបស់គាត់»

អត់ទេ អ្នករាល់គ្នាមកដើម្បីមកស៊ើបការណ៍ទឹកដីនេះមែន

generated on Wed Sep 10 16:16:32 2025

អត្ថន័យពេញលេញអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«ទេអ្នកបានមករកកន្លែងដែលយើងមិនយាមដីរបស់យើងដើម្បីអ្នកអាចវាយប្រហារយើង»
បងប្អូនដប់ពីរនាក់
«បងប្អូន១២នាក់»
មើល ប្អូនប្រុសពៅ
«ស្តាប់យើងខ្ញុំ,ប្អូនប្រុសពៅ។» ពាក្យ«មើល»
ត្រូវបានប្រើដើម្បីបញ្ជាក់ពីអ្វីដែលពួកគេនិយាយបន្ទាប់។
ប្អូនប្រុសពៅរបស់យើងនៅជាមួយឪពុករបស់យើង
«ឥឡូវនេះប្អូនពៅរបស់យើងបាននៅជាមួយឪពុករបស់យើង»
Genesis 42:14
នោះជាអ្វីដែលអ្នករាល់គ្នានិយាយ អ្នករាល់គ្នាគឺជាអ្នកស៊ើបការណ៍
«ដូចខ្ញុំបាននិយាយរួចហើយ,អ្នកគឺជាអ្នកស៊ើបការណ៍។»
សូមមើលពីរបៀបដែលអ្នកបកប្រែ« អ្នកស៊ើបការណ៍»នៅក្នុង ៤២: ៩ ។
ដោយហេតុនេះ ខ្ញុំនឹងល្បងលអ្នក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«នេះជារបៀបដែលខ្ញុំនឹងសាកល្បងអ្នក»
ដរាបណាផារ៉ោននៅមានព្រះជន្ម
ឃ្លានេះបញ្ជាក់ពីសម្បថដ៏ឧឡារិក។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំស្បថដោយព្រះជន្មស្តេចផារ៉ោន» (សូមមើល [[rc://*/tw/bible/other/oath]])
ចូរចាត់នរណាម្នាក់ឲ្យទៅហើយនាំប្អូនពៅរបស់អ្នក
«ជ្រើសរើសម្នាក់ក្នុងចំណោមអ្នកដើម្បីទៅទទួលយកប្អូនរបស់អ្នក»
អ្នកនឹងត្រូវជាប់គុក
«អ្នកដែលនៅសល់នឹងស្ថិតនៅក្នុងពន្ធនាគារសិន»
រហូតទាល់តែបានល្បងលមើលដឹងថា ពាក្យរបស់អ្នករាល់គ្នាពិតមែន
នៅទីនេះ«ពាក្យ» តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះខ្ញុំអាចដឹងថាតើអ្នកកំពុងនិយាយការពិត»
ត្រូវជាប់គុក
«នៅក្នុងគុក» (UDB)
Genesis 42:18
នៅថ្ងៃទីបី
ពាក្យ «ទីបី» គឺជាលេខធម្មតា។ ការបកប្រែផ្សេងទៀត៖ «បន្ទាប់ពីថ្ងៃទីពីរ!»
ចូរធ្វើដូច្នេះ ហើយអ្នករាល់គ្នានឹងបានរស់
ព័ត៌មានដែលអាចយល់បានអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត៖ «ប្រសិនបើអ្នកនឹងធ្វើអ្វីដែលខ្ញុំនិយាយខ្ញុំនឹងឱ្យអ្នករស់នៅ»
គោរពកោតខ្លាចព្រះជាម្ចាស់
នេះសំដៅទៅលើការគោរពព្រះយ៉ាងជ្រាលជ្រៅហើយបង្ហាញការគោរពនោះដោយស្តាប់បង្គាប់ព្រះអង្គ
ចូរឲ្យបងប្អូនរបស់អ្នករាល់គ្នាណាម្នាក់នៅជាប់ក្នុងគុកនេះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ទុកបងប្អូនម្នាក់របស់អ្នកនៅទីនេះនៅក្នុងគុក»
ប៉ុន្តែ អ្នកទៅ
នៅទីនេះ «អ្នក»
មានពហុវចនៈហើយសំដៅលើបងៗទាំងអស់ដែលនឹងមិនជាប់ពន្ធនាគារ។
ការបកប្រែផ្សេងទៀត៖ «ប៉ុន្តែនៅសល់ពីអ្នកទៅ»
នាំយកស្រូវទៅផ្ទះរបស់អ្នករាល់គ្នាព្រោះមានភាពអត់ឃ្លាននៅទីនោះ
នៅទីនេះ «ផ្ទះ» តំណាងឱ្យគ្រួសារ។ ការបកប្រែផ្សេងទៀត៖
«យកស្រូវទៅផ្ទះដើម្បីជួយគ្រួសាររបស់អ្នកក្នុងកំឡុងពេលទុរ្ភិក្សនេះ»
ដើម្បីបញ្ជាក់ថាអ្នករាល់គ្នាស្មោះត្រង់
នៅទីនេះ «ពាក្យ» តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះខ្ញុំប្រហែលជាដឹងថាអ្វីដែលអ្នកនិយាយគឺជាការពិត»
អ្នករាល់គ្នាមិនត្រូវស្លាប់ឡើយ
នេះបានន័យថាយ៉ូសែបនឹងអោយទាហានរបស់គាត់សម្លាប់បងប្អូនប្រសិនបើគាត់ដឹងថាពួកគេកុហក
Genesis 42:21
ឃើញពីទុក្ខកង្វល់នៃព្រលឹងរបស់គាត់
ពាក្យ «ព្រលឹង» តំណាងឱ្យយ៉ូសែប។ ការបកប្រែផ្សេងទៀត៖
«ពីព្រោះយើងឃើញថាយ៉ូសែបមានទុក្ខព្រួយយ៉ាងខ្លាំង»ឬ«
ពីព្រោះយើងឃើញថាយ៉ូសែបកំពុងរងទុក្ខ»
បានជាទុក្ខកង្វល់របស់គាត់បានធ្លាក់មកលើយើង
ពាក្យអរូបី «ទុក្ខព្រួយ» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ
«ងទុក្ខ។»ការបកប្រែផ្សេងទៀត៖
«នោះហើយជាមូលហេតុដែលយើងកំពុងរងទុក្ខដូចនេះ»(សូមមើលfigs-abstractnouns)
តើបងមិនបានប្រាប់អ្នកទាំងអស់គ្នាទេឬអីថា,កុំធ្វើបាបទាស់នឹងប្អូនប្រុសឡើយ,ប៉ុន្តែ
អ្នករាល់គ្នាមិនស្តាប់សោះ
រូបនេប្រើសំណួរដើម្បីស្តីបន្ទោសបងប្អូនរបស់គាត់។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំបានប្រាប់អ្នកកុំធ្វើបាបក្មេងប្រុស ប៉ុន្តែអ្នកនឹងមិនស្តាប់ទេ!»
តើបងមិនបានប្រាប់អ្នកទាំងអស់គ្នាទេឬអីថា កុំធ្វើបាបទាស់នឹងប្អូនប្រុសឡើយ
នេះមានសម្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖
«តើខ្ញុំមិនបានប្រាប់អ្នកថាមិនត្រូវប្រព្រឹត្តអំពើបាបប្រឆាំងនឹងក្មេងប្រុសនេះ »ឬ«
ខ្ញុំបានប្រាប់អ្នកមិនឱ្យប៉ះពាល់ដល់ក្មេងប្រុសនេះ»
ឥឡូវ,មើល៍
នៅទីនេះ«ឥឡូវនេះ»មិនមានន័យថា «នៅពេលនេះទេ» ប៉ុន្តែទាំងពីរ «ឥឡូវ»
និង«មើល»
ត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះចំណុចសំខាន់ដែលនៅខាងក្រោម។
ឈាមរបស់វាបានទាមទារពីយើងវិញហើយ
នៅទីនេះ «ឈាម» តំណាងឱ្យការស្លាប់របស់យ៉ូសែប។
បងប្អូនប្រុសរបស់គាត់បានគិតថាយ៉ូសែបបានស្លាប់ហើយ។
ឃ្លា«ត្រូវបានទាមទារពីពួកយើង»មានន័យថាពួកគេត្រូវតែទទួលទណ្ឌកម្មចំពោះអ្វីដែលពួកគេបានធ្វើ។
ការបកប្រែផ្សេងទៀត៖
«យើងកំពុងទទួលបានអ្វីដែលយើងសមនឹងទទួលមរណភាពរបស់គាត់» ឬ
«យើងកំពុងរងទុក្ខដោយសារការសម្លាប់គាត់»
Genesis 42:23
ពួកគេមិនបានដឹងថា....មានអ្នកបកប្រែឲ្យពួកគេ
ការផ្លាស់ប្តូរនេះពីខ្សែរឿងសំខាន់ទៅព័ត៌មានផ្ទៃខាងក្រោមដែលពន្យល់ពីមូលហេតុដែលបងប្អូនប្រុសគិត
អ្នកបកប្រែ
«អ្នកបកប្រែ»គឺជាអ្នកដែលបកប្រែអ្វីដែលមនុស្សម្នាក់និយាយទៅជាភាសាមួយទៀត។
យ៉ូសែបបានដាក់អ្នកបកប្រែរវាងខ្លួនគាត់និងបងប្អូនគាត់ដើម្បីធ្វើឱ្យគាត់ហាក់ដូចជាគាត់មិនចេះនិយាយភ
គាត់បានបែរមុខពីពួកគេ ហើយយំ
វាបញ្ជាក់ថាយ៉ូសែបបានយំដោយសារតែគាត់រំជួលចិត្តបន្ទាប់ពីបាន លឺ
អ្វីដែលបងប្អូនគាត់បាននិយាយ។
និយាយទៅកាន់ពួកគេ
យ៉ូសែបនៅតែនិយាយភាសាផ្សេងហើយប្រើអ្នកបកប្រែនិយាយទៅបងប្អូនរបស់គាត់។
ចងគាត់នៅចំពោះមុខពួកគេ
នៅចំពោះភ្នែក»សំដៅទៅលើការមើលឃើញរបស់ពួកគេ។ ការបកប្រែផ្សេងទៀត៖
«បានចងគាត់នៅចំពោះមុខពួកគេ» ឬ «បានចងគាត់នៅពេលពួកគេមើល»
ហើយផ្គត់ផ្គង់ដល់ដំណើររបស់ពួកគេដែរ
«ដើម្បីផ្តល់ការផ្គត់ផ្គង់ដែលពួកគេត្រូវការ»
គាត់បានធ្វើដូច្នេះជាមួយបងៗគាត់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖ «
ពួកអ្នកបំរើបានធ្វើសំរាប់ពួកគេនូវអ្វីគ្រប់យ៉ាងដែលយ៉ូសែបបានបញ្ជា»
Genesis 42:26
ម្នាក់ក្នុងចំណោមពួកគេបានបើកបាវរបស់គាត់ដើម្បីឲ្យស្មៅលាស៊ីនៅពេលសម្រាក
គាត់បានឃើញលុយរបស់គាត់ មើល៍ ឃើញលុយនៅក្នុងបាវរបស់គាត់
«នៅពេលពួកគេឈប់នៅកន្លែងមួយយប់បងប្អូនម្នាក់បានបើកបាវរបស់គាត់ដើម្បីចំណីសម្រាប់លារបស់គ
នៅក្នុងបាវគាត់បានឃើញប្រាក់របស់គាត់!»
មើល៍
ពាក្យថា« មើល»
នៅទីនេះដាស់តឿនយើងឱ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលកើតឡើង។
គេដាក់លុយខ្ញុំមកវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«មាននរណាម្នាក់បានដាក់ប្រាក់របស់ខ្ញុំត្រឡប់មកវិញ»
មើលនែ៎
«មើលក្នុងបាវរបស់ខ្ញុំ!»
បេះដូងពួកគេចាប់ផ្តើមភ័យញ័រ
ដើម្បីក្លាយជាការភ័យខ្លាចត្រូវបានគេនិយាយដូចជាបេះដូងរបស់ពួកគេកំពុងស្រយុត។

generated on Wed Sep 10 16:16:32 2025

នៅទីនេះ «ដួងចិត្ត» តំណាងឱ្យភាពក្លាហាន។ ការបកប្រែផ្សេងទៀត៖ «ពួកគេបានក្លាយជាភ័យខ្លាចខ្លាំងណាស់» (សូមមើល និង Genesis 42:29
លោកដែលជាចៅហ្វាយរបស់ទឹកដីនោះ
«ចៅហ្វាយនៃស្រុកអេស៊ីប»
បាននិយាយសម្ងួត
«និយាយយ៉ាងសាហាវ»
យើងគឺជាអ្នកស៊ើបការណ៍
អ្នកស៊ើបការណ៍គឺជាមនុស្សដែលព្យាយាមយកព័ត៌មានអំពីប្រទេសមួយដោយសម្ងាត់ ដើម្បីជួយ Genesis 42:9 ឬមួយផ្សេងទៀត។ សូមមើលពីរបៀបដែលអ្នកបកប្រែ«អ្នកស៊ើបការណ៍» នៅក្នុង ៤២: ៩
យើងប្រាប់គាត់ថា យើងជាមនុស្សស្មោះត្រង់ យើងមិនមែនជាអ្នកស៊ើបការណ៍ទេ
យើងមានបងប្អូនដប់ពីរនាក់ ជាកូនដែលចេញពីឪពុកតែមួយ ម្នាក់បានស្លាប់បាត់ហើយ
នៅក្នុងទឹកដីកាណាន
នេះមានសម្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ «យើងបានប្រាប់គាត់ថាយើងជាមនុស្សស្មោះត្រង់ហើយមិនមែនជាអ្នកស៊ើបការណ៍ទេ។ យើងបាននិយាយថាយើងជាបងប្អូន ១២
នាក់គឺជាកូនប្រុសរបស់ឪពុកយើងហើយប្អូនប្រុសម្នាក់មិននៅរស់ទៀតទេ ...
ទឹកដីស្រុកកាណាន»(សូមមើល និងfigs-quotations)
ម្នាក់បានស្លាប់បាត់ហើយ
ពាក្យថា«បងប្អូន»ត្រូវបានយល់។ ការបកប្រែផ្សេងទៀត៖ «បងប្រុសម្នាក់លែងមានជីវិត»
ហើយប្អូនប្រុសពៅនៅជាមួយឪពុករបស់យើង
ពាក្យថា«បងប្អូនត្រូវ»បានយល់។» ។ ការបកប្រែផ្សេងទៀត៖ «ប្អូនពៅនៅជាមួយឪពុករបស់យើងឥឡូវនេះ»
Genesis 42:33
បុរសដែលជាម្ចាស់ទឹកដីនោះ
«ចៅហ្វាយនៃស្រុកអេស៊ីប»
យយកស្រូវទៅដោយព្រោះគ្រោះអត់ឃ្លាននៅក្នុងផ្ទះរបស់អ្នក
នៅទីនេះ «ផ្ទះ»តំណាងឱ្យ «គ្រួសារ។» ការបកប្រែផ្សេងទៀត៖ «យកស្រូវដើម្បីជួយគ្រួសារអ្នកក្នុងពេលមានគ្រោះទុរ្ភិក្ស»
ទៅតាមផ្លូវរបស់អ្នក
«ទៅផ្ទះ»ឬ«ចេញ»
ហើយអ្នករាល់គ្នាអាចប្រកបរបរនៅក្នុងទឹកដីនេះបាន
«ហើយខ្ញុំនឹងអនុញ្ញាតឱ្យអ្នកទិញនិងលក់នៅក្នុងទឹកដីនេះ»
Genesis 42:35
វាបានកើតឡើងយ៉ាងនេះ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
មើល៏
«ដើម្បីឱ្យមានការភ្ញាក់ផ្អើលរបស់ពួកគេ។» ពាក្យថា« មើល៏» នៅទីនេះបង្ហាញថាបងប្អូនមានការភ្ញាក់ផ្អើលចំពោះអ្វីដែលពួកគេបានឃើញ។
ឯងរាល់គ្នាបានធ្វើឲ្យឪពុកបាត់កូនអស់ហើយ
«អ្នកបានដកហូតខ្ញុំពីកូន ៗ របស់ខ្ញុំ»ឬ «អ្នកបានធ្វើឱ្យខ្ញុំបាត់បង់កូនពីរនាក់»
ការទាំងអស់នេះទាស់នឹងឪពុកហើយ
«រឿងទាំងអស់នេះធ្វើអោយពុកឈឺចាប់»
ដើម្បីជួយ Genesis 42:36 ឬមួយផ្សេងទៀត។
សូមឲ្យវាមកក្នុងដៃរបស់ខ្ញុំចុះ
នេះជាការស្នើសុំឱ្យរូបននាំយ៉ូសែបទៅជាមួយហើយមើលថែគាត់ពេលធ្វើដំណើរ។
ការបកប្រែផ្សេងទៀត៖ «ដាក់ខ្ញុំឱ្យទទួលខុសត្រូវលើគាត់»
ឬ«សូមឱ្យខ្ញុំថែរក្សាគាត់»
យើងមិនឲ្យកូនរបស់យើងទៅជាមួយឯងទេ
វាជារឿងធម្មតាទេដែលប្រើឃ្លាថា« ចុះទៅ» នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។
ការបកប្រែផ្សេងទៀត៖
«កូនប្រុសរបស់ខ្ញុំ,បេនយ៉ាមីននឹងមិនទៅជាមួយអ្នកទៅកាន់ប្រទេសអេស៊ីបទេ»
ជាមួួយអ្នក
នៅទីនេះ «អ្នក» មានពហុវចន:ហើយសំដៅទៅលើកូនប្រុសច្បងរបស់យ៉ាកុប។
ដ្បិត បងប្រុសរបស់វាបានស្លាប់ហើយ នៅសល់តែវាទេ
អត្ថន័យពេញលេញអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត៖
«ចំពោះភរិយាខ្ញុំរ៉ាជែល មានតែកូនពីរនាក់ទេ។
យ៉ូសែបបានស្លាប់ហើយបេនយ៉ាមីននៅសល់តែមួយ»
នៅតាមផ្លូវដែលទៅជាមួយឯងទៅ
«ខណៈពេលដែលអ្នកធ្វើដំណើរទៅប្រទេសអេស៊ីបនិងត្រឡប់មកវិញ»ឬ
«ខណៈពេលដែលអ្នកនៅឆ្ងាយ។ » នៅទីនេះ «ផ្លូវ» តំណាងឱ្យការធ្វើដំណើរ។
ដូច្នេះ ឯងរាល់គ្នាមុខជានាំសក់ស្កូវរបស់ឪពុកជាមួយនឹងភាពសោកសៅទៅស្ថានឃុំព្រលឹងហើយ
ដើម្បី«នាំចុះ ...
ទៅស្ថានមនុស្សស្លាប់»គឺជាវិធីនៃការនិយាយថាពួកគេនឹងធ្វើឱ្យគាត់ស្លាប់ហើយទៅស្ថានមនុស្សស្លាប់។
គាត់ប្រើពាក្យ« ចុះ»
ពីព្រោះវាត្រូវបានគេជឿថាជាទូទៅស្ថានឃុំព្រលឹងគឺស្ថិតនៅកន្លែងណាមួយនៅក្រោមដី។
ការបកប្រែផ្សេងទៀត៖ «បន្ទាប់មកអ្នកនឹងធ្វើឱ្យខ្ញុំជាបុរសចំណាស់ម្នាក់
ស្លាប់ដោយទុក្ខព្រួយ»
សក់ស្កូវរបស់ឪពុក
នេះតំណាងឱ្យយ៉ាកុបហើយសង្កត់ធ្ងន់លើអាយុចាស់របស់គាត់។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំ ជាបុរសចំណាស់»

---

43 [1]គ្រោះទុរ្ភិក្សបានកើតមាននៅក្នុងស្រុកកាន់តែខ្លាំងឡើង។[2]នៅពេលពួកគេបានហូបស្រូវដែលបានទិញពីអេស៊ីបមកអស់ហើយ
ឪពុករបស់ពួកគេបាននិយាយទៅពួកគេថា៖ «ចូរទៅម្តងទៀតចុះ ទៅទិញអាហារខ្លះសម្រាប់យើង»។
[3]លោកយូដាប្រាប់គាត់ថា៖ «បុរសនោះបានប្រាប់ពួកយើងយ៉ាងច្បាស់ថា៖ «ប្រសិនបើ មិននាំប្អូនប្រុសរបស់យើងទៅទេ កុំមកជួបមុខយើងទៀត»។[4]ប្រសិនបើ
លោកឪពុកឲ្យប្អូនប្រុសទៅជាមួយយើង យើងនឹងចុះទៅម្តងទៀត ហើយទិញអាហារជូនលោកឪពុក»។[5]ប៉ុន្តែ ប្រសិនបើ លោកឪពុកមិនឲ្យប្អូនប្រុសទៅជាមួយយើងទេ
យើងនឹងមិនទៅទេ។ ដ្បិត បុរសនោះបានប្រាប់យើងរួចហើយថា៖ «ប្រសិនបើ មិននាំប្អូនប្រុសរបស់យើងទៅទេ កុំមកជួបមុខយើងទៀត»។
[6]លោកអ៊ីស្រាអែលប្រាប់ថា៖ «ហេតុអ្វីបានជាឯងរាល់គ្នាប្រព្រឹត្តនឹងយើងអាក្រក់យ៉ាងដូច្នេះ ដោយប្រាប់បុរសនោះថា ឯងមានប្អូនម្នាក់ទៀត?»[7]ពួកគេ និយាយថា៖
«បុរសនោះសួរយ៉ាងលម្អិតពីយើង និងគ្រួសាររបស់យើង។ គាត់សួរថា៖ «តើឪពុករបស់អ្នករាល់គ្នានៅរស់ទេ? តើអ្នករាល់គ្នាមានបងប្អូនផ្សេងទៀតទេ?
ពួកយើងឆ្លើយទៅគាត់តាមសំនួររបស់គាត់។ ធ្វើដូចម្តេចយើងខ្ញុំអាចដឹងបានថាគាត់សួរបែបនឹងថា៖ «ចូរនាំប្អូនប្រុសរបស់អ្នករាល់គ្នាមកផង?»
[8]លោកយូដាឆ្លើយទៅលោកអ៊ីស្រាអែល ឪពុករបស់គាត់ថា៖ «ឲ្យប្អូនប្រុសទៅជាមួយខ្ញុំទៅ។ យើងនឹងក្រោក ហើយចេញទៅ ដើម្បីឲ្យយើងបានរស់ មិនស្លាប់ឡើយ
ទាំងយើងខ្ញុំ ទាំងលោកឪពុក និងទាំងកូនៗរបស់យើងដែរ។[9]ខ្ញុំធានាមើលថែវា។ ខ្ញុំនឹងទទួលខុសត្រូវចំពោះលោកឪពុក។ ប្រសិនបើ ខ្ញុំមិននាំវាត្រឡប់មករកលោកឪពុក
ហើយយកវាមកដាក់នៅចំពោះលោកឪពុកវិញទេ ខ្ញុំនឹងទទួលកំហុសរហូត។[10]ដ្បិត ប្រសិនបើ លោកឪពុកមិនពន្យាពេលទេនោះ
ម្ល៉េះយើងបានត្រឡប់មកវិញជាលើទីពីរបានទៅហើយ»។
[11]លោកអ៊ីស្រាអែល ឪពុករបស់ពួកគេប្រាប់ពួកគេថា៖ «បើដូច្នោះមែន ចូរធ្វើដូច្នោះទៅ។ ចូរយកផលិតផលពីទឹកដីនេះ ដាក់នៅក្នុងបាវរបស់កូនៗទៅ។
យកវាទៅទុកជាអំណោយដល់បុរសនោះ មានត្នោត និងទឹកឃ្មុំ គ្រឿងម្ហូប ជ័រល្វីងទេស គ្រាប់ធញ្ញជាតិ និងគ្រាប់ចំបក់ខ្លះផង។
[12]ចូរយកប្រាក់មួយទ្វេជាពីរនៅក្នុងដៃរបស់ឯងរាល់គ្នា។ ប្រាក់ដែលបានដាក់ត្រឡប់មកនៅក្នុងបាវរបស់កូនៗនោះ ចូរយកវាទៅជាមួយកូនៗម្តងទៀត។
ប្រហែលជាច្រឡំហើយមើលទៅ។
[13]ចូរយកប្អូនប្រុសរបស់កូនៗទៅជាមួយផង។ ចូរក្រោកឡើង ហើយចេញទៅរកបុរសនោះចុះ។
[14]សូមព្រះជាម្ចាស់ដ៏មានគ្រប់ព្រះចេស្តាប្រទានព្រះគុណដល់កូនៗនៅចំពោះបុរសនោះ ដើម្បីឲ្យគាត់បានដោះលែងប្អូនប្រុសរបស់កូនៗមកកូនវិញ
ព្រមទាំងបេនយ៉ាមីនផង។ ប្រសិនបើ ឪពុកបាត់បង់កូន សូមឲ្យវាបាត់ទៅចុះ»។[15]ពួកគេបានយកអំណោយនេះ ហើយនៅក្នុងដៃរបស់ពួកគេ ពួកគេបានយកប្រាក់ទ្វេដង
ហើយបេនយ៉ាមីនក៏ទៅជាមួយដែរ។

generated on Wed Sep 10 16:16:32 2025

[16]នៅពេលលោកយ៉ូសែបឃើញបេនយ៉ាមីននៅជាមួយពួកគេ គាត់ប្រាប់ទៅអ្នកបម្រើនៅក្នុងផ្ទះរបស់គាត់ថា៖ «ចូរនាំបុរសទាំងនោះមកក្នុងផ្ទះខ្ញុំមក ហើយសម្លាប់សត្វ
ហើយចម្អិនវា សម្រាប់ពួកគេហូបពេលថ្ងៃត្រង់នេះ»។[17]អ្នកបម្រើបានធ្វើតាមលោកយ៉ូសែបង្គាប់។ គាត់បាននាំពួកគេទៅក្នុងផ្ទះរបស់លោកយ៉ូសែប។
[18]បុរសទាំងនោះមានការភ័យខ្លាចជាខ្លាំង ដោយសារពួកគេបាននាំចូលទៅក្នុងផ្ទះរបស់លោកយ៉ូសែប។ ពួកគេនិយាយថា៖
«ដោយសារប្រាក់ដែលនៅក្នុងបាវលើកទីមួយដែលយើងបាននាំទៅទេដឹង ហើយប្រហែលជាគាត់រកឱកាសដើម្បីប្រឆាំងជាមួយយើងហើយ។
គាត់ប្រហែលជាចាប់ពួកយើង ហើយយកពួកយើងធ្វើជាឈ្លើយ ហើយយកទាំងលារបស់យើងទៀត»។[19]ពួកគេបាននិយាយទៅអ្នកបម្រើនៅក្នុងផ្ទះរបស់លោកយ៉ូសែប
ហើយពួកគេបាននិយាយទៅគាត់នៅមាត់ទ្វារផ្ទះ[20]ដោយពោលថា៖ «លោកម្ចាស់ យើងចុះមកនេះ លើកទីមួយដើម្បីទិញស្បៀង។
[21]នៅពេលទៅដល់កន្លែងសម្រាក នោះពួកគេហើយបានបើកបាវរបស់ពួកយើង ហើយមើល៍ មានប្រាក់នៅក្នុងបាវរបស់យើងគ្រប់គ្នា ប្រាក់របស់យើងនៅគ្រប់គីឡូ។
យើងបាននាំវាត្រឡប់មកជាមួយយើងដែរ។[22]ហើយប្រាក់ផ្សេងទៀត យើងក៏បានយកមកនៅក្នុងដៃរបស់យើងដែរ ដើម្បីទិញស្បៀង។
យើងមិនដឹងថានរណាបានដាក់ប្រាក់របស់យើងទៅក្នុងបាវរបស់យើងវិញនោះទេ»។[23]អ្នកបម្រើនោះនិយាយថា៖ «សូមសេចក្តីសុខសាន្តនៅជាមួយអ្នកចុះ កុំខ្លាចអ្វី
ឡើយ។ ព្រះជាម្ចាស់របស់អ្នករាល់គ្នា និងជាព្រះជាម្ចាស់នៃឪពុករបស់អ្នករាល់គ្នាទេ ដែលបានដាក់ប្រាក់ក្នុងបាវរបស់អ្នករាល់គ្នាវិញនោះ ឯប្រាក់របស់អ្នករាល់គ្នា គឺខ្ញុំបាន
ទទួលហើយ»។ បន្ទាប់មក អ្នកបម្រើនោះបាននាំលោកស៊ីម្មានចេញមករកពួកគេដែរ។
[24]អ្នកបម្រើបាននាំបុរសទាំងអស់នោះចូលទៅក្នុងផ្ទះរបស់លោកយ៉ូសែប។ គាត់ឲ្យទឹកពួកគេពិសា ហើយលាងជើងរបស់ពួកគេ។ គាត់ឲ្យស្មៅទៅសត្វលារបស់ពួកគេ។
[25]ពួកគេបានរៀបចំអំណោយជូនលោកយ៉ូសែបមកដល់ពេលថ្ងៃត្រង់ ដ្បិត ពួកគេបានឮថា ពួកគេនឹងហូបអាហារនៅទីនោះ។
[26]នៅពេលលោកយ៉ូសែបមកដល់ផ្ទះវិញ ពួកគេបាននាំយកអំណោយដែលនៅក្នុងដៃរបស់ពួកគេចូលមកក្នុងផ្ទះ ហើយលុតជង្គង់ចុះនៅចំពោះមុខគាត់ ឱនមុខទៅដី។
[27]គាត់បានសួរពួកគេពីសុខទុក្ខរបស់ពួកគេ ដោយនិយាយថា៖ «តើឪពុករបស់អ្នករាល់គ្នាសុខសប្បាយជាទេ គាត់សួរទៅបងច្បង? តើគាត់នៅរស់ទេ?»
[28]ពួកគេឆ្លើយថា៖ «បាទលោកម្ចាស់ ឪពុកយើងខ្ញុំសុខសប្បាយជាទេ គាត់ក៏នៅរស់ដែរ»។ ពួកគេឱន ហើយលុតជង្គង់ចុះ។[29]នៅពេលគាត់ក្រឡេកភ្នែករបស់គាត់ឡើង
គាត់បានឃើញបេនយ៉ាមីន ប្អូនប្រុសរបស់គាត់ កូនរបស់ម្តាយគាត់ ហើយគាត់និយាយថា៖ «តើគាត់នោះគឺជាប្អូនប្រុសពៅដែលអ្នករាល់គ្នាបានប្រាប់ខ្ញុំ?»
បន្ទាប់មកគាត់និយាយថា៖ «សូមព្រះជាម្ចាស់ផ្តល់ព្រះគុណដល់អ្នក កូនប្រុស»។
[30]លោកយ៉ូសែបប្រញាប់ចេញទៅក្រៅបន្ទប់ ដ្បិតគាត់មានចិត្តក្តុកក្តួលជាមួយប្អូនប្រុសរបស់គាត់។ គាត់បានស្វែងរកន្លែងដើម្បីយំ។ គាត់បានទៅបន្ទប់របស់គាត់
ហើយយំនៅទីនោះ។[31]គាត់បានលាងមុខរបស់គាត់ ហើយចេញមកក្រៅវិញ។ គាត់បានគ្រប់គ្រងខ្លួនឯង ដោយនិយាយថា៖ «លើកម្ហូបអាហារមក»។
[32]អ្នកបម្រើរបស់លោកយ៉ូសែបបានលើកម្ហូបជូនលោកយ៉ូសែបដោយផ្ទាល់ ហើយឲ្យបងៗដួសម្ហូបខ្លួនឯង។
ជនជាតិអេស៊ីបនៅទីនោះហូបអាហារជាមួយគាត់ដោយឡែកដោយខ្លួនរបស់ពួកគេ ព្រោះជនជាតិអេស៊ីបមិនហូបនំបុ័ងជាមួយជនជាតិហេព្រើរទេ
ដ្បិតជនជាតិអេស៊ីបខ្ពើមនឹងការនោះ។[33]បងៗអង្គុយទល់មុខគាត់ ពួកគេអង្គុយតាមលេខរៀងពីបងច្បងទៅប្អូនពៅ តាមអាយុរបស់ពួកគេ។ ពួកគេមានការឆ្ងល់ទាំងអស់
គ្នា។[34]លោកយ៉ូសែបបានដាក់ចំណែកអាហារដល់ពួកគេនៅចំពោះពួកគេ។ ប៉ុន្តែ ចំណែករបស់បេនយ៉ាមីន ប្អូនប្រុសរបស់គាត់វិញ ប្រាំដងលើសបងៗរបស់គាត់។ ពួកគេ
ផឹកស្រាយ៉ាងសប្បាយរីករាយជាមួយគាត់។

Genesis 43:1

គ្រោះទុរ្ភិក្សបានកើតមាននៅក្នុងស្រុកកាន់តែខ្លាំងឡើង

ពាក្យថា«កាណាន»ត្រូវបានយល់។ ព័ត៌មាននេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត៖ «ទុរ្ភិក្សកើតមានយ៉ាងខ្លាំងនៅក្នុងស្រុកកាណាន»

វាបានកើតមកយ៉ាងនេះ

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ប្រសិនបើភាសារបស់អ្នកមានមធ្យោបាយសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។

នៅពេលពួកគេបានហូប

«នៅពេលលោកយ៉ាកុបនិងក្រុមគ្រួសារគាត់កំពុងបរិភោគ»

ដែលពួកគេបាននាំយកពី

"លោកយ៉ាកុបបានបង្គាប់កូនប្រុសរបស់គាត់ដែលបានទៅនាំមក"

ទិញអោយយើង

នៅទីនេះ «យើង» សំដៅទៅលើលោកយ៉ាកុប
កូនប្រុសរបស់គាត់និងគ្រួសារដទៃទៀត។

Genesis 43:3

លោកយូដាប្រាប់គាត់

«យូដាបានដល់ឮពុករបស់គាត់គឺលោកយ៉ាកុប»

បុរសនោះ

នេះសំដៅទៅលើយ៉ូសែបតែបងប្អូនមិនបានដឹងថាជាយ៉ូសែបទេ។
ពួកគេបានហៅគាត់ថាជា« បុរស» ឬ« បុរសដែលជាម្ចាស់ដី» ដូចនៅក្នុង ៤២:២៩
។

បានព្រមានយើង,អ្នកនិងមិនឃើញមុខខ្ញុំលុះត្រាណាតែប្អូនប្រុសរបស់អ្នកមកជាមួយអ្នក

នេះមានសម្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖
«បានព្រមានយើងថាយើង
នឹងមិនឃើញមុខគាត់ទេដរាបណាយើងនាំប្អូនពៅរបស់យើងទៅជាមួយយើង»

ព្រមានយើងយ៉ាងឱឡារិក

«គឺធ្ងន់ធ្ងរណាស់នៅពេលគាត់ព្រមានយើងដោយនិយាយថា»

អ្នកនិងមិនឃើញមុខយើងទៀតទេ

យូដាប្រើឃ្លានេះពីរដងក្នុង ៤៣: ៣-៥
ដើម្បីបញ្ជាក់ទៅឪពុកគាត់ថាពួកគេមិនអាចវិលត្រឡប់ទៅស្រុកអេស៊ីបបានទេបើគ្មានបងប្អូនម្នាក់ទៀត
ឃ្លា« មុខខ្ញុំ»សំដៅទៅលើបុរសនោះឈ្មោះយ៉ូសែប។ ការបកប្រែផ្សេងទៀត៖
«អ្នកនឹងមិនឃើញខ្ញុំទេ»

ប្អូនប្រុសអ្នកមកជាមួយអ្នក

យូដាកំពុងសំដៅទៅលើបេនយ៉ាមីនដែលកើតចុងក្រោយបង្អស់របស់រ៉ាជែលមុនពេលនាងស្លាប់។

យើងនិងមិនចុះទៅទេ

វាជារឿងធម្មតាទេដែលប្រើឃ្លាថា«ចុះទៅ»នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។

Genesis 43:6

ហេតុអ្វីបានជាអ្នកធ្វើអោយខ្ញុំមានបញ្ហាច្រើន

«ហេតុអ្វីបានជាអ្នកធ្វើអោយខ្ញុំមានបញ្ហាច្រើន»

បុរសនោះសួរយ៉ាងលម្អិតពីយើង

«បុរសនោះបានសួរសំនួរយ៉ាងច្រើន»

អំពីយើង

នៅទីនេះ«យើង»
គឺផ្តាច់មុខហើយសំដៅទៅលើបងប្អូនដែលបានចុះទៅប្រទេសអេស៊ីបហើយនិយាយជាមួយ«បុរសនោះ»
។

តើឪពុករបស់អ្នករាល់គ្នានៅរស់ទេ? តើអ្នករាល់គ្នាមានបងប្អូនផ្សេងទៀតទេ?

នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖
«គាត់បានសួរយើងដោយផ្ទាល់ថាតើឪពុករបស់យើងនៅរស់ទេ
ហើយប្រសិនបើយើងមានបងប្អូនប្រុសផ្សេងទៀត។»

ពួកយើងឆ្លើយទៅគាត់តាមសំនួររបស់គាត់

«យើងបានឆ្លើយសំណួរដែលគាត់បានសួរយើង»

ធ្វើដូចម្តេចយើងខ្ញុំអាចដឹងបានថាគាត់សួរបែបនឹង?

កូនប្រុសប្រើសំណួរសង្កត់ធ្ងន់ថាបុរសមិនដឹងថាបុរសនោះនឹងប្រាប់ពួកគេឱ្យធ្វើអ្វីទេ។
សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត៖
«យើងមិនដឹងថាគាត់នឹងនិយាយថា ... ចុះ!»

គាត់និយាយថា,ចូរនាំប្អូនប្រុសរបស់អ្នករាល់គ្នាមកផង

នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖
«គាត់នឹងប្រាប់យើងឱ្យនាំប្អូនយើងចុះទៅស្រុកអេស៊ីប»

នាំប្អូនប្រុសរបស់អ្នកចុះមក

យ៉ាងម៉ឺងម្ត
ឃ្លានេះគឺជាការធ្វើឱ្យ
ធម្មតាទេដែលប្រើពាក្យថា« ចុះ»
នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។

generated on Wed Sep 10 16:16:32 2025

Genesis 43:8
យើងនឹងក្រោក ហើយចេញទៅ ដើម្បីឲ្យយើងបានរស់ មិនស្លាប់ឡើយ ទាំងយើងខ្ញុំ ទាំងលោកឪពុក និងទាំងកូនៗរបស់យើងដែរ
ឃ្លាដែលថា«យើងអាចរស់នៅ» និង« មិនស្លាប់» បានន័យដូចគ្នា។
យូដាកំពុងសង្កត់ធ្ងន់ថាពួកគេត្រូវទិញស្បៀងអាហារនៅអេស៊ីបដើម្បីរស់។
ការបកប្រែផ្សេងទៀត៖
«ឥឡូវនេះយើងនឹងទៅប្រទេសអេស៊ីបហើយទទួលបានស្រូវ
ដូច្នេះគ្រួសារទាំងមូលរបស់យើងនឹងរស់នៅ»
យើងនឹងក្រោក
នៅទីនេះ «យើង» សំដៅទៅលើបងប្អូនដែលនឹងធ្វើដំណើរទៅប្រទេសអេស៊ីប។
ដើម្បីឲ្យយើងបានរស់
នៅទីនេះ «យើង» សំដៅទៅលើបងប្អូនអ៊ីស្រាអែលនិងក្រុមគ្រួសារទាំងមូល។
ទាំងយើងខ្ញុំ
នៅទីនេះ« យើង» សំដៅលើបងប្អូន។
យើង អ្នក
នៅទីនេះ«អ្នក» មានលក្ខណៈឯកតាហើយសំដៅទៅលើអ៊ីស្រាអែល។
ទាំងកូនៗរបស់យើងដែរ
នៅទីនេះ «របស់យើង»សំដៅទៅលើបងប្អូន។
នេះសំដៅទៅលើកុមារតូចៗដែលងាយនឹងស្លាប់ក្នុងអំឡុងពេលមានទុរ្ភិក្ស។
ខ្ញុំធានាមើលថែវា
នាមអរូបី «ការធានា»អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ «ការសន្យា។»
ការបកប្រែផ្សេងទៀត៖ «ខ្ញុំនឹងសន្យាថានឹងនាំគាត់ត្រឡប់មកវិញ»
ខ្ញុំនឹងទទួលខុសត្រូវចំពោះលោកឪពុក
យើងអាចនិយាយយ៉ាងច្បាស់អំពីវិធីដែលយ៉ាកុបនឹងទទួលខុសត្រូវចំពោះយូដា។
ការបកប្រែផ្សេងទៀត៖
«ពុកនឹងឱ្យខ្ញុំឆ្លើយទៅពុកអំពីអ្វីដែលកើតឡើងចំពោះបេនយ៉ាមីន»
ខ្ញុំនឹងទទួលកំហុសរហូត
នេះនិយាយអំពី «ស្តីបន្ទោស» ដូចជាវាជាវត្ថុដែលមនុស្សម្នាក់ត្រូវកាន់។
ការបកប្រែផ្សេងទៀត៖ «អ្នកអាចស្តីបន្ទោសខ្ញុំ»
ប្រសិនបើ លោកឪពុកមិនពន្យាពេលទេនោះ
យូដាកំពុងពិពណ៌នាអំពីអ្វីដែលអាចកើតឡើងនៅអតីតកាលប៉ុន្តែមិនបានធ្វើទេ។
យូដាកំពុងស្តីបន្ទោសឪពុករបស់គាត់ដែលបានរង់ចាំយូរដើម្បីបញ្ជូនកូន ៗ
របស់គាត់ទៅស្រុកអេស៊ីបដើម្បីទទួលបានស្បៀងអាហារថែមទៀត។
ម្ល៉ះយើងបានត្រឡប់មកវិញជាលើទីពីរបានទៅហើយ
«យើងនិងត្រលប់មកវិញ២ដងហើយ»
Genesis 43:11
បើដូច្នោះមែន ចូរធ្វើដូច្នោះទៅ
«ប្រសិនបើនេះជាជំរើសតែមួយគត់របស់យើងបន្ទាប់មកធ្វើវា»
យកវាទៅ
វាជារឿងធម្មតាទេដែលប្រើពាក្យថា«
ចុះ»នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។
ប្រេង
ជាសារធាតុប្រេងដែលមានក្លិនផ្អែមប្រើសម្រាប់ព្យាបាលនិងការពារស្បែក។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យទាំងនេះនៅក្នុង ៣៧:២៥ ។
ការបកប្រែផ្សេងទៀត៖ «ថ្នាំ»
គ្រឿងម្ហូប
«គ្រឿង » សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យទាំងនេះនៅក្នុង ៣៧:២៥ ។
គ្រាប់ឈើ
«តូច ផ្លែដើមឈើខៀវ»
គ្រាប់ចំបក់
គ្រាប់ផ្លែឈើដែលមានរសជាតិផ្អែម
ចូរយកប្រាក់មួយទ្វេជាពីរនៅក្នុងដៃរបស់ឯងរាល់គ្នា
នៅទីនេះ «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ការបកប្រែផ្សេងទៀត៖
«យកប្រាក់ទ្វេដងជាមួយអ្នក»
ប្រាក់ដែលបានដាក់ត្រឡប់មកនៅក្នុងបាវរបស់កូនៗនោះ ចូរយកវាទៅជាមួយកូនៗម្តងទៀត
នៅទីនេះ«ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ឃ្លា «ដែលត្រូវបានត្រឡប់មកវិញ»
អាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«យកប្រាក់ទៅឱ្យប្រទេសអេស៊ីបវិញនូវប្រាក់ដែលនរណាម្នាក់ដាក់ក្នុងបាវរបស់អ្នក»

Genesis 43:13
ចូរយកប្អូនប្រុស
«ចូរយកបេនយ៉ាមីន»
ទៅម្តងទៀត
«ត្រលប់ទៅ»
សូមព្រះជាម្ចាស់ដ៏មានគ្រប់ព្រះចេស្តាប្រទានព្រះគុណដល់កូនៗនៅចំពោះបុរសនោះ
នាមអរូបី «មេត្តា» អាចត្រូវបានបញ្ជាក់ថាជាគុណនាម «សប្បុរស។
»ការបកប្រែផ្សេងទៀត៖
«សូមព្រះជាម្ចាស់ដ៏មានព្រះចេស្តាធ្វើឱ្យបុរសនោះធ្វើល្អដល់អ្នក»
ប្អូនប្រុសរបស់កូន
«ស៊ីម្មាន»
ប្រសិនបើ ឪពុកបាត់បង់កូន សូមឲ្យវាបាត់ទៅចុះ
«ប្រសិនបើខ្ញុំបាត់បង់កូន ៗ ខ្ញុំនឹងបាត់បង់កូន ៗ របស់ខ្ញុំ»។
នេះមានន័យថាយ៉ាកុបដឹងថាគាត់ត្រូវតែទទួលយកអ្វីដែលកើតឡើងចំពោះកូនប្រុសរបស់គាត់។
នៅក្នុងដៃរបស់ពួកគេ
នៅទីនេះ «ដៃ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត៖
«ពួកគេបានយក»
បានចុះទៅអេស៊ីប
វាជារឿងធម្មតាទេដែលប្រើឃ្លាថា« ចុះទៅ»
នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។
Genesis 43:16
បេនយ៉ាមីននៅជាមួយពួកគេ
«បេនយ៉ាមីនជាមួយបងប្រុសៗរបស់យ៉ូសែប»
អ្នកបម្រើនៅក្នុងផ្ទះរបស់គាត់
«អ្នកបម្រើ» ទទួលខុសត្រូវក្នុងការគ្រប់គ្រងសកម្មភាពគ្រួសាររបស់យ៉ូសែប។
គាត់បាននាំពួកគេ
នៅទីនេះ «នាំយក» អាចត្រូវបានបកប្រែជា «យក»
ទៅក្នុងផ្ទះរបស់លោកយ៉ូសែប
«ចូលទៅក្នុងផ្ទះរបស់លោកយ៉ូសែប»
Genesis 43:18
បុរសទាំងនោះមានការភ័យខ្លាចជាខ្លាំង
«បងប្អូនរបស់យ៉ូសែបភ័យខ្លាច»
ពួកគេបាននាំចូលទៅក្នុងផ្ទះរបស់លោកយ៉ូសែប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ការបកប្រែផ្សេងទៀត៖ «
ពួកគេនឹងចូលទៅក្នុងផ្ទះរបស់យ៉ូសែប»ឬ«
អ្នកបម្រើបាននាំពួកគេចូលក្នុងផ្ទះរបស់យ៉ូសែប»
ដោយសារប្រាក់ដែលនៅក្នុងបាវលើកទីមួយដែលយើងបាននាំទៅទេដឹង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«អ្នកបម្រើកំពុងនាំយើងចូលទៅក្នុងផ្ទះដោយសារប្រាក់ដែលអ្នកណាម្នាក់ដាក់ក្នុងបាវរបស់យើង»
គាត់រកឱកាសដើម្បីប្រឆាំងជាមួយយើងហើយ។ គាត់ប្រហែលជាចាប់ពួកយើង
នេះអាចត្រូវបានបកប្រែជាប្រយោគថ្មី។ ការបកប្រែផ្សេងទៀត៖
«គាត់កំពុងរង់ចាំឱកាសដើម្បីចោទប្រកាន់យើងដើម្បីឱ្យគាត់ចាប់ខ្លួនយើង»
យើងចុះមកនេះ
វាជារឿងធម្មតាទេដែលប្រើឃ្លាថា« ចុះមក»
នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។
Genesis 43:21
ភ្ជាប់៖សេចក្តីថ្លែងការណ៍
បងប្អូនបន្តនិយាយទៅកាន់អ្នកបម្រើផ្ទះ។
វាបានកើតមកយ៉ាងនេះ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
នៅពេលទៅដល់កន្លែងសម្រាក
«នៅពេលយើងមកដល់កន្លែងដែលយើងនឹងស្នាក់នៅពេលយប់»
មើល៏
ពាក្យថា«មើល»នៅទីនេះបង្ហាញថាបងប្អូនមានការភ្ញាក់ផ្អើលចំពោះអ្វីដែលពួកគេបានឃើញ។
មានប្រាក់នៅក្នុងបាវរបស់យើងគ្រប់គ្នា ប្រាក់របស់យើងនៅគ្រប់គីឡូ
«យើងម្នាក់ៗបានរកឃើញចំនួនប្រាក់របស់គាត់នៅក្នុងបាវរបស់គាត់»
យើងបាននាំវាត្រឡប់មកជាមួយយើងដែរ
នៅទីនេះ «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត៖
«យើងបានយកប្រាក់ត្រឡប់មកវិញជាមួយយើង»

generated on Wed Sep 10 16:16:32 2025

ហើយប្រាក់ផ្សេងទៀត យើងក៏បានយកមកនៅក្នុងដៃរបស់យើងដែរ ដើម្បីទិញស្បៀង
នៅទីនេះ «ដៃ»តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត៖
«យើងក៏បាននាំប្រាក់បន្ថែមដើម្បីទិញស្បៀង»
បានយកមក
វាជារឿងធម្មតាទេដែលប្រើពាក្យថា« ចុះ»
នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។
សូមសេចក្តីសុខសាន្តនៅជាមួយអ្នកចុះ
នាមអរូបី«សេចក្តីសុខសាន្ត» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត៖ «សម្រាក»
ព្រះជាម្ចាស់របស់អ្នករាល់គ្នា និងជាព្រះជាម្ចាស់នៃឪពុករបស់អ្នក
អ្នកបម្រើមិននិយាយអំពីព្រះពីរផ្សេងគ្នាទេ។ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់របស់អ្នកគឺជាព្រះជាម្ចាស់ដែលឪពុករបស់អ្នកគោរពថ្វាយបង្គំ» (UDB)
Genesis 43:24
លាងជើងរបស់ពួកគេ
ទំនៀមទម្លាប់នេះបានជួយអ្នកធ្វើដំណើរដែលនឿយហត់ឱ្យមានកម្លាំងចិត្តឡើងវិញបន្ទាប់ពីមួយរយៈ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ឲ្យស្មៅទៅសត្វលារបស់ពួកគេ
«ចំណី» គឺជាអាហារស្ងួតដែលត្រូវបានទុកសម្រាប់សត្វ។
Genesis 43:26
ពួកគេបាននាំយកអំណោយដែលនៅក្នុងដៃរបស់ពួកគេ
នៅទីនេះ«ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត៖
«បងប្អូនបាននាំអំណោយដែលពួកគេមានជាមួយពួកគេ»
លុតជង្គង់ចុះនៅចំពោះមុខគាត់ ឱនមុខទៅដី
នេះជាវិធីបង្ហាញកិត្តិយសនិងការគោរព។
Genesis 43:28
ឪពុកយើងខ្ញុំសុខជាអ្នកបំរើលោកម្ចាស់
ពួកគេចាត់ទុកឪពុករបស់ពួកគេថាជា
«អ្នកបម្រើរបស់លោក»ដើម្បីបង្ហាញការគោរព។ ការបកប្រែផ្សេងទៀត៖
«ឪពុករបស់យើងដែលបម្រើលោកម្ចាស់»
ពួកគេឱន ហើយលុតជង្គង់ចុះ
ពាក្យទាំងនេះជាទូទៅមានន័យដូចគ្នា។
ពួកគេបានដាក់នៅពីមុខបុរសដើម្បីបង្ហាញការគោរពដល់គាត់។
ការបកប្រែផ្សេងទៀត៖ «ពួកគេក្រាបនៅពីមុខគាត់»
គាត់ក្រឡេកភ្នែករបស់គាត់ឡើង
នេះមានន័យថ«គាត់បានក្រឡេកមើលទៅ។»
បួនប្រុសរបស់គាត់ កូនរបស់ម្តាយគាត់ ហើយគាត់និយាយថា
នេះអាចត្រូវបានបកប្រែជាមួយនឹងប្រយោគថ្មី។ ការបកប្រែផ្សេងទៀត៖
«កូនប្រុសរបស់ម្តាយគាត់។ យ៉ូសែបបាននិយាយថា»
តើគាត់នោះគឺជាប្អូនប្រុសពៅដែលអ្នករាល់គ្នាបានប្រាប់ខ្ញុំ?
អត្ថន័យដែលមានគឺ ១)
យ៉ូសែបពិតជាកំពុងសួរសំណួរមួយដើម្បីបញ្ជាក់ថាបុរសនេះគឺជាបេនយ៉ាមីនឬ ២)
វាគឺជាសំណួរវោហាសាស្ត្រ។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះនេះគឺជាប្អូនប្រុសពៅរបស់អ្នក ... ខ្ញុំ»
កូនប្រុស
នេះជាវិធីរួសរាយរាក់ទាក់ដែលបុរសម្នាក់និយាយទៅកាន់បុរសម្នាក់ទៀតដែលមានឋានៈទាប។
ការបកប្រែផ្សេងទៀត៖ « យុវជន» (UDB)
Genesis 43:30
ប្រញាប់ចេញទៅក្រៅបន្ទប់
«ប្រញាប់ចេញពីបន្ទប់»
ដ្បិតគាត់មានចិត្តក្តុកក្តួលជាមួយប្អូនប្រុសរបស់គាត់
ឃ្លាថា« រំជួលចិត្ត»
សំដៅទៅលើការមានអារម្មណ៍ឬអារម្មណ៍ខ្លាំងនៅពេលមានរឿងសំខាន់កើតឡើង។
ការបកប្រែផ្សេងទៀត៖ «
សម្រាប់គាត់មានអារម្មណ៍អាណិតអាសូរយ៉ាងខ្លាំងចំពោះបងប្អូនរបស់គាត់» ឬ
«សម្រាប់គាត់មានអារម្មណ៍ស្រលាញ់ខ្លាំងចំពោះបងប្អូនរបស់គាត់»
ដោយនិយាយ
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ចំពោះនរណាដែលយ៉ូសែបកំពុងនិយាយ។
ការបកប្រែផ្សេងទៀត៖ « ហើយបាននិយាយទៅកាន់អ្នកបម្រើរបស់គាត់»
យ៉ាងឆាប់រហ័ស។
នេះមានន័យថាចែកចាយអាហារដើម្បីឱ្យមនុស្សអាចញ៉ាំបាន។
Genesis 43:32
អ្នកបម្រើរបស់លោកយ៉ូសែបបានលើកម្ហូបជូនលោកយ៉ូសែបដោយផ្ទាល់
ហើយឲ្យបងៗដួសម្ហូបខ្លួនឯង។
ជនជាតិអេស៊ីបនៅទីនោះហូបអាហារជាមួយគាត់ដោយឡែកដោយខ្លួនរបស់ពួកគេ
នេះមានន័យថាយ៉ូសែបបងប្អូននិងប្រជាជនអេស៊ីបផ្សេងទៀតកំពុងបរិភោគនៅកន្លែងបីផ្សេងគ្នានៅក្នុងប
ការបកប្រែផ្សេងទៀត៖ «
ពួកអ្នកបំរើបានបម្រើលោកយ៉ូសែបដោយខ្លួនឯង,និងបងប្អូនរបស់គាត់ផ្ទាល់ និង
ជនជាតិអេស៊ីបដែលកំពុងបរិភោគជាមួយគាត់ផ្ទាល់»
ជនជាតិអេស៊ីបនៅទីនោះហូបអាហារជាមួយគាត់ដោយឡែកដោយខ្លួនរបស់ពួកគេ
ទាំងនេះប្រហែលជាមន្ត្រីអេស៊ីបផ្សេងទៀតដែលបានបរិភោគជាមួយយ៉ូសែបប៉ុន្តែពួកគេនៅតែអង្គុយដាច់
ព្រោះជនជាតិអេស៊ីបមិនហូបនំប៉័ងជាមួយជនជាតិហេព្រើរទេ ដ្បិតជនជាតិអេស៊ីបខ្ពើមនឹងការនោះ
នេះអាចត្រូវបានបកប្រែជាប្រយោគថ្មី
«ពួកគេបានធ្វើបែបនេះពីព្រោះជនជាតិអេស៊ីបគិតថាវាគួរឱ្យខ្មាស់ណាស់ក្នុងការបរិភោគជាមួយជនជាតិ
មិនហូបនំប៉័ង
នៅទីនេះ «នំប៉័ង» តំណាងឱ្យអាហារជាទូទៅ។
បងៗអង្គុយទល់មុខគាត់
នេះបញ្ជាក់ថាយ៉ូសែបបានរៀបចំកន្លែងដែលបងប្រុសម្នាក់ៗនឹងអង្គុយ។
អ្នកអាចធ្វើឱ្យច្បាស់នូវព័ត៌មានដែលបង្កប់ន័យ។ ការបកប្រែផ្សេងទៀត៖ «
បងប្អូនបានអង្គុយនៅពីមុខបុរសនោះតាមរបៀបដែលគាត់រៀបចំកន្លែងរបស់ពួកគេ»
ពួកគេអង្គុយតាមលេខរៀងពីបងច្បងទៅប្អូនពៅ តាមអាយុរបស់ពួកគេ
«កូនច្បង»និង
«កូនពៅ»ត្រូវបានប្រើរួមគ្នាដើម្បីមានន័យថាបងប្អូនទាំងអស់កំពុងអង្គុយតាមលំដាប់លំដោយយោងទៅ
ពួកគេមានការឆ្ងល់ទាំងអស់គ្នា
«បុរសទាំងនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលពួកគេដឹងរឿងនេះ»
ប៉ុន្តែ ចំណែករបស់បេនយ៉ាមីន ប្អូនប្រុសរបស់គាត់វិញ ប្រាំដងលើសបងៗរបស់គាត់
ឃ្លា «ប្រាំដង» អាចត្រូវបានបញ្ជាក់ជាទូទៅ។ ការបកប្រែផ្សេងទៀត៖ «
ប៉ុន្តែបេនយ៉ាមីនបានទទួលចំណែកដែលធំជាងអ្វីដែលបងប្អូនរបស់គាត់បានទទួល»

---

44 [1]លោកយ៉ូសែបបានបង្គាប់អ្នកបម្រើនៅក្នុងផ្ទះរបស់គាត់ ដោយពោលថា៖ «ចូរយកស្បៀងដាក់បាវ ច្រើនតាមដែលអាច ពួកគេអាចយកបាន
ហើយដាក់ប្រាក់នៅក្នុងបាវរបស់បុរសម្នាក់ៗវិញ។[2]ដាក់ពែងរបស់ខ្ញុំ ពែងប្រាក់នៅក្នុងបួនពៅ ហើយនិងប្រាក់ថ្លៃទិញស្រូវរបស់គាត់ទៅក្នុងបាវរបស់គាត់វិញ»។
អ្នកបម្រើបានធ្វើដូចដែលលោកយ៉ូសែបបានបង្គាប់។
[3]ពេលព្រឹកព្រលឹម ហើយគេបានឲ្យបុរសទាំងនោះត្រឡប់ទៅវិញ ទាំងពួកគេ និងលារបស់ពួកគេ។[4]នៅពេលពួកគេចេញក្រៅក្រុង ប៉ុន្តែ មិនទាន់ឆ្ងាយប៉ុន្មានទេ
លោកយ៉ូសែបប្រាប់ទៅអ្នកបម្រើរបស់គាត់ថា៖ «ចូរក្រោកឡើង ដេញតាមពួកគេ ហើយនៅពេលតាមពួកគេទាន់ ចូរនិយាយទៅពួកគេថា៖
ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើអាក្រក់ស្នងនឹងការល្អដូច្នេះ?[5]តើនេះមិនមែនជាពែងដែលចៅហ្វាយរបស់ខ្ញុំផឹក និងជាពែងដែលគាត់ប្រើសម្រាប់ទស្សន៍ទាយទេឬ?
ការដែលអ្នកធ្វើនេះ អ្នករាល់គ្នាបានធ្វើអាក្រក់ហើយ»។
[6]អ្នកបម្រើបានដេញតាមទាន់ពួកគេ ហើយនិយាយការទាំងនេះជាមួយពួកគេ។[7]ពួកគេនិយាយទៅគាត់វិញថា៖ «ហេតុអ្វីបានជាលោកម្ចាស់មានប្រសាសន៍បែបនេះ?
យើងខ្ញុំមិនបានធ្វើការយ៉ាងដូច្នេះឡើយ។
[8]មើល៍ ប្រាក់ដែលយើងខ្ញុំបានឃើញនៅក្នុងបាវរបស់យើងខ្ញុំ យើងបានយកវាមកពីទឹកដីកាណានមកជូនលោកវិញ។ បើដូច្នេះមែន ធ្វើដូចម្តេចឲ្យយើងខ្ញុំអាចលួចប្រាក់
និងមាសពីផ្ទះចៅហ្វាយរបស់លោកបានទៅ?[9]ប្រសិនបើ ឃើញនៅក្នុងបាវរបស់នរណា ចូរឲ្យអ្នកនោះស្លាប់ចុះ
ហើយយើងខ្ញុំនឹងធ្វើជាអ្នកបម្រើរបស់ចៅហ្វាយរបស់លោក»។[10]អ្នកបម្រើនោះពោលថា៖ «សូមឲ្យវាកើតឡើងតាមសម្តីរបស់លោកចុះ។ ប្រសិនបើ
រកឃើញពែងនៅក្នុងបាវរបស់នរណា អ្នកនោះនឹងក្លាយជាអ្នកបម្រើរបស់ខ្ញុំ ហើយអ្នកផ្សេងទៀតនឹងរួចខ្លួន»។

generated on Wed Sep 10 16:16:32 2025

[11]បន្ទាប់មក ពួកគេប្រញាប់ ហើយយកបាវរបស់ពួកគេចុះដល់ដី ហើយពួកគេម្នាក់បានបើកបាវរបស់ពួកគេ។ អ្នកបម្រើបានបានឆែកឆេរ។
[12]គាត់បានចាប់ផ្តើមឆែកឆេរតាំងពីបងប្រុសច្បងរហូតដល់ប្អូនពៅ ហើយពែងនោះត្រូវបានរកឃើញនៅក្នុងបាវរបស់បេនយ៉ាមីន។[13]ពួកគេបានហែកអាវរបស់ពួកគេ។
ពួកគេម្នាក់ៗបានលើកបាវដាក់លើខ្នងលាវិញ ហើយត្រឡប់ទៅទីក្រុងវិញ។
[14]លោកយូដា និងបងប្អូនរបស់គាត់បានមកឯផ្ទះរបស់លោកយ៉ូសែបវិញ ហើយពួកគេបានលុតជង្គង់នៅចំពោះមុខគាត់ដល់ដី។[15]លោកយ៉ូសែបនិយាយទៅពួកគេថា៖
«ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើដូច្នេះ? តើអ្នករាល់គ្នាមិនដឹងទេថា មនុស្សដូចខ្ញុំនេះចេះទស្សន៍ទាយទេឬ?»។
[16]លោកយូដាប្រាប់ថា៖ «តើយើងខ្ញុំអាចឆ្លើយនឹងលោកម្ចាស់បានយ៉ាងដូចម្តេច? តើយើងអាចនិយាយអ្វីបាន? ឬតើយើងអាចបង្ហាញថាត្រឹមត្រូវបានយ៉ាងដូចម្តេច?
ព្រះជាម្ចាស់បានរកឃើញកំហុសរបស់យើងខ្ញុំហើយ។ មើល យើងខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់ហើយ ទាំងយើងខ្ញុំ
និងអ្នកដែលត្រូវបានគេរកឃើញពែងនៅនឹងដៃដែរ»។[17]លោកយ៉ូសែបនិយាយថា៖ «ទេ ខ្ញុំមិនធ្វើដូច្នេះទេ។ នរណាដែលត្រូវបានគេរកឃើញពែងនៅនឹងដៃ
អ្នកនោះហើយនឹងក្លាយជាអ្នកបម្រើរបស់ខ្ញុំ ប៉ុន្តែ សម្រាប់លោក និងអ្នកផ្សេងៗទៀត ចូរទៅផ្ទះរបស់ឪពុកអ្នករាល់គ្នាឲ្យបានសុខចុះ»។
[18]បន្ទាប់មក លោកយូដាបានមកជិតគាត់ ហើយប្រាប់ថា៖ «លោកម្ចាស់ សូមលោកម្ចាស់ស្តាប់ពាក្យខ្ញុំដែលជាអ្នកបម្រើរបស់លោកសិន
ហើយសូមលោកម្ចាស់ខឹងនឹងអ្នកបម្រើរបស់លោកចុះ ដ្បិត លោកប្រៀបដូចជាស្តេចផារោនទៅហើយ។[19]លោកម្ចាស់បានសួរយើងខ្ញុំជាអ្នកបម្រើថា៖ «អ្នករាល់គ្នាមាន
ឪពុក មានប្អូនឬទេ?»
[20]យើងខ្ញុំជម្រាបលោកម្ចាស់ហើយថា៖ «យើងមានឪពុកម្នាក់ គាត់ចាស់ហើយ ហើយគាត់មានកូនមួយក្នុងការដែលគាត់មានអាយុច្រើនហើយ មានកូនតូចមួយ។ ប៉ុន្តែ
បងប្រុសរបស់គាត់បានស្លាប់ហើយ ហើយមានគាត់តែម្នាក់ទេដែលម្តាយរបស់គាត់បានសន្សល់ទុកឲ្យគាត់ ហើយឪពុករបស់គាត់ស្រឡាញ់គាត់ណាស់។
[21]ពេលលោកម្ចាស់មានប្រសាសន៍មកយើងខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់ ឲ្យនាំគាត់ចុះមកជាមួយខ្ញុំ ដើម្បីឲ្យលោកម្ចាស់បានឃើញគាត់»។[22]បន្ទាប់មកទៀត
យើងបានជម្រាបលោកម្ចាស់ហើយថា៖ «ក្មេងប្រុសនេះមិនអាចចាកចេញពីឪពុករបស់គាត់បានឡើយ។ ដ្បិត ប្រសិនបើ គាត់ចេញពីឪពុករបស់
នោះឪពុករបស់គាត់នឹងស្លាប់»។
[23]បន្ទាប់មក លោកម្ចាស់មានប្រសាសន៍មកកាន់យើងខ្ញុំថា៖ «លុះត្រាតែប្អូនប្រុសពៅរបស់យើងខ្ញុំចុះមករកលោកម្ចាស់ បានលោកម្ចាស់ព្រមជួបមុខយើងខ្ញុំម្តងទៀត»។
[24]បន្ទាប់មក យើងខ្ញុំបានត្រឡប់ទៅរកឪពុករបស់យើងខ្ញុំវិញ យើងខ្ញុំបានប្រាប់គាត់តាមពាក្យរបស់លោកម្ចាស់។[25]ឪពុករបស់យើងខ្ញុំប្រាប់ថា៖
«ចូរកូនៗទៅទិញស្បៀងឲ្យយើងម្តងទៀតចុះ»។[26]នៅពេលយើងប្រាប់គាត់ថា៖ «យើងមិនអាចទៅបានទេ។ ប្រសិនបើ ប្អូនប្រុសពៅទៅជាមួយយើង ទើបយើងចុះទៅ
ដើម្បីយើងនឹងមិនអាចឃើញមុខលោកម្ចាស់បានទេ លុះត្រាតែប្អូនប្រុសពៅទៅជាមួយយើង»។
[27]ឪពុករបស់យើងខ្ញុំប្រាប់មកយើងខ្ញុំថា៖ «កូនដឹងទេថា ភរិយារបស់ឪពុកបង្កើតកូនប្រុសពីរនេះឲ្យឪពុក។[28]ម្នាក់ក្នុងចំណោមពួកគេបានចាកចាញ្ចពីឪពុក
ហើយឪពុកប្រាប់ថា៖ «ប្រាកដណាស់ គាត់ត្រូវសត្វហែកស៊ីអស់ហើយ ហើយឪពុកក៏លែងឃើញគាត់ទៀតដែរ»។[29]ឥឡូវ ប្រសិនបើ
កូនយកកូនប្រុសម្នាក់ទៀតចេញពីឪពុក ហើយកូនរបស់ឪពុកមានគ្រោះថ្នាក់អ្វីនោះ កូននឹងនាំឪពុកដែលចាស់សក់ស្កូវម្នាក់នេះកើតទុក្ខនៅក្នុងស្ថានឃុំព្រលឹងហើយ»។
[30]ដូច្នេះ នៅពេលយើងខ្ញុំទៅជួបឪពុករបស់យើងខ្ញុំ ដែលជាអ្នកបម្រើលោកម្ចាស់ ក្មេងប្រុសនេះមិននៅជាមួយយើងខ្ញុំទេ
ក្មេងនេះជាទីស្រឡាញ់នៅក្នុងជីវិតរបស់គាត់ណាស់ ហើយនៅពេលគាត់ដឹងថា ក្មេងនេះមិននៅជាមួយយើងខ្ញុំ គាត់មុខជាស្លាប់មិនខាន។
[31]យើងខ្ញុំជាអ្នកបម្រើលោកម្ចាស់នឹងធ្វើឲ្យឪពុកដែលចាស់សក់ស្កូវ កើតទុក្ខនៅក្នុងស្ថានឃុំព្រលឹងមិនខាន។[32]ដ្បិត
យើងខ្ញុំដែលជាអ្នកបម្រើលោកម្ចាស់បានធានាការពារកូនប្រុសនេះ ចំពោះឪពុករបស់យើងខ្ញុំហើយ ដោយនិយាយថា៖ «ប្រសិនបើ
កូនមិននាំក្មេងនេះមកជូនលោកឪពុកវិញទេ កូននឹងមានកំហុសចំពោះលោកឪពុករហូត»។
[33]ដូច្នេះ សូមលោកម្ចាស់ មេត្តាដល់យើងខ្ញុំជាអ្នកបម្រើលោកម្ចាស់ ជំនួសឲ្យ ក្មេងប្រុសនេះធ្វើជាអ្នកបម្រើលោកម្ចាស់ សូមអនុញ្ញាតឲ្យក្មេងប្រុសនេះ
បានឡើងទៅជាមួយបងប្អូនរបស់គាត់ទៅ។[34]តើឲ្យខ្ញុំអាចឡើងទៅរកឪពុករបស់ខ្ញុំបានយ៉ាងដូចម្តេច ប្រសិនបើ ក្មេងប្រុសនេះមិននៅជាមួយខ្ញុំទេនោះ? ខ្ញុំខ្លាច
មានរឿងអាក្រក់ដែលអាចនឹងកើតឡើងចំពោះឪពុករបស់ខ្ញុំ»។

Genesis 44:1
ព័ត៌មានទូទៅ
នេះចាប់ផ្តើមព្រឹត្តិការណ៍ថ្មីនៅក្នុងរឿង។
ច្រើនទំនងនេះគឺនៅព្រឹកបន្ទាប់បន្ទាប់ពីពិធីជប់លៀង។
អ្នកបម្រើនៅក្នុងផ្ទះ
«អ្នកបម្រើ» ទទួលខុសត្រូវក្នុងការគ្រប់គ្រងសកម្មភាពគ្រួសាររបស់យ៉ូសែប។
លុយក្នុងម្ហូបក្ងាន
ប្រាក់របស់ពួកគេគឺជាកាក់ប្រាក់ដែលភាគច្រើនទំនងជានៅក្នុងកាបូបតូចមួយ។
ដាក់ប្រាក់នៅក្នុងបាវ
«នៅក្នុងបាវរបស់គាត់»
ដាក់ពែងរបស់ខ្ញុំ ,ពែងប្រាក់
«ដាក់ពែងប្រាក់របស់ខ្ញុំ»
នៅក្នុងប្អូនពៅ
ពាក្យថាបងប្អូនត្រូវបានយល់។ ការបកប្រែផ្សេងទៀត៖ «
នៅក្នុងបាវរបស់ប្អូនប្រុសពៅ»
Genesis 44:3
ពេលព្រឹកព្រលឹម
«ពន្លឺពេលព្រឹកបានបង្ហាញ»
បុរសទាំងនោះត្រឡប់ទៅវិញ ទាំងពួកគេ និង លារបស់ពួកគេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ពួកគេបានបញ្ជូនបុរសទាំងនោះចេញទៅ ជាមួយលារបស់ពួកគេ»
ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើអាក្រក់ស្មុងនឹងការល្អដូច្នេះ?
សំណួរនេះត្រូវបានប្រើដើម្បីស្តីបន្ទោសបងប្អូន។ អេធី:
«អ្នកបានធ្វើបាបយើងយ៉ាងធ្ងន់ធ្ងរ បន្ទាប់ពីយើងបានល្អចំពោះអ្នក!»
តើនេះមិនមែនជាពែងដែលចៅហ្វាយរបស់ខ្ញុំផឹក និងជាពែងដែលគាត់ប្រើសម្រាប់ទស្សន៍ទាយទេឬ?
សំណួរនេះត្រូវបានប្រើដើម្បីស្តីបន្ទោសបងប្អូន។ ការបកប្រែផ្សេងទៀត៖ «
អ្នកដឹងរួចហើយថានេះគឺជាពែងដែលចៅហ្វាយខ្ញុំប្រើសម្រាប់ផឹកនិងសម្រាប់ប្រាប់សំណាង!»(សូមមើល
ការដែលអ្នកធ្វើនេះ អ្នករាល់គ្នាបានធ្វើអាក្រក់ហើយ
នេះនិយាយឡើងវិញ«អ្នកបានធ្វើ» សម្រាប់ការសង្កត់ធ្ងន់។ការបកប្រែផ្សេងទៀត៖
« អ្វីដែលអ្នកបានធ្វើគឺអាក្រក់ណាស់»
Genesis 44:6
និយាយការទាំងនេះជាមួយពួកគេ
នៅទីនេះ «ពាក្យ» តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។ ការបកប្រែផ្សេងទៀត៖
« និយាយអ្វីដែលយ៉ូសែបបានប្រាប់គាត់ឱ្យនិយាយ»
ហេតុអ្វីបានជាលោកម្ចាស់មានប្រសាសន៍បែបនេះ?
នៅទីនេះ «ពាក្យ» តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។
បងប្អូនទាំងនោះចាត់ទុកអ្នកបម្រើនោះថាជា«ម្ចាស់របស់ខ្ញុំ»។
នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
វាអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីពីរ។ ការបកប្រែផ្សេងទៀត៖ «
ហេតុអ្វីបានជាអ្នកនិយាយបែបនេះចៅហ្វាយខ្ញុំអើយ?»
យើងខ្ញុំមិនបានធ្វើការយ៉ាងដូច្នេះឡើយ
បងប្អូនបានចាត់ទុកខ្លួនឯងថាជា «អ្នកបម្រើរបស់អ្នក» និង«ពួកគេ។»
នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
ការបកប្រែផ្សេងទៀត៖ « យើងនឹងមិនធ្វើរឿងបែបនេះទេ!»
ឆ្ងាយពីអ្នកបម្រើរបស់លោកម្ចាស់
អ្វីមួយដែលមនុស្សម្នាក់នឹងមិនបានធ្វើ
ត្រូវបានគេនិយាយដូចជាវត្ថុដែលមនុស្សចង់ដាក់ឆ្ងាយពីខ្លួនឯង។
Genesis 44:8
មើល៏
នេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលបងប្អូននិយាយបន្ទាប់។

generated on Wed Sep 10 16:16:32 2025

ប្រាក់ដែលយើងខ្ញុំបានឃើញនៅក្នុងបាវរបស់យើងខ្ញុំ
«អ្នកដឹងពីប្រាក់ដែលយើងរកឃើញនៅក្នុងបាវរបស់យើងហើយ»
យើងបានយកវាមកពីទឹកដីកាណានមកជូនលោកវិញ
«យើងបាននាំអ្នកពីកាណានមកវិញ»
ធ្វើដូចម្តេចឲ្យយើងខ្ញុំអាចលួចប្រាក់ និងមាសពីផ្ទះចៅហ្វាយរបស់លោកបានទៅ?
បងប្អូនប្រុសប្រើសំណួរដើម្បីបញ្ជាក់ថាពួកគេនឹងមិនលួចពីម្ចាស់ស្រុកអេស៊ីបទេ។
ការបកប្រែផ្សេងទៀត៖ « ដូច្នេះពួកយើង នឹងមិនយកអ្វីពីផ្ទះម្ចាស់របស់អ្នកទេ!»
ប្រាក់ ឬមាស
ពាក្យទាំងនេះត្រូវបានប្រើរួមគ្នាដើម្បីមានន័យថាពួកគេនឹងមិនលួចអ្វីដែលមានតម្លៃនោះទេ
ប្រសិនបើ ឃើញនៅក្នុងបាវរបស់នរណា
បងប្អូនបានចាត់ទុកខ្លួនឯងថាជា«អ្នកបម្រើរបស់លោក។»
នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
វាអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីមួយ។ ដូចគ្នានេះផងដែរ
«ត្រូវបានរកឃើញ» អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត៖ «
ប្រសិនបើអ្នករកឃើញថាយើងណាម្នាក់បានលួចយកពែង»
យើងខ្ញុំនឹងធ្វើជាអ្នកបម្រើរបស់ចៅហ្វាយរបស់លោក
ឃ្លា «ម្ចាស់របស់ខ្ញុំ» សំដៅទៅលើអ្នកបម្រើ។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីពីរ។ ការបកប្រែផ្សេងទៀត៖ «
លោកអាចយកយើងធ្វើជាទាសកររបស់លោក»
សូមឲ្យវាកើតឡើងតាមសម្តីរបស់លោកចុះ
នៅទីនេះ «ឥឡូវនេះ» មិនមានន័យថា «នៅពេលនេះទេ»
ប៉ុន្តែត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះចំណុចសំខាន់ដែលនៅខាងក្រោយ
ដូចគ្នានេះផងដែរ«ពាក្យ» តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។
ការបកប្រែផ្សេងទៀត៖ « ល្អណាស់ ខ្ញុំនឹងធ្វើតាមអ្វីដែលអ្នកបាននិយាយ»
ប្រសិនបើ រកឃើញពែងនៅក្នុងបាវរបស់នរណា អ្នកនោះនឹងក្លាយជាអ្នកបម្រើរបស់ខ្ញុំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ប្រសិនបើខ្ញុំរកឃើញពែងនៅក្នុងបាវរបស់អ្នកម្នាក់នោះនឹងក្លាយជាបាវខ្ញុំ»
Genesis 44:11
យកបាវរបស់ពួកគេចុះដល់ដី
«ដាក់បាវរបស់ពួកគេចុះក្រោម»
ពីបងច្បង.....ដល់ប្អូនពៅ
ពាក្យថា«បងប្អូន»ត្រូវបានយល់។ ការបកប្រែផ្សេងទៀត៖ «បងប្រុសច្បង...
ប្អូនពៅ»
ប្អូនពៅ,ហើយពែងនោះត្រូវបានរកឃើញនៅក្នុងបាវរបស់បេនយ៉ាមីន
នេះអាចត្រូវបានបកប្រែជាប្រយោគថ្មីនិងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
« ប្អូនពៅ,អ្នកបម្រើបានរកឃើញពែងនៅក្នុងបាវរបស់បេនយ៉ាមីន»
ពួកគេបានហែកអាវរបស់ពួកគេ
ពាក្យថា«ពួកគេ»សំដៅលើបងប្អូន។
សម្លៀកបំពាក់រហែកគឺជាសញ្ញាមួយនៃភាពទុក្ខព្រួយនិងទុក្ខព្រួយយ៉ាងខ្លាំង។
ហើយត្រឡប់ទៅទីក្រុងវិញ
«ហើយពួកគេបានវិលត្រលប់ទៅវិញ»
Genesis 44:14
គាត់បាននៅទីនោះ
«លោកយ៉ូសែបកំពង់តែនៅទីនោះ»
ពួកគេបានលុតជង្គង់នៅចំពោះមុខគាត់
«ពួកគេបានលុតនៅចំពោះគាត់។
»នេះជាសញ្ញាសំគាល់របស់បងប្អូនដែលចង់អោយចៅហ្វាយមានក្តីអាណិតអាសូរដល់ពួកគេ
តើអ្នករាល់គ្នាមិនដឹងទេថា មនុស្សដូចខ្ញុំនេះចេះទស្សន៍ទាយទេឬ?
យ៉ូសែបប្រើសំនួរមួយដើម្បីស្តីបន្ទោសបងប្អូនរបស់គាត់។ ការបកប្រែផ្សេងទៀត៖ «
អ្នកប្រាកដជាដឹងហើយថាបុរសដូចខ្ញុំអាចរៀនអ្វីៗដោយការទស្សន៍ទាយ!»
Genesis 44:16
តើយើងខ្ញុំអាចឆ្លើយនឹងលោកម្ចាស់បានយ៉ាងដូចម្តេច? តើយើងអាចនិយាយអ្វីបាន?
ឬតើយើងអាចបង្ហាញថាត្រឹមត្រូវបានយ៉ាងដូចម្តេច?
សំណួរទាំង ៣ មានន័យថាមានន័យដូចគ្នា។
ពួកគេប្រើសំណួរទាំងនេះដើម្បីបញ្ជាក់ថាគ្មានអ្វីដែលពួកគេអាចនិយាយដើម្បីពន្យល់ពីអ្វីដែលបានកើតឡើង
ការបកប្រែផ្សេងទៀត៖ « យើងគ្មានអ្វីដែលត្រូវនិយាយ ទៅចៅហ្វាយខ្ញុំទេ។
យើងមិនអាចនិយាយអ្វីដែលមានតម្លៃទេ។
យើងមិនអាចបង្ហាញអំពីភាពត្រឹមត្រូវចំពោះខ្លួនយើងទេ។»
តើយើងខ្ញុំអាចឆ្លើយនឹងលោកម្ចាស់បានយ៉ាងដូចម្តេច.....យើងខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់
នៅទីនេះ «ម្ចាស់របស់ខ្ញុំ» សំដៅទៅលើយ៉ូសែប។
នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
វាអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទី២ ។ ការបកប្រែផ្សេងទៀត៖ «
តើយើងអាចនិយាយអ្វីទៅលោកម្ចាស់ ... អ្នកបំរើរបស់លោកម្ចាស់»
ព្រះជាម្ចាស់បានរកហើយ
ត្រង់នេះ«
បានរកឃើញ»មិនមានន័យថាព្រះជាម្ចាស់បានរកឃើញនូវអ្វីដែលបងប្អូនបានធ្វើ។
ពាក្យនេះមានន័យថាព្រះជាម្ចាស់កំពុងតែដាក់ទណ្ឌកម្មពួកគេចំពោះអ្វីដែលពួកគេបានធ្វើ។
ការបកប្រែផ្សេងទៀត៖ «
ព្រះកំពុងដាក់ទណ្ឌកម្មយើងចំពោះអំពើបាបពីអតីតកាលរបស់យើង»
ឃើញកំហុសរបស់យើងខ្ញុំជាអ្នកបំរើលោកម្ចាស់
បងប្អូនបានចាត់ទុកខ្លួនឯងថាជា« អ្នកបម្រើរបស់លោកម្ចាស់។
»នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
វាអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីមួយ។ ការបកប្រែផ្សេងទៀត៖ «
អំពើទុច្ចរិតរបស់យើង»
អ្នកដែលត្រូវបានគេរកឃើញពែងនៅនឹងដៃដែរ
នៅទីនេះ«ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ដូចគ្នានេះផងដែរ
«ត្រូវបានគេរកឃើញ» អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត៖ « និងអ្នកដែលមានពែងរបស់លោក»
ខ្ញុំមិនធ្វើដូច្នេះទេ។
អ្វីមួយដែលមនុស្សម្នាក់នឹងមិនធ្វើត្រូវបានគេនិយាយដូចជាវត្ថុដែលមនុស្សចង់ដាក់ឆ្ងាយពីគាត់។
ការបកប្រែផ្សេងទៀត៖ « វាមិនដូចខ្ញុំដែលធ្វើអ្វីមួយដូចនោះទេ»
នរណាដែលត្រូវបានគេរកឃើញពែងនៅនឹងដៃ
នៅទីនេះ «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ដូចគ្នានេះផងដែរ
«ត្រូវបានគេរកឃើញ» អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត៖ « បុរសដែលមានពែងរបស់ខ្ញុំ»
Genesis 44:18
បានមកជិត
«ចូលទៅ ិជិត»
សូមអ្នកបម្រើរបស់លោក
យូដាចាត់ទុកខ្លួនគាត់ថាជា
«អ្នកបម្រើរបស់លោក»នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចច្រើនជាង។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីមួយ។ ការបកប្រែផ្សេងទៀត៖ «
សូមឱ្យខ្ញុំ,អ្នកបម្រើរបស់លោក»
សូមលោកម្ចាស់ស្តាប់ពាក្យ
នៅទីនេះ «ពាក្យ»គឺជាការប្រៀបធៀបដែលតំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។
ហើយ «ត្រចៀក» គឺជា synecdoche ដែលតំណាងឱ្យមនុស្សទាំងមូល។
ការបកប្រែផ្សេងទៀត៖ « និយាយទៅកាន់លោកម្ចាស់របស់ខ្ញុំ» (សូមមើល: និង
ក្នុងត្រចៀកលោកម្ចាស់ខ្ញុំសិន
នៅទីនេះ «ម្ចាស់ខ្ញុំ» សំដៅទៅលើយ៉ូសែប។
នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចច្រើនជាង។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីពីរ។ ការបកប្រែផ្សេងទៀត៖ «
ទៅកាន់លោក»
សូមលោកម្ចាស់ខឹងនឹងអ្នកបម្រើរបស់លោកចុះ
ការខឹងត្រូវបានគេនិយាយដូចជាវាជាភ្លើងដែលកំពុងឆេះ។ ការបកប្រែផ្សេងទៀត៖
« សូមកុំខឹងនឹងខ្ញុំដែលជាអ្នកបំរើរបស់អ្នក»
ចាប់ដូចជាស្តេចផារោនទៅហើយ
យូដាប្រៀបធៀបម្ចាស់ទៅនឹងព្រះចៅផារ៉ោនដើម្បីបញ្ជាក់ពីអំណាចដ៏អស្ចារ្យដែលម្ចាស់មាន។
គាត់ក៏កំពុងតែអះអាងថាគាត់ពិតជាចង់អោយម្ចាស់គាត់ខឹងហើយប្រហារជីវិតគាត់។
ការបកប្រែផ្សេងទៀត៖ «
ដ្បិតលោកមានអំណាចដូចព្រះចៅផារ៉ោនហើយអាចអោយទាហានរបស់លោកសម្លាប់ខ្ញុំ»
លោកម្ចាស់បានសួរយើងខ្ញុំជាអ្នកបម្រើថា៖ «អ្នករាល់គ្នាមានឪពុក មានប្អូនឬទេ?
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ «
អ្នកបានសួរយើងខ្ញុំថាតើយើងមានឪពុកឬប្អូនប្រុសឬ ។»
លោកម្ចាស់បានសួរយើងខ្ញុំជាអ្នកបម្រើថា
យូដាសំដៅលើយ៉ូសែបដោយពាក្យថា «លោកម្ចាស់របស់ខ្ញុំ» និង «របស់គាត់។»
គាត់ក៏ចាត់ទុកខ្លួនគាត់និងបងប្អូនគាត់ថាជា«អ្នកបម្រើរបស់គាត់» ដែរ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត៖ « លោកម្ចាស់ខ្ញុំបានសួរយើងពួកអ្នកបម្រើរបស់លោក» ឬ «លោកបានសួរយើង»
Genesis 44:20
ព័ត៌មានទូទៅ
លោកយូដាបន្តរៀបរាប់ប្រាប់ចណពោះមុខលោកយ៉ូសែប។
យើងខ្ញុំជម្រាបលោកម្ចាស់ហើយថា,យើងមានឪពុកម្នាក់.....ឪពុករបស់គាតស្រលាញ។គាត់ណាស់
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ « ហើយយើងបាននិយាយទៅកាន់ម្ចាស់របស់ខ្ញុំថាយើងមានឪពុក ... ឪពុកស្រឡាញ់គាត់»
យើងខ្ញុំជម្រាបលោកម្ចាស់ហើយថា
យូដាហៅយ៉ូសែបថាជា«ម្ចាស់របស់ខ្ញុំ»។
នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
ការបកប្រែផ្សេងទៀត៖ « យើងបាននិយាយទៅកាន់លោកថា,លោកម្ចាស់របស់ខ្ញុំ»
ឪពុករបស់គាត់ស្រឡាញ់គាត់ណាស់
នេះសំដៅទៅលើសេចក្តីស្រឡាញ់ចំពោះមិត្តភក្តិឬសមាជិកគ្រួសារ។
ពេលលោកម្ចាស់មានប្រសាសន៍មកយើងខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់ ឲ្យនាំគាត់ចុះមកជាមួយខ្ញុំ ដើម្បីឲ្យលោកម្ចាស់បានឃើញគាត់
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ « ហើយលោកបានមានប្រសាសន៏ទៅកាន់អ្នកបម្រើរបស់លោកថាយើងគួរតែនាំប្អូនពៅរបស់យើងមកដែរ»
លោកម្ចាស់មានប្រសាសន៍មកយើងខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់
យូដាចាត់ទុកខ្លួនគាត់និងបងប្អូនរបស់គាត់ថាជា«អ្នកបំរើរបស់លោក។
»ការបកប្រែផ្សេងទៀត៖ « បន្ទាប់មកលោកបាននិយាយមកយើងពួកអ្នកបម្រើរបស់លោក» (សូមមើល:figs-123person)
ឲ្យនាំគាត់ចុះមកជាមួយខ្ញុំ
វាជារឿងធម្មតាទេដែលប្រើពាក្យថា« ចុះ»
នៅពេលនិយាយពីការធ្វើដំណើរពីកាណានទៅស្រុកអេស៊ីប។
ការបកប្រែផ្សេងទៀត៖ « នាំគាត់មកខ្ញុំ»
បន្ទាប់មកទៀត យើងបានជម្រាបលោកម្ចាស់ហើយថា៖
«ក្មេងប្រុសនេះមិនអាចចាក....នោះឪពុករបស់គាត់នឹងស្លាប់
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ « ជាការឆ្លើយតបយើងបាននិយាយទៅកាន់ម្ចាស់របស់ខ្ញុំថាក្មេងប្រុសនេះមិនអាច... ឪពុកនឹងត្រូវស្លាប់»
នោះឪពុករបស់គាត់នឹងស្លាប់
វាបញ្ជាក់ថាឪពុករបស់ពួកគេនឹងស្លាប់ដោយសារទុក្ខព្រួយ។
Genesis 44:23
ព័ត៌មានទូទៅ
លោកយូដាបន្តប្រាប់រឿងដល់លោកយ៉ូសែប
បន្ទាប់មក លោកម្ចាស់មានប្រសាសន៍មកកាន់យើងខ្ញុំថា
លុះត្រាតែប្អូនប្រុសពៅរបស់យើងខ្ញុំចុះមករកលោកម្ចាស់
បានលោកម្ចាស់ព្រមជួបមុខយើងខ្ញុំម្តងទៀត
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ « បន្ទាប់មកអ្នកបាននិយាយទៅកាន់អ្នកបំរើរបស់លោកថា លើកលែងតែប្អូនប្រុសពៅរបស់យើងមកជាមួយយើង យើងនឹងមិនជួបលោកទៀតទេ»
បន្ទាប់មក លោកម្ចាស់មានប្រសាសន៍មកកាន់យើងខ្ញុំជាអ្នកបម្រើលោក
យូដាចាត់ទុកខ្លួនគាត់និងបងប្អូនរបស់គាត់ថាជា« អ្នកបំរើរបស់លោក។»
នេះគឺជាវិធីផ្លូវការនៃការនិយាយទៅកាន់នរណាម្នាក់ដែលមានអំណាចខ្ពស់។
ការបកប្រែផ្សេងទៀត៖ « បន្ទាប់មកលោកបាននិយាយមកយើងពួកអ្នកបំរើរបស់លោក»
ចុះមក.....ចុះទៅ
វាជារឿងធម្មតាក្នុងការប្រើពាក្យ «ចុះ»នៅពេលដែលនិយាយពីការធ្វើដំណើរពីស្រុកកាណានស្រុកអេស៊ីប។
តើងខ្ញុំមិនបានជួបមុខលោកម្ចាស់ទៀតទេ
នៅទីនេះ «មុខ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត៖ « យើងខ្ញុំនឹងមិនឃើញខ្ញុំទៀតទេ»
បន្ទាប់មករវាក៏បានកើតមកដូច្នេះ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ប្រសិនបើភាសារបស់អ្នកមានមធ្យោបាយសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
យើងខ្ញុំបានត្រឡប់ទៅរកឪពុករបស់យើងខ្ញុំវិញ
វាជារឿងធម្មតាទេដែលប្រើឃ្លាដែលថា «បានត្រលប់ទៅ»
នៅពេលនិយាយពីការធ្វើដំណើរពីស្រុកអេស៊ីបទៅស្រុកកាណាន។
យើងខ្ញុំបានប្រាប់គាត់តាមពាក្យរបស់លោកម្ចាស់
យូដាហៅយ៉ូសែបថាជា«ម្ចាស់របស់ខ្ញុំ»។ ដូចគ្នានេះផងដែរ «ពាក្យ»
តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។ ការបកប្រែផ្សេងទៀត៖ « យើងបានប្រាប់គាត់ពីអ្វីដែលលោកម្ចាស់បាននិយាយ,ប្របាទលោកម្ចាស់ខ្ញុំ»
ឪពុករបស់យើងខ្ញុំប្រាប់ថា ចូរកូនៗទៅទិញស្បៀងឲ្យយើងម្តងទៀតចុះ
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ « ឪពុករបស់យើងបានប្រាប់យើងឱ្យទៅប្រទេសអេស៊ីបម្តងទៀតដើម្បីទិញអាហារសម្រាប់យើងនិងគ្រួសារ
បន្ទាប់មកយើងនិយាយថា«យើងមិនអាចទៅបានទេ ប្រសិនបើ ប្អូនប្រុសពៅទៅ.....ជាមួយយើង
នេះគឺជាការដកស្រង់នៅក្នុងសម្រង់មួយ។
វាអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត៖ «បន្ទាប់មកយើងបាននិយាយទៅកាន់គាត់ថាយើងមិនអាចចុះទៅស្រុកអេស៊ីបបានទេ។ យើងបានប្រាប់គាត់ថាប្រសិនបើប្អូនពៅរបស់យើងនៅជាមួយយើង ... គឺនៅជាមួយយើង»
ដើម្បីឲ្យលោកបានឃើញគាត់»
នៅទីនេះ«មុខ»តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត៖ « ដើម្បីឃើញមុខលោកម្ចាស់»
4 [1]លោកម៉ូសេបានទូលថា៖ «ចុះប្រសិនបើ ពួកគេមិនជឿទូលបង្គំ ឬមិនស្តាប់ទូលបង្គំ ប៉ុន្តែ ផ្ទុយទៅវិញ ព្រះជាម្ចាស់មិនបានយាងមកឲ្យអ្នកឃើញទេ»។
[2]ព្រះអម្ចាស់មានបន្ទូលទៅគាត់ថា៖ «តើអ្វីនោះនៅក្នុងដៃរបស់អ្នក?» លោកម៉ូសេទួលថា៖ «មានដំបងមួយ»។[3]ព្រះអម្ចាស់មានបន្ទូលថា៖ «ចូរបោះវាទៅលើដីចុះ»
លោកម៉ូសេក៏បោះវាទៅលើដី ហើយវាក៏បានក្លាយទៅជាសត្វពស់។ លោកម៉ូសេក៏បានរត់ចេញពីវា។
[4]ព្រះអម្ចាស់មានបន្ទូលទៅកាន់លោកម៉ូសេថា៖ «ចូរលូកដៃរបស់អ្នកហើយចាប់កន្ទុយរបស់វាចុះ»។ ដូច្នេះ គាត់លូកដៃចាប់សត្វពស់នោះ។
វាក៏បានក្លាយទៅជាដំបងនៅក្នុងដៃរបស់គាត់វិញ។[5]«បែបនេះពួកគេនឹងមានជំនឿលើដល់ព្រះអម្ចាស់ គឺជាព្រះជាម្ចាស់នៃបុព្វបុរសរបស់ពួកគេ
គឺជាព្រះជាម្ចាស់របស់លោកអប្រាហាំ ជាព្រះជាម្ចាស់របស់អ៊ីសាក និងជាព្រះជាម្ចាស់របស់លោកយ៉ាកុប ដែលបានយាងមកជួបអ្នក»។
[6]ព្រះអម្ចាស់ក៏បានមានបន្ទូលនឹងគាត់ថែមទៀតថា៖ «ចូរដាក់ដៃរបស់អ្នកទៅក្នុងអាវរែងរបស់អ្នក»។ ដូច្នេះ លោកម៉ូសេក៏ដាក់ដៃរបស់គាត់នៅលើអាវរែងរបស់គាត់។
នៅពេលគាត់ដកដៃចេញ មើល៍ដៃរបស់គាត់បានក្លាយទៅជាឃ្លង់ សដូចជាហិមៈ។[7]ព្រះអម្ចាស់មានបន្ទូលថា៖ «ចូរដាក់ដៃរបស់អ្នកទៅក្នុងអាវរែងរបស់អ្នកម្តងទៀត»។
ដូច្នេះ លោកម៉ូសេក៏បានដាក់ដៃរបស់គាត់ទៅក្នុងអាវរែងរបស់គាត់ម្តងទៀត ហើយនៅពេលគាត់ដកដៃរបស់គាត់ចេញ គាត់បានឃើញថា វាបានជាសះស្បើយវិញ
ដូចសាច់ធម្មតារបស់គាត់វិញ។
[8]ព្រះអម្ចាស់មានបន្ទូលថា៖ «ប្រសិនបើ ពួកគេមិនជឿអ្នកទេ ហើយបើពួកគេមិនយកចិត្តទុកដាក់ជាមួយទីសម្គាល់នៃអំណាចរបស់យើងដំបូងនេះទេ
ឬមិនជឿលើទីសម្គាល់នោះទេ ដូច្នេះ ពួកគេនឹងជឿលើទីសម្គាល់ទីពីរ។[9]ហើយប្រសិនបើ ពួកគេមិនជឿ ទោះបីជាទីសម្គាល់ទីពីរនៃអំណាចរបស់យើង ឬមិនស្តាប់តាមអ្នក
ដូច្នេះ ចូរយកទឹកពីទន្លេ ហើយចាក់វាទៅលើដីស្ងួតចុះ។ ទឹកដែលអ្នកបានចាក់នោះ នឹងត្រឡប់ទៅជាឈាមនៅលើដីស្ងួតនោះ»។
[10]បន្ទាប់មក លោកម៉ូសេទូលទៅព្រះអម្ចាស់ថា៖ «ព្រះអម្ចាស់អើយ ទូលបង្គំជាមនុស្សមិនសូវមានវោហារទេ គឺតាំងពីដើមរៀងមក ហើយរហូតដល់ព្រះអង្គមានព្រះបន្ទូល
មកទូលបង្គំនៅពេលនេះ។ ទូលបង្គំនិយាយយឺត ហើយអណ្តាតទូលបង្គំក៏យឺតដែរ»។[11]ព្រះអម្ចាស់មានបន្ទូលថា៖ «តើនរណាជាអ្នកបង្កើតអណ្តាតរបស់មនុស្ស?
តើអ្នកណាធ្វើឲ្យមនុស្សគ ឬថ្លង់ ឬមើលមិនឃើញ? តើមិនមែនយើងដែលជាព្រះអម្ចាស់ទេឬ?[12]ដូច្នេះ ចូរចេញទៅ ហើយយើងនឹងនៅជាមួយនឹងមាត់របស់អ្នក
ហើយបង្រៀនអ្នកនូវអ្វីដែលអ្នកត្រូវនិយាយ»។[13]ប៉ុន្តែ លោកម៉ូសេទូលថា៖ «ព្រះអម្ចាស់អើយ សូមចាត់អ្នកផ្សេងចុះ អ្នកណាដែលព្រះអង្គគាប់ព្រះហឫទ័យនឹងចាត់គេ»។
[14]បន្ទាប់មក ព្រះអម្ចាស់ព្រះពិរោធជាមួយលោកម៉ូសេ។ ព្រះអង្គមានបន្ទូលថា៖ «តើលោកអ៊ើរ៉ុន ជាកូនចៅលេវី ជាបងប្រុសរបស់អ្នកមែនទេ? យើងជ្រាបថា
គាត់អាចនិយាយបានល្អ។ លើសពីនេះទៀត គាត់នឹងមកជួបអ្នក ហើយពេលគាត់ឃើញអ្នក គាត់នឹងសប្បាយចិត្ត។[15]អ្នកនឹងនិយាយជាមួយគាត់
ហើយឲ្យគាត់និយាយជំនួសអ្នក។ យើងនឹងនៅជាមួយមាត់របស់អ្នក ហើយនៅជាមួយមាត់របស់គាត់ ហើយយើងនឹងបង្ហាញអ្នកទាំងពីរពីអ្វីដែលត្រូវធ្វើ។
[16]គាត់នឹងនិយាយទៅកាន់ប្រជាជនជំនួសអ្នក។ គាត់និងធ្វើជាមាត់របស់អ្នក ហើយអ្នកនឹងបានដូចជាព្រះសម្រាប់គាត់។[17]អ្នកត្រូវយកដំបងនេះទៅជាមួយអ្នក។
អ្នកនឹងធ្វើទីសម្គាល់ជាមួយនឹងដំបងនេះ»។
[18]ដូច្នេះ លោកម៉ូសេបានត្រឡប់ទៅឯលោកយេត្រូ ជាឪពុកក្មេករបស់គាត់ ហើយប្រាប់គាត់ថា៖ «សូមឲ្យខ្ញុំបានទៅ ដើម្បីឲ្យខ្ញុំបានត្រឡប់ទៅញាតិសណ្តានរបស់ខ្ញុំ
ដែលនៅអេស៊ីបវិញ ហើយទៅមើល ដើម្បីឲ្យដឹងថាពួកគេនៅរស់ឬយ៉ាងណា?»។ លោកយេត្រូមានប្រសាសន៍ទៅលោកម៉ូសេថា៖ «ចូរទៅចុះ សូមឲ្យបានសេចក្តីសុខ»។
[19]ព្រះអម្ចាស់មានបន្ទូលជាមួយលោកម៉ូសេនៅស្រុកម៉ាឌានថា៖ «ចូរ ត្រឡប់ទៅអេស៊ីបវិញចុះ ដ្បិត អ្នកដែលចង់សម្លាប់អ្នក គេស្លាប់អស់ហើយ»។
[20]លោកម៉ូសេបានយកភរិយារបស់គាត់ និងកូនប្រុសរបស់គាត់ ហើយដាក់ពួកគេនៅលើសត្វលា។ គាត់បានត្រឡប់ទៅទឹកដីអេស៊ីបវិញ
ហើយគាត់បានយកដំបងរបស់ព្រះជាម្ចាស់នៅក្នុងដៃរបស់គាត់។
[21]ព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកម៉ូសេថា៖ «នៅពេលអ្នកត្រឡប់ទៅអេស៊ីបវិញ ចូរធ្វើទីសម្គាល់គ្រប់យ៉ាងដែលយើងបានដាក់នៅក្រោមអំណាចរបស់អ្នកហើយ។
ប៉ុន្តែ យើងនឹងធ្វើឲ្យស្តេចផារ៉ោនមានចិត្តរឹង ហើយគាត់នឹងមិនអនុញ្ញាតឲ្យប្រជាជនចេញទៅទេ។[22]អ្នកត្រូវទូលទៅស្តេចផារ៉ោនថា៖ «នេះជាអ្វីដែលព្រះអម្ចាស់មានបន្ទូល៖
អ៊ីស្រាអែលជាកូនរបស់យើង ជាកូនច្បងរបស់យើង[23]ហើយយើងនិយាយទៅកាន់អ្នកថា៖ «ចូរអនុញ្ញាតឲ្យកូនប្រុសរបស់យើងចេញទៅ
ដើម្បីឲ្យគាត់បានថ្វាយបង្គំហើយ»។ ប៉ុន្តែ ប្រសិនបើ ស្តេចនៅតែបដិសេធមិនព្រមអនុញ្ញាតឲ្យគាត់ចេញទៅទេ យើងនឹងសម្លាប់កូនប្រុសរបស់អ្នកជាប្រាកដ
គឺកូនច្បងរបស់អ្នក»។
[24]នៅតាមផ្លូវ នៅពេលពួកគេឈប់សម្រាប់នៅពេលយប់ ព្រះជាអម្ចាស់យាងមកជួបលោកម៉ូសេ ហើយចង់សម្លាប់គាត់។[25]បន្ទាប់មក នាងសេផូរ៉ាបានយកកាំបិតមួយធ្វើពីថ្ម កាត់ស្បែកចុងលឹង្គរបស់កូនប្រុសនាង ហើយយកទៅប៉ះជើងរបស់លោកម៉ូសេ។ បន្ទាប់មកនាងនិយាយថា៖ «ដោយសារឈាមនេះ បងពិតជាប្តីរបស់អូនមែន!»។
[26]ដូច្នេះ ព្រះអម្ចាស់បានចាកចេញពីគាត់ទៅ។ នាងប្រាប់ថា៖ «ដោយសារឈាមនេះ បងពិតជាប្តីរបស់អូនមែន!» ដោយសារការកាត់ស្បែក។
[27]ព្រះអម្ចាស់មានបន្ទូលទៅលោកអ៊ើរ៉ុនថា៖ «ចូរទៅទីរហោស្ថានទៅជួបលោកម៉ូសេ»។ លោកអ៊ើរ៉ុនបានចេញទៅ ហើយជួបគាត់នៅឯភ្នំរបស់ព្រះជាម្ចាស់
ហើយបានថើបគាត់។[28]លោកម៉ូសេបានប្រាប់លោកអ៊ើរ៉ុនទាំងអស់តាមព្រះបន្ទូលដែលព្រះអម្ចាស់បានចាត់គាត់ឲ្យទៅនិយាយ
និងពីទីសម្គាល់ផ្សេងៗនៃអំណាចរបស់ព្រះអម្ចាស់ដែលព្រះអង្គបានបង្គាប់ឲ្យគាត់ធ្វើ។
[29]បន្ទាប់មក លោកម៉ូសេ និងលោកអ៊ើរ៉ុនបានចេញទៅ ហើយប្រមូលពួកចាស់ទុំរបស់ជនជាតិអ៊ីស្រាអែលទាំងអស់។
[30]លោកអ៊ើរ៉ុនបាននាំព្រះបន្ទូលដែលព្រះអម្ចាស់មានបន្ទូលជាមួយលោកម៉ូសេ។ គាត់ក៏បានធ្វើទីសម្គាល់នៃអំណាចរបស់ព្រះអម្ចាស់នៅចំពោះមុខប្រជាជនទាំងឡាយ។
[31]ប្រជាជនក៏ជឿ។ នៅពេលពួកគេបានឮថាព្រះអម្ចាស់បានយាងមករកជនជាតិអ៊ីស្រាអែល
ហើយថាព្រះអង្គបានទតឃើញការដែលពួកគេត្រូវទទួលរងការសង្កត់សង្កិនរបស់ពួកគេ បន្ទាប់មក ពួកគេបានឱនក្បាលពួកគេដល់ដី ហើយថ្វាយបង្គំព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

Exodus 4:1
បើ ពួកគេមិនជឿទូលបង្គំ
«ប្រសិនបើជនជាតិអ៊ីស្រាអែលមិនជឿ»
Exodus 4:4
ចាប់កន្ទុយរបស់វាចុះ
«ចូរចាប់យកកន្ទុយវា» ឬ «ចាប់កន្ទុយវា»
បានក្លាយទៅជាដំបង
«បានប្រែក្លាយទៅជាដំបង» ឬ «បានផ្លាស់ប្តូរទៅជាដំបង»
 គឺជាព្រះជាម្ចាស់នៃបុព្វបុរសរបស់ពួកគេ គឺជាព្រះជាម្ចាស់របស់លោកអប្រាហាំ
ជាព្រះជាម្ចាស់របស់អ៊ីសាក និងជាព្រះជាម្ចាស់របស់លោកយ៉ាកុប ដែលបានយាងមកជួបអ្នក។
លោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប គឺ
ជាបុព្វបុរសទាំងបីនាក់របស់ពួកគាត់។
ពួកគាត់ទាំងអស់ថ្វាយបង្គំព្រះជាម្ចាស់តែមួយ។
Exodus 4:6
មើល៍
ពាក្យនេះគឺត្រូវបានប្រើដើម្បីបង្កើតឧទានសព្ទដែលបង្ហាញពីការភ្ញាក់ផ្អើល។
សដូចជាហិម:
ពាក្យថា «ដូច» ត្រូវបានប្រើដើម្បីប្រៀបធៀបដៃរបស់លោកម៉ូសេ។
រោគឃ្លង់ធ្វើឱ្យស្បែកមើលទៅស។
អ្នកប្រហែលជាមិនមានពាក្យសម្រាប់ហិម:នៅក្នុងភាសារបស់អ្នកទេ។
បើដូច្នេះសូមពិចារណាជម្រើសមួយដែលពិពណ៌នាអំពីអ្វីដែលមានពណ៌ស។
ការបកប្រែផ្សេងទៀត «ពណ៌សដូចរោមចៀម ឬពណ៌សដូចខ្សាច់នៅឆ្នេរខ្សាច់»
Exodus 4:8
យកចិត្តទុកដាក់
«ទទួលស្គាល់» ឬ «ទទួលយក»
Exodus 4:10
ហោហារ
«អ្នកនិយាយបានល្អ»
ទូលបង្គំនិយាយយឺត ហើយអណ្តាតទូលបង្គំក៏យឺតដែរ។
ឃ្លា «និយាយយឺត» និង «អណ្តាតក៏យឺត» មានន័យថាជារឿងដូចគ្នា។
លោកម៉ូសេប្រើពួកគេដើម្បីបញ្ជាក់ថាគាត់មិនមែនជាអ្នកនិយាយល្អទេ។
ហើយអណ្តាតទូលបង្គំក៏យឺតដែរ។
នៅទីនេះ «អណ្តាត» សំដៅទៅលើសមត្ថភាពនិយាយរបស់លោកម៉ូសេ។
ការបកប្រែផ្សេងទៀត «មិនអាចនិយាយបានល្អ»
តើនរណាជាអ្នកបង្កើតអណ្តាតរបស់មនុស្ស?
ព្រះអម្ចាស់ប្រើសំណួរនេះដើម្បីបញ្ជាក់ថា
ព្រះអង្គជាអ្នកបង្កើតដែលធ្វើឲ្យមនុស្សអាចនិយាយបាន។ ការបកប្រែផ្សេងទៀត
«យើងជាព្រះអម្ចាស់ដែលបានបង្កើតមាត់មនុស្ស និងសមត្ថភាពនិយាយ!»
តើអ្នកណាធ្វើឲ្យមនុស្សគ ឬថ្លង់ ឬមើលមិនឃើញ?
ព្រះអម្ចាស់ប្រើសំណួរនេះដើម្បីបញ្ជាក់ថា ព្រះអង្គគឺជាមួយអង្គដែលសម្រេចចិត្ត
បើមនុស្សអាចនិយាយ និងស្តាប់ឮបាន ហើយបើពួកគេអាចមើលឃើញ។
ការបកប្រែផ្សេងទៀត
«យើងជាព្រះអម្ចាស់ជាអ្នកធ្វើឱ្យមនុស្សអាចនិយាយស្តាប់ឬស្តាប់ឮ
ឬមើលឃើញឬជាអ្នកខ្វាក់» ។
តើមិនមែនយើងដែលជាព្រះអម្ចាស់ទេឬ?
ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីបញ្ជាក់ថា មានតែទ្រង់ទេ
ដែលធ្វើការសម្រេចចិត្តទាំងនេះ។ ការបកប្រែផ្សេងទៀត «យើងជាព្រះអម្ចាស់
ដែលធ្វើបែបនេះ!»
យើងនឹងនៅជាមួយនឹងមាត់របស់អ្នក
នៅទីនេះ «មាត់» សំដៅទៅលើសមត្ថភាពរបស់លោកម៉ូសេក្នុងការនិយាយ។
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងផ្តល់ឱ្យអ្នកនូវសមត្ថភាព ក្នុងការនិយាយ»
Exodus 4:14
គាត់នឹងសប្បាយចិត្ត
នៅទីនេះ «ចិត្ត» សំដៅទៅលើគំនិត និងអារម្មណ៍ខាងក្នុង។ ការបកប្រែផ្សេងទៀត
«គាត់នឹងសប្បាយចិត្តណាស់»
គាត់និយាយជំនួសអ្នក។
ពាក្យនៅទីនេះត្រូវបានគេនិយាយ
ដូចជាពួកគេជាអ្វីមួយដែលអាចត្រូវបានគេដាក់នៅក្នុងរាងកាយរបស់មនុស្សម្នាក់។
នៅទីនេះ «ពាក្យ» សំដៅទៅលើសារ។ ការបកប្រែផ្សេងទៀត «ផ្តល់ឱ្យគាត់នូវសារ
ដែលគាត់ត្រូវនិយាយដដែល»
យើងនឹងនៅជាមួយមាត់របស់អ្នក
ពាក្យ «មាត់» នៅទីនេះតំណាងឱ្យជម្រើស នៃពាក្យលោកម៉ូសេ។
ការបកប្រែផ្សេងទៀត «យើងនឹងផ្តល់ឱ្យអ្នកនូវពាក្យត្រឹមត្រូវដើម្បីនិយាយ»
ជាមួយមាត់របស់អ្នក
ពាក្យ «មាត់» នៅទីនេះតំណាងឱ្យការជ្រើសរើសពាក្យរបស់លោកអើរ៉ុន។
ការបកប្រែផ្សេងទៀត «យើងនឹងផ្តល់ឱ្យគាត់នូវពាក្យត្រឹមត្រូវដើម្បីនិយាយ»
គាត់និងធ្វើជាមាត់របស់អ្នក
ពាក្យ «មាត់» នៅទីនេះតំណាងឱ្យលោកអើរ៉ុននិយាយឡើងវិញ
នូវអ្វីដែលលោកម៉ូសេបានប្រាប់គាត់។ ការបកប្រែផ្សេងទៀត
«គាត់នឹងនិយាយអ្វីដែលអ្នកប្រាប់គាត់ឱ្យនិយាយ»
អ្នកនឹងបានដូចជាព្រះសម្រាប់គាត់។
ពាក្យ «ដូច» នៅទីនេះមានន័យថាលោកម៉ូសេតំណាងសិទ្ធិអំណាចដូចគ្នា
នឹងលោកអើរ៉ុនដូចព្រះជាម្ចាស់បានធ្វើចំពោះលោកម៉ូសេដែរ។
ការបកប្រែផ្សេងទៀត
«អ្នកនឹងនិយាយទៅកាន់លោកអើរ៉ុនដោយមានអំណាចដូចគ្នា
ដែលយើងបាននិយាយជាមួយអ្នក»
Exodus 4:18
ឪពុកក្មេករបស់គាត់
ឪពុកក្មេក - នេះសំដៅទៅលើឪពុកនៃភរិយា របស់លោកម៉ូសេ។
Exodus 4:21
យើងនឹងធ្វើឲ្យស្តេចផារ៉ោនមានចិត្តរឹង
នៅទីនេះ « ចិត្ត» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសរបស់ស្តេចផារ៉ោនត្រូវបានគេនិយាយដូចជាស្តេចផារ៉ោនមានចិត្តរឹង។
ការបកប្រែផ្សេងទៀត «នឹងធ្វើឱ្យស្តេចផារ៉ោន មានចិត្តរឹងរូស»
អ៊ីស្រាអែលជាកូនរបស់យើង
ពាក្យថា «អ៊ីស្រាអែល» នៅទីនេះតំណាងអោយប្រជាជនអ៊ីស្រាអែលទាំងអស់។
ការបកប្រែផ្សេងទៀត « ប្រជាជនអ៊ីស្រាអែលគឺជាកូនៗរបស់ផ្ទាល់ខ្លួនយើង»
ជាកូនរបស់យើង ជាកូនច្បងរបស់យើង
នៅទីនេះប្រជាជនអ៊ីស្រាអែលត្រូវបានគេនិយាយដូចជាពួកគេជាកូនប្រុសច្បងដែលនាំឱ្យមានអំណារនិងប
ការបកប្រែផ្សេងទៀត «គឺដូចជាកូនប្រុសច្បងរបស់យើង»
ស្តេចនៅតែបដិសេធមិនព្រមអនុញ្ញាតឲ្យគាត់ចេញទៅទេ
ពាក្យថា « គាត់» សំដៅទៅលើប្រជាជនអ៊ីស្រាអែលជាកូនប្រុសរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «អ្នកបានបដិសេធ មិនឱ្យកូនប្រុសយើងទៅ»
យើងនឹងសម្លាប់កូនប្រុសរបស់អ្នកជាប្រាកដ គឺកូនច្បងរបស់អ្នក។
ពាក្យថា «កូនប្រុស» នៅទីនេះសំដៅទៅលើកូនប្រុសនៃស្តេចផារ៉ោន។
Exodus 4:24
ព្រះជាអម្ចាស់យាងមកជួបលោកម៉ូសេ ហើយចង់សម្លាប់គាត់។
នេះប្រហែលជាដោយសារលោកម៉ូសេ មិនបានកាត់ស្បែកកូនប្រុសរបស់គាត់។
នាងសេផូរ៉ា
នេះជាឈ្មោះភរិយារបស់លោកម៉ូសេ។
កាំបិតមួយធ្វើពីថ្ម
នេះគឺជាកាំបិតដែលបានមកដោយសារ យកថ្មរាងសំប៉ែតទៅសំលៀង។
ជើងរបស់លោកម៉ូសេ
វាអាចទៅរួចដែលថាពាក្យ «ជើង» នៅទីនេះប្រហែលជារបៀបគួរឱ្យគោរពជាងមុន
ដើម្បីសំដៅទៅលើតំបន់ប្រដាប់បន្តពូជនៃរាងកាយ។
«ដោយសារឈាមនេះ បងពិតជាប្តីរបស់អូនមែន!»
អត្ថន័យនៃពាក្យប្រៀបធៀបនេះគឺមិនច្បាស់លាស់ទេ។ វាប្រហែលជាការនិយាយ
ដែលគេស្គាល់នៅក្នុងវប្បធម៌នោះ។ ការបកប្រែផ្សេងទៀត
«បងមានទំនាក់ទំនងជាមួយអូន ដោយសារឈាមនេះ» ឬ
«បងគឺជាប្តីរបស់អូនដោយសារឈាម»
Exodus 4:27
ព្រះអម្ចាស់មានបន្ទូលទៅលោកអើរ៉ុន
អ្នកប្រហែលជាចង់បន្ថែមពាក្យដែលសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿងដូចយូឌីបីធ្វើ។
នៅឯភ្នំរបស់ព្រះជាម្ចាស់
នេះប្រហែលជាភ្នំនៅឯស៊ីណៃ ប៉ុន្តែអត្ថបទមិនរាប់បញ្ចូលព័ត៌មាននោះទេ។
ព្រះអម្ចាស់បានចាត់គាត់ឲ្យទៅនិយាយ
ពាក្យថា «គាត់» គឺសំដៅទៅលើព្រះអម្ចាស់ហើយ «គាត់»
សំដៅទៅលើលោកម៉ូសេ។

generated on Wed Sep 10 16:16:32 2025

Exodus 4:29
នៅចំពោះមុខប្រជាជនទាំងឡាយ
«មុខប្រជាជន» ឬ «នៅចំពោះមុខប្រជាជន»
បានយាងមករកជនជាតិអ៊ីស្រាអែល
«ឃើញពួកអ៊ីស្រាអែល» ឬ «យល់ចិត្តទុកអំពីជនជាតិអ៊ីស្រាអែល»
ពួកគេបានឱនក្បាលពួកគេដល់ដី
ទី១អត្ថន័យដែលប្រហែលគឺ) «ពួកគេបានឱនក្បាលដោយការភ្ញាក់ផ្អើល» ឬ ទី២) ពួកគេបានឱនគោរពដោយការគោរព។

5 [1]បន្ទាប់ពីការទាំងនេះបានកើតឡើង លោកម៉ូសេ និងលោកអ៊ើរ៉ុនបានទៅជួបស្តេចផារ៉ោន ហើយទូលថា៖ «នេះគឺជាអ្វីដែលព្រះអម្ចាស់
ជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលមានបន្ទូល៖ «ចូរអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងចេញទៅ ដើម្បីឲ្យពួកគេអាចធ្វើពិធីបុណ្យសម្រាប់យើងនៅទីរហោស្ថាន»។
[2]ស្តេចផារ៉ោនរាជឱង្ការថា៖ «តើព្រះអម្ចាស់ជានរណា? េហតុអ្វីបានជាយើងត្រូវស្តាប់បង្គាប់តាមពាក្យរបស់លោក ហើយអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលចេញទៅ?
យើងមិនស្គាល់ព្រះអម្ចាស់ទេ ហើយយើងក៏មិនអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលចេញទៅដែរ»។
[3]ពួកគេបានទូលថា៖ «ព្រះជាម្ចាស់របស់ជនជាតិហេព្រើរបានយាងមកជួបយើងខ្ញុំ។ សូមអនុញ្ញាតឲ្យយើងខ្ញុំចេញទៅក្នុងដំណើរទៅទីរហោស្ថានក្នុងរយៈពេលបីថ្ងៃ
ហើយថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់យើង នោះព្រះអង្គនឹងមិនប្រហារយើងខ្ញុំដោយគ្រោះកាច ឬដោយដាវទេ»។[4]ប៉ុន្តែ ស្តេចអេស៊ីបមានរាជឱង្ការ
ទៅកាន់ពួកគេថា៖ «លោកម៉ូសេ និងលោកអ៊ើរ៉ុន ហេតុអ្វីបានជាអ្នកយកប្រជាជនមិនឲ្យធ្វើការដូច្នេះ? ចូរត្រឡប់ទៅធ្វើការរបស់អ្នកវិញទៅ»។[5]ស្តេចមានរាជឱង្ការបន្តទៀត
ថា៖ «មានជនជាតិហេព្រើរច្រើនណាស់នៅក្នុងទឹកដីរបស់យើង ហើយអ្នកធ្វើឲ្យពួកគេឈប់ធ្វើការមែនទេ?»។
[6]នៅថ្ងៃដដែលនោះ ស្តេចផារ៉ោនបានបង្គាប់ដល់មេត្រួតត្រា និងពួកមេក្រុម។ ស្តេចមានរាជឱង្ការថា៖[7]«មិនត្រូវផ្តល់ចម្បើងដើម្បីឲ្យប្រជាជនធ្វើឥដ្ឋទៀតទេ។
ចូរឲ្យពួកគេចេញទៅ ហើយប្រមូលចម្បើងដោយខ្លួនឯង។[8]ប៉ុន្តែ អ្នករាល់គ្នាត្រូវតម្រូវឲ្យពួកគេធ្វើឥដ្ឋតាមចំនួនដូចពីមុន។ កុំបន្ថយចំនួនឲ្យសោះ ដ្បិត ពួកគេខ្ជិល។
ហេតុដូច្នេះហើយបានជាពួកគេស្រែក ហើយនិយាយថា៖ សូមអនុញ្ញាតឲ្យយើងខ្ញុំចេញទៅ ហើយថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់របស់យើង»។
[9]ត្រូវបន្ថែមការងារដល់ពួកគេ ដើម្បីឲ្យពួកគេនៅបន្តធ្វើវា ហើយកុំឲ្យគេយកចិត្តទុកដាក់នឹងពាក្យភូតភរឡើយ»។
[10]ដូច្នេះ ពួកមេត្រួតត្រា និងពួកមេក្រុមបានចេញទៅ ហើយប្រាប់ដល់ប្រជាជន។ ពួកគេនិយាយថា៖ «នេះគឺជាអ្វីដែលព្រះបាទផារ៉ោនមានរាជឱង្ការ៖
យើងលែងឲ្យចម្បើងដល់អ្នករាល់គ្នាទៀតហើយ។[11]អ្នករាល់គ្នាត្រូវចេញទៅ ហើយរកចម្បើង នៅកន្លែងណាដែលអ្នករាល់គ្នាអាចរកវាឃើញ ប៉ុន្តែ
សូមកុំបន្ថយចំនួនឥដ្ឋឡើយ»។
[12]ដូច្នេះ ប្រជាជនបានចេញទៅគ្រប់កន្លែងពាសពេញទឹកដីអេស៊ីប ដើម្បីប្រមូលជញ្ជ្រាំងមកប្រើជំនួសចំបើង។[13]ពួកមេត្រួតត្រាបានបន្តប្រមានពួកគេ ដោយនិយាយថា៖
«ត្រូវបង្ហើយការងាររបស់អ្នករាល់គ្នា ដូចនៅពេលដែលអ្នករាល់គ្នាមានចម្បើងពីមុន»។[14]ពួកមេត្រួតត្រារបស់ស្តេចផារ៉ោនបានវាយមេក្រុមរបស់ជនជាតិអ៊ីស្រាអែល
គឺពួកអ្នកដែលពួកគេបានដាក់ឲ្យទទួលខុសត្រូវលើកម្មករ។ ពួកមេត្រួតត្រាបន្តសួរពួកគេថា៖ «ហេតុអ្វីបានជាធ្វើឥដ្ឋមិនបានគ្រប់ចំនួនតាមការតម្រូវដល់អ្នករាល់គ្នា
មិនថាពីម្សិលមិញ ឬថ្ងៃនេះ ដូចដែលអ្នករាល់គ្នាធ្លាប់ធ្វើពីមុន?»
[15]ដូច្នេះ ពួកគេមេក្រុមរបស់ជនជាតិអ៊ីស្រាអែលបានទៅគាល់ស្តេចផារ៉ោន ហើយបានស្រែកអង្វរស្តេចផារ៉ោន។ ពួកគេនិយាយថា៖
«ហេតុអ្វីបានជាប្រព្រឹត្តនឹងយើងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គបែបនេះ?[16]ព្រះអង្គមិនបានប្រទានចម្បើងមកយើងខ្ញុំសោះ ប៉ុន្តែ ពួកគេប្រាប់យើងខ្ញុំថា៖ «ចូរធ្វើឥដ្ឋ!»។
អ្នកបម្រើរបស់ព្រះអង្គបានវាយយើងខ្ញុំថែមទៀតផង ប៉ុន្តែ នោះជាកំហុសរបស់ប្រជារាស្ត្ររបស់ព្រះអង្គទេ»។[17]ប៉ុន្តែ ស្តេចផារ៉ោនមានរាជឱង្ការថា៖ «ពួកឯងខ្ជិល! ពួក
ឯងខ្ជិល! អ្នករាល់គ្នានិយាយថា៖ «សូមអនុញ្ញាតឲ្យយើងខ្ញុំចេញទៅថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់»។[18]ដូច្នេះ ចូរត្រឡប់ទៅធ្វើការវិញទៅ។
យើងលែងឲ្យចម្បើងអ្នករាល់គ្នាទៀតហើយ ប៉ុន្តែ អ្នករាល់គ្នាត្រូវធ្វើឥដ្ឋឲ្យគ្រប់ចំនួន»។
[19]ពួកមេក្រុមរបស់ជនជាតិអ៊ីស្រាអែលឃើញថា ពួកគេធ្លាក់ក្នុងបញ្ហាហើយ ពេលនោះពួកគេបានទូលថា៖ «សូមព្រះអង្គកុំបន្ថយចំនួនឥដ្ឋប្រចាំថ្ងៃអី»។
[20]ពួកគេបានទៅជួបលោកម៉ូសេ និងលោកអ៊ើរ៉ុន ជាអ្នកដែលឈរនៅខាងក្រៅរាជវាំង នៅពេលពួកគេចេញពីស្តេចផារ៉ោន។
[21]ពួកគេនិយាយជាមួយលោកម៉ូសេនិងលោកអ៊ើរ៉ុនថា៖ «ព្រះអម្ចាស់ទតមើលអ្នកទាំងពីរ ហើយដាក់ទោសអ្នកទាំងពីរ
ព្រោះអ្នកទាំងពីរបានធ្វើឲ្យយើងត្រូវគេស្អប់នៅចំពោះស្តេចផារ៉ោន និងមន្ត្រីរបស់ស្តេច។ អ្នកទាំងពីរបានដាក់ដាវនៅនឹងដៃរបស់ពួកគេ ដើម្បីសម្លាប់យើង»។
[22]លោកម៉ូសេត្រឡប់ទៅរកព្រះអម្ចាស់វិញ ហើយទូលថា៖ «ព្រះអម្ចាស់អើយ ហេតុបានជាព្រះអង្គធ្វើឲ្យមានបញ្ហាជាមួយប្រជាជននេះដូច្នេះ?
ហេតុអ្វីបានជាចាត់ទូលបង្គំឲ្យមកដូច្នេះ?[23]ដ្បិត ចាប់តាំងពីទូលបង្គំបានចូលគាល់ស្តេចផារ៉ោន ដើម្បីទូលស្តេចដោយនូវនាមរបស់ព្រះអង្គ
ស្តេចបានធ្វើឲ្យមានបញ្ហាដល់ប្រជាជននេះ ហើយព្រះអង្គមិនបានធ្វើឲ្យប្រជាជននេះមានសេរីភាពសោះ»។

Exodus 5:1
បន្ទាប់ពីការទាំងនេះបានកើតឡើង
គឺមិនច្បាស់អំពីរបៀបដែលលោកម៉ូសេ
និងលោកអ៊ើរ៉ុនបានរង់ចាំរហូតពួកគេបានទៅជួបស្តេចផារ៉ោន។
ពិធីបុណ្យសម្រាប់យើង
នេះជាការអបអរសាទរចំពោះការថ្វាយបង្គំព្រះអម្ចាស់។
តើព្រះអម្ចាស់ជានរណា?
ស្តេចផារ៉ោនប្រើសំណួរនេះដើម្បីបង្ហាញថាស្តេចផារ៉ោនមិនទទួលស្គាល់ព្រះអម្ចាស់
ជាព្រះពិតប្រាកដទេ។ ការបកប្រែផ្សេងទៀត «យើងមិនស្គាល់ព្រះអម្ចាស់»
ហេយតុអ្វីបានជាយើង ... ហើយអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលចេញទៅ?
ស្តេចផារ៉ោនប្រើសំណួរនេះដើម្បីថ្លែងថាស្តេចផារ៉ោនមិនមានចំណាប់អារម្មណ៍
ក្នុងការស្តាប់បង្គាប់ព្រះអម្ចាស់
ឬអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលទៅថ្វាយបង្គំព្រះអម្ចាស់ឡើយ។
ការបកប្រែផ្សេងទៀត«ព្រះអម្ចាស់គ្មានអ្វីសំខាន់សម្រាប់យើងទេ
ហើយយើងនឹងមិនអនុញ្ញាតឱ្យអ៊ីស្រាអែលចេញទៅទេ!»
ត្រូវស្តាប់បង្គាប់តាមពាក្យរបស់លោក
ពាក្យថា៖ «តាមពាក្យរបស់លោក»
តំណាងឱ្យពាក្យដែលព្រះជាម្ចាស់បានមានបន្ទូល។ ការបកប្រែផ្សេងទៀត
«ត្រូវស្តាប់នូវអ្វីដែលព្រះអង្គមានបន្ទូល»
Exodus 5:3
ព្រះជាម្ចាស់របស់ជនជាតិហេព្រើរ
ពាក្យនេះត្រូវបានប្រើសម្រាប់ព្រះជាម្ចាស់ របស់ជនជាតិអ៊ីស្រាអែលផងដែរ
ឬព្រះអម្ចាស់។
ឬដោយដាវទេ
នៅទីនេះ «ដាវ» តំណាងឱ្យសង្គ្រាម ឬការវាយប្រហារដោយសត្រូវ។
ការបកប្រែផ្សេងទៀត «ឬបណ្តាលឱ្យខ្មាំងសត្រូវវាយប្រហារយើង»
ហេតុអ្វីបានជាអ្នកយកប្រជាជនមិនឲ្យធ្វើការដូច្នេះ?
ស្តេចផារ៉ោនប្រើសំណួរនេះដើម្បីបង្ហាញ
នូវព្រះពិរោធរបស់ស្តេចផារ៉ោនចំពោះលោកម៉ូសេ
និងលោកអ៊ើរ៉ុនចំពោះការនាំជនជាតិអ៊ីស្រាអែលចេញពីការងាររបស់ពួកគេ។
ការបកប្រែផ្សេងទៀត: «ចូរបញ្ឈប់ការរំខានដល់ប្រជាជន
ពីការធ្វើការងាររបស់ពួកគេទៅ!»
Exodus 5:6
មេត្រួតត្រា
«អ្នកជម្រុញទាសករ» ទាំងនេះគឺជាការងាររបស់ជនជាតិអេស៊ីប
ដែលត្រូវបង្ខំជនជាតិអ៊ីស្រាអែលអោយធ្វើការយ៉ាងខ្លាំង។សូមមើលនៅក្នុង ១:១១ ។
ឯងមិនត្រូវផ្តល់ចម្បើងដើម្បីឲ្យប្រជាជនធ្វើឥដ្ឋទៀតទេ។
ពាក្យថា «អ្នក» នៅក្នុងខទាំងនេះគឺពហុវចនៈហើយសំដៅទៅលើ មេត្រួតត្រា
និងអ្នកនាំមុខ។
Exodus 5:10
មេត្រួតត្រា

generated on Wed Sep 10 16:16:32 2025

«អ្នកជម្រុញទាសករ» ទាំងនេះគឺជាការងាររបស់ជនជាតិអេស៊ីប
ដែលត្រូវបង្ខំជនជាតិអ៊ីស្រាអែលអោយធ្វើការយ៉ាងខ្លាំង។សូមមើលនៅក្នុង ១:១១
។
យើងលែងឲ្យចម្បើងដល់អ្នករាល់គ្នាទៀតហើយ ... រកចម្បើង
នៅកន្លែងណាដែលអ្នករាល់គ្នាអាចរកវាឃើញ
ពាក្យ «អ្នក»
នៅក្នុងខទាំងនេះគឺពហុវចនៈហើយសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
អ្នករាល់គ្នាត្រូវចេញទៅ
នៅទីនេះ «អ្នករាល់គ្នា»
គឺបញ្ជាក់ថាប្រជាជនអេស៊ីបនឹងលែងជួយពួកគេទៀតហើយ។
សូមកុំបន្ថយចំនួនឥដ្ឋឡើយ។
នេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែបន្តធ្វើចំនួនឥដ្ឋដូចមុន»
Exodus 5:12
គ្រប់កន្លែងពាសពេញទឹកដីអេស៊ីប
នេះគឺជាការនិយាយបំផ្លើសមួយដែលត្រូវបានប្រើដើម្បីបង្ហាញពីការប្រឹងប្រែងបន្ថែមដែ
នឹងការទាមទាររបស់ស្តេចផារ៉ោន។ ការបកប្រែផ្សេងទៀត «តំបន់ធំទូលាយ»
មេត្រួតត្រា
«អ្នកជម្រុញទាសករ» ទាំងនេះគឺជាការងាររបស់ជនជាតិអេស៊ីប
ដែលត្រូវបង្ខំជនជាតិអ៊ីស្រាអែលអោយធ្វើការយ៉ាងខ្លាំង។សូមមើលនៅក្នុង ១:១១
។
ជញ្ជាំង
ផ្នែកនៃដាំណាំស្រូវដែលនៅសល់បន្ទាប់ពីច្រូតកាត់
«ហេតុអ្វីបានជាធ្វើឥដ្ឋមិនបានគ្រប់ចំនួនតាមការតម្រូវដល់អ្នករាល់គ្នា ...ពីមុន?»
មេត្រួតត្រាត្រូវបានប្រើសំណួរនេះដើម្បីបង្ហាញថាពួកគេខឹងនឹងឥដ្ឋមិនគ្រប់។
ការបកប្រែផ្សេងទៀត «អ្នកមិនបានធ្វើឥដ្ឋគ្រប់គ្រាន់ទេ កាលពីម្សិលមិញ ឬថ្ងៃនេះ
ដូចអ្នកបានធ្វើកាលពីមុនដែរ!»
Exodus 5:15
បានស្រែកអង្វរ
«បានតួញត្អែរ»
ពួកគេប្រាប់យើងខ្ញុំថា៖ «ចូរធ្វើឥដ្ឋ!»
នៅទីនេះ «ពួកគេ» សំដៅទៅលើមេត្រួតត្រាជនជាតិអេស៊ីប។
Exodus 5:19
ពេលនោះពួកគេបានទូល
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលស្តេចផារ៉ោនបានប្រាប់ពួកគេ»
រាជវាំង
នេះជាព្រះដំណាក់ធំមួយដែលស្តេចគង់នៅ។
អ្នកទាំងពីរបានធ្វើឲ្យយើងត្រូវគេស្អប់
ជនជាតិអេស៊ីបបានឆ្លើយតប នឹងជនជាតិអ៊ីស្រាអែលតាមរបៀប
ដែលពួកគេនឹងឆ្លើយតបចំពោះក្លិនអាក្រក់។ ការបកប្រែផ្សេងទៀត
«អ្នកបានបណ្តាលឱ្យពួកគេស្អប់យើង»
អ្នកទាំងពីរបានដាក់ដាវនៅនឹងដៃរបស់ពួកគេ ដើម្បីសម្លាប់យើង។
នៅទីនេះ «ដាវ» តំណាងឱ្យឱកាសដើម្បីបំផ្លាញសត្រូវ។ ការបកប្រែផ្សេងទៀត
«
ការសម្លាប់យើង»
Exodus 5:22
ព្រះអម្ចាស់អើយ ហេតុបានជាព្រះអង្គធ្វើឲ្យមានបញ្ហាជាមួយប្រជាជននេះដូច្នេះ?
សំណួរនេះបង្ហាញពីការខកចិត្តរបស់គាត់
ដែលជនជាតិអេស៊ីបបានធ្វើបាបប្រជាជនអ៊ីស្រាអែលកាន់តែអាក្រក់ទៅ ៗ ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ខ្ញុំសោកស្តាយ
ដែលព្រះអង្គបានបង្កបញ្ហាដល់ប្រជាជនដូច្នេះ» ។
ហេតុអ្វីបានជាចាត់ទូលបង្គំឲ្យមកដូច្នេះ?
សំណួរនេះបង្ហាញពីការខកចិត្តរបស់លោកម៉ូសេដែលព្រះបានបញ្ជូនគាត់ទៅស្រុកអេស៊ីប។
ការបកប្រែផ្សេងទៀត «ខ្ញុំប្រាថ្នាថាព្រះអង្គ
នឹងមិនបានបញ្ជូនទូលបង្គំមកទីនេះទេ!»
ដើម្បីទូលស្តេចដោយនូវនាមរបស់ព្រះអង្គ
ពាក្យ «នាម» នៅទីនេះតំណាងឱ្យសាររបស់ព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត
«ដើម្បីផ្តល់ឱ្យស្តេចនូវសាររបស់ព្រះអង្គ»

---

6 [1]ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេថា៖ «ឥឡូវនេះ អ្នកនឹងឃើញអ្វីដែលយើងនឹងធ្វើចំពោះស្តេចផារ៉ោន។ អ្នកនឹងឃើញការនេះ ដ្បិត
ស្តេចនឹងអនុញ្ញាតឲ្យពួកគេចេញទៅដោយសារព្រះហស្តដ៏ខ្លាំងពូកែរបស់យើង។ យើងនឹងនាំពួកគេចេញពីទឹកដីរបស់ស្តេចនេះ
ដោយសារព្រះហស្តដ៏ខ្លាំងពូកែរបស់យើង»។
[2]ព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកម៉ូសេ ដោយមានបន្ទូលទៅគាត់ថា៖ «យើងគឺជាព្រះអម្ចាស់»។[3]យើងបានយាងមកជួបលោកអប្រាហាំ លោកអ៊ីសាក
និងលោកយ៉ាកុប ក្នុងនាមជាព្រះជាម្ចាស់ដ៏មានគ្រប់ទាំងព្រះចេស្តា ប៉ុន្តែ មានព្រះអម្ចាស់របស់យើង យើងមិនបានបង្ហាញឲ្យពួកគេស្គាល់ទេ។
[4]យើងក៏បានចងសម្ពន្ធមេត្រីជាមួយពួកគេនៅក្នុងទឹកដីកាណាន ជាទឹកដីដែលពួកគេរស់នៅក្នុងនាមជាជនបរទេស ទឹកដីដែលពួកគេដើរខ្ចាត់ព្រាត់។[5]លើសពីនេះ
យើងបានឮសម្រែងទួញថ្ងូរបស់ជនជាតិអ៊ីស្រាអែល ដែលជនជាតិអេស៊ីបបានឲ្យពួកគេក្លាយជាទាសករ។
[6]ដូច្នេះហើយ ព្រះអង្គមានបន្ទូលទៅជនជាតិអ៊ីស្រាអែលថា៖ «យើងគឺជាព្រះអម្ចាស់។ យើងនឹងនាំអ្នករាល់គ្នាចេញពីទាសកររនៅក្រោមជនជាតិអេស៊ីប
ហើយយើងនឹងរំដោះអ្នករាល់គ្នាចេញពីអំណាចរបស់ពួកគេ។ យើងនឹងសង្គ្រោះអ្នករាល់គ្នាដោយធ្វើការដោយអំណាចរបស់យើង
ហើយយើងនឹងជំនុំជម្រះដោយឫទ្ធិអំណាចរបស់យើង។[7]យើងនឹងយកអ្នករាល់គ្នាធ្វើជាប្រជារាស្ត្ររបស់យើង ហើយយើងនឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ។
អ្នកនឹងដឹងថា យើងគឺជាព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នក ដែលបាននាំអ្នករាល់គ្នាចេញពីភាពជាទាសកររនៅក្រោមជនជាតិអេស៊ីប។
[8]យើងនឹងនាំអ្នករាល់គ្នាទៅកាន់ទឹកដីដែលយើងបានស្បថនឹងប្រទានឲ្យលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប។ យើងនឹងឲ្យវាដល់អ្នករាល់គ្នាទុកជាកេរអាករ។
យើងគឺជាព្រះអម្ចាស់»។[9]ពេលលោកម៉ូសេប្រាប់ការនេះដល់ជនជាតិអ៊ីស្រាអែល ពួកគេមិនស្តាប់គាត់ទេ
ដោយសារពួកគេបានបាក់ទឹកចិត្តទុក្ខវេទនានៃភាពជាទាសកររបស់ពួកគេ។
[10]ដូច្នេះ ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេដោយបន្ទូលថា៖[11]«ចូរទូលព្រះបាទផារ៉ោន ស្តេចរបស់អេស៊ីប
ចូរអនុញ្ញាតឲ្យប្រជាជនអ៊ីស្រាអែលចេញពីទឹកដីរបស់ស្តេចចុះ»។[12]លោកម៉ូសេទូលទៅព្រះអម្ចាស់ថា៖ «បើជនជាតិអ៊ីស្រាអែលមិនស្តាប់ទូលបង្គំផង
តើស្តេចផារ៉ោនស្តាប់ទូលបង្គំទេ? ហើយទូលបង្គំក៏មិនសូវចេញនិយាយផង»[13]ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេនិងលោកអ៊ើរ៉ុនថា៖ «ព្រះអង្គបានបង្គាប់ដល់ពួកគេ
ឲ្យនាំព្រះបន្ទូលទៅប្រាប់ជនជាតិអ៊ីស្រាអែល និងព្រះបាទផារ៉ោន ស្តេចរបស់អេស៊ីប ដើម្បីឲ្យជនជាតិអ៊ីស្រាអែលចេញពីទឹកដីអេស៊ីប។
[14]អ្នកទាំងនេះគឺមេត្រួសារនៃឪពុកពួកគេ កូនរបស់លោករូបេន ត្រូវជាកូនច្បងរបស់លោកអ៊ីស្រាអែល មានលោកហេណុក លោកប៉ាលូវ លោកហេតស្រុន និងលោកកើមី។
អ្នកទាំងនោះគឺជាបុព្វបុរសនៃអំបូររូបេន។[15]កូនរបស់លោកស៊ីម្មានមានលោកយេមូអែល លោកយ៉ាមីន លោកអូហាត់ លោកយ៉ាគិន លោកសូហារ និងលោកសូល ជាកូន
របស់ស្ត្រីជនជាតិកាណាន។ អ្នកទាំងនោះជាបុព្វបុរសនៃអំបូរស៊ីម្មាន។
[16]នេះគឺជាបញ្ជីឈ្មោះរបស់កូនចៅលោកលេវី តាមពូជពង្សរបស់ពួកគេ។ ពួកគេគឺលោកគើសុន លោកកេហាត់ និងលោកម៉្រារី។ លោកលេវីរស់បាន១៣៧ឆ្នាំ។[17]កូន
របស់លោកគើសុនមានលោកលីបនី និងលោកស៊ីម៉ែ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ។[18]កូនរបស់លោកកេហាត់មានលោកអាំរ៉ាម លោកយីតសារ លោកហេប្រុន
និងលោកអ៊ូសាល។ លោកកេហាត់រស់បាន១៣៣ឆ្នាំ។[19]កូនរបស់លោកម៉្រារីមានលោកម៉ាស់លី និងលោកមូស៊ី។ អ្នកទាំងនោះជាបុព្វបុរសនៃអំបូរលេវី តាមតំណ
ពូជពង្សរបស់ពួកគេ។
[20]លោកអាំរ៉ាមរៀបការជាមួយនាងយ៉ូកេបិត ដែលត្រូវជាម្តាយមីងរបស់គាត់ នាងបង្កើតបានកូនប្រុសពីរនាក់ឲ្យគាត់ គឺលោកអ៊ើរ៉ុន និងលោកម៉ូសេ។ លោកអាំរ៉ាមរស់បាន
១៣៧ឆ្នាំ។[21]កូនរបស់លោកយីតសារមានលោកកូរេ លោកណេផេក និងលោកស៊ីកគ្រី។[22]កូនរបស់លោកអ៊ូសាលគឺ លោកមីសាអែល លោកអែលសាផាន និងលោក
ស៊ីតទ្រី។

generated on Wed Sep 10 16:16:32 2025

[23]លោកអើរ៉ុនរៀបការជាមួយនាងអេលីសេបា ជាកូនរបស់លោកអមីណាដាប់ និងជាប្អូនរបស់លោកណាសូន។ នាងបង្កើតបានកូនប្រុសបួននាក់ឲ្យគាត់គឺ លោកណាដាប លោកអប៊ីហ៊ូវ លោកអេឡាសារ និងលោកអ៊ីថាម៉ារ។[24]កូនរបស់លោកកូរេមានលោកអាស់សៀរ លោកអែលកាណា និងលោកអេបៀសាប់ ដែលជាបុព្វបុរសនៃអំបូរកូរេ។
[25]លោកអេឡាសារ កូនប្រុសរបស់លោកអើរ៉ុន បានរៀបការជាមួយកូនស្រីលោកពូធាល នាងបង្កើតបានកូនប្រុសម្នាក់ឲ្យគាត់គឺ លោកភីនេហាស។ អ្នកទាំងនេះជាមេគ្រួសារនៃកុលសម្ព័ន្ធលេវី តាមពូជពង្សរបស់ពួកគេ។
[26]បុរសពីរនាក់នេះគឺលោកអើរ៉ុន និងលោកម៉ូសេ ដែលព្រះអម្ចាស់បានបង្គាប់ឲ្យនាំជនជាតិអ៊ីស្រាអែលចេញពីទឹកដីអេស៊ីប តាមក្រុមរបស់ពួកគេដូចកងទ័ពមួយ។[27]លោកអើរ៉ុន លោកម៉ូសេនេះហើយដែលបានទៅគាល់ស្តេចផារ៉ោន ជាស្តេចស្រុកអេស៊ីប ដើម្បីឲ្យស្តេចបានអនុញ្ញាតឲ្យពួកគេនាំជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីប។ គឺលោកម៉ូសេ និងលោកអើរ៉ុននេះហើយ។
[28]ពេលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេ នៅទឹកដីអេស៊ីប[29]ព្រះអង្គមានព្រះបន្ទូលមកគាត់ថា៖ «យើងជាព្រះអម្ចាស់។ ចូរទូលទៅស្តេចផារ៉ោន ស្តេចរបស់ស្រុកអេស៊ីបគ្រប់យ៉ាងតាមដែលយើងបានប្រាប់ដល់អ្នក»។[30]ប៉ុន្តែ លោកម៉ូសេទូលព្រះអម្ចាស់ថា៖ «ទូលបង្គំមិនសូវចេះនិយាយទេ ធ្វើម្តេចឲ្យស្តេចផារ៉ោនស្តាប់ទូលបង្គំទៅ»។

Exodus 6:1
ព្រះហស្តដ៏ខ្លាំងពូកែរបស់យើង
ពាក្យថា « ព្រះហស្ត» នៅទីនេះតំណាងអោយសកម្មភាព
ឬព្រះរាជកិច្ចរបស់ព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត
«អំណាចដែលយើងបង្ហាញនៅក្នុងស្នាព្រះហស្តរបស់យើង»
Exodus 6:2
យើងបានយាងមកជួបលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប
«យើងបានបង្ហាញខ្លួនយើង ដល់លោកអប្រាហាំ លោកអ៊ីសាក និង លោកយ៉ាកុប»
យើងមិនបានបង្ហាញឲ្យពួកគេស្គាល់ទេ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេមិនបានស្គាល់យើងទេ»
សម្លេងទួញថ្ងូរ
នេះមានន័យថាធ្វើឱ្យសម្លេងទុក្ខព្រួយ ដោយសារតែការឈឺចាប់ និងទុក្ខវេទនា។
Exodus 6:6
ព្រះអង្គមានបន្ទូលទៅជនជាតិអ៊ីស្រាអែល
នេះជាការបង្គាប់របស់ព្រះអម្ចាស់ដល់លោកម៉ូសេ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានប្រាប់លោកម៉ូសេអោយនិយាយ ទៅកាន់ជនជាតិអ៊ីស្រាអែល» ។
Exodus 6:8
យើងបានស្បថ
«យើងបានសន្យា» ឬ «យើងបានមានបន្ទូលថាយើងនឹង»
Exodus 6:10
«បើជនជាតិអ៊ីស្រាអែលមិនស្តាប់ទូលបង្គំផង តើស្តេចផារ៉ោនស្តាប់ទូលបង្គំទេ?
ហើយទូលបង្គំក៏មិនសូវចេញនិយាយផង»
លោកម៉ូសេបានសួរសំណួរនេះដោយសង្ឃឹមថាព្រះជាម្ចាស់នឹងផ្លាស់ប្តូរគំនិតរបស់ព្រះអង្គ
អំពីការប្រើប្រាស់លោកម៉ូសេ។
សំណួរដ៏ប៉ិនប្រសប់នេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ចាប់តាំងពីជនជាតិអ៊ីស្រាអែល មិនបានស្តាប់ខ្ញុំហើយ
នឹងស្តេចផារ៉ោនផងដែរព្រោះខ្ញុំមិនពូកែនិយាយ!»
Exodus 6:14
មេគ្រួសារនៃឪពុកពួកគេ
នៅទីនេះ «មេ» សំដៅទៅលើបុព្វបុរសដើមនៃអំបូរ។ មេគ្រួសារនៃឪពុកពួកគេ
«បុព្វបុរសនៃអំបូរ»
លោកហេណុក ... លោកសូល
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
Exodus 6:16
លោកគើសុន ... លោកម៉្រារី
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
លោកអាំរ៉ាម.....លោកអ៊ូសាល
ទាំងអស់នេះគឺជាឈ្មោះបុរស។
Exodus 6:20
លោកយីតសារ ...លោកកូរេ ... លោកស៊ីកគ្រី
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
លោកអ៊ូសាល ... លោកមីសាអែល ... លោកស៊ីតទ្រី
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
Exodus 6:23
លោកអមីណាដាប់ ... លោកអ៊ីថាម៉ារ
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
លោកភីនេហាស
នេះជាឈ្មោះរបស់មនុស្សប្រុស។
អ្នកទាំងនេះជាមេគ្រួសារ
ពាក្យ «មេ» នៅទីនេះតំណាងឱ្យអ្នកដឹកនាំគ្រួសារ។ ការបកប្រែផ្សេងទៀត
«អ្នកទាំងនេះគឺជាអ្នកដឹកនាំគ្រួសារ»
Exodus 6:26
តាមក្រុមរបស់ពួកគេដូចកងទ័ពមួយ។
«បានរៀបចំសម្ព័ន្ធមួយនៅជំនាន់ពេលតែមួយ» ឬ
«ក្រុមគ្រួសារមួយក្រោយមកក្រុមគ្រួសារមួយផ្សេងទៀត»
Exodus 6:28
ទូលបង្គំមិនសូវចេះនិយាយទេ ... ធ្វើម្តេចឲ្យស្តេចផារ៉ោនស្តាប់ទូលបង្គំទៅ?
លោកម៉ូសេសួរសំណួរនេះដោយសង្ឃឹមថា នឹងផ្លាស់ប្តូរគំនិតរបស់ព្រះជាម្ចាស់។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែ ជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ខ្ញុំមិនពូកែនិយាយ ...
ស្តេចផារ៉ោនប្រាកដជាមិនស្តាប់ទូលបង្គំទេ!»

---

7 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «មើល៍ យើងបានធ្វើឲ្យអ្នកក្លាយជាព្រះរបស់ស្តេចផារ៉ោនហើយ។ លោកអើរ៉ុនបងប្រុសរបស់អ្នកនឹងធ្វើជាព្យាការីរបស់អ្នក។
[2]អ្នកត្រូវនិយាយតាមអ្វីៗដែលយើងបានបង្គាប់ដល់អ្នកឲ្យនិយាយ។ លោកអើរ៉ុន បងប្រុសរបស់អ្នកនឹងទូលទៅស្តេចផារ៉ោន ដូច្នេះ
ស្តេចនឹងអនុញ្ញាតឲ្យប្រជាជនអ៊ីស្រាអែលចេញពីទឹកដីរបស់ស្តេចហើយ។
[3]ប៉ុន្តែ យើងនឹងធ្វើឲ្យស្តេចផារ៉ោនមានចិត្តរឹង ហើយយើងនឹងធ្វើទីសម្គាល់នៃអំណាចរបស់យើង និងការអស្ចារ្យជាច្រើន នៅក្នុងទឹកដីអេស៊ីប។[4]ប៉ុន្តែ
ស្តេចផារ៉ោននឹងមិនស្តាប់តាមអ្នកឡើយ ដូច្នេះ យើងនឹងដាក់ដៃរបស់យើងលើស្រុកអេស៊ីប ហើយនឹងនាំជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើង
និងពូជពង្សអ៊ីស្រាអែល ចេញពីទឹកដីអេស៊ីបដោយដោយការដាក់ទោសយ៉ាងធ្ងន់ធ្ងរ។[5]ជនជាតិអេស៊ីបនឹងដឹងថា យើងគឺជាព្រះអម្ចាស់
នៅពេលយើងវាយប្រហារលើអេស៊ីប ហើយនាំជនជាតិអ៊ីស្រាអែលចេញពីចំណោមពួកគេ»។
[6]លោកម៉ូសេ និងលោកអើរ៉ុនបានដូច្នោះ ពួកគេបានធ្វើដូចព្រះអម្ចាស់បានបង្គាប់ដល់ពួកគេ។[7]លោកម៉ូសេមានអាយុប៉ែតសិបឆ្នាំ ហើយលោកអើរ៉ុនមានអាយុប៉ែតសិបបីឆ្នាំ
នៅពេលពួកគេទូលទៅស្តេចផារ៉ោន។
[8]ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេ និងលោកអើរ៉ុនថា៖[9]«ពេលស្តេចផារ៉ោនមានរាជឱង្ការមកអ្នក «ឲ្យធ្វើការអស្ចារ្យ» ដូច្នេះ អ្នកត្រូវប្រាប់លោកអើរ៉ុនឲ្យ យកដំបង
ហើយបោះវាទៅលើដីនៅចំពោះស្តេចផារ៉ោន ដូច្នេះ វានឹងក្លាយទៅជាសត្វពស់»។[10]បន្ទាប់មក លោកម៉ូសេ និងលោកអើរ៉ុន បានទៅជួបស្តេចផារ៉ោន
ហើយពួកគេបានធ្វើដូចដែលព្រះអម្ចាស់បានបង្គាប់។ លោកអើរ៉ុនបោះដំបងរបស់គាត់នៅចំពោះស្តេចផារ៉ោន និងមន្ត្រីរបស់ស្តេច ហើយវាបានក្លាយជាសត្វពស់មែន។
[11]បន្ទាប់មក ស្តេចផារ៉ោនក៏បានកោះហៅអ្នកប្រាជ្ញរបស់ស្តេច និងពួកគ្រូមន្តអាគមផង។ ពួកគេបានប្រើមន្តអាគមរបស់ពួកគេដូចគ្នាដែរ។
[12]បុរសម្នាក់ៗបោះដំបងរបស់ពួកគេ ហើយដំបងទាំងនោះបានក្លាយជាសត្វពោះទាំងអស់។ ប៉ុន្តែ ដំបងរបស់លោកអើរ៉ុនបានលេបសត្វពស់របស់ពួកគេអស់។
[13]ដួងចិត្តរបស់ស្តេចផារ៉ោនបានរឹង ហើយស្តេចមិនបានស្តាប់តាម ដូចជាព្រះអម្ចាស់បានបង្គាប់ទេ។

generated on Wed Sep 10 16:16:32 2025

[14]ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេថា៖ «ស្តេចផារ៉ោនមានចិត្តរឹង ហើយស្តេចបានបដិសេធមិនអនុញ្ញាតឲ្យប្រជាជនចេញទៅទេ។[15]ចូរទៅគាល់ស្តេចផារ៉ោន
នៅពេលព្រឹក គឺពេលដែលស្តេចចេញទៅមាត់ទឹក ឈរនៅតាមមាត់ទន្លេ ហើយត្រូវកាន់ដំបងដែលបានក្លាយជាពស់ទៅជាមួយផង។
[16]ចូរទូលទៅស្តេចថា៖ «ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ជនជាតិហេព្រើរ បានចាត់យើងខ្ញុំមកគាល់ព្រះអង្គ ហើយទូលថា៖ «ចូរអនុញ្ញាតឲ្យប្រជាជនចេញទៅ
ដើម្បីឲ្យពួកគេអាចថ្វាយបង្គំយើងនៅទីរហោស្ថាន។ រហូតមកដល់ពេលនេះ ព្រះអង្គនៅតែមិនព្រមទៀត»។[17]ព្រះអម្ចាស់មានបន្ទូលដូច្នេះថា៖ «ដោយសារការនេះ
អ្នកនឹងដឹងថា យើងគឺជាព្រះអម្ចាស់។ យើងនឹងវាយទឹកទន្លេនីលដោយដំបងដែលនៅក្នុងដៃរបស់យើង ហើយទឹកនឹងក្លាយជាឈាម។[18]ត្រីដែលនៅក្នុងទន្លេនឹងស្លាប់
ហើយទន្លេនឹងស្អុយ។ ជនជាតិអេស៊ីបមិនអាចផឹកទឹកពីទន្លេនេះបានទេ»។
[19]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេថា៖ «ចូរប្រាប់អ៊ើរ៉ុន ឲ្យយកដំបងរបស់អ្នក ហើយលើកដៃរបស់អ្នកវាយទឹកនៅស្រុកអេស៊ីប ហើយវាយលើទន្លេ ស្ទឹង
បឹងព្រមទាំងត្រពាំង ដើម្បីឲ្យទឹករបស់ពួកគេបានក្លាយជាឈាម។ ចូរធ្វើដូច្នេះ ដើម្បីឲ្យក្លាយជាឈាមនៅពាសពេញទឹកដីអេស៊ីបទាំងមូល សូម្បីតែនៅក្នុងធុង និងក្នុងពាង
ក៏មានឈាមដែរ»។
[20]លោកម៉ូសេ និងលោកអ៊ើរ៉ុនបានធ្វើដូចព្រះអម្ចាស់បានបង្គាប់។ លោកអ៊ើរ៉ុនបានលើកដំបង ហើយបានវាយលើទឹកទន្លេ នៅចំពោះស្តេចផារ៉ោន និងមន្ត្រីរបស់ស្តេច។
ទឹកទាំងអស់នៅក្នុងទន្លេបានក្លាយជាឈាម។[21]ត្រីនៅក្នុងទន្លេងាប់អស់ ហើយទន្លេបានស្អុយ។ ជនជាតិអេស៊ីបមិនអាចផឹកទឹកពីទន្លេនោះបានឡើយ
ហើយឈាមមាននៅគ្រប់កន្លែងនៅក្នុងទឹកដីអេស៊ីប។[22]ប៉ុន្តែ ពួកមន្តអាគមរបស់អេស៊ីបធ្វើការនេះបានដូចគ្នាដោយសារមន្តអាគមរបស់ពួកគេ។
តែដួងចិត្តរបស់ផារ៉ោននៅតែរឹតដដែល ហើយស្តេចបានបដិសេធមិនព្រមតាមលោកម៉ូសេ និងលោកអ៊ើរ៉ុនឡើយ ដូចដែលព្រះអម្ចាស់មានបន្ទូលមែន។
[23]បន្ទាប់មក ស្តេចផារ៉ោនក៏ចាកចេញ ហើយទៅក្នុងដំណាក់របស់ស្តេចវិញ។ ស្តេចមិនបានយកព្រះទ័យទុកដាក់ជាមួយនឹងការនេះទេ។
[24]ជនជាតិអេស៊ីបទាំងអស់នៅជុំវិញទន្លេដើម្បីរកទឹកផឹក ប៉ុន្តែ ពួកគេមិនអាចផឹកទឹកដែលចេញពីទន្លេបានទេ។[25]ប្រាំពីរថ្ងៃបានកន្លងផុតទៅ
បន្ទាប់ពីព្រះអម្ចាស់វាយលើទន្លេ។

Exodus 7:1
យើងបានធ្វើឲ្យអ្នកក្លាយជាព្រះ
« យើងនឹងធ្វើអោយស្តេចផារ៉ោន ចាត់ទុកអ្នកជាព្រះមួយអង្គ»
Exodus 7:3
ធ្វើឲ្យស្តេចផារ៉ោនមានចិត្តរឹង
នៅទីនេះ « ចិត្ត» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសរបស់ស្តេចផារ៉ោនត្រូវបានគេនិយាយដូចជាចិត្តរឹងរបស់ស្តេចផារ៉ោន។ សូមមើលនៅក្នុង ៤:២១ ។ ការបកប្រែផ្សេងទៀត «នឹងធ្វើឱ្យស្តេចផារ៉ោនរឹងចេស»
ទីសម្គាល់ ... ការអស្ចារ្យជាច្រើន
ពាក្យ «ទីសម្គាល់» និង «ការអស្ចារ្យ» មានន័យថាជារួមដូចគ្នា។
ព្រះជាម្ចាស់ប្រើពួកគេដើម្បីបញ្ជាក់ពីភាពអស្ចារ្យនៃអ្វីដែលព្រះអង្គនឹងធ្វើនៅអេស៊ីប។
ដាក់ដៃរបស់យើងលើ ... វាយប្រហារលើ
ពាក្យថា «ដៃរបស់យើង» តំណាងឱ្យព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះ។
ការបកប្រែផ្សេងទៀត «ប្រើអំណាចរបស់យើងប្រឆាំងនឹង ...
បង្ហាញសកម្មភាពពេញអំណាចរបស់យើងប្រឆាំងនឹង»
Exodus 7:6
លោកអ៊ើរ៉ុនមានអាយុប៉ែតសិបបីឆ្នាំ
អាយុបីឆ្នាំ -«និងលោកអ៊ើរ៉ុនមានអាយុប៉ែតសិបបីឆ្នាំ»
Exodus 7:8
«ពេលស្តេចផារ៉ោនមានរាជឱង្ការមកអ្នក «ឲ្យធ្វើការអស្ចារ្យ» ដូច្នេះ អ្នកត្រូវប្រាប់លោកអ៊ើរ៉ុនឲ្យ
យកដំបង ហើយបោះវាទៅលើដីនៅចំពោះស្តេចផារ៉ោន ដូច្នេះ វានឹងក្លាយទៅជាសត្វពស់»។
នេះអាចត្រូវបានថ្លែងជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«នៅពេលស្តេចផារ៉ោនប្រាប់អ្នកឱ្យធ្វើការអស្ចារ្យនាំមកអ្នកនឹងប្រាប់លោកអ៊ើរ៉ុនឱ្យយកដំបងរបស់គាត់ទៅ ហើយបោះវានៅចំពោះស្តេចផារ៉ោនដើម្បីឱ្យវាក្លាយជាសត្វពស់»
។
Exodus 7:11
បានលេប
«បានលេប» ឬ «លេបត្របាក់»
ដួងចិត្តរបស់ស្តេចផារ៉ោនបានរឹង
នៅទីនេះ « ចិត្ត» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសរបស់ស្តេចផារ៉ោន
ត្រូវបានគេនិយាយដូចជាចិត្តរបស់ស្តេចផារ៉ោនរឹង។ ការបកប្រែផ្សេងទៀត
«ស្តេចផារ៉ោនកាន់តែរឹងរូសជាងមុន»
Exodus 7:14
ស្តេចផារ៉ោនមានចិត្តរឹង
នៅទីនេះ « ចិត្ត» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសរបស់ស្តេចផារ៉ោន
ត្រូវបានគេនិយាយដូចជាចិត្តរបស់ស្តេចផារ៉ោនរឹង។ សូមមើលនៅក្នុង ៧:១១ ។ ការបកប្រែផ្សេងទៀត «ស្តេចផារ៉ោនរឹងចចេស»
គឺពេលដែលស្តេចចេញទៅមាត់ទឹក
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «នៅពេលស្តេចចុះទៅទន្លេនីលដើម្បីងូតទឹក» (សូមមើល
Exodus 7:16
ចូរទូលទៅស្តេចថា
«ចូរទូលដល់ស្តេចផារ៉ោន»
វាយទឹក
«វាយទឹក»
Exodus 7:19
ពាសពេញ
«គ្រប់ផ្នែកនៃ»
Exodus 7:20
តែដួងចិត្តរបស់ផារ៉ោននៅតែរឹតដដែល
នៅទីនេះ «ចិត្ត» សំដៅទៅលើស្តេចផារ៉ោន។ អាកប្បកិរិយារឹងរូសរបស់ស្តេច
ត្រូវបានគេនិយាយដូចជាចិត្តរបស់ស្តេចរឹង។ សូមមើលនៅក្នុង ៧:១១ ។
ការបកប្រែផ្សេងទៀត «ស្តេចផារ៉ោនរឹងរូសពេក» ឬ

[8]បន្ទាប់មក ស្តេចផារ៉ោនបានកោះហៅលោកម៉ូសេ និងលោកអ៊ើរ៉ុន ហើយមានរាជឱង្ការថា៖ «ចូរអធិស្ឋានដល់ព្រះអម្ចាស់ ដើម្បីឲ្យយកកង្កែបចេញពីយើង
និងប្រជារាស្ត្ររបស់យើង។ នោះ យើងនឹងអនុញ្ញាតឲ្យប្រជារាស្ត្រ ដើម្បីពួកគេថ្វាយយញ្ញបូជាដល់ព្រះអង្គ»។[9]លោកម៉ូសេទូលទៅស្តេចផារ៉ោនថា៖ «សូមព្រះអង្គកំណត់
ពេលវេលា ថាតើពេលណាទូលបង្គំត្រូវអង្វរព្រះអម្ចាស់សម្រាប់ព្រះអង្គ សម្រាប់នាម៉ឺនមន្ត្រី និងប្រជារាស្ត្ររបស់ព្រះអង្គ ដើម្បីបំបាត់កង្កែបចេញពីព្រះអង្គ និងចេញពី
ដំណាក់របស់ព្រះអង្គ គឺនៅតែក្នុងទន្លេនីលប៉ុណ្ណោះ»។
[10]ស្តេចផារ៉ោនមានរាជឱង្ការថា៖ «ថ្ងៃស្អែក»។ លោកម៉ូសេទូលថា៖ «សូមឲ្យបានកើតឡើងតាមព្រះរាជឱង្ការរបស់ស្តេចចុះ ដើម្បីឲ្យព្រះអង្គបានជ្រាបថា
គ្មាននរណាដូចជាព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់យើងឡើយ។[11]កង្កែបនឹងចាកចេញពីព្រះអង្គ ពីដំណាក់ ពីពួកមន្ត្រី និងពីប្រជារាស្ត្ររបស់ព្រះអង្គ។
ពួកគេនឹងនៅក្នុងតែទន្លេប៉ុណ្ណោះ»។[12]លោកម៉ូសេ និងលោកអ៊ើរ៉ុនបានចាកចេញពីអេស៊ីប។ បន្ទាប់មក លោកម៉ូសេទូលទៅព្រះអម្ចាស់ទាក់ទងនឹងកង្កែប
ដែលព្រះអង្គបាននាំមកដល់ស្តេចផារ៉ោន។
[13]ព្រះអម្ចាស់បានធ្វើដូចដែលលោកម៉ូសេបានទូលសុំ គឺកង្កែបបានងាប់នៅក្នុងផ្ទះ ដំណាក់ និងតាមស្រែចង្ការ។[14]ប្រជាជនបានប្រមូលខ្មោចកង្កែបគរជាគំនរ ហើយមាន
ក្លិនស្អុយពាសពេញស្រុក។[15]ប៉ុន្តែ នៅពេលស្តេចផារ៉ោនឃើញថា បានធូរស្បើយហើយ ស្តេចនៅតែមានព្រះទ័យរឹងរូស ហើយមិនយល់ព្រមស្តាប់តាមលោកម៉ូសេ
និងលោកអ៊ើរ៉ុនឡើយ ដូចដែលព្រះអម្ចាស់បានមានបន្ទូលឲ្យស្តេចបានធ្វើ។
[16]ព្រះអម្ចាស់មានបន្ទូលមកកាន់លោកម៉ូសេថា៖ «ចូរប្រាប់ទៅលោកអ៊ើរ៉ុន ឲ្យលើកដំបង ហើយវាទៅលើដី នោះវានឹងក្លាយជាចៃពាសពេញទឹកដីអេស៊ីបទាំងមូល»។
[17]ពួកគេក៏ធ្វើដូច្នោះ លោកអ៊ើរ៉ុនក៏លើកដៃ និងដំបងរបស់គាត់។ គាត់បានវាយទៅលើដី។ ចៃបានកើតឡើងនៅលើមនុស្សនិងសត្វ។
ធូលីដីដែលនៅដីបានកើតជាចៃពាសពេញទឹកដីអេស៊ីបទាំងមូល។
[18]ពួកគ្រូមន្តអាគមព្យាយាមធ្វើមន្តអាគមរបស់ពួកគេ ឲ្យកើតចៃ ប៉ុន្តែ ពួកគេមិនអាចធ្វើបានទេ។ មានចៃនៅលើមនុស្ស និងសត្វ។[19]បន្ទាប់មក
ពួកគ្រូមន្តអាគមបានទូលទៅស្តេចផារ៉ោនថា៖ «នេះគឺជាព្រះហស្តរបស់ព្រះជាម្ចាស់»។ ប៉ុន្តែ ស្តេចផារ៉ោនមានព្រះទ័យរឹងរូស ដូច្នេះ
ស្តេចបានបដិសេធក្នុងការស្តាប់តាមពួកគេ។ វាបានកើតឡើងដូចព្រះអម្ចាស់បានមានបន្ទូលទៅផារ៉ោនឲ្យធ្វើ។
[20]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរក្រោកពីព្រលឹម ហើយឈរនៅចំពោះស្តេចផារ៉ោន នៅពេលដែលស្តេចយាងទៅមាត់ទន្លេ។ ចូរទូលស្តេចថា៖
«ព្រះអម្ចាស់មានបន្ទូលដូច្នេះ៖ «ចូរអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងចេញទៅ ដើម្បីឲ្យពួកគេអាចថ្វាយបង្គំយើង។[21]ប៉ុន្តែ ប្រសិនបើ
ស្តេចមិនព្រមអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងទៅទេ យើងនឹងចាត់ហ្វូងរុយមកលើស្តេច លើពួកមន្ត្រី និងនៅក្នុងដំណាក់របស់ស្តេច។ នៅក្នុងផ្ទះរបស់ជនជាតិអេស៊ីប
នឹងពេញទៅដោយសត្វរុយ ហើយសូម្បីតែនៅលើដីដែលពួកគេឈរ នឹងមានពេញទៅដោយសត្វរុយ។
[22]ប៉ុន្តែ នៅថ្ងៃនោះ យើងនឹងប្រព្រឹត្តជាមួយនឹងអ្នកដែលនៅក្នុងទឹកដីកូសែនបែបផ្សេង ទឹកដីដែលប្រជារាស្ត្ររបស់យើងរស់នៅ ដូច្នេះ
នឹងមិនមានហ្វូងសត្វរុយនៅទីនោះទេ។ ការនេះនឹងកើតឡើង ដើម្បីឲ្យស្តេចបានជ្រាបថា យើងគឺជាព្រះអម្ចាស់នៅកណ្តាលចំណោមទឹកដីនេះ។
[23]យើងនឹងញែករវាងប្រជារាស្ត្ររបស់យើង និងប្រជារាស្ត្ររបស់ស្តេច។ ទីសម្គាល់នៃអំណាចរបស់យើងនេះ នឹងកើតឡើងនៅថ្ងៃស្អែក»។[24]ព្រះអម្ចាស់បានធ្វើដូច្នោះ
ហើយមានហ្វូងរុយយ៉ាងក្រាសបានហើរចូលទៅក្នុងដំណាក់របស់ស្តេចផារ៉ោន និងផ្ទះពួកមន្ត្រីរបស់ស្តេច។ នៅក្នុងទឹកដីអេស៊ីបទាំងមូល
ត្រូវបានបំផ្លាញដោយសារតែហ្វូងរុយទាំងនោះ។
[25]ស្តេចផារ៉ោនបានកោះហៅលោកម៉ូសេ និងលោកអ៊ើរ៉ុន ហើយទូលថា៖ «ចូរទៅ ថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់របស់អ្នកនៅក្នុងទឹកដីរបស់អ្នកផ្ទាល់ចុះ»។
[26]លោកម៉ូសេទូលថា៖ «យើងខ្ញុំធ្វើដូច្នេះ មិនត្រឹមត្រូវទេ ដ្បិត យញ្ញបូជារបស់យើងដែលត្រូវថ្វាយដល់ព្រះជាម្ចាស់ជាទីស្អប់ខ្ពើមចំពោះជនជាតិអេស៊ីប។[27]ប្រសិនបើ
យើងខ្ញុំថ្វាយយញ្ញបូជានៅចំពោះមុខពួកគេ ដែលជាទីស្អប់សខ្ពើមដល់ជនជាតិអេស៊ីបនោះ តើពួកគេនឹងមិនចោលយើងខ្ញុំនឹងដុំថ្មទេឬ? អត់ទេ
យើងត្រូវធ្វើដំណើរក្នុងរយៈពេលបីថ្ងៃទៅទីរហោស្ថាន ដើម្បីថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់យើង ដូចដែលព្រះអង្គបានបង្គាប់»។
[28]ស្តេចផារ៉ោនមានរាជឱង្ការថា៖ «យើងនឹងអនុញ្ញាតឲ្យអ្នកចេញទៅ ហើយថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ្នកនៅទីរហោស្ថាន។
តែអ្នកមិនត្រូវទៅឆ្ងាយពេកទេ។ សូមជួយអធិស្ឋានឲ្យយើងផង»។[29]លោកម៉ូសេទូលថា៖ «នៅពេលទូលបង្គំចាកចេញពីព្រះអង្គពេលណា
នោះទូលបង្គំនឹងអធិស្ឋានដល់ព្រះអម្ចាស់ ឲ្យហ្វូងសត្វរុយចាកចេញពីព្រះអង្គ ស្តេចផារ៉ោន និងពីពួកមន្ត្រី និងប្រជារាស្ត្ររបស់ព្រះអង្គនៅថ្ងៃស្អែក។ ប៉ុន្តែ
ព្រះអង្គមិនត្រូវបោកប្រាស់យើងខ្ញុំ ដោយមិនឲ្យប្រជាជនរបស់យើងចាកចេញទៅ ដើម្បីថ្វាយយញ្ញបូជានោះឡើយ»។
[30]លោកម៉ូសេបានចាកចេញពីស្តេចផារ៉ោន ហើយអធិស្ឋានដល់ព្រះអម្ចាស់។[31]ព្រះអម្ចាស់បានធ្វើតាមសំណូមពររបស់លោកម៉ូសេ
គឺព្រះអង្គបានយកហ្វូងសត្វរុយពីស្តេចផារ៉ោន ពីពួកមន្ត្រី និងពីប្រជារាស្ត្ររបស់ស្តេច។ គ្មាននៅសល់មួយឡើយ។[32]ប៉ុន្តែ នៅពេលនេះ
ស្តេចផារ៉ោនមានព្រះទ័យរឹងរូសដដែល ហើយស្តេចមិនព្រមអនុញ្ញាតឲ្យប្រជាជនទៅទេ។

Exodus 8:1
ទន្លេ
«ទន្លេនីល»
ធើងម្សៅ
ទាំងនេះគឺជាធើងដែលធ្វើនំប៉័ង។
Exodus 8:8
បន្ទាប់មក ស្តេចផារ៉ោនបានកោះហៅលោកម៉ូសេ និងលោកអ៊ើរ៉ុន
«បន្ទាប់មកស្តេចផារ៉ោនបានបញ្ជូនលោកម៉ូសេ និងលោកអ៊ើរ៉ុន»
សូមព្រះអង្គកំណត់ពេលវេលា ថាតើពេលណាទូលបង្គំត្រូវអង្វរព្រះអម្ចាស់សម្រាប់ព្រះអង្គ
«សូមព្រះអង្គជ្រើសរើសពេលណាទូលបង្គំ នឹងអធិស្ឋានអោយព្រះអង្គ» ឬ
«សូមព្រះអង្គជ្រើសរើសពេលវេលា ដែលទូលបង្គំគួរតែអធិស្ឋានអោយព្រះអង្គ»
Exodus 8:13
ស្តេចនៅតែមានព្រះទ័យរឹងរូស
«ស្តេចផារ៉ោនមានព្រះទ័យរឹងរូស»។ នៅទីនេះ «រឹងរូស»
មានន័យថាស្តេចត្រឡប់ជាមាន:។
ដូចដែលព្រះអម្ចាស់បានមានបន្ទូលឲ្យស្តេចបានធ្វើ។
«ដូចព្រះអម្ចាស់បានមានបន្ទូលថា ស្តេចផារ៉ោននឹងធ្វើ»
Exodus 8:18
«នេះគឺជាព្រះហស្តរបស់ព្រះជាម្ចាស់»។
ពាក្យថា «ព្រះហស្តរបស់ព្រះជាម្ចាស់» តំណាងឲ្យអំណាចរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «នេះគឺកិច្ចការពេញដោយអំណាចរបស់ព្រះជាម្ចាស់»
ស្តេចផារ៉ោនមានព្រះទ័យរឹងរូស
នៅទីនេះ « ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។ សូមមើលនៅក្នុង ៧:១១ ។
ការបកប្រែផ្សេងទៀត «ស្តេចផារ៉ោនកាន់តែរឹងមាន:»
Exodus 8:20
ហើយឈរនៅចំពោះស្តេចផារ៉ោន
«បង្ហាញខ្លួនអ្នកទៅស្តេចផារ៉ោន»
ចូរអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងចេញទៅ
«រំដោះប្រជាជនរបស់យើងឱ្យមានសេរីភាព»
Exodus 8:22
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់ស្តេចផារ៉ោនតាមរយៈលោកម៉ូសេ។
ត្រូវបានបំផ្លាញដោយសារតែហ្វូងរុយទាំងនោះ។
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ហ្វូងរុយបំផ្លាញស្រុកទាំងអស់ហើយ»
Exodus 8:25
នៅចំពោះមុខពួកគេ
នេះជាទម្លាប់នៃការនិយាយថា «នៅចំពោះមុខនរណាម្នាក់» ។
ការបកប្រែផ្សេងទៀត «នៅក្នុងវត្តមានរបស់ពួកគេ»
តើពួកគេនឹងមិនចោលយើងខ្ញុំនឹងដុំថ្មទេឬ?

generated on Wed Sep 10 16:16:32 2025

លោកម៉ូសេសួរសំណួរនេះដើម្បីបង្ហាញស្តេចផារ៉ោនថាជនជាតិអេស៊ីប
នឹងអោយជនជាតិអ៊ីស្រាអែលគោរពបម្រើព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ពួកគេប្រាកដជានឹងគប់ដុំថ្មពួកយើង!»
Exodus 8:28
ព្រះអង្គមិនត្រូវបោកប្រាស់យើងខ្ញុំ ដោយមិនឲ្យប្រជាជនរបស់យើងចាកចេញទៅ។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ព្រះអង្គត្រូវតែចាប់ផ្តើមដោះស្រាយដោយស្មោះត្រង់ជាមួយយើងខ្ញុំ
ហើយឱ្យប្រជាជនរបស់យើងខ្ញុំចេញទៅ»
ប៉ុន្តែ ព្រះអង្គមិនត្រូវបោកប្រាស់យើងខ្ញុំ
«ប៉ុន្តែព្រះអង្គមិនត្រូវបញ្ឆោតយើងខ្ញុំទេ» ឬ «ប៉ុន្តែព្រះអង្គមិនត្រូវកុហកយើងខ្ញុំ»
Exodus 8:30
ស្តេចផារ៉ោនមានព្រះទ័យរឹងរូស
នៅទីនេះ « ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។ សូមមើលនៅក្នុង ៧:១១ ។
ការបកប្រែផ្សេងទៀត «ស្តេចផារ៉ោនកាន់តែកាន់តែមានៈជាងមុន»

---

9 [1]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលនឹងលោកម៉ូសេថា៖ «ចូរទៅគាល់ស្តេចផារ៉ោន ហើយទូលស្តេចថា៖ «ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ជនជាហេព្រើរ
មានបន្ទូលដូច្នេះ៖ «ចូរអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងចេញទៅ ដើម្បីឲ្យពួកគេអាចថ្វាយបង្គំដល់យើង»។[2]ប៉ុន្តែ ប្រសិនបើ ស្តេចបដិសេធមិនអនុញ្ញាតឲ្យពួកគេទៅ
ហើយប្រសិនបើ អ្នកនៅតែឃាំងពួកគេ[3]ដូច្នេះ ព្រះហស្តរបស់ព្រះអម្ចាស់នឹងវាយប្រហារហ្វូងសត្វនៅស្រែចម្ការ និងនៅលើហ្វូងសេះ និងហ្វូងលា ហ្វូងអូដ្ឋ និងហ្វូងចៀម
ព្រមទាំងហ្វូងគោ វានឹងកើតជំងឺអាសន្នរោគយ៉ាងវេទនា។[4]ព្រះអម្ចាស់នឹងប្រព្រឹត្តជាមួយហ្វូងសត្វជនជាតិអ៊ីស្រាអែល ខុសពីជនជាតិអេស៊ីប៖
គឺនឹងមិនមានសត្វណាដែលជាកម្មសិទ្ធិរបស់ជនជាតិអ៊ីស្រាអែលត្រូវស្លាប់ឡើយ។
[5]ព្រះអម្ចាស់បានកំណត់ពេលវេលា ព្រះអង្គមានបន្ទូលថា៖ «ថ្ងៃស្អែក យើងនឹងធ្វើការនេះនៅក្នុងទឹកដីនេះ»។[6]ព្រះអម្ចាស់ធ្វើការនេះនៅថ្ងៃបន្ទាប់៖
ហ្វូងសត្វទាំងអស់នៅអេស៊ីបងាប់គ្មានសល់។ ប៉ុន្តែ គ្មានសត្វរបស់ជនជាតិអ៊ីស្រាអែលណាមួយនៅបានងាប់ឡើយ សូម្បីតែមួយ។[7]ស្តេចផារ៉ោនបានចាត់គេឲ្យទៅ
ស៊ើបអង្កេត ហើយជ្រាបថាគ្មានសត្វណាមួយក្នុងហ្វូងសត្វរបស់ជនជាតិអ៊ីស្រាអែលងាប់ឡើយ។ ប៉ុន្តែ ស្តេចផារ៉ោននៅតែមានព្រះទ័យមានៈ ដូច្នេះ ស្តេចមិនព្រមអនុញ្ញាត
ឲ្យប្រជាជនចេញទៅទេ។
[8]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេ និងលោកអ៊ើរ៉ុនថា៖ «ចូរយកផេះពីចង្ក្រាន គឺអ្នកហើយម៉ូសេ ចូរបាចទៅលើមេឃ នៅចំពោះផារ៉ោនទៅ[9]ផេះនោះនឹង
ក្លាយជាធូលីយ៉ាងម៉ដ្ត នៅពាសពេញលើស្រុកអេស៊ីប។ ហើយនឹងធ្វើឲ្យក្លាយជាបូស ហើយធ្លាយចេញជាដំបៅលើខ្លួនមនុស្ស និងសត្វ ពាសពេញក្នុងទឹកដីអេស៊ីបទាំង
មូល»។[10]ដូច្នេះ លោកម៉ូសេ និងលោកអ៊ើរ៉ុនបានយកផេះពីចង្ក្រាន ហើយឈរនៅចំពោះស្តេចផារ៉ោន។ បន្ទាប់មក លោកម៉ូសេបានបោះផេះនោះទៅលើមេឃ។
ផេះនោះបានធ្វើឲ្យកើតមានបូស ហើយធ្លាយចេញជាដំបៅលើខ្លួនមនុស្ស និងសត្វ។
[11]ពួកគ្រូមន្តអាគមមិនអាចតតាំងនឹងលោកម៉ូសេបានទេ ដោយសារតែបូស ហើយបូសនោះក៏កើតនៅលើពួកគេ និងនៅលើជនជាតិអេស៊ីបផ្សេងទៀតដែរ។
[12]ព្រះអម្ចាស់បានធ្វើឲ្យស្តេចផារ៉ោនមានព្រះទ័យរឹងរូស ដូច្នេះ ស្តេចផារ៉ោនមិនបានធ្វើតាមលោកម៉ូសេ និងលោកអ៊ើរ៉ុនទេ។
ការនេះកើតឡើងដូចព្រះអម្ចាស់បានប្រាប់លោកលោកម៉ូសេរួចហើយ ថាស្តេចផារ៉ោននឹងធ្វើដូច្នេះ។
[13]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរក្រោកឡើងពីព្រឹក ឈរនៅចំពោះស្តេចផារ៉ោន ហើយទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់
ជាព្រះជាម្ចាស់របស់ជនជាតិហេព្រើរ មានបន្ទូលដូច្នេះ «ចូរអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងចេញទៅ ដើម្បីពួកគេអាចថ្វាយបង្គំយើង។[14]ដ្បិត នៅពេលនេះ
យើងនឹងចាត់គ្រោះកាចគ្រប់យ៉ាងរបស់យើង មកលើស្តេច នៅលើពួកមន្ត្រី និងប្រជារាស្ត្ររបស់ស្តេច។ យើងនឹងធ្វើការនេះ ដើម្បីឲ្យស្តេចបានដឹងថា
គ្មាននរណាដូចជាយើងនៅលើផែនដីនេះឡើយ។
[15]ដ្បិត ប្រសិនបើយើងបានលើកដៃវាយអ្នក និងប្រជារាស្ត្ររបស់អ្នក ដោយជំងឺអាសន្នរោគនៅពេលនេះ ម្ល៉ៈអ្នករាល់គ្នានឹងវិនាសសូន្យពីផែនដីបាត់ទៅហើយ។[16]ប៉ុន្តែ
យើងបានទុកឲ្យអ្នកនៅរស់ ដើម្បីឲ្យអ្នកបានឃើញពីអំណាចរបស់យើង ដើម្បីឲ្យនាមរបស់យើងត្រូវប្រកាសពាសពេញផែនដី។[17]ស្តេចនៅតែតម្កើងខ្លួនទាស់នឹងប្រជារាស្ត្រ
របស់យើង ដោយមិនព្រមអនុញ្ញាតឲ្យពួកគេចេញទៅទេ។
[18]ចូរស្តាប់! ថ្ងៃស្អែក ពេលថ្មើរនេះ យើងនឹងធ្វើឲ្យមានព្យុះព្រិលយ៉ាងខ្លាំងកើតឡើង ដែលមិនធ្លាប់មាននៅក្នុងអេស៊ីប តាំងពីស្រុកនេះកើតមក រហូតមកដល់ពេលនេះ។
[19]ឥឡូវនេះ ចូរចាត់ពួកប្រុសៗឲ្យទៅប្រមូលហ្វូងសត្វ និងអ្វីៗទាំងអស់ដែលស្តេចមាននៅស្រែចម្ការ ទៅកាន់កន្លែងមានសុវត្ថិភាព។ បុរស
និងសត្វទាំងអស់ដែលនៅស្រែចម្ការ ដែលមិនបាននៅផ្ទះ ព្រិលនឹងធ្លាក់មកលើពួកគេ ហើយពួកគេនឹងស្លាប់»។
[20]បន្ទាប់មក ពួកមន្ត្រីរបស់ស្តេចផារ៉ោនបានជឿនៅព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏ប្រញាប់ទៅនាំទាសករ និងហ្វូងសត្វរបស់ពួកគេមកផ្ទះវិញ។[21]ប៉ុន្តែ
អស់អ្នកដែលមិនជឿលើព្រះបន្ទូលរបស់ព្រះអម្ចាស់បានទុកពួកទាសករ និងហ្វូងសត្វរបស់ពួកគេនៅស្រែចម្ការ។
[22]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរលើកដៃរបស់អ្នកទៅលើមេឃ ដើម្បីធ្វើឲ្យមានព្រិលធ្លាក់មកពេញទឹកដីអេស៊ីប លើប្រជារាស្ត្រ លើសត្វ
និងលើរុក្ខជាតិនៅស្រែចម្ការពាសពេញទឹកដីអេស៊ីបទាំងមូល»។[23]លោកម៉ូសេបានលើកដំបងរបស់គាត់ទៅលើមេឃ ហើយព្រះអម្ចាស់បានធ្វើឲ្យមានផ្គរលាន់ ព្រិល
និងផ្លេកបន្ទោរមកលើដី។ ព្រះអង្គបានធ្វើឲ្យមានភ្លៀងព្រិលធ្លាក់មកលើទឹកដីអេស៊ីបដែរ។[24]ដូច្នេះ ក៏មានព្រិល ផ្លេកបន្ទោលាយជាមួយនឹងព្រិលយ៉ាងខ្លាំង
ដែលមិនធ្លាប់កើតឡើងនៅក្នុងទឹកដីអេស៊ីបទាំងមូល ចាប់តាំងពីនាមប្រទេសនេះមក។
[25]ពេញទឹកដីអេស៊ីបទាំងមូល ព្រិលបានធ្លាក់មកលើស្រែចម្ការទាំងអស់ ធ្លាក់មកលើទាំងមនុស្ស និងសត្វ។ វាធ្លាក់មកលើដំណាំនៅក្នុងស្រែចម្ការ
ហើយបានបំបាក់ដើមឈើទាំងអស់។[26]លើកលែងតែទឹកដីកូសែន ជាកន្លែងដែលជនជាតិអ៊ីស្រាអែលរស់នៅប៉ុណ្ណោះ ដែលគ្មានព្រិល។
[27]បន្ទាប់មក ស្តេចផារ៉ោនបានចាត់គេឲ្យទៅកោះហៅលោកម៉ូសេ និងលោកអ៊ើរ៉ុន។ ស្តេចមានរាជឱង្ការទៅពួកគេថា «លើកនេះ យើងបានប្រព្រឹត្តបាបមែន។
ព្រះអម្ចាស់សុចរិត ហើយយើង និងប្រជារាស្ត្ររបស់យើងជាមនុស្សអាក្រក់។[28]សូមអធិស្ឋានទៅកាន់ព្រះអម្ចាស់ ព្រោះព្យុះភ្លៀងព្រិលនេះខ្លាំងណាស់។
យើងនឹងអនុញ្ញាតឲ្យអ្នកទៅហើយ ហើយអ្នកនឹងលែងនៅទីនេះទៀតដែរ»។
[29]លោកម៉ូសេទូលទៅស្តេចថា៖ «ពេលទូលបង្គំចាកចេញពីក្រុងនេះពេលណា ទូលបង្គំនឹងលើកដៃទៅឯព្រះអម្ចាស់។ ផ្គរនឹងឈប់ ហើយនឹងលែងមានព្រិលទៀតហើយ។
បែបនេះ ព្រះអង្គនឹងជ្រាបថា ផែនដីនេះជាកម្មសិទ្ធិរបស់ព្រះអម្ចាស់។[30]ប៉ុន្តែ ទូលបង្គំដឹងថា ព្រះអង្គ និងពួកនាម៉ឺនមន្ត្រីរបស់ព្រះអង្គមិនទាន់កោតខ្លាចព្រះអម្ចាស់ដ៏ជា
ព្រះជាម្ចាស់នៅឡើយទេ»។
[31]ពេលនោះ ដើមធ្នៃកំពុងចេញផ្កា និងស្រូវស្រាលកំពុងដាក់គ្រាប់[32]ចំណែកស្រូវសាលី និងស្រូវធ្ងន់វិញមិនត្រូវខូចខាតឡើយ ព្រោះមិនទាន់ចេញកួរ។[33]នៅពេល លោក
ម៉ូសេចាកចេញពីស្តេចផារ៉ោន រួចចេញទៅក្រៅទីក្រុង គាត់បានលើកដៃរបស់គាត់ទៅចំពោះព្រះអម្ចាស់ ផ្គរឈប់លាន់ឮ ព្រិលឈប់ធ្លាក់ ហើយភ្លៀងក៏លែងធ្លាក់មកលើ
ផែនដីទៀតដែរ។
[34]នៅពេលស្តេចផារ៉ោនឃើញភ្លៀងរាំង ព្រិលឈប់ធ្លាក់ និងផ្គរលែងលឺ ស្តេចបានធ្វើបាបសារជាថ្មី ហើយបានព្រះទ័យរឹងរូស រួមជាមួយមន្ត្រីរបស់ស្តេចផង។
[35]ស្តេចផារ៉ោនមានព្រះទ័យរឹងរូស ដូច្នេះហើយ ស្តេចមិនព្រមអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលចេញទៅឡើយ។ នេះគឺជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា
ស្តេចផារ៉ោននឹងប្រព្រឹត្តដូច្នេះ។

Exodus 9:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលជាមួយលោកម៉ូសេ អំពីការទាក់ទងជាមួយស្តេចផារ៉ោន
និងនាំប្រជាជនជាតិហេព្រើរចេញពីស្រុកអេស៊ីប។
ប្រសិនបើ ស្តេចបដិសេធមិនអនុញ្ញាតឲ្យពួកគេទៅ ហើយប្រសិនបើ អ្នកនៅតែឃាំងពួកគេ
ឃ្លាទាំងពីរនេះមានអត្ថន័យជារួមដូចគ្នា។

generated on Wed Sep 10 16:16:32 2025

ពួកគេនឹងបញ្ជាក់ដល់ស្តេចផារ៉ោននូវអ្វីកើតដែលនឹងឡើងប្រសិនបើស្តេចផារ៉ោនធ្វើបែបនេះ។
ការបកប្រែផ្សេងទៀត
«ប្រសិនបើស្តេចផារ៉ោននៅតែបន្តបដិសេធមិនឱ្យពួកគេចាកចេញ»
ដូច្នេះ ព្រះហស្តរបស់ព្រះអម្ចាស់នឹងវាយប្រហារហ្វូងសត្វ
ពាក្យថា «ព្រះហស្ត» ត្រង់នេះតំណាង ឲ្យ ព្រះចេស្តារបស់ព្រះអម្ចាស់ ក្នុង
ការធ្វើបាបសត្វរបស់ពួកគេដែលមានជម្ងឺ។ បកប្រែផ្សេងទៀត
«ពេលនោះអំណាចរបស់ព្រះអម្ចាស់ នឹងធ្វើបាបហ្វូងសត្វរបស់អ្នក»
ហ្វូងសត្វរបស់អ្នក
ពាក្យថា «អ្នក»
នៅទីនេះសំដៅទៅលើប្រជាជនអេស៊ីបទាំងអស់ដែលមានហ្វូងសត្វផ្ទាល់ខ្លួន។
ហ្វូងសត្វជនជាតិអ៊ីស្រាអែល
នៅទីនេះ « អ៊ីស្រាអែល» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ហ្វូងសត្វដែលជាកម្មសិទ្ធិរបស់ប្រជាជនអ៊ីស្រាអែល»
ជនជាតិអេស៊ីប
នៅទីនេះ «អេស៊ីប» សំដៅទៅលើប្រជាជនអេស៊ីប។ ការបកប្រែផ្សេងទៀត
«ហ្វូងសត្វជាកម្មសិទ្ធិរបស់ប្រជាជនអេស៊ីប»
Exodus 9:5
កំណត់ពេលវេលា
«កំណត់ពេលវេលា» ឬ «តាមពេលវេលាកំណត់»
ហ្វូងសត្វទាំងអស់នៅអេស៊ីបងាប់គ្មានសល់។
នេះគឺជាការនិយាយបំផ្លើសដើម្បីបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃព្រឹត្តិការណ៍។
ការបកប្រែផ្សេងទៀត « គោក្របីនៅស្រុកអេស៊ីបបានស្លាប់អស់ជាច្រើន»
ហ្វូងសត្វទាំងអស់នៅអេស៊ីប
នៅទីនេះ « អេស៊ីប» សំដៅទៅលើប្រជាជនអេស៊ីប។ ការបកប្រែផ្សេងទៀត
«ហ្វូងសត្វជាកម្មសិទ្ធិរបស់ប្រជាជនអេស៊ីប»
ស្តេចផារ៉ោនបានចាត់គេឲ្យទៅស៊ើបអង្កេត
ស្តេចផារ៉ោនបានប្រមូលការពិតអំពីស្ថានការណ៍នេះ។
មើល៍
ពាក្យថា « មើល» នៅទីនេះបង្ហាញថាស្តេចផារ៉ោនមានការភ្ញាក់ផ្អើល
ចំពោះអ្វីដែលស្តេចបានទតឃើញ។
ស្តេចផារ៉ោននៅតែមានព្រះទ័យមានះ
នៅទីនេះ « ព្រះហឫទ័យ» សំដៅទៅលើស្តេចផារ៉ោន។ ការបកប្រែផ្សេងទៀត
«ស្តេចផារ៉ោនបានបដិសេធ មិនផ្លាស់ប្តូរគំនិតរបស់ស្តេច»
Exodus 9:8
ចង្ក្រាន
ឡសម្រាប់ដុតកំដៅនៅផ្ទះ
ម៉ដ្ត
«តូចខ្លាំង»
ហើយធ្លាយចេញ
«លិចចេញយ៉ាងរហ័ស»
Exodus 9:11
ព្រះអម្ចាស់បានធ្វើឲ្យស្តេចផារ៉ោនមានព្រះទ័យរឹងរូស
នៅទីនេះ « ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសរបស់ស្តេចត្រូវបានគេនិយាយដូចជាព្រះទ័យរបស់ស្តេចរឹងរូស។
សូមមើលនៅក្នុង ៧:១១ ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានធ្វើអោយផារ៉ោន មានព្រះទ័យជម្នះថែមទៀត» និង
Exodus 9:13
មកលើស្តេច
នេះមានន័យថាសូម្បីតែស្តេចផារ៉ោន ក៏នឹងរងទុក្ខដោយសារគ្រោះកាចដែរ។
យើងនឹងធ្វើការនេះ ដើម្បីឲ្យស្តេចបានដឹងថា
ពាក្យថា «នេះ» សំដៅទៅលើគ្រោះកាចនានា
ដែលលោកម៉ូសេបានប្រាប់ដល់ស្តេចផារ៉ោន។
Exodus 9:15
លើកដៃវាយអ្នក និងប្រជារាស្ត្ររបស់អ្នក
នៅទីនេះ «ដៃរបស់យើង» សំដៅទៅលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «ប្រើអំណាចរបស់យើង ដើម្បីធ្វើបាបអ្នក»
ដើម្បីឲ្យនាមរបស់យើងត្រូវប្រកាសពាសពេញផែនដី។
នៅតីនេះ « ព្រះនាមរបស់យើង» តំណាងអោយកិក្តិសព្ទរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ដើម្បីឱ្យមនុស្សគ្រប់ទីកន្លែង នឹងដឹងថាយើងគឺខ្លាំងអស្ចារ្យ»
ប្រជារាស្ត្ររបស់យើង ដោយមិនព្រមអនុញ្ញាតឲ្យពួកគេចេញទៅទេ។
ផ្ទុយពីការអនុញ្ញាតរបស់ស្តេចផារ៉ោន ដើម្បីឲ្យប្រជារាស្ត្រទៅថ្វាយបង្គំព្រះអម្ចាស់
គឺត្រូវបាននិយាយដូចជាស្តេចបានលើកតម្កើងអង្គទ្រង់ ជារនាំងចំពោះពួកគេ។
Exodus 9:18
ចូរស្តាប់!
«ចូរយកចិត្តទុកដាក់លើរឿងសំខាន់ ដែលយើងកំពុងប្រាប់អ្នក»
Exodus 9:27
កោះហៅ
«ហៅ»
Exodus 9:29
លោកម៉ូសេទូលទៅស្តេច
«ម៉ូសេបានទូលទៅកាន់ ស្តេចផារ៉ោន»
លើកដៃទៅឯព្រះអម្ចាស់។
កាយវិការនេះជានិមិត្តរូបនៃការអធិស្ឋានអមជាមួយ។ ការបកប្រែផ្សេងទៀត
«ទូលបង្គំលើកដៃ ហើយអធិស្ឋានដល់ព្រះអម្ចាស់»
កោតខ្លាចព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់
ការកោតខ្លាចព្រះជាម្ចាស់ ទាក់ទងការស្តាប់បង្គាប់ទ្រង់
ហើយរស់នៅតាមរបៀបដែលបង្ហាញថាព្រះអង្គពិតជាអស្ចារ្យណាស់។
Exodus 9:31
ដើមធ្មៃ
នេះគឺជារុក្ខជាតិដែលបង្កើតសរសៃ ដែលអាចផលិតចេញជាក្រណាត់ទេសឯក។
ស្រូវស្រាល
នេះគឺជាប្រភេទស្រូវដែលត្រូវបានប្រើសម្រាប់ធ្វើនំប៉័ង។
ក៏ត្រូវបានប្រើសម្រាប់ចំណីសត្វ។
ស្រូវធ្ងន់
នេះគឺជាប្រភេទនៃស្រូវសាលី។
បានលើកដៃរបស់គាត់ទៅចំពោះព្រះអម្ចាស់
កាយវិការនេះជានិមិត្តរូបនៃការអធិស្ឋានអមជាមួយ។ ការបកប្រែផ្សេងទៀត
«ទូលបង្គំលើកដៃហើយអធិស្ឋានដល់ព្រះអម្ចាស់»។
សូមមើលរបៀបស្រដៀងគ្នានៅ ៩:២៩ ។
Exodus 9:34
ព្រះទ័យរឹងរូស
នៅទីនេះ « ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងចចេសរបស់ស្តេច ត្រូវបានគេនិយាយ
ដូចជាព្រះហទ័យរបស់ស្តេចមាន:។ ការបកប្រែផ្សេងទៀត
«កាន់តែមាន:ថែមទៀត»
ស្តេចផារ៉ោនមានព្រះទ័យរឹងរូស
នៅទីនេះ « ព្រះហទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងចចេសរបស់ស្តេចត្រូវបានគេនិយាយដូច
ជាព្រះទ័យរបស់ស្តេចរឹងរូស។ សូមមើលនៅក្នុង ៧:១១ ។ ការបកប្រែផ្សេងទៀត
«ស្តេចផារ៉ោនកាន់តែមាន:ថែមទៀត»

---

10 [1]ព្រះអម្ចាស់មានបន្ទូលមកកាន់លោកម៉ូសេថា៖ «ចូរទៅជួបស្តេចផារ៉ោន ដ្បិត យើងបានធ្វើឲ្យស្តេច និងមន្ត្រីរបស់ស្តេចមានចិត្តរឹង។ យើងបានធ្វើការនេះ
ដើម្បីបង្ហាញទីសម្គាល់ផ្សេងៗនៃអំណាចរបស់យើងនៅក្នុងចំណោមពួកគេ។[2]យើងបានធ្វើការនេះ ដើម្បីឲ្យអ្នករាល់គ្នាអាចដំណាលប្រាប់កូន
និងចៅរបស់អ្នករាល់គ្នាពីការដែលយើងបានធ្វើ គឺបានប្រព្រឹត្តនឹងអេស៊ីបយ៉ាងធ្ងន់ធ្ងរ
និងពីការដែលយើងបានធ្វើការអស្ចារ្យផ្សេងៗដែលសម្តែងពីអំណាចរបស់យើងនៅក្នុងចំណោមពួកគេ។ បែបនេះ អ្នករាល់គ្នានឹងដឹងថា យើងជាព្រះអម្ចាស់»។
[3]ដូច្នេះ លោកម៉ូសេ និងលោកអ៊ើរ៉ុនបានទៅគាល់ស្តេចផារ៉ោន ហើយទូលស្តេចថា៖ «ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ជនជាតិហេព្រើរ មានបន្ទូលដូច្នេះ
«តើស្តេចនៅតែមិនព្រមបន្ទាបខ្លួននៅចំពោះយើងដល់កាលណាទៀត? ចូរអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងចេញទៅ ដើម្បីឲ្យពួកគេអាចថ្វាយបង្គំយើងបាន។[4]ប៉ុន្តែ
ប្រសិនបើ ស្តេចបដិសេធមិនព្រមអនុញ្ញាតឲ្យប្រជារាស្ត្ររបស់យើងទៅទេ ចូរស្តាប់ ថ្ងៃស្អែក យើងនឹងនាំសត្វកណ្តូបមកក្នុងទឹកដីរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[5]ពួកវានឹងហើរមកពាសពេញដី ដូច្នេះ គ្មានសល់ដីមួយកន្លែងដែលអាចមើលឃើញឡើយ។ ពួកវានឹងស៊ីអ្វីៗដែលនៅសល់ពីព្រិល។
វាក៏នឹងស៊ីដើមឈើទាំងអស់របស់ស្តេចដែលដុះនៅឯស្រែចម្ការ។[6]ពួកវានឹងចូលទៅពេញដំណាក់ និងផ្ទះមន្ត្រីរបស់ស្តេច និងផ្ទះរបស់ជនជាតិអេស៊ីបទាំងអស់
ជាអ្វីមួយដែលឪពុក និងជីតារបស់អ្នកមិនដែលឃើញពីមុន និងជាអ្វីដែលមិនដែលឃើញតាំងពីផែនដីបានកើតមក រហូតមកដល់សព្វថ្ងៃនេះ»។ បន្ទាប់មក
លោកម៉ូសេក៏ចាកចេញពីស្តេចផារ៉ោនទៅ។
[7]ពួកមន្ត្រីរបស់ស្តេចផារ៉ោនទូលទៅស្តេចថា៖ «តើបុរសនេះឲ្យធ្វើបានយើងដល់កាលណាទៀត? ចូរអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលចេញទៅ
ដើម្បីឲ្យពួកគេអាចថ្វាយបង្គំព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ពួកគេ។ តើព្រះអង្គមិនជ្រាបទេឬថា អេស៊ីបត្រូវបានបំផ្លាញ?»[8]គេបាននាំលោកម៉ូសេ
និងលោកអ៊ើរ៉ុនមកគាល់ស្តេចផារ៉ោនម្តងទៀត ស្តេចបានមានរាជឱង្ការថា៖ «ចូរទៅថ្វាយបង្គំព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នកចុះ។ តើនរណាខ្លះនឹងទៅ?»
[9]លោកម៉ូសេទូលថា៖ «យើងនឹងចេញទៅទាំងចាស់ទាំងក្មេង ទាំងកូនប្រុស និងកូនស្រីរបស់យើង។ យើងនឹងចេញទៅជាមួយហ្វូងសត្វ និងហ្វូងចៀមរបស់យើង។ ដ្បិត
យើងខ្ញុំនឹងធ្វើពិធីបុណ្យថ្វាយព្រះអម្ចាស់»។[10]ស្តេចផារ៉ោនមានរាជឱង្ការទៅពួកគេថា៖ «សូមព្រះអម្ចាស់នៅជាមួយអ្នករាល់គ្នាចុះ ប្រសិនបើ យើងអនុញ្ញាតឲ្យអ្នក
និងកូនតូចៗរបស់អ្នកទៅ។ មើល៍ អ្នករាល់គ្នាមានគំនិតអាក្រក់។[11]អត់ទេ! ចូរចេញទៅតែប្រុសៗដែលនៅក្នុងចំណោមអ្នករាល់គ្នាបានហើយ ហើយថ្វាយបង្គំព្រះអម្ចាស់ចុះ
ដ្បិត នោះគឺជាអ្វីដែលអ្នកចង់បាន»។ បន្ទាប់មក គេបានបណ្តេញលោកម៉ូសេ និងលោកអ៊ើរ៉ុនចេញពីស្តេចផារ៉ោន។
[12]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរលើកដៃរបស់អ្នកលើទឹកដីអេស៊ីប ដើម្បីឲ្យកើតមានកណ្តូបឲ្យពួកវាបានវាយប្រហារទឹកដីអេស៊ីប
និងស៊ីដំណាំទាំងឡាយនៅក្នុងទឹកដីអេស៊ីបដែលនៅសល់ពីព្រិល»។[13]លោកម៉ូសេបានលើកដៃ ជាមួយនឹងដំបងរបស់គាត់លើទឹកដីអេស៊ីប
ហើយព្រះអម្ចាស់បាននាំឲ្យមានខ្យល់បក់ពីទិសខាងកើតលើទឹកដីទាំងអស់ពេញមួយថ្ងៃមួយយប់។ នៅព្រឹកឡើង ខ្យល់ពីទិសខាងកើតបាននាំសត្វកណ្តូបមក។
[14]សត្វកណ្តូបបានចេញទៅពាសពេញទឹកដីអេស៊ីបទាំងមូល ហើយបានទំពាស់ពេញទឹកដីតែម្តង។ មិនដែលធ្លាប់មានហ្វូងកណ្តូបនៅក្នុងទឹកដីបែបនេះទេ
ហើយក្រោយពីនេះក៏មានកណ្តូបច្រើនយ៉ាងនេះដែរ។[15]ពួកវាបានគ្រប់ដណ្តប់ពាសពេញទឹកដីទាំងមូល ធ្វើឲ្យដ្បែដីខ្មៅងងឹត។ ពួកវាបានស៊ីដំណាំ
ផលផ្លែដើមឈើដែលនៅសល់ពីព្រិលទាំងអស់។ នៅពាសពេញទឹកដីអេស៊ីបទាំងមូល គ្មានសល់ស្លឹងខៀវខ្ចីនៅសល់ទេ ឬដើមឈើ និងដំណាំនៅស្រែចម្ការនៅសល់ទេ។
[16]បន្ទាប់មក ស្តេចផារ៉ោនបានកោះហៅលោកម៉ូសេ និងលោកអ៊ើរ៉ុនមកយ៉ាងលឿន ហើយមានរាជឱង្ការថា៖ «យើងបានធ្វើបាបទាស់នឹងព្រះអម្ចាស់
ជាព្រះជាម្ចាស់របស់អ្នក និងអ្នកផងដែរ។[17]បន្ទាប់មក សូមអត់ទោសបាបរបស់យើងនៅពេលនេះ ហើយអធិស្ឋានដល់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នក
ដែលព្រះអង្គនឹងដកសេចក្តីស្លាប់នេះចេញពីយើង»។[18]ដូច្នេះ លោកម៉ូសេបានចាកចេញពីស្តេចផារ៉ោនទៅ ហើយបានអធិស្ឋានដល់ព្រះអម្ចាស់។
[19]ព្រះអម្ចាស់បាននាំឲ្យមានខ្យល់បង់យ៉ាងខ្លាំងពីទិសខាងលិច ដែលនាំឲ្យមានសត្វកណ្តូប ហើយកៀរចូលទៅក្នុងសមុទ្រកក់
គ្មានសត្វកណ្តូបណាមួយនៅសល់នៅក្នុងទឹកដីអេស៊ីបឡើយ។[20]ប៉ុន្តែ ព្រះអម្ចាស់បានធ្វើឲ្យព្រះទ័យស្តេចផារ៉ោនរឹង
ហើយស្តេចផារ៉ោនមិនអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលចេញទេ។
[21]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរលើកដៃរបស់អ្នកទៅលើមេឃ ដើម្បីឲ្យមានភាពងងឹងគ្របដណ្តប់ទឹកដីអេស៊ីបទាំងមូល
គឺជាភាពងងឹតដែលមើលអ្វីមិនឃើញឡើយ»។[22]លោកម៉ូសេក៏លើកដៃរបស់គាត់ទៅលើមេឃ
ហើយមានភាពងងឹតយ៉ាងក្រាសនៅក្នុងទឹកដីអេស៊ីបទាំងមូលអស់រយៈពេលបីថ្ងៃ។[23]គ្មាននរណាអាចមើលគ្នាទៅវិញទៅមកឃើញឡើយ ក្នុងរយៈពេលបីថ្ងៃ
គ្មាននរណាចេញពីផ្ទះឡើយ។ ប៉ុន្តែ សម្រាប់ជនជាតិអ៊ីស្រាអែលវិញមានពន្លឺនៅក្នុងដែលពួកគេរស់នៅ។
[24]ស្តេចផារ៉ោនបានកោះហៅលោកម៉ូសេ ហើយមានរាជឱង្ការថា៖ «ចូរទៅថ្វាយបង្គំព្រះអម្ចាស់ចុះ។ ទាំងគ្រួសាររបស់អ្នកក៏ទៅជាមួយអ្នកដែរ ប៉ុន្តែ ទុកហ្វូងសត្វ
និងហ្វូងចៀមនៅទីនេះហើយ»។[25]ប៉ុន្តែ លោកម៉ូសេទូលថា៖ «ព្រះអង្គត្រូវប្រទានសត្វដល់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំយកទៅធ្វើជាយញ្ញបូជា ហើយធ្វើជាយញ្ញបូជាដុត
ដើម្បីយើងធ្វើយញ្ញបូជាសត្វទាំងនោះថ្វាយព្រះអម្ចាស់ជាព្រះជាម្ចាស់របស់យើង។[26]ហ្វូងគោរបស់យើងខ្ញុំក៏ត្រូវចេញទៅជាមួយយើងខ្ញុំដែរ។
មិនត្រូវឲ្យនៅសល់ក្រចកជើងរបស់ពួកវាណាមួយឡើយ ព្រោះយើងខ្ញុំត្រូវយកពួកវាទៅថ្វាយបង្គំព្រះអម្ចាស់ជាព្រះជាម្ចាស់របស់យើងខ្ញុំ។ ដ្បិត យើងខ្ញុំមិនដឹងថា
យើងខ្ញុំត្រូវយកអ្វីទៅថ្វាយបង្គំព្រះអម្ចាស់នៅឡើយទេ លុះត្រាតែយើងខ្ញុំទៅដល់ទីនោះសិន។
[27]ប៉ុន្តែ ព្រះអម្ចាស់បានធ្វើឲ្យព្រះទ័យរបស់ស្តេចផារ៉ោនរឹង ហើយស្តេចមិនព្រមអនុញ្ញាតឲ្យពួកគេចេញទៅទេ។[28]ស្តេចផារ៉ោនមានរាជឱង្ការទៅលោកម៉ូសេថា៖
«ចូរចេញពីយើងទៅ» ចូរប្រយ័ត្នការមួយ សូមកុំឲ្យយើងឃើញមុខអ្នកទៀត ដើម្បីនៅថ្ងៃដែលអ្នកឃើញមុខយើង អ្នកនឹងស្លាប់»។[29]លោកម៉ូសេទូលថា៖
«ព្រះអង្គមានរាជឱង្ការដោយអង្គទ្រង់ទេ។ ទូលបង្គំនឹងមិនឃើញព្រះភក្ត្រព្រះអង្គទៀតទេ»។

Exodus 10:1
ដ្បិត យើងបានធ្វើឲ្យស្តេច និងមន្ត្រីរបស់ស្តេចមានចិត្តរឹង។
ព្រះអម្ចាស់មានព្រះបន្ទូលអំពី ការធ្វើអោយស្តេចផារ៉ោន
និងអ្នកបម្រើរបស់ព្រះអង្គមានចិត្តចចេសដូចព្រះអង្គធ្វើអោយចិត្តរបស់គេរឹងរូស។
សូមមើលពាក្យថា «ព្រះអម្ចាស់បានធ្វើឲ្យស្តេចផារ៉ោនមានព្រះទ័យរឹងរូស» នៅក្នុង
៩:១១ ។
ផ្សេងៗ
«ខុសៗគ្នាច្រើន»
Exodus 10:3
ចូរស្តាប់
ពាក្យនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលត្រូវនិយាយបន្ទាប់។
ការបកប្រែផ្សេងទៀត «ចូរយកចិត្តទុកដាក់លើអ្វី ដែលយើងរៀបរាប់ប្រាប់អ្នក»
Exodus 10:5
ព្រិល
ព្រិលគឺជាតំណក់ទឹកភ្លៀង ដែលកកនៅពេលធ្លាក់មកពីពពក។
អ្វីដែលមិនដែលឃើញ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គ្មានអ្វីដែលធ្លាប់បានឃើញ»
Exodus 10:7
ធ្វើបាប
ពាក្យ «ធ្វើបាប» គឺជាអ្នកដែលនាំមកនូវបញ្ហា ឬគ្រោះថ្នាក់។
តើបុរសនេះឲ្យធ្វើបាបយើងដល់កាលណាទៀត?
អ្នកបម្រើរបស់ស្តេចផារ៉ោនសួរសំណួរនេះ
ដើម្បីបង្ហាញពីការពង្រីកនៃការបំផ្លាញរបស់ស្តេចផារ៉ោនក្នុងស្រុកអេស៊ីប។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «យើងមិនអាចអោយបុរសនេះ
បន្តនាំបញ្ហាដល់ពួកយើងបានទេ!»
តើព្រះអង្គមិនជ្រាបទេឬថា អេស៊ីបត្រូវបានបំផ្លាញ?
អ្នកបម្រើរបស់ស្តេចផារ៉ោនសួរសំនួរនេះ
ដើម្បីនាំស្តេចផារ៉ោនអោយទទួលស្គាល់ពីអ្វី ដែលស្តេចមិនព្រមទតឃើញ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ស្តេចគួរតែដឹងថាស្រុកអេស៊ីបត្រូវបានបំផ្លាញ!»
អេស៊ីបត្រូវបានបំផ្លាញ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គ្រោះកាចទាំងនេះបានបំផ្លាញ ស្រុកអេស៊ីប» ឬ «
ព្រះជាម្ចាស់របស់ពួកគេបានបំផ្លាញស្រុកអេស៊ីប»
Exodus 10:9
ប្រសិនបើ យើងអនុញ្ញាតឲ្យអ្នក និងកូនតូចៗរបស់អ្នកទៅ។
ស្តេចផារ៉ោនមានព្រះរាជឱង្ការថានេះ ដើម្បី
បញ្ជាក់ថាស្តេចមិនអនុញ្ញាតអោយលោកម៉ូសេ
នាំកូនៗមកជាមួយដើម្បីគោរពថ្វាយបង្គំព្រះអម្ចាស់ទេ។
គេបានបណ្តេញលោកម៉ូសេ និងលោកអ៊ើរ៉ុនចេញពីស្តេចផារ៉ោន។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ព្រះចៅផារ៉ោនបណ្តេញលោកម៉ូសេនិងលោកអើរ៉ុន ចេញពីមុខព្រះអង្គ» ឬ «

generated on Wed Sep 10 16:16:32 2025

ស្តេចផារ៉ោនអោយអ្នកបម្រើរបស់ព្រះអង្គបណ្តេញលោកម៉ូសេ
និងលោកអើរ៉ុនចេញពីមុខព្រះអង្គ»
Exodus 10:14
ធ្វើឲ្យផ្ទៃដីខ្មៅងងឹត។
មានសត្វកណ្តូបច្រើនណាស់ ដែលមើលទៅងងឹតពេញដី។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីឱ្យពួកគេមើលទៅងងឹតពេញដី» ឬ «ដើម្បីឱ្យមើលទៅ
ភាពងងឹតកើតឡើងពេញស្រុក»
Exodus 10:16
ពេលនេះ
«ម្តងទៀត»
ដកសេចក្តីស្លាប់នេះចេញពីយើង។
ពាក្យថា «សេចក្តីស្លាប់» នៅទីនេះសំដៅទៅលើការបំផ្លាញ
ដោយសត្វកណ្តូបនៃរុក្ខជាតិទាំងអស់ នៅក្នុងប្រទេសអេស៊ីបដែលនៅទីបំផុត
នឹងនាំឱ្យមានមនុស្សស្លាប់ដោយសារតែគ្មានដំណាំ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ចូរបញ្ឈប់ការបំផ្លាញនេះ
ដែលនឹងនាំទៅដល់សេចក្តីស្លាប់របស់យើង»
Exodus 10:19
ដែលនាំឲ្យមានសត្វកណ្តូប
«បានបំផ្លាស់ទីសត្វកណ្តូបទៅមុខ»
ព្រះអម្ចាស់បានធ្វើឲ្យ ព្រះទ័យស្តេចផារ៉ោនរឹង
នៅទីនេះ « ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសចចេសរបស់ស្តេច
ត្រូវបានគេនិយាយដូចជាព្រះហទ័យរបស់ស្តេចរឹងរូស។ សូមមើលឃ្លានេះក្នុង
៩:១១ ។ ការបកប្រែផ្សេងទៀត
«បណ្តាលឱ្យស្តេចផារ៉ោនកាន់តែតែមាន:ថែមទៀត»
Exodus 10:21
គឺជាភាពងងឹតដែលមើលអ្វីមិនឃើញឡើយ។
ព្រះអម្ចាស់មានព្រះបន្ទូលអំពី
ភាពងងឹតសូន្យប្រៀបដូចជាកម្រាស់ដែលមនុស្សអាចចាប់យកទៅក្នុងកណ្តាប់ដៃរបស់គេ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ភាពងងឹតប្រៀបដូចកម្រាស់មួយ
ដែលមនុស្សអាចចាប់បានដោយដៃរបស់ពួកគេ»
Exodus 10:24
មិនត្រូវឲ្យនៅសល់ក្រចកជើងរបស់ពួកវាណាមួយឡើយ
ត្រង់នេះពាក្យថា « ក្រចក» សំដៅទៅលើសត្វទាំងមូល។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«យើងមិនអាចទុកចោលសត្វសូម្បីតែមួយគត់»
Exodus 10:27
ព្រះអម្ចាស់បានធ្វើឲ្យព្រះទ័យរបស់ស្តេចផារ៉ោនរឹង
នៅទីនេះ « ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសចចេសរបស់ស្តេច
ត្រូវបានគេនិយាយដូចជាព្រះហទ័យរបស់ស្តេចរឹងរូស។ សូមមើលឃ្លានេះក្នុង
៩:១១ ។ ការបកប្រែផ្សេងទៀត «បណ្តាលឱ្យស្តេចផារ៉ោន កាន់តែមាន:ថែមទៀត»
ស្តេចមិនព្រមអនុញ្ញាតឲ្យពួកគេចេញទៅទេ។
«ស្តេចផារ៉ោនមិនអនុញ្ញាតឲ្យពួកគេចេញទៅទេ»
ចូរប្រយ័ត្នការមួយ
«ចូរឲ្យច្បាស់រឿងមួយ» ឬ «ត្រូវប្រាកដថារឿងមួយ»
ឃើញព្រះភក្ត្រព្រះអង្គទៀត
នៅទីនេះពាក្យ «មុខ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«ស្តេចបានទតឃើញទូលបង្គំ»
ព្រះអង្គមានរាជឱង្ការដោយអង្គទ្រង់ទេ។
ជាមួយនឹងពាក្យទាំងនេះ លោកម៉ូសេបញ្ជាក់ថាស្តេចផារ៉ោននិយាយការពិត។
ការបកប្រែផ្សេងទៀត «អ្វីដែលស្តេចបានមានបន្ទូលគឺជាការពិត»

---

11 [1]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «នៅមានគ្រោះកាចមួយទៀត ដែលយើងនឹងនាំមកលើស្តេចផារ៉ោន និងស្រុកអេស៊ីប។ បន្ទាប់មក
ស្តេចនឹងអនុញ្ញាតឲ្យអ្នកចេញពីទីនេះហើយ។ នៅពេលស្តេចអនុញ្ញាតឲ្យអ្នកចេញហើយ ស្តេចនឹងបណ្តេញអ្នកឲ្យចេញទាំងអស់។[2]ចូរបង្គាប់ទៅពួកប្រុសៗ
និងស្រីៗទាំងអស់ឲ្យសូមគ្រឿងប្រាក់ និងគ្រឿងមាស ពីអ្នកជិតខាងរបស់ពួកគេ»។[3]ព្រះអម្ចាស់បានធ្វើឲ្យជនជាតិអេស៊ីបមានចិត្តមេត្តាដល់ជនជាតិអ៊ីស្រាអែល។
លើសពីនេះ លោកម៉ូសេជាមនុស្សដ៏សំខាន់នៅចំពោះពួកមន្ត្រីរបស់ស្តេចផារ៉ោន និងនៅចំពោះប្រជាជននៅក្នុងស្រុកអេស៊ីប។
[4]លោកម៉ូសេទូលថា៖ «ព្រះអម្ចាស់មានបន្ទូលដូច្នេះ៖ «នៅពាក់កណ្តាលយប់ យើងនឹងចេញទៅពាសពេញទឹកដីអេស៊ីប។[5]កូនច្បងទាំងអស់ដែលនៅក្នុងទឹកដីរបស់អេស៊ីប
នឹងត្រូវស្លាប់ គឺចាប់តាំងពីកូនច្បងរបស់ស្តេចផារ៉ោន ដែលសោយរាជ្យនៅលើបល្ល័ង្ក ដល់កូនច្បងរបស់ស្ត្រីបាវបម្រើដែលនៅខាងក្រោយត្បាល់កិន និងកូនច្បងក្នុងហ្វូង
សត្វទាំងអស់ថែមទៀតផង។
[6]បន្ទាប់មក នឹងមានឮសូរសម្រែកទ្រហោយំនៅក្នុងទឹកដីអេស៊ីបទាំងមូល ចាប់តាំងពីដើមរៀងមកមិនធ្លាប់មាន ហើយទៅមុខក៏មិនធ្លាប់មានដូច្នេះដែរ។[7]សូម្បីឆ្កែក៏មិនឮ
ព្រុសដាក់ជនជាតិអ៊ីស្រាអែល ដាក់មនុស្ស ឬសត្វណាមួយផង។ បែបនេះ អ្នករាល់គ្នានឹងដឹងថា ព្រះអម្ចាស់បានប្រព្រឹត្តនឹងជនជាតិអេស៊ីប និងជនជាតិ
អ៊ីស្រាអែលផ្សេងគ្នា។[8]ពួកមន្ត្រីរបស់ស្តេចផារ៉ោនទាំងអស់ នឹងចូលមករកឃើញ ហើយលុតជង្គង់ចុះនៅចំពោះយើង។ ពួកគេនឹងនិយាយថា៖ «ចូរចេញទៅ
ហើយមនុស្សទាំងអស់នឹងទៅជាមួយអ្នកដែរ!»។ បន្ទាប់ពីនោះ យើងនឹងចេញទៅ»។ បន្ទាប់មក គាត់ក៏ចេញពីស្តេចផារ៉ោនទាំងមានកំហឹងយ៉ាងខ្លាំង។
[9]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ស្តេចផារ៉ោននឹងមិនស្តាប់តាមអ្នកទេ។ ការនេះកើតឡើងដូច្នេះ ដើម្បីយើងអាចនឹងធ្វើការអស្ចារ្យ នៅក្នុងទឹកដីអេស៊ីប»។
[10]លោកម៉ូសេ និងលោកអើរ៉ុនបានធ្វើទីសម្គាល់ទាំងអស់នេះ នៅចំពោះស្តេចផារ៉ោន។ ប៉ុន្តែ ព្រះអម្ចាស់បានធ្វើឲ្យព្រះទ័យរបស់ស្តេចផារ៉ោនរឹង
ហើយស្តេចផារ៉ោនមិនព្រមអនុញ្ញាតឲ្យប្រជាជនអ៊ីស្រាអែលចេញពីទឹកដីរបស់ស្តេចទេ។

Exodus 11:1
ស្តេចនឹងអនុញ្ញាតឲ្យអ្នកចេញពីទីនេះហើយ។
គ្រប់ពាក្យដែលកើតឡើង «អ្នក»
នៅក្នុងខនេះគឺពហុវចន:ហើយសំដៅទៅលើលោកម៉ូសេ
និងជនជាតិអ៊ីស្រាអែលទាំងអស់។
Exodus 11:4
ពាក់កណ្តាលយប់
នេះគឺជាពេលវេលានៃនៅម៉ោង ១២យប់ រម្លងអធ្រាត (ពេលយប់) ឬ ២៤ម៉ោង។
កូនច្បងទាំងអស់ ... កូនច្បងរបស់ស្តេចផារ៉ោន ... ល់កូនច្បងរបស់ស្ត្រីបាវបម្រើ... កូនច្បងក្នុងហ្វូង
សត្វទាំងអស់ថែមទៀតផង។
«កូនច្បង» តែងតែសំដៅទៅលើកូនប្រុសអាយុជាងគេ។
ដែលសោយរាជ្យនៅលើបល្ល័ង្ក
ឃ្លានេះសំដៅទៅលើស្តេចផារ៉ោន។
ដល់កូនច្បងរបស់ស្ត្រីបាវបម្រើដែលនៅខាងក្រោយត្បាល់កិន
«អស់អ្នកដែលកំពុងកិនស្រូវ នៅឯងរោងកិនស្រូវ
ឬអស់អ្នកដែលនៅពីក្រោយរោងកិនស្រូវកិន»
Exodus 11:6
បន្ទាប់មក គាត់ក៏ចេញពីស្តេចផារ៉ោន
នេះមានន័យថាលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល នឹងចាកចេញពីស្រុកអេស៊ីប។
ការបកប្រែផ្សេងទៀត «បន្ទាប់ពីនោះខ្ញុំនឹងចាកចេញពីទីនេះ» ឬ
«បន្ទាប់មកខ្ញុំនឹងចាកចេញពីអេស៊ីប»
Exodus 11:9
ព្រះអម្ចាស់បានធ្វើឲ្យព្រះទ័យរបស់ស្តេចផារ៉ោនរឹង
នៅទីនេះ « ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសចចេសរបស់ស្តេច
ត្រូវបានគេនិយាយដូចជាព្រះទ័យរបស់ស្តេចរឹងរូស។ សូមមើលបកប្រែឃ្លានេះក្នុង
៩:១១ ។ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានធ្វើអោយស្តេចផារ៉ោនមានៈថែមទៀត»

generated on Wed Sep 10 16:16:32 2025

12 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ និងលោកអ៊ើរ៉ុននៅក្នុងទឹកដីអេស៊ីប។ ព្រះអង្គមានបន្ទូលថា៖[2]«សម្រាប់អ្នក ខែនេះគឺជាខែដែលត្រូវចាប់ផ្តើម
គឺខែដំបូងនៃឆ្នាំរបស់អ្នក។
[3]ចូរប្រាប់ដល់សហគមន៍អ៊ីស្រាអែលថា៖ «នៅថ្ងៃទីដប់ខែនេះ ពួកគេម្នាក់ៗត្រូវយកចៀមមួយ ឬពពែស្ទាវមួយសម្រាប់ពួកគេ គ្រួសារនីមួយៗត្រូវធ្វើដូច្នេះ
គឺត្រូវយកចៀមមួយសម្រាប់គ្រួសារមួយ។[4]ប្រសិនបើ គ្រួសារនោះតូចហូបចៀមមួយមិនអស់ អ្នកនោះនិងអ្នកជិតខាង ត្រូវយកសាច់ចៀម
ឬពពែស្ទាវចែកឲ្យល្មមសម្រាប់មនុស្សគ្រប់គ្នា។ គ្រប់គ្នាត្រូវតែបរិភោគឲ្យឆ្អែត ដូច្នេះ ពួកគេត្រូវយកសាច់ល្មម ដើម្បីចម្អែតពួកគេគ្រប់គ្នា។
[5]កូនចៀម ឬពពែឈ្មោលរបស់អ្នកត្រូវតែល្អឥតខ្ចោះ ដែលមានអាយុមួយខួប។ អ្នកត្រូវយកចៀមមួយ ឬពពែមួយពីហ្វូងសត្វ។
អ្នកត្រូវទុកវារហូតដល់ដប់បួនថ្ងៃនៅក្នុងខែនោះ។[6]បន្ទាប់មក សហគមន៍អ៊ីស្រាអែលទាំងមូលត្រូវសម្លាប់វានៅពេលថ្ងៃលិច។[7]អ្នកត្រូវយកឈាមខ្លះ
ហើយលាបវានៅលើក្របទ្វារទាំងសងខាង និងនៅលើក្របទ្វារផ្ទះដែលអ្នកហូបសាច់នោះផង។[8]អ្នកត្រូវហូបសាច់នៅយប់នោះ
បន្ទាប់ពីអ្នកបានអាំងវានៅលើភ្លើងហើយ។ ចូរហូបវាជាមួយនំប៉័ង ឥតមេ និងបន្លែល្វីង។
[9]កុំហូបសាច់ឆៅ ឬស្ងោរនឹងទឹកឡើយ។ ផ្ទុយទៅវិញ ត្រូវអាំងវាលើភ្លើង ជាមួយនឹងក្បាល ជើងនិងគ្រឿងក្នុងរបស់វា។
[10]អ្នកមិនត្រូវទុកឲ្យអ្វីមួយនៅសល់រហូតដល់ពេលព្រឹកឡើយ។ អ្នកត្រូវដុតអ្វីៗដែលនៅសល់ចោលឲ្យអស់នៅពេលព្រឹក។[11]នេះគឺជារបៀបដែលអ្នកត្រូវហូប
ត្រូវក្រវាត់ចង្កេះ ពាក់ស្បែកជើងនៅលើជើងរបស់អ្នក និងកាន់ដំបងនៅនឹងដៃរបស់អ្នកដែរ។ អ្នកត្រូវហូបវាឲ្យលឿន។ នេះគឺជាបុណ្យចម្លងរបស់ព្រះអម្ចាស់។
[12]ព្រះអម្ចាស់មានបន្ទូលដូច្នេះ យើងនឹងឆ្លងកាត់ទឹកដីអេស៊ីប ហើយប្រហារកូនច្បងរបស់មនុស្ស និងសត្វនៅក្នុងទឹកដីអេស៊ីប។
យើងនឹងនាំការជំនុំជម្រះនៅលើព្រះរបស់អេស៊ីបទាំងអស់។ យើងគឺព្រះអម្ចាស់។[13]ឈាមនឹងធ្វើជាទីសម្គាល់នៅក្នុងផ្ទះរបស់អ្នក នៅពេលយើងមក។
ពេលយើងប្រហារទឹកដីអេស៊ីប ហើយយើងឃើញឈាម យើងនឹងហោះរំលង។ គ្រោះកាចនេះនឹងមិនមកដល់អ្នករាល់គ្នាឡើយ ហើយយើងក៏មិនបំផ្លាញអ្នករាល់គ្នាដែរ។
[14]ថ្ងៃនេះនឹងក្លាយជាថ្ងៃដែលរំលឹកដល់អ្នករាល់គ្នា ដែលអ្នករាល់គ្នាត្រូវយកថ្ងៃនេះទុកជាពិធីបុណ្យថ្វាយព្រះអម្ចាស់។ វាជាច្បាប់សម្រាប់អ្នករាល់គ្នា
អ្នករាល់គ្នាត្រូវកាន់តាមគ្រប់ជំនាន់ ទុកជាច្បាប់រហូតតទៅ។
[15]អ្នករាល់គ្នាត្រូវហូបនំប៉័ងឥតមេ ក្នុងរយៈពេលប្រាំពីរថ្ងៃ។ នៅថ្ងៃដំបូង អ្នកត្រូវយកមេចេញពីផ្ទះរបស់អ្នករាល់គ្នា។ អ្នកណាដែលហូបនំប៉័ងមានមេក្នុងរយៈពេលប្រាំពីរថ្ងៃ
អ្នកនោះត្រូវកាត់ចេញពីអ៊ីស្រាអែល។[16]នៅថ្ងៃទីមួយ ត្រូវញែកសហគមន៍ឲ្យនៅដោយឡែកសម្រាប់យើង ហើយនៅថ្ងៃទីប្រាំពីរ នឹងមានការជួបជុំសារជាថ្មីម្តងទៀត។
នៅថ្ងៃនោះ មិនត្រូវធ្វើការអ្វីឡើយ លើកលែងតែចម្អិនម្ហូបសម្រាប់មនុស្សគ្រប់គ្នាហូបតែប៉ុណ្ណោះ។ អ្នករាល់អ្នកអាចធ្វើការលុះត្រាតែការងារដែលត្រូវធ្វើម្ហូបប៉ុណ្ណោះ។
[17]អ្នករាល់គ្នាត្រូវកាន់តាមពិធីបុណ្យនំប៉័ងឥតមេនេះ ព្រោះវាគឺជាថ្ងៃដែលយើងបាននាំប្រជាជនរបស់អ្នករាល់គ្នា ពួកពលរបស់អ្នករាល់គ្នាជាក្រុមៗ ចេញពីទឹកដីអេស៊ីប។
ដូច្នេះ អ្នករាល់គ្នាត្រូវរក្សាថ្ងៃនេះ នៅគ្រប់ជំនាន់របស់អ្នករាល់គ្នា។ នេះគឺជាច្បាប់សម្រាប់អ្នករាល់គ្នា។[18]អ្នករាល់គ្នាត្រូវហូបនំប៉័ងនៅពេលថ្ងៃលិច
ចាប់ពីថ្ងៃដប់បួននៅក្នុងខែដំបូងនៃឆ្នាំ រហូតដល់ថ្ងៃម្ភៃមួយនៃខែនោះ។
[19]ក្នុងរយៈពេលប្រាំពីរថ្ងៃ មិនត្រូវឲ្យមានមេនៅក្នុងផ្ទះរបស់អ្នករាល់គ្នាឡើយ។ អស់អ្នកណាដែលបរិភោគនំប៉័ងដែលធ្វើដោយមេ ត្រូវកាត់ចេញពីសហគមន៍អ៊ីស្រាអែល
ទោះបើ អ្នកនោះគឺជាជនបរទេស ឬអ្នកដែលកើតនៅក្នុងទឹកដីរបស់អ្នករាល់គ្នា។ អ្នករាល់គ្នាមិនត្រូវហូបនំប៉័ងដែលធ្វើដោយមេឡើយ។
[20]នៅគ្រប់កន្លែងដែលអ្នករាល់គ្នារស់នៅ អ្នករាល់គ្នាត្រូវហូបនំប៉័ងដែលឥតមេ។
[21]បន្ទាប់មក លោកម៉ូសេបានកោះហៅពួកចាស់ទុំអ៊ីស្រាអែលទាំងអស់ ហើយប្រាប់ដល់ពួកគេថា៖ «ចូរទៅ ហើយជ្រើសរើសកូនចៀម ឬចៀមតូច
ដែលល្មមនឹងចម្អែតគ្រួសាររបស់អ្នករាល់គ្នា ហើយសម្លាប់វាធ្វើពិធីបុណ្យចម្លង។[22]បន្ទាប់មក យកមែកហ៊ីសុប ហើយជ្រលក់វាទៅក្នុងឈាមដែលនៅក្នុងផើង។
ហើយលាបឈាមដែលនៅក្នុងផើងនៅពីលើក្របទ្វារ ហើយលាបលើក្របទ្វារទាំងសងខាង។ កុំឲ្យនរណាម្នាក់ចេញក្រៅទ្វារផ្ទះរបស់គាត់ឡើងរហូតដល់ពេលព្រឹកឡើយ។
[23]ដ្បិត ព្រះអម្ចាស់នឹងឆ្លងកាត់ ដើម្បីប្រហារជនជាតិអេស៊ីប។ នៅពេលព្រះអង្គទតឃើញឈាមដែលនៅលើក្របទ្វារ ព្រះអង្គនឹងរំលងទ្វាររបស់អ្នក
ហើយមិនអនុញ្ញាតឲ្យមេបំផ្លាញចូលទៅក្នុងផ្ទះរបស់អ្នករាល់គ្នា ហើយប្រហារអ្នករាល់គ្នាឡើយ។
[24]អ្នករាល់គ្នាត្រូវកាន់តាមច្បាប់នេះ។ ហើយវានឹងត្រូវធ្វើជាច្បាប់សម្រាប់អ្នករាល់គ្នា និងពូជពង្សរបស់អ្នករាល់គ្នា។
[25]នៅពេលអ្នករាល់គ្នាចូលទៅក្នុងទឹកដីដែលព្រះអម្ចាស់បានប្រទានដល់អ្នករាល់គ្នា ដូចដែលព្រះអង្គបានសន្យានឹងធ្វើ អ្នករាល់គ្នាត្រូវធ្វើការនេះ ទុកជាការថ្វាយបង្គំ។
[26]នៅពេលកូនចៅរបស់អ្នករាល់គ្នាសួរថា៖ «តើពិធីបុណ្យនេះមានន័យដូចម្តេច?»[27]នោះ អ្នកត្រូវប្រាប់ពួកគេថា៖ «នេះគឺជាយញ្ញបូជានៃពិធីបុណ្យចម្លងរបស់ព្រះអម្ចាស់
ព្រោះព្រះអម្ចាស់បានឆ្លងកាត់ផ្ទះរបស់ជនជាតិអ៊ីស្រាអែលនៅអេស៊ីប នៅពេលព្រះអង្គប្រហារជនជាតិអេស៊ីប។ ព្រះអង្គបានរំដោះផ្ទះរបស់ពួកយើងឲ្យមានសេរីភាព។
បន្ទាប់មក ជនជាតិអ៊ីស្រាអែលបានលុតជង្គង់ចុះ ហើយថ្វាយបង្គំព្រះអម្ចាស់។[28]ជនជាតិអ៊ីស្រាអែលបានចាកចេញយ៉ាងប្រាកដ ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ
និងលោកអ៊ើរ៉ុន។
[29]ការនោះបានកើតឡើងនៅពេលយប់ គឺព្រះអម្ចាស់បានប្រហារកូនច្បងទាំងអស់ដែលនៅក្នុងទឹកដីអេស៊ីប ចាត់តាំងពីបុត្រច្បងរបស់ស្តេចផារ៉ោន
ដែលសោយរាជ្យនៅលើបល្ល័ង្ក ដល់កូនច្បងរបស់មនុស្សដែលនៅក្នុងគុក និងកូនច្បងទាំងអស់នៃហ្វូងសត្វដែរ។[30]ស្តេចផារ៉ោនបានតើនឡើងនៅពេលយប់
ព្រះអង្គទតឃើញ ពួកមន្ត្រីរបស់ស្តេច និងជនជាតិអេស៊ីបទាំងអស់។ មានការយំកាន់ទុក្ខជាខ្លាំង ដ្បិត គ្មានផ្ទះណាមួយ ដែលគ្មានមនុស្សស្លាប់ឡើយ។
[31]ស្តេចផារ៉ោនបានកោះហៅលោកម៉ូសេ និងលោកអ៊ើរ៉ុននៅពេលយប់នោះ ហើយមានរាជឱង្ការថា៖ «ចូរក្រោកឡើយ ចូរចេញពីចំណោមប្រជារាស្ត្ររបស់យើងទៅ អ្នក
និងជនជាតិអ៊ីស្រាអែល។ ចូរទៅ ថ្វាយបង្គំព្រះអម្ចាស់ ដូច្នេះដែលអ្នកនិយាយថាអ្នកចង់ធ្វើទៅ។[32]ចូរយកហ្វូងចៀម និងហ្វូងសត្វរបស់អ្នក ដូចអ្នកបាននិយាយ
ហើយទៅចុះ ព្រមទាំងឲ្យពរដល់យើងផង»។[33]ជនជាតិអេស៊ីបបានប្រញាប់ប្រញាលចាត់ពួកគេឲ្យចាកចេញពីទឹកដី ដ្បិត ពួកគេនិយាយថា៖ «យើងមុខជាស្លាប់ទាំងអស់
គ្នា»។
[34]ដូច្នេះ ប្រជាជនបានយកម្សៅដែលមិនទាន់ដាក់ដំបែ និងផើងសម្រាប់លាយម្សៅរបស់ពួកគេមករុំក្នុងអាវ ហើយលីចេញទៅ។[35]ជនជាតិអ៊ីស្រាអែលបានធ្វើដូចលោក
ម៉ូសេបានប្រាប់ដល់ពួកគេ។ ពួកគេបានសុំគ្រឿងប្រាប់ គ្រឿងមាស និងសម្លៀកបំពាក់ពីជនជាតិអេស៊ីប។
[36]ព្រះអម្ចាស់បានធ្វើឲ្យជនជាតិអេស៊ីបមានចិត្តមេត្តាដល់ជនជាតិអ៊ីស្រាអែល។ ដូច្នេះ ជនជាតិអេស៊ីបបានឲ្យអ្វីៗតាមដែលពួកគេសុំ។ បែបនេះ
ជនជាតិអ៊ីស្រាអែលបានរឹមអូសពីជនជាតិអេស៊ីប។
[37]ជនជាតិអ៊ីស្រាអែលបានធ្វើដំណើរពីក្រុងរ៉ាមសេសទៅក្រុងសិកូត។ មានបុរសចំនួន៦០០, ០០០នាក់ធ្វើដំណើរថ្មើរជើង ដោយមិនបានរាប់ស្ត្រី និងក្មេងៗទេ។
[38]មានបណ្តាជនដែលមិនមែនជាជនជាតិអ៊ីស្រាអែលធ្វើដំណើរជាមួយពួកគេដែរ ជាមួយនឹងហ្វូងចៀម និងហ្វូងគោ និងហ្វូងសត្វយ៉ាងច្រើនសន្ធឹកសន្ធាប់។
[39]ពួកគេបានដុតនំប៉័ងដែលឥតមេ ដែលមិនដោល ដែលបាននាំពីអេស៊ីបមក។ ជានំប៉័ងដែលឥតមេ ដោយសារពួកគេត្រូវបានបណ្តេញចេញពីអេស៊ីប
ហើយពួកគេត្រូវចម្អិនអាហារជាប្រញាប់។[40]ជនជាតិអ៊ីស្រាអែលរស់នៅអេស៊ីប ៤៣០ឆ្នាំ។
[41]នៅចុងឆ្នាំ ៤៣០ នៅថ្ងៃដំបូង ប្រជារាស្ត្ររបស់ព្រះអម្ចាស់បានចាកចេញពីទឹកដីអេស៊ីប។[42]នេះគឺជាយប់ដែលពួកគេមិនគេងឡើយ
ដ្បិតព្រះអម្ចាស់នឹងនាំពួកគេចេញពីទឹកដីអេស៊ីប។ នេះគឺជាយប់នៃព្រះអម្ចាស់ ដែលជនជាតិអ៊ីស្រាអែលត្រូវរក្សាទុកដល់ជនជាតិរបស់ពួកគេគ្រប់ជំនាន់។
[43]ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេ និងលោកអ៊ើរ៉ុនថា៖ «នេះគឺជាច្បាប់របស់ពិធីបុណ្យចម្លង ជនបរទេសមិនអាចចូលរួមហូបបានទេ។[44]ប៉ុន្តែ
ទាសកររបស់ជនជាតិអ៊ីស្រាអែលទាំងអស់ ដែលបានទិញដោយប្រាក់ អាចហូបបាន បន្ទាប់ពីពួកគេបានកាត់ស្បែកហើយ។
[45]ជនបរទេស និងអ្នកបម្រើដែលបានជួលមិនត្រូវឲ្យហូបអាហារទាំងនេះឡើយ។[46]អាហារទាំងនេះ ត្រូវតែហូបនៅក្នុងផ្ទះ។
អ្នករាល់គ្នាមិនត្រូវយកសាច់ណាមួយចេញក្រៅផ្ទះឡើយ ហើយអ្នករាល់គ្នាក៏មិនត្រូវបំបាក់ឆ្អឹងដែរ។

generated on Wed Sep 10 16:16:32 2025

[47]នៅក្នុងសហគមន៍អ៊ីស្រាអែលទាំងមូលត្រូវរក្សាពិធីបុណ្យនេះ។[48]ប្រសិនបើ ជនបរទេសដែលរស់នៅជាមួយអ្នករាល់គ្នា ចង់រក្សាពិធីបុណ្យចម្លងរបស់ព្រះអម្ចាស់នេះ
ត្រូវឲ្យសាច់ញាតិរបស់គេទាំងអស់កាត់ស្បែក។ បន្ទាប់មកគាត់អាចចូលមក ហើយធ្វើពិធីនេះបាន។ អ្នកទាំងនោះនឹងក្លាយជាប្រជារាស្ត្រដែលបានកើតនៅក្នុងទឹកដីនេះ។
ប៉ុន្តែ មនុស្សដែលមិនកាត់ស្បែកមិនអាចហូបអាហារទាំងនេះឡើយ។
[49]នេះគឺជាច្បាប់ដូចគ្នា ដែលត្រូវអនុវត្តទាំងម្ចាស់ស្រុក និងជនបរទេសដែលរស់នៅក្នុងចំណោមអ្នករាល់គ្នា»។[50]ដូច្នេះ
ជនជាតិអ៊ីស្រាអែលបានធ្វើតាមដូចដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ និងលោកអ៊ើរ៉ុន។[51]នៅថ្ងៃកំណត់នោះ
ព្រះអម្ចាស់បាននាំជនជាតិអ៊ីស្រាអែលចេញពីទឹកដីអេស៊ីប ដោយមានរបៀបដូចជាកងទ័ព។

Exodus 12:1
«សម្រាប់អ្នក ខែនេះគឺជាខែដែលត្រូវចាប់ផ្តើម គឺខែដំបូងនៃឆ្នាំរបស់អ្នក»។
ឃ្លាទាំងពីរនេះមានអត្ថន័យរួមដូចគ្នា
ហើយបញ្ជាក់ថាខែដែលព្រឹត្តិការណ៍នៃជំពូកនេះកើតឡើង
នឹងចាប់ផ្តើមនៅដើមឆ្នាំប្រតិទិនរបស់ពួកគេ។
គឺខែដំបូងនៃឆ្នាំ
ខែដំបូងនៃប្រតិទិនហេព្រើររួមមានផ្នែកចុងក្រោយនៃខែមិនា
និងផ្នែកដំបូងនៃខែមេសាតាមប្រតិទិនលោកខាងលិច។
វាជាពេលដែលព្រះអម្ចាស់បានសង្គ្រោះជនជាតិអ៊ីស្រាអែលពីជនជាតិអេស៊ីប។
Exodus 12:3
ប្រសិនបើ គ្រួសារនោះតូចហូបចៀមមួួយមិនអស់
នេះមានន័យថាមិនមានមនុស្សគ្រប់គ្រាន់
ក្នុងគ្រួសារបរិភោគសាច់ចៀមទាំងមូលទេ។ ការបកប្រែផ្សេងទៀត
«ប្រសិនបើមិនមានមនុស្សគ្រប់គ្រាន់ ក្នុងគ្រួសារបរិភោគសាច់ចៀមទាំងមូល»
អ្នកនោះនិងអ្នកជិតខាង
ត្រង់នេះ « អ្នកនោះ» សំដៅទៅលើមនុស្សដែលជាមេនៃគ្រួសារ។
Exodus 12:5
ថ្ងៃលិច
នេះសំដៅទៅលើពេលវេលា នៃពេលល្ងាចបន្ទាប់ពីព្រះអាទិត្យបានលិច
ប៉ុន្តែពេលដែលនៅតែមានពន្លឺខ្លះ។
លាបវានៅលើក្របទ្វារទាំងសងខាង និងនៅលើក្របទ្វារផ្ទះ
«នៅសងខាង និងខាងលើផ្លូវចូលផ្ទះ»
ចូរហូបវាជាមួយនំប៉័ង ឥតមេ និងបន្លែល្វីង។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ការបកប្រែផ្សេងទៀត
«បរិភោគវាជាមួយនំប៉័ងដែលអ្នកបានធ្វើដោយគ្មានមេ»
បន្លែល្វីង
ទាំងនេះគឺជារុក្ខជាតិតូចៗ ដែលមានក្លិនខ្លាំងហើយជាទូទៅល្វីង។
Exodus 12:9
កុំហូបសាច់ឆៅ
«កុំបរិភោគសាច់ចៀម ឬពពែឥតចម្អិន»
អ្នកមិនត្រូវទុកឲ្យអ្វីមួយនៅសល់រហូតដល់ ពេលព្រឹកឡើយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«កុំទុកវាចោលរហូតដល់ព្រឹក»
ក្រវាត់
នេះសំដៅទៅលើបន្ទះស្បែក ឬក្រណាត់សម្រាប់ចងជុំវិញចង្កេះ។
ហូបវាឲ្យលឿន
«បរិភោគយ៉ាងលឿន»
នេះគឺជាបុណ្យចម្លងរបស់ព្រះអម្ចាស់។
នៅទីនេះពាក្យ « នេះ» សំដៅទៅលើការបរិភោគសត្វនៅថ្ងៃទី ១០ នៃខែ។
ការបកប្រែផ្សេងទៀត «នេះគឺពិធីបុណ្យចម្លងរបស់ព្រះអម្ចាស់»
Exodus 12:12
យើងនឹងនាំការជំនុំជម្រះ នៅលើព្រះរបស់អេស៊ីបទាំងអស់។
នេះអាចត្រូវបានថ្លែងដោយទម្រង់ពាក្យសំដី។ ការបកប្រែផ្សេងទៀត
«យើងនឹងដាក់ទោសព្រះទាំងអស់នៅស្រុកអេស៊ីប»
នៅពេលយើងមក
នេះបញ្ជាក់ថាព្រះអម្ចាស់ នឹងឃើញឈាមដែលចង្កួលបង្ហាញពីផ្ទះអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «យើងនឹងឃើញនៅពេលយើងមករកអ្នក»
យើងនឹងហោះរំលង។
ពាក្យថា «រំលង» គឺជាទំនៀមទំលាប់របៀបនៃងការនិយាយថាមិនចូលសួរសុខទុក្ខ
ឬចូល។ការបកប្រែផ្សេងទៀត «យើងនឹងមិនចូលក្នុងផ្ទះរបស់អ្នកទេ»
សម្រាប់អ្នករាល់គ្នា អ្នករាល់គ្នាត្រូវកាន់តាមគ្រប់ជំនាន់
«សម្រាប់អ្នករាល់គ្នា និងគ្រប់ជំនាន់ទាំងអស់នៃកូនចៅរបស់អ្នក»
Exodus 12:15
អ្នកនោះត្រូវកាត់ចេញពីអ៊ីស្រាអែល។
ពាក្យប្រៀបធៀប «កាត់ចេញ» មានអត្ថន័យយ៉ាងតិចបីយ៉ាង។
ពួកគេអាចត្រូវបានបង្ហាញជាទម្រង់សកម្ម៖ ១) «
ប្រជាជនអ៊ីស្រាអែលត្រូវបញ្ជូនគាត់ទៅឆ្ងាយ» ឬ ទី២)«
ខ្ញុំនឹងលែងចាត់ទុកគាត់ថាជាប្រជាជនអ៊ីស្រាអែលម្នាក់ឬ ទី៣)»
ប្រជាជនអ៊ីស្រាអែលត្រូវតែសម្លាប់គាត់» ។
ញែកសហគមន៍ឲ្យនៅដោយឡែកសម្រាប់យើង
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ការជួបប្រជុំគ្នាដែលអ្នកបានញែកចេញសម្រាប់យើង»
នៅថ្ងៃនោះ មិនត្រូវធ្វើការអ្វីឡើយ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«អ្នកនឹងមិនធ្វើការនៅថ្ងៃនោះទេ»
អ្នករាល់អ្នកអាចធ្វើការលុះត្រាតែការងារដែលត្រូវធ្វើម្ហូបប៉ុណ្ណោះ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នោះត្រូវតែជាការងារតែមួយគត់ដែលអ្នកធ្វើ» (សូមមើលfigs-activepassive)
Exodus 12:17
ពួកពលរបស់អ្នករាល់គ្នាជាក្រុមៗ
ពាក្យដែលប្រើសម្រាប់ក្រុមទាំងនេះ
គឺជាពាក្យទាហានសំដៅទៅលើទាហានចំនួនច្រើនសន្ធឹក។ ការបកប្រែផ្សេងទៀត
«ការបែងចែកតាមក្រុម» ឬ «កងទ័ពតាមចំនួនកងទ័ព»
ថ្ងៃលិច
នេះសំដៅទៅលើពេលវេលា នៃពេលល្ងាចបន្ទាប់ពីព្រះអាទិត្យបានលិច
ប៉ុន្តែខណៈពេលដែលនៅតែមានពន្លឺខ្លះ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១២: ៥ ។
ចាប់ពីថ្ងៃដប់បួននៅក្នុងខែដំបូង
នេះជាខែដំបូងនៃប្រតិទិនហេព្រើរ។
ថ្ងៃទីដប់បួនគឺនៅជិតដើមខែមេសានៅលើប្រតិទិនលោកខាងលិច។
ថ្ងៃម្ភៃមួយនៃខែនោះ។
ថ្ងៃដំបូងនៃខែ - «ថ្ងៃទីម្ភៃដំបូងនៃខែដំបូង»។
«នេះគឺនៅជិតពាក់កណ្តាលខែមេសានៅលើប្រតិទិនលោកខាងលិច»។
Exodus 12:19
មិនត្រូវឲ្យមានមេនៅក្នុងផ្ទះរបស់អ្នករាល់គ្នាឡើយ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
មិនត្រូវមានដំបែនៅក្នុងផ្ទះរបស់អ្នកឡើយ»
ត្រូវកាត់ចេញពីសហគមន៍អ៊ីស្រាអែល
ពាក្យប្រៀបធៀប «កាត់ចេញ» មានអត្ថន័យយ៉ាងតិចបីយ៉ាង។
ពួកគេអាចត្រូវបានបង្ហាញជាទម្រង់សកម្ម៖ ១) «
ប្រជាជនអ៊ីស្រាអែលត្រូវបញ្ជូនគាត់ទៅឆ្ងាយ» ឬ ទី២)«
ខ្ញុំនឹងលែងចាត់ទុកគាត់ថាជាប្រជាជនអ៊ីស្រាអែលម្នាក់ឬ ទី៣)»
ប្រជាជនអ៊ីស្រាអែលត្រូវតែសម្លាប់គាត់» ។
នំប៉័ងដែលឥតមេ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ សូមមើលបកប្រែវានៅក្នុង ១២: ៥ ។
ការបកប្រែផ្សេងទៀត «នំប៉័ងដែលអ្នកបានធ្វើដោយគ្មានមេ» (សូមមើល Active or Passive)
Exodus 12:21
បានកោះហៅ
«បានហៅជាផ្លូវការ»
យកមែកហ៊ីស៊ុប

generated on Wed Sep 10 16:16:32 2025

នេះគឺជារុក្ខជាតិនៅក្នុងគ្រួសារ ដែលជារុក្ខជាតិ
និងត្រូវបានប្រើសម្រាប់មែកឈើតូចៗ។
នៅពីលើក្របទ្វារ ហើយលាបលើក្របទ្វារទាំងសងខាង។
«នៅសងខាងនិងលើផ្លូវចូលផ្ទះ»។ សូមមើលបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១២:
៥ ។
Exodus 12:23
ព្រះអង្គនឹងរំលងទ្វាររបស់អ្នក
នៅទីនេះពាក្យថា «ទ្វារ» បញ្ជាក់ផ្ទះទាំងមូល។ នេះមានន័យថាព្រះជាម្ចាស់
នឹងរំដោះជនជាតិអ៊ីស្រាអែលនៅក្នុងផ្ទះ ដោយមានឈាមនៅលើទ្វារ។
ការបកប្រែផ្សេងទៀត «រំលងផ្ទះរបស់អ្នក»
Exodus 12:24
ច្បាប់នេះ... ទុកជាការថ្វាយបង្គំ។
ឃ្លាទាំងនេះសំដៅទៅលើបុណ្យចម្លងឬបុណ្យនំបុ័ងឥតដំបែ។ ការធ្វើបុណ្យចម្លង
គឺជាការថ្វាយបង្គំដល់ព្រះអម្ចាស់។
Exodus 12:26
ព្រះអង្គបានរំដោះផ្ទះរបស់ពួកយើងឲ្យមានសេរីភាព។
នេះមានន័យថាព្រះអម្ចាស់ បានទុកកូនច្បងរបស់ជនជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត
«ព្រះអង្គមិនបានសម្លាប់កូនប្រុសច្បងនៅក្នុងផ្ទះរបស់យើងទេ»
ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ និងលោកអើរ៉ុន។
«អ្វីៗទាំងអស់ដែលព្រះអម្ចាស់ បានប្រាប់ដល់ម៉ូសេនិងអើរ៉ុនត្រូវធ្វើ»
Exodus 12:29
នៅពេលយប់
«នៅពាក់កណ្តាលអធ្រាត្រ»
កូនច្បងទាំងអស់ដែលនៅក្នុងទឹកដីអេស៊ីប ... កូនច្បងទាំងអស់នៃហ្វូងសត្វដែរ។
នៅទីនេះ «កូនច្បង» តែងតែសំដៅទៅលើកូនប្រុសអាយុច្រើនជាងគេ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១១: ៤ ។
ដែលសោយរាជ្យនៅលើបល្ល័ង្ក
នេះសំដៅទៅលើស្តេចផារ៉ោន។
កូនច្បងរបស់មនុស្សដែលនៅក្នុងគុក
«ចំពោះកូនច្បងរបស់មនុស្សនៅក្នុងគុក» នេះសំដៅទៅលើអ្នកទោសជាទូទៅ
ហើយមិនមែនសំដៅទៅលើមនុស្សជាក់លាក់ណាមួយនៅក្នុងពន្ធនាគារឡើយ។
មានការយំកាន់ទុក្ខជាខ្លាំង
នេះអាចត្រូវបានថ្លែងដោយទម្រង់ពាក្យសំដី។ ការបកប្រែផ្សេងទៀត
«ប្រជាជនអេស៊ីបទាំងអស់បានស្រែកយំយ៉ាងខ្លាំង»
ដ្បិត គ្មានផ្ទះណាមួយ ដែលគ្មានមនុស្សស្លាប់ឡើយ។
នេះគឺការបញ្ជាក់អវិជ្ជមានទ្វេដង លើភាពវិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ដោយសារតែមានមនុស្សម្នាក់បានស្លាប់នៅគ្រប់ផ្ទះ»
Exodus 12:31
«យើងមុខជាស្លាប់ទាំងអស់គ្នា»។
ជនជាតិអេស៊ីបប្រើភាពតានតឹងបច្ចុប្បន្ន
ដើម្បីបញ្ជាក់ថាពួកគេប្រាកដជានឹងត្រូវស្លាប់ជាមិនខានប្រសិនបើជនជាតិអ៊ីស្រាអែលមិនចាកចេញ
ពីស្រុកអេស៊ីប។ ការបកប្រែផ្សេងទៀត «យើងនឹងស្លាប់ទាំងអស់ប្រសិនបើ
អ្នករាល់គ្នាមិនចាកចេញ»
Exodus 12:34
ធើងសម្រាប់លាយម្សៅរបស់ពួកគេមករុំក្នុងអាវ ហើយលីចេញទៅ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ពួកគេបានចងធើងដាក់ក្នុងសម្លៀកបំពាក់ និងស្មារបស់ពួកគេរួចហើយ»
Exodus 12:37
ក្រុងរ៉ាមសេស
ក្រុងរ៉ាមសេស គឺជាទីក្រុងសំខាន់របស់អេស៊ីប ដែលជាកន្លែងរក្សាទុកគ្រាប់ស្រូវ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១:១១ ។
ពួកគេមានចំនួនប្រហែលមនុស្ស៦០០,០០០នាក់
«ចំនួនមនុស្សសរុបគឺ ៦០ ម៉ឺននាក់»
បានដុតនំបុ័ងដែលឥតមេ ដែលមិនដោល
«នំបុ័ងជាមួយម្សៅដែលមិនមានផ្ទុកមេ»
ពួកគេត្រូវបានបណ្តេញចេញពីអេស៊ីប
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនអេស៊ីបបានបណ្តេញ ពួកគេចេញពីស្រុកអេស៊ីប»
Exodus 12:41
ព្រះអម្ចាស់បានចាកចេញពីទឹកដីអេស៊ីប។
នេះសំដៅទៅលើកុលសម្ព័ន្ធអ៊ីស្រាអែល។ សូមមើលពីរបៀបដែលអ្នកបកប្រែ
«ពួកពលរបស់អ្នករាល់គ្នាជាក្រុមៗ» នៅក្នុង ១២:១៧ ។
ដែលជនជាតិអ៊ីស្រាអែលត្រូវរក្សាទុក
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ជនជាតិអ៊ីស្រាអែលទាំងអស់ ត្រូវគោរព»
ដែលជនជាតិអ៊ីស្រាអែលត្រូវរក្សាទុកដល់ជនជាតិរបស់ពួកគេគ្រប់ជំនាន់។
«ជនជាតិអ៊ីស្រាអែលទាំងអស់ និងគ្រប់ជំនាន់នៃកូនចៅរបស់ពួកគេ»
Exodus 12:43
ជនបរទេសមិនអាចចូលរួមហូបបានទេ។
សព្វនាម «វា» សំដៅទៅលើអាហារបុណ្យចម្លង។
ទាសកររបស់ជនជាតិអ៊ីស្រាអែលទាំងអស់
«គ្រប់ទាសករនៃជនជាតិអ៊ីស្រាអែល»
ដែលបានទិញដោយប្រាក់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អស់អ្នកណាដែលជនជាតិអ៊ីស្រាអែលបានទិញដោយប្រាក់»
Exodus 12:45
អាហារទាំងនេះ ត្រូវតែហូបនៅក្នុងផ្ទះ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គ្រប់គ្រួសារអ៊ីស្រាអែលទាំងអស់ ត្រូវតែបរិភោគអាហារនៅក្នុងផ្ទះតែមួយ»
អ្នករាល់គ្នាក៏មិនត្រូវបំបាក់ឆ្អឹងដែរ។
អ្នកមិនត្រូវបំបាក់ឆ្អឹងណាមួយឡើយ។ នៅទីនេះពាក្យថា «វា»
សំដៅទៅលើកូនចៀមដែលគ្រួសារអ៊ីស្រាអែលនឹងបរិភោគ។
Exodus 12:47
ត្រូវឲ្យសាច់ញាតិរបស់គេទាំងអស់កាត់ស្បែក។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សម្នាក់ត្រូវតែកាត់ស្បែកអោយសាច់ញាតិប្រុសៗរបស់គាត់ទាំងអស់»
ប្រជារាស្ត្រដែលបានកើតនៅក្នុងទឹកដីនេះ។
នៅទីនេះពាក្យថា « ទឹកដី» សំដៅទៅលើស្រុកកាណាន។ ឃ្លាថា«
កើតនៅលើទឹកដី»
មានន័យថាមនុស្សម្នាក់ដែលមានដើមកំណើតជាជនជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «អស់អ្នកដែលជាជនជាតិអ៊ីស្រាអែលពីកំណើត»
មនុស្សដែលមិនកាត់ស្បែកមិនអាចហូបអាហារទាំងនេះឡើយ។
នេះអាចត្រូវបានថ្លែងក្នុងន័យវិជ្ជមាន។ ការបកប្រែផ្សេងទៀត
«មានតែមនុស្សប្រុសដែលកាត់ស្បែកតែប៉ុណ្ណោះដែលអាចបរិភោគបាន»
Exodus 12:49
ព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ និងលោកអើរ៉ុន។
«អ្វីៗទាំងអស់ដែលព្រះអម្ចាស់ បានប្រាប់ដល់ម៉ូសេនិងអើរ៉ុនត្រូវធ្វើ»
នៅថ្ងៃកំណត់នោះ
ឃ្លានេះត្រូវបានប្រើដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
ដោយមានរបៀបដូចជាកងទ័ព។
ពាក្យដែលប្រើសម្រាប់ក្រុមទាំងនេះ គឺជាទាហានសំដៅទៅលើទាហានចំនួនច្រើន។
សូមមើលពីរបៀបដែលអ្នកបកប្រែ « ពួកពលរបស់អ្នករាល់គ្នាជាក្រុមៗ » នៅក្នុង
១២:១៧ ។ ការបកប្រែផ្សេងទៀត «តាមរយៈការបែងចែករបស់ពួកគេ» ឬ
«តាមរយៈចំនួនទ័ពរបស់ពួកគេ»

---

13 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[2]«ចូរញែកកូនច្បងដោយឡែកសម្រាប់យើង គឺកូនច្បងទាំងអស់ ពីចំណោមជនជាតិអ៊ីស្រាអែល
ទាំងមនុស្សទាំងសត្វ។ កូនច្បងជាកម្មសិទ្ធិរបស់យើង។
[3]លោកម៉ូសេប្រាប់ទៅប្រជាជនថា៖ «ចូរនឹងចាំពីថ្ងៃនេះ ជាថ្ងៃដែលអ្នករាល់គ្នាបានចេញពីអេស៊ីប ចេញពីផ្ទះនៃភាពជាទាសករ
ដ្បិតដោយសារព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអម្ចាស់ ព្រះអង្គបាននាំអ្នករាល់គ្នាចេញពីកន្លែងនេះ។ មិនត្រូវហូបនំបុ័ងដែលមានមេឡើយ។
[4]ថ្ងៃនេះអ្នករាល់គ្នានឹងចេញពីទឹកដីអេស៊ីប គឺនៅក្នុងខែអាប៊ីប។[5]នៅពេលព្រះអម្ចាស់នាំអ្នករាល់គ្នាទៅក្នុងទឹកដីជនជាតិកាណាន ជនជាតិហេត ជនជាតិអាម៉ូរី ជនជាតិហេវី

generated on Wed Sep 10 16:16:32 2025

និងជនជាតិយេប៊ូស ជាទឹកដីដ៏សម្បូរសប្បាយ ដែលព្រះអង្គសន្យាជាមួយពួកបុព្វបុរសរបស់អ្នករាល់គ្នាថា នឹងប្រទានឲ្យអ្នករាល់គ្នា នោះត្រូវនាំគ្នាគោរពបម្រើព្រះអម្ចាស់
ដោយធ្វើពិធីបុណ្យចម្លងក្នុងខែនេះ។
[6]ក្នុងរយៈពេលប្រាំពីរថ្ងៃអ្នករាល់គ្នាត្រូវហូបនំប៉័ងឥតមេ នៅថ្ងៃទីប្រាំពីរ ត្រូវធ្វើពិធីបុណ្យថ្វាយព្រះអម្ចាស់។[7]ត្រូវហូបនំប៉័ងឥតមេក្នុងរយៈពេលប្រាំពីរថ្ងៃ
មិនត្រូវឲ្យឃើញមាននំប៉័ងមាននៅក្នុងចំណោមអ្នករាល់គ្នាឡើយ។ ក៏មិនត្រូវឲ្យឃើញមានមេនៅក្នុងទឹកដីរបស់អ្នករាល់គ្នាដែរ។
[8]នៅថ្ងៃនោះ អ្នករាល់គ្នាត្រូវប្រាប់ដល់កូនចៅរបស់អ្នករាល់គ្នាថា៖ «នេះគឺដោយអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់យើងពេល យើងចេញពីស្រុកអេស៊ីបមក»។
[9]ការនេះនឹងរំលឹកនៅនឹងដៃរបស់អ្នករាល់គ្នា និងរំលឹកនៅលើថ្ងាស់របស់អ្នករាល់គ្នា ដ្បិត
ព្រះអម្ចាស់បាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីបដោយព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គ។[10]ដូច្នេះ អ្នករាល់គ្នាត្រូវរក្សាច្បាប់នេះ រៀងរាល់ឆ្នាំ តាមពេលកំណត់របស់វា។
[11]នៅពេលព្រះអម្ចាស់បាននាំអ្នករាល់គ្នាចូលទៅក្នុងទឹកដីជនជាតិកាណាន តាមការដែលព្រះអង្គបានស្បថនឹងធ្វើជាមួយអ្នករាល់គ្នា និងជាមួយពូជពង្សរបស់អ្នករាល់គ្នា។
[12]អ្នករាល់គ្នាត្រូវញែកកូនច្បងទាំងអស់ដោយឡែក និងកូនច្បងនៃសត្វរបស់អ្នករាល់គ្នាតាមពូជដែរ។ កូនច្បងទាំងអស់ជាកម្មសិទ្ធិរបស់ព្រះអម្ចាស់។
[13]កូនច្បងរបស់សត្វលា អ្នករាល់គ្នាត្រូវទិញមកវិញ ដោយយកកូនចៀមមកជំនួសវិញ។ ប្រសិនបើ អ្នករាល់គ្នាមិនទិញត្រឡប់មកវិញទេ នោះអ្នករាល់គ្នាត្រូវបំបាក់កវា។
ប៉ុន្តែ កូនច្បងនៅក្នុងចំណោមកូនរបស់អ្នករាល់គ្នាទាំងអស់ត្រូវទិញវាមកវិញដែរ។
[14]ក្រោយមក នៅពេលកូនចៅរបស់អ្នកសួរថា៖ «តើការនេះមានន័យយ៉ាងដូចម្តេច?» នោះអ្នករាល់គ្នាត្រូវប្រាប់ពួកគេថា៖
«គឺជាព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអម្ចាស់ដែលបាននាំចេញពីផ្ទះនៃភាពជាទាសករ។[15]នៅពេលស្តេចផារ៉ោនមានព្រះទ័យរឹង បដិសេធមិនអនុញ្ញាតឲ្យយើងចេញទៅ
ព្រះអម្ចាស់បានស្លាប់កូនច្បងដែលនៅក្នុងទឹកដីអេស៊ីបចោលទាំងអស់ ទាំងកូនច្បងរបស់មនុស្ស និងកូនដំបូងរបស់សត្វ។ ហេតុដូច្នេះហើយ
បានជាយើងថ្វាយកូនច្បងដល់ព្រះអម្ចាស់ ទាំងមនុស្ស ទាំងសត្វ ហើយនោះគឺជាហេតុដែលយើងទិញកូនច្បងរបស់យើងត្រឡប់មកវិញ»។
[16]ការនេះនឹងក្លាយជាការរំលឹកនៅលើដៃ និងនៅលើថ្ងាសរបស់អ្នករាល់គ្នា ដ្បិត គឺដោយសារព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអម្ចាស់ បាននាំយើងចេញពីអេស៊ីបមក»។
[17]នៅពេលស្តេចផារ៉ោនអនុញ្ញាតឲ្យប្រជាជនចេញ ព្រះជាម្ចាស់មិនបាននាំពួកគេតាមផ្លូវកាត់តាមទឹកដីភីលីស្ទីនទេ ទោះបីជាតាមទឹកដីនោះជិតក្តី។
ដ្បិតព្រះជាម្ចាស់មានបន្ទូលថា៖ «ប្រហែលជាមនុស្សអាចប្តូរគំនិតរបស់ពួកគេ នៅពេលពួកគេជួបជាមួយនឹងសង្គ្រាម ហើយពួកគេនឹងត្រឡប់ទៅស្រុកអេស៊ីបវិញ»។
[18]ដូច្នេះ ព្រះជាម្ចាស់បាននាំបណ្តាជនវាងកាត់តាមទីរហោរស្ថានឆ្ពោះទៅសមុទ្រក្រែង។ ជនជាតិអ៊ីស្រាអែលចេញពីទឹកដីអេស៊ីប ទាំងកាន់អាវុធសម្រាប់ធ្វើសង្គ្រាមផង។
[19]លោកម៉ូសេបានយកឆ្អឹងរបស់លោកយ៉ូសែបទៅជាមួយគាត់ដែរ ដ្បិតលោកយ៉ូសែបបានឲ្យជនជាតិអ៊ីស្រាអែលស្បថ ហើយនិយាយថា៖
«ព្រះជាម្ចាស់ប្រាកដជាសង្គ្រោះអ្នករាល់គ្នា ហើយអ្នករាល់គ្នាត្រូវយកឆ្អឹងរបស់ខ្ញុំទៅជាមួយផង»។[20]ជនជាតិអ៊ីស្រាអែលបានធ្វើដំណើរពីក្រុងសិកូត ទៅបោះជំរំត្រង់
អេថាម ដែលស្ថិតនៅជាយទីរហោស្ថាន។[21]ព្រះអម្ចាស់យាងពីមុខពួកគេ ដោយនៅពេលថ្ងៃ ព្រះអង្គធ្វើឲ្យមានបង្គោលពពកនៅតាមផ្លូវ ដើម្បីនាំពួកគេ។ នៅពេលយប់
ព្រះអង្គធ្វើឲ្យមានបង្គោលភ្លើង ដើម្បីជាពន្លឺបំភ្លឺដល់ពួកគេ។ ដូច្នេះ ពួកគេអាចធ្វើដំណើរទាំងយប់ទាំងថ្ងៃ។
[22]ព្រះអម្ចាស់មិនបានដកបង្គោលពពកនៅពេលថ្ងៃចេញពីប្រជាជនឡើយ ហើយនៅពេលយប់ក៏ដូចគ្នាដែរ។

Exodus 13:1

ចូរញែកកូនច្បងដោយឡែកសម្រាប់យើង ...គឺកូនច្បងទាំងអស់

ព្រះជាម្ចាស់តម្រូវឲ្យកូនប្រុសច្បងទាំងអស់ត្រូវញែកចេញសម្រាប់ទ្រង់។

Exodus 13:3

ចូរនឹងចាំពីថ្ងៃនេះ

ពាក្យថា « ចូរ...ចាំ» គឺជាទម្លាប់នៃរបៀបក្នុងការប្រាប់នរណាម្នាក់ឱ្យចងចាំអ្វីមួយ។
ការបកប្រែផ្សេងទៀត «ចងចាំ និងអបអរសាទរថ្ងៃនេះ»

ផ្ទះនៃភាពជាទាសករ

លោកម៉ូសេនិយាយអំពីស្រុកអេស៊ីបដូចជាផ្ទះដែលមនុស្សរក្សាទុកទាសករ។
ការបកប្រែផ្សេងទៀត «កន្លែងដែលអ្នកធ្លាប់ជាទាសករ»

ដោយសារព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអម្ចាស់

ត្រង់នេះពាក្យថា «ស្នាព្រះហស្ត» សំដៅទៅលើអំណាច។
សូមមើលពីរបៀបដែលអ្នកបកប្រែ « ព្រះហស្តដ៏ខ្លាំង» នៅក្នុង ៦: ១ ។

មិនត្រូវហូបនំប៉័ងដែលមានមេឡើយ។

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវបរិភោគនំប៉័ងមានមេទេ»

នៅក្នុងខែអាប៊ីប

នេះគឺជាឈ្មោះខែដំបូងនៃប្រតិទិនហេព្រើរ។ អាប៊ីបគឺពេលចុងក្រោយនៃខែមីនា
និងដើមខែមេសាតាមប្រតិទិនលោកខាងលិច។

ជាទឹកដីសម្បូរដោយទឹកឃ្មុំនិងទឹកដោះ

ដោយសារទឹកដោះគោកើតចេញពីគោ និងពពែ «ទឹកដោះគោ »
តំណាងឱ្យអាហារដែលផលិតដោយសត្វចិញ្ចឹម។
ដោយសារតែទឹកឃ្មុំត្រូវបានផលិតចេញពីផ្កា «ទឹកឃ្មុំ» តំណាងឱ្យអាហារពីផ្កា។
សូមមើលបកប្រែនៅក្នុង ៣: ៧ ។ ការបកប្រែផ្សេងទៀត «អាហារពីសត្វស្រុក
និងពីដំណាំ»

នោះត្រូវនាំគ្នាគោរពបម្រើព្រះអម្ចាស់

នៅពេលដែលជនជាតិអ៊ីស្រាអែលរស់នៅស្រុកកាណាន
ពួកគេត្រូវធ្វើបុណ្យចម្លងនៅថ្ងៃនេះរាល់ឆ្នាំ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លានេះនៅក្នុង ១២:២៤ ។

Exodus 13:6

ព័ត៌មានទូទៅ

ម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

ក្នុងរយៈពេលប្រាំពីរថ្ងៃ

«រយៈពេល៧ថ្ងៃ»

ត្រូវហូបនំប៉័ងឥតមេ

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែបរិភោគនំប៉័ងដោយគ្មានមេ»

មិនត្រូវឲ្យឃើញមាននំប៉័ងមានមេនៅក្នុងចំណោមអ្នករាល់គ្នាឡើយ។

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនអាចមាននំប៉័ងមានមេទេក្នុងចំណោមអ្នក»

ក៏មិនត្រូវឲ្យឃើញមានមេ

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រហែលជាមិនមានមេ»

ក្នុងទឹកដីរបស់អ្នករាល់គ្នាដែរ។

«នៅក្នុងព្រំដែន នៃស្រុករបស់អ្នក»

Exodus 13:8

នៅថ្ងៃនោះ អ្នករាល់គ្នាត្រូវប្រាប់ដល់កូនចៅរបស់អ្នករាល់គ្នាថា៖

«នេះគឺដោយអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់យើងពេល យើងចេញពីស្រុកអេស៊ីបមក»។

ការដកស្រង់អាចត្រូវបានបញ្ជាក់ជាដកស្រង់ដោយប្រយោល។
ការបកប្រែផ្សេងទៀត «នៅថ្ងៃនោះអ្នកត្រូវប្រាប់កូនចៅរបស់អ្នកថា
នេះគឺដោយសារតែអ្វីដែលព្រះអម្ចាស់បានធ្វើចំពោះអ្នក
នៅពេលដែលអ្នកចេញពីស្រុកអេស៊ីបមក»

ការនេះនឹងរំលឹកនៅនឹងដៃរបស់អ្នករាល់គ្នា និងរំលឹកនៅលើថ្ងាស់របស់អ្នករាល់គ្នា

ទាំងនេះគឺជាការរម្លឹកផ្នែករាងកាយពីរប្រភេទផ្សេងគ្នា
ដូច្នេះមនុស្សនឹងមិនភ្លេចអ្វីដែលសំខាន់ទេ។

ការនេះនឹងរំលឹកនៅនឹងដៃរបស់អ្នករាល់គ្នា

លោកម៉ូសេនិយាយអំពីការប្រារព្ធពិធីបុណ្យនេះ
ដូចជាវាបានកំពុងចងវត្ថុមួយនៅជុំវិញដៃរបស់ពួកគេដើម្បីរម្លឹកពួកគេ
ពីអ្វីដែលព្រះអម្ចាស់បានធ្វើ។ ការបកប្រែផ្សេងទៀត
«ដូចជាអ្វីមួយដែលអ្នកចងដៃរបស់អ្នកជាការរម្លឹក»

ព្រះអម្ចាស់បាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីបដោយព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គ។

ពាក្យ «នៅក្នុងមាត់របស់អ្នក» នៅទីនេះសំដៅទៅលើពាក្យដែលពួកគេនិយាយ។
ការបកប្រែផ្សេងទៀត «ដូច្នេះអ្នកគួរតែនិយាយអំពីក្រឹត្យវិន័យ
របស់ព្រះអម្ចាស់ជានិច្ច»

ព្រះហស្តដ៏ខ្លាំងពូកែ

ពាក្យថា «ព្រះហស្ត» ត្រង់នេះតំណាងអោយសកម្មភាព

generated on Wed Sep 10 16:16:32 2025

ឬកិច្ចការរបស់ព្រះជាម្ចាស់។ សូមមើលនៅក្នុង ៦: ១ ។ ការបកប្រែផ្សេងទៀត «អំណាចដែលយើងបង្ហាញដោយស្នាព្រះហស្តរបស់ព្រះអង្គ»
Exodus 13:11
និងជាមួយពូជពង្សរបស់អ្នករាល់គ្នា។
«ហើយនៅពេលដែលព្រះអង្គប្រគល់ទឹកដីកាណានអោយអ្នករាល់គ្នា»
កូនច្បងរបស់សត្វលា
អ៊ីស្រាអែលត្រូវបានផ្តល់ជម្រើសដើម្បីសម្លាប់កូនច្បងសត្វលា
ឬទិញវាមកវិញជាមួយកូនចៀម។
កូនច្បងនៅក្នុងចំណោមកូនរបស់អ្នករាល់គ្នាទាំងអស់
ជនជាតិអ៊ីស្រាអែលទាំងអស់ដែលមានកូនប្រុសច្បង ត្រូវទិញកូនមកវិញ។
Exodus 13:14
ក្រោយមក នៅពេលកូនចៅរបស់អ្នកសួរថា៖ «តើការនេះមានន័យយ៉ាងដូចម្តេច?»
នោះអ្នករាល់គ្នាត្រូវប្រាប់ពួកគេថា៖
ការដកស្រង់ទីមួយអាចត្រូវបានបញ្ជាក់ជាការដកស្រង់ដោយប្រយោល។
ការបកប្រែផ្សេងទៀត «នៅពេលដែលកូនប្រុសរបស់អ្នកសួរអ្នក
នៅពេលក្រោយតើនេះមានន័យថាអ្នកត្រូវប្រាប់គេថា»
គឺជាព្រះហស្តដ៏ខ្លាំងពូកែ
ពាក្យថា « ព្រះហស្ត» ត្រង់នេះតំណាងអោយសកម្មភាព
ឬកិច្ចការរបស់ព្រះជាម្ចាស់។ សូមមើលនៅក្នុង ៦: ១ ។ ការបកប្រែផ្សេងទៀត « អំណាចដែលយើងបង្ហាញក្នុងស្នាព្រះហស្តរបស់ព្រះអង្គ»
ផ្ទះនៃភាពជាទាសករ
លោកម៉ូសេនិយាយអំពីស្រុកអេស៊ីប
ដូចជាផ្ទះជាទីកន្លែងដែលប្រជាជនរក្សាទុកទាសករ។ សូមមើលនៅក្នុង ១៣: ៣ ។ ការបកប្រែផ្សេងទៀត «កន្លែងដែលអ្នកធ្លាប់ធ្វើជាទាសករ»
ក្លាយជាការរំលឹកនៅលើដៃ និងនៅលើថ្ងាសរបស់អ្នករាល់គ្នា
នេះបង្ហាញពីរបៀបពីរយ៉ាង ដើម្បីចងចាំពីសារៈសំខាន់នៃព្រឹត្តិការណ៍បុណ្យចម្លង។ សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១៣: ៨ ។
Exodus 13:17
នោះជិតក្តី
«នៅជិតទីកន្លែងដែលពួកគេបានស្ថិតនៅ»
មនុស្សអាចប្តូរគំនិតរបស់ពួកគេ... ហើយ ... ត្រឡប់ទៅស្រុកអេស៊ីបវិញ
ចាប់តាំងពីជនជាតិអ៊ីស្រាអែល បានរស់នៅក្នុងទាសភាពក្នុងមួយជីវិតពួកគេ
មានភាពសាំុជាមួយសន្តិភាពជាជាងធ្វើសង្គ្រាម
ហើយពួកគេត្រឡប់ទៅរកភាពទាសភាពជាជាងការប្រយុទ្ធ។
Exodus 13:19
ទៅបោះជំរំត្រង់អេថាម
អេថាមមានទីតាំងស្ថិតនៅខាងត្បូង
នៃផ្លូវឆ្ពោះទៅកាន់ពួកភីលីស្ទីននៅព្រំដែននៃទីរហោស្ថាន។
ព្រះអង្គធ្វើឲ្យមានបង្គោលពពក ...បង្គោលភ្លើង
«ពពកមានរាងជាជួរឈរ ... ភ្លើងមានរាងជាជួរឈរ» ។
ព្រះជាម្ចាស់នៅជាមួយពួកគេក្នុងពពកពេលថ្ងៃនិងដោយភ្លើងនៅពេលយប់។

---

14 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ ដោយមានបន្ទូលថា៖[2]«ចូរប្រាប់ដល់ជនជាតិអ៊ីស្រាអែលថា ពួកគេត្រូវបែរទៅ ហើយបោះជំរំនៅក្បែរពីហាហ៊ីរ៉ុត គឺនៅចន្លោះ
មីគដួល និងសមុទ្រ នៅទល់មុខបាលសេផុន។ អ្នករាល់គ្នាត្រូវបោះជំរំនៅតាមឆ្នេរសមុទ្រទល់មុខនឹងពីហាស៊ីរ៉ុត។[3]ស្តេចផារ៉ោននឹងនិយាយ
ពីជនជាតិអ៊ីស្រាអែលថា៖ «ពួកគេកំពុងវង្វេងនៅក្នុងស្រុកនេះហើយ។ ហើយទីរហោស្ថាននៅជិតនឹងពួកគេ»។
[4]យើងនឹងធ្វើឲ្យស្តេចផារ៉ោនមានព្រះទ័យរឹងរូស ហើយព្រះអង្គនឹងដេញតាមពួកគ។ យើងនឹងបានទទួលកិត្តិយស ដោយសារស្តេចផារ៉ោន និងកងទ័ពរបស់ព្រះអង្គ។
ជនជាតិអេស៊ីបនឹងដឹងថា យើងគឺជាព្រះអម្ចាស់»។ ដូច្នេះ ជនជាតិអ៊ីស្រាអែលនឹងបោះជំរំ តាមសេចក្តីបង្គាប់របស់ព្រះអង្គ។[5]នៅពេលគេទូលស្តេចអេស៊ីបថា
«អ៊ីស្រាអែលបានរត់ ស្តេចផារ៉ោន និងពួកមន្ត្រីរបស់ស្តេចមានគំនិតទាស់នឹងជនជាតិអ៊ីស្រាអែល។ ពួកគេនិយាយថា៖
«ហេតុអ្វីបានជាយើងអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលមានសេរីភាពពីការធ្វើការឲ្យយើងដូច្នេះ?»
[6]បន្ទាប់មក ស្តេចផារ៉ោនបានយករទេះចម្បាំងរួចរាល់ ហើយយកទាហានរបស់ស្តេចទៅជាមួយ។[7]ស្តេចបានយករទេះចម្បាំងប្រាំរយ និងរទេះចម្បាំងផ្សេងៗនៅអេស៊ីប
ជាមួយកងទ័ពនៅជាមួយផង។[8]ព្រះអម្ចាស់បានធ្វើឲ្យស្តេចផារ៉ោន ជាស្តេចស្រុកអេស៊ីបមានព្រះទ័យរឹងរូស ហើយស្តេចបានដេញតាមជនជាតិអ៊ីស្រាអែល។
ជនជាតិបានចាកចេញដោយជ័យជម្នះ។[9]ប៉ុន្តែ ស្តេចអេស៊ីបបានដេញតាមពួកគេ ជាមួយកងទ័ពសេះ និងរទេះសេះរបស់ស្តេច ព្រមទាំងកងទ័ពរបស់ទ្រង់ផង។
ពួកគេបានដេញទាន់ជនជាតិអ៊ីស្រាអែលនៅត្រង់ជំរំនៅក្បែរសមុទ្រជិតពីហាហ៊ីរ៉ុត ទល់មុខនឹងបាលសេផុន។
[10]នៅពេលស្តេចផារ៉ោនចូលមកជិត ជនជាតិអ៊ីស្រាអែលសម្លឹងមើល ហើយភ្ញាក់ផ្អើល។ ជនជាតិអេស៊ីបបានចេញតាមពួកគេ ហើយពួកគេមានការភិតភ័យជាខ្លាំង។
ជនជាតិអ៊ីស្រាអែលបានស្រែករកព្រះអម្ចាស់។[11]ពួកគេនិយាយទៅកាន់លោកម៉ូសេថា៖ «តើនៅស្រុកអេស៊ីបគ្មានផ្នូរមែនទេ
បានជាលោកយកពួកយើងចេញពីទីនោះឲ្យមកស្លាប់នៅទីរហោស្ថានដូច្នេះ? ហេតុអ្វីបានជាលោកប្រព្រឹត្តនឹងពួកយើងដូច្នេះ គឺនាំពួកយើងចេញពីអេស៊ីប?
[12]តើពួកយើងមិនប្រាប់លោកនៅអេស៊ីបរួចហើយទេឬ? យើងបានប្រាប់លោកថា៖ «កុំមករវល់ជាមួយពួកយើងធ្វើអ្វី ទុកឲ្យពួកយើងធ្វើការនៅឲ្យជនជាតិអេស៊ីបទៅ»។
ពួកយើងធ្វើការឲ្យពួកគេ ប្រសើរជាងយើងស្លាប់នៅទីរហោស្ថានដូច្នេះ»។
[13]លោកម៉ូសេប្រាប់ទៅប្រជាជនថា៖ «កុំភ័យខ្លាចឡើយ។ ចូរតាំងស្មារតី ហើយមើលសេចក្តីសង្គ្រោះដែលព្រះអម្ចាស់នឹងប្រទានដល់អ្នករាល់គ្នានៅថ្ងៃនេះ។ ដ្បិត
អ្នករាល់គ្នានឹងលែងឃើញជនជាតិអេស៊ីបដែលអ្នកបានឃើញនៅថ្ងៃនេះទៀតហើយ។[14]ព្រះអម្ចាស់នឹងច្បាំងជំនួសអ្នករាល់គ្នា
ហើយអ្នករាល់គ្នាគ្រាន់តែតាំងស្មារតីឲ្យរឹងមាំឡើង»។
[15]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ម៉ូសេ ហេតុអ្វីបានជាអ្នកបន្តស្រែករកយើងទៀត? ចូរប្រាប់ជនជាតិអ៊ីស្រាអែលឲ្យបន្តដំណើរទៅមុខទៀត។
[16]ចូរលើកដំបងរបស់អ្នកឡើង យកដៃរបស់អ្នកលើកវាឡើងវាយទៅលើសមុទ្រ ហើយញែកវាចេញជាពីរ ដើម្បីឲ្យប្រជាជនអ៊ីស្រាអែលអាចឆ្លងកាត់សមុទ្រនៅលើដីស្ងួត។
[17]ចូរដឹងថា យើងបានធ្វើឲ្យស្តេចផារ៉ោនមានចិត្តរឹងរូស ដូច្នេះ ស្តេចនឹងដេញតាមពួកគេ។ យើងនឹងបានទទួលកិត្តិយស ដោយសារស្តេចផារ៉ោន និងកងទ័ព
ព្រមទាំងទ័ពសេះរបស់ស្តេច។[18]នោះ ជនជាតិអេស៊ីបនឹងដឹងថា យើងគឺជាព្រះអម្ចាស់ នៅពេលយើងបានទទួលកិត្តិយសដោយសារស្តេចផារ៉ោន និងរទេះចម្បាំង
ព្រមទាំងកងទ័ពសេះរបស់ស្តេចផង»។
[19]ទេវតារបស់ព្រះជាម្ចាស់ ដែលបាននៅខាងមុខជនជាតិអ៊ីស្រាអែល ក៏បានទៅពីក្រោយពួកគេ។ បង្គោលពពកក៏នៅនាំមុខពួកគេ ហើយក៏នៅពីក្រោយពួកគេដែរ។
[20]ពពកបានមកនៅចន្លោះជំរំរបស់អេស៊ីប និងជំរំរបស់អ៊ីស្រាអែល។ វាជាពពកខ្មៅនៅខាងអេស៊ីប ប៉ុន្តែ ភ្លឺនៅពេលយប់សម្រាប់ជនជាតិអ៊ីស្រាអែល ដូច្នេះហើយ
បានជាកងទ័ពមិនហ៊ានចូលជិតគ្នាឡើយពេញមួយយប់។
[21]លោកម៉ូសេបានលើកដៃរបស់គាត់ទៅលើសមុទ្រ។ ព្រះអម្ចាស់បានញែកសមុទ្រដោយខ្យល់ពីទិសខាងកើតយ៉ាងខ្លាំងពេញមួយយប់នោះ ហើយបានធ្វើឲ្យសមុទ្រស្ងួត។
ដូច្នេះ ទឹកបានញែកចេញពីគ្នា។[22]ជនជាតិអ៊ីស្រាអែលបាននាំគ្នាដើរទៅដល់ពាក់កណ្តាលសមុទ្រនៅលើដីស្ងួត។ ទឹកបានទៅជាកំពែងសម្រាប់ពួកគេគឺនៅខាងស្តាំ
និងខាងឆ្វេងដៃរបស់ពួកគេ។
[23]ជនជាតិអេស៊ីបបានដេញតាមពួកគេ។ ពួកគេបានដេញតាមជនជាតិអ៊ីស្រាអែលដល់ពាក់កណ្តាលសមុទ្រ គឺសេះរបស់ស្តេចផារ៉ោន រទេះចម្បាំង
និងកងទ័ពសេះទាំងអស់របស់ស្តេច។[24]ប៉ុន្តែ នៅពេលព្រឹកព្រលឹម ព្រះអម្ចាស់បានទតចុះមកលើកងទ័ពរបស់ទាហានជនជាតិអេស៊ីបតាមរយៈបង្គោលភ្លើង និងពពក។
[25]ព្រះអង្គបានធ្វើឲ្យជនជាតិអេស៊ីបមានការភ័យខ្លាចជាខ្លាំង។ កង់រទេះរបស់ពួកគេរបូត ហើយកងទ័ពសេះក៏បរាជ័យ។ ដូច្នេះ ជនជាតិអេស៊ីបនិយាយថា៖
«ចូរពួកយើងរត់ចេញពីអ៊ីស្រាអែលទៅ ដ្បិតព្រះអម្ចាស់នឹងច្បាំងជាមួយយើងជំនួសពួកគេ»។
[26]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរលើកដៃរបស់អ្នកទៅលើសមុទ្រ ដើម្បីឲ្យទឹកបានធ្លាក់ចុះមកវិញលើជនជាតិអេស៊ីប និងលើរទេះ
និងលើទ័ពសេះរបស់ពួកគេផង»។[27]ដូច្នេះ លោកម៉ូសេក៏លើកដៃរបស់គាត់ទៅលើសមុទ្រ ហើយវាក៏ត្រឡប់ដូចដើមឡើងវិញ នៅពេលព្រឹកមកដល់។

generated on Wed Sep 10 16:16:32 2025

ជនជាតិអេស៊ីបាននាំគ្នារត់ចេញពីសមុទ្រ ហើយព្រះអម្ចាស់បាននាំជនជាតិអេស៊ីបចូលទៅកណ្តាលសមុទ្រ។[28]ទឹកបានត្រឡប់មកវិញ
ហើយបានគ្របពីលើរទេះរបស់ស្តេចផារ៉ោន ទ័ពសេះ និងកងទ័ពរបស់ស្តេចទាំងអស់ដែលដេញតាមរទេះចូលទៅក្នុងសមុទ្រ។ គ្មាននរណាម្នាក់រស់ឡើយ។
[29]ប៉ុន្តែ ជនជាតិអ៊ីស្រាអែលវិញ បានដើរនៅលើដីស្ងួតនៅចំកណ្តាលសមុទ្រ។ ទឹកបានធ្វើជាជញ្ជាំងសម្រាប់ពួកគេ នៅខាងស្តាំ និងខាងឆ្វេងដៃរបស់ពួកគេ។[30]ដូច្នេះ
ព្រះអម្ចាស់បានសង្គ្រោះអ៊ីស្រាអែល នៅថ្ងៃនោះពីកណ្តាប់ដៃរបស់ជនជាតិអេស៊ីប ហើយអ៊ីស្រាអែលបានឃើញជនជាតិអេស៊ីបស្លាប់នៅតាមមាត់សមុទ្រ។
[31]នៅពេលអ៊ីស្រាអែលឃើញអំណាចដ៏អស្ចារ្យដែលព្រះអម្ចាស់ប្រើទាស់នឹងជនជាតិអេស៊ីប ប្រជាជននាំគ្នាកោតសរសើរដល់ព្រះអម្ចាស់
ហើយពួកគេបានទុកចិត្តលើព្រះអម្ចាស់ ព្រមទាំងលើលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គដែរ។

Exodus 14:1

ពីហាស៊ីរ៉ុត ... មីគដួល ... បាលសេផុន

ទាំងនេះជាក្រុងនៅតាមព្រំដែនខាងកើតរបស់ស្រុកអេស៊ីប។

អ្នករាល់គ្នាត្រូវបោះជំរំ

នៅទីនេះពាក្យថា «អ្នក» គឺជាពហុវចនៈ ហើយសំដៅទៅលើលោកម៉ូសេ
និងជនជាតិអ៊ីស្រាអែល។

ស្តេចផារ៉ោននឹងនិយាយពីជនជាតិអ៊ីស្រាអែលថា៖ «ពួកគេកំពុងវង្វេងនៅក្នុងស្រុកនេះហើយ។
ហើយទីរហោស្ថាននៅជិតនឹងពួកគេ»។

នេះអាចត្រូវបានថ្លែងជាការដកស្រង់ដោយប្រយោល។ការបកប្រែផ្សេងទៀត
«ផារ៉ោននឹងនិយាយថាជនជាតិអ៊ីស្រាអែលកំពុងវង្វេង
នៅលើទឹកដីហើយទីរហោស្ថានបានបិទទ្វារពួកគេ»។

ទីរហោស្ថាននៅជិតនឹងពួកគេ

ផារ៉ោននិយាយអំពីទីរហោស្ថានថាជាមនុស្សម្នាក់ដែលបានធ្វើអោយជនជាតិអ៊ីស្រាអែលបាត់បង់។ ការបកប្រែផ្សេងទៀត «នៅពេលស្តេចផារ៉ោន
និងកងទ័ពរបស់ស្តេចបានចូលមកជិត»

Exodus 14:4

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តណែនាំម៉ូសេ អំពីកន្លែងដែលត្រូវទៅ និងអ្វីដែលព្រះអម្ចាស់នឹងធ្វើ។

យើងនឹងធ្វើឲ្យស្តេចផារ៉ោនមានព្រះទ័យរឹងរូស

នៅទីនេះ «ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសចចេសរបស់ស្តេចត្រូវបានគេនិយាយ
ដូចជាព្រះទ័យរបស់ស្តេចរឹងរូស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៩:១១ ។
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើឱ្យស្តេចផារ៉ោនមានព្រះទ័យមានៈថែមទៀត»

ព្រះអង្គនឹងដេញតាមពួកគ។

«ស្តេចផារ៉ោននឹងដេញតាមជនជាតិអ៊ីស្រាអែល»

យើងនឹងបានទទួលកិត្តិយស

«ប្រជាជននឹងផ្តល់កិក្តិយសដល់យើង»

ជនជាតិអេស៊ីបនឹងដឹងថា យើងគឺជាព្រះអម្ចាស់។

«ជនជាតិអេស៊ីបនឹងយល់ថា យើងជាព្រះអម្ចាស់ គឺជាព្រះជាម្ចាស់ពិតតែមួយ»

ដូច្នេះ ជនជាតិអ៊ីស្រាអែលនឹងបោះជំរំ តាមសេចក្តីបង្គាប់របស់ព្រះអង្គ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះជនជាតិអ៊ីស្រាអែលបោះជំរុំដូចព្រះអម្ចាស់បានបង្គាប់ពួកគេ»

នៅពេលគេទូលស្តេចអេស៊ីបថា

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលមនុស្សម្នាក់ទូលស្តេចអេស៊ីប»

ស្តេចអេស៊ីប

នេះសំដៅទៅលើស្តេចផារ៉ោន។

បានរត់

«បានរត់ចេញ»

ស្តេចផារ៉ោន និងពួកមន្ត្រីរបស់ស្តេចមានគំនិតទាស់នឹងជនជាតិអ៊ីស្រាអែល

នៅទីនេះពាក្យ « គំនិត» សំដៅទៅលើឥរិយាបថរបស់ពួកគេ
ចំពោះជនជាតិអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «ស្តេចផារ៉ោន
និងអ្នកបម្រើរបស់ស្តេចបានផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេអំពីប្រជាជន»

«ហេតុអ្វីបានជាយើងអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលមានសេរីភាពពីការធ្វើការឲ្យយើងដូច្នេះ?»

ពួកគេបានសួរសំណួរនេះដើម្បីបង្ហាញថាពួកគេគិតថាពួកគេបានធ្វើរឿងល្ងីល្ងើ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «យើងបានធ្វើរឿងឆោតល្ងង់ដោយអនុញ្ញាតឱ្យអ៊ីស្រាអែល
មានសេរីភាពចេញពីការធ្វើការឱ្យពួកយើង!»

Exodus 14:6

ស្តេចបានយករទេះចម្បាំងប្រាំរយ

«ស្តេចបានយករទេះចំបាំងល្អបំផុតចំនួន ៦០០ គ្រឿងរបស់ស្តេច»

ព្រះអម្ចាស់បានធ្វើឲ្យស្តេចផារ៉ោន ជាស្តេចស្រុកអេស៊ីបមានព្រះទ័យរឹងរូស
នៅទីនេះ «ព្រះទ័យ» សំដៅទៅលើស្តេចផារ៉ោន។
អាកប្បកិរិយារឹងរូសចចេសរបស់ស្តេចត្រូវបានគេនិយាយ
ដូចជាព្រះទ័យរបស់ស្តេចរឹងរូស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៩:១១ ។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានធ្វើអោយស្តេចផារ៉ោនមានព្រះទ័យមានៈថែមទៀត»

ពីហាហ៊ីរ៉ុត... បាលសេផុន។

ទាំងនេះជាក្រុងនៅតាមព្រំដែនខាងកើតរបស់អេស៊ីប។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១៤: ១ ។

Exodus 14:10

នៅពេលស្តេចផារ៉ោនចូលមកជិត

ពាក្យថា «ស្តេចផារ៉ោន» នៅទីនេះតំណាងអោយកងទ័ពអេស៊ីបទាំងមូល។ ការបកប្រែផ្សេងទៀត «នៅពេលស្តេចផារ៉ោន
និងកងទ័ពរបស់ស្តេចបានចូលមកជិត»

ពួកគេមានការភិតភ័យជាខ្លាំង។

«ជនជាតិអ៊ីស្រាអែលភិតភ័យជាខ្លាំង»

«តើនៅស្រុកអេស៊ីបគ្មានផ្នូរមែនទេ
បានជាលោកយកពួកយើងចេញពីទីនោះឲ្យមកស្លាប់នៅទីរហោស្ថានដូច្នេះ?

ជនជាតិអ៊ីស្រាអែលសួរសំណួរនេះ ដើម្បីបង្ហាញពីការខកចិត្ត
និងការភ័យខ្លាចនៃការស្លាប់។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
«មានផ្នូរជាច្រើននៅក្នុងប្រទេសអេស៊ីបសម្រាប់បញ្ចុះសពពួកយើង។
អ្នកមិនចាំបាច់នាំយើងទៅវាលរហោស្ថានដើម្បីស្លាប់ទេ!»

ហេតុអ្វីបានជាលោកប្រព្រឹត្តនឹងពួកយើងដូច្នេះ គឺនាំពួកយើងចេញពីអេស៊ីប?

ប្រជាជនអ៊ីស្រាអែលសួរសំនួរនេះ
ដើម្បីស្តីបន្ទោសលោកម៉ូសេចំពោះការនាំមកវាលរហោស្ថានអោយពួកគេ។
សំណួរដ៏ប៉ិនប្រសប់នេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «អ្នកមិនគួរប្រព្រឹត្តចំពោះពួកយើងបែបនេះទេ
ដោយនាំយើងចេញពីអេស៊ីប!»

តើពួកយើងមិនប្រាប់លោកនៅអេស៊ីបរួចហើយទេឬ?

ជនជាតិអ៊ីស្រាអែលសួរសំណួរនេះ
ដើម្បីបញ្ជាក់ថានេះជាអ្វីដែលពួកគេបានប្រាប់ដល់លោកម៉ូសេ។
សំណួរវោហារដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
«នេះជាការជាក់ស្តែងដែលយើងបានប្រាប់លោកពេលយើងនៅស្រុកអេស៊ីប»។

យើងបានប្រាប់លោកថា៖ «កុំមករវល់ជាមួយពួកយើងធ្វើអ្វី
ទុកឲ្យពួកយើងធ្វើការនៅឲ្យជនជាតិអេស៊ីបទៅ»។

នេះអាចត្រូវបានថ្លែងជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«កុំមករវល់ជាមួយពួកយើងធ្វើអ្វី ទុកឲ្យពួកយើងធ្វើការនៅឲ្យជនជាតិអេស៊ីបទៅ»
។

Exodus 14:13

លោកម៉ូសេប្រាប់ទៅប្រជាជន

លោកម៉ូសេឆ្លើយតប នឹងការភ័យខ្លាចរបស់ជនជាតិអ៊ីស្រាអែល។

ប្រទានដល់អ្នករាល់គ្នា

សព្វនាម «អ្នករាល់គ្នា» សំដៅទៅលើជនជាតិអ៊ីស្រាអែល។

ដ្បិត អ្នករាល់គ្នានឹងលែងឃើញជនជាតិអេស៊ីប

លោកម៉ូសេបានប្រើពាក្យគួរសមក្នុងការនិយាយថាព្រះជាម្ចាស់
នឹងបំផ្លាញកងទ័ពអេស៊ីប។ ការបកប្រែផ្សេងទៀត «ត្បិតព្រះជាម្ចាស់
នឹងសម្លាប់ជនជាតិអេស៊ីប»

Exodus 14:15

generated on Wed Sep 10 16:16:32 2025

ម៉ូសេ ហេតុអ្វីបានជាអ្នកបន្តស្រែករកយើងទៀត?
តាមមើលទៅលោកម៉ូសេបានអធិស្ឋានសុំជំនួយពីព្រះជាម្ចាស់
ដូច្នេះព្រះជាម្ចាស់ប្រើសំណួរនេះដើម្បីបង្ខំលោកម៉ូសេឲ្យធ្វើ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «កុំស្រែករកយើងទៀត ម៉ូសេ» ។ សូមមើល
ញែកវាចេញជាពីរ
«ចែកសមុទ្រជាពីរផ្នែក»
ចូរដឹងថា
«ដឹង»
យើងបានធ្វើឲ្យស្តេចផារ៉ោនមានចិត្តរឹងរូស
នៅទីនេះ « ចិត្ត» សំដៅទៅលើជនជាតិអេស៊ីបខ្លួនឯង។
អាកប្បកិរិយារឹងរូសរបស់ពួកគេត្រូវបានគេនិយាយដូចជាចិត្តរបស់ពួកគេរឹងរូស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៩:១១ ។
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើអោយជនជាតិអេស៊ីបកាន់តែមានៈថែមទៀត»
ដូច្នេះ ស្តេចនឹងដេញតាមពួកគេ។
«ដូច្នេះជនជាតិអេស៊ីប នឹងចូលទៅក្នុងសមុទ្រតាមពីក្រោយជនជាតិអ៊ីស្រាអែល»

Exodus 14:19

ជំរំរបស់អេស៊ីប និងជំរំរបស់អ៊ីស្រាអែល។
«កងទ័ពអេស៊ីប និងប្រជាជនអ៊ីស្រាអែល»
ដូច្នេះហើយ បានជាកងទ័ពមិនហ៊ានចូលជិតគ្នាឡើយពេញមួយយប់។
នេះមានន័យថាប្រជាជនអេស៊ីប
និងជនជាតិអ៊ីស្រាអែលមិនអាចចូលជិតគ្នាបានឡើយ។

Exodus 14:21

ខ្យល់ពីទិសខាងកើត
ខ្យល់ចាប់ផ្តើមបក់ពីទិសខាងកើត ហើយខ្យល់បក់ឆ្ពោះទៅទិសខាងលិច។
ខាងកើត
ជាកន្លែងដែលព្រះអាទិត្យរះ
ទឹកបានញែកចេញពីគ្នា
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានញែកទឹក»
គឺនៅខាងស្តាំ និងខាងឆ្វេងដៃរបស់ពួកគេ។
«នៅសងខាងពួកគេ» ឬ «នៅទាំងសងខាងពួកគេ»

Exodus 14:23

ព្រះអង្គបានធ្វើឲ្យជនជាតិអេស៊ីបមានការភ័យខ្លាចជាខ្លាំង។
ការភ័យស្លន់ស្លោគឺនៅពេលមនុស្សម្នាក់ភ័យខ្លាចខ្លាំង
ថាពួកគេមិនអាចគិតធម្មតាបាន។
កង់រទេះរបស់ពួកគេរបូត
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ភក់ស្អុះកង់រទេះរបស់ពួកគេ» ឬ
«រទេះរទេះសេះរបស់ពួកគេត្រូវជាប់គាំងនៅក្នុងភក់»

Exodus 14:26

ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរលើកដៃរបស់អ្នកទៅលើ...
លើទ័ពសេះរបស់ពួកគេផង»
នេះអាចត្រូវបានថ្លែងជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានប្រាប់លោកម៉ូសេឲ្យលាតដៃទៅលើសមុទ្រ
ដើម្បីឲ្យទឹកធ្លាក់ចុះមកលើជនជាតិអេស៊ីប រទេះចំបាំង និង ទ័ពសេះរបស់ពួកគេ»។
បានធ្លាក់ចុះ
«ធ្លាក់លើ»
ជនជាតិអេស៊ីបាននាំគ្នារត់ចេញពីសមុទ្រ
ចាប់តាំងពីពេលទឹកសមុទ្របានបិទនៅលើជនជាតិអេស៊ីប
ជំនួសឱ្យការរត់គេចខ្លួនពួកគេពិតជាកំពុងរត់ចូលទៅក្នុងទឹក។
ព្រះអម្ចាស់បាននាំជនជាតិអេស៊ីប
«ព្រះអម្ចាស់រុញច្រានជនជាតិអេស៊ីប» ឬ «ព្រះអម្ចាស់បានបោះជនជាតិអេស៊ីប»

Exodus 14:29

ជនជាតិអ៊ីស្រាអែល
គ្រប់ការកើតមានឡើងនៃ « ជនជាតិអ៊ីស្រាអែល» នីមួយៗ
គឺសំដៅទៅលើប្រជាជនអ៊ីស្រាអែល។ការបកប្រែផ្សេងទៀត
«ប្រជាជនអ៊ីស្រាអែល» ឬ «ជនជាតិអ៊ីស្រាអែល»
ពីកណ្តាប់ដៃរបស់ជនជាតិអេស៊ីប
នៅទីនេះពាក្យថា « ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«ពីអំណាចរបស់ប្រជាជនអេស៊ីប»
នៅតាមមាត់សមុទ្រ
«នៅលើដីតាមបណ្តោយសមុទ្រ»

---

15 [1]បន្ទាប់មក លោកម៉ូសេ និងប្រជាជនអ៊ីស្រាអែលច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។ ពួកគេច្រៀងថា៖ «យើងនឹងច្រៀងថ្វាយព្រះអម្ចាស់ ដ្បិត
ព្រះអង្គមានជ័យជម្នះយ៉ាងត្រចះត្រចង់ សេះ និងអ្នកដែលជិះលើវាត្រូវបានបោះចូលទៅក្នុងសមុទ្រ។
[2]ព្រះអម្ចាស់គឺជាកម្លាំង និងចម្រៀងរបស់ខ្ញុំ ហើយព្រះអង្គគឺជាសេចក្តីសង្គ្រោះរបស់ខ្ញុំ។ នេះគឺជាព្រះជាម្ចាស់របស់ខ្ញុំ ហើយខ្ញុំនឹងសរសើរព្រះអង្គ
ជាព្រះជាម្ចាស់ឪពុករបស់ខ្ញុំ ហើយខ្ញុំនឹងលើកតម្កើងព្រះអង្គ។[3]ព្រះអម្ចាស់គឺជាអ្នកចម្បាំង ព្រះអម្ចាស់គឺជាឈ្មោះរបស់ព្រះអង្គ។
[4]ព្រះអង្គបានបោះរទេះ និងកងទ័ពរបស់ស្តេចផារ៉ោនចូលទៅក្នុងសមុទ្រ។ ពួកមន្ត្រីដែលស្តេចផារ៉ោនបានជ្រើសរើសត្រូវបានបោះចូលទៅក្នុងសមុទ្រដើមត្រែង។
[5]ជម្រៅទឹកបានគ្របពីលើពួកគេ ពួកគេធ្លាក់ចូលទៅក្នុងទឹកដ៏ជ្រៅដូចជាថ្មមួយដុំ។
[6]ឱព្រះអម្ចាស់អើយ ព្រះហស្តស្តាំរបស់ព្រះអង្គ មានឫទ្ធិដ៏ខ្លាំងពិសេស ហើយឱ ព្រះអម្ចាស់អើយ ព្រះហស្តស្តាំរបស់ព្រះអង្គបានផ្តួលរំលំពួកខ្មាំងសត្រូវ។
[7]ដោយសារអំណាចចេស្តាដ៏ខ្លាំងអស្ចារ្យ ព្រះអង្គបានបោះអស់អ្នកដែលក្រោកឡើងប្រឆាំងនឹងព្រះអង្គ។ ព្រះអង្គបានបញ្ចេញព្រះពិរោធរបស់ព្រះអង្គ
ហើយព្រះពិរោធនោះបានត្របាក់លេបពួកគេដូចជាភ្លើងឆេះគំនរចំបើង។[8]ដោយសារកម្លាំងខ្យល់ពីព្រះនាសាព្រះអង្គទឹកក៏ឈរឡើងជាគំនរទឹកធំបានពូនឡើងដូច
កំពែងអស់ទាំងទីជម្រៅក៏បានកកខះនៅបាតសមុទ្រ។
[9]ខ្មាំងត្រូវនិយាយថា៖ «យើងដឹងដេញតាម យើងនឹងដេញតាមទាន់ យើងនឹងចែកជ័យភណ្ឌគ្នា បំណងប្រាថ្នារបស់យើងនឹងបានស្កប់ចិត្តដោយសារពួកគេ
ដៃរបស់យើងនឹងបំផ្លាញពួកគេ»។[10]ប៉ុន្តែ ព្រះអង្គបានផ្លុំដោយខ្យល់របស់ព្រះអង្គ ហើយសមុទ្រនឹងគ្របពីលើពួកគេ ហើយពួកគេនឹងលិចដូចជាដំសំណនៅក្នុងទឹកដ៏ជ្រៅ។
[11]ឱព្រះអម្ចាស់អើយ តើនរណាដូចព្រះអង្គ នៅក្នុងចំណោមព្រះដទៃ? តើនរណាមានព្រះចេស្តាដ៏វិសុទ្ធដូចព្រះអង្គ ដែលគួរឲ្យសរសើរតម្កើង និងធ្វើការអស្ចារ្យ?
[12]ព្រះអង្គបានលូកព្រះហស្តស្តាំរបស់ព្រះអង្គ ហើយផែនដីបានលេបពួកគេ។[13]ព្រះអង្គស្មោះត្រង់នឹងសម្ពន្ធមេត្រីព្រះអង្គ បាននាំប្រជារាស្ត្ររបស់ព្រះអង្គ
ព្រះអង្គបានសង្គ្រោះពួកគេ។ នៅក្នុងព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គ ព្រះអង្គបាននាំពួកគេចូលទៅកន្លែងបរិសុទ្ធ ជាកន្លែងដែលព្រះអង្គរស់នៅ។
[14]មនុស្សនឹងឮ ហើយពួកគេនឹងញាប់ញ័រ អ្នកស្រុកភីលីស្ទីននាំគ្នាភ័យតក់ស្លុតដែរ។[15]ហើយពួកនៃជនជាតិអេដុំនឹងភ័យខ្លាច ពួកទាហានរបស់ម៉ូអាប់នឹងភ័យញ័រ
ប្រជាជននៅក្នុងទឹកដីកាណានទាំងអស់នឹងត្រូវរលាយទៅ។
[16]ភាពភ័យខ្លាច និងភាពថប់បារម្ភបានគ្របសង្កត់លើគេ។ ដោយព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គ ពួកគនឹងបានដូចជាថ្មដែលនៅនឹងមួយកន្លែង រហូតទាល់តែប្រជារាស្ត្រ
ព្រះអង្គឆ្លងផុត ឱព្រះអម្ចាស់អើយ រហូតទាល់តែប្រជារាស្ត្រដែលព្រះអង្គបានលោះឆ្លងផុត។
[17]ព្រះអង្គបាននាំពួកគេ ហើយបានដាំពួកគេនៅលើភ្នំនៃមរតករបស់ព្រះអង្គ ឱព្រះអម្ចាស់អើយ ជាកន្លែងដែលព្រះអង្គបានបង្កើត សម្រាប់ព្រះអង្គរស់នៅ
ឱព្រះអម្ចាស់អើយ ព្រះអង្គបានសង់ទីបរិសុទ្ធ។[18]ព្រះអម្ចាស់នឹងសោយរាជ្យអស់កល្បរៀងរាបតទៅ»។
[19]ដ្បិត សេះរបស់ស្តេចផារ៉ោនបានធ្លាក់ទៅជាមួយនឹងរទេះរបស់ព្រះអង្គ ហើយទ័ពសេះក៏ត្រូវធ្លាក់ទៅក្នុងសមុទ្រដែរ។[20]ព្រះអម្ចាស់បានធ្វើឲ្យទឹកត្រឡប់មកឯសមុទ្រវិញ
ហើយបានធ្លាក់លើពួកគេ។ ប៉ុន្តែ ជនជាតិអ៊ីស្រាអែលបានដើរនៅលើដីស្ងួត នៅក្នុងកណ្តាលសមុទ្រ។[21]នាងម៉ារាម ជាព្យាការានី ត្រូវជាបងស្រីរបស់លោកអ៊ើរ៉ុន
បានយកក្រាប់មក ហើយស្ត្រីទាំងអស់បានចេញមកជាមួយក្រាប់ រាំជាមួយនាងដែរ។ នាងម៉ារាមច្រៀងដល់ពួកគេថា៖ «ចូរច្រៀងថ្វាយព្រះអម្ចាស់ ដ្បិត
ព្រះអង្គមានជ័យជម្នះយ៉ាងត្រចះត្រចង់។ សេះ និងអ្នកជិះ ព្រះអង្គបានបោះពួកគេចូលទៅក្នុងសមុទ្រ»។

generated on Wed Sep 10 16:16:32 2025

[22]លោកម៉ូសេបាននាំជនជាតិអ៊ីស្រាអែលបន្តចេញពីសមុទ្រដើមត្រែង។ ពួកគេបានចេញដំណើរឆ្ពោះទៅទីរហោស្ថានស៊ើរ។ ពួកគេបានធ្វើដំណើរអស់រយៈពេលបីថ្ងៃ
ដើម្បីចូលទៅឯទីរហោស្ថាននោះ ហើយមិនឃើញមានទឹកទេ។[23]នោះពួកគេបានទៅដល់ម៉ារ៉ា ប៉ុន្តែ ពួកគេមិនអាចផឹកទឹកនៅទីនោះទេ ដោយសារវាល្វីង។ដូច្នេះ
ពួកគេហៅទីនោះថា ម៉ារ៉ា។
[24]ដូច្នេះ ប្រជាជនបានរអ៊ូរទាំចំពោះលោកម៉ូសេ ហើយនិយាយថា៖ «តើយើងបានទឹកអីផឹក?»[25]លោកម៉ូសេបានអំពាវនាវរកព្រះអម្ចាស់
ហើយព្រះអម្ចាស់បានបង្ហាញគាត់នូវដើមឈើមួយដើម។ លោកម៉ូសេបានបោះវាចូលទៅក្នុងទឹក ហើយនឹងនោះបានត្រឡប់ទៅជាទឹកសាបអាចផឹកបានវិញ។
នៅទីនោះហើយ ព្រះអម្ចាស់បានប្រទានច្បាប់ដល់ពួកគេយ៉ាងតឹងរឹង ហើយព្រះអង្គក៏បានល្បងលពួកគេនៅទីនោះដែរ។[26]ព្រះអង្គមានបន្ទូលថា៖ «ប្រសិនបើ
អ្នករាល់គ្នាប្រុងប្រយ័ត្នស្តាប់សម្លេងរបស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា ហើយធ្វើតាមអ្វីដែលត្រឹមត្រូវនៅចំពោះព្រះភក្ត្រព្រះអង្គ
ហើយប្រសិនបើអ្នករាល់គ្នាផ្ទៀងត្រចៀកចំពោះបញ្ញត្តិ ហើយស្តាប់តាមបញ្ញត្តិទាំងអស់របស់ព្រះអង្គ
យើងនឹងមិនធ្វើឲ្យមានជំងឺណាមួយដែលបានកើតឡើងនៅអេស៊ីបលើអ្នករាល់គ្នាឡើយ ដ្បិត យើងគឺព្រះអម្ចាស់ ដែលប្រោសអ្នករាល់គ្នាឲ្យជា»។
[27]បន្ទាប់មក ប្រជាជនបានមកដល់ អេលីម ជាកន្លែងដែលមានផ្លូវទឹកដប់ពីរ ហើយមានដើមលម៉ើចំនួនចិតសិបដើមទៀតផង។ ពួកគេក៏បោះជំរំនៅក្បែរមាត់ទឹកនោះ។

Exodus 15:1

ព័ត៌មានទូទៅ

នេះជាបទចម្រៀងដែលនិយាយអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅ ១៤:២៦។

និងអ្នកដែលជិះលើវាត្រូវបានបោះចូលទៅក្នុងសមុទ្រ។

លោកម៉ូសេបានច្រៀងអំពីព្រះជាម្ចាស់ ធ្វើអោយសមុទ្រគ្របពីលើហើយលង់សេះ
និងអ្នកជិះសេះដូចព្រះជាម្ចាស់បានបោះពួកគេចូលទៅក្នុងសមុទ្រ។
ការបកប្រែផ្សេងទៀត «ព្រះអង្គបានធ្វើសមុទ្រគ្របពីលើសេះនិងអ្នកជិះ» ឬ
«ព្រះអង្គបានធ្វើឱ្យសេះនិងអ្នកជិះលង់ទឹកនៅក្នុងសមុទ្រ»

សេះ និងអ្នកដែលជិះលើវា

នេះសំដៅទៅលើសេះ
និងអ្នកជិះសេះរបស់ជនជាតិអេស៊ីបទាំងអស់ឬច្រើនដែលដេញតាមជនជាតិអ៊ីស្រាអែលមកដល់
ការបកប្រែផ្សេងទៀត «សេះនិងអ្នកជិះរបស់ពួកគេ»

អ្នកជិះ

នេះគឺជាមនុស្សដែលអង្គុយលើសេះឬធ្វើដំណើរតាមរទេះសេះដែលសេះកំពុងអូស។

Exodus 15:2

ព្រះអម្ចាស់គឺជាកម្លាំង

ទី១អត្ថន័យដែលប្រហែលគឺ) « ព្រះអម្ចាស់គឺជាអ្នកដែលផ្តល់កម្លាំងដល់ខ្ញុំ» ឬ
ទី២) «ព្រះអម្ចាស់គឺជាកម្លាំងដែលការពារខ្ញុំ» ។

និងចម្រៀង

លោកម៉ូសេហៅព្រះអម្ចាស់ថា
ចំរៀងរបស់គាត់ព្រោះព្រះអម្ចាស់ជាមួយអង្គដែលច្រៀង។ ការបកប្រែផ្សេងទៀត
«ហើយមួយអង្គដែលខ្ញុំច្រៀងរៀបរាប់»

ព្រះអង្គគឺជាសេចក្តីសង្គ្រោះរបស់ខ្ញុំ។

លោកម៉ូសេបានហៅព្រះជាម្ចាស់ថា
ជាសេចក្តីសង្គ្រោះពីព្រោះព្រះជាម្ចាស់បានសង្គ្រោះគាត់។ ការបកប្រែផ្សេងទៀត
«ព្រះអង្គបានសង្គ្រោះខ្ញុំ» ឬ «ព្រះអង្គគឺជាអ្នកដែលជួយសង្គ្រោះខ្ញុំ»

ព្រះអម្ចាស់គឺជាអ្នកចម្បាំង

លោកម៉ូសេបានហៅព្រះជាម្ចាស់ថាជាអ្នកចម្បាំងពីព្រោះព្រះជាម្ចាស់បានច្បាំងនឹងជនជាតិអេស៊ីបហើយបានឈ្នះ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ គឺដូចជាអ្នកចម្បាំងម្នាក់»

Exodus 15:4

ព្រះអង្គបានបោះរទេះ និងកងទ័ពរបស់ស្តេចផារ៉ោនចូលទៅក្នុងសមុទ្រ។

លោកម៉ូសេច្រៀងអំពីព្រះជាម្ចាស់ ធ្វើអោយសមុទ្រគ្របលើរទេះចម្បាំង
និងកងទ័ពរបស់ស្តេចផារ៉ោនដូចព្រះបានគ្រវែងពួកគេចូលក្នុងសមុទ្រ។
ការបកប្រែផ្សេងទៀ « ព្រះអង្គបានធ្វើឱ្យមានសមុទ្រគ្របលើរទេះចម្បាំង
និងកងទ័ពរបស់ស្តេចផារ៉ោន» ឬ « ព្រះអង្គបានធ្វើអោយរទេះ
និងកងទ័ពរបស់ស្តេចផារ៉ោនលង់ក្នុងសមុទ្រ» ។

ពួកគេធ្លាក់ចូលទៅក្នុងទឹកដ៏ជ្រៅដូចជាថ្មមួយដុំ។

ដូចដុំថ្មមិនអណ្តែតទេតែលិចដល់បាតសមុទ្រទាហានសត្រូវបានលិចទៅបាតសមុទ្រ។
ការបកប្រែផ្សេងទៀត « ពួកគេបានធ្លាក់ចូលទៅក្នុងទឹកដ៏ជ្រៅ
ដូចជាដុំថ្មលិចដល់បាតសមុទ្រ»

Exodus 15:6

ឱព្រះអម្ចាស់អើយ ព្រះហស្តស្តាំរបស់ព្រះអង្គ មានឫទ្ធិដ៏ខ្លាំងពិសេស

លោកម៉ូសេនិយាយ អំពីព្រះជាម្ចាស់ដូចជាព្រះជាម្ចាស់មានព្រះហស្ត។
ព្រះហស្តស្តាំសំដៅទៅលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់
ឬអ្វីៗដែលព្រះជាម្ចាស់ធ្វើពេញដោយអំណាចចេស្តា។ ការបកប្រែផ្សេងទៀត «
ឱព្រះអម្ចាស់អើយ ឫទ្ធានុភាពរបស់ព្រះអង្គ ថ្កុំថ្កើងរុងរឿង» ឬ «
ព្រះអម្ចាស់អើយអ្វីៗដែលព្រះអង្គធ្វើ គឺសំដែងដោយឫទ្ធានុភាព»

ព្រះអម្ចាស់អើយ ព្រះហស្តស្តាំរបស់ព្រះអង្គបានផ្តួលរំលំពួកខ្មាំងសត្រូវ។

លោកម៉ូសេនិយាយអំពីព្រះជាម្ចាស់ ដូចជាព្រះជាម្ចាស់មានព្រះហស្ត។
ព្រះហស្តស្តាំសំដៅទៅលើអំណាចរបស់ព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត «
ឱព្រះអម្ចាស់អើយ អំណាចចេស្តារបស់ព្រះអង្គបានផ្តួលរលំខ្មាំងសត្រូវ» ឬ «
ព្រះអម្ចាស់អើយ ព្រះចេស្តារបស់ព្រះអង្គបានផ្តួលរលំខ្មាំងសត្រូវ»

បានផ្តួលរំលំពួកខ្មាំងសត្រូវ។

លោកម៉ូសេនិយាយអំពី សត្រូវដូចជាវាងាយបែកបាក់ហើយអាចផ្តួលរលំដូចកែវ
ឬថូ។ ការបកប្រែផ្សេងទៀត «បានបំផ្លាញសត្រូវទាំងស្រុង»

អស់អ្នកដែលក្រោកឡើងប្រឆាំងនឹងព្រះអង្គ។

ការបះបោរប្រឆាំងនឹងព្រះជាម្ចាស់ត្រូវបានគេនិយាយ
ថាជាការក្រោកឡើងប្រឆាំងនឹងព្រះអង្គ។ ការបកប្រែផ្សេងទៀត
«អស់អ្នកដែលបះបោរប្រឆាំងនឹងព្រះអង្គ» ឬ «សត្រូវរបស់ព្រះអង្គ»

ព្រះអង្គបានបញ្ចេញព្រះពិរោធរបស់ព្រះអង្គ

លោកម៉ូសេនិយាយអំពី ព្រះពិរោធរបស់ព្រះជាម្ចាស់
ដូចជាអ្នកបម្រើដែលព្រះជាម្ចាស់បានចាត់អោយទៅធ្វើអ្វីមួយ។
ការបកប្រែផ្សេងទៀត «ព្រះអង្គបានបង្ហាញព្រះពិរោធរបស់ព្រះអង្គ» ឬ
«ព្រះអង្គបានប្រព្រឹត្តស្របតាមព្រះពិរោធរបស់ព្រះអង្គ»

ព្រះពិរោធនោះបានត្របាក់លេបពួកគេដូចជាភ្លើងឆេះគំនរចំបើង។

លោកម៉ូសេនិយាយអំពីព្រះពិរោធរបស់ព្រះជាម្ចាស់ដូចជាភ្លើងដែលអាចឆេះបំផ្លាញអ្វីៗទាំងអស់។
ខ្មាំងសត្រូវរបស់ព្រះអង្គត្រូវវិនាសសូន្យដូចជាចំបើងដែលត្រូវភ្លើងឆេះ។
ការបកប្រែផ្សេងទៀត:
«ព្រះពិរោធបានបំផ្លាញសត្រូវរបស់អ្នកទាំងស្រុងដូចជាភ្លើងដែលឆេះចំបើង»

ដោយសារកម្លាំងខ្យល់ពីព្រះនាសាព្រះអង្គ

ម៉ូសេនិយាយអំពីព្រះជាម្ចាស់ ដូចជាព្រះជាម្ចាស់មានព្រះនាសា ហើយគាត់និយាយ
ពីខ្យល់ដូចជាព្រះជាម្ចាស់ផ្លុំខ្យល់ចេញពីនាសារបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គផ្លុំលើសមុទ្រហើយ»។

Exodus 15:9

ជាតិអេស៊ីបហើយបានឈ្នះ។ ស្កប់ចិត្តដោយសារពួកគេ

នេះអាចត្រូវបានបង្ហាញជាមួយទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«យើងនឹងស្កប់ចិត្តដោយសារបំណងប្រាថ្នារបស់យើងលើពួកគេ» ឬ
«យើងនឹងយកអ្វីដែលយើងចង់បានពីពួកគេ»

ដៃរបស់យើងនឹងបំផ្លាញពួកគេ។

សត្រូវនិយាយពីការបំផ្លាញជនជាតិអ៊ីស្រាអែលដោយអំណាចនៃដៃរបស់ពួកគេ
ដូចជាដៃរបស់ពួកគេដែលនឹងបំផ្លាញពួកគេ។ ការបកប្រែផ្សេងទៀត
«យើងនឹងបំផ្លាញពួកគេ ដោយដៃយើង»

ប៉ុន្តែ ព្រះអង្គបានផ្លុំដោយខ្យល់របស់ព្រះអង្គ

លោកម៉ូសេបាននិយាយអំពី
ព្រះជាម្ចាស់ធ្វើឱ្យខ្យល់បក់ដូចជាព្រះជាម្ចាស់បានផ្លុំខ្យល់តាមព្រះនាសា
ឬព្រះឱសរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត «ប៉ុន្តែព្រះអង្គធ្វើឱ្យខ្យល់បក់»

លិចដូចជាដំសំណនៅក្នុងទឹកដ៏ជ្រៅ។

ដំសំណគឺជាលោហៈធ្ងន់ដែលជាធម្មតាត្រូវបានប្រើដើម្បីពន្លិចវត្ថុចូលក្នុងទឹក។
ពាក្យថា «នាំមុខ»
នៅទីនេះត្រូវបានប្រើដើម្បីបង្ហាញពីរបៀបដែលសត្រូវរបស់ព្រះជាម្ចាស់
ត្រូវបានបំផ្លាញយ៉ាងឆាប់រហ័ស។ ការបកប្រែផ្សេងទៀត
«លិចយ៉ាងលឿនដូចសំណនៅក្នុងទឹកដ៏ជ្រៅ »

ឱព្រះអម្ចាស់អើយ តើនរណាដូចព្រះអង្គ នៅក្នុងចំណោមព្រះដទៃ?

លោកម៉ូសេប្រើសំណួរនេះ ដើម្បីបង្ហាញរបៀបព្រះជាម្ចាស់ធំអស្ចារ្យយ៉ាងណា។

ការបកប្រែផ្សេងទៀត «ឱព្រះអម្ចាស់អើយ គ្មានព្រះណាមួយដូចព្រះអង្គ
ក្នុងចំណោមព្រះទាំងនោះ!» ឬ «ព្រះអម្ចាស់អើយ គ្មានព្រះណាដូចព្រះអង្គ!» ។
តើនរណាដូចព្រះអង្គ ... និងធ្វើការអស្ចារ្យ?
លោកម៉ូសេប្រើសំណួរនេះ ដើម្បីបង្ហាញរបៀបព្រះជាម្ចាស់ធំអែស្ចារ្យយ៉ាងណា។
ការបកប្រែផ្សេងទៀត គ្មានព្រះណាដូចព្រះអង្គទេ។
«គ្មានព្រះមួយណាមានភាពបរិសុទ្ធអស្ចារ្យដូចព្រះអង្គឡើយ!
គ្មានព្រះមួយណាត្រូវបានគេសរសើរតម្កើងដូចជាព្រះអង្គឡើយ!
ហើយគ្មានព្រះមួយណាអាចធ្វើការអស្ចារ្យដូចព្រះអង្គធ្វើបានទេ!»
Exodus 15:12
ព្រះហស្តស្តាំរបស់ព្រះអង្គ
ឃ្លាថា «ព្រះហស្តស្តាំ» តំណាងឱ្យអំណាចដ៏ខ្លាំងរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «ដោយអំណាចដ៏ខ្លាំងរបស់ព្រះអង្គ»
ព្រះអង្គបានលូកព្រះហស្តស្តាំរបស់ព្រះអង្គ
លោកម៉ូសេនិយាយអំពីព្រះជាម្ចាស់ដែលបណ្តាលឱ្យមានអ្វីកើតឡើង
ដូចជាព្រះជាម្ចាស់បានលូកព្រះហស្តរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ដោយអំណាចដ៏ខ្លាំងពូកែរបស់ព្រះអង្គ ព្រះអង្គបានធ្វើឱ្យវាកើតឡើង»
ហើយផែនដីបានលេបពួកគេ។
លោកម៉ូសេតំណាងឲ្យមនុស្សនៅលើផែនដីហាក់ដូចជាវាអាចលេប ឬ
វានឹងត្របាក់លេបបាន។ ការបកប្រែផ្សេងទៀត «ផែនដីបានលេបត្របាក់ពួកវា»
Exodus 15:14
ញាប់ញ័រ
នេះមានន័យថាញ័រព្រោះអ្នកភ័យខ្លាច។
អ្នកស្រុកភីលីស្ទីននាំគ្នាភ័យតក់ស្លុតដែរ។
លោកម៉ូសេនិយាយពីការភ័យតក់ស្លុត
ដែលហាក់ដូចជាមនុស្សដែលអាចចាប់យកមនុស្សណាម្នាក់ដោយបង្ខំ
ហើយធ្វើឱ្យពួកគេភ័យខ្លាចយ៉ាងខ្លាំង។ ការបកប្រែផ្សេងទៀត «អ្នកស្រុកភីលីស្ទីន
នឹងភ័យខ្លាច»
នឹងត្រូវរលាយទៅ
លោកម៉ូសេនិយាយអំពីមនុស្សចុះថយ
ពីការភ័យខ្លាចរបស់ពួកគេដូចជារលាយទៅ។ ការបកប្រែផ្សេងទៀត
«នឹងចុះថយពីការភ័យខ្លាច» ឬ «នឹងភ័យខ្លាចហើយដួលសន្លប់»
Exodus 15:16
ឃ្លាភ្ជាប់
លោកម៉ូសេនៅតែបន្តច្រៀងអំពីអារម្មណ៍
របស់ប្រជាជននៃប្រជាជាតិដទៃទៀតនៅពេលពួកគេឃើញប្រជារាស្ត្ររបស់ព្រះជាម្ចាស់។
ភាពភ័យខ្លាច និងភាពថប់បារម្ភបានគ្របសង្កត់លើគេ។
ពាក្យទាំងពីរនេះមានន័យថាការភ័យខ្លាច នឹងកើតមានលើពួកគេ។
ការបកប្រែផ្សេងទៀត «ការភ័យខ្លាចនឹងមកលើពួកគេ»
ភាពថប់បារម្ភ
ភាពថប់បារម្ភគឺជាការភ័យខ្លាចខ្លាំង ឬការព្រួយបារម្ភខ្លាំងចំពោះអ្វីមួយដែល
នឹងកើតឡើង ឬអាចនឹងកើតឡើង ។
ដោយព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គ
ព្រះហស្តរបស់ព្រះជាម្ចាស់តំណាងឲ្យកម្លាំងដ៏អស្ចារ្យរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «ដោយសារតែកម្លាំងដ៏អស្ចារ្យរបស់ព្រះអង្គ»
ពួកគនឹងបានដូចជាថ្មដែលនៅនឹងមួយកន្លែង
ទីអត្ថន័យដែលប្រហែលគឺ) «ពួកគេនឹងនៅស្ងៀមដូចដុំថ្ម» ឬ ទី២)
«ពួកគេនឹងគ្មានអារម្មណ៍ដូចដុំថ្ម»
Exodus 15:17
ព្រះអង្គបាននាំពួកគេ
កន្លែងដែលព្រះជាម្ចាស់ នឹងនាំពួកគេអាចត្រូវបានថ្លែងយ៉ាងច្បាស់។
ដោយសារលោកម៉ូសេមិនទាន់ទៅដល់ស្រុកកាណាននៅឡើយទេ ភាសាខ្លះនឹងប្រើ
ពាក្យ «យក» ជាជាងពាក្យ «នាំ» ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គនឹងយកប្រជាជនរបស់ព្រះអង្គទៅស្រុកកាណាន»
ហើយបានដាំពួកគេនៅលើភ្នំ
លោកម៉ូសេនិយាយអំពីព្រះជាម្ចាស់ប្រទានទឹកដីអោយប្រជារាស្ត្ររបស់ព្រះអង្គ
ប្រៀបដូចជាដើមឈើដែលព្រះជាម្ចាស់បានកំពុងដាំ។ ការបកប្រែផ្សេងទៀត
«តាំងទីលំនៅលើភ្នំ» ឬ «អនុញ្ញាតឱ្យពួកគេនៅលើភ្នំ»
ភ្នំនៃមរតករបស់ព្រះអង្គ
នេះសំដៅទៅលើភ្នំស៊ីយ៉ូននៅស្រុកកាណាន។
នៃមរតករបស់ព្រះអង្គ
លោកម៉ូសេនិយាយអំពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់
ដើើម្បីប្រទានដល់ប្រជារាស្ត្ររបស់ព្រះអង្គនៅលើភ្នំជារៀងរហូត
ដូចជាព្រះអង្គបានប្រគល់អោយពួកគេជាមរតក។ ការបកប្រែផ្សេងទៀត
«ដែលព្រះអង្គបានផ្តល់ឱ្យពួកគេជាមរតក»
ព្រះអង្គបានសង់ទីបរិសុទ្ធ។
ឃ្លាថា « បានសង់» សំដៅទៅលើអំណាចរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «ដែលព្រះអង្គបានកសាង ដោយអំណាចរបស់ព្រះអង្គ»
Exodus 15:19
ម៉ារាម ... លោកអ៊ើរ៉ុន
ម៉ារាមគឺជាបងស្រីរបស់លោកម៉ូសេ និងលោកអើរ៉ុន។
ក្រាប់
នេះគឺជាឧបករណ៍តន្ត្រីដូចជាស្គរតូចមួយ
ដែលមានបំណែកដែកលោហៈធាតុព័ទ្ធជុំវិញដែលធ្វើឱ្យមានសម្លេងនៅពេលគ្រវី។
មានជ័យជម្នះយ៉ាងត្រចះត្រចង់
«មានជ័យជម្នះយ៉ាងត្រចះត្រចង់ លើសត្រូវរបស់ព្រះអង្គ»។
មើលរបៀបដែលអ្នកបកប្រែនេះ [Exodus 15:1]
សេះ និងអ្នកជិះ ព្រះអង្គបានបោះពួកគេចូលទៅក្នុងសមុទ្រ។
ម៉ារាមបានច្រៀងអំពីព្រះជាម្ចាស់ បណ្តាលឱ្យសមុទ្រគ្របពីលើហើយលង់សេះ
និងអ្នកជិះដូចជាព្រះបានបោះពួកគេចូលទៅក្នុងសមុទ្រ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង [Exodus 15:1]
Exodus 15:22
លោកម៉ូសេបាននាំជនជាតិអ៊ីស្រាអែល
ពាក្យថា «អ៊ីស្រាអែល» តំណាងអោយប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «លោកម៉ូសេបានដឹកនាំប្រជាជនអ៊ីស្រាអែល»
ទីរហោស្ថានស៊ើរ ...ម៉ារ៉ា
យើងមិនដឹងទីតាំងពិតប្រាកដ នៃកន្លែងទាំងនេះទេ។
Exodus 15:24
បានរអ៊ូរទាំចំពោះលោកម៉ូសេ ហើយនិយាយថា
«មិនសប្បាយចិត្ត ហើយប្រាប់លោកម៉ូសេ» ឬ
«ប្រាប់ទៅលោកម៉ូសេដោយកំហឹង»
សម្លេងរបស់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា
ព្រះអម្ចាស់កំពុងមានបន្ទូលអំពីសម្លេងរបស់ទ្រង់ផ្ទាល់។ ការបកប្រែផ្សេងទៀត
«សម្លេងរបស់យើង»
ធ្វើតាមអ្វីដែលត្រឹមត្រូវនៅចំពោះព្រះភក្ត្រព្រះអង្គ
ឃ្លា «ព្រះភក្ត្រព្រះអង្គ » នៅទីនេះតំណាងឱ្យអ្វីដែលព្រះជាម្ចាស់គិត
ឬបានសម្រេចព្រះទ័យ។ ការបកប្រែផ្សេងទៀត
«ធ្វើនូវអ្វីដែលព្រះអម្ចាស់ចាត់ទុកថាត្រឹមត្រូវ»
យើងនឹងមិនធ្វើឲ្យមានជំងឺ
ព្រះមានបន្ទូលអំពី ការធ្វើឱ្យមនុស្សមានជំងឺដូចជាដាក់ជំងឺលើពួកគេ។
ការបកប្រែផ្សេងទៀត «យើងនឹងមិនបណ្តាលឱ្យអ្នកណាមួយ
ក្នុងចំណោមអ្នករាល់គ្នាមានជំងឺឡើយ»
Exodus 15:27
អេលីម
នេះគឺជាវាលខ្សាច់នៅទីរហោស្ថាន ជាកន្លែងដែលមានទឹក និងម្លប់ដើមឈើ។
ដប់ពីរ
«១២»
ចំនួនចិតសិប
«៧០»

---

16 [1]ប្រជាជននាំគ្នាដើរពីអេលីម ហើយសហគមន៍អ៊ីស្រាអែលទាំងមូលបានមកដល់ទីរហោស្ថានស៊ីន ដែលនៅចន្លោះអេលីប និងស៊ីណាយ នៅថ្ងៃទីដប់ប្រាំ
ខែទីពីរបន្ទាប់ពីពួកគេចេញដំណើរពីទឹកដីអេស៊ីប។[2]សហគមន៍អ៊ីស្រាអែលទាំងអស់រអ៊ូរទាំទាស់នឹងលោកម៉ូសេ និងលោកអ៊ើរ៉ុននៅទីរហោស្ថាន។
[3]ជនជាតិអ៊ីស្រាអែលប្រាប់ពួកគេថា៖ «បើទុកឲ្យយើងស្លាប់ដោយព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងទឹកដីអេស៊ីប ជាកន្លែងដែលយើងអង្គុយនៅក្បែរឆ្នាំងដែលមានសាច់
ហើយហូបនំប៉័ងយ៉ាងឆ្អែត។ ប៉ុន្តែ លោកបាននាំយើងចេញមកទីរហោស្ថាន ដើម្បីសម្លាប់សហគមន៍ទាំងមូលដោយភាពអត់ឃ្លានមែនទេ»។

generated on Wed Sep 10 16:16:32 2025

[4]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេថា៖ «យើងនឹងធ្វើឲ្យមានភ្លៀងធ្លាក់ពីស្ថានសួគ៌មកដល់អ្នករាល់គ្នា។ ប្រជាជនទាំងអស់ត្រូវចេញទៅ
ហើយប្រមូលមួយថ្ងៃមួយចំណែករាល់ថ្ងៃ ដើម្បីឲ្យយើងបានល្បងលជាមួយពួកគេ ឲ្យដឹងថាពួកគេដើរតាមច្បាប់របស់យើងឬយ៉ាងណា។
[5]វានឹងធ្លាក់ចុះមកក្នុងរយៈពេលប្រាំមួយថ្ងៃ ពួកគេត្រូវប្រមូលពីរដង លើសពីថ្ងៃធម្មតា ហើយពួកគេនឹងចម្អិនអ្វីដែលពួកគេប្រមូលបាន»។
[6]បន្ទាប់មក លោកម៉ូសេ និងលោកអើរ៉ុនប្រាប់ទៅប្រជាជនអ៊ីស្រាអែលទាំងអស់ថា៖ «នៅពេលល្ងាច អ្នករាល់គ្នានឹងដឹងថា
គឺជាព្រះអម្ចាស់ហើយដែលបាននាំអ្នករាល់គ្នាចេញពីអេស៊ីបមក។[7]នៅពេលព្រឹក អ្នកនឹងបានឃើញសិរីល្អរបស់ព្រះអម្ចាស់ ដ្បិត
ព្រះអង្គបានឮការរអ៊ូរទាំរបស់អ្នករាល់គ្នាទាស់នឹងព្រះអង្គ។ តើពួកយើងជានរណា ដែលអ្នករាល់គ្នាមករអ៊ូរទាំដាក់យើង?»[8]លោកម៉ូសេក៏បានប្រាប់ផងដែរថា៖
«អ្នករាល់គ្នានឹងបានដឹងពីការនេះ នៅពេលព្រះអម្ចាស់ប្រទានសាច់នៅពេលល្ងាច ហើយនិងនំប៉័ងនៅពេលព្រឹកដើម្បីចម្អែតអ្នករាល់គ្នា ដ្បិត
ព្រះអង្គបានឮការរអ៊ូរទាំដែលអ្នករាល់គ្នាបាននិយាយទាស់នឹងព្រះអង្គ។ តើបងអើរ៉ុន និងខ្ញុំជានរណា? ការរអ៊ូរទាំងរបស់អ្នករាល់គ្នាមិនមែនទាល់ជាមួយយើងទេ
គឺទាស់ជាមួយនឹងព្រះអម្ចាស់វិញ»។
[9]លោកម៉ូសេប្រាប់លោកអើរ៉ុនថា៖ «ចូរប្រាប់ប្រជាជននៅក្នុងសហគមន៍អ៊ីស្រាអែលទាំងអស់ថា៖ «ចូរចូលទៅជិតព្រះអម្ចាស់ ដ្បិត
ព្រះអង្គបានឮការរអ៊ូរទាំរបស់អ្នករាល់គ្នា»។[10]នៅគ្រានោះ នៅពេលលោកអើរ៉ុនប្រាប់ដល់សហគមន៍អ៊ីស្រាអែលទាំងអស់ថា ពួកគេត្រូវមើលឆ្ពោះទៅទីរហោស្ថាន
ហើយមើល៍ សិរីល្អរបស់ព្រះអម្ចាស់បានលេចមកនៅលើពពក។[11]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖
«យើងបានឮការរអ៊ូរទាំងរបស់ប្រជាជនអ៊ីស្រាអែល។[12]ចូរប្រាប់ដល់ពួកគេ ហើយនិយាយថា៖ «នៅពេលល្ងាចនេះ អ្នករាល់គ្នានឹងបានហូបសាច់
ហើយនៅពេលព្រឹកអ្នករាល់គ្នានឹងបានឆ្អែតដោយសារនំប៉័ង។ បន្ទាប់មក អ្នករាល់គ្នានឹងថា យើងគឺជាព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា។
[13]នៅពេលល្ងាចនោះមានសត្វក្រួចបានហើរចេញមក ហើយបានគ្របជំរំ។ នៅពេលព្រឹកមានទឹកសន្សើមធ្លាក់ចុះមកនៅជុំវិញជំរំ។[14]នៅពេលទឹកសន្សើមអស់
នៅលើផ្ទៃនៃទីរហោស្ថានមានគ្រាប់ល្អិតៗដូចព្រិលនៅលើដី។[15]នៅពេលជនជាតិអ៊ីស្រាអែលឃើញវា ពួកគេនិយាយទៅកាន់គ្នាទៅវិញទៅមកថា៖ «តើនេះជាអ្វី?»
ពួកគេមិនដឹងថាវាជាអ្វីទេ។ លោកម៉ូសេប្រាប់ពួកគេថា៖ «វាគឺជានំប៉័ងដែលព្រះអម្ចាស់ប្រទានឲ្យអ្នករាល់គ្នាហូប។
[16]នេះគឺជាសេចក្តីបង្គាប់ដែលព្រះអម្ចាស់ប្រទានដល់អ្នករាល់គ្នា គឺឲ្យម្នាក់ៗប្រមូល ល្មមសម្រាប់មនុស្សតែម្នាក់ឲ្យបានឆ្អែតប៉ុណ្ណោះ។
នេះគឺជារបៀបដែលអ្នករាល់គ្នាត្រូវប្រមូលវា គឺត្រូវប្រមូលល្មមសម្រាប់មនុស្សម្នាក់ៗដែលរស់នៅក្នុងត្រសាលរបស់អ្នករាល់គ្នា»។[17]ជនជាតិអ៊ីស្រាអែលក៏ធ្វើតាម។
អ្នកខ្លះប្រមូលបានច្រើន ហើយអ្នកខ្លះក៏ប្រមូលបានតិច។[18]នៅពេលដែលពួកគេវាល់វាជាមួយនឹងរង្វាល់ អស់អ្នកដែលប្រមូលបានច្រើនក៏គ្មានអ្វីនៅសល់ដែរ
ហើយអស់អ្នកដែលប្រមូលបានតិចក៏មិនខ្វះដែរ។ មនុស្សម្នាក់ៗត្រូវប្រមូលល្មមតាមតែសេចក្តីត្រូវការរបស់ពួកគេ។
[19]បន្ទាប់មក លោកម៉ូសេប្រាប់ដល់ពួកគេថា៖ «កុំឲ្យនរណាទុកវារហូតដល់ព្រឹកឡើយ»។[20]ប៉ុន្តែ ពួកគេមិនបានស្តាប់តាមលោកម៉ូសេទេ។ អ្នកខ្លះទុកវាខ្លះរហូតដល់ព្រឹក
ប៉ុន្តែ វាក៏កើតមានដង្កូវហើយមានក្លិនស្អុយផង។ នោះលោកម៉ូសេបានខឹងជាមួយនឹងពួកគេ។[21]ពួកគេបានប្រមូលវាមួយព្រឹកម្តងៗតែប៉ុណ្ណោះ។
មនុស្សម្នាក់ៗត្រូវប្រមូលល្មមដើម្បីនឹងហូបសម្រាប់តែថ្ងៃនោះប៉ុណ្ណោះ។ នៅពេលថ្ងៃក្តៅឡើង វាក៏រលាយអស់ទៅ។
[22]នៅថ្ងៃទីប្រាំមួយ ពួកគេបានប្រមូលនំប៉័ងគុណនឹងពីរ ពីរង្វាល់សម្រាប់មនុស្សម្នាក់ៗ។ អ្នកដឹកនាំនៅក្នុងសហគមន៍ទាំងអស់បានចូលមក
ហើយប្រាប់ការនេះដល់លោកម៉ូសេ។[23]គាត់ប្រាប់ពួកគេវិញថា៖ «នេះគឺជាអ្វីដែលព្រះអម្ចាស់បានមានបន្ទូល ថ្ងៃស្អែកត្រូវឈប់សម្រាក ជាថ្ងៃសប្ប័ទដ៏វិសុទ្ធ
ដើម្បីថ្វាយកិត្តិយសដល់ព្រះអម្ចាស់។ ចូរដុតអ្វីដែលអ្នកចង់ដុត ហើយស្ងោអ្វីដែលអ្នកចង់ស្ងោ។ ហើយអ្វីដែលនៅសល់ ចូរញែកវាដោយឡែករហូតដល់ពេលព្រឹក»។
[24]ដូច្នេះ ពួកគេក៏ញែកដោយឡែករហូតដល់ពេលព្រឹក ដូចលោកម៉ូសេបានបង្គាប់ដល់ពួកគេ។ ហើយវាអត់ស្អុយ ហើយក៏គ្មានដង្កូវនៅក្នុងវាដែរ។[25]លោកម៉ូសេប្រាប់ថា៖
«ចូរហូបអាហារនោះនៅថ្ងៃនេះ ដ្បិតថ្ងៃនេះ គឺជាថ្ងៃដែលត្រូវរក្សាទុកជាថ្ងៃសប្ប័ទថ្វាយកិត្តិយសដល់ព្រះអម្ចាស់។ ថ្ងៃនេះអ្នករាល់គ្នាមិនត្រូវទៅរកអ្វីនៅស្រែចម្ការឡើយ។
[26]អ្នកនឹងប្រមូលវាក្នុងរយៈពេលប្រាំមួយថ្ងៃ ប៉ុន្តែ ថ្ងៃទីប្រាំពីរគឺជាសប្ប័ទ។ នៅថ្ងៃសប្ប័ទ នឹងគ្មាននំម៉ាណាទេ»។[27]នៅថ្ងៃសប្ប័ទ មានអ្នកខ្លះចេញទៅប្រមូលនំម៉ាណា
ប៉ុន្តែគ្មាននំម៉ាណាទេ។
[28]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «តើអ្នករាល់គ្នានៅបដិសេធមិនធ្វើតាមបង្គាប់ និងច្បាប់របស់យើងដល់កាលណាទៀត?[29]មើល៍
ព្រះអម្ចាស់បានប្រទានថ្ងៃសប្ប័ទដល់អ្នករាល់គ្នា។ ដូច្នេះ នៅថ្ងៃទីប្រាំមួយ ព្រះអង្គបានប្រទាននំប៉័ងដល់អ្នករាល់គ្នាសម្រាប់ពីរថ្ងៃ។
អ្នករាល់គ្នាម្នាក់ៗត្រូវនៅកន្លែងរបស់ខ្លួន មិនត្រូវឲ្យនរណាចេញក្រៅពីកន្លែងរបស់គាត់នៅថ្ងៃទីប្រាំពីរឡើយ»។[30]ដូច្នេះ មនុស្សត្រូវសម្រាកនៅថ្ងៃទីប្រាំពីរ។
[31]ជនជាតិអ៊ីស្រាអែលបានហៅអាហារនោះថា៖ «ម៉ាណា»។ វាមានពណ៌សដូចជាគ្រាប់ល្ង ហើយរសជាតិរបស់វាដូចជានំធ្វើពីទឹកឃ្មុំ។[32]លោកម៉ូសេប្រាប់ថា៖
«នេះគឺជាអ្វីដែលព្រះអម្ចាស់បានបង្គាប់ «ចូរដាក់ម៉ាណាក្នុងភាជន៍មួយឲ្យពេញ ហើយរក្សាទុក សម្រាប់ឲ្យជនជាតិអ៊ីស្រាអែលនៅជំនាន់ក្រោយ ឃើញអាហារដែលយើង
ឲ្យអ្នករាល់គ្នាហូប ក្នុងទីរហោស្ថាន បន្ទាប់ពីយើងនាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីប»។
[33]លោកម៉ូសេប្រាប់លោកអើរ៉ុនថា៖ «ចូរយកឆ្នាំង ហើយដាក់ម៉ាណាចូលទៅក្នុងវា។ ចូររក្សាវាទុកថ្វាយព្រះអម្ចាស់
ដើម្បីឲ្យជនជាតិអ៊ីស្រាអែលនៅជំនាន់ក្រោយបានឃើញ»។[34]ដូច ព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ លោកអើរ៉ុនបានរក្សាវាទុកនៅជិតហិបនៃសម្ពន្ធមេត្រី។
[35]ជនជាតិអ៊ីស្រាអែលហូបម៉ាណាអស់រយៈពេលសែសិបឆ្នាំ រហូតពួកគេទៅដល់ទឹកដីដែលមានមនុស្សរស់នៅ។
ពួកហូបវារហូតដល់ពួកគេបានទៅដល់ព្រំប្រទល់ទឹកដីកាណាន។[36]រីឯរង្វាល់សម្រាប់វាល់ម៉ាណានោះ គឺមួយភាគដប់នៃអេផា។

Exodus 16:1

ទីរហោស្ថានស៊ីន

ពាក្យថាស៊ីននៅទីនេះគឺជាឈ្មោះភាសាហេព្រើរនៃទីរហោស្ថាន។
វាមិនមែនជាពាក្យអង់គ្លេស «បាប» ទេ។

នៅថ្ងៃទីដប់ប្រាំ ខែទីពីរ

ពេលវេលានេះស្របគ្នានៅចុងខែមេសា
និងដើមខែឧសភានៅលើប្រតិទិនលោកខាងលិច។ ការបកប្រែផ្សេងទៀត «នៅថ្ងៃទី
១៥ នៃខែទី ២»

សហគមន៍អ៊ីស្រាអែលទាំងអស់

«ប្រជាជនអ៊ីស្រាអែលទាំងអស់» នេះគឺជាការធ្វើឱ្យមានលក្ខណៈទូទៅ។
លោកម៉ូសេ និងលោកអើរ៉ុនមិនបានរអ៊ូរទាំ។ ការបកប្រែផ្សេងទៀត
«ជនជាតិអ៊ីស្រាអែល»

រអ៊ូរ

«បានខឹងហើយបាននិយាយ»

បើទុកឲ្យយើងស្លាប់

នេះគឺជារបៀបនៃការនិយាយថា ពួកគេប្រាថ្នាថាពួកគេបានស្លាប់។
ការបកប្រែផ្សេងទៀត «យើងប្រាថ្នាថាយើងបានស្លាប់»

ដោយព្រះហស្តរបស់ព្រះអម្ចាស់

ឃ្លាដែលថា «ព្រះហស្តរបស់ព្រះអម្ចាស់» តំណាងសកម្មភាពរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ដោយសកម្មភាពរបស់ព្រះអម្ចាស់»

Exodus 16:4

យើងនឹងធ្វើឲ្យមានភ្លៀងធ្លាក់ពីស្ថានសួគ៌មកដល់អ្នករាល់គ្នា។
ព្រះជាម្ចាស់មានបន្ទូលអំពីអាហារ ដែលធ្លាក់មកពីលើមេឃដូចជាភ្លៀង។
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើឱ្យនំប៉័ងចុះពីលើមេឃដូចភ្លៀង» ឬ
«យើងនឹងធ្វើឱ្យនំប៉័ងធ្លាក់ពីលើមេឃ»

នំប៉័ង

ព្រះជាម្ចាស់មានបន្ទូលអំពីអាហារ ដែលព្រះអង្គនឹងបញ្ជូនដូចជានំប៉័ង។
ជនជាតិអ៊ីស្រាអែលបរិភោគអាហារនេះជារៀងរាល់ថ្ងៃ
ដូចពួកគេបានបរិភោគនំប៉័ងរាល់ថ្ងៃពីមុនដែរ។ ការបកប្រែផ្សេងទៀត «អាហារ» ឬ
«អាហារដូចជានំប៉័ង»

ដើរតាមច្បាប់របស់យើង

ព្រះជាម្ចាស់មានបន្ទូល អំពីការធ្វើតាមច្បាប់របស់ទ្រង់ដូចជាការដើរតាមច្បាប់នោះ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «គោរពច្បាប់របស់យើង» ឬ
«រស់នៅស្របតាមច្បាប់របស់យើង»
ច្បាប់របស់យើង
«បង្គាប់របស់យើង»
វានឹងធ្លាក់ចុះមកក្នុងរយៈពេលប្រាំមួយថ្ងៃ ពួកគេ
«វានឹងកើតឡើងនៅថ្ងៃទីប្រាំមួយដែលពួកគេ» ឬ «នៅថ្ងៃទីប្រាំមួយពួកគេ»
រយៈពេលប្រាំមួយថ្ងៃ
«នៅថ្ងៃទី ៦»
ពីរដង
«ពីរពេល» ឬ «២ ដង»
Exodus 16:6
តើពួកយើងជានរណា ដែលអ្នករាល់គ្នាមករអ៊ូរទាំដាក់យើង?
លោកម៉ូសេ និងលោកអើរ៉ុនបានប្រើសំណួរនេះដើម្បីបង្ហាញប្រជាជនថា
វាជាការល្ងីល្ងើក្នុងការរអ៊ូរទាំប្រឆាំងនឹងពួកគេ។ ការបកប្រែផ្សេងទៀត
«យើងមិនមានអំណាចគ្រប់គ្រាន់សម្រាប់អ្នកដើម្បីមករអ៊ូរទាំប្រឆាំងនឹងយើងទេ»
។ ឬ «វាជាការល្ងីល្ងើក្នុងការមករអ៊ូរទាំប្រឆាំងនឹងយើង
ពីព្រោះយើងមិនអាចធ្វើអ្វីដែលអ្នកចង់បានទេ» ។
នំប៉័ង
លោកម៉ូសេនិយាយអំពីអាហារដែលព្រះជាម្ចាស់នឹងបញ្ជូនដូចជានំប៉័ង។
ជនជាតិអ៊ីស្រាអែលបរិភោគអាហារនេះជារៀងរាល់ថ្ងៃដូចពួកគេបានបរិភោគនំប៉័ងរាល់ថ្ងៃពីមុនមកដែរ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១៦: ៤ ។ ការបកប្រែផ្សេងទៀត
«អាហារ» ឬ «អាហារដូចជានំប៉័ង»
តើបងអ៊ើរ៉ុន និងខ្ញុំជានរណា?
លោកម៉ូសេបានប្រើសំណួរនេះ ដើម្បីបង្ហាញប្រជាជនថាគាត់
និងលោកអើរ៉ុនមិនមានអំណាចផ្តល់ឱ្យពួកគេនូវអ្វីដែលពួកគេចង់បានទេ។
ការបកប្រែផ្សេងទៀត «លោកអើរ៉ុន
និងខ្ញុំមិនអាចផ្តល់ឱ្យអ្នករាល់គ្នានូវអ្វីដែលអ្នកចង់បានទេ»។
ការអ៊ូរទាំរបស់អ្នករាល់គ្នាមិនមែនទាល់ជាមួយយើងទេ គឺទាស់ជាមួយនឹងព្រះអម្ចាស់វិញ។
ប្រជាជនមានការអ៊ូរទាំប្រឆាំងនឹងលោកម៉ូសេ
និងលោកអើរ៉ុនដែលជាអ្នកបម្រើរបស់ព្រះអម្ចាស់។
ដូច្នេះតាមរយៈការអ៊ូរទាំប្រឆាំងនឹងពួកគេប្រជាជនពិតជាមានការអ៊ូរទាំប្រឆាំងនឹងព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ការអ៊ូរទាំរបស់អ្នកពិតជាមិនប្រឆាំងនឹងយើងទេ
ពួកគេប្រឆាំងនឹងព្រះអម្ចាស់ពីព្រោះយើងជាអ្នកបម្រើរបស់ព្រះអង្គ»។
Exodus 16:9
នៅគ្រានោះ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
ព្រឹត្តិការណ៍សំខាន់នៅទីនេះគឺប្រជាជនមើលឃើញសិរីរុងរឿងរបស់ព្រះអម្ចាស់។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
មើល៍
ពាក្យថា «មើល៍»
នៅទីនេះបង្ហាញថាប្រជាជនបានឃើញអ្វីដែលគួរអោយចាប់អារម្មណ៍។
នំប៉័ង
ព្រះមានបន្ទូលអំពីអាហារដែលលោកនឹងបញ្ជូនដូចជានំប៉័ង។
ជនជាតិអ៊ីស្រាអែលបរិភោគអាហារនេះជារៀងរាល់ថ្ងៃ
ដូចពួកគេបានបរិភោគនំប៉័ងរាល់ថ្ងៃមុនពេលនោះដែរ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១៦: ៤ ។ ការបកប្រែផ្សេងទៀត
«អាហារ» ឬ «អាហារដូចជានំប៉័ង»
Exodus 16:13
នៅពេល ... នោះ
ឃ្លានេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ផ្នែកសំខាន់នៃព្រឹត្តិការណ៍។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
សត្វក្រួច
ទាំងនេះគឺជាបក្សីតូច។
ដូចព្រិល
អ្នកអានដើមដឹងថាព្រិលមានសភាពយ៉ាងម៉េចដូច្នេះឃ្លានេះនឹងជួយឱ្យពួកគេយល់ពីរបៀបដែលវាត្រូវបានធ្វើឡើង
ល្អិតៗស្តើងដូច។ ព្រិលគឺជាទឹកសន្សឹមមកដែលរាយប៉ាយកកនៅលើដី។
វាគឺស្អាត។ ការបកប្រែផ្សេងទៀត «ដែលមើលទៅដូចជាព្រិល» ឬ
«នោះល្អដូចជាព្រិល»
នំប៉័ង
លោកម៉ូសេនិយាយអំពីអាហារដែលព្រះជាម្ចាស់បានចាត់ដូចជានំប៉័ង។
ជនជាតិអ៊ីស្រាអែលបរិភោគអាហារនេះជារៀងរាល់ថ្ងៃ
ដូចពួកគេបានបរិភោគនំប៉័ងរាល់ថ្ងៃពីមុនមកដែរ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១៦: ៤ ។ ការបកប្រែផ្សេងទៀត
«អាហារ» ឬ «អាហារដូចជានំប៉័ង»
Exodus 16:16
ឃ្លាភ្ជាប់
លោកម៉ូសេបន្តប្រាប់ប្រជាជនអំពីអាហារ
ដែលព្រះជាម្ចាស់កំពុងផ្តត់ផ្គង់សម្រាប់ពួកគេ។
រង្វាល់
«ពីរលីត្រ»
ក៏មិនខ្វះដែរ
«មិនខ្វះទាល់តែសោះ» ឬ «មានគ្រប់គ្រាន់»
Exodus 16:22
នៅគ្រានោះ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។ ខ ១៦:
២២-៣០ ប្រាប់អំពីអ្វីដែលប្រជាជនបានធ្វើទាក់ទង នឹងនំម៉ាណានៅថ្ងៃទី ៦ និង ៧
នៃសប្តាហ៍។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់សម្គាល់នេះជាផ្នែកថ្មីនៃរឿងអ្នកអាចពិចារណាប្រើវានៅទីនេះ។
«នៅថ្ងៃទី ៦»
ពីរ
«ពីរពេល» ឬ «២ ដង»
នំប៉័ង
នេះសំដៅទៅលើនំប៉័ងដែលបានលេចឡើងជាដុំស្តើងនៅលើដីរៀងរាល់ព្រឹក។
ឈប់សម្រាក
«ម៉ឺងមាត់» ឬ «ស្ងាត់និងគិត»
Exodus 16:24
ហើយវាអត់ស្អុយ
«មិនរលួយ»
ថ្ងៃសប្ប័ទ គឺជាថ្ងៃដែលត្រូវរក្សាទុកជាថ្ងៃសប្ប័ទថ្វាយកិត្តិយសដល់ព្រះអម្ចាស់។
ថ្ងៃនេះជាថ្ងៃសប្ប័ទ ហើយត្រូវប្រើសម្រាប់កិត្តិយសដល់ព្រះអម្ចាស់ប៉ុណ្ណោះ។
Exodus 16:26
ប៉ុន្តែ ថ្ងៃទីប្រាំពីរគឺជាសប្ប័ទ។
«ប៉ុន្តែនៅថ្ងៃទីប្រាំពីរ»
នំម៉ាណា
នេះជាឈ្មោះដែលជនជាតិអ៊ីស្រាអែលដាក់ឲ្យ
នំប៉័ងដែលព្រះអម្ចាស់ធ្វើឲ្យលិចឡើងសម្រាប់ពួកគេរៀងរាល់ពេលព្រឹក។
ប៉ុន្តែគ្មាននំម៉ាណាទេ។
«ពួកគេរកមិនឃើញនំម៉ាណាទេ»
Exodus 16:28
ព័ត៌មានទូទៅ
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេ ប៉ុន្តែពាក្យ «អ្នក»
សំដៅលើជនជាតិអ៊ីស្រាអែលជាទូទៅ។
តើអ្នករាល់គ្នានៅបដិសេធមិនធ្វើតាមបង្គាប់ និងច្បាប់របស់យើងដល់កាលណាទៀត?
ព្រះជាម្ចាស់បានប្រើសំណួរនេះ
ដើម្បីវាយដំប្រជាជនពីព្រោះពួកគេមិនគោរពច្បាប់របស់ទ្រង់។ការបកប្រែផ្សេងទៀត
«អ្នកនៅតែមិនរក្សាបទបញ្ញត្តិនិងច្បាប់របស់យើង!»
ធ្វើតាមបង្គាប់ និងច្បាប់របស់យើង
«ដើម្បីគោរពតាមបទបញ្ជា និងច្បាប់របស់យើង»
ព្រះអម្ចាស់បានប្រទានថ្ងៃសប្ប័ទដល់អ្នករាល់គ្នា។
ព្រះអម្ចាស់មានបន្ទូលអំពីការបង្រៀនមនុស្សអោយឈប់សម្រាក
នៅថ្ងៃឈប់សម្រាកដូចជាថ្ងៃឈប់សម្រាកគឺជាអំណោយ។ ការបកប្រែផ្សេងទៀត
«យើង ជាព្រះអម្ចាស់បានបង្រៀនអ្នកឱ្យសម្រាកនៅថ្ងៃថ្ងៃសប្ប័ទ»
«ថ្ងៃទី ៦ ... ថ្ងៃទី២ ... ថ្ងៃទី ៧»
នំប៉័ង
នេះសំដៅទៅលើនំប៉័ងដែលបានលេចឡើងជាម្សៅស្តើងនៅលើដីរៀងរាល់ព្រឹក។
Exodus 16:31

generated on Wed Sep 10 16:16:32 2025

ម៉ាណា
នេះជាឈ្មោះដែលជនជាតិអ៊ីស្រាអែល
ផ្តល់ឲ្យនំបុ័ងដែលព្រះអម្ចាស់ប្រទានអោយពួកគេនៅពេលព្រឹក។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងម៉ោង ១៦:២៦ ។
គ្រាប់ល្ង
គ្រាប់ល្ង ត្រូវបានគេស្គាល់ថាជាគ្រប់ល្ងខ្មៅ ។ មនុស្សយកទៅហាលឲ្យស្ងួត
ហើយកិនវាឱ្យទៅជាម្សៅហើយដាក់វានៅក្នុងអាហារដើម្បីឱ្យវាមានរសជាតិ។
ជានំ
នំស្តើង ឬស្វិត
រង្វាល់
«២ លីត្រ»
នំប័ុង
នេះសំដៅទៅលើនំប័ុងដែលបានលេចឡើងជាដុំស្តើងនៅលើដីរៀងរាល់ព្រឹក។
Exodus 16:33
រង្វាល់សម្រាប់វាល់ម៉ាណានោះ គឺមួយភាគដប់នៃអេផា។
រង្វាល់និងអេផាមួយគឺជាធុងសម្រាប់វាស់បរិមាណ។
អ្នកអានដើមប្រហែលជាបានដឹងថា អេផាមានចំនួនប៉ុន្មាន។
ប្រយោគនេះអាចជួយពួកគេឱ្យដឹងថារង្វាល់មានចំនួនប៉ុន្មាន។
សម្រាប់ភាសាដែលមិនប្រើចំណែកនេះអាចត្រូវបានប្រើឡើងវិញ។
ការបកប្រែផ្សេងទៀត « មួយភាគដប់នៃរង្វាល់ស្មើនឹងមួយអេផា»
រង្វាល់
«ពីរលីត្រ»

17 [1]នៅក្នុងសហគមន៍អ៊ីស្រាអែលទាំងមូលបានធ្វើដំណើរពីទីរហោស្ថានស៊ីន តាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់។ ពួកគេបោះជំរំនៅរេផីឌីម ប៉ុន្តែ
នៅទីនោះគ្មានទឹកសម្រាប់ប្រជាជនឲ្យប្រជាជនផឹក។[2]ដូច្នេះ ប្រជាជនក៏បន្ទោសលោកម៉ូសេ ដោយព្រោះគ្មានទឹកផឹក ដោយនិយាយថា៖ «សូមឲ្យទឹកយើងផឹកផង»។
លោកម៉ូសេប្រាប់ថា៖ «ហេតុអ្វីបានអ្នករាល់គ្នាឈ្លោះជាមួយខ្ញុំ? ហេតុអ្វីបានជាអ្នករាល់គ្នាល្បងលព្រះអម្ចាស់ដូច្នេះ?»[3]ប្រជាជនស្រេកទឹកយ៉ាងខ្លាំង
ហើយពួកគេរអ៊ូរទាំទាស់នឹងលោកម៉ូសេ។ ពួកគេនិយាយថា៖ «ហេតុអ្វីបានជាលោកនាំពួកយើងចេញពីអេស៊ីប? ដើម្បីសម្លាប់យើង និងកូនចៅយើង
ព្រមទាំងហ្វូងសត្វរបស់យើងដោយការស្រេកទឹកដូច្នេះ?»
[4]បន្ទាប់មក លោកម៉ូសេបានអំពាវនាវរកព្រះអម្ចាស់ថា៖ «តើឲ្យទូលបង្គំធ្វើយ៉ាងដូចម្តេចជាមួយប្រជាជននេះ? ពួកគេជិតចោលទូលបង្គំនឹងដុំថ្មហើយ»។
[5]ព្រះអម្ចាស់មានបន្ទូលទៅលោកម៉ូសេថា៖ «ចូរទៅមុខប្រជាជន ហើយនាំពួកចាស់ទុំអ៊ីស្រាអែលខ្លះទៅជាមួយអ្នកផង។ ចូរយកដំបងដែលអ្នកវាយទន្លេទៅជាមួយអ្នក
ហើយចេញទៅ។[6]យើងនឹងឈរនៅចំពោះអ្នកទីនោះ នៅលើថ្មឯហារ៉ែប ហើយអ្នកត្រូវវាយថ្ម។ ទឹកនឹងចេញពីវាមក ដើម្បីឲ្យប្រជាជនបានផឹក»។ បន្ទាប់មក
លោកម៉ូសេក៏បានធ្វើដូច្នោះ នៅចំពោះមុខរបស់ពួកចាស់ទុំអ៊ីស្រាអែល។[7]គាត់បានហៅទីនោះថា ម៉ាសា និងមេរីបា ព្រោះជនជាតិអ៊ីស្រាអែលរអ៊ូរទាំ
ហើយដោយសារពួកគេបានល្បងលព្រះអម្ចាស់ដោយពោលថា៖ «តើព្រះអម្ចាស់នៅជាមួយយើងឬអត់?»
[8]បន្ទាប់មក ទាហានរបស់ប្រជាជនអាម៉ាឡេកបានមក ហើយបានវាយអ៊ីស្រាអែលនៅឯរេផិឌីម។[9]ដូច្នេះ លោកម៉ូសេបានប្រាប់លោកយ៉ូស្វេថា៖
«ចូរជ្រើសរើសពួកប្រុសៗមួយចំនួន ហើយចេញក្រៅ។ ប្រយុទ្ធជាមួយអាម៉ាឡេក។ ស្អែកយើងនឹងឈរនៅលើកំពូលភ្នំ
ជាមួយនឹងដំបងរបស់ព្រះជាម្ចាស់នៅនឹងដៃរបស់យើង»។[10]ដូច្នេះ លោកយ៉ូស្វេបានប្រយុទ្ធជាមួយអាម៉ាឡេក ដូចលោកម៉ូសេបានបង្គាប់ ក្នុងពេលនោះ លោកម៉ូសេ
លោកអ៊ើរ៉ុន និងលោកហ៊ើរកំពុងឡើងទៅលើកំពូលភ្នំ។
[11]អំឡុងពេលដែលលោកម៉ូសេកាន់ដំបងនៅនឹងដៃរបស់គាត់នោះ ជនជាតិអ៊ីស្រាអែលឈ្នះ ហើយនៅពេលគាត់ដាក់ដៃចុះសម្រាក អាម៉ាឡេកមានប្រៀបជាងវិញ។
[12]នៅពេលដៃរបស់លោកម៉ូសេចាប់ផ្តើមអស់កម្លាំង លោកអ៊ើរ៉ុន និងលោកហ៊ើរបានយកថ្ម ហើយដាក់វាពីក្រោមគាត់ ឲ្យគាត់អង្គុយលើថ្មនោះ។ ក្នុងពេលដដែលនោះ
លោកអ៊ើរ៉ុន និងហ៊ើរបានលើកដៃគាត់ឡើង ម្នាក់ម្ខាងលោកម៉ូសេ ហើយម្នាក់ទៀតនៅម្ខាងទៀតនៃរបស់គាត់។ ដូច្នេះ
ដៃរបស់លោកម៉ូសេអាចលើកឡើងរហូតដល់ថ្ងៃលិច។[13]នោះ លោកយ៉ូស្វេបានយកជ័យជម្នះលើប្រជាជនអាម៉ាឡេកដោយដាវ។
[14]ព្រះអម្ចាស់មានបន្ទូលនឹងលោកម៉ូសេថា៖ «ចូរសរសេរការនេះចុះនៅក្នុងសៀវភៅ ហើយអានវាឲ្យលោកយ៉ូស្វេស្តាប់ ពីព្រោះ យើងនឹងលុបបំបាត់ជនជាតិអាម៉ាឡេកឲ្យ
អស់ពីផែនដី ឥតឲ្យនរណានឹកចាំពីពួកគេទៀតឡើយ»។[15]បន្ទាប់មក លោកម៉ូសេបានសង់អាសនៈមួយ ហើយគាត់ហៅកន្លែងនោះថា៖ «ព្រះអម្ចាស់ជាទង់ជ័យរបស់ខ្ញុំ»។
[16]គាត់និយាយថា៖ «ដ្បិត មានដៃបានលើកឡើងនៅចំពោះបល្ល័ង្ករបស់ព្រះអម្ចាស់ នោះព្រះអម្ចាស់បានធ្វើសង្គ្រាមជាមួយនឹងអាម៉ាឡេក ពីមួយជំនាន់ទៅមួយជំនាន់»។

Exodus 17:1
ទីរហោស្ថានស៊ីន
ពាក្យថាស៊ីននៅទីនេះ គឺជាឈ្មោះភាសាហេព្រើរនៃទីរហោស្ថាន។
វាមិនមែនជាពាក្យអង់គ្លេស «បាប» ទេ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១៦: ១ ។
រេផីឌីម
នេះមានន័យថា « កន្លែងសម្រាក»
ដែលជាកន្លែងដើម្បីសម្រាកលើការធ្វើដំណើរឆ្ងាយឆ្លងកាត់ទីរហោស្ថាន។
«ហេតុអ្វីបានអ្នករាល់គ្នាឈ្លោះជាមួយខ្ញុំ? ហេតុអ្វីបានជាអ្នករាល់គ្នាល្បងលព្រះអម្ចាស់ដូច្នេះ?»
លោកម៉ូសេប្រើសំណួរទាំងនេះដើម្បីស្តីបន្ទោសប្រជាជន។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរឈ្លោះជាមួយខ្ញុំទេ អ្នកមិនគួរល្បងលព្រះអម្ចាស់ទេ!»
ដើម្បីសម្លាប់យើង និងកូនចៅយើង ព្រមទាំងហ្វូងសត្វរបស់យើងដោយការស្រេកទឹកដូច្នេះ?
ប្រជាជនប្រើសំណួរនេះដើម្បីចោទប្រកាន់លោកម៉ូសេថាចង់សម្លាប់ពួកគេ។
ការបកប្រែផ្សេងទៀត «អ្នកបាននាំយើងចេញពីទីនេះដើម្បីសម្លាប់យើងនិងកូនៗ
និងហ្វូងសត្វរបស់យើងដោយមិនអនុញ្ញាតឱ្យយើងទឹកផឹកទាល់តែសោះតែប៉ុណ្ណោះ!»
Exodus 17:4
ម៉ាសា
កន្លែងនៅវាលខ្សាច់ដែលឈ្មោះរបស់វាមានន័យថា «ការសាកល្បង»
មេរីបា
កន្លែងនៅវាលខ្សាច់ដែលមានឈ្មោះថា « រអ៊ូរទាំ»
Exodus 17:8
រេផិឌីម
នេះជាឈ្មោះកន្លែងនៅវាលខ្សាច់។
ដូច្នេះ លោកយ៉ូស្វេបានប្រយុទ្ធជាមួយអាម៉ាឡេក
លោកយ៉ូស្វេតំណាង ជនជាតិអ៊ីស្រាអែលដែលគាត់បានដឹកនាំទៅប្រយុទ្ធ។
ការបកប្រែផ្សេងទៀត «ដូច្នេះលោកយ៉ូស្វេ
និងទាហានដែលគាត់បានជ្រើសរើសបានប្រយុទ្ធ នឹងជនជាតិអាម៉ាឡេក»
លោកហ៊ើរ
លោកហ៊ើរជាមិត្តសំឡាញ់របស់លោកម៉ូសេ និងអ៊ើរ៉ុន។
Exodus 17:11
ជនជាតិអ៊ីស្រាអែលឈ្នះ ...អាម៉ាឡេកមានប្រៀបជាងវិញ។អាម៉ាឡេកមានប្រៀបជាងវិញ។
ពាក្យថា «អ៊ីស្រាអែល» និង «អាម៉ាឡេក»
តំណាងឱ្យអ្នកប្រយុទ្ធមកពីក្រុមទាំងនោះ។ ការបកប្រែផ្សេងទៀត «
អ្នកប្រយុទ្ធអ៊ីស្រាអែលកំពុងតែឈ្នះ...
អ្នកប្រយុទ្ធអាម៉ាឡេកចាប់មានប្រៀបជាងវិញ»
ដៃរបស់លោកម៉ូសេចាប់ផ្តើមអស់កម្លាំង
អ្នកនិពន្ធសរសេរអំពីដៃរបស់លោកម៉ូសេអស់កម្លាំងដូចជាដៃរបស់គាត់ធ្ងន់។
ការបកប្រែផ្សេងទៀត «ដៃត្រឡប់ជាអស់កម្លាំង»
ដោយដាវ
ដាវតំណាងឱ្យការប្រយុទ្ធ។ ការបកប្រែផ្សេងទៀត «នៅក្នុងការប្រយុទ្ធ»
Exodus 17:14
យើងនឹងលុបបំបាត់ជនជាតិអាម៉ាឡេកឲ្យអស់ពីផែនដី
ព្រះជាម្ចាស់មានបន្ទូលអំពីការបំផ្លាញជនជាតិអាម៉ាឡេក
ដូចជាព្រះអង្គកំពុងលុបបំបាត់ការចងចាំរបស់ប្រជាជនពីជនជាតិអាម៉ាឡេក។
នៅពេលមនុស្សមួយក្រុមត្រូវបានបំផ្លាញទាំងស្រុង
គ្មានអ្វីត្រូវរម្លឹកប្រជាជនអំពីពួកគេទេ។ ការបកប្រែផ្សេងទៀត
«យើងនឹងបំផ្លាញជនជាតិអាម៉ាឡេកទាំងស្រុង»
មានដៃបានលើកឡើង

generated on Wed Sep 10 16:16:32 2025

មនុស្សនឹងលើកដៃឡើង នៅពេលពួកគេបានសន្យា
ឬការសន្យាដូច្នេះជាការលើកដៃឡើងតំណាងឱ្យការសន្យា។ ការបកប្រែផ្សេងទៀត «ការសន្យាត្រូវបានធ្វើឡើង»
មានដៃបានលើកឡើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត « ព្រះអម្ចាស់លើកដៃទ្រង់ឡើង» ឬ « ព្រះអម្ចាស់បានសន្យាយ៉ាងម៉ឺងម៉ាត់»
ជនជាតិអាម៉ាឡេក
នេះសំដៅទៅលើជនជាតិអាម៉ាឡេក។ ការបកប្រែផ្សេងទៀត « អាម៉ាឡេក»

18 [1]លោកយេត្រូ ជាបូជាចារ្យរបស់ម៉ាឌាន ត្រូវជាឪពុកក្មេករបស់លោកម៉ូសេ បានឮពីកិច្ចការទាំងអស់ដែលព្រះជាម្ចាស់បានធ្វើជាមួយលោកម៉ូសេ
និងជាមួយជនជាតិអ៊ីស្រាអែល។ គាត់បានឮថា ព្រះអម្ចាស់បាននាំជនជាតិអ៊ីស្រាអែលចេញពីអេស៊ីប។[2]លោកយេត្រូវ ឪពុកក្មេករបស់លោកម៉ូសេ បាននាំនាងស្រី
សេផ្ទរ៉ា ជាភរិយារបស់លោកម៉ូសេ ហើយក្រោមមកបានចាត់នាងឲ្យទៅផ្ទះវិញ[3]ហើយនាងមានកូនប្រុសពីរនាក់ កូនម្នាក់ឈ្មោះ គើសម ដ្បិត លោកម៉ូសេគិតថា «ខ្ញុំជាជន
បរទេសដែលរស់នៅក្នុងស្រុកដទៃ»។[4]ហើយម្នាក់ទៀតឈ្មោះថា អេលាស៊ើរ ដ្បិត លោកម៉ូសេបានមានប្រសាសន៍ថា៖ «ព្រះរបស់បុព្វបុរសរបស់ខ្ញុំបានជួយខ្ញុំ ព្រះអង្គបាន
សង្គ្រោះខ្ញុំឲ្យរួចពីមុខដាវរបស់ស្តេចផារ៉ោន»។
[5]លោកយេត្រូ ឪពុកក្មេកលោកម៉ូសេ បានមកជាមួយកូនប្រុសរបស់លោកម៉ូសេ និងភរិយារបស់លោកម៉ូសេ នៅទីរហោស្ថាន
ជាកន្លែងដែលគាត់បោះជំរំនៅឯភ្នំរបស់ព្រះជាម្ចាស់។[6]គាត់មានប្រសាសន៍ទៅលោកម៉ូសេថា៖ «ខ្ញុំជាឪពុកក្មេក ឈ្មោះយេត្រូ ខ្ញុំបាននាំប្រពន្ធ និងកូនប្រុសទាំង
ពីររបស់លោក មកជួបលោក»។
[7]លោកម៉ូសេបានចេញក្រៅជួបឪពុកក្មេករបស់គាត់ ហើយលុតជង្គង់ចុះ ហើយថើបគាត់។ ពួកគេបានសួរសុខទុក្ខគ្នាទៅវិញទៅមក ហើយក៏ចូលទៅក្នុងជំរំ។
[8]លោកម៉ូសេប្រាប់ឪពុកក្មេករបស់គាត់នូវអ្វីៗដែលព្រះអម្ចាស់បានធ្វើជាមួយស្តេចផារ៉ោន ហើយនិងជនជាតិអេស៊ីប ដោយព្រោះជនជាតិអ៊ីស្រាអែល
និងពីទុក្ខលំបាកដែលពួកគេបានជួបនៅតាមផ្លូវ ហើយពីរបៀបដែលព្រះអម្ចាស់សង្គ្រោះពួកគេ។
[9]លោកយេត្រូមានអំណរចំពោះការល្អដែលព្រះអម្ចាស់បានធ្វើជាមួយជនជាតិអ៊ីស្រាអែល ក្នុងនោះព្រះអង្គបានសង្គ្រោះពួកគេចេញពីដៃរបស់ជនជាតិអេស៊ីប។
[10]លោកយេត្រូប្រាប់ថា៖ «សូមសរសើរដល់ព្រះអម្ចាស់ ដ្បិត ព្រះអង្គបានសង្គ្រោះកូនពីដៃរបស់ជនជាតិអេស៊ីប ហើយចេញពីដៃរបស់ស្តេចផារ៉ោន
ហើយបានរំដោះប្រជាជានពីដៃរបស់ជនជាតិអេស៊ីប។[11]ឥឡូវនេះ ខ្ញុំដឹងថា ព្រះអម្ចាស់ធំជាងព្រះផ្សេងៗទាំងអស់ ព្រោះ
នៅពេលជនជាតិអេស៊ីប្រព្រឹត្តអំពើឃោឃៅដល់ជនជាតិអ៊ីស្រាអែល ព្រះជាម្ចាស់សង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ»។
[12]លោកយេត្រូ ឪពុកក្មេករបស់លោកម៉ូសេ បាននាំតង្វាយដុត ហើយថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់។ លោកអ៊ើរ៉ុន
និងពួកចាស់ទុំអ៊ីស្រាអែលទាំងអស់បានមកហូបអាហារ នៅចំពោះព្រះជាម្ចាស់ជាមួយឪពុកក្មេកលោកម៉ូសេ។
[13]នៅថ្ងៃបន្ទាប់ លោកម៉ូសេបានអង្គុយកាត់ក្តីប្រជាជន។ ប្រជាជនឈរជុំវិញគាត់តាំងពីព្រឹករហូតដល់ល្ងាច។
[14]ពេលឪពុកក្មេករបស់លោកម៉ូសេឃើញអ្វីៗគ្រប់យ៉ាងដែលគាត់បានធ្វើសម្រាប់ប្រជាជន គាត់ប្រាប់ថា៖ «ម្តេចក៏កូនធ្វើជាមួយប្រជាជនដូច្នេះ?
ហេតុអ្វីបានជាកូនអង្គុយម្នាក់ឯង ហើយប្រជាជនទាំងអស់ឈរកចាំកូនតាំងពីព្រឹកដល់ល្ងាចយ៉ាងនេះ?»
[15]លោកម៉ូសេប្រាប់ទៅឪពុកក្មេករបស់គាត់វិញថា៖ «ប្រជាជនបានចូលមករកខ្ញុំ ដើម្បីសូមការណែនាំពីព្រះជាម្ចាស់។[16]នៅពេលពួកគេឈ្លោះគ្នា ពួកគេបានចូលមករកខ្ញុំ។
ខ្ញុំក៏សម្រេចក្តីរបស់មនុស្សម្នាក់ និងមនុស្សម្នាក់ទៀត ហើយខ្ញុំបង្រៀនពួកគេពីច្បាប់ និងបញ្ញាតរបស់ព្រះជាម្ចាស់»។
[17]ឪពុកក្មេករបស់លោកម៉ូសេប្រាប់គាត់ថា៖ «អ្វីដែលកូនធ្វើនេះ មិនល្អទេ។[18]កូនប្រាកដជាអស់កម្លាំង ហើយកូន និងប្រជាជនមួយដែលនៅមួយក៏អស់កម្លាំងដែរ។
បន្ទុកនេះធ្ងន់ណាស់សម្រាប់កូន។ កូនមិនអាចធ្វើការនេះដោយខ្លួនឯងបានទេ។[19]សូមស្តាប់ឪពុក។ យើងនឹងផ្តល់យោបល់ឲ្យកូន ហើយព្រះជាម្ចាស់នៅជាមួយកូន
ដោយសារកូនគឺជាតំណាងរបស់ប្រជាជននៅចំពោះព្រះជាម្ចាស់ ហើយកូននាំរឿងរ៉ាវរបស់ពួកគេថ្វាយព្រះអង្គ។[20]កូនត្រូវបង្រៀនពួកគេពីច្បាប់និងបញ្ញាតរបស់ព្រះអង្គ។
កូនត្រូវបង្ហាញពួកគេនូវរបៀប ដែលពួកគេត្រូវដើរ និងអ្វីដែលពួកគេត្រូវធ្វើ។
[21]លើសពីនេះ កូនត្រូវជ្រើសរើសពួកប្រុសៗដែលមានសមត្ថភាពពីប្រជាជន មនុស្សដែលកោតខ្លាចដល់ព្រះជាម្ចាស់ មនុស្សទៀតត្រង់ ស្អប់អំពើទុច្ចរិត។
កូនត្រូវដាក់ពួកគេឲ្យគ្រប់គ្រងលើប្រជាជន ធ្វើជាអ្នកដឹកនាំគ្រប់គ្រងលើ មួយពាន់ មួយរយ និងហាសិប ព្រមទាំងដប់នាក់ផង។[22]ពួកគេនឹងកាត់ក្តីប្រជាជនគ្រប់រឿងរ៉ាវ
ប៉ុន្តែ រឿងក្តីលំបាកៗឲ្យប្រជាជននាំវាមករកអ្នក។ សូមឲ្យរឿងក្តីតូចៗ ឲ្យពួកគេអាចកាត់ក្តីនៅក្នុងចំណោមពួកគេ។ ធ្វើបែបនេះ វានឹងងាយស្រួលសម្រាប់កូន
ហើយពួកគេនឹងបន្ធូរបន្ថយបន្ទុករបស់កូន។[23]ប្រសិនបើ កូនធ្វើដូច្នេះ ហើយប្រសិនបើព្រះជាម្ចាស់បង្គាប់កូនឲ្យធ្វើដូច្នេះ នោះកូនអាចទ្រាំបាន
ហើយមនុស្សទាំងអស់ក៏អាចត្រឡប់ទៅផ្ទះដោយស្កប់ចិត្តដែរ»។
[24]ដូច្នេះ លោកម៉ូសេក៏ស្តាប់តាមពាក្យឪពុកក្មេករបស់គាត់ ហើយធ្វើតាមអ្វីៗគ្រប់យ៉ាងដែលគាត់បានប្រាប់។[25]លោកម៉ូសេបានជ្រើសរើស មនុស្សដែលមានសមត្ថភាព
ពីជនជាតិអ៊ីស្រាអែលទាំងអស់ ហើយតាំងពួកគេឲ្យធ្វើមេដឹកនាំប្រជាជន មេដឹកនាំនៃមនុស្សមួយពាន់ មួយរយ ហាសិប និងដប់នាក់។
[26]ពួកគេត្រូវកាត់ក្តីប្រជាជនដែលកាត់ស្បែកធម្មតា។ ហើយរឿងក្តីលំបាក ឲ្យពួកគេនាំមកឲ្យម៉ូសេ ប៉ុន្តែ ពួកគេត្រូវកាត់ក្តីរឿងក្តីតូចៗ។[27]នោះលោកម៉ូសេ
បានអនុញ្ញាតឲ្យឪពុកក្មេករបស់គាត់ចេញទៅ ហើយលោកយេត្រូវបានត្រឡប់ ហើយទៅស្រុកកំណើតវិញ។

Exodus 18:1
ត្រូវជាឪពុកក្មេករបស់លោកម៉ូសេ
នៅក្នុងច្បាប់ - នេះសំដៅទៅលើឪពុក នៃភរិយារបស់លោកម៉ូសេ។
បាននាំនាងស្រីសេផ្ទរ៉ា ជាភរិយារបស់លោកម៉ូសេ ... ហើយនាងមានកូនប្រុសពីរនាក់
ទី១ អត្ថន័យដែលប្រហែលគឺ) លោកយេត្រូបាននាំនាងស៊ីផ្ទរ៉ា
និងកូនប្រុសពីរនាក់របស់នាងទៅឲ្យម៉ូសេ ឬទី ២)
លោកយេត្រូបានស្វាគមន៍នាងស៊ីផ្ទរ៉ានិងកូនប្រុសពីរនាក់របស់នាងមុន។
ហើយក្រោមមកបានចាត់នាងឲ្យទៅផ្ទះវិញ
នេះជាអ្វីដែលលោកម៉ូសេបានធ្វើមុននេះ។
អត្ថន័យពេញលេញអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីលោកម៉ូសេបានបញ្ជូននាងទៅផ្ទះឪពុកម្តាយនាង»
គើសម
នេះជាកូនរបស់លោកម៉ូសេ និងនាងស៊ីផ្ទរ៉ាដែលឈ្មោះរបស់គាត់មានន័យថា« ជនបរទេស»។
អេលាស៊ើរ
នេះជាកូនរបស់លោកម៉ូសេ និងនាងស៊ីផ្ទរ៉ាដែលឈ្មោះរបស់គាត់មានន័យថា «ព្រះជាម្ចាស់ជាអ្នកដែលជួយខ្ញុំ»។
មុខដាវរបស់ស្តេចផារ៉ោន
នេះតំណាងឱ្យការសម្លាប់តាមរយៈស្តេចផារ៉ោន ឬកងទ័ពរបស់ស្តេចផារ៉ោន។
ការបកប្រែផ្សេងទៀត « ត្រូវបានសម្លាប់ដោយស្តេចផារ៉ោន» ឬ «
ត្រូវបានសម្លាប់ដោយកងទ័ពរបស់ស្តេចផារ៉ោន»
Exodus 18:5
ជាកន្លែងដែលគាត់បោះជំរំ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
កន្លែងដែលគាត់បោះជំរុំជាមួយពួកអ៊ីស្រាអែល»
Exodus 18:7
ហើយលុតជង្គង់ចុះ ហើយថើបគាត់។
សកម្មភាពនិមិត្តរូបទាំងនេះ គឺជារបៀបធម្មតាដែលមនុស្សបង្ហាញការគោរព
និងលះបង់យ៉ាងខ្លាំងនៅក្នុងវប្បធម៌នោះ។
ដោយព្រោះជនជាតិអ៊ីស្រាអែល
ពាក្យថាអ៊ីស្រាអែលតំណាងអោយប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ដើម្បីជួយប្រជាជនអ៊ីស្រាអែល»
ទុកលំបាកដែលពួកគេបានជួបនៅតាមផ្លូវ ហើយពីរបៀបដែលព្រះអម្ចាស់សង្គ្រោះពួកគេ។
លោកម៉ូសេសរសេរអំពីទុក្ខលំបាកដែលកើតឡើងចំពោះពួកគេ

generated on Wed Sep 10 16:16:32 2025

ដូចជាមានទុក្ខលំបាកបានកើតដល់ពួកគេ។ ការបកប្រែផ្សេងទៀត «
រាល់ទុក្ខលំបាកដែលបានកើតឡើងចំពោះពួកគេ» ឬ «
រាល់ទុក្ខលំបាកដែលពួកគេបានឆ្លងកាត់»
Exodus 18:9
ពីដៃរបស់ជនជាតិអេស៊ីប ... ហើយចេញពីដៃរបស់ស្តេចផារ៉ោន
ដៃតំណាងឱ្យអំណាចរបស់មនុស្សណាម្នាក់ក្នុងការធ្វើអ្វីមួយ។
ការបកប្រែផ្សេងទៀត «អំណាចរបស់ជនជាតិអេស៊ីប ...
អំណាចរបស់ស្តេចផារ៉ោន» ឬ «អ្វីដែលជនជាតិអេស៊ីបកំពុងធ្វើចំពោះអ្នក ...
អ្វីដែលស្តេចផារ៉ោនកំពុងធ្វើចំពោះអ្នក»
Exodus 18:13
ម្តេចក៏កូនធ្វើជាមួយប្រជាជនដូច្នេះ?
លោកយេត្រូប្រើសំណួរនេះ
ដើម្បីបង្ហាញលោកម៉ូសេថាអ្វីដែលគាត់បានកំពុងធ្វើគឺមិនល្អទេ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «អ្នកមិនគួរធ្វើអ្វីៗទាំងអស់នេះ សម្រាប់ប្រជាជនទេ!»
ហេតុអ្វីបានជាកូនអង្គុយម្នាក់ឯង ... តាំងពីព្រឹកដល់ល្ងាចយ៉ាងនេះ?
លោកយេត្រូបានប្រើសំណួរនេះ
ដើម្បីបង្ហាញលោកម៉ូសេថាគាត់បានកំពុងធ្វើច្រើនពេក។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «អ្នកមិនគួរអង្គុយម្នាក់ឯងទេ ... ពីព្រឹកដល់ល្ងាចទេ!»
កូនអង្គុយម្នាក់ឯង
ពាក្យ «អង្គុយ» នៅទីនេះគឺពាក្យប្រៀបធៀបសម្រាប់ «ចៅក្រម» ។
ចៅក្រមនឹងអង្គុយនៅពេលពួកគេស្តាប់ពាក្យបណ្តឹងរបស់ប្រជាជន។
ការបកប្រែផ្សេងទៀត «កូនកាត់សេចក្តីតែម្នាក់ឯង» ឬ
«កូនគឺជាមនុស្សតែម្នាក់គត់ដែលកាត់សេចក្តីសម្រាប់ប្រជាជន»
Exodus 18:17
កូនប្រាកដជាអស់កម្លាំង ហើយកូន
«កូនប្រាកដជាធ្វើឱ្យខ្លួនកូននឿយហត់ណាស់»
បន្ទុកនេះធ្ងន់ណាស់សម្រាប់កូន។
លោកយេត្រូនិយាយអំពីការខំប្រឹងធ្វើការ
ដែលលោកម៉ូសេបានធ្វើហាក់ដូចជាបន្ទុកដ៏ធ្ងន់ដែលលោកម៉ូសេកំពុងធ្វើ។
ការបកប្រែផ្សេងទៀត «ការងារនេះគឺច្រើនពេកសម្រាប់កូន»
ផ្តល់យោបល់
«ការណែនាំ» ឬ «ការបង្រៀន»
ព្រះជាម្ចាស់នៅជាមួយកូន
លោកយេត្រូនិយាយអំពីព្រះជាម្ចាស់ជួយលោកម៉ូសេ
ដូចជាព្រះជាម្ចាស់នឹងនៅជាមួយលោកម៉ូសេដែរ។ ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់នឹងជួយកូន» ឬ «ព្រះនឹងផ្តល់ឱ្យកូននូវប្រាជ្ញា»
កូននាំរឿងរ៉ាវរបស់ពួកគេថ្វាយព្រះអង្គ។
លោកយេត្រូនិយាយអំពីលោកម៉ូសេប្រាប់ព្រះជាម្ចាស់អំពីរឿងរ៉ាវរបស់ពួកគេ
ដូចជាលោកម៉ូសេបានកំពុងនាំរឿងរ៉ាវរបស់ពួកគេទៅកាន់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «កូនប្រាប់ព្រះជាម្ចាស់អំពីរឿងរ៉ាវរបស់ពួកគេ» ឬ
«កូនប្រាប់ព្រះជាម្ចាស់ពីអ្វីដែលពួកគេកំពុងឈ្លោះប្រកែកគ្នា»
កូនត្រូវបង្ហាញពួកគេនូវរបៀប ដែលពួកគេត្រូវដើរ
លោកយេត្រូ និយាយអំពីការរស់នៅ ឬអាកប្បកិរិយាដូចជាការដើរ។
ការបកប្រែផ្សេងទៀត «កូនត្រូវតែបង្ហាញពួកគេពីរបៀបរស់នៅ» ឬ
«កូនត្រូវតែបង្ហាញពួកគេពីរបៀបប្រព្រឹត្ត»
Exodus 18:21
ឃ្លាភ្ជាប់
លោកយេត្រូបន្តនិយាយទៅកាន់លោកម៉ូសេ។
លើសពីនេះ កូនត្រូវជ្រើសរើស
«លើសពីនេះទៀតកូនត្រូវតែជ្រើសរើស» ឬ «កូនត្រូវតែជ្រើសរើសផងដែរ» ។
កូនត្រូវដាក់ពួកគេឲ្យគ្រប់គ្រងលើប្រជាជន
លោកយេត្រូវ និយាយពីការផ្តល់សិទ្ធិអំណាចដល់ពួកគេ
ដូចជាការដាក់ពួកគេគ្រប់គ្រងលើមនុស្ស។ ការបកប្រែផ្សេងទៀត
«កូនត្រូវតែផ្តល់សិទ្ធិអំណាចដល់ពួកគេគ្រប់គ្រងលើប្រជាជន»
មួយពាន់ មួយរយ និងហាសិប ព្រមទាំងដប់នាក់ផង។
«ក្រុម ១,០០០ ក្រុម ១០០ ក្រុម ៥០ និងក្រុម ១០»
គ្រប់រឿងរ៉ាវ
«ករណីងាយៗ»
រឿងក្តីលំបាកៗឲ្យប្រជាជននាំវាមករកអ្នក។
លោកយេត្រូវនិយាយប្រាប់លោកម៉ូសេ
អំពីករណីពិបាកៗដូចជាការនាំការលំបាកមករកគាត់។ ការបកប្រែផ្សេងទៀត
«ករណីពិបាកដែលពួកគេនឹងរៀបរាប់ប្រាប់អ្នក» ឬ
«នៅពេលមានករណីលំបាកពួកគេ នឹងប្រាប់អ្នកដូច្នេះអ្នកអាចកាត់ក្តីពួកគេបាន»
ពួកគេនឹងបន្ធូរបន្ថយបន្ទុករបស់កូន។
លោកយេត្រូវនិយាយអំពីការខិតខំ
ដែលពួកគេនឹងធ្វើដូចជាបន្ទុកដែលពួកគេត្រូវអនុវត្ត។ ការបកប្រែផ្សេងទៀត
«ពួកគេនឹងខិតខំធ្វើការជាមួយកូន» ឬ «ពួកគេនឹងជួយកូនធ្វើការលំបាក»
អាចទ្រាំបាន
អ្វីដែលពួកគេនឹងស៊ូទ្រាំ អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«អាចទ្រាំនឹងភាពតានតឹងនៃការងារ»
Exodus 18:24
មេដឹកនាំប្រជាជន
លោកម៉ូសេសរសេរអំពីអ្នកដឹកនាំរបស់ប្រជាជនដូចជាពួកគេជាក្បាលនៃរាងកាយ។
ការបកប្រែផ្សេងទៀត «មេដឹកនាំប្រជាជន»
មនុស្សដែលមានសមត្ថភាព
នូវអ្វីដែលពួកគេមានសមត្ថភាពធ្វើអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «មនុស្សដែលអាចដឹកនាំ» ឬ
«មនុស្សដែលមានសមត្ថភាពអាចវិនិច្ឆ័យ»
ធម្មតា
«ស្ថានភាព»
ហើយរឿងក្តីលំបាក ឲ្យពួកគេនាំមកឲ្យម៉ូសេ
អ្នកនិពន្ធសរសេរប្រាប់លោកម៉ូសេអំពីករណីពិបាកៗ
ដូចជានាំរឿងក្តីពិបាកមកគាត់។ ការបកប្រែផ្សេងទៀត
«ករណីពិបាកដែលពួកគេបានរៀបរាប់ប្រាប់លោកម៉ូសេ» ឬ
«នៅពេលមានករណីលំបាកពួកគេបានប្រាប់លោកម៉ូសេអំពីរឿងក្តី
ទាំងនោះដើម្បីគាត់កាត់ក្តីឲ្យពួកគេ»
រឿងក្តីតូចៗ
«ករណីងាយៗ»

---

19 [1]នៅខែទីបី បន្ទាប់ពីប្រជាជនអ៊ីស្រាអែលបានចាកចេញពីអេស៊ីប នៅថ្ងៃដដែលនោះ ពួកគេបានទៅដល់ទីរហោស្ថានស៊ីណាយ។[2]បន្ទាប់ពី ចាកចេញពីរេភីឌីម
ហើយឆ្ពោះទៅទីរហោស្ថានស៊ីណាយ ពួកគេបានបោះជំរំនៅទីរហោស្ថានទល់មុខនឹងភ្នំ។
[3]លោកម៉ូសេបានឡើងទៅជួបព្រះជាម្ចាស់។ ព្រះអម្ចាស់បានហៅគាត់ពីភ្នំមកថា៖ «អ្នកត្រូវប្រាប់កូនចៅរបស់លោកយ៉ាកុប
ដែលជាជនជាតិអ៊ីស្រាអែលថា[4]អ្នករាល់គ្នាបានឃើញអ្វីដែលយើងបានធ្វើចំពោះជនជាតិអេស៊ីប និងពីការដែលយើងនាំអ្នករាល់គ្នាដូចជាស្លាបឥន្ទ្រី
ហើយបាននាំអ្នករាល់គ្នាដោយខ្លួនយើងផ្ទាល់។[5]ដូច្នេះ ប្រសិនបើ អ្នករាល់គ្នាស្តាប់តាមសម្លេងនិងកាន់តាមសម្ពន្ធមេត្រីរបស់យើង ដូច្នេះ
អ្នករាល់គ្នានឹងបានក្លាយជាកេរអាកររបស់យើងជាពិសេស ពីក្នុងចំណោមប្រជាជាតិ ដ្បិត ផែនដីទាំងមូលជារបស់យើង។[6]អ្នករាល់គ្នានឹងបានជានគរនៃពួកបូជាចារ្យ
និងជាប្រជាជាតិដ៏វិសុទ្ធសម្រាប់យើង។ នេះគឺជាព្រះបន្ទូលដែលអ្នកត្រូវនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
[7]ដូច្នេះ លោកម៉ូសេបានត្រឡប់មកវិញ ហើយកោះហៅពួកចាស់ទុំរបស់ជនជាតិអ៊ីស្រាអែល។ គាត់បានប្រាប់ព្រះបន្ទូលដែលព្រះអម្ចាស់បានបង្គាប់ដល់គាត់ទាំងអស់។
[8]ជនជាតិអ៊ីស្រាអែលបានឆ្លើយទាំងអស់គ្នា ហើយពោលថា៖ «យើងនឹងធ្វើតាមអ្វីៗគ្រប់យ៉ាងដែលព្រះអម្ចាស់បានមានបន្ទូល»។ បន្ទាប់មក
លោកម៉ូសេបានត្រឡប់ទៅរាយការណ៍សំដីរបស់ប្រជាជនប្រាប់ព្រះអម្ចាស់វិញ។[9]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «យើងនឹងមករកអ្នកនៅក្នុងពពកដ៏ក្រាស
ដើម្បីឲ្យប្រជាជនបានឮ នៅពេលយើងនិយាយជាមួយអ្នក ហើយពួកគេអាចជឿអ្នកជារៀងរហូតតទៅ»។ ពេលនោះ
លោកម៉ូសេបានប្រាប់តាមសំដីរបស់ប្រជាជនដល់ព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

[10]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរទៅរកប្រជាជន។ ថ្ងៃនេះ និងថ្ងៃស្អែក អ្នកត្រូវញែកពួកគេដោយឡែកសម្រាប់យើង
ហើយឲ្យពួកគេបោកសម្លៀកបំពាក់របស់ពួកគេ។[11]ឲ្យពួកគេរួចរាល់នៅថ្ងៃទីបី ដ្បិតនៅថ្ងៃទីបី ព្រះអម្ចាស់នឹងយាងមកលើភ្នំស៊ីណាយ។
[12]អ្នកត្រូវកំណត់ព្រំប្រទល់នៅជុំវិញភ្នំសម្រាប់ប្រជាជន។ ប្រាប់ពួកគេឲ្យ៖ «ចូរប្រយ័ត្ន កុំឲ្យអ្នករាល់គ្នាឡើងទៅឯភ្នំ ឬប៉ះព្រំប្រទល់របស់វាឡើយ។ អ្នកណាដែលប៉ះភ្នំ
នឹងត្រូវសម្លាប់ចោល»។[13]មិនត្រូវឲ្យមានដៃណាប៉ះអ្នកនោះឡើយ។ ផ្ទុយទៅវិញ ត្រូវចោលអ្នកនោះនឹងដុំថ្ម ឬបាញ់ព្រួញវិញ។ ទោះបើមនុស្សឬក៏សត្វក្តី
គឺត្រូវសម្លាប់ចោល។ នៅពេលឮសម្លេងត្រែផ្លុំយ៉ាងវែង ពួកគេត្រូវឡើងមកឯជើងភ្នំ»។
[14]បន្ទាប់មក លោកម៉ូសេបានចុះពីភ្នំមកវិញទៅរកប្រជាជន។ គាត់បានញែកប្រជាជនដោយឡែកថ្វាយព្រះអម្ចាស់ ហើយពួកគេបានបោកសម្លៀកបំពាក់របស់ពួកគេ។
[15]គាត់បានប្រាប់ដល់ប្រជាជនថា៖ «ចូររួចរាល់នៅថ្ងៃទីបី កុំចូលទៅជិតភរិយារបស់អ្នកឡើយ»។
[16]នៅថ្ងៃទីបី នៅពេលព្រឹក មានសម្លេងផ្គរលាន់ និងរន្ទះ ហើយមានពពកយ៉ាងក្រាសនៅលើភ្នំ ហើយមានសម្លេងត្រែយ៉ាងខ្លាំង។
ប្រជាជនទាំងអស់ដែលនៅជំរំភ័យខ្លាចជាខ្លាំង។[17]លោកម៉ូសេបាននាំប្រជាជនចេញពីជំនុំមកជួបព្រះជាម្ចាស់ ហើយពួកគេឈរនៅជើងភ្នំ។
[18]ភ្នំស៊ីណាយទាំងមូលគ្រប់ជិតទៅដោយផ្សែង ដោយសារព្រះអម្ចាស់បានយាងចុះមកនៅវា ដោយភ្លើង និងផ្សែង។ ផ្សែងបានឡើងទៅលើដូចជាភ្លើងឡ
ហើយភ្នំទាំងមូលរញ្ជួយជាខ្លាំង។
[19]នៅពេលសម្លេងត្រែបន្លឺកាន់តែខ្លាំងឡើង ហើយខ្លាំងឡើង លោកម៉ូសេក៏ទូលដល់ព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏មានបន្ទូលមកគាត់ជាសម្លេង។
[20]ព្រះអម្ចាស់បានយកចុះមកលើភ្នំស៊ីណាយ គឺនៅលើកំពូលភ្នំ ហើយកោះហៅលោកម៉ូសេពីលើកំពូលភ្នំមក។ ដូច្នេះ លោកម៉ូសេក៏ឡើងទៅលើភ្នំ។
[21]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរចុះទៅវិញ ហើយហាមប្រាមប្រជាជនកុំឲ្យទម្លាយចូលមក ដើម្បីមើលយើងឡើយ មិនដូច្នោះទេ
ពួកគេជាច្រើននឹងត្រូវវិនាស។[22]ចូរឲ្យពួកបូជាចារ្យ និងពួកអ្នកដែលចូលមកជិតយើងត្រូវញែកខ្លួនគេដោយឡែក ចូររៀបចំខ្លួនរបស់ពួកគេសម្រាប់ការមកដល់របស់យើង
ដើម្បីកុំឲ្យយើងប្រហារដល់ពួកគេ»។
[23]លោកម៉ូសេទូលទៅព្រះអម្ចាស់ថា៖ «ប្រជាជនមិនអាចឡើងទៅលើភ្នំបានទេ ដ្បិតព្រះអង្គបានបង្គាប់ដល់យើងខ្ញុំរួចហើយឲ្យ កំណត់ព្រំប្រទល់នៅជុំវិញភ្នំ
ហើយញែកភ្នំនេះថ្វាយដល់ព្រះអម្ចាស់»។[24]ព្រះអម្ចាស់មានបន្ទូលមកគាត់ថា៖ «ចូរចុះពីភ្នំ ហើយនាំអើរ៉ុនឡើងមកជាមួយអ្នក ប៉ុន្តែកុំអនុញ្ញាតឲ្យពួកបូជាចារ្យ
និងប្រជាជនទម្លាយព្រំប្រទល់ដើម្បីចូលមករកយើងឡើយ បើមិនដូច្នេះទេ យើងនឹងប្រហារពួកគេ»។[25]ដូច្នេះ លោកម៉ូសេបានចុះពីភ្នំ ទៅរកប្រជាជន
ហើយប្រាប់ដល់ពួកគេ។

Exodus 19:1

នៅខែទីបី ... នៅថ្ងៃដដែលនោះ

នេះមានន័យថាពួកគេបានទៅដល់ទីរហោស្ថាននៅថ្ងៃដំបូងនៃខែ
ដូចដែលពួកគេបានចាកចេញពីស្រុកអេស៊ីបនៅថ្ងៃទីមួយនៃខែ។ ថ្ងៃទីមួយនៃខែទី
៣ តាមប្រតិទិនហេព្រើរ
គឺជិតពាក់កណ្តាលខែឧសភាតាមប្រតិទិនលោកខាងលិច។ ការបកប្រែផ្សេងទៀត
«នៅខែទី ៣ ... នៅថ្ងៃដំបូងនៃខែ»

បានចាកចេញពី

«បានចាកចេញ»

រេភីឌីម

នេះជាតំបន់ស្ថិតនៅលើវាលរហោស្ថានស៊ីណៃ
ជាកន្លែងដែលជនជាតិអ៊ីស្រាអែលបោះជំរុំ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះនេះនៅក្នុង ១៧: ១ ។

Exodus 19:3

កូនចៅរបស់លោកយ៉ាកុប

ពាក្យថា «កូនចៅ» នៅទីនេះតំណាងឱ្យក្រុមគ្រួសាររបស់លោកយ៉ាកុបនិងកូនចៅ។
ការបកប្រែផ្សេងទៀត «កូនចៅនៃយ៉ាកុប»

កូនចៅរបស់លោកយ៉ាកុប ដែលជាជនជាតិអ៊ីស្រាអែល

ឃ្លាថា «ប្រជាជនអ៊ីស្រាអែល» ពន្យល់ពីអត្ថន័យនៃពាក្យថា
«កូនចៅរបស់លោកយ៉ាកុប »។

អ្នករាល់គ្នាបានឃើញ

ពាក្យថា «អ្នករាល់គ្នា» នៅទីនេះសំដៅទៅលើជនជាតិអ៊ីស្រាអែល។
ព្រះអម្ចាស់កំពុងប្រាប់លោកម៉ូសេ នូវអ្វីដែលត្រូវប្រាប់ជនជាតិអ៊ីស្រាអែល។

យើងនាំអ្នករាល់គ្នាដូចជាស្លាបឥន្ទ្រី

ព្រះជាម្ចាស់មានបន្ទូលអំពីការថែរក្សាប្រជាជនរបស់ព្រះអង្គ
នៅពេលដែលពួកគេធ្វើដំណើរដូចជាព្រះអង្គឥន្ទ្រី
ហើយលើកពួកគេដាក់លើស្លាបរបស់វា។ ការបកប្រែផ្សេងទៀត
«យើងបានជួយអ្នករាល់គ្នាធ្វើដំណើរដូចជាឥន្ទ្រីដែលនាំកូនរបស់វាដាក់លើស្លាបរបស់វ

ស្តាប់តាមសម្លេងរបស់យើង

ការគោរពប្រតិបត្តិអាចត្រូវបានបង្ហាញជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ស្តាប់សម្លេងរបស់យើងហើយស្តាប់បង្គាប់យើង»

សម្លេងរបស់យើង

សម្លេងរបស់ព្រះជាម្ចាស់តំណាងឱ្យអ្វី ដែលព្រះអង្គមានបន្ទូល។
ការបកប្រែផ្សេងទៀត «អ្វីដែលយើងមានបន្ទូល» ឬ «ព្រះបន្ទូលរបស់យើង»

កាន់តាមសម្ពន្ធមេត្រីរបស់យើង

«ធ្វើអ្វីតាមសម្ពន្ធមេត្រីរបស់យើងតម្រូវឱ្យអ្នកធ្វើ»

កេរអាករបស់យើងជាពិសេស

«ទ្រព្យសម្បត្តិ»

នគរនៃពួកបូជាចារ្យ

ព្រះជាម្ចាស់មានបន្ទូលអំពីប្រជារាស្ត្ររបស់ព្រះអង្គថា ពួកគេជាបូជាចារ្យ។
ការបកប្រែផ្សេងទៀត «នគរមួយរបស់ប្រជាជនដែលដូចជាបូជាចារ្យ» ឬ
«នគររបស់ប្រជាជនដែលធ្វើអ្វីដែលបូជាចារ្យធ្វើ»

Exodus 19:7

គាត់បានប្រាប់ព្រះបន្ទូល

អ្នកនិពន្ធសរសេរអំពីលោកម៉ូសេប្រាប់ប្រជាជន
អំពីរឿងដូចជាគាត់កំពុងប្រាប់នៅចំពោះមុខពួកគេ។ ការបកប្រែផ្សេងទៀត
«បានប្រាប់ពួកគេនូវពាក្យទាំងអស់នេះ»

ព្រះបន្ទូលដែលព្រះអម្ចាស់បានបង្គាប់ដល់គាត់ទាំងអស់។

ពាក្យ «ព្រះបន្ទូល» សំដៅទៅលើអ្វីដែលព្រះអម្ចាស់បានមានបន្ទូល។
ការបកប្រែផ្សេងទៀត «អ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបង្គាប់គាត់»

លោកម៉ូសេបានត្រឡប់ទៅរាយការណ៍

កន្លែងដែលលោកម៉ូសេទៅអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«លោកម៉ូសេបានត្រឡប់ទៅភ្នំវិញ ដើម្បីរាយការណ៍»

តាមសំដីរបស់ប្រជាជន

ពាក្យ «សំដី» សំដៅទៅលើអ្វីដែលប្រជាជនបាននិយាយ។ ការបកប្រែផ្សេងទៀត
«អ្វីដែលប្រជាជនបាននិយាយ»

Exodus 19:10

អ្នកត្រូវញែកពួកគេដោយឡែកសម្រាប់យើង

នេះប្រហែលជាមានន័យថា «ប្រាប់ពួកគេឱ្យលះបង់ខ្លួនឯងចំពោះយើង» ឬ
«ប្រាប់ពួកគេឱ្យធ្វើខ្លួនឱ្យបរិសុទ្ធសម្រាប់យើង» ។

សម្លៀកបំពាក់

«ក្រណាត់»

រួចរាល់

នេះគឺជាបង្គាប់ដល់ប្រជាជនអ៊ីស្រាអែល។

Exodus 19:12

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។

កំណត់ព្រំប្រទល់

«ធ្វើព្រំដែន» ។ នេះជាសញ្ញាសម្គាល់ដែរឬប្រភេទរនាំងណាមួយ។

អ្នកណាដែលប៉ះភ្នំ នឹងត្រូវសម្លាប់ចោល

នេះអាចត្រូវបានថ្លែងដោយទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកណាក៏ដោយដែលប៉ះភ្នំច្បាស់ជាត្រូវស្លាប់ជាមិនខាន» ឬ «
អ្នកប្រាកដជាត្រូវសម្លាប់អស់អ្នកណាដែលប៉ះភ្នំ»

អ្នកណាដែលប៉ះ

generated on Wed Sep 10 16:16:32 2025

«មនុស្សណាមួយដែលប៉ះ» ឬ «អ្នកណាមួយដែលប៉ះ»
អ្នកនោះឡើយ
«មនុស្សដែលធ្វើដូច្នោះ» ឬ «មនុស្សដែលប៉ះលើភ្នំ»
ត្រូវចោលអ្នកនោះនឹងដុំថ្ម ឬបាញ់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវគប់ដុំថ្មឬបាញ់គាត់»
បាញ់
នេះសំដៅទៅលើការសម្លាប់ដោយនរណាម្នាក់ដែលបាញ់ព្រួញពីធ្នូ ឬថ្មពីដង្ហក់។
ត្រែផ្លុំយ៉ាងវែង
«សម្លេងវែងនិងខ្លាំង»
Exodus 19:14
កុំចូលទៅជិតភរិយារបស់អ្នកឡើយ។
នេះជារបៀបគួរសមក្នុងការនិយាយអំពីការដេកជាមួយប្រពន្ធ។
ការបកប្រែផ្សេងទៀត «កុំរួមដំណេកជាមួយប្រពន្ធរបស់អ្នក»
Exodus 19:16
ភ័យខ្លាចជាខ្លាំង
«ញ័រដោយការភ័យខ្លាច»
បានយាងចុះមក
«ចុះមក»
ដូចជាភ្លើងឡ
នេះបង្ហាញថាវាជាចំនួនដ៏ច្រើនណាស់។ ការបកប្រែផ្សេងទៀត
«ដូចជាផ្សែងចេញពីភ្នក់ភ្លើងដ៏ធំ»
ភ្លើងឡ ដែលអាចត្រូវបានធ្វើឱ្យក្តៅខ្លាំង
Exodus 19:19
បន្លឺកាន់តែខ្លាំងឡើង ហើយខ្លាំងឡើង
«បន្តកាន់តែឮខ្លាំងឡើង ហើយឮខ្លាំងឡើង»
ជាសម្លេង
ពាក្យ «សម្លេង» នៅទីនេះសំដៅទៅលើសម្លេងដែលព្រះជាម្ចាស់បានបង្កើត។ ទី១អត្ថន័យដែលប្រហែលគឺ) «ដោយមានបន្ទូលខ្លាំងៗដូចជាផ្គរលាន់» ឬទី២) «ដោយមានបន្ទូល» ឬ ទី៣)«ដោយបង្កឱ្យមានសម្លេងផ្គរលាន់»
កោះហៅលោកម៉ូសេ
«ទ្រង់បង្គាប់លោកម៉ូសេឲ្យឡើងមក»
កុំឲ្យទម្លាយចូលមក
ព្រះជាម្ចាស់បានមានបន្ទូលអំពី ការដើរឆ្លងកាត់ព្រំដែនដូចជាពួកគេអាចបំបែករនាំងហើយដើរឆ្លងកាត់វា។ សូមមើលពីរបៀបដែលអ្នកបានបកប្រែ «កំណត់ព្រំដែន» នៅឆ្នាំ ១៩:១២ ។ ការបកប្រែផ្សេងទៀត «កុំទៅហួសព្រំដែន» ឬ «មិនឱ្យហួសពីរនាំង»
Exodus 19:23
ចុះពីភ្នំ
«ចូរចុះ»
ទម្លាយព្រំប្រទល់
ព្រះជាម្ចាស់បានមានបន្ទូលអំពីការ ដើរឆ្លងកាត់ព្រំដែនដូចជាពួកគេអាចទម្លាយរនាំង ហើយដើរឆ្លងកាត់វា។ សូមមើលឃ្លាស្រដៀងគ្នានៅឆ្នាំ ១៩:១៩ ។ ការបកប្រែផ្សេងទៀត «ទៅហួសព្រំដែន» ឬ «ឆ្លងកាត់រនាំង»

---

20 [1]ព្រះជាម្ចាស់មានបន្ទូលពាក្យទាំងអស់នេះដូចតទៅ[2]«យើងគឺជាព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ្នក ដែលបាននាំអ្នកចេញពីអេស៊ីបមក
ចេញពីផ្ទះដែលអ្នកធ្វើជាទាសករ។[3]អ្នកមិនត្រូវមានព្រះណាផ្សេងទៀតក្រៅពីយើងឡើយ។
[4]អ្នកមិនត្រូវឆ្លាក់ធ្វើរូបណា ឬអ្វីមួយពីអ្វីដែលនៅស្ថានសួគ៌ខាងលើ ឬអ្វីៗដែលនៅក្រោមដី ឬនៅក្រោមទឹក។
[5]អ្នកមិនត្រូវលុតជង្គង់ចុះចំពោះរបស់ទាំងនោះឬថ្វាយបង្គំរបស់ទាំងនោះឡើយ ដ្បិត យើងគឺព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ្នក យើងជាព្រះជាម្ចាស់ដែលប្រចណ្ឌ។
យើងនឹងដាក់ទោសអំពើអាក្រក់របស់បុព្វបុរស ដោយនាំការដាក់ទោសលើពូជពង្ស រហូតដល់បី និងបួនជំនាន់ដល់អស់អ្នកដែលស្អប់យើង។[6]ប៉ុន្តែ
យើងនឹងបង្ហាញពីសម្ពន្ធមេត្រីដ៏ស្មោះត្រង់ទាំងពាន់ជំនាន់ ដល់អស់អ្នកដែលស្រឡាញ់យើង ហើយកាន់តាមសេចក្តីបង្គាប់របស់យើង។
[7]អ្នកមិនត្រូវបញ្ចេញព្រះនាមរបស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នកដោយឥតប្រយោជន៍ឡើយ ដ្បិត
យើងនឹងមិនរាប់ថាឥតមានទោសដល់អស់អ្នកដែលប្រើនាមរបស់យើងឥតប្រយោជន៍។
[8]ចូរនឹកចាំពីថ្ងៃសប្ប័ទ ត្រូវញែកដោយឡែកសម្រាប់យើង។[9]អ្នកត្រូវធ្វើការ ហើយធ្វើការងាររបស់អ្នកក្នុងរយៈពេលប្រាំមួយថ្ងៃ។[10]ប៉ុន្តែ នៅថ្ងៃទីប្រាំពីរគឺជាថ្ងៃសប្ប័ទ
ថ្វាយព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នក។ នៅថ្ងៃនោះអ្នកមិនត្រូវធ្វើការអ្វីឡើយ អ្នក ឬកូនប្រុសរបស់អ្នក ឬកូនស្រីរបស់អ្នក ឬអ្នកបម្រើប្រុស ឬអ្នកបម្រើស្រី
ឬហ្វូងសត្វរបស់អ្នក ឬជនប្រទេស ដែលនៅក្នុងផ្ទះរបស់អ្នកក្តី។[11]ដ្បិត ប្រាំមួយថ្ងៃ ព្រះអម្ចាស់បានបង្កើតស្ថានសួគ៌ និងផែនដី សមុទ្រ និងអ្វីៗដែលនៅក្នុងទីទាំងនោះ
ហើយព្រះអង្គបានសម្រាកនៅថ្ងៃទីប្រាំពីរ។ ដូច្នេះហើយ ព្រះអម្ចាស់បានប្រទានពរនៅថ្ងៃសប្ប័ទ ហើយញែកថ្ងៃនោះដោយឡែក។
[12]ចូរគោរពឪពុក និងម្តាយរបស់អ្នក ដូច្នេះ អ្នកអាចនឹងមានអាយុវែងនៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នកបានប្រទានដល់អ្នក។
[13]អ្នកមិនត្រូវសម្លាប់នរណាឡើយ។[14]អ្នកមិនត្រូវប្រព្រឹត្តកំផិតឡើយ។
[15]អ្នកមិនត្រូវលួចពីនរណាឡើយ។[16]អ្នកមិនត្រូវធ្វើបន្ទាល់ក្លែងក្លាយទាស់នឹងអ្នកជិតខាងឡើយ។[17]អ្នកមិនត្រូវលោភចង់បានផ្ទះរបស់អ្នកជិតខាង
អ្នកមិនត្រូវលោភចង់បានភរិយារបស់អ្នកជិតខាង អ្នកបម្រើប្រុស អ្នកបម្រើស្រី គោ លា ឬអ្វីៗដែលជាកម្មសិទ្ធិរបស់អ្នកជិតខាងរបស់អ្នកឡើយ»។
[18]ប្រជាជនទាំងអស់បានឃើញផ្គរលាន់ ហើយរន្ទះ ហើយបានឮសម្លេងត្រែ ហើយឃើញផ្សែងហុយពីលើភ្នំ។ នៅពេលប្រជាជនឃើញវា ពួកគេភ័យញ័រ
ហើយឈរពីចម្ងាយ។[19]ពួកគេនិយាយនឹងលោកម៉ូសេថា៖«សូមនិយាយមកយើងខ្ញុំ យើងខ្ញុំនឹងស្តាប់ ប៉ុន្តែ មិនជាបាច់ឲ្យព្រះជាម្ចាស់មានបន្ទូលមកយើងខ្ញុំទេ
យើងខ្ញុំនឹងស្លាប់»។[20]លោកម៉ូសេប្រាប់ទៅប្រជាជនវិញថា៖ «កុំខ្លាចឡើយ ដ្បិត ព្រះជាម្ចាស់បានយាងមក ដើម្បីល្បងលអ្នករាល់គ្នា
ដើម្បីឲ្យមានការគោរពកោតខ្លាចព្រះអង្គនៅក្នុងអ្នករាល់គ្នា និងដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាប»។[21]ដូច្នេះ ប្រជាជន ឈរនៅពីចម្ងាយ
ហើយលោកម៉ូសេបានចូលទៅជិតពពកដ៏ក្រាស់ជាកន្លែងដែលព្រះជាម្ចាស់គង់នៅ។
[22]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «នេះគឺជាអ្វីដែលអ្នកត្រូវប្រាប់ដល់ជនជាតិអ៊ីស្រាអែល អ្នកខ្លួនឯងផ្ទាល់
បានឃើញអ្វីដែលយើងបាននិយាយជាមួយអ្នកពីស្ថានសួគ៌[23]អ្នកមិនត្រូវមានព្រះផ្សេងទៀតនៅជាមួយយើងឡើយ ជាព្រះដែលធ្វើពីប្រាក់ ឬមាស។
[24]អ្នកត្រូវសង់អាសនាមួយពីដីសម្រាប់យើង ហើយអ្នកត្រូវថ្វាយយញ្ញបូជា ជាតង្វាយដុត តង្វាយមេត្រី ចៀម និងគោ។ នៅគ្រប់កន្លែង
ជាកន្លែងដែលយើងធ្វើឲ្យឈ្មោះរបស់យើងបានទទួលការគោរពបូជា យើងនឹងមករកអ្នក ហើយប្រទានពរដល់អ្នក។[25]ប្រសិនបើ អ្នកធ្វើអាសនាសម្រាប់យើងពីថ្ម
អ្នកមិនត្រូវសង់វាពីថ្មដែលកាត់ឡើយ ដ្បិត ប្រសិនបើ អ្នកបម្រើសម្ភាររបស់អ្នកនៅលើអាសនា នោះអ្នកបានបង្ខូចវាហើយ។
[26]អ្នកមិនត្រូវឡើងជាន់នៅលើអាសនារបស់យើងឡើយ ធ្វើដូច្នេះ ដើម្បីកុំឲ្យគេឃើញកេរ្តិ៍ខ្មាសរបស់អ្នក»។

Exodus 20:1
ផ្ទះដែលអ្នកធ្វើជាទាសករ
«កន្លែងដែលអ្នកធ្លាប់ជាទាសករ»
អ្នកមិនត្រូវមានព្រះណាផ្សេងទៀតក្រៅពីយើងឡើយ។
«អ្នកមិនត្រូវថ្វាយបង្គំព្រះដទៃក្រៅពីយើងទេ»
Exodus 20:4
ឬអ្វីមួយ
«ហើយអ្នកមិនត្រូវធ្វើឱ្យមានលក្ខណៈដូច»
អ្នកមិនត្រូវលុតជង្គង់ចុះចំពោះរបស់ទាំងនោះ ឬថ្វាយបង្គំរបស់ទាំងនោះឡើយ
ពាក្យថា «របស់ទាំងនោះ» សំដៅទៅលើរូបចម្លាក់ឆ្លាក់ ឬរូបបដិមា។
ប្រចណ្ឌ
ព្រះជាម្ចាស់ចង់ឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ថ្វាយបង្គំព្រះអង្គតែមួយគត់។

generated on Wed Sep 10 16:16:32 2025

ដាក់ទោសអំពើអាក្រក់របស់បុព្វបុរស ដោយនាំការដាក់ទោសលើពូជពង្ស
ព្រះជាម្ចាស់នឹងដាក់ទោសប្រជាជន ចំពោះអំពើបាបឪពុកម្តាយរបស់ពួកគេ។
រហូតដល់បី និងបួនជំនាន់
«ជំនាន់ទី ៣ និងទី ៤ »។នៅទីនេះ «ទីបី» និង «ទីបួន»
គឺជាចំនួនលេខធម្មតា«៣» និង«៤» ។
យើងនឹងបង្ហាញពីសម្ពន្ធមេត្រីដ៏ស្មោះត្រង់ទាំងពាន់ជំនាន់
«ដោយសារសម្ពន្ធមេត្រីរបស់យើង យើងស្មោះត្រង់នឹងមនុស្សរាប់ពាន់នាក់» ឬ
«យើងស្មោះត្រង់ស្រឡាញ់រាប់ពាន់ជំនាន់»
ទាំងពាន់ជំនាន់
«ជំនាន់ជាច្រើននៃអ្នកទាំងនោះ»
Exodus 20:7
បញ្ចេញព្រះនាមរបស់ព្រះអម្ចាស់
«ប្រើព្រះនាមយើង»
ឥតប្រយោជន៍
«ធ្វេសប្រហែស» ឬ «ដោយគ្មានការគោរពត្រឹមត្រូវ»
យើងនឹងមិនរាប់ថាឥតមានទោស
«យើងប្រាកដជាពិចារណាថាមានទោស» ឬ «យើងនឹងប្រាកដជាដាក់ទោស»
Exodus 20:8
ធ្វើការងាររបស់អ្នក
«ធ្វើការងារធម្មតារបស់អ្នក»
ដែលនៅក្នុងផ្ទះរបស់អ្នកក្តី
ទីក្រុងជាទូទៅមានកំពែងព័ទ្ធជុំវិញវាដើម្បីការពារសត្រូវ
និងច្រកទ្វារសម្រាប់មនុស្សចូលនិងចេញ។ការបកប្រែផ្សេងទៀត
«នៅក្នុងសហគមន៍របស់អ្នក» ឬ «នៅខាងក្នុងទីក្រុងរបស់អ្នក»
សម្រាកនៅថ្ងៃទីប្រាំពីរ
«នៅថ្ងៃទីប្រាំពីរ» ។ នៅទីនេះ «ទីប្រាំពីរ» គឺជាចំនួនលេខធម្មតាសម្រាប់ «៧» ។
បានប្រទានពរនៅថ្ងៃសប្ប័ទ
ទី១ អត្ថន័យដែលអាចទៅរួចគឺថា)
ព្រះជាម្ចាស់បណ្តាលឲ្យថ្ងៃឈប់សម្រាកផ្តល់លទ្ធផលល្អ ឬទី២)
ព្រះជាម្ចាស់បានមានបន្ទូលថាថ្ងៃឈប់សម្រាកគឺល្អ។
ញែកថ្ងៃនោះដោយឡែក
«កំណត់វាដាច់ដោយឡែកសម្រាប់គោលបំណងពិសេស»
Exodus 20:12
អ្នកមិនត្រូវប្រព្រឹត្តកំផិតឡើយ។
«អ្នកមិនត្រូវរួមភេទជាមួយអ្នកណាផ្សេងទៀតក្រៅពីប្តីប្រពន្ធរបស់អ្នក»
Exodus 20:15
មិនត្រូវធ្វើបន្ទាល់ក្លែងក្លាយ
«មិនត្រូវនិយាយបន្លំហេតុការណ៍» ឬ «មិនត្រូវនិយាយកុហកអ្នកណាម្នាក់ឡើយ»
មិនត្រូវលោភចង់បាន
«មិនត្រូវលោភចង់មាន» ឬ «មិនត្រូវចង់បានខ្លាំង»
Exodus 20:18
សម្លេង
«សម្លេង»
ផ្សែងហុយពីលើភ្នំ
«ផ្សែងចេញពីភ្នំ»
ពួកគេភ័យញ័រ
«ពួកគេបានញ័រដោយការភ័យខ្លាច»
ហើយឈរពីចម្ងាយ
«ឈរនៅឆ្ងាយ» ឬ «ឈរនៅពីចម្ងាយ»
ម្បីឲ្យមានការគោរពកោតខ្លាចព្រះអង្គនៅក្នុងអ្នករាល់គ្នា និងដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាប។
«ដូច្នេះអ្នកនឹងគោរពព្រះអង្គហើយមិនមែនធ្វើអំពើបាប»
បានចូលទៅជិត
«បានខិតទៅជិត»
Exodus 20:22
នេះគឺជាអ្វីដែលអ្នកត្រូវប្រាប់ដល់ជនជាតិអ៊ីស្រាអែល
«ចូរប្រាប់ជនជាតិអ៊ីស្រាអែលដូចតទៅនេះ»
អ្នកខ្លួនឯងផ្ទាល់ បានឃើញអ្វីដែលយើងបាននិយាយជាមួយអ្នកពីស្ថានសួគ៌
«អ្នកបានឮយើងមានបន្ទូលជាមួយអ្នកពីស្ថានសួគ៌»
អ្នកមិនត្រូវមានព្រះផ្សេងទៀតនៅជាមួយយើងឡើយ
«អ្នកមិនត្រូវធ្វើរូបព្រះដូចជាព្រះផ្សេងទៀតជំនួសយើង»
ជាព្រះដែលធ្វើពីប្រាក់ ឬមាស។
«ព្រះធ្វើពីប្រាក់ឬមាស» ឬ « រូបព្រះធ្វើពីប្រាក់ ឬមាស»
Exodus 20:24
សង់អាសនា
អាសនាធ្វើពីដី ដូចជាថ្ម ភក់ ឬដីឥដ្ឋ
ធ្វើឲ្យព្រះនាមរបស់យើងបានទទួលការគោរពបូជា
នៅទីនេះ «ព្រះនាម» គឺជាពាក្យប្រៀបធៀបសម្រាប់ព្រះជាម្ចាស់ដែលគង់នៅ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ជ្រើសរើសសម្រាប់អ្នកគោរពបូជាយើង»
អ្នកមិនត្រូវឡើងជាន់នៅលើអាសនារបស់យើងឡើយ
«កុំធ្វើអាសនាដែលមានជណ្តើរ»
ដើម្បីកុំឲ្យគេឃើញកេរ្តិ៍ខ្មាសរបស់អ្នក។
«លេចកេរ្តិ៍ខ្មាសរបស់អ្នក»

---

21 [1]ឥឡូវ នេះគឺជាច្បាស់ផ្សេងៗ ដែលអ្នកត្រូវដាក់ចំពោះពួកគេ៖
[2]«ប្រសិនបើ អ្នកទិញអ្នកបម្រើជនជាហេព្រើរ គាត់ត្រូវបម្រើប្រាំមួយឆ្នាំ ហើយនៅឆ្នាំទីប្រាំពីរ គាត់នឹងមានសេរីភាពដោយមិនចាំបាច់បង់ថ្លៃអ្វីៗទាំងអស់។[3]ប្រសិនបើ
គាត់មកដោយខ្លួនឯង គាត់ត្រូវទៅវិញដោយខ្លួនឯង។ ប្រសិនបើ គាត់រៀបការហើយ ដូច្នេះ ភរិយារបស់គាត់ក៏ត្រូវមានសេរីភាពជាមួយគាត់ដែរ។[4]ប្រសិនបើ
ចៅហ្វាយរបស់គាត់យកប្រពន្ធឲ្យគាត់ ហើយនាងបង្កើតកូនប្រុស កូនស្រីឲ្យគាត់ ប្រពន្ធនិងកូនៗរបស់នាងជាកម្មសិទ្ធិរបស់ចៅហ្វាយ
ហើយគាត់នឹងទៅបានតែខ្លួនគាត់ម្នាក់ប៉ុណ្ណោះ។
[5]ប៉ុន្តែ ប្រសិនបើ អ្នកបម្រើនោះនិយាយថា៖ «ខ្ញុំស្រឡាញ់ចៅហ្វាយ ហើយប្រពន្ធ និងកូនៗរបស់ខ្ញុំ ខ្ញុំមិនចេញទៅទេ»។[6]ដូច្នេះ ចៅហ្វាយត្រូវនាំគាត់ទៅថ្វាយព្រះជាម្ចាស់។
ចៅហ្វាយត្រូវនាំគាត់ទៅកាន់ទ្វារ ឬក្របទ្វារ ហើយចៅហ្វាយរបស់គាត់ត្រូវយកដែកចោះត្រចៀករបស់គាត់។ ដូច្នេះ អ្នកបម្រើនោះ នឹងបម្រើគាត់អស់មួយជីវិតរបស់គាត់។
[7]ប្រសិនបើ បុរសម្នាក់លក់កូនស្រីរបស់គាត់ឲ្យទៅជាអ្នកបម្រើស្រី នាងត្រូវអាចមានសេរីភាពដូចជាអ្នកបម្រើប្រុសឡើយ។[8]ប្រសិនបើ នាងមិនចូលចិត្តចៅហ្វាយរបស់នាង
ដែលបានទិញមកសម្រាប់គាត់ ដូច្នេះ គាត់ត្រូវអនុញ្ញាតឲ្យគេទិញនាងត្រឡប់ទៅវិញ។ គាត់គ្មានសិទ្ធិលក់នាងឲ្យជនជាតិដទៃឡើយ។ គាត់គ្មានសិទ្ធិបែបនោះទេ ធ្វើដូច្នេះ
គាត់បោកប្រាស់នាងហើយ។
[9]ប្រសិនបើ ចៅហ្វាយរបស់នាងចង់បាននាងឲ្យធ្វើជាប្រពន្ធរបស់កូនប្រុសគាត់ គាត់ត្រូវប្រព្រឹត្តនឹងនាងដូចជាកូនស្រីរបស់គាត់ដែរ។[10]ប្រសិនបើ
គាត់យកប្រពន្ធមួយផ្សេងទៀតសម្រាប់ខ្លួនគាត់ គាត់មិនត្រូវកាត់បន្ថយអាហារ សម្លៀកបំពាក់ ឬសិទ្ធិជាប្រពន្ធឡើយ។[11]ប៉ុន្តែ ប្រសិនបើ មិនផ្តល់ការទាំងបីនេះទេ ដូច្នេះ
នាងត្រូវចេញទៅដោយសេរីភាពគ្មានការបង់ប្រាក់ឡើយ។
[12]អស់អ្នកណាដែលវាយបុរសណាម្នាក់ ធ្វើឲ្យអ្នកនោះស្លាប់ អ្នកនោះនឹងត្រូវទទួលទោសដល់ស្លាប់។[13]ប្រសិនបើ អ្នកនោះមិនមានចេតនា ប៉ុន្តែ ធ្វើដោយអចេតនា ដូច្នេះ
យើងនឹងរៀបចំកន្លែងមួយ ដើម្បីឲ្យអ្នកនោះអាចរត់ទៅជ្រកកោននៅទីនោះ។[14]ប្រសិនបើ អ្នកនោះវាយដោយចេតនាដល់អ្នកជិតខាង
ហើយសម្លាប់គាត់ដោយមានគម្រោងការនោះ ដូច្នេះ អ្នកត្រូវចាប់អ្នកនោះ ហើយបើទោះគាត់នៅឯអាសនារបស់ព្រះជាម្ចាស់ក៏ដោយ ក៏ត្រូវយកអ្នកនោះទៅសម្លាប់ដែរ។
[15]អស់អ្នកណាដែលវាយឪពុក ឬម្តាយរបស់ខ្លួន ត្រូវសម្លាប់អ្នកនោះចោល។[16]អស់អ្នកណាដែលចាប់ជំរិតអ្នកណាម្នាក់ ហើយលក់គាត់
ឬរកឃើញទ្រព្យសម្បត្តិរបស់គាត់នៅនឹងដៃរបស់អ្នកនោះ អ្នកដែលជំរិតគេនោះនឹងត្រូវទទួលទោសដល់ស្លាប់។[17]អស់អ្នកណាដែលដាក់បណ្តាសាឪពុក
ឬម្តាយត្រូវទទួលទោសដល់ស្លាប់។

generated on Wed Sep 10 16:16:32 2025

[18]ប្រសិនបើ បុរសម្នាក់ឈ្លោះគ្នា ហើយម្នាក់វាយអ្នកម្នាក់ទៀតដោយដុំថ្ម ឬដាល់ ហើយមិនធ្វើឲ្យអ្នកនោះស្លាប់ទេ តែធ្វើឲ្យគាត់ដេកនៅលើគ្រែ។[19]ដូច្នេះ ប្រសិនបើគាត់ជា
ហើយអាចដើរដោយប្រើឈើជ្រាត់របស់គាត់បាន បុរសដែលវាយគាត់ត្រូវបង់ថ្លៃខាតពេលវេលារបស់គាត់ ហើយគាត់ក៏ត្រូវបង់ថ្លៃរហូតទាល់តែអ្នកនោះបានជាដែរ។ ប៉ុន្តែ
បុរសនោះមិនមានកំហុសនៃការធ្វើឃាតមនុស្សឡើយ។
[20]ប្រសិនបើ បុរសម្នាក់វាយអ្នកបម្រើប្រុស ឬអ្នកបម្រើស្រីរបស់គាត់ដោយដំបង ហើយប្រសិនបើ អ្នកបម្រើនោះស្លាប់ដោយសារបុរសនោះ ដូច្នេះ
បុរសនោះត្រូវមានទោស។[21]ប៉ុន្តែ ប្រសិនបើ អ្នកបម្រើនោះនៅរស់បានមួយថ្ងៃឬពីរថ្ងៃ ចៅហ្វាយនោះគ្មានទោសទេ
ដ្បិតគាត់បានឈឺចាប់ដោយសារបាត់បង់អ្នកបម្រើនោះ។
[22]ប្រសិនបើ បុរសវាយគ្នា ហើយធ្វើឲ្យស្ត្រីមានផ្ទៃពោះ បណ្តាលឲ្យនាងរលូតកូន ប៉ុន្តែ គ្មានរបួសនៅកន្លែងផ្សេងទៀតដល់នាងទេនោះ ដូច្នេះ
កំហុសរបស់បុរសម្នាក់នោះត្រូវពិនិត្យតាមការទាមទាររបស់ស្វាមីរបស់នាងពីគាត់។ ហើយគាត់ត្រូវបង់ថ្លៃតាមការសម្រេចក្តីរបស់ចៅក្រម។[23]ប៉ុន្តែ ប្រសិនបើ មានរបួសធ្ងន់
ដូច្នេះ អ្នកត្រូវឲ្យជីវិតសងដោយជីវិត។[24]ហើយភ្នែកសងដោយភ្នែក ធ្មេញសងដោយធ្មេញ ដៃសងដោយដៃ ជើងសងដោយជើង[25]រលាកសងដោយរលាក
របួសសងដោយរបួស ឬបើជាំសងដោយជាំ។
[26]ប្រសិនបើ បុរសម្នាក់វាយភ្នែករបស់អ្នកបម្រើប្រុស ឬអ្នកបម្រើស្រីរបស់គាត់ ហើយធ្វើឲ្យខ្វាក់ ដូច្នេះ កាត់ត្រូវអនុញ្ញាតឲ្យអ្នកបម្រើនោះមានសេរីភាព ជាថ្លៃសងជំងឺចិត្ត
ដោយព្រោះភ្នែករបស់គាត់។[27]ប្រសិនបើ គាត់វាយអ្នកបម្រើប្រុស ឬអ្នកបម្រើស្រីរបស់គាត់បាក់ធ្មេញ គាត់ត្រូវឲ្យអ្នកបម្រើនោះមានសេរីភាព
ជាថ្លៃសងជំងឺចិត្តសម្រាប់ធ្មេញនោះ។
[28]ប្រសិនបើគោជល់បុរស ឬស្ត្រីណាម្នាក់ស្លាប់ ត្រូវយកគោនោះទៅចោលនឹងដុំថ្មសម្លាប់ ហើយមិនត្រូវស៊ីសាច់របស់វាឡើយ ប៉ុន្តែ
ម្ចាស់គោមិនត្រូវរាប់ជាមានទោសឡើយ។[29]ប៉ុន្តែ ប្រសិនបើគោនោះមានទម្លាប់ជល់គេកាលពីមុន ហើយមានគេដាស់តឿនម្ចាស់របស់វាហើយ ប៉ុន្តែគាត់មិនធ្វើតាម
ហើយគោនោះបានសម្លាប់បុរស ឬស្ត្រីណាម្នាក់ នោះត្រូវចោលគោនឹងដុំថ្មសម្លាប់ ថែមទាំងសម្លាប់ម្ចាស់វាដែរ។[30]ប្រសិនបើ ការបង់ថ្លៃតម្រូវឲ្យបង់ថ្លៃលោះជីវិតរបស់គាត់
ដូច្នេះ គាត់ត្រូវបង់ថ្លៃនូវអ្វីដែលគេត្រូវឲ្យគាត់បង់។
[31]ប្រសិនបើ គោនោះជល់កូនប្រុស ឬកូនស្រីបុរសណាម្នាក់ ម្ចាស់គោនោះត្រូវធ្វើអ្វីតាមច្បាប់តម្រូវឲ្យគាត់ធ្វើ។[32]ប្រសិនបើ គោនោះជល់អ្នកបម្រើប្រុស ឬអ្នកបម្រើស្រី
ម្ចាស់គោត្រូវបង់ថ្លៃសាមសិបសេកែលទៅចៅហ្វាយជនរងគ្រោះ ហើយគោនោះត្រូវចោលសម្លាប់នឹងដុំថ្ម។
[33]ប្រសិនបើ បុរសម្នាក់បើកអណ្តូងចោល ឬប្រសិនបើ បុរសនោះជីកអណ្តូង ហើយមិនបានគ្របវា ហើយមានគោ
ឬសត្វលាធ្លាក់ចូលទៅក្នុងអណ្តូងនោះ[34]ម្ចាស់អណ្តូងត្រូវបង់ថ្លៃការខូចខាតនោះ។ គាត់ត្រូវបង់លុយដល់ម្ចាស់សត្វដែលស្លាប់នោះ
ហើយសត្វដែលស្លាប់នោះជាកម្មសិទ្ធិរបស់គាត់។
[35]ប្រសិនបើ គោរបស់បុរសម្នាក់ធ្វើឲ្យគោរបស់បុរសម្នាក់ទៀតរបួសដល់ស្លាប់ ដូច្នេះ គេត្រូវលក់គោដែលរស់នោះ ហើយចែកគ្នា ហើយសាច់គោដែលស្លាប់ត្រូវចែកគ្នាដែរ។
[36]ប៉ុន្តែ ប្រសិនបើដឹងថាគោនោះមានទម្លាប់ជល់ពីមុន ហើយម្ចាស់គោនោះនៅតែទុកគោនោះទៀត គាត់ត្រូវលក់គោនោះបង់ថ្លៃម្ចាស់គោ
ហើយគោដែលស្លាប់ត្រូវតែជាកម្មសិទ្ធិរបស់ម្ចាស់វា។

Exodus 21:1

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។

អ្នកត្រូវដាក់ចំពោះពួកគេ

«អ្នកត្រូវតែផ្តល់ឱ្យពួកគេ» ឬ «អ្នកត្រូវតែប្រាប់ពួកគេ»

Exodus 21:2

ព័ត៌មានទូទៅ

ព្រះអម្ចាស់ប្រាប់លោកម៉ូសេ ពីក្រឹត្យវិន័យរបស់ទ្រង់សម្រាប់ប្រជាជនអ៊ីស្រាអែល។

ប្រសិនបើ គាត់មកដោយខ្លួនឯង គាត់ត្រូវទៅវិញដោយខ្លួនឯង។

អ្វីដែលមានន័យថា «ដោយខ្លួនឯង» អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។

ភាសាខ្លះតម្រូវឱ្យមានលក្ខខណ្ឌបន្ថែមត្រូវបានបញ្ជាក់យ៉ាងច្បាស់។

ការបកប្រែផ្សេងទៀត

«ប្រសិនបើគាត់បានក្លាយជាទាសករខណៈពេលដែលគាត់មិនមានប្រពន្ធ
ហើយប្រសិនបើគាត់រៀបការនៅពេលគាត់ជាទាសករចៅហ្វាយត្រូវតែដោះលែងមនុស្សនោះ»

ដោយខ្លួនឯង

«ម្នាក់ឯង« ឬ «គ្មានប្រពន្ធ»

ប្រសិនបើ គាត់រៀបការហើយ

«ប្រសិនបើគាត់បានរៀបការនៅពេលគាត់ក្លាយជាទាសករ» ឬ
«ប្រសិនបើគាត់បានរៀបការហើយ»

Exodus 21:5

អ្នកបម្រើនោះនិយាយថា

«និយាយយ៉ាងច្បាស់»

ខ្ញុំមិនចេញទៅទេ

«ខ្ញុំមិនចង់អោយចៅហ្វាយរបស់ខ្ញុំ ដោះលែងខ្ញុំឲ្យមានសេរីភាពទេ»

ត្រូវយកដែកចោះត្រចៀករបស់គាត់

«ចោះរន្ធត្រចៀករបស់គាត់»

ដែកចោះ

ឧបករណ៍ដែលមានចុងស្រួចគឺត្រូវបានប្រើដើម្បីធ្វើចោះ

អស់មួយជីវិតរបស់គាត់។

«រហូតដល់ចុងបញ្ចប់នៃជីវិតរបស់គាត់» ឬ «រហូតដល់គាត់ស្លាប់»

Exodus 21:7

បានទិញមកសម្រាប់គាត់

«បានជ្រើសរើស»

គាត់ត្រូវអនុញ្ញាតឲ្យគេទិញនាងត្រឡប់ទៅវិញ។

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែអនុញ្ញាតឱ្យឪពុករបស់នាងទិញនាងមកវិញ»

គ្មានសិទ្ធិលក់នាង

«គ្មានសិទ្ធិលក់»

គាត់បោកប្រាស់នាងហើយ។

«គាត់បានបោកប្រាស់នាង»

Exodus 21:9

ចង់បាន

«ជ្រើសរើស»

គាត់មិនត្រូវកាត់បន្ថយអាហារ សម្លៀកបំពាក់ ឬសិទ្ធិជាប្រពន្ធឡើយ។

នេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែផ្តល់ឱ្យប្រពន្ធទីមួយនូវអាហារ សម្លៀកបំពាក់ និង
សិទ្ធិជាប្រពន្ធដែលនាងមានពីមុន»

កាត់បន្ថយ

«យកទៅឆ្ងាយ» ឬ «កាត់បន្ថយ»

ឬសិទ្ធិជាប្រពន្ធ

នេះរួមបញ្ចូលទាំងរឿងដែលប្តីត្រូវធ្វើសម្រាប់ភរិយារួមទាំងដេកជាមួយនាងផង។
ការបកប្រែផ្សេងទៀត «ហើយគាត់ត្រូវតែបន្តគេងជាមួយនាងដូចមុន»

Exodus 21:12

វាយ

«បុក» ឬ «វាយប្រហារ»

អ្នកនោះនឹងត្រូវទទួលទោសដល់ស្លាប់។

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែកាត់ទោសប្រហារជីវិតមនុស្សនោះយ៉ាងពិតប្រាកដ» ឬ «
អ្នកត្រូវតែសម្លាប់មនុស្សនោះជាប្រាកដ»

ធ្វើដោយអចេតនា

«មិនមានផែនការនឹងធ្វើវា» ឬ «ធ្វើដោយគ្មានគោលបំណង»

យើងនឹងរៀបចំកន្លែងមួយ ដើម្បីឲ្យអ្នកនោះអាចរត់ទៅជ្រកកោននៅទីនោះ។

គោលបំណងនៃការជ្រើសរើសទីកន្លែងអាចមានលក្ខណៈច្បាស់លាស់នៅទីនេះ។
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងជ្រើសរើសកន្លែងដែលគាត់អាចរត់ទៅឆ្ងាយ

generated on Wed Sep 10 16:16:32 2025

ដើម្បីឱ្យមានសុវត្ថិភាព»
ហើយសម្លាប់គាត់ដោយមានគម្រោងការនោះ
«ក្រោយពីបានគិតយ៉ាងហ្មត់ចត់អំពីវា»
អ្នកត្រូវចាប់អ្នកនោះ
ពាក្យថា «អ្នក» គឺសំដៅទៅលើអ្នកដែលសម្លាប់អ្នកជិតខាង។
ក៏ត្រូវយកអ្នកនោះទៅសម្លាប់ដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះអ្នកអាចសម្លាប់គាត់»
Exodus 21:15
អស់អ្នកណាដែលវាយឪពុក ឬម្តាយរបស់ខ្លួន ត្រូវសម្លាប់អ្នកនោះចោល។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
បើអ្នកណាវាយឪពុក ឬម្តាយអ្នកប្រាកដជាត្រូវគេសម្លាប់ចោល» ឬ «
អ្នកណាដែលវាយឪពុកឬម្តាយ អ្នកច្បាស់ជាត្រូវសម្លាប់»
ត្រូវសម្លាប់
«ប្រាកដជាស្លាប់»
រកឃើញទ្រព្យសម្បត្តិរបស់គាត់
«ជាមួយគាត់»
អ្នកដែលជំរិតគេនោះនឹងត្រូវទទួលទោសដល់ស្លាប់។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលចាប់ជំរិតប្រាកដជាត្រូវសម្លាប់ចោល»
អស់អ្នកណាដែលដាក់បណ្តាសាឪពុក ឬម្តាយត្រូវទទួលទោសដល់ស្លាប់។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
អស់អ្នកណាដែលដាក់បណ្តាសាឪពុក ឬម្តាយរបស់ខ្លួនប្រាកដជាត្រូវសម្លាប់»
Exodus 21:18
ធ្វើឲ្យគាត់ដេកនៅលើគ្រែ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មិនអាចចេញពីគ្រែបាន» ឬ «ត្រូវតែនៅលើគ្រែ»
ហើយអាចដើរ
«កាន់តែប្រសើរឡើង»
ឈើច្រាត់
នេះគឺឈើទប់ ដែលអាចទប់ទ្រពេលដើរ។
ត្រូវបង់ថ្លៃខាតពេលវេលារបស់គាត់
នេះសំដៅទៅលើស្ថានភាពនៅពេលមនុស្សណាម្នាក់ មិនអាចធ្វើការដើម្បីរកប្រាក់។
អ្នកអាចបង្ហាញចំណុចនេះយ៉ាងច្បាស់នៅក្នុងការបកប្រែ។
ការបកប្រែផ្សេងទៀត«ពេលវេលាដែលគាត់មិនអាចធ្វើការបាន»
ក៏ត្រូវបង់ថ្លៃរហូតទាល់តែអ្នកនោះបានជាដែរ។
«បង់ថ្លៃថ្នាំពេទ្យរបស់គាត់» ឬ «បង់ថ្លៃព្យាបាលរបស់គាត់»
Exodus 21:20
ដោយសារបុរសនោះ
«ដោយសារតែការរងរបួស» ឬ «ដោយសារតែចៅហ្វាយរបស់គាត់វាយគាត់»
បុរសនោះត្រូវមានទោស។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវដាក់ទោសមនុស្សនោះ»
ដ្បិតគាត់បានឈឺចាប់ដោយសារបាត់បង់អ្នកបម្រើនោះ។
អ្នកអាចបង្ហាញយ៉ាងច្បាស់នៅក្នុងការបកប្រែថា
អ្នកបម្រើមានតម្លៃចំពោះចៅហ្វាយរបស់គាត់។ ការបកប្រែផ្សេងទៀត
«ពីព្រោះគាត់បានបាត់បង់អ្នកបម្រើរបស់គាត់ ដែលមានតម្លៃសម្រាប់គាត់»
Exodus 21:22
នាងរលូតកូន
«ទារកបានស្លាប់នៅក្នុងពោះរបស់នាង» ឬ
«កូនរបស់នាងបានកើតមុនពេលកំណត់ច្រើនពេកហើយស្លាប់»
កំហុសរបស់បុរសម្នាក់នោះត្រូវពិនិត្យតាមការទាមទារ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
អ្នកប្រាកដជាត្រូវពិន័យមនុស្សដែលមានកំហុស» ឬ «
មនុស្សដែលមានកំហុសត្រូវតែពិន័យជាប្រាក់»
តាមការសម្រេចក្តីរបស់ចៅក្រម។
«អ្វីដែលចៅក្រមសម្រេចចិត្ត»
អ្នកត្រូវឲ្យជីវិតសងដោយជីវិតហើយភ្នែកសងដោយភ្នែក
នេះមានន័យថាប្រសិនបើនាងឈឺចាប់
មនុស្សដែលធ្វើបាបនាងត្រូវតែឈឺចាប់ដូចគ្នា។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែលះបង់ជីវិតរបស់គាត់សម្រាប់សងជីវិតរបស់នាង
ភ្នែករបស់គាត់សម្រាប់សងភ្នែករបស់នាង»
Exodus 21:26
ប្រសិនបើ បុរសម្នាក់
នៅទីនេះ «បុរស» សំដៅទៅលើមនុស្សដែលជាម្ចាស់ផ្ទាល់របស់ទាសករ។
ជាថ្លៃសងជំងឺចិត្ត
«ជាការទូទាត់ប្រាក់សំណង»
សំណងគឺជាអ្វីដែលមនុស្សណាម្នាក់ធ្វើសម្រាប់មនុស្សម្នាក់ផ្សេងទៀត
ឬផ្តល់ឱ្យអ្នកដទៃដើម្បីបំពេញនូវអ្វីដែលគាត់បានធ្វើឱ្យមនុស្សនោះបាត់បង់។
Exodus 21:28
ជល់
«រងរបួសដោយសារស្នែងរបស់គោ»
គោនោះទៅចោលនឹងដុំថ្មសម្លាប់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
អ្នកត្រូវតែយកដុំថ្មគប់គោដល់ស្លាប់» (សូមមើល
ហើយមិនត្រូវស៊ីសាច់របស់វាឡើយ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវបរិភោគសាច់របស់វាទេ»
ម្ចាស់គោមិនត្រូវរាប់ជាមានទោសឡើយ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែលើកលែងទោសម្ចាស់គោ»
ចែមទាំងសម្លាប់ម្ចាស់វាដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកក៏ត្រូវសម្លាប់ម្ចាស់របស់វាដែរ»
ប្រសិនបើ ការបង់ថ្លៃតម្រូវឲ្យបង់ថ្លៃលោះជីវិតរបស់គាត់
ប្រសិនបើម្ចាស់គោអាចបង់ប្រាក់ពិន័យដើម្បីសង្គ្រោះជីវិតផ្ទាល់របស់ខ្លួន
បន្ទាប់មកគាត់ត្រូវបង់ប្រាក់តាមអ្វីដែលចៅក្រមសម្រេច។
អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
នេះក៏អាចត្រូវបានបញ្ជាក់ជាទម្រង់សកម្មផងដែរ។ ការបកប្រែផ្សេងទៀត
«ប្រសិនបើម្ចាស់គោអាចបង់ប្រាក់ពិន័យដើម្បីជួយសង្គ្រោះជីវិតរបស់គាត់
គាត់ត្រូវតែបង់ចំនួនទឹកប្រាក់ដែលចៅក្រមបាននិយាយថាគាត់ត្រូវតែបង់ប្រាក់»
Exodus 21:31
ជល់
«បានរងរបួសដោយស្នែងរបស់គោ»
សាមសិបសេកែល
«ប្រាក់ ៣៣០ ក្រាម» ។ មួយសេកែលមានទម្ងន់ដប់មួយក្រាម។
គោនោះត្រូវចោលសម្លាប់នឹងដុំថ្ម។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែសម្លាប់គោដោយគប់នឹងដុំថ្មវា»
Exodus 21:33
បើកអណ្តូងចោល
«រកឃើញប្រហោងក្នុងដី» ឬ «យកគម្របបិទប្រហោងក្នុងដី»
ត្រូវបង់លុយ
ម្ចាស់កម្មសិទ្ធផ្ទាល់ត្រូវតែទទួលបានប្រាក់សម្រាប់ការបាត់បង់សត្វរបស់គាត់។
ការបកប្រែផ្សេងទៀត «បង់លុយឲ្យម្ចាស់សត្វដែលស្លាប់»
ជាកម្មសិទ្ធិរបស់គាត់។
អ្នកដែលបានចំណាយសម្រាប់ការបាត់បង់សត្វនេះនឹងក្លាយជាម្ចាស់នៃសត្វដែលបានស្លាប់
ហើយអាចធ្វើអ្វីដែលគាត់ចង់បានជាមួយវា។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «នឹងជាកម្មសិទ្ធិផ្ទាល់របស់រណ្តៅនោះ»
Exodus 21:35
ហើយចែកគ្នា
«ចែកលុយ» ឬ «ចែកលុយដែលពួកគេទទួល»
ប្រសិនបើដឹងថា
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើមនុស្សបានស្គាល់» ឬ «ប្រសិនបើម្ចាស់បានដឹង»
មានទម្លាប់ជល់ពីមុន
«បានជល់គោផ្សេងៗពីមុន»

generated on Wed Sep 10 16:16:32 2025

ម្ចាស់គោនោះនៅតែទុកគោនោះទៀត
នេះមានន័យថាម្ចាស់មិនបានទុកគោរបស់ខ្លួននៅក្នុងរបងដោយសុវត្ថិភាពឡើយ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«ម្ចាស់របស់វាមិនបានទុកវានៅក្នុងរបងទេ»
គាត់ត្រូវលក់គោនោះបង់ថ្លៃម្ចាស់គោ
ម្ចាស់គោដែលបានសម្លាប់គោត្រូវប្រគល់គោមួយអោយមនុស្សដែលបាត់បង់គោ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«ម្ចាស់គោដែលបានសម្លាប់ត្រូវតែប្រគល់គោ
ដែលនៅរស់អោយម្ចាស់គោដែលស្លាប់»

---

22 [1]ប្រសិនបើ បុរសណាម្នាក់លួចគោ ឬចៀម ហើយសម្លាប់វា ឬលក់វា អ្នកនោះត្រូវបងថ្លៃគោមួយជាប្រាំ ហើយចៀមមួយជាបួនវិញ។[2]ប្រសិនបើ ទាន់ចោរកំពុងតែលួច
ហើយ ប្រសិនបើគេវាយគាត់រហូតដល់ស្លាប់ នៅក្នុងករណីនេះ អ្នកសម្លាប់អ្នកនោះគ្មានទោសទេ។[3]ប៉ុន្តែ ប្រសិនបើ គេទាន់ចោរនៅពេលថ្ងៃ
អ្នកដែលសម្លាប់ចោរនោះ នឹងមានទោស។ ត្រូវពិន័យចោរនោះ។ ប្រសិនបើ គាត់គ្មានប្រាក់សងទេ ដូច្នេះត្រូវលក់ចោរនោះ ដោយព្រោះគាត់បានលួច។[4]ប្រសិនបើ
រកឃើញសត្វដែលត្រូវគេលួចនោះនៅរស់នៅក្នុងកណ្តាប់ដៃរបស់អ្នកលួច ទោះបើគោ លា ឬចៀម នោះគាត់ត្រូវសងមួយជាពីរ។
[5]ប្រសិនបើ បុរសណាម្នាក់ឲ្យហ្វូងសត្វរបស់ខ្លួនស៊ីបំផ្លាញស្មៅ ឬចម្ការទំពាំងបាយជូរ ហើយប្រលែងសត្វរបស់គាត់ចោល ហើយវាស៊ីបំផ្លាញចម្ការរបស់អ្នកដទៃ
អ្នកនោះត្រូវយកផលដែលល្អបំផុតពីស្រែចម្ការ និងពីចម្ការទំពាំងបាយជូររបស់ខ្លួនទៅសងអ្នកនោះវិញ។
[6]ប្រសិនបើ អ្នកណាដុតគុម្ពបន្លា ហើយភ្លើងឆេះរាល ហើយឆេះដល់កណ្តាប់ស្រូវ ឬត្រូវដែលទុំ ឬស្រូវមិនទាន់ទុំក្តី អ្នកដែលដុតភ្លើងនោះត្រូវសងទៅម្ចាស់ស្រែវិញ។
[7]ប្រសិនបើ ឲ្យប្រាក់ ឬរបស់របស់គាត់ទៅអ្នកជិតខាងទុក ហើយប្រសិនបើ មានចោរលួចរបស់នោះចេញពីផ្ទះរបស់បុរសដែលទុកនោះ ហើយប្រសិនបើចាប់ចោរបាន
នោះចោរត្រូវសងមួយជាពីរ។[8]ប៉ុន្តែ ប្រសិនបើ រកចោរមិនឃើញទេ ដូច្នេះ ម្ចាស់ផ្ទះត្រូវមកចំពោះចៅក្រម
ហើយមើលថាគាត់មិនបានរួមដៃលួចរបស់អ្នកជិតខាងរបស់គាត់ឡើយ។[9]គ្រប់ទាំងជម្លោះពីអ្វីៗគ្រប់យ៉ាង ទោះបើ គោ លា ចៀម ឬសម្លៀកបំពាក់
ឬរបស់អ្នកណាម្នាក់បាត់ ហើយមានអ្នកប្រកាសថា «វាជាកម្មសិទ្ធិរបស់ខ្ញុំ» ទាំងពីរនាក់ នោះត្រូវនាំទៅចៅក្រម។ បុរសដែលចៅក្រមរកឃើញកំហុស
ត្រូវសងអ្នកជិតខាងរបស់ខ្លួនមួយជាពីរ។
[10]ប្រសិនបើ បុរសម្នាក់ផ្ញើលា គោ និងចៀម ឬសត្វផ្សេងទៀតឲ្យអ្នកជិតខាងគាត់មើលឲ្យ ហើយប្រសិនបើវាងាប់ ឬឈឺ
ឬត្រូវបានគេយកទៅបាត់ដោយគ្មាននរណាឃើញវាទេ។[11]អ្នកទាំងពីរត្រូវស្បថជាមួយនឹងព្រះអម្ចាស់ ដើម្បីបញ្ជាក់ថា អ្នកទទួលបញ្ញើមិនបានចូលដៃយករបស់ទ្រព្យ
អ្នកជិតខាងរបស់គាត់ទេ។ ហើយម្ចាស់សត្វត្រូវតែទទួលយកការនេះ ហើយអ្នកម្នាក់ទៀតមិនតម្រូវឲ្យមានសំណងឡើយ។[12]ប៉ុន្តែ ប្រសិនបើ វាត្រូវបានគេលួចពីគាត់ ដូច្នេះ
អ្នកទទួលបញ្ញើនឹងសងទៅម្ចាស់វាវិញ។[13]ប្រសិនបើ សត្វនោះត្រូវបានកាប់ជាបំណែកៗ ចូរឲ្យបុរសនោះនាំសត្វនោះមក ដើម្បីធ្វើជាភស្តុតាង។
គាត់នឹងមិនត្រូវបង់ថ្លៃដើម្បីអ្វីដែលបានកាត់ជាបំណែកៗនោះទេ។
[14]ប្រសិនបើ បុរសណាម្នាក់ ខ្ចីសត្វពីអ្នកជិតខាងរបស់គាត់ ហើយសត្វនោះមានរបួសឬស្លាប់ដោយម្ចាស់មិនបានឃើញវា អ្នកខ្ចីត្រូវសងពេញថ្លៃ។[15]ប៉ុន្តែ ប្រសិនបើ
ម្ចាស់នៅជាមួយ អ្នកខ្ចីមិនចាំបាច់សងទេ ប្រសិនបើ ជួល តែត្រូវបង់ថ្លៃជួលវា។
[16]ប្រសិនបើ បុរសណាម្នាក់បោកប្រាស់ស្រីក្រមុំ ដែលមិនបានភ្ជាប់ពាក្យ ហើយប្រសិនបើ បានគេងជាមួយនាង គាត់ត្រូវតែយកនាងមកធ្វើជាប្រពន្ធ
ត្រូវបង់ថ្លៃបណ្តាការតាមការតម្រូវ។[17]ប្រសិនបើ ឪពុករបស់នាងបដិសេធឲ្យនាងទៅគាត់ គាត់ត្រូវបង់ប្រាក់តាមបណ្តាការរបស់ស្រីក្រមុំ។
[18]អ្នកមិនត្រូវអនុញ្ញាតឲ្យគ្រូមន្តអាគមនៅរស់ឡើយ។[19]អស់អ្នកណាដែលរួមរ៉ែកជាមួយសត្វ ត្រូវសម្លាប់អ្នកនោះចោល។
[20]អស់អ្នកណាដែលថ្វាយយញ្ញបូជាដល់ព្រះផ្សេងក្រៅពីព្រះអម្ចាស់ ត្រូវបំផ្លាញអ្នកនោះចោលទាំងស្រុង។[21]អ្នកមិនត្រូវធ្វើខុសជាមួយជនបរទេស
ឬសង្កត់សង្កិនពួកគេឡើយ ដ្បិត អ្នកក៏ជាជនបរទេសនៅក្នុងទឹកដីអេស៊ីបដែរ។
[22]អ្នកមិនត្រូវធ្វើបានស្ត្រីមេម៉ាយ ឬកូនកំព្រាណាឡើយ។[23]ប្រសិនបើអ្នកធ្វើទុក្ខដល់ពួកគេ ហើយពួកគេអំពាវនាវរកយើង យើងប្រាកដជាបានឮពួកគេអំពាវនាវរកយើង។
[24]យើងនឹងមានសេចក្តីក្រោធ ហើយយើងនឹងសម្លាប់អ្នកដោយមុខដាវ ប្រពន្ធរបស់អ្នកនឹងក្លាយជាស្ត្រីមេម៉ាយ ហើយកូនរបស់អ្នកនឹងក្លាយជាកូនកំព្រា។
[25]ប្រសិនបើ អ្នកឲ្យអ្នកណាម្នាក់ដែលជារាស្ត្ររបស់យើងខ្ចីក្នុងចំណោមអ្នក ដែលក្រ អ្នកមិនត្រូវធ្វើដូចជាអ្នកចងការដល់គាត់ ឬយកការប្រាក់ពីគាត់ឡើយ។[26]ប្រសិនបើ
អ្នកទទួលបញ្ចាំអាវធំអ្នកជិតខាង អ្នកត្រូវប្រគល់វាឲ្យទៅគាត់វិញមុនពេលថ្ងៃលិច ដ្បិតអាវធំនោះសម្រាប់ដណ្តប់គាត់ វាគឺជាអាវធំសម្រាប់ដណ្តប់រូបកាយរបស់គាត់។
[27]តើគាត់បានអ្វីមកដណ្តប់នៅពេលគាត់គេង? នៅពេលអ្នកនោះអំពាវនាវរកយើង យើងនឹងស្តាប់គាត់ ដ្បិតយើងមានចិត្តមេត្តា។
[28]អ្នកមិនត្រូវប្រមាថយើងឡើយ ឬដាក់បណ្តាសាអ្នកគ្រប់គ្រងលើអ្នកឡើយ។
[29]អ្នកមិនត្រូវយកតង្វាយពីចម្រូតរបស់អ្នក ឬពីកន្លែងបញ្ជាន់ទំពាំងបាយជូរឡើយ។ អ្នកត្រូវប្រគល់កូនប្រុសច្បងរបស់អ្នកទុកសម្រាប់យើង។
[30]ហើយអ្នកត្រូវធ្វើជាមួយគោ និងចៀមរបស់អ្នកដែរ។ ដ្បិត ទុកពេលប្រាំពីរថ្ងៃ ឲ្យពួកគេនៅជាមួយម្តាយរបស់វា ប៉ុន្តែ នៅថ្ងៃទីប្រាំបី អ្នកត្រូវប្រគល់ពួកគេមកឲ្យយើង។
អ្នកនឹងត្រូវជាប្រជាជនដែលត្រូវបានញែកដោយឡែកសម្រាប់យើង។[31]ដូច្នេះ អ្នកមិនត្រូវហូបសាច់ណាដែលត្រូវសត្វព្រៃហែកស៊ីនៅឯវាលឡើយ។ ផ្ទុយទៅវិញ
អ្នកត្រូវបោះវាចោល ឲ្យឆ្កែវិញ។

Exodus 22:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល
ប្រសិនបើទាន់ចោរ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត«ប្រសិនមនុស្សណាម្នាក់រកឃើញចោរ» (សូមមើល
កំពុងតែលួច
«ប្រើកម្លាំងដើម្បីចូលទៅក្នុងផ្ទះ»
ប្រសិនបើគេវាយគាត់រហូតដល់ស្លាប់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនមនុស្សណាម្នាក់វាយចោរដូច្នេះរហូតវាស្លាប់»
អ្នកសម្លាប់អ្នកនោះគ្មានទោសទេ។
«គ្មាននរណាម្នាក់នឹងមានកំហុសក្នុងការសម្លាប់ចោរ»
ប្រសិនបើ គេទាន់ចោរនៅពេលថ្ងៃ
«ប្រសិនបើថ្ងៃរះមុនពេលគាត់តាមទាន់» ឬ
«ប្រសិនបើគាត់តាមទាន់ហើយបន្ទាប់មកព្រះអាទិត្យរះ»
នឹងមានទោស។ ត្រូវពិន័យចោរនោះ។
«អ្នកដែលសម្លាប់គាត់នឹងមានទោសពីបទឃាតកម្ម»
គ្មានប្រាក់សងទេ
«ប្រសិនបើគាត់គ្មានអ្វីសងសម្រាប់អ្វីដែលគាត់បានលួច»
ដោយព្រោះគាត់បានលួច។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែលក់គាត់
ឱ្យធ្វើជាទាសករដើម្បីបង់ថ្លៃនូវអ្វីដែលគាត់បានលួច»
ប្រសិនបើ រកឃើញសត្វដែលត្រូវគេលួចនោះនៅរស់នៅក្នុងកណ្តាប់ដៃរបស់អ្នកលួច
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើពួកគេរកឃើញថាគាត់នៅតែមានសត្វ មានជីវិតដែលគាត់បានលួច»
ត្រូវសងមួយជាពីរ។
សងសត្វពីរសម្រាប់សត្វនីមួយៗដែលគាត់បានយក
Exodus 22:5
ប្រសិនបើ បុរសណាម្នាក់ឲ្យហ្វូងសត្វរបស់ខ្លួន
«ប្រសិនបើបុរសអនុញ្ញាតឱ្យសត្វរបស់គាត់ស៊ីបំផ្លាញផលដំណាំ»
វាស៊ីបំផ្លាញចម្ការ
«វាស៊ីបំផ្លាញផលដំណាំ»
អ្នកនោះត្រូវយកផល

generated on Wed Sep 10 16:16:32 2025

«គាត់ត្រូវសងម្ចាស់ស្រែចំការនោះវិញ»
Exodus 22:6
ប្រសិនបើ អ្នកណាដុតគុម្ពបន្លា ហើយភ្លើងឆេះរាល
«ប្រសិនបើមនុស្សណាម្នាក់ចាប់ផ្តើមដុតភ្លើងហើយឆេះរាលដាលដល់គុម្ពបន្លា»
ភ្លើងឆេះរាល
«រាលទៅតាមដីដែលមានស្រូវស្ងួត»
ឆេះដល់កណ្តាប់ស្រូវ
នេះគឺជាស្រូវដែលត្រូវបានគេកាត់និងចងជាបាច់។ «កណ្តាប់ស្រូវ» ឬ
«អ្នកច្រូតស្រូវ»
ស្រូវដែលទុំ
នេះគឺជាស្រូវដែលមិនទាន់ត្រូវបានគេកាត់ ប៉ុន្តែវាជារដូវត្រូវប្រមូលផលហើយ។
ស្រូវមិនទាន់ទុំក្តី
«ភ្លើងឆេះស្រូវមិនទានទុំ» ឬ «ភ្លើងឆេះបំផ្លាញវាលស្រែ»
ត្រូវសងទៅម្ចាស់ស្រែវិញ។
«ពិតប្រាកដជាត្រូវសងសម្រាប់ដែលភ្លើងឆេះបំផ្លាញ»
Exodus 22:7
ដើម្បីរក្សាសុវត្ថិភាព
«ឃ្លាំមើលវា» ឬ «ដើម្បីរក្សាវាឱ្យមានសុវត្ថិភាព»
ហើយប្រសិនបើ មានចោរលួច
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនមនុស្សណាម្នាក់លួចវា»
ចោរ
មនុស្សម្នាក់ដែលលួចអ្វីមួយ
ហើយប្រសិនបើចាប់ចោរបាន
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នករកឃើញចោរ»
ត្រូវមកចំពោះចៅក្រម ហើយមើលថា
«មកចំពោះមុខចៅក្រម ដើម្បីឱ្យពួកគេអាចមើលឃើញថា»
បានរួមដៃលួចរបស់អ្នកជិតខាងរបស់គាត់ឡើយ។
នេះគឺជាឃ្លា។
ប្រសិនបើអ្នកមានរបៀបនៃការនិយាយបែបនេះជាភាសារបស់អ្នកអ្នកអាចប្រើវានៅទីនេះ។
ការបកប្រែផ្សេងទៀត «បានលួចទ្រព្យសម្បត្តិអ្នកជិតខាងរបស់គាត់»
ទាំងពីរនាក់ នោះត្រូវនាំទៅចៅក្រម។
ចៅក្រមត្រូវស្តាប់អ្នកទាំងពីរដែលអះអាងថារបស់នោះជាកម្មសិទ្ធរបស់ពួកគេ
ហើយចៅក្រមនឹងសម្រេចថានរណាជាអ្នកមានទោស។
Exodus 22:10
អ្នកទាំងពីរត្រូវស្បថជាមួយនឹងព្រះអម្ចាស់
មានតែមនុស្សដែលត្រូវបានចោទប្រកាន់ថាបានលួចសត្វនោះទេត្រូវតែស្បថ។
ម្ចាស់សត្វដែលបាត់បង់ត្រូវតែទទួលយកពាក្យសម្បថដែលបានស្បថ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលថែរក្សាសត្វនោះត្រូវតែស្បថនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ហើយម្ចាស់ផ្នែកដទៃទៀតត្រូវតែ
ប៉ុន្តែ ប្រសិនបើ វាត្រូវបានគេលួចពីគាត់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែប្រសិនបើមានមនុស្សណាម្នាក់លួចសត្វពីគាត់»
ប្រសិនបើ សត្វនោះត្រូវបានកាប់ជាបំណែកៗ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែប្រសិនបើសត្វព្រៃហែកសត្វជាបំណែក ៗ »
គាត់នឹងមិនត្រូវបង់ថ្លៃដើម្បីអ្វីដែលបានកាត់ជាបំណែកៗនោះទេ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់នឹងមិនចាំបាច់បង់ប្រាក់សម្រាប់សត្វដែលសត្វព្រៃរបានបំផ្លាញទេ»
Exodus 22:14
ត្រូវសងពេញថ្លៃ
«ត្រូវសងបំណុលជាមួយសត្វផ្សេងទៀត» ឬ «ត្រូវសងឲ្យម្ចាស់សត្វផ្ទាល់»
ប្រសិនបើជួល
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើមនុស្សណាម្នាក់ជួលសត្វ»
តែត្រូវបង់ថ្លៃជួលវា។
អ្នកដែលបានខ្ចីសត្វនោះ នឹងមិនត្រូវសងថ្លៃអ្វីដល់ម្ចាស់សត្វបន្ថែមលើថ្លៃជួល
ឬថ្លៃឈ្នួលឡើយ។ ថ្លៃឈ្នួលនេះនឹងត្រូវបង់សម្រាប់ការបាត់បង់សត្វ។
នេះអាចត្រូវបានថ្លែងយ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«ប្រាក់ដែលមនុស្សណាម្នាក់បានសង
ដើម្បីជួលសត្វនឹងចេញថ្លៃទាំងអស់នៃការបាត់បង់សត្វ»
ថ្លៃជួល
«ថ្លៃជួល» ឬ «ប្រាក់ដែលសងចំពោះការជួលសត្វ»
Exodus 22:16
បោកប្រាស់
«បញ្ចុះបញ្ចូល»
ដែលមិនបានភ្ជាប់ពាក្យ
«មិនបានសន្យាថានឹងរៀបការ»
ហើយប្រសិនបើ បានគេងជាមួយនាង
ការគេងជាមួយមនុស្សណាម្នាក់ គឺជាការអរសប្បាយចំពោះការរួមភេទ។
ការបកប្រែផ្សេងទៀត «ប្រសិនបើគាត់រួមភេទជាមួយនាង»
ត្រូវបង់ប្រាក់តាមបណ្តាការ
«ថ្លៃបណ្តាការ» ឬ «ថ្លៃកូនក្រមុំ»
គាត់,គាត់
សព្វនាមទាំងនេះសំដៅទៅលើមនុស្សដែលបោកប្រាសស្រីក្រមុំ។
Exodus 22:18
អស់អ្នកណាដែលរួមរ៉ែកជាមួយសត្វ ត្រូវសម្លាប់អ្នកនោះចោល។
នៅទីនេះ «ដេកជាមួយសត្វ»
គឺជាការត្រេកត្រអាលដែលមានន័យថាមនុស្សម្នាក់រួមភេទជាមួយសត្វ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវសម្លាប់ អ្នកណាដែលរួមភេទជាមួយសត្វ»
Exodus 22:20
ព្រះអម្ចាស់ ត្រូវបំផ្លាញអ្នកនោះចោលទាំងស្រុង។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់អើយ
ព្រះអង្គត្រូវតែបំផ្លាញទាំងស្រុង»
Exodus 22:22
អ្នកមិនត្រូវធ្វើបានស្ត្រីមេម៉ាយ ឬកូនកំព្រាណាឡើយ។
នេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែប្រព្រឹត្តចំពោះស្ត្រីមេម៉ាយ និងកូនដែលគ្មានឪពុកដោយយុត្តិធម៌»
ស្ត្រីមេម៉ាយ
«ស្ត្រីដែលប្តីបានស្លាប់»
កូនកំព្រា
«ក្មេងកំព្រា» ឬ «កូនដែលគ្មានឪពុកម្តាយ»
យើងនឹងសម្លាប់អ្នកដោយមុខដាវ
ត្រូវបានសម្លាប់ «ដោយមុខដាវ» គឺជាពាក្យប្រៀបធៀបដែលមានន័យថា
មនុស្សម្នាក់នឹងស្លាប់យ៉ាងសាហាវ ឬប្រហែលជាកំពុងប្រយុទ្ធនៅក្នុងសង្គ្រាម។
ការបកប្រែផ្សេងទៀត «អ្នកនឹងស្លាប់ដោយសាហាវ»
Exodus 22:25
ឬត្រូវតែ
ទទួលយកពាក្យសម្បថនោះ»
«អ្នកណាអោយខ្ចីប្រាក់»
យកការប្រាក់ពីគាត់
«យកប្រាក់បន្ថែមពីគាត់សម្រាប់ការខ្ចីប្រាក់» ឬ
«យកប្រាក់បន្ថែមពីគាត់សម្រាប់ប្រាក់កម្ចី»
អ្នកទទួលបញ្ចាំអាវធំ
«អាវធំជាវត្ថុបញ្ចាំ» ឬ «អាវធំជាការធានាដើម្បីសងការខ្ចីប្រាក់»
មកដណ្តប់
«មានតែអាវ» ឬ «សម្លៀកបំពាក់តែមួយគត់ដើម្បីធ្វើឱ្យគាត់មានភាពកក់ក្តៅ»
តើគាត់បានអ្វីមកដណ្តប់នៅពេលគាត់គេង?
សំណួរនេះបន្ថែមការសង្កត់ធ្ងន់។ អ្នកអាចបកប្រែវាជាសេចក្តីថ្លែងការណ៍ដ៏រឹងមាំ។
ការបកប្រែផ្សេងទៀត «គាត់នឹងមិនមានអ្វីស្មៀកពាក់ទេ ពេលគាត់គេង!»
មានចិត្តមេត្តា។
«មេត្តាករុណា» ឬ «មានព្រះគុណ»
Exodus 22:28
អ្នកមិនត្រូវប្រមាថយើងឡើយ
«កុំប្រមាថព្រះជាម្ចាស់» ឬ «កុំនិយាយអាក្រក់អំពីព្រះជាម្ចាស់»
ឬដាក់បណ្តាសាអ្នកគ្រប់គ្រង
«ហើយកុំសុំអោយព្រះជាម្ចាស់ ធ្វើអំពើអាក្រក់ចំពោះអ្នកគ្រប់គ្រង»

generated on Wed Sep 10 16:16:32 2025

Exodus 22:29
អ្នកមិនត្រូវយកតង្វាយ
នេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែនាំយកតង្វាយទាំងអស់របស់អ្នក»
ប្រគល់កូនប្រុសច្បងរបស់អ្នកទុកសម្រាប់យើង។
«លះបង់កូនប្រុសច្បង របស់អ្នកអោយយើង»
ត្រូវធ្វើជាមួយ
«ថ្វាយកូនច្បងដល់យើង»
ទុកពេលប្រាំពីរថ្ងៃ
នេះអាចត្រូវបានសរសេរជាចំនួនលេខ។ ការបកប្រែផ្សេងទៀត «រយៈពេល ៧
ថ្ងៃបន្ទាប់ពីពួកគេកើត»
នៅថ្ងៃទីប្រាំបី
នេះអាចត្រូវបានសរសេរជាចំនួនលេខ។ ការបកប្រែផ្សេងទៀត «ថ្ងៃទី ៨»
សម្រាប់យើង
«ថ្វាយពួកគេអោយយើង»

23

[1]អ្នកមិនត្រូវផ្តល់ទីបន្ទាល់ក្លែងក្លាយពីនរណាម្នាក់ឡើយ។[2]កុំចូលរួមជាមួយមនុស្សអាក្រក់ ហើយធ្វើជាសាក្សីក្លែងក្លាយឡើយ។ អ្នកមិនត្រូវដើរតាមបណ្តាជនធ្វើការអាក្រក់ ឬធ្វើសាក្សីនៅខាងមនុស្សភាគច្រើន ដើម្បីបង្ខូចសេចក្តីសុចរិតឡើយ។[3]អ្នកក៏មិនត្រូវយោគយល់ដល់អ្នកក្រណាម្នាក់នៅក្នុងរឿងក្តីរបស់គាត់ឡើយ។
[4]ប្រសិនបើ អ្នកជួបប្រទះឃើញគោរបស់សត្រូវ ឬលារបស់អ្នកវង្វេង អ្នកត្រូវនាំវាត្រឡប់ទៅឲ្យម្ចាស់វាវិញ។[5]ប្រសិនបើ អ្នកឃើញលារបស់នរណាម្នាក់ ដែលស្អប់អ្នកទន់ជង្គង់ដួលដោយសារបន្ទុកធ្ងន់ អ្នកមិនត្រូវដើរចេញពីអ្នកនោះឡើយ។ អ្នកត្រូវជួយដល់គាត់និងលារបស់គាត់វិញ។
[6]អ្នកមិនត្រូវបង្វែរសេចក្តីយុត្តិធម៌ នៅពេលអ្នកកាត់ក្តីឲ្យប្រជាជនក្រីក្រឡើយ។[7]មិនត្រូវចូលរួមជាមួយអ្នកដទៃ ធ្វើរឿងក្លែងក្លាយទាស់ និងមិនត្រូវសម្លាប់មនុស្សទៀងត្រង់ ឬមនុស្សសុចរិតឡើយ ដ្បិតយើងមិនលើកលែងឲ្យមនុស្សទុច្ចរិតឡើយ។[8]កុំស៊ីសំណូកឲ្យសោះ ដ្បិតសំណូកនឹងធ្វើឲ្យមនុស្សខ្វាក់ភ្នែក
ហើយបង្វែរពាក្យទៀតរបស់មនុស្ស។[9]អ្នកមិនត្រូវសង្កត់សង្កិនជនបរទេសឡើយ ព្រោះអ្នកដឹងពីជីវិតនៃភាពជាជនបរទេសហើយ ដ្បិត
អ្នកក៏ធ្លាប់ជាជនបរទេសនៅក្នុងទឹកដីអេស៊ីបដែរ។
[10]ដ្បិត ក្នុងរយៈពេលប្រាំមួយឆ្នាំ អ្នកនឹងសាបព្រោះនៅលើដីរបស់អ្នក ហើយប្រមូលផលរបស់វា។ ប៉ុន្តែ នៅឆ្នាំទីប្រាំពីរ អ្នកមិនត្រូវភ្ជួររាស់ ឬដាំអ្វីឡើយ ធ្វើដូច្នេះ ដើម្បីឲ្យអ្នកក្រនៅក្នុងចំណោមប្រជាជនរបស់អ្នកអាចមានអ្វីហូប។[11]ហើយនៅពេលពួកគេទុកដីចោល សត្វព្រៃនឹងមកស៊ីអ្វីៗដែលនៅសេសសល់នោះ។
អ្នកត្រូវធ្វើដូចគ្នានៅក្នុងចម្ការទំពាំងបាយជូរ និងចម្ការអូលីវរបស់អ្នកដែរ។
[12]នៅក្នុងអំឡុងពេលប្រាំមួយថ្ងៃ អ្នកត្រូវធ្វើការរបស់អ្នក ប៉ុន្តែ នៅថ្ងៃទីប្រាំពីរ អ្នកត្រូវសម្រាក។ ធ្វើបែបនេះ ជាមួយគោ និងលារបស់អ្នកដែរ ដើម្បីឲ្យវាបានសម្រាក ហើយឲ្យកូនប្រុសរបស់អ្នកបម្រើស្រីរបស់អ្នក និងជនបរទេសបានសម្រាកនិងបានទទួលការលំហែផង។
[13]ចូរយកចិត្តទុកដាក់ចំពោះអ្វីៗគ្រប់យ៉ាងដែលយើងបានប្រាប់ដល់អ្នក។ កុំបញ្ចេញនាមរបស់ព្រះផ្សេងៗ ឬកុំឲ្យឈ្មោះរបស់ព្រះដទៃចេញពីមាត់របស់អ្នកឡើយ។
[14]អ្នកត្រូវធ្វើដំណើរទៅចូលរួមពិធីបុណ្យសម្រាប់យើងបីដងក្នុងមួយឆ្នាំ រៀងរាល់ឆ្នាំ។[15]អ្នកត្រូវរក្សាពិធីបុណ្យនំបុ័ងឥតមេ។ ដូចយើងបានបង្គាប់ដល់អ្នក
អ្នកត្រូវហូបនំបុ័ងឥតមេនេះក្នុងរយៈពេលប្រាំពីរថ្ងៃ។ នៅថ្ងៃនោះ អ្នកត្រូវបង្ហាញខ្លួននៅចំពោះយើង នៅក្នុងខែអាប៊ីប ដែលបានកំណត់សម្រាប់គោលបំណងនេះ។
វាស្ថិតនៅក្នុងខែដែលអ្នកបានចេញពីអេស៊ីបមក។ ប៉ុន្តែ អ្នកមិនត្រូវបង្ហាញខ្លួននៅចំពោះយើងដោយដៃទទេឡើយ។
[16]អ្នកត្រូវរក្សាពិធីបុណ្យចម្រូត ផលដំបូងពីការនឿយហត់ ពេលអ្នកសាបព្រោះពូជនៅលើដីស្រែ។ ហើយត្រូវរក្សាពិធីបុណ្យនៃការប្រមូលផល នៅចុងឆ្នាំដែរ
នៅពេលអ្នកប្រមូលផលនៃដំណាំពីចម្ការរបស់អ្នក។[17]អ្នកបម្រើប្រុសទាំងអស់របស់អ្នកត្រូវបង្ហាញខ្លួននៅចំពោះព្រះអម្ចាស់ បីដងក្នុងមួយឆ្នាំ។
[18]អ្នកមិនត្រូវថ្វាយឈាមពីយញ្ញបូជាថ្វាយដល់យើងជាមួយនំបុ័ងដែលមានមេឡើយ។ ខ្លាញ់ពីយញ្ញបូជានៅក្នុងពិធីបុណ្យរបស់យើង មិនត្រូវទុកឲ្យនៅរហូតតាំងពីយប់រហូតដល់ព្រឹកឡើយ។[19]អ្នកត្រូវជ្រើសរើសផលដំបូងដែលចេញពីដីរបស់អ្នកមកក្នុងដំណាក់របស់យើង ដំណាក់របស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នក។
អ្នកមិនត្រូវស្ងោពពែឈ្មោលនៅក្នុងទឹកដោះមេរបស់វាឡើយ។
[20]យើងនឹងចាត់ទេវតារបស់យើងនៅពីមុខអ្នក ដើម្បីការពារអ្នកនៅតាមផ្លូវ និងដើម្បីនាំអ្នកទៅកន្លែងដែលយើងបានរៀបចំទុកឲ្យអ្នក។[21]ត្រូវយកចិត្តទុកដាក់ជាមួយលោក ហើយស្តាប់តាមលោក។ មិនត្រូវប្រឆាំងជាមួយនឹងលោកឡើយ ដ្បិតលោកនឹងមិនអត់ទោសដល់អំពើរំលងរបស់អ្នកឡើយ។ នាមរបស់យើងនៅលើលោក។[22]ប្រសិនបើ អ្នកស្តាប់តាមសម្លេងរបស់លោក ហើយធ្វើតាមអ្វីៗដែលយើងបានប្រាប់ដល់អ្នករាល់គ្នា នោះយើងនឹងធ្វើជាសត្រូវ ជាមួយនឹងសត្រូវរបស់អ្នក ហើយក៏ធ្វើជាបច្ចាមិត្ត ប្រឆាំងនឹងបច្ចាមិត្តរបស់អ្នកដែរ។
[23]ទេវតារបស់យើងនឹងទៅមុខអ្នក ហើយនាំអ្នកចូលទៅក្នុងទឹកដីរបស់ជនជាតិអាម៉ូរី ជនជាតិហេត ជនជាតិពេរិស៊ីត ជនជាតិកាណាន ជនជាតិហេវី និងជនជាតិយេប៊ូស។ យើងនឹងបំផ្លាញពួកគេ។[24]អ្នកមិនត្រូវលុតជង្គង់ចុះនៅចំពោះព្រះ របស់ពួកគេ ឬថ្វាយបង្គំ ឬធ្វើអ្វីដូចពួកគេធ្វើឡើយ។ ផ្ទុយទៅវិញ អ្នកត្រូវបោះវាចោល
ហើយវាយកម្ទេចបង្គោលថ្មរបស់ពួកគេឲ្យខ្ទិច។[25]អ្នកត្រូវថ្វាយបង្គំ ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ្នក ហើយព្រះអង្គនឹងឲ្យពរដល់នំបុ័ង និងទឹករបស់អ្នក។
យើងនឹងយកជំងឺចេញពីអ្នករាល់គ្នា។
[26]គ្មានស្ត្រីណាអារ ឬរលូតកូនរបស់នាងនៅក្នុងទឹកដីរបស់អ្នកឡើយ។ យើងនឹងប្រទានឲ្យអ្នកមានអាយុវែង។
[27]យើងនឹងឲ្យជនជាតិទាំងអស់ភ័យខ្លាចអ្នកមុនពេលអ្នកទៅដល់។ យើងនឹងសម្លាប់ប្រជាជនទាំងអស់ដែលអ្នកជួប។
[28]យើងនឹងធ្វើឲ្យសត្រូវរបស់អ្នកបាក់ទ័ពដោយភាពភ័យខ្លាចចំពោះអ្នក។ យើងនឹងចាត់ឪម៉ាល់ទៅមុនអ្នក វានឹងបណ្តេញជនជាតិហេវី ជនជាតិកាណាន និងជនជាតិហេត ចេញពីអ្នក។[29]យើងនឹងមិនបណ្តេញពួកគេឲ្យអស់ ក្នុងរយៈពេលតែមួយឆ្នាំទេ ឬទឹកដីក្លាយទៅជាទីស្មសាន ហើយមានសត្វព្រៃរស់នៅកាន់តែច្រើនឡើងៗឡើយ នាំតែបង្ក ការលំបាកដល់អ្នក។
[30]ផ្ទុយទៅវិញ យើងនឹងបណ្តេញពួកគេបន្តិចម្តងៗ ពីចំពោះមុខអ្នក រហូតទាល់តែអ្នកមានគ្នាច្រើន ហើយកាន់កាប់ទឹកដីនោះ។
[31]យើងនឹងដាក់ព្រំប្រទល់របស់អ្នកពីសមុទ្រដើមត្រែង ដល់សមុទ្រភីលីស្ទីន និងពីទីរហោស្ថានទៅដល់ទន្លេអ៊ើប្រាត។
យើងនឹងប្រទានជ័យជម្នះដល់អ្នកលើអ្នកស្រុកនោះ។ អ្នកនឹងបណ្តេញពួកគេចេញពីមុខអ្នក។[32]អ្នកមិនត្រូវចងសម្ពន្ធមេត្រីជាមួយពួកគេឬ ជាមួយព្រះរបស់ពួកគេឡើយ។
[33]ពួកគេមិនត្រូវរស់នៅក្នុងទឹកដីរបស់អ្នកឡើយ ដ្បិតពួកគេអាចនឹងធ្វើបាបទាស់នឹងយើង។ ប្រសិនបើ អ្នកថ្វាយបង្គំព្រះរបស់ពួកគេ នោះអ្នកនឹងត្រូវឆ្លាក់ទៅក្នុងអន្ទាក់
របស់គេជាមិនខាន»។

Exodus 23:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
ផ្តល់ទីបន្ទាល់ក្លែងក្លាយ
នេះគឺដូចគ្នានឹងការនិយាយកុហក ឬទីបន្ទាល់ក្លែងក្លាយ។
ហើយធ្វើជាសាក្សីក្លែងក្លាយឡើយ។
«ហើយអ្នកក៏មិនត្រូវនិយាយដែរ»
នៅខាងមនុស្សភាគច្រើន
នេះគឺជាពាក្យប្រៀបធៀបដែលពិពណ៌នាអំពីការយល់ព្រមរបស់មនុស្សមួយក្រុម
ដូចជាគាត់បានដើរហើយឈរជាមួយក្រុមនោះ។ ការបកប្រែផ្សេងទៀត
«ធ្វើអ្វីដែលមនុស្សភាគមនុស្សចង់បាន» ឬ «យល់ព្រមជាមួយភាគច្រើន»
បង្ខូចសេចក្តីសុចរិតឡើយ។
ធ្វើសកម្មភាពខុសច្បាប់ឬអសីលធម៌ដែលបណ្តាលឱ្យមានការគ្រប់គ្រងអយុត្តិធម៌

generated on Wed Sep 10 16:16:32 2025

Exodus 23:4
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
Exodus 23:6
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
អ្នកមិនត្រូវបង្វែរសេចក្តីយុត្តិធម៌
«អ្នកមិនត្រូវធ្វើសកម្មភាពណា ដែលបង្កើតលទ្ធផលមិនត្រឹមត្រូវតាមច្បាប់»
ដែលជាលទ្ធផលនៅក្នុងសេរីភាពសម្រាប់មនុស្សដែលមានកំហុសដែរ
ឬការដាក់ទណ្ឌកម្មចំពោះជនស្លូតត្រង់។
នៅពេលអ្នកកាត់ក្តី
នៅក្នុងឃ្លានេះ «អ្នក»
សំដៅទៅលើយុត្តិធម៌ត្រឹមត្រូវដែលជាការសម្រេចចិត្តត្រឹមត្រូវ។
កាត់ក្តី
«ជម្លោះ»
យើងមិនលើកលែងឲ្យមនុស្សទុច្ចរិតឡើយ។
«យើងនឹងមិនឃើញមនុស្សអាក្រក់មិនមានទោស» ឬ «យើងនឹងមិននិយាយ
ពីមនុស្សអាក្រក់ថាពួកគេគ្មានកំហុស»
ដ្បិតសំណួក ... ហើយបង្វែរពាក្យ
នៅទីនេះ «សំណូក» ត្រូវបានពិពណ៌នាថាជាមនុស្ស។ ការបកប្រែផ្សេងទៀត
«សំណូកធ្វើឲ្យខូចកិក្តិយស...ធ្វើឱ្យអន្តរាយ»
ជីវិតនៃភាពជាជនបរទេស
«ប្រភេទជីវិតនៃជនចម្លែករស់នៅក្នុងទឹកដីបរទេស»
Exodus 23:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
ប្រមូលផល
«ផលិតផលពីផលដំណាំ»
អ្នកមិនត្រូវភ្ជួររាស់
«អ្នកមិនធ្វើស្រែ» ឬ «អ្នកមិនកាប់គាស់រាស់ដី»
ដាំអ្វីឡើយ
«នៅក្នុងភាពធម្មជាតិរបស់វា» ឬ «មិនបានប្រើសម្រាប់ផលិតផល»
ធ្វើដូច្នេះ ដើម្បីឲ្យអ្នកក្រនៅក្នុងចំណោមប្រជាជនរបស់អ្នកអាចមានអ្វីហូប។
អ្នកក្រអាចបរិភោគចំណីអាហារណាដែលដុះដោយខ្លួនឯង
នៅក្នុងវាលស្រែដែលមិនត្រូវបានដាំដុះ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«ដូច្នេះអ្នកក្រក្នុងចំណោមប្រជាជនរបស់អ្នកអាចប្រមូលផល
និងបរិភោគអាហារណាដែលដុះដោយខ្លួនឯងនៅក្នុងវាលនោះ»
Exodus 23:12
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
ចូរយកចិត្តទុកដាក់ចំពោះ
«ធ្វើ» ឬ «ស្តាប់បង្គាប់»
ជាមួយគោ និងលារបស់អ្នកដែរ
«ការងារសត្វរបស់អ្នក»
ជនបរទេសបានសម្រាក និងបានទទួលការលំហែផង។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ជនបរទេសណាក៏អាចសម្រាក និងទទួលបានកម្លាំងរបស់គាត់ឡើងវិញ»
កុំបញ្ចេញនាមរបស់ព្រះផ្សេងៗ
នៅទីនេះ «នាម» គឺជាពាក្យប្រៀបធៀបសម្រាប់អធិស្ឋានដល់ព្រះដទៃទៀត។
ការបកប្រែផ្សេងទៀត «កុំអធិស្ឋានដល់ព្រះដទៃទៀត»
Exodus 23:14
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
អាប៊ីប
នេះគឺជាឈ្មោះខែដំបូងនៃប្រតិទិនហេព្រើរ។
អាប៊ីបគឺស្ថិតនៅផ្នែកចុងក្រោយនៃខែមិនា
និងផ្នែកដំបូងនៃខែមេសាតាមប្រតិទិនលោកខាងលិច។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១៣: ៣ ។
មិនត្រូវបង្ហាញខ្លួននៅចំពោះយើងដោយដៃទទេឡើយ។
ដៃ - នៅទីនេះគឺជាការថ្លែងគឺត្រូវបានប្រើដើម្បីបញ្ជាក់ថា
ជនជាតិអ៊ីស្រាអែលត្រូវយកតង្វាយដ៏សមរម្យមកថ្វាយព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ចូរមករកយើងដោយគ្មានការថ្វាយតង្វាយត្រឹមត្រូវ» ឬ
«ចូរយកតង្វាយមកយើងជានិច្ច»
Exodus 23:16
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
អ្នកត្រូវរក្សា
«អ្នកត្រូវតែគោរព» ឬ «អ្នកត្រូវតែអបអរសាទរ»
ពិធីបុណ្យនៃការប្រមូលផល
ពិធីបុណ្យនេះអបអរសាទរការប្រមូលផលចុងក្រោយនៃផលដំណាំទាំងអស់ប្រចាំឆ្នាំ។
អ្នកបម្រើប្រុសទាំងអស់របស់អ្នកត្រូវបង្ហាញខ្លួននៅចំពោះព្រះអម្ចាស់
នៅទីនេះដើម្បី «បង្ហាញខ្លួន»
មានន័យថាដើម្បីប្រមូលផ្តុំការជួបជុំសម្រាប់ការថ្វាយបង្គំ។ ការបកប្រែផ្សេងទៀត
«មនុស្សទាំងអស់ត្រូវតែប្រមូលផ្តុំគ្នាដើម្បីថ្វាយបង្គំយើង»
Exodus 23:18
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
ខ្លាញ់ពីយញ្ញបូជា
ខ្លាញ់នេះត្រូវបានដុតជាតង្វាយថ្វាយព្រះអម្ចាស់ហើយមិនត្រូវបរិភោគឡើយ។
អ្នកត្រូវជ្រើសរើសផលដំបូង
«ល្អបំផុតនិងជាផលដំបូង នៃការប្រមូលផល»
អ្នកមិនត្រូវស្ងោពពែឈ្មោលនៅក្នុងទឹកដោះមេរបស់វាឡើយ។
នេះគឺជាការអនុវត្តន៍ការបង្កកំណើតដោយប្រើ
មន្តអាគមក្នុងចំណោមជនជាតិកាណានដែលជនជាតិអ៊ីស្រាអែល
មិនត្រូវបានអនុញ្ញាតឱ្យចូលរួម។
Exodus 23:20
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
ត្រូវយកចិត្តទុកដាក់ជាមួយលោក
«ចូរស្តាប់លោក»
មិនត្រូវប្រឆាំងជាមួយនឹងលោកឡើយ ដ្បិតលោកនឹងមិនអត់ទោស
«ប្រសិនបើអ្នកធ្វើឱ្យលោកខឹងលោក នឹងមិនអត់ទោសទេ»
នាមរបស់យើងនៅលើលោក។
នៅទីនេះ «នាម» សំដៅទៅលើសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «គាត់មានសិទ្ធិអំណាចរបស់ខ្ញុំ»
ប្រសិនបើ អ្នកស្តាប់តាមសម្លេងរបស់លោក
នៅទីនេះ «សំឡេង» តំណាងឱ្យអ្វីដែលទេវតានិយាយ។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នកគោរពតាមអ្វីដែលលោកនិយាយ»
សត្រូវរបស់អ្នក ហើយក៏ធ្វើជាបច្ចាមិត្តប្រឆាំងនឹងបច្ចាមិត្តរបស់អ្នកដែរ។
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយត្រូវបានប្រើសម្រាប់ការបញ្ជាក់។
Exodus 23:23
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
អ្នកមិនត្រូវ ... ធ្វើអ្វីដូចពួកគេធ្វើឡើយ។
ជនជាតិអ៊ីស្រាអែលមិនត្រូវរស់នៅ ដូចប្រជាជនដែលគោរពព្រះដទៃឡើយ។
ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវ ...
រស់នៅដូចមនុស្សដែលគោរពព្រះទាំងនេះឡើយ»
ព្រះអង្គនឹងឲ្យពរដល់នំប៉័ង និងទឹករបស់អ្នក។

generated on Wed Sep 10 16:16:32 2025

នេះគឺជាការរួមបញ្ចូលគ្នាដែលមានន័យថាមួយអាហារនិងទឹក។
ការបកប្រែផ្សេងទៀត «យើងនឹងប្រទានពរអាហារនិងទឹករបស់អ្នក» ឬ
«យើងនឹងប្រទានពរឲ្យអ្នកតាមរយៈការប្រទានអាហារនិងទឹក»
Exodus 23:26
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់ក្រឹត្យវិន័យរបស់ព្រះអង្គ
ដល់លោកម៉ូសេសម្រាប់ជនជាតិអ៊ីស្រាអែល។
គ្មានស្ត្រីណាអារ ឬរលូតកូនរបស់នាងនៅក្នុងទឹកដីរបស់អ្នកឡើយ។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ការបកប្រែផ្សេងទៀត
«ស្ត្រីគ្រប់រូបនឹងអាចមានផ្ទៃពោះ និងផ្តល់កំណើតឱ្យទារកដែលមានសុខភាពល្អ»
រលូតកូន
បញ្ចប់ការមានគភ៌មុនពេលហើយមិននឹកស្មានដល់
ឪម៉ាល់
សត្វល្អិតហើរដែលអាចទិញមនុស្ស និងបណ្តាលឱ្យឈឺចាប់
ឬទឹកដីក្លាយទៅជាទីស្មសាន
«ពីព្រោះគ្មានមនុស្សណាម្នាក់នឹងរស់នៅក្នុងទឹកដី»
Exodus 23:30
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់ក្រឹត្យវិន័យរបស់ទ្រង់ដល់លោកម៉ូសេសំរាប់ជនជាតិអ៊ីស្រាអែល។
នោះអ្នកនឹងត្រូវធ្លាក់ទៅក្នុងអន្ទាក់របស់គេជាមិនខាន។
នេះមានន័យថាការថ្វាយបង្គំព្រះឯទៀត
នឹងនាំប្រជាជនអ៊ីស្រាអែលអោយវិនាសអន្តរាយពិតប្រាកដ
ដូចជាគេចាប់សត្វដែលជាប់អន្ទាក់របស់អ្នកប្រមាញ់។

---

24 [1]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរអ្នក អើរ៉ុន ណាដាប អប៊ីហ៊ូវ និងពួកចាស់ទុំរបស់ជនជាតិអ៊ីស្រាអែល ចំនួនចិតសិបនាក់ ឡើងមកជួប
យើង ហើយថ្វាយបង្គំយើងពីចម្ងាយ។[2]មានតែម៉ូសេតែម្នាក់ទេ ដែលអាចចូលមករកយើងបាន។ អ្នកផ្សេងៗទៀតមិនត្រូវចូលមកជិតឡើយ
ឬប្រជាជនមិនត្រូវឡើងមកជាមួយម៉ូសេទេ»។
[3]លោកម៉ូសេបានឡើយទៅ ហើយប្រាប់ប្រជាជននូវព្រះបន្ទូល និងច្បាប់របស់ព្រះជាម្ចាស់ទាំងអស់។ ប្រជាជនទាំងអស់ឆ្លើយជាមួយសម្លេងតែមួយថា៖
«យើងខ្ញុំនឹងធ្វើតាមព្រះបន្ទូលទាំងអស់ដែលព្រះអម្ចាស់បានមានបន្ទូល»។[4]នោះ លោកម៉ូសេបានសរសេរចុះព្រះបន្ទូលរបស់ព្រះអម្ចាស់ទាំងអស់។ នៅពេលព្រឹកព្រលឹម
លោកម៉ូសេបានសង់អាសនាមួយនៅជើងភ្នំ ហើយបានរៀបចំបង្គោលថ្មដប់ពីរ ហើយថ្មនោះជាតំណាងឲ្យកុលសម្ព័ន្ធទាំងដប់ពីររបស់ជនជាតិអ៊ីស្រាអែល។
[5]គាត់បានចាត់យុវជនជនជាតិអ៊ីស្រាអែលមួយចំនួនដើម្បីថ្វាយតង្វាយដុត និងថ្វាយគោដល់ព្រះអម្ចាស់ជាតង្វាយមេត្រីភាព។
[6]លោកម៉ូសេបានយកឈាមពាក់កណ្តាលដាក់វាចូលទៅក្នុងធើង ហើយគាត់បានយកពាក់កណ្តាលទៀតទៅប្រោះលើអាសនា។
[7]គាត់បានយកសៀវភៅសម្ពន្ធមេត្រី ហើយអានវាឮៗដល់ប្រជាជន។ ពួកគេនិយាយថា៖ «យើងខ្ញុំនឹងធ្វើគ្រប់យ៉ាងតាមដែលព្រះអម្ចាស់បានមានបន្ទូល។
យើងនឹងស្តាប់បង្គាប់តាម»។[8]បន្ទាប់មក លោកម៉ូសេបានយកឈាម ហើយប្រោះវាទៅលើប្រជាជន។ គាត់ប្រាប់ថា៖ «នេះគឺជាឈាមនៃសម្ពន្ធមេត្រី
ដែលព្រះអម្ចាស់បានធ្វើជាមួយអ្នក ដោយប្រទានដល់អ្នកនូវសេចក្តីសន្យាជាមួយនឹងព្រះបន្ទូលទាំងនេះ»។
[9]បន្ទាប់មក លោកម៉ូសេ លោកអ៊ើរ៉ុន លោកណាដាប់ អប៊ីហ៊ូវ និងពួកចាស់ទុំរបស់ជនជាតិអ៊ីស្រាអែល ចំនួនចិតសិបនាក់ឡើងទៅលើភ្នំ។
[10]ពួកគេបានឃើញព្រះជាម្ចាស់របស់អ៊ីស្រាអែល។ នៅក្រោមព្រះបាទាព្រះអង្គ មានដូចជាត្បូងកណ្តៀងសុទ្ធ ភ្លឺថ្លាដូចផ្ទៃមេឃ។
[11]ព្រះជាម្ចាស់មិនបានប្រហារលើអ្នកដឹកនាំជនជាតិអ៊ីស្រាអែលឡើយ។ ពួកគេបានឃើញព្រះជាម្ចាស់ ពួកគេបានហូបអាហារ។
[12]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរឡើងមករកយើងនៅលើភ្នំ ហើយស្នាក់នៅទីនោះហើយ។ យើងនឹងប្រទានបន្ទះថ្ម ហើយយើងបានសរសេរក្រឹត្យវិន័យ
និងបទបញ្ជានៅលើនោះ ដើម្បីអ្នកអាចបង្រៀនដល់ពួកគេ»។[13]ដូច្នេះ លោកម៉ូសេបានរៀបចំឡើងទៅលើភ្នំរបស់ព្រះជាម្ចាស់ជាមួយនឹងយ៉ូស្វេជាអ្នកជំនួយរបស់គាត់។
[14]លោកម៉ូសេបាននិយាយទៅកាន់អ្នកដឹកនាំថា៖ «ចូរនៅទីនេះហើយចាំយើងរហូតទាល់តែយើងត្រឡប់មករកអ្នករាល់គ្នាវិញ។ លោកអ៊ើរ៉ុន
និងហ៊ើរនៅជាមួយអ្នករាល់គ្នាហើយ។ ប្រសិនបើ នរណាមានជម្លោះនឹងគ្នា ឲ្យគេចូលទៅរកពួកគេចុះ»។[15]ដូច្នេះ លោកម៉ូសេបានឡើងទៅលើភ្នំ
ហើយពពកបានគ្របបាំងភ្នំជិត។
[16]សិរីល្អរបស់ព្រះអម្ចាស់ស្ថិតនៅលើភ្នំស៊ីណាយ ហើយពពកបានគ្របបាំងវាជិតអស់រយៈពេលប្រាំមួយថ្ងៃ។ នៅថ្ងៃទីប្រាំពីរ ព្រះអង្គបានហៅលោកម៉ូសេចេញពីពពក។
[17]លក្ខណៈនៃសិរីល្អរបស់ព្រះអម្ចាស់ដូចជាភ្លើងឆេះសន្ធោសន្ធៅនៅលើកំពូលភ្នំ នៅចំពោះភ្នែករបស់ជនជាតិអ៊ីស្រាអែល។[18]លោកម៉ូសេបានចូលទៅក្នុងពពកនោះ
ហើយបានឡើងទៅលើភ្នំ។ គាត់បានឡើងទៅលើភ្នំអស់រយៈពេលសែសិបយប់សែសិបថ្ងៃ។

Exodus 24:1
ណាដាប ... អប៊ីហ៊ូវ
ទាំងនេះគឺជាឈ្មោះបុរស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះទាំងនេះនៅក្នុង ៦:២៣ ។
ពួកចាស់ទុំរបស់ជនជាតិអ៊ីស្រាអែល ចំនួនចិតសិបនាក់
«ពួកចាស់ទុំ ៧០ នាក់របស់អ៊ីស្រាអែល»
Exodus 24:3
ជាមួយសម្លេងតែមួយ
នេះគឺជាឃ្លាមួយដែលមានន័យថាប្រជាជនយល់ព្រមព្រៀងទាំងស្រុង។
ការបកប្រែផ្សេងទៀត «ទាំងអស់គ្នា» ឬ «មានការយល់ព្រមព្រៀងគ្នា»
នៅជើងភ្នំ
«មូលដ្ឋានគ្រឹះនៃភ្នំ» ឬ «បាតភ្នំ»
Exodus 24:5
លោកម៉ូសេបានយកឈាមពាក់កណ្តាលដាក់វាចូលទៅក្នុងធើង
លោកម៉ូសេបានប្រមូលឈាមពាក់កណ្តាល
នៅក្នុងធើងដើម្បីប្រោះឈាមលើប្រជាជន ២៤: ៧ ។
នេះនឹងបញ្ជាក់ពីការចូលរួមរបស់ប្រជាជននៅក្នុងសម្ពន្ធមេត្រីរវាងប្រជាជនអ៊ីស្រាអែលនិងព្រះជាម្ចាស់
គាត់បានយកពាក់កណ្តាលទៀតទៅប្រោះលើអាសនា។
នៅទីនេះអាសនាតំណាងឱ្យព្រះជាម្ចាស់។
នេះនឹងបញ្ជាក់ពីការចូលរួមរបស់ព្រះជាម្ចាស់ក្នុងសម្ពន្ធមេត្រី រវាងព្រះជាម្ចាស់
និងប្រជាជនអ៊ីស្រាអែល។
Exodus 24:7
យើងនឹងស្តាប់បង្គាប់តាម
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«យើងនឹងគោរពតាមអ្វីៗគ្រប់យ៉ាង»
បន្ទាប់មក លោកម៉ូសេបានយកឈាម
នេះសំដៅទៅលើឈាមដែលលោកម៉ូសេបានដាក់ក្នុងចាន។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកលោកម៉ូសេយកឈាមដែលនៅក្នុងចាននោះមក» ។
Exodus 24:9
លោកណាដាប់ ... អប៊ីហ៊ូវ
ទាំងនេះគឺជាឈ្មោះរបស់បុរស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះទាំងនេះនៅក្នុង ៦:២៣ ។
នៅក្រោមព្រះបាទាព្រះអង្គ
នេះនិយាយអំពីព្រះជាម្ចាស់ដូចជាព្រះអង្គមានជើងមនុស្សដែរ។
មានដូចជាត្បូងកណ្តៀងសុទ្ធ
«ធ្នាំងថ្មនៅក្នុងដីបង្កើតជាថ្មខៀវៗ ហៅថាត្បូងកណ្តៀង»
កំរាលថ្ម
[illegible]សម្រាប់ដើរឬជិះ
ត្បូងកណ្តៀង
នេះគឺជាត្បូងពេជ្រដែលមានពណ៌ខៀវ។
ភ្លឺថ្លាដូចផ្ទៃមេឃ។
នេះគឺជាគំរូមួយ។ ការបកប្រែផ្សេងទៀត « ច្បាស់ដូចមេឃគឺពេលគ្មានពពក»
ព្រះជាម្ចាស់មិនបានប្រហារលើអ្នកដឹកនាំជនជាតិអ៊ីស្រាអែលឡើយ។

generated on Wed Sep 10 16:16:32 2025

នេះមានន័យថាព្រះមិនបានធ្វើបាបមេដឹកនាំទេ។ ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់មិនបានធ្វើបាបមេដឹកនាំអ៊ីស្រាអែលទេ»
Exodus 24:12
ប្រទានបន្ទះថ្ម ហើយយើងបានសរសេរក្រឹត្យវិន័យ និងបទបញ្ជានៅលើនោះ
ព្រះបានសរសេរក្រឹត្យវិន័យ និងបទបញ្ញត្តិនៅលើបន្ទះថ្ម។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ផ្នាំងថ្មពីរដែលយើងបានសរសេរក្រឹត្យវិន័យទាំងអស់»
មួយនឹងយ៉ូស្វេជាអ្នកជំនួយរបស់គាត់។
«ជាមួយលោកយ៉ូស្វេដែលបានជួយគាត់» ឬ
«ជាមួយលោកយ៉ូស្វេដែលបានជួយគាត់»
Exodus 24:14
ចាំយើងរហូតទាល់តែ
«រង់ចាំលោកយ៉ូស្វេ និងយើង»
ហ៊ើរ
ហ៊ើរគឺជាមនុស្សម្នាក់ដែលជាមិត្តភក្តិរបស់លោកម៉ូសេ និងលោកអ៊ើរ៉ុន។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះនេះនៅក្នុង ១៧: ៨ ។
Exodus 24:16
សិរីល្អរបស់ព្រះអម្ចាស់
នេះគឺជាពន្លឺដ៏អស្ចារ្យនៃវត្តមានរបស់ព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត
«ពន្លឺដ៏អស្ចារ្យបង្ហាញពីវត្តមានរបស់ព្រះជាម្ចាស់»
ដូចជាភ្លើងឆេះសន្ធោសន្ធៅ
នេះមានន័យថាសិរីរុងរឿងរបស់ព្រះអម្ចាស់ធំណាស់
ហើយហាក់ដូចជាត្រូវឆេះដូចភ្លើង។ ការបកប្រែផ្សេងទៀត
«ដូចជាភ្លើងឆេះដ៏ធំមួយ»
នៅចំពោះភ្នែករបស់ជនជាតិអ៊ីស្រាអែល។
នៅទីនេះ «ភ្នែក» សំដៅទៅលើគំនិតរបស់ពួកគេអំពីអ្វីដែលពួកគេបានឃើញ។
ការបកប្រែផ្សេងទៀត «ទៅកាន់ជនជាតិអ៊ីស្រាអែល»
ពេលសែសិបយប់សែសិបថ្ងៃ។
«៤០ ថ្ងៃ ៤០ យប់»

---

25 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖[2]«ចូរប្រាប់ជនជាតិអ៊ីស្រាអែល ឲ្យយកតង្វាយមកថ្វាយដល់យើងពីមនុស្សគ្រប់គ្នា ដែលមានដួងចិត្តនៃការថ្វាយ។
អ្នកត្រូវទទួលតង្វាយនេះសម្រាប់យើង។
[3]ទាំងនេះជាតង្វាយដែលអ្នកត្រូវទទួលពីពួកគេ មានមាស ប្រាប់ និងលង្ហិន[4]ក្រណាត់ពណ៌ស្វាយ ពណ៌ក្រហម និងពណ៌ក្រហមទុំ ក្រណាត់ទេសឯក[5]ក្រណាត់ធ្វើពីរោម
ពពែឈ្មោល ស្បែកពពែជ្រលក់ពណ៌ក្រហម ស្បែកផ្សោត និងឈើនាងនួន[6]ប្រេងសម្រាប់ដុតបំភ្លឺទីសក្ការៈ ប្រេងក្រអូបសម្រាប់ពិធីលាបប្រេង និងគ្រឿងក្រអូបសម្រាប់
ដុត[7]ត្បូងមណីជោតិរស និងត្បូងដ៏មានតម្លៃផ្សេងៗ សម្រាប់ដាំនៅលើអាវអេផូដ និងសម្រាប់លំអដើមទ្រូងបូជាចារ្យ។
[8]ចូរឲ្យពួកគេសង់ទីសក្ការៈមួយសម្រាប់យើង ដើម្បីឲ្យយើងស្នាក់នៅក្នុងចំណោមពួកគេ។[9]អ្នករាល់គ្នាត្រូវធ្វើវា ដូចដែលយើងបានបង្ហាញដល់អ្នករាល់គ្នានៅក្នុងផែនការ
សម្រាប់សង់ព្រះពន្លា និងធ្វើគ្រឿងបរិក្ខារទាំងប៉ុន្មានផង។
[10]ពួកគេត្រូវធ្វើហឹបមួយពីឈើនាងនួន។ ហឹបនោះមានបណ្តោយពីរហត្ថកន្លះ ទទឹងមួយហត្ថកន្លះ និងកម្ពស់មួយហត្ថកន្លះ។[11]អ្នកស្រោបហឹបនោះទាំងខាងក្នុង ទាំងខាង
ក្រៅដោយមាសសុទ្ធ ហើយអ្នកត្រូវធ្វើគែមមាសព័ទ្ធជុំវិញហឹបនោះ។
[12]អ្នកត្រូវធ្វើកងមាសបួនសម្រាប់វា ហើយដាក់ភ្ជាប់ទៅនឹងជើងទាំងបួន ជាមួយនឹងជើងនៅម្ខាងពីរៗ។[13]អ្នកត្រូវយកឈើនាងនួនមកធ្វើជាឈើស្នែង ហើយស្រោបវាដោយ
មាសផងដែរ។[14]អ្នកត្រូវសកឈើស្នែងទៅក្នុងកងដែលនៅសងខាងហឹប ដើម្បីសែងហឹបនោះបាន។
[15]ឈើស្នែងត្រូវនៅជាប់នឹងកងរបស់ហឹប មិនត្រូវយកចេញពីវាឡើយ។[16]អ្នកត្រូវដាក់ច្បាប់នៃសម្ពន្ធមេត្រីដែលយើងបានឲ្យដល់អ្នកទៅក្នុងហឹបនោះ។
[17]អ្នកត្រូវធ្វើគម្របហឹបពីមាសសុទ្ធ។ ដែលបណ្តោយរបស់វាពីរហត្ថកន្លះ ហើយទទឹងរបស់វាមួយហត្ថកន្លះ ។[18]អ្នកត្រូវធ្វើរូបចេរូប៊ីនពីរមាសនៅចុងនៃគម្របទាំងសងខាង។
[19]ចូរធ្វើរូបចេរូប៊ីនមួយនៅចុងម្ខាងនៃគម្របហឹប ហើយរូបចេរូប៊ិនមួយទៀតនៅចុងគម្របហឹបម្ខាងទៀត។ ត្រូវភ្ជាប់ចេរូប៊ិននេះនៅលើគម្របហឹបទាំងសងខាង។
[20]រូបចេរូប៊ិនត្រូវត្រដាងស្លាប ហើយត្រូវដាក់ទល់មុខគ្នា ព្រមទាំងត្រដាងស្លាបគ្របពីលើគម្របហឹបថែមទៀតផង។ មុខរបស់រូបចេរូប៊ិនត្រូវដាក់ទល់មុខគ្នា
ហើយឱ្យងាមុខនៅលើគម្របហឹបផង។[21]អ្នកត្រូវដាក់គម្របនៃទីសន្តោសប្រោសពីលើហឹប ហើយអ្នកត្រូវដាក់ច្បាប់នៃសម្ពន្ធមេត្រីដែលយើងឲ្យដល់អ្នកនៅក្នុងនោះ។
[22]យើងនឹងជួបអ្នកនៅកន្លែងហឹបនោះ។ យើងនឹងនិយាយជាមួយអ្នកពីកន្លែងនោះមកគឺពីលើគម្របនៃទីសន្តោសប្រោស។
នៅចំកណ្តាលចេរូប៊ិនទាំងពីរនៅលើហឹបនៃទីបន្ទាល់ដែលយើងនឹងនិយាយមកអ្នកពីសេចក្តីបង្គាប់គ្រប់យ៉ាង ដែលយើងនឹងប្រទានដល់ជនជាតិអ៊ីស្រាអែល។
[23]អ្នកត្រូវធ្វើតុមួយពីឈើនាងនួន។ ប្រវែងរបស់វាត្រូវមានបណ្តោយពីរហត្ថ ហើយទទឹងរបស់វាមួយហត្ថ និងកម្ពស់របស់វាមួយហត្ថកន្លះ។
[24]អ្នកត្រូវស្រោបវាជាមួយនឹងមាសសុទ្ធ ហើយធ្វើគែមមាសនៅជុំវិញផង។
[25]អ្នកត្រូវធ្វើគែមព័ទ្ធជុំវិញតុកម្ពស់មួយទះ ហើយធ្វើក្បាច់ជាមាសភ្ជាប់នឹងគែមព័ទ្ធជុំវិញផង។[26]អ្នកត្រូវធ្វើកងមាសបួន ហើយដាក់ភ្ជាប់កងទាំងនោះ ទៅនឹងជ្រុងទាំងបួន
ត្រង់ជើងតុទាំងបួននោះផង។[27]កងទាំងនោះត្រូវនៅជាប់គែមតុ ដើម្បីឲ្យមានកន្លែងសម្រាប់សែកឈើស្នែង ដើម្បីឲ្យអាចសែងបាន។
[28]អ្នកត្រូវធ្វើឈើស្នែងពីឈើនាងនួន ហើយស្រោបឈើនោះដោយមាស ដើម្បីប្រើស្នែងនោះសែងតុ។[29]អ្នកត្រូវធ្វើចាន ស្លាបព្រា ក្អមនិងពែង ប្រើដើម្បីចាក់តង្វាយច្រួច។
[30]អ្នកត្រូវធ្វើរបស់ទាំងនេះពីមាសសុទ្ធ។ អ្នកត្រូវរៀបចំនំប៉័ងនៅលើតុនោះចំពោះយើងជាប្រចាំ។
[31]អ្នកត្រូវធ្វើជើងចង្កៀងមាសមានឆ្លាក់។ ជើងចង្កៀងគឺត្រូវធ្វើឲ្យមានក្បាច់រចនា នៅផ្នែកខាងក្រោម និងពីមាសសុទ្ធមួយដុំ។ មានពែង មានមែង និងមានផ្កា
ទាំងអស់ធ្វើឡើងពីដុំតែមួយ។[32]មានមែកប្រាំមួយ បែកចេញពីគួតណ្តាល ហើយមែកម្ខាងនៃជើងចង្កៀងមានបី ហើយម្ខាងទៀតក៏មានបីដែរ។
ហើយមែកនៃជើងចង្កៀងនោះញែកចេញពីគ្នា មានកន្លាក់ៗ ហើយមែកបីនៃជើងចង្កៀងម្ខាងទៀតក៏បែកចេញពីគ្នាដែរ។
[33]មែកទីមួយត្រូវមានពែងបី ធ្វើឲ្យដូចជាគ្រាប់ចំបក់ មានទាំងកន្សោមគ្រាប់ និងផ្កាផង ហើយមែកទាំងប្រាំមួយដែលបែកចេញពីតួជើងចង្កៀងមក នោះក៏ត្រូវមានរាងដូចជា
គ្រាប់ចំបក់ដែរ ព្រមទាំងកន្សោមគ្រាប់ និងផ្កា ដូចគ្នាទាំងអស់លាតចេញមកពីជើងចង្កៀង។[34]ចំណែក ជើងចង្កៀងវិញ ដងកណ្តាល ត្រូវមានពែងបួន
ធ្វើឲ្យដូចជាគ្រាប់ចំបក់ ព្រមទាំងកន្សោមគ្រាប់ និងផ្កាផង។
[35]ត្រូវមានកន្សោមគ្រាប់មួយ នៅក្រោមមែកមួយគូដំបូង ត្រូវធ្វើវាពីដុំតែមួយ ហើយត្រូវមានកន្សោមគ្រាប់មួយ នៅក្រោមមែកគូទីពីរ ដែលមានមែកមួយគូទៀត
ត្រូវធ្វើវាពីដុំតែមួយ។ ដូចគ្នានោះដែរ ត្រូវមានកន្សោមគ្រាប់មួយនៅក្រោមបែកទីបីនៃមែកគូទីបី ត្រូវធ្វើវាពីដុំតែមួយ។
មែកទាំងប្រាំមួយនៃជើងចង្កៀងនោះត្រូវតែដូចគ្នាទាំងអស់។[36]កន្សោមគ្រាប់ និងមែកទាំងប៉ុន្មាន ត្រូវរ្លាក់ជាក្បាច់រចនាពីមាសសុទ្ធភ្ជាប់ជាមួយគ្នា។
[37]អ្នកត្រូវធ្វើជើងចង្កៀង ហើយមានចង្កៀងប្រាំពីរ ព្រមទាំងរៀបចំចង្កៀង ដើម្បីឲ្យមានពន្លឺចេញពីវា។[38]ឃ្នាបប្រឆេះ និងថាសដាក់កម្ទេចសម្រាប់ជើងចង្កៀង នោះក៏ត្រូវធ្វើពី
មាសសុទ្ធដែរ។[39]ត្រូវយកមាសសុទ្ធមួយហាប មកធ្វើជើងចង្កៀង និងគ្រឿងប្រដាប់ទាំងអស់របស់វា។[40]ត្រូវប្រយ័ត្នធ្វើវាឲ្យត្រឹមត្រូវតាមគំរូ ដែលបានបង្ហាញដល់អ្នកនៅលើ
ភ្នំ។

Exodus 25:1
ដែលមានដួងចិត្តនៃការថ្វាយ។
នេះគឺជាឃ្លាដែលចង្អុលបង្ហាញ ពីបំណងប្រាថ្នារបស់មនុស្សក្នុងការថ្វាយតង្វាយ។
ការបកប្រែផ្សេងទៀត «អ្នកដែលចង់ថ្វាយតង្វាយ»
អ្នកត្រូវទទួល
ពាក្យថា «អ្នក» គឺសំដៅទៅលើលោកម៉ូសេ និងអ្នកដឹកនាំ។
Exodus 25:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ក្រណាត់ពណ៌ស្វាយ ពណ៌ក្រហម និងពណ៌ក្រហមទុំ

generated on Wed Sep 10 16:16:32 2025

ទី១អត្ថន័យដែលប្រហែលគឺ) «ក្រណាត់ដែលលាបពណ៌ខៀវ ស្វាយ និង ក្រហមទុំ» ប្រហែលជាអំបោះធ្វើអំពីឡែនឬ ទី២)
«ពណ៌ខៀវពណ៌ស្វាយនិងពណ៌ក្រហមទុំ» ដើម្បីជ្រលក់ក្រណាត់ទេសឯក។
ពណ៌ក្រហមទុំ
«ក្រហម»
ស្បែកផ្សោត
ជាសត្វធំមួយដែលរស់នៅក្នុងសមុទ្រ និងស៊ីរុក្ខជាតិ
ប្រេងក្រអូប
រុក្ខជាតិស្ងួតហួតហែងដែលមនុស្សកិនទៅជាម្សៅហើយដាក់ប្រេង ឬអាហារដើម្បីឱ្យវាមានក្លិនឈ្ងុយឆ្ងាញ់
ត្បូងមណីជោតិរស
ថ្មដែលមានតម្លៃដែលមានស្រទាប់ពណ៌ស និងខ្មៅក្រហម ឬត្នោត។
ត្បូងដ៏មានតម្លៃផ្សេងៗ សម្រាប់ដាំនៅលើ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ត្បូងដ៏មានតម្លៃសម្រាប់នរណាម្នាក់កំណត់»
ត្បូងដ៏មានតម្លៃ
«ត្បូងមានតម្លៃ» ឬ «រតនសម្បត្តិ»
Exodus 25:8
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ទីសក្ការៈ ... ព្រះពន្លា
នៅទីនេះពាក្យទាំងនេះមានន័យដូចគ្នា។
អ្នករាល់គ្នាត្រូវធ្វើវា
នៅទីនេះ «អ្នក» គឺជាពហុវចនៈហើយសំដៅទៅលើលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល។
បង្ហាញដល់អ្នករាល់គ្នានៅក្នុងផែនការ
«បង្ហាញអ្នកនៅគម្រោងការណ៍» ឬ «បង្ហាញអ្នកតាមគម្រូ » នៅទីនេះ «អ្នក» គឺឯកវចនៈហើយសំដៅទៅលើលោកម៉ូសេ។
Exodus 25:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ពីរហត្ថកន្លះ ... មួយហត្ថកន្លះ
«២,៥ ហត្ថ ... ១,៥ ហត្ថ»
Exodus 25:12
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ធ្វើកងមាសបួនសម្រាប់វា
ការខាតគឺជាដំណើរការមួយដែលមាសត្រូវបានរលាយចាក់ចូលទៅក្នុងពុម្ព ដែលមានរាងជាចិញ្ចៀន ហើយបន្ទាប់មកត្រូវបានទុកឱ្យរឹង។
ដើម្បីសែងហឹប
«ដូច្នេះអ្នកអាចយកហឹបបាន»
Exodus 25:15
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
គម្រប
នេះជាគម្របនៅពីលើហឹប ដែលជាកន្លែងថ្វាយតង្វាយប្រោសលោះ។
ពីរហត្ថកន្លះ ... មួយហត្ថកន្លះ
«២,៥ ហត្ថ ... ១,៥ ហត្ថ»
ពីរមាស
«ដុំមាស»
Exodus 25:19
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
គម្របហឹបទាំងសងខាង
នេះជាគម្របដែលនៅពីលើហឹបដែលជាកន្លែងថ្វាយតង្វាយលោះបាប។ សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៥:១៥ ។
ត្រូវភ្ជាប់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតភ្ជាប់វា»
អ្នកត្រូវដាក់
នៅទីនេះ «អ្នក» សំដៅទៅលើលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល។
Exodus 25:22
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមនាបន្ទូលទៅកាន់លោកម៉ូសេ។
យើងនឹងជួបអ្នកនៅកន្លែងហឹបនោះ។
«យើងនឹងជួបអ្នកនៅឯហឹប» ។ ក្នុង ២៥:២២ ពាក្យថា «អ្នក» គឺជាឯកវចនៈហើយសំដៅទៅលើលោកម៉ូសេ។
គម្របនៃទីសន្តោសប្រោស
នេះជាគម្របដែលនៅពីលើហឹប ដែលជាកន្លែងថ្វាយតង្វាយលោះបាប។ សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៥:១៥ ។
Exodus 25:23
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ពីរហត្ថ ...មួយហត្ថ ...មួយហត្ថកន្លះ
Exodus 25:25
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ធ្វើក្បាច់ជាមាសភ្ជាប់
ការវាស់ពី ៧ ទៅ ៨ សង្ទីម៉ែត្រ
ព័ទ្ធជុំវិញផង
«ស៊ុមសម្រាប់តុ»
ជើងតុ
«ជើង»
កងទាំងនោះត្រូវនៅជាប់តែមតុ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែភ្ជាប់កង»
ដើម្បីឲ្យអាចសែងបាន។
«ដូច្នេះអ្នកអាចសែងបាន»
Exodus 25:28
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ដើម្បីប្រើស្នែងនោះសែងតុ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ដូច្នេះអ្នកអាចយកតុជាមួយពួកគេ»
ប្រើដើម្បីចាក់តង្វាយច្រួច។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ដូច្នេះអ្នកអាចប្រើវាដើម្បីចាក់បង្ហូរតង្វាយច្រួត»
នំប៉័ងនៅលើតុ
នំប៉័ងនេះតំណាងឲ្យព្រះវត្តមានរបស់ព្រះជាម្ចាស់។
Exodus 25:31
មាសមានឆ្លាក់
«ដុំមាស» សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៥:១៥ ។
ចង្កៀងគឺត្រូវធ្វើ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ធ្វើជើងចង្កៀង»
មានពែង មានមែង និងមានផ្កា ទាំងអស់ធ្វើឡើងពីដុំតែមួយ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ធ្វើពែង ធ្វើស្លឹក និង ផ្ការបស់វាទាំងអស់មានមួយចំណែក ជាមួយនឹងជើងចង្កៀង»
Exodus 25:33
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ព្រះអម្ចាស់កំពុងតែពិពណ៌នាអំពីជើងចង្កៀង។ (សូមមើល 25:31)
កន្សោមគ្រាប់
ផ្កាពណ៌ស ឬពណ៌ផ្កាឈូក ដែលមានចំនួន ៥ស្រទាប់
Exodus 25:35
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ព្រះអម្ចាស់កំពុងតែពិពណ៌នាអំពីជើងចង្កៀង។ (សូមមើល 25:31)
ត្រូវធ្វើវាពីដុំតែមួយ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«អ្នកត្រូវធ្វើវាជាដុំតែមួយជាមួយនឹងជើងចង្កៀង»
Exodus 25:37
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ដើម្បីឲ្យមានពន្លឺចេញពីវា។
«ដូច្នេះចាំងពន្លឺចេញពីវា»
ឃ្នាបប្រឆេះ និងថាសដាក់កម្ទេចសម្រាប់ជើងចង្កៀង នោះក៏ត្រូវធ្វើពីមាសសុទ្ធដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ធ្វើដង្កៀបនិងថាសមាសសុទ្ធ»
មួយហាប
មួយហាប មានទម្ងន់ ៣៤ គីឡូក្រាម។
គ្រឿងប្រដាប់ទាំងអស់របស់វា
ដង្កៀប និងថាស
ដែលបានបង្ហាញដល់អ្នកនៅលើភ្នំ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ខ្ញុំកំពុងបង្ហាញអ្នកនៅលើភ្នំ»

---

26 [1]អ្នកត្រូវធ្វើព្រះពន្លាពីវាំងននដប់ ធ្វើពីអំបោះធ្មៃគឺក្រណាត់ពណ៌ស ពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហមទុំ ក្រណាត់ទាំងនោះត្រូវប៉ាក់លម្អដោយរូបចេរូប៊ីន។
ការងារនេះនឹងធ្វើឡើយដោយជាងដែលមានស្នាដៃល្អ។[2]បណ្តោយនៃវាំងននីមួយៗមានប្រវែងម្ភៃប្រាំបីហត្ថ ទទឹងបួនហត្ថ។ វាំងននទាំងអស់ត្រូវមានទំហំស្មើគ្នា។
[3]វាំងននប្រាំត្រូវភ្ជាប់ជាមួយគ្នា ហើយវាំងននប្រាំទៀតក៏ត្រូវភ្ជាប់ជាមួយគ្នាដែរ។
[4]អ្នកត្រូវធ្វើកងដែលមានពណ៌ខៀវតាមជាយវាំងននទីមួយ ខាងចុងផ្នាំងត្រង់កន្លែងដែលភ្ជាប់គ្នា។ ដូចគ្នានេះ អ្នកត្រូវធ្វើតាមជាយខាងចុងផ្នាំងមួយទៀត ត្រង់កន្លែងដែលភ្ជាប់គ្នាដែរ។[5]អ្នកត្រូវធ្វើកងហាសិបនៅវាំងននទីមួយ ហើយហាសិបទៀតនៅវាំងននទីពីរ ហើយអ្នកត្រូវធ្វើកងហាសិប នៅខាងចុងវាំងននទីពីរដែរ។ ធ្វើដូច្នេះ
ដើម្បីឲ្យកងនោះបាននៅទល់មុខគ្នា[6]អ្នកត្រូវធ្វើដង្កៀបមាសហាសិប ហើយភ្ជាប់វាំងននទាំងពីរផ្នាំងនឹងដង្កៀបនោះ ដើម្បីឲ្យព្រះពន្លាបានជាប់នៅជារោងតែមួយ។
[7]អ្នកត្រូវធ្វើវាំងននពីរោមពពែ សម្រាប់គ្របព្រះពន្លា។[8]អ្នកត្រូវធ្វើវាំងននរោមពពែនេះដប់មួយវាំងនន។ ហើយវាំងននីមួយៗត្រូវមានប្រវែងសាមសិបហត្ថ
ហើយទទឹងវាំងននីមួយៗមានប្រវែងបួនហត្ថ។ វាំងននទាំងដប់មួយត្រូវមានទំហំស្មើៗគ្នា។[9]អ្នកត្រូវភ្ជាប់វាំងននប្រាំជាមួយគ្នានឹងគ្នា
ហើយវាំងននប្រាំមួយទៀតក៏ត្រូវភ្ជាប់ជាមួយគ្នាដែរ។ អ្នកត្រូវបត់វាំងននទីប្រាំមួយនៅខាងមុខព្រះពន្លា។
[10]អ្នកត្រូវធ្វើកងហាសិបដាក់នៅលើជាយវាំងននីមួយៗ នៃផ្នាំងទីមួយ ហើយហាសិបទៀតនៅខាងចុងវាំងននដែលភ្ជាប់គ្នានៅផ្នាំងទីពីរ។[11]អ្នកត្រូវធ្វើដង្កៀបពីលង្ហិន
ហើយដាក់វាទៅក្នុងដង្កៀបនោះ។ បន្ទាប់មក អ្នកត្រូវតំឡើងព្រះពន្លាជាមួយគ្នា ដើម្បីភ្ជាប់ព្រះពន្លាមកតែមួយ។
[12]វាំងននដែលនៅសល់ពាក់កណ្តាល គឺវាំងននដែលនៅសល់ពីវាំងននព្រះពន្លា ត្រូវព្យួរនៅពីក្រោយព្រះពន្លា។[13]ត្រូវតែមានវាំងននសល់មួយហត្ថនៅម្ខាង
ហើយមួយហត្ថទៀតនៅម្ខាងទៀត ជាវាំងននដែលនៅសល់ពីវាំងននព្រះពន្លា ត្រូវព្យួរនៅសងខាងព្រះពន្លា ដើម្បីបាំងព្រះពន្លា។
[14]អ្នកត្រូវធ្វើគម្របសម្រាប់គ្របព្រះពន្លាដែលធ្វើពីស្បែកចៀម ជ្រលក់ពណ៌ក្រហម ហើយគម្របមួយទៀតធ្វើពីស្បែកផ្សោតមកគ្រប់ពីលើនោះ។
[15]អ្នកត្រូវធ្វើស៊ុមពីឈើនាងនួនសម្រាប់ព្រះពន្លា។[16]ស៊ុមនីមួយៗមានបណ្តោយដប់ហត្ថ ហើយទទឹងមួយហត្ថកន្លះ។[17]ត្រូវមានពន្លូញឈើពីរភ្ជាប់ជាមួយនឹងស៊ុមនីមួយៗ
ដើម្បីភ្ជាប់ស៊ុមជាមួយគ្នា។ អ្នកត្រូវធ្វើស៊ុមរបស់ព្រះពន្លាទាំងអស់រៀបនេះឯង។[18]នៅពេលអ្នកត្រូវធ្វើស៊ុមសម្រាប់ព្រះពន្លា អ្នកត្រូវធ្វើស៊ុមម្ភៃសម្រាប់ផ្នែកខាងត្បូង។
[19]អ្នកត្រូវធ្វើជើងទ្រប្រាក់ចំនួនសែសិបនៅក្រោមស៊ុមទាំងម្ភៃនោះ។ ត្រូវមានជើងទ្រពីរនៅក្រោមស៊ុមមួយ ត្រង់កន្លែងដែលមានពន្លូញទាំងពីរ។[20]នៅផ្នែកទីពីរនៃព្រះពន្លា
គឺនៅប៉ែកខាងជើង អ្នកត្រូវធ្វើស៊ុមម្ភៃ[21]ហើយជើងទ្រស៊ុមពីប្រាក់ចំនួនសែសិបផង។ ត្រូវមានជើងទ្រពីរនៅក្រោមស៊ុមមួយ ជើងទ្រពីរនៅក្រោមស៊ុមបន្ទាប់
និងជាបន្តបន្ទាប់។
[22]សម្រាប់ផ្នែកខាងក្រោយរបស់ព្រះពន្លាដែលនៅប៉ែកខាងលិច អ្នកត្រូវធ្វើស៊ុមប្រាំមួយ។[23]អ្នកត្រូវធ្វើស៊ុមពីរសម្រាប់ជ្រុងខាងក្រោយព្រះពន្លា។
[24]ស៊ុមទាំងនេះត្រូវញែកដោយឡែកនៅខាងក្រោម ប៉ុន្តែ ត្រូវភ្ជាប់នៅខាងលើជាមួយនឹងកងមួយ។ នៅជ្រុងខាងក្រោយទាំងពីរត្រូវមានស៊ុមពីរដូចគ្នា។[25]ត្រូវមានស៊ុមប្រាំបី
និងជើងទ្រធ្វើពីប្រាក់ចំនួនទាំងអស់ដប់ប្រាំមួយ ជើងទ្រពីរនៅក្រោមស៊ុមទីមួយ ហើយជើងទ្រពីរទៀត នោក្រោមស៊ុមបន្ទាប់ និងជាបន្តបន្ទាប់ទៀត។
[26]អ្នកត្រូវធ្វើរនុកពីឈើនាងនួន ប្រាំសម្រាប់ស៊ុមមួយផ្នែករបស់ព្រះពន្លា។[27]រនុកប្រាំទៀតសម្រាប់ស៊ុមនៃផ្នែកមួយទៀតរបស់ព្រះពន្លា
ហើយរនុកប្រាំផ្សេងទៀតសម្រាប់ស៊ុម សម្រាប់ផ្នែកខាងក្រោយរបស់ព្រះពន្លានៅប៉ែកខាងលិច។[28]រនុកកណ្តាល ពាក់កណ្តាលស៊ុមឡើងលើ ត្រូវបង្ហួតចាប់ពីចុងម្ខាងដល់ចុងម្ខាង។
[29]អ្នកត្រូវស្រោបស៊ុមជាមួយនឹងមាស។ អ្នកត្រូវធ្វើកងពីមាស សម្រាប់ស៊កចូលរនុក ហើយអ្នកត្រូវស្រោមរនុកជាមួយនឹងមាស។[30]អ្នកត្រូវរៀបចំព្រះពន្លា
តាមផែនការដែលបានបង្ហាញអ្នកនៅលើភ្នំ។
[31]អ្នកត្រូវធ្វើវាំងននពីមួយ ត្បាញដោយអំបោះធ្មៃ ដែលលាយនឹងអំបោះពណ៌ស ពណ៌ស្វាយ ពណ៌ក្រហម និងពណ៌ក្រហមទុំ។[32]វាំងននេះត្រូវតែប៉ាក់លម្អដោយរូប
ចេរូប៊ីន ដោយការចនានៃជាងមានស្នាដៃ។ អ្នកត្រូវព្យួរវានៅលើសរសរនាងនួនបួនដែលស្រោមមាស។ សរសរទាំងនេះត្រូវមានទំពក់ពីមាស បញ្ឈរនៅលើជើងទ្រប្រាក់។
[33]អ្នកត្រូវព្យួរវាំងននេះនៅតម្កក់ទាំងនោះ ហើយអ្នកត្រូវយកហឹបដែលដាក់បន្ទះថ្មនៃសម្ពន្ធមេត្រី។ វាំងននត្រូវញែកទីបរិសុទ្ធ ពីទីបរិសុទ្ធបំផុត។
[34]អ្នកត្រូវដាក់ទីសន្តោសប្រោសនៅលើហិបនៃសម្ពន្ធមេត្រី នៅក្នុងទីបរិសុទ្ធបំផុត។[35]អ្នកត្រូវដាក់តុនៅខាងក្រៅវាំងនន។
អ្នកត្រូវដាក់ជើងចង្កៀងទល់មុខនឹងតុនៅប៉ែកខាងត្បូងនៃព្រះពន្លា។ តុត្រូវនៅប៉ែកខាងជើង។
[36]អ្នកត្រូវធ្វើរនាំងសម្រាប់ផ្លូវចូលព្រះពន្លា។ អ្នកត្រូវធ្វើវាចេញពីអំបោះធ្មៃ ដែលមានពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម ព្រមទាំងវិញនឹងអំបោះខ្លូតទេស ត្រូវប៉ាក់ផង។
[37]ដ្បិត កន្លែងព្បួរ អ្នកត្រូវធ្វើសសរនាងនួនប្រាំ ហើយស្រោបមាសសម្រាប់គ្របពីលើវា។ តម្ពក់របស់វាត្រូវធ្វើពីមាស ហើយអ្នកត្រូវសិតធ្វើជើងលង្ហិនប្រាំសម្រាប់ទ្រសសរ
ទាំងនោះ។

Exodus 26:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។ (សូមមើល ២៥:១)
អ្នកត្រូវធ្វើ
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់លោកម៉ូសេដូច្នេះពាក្យថា «អ្នក»
គឺមានតែមួយ។ ព្រះអម្ចាស់ប្រហែលជាសង្ឃឹមថា
លោកម៉ូសេនឹងប្រាប់មនុស្សណាម្នាក់អោយធ្វើកិច្ចការជាក់ស្តែង
ប៉ុន្តែលោកម៉ូសេជាអ្នកទទួលខុសត្រូវដែលឃើញថាការងារនេះបានធ្វើត្រឹមត្រូវ។
«ប្រាប់ដល់សិប្បករម្នាក់ឱ្យធ្វើ»
វាំងនន
ក្រណាត់ទាំងនេះគឺធំ
គឺចែកជាផ្នែកនៃក្រណាត់ដែលត្រូវបានប្រើដើម្បីបង្កើតជាការបិទបាំងនិងបែងចែកជញ្ជាំងនៃព្រះវិហារ
ក្រណាត់ពណ៌ក្រហមទុំ
ក្រណាត់លាបពណ៌ក្រហម
ជាងដែលមានស្នាដៃល្អ
មនុស្សម្នាក់ដែលមានជំនាញ ក្នុងការធ្វើឱ្យវត្ថុស្រស់ស្អាតដោយដៃ
ម្ភៃប្រាំបីហត្ថ ...បួនហត្ថ
ប្រាំបីហត្ថ ... បួនហត្ថ - «28 ហត្ថ ... 4 ហត្ថ» ។ មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
វាំងននប្រាំត្រូវភ្ជាប់ជាមួយគ្នា ... ក៏ត្រូវភ្ជាប់ជាមួយគ្នាដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដេរវាំងននប្រាំជាមួយគ្នា ដើម្បីបង្កើតមួយឈុត
ហើយដេរវាំងននប្រាំផ្សេងទៀតរួមគ្នាដើម្បីបង្កើតឈុតមួយផ្សេងទៀត»
Exodus 26:4
កង ... ដង្កៀប
ដង្កៀបពណ៌មាសនឹងកង
មួយទៀត

generated on Wed Sep 10 16:16:32 2025

«វាំងននមួយឈុតប្រាំ»
វាំងននទីពីរ
«វាំងននឈុតទីពីរប្រាំ»
Exodus 26:7
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ដប់មួយ ... សាមសិប ... បួន
«១១ ... ៣០ ... ៤»
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
Exodus 26:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
កង ... ដង្កៀប
ដង្កៀបសម នឹងកងដើម្បីទ្រវាំងននជាមួយគ្នា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យទាំងនេះនៅក្នុង ២៦: ៤ ។
Exodus 26:12
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
ជ្រលក់ពណ៌
«ពណ៌»
Exodus 26:15
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ស៊ុម
នេះសំដៅទៅលើស៊ុមឬបន្ទះក្តារដែលពួកគេបានធ្វើដោយភ្ជាប់គ្នាជាបំណែកតូចៗនៃឈើ
ដប់ហត្ថ ... មួយហត្ថកន្លះ។
«១០ ហត្ថ ... ១,៥ ហត្ថ»
Exodus 26:19
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ជើងទ្រប្រាក់
ទាំងនេះគឺជាដុំប្រាក់ដែលមានរន្ធស៊ក
នៅក្នុងពួកវាដើម្បីរក្សាបន្ទះក្តារឲ្យនៅនឹងកន្លែង។
ពន្លូញ
ជើងទ្រប្រាក់បានរក្សាបន្ទះឈើមិនជាប់ពីដី។
ត្រូវមានជើងទ្រពីរ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ដាក់ជើងទ្រពីរ»
និងជាបន្តបន្ទាប់។
នេះមានន័យថាអ្វីដែលត្រូវបានគេនិយាយដំបូងអំពីបន្ទះក្តារពីរ
គួរតែត្រូវបានធ្វើសម្រាប់បន្ទះក្តារដែលនៅសល់។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«និងជើងទ្រពីរសម្រាប់បន្ទះក្តារនីមួយៗ ដែលនៅសល់»
Exodus 26:22
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ស៊ុមទាំងនេះត្រូវញែកដោយឡែកនៅខាងក្រោម ប៉ុន្តែ ត្រូវភ្ជាប់នៅខាងលើ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ញែកដោយឡែកស៊ុមទាំងនេះនៅខាងក្រោម ប៉ុន្តែភ្ជាប់ពួកវានៅកំពូលខាងលើ»
ជើងទ្រធ្វើពីប្រាក់
ទាំងនេះគឺជាដុំប្រាក់ដែលមានរន្ធស៊កនៅក្នុងពួកវាដើម្បីរក្សាបន្ទះនឹងកន្លែង។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៦:១៩ ។
ទាំងអស់
«សរុប»
និងជាបន្តបន្ទាប់ទៀត។
នេះមានន័យថាអ្វីដែលត្រូវបានគេនិយាយដំបូង
អំពីស៊ុមពីរគួរតែត្រូវបានធ្វើសម្រាប់ស៊ុមដែលនៅសល់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៦:១៩ ។ ការបកប្រែផ្សេងទៀត
«និងជើងទ្រពីរសម្រាប់ស៊ុមនីមួយៗ ដែលនៅសល់»
Exodus 26:26
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេពីរបៀបដែលត្រូវសង់ព្រះពន្លា។
រនុក
ទាំងនេះគឺជាធ្នឹមទ្រទ្រង់ ដែលផ្តល់ភាពរឹងមាំដល់គ្រោងអគារ។
ផ្នែកខាងក្រោយរបស់ព្រះពន្លានៅប៉ែកខាងលិច។
នៅខាងមុខព្រះពន្លា បែរមុខទៅទិសខាងកើត។
Exodus 26:29
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ អំពីរបៀបសង់ព្រះពន្លា។
សម្រាប់ស៊កចូលរនុក ហើយអ្នកត្រូវស្រោមរនុក
«ដែលនឹងកាន់រនុក» ឬ «ពីព្រោះពួកគេនឹងរនុក»
រនុក
ទាំងនេះគឺជាធ្នឹមទ្រទ្រង់ដែលផ្តល់ភាពរឹងមាំដល់គ្រោងអគារ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៦:២៦ ។
ដែលបានបង្ហាញអ្នកនៅលើភ្នំ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលខ្ញុំបានបង្ហាញអ្នកនៅលើភ្នំនេះ»
Exodus 26:31
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ អំពីរបៀបសង់ព្រះពន្លា។
អ្នកត្រូវធ្វើ
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់លោកម៉ូសេដូច្នេះពាក្យថា «អ្នក»
គឺជាឯកវចនៈ។ ព្រះអម្ចាស់ប្រហែលជារំពឹងទុកថា
លោកម៉ូសេនឹងប្រាប់មនុស្សណាម្នាក់អោយធ្វើកិច្ចការជាក់ស្តែង
ប៉ុន្តែលោកម៉ូសេជាអ្នកទទួលខុសត្រូវដែលឃើញថាការងារនេះបានធ្វើត្រឹមត្រូវ។
«ប្រាប់អ្នកសិប្បករឱ្យធ្វើ» ។ សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៦:
១ ។
ដង្កៀប
ដង្កៀបសម នឹងកងដើម្បីទ្រវាំងននជាមួយគ្នា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យទាំងនេះនៅក្នុង ២៦: ៤ ។
ហើយអ្នកត្រូវយកហឹបដែលដាក់បន្ទះថ្មនៃសម្ពន្ធមេត្រី។
ហឹបនៃសម្ពន្ធមេត្រី គឺជាហឹបដែលមានបទបញ្ញត្តិ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែនាំយកហឹបដែលមានបទបញ្ញត្តិ»
វាំងននត្រូវញែកទីបរិសុទ្ធ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«វាំងននត្រូវញែកកន្លែងទីបរិសុទ្ធ»
Exodus 26:34
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ
ទីសន្តោសប្រោស
នេះជាគម្របនៅពីលើហឹប ដែលជាកន្លែងថ្វាយតង្វាយប្រោសលោះ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៥:១៥ ។
នៅលើហឹបនៃសម្ពន្ធមេត្រី
«នៅលើហឹបដែលមានបទបញ្ញត្តិ»
តុត្រូវនៅប៉ែកខាងជើង។
នេះគឺជាតុដែលតាំងនំបុ័ង ដែលតំណាងឱ្យព្រះវត្តមានរបស់ព្រះជាម្ចាស់។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ដាក់តុសម្រាប់នំបុ័ង
នៃព្រះវត្តមានរបស់ព្រះជាម្ចាស់នៅភាគខាងជើង»
Exodus 26:36
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីរបៀបសង់ព្រះពន្លា។
កន្លែងព្យួរ
នេះគឺជាវាំងនន ដ៏ធំមួយធ្វើពីក្រណាត់។
មានពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម
ទី១អត្ថន័យដែលប្រហែលគឺ) «ក្រណាត់ដែលលាបពណ៌ខៀវ ស្វាយ និង

generated on Wed Sep 10 16:16:32 2025

ក្រហមទុំ» ប្រហែលជាអំបោះរោមចៀមឬ ទី២) «ពណ៌ខៀវពណ៌ស្វាយ
និងពណ៌ក្រហមទុំ» ដើម្បីជ្រលក់ក្រណាត់ទេសឯក។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៥: ៣ ។
វិញនឹងអំបោះខ្លូតទេស

«អំបោះខ្លូតទេស» នេះគឺជាក្រណាត់ធ្វើអំបោះខ្លូតទេស
ដែលមនុស្សណាម្នាក់ច្របាច់បញ្ចូលគ្នាដើម្បីធ្វើឱ្យអំបោសកាន់តែរឹងមាំ។
ត្រូវប៉ាក់ផង
«មនុស្សដែលដេររចនាម៉ូដជាក្រណាត់» ឬ «មនុស្សដែលជាជាងដេរប៉ាក់» ។

---

27 [1]អ្នកត្រូវធ្វើកន្លែងថ្វាយយញ្ញបូជាពីឈើនាងនួន ដែលមានប្រវែងប្រាំហត្ថ និងទទឹកប្រាំហត្ថ។ កន្លែងថ្វាយយញ្ញបូជានោះត្រូវមានរាងការ៉េ និងកម្ពស់បីហត្ថ។
[2]អ្នកត្រូវធ្វើស្នែងគោជាប់ទាំងបួនជ្រុងនៃកន្លែងថ្វាយយញ្ញបូជានោះ។ ស្នែងត្រូវភ្ជាប់ដុំតែមួយជាមួយនឹងកន្លែងថ្វាយយញ្ញបូជា
អ្នកត្រូវស្រោបស្នែងនោះដោយលង្ហិន។
[3]អ្នកត្រូវធ្វើឧបករណ៍សម្រាប់ប្រើនៅកន្លែងថ្វាយយញ្ញបូជា មានឆ្នាំង ប៉ែល ធើង សម និងជើងក្រាន។ អ្នកត្រូវធ្វើឧបរណ៍នេះជាមួយនឹងលង្ហិនទាំងអស់។
[4]អ្នកត្រូវធ្វើប្រទាសសម្រាប់កន្លែងថ្វាយយញ្ញបូជា ខ្ទាស់ក្រឡាគ្នាជាមួយលង្ហិន។ ត្រូវធ្វើកងលង្ហិនបួនសម្រាប់ប្រទាសនីមួយៗទាំងបួនជ្រុងដែរ។
[5]អ្នកត្រូវដាក់ប្រទាសនៅក្រោមក្រោមជ្រុងទាំងបួន គឺនៅចំពាក់កណ្តាលនៃកន្លែងថ្វាយយញ្ញបូជា។[6]អ្នកត្រូវធ្វើឈើស្នែងសម្រាប់សែងកន្លែងថ្វាយយញ្ញបូជា
ឈើស្នែងនោះត្រូវធ្វើពីឈើនាងនួន ហើយអ្នកត្រូវស្រោបវាដោយលង្ហិន។
[7]ត្រូវដាក់ឈើស្នែងនៅក្នុងកង ហើយឈើស្នែងសម្រាប់សែងកន្លែងថ្វាយយញ្ញបូជាត្រូវមានទាំងសងខាង។
[8]អ្នកត្រូវធ្វើកន្លែងថ្វាយយញ្ញបូជាពីក្តាដែលមានប្រហោងកណ្តាល ចេញពីបន្ទះក្តានោះ។ អ្នកត្រូវធ្វើវាបែបនេះ តាមដែលបានបង្ហាញនៅលើភ្នំ។
[9]អ្នកត្រូវធ្វើទីលានសម្រាប់ព្រះពន្លា។ ត្រូវមានរនាំងព័ទ្ធជុំវិញភាគខាងត្បូងនៃទីលាន រនាំងធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ប្រវែងមួយរយហត្ថ។
[10]រនាំងត្រូវមាននោះត្រូវមានសរសេរម្ភៃ ជាមួយនឹងជើងទ្រម្ភៃដែលធ្វើពីលង្ហិនផង។ ត្រូវមានតម្ពក់ភ្ជាប់ទៅនឹងសរសរ និងគន្លឹះ ត្រូវធ្វើពីប្រាក់។
[11]នៅប៉ែកខាងជើងក៏ដូចគ្នាដែរ ត្រូវធ្វើរនាំងប្រវែងមួយហត្ថ ជាមួយនឹងសសរម្ភៃដែរ ជើងទ្រម្ភៃធ្វើពីលង្ហិន តម្ពក់ដែលភ្ជាប់នឹងសសរ និងកន្លឹះ ធ្វើពីប្រាក់។
[12]នៅប៉ែកខាងលិច ត្រូវធ្វើវាំងននប្រវែងហាសិបហត្ថ។ ត្រូវធ្វើសសរដប់ និងជើងទ្រដប់។[13]ទីលានត្រូវមានប្រវែងហាសិបហត្ថ ទៅប៉ែកខាងកើត។
[14]រនាំងសម្រាប់ប៉ែកផ្លូវចូលត្រូវមានប្រវែងដប់ប្រាំហត្ថ។ ត្រូវធ្វើសសរបី និងជើងទ្របី។ នៅប៉ែកម្ខាងទៀតក៏ត្រូវមានរនាំងប្រវែងដប់ប្រាំហត្ថដែរ។[15]ត្រូវធ្វើសសរបី
និងជើងទ្របី។ ច្រកចូលទីលានត្រូវធ្វើវាំងននមានប្រវែងម្ភៃហត្ថ។[16]វាំងននត្រូវមានពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហមទុំ ធ្វើពីក្រណាត់អំបោះធ្មៃយ៉ាងស្អាត
ជាមួយនឹងក្បាច់បាក់ផង។ ត្រូវមានសសរបួនជាមួយនឹងជើងទ្របួន។
[17]សសរទីលានទាំងអស់ត្រូវមានគន្លឹះ និងតម្ពក់ស្រោបដោយប្រាក់ និងមានជើងទ្រលង្ហិន។[18]ទីលានត្រូវមានបណ្តោយប្រវែងមួយរយហត្ថ
និងទទឹងប្រវែងហាសិបហត្ថស្មើគ្នា ហើយនិងកម្ពស់ប្រាំហត្ថ ជាមួយនឹងរនាំងវិញត្រូវធ្វើពីអំបោះធ្មៃយ៉ាងស្អាតចងព័ទ្ធជុំវិញ ដែលមានជើងទ្រលង្ហិនផង។
[19]គ្រប់ឧបករណ៍ទាំងអស់ដែលត្រូវប្រើនៅក្នុងព្រះពន្លា និងចម្រឹងព្រះពន្លា និងចម្រឹងរនាំងរបស់ទីលាន ត្រូវធ្វើពីលង្ហិនទាំងអស់។
[20]អ្នកត្រូវបង្គាប់ដល់ប្រជាជនអ៊ីស្រាអែលឲ្យយកប្រេងអូលីវសុទ្ធដែលល្អបំផុត សម្រាប់ដុតឲ្យចង្កៀងភ្លឺជាអចិន្ត្រៃយ៍។[21]នៅខាងមុខព្រះពន្លានៃការជួបជុំ
នៅខាងក្រៅវាំងននដែលនៅខាងមុខព្រះពន្លាដែលនៅទីនោះមានហឹបនៃសម្ពន្ធមេត្រី លោកអ៊ើរ៉ុន
និងកូនប្រុសៗរបស់គាត់ត្រូវរក្សាចង្កៀងឲ្យឆេះនៅចំពោះព្រះអម្ចាស់ជានិច្ច តាំងពីព្រឹករហូតដល់ល្ងាច។ សេចក្តីបង្គាប់នេះ នឹងត្រូវជាពិធីបរិសុទ្ធសម្រាប់កូនចៅអ៊ីស្រាអែល
គ្រប់ជំនាន់អនុវត្តតាមជារៀងរហូតតទៅ។

Exodus 27:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។ (សូមមើល EXO 25:1)
ដែលមានប្រវែងប្រាំហត្ថ និងទទឹកប្រាំហត្ថ។
«ប្រវែង ២,២ ម៉ែត្រនៅសងខាង»
កន្លែងថ្វាយយញ្ញបូជានោះត្រូវមានរាងការ៉េ និងកម្ពស់បីហត្ថ។
«អាសនាត្រូវមានរាងការេនិងកំពស់ ១,៣ ម៉ែត្រ»
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
អ្នកត្រូវធ្វើស្នែងគោជាប់ទាំងបួនជ្រុងនៃកន្លែងថ្វាយយញ្ញបូជានោះ។
«អ្នកត្រូវធ្វើការប៉ានស្មានដែលមើលទៅ ដូចជាស្នែងគោនៅជ្រុងទាំងបួនរបស់វា»
ស្នែងត្រូវភ្ជាប់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវធ្វើស្នែង»
ត្រូវស្រោបស្នែងនោះ
«ត្រូវតែគ្របអាសនានិងស្នែង»
Exodus 27:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ធើង
«ចានគោម»
ជើងក្រាន
មានឆ្នាំងដែលដាក់ធ្យូងក្តៅពីអាសនា។
ឧបរណ៍
ទាំងនេះជាឧបករណ៍នា ភាជនដ៍
ឬឧបករណ៍ដែលបានប្រើក្នុងគោលបំណងមានប្រយោជន៍។
អ្នកត្រូវធ្វើប្រទាសសម្រាប់កន្លែងថ្វាយយញ្ញបូជា ខ្ទាស់ក្រឡាគ្នាជាមួយលង្ហិន។
«អ្នកត្រូវធ្វើខ្ទាស់ក្រឡាគ្នាជាមួយលង្ហិនសម្រាប់អាសនា»
ប្រទាស
ស៊ុមព័ទ្ធជុំវិញរបាសម្រាប់ដាក់អុសនៅពេលដុត
Exodus 27:5
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
អ្នកត្រូវដាក់ប្រទាសនៅក្រោមក្រោមជ្រុងទាំងបួន
ប្រទាសត្រូវបានដាក់នៅខាងក្នុងអាសនា។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវដាក់ប្រទាសនៅក្រោមគែមនៃអាសនា ខាងក្នុងអាសនា »
ប្រទាស
ស៊ុមនៃរបាសម្រាប់ដាក់អុសនៅពេលដុត
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧: ៣ ។
អ្នកត្រូវធ្វើឈើស្នែងសម្រាប់សែងកន្លែងថ្វាយយញ្ញបូជា
ស្នែងទាំងនេះត្រូវបានប្រើសម្រាប់សែងអាសនា។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវធ្វើស្នែងសម្រាប់សែងអាសនា»
Exodus 27:7
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនគួរធ្វើ។
ត្រូវដាក់ឈើស្នែងនៅក្នុងកង
ហើយឈើស្នែងសម្រាប់សែងកន្លែងថ្វាយយញ្ញបូជាត្រូវមានទាំងសងខាង។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
អ្នកត្រូវដាក់ស្នែងទៅក្នុងកង ហើយដាក់វានៅសងខាងអាសនាដើម្បីសែងវា»
ក្តា
ឈើវែង មួយដុំរាបស្មើក្រាស់ជាងបន្ទះក្តា
តាមដែលបានបង្ហាញនៅលើភ្នំ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលយើងបានបង្ហាញដល់អ្នកនៅលើភ្នំនេះ»
Exodus 27:9
ត្រូវមានរនាំងព័ទ្ធ ... ទីលាន

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវដាក់រនាំងព័ទ្ធ ... ទីលាន»
រនាំងធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់
"រនាំង" គឺជាវាំងននដ៏ធំមួយធ្វើពីក្រណាត់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែរឿងនេះនៅក្នុង ២៦:៣៦
រនាំងធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់
«រនាំងធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់» នេះគឺជាក្រណាត់ធ្វើពីអំបោះទេស
ដែលមានមនុស្សណាម្នាក់វេញបញ្ចូលគ្នា ដើម្បីធ្វើឱ្យអំបោះកាន់តែរឹងមាំ
ប្រវែងមួយរយហត្ថ
«៤៤ ម៉ែត្រ»
ត្រូវមានតម្លក់ ... សរសរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវភ្ជាប់តម្លក់ ... សរសរ»
សរសរ
ឈើមួយដុំរឹងមាំដាក់បញ្ឈរ ហើយប្រើជាជំនួយ។
Exodus 27:11
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
នៅប៉ែក ... កន្លឹះ ធ្វើពីប្រាក់
សម្រាប់ ២៧:១១
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យស្រដៀងគ្នាជាច្រើននៅក្នុង ២៧: ៩ ។
ត្រូវធ្វើរនាំង
នេះអាចត្រូវបានបញ្ជាក់ជាពាក្យបញ្ជា។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែធ្វើរនាំង»
ត្រូវធ្វើវាំងនន
នេះអាចត្រូវបានបញ្ជាក់ជាពាក្យបញ្ជា។ ការបកប្រែផ្សេងទៀត «អ្នកត្រូវធ្វើវាំងនន»
ត្រូវធ្វើសសរដប់
នេះអាចត្រូវបានបញ្ជាក់ជាពាក្យបញ្ជា។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវធ្វើសសរចំនួនដប់»
ទីលានត្រូវមានប្រវែងហាសិបហត្ថ
នេះអាចត្រូវបានបញ្ជាក់ជាពាក្យបញ្ជា។ ការបកប្រែផ្សេងទៀត
«ធ្វើទីលានដែលមានបណ្តោយហាសិបហត្ថ"
Exodus 27:14
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលប្រជាជនត្រូវធ្វើ។
រនាំង
ទាំងនេះគឺជាវាំងននធំធ្វើពីក្រណាត់។ សូមមើលនៅក្នុង ២៦:៣៦ ។
សសរ
ទាំងនេះគឺជាដុំឈើរឹងមាំ ដែលត្រូវបានដាក់បញ្ឈរហើយត្រូវបានប្រើជាជំនួយ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧: ៩ ។
ជើងទ្រ
ទាំងនេះគឺជាដុំដែកដែលមានរន្ធនៅក្នុងពួកវា ដើម្បីរក្សាក្តារឱ្យនៅនឹងកន្លែង។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងម៉ោង ២៦:១៩ ។
ដប់ជ្រាំហត្ថ
ប្រហែលជ្រាំពីរម៉ែត្រ
ធ្វើពីក្រណាត់អំបោះធ្មៃយ៉ាងស្អាត ជាមួយនឹងក្បាច់បាក់ផង
នេះអាចត្រូវបានបញ្ជាក់ជាពាក្យបង្គាប់។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវធ្វើវាំងននប្រវែងម្ភៃហត្ថ ដើម្បីធ្វើជាក្លោងទ្វារទីលាន»
វាំងននត្រូវមាន ... ធ្វើពីក្រណាត់អំបោះធ្មៃយ៉ាងស្អាត ជាមួយនឹងក្បាច់បាក់ផង។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ពួកគេត្រូវធ្វើវាំងនន...ពីក្រណាត់អំបោះធ្មៃយ៉ាងស្អាត ជាស្នាដៃរបស់ជាងប៉ាក់» ឬ
« ជាងប៉ាក់ត្រូវតែធ្វើវាំងនន ... ពីក្រណាត់អំបោះធ្មៃយ៉ាងស្អាត» ។
ពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហមទុំ ធ្វើពីក្រណាត់អំបោះធ្មៃយ៉ាងស្អាត
ទី១អត្ថន័យដែលប្រហែលគឺ) «អំបោះដែលត្រូវបានគេលាបពណ៌ខៀវស្វាយ
និងក្រហមទុំ» ប្រហែលជាអំបោះរោមចៀមឬទី ២)
«ពណ៌ខៀវពណ៌ស្វាយនិងពណ៌ក្រហមទុំ» ដើម្បីជ្រលក់លើក្រណាត់។
ក្បាច់បាក់
មនុស្សដែលដេររចនាម៉ូដក្រណាត់
Exodus 27:17
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
មួយរយហត្ថ
«១០០ ហត្ថ» ។ មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
ជាមួយនឹងរនាំងវិញត្រូវធ្វើពីអំបោះធ្មៃយ៉ាងស្អាត
«ត្រូវធ្វើពីអំបោះធ្មៃយ៉ាងស្អាត»
នេះគឺជាក្រណាត់ធ្វើពីអំបោះដែលមានមនុស្សណាម្នាក់វេញបញ្ចូលគ្នា
ដើម្បីធ្វើឱ្យអំបោះកាន់តែរឹងមាំ។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង
២៦:៣៦ ។
និងចម្រឹងព្រះពន្លា និងចម្រឹងរនាំងរបស់ទីលាន ត្រូវធ្វើពីលង្ហិនទាំងអស់។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ហើយធ្វើចម្រឹង
ព្រះពន្លាទាំងអស់សម្រាប់ព្រះពន្លា និងទីលានពីលង្ហិន»
ចម្រឹងព្រះពន្លា
កំណាត់ឈើ ឬដែកមុតដែលត្រូវបានប្រើដើម្បីការពារជ្រុងនៃព្រះពន្លាជាប់ដី
Exodus 27:20
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ព្រះពន្លានៃការជួបជុំ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។
ហឹបនៃសម្ពន្ធមេត្រី
នេះជាហឹបដែលមាននូវឆ្នាំងថ្ម
ដ៏សក្ការៈដែលព្រះអម្ចាស់បានចារនៅបទបញ្ញត្តិរបស់ព្រះអង្គ។
សេចក្តីបង្គាប់នេះ នឹងត្រូវជាពិធីបរិសុទ្ធ
«យើងបង្គាប់ឱ្យថាប្រជាជន ធ្វើពិធីបរិសុទ្ធបែបនេះជាជារៀងរហូតតទៅ»

---

28 [1]ចូរហៅអើរ៉ុន បងប្រុសរបស់អ្នក ព្រមទាំងកូនប្រុសៗរបស់គាត់ មានណាដាប់ អប៊ីហ៊ូវ អេលាសារ និងអ៊ីថាម៉ារ ពីក្នុងចំណោមជនជាតិអ៊ីស្រាអែល ដើម្បី
ឲ្យពួកគេបម្រើយើងក្នុងមុខងារជាបូជាចារ្យ។[2]អ្នកត្រូវធ្វើសម្លៀកបំពាក់សម្រាប់អើរ៉ុន បងប្រុសរបស់អ្នក ញែកដោយឡែកសម្រាប់យើង។
សម្លៀកបំពាក់នេះសម្រាប់ផ្តល់កិត្តិយស និងជាលម្អដល់គាត់។[3]អ្នកត្រូវប្រាប់ឲ្យប្រជាជនទាំងអស់ដែលមានប្រាជ្ញា គឺអស់អ្នកដែលបានពេញដោយវិញ្ញាណនៃប្រាជ្ញា
ដើម្បីឲ្យពួកគេធ្វើសម្លៀកបំពាក់របស់អើរ៉ុន ដើម្បីញែកគាត់ដោយឡែកបម្រើយើងក្នុងមុខងារជាបូជាចារ្យ។
[4]សម្លៀកបំពាក់ដែលពួកគេត្រូវធ្វើគឺប្រដាប់ពាក់លើទ្រូងមួយ អាវអេផូដមួយ អាវវែងមួយ អាវក្នុងមួយជាអាវប៉ាក់ ឈ្នួតក្បាលមួយ និងខ្សែក្រវាត់មួយ។ ពួកគេត្រូវធ្វើ
សម្លៀកបំពាក់ទាំងនេះ ដើម្បីញែកពួកគេដោយឡែកសម្រាប់យើង។ ពួកគេគឺជាអើរ៉ុន បងប្រុសរបស់អ្នក និងទាំងកូនប្រុសៗរបស់គាត់ ដើម្បីឲ្យបម្រើមុខងារជាបូជាចារ្យ។
[5]ពួកសិប្បករត្រូវប្រើអំបោះមាស អំបោះពណ៌ស្វាយ ពណ៌ក្រហម និងពណ៌ក្រហមទុំ ព្រមទាំងអំបោះធ្មៃ។
[6]ពួកគេត្រូវធ្វើអាវអេផូដ ពីអំបោះមាស អំបោះពណ៌ស្វាយ ពណ៌ក្រហម និងពណ៌ក្រហមទុំ ព្រមទាំងអំបោះធ្មៃ ដោយមានប៉ាក់លំអផង។ ត្រូវធ្វើតាមរចនានៃពួកជាងដែល
មានស្នាដៃ។[7]ត្រូវមានខ្សែស្មាពីរ ភ្ជាប់នៅចុងអាវអេផូដទាំងមុខទាំងក្រោយ ឲ្យបានជាប់ជាមួយគ្នា។[8]រីឯខ្សែក្រវាត់របស់អាវអេផូដ ត្រូវធ្វើដោយសរសៃអំបោះយ៉ាងល្អ ដូច
អាវអេផូដដែរ គឺមានអំបោះមាស អំបោះពណ៌ស្វាយ ពណ៌ក្រហម និងពណ៌ក្រហមទុំ។[9]ត្រូវយកត្បូងមណីជោគិរសពីរមក ហើយចារឈ្មោះកូនរបស់អ៊ីស្រាអែលទាំងដប់ពីរ
នៅលើនោះ។
[10]ឈ្មោះរបស់ពួកគេប្រាំមួយ ត្រូវនៅលើត្បូងមណីជោគិរសមួយ ហើយឈ្មោះប្រាំមួយទៀតនៅលើត្បូងមណីជោគិរសមួយទៀត
ដើម្បីឲ្យមានឈ្មោះតាមលំដាប់របស់ពួកគេ។[11]តាមរបៀបដូចគេឆ្លាក់ត្រា ហើយត្រូវធ្វើក្រចាប់មាសភ្ជាប់នឹងត្បូងទាំងពីរនោះ
ជាមួយនឹងឈ្មោះកូនចៅអ៊ីស្រាអែលទាំងដប់ពីរផង។[12]អ្នកត្រូវដាក់ត្បូងទាំងពីរភ្ជាប់នឹងខ្សែរបស់អាវអេផូដ ទុកជាតំណាងកូនរបស់អ៊ីស្រាអែល។ អើរ៉ុននឹងពាក់ឈ្មោះរបស់
ពួកគេ នៅចំពោះព្រះអម្ចាស់នៅលើស្មាទាំងពីររបស់កាត់ ទុកជាការរំលឹកដល់ពួកគេ។
[13]អ្នកត្រូវធ្វើក្រចាប់ទាំងនោះពីមាស[14]ហើយធ្វើខ្សែពីមាសសុទ្ធ ដែលវេញចូលគ្នាជារបៀបខ្សែពួរ ហើយអ្នកត្រូវភ្ជាប់ខ្សែ និងក្រចាប់ជាប់គ្នា។

generated on Wed Sep 10 16:16:32 2025

[15]អ្នកត្រូវធ្វើប្រដាប់ពាក់លើទ្រូងមួយ សម្រាប់វិនិច្ឆ័យ ឲ្យត្រូវតាមរចនានៃពួកជាងដែលមានស្នាដៃ ហើយតាមរបៀបអាវអេផូដដែរ គឺធ្វើពីមាស ពីសំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម ដែលត្បាញដោយអំបោះធ្មៃ។[16]ត្រូវឲ្យបានបួនជ្រុងស្មើ។ អ្នកត្រូវបត់ប្រដាប់ពាក់ដើមទ្រូវជាពីរផ្នត់។ ត្រូវមានបណ្តោយមួយចំអាម ទទឹងមួយចំអាម។
[17]អ្នកត្រូវដាក់ដាំត្បូងបួនជួរនៅប្រដាប់នោះ។ ក្នុងជួរទីមួយ ត្រូវដាំត្បូងទទឹមមួយគ្រាប់ ត្បូងប៊ុតលឿងមួយគ្រាប់ និងត្បូងមរកតមួយគ្រាប់។[18]ក្នុងជួរទីពីរ មានត្បូងមរកតមួយ ត្បូងកណ្តៀងមួយ និងពេជ្រមួយ។[19]ជួរទីបី ត្រូវដាំត្បូងទទឹមមួយគ្រាប់ ត្បូងនិលវ័ត្តមួយគ្រាប់ និងត្បូងជម្ពូវ័ត្តមួយគ្រាប់។[20]ជួរទីបួន ត្រូវដាំត្បូងដៃរគៀមមួយគ្រាប់ ត្បូងកែវយក់មួយគ្រាប់ និងមណីជោតិរសមួយគ្រាប់។ ត្បូងនីមួយៗត្រូវតែដាំបង្កប់ក្នុងក្រចាប់ធ្វើអំពីមាស។
[21]ត្បូងទាំងនេះត្រូវរៀបចំឡើងតាមឈ្មោះរបស់កូនចៅនៃជនជាតិអ៊ីស្រាអែលទាំងអស់ដប់ពីរ ជាលំដាប់តាមឈ្មោះនីមួយៗ។ ត្រូវឆ្លាក់ទាំងអស់បែបដូចជាឆ្លាក់ត្រា គ្រប់ត្បូង ត្រូវចារឹកឈ្មោះមួយៗ ក្នុងឈ្មោះកុលសម្ព័ន្ធទាំងដប់ពីរនោះ។[22]អ្នកត្រូវធ្វើជាខ្សែពាក់លើដើមទ្រូងដូចជាខ្សែពួរ ត្រូវធ្វើវាពីមាសសុទ្ធ។[23]ត្រូវធ្វើក្រវិលមាសពីរសម្រាប់ពាក់លើដើមទ្រូង ហើយត្រូវភ្ជាប់នៅចុងសងខាងនៃដើមទ្រូងដែរ។[24]បន្ទាប់មក ត្រូវភ្ជាប់ខ្សែមាសទាំងពីរទៅនឹងកងទាំងពីរនៃប្រដាប់ពាក់លើទ្រូង។
[25]អ្នកត្រូវភ្ជាប់ចុងម្ខាងទៀតនៃខ្សែពីរជាមួយនឹងក្រចាប់ពីរទៀត។ បន្ទាប់មកអ្នកត្រូវភ្ជាប់របស់ទាំងនោះទៅនឹងប្រដាប់ពាក់លើដើមទ្រូងនៅខាងមុខ។
[26]អ្នកត្រូវធ្វើកងពីរពីមាស ហើយអ្នកដាក់កងនោះនៅលើជ្រុងទាំងពីរនៃប្រដាប់ពាក់លើដើមទ្រូង និងនៅលើជ្រុងដែលនៅជិតជាយខាងក្នុង។
[27]អ្នកត្រូវធ្វើកងពីមាសពីរថែមទៀត ហើយអ្នកត្រូវភ្ជាប់កងនោះទៅនឹងខាងក្រោមនៃខ្សែចងស្មាពីនៅខាងមុខអាវអេផូដ ជិតកន្លែងដែលខ្សែស្មាភ្ជាប់គ្នា និងខាងលើខ្សែអាវអេផូឌដែរ។[28]ពួកគេត្រូវចងប្រដាប់ពាក់លើដើមទ្រូងដោយភ្ជាប់កងទៅនឹងកងរបស់អាវអេផូដចងដោយខ្សែពណ៌ស្វាយ ដើម្បីវាអាចភ្ជាប់ប្រដាប់ពាក់លើដើមទ្រូងស្ថិតនៅលើខ្សែក្រវាត់។ ធ្វើបែបនេះ ដើម្បីឲ្យប្រដាប់ពាក់លើដើមទ្រូងអាចរបូតពីអាវអេផូដឡើយ។
[29]បន្ទាប់មក លោកអ៊ើរ៉ុនត្រូវចូលទៅក្នុងទីបរិសុទ្ធបំផុត គាត់ត្រូវយកឈ្មោះជនជាតិអ៊ីស្រាអែលដែលឆ្លាក់នៅលើដួងចិត្តរបស់គាត់គឺនៅលើប្រដាប់ពាក់លើដើមទ្រូង ដើម្បីវិនិច្ឆ័យ ដើម្បីបន្តរំលឹកនៅចំពោះព្រះអម្ចាស់។[30]អ្នកត្រូវដាក់យូរីម និងធូមីម ទៅក្នុងប្រដាប់ពាក់លើទ្រូង សម្រាប់វិនិច្ឆ័យ ដើម្បីឲ្យវត្ថុទាំងនេះស្ថិតនៅជាប់នឹងដួងចិត្តអ៊ើរ៉ុនជានិច្ច នៅពេលគាត់ចូលមករកព្រះអម្ចាស់។ ដូច្នេះ អ៊ើរ៉ុនត្រូវពាក់គ្រឿងសម្រាប់វិនិច្ឆ័យជនជាតិអ៊ីស្រាអែលជាប់នឹងដួងចិត្តរបស់គាត់នៅចំពោះព្រះអម្ចាស់ជានិច្ច។
[31]អ្នកត្រូវធ្វើអាវអេផូដមួយវែងដែលមានពណ៌ស្វាយ។ ត្រូវបើកប្រឡោះសម្រាប់ក្បាល ហើយនិងប្រឡោះមួយចំកណ្តាល។[32]ត្រូវដេរឫមជុំវិញប្រឡោះនោះ ដើម្បីកុំឲ្យរហែក។ ការនេះត្រូវដេរតាមរបៀបដែលគេដេរជាយអាវស្បែក។
[33]នៅជាយខាងក្រោម អ្នកត្រូវធ្វើផ្លែទទឹមពីអំបោះពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហមទុំនៅជុំវិញ។ ត្រូវចងឆ្លាស់គ្នានឹងកណ្តឹងមាសនៅជុំវិញ។
[34]ត្រូវមានកណ្តឹងមាសមួយ និងផ្លែទទឹមមួយ កណ្តឹងមាសមួយ និងផ្លែទទឹមមួយនៅព័ទ្ធជុំវិញជាយខាងក្រោមអាវវែង។[35]អាវវែងត្រូវពាក់លើអ៊ើរ៉ុន នៅពេលគាត់បម្រើ ដើម្បីឲ្យសម្លេងរបស់វាអាចឮ ពេលគាត់ចូលទៅក្នុងទីបរិសុទ្ធនៅចំពោះព្រះអម្ចាស់ និងពេលគាត់ចាកចេញ។ ធ្វើដូច្នេះ គាត់នឹងមិនត្រូវស្លាប់ឡើយ។
[36]អ្នកត្រូវធ្វើស្លាកមួយពីមាសសុទ្ធ ហើយឆ្លាក់លើវា ដូចជាត្រាមួយថា «វិសុទ្ធថ្វាយព្រះអម្ចាស់»។
[37]អ្នកត្រូវភ្ជាប់ស្លាកនេះជាមួយនឹងខ្សែពណ៌ខៀវភ្ជាប់នឹងឈ្នួតក្បាលផ្នែកខាងមុខ។[38]ត្រូវពាក់វានៅលើក្បាលរបស់អ៊ើរ៉ុន
គាត់ផ្ទុកបាបផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងតង្វាយបរិសុទ្ធ ដែលជនជាតិអ៊ីស្រាអែលត្រូវញែកដោយឡែកថ្វាយព្រះអម្ចាស់។
ឈ្នួតក្បាលត្រូវពាក់នៅពីលើក្បាលរបស់គាត់ជានិច្ច ដើម្បីឲ្យព្រះអម្ចាស់បានទទួលតង្វាយរបស់ពួកគេ។
[39]អ្នកត្រូវធ្វើអាវខ្លួនពីក្រណាត់ដ៏ល្អ ហើយអ្នកត្រូវធ្វើឈ្នួតក្បាលមួយពីក្រណាត់ដ៏ល្អដែរ។ អ្នកត្រូវធ្វើខ្សែក្រវាត់មួយដើម្បីពាក់ឈៀង។
[40]សម្រាប់កូនប្រុសៗរបស់អ៊ើរ៉ុនវិញ អ្នកត្រូវធ្វើអាវធំ ខ្សែក្រវាត់ និងឈ្នួតក្បាល ដើម្បីជាកិត្តិយស និងភាពថ្លៃថ្នូរដល់ពួកគេ។[41]អ្នកត្រូវស្លៀកពាក់ឲ្យលោកអ៊ើរ៉ុន បងប្រុសរបស់អ្នក ហើយនិងកូនប្រុសៗដែលនៅជាមួយគាត់។ អ្នកត្រូវចាក់ប្រេងលើពួកគេ និងតែងតាំងពួកគេ ព្រមទាំងញែកពួកគេដោយឡែកសម្រាប់យើង ដើម្បីឲ្យពួកគេបម្រើយើងក្នុងមុខងារជាបូជាចារ្យ។
[42]អ្នកត្រូវធ្វើខោក្នុងពីអំបោះធ្មៃ ដើម្បីគ្របបាំងកេរ្តិ៍ខ្មាសរបស់ពួកគេ ខោក្នុងនោះ នឹងគ្របបាំងពីចង្កេះដល់ភ្លៅ។[43]លោកអ៊ើរ៉ុន
និងកូនប្រុសៗរបស់គាត់ត្រូវស្លៀកសម្លៀកបំពាក់ទាំងនេះ នៅពេលពួកគេចូលទៅក្នុងព្រះពន្លានៃត្រសាលប្រជុំ
ឬនៅពេលពួកគេចូលទៅកន្លែងថ្វាយយញ្ញបូជានៅក្នុងទីបរិសុទ្ធ។ ពួកគេត្រូវធ្វើបែបនេះ ដើម្បីកុំឲ្យពួកគេធ្វើខុស ឬពួកគេមិនត្រូវស្លាប់ឡើយ។
នេះគឺជាច្បាស់ដែលស្ថិតស្ថេររៀងរហូតតទៅ សម្រាប់លោកអ៊ើរ៉ុន និងពូជពង្សដែលនៅក្រោយគាត់។

Exodus 28:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។ (សូមមើល ២៥: ១)
ចូរហៅ
នៅទីនេះ «ហៅ» សំដៅទៅលើលោកម៉ូសេ។
មានណាដាប់ អប៊ីហ៊ូវ អេលាសារ និងអ៊ីថាម៉ារ
ទាំងនេះគឺជាឈ្មោះរបស់បុរស។
អ្នកត្រូវធ្វើ
នៅទីនេះ «អ្នក» សំដៅទៅលើប្រជាជន។
ញែកដោយឡែកសម្រាប់យើង។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
សម្លៀកបំពាក់ដែលអ្នក នឹងញែកចេញសម្រាប់យើង»
Exodus 28:4
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
អាវក្នុងមួយជាអាវប៉ាក់
«អាវធំមួយដែលមានក្បាច់រចនាចូលទៅក្នុងនោះ»
ឈ្នួតក្បាលមួយ
គម្របក្បាលខ្ពស់ធ្វើពីក្រណាត់រុំជុំវិញក្បាលជាច្រើនដង។
ខ្សែក្រវាត់មួយ
ចំណែកក្រណាត់មួយដែលមនុស្សពាក់ជុំវិញចង្កេះ ឬពាក់ឈៀងដើមទ្រូង
Exodus 28:6
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ព្រមទាំងអំបោះធ្មៃ
អំបោះធ្មៃ -« ព្រមទាំងអំបោះធ្មៃ» ។ នេះគឺជាក្រណាត់ធ្វើពីអំបោះធ្មៃ
ដែលមានមនុស្សណាម្នាក់វេញបញ្ចូលគ្នា ដើម្បីធ្វើឱ្យខ្សែអំបោះកាន់តែរឹងមាំ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៦:៣៦ ។
ដែលមានស្នាដៃ។
មនុស្សម្នាក់ដែលអាចធ្វើឱ្យវត្ថុស្រស់ស្អាតដោយដៃ
ត្រូវធ្វើដោយសរសៃ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវធ្វើវាជាសរសៃតែមួយ»
មណីជោតិរស
ទាំងនេះគឺជាថ្មមានតម្លៃ ដែលមានស្រទាប់ពណ៌សនិងខ្មៅក្រហម ឬត្នោត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៥: ៣ ។
Exodus 28:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
តាមរបៀបដូចគេឆ្លាក់ត្រា ហើយត្រូវធ្វើក្រចាប់មាស
«តាមរបៀបដូចមនុស្សម្នាក់ឆ្លាក់ត្រាបោះ»
ឆ្លាក់
មនុស្សម្នាក់ដែលកាត់កែច្នៃរូបរាងសម្ភារៈរឹងដូចជាឈើ ថ្ម ឬដែក
ឆ្លាក់ត្រា
ឆ្លាក់ថ្មត្រូវបានប្រើដើម្បីបោះត្រា បង្កើតទៅជាត្រាក្រមួន
ក្រចាប់
បំណែកនៃលោហៈធាតុដែលកាន់ដុំថ្មនៅលើអេផូដ
Exodus 28:13

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ក្រចាប់
ទាំងនេះគឺជាបំណែកនៃលោហៈធាតុដែលចាប់កាន់ដុំថ្មនីមួយៗនៅលើអេផូដ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨:១០ ។
ធ្វើខ្សែពីមាសសុទ្ធ ដែលវេញចូលគ្នាជារបៀបខ្សែពួរ
«ច្រវាក់មាសសុទ្ធពីរដែលត្រូវបានគេវេញដូចជាខ្សែពួរ»
Exodus 28:15
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ពួកជាងដែលមានស្នាដៃ ហើយតាមរបៀបអាវអេផូដដែរ
«ជាងដែលមានស្នាដៃ នឹងវាធ្វើឱ្យវាដូចអាវអេផូដ»
ចំអាម
មួយចំអាមគឺ ២២ សង្ទីម៉ែត្រ។
Exodus 28:17
ព័ត៌មានទូទៅ
ពណ៌នៃត្បូងមានតម្លៃដែលបានរៀបរាប់នៅទីនេះអាចខុសគ្នាពីទាំងអស់នៅក្នុងយូឌីប៊ី
ត្បូង
«ត្បូងមានតម្លៃ» ឬ «រតនៈសម្បត្តិ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែទាំងនេះនៅក្នុង ២៥: ៣ ។
ត្បូងទទឹម ... មណីជោតិរស
ទាំងនេះគឺជាត្បូង។
ត្បូងកណ្តៀង
នេះគឺជាត្បូងពេជ្រដែលមានពណ៌ខៀវ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៤: ៩ ។
ត្បូងកែវយក់
នេះគឺជាថ្មដ៏មានតម្លៃដែលមានស្រទាប់ពណ៌ស និងខ្មៅក្រហម ឬត្នោត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែទាំងនេះនៅក្នុង ២៥: ៣ ។
ត្បូងនីមួយៗត្រូវតែដាំបង្កប់ក្នុងក្រចាប់ធ្វើអំពីមាស។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែដាំបង្កប់ក្នុងក្រចាប់ធ្វើអំពីមាស។»
Exodus 28:21
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ត្បូងទាំងនេះត្រូវរៀបចំ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវរៀបចំត្បូង»
ឆ្លាក់ត្រា
ឆ្លាក់ត្រាគឺ ឆ្លាក់ថ្មត្រូវបានប្រើដើម្បីបោះត្រាបង្កើតទៅជាត្រាក្រមួន។
នៅទីនេះដុំថ្មត្រូវបានរាប់ចំនួនទៅតាមត្រាទម្រង់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែ «ឆ្លាក់ត្រា» នៅក្នុង ២៨:១០ ។
ដូចជាខ្សែពួរ ត្រូវធ្វើវាពីមាសសុទ្ធ។
«ច្រវាក់ដែលធ្វើពីមាសសុទ្ធ ហើយត្រូវបានគេធ្វើដូចជាខ្សែពួរ»។
សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លាស្រដៀងគ្នានៅ ២៨:១៣ ។
Exodus 28:25
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ខ្សែ
«ច្រវាក់ដូចខ្សែពួរ»។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨:១៣ ។
ក្រចាប់ពីរទៀត
ទាំងនេះគឺជាក្រចាប់ពីរដែលព័ទ្ធជុំវិញថ្ម។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត «ចំពោះក្រចាប់ពីរ ដែលព័ទ្ធជុំវិញថ្ម»
Exodus 28:27
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ខាងលើខ្សែ
ខ្សែក្រវ៉ាត់រុំ - នេះគឺជាខ្សែក្រវ៉ាត់ក្រណាត់ធ្វើពីអំបោះត្បាញតូចៗ
ដែលមនុស្សណាម្នាក់វេញជាមួយគ្នា ដើម្បីធ្វើឱ្យខ្សែអំបោះកាន់តែរឹងមាំ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៦ ។
ដើម្បីវាអាចភ្ជាប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះពួកគេអាចភ្ជាប់វាបាន»
ដើម្បីឲ្យប្រដាប់ពាក់លើដើមទ្រូងអាចរបូតពីអាវអេផូដឡើយ។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ប្រដាប់ពាក់លើដើមទ្រូង នឹងជាប់អាវអេផូដ»
Exodus 28:29
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
គាត់ត្រូវយកឈ្មោះជនជាតិអ៊ីស្រាអែលដែលឆ្លាក់នៅលើដួងចិត្តរបស់គាត់គឺនៅលើប្រដាប់ពាក់លើដើមទ្រូង
នេះសំដៅទៅលើឈ្មោះកុលសម្ព័ន្ធ ដែលឆ្លាក់នៅលើថ្មទាំងដប់ពីរ
ដែលជាប្រដាប់ពាក់លើដើមទ្រូងដូចបានរៀបរាប់នៅ ២៨:១៧ ។
នៅលើដួងចិត្តរបស់គាត់
«នៅលើដួងចិត្តរបស់លោកអ៊ើរ៉ុន» ឬ «នៅលើដើមទ្រូងរបស់គាត់»
យូរីម និងធូមីម ... សម្រាប់វិនិច្ឆ័យ
ឃ្លាទីពីរលេចឡើងសំដៅទៅលើយូរីម
និងធូមីមហើយពន្យល់ពីគោលបំណងរបស់ពួកគេ។
យូរីម និងធូមីម
គឺមិនច្បាស់ថាទាំងនេះជាអ្វីទេ។ ពួកវាជាវត្ថុដែលអាចជាថ្ម
ដែលបូជាចារ្យប្រើដើម្បីកំណត់ឆន្ទៈរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច។
Exodus 28:31
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ការនេះត្រូវដេរតាមរបៀបដែលគេដេរជាយអាវស្បែក។
នេះអាចត្រូវបានបញ្ជាក់ជាពាក្យបញ្ជា។ ការបកប្រែផ្សេងទៀត
«អ្នកតម្បាញត្រូវតែធ្វើអាវផាយនេះ»
អ្នកតម្បាញ
«មនុស្សដែលត្បាញ» ឬ «អ្នកដែលបង្កើតក្រណាត់ដោយប្រើខ្សែអំបោះ»
Exodus 28:33
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ផ្លែទទឹម
ផ្លែទទឹមគឺជាផ្លែឈើមូលដែលមានសំបកខាងក្រៅពណ៌ក្រហម។
កណ្តឹងមាសមួយ និងផ្លែទទឹមមួយ
ឃ្លានេះត្រូវបានធ្វើម្តងទៀត ដើម្បីបង្ហាញគម្លូនៃការរចនានៅលើអាវផាយ។
អាវរែងត្រូវពាក់លើអ៊ើរ៉ុន នៅពេលគាត់បម្រើ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ៊ើរ៉ុនត្រូវតែពាក់អាវពេលគាត់បម្រើ»
ដើម្បីឲ្យសម្លេងរបស់វាអាចឮ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះកណ្តឹងធ្វើឱ្យមានសម្លេង»
ធ្វើដូច្នេះ គាត់នឹងមិនត្រូវស្លាប់ឡើយ។
គឺបញ្ជាក់ថាគាត់នឹងស្លាប់ ដោយសារគាត់មិនបានស្តាប់បង្គាប់ព្រះអម្ចាស់។
នេះអាចត្រូវបានបញ្ជាក់។ ការបកប្រែផ្សេងទៀត
«ជាលទ្ធផលដែលគាត់នឹងមិនស្លាប់ទេ
ដោយសារតែមិនគោរពតាមការណែនាំរបស់យើង»
Exodus 28:36
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ហើយឆ្លាក់លើវា ដូចជាត្រាមួយថា
«សរសេរលើវាតាមរបៀបដែលមនុស្សម្នាក់ឆ្លាក់លើត្រា»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យស្រដៀងគ្នានៅ ២៨:១០
ឈ្នួតក្បាល
នេះគឺជាគម្របក្បាលខ្ពស់ធ្វើពីក្រណាត់រុំជុំវិញក្បាលជាច្រើនដង។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៤ ។
ត្រូវពាក់វានៅលើក្បាលរបស់អ៊ើរ៉ុន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ៊ើរ៉ុនត្រូវពាក់វានៅលើថ្ងាសរបស់គាត់»
ឈ្នួតក្បាលត្រូវពាក់នៅពីលើក្បាលរបស់គាត់ជានិច្ច

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ៊ើរ៉ុនត្រូវពាក់ឆ្នួតក្បាលនៅលើថ្ងាសរបស់គាត់»
Exodus 28:39
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ឈ្នួតក្បាល
នេះគឺជាគម្របក្បាលខ្ពស់ ធ្វើពីក្រណាត់រុំជុំវិញក្បាលជាច្រើនដង។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៤ ។
ខ្សែក្រវាត់
ខ្សែក្រវាត់គឺជាសម្លៀកបំពាក់តុបតែងមួយ ដែលមនុស្សម្នាក់ពាក់នៅជុំវិញចង្កេះ
ឬឈៀងនៅលើទ្រូងរបស់គាត់។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង
២៨: ៤ ។
មួយដើម្បីពាក់ឈៀង។
អ្នកប៉ាក់គឺជាមនុស្សដែលដេររចនាម៉ូដលើក្រណាត់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៦:៣៦ ។
Exodus 28:40
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ខ្សែក្រវាត់
ខ្សែក្រវាត់គឺជាតុបតែងមួយដែលមនុស្សម្នាក់ពាក់នៅជុំវិញចង្កេះ
ឬឈៀងនៅលើទ្រូងរបស់គាត់។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង
២៨: ៤ ។
ឈ្នួតក្បាល
ឈ្នួតក្បាលគឺជាបន្ទះតុបតែងតូច
ដែលត្រូវបានគេពាក់នៅជុំវិញក្បាលខាងលើភ្នែក។
អ្នកត្រូវស្លៀកពាក់ឲ្យលោកអ៊ើរ៉ុន
អ៊ើរ៉ុនគឺជាបងប្រុសរបស់លោកម៉ូសេ។
អ្នកអាចបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«ពាក់សម្លៀកបំពាក់ទាំងនេះលើបងប្រុសរបស់អ្នកអ៊ើរ៉ុន»
Exodus 28:42
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
គ្របបាំងកេរ្តិ៍ខ្មាស
ទាំងនេះគឺជាខោទ្រនាប់ គឺជាសម្លៀកបំពាក់នៅក្នុងជាប់នឹងស្បែក។
ព្រះពន្លានៃត្រសាលប្រជុំ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧:២០ ។
ច្បាប់ដែលស្ថិតស្ថេររៀងរហូត
«ច្បាប់មួយនឹងមិនចប់ទេ»

---

29 [1]ឥឡូវនេះ នេះគឺជាអ្វីដែលអ្នកត្រូវធ្វើ ដើម្បីញែកពួកគេសម្រាប់យើង ដើម្បីឲ្យពួកគេបានបម្រើដល់យើងក្នុងមុខងារជាបូជាចារ្យ។[2]ចូរយកគោឈ្មោលមួយ
ហើយនិងចៀមឈ្មោលពីរដែលល្អឥតខ្ចោះ ត្រូវធ្វើនំបុ័ងឥតមេ និងនំឥតមេលាយជាមួយប្រេង។ ត្រូវធ្វើនំដោយប្រើម្សៅយ៉ាងម៉ដ្ត។
[3]អ្នកត្រូវដាក់ពួកគេនៅក្នុងល្អីមួយ ចូរនាំនំដែលនៅក្នុងល្អីនោះ ហើយត្រូវថ្វាយនំនោះជាមួយនឹងគោឈ្មោល និងចៀមឈ្មោលពីរ។[4]អ្នកត្រូវយកអ៊ើរ៉ុន
និងកូនប្រុសៗរបស់គាត់មកចូលតាមច្រកទ្វារចូលទៅពន្លាជួបជុំ។ អ្នកត្រូវលាងទឹកដល់អ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់។
[5]អ្នកត្រូវយកសម្លៀកបំពាក់ ហើយពាក់ដល់អ៊ើរ៉ុន គឺអាវក្នុង អាវវែងអេផូដ និងប្រដាប់ពាក់លើដើមទ្រូង ត្រូវក្រវាត់អេផូដនៅជុំវិញគាត់។
[6]អ្នកត្រូវឈ្នួតក្បាលនៅលើក្បាលរបស់គាត់ ហើយដាក់មកុដបរិសុទ្ធនៅលើឈ្នួតក្បាលនោះ។[7]បន្ទាប់មក ត្រូវចាក់ប្រេង ហើយបង្ហូរវានៅលើក្បាលរបស់គាត់
ត្រូវចាក់ប្រេងលើគាត់បែបនេះឯង។
[8]អ្នកត្រូវនាំកូនប្រុសៗរបស់គាត់ ហើយពាក់អាវលើពួកគេ។ អ្នកត្រូវស្លៀកពាក់ឲ្យអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់ជាមួយនឹងខ្សែក្រវាត់ ហើយពាក់មកុដលើពួកគេ។
[9]កិច្ចការរបស់បូជាចារ្យគឺជាកម្មសិទ្ធិរបស់ពួកគេ គឺជាច្បាប់ស្ថិតស្ថេរជានិច្ច។ អ្នកត្រូវតែងតាំងអ៊ើរ៉ុន និងកូនប្រុៗរបស់គាត់ ដើម្បីឲ្យពួកគេបានបម្រើយើង។
[10]អ្នកត្រូវនាំគោឈ្មោលមកនៅចំពោះព្រះពន្លានៃការជួបជុំ ហើយអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់ ត្រូវដាក់ដៃលើក្បាលរបស់វា។
[11]អ្នកត្រូវសម្លាប់គោឈ្មោលនោះនៅចំពោះព្រះអម្ចាស់នៅច្រកទ្វារចូលទៅព្រះពន្លានៃការជួបជុំ។
[12]អ្នកត្រូវយកឈាមគោឈ្មោលខ្លះ ហើយដាក់វាទៅលើស្នែងនៃកន្លែងថ្វាយយញ្ញបូជាជាមួយនឹងម្រាមដៃរបស់អ្នក
ហើយអ្នកត្រូវចាក់ឈាមដែលនៅសល់ទៅលើជើងទ្រកន្លែងថ្វាយយញ្ញបូជា។[13]អ្នកត្រូវយកខ្លាញ់ទាំងអស់ដែលនៅជាប់គ្រឿងក្នុង និងនៅជាប់ថ្លើម
និងនៅជាប់គ្រលៀនទាំងពីរ គឺជាខ្លាញ់នៅជាប់ទាំងនេះ ចូរដុតវាចោលទាំងអស់នៅលើកន្លែងថ្វាយយញ្ញបូជា។[14]ប៉ុន្តែ ចំណែកសាច់គោ និងស្បែក និងលាមករបស់វា
អ្នកត្រូវដុតវាចោលនៅខាងក្រៅជំរំ។ វាគឺជាតង្វាយលោះបាប។
[15]អ្នកត្រូវយកចៀមឈ្មោលមួយមកដែរ ហើយអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់ត្រូវដាក់ដៃរបស់ពួកគេនៅលើក្បាលរបស់វា។[16]អ្នកត្រូវសម្លាប់ចៀមឈ្មោលនោះ បន្ទាប់មក
យកឈាមរបស់វា និងប្រោះវានៅលើជ្រុងទាំងបួននៃកន្លែងថ្វាយយញ្ញបូជា។[17]អ្នកត្រូវកាត់ចៀមឈ្មោលជាដុំៗ
ជាមួយនឹងក្បាលរបស់វាដែលនៅលើកន្លែងថ្វាយយញ្ញបូជា។[18]បន្ទាប់មក ត្រូវដុតចៀមឈ្មោលនោះទាំងមូល។ វាគឺជាយញ្ញបូជាដុតថ្វាយព្រះអម្ចាស់ ហើយជាក្លិនឈ្ងុយ
យញ្ញបូជានេះ ត្រូវដុតថ្វាយព្រះអម្ចាស់។
[19]បន្ទាប់មក អ្នកត្រូវយកចៀមឈ្មោលមួយទៀត ហើយអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់ត្រូវដាក់ដៃទៅលើក្បាលរបស់វា។[20]បន្ទាប់មក អ្នកត្រូវសម្លាប់ចៀមឈ្មោលនោះ
ហើយត្រូវយកឈាមរបស់វាខ្លះ។ ដើម្បីលាបពីលើស្លៀកត្រចៀកស្តាប់ លើមេដៃស្តាប់ និងលើមេជើងស្តាប់របស់ពួកគេ។ បន្ទាប់មក
អ្នកត្រូវប្រោះឈាមនោះទៅលើកន្លែងថ្វាយយញ្ញបូជាគ្រប់ជ្រុង។
[21]អ្នកត្រូវយកឈាមដែលនៅលើកន្លែងថ្វាយយញ្ញបូជា និងប្រេងសម្រាប់ចាក់ប្រេងតាំងខ្លះ ហើយប្រោះវាទាំងអស់លើអ៊ើរ៉ុន ហើយលើសម្លៀកបំពាក់កូនប្រុសៗរបស់គាត់
ព្រមទាំងប្រោះលើសម្លៀកបំពាក់ពួកគេផង។ ដូច្នេះ ត្រូវញែកអ៊ើរ៉ុនដោយឡែកសម្រាប់យើង រួមទាំងសម្លៀកបំពាក់របស់គាត់ និងលើកូនរបស់គាត់
ព្រមទាំងប្រោះលើសម្លៀកបំពាក់កូនប្រុសៗរបស់គាត់ដែរ។
[22]អ្នកត្រូវយកខ្លាញ់ចៀមឈ្មោល គឺជាខ្លាញ់ដែលជាប់កន្ទុយ ជាប់ជាមួយនឹងគ្រឿងក្នុង ជាប់ជាមួយនឹងថ្លើម ជាប់ជាមួយក្រលៀនទាំងពីរ និងខ្លាញ់នៅភ្លៅស្តាំ ដ្បិត
ចៀមឈ្មោលគឺធ្វើសម្រាប់ញែកបូជាចារ្យឲ្យយើង។[23]ចូរយកនំបុ័ងមួយដុំ និងនំលាយប្រេងមួយដុំ ព្រមទាំងនំដែលនំបុ័ងដែលឥតមេចេញពីល្អីដែលនៅចំពោះព្រះអម្ចាស់។
[24]អ្នកត្រូវដាក់នំទាំងអស់នេះនៅលើដៃរបស់អ៊ើរ៉ុន និងដៃកូនប្រុសៗរបស់គាត់ ហើយគ្រវីនំទាំងនោះនៅចំពោះយើង ដ្បិតវាជាតង្វាយគ្រវីនៅចំពោះព្រះអម្ចាស់។[25]ដូច្នេះ
អ្នកត្រូវយកអាហារពីដៃរបស់ពួកគេ ហើយដុតវានៅលើកន្លែងថ្វាយយញ្ញបូជា ជាមួយនឹងតង្វាយដុត។ វានឹងធ្វើឲ្យមានក្លិនឈ្ងុយសម្រាប់យើង
វាគឺជាតង្វាយដុតថ្វាយដល់យើង។
[26]អ្នកត្រូវយកសាច់ទ្រូងរបស់ចៀមឈ្មោលដែលបានថ្វាយ ហើយគ្រវីវា សម្រាប់ជាតង្វាយគ្រវីនៅចំពោះព្រះអម្ចាស់ ហើយវានឹងបានជាចំណែករបស់អ្នក។
[27]អ្នកត្រូវញែកសាច់ទ្រូងដោយឡែកសម្រាប់ជាតង្វាយគ្រវីដល់យើង ជាតង្វាយគ្រវី ហើយភ្លៅនោះ ត្រូវចែកដល់ពួកបូជាចារ្យ ទាំងសាច់ទ្រូង ដែលបានគ្រវី
និងសាច់ភ្លៅដែលបានចែងដល់អ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់។ នេះគឺជាច្បាប់សម្រាប់អ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់។
[28]វានឹងត្រូវតង្វាយវិភាគទានពីប្រជាជនអ៊ីស្រាអែលថ្វាយដល់ព្រះអម្ចាស់ ពីតង្វាយមេត្រីរបស់ពួកគេ។
[29]សម្លៀកបំពាក់បរិសុទ្ធរបស់អ៊ើរ៉ុន ត្រូវតែរក្សាទុកឲ្យកូនប្រុសៗរបស់គាត់ដែលបន្តវេនពីគាត់។ ពួកគេត្រូវបានចាក់ប្រេងតាំងនៅលើពួកគេ
ហើយតាំងពួកគេឡើងសម្រាប់យើង។[30]បូជាចារ្យ ដែលទទួលតំណែងពីគាត់ គឺកូនប្រុសៗរបស់គាត់ គឺជាអ្នកដែលចូលទៅក្នុងត្រសាលនៃការជួបជុំ
ដើម្បីបម្រើយើងនៅក្នុងទីបរិសុទ្ធ ត្រូវស្លៀកពាក់សម្លៀកបំពាក់នេះប្រាំពីរថ្ងៃ។

generated on Wed Sep 10 16:16:32 2025

[31]អ្នកត្រូវយកចៀមឈ្មោលសម្រាប់ធ្វើពិធីតែងតាំងបូជាចារ្យសម្រាប់យើង ហើយស្ងោសាច់វានៅក្នុងទីបរិសុទ្ធ។[32]អ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់ត្រូវហូបសាច់ចៀមឈ្មោល
និងនំបុ័ងដែលនៅក្នុងល្អី ដែលនៅច្រកចូលត្រសាលនៃការជួបជុំ។[33]ពួកគេត្រូវហូបសាច់ និងនំបុ័ងដែលបានថ្វាយសម្រាប់លោះពួកគេ និងតែងតាំងពួកគេ
ព្រមទាំងញែកពួកគេដោយឡែកសម្រាប់យើង។ អ្នកផ្សេងទៀតមិនអាចហូបអាហារនេះបានទេ ព្រោះពួកគេរាប់អាហារនេះថាជាអាហារបរិសុទ្ធសម្រាប់យើង
និងជាអាហារដែលបម្រុងទុកសម្រាប់យើង។[34]ប្រសិនបើ សាច់នៃពិធីតែងតាំងនេះនៅសល់ ឬនំបុ័ងណានៅសល់ រហូតដល់ព្រឹកបន្ទាប់ ឬនំបុ័ងនៅសល់ដល់ព្រឹកបន្ទាប់
ដូច្នេះ អ្នកត្រូវដុតវាចោល។ មិនត្រូវហូបវាឡើយ ដោយសារវាបានញែកដោយឡែកសម្រាប់យើង។
[35]អ្នកត្រូវធ្វើបែបនេះ គឺត្រូវធ្វើតាមគ្រប់ទាំងអស់ដែលយើងបានបង្គាប់ឲ្យអ្នកធ្វើ អ្នកត្រូវប្រព្រឹត្តនឹងអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់បែបនេះ។
[36]អ្នកត្រូវត្រៀមពួកគេប្រាំពីរថ្ងៃ។ អ្នកត្រូវថ្វាយយញ្ញបូជាលោះបាប ពីគោឈ្មោលមួយ។ អ្នកត្រូវសម្អាតកន្លែងថ្វាយយញ្ញបូជា ដោយធ្វើពិធីលោះបាបសម្រាប់វា
ហើយអ្នកត្រូវចាក់ប្រេងលើវាដើម្បីញែកវាដោយឡែកដល់យើង។[37]នៅក្នុងរយៈពេលប្រាំពីរថ្ងៃ អ្នកត្រូវធ្វើពិធីលោះបាបសម្រាប់កន្លែងថ្វាយយញ្ញបូជា
និងញែកវាដោយឡែកថ្វាយព្រះអម្ចាស់។ បន្ទាប់មក កន្លែងថ្វាយយញ្ញបូជានឹងត្រូវបានញែកដោយឡែកសម្រាប់យើង។
អ្វីក្តីដែលប៉ះកន្លែងថ្វាយយញ្ញបូជានោះនឹងត្រូវញែកដោយឡែកសម្រាប់ព្រះអម្ចាស់ដែរ។
[38]អ្នកត្រូវថ្វាយរាល់ថ្ងៃនៅកន្លែងថ្វាយយញ្ញបូជា ចៀមឈ្មោលពីរមានអាយុពីរឆ្នាំ។[39]ចៀមឈ្មោលមួយ ថ្វាយនៅពេលព្រឹក
ហើយចៀមឈ្មោលមួយទៀតថ្វាយនៅពេលល្ងាចបន្ទាប់ពីថ្ងៃលិច។
[40]ចៀមឈ្មោលទីមួយ ត្រូវយកម្សៅយ៉ាងម៉ដ្តចំនួនមួយភាគដប់នៃអេផាយលាយជាមួយប្រេងអូលីវដ៏ល្អមួយភាគបួននៃហ៊ីន ហើយលាយស្រាទំពាំងបាយជូរមួយភាគបួន
នៃហ៊ីន ទុកជាតង្វាយច្រួច។
[41]អ្នកត្រូវថ្វាយចៀមទីពីរនៅពេលថ្ងៃលិច។ អ្នកត្រូវថ្វាយតង្វាយធញ្ញជាតិ ដូចនៅពេលព្រឹកដែរ ហើយតង្វាយច្រួចដូចគ្នាដែរ។
ទាំងនេះគឺជាតង្វាយដុតដែលត្រូវធ្វើឡើងសម្រាប់យើង ដើម្បីធ្វើឲ្យមានក្លិនឈ្ងុយដល់យើង។[42]ទាំងនេះគឺជាតង្វាយដុតរាល់ថ្ងៃនៅគ្រប់ជំនាន់របស់អ្នក
នៅត្រង់ច្រក់ផ្លូវចូលត្រសាលនៃការជួបជុំនៅចំពោះព្រះអម្ចាស់ ជាកន្លែងដែលយើងជួបអ្នក ហើយនិយាយជាមួយអ្នកនៅទីនោះ។
[43]នោះជាកន្លែងដែលយើងជួបជាមួយជនជាតិអ៊ីស្រាអែល ព្រះពន្លាត្រូវញែកដោយឡែកសម្រាប់យើង ដោយសារសិរីល្អរបស់យើង។[44]យើងនឹងញែកត្រសាលនៃការជួបជុំ
និងកន្លែងថ្វាយយញ្ញបូជា ដ្បិត របស់ទាំងនេះគឺជាកម្មសិទ្ធិរបស់យើងតែម្នាក់គត់។ យើងនឹងញែកអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់ដោយឡែក
ដើម្បីបម្រើយើងក្នុងមុខងារជាបូជាចារ្យ។
[45]យើងនឹងរស់នៅក្នុងចំណោមជនជាតិអ៊ីស្រាអែល ហើយយើងនឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ។[46]ពួកគេនឹងដឹងថា យើងគឺជាព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ពួកគេ
ដែលបាននាំពួកគេចេញពីទឹកដីអេស៊ីប ដើម្បីឲ្យយើងបានរស់នៅក្នុងចំណោមពួកគេ។ យើងគឺជាព្រះអម្ចាស់ គឺជាព្រះជាម្ចាស់របស់ពួកគេ។

Exodus 29:1

ឥឡូវនេះ

ពាក្យថា «ឥឡូវនេះ»
សម្គាល់ការផ្លាស់ប្តូរប្រធានបទពីសម្លៀកបំពាក់សម្រាប់បូជាចារ្យទៅផ្តោតលើបូជាចារ្យ។

អ្នកត្រូវធ្វើ

នៅទីនេះ «អ្នក» សំដៅទៅលើលោកម៉ូសេ។

ដើម្បីញែកពួកគេ

«ដើម្បីញែកលោកអ៊ើរ៉ុន និងកូនៗរបស់គាត់»

បម្រើដល់យើង

នៅទីនេះ «យើង» សំដៅទៅលើព្រះអម្ចាស់។

គោឈ្មោលមួយ

គោឈ្មោល

ត្រូវធ្វើនំបុ័ងឥតមេ និងនំឥតមេលាយជាមួយប្រេង។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ចូរយកនំបុ័ងឥតមេលាយជាមួយប្រេងផងដែរ»

នំបុ័ង ...នំឥតមេ ... នំ

ទាំងនេះគឺជាអាហារខុសៗគ្នាដែលធ្វើពីម្សៅ។

Exodus 29:3

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ

អ្នកត្រូវដាក់ពួកគេ

«អ្នកត្រូវដាក់នំបុ័ង នំឥតមេ និង នំ»

ហើយត្រូវថ្វាយនំនោះជាមួយនឹងគោឈ្មោល និងចៀមឈ្មោលពីរ។

នៅទីនេះ «បច្ចុប្បន្ន» មានន័យថាថ្វាយជាយញ្ញបូជា។

អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានបកប្រែយ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ហើយជូនពួកវាដល់យើង
នៅពេលអ្នកថ្វាយយញ្ញបូជាគោឈ្មោល និងចៀមឈ្មោលទាំងពីរ»

ពន្លាជួបជុំ

នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧:២០ ។

Exodus 29:5

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ

អាវ

នេះគឺជាអាវធំដែលមានរចនាម៉ូដត្បាញចូល។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៤ ។

ត្រូវក្រវាត់

ខ្សែក្រវ៉ាត់ - នេះគឺជាខ្សែក្រវ៉ាត់ក្រណាត់ធ្វើពីអំបោះត្បាញតូច
ដែលមនុស្សណាម្នាក់វេញជាមួយគ្នាដើម្បីធ្វើឱ្យខ្សែអំបោះកាន់តែរឹងមាំ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៦ ។

ឈ្នួតក្បាល

នេះគឺជាគម្របក្បាលខ្ពស់ធ្វើពីក្រណាត់រុំជុំវិញក្បាលជាច្រើនដង។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៤ ។

មកុដបរិសុទ្ធ

មកុដនេះត្រូវបានពិពណ៌នានៅក្នុង ២៩: ៥ ថាត្រូវបានឆ្លាក់ដោយពាក្យ
«ថ្វាយដល់ព្រះអម្ចាស់» និងធ្វើពីមាសសុទ្ធ។

Exodus 29:8

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។

នាំកូនប្រុសៗរបស់គាត់

«នាំកូនប្រុសៗរបស់អ៊ើរ៉ុនមក»

អាវ

ទាំងនេះជាអាវធំដែលមានរចនាម៉ូដត្បាញចូល។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៤ ។

ខ្សែក្រវាត់

ខ្សែក្រវាត់គឺជាការតុបតែងមួយដែលមនុស្សពាក់ជុំវិញចង្កេះ ឬឈៀងដើមទ្រូង។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៤ ។

ពាក់មកុដ

ឈ្នួតក្បាលគឺជាបន្ទះតុបតែងតូចដែលត្រូវបានគេពាក់នៅជុំវិញក្បាលខាងលើភ្នែក។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៨: ៤០ ។

កិច្ចការរបស់បូជាចារ្យ

«កាតព្វកិច្ចក្នុងនាមជាបូជាចារ្យ»

ជាកម្មសិទ្ធិរបស់ពួកគេ

កាតព្វកិច្ចជាបូជាចារ្យ នឹងក៏ជាកម្មសិទ្ធិរបស់កូនចៅរបស់កូនប្រុសលោកអ៊ើរ៉ុនដែរ។
អ្នកអាចបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«នឹងជាកម្មសិទ្ធិរបស់ពួកគេ និងកូនចៅរបស់ពួកគេ»

ច្បាប់ស្ថិតស្ថេរជានិច្ច

ច្បាប់មួយដែលនឹងមិនចប់ទេ។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង
២៨:៤២ ។

Exodus 29:10

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ព្រះពន្លានៃការជួបជុំ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧:២០ ។
អ្នកត្រូវសម្លាប់គោឈ្មោល
តង្វាយគោលឈ្មោល គឺត្រូវសម្លាប់ដោយលោកម៉ូសេ
គឺមិនមែនបូជាចារ្យនៅមាត់ទ្វារទេ គឺនៅខាងក្នុងព្រះពន្លាជួបព្រះអម្ចាស់។
សម្លាប់គោឈ្មោល
ចាប់តាំងពីខាងក្រោមនឹងប្រាប់ពីអ្វីដែលត្រូវធ្វើ
ជាមួយឈាមពីគោសូមប្រើពាក្យសម្រាប់ «សម្លាប់»
ដែលនឹងបញ្ជាក់ពីវិធីសាស្ត្រស្រដៀងនឹង «អាបំពង់ករបស់វា
ហើយយកឈាមដាក់ក្នុងចាន» ។
Exodus 29:12
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ស្នែង
ទាំងនេះគឺជាការប៉ាន់ស្មានដែលមើលទៅដូចជាស្នែងគោ
ដែលភ្ជាប់នឹងជ្រុងទាំងបួននៃអាសនា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧: ១
ឈាមដែលនៅសល់
«ឈាមនៅសល់»
ដែលនៅជាប់គ្រឿងក្នុង
«ជាប់ក្នុងសរីរាង្គ»
ថ្លើម ... ត្រលៀន
ទាំងនេះគឺជាសរីរាង្គនៅក្នុងរាងកាយ។
ប៉ុន្តែ ចំណែក និងស្បែក និងលាមករបស់វា
«ប៉ុន្តែសម្រាប់ផ្នែកដែលនៅសល់នៃគោឈ្មោល»
Exodus 29:15
អ្នកត្រូវសម្លាប់ចៀមឈ្មោល
ចំពោះការថ្វាយយញ្ញបូជាសម្រាប់បូជាចារ្យនេះ
គឺលោកម៉ូសេមិនមែនជាលោកអើរ៉ុន និងកូនប្រុសរបស់គាត់ទេ
ដែលត្រូវសម្លាប់សត្វទាំងនោះ។
នៅលើអាសនា
មិនដូចតង្វាយដុតដែលត្រូវបានដុតនៅខាងក្រៅព្រះពន្លានោះទេ
នេះគឺគេដុតចៀមឈ្មោលនៅលើអាសនាខាងក្នុង។
ផ្នែកខាងក្នុង
«សរីរាង្គ»។សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៩:១២ ។
Exodus 29:19
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
អ្នកត្រូវសម្លាប់ចៀមឈ្មោល
ចៀមឈ្មោលត្រូវបានសម្លាប់ដោយកាត់បំពង់ករបស់វា។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«សម្លាប់ចៀមឈ្មោលដោយអារបំពង់ករបស់វា» ឬ «
សម្លាប់ចៀមឈ្មោលដោយកាត់បំពង់ករបស់វាចោល»
Exodus 29:21
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ត្រូវញែកអ៊ើរ៉ុនដោយឡែកសម្រាប់យើង
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«តាមរយៈការធ្វើបែបនេះអ្នក នឹងថ្វាយអ៊ើរ៉ុនមកយើង»
Exodus 29:22
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ជាមួយនឹងគ្រឿងក្នុង ... ថ្លើម ... ក្រលៀន
ទាំងនេះសំដៅទៅលើសរីរាង្គខាងក្នុងនៃរាងកាយ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៩:១២ ។
ចូរយកនំប៉័ងមួយដុំ ... នៅចំពោះព្រះអម្ចាស់។
សម្រាប់ ២៩:២៣ សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យស្រដៀងគ្នានៅក្នុង
២៩: ១ ។
ដែលនៅចំពោះព្រះអម្ចាស់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលអ្នកបានដាក់នៅចំពោះយើង»
Exodus 29:24
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
អ្នកត្រូវដាក់នំទាំងអស់នេះ
នៅទីនេះ «ទាំងនេះ» សំដៅទៅលើផ្នែកនៃយញ្ញបូជាដែលបានរៀបរាប់ក្នុងខមុន ៗ
។
វាគឺជាតង្វាយដុតថ្វាយដល់យើង។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដុតវាជាតង្វាយសម្រាប់យើង»
Exodus 29:26
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ចៀមឈ្មោលដែលបានថ្វាយ
«ចៀមឈ្មោលដែលអ្នកថ្វាយ» ឬ «ចៀមឈ្មោលដែលអ្នកបានសម្លាប់»
ចៀមឈ្មោលរបស់លោកអ៊ើរ៉ុនដែលបានថ្វាយ
«ចៀមឈ្មោលដែលអ្នកបានប្រើដើម្បីថ្វាយលោកអ៊ើរ៉ុន»
វិភាគទានពីប្រជាជនអ៊ីស្រាអែល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលជនជាតិអ៊ីស្រាអែលនឹងអោយ»
នេះគឺជាច្បាប់
«ទាំងនេះជាច្បាប់ជារៀងរហូត»
ពីប្រជាជនអ៊ីស្រាអែលថ្វាយដល់ព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលពួកគេនឹងយកពីដង្វាយរបស់ជនជាតិអ៊ីស្រាអែល»
Exodus 29:29
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
សម្លៀកបំពាក់បរិសុទ្ធរបស់អ៊ីរ៉ុន ត្រូវតែរក្សាទុកឲ្យកូនប្រុសៗរបស់គាត់ដែលបន្តវេនពីគាត់។
សម្លៀកបំពាក់ទាំងនេះជារបស់ភាពបូជាចារ្យហើយមិនមែនគ្រាន់តែសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់អ៊ើរ៉ុនទេ
ការបកប្រែផ្សេងទៀត «អើរ៉ុនត្រូវទុកសម្លៀកបំពាក់បរិសុទ្ធ
សម្រាប់កូនប្រុសរបស់គាត់បន្ទាប់ពីគាត់»
ពួកគេត្រូវបានចាក់ប្រេងតាំងនៅលើពួកគេ ហើយតាំងពួកគេឡើងសម្រាប់យើង។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវស្លៀកសម្លៀកបំពាក់បរិសុទ្ធនៅពេលអ្នកចាក់ប្រេងតែងតាំងកូនប្រុសរបស់គាត់ហើយតែងតាំង
ត្រសាលនៃការជួបជុំ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧:២០ ។
Exodus 29:31
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ចៀមឈ្មោលសម្រាប់ធ្វើពិធីតែងតាំងបូជាចារ្យសម្រាប់យើង
«ចៀមឈ្មោលដែលអ្នកបានសម្លាប់នៅពេលតាំងពួកបូជាចារ្យ»
នៅក្នុងទីបរិសុទ្ធ
កន្លែងនេះមិនខុសពីទីសក្ការៈក្រៅពីកន្លែងបរិសុទ្ធបំផុតទេ។
នេះសំដៅទៅលើកន្លែងមួយនៅក្នុងទីលាន។ ការបកប្រែផ្សេងទៀត
«នៅច្រកចូលត្រសាលនៃការជួបជុំ»
ត្រសាលនៃការជួបជុំ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧:២០ ។
បានថ្វាយសម្រាប់លោះពួកគេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលអ្នកបានថ្វាយ»
មិនត្រូវហូបវាឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«គ្មាននរណាម្នាក់ត្រូវបរិភោគវាឡើយ»
ដោយសារវាបានញែកដោយឡែកសម្រាប់យើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពីព្រោះអ្នកបានញែកវាដាច់ដោយឡែកសម្រាប់យើង»
Exodus 29:35
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
អ្នកត្រូវធ្វើបែបនេះ គឺត្រូវធ្វើតាមគ្រប់ទាំងអស់ដែលយើងបានបង្គាប់ឲ្យអ្នកធ្វើ
អ្នកត្រូវប្រព្រឹត្តនឹងអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់បែបនេះ។
«យើងបានបង្គាប់អ្នកប្រព្រឹត្តចំពោះលោកអ៊ើរ៉ុន និងកូនៗរបស់គាត់របៀបនេះ»។
បន្ទាប់មក កន្លែងថ្វាយយញ្ញបូជានឹងត្រូវបានញែកដោយឡែកសម្រាប់យើង។
«បន្ទាប់មកអាសនា នឹងត្រូវបានចាត់ទុកជាបរិសុទ្ធបំផុត»
នឹងត្រូវញែកដោយឡែកសម្រាប់ព្រះអម្ចាស់ដែរ។
«នឹងបរិសុទ្ធផងដែរ»
Exodus 29:38
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
អ្នកត្រូវថ្វាយរាល់ថ្ងៃនៅកន្លែងថ្វាយយញ្ញបូជា
«អ្នកត្រូវថ្វាយតង្វាយ នៅលើអាសនាជារៀងរាល់ថ្ងៃ»។
Exodus 29:40
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ចំនួនមួយភាគដប់ ... មួយភាគបួន
«១/១០ ... ១/៤»
អេផាយ
អេផាយគឺ ២២ លីត្រ។
ហ៊ីន
ហ៊ីនគឺ ៣.៧ លីត្រ។
Exodus 29:41
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ទាំងនេះគឺជាតង្វាយដុតដែលត្រូវធ្វើឡើងសម្រាប់យើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គឺនឹងថ្វាយតង្វាយដុតសម្រាប់យើង»
នៅគ្រប់ជំនាន់របស់អ្នក
«គ្រប់ជំនាន់នៃកូនចៅរបស់អ្នក»។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១២:១២ ។
ត្រសាលនៃការជួបជុំ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧:២០ ។
Exodus 29:43
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ព្រះពន្លាត្រូវញែកដោយឡែកសម្រាប់យើង ដោយសារសិរីល្អរបស់យើង។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះវត្តមានដ៏អស្ចារ្យរបស់យើងនឹងថ្វាយព្រះពន្លាសម្រាប់យើង»
Exodus 29:45
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។

---

30 [1]អ្នកត្រូវធ្វើកន្លែងថ្វាយយញ្ញបូជាគ្រឿងក្រអូប។ អ្នកត្រូវធ្វើវាពីឈើនាងនួន។[2]ត្រូវមានបណ្តោយមានប្រវែងមួយហត្ថ និងទទឹងមួយហត្ថ។ ត្រូវធ្វើជារាងការ៉េ
ហើយកម្ពស់របស់វាត្រូវធ្វើប្រវែងពីរហត្ថ។ ស្នែងរបស់កន្លែងថ្វាយគ្រឿងក្រអូបនោះ ត្រូវធ្វើភ្ជាប់នឹងតួនៃកន្លែងថ្វាយគ្រឿងក្រអូបនោះ។
[3]អ្នកត្រូវស្រោមកន្លែងថ្វាយយញ្ញបូជាគ្រឿងក្រអូបនោះពីមាសសុទ្ធ គឺត្រូវស្រោបពីលើ ពីចំហៀងទាំងសងខាង និងពីលើស្នែងផង។ អ្នកត្រូវធ្វើគែមមាសព័ទ្ធជុំវិញវា។
[4]អ្នកត្រូវធ្វើកងពីរភ្ជាប់ជាមួយវានៅខាងក្រោមគែមនោះម្ខាងពីរទាំងសងខាង។ កងត្រូវដើម្បីស៊កឈើស្នែង ដើម្បីសែងកន្លែងថ្វាយយញ្ញបូជា។
[5]អ្នកត្រូវធ្វើឈើស្នែងពីឈើនាងនួន ហើយអ្នកត្រូវស្រោបឈើនោះពីមាស។[6]អ្នកត្រូវដាក់គ្រឿងក្រអូបនៅលើកន្លែងថ្វាយយញ្ញបូជានោះ
នៅពីមុខវាំងននដែលនៅក្បែរហិបនៃសម្ពន្ធមេត្រី។ វានឹងនៅពីមុខទីសន្តោសប្រោសដែលគ្របពីលើហិបនៃសម្ពន្ធមេត្រី ជាកន្លែងដែលយើងនឹងជួបជាមួយអ្នក។
[7]អ៊ើរ៉ុនត្រូវដុតគ្រឿងក្រអូបរៀងរាល់ព្រឹក។ គាត់ត្រូវរៀបចំចង្កៀង ហើយក៏ជាអ្នកដុតចង្កៀងដែរ។[8]ហើយអ៊ើរ៉ុននឹងដុតគ្រឿងក្រអូបនៅពេលល្ងាចជាប្រចាំ
ថ្វាយដល់ព្រះអម្ចាស់ដែរ នៅគ្រប់ជំនាន់របស់អ្នក។[9]ប៉ុន្តែ អ្នកមិនត្រូវដុតគ្រឿងក្រអូបណាផ្សេងទៀតនៅលើកន្លែងថ្វាយយញ្ញបូជាគ្រឿងក្រអូប ឬតង្វាយដុត
ឬតង្វាយធញ្ញជាតិឡើយ។ អ្នកមិនត្រូវចាក់តង្វាយច្រូចនៅលើវាឡើយ។
[10]អ៊ើរ៉ុនត្រូវធ្វើពិធីលោះបាបនៅលើស្នែងរបស់វា ម្តងមួយឆ្នាំ។ ជាមួយនឹងតង្វាយលោះបាប គាត់ត្រូវធ្វើពិធីលោះបាបសម្រាប់វាមួយឆ្នាំម្តង នៅគ្រប់ជំនាន់របស់អ្នក។
ត្រូវញែកវាដោយឡែកថ្វាយព្រះអម្ចាស់»។
[11]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[12]«នៅពេលអ្នកធ្វើជំរឿនជនជាតិអ៊ីស្រាអែល
មនុស្សម្នាក់ៗត្រូវថ្វាយជាថ្លៃលោះសម្រាប់ជីវិតរបស់គាត់ថ្វាយដល់ព្រះអម្ចាស់។ អ្នកត្រូវធ្វើការនេះ បន្ទាប់ពីជំរឿនពួកគេហើយ ធ្វើដូច្នេះ
ដើម្បីកុំឲ្យមានគ្រោះកាចកើតឡើងក្នុងចំណោមពួកគេ នៅពេលអ្នកជំរឿនពួកគេ។[13]មនុស្សគ្រប់គ្នាដែលបានរាប់យើងនៅក្នុងជំរឿនគឺត្រូវបង់ថ្លៃកន្លះសេកែល តាមខ្នាត
សេកែលដែលប្រើនៅក្នុងទីបរិសុទ្ធ (មួយសេកែលស្មើនឹងម្ភៃកេរ៉ា)។ កន្លះសេកែលនេះ ជាតង្វាយថ្វាយដល់ព្រះអម្ចាស់។[14]មនុស្សគ្រប់គ្នាដែលបានរាប់ហើយ
គឺចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ ត្រូវថ្វាយតង្វាយនេះដល់យើង។
[15]នៅពេលប្រជាជនថ្វាយតង្វាយនេះដល់យើង ដើម្បីធ្វើជាយញ្ញបូជាលោះបាបសម្រាប់ជីវិតរបស់ពួកគេ អ្នកមានមិនអាចថ្វាយលើសពីកន្លះសេកែលទេ
ហើយអ្នកក្រក៏មិនអាចថ្វាយតិចជាកន្លះសេកែលដែរ។[16]អ្នកត្រូវទទួលប្រាក់នៃតង្វាយលោះបាបនេះពីជនជាតិអ៊ីស្រាអែល
ហើយអ្នកត្រូវប្រាក់ទាំងនេះទៅប្រើនៅក្នុងត្រសាលនៃការជួបជុំ។ វាគឺជាការរំលឹកដល់ជនជាតិអ៊ីស្រាអែលនៅចំពោះយើង
ដើម្បីធ្វើជាតង្វាយលោះបាបសម្រាប់ជីវិតរបស់អ្នក»។
[17]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ ហើយបន្ទូលថា៖[18]«អ្នកត្រូវធ្វើអាងមួយយ៉ាងធំពីលង្ហិន និងជើងទ្រមួយពីលង្ហិនដែរ អាងមួយនោះសម្រាប់លាងសម្អាត។
អ្នកត្រូវដាក់វានៅចន្លោះត្រសាលនៃការជួបជុំ និងកន្លែងថ្វាយយញ្ញបូជា ហើយអ្នកត្រូវដាក់ទឹកនៅក្នុងអាងនោះ។
[19]លោកអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់ត្រូវលាងសម្អាតដៃ និងជើងរបស់ពួកគេជាមួយទឹកនៅក្នុងអាងនោះ។[20]នៅពេលពួកគេចូលទៅក្នុងត្រសាលនៃការជួបជុំ
ឬនៅពេលពួកគេចូលទៅជិតកន្លែងថ្វាយយញ្ញបូជា ដើម្បីបម្រើយើង ដោយថ្វាយតង្វាយដុត ពួកគេត្រូវលាងសម្អាតដោយទឹក ដើម្បីកុំឲ្យពួកគេបានស្លាប់ឡើយ។
[21]ពួកគេត្រូវលាងសម្អាតដៃ និងជើងរបស់ពួកគេ ដើម្បីកុំឲ្យពួកគេស្លាប់ឡើយ។ នេះគឺជាច្បាប់ដ៏នូវអស់កល្បសម្រាប់អ៊ើរ៉ុន និងពូជពង្សរបស់គាត់
នៅគ្រប់ជំនាន់របស់ពួកគេ»។
[22]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[23]«ចូរយកគ្រឿងក្រអូបដែលល្អ ចំនួនប្រាំរយសេកែលនៃជ័រល្វីងទេស មានឈើយីហុបផ្អែមចំនួន ២៥០ សេកែល
និង អំពៅផ្អែមចំនួន ២៥០សេកែលដែរ។[24]ឈើនាងនួនចំនួនប្រាំរយសេកែល តាមរង្វាល់របស់ទម្ងន់សេកែលនៅក្នុងទីសក្ការៈ ហើយនិងប្រេងចំនួនមួយប្រាំបីកំប៉ុង។
[25]អ្នកត្រូវធ្វើចាក់ប្រេងតាំងជាមួយនឹងគ្រឿងផ្សំទាំងនេះ ធ្វើជាគ្រឿងក្រអូប។ វានឹងក្លាយជាប្រេងតាំងបរិសុទ្ធ ដែលបានសម្រាំងសម្រាប់យើង។
[26]អ្នកត្រូវចាក់ប្រេងនៅលើ ត្រសាលនៃការជួបជុំជាមួយនឹងប្រេងនេះ ដូចចាក់ប្រេងនៅលើហិបនៃសម្ពន្ធមេត្រីដែរ[27]តុ និងសម្ភារផ្សេងៗ ជើងចង្កៀង និងរបស់ផ្សេងទៀត
កន្លែងថ្វាយគ្រឿងក្រអូប[28]កន្លែងថ្វាយយញ្ញបូជាជាមួយនឹងរបស់ផ្សេងៗ និងអាងជាមួយនឹងជើងរបស់វាដែរ។

generated on Wed Sep 10 16:16:32 2025

[29]អ្នកត្រូវញែករបស់ទាំងនោះសម្រាប់យើង ដើម្បីឲ្យរបស់ទាំងនោះបានបរិសុទ្ធសម្រាប់យើង។ អ្វីក្តីដែលប៉ះរបស់នោះនឹងបានបរិសុទ្ធដែរ។[30]អ្នកត្រូវចាក់ប្រេងលើអ៊ើរ៉ុន
និងកូនប្រុសៗរបស់គាត់ ហើយត្រូវញែកពួកគេដោយឡែកសម្រាប់យើង ដើម្បីឲ្យពួកគេបានបម្រើយើង ក្នុងមុខងារជាពួកបូជាចារ្យ។
[31]អ្នកត្រូវប្រាប់ទៅជនជាតិអ៊ីស្រាអែលថា៖ «នេះគឺជាប្រេងនៃការចាក់ប្រេងតាំងដែលត្រូវញែកដោយឡែកថ្វាយព្រះអម្ចាស់ នៅក្នុងគ្រប់ជំនាន់របស់អ្នករាល់គ្នា។
[32]មិនត្រូវយកវាទៅលាបលើស្បែករបស់មនុស្សឡើយ ឬមិនត្រូវធ្វើប្រេងណាផ្សេងទៀតដែលមានលក្ខណដូចជាប្រេងនេះឡើយ
ដោយសារវាជាប្រេងដែលញែកដោយឡែកថ្វាយព្រះអម្ចាស់។[33]អ្នកត្រូវរាប់វាទុកជារបស់បរិសុទ្ធ។ អ្នកណាដែលធ្វើទឹកអប់ដូចចាក់
ឬអ្នកណាដែលយកវាទៅលាបលើនរណាម្នាក់ ត្រូវកាត់អ្នកនោះចេញពីប្រជាជនរបស់ខ្លួន»។
[34]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរយកគ្រឿងក្រអូបទាំងនេះ គឺពុំសែនទេស សន្ទះក្រអូប ហើយកប៉ិរ និងកំញានសុទ្ធ គ្រឿងនីមួយៗត្រូវឲ្យស្មើគ្នា។
[35]ចូរធ្វើវាឲ្យទៅជាទម្រង់នៃគ្រឿងក្រអូប កិនវាឲ្យទៅជាគ្រឿងក្រអូបដោយបង់អំបិល ចម្រាញ់វាឲ្យស្អាត ហើយបរិសុទ្ធ។[36]អ្នកត្រូវកិនឲ្យម៉ដ្តលាយចូលគ្នា។
ចូរដាក់វាមួយចំណែកនៅខាងមុខហិបនៃទីបន្ទាល់ ដែលនៅខាងក្នុងត្រសាលនៃការជួបជុំ ជាកន្លែងដែលយើងនឹងជួបអ្នក។
អ្នកត្រូវការពារវាជារបស់បរិសុទ្ធសម្រាប់យើង។
[37]អ្នកមិនត្រូវធ្វើគ្រឿងក្រអូបណាដែលមានលក្ខណដូចជារបស់នេះ សម្រាប់អ្នកឡើយ។ អ្នកត្រូវរាប់គ្រឿងក្រអូបនេះថាបរិសុទ្ធសម្រាប់អ្នក។
[38]អ្នកណាដែលធ្វើអ្វីៗដែលដូចវា ដើម្បីប្រើជាគ្រឿងក្រអូប ត្រូវកាត់អ្នកនោះចេញពីប្រជាជនរបស់គាត់»។

Exodus 30:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រាប់លោកម៉ូសេ ពីរបៀបធ្វើឧបករណ៍សម្រាប់ថ្វាយបង្គំ។
អ្នកត្រូវធ្វើ
នៅទីនេះ « អ្នក» គឺសំដៅទៅលើលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល។
ស្នែងរបស់កន្លែងថ្វាយគ្រឿងក្រអូបនោះ ត្រូវធ្វើភ្ជាប់
ទាំងនេះគឺជាការស្មាន់ដែលមើលទៅដូចជាស្នែងគោដែលភ្ជាប់
នឹងជ្រុងទាំងបួននៃអាសនា។ សូមមើលពីរបៀបដែលអ្នកបកប្រែ « ស្នែង» នៅក្នុង ២៧: ១ ។ ការបកប្រែផ្សេងទៀត «អ្នកត្រូវធ្វើស្នែងរបស់វា»
Exodus 30:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
កន្លែងថ្វាយយញ្ញបូជាគ្រឿងក្រអូប
«អាសនាសម្រាប់ដុតគ្រឿងក្រអូប»
ភ្ជាប់ជាមួយវា
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលអ្នកនឹងភ្ជាប់ជាមួយអាសនា»
Exodus 30:5
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ហឹបនៃសម្ពន្ធមេត្រី
ហឹបគឺជាហឹបដែលមានបទបញ្ញត្តិ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៦:៣១ ។ ការបកប្រែផ្សេងទៀត
«ហឹបមានបទបញ្ញត្តិ»
ទីសន្តោសប្រោស
នេះជាគម្របដែលនៅពីលើហឹប ជាកន្លែងថ្វាយតង្វាយប្រោះលោះ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៥:១៥ ។
ជាកន្លែងដែលយើងនឹងជួបជាមួយអ្នក។
នៅទីនេះ «អ្នក» សំដៅទៅលើលោកម៉ូសេ។
Exodus 30:7
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
នៅគ្រប់ជំនាន់របស់អ្នក
«ឆ្លងកាត់គ្រប់ជំនាន់នៃកូនចៅរបស់អ្នក» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១២:១២ ។
ប៉ុន្តែ អ្នកមិនត្រូវ
ទោះបីពាក្យថា «អ្នក» ត្រូវបាននិយាយទៅកាន់លោកម៉ូសេ
ក៏ដោយការណែនាំត្រូវបានផ្តល់ជាពិសេសដល់អ៊ើរ៉ុន
និងកូនចៅរបស់គាត់អំពីពេលណា
និងអ្វីខ្លះដែលពួកគេត្រូវដុតគ្រឿងក្រអូបនៅលើអាសនា។
Exodus 30:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ស្នែង
ទាំងនេះគឺជាប៉ាន់ស្មានដែលមើលទៅដូចជាស្នែងគោដែលភ្ជាប់
នឹងជ្រុងទាំងបួននៃអាសនា។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧: ១ ។
នៅគ្រប់ជំនាន់របស់អ្នក
«គ្រប់ជំនាន់នៃកូនចៅរបស់អ្នក»។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១២:១២ ។
Exodus 30:11
នៅពេលអ្នកធ្វើ
ទី១អត្ថន័យដែលប្រហែលគឺ) « អ្នក» សំដៅទៅលើតែលោកម៉ូសេ ឬទី២) « អ្នក» សំដៅទៅលើលោកម៉ូសេ និងមេដឹកនាំអ៊ីស្រាអែលនៅជំនាន់ក្រោយ
នៅពេលពួកគេធ្វើជំរឿន។
ជំរឿនជនជាតិអ៊ីស្រាអែល
អ្នកដឹកនាំរាប់មនុស្សជនជាតិអ៊ីស្រាអែលតែប៉ុណ្ណោះ។
មនុស្សគ្រប់គ្នាដែលបានរាប់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ពួកគេរាប់តែមនុស្សប្រុសប៉ុណ្ណោះ។
ការបកប្រែផ្សេងទៀត «មនុស្សគ្រប់គ្នាដែលអ្នករាប់» ឬ
«គ្រប់មនុស្សទាំងអស់ដែលអ្នករាប់»
កន្លះសេកែល
«១/២ ប្រាក់រៀល»។ អ្នកបកប្រែអាចប្រើឯកតារង្វាស់មួយ
ដែលមនុស្សយល់និងលេខទាំងអស់« ប្រាក់ ៥,៥ ក្រាម» ឬ «ប្រាក់ប្រាំមួយក្រាម»
តាមខ្នាតសេកែលដែលប្រើនៅក្នុងទីបរិសុទ្ធ
នេះគឺជារង្វាស់ជាក់ស្តែងសេកែលមានទម្ងន់លើសពីមួយនៅពេលនោះ។
នេះបានបញ្ជាក់ថាមួយណាត្រូវបានប្រើ។នេះបានបញ្ជាក់ថាមួយណាត្រូវបានប្រើ។
ម្ភៃកេរ៉ា
«ម្ភៃកេរ៉ា» ។ ម្ភៃកេរ៉ាគឺជាឯកតាមួយដែលមនុស្សប្រើសម្រាប់វាស់របស់
ដែលមានទំងន់ស្រាលប៉ុណ្ណា។
គឺចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ
ចំនួនកាន់តែច្រើនត្រូវបានគេនិយាយថា កំពុងកើនឡើង ឬខាងលើលេខតូចជាង។
។ ការបកប្រែផ្សេងទៀត «ចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ» ឬ
«ដែលមានអាយុម្ភៃឆ្នាំឬចាស់ជាងនេះ»
Exodus 30:15
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ប្រជាជន
មានតែមនុស្សប្រុសទេ ដែលបានថ្វាយតង្វាយនេះ។
កន្លះសេកែល
អ្នកបកប្រែអាចប្រើឯកតារង្វាស់ ដែលមនុស្សយល់និងលេខទាំងអស់:« ប្រាក់ ៥.៥ ក្រាម» ឬ « ប្រាក់ ៦ ក្រាម»។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣០:១១ ។
វាគឺជាការរំលឹកដល់ជនជាតិអ៊ីស្រាអែលនៅចំពោះយើង
ដើម្បីធ្វើជាតង្វាយលោះបាបសម្រាប់ជីវិតរបស់អ្នក។
ទី១អត្ថន័យដែលប្រហែលគឺ) «វានឹងរម្លឹកប្រជាជនអ៊ីស្រាអែល
ឱ្យធ្វើតង្វាយលោះបាបសម្រាប់ជីវិតរបស់ពួកគេ» ឬ ទី២) «
វានឹងរម្លឹកប្រជាជនអ៊ីស្រាអែលថា
ពួកគេបានថ្វាយតង្វាយលោះបាបសម្រាប់ជីវិតរបស់ពួកគេ» ។

generated on Wed Sep 10 16:16:32 2025

Exodus 30:17
អ្នកត្រូវធ្វើ
នៅទីនេះ « អ្នក» សំដៅទៅលើលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល។
អាង
«ចាន» ឬ «ធុង»
ជើងទ្រមួយពីលង្ហិន
នេះគឺជាអ្វីដែលចាន នឹងត្រូវដាក់។
អាងមួយនោះសម្រាប់លាងសម្អាត។
ឃ្លានេះពន្យល់ពីអ្វី ដែលពួកបូជាចារ្យត្រូវប្រើអាងលង្ហិនធំ។
កន្លែងថ្វាយយញ្ញបូជា
អាសនាថ្វាយយញ្ញបូជា
Exodus 30:19
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ជាមួយទឹកនៅក្នុងអាងនោះ
«ទឹកនៅក្នុងអាង»
សម្រាប់អ៊ើរ៉ុន និងពូជពង្សរបស់គាត់ នៅគ្រប់ជំនាន់របស់ពួកគេ។
«សម្រាប់អ៊ើរ៉ុននិងកូនចៅរបស់គាត់គ្រប់ជំនាន់» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១២:១២ ។
Exodus 30:22
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
គ្រឿងក្រអូប
រុក្ខជាតិសួតដែលមនុស្សកិនទៅជាម្សៅ
ហើយដាក់ប្រេងឬអាហារដើម្បីឱ្យវាមានក្លិនឈ្ងុយឆ្ងាញ់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៥: ៣ ។
ចំនួនប្រាំរយសេកែល ...ចំនួន ២៥០ សេកែល
«៥០០ សេកែល ... ២៥០ សេកែល»។ មួយដុំគឺប្រហែល ១១ ក្រាម។
អ្នកបកប្រែអាចប្រើឯកតាដែលមនុស្សស្គាល់ និងលេខទាំងអស់:«៥,៧
គីឡូក្រាម... ១១,៤ គីឡូក្រាម» ឬ « ប្រាំមួយគីឡូក្រាម...បីគីឡូក្រាម»
ឈើយីហុប ... អំពៅផ្អែម ... ឈើនាងនួន
ទាំងនេះគឺជាគ្រឿងទេសក្រអូប។
តាមរង្វាស់របស់ទម្ងន់សេកែលនៅក្នុងទីសក្ការៈ
នេះគឺជារង្វាស់ជាក់ស្តែងសេកែលមានទម្ងន់លើសពីមួយនៅពេលនោះ។
នេះបានបញ្ជាក់ថាមួយណាត្រូវបានប្រើ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣០:១១ ។
ប្រេងមួយកំប៉ុង
អ្នកបកប្រែអាចប្រើឯកតាដែលមនុស្សស្គាល់និងលេខទាំងអស់:« ៣,៧ លីត្រ» ឬ
« បួនលីត្រ»
ជាមួយនឹងគ្រឿងផ្សំទាំងនេះ
«ជាមួយរបស់ទាំងនេះ»
ធ្វើជាគ្រឿងក្រអូប។
ទី១អត្ថន័យដែលប្រហែលគឺ) លោកម៉ូសេត្រូវមានទឹកអប់ធ្វើកិច្ចការនេះ ឬ ទី២)
លោកម៉ូសេត្រូវធ្វើការងារខ្លួនឯងតាមរបៀបដែលអ្នកជំនាញធ្វើទឹកអប់។
គ្រឿងក្រអូប
មនុស្សម្នាក់ដែលមានជំនាញ ក្នុងការលាយគ្រឿងក្រអូបជាមួយប្រេង។
Exodus 30:26
ព័ត៌មានទូទៅ
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេជានិច្ច។
អ្នកត្រូវចាក់ប្រេងនៅលើ
នៅទីនេះ «អ្នក» សំដៅទៅលើលោកម៉ូសេ។
នៅលើហឹបនៃសម្ពន្ធមេត្រី
ហឹបគឺជាហឹបដែលមានបទបញ្ញត្តិ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៦:៣១ ។ ការបកប្រែផ្សេងទៀត
«ទ្រូងមានបទបញ្ជា» ។
កន្លែងថ្វាយយញ្ញបូជា
«អាសនាដែលត្រូវថ្វាយតង្វាយដុត»
Exodus 30:29
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ត្រូវញែក
នេះសំដៅទៅលើរបស់របរដែលបានរាយក្នុង ៣០:២៦ ។
នៅក្នុងគ្រប់ជំនាន់របស់អ្នករាល់គ្នា។
«កូនចៅរបស់អ្នកគ្រប់ជំនាន់ទាំងអស់» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១២:១២ ។
Exodus 30:32
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលលោកម៉ូសេត្រូវប្រាប់ប្រជាជន។
មិនត្រូវយកវាទៅលាបលើស្បែករបស់មនុស្សឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
អ្នកមិនត្រូវយកប្រេងដែលបានចាក់ប្រេង
ដែលបានឧទ្ទិសថ្វាយដល់ព្រះអម្ចាស់លើស្បែករបស់មនុស្សនោះទេ»
ដែលមានលក្ខណដូចជាប្រេងនេះឡើយ
«ជាមួយគ្រឿងផ្សំដូចគ្នា» ឬ «ជាមួយរបស់ដូចគ្នា»
ត្រូវកាត់អ្នកនោះចេញពីប្រជាជនរបស់ខ្លួន។
ពាក្យប្រៀបធៀប «កាត់ចេញ» មានអត្ថន័យយ៉ាងហោចណាស់បីយ៉ាង។
ពួកគេអាចត្រូវបានបង្ហាញជាទម្រង់សកម្ម ទី១) «
ខ្ញុំនឹងមិនចាត់ទុកគាត់ថាជាជនជាតិអ៊ីស្រាអែលម្នាក់ទៀតទេ ទី២)»
ប្រជាជនអ៊ីស្រាអែលត្រូវតែបញ្ជូនគាត់ទៅឆ្ងាយ» ឬ ទី៣) «
ប្រជាជនអ៊ីស្រាអែលត្រូវតែសម្លាប់គាត់»។
Exodus 30:34
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលត្រូវធ្វើ។
ព្រះអម្ចាស់ប្រទានបទបញ្ជាដល់លោកម៉ូសេតែប៉ុណ្ណោះ។ ឧទាហរណ៍នៃ «អ្នក»
គឺមានលក្ខណៈឯកវចនៈ។ ទោះយ៉ាងណាពាក្យថា « លាយដោយទឹកអប់»
អាចមានន័យថាលោកម៉ូសេអាចអោយអ្នកយកប្រេងក្រអូបយកគ្រឿងក្រអូបលាយបញ្ចូលគ្នា
កិននិងអោយទៅលោកម៉ូសេ
ដូច្នេះលោកម៉ូសេអាចដាក់ផ្នែកខ្លះនៃល្បាយនៅខាងមុខហឹបដូចជានៅយូឌីប៊ី ។
ពុំសែនទេស, សន្ទះក្រអូប, ហើយកប៉ូរ
ទាំងនេះគឺជាគ្រឿងក្រអូប។
ចូរធ្វើវាឲ្យទៅជាទម្រង់នៃគ្រឿងក្រអូប
ឃ្លាជាមួយ «លាយបញ្ចូលគ្នា» អាចត្រូវបានបកប្រែជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត « ធ្វើវាឱ្យទៅជាទំរង់ធូប ដែលទឹកអប់បានលាយបញ្ចូលគ្នា»
ឬ «ទឹកអប់ត្រូវតែលាយបញ្ចូលវាទៅជាគ្រឿងក្រអូប»
ទម្រង់នៃគ្រឿងក្រអូប។
ទី១អត្ថន័យដែលប្រហែលគឺ) លោកម៉ូសេត្រូវមានទឹកអប់ធ្វើកិច្ចការនេះឬ ទី២)
លោកម៉ូសេត្រូវធ្វើការងារខ្លួនឯងតាមរបៀបដែលអ្នកជំនាញធ្វើទឹកអប់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យទាំងនេះនៅក្នុង ៣០:២២ ។
អ្នកត្រូវកិនឲ្យម៉ដ្តលាយចូលគ្នា។
«អ្នកនឹងកម្ទេចវា» ។ នៅទីនេះ «អ្នក» សំដៅទៅលើលោកម៉ូសេ។
អ្នកត្រូវការពារ
នៅទីនេះ «អ្នក» គឺជាពហុវចនៈហើយសំដៅទៅលើលោកម៉ូសេ
និងប្រជាជនទាំងអស់។
Exodus 30:37
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
អ្នកត្រូវរាប់គ្រឿងក្រអូប
ពាក្យថា «អ្នក» នៅទីនេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ដែលមានលក្ខណដូច
«ជាមួយគ្រឿងផ្សំដូចគ្នា» ឬ «ជាមួយធាតុដូចគ្នា» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅ ៣០:៣២ ។
ក្រអូបនេះថាបរិសុទ្ធសម្រាប់អ្នក។
"អ្នកត្រូវតែចាត់ទុកវា ថាបរិសុទ្ធបំផុត"
គ្រឿងក្រអូប
នេះគឺជាវត្ថុធាតុរាវដែលមានក្លិនរីករាយ
ដែលមនុស្សម្នាក់ដាក់លើខ្លួនរបស់គាត់ឬរបស់នាង។
ត្រូវកាត់អ្នកនោះចេញពីប្រជាជនរបស់គាត់។

generated on Wed Sep 10 16:16:32 2025

ពាក្យប្រៀបធៀប «កាត់ចេញ» មានអត្ថន័យយ៉ាងហោចណាស់បីយ៉ាង។
ពួកគេអាចត្រូវបានបង្ហាញជាទម្រង់សកម្ម ទី១)
«ខ្ញុំនឹងមិនចាត់ទុកគាត់ថាជាជនជាតិអ៊ីស្រាអែលម្នាក់ទៀតទេ ទី២)»
ប្រជាជនអ៊ីស្រាអែលត្រូវតែបញ្ឈប់គាត់ទៅឆ្ងាយ» ឬ ទី៣)»
ប្រជាជនអ៊ីស្រាអែលត្រូវតែសំលាប់គាត់»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅ ៣០:៣២ ។

---

31 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖[2]«មើល៍ យើងបានហៅបេតសាលាល ជាកូនរបស់យូរី និងជាចៅរបស់ហ៊ើរ ក្នុងកុលសម្ព័ន្ធយូដាចំឈ្មោះ។
[3]យើងបានបំពេញបេតសាលាល ដោយវិញ្ញាណរបស់យើង យើងបានប្រទានឲ្យគាត់មានប្រាជ្ញា ការយល់ដឹង និងចំណេះដឹង
សម្រាប់ធ្វើការគ្រប់មុខ[4]ដើម្បីធ្វើគម្រោង និងចេះធ្វើមាស ប្រាក់ និងលង្ហិន[5]ឲ្យចេះច្នៃ និងដាំត្បូង ព្រមទាំងចេះឆ្លាក់ឈើផង គឺចេះធ្វើការគ្រប់មុខ។
[6]យើងក៏បានជ្រើសរើសអូហូលីអាប់ កូនរបស់អហ៊ីសាម៉ាក មកពីកុលសម្ព័ន្ធដាន់ឲ្យជួយគាត់ដែរ។ យើងបាន
ដាក់ឲ្យគាត់មានជំនាញនៅក្នុងចិត្តរបស់អស់អ្នកដែលមានប្រាជ្ញា ដើម្បីឲ្យពួកគេអាចធ្វើអ្វីៗគ្រប់យ៉ាងដែលយើងបានបង្គាប់ដល់អ្នក។[7]ការនេះ រួមទាំងត្រសាលនៃការជួបជុំ
ហិបនៃទីបន្ទាល់ ទីសន្តោសប្រោសនៅលើហិប និងគ្រប់ទាំងគ្រឿងសម្ភារនៅក្នុងព្រះពន្លាផង[8]មាន តុ និងសម្ភារផ្សេងៗដែលត្រូវប្រើជាមួយវា ជើងចង្កៀងពីមាសសុទ្ធ
និងសម្ភាររបស់វាទាំងអស់ កន្លែងថ្វាយគ្រឿងក្រអូប[9]កន្លែងថ្វាយយញ្ញបូជា ជាមួយនឹងសម្ភាររបស់វាទាំងអស់ និងអាងទឹកធំនិងជើងរបស់វា។
[10]ការនេះ បូករួមជាមួយនឹងសម្លៀកបំពាក់ គឺសម្លៀកបំពាក់បរិសុទ្ធសម្រាប់អ៊ើរ៉ុន ជាបូជាចារ្យ និងកូនប្រុសៗរបស់គាត់ទាំងអស់ ដែលបានត្រៀមទុកសម្រាប់យើង
ដើម្បីឲ្យពួកគេបានបម្រើយើងក្នុងមុខងារជាបូជាចារ្យ។[11]ការនេះ បូករួមជាមួយនឹងប្រេងសម្រាប់ចាក់ប្រេងតាំង និងគ្រឿងក្រអូបសម្រាប់ទីបរិសុទ្ធ។ ពួកសិប្បករទាំងនេះ
ត្រូវធ្វើរបស់ទាំងអស់នេះ ដូចដែលយើងបានបង្គាប់ដល់អ្នក»។
[12]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[13]«ចូរប្រាប់ជនជាតិអ៊ីស្រាអែលថា «អ្នករាល់គ្នាត្រូវរក្សាថ្ងៃសប្ប័ទរបស់ព្រះអម្ចាស់ ដ្បិត
ថ្ងៃសប្ប័ទគឺជាទីសម្គាល់រវាងព្រះអង្គ និងអ្នករាល់គ្នា គ្រប់ជំនាន់តរៀងទៅ ដើម្បីឲ្យអ្នករាល់គ្នាអាចដឹងថាព្រះអង្គគឺជាព្រះអម្ចាស់
ដែលបានញែកអ្នករាល់គ្នាសម្រាប់ព្រះអង្គ។[14]ដូច្នេះ អ្នកត្រូវរក្សាថ្ងៃសប្ប័ទ ដ្បិត អ្នករាល់គ្នាត្រូវចាត់ទុកថ្ងៃសប្ប័ទជាថ្ងៃបរិសុទ្ធ រក្សាថ្ងៃនោះសម្រាប់ព្រះអង្គ។
អ្នកណាដែលបង្ខូចវា ត្រូវសម្លាប់ចោល។ អ្នកណាដែលធ្វើការនៅថ្ងៃសប្ប័ទ អ្នកនោះត្រូវកាត់ចេញពីប្រជាជនរបស់ខ្លួន។[15]ត្រូវធ្វើការត្រឹមតែប្រាំមួយថ្ងៃបានហើយ ប៉ុន្តែ
ថ្ងៃទីប្រាំពីរ គឺជាថ្ងៃសប្ប័ទ ជាថ្ងៃសម្រាក ថ្ងៃបរិសុទ្ធ ត្រូវរក្សាវាសម្រាប់គោរពដល់ព្រះអម្ចាស់។ អ្នកណាដែលធ្វើការនៅថ្ងៃសប្ប័ទ ត្រូវសម្លាប់ចោល។
[16]ដូច្នេះហើយ បានជាជនជាតិអ៊ីស្រាអែលត្រូវរក្សាថ្ងៃសប្ប័ទ។ ពួកគេត្រូវគោរពថ្ងៃសប្ប័ទជារៀងរហូតតទៅគ្រប់ជំនាន់ ជាច្បាប់អស់កល្បជានិច្ច។
[17]ថ្ងៃសប្ប័ទនឹងធ្វើជាទីសម្គាល់រវាងព្រះអម្ចាស់ និងជនជាតិអ៊ីស្រាអែល ដ្បិត ក្នុងរយៈពេលប្រាំមួយថ្ងៃ ព្រះអម្ចាស់បានបង្កើតស្ថានសួគ៌ និងផែនដី ហើយនៅថ្ងៃទីប្រាំពីរ
ព្រះអង្គបានសម្រាក ហើយលំហែ»។
[18]នៅពេលព្រះជាម្ចាស់ឈប់មានបន្ទូលជាមួយលោកម៉ូសេនៅលើភ្នំស៊ីណាយ ព្រះអង្គបានប្រទានបន្ទះថ្មនៃសម្ពន្ធមេត្រី ដែលព្រះអង្គបានចារ
ដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់។

Exodus 31:1
យើងបានហៅ
ព្រះជាម្ចាស់មានបន្ទូលអំពីការជ្រើសរើសមនុស្សជាក់លាក់
ដែលជាការហៅពួកគេតាមឈ្មោះ។ ការបកប្រែផ្សេងទៀត «ខ្ញុំបានជ្រើសរើស»
បេតសាលាល ... យូរី ... ហ៊ើរ
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
Exodus 31:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
យើងបានបំពេញបេតសាលាល ដោយវិញ្ញាណរបស់យើង
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការប្រទានឲ្យបេតសាលាល ដោយវិញ្ញាណរបស់ទ្រង់
ដូចជាបេតសាលាលមានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ជាអង្គធាតុរាវ។
ការបកប្រែផ្សេងទៀត «យើងបានប្រគល់វិញ្ញាណរបស់យើង អោយបេតសាលាល»
ចំណេះដឹង សម្រាប់ធ្វើការគ្រប់មុខ
នាមអរូបី «ធ្វើការគ្រប់មុខ» អាចត្រូវបានបកប្រែជា «ការធ្វើសិប្បកម្ម» ឬ «ធ្វើអ្វីៗ»
។ការបកប្រែផ្សេងទៀត «សម្រាប់ធ្វើសិប្បកម្មគ្រប់ប្រភេទ» ឬ
«ដើម្បីឱ្យគាត់អាចបង្កើតវត្ថុគ្រប់ប្រភេទ»
Exodus 31:6
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
អូហូលីអាប់ ... អហ៊ីសាម៉ាក
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
យើងបានដាក់ឲ្យគាត់មានជំនាញនៅក្នុងចិត្តរបស់អស់អ្នកដែលមានប្រាជ្ញា
ព្រះជាម្ចាស់មានបន្ទូលអំពីការ ធ្វើឱ្យមនុស្សមានសមត្ថភាពធ្វើអ្វីៗ
ដូចជាព្រះអង្គបានដាក់សមត្ថភាពក្នុងចិត្តរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«យើងបានប្រទានឲ្យជំនាញទាំងអស់ដល់អស់អ្នក ដែលមានប្រាជ្ញា» ឬ
«យើងបានធ្វើឱ្យទាំងអស់អ្នកដែលមានប្រាជ្ញាមានសមត្ថភាពអាចធ្វើអ្វីៗបានល្អ»
ត្រសាលនៃការជួបជុំ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ព្រះពន្លា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៧:២០ ។
ហិបនៃទីបន្ទាល់
ហិបគឺជាទ្រូងដែលមានបទបញ្ញត្តិ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៦:៣១ ។ ការបកប្រែផ្សេងទៀត
«ទ្រូងមានបទបញ្ញត្តិ»
ទីសន្តោសប្រោស
នេះជាគម្របដែលនៅពីលើហឹបដែលជាកន្លែងថ្វាយតង្វាយលោះបាប។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៥:១៥ ។
កន្លែងថ្វាយគ្រឿងក្រអូប
«អាសនាសម្រាប់ដុតគ្រឿងក្រអូប» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣០: ៣ ។
កន្លែងថ្វាយយញ្ញបូជា
«អាសនាដែលត្រូវថ្វាយជាតង្វាយដុត» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣០:២៦ ។
Exodus 31:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ជាមួយនឹងសម្លៀកបំពាក់
សម្លៀកបំពាក់ត្បាញ - ទាំងនេះគឺជាសម្លៀកបំពាក់ធ្វើពីអំបោះតូច
ដែលមនុស្សណាម្នាក់វេញជាមួយគ្នា ដើម្បីធ្វើឱ្យកាន់តែរឹងមាំ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ២៨: ៦ ។
ពួកសិប្បករទាំងនេះ
«មនុស្សទាំងនេះដែលមានជំនាញ ក្នុងការបង្កើតរបស់ស្រស់ស្អាត»
Exodus 31:12
អ្នករាល់គ្នាត្រូវរក្សាថ្ងៃសប្ប័ទរបស់ព្រះអម្ចាស់
ព្រះជាម្ចាស់មានបន្ទូលអំពី ការគោរពតាមការបង្រៀនរបស់ព្រះអង្គអំពីថ្ងៃសប្ប័ទ
ដូចជាការរក្សាថ្ងៃសប្ប័ទ។ ការបកប្រែផ្សេងទៀត «
អ្នកត្រូវតែគោរពតាមការណែនាំរបស់ព្រះអម្ចាស់អំពីថ្ងៃឈប់សម្រាក»
គ្រប់ជំនាន់តរៀងទៅ
«គ្រប់ជំនាន់នៃកូនចៅរបស់អ្នក» ។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១២:១២ ។
ដែលបានញែកអ្នករាល់គ្នាសម្រាប់ព្រះអង្គ។
ព្រះជាម្ចាស់មានព្រះបន្ទូលអំពី
ការជ្រើសរើសមនុស្សដែលបានញែកពួកគេចេញសម្រាប់ព្រះអង្គផ្ទាល់។
ការបកប្រែផ្សេងទៀត «អស់អ្នកដែលណាបានជ្រើសរើសអ្នក
ឱ្យធ្វើជាប្រជាជនរបស់ព្រះអង្គ»

generated on Wed Sep 10 16:16:32 2025

ដ្បិត អ្នករាល់គ្នាត្រូវចាត់ទុកថ្ងៃសប្ប័ទជាថ្ងៃបរិសុទ្ធ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«សម្រាប់អ្នកត្រូវតែចាត់ទុកវាជាបរិសុទ្ធ»
អ្នកណាដែលបង្ខូចវា
ព្រះជាម្ចាស់មានបន្ទូលអំពី ការការប្រព្រឹត្តចំពោះថ្ងៃសប្ប័ទ
ដោយការមិនគោរពដូចជាការបង្ខូចវា។ ការបកប្រែផ្សេងទៀត
«មនុស្សគ្រប់គ្នាដែលប្រព្រឹត្តចំពោះថ្ងៃឈប់សម្រាកដោយមិនគោរព» ឬ
«អ្នកដែលមិនគោរពច្បាប់អំពីថ្ងៃឈប់សម្រាក»
ត្រូវសម្លាប់ចោល។
«ច្បាស់ជាត្រូវគេសម្លាប់»។ នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត «អ្នកប្រាកដជាត្រូវស្លាប់» ឬ
«អ្នកប្រាកដជាត្រូវកាត់ទោសប្រហារជីវិត»
អ្នកនោះត្រូវកាត់ចេញពីប្រជាជនរបស់ខ្លួន។
ពាក្យប្រៀបធៀប «កាត់ចេញ» មានអត្ថន័យយ៉ាងហោចណាស់បីយ៉ាង។
ពួកគេអាចត្រូវបានបង្ហាញជាទម្រង់សកម្ម ទី១)
«ព្រះអម្ចាស់នឹងលែងចាត់ទុកគាត់ថាជាមនុស្សម្នាក់ក្នុងចំណោមប្រជាជនរបស់ព្រះអង្គ។
ទី២) «អ្នកច្បាស់ជាត្រូវបញ្ជូនគាត់ទៅឆ្ងាយ» ឬ ទី៣)
«អ្នកប្រាកដជាត្រូវសម្លាប់គាត់ជាមិនខាន» ។
ប៉ុន្តែ ថ្ងៃទីប្រាំពីរ
«ប៉ុន្តែថ្ងៃទី ៧»
Exodus 31:16
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលគាត់ត្រូវប្រាប់ប្រជាជនអ៊ីស្រាអែល។
ត្រូវរក្សាថ្ងៃសប្ប័ទ
ព្រះជាម្ចាស់មានបន្ទូលអំពីការគោរពតាមការបង្រៀនរបស់ព្រះអង្គ
អំពីថ្ងៃសប្ប័ទដូចជាការរក្សាថ្ងៃសប្ប័ទ។ ការបកប្រែផ្សេងទៀត
«ត្រូវតែគោរពតាមការណែនាំរបស់ព្រះអម្ចាស់អំពីថ្ងៃសប្ប័ទ»
ពួកគេត្រូវគោរពថ្ងៃសប្ប័ទជារៀងរហូតតទៅគ្រប់ជំនាន់
«ពួកគេនិងកូនចៅជំនាន់ទាំងអស់ ត្រូវតែគោរពតាមថ្ងៃសប្ប័ទ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែ «គ្រប់ជំនាន់ប្រជាជនរបស់ពួកគេ» នៅក្នុង
១២:១២ ។
ជាច្បាប់អស់កល្បជានិច្ច។
«ច្បាប់នឹងមិនគ្មានទីបញ្ចប់ទេ»។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង
២៨:៤២ ។
Exodus 31:18
ដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់។
នេះអាចត្រូវបានបកប្រែដោយកិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត
«ដែលព្រះអម្ចាស់បានសរសេរដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់»

---

32 [1]នៅពេលប្រជាជនឃើញថាលោកម៉ូសេពន្យាពេលនៃការចុះពីលើភ្នំមកវិញ ពួកគេបានប្រមូលគ្នាមកឯលោកអើរ៉ុន ហើយប្រាប់គាត់ថា៖ «មក៍ ចូរធ្វើរូបព្រះមួយ
ដែលនឹងនាំមុខយើង។ ដ្បិត លោកម៉ូសេ ជាម្នាក់ដែលបាននាំយើងចេញពីទឹកដីអេស៊ីប យើងមិនដឹងថាមានរឿងអ្វីកើតឡើងជាមួយនឹងគាត់ទេ»។[2]ដូច្នេះ
លោកអើរ៉ុនក៏ប្រាប់ពួកគេថា៖ «ចូរដោះចិញ្ចៀនមាស ដែលនៅនឹងត្រចៀកប្រពន្ធ និងកូនប្រុស កូនស្រីរបស់អ្នករាល់គ្នាមក ហើយយកវាមកឲ្យខ្ញុំ»។
[3]ប្រជាជនទាំងអស់បានដោះក្រវិលដែលនៅត្រចៀករបស់ពួកគេ យកមកឲ្យលោកអើរ៉ុន។[4]គាត់បានទទួលមាសពីពួកគេ ធ្វើវាចេញជារូប ហើយធ្វើវាឲ្យទៅជារូបគោ។
បន្ទាប់មក ប្រជាជននិយាយថា៖ «ឱអ៊ីស្រាអែល នេះគឺជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីបមក»។
[5]នៅពេលលោកអើរ៉ុនឃើញដូច្នេះ គាត់បានសង់កន្លែងថ្វាយយញ្ញបូជាមួយនៅពីមុខរូបគោនោះ ហើយបានប្រកាសថា ដោយនិយាយថា៖ «ថ្ងៃស្អែកយើងនឹងធ្វើបុណ្យ
ដើម្បីគោរពដល់ព្រះអម្ចាស់»។[6]ប្រជាជនទាំងអស់បានក្រោកតាំងពីព្រលឹមនៅថ្ងៃបន្ទាប់ ហើយបានថ្វាយតង្វាយដុត និងនាំតង្វាយមេត្រីមកជាមួយផង។ បន្ទាប់ពី
ពួកគេបានអង្គុយហូប ហើយផឹក ព្រមទាំងក្រោកឡើង រាំលេងស៊ីផឹកឡូឡាយ៉ាងសប្បាយ។
[7]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរទៅវិញចុះ ដ្បិតប្រជាជន ដែលអ្នកបាននាំពីទឹកដីអេស៊ីបមក ពួកគេបានបង្ខូចខ្លួនរបស់ពួកគេ។
[8]ពួកគេរហ័សក្នុងការចេញពីផ្លូវដែលយើងបានបង្គាប់ដល់ពួកគេ។ ពួកគេបានឆ្លាក់ធ្វើរូបគោមួយសម្រាប់ខ្លួនគេ ហើយបានថ្វាយបង្គំវា ហើយថ្វាយយញ្ញបូជាដល់វា។
ពួកគេបាននិយាយថា៖ «អ៊ីស្រាអែល នេះគឺជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីបមក»។
[9]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «យើងបានឃើញប្រជាជននេះ មើល៍ ពួកគេជាមនុស្សក្បាលរឹក។[10]ដូច្នេះ ឥឡូវនេះ កុំព្យាយាមបញ្ឈប់យើងធ្វើអ្វី។
សេចក្តីក្រោធរបស់យើងបានឆេះឡើងទាស់នឹងពួកគេ ដូច្នេះ យើងនឹងបំផ្លាញពួកគេ។ បន្ទាប់មក យើងនឹងបង្កើតប្រជាជាតិមួយដ៏ធំចេញពីអ្នក»។[11]ប៉ុន្តែ
លោកម៉ូសេបានព្យាយាមរម្ងាប់សេចក្តីក្រោធរបស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់គាត់។ គាត់ទូលថា៖ «ព្រះអម្ចាស់អើយ
េហតុអ្វីបានជាព្រះអង្គមានសេចក្តីក្រោធជាមួយប្រជារាស្ត្ររបស់ព្រះអង្គ ដែលព្រះអង្គបាននាំពួកគេចេញពីទឹកដីអេស៊ីបមក ប្រកកដោយអំណាចចេស្តា
និងព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គដូច្នេះ?
[12]ហេតុអ្វីបានជាជនជាតិអេស៊ីបនិយាយថា៖«ព្រះអង្គបាននាំពួកគេចេញដោយបំណងអាក្រក់ គឺដើម្បីសម្លាប់ពួកគេនៅឯភ្នំ ហើយបំផ្លាញពួកគេឲ្យអស់ពីផែនដីដូច្នេះ?
សូមព្រះអង្គបង្វែរសេចក្តីក្រោធរស់ព្រះអង្គ ហើយប្រែព្រះទ័យពីការដាក់ទោសលើប្រជារាស្ត្ររបស់ព្រះអង្គចេញទៅ។
[13]សូមព្រះអង្គនឹកចាំពីសម្ពន្ធមេត្រីរបស់ព្រះអង្គជាមួយលោកអប្រាហាំ លោកអ៊ីសាក និងលោកអ៊ីស្រាអែលជាអ្នកបម្រើរបស់ព្រះអង្គ
ព្រះអង្គបានស្បថជាមួយពួកគេដោយអង្គទ្រង់ផ្ទាល់ ហើយមានបន្ទូលទៅពួកគេថា៖«យើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកមានគ្នាច្រើនដូចជាផ្កាយនៅលើមេឃ
ហើយយើងនឹងប្រទានទឹកដីទាំងអស់នេះឲ្យពូជពង្សរបស់អ្នក តាមសេចក្តីដែលយើងបានសន្យា។ ពួកគេនឹងគ្រងទឹកដីនេះជាមរតកជារៀងរហូត»។[14]បន្ទាប់មក
ព្រះអង្គក៏ប្រែព្រះទ័យពីការដាក់ទោសដែលព្រះអង្គបានមានបន្ទូលថានឹងដាក់លើប្រជារាស្ត្ររបស់ព្រះអង្គ។
[15]បន្ទាប់មក លោកម៉ូសេបានត្រឡប់ ហើយចុះពីភ្នំមកវិញ ដោយកាន់បន្ទះថ្មនៃសម្ពន្ធមេត្រីទាំងពីរ ដែលបានសរសេរដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់។
បន្ទះថ្មនោះត្រូវបានសរសេរទាំងសងខាង គឺសរសេរទាំងខាងមុខ និងខាងក្រោយ។[16]បន្ទះថ្មនោះជាស្នាព្រះហស្តរបស់ព្រះអង្គ ហើយព្រះអង្គផ្ទាល់គឺជាអ្នកសរសេរ
នៅលើបន្ទះថ្មនោះ។
[17]បន្ទាប់មក លោកយ៉ូស្វេបានឮសម្លេងរបស់មនុស្ស នៅពេលពួកគេហ៊ោកញ្ជ្រៀវ គាត់ប្រាប់លោកម៉ូសេថា៖ «មានឮសម្លេងចម្បាំងនៅក្នុងជំរំ»។[18]ប៉ុន្តែ
លោកម៉ូសេប្រាប់ថា៖ «មិនមែនជាសម្លេងនៃអ្នកមានជ័យជម្នះ ហើយក៏មិនមែនជាសម្លេងបរាជ័យដែរ ប៉ុន្តែ ខ្ញុំឮសម្លេងច្រៀងវិញ»។
[19]នៅពេលលោកម៉ូសេចូលទៅជិតជំរំ គាត់បានឃើញគោ ហើយប្រជាជនកំពុងរាំ។ គាត់កើតមានកំហឹងជាខ្លាំង។ គាត់បានបោះបន្ទះថ្មចេញពីដៃរបស់គាត់
ហើយបន្ទះថ្មនោះបានបែកនោះលើជើងភ្នំ។[20]គាត់បានយករូបគោដែលប្រជាជនធ្វើនោះមកដុតវា ហើយកិនវាទៅជាម្សៅ ហើយបានចាក់វាចូលទៅក្នុងទឹក។ បន្ទាប់មក
ជនជាតិអ៊ីស្រាអែលបានផឹកទឹកនោះ។
[21]បន្ទាប់មក លោកម៉ូសេប្រាប់លោកអើរ៉ុនថា៖ «តើប្រជាជនបានធ្វើអ្វីដល់បង បានជាបងនាំពួកគេធ្វើបាបយ៉ាងធំលើពួកគេដូច្នេះ?»[22]លោកអើរ៉ុនឆ្លើយថា៖
«សូមកុំខឹងធ្វើអ្វី លោកម្ចាស់។ លោកស្គាល់ប្រជាជនទាំងអស់នេះហើយ ពួកគេទោទន់ទៅរកតែការអាក្រក់ទេ។[23]ពួកគេប្រាប់ខ្ញុំថា៖ «ចូរធ្វើព្រះមួយឲ្យពួកយើង
ដែលនាំមុខយើង។ ដូចលោកម៉ូសេគឺជាម្នាក់បាននាំយើងចេញពីទឹកដីអេស៊ីប យើងមិនដឹងថាមានរឿងអ្វីកើតឡើងជាមួយលោកទេ»។[24]ដូច្នេះ ខ្ញុំបានប្រាប់ទៅពួកគេថា៖
«អ្នកណាដែលមានមាស ចូរឲ្យគាត់ដោះយកវាមក»។ ពួកគេបានឲ្យមាសមកខ្ញុំ ហើយខ្ញុំក៏បោះចូលទៅក្នុងភ្លើង ហើយវាក៏កើតចេញជារូបគោនេះ»។
[25]លោកម៉ូសេឃើញថា ប្រជាជនធ្វើតាមតែអំពើចិត្ត (ដ្បិត លោកអើរ៉ុនបានបណ្តោយពួកគេ លែងគ្រប់គ្រងបាន ធ្វើឲ្យសត្រូវរបស់ពួកគេបានប្រមាថមើលងាយពួកគេ)។
[26]បន្ទាប់មក លោកម៉ូសេក៏ក្រោកឡើងឈរនៅច្រកទ្វារចូលទៅក្នុងជំរំ ហើយមានប្រសាសន៍ថា៖ «អ្នកណាដែលនៅខាងព្រះអម្ចាស់ ចូរមកខាងខ្ញុំ»។
ពួកលេវីទាំងអស់ចូលមកខាងគាត់។[27]គាត់ប្រាប់ពួកគេថា៖ «ព្រះអម្ចាស់ ជាព្រះរបស់លោកអ៊ីស្រាអែលមានបន្ទូលដូច្នេះ
«ចូរឲ្យមនុស្សគ្រប់គ្នាស្ពាយដាវរបស់ខ្លួននៅផ្នែកចំហៀងរបស់ខ្លួន ហើយដើរចុះឡើងពីច្រកមួយទៅច្រកមួយនៅក្នុងជំរំ ហើយសម្លាប់បងប្អូន មិត្តភក្តិ
ព្រមទាំងអ្នកជិតខាងរបស់ខ្លួនផង»។

generated on Wed Sep 10 16:16:32 2025

[28]ពួកលេវី បានធ្វើតាមសេចក្ដីបង្គាប់របស់លោកម៉ូសេ។ នៅថ្ងៃនោះមានមនុស្សស្លាប់ប្រហែលបីពាន់អ្នក។[29]លោកម៉ូសេប្រាប់ទៅពួកលេវីថា៖
«អ្នកបានញែកខ្លួនបម្រើព្រះអម្ចាស់ ដ្បិតអ្នកទាំងអស់គ្នាបានធ្វើកម្មភាពប្រឆាំងទាស់នឹងកូនប្រុស និងបងប្អូនប្រុសរបស់ខ្លួន ដូច្នេះ
ព្រះអម្ចាស់បានប្រទានព្រះពរដល់អ្នកនៅថ្ងៃនេះ»។
[30]នៅថ្ងៃបន្ទាប់ លោកម៉ូសេបានប្រាប់ទៅប្រជាជនថា៖ «អ្នកបានប្រព្រឹត្តអំពើបាបធំណាស់។ ឥឡូវនេះ ខ្ញុំនឹងឡើងទៅជួបព្រះអម្ចាស់។
ប្រហែលជាខ្ញុំអាចនឹងលោះបាបសម្រាប់បាបរបស់អ្នករាល់គ្នា»។[31]លោកម៉ូសេបានត្រឡប់ទៅព្រះអម្ចាស់វិញ ហើយមានប្រសាសន៍ថា
«ឱប្រជាជនដែលបានធ្វើបាបយ៉ាងធំអើយ ហើយអ្នករាល់គ្នាបានដាក់ខ្លួនថ្វាយបង្គំរូបព្រះធ្វើពីមានដូច្នេះ?[32]ប៉ុន្តែ ឥឡូវនេះ សូមអត់ទោសបាបដល់ពួកគេផង ប៉ុន្តែ
ប្រសិនបើព្រះអង្គមិនអត់ទោសបាបដល់ពួកគេក្តី សូមលុបឈ្មោះទូលបង្គំចោលពីសៀវភៅដែលព្រះអង្គបានសរសេរចុះ»។
[33]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «អស់អ្នកណាដែលធ្វើបាបទាស់នឹងយើង យើងនឹងលុបឈ្មោះអ្នកនោះពីសៀវភៅរបស់យើង។[34]ដូច្នេះ
ឥឡូវនេះចូលអ្នកចេញទៅនាំជនជាតិអ៊ីស្រាអែលទៅកន្លែងដែលើងមានបន្ទូលទៅកាន់អ្នក។ មើល សេចក្ដីក្រោធរបស់យើង យើងនឹងដាក់ទោសបាបរបស់ពួកគេ»។
[35]បន្ទាប់មក ព្រះអម្ចាស់បានចាត់គ្រោះកាចឲ្យធ្លាក់លើមនុស្ស ព្រោះពួកគេបានធ្វើរូបគោ ហើយម្នាក់ដែលលោកអ៊ើរ៉ុនបានបង្កើត។

Exodus 32:1

ប្រជាជនឃើញ

នៅទីនេះការយល់ដឹងអ្វីមួយត្រូវបានគេនិយាយដូចជាវាត្រូវបានគេមើលឃើញ។
ការបកប្រែផ្សេងទៀត «ប្រជាជនបានដឹង»

មក ចូរធ្វើរូបព្រះមួយ

ពាក្យថា«មក៍» ពង្រឹងកម្លាំងនៃពាក្យបង្គាប់ដែលធ្វើតាមវា។
ប្រជាជនបានទាមទារឲ្យអ៊ើរ៉ុនធ្វើរូបព្រះសម្រាប់ពួកគេ។

នាំមុខយើង

«ដឹកនាំយើង» ឬ «ធ្វើជាអ្នកដឹកនាំរបស់យើង»

ហើយយកវាមកឲ្យខ្ញុំ។

ពាក្យថា «ពួកគេ» សំដៅទៅលើចិញ្ចៀនមាស។

Exodus 32:3

ប្រជាជនទាំងអស់

នេះសំដៅទៅលើប្រជាជនទាំងអស់ ដែលបានបដិសេធលោកម៉ូសេ
ជាមេដឹកនាំរបស់ពួកគេហើយព្រះជាម្ចាស់របស់លោកម៉ូសេ
ជាព្រះជាម្ចាស់របស់ពួកគេ។

ធ្វើវាចេញជារូប ហើយធ្វើវាឲ្យទៅជារូបគោ។

លោកអ៊ើរ៉ុនលាយមាស ហើយចាក់វាទៅក្នុងពុម្ពមួយដែលមានរាងដូចកូនគោ។
នៅពេលមាសរឹងគាត់បានយកពុម្ពចេញ ហើយមាសរឹងមានរាងដូចកូនគោ។

Exodus 32:5

នៅពេលលោកអ៊ើរ៉ុនឃើញដូច្នេះ

«ពេលលោកអ៊ើរ៉ុនបានឃើញអ្វីដែលប្រជាជនបានធ្វើ»

រំលេងស៊ីផឹកឡូឡាយ៉ាងសប្បាយ។

«ដើម្បីឱ្យមានពិធីជប់លៀងឆ្លុតលីលា» ។
ប្រជាជនទំនងជាមានអាកប្បកិរិយាអសីលធម៌ផ្លូវភេទនៅក្នុងពិធីជប់លៀង។

Exodus 32:7

ចេញពីផ្លូវដែលយើងបានបង្គាប់ដល់ពួកគេ។

នៅទីនេះព្រះមានបន្ទូលអំពីមនុស្សដែលមិនគោរពតាមអ្វីដែលទ្រង់បានបញ្ជាពួកគេ
ដូចជាទ្រង់បានប្រាប់ពួកគេឱ្យដើរនៅលើផ្លូវជាក់លាក់មួយហើយពួកគេបានចាកចេញពីផ្លូវនោះ។

ការបកប្រែផ្សេងទៀត “ ឈប់ធ្វើអ្វីដែលយើងបានបញ្ជាឱ្យពួកគេធ្វើ” ឬ“
ឈប់ធ្វើតាមអ្វីដែលយើងបានបញ្ជាឱ្យពួកគេធ្វើ”

ពួកគេបានឆ្លាក់ធ្វើរូបគោមួយសម្រាប់ខ្លួនគេ

«ពួកគេបានឆ្លាក់រូបគោមាសសម្រាប់ខ្លួនគេ មានរូបរាងដូចកូនគោ»

Exodus 32:9

យើងបានឃើញប្រជាជននេះ

នៅទីនេះព្រះអម្ចាស់ប្រៀបធៀបការស្គាល់ប្រជាជនទៅនឹងការមើលឃើញពួកគេ។
ការបកប្រែផ្សេងទៀត «យើងស្គាល់ប្រជាជននេះ»

ជាមនុស្សក្បាលរឹង។

មនុស្សក្បាលរឹង - ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនក្បាលរឹង
ដូចពួកគេមានករឹង។ ការបកប្រែផ្សេងទៀត «ប្រជាជនក្បាលរឹង»

ដូច្នេះ ឥឡូវនេះ

ពាក្យ «ឥឡូវនេះ» ត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការសម្រាក
នៅក្នុងអ្វីដែលព្រះអម្ចាស់កំពុងមានបន្ទូលប្រាប់លោកម៉ូសេ។
នៅទីនេះព្រះអម្ចាស់ប្រាប់ពីអ្វីដែលព្រះអង្គ នឹងធ្វើចំពោះប្រជាជន។

សេចក្ដីក្រោធរបស់យើងបានឆេះឡើងទាស់នឹងពួកគេ

ព្រះអម្ចាស់មានព្រះបន្ទូលអំពីកំហឹងរបស់ព្រះអង្គដូចជាភ្លើង ដែលអាចឆេះបាន។
ការបកប្រែផ្សេងទៀត «សេចក្ដីក្រោធរបស់យើងចំពោះពួកគេ
នឹងក្លាយជារឿងដ៏គួរឱ្យភ័យខ្លាច» ឬ «យើងក្រោធយ៉ាងខ្លាំងចំពោះពួកគេ»

ចេញពីអ្នក

ពាក្យ «អ្នក» សំដៅទៅលើលោកម៉ូសេ។

ហេតុអ្វីបានជាព្រះអង្គមានសេចក្ដីក្រោធជាមួយប្រជារាស្ត្ររបស់ព្រះអង្គ
លោកម៉ូសេបានប្រើសំណួរនេះដើម្បីព្យាយាមបញ្ចុះបញ្ចូលព្រះអម្ចាស់
កុំអោយខឹងប្រជាជន។
សំណួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាសេចក្ដីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «កុំអោយសេចក្ដីក្រោធរបស់ព្រះអង្គឆេះឡើង
ទាស់នឹងប្រជារាស្ត្ររបស់ព្រះអង្គ» ឬ «កុំសេចក្រោធនឹងប្រជាជនរបស់ព្រះអង្គ»

ដោយអំណាចចេស្តា ... ព្រះហស្តដ៏ខ្លាំងពូកែ

ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នាហើយត្រូវបានផ្សំសម្រាប់ការសង្កត់ធ្ងន់។

ព្រះហស្តដ៏ខ្លាំងពូកែ

ត្រង់នេះពាក្យថា« ព្រះហស្ត» សំដៅទៅលើអ្វីដែលព្រះអម្ចាស់បានធ្វើ។
ការបកប្រែផ្សេងទៀត «និងរឿងពេញដោយអំណាចចេស្តា ដែលព្រះអង្គបានធ្វើ»

Exodus 32:12

ព័ត៌មានទូទៅ

លោកម៉ូសេបន្តឲ្យហេតុផលជាមួយព្រះជាម្ចាស់កុំបំផ្លាញជនជាតិអ៊ីស្រាអែល។

ហេតុអ្វីបានជាជនជាតិអេស៊ីបនិយាយថា៖ «ព្រះអង្គបាននាំពួកគេចេញដោយបំណងអាក្រក់ ...
ហើយបំផ្លាញពួកគេឲ្យអស់ពីផែនដីដូច្នេះ?
លោកម៉ូសេបានប្រើសំណួរនេះដើម្បីព្យាយាមបញ្ចុះបញ្ចូលព្រះជាម្ចាស់
កុំបំផ្លាញប្រជាជនរបស់ព្រះអង្គ។
សំណួរដ៏ប៉ិនប្រសប់នេះអាចត្រូវបានបកប្រែដោយសេចក្ដីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
ប្រសិនបើព្រះអង្គបំផ្លាញប្រជាជនរបស់ព្រះអង្គជនជាតិអេស៊ីបអាចនិយាយថា
«ព្រះអង្គបាននាំពួកគេចេញពី ... ហើយបំផ្លាញពួកគេឲ្យអស់ពីផែនដី» ។

ឲ្យអស់ពីផែនដី

«ពីលើផែនដី» ឬ «ពីផែនដី»

សូមព្រះអង្គបង្វែរសេចក្ដីក្រោធរបស់ព្រះអង្គ

«សូមបង្វែរសេចក្ដីក្រោធរបស់ព្រះអង្គ» ឬ «សូមព្រះអង្គឈប់ក្រោធ»

បង្វែរសេចក្ដីក្រោធរបស់ព្រះអង្គ

លោកម៉ូសេនិយាយអំពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ដូចជាភ្លើង
ដែលបានកំពុងតែឆេះ។ ការបកប្រែផ្សេងទៀត
«សេចក្ដីក្រោធដ៏គួរឱ្យភ័យខ្លាចរបស់ព្រះអង្គ»

សូមព្រះអង្គនឹកចាំពីសម្ពន្ធមេត្រីរបស់ព្រះអង្គជាមួយលោកអប្រាហាំ

«សូមចងចាំលោកអប្រាហាំ» ឬ «សូមគិតអំពីលោកអប្រាហាំ»

បានស្បថ

«បានធ្វើសម្បថ» ឬ «បានសន្យាយ៉ាងមុតមាំ»

ពួកគេនឹងគ្រងទឹកដីនេះជាមរតកជារៀងរហូត។

ព្រះជាម្ចាស់មានបន្ទូលអំពីពួកគេដែលកាន់កាប់ទឹកដីដូចជាពួកគេ
នឹងទទួលទឹកដីជាមរតក។ ការបកប្រែផ្សេងទៀត
«ពួកគេនឹងកាន់កាប់ទឹកដីជារៀងរហូត»

Exodus 32:15

បន្ទះថ្មនៃសម្ពន្ធមេត្រី

នេះជាផ្នាំងថ្មពីរដែលព្រះជាម្ចាស់បានចារបទបញ្ញត្តិរបស់ព្រះអង្គ។

បន្ទះថ្មនោះជាស្នាព្រះហស្តរបស់ព្រះអង្គ ហើយព្រះអង្គផ្ទាល់គឺជាអ្នកសរសេរ នៅលើបន្ទះថ្មនោះ។

ឃ្លាទាំងពីរនេះមានអត្ថន័យជារួមស្រដៀងគ្នា។
ទីពីរពន្យល់ពីរបៀបដែលបន្ទះថ្មទាំងនោះជា « ជាស្នាព្រះហស្តរបស់ព្រះអង្គផ្ទាល់»

generated on Wed Sep 10 16:16:32 2025

។
Exodus 32:17
គាត់ប្រាប់លោកម៉ូសេ
គឺស្មានថាលោកយ៉ូស្វេបានជួបលោកម៉ូសេ
ពេលលោកម៉ូសេបានកំពុងត្រឡប់ទៅជំរំវិញ។
Exodus 32:19
បន្ទះថ្ម
«ផ្ទាំងថ្មពីរបន្ទះដែលព្រះអម្ចាស់បានចារលើ»
Exodus 32:21
បន្ទាប់មក លោកម៉ូសេប្រាប់លោកអ៊ើរ៉ុនថា៖ «តើប្រជាជនបានធ្វើអ្វី...
ធ្វើបាបយ៉ាងធំលើពួកគេដូច្នេះ?»
នេះអាចត្រូវបានបញ្ជាក់ជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកលោកម៉ូសេបានសួរលោកអ៊ើរ៉ុន នូវអ្វីដែលប្រជាជនបានធ្វើចំពោះគាត់
ដែលគាត់បាននាំអំពើបាបដ៏ធំបែបនេះមកលើពួកគេ»
បានជាបងនាំពួកគេធ្វើបាបយ៉ាងធំលើពួកគេ
លោកម៉ូសេបាននិយាយអំពីការបណ្តាលឱ្យមនុស្សធ្វើបាប
ដូចជាបាបគឺជាវត្ថុមួយហើយអ៊ើរ៉ុនបានពាក់វា។ ការបកប្រែផ្សេងទៀត
«បងបានធ្វើឱ្យពួកគេធ្វើបាបយ៉ាងអាក្រក់បំផុត»
សូមកុំខឹងធ្វើអ្វី លោកម្ចាស់
លោកអ៊ើរ៉ុនបាននិយាយអំពីកំហឹងរបស់លោកម៉ូសេដូចជាភ្លើងដែលអាចឆេះបាន។
«កុំខឹងខ្លាំងពេក»
ពួកគេទោទន់ទៅរកតែការអាក្រក់ទេ។
ការតាំងចិត្តធ្វើអំពើអាក្រក់ត្រូវបានគេនិយាយថាដូចជាការទោទន់ទៅរកអំពើអាក្រក់។
ការបកប្រែផ្សេងទៀត« ពួកគេតាំងចិត្តធ្វើអ្វីដែលអាក្រក់»
ដូចលោកម៉ូសេ
ប្រជាជនបានបង្ហាញការមិនគោរពដោយដាក់ពាក្យ «ដូច»
នៅពីមុខឈ្មោះរបស់គាត់ដូចជាលោកម៉ូសេជាមនុស្សដែលពួកគេមិនស្គាល់
និងមិនអាចទុកចិត្តបាន
ដូច្នេះ ខ្ញុំបានប្រាប់ទៅពួកគេថា៖ «អ្នកណាដែលមានមាស ចូរឲ្យគាត់ដោះយកវាមក»។
នេះអាចត្រូវបានបញ្ជាក់ជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«ដូច្នេះខ្ញុំបានប្រាប់ពួកគេថា អ្នកណាដែលមានមាសគួរតែដោះវាចេញ»
ហើយខ្ញុំក៏បោះចូលទៅក្នុងភ្លើង ហើយវាក៏កើតចេញជារូបគោនេះ។
ជំនួសឱ្យការទទួលខុសត្រូវក្នុងភាពជាអ្នកគ្រប់គ្រងម្រាប់ការធ្វើរូបគោនោះ
លោកអ៊ើរ៉ុនបានអះអាងថារូបគោបានចេញពីភ្លើងយ៉ាងអស្ចារ្យលើសពីធម្មជាតិ។
Exodus 32:25
ធ្វើតាមតែអំពើចិត្ត
«បានប្រព្រឹត្តយ៉ាងឆ្គួតលីលា» ឬ «មិនបានគ្រប់គ្រងខ្លួនឯង»
បន្ទាប់មក លោកម៉ូសេក៏ក្រោកឡើងឈរនៅច្រកទ្វារចូល ... «អ្នកណាដែលនៅខាងព្រះអម្ចាស់
ចូរមកខាងខ្ញុំ»។
នេះអាចត្រូវបានបញ្ជាក់ជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកលោកម៉ូសេបានឈរនៅមាត់ទ្វារចូលជំរំ
ហើយបាននិយាយថាអ្នកណាដែលនៅខាងព្រះអម្ចាស់គួរតែមករកគាត់»
អ្នកណាដែលនៅខាងព្រះអម្ចាស់
លោកម៉ូសេនិយាយអំពីភាក្តីភាពចំពោះព្រះអម្ចាស់ថា នៅខាងព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត « អ្នកណាដែលស្មោះត្រង់នឹងព្រះអម្ចាស់» ឬ «
អ្នកណាដែលបម្រើព្រះអម្ចាស់»
ហើយដើរចុះឡើងពីច្រកមួយទៅច្រកមួយ
«ចូលហើយនិងចេញពីច្រកចូលមួយនៃជំរុំទៅច្រកចូលផ្សេងទៀត»
Exodus 32:28
មានមនុស្សស្លាប់ប្រហែលបីពាន់អ្នក។
«3000 នាក់»
អ្នកបានញែកខ្លួនបម្រើព្រះអម្ចាស់
នេះប្រហែលជាមានន័យថា «អ្នកត្រូវបានគេជ្រើសរើសឱ្យបម្រើព្រះអម្ចាស់» ឬ
«អ្នកបានក្លាយជាអ្នកបម្រើរបស់ព្រះអម្ចាស់» ។
ដ្បិតអ្នកទាំងអស់គ្នាបានធ្វើកម្មភាពប្រឆាំងទាស់នឹងកូនប្រុស និងបងប្អូនប្រុសរបស់ខ្លួន
ការពិតជាកស្តែងដែលថាពួកគេបានធ្វើបែបនេះ
ក្នុងការស្តាប់បង្គាប់ចំពោះព្រះជាម្ចាស់ អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «
ដ្បិតអ្នកបានស្តាប់បង្គាប់ព្រះអម្ចាស់ហើយបានសម្លាប់កូនប្រុស
និងបងប្អូនរបស់អ្នក»
Exodus 32:30
អ្នកបានប្រព្រឹត្តអំពើបាបធំណាស់។
ពួកគេថ្វាយបង្គំរូបព្រះ។
ប្រហែលជាខ្ញុំអាចនឹងលោះបាបសម្រាប់បាបរបស់អ្នករាល់គ្នា។
លោកម៉ូសេបាននិយាយអំពីការបញ្ចុះបញ្ចូលព្រះជាម្ចាស់
អោយអត់ទោសប្រជាជនដូចជាគាត់អាចធ្វើតង្វាយលោះបាបសម្រាប់អំពើបាបរបស់ពួកគេ។
ការបកប្រែផ្សេងទៀត
«ប្រហែលជាខ្ញុំអាចបញ្ចុះបញ្ចូលព្រះអម្ចាស់ឱ្យអត់ទោសឱ្យអ្នក»
សូមលុបឈ្មោះទូលបង្គំចោលពីសៀវភៅ
ពាក្យថា «ខ្ញុំ» នៅទីនេះសំដៅទៅលើឈ្មោះរបស់លោកម៉ូសេ។
ការបកប្រែផ្សេងទៀត «លុបឈ្មោះខ្ញុំចេញពីសៀវភៅ»
សូមលុបឈ្មោះទូលបង្គំចោលពីសៀវភៅដែលព្រះអង្គបានសរសេរចុះ។
អ្វីដែលព្រះជាម្ចាស់បានសរសេរនៅក្នុងសៀវភៅអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត
«សៀវភៅដែលព្រះអង្គបានសរសេរឈ្មោះប្រជាជនរបស់ព្រះអង្គ»
Exodus 32:33
យើងនឹងលុបឈ្មោះអ្នកនោះពីសៀវភៅរបស់យើង។
ឃ្លា «អ្នកនោះ» តំណាងឱ្យ «ឈ្មោះរបស់មនុស្សនោះ» ។ ការបកប្រែផ្សេងទៀត
«យើងនឹងលុបឈ្មោះរបស់មនុស្សនោះចេញពីសៀវភៅរបស់យើង»
ពីសៀវភៅរបស់យើង
នេះសំដៅទៅលើសៀវភៅរបស់ព្រះអម្ចាស់
ដែលលោកម៉ូសេបានមានប្រសាសន៍នៅ ៣២:៣០ ។
យើងនឹងដាក់ទោសបាបរបស់ពួកគេ
នៅថ្ងៃដែលព្រះសម្រេចដាក់ទោសពួកគេ
គឺគេនឹងដឹងច្បាស់ថាជាព្រះជាម្ចាស់ដែលកាត់ទោសពួកគេ។
ព្រះអម្ចាស់បានចាត់គ្រោះកាចឲ្យធ្លាក់លើមនុស្ស
គ្រោះកាចនេះអាចជាជំងឺធ្ងន់ធ្ងរ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានធ្វើអោយប្រជាជនឈឺធ្ងន់យ៉ាងខ្លាំង»
ពួកគេបានធ្វើរូបគោ ហើយម្នាក់ដែលលោកអ៊ើរ៉ុនបានបង្កើត។
ទោះបីអ៊ើរ៉ុនបានធ្វើរូបគោក៏ដោយប្រជាជនក៏មានកំហុសដែរ
ពីព្រោះពួកគេបានប្រាប់អ៊ើរ៉ុនឲ្យធ្វើរូបគោ។ ការបកប្រែផ្សេងទៀត
«ពួកគេបានប្រាប់អ៊ើរ៉ុនឱ្យធ្វើរូបគោ»

---

33 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរចេញពីទីនេះ អ្នកនឹងប្រជាជនដែលអ្នកបាននាំចេញពីទឹកដីអេស៊ីប។
ចូរចេញទៅទឹកដីដែលយើងបានស្បថឲ្យដល់លោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប នៅពេលយើងនិយាយថា៖ «យើងនឹងឲ្យវាដល់ពូជពង្សរបស់អ្នក»។
[2]យើងនឹងចាត់ទេវតាឲ្យនាំមុខអ្នក យើងនឹងបណ្តេញជនជាតិកាណាន ជនជាតិអាម៉ូរី ជនជាតិហេត ជនជាតិពេរិស៊ីត ជនជាតិហេវី និងជនជាតិយេប៊ូស។
[3]ចូរចេញទៅទឹកដីនោះ ដែលពេញទៅដោយទឹកដោះ និងទឹកឃ្មុំ ប៉ុន្តែ យើងនឹងមិនឡើងទៅជាមួយអ្នកទេ ព្រោះអ្នករាល់គ្នាជាមនុស្សក្បាលរឹង។
យើងអាចនឹងបំផ្លាញអ្នករាល់គ្នានៅតាមផ្លូវ»។
[4]នៅពេលប្រជាជនឮព្រះបន្ទូលធ្ងន់ៗទាំងនេះ ពួកគេមានការសោកសៅ ហើយគ្មាននរណាពាក់គ្រឿងអលង្ការឡើយ។[5]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេថា៖
«ចូរប្រាប់ដល់ជនជាតិអ៊ីស្រាអែលថា៖ «អ្នករាល់គ្នាជាមនុស្សក្បាលរឹង។ ប្រសិនបើ យើងចេញទៅជាមួយអ្នករាល់គ្នា ទោះបីជាមួយរយៈខ្លី យើងអាចនឹងបំផ្លាញអ្នក។
ដូច្នេះ ឥឡូវនេះ ចូរដោះគ្រឿងអលង្ការចេញ ដើម្បីឲ្យយើងអាចសម្រេចថា តើយើងគួរធ្វើអ្វីដល់អ្នករាល់គ្នា»។[6]ដូច្នេះ ជនជាតិអ៊ីស្រាអែល
មិនបានពាក់គ្រឿងអលង្ការចាប់តាំងពីភ្នំមហារែបមក។
[7]លោកម៉ូសេបានយកព្រះពន្លា និងទៅតំឡើងនៅខាងក្រៅជំរំ គឺឆ្ងាយពីជំរំបន្តិច។ គាត់បានហៅថា ត្រសាលនៃការជួបជុំ។ អ្នកណាចង់ទូលសូមព្រះអម្ចាស់អ្វីមួយ
ឲ្យចេញទៅត្រសាលនៃការជួបជុំ នៅខាងក្រៅជំរំ។[8]នៅពេលលោកម៉ូសេចេញទៅព្រះពន្លា ប្រជាជនគ្រប់គ្នាឈរនៅទីនោះ នៅត្រង់ច្រកចូលរបស់ពួកគេ

generated on Wed Sep 10 16:16:32 2025

ហើយមើលលោកម៉ូសេរហូតទាល់តែគាត់ចូលទៅខាងក្នុង។[9]នៅពេលលោកម៉ូសេចូលទៅខាងក្នុងព្រះពន្លា សសរពពកក៏ចុះមក ហើយឈរនៅត្រង់ច្រកចូលព្រះពន្លា
ហើយព្រះអម្ចាស់នឹងមានបន្ទូលមកលោកម៉ូសេ។
[10]នៅពេលប្រជាជនអ៊ីស្រាអែលទាំងអស់ឃើញសសរពពកឈរនៅត្រង់ច្រកចូលព្រះពន្លា ពួកគេអាចក្រោកឡើង ហើយថ្វាយបង្គំ
មនុស្សគ្រប់គ្នាឈរនៅច្រកចូលរៀងៗខ្លួន។[11]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេមុខទល់នឹងមុខ ដូចជាមនុស្សនិយាយជាមួយនឹងមិត្តភក្ត្ររបស់ខ្លួន។ បន្ទាប់មក
លោកម៉ូសេក៏ត្រឡប់ទៅជំរំវិញ ប៉ុន្តែ អ្នកបម្រើរបស់គាត់ លោកយ៉ូស្វេ កូនរបស់លោកនូន ជាយុវជន នៅក្នុងព្រះពន្លាដដែល។
[12]លោកម៉ូសេទូលទៅព្រះអម្ចាស់ថា៖ «មើល៍ ព្រះអង្គបានមានបន្ទូលមកទូលបង្គំ» ឲ្យនាំប្រជាជននេះធ្វើដំណើរ ប៉ុន្តែ ព្រះអង្គមិនប្រាប់ទូលបង្គំដឹងទេថា
ព្រះអង្គបានចាត់នរណាទៅជាមួយទូលបង្គំ។ ព្រះអង្គមានបន្ទូលថា៖ «យើងឈ្មោះអ្នក ហើយអ្នកប្រកបដោយព្រះគុណនៅចំពោះយើងដែរ»។[13]ឥឡូវនេះ ប្រសិនបើ
ទូលបង្គំបានប្រកដោយព្រះគុណនៅចំពោះព្រះអង្គមែន សូមបង្ហាញផ្លូវរបស់ព្រះអង្គឲ្យទូលបង្គំផង ដើម្បីឲ្យទូលបង្គំបានស្គាល់ព្រះអង្គ
ហើយបន្តក្នុងការទទួលព្រះគុណនៅចំពោះព្រះអង្គ។ សូមព្រះអង្គចាំថា ប្រជាជាតិនេះគឺជាប្រជារាស្ត្ររបស់ព្រះអង្គ»។
[14]ព្រះអម្ចាស់ឆ្លើយថា៖ «វត្តមានរបស់យើងផ្ទាល់នឹងនាំអ្នក ហើយយើងនឹងឲ្យអ្នកបានសម្រាក»។[15]លោកម៉ូសេទូលទៅព្រះអង្គវិញថា៖ «ប្រសិនបើ
វត្តមានរបស់ព្រះអង្គមិនយាងទៅជាមួយយើងទេ សូមកុំនាំយើងខ្ញុំចេញពីទីនេះឡើយ។[16]ដ្បិត បើមិនដូច្នោះទេ តើឲ្យគេដឹងថា ទូលបង្គំ
និងប្រជារាស្ត្ររបស់ព្រះអង្គបានប្រកបដោយព្រះគុណរបស់ព្រះអង្គបាន? វាមិនអាចទៅរួចទេ ប្រសិនបើ ព្រះអង្គយាងទៅជាមួយយើង ដើម្បីឲ្យទូលបង្គំ
និងប្រជារាស្ត្ររបស់ព្រះអង្គ តើមានភាពខុសគ្នាពីប្រជាជនផ្សេងទៀតដែលនៅលើផ្ទៃនៃផែនដីនេះ?
[17]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «យើងនឹងធ្វើការនេះ តាមការស្នើសុំដែលអ្នកបានសុំ ដ្បិតអ្នកបានប្រកបដោយព្រះគុណនៅចំពោះយើង
ហើយយើងក៏ស្គាល់ឈ្មោះអ្នកដែរ»។[18]លោកម៉ូសេទូលថា៖ «សូមបង្ហាញសិរីល្អរបស់ព្រះអង្គ»។
[19]ព្រះអម្ចាស់មានបន្ទូលថា៖ «យើងនឹងសម្តែងសេចក្តីសប្បុរសរបស់យើងនៅចំពោះអ្នក ហើយយើងនឹងប្រកាសនាមរបស់យើងថា៖ «ព្រះអម្ចាស់» នៅចំពោះអ្នកដែរ។
យើងនឹងផ្តល់សេចក្តីមេត្តាដល់អស់អ្នកណាដែលយើងផ្តល់សេចក្តីមេត្តា ហើយយើងនឹងបង្ហាញព្រះគុណដល់អស់អ្នកណាដែលយើងផ្តល់ព្រះគុណ»។[20]ប៉ុន្តែ
ព្រះអម្ចាស់មានបន្ទូលថា៖ អ្នកមិនអាចឃើញមុខរបស់យើងទៀតបានទេ ដ្បិតគ្មាននរណាឃើញមុខយើងហើយ នៅរស់ទៀតទេ»។
[21]ព្រះអម្ចាស់មានបន្ទូលថា៖ «មើល៍ មានកន្លែងមួយនៅជិតយើង អ្នកទៅឈរនៅជិតថ្មនេះហើយ។[22]នៅពេលសិរីល្អរបស់យើងឆ្លងកាត់
យើងនឹងដាក់អ្នកនៅត្រង់ក្រហែងថ្មនោះ ដើម្បីគ្របបាំងអ្នកពីព្រះហស្តរបស់យើងរហូតយើងបានឆ្លងផុត។ បន្ទាប់មក[23]យើងនឹងដកព្រះហស្តរបស់យើងចេញ
ហើយអ្នកនឹងឃើញខ្នងរបស់យើង ប៉ុន្តែ មិនឃើញមុខរបស់យើងទេ»។

Exodus 33:1

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេពីសេចក្តីក្រោធរបស់ព្រះអង្គ។

ទឹកដីនោះ ដែលពេញទៅដោយទឹកដោះ និងទឹកឃ្មុំ

ដីនេះល្អសម្រាប់ចិញ្ចឹមសត្វនិងដាំដំណាំផ្សេងៗ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣: ៧ ។ ការបកប្រែផ្សេងទៀត
«ទឹកដីដែលល្អប្រសើរសម្រាប់ចិញ្ចឹមសត្វ និងដាំដំណាំ»

ពេញទៅដោយ

«ពេញពោរដោយ» ឬ «ជាមួយភាពបរិបូរណ៍នៃ»

ទឹកដោះ

ដោយសារទឹកដោះគោចេញពីគោ និងពពែ
នេះគឺតំណាងឱ្យអាហារដែលផលិតតាមរយៈសត្វចិញ្ចឹម។ ការបកប្រែផ្សេងទៀត
«អាហារពីសត្វ»

ទឹកឃ្មុំ

ចាប់តាំងពីទឹកឃ្មុំត្រូវបានផលិតចេញពីផ្កា នេះគឺតំណាងឱ្យអាហារពីផលដំណាំ។
ការបកប្រែផ្សេងទៀត «អាហារពីផលដំណាំ»

មនុស្សក្បាលរឹង

«មនុស្សដែលបដិសេធមិនផ្លាស់ប្រែ»

Exodus 33:4

គ្រឿងអលង្ការ

សម្លៀកបំពាក់ស្អាតៗ ព្រមទាំងច្រវាក់
និងចិញ្ចៀនដែលមានគ្រឿងអលង្ការនៅក្នុងពួកគេ

មនុស្សក្បាលរឹង

«មនុស្សដែលបដិសេធមិនផ្លាស់ប្រែ»
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣៣: ១ ។

Exodus 33:7

សសរពពក

ពពកមានរាងជាសសរ។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ១៣:១៩
។ ការបកប្រែផ្សេងទៀត «ពពកមានរាងដូចសសរ»

ក៏ចុះមក

កន្លែងដែលវាចុះមកអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ក៏ចុះមកពីលើមេឃ»

Exodus 33:10

ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេមុខទល់នឹងមុខ

និយាយដោយផ្ទាល់ជាជាងតាមសុបិន្តហើយ
និងនិមិត្តគឺត្រូវបាននិយាយដូចជាលោកម៉ូសេ
និងព្រះជាម្ចាស់បានឃើញមុខគ្នាទៅវិញទៅមកនៅពេលពួកគេបាននិយាយគ្នា។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងមានព្រះបន្ទូលផ្ទាល់មកលោកម៉ូសេ»

ជាយុវជន

មានអាយុគ្រប់ល្មមធ្វើជាទាហាន (១៧: ៨) ប៉ុន្តែក្មេងជាងលោកម៉ូសេ

Exodus 33:12

មើល៍

«មើល!» ឬ «ស្តាប់!» ឬ «ចូរយកចិត្តទុកដាក់ចំពោះនូវអ្វីដែលយើងប្រាប់អ្នក»។

យើងឈ្មោះអ្នក

ការស្គាល់មនុស្សណាម្នាក់តាមរយៈឈ្មោះ គឺស្គាល់ពួកគេច្បាស់ណាស់។
ការបកប្រែផ្សេងទៀត «យើងស្គាល់អ្នកច្បាស់»

អ្នកប្រកបដោយព្រះគុណនៅចំពោះយើងដែរ។

នេះជាផ្នែកមួយនៃអ្វីដែលព្រះជាម្ចាស់បានប្រាប់លោកម៉ូសេ។ ការបកប្រែផ្សេងទៀត
«យើងពេញចិត្តនឹងអ្នក» ឬ «យើងយល់ព្រមជាមួយអ្នក»

សូមបង្ហាញផ្លូវរបស់ព្រះអង្គឲ្យទូលបង្គំផង

ទី១អត្ថន័យដែលអាចមាន)
«បង្ហាញទូលបង្គំពីអ្វីដែលព្រះអង្គនឹងធ្វើនៅពេលអនាគត» ឬទី២)
«បង្ហាញទូលបង្គំពីរបៀបដែលមនុស្សអាចធ្វើនូវអ្វីដែលគាប់ព្រះហឫទ័យព្រះអង្គ»
។

Exodus 33:14

វត្តមានរបស់យើងផ្ទាល់នឹងនាំ

ព្រះវត្តមានរបស់ព្រះជាម្ចាស់ជាតំណាងអង្គទ្រង់ផ្ទាល់។ ការបកប្រែផ្សេងទៀត
«យើងនឹងទៅ»

នាំអ្នក ... ឲ្យអ្នក

ពាក្យថា «អ្នក» នៅទីនេះសំដៅទៅលើលោកម៉ូសេ។ វាគឺឯកវចនៈ។

យើងនឹងឲ្យអ្នកបានសម្រាក

«យើងនឹងឱ្យអ្នកសម្រាក»

បើមិនដូច្នោះទេ

«ដ្បិតប្រសិនបើវត្តមានរបស់ព្រះអង្គ មិនទៅជាមួយពួកយើង»

តើឲ្យគេដឹងថា

នេះអាចត្រូវបានបង្ហាញជាមួយទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«តើមនុស្សនឹងដឹងដោយរបៀបណា?»

តើឲ្យគេដឹងថា ...ប្រជារាស្ត្រ?

លោកម៉ូសេបានប្រើសំណួរនេះដើម្បីបញ្ជាក់ថាប្រសិនបើព្រះជាម្ចាស់មិនយាងទៅជាមួយពួកគេទេគ្មាននរ
ការបកប្រែផ្សេងទៀត «គ្មានមនុស្សណាម្នាក់នឹងស្គាល់ ... ប្រជារាស្ត្រ» ។

វាមិនអាចទៅរួចទេ ប្រសិនបើ

«វាមិនមែនគ្រាន់តែនឹងមិនដឹងប៉ុណ្ណោះទេប្រសិនបើ»

generated on Wed Sep 10 16:16:32 2025

Exodus 33:17
ព័ត៌មានទូទៅ
នៅពេលដែលព្រះអម្ចាស់ប្រើពាក្យ «អ្នក» នៅក្នុងខនេះវាគឺឯកវចន:
ហើយសំដៅទៅលើលោកម៉ូសេ។ :
អ្នកបានប្រកបដោយព្រះគុណនៅចំពោះយើង
នេះគឺជាឃ្លាមួយដែលមានន័យថាព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងគាត់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣៣:១២ ។ ការបកប្រែផ្សេងទៀត
«យើងពេញចិត្តនឹងអ្នក» ឬ «យើងយល់ព្រមជាមួយអ្នក»
យើងក៏ស្គាល់ឈ្មោះអ្នកដែរ
ការស្គាល់មនុស្សណាម្នាក់ដោយឈ្មោះគឺស្គាល់ពួកគេច្បាស់ណាស់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣៣:១២ ។
ការបកប្រែផ្សេងទៀត«យើងស្គាល់អ្នកច្បាស់ណាស់»
Exodus 33:19
យើងនឹងសម្តែងសេចក្តីសប្បុរសរបស់យើងនៅចំពោះអ្នក
ព្រះជាម្ចាស់មានបន្ទូលអំពីការឆ្លងពីអតីតកាលរបស់លោកម៉ូសេ
ដូច្នេះលោកម៉ូសេអាចមើលឃើញសេចក្តីសប្បុរសរបស់ទ្រង់ហាក់ដូចជាមានតែសេចក្តីសប្បុរសរបស់ទ្រង់
ដែលអាចឲ្យលោកម៉ូសេឆ្លងកាត់អតីតកាលបាន។ ការបកប្រែផ្សេងទៀត
«យើងនឹងបន្តអតីតកាលអ្នកដើម្បីអ្នកអាចមើលឃើញពីសប្បុរសរបស់យើង»
Exodus 33:21
មើល៍
«មើល៍» ឬ «ស្តាប់» ឬ «ចូរយកចិត្តទុកដាក់នូវអ្វីដែលយើងនឹងប្រាប់អ្នក»។
អ្នកនឹងឃើញខ្នងរបស់យើង
នេះមកពីព្រះអម្ចាស់នឹងយាងចេញពីលោកម៉ូសេ។
ប៉ុន្តែ មិនឃើញមុខរបស់យើងទេ។
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែអ្នកនឹងមិនឃើញមុខរបស់យើងទេ»

---

34 [1]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរកាត់ថ្មពីរបន្ទះ ដូចបន្ទះថ្មលើកមុន។ យើងនឹងសរសេរព្រះបន្ទូលនៅលើន្ទះថ្មទាំងនេះ
គឺជាបន្ទះថ្មដែលអ្នកបានបំបាក់។[2]ចូររួចរាល់តាំងពីព្រឹក ហើយឡើងមកលើភ្នំស៊ីណាយ ហើយបង្ហាញខ្លួនរបស់អ្នកនៅចំពោះយើង នៅលើកំពូលភ្នំ។
[3]មិនត្រូវយកនរណាឡើងមកជាមួយអ្នកឡើយ។ មិនត្រូវអនុញ្ញាតឲ្យអ្នកផ្សេងទៀតឃើញកន្លែងណាមួយនៅលើភ្នំឡើយ។ មិនត្រូវឲ្យមានហ្វូងចៀម
ឬហ្វូងសត្វមកស៊ីស្មៅនៅខាងមុខភ្នំឡើយ»។[4]ដូច្នេះ លោកម៉ូសេបានកាត់បន្ទះថ្មីពីដូចលើកមុន ហើយគាត់បានក្រោកតាំងពីព្រលឹម ហើយឡើងទៅលើភ្នំស៊ីណាយ
ដូចព្រះអម្ចាស់បានបង្គាប់ដល់គាត់។ លោកម៉ូសេបានយកបន្ទះថ្មនៅក្នុងដៃរបស់គាត់ដែរ។
[5]ព្រះអម្ចាស់បានយាងចុះមកពីពពក ហើយគង់នៅជិតលោកម៉ូសេនៅទីនោះ ហើយព្រះអង្គបានប្រកាសព្រះនាម «ព្រះអម្ចាស់» ផង។
[6]ព្រះអម្ចាស់បានយាងកាត់ខាងមុខគាត់ ហើយបានប្រកាសព្រះនាម «ព្រះអម្ចាស់ ព្រះអម្ចាស់ ព្រះជាម្ចាស់ដែលប្រកបដោយសេចក្តីមេត្តា និងព្រះគុណ
ព្រះអង្គយឺតនឹងខ្ញាល់ ហើយមានព្រះទ័យស្មោះត្រង់ និងសប្បុរសជានិច្ចនៅក្នុងសម្ពន្ធមេត្រីរបស់ព្រះអង្គ[7]ព្រះអង្គស្មោះត្រង់នឹងសម្ពន្ធមេត្រីដល់ទាំងពាន់តំណរ
អត់ទោសកំហុស និងការរំលង ព្រមទាំងបាបផង។ ប៉ុន្តែព្រះអង្គមិនមែនមិនរាប់មនុស្សមានកំហុស ថាគ្មានកំហុសឡើយ។
ព្រះអង្គនឹងនាំការដាក់ទោសសម្រាប់បាបរបស់ឪពុកទៅលើកូន និងចៅរបស់គេផង ព្រមទាំងដល់មនុស្សនៅជំនាន់ទីបីឬទីបួនផង»។
[8]លោកម៉ូសេបានឱនក្បាលគាត់ចុះទៅដល់ដី ហើយបានថ្វាយបង្គំព្រះអង្គ។[9]បន្ទាប់មក គាត់ទូលថា៖ «ឱព្រះអម្ចាស់អើយ ប្រសិនបើ
ទូលបង្គំបានប្រកដដោយព្រះគុណនៅចំពោះព្រះអម្ចាស់មែន សូមចេញពីចំណោមយើងខ្ញុំចុះ ដ្បិត មនុស្សនេះគេក្បាលរឹងណាស់។ សូមអត់ទោសកំហុស
និងបាបរបស់យើងខ្ញុំ ហើយសូមទទួលយើងខ្ញុំជាមរតករបស់ព្រះអង្គផង»។
[10]ព្រះអម្ចាស់មានបន្ទូលថា៖ «មើល៍ យើងនឹងចងសម្ពន្ធមេត្រី នៅចំពោះប្រជាជនទាំងអស់ យើងនឹងធ្វើការអស្ចារ្យ ដែលមិនធ្លាប់កើតមានឡើងនៅលើផែនដី
ឬនៅលើប្រជាជាតិណាឡើយ។ ប្រជាជនទាំងអស់នៅក្នុងចំណោមអ្នកនឹងបានឃើញការដែលយើងធ្វើ ដ្បិត វាគឺជាការដែលគួរឲ្យខ្លាច ដែលយើងនឹងធ្វើជាមួយអ្នក។
[11]ចូរស្តាប់តាមអ្វីដែលយើងបានបង្គាប់ដល់អ្នកនៅថ្ងៃនេះ។ យើងនឹងបណ្តេញជនជាតិអាម៉ូរី ជនជាតិកាណាន ជនជាតិហេត ជនជាតិពេរិស៊ីត ជនជាតិហេវី និងជនជាតិ
យេប៊ូស ចេញពីមុខអ្នករាល់គ្នា។
[12]ចូរប្រយ័ត្ន មិនត្រូវចងសម្ពន្ធមេត្រីជាមួយប្រជាជនដែលរស់នៅក្នុងទឹកដីដែលអ្នកនឹងទៅឡើយ ឬ ពួកគេនឹងក្លាយជាអន្ទាក់សម្រាប់អ្នក។[13]ផ្ទុយទៅវិញ
អ្នកត្រូវបំផ្លាញកន្លែងថ្វាយយញ្ញបូជា វាយបំបែកសសរថ្ម ហើយកាត់សសរព្រះអាសេរ៉ាជាព្រះរបស់ពួកគេចោល។[14]ព្រោះ អ្នកមិនត្រូវថ្វាយបង្គំព្រះណាផ្សេងទៀតឡើយ
ដ្បិត ព្រះអម្ចាស់ ជានាមដែលប្រចណ្ឌ ព្រះអង្គជាព្រះជាម្ចាស់ដែលប្រចណ្ឌ។
[15]ដូច្នេះ ចូរប្រយ័ត្ន កុំចងសម្ពន្ធមេត្រីជាមួយប្រជាជននៅក្នុងទឹកដីនោះឡើយ ដ្បិត ពួកគេបានផិតក្បត់ចំពោះព្រះរបស់ពួកគេ
ហើយពួកគេបានថ្វាយយញ្ញបូជាដល់ព្រះរបស់ពួកគេ។ បន្ទាប់មក មានម្នាក់នៅក្នុងចំណោមពួកគេបានអញ្ជើញអ្នក
ហើយអ្នកបានហូបយញ្ញបូជារបស់ពួកគេ[16]ហើយបន្ទាប់មក អ្នកបានយកកូនស្រីរបស់ពួកគេឲ្យកូនប្រុសរបស់អ្នក
និងកូនស្រីរបស់គេនឹងផិតក្បត់ជាមួយនឹងព្រះរបស់ពួកគេ ហើយពួកគេនឹងឲ្យកូនប្រុសរបស់អ្នកផិតក្បត់ចំពោះព្រះរបស់ពួកគេ។
[17]មិនត្រូវធ្វើរូបចម្លាក់ព្រះណាមួយសម្រាប់អ្នកឡើយ។
[18]អ្នកត្រូវធ្វើពិធីបុណ្យនំបុ័ងឥតមេ។ ដូចដែលយើងបានបង្គាប់ដល់អ្នក ហើយអ្នកត្រូវហូបនំបុ័ងឥតមេក្នុងរយៈពេលប្រាំពីរថ្ងៃ នៅក្នុងពេលកំណត់នៃខែអាប៊ីប ដ្បិត
ពិធីបុណ្យនេះគឺត្រូវធ្វើនៅក្នុងខែអាប៊ីប ជាខែដែលអ្នកចេញពីអេស៊ីប។
[19]កូនច្បងទាំងអស់ជាកម្មសិទ្ធិរបស់យើង ទោះបើកូនដំបូងនៃហ្វូងសត្វ ទាំងគោ និងចៀម។[20]អ្នកត្រូវទិញកូនដំបូងត្រឡប់មកវិញ គឺពីកូនលា និងកូនចៀមដំបូង ប៉ុន្តែ
ប្រសិនបើ អ្នកមិនទិញវាត្រឡប់មកវិញទេ ដូច្នេះ អ្នកត្រូវបំបាក់កវា។ អ្នកត្រូវទិញកូនច្បងរបស់អ្នកត្រឡប់មកវិញ។ គ្មាននរណាដែលមកចំពោះយើងដោយដៃទទេឡើយ។
[21]អ្នកអាចធ្វើការក្នុងរយៈប្រាំមួយថ្ងៃ ប៉ុន្តែ នៅថ្ងៃទីប្រាំពីរ អ្នកត្រូវសម្រាក។ ទោះបីជាដល់រដូវភ្ជួរ ហើយក្នុងរដូវចម្រូតក្តី អ្នកត្រូវសម្រាក។[22]អ្នកត្រូវធ្វើពិធីបុណ្យសប្តាហ៍
ជាមួយនឹងផលដំបូងនៃការច្រូតស្រូវ អ្នកត្រូវធ្វើពិធីបុណ្យនៃការប្រមូលផលនៅចុងឆ្នាំ។
[23]មួយឆ្នាំបីដង ចូរឲ្យពួកប្រុសៗទាំងអស់បង្ហាញខ្លួននៅចំពោះព្រះអម្ចាស់ដ៏ជាព្រះ ជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែល។[24]ដ្បិត យើងនឹងបណ្តេញប្រជាជាតិនានា
ហើយពង្រីកព្រំប្រទល់របស់អ្នក។ គ្មាននរណាមានចិត្តចង់បានទឹកដីរបស់អ្នកមកធ្វើជារបស់គេឡើយ
នៅពេលអ្នកឡើងទៅគាល់នៅចំពោះព្រះជាម្ចាស់ជាព្រះរបស់អ្នកបីដងក្នុងមួយឆ្នាំ។
[25]អ្នកមិនត្រូវថ្វាយឈាមនៃយញ្ញបូជារបស់យើង ជាមួយនឹងមេណាមួយ ឬសាច់ពីយញ្ញបូជានៅថ្ងៃបុណ្យចម្លង ទុកឲ្យនៅសល់រហូតដល់ព្រឹកឡើយ។
[26]អ្នកត្រូវនាំយកផ្លែឈើដែលល្អបំផុតពីស្រែចម្ការរបស់អ្នកមកដំណាក់របស់យើង។ អ្នកមិនត្រូវស្ងោរពពែឈ្មោលនៅក្នុងទឹកដោះម្តាយរបស់វាឡើយ»។
[27]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេថា៖ «ចូរសរសេរព្រះបន្ទូលទាំងនេះ ដ្បិត យើងបានសន្យានឹងខ្លួនយើងចំពោះពាក្យដែលយើងបាននិយាយទាំងនេះ
ហើយបានចងសម្ពន្ធមេត្រីជាមួយអ្នក និងអ៊ីស្រាអែល»។[28]លោកម៉ូសេបាននៅទីនោះ ជាមួយនឹងព្រះអម្ចាស់អស់រយៈពេលសែសិបយប់ សែសិបថ្ងៃ គាត់មិនបានហូប
ឬផឹកទឹកអ្វីឡើយ។ គាត់បានកត់ត្រាលើបន្ទះថ្ម ជាពាក្យនៃសម្ពន្ធមេត្រី គឺជាបញ្ញត្តដប់ប្រការ។
[29]នៅពេលលោកម៉ូសេចុះពីភ្នំស៊ីណាយមកវិញ ទាំងមានបន្ទះថ្មនៃសម្ពន្ធមេត្រីនៅនឹងដៃរបស់គាត់ គាត់មិនបានដឹងថាស្បែកមុខរបស់គាត់មានពន្លឺរស្មី
ពេលគាត់និយាយជាមួយនឹងព្រះជាម្ចាស់។[30]នៅពេលលោកអ៊ើរ៉ុន និងជនជាតិអ៊ីស្រាអែលឃើញលោកម៉ូសេ ឃើញស្បែកមុខរបស់គាត់មានពន្លឺរស្មី
ហើយពួកគេមានការភ័យខ្លាចក្នុងការចូលមកជិតគាត់។[31]ប៉ុន្តែ លោកម៉ូសេបានហៅពួកគេ ហើយលោកអ៊ើរ៉ុន និងអ្នកដឹកនាំទាំងអស់នៅក្នុងសហគមន៍ចូលមករកគាត់។
បន្ទាប់មក លោកម៉ូសេបានមានប្រសាសន៍ជាមួយពួកគេ។

generated on Wed Sep 10 16:16:32 2025

[32]បន្ទាប់ពីនេះ ប្រជាជាតិអ៊ីស្រាអែលទាំងអស់បានឡើងមករកលោកម៉ូសេ
ហើយលោកបានប្រាប់ដល់ពួកគេនូវសេចក្ដីបង្គាប់ទាំងអស់ដែលព្រះអម្ចាស់បានប្រទានដល់គាត់នៅលើភ្នំស៊ីណាយ។
[33]នៅពេលលោកម៉ូសេមានប្រសាសន៍ជាមួយពួកគេរួចហើយ លោកបានគ្របស្បៃលើមុខគាត់វិញ។
[34]នៅពេលណាលោកម៉ូសេចូលទៅគាល់ព្រះអម្ចាស់ ដើម្បីទូលព្រះអង្គ គាត់បានយកស្បៃចេញ រហូតគាត់ត្រឡប់មកវិញ។ នៅពេលគាត់ត្រឡប់មកវិញ
គាត់បានប្រាប់ជនជាតិអ៊ីស្រាអែល នូវអ្វីដែលព្រះអង្គបានបង្គាប់ឲ្យគាត់និយាយ។[35]នៅពេលជនជាតិអ៊ីស្រាអែលឃើញពន្លឺរស្មីនៅលើមុខរបស់លោកម៉ូសេ
គាត់បានបាំងស្បៃនៅលើមុខរបស់គាត់សារជាថ្មី រហូតទាល់តែគាត់ត្រឡប់ទៅគាល់ព្រះអម្ចាស់វិញ។

Exodus 34:1

បន្ទះថ្ម

«បន្ទះថ្មរាបស្មើ»។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅក្នុង ៣១:១៨

Exodus 34:3

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។

មិនត្រូវអនុញ្ញាតឲ្យអ្នកផ្សេងទៀតឃើញកន្លែងណាមួយនៅលើភ្នំឡើយ។

ត្រូវបានគេមើលឃើញថាកំពុងធ្វើអ្វីមួយតំណាងឱ្យការធ្វើដូច្នោះ។
ការបកប្រែផ្សេងទៀត
«កុំអនុញ្ញាតឲ្យអ្នកផ្សេងទៀតឃើញកន្លែងណាមួយនៅលើភ្នំឡើយ។ »

មិនត្រូវឲ្យមានហ្វូងចៀម ឬហ្វូងសត្វមកស៊ីស្មៅនៅខាងមុខភ្នំឡើយ។

សូម្បីតែសត្វចៀម
ឬហ្វូងសត្វក៏មិនត្រូវបានអនុញ្ញាតឱ្យមកក្បែរភ្នំដើម្បីស៊ីស្មៅដែរ។

Exodus 34:5

គង់នៅជិតលោកម៉ូសេនៅទីនោះ

«បានឈរជាមួយលោកម៉ូសេនៅលើភ្នំ»

ព្រះអង្គបានប្រកាសព្រះនាម «ព្រះអម្ចាស់»

ទី១អត្ថន័យដែលប្រហែលគឺ) « ព្រះអង្គបានមានបន្ទូលព្រះនាមគឺ « ព្រះអម្ចាស់» ឬ ទី២) « ព្រះអង្គបានប្រកាសថា នរណាជាព្រះអម្ចាស់» ។ សម្រាប់អត្ថន័យទីពីរ «ព្រះនាម» នឹងតំណាងឱ្យព្រះជាម្ចាស់ជានរណា។

ព្រះអម្ចាស់ ព្រះអម្ចាស់ ព្រះជាម្ចាស់ដែលប្រកបដោយសេចក្តីមេត្តា និងព្រះគុណ

ព្រះជាម្ចាស់កំពុងមានបន្ទូលអំពីអង្គទ្រង់ផ្ទាល់។ការបកប្រែផ្សេងទៀត
«យើងជាព្រះអម្ចាស់គឺជាព្រះម្ចាស់ ហើយយើងគឺប្រកបដោយសេចក្តីមេត្តា និងព្រះគុណ »

ហើយមានព្រះទ័យស្មោះត្រង់ និងសប្បុរសជានិច្ចនៅក្នុងសម្ពន្ធមេត្រីរបស់ព្រះអង្គ

«បង្ហាញភាពស្មោះត្រង់ក្នុងសម្ពន្ធមេត្រី និងភាពគួរឲ្យជឿទុកចិត្តបាន»

មានព្រះទ័យស្មោះត្រង់នៅក្នុងសម្ពន្ធមេត្រីរបស់ព្រះអង្គ

«ស្មោះត្រង់ជានិច្ចនៅក្នុងសម្ពន្ធមេត្រីរបស់យើង»។

សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ២០: ៤ ។

នៅក្នុង ... មានព្រះទ័យស្មោះត្រង់

«គួរអោយជឿទុកចិត្តបានជានិច្ច»

ប៉ុន្តែព្រះអង្គ

ព្រះអម្ចាស់កំពុងមានបន្ទូលអំពីអង្គទ្រង់ផ្ទាល់។ ការបកប្រែផ្សេងទៀត
«តែយើងនឹង»

ព្រះអង្គមិនមែនមិនរាប់មនុស្សមានកំហុស ថាគ្មានកំហុសឡើយ។

ព្រះអម្ចាស់កំពុងតែមានបន្ទូលអំពីអង្គទ្រង់ផ្ទាល់។ ការបកប្រែផ្សេងទៀត
«យើងនឹងមិនមែនមិនរាប់មនុស្សមានកំហុស ថាគ្មានកំហុសឡើយ។ »

មិនមែនមិនរាប់មនុស្សមានកំហុស ថាគ្មានកំហុសឡើយ។

ប្រាកដជានឹងមិនលុបឈ្មោះអ្នកមានទោសទេ៎ក៏ពិតជានឹងមិននិយាយថាអ្នកមានកំហុសគ្មានទោសនោះទេ។

ព្រះអង្គនឹងនាំការដាក់ទោសសម្រាប់បាបរបស់ឪពុកទៅលើកូន និងចៅរបស់គេផង

ការដាក់ទោសមនុស្សត្រូវបានគេនិយាយដូចជាការដាក់ទោសគឺជាវត្ថុមួយដែលមនុស្សអាចមើលឃើញ

ការបកប្រែផ្សេងទៀត « ព្រះអង្គនឹងដាក់កូនៗសម្រាប់អំពើបាបឪពុករបស់ពួកគេ»

ចៅរបស់គេផង

ពាក្យថា «ចៅ» តំណាងឱ្យកូនចៅ។ ការបកប្រែផ្សេងទៀត «កូនចៅរបស់ពួកគេ»

Exodus 34:8

ប្រសិនបើ ទូលបង្គំបានប្រកដដោយព្រះគុណនៅចំពោះព្រះអម្ចាស់មែន

ការផ្តាប់ចិត្តមនុស្សណាម្នាក់ត្រូវបានគេនិយាយថាជាការពេញចិត្តចំពោះពួកគេ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ៣៣:១២ ។ ការបកប្រែផ្សេងទៀត
«ឥឡូវនេះប្រសិនបើព្រះអង្គគាប់ព្រះទ័យនឹងទូលបង្គំ» ឬ
«ឥឡូវនេះប្រសិនបើព្រះអង្គយល់ព្រមនឹងទូលបង្គំ»

ទោសកំហុស និងបាបរបស់យើងខ្ញុំ

ពាក្យ «អំពើទុច្ចរិត» និង «បាប»

មានន័យថាជារួមដូចគ្នាហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការបញ្ជាក់។

ការបកប្រែផ្សេងទៀត «អំពើបាបរបស់យើងទាំងអស់»

សូមទទួលយើងខ្ញុំជាមរតករបស់ព្រះអង្គផង។

អ្វីមួយដែលមនុស្សណាម្នាក់គ្រប់គ្រងជារៀងរហូតត្រូវបានគេនិយាយដូចវាជារបស់អ្វីដែលពួកគេបានទទួ

ការបកប្រែផ្សេងទៀត
«យកយើងខ្ញុំធ្វើជាមនុស្សដែលព្រះអង្គគ្រប់គ្រងជារៀងរហូត» ឬ
«ទទួលយកយើងខ្ញុំជាមនុស្សដែលជាកម្មសិទ្ធិរបស់ព្រះអង្គជារៀងរហូត»

Exodus 34:10

ប្រជាជនរបស់អ្នកទាំងអស់

នៅទីនេះ «របស់អ្នក»សំដៅទៅលើលោកម៉ូសេ។

វាគឺជាការដែលគួរឲ្យខ្លាច ដែលយើងនឹងធ្វើជាមួយអ្នក។

អ្វីដែលគួរឱ្យខ្លាចគឺជារឿងដែលធ្វើឱ្យមនុស្សភ័យខ្លាច។

ក្នុងករណីនេះមនុស្សនឹងកោតខ្លាចព្រះជាម្ចាស់នៅពេលពួកគេឃើញអ្វីដែលព្រះងង្គធ្វើ។
ការបកប្រែផ្សេងទៀត
«អ្វីដែលយើងធ្វើដើម្បីអ្នកនឹងបណ្តាលឱ្យមនុស្សភ័យខ្លាចយើង»

យើងនឹងធ្វើជាមួយអ្នក។

នៅទីនេះ « អ្នក» សំដៅទៅលើលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល។

Exodus 34:12

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តនិយាយទៅកាន់លោកម៉ូសេ។

នៅទីនេះព្រះអង្គប្រាប់គាត់នូវអ្វីដែលលោកម៉ូសេ និងប្រជាជនត្រូវធ្វើ។

ពួកគេនឹងក្លាយជាអន្ទាក់សម្រាប់អ្នក។

មនុស្សដែលល្បួងអ្នកដទៃឱ្យប្រព្រឹត្តអំពើបាបត្រូវបានគេនិយាយដូចពួកគេជាអន្ទាក់។

ការបកប្រែផ្សេងទៀត « ពួកគេនឹងល្បួងអ្នកអោយធ្វើបាប»

ជានាមដែលប្រចណ្ឌ

ពាក្យ «នាម» នៅទីនេះតំណាងឱ្យលក្ខណៈរបស់ព្រះជាម្ចាស់។

ការបកប្រែផ្សេងទៀត «យើងជាព្រះអម្ចាស់ដែលតែងតែប្រចណ្ឌ» ឬ
«យើងជាព្រះអម្ចាស់ប្រចណ្ឌជានិច្ច»

ជានាមដែលប្រចណ្ឌ ព្រះអង្គជាព្រះជាម្ចាស់ដែលប្រចណ្ឌ។

ពាក្យថា « ប្រចណ្ឌ »

ត្រង់នេះមានន័យថាព្រះជាម្ចាស់យកចិត្តទុកដាក់រក្សាកិត្តិយសរបស់ព្រះអង្គ។

ប្រសិនបើប្រជាជនរបស់ទ្រង់ថ្វាយបង្គំព្រះដទៃគាត់បាត់បង់កិត្តិយស

ពីព្រោះនៅពេលដែលប្រជាជនរបស់ព្រះអង្គមិនគោរពព្រះអង្គមនុស្សផ្សេងទៀតក៏នឹងមិនគោរពពញព្រះអ

ការបកប្រែផ្សេងទៀត «យើងជាព្រះអម្ចាស់ថែរក្សាកិត្តិយសរបស់យើងជានិច្ច»

Exodus 34:15

ឃ្លាភ្ជាប់

[illegible]

ដ្បិត ពួកគេបានធ្វើតក្បត់ចំពោះព្រះរបស់ពួកគេ

ព្រះជាម្ចាស់មានបន្ទូលអំពីមនុស្សដែលថ្វាយបង្គំព្រះដទៃទៀតដូចជាពួកគេជាស្រីពេស្យាចំពោះបុរសផ្សេង

ដ្បិតពួកគេថ្វាយបង្គំព្រះដទៃដូចជាស្រីពេស្យាដែលទៅមនុស្សប្រុសផ្សេងទៀត»

អ្នកបានហូបយញ្ញបូជារបស់ពួកគេ

លទ្ធផលនៃការហូបអាហារដែលបានថ្វាយដល់ព្រះដទៃផ្សេងទៀតអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «
អ្នកនឹងបរិភោគយញ្ញបូជារបស់គាត់ហើយអ្នកមានកំហុសក្នុងការថ្វាយបង្គំព្រះរបស់គាត់»
ឬ «
អ្នកនឹងធ្វើពេស្យាចារខ្លួនឯងចំពោះព្រះរបស់ពួកគេតាមរយៈបរិភោគយញ្ញបូជារបស់ពួកគេ»

Exodus 34:18

ព័ត៌មានទូទៅ

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលប្រជាជនត្រូវធ្វើ។
ប្រាំពីរថ្ងៃ
«៧ថ្ងៃ»
នៅក្នុងពេលកំណត់នៃខែអាប៊ីប
នេះគឺជាឈ្មោះខែដំបូងនៃប្រតិទិនហេព្រើរ។
អាប៊ីបគឺស្ថិតនៅពេលចុងក្រោយនៃខែមីនានិងដើមខែមេសាតាមប្រតិទិនលោកខាងលិច។
សូមមើលការបកប្រែអក្សរ «អាប៊ីប» ក្នុង ១៣: ៣ ។
Exodus 34:19
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលប្រជាជនត្រូវធ្វើ។
ទិញកូនដំបូងត្រឡប់មកវិញ
កូនច្បងនិងសត្វលាដំបូងជាកម្មសិទ្ធិរបស់ព្រះអម្ចាស់
តែព្រះអម្ចាស់មិនចង់អោយពួកគេថ្វាយយញ្ញបូជាឡើយ។
ផ្ទុយទៅវិញជនជាតិអ៊ីស្រាអែលត្រូវបូជាកូនចៀមជំនួសពួកគេ។
នេះបានអនុញ្ញាតអោយជនជាតិអ៊ីស្រាអែលទិញលា
និងកូនប្រុសត្រឡប់មកវិញពីព្រះអម្ចាស់។
គ្មាននរណាដែលមកចំពោះយើងដោយដៃទទេឡើយ។
ប្រគល់ -
ព្រះជាម្ចាស់មានបន្ទូលអំពីការថ្វាយនេះដូចជាមនុស្សនោះត្រូវយួររវាទៅក្នុងដៃរបស់គេ។
ការបកប្រែផ្សេងទៀត
«គ្មានមនុស្សណាម្នាក់អាចមករកយើងដោយគ្មានការថ្វាយតង្វាយ» ឬ
«អ្នកដែលមករកយើងត្រូវតែយកតង្វាយមកយើង»
Exodus 34:21
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលប្រជាជនត្រូវធ្វើ។
ទោះបីជាដល់រដូវភ្ជួរ ហើយក្នុងរដូវច្រូតក្តី
«សូម្បីតែពេលអ្នកកំពុងរៀបចំដី ឬប្រមូលផល»
ពិធីបុណ្យនៃការប្រមូលផល
ពិធីបុណ្យនេះត្រូវបានគេស្គាល់ផងដែរថាជាពិធីបុណ្យនៃជម្រក
ឬពិធីបុណ្យនៃស្លុង។ គំនិតនេះបានមកពីការអនុវត្តរបស់កសិករ
ដែលរស់នៅក្នុងស្លុង
ឬខ្ទមបណ្តោះអាសន្ននៅតាមវាលដើម្បីការពារដំណាំនៅពេលវាទុំ។ ពាក្យថា
«ការប្រមូលផល» មានន័យថាពេលពួកគេប្រមូលផលដំណាំរបស់ពួកគេ។
Exodus 34:23
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលប្រជាជនត្រូវធ្វើ។
Exodus 34:25
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលប្រជាជនត្រូវធ្វើ។
ឈាមនៃយញ្ញបូជា
ការពិតដែលថាឈាមគឺមកពីសត្វអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ឈាមរបស់សត្វដែលអ្នកថ្វាយយញ្ញបូជាដល់យើង»
ជាមួយនឹងមេណាមួយ
ជាការពិតដែលជាមួយមេណាមួយនៅក្នុងនំប៉័ងអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ជាមួយនំប៉័ងដែលមានមេនៅក្នុងវា»
Exodus 34:27
លោកម៉ូសេបាននៅទីនោះ
«ម៉ូសេនៅលើភ្នំ»
សែសិបថ្ងៃ
«40 ថ្ងៃ»
សែសិបយប់ សែសិបថ្ងៃ
«រយៈពេលសែសិបថ្ងៃ ទាំងយប់ទាំងថ្ងៃ»
គាត់បានកត់ត្រា
«ម៉ូសេបានសរសេរ»
Exodus 34:29
មានពន្លឺរស្មី
«បានចាប់ផ្តើមភ្លឺ»
ចូលមករកគាត់
«ចូរទៅជិតគាត់» ឬ «បានទៅរកគាត់» ។ ពួកគេមិនបានឡើងភ្នំទេ។
Exodus 34:32
នូវសេចក្តីបង្គាប់ទាំងអស់ដែលព្រះអម្ចាស់បានប្រទានដល់គាត់
ការប្រាប់សេចក្តីបង្គាប់ត្រូវបានគេនិយាយដូចជាការបង្គាប់គឺជាវត្ថុដែលអាចត្រូវបានផ្តល់ឱ្យ។
ការបកប្រែផ្សេងទៀត « ការបង្គាប់ទាំងអស់ដែលព្រះអម្ចាស់បានប្រាប់គាត់» ឬ «
អ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបង្គាប់ពួកគេ»
Exodus 34:34
គាត់បានយកស្បៃចេញ
«លោកម៉ូសេនឹងយកចេញ»
នូវអ្វីដែលព្រះអង្គបានបង្គាប់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ការបកប្រែផ្សេងទៀត «
នូវអ្វីដែលព្រះអម្ចាស់បានបញ្ជាគាត់»

---

35 [1]លោកម៉ូសេបានប្រមូលសហគមន៍របស់អ៊ីស្រាអែលទាំងមូល ហើយប្រាប់ដល់ពួកគេថា៖
«សេចក្តីទាំងនេះគឺជាអ្វីដែលព្រះអម្ចាស់បានបង្គាប់ឲ្យអ្នករាល់គ្នាប្រព្រឹត្តតាម។[2]អ្នករាល់គ្នាអាចធ្វើការក្នុងរយៈពេលប្រាំមួយថ្ងៃ ប៉ុន្តែ សម្រាប់អ្នករាល់គ្នា
ថ្ងៃទីប្រាំពីរត្រូវជាថ្ងៃបរិសុទ្ធ ជាថ្ងៃសប្ប័ទសម្រាប់ទាំងស្រុង ជាថ្ងៃបរិសុទ្ធថ្វាយព្រះអម្ចាស់។[3]អ្នកណាដែលធ្វើការនៅថ្ងៃនោះ ត្រូវសម្លាប់ចោល។
អ្នកមិនត្រូវបង្កាត់ភ្លើងនៅក្នុងផ្ទះណាមួយនៅថ្ងៃសប្ប័ទឡើយ»។
[4]លោកម៉ូសេបានមានប្រសាសន៍ទៅកាន់សហគមន៍របស់ជនជាតិអ៊ីស្រាអែលទាំងអស់ ពោលថា៖
នេះគឺជាអ្វីដែលព្រះអម្ចាស់បានបង្គាប់មក[5]ត្រូវថ្វាយតង្វាយដល់ព្រះអម្ចាស់ អ្នករាល់គ្នាត្រូវថ្វាយដោយស្ម័គ្រចិត្ត។ ចូរនាំតង្វាយមកថ្វាយព្រះអម្ចាស់ មានមាស ប្រាក់
លង្ហិន[6]ក្រណាត់ពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម ព្រមទាំងក្រណាត់ទេសឯកសុទ្ធ រោមពពែឈ្មោល[7]ស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម ស្បែកផ្សោត ឈើ
នាងនួន ប្រេងសម្រាប់ចង្កៀង[8]ប្រេងក្រអូបសម្រាប់ចាក់ប្រេងតាំង និងគ្រឿងក្រអូបសម្រាប់ដុត[9]ត្បូងមណីជោតិរស និងត្បូងផ្សេងៗទៀត សម្រាប់លំអអាវអេផូដ និង
ប្រដាប់ពាក់លើទ្រូង។
[10]បុរសគ្រប់រូបដែលមានជំនាញនៅក្នុងចំណោមអ្នក ត្រូវចូលមក ហើយត្រូវធ្វើតាមអ្វីៗដែលព្រះអម្ចាស់បានបង្គាប់[11]ព្រះពន្លាជាមួយនិងត្រសាល គឺត្រូវធ្វើគម្របរបស់វា
ហើយតម្លក់ ស៊ុម រនុក សសរ និងជើងទ្រូរបស់វា[12]រួមទាំងហឹប និងឈើសែងរបស់វាផង ទីសណ្ដោសប្រោស និងវាំងននសម្រាប់លាក់បាំងវាផង។
[13]ពួកគេត្រូវយកតុជាមួយ និងឈើស្នែង សម្ភាររបស់វាទាំងអស់ ហើយនិងនំប៉័ងសម្រាប់ដាក់តាំង[14]ជើងចង្កៀងសម្រាប់បំភ្លឺ ជាមួយនឹងគ្រឿងបរិក្ខាររបស់វា មានចង្កៀង
និងប្រេងសម្រាប់ចង្កៀង[15]កន្លែងថ្វាយគ្រឿងក្រអូប ជាមួយនិងឈើសែងរបស់វា ត្រូវចាក់ប្រេងតាំង និងគ្រឿងក្រអូប
រនាំងសម្រាប់ច្រកចូលព្រះពន្លា[16]កន្លែងថ្វាយយញ្ញបូជា ជាមួយនឹងប្រទាសលង្ហិន និងឈើសែង ព្រមទាំងគ្រឿងបរិក្ខារផ្សេងៗ និងអាងទឹកធំមួយ
ជាមួយនឹងជើងទ្រូរបស់វា។
[17]ពួកគេបានយករនាំងសម្រាប់បាំងទីលានជាមួយនឹងសសរ និងជើងទ្រ ហើយវាំងននសម្រាប់ច្រកចូលទីលាន[18]ចម្រឹងព្រះពន្លា សម្រាប់ព្រះពន្លា និងទីលាន
ជាមួយនឹងខ្សែចងរបស់ទាំងនោះដែរ។[19]ពួកគេបានយកសម្លៀកបំពាក់យ៉ាងស្អាត សម្រាប់បម្រើនៅក្នុងទីបរិសុទ្ធ សម្លៀកបំពាក់បរិសុទ្ធសម្រាប់អ៊ើរ៉ុន ជាបូជាចារ្យ
និងកូនប្រុសៗរបស់គាត់ សម្រាប់ពួកគេបម្រើក្នុងមុខងារជាបូជាចារ្យ»។
[20]បន្ទាប់មក កុលសម្ព័ន្ធរបស់អ៊ីស្រាអែលទាំងអស់បានចាកចេញពីវត្តមានរបស់លោកម៉ូសេទៅ។[21]មនុស្សគ្រប់គ្នាមានការរំជួលចិត្ត និងអស់អ្នកដែលព្រះវិញ្ញាណធ្វើការ
បានចូលមក ហើយបាននាំតង្វាយមកថ្វាយសម្រាប់ការសាងសង់ព្រះពន្លានេះ សម្ភារទាំងអស់សម្រាប់ប្រើការនៅក្នុងការសាងសង់ និងសម្រាប់ធ្វើសម្លៀកបំពាក់ផងដែរ។
[22]ពួកគេចូលមក ទាំងប្រុសទាំងស្រីនាំយកគ្រឿងអលង្ការ មានក្រវិល ចិញ្ចៀននិងគ្រឿងតុបតែង គ្រឿងអលង្ការដែលធ្វើពីមាសគ្រប់ប្រភេទ។
ពួកគេបាននាំតង្វាយមាសជាតង្វាយគ្រវីទាំងអស់ មកថ្វាយដល់ព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

[23]អស់អ្នកដែលមានក្រណាត់ពណ៌ខៀវ ពណ៌ស្វាយ ឬក្រណាត់ពណ៌ក្រហម ក្រណាត់ទេសឯកសុទ្ធ រោមពពែ ស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម ឬស្បែកផ្សោត
បានយករបស់ទាំងនោះមកថ្វាយដែរ។[24]អស់អ្នកដែលថ្វាយតង្វាយពីប្រាក់ ឬលង្ហិន បានយកវាមកធ្វើជាតង្វាយថ្វាយដល់ព្រះអម្ចាស់ដែរ
ហើយអស់អ្នកដែលមានឈើនាងនួន ដើម្បីធ្វើរបស់ផ្សេងៗ បានយកវាមកថ្វាយដែរ។
[25]ស្ត្រីគ្រប់រូបដែលជំនាញនៃការត្បាញដោយដៃរបស់នាង ហើយបាននាំអ្វីដែលនាងមានមកថ្វាយដែរ មានក្រណាត់ខៀវ ពណ៌ស្វាយ ឬពណ៌ក្រហម ឬក្រណាត់ទេសឯក
សុទ្ធ។[26]ស្ត្រីដែលមានការរំជួយចិត្តពួកគេ ពួកគេដែលមានជំនាញត្បាញរោមពពែពួកគេត្បាញ។
[27]ពួកអ្នកដឹកនាំបាននាំយកត្បូងមណីជោតិរស និងត្បូងឯទៀតៗ ដើម្បីលំអអាវអេផូដ និងប្រដាប់ពាក់លើទ្រូង[28]ពួកគេបានយកគ្រឿងក្រអូប និងប្រេងសម្រាប់ចង្កៀង
ប្រេងសម្រាប់ចាក់ប្រេងតាំង និងគ្រឿងក្រអូបផង។[29]ជនជាតិអ៊ីស្រាអែលបាននាំតង្វាយទាំងនោះដោយស្ម័គ្រពីចិត្តថ្វាយដល់ព្រះអម្ចាស់ បុរស
និងស្ត្រីទាំងអស់ដែលស្ម័គ្រចិត្តនាំយកសម្ភារសម្រាប់កិច្ចការទាំងអស់ដែលព្រះអម្ចាស់បានបង្គាប់តាមរយៈលោកម៉ូសេ ឲ្យធ្វើ។
[30]លោកម៉ូសេបានប្រាប់ដល់ជនជាតិអ៊ីស្រាអែលថា៖ «មើល៍ ព្រះអម្ចាស់បានហៅលោកបេតសាលាល កូនប្រុសរបស់លោកយូរី ត្រូវជាចៅរបស់លោកហ៊ើរ ដែលមកពី
កុលសម្ព័ន្ធយូដាចំឈ្មោះ[31]ព្រះអង្គចាក់បំពេញលោកបេតសាលា ជាមួយនឹងវិញ្ញាណរបស់ព្រះអង្គ ព្រះអង្គប្រទានគាត់មានប្រាជ្ញា ការយល់ដឹង និងចំណេះ[32]ចេះធ្វើ
កិច្ចការសប្បកម្មគ្រប់មុខ ដើម្បីធ្វើការសប្បកម្ម និងធ្វើពីមាស ពីប្រាក់ និងពីលង្ហិន[33]ព្រមទាំងកាត់ និងឆ្លាក់ថ្ម ព្រមទាំងកាត់ឈើ
ដើម្បីឲ្យគាត់ចេះធ្វើការងារសប្បកម្មគ្រប់មុខ។
[34]ព្រះអង្គបានដាក់វានៅក្នុងចិត្តរបស់គាត់ ដើម្បីបង្រៀន ទាំងគាត់និងលោកអូហូលីអាប់ កូនប្រុសរបស់លោកអហ៊ីសាម៉ាក មកពីកុលសម្ព័ន្ធដាន់។
[35]ព្រះអង្គបានបំពេញពួកគេឲ្យមានជំនាញ ក្នុងការធ្វើការគ្រប់មុខ ដើម្បីធ្វើការជាអ្នកសប្បកម្ម ដូចជាជាងចម្លាក់ អ្នករចនា អ្នកប៉ាក់ អ្នកត្បាញសំពត់ពណ៌ផ្ទៃមេឃ ពណ៌
ស្វាយ និងពណ៌ក្រហម និងក្រណាត់ទេសឯកសុទ្ធ។ ពួកគេប៉ិនប្រសប់ក្នុងការធ្វើការងារគ្រប់មុខ ហើយពួកគេចេះបង្កើតគម្រោងការផ្សេងៗផង»។

Exodus 35:1

ថ្ងៃទីប្រាំពីរ

«ថ្ងៃទី ៧» ឬ «ថ្ងៃសៅរ៍»

អ្នកណាដែលធ្វើការនៅថ្ងៃនោះ ត្រូវសម្លាប់ចោល។

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែសម្លាប់មនុស្សណាដែលធ្វើការនៅថ្ងៃនោះ»

Exodus 35:4

ព័ត៌មានទូទៅ

លោកម៉ូសេប្រាប់ជនជាតិអ៊ីស្រាអែលអោយធ្វើអ្វីៗដែលព្រះអម្ចាស់បានបង្គាប់គាត់ក្នុង ២៥: ៣ ។

ត្រូវថ្វាយតង្វាយដល់ព្រះអម្ចាស់

«ប្រមូលតង្វាយសម្រាប់ព្រះអម្ចាស់»

អ្នករាល់គ្នាត្រូវថ្វាយដោយស្ម័គ្រចិត្ត។

នៅទីនេះ « ចិត្ត» សំដៅទៅលើអ្នកដែលថ្វាយតង្វាយ។ ការបកប្រែផ្សេងទៀត
«គ្រប់ៗគ្នាដែលមានឆន្ទៈ»

Exodus 35:10

ព័ត៌មានទូទៅ

លោកម៉ូសេបន្តប្រាប់ប្រជាជននូវអ្វីដែលព្រះបានបង្គាប់ពួកគេឲ្យធ្វើ។

បុរសគ្រប់រូបដែលមានជំនាញ

«បុរសគ្រប់រូបមានជំនាញ»

តម្ពក់

តម្ពក់សមនឹងកងដើម្បីទ្រវាំងននជាមួយគ្នា។

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះនៅក្នុង ២៦: ៤ ។

ជើងទ្រ

ទាំងនេះគឺជាដុំដែកធ្ងន់ដែលសល់នៅលើដីហើយរក្សាវត្ថុដែលនៅជាប់
នឹងពួកវាពីការផ្លាស់ទី។ សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង ២៥:៣១ ។

ទីសណ្ដោសប្រោស

នេះជាគម្របនៅពីលើហឹបដែលជាកន្លែងថ្វាយតង្វាយប្រោសលោះ។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង ២៥:១៥ ។

Exodus 35:13

ពួកគេត្រូវយក

«ប្រជាជនអ៊ីស្រាអែលនាំយកមក»

នំប៉័ងសម្រាប់ដាក់តាំង

នំប៉័ងនេះតំណាងឲ្យព្រះវត្តមានរបស់ព្រះជាម្ចាស់។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង ២៥:២៨ ។

ប្រទាសលង្ហិន

នេះគឺជាស៊ុមនៃរបាលង្ហិនដែលក្រវ៉ាត់ជុំវិញសម្រាប់អោបឈើនៅពេលឆេះភ្លើង។

សូមមើលពីរបៀបដែលបានបកប្រែពាក្យ «ដឹងគុណ» នៅក្នុង ២៧: ៣ ។

Exodus 35:17

រនាំង

ទាំងនេះគឺជាវាំងននធំធ្វើពីក្រណាត់។

សូមមើលពីរបៀបដែលបានបកប្រែរឿងនេះនៅក្នុង ២៦:៣៦

សសរ

ទាំងនេះគឺជាដុំឈើរឹងមាំដែលត្រូវបានដាក់បញ្ឈរហើយត្រូវបានប្រើជាជំនួយ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែអត្ថបទទាំងនេះនៅក្នុង ២៧: ៩ ។

ជើងទ្រ

ទាំងនេះគឺជាដុំប្រាក់ដែលមានរន្ធស៊កនៅក្នុងពួកវាដើម្បីរក្សាបន្ទះក្តារឲ្យនៅនឹងកន្លែង។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ២៦:១៩ ។

ចម្រឹងព្រះពន្លា

កំណាត់ឈើឬដែកមុតដែលត្រូវបានប្រើដើម្បីការពារជ្រុងនៃតង់ជាប់ដល់ដី។

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៧:១៧ ។

សម្លៀកបំពាក់យ៉ាងស្អាត

សម្លៀកបំពាក់ត្បាញ -

នេះជាសម្លៀកបំពាក់ធ្វើពីអំបោះតូចដែលមនុស្សណាម្នាក់វេញបញ្ចូលគ្នាដើម្បីធ្វើឱ្យខ្សែអំបោះកាន់តែរឹងម

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៨: ៦ ។

Exodus 35:20

កុលសម្ព័ន្ធរបស់អ៊ីស្រាអែលទាំងអស់

នេះសំដៅទៅលើប្រជាជននៅក្នុងកុលសម្ព័ន្ធ។ ការបកប្រែផ្សេងទៀត
«ប្រជាជនមកពីកុលសម្ព័ន្ធអ៊ីស្រាអែលទាំងអស់»

មានការរំជួលចិត្ត

នៅទីនេះ «ចិត្ត » សំដៅទៅលើមនុស្ស។ ចិត្ត
ដែលឆ្លើយតបចំពោះព្រះជាម្ចាស់ត្រូវបានគេនិយាយថាដូចជាទឹកដែលត្រូវបានកូរឡើងដោយខ្យល់ព្យុះ។
ការបកប្រែផ្សេងទៀត «អ្នកដែលបានឆ្លើយតបនឹងព្រះជាម្ចាស់»

អស់អ្នកដែលព្រះវិញ្ញាណ

នៅទីនេះ «ព្រះវិញ្ញាណ» សំដៅទៅលើមនុស្ស។ ការបកប្រែផ្សេងទៀត
«អ្នកណាដែលមានឆន្ទៈ» ឬ« អ្នកដែលចង់»

អស់អ្នកដែលស្ម័គ្រចិត្ត

នៅទីនេះ «ចិត្ត» សំដៅទៅលើមនុស្ស។ ការបកប្រែផ្សេងទៀត
«មនុស្សគ្រប់គ្នាដែលមានឆន្ទៈ»

គ្រឿងអលង្ការ មានក្រវិល ចិញ្ចៀននិងគ្រឿងតុបតែង គ្រឿងអលង្ការ

ទាំងនេះគឺជាគ្រឿងអលង្ការប្រភេទផ្សេងៗគ្នា។

Exodus 35:23

អស់អ្នកដែលមាន ... មកថ្វាយ

សម្រាប់ ៣៥:២៣

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥: ៣ ។

Exodus 35:25

ណាត់ខៀវ ពណ៌ស្វាយ ឬពណ៌ក្រហម

ទី១អត្ថន័យដែលប្រហែលគឺ) «សម្ភារៈដែលត្រូវបានគេលាបពណ៌ខៀវ ស្វាយ និង
ក្រហមទុំ» ប្រហែលជាធ្វើអំពីឡែនឬទី២) «ពណ៌ខៀវពណ៌ស្វាយនិងពណ៌ក្រហម»
ដើម្បីជ្រលក់ក្រណាត់។ សូមមើលពីរបៀបដែលបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង
២៥: ៣ ។

ដែលមានការរំជួយចិត្តពួកគេ

នៅទីនេះ «ចិត្ត» សំដៅទៅលើស្ត្រី។ ចិត្តរបស់ស្ត្រីដែលឆ្លើយតប
នឹងព្រះត្រូវបានគេនិយាយដូចជាពួកគេត្រូវបានទឹកកូរឡើងដោយខ្យល់ព្យុះ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «អ្នកដែលបានឆ្លើយតបនឹងព្រះជាម្ចាស់»
Exodus 35:27
ពួកអ្នកដឹកនាំបាននាំយក ... តាមរយៈលោកម៉ូសេ ឲ្យធ្វើ។
សម្រាប់ ៣៥: ២៧-២៩
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥: ១ និង ២៥: ៣ ។
ដោយស្ម័គ្រពីចិត្ត
នៅទីនេះ « ចិត្ត» សំដៅទៅលើប្រជាជន។ ការបកប្រែផ្សេងទៀត
«អ្នកណាដែលមានឆន្ទៈ»
Exodus 35:30
ព្រះអង្គចាក់បំពេញលោកបេតសាលាល ជាមួយនឹងវិញ្ញាណរបស់ព្រះអង្គ
វិញ្ញាណរបស់ព្រះជាម្ចាស់ដែលបានប្រទានសមត្ថភាព
ឱ្យលោកបេតសាលាលត្រូវបានគេនិយាយនៅទីនេះដូចជាព្រះអង្គជាអ្វីមួយដែលបានបំពេញគាត់
ការងារសិប្បកម្មគ្រប់មុខ។
សម្រាប់ ៣៥: ៣០-៣៣ សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះនៅក្នុង ៣១: ១ និង ៣១: ៣ ។
Exodus 35:34
ព័ត៌មានទូទៅ
ម៉ូសេបន្តមានបន្ទូលទៅកាន់ប្រជាជន។
ព្រះអង្គបានដាក់វានៅក្នុងចិត្តរបស់គាត់ ដើម្បីបង្រៀន
នៅទីនេះ « ចិត្ត» សំដៅទៅលើលោកបេតសាលាល ។ សមត្ថភាពក្នុងការបង្រៀន
ត្រូវបានគេនិយាយដូចវាជាអ្វីដែលអាចត្រូវបានដាក់នៅក្នុងចិត្ត។
ការបកប្រែផ្សេងទៀត
«ព្រះអង្គបានផ្តល់ឱ្យបេតសាលាលនូវសមត្ថភាពដើម្បីបង្រៀន»
បានបំពេញពួកគេឲ្យមានជំនាញ
ជំនាញក្នុងការបង្កើតវត្ថុស្រស់ស្អាតត្រូវបានគេនិយាយថា
វាជាអ្វីមួយដែលអាចបំពេញមនុស្សម្នាក់។ ការបកប្រែផ្សេងទៀត
«ធ្វើឱ្យពួកគេមានជំនាញគ្រប់បែបយ៉ាង»
លោកអូហូលីអាប់ កូនប្រុសរបស់លោកអហ៊ីសាម៉ាក មកពីកុលសម្ព័ន្ធដាន់។
«លោកអូហូលីអាប់» និង «លោកអហ៊ីសាម៉ាក » គឺជាឈ្មោះរបស់មនុស្សប្រុស។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ៦ ។
ជាងចម្លាក់
មនុស្សដែលកាត់សម្ភារៈរឹងបង្កើតជារូបរាង ដូចជា ឈើ ថ្ម ឬ ដែក
[illegible]
មនុស្សដែលដេរចនាម៉ូដនៅលើក្រណាត់
ធ្វើការងារគ្រប់មុខ
មនុស្សដែលមានជំនាញក្នុងការធ្វើឱ្យវត្ថុស្រស់ស្អាតដោយដៃ
អ្នកត្បាញ
មនុស្សដែលបង្កើតក្រណាត់ដោយប្រើអំបោះ
បង្កើតគម្រោងការ
មនុស្សដែលកែច្នៃលម្អជាមួយសម្ភារៈ

---

36 [1]លោកបេតសាលាល និងលោកអូហូលីអាប់ ព្រមទាំងបុរសទាំងអស់ដែលមានជំនាញ ដែលព្រះអម្ចាស់បានប្រទានជំនាញ
និងសមត្ថភាពឲ្យដឹងនិងស្គាល់របៀបនៃការធ្វើការនៅក្នុងការសាងសង់កន្លែងបរិសុទ្ធ គឺត្រូវធ្វើទៅតាមអ្វីៗដែលព្រះអម្ចាស់បានបង្គាប់»។
[2]លោកម៉ូសេបានកោះហៅលោកបេតសាលាល និងលោកអូហូលីអាប់ ព្រមទាំងបុរសទាំងអស់ដែលមានជំនាញនៅក្នុងគំនិតរបស់ពួកគេ
គឺព្រះអម្ចាស់បានប្រទានជំនាញដល់ពួកគេ ហើយបានធ្វើការនៅក្នុងចិត្តរបស់ពួកគេឲ្យចូលមក ហើយបំពេញកិច្ចការនេះ។
[3]ពួកគេបានទទួលតង្វាយគ្រប់យ៉ាងពីលោកម៉ូសេ ដែលជនជាតិអ៊ីស្រាអែលបាននាំមកសម្រាប់ការសាងសង់ទីបរិសុទ្ធ។
ប្រជាជនបាននាំយកតង្វាយស្ម័គ្រចិត្តរៀងរាល់ព្រឹកមកលោកម៉ូសេ។[4]ដូច្នេះ បុរសដែលមានជំនាញទាំងអស់បានធ្វើការនៅទីបរិសុទ្ធមកពីកិច្ចការដែលពួកគេធ្លាប់បានធ្វើ។
[5]ពួកអ្នកសិប្បករបានប្រាប់លោកម៉ូសេថា៖ «ប្រជាជនបាននាំរបស់របរច្រើនលើសពីសេចក្តីត្រូវទៅទៀត សម្រាប់ធ្វើកិច្ចការដែលព្រះអម្ចាស់បានបង្គាប់ឲ្យយើងធ្វើ»។[6]ដូច្នេះ
លោកម៉ូសេបានបង្គាប់ថា គ្មាននរណានៅក្នុងជំរំនាំយកតង្វាយមកថ្វាយដើម្បីសាងសង់ទីបរិសុទ្ធទៀតទេ។ ប្រជាជនឈប់យកអំណោយមកជូនទៀត។
[7]ពួកគេមានសម្ភារគ្រប់គ្រាន់សម្រាប់ការងារទាំងអស់ហើយ។
[8]ដូច្នេះ ពួកសិប្បករនៅក្នុងចំណោមពួកគេបានសាងសង់ព្រះពន្លា ជាមួយនឹងវាំងនន ដប់ធ្វើឡើងពីក្រណាត់ទេសឯកល្អ និងពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម
ជាមួយនឹងប៉ាក់រូបចេរូប៊ីន។ ការងារសិប្បកម្មនេះ គឺជាកិច្ចការរបស់លោកបេតសាលាល ជាមនុស្សដែលមានជំនាញជាសិប្បករ។
[9]ប្រវែងវាំងននទីមួយៗមានបណ្តោយម្ភៃប្រាំបីហត្ថ ទទឹងបួនហត្ថ។ វាំងននទាំងអស់មានទំហំស្មើគ្នា។[10]លោកបេសាលាលបានភ្ជាប់វាំងននជាមួយគ្នា
ហើយវាំងនន‌ប្រាំទៀតត្រូវតភ្ជាប់ជាមួយគ្នាដែរ។
[11]គាត់បានធ្វើកងខៀវតាមជាយវាំងនន នៅចុងផ្ទាំងវាំងននទីមួយ ហើយគាត់បានធ្វើដូចគ្នានៅតាមជាយវាំងនន នៅផ្ទាំងទីពីរដែរ។[12]គាត់បានធ្វើកងចំនួនហាសិប
នៅលើវាំងននទីមួយ និងកងហាសិបទៀតនៅចុងជាយវាំងននទីពីរដែរ។ ដូច្នេះ កងនីមួយៗនៅទន្ទឹមគ្នា។[13]គាត់បានធ្វើតម្លក់មាសចំនួនហាសិប
ហើយបានភ្ជាប់វាំងននទាំងនោះជាមួយគ្នា ដើម្បីភ្ជាប់ព្រះពន្លាជាមួយគ្នា។
[14]លោកបេតសាលាលធ្វើវាំងននពីរោមពពែសម្រាប់គ្របពីលើព្រះពន្លា កាត់បានធ្វើវាំងននទាំងនោះចំនួនដប់មួយ។[15]វាំងននទីមួយមានបណ្តោយប្រវែងសាមសិបហត្ថ
ហើយទទឹងមានប្រវែងបួនហត្ថ។ វាំងននទាំងដប់មួយនោះមានទំហំស្មើគ្នា។[16]គាត់បានភ្ជាប់វាំងន‌ប្រាំជាមួយវាំងន‌ប្រាំមួយទៀតជាមួយគ្នា។
[17]គាត់បានធ្វើកងនៅលើចុងវាំងននទីមួយៗនៃផ្ទាំងទីមួយ ហើយហាសិបកងទៀតនៅខាងនៃវាំងននដែលភ្ជាប់គ្នានៅផ្ទាំងទីពីរ។
[18]លោកបេតសាលាលបានធ្វើតម្លក់លង្ហិន ដើម្បីភ្ជាប់ត្រសាលជាមួយគ្នា ដើម្បីឲ្យវាបានក្លាយជាគ្នាតែមួយផ្ទាំង។[19]គាត់ធ្វើដំបូលសម្រាប់គ្របព្រះពន្លា ពីស្បែកចៀមឈ្មោល
ជ្រលក់ពណ៌ក្រហម និងដំបូលផ្សេងទៀតពីស្បែកយ៉ាងល្អ ដើម្បីគ្របពីលើវា។
[20]លោកបេតសាលាលបានធ្វើស៊ុមបញ្ឈរពីឈើនាងនួនសម្រាប់ព្រះពន្លា។[21]បណ្តោយស៊ុមនីមួយៗមានប្រវែងដប់ហត្ថ ហើយទទឹងស៊ុមនីមួយៗមានប្រវែងមួយហត្ថកន្លះ។
[22]ស៊ុមនីមួយៗពន្លូញពីរសម្រាប់ភ្ជាប់ស៊ុមជាមួយគ្នា។ គាត់បានធ្វើការនេះ សម្រាប់ស៊ុមព្រះពន្លាទាំងអស់។[23]គាត់បានធ្វើស៊ុមសម្រាប់ព្រះពន្លាយ៉ាងដូច្នេះគឺ
មានស៊ុមម្ភៃសម្រាប់ផ្នែកខាងត្បូង។
[24]លោកបេតសេលាលបានធ្វើជើងទ្រពីប្រាក់ចំនួនសែសិប ដើម្បីទ្រស៊ុមទាំងម្ភៃ។ មានជើងទ្រពីរនៅក្រោមស៊ុមនីមួយៗ ដើម្បីភ្ជាប់ស៊ុមជាមួយគ្នា
ហើយជើងទ្រពីរទៀតសម្រាប់ស៊ុមផ្សេងៗទៀត ដើម្បីភ្ជាប់ស៊ុមជាមួយគ្នា។[25]ដ្បិត នៅផ្នែកទីពីររបស់ព្រះពន្លា គឺនៅផ្នែកខាងជើង គាត់បានធ្វើស៊ុមម្ភៃដែរ
ហើយមានជើងទ្រស៊ុមនោះចំនួនសែសិបធ្វើពីប្រាក់។[26]មានជើងទ្រពីរនៅក្រោមស៊ុមទីមួយ ជើងទ្រពីរនៅក្រោមស៊ុមបន្ទាប់ និងស៊ុមជាបន្តបន្ទាប់ទៀត។
[27]នៅផ្នែកខាងក្រោយព្រះពន្លាគឺប៉ែកខាងលិច លោកបេតសេលាលបានធ្វើស៊ុមប្រាំមួយ។[28]គាត់បានធ្វើស៊ុមពីសម្រាប់ជ្រុងខាងក្រៅរបស់ព្រះពន្លា។
[29]ស៊ុមទាំងនេះ បែកចេញពីគ្នានៅប៉ែកខាងក្រោម ប៉ុន្តែ ជាប់គ្នានៅប៉ែកខាងលើដោយសាកងមួយ។ គាត់បានធ្វើបែបនេះសម្រាប់ជ្រុងទាំងពីរ។[30]មានស៊ុមចំនួនប្រាប់បី
រួមជាមួយជើងទ្រប្រាក់ផង។ មានជើងត្រទាំងអស់ដប់ប្រាំមួយ រួមទាំងជើងទ្រប្រាក់ផងដែរ។ មានជើងទ្រពីរនៅក្រោមស៊ុមនីមួយៗ ជើងទ្រពីរនៅក្រោមស៊ុមបន្ទាប់
និងបន្តបន្ទាប់ទៀត។
[31]លោកបេតសាលាលបានធ្វើរនុកពីឈើនាងនួន ប្រាំសម្រាប់ស៊ុមនៅមួយផ្នែកនៃព្រះពន្លា[32]រនុកប្រាំទៀត សម្រាប់ស៊ុមនៃផ្នែកមួយទៀតរបស់ព្រះពន្លា
ហើយរនុកប្រាំសម្រាប់ស៊ុម ដែលនៅប៉ែកខាកក្រោយនៃព្រះពន្លា គឺភាគខាងលិច។[33]គាត់បានធ្វើរនុកនៅចំកណ្តាលស៊ុម ដែលពាក់កណ្តាលឡើងឈើ
គឺចាប់ពីចុងម្ខាងទៅចុងម្ខាងទៀត។ គាត់បានស្រោបស៊ុមនៅជាមួយនឹងមាស។[34]គាត់បានធ្វើកងពីមាសដែរ គឺសម្រាប់ស៊ីករនុក
ហើយគាត់បានស្រោបរនុកនោះជាមួយនឹងមាសដែរ។

generated on Wed Sep 10 16:16:32 2025

[35]លោកបេតសាលាលបានធ្វើវាំងននពីក្រណាត់ពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម ព្រមទាំងជាមួយនឹងក្រណាត់ទាសឯកយ៉ាងស្អាត ដោយមានរចនារូបចេរូប៊ីមផង
កិច្ចការទាំងនេះ ធ្វើឡើងពីជាងដែលមានស្នាដៃល្អ។[36]គាត់បានធ្វើរនាំង ដែលមានសសរបួនពីឈើនាងនួន ហើយគាត់បានស្រោមសសរទាំងនោះជាមួយនឹងមាស។
គាត់បានធ្វើតម្ពក់សម្រាប់សសរ ហើយគាត់បានធ្វើជើងទ្របួនពីប្រាក់ដែរ។
[37]គាត់បានធ្វើរនាំងសម្រាប់ច្រកចូលត្រសាល។ ដែលមានពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម ដោយប្រើក្រណាត់ទាសឯកយ៉ាងល្អ ព្រមទាំងប៉ាក់ផងដែរ។
[38]គាត់បានធ្វើរនាំងសសរប្រាំ ជាមួយនឹងតម្ពក់។ គាត់បានស្រោបនៅលើក្បាលរបស់វា និងគន្លឹះពីមាស។ ជើងទ្រទាំងប្រាំរបស់វាធ្វើពីលង្ហិន។

Exodus 36:1

ព័ត៌មានទូទៅ

លោកម៉ូសេបន្តមានបន្ទូលទៅកាន់ប្រជាជន។

លោកបេតសាលាល

នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។

លោកអូហ៊ីលីអាប់

នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ៦ ។

ដែលព្រះអម្ចាស់បានប្រទានជំនាញ និងសមត្ថភាព

នៅទីនេះជំនាញនិងសមត្ថភាពត្រូវបានគេនិយាយដូចជាពួកវាជាអ្វីម៉្យាងដែលព្រះអម្ចាស់បានដាក់ក្នុងមនុស្ស។ សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦: ៧ និង ២៦:១០ ។

ទៅតាមអ្វីៗដែលព្រះអម្ចាស់បានបង្គាប់។

«ដូចព្រះអម្ចាស់បានបង្គាប់មក»

Exodus 36:2

លោកបេតសាលាល

នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។

លោកអូហ៊ីលីអាប់

នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ៦ ។

នៅក្នុងគំនិតរបស់ពួកគេ គឺព្រះអម្ចាស់បានប្រទានជំនាញដល់ពួកគេ

នៅទីនេះ « គំនិត» សំដៅទៅលើមនុស្សដែលមានជំនាញដោយព្រះអម្ចាស់។

ការបកប្រែផ្សេងទៀត «អ្នកដែលព្រះអម្ចាស់បានប្រទានជំនាញ»

ហើយបានធ្វើការនៅក្នុងចិត្តរបស់ពួកគេឲ្យចូលមក

នៅទីនេះ «ចិត្ត» សំដៅទៅលើមនុស្ស។

ចិត្តដែលឆ្លើយតបចំពោះព្រះជាម្ចាស់ត្រូវបានគេនិយាយថាដូចជាទឹកដែលត្រូវបានកូរឡើងវិញ។ សូមមើលរបៀបដែលបានបកប្រែពាក្យទាំងនេះនៅក្នុង ៣៥:២១

ការបកប្រែផ្សេងទៀត «អ្នកដែលបានឆ្លើយតប នឹងព្រះជាម្ចាស់»

Exodus 36:5

ពួកអ្នកសិប្បករបានប្រាប់លោកម៉ូសេ ... បានបង្គាប់ឲ្យយើងធ្វើ

សៀវភៅនេះអាចត្រូវបានបញ្ជាក់ជាការដកស្រង់ដោយប្រយោល។

ការបកប្រែផ្សេងទៀត « សិប្បករបានប្រាប់លោកម៉ូសេថា

ប្រជាជនបាននាំច្រើនជាងអ្វីដែលព្រះអម្ចាស់បានបញ្ជា ឲ្យ ពួកគេធ្វើ»

ពួកអ្នកសិប្បករបានប្រាប់លោកម៉ូសេ

«ពួកអ្នកដែលធ្វើការនៅទីសក្ការៈបានប្រាប់លោកម៉ូសេថា»

Exodus 36:8

ដូច្នេះ ពួកសិប្បករ ... តភ្ជាប់ជាមួយគ្នាដែរ។

សម្រាប់ ៣៨: ៨-១០

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦: ១ ។

ជាមួយនឹងវាំងនន ដប់ធ្វើឡើងពីក្រណាត់ទេសឯកល្អ

វាំងននទាំងនេះគឺជាក្រណាត់ត្បាញ

និងដេរភ្ជាប់គ្នាដូច្នេះវាអាចព្យួរដើម្បីបង្កើតជាជញ្ជាំង ឬតង់។

លោកបេតសាលាល

នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។

Exodus 36:11

គាត់បានធ្វើកង ... ដើម្បីភ្ជាប់ព្រះពន្លាជាមួយគ្នា។

សម្រាប់ ៣៦: ១១-១៣

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦: ៤ ។

កងខៀវ

កងនៃក្រណាត់ពណ៌ខៀវ

វាំងនន

ទាំងនេះជាផ្នែកធំៗនៃត្បាញដែលត្រូវបានប្រើ
ដើម្បីបង្កើតជាគម្របនិងចែកជញ្ជាំងនៃព្រះពន្លា។

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៦: ១ ។

គាត់បានធ្វើ

ទាំងនេះជាផ្នែកធំ ៗ នៃត្បាញដែលត្រូវបានប្រើដើម្បីបង្កើតជាគម្រប
និងចែកជញ្ជាំងនៃត្រសាល។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៦: ១ ។

តម្ពក់មាសចំនួនហាសិប

«តម្ពក់មាសចំនួន ៥០»

Exodus 36:14

លោកបេតសាលាលធ្វើវាំនន ... ផ្ទាំងទីពីរ។

សម្រាប់ ៣៦: ១៤-១៧

សូមមើលពីរបៀបដែលបានបកប្រែ[illegible]ក្នុង ២៦: ៧ និង ២៦:១០ ។

ធ្វើវាំងននទាំងនោះចំនួនដប់មួយ។

«បានធ្វើ ១១»

ប្រវែងសាមសិបហត្ថ

«៣០ ហត្ថ» (សូមមើល និងtranslate-bdistance)

ហាសិបកង

«កងចំនួន ៥០»

Exodus 36:18

លោកបេតសាលាលបានធ្វើ... ដើម្បីគ្របពីលើវា។

សម្រាប់ ៣៦: ១៨-១៩

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:១០ និង ២៦:១២ ។

បានធ្វើតម្ពក់លង្ហិនចំនួន ៥០

«តម្ពក់លង្ហិនចំនួន ៥០»

Exodus 36:20

លោកបេតសាលាលបានធ្វើ ...សម្រាប់ផ្នែកខាងត្បូង។

សម្រាប់ ៣៦: ២០-២៣

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:១៥ ។

ដប់ហត្ថ ... មួយហត្ថកន្លះ។

«១០ ហត្ថ ... ១,៥ ហត្ថ»

ពីរសម្រាប់ភ្ជាប់ស៊ុមជាមួយគ្នា។

ស៊ុមគឺជាបន្ទះឈើតូចដែលនៅជាប់នឹងចុងក្តារដូច្នេះវាអាចធានាបាន។

Exodus 36:24

លោកបេតសេលាលបានធ្វើ ... និងស៊ុមជាបន្តបន្ទាប់ទៀត។

សម្រាប់ ៣៦: ២៤-២៦

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:១៩ ។

មានជើងទ្រស៊ុមនោះចំនួនសែសិបធ្វើពីប្រាក់។

«ជើងទ្រស៊ុមធ្វើពីប្រាក់ ៤០»

ស៊ុមម្ខែ

«ស៊ុម២០»

ជាបន្តបន្ទាប់ទៀត។

នឹងមានជើងពីរនៅខាងក្រោមស៊ុមនីមួយៗ។

Exodus 36:27

នៅផ្នែកខាងក្រោយ ... ជ្រុងខាងក្រៅរបស់ព្រះពន្លា។

សម្រាប់ ៣៦: ២៧-២៨

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:២២ ។

ប៉ែកខាងលិច

នៅចំហៀងដែលនៅប៉ែកខាងលិច

សម្រាប់ជ្រុង

សម្រាប់ជ្រុងខាងផ្នែកក្រោយព្រះពន្លា

Exodus 36:29

generated on Wed Sep 10 16:16:32 2025

ស៊ុមទាំងនេះ ...និងបន្តបន្ទាប់ទៀត។
សម្រាប់ ៣៦: ២៩-៣០
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:២២ ។
មានជើងទ្រទាំងអស់ដប់ប្រាំមួយ
«១៦ ជើងទ្រនៅក្នុងទាំងអស់»
និងបន្តបន្ទាប់ទៀត។
នឹងមានជើងទ្រពីរនៅខាងក្រោមស៊ុមនីមួយៗ។
Exodus 36:31
លោកបេតសាលាលបាន ... ជាមួយនឹងមាសដែរ។
សម្រាប់ ៣៦: ៣១-៣៤
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:២៦ និង ២៦:២៩ ។
គឺភាគខាងលិច។
នៅចំហៀងផ្នែកខាងលិច
គឺចាប់ពីចុងម្ខាងទៅចុងម្ខាងទៀត។
ពីម្ខាងនៃព្រះពន្លាទៅម្ខាងផ្សេងទៀត
Exodus 36:35
លោកបេតសាលាលបានធ្វើ ... ជើងទ្របួនពីប្រាក់ដែរ។
សម្រាប់ ៣៦: ៣៥-៣៦
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:៣១ ។
Exodus 36:37
គាត់បានធ្វើ ... ធ្វើពីលង្ហិន។
សម្រាប់ ៣៦: ៣៧-៣៨
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៦:៣៦ ។
គាត់បានធ្វើ
នៅទីនេះ «គាត់» សំដៅទៅលើលោកបេតសាលាល និងអ្នកដែលធ្វើការឱ្យគាត់។ «បេតសាលាល និងមនុស្សរបស់គាត់បានបង្កើត»
រនាំង
វាំងនន

---

37 [1]លោកបេតសាលាលធ្វើហិបពីឈើនាងនួន ដែលមានបណ្តោយពីហត្ថកន្លះ និងទទឹងមួយហត្ថកន្លះ ព្រមទាំងកម្ពស់មួយហត្ថកន្លះដែរ។
[2]គាត់បានស្រោបវាដោយមាសសុទ្ធទាំងខាងក្រៅ និងខាងក្នុង ហើយក៏ធ្វើគែមមាសជុំវិញដែរ។[3]គាត់បានសិតធ្វើកងមាសសម្រាប់ជើងវាទាំងបួន
ជាមួយនឹងកងម្ខាងពីរ ហើយកងម្ខាងទៀតពីរទៀតដែរ។
[4]គាត់បានធ្វើឈើស្នែងពីឈើនាងនួន ហើយស្រោបវាជាមួយនឹងមាស។[5]គាត់ដាក់ឈើស្នែងទៅក្នុងកងនៅចំហៀងហិតដើម្បីសែងហិប។
[6]គាត់បានធ្វើទីសន្តោសប្រោសពីមាសសុទ្ធ។ ដែលមានបណ្តោយពីរហត្ថកន្លះ និងទទឹងមួយហត្ថកន្លះ។
[7]លោកបេតសាលាលបានធ្វើចេរូប៊ីមពីរ ឆ្លាក់ធ្វើពីមាសសម្រាប់ចុងសងខាងនៃទីសន្តោសប្រោស។[8]រូបចេរូប៊ីមមួយសម្រាប់ចុងទីសន្តោសប្រោសម្ខាង
ហើយចេរូប៊ីមមួយទៀតសម្រាប់នៅខាងចុងទីសន្តោសប្រោសម្ខាងទៀត។ ពួកគេបានភ្ជាប់វាមកតែមួយចំណែកនៅលើទីសន្តោសប្រោស។
[9]រូបចេរូប៊ីមត្រដាសស្លាបរបស់ពួកគេទល់មុខគ្នា ហើយគ្រប់ពីលើទីសន្តោសប្រោសជាមួយនឹងស្រមោលពីលើហិប។ មុខរបស់ចេរូប៊ីមទល់មុខគ្នា
ហើយបានសម្លឹងមើលទៅចំកណ្តាលទីសន្តោសប្រោស។
[10]លោកបេតសាលាលធ្វើតុពីឈើនាងនួន ដែលមានបណ្តោយពីហត្ថ និងទទឹងមួយហត្ថ ព្រមទាំងកម្ពស់មួយហត្ថកន្លះផង។[11]គាត់បានស្រោបវាដោយមាសសុទ្ធ
ហើយបានធ្វើគែមព័ទ្ធជុំវិញ។[12]គាត់បានធ្វើស៊ុមព័ទ្ធជុំវិញ ដែលមានកម្ពស់មួយទះ ហើយធ្វើស៊ុមពីមាសព័ទ្ធជុំវិញដែរ។[13]គាត់បានសិតកងបួនពីមាស
ហើយភ្ជាប់កងនោះទៅនឹងជ្រុងទាំងបួន គឺនៅនឹងជើងរបស់វា។
[14]កងនោះបានភ្ជាប់ទៅនឹងស៊ុមដើម្បីផ្តល់ជាកន្លែងសម្រាប់ស៊កឈើស្នែង ដើម្បីសែងតុនោះ។[15]គាត់បានធ្វើឈើស្នែងបួនពីឈើនាងនួន ហើយស្រោបវាដោយមាស
ដើម្បីសែងតុនោះ។[16]គាត់បានធ្វើគ្រឿងបរិក្ខារដែលដាក់នៅលើតុនោះ មានដូចជា ចាន ស្លាបព្រា និងចានគោម សម្រាប់ប្រើក្នុងពិធីថ្វាយតង្វាយ។
គាត់ធ្វើរបស់ទាំងអស់នោះពីមាសសុទ្ធ។
[17]គាត់បានឆ្លាក់ធ្វើជើងចង្កៀងមួយពីមាសសុទ្ធ។ គាត់ធ្វើជើងចង្កៀងនោះជាមួយនឹងជើងទ្រ ព្រមទាំងដងផង។ មានពែង មែកនិងជើងទ្ររបស់វា
ហើយផ្ការបស់វាត្រូវបានធ្វើឡើងតែមួយដុំ។[18]មានមែកប្រាំមួយបែកចេញពីសងខាង ហើយម្ខាងនៃជើងចង្កៀងមានមែកបី ហើយម្ខាងទៀតមានមែកបីដែរ។
[19]មែកទីមួយមានពែងបី ធ្វើជារាងដូចជាផ្កាចំបក់ ដែលមានស្រទាប់ទ្រ និងផ្កាមួយ ហើយពែងបីទៀតក៏មានរាងដូចផ្លែចំបក់ដែលនៅមែកម្ខាងទៀត ដែលមានស្រទាប់
និងផ្កាមួយ។ មែកទាំងប្រាំមួយមានរាងដូចគ្នា បែកមែកចេញពីជើងចង្កៀង។
[20]នៅលើជើងចង្កៀងនោះ ផ្នែកកណ្តាល មានពែងបួនធ្វើរាងដូចជាផ្លែចំបក់ មានស្លឹកទ្រ ហើយនិងផ្កាផង។[21]មានក្រោមជើងទ្រស្លឹក គូដំបូងរបស់មែក ធ្វើឡើងជាមួយដុំ
ហើយជើងទ្រស្លឹក គូទីពីររបស់មែងក៏ធ្វើឡើងជាមួយដុំដែរ។ ហើយជើងទ្រស្លឹកផ្សេងៗទៀតដែលនៅក្រោមជើងទ្រស្លឹក គូទីបី ក៏ធ្វើឡើងជាមួយដុំដែរ។
មែងទាំងប្រាំមួយធ្វើរាងដូចៗគ្នាទាំងអស់ មានមែកបែកចេញពីជើងចង្កៀង។[22]ជើងទ្រ និងមែករបស់វាទាំងអស់ ធ្វើឡើងតែមួយដុំ គឺធ្វើពីមាសសុទ្ធមួយដុំគត់។
[23]លោកបេតសាលាលធ្វើជើងចង្កៀង និងចង្កៀងទាំងប្រាំពីរ និងប្រឆេះ និងថាសពីមាសសុទ្ធ។[24]គាត់ធ្វើចង្កៀង ហើយនិងសម្ភាររបស់វា
សម្រាប់គោះកម្ទេចពីមាសសុទ្ធដែរ។
[25]លោកបេតសាលាលធ្វើកន្លែងថ្វាយគ្រឿងក្រអូប។ គាត់បានធ្វើវាពីឈើងនាងនួន។ បណ្តោយរបស់វាមានប្រវែងមួយហត្ថ និងទទឹងរបស់វាមានប្រវែងមួយហត្ថដែរ។
វាមានរាងបួនជ្រុង ហើយកម្ពស់របស់វាមានប្រវែងពីរហត្ថ។ ហើយស្នែងរបស់វាត្រូវបានធ្វើឡើងភ្ជាប់ជាបំណែកតែមួយ។
[26]គាត់បានស្រោបកន្លែងថ្វាយគ្រឿងក្រអូបនោះជាមួយនឹងមាសសុទ្ធ នៅពីលើ ពីចំហៀង និងនៅលើស្នែងរបស់វា។
គាត់ក៏បានស្រោបមាសនៅតាមគែមរបស់វាពីមាសដែរ។
[27]គាត់បានធ្វើកងពីមាសពីរ ដើម្បីភ្ជាប់វានៅក្រោមគែមទាំងសងខាងរបស់វា។ កងនោះសម្រាប់ស៊កឈើស្នែងដើម្បីសែងកន្លែងថ្វាយយញ្ញបូជា។
[28]គាត់បានធ្វើឈើស្នែងពីឈើនាងនួន ហើយគាត់បានស្រោបវាជាមួយនឹងមាស។[29]គាត់បានធ្វើប្រេងចាក់ប្រេងតាំងបរិសុទ្ធ និងគ្រឿងក្រអូបបរិសុទ្ធ
គឺជាកិច្ចការរបស់អ្នកធ្វើទឹកអប់។

Exodus 37:1
លោកបេតសាលាល
នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។
ពីហត្ថកន្លះ ... មួយហត្ថកន្លះ
«២,៥ ហត្ថ ... ១,៥ ហត្ថ»
សម្រាប់ជើងវាទាំងបួន
ឈើទាំងបួនដុំដែលទ្រទ្រង់ហឹបនោះត្រូវបានគេនិយាយថា ដូចជាជើងមនុស្ស ឬជើងសត្វ។
Exodus 37:4
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាលបន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
មួយហត្ថកន្លះ។ ... មួយហត្ថកន្លះ។
សម្រាប់ ៣៧: ៤-៦
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥:១២ និង ២៥:១៥ ។
គាត់បានធ្វើ
ទោះបីជា «គាត់» សំដៅទៅលើបេតសាលាល«គាត់» អាចរួមបញ្ចូលកម្មករទាំងអស់ដែលបានជួយគាត់។
ពីរហត្ថកន្លះ ... មួយហត្ថកន្លះ។

generated on Wed Sep 10 16:16:32 2025

«២,៥ ហត្ថ ... ១,៥ ហត្ថ»
Exodus 37:7
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាលបន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
លោកបេតសាលាលបានធ្វើ ... ចំកណ្តាលទីសន្តោសប្រោស។
សម្រាប់ ៣៧: ៧-៩
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥:១៥ និង ២៥:១៩ ។
ពួកគេបានភ្ជាប់វាមកតែមួយចំណែក
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់បានធ្វើវាជាបំណែកតែមួយ»
រូបចេរូប៊ីមត្រដាសស្លាបរបស់ពួកគេទល់មុខគ្នា ហើយគ្រប់ពីលើ
រូបចេរូប៊ីម បានដាក់រូបចម្លាក់នៃចេរូប៊ីមដូចជា
រូបចេរូប៊ីនពិតដែលកំពុងត្រដាងស្លាបរបស់វាហើយគ្របលើទីសន្តោសប្រោស។
ការបកប្រែផ្សេងទៀត « ពួកគេបានដាក់សត្វស្លាប
ដើម្បីឱ្យស្លាបរបស់វាប៉ះគ្នាហើយលាតត្រដាងពេញ»
មុខរបស់ចេរូប៊ីមទល់មុខគ្នា
លោកបេតសាលាលបានដាក់រូបចម្លាក់របស់ចេរូប៊ីម
គឺហាក់ដូចជាវាគឺចេរូប៊ីមពិតប្រាកដដែលបែរមុខដាក់គ្នា
ហើយក្រឡេកមើលទៅលើគម្របទីសន្តោសប្រោសនោះ។
Exodus 37:10
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាលបន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
លោកបេតសាលាលធ្វើ ... គឺនៅនឹងជើងរបស់វា។
សម្រាប់ ៣៧: ១០-១៣
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥:២៣ និង ២៥:២៥ ។
ពីហត្ថ ... មួយហត្ថ ... មួយហត្ថកន្លះ
«២ ហត្ថ ... ១ ហត្ថ ... ១,៥ ហត្ថ»
ដែលមានកម្ពស់មួយទះ
នេះជាទទឹងដៃរបស់មនុស្សប្រុស ដែលមានម្រាមដៃលាតត្រដាង។
គឺនៅនឹងជើងទាំងបួនរបស់វា។
ឈើទាំងបួនដុំដែលទ្រហឹបនោះត្រូវបានគេនិយាយថាដូចជាជើងមនុស្ស ឬជើងសត្វ។
Exodus 37:14
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាលបន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
កងនោះ ... ទាំងអស់នោះពីមាសសុទ្ធ។
សម្រាប់ ៣៧:១៤ - ១៦
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥:២៥ និង ២៥:២៨ ។
កងនោះបានភ្ជាប់ទៅនឹង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«លោកបេតសាលាលបានភ្ជាប់ចិញ្ចៀន»
ចាន ស្លាបព្រា និងចានគោម សម្រាប់ប្រើក្នុងពិធីថ្វាយតង្វាយ។
វាគ្រាន់តែជាចានគោម និងចានដែកដែលត្រូវបានប្រើសម្រាប់ចាក់តង្វាយប៉ុណ្ណោះ។
ការបកប្រែផ្សេងទៀត «ចាន និងពែង ព្រមទាំងថូ
និងចានគោមដែលពួកបូជាចារ្យប្រើសម្រាប់តង្វាយច្រួត»
Exodus 37:17
ឃ្លាភ្ជាប់
ក្រុមធ្វើការរបស់លោកបេតសាលាលបន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
ព័ត៌មានទូទៅ
គាត់បាន... ចេញពីជើងចង្កៀង។
សម្រាប់ ៣៧: ១៧-១៩
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥:៣១ និង ២៥:៣៣ ។
មានពែង មែកនិងជើងទ្ររបស់វា ហើយផ្ការបស់វាត្រូវបានធ្វើឡើងតែមួយដុំ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់បានធ្វើពែងពែងមែក និងជើងទ្ររបស់វា
និងផ្ការបស់វាជាដុំតែមួយនៅលើជើងចង្កៀង»
ហើយពែងបីទៀតក៏មានរាងដូចផ្លែចំបក់ដែលនៅមែកម្ខាងទៀត
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ហើយគាត់បានធ្វើឱ្យពែងទាំងបី មើលមានរាងដូចផ្លែចំបក់»
ផ្លែចំបក់
ផ្លែចំបក់គឺជាផ្កាពណ៌ស
ឬពណ៌ផ្កាឈូកដែលមានត្របកផ្កាចំនួន៥ដែលលូតលាស់នៅលើដើម។
Exodus 37:20
នៅលើជើងចង្កៀង ... គឺធ្វើពីមាសសុទ្ធមួយដុំគត់។
សម្រាប់ ៣៧: ២០-២២
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥:៣៣ និង ២៥:៣៥ ។
មានពែងបួនធ្វើរាងដូចជាផ្លែចំបក់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
មានពែង៤ដែលលោកបេតសាលាលធ្វើរាងដូចជាផ្លែចំបក់»
ក៏ធ្វើឡើងជាមួយដុំដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលគាត់បានធ្វើជាដុំតែមួយជាមួយនឹងជើងចង្កៀង»
Exodus 37:23
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
លោកបេតសាលាលធ្វើ ...សម្រាប់គោះកម្ទេចពីមាសសុទ្ធដែរ។
សម្រាប់ ៣៧: ២៣-២៤
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៥:៣៧ ។
ប្រឆេះ
នេះគឺជាឧបករណ៍ដែលធ្វើពីឈើ ឬដែកចំនួនពីរភ្ជាប់គ្នានៅចុងម្ខាង
ហើយប្រើសម្រាប់យកវត្ថុផ្សេងៗ។
សម្រាប់គោះកម្ទេច
«៣៤ គីឡូក្រាម»
Exodus 37:25
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
លោកបេតសាលាលធ្វើ... ពីមាសដែរ។
សម្រាប់ ៣៧: ២៥-២៦
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ៣០: ១ និង ៣០: ៣ ។
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
ហើយស្មែងរបស់វាត្រូវបានធ្វើឡើងភ្ជាប់ជាបំណែកតែមួយ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
គាត់បានធ្វើស្មែងជាបំណែកតែមួយជាមួយអាសនា»
Exodus 37:27
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
គាត់បានធ្វើកងពីមាសពីរ ... ជាមួយនឹងមាស។
សម្រាប់ ៣៧: ២៧-២៨
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ៣០: ៣ និង ៣០: ៥
ដើម្បីភ្ជាប់វានៅ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលវាភ្ជាប់ជាមួយនឹងអាសនា»
គឺជាកិច្ចការរបស់អ្នកធ្វើទឹកអប់។
អ្នកធ្វើទឹកអប់មានជំនាញក្នុងការលាយគ្រឿងទេស និងប្រេង។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣០:២២ ។

generated on Wed Sep 10 16:16:32 2025

38

[1]លោកបេតសាលាលបានធ្វើកន្លែងថ្វាយតង្វាយដុតពីឈើនាងនួន។ វាមានប្រវែងប្រាំហត្ថ ហើយទទឹងប្រាំហត្ថដែរ មានរាងបួនជ្រុង ហើយមានកម្ពស់បីហត្ថ។
[2]គាត់ធ្វើស្នែងបួននៅជាប់នឹងជ្រុងទាំងបួនមានរាងដូចជាស្នែងគោ។ ស្នែងត្រូវបានធ្វើឡើងជាប់ជាមួយនឹងកន្លែងថ្វាយតង្វាយ ហើយគាត់បានស្រោបវាជាមួយនឹងលង្ហិន។
[3]គាត់ធ្វើគ្រឿងបរិក្ខារសម្រាប់កន្លែងថ្វាយតង្វាយមានដូចជា ឆ្នាំសម្រាប់កើបផេះ ប៉ែល អាងទឹក ធើង សម និងជើងក្រាន។ គាត់បានធ្វើគ្រឿងបរិក្ខាទាំងអស់នេះពីលង្ហិន។
[4]គាត់បានធ្វើប្រទាសសម្រាប់កន្លែងថ្វាយតង្វាយ ខ្នាស់ក្រឡាគ្នាពីលង្ហិន ដើម្បីដាក់នៅក្រោមគែម នៅចំកណ្តាលនៃកន្លែងថ្វាយតង្វាយ។[5]គាត់បានសិតធ្វើកងបួន
ដាក់នៅតាមជ្រុងទាំងបួននៃប្រទាសលង្ហិន ដើម្បីស៊កឈើស្នែង។
[6]លោកបេតសាលាលបានធ្វើឈើស្នែងពីឈើនាងនួន ហើយស្រោបវាជាមួយនឹងលង្ហិន។[7]គាត់បានដាក់ឈើស្នែងនៅសងខាងនៃកន្លែងថ្វាយតង្វាយ ដើម្បីសែងវា។
គាត់បានធ្វើកន្លែងតង្វាយពីក្តារដែលមានប្រហោងកណ្តាល។
[8]លោកបេតសាលាលធ្វើអាងទឹកធំមួយពីលង្ហិន កំណល់ពីលង្ហិន។
គាត់បានធ្វើអាងទឹកចេញពីកញ្ចក់ដែលជាកម្មសិទ្ធិរបស់ស្ត្រីៗដែលបម្រើនៅត្រង់ច្រកចូលត្រសាលនៃការជួបជុំ។
[9]គាត់ក៏បានធ្វើទីលាន។ ដែលមានរនាំងព័ទ្ធជុំវិញពីភាគខាងត្បូងនៃទីលានដែលធ្វើពីក្រណាត់ទេសឯកយ៉ាងល្អ ប្រវែងមួយរយហត្ថ។
[10]ហើយរនាំនោះមានសសរម្ភៃជាមួយនឹងជើងទ្រលង្ហិន។ មានតម្កក់ភ្ជាប់សសរ និងគន្លឹះធ្វើពីប្រាក់។
[11]នៅប៉ែកខាងជើងក៏ដូចគ្នាដែរ មានរនាំងប្រវែងមួយរយហត្ថ ជាមួយនឹងសសរម្ភៃ និងជើងទ្រលង្ហិនម្ភៃដែរ តម្កក់ភ្ជាប់សសរ និងកន្លឹះធ្វើពីប្រាក់។
[12]រនាំងនៅប៉ែកខាងលិចមានប្រវែងហាសិបហត្ថ និងមានសសរ និងជើងទ្រដប់។ ទម្លុក់ និងគន្លឹះសសរធ្វើពីប្រាក់។
[13]នៅក្នុងទីលាននៅប៉ែកខាងកើតក៏មានហាសិបហត្ថដូចគ្នាដែរ។[14]រនាំងមួយចំហៀងនៃច្រកចូលមានប្រវែងដប់ប្រាំហត្ថ។ មានសសរបី និងជើងទ្របី។
[15]នៅប៉ែកម្ខាងទៀតនៃច្រកចូលទីលានក៏មានរនាំងប្រវែងដប់ប្រាំហត្ថដែរ ជាមួយនឹងសសរបី និងជើងទ្របី។
[16]រនាំងទាំងអស់នៅជុំវិញទីលានត្រូវបានធ្វើឡើងពីក្រណាត់ទេសឯកយ៉ាងស្អាត។
[17]ជើងទ្រសម្រាប់សសរធ្វើពីលង្ហិន។ តម្កក់ និងគន្លឹះធ្វើឡើងពីប្រាក់ ហើយស្រោបពីលើសសរនោះក៏ធ្វើពីប្រាក់ដែរ។
សសរទីលានទាំងអស់ត្រូវបានស្រោបឡើងដោយប្រាក់ដែរ។[18]រឹងននៅច្រកចូលទីលានមានប្រវែងម្ភៃហត្ថ។ រឹងននត្រូវបានធ្វើឡើងដោយក្រណាត់ពណ៌ខៀវ
ពណ៌ស្វាយ និងពណ៌ក្រហមវេញជាមួយនឹងអំបោះខ្លូតទេស ហើយមានប្រវែងម្ភៃហត្ថ។[19]មានទទឹងម្ភៃហត្ថ និងកម្ពស់ប្រាំហត្ថ ដូចរឹងននៅទីលានដែរ។
មានជើងទ្រពីលង្ហិន ហើយតម្កក់ពីប្រាក់។ គម្របពីលើ និងតម្កក់របស់វាធ្វើពីប្រាក់។[20]ចម្រឹងសម្រាប់ព្រះពន្លា និងទីលានទាំងអស់ធ្វើពីលង្ហិន។
[21]នេះគឺជាបញ្ជីសារពើភ័ណ្ឌរបស់ព្រះពន្លា និងច្បាប់របស់ព្រះពន្លានៃសម្ពន្ធមេត្រី យោងទៅតាមសេចក្តីណែនាំរបស់លោកម៉ូសេ។
វាគឺជាកិច្ចការរបស់ពួកលេវីនៅក្រោមការដឹកនាំរបស់លោកអ៊ីថាម៉ា ជាកូនរបស់លោកបូជាចារ្យអើរ៉ុន។[22]លោកបេតសាលាល គឺជាកូនរបស់លោកយូរី ត្រូវជាចៅរបស់
លោកហ៊ើរ មកពីកុលសម្ព័ន្ធយូដា បានធ្វើតាមអ្វីៗដែលព្រះអម្ចាស់បង្គាប់មកលោកម៉ូសេ។[23]លោកអូហូលីអាប់ ជាកូនលោកអហ៊ីសាម៉ាក់ មកពីកុលសម្ព័ន្ធដាន់ ក៏បានជួយ
ធ្វើការលោកបេតសាលាល ជាជាងចម្លាក់ គឺជាជាងដែលមានជំនាញ និងអ្នកប៉ាក់លំអក្រណាត់ពណ៌ស្វាយ ពណ៌ក្រហម ពណ៌ក្រហមទុំ និងក្រណាត់ធ្វើ
ពីក្រណាត់ទេសឯកយ៉ាងស្អាត។
[24]មាសទាំងអស់ដែលប្រើសម្រាប់គម្រោង នៅគ្រប់ទាំងកិច្ចការដែលពាក់ពាន់នឹងទីបរិសុទ្ធ មាសដែលបានមកពីតង្វាយគ្រវី មានចំនួន ម្ភៃប្រាំបួនហាប និង៧៣០ សេកែល
តាមទម្ងន់សេកែលដែលប្រើក្នុងទីបរិសុទ្ធ។[25]ចំណែក ប្រាក់ដែលបានទទួលពីសហគមន៍មានទម្ងន់មួយរយហាប និង១៧៧៥សេកែលតាមទម្ងន់សេកែលដែលប្រើក្នុងទី
បរិសុទ្ធ។[26]ឬម្នាក់បង់ប្រាំកាក់ ស្មើនឹងកន្លះសេកែល តាមទម្ងន់សេកែលដែលប្រើក្នុងទីបរិសុទ្ធ។ តួលេខនេះបានទទួលពីប្រជាជនគ្រប់រូបដែលបានធ្វើជំរឿន
ចាប់តាំងពីអាយុម្ភៃឆ្នាំ និងឡើងទៅមានចំនួនទាំងអស់ ៦០៣, ៥៥០នាក់។
[27]ប្រាក់ចំនួនមួយរយហាបត្រូវបានសិតធ្វើជាទីបរិសុទ្ធ ហើយនិងជើងទ្រវាំងនន ជើងទ្រមួយរយ ប្រាក់មួយហាបសម្រាប់ជើងទ្រមួយ។[28]ប្រាក់នៅសល់មានចំនួន ១, ៧៧៥
សេកែល លោកបេតសេលាល ធ្វើតម្កក់សម្រាប់សសរ ស្រោបពីលើសសរ ហើយធ្វើគន្លឹះទាំងប៉ុន្មានសម្រាប់សសរដែរ។[29]ចំណែក
លង្ហិនដែលបានមកពីការថ្វាយតង្វាយគ្រវីមានទម្ងន់ចិតសិបហាប និង២, ៤០០សេកែល។
[30]ជាមួយនឹងលង្ហិននេះ គាត់បានថ្វើជើងទ្រសម្រាប់ច្រកចូលទៅក្នុងត្រសាលប្រជុំ កន្លែងថ្វាយតង្វាយពីលង្ហិន
និងគ្រឿងបរិក្ខារសម្រាប់កន្លែងថ្វាយតង្វាយ[31]ជើងទ្រសម្រាប់ទីលាន ជើងទ្រសម្រាប់ទីលានច្រកចូល ចម្រឹងរបស់ព្រះពន្លា និងចម្រឹងរបស់ទីលានទាំងអស់។

Exodus 38:1

ព័ត៌មានទូទៅ

ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។

លោកបេតសាលាលបានធ្វើ... គ្រឿងបរិក្ខាទាំងអស់នេះពីលង្ហិន។

សម្រាប់ ៣៨: ១-៣

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៧: ១ និង ២៧: ៣ ។

ហត្ថ

មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។

ស្នែងត្រូវបានធ្វើឡើងជាប់ជាមួយនឹងកន្លែងថ្វាយតង្វាយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់បានធ្វើស្នែងជាបំណែកតែមួយ»

Exodus 38:4

ព័ត៌មានទូទៅ

ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។

គាត់បានធ្វើ ...ដើម្បីស៊កឈើស្នែង។

សម្រាប់ ៣៨: ៤-៥

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៧: ៣ និង ២៧: ៥ ។

ដើម្បីដាក់នៅក្រោមគែម

នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលពួកគេដាក់នៅខាងក្រោម»

Exodus 38:6

ព័ត៌មានទូទៅ

ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។

លោកបេតសាលាលបានធ្វើ ... មានប្រហោងកណ្តាល។

ប្រហោងកណ្តាល គឺជាបន្ទះឈើមានរាងសំប៉ែតវែងដែលក្រាស់ជាងក្តារ។

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៧: ៧ ។

Exodus 38:8

ព័ត៌មានទូទៅ

ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។

អាងទឹកធំមួយពីលង្ហិន កំណល់ពីលង្ហិន។

កំណល់ទ្រអាងលង្ហិន។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣០:១៧ ។

គាត់បានធ្វើអាងទឹកចេញពីកញ្ចក់

លង្ហិនបានមកពីកញ្ចក់។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។
ការបកប្រែផ្សេងទៀត « លង្ហិនសម្រាប់អាងទឹក គឺបានមកពីកញ្ចក់»

កញ្ចក់

កញ្ចក់គឺជាបំណែកនៃលោហធាតុ ឬកញ្ចក់ដែលឆ្លុះបញ្ចាំងពីរូបភាព។

Exodus 38:9

ព័ត៌មានទូទៅ

ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។

គាត់ក៏បានធ្វើ... គន្លឹះធ្វើពីប្រាក់។

សម្រាប់ ៣៨: ៩-១០

សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៧: ៩ ។

generated on Wed Sep 10 16:16:32 2025

មួយរយហត្ថ ... ម្ភៃ
«១០០ ... ២០»
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
Exodus 38:11
នៅប៉ែកខាងជើងក៏ដូចគ្នាដែរ ...និងគន្លឹះសសរធ្វើពីប្រាក់។
សម្រាប់ ៣៨: ១១-១២
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៧:១១ ។
មួយរយ ... ម្ភៃ ... ហាសិប... ដប់
«១០០ ... ២០ ... ៥០ ... ១០»
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
Exodus 38:13
ទីលាន
សម្រាប់ ៣៨: ១៣-១៦
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៧:១១ និង ២៧:១៤ ។
ហាសិប ... ប់ប្រាំ ... បី
«៥០ ... ១៥ ... ៣»
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
រនាំងទាំងអស់នៅជុំវិញទីលានត្រូវបានធ្វើឡើងពីក្រណាត់ទេសឯកយ៉ាងស្អាត។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «លោកបេតសាលាល និងក្រុមកម្មករបានធ្វើរនាំងនៅជុំវិញទីលាន ជាមួយនឹងក្រណាត់ទេសឯកសុទ្ធ»
Exodus 38:17
ជើងទ្រ ... និងទីលានទាំងអស់ធ្វើពីលង្ហិន។
សម្រាប់ ៣៨: ១៧-២០
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៧:១៤ និង ២៧:១៧ ។
ជើងទ្រសម្រាប់សសរធ្វើពីលង្ហិន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត « លោកបេតសាលាល និងក្រុមកម្មករបានធ្វើជើងទ្រសម្រាប់សសរពីលង្ហិន» ។
តម្ពក់ និងគន្លឹះធ្វើឡើងពីប្រាក់ ហើយស្រោបពីលើសសរនោះក៏ធ្វើពីប្រាក់ដែរ។
សសរទីលានទាំងអស់ត្រូវបានស្រោបឡើងដោយប្រាក់ដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត « ពួកគេបានធ្វើតម្ពក់សម្រាប់គន្លឹះទៅនឹងសសរ និងគម្របសម្រាប់កំពូលនៃសសរដែលធ្វើពីប្រាក់»
សសរទីលានទាំងអស់ត្រូវបានស្រោបឡើងដោយប្រាក់ដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេបានគម្របសសរទីលានដោយប្រាក់»
ម្ភៃ ... ប្រាំ ... បួន
«២០ ... ៥ ... ៤»
ហត្ថ
មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។
វាំងននត្រូវបានធ្វើឡើង
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ «ពួកគេបានធ្វើវាំងននចេញពី»
ហើយស្រោបពីលើសសរនោះក៏ធ្វើពីប្រាក់ដែរ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេបានធ្វើគម្របសម្រាប់កំពូលនៃសសរ និងគន្លឹះរបស់វាដែលធ្វើពីប្រាក់»
ចម្រឹងសម្រាប់ព្រះពន្លា និងទីលានទាំងអស់ធ្វើពីលង្ហិន។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេបានធ្វើចម្រឹងព្រះពន្លាទាំងអស់សម្រាប់ទីលានពីលង្ហិន»
Exodus 38:21
ឃ្លាភ្ជាប់
ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
ព័ត៌មានទូទៅ
យោងទៅតាម
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ដែលលោកម៉ូសេបានណែនាំពួកលេវីអោយសរសេរ»
លោកអ៊ីថាម៉ា
នេះជាឈ្មោះនៃមនុស្សប្រុស។
សូមមើលពីរបៀបដែលបានបកប្រែឈ្មោះនេះនៅក្នុង ៦:២៣ ។
លោកបេតសាលាល គឺជាកូនរបស់លោកយូរី ត្រូវជាចៅរបស់លោកហ៊ើរ
«លោកបេតសាលាល » និង « លោកយូរី» គឺជាឈ្មោះនៃមនុស្សប្រុស។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។
ព្រះអម្ចាស់បង្គាប់មកលោកម៉ូសេ។
«គ្រប់ទាំងសេចក្ដីដែលព្រះអម្ចាស់បានប្រាប់លោកម៉ូសេឲ្យធ្វើ»
លោកអូហូលីអាប់ ជាកូនលោកអហ៊ីសាម៉ាក់
«លោកអូហូលីអាប់» និង «លោកអហ៊ីសាម៉ាក់» គឺជាឈ្មោះរបស់បុរស។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ៦ ។
ជាជាងចម្លាក់ គឺជាជាងដែលមានជំនាញ និងអ្នកប៉ាក់លំអក្រណាត់
«ជាជាងឆ្លាក់ និងអ្នកប៉ាក់លំអក្រណាត់»។
Exodus 38:24
មាសទាំងអស់ដែលប្រើសម្រាប់គម្រោង
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «មាសទាំងអស់ដែលប្រជាជនបានប្រើសម្រាប់គម្រោងនេះ»
ម្ភៃប្រាំបួនហាប ... មួយរយហាប
ប្រាំបួនហាប ... មួយរយហាប - «២៩ ហាប... ១០០ ហាប» ។ ហាបគឺ 34 គីឡូក្រាម។
៧៣០ សេកែល ... ១៧៧៥សេកែល
មួយ សេកែល ១១ ក្រាម។
តាមទម្ងន់សេកែលដែលប្រើក្នុងទីបរិសុទ្ធ។
នេះគឺជារង្វាស់ជាក់ស្តែងសេកែលមានទម្ងន់លើសពីមួយនៅពេលនោះ។ នេះបានបញ្ជាក់ថាមួយណាត្រូវបានប្រើ។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣០:១១ ។
ចំណែក ប្រាក់ដែលបានទទួលពីសហគមន៍
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ប្រាក់ដែលសហគមន៍បានផ្តល់ឱ្យ»
ម្នាក់បង់
ម្នាក់បង់១/២សេកែល។
កន្លះសេគែល
កន្លះសេគែល១/២ សេកែល។
តួលេខនេះបានទទួលពីប្រជាជនគ្រប់រូបដែលបានធ្វើជំរឿន
មនុស្សគ្រប់រូបដែលមានអាយុចាប់ពី ២០ ឆ្នាំឡើងទៅត្រូវបានរាប់បញ្ចូលក្នុងជំរឿន ហើយត្រូវតម្រូវឲ្យ បង់ប្រាក់កន្លះសេកែល
ចាប់តាំងពីអាយុម្ភៃឆ្នាំ
«អាយុ ២០ ឆ្នាំ»
Exodus 38:27
ប្រាក់ចំនួនមួយរយហាបត្រូវបានសិត
ហាបគឺ ៣៤ គីឡូក្រាម។ ការបកប្រែផ្សេងទៀត « កម្មករបានសិត១០០ ហាប» ឬ « កម្មករបានសិត ៣,៤០០ គីឡូក្រាម»
មួយរយ ... ចិតសិប
«១០០ ... ៧០»
សេកែល
មួយសេកែលគឺ ១១ ក្រាម។
លោកបេតសេលាល
នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។
Exodus 38:30
ព័ត៌មានទូទៅ
ក្រុមធ្វើការរបស់លោកបេតសាលាល បន្តកសាងព្រះពន្លា និងគ្រឿងសង្ហារឹម។
កន្លែងថ្វាយតង្វាយ
នេះគឺជាស៊ុមព័ទ្ធជុំវិញរបារសម្រាប់ទ្រអុសនៅពេលដុត។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៧: ៣ ។
ចម្រឹងរបស់ព្រះពន្លា
ទាំងនេះគឺជាបង្គោលលង្ហិនមុតស្រួចដែលត្រូវបានប្រើដើម្បីធានាជ្រុងនៃតង់ជាប់ទៅនឹងដី។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៧:១៧ ។

generated on Wed Sep 10 16:16:32 2025

39 [1]ជាមួយក្រណាត់ពណ៌ខៀវ ពណ៌ស្វាយ ពណ៌ក្រហម គេធ្វើសម្លៀកបំពាក់ដោយត្បាយយ៉ាងស្អាត សម្រាប់បម្រើនៅក្នុងទីបរិសុទ្ធ។
ពួកគេបានធ្វើសម្លៀកបំពាក់ឲ្យលោកអ៊ើរ៉ុន សម្រាប់ទីបរិសុទ្ធ ដូចដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
[2]បេតសាលាលបានធ្វើអាវអេផូដពីមាស ពីក្រណាត់ពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម និងក្រណាត់ទេសឯកត្បាយយ៉ាងល្អ។[3]ពួកគេបានសិតមាសជាសន្លឹកៗ
ហើយកាត់វាជាសរសៃយ៉ាងឆ្មា ដើម្បីធ្វើវាជាពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម ព្រមទាំងក្រណាត់ទេសឯក ធ្វើពីជាងដែលមានស្នាដៃ។
[4]ពួកគេធ្វើខ្សែស្មាសម្រាប់ចងភ្ជាប់អាវអេផូដទាំងសងខាងបានជាប់គ្នាតែមួយ។[5]ខ្សែក្រវាត់ក៏ដូចជាអាវអេផូដដែរ គឺធ្វើជាបំណែកតែមួយជាមួយនឹងអាវអេផូដ
វេញជាមួយនឹងក្រណាត់ទេសឯកយ៉ាងល្អពណ៌មាស ពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
[6]ពួកគេបានច្នៃត្បូងអូនីក្ស ដាំចុះក្នុងគ្រោងមាស ឆ្លាក់ដូចជាគេឆ្លាក់ត្រា ហើយបានចារឈ្មោះរបស់កូនចៅអ៊ីស្រាអែលទាំងដប់ពីរនៅក្នុងនោះ។[7]លោកបេតសាលាលបាន
ភ្ជាប់នៅលើខ្សែស្មារបស់អាវអេផូដ ជាត្បូងដើម្បីរំឭកដល់ព្រះអម្ចាស់នៃកូនចៅអ៊ីស្រាអែលទាំងដប់ពីរ ដូចព្រះអម្ចាស់បានបង្គាប់មកលោកម៉ូសេ។
[8]គាត់បានធ្វើប្រដាប់ពាក់លើដើមទ្រូង តាមការរចនារបស់ជាងដែលមានស្នាដៃ ធ្វើតាមបែបដូចជាអាវអេផូដ។ គាត់បានធ្វើវាពីមាស ពីក្រណាត់ពណ៌ខៀវ ពណ៌ស្វាយ
និងពណ៌ក្រហម និងពីក្រណាត់ពណ៌ទេសឯកយ៉ាងល្អ។[9]វាមានរាងបួនជ្រុង។ ពួកគេបានអាវពាក់លើដើមទ្រូងជាពីរស្រទាប់។ បណ្តោយមួយចំអាម
និងទទឹងមួយចំអាមដែរ។
[10]ពួកគេបានដាំត្បូងបួនជួរ។ ជួរទីមួយមានត្បូងទទឹមមួយគ្រាប់ ត្បូងប៊ុតលឿងមួយគ្រាប់ និងត្បូងមរកតមួយគ្រាប់។[11]ជួរទីពីរមានត្បូងទទឹមមួយគ្រាប់ ត្បូងកណ្តៀងមួយ
គ្រាប់ និងត្បូងពេជ្រមួយគ្រាប់។[12]ជួរទីបីមានត្បូងទទឹមមួយគ្រាប់ ត្បូងនិលវ័ត្តមួយគ្រាប់ និងត្បូងជម្ពូវ័ត្តមួយគ្រាប់។[13]ជួរទីបួនមាន ត្បូងដៃរគៀមមួយគ្រាប់ ត្បូងកែវយក់
មួយគ្រាប់ និងត្បូងមណីជោតិរសមួយគ្រាប់។ ត្បូងទាំងនេះត្រូវបានដាំនៅក្នុងគ្រោងមាស។
[14]ត្បូងទាំងនោះត្រូវបានរៀបតាមលំដាប់ឈ្មោះរបស់កូនចៅអ៊ីស្រាអែល។ ពួកគេធ្វើដូចជាឆ្លាក់ត្រា គឺចាឈ្មោះកុលសម្ព័ន្ធទាំងដប់ពីរនៅលើត្បូងនោះ។
[15]នៅលើអាវសម្រាប់ពាក់លើដើមទ្រូង ពួកគេធ្វើខ្សែដូចខែពួរវេញចូលគ្នាពីមាសសុទ្ធ។[16]ពួកគេធ្វើក្រចាប់មាសពីរ និងកងមាសពីរ
ហើយពួកគេភ្ជាប់កងទាំងពីរនោះទៅនឹងជ្រុងទាំងពីររបស់ប្រដាប់ពាក់ដើមទ្រូង។
[17]ពួកគេបានវេញខ្សែមាសទាំងពីរទៅនឹងកងមាសទាំងពីរ នៅជ្រុងនៃអាវសម្រាប់ពាក់លើដើមទ្រូង។
[18]ពួកគេភ្ជាប់ចុងទាំងពីរនៃខ្សែដែលវេញនោះទៅនឹងក្រចាប់ទាំងពីរនោះ។ ពួកគេភ្ជាប់វាទៅនឹងគ្រោងមាសនៃខ្សែស្មារបស់អាវអេផូដខាងមុខ។
[19]ពួកគេធ្វើកងពីមាសពីរ ហើយដាក់កងនោះនៅលើជ្រុងទាំងទៀតរបស់អាវសម្រាប់ពាក់លើដើមទ្រូង គឺនៅលើគែមជិតទៅនឹងព្រំខាងក្នុង។
[20]ពួកគេបានធ្វើកងមាសពីរទៀត ហើយបានភ្ជាប់កងនោះទៅនឹងមុមរបស់ស្ទាទីពីរនៃអាវអេផូដដែលនៅខាងមុខ។ ដេរភ្ជាប់វាទៅនឹងខ្សែក្រវាត់របស់អាវអេផូដ។
[21]ពួកគេចងប្រដាប់ពាក់លើដើមទ្រូងដោយចងខ្សែរបស់វាទៅនឹងក្រវិលរបស់អាវអេផូដជាមួយនឹងខ្សែពណ៌ខៀវ ដើម្បីឲ្យវាអាចភ្ជាប់ជាមួយខ្សែក្រវាតខាងលើអាវអេផូដ។
ធ្វើបែបនេះ ដើម្បីឲ្យប្រដាប់ពាក់លើទ្រូងនោះស្ថិតនៅពីលើខ្សែក្រវាត់ ហើយកុំឲ្យរបូតចេញពីអាវអេផូដ។ ធ្វើបែបនេះ ដូចព្រះអម្ចាស់បានបង្គាប់មកលោកម៉ូសេ។
[22]លោកបេតសាលាលបានធ្វើអាវវែងរបស់អាវអេផូដមួយ ដែលត្បាញដោយក្រណាត់ពណ៌ស្វាយសុទ្ធ។[23]គេកាត់ចំហនៅចំកណ្តាលសម្រាប់ស៊កក្បាលចូល។ គេដេររឹម
ជុំវិញប្រឡោះនោះ ដើម្បីកុំឲ្យរហែក។[24]នៅតាមជាយខាងក្រោម ពួកគេធ្វើផ្លែទទឹមពណ៌ស្វាយ ពណ៌ក្រហម និងក្រហមព្រមទាំងក្រណាត់ទេសឯកយ៉ាងស្អាត។
[25]ពួកគេធ្វើកណ្តឹងពីមាសសុទ្ធ ហើយពួកគេដាក់កណ្តឹងនៅចន្លោះ រូបផ្លែទទឹមនៅជុំវិញជាយអាវវែងខាងក្រោម នៅចន្លោះរូបផ្លែទទឹម កណ្តឹងមួយ
និងរូបផ្លែទទឹមមួយ[26]កណ្តឹងមួយរូបផ្លែទទឹមមួយ នៅលើជាងអាវវែងនោះ សម្រាប់លោកអ៊ើរ៉ុន ដើម្បីបម្រើ។ ធ្វើបែបនេះ ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
[27]ពួកគេធ្វើអាវធំពីក្រណាត់ទេសឯកសម្រាប់លោកអ៊ើរ៉ុន និងសម្រាប់កូនប្រុសៗរបស់គាត់។[28]ពួកគេធ្វើឈ្នួតពីក្រណាត់ទេសឯក
សម្រាប់លម្អចងក្បាលពីក្រណាត់ទេសឯក ព្រមទាំងខោស្មាប់ភ្លៅពីសំពត់ខ្លូតទេស។[29]និងខ្សែក្រវាត់ពីក្រណាត់ទេសឯក និងពីក្រណាត់ពណ៌ខៀវ ពណ៌ស្វាយ
និងពណ៌ក្រហមទុំ គឺជាកិច្ចការរបស់អ្នកប៉ាក់។ ធ្វើបែបនេះ ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
[30]ពួកគេធ្វើស្លាកពីមាសសុទ្ធនៃមកុដបរិសុទ្ធ ពួកគេឆ្លាក់នៅលើវា ដូចជាជាឆ្លាក់ត្រាមួយថា៖ «បរិសុទ្ធថ្វាយដល់ព្រះអម្ចាស់»។
[31]ពួកគេភ្ជាប់វាទៅនឹងឈ្នួតក្បាលមានខ្សែពណ៌ខៀវ នៅពីលើឈ្នួតក្បាលនោះ។ ធ្វើបែបនេះ ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
[32]ដូច្នេះ កិច្ចការនៅលើព្រះពន្លា គឺត្រសាលនៃការប្រជុំត្រូវបានបញ្ចប់។ ប្រជាជនអ៊ីស្រាអែលបានធ្វើគ្រប់យ៉ាង។
ពួកគេធ្វើតាមសេចក្តីបង្គាប់ទាំងអស់ដែលព្រះអម្ចាស់បានដល់លោកម៉ូសេ។[33]ពួកគេបានយកព្រះពន្លាមកឯលោកម៉ូសេ គឺត្រសាល និងគ្រឿងបរិក្ខាររបស់វាទាំងអស់ ទាំង
តម្លក់ ស៊ុម រនុក សសរ និងជើងទ្រូរបស់វា[34]គម្របធ្វើពីស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម និងគម្របពីស្បែកផ្សោត ព្រមទាំងវាំងននសម្រាប់ឃាំង[35]ហឹបនៃទីបន្ទាល់
រួមទាំងឈើស្នែងនិងទីសន្តោសប្រោស។
[36]ពួកគេបានយកតុ និងគ្រឿងបរិក្ខាររបស់វា ព្រមទាំងនំប៉័ងដែលដាក់តាំង[37]ជើងចង្កៀងដែលធ្វើពីមាសសុទ្ធ និងចង្កៀងរបស់វានៅតាមជួររបស់វា
ព្រមទាំងគ្រឿងបរិក្ខាររបស់វា និងប្រេងសម្រាប់ចង្កៀង[38]អាសនៈមាស ប្រេងសម្រាប់ចាក់ប្រេងតាំង និងគ្រឿងក្រអូប រនាំងសម្រាប់ច្រកចូលព្រះពន្លា[39]អាសនៈលង្ហិន
ជាមួយនឹងប្រទាសលង្ហិន ព្រមទាំងឈើស្នែងលង្ហិន និងគ្រឿងបរិក្ខារ និងអាងទឹកដ៏ធំមួយជាមួយនឹងជើងទ្រូរបស់វាដែរ។
[40]ពួកគេបានយករនាំងសម្រាប់ទីលានជាមួយនឹងសសរ និងជើងទ្រូរបស់វា ហើយវាំងននសម្រាប់ច្រកចូលទីលាន ខ្សែ ចម្រឹង និងគ្រឿងបរិក្ខារទាំងអស់ សម្រាប់ប្រើប្រាស់
ក្នុងព្រះពន្លា គឺត្រសាលនៃការជួបជុំ។[41]ពួកគេបានយកសម្លៀកបំពាក់សម្រាប់បម្រើនៅក្នុងទីបរិសុទ្ធ គឺសម្លៀកបំពាក់បរិសុទ្ធសម្រាប់លោកអ៊ើរ៉ុន ជាបូជាចារ្យ
និងកូនប្រុសៗរបស់គាត់ ដើម្បីឲ្យពួកគេបានបម្រើក្នុងមុខងារជាបូជាចារ្យ។
[42]ដូច្នេះហើយ ប្រជាជនអ៊ីស្រាអែលបានធ្វើគ្រប់កិច្ចការទាំងអស់ ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។[43]លោកម៉ូសេបានពិនិត្យកិច្ចការទាំងអស់ ហើយមើល៍
ពួកគេធ្វើវាបានសម្រេចហើយ ដូច ព្រះអម្ចាស់បានបង្គាប់មែន គឺពួកគេធ្វើបែបនោះឯង។ បន្ទាប់មក លោកម៉ូសេបានឲ្យពរដល់ពួកគេ។

Exodus 39:1
ព័ត៌មានទូទៅ
ក្រុមការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។
គេធ្វើ
ពាក្យថា « ពួកគេ» សំដៅទៅលើលោកបេតសាលាល លោកអូហូលីអាប់ និងអ្នកធ្វើការផ្សេងទៀត។
ដូចដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
«ដូចព្រះអម្ចាស់ បានប្រាប់ម៉ូសេឲ្យធ្វើ»
Exodus 39:2
ព័ត៌មានទូទៅ
ក្រុមការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។
បេតសាលាល
នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។
Exodus 39:4
ព័ត៌មានទូទៅ
ក្រុមការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។
គឺធ្វើជាបំណែកតែមួយជាមួយនឹងអាវអេផូដ វេញជាមួយនឹងក្រណាត់ទេសឯកយ៉ាងល្អ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត « ពួកគេធ្វើវាជាដុំតែមួយជាមួយអាវអេផូដ ជាមួយនឹងក្រណាត់ទេសឯកស្រស់ៗ»
ដូចព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
«ដូចព្រះអម្ចាស់បានប្រាប់លោកម៉ូសេឲ្យធ្វើ»។
សូមមើលពីរបៀបដែលបកប្រែឃ្លានេះក្នុង ៣៩: ១ ។
Exodus 39:6
ព័ត៌មានទូទៅ
ក្រុមការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។

generated on Wed Sep 10 16:16:32 2025

ឆ្លាក់ត្រា
នេះគឺជាថ្មឆ្លាក់ដែលត្រូវបានប្រើដើម្បីបោះត្រាបង្កើតជាត្រាក្រមួន។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៨:១០ ។
កូនចៅអ៊ីស្រាអែលទាំងដប់ពីរ
«កូនប្រុស ១២ នាក់»
ដូចព្រះអម្ចាស់បានបង្គាប់មកលោកម៉ូសេ។
«ដូចព្រះអម្ចាស់បានប្រាប់ម៉ូសេ ឲ្យ ធ្វើ»។
សូមមើលពីរបៀបដែលបកប្រែឃ្លានេះក្នុង ៣៩: ១ ។
Exodus 39:8
ព័ត៌មានទូទៅ
ក្រុមការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។
គាត់បានធ្វើ
«លោកបេតសាលាលបានធ្វើ» ឬ «លោកបេតសាលាល
និងក្រុមការងារបានបង្កើត»
មួយចំអាម
មួយចំអាមគឺ ២៣ សង្ទីម៉ែត្រ។
Exodus 39:10
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។
ពួកគេបាន
«ក្រុមការងារបានដាំត្បូង ក្នុងប្រដាប់បាំងទ្រូង»
ត្បូងដៃរគៀម... កែវយក់
ភាសាខ្លះប្រហែលជាមិនមានពាក្យសម្រាប់ត្បូងនីមួយៗនោះទេ។
ការពិតសំខាន់គឺថាពួកវាមានតម្លៃនិងខុសពីគ្នា។
សូមមើលពីរបៀបដែលបានបកប្រែទាំងនេះនៅក្នុង ២៨:១៧ ។
ត្បូងទាំងនេះត្រូវបានដាំនៅក្នុងគ្រោងមាស។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត«ពួកគេបានត្រូវដាំត្បូង ក្នុងគ្រោងមាស»
Exodus 39:14
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។
ត្បូងទាំងនោះត្រូវបានរៀបតាមលំដាប់
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ក្រុមការងារបានរៀបចំត្បូង»
Exodus 39:17
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាលផ្លាស់ប្តូរសម្លៀកបំពាក់របស់បូជាចារ្យ។
វេញខ្សែ
ខ្សែដែលធ្វើពីមាសសុទ្ធហើយត្រូវបានគេវេញដូចជាខ្សែពួរ។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៨:១៣ ។
Exodus 39:19
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាល ផ្លាស់ប្តូរសម្លៀកបំពាក់បូជាចារ្យ
ដែលត្រូវបានបង្គាប់នៅក្នុង ២៨:២៥ និង ២៨:២៧ ។
ខ្សែក្រវាត់
ខ្សែក្រវ៉ាត់ - នេះគឺជាខ្សែក្រវ៉ាត់ក្រណាត់ធ្វើពីអំបោះត្បាញតូច
ដែលមនុស្សណាម្នាក់វេញជាមួយគ្នា ដើម្បីធ្វើឱ្យខ្សែអំបោះកាន់តែរឹងមាំ។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៨: ៦ ។
Exodus 39:21
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាល
បន្តធ្វើសម្លៀកបំពាក់របស់បូជាចារ្យតាមបង្គាប់ក្នុង ២៨:២៧ ។
ដើម្បីឲ្យវាអាចភ្ជាប់ជាមួយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះពួកគេអាចភ្ជាប់វាបាន»
ប្រដាប់ពាក់លើដើមទ្រូងដោយចងខ្សែរបស់វាទៅនឹងក្រវិលរបស់អាវអេផូដ
«ប្រដាប់ពាក់លើដើមទ្រូងនឹងនៅជាប់នឹងអាវអេផូដ»
Exodus 39:22
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាល បន្តធ្វើសម្លៀកបំពាក់បូជាចារ្យតាមបង្គាប់ក្នុង ២៨:២៧ ។
លោកបេតសាលាល
នេះជាឈ្មោះនៃមនុស្សប្រុស។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៣១: ១ ។
Exodus 39:25
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាល បន្តធ្វើសម្លៀកបំពាក់បូជាចារ្យតាមបង្គាប់ក្នុង ២៨:២៧ ។
កណ្តឹងពីមាសសុទ្ធ
ទាំងនេះគឺជាកណ្តឹងតូច។
6កណ្តឹងមួយរូបផ្លែទទឹមមួយ
នេះជារបៀបដែលគម្រូត្រូវបានគេសន្មត់ថា
ធ្វើឡើងវិញនៅតាមគែមខាងក្រោមនៃរ៉ូប។
Exodus 39:27
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាល បន្តធ្វើសម្លៀកបំពាក់បូជាចារ្យ
ពួកគេធ្វើ ... បង្គាប់ដល់លោកម៉ូសេ។
សម្រាប់ ៣៩: ២៧-២៩
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ២៨:៣៩ និង ២៨:៤០ និង ២៨:៤២ ។
ឈ្នួត
នេះគឺជាគម្របក្បាលដែលពាក់ដោយមនុស្សប្រុសធ្វើពីក្រណាត់វែងរុំព័ទ្ធជុំវិញក្បាល។
ខោស្មាប់ភ្លៅពីសំពត់
នេះគឺជាសម្លៀកបំពាក់ដែលពាក់នៅក្រោមសម្លៀកបំពាក់ខាងក្រៅជាប់នឹងស្បែក។
ការបកប្រែផ្សេងទៀត «ខោក្នុង»
ខ្សែក្រវាត់
នេះគឺជាក្រណាត់វែងដែលពាក់លើស្មា ឬជុំវិញចង្កេះ។
Exodus 39:30
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាល បន្តធ្វើសម្លៀកបំពាក់បូជាចារ្យតាមបង្គាប់ក្នុង ២៨:២៧ ។
មកុដបរិសុទ្ធ
នេះជាមកុដឆ្លាក់ធ្វើពីមាសសុទ្ធ។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៩: ៥ ។
Exodus 39:32
ព័ត៌មានទូទៅ
ជនជាតិអ៊ីស្រាអែលបញ្ចប់អ្វី ដែលព្រះអម្ចាស់បានបង្គាប់នៅក្នុង ៣៥: ៤ និង ៣៥:១០ ។
ដូច្នេះ កិច្ចការនៅលើព្រះពន្លា គឺត្រសាលនៃការប្រជុំត្រូវបានបញ្ចប់។
ប្រជាជនអ៊ីស្រាអែលបានធ្វើគ្រប់យ៉ាង។
«ព្រះពន្លា» និង «ព្រះពន្លានៃការប្រជុំ» គឺដូចគ្នា។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះប្រជាជនអ៊ីស្រាអែលបានបញ្ចប់កិច្ចការទាំងអស់នៅលើព្រះពន្លា»
តម្ពក់
តម្ពក់សមនឹងកងដើម្បីទប់វាំងននជាមួយគ្នា។
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះនៅក្នុង ២៦: ៤ ។
ជើងទ្រ
ទាំងនេះគឺជាវត្ថុធ្ងន់ៗដែលនៅលើដីហើយរក្សាវត្ថុដែលនៅជាប់នឹងវាពីការផ្លាស់ទីកន្លែង។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៥:៣១ ។
ទីសន្តោសប្រោស
នេះជាគម្របដែលនៅពីលើហឹបដែលតង្វាយប្រោសលោះ។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៥:១៥ ។
Exodus 39:36
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាលបន្តបង្ហាញអ្វីៗទាំងអស់
ដែលពួកគេបានធ្វើដល់លោកម៉ូសេ។
នំប៉័ងដែលដាក់តាំង
នំប៉័ងនេះតំណាងឲ្យវត្តមានរបស់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៥:២៨ ។
ប្រទាស
នេះគឺជាស៊ុមព័ទ្ធជុំវិញដែលទ្រឈើពេលកំពុងឆេះ។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២៧: ៣ ។
Exodus 39:40
ព័ត៌មានទូទៅ
ការងាររបស់លោកបេតសាលាល
បន្តបង្ហាញអ្វីៗទាំងអស់ដែលពួកគេបានធ្វើដល់លោកម៉ូសេ។
ពួកគេបានយក
«ប្រជាជនអ៊ីស្រាអែលបាននាំ»
ព្រះពន្លា គឺត្រសាលនៃការជួបជុំ។
ទាំងនេះសំដៅលើកន្លែងតែមួយ។
Exodus 39:42
ដូច្នេះហើយ ប្រជាជន
"ហើយដូច្នេះប្រជាជន"
មើល៍
ពាក្យថា « មើល៍ » នៅទីនេះទាញការយកចិត្តទុកដាក់ចំពោះព័ត៌មាន
ដែលមាននៅខាងក្រោម។
ដូចព្រះអម្ចាស់បានបង្គាប់ គឺពួកគេធ្វើបែបនោះឯង។
«ពួកគេបានធ្វើវាតាមរបៀបដែលព្រះអម្ចាស់បានបង្គាប់ពួកគេ»

---

40 [1]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[2]«នៅថ្ងៃទីមួយនៃខែទីមួយរបស់ឆ្នាំថ្មី អ្នកត្រូវតម្លើងព្រះពន្លា គឺត្រសាលនៃការជួបជុំ។
[3]អ្នកត្រូវដាក់ហិបនៃទីបន្ទាល់នៅខាងក្នុង ហើយអ្នកត្រូវបាំងហឹបនោះនឹងវាំងនន។[4]អ្នកត្រូវយកតុ ហើយរៀបចំរបស់របរឲ្យមានរបៀបរៀបរយ។ បន្ទាប់មក
អ្នកត្រូវយកជើងចង្កៀង ហើយតម្លើងចង្កៀង។
[5]អ្នកត្រូវដាក់អាសនាមាសថ្វាយគ្រឿងក្រអូបនៅខាងមុខហឹបនៃទីបន្ទាល់ ហើយអ្នកត្រូវដាក់វាំងននៅត្រង់ច្រកចូលទៅក្នុងព្រះពន្លាផង។[6]
អ្នកត្រូវដាក់អាសនាថ្វាយតង្វាយដុតនៅខាងមុខច្រកចូលទៅក្នុងព្រះពន្លា គឺត្រសាលនៃការជួបជុំ។[7]អ្នកត្រូវដាក់អាងទឹកធំនៅចន្លោះត្រសាលនៃការជួបជុំ និងអាសនា
ហើយអ្នកត្រូវចាក់ទឹកចូលទៅក្នុងអាងនោះផង។
[8]អ្នកត្រូវតម្លើងទីលាននៅជុំវិញវា ហើយអ្នកត្រូវចងវាំងននៅច្រកចូលទីលាន។[9]អ្នកត្រូវយកប្រេងចាក់ប្រេងតាំង ហើយចាក់ទៅលើព្រះពន្លា
និងអ្វីៗដែលនៅក្នុងព្រះពន្លានោះ។ អ្នកត្រូវចែកវាដោយឡែក ហើយគ្រឿងបរិក្ខារទាំងអស់សម្រាប់យើង នោះវានឹងបានបរិសុទ្ធ។
[10]អ្នកត្រូវចាក់ប្រេងលើកន្លែងថ្វាយតង្វាយដុត និងលើគ្រឿងបរិក្ខាររបស់វាទាំងអស់ដែរ។ អ្នកត្រូវញែកកន្លែងថ្វាយតង្វាយដុតសម្រាប់យើង
ហើយវានឹងបានជាវិសុទ្ធសម្រាប់យើង។[11]អ្នកត្រូវចាក់ប្រេងលើអាងលង្ហិន និងជើងទ្ររបស់វា ព្រមទាំងញែកវាដោយឡែកសម្រាប់យើង។
[12]អ្នកត្រូវនាំអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់មកកាន់ច្រកចូលត្រសាលនៃការជួបជុំ ហើយអ្នកត្រូវលាងពួកគេដោយទឹក។[13]អ្នកត្រូវស្លៀកពាក់ឲ្យអ៊ើរ៉ុន
ជាមួយនឹងសម្លៀកបំពាក់ដែលបានញែកដោយឡែកសម្រាប់យើង ចាក់ប្រេងលើគាត់ ហើយញែកគាត់ដោយឡែក ដើម្បីគាត់អាចបម្រើជាបូជាចារ្យរបស់យើង។
[14]អ្នកត្រូវនាំកូនប្រុសៗរបស់គាត់ ហើយស្លៀកពាក់ពួកគេជាមួយនឹងអាវធំ។[15]អ្នកត្រូវចាក់ប្រេងពួកគេដូចអ្នកបានចាក់ប្រេងលើឪពុករបស់ពួកគេដែរ
ដើម្បីឲ្យពួកគេអាចបម្រើយើងក្នុងមុខងារជាពួកបូជាចារ្យ។ ការចាក់ប្រេងតាំងលើពួកគេនេះ នឹងធ្វើឲ្យពួកគេក្លាយជាបូជាចារ្យជារៀងរហូតនៅក្នុងគ្រប់ជំនាន់របស់ពួកគេ»។
[16]នេះគឺជាអ្វីដែលលោកម៉ូសេបានធ្វើ គាត់បានធ្វើតាមអ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបង្គាប់ដល់គាត់។ គាត់ធ្វើការទាំងនោះសម្រេចគ្រប់យ៉ាង។
[17]ដូច្នេះ ព្រះពន្លាត្រូវបានតម្លើងនៅថ្ងៃទីមួយនៃខែទីមួយនៅក្នុងឆ្នាំទីពីរ។[18]លោកម៉ូសេបានតម្លើងព្រះពន្លា បានដាក់ជើងទ្ររបស់វាតាមកន្លែងរបស់វា
បានតម្លើងស៊ុមភ្ជាប់ជាមួយនឹងរនុករបស់វា ហើយបានតម្លើងសសរ និងបង្គោលរបស់វា។[19]គាត់បានត្រដាងគ្របពីលើព្រះពន្លា ហើយបានដាក់តង់ពីលើវា
ដូចព្រះអម្ចាស់បានបង្គាប់ដល់គាត់។[20]គាត់បានយកបន្ទះថ្មនៃសម្ពន្ធមេត្រី ហើយដាក់វាចូលទៅក្នុងហឹប។ គាត់ក៏បានដាក់ឈើស្នែងនៅលើហឹប
និងលើទីសន្តោសប្រោសផងដែរ។
[21]គាត់បានយកហឹបចូលទៅក្នុងព្រះពន្លា។ គាត់បានតម្លើងវាំងននសម្រាប់វា ដើម្បីបាំងហឹបនៃទីបន្ទាល់ ដូចព្រះអម្ចាស់បានបង្គាប់ដល់គាត់។
[22]គាត់បានដាក់ទុកនៅក្នុងត្រសាលនៃការជួបជុំ នៅប៉ែកខាងជើងនៃព្រះពន្លា ខាងក្រៅវាំងនន។[23]គាត់បានដាក់នំប៉័ងតាមលំដាប់ នៅចំពោះព្រះអម្ចាស់
ដូចព្រះអម្ចាស់បានបង្គាប់ដល់គាត់។
[24]គាត់បានដាក់ជើងចង្កៀងចូលទៅក្នុងត្រសាលនៃការជួបជុំ ទល់មុខនឹងតុ នៅប៉ែកខាងត្បូងនៃព្រះពន្លា។[25]គាត់បានអុជចង្កៀងនៅចំពោះព្រះអម្ចាស់
ដូចព្រះអម្ចាស់បានបង្គាប់ដល់គាត់។
[26]គាត់បានដាក់អាសនាមាសថ្វាយគ្រឿងក្រអូបទៅក្នុងត្រសាលនៃការជួបជុំនៅខាងមុខវាំងនន។[27]គាត់បានដុតគ្រឿងក្រអូបនៅលើវា ដូចព្រះអម្ចាស់បានបង្គាប់ដល់គាត់។
[28]គាត់បានបាំងវាំងននៅត្រង់ច្រកចូលព្រះពន្លា។[29]គាត់បានដាក់កន្លែងថ្វាយតង្វាយដុតនៅត្រង់ច្រកចូលទៅក្នុងព្រះពន្លា គឺត្រសាលនៃការជួបជុំ។
គាត់បានថ្វាយតង្វាយដុត និងតង្វាយម្សៅនៅលើវា ដូច ព្រះអម្ចាស់បានបង្គាប់ដល់គាត់។[30]គាត់បានដាក់អាងទឹក នៅចន្លោះត្រសាលនៃការប្រជុំ និងកន្លែងថ្វាយតង្វាយ
ហើយគាត់បានចាក់ទឹកចូលទៅក្នុងអាងនោះសម្រាប់លាង។
[31]លោកម៉ូសេ លោកអ៊ើរ៉ុន និងកូនប្រុសៗរបស់គាត់បានលាងដៃរបស់ពួកគេ ហើយនិងជើងរបស់ពួកគេពីអាងទឹកនោះ។[32]នៅពេលពួកគេចូលទៅត្រសាលនៃការប្រជុំ
និងនៅពេលពួកគេឡើងទៅកន្លែងថ្វាយតង្វាយនោះ។ ពួកគេត្រូវលាងសម្អាត ដូច ព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។
[33]លោកម៉ូសេបានតម្លើងទីលាននៅជុំវិញព្រះពន្លា និងកន្លែងថ្វាយតង្វាយ។ គាត់បានតម្លើងវាំងននៅច្រកចូលទីលាន។ លោកម៉ូសេបានធ្វើការចប់សព្វគ្រប់បែបនេះឯង។
[34]បន្ទាប់មក មានពពកគ្របពីលើត្រសាលនៃការជួបជុំនោះ ហើយសិរីល្អរបស់ព្រះអម្ចាស់ស្ថិតនៅពេញព្រះពន្លា។
[35]លោកម៉ូសេមិនអាចចូលទៅក្នុងត្រសាលនៃការជួបជុំបានទេ ដោយសារពពកគ្របពីលើវា ហើយដោយសារសិរីល្អរបស់ព្រះអម្ចាស់ស្ថិតនៅពេញព្រះពន្លា។
[36]នៅពេលណាពពកឡើងផុតពីលើព្រះពន្លា ប្រជាជនអ៊ីស្រាអែលនាំគ្នាចេញដំណើរ។[37]ប៉ុន្តែ ប្រសិនបើ ពពកមិនឡើងផុតពីព្រះពន្លាទេ
ប្រជាជនអ៊ីស្រាអែលមិនចេញដំណើរទេ។ ពួកគេនៅរហូតដល់ថ្ងៃដែលពពកឡើងផុត។[38]ដ្បិត ពពករបស់ព្រះអម្ចាស់ស្ថិតនៅពីលើព្រះពន្លានៅពេលថ្ងៃ
ហើយភ្លើងនៅពីលើវានៅពេលយប់ ដើម្បីបំភ្លឺប្រជាជនអ៊ីស្រាអែលនៅក្នុងការធ្វើដំណើររបស់ពួកគេ។

Exodus 40:1
នៅថ្ងៃទីមួយនៃខែទីមួយរបស់ឆ្នាំថ្មី
ឆ្នាំថ្មីគឺសម្គាល់ជាពេលវេលាដែលព្រះជាម្ចាស់បានជួយសង្គ្រោះប្រជាជនរបស់ព្រះអង្គពី**ស្រុកអេស៊ីប**។
រឿងនេះកើតឡើងនៅពាក់កណ្តាលខែមីនាតាមប្រតិទិនលោកខាងលិច។
Exodus 40:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ដាក់ហឹបនៃទីបន្ទាល់នៅខាងក្នុង
«ដាក់ហឹបនៃសម្ពន្ធមេត្រីនៅក្នុងហឹបដ៏ពិសិដ្ឋ»
បាំងហឹបនោះនឹងវាំងនន។
«ដាក់ហឹបនៅពីក្រោយវាំងនន»
Exodus 40:5
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
មុខហឹបនៃទីបន្ទាល់
នេះសំដៅទៅលើ «ហឹបដ៏ពិសិដ្ឋ»។
Exodus 40:8
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
គ្រឿងបរិក្ខារទាំងអស់
«អ្វីៗទាំងអស់ដែលជាផ្នែករបស់វា»
Exodus 40:12

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
អ្នកត្រូវនាំ
លោកម៉ូសេ នឹងធ្វើការទាំងនេះដោយខ្លួនឯង។
ដែលបានញែកដោយឡែកសម្រាប់យើង
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលអ្នកបានញែកដាច់សម្រាប់យើង»
Exodus 40:14
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
នៅក្នុងគ្រប់ជំនាន់របស់ពួកគេ
«ឆ្លងកាត់គ្រប់ជំនាន់នៃកូនចៅរបស់ពួក» ។
សូមមើលពីរបៀបដែលបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១២:១២ ។
Exodus 40:17
ដូច្នេះ ព្រះពន្លាត្រូវបានតម្លើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះប្រជាជនបានដំឡើងព្រះពន្លា»
នៅថ្ងៃទីមួយនៃខែទីមួយ
នេះសំដៅទៅលើរយៈពេលមួយឆ្នាំបន្ទាប់ពីព្រះជាម្ចាស់បានជួយសង្គ្រោះប្រជាជនរបស់ទ្រង់ពីប្រទេសអេស៊ីប។
រឿងនេះកើតឡើងនៅពាក់កណ្តាលខែមីនាតាមប្រតិទិនលោកខាងលិច។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៤០: ១ ។
ក្នុងឆ្នាំទីពីរ
នេះជាឆ្នាំទីពីរហើយ បន្ទាប់ពីព្រះអម្ចាស់បាននាំប្រជារាស្ត្ររបស់ព្រះអង្គ
ចេញពីស្រុកអេស៊ីប។
លោកម៉ូសេបានតម្លើង
លោកម៉ូសេជាអ្នកដឹកនាំ។ ប្រជាជនបានជួយគាត់ដំឡើងព្រះពន្លា។
បង្គោល
ឈើមួយដុំរឹងមាំដាក់បញ្ឈរ ហើយប្រើជាជំនួយ
Exodus 40:21
គាត់បានយក
លោកម៉ូសេជាអ្នកដឹកនាំ។ គាត់មានក្រុមការងារជួយគាត់។
សម្រាប់វា ដើម្បីបាំង
«នៅខាងមុខ»
Exodus 40:24
គាត់បានដាក់ជើងចង្កៀងចូលទៅក្នុងត្រសាលនៃការជួបជុំ
លោកម៉ូសេបានបង្រៀនក្រុមការងាររបស់គាត់ឲ្យ ផ្លាស់ជើងចង្កៀង។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«ក្រុមការងាររបស់លោកម៉ូសេបានដាក់ជើងចង្កៀងនៅខាងក្នុងព្រះពន្លាដ៏ពិសិដ្ឋ»
Exodus 40:26
នៅខាងមុខវាំងនន
វាំងននេះញែកទីសក្ការៈ ចេញពីទីសក្ការៈបរិសុទ្ធបំផុត។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«នៅពីមុខវាំងននដែលញែកទីបរិសុទ្ធ ពីទីបរិសុទ្ធបំផុត» (សូមមើលfigs-explicit)
Exodus 40:31
លាងដៃរបស់ពួកគេ ហើយនិងជើងរបស់ពួកគេពីអាងទឹកនោះ។
ពួកគេលាងសម្អាតជាមួយទឹកពីអាង។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការបកប្រែ។ ការបកប្រែផ្សេងទៀត
«លោកម៉ូសេ អើរ៉ុន និងកូនប្រុសរបស់ពួកគេបានលាងដៃ និងជើងរបស់ពួកគេជាមួយទឹកពីអាង»
សព្វគ្រប់បែបនេះឯង។
«ហើយដូច្នេះ»
Exodus 40:34
សិរីល្អរបស់ព្រះអម្ចាស់ស្ថិតនៅពេញ
«ព្រះវត្តមានដ៏អស្ចារ្យរបស់ព្រះអម្ចាស់បានបំពេញ»
Exodus 40:36
ឡើងផុតពីលើ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «បានក្រោកឡើងពី»
ដែលពពកឡើងផុត។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ពេលវាងើបឡើង»

លេវីវិន័យ

1 [1]ព្រះអម្ចាស់បានត្រាស់ហៅលោកម៉ូសេ ពីក្នុងពន្លាជួបព្រះអម្ចាស់ថា៖[2]«ចូរប្រកាសដល់ប្រជាជនអ៊ីស្រាអែល និងប្រាប់ពួកគេថា៖
«នៅពេលដែលអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា នាំយកតង្វាយមកថ្វាយព្រះអម្ចាស់ គេត្រូវយកតង្វាយមកជាសត្វ មិនថាសត្វពីហ្វូងសត្វ
ឬពីហ្វូងចៀមរបស់ពួកគេឡើយ។
[3]ប្រសិនបើ គេចង់ថ្វាយតង្វាយដុតទាំងមូល គេត្រូវនាំយកគោឈ្មោលដែលឥតខ្ចោះមួយមកថ្វាយ។ គាត់ត្រូវនាំយកតង្វាយនោះទៅត្រង់ទ្វារចូលនៃព្រះពន្លាជួបព្រះអម្ចាស់
ដើម្បីឲ្យវាអាចទទួលយកបាននៅចំពោះព្រះអម្ចាស់។[4]ម្ចាស់តង្វាយត្រូវដាក់ដៃលើក្បាលសត្វដែលត្រូវថ្វាយជាតង្វាយដុត នោះព្រះអម្ចាស់នឹងទទួលយកតង្វាយនោះ
ហើយអត់ទោសគេឲ្យរួចពីបាប។
[5]បន្ទាប់មក គាត់ត្រូវសម្លាប់គោឈ្មោលនោះនៅចំពោះព្រះអម្ចាស់។ កូនប្រុសរបស់លោកអើរ៉ុន ដែលជាបូជាចារ្យត្រូវយកឈាមគោនោះ
ហើយប្រោះវានៅលើកន្លែងថ្វាយតង្វាយ ដែលជាច្រកចូលនៃព្រះបន្ទាប់ជួបព្រះអម្ចាស់។[6]បន្ទាប់មក គាត់ត្រូវពន្លាត់ស្បែកសត្វដែលថ្វាយជាតង្វាយដុតនោះ
ហើយត្រូវកាត់វាជាដុំៗ។
[7]ពួកបូជាចារ្យជាកូនរបស់បូជាចារ្យ អើរ៉ុន នឹងដាក់ភ្លើងលើអាសនៈរួចបង្គរអុសពីលើភ្លើង។[8]លោកនឹងដាក់ដុំសាច់ដែលបានកាប់នោះគឺក្បាល ខ្លាញ់
ពីលើអុសដែលបានបង្គរលើភ្លើងនៅលើអាសនៈនោះ។[9]ប៉ុន្តែ គ្រឿងក្នុង និងជើងនៃតង្វាយនោះត្រូវលាងសម្អាតជាមួយទឹក។ បន្ទាប់មក
ត្រូវដុតអ្វីៗទាំងអស់នៅលើអាសនៈជាតង្វាយដុតទាំងមូល។ នេះជាតង្វាយដុតទាំងមូល ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់។
[10]ប្រសិនបើ គេយកចៀមមកធ្វើជាតង្វាយដុតទាំងមូល នោះត្រូវឲ្យគេយកចៀមឈ្មោលមួយ ឬពពែឈ្មោលមួយដែលល្អឥតខ្ចោះ។
[11]ម្ចាស់តង្វាយត្រូវសម្លាប់សត្វតង្វាយនោះនៅខាងជើងអាសនៈ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់។ ពួកបូជាចារ្យជាកូនរបស់លោកអើរ៉ុន
នឹងប្រោះឈាមនៃដង្វាយនោះនៅគ្រប់ជ្រុងទាំងរបស់របស់អាសនៈ។
[12]បន្ទាប់មក គេត្រូវកាប់តង្វាយនោះជាដុំៗ រួមទាំងក្បាល និងខ្លាញ់នៃសត្វនោះដែរ រួចបូជាចារ្យដាក់សាច់ទាំងនោះពីលើអុសដែលបង្គរ
លើភ្លើងដែលនៅលើអាសនៈនោះ[13]ប៉ុន្តែ គេត្រូវយកទឹកមកលាងគ្រឿងក្នុងនិងជើងទាំងអស់។ បន្ទាប់មក បូជាចារ្យថ្វាយអ្វីៗទាំងអស់ទៅព្រះអម្ចាស់
ហើយដុតវានៅលើអាសនៈ។ នោះជាតង្វាយដុតទាំងមូល ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់។
[14]ប្រសិនបើ គេយកសត្វស្លាបមកថ្វាយជាតង្វាយដុតទាំងមូល នោះគេត្រូវនាំយកសត្វលលក ឬព្រាបជម្ពើរមកថ្វាយ។[15]បូជាចារ្យត្រូវយកវាមកថ្វាយនៅលើអាសនៈ
ត្រូវកាត់ក្បាលវាចេញ ហើយដុតទាំងមូលនៅលើអាសនៈ។ បន្ទាប់មក ឈាមនៃសត្វនោះ ត្រូវសម្រក់នៅគែមអាសនៈ។
[16]គាត់ត្រូវតែយកគែររបស់វាចេញ ព្រមទាំងបោះវាចោលទៅទិសខាងកើតនៃអាសនៈ កន្លែងដាក់ផេះ។[17]គាត់ត្រូវពុះសត្វនោះត្រង់ចន្លោះស្លាប
តែមិនត្រូវកាត់ផ្តាច់ចេញពីគ្នាទេ។ បន្ទាប់មក ពួកបូជាចារ្យត្រូវដុតវានៅលើអាសនៈ នៅលើអុសដែលបានបង្គរនៅលើភ្លើង។ នេះជាតង្វាយដុតទាំងមូល
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់»។

---

generated on Wed Sep 10 16:16:32 2025

Leviticus 1:1
ព្រះអម្ចាស់
នេះគឺជាព្រះនាមរបស់ព្រះ ដែលទ្រង់បានបង្ហាញដល់ប្រជាជនរបស់ទ្រង់
នៅក្នុងគម្ពីរសញ្ញាចាស់។
សូមមើលទំព័របកប្រែពាក្យអំពីព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។
ពីក្នុងពន្លាជួបព្រះអម្ចាស់ថា៖ «ចូរប្រកាសដល់ប្រជាជនអ៊ីស្រាអែល និងប្រាប់ពួកគេថា៖
«នៅពេលដែលអ្នកណាម្នាក់
នៅទីនេះព្រះអម្ចាស់ចាប់ផ្តើមមានបន្ទូលទៅកាន់លោកម៉ូសេ។
ការមានបន្ទូលនេះបញ្ចប់នៅជំពូក ៣:១៧ ។
នេះអាចត្រូវបានបកប្រែដោយគ្មានការដកស្រង់នៅក្នុងសម្រង់។
ការបកប្រែផ្សេងទៀត «ពីក្នុងពន្លាជួបព្រះអម្ចាស់ និងត្រង់ ប្រាប់លោកម៉ូសេ ឲ្យ
និយាយរឿងនេះទៅកាន់ប្រជាជនអ៊ីស្រាអែលថា «នៅពេលដែលអ្នកណាម្នាក់»
នៅពេលដែលអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា
«នៅពេលដែលអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា» ឬ «នៅពេលដែលអ្នក»
Leviticus 1:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ
នូវអ្វីដែលប្រជាជនត្រូវធ្វើដើម្បីឲ្យព្រះអម្ចាស់ទទួលយញ្ញបូជារបស់ពួកគេ។
ប្រសិនបើ គេចង់ថ្វាយតង្វាយ...គេត្រូវនាំយក
នៅទីនេះ «របស់គេ» និង «គេ» សំដៅទៅលើអ្នកដែលយកតង្វាយ
មកថ្វាយព្រះអម្ចាស់។ វាអាចត្រូវបានបកប្រែជាមនុស្សទីពីរ
ដូចដែលវាមាននៅក្នុងជំពូកទី 1: 1 ។ ការបកប្រែផ្សេងទៀត
«ប្រសិនបើដង្វាយរបស់អ្នក ... អ្នកត្រូវថ្វាយ» (សូមមើល|First, Second or Third Person)
ដើម្បីឲ្យវាអាចទទួលយកបាននៅចំពោះព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះព្រះអម្ចាស់នឹងទទួលយកវា» (សូមមើល|Active or Passive))
ដាក់ដៃលើក្បាល
នេះគឺជាសកម្មភាពនិមិត្តរូប ដែលកំណត់អត្តសញ្ញាណមនុស្ស
ជាមួយសត្វដែលគាត់កំពុងថ្វាយ។
តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វដល់ព្រះអម្ចាស់
ដើម្បីឲ្យព្រះនឹងអត់ទោសបាបរបស់អ្នកនោះ នៅពេលពួកគេសម្លាប់សត្វ។
(សូមមើល|Symbolic Action)
នោះព្រះអម្ចាស់នឹងទទួលយកតង្វាយនោះ ហើយអត់ទោសគេឲ្យរួចពីបាប
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «នោះព្រះអម្ចាស់
នឹងទទួលយកតង្វាយនោះ នៅត្រង់កន្លែងគេនោះ
ហើយអត់ទោសគេឲ្យរួចពីបាប» (សូមមើល|Active or Passive)
Leviticus 1:5
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
បន្ទាប់មក គាត់ត្រូវសម្លាប់គោឈ្មោលនោះ
នៅទីនេះ «គាត់» សំដៅទៅលើអ្នកដែលថ្វាយតង្វាយ។
វាអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីពីរ។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកអ្នកត្រូវសម្លាប់គោនេះ»
នៅចំពោះព្រះអម្ចាស់
«នៅក្នុងវត្តមានរបស់ព្រះអម្ចាស់»
ត្រូវយកឈាម
វាជាការបង្គប់ន័យថា
បូជាចារ្យនឹងចាប់ឈាមនៅក្នុងចានមួយនៅពេលវាបង្ហូរចេញពីសត្វ។
បន្ទាប់មកពួកគេយកចានឈាមនិងឈាមទៅថ្វាយព្រះ អម្ចាស់នៅលើអាសនៈ។
បន្ទាប់មក គាត់ត្រូវពន្លាត់ស្បែកសត្វដែលថ្វាយជាតង្វាយដុតនោះ ហើយត្រូវកាត់វាជាដុំៗ
ដូចដែលបានចង្អុលបង្ហាញនៅក្នុងជំពូក ១: ៩
អ្នកនោះក៏ត្រូវលាងសម្អាតផ្នែកខាងក្នុង និងជើងរបស់សត្វដោយទឹក។
អ្នកនោះត្រូវធ្វើដូច្នេះមុននឹងប្រគល់ចំណែកទៅបូជាចារ្យ
ដើម្បីអោយគេដាក់នៅលើអាសនៈ។ ដូចនៅក្នុង
អ្នកអាចបញ្ជាក់សេចក្តីណែនាំនៅទីនេះគឺផ្នែកខាងក្នុងនិងជើង។
បន្ទាប់មក គាត់ត្រូវពន្លាត់ស្បែក
នៅទីនេះ «គាត់» សំដៅទៅលើអ្នកដែលថ្វាយតង្វាយ។
Leviticus 1:7
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត
នូវអ្វីដែលប្រជាជនត្រូវធ្វើអោយតង្វាយរបស់ពួកគេគាប់ព្រះហឫទ័យដល់ព្រះអង្គ។
នឹងដាក់ភ្លើងលើអាសនៈរួចបង្គរអុសពីលើភ្លើង
នេះអាចមានន័យថាបូជាចារ្យដាក់ធ្យូងក្តៅនៅលើអាសនៈបន្ទាប់មកដាក់អុសលើធ្យូង។
ឬអ្នកអ្នកអាចរៀបចំលំដាក់ពាក្យឡើងវិញវាដូចនៅក្នុង។ ការបកប្រែផ្សេងទៀត
«នឹងដាក់អុសលើអាសនៈហើយបង្កាត់ភ្លើង»
ពីលើភ្លើង
នេះគឺជាពាក្យក្រៀមភាសារដែលមានន័យថាបន្តដាក់អុសទៅក្នុងភ្លើង។
ការបកប្រែពាក្យក្រៀមភាសារនេះដើម្បីឲ្យយល់អត្ថន័យថា
ភ្លើងនៅលើអាសនៈត្រូវតែរក្សាឱ្យឆេះជានិច្ច។ ការបកប្រែផ្សេងទៀត:
«ដើម្បីរក្សាភ្លើងឱ្យឆេះ»
ប៉ុន្តែ គ្រឿងក្នុង និងជើងនៃតង្វាយនោះត្រូវលាងសម្អាតជាមួយទឹក
អ្នកនោះត្រូវធ្វើដូច្នេះមុននឹងប្រគល់ចំណែកទៅបូជាចារ្យអោយដាក់នៅលើអាសនៈ។
អ្នកអាចបញ្ជាក់ពីចំណុចនេះនៅចុងបញ្ចប់ ១: ៥ ។
គ្រឿងក្នុង
នេះគឺជាក្រពះ និងពោះវៀន។
គេត្រូវលាងសម្អាត
នៅទីនេះ «គាត់» សំដៅទៅលើអ្នកដែលថ្វាយតង្វាយ។
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់
ព្រះអម្ចាស់សព្វព្រះហឫទ័យ ជាមួយអ្នកដែលថ្វាយបង្គំទ្រង់ដោយស្មោះស្ម័គ្រ
ដែលថ្វាយដង្វាយយញ្ញបូជាដល់ទ្រង់ ដូចដែលបាននិយាយថា
ព្រះអម្ចាស់សព្វព្រះហឫទ័យ នឹងក្លិននៃដង្វាយដុត។
តង្វាយដែលថ្វាយដល់ព្រះអម្ចាស់ដោយភ្លើង
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលប្រាប់លោកម៉ូសេថាតង្វាយទាំងនោះត្រូវយកទៅដុត។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«តង្វាយដុតថ្វាយដល់ព្រះអម្ចាស់»
Leviticus 1:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូល មកកាន់លោកម៉ូសេទៀតនូវអ្វីដែលប្រជាជនត្រូវធ្វើ
នៅចំពោះព្រះភក្ត្រព្រះអម្ចាស់
«នៅក្នុងវត្តមានរបស់ព្រះអម្ចាស់»
Leviticus 1:12
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត នូវអ្វីដែលប្រជាជនត្រូវធ្វើ
បន្ទាប់មក គេត្រូវកាប់... នោះជាតង្វាយដុតទាំងមូល
សម្រាប់ជំពូក ១: ១២-១៣
សូមមើលពីរបៀបដែលបានបកប្រែពាក្យជាច្រើនទាំងនេះនៅក្នុង ជំពូក១: ៧ ។
បន្ទាប់មក គេត្រូវកាប់
នៅទីនេះ «គេ» សំដៅទៅលើអ្នកដែលថ្វាយយញ្ញបូជា។
វាអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីពីរ។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកអ្នកត្រូវកាត់វាចោល»
បន្ទាប់មក បូជាចារ្យថ្វាយអ្វីៗទាំងអស់ទៅព្រះអម្ចាស់ ហើយដុតវានៅលើអាសនៈ
«បន្ទាប់មក បូជាចារ្យនឹងដុតអ្វីៗទាំងអស់នៅលើអាសនៈ»
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់
ព្រះអម្ចាស់សព្វព្រះហឫទ័យ នឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់
ដែលថ្វាយយញ្ញបូជាគឺដូចដែលបាននិយាយថា
ព្រះសព្វព្រះហឫទ័យនឹងក្លិននៃដង្វាយដុត។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង ១: ៧ ។
តង្វាយដែលថ្វាយដល់ព្រះអម្ចាស់ដោយភ្លើង
ព្រះអម្ចាស់ប្រាប់លោកម៉ូសេថាបូជាចារ្យត្រូវដុតតង្វាយរបស់ពួកគេ។
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«វានឹងជាតង្វាយដុតដល់យើង» ឬ «វាជាតង្វាយដុតដល់ព្រះអម្ចាស់»
Leviticus 1:14
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ត្រូវកាត់ក្បាលវាចេញ
«មួលផ្តាច់ក្បាលរបស់វា»
បន្ទាប់មក ឈាមនៃសត្វនោះ ត្រូវសម្រក់

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកបូជាចារ្យត្រូវសម្រក់ឈាមរបស់វា»
Leviticus 1:16
គាត់ត្រូវ
«បូជាចារ្យត្រូវ»
គែររបស់វាចេញ
គែរគឺជាចង់មួយនៅក្នុងបំពង់ករបស់បក្សី
ដែលជាកន្លែងផ្ទុកមុនពេលរំលាយចំណី។
បោះវាចោលទៅក្បែរអាសនៈ
នៅទីនេះ «វា» សំដៅលើគែរ
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់
ព្រះអម្ចាស់សព្វព្រះហឫទ័យ នឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដែលថ្វាយយញ្ញបូជា
គឺដូចដែលបាននិយាយថា ព្រះសព្វព្រះហឫទ័យ នឹងក្លិននៃដង្វាយដុត។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ១: ៧។
នេះជាតង្វាយដុតទាំងមូល
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«វានឹងជាតង្វាយដុតដល់យើង» ឬ «វាជាតង្វាយដុតដល់ព្រះអម្ចាស់»

---

2 [1]នៅពេលដែលអ្នកណាម្នាក់នាំយកម្សៅមកថ្វាយព្រះអម្ចាស់ តង្វាយរបស់គេនោះត្រូវតែជាម្សៅម៉ដ្ត ហើយគេត្រូវតែលាយជាមួយនឹងប្រេង
ព្រមទាំងដាក់គ្រឿងក្រអូបក្នុងនោះផង។ [2]គេត្រូវយកតង្វាយនោះទៅជូនពួកបូជាចារ្យដែលជាកូនរបស់លោកអើរ៉ុន
ហើយនៅទីនោះបូជាចារ្យនឹងយកម្សៅម៉ដ្តមួយក្តាប់ដែលលាយជាមួយនឹងគ្រឿងក្រអូប រួចបូជាចារ្យត្រូវដុតតង្វាយនៅលើអាសនៈ ដើម្បីទុកជាការរំលឹក។
នេះជាតង្វាយដុត ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់ នេះជាឫង្វាយដុតដែលថ្វាយដល់ព្រះអម្ចាស់។[3]ចំណែកឯ តង្វាយម្សៅឯទៀត
គឺត្រូវបានទៅលើលោកអើរ៉ុន និងកូនៗរបស់លោក គឺជាចំណែកដ៏បរិសុទ្ធបំផុតនៃយញ្ញបូជាដែលគេថ្វាយចំពោះព្រះអម្ចាស់។
[4]ប្រសិនបើ អ្នកថ្វាយតង្វាយជានំដែលចម្អិនក្នុងឡគឺត្រូវតែគ្មានមេតំបែរ វាត្រូវតែជានំប៉័ងទន់ៗដែលធ្វើពីម្សៅម៉ដ្តលាយជាមួយប្រេង ឬជានំប៉័ងលាយប្រេងមិនដាក់មេ។
[5]ប្រសិនបើ តង្វាយដែលយកមកថ្វាយជានំដែលចម្អិនដោយពុម្ព នោះត្រូវធ្វើពីម្សៅម៉ដ្តលាយជាមួយប្រេង តែមិនដាក់ប្រេង។
[6]អ្នកត្រូវតែកាត់នំជាដុំៗ ហើយច្រួចប្រេងពីលើ។ នេះគឺជាតង្វាយម្សៅ។[7]ប្រសិនបើ តង្វាយម្សៅរបស់អ្នកជានំចៀន នោះត្រូវធ្វើនំពីម្សៅម៉ដ្ត និងប្រេង។
[8]អ្នកត្រូវតែនាំយកតង្វាយធម្មជាតិដែលចម្អិនហើយនោះថ្វាយព្រះអម្ចាស់ គឺត្រូវលើកជូនបូជាចារ្យ ហើយលោកបូជាចារ្យនាំយកតង្វាយនោះទៅកាន់អាសនៈ។
[9]បូជាចារ្យយកតង្វាយមួយចំណែកដុតនៅលើអាសនៈ ទុកជាទីរំលឹក។ នោះគឺជាតង្វាយដុត ហើយតង្វាយដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់។
[10]រីឯតង្វាយដែលនៅសល់ត្រូវបានទៅជាចំណែករបស់លោកអើរ៉ុន និងកូនៗរបស់លោក។
នោះគឺជាចំណែកដ៏វិសុទ្ធបំផុតនៃយញ្ញបូជាដែលគេថ្វាយជាតង្វាយដុតចំពោះព្រះអម្ចាស់។
[11]មិនត្រូវយកតង្វាយម្សៅដែលមានមេ ទៅថ្វាយព្រះអម្ចាស់ទេ គឺតង្វាយទាំងប៉ុន្មានដែលអ្នករាល់គ្នាដុតថ្វាយព្រះអម្ចាស់ គឺមិនត្រូវដាក់មេ ឬទឹកឃ្មុំឡើយ។
[12]ត្រូវថ្វាយតង្វាយទាំងនេះដល់ព្រះអម្ចាស់ ជាតង្វាយដែលចេញពីផលដំបូង ប៉ុន្តែ ពួកវាមិនត្រូវបានប្រើនៅលើអាសនៈទុកជាតង្វាយដែលមានក្លិនឈ្ងុយទេ។
[13]អ្នកត្រូវលាយអំបិលជាមួយតង្វាយម្សៅ។ អ្នកមិនត្រូវភ្លេចលាយអំបិលជាមួយតង្វាយម្សៅឡើយ
ព្រោះអំបិលជានិមិត្តរូបនៃសម្ព័ន្ធមេត្រីដែលព្រះអម្ចាស់បានចងជាមួយអ្នក។ ដូច្នេះ គ្រប់តង្វាយរបស់អ្នកត្រូវលាយអំបិល។
[14]ប្រសិនបើ អ្នកយកផលដំបូងនៃចម្រូតរបស់អ្នកទៅព្រះអម្ចាស់ ត្រូវយកគ្រាប់ស្រូវទៅលីង រួចបុកគ្រាប់ស្រូវនោះ ទុកជាតង្វាយផលដំបូង។[15]គេត្រូវដាក់ប្រេង
និងគ្រឿងក្រអូបទៅក្នុងនោះផង នេះជាតង្វាយធញ្ញជាតិ។[16]បន្ទាប់មក បូជាចារ្យនឹងដុត ស្រូវលីងដែលបានបុកលាយជាមួយប្រេងនិងគ្រឿងក្រអូប ទុកជាការរំលឹក។
នេះជាតង្វាយដែលគេដុតថ្វាយព្រះអម្ចាស់។

Leviticus 2:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀតនូវអ្វីដែលប្រជាជនត្រូវធ្វើ។
ត្រូវតែជាម្សៅម៉ដ្ត
«ត្រូវតែជាម្សៅម៉ដ្ត» ឬ «ត្រូវតែជាម្សៅល្អបំផុត»
ម្សៅ
ជាម្សៅម៉្យាងដែលធ្វើពីស្រូវសាលី
គេត្រូវយក
«គេត្រូវតែយក»
មួយក្តាប់
«យកនូវអ្វីដែលដៃបូជាចារ្យអាចកាន់អស់បាន»
ទុកជាការរំលឹក
ដង្វាយម្សៅមួយក្តាប់ជាតង្វាយតំណាងឲ្យម្សៅទាំងអស់។
នេះមានន័យថាតង្វាយទាំងមូលជារបស់ព្រះអម្ចាស់។
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់
ព្រះអម្ចាស់សព្វព្រះហឫទ័យ នឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដែលថ្វាយយញ្ញបូជា
គឺដូចដែលបាននិយាយថា ព្រះសព្វព្រះហឫទ័យនឹងក្លិននៃដង្វាយដុត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១: ៧
នេះជាតង្វាយដុតទាំងមូល
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«វាជាតង្វាយដុតដល់ព្រះអម្ចាស់»
Leviticus 2:4
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត
នូវអ្វីដែលប្រជាជនត្រូវធ្វើអោយតង្វាយរបស់ពួកគេគាប់ព្រះហឫទ័យដល់ព្រះអង្គ។
ដែលចម្អិន
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ដែលអ្នកចម្អិន»
ពុម្ព
នេះប្រហែលជាវត្ថុប្រហោងដែលធ្វើពីដីឥដ្ឋ។ ភ្លើងត្រូវបានបង្កាត់នៅក្រោមឡ
ហើយកំដៅនឹងដុតនំនៅខាងក្នុងឡ។
នំប៉័ងទន់ៗដែលធ្វើពីម្សៅម៉ដ្ត
ត្រូវបានគេដឹងថានំប៉័ងទន់នេះជានំគ្មានដំបែ។
លាយប្រេង
ការបកប្រែត្រង់នេះគឺចង់បញ្ជាក់ថា ប្រេងត្រូវបានលាបពីលើនំ។
ការបកប្រែផ្សេងទៀត «លាយប្រេង»
ប្រសិនបើ តង្វាយដែលយកមកថ្វាយជានំដែលចម្អិនដោយពុម្ព
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ប្រសិនបើ
តង្វាយដែលអ្នកយកមកថ្វាយជានំដែលចម្អិនដោយពុម្ព»
ពុម្ព
គឺជាបន្ទះក្រាស់ដែលធ្វើពីដីឥដ្ឋឬដែក។
បន្ទះពុម្ពនេះត្រូវបានគេដុតនិងភ្លើងហើយគេដាក់នំពីលើវា។
Leviticus 2:6
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត
នូវអ្វីដែលប្រជាជនត្រូវធ្វើអោយតង្វាយរបស់ពួកគេគាប់ព្រះហឫទ័យដល់ព្រះអង្គ។
ត្រូវកាត់នំ
ត្រង់ «នំ» សំដៅលើដង្វាយម្សៅដែលចម្អិនលើបន្ទះដែក
ប្រសិនបើ តង្វាយម្សៅរបស់អ្នកជានំចៀន
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នកចម្អិនតង្វាយម្សៅរបស់អ្នក»
ក្នុងខ្ទះ
ខ្ទះគឺបន្ទះដែកដែលមានរាងមូល។ គេដាក់នំលើខ្ទះរួចចម្អិនលើភ្លើង។
នោះត្រូវធ្វើ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវធ្វើនំ»
Leviticus 2:8
ព័ត៌មានទូទៅ

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត
នូវអ្វីដែលប្រជាជនត្រូវធ្វើអោយតង្វាយរបស់ពួកគេគាប់ព្រះហឫទ័យដល់ព្រះអង្គ។
ដែលចម្អិន
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវចម្អិននំពីម្សៅ និងប្រេង»
លើកជូន
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវលើកជូន»
ហើយលោកបូជាចារ្យ...ជាតង្វាយដុត
សម្រាប់ ជំពូក ២: ៩-១០
សូមមើលពីរបៀបដែលបានបកប្រែពាក្យទាំងនេះជាច្រើននៅក្នុង ជំពូក ២: ១ ។
ទុកជាទីរំលឹក
ដង្វាយម្សៅមួយក្តាប់ជាតង្វាយតំណាងឲ្យម្សៅទាំងអស់។
នេះមានន័យថាតង្វាយទាំងមូលជារបស់ព្រះអម្ចាស់។ សូមមើលការបកប្រែនៅក្នុង ២: ១។
នេះជាតង្វាយដុតទាំងមូល
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«វានឹងជាតង្វាយដុត»
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់
ព្រះអម្ចាស់សព្វព្រះហឫទ័យ នឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដែលថ្វាយយញ្ញបូជា
គឺដូចដែលបាននិយាយថា ព្រះសព្វព្រះហឫទ័យនឹងក្លិននៃដង្វាយដុត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ១: ៧ ។
យញ្ញបូជាដែលគេថ្វាយជាតង្វាយដុតចំពោះព្រះអម្ចាស់។
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ជាតង្វាយដុតចំពោះព្រះអម្ចាស់» (សូមមើលfigs-activepassive)
Leviticus 2:11
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត
នូវអ្វីដែលប្រជាជនត្រូវធ្វើអោយតង្វាយរបស់ពួកគេគាប់ព្រះហឫទ័យដល់ព្រះអង្គ។
មិនត្រូវយកតង្វាយម្សៅដែលមានមេ ទៅថ្វាយព្រះអម្ចាស់ទេ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មិនត្រូវយកតង្វាយម្សៅដែលមានមេ
ដែលអ្នកយកទៅថ្វាយព្រះអម្ចាស់ទេនោះទេ»
ដែលអ្នករាល់គ្នាដុត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត«ជាដង្វាយដុត»
ត្រូវថ្វាយតង្វាយទាំងនេះ
«អ្នកនឹងថ្វាយតង្វាយម្សៅធ្វើពីដំបែ ឬទឹកឃ្មុំ»
ពួកវាមិនត្រូវបានប្រើនៅលើអាសនៈទុកជាតង្វាយដែលមានក្លិនឈ្ងុយទេ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវប្រើពួកវានៅលើអាសនៈទុកជាតង្វាយដែលមានក្លិនឈ្ងុយទេ» ឬ
«អ្នកមិនអាចដុតវាលើអាសនៈ»
អំបិលជានិមិត្តរូបនៃសម្ព័ន្ធមេត្រីដែលព្រះអម្ចាស់បានចងជាមួយអ្នក
វាជាការបង្កប់ន័យថា អំបិលជានិមិត្តរូប
ដែលតំណាងឲ្យការចងសម្ព័ន្ធមេត្រីជាមួយព្រះ។
Leviticus 2:14
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត
នូវអ្វីដែលប្រជាជនត្រូវធ្វើអោយតង្វាយរបស់ពួកគេគាប់ព្រះហឫទ័យដល់ព្រះអង្គ។
លីង រួចបុក
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវចម្អិនដោយភ្លើងរួចបុក»
ទុកជាការរំលឹក
ដង្វាយម្សៅមួយក្តាប់ជាតង្វាយតំណាងឲ្យម្សៅទាំងអស់។
នេះមានន័យថាតង្វាយទាំងមូលជារបស់ព្រះអម្ចាស់។ សូមមើលការបកប្រែនៅក្នុង ២: ១។
នេះជាតង្វាយដែលគេដុតថ្វាយព្រះអម្ចាស់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ជាដង្វាយដុត
ដើម្បីព្រះអម្ចាស់»

---

3 [1]ប្រសិនបើ អ្នកណាម្នាក់ថ្វាយតង្វាយ ជាយញ្ញបូជាមេត្រីភាព ជាសត្វដែលចេញពីហ្វូង ទោះបីគោនោះ ឈ្មោលក្តី ញីក្តី
គេត្រូវតែថ្វាយសត្វដែលល្អឥតខ្ចោះនៅចំពោះព្រះអម្ចាស់។[2]អ្នកថ្វាយត្រូវដាក់ដៃនៅលើក្បាលសត្វដែលជាដង្វាយ
ហើយត្រូវចាក់កសម្លាប់វានៅច្រកចូលព្រះពន្លាជួបព្រះអម្ចាស់។ ពួកបូជាចារ្យ ដែលជាកូនរបស់លោកអើរ៉ុនប្រោះឈាមគោនោះ លើជ្រុងទាំងបួនរបស់អាសនៈ។
[3]យញ្ញបូជាមេត្រីភាពមួយចំណែក នឹងថ្វាយជាតង្វាយដុតចំពោះព្រះអម្ចាស់ គឺខ្លាញ់ដែលរុំប្ញ ខ្លាញ់ដែលជាប់នឹងពោះវៀន។
[4]ហើយក្រលៀនទាំងពីរនិងខ្លាញ់ដែលជាប់នឹងវារហូតដល់ចង្កេះ ព្រមទាំងអ្វីៗទាំងអស់ដែលជាប់នឹងថ្លើម គេផ្តាច់ចេញពីក្រលៀនទាំងអស់។[5]កូនៗរបស់លោកអើរ៉ុន
ដុតរបស់ទាំងនោះនៅលើអាសនៈជាមួយនឹងតង្វាយដុតទាំងមូល នៅលើអុសដែលបង្ករនៅលើភ្លើងនោះ។ នេះគឺជាយញ្ញបូជា ដែលមានក្លិនឈ្ងុយ
ជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់ ។
[6]ប្រសិនបើ យញ្ញបូជាមេត្រីភាព ដែលយកមកថ្វាយព្រះអម្ចាស់នោះជាចៀម ទោះបីជាឈ្មោលក្តី ញីក្តី ត្រូវតែជាសត្វដែលល្អឥតខ្ចោះ។[7]ប្រសិនបើ ថ្វាយកូនចៀម
ជាតង្វាយ នោះត្រូវថ្វាយនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់។[8]គេត្រូវដាក់ដៃលើក្បាលសត្វជាតង្វាយរបស់គាត់ ហើយសម្លាប់វានៅខាងមុខព្រះពន្លាជួបព្រះអម្ចាស់។
កូនៗរបស់លោកអើរ៉ុន នឹងប្រោះឈាមនៃតង្វាយនោះលើជ្រុងទាំងបួនអាសនៈ។
[9]យញ្ញបូជាមេត្រីភាពមួយចំណែក ត្រូវថ្វាយជាតង្វាយដុតថ្វាយព្រះអម្ចាស់។ គឺខ្លាញ់ ខ្លាញ់កន្ទុយទាំងមូលដែលកាត់ផ្តាច់ចេញពីឆ្អឹងខ្នង
ហើយខ្លាញ់ដែលជាប់នឹងពោះវៀន រួមទាំងខ្លាញ់ដែលនៅលើពោះវៀន[10]ក្រលៀនទាំងពីររួមទាំងខ្លាញ់ដែលជាប់ជាមួយ រហូតដល់ចង្កេះ ព្រមទាំងអ្វីៗដែលជាប់នឹងថ្លើម
ដែលគេផ្តាច់ចេញមកជាមួយក្រលៀន។[11]បូជាចារ្យនឹងដុតអ្វីៗទាំងអស់នេះនៅលើអាសនៈ ជាអាហារដែលគេដុតថ្វាយព្រះអម្ចាស់។
[12]ប្រសិនបើ គេយកពពែមកថ្វាយ គេត្រូវថ្វាយនៅចំពោះព្រះអម្ចាស់។[13]គេត្រូវដាក់ដៃលើក្បាលពពែនោះហើយសម្លាប់វានៅខាងមុខព្រះពន្លាជួបព្រះជាម្ចាស់។ បន្ទាប់មក
ពួកកូនរបស់លោកអើរ៉ុនត្រូវប្រោះឈាមនៃតង្វាយនោះលើជ្រុងទាំងបួនរបស់អាសនៈ។[14]តង្វាយមួយចំណែកត្រូវថ្វាយជាតង្វាយដុតថ្វាយព្រះអម្ចាស់។
គឺខ្លាញ់ដែលនៅជាប់នឹងពោះវៀន និងខ្លាញ់ទាំងអស់ដែលនៅលើពោះវៀន។
[15]ក្រលៀនទាំងពីរហើយខ្លាញ់ដែលជាប់នឹងក្រលៀន រហូតដល់ចង្កេះ ព្រមទាំងអ្វីៗដែលជាប់នឹងថ្លើម គេត្រូវកាត់ផ្តាច់ចេញជាមួយក្រលៀន។
[16]បូជាចារ្យនឹងដុតអ្វីៗទាំងអស់នៅលើអាសនៈជាអាហារដុតថ្វាយព្រះអម្ចាស់ ជាក្លិនឈ្ងុយដល់ទ្រង់។ ខ្លាញ់ទាំងអស់ជាចំណែករបស់ព្រះអម្ចាស់។
[17]នេះជាច្បាប់សម្រាប់អ្នករាល់គ្នា ដែលត្រូវអនុវត្តតាមគ្រប់ជំនាន់រហូតតទៅ នៅគ្រប់កន្លែងដែលអ្នករាល់គ្នារស់នៅ គឺអ្នករាល់គ្នាមិនត្រូវបរិភោគខ្លាញ់
ឬឈាមរបស់សត្វនោះទេ។

Leviticus 3:1
ព័ត៌មានទូទៅ
លោកម៉ូសេបន្តប្រាប់ប្រជាជន
នូវអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ពួកគេត្រូវធ្វើ។
នៅចំពោះព្រះភក្ត្រព្រះអម្ចាស់
«នៅក្នុងវត្តមានរបស់ព្រះអម្ចាស់» ឬ «នៅចំពោះព្រះអម្ចាស់»
ដាក់ដៃលើក្បាល
នេះគឺជាសកម្មភាពនិមិត្តរូប ដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វ
ដែលគាត់កំពុងថ្វាយ។ តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនដល់ព្រះអម្ចាស់
តាមរយៈសត្វ។ សូមមើលនៅក្នុង១: ៣។
ពួកបូជាចារ្យ ដែលជាកូនរបស់លោកអើរ៉ុនប្រោះឈាម
វាបញ្ជាក់ថាមុនពេលពួកគេប្រោះឈាម
ពួកគេចាប់ឈាមនៅក្នុងចានមួយនៅពេលដែលវាហូរចេញពីសត្វ។
Leviticus 3:3

generated on Wed Sep 10 16:16:32 2025

គ្រឿងក្នុង
នេះគឺជាក្រពះ និងពោះវៀន។
រហូតដល់ចង្កេះ
នេះគឺជាផ្នែកនៃរាងកាយនៅលើឆ្អឹងខ្នងរវាងឆ្អឹងជំនីនិងឆ្អឹងត្រគាក។
ជាប់នឹងថ្លើម
នេះគឺជាផ្នែកកោងឬរាងមូលនៃថ្លើម។
នេះត្រូវបានគេចាត់ទុកថាជាផ្នែកល្អបំផុតនៃថ្លើមដែលត្រូវបរិភោគ។
ការបកប្រែផ្សេងទៀត «ផ្នែកពិសេសនៃថ្លើម»
ដែលមានក្លិនឈ្ងុយ ជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់
ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដែលថ្វាយយញ្ញបូជាគឺដូចដែលបាននិយាយថា
ព្រះសព្វព្រះហឫទ័យនឹងក្លិននៃដង្វាយដុត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ជំពូក១: ៧ ។
នេះជាតង្វាយដុតទាំងមូល
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«វាជាតង្វាយដុតដល់ព្រះអម្ចាស់»
Leviticus 3:6
ដែលយកមកថ្វាយព្រះអម្ចាស់
«ថ្វាយវានៅចំពោះវត្តមានរបស់ព្រះអម្ចាស់» ឬ «ថ្វាយទៅព្រះអម្ចាស់»។
ដាក់ដៃលើក្បាល
នេះគឺជាសកម្មភាពនិមិត្តរូបដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វ
ដែលគាត់កំពុងថ្វាយ។
តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វដល់ព្រះអម្ចាស់។
កូនរបស់លោកអើរ៉ុនប្រោះឈាម
វាបញ្ជាក់ថាមុនពេលពួកគេប្រោះឈាម
ពួកគេចាប់ឈាមនៅក្នុងចានមួយនៅពេលដែលវាហូរចេញពីសត្វ។
Leviticus 3:9
ត្រូវថ្វាយជាតង្វាយដុត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូចជាតង្វាយដុត»
ខ្លាញ់ ខ្លាញ់កន្ទុយទាំងមូល...ដែលគេផ្តាច់ចេញមកជាមួយក្រលៀន
ត្រង់ឃ្លា «គាត់ផ្តាច់មកជាមួយ» អាចត្រូវបានដាក់នៅដើមនៃប្រយោគ។
ការបកប្រែផ្សេងទៀត «គាត់នឹងយកខ្លាញ់ ខ្លាញ់ទាំងមូល ... ក្រលៀន»
គ្រឿងក្នុង
នេះគឺជាក្រពះ និងពោះវៀន។
ដែលនៅលើពោះវៀន ក្រលៀនទាំងពីរ
ឃ្លាថ្មីថាចាប់ផ្តើមត្រូវនេះថា «ដែលនៅលើពោះវៀន។ គេត្រូវយកក្រលៀនចេញ»
រហូតដល់ចង្កេះ
នេះគឺជាផ្នែកនៃរាងកាយនៅលើឆ្អឹងខ្នងរវាងឆ្អឹងជំនីនិងឆ្អឹងត្រគាក។
ជាប់នឹងថ្លើម
នេះគឺជាផ្នែកកោងឬរាងមូលនៃថ្លើម។
នេះត្រូវបានគេចាត់ទុកថាជាផ្នែកល្អបំផុតនៃថ្លើមដែលត្រូវបរិភោគ។
ការបកប្រែផ្សេងទៀត «ផ្នែកដ៏ពិសេសនៃថ្លើម»
នឹងដុតអ្វីៗទាំងអស់នេះនៅលើអាសនៈ ជាអាហារដែលគេដុតថ្វាយព្រះអម្ចាស់
បកប្រែនេះរបៀបដែលធ្វើឱ្យវាកាន់តែច្បាស់ថាព្រះអម្ចាស់ពិតជាមិនសោយម្ហូបទេ។
ការបកប្រែផ្សេងទៀត
«នឹងដុតរបស់ទាំងនោះនៅលើអាសនៈជាតង្វាយដល់ព្រះអម្ចាស់។
របស់ទាំងនោះនឹងបានមកពីអាហាររបស់អ្នក»
Leviticus 3:12
ដែលមានក្លិនឈ្ងុយ ជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់
«នៅក្នុងវត្តមានរបស់ព្រះអម្ចាស់» ឬ «ចំពោះព្រះអម្ចាស់»
ដាក់ដៃលើក្បាល
នេះគឺជាសកម្មភាពនិមិត្តរូបដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វដែលគាត់កំពុងថ្វាយ។
តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វដល់ព្រះអម្ចាស់។
សូមមើលការបកប្រែនៅក្នុង ១: ៣។
កូនរបស់លោកអើរ៉ុនប្រោះឈាម
បញ្ជាក់ថាមុនពេលពួកគេប្រោះឈាម
ពួកគេចាប់ឈាមនៅក្នុងចានមួយនៅពេលដែលវាហូរចេញពីសត្វ។
តង្វាយមួយចំណែកត្រូវថ្វាយជាតង្វាយដុត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ «នឹងថ្វាយយញ្ញបូជារបស់គេដោយភ្លើង»
ឬ «នឹងដុតការដង្វាយរបស់គេ»
Leviticus 3:15
គេត្រូវ
នៅទីនេះ «គេ» សំដៅទៅលើអ្នកដែលថ្វាយយញ្ញបូជា។
នឹងដុតអ្វីៗទាំងអស់នេះនៅលើអាសនៈជាដង្វាយអាហារដែលគេដុតដោយភ្លើង
បកប្រែនេះរបៀបដែលធ្វើឱ្យវាកាន់តែច្បាស់ថាព្រះអម្ចាស់ពិតជាមិនសោយម្ហូបទេ។
ការបកប្រែផ្សេងទៀត
«នឹងដុតរបស់ទាំងនោះនៅលើអាសនៈជាតង្វាយដល់ព្រះអម្ចាស់។
របស់ទាំងនោះនឹងបានមកពីអាហាររបស់អ្នក ថ្វាយទៅកាន់ព្រះជាម្ចាស់»
ជាក្លិនឈ្ងុយ
ព្រះអម្ចាស់សព្វព្រះហឫទ័យ នឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់
ដែលថ្វាយយញ្ញបូជាគឺដូចដែលបាននិយាយថា ព្រះសព្វព្រះហឫទ័យ
នឹងក្លិននៃដង្វាយដុត។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុង ជំពូក១: ៧ ។
នេះជាច្បាប់សម្រាប់អ្នករាល់គ្នា ដែលត្រូវអនុវត្តតាមគ្រប់ជំនាន់រហូតតទៅ
នេះមានន័យថាពួកគេនិងកូនចៅរបស់ពួកគេត្រូវតែគោរពតាមច្បាប់នេះជារៀងរហូត។
ឬឈាម
«ឬទទួលទានឈាម»

---

4 [1]ព្រះអម្ចាស់មានព្រះបន្ទូលទៅលោកម៉ូសេដូចតទៅ៖[2]«ចូរប្រកាសប្រាប់ជនជាតិអ៊ីស្រាអែលទាំងអស់ថា៖ «ប្រសិនបើ អ្នកណាម្នាក់បានប្រព្រឹត្តអំពើបាបដោយអចេតនា
គឺគេបានធ្វើនូវអ្វីដែលព្រះអម្ចាស់បានហាមប្រាមមិនឲ្យធ្វើ ហើយប្រសិនបើ គេបានធ្វើ ហើយអ្វីដែលគេបានធ្វើនោះជាការដែលបានហាមឃាត់ ត្រូវធ្វើដូចតទៅ
[3]ប្រសិនបើ បូជាចារ្យ បានប្រព្រឹត្តអំពើបាប ដែលនាំឲ្យប្រជាជនទាំងអស់មានបាប នោះលោកត្រូវយកគោឈ្មោលស្ទាវមួយដែលល្អឥតខ្ចោះ
មកថ្វាយព្រះអម្ចាស់ជាយញ្ញបូជារំដោះបាប។
[4]លោកត្រូវនាំគោឈ្មោលស្ទាវនោះទៅច្រកចូលព្រះពន្លាជួបព្រះអម្ចាស់ ហើយលោកត្រូវដាក់ដៃលើក្បាលសត្វនោះ
ហើយសម្លាប់គោឈ្មោលស្ទាវនោះនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់។[5]បូជាចារ្យដែលបានចាក់ប្រេងតាំង នឹងយកឈាមគោស្ទាវមួយចំណែក
ហើយនាំយកចូលទៅក្នុងព្រះពន្លា។
[6]លោកបូជាចារ្យជ្រលក់ម្រាមដៃរបស់លោកទៅក្នុងឈាម ហើយប្រោះប្រាំពីរដងចំពោះព្រះភក្ត្រព្រះអម្ចាស់ ខាងមុខវាំងននទីសក្ការបំផុត។[7]បន្ទាប់មក
លោកបូជាចារ្យនឹងលាបឈាមលើស្នែងអាសនៈគ្រឿងក្រអូប ចំពោះព្រះភក្ត្រព្រះអម្ចាស់ ដែលនៅខាងក្នុងព្រះពន្លាជួបព្រះអម្ចាស់ បន្ទាប់មក
លោកយកឈាមដែលនៅសល់ ទៅចាក់នៅត្រង់ជើងអាសនៈ ធ្វើជាយញ្ញបូជា ដែលនៅត្រង់ច្រកចូលព្រះពន្លាជួបព្រះអម្ចាស់។
[8]គាត់យកខ្លាញ់នៃយញ្ញបូជារំដោះបាបទាំងអស់ ខ្លាញ់ដែលជាប់នឹងពោះវៀន ខ្លាញ់ដែលនៅលើពោះវៀន[9]ក្រលៀនទាំងពីរ
រួមទាំងខ្លាញ់ដែលនៅជាប់នឹងក្រលៀនរហូតដល់ចង្កេះ ព្រមទាំងអ្វីៗដែលជាប់នឹងថ្លើម
ដែលគេកាត់ផ្តាច់ចេញជាមួយក្រលៀន[10]លោកបូជាចារ្យត្រូវដុតចំណែកទាំងនោះនៅលើអាសនៈថ្វាយយញ្ញបូជា ដូចគេដុតចំណែករបស់យញ្ញបូជាមេត្រីភាពដែរ។
[11]ស្បែករបស់គោស្ទាវ សាច់ទាំងអស់ ជាមួយក្បាល និងជើង ព្រមទាំងលាមក[12]គឺផ្នែកទាំងអស់នៃគោស្ទាវ ត្រូវយកទៅក្រៅជំរំ ត្រង់កន្លែងបរិសុទ្ធ
ជាកន្លែងសម្រាប់ចាក់ផេះ និងដុតវានៅលើអុសដែលកំពុងឆេះ។ ពួកគេត្រូវដុតចំណែកទាំងអស់នោះនៅកន្លែងដែ ពួកគេចាក់ផេះ។
[13]ប្រសិនបើ សហគមន៍អ៊ីស្រាអែលទាំងមូលបានប្រព្រឹត្តអំពើបាបដោយអចេតនា
ហើយសហគមន៍បានប្រព្រឹត្តអំពើបាបណាមួយដែលរំលោភលើបទបញ្ជារបស់ព្រះអម្ចាស់
ដែលបណ្តាលឲ្យខ្លួនមានទោសដោយមិនបានដឹង[14]នៅពេលដែលសហគមន៍ទាំងមូលបានដឹងកំហុសនោះយកគេត្រូវយកគោបាមួយទៅថ្វាយព្រះអម្ចាស់

generated on Wed Sep 10 16:16:32 2025

សម្រាប់ជាតង្វាយរំដោះបាប ហើយត្រូវនាំយកគោបានោះទៅមុខព្រះពន្លាជួបព្រះអម្ចាស់។[15]ពួកចាស់ទុំនៃសហគមន៍ទាំងមូល
ត្រូវដាក់ដៃលើក្បាលគោបាចំពោះព្រះភក្ត្រព្រះអម្ចាស់ ហើយត្រូវចាក់សម្លាប់វានៅចំពោះព្រះភក្ត្រព្រះអម្ចាស់។
[16]លោកបូជាចារ្យត្រូវយកឈាមគោបា ចូលទៅក្នុងព្រះដំណាក់ជួបព្រះអម្ចាស់។[17]លោកយកម្រាមដៃជ្រលក់ក្នុងឈាម ហើយប្រោះប្រាំពីរដង នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់
ខាងមុខវាំងនន។
[18]លោកយកឈាមលាបលើស្នែងនៃអាសនៈនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ដែលនៅក្នុងព្រះពន្លា ហើយលោកយកឈាមដែលនៅសល់ ចាក់នៅជើងអាសនៈ
ដែលនៅត្រង់ច្រកចូលព្រះពន្លាជួបព្រះអម្ចាស់។[19]លោកកាត់ខ្លាញ់ទាំងអស់របស់គោបា ហើយដុតនៅលើអាសនៈ។
[20]លោកធ្វើពិធីថ្វាយយញ្ញបូជាគោបានេះ ដូចគ្នានឹងការដែរលោកធ្វើចំពោះគោបាសម្រាប់រំដោះបាបដែរ គឺធ្វើរបៀបដូចគ្នា
ហើយលោកបូជាចារ្យក៏ធ្វើរបៀបនេះជាមួយមនុស្សដែរ ដើម្បីឲ្យគេបានទទួលការអត់ទោស។[21]លោកត្រូវយកគោបានោះទៅខាងក្រៅជំរំ
ហើយដុតវាដូចជាដុតគោបាទីមួយដែរ។ នេះជាតង្វាយលោះបាបសម្រាប់សហគមន៍ទាំងមូល។
[22]នៅពេលដែលអ្នកដឹកនាំបានប្រព្រឹត្តអំពើបាបដោយអចេតនា ដោយបានប្រព្រឹត្តការណាមួយដែលព្រះអម្ចាស់បានហាមមិនឲ្យធ្វើ។
[23]នៅពេលដែលលោកបានដឹងពីកំហុសរបស់លោក គាត់ត្រូវយកពពែឈ្មោលមួយល្អឥតខ្ចោះមកធ្វើជាដង្វាយថ្វាយព្រះអម្ចាស់។
[24]លោកត្រូវដាក់ដៃលើក្បាលពពែឈ្មោលនោះ ហើយចាក់កវាសម្លាប់នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ត្រង់កន្លែងដែលគេសម្លាប់សត្វសម្រាប់ថ្វាយជាតង្វាយដុតទាំងមូល។
[25]លោកបូជាចារ្យត្រូវជ្រលក់ម្រាមដៃរបស់លោកទៅក្នុងឈាមនៃតង្វាយរំដោះបាប ហើយលាបនោះលើស្នែងអាសនៈសម្រាប់តង្វាយដុតទាំងមូល បន្ទាប់មក
គាត់យកឈាមដែលនៅសល់ទៅចាក់នៅជើងអាសនៈតង្វាយដុត។
[26]លោកនឹងដុតខ្លាញ់ទាំងអស់នៅលើអាសនៈ ដូចលោកដុតខ្លាញ់សម្រាប់តង្វាយនៃយញ្ញបូជាមេត្រីភាពដែល។ លោកបូជាចារ្យធ្វើពិធីនេះ ដើម្បីរំដោះបាបមេដឹកនាំ
ហើយគាត់ក៏បានរួចពីបាប»។
[27]ប្រសិនបើ ប្រជាជនណាម្នាក់ប្រព្រឹត្តអំពើបាបដោយអចេតនា ដោយបានប្រព្រឹត្តការណ៍ណាមួយដែលព្រះអម្ចាស់បានហាមមិនឲ្យធ្វើ
ដែលនាំឲ្យគាត់មានទោស[28]ហើយគាត់បានដឹងពីកំហុសរបស់គេ គេត្រូវយកពពែឈ្មោលមួយដែលល្អឥតខ្ចោះសម្រាប់រំដោះបាបដែលគាត់បានប្រព្រឹត្តនោះ។
[29]គេត្រូវដាក់ដៃលើក្បាលពពែឈ្មោលនោះ ហើយចាក់កវាសម្លាប់នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ត្រង់កន្លែងដែលគេសម្លាប់សត្វសម្រាប់ថ្វាយជាតង្វាយដុតទាំងមូល។
[30]លោកបូជាចារ្យត្រូវជ្រលក់ម្រាមដៃរបស់លោកទៅក្នុងឈាមនៃតង្វាយរំដោះបាបនោះ ហើយលាបនោះលើស្នែងអាសនៈសម្រាប់តង្វាយដុតទាំងមូល បន្ទាប់មក
គាត់យកឈាមដែលនោសល់ទៅចាក់នៅជើងអាសនៈតង្វាយដុត។
[31]លោកបូជាចារ្យត្រូវកាត់ខ្លាញ់ទាំងអស់ចេញ ដូចជាកាត់ចេញពីតង្វាយនៃយញ្ញបូជាមេត្រីភាពដែរ។ លោកបូជាចារ្យត្រូវដុតខ្លាញ់ទាំងអស់នោះនៅលើអាសនៈ
ជាក្លិនឈ្ងុយ ជាទីគាត់ព្រះហឫទ័យព្រះអម្ចាស់។ លោកធ្វើពិធីនេះ ដើម្បីរំដោះបាបរបស់អ្នកនោះ ហើយគេក៏រួចពីបាប។
[32]ប្រសិនបើ គេយកចៀមមកថ្វាយជាតង្វាយរំដោះបាប គេត្រូវយកពពែឈ្មោលមួយដែលល្អឥតខ្ចោះ។[33]គេត្រូវដាក់ដៃលើក្បាលនៃតង្វាយរំដោះបាបនោះ
ហើយសម្លាប់វាសម្រាប់ជាតង្វាយលោះបាបនៅកន្លែងដែលពួកគេសម្លាប់តង្វាយដុតទាំងមូល។
[34]លោកបូជាចារ្យត្រូវជ្រលក់ម្រាមដៃរបស់លោកទៅក្នុងឈាមនៃតង្វាយរំដោះបាបនោះ ហើយលាបឈាមនោះលើស្នែងអាសនៈសម្រាប់តង្វាយដុតទាំងមូល បន្ទាប់មក
គាត់យកឈាមដែលនៅសល់ទៅចាក់នៅជើងអាសនៈតង្វាយដុត។[35]លោកបូជាចារ្យកាត់ខ្លាញ់ទាំងអស់ចេញ
ដូចជាខ្លាញ់កូនចៀមគឺកាត់ចេញពីតង្វាយនៃយញ្ញបូជាមេត្រីភាពដែរ ហើយលោកបូជាចារ្យដុតខ្លាញ់ទាំងអស់នោះនៅលើអាសនៈ ជាក្លិនឈ្ងុយ
ជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់។ លោកធ្វើពិធីនេះ ដើម្បីរំដោះបាបរបស់អ្នកនោះ ហើយគេក៏រួចពីបាប។

Leviticus 4:1

ព្រះអម្ចាស់មានព្រះបន្ទូលទៅលោកម៉ូសេដូចតទៅ៖

«ចូរប្រកាសប្រាប់ជនជាតិអ៊ីស្រាអែលទាំងអស់ថា៖ «ប្រសិនបើ អ្នកណាម្នាក់បានប្រព្រឹត្តអំពើបាប»

នេះជាទម្រង់នៅក្នុងសម្រង់។

សម្រង់ផ្ទាល់អាចត្រូវបានបញ្ចាក់ជាសម្រង់ដោយប្រយោល។ការបកប្រែផ្សេងទៀត

«ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេ

ហើយមានព្រះបន្ទូលប្រាប់គាត់អោយប្រាប់ប្រជាជនអ៊ីស្រាអែលថា

«នៅពេលមាននរណាម្នាក់បានប្រព្រឹត្តអំពើបាប»

អ្វីដែលព្រះអម្ចាស់បានហាមប្រាមមិនឲ្យធ្វើ

នេះអាចត្រូវបានបញ្ចាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«ដែលព្រះអម្ចាស់បានហាមប្រជាជនមិនអោយធ្វើ»

ហើយអ្វីដែលគេបានធ្វើនោះជាការដែលបានហាមឃាត់

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «

ប្រសិនបើគេធ្វើអ្វីមួយដែលព្រះអម្ចាស់មិនអនុញ្ញាត»

ត្រូវធ្វើដូចតទៅ

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ការបកប្រែផ្សេងទៀត

«គេត្រូវតែធ្វើដូចតទៅ»

ដែលនាំឲ្យប្រជាជនទាំងអស់មានបាប

នាមអរូបី «អំពើបាប» អាចត្រូវបានបញ្ចាក់ជាគុណនាម។ ការបកប្រែផ្សេងទៀត

«ដើម្បីបណ្តាលឱ្យប្រជាជនមានទោស»

Leviticus 4:4

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀតនូវអ្វីដែលប្រជាជនត្រូវធ្វើ។

លោកត្រូវនាំគោឈ្មោលស្ទាវ

«បូរជាចារ្យជាន់ខ្ពស់ត្រូវនាំគោឈ្មោលមក»

ដាក់ដៃលើក្បាល

នេះគឺជាសកម្មភាពនិមិត្តរូបដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វដែលគាត់កំពុងថ្វាយ។ តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វដល់ព្រះអម្ចាស់។

សូមមើលការបកប្រែនេះនៅក្នុង១:៣។

បូជាចារ្យដែលបានចាក់ប្រេងតាំង នឹងយកឈាមមួយចំណែក

បញ្ជាក់ថាបូជាចារ្យចាប់ឈាមនៅក្នុងចានមួយនៅពេលវាហូរចេញពីសត្វ។

Leviticus 4:6

ប្រោះ

«ស្រោចទឹកវាខ្លះ» ឬ «បំបែកវាខ្លះ»

ស្នែងអាសនៈ

នេះសំដៅទៅលើជ្រុងអាសនៈ។ វាមានរាងដូចស្នែងរបស់គោ។

ការបកប្រែផ្សេងទៀត «ការបង្ហាញនៅជ្រុងនៃអាសនៈ»

ទៅចាក់

«ចាក់ឈាមចេញឲ្យអស់»

ត្រង់ជើងអាសនៈ

«នៅខាងក្រោមអាសនៈ»

Leviticus 4:8

គាត់យក

«បូជាចារ្យនិងយក»

ខ្លាញ់ដែលនៅលើពោះវៀន...នឹងក្រលៀន ដែលគេកាត់ផ្តាច់ចេញ

នៅក្នុងអត្ថបទនេះ «គាត់នឹងកាត់ចោលអ្វីៗទាំងអស់នេះ»

អាចត្រូវបានដាក់នៅដើមនៃប្រយោគ។ការបកប្រែផ្សេងទៀត

«គាត់នឹងកាត់ខ្លាញ់ដែលគ្របដណ្តប់ផ្នែកខាងក្នុង ... ជាមួយតំរងនោម»

ពោះវៀន

នេះគឺជាក្រពះ និងពោះវៀន។

រហូតដល់ចង្កេះ

នេះគឺជាផ្នែកនៃរាងកាយនៅលើឆ្អឹងខ្នងរវាងឆ្អឹងជំនីនិងឆ្អឹងត្រគាក។

ជាប់នឹងថ្លើម

នេះគឺជាផ្នែកកោងឬរាងមូលនៃថ្លើម។

[illegible]គេចាត់ទុកថាជាផ្នែកល្អបំផុតនៃថ្លើមដែលត្រូវបរិភោគ។

ការបកប្រែផ្សេងទៀត «ផ្នែកពិសេសនៃថ្លើម»

generated on Wed Sep 10 16:16:32 2025

Leviticus 4:11

ស្បែក...ផ្នែកទាំងអស់នៃគោ ត្រូវយកទៅក្រៅ

អត្ថបទនេះគឺ «អ្នកនោះនឹងយកផ្នែកទាំងអស់»
អាចត្រូវបានដាក់ជំនួសនៅដើមនៃប្រយោគ។ ការបកប្រែផ្សេងទៀត
«បូជាចារ្យនឹងកាន់ស្បែក...ផ្នែកនៃគោខាងក្រៅ»

ត្រង់កន្លែងបរិសុទ្ធ

កន្លែងមួយដែលស្អាតស្អំ និងសមរម្យសំរាប់ប្រើក្នុងការប្រើប្រាស់
ព្រះទ្រង់សំដៅលើបរិវេនដែលបានសម្អាត់ពិតប្រាកដ។

ពួកគេបានសម្អាតសម្រាប់យើង

ត្រង់នេះ «ពួកគេ» សំដៅទៅលើពួកបូជាចារ្យ ហើយ «យើង»
សំដៅទៅលើព្រះអម្ចាស់។

Leviticus 4:13

ដោយអចេតនា

«មិនបានដឹង»

រំលោភលើបទបញ្ជា

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បានបញ្ជាពួកគេមិនអោយធ្វើ»

ដែលបណ្តាលឲ្យខ្លួនមានទោស

«ហើយពួកគេមានទោស» ឬ «ហើយពួកគេសមនឹងឲ្យព្រះដាក់ទណ្ឌកម្មពួកគេ»

បានដឹងកំហុស

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលពួកគេដឹងថាពួកគេបានធ្វើបាប»

ដាក់ដៃពួកគេលើក្បាល

នេះគឺជាសកម្មភាពនិមិត្តរូបដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វដែលគាត់កំពុងថ្វាយ។
តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វដល់ព្រះអម្ចាស់។
មើលការបកប្រែនៅក្នុង ១:៣

ចាក់សម្លាប់វា

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ហើយពួកគេនឹងសម្លាប់គោ»

Leviticus 4:16

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត នូវអ្វីដែលប្រជាជនត្រូវធ្វើ។

លោកបូជាចារ្យត្រូវយកឈាម

មានន័យថាបូជាចារ្យចាប់ឈាមក្នុងចានដូចឈាមហូរចេញពីគោ។

ខាងមុខវាំងនន

វាបញ្ជាក់ថានេះគឺជាវាំងននៅមុខកន្លែងបរិសុទ្ធបំផុត។

Leviticus 4:18

លោកយក

«បូជាចារ្យនឹងយក»

ស្នែងអាសនៈ

នេះសំដៅទៅលើជ្រុងអាសនៈ។ វាមានរាងដូចស្នែងរបស់គោ។
សូមមើលការបកប្រែនៅក្នុង ៤:៦។

ចាក់

«គាត់និងចាក់ឈាមដែលនៅសល់ »

ខ្លាញ់ទាំងអស់របស់គោបា ហើយដុត

«ខ្លាញ់ទាំងអស់ចេញពីគោហើយដុតបំខ្លាញ់នោះ»

Leviticus 4:20

លោកធ្វើពិធី

«បូជាចារ្យត្រូវធ្វើពិធី»

លោកបូជាចារ្យក៏ធ្វើរបៀបនេះជាមួយមនុស្សដែរ

នាមអរូបី «ដង្វាយធួន» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«បូជាចារ្យនឹងធ្វើពិធីអត់ទោសអំពើបាបរបស់ប្រជាជន»

គេបានទទួលការអត់ទោស

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអត់ទោសឱ្យពួកគេ»

Leviticus 4:22

ដែលព្រះអម្ចាស់បានហាមមិនឲ្យធ្វើ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះបានបញ្ជាប្រជាជនមិនអោយធ្វើ»

នៅពេលដែលលោកបានដឹងពីកំហុសរបស់លោក

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកលោកដឹងថាលោកបានធ្វើបាប»

Leviticus 4:24

លោកត្រូវដាក់ដៃ

«អ្នកដឹកនាំនឹងដាក់ដៃ»

ដាក់ដៃលើក្បាល

នេះគឺជាសកម្មភាពនិមិត្តរូបដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វដែលគាត់កំពុងថ្វាយ។
តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វដល់ព្រះអម្ចាស់។
សូមមើលការបកប្រែនៅក្នុង១:៣។

ចាក់កវាសម្លាប់

«លោកបូជាចារ្យនឹងចាក់កវាសម្លាប់»

នៅចំពោះព្រះភក្ត្រព្រះអម្ចាស់

«នៅក្នុងវត្តមានរបស់ព្រះអម្ចាស់» ឬ «នៅចំពោះព្រះអម្ចាស់»

លោកបូជាចារ្យនឹងយកឈាម

បញ្ជាក់ថាបូជាចារ្យ នឹងចាប់ឈាមនៅក្នុងចានមួយនៅពេលឈាមហូរចេញពីពពែ។

លើស្នែងអាសនៈ

នេះសំដៅទៅលើជ្រុងអាសនៈ។ វាមានរាងដូចស្នែងរបស់គោ។
សូមមើលការបកប្រែនៅក្នុង ៤:៦។

Leviticus 4:26

លោកនឹងដុត

«លោកបូជាចារ្យនឹងដុត»

លោកបូជាចារ្យធ្វើពិធីនេះ ដើម្បីរំដោះបាបមេដឹកនាំ

នាមអរូបី «រំដោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
« បូជាចារ្យនឹងធ្វើដោះបាបឲ្យមេដឹកនាំ»

គាត់ក៏បានរួចពីបាប

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ព្រះអម្ចាស់នឹងអត់ទោសចំពោះកំហុសរបស់មេដឹកនាំ»

Leviticus 4:27

ដែលព្រះអម្ចាស់បានហាមមិនឲ្យធ្វើ

ប្រជាជនអ៊ីស្រាអែលទាំងអស់ត្រូវបានបញ្ជាមិនអោយធ្វើបាបឡើយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានបញ្ជាប្រជាជនមិនអោយធ្វើ»

អំពើរបាបដែលគេបានប្រព្រឹត្តហើយគេដឹងថាគេបានប្រព្រឹត្តបាបនោះ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គេដឹងខ្លួនពីអំពើបាបដែលគេបានធ្វើ»

Leviticus 4:29

ត្រូវដាក់ដៃលើក្បាល

នេះគឺជាសកម្មភាពនិមិត្តរូបដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វដែលគាត់កំពុងថ្វាយ។
តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វ ដល់ព្រះអម្ចាស់។
មើលការបកប្រែនៅក្នុង១:៣។

លោកបូជាចារ្យនឹងយកឈាម

បញ្ជាក់ថាបូជាចារ្យនឹងចាប់ឈាមនៅក្នុងចានមួយនៅពេលឈាមហូរចេញពីសត្វ។

លើស្នែងអាសនៈ

នេះសំដៅទៅលើជ្រុងអាសនៈ។ វាមានរាងដូចស្នែងរបស់គោ។
មើលការបកប្រែនៅក្នុង ៤:៦។

ឈាមដែលនោសល់

«ឈាមទាំងអស់ដែលនៅសល់ក្នុងចាន»

Leviticus 4:31

គេត្រូវកាត់ចេញ

នៅទីនេះ «គេ» សំដៅលើអ្នកដែលថ្វាយដង្វាយយញ្ញបូជា។

ដូចជាកាត់ខ្លាញ់ចេញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូចដែលអ្នកនោះកាត់ខ្លាញ់ចេញ»

នឹងដុតវា

«នឹងដុតខ្លាញ់»

ជាក្លិនឈ្ងុយ ជាទីគាត់ព្រះហឫទ័យព្រះអម្ចាស់

ព្រះអម្ចាស់សព្វព្រះហឫទ័យ
នឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដែលថ្វាយយញ្ញបូជាគឺដូចដែលបាននិយាយថា

generated on Wed Sep 10 16:16:32 2025

ព្រះសព្វព្រះហឫទ័យនឹងក្លិននៃដង្វាយដុត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ជំពូក១: ៧ ។
លោកធ្វើពិធីនេះ ដើម្បីរំដោះបាបរបស់អ្នកនោះ
នាមអរូបី "ដង្វាយធួន" អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«បូជាចារ្យនឹងថ្វាយបាបរបស់បុរសមានបាប»
ហើយគេក៏រួចពីបាប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអត់ទោសបាបរបស់អ្នកនោះ»
Leviticus 4:32
ដាក់ដៃលើក្បាល
នេះគឺជាសកម្មភាពនិមិត្តរូបដែលកំណត់អត្តសញ្ញាណមនុស្សជាមួយសត្វដែលគាត់កំពុងថ្វាយ
តាមរបៀបនេះបុគ្គលនេះកំពុងថ្វាយខ្លួនតាមរយៈសត្វដល់ព្រះអម្ចាស់។
មើលការបកប្រែនៅក្នុង១:៣។
នៅកន្លែងដែលពួកគេសម្លាប់
«នៅកន្លែងដែលពួកបូជាចារ្យសម្លាប់»
Leviticus 4:34
លើស្មែងអាសនៈ
នេះសំដៅទៅលើជ្រុងអាសនៈ។ វាមានរាងដូចស្នែងរបស់គោ។
មើលការបកប្រែនៅក្នុង ៤:៦។
គាត់យកឈាមដែលនៅសល់ទៅចាក់
«គាត់យកឈាមដែលនៅសល់ទាំងអស់ទៅចាក់»
គេត្រូវកាត់ចេញ
នៅទីនេះ «គេ» សំដៅលើអ្នកដែលថ្វាយដង្វាយយញ្ញបូជា
ដូចជាកាត់ខ្លាញ់កូនចៀម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូចដែលអ្នកនោះកាត់ខ្លាញ់កូនចៀមចេញ»
លោកបូជាចារ្យដុត
«លោកបូជាចារ្យដុតខ្លាញ់»
តង្វាយរបស់ព្រះអម្ចាស់ដែលធ្វើដោយភ្លើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«តង្វាយដែលដុតសំរាប់ព្រះអម្ចាស់»
លោកធ្វើពិធីនេះ ដើម្បីរំដោះបាបរបស់អ្នកនោះ
នាមអរូបី «រំដោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
« បូជាចារ្យនឹងធ្វើពិធីរំដោះបាបអ្នកនោះ»
គេក៏រួចពីបាប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអត់ទោសបាបរបស់អ្នកនោះ»

---

5 [1]ប្រសិនបើ អ្នកណាម្នាក់មិនព្រមនិយាយការពិត នៅពេលដែលគាត់ជាសាក្សី បានឮអ្នកណាម្នាក់ស្បថបំពាន នូវអ្វីដែលគាត់បានឃើញ ឬបានឮទេនោះ
គាត់នឹងត្រូវទទួលខុសត្រូវ។[2]ឬប្រសិនបើ អ្នកណាម្នាក់បានប៉ះរបស់អ្វីមួយដែលព្រះអម្ចាស់បានរាប់ថាជារបស់មិនបរិសុទ្ធ ដូចជាប៉ះខ្មោចសត្វព្រៃ
ឬសត្វស្រុកដែលមិនបរិសុទ្ធ ឬខ្មោចសត្វលូនវាដែលមិនបរិសុទ្ធ ទោះបីជាគេប៉ះវាដោយអចេតនាក្តី ក៏គេទៅជាសៅហ្មង ហើយមានបាបដែរ។
[3]ឬប្រសិនបើ អ្នកណាម្នាក់ប៉ះមនុស្សមិនបរិសុទ្ធណាម្នាក់ នោះខ្លួនគេនឹងទៅជាសៅហ្មង នោះធ្វើឲ្យគាត់មានបាប គេនឹងត្រូវទទួលទោស នៅពេលដែលគេដឹងខ្លួន។
[4]ប្រសិនបើ អ្នកណាម្នាក់បានស្បថលេងដោយអចេតនា ទោះជាការអាក្រក់ក្តី ឬល្អក្តី ទោះបីជាអំពើអ្វីក៏ដោយ នៅពេលដែលគេដឹងខ្លួន គេនឹងត្រូវទទួលទោស។
[5]ពេលដែលនរណាម្នាក់មានទោស ដោយប្រព្រឹត្តកំហុសណាមួយខាងលើ គេត្រូវសារភាពអំពើបាបដែលខ្លួនបានប្រព្រឹត្ត។[6]បន្ទាប់មក គេត្រូវនាំយកចៀមញីមួយ
ឬពពែញីមួយមកថ្វាយព្រះអម្ចាស់ ជាតង្វាយរំដោះបាប ហើយលោកបូជាចារ្យនឹងធ្វើពិធីរំដោះបាបឲ្យពួកគេ។
[7]ប្រសិនបើ នរណាម្នាក់មិនមានលទ្ធភាពថ្វាយកូនចៀមទេ នោះគេត្រូវយកលលកពីរ ឬព្រាបជំទើរពីរមកថ្វាយព្រះអម្ចាស់ជាតង្វាយរំដោះបាបសម្រាប់អំពើបាបរបស់គេ
គឺសត្វមួយសម្រាប់តង្វាយយញ្ញបូជារំដោះបាប និងមួយទៀតជាតង្វាយដុតទាំងមូល។[8]គេត្រូវយកសត្វទាំងនោះទៅជូនលោកបូជាចារ្យ
ដែលមុនដំបូងគឺលោកថ្វាយជាតង្វាយរំដោះបាប គឺលោកត្រូវមួលកសត្វនោះ តែមិនកាត់ក្បាលផ្តាច់ចេញពីខ្លួនទេ។[9]បន្ទាប់មក លោកបូជាចារ្យ
យកឈាមមួយចំនួននៃតង្វាយរំដោះបាបនោះប្រោះលើជញ្ជាំងអាសនៈ ហើយលោកចាក់ឈាមដែលនោះសល់នៅត្រង់ជើងអាសនៈ។ នេះជាយញ្ញបូជារំដោះបាប។
[10]បន្ទាប់មក លោកបូជាចារ្យត្រូវថ្វាយសត្វស្លាបទីពីរ ជាតង្វាយដុតទាំងមូល ស្របតាមច្បាប់ ហើយលោកបូជាចារ្យ ធ្វើពិធីនេះ ដើម្បីរំដោះបាបឲ្យគេ
ហើយគេបានរួចពីបាប។
[11]ប្រសិនបើ គេមិនមានលទ្ធភាពថ្វាយលលកពីរ ឬព្រាបជំទើរពីរទេនោះ គេអាចយកម្សៅម៉ដ្ត មួយភាគដប់នៃអេផា មកថ្វាយជាយញ្ញបូជារំដោះបាប។ គេមិនត្រូវដាក់ប្រេង
ឬគ្រឿងក្រអូបទៅក្នុងម៉្សៅនោះទេ ព្រោះជាយញ្ញបូជារំដោះបាប។
[12]គេយកម្សៅនោះទៅជូនបូជាចារ្យ ហើយបូជាចារ្យ យកម្សៅពេញមួយក្តាប់ទុកជាទីរំលឹក ហើយដុតម្សៅនោះលើអាសនៈ
រួមជាមួយយញ្ញបូជាដទៃទៀតនៅចំពោះព្រះអម្ចាស់។ នេះជាតង្វាយរំដោះបាប។[13]បូជាចារ្យ ធ្វើពិធីនេះដើម្បីរំដោះបាបណាមួយដែលអ្នកនោះបានប្រព្រឹត្ត
ហើយគាត់ក៏បានរួចពីបាប។ រីឯចំណែកដែលនៅសល់ ត្រូវបានជារបស់បូជាចារ្យ ដូចជាតង្វាយម្សៅ»។
[14]បន្ទាប់មក ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់លោកម៉ូសេ ថា៖[15]«ប្រសិនបើ អ្នកណាម្នាក់ប្រព្រឹត្តអំពើបាបដោយអចេតនា
គឺបំពានលើក្រឹត្យវិន័យស្តីអំពីវត្ថុសក្ការៈដែលត្រូវថ្វាយព្រះអម្ចាស់ នោះគេត្រូវយកយញ្ញបូជារំដោះបាបរបស់គេថ្វាយព្រះអម្ចាស់។
តង្វាយនោះត្រូវជាចៀមឈ្មោលដែលល្អឥតខ្ចោះពីហ្វូងសត្វរបស់គេ ដែលវាត្រូវមានតម្លៃគិតតាមប្រាក់ដែលគេប្រើក្នុងទីសក្ការៈ ជាចំណែកនៃទីសក្ការៈ
ដូចគ្នានឹងយញ្ញបូជារំដោះបាប។[16]ម៉្យាងអ្នកនោះត្រូវសងព្រះអម្ចាស់សម្រាប់អ្វីដែលគេបានធ្វើខុសក្នុងទំនាក់ទំនងជាមួយអ្វីដែលបរិសុទ្ធ
ហើយគេត្រូវបន្ថែមលើនោះប្រាំភាគរយ ហើយប្រគល់ទៅលោកបូជាចារ្យ។ បូជាចារ្យធ្វើពិធីនេះដើម្បីរំដោះបាបអោយគេ ហើយព្រះអម្ចាស់នឹងអត់ទោសឲ្យគេ។
[17]ប្រសិនបើ អ្នកណាម្នាក់ប្រព្រឹត្តអំពើបាប ដោយមិនដឹងខ្លួន គឺបានប្រព្រឹត្តអំពើណាមួយដែលបំពានលើបទបញ្ជារបស់ព្រះអម្ចាស់
ដែលបណ្តាលឲ្យគេមានទោស[18]គេត្រូវយកចៀមមួយក្បាលដែលល្អឥតខ្ចោះពីហ្វូងសត្វរបស់គេ ទៅជូនលោកបូជាចារ្យ ដោយមិនគិតតាមតម្លៃយញ្ញបូជា
សម្រាប់រំដោះខ្លួនអោយរួចពីបាប។ លោកបូជាចារ្យធ្វើពិធីរំដោះបាបដែលគាត់បានប្រព្រឹត្តដោយអចេតនា ហើយគាត់ក៏បានរួចពីបាប។[19]នេះជាយញ្ញបូជាលោះបាប ដ្បិត
អ្នកនោះពិតជាបានប្រព្រឹត្តខុសចំពោះព្រះអម្ចាស់»។

Leviticus 5:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ជាសាក្សី បានឮអ្នកណាម្នាក់
ច្បាប់និងមេដឹកនាំសាសន៍យូដាទាំងពីរ តម្រូវឲ្យ
ប្រជាជនផ្តល់សក្ខីកម្មប្រសិនបើពួកគេជាសាក្សីចំពោះឧក្រិដ្ឋកម្ម។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ជាសាក្សី
បានឮអ្នកណាម្នាក់ ដែលតុលាការតម្រូវឲ្យគេធ្វើជាសាក្សី»
ព្រះអម្ចាស់បានរាប់ថាជារបស់មិនបរិសុទ្ធ
អ្វីមួយដែលព្រះបានប្រកាសថាមិនសមរម្យសម្រាប់មនុស្សប៉ះ
ឬបរិភោគត្រូវបានគេរាប់ថាជារបស់មិនស្អាតខាងក្នុង នឹងខាងក្រៅ។
ខ្មោច
«សាកសព»
ជាសៅហ្មង
មនុស្សដែលមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះ
ត្រូវបានគេនិយាយថាដូចជាមនុស្សនោះមិនស្អាតស្អំខាងរាងកាយ។
Leviticus 5:3
ប្រសិនបើ អ្នកណាម្នាក់ប៉ះមនុស្សមិនបរិសុទ្ធណាម្នាក់
នាមអរូបី «មិនបរិសុទ្ធ» អាចត្រូវបានចែងថាជាគុណនាម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នកណាម្នាក់ប៉ះអ្វីដែលធ្វើឱ្យមនុស្សម្នាក់មិនស្អាត»

generated on Wed Sep 10 16:16:32 2025

សៅហ្មង
អ្វីមួយដែលព្រះបានប្រកាសថា មិនសមរម្យសម្រាប់ប៉ះមនុស្ស
ឬបរិភោគត្រូវបានគេរាប់ថាជារបស់មិនស្អាតខាងក្នុងនឹងខាងក្រៅ។
អ្នកនោះមិនបានដឹងខ្លួន
«អ្នកនោះមិនដឹងខ្លួន» ឬ «អ្នកនោះមិនបានស្គាល់ដឹងអំពីវា»
ប្រសិនបើ អ្នកណាម្នាក់បានស្បថលេងដោយអចេតនា
នៅទីនេះ «បបូរមាត់» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«បើអ្នកណាស្បថលេង»
ប្រសិនបើ អ្នកណាម្នាក់បានស្បថលេង
នេះមានន័យថាស្បថដោយមិនពិតប្រាកដ។
វាបញ្ជាក់ថាបន្ទាប់ពីបុគ្គលនោះបានស្បថ គឺគាត់មិនអាចធ្វើតាមការស្បថបាន
ឬគាត់ពិតជាមិនចង់ធ្វើតាមការស្បថរបស់គាត់។
Leviticus 5:5
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលមកកាន់លោកម៉ូសេទៀត នូវអ្វីដែលប្រជាជនត្រូវធ្វើ។
លោកបូជាចារ្យនឹងធ្វើពិធីរំដោះបាបឲ្យពួកគេ
នាមអរូបី «រំដោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«បូជាចារ្យនឹងធ្វើពិធីរំដោះបាបអ្នកនោះ»
Leviticus 5:7
នរណាម្នាក់មិនមានលទ្ធភាពថ្វាយកូនចៀមទេ
«ប្រសិនបើគាត់មិនមានប្រាក់គ្រប់គ្រាន់ដើម្បីទិញកូនចៀម»
លោកត្រូវមួលកសត្វនោះ តែមិនកាត់ក្បាលផ្តាច់ចេញ
«គេនឹងសម្លាប់វាដោយមួលករបស់វា និងកាច់បំបាក់ក
ប៉ុន្តែគាត់នឹងមិនដកក្បាលចេញទេ»
Leviticus 5:10
ស្របតាមច្បាប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូចដែលព្រះអម្ចាស់បានណែនាំ»
លោកបូជាចារ្យ ធ្វើពិធីនេះ ដើម្បីរំដោះបាបឲ្យគេ ហើយគេបានរួចពីបាប
នាមអរូបី «រំដោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«លោកបូជាចារ្យ ធ្វើពិធីនេះ ដើម្បីរំដោះបាបឲ្យគេ ហើយគេបានរួចពីបាប»
គេបានរួចពីបាប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះអម្ចាស់នឹងអត់ទោសអោយអ្នកនោះ»
Leviticus 5:11
មួយភាគដប់នៃអេផា
១ អេផាគឺ ២២ លីត្រ។ មួយភាគដប់នៃអេផាគឺប្រហែលពីរលីត្រ។
មួយភាគដប់
នេះគឺជាមួយផ្នែកក្នុងចំណោមដប់ចំណែកស្មើគ្នា។
Leviticus 5:12
គេយក
«គេត្រូវយកម្សៅម៉ដ្ដនោះ»
ទុកជាការរំលឹក
ដង្វាយម្សៅមួយក្តាប់ ជាតង្វាយតំណាងឲ្យម្សៅទាំងអស់។
នេះមានន័យថាតង្វាយទាំងមូលជារបស់ព្រះអម្ចាស់។ មើលការបកប្រែនៅក្នុង
២:១។
លើអាសនៈ រួមជាមួយយញ្ញបូជាដទៃទៀតនៅចំពោះព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
«នៅលើតង្វាយដុតថ្វាយដល់ព្រះអម្ចាស់»
ធ្វើពិធីនេះដើម្បីរំដោះបាប
នាមអរូបី «រំដោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ធ្វើពិធីរំដោះបាប»
គាត់ក៏បានរួចពីបាប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអត់ទោសអោយអ្នកនោះ»
Leviticus 5:14
ធ្វើបាបនឹងអ្វីៗដែលជារបស់ព្រះអម្ចាស់
នេះមានន័យថាអ្នកដែលបានធ្វើបាបដោយមិនថ្វាយដល់ព្រះអម្ចាស់
នូវអ្វីដែលព្រះអម្ចាស់បានបង្គាប់អោយធ្វើ។
ការបកប្រែផ្សេងទៀត«បាបដោយបរាជ័យក្នុងការថ្វាយអ្វីដែលជារបស់ព្រះអម្ចាស់ដល់ព្រះអម្ចាស់»
តម្លៃរបស់វាត្រូវតែមានតម្លៃជាប្រាក់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវកំណត់តម្លៃចៀមឈ្មោលដែលគិតតម្លៃជាប្រាក់»។
តម្លៃគិតតាមប្រាក់ដែលគេប្រើក្នុងទីសក្ការៈ
នេះប្រហែលជាមានន័យថាយ៉ាងហោចណាស់មានវិធីពីរយ៉ាងក្នុងការវាស់វែងប្រាក់រៀល។
នេះសំដៅទៅលើរបៀបដែលបូជាចារ្យនៃទីសក្ការៈថ្លឹងទម្ងន់។ ការបកប្រែផ្សេងទៀត
«ស្តង់ដារផ្លូវការនៅក្នុងក្នុងទីសក្ការៈ»
ប្រាក់
មួយប្រាក់រៀលស្មើរ និងទំងន់១១ក្រាម។
ទីសក្ការៈ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ទីសក្ការៈ ដ៏បរិសុទ្ធ។
ប្រាំភាគរយ
ប្រាំភាគ -
នេះមានន័យថាបុគ្គលនោះត្រូវបង់មួយភាគប្រាំនៃតម្លៃដែលខ្លួនជំពាក់ព្រះអម្ចាស់។
លោកបូជាចារ្យ ធ្វើពិធីនេះ ដើម្បីរំដោះបាបឲ្យគេ
នាមអរូបី «រំដោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«លោកបូជាចារ្យ ធ្វើពិធីនេះ ដើម្បីរំដោះបាបឲ្យគេ»
អ្នកនោះក៏បានរួចពីបាប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអត់ទោសអោយអ្នកនោះ»
Leviticus 5:17
បានបញ្ជាប្រជាជនមិនឱ្យធ្វើ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បានបញ្ជាប្រជាជនមិនឱ្យធ្វើ»
ត្រូវទទួលទោសចំពោះកំហុសរបស់ខ្លួន
កំហុសរបស់មនុស្សម្នាក់ត្រូវបានគេនិយាយថា វាជាវត្ថុដែលបុគ្គលនោះកាន់។
ត្រង់នេះពាក្យថា «កំហុស» តំណាងឱ្យការដាក់ទណ្ឌកម្មចំពោះកំហុសនោះ។
ការបកប្រែផ្សេងទៀត «អ្នកនោះទទួលខុសត្រូវចំពោះកំហុសរបស់គាត់» ឬ
«ព្រះអម្ចាស់នឹងដាក់ទណ្ឌកម្មគាត់ចំពោះអំពើបាបរបស់គាត់»
មានតម្លៃស្មើរនឹងតម្លៃបច្ចុប្បន្ន
នេះមានន័យថាបុគ្គលនោះត្រូវកំណត់ចំនួនចៀមឈ្មោលដែលមានតម្លៃស្មើនឹងការប្រើប្រាស់ស្តង់ដាផ្លូវការ
មើល ៥:១៤។
គាត់ក៏បានរួចពីបាប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអត់ទោសអោយគេ»
អ្នកនោះពិតជាបានប្រព្រឹត្តខុសចំពោះព្រះអម្ចាស់
«ព្រះជាម្ចាស់ចាត់ទុកអ្នកនោះជាអ្នកមានទោស»

6

[1]ព្រះអម្ចាស់មានព្រះបន្ទូលទៅលោកម៉ូសេថា៖[2]«ប្រសិនបើអ្នកណាម្នាក់ប្រព្រឹត្តអំពើបាបដោយបំពានលើវិន័យរបស់ព្រះអម្ចាស់ ដូចជាបំបាត់យកវត្ថុអ្វីមួយពីអ្នកជិតខាង
ឬប្រសិនបើ គាត់បោកប្រាស់ ឬលួចរបស់គេ ឬក៏ហែងយកទ្រព្យជនរួមជាតិរបស់ខ្លួន[3]ឬគេបានកុហក ឬស្បថដោយបំពានថា មិនបានឃើញរបស់ដែលបាត់
នៅពេលដែលបានរកឃើញរបស់នោះ ឬក៏ក្នុងកិច្ចការដូចគ្នានឹងបញ្ហាទាំងនេះ[4]នោះវាបណ្តាលឲ្យគេមានទោស ឬមានបាប គេត្រូវតែសងរបស់ដែលគេបានលួច
ឬបានកំហែងយក ឬត្រូវសងរបស់ដែលបានយកមកបញ្ចាំ ទៅសងម្ចាស់ដើម ឬដែលបានបាត់ វត្ថុដែលបានរកឃើញនោះវិញ។
[5]នៅពេលដែលគេបានដឹងពីកំហុសរបស់ខ្លួន គេត្រូវសងរបស់ដែលគេបានបន្លំយក ឬលួចយកនោះទៅម្ចាស់ដើមវិញ ទាំងបន្ថែមតម្លៃមួយភាគប្រាំលើវត្ថុនោះផង។
[6]បន្ទាប់មក គេត្រូវនាំយកតង្វាយលោះបាបទៅថ្វាយព្រះអម្ចាស់ គឺគេត្រូវយកចៀមឈ្មោលមួយល្អឥតខ្ចោះពីហ្វូងសត្វរបស់ខ្លួន ទៅជូនលោកបូជាចារ្យ
ដោយគិតតាមតម្លៃយញ្ញបូជាលោះបាប។[7]លោកបូជាចារ្យនឹងធ្វើពិធីនេះ សម្រាប់រំដោះបាបដែលអ្នកនោះបានប្រព្រឹត្ត ទោះបីគេបានប្រព្រឹត្តកុំហុសអ្វីក៏ដោយ»។

generated on Wed Sep 10 16:16:32 2025

[8]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[9]«ចូរបង្គាប់អើរ៉ុន និងកូនចៅរបស់គាត់ដូចតទៅ នេះគឺជាក្រឹត្យវិន័យស្តីពីតង្វាយដុតទាំងមូល
ត្រូវរក្សាទុកតង្វាយដុតទាំងមូល នៅលើអាសនៈពេញមួយយប់រហូតដល់ព្រឹក ហើយភ្លើងត្រូវរក្សាឲ្យឆេះរហូត។
[10]បូជាចារ្យត្រូវតែពាក់អាវវែង និងស្លៀកខោខ្លីធ្វើពីក្រណាត់ទេសឯក។ គាត់ត្រូវតែកើបផេះដែលបានពីការបូជាតង្វាយដុតទាំងមូលចេញពីអាសនៈ
ហើយយកវាទៅដាក់ក្បែរអាសនៈ។[11]បន្ទាប់មកលោកត្រូវដោះសម្លៀកបំពាក់របស់លោក ហើយស្លៀកសម្លៀកបំពាក់ដទៃទៀត ដើម្បីយកផេះទៅខាងក្រៅជំរំ
ចាក់នៅកន្លែងបរិសុទ្ធ។
[12]ភ្លើងនៅលើអាសនៈត្រូវតែរក្សាឲ្យឆេះជានិច្ច គឺមិនត្រូវឲ្យរលត់ឡើយ ហើយជារៀងរាល់ព្រឹកបូជាចារ្យត្រូវតែថែមអុសនៅលើអាសនៈ
គាត់ត្រូវដាក់តង្វាយដុតទាំងមូលពីលើ ព្រមទាំងដុតខ្លាញ់នៃយញ្ញបូជាមេត្រីភាពរួមជាមួយផង។[13]ភ្លើងត្រូវតែរក្សាឲ្យឆេះជានិច្ចនៅលើអាសនៈ គឺមិនត្រូវឲ្យរលត់ឡើយ។
[14]នេះគឺជាក្រឹត្យវិន័យស្តីអំពីតង្វាយម្សៅ។ កូនរបស់លោកអើរ៉ុនត្រូវថ្វាយដង្វាយម្សៅនៅចំពោះព្រះភក្ត្រព្រះអម្ចាស់នៅខាងមុខអាសនៈ។
[15]បូជាចារ្យត្រូវយកម្សៅម៉ដ្តពេញមួយក្តាប់ ព្រមទាំងប្រេង និងគ្រឿងក្រអូបទាំងអស់ ដែលមាននៅលើដង្វាយម្សៅ រួចដុតនៅលើអាសនៈទុកជាទីរំលឹក
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់។
[16]រីឯតង្វាយដែលនៅសល់ត្រូវបានជាចំណែករបស់លោកអើរ៉ុន និងកូនៗរបស់គាត់ ពួកគេត្រូវបរិភោគនំបុ័ងឥតមេ នៅក្នុងទីបរិសុទ្ធ
ពួកគេត្រូវបរិភោគនៅទីដ៏សក្ការៈនៅក្នុងព្រះពន្លាជួបព្រះអម្ចាស់។[17]មិនត្រូវដុតនំបុ័ងលាយមេឡើយ។ ដ្បិត យើងបានយកចំណែកពីតង្វាយដុតរបស់យើងឲ្យពួកគេ។
នេះជាចំណែកដ៏វិសុទ្ធបំផុត ដូចយញ្ញបូជារំដោះបាប និងតង្វាយលោះបាបដែរ។[18]គ្រប់ជំនាន់ទាំងអស់ គឺមានតែមនុស្សប្រុសជាពូជពង្សរបស់លោកអើរ៉ុនតែប៉ុណ្ណោះ
ដែលមានសិទ្ធិបរិភោគនំបុ័ងនេះ ដែលជាចំណែកដែលត្រូវញែកចេញពីតង្វាយដុតរបស់ព្រះអម្ចាស់។ អ្វីៗដែលប៉ះនឹងតង្វាយទាំងនេះនឹងបានបរិសុទ្ធ»។
[19]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេសារជាថ្មីថា៖[20]«នេះគឺជាការថ្វាយសម្រាប់លោកអើរ៉ុន
និងកូនៗរបស់គាត់នៅថ្ងៃដែលពួកគេទទួលការចាក់ប្រេងតែងតាំងធ្វើជាបូជាចារ្យ សម្រាប់ព្រះអម្ចាស់ គឺត្រូវយកម្សៅម៉ដ្តទម្ងន់មួយភាគដប់នៃអេផា ទុកជាតង្វាយអចិន្ត្រៃ
គឺពាក់កណ្តាលថ្វាយនៅពេលព្រឹក និងពាក់កណ្តាលថ្វាយនៅពេលល្ងាច។
[21]ត្រូវយកម្សៅលាយជាប្រេង ហើយដុតនៅក្នុងពុម្ព នៅពេលដែលនំឆ្អិនហើយ ត្រូវកាត់នំនេះជាដុំៗ ហើយលើកនំថ្វាយព្រះអម្ចាស់ ជាតង្វាយដែលក្លិនឈ្ងុយ
ជាទីគាប់ព្រះហឫទ័យព្រះអង្គ។[22]កូនប្រុសរបស់មហាបូជាចារ្យ ដែលទទួលការចាក់ប្រេងតាំងជាមហាបូជាចារ្យបន្តពីគាត់ ត្រូវថ្វាយតង្វាយនេះដែរ។
គឺជាតង្វាយដែលត្រូវដុតទាំងអស់ ថ្វាយព្រះអម្ចាស់ ជារៀងរហូត។[23]សម្រាប់បូជាចារ្យតង្វាយម្សៅទាំងអស់ត្រូវដុត គឺមិនត្រូវទុកបរិភោគឡើយ។
[24]ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ សារជាថ្មីថា៖[25]«ចូរនិយាយទៅកាន់អើរ៉ុន និងកូនៗរបស់គាត់ថា នេះគឺជាក្រឹត្យវិន័យស្តីអំពីយញ្ញបូជារំដោះបាប
សត្វនៃយញ្ញបូជារំដោះបាបត្រូវចាក់កសម្លាប់នៅកន្លែងដែលគេសម្លាប់សត្វ សម្រាប់តង្វាយដុតទាំងមូលថ្វាយព្រះជាម្ចាស់។[26]បូជាចារ្យដែលថ្វាយយញ្ញបូជារំដោះបាប
ត្រូវបរិភោគតង្វាយនេះ នៅក្នុងទីធ្លានៃព្រះពន្លាជួបព្រះជាម្ចាស់។
[27]អ្វីៗដែលប៉ះជាមួយនឹងសាច់នេះ គឺបានបរិសុទ្ធទាំងអស់ ហើយប្រសិនបើ ឈាមខ្ចាតប្រឡាក់សម្លៀកបំពាក់ អ្នកត្រូវលាងកន្លែងដែលប្រឡាក់នោះ នៅក្នុងទីដ៏សក្ការៈ។
[28]ប៉ុន្តែ ថ្លាងដីដែលប្រើសម្រាប់ចម្អិនសាច់នោះ ត្រូវបំបែកចោល បន្ទាប់ពីចម្អិនហើយ។ ប្រសិនបើ ប្រើថ្លាងលង្ហិនចម្អិនសាច់ បន្ទាប់ពី ប្រើហើយ ត្រូវយកថ្លាងនោះទៅដុស
និងលាងសម្អាតក្នុងទឹក។
[29]មានតែប្រុសៗក្នុងចំណោមបូជាចារ្យប៉ុណ្ណោះដែលមានសិទ្ធិបរិភោគសាច់នេះ ព្រោះជារបស់ដ៏បរិសុទ្ធ។[30]ប៉ុន្តែ
សម្រាប់សាច់នៃយញ្ញបូជារំដោះបាបដែលគេយកឈាមចូលទៅក្នុងព្រះពន្លាជួបព្រះអម្ចាស់ សម្រាប់ពិធីរំដោះបាប មិនត្រូវបរិភោគទេ គឺត្រូវដុតទាំងអស់។

Leviticus 6:1

បំពានលើវិន័យរបស់ព្រះអម្ចាស់

«មិនគោរពបទបញ្ញត្តិមួយរបស់ព្រះអម្ចាស់»

បំបាត់យករបស់អ្វីមួយពីអ្នកជិតខាង ឬប្រសិនបើ គាត់បោកប្រាស់

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«និយាយកុហកអ្នកជិតខាងរបស់គាត់ អំពីអ្វីមួយដែលអ្នកជិតខាងឱ្យគាត់ខ្ចី»

អ្នកជិតខាង

ត្រង់នេះ «អ្នកជិតខាង» មានន័យថាជាជនជាតិអ៊ីស្រាអែលណាមួយ
មិនមែនត្រឹមតែអ្នកដែលរស់នៅក្បែរនោះទេ។

យកអ្វីដែលត្រូវបានប្រគល់ឱ្យគាត់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«មិនបានប្រគល់អ្វីដែលគាត់បានខ្ចីទេ»

Leviticus 6:5

សងគ្រប់ចំនួន

«គ្រប់ចំនួន» ឬ «ទាំងស្រុង»

បន្ថែមប្រាំភាគរយ

ប្រាំភាគ -

នេះមានន័យថាបុគ្គលនោះត្រូវសងមកវិញនូវអ្វីដែលគាត់ជំពាក់នរណាម្នាក់
ហើយត្រូវបង់បន្ថែមមួយភាគប្រាំនៃតម្លៃ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ៥:១៤ ។

បង់ឱ្យគាត់ដែលអ្នកណាត្រូវជំពាក់

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«ដើម្បីសងអ្នកដែលគាត់ជំពាក់»

គេបានដឹងពីកំហុស

អ្នកដែលបានលួចនឹងត្រូវនាំខ្លួនទៅកាន់ចៅក្រមហើយត្រូវបានប្រកាសថាមានទោស។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«ចៅក្រមប្រកាសថាគាត់មានកំហុស»

មានតម្លៃស្មើនឹងតម្លៃបច្ចុប្បន្ន

នេះមានន័យថាបុគ្គលនោះត្រូវកំណត់ថាតើចៀមឈ្មោលមានតម្លៃប៉ុន្មានដោយប្រើស្តង់ដារបច្ចុប្បន្ន

អ្នកអាចធ្វើឱ្យច្បាស់នូវព័ត៌មានដែលបានយល់។

សូមមើលពីរបៀបដែលការបកប្រែនេះត្រូវបានបកប្រែនៅក្នុង ៥:១៤ ។

លោកបូជាចារ្យ ធ្វើពិធីនេះ ដើម្បីរំដោះបាបឲ្យគេ

នាមអរូបី «រំដោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត

«លោកបូជាចារ្យ ធ្វើពិធីនេះ ដើម្បីរំដោះបាបឲ្យគេ»

នៅចំពោះព្រះភក្ត្រព្រះអម្ចាស់

«នៅក្នុងវត្តមានរបស់ព្រះអម្ចាស់»

គាត់ក៏បានរួចពីបាប

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«ព្រះអម្ចាស់នឹងអត់ទោសអោយគេ»

Leviticus 6:8

ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ 9«ចូរបង្គាប់អើរ៉ុន និងកូនចៅរបស់គាត់ដូចតទៅ

នេះគឺជាក្រឹត្យវិន័យ

នេះមានសម្រង់នៅក្នុងសម្រង់មួយ។

សម្រង់ផ្ទាល់អាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត

«បន្ទាប់មកព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេ
ហើយប្រាប់អោយបញ្ជាអើរ៉ុននិងកូន ៗ របស់គាត់ថា នេះជាក្រឹត្យវិន័យ»

ត្រូវតែនៅលើអាសនៈ

«ត្រូវតែនៅលើអាសនៈ»

អាសនៈនឹងរក្សាឲ្យនៅតែឆេះ

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«អ្នកត្រូវតែរក្សាអណ្តាតភ្លើងនៅលើអាសនៈអោយឆេះ»

Leviticus 6:10

សំលៀកបំពាក់ធ្វើពីក្រណាត់ទេសឯក

ក្រណាត់ទេសឯកគឺជាក្រណាត់ពណ៌សុ។ ការបកប្រែផ្សេងទៀត

«ជាសំលៀកបំពាក់ក្រណាត់ពណ៌សរបស់គាត់»

គាត់ត្រូវតែកើបផេះ

«គាត់នឹងប្រមូលផេះ»

ដង្វាយដុតទាំងមូល

generated on Wed Sep 10 16:16:32 2025

ភ្លើងឆេះតង្វាយដុតទាំងស្រុង គឺនិយាយថាភ្លើងឆេះ ឬប្រើប្រាស់ដង្វាយដុត។
ទៅកន្លែងស្អាត
កន្លែងដែលសមនឹងប្រើសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយថាវាស្អាត។
Leviticus 6:12
ភ្លើងនៅលើអាសនៈត្រូវតែរក្សាឲ្យឆេះជានិច្ច
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បូជាចារ្យនឹងរក្សាអណ្តាតភ្លើងអោយឆេះនៅលើអាសនៈ»។
ដូចដែលបានតម្រូវ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នៅលើដូចដែលព្រះអម្ចាស់តម្រូវ»
Leviticus 6:14
ដែលមានក្លិនឈ្ងុយ
ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់
ដែលបានថ្វាយយញ្ញបូជាគឺហាក់ដូចជាព្រះសព្វព្រះហឫទ័យនឹងក្លិននៃគ្រឿងបូជា។
មើលការបកប្រែស្រដៀងគ្នានៅក្នុង ១:៧។
ថ្វាយទុកជាទីរំលឹក
ដង្វាយម្សៅមួយក្តាប់តូចជាតង្វាយម្សៅទាំងមូល។
នេះមានន័យថាតង្វាយទាំងមូលជារបស់ព្រះអម្ចាស់។
សូមមើលការបកប្រែនៅក្នុង២:១។
Leviticus 6:16
ត្រូវបរិភោគ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវតែបរិភោគ»
មិនត្រូវដុតនំប៉័ងលាយមេឡើយ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត«កុំដុតនំជាមួយដំបែ»
ការថ្វាយដង្វាយដោយភ្លើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «តង្វាយដុត»
អ្នកដែលប៉ះនឹងតង្វាយទាំងនេះនឹងបានបរិសុទ្ធ
នេះជាការព្រមានដែលបញ្ជាក់ថាអ្នកដែលមិនមែនជាកូនចៅរបស់អើរ៉ុន
មិនត្រូវប៉ះដង្វាយនេះទេ។
អត្ថន័យពេញលេញនៃសេចក្តីនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
Leviticus 6:19
នៅថ្ងៃដែលពួកគេទទួលការចាក់ប្រេងតែងតាំង
នេះបញ្ជាក់ថាពួកគេនឹងត្រូវចាក់ប្រេងតាំងនៅពេលពួកគេក្លាយជាបូជាចារ្យ។
អត្ថន័យពេញលេញនៃអត្ថបទនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
នេះក៏អាចត្រូវបានបញ្ជាក់ជាទម្រង់សកម្មផងដែរ។ ការបកប្រែផ្សេងទៀត
«នៅពេលដែលគាត់ចាក់ប្រេងតែងតាំងកូនប្រុសគាត់ម្នាក់ៗ
តែងតាំងពួកគេជាបូជាចារ្យ» (សូមមើល និងfigs-activepassive)
មួយភាគដប់នៃអេផា
មួយអេផាគឺ ២២ លីត្រ។ មួយភាគដប់នៃអេផាគឺប្រហែល ២ លីត្រ។
មួយភាគដប់
នេះគឺជាផ្នែកមួយនៃដប់ផ្នែកស្មើគ្នា។
Leviticus 6:21
ត្រូវធ្វើពី
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកនឹងធ្វើវាពី»
ដុតនៅក្នុងពុម្ព
នេះគឺជាចានក្រាស់ដែលធ្វើពីដីឥដ្ឋឬដែក។ ចានត្រូវបានដាក់នៅលើភ្លើងហើយ
នុំត្រូវបានចម្អិននៅលើចាន។ សូមមើលការបកប្រែ«បន្ទះដែករាបស្មើ» នៅក្នុង 2:
4 ។
នៅពេលបានជ្រលក់
«នៅពេលម្សៅបានជ្រលក់ជោគជាមួយប្រេង»
ហើយអ្នកត្រូវលើក
នៅទីនេះ «អ្នក» សំដៅលើអ្នកដែលថ្វាយយញ្ញបូជា។
ដែលក្លិនឈ្ងុយ ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដែលបានថ្វាយយញ្ញបូជាគឺដូចជាព្រះសព្វព្រះហឫទ័យនឹងក្លិនដង្វាយដុត
សូមមើលការបកប្រែនៅក្នុង ១:៧។
ដូចដែលបានបង្គាប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដូចដែលព្រះអម្ចាស់បានបញ្ជាអ្នក»
តង្វាយដែលត្រូវដុតទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែដុតវាទាំងអស់»
នឹងត្រូវបានដុតទាំងស្រុង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែដុតដង្វាយទាំងស្រុង»
មិនត្រូវទុកបរិភោគឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់ត្រូវបរិភោគវាទេ»
Leviticus 6:24
ព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ សារជាថ្មីថា៖ «ចូរនិយាយទៅកាន់អើរ៉ុន
និងកូនៗរបស់គាត់ថា នេះគឺជាក្រឹត្យវិន័យ
នេះមានសម្រង់នៅក្នុងសម្រង់មួយ។
សម្រង់ផ្ទាល់អាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានមានព្រះបន្ទូលមកកាន់លោកម៉ូសេម្តងទៀត
ហើយប្រាប់អោយគាត់និយាយទៅកាន់លោកអើរ៉ុននិងកូន ៗ របស់គាត់ថា
នេះជាក្រឹត្យវិន័យ»
និយាយទៅកាន់លោកអើរ៉ុននិងកូន ៗ របស់គាត់
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអើរ៉ុន និងកូនៗរបស់គាត់
ប៉ុន្តែបទបញ្ជាទាំងនេះត្រូវអនុវត្តចំពោះបូជាចារ្យទាំងអស់
ដែលថ្វាយយញ្ញបូជាទាំងនេះ។
អត្ថន័យពេញលេញនៃប្រយោគនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
យញ្ញបូជារំដោះបាបគឺត្រូវសំលាប់...នៅចំពោះព្រះជាម្ចាស់
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថានេះសំដៅទៅលើផ្នែកខាងជើងនៃអាសនៈ។
មើល១:១០។
យញ្ញបូជារំដោះបាបគឺត្រូវសំលាប់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវសំលាប់ដង្វាយលោះបាប»
កន្លែងដែលគេថ្វាយតង្វាយដុត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«កន្លែងដែលអ្នកសំលាប់សត្វសំរាប់ដង្វាយដុត»
នៅចំពោះព្រះជាម្ចាស់
«ថ្វាយចំពោះព្រះជាម្ចាស់»
ត្រូវបរិភោគ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែបរិភោគវា»
Leviticus 6:27
អ្នកដែលប៉ះនឹងតង្វាយទាំងនេះនឹងបានបរិសុទ្ធ
នេះជាការព្រមានដែលបញ្ជាក់ថា អ្នកដែលមិនមែនជាកូនចៅរបស់អើរ៉ុន
មិនត្រូវប៉ះដង្វាយនេះទេ។
អត្ថន័យពេញលេញនៃសេចក្តីនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ប្រសិនបើ ឈាមខ្ចាតប្រឡាក់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើឈាមប្រោះលើ»
ថ្លាងដីដែលប្រើសម្រាប់ចម្អិនសាច់នោះ ត្រូវបបែក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែបំបែកឆ្នាំងដីឥដ្ឋដែលអ្នកបានស្ងោរសាច់»
ប្រសិនបើវាត្រូវបានដាំឱ្យពុះក្នុងឆ្នាំងស្ពាន់វាត្រូវយកទៅកោសនិងលាងជម្រះឱ្យស្អាតក្នុងទឹក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នកដាំសាច់ដាក់ក្នុងឆ្នាំងស្ពាន់
បន្ទាប់មកអ្នកត្រូវដុសខាត់ហើយលាងសំអាតវាដោយទឹកស្អាត»
Leviticus 6:29
មិនត្រូវបរិភោគតង្វាយលោះបាបឡើយ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គ្មានអ្នកណាម្នាក់អាចស៊ីនូវអ្វីដែលថ្វាយជាដង្វាយដុតបានឡើយ»
គេយកឈាមចូលទៅក្នុងព្រះពន្លាជួបព្រះអម្ចាស់
នេះអាចត្រូវបានបកប្រែជា
ត្រូវដុតទាំងអស់

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បូជាចារ្យត្រូវដុតវាចោល»

---

7 [1]នេះគឺជាក្រឹត្យវិន័យអំពីយញ្ញបូជារំដោះបាប ជាតង្វាយដ៏វិសុទ្ធ។[2]ត្រូវសម្លាប់សត្វសម្រាប់យញ្ញបូជារំដោះបាបនៅកន្លែងដែលត្រូវសម្លាប់
ហើយត្រូវប្រោះឈាមរបស់សត្វនោះលើជញ្ជាំងអាសនៈ។[3]ខ្លាញ់ទាំងអស់ រួមមានខ្លាញ់ដែលជាប់កន្ទុយ ខ្លាញ់ដែលជាប់នឹងពោះវៀន[4]ក្រលៀនទាំងពីរ
រួមទាំងខ្លាញ់ដែលជាប់ជាមួយរហូតដល់ចង្កេះ និងអ្វីៗទាំងអស់ដែលជាប់ជាមួយថ្លើម ត្រូវកាត់ផ្តាច់ចេញជាមួយក្រលៀន។
[5]បូជាចារ្យត្រូវដុតផ្នែកទាំងអស់នេះនៅលើអាសនៈ ជាតង្វាយដុតថ្វាយដល់ព្រះអម្ចាស់ នេះជាយញ្ញបូជារំដោះបាប។
[6]មានតែមនុស្សប្រុសក្នុងចំណោមបូជាចារ្យតែប៉ុណ្ណោះដែលអាចបរិភោគចំណែកនៃតង្វាយនេះបាន។ ពួកគេត្រូវបរិភោគនៅក្នុងទីសក្ការៈ ព្រោះនេះជារបស់ដ៏បរិសុទ្ធ។
[7]ក្រឹត្យវិន័យទាំងប៉ុន្មានស្តីពីយញ្ញបូជាលោះបាប ក៏ដូចគ្នាទៅនឹងក្រឹត្យវិន័យស្តីពីយញ្ញបូជារំដោះបាបដែល សាច់របស់សត្វនៃយញ្ញបូជា
ជាចំណែករបស់បូជាចារ្យដែលធ្វើពិធីនោះ។[8]ប្រសិនបើ បូជាចារ្យថ្វាយតង្វាយដុតទាំងមូលសម្រាប់អ្នកណាម្នាក់ ស្បែកនៃសត្វដែលគេថ្វាយនោះ
ត្រូវជាចំណែករបស់បូជាចារ្យ។
[9]តង្វាយម្សៅទាំងអស់ ទោះបីនំដែលដុតក្នុងឡ ឬដុតក្នុងពុម្ព ឬនំចៀន ត្រូវបានជាចំណែករបស់បូជាចារ្យ ដែលធ្វើពិធីនោះ។[10]តង្វាយម្សៅទាំងអស់
ដែលលាយជាមួយប្រេងក្តី មិនទាន់លាយក្តី ត្រូវបានជាចំណែកស្មើៗគ្នា សម្រាប់កូនចៅទាំងអស់របស់លោកអើរ៉ុន»។
[11]នេះជាក្រឹត្យវិន័យស្តីពីតង្វាយនៃយញ្ញបូជាមេត្រីភាពដែលគេថ្វាយព្រះជាម្ចាស់។[12]ប្រសិនបើ នរណាម្នាក់ ថ្វាយតង្វាយសម្រាប់ការអរព្រះគុណ
ត្រូវយកនំដែលធ្វើពីម្សៅឥតមេ ប៉ុន្តែ ត្រូវលាយប្រេង នំក្រៀប ជានំឥតមេ តែត្រូវលាយជាមួយប្រេង ជានំដែលធ្វើពីម្សៅម៉ដ្ដដែលលាយជាមួយប្រេង។
[13]គេត្រូវយកនំប៉័ងដែលមានមេ មកថ្វាយរួមជាមួយជាមួយយញ្ញបូជាមេត្រីភាព សម្រាប់ការអរព្រះគុណដែរ។[14]ត្រូវរំលែកនំដែលគេយកមកតាមប្រភេទតង្វាយនីមួយៗ
ទុកសម្រាប់ព្រះអម្ចាស់ គឺជាចំណែករបស់បូជាចារ្យ ដែលធ្វើពិធីប្រោះឈាមនៃយញ្ញបូជាមេត្រីភាពលើអាសនា។
[15]ចំណែកឯសាច់នៃយញ្ញបូជាមេត្រីភាពដែលថ្វាយសម្រាប់ការអរព្រះគុណ ត្រូវបរិភោគនៅក្នុងថ្ងៃនោះឲ្យអស់
គឺមិនត្រូវទុកឲ្យនៅសល់រហូតដល់ពេលព្រឹកថ្ងៃបន្ទាប់ឡើយ។[16]ប៉ុន្តែ ប្រសិនបើតង្វាយនោះជាតង្វាយលាបំណន់ ឬជាតង្វាយស្ម័គ្រពីចិត្ត
សាច់នៃតង្វាយនោះត្រូវបរិភោគនៅក្នុងថ្ងៃដែលគេថ្វាយតង្វាយ ប៉ុន្តែ ប្រសិនបើសាច់នៅសល់គេអាចបរិភោគនៅថ្ងៃបន្ទាប់បាន។
[17]សាច់នៃតង្វាយមេត្រីដែលនៅសល់រហូតដល់ថ្ងៃទីបីត្រូវដុតចោល។[18]ប្រសិនបើ សាច់នៃយញ្ញបូជាមេត្រីភាពនៅសល់ដល់ថ្ងៃទីបី ហើយគេបរិភោគសាច់នោះ
នោះនឹងនាំឲ្យគេមានទោស ព្រះអម្ចាស់មិនទទួលយកតង្វាយនោះទេ ព្រោះជាតង្វាយឥតបានការ ហើយជាសាច់ដែលសៅហ្មង។
[19]សាច់ដែលប៉ះជាមួយវត្ថុដែលមិនបរិសុទ្ធ មិនត្រូវបរិភោគទេ គឺត្រូវដុតវាចោលវិញ។ សាច់នៃយញ្ញបូជាគឺមានតែមនុស្សបរិសុទ្ធតែប៉ុណ្ណោះដែលអាចបរិភោគបាន។
[20]ប្រសិនបើ អ្នកណាម្នាក់មិនបរិសុទ្ធ ហើយបរិភោគសាច់នៃយញ្ញបូជាមេត្រីភាពដែលគេថ្វាយព្រះអម្ចាស់
អ្នកនោះត្រូវបណ្តេញចេញពីចំណោមប្រជាជនជាកុលសម្ព័ន្ធរបស់ខ្លួន។
[21]ប្រសិនបើ អ្នកណាម្នាក់ប៉ះពាល់របស់មិនបរិសុទ្ធ គេនឹងទៅជាមនុស្សមិនបរិសុទ្ធ ឬជាសត្វមិនបរិសុទ្ធ ឬវត្ថុមិនបរិសុទ្ធ ឬជារបស់ដ៏គួរស្អប់ខ្ពើម។ ហើយប្រសិនបើ
មនុស្សម្នាក់នោះ បរិភោគសាច់នៃយញ្ញបូជាមេត្រីភាពដែលគេថ្វាយព្រះអម្ចាស់ គេត្រូវបណ្តេញចេញពីចំណោមប្រជាជនជាកុលសម្ព័ន្ធរបស់គេ។
[22]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[23]«ចូរប្រកាសប្រាប់ដល់ប្រជាជនអ៊ីស្រាអែលថា៖ «អ្នករាល់គ្នាមិនត្រូវបរិភោគខ្លាញ់ពី គោឈ្មោល ឬចៀម ឬពពែទេ។
[24]ខ្លាញ់នៃសត្វដែលស្លាប់មិនមែនសម្រាប់ថ្វាយជាតង្វាយ ឬខ្លាញ់នៃសត្វដែលងាប់ដោយសត្វដទៃហែក អាចប្រើទៅធ្វើអ្វីក៏បាន តែមិនត្រូវបរិភោគទេ។
[25]ប្រសិនបើ អ្នកណាម្នាក់បរិភោគខ្លាញ់សត្វដែលគេថ្វាយជាតង្វាយដុតទៅព្រះអម្ចាស់ អ្នកនោះត្រូវបណ្តេញចេញពីចំណោមកុលសម្ព័ន្ធរបស់គេ។
[26]ទោះបីអ្នករាល់គ្នារស់នៅទីណាក្តី អ្នករាល់គ្នាមិនត្រូវបរិភោគឈាមពីសត្វស្លាប ឬពីសត្វចតុបាទឡើយ។[27]ប្រសិនបើ អ្នកណាម្នាក់បរិភោគឈាម
ត្រូវបណ្តេញអ្នកនោះចេញពីចំណោមកុលសម្ព័ន្ធរបស់គេ។
[28]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[29]ចូរប្រកាសប្រាប់ប្រជាជនអ៊ីស្រាអែលថា ប្រសិនបើ អ្នកណាម្នាក់ចង់ថ្វាយយញ្ញបូជាមេត្រីភាព
គេត្រូវបណ្តេញចេញពីកុលសម្ព័ន្ធរបស់គេ។[30]គេត្រូវយកតង្វាយដុតមកថ្វាយព្រះអម្ចាស់ ដោយផ្ទាល់ដៃរបស់គាត់។ គឺត្រូវនាំយកខ្លាញ់ជាមួយនឹងសាច់ទ្រូង
ដែលត្រូវលើកថ្វាយព្រះអម្ចាស់។
[31]បូជាចារ្យត្រូវដុតខ្លាញ់នៅលើអាសនៈ ប៉ុន្តែ សាច់ទ្រូងនៃតង្វាយជាចំណែករបស់អើរ៉ុន និងពូជពង្សរបស់គាត់។[32]អ្នកត្រូវរំលែកភ្លៅស្តាំនៃយញ្ញបូជាមេត្រី
ទៅជូនបូជាចារ្យដែលលើកតង្វាយនោះ។
[33]ភ្លៅស្តាំត្រូវជាចំណែករបស់បូជាចារ្យណា ដែលថ្វាយខ្លាញ់និងឈាមនៅលើអាសនៈ។[34]យើងនឹងយកសាច់ទ្រូងមួយចំណែក និងចំណែកខ្លះនៃតង្វាយដែលគេលើកថ្វាយ
អោយទៅអើរ៉ុន និងកូនចៅរបស់គាត់។ ប្រជាជនអ៊ីស្រាអែលត្រូវប្រគល់ចំណែកទាំងនោះជូនបូជាចារ្យ ជារៀងរហូត។
[35]នេះគឺជាចំណែកនៃតង្វាយដុតដែលជារបស់លោកអើរ៉ុន និងកូនៗរបស់គាត់ចាប់តាំងពីថ្ងៃដែលលោកម៉ូសេ បានធ្វើពិធីតែងតាំងពួកគេជាបូជាចារ្យ
សម្រាប់បម្រើព្រះអម្ចាស់។[36]នេះជាចំណែកដែលព្រះអម្ចាស់បានបង្គាប់មកដល់ជនជាតិអ៊ីស្រាអែល ដែលត្រូវឲ្យទៅពួកគេ។
នេះជាច្បាប់ដែលត្រូវអនុវត្តតាមគ្រប់ជំនាន់តទៅ ឥតមានការប្រែប្រួលឡើយ។
[37]នេះជាក្រឹត្យវិន័យស្តីពីតង្វាយដុតទាំងមូល តង្វាយម្សៅ យញ្ញបូជារំដោះបាប យញ្ញបូជាលោះបាប យញ្ញបូជាសម្រាប់តែងតាំងបូជាចារ្យ
និងយញ្ញបូជាមេត្រីភាព[38]ដែលព្រះអម្ចាស់បានប្រគល់មកឲ្យលោកម៉ូសេ នៅភ្នំស៊ីណៃ
នៅថ្ងៃដែលព្រះអម្ចាស់បានបង្គាប់ឲ្យជនជាតិអ៊ីស្រាអែលឲ្យយកតង្វាយមកថ្វាយព្រះអម្ចាស់នៅវាលរហោស្ថានស៊ីណៃ»។

Leviticus 7:1

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលគាត់ត្រូវប្រាប់អើរ៉ុន
និងកូនប្រុសរបស់គាត់។

នៅកន្លែងដែលត្រូវសម្លាប់

វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា
នេះសំដៅទៅលើកន្លែងដែលសត្វសម្រាប់ថ្វាយតង្វាយដុត។ មើល ១:១០។

ខ្លាញ់ទាំងអស់ដែលមាននៅក្នុងវានឹងត្រូវថ្វាយព្រះ

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បូជាចារ្យត្រូវយកខ្លាញ់ទាំងអស់ដែលមាននៅក្នុងសត្វ»

គ្រឿងក្នុង

នេះគឺជាក្រពះ និងពោះវៀន។

ថ្លើម ... តំរងនោម

បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានបកប្រែនៅក្នុង ជំពូក ៣: ៣ ។

រហូតដល់ចង្កេះ

នេះគឺជាផ្នែកនៃរាងកាយនៅលើឆ្អឹងខ្នង រវាងឆ្អឹងជំនីនិងឆ្អឹងត្រគាក។
សូមមើលការបកប្រែនៅក្នុង ៣:៣។

ទាំងអស់នេះត្រូវតែត្រូវបានយកចេញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បូជាចារ្យត្រូវដកវត្ថុទាំងអស់នេះចេញ»

Leviticus 7:5

ជាតង្វាយដែលត្រូវបានធ្វើដោយភ្លើង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ជាតង្វាយដុត»

វាត្រូវតែយកទៅបរិភោគ

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវតែបរិភោគវា»
Leviticus 7:7
ច្បាប់ដូចគ្នាអនុវត្តចំពោះពួកគេទាំងពីរ
«ច្បាប់គឺដូចគ្នាសម្រាប់ពួកគេទាំងពីរ»
បូជាចារ្យដែលធ្វើពិធីលោះបាបអោយពួកគេ
នាមអរូបី «ដង្វាយលោះបាប» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «ចំពោះបូជាចារ្យដែលថ្វាយយញ្ញបូជា
ដើម្បីលោះបាបរបស់នរណាម្នាក់»
Leviticus 7:9
ដែលដុតក្នុងឡ...ដុតក្នុងពុម្ព
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មាននរណាម្នាក់ដុតនំនៅក្នុងឡ ... ដែលមាននរណាម្នាក់ចំអិននៅក្នុងខ្ទះ»
ឡ
នេះប្រហែលជាវត្ថុមានចន្លោះដែលធ្វើពីដីឥដ្ឋ។
ភ្លើងត្រូវបានឆេះនៅក្រោមហើយកំដៅ នឹងដុតនំនៅខាងក្នុងឡ។
មើលការបកប្រែនៅក្នុង ២:៤។
ដុតក្នុងពុម្ព
នេះគឺជាបន្ទះដែកដែលមានតែមរាងមូល។
នុំត្រូវបានដាក់ក្នុងខ្ទះហើយចម្អិននៅលើភ្លើង។ មើលការបកប្រែនៅក្នុង ២: ៦។
ខ្ទះ
នេះគឺជាចានក្រាស់ដែលធ្វើពីដីឥដ្ឋឬដែក។ ចានត្រូវបានដាក់នៅលើភ្លើងហើយ នុំ
ត្រូវបានចម្អិននៅលើចាន។ សូមមើលការបកប្រែនៅក្នុង ២:៤។
Leviticus 7:11
នំធ្វើដោយគ្មានដំបែតែលាយជាមួយប្រេង
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នំគាត់ធ្វើដោយគ្មានមេ តែលាយជាមួយប្រេង»
នំ...លាយជាមួយប្រេង
នៅទីនេះ «នំ» សំដៅទៅលើនំប៉័ងក្រាស់។
នំធ្វើដោយគ្មានដំបែតែលាបជាមួយប្រេង
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នំស្តើងដែលគាត់ធ្វើដោយគ្មានមេតែលាបជាមួយប្រេង»
នំ...លាបជាមួយប្រេង
នេះ «នំ» សំដៅទៅនំប៉័ងស្តើង។
នំដែលធ្វើពីម្សៅម៉ដ្ដដែលលាយជាមួយប្រេង
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នំដែលគាត់លាយម្សៅម៉ដ្ដលាយជាមួយប្រេង»
នំធ្វើពីម្សៅម៉ដ្ដ
នៅទីនេះ "នំ" សំដៅទៅលើនំប៉័ងក្រាស់។ វាស្រដៀងនឹងនំប៉័ងប្រភេទទីមួយ
លើកលែងតែវាត្រូវបានធ្វើឡើងដោយម្សៅម៉ដ្ដបំផុត។
Leviticus 7:13
នំធ្វើដោយមានមេ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នំដែលលោកធ្វើជាមួយដំបែ»
នំ
សំដៅទៅលើនំប៉័ងក្រាស់។
Leviticus 7:15
អ្នកដែលនាំយក
«អ្នកដែលថ្វាយដង្វាយ»
សម្រាប់ការអរព្រះគុណ
នាមអរូបី «អរគុណ» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«សម្រាប់គោលបំណងអរគុណព្រះដល់ព្រះអម្ចាស់»
សាច់ត្រូវតែបរិភោគ ... វាអាចត្រូវបានគេបរិភោគ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែបរិភោគសាច់ ... គាត់អាចបរិភោគបាន»
Leviticus 7:17
ដល់ថ្ងៃទីបី
ទីបីគឺជាលេខធម្មតាសម្រាប់លេខបី។ ការបកប្រែផ្សេងទៀត «បន្ទាប់ពីថ្ងៃទីពីរ»
ត្រូវដុត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សត្រូវដុតវា»
នៅថ្ងៃទីបីបើមាននរណាបរិភោគសាច់របស់សត្វដែលគេថ្វាយជាយញ្ញបូជាមេត្រីភាព
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នកណាបរិភោគសាច់នៃយញ្ញបូជាមេត្រីភាពរបស់គាត់នៅថ្ងៃទីបី»
មិនទទួលយក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងមិនទទួលយកវាទេ»
ទុកដូចជាអ្នកនោះមិនបានថ្វាយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ក៏នឹងមិនគោរពការថ្វាយដង្វាយដែលមនុស្សនោះបានថ្វាយ»
នឹងត្រូវមានទោសដល់ខ្លួន
មនុស្សម្នាក់ដែលទទួលខុសត្រូវចំពោះអំពើបាបដែលគាត់បានធ្វើ
ត្រូវបានគេនិយាយថាគាត់ត្រូវមានកំហុសខាងរូបកាយ។
Leviticus 7:19
សាច់ដែលប៉ះជាមួយវត្ថុដែលមិនបរិសុទ្ធ មិនត្រូវបរិភោគទេ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់អាចបរិភោគសាច់ដែលប៉ះនឹងអ្វីដែលមិនស្អាត»
វត្ថុមិនបរិសុទ្ធ
អ្វីមួយដែលព្រះអម្ចាស់បានមានបន្ទូលថាមិនសម
នឹងការប៉ះឬបរិភោគត្រូវបានគេនិយាយថា ដូចជាមិនស្អាតខាងរូបកាយ។
ត្រូវដុត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែដុតវា»
មនុស្សដែលបរិសុទ្ធ
មនុស្សដែលអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយថា
ដូចជាមនុស្សនោះស្អាតស្អំខាងរូបកាយ។
អ្នកណាម្នាក់មិនបរិសុទ្ធ
មនុស្សដែលមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយ
ដូចជាមនុស្សនោះមិនស្អាតស្អំខាងរាងកាយ។
អ្នកនោះត្រូវបណ្តេញចេញពីចំណោមប្រជាជនជាកុលសម្ព័ន្ធរបស់ខ្លួន
មនុស្សម្នាក់ដែលត្រូវបានគេដកចេញពីសហគមន៍របស់គាត់
ត្រូវបានគេនិយាយថាដូចជាគាត់ត្រូវបានគេកាត់ចេញពីប្រជាជនរបស់គាត់
ដូចជាមនុស្សម្នាក់នឹងកាត់ក្រណាត់ ឬកាត់មែកឈើចេញពីមែកឈើ។
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សនោះអាចនឹងលែងរស់នៅក្នុងចំណោមប្រជាជនរបស់គាត់» ឬ
«អ្នកត្រូវតែញែកមនុស្សនោះចេញពីប្រជាជនរបស់គាត់»
Leviticus 7:21
របស់មិនបរិសុទ្ធ
អ្វីមួយដែលព្រះអម្ចាស់បានមានបន្ទូលថាមិនសមនឹងការប៉ះឬបរិភោគត្រូវបានគេនិយាយថាដូចជាមិនស្អា
គេនឹងទៅជាមនុស្សមិនបរិសុទ្ធ ឬជាសត្វមិនបរិសុទ្ធ
នៅទីនេះ "មនុស្ស" មានន័យថាមនុស្សជាទូទៅ។ ការបកប្រែផ្សេងទៀត
«មិនថាមនុស្ស ឬសត្វ»
តុមិនបរិសុទ្ធ ឬជារបស់ដ៏គួរស្អប់ខ្ពើម
«ឬរបស់អ្វីដែលមិនស្អាតគួរស្អប់ខ្ពើមដល់ព្រះអម្ចាស់»
អ្នកនោះត្រូវបណ្តេញចេញពីចំណោមប្រជាជនជាកុលសម្ព័ន្ធរបស់ខ្លួន
មនុស្សម្នាក់ដែលត្រូវបានគេដកចេញពីសហគមន៍របស់គាត់
[12]ប្រសិនបើ បូជាចារ្យបានឃើញថា រោគឃ្លង់នេះកើតពេញលើស្បែងក ហើយរាលដាលពេញខ្លួនអ្នកជំងឺ តាំងពីក្បាលរហូតដល់ចុងជើងនោះ[13]ដូច្នេះ
បូជាចារ្យត្រូវពិនិត្យឲ្យបានហ្មត់ចត់ ប្រសិនបើ ឃើញថារោគឃ្លង់នេះបានកើតពេញខ្លួនរបស់គេហើយ លោកត្រូវប្រកាសថាមនុស្សម្នាក់នេះជាមនុស្សបរិសុទ្ធ
ព្រោះខ្លួនរបស់គាត់បានប្រែជាសទាំងអស់ដូច្នេះ នោះបានសេចក្ដីថាគាត់បរិសុទ្ធ។[14]ប៉ុន្តែប្រសិនបើ មានសាច់ខ្ចី ដុះចេញនៅលើខ្លួនគាត់ នោះគាត់នឹងទៅជាមិនបរិសុទ្ធ។
[15]បូជាចារ្យត្រូវពិនិត្យមើលសាច់ខ្ចីនោះ ហើយត្រូវប្រកាសថា គាត់ជាមនុស្សមិនបរិសុទ្ធ ព្រោះសាច់ខ្ចីនោះមិនបរិសុទ្ធ។[16]នៅពេលដែលសាច់ខ្ចីនោះដុះឡើងសារជាថ្មី
គាត់ត្រូវទៅជួបលោកបូជាចារ្យ។[17]ប្រសិនបើ បូជាចារ្យពិនិត្យឃើញថា សាច់ខ្ចីនោះប្រែជាព៌ណស នោះគាត់ត្រូវប្រកាសថា អ្នកជំងឺនោះជាមនុស្សបរិសុទ្ធវិញ។
[18]ប្រសិនបើន រណាម្នាក់មានដំបៅនៅលើស្បែក ហើយក៏បានជាវិញ[19]ហើយប្រសិនបើ នៅកកន្លែងដំបៅនោះនៅមានកន្ទួលព៌ណស ឬស្នាមក្រហម ឬក្រហមព្រឿងៗ
នោះគាត់ត្រូវទៅជួបលោកបូជាចារ្យ។[20]បូជាចារ្យត្រូវពិនិត្យអ្នកជំងឺ ប្រសិនបើ ឃើញថាស្បែកខូងចូល ហើយរោមនៅទីនោះប្រែជាព៌ណស នោះបូជាចារ្យត្រូវប្រកាសថា
អ្នកនោះជាមនុស្សមិនបរិសុទ្ធ។ គឺមានរោគឃ្លុង វិវត្តន៍នៅកន្លែងដែលធ្លាប់មានដំបៅនោះ។

generated on Wed Sep 10 16:16:32 2025

[21]ប៉ុន្តែ ប្រសិនបើ បូជាចារ្យពិនិត្យឃើញថា រោមនៅកន្លែងនោះមិនបានប្រែទៅជាព៌ណសទេ ហើយស្នាមដំបៅមិនខូងចូលទៅក្នុងស្បែក
នោះបូជាចារ្យត្រូវនាំគាត់ឲ្យរស់នៅដាច់ដោយឡែកពីគេរយៈពេលប្រាំពីរថ្ងៃ។[22]ប្រសិនបើ ពិនិត្យឃើញថាស្នាមនោះរាលដាលនៅលើស្បែក បូជាចារ្យត្រូវប្រកាសថា
គាត់ជាមនុស្សមិនបរិសុទ្ធ គឺមានរោគឃ្លង់។[23]ប៉ុន្តែប្រសិនបើ ស្នាមនៅនៅដដែល មិនរាលទេ នោះមានន័យថា វាគ្រាន់តែជាស្នាមតែប៉ុណ្ណោះ បូជាចារ្យត្រូវប្រកាសថា
គាត់ជាមនុស្សបរិសុទ្ធ។
[24]នៅពេលស្បែករបស់នរណាម្នាក់ ត្រូវរលាកដោយសារភ្លើង ហើយសាច់ត្រង់កន្លែងរលាកនោះ ប្រែទៅជាក្រហមព្រឿងៗ
ឬមានជាពណ៌ស[25]លោកបូជាចារ្យត្រូវពិនិត្យគាត់ ប្រសិនបើ រោមនៅកន្លែងដែលរលាកនោះប្រែទៅជាពណ៌ស ហើយស្បែកមានការខូងចុះ។
នោះគឺរោគឃ្លង់កើតត្រង់កន្លែងរលាក បូជាចារ្យត្រូវប្រកាសថា គាត់ជាមនុស្សមិនបរិសុទ្ធ។ គឺមានន័យថា គាត់មានរោគឃ្លង់។
[26]ប្រសិនបើ បូជាចារ្យពិនិត្យវាហើយ ឃើញថារោមមិនប្រែជាព៌ណស ហើយដំបៅក៏មិនខូងចូលទៅក្នុងស្បែក ហើយស្នាមនៅលើស្បែកក៏មិនស្រអាប់នោះ
លោកបូជាចារ្យត្រូវនាំគាត់ឲ្យរស់នៅដាច់ពីគេរយៈពេលប្រាំពីរថ្ងៃ។[27]លុះដល់ថ្ងៃទីប្រាំពីរ បូជាចារ្យត្រូវពិនិត្យគាត់។ ប្រសិនបើ ស្នាមនោះរាលនៅលើស្បែក
នោះបូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនបរិសុទ្ធ។[28]ប្រសិនបើ ស្នាមនៅមានដដែល មិនរាលដាល ប៉ុន្តែ ប្រែទៅជាស្រអាប់ នោះមានសេចក្តីថាជាស្នាមរលាក។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សបរិសុទ្ធ ព្រោះវាគ្រាន់តែជាស្នាមរលាកភ្លើងប៉ុណ្ណោះ។
[29]ប្រសិនបើបុរស ឬស្ត្រី ណាកើតជំងឺលើស្បែកលើក្បាល ឬត្រង់ចង្ការ[30]បូជាចារ្យត្រូវពិនិត្យគាត់កន្លែងដែលមានជំងឺលើស្បែកនោះ ប្រសិនបើ
មានស្នាមខូងចូលទៅក្នុងស្បែក ហើយប្រសិនបើ វាប្រែជាពណ៌លឿង និងមានជ្រុះរោមនៅកន្លែងនោះ។ បើដូច្នេះ
បូជាចារ្យត្រូវប្រកាសថាអ្នកជំងឺនោះជាមនុស្សមិនបរិសុទ្ធ។ គឺគេមានរោគឃ្លង់ម៉្យាងដែលមានអង្កែនៅលើក្បាល និងត្រង់ចង្ការ។
[31]ហើយប្រសិនបើ បូជាចារ្យពិនិត្យឃើញថា អង្កែរនោះមិនមានស្នាមខូងចូលទៅក្នុងស្បែក ហើយមិនមានរោមខ្មៅនៅកន្លែងនោះ នោះលោកបូជាចារ្យត្រូវឲ្យអ្នកជំងឺនោះ
នៅដាច់ដោយឡែកពីគេរយៈពេលប្រាំពីរថ្ងៃ។
[32]នៅថ្ងៃទីប្រាំពីរ បូជាចារ្យត្រូវពិនិត្យអ្នកជម្ងឺនោះម្តងទៀត ប្រសិនបើឃើញថាអង្កែនោះមិនបានរាល ហើយរោមមិនមានព៌ណលឿង
ហើយមិនមានស្នាមខូងចូលទៅក្នុងស្បែកនោះទេ[33]អ្នកជំងឺនោះត្រូវកោរសក់របស់គាត់ ប៉ុន្តែ ត្រង់កន្លែងដែលមានកើតអង្កែនោះគឺមិនត្រូវកោរទេ បន្ទាប់មក
លោកបូជាចារ្យត្រូវអោយអ្នកជំងឺដែលអង្កែនោះនៅដាច់ដោយឡែកពីគេបន្ថែមប្រាំពីរថ្ងៃទៀត។
[34]នៅថ្ងៃទីប្រាំពីរ បូជាចារ្យត្រូវពិនិត្យកន្លែងកើតអង្កែម្តងទៀត ប្រសិនបើ អង្កែមិនរាលដាលទៅលើស្បែក ហើយស្នាមមិនខូងចូលទេ នោះបូជាចារ្យត្រូវប្រកាស់ថា
គាត់ជាមនុស្សបរិសុទ្ធ។ គាត់ត្រូវបោកសម្លៀកបំពាក់របស់គាត់ ហើយគាត់នឹងបានបរិសុទ្ធ។
[35]ប៉ុន្តែប្រសិនបើ រោគអង្កែរាលដាល ពេញលើស្បែកបន្ទាប់ពីលោកបូជាចារ្យបានប្រកាសថាគាត់បរិសុទ្ធហើយ[36]នោះបូជាចារ្យត្រូវពិនិត្យអ្នកជំងឺនោះម្តងទៀត។ ប្រសិនបើ
ជំងឺរាលដាលលើស្បែក បូជាចារ្យមិនចាំបាច់ស្វែងរកមើលរោមពណ៌លឿងទេ ព្រោះគាត់ជាមនុស្សមិនបរិសុទ្ធ។[37]ប្រសិនបើ ស្នាមអង្កែនៅដដែលមិនប្រែប្រួល
ហើយមានរោមខ្មៅដុះឡើង នោះមានន័យថារោគអង្កែជាសះស្បើយហើយ។ គាត់ជាមនុស្សបរិសុទ្ធ ហើយបូជាចារ្យត្រូវប្រកាសថា គាត់ជាមនុស្សបរិសុទ្ធ។
[38]ប្រសិនបើ បុរស ឬស្ត្រីណាមានស្នាមអុច នៅលើស្បែក[39]បូជាចារ្យត្រូវធ្វើការពិនិត្យអ្នកជំងឺនោះ បើឃើញថាស្នាមអុច ប្រែជាពណ៌ស្រអាប់វិញ
នោះគ្រាន់តែជារោគសើរស្បែកធម្មតាប៉ុណ្ណោះ។ គាត់ជាមនុស្សបរិសុទ្ធ។
[40]ប្រសិនបើ សក់របស់មនុស្សប្រុសជ្រុះ គាត់ជាមនុស្សទំពែក តែគាត់នៅតែជាមនុស្សបរិសុទ្ធដដែល។[41]ប្រសិនបើ សក់របស់គាត់ផ្នែកខាងមុខជ្រុះ គាត់ជាមនុស្សឆក
តែគាត់នៅតែជាមនុស្សបរិសុទ្ធដដែល។
[42]ប៉ុន្តែ ប្រសិនបើ ក្បាលរបស់គាត់ផ្នែកទំពែកក្តី ផ្នែកដែលឆកក្តី មានឡើងព៌ណក្រហមព្រឿងៗ នោះមានន័យថាគាត់មានកើតរោងឃ្លង់ហើយ។[43]បូជាចារ្យត្រូវពិនិត្យគាត់
ប្រសិនបើ មានកន្ទួលក្រហមៗដូចជារោគឃ្លង់ទោះនៅកន្លែងទំពែកក្តី ឬកន្លែងឆកក្តី[44]នោះគឺមានន័យថា គាត់មានរោគឃ្លង់ ហើយគាត់ជាមនុស្សមិនបរិសុទ្ធ។
បូជាចារ្យត្រូវតែប្រកាសថា គាត់ជាមនុស្សមិនបរិសុទ្ធ ព្រោះគាត់មានកើតរោគឃ្លង់លើក្បាលរបស់គាត់។
[45]មនុស្សដែលមានជំងឺឃ្លង់ គឺត្រូវស្លៀកសម្លៀកបំពាក់រហែក ត្រូវចំហរត្រង់ក្បាល ហើយបិតមុខនៅត្រង់ច្រមុះ ហើយស្រែកថា ខ្ញុំជាមនុស្សមិនបរិសុទ្ធ!
ខ្ញុំជាមនុស្សមិនបរិសុទ្ធ![46]ក្នុងអំឡុងពេលដែលគាត់កើតឃ្លង់នោះ គាត់ជាមនុស្សមិនបរិសុទ្ធ គាត់ត្រូវរស់នៅដាច់ពីគេ នៅខាងក្រៅជំរំ។
[47]សម្លៀកបំពាក់ដែលមានដុះផ្សិត ទោះបីសម្លៀកបំពាក់ធ្វើពីក្រណាត់រោមចៀម ឬសំពត់ទេសឯក[48]ឬស្នាមលើក្រណាត់ ឬលើអំបោះរោមចៀម អំបោះឆៅ សម្លៀកបំពាក់
ឬវត្ថុធ្វើអំពីស្បែក[49]បើស្នាមទាំងនោះប្រែទៅជាពណ៌បៃតង ឬក្រហមព្រឿងៗប្រឡាក់នៅលើសម្លៀកបំពាក់ ធ្វើពីស្បែក អំបោះរោមចៀម អំបោះឆៅ
ឬអ្វីផ្សេងទៀតដែលធ្វើពីស្បែក ប្រសិនបើស្នាមផ្សិតនោះរាលដាល នោះត្រូវបង្ហាញរបស់នោះទៅជូនបូជាចារ្យ។
[50]បូជាចារ្យត្រូវពិនិត្យរបស់ទាំងនោះ គាត់ត្រូវយករបស់ដែលមានចុះផ្សិតនៅដាក់ដោយឡែកពីគេរយៈពេលប្រាំពីរថ្ងៃ។[51]លុះដល់ថ្ងៃទីប្រាំពីរ
បូជាចារ្យត្រូវពិនិត្យស្នាមផ្សិតនោះម្តងទៀត។ ប្រសិនបើមានរាលដាលលើសម្លៀកបំពាក់ ឬវត្ថុផ្សេងៗដូចជា លើក្រណាត់ ឬលើអំបោះរោមចៀម អំបោះឆៅ សម្លៀកបំពាក់
ឬវត្ថុធ្វើអំពីស្បែក នោះមានន័យថាវាមានដុះផ្សិតហើយ ហើយរបស់ទាំងនោះជារបស់មិនបរិសុទ្ធ។[52]បូជាចារ្យត្រូវដុតសម្លៀកបំពាក់ ឬវត្ថុផ្សេងៗដូចជា លើក្រណាត់
ឬលើអំបោះរោមចៀម អំបោះឆៅ សម្លៀកបំពាក់ ឬវត្ថុធ្វើអំពីស្បែក ដែលរកឃើញថាមានដុះផ្សិតនោះដោល ព្រោះវាជាវត្ថុដុះផ្សិតមិនអាចចំបាត់បាន។ ដូច្នេះ
ត្រូវដុតវាចោលទាំងស្រុង។
[53]ប្រសិនបើបូជាចារ្យពិនិត្យហើយមិនមានឃើញផ្សិតនោះរាលដាលលើ សម្លៀកបំពាក់ ឬវត្ថុផ្សេងៗដូចជា ក្រណាត់ ឬលើអំបោះរោមចៀម អំបោះឆៅ សម្លៀកបំពាក់
ឬវត្ថុធ្វើអំពីស្បែក ទេនោះ[54]នោះលោកត្រូវបញ្ជាអោយពួកគេបោកសម្អាតរបស់អស់ទាំងនោះ
ហើយលោកត្រូវដាក់របស់ទាំងនោះអោយនៅដាច់ឡែកពីគេរយៈពេលប្រាំពីរថ្ងៃ។[55]បន្ទាប់មកលោកត្រូវពិនិត្យវាម្តងទៀត។ ទោះបីស្នាមផ្សិតមិនប្រែប្រួលពណ៌
ឬមិនមានការរាលដាលក្តី ក៏វានៅតែជាវត្ថុមិនបរិសុទ្ធដដែល។ អ្នកត្រូវដុតរបស់ទាំងនោះចោល ព្រោះថាផ្សិតនោះវាបានធ្វើអោយកខ្វក់។
[56]ប្រសិនបើ លោកបូជាចារ្យពិនិត្យរបស់នោះ ហើយឃើញថា ស្នាមដុះផ្សិតនោះបានរលុប នោះគាត់ត្រូវកាត់ផ្នែកដែលមានស្នាមនោះចេញពីសម្លៀកបំពាក់
ឬចេញពីអំបោះរោមចៀម អំបោះឆៅ សម្លៀកបំពាក់ ឬវត្ថុធ្វើអំពីស្បែក។[57]ហើយប្រសិនបើ ក្រោយមក ស្នាមនោះដុះឡើងនៅលើសម្លៀកបំពាក់ អំបោះរោមចៀម
អំបោះឆៅ សម្លៀកបំពាក់ ឬវត្ថុធ្វើអំពីស្បែក អ្នកត្រូវដុតវត្ថុដែលមានដុះផ្សិតនោះចោល។[58]ប្រសិនបើ អ្នកបានបោកសម្អាត សម្លៀកបំពាក់ ឬអំបោះរោមចៀម អំបោះឆៅ
សម្លៀកបំពាក់ ឬវត្ថុធ្វើអំពីស្បែករួច ហើយស្នាមផ្សិតនោះបានបាត់ទៅ អ្នកត្រូវបោកសម្អាតវាជាលើកទីពីរ ដូច្នេះ វានឹងបានបរិសុទ្ធ។
[59]នេះគឺជាក្រឹត្យវិន័យស្តីពីស្នាមដុះផ្សិតលើសម្លៀកបំពាក់ដែលធ្វើពី អំបោះរោមចៀម អំបោះឆៅ នៅលើក្រណាត់ លើអំបោះរោមចៀម ឬវត្ថុធ្វើអំពីស្បែក ដូច្នេះ
អ្នកត្រូវប្រកាស់ថា វាជារបស់បរិសុទ្ធ ឬមិនបរិសុទ្ធ។

Leviticus 13:1

ត្រូវនាំគេទៅ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

«បន្ទាប់មកនរណាម្នាក់ត្រូវនាំគាត់»

កូនប្រុសណាម្នាក់របស់គាត់

«ទៅកូនប្រុសម្នាក់របស់អើរ៉ុន»

Leviticus 13:3

ព័ត៌មានទូទៅ

ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើ។

ស្បែកលើរូបកាយរបស់គេ

នៅទីនេះ «របស់គាត់» សំដៅទៅលើអ្នកដែលមានជំងឺស្បែក។

ជំងឺឃ្លង់

generated on Wed Sep 10 16:16:32 2025

ជំងឺដលអាចរាលដាលយ៉ាងងាយពីមនុស្សមាក់មនុស្សមាក់ទៀត
គាត់ត្រូវប្រកាសថាគាត់ជាមនុស្សមិនស្អាត
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនស្អាត។ បុរសដែលមនុស្សផ្សេងទៀត
មិនត្រូវប៉ះត្រូវបានគេរាប់ថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
សម្រាប់ប្រាំពីរថ្ងៃ
«រយៈពេល ៧ ថ្ងៃ»
Leviticus 13:5
បូជាចារ្យត្រូវពិនិត្យគាត់
នៅទីនេះ «គាត់» សំដៅទៅលើអ្នកដែលមានជំងឺស្បែក។
លើវាមិនរាលដាលក្នុងស្បែក
នេះមានន័យថាប្រសិនបើជំងឺស្បែកមិនបានកើនឡើងក្នុងទំហំឬផ្លាស់ទៅផ្នែកផ្សេងទៀតនៃរាងកាយ
ថ្ងៃទីប្រាំពីរ
«ទីប្រាំពីរ» គឺជាលេខធម្មតាសម្រាប់លេខ ៧ ។ ការបកប្រែផ្សេងទៀត «ថ្ងៃទី ៧»
ប្រាំពីរថ្ងៃ
"៧ ថ្ងៃ"
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សស្អាត
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះបាននិយាយថាគាត់ស្អាតស្អំខាងរាងកាយ។
(សូមមើលfigs-metaphor)
ជំងឺស្រែង
នេះគឺជាតំបន់នៃស្បែកដែលរលាក
ប៉ុន្តែកន្ទួលនឹងមិនរាលដាលដល់មនុស្សផ្សេងទៀតទេ។
Leviticus 13:7
គាត់ ... ខ្លួនគាត់ផ្ទាល់
នេះសំដៅទៅលើអ្នកដែលមានជំងឺស្បែក។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនបរិសុទ្ធ
បុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេរាប់ថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
ជំងឺឃ្លង់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក១៣: ៣ ។
Leviticus 13:9
ត្រូវនាំគាត់ឲ្យទៅជួបបូជាចារ្យ
ពួកបូជាចារ្យអ្នកកំណត់ថាតើជំងឺមួយណាជាជំងឺឆ្លងរាលដាល។
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នរណាម្នាក់ត្រូវនាំគាត់ទៅបូជាចារ្យ» ឬ «គាត់ត្រូវតែទៅរកបូជាចារ្យ»
មានសាច់ដុះចេញពីកន្ទួលនោះមក
នៅទីនេះ «សាច់ដុះ"» អាចសំដៅទៅលើដំបៅដែលបើកនៅលើស្បែក
ឬវាអាចសំដៅទៅលើស្បែកថ្មីដែលបានដុះប៉ុន្តែតំបន់ជុំវិញវានៅតែមានជំងឺ។
ណាមួយចង្អុលបង្ហាញថាជំងឺស្បែកមិនបានជាសះស្បើយត្រឹមត្រូវទេ។
ជំងឺឃ្លង់រាំរៃ
នេះគឺជាជំងឺដែលនៅតែបន្តឬកើតឡើងក្នុងរយៈពេលយូរ។
លោកបូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនស្អាត...ពីព្រោះគាត់មិនស្អាតរួចទៅហើយ
បុរសដែលមនុស្សផ្សេងទៀត
មិនត្រូវប៉ះត្រូវបានគេរាប់ថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
Leviticus 13:12
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្ស...ស្អាត...គាត់នឹងទៅជាមិនស្អាត
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះត្រូវបានគេរាប់ថាគាត់ស្អាតស្អំខាងរាងកាយ
ហើយបុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេរាប់ថាគាត់មិនស្អាតខាងរាងកាយ
Leviticus 13:15
បូជាចារ្យត្រូវ...ប្រកាសថាគាត់ជាមនុស្សមិនស្អាតព្រោះសាច់ដុះគឺមិនស្អាត
បុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះ
ត្រូវបានគេនិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
ប្រកាសថាគាត់ជាមនុស្សមិនស្អាត
នៅទីនេះ «គាត់» សំដៅទៅលើអ្នកដែលមានជំងឺឃ្លង់។
សាច់ដុះ
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក១៣: ៩ ។
ជំងឺឃ្លង់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១៣: ៣ ។
បូជាចារ្យត្រូវប្រកាសថាអ្នកជំងឺនោះជាមនុស្សស្អាត
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះបានរាប់ថាគាត់ស្អាតស្អំខាងរាងកាយ។
Leviticus 13:18
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
ដំបៅ
កន្លែងដែលឈឺចាប់នៅលើស្បែកដែលឆ្លង
បន្ទាប់មកត្រូវបង្ហាញដល់បូជាចារ្យ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
ឆ្លងបង្ហាញថាគាត់ត្រូវបង្ហាញជំងឺនោះដល់បូជាចារ្យ»
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនបរិសុទ្ធ
បុរសដែលមនុស្សផ្សេងទៀត
មិនត្រូវប៉ះត្រូវបានគេនិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
Leviticus 13:21
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
ពិនិត្យវា
នៅទីនេះ «វា» សំដៅទៅលើការហើមពណ៌ស ឬចំណុចភ្លឺនៅលើស្បែក។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនបរិសុទ្ធ
បុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះ
ត្រូវបានគេរាប់ថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សបរិសុទ្ធ
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះបានរាប់ថាគាត់ស្អាតស្អំខាងរាងកាយ។
Leviticus 13:24
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺឃ្លង់។
ជំងឺឃ្លង់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក១៣: ៣ ។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនបរិសុទ្ធ
បុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេរាប់ថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
Leviticus 13:26
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺឃ្លង់។
ពិនិត្យវា
នៅទីនេះ «វា» សំដៅទៅការរលៀកលើស្បែករបស់អ្នកនោះ។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនស្អាត
បុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះ
ត្រូវបានគេនិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
ជំងឺឃ្លង់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក១៣: ៣ ។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សបរិសុទ្ធ
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះបានរាប់ថាគាត់ស្អាតស្អំខាងរាងកាយ។
Leviticus 13:29
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សមិនបរិសុទ្ធ
បុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេនិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ។
Leviticus 13:31
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើ
នៅពេលមាននរណាម្នាក់កើតជំងឺឃ្លង់។
Leviticus 13:32
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ

generated on Wed Sep 10 16:16:32 2025

និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺឃ្លង់។
អ្នកជំងឺនោះត្រូវកោរសក់របស់គាត់ ប៉ុន្តែ ត្រង់កន្លែងដែលមានកើតអង្គែនោះគឺមិនត្រូវកោរទេ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សត្រូវកោរសក់សក់នៅក្បែរកន្លែងឈឺប៉ុន្តែមិនមែនសក់នៅលើកន្លែងឈឺទេ»
Leviticus 13:34
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក ។
អង្គែ
នៅទីនេះ «ជំងឺ» សំដៅទៅលើជំងឺនៅលើក្បាល ឬចង្ការរបស់មនុស្ស។
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សស្អាតគាត់នឹងបានស្អាត
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះបានរាប់ថាគាត់ស្អាតស្អំខាងរាងកាយ។
Leviticus 13:35
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
បន្ទាប់ពីបូជាចារ្យបាននិយាយថាគាត់ស្អាតហើយ...គាត់បានស្អាតហើយបូជាចារ្យត្រូវប្រកាសថាគាត់ស្អាត
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះបាននិយាយថាគាត់ស្អាតស្អំខាងរាងកាយ។
មនុស្សមិនស្អាត
បុរសដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេនិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ
Leviticus 13:38
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
ប្រែជាពណ៌ស្រអាប់
«ពណ៌សស្រអាប់»
ជំងឺស្បែង
បកប្រែពាក្យនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក ១៣: ៥ ។
គាត់ជាមនុស្សស្អាត
«មនុស្សនោះស្អាត»
គាត់ជាមនុស្សស្អាត
មនុស្សដែលមនុស្សផ្សេងទៀតអាចប៉ះបាននិយាយថាគាត់ស្អាតស្អំខាងរាងកាយ។
Leviticus 13:40
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
គាត់ជាមនុស្សស្អាត
មនុស្សដែលមនុស្សផ្សេងទៀតអាចប៉ះបាននិយាយថាគាត់ស្អាតស្អំខាងរាងកាយ។
Leviticus 13:42
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
ជំងឺឃ្លង់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក១៣: ៣ ។
គាត់គឺមិនស្អាត ... ប្រកាសថាគាត់មិនស្អាត
មនុស្សដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេរាប់ថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ
Leviticus 13:45
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់កើតជំងឺស្បែក។
នៅខាងក្រៅជំរំ
ជំរំគឺជាតំបន់ដែលប្រជាជនអ៊ីស្រាអែលភាគច្រើនរស់នៅ។
មនុស្សមិនបរិសុទ្ធមិនត្រូវបានអនុញ្ញាតឱ្យរស់នៅក្នុងចំណោមពួកគេទេព្រោះជំងឺរបស់គាត់
មិនស្អាត,មិនស្អាត
មនុស្សដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេនិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ
Leviticus 13:47
សម្លៀកបំពាក់ដែលមានដុះផ្សិត
«សម្លៀកបំពាក់ដែលមានដុះផ្សិតនៅលើវា» ឬ
«ក្រណាត់ដែលមានដុះផ្សិតនៅលើវា»
កខ្វក់
ដើម្បីក្លាយជាមិនស្អាត ព្រោះមានអ្វីដែលបង្កគ្រោះថ្នាក់ត្រូវបានបន្ថែមទៅវា
ដុះផ្សិត
ផ្សិតដលមានពណ៌សជាពណ៌ដលដុះលើវត្ថុដែលសើមឬមានសំណើម
ឬវត្ថុត្បាញឬប៉ាក់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ឬរបស់អ្វីដែលនរណាម្នាក់បានត្បាញឬប៉ាក់»
បើស្មាមទាំងនោះប្រែទៅជាពណ៌បៃតង ឬក្រហមព្រឿងៗប្រឡាក់នៅលើសម្លៀកបំពាក់
«ប្រសិនបើសម្លៀកបំពាក់មានពណ៌បៃតង ឬក្រហមនៅក្នុងសម្លៀកបំពាក់»
របស់របរធ្វើពីស្បែក
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«របស់អ្វីដែលនរណាម្នាក់ធ្វើពីស្បែក»
ត្រូវយកវត្ថុនោះទៅជូនបូជាចារ្យ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ម្ចាស់ត្រូវបង្ហាញវាដល់បូជាចារ្យ»
Leviticus 13:50
ប្រាំពីរថ្ងៃ
«៧ ថ្ងៃ»
ថ្ងៃទីប្រាំពីរ
«ទីប្រាំពីរ» គឺជាលេខធម្មតាសម្រាប់លេខ ៧ ។ ការបកប្រែផ្សេងទៀត «ថ្ងៃទី ៧»
អ្វីដែលប្រែពីស្បែក
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្វីដែលមនុស្សម្នាក់ប្រើស្បែក»
អ្វីដែលដែលមានគ្រោះថ្នាក់ដោយផ្សិត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្វីដែលគាត់បានរកឃើញរោគរាតត្បាតដែលបង្កគ្រោះថ្នាក់»
វត្ថុមិនស្អាត
អ្វីមួយដែលព្រះបានប្រកាសថាមិនសមនឹងមនុស្សដែលត្រូវប៉ះត្រូវបានគេនិយាយដូចជាមិនស្អាតខាងរាង
វាអាចនាំឱ្យមានជំងឺ
រោគដែលបង្កគ្រោះថ្នាក់អាចបង្កឱ្យមានជំងឺចំពោះមនុស្សដែលទាក់ទងនឹងរបស់របរ។
វត្ថុត្រូវតែឆេះទាំងស្រុង
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែដុតរបស់របរទាំងអស់ចោល»
Leviticus 13:53
លោកត្រូវបញ្ជាអោយពួកគេ
«បូជាចារ្យត្រូវបញ្ជាម្ចាស់» នៅទីនេះព្រះជាម្ចាស់
អោយប្រជាជនធ្វើអ្វីៗដែលជារបស់របរប្រើប្រាស់ក្នុងផ្ទះដែលអាចឆ្លងបាន។
អ្វីដែលដែលមានគ្រោះថ្នាក់ដោយផ្សិត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្វីដែលគាត់បានរកឃើញរោគរាតត្បាតដែលបង្កគ្រោះថ្នាក់»
បន្ទាប់មកពីវត្ថុដែលបានលាងសម្អាត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីពួកគេបានលាងសម្អាតធាតុដែលមានផ្សិត»
វាមិនស្អាត
អ្វីមួយដែលព្រះបានប្រកាសថាមិនសមនឹងមនុស្សដែលត្រូវប៉ះត្រូវបានគេនិយាយដូចជាមិនស្អាតខាងរាង
ឬវត្ថុត្បាញរបស់របរ
នៅទីនេះ «អ្នក» មិនសំដៅទៅលើបូជាចារ្យទេ។
វាមានន័យថានរណាម្នាក់ត្រូវតែដុតវត្ថុនោះ។
Leviticus 13:56
បន្ទាប់ពីវាត្រូវបានលាងទឹក
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីម្ចាស់បានលាងសម្អាតវាហើយ»
នៅទីនេះ «អ្នក» មិនសំដៅទៅលើបូជាចារ្យទេ។
ប្រសិនបើអ្នកលាងសម្អាតរបស់របរ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើម្ចាស់លាងវា»
បន្ទាប់មករវត្ថុត្រូវលាងសម្អាត

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកម្ចាស់ត្រូវតែលាងសំអាតវា»
វានឹងស្អាត
អ្វីមួយដែលព្រះបានប្រកាសថាសម
នឹងមនុស្សដែលត្រូវប៉ះត្រូវបានគេនិយាយដូចជាស្អាត។
Leviticus 13:59
ដុះផ្សិតលើសម្លៀក...ធ្វើអំពីស្បែក
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក១៣:៤៧ ។

ដូច្នេះ អ្នកត្រូវប្រកាស់ថា
«ដូច្នេះបូជាចារ្យអាចប្រកាសអំពីរឿងនេះបាន»
ស្អាតឬមិនស្អាត
អ្វីមួយដែលព្រះបានប្រកាសថាសម
នឹងមនុស្សដែលត្រូវប៉ះត្រូវបានគេរាប់ថាដូចជាស្អាត
ហើយអ្វីដែលព្រះបានប្រកាសថាមិនសម
នឹងមនុស្សដែលត្រូវប៉ះត្រូវបានគេរាប់ដូចជាមិនស្អាតខាងរាងកាយ។

---

14 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[2]«នេះជាច្បាប់ស្តីពីពិធីសម្រាប់ជម្រះកាយមនុស្សឃ្លង់ឲ្យបានបរិសុទ្ធនៅថ្ងៃធ្វើពិធីជម្រះកាយ។
[3]បូជាចារ្យត្រូវចេញទៅក្រៅជំរំ ដើម្បីពិនិត្យមនុស្សឃ្លង់ ប្រសិនបើឃើញថាជំងឺឃ្លង់បានជាសះស្បើយហើយ។
[4]បូជាចារ្យត្រូវបញ្ជាឲ្យគេយកសត្វស្លាបរស់ពីរក្បាលដែលបរិសុទ្ធ ព្រមទាំងយកឈើតាត្រៅ អំបោះក្រហម និងមែកហ៊ីសុប។[5]បូជាចារ្យត្រូវបញ្ជាឲ្យគេ
អារកសត្វមួយនៅលើផើងដែលធ្វើពីដី ដែលមានទឹកជ្រោះនៅក្នុងនោះ។
[6]បូជាចារ្យយកសត្វស្លាបមួយទៀត ព្រមទាំងយកឈើតាត្រៅ អំបោះ រោមចៀមពណ៌ក្រហមទុំ និងមែកហ៊ីសុប
ហើយយករបស់ទាំងអស់នេះមកជ្រលក់ក្នុងឈាមសត្វស្លាបដែលបានសម្លាប់នៅលើទឹកជ្រោះ។
[7]បន្ទាប់មកលោកបូជាចារ្យប្រោះឈាមនោះប្រាំពីរដងលើមនុស្សដែលបានជាពីជំងឺឃ្លង់នោះ ហើយបន្ទាប់មក លោកត្រូវប្រកាសថាគាត់បានបរិសុទ្ធ។
លោកបូជាចារ្យត្រូវលែងសត្វស្លាបដែលនៅរស់ឲ្យហើរទៅវាល។
[8]មនុស្សដែលទើបនឹងបានបរិសុទ្ធនោះត្រូវបោកសម្លៀកបំពាក់របស់គាត់ កោរសក់របស់គាត់ចេញ ព្រមទាំងងូតទឹកសម្អាតខ្លួនរបស់គាត់ ទើបគាត់បានបរិសុទ្ធ។ បន្ទាប់មក
គាត់ចូលទៅក្នុងជំរំវិញ ប៉ុន្តែ គាត់ត្រូវរស់នៅក្រៅត្រសាលរបស់គាត់រយៈពេលប្រាំពីរថ្ងៃទៀត។[9]លុះដល់ថ្ងៃទីប្រាំពីរ គាត់ត្រូវកោរសក់ដែលនៅលើក្បាលរបស់គាត់
ទាំងពុកចង្កា រោមចិញ្ចើម។ រោម ដែលមាននៅលើខ្លួនរបស់គាត់ក៏ត្រូវកោរចេញទាំងអស់ ហើយគាត់ត្រូវបោកសម្លៀកបំពាក់របស់គាត់ ហើយជម្រះខ្លួនរបស់គាត់ក្នុងទឹក
បន្ទាប់មក គាត់នឹងបានបរិសុទ្ធ។
[10]នៅថ្ងៃទីប្រាំបីគាត់ត្រូវនាំយក ចៀមឈ្មោលល្អឥតខ្ចោះពីរ ចៀមញីអាយុមួយឆ្នាំដែលល្អឥតខ្ចោះមួយ ហើយម្សៅម៉ដ្តបីរង្វាល់លាយជាមួយប្រេងសម្រាប់ជាតង្វាយម្សៅ
និងប្រេងកន្លះលីត។[11]បូជាចារ្យដែលធ្វើពិធីជម្រះកាយនាំអ្នកដែលបានជា និងតង្វាយរបស់គាត់ ចូលទៅចំពោះព្រះអម្ចាស់នៅត្រង់ច្រកចូលព្រះពន្លាជួបព្រះអម្ចាស់។
[12]លោកបូជាចារ្យត្រូវយកចៀមឈ្មោលមួយមកថ្វាយជាយញ្ញបូជាលោះបាប ជាមួយនឹងប្រេងកន្លះលីត លោកលើករបស់ទាំងនោះសម្រាប់ថ្វាយនៅចំពោះព្រះអម្ចាស់។
[13]គាត់ត្រូវសម្លាប់ចៀមនៅកន្លែងដែលពួកគេសម្លាប់សត្វសម្រាប់យញ្ញបូជារំដោះបាប និងតង្វាយដុតទាំងមូល នៅក្នុងទីសក្ការៈ ដ្បិត
យញ្ញបូជាលោះបាបក៏ដូចជាយញ្ញបូជារំដោះបាប សាច់នៃតង្វាយនេះគឺជាចំណែករបស់បូជាចារ្យព្រោះជាតង្វាយដ៏វិសុទ្ធបំផុត។
[14]បូជាចារ្យត្រូវយកចំណែកខ្លះនៃឈាមយញ្ញបូជាលោះបាប លាបលើស្លឹកត្រចៀកស្តាំ លើមេដៃស្តាំ និងមេជើងស្តាំរបស់អ្នកទទួលពិធីជម្រះកាយនោះ។[15]បន្ទាប់មក
គាត់ត្រូវយកប្រេងកន្លះលីត ហើយចាក់ទៅក្នុងបាតដៃឆ្វេងរបស់គាត់[16]រួចយកដៃស្តាំរបស់លោកជ្រលក់ទៅក្នុងប្រេងដែលនៅក្នុងបាតដៃឆ្វេងរបស់លោក
ហើយប្រោះប្រាំពីរដងនៅចំពោះព្រះភក្ត្រព្រះអម្ចាស់។
[17]បូជាចារ្យយកប្រេងដែលសល់នៅក្នុងដៃរបស់លោក លាបលើត្រចៀកស្តាំ មេដៃស្តាំ និង មេជើងស្តាំ របស់អ្នកដែលទទួលពិធីជម្រះកាយនោះ
គឺលាបលើឈាមសត្វដែលថ្វាយជាយញ្ញបូជាលោះបាបនោះ។[18]ឯឈាមដែលនៅសល់ក្នុងបាតដៃរបស់បូជាចារ្យ
លោកត្រូវលាបលើក្បាលរបស់អ្នកដែលទទួលពិធីជម្រះកាយ ហើយធ្វើពិធីរំដោះបាបឲ្យគាត់នៅចំពោះព្រះអម្ចាស់។
[19]បន្ទាប់មក បូជាចារ្យត្រូវថ្វាយយញ្ញបូជារំដោះបាប និងធ្វើពិធីលោះគាត់ឲ្យរួចពីភាពសៅហ្មង ព្រោះតែភាពសៅហ្មងរបស់គាត់
ហើយលោកត្រូវចាក់កសម្លាប់សត្វសម្រាប់តង្វាយដុត។[20]បូជាចារ្យត្រូវថ្វាយតង្វាយដុតទាំងមូល និងតង្វាយម្សៅនៅលើអាសនៈ។ លោកត្រូវធ្វើពិធីរំដោះបាបជាថ្មីម្តងទៀត
ទើបគេបានបរិសុទ្ធ។
[21]ប្រសិនបើ សាមីុខ្លួនជាអ្នកក្រមិនមានលទ្ធភាពថ្វាយតង្វាយគ្រប់ចំនួនទេ គេត្រូវយកកូនចៀមមួយជាយញ្ញបូជាលោះបាបដើម្បីបូជាចារ្យលើកថ្វាយព្រះអម្ចាស់
ធ្វើពិធីលោះគាត់ ព្រមទាំងម្សៅម៉ដ្តមួយរង្វាល់លាយជាមួយប្រេង និងប្រេងកន្លះលីតផ្សេងទៀត។[22]គាត់ត្រូវយកលលកពីរ ឬព្រាបជំទើរពីរ
តាមលទ្ធភាពដែលគាត់អាចធ្វើបាន គឺមួយសម្រាប់យញ្ញបូជាលោះបាប និងមួយទៀតសម្រាប់តង្វាយដុតទាំងមូល។
[23]នៅថ្ងៃទីប្រាំបីគាត់ត្រូវយកតង្វាយទាំងនោះទៅជូនបូជាចារ្យសម្រាប់ការជម្រះកាយរបស់គាត់ នៅត្រង់ទ្វារព្រះពន្លាជួបព្រះអម្ចាស់ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់។
[24]បូជាចារ្យយកកូនចៀមដែលត្រូវថ្វាយជាយញ្ញបូជាលោះបាប ព្រះអម្ចាស់ និងប្រេងលើកឡើងថ្វាយព្រះអម្ចាស់។
[25]គាត់ត្រូវចាក់កសម្លាប់កូនចៀមសម្រាប់យញ្ញបូជាលោះបាប ហើយយកឈាមខ្លះនៃយញ្ញបូជាបោះលាបលើត្រចៀកស្តាំ មេដៃស្តាំ
និងមេជើងស្តាំរបស់អ្នកទទួលពិធីជម្រះកាយ។
[26]បូជាចារ្យចាក់ប្រេងខ្លះទៅក្នុងបាតដៃឆ្វេងរបស់គាត់[27]ហើយយកម្រាមដៃស្តាំរបស់គាត់ជ្រលក់ទៅក្នុងប្រេងដែលនៅក្នុងបាតដៃឆ្វេង
រួចប្រោះចំនួនប្រាំពីរដងនៅចំពោះព្រះភក្ត្រព្រះអម្ចាស់។
[28]បូជាចារ្យយកប្រេងដែលនៅក្នុងបាតដៃរបស់គាត់លាបលើស្លឹកត្រចៀកស្តាំ មេដៃស្តាំ និងមេជើងឆ្វេង របស់អ្នកដែលទទួលពិធីជម្រះកាយនោះ
នៅពីលើកន្លែងដែលលាបឈាមនៃតង្វាយលោះបាប។[29]ចំណែក ប្រេងដែលសល់នៅក្នុងបាតដៃរបស់គាត់ត្រូវចាក់ទៅលើក្បាលរបស់អ្នកដែលទទួលពិធីជម្រះកាយ
ធ្វើពិធីរំដោះបាបឲ្យគេ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់។
[30]គាត់ត្រូវថ្វាយលលក ឬព្រាបជំទើរមួយ តាមដែលគាត់អាចធ្វើទៅបាន[31]មួយសម្រាប់យញ្ញបូជារំដោះបាប ហើយមួយទៀតជាតង្វាយដុតទាំងមូល
រួមជាមួយតង្វាយម្សៅ។ បន្ទាប់មក បូជាចារ្យធ្វើពិធីរំដោះបាបឲ្យគេនៅចំពោះព្រះភក្ត្រព្រះអម្ចាស់។[32]នេះគឺជាច្បាប់សម្រាប់ធ្វើពិធីកាយឲ្យអ្នកដែលជាពីជំងឺឃ្លង់
ហើយគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការថ្វាយតង្វាយ»។
[33]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេ និងលោកអើរ៉ុនថា៖[34]«នៅពេលដែលអ្នករាល់គ្នាចូលទៅរស់នៅក្នុងទឹកដីកាណាន
ដែលយើងបានប្រគល់ឲ្យអ្នករាល់គ្នាជាមរតក ហើយប្រសិនបើ យើងធ្វើឲ្យមានផ្សិតនៅតាមផ្ទះ
នៅក្នុងទឹកដីជាកម្មសិទ្ធិរបស់អ្នករាល់គ្នា[35]នោះអ្នកដែលជាម្ចាស់ផ្ទះត្រូវទៅជួបបូជាចារ្យ និងជម្រាបគាត់អំពីរឿងនេះ។ គេត្រូវនិយាយថា
ខ្ញុំបានឃើញមានអ្វីម៉្យាងដូចជាផ្សិតក្នុងផ្ទះរបស់ខ្ញុំ។
[36]បូជាចារ្យត្រូវបញ្ជាឲ្យគេរើតវ៉ាន់ចេញពីផ្ទះ មុនពេលដែលគាត់ចូលទៅពិនិត្យស្នាមនៅក្នុងផ្ទះ ដូច្នេះ នឹងមិនមានអ្វីនៅក្នុងផ្ទះដែលធ្វើឲ្យមិនបរិសុទ្ធទេ។
[37]គាត់ត្រូវពិនិត្យស្នាមនោះ ប្រសិនបើ ឃើញថាមានស្នាមនៅលើជញ្ជាំង ហើយស្នាមនោះមានពណ៌បៃតង ឬក្រហមព្រឿងៗ ឬស្នាមនោះខូងរូងចូលទៅក្នុងជញ្ជាំង។
[38]ប្រសិនបើ ផ្ទះនោះមានស្នាម បូជាចារ្យត្រូវចេញទៅខាងក្រៅហើយបិទទ្វារផ្ទះនោះរយៈពេលប្រាំពីរថ្ងៃ។
[39]លុះដល់ថ្ងៃទីប្រាំពីរបូជាចារ្យ ត្រូវត្រឡប់ទៅពិនិត្យស្លែរសាជាថ្មី ប្រសិនបើ ឃើញថាស្លែររាលដាលលើជញ្ជាំងផ្ទះថែមទៀត។[40]ប្រសិនបើមាន
បូជាចារ្យត្រូវបញ្ជាឲ្យយកថ្មដែលបានរកឃើញថាមានស្លែរនោះចេញ ហើយយកវាចេញទៅកន្លែងដែលមិនបរិសុទ្ធ នៅក្រៅទីក្រុង។

generated on Wed Sep 10 16:16:32 2025

[41]លោកត្រូវឲ្យគេកោសជញ្ជាំងផ្ទះទាំងអស់ ហើយពួកគេត្រូវយកកម្ទេចដែលកោសនោះទៅបោះចោលនៅខាងក្រៅទីក្រុង នៅកន្លែងដែលមិនបរិសុទ្ធ។
[42]ពួកគេត្រូវយកថ្មទៅដាក់ជំនួសនៅកន្លែងដែលគេបានយកចេញនោះ ហើយត្រូវយកបាយអរថ្មីមកបូក។
[43]ប្រសិនបើ បន្ទាប់ពីយកថ្មចេញ ហើយកោសស្នាមដែលមាននោះ និងបិទសាជាថ្មី តែស្នាមស្ករដុះឡើងសាជាថ្មីទៀតនោះ[44]បូជាចារ្យត្រូវមកពិនិត្យម្តងទៀត មើលថា
តើមានស្នាមស្ករនៅក្នុងផ្ទះដែរឬទេ។ ប្រសិនបើ ឃើញថាមានស្ករ នោះបានសេចក្តីថា ស្ករដែលមិនអាចកម្ចាត់បាន ហើយផ្ទះនោះមិនបរិសុទ្ធ។
[45]ផ្ទះនោះត្រូវកម្ទេចចោល។ ទាំងថ្ម ទាំងឈើ ទាំងបាយអរ រួចយកអ្វីៗទាំងអស់នោះទៅចោលនៅទីមិនបរិសុទ្ធ នៅខាងក្រៅទីក្រុង។[46]បន្ថែមលើនេះ
អ្នកដែលចូលទៅក្នុងផ្ទះអំឡុងពេលដែលបិទទ្វារ អ្នកនោះមិនបរិសុទ្ធរហូតដល់ពេលល្ងាច។[47]អ្នកដេកក្នុងផ្ទះនោះ ត្រូវបោកសម្លៀកបំពាក់របស់ខ្លួន
ហើយអ្នកដែលបរិភោគក្នុងផ្ទះនោះ ក៏ត្រូវបោកសម្លៀកបំពាក់របស់ខ្លួនដែរ។
[48]ប្រសិនបើ ក្រោយពីគេបូកបាយអរហើយ បូជាចារ្យចូលទៅក្នុងផ្ទះពិនិត្យ ហើយឃើញថា ស្នាមស្ករនោះមិនមានទៀត នោះលោកត្រូវប្រកាសថា ផ្ទះនោះបរិសុទ្ធ។
[49]លោកបូជាចារ្យត្រូវយកសត្វស្លាបពីរក្បាល ឈើតាត្រៅ អំបោះរោមចៀមពណ៌ក្រហមទុំ និងមែកហ៊ីសុ៊ប មកធ្វើពិធីជម្រះបាបពីក្នុងផ្ទះនោះ។
[50]លោកត្រូវអារកសត្វស្លាបទីមួយនៅលើផើងដែលធ្វើពីដី ដែលដាក់ទឹកជ្រោះ។[51]ហើយលោកត្រូវយកដើមតាត្រៅ មែកហ៊ីសុ៊ប អំបោះរោមចៀមពណ៌ក្រហមទុំ
និងសត្វស្លាបមួយទៀតដែលនៅរស់ ជ្រលក់ទៅក្នុងឈាមសត្វស្លាប ដែលគេអារកលាយជាមួយទឹកជ្រោះ ហើយប្រោះប្រាំពីរដងទៅលើផ្ទះនោះ។
[52]លោកបូជាចារ្យត្រូវជម្រះផ្ទះនោះដោយឈាមសត្វស្លាបលាយជាមួយទឹកជ្រោះ ជាមួយនឹងសត្វស្លាបដែលនៅរស់ ឈើតាត្រៅ មែកហ៊ីសុ៊ប
និងអំបោះរោមចៀមពណ៌ក្រហមទុំ។[53]ប៉ុន្តែ លោកត្រូវលែងសត្វស្លាបដែលនៅរស់នោះអោយហើរទៅទីវាល។ លោកធ្វើពិធីរំដោះបាបចេញពីផ្ទះ
ហើយផ្ទះនោះនឹងបានបរិសុទ្ធ។
[54]នេះជាច្បាប់ស្តីអំពីរោគឃ្លង់គ្រប់បែបយ៉ាងទាំងអស់ និង រោគអង្គែស៊ី[55]និងច្បាប់ស្តីអំពីផ្សិតនៅលើសម្លៀកបំពាក់ ការដុះស្ករនៅក្នុងផ្ទះ[56]សម្រាប់ការកើតកន្ទួល កើតភ្លឺ
និងកើតស្រែង[57]ដែលជួយឲ្យគេអាចកំណត់លើមនុស្ស ឬវត្ថុដែលបរិសុទ្ធឬ មិនបរិសុទ្ធ។ ទាំងនេះជាច្បាប់ស្តីអំពីរោគឃ្លង់ និងស្ករ។

Leviticus 14:1
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលនរណាម្នាក់ត្រូវបានសំអាតពីជំងឺឃ្លង់
នៅថ្ងៃធ្វើពិធីជម្រះកាយ
នេះសំដៅទៅលើថ្ងៃដែលបូជាចារ្យប្រកាសអោយមនុស្សនោះបានស្អាត។
គាត់ត្រូវនាំទៅបូជាចារ្យ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកណាម្នាក់ត្រូវនាំគាត់ទៅបូជាចារ្យ» ឬ «គាត់ត្រូវតែទៅរកបូជាចារ្យ»
Leviticus 14:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលនរណាម្នាក់ត្រូវបានសំអាតពីជំងឺស្បែក
ជំងឺឃ្លង់
បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក ១៣: ៣ ។
មួយដែលត្រូវបានសំអាត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលគាត់កំពុងជម្រះកាយ»
សត្វស្លាបដែលស្អាតស្អំ
សត្វស្លាបដែលព្រះបានអនុញ្ញាតឱ្យមនុស្សបរិភោគនិងផ្តល់ជាដង្វាយត្រូវបានគេរាប់ដូចជា
អំបោះក្រហម
«អំបោះក្រហម»
មែកហ៊ីសុប
ស្មៅដែលមានក្លិនក្រអូបដែលត្រូវបានប្រើសម្រាប់ថ្នាំ
Leviticus 14:6
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលនរណាម្នាក់ត្រូវបានសំអាតពីឃ្លង់។
សត្វស្លាបដែលត្រូវបានសម្លាប់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«សត្វស្លាបដែលមនុស្សបានសម្លាប់»
អ្នកដែលត្រូវបានសំអាត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលគាត់កំពុងជម្រះកាយ»
បូជាចារ្យត្រូវប្រកាសថាគាត់ជាមនុស្សបានស្អាត
មនុស្សដែលមនុស្សផ្សេងទៀតអាចប៉ះ
និងអ្នកដែលអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេរាប់ដូចជា
Leviticus 14:8
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលនរណាម្នាក់ត្រូវបានសំអាតពីជំងឺឃ្លង់

អ្នកដែលត្រូវបានសំអាត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលគាត់កំពុងជម្រះកាយ»
ក្រោយមកគាត់នឹងបានស្អាត
មនុស្សដែលមនុស្សផ្សេងទៀតអាចប៉ះត្រូវបានគេរាប់ថាគាត់ស្អាតស្អំខាងរាងកាយ។
Leviticus 14:10
គាត់ត្រូវនាំយក
នៅទីនេះ «គាត់» សំដៅទៅលើបុរសដែលត្រូវបានសម្អាត។
អេផា
មួយអេផាគឺ ២២ លីត្រ។
ប្រេងកន្លះលីត
ប្រេងកន្លះលីតគឺ ០,៣១ លីត្រ
អ្នកដែលត្រូវបានសំអាត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលគាត់កំពុងសំអាត»
Leviticus 14:12
ប្រេងកន្លះលីត
ប្រេងកន្លះលីតគឺ ០,៣១ លីត្រ
នៅកន្លែងមួយនៃរោងឧបោសថ
ជាសាច់ឈ្លាត
អំបោះក្រហម
«អំបោះក្រហម»
Leviticus 14:14
អ្នកដែលត្រូវបានសំអាត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលគាត់កំពុងសំអាត»
ប្រេងកន្លះលីត
ប្រេងកន្លះលីតគឺ ០,៣១ លីត្រ។
ប្រោះប្រេង...នៅចំពោះព្រះភក្ត្រព្រះអម្ចាស់
«ប្រោះប្រេង ... នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»។
មិនមានការចង្អុលបង្ហាញពីអ្វីដែលបូជាចារ្យប្រោះប្រេងលើនោះទេ។
Leviticus 14:17
ប្រេងដែលនៅសល់នៅក្នុងដៃរបស់គាត់
«ប្រេងដែលនៅសល់នៅក្នុងដៃរបស់គាត់»
អ្នកដែលទទួលពិធីជម្រះកាយ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលគាត់កំពុងទទួលពិធីជម្រះកាយ»
ពោះព្រះអម្ចាស់
«នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»
Leviticus 14:19
គាត់ឲ្យរួចពីភាពសៅហ្មង
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលគាត់កំពុងធ្វើពិធីជម្រះកាយ»

generated on Wed Sep 10 16:16:32 2025

គេបានបរិសុទ្ធ
មនុស្សដែលមនុស្សផ្សេងទៀតអាចប៉ះបាននិយាយថាគាត់ស្អាតខាងរាងកាយ។
Leviticus 14:21
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលនរណាម្នាក់បានស្អាតពីជំងឺស្បែក។
មិនមានលទ្ធភាព
«មិនមានប្រាក់គ្រប់គ្រាន់ដើម្បីទិញ»
ដើម្បីបូជាចារ្យលើកថ្វាយព្រះអម្ចាស់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បូជាចារ្យនឹងគ្រវី ... សម្រាប់គាត់»
មួយភាគដប់នៃម្សៅម៉ដ្ត
មួយភាគដប់នៃអេភេមួយ - មួយភាគដប់នៃម្សៅម៉ដ្តគឺ ២២ លីត្រ។
ប្រេងកន្លះលីត
ប្រេងកន្លះលីតគឺ ០,៣១ លីត្រ។
Leviticus 14:24
ប្រេងកន្លះលីត
ប្រេងកន្លះលីតគឺ ០,៣១ លីត្រ។
អ្នកទទួលពិធីជម្រះកាយ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ម្នាក់ដែលគាត់កំពុងធ្វើពិធីជម្រះកាយ»
Leviticus 14:26
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើនៅពេលនរណាម្នាក់បានសំអាតពីជំងឺស្បែក។
ជ្រលក់...ក្នុងប្រេង...ចំពោះព្រះភក្ត្រព្រះអម្ចាស់
«ប្រោសប្រេងខ្លះ ... នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»។
មិនមានការចង្អុលបង្ហាញពីអ្វីដែលបូជាចារ្យប្រោះប្រេងលើនោះទេ។
Leviticus 14:28
អ្នកដែលទទួលពិធីជម្រះកាយ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ម្នាក់ដែលគាត់កំពុងសំអាត»
Leviticus 14:30
គាត់ត្រូវថ្វាយ
«បូជាចារ្យត្រូវថ្វាយ»
ធ្វើពិធីរំដោះបាបឲ្យគេ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ម្នាក់ដែលគាត់កំពុងធ្វើពិធីសំអាតកាយ»
ជំងឺឃ្លង់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១៣: ៣ ។
គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការថ្វាយ
បកប្រែវាដូច្នេះ គឺច្បាស់ថាមនុស្សនោះមិនមានប្រាក់គ្រប់គ្រាន់
ដើម្បីទិញតង្វាយតាមស្តង់ដារទេ។ ការប្រែផ្សេងទៀត
«អ្នកណាមិនមានប្រាក់គ្រប់គ្រាន់ដើម្បីទិញ»
Leviticus 14:33
នៅពេលដែលអ្នករាល់គ្នាចូលទៅ
ត្រង់នេះ «អ្នក» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ឆ្បិត
បកប្រែពាក្យនេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១៣:៤៧ ។
ក្នុងទឹកដីជាកម្មសិទ្ធិរបស់អ្នករាល់គ្នា
ពាក្យថាកម្មសិទ្ធិអាចបកប្រែជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«នៅក្នុងទឹកដីដែលអ្នកមាន»
Leviticus 14:36
ដូច្នេះ នឹងមិនមានអ្វីនៅក្នុងផ្ទះដែលធ្វើឲ្យមិនបរិសុទ្ធទេ
ពេលបូជាចារ្យប្រកាសថាផ្ទះនោះមិនស្អាតអ្វីៗក្នុងផ្ទះទាំងអស់
ក៏ក្លាយទៅជាមិនស្អាតដែរ។ នេះអាចបកប្រែជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត
«ដូច្នេះគាត់មិនចាំបាច់ប្រកាសអ្វីដែលនៅសល់នៅក្នុងផ្ទះមិនស្អាតទេ»
ផ្ទះដែលធ្វើឲ្យមិនបរិសុទ្ធ
ផ្ទះដែលព្រះអម្ចាស់បានថ្លែងនោះមិនសមនឹងមនុស្សដែលប៉ះ
ឬរស់នៅទេគឺនិយាយដូចជាមិនស្អាតខាងរូបកាយ។
ស្នាមនោះខូងរូងចូលទៅក្នុងជញ្ជាំង
នេះមានន័យថាបូជាចារ្យត្រូវកំណត់ថាតើស្នាមប្រេះបានប្រែទៅជាជ្រៅដែលគ្រាន់តែជាផ្ទៃជញ្ជាំងប៉ុណ្ណោះ
Leviticus 14:39
ថ្មដែលបានរកឃើញថាមានស្នែរ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលក្នុងនោះពួកគេបានរកឃើញសភាពស្រាលជាងមុន»
កន្លែងដែលមិនបរិសុទ្ធ
កន្លែងដែលមិនសមរម្យសម្រាប់មនុស្សកាន់កាប់
ឬប្រើសម្រាប់គោលបំណងរបស់ព្រះត្រូវគេនិយាយថាវាមិនស្អាតខាងរាងកាយ។
Leviticus 14:41
លោកត្រូវឲ្យគេ
នៅទីនេះ «គាត់» សំដៅទៅលើបូជាចារ្យ។
កោសជញ្ជាំងផ្ទះទាំងអស់
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលម្ចាស់កោសជញ្ជាំងខាងក្នុង»
កម្ទេចដែលកោសនោះទៅបោះចោល
នេះសំដៅទៅលើសម្ភារៈដែលមានឆ្បិត។ នេះអាចបកប្រែជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត «វត្ថុដែលមានជាតិកខ្វក់ដែលពួកគេបានបោះចោល»
កន្លែងដែលមិនបរិសុទ្ធ
កន្លែងដែលមិនសមរម្យសម្រាប់មនុស្សកាន់កាប់
ឬប្រើសម្រាប់គោលបំណងរបស់ព្រះត្រូវគេនិយាយថាវាមិនស្អាតខាងរាងកាយ។
យកថ្មទៅដាក់ជំនួសនៅកន្លែងដែលគេបានយកចេញនោះ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ថ្មដែលពួកគេបានរើចេញ»
ត្រូវយកបាយអរថ្មីមកបូក
«ពួកគេត្រូវតែគ្របថ្មដោយដីឥដ្ឋថ្មី»
Leviticus 14:43
ស្នាមស្នែរដុះឡើងសាជាថ្មី
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នៅក្នុងផ្ទះបន្ទាប់ពីម្ចាស់ផ្ទះដកដុំថ្មខ្ចាត់ជញ្ជាំងនិងគ្របថ្មថ្មីជាមួយដីឥដ្ឋ» (សូមមើល ផ្figs-activepassive)
ផ្ទះនោះមិនបរិសុទ្ធ
ផ្ទះមួយដែលមិនសមរម្យសម្រាប់ប្រជាជនកាន់កាប់ត្រូវគេនិយាយថាដូចជាមិនស្អាតខាងរាងកាយ។
Leviticus 14:45
ផ្ទះនោះត្រូវកម្ទេចចោល
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវតែកម្ទេចផ្ទះនោះចោល»
ទាំងថ្ម ទាំងឈើ ទាំងបាយអរ រួចយកអ្វីៗទាំងអស់នោះទៅចោល
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវយកដុំថ្ម ឈើនិងម្ទាងសិលាទាំងអស់នៅក្នុងផ្ទះ»
កដែលចូលទៅក្នុងផ្ទះ...អ្នកនោះមិនបរិសុទ្ធ
មនុស្សម្នាក់ដែលមនុស្សផ្សេងទៀតមិនអាចប៉ះនិងអ្នកដែលមិនអាចទទួលយកបានសម្រាប់គោលបំណង
រហូតដល់ពេលល្ងាច
«រហូតដល់ថ្ងៃលិច»
Leviticus 14:48
ស្នាមស្នែរនោះ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ម្ចាស់ដាក់ដីឥដ្ឋថ្មីលើថ្ម»
លោកត្រូវប្រកាសថា ផ្ទះនោះបរិសុទ្ធ
កន្លែងដែលសក្តិសមសម្រាប់មនុស្សកាន់កាប់ត្រូវបានគេនិយាយថាវាស្អាត។
Leviticus 14:49
ឈើតាត្រៅ អំបោះរោមចៀមពណ៌ក្រហមទុំ និងមែកហ៊ីសុប
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើនៅក្នុងជំពូក ១៤: ៣ ។
ឈាមសត្វស្លាប ដែលគេអារក
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ឈាមរបស់បក្សីដែលគាត់បានសំលាប់»
Leviticus 14:52

generated on Wed Sep 10 16:16:32 2025

លោកបូជាចារ្យត្រូវជម្រះផ្ទះនោះ
បូជាចារ្យត្រូវធ្វើពិធីជំរះផ្ទះ ឲ្យបានស្អាតបរិសុទ្ធ។
ផ្ទះនោះនឹងបានបរិសុទ្ធ
ផ្ទះមួយដែលសមនឹងមនុស្សកាន់កាប់គឺត្រូវគេនិយាយថាវាស្អាត។
Leviticus 14:54
រោគឃ្លង់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១៣: ៣ ។
ស្លែរ
បកប្រែពាក្យនេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១៣:៤៧ ។
កន្ទួល
បកប្រែពាក្យនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ជំពូក ១៣: ៥ ។
បរិសុទ្ធឬ មិនបរិសុទ្ធ
មនុស្សនិងរបស់របរដែលមនុស្សផ្សេងទៀតមិនអាចប៉ះ
គេនិយាយថាពួកគេមិនស្អាតខាងរាងកាយហើយរបស់ដែលមនុស្សអាចប៉ះត្រូវគេនិយាយថាពួកគេស្អាត

15 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេ និងលោកអើរ៉ុនថា៖[2]«ចូរប្រកាសប្រាប់ជនជាតិអ៊ីស្រាអែលថា នៅពេលដែលបុរសណាម្នាក់មានជំងឺកាមរោគ
ហើយមានខ្ទុះ ចេញពីខ្លួនរបស់គាត់មក គាត់នឹងក្លាយជាមនុស្សមិនបរិសុទ្ធ។[3]ភាពមិនបរិសុទ្ធរបស់គាត់ គឺព្រោះតែជំងឺកាមរោគនេះ។ ទោះបីខ្ទុះហូរចេញមក
ឬមិនហូរចេញពីរាងកាយរបស់គាត់មកក្តី។
[4]គ្រែដែលគាត់ដេក នឹងទៅជាមិនបរិសុទ្ធ ហើយអ្វីៗដែលគាត់អង្គុយពីលើនឹងទៅជាមិនបរិសុទ្ធទាំងអស់។[5]អ្នកណាដែលប៉ះនឹងគ្រែដេករបស់គាត់
ត្រូវបោកសម្លៀកបំពាក់របស់គេ ហើយងូតទឹកសម្អាតខ្លួនរបស់គាត់ ហើយគាត់នឹងមិនបរិសុទ្ធរហូតដល់ពេលល្ងាច។
[6]អ្នកណាដែលអង្គុយលើអ្វីដែលមនុស្សមានជំងឺកាមរោគបានអង្គុយ អ្នកនោះត្រូវបោកសម្លៀកបំពាក់របស់គេ ហើយងូតទឹកសម្អាតខ្លួនរបស់គេ
តែគេនឹងនៅមិនបរិសុទ្ធរហូតដល់ល្ងាច។[7]អ្នកណាដែលប៉ះរូបកាយមនុស្សដែលមានហូរខ្ទុះដោយសារកាមរោគត្រូវបោកសម្លៀកបំពាក់របស់គេ
និងត្រូវងូតទឹកសម្អាតខ្លួនរបស់គេ ហើយគេមិនបរិសុទ្ធដល់ល្ងាច។
[8]ប្រសិនបើ អ្នកជំងឺនោះស្តោះទឹកមាត់លើមនុស្សដែលបរិសុទ្ធ មនុស្សដែលបរិសុទ្ធនោះត្រូវបោកសម្លៀកបំពាក់របស់គេ និងត្រូវងូតទឹកសម្អាត់ខ្លួន
ហើយគេត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ល្ងាច។[9]កែបសេះ ឬកែបលាដែលអ្នកជម្ងឺអង្គុយលើ ក៏ទៅជាមិនបរិសុទ្ធដែរ។
[10]អ្នកណាដែលប៉ះនឹងវត្ថុអ្វីពីក្រោមអ្នកជំងឺ គេនឹងនៅក្នុងភាពមិនបរិសុទ្ធរហូតដល់ពេលល្ងាច ហើយអ្នកដែលលើកកាន់របស់អស់ទាំងនោះ
ត្រូវបោកសម្លៀកបំពាក់របស់គេ ហើយងូតទឹកសម្អាតខ្លួនរបស់គេដែរ គេត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធបែបនេះរហូតដល់ល្ងាច។
[11]បើអ្នកជំងឺបានប៉ះអ្នកណាម្នាក់ដោយមិនបានលាងដៃជាមុន អ្នកនោះត្រូវបោកសម្លៀកបំពាក់របស់គេ និងងូតទឹកសម្អាតខ្លួនរបស់គេ
ហើយគេត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ល្ងាច។[12]ចំណែកធើងដី ដែលត្រូវអ្នកជំងឺប៉ះ ត្រូវបំបែកចោលទាំងអស់
តែបើធើងដែលធ្វើពីឈើត្រូវយកទឹកមកលាងសម្អាត។
[13]ពេលណាដែលខ្ទុះរបស់អ្នកជំងឺកាមរោគនោះឈប់ហូរ គាត់ត្រូវរង់ចាំប្រាំពីរថ្ងៃ ទើបគាត់អាចធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធ គាត់ត្រូវបោកសម្លៀកបំពាក់របស់គាត់
ហើយគាត់ត្រូវងូតទឹកសម្អាតខ្លួនរបស់គាត់ក្នុងទឹកជ្រោះ។ នោះ គាត់បានបរិសុទ្ធហើយ។[14]នៅថ្ងៃទីប្រាំបីគាត់ត្រូវយកលលកពីរ ឬព្រាបជំទើរពីរក្បាល ជូនលោកបូជាចារ្យ
នៅត្រង់ច្រកចូលព្រះពន្លាជួបព្រះអម្ចាស់ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ។[15]បូជាចារ្យត្រូវលើកតង្វាយនោះថ្វាយព្រះអម្ចាស់ មួយសម្រាប់យញ្ញបូជារំដោះបាប
និងមួយផ្សេងទៀតសម្រាប់យញ្ញបូជាដុតទាំងមូល ហើយលោកធ្វើពិធីរំដោះបាបឲ្យគេនៅចំពោះព្រះអម្ចាស់ពីការហូរខ្ទុះនោះ។
[16]ប្រសិនបើ បុរសម្នាក់ហូរទឹកកាម គេត្រូវលាងសម្អាតខ្លួនប្រាណទាំងមូល និងស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ល្ងាច។[17]សម្លៀកបំពាក់ឬកម្រាលដែលទឹកកាមហូរលើ
ត្រូវបោកសម្អាត ហើយវាស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ល្ងាច។[18]ប្រសិនបើ បុរស និងស្ត្រីម្នាក់បានរួមរ័កជាមួយគ្នា នោះគេទាំងពីរនាក់ត្រូវលាងសម្អាតខ្លួន
ហើយស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ពេលល្ងាច។
[19]កាលណាស្ត្រីម្នាក់ធ្លាក់ឈាម ដោយសារនាងមានរដូវ នាងត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធរយៈពេលប្រាំពីរថ្ងៃ ហើយអ្នកដែលប៉ះនាង
នឹងស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ពេលល្ងាច។[20]អំឡុងពេលដែលនាងមានរដូវអ្វីៗដែលនាងដេកលើ នឹងទៅជាមិនបរិសុទ្ធ
ហើយអ្វីដែលនាងអង្គុយពីលើក៏ទៅជាមិនបរិសុទ្ធដែរ។
[21]ប្រសិនបើ អ្នកណាម្នាក់ប៉ះគ្រែនាងដេក គេត្រូវបោកសម្លៀកបំពាក់របស់គេ ហើយគេនឹងស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ល្ងាច។
[22]អ្នកណាដែលប៉ះកៅអីដែលនាងអង្គុយ គេត្រូវបោកសម្លៀកបំពាក់របស់គេ ហើយអ្នកនោះត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ពេលល្ងាច។[23]ប្រសិនបើ
អ្នកណាម្នាក់បានប៉ះវត្ថុអ្វីដែល នៅលើគ្រែ ឬកៅអី ដែលនាងបានដេកឬអង្គុយ គេនឹងស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ល្ងាច។
[24]ប្រសិនបើ មានបុរសណាម្នាក់រួមដំណេកជាមួយនាង ហើយប្រសិនបើ មានភាពមិនបរិសុទ្ធរបស់នាងហូរប៉ះគាត់ នោះគាត់នឹងទៅជាមិនបរិសុទ្ធអស់រយៈពេលប្រាំពីរថ្ងៃ។
គ្រែដែលគាត់ដេកពីលើនឹងទៅជាមិនបរិសុទ្ធ។
[25]ប្រសិនបើ ស្ត្រីណាម្នាក់ធ្លាក់ឈាមយូរថ្ងៃ ដែលខុសពីធម្មតាពីពេលវេលារដូវរបស់នាង ឬប្រសិនបើ នាងធ្លាក់ឈាមយូរហួសលើសពីពេលវេលានៃការមានរដូវរបស់នាង
ក្នុងអំឡុងពេលនៃការហូរភាពមិនបរិសុទ្ធរបស់នាង ដូច្នេះ នាងក៏នឹងមិនបរិសុទ្ធដូចជាពេលដែលនាងមានរដូវដែរ។ នាងជាមនុស្សមិនបរិសុទ្ធ។[26]រាល់គ្រែដែលនាងដេក
នៅអំឡុងពេលដែលនាងធ្លាក់ឈាម នឹងទៅជាមិនបរិសុទ្ធដូចជាអំឡុងពេលដែលនាងមានរដូវដែល
ហើយអ្វីៗដែលនាងអង្គុយពីលើនឹងទៅជាមិនបរិសុទ្ធដូចជាអំឡុងពេលដែលនាងមានរដូវដែរ។[27]ប្រសិនបើ មាននរណាប៉ះពាល់របស់អស់ទាំងនោះ
គេនឹងទៅជាមិនបរិសុទ្ធ គាត់ត្រូវបោកសម្លៀកបំពាក់នឹងងូតទឹកសម្អាតខ្លួនរបស់គាត់ ហើយគាត់នឹងស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ពេលល្ងាច។
[28]ប៉ុន្តែប្រសិនបើនាង បានស្អាតពីការធ្លាក់ឈាមរបស់នាងហើយ នោះនាងត្រូវរាប់ប្រាំពីរថ្ងៃបន្ថែមទៀតសម្រាប់ខ្លួននាង បន្ទាប់ពីនោះមកនាងនឹងបានបរិសុទ្ធ។
[29]លុះដល់ថ្ងៃទីប្រាំបី នាងត្រូវយកលលកពីរ ឬព្រាបជំទើរពីរ ទៅជូនបូជាចារ្យ នៅត្រង់ច្រកព្រះពន្លាជួបព្រះអម្ចាស់។
[30]បូជាចារ្យត្រូវថ្វាយសត្វស្លាបទីមួយជាយញ្ញបូជាលោះបាប ហើយសត្វស្លាបមួយទៀតជាតង្វាយដុតទាំងមូល
លោកធ្វើពិធីរំដោះបាបសម្រាប់គាត់នៅចំពោះព្រះភក្ត្រព្រះអម្ចាស់សម្រាប់ភាពមិនបរិសុទ្ធដោយសារការធ្លាក់ឈាមរបស់គាត់។
[31]នេះគឺជារបៀបដែលអ្នករាល់គ្នាត្រូវញែកជនជាតិអ៊ីស្រាអែល ចេញពីភាពមិនបរិសុទ្ធរបស់ពួកគេ ដូច្នេះ ពួកគេនឹងមិនស្លាប់ដោយសារភាពមិនបរិសុទ្ធរបស់ពួកគេ
ដោយធ្វើឲ្យសៅហ្មងទីសក្ការៈរបស់យើង ជាកន្លែងដែលយើងនៅក្នុងចំណោមអ្នករាល់គ្នា។
[32]នេះជាច្បាប់ដែលស្ថិតស្ថេរសម្រាប់អ្នកដែលមានហូរវត្ថុរាវសម្រាប់មនុស្សប្រុសដែលមានហូរទឹកកាមចេញពីខ្លួនរបស់គាត់
នឹងធ្វើឲ្យគាត់មិនបរិសុទ្ធ[33]សម្រាប់ស្ត្រីណាដែលមានរដូវ សម្រាប់នរណាដែលមានលំហូរសារធាតុរាវទោះបីបុរសក្តី ឬស្ត្រីក្តី
ហើយសម្រាប់បុរសដែលរួមដំណេកជាមួយស្ត្រីដែលមិនបរិសុទ្ធ។

Leviticus 15:1
ចេញពីខ្លួនរបស់គាត់មក
នេះសំដៅទៅលើផ្នែកឯកជនរបស់បុរស។
គាត់នឹងក្លាយជាមនុស្សមិនបរិសុទ្ធ
អ្នកដែលមនុស្សដទទៀតមិនអាចប៉ះបាន គេនិយាយថាគាត់ជាមនុស្សមិនស្អាត
ភាពមិនបរិសុទ្ធ
«រាងកាយរបស់គាត់មិនស្អាត» ឬ «គាត់មិនស្អាត»
Leviticus 15:4
មិនបរិសុទ្ធ
គ្រែរឺរបស់អ្វីដែលបុរសអង្គុយលើ មនុស្សផ្សេងទៀតមិនត្រូវប៉ះ

generated on Wed Sep 10 16:16:32 2025

ត្រូវគេនិយាយដូចជាពួកគេមិនស្អាតខាងរាងកាយ។
អ្នកណាដែលប៉ះនឹងគ្រែដេករបស់គាត់...មិនបរិសុទ្ធ
អ្នកដែលមនុស្សដ៏ទៃទៀតមិនអាចប៉ះពាល់ គេនិយយថាគាត់ជាមនុស្សមិនស្អាត។
រហូតដល់ពេលល្ងាច
«រហូតដល់ថ្ងៃលិច»
Leviticus 15:6
គេនឹងនៅមិនបរិសុទ្ធ
អ្នកដែលមនុស្សដ៏ទៃទៀតមិនអាចប៉ះពាល់បាននិយយថាគាត់ជាមនុស្សមិនស្អាត។
ដល់ល្ងាច
«រហូតដល់ថ្ងៃលិច»
អ្នកណាដែលប៉ះរូបកាយ
«អ្នកណាប៉ះផ្នែកណាមួយនៃរាងកាយ»
Leviticus 15:8
មនុស្សដែលបរិសុទ្ធ
មនុស្សដែលមនុស្សផ្សេងទៀតអាចប៉ះបានគេនិយាយថាគាត់ស្អាតស្អំខាងរាងកាយ។
គេត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធ
អ្នកដែលមនុស្សដ៏ទៃទៀតមិនអាចប៉ះពាល់បាននិយយថាគាត់ជាមនុស្សមិនស្អាត។
កែបសេះ
កៅអីអង្គុយគឺជាកៅអីស្បែកដែលមនុស្សម្នាក់ដាក់នៅលើខ្នងសេះដើម្បីជិះវា។
កែបសេះ ...ក៏ទៅជាមិនបរិសុទ្ធដែរ
អ្វីមួយដែលព្រះអម្ចាស់បានមានបន្ទូលថាមិនគួរប៉ះពាល់ត្រូវបាននិយាយដូចជាមិនស្អាតដែរ។
Leviticus 15:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេ
និងលោកអើរ៉ុននូវអ្វីដែលប្រជាជនត្រូវធ្វើដើម្បីជៀសវាងការឆ្លង។
អ្នកនោះ
នេះសំដៅទៅលើអ្នកដែលមានការឆ្លងរោគ។
ក្នុងភាពមិនបរិសុទ្ធ
អ្នកដែលមនុស្សដ៏ទៃទៀតមិនអាចប៉ះពាល់បាននិយយថាគាត់ជាមនុស្សមិនស្អាត។
រហូតដល់ល្ងាច
«រហូតដល់ថ្ងៃលិច»
បើអ្នកជំងឺបានប៉ះអ្នកណាម្នាក់ដោយមិន
«អ្នកណាដែលមានលំហូរឆ្លងប៉ះ»
អ្នកនោះត្រូវ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកដែលគាត់បានប៉ះ»
ចំណែកធើងដី ដែលត្រូវអ្នកជំងឺប៉ះ ត្រូវបំបែកចោលទាំងអស់
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គេត្រូវតែបំបែកឆ្នាំងណាមួយដែលអ្នកដែលមានទឹកហូរប៉ះ នឹងវត្ថុរាវបែបនេះ»
ធើងដែលធ្វើពីឈើត្រូវយកទឹកមកលាងសម្អាត
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកណាម្នាក់ត្រូវលាងសម្អាតធុងឈើទាំងអស់ក្នុងទឹក»
Leviticus 15:13
ខ្ទុះរបស់អ្នកជំងឺកាមរោគនោះឈប់ហូរ
បុរសដែលបានជាពីជំងឺរបស់គាត់ត្រូវបានគេនិយាយថាគាត់ស្អាតខាងរាងកាយ។
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ស្ទុះងើបឡើងវិញពីលំហូររបស់គាត់»
នោះ គាត់បានបរិសុទ្ធហើយ
បុរសដែលមនុស្សផ្សេងទៀតអាចប៉ះបាននិយាយថាគាត់ស្អាតខាងរាងកាយ។
Leviticus 15:16
មិនបរិសុទ្ធរហូតដល់ល្ងាច
មនុស្សនិងវត្ថុដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេនិយាយថាពួកគេមិនស្អាតខាងរាងកាយ។
រហូតដល់ល្ងាច
«រហូតដល់ថ្ងៃលិច»
សម្លៀកបំពាក់...ត្រូវបោកសម្អាត
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គេលាងសំអាតជាមួយទឹកគ្រប់សម្លៀកបំពាក់ ឬស្បែកដែលមានទឹកកាម»
Leviticus 15:19
ធ្លាក់ឈាម...នាងមានរដូវ
ទាំងពីរនេះសំដៅទៅលើពេលវេលាដែលឈាមហូរចេញពីស្បូនស្ត្រី។
នាងត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធ
«នាងនឹងបន្តមានភាពមិនស្អាត»
ទៅជាមិនបរិសុទ្ធ
មនុស្សនិងវត្ថុដែលមនុស្សផ្សេងទៀត
មិនត្រូវប៉ះត្រូវបានគេនិយាយថាពួកគេមិនស្អាតខាងរាងកាយ។
Leviticus 15:21
គ្រែនាងដេក
នេះសំដៅទៅលើស្ត្រីដែលកំពុងមានរដូវ។
គេនឹងស្ថិតក្នុងភាពមិនបរិសុទ្ធ
អ្នកដែលមនុស្សដ៏ទៃទៀតមិនអាចប៉ះពាល់បាន
គេនិយយថាគាត់ជាមនុស្សមិនស្អាត។
រហូតដល់ល្ងាច
«រហូតដល់ថ្ងៃលិច»
Leviticus 15:24
មានភាពមិនបរិសុទ្ធរបស់នាងហូរប៉ះ
«ឈាមមិនបរិសុទ្ធរបស់នាង» ឬ «ឈាមចេញពីស្បូនរបស់នាង»
ទៅជាមិនបរិសុទ្ធ
មនុស្សនិងវត្ថុដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះ
ត្រូវគេនិយាយថាពួកគេមិនស្អាតខាងរាងកាយ។
Leviticus 15:25
ដូចជាពេលដែលនាងមានរដូវដែរ
នេះមានន័យថាប្រសិនបើស្ត្រីមានឈាមចេញពីស្បូន
គ្រប់ពេលក្រៅពីពេលមានរដូវជាទៀងទាត់នាងនៅតែមិនស្អាតដូចពេលមានរដូវដែរ។
នាងជាមនុស្សមិនបរិសុទ្ធ...ប្រសិនបើ មាននរណាប៉ះពាល់...ស្ថិតក្នុងភាពមិនបរិសុទ្ធ
មនុស្សដែលមនុស្សផ្សេងទៀតមិនអាចប៉ះបាននិយាយថាពួកគេមិនស្អាតខាងរាងកាយ។
ហើយអ្វីៗដែលនាងអង្គុយពីលើនឹងទៅជាមិនបរិសុទ្ធ
វត្ថុដែលមនុស្សផ្សេងទៀតមិនត្រូវប៉ះត្រូវបានគេនិយាយថាពួកគេមិនស្អាតខាងរាងកាយ។
Leviticus 15:28
ប៉ុន្តែប្រសិនបើនាង
ពាក្យថា «នាង» សំដៅទៅលើស្ត្រីដែលកំពុងមានរដូវ។
បានស្អាតពីការធ្លាក់ឈាមរបស់នាងហើយ
ស្ត្រីដែលបានជាសះស្បើយពីការហូរឈាមរបស់នាង
ត្រូវបានគេនិយាយដូចជានាងស្អាតខាងរាងកាយ។
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ស្ទុះងើបឡើងវិញពីលំហូរឈាមរបស់នាង»
នាងនឹងបានបរិសុទ្ធ
ស្ត្រីដែលមនុស្សផ្សេងទៀតអាចប៉ះបាននិយាយថានាងស្អាតខាងរាងកាយ។
នាងត្រូវយក
«នាងនឹងយកសម្រាប់ខ្លួននាងផ្ទាល់»
ភាពមិនបរិសុទ្ធដោយសារការធ្លាក់ឈាម
«ឈាមហូររបស់នាងដែលធ្វើអោយនាងមិនបរិសុទ្ធ»
Leviticus 15:31
នេះគឺជារបៀបដែលអ្នករាល់គ្នាត្រូវញែកជនជាតិអ៊ីស្រាអែល ចេញពីភាពមិនបរិសុទ្ធរបស់ពួកគេ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការការពារប្រជាជនកុំអោយក្លាយទៅជាមិនបរិសុទ្ធដូចជាការពារប្រជាជនពី
ការបកប្រែផ្សេងទៀត «នេះជារបៀបដែលអ្នកត្រូវការពារប្រជាជនអ៊ីស្រាអែល
កុំអោយទៅជាមិនស្អាត»
ភាពមិនបរិសុទ្ធរបស់ពួកគេ
មនុស្សដែលមនុស្សផ្សេងទៀតមិនអាចប៉ះ
និងអ្នកដែលមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយ
ដូចជាពួកគេមិនស្អាតខាងរាងកាយ។
Leviticus 15:32
នេះជាច្បាប់
«ទាំងនេះគឺជាអ្វីដែលត្រូវធ្វើ»
ធ្វើឲ្យគាត់មិនបរិសុទ្ធ...ស្ត្រីដែលមិនបរិសុទ្ធ
មនុស្សដែលមនុស្សផ្សេងទៀតមិនអាចប៉ះបាន
គេនិយាយថាពួកគេមិនស្អាតខាងរាងកាយ។
ដែលមានរដូវ
«អ្នកដែលកំពុងមករដូវ» ឬ «អ្នកណាកំពុងហូរឈាមចេញពីស្បូន»

generated on Wed Sep 10 16:16:32 2025

16 [1]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់មកកាន់លោកម៉ូសេ បន្ទាប់ពីកូនប្រុសទាំងពីររបស់លោកអើរ៉ុនបានស្លាប់ទៅ នៅពេលដែលគេបានចូលទៅក្បែរព្រះអម្ចាស់
ហើយក៏បានស្លាប់ទៅ។[2]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ «ចូរប្រាប់ទៅកាន់អើរ៉ុន ជាបងប្រុសរបស់អ្នកថា
កុំឲ្យចូលទៅទីសក្ការៈគ្រប់ពេលវេលាឡើយ ពោលគឺទៅក្នុងទីដ៏សក្ការៈបំផុតនៅពីក្រោយវាំងនន ពីមុខហិបនៃសម្ពន្ធមេត្រី។ ប្រសិនបើគាត់ចូលទៅគាត់នឹងស្លាប់
ព្រោះយើងនឹងលេចមកនៅក្នុងពពកនៅលើសម្ពន្ធមេត្រី។
[3]ហើយនេះគឺជារបៀបដែលលោកអើរ៉ុនត្រូវធ្វើ នៅពេលដែលគាត់ចូលទៅក្នុងទីសក្ការៈបំផុត។[4]គាត់ត្រូវនាំយកគោឈ្មោលស្ទាវមួយ សម្រាប់យញ្ញបូជារំដោះបាប
ហើយនិងចៀមឈ្មោលមួយសម្រាប់តង្វាយដុតទាំងមូល។ គាត់ត្រូវពាក់អាវវែងសក្ការៈ ដែលធ្វើពីអំបោះធ្មៃ និងស្លៀកខោខ្លីខាងក្នុងធ្វើពីអំបោះធ្មៃ
ពាក់ខ្សែក្រវ៉ាត់ធ្វើពីអំបោះធ្មៃ ហើយពាក់ឆ្នួតក្បាលធ្វើពីអំបោះធ្មៃ។ ដោយសារនេះជាសម្លៀកបំពាក់បរិសុទ្ធ។ គាត់ត្រូវងូតទឹកសម្អាតខ្លួនរបស់គាត់ជាមុនសិន
មុនស្លៀកសម្លៀកបំពាក់។[5]គាត់ត្រូវទទួលពពែឈ្មោលពីរក្បាលពីសហគមន៍ សម្រាប់ថ្វាយជាយញ្ញបូជាលោះបាប មួយសម្រាប់ ថ្វាយជាយញ្ញរំដោះបាប
និងមួយទៀតសម្រាប់តង្វាយដុតទាំងមូល។
[6]បន្ទាប់មក លោកអើរ៉ុនត្រូវថ្វាយយញ្ញបូជាលោះបាប សម្រាប់ខ្លួនលោក ធ្វើពិធីរំដោះបាបរបស់លោក និងក្រុមគ្រួសាររបស់លោក។[7]គាត់ត្រូវយកពពែពីរ
ថ្វាយជាយញ្ញបូជាលោះបាប និងតង្វាយដុតទាំងមូលដូចពីមុនដែរ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់។
[8]លោកត្រូវបោះឆ្នោតសម្រាប់ពពែទាំងពីរនោះ មួយថ្វាយព្រះអម្ចាស់ ហើយមួយទៀតគឺឲ្យលោកអាសាអែល។[9]បន្ទាប់ពី លោកចាប់ឆ្នោតហើយ
ពពែឈ្មោលដែលត្រូវថ្វាយព្រះអម្ចាស់ គឺត្រូវថ្វាយជាយញ្ញបូជាលោះបាប។[10]ប៉ុន្តែ ពពែដែលចាប់ឆ្នោតត្រូវសម្រាប់បំបរបង់ទៅ នោះត្រូវយកមកដាក់ទាំងរស់នៅចំពោះ
ព្រះអម្ចាស់ ដើម្បីធ្វើពិធីរំដោះបាប រួចចាត់គេឲ្យនាំយកទៅបំបរបង់នៅទីរហោស្ថាន។
[11]បន្ទាប់មក លោកអើរ៉ុនត្រូវថ្វាយគោបាជាតង្វាយលោះបាប សម្រាប់ខ្លួនរបស់លោក។ គាត់ត្រូវធ្វើពិធីរំដោះបាប សម្រាប់រូបលោកផ្ទាល់
និងសម្រាប់ក្រុមគ្រួសារលោកផងដែរ។
[12]លោកត្រូវយកភាជន៍ដែលពេញទៅដោយរងើកភ្លើង ដែលយកចេញពីអាសនៈនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ព្រមទាំងយកគ្រឿងក្រអូបម៉ដ្តពីរក្តាប់មកជាមួយ
ចូលទៅក្នុងវាំងននទីសក្ការៈ។[13]នៅទីនោះលោកត្រូវដុតគ្រឿងក្រអូបនៅក្នុងភ្លើងនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ដូច្នេះ ផ្សែងនៃគ្រឿងក្រអូប នឹងហើរឡើងទៅលើគម្របហិប
ដែលគ្របពីលើបន្ទះថ្មនៃសន្ធិសញ្ញា។ ធ្វើដូច្នេះ នោះលោកនឹងមិនត្រូវស្លាប់ឡើយ។
[14]គាត់ត្រូវយកឈាមគោបាមក ហើយជ្រលក់ម្រាមដៃរបស់លោកចូលក្នុងឈាមនោះ រួចប្រោះខាងមុខគម្របហិប។
គាត់ត្រូវយកម្រាមដៃធ្វើពិធីប្រោះឈាមនៅខាងមុខហិប ចំនួនប្រាំពីរដង។
[15]បន្ទាប់មក លោកត្រូវចាក់កពពែសម្រាប់យញ្ញបូជាលោះបាបប្រជាជន ហើយយកឈាមតង្វាយនោះចូលទៅក្នុងវាំងនន។ ហើយគាត់ត្រូវប្រោះឈាមពពែឈ្មោលនេះ
ទៅលើគំរបហិប និងផ្នែកខាងមុខគម្របហិប ដូចគាត់បានប្រោះឈាមគោបាដែរ។[16]គាត់ត្រូវធ្វើពិធីនេះ ដើម្បីជម្រះទីសក្ការៈឲ្យបរិសុទ្ធ
រួចផុតពីភាពសៅហ្មងរបស់ប្រជាជនអ៊ីស្រាអែល ព្រមទាំងអំពើទុច្ចរិត និងអំពើបាបទាំងប៉ុន្មានរបស់ពួកគេ។ គាត់ក៏ត្រូវធ្វើពិធីប្រោះឈាមនេះលើព្រះពន្លាជួបព្រះអម្ចាស់
ដែលព្រះអង្គគង់នៅកណ្តាលចំណោមពួកគេ ដែលជាមនុស្សមិនបរិសុទ្ធ។
[17]នៅពេលដែលលោកអើរ៉ុន ចូលទៅធ្វើពិធីជម្រះបាបនៅក្នុងទីសក្ការៈ រហូតដល់ពេលដែលគាត់បញ្ចប់ពិធី ហើយចេញមកវិញ
គឺមិនត្រូវឲ្យមានអ្នកណាម្នាក់ស្ថិតនៅក្នុងពន្លាជួបព្រះអម្ចាស់ឡើយ គាត់ត្រូវធ្វើពិធីរំដោះបាបឲ្យខ្លួនគាត់ផ្ទាល់ ក្រុមគ្រួសាររបស់គាត់ និងសហគមន៍អ៊ីស្រាអែលទាំងមូល។
[18]គាត់ត្រូវចេញមកខាងមុខអាសនៈ ដែលស្ថិតនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ហើយធ្វើពិធីជម្រះអាសនៈ គឺគាត់ត្រូវយកឈាមគោបា និងឈាមពពែឈ្មោល
ទៅលាបជុំវិញស្នែងទាំងបួនរបស់អាសនៈ។[19]គាត់ត្រូវជ្រលក់ម្រាមដៃទៅក្នុងឈាម ហើយប្រោះប្រាំពីរដង ដើម្បីជម្រះអាសនៈឲ្យបានបរិសុទ្ធ
រួចផុតពីភាពសៅហ្មងទាំងឡាយរបស់ប្រជាជនអ៊ីស្រាអែល និងញែកថ្វាយព្រះអម្ចាស់។
[20]នៅពេលដែលគាត់បានបញ្ចប់ការធ្វើពិធីជំរះទីសក្ការៈ ជំរះព្រះពន្លាជួបព្រះអម្ចាស់ និងជំរះអាសនៈរួចរាល់ហើយ គាត់ត្រូវយកពពែដែលនៅរស់មក។
[21]អើរ៉ុនត្រូវដាក់ដៃទាំងពីររបស់គាត់ទៅលើក្បាលពពែរស់នោះ ហើយលន់តួកំហុសព្រមទាំងអំពើទុច្ចរិត និងអំពើបាបទាំងអស់របស់ជនជាតិអ៊ីស្រាអែល។
បន្ទាប់មកលោកត្រូវផ្ទេរអំពើបាបទាំងអស់ទៅលើក្បាលពពែនោះ ហើយដេញវាទៅវាលរហោស្ថាន ដោយបុរសម្នាក់ដែលបានជ្រើសរើសរួចជាស្រេច។
[22]ពពែនោះនាំយកអំពើបាបទាំងអស់របស់ជនជាតិអ៊ីស្រាអែលទៅកាន់ទីស្មសាន។ បុរសដែលដេញពពែនោះទៅដល់វាលរហោស្ថានហើយ គេត្រូវលែងវាទៅ។
[23]លោកអើរ៉ុនត្រូវត្រឡប់ចូលទៅក្នុងពន្លាជួបព្រះអម្ចាស់ ហើយគាត់ត្រូវដោះសម្លៀកបំពាក់ដែលធ្វើអំពីអំបោះធ្មៃ ដែលគាត់ពាក់សម្រាប់បំពេញមុខងារក្នុងទីសក្ការៈ
ហើយទុកសម្លៀកបំពាក់នៅទីនោះ។[24]គាត់ត្រូវងូតទឹកសម្អាតខ្លួននៅក្នុងទីសក្ការៈ ហើយស្លៀកសម្លៀកបំពាក់ធម្មតាវិញ បន្ទាប់មក គាត់ត្រូវចេញទៅខាងក្រៅ
ហើយថ្វាយតង្វាយដុតទាំងមូលរបស់គាត់ និង ថ្វាយតង្វាយដុតទាំងមូលរបស់ប្រជាជនអ៊ីស្រាអែល ដើម្បីលោះបាបរបស់គាត់ និងបាបរបស់ប្រជាជន។
[25]គាត់ត្រូវដុតខ្លាញ់នៃយញ្ញបូជាលោះបាបនៅលើអាសនៈ។[26]ហើយបុរសដែលដេញពពែទៅវាលរហោស្ថាន ឲ្យអាសាអែល ត្រូវបោកសម្លៀកបំពាក់របសគាត់
និងងូតទឹកសម្អាតខ្លួនរបស់គាត់ បន្ទាប់មក គាត់អាចត្រឡប់មកក្នុងជំរំបាន។
[27]ឯគោបានិងពពែឈ្មោល ដែលគេសម្លាប់សម្រាប់លោះបាប ហើយយកឈាមរបស់វាសម្រាប់ពិធីលោះបាបក្នុងទីសក្ការៈ ត្រូវយកវាទៅខាងក្រៅជំរំ។ ពួកគេត្រូវដុតពួកវា
ទាំងស្បែក ទាំងសាច់ និងគ្រឿងក្នុង។[28]អ្នកដែលដុតផ្នែកទាំងនោះ ត្រូវបោកសម្លៀកបំពាក់របស់គាត់ ហើយងូតទឹកសម្អាតខ្លួនរបស់គាត់
បន្ទាប់មកគេអាចត្រឡប់មកក្នុងជំរំវិញ។
[29]នេះគឺជាច្បាប់ដែលអ្នករាល់គ្នាត្រូវប្រកាន់រហូតតទៅ នៅក្នុងខែទីប្រាំពីរ ថ្ងៃទីដប់ អ្នករាល់គ្នាត្រូវតមអាហារ ហើយមិនត្រូវធ្វើការអ្វីឡើយ គឺទាំងអ្នករាល់គ្នាជាម្ចាស់ស្រុក
ទាំងជនបរទេសដែលរស់នៅជាមួយអ្នករាល់គ្នា[30]ព្រោះនៅថ្ងៃនោះ គេនឹងធ្វើពិធីលោះបាបអ្នករាល់គ្នា ដើម្បីជម្រះអ្នករាល់គ្នាឲ្យបានបរិសុទ្ធ។[31]នោះជាថ្ងៃសប្ប័ទ
ជាថ្ងៃដែលអ្នករាល់គ្នាត្រូវសម្រាក ហើយត្រូវតមអាហារ និងមិនត្រូវធ្វើការងារអ្វីឡើយ។ នេះជាច្បាប់ដែលអ្នករាល់គ្នាត្រូវប្រកាន់រហូតតទៅ ឥតប្រែប្រួលឡើយ។
[32]មានតែមហាបូជាចារ្យ ដែលទទួលការចាក់ប្រេងតែងតាំង និងឲ្យបំពេញមុខងារជាបូជាចារ្យស្នងឪពុករបស់គាត់តែប៉ុណ្ណោះ ដែលអាចធ្វើពិធីលោះបាប
និងពាក់សម្លៀកបំពាក់ធ្វើអំពីអំបោះធ្មៃ ដែលជាសម្លៀកបំពាក់ដ៏បរិសុទ្ធបាន។[33]គាត់ត្រូវធ្វើពិធីជម្រះទីសក្ការៈបំផុត ព្រះពន្លាជួបព្រះអម្ចាស់ ហើយនិងអាសនៈ
ឲ្យបានបរិសុទ្ធ ព្រមទាំងជម្រះបាបបូជាចារ្យ និងប្រជាជនទាំងអស់ក្នុងសហគមន៍។
[34]នេះជាច្បាប់ដែលអ្នករាល់គ្នាត្រូវប្រកាន់ភ្ជាប់ជារៀងរហូតឥតប្រែប្រួល ដើម្បីជម្រះបាបប្រជាជនអ៊ីស្រាអែល ពីអំពើបាបរបស់គេ ជារៀងរាល់ឆ្នាំ»។
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលបានបង្គាប់មកតាមរយៈលោកម៉ូសេ។

Leviticus 16:1
កូនប្រុសទាំងពីររបស់លោកអើរ៉ុន
នេះសំដៅទៅលើណាដាប់និងអាប៊ីហ៊ូ។
ពួកគេបានស្លាប់ដោយសារពួកគេបានយកភ្លើងមកព្រះអម្ចាស់ដែលព្រះអង្គមិនសព្វព្រះទ័យ។
(សូមមើល ជំពូក ១០: ១)
Leviticus 16:3
ហើយនេះគឺជារបៀប
«នេះគឺជារបៀប»
ខោខ្លីខាងក្នុង
«ខោខ្លីខាងក្នុង»
ខោខ្លីខាងក្នុង
សម្លៀកបំពាក់ដែលពាក់ជាប់នឹងស្បែកក្រោមសម្លៀកបំពាក់ខាងក្រៅ។
អំបោះធ្មៃ
ក្រណាត់មួយដុំដែលភ្ជាប់ជុំវិញចង្កេះ ឬទ្រូង
ពាក់ឆ្នួតក្បាល

generated on Wed Sep 10 16:16:32 2025

នេះគឺជាគម្របក្បាលដែលធ្វើពីក្រណាត់រុំ។
ពីសហគមន៍
«ពីក្រុមជំនុំ»
Leviticus 16:6
យញ្ញបូជាលោះបាប សម្រាប់ខ្លួនលោក
«យញ្ញបូជាលោះបាបសំរាប់ខ្លួនគាត់ផ្ទាល់»
Leviticus 16:8
អាសាអែល
«ពពែដែលត្រូវបានបញ្ជូនទៅ»
លោកអើរ៉ុនត្រូវអោយនរណាម្នាក់ដោះលែងពពែនៅវាលរហោស្ថាន។
ដែលត្រូវថ្វាយព្រះអម្ចាស់
«ដែលបានកំណត់ជាច្រើន»
ប៉ុន្តែ ពពែ...ត្រូវយកមកដាក់ទាំងរស់នៅចំពោះព្រះអម្ចាស់
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែអើរ៉ុនត្រូវតែយកពពែ...រស់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»
Leviticus 16:11
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលលោកអើរ៉ុនត្រូវធ្វើនៅថ្ងៃរំដោះបាប។
លោកអើរ៉ុនត្រូវថ្វាយគោបា
អើរ៉ុននឹងចាប់ឈាមគោនៅក្នុងចានមួយដូច្នេះក្រោយមកគាត់អាចប្រោះវាលើគំរបដង្វាយធួន
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឱ្យច្បាស់។
Leviticus 16:12
ភាជន៍
ធុងសំរាប់ដាក់ភ្លើងនិងគ្រឿងក្រអូបដែលពួកបូជាចារ្យប្រើ
គ្រឿងក្រអូប
«គ្រឿងក្រអូប» ។ នេះសំដៅទៅលើក្លិន
និងមិនមែនចំពោះរសជាតិនៃគ្រឿងក្រអូបទេ។
Leviticus 16:14
ឈាមគោបា
នេះគឺជាឈាមដែលអើរ៉ុនចាប់ពីចានមួយនៅជំពូក ១៦:១១ ។
ជ្រលក់ម្រាមដៃរបស់លោកចូលក្នុងឈាមនោះ
គាត់បានប្រើម្រាមដៃរបស់គាត់ប្រោះឈាម។
ខាងមុខគម្របហិប
គាត់ដាក់ឈាមលើផ្នែកខាងលើនៃគំរប។
គាត់ក៏ដាក់វានៅលើគំរបមួយដែលនៅខាងមុខគាត់នៅពេលគាត់ចូលទៅក្នុងទីបរិសុទ្ធបំផុត
នៅខាងមុខហិប
អត្ថន័យដែលអាចមានគឺ ១) «ក្រោមគំរបដង្វាយធួនលើទ្រូង» ឬ ២)
«ទៅនឹងដីនៅពីមុខគំរបដង្វាយរំដោះបាប» ។
Leviticus 16:15
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេពីអ្វីដែលលោកអើរ៉ុនត្រូវធ្វើនៅថ្ងៃរំដោះបាប។
គាត់ត្រូវប្រោះឈាមពពែឈ្មោលនេះ ទៅលើគំរបហិប និងផ្នែកខាងមុខគម្របហិប
ដូចគាត់បានប្រោះឈាមគោបាដែរ
លោកអើរ៉ុនប្រោះឈាមតាមរបៀបដែលលោកធ្វើជាមួយឈាមគោ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែការណែនាំពីមុននៅក្នុងជំពូក ១៦:១៤ ។
គាត់ត្រូវធ្វើពិធីនេះ ដើម្បីជម្រះទីសក្ការៈឲ្យបរិសុទ្ធ រួចផុតពីភាពសៅហ្មងរបស់ប្រជាជនអ៊ីស្រាអែល
អំពើបាបរបស់ប្រជាជនអ៊ីស្រាអែល ធ្វើអោយទីសក្ការៈមិនបរិសុទ្ធ។
ភាពសៅហ្មង...អំពើទុច្ចរិត... និងអំពើបាបទាំងប៉ុន្មាន
ពាក្យទាំងនេះមានន័យជាមូលដ្ឋានដូចគ្នា។
ពួកគេសង្កត់ធ្ងន់ថាប្រជាជនបានប្រព្រឹត្តអំពើបាបគ្រប់ប្រភេទ។
ភាពសៅហ្មង
អំពើបាបដែលធ្វើឱ្យមនុស្សមិនអាចទទួលយកបានចំពោះព្រះជាម្ចាស់ត្រូវបានគេនិយាយថាជាអំ
នៅកណ្តាលចំណោមពួកគេ ដែលជាមនុស្សមិនបរិសុទ្ធ
ឃ្លាដែលថា «សកម្មភាពមិនស្អាតរបស់ពួកគេ»
តំណាងឱ្យមនុស្សដែលប្រព្រឹត្តអំពើបាប។ ការបកប្រែផ្សេងទៀត
«នៅចំពោះមុខមនុស្សដែលប្រព្រឹត្តិអំពើខុសឆ្គង»
Leviticus 16:17
គាត់ត្រូវចេញមកខាងមុខអាសនៈ ដែលស្ថិតនៅចំពោះព្រះភក្ត្រព្រះអម្ចាស់
នេះជាអាសនៈថ្វាយយញ្ញបូជានៅខាងក្នុងទីធ្លាពន្លា។
ហើយធ្វើពិធីជម្រះអាសនៈ
ដូចជាទីសក្ការៈនិងត្រសាលប្រជុំអាសនៈមិនបរិសុទ្ធដោយសារអំពើបាបរបស់ប្រជាជន។
លាបជុំវិញស្នែងទាំងបួនរបស់អាសនៈ
«ការព្យាករណ៍នៅជ្រុងអាសនៈ» ការបកប្រែផ្សេងទៀត
នេះសំដៅទៅលើជ្រុងអាសនៈ ដែលមានរាងដូចស្នែងរបស់គោ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៤: ៦ ។
ដើម្បីជម្រះអាសនៈឲ្យបានបរិសុទ្ធ
អាសនៈដែលត្រូវបានប្រើសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយថាហាក់ដូចជាស្អាត។
ឲ្យបានបរិសុទ្ធ រួចផុតពីភាពសៅហ្មងទាំងឡាយរបស់ប្រជាជនអ៊ីស្រាអែល និងញែកថ្វាយព្រះអម្ចាស់
អាសនៈដែលគេថ្វាយដល់ព្រះអម្ចាស់ប្រៀបដូចជាអាសនៈនោះត្រូវបានញែកចេញពីអំពើបាបរបស់ប្រជាជ
ភាពសៅហ្មង
អំពើបាបដែលធ្វើឱ្យមនុស្សមិនអាចទទួលយកបានចំពោះព្រះជាម្ចាស់ត្រូវបានគេនិយាយថា
ជាអំពើមិនស្អាតខាងរាងកាយ។
Leviticus 16:20
គាត់ត្រូវយកពពែដែលនៅរស់មក
ពពែនេះត្រូវបានគេហៅថា ពពែដែលគេថ្វាយទៅព្រះនៅក្នុងជំពូក ១៦: ៨ ។
លន់តួកំហុស
«លន់តួជំនួសពពែ»
លោកត្រូវផ្ទេរអំពើបាបទាំងអស់ទៅលើក្បាលពពែនោះ
ការលន់តួរបស់អើរ៉ុននៅទីនេះគឺជាការផ្ទេរជានិមិត្តរូបនៃអំពើបាបរបស់ប្រជាជនទៅពពែ
ដែលជាសញ្ញាបង្ហាញថាពពែ នឹងទទួលទោសចំពោះកំហុសរបស់ពួកគេ។
អំពើទុច្ចរិត.... និងអំពើបាបទាំងអស់
ទាំងអស់នេះមានន័យជាមូលដ្ឋានដូចគ្នា។
អើរ៉ុនកំពុងតែលន់តួនូវអំពើបាបគ្រប់ប្រភេទដែលប្រជាជនបានធ្វើ។
Leviticus 16:23
ត្រូវដោះសម្លៀកបំពាក់ដែលធ្វើអំពីអំបោះធ្មៃ
សម្លៀកបំពាក់ទាំងនេះជាសម្លៀកបំពាក់ពិសេសដែលលោកអើរ៉ុនបានពាក់នៅពេលគាត់ចូលក្នុងទីបរិសុទ្ធ
គាត់ត្រូវងូតទឹកសម្អាតខ្លួននៅក្នុងទីសក្ការៈ
នៅទីនេះ «ទីបរិសុទ្ធ» មិនសំដៅទៅលើតង់នៃការប្រជុំទេ។
នេះជាកន្លែងផ្សេងដែលទុកសម្រាប់ឱ្យគាត់ងូតទឹក។
ស្លៀកសម្លៀកបំពាក់ធម្មតាវិញ
ទាំងនេះគឺជាសម្លៀកបំពាក់ដែលអើរ៉ុនបានពាក់សម្រាប់ភារកិច្ចធម្មតារបស់គាត់។
Leviticus 16:25
គាត់ត្រូវដុត
ឈាមនៃអំពើបាបត្រូវដុត»
ហើយបុរសដែលដេញពពែទៅវាលរហោស្ថាន ឲ្យអាសាអែល ត្រូវបោកសម្លៀកបំពាក់របស់គាត់
និងងូតទឹកសម្អាតខ្លួនរបស់គាត់
បុរសនោះជាមនុស្សមិនស្អាតដោយសារគាត់បានទាក់ទងជាមួយពពែ
ដែលទទួលបានបាបមនុស្ស។
ដេញពពែ
«ពពែដែលត្រូវបានបញ្ជូនទៅ»
សូមមើលពីរបៀបដែលអ្នកបានបកប្រែរឿងនេះនៅក្នុងជំពូក ១៦: ៨ ។
Leviticus 16:27
យកឈាមរបស់វា
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ឈាមដែលអើរ៉ុនបាននាំមក»
ត្រូវយកវាទៅ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកណាម្នាក់ត្រូវតែកាន់»
ទាំងស្បែក
«ស្បែករបស់ពួកគេ» នៅទីនេះ «របស់ពួកគេ» សំដៅទៅលើគោនិងពពែ។
Leviticus 16:29
ឃ្លាថា អំពើបាប
ពាក្យថា «អ្នក» គឺជាពហុវចនៈហើយសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
នៅក្នុងខែទីប្រាំពីរ ថ្ងៃទីដប់
នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។
ថ្ងៃទីដប់គឺនៅជិតចុងខែកញ្ញាតាមប្រតិទិនខាងលិច។
គេនឹងធ្វើពិធីលោះបាបអ្នករាល់គ្នា
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អើរ៉ុននឹងធ្វើដង្វាយធួនសំរាប់អ្នក»

generated on Wed Sep 10 16:16:32 2025

ដើម្បីជម្រះអ្នករាល់គ្នាឲ្យបានបរិសុទ្ធ
មនុស្សដែលអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយ
ដូចជាពួកគេស្អាតស្អំខាងរាងកាយ។
នោះជាថ្ងៃសប្ប័ទ ជាថ្ងៃដែលអ្នករាល់គ្នាត្រូវសម្រាក
នេះមិនខុសពីថ្ងៃឈប់សំរាកដែលគេបានសង្កេតរៀងរាល់សប្តាហ៍នៅថ្ងៃទី ៧ ។
នេះជាថ្ងៃឈប់សម្រាកពិសេសនៅថ្ងៃដង្វាយរំដោះបាប។
Leviticus 16:32
ដែលទទួលការចាក់ប្រេងតែងតាំង
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលគេនឹងចាក់ប្រេងតាំងតែងតាំង»
ស្នងឪពុករបស់គាត់
ពេលសម្តេចសង្ឃស្លាប់កូនប្រុសម្នាក់របស់គាត់នឹងជំនួសគាត់។
សម្លៀកបំពាក់ដ៏បរិសុទ្ធ
ទាំងនេះជាសម្លៀកបំពាក់ពិសេសដែលលោកមហាបូជាចារ្យត្រូវស្លៀកនៅពេលដែលលោកចូលក្នុងទីសក្
ប្រជាជនទាំងអស់ក្នុងសហគមន៍
«សម្រាប់ប្រជាជនអ៊ីស្រាអែលទាំងអស់»
Leviticus 16:34
ព័ត៌មានទូទៅ
ព្រះអម្ចាស់បានប្រាប់ដល់លោកម៉ូសេនូវអ្វីដែលប្រជាជនត្រូវធ្វើនៅថ្ងៃដង្វាយលោះបាប។
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលបានបង្គាប់មកតាមរយៈលោកម៉ូសេ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ហើយលោកម៉ូសេបានធ្វើតាមបញ្ជារបស់ព្រះអម្ចាស់» ឬ
«អើរ៉ុនបានធ្វើដូចព្រះអម្ចាស់បានបញ្ជាម៉ូសេ»

---

17 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[2]«ចូរប្រាប់អើរ៉ុន និងកូនប្រុសៗរបស់គាត់ និងប្រជាជនអ៊ីស្រាអែលទាំងអស់ថា ព្រះអម្ចាស់បានបង្គាប់មកថា៖
[3]ក្នុងចំណោមកូនចៅអ៊ីស្រាអែល ប្រសិនបើបុរសណាម្នាក់ចង់ចាក់កសម្លាប់គោ ចៀម ឬពពែ នៅក្នុងជំរំ ឬនៅក្រៅជំរំក្តី
ក្នុងគោលបំណងថ្វាយជាយញ្ញបូជា[4]ហើយប្រសិនបើ គាត់មិនយកសត្វនោះទៅច្រកចូលពន្លាជួបព្រះអម្ចាស់ ដើម្បីថ្វាយព្រះអម្ចាស់ នៅមុខព្រះពន្លា
គាត់ត្រូវមានទោសដោយការបង្ហូរឈាម។ គាត់បានបង្ហូរឈាម ហើយអ្នកនោះត្រូវកាត់ចេញពីចំណោមប្រជាជនរបស់គាត់។
[5]គោលបំណងនៃបទបញ្ជានេះ គឺដើម្បីឲ្យកូនចៅអ៊ីស្រាអែលនាំយកតង្វាយរបស់ពួកគេទៅជូនបូជាចារ្យនៅច្រកចូលព្រះពន្លាជួបព្រះអម្ចាស់
ដើម្បីបូជាចារ្យលើកថ្វាយព្រះអម្ចាស់ជាយញ្ញបូជាមេត្រីភាព គឺដើម្បីឃាត់គេកុំឲ្យសម្លាប់សត្វនៅទីវាល។[6]បូជាចារ្យត្រូវប្រោះឈាមលើអាសនៈរបស់ព្រះអម្ចាស់
ត្រង់ច្រកទ្វារពន្លាជួបព្រះអម្ចាស់ ហើយគាត់ត្រូវដុតខ្លាញ់នៃតង្វាយនោះ ដែលជាក្លិនឈ្ងុយជាទីគាប់ព្រះទ័យព្រះអម្ចាស់។
[7]ដូច្នេះ គេនឹងលែងក្បត់យើង ដោយថ្វាយយញ្ញបូជាទៅព្រះក្លែងក្លាយ ដែលមានរូបរាង្គដូចពពែទៀតហើយ។
នេះគឺជាច្បាប់ដែលមិនមានការប្រែប្រួលសម្រាប់ប្រជាជនរបស់ពួកគេគ្រប់ជំនាន់ទាំងអស់។
[8]អ្នកត្រូវប្រាប់ពួកគេថា ប្រសិនបើ ជនជាតិអ៊ីស្រាអែលណាម្នាក់ ឬជនបរទេសណាម្នាក់ដែលរស់នៅក្នុងចំណោមអ្នករាល់គ្នា ដែលមានបំណងថ្វាយតង្វាយដុត
ឬយញ្ញបូជាអ្វីមួយ[9]ប៉ុន្តែ មិនបាននាំសត្វនោះមកថ្វាយជាយញ្ញបូជាដល់ព្រះអម្ចាស់ នៅទ្វារចូលព្រះពន្លាជួបព្រះអម្ចាស់ទេនោះ
ត្រូវកាត់គេនោះចេញពីចំណោមប្រជាជនរបស់គេ។
[10]ប្រសិនបើ នរណាម្នាក់ក្នុងចំណោមប្រជាជនអ៊ីស្រាអែល ឬជនបរទេសណាម្នាក់ដែលរស់នៅជាមួយអ្នក ដែលបរិភោគឈាមអ្វីក៏ដោយ
យើងនឹងដាក់ទោសអ្នកដែលបរិភោគឈាមនោះ ហើយយើងនឹងកាត់គេចេញពីចំណោមប្រជាជនរបស់គេ។[11]ដ្បិត ជីវិតរបស់សត្វលោកទាំងអស់គឺនៅក្នុងឈាម។
យើងបានឲ្យអ្នករាល់គ្នាបង្ហូរឈាមលើអាសនៈ ដើម្បីធ្វើពិធីដោះបាប ឈាមដែលធ្វើពិធីអាចរំដោះបាបបាន ព្រោះក្នុងឈាមមានជីវិត។
[12]ដូច្នេះហើយបានជាយើងហាមថា មិនត្រូវមានជនជាតិអ៊ីស្រាអែលណាម្នាក់បរិភោគឡើយ សូម្បីតែ ជនបរទេសដែលរស់នៅក្នុងចំណោមអ្នករាល់គ្នាក៏ដោយ
ក៏មិនត្រូវបរិភោគឈាមដែរ។[13]នរណាម្នាក់ក្នុងចំណោមជនជាតិអ៊ីស្រាអែល ឬជនបរទេសណាម្នាក់ដែលរស់ក្នុងចំណោមពួកគេ ដែលប្រម៉ាញ់ហើយសម្លាប់សត្វចតុបាត
ឬសត្វស្លាបក្តី ត្រូវបង្ហូរឈាមសត្វនោះ ទៅលើដីហើយយកធូលីដីគ្របពីលើ។
[14]ដោយសារជីវិតសត្វលោកទាំងអស់ស្ថិតនៅក្នុងឈាមរបស់ខ្លួន។ ដូច្នេះហើយបានជាយើងហាមជនជាតិអ៊ីស្រាអែលថា៖
«អ្នករាល់គ្នាមិនត្រូវបរិភោគឈាមរបស់សត្វណាមួយ ព្រោះជីវិតរបស់សត្វលោកទាំងអស់ស្ថិតនៅក្នុងឈាមរបស់ខ្លួន។ អ្នកណាដែលបរិភោគឈាម
ត្រូវកាត់ចេញពីចំណោមប្រជាជាតិរបស់ខ្លួន»។
[15]មនុស្សទាំងអស់ទោះបីជាជនជាតិអ៊ីស្រាអែល ឬជនបរទេសក្តី ដែលបរិភោគសត្វដែលងាប់ដោយសារជំងឺឬងាប់ដោយសារសត្វព្រៃហែក
គេត្រូវបោកសម្លៀកបំពាក់របស់គេ ហើយងូតទឹកសម្អាតខ្លួន គេនឹងត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធរហូតដល់ល្ងាច បន្ទាប់មក គេនឹងបរិសុទ្ធវិញ។[16]តែប្រសិនបើ
គេមិនបោកសម្លៀកបំពាក់ និងងូតទឹកសម្អាតខ្លួនរបស់គេទេ គេនឹងមានកំហុស។

Leviticus 17:1
នៅមុខព្រះពន្លា
«នៅមុខព្រះពន្លារបស់ព្រះអម្ចាស់»
អ្នកនោះត្រូវកាត់ចេញពីចំណោមប្រជាជនរបស់គាត់
មនុស្សម្នាក់ដែលគេដកចេញពីសហគមន៍របស់គាត់ដូចជាត្រូវគេកាត់ចេញពីប្រជាជនរបស់គាត់
ដូចជាមនុស្សម្នាក់នឹងកាត់ក្រណាត់ឬកាត់មែកឈើចេញពីមែកឈើដែរ។
នេះអាចត្រូវបកប្រែជាទម្រង់សកម្ម។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៧:១៩ ។
ការបកប្រែផ្សេងទៀត
«មនុស្សនោះអាចនឹងលែងរស់នៅក្នុងចំណោមប្រជាជនរបស់គាត់» ឬ
«អ្នកត្រូវញែកមនុស្សនោះចេញពីប្រជាជន»
Leviticus 17:5
បូជាចារ្យលើកថ្វាយព្រះអម្ចាស់
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីបូជាចារ្យដូច្នេះគាត់អាចបូជាពួកគេ»
Leviticus 17:7
ដែលមានរូបរាង្គដូចពពែទៀតហើយ
ប្រជាជនដែលមិនស្មោះត្រង់នឹងព្រះជាម្ចាស់ដោយគោរពបូជាព្រះមិនពិតត្រូវបាន
ពួកគេដូចជាបុរសដែលក្បត់ប្រពន្ធរបស់ខ្លួនដោយផិតក្បត់។ ការបកប្រែផ្សេងទៀត
«ដែលពួកគេមិនស្មោះត្រង់នឹងព្រះអម្ចាស់»
ប្រែប្រួលសម្រាប់ប្រជាជនរបស់ពួកគេគ្រប់ជំនាន់ទាំងអស់
បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានធ្វើនៅ ជំពូក ៣:១៥ ។
Leviticus 17:8
ត្រូវកាត់គេនោះចេញពីចំណោមប្រជាជនរបស់គេ
មនុស្សម្នាក់ដែលត្រូវគេដកចេញពីសហគមន៍របស់ខ្លួន
គឺដូចជាការកាត់ចេញពីប្រជាជនរបស់គាត់ដែរ
ប្រៀបដូចជាមនុស្សម្នាក់កាត់ក្រណាត់ ឬកាត់មែកឈើចេញពីមែកឈើដូច្នេះដែរ។
នេះអាចបកប្រែជាទម្រង់សកម្ម។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៧:១៩ ។ ការបកប្រែផ្សេង
«មនុស្សនោះអាចនឹងលែងរស់នៅក្នុងចំណោមប្រជាជនរបស់គាត់» ឬ
«អ្នកត្រូវញែកមនុស្សនោះចេញពីប្រជាជនរបស់គាត់»
Leviticus 17:10
យើងនឹងដាក់ទោសអ្នកដែល
ពាក្យ «មុខ» តំណាងឱ្យមនុស្ស នេះមានន័យថាបដិសេធនរណាម្នាក់ឬអ្វីមួយ។
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងប្រឆាំងនឹងមនុស្សម្នាក់នោះ» ឬ
«យើងនឹងបដិសេធមនុស្សនោះ»
យើងនឹងកាត់គេចេញពីចំណោមប្រជាជនរបស់គេ
មនុស្សម្នាក់ដែលគេដកចេញពីសហគមន៍របស់គាត់គេនិយាយដូចជាគាត់ត្រូវបានគេកាត់ចេញពីប្រជាជន
ដូចជាមនុស្សម្នាក់នឹងកាត់ក្រណាត់ឬកាត់មែកឈើចេញពីមែកឈើ។
ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«យើងនឹងមិនអនុញ្ញាតឱ្យមនុស្សនោះរស់នៅក្នុងចំណោមប្រជាជនរបស់គាត់ទៀតទេ»នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
ឬ «យើងនឹងញែកមនុស្សនោះចេញពីប្រជាជនរបស់គាត់»
«អ្នកណាបរិភោគឈាមនឹងមិនអាចរស់នៅក្នុងចំណោមប្រជាជនរបស់ខ្លួនបានទៀតឡើយ»
ដ្បិត ជីវិតរបស់សត្វលោកទាំងអស់គឺនៅក្នុងឈាម...ព្រោះក្នុងឈាមមានជីវិត
ឬ «អ្នកត្រូវញែកចេញពីមនុស្សរបស់ខ្លួនអ្នកណាដែលបរិភោគឈាម»
នេះមានន័យថាព្រះប្រើឈាមសម្រាប់ការធ្វើបាបរបស់មនុស្សពីព្រោះឈាមជាជីវិត។
Leviticus 17:15
ប្រជាជនមិនគួរទទួលទានឈាមទេ ។
ព័ត៌មានទូទៅ
Leviticus 17:12
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូល។
យើងហាមថា
ងាប់ដោយសារសត្វព្រៃហែក
នៅទីនេះ «យើង» សំដៅទៅលើព្រះអម្ចាស់។
សត្វមួយបានសម្លាប់ដោយសត្វព្រៃត្រូវបានគេនិយាយដូចជាសត្វព្រៃហែកសត្វនោះទៅជាបំណែក។
មិនត្រូវមានជនជាតិអ៊ីស្រាអែលណាម្នាក់បរិភោគឡើយ
នេះអាចតត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ក្នុងចំណោមអ្នករាល់គ្នា គ្មាននរណាម្នាក់អាចបរិភោគសាច់ដោយឈាមបានទេ»
«សត្វព្រៃបានសំលាប់»
ដែលអាចត្រូវបានបរិភោគ
មានកំណើត
នេះអាចបកប្រែជាទម្រង់សកម្ម។ «ដែលខ្ញុំបាននិយាយថាពួកគេអាចបរិភោគ»
«គឺជាជនជាតិអ៊ីស្រាអែល»
ត្រូវបង្ហូរឈាមសត្វនោះ ទៅលើដីហើយយកធូលីដីគ្របពីលើ
គេនឹងត្រូវស្ថិតក្នុងភាពមិនបរិសុទ្ធ...បន្ទាប់មក គេនឹងបរិសុទ្ធវិញ
«និងគ្របឈាមដោយភាពកខ្វក់»
មនុស្សដែលមនុស្សផ្សេងទៀតមិនអាចប៉ះត្រូវបានគេនិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយនិង
Leviticus 17:14
រហូតដល់ល្ងាច
ជីវិតសត្វលោកទាំងអស់ស្ថិតនៅក្នុងឈាមរបស់ខ្លួន
«រហូតដល់ថ្ងៃលិច»
នេះមានន័យថាឈាមអាចឱ្យសត្វមានជីវិត។
គេនឹងមានកុំហុស
អត្ថន័យពេញលេញនៃឃ្លានេះបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
កំហុសរបស់មនុស្សម្នាក់ត្រូវបានគេនិយាយថាវាជាវត្ថុរូបវន្តដែលបុគ្គលនោះកាន់។
«សត្វនិមួយៗអាចរស់ដោយសារឈាមរបស់វា»
ត្រង់នេះពាក្យថា« ពិរុទ្ធជន» តំណាងឱ្យការដាក់ទណ្ឌកម្មចំពោះពិរុទ្ធភាពនោះ។
អ្នកណាដែលបរិភោគឈាម ត្រូវកាត់ចេញពីចំណោមប្រជាជាតិរបស់ខ្លួន
ការបកប្រែផ្សេងទៀត
មនុស្សម្នាក់ដែលត្រូវបានគេដកចេញពីសហគមន៍របស់គាត់
«បន្ទាប់មកគាត់ទទួលខុសត្រូវចំពោះកំហុសផ្ទាល់ខ្លួនរបស់គាត់» ឬ
គេនិយាយដូចជាគាត់ត្រូវបានគេកាត់ចេញពីប្រជាជនរបស់គាត់
«បន្ទាប់មកខ្ញុំនឹងដាក់ទណ្ឌកម្មគាត់ចំពោះអំពើបាបរបស់គេ»
ដូចជាមនុស្សម្នាក់នឹងកាត់ក្រណាត់ឬកាត់មែកឈើចេញពីមែកឈើ។

---

18 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[2]«ចូរប្រកាសដល់ប្រជាជនអ៊ីស្រាអែលទាំងអស់ ហើយប្រាប់ពួកគេថា «យើងជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[3]អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តនូវអំពើដែលជនជាតិអេស៊ីបធ្លាប់ប្រព្រឹត្ត នៅក្នុងស្រុកដែលអ្នករាល់គ្នារស់នៅឡើយ។
អ្នករាល់គ្នាក៏មិនត្រូវប្រព្រឹត្តដូចជនជាតិកាណាននៅក្នុងស្រុក ដែលយើងនឹងនាំអ្នករាល់គ្នាចូលទៅរស់នៅដែរ។ កុំកាន់តាមច្បាប់របស់ពួកគេឡើយ។
[4]ច្បាប់របស់យើងដែលអ្នករាល់គ្នាត្រូវប្រកាន់ភ្ជាប់ ហើយបញ្ជារបស់យើងអ្នករាល់គ្នាត្រូវរក្សា ដូច្នេះ អ្នករាល់គ្នាត្រូវដើរក្នុងសេចក្តីដែលយើងបានបង្គាប់មក
ពីព្រោះយើងជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។[5]អ្នករាល់គ្នាត្រូវកាន់តាមច្បាប់ និងវិន័យទាំងប៉ុន្មានរបស់យើង។ អ្នកប្រតិបត្តិតាមនឹងមានជីវិតដោយសារច្បាប់
និងវិន័យទាំងនោះ។ ព្រោះយើងជាព្រះអម្ចាស់។
[6]ក្នុងចំណោមអ្នករាល់គ្នាមិនត្រូវឲ្យមានអ្នកណាម្នាក់រួមរ័កជាមួយសាច់ញាតិរបស់ខ្លួនឡើយ។ យើងជាព្រះអម្ចាស់។[7]មិនត្រូវបង្អាប់កិត្តិយសឪពុកអ្នក
ដោយរួមដំណេកជាមួយម្តាយរបស់អ្នកឡើយ។ គាត់ជាម្តាយរបស់អ្នក! អ្នកមិនត្រូវបង្អាប់កិត្តិយសរបស់គាត់ទេ។[8]ក៏មិនត្រូវរួមដំណេកជាមួយប្រពន្ធរបស់ឪពុកអ្នកដែរ
អ្នករាល់គ្នាមិនត្រូវបង្អាប់កិត្តិយសឪពុករបស់អ្នកដោយប្រព្រឹត្តរបៀបដូច្នេះទេ។
[9]មិនត្រូវរួមដំណេកជាមួយបងស្រី ឬប្អូនស្រីរបស់អ្នកឡើយ ទោះបីនាងជាបងប្អូនរួមឪពុកតែមួយ ឬជាបងប្អូនរួមម្តាយក្តី ទោះបីនាងជាកូនមានខាន់ស្លា ឬអត់ខាន់ស្លាក្តី។
អ្នករាល់គ្នាមិនត្រូវរួមដំណេកជាមួយបងឬប្អូនស្រីរបស់អ្នកឡើយ។[10]កុំរួមដំណេកជាមួយកូនស្រីរបស់កូនប្រុសអ្នកឡើយ ក៏មិនត្រូវជាមួយកូនស្រីរបស់កូនស្រីអ្នកដែរ។
ធ្វើដូច្នេះអ្នកនឹងបន្ថោកខ្លួនរបស់អ្នក។[11]កុំរួមដំណេកជាមួយកូនស្រីរបស់ប្រពន្ធឪពុកអ្នកឡើយ នាងជាកូនស្រីរបស់ឪពុកអ្នកដែរ។ នាងគឺជាបងប្អូនស្រីរបស់អ្នក ដូច្នេះ
អ្នកមិនត្រូវរួមដំណេកជាមួយនាងគេទេ។
[12]កុំរួមដំណេកជាមួយបង ឬប្អូនស្រីរបស់ឪពុកអ្នកឡើយ។ គាត់ជាសាច់ញាតិជិតដិតរបស់ឪពុកអ្នក។[13]កុំរួមដំណេកជាមួយបង ឬប្អូនស្រីម្តាយរបស់អ្នកឡើយ។
គាត់ជាសាច់ញាតិជិតដិតរបស់ម្តាយអ្នក។[14]កុំបន្ថោកបង ឬប្អូនប្រុសឪពុករបស់អ្នក ដោយរួមដំណេកជាមួយប្រពន្ធរបស់គាត់ឡើយ។
កុំចូលក្បែរគាត់ដោយគោលបំណងបែបនោះឡើយ ព្រោះគាត់ជាម្តាយមីងរបស់អ្នក។
[15]កុំរួមដំណេកជាមួយកូនប្រសារស្រីរបស់អ្នកឡើយ។ នាងជាប្រពន្ធកូនប្រុសរបស់អ្នក។[16]កុំរួមដំណេកជាមួយប្រពន្ធបងប្រុស ឬប្អូនប្រុសរបស់អ្នកឡើយ
កុំបន្ថោកគាត់ដោយប្រព្រឹត្តរបៀបនេះឡើយ។
[17]មិនត្រូវរួមដំណេកជាមួយម្តាយផង កូនស្រីផងនោះទេ ឬមិនត្រូវរួមដំណេកជាមួយចៅស្រីជាកូនរបស់កូនស្រី ឬកូនប្រុសរបស់អ្នកឡើយ។
[18]នៅពេលប្រពន្ធរបស់អ្នកនៅមានជីវិតរស់នៅឡើយ អ្នកមិនត្រូវរៀបការជាមួយបងថ្លៃ ឬប្អូនថ្លៃស្រីរបស់អ្នកនិងមិនត្រូវរួមដំណេកជាមួយនាងឡើយ។
[19]កុំរួមដំណេកជាមួយស្ត្រីដែលកំពុងមានរដូវឡើយ។ នាងជាមនុស្សមិនបរិសុទ្ធក្នុងកំឡុងពេលនោះ។[20]កុំរួមដំណេកជាមួយប្រពន្ធអ្នកជិតខាង
ដែលនាំឲ្យខ្លួនរបស់អ្នកទៅជាសៅហ្មងជាមួយនាងឡើយ។
[21]មិនត្រូវយកកូនរបស់អ្នកទៅដុតក្នុងភ្លើងឡើយ ធ្វើដូច្នេះគឺអ្នកយកពួកគេធ្វើជាយញ្ញបូជាថ្វាយដល់ព្រះម៉ាឡុក ព្រោះអ្នកមិនត្រូវបង្អាប់ព្រះនាមនៃព្រះរបស់អ្នកឡើយ។
យើងគឺជាព្រះអម្ចាស់។
[22]មិនត្រូវរួមដំណេកជាមួយមនុស្សប្រុសដូចគ្នា ដូចរួមដំណេកជាមួយមនុស្សស្រីឡើយ។[23]មិនត្រូវរួមរ័កជាមួយសត្វធាតុ ដែលនាំឲ្យខ្លួនរបស់អ្នកទៅជាសៅហ្មងឡើយ។
ហើយមនុស្សស្រីក៏មិនត្រូវរួមរ័កជាមួយសត្វដែរ។ ព្រោះវាជាអំពើដ៏ថោកទាបបំផុត។
[24]មិនត្រូវបណ្តោយឲ្យខ្លួនរបស់អ្នកទៅជាសៅហ្មង ដោយសារអំពើណាមួយ ក្នុងចំណោមអំពើអស់ទាំងនោះ
ដ្បិតយើងបានបណ្តេញប្រជាជាតិទាំងឡាយចេញពីមុខអ្នករាល់គ្នា។[25]ដីបានក្លាយទៅជាសៅហ្មង ដូច្នេះហើយបានជាយើងដាក់ទោសពួកគេ
ធ្វើឲ្យពួកគេខ្ចាត់ខ្ចាយចេញពីទឹកដីរបស់ខ្លួន។
[26]អ្នករាល់គ្នាត្រូវប្រតិបត្តិតាមច្បាប់ និងវិន័យរបស់យើង ហើយអ្នករាល់គ្នាមិនត្រូវប្រព្រឹត្តអំពើគួរស្អប់ខ្ពើមទាំងអស់នោះឡើយ ទោះបីអ្នករាល់គ្នាដែលជាម្ចាស់ស្រុក
ទោះបីជាជនបរទេសដែលរស់នៅក្នុងចំណោមអ្នករាល់ក្តី។[27]នេះគឺជាអំពើអាក្រក់ដែលប្រជាជននៅក្នុងស្រុកនោះបានប្រព្រឹត្ត ដែលនាំឲ្យទឹកដីទៅជាសៅហ្មង។[28]ដូច្នេះ
ចូរប្រុងប្រយ័ត្ន នោះទឹកដីនឹងមិនត្រូវសៅហ្មងទេ ហើយអ្នករាល់គ្នាក៏មិនត្រូវខ្ចាត់ខ្ចាយចេញពីទឹកដី ដូចជាតិសាសន៍ដែលនៅមុនអ្នករាល់គ្នាដែរ។
[29]អ្នកណាដែលប្រព្រឹត្តអំពើគួរស្អប់ខ្ពើមណាមួយ ក្នុងចំណោមអំពើទាំងនោះ ត្រូវដកចេញពីចំណោមប្រជាជនរបស់គេ។[30]អ្នករាល់គ្នាត្រូវរក្សាបទបញ្ជារបស់យើង
មិនត្រូវប្រព្រឹត្តអំពើគួរស្អប់ខ្ពើមណាមួយ ដូចដែលអ្នករស់នៅក្នុងស្រុកនេះពីមុនធ្លាប់ប្រព្រឹត្តនោះឡើយ ដូច្នេះ អ្នករាល់គ្នានឹងមិនត្រូវសៅហ្មងដោយសារអំពើទាំងនោះទេ។
យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

Leviticus 18:4
ច្បាប់របស់យើងដែលអ្នករាល់គ្នាត្រូវប្រកាន់ភ្ជាប់ ហើយបញ្ជារបស់យើងអ្នករាល់គ្នាត្រូវរក្សា
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នានិងសង្កត់ធ្ងន់ថាប្រជាជនត្រូវតែគោរពតាមអ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបញ្ជាពួកគេអោយធ្វើ។
អ្នកអាចបកប្រែភាពស្របគ្នានេះទៅជាឃ្លាមួយដែលបង្ហាញពីតម្រូវការដើម្បីរក្សាបទបញ្ជាទាំងអស់របស់ព្រះអម្ចាស់ឱ្យបានល្អ។
ការបកប្រែផ្សេងទៀត «អ្នកត្រូវតែគោរពច្បាប់ និងបទបញ្ញត្តិទាំងអស់របស់យើង»
ដូច្នេះ អ្នករាល់គ្នាត្រូវដើរក្នុងសេចក្តីដែលយើងបានបង្គាប់មក
ការធ្វើតាមបញ្ញត្តិរបស់ព្រះជាម្ចាស់គឺដូចជាបទបញ្ញត្តិជាមាគ៌ាដែលបុគ្គលនោះដើរដែរ។
ការបកប្រែផ្សេងទៀត «ដើម្បីឱ្យអ្នកប្រព្រឹត្តតាម»
Leviticus 18:6
ប្រពន្ធរបស់ឪពុកអ្នកដែរ
ពេលខ្លះបុរសមានប្រពន្ធលើសពីមួយ។
ព្រះមិនអនុញ្ញាតឱ្យកូនប្រុសដេកជាមួយស្ត្រីណាដែលរៀបការជាមួយឪពុករបស់គាត់ទេ។
Leviticus 18:9
ទោះបីនាងជាបងប្អូនរួមឪពុកតែមួយ ឬជាបងប្អូនរួមម្តាយក្តី
នេះមានន័យថាបុរសមិនអាចដេកជាមួយបងស្រីរបស់គាត់បានទេប្រសិនបើពួកគេមានឪពុកម្តាយដូចគ្នា
ឬសូម្បីតែនាងមានម្តាយឬឪពុកផ្សេងក៏ដោយ។
ទោះបីនាងជាកូនមានខាន់ស្លា ឬអត់ខាន់ស្លាក្តី
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ថាតើនាងធំធាត់នៅផ្ទះរបស់អ្នកឬនៅឆ្ងាយពីអ្នក»
កុំរួមដំណេកជាមួយកូនស្រីរបស់ប្រពន្ធឪពុកអ្នកឡើយ
អត្ថន័យដែលអាចមានគឺ ១) «កុំដេកជាមួយប្អូនស្រីពាក់កណ្តាលរបស់អ្នក» ឬ ២)
«កុំដេកជាមួយប្អូនស្រីខាងឪពុកចុងរបស់អ្នក» ។ នៅទីនេះបុរសមិនមានឪពុក
ឬម្តាយដូចស្ត្រីទេ។
ពួកគេបានក្លាយជាបងប្អូនប្រុសស្រីនៅពេលដែលឪពុកម្តាយរបស់ពួកគេរៀបការ។
Leviticus 18:12
កុំចូលក្បែរគាត់ដោយគោលបំណងបែបនោះឡើយ
«កុំទៅរកនាងដើម្បីដេកជាមួយនាងឡើយ»
Leviticus 18:15
កុំរួមដំណេកជាមួយកូនប្រសារស្រីរបស់អ្នកឡើយ
ព្រះអម្ចាស់រំលឹករឿងនេះឡើងវិញដើម្បីបញ្ជាក់ពីបទបញ្ជា។
Leviticus 18:19
មានរដូវ
នេះគឺជារយៈពេលដែលស្ត្រីម្នាក់ហូរឈាមចេញពីស្បូន។
នាងជាមនុស្សមិនបរិសុទ្ធ
ស្ត្រីដែលមនុស្សផ្សេងទៀតមិនអាចប៉ះបាននិយាយថាគាត់ជាមនុស្សមិនស្អាតខាងរាងកាយ
កុំរួមដំណេកជាមួយប្រពន្ធអ្នកជិតខាង
«ប្រពន្ធរបស់បុរសណាម្នាក់»
Leviticus 18:21
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តប្រាប់លោកម៉ូសេនូវអ្វីដែលប្រជាជនមិនត្រូវធ្វើដែលធ្វើអោយពួកគេ
មិនត្រូវយកកូនរបស់អ្នកទៅដុតក្នុងភ្លើងឡើយ
ឃ្លាថា «ត្រូវឆ្លងកាត់ភ្លើង» មានន័យថាដុតអ្វីមួយដោយភ្លើងជាការលះបង់។
ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវដុតកូនរបស់អ្នកទាំងរស់ទេ»
អ្នកមិនត្រូវបង្អាប់ព្រះនាមនៃព្រះរបស់អ្នកឡើយ
ត្រង់នេះពាក្យថា«បង្អាប់» មានន័យថាមិនគោរព។ ពាក្យ «នាម»
តំណាងឱ្យព្រះផ្ទាល់។ ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវបន្ថោកព្រះរបស់អ្នក»
Leviticus 18:22
ស្រដៀងនឹងខាងលើ
ព្រះអម្ចាស់ចង់ឱ្យប្រជាជនរបស់ទ្រង់ដឹងថាទ្រង់ស្អប់ខ្ពើមអំពើបាបទាំងនេះ។
សំដៅទៅលើការបំពានលើសណ្តាប់ធ្នាប់ធម្មជាតិតាមដែលព្រះអម្ចាស់ចង់ ឲ្យ
ពួកគេធ្វើ។
Leviticus 18:24
ប្រជាជាតិនានាត្រូវស្មោកគ្រោក
នេះសំដៅទៅលើក្រុមមនុស្សដែលរស់នៅក្នុងទឹកដីកាណានរួចហើយ។
បកប្រែនេះដូច្នេះពាក្យថា «ប្រជាជាតិ» ត្រូវបានបញ្ជាក់ឱ្យច្បាស់ថាជាមនុស្ស។
ការបកប្រែផ្សេងទៀត «ប្រជាជននៃប្រជាជាតិនានាបានស្មោកគ្រោកខ្លួនឯង»
ត្រូវបានក្លាយទៅជាសៅហ្មង
«ប្រជាជនធ្វើឱ្យដីស្មោកគ្រោក»
ធ្វើឲ្យពួកគេខ្ជាត់ខ្ជាយចេញពីទឹកដីរបស់ខ្លួន
ដែលព្រះអម្ចាស់ជូនដំណើរ
ព្រះអម្ចាស់បានដកប្រជាជនចេញពីទឹកដីដោយបង្ខំដូចជាដីនោះជាមនុស្សដែលក្អួតប្រជាជនចេញ។
ការបកប្រែផ្សេងទៀត
«យើងបានបណ្តេញប្រជាជនចេញពីទឹកដីដោយបង្ខំដូចជាមនុស្សម្នាក់ក្អួតចង្អោរ»
Leviticus 18:26
អំពើគួរស្អប់ខ្ពើម
«រឿងគួរឱ្យស្អប់ខ្ពើមទាំងនេះ»
នេះគឺជាអំពើអាក្រក់
នេះសំដៅទៅលើ «របស់គួរស្អប់ខ្ពើមទាំងនេះ» ។
ដូច្នេះ ចូរប្រុងប្រយ័ត្ន
«ដូច្នេះសូមប្រយ័ត្នគោរពតាមយើង»
នោះទឹកដីនឹងមិនត្រូវសៅហ្មងទេ ហើយអ្នករាល់គ្នាក៏មិនត្រូវខ្ជាត់ខ្ជាយចេញពីទឹកដី
ដូចជាតិសាសន៍ដែលនៅមុនអ្នករាល់គ្នាដែរ
ព្រះអម្ចាស់បានដកប្រជាជនចេញពីទឹកដីដោយបង្ខំដូចជាដីនោះជាមនុស្សដែលក្អួតប្រជាជនចេញ។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យប្រៀបធៀបនេះនៅជំពូក ១៨:២៤ ។
ការបកប្រែផ្សេងទៀត «ដូច្នេះយើងនឹងយកអ្នកចេញពីទឹកដីដោយបង្ខំ ...
ដូចដែលយើងបានបណ្តេញប្រជាជនចេញ»
Leviticus 18:29
ព័ត៌មានទូទៅ
ព្រះអម្ចាស់បានប្រាប់ដល់លោកម៉ូសេនូវអ្វីដែលប្រជាជនមិនត្រូវធ្វើ។
ត្រូវដកចេញពីចំណោមប្រជាជនរបស់គេ
មនុស្សដែលត្រូវបានគេដកចេញពីសហគមន៍ត្រូវបានគេនិយាយដូចជាពួកគេត្រូវបានគេកាត់ចេញពីប្រជ
ដូចជាមនុស្សម្នាក់នឹងកាត់ក្រណាត់ ឬកាត់មែកឈើចេញពីមែកឈើ។
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «មនុស្ស ...
អាចនឹងលែងរស់នៅក្នុងចំណោមប្រជាជនរបស់ពួកគេ» ឬ
«អ្នកត្រូវតែញែកមនុស្ស ... ចេញពីប្រជាជនរបស់ពួកគេ»
ដែលបានរស់នៅក្នុងស្រុកនេះពីមុនធ្លាប់ប្រព្រឹត្តនោះឡើយ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលប្រជាជនបានធ្វើនៅទីនេះមុនពេលអ្នកមកដល់»
ដោយសារអំពើទាំងនោះទេ
នៅទីនេះ «ពួកគេ» សំដៅទៅលើទំនៀមទម្លាប់គួរស្អប់ខ្ពើម។

19

[1]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[2]«ចូរប្រាប់សហគមន៍អ៊ីស្រាអែលទាំងមូលដូចតទៅ៖ អ្នករាល់គ្នាត្រូវតែវិសុទ្ធ យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
យើងជាព្រះដ៏វិសុទ្ធ។[3]មនុស្សទាំងអស់ត្រូវគោរពឪពុក និងម្តាយរបស់គេ ហើយត្រូវរក្សាថ្ងៃសប្ប័ទរបស់យើង។ យើងជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[4]មិនត្រូវត្រឡប់ទៅថ្វាយបង្គំរូបព្រះ ហើយក៏មិនត្រូវសិតធ្វើរូបព្រះសម្រាប់អ្នករាល់គ្នាដែរ។ យើងគឺព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
[5]ពេលដែលអ្នករាល់គ្នាថ្វាយយញ្ញបូជាមេត្រីភាពដល់ព្រះអម្ចាស់ អ្នកត្រូវថ្វាយតាមរបៀបដែលគាប់ព្រះទ័យព្រះអម្ចាស់។
[6]អ្នកត្រូវតែបរិភោគសាច់នៃតង្វាយនៅក្នុងថ្ងៃដែលអ្នកថ្វាយនោះ ឬនៅថ្ងៃបន្ទាប់។ ប្រសិនបើ តង្វាយនោះនៅសល់រហូតដល់ថ្ងៃទីបី គឺត្រូវយកទៅដុតទាំងអស់។[7]ប្រសិនបើ
នរណាម្នាក់បរិភោគសាច់តង្វាយនោះនៅថ្ងៃទីបី គេនឹងទៅជាសៅហ្មង។ ព្រះអម្ចាស់នឹងមិនទទួលយកតង្វាយនោះទេ[8]អ្នកដែលបរិភោគសាច់នោះនឹងមានទោស
ព្រោះគេបានប្រមាថរបស់ដែលញែកជាបរិសុទ្ធថ្វាយព្រះអម្ចាស់។ ត្រូវដេញគេចេញពីចំណោមប្រជាជនរបស់គេ។
[9]នៅពេលដែលអ្នករាល់ច្រូតស្រូវ នៅក្នុងស្រុករបស់អ្នករាល់គ្នា គឺមិនត្រូវច្រូតរហូតដល់ភ្លឺស្រែទេ ហើយក៏មិនត្រូវរើសគួរស្រូវដែលជ្រុះដែរ។
[10]អ្នកក៏មិនត្រូវសន្សំផ្លែទំពាំងបាយជូរដែលនៅសេសសល់ក្នុងចម្ការរបស់អ្នកដែរ សូម្បីតែផ្លែដែលជ្រុះក៏មិនត្រូវរើសដែរ។ អ្នករាល់គ្នាត្រូវទុកវាសម្រាប់អ្នកក្រ
និងជនបរទេសរើសបរិភោគ។ យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

[11]កុំលួច។ កុំកុហក។ កុំបញ្ឆោតយកទ្រព្យសម្បត្តិរបស់អ្នកដទៃ។[12]កុំស្បថដោយប្រើនាមយើងដោយបំពានឡើយ ធ្វើដូច្នេះ
គឺអ្នករាល់គ្នាប្រមាថនាមនៃព្រះរបស់អ្នករាល់គ្នា។ យើងគឺព្រះអម្ចាស់។
[13]មិនត្រូវជិះជាន់សង្កត់សង្កិនអ្នកជិតខាងរបស់អ្នកឡើយ ហើយក៏កុំប្លន់ទ្រព្យសម្បត្តិរបស់គាត់ដែរ។
មិនត្រូវទុកប្រាក់ឈ្នួលរបស់កម្មករឲ្យនៅជាមួយអ្នករហូតដល់ថ្ងៃស្អែកឡើយ។[14]មិនត្រូវជេរប្រមាថមនុស្សថ្លង់ទេ ហើយក៏មិនត្រូវយកអ្វីទៅដាក់ពីមុខមនុស្សខ្វាក់ដែល។
ផ្ទុយទៅវិញ អ្នកត្រូវគោរពកោតខ្លាចព្រះរបស់អ្នករាល់គ្នា។ យើងជាព្រះអម្ចាស់។
[15]កុំកាត់ក្តីដោយអយុត្តិធម៌ឡើយ។ មិនត្រូវរើសមុខអ្នកណា ដោយបង្ហាញការយោគយល់ដោយព្រោះគេជាមនុស្សទុរគត៌ត ឬដោយគេជាមនុស្សសំខាន់នោះឡើយ។
ផ្ទុយទៅវិញ ត្រូវកាត់ក្តីអ្នកជិតខាងរបស់អ្នកដោយសុចរិត។[16]មិនត្រូវដើរបរិហាកេរ្តិ៍មនុស្សនៅជុំវិញខ្លួនរបស់អ្នកទេ
ផ្ទុយទៅវិញត្រូវស្វែងរកដើម្បីការពារជីវិតអ្នកជិតខាងរបស់អ្នក។ យើងជាព្រះអម្ចាស់។
[17]មិនត្រូវមានចិត្តស្អប់បងប្អូនរបស់អ្នករាល់គ្នាឡើយ។ អ្នកត្រូវយកចិត្តទុកដាក់ស្តីបន្ទោសអ្នកជិតខាងរបស់អ្នក នោះអ្នកនឹងមិនរួមគំនិតជាមួយអ្នកនោះ
ក្នុងការប្រព្រឹត្តអំពើបាបរបស់គេឡើយ។[18]កុំសងសឹក ឬក៏គុំគួនប្រឆាំងនឹងជនរួមជាតិរបស់អ្នកឡើយ ប៉ុន្តែ ផ្ទុយទៅវិញ
ត្រូវស្រឡាញ់អ្នកជិតខាងអោយដូចជាស្រឡាញ់ខ្លួនរបស់អ្នក។ យើងគឺជាព្រះអម្ចាស់។
[19]ចូរប្រតិបត្តិតាមច្បាប់របស់យើង។ មិនត្រូវព្យាយាមបង្កាត់សត្វដែលមានប្រភេទរបស់ខុសគ្នារបស់អ្នកឡើយ។ មិនត្រូវព្រោះគ្រាប់ពូជស្រូវពីរប្រភេទផ្សេងគ្នា
ក្នុងស្រែតែមួយទេ។ ក៏មិនត្រូវស្លៀកសម្លៀកបំពាក់ដែលត្បាញឡើងពី អំបោះពីរផ្សេងគ្នាដែរ។
[20]នរណាដែលរួមដំណេកជាមួយស្រីបម្រើ ដែលមានគូរដណ្តឹង ប៉ុន្តែនាងនៅមិនទាន់បានលួស ឬមិនទាន់មានសេរីភាពជាអ្នកជានៅឡើយ
ពួកគេទាំងពីរនាក់នឹងមានទោស។ ពួកគេមិនមានទោសដល់ស្លាប់នោះទេ ព្រោះបាននាងមិនទាន់ទៅជាអ្នកជានៅឡើយ។[21]បុរសដែលបានប្រព្រឹត្តខុស
ត្រូវយកចៀមឈ្មោលមួយទៅថ្វាយជាតង្វាយលោះបាប នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ត្រង់មាត់ទ្វារព្រះពន្លាជួបព្រះអម្ចាស់។[22]បន្ទាប់មកបូជាចារ្យ
ត្រូវធ្វើពិធីរំដោះបាបអោយគាត់ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ គឺបូជាចារ្យថ្វាយចៀមឈ្មោលជាយញ្ញបូជាលោះបាបនៅចំពោះព្រះភក្ត្រព្រះអម្ចាស់
សម្រាប់អំពើបាបដែលគាត់បានប្រព្រឹត្ត។ នោះព្រះអម្ចាស់នឹងលើកលែងទោសអោយគេបានរួចពីបាប។
[23]នៅពេលដែលអ្នករាល់គ្នាចូលទៅរស់នៅក្នុងស្រុក ហើយដាំដើមឈើហូបផ្លែគ្រប់ប្រភេទ អ្នកត្រូវចាត់ទុកផ្លែឈើដែលជាផលទាំងនោះ ជាផ្លែឈើមិនបរិសុទ្ធ។
ផ្លែឈើទាំងនោះនឹងមិនបរិសុទ្ធរយៈពេលបីឆ្នាំ។ អ្នករាល់គ្នាមិនត្រូវបរិភោគផលនៃផ្លែឈើទាំងនោះឡើយ។[24]នៅឆ្នាំទីបួន
ផលផ្លែឈើទាំងនោះនឹងត្រូវញែកជាបរិសុទ្ធថ្វាយដល់ព្រះអម្ចាស់ ដើម្បីសសើរតម្កើងព្រះអង្គ។[25]លុះដល់ឆ្នាំទីប្រាំអ្នករាល់គ្នាអាចបរិភោគផ្លែឈើទាំងនោះបាន
ហើយធ្វើដូច្នេះ ដើមឈើទាំងនេះនឹងផ្តល់ផលយ៉ាងច្រើនឡើង។ យើងគឺព្រះអម្ចាស់ជាព្រះរបស់អ្នក។
[26]មិនត្រូវបរិភោគសាច់សត្វណាដែលមានឈាមនោះឡើយ។ មិនត្រូវទស្សន៍ទាយមើលពីជោគជាតារាសីឡើយ
ហើយក៏មិនត្រូវធ្វើពិធីមន្តអាគមន៍ដើម្បីត្រួតត្រាអ្នកណាដោយអំណាចលើពីធម្មជាតិឡើយ។[27]កុំធ្វើតាមទម្លាប់ពួកអ្នកមិនជឿរដូចជា កោរសក់ចំហៀងក្បាល ឬ
កាត់គែមពុកចង្ការរបស់អ្នកចេញឡើយ។[28]មិនត្រូវឆូតសាច់របស់អ្នក ឬចាក់សាក់ធ្វើសញ្ញានៅលើរូបកាយរបស់អ្នកឡើយ។ យើងគឺព្រះអម្ចាស់។
[29]មិនត្រូវបន្ថោកកូនស្រីរបស់អ្នករាល់គ្នា ដោយជំរុញអោយនាងធ្វើជាស្រីពេស្យាឡើយ ឬក៏ជាតិសាសន៍ធ្លាក់ទៅក្នុងអំពើពេស្យាចារ
ដែលបណ្តាលឲ្យទឹកដីពោពេញដោយអំពើថោកទាប។[30]ត្រូវរក្សាថ្ងៃសប្ប័ទ ហើយគោរពទីសក្ការៈរបស់យើង។ យើងជាព្រះអម្ចាស់។
[31]មិនត្រូវទៅរកគ្រូអន្ទងមនុស្សស្លាប់ ឬព្រលឹងឡើយ។ កុំទៅរកពួកគេឡើយ ក្រែងលោពួកគេធ្វើឲ្យអ្នករាល់គ្នាទៅជាសៅហ្មង។ យើងគឺជាព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នា។
[32]ត្រូវឱនលំទោនចំពោះមនុស្សចាស់ជរា ហើយលោកកិត្តិយសចាស់ព្រឹទ្ធាចារ្យ។ អ្នកត្រូវកោតខ្លាចព្រះជាម្ចាស់។ យើងជាព្រះអម្ចាស់។
[33]ប្រសិនបើ មានជនបរទេសរស់នៅក្នុងចំណោមអ្នករាល់នៅក្នុងស្រុក មិនត្រូវជិះជាន់សង្កត់សង្កិនគេឡើយ។[34]ត្រូវប្រព្រឹត្តចំពោះជនបរទេសដែលរស់ក្នុងស្រុក
ដូចជាជនជាតិអ៊ីស្រាអែលជាម្ចាស់ស្រុកដែរ ហើយត្រូវស្រឡាញ់ពួកគេ ដូចជាស្រឡាញ់ខ្លួនអ្នកដែរ ដ្បិត អ្នករាល់គ្នាក៏ធ្លាប់ជាជនបរទេសនៅក្នុងស្រុកអេស៊ីព្ទដែរ។
យើងគឺព្រះអម្ចាស់ ជាព្រះរបស់អ្នក។
[35]មិនត្រូវប្រើរង្វាស់ដែលមិនត្រឹមត្រូវឡើយ ទោះបីក្នុងការវាស់ក្តី ថ្លឹងក្តី ឬរាប់ចំនួនក្តី។[36]អ្នកត្រូវប្រើជញ្ជីងដែលត្រឹមត្រូវ កូនជញ្ជីងដែលត្រឹមត្រូវ
និងរង្វាស់រង្វាល់ដែលត្រឹមត្រូវ។ យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីព្ទមក។[37]ត្រូវប្រតិបត្តិតាមច្បាប់
និងវិន័យទាំងប៉ុន្មានរបស់យើង ចូរប្រតិបត្តិតាម។ គឺយើងជាព្រះអម្ចាស់»។

Leviticus 19:1

ត្រូវរក្សាថ្ងៃសប្ប័ទរបស់យើង

«គោរពថ្ងៃសប្ប័ទរបស់យើង» ឬ «គោរពថ្ងៃសម្រាករបស់យើង»

មិនត្រូវត្រឡប់ទៅថ្វាយបង្គំរូបព្រះ

ការថ្វាយបង្គំព្រះក្លែងក្លាយត្រូវបានគេនិយាយដូចជាការងាកទៅរកពួកគេ។
ការបកប្រែផ្សេងទៀត «កុំគោរពបូជារូបព្រះដែលគ្មានតម្លៃ»

Leviticus 19:5

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។

អ្នកត្រូវថ្វាយតាមរបៀបដែលគាប់ព្រះទ័យព្រះអម្ចាស់

នេះអាចបកប្រែជាទម្រង់សកម្ម។ អត្ថន័យដែលអាចមានគឺ ១)
ព្រះអម្ចាស់នឹងទទួលយកមនុស្សដែលថ្វាយយញ្ញបូជា។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវថ្វាឱ្យបានត្រឹមត្រូវដើម្បីឱ្យយើងទទួលយក» ឬ 2)
ព្រះអម្ចាស់នឹងទទួលយកការថ្វាយពីមនុស្ស។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែថ្វាយវាឱ្យបានត្រឹមត្រូវ ដូច្នេះយើងនឹងទទួលយកការថ្វាយរបស់អ្នក»

អ្នកត្រូវតែបរិភោគ

នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែបរិភោគវា»

ត្រូវយកទៅដុតទាំងអស់

នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែដុតវា»

ប្រសិនបើ នរណាម្នាក់បរិភោគសាច់តង្វាយនោះ

នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នកញ៉ាំវាណាមួយ»

ព្រះអម្ចាស់នឹងមិនទទួលយកតង្វាយនោះទេ

ការបរិភោគតង្វាយបន្ទាប់ពីការកំណត់ពេលគឺទាស់នឹងព្រះជាម្ចាស់ហើយធ្វើឲ្យកំហុសកើតមានពេលថ្វាយ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រហែលជាមិនយកវាមកបរិភោគ»

អ្នកដែល...នឹងមានទោស

កំហុសរបស់មនុស្សម្នាក់ត្រូវបានគេនិយាយថាវាជាវត្ថុរបវន្តដែលបុគ្គលនោះកាន់។
ត្រង់នេះពាក្យថា «ពិរុទ្ធជន» តំណាងឱ្យការដាក់ទណ្ឌកម្មចំពោះពិរុទ្ធភាពនោះ។
ការបកប្រែផ្សេងទៀត «មនុស្សគ្រប់គ្នា ...
ទទួលខុសត្រូវចំពោះកំហុសផ្ទាល់ខ្លួនរបស់ខ្លួន» ឬ
«ព្រះអម្ចាស់នឹងដាក់ទណ្ឌកម្មដល់មនុស្សគ្រប់គ្នា ... ចំពោះអំពើបាបរបស់គេ»

ត្រូវដេញគេចេញពីចំណោមប្រជាជនរបស់គេ

មនុស្សម្នាក់ដែលគេដកចេញពីសហគមន៍របស់គាត់ត្រូវបានគេនិយាយដូចជាគាត់ត្រូវបានគេកាត់ចេញពី
ប្រៀបដូចជាមនុស្សម្នាក់នឹងកាត់ក្រណាត់ ឬកាត់មែកឈើចេញពីមែកឈើ។
នេះអាចបកប្រែជាទម្រង់សកម្ម។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៧:១៩ ។
ការបកប្រែផ្សេងទៀត
«មនុស្សនោះអាចនឹងលែងរស់នៅក្នុងចំណោមប្រជាជនរបស់គាត់» ឬ
«អ្នកត្រូវញែកមនុស្សនោះចេញពីប្រជាជនរបស់ខ្លួន»

Leviticus 19:9

នៅពេលដែលអ្នករាល់ច្រូតស្រូវ នៅក្នុងស្រុករបស់អ្នករាល់គ្នា គឺមិនត្រូវច្រូតរហូតដល់ភ្លឺស្រែទេ

generated on Wed Sep 10 16:16:32 2025

«នៅពេលដែលអ្នកប្រមូលផលដំណាំរបស់អ្នកកុំប្រមូលផ្តុំគ្នានៅតាមគែមចំការរបស់អ្នក
ហើយក៏មិនត្រូវរើសគួរស្រូវដែលជ្រុះដែរ
នេះសំដៅទៅលើការអនុវត្តនៃការត្រឡប់ទៅចំការវិញជាលើកទីពីរដើម្បីប្រមូលផលណាមួយដែលបានធ្លាក់ចុះ
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឱ្យកាន់ច្បាស់។ ការបកប្រែផ្សេងទៀត
«ហើយកុំថយក្រោយហើយរើសរបស់ទាំងអស់ដែលអ្នកទុកឡើយ»
Leviticus 19:11
ស្បថដោយប្រើនាមយើងដោយបំពានឡើយ
«កុំប្រើឈ្មោះយើងដើម្បីស្បថអំពីអ្វីដែលមិនពិតឡើយ»
Leviticus 19:13
មិនត្រូវជិះជាន់សង្កត់សង្កិនអ្នកជិតខាងរបស់អ្នកឡើយ ហើយក៏កុំប្លន់ទ្រព្យសម្បត្តិរបស់គាត់ដែរ
នៅទីនេះ «អ្នកជិតខាង» មានន័យថា «នរណាម្នាក់» ។
អត្ថន័យនៃរឿងនេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត «កុំធ្វើបាប
ឬប្លន់នរណាម្នាក់ឡើយ»
មិនត្រូវទុកប្រាក់ឈ្នួលរបស់កម្មករឲ្យនៅជាមួយអ្នករហូតដល់ថ្ងៃស្អែកឡើយ
ព្រះអម្ចាស់ត្រាស់បង្គាប់និយោជកអោយបើកប្រាក់ឈ្នួលអោយអ្នកបំរើរបស់ខ្លួនអោយបានទាន់ពេលវេលា
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
Leviticus 19:15
កុំកាត់ក្តីដោយអយុត្តិធម៌ឡើយ
ភាពអវិជ្ជមានទ្វេនេះត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
វាអាចត្រូវបានបង្ហាញតាមរបៀបវិជ្ជមានវិញ។ ការបកប្រែផ្សេងទៀត
«វិនិច្ឆ័យឱ្យបានត្រឹមត្រូវជានិច្ច»
មិនត្រូវរើសមុខអ្នកណា ដោយបង្ហាញការយោគយល់ដោយព្រោះគេជាមនុស្សទុរគត
ឬដោយគេជាមនុស្សសំខាន់នោះឡើយ
ពាក្យថា «ក្រ» និង «សំខាន់» គឺមានន័យថា «នរណាម្នាក់» ។
អ្នកអាចបកប្រែវាដើម្បីបញ្ជាក់ពីលក្ខខណ្ឌ។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវបង្ហាញការពេញចិត្តចំពោះនរណាម្នាក់ដោយផ្អែកលើចំនួនប្រាក់ដែលពួកគេ
ត្រូវកាត់ក្តីអ្នកជិតខាងរបស់អ្នកដោយសុចរិត
«វិនិច្ឆ័យមនុស្សរាល់គ្នាតាមអ្វីដែលត្រឹមត្រូវ»
មិនត្រូវដើរបរិហារកេរ្តិ៍មនុស្សនៅជុំវិញខ្លួនរបស់អ្នកទេ
«កុំទៅនិយាយដើមគេប្រាប់អ្នកដទៃឡើយ»
Leviticus 19:17
មិនត្រូវមានចិត្តស្អប់បងប្អូនរបស់អ្នករាល់គ្នាឡើយ
ការស្អប់មនុស្សម្នាក់គេនិយាយដូចជាកំពុងស្អប់មនុស្សម្នាក់នៅក្នុងចិត្ត។
ការបកប្រែផ្សេងទៀត «កុំស្អប់បងប្អូនឡើយ»
ត្រូវយកចិត្តទុកដាក់ស្តីបន្ទោសអ្នកជិតខាងរបស់អ្នក
«អ្នកត្រូវតែកែមនុស្សដែលធ្វើបាប»
Leviticus 19:19
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ស្លៀកសម្លៀកបំពាក់ដែលត្បាញឡើងពី អំបោះពីរផ្សេងគ្នាដែរ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«សម្លៀកបំពាក់ដែលនរណាម្នាក់ធ្វើពីវត្ថុធាតុដើមពីរប្រភេទ»
Leviticus 19:20
ដែលមានគូរដណ្តឹង
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលភ្ជាប់ពាក្យជាមួយបុរសផ្សេង»
ប៉ុន្តែនាងនៅមិនទាន់បានលួស ឬមិនទាន់មានសេរីភាពជាអ្នកជានៅឡើយ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែអ្នកដែលជាអនាគតស្វាមីរបស់នាងមិនបានលោះ ឬផ្តល់សេរីភាពដល់នាង»
ពួកគេទាំងពីរនាក់នឹងមានទោស
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែដាក់ទណ្ឌកម្មក្មេងស្រីដែលជាទាសករ
និងបុរសដែលបានរួមរស់ជាមួយនាង»
ពួកគេមិនមានទោសដល់ស្លាប់នោះទេ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវសម្លាប់ពួកគេទេ»
បុរសដែលបានប្រព្រឹត្តខុស ត្រូវយកចៀមឈ្មោលមួយទៅថ្វាយជាតង្វាយលោះបាប

ចំពោះព្រះភក្ត្រព្រះអម្ចាស់ ត្រង់មាត់ទ្វារព្រះពន្លាជួបព្រះអម្ចាស់
«បុរសម្នាក់ត្រូវយកចៀមឈ្មោលមួយធ្វើជាតង្វាយរំដោះបាបថ្វាយព្រះអម្ចាស់មកមាត់ទ្វារពន្លាជួបព្រះអម្ចា
[illegible]
នេះអាចប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអត់ទោសបាបដែលគាត់បានប្រព្រឹត្ត»
Leviticus 19:23
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
អ្នកត្រូវចាត់ទុកផ្លែឈើដែលជាផលទាំងនោះ ជាផ្លែឈើមិនបរិសុទ្ធ.....អ្នករាល់គ្នាមិនត្រូវបរិភោគ
ព្រះអម្ចាស់ប្រាប់ឡើយវិញនូវការហាមឃាត់ដើម្បីបញ្ជាក់
និងបញ្ជាក់ថាវាមានសុពលភាពក្នុងរយៈពេល ៣
ឆ្នាំដំបូងដែលដើមឈើនោះបង្កើតផ្លែ។
បកប្រែឃ្លានេះដើម្បីបញ្ជាក់ពីរយៈពេលដែលដើមឈើត្រូវទុកចោលតែម្នាក់ឯង។
ការបកប្រែផ្សេងទៀត
[illegible]
អ្នកត្រូវចាត់ទុកផ្លែឈើដែលជាផលទាំងនោះ ជាផ្លែឈើមិនបរិសុទ្ធ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែចាត់ទុកផ្លែឈើជាអ្វីដែលយើងបានហាមអ្នកមិនឱ្យបរិភោគ» (សូមមើល figs-activepassive)
ផ្លែឈើទាំងនោះនឹងមិនបរិសុទ្ធ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«យើងបានហាមឃាត់ផ្លែឈើនេះដល់អ្នក»
អ្នករាល់គ្នាមិនត្រូវបរិភោគផលនៃផ្លែឈើទាំងនោះឡើយ
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវបរិភោគវាទេ»
Leviticus 19:29
[illegible]
ត្រង់នេះពាក្យ «ជាតិសាសន៍» និង «ទឹកដី»
តំណាងអោយប្រជាជនដែលរស់នៅទីនោះ។
មនុស្សជាច្រើនដែលធ្វើអំពើពេស្យាចារ
និងអំពើអាក្រក់ផ្សេងទៀតពួកគេបានធ្លាក់ចូល ឬពេញទៅដោយរបស់ទាំងនោះ។
ការបកប្រែផ្សេងទៀត «ប្រជាជននឹងចាប់ផ្តើមប្រព្រឹត្តអំពើពេស្យាចារ
និងអំពើអាក្រក់ជាច្រើនទៀត»
Leviticus 19:31
មនុស្សស្លាប់ ឬព្រលឹងឡើយ
អត្ថន័យដែលអាចមានគឺ ១) ថា «មនុស្សស្លាប់» និង «វិញ្ញាណ»
គឺជារបស់ពីរផ្សេងគ្នាឬ ២) ដែលនេះគឺជាការសង្ស័យដែលមានន័យថា
«វិញ្ញាណរបស់មនុស្សស្លាប់» ។
កុំទៅរកពួកគេឡើយ ក្រែងលោពួកគេធ្វើឲ្យអ្នករាល់គ្នាទៅជាសៅហ្មង
«កុំស្វែងរកមនុស្សទាំងនោះ។
ប្រសិនបើអ្នកស្វែងរកពួកគេនឹងធ្វើអោយអ្នកទៅជាស្មោកគ្រោក»
Leviticus 19:32
ត្រូវឱនលំទោន
ការឈរនៅពីមុខនរណាម្នាក់គឺជាសញ្ញានៃការគោរព។
ចំពោះមនុស្សចាស់ជរា
ចំពោះមនុស្ស -
នេះសំដៅទៅលើមនុស្សម្នាក់ដែលសក់របស់គាត់ប្រែទៅជាមានពណ៌ប្រផេះពីអាយុឬ
«មនុស្សចាស់» ។
Leviticus 19:35
មិនត្រូវប្រើរង្វាស់ដែលមិនត្រឹមត្រូវឡើយ
នេះហាមឃាត់ការអនុវត្តជាក់ស្តែងនៃការប្រើប្រាស់ឧបករណ៍ដែលនាំឲ្យមានការអានមិនត្រឹមត្រូវនៅពេល
កូនជញ្ជីងដែលត្រឹមត្រូវ
នេះគឺជារង្វាស់សំរាប់គ្រាប់ធញ្ញជាតិ។
រង្វាស់រង្វាល់
នេះគឺជារង្វាស់សំរាប់វត្ថុរាវ។
ត្រូវប្រតិបត្តិតាមច្បាប់...ចូរប្រតិបត្តិតាម
ឃ្លាទាំងនេះមានន័យដូចគ្នាហើយសង្កត់ធ្ងន់លើបទបញ្ជាសម្រាប់ការគោរពប្រតិបត្តិ។

generated on Wed Sep 10 16:16:32 2025

20 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[2]«ចូរប្រាប់ទៅជនជាតិអ៊ីស្រាអែលទាំងអស់ថា: «ប្រសិនបើជនជាតិអ៊ីស្រាអែលណាម្នាក់
ឬជនបរទេសណាម្នាក់ដែលរស់ក្នុងចំណោមអ្នករាល់គ្រប់គល់កូនប្រុស ឬកូនស្រីរបស់ពួកគេឲ្យគេយកជាសែនព្រះម៉ាឡុក គឺអ្នកនោះត្រូវទទួលទោសដល់ស្លាប់។
មនុស្សទាំងអស់ត្រូវគប់សម្លាប់គេនឹងដុំថ្ម។
[3]រីឯយើង យើងនឹងប្រឆាំងនឹងបុរសនោះ ហើយនឹងកាត់គេចេញពីចំណោមប្រជាជនរបស់គេ ដ្បិត គេបានប្រគល់កូនចៅរបស់គេទៅឲ្យព្រះម៉ូឡុក
ដែលនាំឲ្យទីសក្ការៈរបស់យើងទៅជាសៅហ្មង ហើយបន្ថោកនាមដ៏វិសុទ្ធរបស់យើង។[4]ប្រសិនបើ ប្រជាជននៅក្នុងស្រុកធ្វើមិនដឹងមិនឮរឿងដែលបុរសនោះ
យកកូនចៅរបស់ខ្លួនទៅអោយព្រះម៉ាឡុក ហើយពួកគេមិនសម្លាប់បុរសនោះទេ[5]នោះយើងនឹងប្រឆាំងនឹងបុរសនោះព្រមទាំងអំបូររបស់គេ
ហើយយើងនឹងកាត់បុរសនោះចេញពីប្រជាជាតិរបស់គេ ព្រមទាំងអស់អ្នកដែលបណ្តោយខ្លួនប្រព្រឹត្តពេស្យាជាមួយព្រះម៉ាឡុកដូចបុរសនោះដែរ។
[6]នរណាដែលទៅរកអ្នកដែលអន្ទងមនុស្សស្លាប់ ឬអន្ទងព្រលឹងមនុស្សស្លាប់ អ្នកនោះបានប្រព្រឹត្តខ្លួនពេស្យាចារជាមួយអំពើទាំងនោះ យើងនឹងប្រឆាំងនឹងពួកគេ
យើងនឹងកាត់គេចេញពីចំណោមប្រជាជាតិរបស់គេ។[7]ដូច្នេះ អ្នករាល់គ្នាត្រូវញែកខ្លួនរបស់អ្នករាល់គ្នាឲ្យបានវិសុទ្ធ ដើម្បីជាប្រជាជនដ៏វិសុទ្ធ ព្រោះយើងជាព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នា។
[8]ត្រូវប្រកាន់ និងប្រតិបត្តិតាមច្បាប់របស់យើង។ យើងជាព្រះអម្ចាស់ ដែលប្រោសអ្នករាល់គ្នាឲ្យវិសុទ្ធ។[9]នរណាដែលជេរប្រមាថឪពុក ម្តាយរបស់ខ្លួន
នឹងត្រូវទទួលទោសដល់ស្លាប់។ អ្នកនោះត្រូវទទួលខុសត្រូវលើការស្លាប់របស់គេ ព្រោះគេបានជេរប្រមាថឪពុកម្តាយរបស់គេ។
[10]បុរសណាដែលប្រព្រឹត្តអំពើផិតក្បត់ជាមួយស្ត្រីដែលមានប្តីហើយ គឺគេបានប្រព្រឹត្តអំពើផិតក្បត់ជាមួយប្រពន្ធអ្នកជិតខាងរបស់ខ្លួន អ្នកទាំងពីរ៖ ទាំងបុរស ទាំងស្ត្រី
ដែលប្រព្រឹត្តអំពើផិតក្បត់នោះ ត្រូវទទួលទោសដល់ស្លាប់។[11]បុរសដែលរួមដំណេកជាមួយប្រពន្ធចុងឪពុករបស់ខ្លួន គឺគេបានបន្ថោកកិត្តិយសឪពុករបស់គេ
ដោយបានរួមដំណេកជាមួយនាង។ អ្នកទាំងពីរ ទាំងបុរសនោះ ទាំងស្ត្រីជាប្រពន្ធចុង ត្រូវទទួលទោសដល់ស្លាប់។ ពួកគេត្រូវទទួលខុសត្រូវលើការស្លាប់របស់ខ្លួន។
[12]ប្រសិនបើ បុរសណាម្នាក់រួមដំណេកជាមួយកូនប្រសារស្រីរបស់ខ្លួន គេទាំងពីរនាក់ត្រូវទទួលទោសដល់ស្លាប់។ ពួកគេបានប្រព្រឹត្តអំពើដ៏គួរស្អប់ខ្ពើម។
ពួកគេត្រូវទទួលខុសត្រូវលើសេចក្តីស្លាប់របស់ខ្លួន។
[13]ប្រសិនបើ មនុស្សណាម្នាក់រួមដំណេកជាមួយប្រុសដូចគ្នា ដូចជាការរួមដំណេកជាមួយស្ត្រី ពួកគេទាំងពីរបានប្រព្រឹត្តអំពើដ៏គួរស្អប់ខ្ពើម។
ពួកគេត្រូវទទួលទោសដល់ស្លាប់។[14]ប្រសិនបើបុរសម្នាក់រៀបការកូនស្រីផង រៀបការជាមួយម្តាយផង នេះជារឿងដ៏ថោកទាប។ ពួកគេត្រូវដុតសម្លាប់ ទាំងបុរសនោះ
និងស្ត្រីទាំងពីរនាក់ ដូច្នេះនឹងមិនឮមានអំពើដ៏ថោកទាបក្នុងចំណោមអ្នករាល់គ្នាទេ។
[15]ប្រសិនបើ បុរសណាម្នាក់ដេកជាមួយសត្វចតុបាត បុរសនោះត្រូវទទួលទោសដល់ស្លាប់ ហើយអ្នករាល់គ្នាត្រូវសម្លាប់នោះចោល។ ប្រសិនបើ
ស្ត្រីណាម្នាក់រួមរ័ក្សជាមួយសត្វ ត្រូវសម្លាប់ស្ត្រីនោះ រួមទាំងសត្វផង។[16]ពួកគេត្រូវទទួលខុសត្រូវលើសេចក្តីស្លាប់របស់ពួកគេ។
[17]ប្រសិនបើ បុរសណាម្នាក់រួមដំណេកជាមួយបងឬប្អូនស្រីរបស់គាត់ ទោះជាមួយបងប្អូនស្រីរួមឪពុកក្តី ទោះជាមួយបងប្អូនស្រីរួមម្តាយក្តី ប្រសិនបើ
អ្នកទាំងពីររួមដំណេកជាមួយគ្នា គេប្រព្រឹត្តអំពើដ៏អាម៉ាស់បំផុត។ ត្រូវកាត់ពួកគេចេញពីចំណោមប្រជាជននៅចំពោះមុខមនុស្សទាំងអស់
ព្រោះគេបានរួមដំណេកជាមួយបងប្អូនស្រីរបស់គាត់។ បុរសនោះត្រូវទទួលខុសត្រូវលើកុំហុសរបស់គាត់។
[18]ប្រសិនបើបុរសណាម្នាក់រួមដំណេកជាមួយស្ត្រីដែលកំពុងមានរដូវ ហើយបានរួមដំណេកជាមួយនាង ដោយគាត់បានឃើញឈាមរបស់នាងដែលហូរ
ហើយនាងក៏បានបង្ហាញឈាមរបស់នាង។ ត្រូវកាត់គេទាំងពីរនាក់ចេញពីចំណោមប្រជាជនរបស់គេ។
[19]មិនត្រូវរួមដំណេកជាមួយបង ឬប្អូនស្រីរបស់ម្តាយនាក់ទេ ក៏មិនត្រូវរួមដំណេកជាមួយបង ឬប្អូនស្រីរបស់ឪពុកអ្នកដែរ
ព្រោះអ្នកអាចបន្ថោកកិត្តិយសសាច់ញាតិជិតដិតរបស់អ្នក។ អ្នកត្រូវទទួលខុសត្រូវលើកំហុសរបស់អ្នក។[20]ប្រសិនបើបុរសណាម្នាក់រួមដំណេកជាមួយម្តាយមីងរបស់គាត់
នោះគាត់បានបន្ថោកកិត្តិយសឪពុកមាររបស់គាត់។ នៅពេលដែលពួកគេស្លាប់ យើងនឹងដាក់ទោសពួកគេទាំងពីរនាក់ ហើយនៅពេលដែលពួកគេស្លាប់
យើងនឹងយកកេរ្តិ៍មរតកពីកូនៗរបស់ពួកគេ ជាកេរ្តិ៍មរតកដែលពួកគេសក្តិសមនឹងទទួលពីឪពុកម្តាយរបស់ពួកគេ។[21]ប្រសិនបើ បុរសណាម្នាក់យកប្រពន្ធបង
ឬប្អូនប្រុសរបស់ខ្លួនមកធ្វើជាប្រពន្ធ ក្នុងពេលដែលបង ឬប្អូនប្រុសរបស់ខ្លួននៅរស់នៅឡើង វាជាការដែលអាប់ឱនកិត្តិយសបំផុត។ គេបានបន្ថោកបងប្អូនប្រុសរបស់គេ
ហើយយើងនឹងយកទ្រព្យសម្បត្តិដែលកូនៗរបស់ពួកគេត្រូវទទួលពីឪពុកម្តាយនោះចេញពីពួកគេ។
[22]ចូរកាន់តាមច្បាប់ និងវិន័យរបស់យើង ព្រមទាំងប្រតិបត្តិតាមផង អ្នករាល់គ្នាត្រូវគោរពតាមច្បាប់ទាំងអស់នេះ ដូច្នេះ
អ្នករាល់គ្នានឹងមិនត្រូវខ្ចាត់ខ្ចាយចេញពីទឹកដីដែលយើងបាននាំអ្នករាល់គ្នាចូលមករស់នៅនេះទេ។
[23]អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តដូចជាប្រជាជាតិទាំងឡាយដែលយើងបានដេញចេញពីមុខអ្នករាល់គ្នានោះទេ ព្រោះពួកគេបានធ្វើកិច្ចការទាំងនោះ
ជាកិច្ចការដែលយើងស្អប់ខ្ពើម។
[24]យើងប្រាប់អ្នករាល់គ្នាថា៖ «អ្នករាល់គ្នានឹងកាន់កាប់ទឹកដីរបស់ពួកគេ យើងនឹងប្រគល់ស្រុកនេះឲ្យអ្នករាល់គ្នាជាកម្មសិទ្ធិ ទឹកដីដែលពេញទៅដោយទឹកដោះ និងទឹកឃ្មុំ។
យើងគឺព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា យើងបានញែកអ្នករាល់គ្នាចេញពីចំណោមប្រជាជាតិទាំងឡាយ។[25]អ្នករាល់គ្នាត្រូវចេះសម្គាល់មើលរវាងសត្វបរិសុទ្ធ
និងសត្វមិនបរិសុទ្ធ រវាងបក្សីមិនបរិសុទ្ធ និងបក្សីដែលបរិសុទ្ធ។ អ្នករាល់គ្នាមិនត្រូវបណ្តោយខ្លួនរបស់អ្នករាល់គ្នាឲ្យសៅហ្មង ដោយសារសត្វជើងបួន ឬបក្សី
ឬសត្វលូនវារ ដែលយើងចាត់ទុកជាសត្វមិនបរិសុទ្ធសម្រាប់អ្នករាល់គ្នានោះទេ។
[26]អ្នករាល់គ្នាត្រូវតែវិសុទ្ធសម្រាប់យើង ដ្បិត យើងជាព្រះអម្ចាស់ ជាព្រះដ៏វិសុទ្ធ យើងបានញែកអ្នករាល់គ្នាពីចំណោមជាតិសាសន៍ទាំងឡាយ
ដើម្បីឲ្យអ្នករាល់គ្នាជាប្រជារាស្ត្ររបស់យើង។
[27]បុរស ឬស្ត្រីណាដែលចេះអន្ទងមនុស្សស្លាប់ ឬព្រលឹង ត្រូវទទួលទោសដល់ស្លាប់។ ត្រូវយកដុំថ្មគប់សម្លាប់ពួកគេ។ ពួកគេទទួលខុសត្រូវលើការស្លាប់របស់ខ្លួន»។

Leviticus 20:1

ប្រគល់កូនប្រុស ឬកូនស្រីរបស់ពួកគេឲ្យគេយកជាសែនព្រះម៉ាឡុក

អ្នកដែលថ្វាយបង្គំព្រះម៉ាឡុកដុតកូន ៗ របស់គេក្នុងភ្លើង។

អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«សម្លាប់កូន ៗ របស់គាត់ណាមួយជាការបូជាដល់ព្រះម៉ាឡុក»

កនោះត្រូវទទួលទោសដល់ស្លាប់។ មនុស្សទាំងអស់ត្រូវគប់សម្លាប់គេនឹងដុំថ្ម

នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជននៅលើដីត្រូវតែគប់ដុំថ្មសម្លាប់គេ»

Leviticus 20:3

ឯយើង យើងនឹងប្រឆាំងនឹងបុរសនោះ

ឃ្លា «ប្រឆាំង» គឺជាពាក្យសំដីដែលមានន័យថា «បដិសេធ» ឬ
«ដើម្បីប្រឆាំងយ៉ាងខ្លាំង» ។ ការបកប្រែផ្សេងទៀត «យើងនឹងបដិសេធគេ» ឬ
«យើងនឹងប្រឆាំងនឹងគេដែរ»

គេបានប្រគល់កូនចៅរបស់គេទៅឲ្យ
«គាត់បានលះបង់កូនរបស់គាត់»

ដែលនាំឲ្យទីសក្ការៈរបស់យើងទៅជាសៅហ្មង ហើយបន្ថោកនាមដ៏វិសុទ្ធរបស់យើង
«ហើយតាមរយៈការធ្វើដូច្នេះគេបានធ្វើអោយទីសក្ការៈរបស់យើងក្លាយទៅជាស្មោកគ្រោក
និងធ្វើអោយនាមដ៏វិសុទ្ធរបស់យើងទៅជាសៅហ្មង»

បន្ថោកនាមដ៏វិសុទ្ធរបស់យើង
ឈ្មោះរបស់ព្រះតំណាងឱ្យព្រះនិងកេរ្តិ៍ឈ្មោះរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«បង្អាប់កេរ្តិ៍ឈ្មោះរបស់យើង» ឬ «បង្អាប់កិត្តិយសយើង»

ប្រជាជននៅក្នុងស្រុកធ្វើមិនដឹង
ឃ្លាថា «បិទភ្នែក» មានន័យថាពួកគេ« មិនអាចមើលឃើញ»
និងតំណាងឱ្យអសមត្ថភាពរបស់ពួកគេក្នុងការយល់។ ការបកប្រែផ្សេងទៀត
«មិនយកចិត្តទុកដាក់» ឬ «ព្រងើយកន្តើយ»

ព្រមទាំងអស់អ្នកដែលបណ្តោយខ្លួនប្រព្រឹត្តពេស្យាជាមួយព្រះម៉ាឡុកដូចបុរសនោះដែរ

generated on Wed Sep 10 16:16:32 2025

ឃ្លានេះប្រៀបធៀបអ្នកដែលមិនស្មោះត្រង់នឹងព្រះអម្ចាស់ទៅនឹងស្រីពេស្យា។
ការបកប្រែផ្សេងទៀត «អ្នកណាមិនស្មោះត្រង់នឹងព្រះអម្ចាស់»
Leviticus 20:6
អ្នកនោះបានប្រព្រឹត្តខ្លួនពេស្យាចារជាមួយអំពើទាំងនោះ
ឃ្លានេះប្រៀបធៀបមនុស្សដែលមិនស្មោះត្រង់ទៅនឹងស្រីពេស្យា។
ការបកប្រែផ្សេងទៀត
«ដោយធ្វើដូច្នេះពួកគេស្វែងរកដំបូន្មានពីវិញ្ញាណជាជាងពីយើង»
យើងនឹងប្រឆាំងនឹងពួកគេ
«ដើម្បីបដិសេធ» ឬ «ដើម្បីប្រឆាំងយ៉ាងខ្លាំង» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២០: ៣ ។
Leviticus 20:8
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ត្រូវប្រកាន់ និងប្រតិបត្តិតាមច្បាប់របស់យើង
ពាក្យ «រក្សា» និង «អនុវត្ត» មានន័យថាជាមូលដ្ឋានដូចគ្នា។
ពួកគេត្រូវបានប្រើជាមួយគ្នាដើម្បីបញ្ជាក់ថាប្រជាជនត្រូវតែស្តាប់បង្គាប់ព្រះជាម្ចាស់។
នឹងត្រូវទទួលទោសដល់ស្លាប់
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវគេសម្លាប់»
Leviticus 20:10
រសណាដែលប្រព្រឹត្តអំពើផិតក្បត់ជាមួយស្ត្រីដែលមានប្តីហើយ
គឺគេបានប្រព្រឹត្តអំពើផិតក្បត់ជាមួយប្រពន្ធអ្នកជិតខាងរបស់ខ្លួន
អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«បុរសដែលផិតក្បត់ជាមួយប្រពន្ធរបស់អ្នកដទៃ»
នោះ ត្រូវទទួលទោសដល់ស្លាប់
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវសម្លាប់វាទាំងពីរនាក់"
ដែលរួមដំណេកជាមួយប្រពន្ធចុងឪពុករបស់ខ្លួន
នេះជាវិធីគួរសមក្នុងការនិយាយថាគាត់បានរួមរ័កជាមួយប្រពន្ធរបស់ឪពុកគាត់។
ភាសាខ្លះប្រើឃ្លាផ្ទាល់ច្រើនជាងនេះដូចជា «រួមភេទជាមួយប្រពន្ធឪពុក» ។
ពួកគេបានប្រព្រឹត្តអំពើដ៏គួរស្អប់ខ្ពើម
នៅទីនេះព្រះហៅបុរសម្នាក់រួមភេទជាមួយប្រពន្ធកូនប្រុសរបស់គាត់ថាជា
«ការវង្វេងស្មារតី» ដែលជាអំពើបាបធ្ងន់ធ្ងរ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យ «វង្វេងស្មារតី» នៅក្នុងជំពូក ១៨:២២
។
Leviticus 20:13
ប្រសិនបើ មនុស្សណាម្នាក់រួមដំណេកជាមួយ
នេះជាវិធីគួរសមក្នុងការនិយាយថាគាត់បានរួមភេទជាមួយបុរសផ្សេង។
ភាសាខ្លះប្រើឃ្លាផ្ទាល់ច្រើនជាងនេះដូចជា «បុរសម្នាក់រួមភេទជាមួយ» ។
ដូចជាការរួមដំណេកជាមួយស្ត្រី
វិធីដែលគាត់ធ្វើចំពោះបុរសគឺដូចគ្នានឹងវិធីដែលគាត់ធ្វើចំពោះស្ត្រីដែរ។
ការបកប្រែផ្សេងទៀត «ដូចជាគាត់នឹងជាមួយស្ត្រីម្នាក់»
ពួកគេទាំងពីរបានប្រព្រឹត្តអំពើដ៏គួរស្អប់ខ្ពើម
«អ្វីដែលគួរឱ្យអាម៉ាស់» ឬ «អ្វីដែលគួរឱ្យស្អប់ខ្ពើម»
ពួកគេត្រូវទទួលទោសដល់ស្លាប់
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវសំលាប់ពួកគេ»
ពួកគេត្រូវដុតសម្លាប់ ទាំងបុរសនោះ និងស្ត្រីទាំងពីរនាក់
នេះអាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវដុតទាំងបុរសនិងស្ត្រីនោះ»
Leviticus 20:15
បុរសនោះត្រូវទទួលទោសដល់ស្លាប់
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវសំលាប់គាត់»
ត្រូវសម្លាប់ស្ត្រីនោះ រួមទាំងសត្វផង
ឃ្លាទាំងពីរមានន័យថាដូចគ្នា។ ពួកគេសង្កត់ធ្ងន់ថាស្ត្រីនិងសត្វត្រូវតែស្លាប់។
ត្រូវសម្លាប់ស្ត្រីនោះ រួមទាំងសត្វផង
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវសម្លាប់ពួកគេចោល»
Leviticus 20:17
បុរសណាម្នាក់រួមដំណេកជាមួយ
នេះជាវិធីគួរសមក្នុងការនិយាយថាគាត់បានរួមភេទជាមួយប្អូនស្រីរបស់គាត់។
ភាសាខ្លះប្រើឃ្លាផ្ទាល់ច្រើនជាងនេះដូចជា «បុរសម្នាក់រួមភេទជាមួយ» ។
ទោះជាមួយបងប្អូនស្រីរួមឪពុកក្តី ទោះជាមួយបងប្អូនស្រីរួមម្តាយក្តី
នេះមានន័យថាបុរសមិនអាចដេកជាមួយបងស្រីបានទេ
ទោះបីនាងមានម្តាយឬឪពុកផ្សេងក៏ដោយ។
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«មិនថាជាបងស្រីឬប្អូនស្រីពាក់កណ្តាលរបស់គាត់ទេ»
ត្រូវកាត់ពួកគេចេញពី
មនុស្សម្នាក់ដែលត្រូវបានគេដកចេញពីសហគមន៍របស់គាត់ត្រូវបានគេនិយាយដូចជាគាត់ត្រូវបានគេកាត់
ដូចជាមនុស្សម្នាក់នឹងកាត់ក្រណាត់ឬកាត់មែកឈើចេញពីមែកឈើ។
នេះអាចបកប្រែជាទម្រង់សកម្ម។
សូមមើលពីរបៀបដែលអ្នកបានបកប្រែគំនិតនេះនៅក្នុងជំពូក ៧:១៩ ។
ការបកប្រែផ្សេងទៀត
«មនុស្សនោះអាចនឹងលែងរស់នៅក្នុងចំណោមប្រជាជនរបស់គាត់» ឬ
«អ្នកត្រូវតែញែកមនុស្សនោះចេញពីប្រជាជនរបស់គាត់»
បុរសនោះត្រូវទទួលខុសត្រូវលើកុំហុសរបស់គាត់
ឃ្លានេះមានន័យថាបុរសនោះទទួលខុសត្រូវចំពោះអំពើបាបរបស់គាត់។
ការបកប្រែផ្សេងទៀត «គាត់ទទួលខុសត្រូវចំពោះអំពើបាបរបស់គាត់» ឬ
«អ្នកត្រូវតែដាក់ទណ្ឌកម្មគាត់» (សូមមើល figs idiom)
ដែលកំពុងមានរដូវ
គឺជាពេលវេលាដែលស្ត្រីម្នាក់ហូរឈាមចេញពីស្បូន
គាត់បានឃើញឈាមរបស់នាងដែលហូរ ហើយនាងក៏បានបង្ហាញឈាមរបស់នាង
ឃ្លានេះប្រៀបធៀបការរួមភេទជាមួយស្ត្រីម្នាក់ក្នុងអំឡុងពេលមានរដូវរបស់នាងដើម្បីដកគម្របចេញពីអ្វីដែ
ការពិតដែលថានេះជារឿងគួរឱ្យអាម៉ាស់ដែលត្រូវធ្វើអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត
«គាត់បានធ្វើរឿងគួរឱ្យអាម៉ាស់មួយដោយបង្ហាញពីលំហូរឈាមរបស់នាង»
ត្រូវកាត់គេទាំងពីរនាក់ចេញពី
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ពីមូលហេតុដែលត្រូវធ្វើបែបនេះ។
ការបកប្រែផ្សេងតៀត
«ដោយសារតែពួកគេបានធ្វើរឿងដ៏គួរឱ្យអាម៉ាសនេះទាំងបុរស
និងស្ត្រីត្រូវតែកាត់ផ្តាច់ចេញពី»
Leviticus 20:19
រួមដំណេកជាមួយ
នេះជាវិធីគួរសមដែលនិយាយថាគាត់បានរួមភេទជាមួយមីងរបស់គាត់។
ភាសាខ្លះប្រើឃ្លាផ្ទាល់ដូចជា «រួមភេទជាមួយ»
អ្នកត្រូវទទួលខុសត្រូវលើកំហុសរបស់អ្នក
«អនុវត្តទោសដោយខ្លួនឯង» មានន័យថា
«អ្នកត្រូវទទួលខុសត្រូវចំពោះអំពើបាបរបស់អ្នក» ។ ការបកប្រែផ្សេងទៀត
«អ្នកទទួលខុសត្រូវចំពោះអំពើបាបរបស់អ្នក» ឬ «ខ្ញុំនឹងដាក់ទណ្ឌកម្មអ្នក»
យើងនឹងយកកេរ្តិ៍មរតកពីកូនៗរបស់ពួកគេ
ជាកេរ្តិ៍មរតកដែលពួកគេសក្តិសមនឹងទទួលពីឪពុកម្តាយរបស់ពួកគេ
ព្រះគម្ពីរជាច្រើនបានបកប្រែថា «ពួកគេនឹងស្លាប់ដោយគ្មានកូន» ។
Leviticus 20:22
អ្នករាល់គ្នានឹងមិនត្រូវខ្ចាត់ខ្ចាយចេញពីទឹកដីដែលយើងបាននាំអ្នករាល់គ្នាចូលមករស់នៅនេះទេ
ឃ្លានេះពិពណ៌នាអំពីដីជាមនុស្សដែលក្អួតចង្អោរបដិសេធអាហារមិនល្អ។
ជំនួសឱ្យការបដិសេធអាហារមិនល្អ ដីបដិសេធប្រជាជនហើយយកគេចេញ។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យប្រៀបធៀបនេះនៅជំពូក ១៨:២៤ ។
ការបកប្រែផ្សេងទៀត «ដីដែលយើងនាំអ្នកទៅនឹងមិនបោះបង់ចោលអ្នកទេ»
អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តដូច
ការធ្វើសកម្មភាពរបស់អ្នកគោរពបូជារូបព្រះត្រូវបានគេនិយាយថាកំពុងដើរក្នុងផ្លូវរបស់ពួកគេ។
ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវធ្វើតាម»
ដេញចេញ
«យកចេញ»
Leviticus 20:24
ទឹកដីដែលពេញទៅដោយទឹកដោះ និងទឹកឃ្មុំ
ឃ្លាថា «ពេញទៅដោយទឹកដោះ និងទឹកឃ្មុំ» មានន័យថា
«សម្បូរបែបនិងផលិតភាពដោយមានអាហារគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់គ្នា» ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «ដីដែលល្អប្រសើរសម្រាប់សត្វពាហនៈនិងកសិកម្ម» ឬ «ដីដែលមានផលិតភាព»

Leviticus 20:26

យើងបានញែកអ្នករាល់គ្នា

«ខ្ញុំបានសម្គាល់អ្នក» ឬ «ខ្ញុំបានញែកអ្នក»

Leviticus 20:27

ចេះអន្ទង

«ព្យាយាមទំនាក់ទំនងជាមួយ»

ត្រូវទទួលទោសដល់ស្លាប់

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេប្រាកដជាត្រូវគេសម្លាប់»

---

21 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ «ចូរប្រាប់ពួកបូជាចារ្យជាកូនចៅអើរ៉ុនដូចតទៅ: បូជាចារ្យ មិនត្រូវធ្វើឲ្យខ្លួនសៅហ្មង
ដោយសារប៉ះពាល់សាកសព មនុស្សស្លាប់ណាម្នាក់ក្នុងចំណោមប្រជាជនរបស់អ្នករាល់គ្នាឡើយ។[2]លើកលែងតែសាច់ឈាមបង្កើតដូចជា: ម្តាយបង្កើត ឪពុកបង្កើត
កូនប្រុសបង្កើត កូនស្រីបង្កើត បងប្អូនប្រុសបង្កើត[3]ឬបងប្អូនស្រីដែលនៅក្រមុំមិនទាន់មានគូស្រករ ដែលនាងស្ថិតនៅក្រោមអាណាព្យាបាលរបស់គាត់នៅឡើយ
ប៉ុន្តែគាត់អាចទៅជាសៅហ្មងដោយសារប៉ះពាល់សាកសពរបស់នាង។
[4]ប៉ុន្តែ បូជាចារ្យមិនត្រូវបណ្តោយឲ្យខ្លួនទៅជាសៅហ្មង ដោយសារទំនាក់ទំនងផ្សេងៗ ដែលនាំឲ្យខ្លួនសៅហ្មងឡើយ។[5]បូជាចារ្យមិនត្រូវកោរសក់
ក៏មិនត្រូវកោរជាយពុកចង្ការដែរ ឬធ្វើពិធីឆូតសាច់របស់ពួកគេដែរ។[6]ពួកគេត្រូវតែវិសុទ្ធ សម្រាប់ព្រះរបស់ពួកគេ ហើយមិនត្រូវបន្ថោកព្រះនាមនៃព្រះរបស់ពួកគេដែរ
ព្រោះបូជាចារ្យមានមុខងារថ្វាយយញ្ញបូជា និងអាហារដល់ព្រះអម្ចាស់ ជាព្រះរបស់ខ្លួន។ ដូច្នេះ ពួកគេត្រូវតែបរិសុទ្ធ។
[7]បូជាចារ្យមិនត្រូវយកស្ត្រីពេស្យា ឬស្ត្រីខូច ហើយក៏មិនត្រូវយកស្ត្រីដែលលែងប្តី ធ្វើជាប្រពន្ធដែរ ព្រោះពួកគេបានញែកសម្រាប់ព្រះជាម្ចាស់។
[8]ត្រូវចាត់ទុកបូជាចារ្យជាមនុស្សដ៏វិសុទ្ធ ព្រោះពួកគេគឺជាអ្នកថ្វាយនំបុ័ងដល់ព្រះជាម្ចាស់របស់អ្នក។ បូជាចារ្យត្រូវតែបរិសុទ្ធសម្រាប់អ្នករាល់គ្នា ដ្បិត
យើងព្រះអម្ចាស់ដែលបានញែកគេជាបរិសុទ្ធ យើងជាព្រះដ៏វិសុទ្ធ។[9]ប្រសិនបើ កូនស្រីរបស់បូជាចារ្យបង្ខូចខ្លួន ដោយប្រព្រឹត្តអំពើពេស្យាចារ
នោះនាងបានបន្ថោកឪពុករបស់នាង។ ដូចនេះ ត្រូវយកនាងទៅដុតទាំងរស់។
[10]មហាបូជាចារ្យដែលជាប្រមុខលើពួកបូជាចារ្យ ដែលបានទទួលការចាក់ប្រេងតែងតាំងឲ្យបំពេញមុខងារ
ហើយអ្នកដែលប្រសិទ្ធិពរឲ្យស្លៀកសម្លៀកបំពាក់ពិសេសសម្រាប់មហាបូជាចារ្យ មិនត្រូវដកឆ្នួតក្បាលចេញ ហើយក៏មិនត្រូវហែកសម្លៀកបំពាក់របស់គាត់ដែរ។
[11]មហាបូជាចារ្យមិនត្រូវចូលទៅជិតសាកសព ហើយធ្វើឲ្យខ្លួនគាត់សៅហ្មងនៅឡើយ ទោះបីជាឪពុកម្តាយបង្កើតក្តី។
[12]មហាបូជាចារ្យមិនត្រូវចាកចេញពីបរិវេននៃទីសក្ការៈរបស់ព្រះអម្ចាស់ឡើយ។ ព្រោះគាត់ជាមហាបូជាចារ្យ ដែលបានទទួលការចាក់ប្រេងតាំងពីព្រះរបស់គាត់។
យើងគឺជាព្រះអម្ចាស់។
[13]មហាបូជាចារ្យត្រូវរៀបការជាមួយតែនឹងស្ត្រីព្រហ្មចារីតែប៉ុណ្ណោះ។[14]គាត់មិនត្រូវយកស្ត្រីមេមាយ ស្ត្រីដែលលែងលះប្តី ឬស្ត្រីពេស្យាឡើយ។
គាត់មិនត្រូវយកស្ត្រីប្រភេទនោះឡើយ។ ត្រូវរៀបការតែនឹងនារីក្រមុំព្រហ្មចារី ក្នុងអំបូររបស់គាត់តែប៉ុណ្ណោះ[15]ដូច្នេះ
គាត់នឹងមិនធ្វើឲ្យកូនរបស់គាត់ទៅជាសៅហ្មងក្នុងចំណោមប្រជាជនរបស់គាត់ឡើយ ដ្បិតយើងជាព្រះអម្ចាស់ ដែលបានញែកអ្នករាល់គ្នាជាវិសុទ្ធ»។
[16]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[17]«ចូរប្រាប់លោកអើរ៉ុន ប្រាប់ថា: ក្នុងចំណោមពូជពង្សរបស់អ្នក គ្រប់ជំនាន់
មិនត្រូវអនុញ្ញាតឲ្យអ្នកដែលមានរូបរាងខុសធម្មតា នាំយកតង្វាយទៅថ្វាយព្រះរបស់អ្នកទេ។
[18]មនុស្សណាដែលមានរូបរាងមិនធម្មតា ពុំអាចចូលទៅជិតព្រះអម្ចាស់បានទេ ដូចជា: មនុស្សខ្វាក់ ឬមនុស្សខ្វើចជើង អ្នកដែលមានរូបរាងមិនប្រក្រតី
ឬមិនគ្រប់លក្ខណៈ[19]មនុស្សដែលស្វិតដៃ ឬស្វិតជើង[20]អ្នកដែលមានគមនៅលើខ្នង មនុស្សដែលស្គមខុសពីធម្មតា ឬមនុស្សតឿ អ្នកដែលស្រឡេវភ្នែក
ឬមនុស្សដែលមានរោគសញ្ញាដូចជាកើតរមាស់ កើតស្រែង ប្រដាប់ភេទមិនល្អ។[21]ក្នុងចំណោមពូជ្យពង្សបូជាចារ្យអើរ៉ុន អ្នកដែលមានរូបរាងមិនធម្មតា
មិនត្រូវចូលទៅថ្វាយតង្វាយដុតដល់ព្រះអម្ចាស់ទេ។ ដោយគេមានរូបរាងមិនធម្មតាដូច្នេះ គេមិនអាចនាំយកអាហារទៅថ្វាយព្រះរបស់គេបានទេ។
[22]គាត់អាចបរិភោគអាហាររបស់ព្រះអម្ចាស់ ទោះជាអាហារដ៏វិសុទ្ធ ឬអាហារដ៏វិសុទ្ធបំផុតក្តី។[23]ប៉ុន្តែ គេមិនអាចចូលទៅក្នុងវាំងនន ចូលទៅក្បែរអាសនៈបានទេ
ព្រោះគេមានរូបរាងកាយមិនប្រក្រតី ដូច្នេះគេមិនអាចធ្វើឲ្យសៅហ្មងដល់ទីដ៏វិសុទ្ធរបស់យើងបានទេ ដ្បិត យើងគឺព្រះអម្ចាស់
ដែលធ្វើឲ្យទីនោះទៅជាវិសុទ្ធ។»[24]លោកម៉ូសេនាំយកពាក្យទាំងនេះមកប្រាប់អើរ៉ុន និងកូនប្រុសៗរបស់គាត់ រួមទាំងប្រជាជនអ៊ីស្រាអែលទាំងមូលផង។

Leviticus 21:1

ធ្វើឲ្យខ្លួនសៅហ្មង

មនុស្សដែលព្រះមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយថាធ្វើឲ្យខ្លួនសៅហ្មង

ក្នុងចំណោមប្រជាជនរបស់អ្នករាល់គ្នាឡើយ

«ក្នុងចំណោមជនជាតិអ៊ីស្រាអែល»

ស្រីដែលនៅក្រមុំ

នេះក៏អាចត្រូវបានបកប្រែជា «ស្ត្រីវ័យក្មេង»

Leviticus 21:4

កោរជាយ

«គែម» ឬ «ផ្នែកណាមួយ»

ពួកគេត្រូវតែវិសុទ្ធ

«ពួកគេត្រូវតែញែកដាច់ពីគ្នា»

មិនត្រូវបន្ថោកព្រះនាមនៃព្រះរបស់ពួកគេដែរ

ពាក្យ «នាម» សំដៅព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត «កុំធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់ព្រះអាប់ឱន» ឬ «កុំធ្វើឲ្យព្រះអាប់ឱនកិរិយស»

អាហារដល់ព្រះអម្ចាស់

នៅទីនេះ «នំបុ័ង» តំណាងឱ្យម្ហូបជាទូទៅ។

ព្រះពិតជាមិនសោយតង្វាយទាំងនេះទេ។

វាគឺជាភាពស្មោះត្រង់របស់អ្នកដែលផ្តល់អាហារដែលគាប់ព្រះហឫទ័យព្រះ។

Leviticus 21:7

បូជាចារ្យមិនត្រូវយក

«បូជាចារ្យមិនត្រូវ»

ព្រោះពួកគេបានញែកសម្រាប់ព្រះជាម្ចាស់

«ព្រោះពួកគេត្រូវបានញែកចេញ»

[illegible]

«អ្នកត្រូវចាត់ទុកបូជាចារ្យថាបរិសុទ្ធ»

ព្រោះពួកគេគឺជាអ្នកថ្វាយនំបុ័ងដល់ព្រះជាម្ចាស់របស់អ្នក

នៅទីនេះ «នំបុ័ង» តំណាងឱ្យម្ហូបជាទូទៅ។

ព្រះជាម្ចាស់ពិតជាមិនបរិភោគតង្វាយទាំងនេះទេ។

បកប្រែការនេះតាមវិធីមួយដែលធ្វើឱ្យវាកាន់តែច្បាស់ថាព្រះអម្ចាស់ពិតជាមិនសោយម្ហូបទេ។

បូជាចារ្យត្រូវតែបរិសុទ្ធសម្រាប់អ្នករាល់គ្នា

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវចាត់ទុកគាត់ជាមនុស្សបរិសុទ្ធ»

នាងទៅដុតទាំងរស់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវដុតនាងរហូតដល់ស្លាប់»

Leviticus 21:10

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេពីអ្វីដែលពួកបូជាចារ្យត្រូវធ្វើ។

ការចាក់ប្រេងតែងតាំង

នេះជាឯកសារយោងទាក់ទងនឹងប្រេងដែលបានប្រើសម្រាប់ពិធីតែងតាំងបូជាចារ្យថ្មី។

អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឱ្យច្បាស់។

ដែលបានទទួលការចាក់ប្រេងតែងតាំងឲ្យបំពេញមុខងារ ហើយអ្នកដែលប្រសិទ្ធិពរ

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត«គេចាក់ប្រេងលើក្បាល

generated on Wed Sep 10 16:16:32 2025

ហើយចាក់ប្រេងលើក្បាល គេប្រសិទ្ធិពរ» ។
មិនត្រូវដកឆ្នូតក្បាលចេញ ហើយក៏មិនត្រូវហែកសម្លៀកបំពាក់របស់គាត់ដែរ។
ដកឆ្នូតក្បាលចេញនិងសម្លៀកបំពាក់រហែកគឺជាសញ្ញានៃការកាន់ទុក្ខ។
អត្ថន័យពេញលេញនៃឃ្លានេះអាចធ្វើឱ្យច្បាស់។
មិនត្រូវចាកចេញពីបរិវេននៃទីសក្ការៈ
នេះមិនបានន័យថាសម្តេចសង្ឃមិនអាចចាកចេញបានទេ។
ព្រះមិនបានអនុញ្ញាតឱ្យគាត់ចាកចេញដើម្បីធ្វើឱ្យមានទុក្ខព្រួយចំពោះអ្នកដែលបានស្លាប់នៅទីនោះ។ «ប៉ុង» តំណាងឱ្យម្ហូបជាទូទៅ។ ការបកប្រែផ្សេងទៀត
Leviticus 21:13
ក្នុងអំបូររបស់គាត់តែប៉ុណ្ណោះ
«ក្នុងចំណោមកុលសម្ព័ន្ធរបស់គាត់គឺកុលសម្ព័ន្ធលេវី»
គាត់នឹងមិនធ្វើឲ្យកូនរបស់គាត់ទៅជាសៅហ្មងក្នុងចំណោមប្រជាជនរបស់គាត់ឡើយ
ដោយរៀបការជាមួយស្ត្រីមិនបរិសុទ្ធ
ឬមិនគោរពព្រះបូជាចារ្យអាចមានកូនដែលមិនសក្តិសមជាបូជាចារ្យ។
ការបកប្រែផ្សេងទៀត
«គាត់នឹងមិនមានកូនដែលមិនសមនឹងរៀបការជាមួយស្ត្រីដែលមិនគោរពព្រះទេ»
Leviticus 21:16
នត្រូវអនុញ្ញាតឲ្យអ្នកដែលមានរូបរាងខុសធម្មតា នាំយកតង្វាយទៅថ្វាយព្រះរបស់អ្នកទេ
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«គាត់មិនត្រូវមកដុតតង្វាយដុតនៅលើអាសនៈរបស់ព្រះជាម្ចាស់ទេ»
Leviticus 21:18
ពុំអាចចូលទៅជិតព្រះអម្ចាស់បានទេ
បូជាចារ្យត្រូវតែបំពេញតាមកំរិតជាក់លាក់ដើម្បីចូលទៅជិតព្រះអម្ចាស់។
នេះមិនបានន័យថាពិការភាពរាងកាយគឺបណ្តាលមកពីអំពើអសីលធម៌
ឬមនុស្សពិការទាំងអស់មិនអាចចូលទៅជិតព្រះអម្ចាស់បានឡើយ។
អ្នកដែលមានរូបរាងមិនប្រក្រតី ឬមិនគ្រប់លក្ខណៈ
«អ្នកណាដែលរាងកាយ ឬមុខត្រូវបានខូចទ្រង់ទ្រាយ»
គេមិនអាចនាំយកអាហារទៅថ្វាយព្រះរបស់គេបានទេ
«ថ្វាយតង្វាយដុតនៅលើអាសនៈរបស់ព្រះជាម្ចាស់»
Leviticus 21:22
គាត់អាច
ត្រង់នេះ «គាត់» សំដៅទៅលើបូជាចារ្យដែលមានជម្ងឺប្រចាំកាយ។
បរិភោគអាហាររបស់ព្រះអម្ចាស់
«បរិភោគតង្វាយម្សៅរបស់ព្រះ»។
គ្រឿងបូជាខ្លះជារបស់បូជាចារ្យហើយអាចបរិភោគបាន។
ទោះជាអាហារដ៏វិសុទ្ធ ឬអាហារដ៏វិសុទ្ធបំផុតក្តី
នេះក៏សំដៅទៅលើអាហារដែលត្រូវបានបូជា។
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងតៀត «ការលះបង់ខ្លះដែលត្រូវបានផ្តល់ជូននៅក្នុងទីបរិសុទ្ធបំផុត
ឬការលះបង់ខ្លះដែលត្រូវបានផ្តល់ជូននៅទីបរិសុទ្ធ»
កូនប្រុសៗរបស់គាត់
«ចំពោះកូនប្រុសរបស់អើរ៉ុន»

---

22 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេដូចតទៅ៖[2]«ចូរប្រាប់ទៅអើរ៉ុន និងកូនរបស់គាត់ថា ពួកគេត្រូវរក្សារបស់ដ៏បរិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល
ដែលពួកគេថ្វាយជាសក្ការៈដល់យើង។ ពួកគេមិនត្រូវបន្ថោកនាមរបស់យើងឡើយ។ យើងគឺព្រះអម្ចាស់។[3]ចូរប្រាប់ពួកគេថា: ប្រសិនបើ
អ្នកណាម្នាក់ក្នុងចំណោមពូជពង្សរបស់អ្នកគ្រប់ជំនាន់ ទៅប៉ះពាល់តង្វាយដ៏បរិសុទ្ធ ដែលជនជាតិអ៊ីស្រាអែលថ្វាយជាសក្ការៈដល់ព្រះអម្ចាស់
នៅពេលដែលគេមានភាពមិនបរិសុទ្ធ គេត្រូវបណ្តេញចេញពីមុខរបស់យើង: យើងគឺជាព្រះអម្ចាស់។
[4]ក្នុងពូជពង្សរបស់អើរ៉ុន អ្នកដែលមានជំងឺឃ្លង់នៅលើស្បែក ឬជំងឺកាមរោគ មិនអាចបរិភោគអាហារដ៏វិសុទ្ធដែលថ្វាយដល់ព្រះអម្ចាស់បានទេ
រហូតដល់គេបានបរិសុទ្ធឡើងវិញ។ អ្នកដែលប៉ះពាល់នឹងរបស់មិនបរិសុទ្ធដោយបានប៉ះពាល់នឹងសាកសព
ឬប៉ះពាល់នឹងអ្នកដែលមានហូរទឹកកាមដោយសារកាមរោគ[5]ឬដោយប៉ះបាល់នឹងសត្វលូនវាដែលធ្វើឲ្យគាត់ទៅជាមិនបរិសុទ្ធ
ឬប៉ះជាមួយមនុស្សណាម្នាក់ដែលមិនបរិសុទ្ធដោយប្រការណាមួយ ដែលធ្វើឲ្យគាត់ទៅជាសៅហ្មង[6]បូជាចារ្យដែលបានប៉ះនឹងរបស់ដែលសៅហ្មង
គាត់នឹងទៅជាសៅហ្មងរហូតដល់ពេលល្ងាច។ គាត់គ្មានសិទ្ធិបរិភោគអាហារដ៏សក្ការៈបានទេ លុះត្រាតែយកទឹកមកធ្វើពិធីជម្រះកាយជាមុនសិន។
[7]នៅពេលថ្ងៃលេច គាត់នឹងបរិសុទ្ធវិញ។ បន្ទាប់ពីថ្ងៃលេចគាត់អាចបរិភោគអាហារពីតង្វាយដ៏សក្ការៈបាន ព្រោះនោះជាចំណែករបស់គាត់។
[8]បូជាចារ្យមិនត្រូវបរិភោគសាច់សត្វដែលងាប់ដោយសារជំងឺឬដោយសត្វព្រៃសម្លាប់ឡើយ ដើម្បីកុំឲ្យគេក្លាយទៅជាសៅហ្មង ដោយសារតែសត្វទាំងនោះ។
យើងគឺព្រះអម្ចាស់។[9]ពួកបូជាចារ្យត្រូវកាន់តាមច្បាប់របស់យើង បើមិនដូច្នេះទេ ពួកគេនឹងមានទោសដោយសារអំពើបាប
ហើយអាចនឹងត្រូវស្លាប់ដោយសារការបន្ថោកនាមរបស់យើង។ យើងគឺព្រះអម្ចាស់ ដែលបានញែកពួកគេជាបរិសុទ្ធ។
[10]ក្រៅពីមនុស្សដែលនៅក្នុងគ្រួសាររបស់បូជាចារ្យ មិនមាននរណាម្នាក់មានសិទ្ធិបរិភោគអាហារដ៏សក្ការៈទេ ទោះបីជាភ្ញៀវរបស់បូជាចារ្យ ឬ អ្នកបម្រើដែលបានជួលមកក្តី។
[11]ប៉ុន្តែប្រសិនបើ ជាទាសករដែលលោកបានទិញមកដោយលុយរបស់ផ្ទាល់ អ្នកបម្រើនោះអាចបរិភោគអ្វីៗដែលជារបស់ដ៏សក្ការៈនោះបាន។
សមាជិកក្នុងគ្រួសាររបស់បូជាចារ្យ និងអ្នកបម្រើដែលកើតក្នុងផ្ទះរបស់លោក ពួកគេមានសិទ្ធិបរិភោគពីអ្វីជាចំណែករបស់លោកពីតង្វាយដ៏សក្ការៈនោះ។
[12]ប្រសិនបើ កូនស្រីរបស់បូជាចារ្យ រៀបការនឹងបុរសមិនមែនជាបូជាចារ្យ ដូច្នេះ នាងមិនមានសិទ្ធិបរិភោគអាហារដ៏សក្ការៈទេ។[13]តែបើកូនស្រីរបស់លោកជាស្ត្រីមេម៉ាយ
ឬលែងលះតែមិនមានកូន ហើយនាងត្រឡប់មករស់នៅក្នុងផ្ទះរបស់ឪពុកនាងវិញដូចកាលនាងនៅក្មេង ដូច្នេះនាងអាចបរិភោគអាហាររបស់ឪពុកនាងបាន។ ប៉ុន្តែ
អ្នកដែលមិនមែនជាគ្រួសាររបស់បូជាចារ្យ មិនមានសិទ្ធិបរិភោគអាហាររបស់បូជាចារ្យបានទេ។
[14]ប្រសិនបើ បុរសណាម្នាក់បានបរិភោគអាហារសក្ការៈ ដោយមិនបានដឹងខ្លួន បន្ទាប់ពីគាត់បានដឹង គាត់ត្រូវយកអាហារមកសងបូជាចារ្យដោយគិតតាមតម្លៃអាហារនោះ
និងថែមមួយភាគប្រាំលើនោះ ហើយជូនទៅបូជាចារ្យ។[15]ជនជាតិអ៊ីស្រាអែលមិនត្រូវបន្ថោករបស់ដ៏សក្ការៈដែលពួកគេបានលើកឡើង ហើយថ្វាយព្រះអម្ចាស់ទេ
[16]ដែលបណ្តាលអោយពួកគេទទួលខុសត្រូវលើអំពើបាប ដែលធ្វើឲ្យពួកគេមានកំហុសដោយការបរិភោគអាហារដ៏វិសុទ្ធ គឺយើងជាព្រះអម្ចាស់
ដែលបានញែកពួកគេជាបរិសុទ្ធ»។
[17]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេដូចតទៅ៖[18]«ចូរនិយាយទៅអើរ៉ុន កូនចៅរបស់អើរ៉ុន ព្រមទាំងជនជាតិអ៊ីស្រាអែល។ ប្រាប់ពួកគេថា:
ក្នុងចំណោមជនជាតិអ៊ីស្រាអែល ឬជនបរទេសដែលរស់នៅក្នុងទឹកដីអ៊ីស្រាអែល ពេលដែលពួកគេថ្វាយតង្វាយ ទោះបីជាតង្វាយលាបំណន់ក្តី
ឬជាតង្វាយស្ម័គ្រពីចិត្តក្តី[19]ពួកគេត្រូវយកសត្វឈ្មោលដែលល្អឥតខ្ចោះពីហ្វូងគោក្របី ហ្វូងចៀម ឬហ្វូងពពែ។
[20]អ្នករាល់គ្នាមិនត្រូវថ្វាយសត្វណាដែលពិការឡើយ។ ដ្បិត យើងមិនពេញចិត្តនឹងទទួលយកវាពីអ្នករាល់គ្នាឡើយ។[21]ប្រសិនបើ
អ្នកណាចង់ថ្វាយយញ្ញបូជាមេត្រីភាពពីហ្វូងគោ ឬហ្វូងចៀម ដល់ព្រះអម្ចាស់ ដើម្បីលាបំណន់ ឬជាតង្វាយស្ម័គ្រពីចិត្ត
ត្រូវតែជាសត្វដែលល្អឥតខ្ចោះដែលសព្វព្រះទ័យព្រះអង្គ។ សត្វនោះមិនត្រូវមានភាពពិការឡើយ។
[22]អ្នករាល់គ្នាមិនត្រូវថ្វាយសត្វដែលខ្វាក់ ពិការ ឬរបួស ឬសត្វដែលមានអង្គែរស៊ី កើតរមាស់ ឬសត្វដែលមានកើតស្រែងឡើយ។
អ្នករាល់គ្នាមិនត្រូវដុតសត្វទាំងនោះនៅលើអាសនៈជាតង្វាយដុតថ្វាយដល់ព្រះអម្ចាស់ឡើយ។[23]អ្នករាល់គ្នាអាចយក គោឈ្មោល ឬកូនចៀមដែលមានជើងខ្លីពេក
ឬតូចពេកមកថ្វាយជាតង្វាយស្ម័គ្រពីចិត្ត តែបើថ្វាយជាតង្វាយលាបំណន់ តង្វាយទាំងនេះគឺមិនគាប់ព្រះទ័យព្រះអម្ចាស់ទេ។
[24]មិនត្រូវថ្វាយសត្វដែលមានស្នាមជាំ បាក់បែក ត្រូវគេកាត់ ឬត្រូវក្រៀវ មកថ្វាយបព្រះអម្ចាស់ឡើយ។ មិនត្រូវឲ្យមានការនេះកើតឡើងនៅក្នុងទឹកដីរបស់អ្នកជាដាច់ខាត។
[25]អ្នករាល់គ្នាមិនត្រូវទទួលអាហារទាំងនេះពីដៃជនបរទេសយកមកថ្វាយដល់ព្រះរបស់អ្នកឡើយ។ សត្វទាំងនោះជាសត្វមិនគ្រប់លក្ខណៈ មកពីគេគេក្រៀវ
នោះព្រះអង្គនឹងមិនព្រមទទួលពីអ្នករាល់គ្នាទេ»។
[26]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[27]«នៅពេលដែលសត្វកើតទោះបីជា គោ ចៀម ឬពពែក្តី វាត្រូវនៅជាមួយមេរបស់វាចំនួនប្រាំពីរថ្ងៃ។
ចាប់ពីថ្ងៃទីប្រាំបីទៅ វាអាចយកទៅថ្វាយជាតង្វាយដុតទាំងមូល ដែលសព្វព្រះហឫទ័យព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

[28]កុំសម្លាប់មេគោ ឬមេចៀម ក្នុងថ្ងៃតែមួយជាមួយកូនរបស់វាឡើយ។[29]ពេលដែលអ្នកថ្វាយតង្វាយអរព្រះគុណដល់ព្រះអម្ចាស់
អ្នកត្រូវថ្វាយតាមរបៀបដែលព្រះអង្គសព្វព្រះហឫទ័យ។[30]សាច់របស់សត្វនៃយញ្ញបូជានោះត្រូវបរិភោគក្នុងថ្ងៃដែលថ្វាយតង្វាយនោះ។
អ្នកមិនត្រូវទុកសាច់នៃតង្វាយឲ្យនៅរហូតដល់ថ្ងៃបន្ទាប់ឡើយ។ យើងគឺព្រះអម្ចាស់។
[31]ដូច្នេះ អ្នករាល់គ្នាត្រូវកាន់តាមច្បាប់ និងវិន័យរបស់យើង។ យើងគឺព្រះអម្ចាស់។[32]អ្នករាល់គ្នាមិនត្រូវបន្ថោកនាមដ៏វិសុទ្ធរបស់យើងឡើយ។
ត្រូវឲ្យជនជាតិអ៊ីស្រាអែលទទួលស្គាល់ ថាយើងជាព្រះដ៏វិសុទ្ធ។ យើងគឺព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
ដែលញែកអ្នករាល់គ្នាឲ្យបានបរិសុទ្ធ[33]ដែលបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីព្ទ: យើងគឺព្រះអម្ចាស់»។

Leviticus 22:1

ចូរប្រាប់ទៅអើរ៉ុន និងកូនរបស់គាត់ថា ពួកគេត្រូវរក្សារបស់ដ៏បរិសុទ្ធ

«ប្រាប់ពួកគេពេលណាពួកគេគួរតែឃ្លាតឆ្ងាយពីរបស់ដ៏បរិសុទ្ធ» ។
ព្រះអម្ចាស់ហៀបនឹងរៀបរាប់អំពីកាល:ទេស:ដែលបូជាចារ្យមិនបរិសុទ្ធហើយមិនត្រូវអនុញ្ញាតឱ្យ[illegible]ធ្វើបរិសុទ្ធោះឡើយ។

បន្ថោកនាមរបស់យើង

ពាក្យ «បន្ថោក» នៅទីនេះមានន័យថាបង្អាប់។ ពាក្យ «នាម»
តំណាងឱ្យព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត «បង្អាប់កេរ្តិ៍ឈ្មោះរបស់យើង» ឬ
«បង្អាប់កិត្តិយសយើង»

ក្នុងចំណោមពូជពង្សរបស់អ្នកគ្រប់ជំនាន់

«ចាប់ពីពេលនេះទៅ»

នៅពេលដែលគេមានភាពមិនបរិសុទ្ធ

មនុស្សដែលព្រះមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយដូចជាមនុស្សម្នាក់ដែលត្រូវ[illegible]
គេត្រូវបណ្តេញចេញពីមុខរបស់យើង: យើងគឺជាព្រះអម្ចាស់

បូជាចារ្យដែលមិនអាចបំរើព្រះអម្ចាស់បានត្រូវគេនិយាយដូចជាមនុស្សម្នាក់ដែលត្រូវបាន[illegible]
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បុគ្គលនោះនឹងលែងអាចធ្វើជាសង្ឃបានហើយ»

Leviticus 22:4

ជំងឺឃ្លង់

ជំងឺលើស្បែករាលដាលយ៉ាងងាយពីមនុស្សមាក់មនុស្សមាក់ទៀត

ជំងឺឃ្លង់នៅលើស្បែក

«ការឆក់រាងកាយ»

នៅលើស្បែក

នេះជាវិធីគួរសមក្នុងការសំដៅទៅលើផ្នែកឯកជនរបស់បុរស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ១៥: ១ ។
ការបកប្រែផ្សេងទៀត «ពីផ្នែកឯកជនរបស់គាត់»

រហូតដល់គេបានបរិសុទ្ធឡើងវិញ

មនុស្សដែលព្រះទទួលយកបានសម្រាប់គោលបំណងរបស់ព្រះ
ត្រូវបានគេនិយាយដូចជាមនុស្សនោះស្អាតស្អំខាងរូបកាយ។

អ្នកដែលប៉ះពាល់នឹងរបស់មិនបរិសុទ្ធ

អ្វីដែលព្រះអម្ចាស់មានបន្ទូលគឺមិនសមនឹងប៉ះ ឬបរិភោគគឺមិនស្អាតខាងរូបកាយ។

ដោយបានប៉ះពាល់នឹងសាកសព

«ដោយការប៉ះសាកសព»

អាហារដ៏វិសុទ្ធដែលថ្វាយដល់ព្រះអម្ចាស់

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«តង្វាយដែលមាននរណាម្នាក់បានថ្វាយដល់ព្រះអម្ចាស់»

ឬដោយប៉ះបាល់នឹងសត្វលូនវាដែលធ្វើឲ្យគាត់ទៅជាមិនបរិសុទ្ធ

នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«ឬអ្នកណាដែលមិនស្អាតពីការប៉ះសត្វលូន
ឬពីការប៉ះមនុស្សមិនបរិសុទ្ធម្នាក់ទៀត»

បូជាចារ្យ...នឹងទៅជាសៅហ្មង

មនុស្សដែលព្រះមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះ
ត្រូវបានគេនិយាយដូចជាមនុស្សនោះមិនស្អាតស្អំខាងរាងកាយ។

រហូតដល់ពេលល្ងាច

«រហូតដល់ថ្ងៃលិច»

Leviticus 22:7

គាត់នឹងបរិសុទ្ធវិញ

ពេលនោះបូជាចារ្យនឹងបានស្អាតបរិសុទ្ធ។
មនុស្សដែលព្រះទទួលយកបានសម្រាប់គោលបំណងរបស់ព្រះត្រូវបានគេនិយាយដូច[illegible]

សាច់សត្វដែលងាប់ដោយសារជំងឺឬដោយសត្វព្រៃសម្លាប់ឡើយ

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មាននរណាម្នាក់បានរកឃើញថាបានស្លាប់ ឬសត្វព្រៃមួយបានសម្លាប់»

Leviticus 22:10

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលលោកអើរ៉ុននិងកូនៗ ត្រូវធ្វើ។
[illegible]ធ្វើបរិសុទ្ធោះឡើយ។

អាហារដ៏សក្ការៈ

ពាក្យថា «ការបរិច្ចាគ» អាចត្រូវបានបកប្រែដោយពាក្យសំដី។
ការបកប្រែផ្សេងទៀត «តង្វាយបរិសុទ្ធដែលមនុស្សបានចូលរួម»

Leviticus 22:14

គាត់ត្រូវយកអាហារមកសងបូជាចារ្យដោយគិតតាមតម្លៃអាហារនោះ និងថែមមួយភាគប្រាំលើនោះ

ភាគប្រាំលើនោះ - អត្ថន័យដែលអាចមានគឺ ១)

មនុស្សនោះត្រូវជំនួសអាហារដែលខ្លួនបានបរិភោគជាមួយអាហារដដែលឬ ២)
[illegible]អាហារដែលខ្លួនបានបរិភោគ។

ភាគប្រាំលើនោះ

[illegible]ដែលកាត់ក្រណាត់ឬកាត់មែកឈើ។

មិនត្រូវបន្ថោកបរបស់ដ៏សក្ការៈ

នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ត្រូវតែគោរពអ្វីៗដែលបរិសុទ្ធ»

ដែលពួកគេបានលើកឡើង ហើយថ្វាយ

ឃ្លាដែលបាន «លើកឡើងខ្ពស់»

សំដៅទៅលើកាយវិការនៃការគោរពដែលតំណាងឱ្យការថ្វាយអ្វីមួយដល់ព្រះអម្ចាស់។

វាមានន័យថាជាមូលដ្ឋានដូចគ្នានឹង «ការថ្វាយ» ។ ការបកប្រែផ្សេងទៀត
«ដែលពួកគេបានថ្វាយជូន»

ដែលបណ្តាលអោយពួកគេទទួលខុសត្រូវលើអំពើបាប ដែលធ្វើឲ្យពួកគេមានកំហុស

អំពើបាបត្រូវបានគេនិយាយដូចជាវត្ថុដែលមនុស្សអាចកាន់បាន។
អត្ថន័យដែលអាចមានគឺ ១)
ពួកគេនឹងទទួលខុសត្រូវចំពោះអំពើបាបហើយដូច្នេះគេមានទោស។
ការបកប្រែផ្សេងទៀត
«ពួកគេនឹងមានកំហុសចំពោះអំពើបាបដែលពួកគេបានប្រព្រឹត្ត» ឬ ២) ពាក្យ
«បាប» គឺជាឈ្មោះប្រើសំរាប់ដាក់ទណ្ឌកម្មចំពោះអំពើបាបដែលពួកគេបានធ្វើ។
ការបកប្រែផ្សេងទៀត «ពួកគេនឹងទទួលទណ្ឌកម្មពីព្រោះពួកគេមានពិរុទ្ធ»

Leviticus 22:17

ជនបរទេស

«ជនបរទេស»

ប្រសិនបើវាត្រូវបានទទួលយក

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រសិនបើព្រះអម្ចាស់ព្រមទទួលយកវា» ឬ «ប្រសិនបើយើង
ព្រះអម្ចាស់នឹងទទួលយកវា»

Leviticus 22:20

សព្វព្រះទ័យព្រះអង្គ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីឱ្យយើងទទួលយកវា» ឬ «សម្រាប់ឲ្យព្រះអម្ចាស់ដើម្បីទទួលយកវា»

Leviticus 22:22

ពិការ ឬរបួស

ពាក្យទាំងនេះសំដៅទៅលើពិការភាពដែលបណ្តាលមកពីគ្រោះថ្នាក់។

អង្គែរស៊ី កើតរមាស់ ឬសត្វដែលមានកើតស្រែងឡើយ

ទាំងនេះសំដៅទៅលើប្រភេទជំងឺស្បែក។

គឺមិនគាប់ព្រះទ័យព្រះអម្ចាស់ទេ

[illegible]ធ្វើបរិសុទ្ធោះឡើយ។ ការបកប្រែផ្សេងទៀត
«យើងនឹងមិនទទួលយក» ឬ «ព្រះអម្ចាស់នឹងមិនទទួលយក»

ជើងខ្លីពេក ឬតូចពេក

ពាក្យទាំងនេះសំដៅទៅលើពិការភាពដែលសត្វមានតាំងពីកំណើត។

generated on Wed Sep 10 16:16:32 2025

Leviticus 22:24
មិនត្រូវទទួលអាហារទាំងនេះពីដៃជនបរទេសយកមកថ្វាយដល់ព្រះរបស់អ្នកឡើយ
នៅទីនេះ «នំបុ័ង» តំណាងឱ្យម្ហូបជាទូទៅ។
តាមពិតព្រះជាម្ចាស់មិនបានសោយយញ្ញបូជាទេ។
បូជាចារ្យនឹងថ្វាយយញ្ញបូជានៅលើអាសនៈរបស់ព្រះជាម្ចាស់ហើយពួកគេនឹងបរិភោគសាច់ផង
ការបកប្រែផ្សេងទៀត «មិនត្រូវយកសត្វមកធ្វើជាតង្វាយថ្វាយព្រះរបស់អ្នកឡើយ»
ពីដៃជនបរទេស
ពាក្យថា «ដៃ» តំណាងឱ្យមនុស្សទាំងមូល។
វាបញ្ជាក់ថាជនជាតិអ៊ីស្រាអែលមិនអាចប្រើសត្វជាយញ្ញបូជាដល់ព្រះបានទេ
ប្រសិនបើពួកគេទិញវាពីជនបរទេសពីព្រោះជនបរទេសបានដេញសត្វរបស់ពួកគេធ្វើឱ្យ[illegible]
ការបកប្រែផ្សេងទៀត «ជនបរទេសម្នាក់បានអោយសត្វអ្នក»
នោះព្រះអង្គនឹងមិនព្រមទទួលពីអ្នករាល់គ្នាទេ
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងមិនទទួលយកពួកគេពីអ្នកទេ»
Leviticus 22:26
ដែលសព្វព្រះហឫទ័យព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកអាចទទួលយកវា»
តង្វាយដុតទាំងមូល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«សម្រាប់តង្វាយដុត»
Leviticus 22:28
សាច់របស់សត្វនៃយញ្ញបូជានោះត្រូវបរិភោគ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែបរិភោគវា»
សាច់របស់សត្វនៃយញ្ញបូជា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលអ្នកបានថ្វាយ»
Leviticus 22:31
[illegible]
ពាក្យថា «កាន់តាម» និង «អនុវត្ត» មានន័យដូចគ្នា។
ពួកគេសង្កត់ធ្ងន់ថាប្រជាជនត្រូវតែគោរពតាមបទបញ្ជារបស់ព្រះ។
ការបកប្រែផ្សេងទៀត «គោរពតាមបញ្ញត្តិរបស់យើង»
អ្នករាល់គ្នាមិនត្រូវបន្ថោកនាមដ៏វិសុទ្ធរបស់យើងឡើយ
ត្រង់នេះពាក្យ «នាម» តំណាងអោយព្រះអម្ចាស់ផ្ទាល់និងកេរ្តិ៍ឈ្មោះរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវបង្អាប់កិត្តិយសយើង» ឬ
«អ្នកមិនត្រូវបង្អាប់កេរ្តិ៍ឈ្មោះបរិសុទ្ធរបស់យើងឡើយ»
ត្រូវឲ្យជនជាតិអ៊ីស្រាអែលទទួលស្គាល់ ថាយើងជាព្រះដ៏វិសុទ្ធ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងតៀត
«ប្រជាជនអ៊ីស្រាអែលត្រូវតែទទួលស្គាល់យើងថាជាព្រះដ៏វិសុទ្ធ»

---

23 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[2]«ចូរនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ប្រាប់ពួកគេថា: ពិធីបុណ្យសំខាន់ៗដែលត្រូវជួបជុំសម្រាប់ព្រះអម្ចាស់
ដែលអ្នកត្រូវប្រកាសឲ្យសហគមន៍ទាំងមូលបានបរិសុទ្ធ ទាំងនោះគឺជាពិធីបុណ្យដែលមិនផ្លាស់ប្តូររបស់យើង។
[3]អ្នករាល់គ្នាអាចធ្វើការប្រាំមួយថ្ងៃ ប៉ុន្តែនៅថ្ងៃទីប្រាំពីរជាថ្ងៃសប្ប័ទ ជាថ្ងៃសម្រាប់ សម្រាប់សហគមន៍ទាំងមូល។ អ្នករាល់គ្នាមិនត្រូវធ្វើការអ្វីឡើយ
ព្រោះនោះជាថ្ងៃសប្ប័ទសម្រាប់ព្រះអម្ចាស់នៅគ្រប់ទីកន្លែងទាំងអស់ដែលអ្នករាល់គ្នារស់នៅ។
[4]ពិធីបុណ្យដ៏សំខាន់ៗរបស់ព្រះអម្ចាស់ ដែលសហគមន៍ដ៏បរិសុទ្ធត្រូវកំណត់ពេលជួបជុំគ្នា:[5]នៅខែទីមួយ ថ្ងៃទីដប់បួននៃខែ ក្រោយពេលថ្ងៃលេច ជាបុណ្យចម្លង
ថ្វាយព្រះអម្ចាស់។[6]នៅថ្ងៃទីដប់ប្រាំ ក្នុងខែដដែល គឺជាពិធីបុណ្យនំបុ័ងឥតមេ ថ្វាយព្រះអម្ចាស់។ អ្នករាល់គ្នាត្រូវបរិភោគនំបុ័ងឥតមេរយៈពេលប្រាំពីរថ្ងៃ។
[7]នៅថ្ងៃទីមួយ ត្រូវជួបជុំគ្នាថ្វាយបង្គំព្រះអម្ចាស់ អ្នកមិនត្រូវធ្វើការអ្វីនោះថ្ងៃនោះឡើយ។[8]អ្នករាល់គ្នាត្រូវយកតង្វាយដុតថ្វាយព្រះអម្ចាស់រយៈពេលប្រាំពីរថ្ងៃ។ នៅថ្ងៃទីប្រាំពីរ
សហគមន៍ទាំងមូលត្រូវជួបជុំគ្នាថ្វាយបង្គំព្រះអម្ចាស់ ហើយក្នុងថ្ងៃនោះអ្នករាល់គ្នាមិនត្រូវធ្វើការអ្វីនឿយហត់ឡើយ»។
[9]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[10]«ចូរនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ហើយប្រាប់គេថា:
ពេលដែលអ្នករាល់គ្នាចូលទៅក្នុងទឹកដីដែលយើងនឹងប្រគល់ឲ្យអ្នករាល់គ្នា ហើយនៅពេលដែលអ្នករាល់គ្នាច្រូតស្រូវ
អ្នករាល់គ្នាត្រូវនាំយកកណ្តាប់ទីមួយទៅជូនបូជាចារ្យ។[11]គាត់នឹងលើកកណ្តាប់នោះនៅចំពោះព្រះអម្ចាស់ ហើយថ្វាយដល់ទ្រង់
ដើម្បីឲ្យព្រះអង្គសព្វព្រះហឫទ័យទទួលយកតង្វាយពីអ្នករាល់គ្នា។ នៅថ្ងៃបន្ទាប់ពីថ្ងៃសប្ប័ទ បូជាចារ្យត្រូវលើកកណ្តាប់ស្រូវថ្វាយដល់យើង។
[12]នៅថ្ងៃដែលអ្នករាល់គ្នាលើកកណ្តាប់ស្រូវថ្វាយដល់យើង អ្នកត្រូវថ្វាយចៀមឈ្មោលអាយុមួយឆ្នាំដែលល្អឥតខ្ចោះ ជាតង្វាយដុតទាំងមូលថ្វាយព្រះអម្ចាស់។[13]តង្វាយម្សៅ
ត្រូវយកម្សៅម៉ដ្តពីរភាគដប់នៃអេផា លាយជាមួយប្រេង មកថ្វាយជាមួយតង្វាយដុតនោះ ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យដល់ព្រះអម្ចាស់
ចូរយកស្រាទំពាំងបាយជូរមួយភាគបួននៃហ៊ីន។[14]អ្នករាល់គ្នាមិនអាចបរិភោគនំបុ័ង លាជ ឬស្រូវថ្មីបានទេ
រហូតដល់ពេលដែលអ្នករាល់គ្នានាំយកតង្វាយមកថ្វាយព្រះរបស់អ្នក។ នេះជាច្បាប់ដែលត្រូវអនុវត្តរហូតតទៅគ្រប់ជំនាន់មនុស្សទាំងអស់
នៅគ្រប់ទីកន្លែងដែលអ្នករស់នៅ។
[15]រាប់ចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃសប្ប័ទ ដែលអ្នកបាននាំយកកណ្តាប់ស្រូវថ្វាយព្រះអម្ចាស់ ត្រូវកំណត់ពេលពេញប្រាំពីរអាទិត្យ។[16]អ្នកត្រូវរាប់គិតហាសិបថ្ងៃ
រហូតដល់ថ្ងៃបន្ទាប់ដល់ថ្ងៃបន្ទាប់ពីថ្ងៃសប្ប័ទទីប្រាំពីរ។ ថ្ងៃនោះត្រូវយកតង្វាយពីស្រូវថ្មីមកថ្វាយព្រះអម្ចាស់។
[17]អ្នករាល់គ្នាត្រូវយកនំបុ័ងពីរពីផ្ទះរបស់អ្នករាល់គ្នា ដែលធ្វើពីម្សៅម៉ដ្តចំនួនពីរភាគដប់នៃអេផា។ នំបុ័ងនោះត្រូវធ្វើពីម្សៅម៉ដ្តដុតជាមួយមេនំបុ័ង
នោះជាតង្វាយនំបុ័ងដំបូងបង្អស់ដែលអ្នករាល់គ្នានឹងត្រូវថ្វាយព្រះអម្ចាស់។[18]អ្នករាល់គ្នាត្រូវថ្វាយនំបុ័ង ជាមួយនឹងចៀមអាយុមួយឆ្នាំល្អឥតខ្ចោះ ចំនួនប្រាំពីរ គោស្ទាវមួយ
និងចៀមឈ្មោលពីរ។ នោះជាតង្វាយដុតទាំងមូលថ្វាយព្រះអម្ចាស់ ជាមួយតង្វាយម្សៅ ព្រមទាំងស្រាទំពាំងបាយជូរ នេះជាតង្វាយដុត
ដែលមានក្លិនឈ្ងុយជាទីគាប់ព្រះទ័យព្រះអម្ចាស់។
[19]អ្នករាល់គ្នាត្រូវថ្វាយពពែឈ្មោលមួយសម្រាប់យញ្ញបូជាលោះបាប និងចៀមឈ្មោលពីរអាយុមួយឆ្នាំជាតង្វាយនៃយញ្ញបូជាមេត្រីភាព។[20]បូជាចារ្យត្រូវថ្វាយសត្វទាំងនេះ
ព្រមទាំងនំបុ័ងដែលជាផលដំបូងថ្វាយព្រះអម្ចាស់ រួមជាមួយកូនចៀមពីរ។ ទាំងនោះគឺជាតង្វាយដ៏សក្ការៈថ្វាយដល់ព្រះអម្ចាស់ ហើយប្រគល់ជូនបូជាចារ្យ។
[21]អ្នករាល់គ្នាត្រូវធ្វើការប្រកាសនៅក្នុងថ្ងៃនោះ។ សហគមន៍ទាំងមូលត្រូវបរិសុទ្ធ ហើយអ្នករាល់គ្នាមិនត្រូវធ្វើការអ្វីនៅក្នុងថ្ងៃនោះឡើយ។
នេះជាច្បាប់ដែលអ្នករាល់គ្នាត្រូវអនុវត្តរហូតតទៅ នៅគ្រប់ជំនាន់និងគ្រប់ទីកន្លែងដែលអ្នករាល់គ្នារស់នៅ។
[22]ពេលដែលអ្នករាល់គ្នាច្រូតស្រូវពីស្រែរបស់អ្នក អ្នករាល់គ្នាមិនត្រូវច្រូតដល់ភ្លឺស្រែទេ ហើយក៏មិនត្រូវរើសគួរស្រូវដែលជ្រុះនោះដែរ។ អ្នករាល់គ្នាត្រូវទុកឲ្យអ្នកក្រទុគ៌ត
និងជនបរទេសដែលរស់ក្នុងចំណោមអ្នករើសបរិភោគ។ យើងគឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា»។
[23]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[24]«ចូរនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ហើយប្រាប់ពួកគេថា: នៅខែទីប្រាំពីរ ក្នុងថ្ងៃទីមួយនៃខែ
គឺជាថ្ងៃសម្រាកសម្រាប់អ្នករាល់គ្នា ត្រូវធ្វើពិធីបុណ្យរំឭកជាមួយនឹងការផ្លុំត្រែ ហើយនិងការជួបជុំថ្វាយបង្គំព្រះអម្ចាស់។[25]អ្នករាល់គ្នាមិនត្រូវធ្វើការអ្វីឡើយនៅថ្ងៃនោះ
ហើយត្រូវថ្វាយតង្វាយដុតដល់ព្រះអម្ចាស់»។
[26]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលម្តងទៀតមកលោកម៉ូសេថា៖[27]«ឥឡូវនៅថ្ងៃទីដប់នៃខែទីប្រាំពីរ គឺជាថ្ងៃបុណ្យរំដោះបាប។ គឺត្រូវជួបជុំគ្នាថ្វាយបង្គំព្រះអម្ចាស់
ហើយអ្នករាល់គ្នាត្រូវតមអាហារ និងថ្វាយតង្វាយដុតទាំងមូលថ្វាយព្រះអម្ចាស់។
[28]អ្នករាល់គ្នាមិនត្រូវធ្វើកិច្ចការអ្វីឡើយនៅថ្ងៃនោះ ព្រោះជាថ្ងៃបុណ្យរំដោះបាប ដែលអ្នករាល់គ្នាត្រូវធ្វើពិធីជម្រះបាបនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[29]ប្រសិនបើ មានអ្នកណាម្នាក់មិនតមអាហារនៅថ្ងៃនោះទេ ត្រូវកាត់គេចេញពីចំណោមប្រជាជាតិរបស់គេ។

generated on Wed Sep 10 16:16:32 2025

[30]ប្រសិនបើ មាននរណាម្នាក់ធ្វើការអ្វីមួយនៅថ្ងៃនោះ យើង ព្រះអម្ចាស់នឹងបំផ្លាញអ្នកនោះនៅក្នុងចំណោមប្រជាជាតិរបស់គេ។[31]មិនត្រូវធ្វើការអ្វីមួយឡើយក្នុងថ្ងៃនោះ។
នេះគឺជាច្បាប់ដែលអ្នករាល់គ្នាត្រូវកាន់គ្រប់ជំនាន់ និងនៅគ្រប់ទីកន្លែងដែលអ្នករាល់គ្នារស់នៅ។[32]ថ្ងៃនេះគឺជាថ្ងៃសម្រាករបស់អ្នករាល់គ្នា ដូចជាថ្ងៃសប្ប័ទដែរ
ហើយត្រូវតមអាហារ នៅថ្ងៃទីប្រាំបួននៅក្នុងខែនោះនៅពេលល្ងាច។ ចាប់ពីពេលល្ងាចនោះ រហូតដល់ល្ងាចវិញ អ្នករាល់គ្នាត្រូវសម្រាក ដូចថ្ងៃសប្ប័ទដែរ»។
[33]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[34]«ចូរនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ប្រាប់គេថា: ក្នុងថ្ងៃទីដប់ប្រាំ ក្នុងខែទីប្រាំពីរ គឺជាថ្ងៃនៃពិធីបុណ្យបារាំ
សម្រាប់តម្កើងព្រះអម្ចាស់។ វានឹងត្រូវជា ប្រាំពីរថ្ងៃចុងក្រោយ។
[35]នៅថ្ងៃទីមួយត្រូវជួបជុំគ្នាថ្វាយបង្គំព្រះអម្ចាស់ អ្នករាល់គ្នាមិនត្រូវធ្វើការអ្វីមួយដែលនាំឲ្យហត់នឿយឡើយ។[36]ជារៀងរាល់ថ្ងៃគ្រប់ប្រាំពីរថ្ងៃនេះ
អ្នករាល់គ្នាត្រូវថ្វាយតង្វាយដុតទាំងមូលដល់ព្រះអម្ចាស់។ នៅថ្ងៃទីប្រាំបីត្រូវជួបជុំគ្នាថ្វាយបង្គំព្រះអម្ចាស់ ហើយត្រូវថ្វាយតង្វាយដុតដល់ព្រះអង្គ។
នេះគឺជាថ្ងៃបញ្ចប់នៃពិធីបុណ្យ អ្នករាល់គ្នាមិនត្រូវធ្វើការអ្វីឡើយ។
[37]ទាំងនេះគឺជាការកំណត់ថ្ងៃបុណ្យរបស់សម្រាប់ព្រះអម្ចាស់ ដែលអ្នករាល់គ្នាត្រូវថ្វាយបង្គំព្រះអង្គ ត្រូវធ្វើពិធីថ្វាយតង្វាយដុតដល់ទ្រង់ គឺតង្វាយដុតទាំងមូល
រួមនឹងតង្វាយម្សៅ ព្រមទាំងស្រាទំពាំងបាយជូរ សម្រាប់ថ្ងៃនីមួយៗ។[38]ក្រៅពីពិធីបុណ្យទាំងនេះ អ្នករាល់គ្នាត្រូវកាន់ថ្ងៃសប្ប័ទរបស់ព្រះអម្ចាស់
ហើយថ្វាយតង្វាយរបស់អ្នករាល់គ្នាសម្រាប់ពិធីបុណ្យទាំងនេះ មានតង្វាយលាបំណន់ និងតង្វាយស្ម័គ្រពីចិត្ត ថ្វាយដល់ព្រះអម្ចាស់។
[39]នៅពេលដែលអ្នកប្រមូលភោគផលចប់សព្វគ្រប់ហើយ នៅថ្ងៃទីដប់ប្រាំ ក្នុងខែទីប្រាំពីរ ត្រូវប្រារព្ធពិធីបុណ្យបារាំ ដែលអ្នករាល់គ្នាត្រូវប្រារព្ធពិធីបុណ្យនេះនៅថ្ងៃទីប្រាំពីរ។
អ្នករាល់គ្នាត្រូវឈប់សម្រាកនៅថ្ងៃទីមួយ ហើយនិងថ្ងៃទីប្រាំបីក៏ជាថ្ងៃឈប់សម្រាកសម្រាប់អ្នករាល់គ្នាដែរ។
[40]នៅថ្ងៃទីមួយអ្នករាល់គ្នាត្រូវយកផ្លែឈើដែលល្អបំផុតពីដើមឈើដែលបែកមែកសាខា ធាងចាក និងមែកដ៏ត្រសុំត្រសាយ ព្រមទាំងស្លឹកត្រែងដែលដុះនៅតាមមាត់ទឹក
មកធ្វើពិធីបុណ្យយ៉ាងសប្បាយរយៈពេលប្រាំពីរថ្ងៃចំពោះព្រះអម្ចាស់ជាព្រះរបស់អ្នក។[41]ជារៀងរាល់ឆ្នាំ អ្នករាល់គ្នាត្រូវប្រារព្ធពិធីបុណ្យនេះរយៈពេលប្រាំពីរថ្ងៃ
ថ្វាយព្រះអម្ចាស់។ នេះជាច្បាស់ដែលអ្នករាល់គ្នាត្រូវប្រតិបត្តិគ្រប់ជំនាន់ និងគ្រប់ទីកន្លែងដែលអ្នករាល់គ្នារស់នៅ។ អ្នករាល់គ្នាត្រូវប្រារព្ធពិធីបុណ្យនេះ នៅខែទីប្រាំពីរ។
[42]អ្នករាល់គ្នាត្រូវរស់នៅក្នុងបារាំរយៈពេលប្រាំពីរថ្ងៃ។
ជនជាតិអ៊ីស្រាអែលទាំងអស់ត្រូវរស់នៅក្នុងបារាំរយៈពេលប្រាំពីរថ្ងៃ[43]នោះកូនចៅរបស់អ្នករាល់គ្នាពីមួយជំនាន់ទៅមួយជំនាន់
នឹងអាចរៀនបានពីរបៀបដែលយើងបានឲ្យរាស្ត្រអ៊ីស្រាអែលរស់នៅក្នុងបារាំ នៅពេលដែលយើងនាំពួកគេចេញពីស្រុកអេស៊ីព្ទមក។
យើងគឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។»[44]លោកម៉ូសេបានរៀបរាប់ប្រាប់ជនជាតិអ៊ីស្រាអែលអំពីរបៀបធ្វើពិធីបុណ្យសំខាន់ៗសម្រាប់សសើរតម្កើងព្រះអម្ចាស់។

Leviticus 23:1

ពិធីបុណ្យសំខាន់ៗដែលត្រូវជួបជុំសម្រាប់ព្រះអម្ចាស់

ទាំងនេះជាពិធីបុណ្យដែលព្រះអម្ចាស់បានកំណត់ពេល។
ប្រជាជនត្រូវគោរពបូជាព្រះអង្គក្នុងពិធីបុណ្យទាំងនេះ។ ការបកប្រែផ្សេងទៀត
«ពិធីបុណ្យសំរាប់ព្រះអម្ចាស់» ឬ «ពិធីបុណ្យរបស់ព្រះអម្ចាស់»

Leviticus 23:3

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ នូវអ្វីដែលប្រជាជនត្រូវធ្វើនៅថ្ងៃនិងម៉ោងពិសេស។

នៅថ្ងៃទីប្រាំពីរជាថ្ងៃសប្ប័ទ ជាថ្ងៃសម្រាប់

នេះជាអ្វីដែលប្រជាជនត្រូវធ្វើជាទំលាប់។
បន្ទាប់ពីរៀងរាល់ប្រាំមួយថ្ងៃដែលពួកគេអាចធ្វើការបានពួកគេត្រូវសម្រាកនៅថ្ងៃទីប្រាំពីរ។

សម្រាប់សហគមន៍ទាំងមូល

តម្រូវការដែលមនុស្សប្រជុំគ្នាដើម្បីថ្វាយបង្គំព្រះនៅថ្ងៃនោះគឺដូចជាថ្ងៃនោះជាប្រជុំគ្នា។
ការបកប្រែផ្សេងតៀត
«ជាថ្ងៃដ៏បរិសុទ្ធនៅពេលអ្នកត្រូវប្រមូលផ្តុំគ្នាដើម្បីថ្វាយបង្គំយើង»

Leviticus 23:4

ត្រូវកំណត់ពេលជួបជុំគ្នា

«នៅពេលត្រឹមត្រូវ»

នៅខែទីមួយ ថ្ងៃទីដប់បួននៃខែ ក្រោយពេលថ្ងៃលិច

ខែទីមួយនៃប្រក្រតិទិនភាសាហេប្រឺគឺជាពេលដែលព្រះអម្ចាស់បាននាំជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីប។
ថ្ងៃទីដប់បួននិងថ្ងៃទីដប់ប្រាំគឺនៅជុំវិញដើមខែមេសានៅលើប្រតិទិនលោកខាងលិច។

ក្រោយពេលថ្ងៃលិច

«ពេលថ្ងៃលិច»

Leviticus 23:7

នៅថ្ងៃទីមួយ ត្រូវជួបជុំគ្នាថ្វាយបង្គំព្រះអម្ចាស់

«អ្នកត្រូវតែញែកថ្ងៃដំបូងដើម្បីជួបជុំគ្នា» ឬ
«អ្នកត្រូវចាត់ទុកថ្ងៃដំបូងថាខុសគ្នាហើយជួបជុំគ្នា»

ត្រូវយកតង្វាយដុតថ្វាយ

គេនឹងយកវាទៅថ្វាយព្រះអម្ចាស់ដោយដុតនៅលើអាសនៈ។

នៅថ្ងៃទីប្រាំពីរ សហគមន៍ទាំងមូលត្រូវជួបជុំគ្នាថ្វាយបង្គំព្រះអម្ចាស់

តម្រូវឲ្យមនុស្សប្រជុំនៅថ្ងៃនោះត្រូវបានគេនិយាយដូចជាថ្ងៃនោះជាការប្រជុំ។
ការញែកចេញពីព្រះអម្ចាស់មានន័យថានៅពេលដែលពួកគេជួបជុំពួកគេត្រូវថ្វាយបង្គំព្រះអម្ចាស់

ការបកប្រែផ្សេងទៀត «ថ្ងៃទី ៧
គឺជាថ្ងៃដែលអ្នកត្រូវប្រមូលផ្តុំគ្នាដើម្បីថ្វាយបង្គំព្រះជាម្ចាស់»

Leviticus 23:9

កណ្តាប់ទីមួយ

«គ្រាប់ដំបូង» ឬ «គ្រាប់ដំបូងរបស់ស្រូវ»
គឺជាគ្រាប់ធញ្ញជាតិមួយដែលមនុស្សម្នាក់បានចងភ្ជាប់គ្នា។

ដើម្បីឲ្យព្រះអង្គសព្វព្រះហឫទ័យ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ដើម្បី ឲ្យ
ព្រះអម្ចាស់ទទួលយកវា» ឬ «ហើយយើងនឹងទទួលយកវា»

Leviticus 23:12

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។

ពីរភាគដប់នៃអេផា

អេផាគឺ ២២ លីត្រ។ ការបកប្រែផ្សេងទៀត «បួនលីត្រកន្លះ»

មួយភាគបួននៃហ៊ីន

ហ៊ីនគឺ ៣.៧ លីត្រ។ ការបកប្រែផ្សេងទៀត «មួយលីត្រ»

លាជ ឬស្រូវថ្មីបានទេ

«ក៏មិនមែនជាគ្រាប់ធញ្ញជាតិឆ្អិន ឬគ្មានជាតិខ្លាញ់»

នេះជាច្បាប់ដែលត្រូវអនុវត្តរហូតតទៅគ្រប់ជំនាន់មនុស្សទាំងអស់

នេះមានន័យថាពួកគេនិងកូនចៅរបស់ពួកគេត្រូវតែគោរពតាមបញ្ជានេះជារៀងរហូត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៣:១៥ ។

Leviticus 23:15

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។

ចេញពីស្រុកអេស៊ីប។

«៥០ ថ្ងៃ»

ទីប្រាំពីរ

នេះជាលំដាប់នៃលេខ ៧ ។ មើល

Leviticus 23:17

ព័ត៌មានទូទៅ

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។

ធ្វើពីម្សៅម៉ដ្តចំនួនពីរភាគដប់នៃអេផា នំប៉័ងនោះត្រូវធ្វើពីម្សៅម៉ដ្តដុតជាមួយមេនំប៉័ង

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកបានធ្វើពីម្សៅមួយភាគដប់នៃអេផាមួយនៃម្សៅហើយបន្ទាប់មកដុតនំជាមួយដំបែ"

ពីរភាគដប់នៃអេផា

នេះគឺប្រហែល 4,5 លីត្រ។ ការបកប្រែផ្សេងទៀត «បួនលីត្រកន្លះ»

ជាតង្វាយឈូសជាទីគាប់ព្រះទ័យព្រះអម្ចាស់

ព្រះអម្ចាស់គាប់ព្រះទ័យជាមួយនឹងក្លិនក្រអូបតំណាងឱ្យសេចក្តីរីករាយរបស់ព្រះអង្គជាមួយអ្នកដែលដុតត
ការបកប្រែផ្សេងទៀត «ហើយព្រះអម្ចាស់នឹងគាប់ព្រះហឫទ័យនឹងអ្នក» ឬ
«ដែលគាប់ព្រះហឫទ័យព្រះអម្ចាស់»

Leviticus 23:19

ព័ត៌មានទូទៅ

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
Leviticus 23:22
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
ពេលដែលអ្នករាល់គ្នាច្រូតស្រូវពីស្រែរបស់អ្នក អ្នករាល់គ្នាមិនត្រូវច្រូតដល់ភ្លឺស្រែទេ
«នៅពេលដែលអ្នកប្រមូលផលដំណាំរបស់អ្នកកុំប្រមូលផលទាំងអស់
រហូតដល់គែមនៃចំការរបស់អ្នកឡើយ»
Leviticus 23:23
នៅខែទីប្រាំពីរ ក្នុងថ្ងៃទីមួយនៃខែ
នេះជាខែទីប្រាំពីរនៃប្រតិទិនហេព្រើរ។
ថ្ងៃដំបូងគឺជិតពាក់កណ្តាលខែកញ្ញាតាមប្រតិទិនលោកខាងលិច។
គឺជាថ្ងៃសម្រាកសម្រាប់អ្នករាល់គ្នា
រយៈពេលមួយដែលមានតែសម្រាប់ការថ្វាយបង្គំ និងមិនមែនសម្រាប់ការងារទេ
ហើយត្រូវថ្វាយតង្វាយដុតដល់ព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែថ្វាយយញ្ញបូជាដែលអ្នកថ្វាយដល់ព្រះអម្ចាស់» ឬ
«អ្នកត្រូវដុតតង្វាយនៅលើអាសនៈថ្វាយព្រះអម្ចាស់»
Leviticus 23:26
នៅថ្ងៃទីដប់នៃខែទីប្រាំពីរ
នេះជាខែទីប្រាំពីរនៃប្រតិទិនហេព្រើរ។ ថ្ងៃទី ១០
ជិតដល់ចុងខែកញ្ញាលើប្រតិទិនលោកខាងលិច។
គឺជាថ្ងៃបុណ្យរំដោះបាប
នៅថ្ងៃនេះក្នុងមួយឆ្នាំ ៗ
លោកមហាបូជាចារ្យបានធ្វើពិធីថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ដើម្បីឲ្យព្រះអម្ចាស់
អត់ទោសដល់អំពើបាបទាំងអស់របស់ជនជាតិអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ថ្ងៃនៃការថ្វាយតង្វាយដើម្បីការអត់ទោសបាប»
Leviticus 23:28
ឃ្លាភ្ជាប់
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើរៀងរាល់ឆ្នាំ។
ត្រូវកាត់គេចេញពីចំណោមប្រជាជាតិរបស់គេ
ការដកចេញត្រូវបានគេនិយាយថាត្រូវបានកាត់ផ្តាច់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែគំនិតនេះនៅក្នុងជំពូ ៧:១៩ ។
ការបកប្រែផ្សេងទៀត «ត្រូវតែដកចេញពីប្រជាជនរបស់គេ» ឬ
«អ្នកត្រូវញែកមនុស្សនោះចេញពីប្រជាជនរបស់គាត់»
Leviticus 23:30
ឃ្លាភ្ជាប់
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើរៀងរាល់ឆ្នាំ។
នៅថ្ងៃនោះ
«នៅថ្ងៃដង្វាយរំដោះបាប»
នេះគឺជាច្បាប់ដែលអ្នករាល់គ្នាត្រូវកាន់គ្រប់ជំនាន់
នេះមានន័យថាពួកគេនិងកូនចៅរបស់ពួកគេត្រូវតែគោរពតាមបញ្ញានេះជារៀងរហូត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៣:១៥ ។
ថ្ងៃនេះគឺជាថ្ងៃសម្រាក
នេះមិនខុសពីថ្ងៃឈប់សំរាកដែលគេបានធ្វើរៀងរាល់សប្តាហ៍នៅថ្ងៃទី៧ ។
នេះជាថ្ងៃឈប់សម្រាកពិសេសនៅថ្ងៃដង្វាយរំដោះបាប។
ត្រូវតមអាហារ នៅថ្ងៃទីប្រាំបួន
ក្នុងករណីនេះបន្ទាបខ្លួនបង្ហាញថាពួកគេនឹងមិនបរិភោគអាហារអ្វីឡើយ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែបន្ទាបខ្លួនហើយមិនបរិភោគអ្វី»
នៅថ្ងៃទីប្រាំបួននៅក្នុងខែនោះ
នេះសំដៅទៅលើខែទីប្រាំពីរនៃប្រតិទិនហេព្រើរ។ ថ្ងៃទី ៩
ជិតដល់ចុងខែកញ្ញាលើប្រតិទិនលោកខាងលិច។ នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ថ្ងៃទី ៩ នៃខែទី ៧»
ចាប់ពីពេលល្ងាចនោះ រហូតដល់ល្ងាចវិញ
«ចាប់ពីថ្ងៃលិចរហូតដល់ថ្ងៃលិចនៅថ្ងៃបន្ទាប់»
Leviticus 23:33
ក្នុងថ្ងៃទីដប់ប្រាំ ក្នុងខែទីប្រាំពីរ
នេះជិតដល់ដើមខែតុលាលើប្រតិទិនលោកខាងលិច។
ពិធីបុណ្យបារាំ
នេះជាការប្រារព្ធពិធីដែលប្រជាជនអ៊ីស្រាអែលបានរស់នៅក្នុងជម្រកបណ្តោះអាសន្នអស់រយៈពេលប្រាំពីរ
បន្ទាប់ពីពួកគេបានចាកចេញពីស្រុកអេស៊ីប។
Leviticus 23:35
ព័ត៌មានទូទៅ
ព្រះអម្ចាស់កំពុងតែណែនាំអោយពិធីបុណ្យនៃបារាំ។
Leviticus 23:37
ឃ្លាភ្ជាប់
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើរៀងរាល់ឆ្នាំ។
ទាំងនេះគឺជាការកំណត់ថ្ងៃបុណ្យ
នេះសំដៅទៅលើពិធីបុណ្យដែលបានរៀបរាប់នៅក្នុង ជំពូក២៣: ១-៣៦ ។
Leviticus 23:39
សេចក្តីថ្លែងការណ៍ភ្ជាប់
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេពីអ្វីដែលប្រជាជនត្រូវធ្វើរៀងរាល់ឆ្នាំ។
ពិធីបុណ្យបារាំ
នេះជាការប្រារព្ធពិធីដែលប្រជាជនអ៊ីស្រាអែលបានរស់នៅក្នុងជម្រកបណ្តោះអាសន្នអស់រយៈពេលប្រាំពីរ
ដែលជាវិធីមួយដើម្បីចងចាំពីពេលវេលាដែលពួកគេបានរស់នៅក្នុងទីរហោស្ថាន
បន្ទាប់ពីពួកគេបានចាកចេញពីស្រុកអេស៊ីប។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅជំពូក ២៣:៣៣ ។
នៅថ្ងៃទីដប់ប្រាំ ក្នុងខែទីប្រាំពីរ
នេះជាខែទីប្រាំពីរនៃប្រតិទិនហេព្រើរ។
ថ្ងៃទីដប់ប្រាំគឺនៅជិតដើមខែតុលានៅលើប្រតិទិនលោកខាងលិច។
អ្នករាល់គ្នាត្រូវប្រារព្ធពិធីបុណ្យនេះ
ពាក្យ «ផ្លែឈើ» នៅទីនេះតំណាងឱ្យដំណាំផ្សេងៗ។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីអ្នកបានប្រមូលផលដំណាំ»
Leviticus 23:40
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តការណែនាំរបស់គាត់សម្រាប់ពិធីបុណ្យបារាំ។
មែកសាខា ធាងចាក...ដែលដុះនៅតាមមាត់ទឹក
ការប្រើប្រាស់ដែលអាចធ្វើបានសម្រាប់មែកទាំងនេះគឺ 1)
ដើម្បីបង្កើតជម្រកបណ្តោះអាសន្នឬទី 2)
បក់បោកពួកគេជាផ្នែកមួយនៃការអបអរសាទរដ៏រីករាយរបស់ពួកគេ។
ការបកប្រែខ្លះបញ្ជាក់ពីការប្រើប្រាស់របស់ពួកគេយ៉ាងច្បាស់។
ការបកប្រែផ្សេងទៀតទុកវាឱ្យច្បាស់។
ស្លឹកត្រែង
ដើមឈើដែលមានស្លឹកវែង និងតូចចង្អៀតដែលដុះក្បែរទឹក
Leviticus 23:42
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តការណែនាំរបស់គាត់សម្រាប់ពិធីបុណ្យបារាំ។
នោះកូនចៅរបស់អ្នករាល់គ្នាពីមួយជំនាន់ទៅមួយជំនាន់ នឹងអាចរៀនបាន
«ជំនាន់មួយទៅជំនាន់»
គឺជាសំនួនវោហារស័ព្ទដែលសំដៅទៅលើជំនាន់នីមួយៗដែលរស់នៅជំនាន់ក្រោយ។
ការបកប្រែផ្សេងទៀត
«កូនចៅរបស់អ្នកជាកម្មសិទ្ធិរបស់មនុស្សជំនាន់ក្រោយទាំងអស់អាចរៀនបាន» ឬ
«កូនចៅរបស់អ្នកទាំងអស់អាចរៀនបានជារៀងរហូត»

---

24 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ [2]«ចូរបង្គាប់ទៅជនជាតិអ៊ីស្រាអែល ឲ្យយកប្រេងអូលីវដ៏ល្អបំផុតមកឲ្យអ្នក សម្រាប់ប្រើក្នុងចង្កៀង
ដែលអាចដុតបំភ្លឺជារៀងរហូត។
[3]នៅខាងក្រៅវាំងននពីខាងមុខហិបនៃសម្ពន្ធមេត្រី នៅក្នុងព្រះពន្លាជួបព្រះអម្ចាស់ លោកអើរ៉ុនត្រូវដុតភ្លើងក្នុងចង្កៀង ពីល្ងាចដល់ព្រឹក ត្រូវរក្សាឲ្យឆេះរហូត
នៅចំពោះព្រះភក្ត្រព្រះអម្ចាស់។ នេះជាច្បាប់ដែលអ្នករាល់គ្នាត្រូវអនុវត្តគ្រប់ជំនាន់មនុស្សរបស់អ្នក។[4]មហាបូជាចារ្យត្រូវរក្សាភ្លើងឲ្យឆេះរហូតនៅចំពោះព្រះភក្ត្រព្រះអម្ចាស់
ចង្កៀងនៅលើជើងចង្កៀងធ្វើពីមាសសុទ្ធ។

generated on Wed Sep 10 16:16:32 2025

[5]អ្នកត្រូវយកម្សៅម៉ដ្តហើយដុតនំប៉័ងចំនួនដប់ពីរនំជាមួយម្សៅនោះ។ នំនីមួយៗត្រូវធ្វើពីម្សៅចំនួន ពីរភាគដប់នៃអេផា។[6]បន្ទាប់មក អ្នកត្រូវតម្កល់នំនៅលើតុ
ចំពោះព្រះភក្ត្រព្រះអម្ចាស់ជាពីរជួរ ក្នុងមួយជួរមានប្រាំមួយនំ។
[7]អ្នកត្រូវដាក់គ្រឿងក្រអូបសុទ្ធនៅចន្លោះជួរនំប៉័ងនីមួយៗ ទុកជាតង្វាយនៃការរំលឹក។ គ្រឿងក្រអូបត្រូវដុតថ្វាយព្រះអម្ចាស់។[8]រៀងរាល់ថ្ងៃសប្ប័ទ
មហាបូជាចារ្យត្រូវយកនំប៉័ងពីដៃប្រជាជនអ៊ីស្រាអែលមករៀបចំនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ នេះជាសញ្ញានៃសម្ពន្ធមេត្រីដ៏អស់កល្ប។
[9]នំប៉័ងនេះជាចំណែករបស់លោកអ៊ើរ៉ុន និងកូនចៅរបស់គាត់ ពួកគេត្រូវបរិភោគនៅក្នុងទីសក្ការៈ ព្រោះនេះជាចំណែកដ៏បរិសុទ្ធពីក្នុងតង្វាយដុតរបស់ព្រះអម្ចាស់»។
[10]មានហេតុការណ៍កើតឡើង ដោយមានបុរសម្នាក់ជាកូនរបស់ស្រីជនជាតិអ៊ីស្រាអែល ហើយឪពុកជាជនជាតិអេស៊ីព្ទ
ដែលបានមករស់នៅក្នុងចំណោមជនជាតិអ៊ីស្រាអែល។ កូនប្រុសរបស់ស្ត្រីអ៊ីស្រាអែលនេះបានឈ្លោះប្រកែក និងបុរសអ៊ីស្រាអែលម្នាក់ទៀតនៅក្នុងជំរំ។
[11]គេថែមទាំងជេរប្រមាថ និងដាក់បណ្តាសារព្រះអម្ចាស់ទៀតផង ដូច្នេះ ជនជាតិអ៊ីស្រាអែលបាននាំគាត់ទៅជួបនឹងលោកម៉ូសេ។ ម្តាយរបស់គាត់មានឈ្មោះថា សេឡូមីត
ជាកូនរបស់ឌីបរី ក្នុងកុលសម្ព័ន្ធដាន់។[12]ពួកគេបានឃុំគាត់ រហូតដល់ព្រះអម្ចាស់ឆ្លើយតប អំពីព្រះទ័យរបស់ព្រះអង្គ។
[13]បន្ទាប់មក ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[14]«ត្រូវនាំយកអ្នក ដែលបានដាក់បណ្តាសារព្រះ ទៅខាងក្រៅជំរំ។
អស់អ្នកដែលបានឮពាក្យរបស់គេត្រូវដាក់ដៃលើក្បាលរបស់គេ ហើយសហគមន៍ទាំងមូលត្រូវចោលគេនឹងដុំថ្ម។
[15]អ្នកត្រូវពន្យល់ដល់ជនជាតិអ៊ីស្រាអែល ប្រាប់ពួកគេថា៖ «អស់អ្នកណាដែលដាក់បណ្តាសារព្រះរបស់គេ អ្នកនោះត្រូវទទួលខុសត្រូវលើកំហុសរបស់ខ្លួន។
[16]អ្នកណាដែលជេរប្រមាថព្រះនាមព្រះអម្ចាស់ អ្នកនោះត្រូវទទួលទោសដល់ស្លាប់ សហគមន៍អ៊ីស្រាអែលទាំងមូលត្រូវគប់គេនឹងដុំថ្ម ទោះបីគេជាម្ចាស់ស្រុក
ឬជាជនបរទេសក្តី។ ប្រសិនបើ អ្នកណាម្នាក់ជេរប្រមាថព្រះនាមព្រះអម្ចាស់ អ្នកនោះត្រូវទទួលទោសដល់ស្លាប់។
[17]ប្រសិនបើ អ្នកណាម្នាក់វាយមនុស្សដល់ស្លាប់ អ្នកនោះត្រូវទទួលទោសដល់ស្លាប់។[18]បើគេវាយសត្វពាហនៈរបស់អ្នកណាម្នាក់រហូតងាប់
ម្នាក់នោះត្រូវយកសត្វដូចគ្នានោះទៅសងម្ចាស់សត្វនោះវិញ គឺជីវិតសងដោយជីវិត។
[19]បើអ្នកណាម្នាក់ធ្វើអោយអ្នកជិតខាងរបស់ខ្លួនមានរបួសត្រង់ណា នោះត្រូវធ្វើឲ្យគេមានរបួសត្រង់នោះវិញដូចដែលគាត់បានធ្វើ។[20]បើអ្នកណាធ្វើឲ្យគេបាក់ឆ្អឹង
ត្រូវបំបាក់ឆ្អឹងអ្នកនោះវិញ ភ្នែកសងដោយភ្នែក ធ្មេញសងដោយធ្មេញ។ ត្រូវធ្វើឲ្យគេមានរបួសដូចដែលគេបានធ្វើឲ្យអ្នកដទៃមានរបួសដូច្នេះដែរ។
[21]អ្នកណាម្នាក់ដែលបានសម្លាប់សត្វរបស់អ្នកដទៃ ត្រូវសងសត្វនោះដល់ម្ចាស់គេវិញ រីឯអ្នកដែលសម្លាប់មនុស្ស ត្រូវមានទោសដល់ស្លាប់។
[22]ត្រូវមានច្បាប់តែមួយសម្រាប់ជនជាតិអ៊ីស្រាអែល និងជនបរទេសដែលរស់នៅក្នុងចំណោមអ្នករាល់គ្នា យើងគឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា»។
[23]លោកម៉ូសេបានប្រាប់ទៅជនជាតិអ៊ីស្រាអែលតាមដែលព្រះអង្គបង្គាប់ ហើយពួកគេបាននាំបុរសម្នាក់ដែលបានដាក់បណ្តាសារព្រះអម្ចាស់នោះទៅក្រៅជំរំ។
ហើយពួកគេបានចោលបុរសម្នាក់នោះនឹងដុំថ្ម។ ជនជាតិអ៊ីស្រាអែលធ្វើតាមព្រះបន្ទូល ដែលព្រះអម្ចាស់បង្គាប់មកលោកម៉ូសេ។

Leviticus 24:1
ព័ត៌មានទូទៅ
ព្រះប្រទានការណែនាំដល់លោកម៉ូសេអំពីវត្ថុនៅក្នុងត្រសាលប្រជុំ។
ប្រេងអូលីវដ៏ល្អបំផុត
«ប្រេងអូលីវសុទ្ធ»
ចង្កៀង
នេះសំដៅទៅលើចង្កៀងឬចង្កៀងនៅក្នុងត្រសាលដ៏ពិសិដ្ឋរបស់ព្រះអម្ចាស់។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ចង្កៀងនៅក្នុងត្រសាលប្រជុំ»
Leviticus 24:3
ឃ្លាភ្ជាប់
ព្រះបន្តផ្តល់ការណែនាំដល់ម៉ូសេអំពីអ្វីៗនៅក្នុងត្រសាលប្រជុំ។
នៅខាងក្រៅវាំងននពីខាងមុខហិបនៃសម្ពន្ធមេត្រី
ឃ្លា «ក្រឹត្យនៃសម្ពន្ធមេត្រី »តំណាងទាំងបន្ទះដែលក្រឹត្យត្រូវបានសរសេរនៅលើ ឬប្រអប់ដែលបន្ទះថ្មនោះដាក់ចូល។ ទាំងនេះត្រូវបានរក្សាទុកនៅក្នុងទីបរិសុទ្ធបំផុត ដែលជាបន្ទប់ខាងក្រោយវាំងននក្នុងត្រសាលប្រជុំ។ ការបកប្រែផ្សេងទៀត
«នៅខាងក្រៅវាំងននដែលស្ថិតនៅខាងមុខក្រឹត្យនៃកិច្ចព្រមព្រៀង» ឬ
«នៅខាងក្រៅវាំងននដែលស្ថិតនៅខាងមុខប្រអប់នៃសម្ពន្ធមេត្រី»
វាំងនន
នេះគឺជាក្រណាត់ក្រាស់ព្យួរនៅជញ្ជាំង។ វាមិនដូចជាវាំងននបង្ហួចស្រាលទេ។
ពីល្ងាចដល់ព្រឹក
«ចាប់ពីពេលថ្ងៃលិចរហូតដល់ថ្ងៃរះ» ឬ «ពេញមួយយប់»
នេះជាច្បាប់ដែលអ្នករាល់គ្នាត្រូវអនុវត្តគ្រប់ជំនាន់មនុស្សរបស់អ្នក
នេះមានន័យថាពួកគេ
និងកូនចៅរបស់ពួកគេត្រូវតែគោរពតាមបញ្ញានេះជារៀងរហូត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ជំពូក ៣:១៥ ។
Leviticus 24:5
ឃ្លាភ្ជាប់
ព្រះបន្តផ្តល់ការណែនាំដល់ម៉ូសេអំពីអ្វីៗនៅក្នុងត្រសាលប្រជុំ។
ពីរភាគដប់នៃអេផា
នេះគឺប្រហែល 4,5 លីត្រ។ ការបកប្រែផ្សេងទៀត «បួនលីត្រកន្លះ»
នៅលើតុ ចំពោះព្រះភក្ត្រព្រះអម្ចាស់
តុនេះនៅក្នុងទីបរិសុទ្ធ ដែលនៅមុខកន្លែងបរិសុទ្ធបំផុត។
Leviticus 24:7
ឃ្លាភ្ជាប់
ព្រះបន្តផ្តល់ការណែនាំដល់ម៉ូសេអំពីអ្វីៗនៅក្នុងត្រសាលប្រជុំ។
អ្នកត្រូវដាក់គ្រឿងក្រអូបសុទ្ធនៅចន្លោះជួរនំប៉័ងនីមួយៗ
គ្រឿងក្រអូបប្រហែលជានៅជាប់នឹងនំប៉័ងជាជាងនៅផ្នាល់ពីលើនំប៉័ង។
ការបកប្រែផ្សេងទៀត
«អ្នកត្រូវដាក់គ្រឿងក្រអូបសុទ្ធនៅជាប់នឹងនំប៉័ងនៅជួរនីមួយៗ»
ទុកជាតង្វាយនៃការរំលឹក
អ្វីដែលគ្រឿងក្រអូបតំណាងឲ្យអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «តំណាងឱ្យនំប៉័ងជាដង្វាយមួយ ឬ
ជាតង្វាយដែលតំណាងឲ្យនំប៉័ង»
គ្រឿងក្រអូបត្រូវដុតថ្វាយព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកនឹងដុតគ្រឿងក្រអូបសំរាប់ព្រះអម្ចាស់»
នំប៉័ងនេះ
«នំប៉័ងដែលថ្វាយជូន»
ព្រោះនេះជាចំណែកដ៏បរិសុទ្ធពីក្នុងតង្វាយ
«ពីព្រោះពួកគេបានយកវាពីដង្វាយ»
តង្វាយដុតរបស់ព្រះអម្ចាស់
«តង្វាយដុតទាំងប៉ុន្មានថ្វាយព្រះអម្ចាស់» ឬ
«តង្វាយដែលអ្នកដុតថ្វាយព្រះអម្ចាស់»។
Leviticus 24:10
មានហេតុការណ៍កើតឡើង
ឃ្លានេះសម្គាល់ផ្នែកថ្មីនៃសៀវភៅ។
ជេរប្រមាថ និងដាក់បណ្តាសារព្រះអម្ចាស់ទៀតផង
ឃ្លាទាំងពីរនេះមានន័យថាជាមូលដ្ឋានដូចគ្នា។ ការបកប្រែផ្សេងទៀត
«ប្រមាថដល់ព្រះអម្ចាស់ដោយដាក់បណ្តាសាព្រះអង្គ» ឬ
«និយាយអ្វីដែលគួរអោយខ្លាចអំពីព្រះ»
សេឡូមីត
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
ឌីបរី
នេះជាឈ្មោះបុរសម្នាក់។
Leviticus 24:13
អស់អ្នកដែលបានឮពាក្យរបស់គេត្រូវដាក់ដៃលើក្បាលរបស់គេ
ពួកគេត្រូវដាក់ដៃលើក្បាលរបស់គាត់ដើម្បីបង្ហាញថាគាត់គឺជាអ្នកដែលមានកំហុស។
Leviticus 24:15
ឃ្លាភ្ជាប់

generated on Wed Sep 10 16:16:32 2025

ព្រះនៅតែបន្តប្រាប់ម៉ូសេពីអ្វីដែលពួកគេត្រូវធ្វើចំពោះបុរសដែលប្រមាថព្រះជាម្ចាស់។
ត្រូវទទួលខុសត្រូវលើកំហុសរបស់ខ្លួន
ការរងទុក្ខចំពោះអំពើបាបត្រូវបានគេនិយាយប្រសិនបើមនុស្សម្នាក់ត្រូវទទួលទោស។
ការបកប្រែផ្សេងទៀត «ត្រូវរងទុក្ខសំរាប់អំពើបាបរបស់គាត់» ឬ
«ត្រូវតែទទួលទណ្ឌកម្ម
ត្រូវទទួលទោសដល់ស្លាប់
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនត្រូវតែសម្លាប់គាត់» ឬ «ប្រជាជនពិតជាត្រូវសម្លាប់គាត់»
Leviticus 24:17
ឃ្លាភ្ជាប់
ព្រះនៅតែបន្តប្រាប់ម៉ូសេ
ពីអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់ធ្វើអាក្រក់។
អ្នកនោះត្រូវទទួលទោសដល់ស្លាប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវសំលាប់អ្នកណាដែលសម្លាប់មនុស្សម្នាក់ទៀត»
សងម្ចាស់សត្វនោះវិញ
របៀបដែលគាត់នឹងសងវាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ត្រូវតែសងវាវិញដោយផ្តល់ឱ្យគាត់នូវសត្វមានជីវិតវិញ»
ជីវិតសងដោយជីវិត
នេះគឺសម្គាល់ថាជីវិតមួយនឹងជំនួសជីវិតមួយទៀត។ ការបកប្រែផ្សេងទៀត
«ជីវិតមួយជំនួសដោយជីវិតផ្សេងទៀត» ឬ «ជំនួសជីវិតដែលគាត់បានសម្លាប់»
Leviticus 24:19
ឃ្លាភ្ជាប់
ព្រះនៅតែបន្តប្រាប់ម៉ូសេ
ពីអ្វីដែលប្រជាជនត្រូវធ្វើនៅពេលមាននរណាម្នាក់ធ្វើអាក្រក់។
នោះត្រូវធ្វើឲ្យគេមានរបួសត្រង់នោះវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវធ្វើចំពោះគាត់»
បើអ្នកណាធ្វើឲ្យគេបាក់ឆ្អឹង ត្រូវបំបាក់ឆ្អឹងអ្នកនោះវិញ ភ្នែកសងដោយភ្នែក ធ្មេញសងដោយធ្មេញ
ឃ្លាទាំងនេះសង្កត់ធ្ងន់ថាមនុស្សម្នាក់គួរតែទទួលរងគ្រោះដូចដែលគាត់បានធ្វើចំពោះអ្នកដទៃ។
បើអ្នកណាធ្វើឲ្យគេបាក់ឆ្អឹង ត្រូវបំបាក់ឆ្អឹងអ្នកនោះ
នេះសំដៅទៅលើការបាក់ឆ្អឹង។ ការបកប្រែផ្សេងទៀត «ឆ្អឹងទល់នឹងឆ្អឹង» ឬ
«ប្រសិនបើគាត់បំបាក់ឆ្អឹងនរណាម្នាក់ គាត់ត្រូវសងមកវិញដោយឆ្អឹងរបស់គាត់» ឬ
«ប្រសិនបើគាត់បាក់ឆ្អឹងរបស់នរណាម្នាក់ពួកគេនឹងបាក់ឆ្អឹងមួយរបស់គាត់វិញ»
ភ្នែកសងដោយភ្នែក
នេះសំដៅទៅលើភ្នែកដែលរងរបួស ឬត្រូវគេវាយដំយ៉ាងធ្ងន់ធ្ងរ។
ការបកប្រែផ្សេងទៀត «ប្រសិនបើគាត់បំផ្លាញភ្នែករបស់នរណាម្នាក់
ឆ្អឹងមួយរបស់គាត់ត្រូវតែត្រូវបានបំផ្លាញវិញ» ឬ
«ប្រសិនបើគាត់បំផ្លាញភ្នែករបស់នរណាម្នាក់ពួកគេនឹងបំផ្លាញភ្នែករបស់គាត់វិញដែរ»
ធ្មេញសងដោយធ្មេញ
នេះសំដៅទៅលើធ្មេញដែលគេគោះចេញពីមាត់។ ការបកប្រែផ្សេងទៀត
«ប្រសិនបើគាត់ធ្វើឲ្យធ្មេញរបស់នរណាម្នាក់បាក់ គាត់ត្រូវសងធ្មេញនោះវិញ» ឬ
«ប្រសិនបើគាត់វាយធ្មេញរបស់នរណាម្នាក់ពួកគេនឹងវាយធ្មេញមួយរបស់គាត់វិញ»
អ្នកដែលសម្លាប់មនុស្ស ត្រូវមានទោសដល់ស្លាប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវតែសំលាប់អ្នកណាដែលសម្លាប់គេ»
Leviticus 24:22
ធ្វើតាមព្រះបន្ទូល ដែលព្រះអម្ចាស់បង្គាប់មក
«គោរពតាមបទបញ្ជា»

---

25 [1]នៅភ្នំស៊ីណៃ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖[2]«ចូរនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល
ហើយប្រាប់ពួកគេថា:នៅពេលដែលអ្នករាល់គ្នាចូលទៅរស់នៅក្នុងទឹកដីដែលយើងប្រគល់ឲ្យអ្នករាល់គ្នា
នោះត្រូវរក្សាដីឲ្យឈប់សម្រាប់គឺឆ្នាំសប្ប័ទថ្វាយព្រះអម្ចាស់។
[3]អ្នករាល់គ្នាត្រូវធ្វើការសាបព្រោះក្នុងរយៈពេលប្រាំមួយឆ្នាំ ហើយនៅឆ្នាំទីប្រាំមួយអ្នករាល់គ្នាត្រូវបេះផ្លែទំពាំងបាយជួរ និងប្រមូលផលនៃដំណាំរបស់អ្នក។[4]ប៉ុន្តែ
នៅឆ្នាំទីប្រាំពីរ ជាឆ្នាំសប្ប័ទ ត្រូវទុកដីឲ្យនៅទំនេរទាំងស្រុង ដ្បិត ជាឆ្នាំសប្ប័ទថ្វាយព្រះអម្ចាស់។ អ្នកមិនត្រូវសាបព្រោះក្នុងស្រែចំការ
ក៏មិនត្រូវកាត់លួសទំពាំងបាយជូររបស់អ្នកដែរ។
[5]អ្នករាល់គ្នាមិនត្រូវច្រូតកាត់អ្វីដែលវាដុះឡើងដោយខ្លួនវាទេ ហើយក៏មិនត្រូវកាត់ផ្លែទំពាំងបាយជូរដែលផ្លែដោយអ្នកមានបានក្រៃដែរ។ នេះជាឆ្នាំដែលដីត្រូវសម្រាក។
[6]ទោះក្នុងកំឡុងពេលនៃឆ្នាំសប្ប័ទដីនៅទំនេរក៏ដោយ ក៏នៅតែផ្តល់អាហារសម្រាប់អ្នកដែរ។ ទាំងអ្នករាល់គ្នា ទាំងអ្នកបម្រើប្រុសស្រី ទាំងទាសកររបស់អ្នករាល់គ្នា
និងជនបរទេសដែលរស់នៅក្នុងចំណោមអ្នករាល់គ្នា នៅតែមានអាហារគ្រប់គ្រាន់ [7]ទាំងសត្វពាហនៈ និងសត្វព្រៃនឹងទទួលបានអាហារពីផលនៃដីជាចំណីដែរ។
[8]អ្នករាល់គ្នាត្រូវរាប់ឆ្នាំសប្ប័ទប្រាំពីរដង នោះគឺ ប្រាំពីរឆ្នាំប្រាំពីរដង ដូច្នេះនឹងមានឆ្នាំសប្ប័ទប្រាំពីរដង សរុបចំនួន សែសិបប្រាំបួនឆ្នាំ។[9]ក្នុងខែទីប្រាំពីរ នៅថ្ងៃទីដប់
អ្នកត្រូវផ្លុំត្រែនៅគ្រប់ទីកន្លែងទាំងអស់។ ក្នុងថ្ងៃនោះត្រូវផ្លុំត្រែ និងស្រែកឲ្យលាន់ឮឡើង ព្រោះជាថ្ងៃរំដោះបាប។
[10]អ្នករាល់គ្នាត្រូវចាត់ទុកឆ្នាំទីហាសិបជាឆ្នាំដ៏វិសុទ្ធថ្វាយព្រះអម្ចាស់ ហើយប្រកាសសេរីភាពដល់មនុស្សទាំងអស់នៅក្នុងស្រុកទាំងមូល។ នេះគឺជា ឆ្នាំមេត្តាករុណា
សម្រាប់អ្នករាល់គ្នា គេនឹងទទួលបានមរតករបស់ខ្លួនត្រឡប់មកវិញ រីឯទាសករនឹងត្រលប់ទៅឯគ្រួសាររបស់គេវិញ។
[11]ឆ្នាំទីហាសិប គឺជា ឆ្នាំមេត្តាករុណា សម្រាប់អ្នករាល់គ្នា។ អ្នករាល់គ្នាមិនត្រូវដាំដុះ ឬប្រមូលផលឡើយ។ អ្នករាល់គ្នាត្រូវបរិភោគតែទិន្នផលដែលដុះដោយឯកឯង
និងបេះផ្លែទំពាំងបាយជូរដែលអ្នកមិនបានក្រៃ។[12]ឆ្នាំមេត្តាករុណា ជាឆ្នាំវិសុទ្ធសម្រាប់អ្នករាល់គ្នា។
អ្នករាល់គ្នាត្រូវបរិភោគតែអ្វីដែលផ្តល់ផលដោយឯកឯងពីចម្ការតែប៉ុណ្ណោះ។
[13]អ្នករាល់គ្នាអាចត្រឡប់ទៅកាន់កាប់កម្មសិទ្ធិរបស់ខ្លួនវិញបាន ក្នុងឆ្នាំមេត្តាករុណា។[14]ប្រសិនបើ អ្នកបានលក់ដីទៅអោយអ្នកជិតខាងរបស់អ្នក
ឬបានទិញដីពីអ្នកជិតខាងរបស់អ្នក អ្នកមិនត្រូវកេងបន្លំគេឡើង។
[15]ប្រសិនបើ អ្នកទិញដីពីនាក់ជិតខាងរបស់អ្នក ត្រូវពិចារណាអំពីចំនួនឆ្នាំ ហើយនិងទិន្នផលដែលអ្នកអាចប្រមូលរហូតដល់ ឆ្នាំមេត្តាករុណាបន្ទាប់។
អ្នកដែលលក់ដីឲ្យអ្នកក៏ត្រូវតែគិតពីពេលវេលានេះដូចគ្នា។[16]ប្រសិនបើ នៅមានពេលច្រើនឆ្នាំទើបដល់ឆ្នាំមេត្តាករុណាបន្ទាប់ នោះតម្លៃដីនឹងកើនឡើង ប៉ុន្តែ ប្រសិនបើ
នៅមានរយៈពេលខ្លីដល់ឆ្នាំមេត្តាករុណា នោះតម្លៃដីនឹងធ្លាក់ចុះ ព្រោះចំនួននៃការច្រូតកាត់ នឹងបង្ករបង្កើនផលសម្រាប់ម្ចាស់ថ្មីដោយយោងលើចំនួនឆ្នាំ
មុនពេលឆ្នាំមេត្តាករុណាមកដល់។[17]អ្នករាល់គ្នាមិនត្រូវបោកប្រាស់ ឬកេងប្រវ័ញ្ចជនរួមជាតិឡើយ ផ្ទុយទៅវិញអ្នករាល់គ្នាត្រូវកោតខ្លាចព្រះរបស់អ្នករាល់គ្នា
គឺយើងជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[18]អ្នកត្រូវគោរពតាមបញ្ញត្តិ រក្សាច្បាប់ និងប្រតិបត្តិតាម។ នោះអ្នករាល់គ្នានឹងរស់នៅយ៉ាងសុខសាន្តក្នុងស្រុក។[19]ដីនឹងផ្តល់ភោគផល
ហើយអ្នករាល់គ្នានឹងមានអាហារបរិភោគយ៉ាងបរិបូរ និងរស់នៅយ៉ាងសុខសាន្តក្នុងស្រុក។
[20]អ្នកនឹងសួរថា៖ «តើយើងនឹងបានអ្វីបរិភោគ ក្នុងឆ្នាំទីប្រាំពីរ? មើល៍! យើងមិនអាចសាបព្រោះ ឬសូម្បីតែប្រមូលផលរបស់យើង»។[21]យើងនឹងឲ្យពរអ្នករាល់គ្នា
នៅក្នុងឆ្នាំទីប្រាំមួយ គឺក្នុងឆ្នាំនោះ អ្នករាល់គ្នានឹងទទួលបានភោគផលដែលគ្រប់គ្រាន់សម្រាប់រយៈពេលបីឆ្នាំ។[22]អ្នកនឹងសាបព្រោះក្នុងឆ្នាំទីប្រាំបី
តែអ្នករាល់គ្នានឹងបរិភោគផលដែលប្រមូលពីឆ្នាំមុនរហូតដល់ឆ្នាំទីប្រាំបួន អ្នកនឹងបរិភោគផលចាស់ រហូតដល់បានទទួលភោគផលនៃឆ្នាំថ្មី។
[23]អ្នករាល់គ្នាមិនអាចលក់ដីផ្តាច់ឲ្យគេរហូតបានទេ ព្រោះដីជាកម្មសិទ្ធិរបស់យើង។ អ្នករាល់គ្នាជាជនបរទេស ដែលស្នាក់នៅជាបណ្តោះអាសន្នលើទឹកដីរបស់យើង។[24]
អ្នករាល់គ្នាត្រូវបង្កើតឲ្យមានច្បាប់ក្នុងការលោះដី នៅគ្រប់ទីកន្លែងដែលអ្នកចូលទៅចាប់យក អ្នកត្រូវតែអនុញ្ញាតឲ្យក្រុមគ្រួសារអ្នកដែលបានលក់ដីឲ្យអ្នកនោះ
ទិញត្រឡប់ទៅវិញ។[25]ប្រសិនបើ ជនរួមជាតិរបស់អ្នកធ្លាក់ខ្លួនក្រ ហើយដោយសារការនេះគាត់បានលក់ទ្រព្យសម្បត្តិរបស់គេ ដូច្នេះ
សាច់ញាតិជិតដិតរបស់គាត់ត្រូវមកហើយទិញទ្រព្យសម្បត្តិដែលគាត់បានលក់ឲ្យអ្នកនោះត្រឡប់ទៅវិញ។

generated on Wed Sep 10 16:16:32 2025

[26]ប្រសិនបើ អ្នកនោះមិនមានសាច់ញាតិក្នុងការលោះទ្រព្យសម្បត្តិទេ
ប៉ុន្តែគាត់ធូរធារហើយមានលទ្ធភាពលោះដីមកវិញ[27]នោះគាត់អាចគណនាចំនួនឆ្នាំចាប់តាំងពីឆ្នាំដែលបានលក់ដី រហូតដល់ឆ្នាំមេត្តាករុណា
ហើយបង់ប្រាក់ឲ្យទៅអ្នកទិញ។ បន្ទាប់មក គាត់អាចត្រឡប់ទៅកាន់កាប់ទ្រព្យសម្បត្តិរបស់គាត់វិញ។[28]ប៉ុន្តែប្រសិនបើ
គាត់មិនមានលទ្ធភាពលោះដីត្រឡប់មកវិញដោយខ្លួនគាត់ទេ ដីនោះនឹងនៅជាកម្មសិទ្ធិរបស់អ្នកដែលបានទិញ រហូតដល់ឆ្នាំមេត្តាករុណា។ នៅឆ្នាំមេត្តាករុណា
ដីនឹងត្រឡប់មកនាក់ដែលបានលក់វិញ គឺត្រឡប់មកជាកម្មសិទ្ធិរបស់ម្ចាស់ដើមវិញ។
[29]ប្រសិនបើ អ្នកណាម្នាក់លក់ផ្ទះរបស់គាត់ដែលនៅក្នុងរបងទីក្រុង គាត់អាចទិញផ្ទះត្រឡប់មកវិញក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីលក់។
ក្នុងរយៈពេលពេញមួយឆ្នាំគាត់មានសិទ្ធិលោះផ្ទះត្រឡប់មកវិញបាន។[30]ប្រសិនបើ ពេញមួយឆ្នាំនេះផ្ទះដែលនៅក្នុងរបងទីក្រុងមិនត្រូវបានលោះទេ
ផ្ទះនោះត្រូវក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ និងពូជពង្សរបស់គាត់រហូត។ ក្នុងឆ្នាំមេត្តាករុណា ផ្ទះនោះនឹងមិនបានត្រឡប់ទៅម្ចាស់ដើមវិញដែរ។
[31]ប៉ុន្តែប្រសិនបើ ផ្ទះដែលមិននៅក្នុងរបងក្រុងទេ គឺត្រូវគិតដូចជាដីឯទៀតដែរ។ ដីទាំងនោះអាចលោះពេលណាក៏បាន
ហើយត្រូវត្រឡប់ទៅម្ចាស់ដើមវិញនៅឆ្នាំមេត្តាករុណា។[32]តែឯផ្ទះរបស់ពួកលេវីក្នុងក្រុងរបស់លេវី ពួកគេអាចលោះមកវិញពេលណាក៏បាន។
[33]ប្រសិនបើ លេវីណាម្នាក់មិនអាចលោះផ្ទះដែលបានលក់ទេនោះ ផ្ទះដែលមានទីតាំងនៅក្នុងទីក្រុងរបស់គេត្រូវត្រឡប់ទៅជារបស់ម្ចាស់ដើមវិញក្នុងឆ្នាំមេត្តាករុណា
ព្រោះផ្ទះដែលនៅក្នុងទីក្រុងរបស់លេវី ជាកម្មសិទ្ធិរបស់ពួកគេក្នុងចំណោមជនជាតិអ៊ីស្រាអែល។[34]រីឯស្រែចំការដែលនៅជុំវិញទីក្រុងរបស់ពួកគេ មិនអាចលក់បានទេ
ដ្បិតជាកម្មសិទ្ធិរបស់ពួកលេវីរហូតទៅ។
[35]ប្រសិនបើ បងប្អូនណាម្នាក់របស់អ្នកធ្លាក់ខ្លួនក្រ ដែលមិនអាចផ្គត់ផ្គង់ខ្លួនគាត់បាន ដូច្នេះ អ្នកត្រូវជួយគាត់ ទោះបីជាជនបរទេសក្តី
ឬអ្នកស្នាក់នៅបណ្តោះអាសន្នក្នុងចំណោមអ្នករាល់គ្នាក្តី។[36]មិនត្រូវយកការប្រាក់ ឬចង់បានសគុណពីគេឡើយ ប៉ុន្តែ ត្រូវកោតខ្លាចព្រះអម្ចាស់
ដូច្នេះចូរទុកឲ្យបងប្អូនរបស់អ្នកមានជីវិតរស់នៅជាមួយអ្នករាល់គ្នា។[37]មិនត្រូវឲ្យប្រាក់គេខ្ចី ហើយគិតយកការប្រាក់ពីគេនោះឡើយ
ហើយក៏មិនត្រូវលក់អាហារឲ្យគេដោយត្រូវការផលចំណេញនោះដែរ។[38]យើងគឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីព្ទមក
ដើម្បីប្រគល់ទឹកដីកាណានេះឲ្យអ្នករាល់គ្នា និងដើម្បីឲ្យយើងធ្វើជាព្រះរបស់អ្នករាល់គ្នា។
[39]ប្រសិនបើ បងប្អូនរបស់អ្នកធ្លាក់ខ្លួនក្រ ហើយលក់ខ្លួនរបស់គេឲ្យអ្នក នោះអ្នកមិនត្រូវប្រើគេឲ្យធ្វើការដូចជាទាសករនោះទេ។[40]ត្រូវឲ្យគាត់ធ្វើការដូចអ្នកបម្រើ
ឬដូចជាអ្នកស្នាក់នៅបណ្តោះអាសន្នជាមួយអ្នក។ គាត់នឹងបម្រើអ្នករហូតដល់ឆ្នាំមេត្តាករុណា។[41]បន្ទាប់មក គាត់នឹងចាកចេញពីអ្នក គាត់នឹងកូនៗរបស់គាត់ទៅជាមួយគ្នា
ហើយគាត់នឹងត្រឡប់ទៅកាន់គ្រួសាររបស់គាត់និងអ្វីៗជាកេរ្តិ៍អាកររបស់ឪពុកគាត់វិញ។
[42]ដ្បិត ពួកគេជាអ្នកបម្រើរបស់យើង គឺអស់អ្នកដែលយើងបាននាំចេញពីស្រុកអេស៊ីព្ទមក។ ពួកគេនឹងមិនត្រូវលក់ជាទាសកររទេ។[43]កុំធ្វើបាបជិះជាន់ពួកគេឲ្យសោះ ប៉ុន្តែ
ត្រូវកោតខ្លាចព្រះជាម្ចាស់។[44]ប្រសិនបើ អ្នកត្រូវការអ្នកបម្រើប្រុសឬស្រីក្តី អ្នករាល់គ្នាត្រូវទិញពីចំណោមសាសន៍នានា ដែលរស់នៅជុំវិញអ្នករាល់គ្នា
អ្នកអាចទិញគេពីនោះបាន។
[45]អ្នកក៏អាចទិញទាសកពីជនបរទេសដែលរស់នៅក្នុងចំណោមអ្នករាល់គ្នាដែរ នោះគឺទិញពីគ្រួសាររបស់ពួកគេដែលរស់នៅក្នុងចំណោមអ្នករាល់គ្នា
គឺកូនៗដែលកើតក្នុងទឹកដីរបស់អ្នក។ ពួកគេអាចក្លាយមកជាសម្បត្តិរបស់អ្នករាល់គ្នា។[46]អ្នកអាចបែងចែកទាសកកូនៗរបស់អ្នកសម្រាប់កូនៗរបស់អ្នក
នៅជំនាន់ក្រោយទុកជាមរតក។ អ្នករាល់គ្នាអាចទិញអ្នកបម្រើជារៀងរហូត ប៉ុន្តែ អ្នកមិនត្រូវជិះជាន់សង្កត់សង្កិនជនជាតិអ៊ីស្រាអែល ដែលជាបងប្អូនរបស់អ្នកឡើយ។
[47]ប្រសិនបើ ជនបរទេស ឬអ្នកដែលរស់នៅបណ្តោះអាសន្នជាមួយអ្នករាល់គ្នាជាអ្នកមាន ហើយប្រសិនបើ ជនជាតិអ៊ីស្រាអែលជាបងប្អូនរបស់អ្នកធ្លាក់ខ្លួនផ្ទាល់
ហើយលក់ខ្លួនរបស់គេឲ្យជនបរទេសនោះ ឬលក់ឲ្យអ្នកណាម្នាក់ជាគ្រួសាររបស់ជនបរទេសនោះ[48]បន្ទាប់ពីបងប្អូនរបស់អ្នកត្រូវបានទិញ
គាត់នឹងអាចទិញត្រឡប់មកវិញបាន។ បងប្អូនរបស់គាត់អាចលោះគាត់មកវិញបាន។
[49]ឪពុកមារបស់គាត់ ឬបងប្អូនជីដូនមួយរបស់គាត់ ដែលមានសិទ្ធិលោះគាត់បាន រឺជាអ្នកណាម្នាក់ដែលជាញាតិជិតដិតដែលចេញពីគ្រួសាររបស់គាត់។ ឬ ប្រសិនបើ
គាត់មានភាពធូរធា គាត់អាចលោះខ្លួនគាត់បាន។[50]គាត់ត្រូវគិតចំនួនឆ្នាំជាមួយម្ចាស់ដែលបានទិញគាត់ គេត្រូវរាប់ចំនួនឆ្នាំដែលបានលក់ខ្លួនរបស់គាត់ឲ្យទៅអ្នកទិញនោះ
រហូតដល់ឆ្នាំមេត្តាករុណា។ ប្រាក់នៃការលោះរបស់គាត់ ត្រូវគិតទៅតាមថ្លៃឈ្នួលដែលគេចំណាយឲ្យអ្នកបម្រើ
ហើយសម្រាប់ចំនួននៃឆ្នាំគាត់អាចបន្តសម្រាប់អ្នកដែលបានទិញគាត់
[51]ប្រសិនបើ នៅមានរយៈពេលយូរទើបដល់ឆ្នាំមេត្តាករុណា គាត់ត្រូវបង់ប្រាក់លោះខ្លួនឲ្យទៅម្ចាស់ គិតតាមចំនួនឆ្នាំដែលនៅសល់នោះ។[52]ប្រសិនបើនៅសល់តិចឆ្នាំ
មុននឹងឆ្នាំមេត្តាករុណាមកដល់ នោះគាត់ក៏ត្រូវបង់ប្រាក់ឲ្យទៅម្ចាស់ ដោយគិតតាមចំនួនឆ្នាំដែលនៅសល់នោះ។
[53]គាត់ត្រូវធ្វើការដូចជាអ្នកស៊ីឈ្នួលពីមួយឆ្នាំទៅមួយឆ្នាំ។ អ្នកមិនត្រូវជិះជាន់ធ្វើបាបគាត់ឡើយ។[54]ប្រសិនបើ គាត់មិនត្រូវបានលោះខ្លួននោះទេ រហូតដល់ឆ្នាំមេត្តាករុណា
គាត់ព្រមទាំងកូនៗរបស់គាត់អាចចាកចេញពីម្ចាស់នោះបាន។[55]ជនជាតិអ៊ីស្រាអែលជាអ្នកបម្រើរបស់យើង។ ពួកគេជាអ្នកបម្រើរបស់យើង
ដែលយើងបាននាំចេញពីស្រុកអេស៊ីព្ទមក។ យើងគឺព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា»។

Leviticus 25:1
ទឹកដីដែលយើងប្រគល់ឲ្យអ្នករាល់គ្នា នោះត្រូវរក្សាដីឲ្យឈប់សម្រាប់គឺឆ្នាំសប្ប័ទថ្វាយព្រះអម្ចាស់
ដីនេះត្រូវគេនិយាយថាជាមនុស្សដែលអាចគោរពថ្ងៃឈប់សម្រាកដោយធ្វើកាសម្រាក។
ដូចប្រជាជនត្រូវសំរាកនៅថ្ងៃទីប្រាំពីរ
ប្រជាជនត្រូវគោរពព្រះដោយមិនធ្វើស្រែចំការរៀងរាល់ឆ្នាំទីប្រាំពីរដែរ។
ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែគោរពច្បាប់នៅថ្ងៃឈប់សម្រាកដោយទុកដីនៅរៀងរាល់ឆ្នាំទីប្រាំពីរសំរាប់ព្រះអម្ចាស់
ឬ
«អ្នកត្រូវគោរពថ្ងៃឈប់សម្រាករបស់ព្រះអម្ចាស់ដោយមិនធ្វើស្រែចំការនៅរៀងរាល់ឆ្នាំទីប្រាំពីរ

Leviticus 25:3
អ្នករាល់គ្នាត្រូវបេះផ្លែទំពាំងបាយជូរ
ដើម្បីកាត់ចម្ការទំពាំងបាយជូរគឺកាត់មែក
និងវល្លិដើម្បីជួយឱ្យផ្លែលូតលាស់បានល្អ។
ជាឆ្នាំសប្ប័ទ ត្រូវទុកដីឲ្យនៅទំនេរទាំងស្រុង ដ្បិត ជាឆ្នាំសប្ប័ទថ្វាយព្រះអម្ចាស់
ការមិនធ្វើស្រែចំការត្រូវបានគេនិយាយថាទុកដីនៅសល់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែគោរពថ្ងៃឈប់សម្រាក ដ៏ឧឡារិកសម្រាប់ដី» ឬ
«អ្នកត្រូវតែគោរពច្បាប់ថ្ងៃឈប់សម្រាក ដោយមិនធ្វើស្រែរៀងរាល់ឆ្នាំទីប្រាំពីរទេ»

Leviticus 25:5
អ្នករាល់គ្នាមិនត្រូវច្រូតកាត់...ជនបរទេសដែលរស់នៅក្នុងចំណោមអ្នករាល់គ្នា
នៅតែមានអាហារគ្រប់គ្រាន់
ក្នុងជំពូក ២៥: ៥-៦
ព្រះអម្ចាស់មានន័យថាព្រះអង្គនឹងមិនអនុញ្ញាតឱ្យម្ចាស់ចំការរៀបចំកម្មកររបស់ខ្លួននិងប្រមូលផលដំណាំ
ទោះជាយ៉ាងណាក៏ដោយព្រះអម្ចាស់នឹងអនុញ្ញាតឱ្យបុគ្គលម្នាក់ៗឆ្លងកាត់វាលស្រែ
ដើម្បីយកស្រូវសាលី និងបរិភោគផ្លែឈើដែលពួកគេរកឃើញ។
ហើយក៏មិនត្រូវកាត់ផ្លែទំពាំងបាយជូរដែល
ដែលមានន័យថាគ្មាននរណាម្នាក់ថែរក្សាវល្លិ

Leviticus 25:7
និងកាត់វាដូចដែលពួកគេបានធ្វើក្នុងរយៈពេលប្រាំមួយឆ្នាំទៀតទេ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ «វល្លិរបស់អ្នកដែលអ្នកមិនកាត់ចេញ»
ទោះក្នុងកំឡុងពេលនៃឆ្នាំសប្ប័ទដ៏នៅទំនេរក៏ដោយ ក៏នៅតែផ្តល់អាហារសម្រាប់អ្នកដែរ
«អ្វីដែលដុះលើដីដែលមិនបានធ្វើការ»
ដីនៅទំនេរ
នេះមានន័យថាគ្មាននរណាម្នាក់ថែរក្សាសួនច្បារឬកសិដ្ឋានដូចដែលពួកគេធ្វើក្នុងអំឡុងពេលប្រាំមួយឆ្នាំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«សួនច្បាររបស់អ្នកដែលអ្នកមិនមានអ្នកថែទេ»
ទទួលបានអាហារពីផលនៃដីជាចំណីដែរ

generated on Wed Sep 10 16:16:32 2025

«អ្វីដែលដុះលើដី»
Leviticus 25:8
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
នឹងមានឆ្នាំសប្ប័ទប្រាំពីរដង
«ពួកគេនឹងក្លាយជាប្រាំពីរឈុតនៃប្រាំពីរឆ្នាំ»
សរុបចំនួន សែសិបប្រាំបួនឆ្នាំ
ប្រាំបួនឆ្នាំ - «៤៩ ឆ្នាំ»
ក្នុងខែទីប្រាំពីរ នៅថ្ងៃទីដប់
នេះជាខែទីប្រាំពីរនៃប្រតិទិនហេព្រើរ។ ថ្ងៃទី ១០
ជិតដល់ចុងខែកញ្ញាលើប្រតិទិនលោកខាងលិច។
ថ្ងៃរំដោះបាប
នៅថ្ងៃនេះក្នុងមួយឆ្នាំៗ លោកមហាបូជាចារ្យថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់
ដើម្បីឲ្យព្រះអម្ចាស់អត់ទោសដល់អំពើបាបទាំងអស់របស់ជនជាតិអ៊ីស្រាអែល។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២៣:២៦ ។
Leviticus 25:10
ឆ្នាំទីហាសិប
នេះគឺជាលេខធម្មតា។ ការបកប្រែផ្សេងទៀត «ឆ្នាំ ៥០»
ឆ្នាំមេត្តាករុណា សម្រាប់អ្នករាល់គ្នា
ឆ្នាំមេត្តាករុណាដែលជនជាតិយូដាត្រូវប្រគល់ដីដល់ម្ចាស់ដើមរបស់ខ្លួនវិញហើយបានដោះលែងទាសករ។
ការបកប្រែផ្សេងទៀត «ឆ្នាំនៃការស្តារឡើងវិញសម្រាប់អ្នក» ឬ
«មួយឆ្នាំសម្រាប់អ្នកដើម្បីប្រគល់ដីនិងដោះលែងទាសករ»
គេនឹងទទួលបានមរតករបស់ខ្លួនត្រឡប់មកវិញ រីឯទាសករនឹងត្រលប់ទៅឯគ្រួសាររបស់គេវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែប្រគល់ទ្រព្យសម្បត្តិនិងទាសកររទៅវិញ»
Leviticus 25:11
ឆ្នាំមេត្តាករុណា សម្រាប់អ្នករាល់គ្នា
«មួយឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំសម្រាប់អ្នកដើម្បីប្រគល់ដីមកវិញ» ។
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាពួកគេកំពុងប្រគល់ដីឱ្យគេវិញ។
ការបកប្រែផ្សេងទៀត «មួយឆ្នាំសម្រាប់អ្នកប្រគល់ដីឱ្យខ្ញុំវិញ»
អ្នករាល់គ្នាត្រូវបរិភោគតែអ្វីដែលផ្តល់ផលដោយឯកឯងពីចម្ការតែប៉ុណ្ណោះ
ព្រះអម្ចាស់មិនអនុញ្ញាតឱ្យម្ចាស់ដីរៀបចំកម្មកររបស់ខ្លួន
ហើយប្រមូលដីដូចដែលគាត់បានធ្វើក្នុងរយៈពេលប្រាំមួយឆ្នាំទៀតទេ។
ទោះយ៉ាងណាក៏ដោយគាត់បានអនុញ្ញាតឱ្យបុគ្គលឆ្លងកាត់វាលស្រែនិងបរិភោគអ្វីដែលធ្លាក់ពីដើមឈើ
Leviticus 25:13
ក្នុងឆ្នាំមេត្តាករុណា
«ឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំនេះដើម្បីប្រគល់ដីនិងទាសករមានសេរីភាព»
Leviticus 25:15
ព័ត៌មានទូទៅ
ព្រះនៅតែបន្តប្រាប់ម៉ូសេពីអ្វីដែលប្រជាជនត្រូវធ្វើ។
ដែលអ្នកអាចប្រមូល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលអ្នកអាចប្រមូលផល»
ដល់ឆ្នាំមេត្តាករុណាបន្ទាប់
«ឆ្នាំក្រោយនៃការស្តារឡើងវិញ» ឬ «ឆ្នាំក្រោយនៃការប្រគល់ដី»
Leviticus 25:18
គោរពតាមបញ្ញត្តិ រក្សាច្បាប់ និងប្រតិបត្តិតាម
ឃ្លាទាំងអស់នេះមានន័យដូចគ្នា។
ពួកគេសង្កត់ធ្ងន់ថាប្រជាជនត្រូវតែគោរពតាមអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។
អ្នករាល់គ្នានឹងមានអាហារបរិភោគយ៉ាងបរិបូរ
នេះមានន័យថាពួកគេនឹងបរិភោគគ្រប់គ្រាន់រហូតដល់ក្រពះឆ្អែត។
ការបកប្រែផ្សេងទៀត «អ្នកនឹងបរិភោគរហូតដល់អ្នកឆ្អែត» ឬ
«អ្នកនឹងបរិភោគបានច្រើន»
Leviticus 25:20
អ្នកនឹងសួរថា
ត្រង់នេះ «អ្នក» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
យើងនឹងឲ្យពរអ្នករាល់គ្នា
ព្រះមានបន្ទូលអំពីពររបស់ព្រះអង្គដូចជាមនុស្សដែលអាចស្តាប់បង្គាប់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើព្រះពររបស់អ្វើងមកអ្នក» ឬ
«យើងនឹងប្រទានពរអ្នក»
ផលចាស់ រហូតដល់បានទទួលភោគផលនៃឆ្នាំថ្មី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពីអាហារដែលអ្នករក្សាទុក»
Leviticus 25:23
ព័ត៌មានទូទៅ
ព្រះអម្ចាស់នៅតែបន្តមានបន្ទូល។
អ្នករាល់គ្នាមិនអាចលក់ដីផ្តាច់ឲ្យគេរហូតបានទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវលក់ដីរបស់អ្នកជាអចិន្ត្រៃយ៍ទៅមនុស្សម្នាក់ទៀតទេ»
អ្នករាល់គ្នាត្រូវបង្កើតឲ្យមានច្បាប់ក្នុងការលោះដី
នាម «ការប្រោសលោះ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «លោះ» ឬ
«ទិញត្រឡប់មកវិញ» ។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែចងចាំថាម្ចាស់ដើមមានសិទ្ធិក្នុងការលោះដី
នៅពេលណាដែលគាត់ចង់បាន»
អ្នកត្រូវតែអនុញ្ញាតឲ្យក្រុមគ្រួសារអ្នកដែលបានលក់ដីឲ្យអ្នកនោះ ទិញត្រឡប់ទៅវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែអនុញ្ញាតឱ្យគ្រួសារ ដែលអ្នកបានទិញដី ដើម្បីទិញវាមកវិញ»
Leviticus 25:26
ជាទាសករ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «គាត់បានលក់ដី»
បង់ប្រាក់ឲ្យទៅអ្នកទិញ
នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«តបស្នងទៅអ្នកទិញដែលបានទិញវា លុយដែលអ្នកទិញនឹងរកបាន»
នៅឆ្នាំមេត្តាករុណា
«ឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំប្រគល់ដីមកវិញ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២៥:១០ ។
ដីនឹងត្រឡប់មកនាក់ដែលបានលក់វិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលបានទិញវានឹងប្រគល់ដីមកវិញ»
ត្រឡប់មកជាកម្មសិទ្ធិរបស់ម្ចាស់ដើមវិញ
«នឹងត្រឡប់ទៅទឹកដីរបស់គាត់វិញ»
Leviticus 25:29
ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីលក់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីគាត់បានលក់»
សិទ្ធិលោះផ្ទះត្រឡប់មកវិញ
នាម «ការប្រោសលោះ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «លោះ» ឬ
«ទិញត្រឡប់មកវិញ» ។ ការបកប្រែផ្សេងទៀត «សិទ្ធិក្នុងការលោះវា»
ប្រសិនបើ ពេញមួយឆ្នាំនេះផ្ទះដែលនៅក្នុងរបងទីក្រុងមិនត្រូវបានលោះទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ប្រសិនបើគាត់
ឬគ្រួសាររបស់គាត់មិនបានលោះផ្ទះ»
ផ្ទះនោះនឹងមិនបានត្រឡប់ទៅម្ចាស់ដើមវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បុរសដែលបានទិញផ្ទះនោះនឹងមិនចាំបាច់ប្រគល់វាមកវិញទេ»
ក្នុងឆ្នាំមេត្តាករុណា
«ឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំប្រគល់ដីនិងទាសករឲ្យមានសេរីភាព»
Leviticus 25:31
ប៉ុន្តែប្រសិនបើ ផ្ទះដែលមិននៅក្នុងរបងក្រុងទេ
ភូមិខ្លះមិនមានជញ្ជាំងព័ទ្ធជុំវិញទេ។
ដីទាំងនោះអាចលោះពេលណាក៏បាន ហើយត្រូវត្រឡប់ទៅម្ចាស់ដើមវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកអាចនឹងទិញផ្ទះទាំងនោះមកវិញ ហើយអ្នកដែលបានទិញវា
ត្រូវតែប្រគល់ឱ្យពួកគេវិញ»
នៅឆ្នាំមេត្តាករុណា
«ឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំប្រគល់ដី និងទាសករឲ្យមានសេរីភាព»
ផ្ទះរបស់ពួកលេវីក្នុងក្រុងរបស់លេវី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ផ្ទះដែលពួកលេវីកាន់កាប់នៅក្នុងក្រុងរបស់ពួកគេ»

generated on Wed Sep 10 16:16:32 2025

អាចលោះមកវិញពេលណាក៏បាន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកលេវីអាចលោះពួកគេនៅពេលណាក៏បាន»
Leviticus 25:33
ផ្ទះដែលបានលក់ទេនោះ
ផ្ទះដែលមានទីតាំងនៅក្នុងទីក្រុងរបស់គេត្រូវត្រឡប់ទៅជារបស់ម្ចាស់ដើមវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលបានទិញផ្ទះនៅក្នុងទីក្រុងដែលមានទីតាំង ត្រូវតែប្រគល់វាមកវិញ»
ក្នុងឆ្នាំមេត្តាករុណា
«ឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំប្រគល់ដីនិងទាសករឲ្យមានសេរីភាព»
ជាកម្មសិទ្ធិរបស់ពួកគេក្នុ ុងចំណោមជនជាតិអ៊ីស្រាអែល
ទឹកដីស្រុកកាណានត្រូវបានបែងចែកក្នុងចំណោមប្រជាជនអ៊ីស្រាអែល
ប៉ុន្តែក្នុងចំណោមទឹកដីនោះពួកលេវីត្រូវបានផ្តល់ឱ្យតែ ៤៨
ក្រុងប៉ុណ្ណោះដែលមានដីនៅជុំវិញពួកគេ។ ការបកប្រែផ្សេងទៀត
«ដីរបស់ពួកគេដែលជនជាតិអ៊ីស្រាអែលកាន់កាប់» ឬ
«ទ្រព្យសម្បត្តិរបស់ពួកគេនៅក្នុងទឹកដីអ៊ីស្រាអែល»
រឹងស្រែចំការដែលនៅជុំវិញទីក្រុងរបស់ពួកគេ មិនអាចលក់បានទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែពួកលេវីមិនត្រូវលក់ដី នៅជុំវិញទីក្រុងរបស់ពួកគេទេ»
Leviticus 25:35
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេ ពីអ្វីដែលប្រជាជនត្រូវធ្វើ។
មិនត្រូវយកការប្រាក់
«កុំឱ្យគាត់សងអ្នកច្រើនជាងអ្វីដែលអ្នកឱ្យគាត់ខ្ចីឡើយ»
Leviticus 25:39
អ្នកមិនត្រូវប្រើគេឲ្យធ្វើការដូចជាទាសករនោះទេ។ ត្រូវឲ្យគាត់ធ្វើការដូចអ្នកបម្រើ
នេះមានន័យថាម្ចាស់គឺត្រូវគោរពជនជាតិអ៊ីស្រាអែលច្រើនជាង
គាត់នឹងប្រព្រឹត្តទៅលើទាសករ។
ក្នុងឆ្នាំមេត្តាករុណា
«ឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំប្រគល់ដី និងទាសករឲ្យមានសេរីភាព»
Leviticus 25:42
ឃ្លាភ្ជាប់
ព្រះនៅតែបន្តប្រាប់ម៉ូសេ ពីអ្វីដែលគាត់ត្រូវប្រាប់ដល់ប្រជាជន។
ពួកគេជាអ្នកបម្រើរបស់យើង
«ជនរួមជាតិរបស់អ្នក គឺជាអ្នកបំរើរបស់ខ្ញុំ»
ពួកគេនឹងមិនត្រូវលក់ជាទាសករទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវលក់គេធ្វើជាទាសករទេ»
អ្នកអាចទិញគេពីនោះបាន
«អ្នកអាចទិញទាសករពីប្រជាជាតិទាំងនោះបាន»
Leviticus 25:47
បន្ទាប់ពីបងប្អូនរបស់អ្នកត្រូវបានទិញ គាត់នឹងអាចទិញត្រឡប់មកវិញបាន។
បងប្អូនរបស់គាត់អាចលោះគាត់មកវិញបាន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីជនបរទេសទិញជនជាតិអ៊ីស្រាអែលជាមិត្តរបស់អ្នក
អ្នកណាម្នាក់ក្នុងគ្រួសារអ៊ីស្រាអែលអាចនឹងទិញគាត់មកវិញបាន»
Leviticus 25:49
រហូតដល់ឆ្នាំមេត្តាករុណា
ជនជាតិអ៊ីស្រាអែលអាចធ្វើជាទាសករបានរហូតដល់ឆ្នាំមេត្តាករុណា។
ការណែនាំទាំងនេះគឺសំរាប់ពេលដែលជនជាតិអ៊ីស្រាអែលចង់ទិញសេរីភាពរបស់គេនៅមុនឆ្នាំមេត្តាករុណា
ឆ្នាំមេត្តាករុណា
«ឆ្នាំនៃការស្តារឡើងវិញ» ឬ «ឆ្នាំប្រគល់ដី និងទាសករឲ្យមានសេរីភាព»
ប្រាក់នៃការលោះរបស់គាត់ ត្រូវគិតទៅតាមថ្លៃឈ្នួល
កិរិយាស័ព្ទ «គិត» អាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវគិតគូរពីតម្លៃនៃការប្រោសលោះរបស់គាត់» ឬ
«ពួកគេត្រូវគិតតើត្រូវចំណាយប៉ុន្មាន
សម្រាប់ជនបរទេសដើម្បីរំដោះជនជាតិអ៊ីស្រាអែលឱ្យមានសេរីភាព»
ត្រូវគិតទៅតាមថ្លៃឈ្នួលដែលគេចំណាយឲ្យអ្នកបម្រើ
ប្រសិនបើជនជាតិអ៊ីស្រាអែលទិញសេរីភាពរបស់គាត់មកវិញ
ជនបរទេសនោះត្រូវជួលអ្នកបំរើម្នាក់អោយធ្វើកិច្ចការដែលជនជាតិអ៊ីស្រាអែលបានធ្វើប៉ុន្តែមិនធ្វើទេ។
កិរិយាស័ព្ទ «បង់ប្រាក់» និង «ជួល» អាចត្រូវបានបង្ហាញជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត «យោងទៅតាមអត្រាដែលមនុស្សម្នាក់ត្រូវបង់
ដើម្បីជួលអ្នកបំរើម្នាក់»
ចំនួននៃឆ្នាំគាត់អាចបន្តសម្រាប់អ្នកដែលបានទិញគាត់
«សម្រាប់រយៈពេលជាច្រើនឆ្នាំរហូតដល់ឆ្នាំមេត្តាករុណា ដែលជនជាតិអ៊ីស្រាអែល
នឹងបន្តធ្វើការប៉ុន្តែនឹងមិនធ្វើទេ»
Leviticus 25:51
គាត់ត្រូវបង់ប្រាក់
«ខ្ញុំបម្រើអ៊ីស្រាអែលត្រូវសងត្រលប់មកវិញ»
Leviticus 25:53
គាត់ត្រូវធ្វើការដូច
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ជនបរទេសដែលបានទិញគាត់ ធ្វើជាទាសករត្រូវតែប្រព្រឹត្តចំពោះគាត់»
អ្នកមិនត្រូវជិះជាន់ធ្វើបាបគាត់ឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់ធ្វើបាបគាត់បានទេ»
ប្រសិនបើ គាត់មិនត្រូវបានលោះខ្លួននោះទេ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម ហើយអ្នកណាដែលត្រូវបានគេលោះ
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ប្រសិនបើគ្មាននរណាម្នាក់ លោះគាត់ពីមធ្យោបាយទាំងនេះ
ពីអ្នកដែលបានទិញគាត់ឱ្យធ្វើជាទាសករទេ»
មិនត្រូវបាន
«តាមរបៀបនេះ»
រហូតដល់ឆ្នាំមេត្តាករុណាគាត់ព្រមទាំងកូនៗរបស់គាត់អាចចាកចេញពីម្ចាស់នោះបាន
ខ្ញុំបម្រើអ៊ីស្រាអែល និងកូនៗរបស់គេត្រូវបំរើជនបរទេសរហូតដល់ឆ្នាំមេត្តាករុណា
ហើយជនបរទេសត្រូវរំដោះជនជាតិអ៊ីស្រាអែល និងកូន ៗ
របស់គេអោយមានសេរីភាព។
ជនជាតិអ៊ីស្រាអែលជាអ្នកបម្រើរបស់យើង
«សម្រាប់ខ្ញុំប្រជាជនអ៊ីស្រាអែល ជាបាវបម្រើរបស់ព្រះ»។
នេះជាមូលហេតុដែលព្រះជាម្ចាស់សព្វព្រះហឫទ័យអោយជនជាតិអ៊ីស្រាអែលបានរួចផុតនៅឆ្នាំមេត្តាករុណ
ពួកគេជាអ្នកបំរើរបស់ព្រះអង្គ។
ពួកគេមិនត្រូវបានអនុញ្ញាតឱ្យធ្វើជាទាសករអចិន្ត្រៃយ៍របស់នរណាម្នាក់ឡើយ។

---

26 [1]អ្នករាល់គ្នាមិនត្រូវធ្វើរូបព្រះ ក៏មិនត្រូវឆ្លាក់ធ្វើរូបបដិមា ឬស្តូប ហើយក៏មិនត្រូវបញ្ឈរថ្មរចនានៅក្នុងស្រុករបស់អ្នក សម្រាប់ក្រាបថ្វាយបង្គំឡើយ
គឺយើងជាព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ្នក។[2]ចូរប្រារព្ធពិធីបុណ្យសប្ប័ទរបស់យើង ហើយគោរពទីសក្ការៈរបស់យើង។ យើងគឺព្រះអម្ចាស់។
[3]ប្រសិនបើ អ្នករាល់គ្នាកាន់តាមច្បាប់របស់យើង ហើយគោរព និងប្រតិបត្តិតាមបញ្ជារបស់យើង[4]នោះយើងនឹងធ្វើឲ្យមានភ្លៀងធ្លាក់មកលើស្រុកតាមរដូវកាល
នោះដីនឹងផ្តល់ភោគផល ហើយដើមឈើក៏នឹងផ្តល់ផលផ្លែដែរ។
[5]ការបោកបែនរបស់អ្នកនឹងបន្តរហូតដល់ពេលប្រមូលផលទំពាំងបាយជូរ ហើយការប្រមូលទំពាំងបាយជូររបស់អ្នកនឹងបន្តរហូតដល់រដូវការសាបព្រោះ។
អ្នកនឹងបរិភោគអាហារយ៉ាងបរិបូរ ហើយរស់នៅយ៉ាងសុខសាន្តក្នុងស្រុករបស់អ្នក។[6]យើងនឹងធ្វើឲ្យស្រុករបស់អ្នកមានសន្តិភាព
អ្នកនឹងដេកលក់ដោយមិនមានភ័យខ្លាចអ្វីឡើយ។ យើងនឹងយកសត្វសាហាវទាំងឡាយចេញពីស្រុករបស់អ្នករាល់គ្នា
ហើយក៏នឹងគ្មានសង្គ្រាមកើតឡើងក្នុងស្រុករបស់អ្នករាល់គ្នាដែរ។
[7]អ្នករាល់គ្នានឹងដេញតាមខ្មាំងសត្រូវ ហើយពួកគេនឹងដួលស្លាប់នៅមុខអ្នកដោយមុខដាវ។[8]អ្នករាល់គ្នាតែប្រាំនាក់ នឹងដេញតាមពួកគេមួយរយនាក់
ហើយអ្នករាល់គ្នាមួយរយនាក់ នឹងដេញតាមពួកគេមួយម៉ឺននាក់ ខ្មាំងសត្រូវរបស់អ្នកនឹងដួលស្លាប់នៅខាងមុខអ្នកដោយមុខដាវ។
[9]យើងនឹងសម្តែងសេចក្តីមេត្តាករុណាដល់អ្នករាល់គ្នា យើងនឹងធ្វើឲ្យអ្នករាល់គ្នាបង្កើតកូនចៅ និងកើនចំនួនច្រើនឡើង។
យើងនឹងចងសម្ព័ន្ធមេត្រីរបស់យើងជាមួយអ្នករាល់គ្នា[10]អ្នករាល់គ្នានឹងបរិភោគស្រូវចាស់។ អ្នករាល់គ្នាត្រូវយកស្រូវចាស់ចេញពីជង្រុក ដើម្បីយកជង្រុកដាក់ស្រូវថ្មីវិញ។

generated on Wed Sep 10 16:16:32 2025

[11]យើងនឹងរស់នៅកណ្ដាលចំណោមអ្នករាល់គ្នា ហើយយើងនឹងមិនចាកចេញពីអ្នករាល់គ្នាឡើយ។[12]យើងនឹងស្ថិតក្នុងកណ្ដាលចំណោមអ្នករាល់គ្នា
ដើម្បីធ្វើជាព្រះរបស់អ្នករាល់គ្នា។[13]យើងគឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីព្ទមក
ដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើជាទាសករក្នុងស្រុកនោះទៀតឡើយ។ យើងបានបំបាក់នឹមដែលនៅលើអ្នករាល់គ្នា ហើយធ្វើឲ្យអ្នករាល់គ្នាដើរដោយខ្ពស់មុខ។
[14]ក៏ប៉ុន្តែបើ អ្នករាល់គ្នាមិនស្ដាប់ពាក្យរបស់យើងហើយមិនប្រតិបត្តិតាមបទបញ្ជារបស់យើងទេ[15]ហើយប្រសិនបើ អ្នករាល់គ្នាបោះបង់ច្បាប់របស់យើង
ហើយមិនរវល់នឹងបទបញ្ជារបស់យើង គឺមិនប្រតិបត្តិតាមបទបញ្ជាទាំងប៉ុន្មានរបស់យើង ព្រមទាំងផ្ដាច់សម្ពន្ធមេត្រីរបស់យើង។
[9]ប៉ុន្តែ មិនត្រូវបះបោរប្រឆាំងនឹងព្រះអម្ចាស់ឡើយ ហើយក៏កុំខ្លាចមនុស្សនៅក្នុងស្រុកនោះដែរ។ ពួកយើងនឹងលេបស៊ីពួកគេយ៉ាងងាយដូចជាស៊ីម្ហូបអាហារ។ រនាំងការពាររបស់ពួកគេនឹងត្រូវរើចេញពីពួកគេ ដ្បិត ព្រះអម្ចាស់គង់ជាមួយនឹងយើង ដូច្នេះ កុំខ្លាចពួកកេឡើយ»។[10]ប៉ុន្តែ សហគមន៍ទាំងមូលគម្រាមចោលដុំថ្មសម្លាប់ពួកគេ។ នៅពេលនោះសិរីរុងរបស់ព្រះអម្ចាស់បានលេចចេញមកនៅត្រសាលប្រជុំចំពោះមុខកូនចៅអ៊ីស្រាអែលទាំងអស់គ្នា។
[11]ព្រះអម្ចាស់បានមានបន្ទូលទៅលោកម៉ូសេថា៖ «តើប្រជាជននេះនឹងមើលងាយយើងដល់ពេលណាទៀត? តើពួកគេនៅតេមិនជឿទុកចិត្តដល់យើងដល់ពេលណាទោះបីជាទីសម្គាល់នៃអំណាចរបស់យើង ដែលយើងបានធ្វើនៅកណ្តាលចំណោមពួកគេផងនោះ?[12]យើងនឹងវាយប្រហារពួកគេដោយគ្រោះកាច ហើយនឹងកាត់កាល់ពួកគេ រួចយើងនឹងបង្កើតប្រជាតិមួយដែលធំជាង ហើយខ្លាំងពូកែជាងពួកគេពីពូជពង្សរបស់អ្នក»។
[13]លោកម៉ូសេបានទូលទៅព្រះអម្ចាស់ថា៖ «ប្រសិនបើ ព្រះអង្គធ្វើដូច្នេះ នោះជនជាតិអេស៊ីបនឹងឮអំពីរឿងនេះ ដ្បិត ព្រះអង្គបានសង្គ្រោះប្រជាជននេះពីពួកគេ ដោយអំណាចចេស្តារបស់ព្រះអង្គ។[14]ពួកគេនឹងប្រាប់រឿងនេះដល់មនុស្សដែលរស់នៅក្នុងស្រុកនេះ។ ពួកគេបានឮថាព្រះអង្គគង់ជាមួយប្រជាជននេះ គេបានឃើញព្រះអង្គមុខទល់នឹងមុខ។ ពពករបស់ព្រះអង្គឈរនៅពីលើប្រជាជននេះ។ ព្រះអង្គយាងពីមុខពួកគេដោយសរសរពពកនៅពេលថ្ងៃ ហើយដោយសរសរភ្លើងនៅពេលយប់។
[15]ដូច្នេះ ប្រសិនបើព្រះអង្គសម្លាប់ពួកគេ ដូចជាមនុស្សតែម្នាក់នោះ នោះប្រជាជាតិទាំងឡាយដែលបានឮល្បីអំពីព្រះអង្គនឹងនាំគ្នានិយាយថា៖[16]«ព្រោះតែព្រះអម្ចាស់មិនអាចនាំប្រជាជននេះចូលទៅក្នុងទឹកដីដែលព្រះអង្គបានស្បថថាប្រទានឲ្យដល់ពួកគេបាន ទើបព្រះអង្គសម្លាប់ពួកគេនៅទីរហោស្ថានអស់»។
[17]ឥឡូវនេះ ទូលបង្គំសូមអង្វរព្រះអង្គ សូមព្រះអង្គប្រើអំណាចចេស្តាដ៏ខ្លាំងរបស់ព្រះអង្គ។ ដ្បិត ព្រះអង្គបានមានបន្ទូលថា៖[18]«ព្រះអម្ចាស់យឺតនឹងខ្ញាល់ ហើយពោរពេញទៅដោយសេចក្តីស្មោះត្រង់។ ព្រះអង្គតែងតែលើកលែងទោសដល់កំហុស និងសេចក្តីរំលង។ ប៉ុន្តែ ព្រះអង្គមិនបំភ្លេចកំហុសនោះទេ គឺព្រះអង្គនឹងដាក់ទោសអំពើបាបរបស់ដូនតាទៅលើកូនចៅរបស់ពួកគេបីទៅបួនតំណ។[19]ទូលបង្គំសូមអង្វរព្រះអង្គ សូមព្រះអង្គអត់ទោសចំពោះអំពើបាបរបស់ប្រជាជននេះ ដោយព្រោះតែសេចក្តីស្មោះត្រង់ដ៏អស្ចារ្យរបស់ព្រះអង្គ ដូចដែលព្រះអង្គតែងតែអត់ទោសដល់ប្រជាជននេះតាំងពីពេលដែលពួកគេនៅក្នុងស្រុកអេស៊ីបរហូតមកដល់ពេលនេះ»។
[20]ព្រះអម្ចាស់បានមានបន្ទូលថា៖ «យើងបានលើកលែងទោសឲ្យពួកគេតាមសំណូមពររបស់អ្នកហើយ[21]ប៉ុន្តែ យើងជាព្រះដែលមានព្រះជន្មគង់នៅ ហើយផែនដីទាំងមូលពេញដោយសិរីរុងរឿងរបស់យើង[22]នោះមនុស្សទាំងអស់នេះបានឃើញសិរីរុងរឿង និងទីសម្គាល់នៃអំណាចដ៏អស្ចារ្យរបស់យើង ដែលយើងបានធ្វើនៅស្រុកអេស៊ីប និងនៅក្នុងទីរហោស្ថាន ប៉ុន្តែ ពួកគេនៅតែល្បងលយើងដល់ទៅដប់ដង ហើយនៅតែមិនស្តាប់តាមសម្លេងរបស់យើង។
[23]ដូច្នេះ យើងសូមប្រកាសថា៖ ពួកគេពិតជានឹងមិនបានឃើញស្រុកដែលយើងបានស្បថជាមួយដូនតារបស់ពួកគេឡើយ។ អ្នកណាដែលមើលងាយយើង នឹងមិនបានឃើញស្រុកនោះឡើយ។[24]លើកលែងតែលោកកាលែបជាអ្នកបម្រើយើង ព្រោះលោកមានវិញ្ញាណខុសពីអ្នកផ្សេង ហើយលោកបានធ្វើតាមយើងគ្រប់ជំពូក នោះយើងនឹងនាំលោកចូលក្នុងស្រុកដែលលោកបានទៅសង្កេតមើល។ ពូជពង្សរបស់លោកនឹងបានកាន់កាប់ស្រុកនោះ។[25](ជនជាតិអាម៉ាឡេក និងជនជាតិកាណានរស់នៅតាមជ្រលងភ្នំ)។ ស្អែកនេះ ចូរត្រឡប់ទៅទីរហោស្ថានតាមផ្លូវសមុទ្រកក់វិញ»។
[26]ព្រះអម្ចាស់បានមានបន្ទូលទៅលោកម៉ូសេ និងលោកអ៊ើរ៉ុន។ ព្រះអង្គមានបន្ទូលថា៖[27]«តើយើងត្រូវទ្រាំនឹងសហគមន៍ដ៏អាក្រក់ដែលតែងតែរិះគន់យើងនេះដល់ពេលណា? យើងបានឮការអ៊ូរទាំរបស់កូនចៅអ៊ីស្រាអែលទាស់នឹងយើងហើយ។
[28]ចូរប្រាប់ពួកគេថា៖ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់! យើងជាព្រះដ៏មានព្រះជន្មគង់នៅ យើងនឹងប្រព្រឹត្តិចំពោះអ្នករាល់គ្នា ដូចដែលយើងគ្នាបានឮអ្នករាល់គ្នានិយាយ។
[29]សាកសពរបស់អ្នករាល់គ្នានឹងត្រូវដួលនៅក្នុងទីរហោស្ថាននេះ គឺអស់អ្នកដែលរអ៊ូរទាំទាស់នឹងយើង ជាអ្នកដែលបានរាប់ក្នុងពេលធ្វើរាប់ចំនួនអ្នកដែលមានអាយុចាប់ពីម្ភៃឆ្នាំឡើងទៅ ។[30]អ្នករាល់គ្នាពិតជានឹងមិនបានចូលទៅក្នុងស្រុកដែលយើងបានសន្យាឲ្យអ្នករាល់គ្នារស់នៅឡើយ លើកលែងតែលោកកាលែបជាកូនប្រុសរបស់លោកយេភូនេ និងលោកយ៉ូស្វេ ជាកូនប្រុសរបស់លោកនូន។
[31]ប៉ុន្តែ កូនចៅរបស់អ្នករាល់គ្នាដែលអ្នករាល់គ្នាបាននិយាយថានឹងក្លាយជាជនរងគ្រោះនោះ យើងនឹងនាំពួកគេចូលទៅក្នុងទឹកដីនោះ។ ពួកគេនឹងស្គាល់ស្រុកដែលអ្នករាល់គ្នាបានបដិសេធមិនទទួលយក។[32]ចំណែកអ្នករាល់គ្នាវិញ សាកសពរបស់អ្នករាល់គ្នានឹងដួលនៅក្នុងក្នុងទីរហោស្ថាននេះ។[33]កូនចៅរបស់អ្នករាល់គ្នានឹងឃ្វាលហ្វូងចៀមក្នុងទីហោស្ថាននេះរយៈពេលសែសិបឆ្នាំ។ ពួកគេនឹងទទួលទោសនៃអំពើបះបោររបស់អ្នករាល់គ្នារហូតទាល់តែអ្នករាល់គ្នាស្លាប់ចោលឆ្អឹងនៅក្នុងទីរហោស្ថាននេះអស់។
[34]ដូចដែលអ្នករាល់គ្នាបានទៅសង្កេតមើលស្រុកនោះរយៈពេលសែសិបថ្ងៃ នោះអ្នករាល់គ្នានឹងទទួលទោសនៃអំពើបាបរបស់អ្នករាល់គ្នារយៈពេលសែសិបឆ្នាំដែរ គឺមួយឆ្នាំសម្រាប់មួយថ្ងៃ នោះអ្នករាល់គ្នានឹងដឹងថា ការដែលធ្វើជាខ្មាំងសត្រូវនឹងយើងនោះវាយ៉ាងដូចម្តេចទៅវិញ។[35]យើងគឺជាព្រះអម្ចាស់បានមានបន្ទូលយ៉ាងណា យើងពិតជានឹងធ្វើយ៉ាងនោះដល់សហគមន៍ដ៏អាក្រក់ដែលបានប្រមូលគ្នាបះបោរទាស់នឹងយើងនេះ។ ពួកគេនឹងត្រូវកាត់ចោលទាំងស្រុង ហើយនឹងស្លាប់នៅទីនេះទាំងអស់គ្នា»។
[36]ដូច្នេះ ពួកអ្នកដែលលោកម៉ូសេបានចាត់ឲ្យទៅសង្កេតមើលស្រុកនោះបានស្លាប់ទាំងអស់គ្នាដោយគ្រោះនៅចំពោះព្រះអម្ចាស់។[37]អ្នកទាំងនេះគឺជាអ្នកដែលត្រឡប់មកវិញ ហើយនាំដំណឹងអាក្រក់អំពីស្រុកនោះមករាយការណ៍ ហើយបានធ្វើឲ្យសហគមន៍ទាំងមូលរអ៊ូរទាំទាស់នឹងលោកម៉ូសេ។[38]ក្នុងចំណោមមនុស្សទាំងអស់ដែលបានទៅមើលស្រុកនោះ មានតែលោកយ៉ូស្វេជាកូនប្រុសរបស់លោកនូន និងលោកកាលែបជាកូនប្រុសរបស់លោកយេភូនេទេដែលនៅរស់។
[39]នៅពេលដែលលោកម៉ូសេបានប្រាប់ដំណឹងនេះដល់កូនចៅអ៊ីស្រាអែល ពួកគេទូញសោកយ៉ាងខ្លាំង។[40]ពួកគេក្រោកឡើងពីព្រឹកព្រលឹម ហើយឡើងទៅលើកំពូលភ្នំ ទាំងពោលថា៖ «មើល៍! ពួកយើងនៅទីនេះ យើងនឹងទៅកន្លែងដែលព្រះអម្ចាស់បានសន្យា ដ្បិត ពួកយើងបានធ្វើបាបមែន»។
[41]ប៉ុន្តែ លោកម៉ូសេបានមានប្រសាន៍ថា៖ «ហេតុអ្វីបានជាអ្នករាល់បំពានលើបញ្ជារបស់ព្រះអម្ចាស់ដូច្នេះ? អ្នករាល់គ្នានឹងមិនបានសម្រេចឡើយ។[42]សូមកុំទៅឡើយ ដ្បិត ព្រះអម្ចាស់មិនគង់ជាមួយអ្នករាល់គ្នាដើម្បីការពារអ្នករាល់គ្នាពីការវាយប្រហារពីសត្រូវរបស់អ្នករាល់គ្នាឡើយ។[43]ជនជាតិអាម៉ាឡេក និងជនជាតិកាណាននៅទីនោះ ហើយអ្នករាល់គ្នានឹងស្លាប់ដោយសារដាវ ដ្បិត អ្នករាល់គ្នាបានងាកចេញពីព្រះជាម្ចាស់ហើយ។ ដូច្នេះ ព្រះអង្គនឹងមិនគង់ជាមួយអ្នករាល់គ្នាឡើយ»។
[44]ប៉ុន្តែ ពួកគេនៅតែមានះឡើងទៅស្រុកភ្នំ តែលោកម៉ូសេ និងហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់បានចាកចេញពីជំរំហើយ។[45]ពេលនោះជនជាតិអាម៉ាឡេក និងជនជាតិកាណានដែលរស់នៅតាមតំបន់ភ្នំនោះបានចុះមក។ ពួកគេបានវាយប្រហារជនជាតិអ៊ីស្រាអែលឲ្យចុះចាញ់រហូតដល់ហោម៉ា។

Numbers 14:1
ហេតុអ្វីបានជាព្រះអម្ចាស់នាំពួកយើងមកស្រុកនេះ ហើយត្រូវស្លាប់ដោយសារដាវដូច្នេះ
ប្រជាជនប្រើសំណួរនេះដើម្បីតវ៉ានិងចោទប្រកាន់ព្រះអម្ចាស់
ពីការប្រព្រឹត្តដោយអយុត្តិធម៌។ ត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់មិនគួរនាំយើងមកកាន់ទឹកដីនេះទេគឺត្រូវស្លាប់ដោយមុខដាវ»។
ត្រូវស្លាប់ដោយសារដាវ
នៅទីនេះ «ដាវ»
តំណាងឱ្យទាំងការសម្លាប់ដោយដាវឬត្រូវបានសម្លាប់នៅក្នុងសមរភូមិ។
ការបកប្រែផ្សេងទៀត « ស្លាប់នៅពេលមនុស្សវាយប្រហារយើងដោយដាវ» ឬ « ស្លាប់ក្នុងសមរភូមិ»
តើពួកយើងត្រឡប់ទៅស្រុកអេស៊ីព្ទវិញមិនល្អជាងទេឬ
ប្រជាជនប្រើសំណួរនេះដើម្បីលើកទឹកចិត្តប្រជាជន ឱ្យយល់ស្របជាមួយពួកគេថា
វានឹងប្រសើរជាង ក្នុងការវិលត្រឡប់ទៅប្រទេសអេស៊ីបវិញ។
ត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«វាជាការប្រសើរសម្រាប់ពួកយើងដើម្បីវិលត្រឡប់ទៅស្រុកអេស៊ីបជាជាងព្យាយាមយកឈ្នះស្រុកកាណា
Numbers 14:4
ពួកគេបាននិយាយគ្នាថា
នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
បានឱនមុខចុះ

generated on Wed Sep 10 16:16:32 2025

«ក្រាបចុះឱនមុខចុះប៉ះដី»។
លោកម៉ូសេនិងលោកអើរ៉ុនបានធ្វើដូច្នេះដើម្បីបង្ហាញថា
ពួកគេបានបន្ទាបខ្លួននៅចំពោះព្រះ។ ពួកគេខ្លាចថា
ព្រះនឹងដាក់ទណ្ឌកម្មប្រជាជនចំពោះការបះបោរប្រឆាំងនឹងគាត់។
ការបកប្រែផ្សេងទៀត «ក្រាបសំពះដោយបន្ទាបខ្លួនចំពោះព្រះ» ឬ
«ក្រាបសំពះដើម្បីអធិស្ឋានដល់ព្រះ»
Numbers 14:6
នុន.....យេភូនេ
ទាំងអស់នេះជាឈ្មោះបុរស។
ជាអ្នកដែលបានបញ្ជូន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកទាំងនោះគឺជាអ្នកដែលលោកម៉ូសេបានចាត់ឲ្យ មក»
បានហែកសម្លៀកបំពាក់របស់ខ្លួន
ការហែកសម្លៀកបំពាក់របស់មនុស្សម្នាក់ គឺជាកាយវិការមួយដែលបង្ហាញថា
គាត់មានបញ្ហាហើយកំពុងកាន់ទុក្ខ។
ស្រុកនោះពោរពេញទៅដោយទឹកដោះ និងទឹកឃ្មុំ
ពួកគេបាននិយាយអំពីដីដែលល្អសម្រាប់សត្វនិងរុក្ខជាតិដូចជាទឹកដោះគោនិងទឹកឃ្មុំ[illegible]
សូមមើលការបកប្រែនៅក្នុង ១៣:២៧។ ការបកប្រែផ្សេងទៀត
«វាល្អសម្រាប់ចិញ្ចឹមសត្វនិងដាំដំណាំ» ឬ «វាជាដីមានជីជាតិណាស់»
Numbers 14:9
សេចក្តីថ្លែងការណ៍ភ្ជាប់៖
លោកយ៉ូស្វេនិងលោកកាលែបបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ពួកយើងនឹងលេបស៊ីពួកគេយ៉ាងងាយដូចជាស៊ីម្ហូបអាហារ
លោកយ៉ូស្វេនិងលោកកាលែបនិយាយអំពីការបំផ្លាញសត្រូវរបស់ពួកគេ
ហាក់ដូចជាពួកសត្រូវស៊ីសាច់ពួកគេ។ ការបកប្រែផ្សេងទៀត
«យើងនឹងបំផ្លាញពួកគេយ៉ាងងាយស្រួលដូចដែលយើងអាចញ៉ាំចំណីអាហារ»
រនាំងការពាររបស់ពួកគេនឹងត្រូវរើចេញពីពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងដកការការពារពីពួកគេ»
រនាំងការពាររបស់ពួកគេ
នេះសំដៅទៅលើនរណាម្នាក់ ឬអ្វីក៏ដោយដែលអាចការពារពួកគេ។
ការបកប្រែផ្សេងទៀត «នរណាម្នាក់ដែលអាចការពារពួកគេ»
Numbers 14:11
តើប្រជាជននេះនឹងមើលងាយយើងដល់ពេលណាទៀត? តើពួកគេនៅតែមិនជឿទុកចិត្តដល់យើង
ដល់ពេលណាទោះបីជាទីសម្គាល់.....ពួកគេ?
ព្រះអម្ចាស់ប្រើសំនួរទាំងនេះដើម្បីបង្ហាញថា
ទ្រង់ខឹងហើយបានបាត់បង់ការអត់ធ្មត់ជាមួយប្រជាជន។
ត្រូវបានបកប្រែជាសេចក្តីថ្លែង។ ការបកប្រែផ្សេងទៀត
«ប្រជាជននេះបានមើលងាយយើងអស់រយៈពេលជាយូរមកហើយ»។
ពួកគេបានបរាជ័យក្នុងការជឿទុកចិត្តយើងជាយូរមកហើយ
ទោះបីមានទីសំគាល់អ្វីក៏ដោយ ... " ។
កាត់កាល់ពួកគេ
«បដិសេធន៏ពួកគេមិនឱ្យធ្វើជាប្រជាជនរបស់យើង»
នេះអាចបញ្ជាក់ថាទ្រង់នឹងបំផ្លាញពួកគេ
ហើយមានការបកប្រែខ្លះបកប្រែតាមរបៀបនោះ។
បង្កើតពីពូជពង្សរបស់អ្នក
នៅទីនេះ «របស់អ្នក» មានលក្ខណៈឯកតាហើយសំដៅទៅលើលោកម៉ូសេ។
Numbers 14:13
បានឃើញព្រះអង្គមុខទល់នឹងមុខ
អាចមានន័យថា ១) លោកម៉ូសេនិយាយអំពី
ព្រះបង្ហាញអង្គទ្រង់ដល់ប្រជាជនរបស់ទ្រង់ហាក់ដូចជាព្រះបានអនុញ្ញាតឲ្យពួកគេបាន[illegible]
ការបកប្រែផ្សេងទៀត «ពួកគេបានឃើញទ្រង់» ឬ ២)
លោកម៉ូសេនិយាយអំពីទំនាក់ទំនងជិតស្និទ្ធរវាងគាត់និងព្រះដូចជាលោកម៉ូសេអាចមើលឃើញ[illegible]
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ទ្រង់មានបន្ទូលមកទួលបង្គំដោយផ្ទាល់»
Numbers 14:15
ដូចជាមនុស្សតែម្នាក់នោះ
ការសម្លាប់ពួកគេទាំងអស់ក្នុងពេលតែមួយត្រូវបានគេនិយាយថា
ដូចជាសម្លាប់ពួកគេតែម្នាក់។ ការបកប្រែផ្សេងទៀត «ទាំងអស់ក្នុងពេលតែមួយ»
Numbers 14:17
ព្រះអង្គតែងតែលើកលែងទោសដល់កំហុស និងសេចក្តីរំលង
ទ្រង់ប្រាកដជានឹងមិនលុបបំបាត់មនុស្សដែលមានកំហុសនោះទេ។
ការលុបបំបាត់អំពើបាបរបស់មនុស្ស
គឺជាការប្រៀបធៀបមួយសម្រាប់ការបដិសេធន៏មិនដាក់ទណ្ឌកម្មពួកគេ។
ព្រះជាម្ចាស់នឹងមិនលុបចោលអំពើបាបរបស់មនុស្សដែលមានកំហុសនោះទេ។
ការបកប្រែផ្សេងទៀត «ទ្រង់នឹងដាក់ទោសអ្នកដែលមានកំហុស»
គឺព្រះអង្គនឹងដាក់ទោសអំពើបាបរបស់ដូនតាទៅលើកូនចៅរបស់ពួកគេ
ការដាក់ទណ្ឌកម្មមនុស្ស ត្រូវបានគេនិយាយដូចជាការដាក់ទណ្ឌកម្មគឺ
ជាវត្ថុមួយដែលនាំយកមកដាក់លើមនុស្ស។ ការបកប្រែផ្សេងទៀត
«នៅពេលទ្រង់ដាក់ទោសកូនចៅរបស់មនុស្សដែលមានកំហុសចំពោះអំពើបាបរបស់មនុស្សមានកំហុស»
Numbers 14:20
ហើយផែនដីទាំងមូលពេញដោយសិរីរុងរឿងរបស់យើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«សិរីល្អរបស់យើងនឹងពាសពេញលើផែនដី»
ពួកគេនៅតែល្បងលយើង
[illegible]
ដល់ទៅដប់ដង ហើយ
នៅទីនេះលេខ ១០ តំណាងអោយច្រើនដងពេក។ ការបកប្រែផ្សេងទៀត
«ច្រើនដងពេក»
នៅតែមិនស្តាប់តាមសម្លេងរបស់យើង
ត្រង់នេះ «បានស្តាប់» តំណាងអោយការស្តាប់បង្គាប់ហើយសម្លេងរបស់ព្រះ
តំណាងអោយអ្វីដែលទ្រង់មានបន្ទូល។ ការបកប្រែផ្សេងទៀត
«មិនបានធ្វើតាមអ្វីដែលយើងបាននិយាយទេ»
Numbers 14:23
ឃ្លាភ្ជាប់៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ព្រោះលោកមានវិញ្ញាណខុសពីអ្នកផ្សេង
នៅទីនេះ «វិញ្ញាណ» តំណាងឱ្យអាកប្បកិរិយារបស់គាត់។
លោកកាលែបសុខចិត្តស្តាប់បង្គាប់ព្រះជាម្ចាស់។
អាកប្បកិរិយារបស់គាត់អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «
ដោយសារគាត់មានអាកប្បកិរិយាខុសគ្នា» ឬ
«ពីព្រោះគាត់សុខចិត្តគោរពតាមព្រះ» (សូមមើល និង)
Numbers 14:26
តើយើងត្រូវទ្រាំនឹងសហគមន៍ដ៏អាក្រក់ដែលតែងតែរិះគន់យើងនេះដល់ពេលណា?
ព្រះយេហូវ៉ាសួរសំណួរនេះពីព្រោះគាត់បានបាត់បង់ការអត់ធ្មត់ជាមួយប្រជាជន។
វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«យើងបានអត់ធ្មត់ដល់សហគមន៍អាក្រក់នេះដែលបានរិះគន់យើងយូរមកហើយ»។
យើងបានឮការអ៊ូរទាំរបស់កូនចៅអ៊ីស្រាអែលទាស់នឹងយើងហើយ
ពាក្យ «អ៊ូរទាំ» ជានាមអរូបីអាចត្រូវបានបង្ហាញជាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «យើងបានឮប្រជាជនអ៊ីស្រាអែលរអ៊ូរទាំ»
Numbers 14:28
ដូចដែលយើងគ្នាបានឮអ្នករាល់គ្នានិយាយ
ដូចអ្វីដែលយើងបានលឺអ្នកនិយាយ។
ខ្មោចរបស់អ្នករាល់គ្នានឹងត្រូវដួល
សាកសពរបស់ពួកគេដែលបានធ្លាក់ចុះតំណាងឱ្យពួកគេស្លាប់។
ការបកប្រែផ្សេងទៀត «អ្នកនឹងស្លាប់»
អ្នកដែលបានរាប់ក្នុងពេលធ្វើរាប់ចំនួន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលលោកម៉ូសេបានរាប់នៅក្នុងជំរឿន»
[illegible]
«អាយុ២០ឆ្នាំឡើងទៅ»
[illegible] នៅពេលដែលព្រះជាម្ចាស់បានមានបន្ទូលជាមួយគាត់។
សាកសពរបស់អ្នករាល់គ្នានឹងដួល
សាកសពរបស់ពួកគេដែលបានធ្លាក់ចុះតំណាងឱ្យពួកគេស្លាប់។
ការបកប្រែផ្សេងទៀត «អ្នកនឹងស្លាប់»
កូនចៅរបស់អ្នករាល់គ្នានឹងឃ្វាលហ្វូងចៀមក្នុងទីហោស្ថាននេះ
ជំនាន់ខ្លះបកប្រែថា «កូន ៗ របស់អ្នកនឹងវង្វេងនៅទីរហោស្ថាន» ។
នេះគឺដោយសារតែនៅសម័យបុរាណអ្នកគង្វាលតែងតែដើរពីកន្លែងមួយទៅកន្លែងមួយ

generated on Wed Sep 10 16:16:32 2025

ដូច្នេះហ្វូងចៀមនិងហ្វូងរបស់ពួកគេអាចរកឃើញស្មៅ។
ពួកគេនឹងទទួលទោសនៃអំពើបះបោររបស់អ្នករាល់គ្នា
«ពួកគេត្រូវទទួលផលវិបាកនៃអំពើរបស់គេ» ឬ
«ពួកគេត្រូវតែរងទុក្ខដោយសារអំពើរបស់ពួកគេ»
រហូតទាល់តែអ្នករាល់គ្នាស្លាប់ចោលឆ្អឹង
សាកសពគឺជាសាកសព។
ចុងបញ្ចប់នៃសាកសពរបស់ពួកគេតំណាងឱ្យចុងក្រោយនៃការស្លាប់របស់ពួកគេ។
ការបកប្រែផ្សេងទៀត «រហូតដល់អ្នកចុងក្រោយបានស្លាប់» ឬ «
ទាល់តែអ្នកទាំងអស់គ្នាស្លាប់»
Numbers 14:34
នោះអ្នករាល់គ្នានឹងទទួលទោសនៃអំពើបាបរបស់អ្នករាល់គ្នា
«ទទួលរងនូវផលវិបាកនៃអំពើបាបរបស់អ្នក» ឬ
«រងទុក្ខដោយសារអំពើបាបរបស់អ្នក»
ពួកគេនឹងត្រូវកាត់ចោលទាំងស្រុង
នេះប្រហែលជាមានន័យថា ពួកគេនឹងលែងមានទៀតហើយ។
ការបកប្រែផ្សេងទៀត «ពួកគេនឹងមកដល់ទីបញ្ចប់» ឬ «ពួកគេនឹងត្រូវបំផ្លាញ»
Numbers 14:36
ដូច្នេះ ពួកអ្នក.....អ៊ូរទាំទាស់នឹងលោកម៉ូសេ
ព័ត៌មានក្នុង ១៤:៣៦
ត្រូវបានរៀបចំជាថ្មីដូច្នេះអត្ថន័យរបស់វាអាចងាយយល់ជាង។
បានស្លាប់ទាំងអស់គ្នាដោយគ្រោះនៅចំពោះព្រះអម្ចាស់
«បានស្លាប់ដោយរោគពិសនៅចំពោះព្រះភ័ក្ត្រព្រះអង្គ»។ ដោយសារតែវានិយាយថា
ពួកគេបានស្លាប់នៅចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ
វាបញ្ជាក់ថាទ្រង់បានធ្វើឱ្យពួកគេស្លាប់។ ការបកប្រែផ្សេងទៀត
«បានស្លាប់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ដោយសាររោគពិសដែលទ្រង់បានធ្វើ» (សូមមើលព័ត៌មានផ្ទៃខាងក្រោយ
explicit)
Numbers 14:39
មើល៍!
«មើល៍!» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។ «ជាការពិត»
Numbers 14:41

ហេតុអ្វីបានជាអ្នករាល់បំពានលើបញ្ជារបស់ព្រះអម្ចាស់ដូច្នេះ?
ម៉ូសេសួរសំណួរនេះដើម្បីស្តីបន្ទោសប្រជាជនអ៊ីស្រាអែល។
សំណួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
«អ្នកមិនគួររំលោភសេចក្តីបង្គាប់របស់ព្រះអម្ចាស់ម្តងទៀតទេ»។
ព្រះអម្ចាស់មិនគង់ជាមួយអ្នករាល់គ្នា
ការជួយពួកគេត្រូវបានគេនិយាយថាកំពុងនៅជាមួយពួកគេ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងមិនជួយអ្នកទេ»
ដើម្បីការពារអ្នករាល់គ្នាពីការវាយប្រហារពីសត្រូវរបស់អ្នករាល់គ្នាឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីការពារសត្រូវរបស់អ្នកពីការកម្ចាត់អ្នក» ឬ
«ដើម្បីផ្តល់ឱ្យអ្នកនូវជ័យជម្នះលើសត្រូវរបស់អ្នក»
អ្នករាល់គ្នានឹងស្លាប់ដោយសារដាវ
ត្រង់នេះ «ដាវ» សំដៅទៅលើការប្រយុទ្ធ។ ការបកប្រែផ្សេងទៀត
«អ្នកនឹងស្លាប់នៅក្នុងសមរភូមិ» ឬ
«ពួកគេនឹងសម្លាប់អ្នកនៅពេលអ្នកប្រយុទ្ធនឹងពួកគេ»
អ្នករាល់គ្នាបានងាកចេញពីព្រះជាម្ចាស់ហើយ
ការស្តាប់បង្គាប់ព្រះអម្ចាស់ត្រូវបាននិយាយអំពីការដើរតាមទ្រង់ហើយបញ្ឈប់ការដែលត្រូវបានគេនិយាយ
ជាការងាកចេញពីទ្រង់។ ការបកប្រែផ្សេងទៀត « អ្នកឈប់គោរពតាមព្រះអម្ចាស់»
ឬ «អ្នកបានសម្រេចចិត្តមិនស្តាប់បង្គាប់ព្រះអម្ចាស់»
ព្រះអង្គនឹងមិនគង់ជាមួយអ្នករាល់គ្នាឡើយ
ការជួយពួកគេត្រូវបានគេនិយាយថាកំពុងនៅជាមួយពួកគេ។ ការបកប្រែផ្សេងទៀត
«ទ្រង់នឹងមិនជួយអ្នកទេ»
Numbers 14:44
ត្រូវបានលើកឡើងឬមានឡើងទៅស្រុកភ្នំ
"ពួកគេហ៊ានឡើងទៅលើភ្នំទោះបីព្រះមិនយល់ព្រម"
ឡើងទៅស្រុកភ្នំ
ភាគច្រើននៃទឹកដីអ៊ីស្រាអែលត្រូវបានដំឡើង។
នៅពេលដែលជនជាតិអ៊ីស្រាអែលឆ្លងទន្លេយ័រដាន់ដើម្បីវាយលុកជនជាតិកាណាន
មានភ្នំជាច្រើនដែលពួកគេត្រូវឡើងដើម្បីទៅជិតទឹកដីកាណាន។

---

15 [1]បន្ទាប់មក ព្រះអម្ចាស់បានមានបន្ទូលទៅលោកម៉ូសេថា៖[2]«ចូរប្រាប់ដល់កូនចៅអ៊ីស្រាអែលថា នៅពេលអ្នករាល់គ្នាចូលទៅក្នុងស្រុកដែលអ្នករាល់គ្នានឹងរស់នៅ
ដែលព្រះអម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នានោះ[3]ពេលអ្នករាល់គ្នារៀបចំតង្វាយដោយភ្លើងថ្វាយព្រះអម្ចាស់នោះ ទោះបីជាតង្វាយដុត ឬយញ្ញបូជាលាបំណន់ ឬតង្វាយ
ស្ម័គ្រចិត្ត ឬតង្វាយនៅពេលបុណ្យផ្សេងៗក្តី នោះត្រូវថ្វាយកូនគោ ឬកូនចៀម ដើម្បីធ្វើឲ្យមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យដល់ព្រះអម្ចាស់។
[4]អ្នករាល់គ្នាដែលត្រូវថ្វាយតង្វាយដុតដល់ព្រះអម្ចាស់ ត្រូវយកតង្វាយគ្រាប់ធញ្ញជាតិដែលមានម៉្សៅម៉ដ្ឋបីគីឡូក្រាមជាមួយប្រេងមួយលីត្រកន្លះមកជាមួយផង។[5]និងត្រូវ
យកស្រាទំពាំងបាយជូរមួយលីត្រកន្លះសម្រាប់ជាតង្វាយច្រួច សម្រាប់ចៀមនីមួយៗដែលអ្នករាល់គ្នាត្រូវថ្វាយជាតង្វាយដុត ឬថ្វាយយញ្ញបូជា។
[6]ប្រសិនបើ អ្នករាល់គ្នាថ្វាយចៀមឈ្មោល ត្រូវរៀបចំតង្វាយគ្រាប់ធញ្ញជាតិ ដែលមានម៉្សៅម៉ដ្ឋល្អប្រាំមួយគីឡូក្រាមលាយជាមួយប្រេងពីរលីត្រ។[7]សម្រាប់តង្វាយច្រួចអ្នក
រាល់គ្នាត្រូវថ្វាយស្រាទំពាំងបាយជូរពីរលីត្រ។ វានឹងធ្វើឲ្យមានក្លិនឈ្ងុយដល់ព្រះអម្ចាស់។
[8]នៅពេលអ្នករាល់គ្នារៀបចំគោឈ្មោះមួយសម្រាប់ជាតង្វាយដុតទាំងមូល ឬជាយញ្ញបូជាដើម្បីលាបំណន់ ឬជាតង្វាយមេត្រីដល់ព្រះអម្ចាស់[9]នោះអ្នករាល់គ្នាត្រូវយក
តង្វាយគ្រាប់ធញ្ញជាតិដែលមានម៉្សៅមដ្ឋល្អប្រាំបួនគីឡូក្រាមលាយជាមួយនឹងប្រេងបីលីត្រ មកថ្វាយជាមួយគោឈ្មោលនោះ។[10]អ្នកក៏ត្រូវថ្វាយស្រាទំពាំង
បាយជូរបីលីត្រសម្រាប់ជាតង្វាយច្រួច ដែលជាតង្វាយដោយភ្លើង ដើម្បីធ្វើឲ្យមានក្លិនឈ្ងុយដល់ព្រះអម្ចាស់។
[11]ត្រូវធ្វើរបៀបនេះសម្រាប់រាល់គោឈ្មោល កូនចៀម ឬកូនពពែ សម្រាប់កូនចៀមឈ្មោល និងកូនពពែឈ្មោលនីមួយៗ។[12]គ្រប់ទាំងយញ្ញបូជាដែលអ្នករាល់គ្នារៀបចំ និង
ថ្វាយត្រូវធ្វើតាមដូចដែលបានរៀបរាប់នៅទីនេះ។[13]ជនជាតិអ៊ីស្រាអែលទាំងអស់ដែលកើតនៅក្នុងស្រុកត្រូវធ្វើការទាំងនេះតាមរបៀបនេះ នៅពេលដែលនរណាម្នាក់នាំ
តង្វាយដោយភ្លើងដើម្បីធ្វើឲ្យមានក្លិនឈ្ងុយដែលគាប់ព្រះហឫទ័យដល់ព្រះអម្ចាស់។
[14]ប្រសិនបើ មានជនបរទេសកំពុងស្នាក់នៅជាមួយអ្នករាល់គ្នា ឬអ្នកណាដែលរស់នៅជាមួយអ្នករាល់គ្នាច្រើនតំណមកហើយ គេត្រូវថ្វាយតង្វាយដែលធ្វើដោយភ្លើងដែល
ធ្វើឲ្យមានក្លិនឈ្ងុយដល់ព្រះអម្ចាស់ នោះពួកគេត្រូវធ្វើដូចជាអ្នករាល់គ្នាបានធ្វើដែរ។[15]ត្រូវមានច្បាប់តែមួយសម្រាប់សហគមន៍ និងសម្រាប់ជនបរទេសដែលស្នាក់នៅជា
មួយអ្នករាល់គ្នា គឺជាច្បាប់ដែលមិនប្រែប្រួលសម្រាប់កូនចៅរបស់អ្នករាល់គ្នានៅគ្រប់ជំនាន់តទៅ។ អ្នករាល់គ្នាធ្វើយ៉ាងណា នោះអ្នកធ្វើដំណើរដែលស្នាក់នៅជាមួយអ្នក
រាល់គ្នាក៏ត្រូវធ្វើយ៉ាងនោះដែរ។ ពួកគេត្រូវតែប្រព្រឹត្តិដូចអ្នករាល់គ្នាប្រព្រឹត្តិនៅចំពោះព្រះអម្ចាស់ដែរ។[16]ត្រូវមានច្បាប់តែមួយ និងបញ្ញត្តិតែមួយសម្រាប់អ្នករាល់គ្នា
និងសម្រាប់ជនជបរទេសដែលស្នាក់នៅជាមួយអ្នករាល់គ្នា»។
[17]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេម្តងទៀត។ ព្រះអង្គមានបន្ទូលថា៖[18]«ចូរប្រាប់ទៅកូនចៅអ៊ីស្រាអែលថា ពេលអ្នករាល់គ្នាចូលទៅក្នុងស្រុកដែលយើងនឹង
យកអ្នករាល់គ្នាទៅ[19]ហើយកាលណាអ្នករាល់គ្នាបរិភោគអាហាររបស់ស្រុកនោះ អ្នករាល់គ្រូវទុកខ្លះជាតង្វាយ ថ្វាយដល់យើង។
[20]អ្នករាល់គ្នាត្រូវញែកម៉្សៅដែលលាយដំបូងមកធ្វើនំប៉័ងមួយដុំសម្រាប់ជាតង្វាយ ដូចជាតង្វាយពីទីលានបោកស្រូវដែរ។ គឺអ្នករាល់គ្នាត្រូវធ្វើតាមរបៀបនេះ។[21]អ្នករាល់គ្នា
ត្រូវថ្វាយម៉្សៅដែលលាយដំបូងដល់យើងនៅគ្រប់ជំនាន់តទៅ។
[22]ពេលខ្លះអ្នករាល់នឹងប្រព្រឹត្តិបាបដោយអចេតនា គឺនៅពេលអ្នករាល់គ្នាមិនធ្វើតាមបញ្ញត្តិទាំងនេះដែលយើងបានបង្គាប់លោកម៉ូសេ[23]គឺគ្រប់ទាំងសេចក្តីដែលយើង
បានបង្គាប់តាមរយៈលោកម៉ូសេចាប់តាំងពីថ្ងៃដែលយើងចាប់ផ្តើមប្រទានបញ្ញាត្តិដល់អ្នករាល់គ្នារហូតដល់គ្រប់ជំនាន់មនុស្សតទៅ។[24]ក្នុងករណីដែលប្រព្រឹត្តិអំពើបាប
ដោយអចេតនា ហើយសហគមន៍ក៏មិនបានដឹង នោះសហគមន៍ទាំងមូលត្រូវថ្វាយគោស្ទាវមួយជាតង្វាយដុតដើម្បីធ្វើឲ្យមានក្លិនឈ្ងុតដល់ព្រះអម្ចាស់។ ហើយក៏ត្រូវថ្វាយ
តង្វាយគ្រាប់ធញ្ញជាតិ និងតង្វាយច្រួច តាមបញ្ញត្តិបានបង្គាប់ និងត្រូវថ្វាយពពែឈ្មោលមួយទុកជាតង្វាយលោះបាបដែរ។
[25]បូជាចារ្យត្រូវធ្វើពិធីលោះបាបសម្រាប់សហគមន៍ប្រជាជនអ៊ីស្រាអែលទាំងមូល។ ពួកគេនឹងទទួលបានការលើកលែងទោសដោយព្រោះតែអំពើបាបដោយអចេតនា។ ពួក
ត្រូវបាននាំយញ្ញបូជារបស់ពួកគេ ទុកជាតង្វាយធ្វើដោយភ្លើងដល់យើង។ ពួកត្រូវនាំតង្វាយលោះបាបរបស់ខ្លួនចំពោះយើងសម្រាប់អំពើបាបដោយអចេតនារបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[26]ធ្វើដូច្នោះ សហគមន៍ប្រជាជនអ៊ីស្រាអែលទាំងមូល និងអំពើបាបរបស់ជនបរទេសដែលស្នាក់នៅជាមួយពួកគេ នឹងបានទទួលការលើកលែងទោស ពីព្រោះមនុស្សទាំងអស់បានប្រព្រឹត្តដោយអចេតនា។
[27]ប្រសិនបើ មនុស្សម្នាក់ប្រព្រឹត្តអំពើបាបដោយអចេតនា នោះគេត្រូវថ្វាយពពែញីអាយុមួយឆ្នាំជាតង្វាយលោះបាប។[28]បូជាចារ្យត្រូវធ្វើពិធីលោះបាបនៅចំពោះព្រះអម្ចាស់សម្រាប់អ្នកដែលបានប្រព្រឹត្តអំពើបាបដោយអចេតនានោះ។ អ្នកនោះនឹងទទួលបានការលើកលែងទោស នៅពេលដែលធ្វើពិធីលោះបានរួចហើយ។[29]អ្នកត្រូវមានច្បាប់តែមួយសម្រាប់អស់អ្នកដែលបានប្រព្រឹត្តអ្វីមួយដោយអចេតនា គឺច្បាប់តែមួយសម្រាប់អ្នកដែលកើតក្នុងស្រុកក្នុងចំណោមកូនចៅអ៊ីស្រាអែល និងសម្រាប់ជនបរទេសដែលស្នាក់នៅជាមួយពួកគេ។
[30]ប៉ុន្តែ បើអ្នកណាប្រព្រឹត្តអំពើបាបដោយចេតនា ទោះបីគេកើតក្នុងស្រុក ឬជនបរទេសក្តី គេបានប្រមាថមើលងាយយើងហើយ។[31]ដ្បិត ពួកគេបានមើលងាយពាក្យរបស់យើង ក៏បំពានលើបញ្ជារបស់យើងដែរ គឺត្រូវកាត់អ្នកនោះចោល។ អំពើបាបរបស់គេ នឹងនៅពីលើគេ។
[32]នៅពេលដែលប្រជាជនអ៊ីស្រាអែលនៅក្នុងទីរហោស្ថាន ពួកគេបានឃើញបុរសម្នាក់ដើររើសអុសនៅថ្ងៃសប្ប័ទ។[33]អ្នកដែលបានឃើញគាត់ ក៏នាំគាត់មកជួបលោកម៉ូសេ និងលោកអ៊ើរ៉ុន ព្រមទាំងសហគមន៍អ៊ីស្រាអែលទាំងមូល។[34]ពួកគេបានឃុំគាត់ទុកពីព្រោះពួកគេមិនដឹងច្បាស់ថាតើត្រូវធ្វើយ៉ាងដូចម្តេចចំពោះគាត់។
[35]នោះព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេថា៖ «បុរសម្នាក់នោះត្រូវមានទោសដល់ស្លាប់។ សហគមន៍ទាំងមូលត្រូវយកដុំថ្មគប់សម្លាប់អ្នកនោះនៅក្រៅជំរំ»។[36]ដូច្នេះ សហគមន៍ទាំងមូលបាននាំអ្នកនោះចេញទៅខាងក្រៅជំរំ ហើយចោលដុំថ្មសម្លាប់គាត់ដូចដែលព្រះអម្ចាស់បានបង្គាប់លោកម៉ូសេ។
[37]ព្រះអម្ចាស់ក៏មានបន្ទូលមកលោកម៉ូសេទៀតថា៖[38]«ចូរប្រាប់ដល់ដល់កូនចៅអ៊ីស្រាអែលថា ហើយបង្គាប់ពួកគេថា ចូរដេររំយោលនៅជាយអាវ ហើយភ្ជួរនឹងខ្សែពណ៌ខៀវដែលដេរនៅជាយអាវនោះ។ ពួកគេត្រូវធ្វើបែបនេះនៅគ្រប់ជំនាន់មនុស្សតទៅ។[39]ធ្វើដូច្នេះដើម្បីទុកជាការរំឭកពិសេសសម្រាប់អ្នករាល់គ្នា នៅពេលដែលអ្នករាល់គ្នាក្រឡេកមើលរំយោលនោះ អ្នករាល់គ្នានឹងនឹកឃើញអស់ទាំងក្រឹត្យវិន័យរបស់យើងដែលអ្នករាល់គ្នាត្រូវប្រព្រឹត្តតាម ដើម្បីកុំឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមអំពើចិត្ត និងតាមភ្នែករបស់អ្នករាល់គ្នា ហើយបង្ខូចខ្លួនរបស់អ្នកឲ្យទៅវាឡើយ។
[40]ធ្វើដូច្នេះដើម្បីឲ្យអ្នករាល់គ្នានឹកឃើញនៅក្នុងគំនិត ហើយប្រព្រឹត្តតាមគ្រប់ទាំងបញ្ញត្តិរបស់យើង ហើយដើម្បីឲ្យអ្នករាល់គ្នាបានបរិសុទ្ធសម្រាប់យើងជាព្រះរបស់អ្នករាល់គ្នា។[41]យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាដែលបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីប ដើម្បីធ្វើជាព្រះរបស់អ្នករាល់គ្នា។ យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។

Numbers 15:1
ព័ត៌មានទូទៅ៖
ជនគណនា១៥:១-៣២
ប្រាប់ពីអ្វីដែលព្រះបានប្រាប់ដល់លោកម៉ូសេឲ្យប្រាប់ប្រជាជនអ៊ីស្រាអែល។
ដើម្បីធ្វើឲ្យមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យដល់ព្រះអម្ចាស់
ត្រូវបង្កើតក្លិនឈ្ងុយពីហ្វូងចៀម
ឬធ្វើអោយមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់»។
ជាមួយនឹងក្លិនក្រអូបតំណាងឱ្យសេចក្តីរីករាយរបស់ទ្រង់ ជាមួយអ្នកថ្វាយតង្វាយ។
ការបកប្រែផ្សេងទៀត «ដើម្បីផ្គាប់ព្រះហឫទ័យព្រះអម្ចាស់ដោយដង្វាយដុត យញ្ញបូជាពីហ្វូងចៀមឬហ្វូងចៀម»
Numbers 15:4
ថ្វាយតង្វាយដុ្ត
នេះសំដៅទៅលើដង្វាយដែលបានរៀបរាប់នៅក្នុង ១៥:៤ ។
មួយភាគដប់នៃអេផា
អេផាគឺ មួយឯកតានៃបរិមាណស្មើនឹងប្រហែល ២២ លីត្រ។ ការបកប្រែផ្សេងទៀត «ប្រហែល ២ លីត្រ» ឬ «ពីរលីត្រ»
ប្រេងមួយលីត្រកន្លះមកជាមួយ
ទីបួននៃហ៊ីន «ហ៊ីនគឺជាឯកតានៃបរិមាណស្មើនឹងប្រហែល ៣.៧ លីត្រ»។ ការបកប្រែផ្សេងទៀត «ប្រហែល ១លីត្រ» ឬ «មួយលីត្រ»
Numbers 15:6
ពីរភាគដប់នៃអេផា
អេផាគឺ មួយឯកតានៃបរិមាណស្មើនឹងប្រហែល ២២ លីត្រ។ ការបកប្រែផ្សេងទៀត «លីត្រ» ឬ «៤លីត្រកន្លះ»
មួយភាគបីនៃហ៊ីន
ហ៊ីនគឺ ជាឯកតានៃបរិមាណស្មើនឹងប្រហែល ៣.៧ លីត្រ។ ការបកប្រែផ្សេងទៀត «មួយលីត្រ»
វានឹងធ្វើឲ្យមានក្លិនឈ្ងុយដល់ព្រះអម្ចាស់
វានឹងបង្កើតក្លិនដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។
សេចក្តីរីករាយរបស់ព្រះអម្ចាស់ជាមួយនឹងក្លិនក្រអូបតំណាងឱ្យសេចក្តីរីករាយរបស់ទ្រង់ជាមួយអ្នកថ្វាយតង្វាយ
ការបកប្រែផ្សេងទៀត «អ្នកនឹងគាប់ព្រះហឫទ័យព្រះអម្ចាស់ដោយដង្វាយនេះ»
Numbers 15:8
បីភាគដប់នៃអេផា
អ្នកអាចប្តូរវាទៅជារង្វាស់ទំនើប។ ការបកប្រែផ្សេងទៀត «ប្រាំមួយលីត្រកន្លះ»
ពាក់កណ្តាលហ៊ីន
អ្នកអាចប្តូរវាទៅជារង្វាស់ទំនើប។ ការបកប្រែផ្សេងទៀត «ពីរលីត្រ»
ដោយភ្លើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដែលអ្នកដុតនៅលើអាសនៈ»
ដើម្បីធ្វើឲ្យមានក្លិនឈ្ងុយដល់ព្រះអម្ចាស់
បង្កើតក្លិនដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។
ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ ដែលថ្វាយយញ្ញបូជាត្រូវបាននិយាយដូចជាព្រះសព្វព្រះហឫទ័យនឹងក្លិននៃគ្រឿងបូជា។
ការបកប្រែផ្សេងទៀត «ដើម្បីគាប់ព្រះហឫទ័យព្រះអម្ចាស់ដោយថ្វាយដង្វាយនេះ»
Numbers 15:11
ត្រូវធ្វើរបៀបនេះ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែធ្វើវា»
ត្រូវធ្វើតាមដូចដែលបានរៀបរាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវធ្វើដូចយើងបានពិពណ៌នា»
ដោយភ្លើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេដុតនៅលើអាសនា»
ដើម្បីធ្វើឲ្យមានក្លិនឈ្ងុយដែលគាប់ព្រះហឫទ័យដល់ព្រះអម្ចាស់
បង្កើតក្លិនដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។
ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់
ដែលថ្វាយយញ្ញបូជាគឺហាក់ដូចជាព្រះអម្ចាស់សព្វព្រះហឫទ័យនឹងក្លិននៃគ្រឿងបូជាដែរ។
ការបកប្រែផ្សេងទៀត «ដើម្បីគាប់ព្រះហឫទ័យព្រះអម្ចាស់ដោយថ្វាយដង្វាយនេះ»
Numbers 15:14
គេត្រូវថ្វាយតង្វាយដែលធ្វើដោយភ្លើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «គាត់ត្រូវដុតតង្វាយនៅលើអាសនា»
ដែលធ្វើឲ្យមានក្លិនឈ្ងុយដល់ព្រះអម្ចាស់
បង្កើតក្លិនដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។
ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ ដែលថ្វាយយញ្ញបូជាត្រូវបាននិយាយដូចជាព្រះសព្វព្រះហឫទ័យនឹងក្លិននៃគ្រឿងបូជា។
ការបកប្រែផ្សេងទៀត «ដើម្បីគាប់ព្រះហឫទ័យព្រះអម្ចាស់ដោយថ្វាយដង្វាយនេះ»
[illegible] ដែលស្នាក់នៅជាមួយអ្នករាល់គ្នាក៏ត្រូវធ្វើយ៉ាងនោះដែរ
អាចមានន័យថា ១) «អ្នកនិងអ្នកដំណើរដែលស្នាក់នៅជាមួយអ្នកគឺដូចគ្នានៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់» ឬ ២) «ច្បាប់ដូចគ្នាអនុវត្តនឹចំពោះអ្នកនិងអ្នកធ្វើដំណើរ»
ពួកគេត្រូវតែប្រព្រឹត្តដូចអ្នករាល់គ្នាប្រព្រឹត្តនៅចំពោះព្រះអម្ចាស់ដែរ
«គាត់ត្រូវតែធ្វើដូចអ្នកប្រព្រឹត្តនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់
ព្រោះវានិយាយថាពួកគេត្រូវប្រព្រឹត្តដូចជនជាតិអ៊ីស្រាអែលនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់
វាមានន័យថា ពួកគេត្រូវតែគោរពតាមរាល់បទបញ្ជារបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត
«គាត់ត្រូវតែធ្វើសកម្មភាពដូចដែលអ្នកធ្វើនិងគោរពតាមទាំងអស់

generated on Wed Sep 10 16:16:32 2025

បទបញ្ជារបស់ព្រះអម្ចាស់»
Numbers 15:17
អាហាររបស់ស្រុកនោះ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អាហារដែលដីផលិត» ឬ «អាហារដែលអ្នកផលិតនៅលើដី»
Numbers 15:20
ម៉្សៅដែលលាយដំបូង
អត្ថន័យដែលអាចធ្វើបានគឺសំដៅទៅលើ ១)
គ្រាប់ធញ្ញជាតិដំបូងដែលពួកគេនឹងប្រមូលបានក្នុងអំឡុងពេលប្រមូលផល ឬ ២)
ម្សៅដែលពួកគេនឹងផលិតចេញពីគ្រាប់ដំបូងរបស់ពួកគេ។
មួយដុំ
ការហៅវាថានំប៉័ងបង្កប់ន័យថា ពួកគេនឹងចំអិននំនេះជាមុនសិន។
សម្រាប់ជាតង្វាយ ដូចជាតង្វាយ
លេខសម្គាល់នេះ «លើកវាឡើង» សំដៅទៅលើការផ្តល់វាជាអំណោយ។
ការបកប្រែផ្សេងទៀត «ដើម្បីថ្វាយជូនជាអំណោយ»
ជាតង្វាយ ដូចជាតង្វាយពីទីលានបោកស្រូវដែរ
តង្វាយត្រូវបានគេនិយាយថា
បានមកពីទីលានបោកស្រូវពីព្រោះនេះជាកន្លែងដែលពួកគេនឹងញែកគ្រាប់ចេញពីផ្នែកផ្សេងទៀតនៃដំណាំ
Numbers 15:22
អត្ថបទភ្ជាប់៖
ព្រះជាម្ចាស់បន្តប្រាប់ដល់លោកម៉ូសេពីអ្វីដែលគាត់និងប្រាប់ដល់បណ្តាជន។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះគឺសំដៅដល់ប្រជាជនអ៊ីស្រាអែល។
ដើម្បីធ្វើឲ្យមានក្លិនឈ្ងុតដល់ព្រះអម្ចាស់
បង្កើតក្លិនដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។
ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដែលថ្វាយយញ្ញបូជាគឺ
ហាក់ដូចជាព្រះសព្វព្រះហឫទ័យនឹងក្លិននៃគ្រឿងបូជា។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់គាប់ព្រះទ័យ ដោយដុតវា»
ត្រូវថ្វាយតង្វាយគ្រាប់ធញ្ញជាតិ និងតង្វាយច្រួច
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវធ្វើដង្វាយធញ្ញជាតិនិងដង្វាយច្រួច»
តាមបញ្ញត្តិបានបង្គាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដូចជាក្រឹត្យវិន័យ»
ឬ «ដូចដែលយើងបានបញ្ជានៅពេលយើងធ្វើក្រឹត្យវិន័យនេះ»
Numbers 15:25
ពួកគេនឹងទទួលបានការលើកលែងទោស
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«យើងនឹងអត់ទោសឱ្យពួកគេ»
ធ្វើដោយភ្លើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «គេធ្វើដោយភ្លើង»
ឬ «គេដុតលើអាសនា»
ច្បោះ សហគមន៍កូនចៅអ៊ីស្រាអែលទាំងមូល នឹងបានទទួលការលើកលែងទោស
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«យើងនឹងលើកលែងទោសដល់សហគមន៍ទាំងអស់របស់ប្រជាជនអ៊ីស្រាអែល»
Numbers 15:27
ពពែញីអាយុមួយឆ្នាំ
«ពពែញីអាយុ ១ឆ្នាំ»
អ្នកនោះនឹងទទួលបានការលើកលែងទោស នៅពេលដែលធ្វើពិធីលោះបានរួចហើយ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ខ្ញុំនឹងអត់ទោសអោយមនុស្សនោះនៅពេលបូជាចារ្យបានធ្វើដង្វាយលោះបាប»
Numbers 15:30
គឺត្រូវកាត់អ្នកនោះចោលពីចំណោមប្រជាជនរបស់គេ
ពាក្យប្រៀបធៀប «កាត់ចេញ» មានអត្ថន័យយ៉ាងហោចណាស់បីយ៉ាង។
ពួកគេអាចបង្ហាញជាទម្រង់កិរិយាស័ព្ទសកម្ម ១)
«ប្រជាជនរបស់គាត់ត្រូវបញ្ជូនគាត់ទៅឆ្ងាយ» ឬ ២)
«យើងនឹងលែងចាត់ទុកគាត់ជាប្រជាជនអ៊ីស្រាអែលម្នាក់ទៀត ៣)
«ប្រជាជនរបស់គាត់ត្រូវតែសំលាប់គាត់»។
បំពានលើបញ្ជារបស់យើង
ការមិនគោរពបទបញ្ញត្តិត្រូវបានគេនិយាយថា ជាការបំពាន។ ការបកប្រែផ្សេងទៀត
«មិនបានគោរពតាមបទបញ្ជារបស់យើង« ឬ
«មិនបានស្តាប់តាមអ្វីដែលយើងបានបញ្ជា»
អំពើបាបរបស់គេ នឹងនៅពីលើគេ
នៅទីនេះ «អំពើបាប» តំណាងអោយ ១) ការដាក់ទណ្ឌកម្មចំពោះអំពើបាបនោះឬ
២) កំហុសនៃអំពើបាបនោះ។
ធ្វើឲ្យគ្រាប់ធញ្ញជាតិ
ត្រូវបានដាក់ទណ្ឌកម្មឬ ២) មានទោស។ ការបកប្រែផ្សេងទៀត ១)
«យើងនឹងដាក់ទណ្ឌកម្មគាត់ដោយសារតែអំពើបាបរបស់គាត់» ឬ ២)
«យើងនឹងចាត់ទុកគាត់ថាមានកំហុស»
Numbers 15:32
ពួកគេមិនដឹងច្បាស់ថាតើត្រូវធ្វើយ៉ាងដូចម្តេចចំពោះគាត់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់មិនបានប្រកាសពីអ្វីដែលពួកគេត្រូវធ្វើជាមួយគាត់ទេ»
Numbers 15:35
បុរសម្នាក់នោះត្រូវមានទោសដល់ស្លាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកច្បាស់ជាត្រូវសម្លាប់បុរសនោះ» ឬ «បុរសនោះច្បាស់ជាត្រូវស្លាប់»
Numbers 15:37
កូនចៅអ៊ីស្រាអែល
អ៊ីស្រាអែលគឺជាឈ្មោះមួយផ្សេងទៀតសម្រាប់យ៉ាកុប។
ប្រជាជនអ៊ីស្រាអែលជាកូនចៅរបស់គាត់។ អេធី: "ប្រជាជនអ៊ីស្រាអែល"
ដើម្បីកុំឲ្យអ្នករាល់គ្នាប្រព្រឹត្ត
"ដើម្បីអោយពួកគេគោរពតាម"
ដើម្បីកុំឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមអំពើចិត្ត និងតាមភ្នែករបស់អ្នករាល់គ្នា
«មើលទៅ» នៅទីនេះគឺជាពាក្យប្រៀបធៀបសម្រាប់គិតអំពី។
ចិត្តតំណាងឱ្យអ្វីដែលមនុស្សម្នាក់ចង់បានហើយភ្នែកតំណាងឱ្យអ្វីដែលមនុស្សមើលឃើញនិងចង់បាន។
ការបកប្រែផ្សេងទៀត «ដូច្នេះអ្នកមិនគិតពីអ្វីដែលអ្នកចង់បាន»
Numbers 15:40
អត្ថបទភ្ជាប់៖
ព្រះជាម្ចាស់បន្តប្រាប់លោកម៉ូសេនូវអ្វីដែលត្រូវប្រាប់ប្រជាជនអ៊ីស្រាអែល។ ពាក្យថា
«អ្នក» គឺសំដៅទៅលើប្រជាជន។
សម្រាប់យើង
នេះជាលេខសម្គាល់។ ការបកប្រែផ្សេងទៀត «ចងចាំ»
យើងជាព្រះរបស់អ្នករាល់គ្នា
ឃ្លានេះត្រូវបានធ្វើម្តងទៀតសម្រាប់ការសង្កត់ធ្ងន់។

---

16 [1]លោកកូរេជាកូនប្រុសរបស់លោកយីតសារ ជាចៅរបស់លោកកេហាត់ ក្នុងកុលសម្ព័ន្ធលេវី ជាមួយលោកដាថាន និងលោកអប៊ីរ៉ាម ជាកូនប្រុសរបស់លោកអេលាប
ព្រមទាំងលោកអូន ជាកូនប្រុសរបស់លោកពេឡេត មកពីកុលសម្ព័ន្ធរូបេន។[2]ពួកគេបាននាំគ្នាងើបបះបោរប្រឆាំងនឹងលោកម៉ូសេ ដោយមានមនុស្សផ្សេងទៀតពី
ប្រជាជនអ៊ីស្រាអែលដែលសុទ្ធតែជាមេដឹកនាំរបស់សហគមន៍ និងមនុស្សគ្រប់គ្នាស្គាល់ច្បាស់ ចំនួនពីររយហាសិបនាក់បានចូលរួមដែរ។[3]ពួកគេបានប្រមូលផ្តុំគ្នាតតាំង
ជាមួយលោកម៉ូសេ និងលោកអ៊ើរ៉ុន។ ពួកនោះបាននិយាយទៅលោកទាំងពីរថា៖ «ពួកលោកធ្វើជ្រុលពេកហើយ! សហគន៍ទាំងមូលសុទ្ធតែបានញែកដាច់ដោយឡែក
ហើយព្រះអម្ចាស់គង់ក្នុងចំណោមពួកគេដែរ។ ហេតុអ្វីបានជាពួកលោក លើកខ្លួនឯងខ្ពស់ជាងមនុស្សផ្សេងទៀតក្នុងសហគមន៍របស់ព្រះអម្ចាស់ដូច្នេះ?»
[4]នៅពេលដែលលោកម៉ូសេបានឮដូច្នេះ លោកបានឱនមុខចុះ។[5]លោកបាននិយាយទៅលោកកូរេថា និងអស់អ្នកដែលនៅជាមួយលោកកូរេថា៖ «នៅព្រឹកនេះ ព្រះអម្ចាស់
នឹងធ្វើឲ្យគ្រប់គ្នាដឹងថា តើអ្នកណាជារបស់ព្រះអង្គ ហើយអ្នកណាដែលត្រូវបានញែកដាច់ដោយឡែកសម្រាប់ព្រះអង្គ ព្រះអង្គនឹងនាំមនុស្សទាំងនោះចូលទៅជិតព្រះអង្គ
គឺអ្នកណាដែលព្រះអង្គជ្រើសរើស ព្រះអង្គនឹងនាំចូលជិតព្រះអង្គ។
[6]សូមធ្វើបែបនេះ លោកកូរេ និងបក្សពួករបស់អ្នក[7]គឺស្អែកនេះ ត្រូវយកពានមករៀងៗខ្លួនមក ហើយដាក់ភ្លើង និងគ្រឿងក្រអូបក្នុងនោះនៅចំពោះព្រះអម្ចាស់។ អ្នកណា
ដែលព្រះអម្ចាស់ជ្រើសរើស អ្នកនោះនឹងត្រូវបានញែកដាច់ដោយឡែកសម្រាប់ព្រះអម្ចាស់។ ពូជពង្សដ៏អាក្រក់អើយ! អ្នករាល់គ្នាធ្វើជ្រុលពេកហើយ»។

generated on Wed Sep 10 16:16:32 2025

[8]លោកម៉ូសេបានមានប្រសាសន៍ទៅលោកកូរេទៀតថា៖ «ឥឡូវនេះ កូនចៅលេវីអើយ! សូមស្តាប់ខ្ញុំ[9]តើការដែលព្រះជាម្ចាស់បានញែកអ្នកដាច់ដោយឡែកពីសហគមន៍អ៊ីស្រាអែល នាំអ្នកចូលជិតព្រះអង្គ បម្រើកិច្ចការរបស់ព្រះអង្គនៅក្នុងរោងឧបោសថ ហើយឲ្យឈរនៅមុខសហគមន៍ដើម្បីបម្រើពួកគេ ជាការតូចតាចឬ?[10]ព្រះអង្គបាននាំអ្នក និងពូជពង្សរបស់លេវីជាបងប្អូនរបស់អ្នកចូលជិតព្រះអង្គ ប៉ុន្តែ អ្នកនៅតែចង់បានតំណែងជាបូជាចារ្យថែមទៀត។[11]ហេតុនេះហើយបានជា អ្នក និងបក្សពួករបស់អ្នកបានប្រមូ͏ូលផ្តុំគ្នាប្រឆាំងនឹងព្រះអម្ចាស់។ ហេតុអ្វីបានជាអ្នកអ៊ូរទាំប្រឆាំងនឹងលោកអ៊ើរ៉ុន ដែលជាអ្នកស្តាប់បង្គាប់ព្រះអម្ចាស់ដូច្នេះ?»។
[12]បន្ទាប់មក លោកម៉ូសេបានឲ្យគេទៅហៅលោកដាថាន និងលោកអប៊ីរ៉ាម ជាកូនរបស់លោកអេលាប ប៉ុន្តែ លោកទាំងពីរនិយាយថា៖ «ពួកយើងមិនឡើងទៅទេ។[13]តើការដែលអ្នកបាននាំពួកយើងចេញមកពីស្រុកដែលសម្បូរទៅដោយទឹកដោះ និងទឹកឃ្មុំ ដើម្បីសម្លាប់ពួកយើងនៅក្នុងទីរហោស្ថាននេះ តើជារឿងតូចតាចឬ? ឥឡូវនេះ អ្នកចង់តាំងខ្លួនអ្នកធ្វើជាអ្នកដឹកនាំយើងទៀត។[14]លើសពីនេះទៀត អ្នកមិនបាននាំពួកយើងចូលទៅក្នុងស្រុកដែលសម្បូរទៅដោយទឹកដោះ និងទឹកឃ្មុំទេ ហើយក៏មិនបានឲ្យស្រែ និងចម្ការទំពាំងបាយជូរមកពួកយើងទុកជាមរតកដែរ»។
[15]លោកម៉ូសេខឹងយ៉ាងខ្លាំង ហើយបានទូលដល់ព្រះអម្ចាស់ថា៖ សូមព្រះអង្គកុំទទួលតង្វាយរបស់ពួកគេអី។ ទូលបង្គំមិនបានយកសត្វលាមួយក្បាលពីពួកគេឡើយ ហើយទួលបង្គំក៏មិនបានធ្វើឲ្យពួកគេណាម្នាក់ឈឺចាប់ដែរ»។[16]បន្ទាប់មក លោកម៉ូសេបានមានប្រសាសន៍ទៅលោកកូរេថា៖ «ស្អែកនេះ អ្នក និងបក្សពួករបស់អ្នកទាំងអស់គ្នាត្រូវចូលទៅចំពោះព្រះអម្ចាស់ គឺទាំងអ្នក ទាំងពួកគេ ព្រមទាំងលោកអ៊ើរ៉ុនផងដែរ។[17]ម្នាក់ៗត្រូវយកពានរបស់ខ្លួនមក ហើយដាក់ភ្លើងនៅក្នុងនោះផង។ មនុស្សម្នាក់ៗត្រូវយកពានរបស់ខ្លួនចូលទៅចំពោះព្រះអម្ចាស់ គឺពីររយហាសិបពាន។ អ្នក និងលោកអ៊ើរ៉ុនក៏ត្រូវយកពានរបស់ខ្លួនទៅដែរ។
[18]ដូច្នេះ មនុស្សគ្រប់គ្នាបានយកពានរបស់ខ្លួនទាំងដាក់ភ្លើង ទាំងដាក់គ្រឿងក្រអូបនៅក្នុងនោះមក ហើយបានឈរនៅច្រកទ្វារចូលត្រសាលប្រជុំជាមួយលោកម៉ូសេ និងលោកអ៊ើរ៉ុន។[19]លោកកូរេបានប្រមូលសហគមន៍ទាំងមូលប្រឆាំងនឹងលោកម៉ូសេ និងលោកអ៊ើរ៉ុននៅច្រកទ្វារចូលត្រសាលជួបជុំ ពេលនោះសិរីរុងរឿងរបស់ព្រះអម្ចាស់បានលេចមកឲ្យសហគមន៍ទាំងមូលបានឃើញ។
[20]បន្ទាប់មក ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេ និងលោកអ៊ើរ៉ុនថា៖[21]«ចូរញែកខ្លួនដោយឡែកចេញពីចំណោមសហគមន៍នេះ ដែលយើងនឹងបំផ្លាញពួកគេឲ្យវិនាសឥឡូវនេះ»។[22]លោកម៉ូសេ និងលោកអ៊ើរ៉ុនឱនមុខចុះ ហើយទូលថា៖ «ឱព្រះជាម្ចាស់អើយ! ព្រះអង្គជាព្រះនៃវិញ្ញាណរបស់មនុស្សទាំងអស់ បើមនុស្សតែម្នាក់ប្រព្រឹត្តអំពើបាប តើព្រះអង្គត្រូវខឹងនឹងសហគមន៍ទាំងមូលឬ?»
[23]ព្រះអម្ចាស់ឆ្លើយមកលោកម៉ូសេវិញ។ ព្រះអង្គមានបន្ទូលថា៖[24]«ចូរប្រាប់ទៅសហគមន៍នេះថា ចូរនាំគ្នាចេញឲ្យឆ្ងាយពីត្រសាលរបស់លោកកូរេ ត្រសាលរបស់លោកដាថាន និងត្រសាលរបស់លោកអប៊ីរ៉ាមទៅ»។
[25]នោះលោកម៉ូសេបានក្រោកឡើង ហើយដើរទៅរកលោកដាថាន និងលោកអប៊ីរ៉ាម ទាំងមានមេដឹកនាំរបស់ជនជាតិអ៊ីស្រាអែលទៅជាមួយគាត់ដែរ។
[26]គាត់បានមានប្រសាសន៍ទៅសហគមន៍ទាំងមូលថា៖ «ឥឡូវនេះ ចូរនាំគ្នាចាកចេញពីត្រសាលរបស់ពួកមនុស្សអាក្រក់នេះ ហើយកុំប៉ះពាល់អ្វីរបស់ពួកគេឡើយ បើមិនដូច្នោះទេ អ្នករាល់គ្នាក៏នឹងត្រូវបំផ្លាញដោយព្រោះអំពើបាបរបស់ពួកគេដែរ។[27]ដូច្នេះ សហគមន៍ដែលនៅជិតនឹងត្រសាលរបស់លោកកូរេ លោកដាថាន និងលោកអប៊ីរ៉ាមបានចាកចេញឆ្ងាយពីពួកគេ។ លោកដាថាន និងលោកអប៊ីរ៉ាមបានចេញមកឈរនៅច្រកទ្វារត្រសាលរបស់ខ្លួន ជាមួយនឹងប្រពន្ធ និងកូនៗរបស់ពួកគេ។
[28]នោះ លោកម៉ូសេបានមានប្រសាសន៍ថា៖ «តាមរយៈការនេះ អ្នករាល់គ្នានឹងដឹងថា ព្រះអម្ចាស់បានចាត់ខ្ញុំឲ្យមកធ្វើការទាំងអស់នេះមែន ដ្បិត ខ្ញុំមិនបានធ្វើការទាំងនោះដោយចិត្តខ្លួនឯងឡើយ។[29]ប្រសិនបើ បុរសទាំងនេះស្លាប់តាមបែបធម្មជាតិ ដូចជាការស្លាប់ផ្សេងៗដែលធ្លាប់កើតឡើង នោះបានន័យថា ព្រះអម្ចាស់មិនបានចាត់ខ្ញុំឲ្យមកទេ។[30]ប៉ុន្តែប្រសិនបើ ព្រះអម្ចាស់ធ្វើឲ្យដីបើកឡើងហើយលេបពួកគេចូលដូចជាចូលក្នុងមាត់មួយយ៉ាងធំ ជាមួយនឹងក្រុមគ្រួសារទាំងអស់របស់ពួកគេ ហើយបើពួកគេធ្លាក់ចូ͏ូលទាំងរស់ទៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះអ្នករាល់គ្នាត្រូវយល់ថា បុរសទាំងនេះបានមើលងាយព្រះអម្ចាស់»
[31]ពេលលោកម៉ូសេមានប្រសាសន៍ចប់ភ្លាម ដីនៅពីក្រោមមនុស្សទាំងនេះក៏បើកឡើង។[32]ផែនដីបានបើកមាត់របស់វា ហើយលេបពួកគេ ក្រុមគ្រួសាររបស់គេ និងមនុស្សរបស់លោកកូ͏ូរ ព្រមទាំងអ្វីទាំងអស់ដែលជាកម្មសិទ្ធិរបស់ពួកគេចូលអស់ទៅ។
[33]ពួកគេ និងមនុស្សទាំងអស់នៅក្នុងគ្រួសាររបស់ពួកគេបានធ្លាក់ចូលទៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទាំងរស់។ ផែនដីបានបិទគ្របពីលើពួកគេ គឺពួកគេបានស្លាប់បែបនេះពីចំកណ្តាលណោមសហគមន៍។[34]កូនចៅអ៊ីស្រាអែលទាំងអស់ដែលនៅជុំវិញពួកគេ បានរត់គេចចេញពីសម្រែករបស់ពួកគេ ដោយពោលថា៖ «ដីនឹងលេបពួកយើងចូលដែរ!»។[35]ពេលនោះ អណ្តាតភ្លើងបានចេញមកពីព្រះអម្ចាស់មកបញ្ឆេះមនុស្សពីររយហាសិបនាក់ដែលកពុងតែថ្វាយគ្រឿងក្រអូប។
[36]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេម្តងទៀត ដោយបន្ទូលថា៖[37]«ចូរប្រាប់ លោកអេឡាសារ កូនប្រុសរបស់បូជាចារ្យអ៊ើរ៉ុន ឲ្យគេយកពានចេញពីអណ្តាតភ្លើង ដ្បិតពាននេះត្រូវញែកដាច់ដោយឡែកសម្រាប់យើង។ ហើយឲ្យគេយកកម្ទេចធ្យូងចោលឲ្យឆ្ងាយ[38]រួចត្រូវយកពានរបស់អ្នកដែលស្លាប់ដោយព្រោះតែអំពើរបាបរបស់ខ្លួន ទៅដំជាបន្ទះសម្រាប់ស្រោបកន្លែងថ្វាយតង្វាយ។ ដ្បិត ពួកគេបានថ្វាយរបស់ទាំងនោះនៅចំពោះយើងហើយ ដូច្នេះ របស់ទាំងនេះត្រូវបានញែកដោយឡែកសម្រាប់យើង។ វានឹងបានជាទីសម្គាល់នៃវត្តមានរបស់យើងចំពោះប្រជាជនអ៊ីស្រាអែល»។
[39]លោកបូជាចារ្យអេឡាសារបានយកពានលង្ហិន ជារបស់ដែលមនុស្សបានឆេះភ្លើងស្លាប់នេះធ្លាប់ប្រើ ទៅដំជាបន្ទះសម្រាប់គ្រប់ស្រោបអាសនា។[40]ដើម្បីទុកជាការរំឭកដល់ប្រជាជនអ៊ីស្រាអែលថា ក្រៅពីកូនចៅរបស់លោកអ៊ើរ៉ុន គ្មានអ្នកអាចចូលទៅដុតគ្រឿងក្រអូបនៅចំពោះព្រះអម្ចាស់បានឡើយ ដើម្បីកុំឲ្យពួកគេបានដូចជាលោកកូរេ និងបក្សពួករបស់គាត់ ដូចដែលព្រះអម្ចាស់បានបង្គាប់តាមរយៈលោកម៉ូសេ។
[41]ប៉ុន្តែ នៅព្រឹកស្អែកឡើងសហគមន៍កូនចៅអ៊ីស្រាអែលទាំងមូលបានរអ៊ូរទាំទាស់នឹងលោកម៉ូសេ និងលោកអ៊ើរ៉ុនទៀត។ ពួកគេបានពោលថា៖ «លោកបានសម្លាប់ប្រជារាស្ត្ររបស់ព្រះអម្ចាស់»។[42]នៅពេលដែលហសគមន៍ប្រមូលគ្នាប្រឆាំងនឹងលោកម៉ូសេ និងលោកអ៊ើរ៉ុន ខណៈពេលដែលពួកគេបែរមុខមើលទៅត្រសាលប្រជុំ ហើយមើល៍! មានពពកគ្របពីលើត្រសាលជិត។ សិរីរុងរឿងរបស់ព្រះអម្ចាស់បានលេចមក[43]ហើយលោកម៉ូសេ និងលោកអ៊ើរ៉ុនបានមកឈរពីមុខត្រសាលប្រជុំនោះ។
[44]បន្ទាប់មក ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេ។ ព្រះអង្គមានបន្ទូលថា៖[45]«ចូរចេញឲ្យឆ្ងាយពីមុខសហគមន៍នេះ ដ្បិត យើងនឹងកម្ទេចពួកគេឲ្យវិនាសភ្លាមនេះ»។ ពេលនោះ លោកម៉ូសេ និងលោកអ៊ើរ៉ុនបានឱនមុខក្រាបចុះដល់ដី។[46]លោកម៉ូសេបានប្រាប់ទៅលោកអ៊ើរ៉ុនថា៖ «ចូរយកពាន ហើយដាក់ភ្លើងលើវា ដែលយកចេញពីកន្លែងថ្វាយតង្វាយ ហើយដាក់គ្រឿងក្រអូបក្នុងនោះ យកទៅសហគមន៍ជាប្រញាប់ រួចធ្វើពិធីដោះបាបឲ្យពួកគេទៅ ពីព្រោះ សេចក្តីក្រោធកំពុងមកពីព្រះអម្ចាស់។ គ្រោះកាចក៏បានចាប់ផ្តើមហើយដែរ»។
[47]ដូច្នេះ លោកអ៊ើរ៉ុនក៏បានធ្វើតាមការណែនាំរបស់លោកម៉ូសេ។ គាត់បានរត់ចូលទៅកណ្តាលសហគមន៍។ គ្រោះកាចក៏បានចាប់ផ្តើមកើតឡើងភ្លាមមួយរំពេច រាលដាលពេញក្នុងចំណោមបណ្តាជន។ ដូច្នេះ គាត់បានដាក់គ្រឿងក្រអូបចូលក្នុងពាន ហើយក៏ធ្វើពិធីដោះបាបឲ្យប្រជាជន។[48]លោកអ៊ើរ៉ុនឈរនៅចន្លោះរវាងមនុស្សស្លាប់ និងមនុស្សរស់ ដោយធ្វើបែបនេះ គ្រោះកាចក៏បាត់ភ្លាម។
[49]អ្នកដែលស្លាប់ដោយសារគ្រោះកាចមានចំនួនមួយម៉ឺនបួនពាន់ប្រាំពីររយនាក់ ដោយមិនគិតអ្នកស្លាប់ក្នុងពេលលោកកូរេបះបោះទេ។[50]លោកអ៊ើរ៉ុនបានត្រឡប់ទៅលោកម៉ូសេនៅច្រកទ្វារចូលត្រសាលប្រជុំវិញ ហើយគ្រោះកាចក៏បាត់ដែរ។

Numbers 16:1

លោកកេហាត់

ឈ្មោះបុរសនេះដ៏ដែលបានបកប្រែនៅក្នុង៣:១៧។

ងើបបះបោរប្រឆាំងនឹងលោកម៉ូសេ

ការបះបោរឬការរិះគន់នរណាម្នាក់នៅក្នុងអំណាច

ត្រូវបានគេនិយាយដូចជាពួកគេកំពុងក្រោកឈរដើម្បីប្រយុទ្ធ។

ការបកប្រែផ្សេងទៀត «បះបោរប្រឆាំងនឹងម៉ូសេ»

ចំនួនពីររយហាសិបនាក់

generated on Wed Sep 10 16:16:32 2025

«២៥០នាក់»
សហគមន៍ និងមនុស្សគ្រប់គ្នាស្គាល់ច្បាស់
សមាជិកដែលស្គាល់នៅក្នុងសហគមន៍ «សមាជិកដ៏ល្បីល្បាញរបស់សហគមន៍» ឬ «បុរសសំខាន់នៅក្នុងសហគមន៍»
ពួកលោកធ្វើជ្រុលពេកហើយ!
នេះតំណាងឱ្យការធ្វើច្រើនជាងមួយដែលគួរធ្វើ។ ការបកប្រែផ្សេងទៀត «អ្នកបានធ្វើលើសពីអ្វីដែលអ្នកគួរធ្វើ» ឬ «អ្នកសន្មតថាមានសិទ្ធិអំណាចច្រើនជាងអ្នកគួរតែធ្វើ»
ហេតុអ្វីបានជាពួកលោក លើកខ្លួនឯងខ្ពស់ជាងមនុស្សផ្សេងទៀតក្នុងសហគមន៍របស់ព្រះអម្ចាស់ដូច្នេះ?
បុរសទាំងនោះសួរសំនួរនេះដើម្បីស្តីបន្ទោសលោកម៉ូសេនិងលោកអើរ៉ុន។ វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «អ្នកគឺខុសហើយដែលបានលើកខ្លួនអ្នកខ្ពស់ជាងសហគមន៍របស់ព្រះអម្ចាស់។»
លើកខ្លួនឯងខ្ពស់ជាងមនុស្សផ្សេងទៀត
ពិចារណានរណាម្នាក់ឱ្យសំខាន់ ត្រូវបានគេនិយាយថាជាការលើកឡើង។ ការបកប្រែផ្សេងទៀត «ពិចារណាខ្លួនឯងថាសំខាន់ជាងអ្នកឯទៀត»
Numbers 16:4
លោកបានឱនមុខចុះ
នេះបង្ហាញថាម៉ូសេបានបន្ទាបខ្លួននៅចំពោះព្រះ។
គាត់ខ្លាចថាព្រះនឹងដាក់ទណ្ឌកម្មប្រជាជនចំពោះការបះបោរប្រឆាំងនឹងព្រះនិងមេដឹកនាំដែលព្រះបានជ្រើសរើស។
អ្នកណាដែលត្រូវបានញែកដាច់ដោយឡែកសម្រាប់ព្រះអង្គ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដែលព្រះអម្ចាស់បានញែកចេញសម្រាប់អង្គទ្រង់»
Numbers 16:6
អត្ថបទដែលបានភ្ជាប់
លោកម៉ូសេបន្តនិយាយទៅកាន់លោកកូរេនិងក្រុមមនុស្សដែលមកជាមួយលោកកូរេ។
ការត្រួតពិនិត្យ
ធុងដែលត្រូវដុតថ្វាយ។
នៅចំពោះព្រះអម្ចាស់
នេះជាលេខសម្គាល់។ ការបកប្រែផ្សេងទៀត «នៅក្នុងវត្តមានរបស់ព្រះអម្ចាស់»
អ្នកនោះនឹងត្រូវបានញែកដាច់ដោយឡែកសម្រាប់ព្រះអម្ចាស់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងញែកបុរសនោះចេញសម្រាប់អង្គទ្រង់»
អ្នករាល់គ្នាធ្វើជ្រុលពេកហើយ
នេះតំណាងឱ្យការធ្វើច្រើនជាងមួយដែលគួរធ្វើ។ ការបកប្រែផ្សេងទៀត «អ្នកបានធ្វើលើសពីអ្វីដែលអ្នកគួរធ្វើ» ឬ «អ្នកសន្មតថាមានសិទ្ធិអំណាចច្រើនជាងអ្នកគួរតែធ្វើ»
Numbers 16:8
ជាការតូចតាចឬ.....ដើម្បីបម្រើពួកគេ?
លោកម៉ូសេប្រើសំណួរនេះដើម្បីស្តីបន្ទោសលោកកូរេនិងបុរសដែលនៅជាមួយគាត់។ វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «អ្នកមានអាកប្បកិរិយាដូចជាវាជារឿងតូចតាចសម្រាប់អ្នក ... ដើម្បីបម្រើពួកគេ» ឬ «អ្នកមិនគួរចាត់ទុកវាជារឿងតូចតាចទេ ... ដើម្បីបម្រើពួកគេ»
ជាការតូចតាចឬ
«មិនគ្រប់គ្រាន់សម្រាប់អ្នក» ឬ «មិនសំខាន់សម្រាប់អ្នក»
អ្នកនៅតែចង់បានតំណែងជាបូជាចារ្យថែមទៀត
ការចង់បានតំណែងជាបូជាចារ្យត្រូវបានគេនិយាយដូចជាពួកគេកំពុងស្វែងរកវា។ ការបកប្រែផ្សេងទៀត «អ្នកក៏ចង់បានតំណែងជាបូជាចារ្យដែរ» ឬ «អ្នកក៏ចង់ធ្វើជាបូជាចារ្យដែរ»
ហេតុអ្វីបានជាអ្នករអ៊ូរទាំប្រឆាំងនឹងលោកអើរ៉ុន ដែលជាអ្នកស្តាប់បង្គាប់ព្រះអម្ចាស់ដូច្នេះ?
លោកម៉ូសេប្រើសំណួរនេះដើម្បីបង្ហាញថា
នៅពេលពួកគេត្អូញត្អែរអំពីអ្វីដែលលោកអើរ៉ុនធ្វើ
ពួកគេពិតជាត្អូញត្អែរប្រឆាំងនឹងព្រះអម្ចាស់
ព្រោះលោកអើរ៉ុនបានធ្វើអ្វីដែលព្រះអម្ចាស់បង្គាប់អោយគាត់ធ្វើ។
ការបកប្រែផ្សេងទៀត
«អ្នកមិនត្អូញត្អែរអំពីលោកអើរ៉ុនទេប៉ុន្តែត្អូញត្អែរពីព្រះអម្ចាស់ដែលលោកអើរ៉ុនគោរពតាម[illegible]»
Numbers 16:12
តើជារឿងតូចតាចឬដែលអ្នកបាននាំពួកយើងចេញ.....ដើម្បីសម្លាប់ពួកយើងនៅក្នុងទីរហោស្ថាននេះ
ដាថាននិងអ័ប៊ីរ៉ាមប្រើសំណួរនេះដើម្បីស្តីបន្ទោសលោកម៉ូសេ។ វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ អេធី:
"អ្នកមានឥរិយាបទដូចជាវាជារឿងតូចមួយសម្រាប់អ្នកដើម្បីនាំយើង ... ដូច្នេះយើងអាចស្លាប់នៅវាលរហោស្ថាន" ។
ជារឿងតូចតាចឬ
"មិនគ្រប់គ្រាន់" ឬ "មិនសំខាន់"
ពីស្រុកដែលសម្បូរទៅដោយទឹកដោះ និងទឹកឃ្មុំ
ពួកគេបាននិយាយអំពីដីល្អសម្រាប់សត្វនិងរុក្ខជាតិដូចជាទឹកដោះគោនិងទឹកឃ្មុំពីសត្វនិងរុក្ខជាតិទាំងនោ
សូមមើលការបកប្រែនៅក្នុង ១៤:៦។ ការបកប្រែផ្សេងទៀត
«ល្អណាស់សម្រាប់ចិញ្ចឹមសត្វនិងដាំដំណាំ” ឬ «ដីមានជីជាតិខ្លាំង»
ទុកជាមរតក
ពួកគេបាននិយាយអំពីអ្វីដែលព្រះនឹងផ្តល់ឱ្យពួកគេដើម្បីក្លាយជារបស់ពួកគេជារៀងរហូតដូចជាមរតក។
ឥឡូវនេះតើអ្នកចង់ធ្វើឱ្យយើងខ្វាក់ដោយការសន្យាទទេឬ?
ប្រជាជនប្រើសំណួរនេះដើម្បីចោទប្រកាន់លោកម៉ូសេ។ វាអាចបកប្រែជាសេចក្តីថ្លែងការណ៍។ការបកប្រែផ្សេងទៀត «ឥឡូវនេះអ្នកចង់ធ្វើឱ្យយើងខ្វាក់ដោយការសន្យាទទេឬ?» ។
ធ្វើអោយយើងងងឹតភ្នែក
មនុស្សបោកបញ្ឆោតត្រូវបានគេនិយាយថាធ្វើឱ្យពួកគេងងឹតភ្នែក។ ការបកប្រែផ្សេងទៀត «ដើម្បីបញ្ឆោតយើង»
[illegible]
ពួកគេនិយាយអំពីការសន្យាដែលមិនត្រូវបានរក្សាទុកដូចជាធុងទទេ។ ការបកប្រែផ្សេងទៀត «ជាមួយការសន្យាថាអ្នកមិនរក្សា» ឬ «ដោយសន្យាថានឹងធ្វើអ្វីដែលអ្នកមិនធ្វើ»
Numbers 16:15
ទូលបង្គំមិនបានយកសត្វលាមួយក្បាលពីពួកគេឡើយ
សត្វលាមួយនៅទីនេះតំណាងឱ្យអ្វីដែលមនុស្សម្នាក់យកខ្ញុំពីអ្នកដទៃ។ ការបកប្រែផ្សេងទៀត
«ទូលបង្គំមិនបានយកអ្វីពីពួកគេទេសូម្បីតែសត្វលាមួយក្បាល»
ពាន
ធុងសម្រាប់ដុតគ្រឿងក្រអូប
Numbers 16:20
យើងនឹងបំផ្លាញពួកគេឲ្យវិនាស
ការបំផ្លាញពួកគេត្រូវបានគេនិយាយថា ដូចជាព្រះនឹងស៊ីពួកគេ។ ការបកប្រែផ្សេងទៀត «យើងនឹងបំផ្លាញពួកគេ» ឬ «ហើយយើងនឹងបំផ្លាញពួកគេ»
ឱនមុខចុះ
នេះបង្ហាញថាលោកម៉ូសេនិងលោកអើរ៉ុនបានបន្ទាបខ្លួនចំពោះព្រះ។
ព្រះអង្គជាព្រះនៃវិញ្ញាណរបស់មនុស្សទាំងអស់
នៅទីនេះ «វិញ្ញាណ» តំណាងឱ្យសមត្ថភាពក្នុងការរស់នៅ។ ការបកប្រែផ្សេងទៀត «ព្រះដែលផ្តល់ជីវិតដល់មនុស្សជាតិទាំងអស់»
បើមនុស្សតែម្នាក់ប្រព្រឹត្តអំពើបាប តើព្រះអង្គត្រូវខឹងនឹងសហគមន៍ទាំងមូលឬ?
លោកម៉ូសេនិងលោកអើរ៉ុនប្រើសំនួរនេះដើម្បីទូលអង្វរព្រះជាម្ចាស់អោយប្រជាជន។ វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «សូមកុំខឹងនឹងសហគមន៍ទាំងអស់ព្រោះបុរសម្នាក់ធ្វើបាបឡើយ»
Numbers 16:25
អ្នករាល់គ្នាក៏នឹងត្រូវបំផ្លាញ
ការបំផ្លាញត្រូវបានគេនិយាយដូចជាពួកគេនឹងស៊ី។ ការបកប្រែផ្សេងទៀត «អ្នកនឹងត្រូវបានបំផ្លាញ»
អ្នករាល់គ្នាក៏នឹងត្រូវបំផ្លាញដោយព្រោះអំពើបាបរបស់ពួកគេដែរ
ការបំផ្លាញដោយសារតែអំពើបាបរបស់ពួកគេ
ត្រូវបានគេនិយាយដូចជាអំពើបាបនឹងបំផ្លាញពួកគេ។ ការបកប្រែផ្សេងទៀត «អ្នកនឹងត្រូវបានបំផ្លាញដោយសារតែអំពើបាបរបស់ពួកគេ»
អ្នកនឹងត្រូវបំផ្លាញដោយព្រោះអំពើបាបរបស់ពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «រាល់អំពើបាបរបស់ពួកគេនឹងបំផ្លាញអ្នក» ឬ «[illegible]ព្រះអម្ចាស់នឹងបំផ្លាញអ្នកព្រោះតែអំពើបាបរបស់ពួកគេ»
Numbers 16:28
តាមរយៈការនេះ អ្នករាល់គ្នានឹងដឹងថា
ត្រង់នេះ «នេះ« សំដៅទៅលើអ្វីដែលលោកម៉ូសេនឹងនិយាយបន្ទាប់។

generated on Wed Sep 10 16:16:32 2025

លេបពួកគេចូលដូចជាចូលក្នុងមាត់មួយយ៉ាងធំ
លោកម៉ូសេនិយាយហាក់ដូចជាផែនដីនៅរស់ហើយដីបើកចំហដែលមនុស្សទាំងនេះនឹងធ្លាក់ចូល
គឺជាមាត់ដ៏ធំមួយដែលនឹងស៊ីពួកគេ។ ការបកប្រែផ្សេងទៀត
«ហើយពួកគេបានធ្លាក់ចូលទៅក្នុងវាហើយត្រូវបានគេកប់នៅក្រោមដី»
Numbers 16:31
ផែនដីបានបើកមាត់របស់វា ហើយលេបពួកគេ
លោកម៉ូសេនិយាយអំពីផែនដីដូចជានៅរស់ហើយប្រហោងដែលមនុស្សបានធ្លាក់ចូលនៅក្នុងនោះ
ហាក់ដូចជាមាត់របស់ផែនដី។ ការបកប្រែផ្សេងទៀត
«ផែនដីបានបើកដូចជាមាត់ធំមួយហើយពួកគេបានធ្លាក់ចូលទៅក្នុងនោះ
ហើយត្រូវបានគេកប់នៅក្នុងដីនោះ» ឬ
«មានប្រហោងធំមួយនៅក្នុងដីហើយពួកគេបានធ្លាក់ចូលទៅក្នុងវាហើយត្រូវបានគេកប់នៅក្នុងនោះ»
Numbers 16:33
បានធ្លាក់ចូលទៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់
ឃ្លាស្រដៀងគ្នានេះកើតឡើងនៅ ១៦:២៨ ។ សូមមើលការបកប្រែនៅទីនោះ។
ពួកគេ ដោយពោលថា
«ពួកគេ» សំដៅទៅលើជនជាតិអ៊ីស្រាអែលទាំងអស់។
ដីនឹងលេបពួកយើងចូលដែរ
ប្រជាជននិយាយពីផែនដីដូចជាវានៅរស់។ ការបកប្រែផ្សេងទៀត
«ផែនដីអាចនឹងបើកចំហហើយយើងក៏នឹងធ្លាក់ចូលទៅក្នុងវាដែរ» ឬ
«ប្រសិនបើផែនដីបើកម្តងទៀតយើងក៏នឹងធ្លាក់ចូលទៅក្នុងដីហើយត្រូវគប់»
នោះអណ្តាតភ្លើងបានចេញមកពីព្រះអម្ចាស់មកបញ្ឆេះមនុស្សពីររយហាសិបនាក់
ការបំផ្លាញដោយភ្លើងត្រូវបានគេនិយាយដូចជាពួកគេត្រូវបានស៊ីដោយភ្លើង។
ការបកប្រែផ្សេងទៀត «ភ្លើងបានឆាបឆេះចេញពីព្រះអម្ចាស់ហើយបំផ្លាញមនុស្ស
២៥០ នាក់»
Numbers 16:36
ចេញពីអណ្តាតភ្លើង
នេះសំដៅទៅលើអណ្តាតភ្លើងដែលបានឆេះមនុស្ស ២៥០ នាក់។
របស់អ្នកដែលស្លាប់
ការបាត់បង់ជីវិតតំណាងឱ្យការស្លាប់។ ការបកប្រែផ្សេងទៀត «អ្នកដែលបានស្លាប់»
ដ្បិត ពួកគេបានថ្វាយ
នៅទីនេះ «ពួកគេ» សំដៅទៅលើអ្នកត្រួតពិនិត្យ។
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «សូមឱ្យ
អេឡាសារ ធ្វើឱ្យពួកគេ»
របស់ទាំងនេះត្រូវបានញែកដោយឡែក.....វានឹងបានជាទីសម្គាល់
នៅទីនេះ «ពួកគេ» និង «ពួកគេ» សំដៅទៅលើពាន។
Numbers 16:39
ជារបស់ដែលមនុស្សបានឆេះភ្លើងស្លាប់នេះធ្លាប់ប្រើ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលភ្លើងបានឆេះបានប្រើ»
ដូចជាលោកកូរេ និងបក្សពួករបស់គាត់
ភ្លើងដែលពួកគេអាចប្រែក្លាយដូចជាពួកគេអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ស្លាប់ដូចលោកកូរេនិងក្រុមរបស់គាត់បានស្លាប់»
Numbers 16:41
នៅពេលដែល
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
ទាំងមូលបានអ៊ូរទាំទាស់នឹងលោកម៉ូសេ និងលោកអ៊ីរ៉ុន
«បានប្រមូលផ្តុំដើម្បីប្តឹងលោកម៉ូសេនិងលោកអើរ៉ុន»
មើល!
«ភ្លាមៗ»។ នៅទីនេះ «មើល!»
បង្ហាញថាប្រជាជនមានការភ្ញាក់ផ្អើលចំពោះអ្វីដែលពួកគេបានឃើញ។
Numbers 16:44
ដ្បិត យើងនឹងកម្ទេចពួកគេឲ្យវិនាសភ្លាមនេះ
ព្រះមានបន្ទូលអំពីការបំផ្លាញពួកគេដូចជាព្រះអង្គនឹងស៊ីពួកគេដែរ។
ការបកប្រែផ្សេងទៀត «ដូច្នេះយើងអាចបំផ្លាញពួកគេ» ឬ
«ហើយយើងនឹងបំផ្លាញពួកគេ»
បានឱនមុខក្រាបចុះដល់ដី
នេះបង្ហាញថាលោកម៉ូសេនិងលោកអើរ៉ុនកំពុងបន្ទាបខ្លួននៅចំពោះព្រះ។
សេចក្តីក្រោធកំពុងមកពីព្រះអម្ចាស់
កំហឹងមកពីព្រះ ជាតំណាងព្រះជាម្ចាស់បង្ហាញកំហឹងរបស់ទ្រង់។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់កំពុងតែសំដែងព្រះហឫទ័យអោយយើងខ្ញុំ» ឬ
«ព្រះអម្ចាស់ទ្រង់ព្រះពិរោធយ៉ាងខ្លាំងហើយសំដែងតាមកំហឹងរបស់ព្រះអង្គ»
Numbers 16:47
គាត់បានដាក់គ្រឿងក្រអូបចូល
ការដាក់គ្រឿងក្រអូបនៅក្នុងពាននៅទីនេះតំណាងឱ្យការដុតវា។
ការបកប្រែផ្សេងទៀត «គាត់បានដុតគ្រឿងក្រអូប»
គ្រោះកាចក៏បាត់ភ្លាម
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គ្រោះកាចឈប់រាលដាល»

---

17 [1]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេ។ ព្រះអង្គមានបន្ទូលថា៖[2]«ចូរប្រាប់ទៅប្រជាជនអ៊ីស្រាអែល ឲ្យយកដំបងមកពីមេដឹកនាំ
កុលសម្ព័ន្ធនីមួយៗត្រូវយកដំបងមួយ ដំបងទាំងអស់ចំនួនដប់ពីរមកឲ្យអ្នក។ ត្រូវសរសេរឈ្មោះរបស់ពួកគេម្នាក់នៅលើដំបងរបស់ខ្លួន។
[3]អ្នកត្រូវសរសេរឈ្មោះរបស់លោកអើរ៉ុននៅលើដំបងរបស់កុលសម្ព័ន្ធលេវី។ ត្រូវមានដំបងមួយសម្រាប់មេដឹកនាំពីកុលសម្ព័ន្ធមួយ។[4]អ្នកត្រូវដាក់ដំបង
ទាំងនោះនៅក្នុងត្រសាលប្រជុំ នៅពីមុខច្បាប់នៃសម្ពន្ធមេត្រី កន្លែងដែលយើងជួបអ្នក។[5]ដំបងរបស់អ្នកណាដែលយើងជ្រើសរើសនោះនឹងដុះពន្លកចេញ។ យើងនឹងធ្វើឲ្យ
កូនចៅអ៊ីស្រាអែលឈប់រអ៊ូរប្រឆាំងនឹងយើងទៀត។
[6]ដូច្នេះ លោកម៉ូសេបានមានប្រសាសន៍ទៅប្រជាជនអ៊ីស្រាអែលថា៖ «មេដឹកនាំលើកុលសម្ព័ន្ធទាំងអស់ត្រូវឲ្យដំបងរបស់ខ្លួនមកខ្ញុំ គឺមេដឹកនាំម្នាក់ឲ្យដំបងមួយ ពី
គ្រប់កុលសម្ព័ន្ធ ទាំងអស់មានដប់ពីរដំបង។ រីឯដំបងរបស់លោកអើរ៉ុនក៏ដាក់នៅជាមួយដំបងរបស់ពួកគេដែរ។[7]បន្ទាប់មក លោកម៉ូសេក៏យកដំបងទាំងអស់ទៅដាក់
នៅចំពោះព្រះអម្ចាស់ក្នុងត្រសាលនៃច្បាប់សម្ពន្ធមេត្រី។
[8]នៅថ្ងៃបន្ទាប់ លោកម៉ូសេបានទៅក្នុងត្រសាលនៃច្បាប់សម្ពន្ធមេត្រី ហើយមើល៍! ដំបងរបស់លោកអើរ៉ុនសម្រាប់កុលសម្ព័ន្ធលេវីបានដុះពន្លក។ គឺដុះពន្លក រួចចេញផ្កា មាន
ជាផ្លែអាល់ម៉ុនទុំ។[9]រួចលោកម៉ូសេបានយកដំបងទាំងអស់ចេញពីចំពោះព្រះអម្ចាស់ទៅបង្ហាញកូនចៅអ៊ីស្រាអែល ហើយម្នាក់ៗសម្លឹងមើលដំបងរបស់ខ្លួន។
[10]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេថា៖ «ចូរដាក់ដំបងរបស់អើរ៉ុននៅពីមុខច្បាប់នៃសម្ពន្ធមេត្រី។ ទុកដំបងនោះជាទីសម្គាល់នៃកំហុសរបស់មនុស្សបះបោរ ដើម្បី
ឲ្យអ្នករាល់គ្នាឈប់រអ៊ូប្រឆាំងនឹងយើង បើមិនដូច្នោះទេ ពួកគេនឹងស្លាប់»។[11]លោកម៉ូសេបានធ្វើតាមដូចដែលព្រះអម្ចាស់បង្គាប់គាត់។
[12]ប្រជាជនអ៊ីស្រាអែលបាននិយាយទៅលោកម៉ូសេថា៖ «ពួកយើងនឹងស្លាប់នៅទីនេះ។ ពួកយើងទាំងអស់គ្នាពិតជាវិនាសមិនខាន![13]អ្នកណាដែលឡើងមក ហើយចូលទៅ
ជិតព្រះពន្លារបស់ព្រះអម្ចាស់នឹងត្រូវស្លាប់។ តើពួកយើងទាំងអស់គ្នាត្រូវវិនាសមែនទេ?

Numbers 17:1
ចំនួនដប់ពីរ
«១២»
Numbers 17:3
ឃ្លាភ្ជាប់៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
កុលសម្ព័ន្ធលេវី
ឈ្មោះលេវីនៅត្រង់ចំនុចនេះគឺសំដៅទៅកុលសម្ព័ន្ធលេវី។
មួយសម្រាប់មេដឹកនាំពីកុលសម្ព័ន្ធនីមួយៗ
នៅទីនេះ «របស់គាត់» សំដៅទៅលើ «មេដឹកនាំនីមួយៗ» ។
ច្បាប់នៃសម្ព័ន្ធមេត្រី
ឃ្លា «រាជក្រឹត្យនៃកិច្ចព្រមព្រៀង»
សំដៅទៅលើប្រអប់បន្ទះដែលមានក្រឹត្យនៃកិច្ចព្រមព្រៀងត្រូវបានសរសេរ។
ការបកប្រែផ្សេងទៀត «ហឹបនៃសេចក្តីសញ្ញា» ឬ
«ប្រអប់ដែលកាន់ក្រិត្យនៃសម្ព័ន្ធមេត្រី»
ដំបងរបស់អ្នកណាដែលយើងជ្រើសរើសនោះនឹងដុះពន្លកចេញ

generated on Wed Sep 10 16:16:32 2025

«ពន្លកនឹងចាប់ផ្តើមដុះលើដំបងរបស់បុរសដែលយើងបានជ្រើសរើស»
យើងនឹងធ្វើឲ្យកូនចៅអ៊ីស្រាអែលឈប់រអ៊ូរទាំប្រឆាំងនឹងយើងទៀត
នេះ «ពាក្យទាស់ប្រឆាំង» គឺជានាមអរូបីដែលអាចបង្ហាញជាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «ធ្វើឱ្យប្រជាជនអ៊ីស្រាអែលឈប់ប្រឆាំងនឹងអ្នក
Numbers 17:6
នាំយកមួយ ពីគ្រប់កុលសម្ព័ន្ធ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលលោកម៉ូសេបានជ្រើសរើសពីកុលសម្ព័ន្ធនីមួយៗរបស់បុព្វបុរស»
ត្រសាលនៃច្បាប់សម្ព័ន្ធមេត្រី
ឃ្លា «រាជក្រឹត្យនៃសម្ព័ន្ធមេត្រី»
សំដៅទៅលើហិបដែលដាក់បន្ទះដែលក្រឹត្យនៃសម្ព័ន្ធមេត្រីត្រូវបានសរសេរ។
ការបកប្រែផ្សេងទៀត «ត្រសាលនៃហិបសេចក្តីសញ្ញា» ឬ
«ត្រសាលដែលក្រឹត្យវិន័យនៃសម្ព័ន្ធមេត្រីមាននៅក្នុង»
Numbers 17:8
មើល៎!
ពាក្យថា «មើល៎!» ត្រង់នេះបង្ហាញថាមានអ្វីមួយពិសេសដែលបានកើតឡើង។
Numbers 17:10
ច្បាប់នៃសម្ព័ន្ធមេត្រី
ឃ្លា «ច្បាប់នៃសម្ព័ន្ធមេត្រី»
សំដៅទៅលើហិបដែលដាក់បន្ទះដែលក្រឹត្យនៃសម្ព័ន្ធមេត្រី
ដើម្បីឲ្យអ្នករាល់គ្នាឈប់រអ៊ូរទាំប្រឆាំងនឹងយើង
ពាក្យថា «រអ៊ូរទាំ» គឺជានាមអរូបីដែលអាចត្រូវបានបង្ហាញជាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «ដូច្នេះអ្នកអាចបញ្ឈប់ពួកគេពីការអ៊ូរទាំប្រឆាំងនឹងយើង»
បើមិនដូច្នោះទេ ពួកគេនឹងស្លាប់
នេះជាអ្វីដែលនឹងកើតឡើងប្រសិនបើប្រជាជនបន្តតវ៉ា។ ព្រះចង់ការពារបញ្ហានេះ។
ការបកប្រែផ្សេងទៀត «ដូច្នេះពួកគេនឹងមិនស្លាប់ទេ»
Numbers 17:12
ពួកយើងនឹងស្លាប់នៅទីនេះ។ពួកយើងទាំងអស់គ្នាពិតជាវិនាសមិនខាន!
ឃ្លាទាំងពីរនេះមានន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។

---

18 [1]ព្រះអម្ចាស់បានមានបន្ទូលមកលោកអើរ៉ុនថា៖ «អ្នក និងកូនចៅរបស់អ្នក ព្រមទាំងវង្សានុវង្សនៃដូនតារបស់អ្នកនឹងទទួលខុសត្រូវលើអស់ទាំងអំពើបាបដែលបានធ្វើទាស់នឹងទីបរិសុទ្ធ។ ប៉ុន្តែ មានតែអ្នក និងកូនចៅរបស់អ្នកប៉ុណ្ណោះ ទទួលខុសត្រូវចំពោះអំពើបាបរបស់អស់អ្នកដែលទាក់ទងនឹងមុខងារជាបូជាចារ្យ។[2]ដោយសារសមាជិកគ្រួសារនៃកុលសម្ព័ន្ធរបស់លេវី ជាកុលសម្ព័ន្ធនៃដូនតារបស់អ្នក អ្នកត្រូវនាំពួកគេមកជាមួយអ្នកផង ដើម្បីឲ្យពួកគេអាចចូលរួមជាមួយអ្នក និងជួយអ្នកនៅពេលដែលអ្នក និងកូនៗរបស់អ្នកបម្រើនៅពីមុខត្រសាលនៃច្បាប់សម្ពន្ធមេត្រី។
[3]ពួកគេត្រូវបម្រើអ្នក និងកិច្ចការទាំងអស់របស់ត្រសាល។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនត្រូវចូលទៅជិតអ្វីៗនៅក្នុងទីបរិសុទ្ធ ឬអ្វីដែលទាក់ទងនឹងអាសនាឡើយ ក្រែងលោកទាំងពួកគេ ទាំងអ្នកត្រូវស្លាប់។[4]ពួកគេត្រូវតែនៅជាប់នឹងអ្នក ហើយមើលថែត្រសាលប្រជុំ គឺការងារទាំងអស់ទាក់ទងនឹងព្រះពន្លា។ មិនត្រូវឲ្យជនបរទេសចូលមកជិតអ្នកឡើយ។[5]អ្នកត្រូវទទួលខុសត្រូវលើការងារទាំងអស់ក្នុងទីបរិសុទ្ធ និងអាសនា ដើម្បីកុំឲ្យកំហឹងរបស់យើងមកលើប្រជាជនអ៊ីស្រាអែលម្តងទៀតឡើយ។
[6]មើល៎! យើងគឺជាអ្នកបានជ្រើសរើសសមាជិកបងប្អូនរបស់អ្នក គឺកុលសម្ព័ន្ធលេវីពីក្នុងចំណោមកូនចៅអ៊ីស្រាអែល។ ពួកគេជាអំណោយរបស់អ្នក ជាតង្វាយដល់យើង ដើម្បីធ្វើកិច្ចការក្នុងត្រសាលប្រជុំ។[7]ប៉ុន្តែ មានតែអ្នក និងកូនរបស់អ្នកប៉ុណ្ណោះ ដែលត្រូវបំពេញការងារជាបូជាចារ្យទាក់ទងនឹងអ្វីៗទាំងអស់របស់អាសនា និងអ្វីៗទាំងអស់ខាងក្នុងវាំនន។ អ្នកត្រូវបំពេញការទទួលខុសត្រូវទាំងនោះឲ្យបាន។ យើងប្រទានឲ្យអ្នកមានមុខងារជាបូជាចារ្យ ទុកជាអំណោយ។
ជនបរទេសណាចូលទៅជិត ត្រូវតែសម្លាប់ចោល»។
[8]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកអើរ៉ុនទៀតថា៖ «មើល៎! យើងបានប្រទានឲ្យអ្នកមានភារកិច្ចមើលខុសត្រូវតង្វាយដែលថ្វាយដល់យើង និងតង្វាយបរិសុទ្ធទាំងអស់ដែលកូនចៅអ៊ីស្រាអែលថ្វាយដល់យើង។ យើងប្រគល់តង្វាយនេះឲ្យអ្នក និងកូនៗរបស់អ្នកទុកជាចំណែករបស់អ្នកជារៀងរហូត។[9]ទាំងនេះជារបស់បរិសុទ្ធបំផុតដែលមិនបានដុត គឺតង្វាយទាំងអស់របស់ពួកគេ មានតង្វាយគ្រាប់ធញ្ញជាតិ តង្វាយលោះបាប តង្វាយសុំលើកលែងទោស តង្វាយទាំងនោះបរិសុទ្ធបំផុតសម្រាប់អ្នក និងកូនៗរបស់អ្នក។
[10]តង្វាយទាំងនោះបរិសុទ្ធបំផុត ហើយបុរសទាំងអស់ត្រូវបរិភោគតង្វាយនោះ ដ្បិត តង្វាយទាំងនោះបរិសុទ្ធចំពោះអ្នករាល់គ្នា។[11]តង្វាយដែលជាចំណែករបស់អ្នករាល់គ្នានោគឺ តង្វាយទាំងអស់ដែលប្រជាជនអ៊ីីស្រាអែលយកមកថ្វាយ យើងបានប្រគល់ឲ្យដល់អ្នក ព្រមទាំងកូនប្រុសកូូនស្រីរបស់អ្នកជារៀងរហូតទៅ។ នៅក្នុងគ្រួសាររបស់អ្នក គ្រប់គ្នាដែលធ្វើពិធីសម្អាតខ្លួនបរិសុទ្ធ អាចបរិភោគតង្វាយទាំងនេះបាន។
[12]អស់ទាំងប្រេងដ៏ល្អបំផុត ស្រាទំពាំងបាយជូរថ្មីដ៏ល្អបំផុត គ្រាប់ធញ្ញជាតិ និងផលដំបូងទាំងអស់ដែលប្រជាជនយកមកថ្វាយយើង យើងក៏ប្រគល់ឲ្យអ្នកដែរ។
[13]ផលផ្លែទុំដំបងបង្អស់ពីចម្ការរបស់ពួកគេ ដែលពួកគេយកមកថ្វាយយើង នឹងបានជារបស់អ្នក។ គ្រប់គ្នាដែលស្អាតហើយអាចបរិភោគតង្វាយទាំងនេះបាន។
[14]អ្វីៗទាំងអស់ដែលកូនចៅអ៊ីស្រាអែលថ្វាយដាច់ដល់យើង នឹងបានជារបស់អ្នក។[15]កូនដំបូងទាំងអស់ដែលកើតពីផ្ទៃ ដែលប្រជាជនថ្វាយដល់ព្រះអម្ចាស់ ទាំងកូនរបស់មនុស្ស ទាំងកូនរបស់សត្វ នឹងបានជារបស់អ្នក។ ប៉ុន្តែ ប្រជាជនត្រូវទិញ កូនប្រុសច្បងរបស់មនុស្ស និងកូនច្បងឈ្មោលរបស់សត្វទាំងអស់ដែលមិនស្អាតទៅវិញ។
[16]កូនច្បងទាំងអស់ដែលប្រជាជនត្រូវទិញយកទៅវិញ គឺត្រូវមានអាយុចាប់ពីមួយខែឡើងទៅ។ ពួកគេអាចទិញត្រឡប់ទៅវិញក្នុងតម្លៃប្រាំសេកែល តាមខ្នាតទម្ងន់របស់ទីបរិសុទ្ធ ដែលស្មើនឹងម្ភៃកេរ៉ា។
[17]ប៉ុន្តែ អ្នកមិនត្រូវឲ្យគេទិញកូនដំបូងរបស់គោ ឬកូនដំបូងរបស់ចៀម ឬកូនដំបូងរបស់ពពែមកវិញទេ។ សត្វទាំងនោះត្រូវញែកដាច់ដោយឡែកសម្រាប់យើង។ អ្នកត្រូវប្រោះឈាមរបស់វានៅលើអាសនា ហើយដុតខ្លាញ់របស់វាទុកជាតង្វាយធ្វើឡើងដោយភ្លើង ដើម្បីជាក្លិនឈ្ងុយដែលគាប់ព្រះហឫទ័យដល់ព្រះព្រះអម្ចាស់។
[18]រីឯសាច់របស់វាជាចំណែករបស់អ្នក ដូចជាសាច់ដើមទ្រូងដែលគេថ្វាយជាតង្វាយ និងសាច់ភ្លៅស្តាំ គឺសាច់ទាំងនេះនឹងបានជារបស់អ្នក។
[19]គ្រប់ទាំងតង្វាយបរិសុទ្ធទាំងអស់ដែលប្រជាជនអ៊ីស្រាអែលយកមកថ្វាយដល់ព្រះអម្ចាស់ យើងប្រគល់ឲ្យអ្នក កូនប្រុសរបស់អ្នក និងកូនស្រីរបស់អ្នក ដែលនៅជាមួយអ្នកជាចំណែកជារៀងរហូត។ នេះគឺជាសម្ពន្ធមេត្រីនៃអំបិលមួយដ៏នៅអស់កល្បជានិច្ច ជាសម្ពន្ធមេត្រីដែលនៅជាប់ជារៀងរហូតនៅចំពោះព្រះអម្ចាស់ សម្រាប់អ្នក និងពូជពង្សរបស់អ្នកដែលនៅជាមួយអ្នក។[20]ព្រះអម្ចាស់បានមានបន្ទូលមកលោកអើរ៉ុនថា៖ «អ្នកនឹងគ្មានដីនៅក្នុងស្រុកទុកជារតកឡើយ ហើយក៏គ្មានចំណែកដីពីក្នុងចំណោមប្រជាជនដែរ។ យើងគឺជាចំណែក និងជាមរតករបស់អ្នកនៅក្នុងចំណោមប្រជាជនអ៊ីស្រាអែល។
[21]ចំពោះកូនចៅរបស់ពួកលេវីវិញ យើងប្រគល់មួយភាគដប់ពីភោគផលទាំងអស់របស់ជនជាតិអ៊ីស្រាអែល ជាមរតករបស់ពួកគេ ទុកជាថ្នូរនៃកិច្ចការដែលគេបម្រើនៅក្នុងត្រសាលប្រជុំ។[22]ចាប់តាំងពីពេលនេះតទៅ ប្រជាជនអ៊ីស្រាអែលមិនត្រូវចូលមកជិតត្រសាលប្រជុំជាដាច់ខាត បើមិនដូច្នោះទេ គេត្រូវទទួលខុសត្រូវចំពោះអំពើបាបរបស់ខ្លួន ហើយត្រូវស្លាប់។
[23]កុលសម្ព័ន្ធលេវីត្រូវធ្វើកិច្ចការរបស់ត្រសាលប្រជុំ។ ពួកគេត្រូវទទួលខុសត្រូវលើអស់ទាំងអំពើបាបទាក់នឹងត្រសាល។ នេះគឺជាច្បាប់ដែលមិនប្រែប្រួលនៅគ្រប់ជំនាន់មនុស្សរៀងរហូតទៅ។ ពួកគេមិនត្រូវមានចំណែកមរតកនៅក្នុងប្រជាជនអ៊ីស្រាអែលឡើយ។[24]សម្រាប់តង្វាយមួយភាគដប់របស់ជនជាតិអ៊ីស្រាអែលដែលពួកគេថ្វាយដល់យើង គឺយើងប្រគល់ដល់ពួកលេវីទុកជាមរតកសម្រាប់ពួកគេ។ ពួកគេមិនត្រូវមានចំណែកមរតកនៅក្នុងប្រជាជនអ៊ីស្រាអែលឡើយ»។
[25]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេថា៖[26]«អ្នកត្រូវប្រាប់ពួកលេវីថា នៅពេលដែលអ្នករាល់គ្នាទទួលតង្វាយមួយភាគដប់ពីប្រជាជនអ៊ីស្រាអែល ដែលយើងប្រគល់ឲ្យដល់អ្នករាល់គ្នាទុកជាមរតកនោះ អ្នករាល់គ្នាត្រូវថ្វាយមួយចំណែកដល់ព្រះអម្ចាស់ គឺមួយភាគដប់នៃតង្វាយនោះ។[27]តង្វាយរបស់អ្នករាល់គ្នានោះគឺប្រៀបដូចជាតង្វាយមួយភាគដប់ពីស្រូវដែលបញ្ជាន់នៅទីលាន និងស្រាទំពាំងបាយជូរពីកន្លែងគាបដែរ។
[28]ដូច្នេះ អ្នករាល់គ្នាក៏ត្រូវថ្វាយដល់ព្រះអម្ចាស់ ពីតង្វាយមួយភាគដប់ដែលអ្នករាល់គ្នាទទួលពីប្រជាជនអ៊ីស្រាអែល ហើយត្រូវប្រគល់តង្វាយនោះឲ្យទៅបូជាចារ្យអើរ៉ុន។[29]អស់ទាំងតង្វាយដែលអ្នករាល់គ្នាបានទទួល អ្នករាល់គ្នាត្រូវញែកថ្វាយដល់ព្រះអម្ចាស់ គឺអ្នកត្រូវញែកតង្វាយល្អបំផុត និងបរិសុទ្ធបំផុតដែលបានប្រគល់ឲ្យមកអ្នក។

generated on Wed Sep 10 16:16:32 2025

[30]ដូច្នេះ អ្នកត្រូវប្រាប់ពួកគេថា៖ នៅពេលអ្នកថ្វាយតង្វាយល្អបំផុត នោះត្រូវចាត់ទុកជាចំណែករបស់ពួកលេវី ដូចជាផលបានពីទីលានបញ្ជាន់ និងផលបានពីកន្លែងគាបដែរ។[31]អ្នករាល់គ្នា និងគ្រួសាររបស់អ្នកអាចបរិភោគតង្វាយទាំងនេះនៅកន្លែងណាក៏បាន ដ្បិត នោះជាកម្រៃដែលអ្នកទទួលបានពីការងាររបស់ខ្លួននៅក្នុងត្រសាលប្រជុំ។[32]ប្រសិនបើ អ្នករាល់គ្នាបានថ្វាយចំណែកដ៏ល្អបំផុតដល់ព្រះអម្ចាស់ហើយ នោះអ្នកនឹងមិនមានទោសដោយព្រោះបរិភោគ និងផឹកវាឡើយ។ ប៉ុន្តែ អ្នកមិនត្រូវបង្អាប់តង្វាយបរិសុទ្ធរបស់កូនចៅអ៊ីស្រាអែលឡើយ ក្រែងអ្នករាល់គ្នាត្រូវស្លាប់»។

Numbers 18:1

អស់ទាំងអំពើបាបដែលបានធ្វើទាស់នឹងទីបរិសុទ្ធ

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«រាល់អំពើបាបដែលអ្នកណាម្នាក់ប្រព្រឹត្តប្រឆាំងនឹងទីបរិសុទ្ធ»

ចំពោះអំពើបាបរបស់អស់អ្នកដែលទាក់ទងនឹងមុខងារជាបូជាចារ្យ

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«អំពើបាបទាំងអស់ដែលនរណាម្នាក់ក្នុងបូជាចារ្យប្រព្រឹត្ត»

អស់អ្នកដែលទាក់ទងនឹងមុខងារជាបូជាចារ្យ

«អស់ទាំងសង្ឃ»

Numbers 18:3

ឃ្លាភ្ជាប់៖

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។

ពួកគេត្រូវបម្រើអ្នក.....ពួកគេត្រូវតែនៅជាប់នឹងអ្នក

«ពួកគេ» សំដៅទៅលើសមាជិកនៃកុលសម្ព័ន្ធលេវី; ពាក្យថា «អ្នក» គឺជាឯកវចន:ហើយសំដៅទៅលើអើរ៉ុន។

ឬអ្វីដែលទាក់ទងនឹងអាសនាឡើយ ក្រែងលោកទាំងពួកគេ ទាំងអ្នកត្រូវស្លាប់

នៅទីនេះ «ពួកគេ»

សំដៅទៅលើសមាជិកនៃកុលសម្ព័ន្ធលេវីដែលចូលមកជិតអ្វីៗនៅក្នុងទីបរិសុទ្ធ។

ពាក្យ «អ្នក»

គឺពហុវចន:ហើយសំដៅទៅលើទាំងអើរ៉ុននិងក្រុមលេវីដែលនៅសល់ក្នុងមុខងារដែលត្រូវបានតែងតាំង

ចូលមកជិតអ្នកឡើយ។អ្នកត្រូវទទួលខុសត្រូវលើការងារ

នៅទីនេះ «អ្នក»

ជាពហុវចន:ហើយសំដៅទៅលើអើរ៉ុននិងក្រុមលេវីដែលនៅសល់។

ដើម្បីកុំឲ្យកំហឹងរបស់យើងមកលើកូនចៅអ៊ីស្រាអែលម្តងទៀតឡើយ

អាចមានន័យថា ១) នេះតំណាងអោយព្រះជាម្ចាស់ដែលមានកំហឹងយ៉ាងខ្លាំងចំពោះប្រជាជនរបស់ទ្រង់។ ការបកប្រែផ្សេងទៀត «ដូច្នេះយើងមិនខឹងនឹងប្រជាជនអ៊ីស្រាអែលម្តងទៀតទេ» ឬ 2) នេះតំណាងឱ្យព្រះដាក់ទណ្ឌកម្មពួកគេដោយសារតែកំហឹងរបស់ទ្រង់។ ការបកប្រែផ្សេងទៀត «ដូច្នេះយើងមិនដាក់ទណ្ឌកម្មប្រជាជនអ៊ីស្រាអែលម្តងទៀតទេ»

Numbers 18:6

ឃ្លាភ្ជាប់៖

ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។

ពួកគេជាអំណោយរបស់អ្នក

ព្រះអម្ចាស់តែងតាំងពួកលេវីអោយជួយលោកអើរ៉ុនគឺដូចជាពួកគេជាតង្វាយដែលព្រះអម្ចាស់ប្រទានដល់លោកអើរ៉ុន។ ការបកប្រែផ្សេងទៀត «ពួកគេដូចជាអំណោយសម្រាប់អ្នក»

ជាតង្វាយដល់យើង

នៅទីនេះ «ដែលបានប្រគល់ឲ្យ»

ដល់ព្រះជាម្ចាស់តំណាងអោយការញែកចេញដើម្បីបំរើព្រះជាម្ចាស់។

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«ដែលយើងបានញែកចេញសម្រាប់ខ្លួនយើង» ឬ «ហើយយើងបានញែកពួកគេដាច់ដោយឡែកសម្រាប់ខ្លួនយើង»

មានតែអ្នក និងកូនរបស់អ្នកប៉ុណ្ណោះ

នៅទីនេះ «អ្នក» និង «របស់អ្នក» មានលក្ខណៈធម្មតាហើយសំដៅទៅអើរ៉ុន។ ការកើតឡើងផ្សេងទៀតនៃ «អ្នក» និង «របស់អ្នក» គឺពហុវចន:ហើយសំដៅទៅលើអើរ៉ុននិងកូនប្រុសរបស់គាត់។

បំពេញការងារជាបូជាចារ្យ

«ធ្វើកិច្ចការងារនៃពួកសង្ឃ»

អ្វីៗទាំងអស់ខាងក្នុងវាំនន

ការស្ថិតនៅខាងក្នុងវាំងននតំណាងឱ្យស្ថិតនៅខាងក្នុងបន្ទប់នៅពីក្រោយវាំងនន។ ការបកប្រែផ្សេងទៀត «អ្វីៗនៅក្នុងបន្ទប់នៅពីក្រោយវាំងនន»

ជនបរទេសណាចូលទៅជិត ត្រូវតែសម្លាប់ចោល

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«ជនបរទេសណាដែលចូលជិតត្រូវតែស្លាប់» ឬ «អ្នកត្រូវតែសម្លាប់ជនបរទេសណាដែលចូលមកជិត»

អ្នកណាចូលទៅជិត

អ្វីដែលពួកគេមិនគួរទាក់ទងអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «អ្នកដែលចូលទៅជិតអ្វីៗដែលបរិសុទ្ធ»

Numbers 18:8

តង្វាយដែលថ្វាយដល់យើង

ត្រង់នេះ «បានលើកថ្វាយមកយើង» តំណាងឱ្យការថ្វាយឬថ្វាយអ្វីមួយដល់ព្រះ។ អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«ដង្វាយដែលមនុស្សថ្វាយឱ្យយើង» (សូមមើល និងfigs-activepassive)

យើងប្រគល់តង្វាយនេះឲ្យអ្នក

ព្រះមានបន្ទូលដូចជាទ្រង់បានធ្វើរឿងនេះរួចហើយពីព្រោះវាជាការសម្រេចចិត្តដែលទ្រង់បានធ្វើរួចហើយ។ ការបកប្រែផ្សេងទៀត «យើងប្រគល់តង្វាយទាំងនេះដល់អ្នក»

ទុកជាចំណែករបស់អ្នកជារៀងរហូត

ចំណែកមួយគឺជាចំណែកនៃអ្វីដែលនរណាម្នាក់ទទួល។ ការបកប្រែផ្សេងទៀត

«ជាចំណែកដែលអ្នកនឹងទទួលបានជាបន្ត»

ដែលមិនបានដុត

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«អ្នកមិនត្រូវដុតនៅលើអាសនា»

[illegible]

«ផ្នែកទាំងនេះគឺបរិសុទ្ធណាស់»

Numbers 18:10

ឃ្លាភ្ជាប់៖

ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។

ពិធីសម្អាត

ព្រះសព្វព្រះហឫទ័យនឹងគេ ដោយទទួលយកថា គេស្អាតស្អំ។ ការបកប្រែផ្សេងទៀត «អាចទទួលយកបាន»

Numbers 18:12

ឃ្លាភ្ជាប់៖

ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។

ផលផ្លែទុំដំបងបង្អស់

នេះសំដៅទៅលើប្រេងស្រានិងគ្រាប់ធញ្ញជាតិដំបូងបំផុតដែលពួកគេប្រមូលផល។

គ្រប់គ្នាដែលស្អាតនៅក្នុងគ្រួសាររបស់អ្នក

ព្រះសព្វព្រះហឫទ័យនឹងគេ ដោយទទួលយកថា ដូចជាគេស្អាតស្អំ។ [illegible] ការបកប្រែផ្សេងទៀត

«មនុស្សគ្រប់គ្នានៅក្នុងគ្រួសាររបស់អ្នកដែលអាចទទួលយកបានចំពោះខ្ញុំ»

Numbers 18:14

ឃ្លាភ្ជាប់៖

ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។

កូនដំបូងទាំងអស់ដែលកើតពីផ្ទៃ

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ ការបកប្រែផ្សេងទៀត

«កូនប្រុសច្បងទាំងអស់»

ទាំងអស់ដែលកើតពីផ្ទៃ

សម្គាល់ «បើកស្បូន»

មានន័យថាជាមនុស្សប្រុសដំបូងដែលម្តាយផ្តល់កំណើតអោយ។

ប្រជាជនត្រូវទិញ កូនប្រុសច្បងរបស់មនុស្ស

ជំនួសឱ្យការលះបង់កូនប្រុសច្បងរបស់ពួកគេ ប្រជាជនត្រូវបង់ថ្លៃបូជាជូនបូជាចារ្យសម្រាប់កូនប្រុសរបស់ពួកគេ។

កូនច្បងទាំងអស់ដែលប្រជាជនត្រូវទិញយកទៅវិញ គឺត្រូវមានអាយុចាប់ពីមួយខែឡើងទៅ

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«ប្រជាជនត្រូវទិញវាមកវិញនៅពេលពួកគេមានអាយុមួយខែ»

ទាំងអស់ដែលត្រូវទិញយកទៅវិញ

ភាគច្រើនវាសំដៅទៅលើតែកូនច្បងរបស់មនុស្ស ដែលត្រូវទិញមកវិញ

generated on Wed Sep 10 16:16:32 2025

ហើយមិនសំដៅទៅលើកូនដំបូងរបស់សត្វដែលមិនស្អាតឡើយ។
តម្លៃប្រាំសេកែល.....ដែលស្មើនឹងម្ភៃកេរ៉ា
ប្រសិនបើចាំបាច់ប្រើឯកតាទម្ងន់ទំនើប។ នេះគឺជាវិធីពីរយ៉ាងក្នុងការធ្វើវា។
ការបកប្រែផ្សេងទៀត «ប្រាក់ប្រាំដុំ ... វត្ថុនីមួយៗស្មើនឹងដប់ក្រាម» ឬ
«ប្រាក់ហាសិបក្រាមដោយប្រើទម្ងន់ស្តង់ដារដែលត្រូវបានប្រើនៅក្នុងទីបរិសុទ្ធ»
តម្លៃប្រាំសេកែល
មួយផោនគឺជាឯកតានៃទម្ងន់។ អ្វីដែលថ្លឹងអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ប្រាក់ប្រាំសេកែល»
តម្លៃប្រាំសេកែល តាមខ្នាតទម្ងន់របស់ទីបរិសុទ្ធ
មានទម្ងន់ផ្សេងៗគ្នា។
នេះជារបស់មួយដែលមនុស្សត្រូវប្រើនៅក្នុងទីបរិសុទ្ធនៃព្រះពន្លាដ៏វិសុទ្ធ។
វាមានទំងន់ធរណីមាត្រចំនួនម្ភៃដែលមានទម្ងន់ប្រហែល ១១ក្រាម។
Numbers 18:17
ឃ្លាភ្ជាប់៖
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។
អ្នកត្រូវប្រោះឈាមរបស់វា
អ្នកត្រូវតែសម្លាប់សត្វជាមុនសិន អាចបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែសម្លាប់ពួកគេហើយប្រោះឈាមរបស់ពួកគេ»
ធ្វើឡើងដោយភ្លើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលអ្នកធ្វើដោយភ្លើង» ឬ «អ្នកដុតដោយភ្លើងនៅលើអាសនា»
ដើម្បីជាក្លិនឈ្ងុយដែលគាប់ព្រះហឫទ័យដល់ព្រះព្រះអម្ចាស់
គាប់ព្រះហឫទ័យព្រះអម្ចាស់ជាមួយនឹងក្លិនក្រអូបតំណាងឱ្យសេចក្តីរីករាយរបស់ទ្រង់ជាមួយ
ការបកប្រែផ្សេងទៀត «ហើយព្រះអម្ចាស់នឹងពេញចិត្តអ្នក»
សាច់ដើមទ្រូង និងសាច់ភ្លៅស្តាំ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«សាច់ទ្រូងនិងភ្លៅខាងស្តាំដែលអ្នកលើកជាតង្វាយដល់យើង»
Numbers 18:19
ឃ្លាភ្ជាប់៖
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។
យើងប្រគល់ឲ្យអ្នក
ព្រះមានបន្ទូលដូចជាទ្រង់បានធ្វើរឿងនេះរួចហើយពីព្រោះវាជាការសម្រេចចិត្តដែលទ្រង់បានធ្វើរួចហើយ
ការបកប្រែផ្សេងទៀត «យើងបានប្រគល់អោយអ្នក»
ជាចំណែកជារៀងរហូត
ចំណែកមួយ គឺជាចំណែកនៃអ្វីដែលនរណាម្នាក់ទទួល។
«ជាចំណែកដែលអ្នកនឹងទទួលបានជាបន្ត»
គឺជាសម្ព័ន្ធមេត្រីនៃអំបិលមួយដ៏នៅអស់កល្បជានិច្ច..... ...ជាសម្ព័ន្ធមេត្រីដែលនៅជាប់ជារៀងរហូត
ឃ្លាទាំងពីរសំដៅទៅលើរឿងតែមួយ។ ពួកគេរួមគ្នាបញ្ជាក់ថា
សម្ព័ន្ធមេត្រីនឹងស្ថិតស្ថេរជារៀងរហូត។ ការបកប្រែផ្សេងទៀត
«កិច្ចព្រមព្រៀងជារៀងរហូត»
នៃអំបិលមួយដ៏នៅអស់កល្បជានិច្ច
«សម្ព័ន្ធមេត្រីជាមួយអំបិល»។
អំបិលតំណាងឱ្យភាពស្ថិតស្ថេរហើយត្រូវបានគេប្រើក្នុងការថ្វាយនិងអាហារ។
ការបកប្រែផ្សេងទៀត «សេចក្តីសញ្ញាអចិន្ត្រៃយ៍» ឬ
«សេចក្តីសញ្ញាដែលមានជារៀងរហូត»
អ្នកនឹងគ្មានដីនៅក្នុងស្រុកទុកជារតកឡើយ
ព្រះមានបន្ទូលអំពីទឹកដីដែលមនុស្សផ្សេងទៀតនឹងកាន់កាប់
ដូចជាពួកគេនឹងទទួលទឹកដីជាមត៌ក។ ការបកប្រែផ្សេងទៀត
«អ្នកនឹងមិនមានដីរបស់ប្រជាជន» ឬ
«អ្នកនឹងមិនទទួលបានទឹកដីណាមួយដែលជនជាតិអ៊ីស្រាអែលនឹងកាន់កាប់ទេ»
យើងគឺជាចំណែក និងជាមរតករបស់អ្នក
ព្រះមានបន្ទូលអំពីកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលលោកអើរ៉ុននិងកូនចៅរបស់គាត់
នឹងមាន ដោយបម្រើទ្រង់ជាសង្ឃ ដូចជាព្រះជាអ្វីដែលពួកគេនឹងទទួលជាមត៌ក។
ការបកប្រែផ្សេងទៀត «ផ្ទុយទៅវិញខ្ញុំជាអ្វីដែលអ្នកនឹងមាន» ឬ
«ផ្ទុយទៅវិញខ្ញុំនឹងអនុញ្ញាតឱ្យអ្នកបម្រើយើង
ហើយយើងនឹងផ្តល់ផ្តង់អ្នកតាមរយៈការបម្រើនោះ»
Numbers 18:21
ឃ្លាភ្ជាប់៖
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។
មើល៎,យើងបានប្រគល់
ពាក្យ «មើល៎» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែផ្សេងទៀត «យើងបានប្រគល់ឱ្យ»
ជាមរតករបស់ពួកគេ
ព្រះមានបន្ទូលអំពីអ្វីដែលលោកអើរ៉ុននិងកូនចៅរបស់គាត់នឹងទទួលដូចជាពួកគេនឹងទទួលមរតក។
ការបកប្រែផ្សេងទៀត
«ជាចំណែករបស់ពួកគេនូវអ្វីដែលយើងបានប្រគល់ដល់អ៊ីស្រាអែលទាំងអស់»
Numbers 18:23
ឃ្លាភ្ជាប់៖
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកអើរ៉ុន។
ពួកគេមិនត្រូវមានចំណែកមរតកនៅក្នុងកូនចៅអ៊ីស្រាអែលឡើយ
ព្រះមានបន្ទូលអំពីទឹកដីដែលប្រជាជនអ៊ីស្រាអែលផ្សេងទៀតនឹងកាន់កាប់
ដូចជាពួកគេនឹងទទួលទឹកដីជាមរតក។ ពួកលេវីមិនទទួលដីណាទេ។
ការបកប្រែផ្សេងទៀត
«ពួកគេមិនត្រូវមានទឹកដីណាមួយដែលប្រជាជនអ៊ីស្រាអែលផ្សេងទៀតទទួលបានឡើយ»
មរតកសម្រាប់ពួកគេ
ព្រះមានបន្ទូលអំពីអ្វីដែលអើរ៉ុននិងកូនចៅរបស់គាត់នឹងទទួលដូចជាពួកគេនឹងទទួលមរតក។
ការបកប្រែផ្សេងទៀត
«ជាចំណែករបស់ពួកគេនូវអ្វីដែលយើងបានប្រគល់ដល់អ៊ីស្រាអែលទាំងអស់»
Numbers 18:25
នៅពេលដែលអ្នករាល់គ្នាទទួលតង្វាយមួយភាគដប់ពីពួកកូនចៅអ៊ីស្រាអែល
ជនជាតិអ៊ីស្រាអែលនឹងថ្វាយតង្វាយដល់ព្រះអម្ចាស់ចំនួនមួយភាគដប់ពីហ្វូងសត្វនិងហ្វូងសត្វរបស់ពួកគេ
ដែលព្រះជាម្ចាស់បានប្រគល់សម្រាប់ពួកលេវី។
សំរាប់ជាមរតករបស់អ្នក
ព្រះមានបន្ទូលអំពីអ្វីដែលលោកអើរ៉ុននិងកូនចៅរបស់គាត់នឹងទទួលមរតកដូចពួកគេដែរ។
ការបកប្រែផ្សេងទៀត
«ជាចំណែករបស់អ្នកនូវអ្វីដែលយើងបានប្រគល់ដល់អ៊ីស្រាអែលទាំងអស់»
ដែលបានប្រគល់ឲ្យអ្នក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែពិចារណាការចូលរួមចំណែករបស់អ្នក»
Numbers 18:28
ឃ្លាភ្ជាប់៖
ព្រះជាម្ចាស់បន្តប្រាប់ដល់លោកម៉ូសេពីអ្វីដែលគាត់និងប្រាប់ដល់ពួកលេវី។
អ្នកត្រូវប្រគល់តង្វាយនោះឲ្យទៅបូជាចារ្យអើរ៉ុន
នៅទីនេះ «របស់គាត់» សំដៅទៅលើព្រះអម្ចាស់។
នេះគឺជាវិភាគទានរបស់ព្រះអម្ចាស់ក្នុងន័យថា ពួកគេត្រូវថ្វាយដល់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «អ្នកត្រូវប្រគល់ប្រាក់ដែលបូជាចារ្យអើរ៉ុនអោយអ្នក»
ដែលបានប្រគល់ឲ្យមកអ្នក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលប្រជាជនអ៊ីស្រាអែលប្រគល់ដល់អ្នក
Numbers 18:30
អត្ថបទភ្ជាប់
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ល្អបំផុត
«អ្វីដែលល្អបំផុតដែលអ្នកបានទទួលពីប្រជាជនអ៊ីស្រាអែល»
អំណោយរបស់អ្នក
«អំណោយ»
ជាតង្វាយដែលជនជាតិអ៊ីស្រាអែលថ្វាយដល់ព្រះជាម្ចាស់ហើយពួកលេវីទទួលពីពួកគេ។
ប្រសិនបើអ្នករាល់គ្នាបានថ្វាយចំណែកដ៏ល្អបំផុតដល់ព្រះអម្ចាស់ហើយ នោះអ្នកនឹងមិន
មានទោសដោយព្រោះបរិភោគ និងផឹកវាឡើយ
«អ្នកនឹងមិនមានកំហុសទេនៅពេលអ្នកបរិភោគនិងផឹកវា»

19 [1]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេ និងលោកអើរ៉ុន។ ព្រះអង្គមានបន្ទូលថា៖ [2]«នេះគឺជាបញ្ញត្តិ ជាច្បាប់ដែលយើងបង្គាប់អ្នករាល់គ្នា៖ ចូរប្រាប់ទៅ
ប្រជាជនអ៊ីស្រាអែលថា ពួកគេត្រូវយកគោញីពណ៌ក្រហមមួយក្បាលដែលគ្មានស្លាកស្នាម និងឥតមានខ្ចោះ ហើយមិនធ្លាប់ទឹមសោះមក។

generated on Wed Sep 10 16:16:32 2025

[3]រួចត្រូវប្រគល់គោញីនោះឲ្យទៅបូជាចារ្យអេឡាសារ។ គាត់ត្រូវយកវាទៅក្រៅជំរំ ហើយឲ្យនរណាម្នាក់សម្លាប់គោនោះនៅចំពោះមុខគាត់។[4]បូជាចារ្យអេឡាសារត្រូវយកម្រាមដៃគាត់ជ្រលក់ឈាមក្នុងគោនោះ ហើយប្រោះឈាមវាប្រាំពីរដងទៅមុខត្រសាលប្រជុំ។[5]បន្ទាប់មក បូជាចារ្យម្នាក់ទៀត ត្រូវដុតគោញីនោះនៅចំពោះមុខគាត់ គឺត្រូវដុតទាំងស្បែក ទាំងសាច់ ទាំងឈាម និងលាមករបស់វា។[6]បូជាចារ្យនោះត្រូវយកឈើតាត្រៅ មែកហ៊ីសុប និងរោមចៀមជ្រលក់ពណ៌ក្រហមមក ហើយបោះទៅកណ្តាលភ្លើងដែលកំពុងដុតគោញីនោះ។
[7]បន្ទាប់មក គាត់ត្រូវបោកសម្អាតសម្លៀកបំពាក់របស់ខ្លួន ហើយងូតទឹកចេញ ទើបគាត់អាចចូលមកក្នុងជំរំវិញបាន តែបូជាចារ្យនោះនៅតែសៅហ្មងរហូតដល់ល្ងាច។[8]បូជាចារ្យដែលជាអ្នកដុតគោញីនោះ ត្រូវបោកសម្អាតសម្លៀកបំពាក់របស់គាត់ក្នុងទឹក ហើយត្រូវងូតទឹកដែរ។ បូជាចារ្យនោះក៏នៅតែសៅហ្មងរហូតដល់ល្ងាចដែរ។
[9]បន្ទាប់មក ត្រូវឲ្យមនុស្សម្នាក់ដែលឥតសៅហ្មង ប្រមូលផេះដែលដុតគោញីនោះ យកទៅដាក់នៅខាងក្រៅជំរំត្រង់កន្លែងដែលស្អាត។ ត្រូវទុកផេះនោះសម្រាប់សហគមន៍ប្រជាជនអ៊ីស្រាអែល។ ពួកគេត្រូវលាយផេះនោះជាមួយទឹកសម្រាប់ធ្វើពិធីសម្អាតពីអំពើបាប។[10]អ្នកដែលប្រមូលផេះដុតគោញីនោះ ត្រូវបោកសម្អាតសម្លៀកបំពាក់របស់ខ្លួនដែរ ហើយគេក៏នៅតែមិនស្អាតរហូតដល់ល្ងាច។ នេះគឺច្បាប់ដែលមិនប្រែប្រួលសម្រាប់ប្រជាជនអ៊ីស្រាអែល និងជនបរទេសដែលស្នាក់នៅជាមួយពួកគេ។
[11]អ្នកណាដែលប៉ះពាល់សាកសពរបស់មនុស្សស្លាប់ណាម្នាក់ អ្នកនោះនឹងសៅហ្មងរយៈពេលប្រាំពីរថ្ងៃ។[12]មនុស្សនោះត្រូវធ្វើពិធីសម្អាតខ្លួននៅថ្ងៃទីបី និងថ្ងៃទីប្រាំពីរ នោះគាត់ទើបលែងសៅហ្មង។ ប៉ុន្តែ បើគាត់មិនធ្វើពិធីសម្អាតខ្លួននៅថ្ងៃទីបីទេ នោះនៅថ្ងៃទីប្រាំពីរគាត់ក៏មិនបាត់សៅហ្មងដែរ។[13]អ្នកណាដែលប៉ះពាល់សាកសពមនុស្សស្លាប់ ហើយមិនធ្វើពិធីសម្អាតខ្លួនទេ អ្នកនោះបានធ្វើឲ្យព្រះពន្លារបស់ព្រះអម្ចាស់ទៅជាសៅហ្មងហើយ។ ត្រូវកាត់មនុស្សនេះចេញពីកូនចៅអ៊ីស្រាអែល ពីព្រោះទឹកសម្រាប់ធ្វើពិធីសម្អាតខ្លួនមិនបានប្រោះនៅលើគាត់ទេ។ គាត់នៅតែសៅហ្មង ភាពសៅហ្មងនៅតែស្ថិតនៅលើគាត់។
[14]នេះគឺជាច្បាប់សម្រាប់នៅពេលមាននរណាម្នាក់ស្លាប់នៅក្នុងផ្ទះ។ អ្នកណាដែលចូលទៅក្នុងផ្ទះ និងអ្នកណាដែលនៅក្នុងផ្ទះស្រាប់ នោះនឹងត្រូវសៅហ្មងចំនួនប្រាំពីរថ្ងៃ។[15]អស់ទាំងភាជនៈដែលមិនបិទគម្របនឹងត្រូវសៅហ្មងដែរ។[16]ដូចគ្នានឹងអស់អ្នកណាដែលនៅក្រៅផ្ទះ ប៉ះពាល់សាសពដែលត្រូវគេសម្លាប់ដោយដាវ ប៉ះពាល់សាកសពផ្សេងៗ ឆ្អឹងរបស់មនុស្ស ឬប៉ះពាល់ផ្នូរខ្មោច អ្នកនោះនឹងត្រូវសៅហ្មងចំនួនប្រាំពីរថ្ងៃ។
[17]ចូរធ្វើបែបនេះសម្រាប់មនុស្សដែលសៅហ្មង៖ ត្រូវយកផេះខ្លះពីតង្វាយដុតសម្រាប់លោះបាបមកលាយជាមួយទឹកស្អាតនៅក្នុងផើងមួយ។
[18]អ្នកណាម្នាក់ដែលឥតសៅហ្មងត្រូវយកមែកហ៊ីសុបជ្រលក់ក្នុងទឹកនោះយកទៅប្រោះលើផ្ទះ និងលើភាជនៈទាំងអស់នៅក្នុងផ្ទះនោះ និងប្រោះលើមនុស្សដែលនៅក្នុងផ្ទះនោះ ប្រោះលើអស់អ្នកដែលប៉ះពាល់ឆ្អឹងរបស់មនុស្សដែលត្រូវគេសម្លាប់ ប៉ះពាល់សាកសព ឬប៉ះពាល់ផ្នូរខ្មោច។[19]មនុស្សដែលឥតសៅហ្មងត្រូវប្រោះទឹកនោះលើមនុស្សសៅហ្មងនៅថ្ងៃទីបី និងនៅថ្ងៃទីប្រាំពីរ។ នៅថ្ងៃទីប្រាំពីរ មនុស្សសៅហ្មងនោះត្រូវធ្វើពិធីសម្អាតខ្លួនឯង។ គាត់ត្រូវបោកសម្អាតសម្លៀកបំពាក់របស់គាត់ ហើយត្រូវងូតទឹក។ នៅពេលល្ងាចនោះគាត់នឹងលែងសៅហ្មង។
[20]ប៉ុន្តែ អ្នកណាដែលនៅតែសៅហ្មង ដែលបដិសេធមិនព្រមធ្វើពិធីសម្អាតខ្លួន ត្រូវកាត់អ្នកនោះចេញពីសហគមន៍ ពីព្រោះគេបានធ្វើឲ្យទីបរិសុទ្ធរបស់ព្រះអម្ចាស់ទៅជាសៅហ្មង។ ទឹកសម្រាប់ធ្វើពិធីសម្អាតខ្លួនមិនបានប្រោះនៅលើគាត់ទេ គឺគាត់នៅតែសៅហ្មង។[21]នេះគឺជាច្បាប់សម្រាប់ការនេះជារៀងរហូតទៅ។ អ្នកដែលប្រោះទឹកសម្រាប់ធ្វើពិធីសម្អាតខ្លួន ត្រូវបោកសម្អាតសម្លៀកបំពាក់របស់ខ្លួន។ អ្នកដែលប៉ះទឹកសម្រាប់ធ្វើពិធីសម្អាតខ្លួន អ្នកនោះត្រូវសៅហ្មងរហូតដល់ល្ងាច។[22]អ្វីក៏ដោយដែលមនុស្សសៅហ្មងប៉ះ នឹងត្រឡប់ជាសៅហ្មងទាំងអស់។ ហើយអ្នកណាដែលប៉ះពាល់របស់នោះ អ្នកនោះនឹងត្រូវសៅហ្មងរហូតដល់ល្ងាច។

Numbers 19:1
នេះគឺជាបញ្ញត្តិ ជាច្បាប់
ពាក្យទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ការបកប្រែផ្សេងទៀត «បទបញ្ញត្តិ» ឬ «ច្បាប់បញ្ញត្តិ»
បង្គាប់អ្នករាល់គ្នា
នៅទីនេះ «អ្នក» គឺឯកវាទហើយសំដៅទៅលើលោកម៉ូសេ។
គ្មានស្លាកស្នាម និងឥតមានខ្ចោះ
ពាក្យទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា
និងបញ្ជាក់ថាសត្វនេះគឺល្អឥតខ្ចោះឡើយ។
Numbers 19:3
នៅចំពោះមុខគាត់
«តាមទស្សនៈរបស់គាត់» ឬ «ដូច្នេះគាត់អាចមើលឃើញ»
បូជាចារ្យនោះត្រូវយកឈើតាត្រៅ
«បូជាចារ្យ» សំដៅទៅលើអេឡាសារ។
រោមចៀមជ្រលក់
«រោមចៀមក្រហម»
Numbers 19:7
បន្ទាប់មក គាត់ត្រូវបោកសម្អាតសម្លៀកបំពាក់របស់ខ្លួន
នៅទីនេះ «គាត់» សំដៅទៅលើបូជាចារ្យអេឡាសារ។
បូជាចារ្យនោះក៏នៅតែសៅហ្មងរហូត
ព្រះមិនអាចទទួលយកបានឬមិនសមនឹងធ្វើកិច្ចការបរិសុទ្ធណាមួយ
ត្រូវបានគេនិយាយថាមិនស្អាតស្អំ។
Numbers 19:9
មនុស្សម្នាក់ដែលឥតសៅហ្មង
ព្រះជាម្ចាស់សព្វព្រះហឫទ័យអោយយើងទទួលយកនិងសមនឹងធ្វើកិច្ចការដ៏បរិសុទ្ធដោយ
ផេះទាំងនេះត្រូវរក្សាទុក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែរក្សាផេះទាំងនេះ»
ត្រង់កន្លែងដែលស្អាត
ព្រះជាម្ចាស់សព្វព្រះហឫទ័យអោយយើងស្អាត។
គេក៏នៅតែមិនស្អាតរហូត
ព្រះមិនអាចទទួលយកបានឬមិនសមនឹងធ្វើកិច្ចការបរិសុទ្ធណាមួយ
ត្រូវបានគេនិយាយថាមិនស្អាតស្អំ។
Numbers 19:11
ព័ត៌មានទូទៅ៖
គំនិតនៃ «ស្អាត» និង «បន្សុទ្ធ» តំណាងឱ្យការទទួលយកពីព្រះ។
ព័ត៌មានទូទៅ៖
គំនិតនៃ «មិនស្អាត» «ស្មោកគ្រោក» «ភាពមិនបរិសុទ្ធ» និង «ភាពមិនស្អាតស្អំ» តំណាងឱ្យព្រះជាម្ចាស់មិនទទួលយក។
សាកសពរបស់មនុស្សស្លាប់ណាម្នាក់
«សាកសពរបស់មនុស្សណាម្នាក់»
ធ្វើពិធីសម្អាតខ្លួន
អ្នកនោះនឹងសុំអោយអ្នកដែលស្អាតស្អំធ្វើពិធីជំរះខ្លួនអោយបរិសុទ្ធ
ដោយប្រោះទឹកទៅលើគោលាយជាមួយផេះ។
ការស្នើសុំឱ្យនរណាម្នាក់ធ្វើឱ្យគាត់បរិសុទ្ធ
ត្រូវបានគេនិយាយដូចជាគាត់ត្រូវធ្វើឱ្យខ្លួនគាត់បរិសុទ្ធ។ ការបកប្រែផ្សេងទៀត
«សុំឱ្យនរណាម្នាក់ធ្វើឱ្យគាត់បរិសុទ្ធ»
បើគាត់មិនធ្វើពិធីសម្អាតខ្លួននៅថ្ងៃទីបីទេ នោះនៅថ្ងៃទីប្រាំពីរគាត់ក៏មិនបាត់សៅហ្មងដែរ
អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«គាត់នឹងបានស្អាតនៅថ្ងៃទីប្រាំពីរលុះត្រាតែគាត់សម្អាតខ្លួនគាត់នៅថ្ងៃទីបី»
ត្រូវកាត់មនុស្សនេះចេញ
នៅទីនេះឃ្លា «ត្រូវបានកាត់ផ្តាច់»
មានន័យថាត្រូវបានគេបោះបង់ចោលនិងបញ្ជូនទៅ។
សូមមើលការបកប្រែរឿងនេះនៅ ៩:១៣។ ការបកប្រែផ្សេងទៀត
«មនុស្សនោះត្រូវតែបញ្ជូនទៅឆ្ងាយ» ឬ «អ្នកត្រូវតែបញ្ជូនមនុស្សនោះទៅឆ្ងាយ»
ពីព្រោះទឹកសម្រាប់ធ្វើពិធីសម្អាតខ្លួនមិនបានប្រោះនៅលើគាត់ទេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់ប្រោះទឹកសម្រាប់ភាពមិនបរិសុទ្ធលើគាត់»
កសម្រាប់ធ្វើពិធីសម្អាតខ្លួន
«ទឹកដែលប្រោះលើវត្ថុមិនបរិសុទ្ធដើម្បីធ្វើឱ្យវាបរិសុទ្ធ» ឬ
«ទឹកសម្រាប់ធ្វើឱ្យអ្វីៗស្អាត»
គាត់នៅតែសៅហ្មង ភាពសៅហ្មងនៅតែស្ថិតនៅលើគាត់
ជារួម ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។

generated on Wed Sep 10 16:16:32 2025

Numbers 19:14
ព័ត៌មានទូទៅ៖
គំនិតនៃ «មិនស្អាត» តំណាងឱ្យការមិនអាចទទួលយកបានពីព្រះ ឬសាកសមនឹងការប្រើប្រាស់។
អស់ទាំងភាជនៈដែលមិនបិទគម្របនឹងត្រូវសៅហ្មងដែរ
អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «ធុងបើកចំហនឹងនៅតែស្អាតប្រសិនបើពួកគេមានគម្រប»
គេសម្លាប់ដោយដាវ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «នរណាម្នាក់ដែលនរណាម្នាក់ផ្សេងទៀតបានសម្លាប់ដោយដាវ»

Numbers 19:17
ព័ត៌មានទូទៅ៖
គំនិតនៃ «មិនស្អាត» តំណាងឱ្យការមិនអាចទទួលយកបានពីព្រះជាម្ចាស់ ឬសមនឹងការប្រើប្រាស់។
ព័ត៌មានទូទៅ៖
គំនិតនៃ «ស្អាត» និង «ធ្វើឱ្យបរិសុទ្ធ» នៅទីនេះតំណាងឱ្យការទទួលយកពីព្រះជាម្ចាស់។

Numbers 19:20
ព័ត៌មានទូទៅ៖
គំនិតនៃ «ស្អាត» និង «បន្សុទ្ធ» តំណាងឱ្យការទទួលយកពីព្រះជាម្ចាស់។
ព័ត៌មានទូទៅ៖
គំនិតនៃ «មិនស្អាត» «ស្មោកគ្រោក» និង «ភាពមិនស្អាតស្អំ» តំណាងឱ្យព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យ។
ត្រូវកាត់អ្នកនោះចេញ
នៅទីនេះឃ្លា «ត្រូវបានកាត់ផ្តាច់» មានន័យថាត្រូវបានគេបោះបង់ចោលនិងបញ្ជូនទៅ។ សូមមើលការបកប្រែនៅក្នុង ៩:១៣។ ការបកប្រែផ្សេងទៀត «មនុស្សនោះត្រូវតែត្រូវបានបញ្ជូនទៅឆ្ងាយ» ឬ «អ្នកត្រូវតែបញ្ជូនមនុស្សនោះទៅឆ្ងាយ»
ទឹកសម្រាប់ធ្វើពិធីសម្អាតខ្លួន អ្នកនោះត្រូវសៅហ្មង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់ប្រោះទឹកសម្រាប់ភាពមិនបរិសុទ្ធលើគាត់ទេ»
ទឹកសម្រាប់ធ្វើពិធីសម្អាត
«ទឹកដែលប្រោះលើវត្ថុមិនបរិសុទ្ធ ដើម្បីធ្វើឱ្យវាបរិសុទ្ធ» ឬ «ទឹកសម្រាប់ធ្វើឱ្យអ្វីៗបរិសុទ្ធ» សូមមើលការបកប្រែនៅក្នុង ១៩:១១។

---

20 [1]ដូច្នេះ សហគមន៍ប្រជាជនអ៊ីស្រាអែលទាំងមូលបានធ្វើដំណើរទៅទីរហោស្ថានស៊ីននៅខែទីមួយ ហើយពួកគេបានស្នាក់នៅត្រង់កាដែស កន្លែងដែលលោកស្រីម៉ារាមស្លាប់ ហើយគេបានបញ្ចុះសពនៅទីនោះ។
[2]ពេលនោះ មិនមានទឹកសម្រាប់ សហគមន៍ប្រើប្រាស់ទេ ដូច្នេះ ពួកគេក៏បានប្រមូលគ្នាប្រឆាំងនឹងលោកម៉ូសេ និងលោកអើរ៉ុន។[3]ប្រជាជននាំគ្នារអ៊ូរប្រឆាំងនឹងលោកម៉ូសេដោយពោលថា៖ «ប្រសិនបើ យើងខ្ញុំស្លាប់ជាមួយបងប្អូនរបស់យើងខ្ញុំ ដែលបានស្លាប់នៅចំពោះព្រះអម្ចាស់ នោះប្រសើរជាង!
[4]ហេតុអ្វីបានជាពួកលោកនាំសហគមន៍ របស់ព្រះអម្ចាស់មកក្នុងទីរហោស្ថាន ដើម្បីឲ្យស្លាប់នៅទីនេះ ជាមួយនឹងហ្វូងសត្វរបស់ពួកយើងដូច្នេះ?[5]ហេតុអ្វីបានជាពួកលោកធ្វើឲ្យពួកយើងចាកចេញពីស្រុកអេស៊ីប ដើម្បីនាំពួកយើងមកកាន់ទឹកដីដ៏អាក្រក់បែបនេះ? ដ្បិត នៅទីនេះគ្មានគ្រាប់ពូជ គ្មានដើមល្វា គ្មានដើមទំពាំងបាយជូរ និងដើមទទឹម ហើយក៏គ្មានទឹកផឹកដែរ»។
[6]ដូច្នេះ លោកម៉ូសេ និងលោកអើរ៉ុនបានចេញទៅឆ្ងាយពីមុខក្រុមជំនុំ។ ពួកលោកបានទៅឯមាត់ទ្វារចូលត្រសាលប្រជុំ ហើយក៏ឱនមុខចុះ។ នៅពេលនោះ សិរីរុងរឿងរបស់ព្រះអម្ចាស់បានលេចមកមកឲ្យពួកលោកឃើញ។
[7]ព្រះអម្ចាស់បានមានបន្ទូលទៅលោកម៉ូសេ ដោយបន្ទូលថា៖[8]«ចូរយកដំបងមក ហើយប្រមូលសហគមន៍ឲ្យជួបជុំគ្នា ទាំងអ្នក និងអើរ៉ុនបងប្រុសរបស់អ្នកដែរ។ ហើយចូរនិយាយទៅថ្មនៅចំពោះភ្នែកគេ ហើយបង្គាប់ថ្មឲ្យមានទឹកហូរចេញមក។ អ្នកនឹងធ្វើឲ្យមានទឹកចេញពីថ្មនោះសម្រាប់ពួកគេ ហើយអ្នកត្រូវឲ្យទឹកនោះទៅសហគមន៍ និងហ្វូងសត្វរបស់គេផឹក»។[9]ពេលនោះ លោកម៉ូសេបានយកដំបងពីចំពោះព្រះអម្ចាស់ ដូចដែលព្រះអម្ចាស់បង្គាប់គាត់ឲ្យធ្វើ។
[10]បន្ទាប់មក លោកម៉ូសេ និងលោកអើរ៉ុន បានប្រមូលសហគមន៍ទាំងអស់មកជួបជុំគ្នានៅពីមុខថ្មនោះ។ លោកម៉ូសេបានមានប្រសាសន៍ទៅពួកគេថា៖ «ឥឡូវនេះសូមស្តាប់ខ្ញុំ ពួកបះបោរអើយ! តើយើងត្រូវយកទឹកចេញពីថ្មីនេះសម្រាប់អ្នករាល់គ្នាឬ?»[11]រួចលោកម៉ូសេបានលើកដំបងវាយថ្មនោះពីរដង នោះក៏មានទឹកជាច្រើនហូរចេញពីថ្មមក។ សហគមន៍បានផឹកទឹកនោះ ហើយហ្វូងសត្វរបស់ពួកគេក៏ផឹកដែរ។
[12]បន្ទាប់មក ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេ និងលោកអើរ៉ុនថា៖ «ពីព្រោះអ្នកមិនបានទុកចិត្តយើង និងមិនបានលើកយើងជាបរិសុទ្ធនៅចំពោះភ្នែកកូនចៅអ៊ីស្រាអែល ពួកអ្នកនឹងមិនបាននាំក្រុមជំនុំនេះចូលទៅក្នុងទឹកដីដែលយើងបានប្រគល់ឲ្យអ្នកឡើយ។[13]កន្លែងនេះត្រូវបានគេហៅថា ទឹកមេរីបា ដ្បិត កូនចៅអ៊ីស្រាអែលបានតវ៉ាជាមួយព្រះអម្ចាស់ ហើយព្រះអង្គបានសម្តែងអង្គទ្រង់ជាបរិសុទ្ធនៅចំពោះពួកគេ។
[14]លោកម៉ូសេបានបញ្ជូនអ្នកនាំសារពីកាដែសឲ្យទៅជួបស្តេចស្រុកអេដុម ហើយទូលស្តេចថា៖ «កូនចៅអ៊ីស្រាអែល ជាបងប្អូនរបស់ព្រះអង្គបាននិយាយបែបនេះថា[15]ព្រះអង្គជ្រាបគ្រប់ទាំងការលំបាកបានកើតឡើងចំពោះពួកយើង ហើយព្រះអង្គក៏ដឹងដែរថា ដូនតារបស់យើងបានចុះទៅស្រុកអេស៊ីប និងបានរស់នៅទីនោះយ៉ាងយូរ។ នៅទីនោះជនជាតិអេស៊ីបបានប្រព្រឹត្តយ៉ាងសាហាវចំពោះពួកយើង និងដូនតារបស់យើង។[16]នៅពេលដែលពួកយើងបានអំពាវនាវរកព្រះអម្ចាស់ ព្រះអង្គបានឮសម្លេងរបស់យើង ហើយព្រះអង្គបានចាត់ទេវតានាំពួកយើងចេញពីស្រុកអេស៊ីបមក។ មើល៍! ឥឡូវនេះ ពួកយើងនៅកាដែស ជាក្រុងនៅជាប់នឹងព្រំប្រទល់ស្រុករបស់ព្រះអង្គ។
[17]យើងខ្ញុំសូមព្រះអង្គអនុញ្ញាតឲ្យយើងខ្ញុំដើរឆ្លងកាត់ស្រុករបស់ព្រះអង្គផង។ ពួកយើងនឹងមិនដើរឆ្លងកាត់ស្រែ ឬចម្ការទំពាំងបាយជូរទេ ហើយក៏មិនផឹកទឹកពីអណ្តូងរបស់ព្រះអង្គដែរ។ ពួកយើងនឹងធ្វើដំណើរតាមផ្លូវធំរបស់ស្តេច ហើយក៏នឹងមិនងាកទៅឆ្វេង ឬទៅស្តាំឡើយ រហូតទាល់តែពួកយើងឆ្លងផុតព្រំប្រទល់ស្រុករបស់ព្រះអង្គ»។
[18]ប៉ុន្តែ ស្តេចស្រុកអេដុមបានតបទៅគាត់ថា៖ «ពួកលោកមិនអាចដើរឆ្លងកាត់ស្រុកនេះបានទេ បើអស់លោកនៅតែដើរឆ្លងកាត់ យើងនឹងមកវាយប្រហារអស់លោកដោយដាវជាមិនខាន»។[19]នោះ កូនចៅអ៊ីស្រាអែលបានទូលស្តេចទៀតថា៖ «ពួកយើងគ្រាន់តែដើរតាមផ្លូវធំទេ ប្រសិនបើ ពួកយើង ឬហ្វូងសត្វរបស់ពួកយើងផឹកទឹករបស់ព្រះអង្គ នោះពួកយើងនឹងចេញថ្លៃសង។ សូមគ្រាន់តែអនុញ្ញាតឲ្យពួកយើងដើរឆ្លងកាត់ដោយថ្មើរជើងតែប៉ុណ្ណោះ គឺពួកយើងមិនធ្វើអ្វីផ្សេងឡើយ»។
[20]ប៉ុន្តែ ស្តេចស្រុកអេដុមបានតបទៀតថា៖ «អស់លោកមិនអាចដើរឆ្លងកាត់ស្រុកនេះបានទេ»។ ដូច្នេះហើយ ស្តេចស្រុកអេដុមបានលើកទ័ពជាច្រើន និងអាវុធគ្រប់ដៃចេញទៅទាស់នឹងជនជាតិអ៊ីស្រាអែល។[21]ស្តេចស្រុកអេដុមបានបដិសេធមិនឲ្យជនជាតិអ៊ីស្រាអែលឆ្លងកាត់ស្រុករបស់ខ្លួនទេ។ ហេតុនេះហើយបានជាជនជាតិអ៊ីស្រាអែលចាកចេញពីស្រុកអេដុម។
[22]ដូច្នេះ ប្រជាជនបានធ្វើដំណើរចាកចាញពីកាដែស។ ប្រជាជនអ៊ីស្រាអែល គឺសហគមន៍ទាំងមូល បានទៅដល់ភ្នំហោរ។[23]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេ និងលោកអើរ៉ុននៅភ្នំហោរជាប់ព្រំប្រទល់ស្រុកអេដុមថា៖[24]«លោកអើរ៉ុនត្រូវទៅជួបជុំនឹងដូនតារបស់គាត់ហើយ ដ្បិត គាត់មិនអាចចូលទៅក្នុងស្រុកដែលយើងបានប្រគល់ឲ្យកូនចៅអ៊ីស្រាអែលទេ។ នេះព្រោះតែអ្នកទាំងពីរបានបះបោរប្រឆាំងនឹងសំដីរបស់យើងនៅត្រង់ទឹកមេរីបា។
[25]ចូរនាំលោកអើរ៉ុន និងលោកអេលាសារ កូនប្រុសរបស់គាត់ហើយនាំពួកគេឡើងមកភ្នំហោរ។[26]ចូរដោះសម្លៀកបំពាក់បូជាចារ្យពីខ្លួនលោកអើរ៉ុន ហើយពាក់ឲ្យលោកអេលាសារកូនប្រុសរបស់គាត់។ ដ្បិត លោកអើរ៉ុនត្រូវស្លាប់ទៅជួបជុំជាមួយបងប្អូនរបស់គាត់នៅទីនោះ»។
[27]លោកម៉ូសេបានធ្វើដូចដែលព្រះអម្ចាស់បង្គាប់គាត់។ ពួកគេបានឡើងទៅភ្នំហោរនៅចំពោះមុខសហគមន៍ទាំងមូល។[28]លោកម៉ូសេបានដោះសម្លៀកបំពាក់បូជាចារ្យពីលោកអើរ៉ុន ហើយពាក់ឲ្យលោកអេលាសារកូនប្រុសរបស់លោកអើរ៉ុន។ លោកអើរ៉ុនបានស្លាប់នៅលើកំពូលភ្នំហោរនោះ។ បន្ទាប់មក លោកម៉ូសេ និងលោកអេលាសារបានចុះពីលើភ្នំមកវិញ។[29]នៅពេលសហគមន៍ទាំងមូលបានឃើញថា លោកអើរ៉ុនស្លាប់ ប្រជាជនទាំងអស់បាននាំគ្នាយំកាន់ទុក្ខសម្រាប់គាត់រយៈពេលសាមសិបថ្ងៃ។

generated on Wed Sep 10 16:16:32 2025

Numbers 20:1
ទីរហោស្ថានស៊ីន
ពាក្យថា ស៊ីននៅទីនេះជាភាសាហេប្រឺ គឺជាទីរហោស្ថាន។
វាមិនមែនជាពាក្យអង់គ្លេស «បាប» ទេ។
នៅខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។
ជាពេលដែលព្រះជាម្ចាស់បានជួយសង្គ្រោះជនជាតិអ៊ីស្រាអែល ពីជនជាតិអេស៊ីប។
ខែដំបូងគឺចុងក្រោយខែមីនា និងដើមខែមេសាតាមប្រតិទិនលោកខាងលិច។
បានបញ្ចុះសព
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយពួកគេបានបញ្ចុះនាង»
Numbers 20:2
ពួកគេក៏បានប្រមូលគ្នា
នៅទីនេះ «ពួកគេ» សំដៅទៅលើសហគមន៍។
ពួកគេក៏បានប្រមូលគ្នា
«បានមកដូចហ្វូងមនុស្សមួយ»
នៅចំពោះព្រះអម្ចាស់
នេះតំណាងឱ្យការឈរនៅមុខត្រសាលរបស់ព្រះអម្ចាស់។
Numbers 20:4
ឃ្លាភ្ជាប់៖
ប្រជាជនអ៊ីស្រាអែលបន្តរអ៊ូរទាំទៅលោកម៉ូសេ និងលោកអើរ៉ុន។
ហេតុអ្វីបានជាពួកលោកនាំសហគមន៍ របស់ព្រះអម្ចាស់មកក្នុងទីរហោស្ថាន ដើម្បីឲ្យស្លាប់នៅទីនេះ ជាមួយនឹងហ្វូងសត្វរបស់ពួកយើងដូច្នេះ?
ប្រជាជនប្រើសំណួរនេះដើម្បីតវ៉ានឹងលោកម៉ូសេ និងលោកអើរ៉ុន។
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរនាំសហគមន៍របស់ព្រះអម្ចាស់ចូលទៅក្នុងទីរហោស្ថាននេះ
ដើម្បីសម្លាប់យើងនិងសត្វរបស់យើងនៅទីនេះទេ»។
ហេតុអ្វីបានជាពួកលោកធ្វើឲ្យពួកយើងចាកចេញពីស្រុកអេស៊ីប ដើម្បីនាំពួកយើងមកកាន់ទឹកដីដ៏អាក្រក់បែបនេះ?
ប្រជាជនប្រើសំណួរនេះដើម្បីតវ៉ានឹងលោកម៉ូសេ និងលោកអើរ៉ុន។
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរឱ្យយើងចាកចេញពីប្រទេសអេស៊ីប
ដើម្បីនាំយើងទៅកន្លែងដ៏គួរឱ្យរន្ធត់នេះទេ»។
Numbers 20:6
ឱនមុខចុះ
បង្ហាញថា លោកម៉ូសេនិងអើរ៉ុនកំពុងបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់។
Numbers 20:7
នៅចំពោះភ្នែកគេ
ត្រង់នេះ «ភ្នែករបស់ពួកគេ»
តំណាងឱ្យប្រជាជនឃើញអ្វីដែលលោកម៉ូសេបានធ្វើ។ ការបកប្រែផ្សេងទៀត
«ខណៈពេលពួកគេចាំមើលអ្នក»
ពីចំពោះព្រះអម្ចាស់
នេះតំណាងឱ្យត្រសាលរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«មកពីត្រសាលរបស់ព្រះអម្ចាស់»
Numbers 20:10
តើយើងត្រូវយកទឹកចេញពីថ្មនេះសម្រាប់អ្នករាល់គ្នាឬ?
លោកម៉ូសេសួរសំណួរនេះដោយការមិនសប្បាយចិត្ត
ដើម្បីស្តីបន្ទោសប្រជាជនចំពោះការត្អូញត្អែរ។ អាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «អ្នកត្អូញត្អែរថាគ្មានទឹកទេ។
យើងនឹងធ្វើឱ្យទឹកចេញពីថ្មនេះ» ឬ «អ្នកនឹងមិនសប្បាយចិត្តទេ
ទោះបីយើងធ្វើឱ្យទឹកចេញពីថ្មនេះក៏ដោយក៏ ខ្ញុំនឹងធ្វើវាដែរ»។
តើយើងត្រូវយក
ត្រង់នេះ «យើង»
សំដៅទៅលើលោកម៉ូសេនិងលោកអើរ៉ុនហើយអាចរាប់បញ្ចូលព្រះអម្ចាស់ផង
ប៉ុន្តែមិនរាប់បញ្ចូលប្រជាជនទេ។
Numbers 20:12
ពីព្រោះអ្នកមិនបានទុកចិត្តយើង និងមិនបានលើកយើងជាបរិសុទ្ធនៅចំពោះភ្នែកកូនចៅអ៊ីស្រាអែល
របៀបដែលលោកម៉ូសេបានបង្ហាញថា
គាត់មិនទុកចិត្តនិងផ្តល់កិត្តិយសដល់ព្រះជាម្ចាស់អាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ពីព្រោះអ្នកមិនបានជឿទុកចិត្តលើខ្ញុំ
ឬគោរពយើងជាមនុស្សបរិសុទ្ធចំពោះមុខប្រជាជនអ៊ីស្រាអែល ប៉ុន្តែ
បានវាយថ្មជំនួសការនិយាយទៅកាន់ថ្មដូចដែលខ្ញុំបានប្រាប់អ្នក»
នៅចំពោះភ្នែកកូនចៅអ៊ីស្រាអែល
នៅទីនេះភ្នែកតំណាងឱ្យប្រជាជនបានឃើញអ្វី ដែលម៉ូសេបានធ្វើ។
ការបកប្រែផ្សេងទៀត «ខណៈពេលប្រជាជនអ៊ីស្រាអែលកំពុងចាំមើលអ្នក»
កន្លែងនេះត្រូវបានគេហៅថា
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនបានហៅកន្លែងនេះ»
Numbers 20:14
កូនចៅអ៊ីស្រាអែល
លោកម៉ូសេប្រើឃ្លានេះដើម្បីបញ្ជាក់ថា
ជនជាតិអ៊ីស្រាអែលនិងជនជាតិអេដុមមានទំនាក់ទំនងគ្នា
ព្រោះបុព្វបុរសរបស់ពួកគេឈ្មោះលោកយ៉ាកុប និងលោកអេសាវជាបងប្អូននឹងគ្នា។
នៅពេលដែលពួកយើងបានអំពាវនាវរកព្រះអម្ចាស់
«ពេលយើងអធិស្ឋានដល់ព្រះអម្ចាស់ សូមទ្រង់ជួយដល់ពួកយើង»
ព្រះអង្គបានឮសំឡេងរបស់យើង
នៅទីនេះ «សំឡេង» តំណាងឱ្យការយំរបស់ពួកគេ
ឬអ្វីដែលពួកគេបាននិយាយទៅកាន់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ទ្រង់ឮសំឡេងយំរបស់យើង» ឬ »ទ្រង់បានឮអ្វីដែលយើងបានស្នើសុំ»
មើល!
«មើល!» នៅទីនេះបង្ហាញពីការផ្លាស់ប្តូរប្រធានបទ។
ពួកគេគ្រាន់តែនិយាយអំពីអតីតកាលរបស់ពួកគេ។ ឥឡូវនេះ
ពួកគេនិយាយអំពីស្ថានភាពបច្ចុប្បន្នរបស់ពួកគេនៅពេលពួកគេរៀបចំ
ស្នើសុំស្តេចឱ្យធ្វើអ្វីមួយ។
Numbers 20:17
ឃ្លាភ្ជាប់៖
អ្នកនាំសារបន្តទួលថ្វាយស្រុកស្តេចអេដុម។
ហើយក៏នឹងមិនងាកទៅឆ្វេង ឬទៅស្តាំឡើយ
នៅទីនេះ «ងាកទៅម្ខាង» តំណាងឱ្យការចាកចេញពីផ្លូវ។ ការបកប្រែផ្សេងទៀត
«យើងនឹងមិនចាកចេញពីផ្លូវក្នុងទិសដៅណាមួយទេ»
តាមផ្លូវធំរបស់ស្តេច
នេះជាផ្លូវសំខាន់ ដែលភ្ជាប់ក្រុងដាម៉ាសនៅភាគខាងជើង
ទៅឈូងសមុទ្រអាកាបានៅភាគខាងត្បូង។
Numbers 20:18
ពួកអ្នកមិនអាចដើរឆ្លងកាត់.....នឹងមកវាយប្រហារអ្នក
នៅទីនេះ «អ្នក»
ជាឯកវចនៈហើយសំដៅទៅលើលោកម៉ូសេដែលតំណាងឱ្យប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ប្រជាជនរបស់អ្នកមិនអាចឆ្លងកាត់ ...
ដើម្បីវាយប្រហារពួកគេ»
យើងនិងមកជាមួយនិងដាវ
នៅទីនេះដាវតំណាងឱ្យកងទ័ពរបស់ស្តេច។ ការបកប្រែផ្សេងទៀត
«យើងនឹងបញ្ជូនកងទ័ពរបស់យើង»
កូនចៅអ៊ីស្រាអែល
ឃ្លានេះសំដៅទៅលើអ្នកនាំសារអ៊ីស្រាអែល។
ដើរឆ្លងកាត់ដោយថ្មើរជើង
លេខសម្គាល់នេះមានន័យថា
ពួកគេនឹងធ្វើដំណើរឆ្លងកាត់តំបន់នោះដោយការដើរ។
ពួកគេមិនចូលមករទេះសេះដើម្បីវាយប្រហារប្រជាជនអេដុមទេ។
Numbers 20:20
នោះស្តេចស្រុកអេដុមបានលើកទ័ពជាច្រើន និងអាវុធគ្រប់ដៃចេញទៅទាស់នឹងពួកអ៊ីស្រាអែល
នៅទីនេះដៃតំណាងឱ្យកងទ័ពដ៏មានឥទ្ធិពលរបស់ស្តេច។ ការបកប្រែផ្សេងទៀត
«ស្តេចអេដុមបានបញ្ជូនកងទ័ពដ៏ខ្លាំងរបស់ទាហានជាច្រើនដើម្បីវាយលុកអ៊ីស្រាអែល»
ឆ្លងកាត់ស្រុករបស់ពួកគេ

generated on Wed Sep 10 16:16:32 2025

នៅទីនេះ «របស់ពួកគេ» សំដៅទៅលើជនជាតិអេដុម។
Numbers 20:22
ចៅអ៊ីស្រាអែល គឺសហគមន៍ទាំងមូល
ឃ្លា «សហគមន៍ទាំងមូល» សង្កត់ធ្ងន់ថា មនុស្សគ្រប់រូបដែលជាផ្នែកនៃ
«ប្រជាជនអ៊ីស្រាអែល» មានវត្តមានដោយគ្មានករណីលើកលែង។
លោកអើរ៉ុនត្រូវទៅជួបជុំនឹងដូនតារបស់គាត់ហើយ
នេះជាវិធីសុភាពរាបសាដែលត្រូវនិយាយថា លោកអើរ៉ុនត្រូវតែស្លាប់។ មានន័យថា
ដល់ពេលលោកអើរ៉ុនត្រូវស្លាប់ហើយវិញ្ញាណរបស់គាត់
ត្រូវទៅកន្លែងដែលដូនតាគាត់នៅ។ ការបកប្រែផ្សេងទៀត
«លោកអើរ៉ុនត្រូវតែស្លាប់»
បានបះបោរប្រឆាំងនឹងបញ្ជារបស់យើង
ត្រង់នេះ «ពាក្យរបស់ខ្ញុំ» តំណាងឱ្យអ្វីដែលព្រះជាម្ចាស់មានបន្ទូល។
ការបកប្រែផ្សេងទៀត «បដិសេធន៏មិនធ្វើអ្វីដែលយើងបាននិយាយ»
Numbers 20:25
ឃ្លាភ្ជាប់៖
ព្រះជាម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ត្រូវស្លាប់ទៅជួបជុំជាមួយបងប្អូនរបស់គាត់
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ពួកគេមានន័យថា ដល់ពេលលោកអើរ៉ុនត្រូវស្លាប់
ហើយវិញ្ញាណរបស់គាត់ត្រូវទៅកន្លែងដែលដូនតាគាត់នៅ។
Numbers 20:27
សាមសិបថ្ងៃ
«៣០ថ្ងៃ»

21 [1]នៅពេលដែលព្រះបាទអើរ៉ាត ជាស្តេចជនជាតិកាណានដែលរស់នៅតំបន់ណេកិប បានឮថាជនជាតិអ៊ីស្រាអែលកំពុងតែធ្វើដំណើរតាមផ្លូវស្រុកអថារីម
ស្តេចក៏ចេញមកច្បាំងនឹងជនជាតិអ៊ីស្រាអែល ហើយបានចាប់ពួកគេខ្លះជាឈ្លើយ។[2]ជនជាតិអ៊ីស្រាអែលបានស្បថនឹងព្រះអម្ចាស់ថា៖ «ប្រសិនបើ ព្រះអង្គ
ប្រទានឲ្យពួកយើងមានជ័យជម្នះលើជនជាតិនេះ នោះពួកយើងនឹងបំផ្លាញក្រុងទាំងប៉ុន្មានរបស់ពួកគេឲ្យខ្ទេច»។[3]ព្រះអម្ចាស់បានស្តាប់តាមពាក្យរបស់ជនជាតិអ៊ីស្រាអែល
ហើយព្រះអង្គបានប្រទានឲ្យពួកគេមានជ័យជម្នះលើជនជាតិកាណាន។ ជនជាតិអ៊ីស្រាអែលបានបំផ្លាញពួកគេ និងទីក្រុងទាំងឡាយរបស់ពួកគេអស់។
[4]ជនជាតិអ៊ីស្រាអែលបានធ្វើដំណើរពីភ្នំហោរតាមផ្លូវទៅសមុទ្រកក់ដើម្បីវាងស្រុកអេដុម ប៉ុន្តែ នៅតាមផ្លូវប្រជាជនបាក់ទឹកចិត្តជាខ្លាំង។[5]ពេលនោះប្រជាជនក៏និយាយ
ប្រឆាំងនឹងព្រះអម្ចាស់ និងលោកម៉ូសេដោយពោលថា៖ «ហេតុអ្វីបានជាអ្នកនាំពួកយើងចេញមកពីស្រុកអេស៊ីបឲ្យស្លាប់នៅទីរហោស្ថានដូច្នេះ? នៅទីនេះគ្មាននំប៉័ង
គ្មានទឹក ហើយពួកយើងធុញនឹងអាហារដ៏គម្រក់នេះណាស់»។
[6]នោះ ព្រះអម្ចាស់បានបញ្ជូនពស់ពិសមកក្នុងចំណោមប្រជាជន។ ពស់បានចឹកប្រជាជន ហើយប្រជាជនជាច្រើននាក់បានស្លាប់។[7]ប្រជាជនបានមកជួបលោកម៉ូសេហើយ
និយាយថា៖ «ពួកយើងបានធ្វើបាប ពីព្រោះពួកយើងបាននិយាយប្រឆាំងនឹងព្រះអម្ចាស់ និងលោក។ សូមលោកអធិស្ឋានដល់ព្រះអម្ចាស់ សូមព្រះអង្គយកពស់ទាំងនេះ
ចេញឲ្យឆ្ងាយពីពួកយើងទៅ»។ ដូច្នេះ លោកម៉ូសេក៏បានអធិស្ឋានសម្រាប់ប្រជាជន។
[8]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេថា៖ «ចូរធ្វើពស់មួយ ហើយដាក់នៅលើបង្គោល។ អស់អ្នកណាដែលត្រូវពស់ចឹក បានមកមើលពស់នោះ គេនឹងមិនស្លាប់ទេ»។
[9]ដូច្នេះ លោកម៉ូសេបានធ្វើពស់ពីលង្ហិន ហើយយកវាទៅដាក់នៅលើបង្គោលមួយ។ នៅពេលពស់ចឹកនរណាម្នាក់ ប្រសិនបើ គេបានសម្លឹងមើលពស់លង្ហិននោះ គេ
មិនស្លាប់ឡើយ។
[10]បន្ទាប់មក ប្រជាជនអ៊ីស្រាអែលក៏បានបន្តធ្វើដំណើរទៀត ហើយបានទៅបោះជំរំនៅអូបូត។[11]ពួកគេបានធ្វើដំណើរពីទីនោះទៅបោះជំរំនៅអ៊ីយេអាបារីមក្នុងទីរហោស្ថាន
ដែលជាប់ព្រំប្រទល់ខាងកើតស្រុកម៉ូអាប់។
[12]ហើយពួកគេបានធ្វើដំណើរចេញពីទីនោះ ទៅបោះជំរំនៅជ្រលងភ្នំសេរេឌ។[13]បន្ទាប់មក ពួកគេបានធ្វើដំណើរចេញពីទីនោះទៀត ទៅបោះជំរំនៅត្រើយម្ខាងស្ទឹងអើណូន
ជាស្ទឹងដែលហូរចេញពីស្រុកអាម៉ូរី កាត់តាមទីរហោស្ថាន។ ស្ទឹងអើណូនបង្កើតបានជាព្រំប្រទល់របស់ស្រុកម៉ូអាប់ គឺជាព្រំប្រទល់រវាងស្រុកម៉ូអាប់ និងស្រុកអាម៉ូរី។
[14]ហេតុនេះហើយបានជាមានគេនិយាយនៅក្នុងសៀវភៅសង្គ្រាមរបស់ព្រះអម្ចាស់ពី៖ «ស្ទឹងវ៉ាហេប ក្នុងស្រុកស៊ូផា និងជ្រលងភ្នំអើណូន[15]ព្រមទាំងជម្រាលភ្នំដែល
លាតសន្ធឹងទៅក្រុងអើរ ហើយចុះទៅរហូតដល់ព្រំប្រទល់ស្រុកម៉ូអាប់»។
[16]ពួកគេបានធ្វើដំណើរចេញពីទីនោះ ទៅបោះជំរំនៅប៊ៀរ គឺត្រង់អណ្តូងទឹកដែលព្រះអម្ចាស់បានមានបន្ទូលទៅលោកម៉ូសេថា៖ «ចូរប្រមូលប្រជាជនមកជួបជុំគ្នា យើងនឹង
ឲ្យទឹកពួកគេ»។
[17]បន្ទាប់មក ជនជាតិអ៊ីស្រាអែលបានច្រៀងចម្រៀងថា៖[18]«អណ្តូងអើយ! ចូរផុសទឹកចេញមក! ចូរយើងច្រៀងអំពីអណ្តូងនោះ។ ជាអណ្តូងដែលអ្នកដឹកនាំរបស់យើង
បានជីក ជាអណ្តូងដែលពួកអ្នកត្រកូលខ្ពស់បានជីក ដោយដំបងរាជ និងដំបងរបស់ពួកគេ»។ បន្ទាប់មក ពួកគេបានធ្វើដំណើរពីទីរហោស្ថានទៅដល់ម៉ាថាណា។
[19]ពីម៉ាណាថា ពួកគេបានធ្វើដំណើរទៅដល់ណាហាលាល ពីណាហាលាលទៅបាម៉ុត[20]ពីបាម៉ុតទៅជ្រលងភ្នំដែលស្ថិតនៅវាលស្រុកម៉ូអាប់។ ទីនោះគឺជាកំពូលភ្នំពីស្គា
ដែលមើលទៅឃើញទីរហោស្ថាន។
[21]បន្ទាប់មក ជនជាតិអ៊ីស្រាអែលបានបានចាត់អ្នកនាំសារទៅព្រះបាទស៊ីហុនស្តេចជនជាតិអាម៉ូរី ឲ្យទូលស្តេចថា៖[22]«សូមអនុញ្ញាតឲ្យយើងខ្ញុំដើរឆ្លងកាត់ស្រុករបស់ព្រះ
អង្គផង។ ពួកយើងនឹងមិនងាកមើលស្រែ ឬចម្ការទំពាំងបាយជូរទេ។ ពួកយើងក៏មិនផឹកទឹកពីអណ្តូងរបស់ព្រះអង្គដែរ គឺពួកយើងនឹងដើរតាមផ្លូវធំរបស់ស្តេច
រហូតទាល់តែពួកយើងបានដើរផុតព្រំប្រទល់ស្រុករបស់ព្រះអង្គ។ [23]ប៉ុន្តែ ព្រះបាទស៊ីហុនមិនអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលដើរឆ្លងកាត់ព្រំស្រុករបស់ខ្លួនទេ។
លើសពីនោះទៀត ព្រះបាទស៊ីហុនបានប្រមូលកងទ័ពទាំងអស់របស់ព្រះអង្គទៅវាយប្រហារជនជាតិអ៊ីស្រាអែលនៅទីរហោស្ថាន។ ស្តេចបានមកច្បាំងនឹងជនជាតិ
អ៊ីស្រាអែលនៅត្រង់យ៉ាហាស់។
[24]ជនជាតិអ៊ីស្រាអែលបានវាយប្រហារកងទ័ពរបស់ព្រះបាទស៊ីហុនដោយមុខដាវ ហើយដណ្តើមយកស្រុករបស់ពួកគេចាប់ពីស្ទឹងអើណូន រហូតដល់ស្ទឹងយ៉ាបុក គឺមក
ដល់ស្រុករបស់ជនជាតិអាំម៉ូន រីឯព្រំប្រទល់របស់ជនជាតិអាំម៉ូន មានកំពែងរឹងមាំណាស់។[25]ដូច្នេះ ជនជាតិអ៊ីស្រាអែលវាយយកបានទីក្រុងទាំងអស់របស់ជនជាតិអាម៉ូរី
ហើយបានរស់នៅក្នុងក្រុងទាំងនោះ រួមទាំងក្រុងហែសបូន និងភូមិទាំងអស់របស់ក្រុងនោះផង។[26]ក្រុងហែសបូន គឺជាទីក្រុងរបស់ព្រះបាទស៊ីហុន ជាស្តេចរបស់ជនជាតិ
អាម៉ូរី ដែលបានច្បាំងនឹងស្តេចមុនរបស់ជនជាតិម៉ូអាប់។ ព្រះបាទស៊ីហុន បានវាយដណ្តើមយកទឹកដីរបស់ស្តេចនោះរហូតដល់ស្ទឹងអើណូន។
[27]ហេតុនេះហើយបានជាអស់អ្នកដែលសរសេរកំណាព្យបានសរសេរថា៖ «ចូរមកក្រុងហែសបូន! ចូរសង់ទីក្រុងរបស់ព្រះបាទស៊ីហុនឡើងវិញ ចូរសង់ទីក្រុងនេះម្តងទៀត!
[28]បន្ទាប់ពីមានភ្លើងឆេះពីក្រុងហែសបូន អណ្តាតភ្លើងពីទីក្រុងរបស់ព្រះបាទស៊ីហុនដែលឆេះបំផ្លាញក្រុងអើររបស់ស្រុកម៉ូអាប់ និងម្ចាស់នៃទីខ្ពស់ៗរបស់ស្ទឹងអើណូន។
[29]ជនជាតិម៉ូអាប់អើយ! អ្នកវេទនាហើយ! ប្រជាជនរបស់ព្រះកេម៉ូសអើយ! អ្នកវិនាសហើយ។ ព្រះនេះបានធ្វើឲ្យកូនប្រុសរបស់ខ្លួនរត់ភៀសខ្លួន ហើយកូនស្រីរបស់ខ្លួនត្រូវ
ក្លាយជាអ្នកទោសរបស់ព្រះបាទស៊ីហុន ជាស្តេចរបស់ជនជាតិអាម៉ូរី។[30]ប៉ុន្តែ ពួកយើងមានជ័យជម្នះលើព្រះបាទស៊ីហុន។ ក្រុងហែសបូនត្រូវវិនាសរហូតដល់ឌីបូន។ យើង
បានកម្ទេចពួកគេរហូតដល់ណូផា គឺរហូតដល់មេឌីបា»។
[31]ដូច្នេះ ជនជាតិអ៊ីស្រាអែលបានរស់នៅក្នុងស្រុករបស់ជនជាតិអាម៉ូរី។[32]បន្ទាប់មក លោកម៉ូសេបានចាត់មនុស្សឲ្យទៅអង្កេតមើលក្រុងយ៉ាស៊ើរ។ ពួកគេបានចាប់យក
ភូមិទាំងឡាយរបស់ក្រុងនោះ ហើយក៏បានបណ្តេញជនជាតិអាម៉ូរីចេញពីទីនោះដែរ។
[33]បន្ទាប់មក ពួគគេបានត្រឡប់មកវិញ ហើយបានធ្វើដំណើរឡើងទៅស្រុកបាសាន។ ព្រះបាទអុក ជាស្តេចនស្រុកបាសាន បានលើកទ័ពចេញមកច្បាំង
នឹងពួកគេនៅអេទ្រី។[34]ពេលនោះព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេថា៖ «កុំខ្លាចគេឡើយ! ដ្បិត យើងបានឲ្យអ្នកមានជ័យជម្នះលើស្តេចនេះហើយ ហើយក៏ប្រគល់
កងទ័ពទាំងអស់របស់គេ និងស្រុករបស់គេឲ្យអ្នកដែរ។ ចូរប្រព្រឹត្តចំពោះគេ ដូចដែលបានប្រព្រឹត្តចំពោះព្រះបាទស៊ីហុន ស្តេចរបស់ជនជាតិអាម៉ូរីនៅក្រុងហែសបូនដែរ។
[35]ដូច្នេះ ពួកគេបានសម្លាប់ស្តេចនោះ និងកូនៗរបស់ស្តេច ព្រមទាំងកងទ័ពរបស់ស្តេចទាំងអស់ចោល គឺគ្មាននរម្នាក់នៅរស់ឡើយ។ ហើយជនជាតិអ៊ីស្រាអែលបាន
ចាប់យកស្រុកនោះ។

generated on Wed Sep 10 16:16:32 2025

Numbers 21:1

ស្តេចក៏ចេញមកច្បាំងនឹងអ៊ីស្រាអែល

ត្រង់នេះ «ស្តេចបានប្រយុទ្ធ» មានន័យថា កងទ័ពរបស់ស្តេចបានប្រយុទ្ធ។ ការបកប្រែផ្សេងទៀត «កងទ័ពរបស់ស្តេចបានច្បាំងនឹងអ៊ីស្រាអែល»

អ៊ីស្រាអែលបានស្បថ

សំដៅទៅលើប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «ប្រជាជនអ៊ីស្រាអែលបានស្បថ» ឬ «ជនជាតិអ៊ីស្រាអែលបានស្បថ»

ស្តាប់តាមពាក្យរបស់អ៊ីស្រាអែល

ត្រង់នេះ «ស្តាប់» មានន័យថាព្រះអម្ចាស់បានធ្វើដូច ដែលពួកគេបានសួរ។ ការបកប្រែផ្សេងទៀត «បានធ្វើអ្វីដែលជនជាតិអ៊ីស្រាអែលបានស្នើសុំ»

សំឡេងអ៊ីស្រាអែល

នៅទីនេះ «សំឡេង» សំដៅទៅលើសំណើរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «អ្វីដែលអ៊ីស្រាអែលបានស្នើសុំ»

ពួកយើងនឹងបំផ្លាញក្រុងទាំងប៉ុន្មានរបស់ពួកគេឲ្យខ្ទេច

«ប្រជាជនអ៊ីស្រាអែលបានបំផ្លាញកងទ័ពកាណាននិងទីក្រុងរបស់ពួកគេទាំងស្រុង»

គេហៅកន្លែងនោះថាហោរម៉ា

អាចថ្លែងនៅក្នុងទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេបានហៅកន្លែងនោះថាហោរម៉ា»

Numbers 21:4

ហេតុអ្វីបានជាអ្នកនាំពួកយើងចេញមកពីស្រុកអេស៊ីបឲ្យស្លាប់នៅទីរហោស្ថានដូច្នេះ?

ប្រជាជនប្រើសំណួរនេះដើម្បីស្តីបន្ទោសលោកម៉ូសេ។ អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «អ្នកមិនគួរឱ្យយើងចាកចេញពីអេស៊ីប ឱ្យស្លាប់នៅទីរហោស្ថានទេ!»

Numbers 21:6

ពួកយើងបាននិយាយប្រឆាំងនឹងព្រះអម្ចាស់ និងលោក

«យើងបាននិយាយអាក្រក់ពីព្រះអម្ចាស់និងអ្នក»

យើង

ពាក្យថា «យើង» ត្រង់នេះសំដៅទៅលើប្រជាជន តែមិនមែនចំពោះព្រះអម្ចាស់ ឬលោកម៉ូសេទេ។

Numbers 21:8

ធ្វើពស់មួយ

ដោយសារម៉ូសេមិនអាចបង្កើតពស់ពិតប្រាកដបាននោះមានន័យថាគាត់ត្រូវធ្វើពស់គំរូ។ ព័ត៌មានដែលបញ្ជាក់នេះអាចបញ្ជាក់ឱ្យកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត «ធ្វើពស់គំរូ

អស់អ្នកណាដែលត្រូវពស់ចឹក

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «មនុស្សគ្រប់គ្នាដែលពស់ចឹក»

ពស់ពីពីលង្ហិន

«ពស់មួយធ្វើពីសំរិទ្ធ»

ប្រសិនបើ គេបានសម្លឹងមើលពស់លង្ហិននោះ គេមិនស្លាប់ឡើយ

នៅទីនេះ «គាត់» សំដៅទៅលើ «មនុស្សណាម្នាក់» ដែលត្រូវបានពស់ចឹក។

Numbers 21:10

ប្រទល់ស្រុកម៉ូអាប់

ត្រង់នេះ «មុខ» ជាសំណួរដែលមានន័យថា «ឆ្លងពី» ឬ «នៅជាប់»។ ការបកប្រែផ្សេងទៀត «នោះគឺនៅជាប់នឹងម៉ូអាប់»

Numbers 21:12

ព្រំប្រទល់រវាងស្រុកម៉ូអាប់ និងស្រុកអាម៉ូរី

គាត់មានន័យថា

ប្រជាជនទាំងពីររស់នៅតាមដងទន្លេផ្សេងគ្នាដែលជាព្រំប្រទល់រវាងពួកគេ។ ជនជាតិម៉ូអាប់រស់នៅខាងត្បូងជាប់នឹងទន្លេ ហើយជនជាតិអាម៉ូរីរស់នៅខាងជើង។

Numbers 21:14

វ៉ាហេប ក្នុងស្រុកស៊ូផា

ទាំងពីរនេះជាឈ្មោះទីកន្លែង។

ព្រមទាំងជម្រាលភ្នំដែលលាតសន្ធឹងទៅក្រុងអើរ ហើយចុះទៅរហូតដល់ព្រំប្រទល់ស្រុកម៉ូអាប់

«ចុះពីលើភ្នំទៅកាន់ ក្រុងអើរ និងព្រំប្រទល់ប្រទេសម៉ូអាប់»

Numbers 21:16

ប៊ៀរ គឺត្រង់អណ្តូងទឹក

អាចបញ្ជាក់ជាពីរប្រយោគ។ ការបកប្រែផ្សេងទៀត «ទៅស្រុកបៀរ។ មានអណ្តូងមួយនៅទីនោះ»

ជាកន្លែងដែលព្រះអម្ចាស់បានមានបន្ទូលទៅលោកម៉ូសេថា៖ «ចូរប្រមូលកូនចៅអ៊ីស្រាអែលមក យើងនឹងឲ្យទឹកពួកគេផឹក»

អាចបញ្ជាក់ជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត «កន្លែងដែលព្រះអម្ចាស់បានប្រាប់លោកម៉ូសេ ឲ្យប្រមូលប្រជាជនរួមគ្នាសម្រាប់គាត់ ដើម្បីផ្តល់ទឹកដល់ពួកគេ»

Numbers 21:17

អណ្តូងអើយ! ចូរផុសទឹកចេញមក!

នៅទីនេះ «អណ្តូង» តំណាងឱ្យទឹកនៅក្នុងអណ្តូង។ ជនជាតិអ៊ីស្រាអែលកំពុងនិយាយទៅកាន់ទឹក ដូចជាមនុស្សដែលអាចស្តាប់ពួកគេ ហើយពួកគេបានស្នើសុំឱ្យបំពេញអណ្តូងទឹក។ ការបកប្រែផ្សេងទៀត «ទឹក ចូរបំពេញអណ្តូងទឹក»

ជាអណ្តូងដែលអ្នកដឹកនាំរបស់យើងបានជីក ជាអណ្តូងដែលពួកអ្នកត្រកូលខ្ពស់បានជីក

ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា និងសង្កត់ធ្ងន់លើតួនាទីរបស់អ្នកដឹកនាំក្នុងការជីកអណ្តូង។

ដោយដំបងរាជ និងដំបងរបស់ពួកគេ

ដំបងមួយត្រូវបានដឹកដោយអ្នកមានអំណាច ហើយដំបងត្រូវបានដឹកដោយមនុស្សគ្រប់គ្នា។ ទាំងពីរនេះមិនមែនជាឧបករណ៍ជីកទេ។ ធាតុទាំងពីរនេះសង្កត់ធ្ងន់ថា ពួកគេមិនមានមោទនភាពពេក ក្នុងការប្រើមធ្យោបាយណា ដែលមាន។ ការបកប្រែផ្សេងទៀត «ប្រើសូម្បីតែដំបងនិងដំបងរបស់ពួកគេ»

Numbers 21:19

ណាហាលាល .....បាម៉ុត

ទាំងនេះជាឈ្មោះទីកន្លែង។

ភ្នំពីស្កា

នេះជាឈ្មោះភ្នំ។

មើលទៅឃើញទីរហោស្ថាន

នេះជាលេខសម្គាល់។ វាគឺជាវិធីនៃការនិយាយថា ភ្នំខ្ពស់ហើយនិយាយពីភ្នំហាក់ដូចជា មនុស្សដែលក្រឡេកមើលទៅទីរហោស្ថាននៅខាងក្រោម។ ការបកប្រែផ្សេងទៀត «ឡើងនៅលើទីរហោស្ថាន»

Numbers 21:21

បន្ទាប់មក ជនជាតិអ៊ីស្រាអែល

នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើប្រជាជនអ៊ីស្រាអែល និងជាពិសេសចំពោះមេដឹកនាំរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «បន្ទាប់មកជនជាតិអ៊ីស្រាអែល»

ពួកយើងនឹងមិនងាកមើលស្រែ ឬចម្ការទំពាំងបាយជូរទេ

«យើងនឹងមិនចូលទៅក្នុងចំការ ឬចម្ការទំពាំងបាយជូររបស់អ្នកទេ»

តាមផ្លូវធំរបស់ស្តេច

នេះជាផ្លូវសំខាន់ដែលភ្ជាប់ក្រុងដាម៉ាសនៅភាគខាងជើងទៅឈូងសមុទ្រអាកាបានៅភាគខាងត្បូង។ សូមមើលការបកប្រែនៅក្នុង ២០:១៧។

ឆ្លងកាត់ព្រំស្រុករបស់ពួកគេ

«ឆ្លងកាត់ព្រំដែនរបស់ពួកគេ» នៅទីនេះ «របស់ពួកគេ» សំដៅទៅលើជនជាតិអាម៉ូរី។

ត្រង់យ៉ាហាស់

នេះជាឈ្មោះទីកន្លែង។

ស្តេចបានមកច្បាំងនឹងជនជាតិអ៊ីស្រាអែល

ត្រង់នេះ «គាត់» សំដៅទៅលើកងទ័ពរបស់ស្តេចហើយ «អ៊ីស្រាអែល» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «កងទ័ពរបស់គាត់បានច្បាំងនឹងពួកអ៊ីស្រាអែល»

Numbers 21:24

ជនជាតិអ៊ីស្រាអែលបានវាយប្រហារ

ត្រង់នេះ «អ៊ីស្រាអែល» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «ជនជាតិអ៊ីស្រាអែលបានវាយប្រហារ»

ដោយមុខដាវ

«ជាមួយនឹងផ្នែកមុតស្រួចនៃដាវ»។ «គែមដាវ»

មានជាប់ទាក់ទងនឹងការស្លាប់និងការបំផ្លាញទាំងស្រុង។ ការបកប្រែផ្សេងទៀត «ហើយបានកម្ចាត់ពួកគេទាំងស្រុង»

យកបានទីក្រុងទាំងអស់

«បានដណ្តើមទឹកដីរបស់ជនជាតិអាម៉ូរី»។ ត្រង់នេះពាក្យ «របស់ពួកគេ»

generated on Wed Sep 10 16:16:32 2025

សំដៅទៅលើជនជាតិអាម៉ូរី។
ជនជាតិអាំម៉ូន...ជនជាតិអាម៉ូរី
«ជនជាតិអាម៉ូរី ... នៃជនជាតិអាម៉ូរី» ឬ «ប្រជាជនអាំម៉ូន ... នៃប្រជាជនអាំម៉ូន»។
ឈ្មោះទាំងនេះគឺស្រដៀងគ្នាប៉ុន្តែពួកគេជាក្រុមមនុស្សពីរផ្សេងគ្នា។
រឹងមាំ
«ត្រូវបានការពារយ៉ាងខ្លាំង» (យូឌីប៊ី) ។
ជនជាតិអ៊ីស្រាអែលមិនបានវាយប្រហារជនជាតិអាំម៉ូនទេ។
ក្រុងហែសបូន និងភូមិទាំងអស់
នៅទីនេះ «របស់វា»
ដើម្បីបង្ហាញថាមានទំនាក់ទំនងរវាងទីក្រុងហែសបូននិងភូមិក្បែរៗនេះ។
ការបកប្រែផ្សេងទៀត «ហែសបូននិងភូមិក្បែរៗដែលគ្រប់គ្រង»
ព្រះបាទស៊ីហុន បានវាយដណ្តើមយកទឹកដីរបស់គាត់
នៅទីនេះ «របស់គាត់» សំដៅទៅលើស្តេចម៉ូអាប់។
Numbers 21:27
ហែសបូន.....ទីក្រុងនៃស៊ីហុន
ទាំងនេះជាឈ្មោះពីរដែលសំដៅទៅលើទីក្រុងតែមួយ។
ចូរសង់ទីក្រុងរបស់ព្រះបាទស៊ីហុនឡើងវិញ ចូរសង់ទីក្រុងនេះម្តងទៀត
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«សូមអោយនរណាម្នាក់កសាងនិងបង្កើតទីក្រុងស៊ីហុនឡើងវិញ»
ចូរសង់និងចូរសង់ទីក្រុងនេះឡើងវិញ
ល័ក្ខខ័ណ្ឌទាំងពីរនេះគឺប្រហាក់ប្រហែលគ្នា ហើយសង្កត់ធ្ងន់ថា
ទីក្រុងនឹងត្រូវកសាងឡើងវិញទាំងស្រុង។ ការបកប្រែផ្សេងទៀត
«បានកសាងឡើងវិញទាំងស្រុង»
មានភ្លើងឆេះពីក្រុងហែសបូន អណ្តាតភ្លើងពីទីក្រុងរបស់ព្រះបាទស៊ីហុនដែលឆេះ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន ហើយបញ្ជាក់ថា
ការបំផ្លាញនឹងចាប់ផ្តើមនៅហែសបូន។ ភ្លើងសំដៅទៅលើកងទ័ពដែលបំផ្លាញ។
ការបកប្រែផ្សេងទៀត «ស្តេចស៊ីហុនបានដឹកនាំកងទ័ពដ៏ខ្លាំងមួយ
ពីទីក្រុងហែសបូន»។
បំផ្លាញក្រុងអើររបស់ស្រុកម៉ូអាប់
កងទ័ពស៊ីហុនត្រូវបានគេនិយាយថា វាជាសត្វដែលស៊ីទីក្រុងអើរ។
ការបកប្រែផ្សេងទៀត «បានបំផ្លាញទីក្រុងអើរនៅស្រុកម៉ូអាប់»
Numbers 21:29
ម៉ូអាប់.....ប្រជាជនរបស់ព្រះកេម៉ូស
ឃ្លាទាំងពីរនេះសំដៅទៅលើមនុស្សតែមួយ។
ប្រជាជនរបស់ព្រះកេម៉ូស
«កេម៉ូស» ជាឈ្មោះរបស់ព្រះមិនពិត ដែលជនជាតិម៉ូអាប់បានថ្វាយបង្គំ។
ការបកប្រែផ្សេងទៀត «ប្រជាជនដែលថ្វាយបង្គំព្រះកេម៉ូស»
ព្រះនេះបានធ្វើឲ្យកូនប្រុសរបស់ខ្លួន
«គាត់ និង «របស់គាត់» សំដៅទៅលើព្រះកេម៉ូស។
យើងមានជ័យជម្នះ
ត្រង់នេះ «យើង»
និយាយអំពីជនជាតិអ៊ីស្រាអែលដែលបានវាយឈ្នះស្តេចស៊ីហុន។
ក្រុងហែសបូនត្រូវរិនាស
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«យើងបានបំផ្លាញហែសបូន»
ហែសបូន.....រហូតដល់ឌីបូន.....រហូតដល់ណូផា....រហូតដល់មេឌីបា
ទាំងនេះជាកន្លែងទាំងអស់នៅក្នុងអាណាចក្ររបស់ស្តេចស៊ីហុន។ នេះមានន័យថា
ប្រជាជនអ៊ីស្រាអែលបានបំផ្លាញប្រជាជាតិទាំងមូលរបស់ស្តេចស៊ីហុន។
Numbers 21:31
បានបណ្តេញ
«ដេញចេញ»
Numbers 21:33
បានចេញទៅប្រឆាំងពួកគេ
«វាយប្រហារពួកគេ»
ចូរប្រព្រឹត្តចំពោះគេ ដូចដែលបានប្រព្រឹត្តចំពោះព្រះបាទស៊ីហុន
ជនជាតិអ៊ីស្រាអែលបានបំផ្លាញស៊ីហុនទាំងស្រុង។ ការបកប្រែផ្សេងទៀត
«បំផ្លាញគាត់ដូចអ្នកបានបំផ្លាញស៊ីហុនជាស្តេចរបស់ជនជាតិអាម៉ូរី»
ដូច្នេះ ពួកគេបានសម្លាប់ស្តេចនោះ
«ដូច្នេះកងទ័ពអ៊ីស្រាអែលបានសម្លាប់អូក»
គឺគ្មាននរម្នាក់នៅរស់ឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនរបស់គាត់ទាំងអស់បានស្លាប់»
បានចាប់យកស្រុកនោះ
«ពួកគេបានគ្រប់គ្រងទឹកដីរបស់គាត់»

---

22 [1]ជនជាតិអ៊ីស្រាអែលបានធ្វើដំណើរពីទីនោះ ទៅដល់វាលទំនាបស្រុកម៉ូអាប់ដែលនៅជិតទីក្រុងយេរ៉េខូ ស្ថិតនៅត្រើយម្ខាងនៃទន្លេយ័រដាន់ គឺទល់មុខនឹងទីក្រុងយេរីខូ។
[2]ព្រះបាទបាឡាក់ជាបុត្រារបស់ព្រះបាទស៊ីបព័របានឃើញអស់ទាំងការដែលជនជាតិអ៊ីស្រាអែលបានធ្វើចំពោះជនជាតិអ៊ីម៉ូរី។[3]ជនជាតិម៉ូអាប់ភ័យខ្លាចប្រជាជននោះយ៉ាងខ្លាំង ហើយក៏ភ័យរន្ធត់ចំពោះជនជាតិអ៊ីស្រាអែលដែរ ព្រោះមានចំនួនច្រើន។[4]ស្តេចរបស់ជនជាតិម៉ូអាប់បាននិយាយជាមួយពួកចាស់ទុំរបស់ជនជាតិម៉ាឌានថា៖ «ហ្វូងមនុស្សដ៏ច្រើនសន្ធឹកនេះ មុខជាបង្ហិនអ្វីៗដែលមាននៅជុំវិញពួកយើង ដូចគោស៊ីរំលីងស្មៅនៅទីវាលមិនខាន»។ នៅពេលនោះ ព្រះបាទបាឡាក់ ជាបុត្រារបស់ព្រះបាទស៊ីបព័រ សោយរាជ្យនៅស្រុកម៉ូអាប់។
[5]ស្តេចបានចាត់អ្នកនាំសារទៅជួបលោកបាឡាម ជាកូនប្រុសរបស់លោកបេអ៊ូរ នៅក្រុងពេថោរជាប់មាត់ទន្លេអ៊ើប្រាត ជាស្រុកកំណើតរបស់ជនជាតិលោក និងរបស់ញាតិសន្តានរបស់លោក។ លោកបានហៅពួកគេមក ដោយប្រាប់ថា៖ «មើល៍! មានជនជាតិមួយចេញមកពីស្រុកអេស៊ីប នាំគ្នាមកនៅពាសពេញផែនដី ហើយឥឡូវនេះ ពួកគេបោះជំរំនៅក្បែរទឹកដីរបស់យើង។[6]ដូច្នេះ សូមលោកអញ្ជើញមកដាក់បណ្តាសាជនជាតិនេះឲ្យយើងផង ព្រោះពួកគេខ្លាំងពូកែជាងយើង។ ប្រហែលជាយើងអាចរៀបចំវាយប្រហារពួកគេ ហើយបណ្តេញពួកគេចេញពីស្រុកនេះបាន ដ្បិត យើងដឹងថា ពេលលោកឲ្យពរអ្នកណា អ្នកនោះនឹងទទួលពរ តែបើលោកដាក់បណ្តាសាអ្នកណា អ្នកនោះពិតជាត្រូវបណ្តាសាមិនខាន»។
[7]ដូច្នេះ ពួកមេដឹកនាំរបស់ជនជាតិម៉ូអាប់ និងចាស់ទុំរបស់ជនជាតិម៉ាឌានទាំងអស់ក៏នាំគ្នាចេញដំណើរទៅ ទាំងនាំយកជំនួនសម្រាប់ជូនគ្រូទាយទៅជាមួយផង។ ពួកគេបានទៅដល់ផ្ទះរបស់លោកបាឡាម ហើយរៀបរាប់ប្រាប់លោកនូវពាក្យរបស់ព្រះបាទបាឡាក់។[8]លោកបាឡាមបានមានប្រសាសន៍ទៅពួកគេថា៖ «សូមអស់លោកស្នាក់នៅទីនេះមួយយប់សិន ខ្ញុំនឹងជូនចម្លើយដល់អស់លោកវិញ តាមសេចក្តីដែលព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ»។ ដូច្នេះ ពួកមេដឹកនាំរបស់ជនជាតិម៉ូអាប់ក៏ស្នាក់នៅក្នុងផ្ទះរបស់លោកបាឡាមនៅយប់នោះ។
[9]ព្រះជាម្ចាស់យាងមកជួបលោកបាឡាម ហើយមានព្រះបន្ទូលថា៖ «តើមនុស្សដែលមកឯអ្នកទាំងនេះជានរណា?»។ លោកបាឡាមទូលព្រះជាម្ចាស់ថា៖[10]«ព្រះបាទបាឡាក់ជាបុត្រារបស់ព្រះបាទស៊ីបព័រ ដែលជាស្តេចរបស់ជនជាតិម៉ូអាប់ បានចាត់ពួកគេឲ្យមកប្រាប់ទូលបង្គំថា៖[11]មើល៍! មានជនជាតិមួយចេញមកពីស្រុកអេស៊ីប នាំគ្នាមកនៅពាសពេញស្រុករបស់យើង។ ដូច្នេះ សូមលោកមកជួយដាក់បណ្តាសាជនជាតិនេះឲ្យយើងផង។ បើលោកដាក់បណ្តាសាពួកគេនោះ ប្រហែលជាយើងអាចរៀបចំវាយប្រហារពួកគេ និងបណ្តេញពួកគេចេញបាន»។
[12]ព្រះជាម្ចាស់មានព្រះបន្ទូលមកលោកបាឡាមថា៖ «អ្នកមិនត្រូវទៅជាមួយពួកគេជាដាច់ខាត ហើយក៏មិនត្រូវដាក់បណ្តាសាជនជាតិអ៊ីស្រាអែលដែរ ដ្បិត ពួកគេមានពរហើយ!»។[13]លោកបាឡាមក្រោកពីព្រលឹម ហើយបានប្រាប់ទៅពួកមេដឹកនាំរបស់ព្រះបាទបាឡាក់ថា៖ «សូមអស់លោកវិលត្រឡប់ទៅស្រុករបស់អស់លោកវិញចុះ ព្រះអម្ចាស់មិនអនុញ្ញាតឲ្យខ្ញុំទៅជាមួយអស់លោកទេ»។[14]មេដឹកនាំរបស់ជនជាតិម៉ូអាប់នាំគ្នាវិលត្រឡប់ទៅគាល់ព្រះបាឡាក់វិញ ទូលថា៖ «លោកបាឡាមមិនព្រមមកជាមួយពួកយើងទេ»។
[15]ព្រះបាទបាឡាក់បានចាត់មេដឹកនាំជាច្រើននាក់ឲ្យទៅម្តងទៀត សុទ្ធតែអ្នកមានយសស័ក្តិខ្ពស់ជាងមុន។[16]ពួកគេទៅជួបលោកបាឡាម ហើយប្រាប់ថា៖ «ព្រះបាទបាឡាក់ជាបុត្ររបស់ព្រះបាទស៊ីបព័រ មានរាជឱង្ការថា៖ «សូមកុំឲ្យមានអ្វីបង្អាក់លោកមិនឲ្យមកជួបយើងឡើយ[17]ដ្បិត យើងនឹងបង់ថ្លៃជូនលោកដ៏ច្រើនលើសលប់ ហើយយើងនឹងលើកកិត្តិយសលោកយ៉ាងខ្ពស់ អ្វីដែលលោកបង្គាប់យើងឲ្យធ្វើ យើងសុខចិត្តធ្វើតាមទាំងអស់ ដូច្នេះ សូមលោកអញ្ជើញមកដាក់បណ្តាសាជនជាតិនេះឲ្យយើងផង»។

generated on Wed Sep 10 16:16:32 2025

[18]លោកបាឡាមឆ្លើយទៅពួកគេវិញថា៖ «ទោះបីព្រះបាទបាឡាក់ប្រទានវាំងរបស់ព្រះអង្គដែលពេញទៅដោយប្រាក់ និងមាសមកខ្ញុំក្តី ក៏ខ្ញុំពុំអាចល្មើសនឹងបញ្ជារបស់ព្រះអម្ចាស់ ជាព្រះរបស់ខ្ញុំជាដាច់ខាត ហើយក៏មិនអាចធ្វើការតិច ឬច្រើនជាងអ្វីដែលព្រះអង្គបង្គាប់ដល់ខ្ញុំដែរ។[19]ឥឡូវនេះ យប់នេះសូមអស់លោកចាំនៅទីនេះសិន ដើម្បីឲ្យខ្ញុំដឹងបន្ថែមទៀតនូវអ្វីដែលព្រះអម្ចាស់នឹងមានបន្ទូលប្រាប់ខ្ញុំ»។[20]នៅយប់ ព្រះជាម្ចាស់យាងមកជួបលោកបាឡាម មានព្រះបន្ទូលថា៖ «ដោយអ្នកទាំងនោះនាំគ្នាមកហៅអ្នកដូច្នេះ ចូរក្រោកឡើង ចេញដំណើរទៅជាមួយពួកគេចុះ។ ប៉ុន្តែ ត្រូវធ្វើតាមសេចក្តីណាដែលយើងនឹងបង្គាប់ឲ្យអ្នកធ្វើតែប៉ុណ្ណោះ»។
[21]លោកបាឡាមក្រោកឡើងពីព្រលឹម លោករៀបចំកែបលា របស់គាត់ ហើយបានចេញដំណើរទៅជាមួយពួកមេដឹកនាំរបស់ជនជាតិម៉ូអាប់។[22]ប៉ុន្តែ ព្រះជាម្ចាស់ ពិរោធយ៉ាងខ្លាំង ព្រោះគាត់ចេញទៅដូច្នេះ។ ទេវតារបស់ព្រះអម្ចាស់ឈរវាំងផ្លូវរបស់គាត់ ដូចជាសត្រូវរបស់គាត់ ពេលដែលគាត់កំពុងជិះលើសត្វលា។ មានអ្នកបម្រើរបស់លោកបាឡាមពីរនាក់រួមដំណើរជាមួយគាត់ដែរ។[23]លាបានឃើញទេវតារបស់ព្រះអម្ចាស់ឈរនៅកណ្តាលផ្លូវ ទាំងមានដាវហូតជាស្រេចកាន់នៅដៃផង។ លាក៏ងាកចេញពីផ្លូវ ទៅដើរនៅក្នុងចម្ការ។ លោកបាឡាមវាយលាឲ្យមកដើរតាមផ្លូវវិញ។
[24]នោះទេវតារបស់ព្រះអម្ចាស់ឈរនៅកណ្តាលផ្លូវតូចចង្អៀត ដែលមានចម្ការទំពាំងបាយជូរនៅសងខាង ហើយសងខាងផ្លូវមានរបង។[25]ធ្វើឲ្យជើងរបស់លោកបាឡាមគាបទៅនឹងរបង លោកបាឡាមក៏វាយវាទៀត។
[26]ទេវតារបស់ព្រះអម្ចាស់ទៅឆ្ងាយបន្តិច ហើយឈរនៅត្រង់កន្លែងមានច្រកចង្អៀត ដែលពុំអាចវាងទៅស្តាំ ឬទៅឆ្វេងឡើយ។[27]លាឃើញទេវតារបស់ព្រះអម្ចាស់ វាក៏ក្រាបចុះ ធ្វើឲ្យលោកបាឡាមខឹងជាខ្លាំង ហើយយកដំបងវាយលាទៀត។
[28]ពេលនោះ ព្រះអម្ចាស់បានបើកមាត់របស់សត្វលា ធ្វើឲ្យលានោះចេះនិយាយ។ វានិយាយទៅលោកបាឡាមថា៖ «តើខ្ញុំធ្វើអ្វីលោក បានជាលោកវាយខ្ញុំដល់ទៅបីដងដូច្នេះ?»។[29]លោកបាឡាមតបទៅលាថា៖ «មកពីឯងធ្វើឆ្កួតៗចំពោះអញ! ប្រសិនបើ អញមានដាវនៅដៃ នោះអញមុខជាសម្លាប់ឯងបាត់ហើយ!»។[30]លាឆ្លើយទៅលោកបាឡាមវិញថា៖ «តើខ្ញុំមិនមែនជាលារបស់លោក ដែលលោកធ្លាប់ជិះពេញមួយជីវិតរបស់លោករហូតមកទល់ថ្ងៃនេះទេឬ? តើពីមុនៗមក ខ្ញុំធ្លាប់ធ្វើបែបនេះចំពោះលោកទេ?»។ លោកបាឡាមតបថា៖ «ទេ!»។
[31]ពេលនោះ ព្រះអម្ចាស់បានបើកភ្នែករបស់យលោកបាឡាមមើលឃើញទេវតារបស់ព្រះអម្ចាស់ដែលឈរវាំងផ្លូវ ទាំងដកដាវជាស្រេចកាន់នៅដៃ។ លោកបាឡាមក៏ឱនក្បាល និងមុខរបស់ខ្លួនចុះ។[32]ទេវតារបស់ព្រះអម្ចាស់មានប្រសាសន៍មកលោកថា៖ «ហេតុអ្វីបានជាអ្នកវាយលារបស់អ្នកដល់ទៅបីដងដូច្នេះ? មើល៍! យើងបានចេញមកដូចជាសត្រូវរបស់អ្នក ដ្បិត ទង្វើរបស់អ្នកចំពោះយើងនោះអាក្រក់ខ្លាំងណាស់។[33]សត្វលាវាបានឃើញយើង ហើយវាងាកចេញពីយើងដល់ទៅបីដង ប្រសិនបើ វាមិនងាកចេញពីយើងទេនោះ ម្លេ៎ះយើងសម្លាប់អ្នកបាត់ហើយ និងទុកជីវិតឲ្យវាវិញ»។
[34]លោកបាឡាមមានប្រសាសន៍ទៅទេវតារបស់ព្រះអម្ចាស់ថា៖ «ខ្ញុំបានប្រព្រឹត្តអំពើបាប ដ្បិត ខ្ញុំមិនបានដឹងថា លោកម្ចាស់ឈរបាំងផ្លូវពីមុខខ្ញុំទេ។ ឥឡូវនេះ ប្រសិនបើលោកមិនពេញចិត្តឲ្យខ្ញុំទៅទេ នោះខ្ញុំនឹងបកក្រោយវិញ»។[35]ទេវតារបស់ព្រះអម្ចាស់មានប្រសាសន៍ទៅលោកបាឡាមថា៖ «ចូរទៅជាមួយអ្នកទាំងនោះចុះ តែអ្នកត្រូវនិយាយតាមសេចក្តីដែលយើងប្រាប់អ្នកប៉ុណ្ណោះ»។ ដូច្នេះ លោកបាឡាមក៏ទៅជាមួយពួកមេដឹកនាំរបស់ព្រះបាទបាឡាក់។
[36]នៅពេលដែលលព្រះបាទបាឡាក់បានឮថាលោកបាឡាមមកដល់ហើយ ស្តេចក៏ចេញទៅទទួលលោកនៅក្រុងរបស់ស្រុកម៉ូអាប់ ដែលនៅមាត់ស្ទឹងអើណូន ក្បែរព្រំដែន។
[37]ព្រះបាទបាឡាក់មានរាជឱង្ការទៅលោកបាឡាមថា៖ «តើយើងមិនបានចាត់គេឲ្យជួបលោក ដើម្បីអញ្ជើញលោកមកទេឬ? ហេតុអ្វីបានជាលោកមិនព្រមមកជួបយើង? តើយើងមិនអាចលើកកិត្តិយសលោកបានឬ?»។
[38]លោកបាឡាមឆ្លើយទៅស្តេចថា៖ «មើល៍! ទូលបង្គំបានមកជួបព្រះករុណាហើយ។ ឥឡូវនេះ តើទូលបង្គំគ្មានសិទ្ធិនឹងនិយាយពាក្យអ្វីទេឬ? ទូលបង្គំនិយាយតែពាក្យដែលព្រះជាម្ចាស់ដាក់នៅក្នុងមាត់របស់ទូលបង្គំតែប៉ុណ្ណោះ»។[39]លោកបាឡាមក៏ទៅជាមួយព្រះបាទបាឡាក់ រហូតដល់ក្រុងគារយ៉ាត់ហាសូត។[40]ព្រះបាទបាឡាក់បានយកគោ និងចៀម ធ្វើយញ្ញបូជា ហើយឲ្យសាច់ខ្លះទៅលោកបាឡាម ព្រមទាំងមេដឹកនាំដែលមកជាមួយលោក។
[41]លុះព្រឹកឡើង ព្រះបាទបាឡាក់បាននាំលោកបាឡាមឡើងទៅទីខ្ពស់របស់ព្រះបាល។ នៅកន្លែងនោះ លោកបាឡាមអាចមើលឃើញតែជំរំខ្លះរបស់ប្រជាជនអ៊ីស្រាអែលប៉ុណ្ណោះ។

Numbers 22:1
ត្រើយម្ខាងនៃទន្លេយ័រដាន់ គឺទល់មុខនឹងទីក្រុង
ជនជាតិអ៊ីស្រាអែលបានបោះជំរំនៅត្រើយខាងកើតទន្លេយ័រដាន់។ ក្រុងយេរីខូគឺនៅត្រើយខាងលិចនៃទន្លេ។
Numbers 22:2
ព្រះបាទបាឡាក់ជាបុត្រារបស់ព្រះបាទស៊ីបព័រ
ព្រះបាទបាឡាក់ជាស្តេចនៃស្រុកម៉ូអាប់។
ព្រះបាទស៊ីបព័រ
ព្រះបាទស៊ីបព័រគឺជាព្រះបិតានៃព្រះបាទបាឡាក់។
ជនជាតិម៉ូអាប់ភ័យខ្លាចប្រជាជននោះយ៉ាងខ្លាំង.....នជាតិម៉ូអាប់ក៏ភ័យរន្ធត់ចំពោះជនជាតិអ៊ីស្រាអែលដែរ
ឃ្លាទាំងពីរនេះមានន័យដូចគ្នាហើយបញ្ជាក់ពីការភ័យខ្លាចរបស់ម៉ូអាប់។
ជនជាតិម៉ូអាប់ភ័យខ្លាចយ៉ាងខ្លាំង
នៅទីនេះ «ម៉ូអាប់» សំដៅទៅលើប្រជាជនម៉ូអាប់។ ការបកប្រែផ្សេងទៀត
«ជនជាតិម៉ូអាប់ទាំងអស់ភ័យខ្លាចយ៉ាងខ្លាំង»
ព្រោះមានចំនួនច្រើន
«ពីព្រោះវាមានច្រើន»
ស្តេចរបស់ជនជាតិម៉ូអាប់បាននិយាយជាមួយពួកចាស់ទុំរបស់ជនជាតិម៉ាឌានថា
ជនជាតិម៉ូអាប់និងជនជាតិម៉ាឌានគឺជាមនុស្សពីរក្រុមផ្សេងគ្នាប៉ុន្តែជនជាតិម៉ាឌានកំពុង[illegible]។ ការបកប្រែផ្សេងទៀត
ហ្វូងមនុស្សដ៏ច្រើនសន្ធឹកនេះ មុខជាបង្ហិនអ្វីៗដែលមាននៅជុំវិញពួកយើង ដូចគោស៊ីរំលីងស្មៅនៅទីវាលមិនខាន
វិធីដែលជនជាតិអ៊ីស្រាអែលនឹងបំផ្លាញសត្រូវរបស់ពួកគេត្រូវបានគេនិយាយដូចជាពួកគេ[illegible]។
នៅពេលនោះ ព្រះបាទបាឡាក់ ជាបុត្រារបស់ព្រះបាទស៊ីបព័រ សោយរាជ្យនៅស្រុកម៉ូអាប់
ការផ្លាស់ប្តូរនេះពីរឿងសំខាន់ទៅព័ត៌មានផ្ទៃខាងក្រោយអំពីព្រះបាទបាឡាក់។
Numbers 22:5
ស្តេចបានចាត់អ្នកនាំសារ
«ព្រះបាទបាឡាក់បានបញ្ជូនអ្នកនាំសារ»
លោកបេអ៊ូរ
នេះជាឈ្មោះឪពុករបស់លោកបាឡាម។
ក្រុងពេថោ
នេះជាឈ្មោះនៃទីក្រុងមួយ។
ជនជាតិលោក និងរបស់ញាតិសន្តានរបស់លោក
«ប្រជាជនរបស់លោកបាឡាម»
លោកបានហៅ
«ព្រះបាទបាឡាក់ហៅលោកបាឡាម»។
ព្រះបាទបាឡាក់មិនបានមានបន្ទូលទៅកាន់លោកបាឡាមដោយផ្ទាល់ទេ ប៉ុន្តែបានមានបន្ទូលតាមរយៈអ្នកនាំសាររបស់ទ្រង់។
នាំគ្នាមកនៅពាសពេញផែនដី
នេះជាការបំផ្លើសមួយដើម្បីបញ្ជាក់ពីចំនួនរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«ពួកគេមានច្រើនណាស់»
បណ្តេញពួកគេ
«ដេញពួកគេ»
យើងដឹងថា ពេលលោកឲ្យពរអ្នកណា អ្នកនោះនឹងទទួលពរ តែបើលោកដាក់បណ្តាសាអ្នកណា អ្នកនោះពិតជាត្រូវបណ្តាសាមិនខាន
[illegible]។ ការបកប្រែផ្សេងទៀត
«ខ្ញុំដឹងថាអ្នកមានអំណាចដើម្បីប្រទានពរឬដាក់បណ្តាសាមនុស្ស»
Numbers 22:7
[illegible]។
នាមអរូបី «ទាយ» អាចត្រូវបានថ្លែងជាសកម្មភាព។ ការបកប្រែផ្សេងទៀត
«ប្រាក់បង់ទៅបាឡាមដើម្បីដាក់បណ្តាសាអ៊ីស្រាអែល»
ពួកគេបានទៅលោកបាឡាម
អ្នកអាចនិយាយថា" ពួកគេបានទៅបាឡាម"

generated on Wed Sep 10 16:16:32 2025

រៀបរាប់ប្រាប់លោកនូវពាក្យរបស់ព្រះបាទបាឡាក់
នៅទីនេះ «ពាក្យ» សំដៅទៅលើសារ។ ការបកប្រែផ្សេងទៀត
«បានប្រាប់គាត់នូវសារពីព្រះបាទបាឡាក់»
ព្រះបាទបាឡាក់
នេះជាឈ្មោះបុរស។ សូមមើលពីររបៀបដែលបានបកប្រែវានៅក្នុង ២២:២។
ខ្ញុំនឹងជូនចម្លើយដល់អស់លោកវិញ
របាយការណ៍របស់លោកបាឡាមត្រូវបានគេនិយាយហាក់ដូចជាវាជាអ្វីមួយ
ដែលគាត់នឹងយកទៅអ្នកនាំសារ។ ការបកប្រែផ្សេងទៀត «ខ្ញុំនឹងប្រាប់អ្នក»
Numbers 22:9
ព្រះជាម្ចាស់យាងមកជួបលោកបាឡាម
«ព្រះបានលេចមកឯលោកបាឡាម»
តើមនុស្សដែលមកឯអ្នកទាំងនេះជានរណា?
ព្រះអម្ចាស់ប្រើសំណួរដើម្បីណែនាំប្រធានបទថ្មីនៃការសន្ទនា។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ប្រាប់យើងអំពីបុរសទាំងនេះដែលបានមករកអ្នក»។
ព្រះបាទបាឡាក់.....ព្រះបាទស៊ីបព័រ
ទាំងនេះជាឈ្មោះរបស់បុរស។ សូមមើលការបកប្រែទាំងនេះនៅក្នុង ២២:២។
មើល៍! មានជនជាតិ.....បណ្តេញពួកគេចេញ
លោកបាឡាមរំលឹកសារដែលព្រះបាទបាឡាក់ផ្ញើទៅគាត់។
សូមមើលការបកប្រែឃ្លាទាំងនេះជាច្រើននៅក្នុង ២២:៥ ។
បណ្តេញពួកគេចេញ
«ដេញពួកគេចេញ»
Numbers 22:12
ដ្បិត ពួកគេមានពរហើយ!
អាចត្រូវបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ពីព្រោះខ្ញុំបានប្រទានពរដល់ពួកគេ»
ព្រះបាទបាឡាក់
នេះជាឈ្មោះបុរស។ សូមមើលការបកប្រែនៅក្នុង ២២:២ ។
Numbers 22:15
ពួកគេទៅជួបលោកបាឡាម
អ្នកអាចនិយាយថា «ពួកគេបានទៅជួបលោកបាឡាម»
ព្រះបាទបាឡាក់
នេះជាឈ្មោះបុរស។ សូមមើលការបកប្រែនៅក្នុង ២២:២ ។
ជនជាតិនេះ
នាមព្យញ្ជនៈសំដៅទៅលើជនជាតិអ៊ីស្រាអែលជាក្រុម។ ការបកប្រែផ្សេងទៀត
«ក្រុមមនុស្សនេះ»
Numbers 22:18
ព្រះបាទបាឡាក់
នេះជាឈ្មោះបុរស។ សូមមើលការបកប្រែនៅក្នុង ២២:២ ។
ទោះបីព្រះបាទបាឡាក់ប្រទានវាំងរបស់ព្រះអង្គដែលពេញទៅដោយប្រាក់ និងមាសមកខ្ញុំក្តី
លោកបាឡាមកំពុងពិពណ៌នាអំពីអ្វីមួយដែលនឹងមិនកើតឡើង។
គាត់កំពុងសង្កត់ធ្ងន់ថាគ្មានអ្វីដែលអាចធ្វើឱ្យគាត់មិនស្តាប់បង្គាប់ព្រះជាម្ចាស់ឡើយ។
ខ្ញុំពុំអាចល្មើសនឹងបញ្ជារបស់ព្រះអម្ចាស់ .....ហើយក៏មិនអាចធ្វើការតិច ឬច្រើនជាងអ្វីដែល
ព្រះអង្គបង្គាប់ដល់ខ្ញុំដែរ
នេះមានន័យថា
លោកបាឡាមមិនអាចមិនស្តាប់បង្គាប់ព្រះជាម្ចាស់តាមវិធីណាក៏ដោយ។
Numbers 22:21
លោករៀបចំកែបលា របស់គាត់
រៀបចំចងកែបដាក់នៅលើខ្នងសត្វ ដើម្បីជិះវា។
ព្រះជាម្ចាស់ ពិរោធយ៉ាងខ្លាំង ព្រោះគាត់ចេញទៅដូច្នេះ
ការកើនឡើងនូវកំហឹងរបស់ព្រះជាម្ចាស់ គេនិយាយដូចជាវាចាប់ផ្តើមឆេះ។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះបានខឹងយ៉ាងខ្លាំង»
ដូចជាសត្រូវទៅឯលោកបាឡាម
«ជាសត្រូវនឹងលោកបាឡាម» ឬ «ដើម្បីបញ្ឈប់លោកបាឡាម»
មានដាវហូតជាស្រេចកាន់នៅដៃផង
ដាវមួយត្រូវបានដកចេញពីស្រោមរបស់វា ដើម្បីអាចប្រើវាបាន។
ការបកប្រែផ្សេងទៀត «ដោយដាវរបស់គាត់ត្រៀមខ្លួនវាយប្រហារ»
លាក៏ងាកចេញពីផ្លូវ ទៅដើរនៅក្នុងចម្ការ
សត្វលាបានធ្វើបែបនេះដើម្បីគេចពីទេវតារបស់ព្រះអម្ចាស់។
លាឲ្យមកដើរតាមផ្លូវវិញ
ជួនកាលសត្វត្រូវបានគេហៅថា «នាង» ឬ «នាង»។ ការបកប្រែផ្សេងទៀត
«ដើម្បីបង្វែរវាត្រឡប់មកវិញ»
Numbers 22:24
វាគេចនិងជញ្ជាំង
នេះជាការប៉ុនប៉ងរត់គេចពីទេវតារបស់ព្រះអម្ចាស់នៅតាមផ្លូវ។
នាងបានចេញ
ជួនកាលសត្វត្រូវបានគេហៅថា «នាង» ឬ «នាង» ។ ការបកប្រែផ្សេងទៀត
«វាបានទៅ»
ធ្វើឲ្យជើងរបស់លោកបាឡាមគាប
«រុញជើងលោកបាឡាមគេច» ឬ «ធ្វើឲ្យជើងរបស់លោកបាឡាមឈឺ»។
Numbers 22:26
លោកបាឡាមខឹងជាខ្លាំង ហើយយកដំបងវាយលាទៀត
ការកើនឡើងកំហឹងរបស់លោកបាឡាម គេនិយាយដូចជាវាកំពុងចាប់ផ្តើមឆេះ។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ២២:២១។ ការបកប្រែផ្សេងទៀត
«លោកបាឡាមខឹងយ៉ាងខ្លាំង»
Numbers 22:28
ព្រះអម្ចាស់បានបើកមាត់របស់សត្វលា ធ្វើឲ្យលានោះចេះនិយាយ
ការបើកមាត់ត្រូវបានផ្សារភ្ជាប់ជាមួយនឹងសមត្ថភាពក្នុងការនិយាយ។
ការបកប្រែផ្សេងទៀត
«បន្ទាប់មកព្រះអម្ចាស់បានផ្តល់ឱ្យសត្វលានូវសមត្ថភាពនិយាយដូចមនុស្សនឹងនិយាយ»
វានិយាយទៅលោកបាឡាមថា
«សត្វលាបាននិយាយទៅកាន់លោកបាឡាម»
តើខ្ញុំមិនមែនជាលារបស់លោក ដែលលោកធ្លាប់ជិះពេញមួយជីវិតរបស់លោករហូតមកទល់ថ្ងៃនេះទេ
ឬ?
សំណួរនេះត្រូវបានប្រើដើម្បីកាត់ទោសលោកបាឡាមថាការវិនិច្ឆ័យរបស់គាត់ចំពោះសត្វលាគឺមិនយុត្តិធម៌
នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំគឺជាលារបស់អ្នកដែលអ្នកបានជិះពេញមួយជីវិតរបស់អ្នករហូតមកដល់ពេលនេះ»។
តើពីមុនៗមក ខ្ញុំធ្លាប់ធ្វើបែបនេះចំពោះលោកទេ?
សំណួរនេះត្រូវបានប្រើដើម្បីផ្តន្ទាទោសលោកបាឡាមបន្ថែមទៀតថា
ការវិនិច្ឆ័យរបស់គាត់ចំពោះសត្វលាគឺមិនយុត្តិធម៌។
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនដែលមានទម្លាប់ធ្វើរឿងបែបនេះចំពោះអ្នកទេ!»
Numbers 22:31
ពេលនោះ ព្រះអម្ចាស់បានបើកភ្នែករបស់យលោកបាឡាមមើលឃើញទេវតារបស់ព្រះអម្ចាស់
ដើម្បី «បើកភ្នែករបស់មនុស្សម្នាក់» ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការមើលឃើញ។
ការបកប្រែផ្សេងទៀត
«ពេលនោះព្រះអម្ចាស់បានប្រទានអោយលោកបាឡាមនូវសមត្ថភាពមើលឃើញទេវតារបស់ព្រះអម្ចាស់»
ទាំងដកដាវជាស្រេចកាន់នៅដៃ
ដាវមួយត្រូវបានដកចេញពីស្រោមរបស់វា ដើម្បីអាចប្រើវាបាន។
សូមមើលការបកប្រែនៅក្នុង ២២:២១។ ការបកប្រែផ្សេងទៀត
«ដោយដាវរបស់ទេវតាត្រៀមខ្លួនវាយប្រហារ»
លោកបាឡាមក៏ឱនក្បាល និងមុខរបស់ខ្លួនចុះ
នេះបង្ហាញថាលោកបាឡាមកំពុងតែបន្ទាបខ្លួននៅចំពោះមុខទេវតា។
ហេតុអ្វីបានជាអ្នកវាយលារបស់អ្នកដល់ទៅបីដងដូច្នេះ?
សំណួរនេះត្រូវបានប្រើដើម្បីចោទប្រកាន់លោកបាឡាមថាបានធ្វើខុស។
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរវាយសត្វលារបស់អ្នកបីដងទេ» ។
ដូចជាសត្រូវរបស់អ្នក
«ជាសត្រូវនឹងអ្នក» ឬ «ដើម្បីប្រឆាំងនឹងអ្នក»
ប្រសិនបើ វាមិនងាកចេញពីយើងទេនោះ.....ម្ល៉ោះយើងសម្លាប់អ្នកបាត់ហើយ និងទុកជីវិតឲ្យវារិញ
សេចក្តីថ្លែងការណ៍សម្មតិកម្មនេះបានចង្អុលបង្ហាញពីអ្វីដែលអាចកើតឡើង
ប៉ុន្តែវាមិនមែនដោយសារតែសកម្មភាពរបស់សត្វលាបានជួយរក្សាលោកបាឡាមទេ។
Numbers 22:34
ឥឡូវនេះ ប្រសិនបើ លោកមិនពេញចិត្តឲ្យខ្ញុំទៅទេ
«ដូច្នេះប្រសិនបើអ្នកមិនចង់អោយខ្ញុំបន្តទៅមុខទៀត»
ទៅជាមួយពួកមេដឹកនាំរបស់ព្រះបាទបាឡាក់

generated on Wed Sep 10 16:16:32 2025

«ជាមួយមេដឹកនាំដែលព្រះបាទបាឡាក់បានបញ្ជូន។» សូមមើលការបកប្រែ «ព្រះបាទបាឡាក់» នៅក្នុង ២២:២ ។
Numbers 22:36
អើណូន
នេះជាឈ្មោះនៃស្ទឹងមួយ។ សូមមើលការបកប្រែនៅក្នុង ២១:១២។
តើយើងមិនបានចាត់គេឲ្យជួបលោក ដើម្បីអញ្ជើញលោកមកទេឬ?
សំណួរនេះត្រូវបានប្រើដើម្បីស្តីបន្ទោសលោកបាឡាមសម្រាប់ការពន្យាពេលដើម្បីមក។ សារត្រូវបានគេនិយាយហាក់ដូចជា
នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ប្រាកដណាស់យើងបានបញ្ជូនបុរសទៅកោះហៅអ្នក»
ហេតុអ្វីបានជាលោកមិនព្រមមកជួបយើង?
សំណួរនេះត្រូវបានប្រើដើម្បីស្តីបន្ទោសលោកបាឡាមសម្រាប់ការពន្យាពេលមក។
នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកគួរតែមករកយើង!»
តើយើងមិនអាចលើកកិត្តិយសលោកបានឬ?
សំណួរនេះត្រូវបានប្រើដើម្បីស្តីបន្ទោសលោកបាឡាមសម្រាប់ការពន្យាពេលមក។
នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ប្រាកដណាស់អ្នកដឹងថាយើងអាចបង់លុយអ្នកសម្រាប់ការមករកយើង»។
Numbers 22:38
តើទូលបង្គំគ្មានសិទ្ធិនឹងនិយាយពាក្យអ្វីទេឬ?
លោកបាឡាមប្រើសំនួរនេះដើម្បីប្រាប់ដល់ព្រះបាទបាឡាក់ថា
គាត់នឹងមិនអាចធ្វើអ្វីគ្រប់យ៉ាងដែលព្រះបាទបាឡាក់សុំឱ្យគាត់ធ្វើទេ។
នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែខ្ញុំគ្មានអំណាចនិយាយអ្វីដែលខ្ញុំចង់បានទេ» .
តែពាក្យដែលព្រះជាម្ចាស់ដាក់នៅក្នុងមាត់របស់ទូលបង្គំតែប៉ុណ្ណោះ
នៅទីនេះ «ពាក្យ» សំដៅទៅលើសារដែលមកពីព្រះ។
វាជាអ្វីដែលព្រះបានដាក់ចូលទៅក្នុងមាត់របស់គាត់។ ការបកប្រែផ្សេងទៀត
«សារដែលព្រះចង់អោយខ្ញុំនិយាយ»
ក្រុងគារយ៉ាត់ហាសូត
នេះជាឈ្មោះនៃទីក្រុង។
សាច់ខ្លះ
«សាច់ខ្លះពីការបូជា»
Numbers 22:41
ឡើងទៅទីខ្ពស់របស់ព្រះបាល
អាចមានន័យថា ១) នេះសំដៅទៅលើកន្លែងដូចគ្នានឹងបាម៉ូតក្នុង ២១:១៩ ។ ពាក្យបាម៉ូតមានន័យថា «កន្លែងខ្ពស់» ឬ ២)
នេះជាកន្លែងខ្ពស់មួយទៀតដែលប្រជាជនបានបូជាដល់ព្រះបាល។

---

23 [1]លោកបាឡាមបានទូលទៅព្រះបាទបាឡាក់ថា៖ «សូមព្រះករុណាឲ្យគេសង់កន្លែងថ្វាយតង្វាយប្រាំពីរនៅទីនេះឲ្យទូលបង្គំ ហើយរៀបចំគោបាប្រាំពីរ និងចៀមឈ្មោលប្រាំពីរ ឲ្យទូលបង្គំផង»។[2]ដូច្នេះ ព្រះបាទបាឡាក់ក៏ធ្វើតាមសំណូមពររបស់លោកបាឡាម។ ព្រះបាទបាឡាក់ និងលោកបាឡាមបានថ្វាយគោបាមួយ និងចៀមឈ្មោលមួយ នៅលើកន្លែងថ្វាយតង្វាយនីមួយៗ។[3]បន្ទាប់មក លោកបាឡាមទូលទៅព្រះបាទបាឡាក់ទៀតថា៖ «សូមព្រះករុណាគង់នៅក្បែរតង្វាយដុតរបស់ព្រះករុណានេះហើយ ទូលបង្គំនឹងចេញទៅឆ្ងាយបន្តិច ប្រហែលព្រះអម្ចាស់យាងមកជួបទូលបង្គំ។ ពេលព្រះអង្គមានព្រះបន្ទូលមកទូលបង្គំ នោះទូលបង្គំនឹងទូលដល់ព្រះករុណា»។ ដូច្នេះ លោកក៏ឡើងទៅលើកំពូលភ្នំត្រង់កន្លែងដែលគ្មានដើមឈើ។
[4]នៅពេលដែលលោកបាឡាមនៅលើកំពូលភ្នំ ព្រះជាម្ចាស់បានយាងមកជួបលោក ហើយលោកបាឡាមបានទូលព្រះអង្គថា៖ «ទូលបង្គំបានសង់កន្លែងថ្វាយតង្វាយប្រាំពីរ ហើយនៅលើកន្លែងថ្វាយតង្វាយនោះទូលបង្គំបានថ្វាយគោបាមួយ និងចៀមឈ្មោលមួយ»។[5]ព្រះអម្ចាស់បានដាក់ព្រះបន្ទូលនៅក្នុងមាត់របស់លោកបាឡាម ហើយប្រាប់គាត់ថា៖ ចូរត្រឡប់ទៅជួបព្រះបាទបាឡាក់វិញ ហើយនិយាយប្រាប់គេទៅ។[6]ដូច្នេះ លោកបាឡាមក៏ត្រឡប់ទៅគាល់ព្រះបាទបាឡាក់ ដែលកំពុងគង់នៅក្បែរតង្វាយដុតរបស់ទ្រង់ ដោយមានមេដឹកនាំទាំងអស់របស់ជនជាតិម៉ូអាប់នៅជាមួយដែរ។
[7]នោះ លោកបាឡាមក៏ចាប់ផ្តើមថ្លែងដូចតទៅ៖ «ព្រះបាទបាឡាក់ហៅទូលបង្គំមកពីស្រុកអើរ៉ាម ស្តេចស្រុកម៉ូអាប់បានហៅទូលបង្គំពីភ្នំទិសបូព៌ា ហើប្រាប់ថា៖ «ចូរមកដាក់បណ្តាសាយ៉ាកុបឲ្យយើង!» ពួកគេបានប្រាប់ទៀតថា៖ «ចូរមកប្រទេចផ្តាសាកូនចៅអ៊ីស្រាអែល!»[8]តើឲ្យទូលបង្គំដាក់បណ្តាសាអ្នកដែលព្រះជាម្ចាស់មិនដាក់បណ្តាសាដូចម្តេចកើត? តើឲ្យទូលបង្គំរារាំងអ្នកដែលព្រះអម្ចាស់មិនរារាំងដូចម្តេចបាន?
[9]ពីលើកំពូលថ្មនេះ ទូលបង្គំឃើញពួកគេ។ ពីលើកំពូលភ្នំនេះ ទូលបង្គំសម្លឹងមើលពួកគេ។ មើល៍! មានជនជាតិមួយដែលរស់នៅតែម្នាក់ឯង ដោយមិនចាត់ទុកពួកគេដូចជនជាតិធម្មតាមួយទេ។
[10]តើនរណាអាចរាប់ខ្សាច់របស់លោកយ៉ាកុប ឬរាប់ចំនួនមួយភាគបួនរបស់ជនជាតិអ៊ីស្រាអែលបាន? សូមឲ្យទូលបង្គំស្លាប់ដូចមនុស្សសុចរិតម្នាក់ ហើយសូមឲ្យជីវិតរបស់ទូលបង្គំត្រូវបញ្ចប់ដូចពួកគេដែរចុះ!»។
[11]ព្រះបាទបាឡាក់មានរាជឱង្កាទៅលោកបាឡាមថា៖ «ហេតុអ្វីបានជាលោកធ្វើដូច្នេះចំពោះយើង? យើងបាននាំលោកមក ដើម្បីឲ្យដាក់បណ្តាសាខ្មាំងសត្រូវរបស់យើង ប៉ុន្តែ មើល៍! លោកបែរជាឲ្យពរពួកគេទៅវិញ!»។[12]លោកបាឡាមបានឆ្លើយថា៖ «តើមិនគួរឲ្យទូលបង្គំប្រុងប្រយ័ត្ននិយាយតែអ្វីដែលព្រះអម្ចាស់ដាក់ក្នុងមាត់របស់ទូលបង្គំទេឬ?
[13]នោះ ព្រះបាទបាឡាក់មានរាជឱង្កាថា៖ «ដូច្នេះ សូមលោកមកជាមួយយើង មានកន្លែងមួយទៀត ដែលលោកអាចមើលឃើញពួកគេច្បាស់។ លោកនឹងឃើញពួកគេតែជិតៗប៉ុណ្ណោះ គឺមិនឃើញទាំងអស់ទេ។ នៅទីនោះ លោកត្រូវតែដាក់បណ្តាសាពួកគេឲ្យយើង»។[14]ស្តេចក៏នាំលោកបាឡាមទៅវាលសូភីម ដែលស្ថិតនៅលើកំពូលភ្នំពីសកា ហើយស្តេចបានសង់កន្លែងថ្វាយតង្វាយប្រាំពីរនៅទីនោះ។ នៅលើលើកន្លែងថ្វាយតង្វាយនីមួយៗ ស្តេចថ្វាយគោបាមួយ និងចៀមឈ្មោលមួយ។[15]បន្ទាប់មក លោកបាឡាមបានទូលស្តេចថា៖ «សូមព្រះករុណាគង់នៅទីនេះ ក្បែរតង្វាយដុតរបស់ព្រះករុណា ពេលដែលទូលបង្គំចេញទៅជួបព្រះជាម្ចាស់នៅទីនោះ»។
[16]ដូច្នេះ ព្រះអម្ចាស់យាងមកជួបលោកបាឡាម ហើយបានដាក់ពាក្យនៅក្នុងមាត់របស់គាត់។ ព្រះអង្គបានមានបន្ទូលថា៖ «ចូរត្រឡប់ទៅជួបបាឡាក់វិញ ដើម្បីប្រាប់ពាក្យរបស់យើងដល់គេ»។[17]លោកបាឡាមក៏ត្រឡប់ទៅជួបព្រះបាទបាឡាក់ ដែលឈរនៅក្បែរតង្វាយដុត ដោយមានពួកមេដឹកនាំរបស់ជនជាតិម៉ូអាប់នៅជាមួយផង។ ព្រះបាទបាឡាក់សួរគាត់ថា៖ «តើព្រះអម្ចាស់មានព្រះបន្ទូលដូចម្តេច?»។[18]លោកបាឡាមចាប់ផ្តើមថ្លែងដូចតទៅ៖ «ឱព្រះរាជាបាឡាក់អើយ! សូមក្រោកឡើង! ហើយស្តាប់ទូលបង្គំឲ្យច្បាស់ ទាំងព្រះអង្គ និងព្រះបាទស៊ីបព័របុត្រារបស់ព្រះអង្គ។
[19]ព្រះជាម្ចាស់មិនមែនមនុស្សទេ ព្រះអង្គគមិនចេះកុហកឡើយ ព្រះអង្គក៏មិនចេះប្តូរគំនិតរបស់ព្រះអង្គដូចមនុស្សដែរ។ តើព្រះអង្គបានសន្យាអ្វីមួយ ហើយព្រះអង្គមិនធ្វើតាមដែរឬទេ? តើព្រះអង្គធ្លាប់មានបន្ទូលថានឹងធ្វើអ្វីមួយ ហើយមិនបានធ្វើឬទេ?[20]មើល៍! ទូលបង្គំបានទទួលបញ្ជាឲ្យពរ។ ព្រះជាម្ចាស់បានប្រទានព្រះពរហើយ ខ្ញុំមិនអាចឲ្យផ្លាស់ប្តូរបានទេ។
[21]គ្មានការលំបាកនៅក្នុងពួកយ៉ាកុបឡើយ ឬទុក្ខវេទនាណានៅក្នុងកូនចៅអ៊ីស្រាអែលដែរ។ ព្រះអម្ចាស់ ជាព្រះរបស់ពួកគេ គង់នៅជាមួយពួកគេ ហើយពួកគេប្រកាសថាមហាក្សត្ររបស់ពួកគេគង់ក្នុងចំណោមពួកគេ។[22]ព្រះជាម្ចាស់បាននាំពួកគេចាកចេញពីស្រុកអេស៊ីបដោយប្រើកម្លាំងដ៏ខ្លាំង ដូចសត្វរមាស។
[23]គ្មានមន្តអាគមអាចធ្វើប្រឆាំងនឹងលោកយ៉ាកុបបានទេ ហើយក៏គ្មានគ្រូទាយណាអាចធ្វើឲ្យជនជាតិអ៊ីស្រាអែលឈឺចាប់បានដែរ។ នឹងមានគេថ្លែងអំពីលោកយ៉ាកុប និងជនជាតិអ៊ីស្រាអែលថា ចូរសម្លឹងមើលអ្វីដែលព្រះជាម្ចាស់ធ្វើចុះ!
[24]មើលចុះ ប្រជាជននេះងើបឡើងដូចសិង្ហញី ពួកគេដូចសិង្ហឈ្មោលស្ទុះឡើង ហើយចាប់រំពារ។ វាមិនដេកវិញទេ ទាល់តែបានស៊ីរំពារ ហើយហុតឈាមសត្វដែលវាបានសម្លាប់។
[25]ពេលនោះ ព្រះបាទបាឡាក់បានមានរាជឱង្ការមកលោកបាឡាមថា៖ «កុំដាក់បណ្តាសាពួកគេ ហើយក៏កុំឲ្យពរពួកគេឡើយ!»។[26]ប៉ុន្តែ លោកបាឡាមតបទៅព្រះបាទបាឡាក់ថា៖ «តើទូលបង្គំមិនបានទូលព្រះករុណារួចហើយទេឬថា ទូលបង្គំត្រូវនិយាយអ្វីដែលព្រះអម្ចាស់ប្រាប់ទូលបង្គំឲ្យនិយាយ»។[27]ដូច្នេះ ព្រះបាទបាឡាក់បាន

generated on Wed Sep 10 16:16:32 2025

មានរាជឱង្ការមកលោកបាឡាមថា៖ «ឥឡូវនេះ សូមអញ្ជើញមក យើងនាំលោកទៅកន្លែងមួយទៀត។ នៅកន្លែងនោះ ព្រះជាម្ចាស់ប្រហែលជាសព្វព្រះហឫទ័យឲ្យលោកដាក់បណ្តាសាពួកគេឲ្យយើង»។
[28]ព្រះបាទបាឡាក់នាំលោកបាឡាមទៅដល់កំពូលភ្នំពេអ៊រ ដែលមើលទៅឃើញទីរហោស្ថាន។[29]លោកបាឡាមទូលព្រះបាទបាឡាក់ថា៖ «សូមព្រះករុណាឲ្យគេសង់កន្លែងថ្វាយប្រាំពីរនៅទីនេះ ហើយរៀបចំគោបាប្រាំពីរ និងចៀមឈ្មោលប្រាំពីរ»។[30]ព្រះបាទបាឡាក់ក៏ធ្វើតាមអ្វីដែលលោកបាឡាមបានប្រាប់។ ស្តេចបានថ្វាយគោបាមួយ និងចៀមឈ្មោលមួយនៅលើកន្លែងថ្វាយតង្វាយនីមួយៗ។

Numbers 23:1
ព្រះបាទបាឡាក់
នេះជាស្តេចម៉ូអាប់។ សូមមើលការបកប្រែនៅក្នុង ២២:២ ។
រៀបចំគោបាប្រាំពីរ និងចៀមឈ្មោលប្រាំពីរ
«សម្លាប់គោប្រាំពីរក្បាល និងចៀមឈ្មោលប្រាំពីរជាយញ្ញបូជា»
សូមព្រះករុណាគង់នៅក្បែរតង្វាយដុតរបស់ព្រះករុណានេះហើយ ទូលបង្គំនឹងចេញទៅឆ្ងាយបន្តិច
«នៅទីនេះជាមួយតង្វាយដុតរបស់ព្រះករុណា ហើយខ្ញុំនឹងទៅឆ្ងាយ»
Numbers 23:4
ទូលបង្គំបានថ្វាយគោបាមួយ និងចៀមឈ្មោលមួយ
មានគេនិយាយរួចហើយថា គាត់បានសម្លាប់សត្វទាំងនេះជាតង្វាយដុត។
ការបកប្រែផ្សេងទៀត
«ទូលបង្គំបានសម្លាប់គោមួយក្បាលនិងចៀមឈ្មោលមួយហើយដុតវាធ្វើជាដង្វាយ»
ព្រះអម្ចាស់បានដាក់ព្រះបន្ទូលនៅក្នុងមាត់របស់លោកបាឡា
នៅទីនេះ ព្រះអម្ចាស់ផ្តល់អោយលោកបាឡាមនូវសំដីមួយដែលត្រូវនិយាយ
ដូចជាព្រះអម្ចាស់ដាក់នៅក្នុងមាត់របស់គាត់។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានមានបន្ទូលប្រាប់លោកបាឡាមនូវអ្វីដែលទ្រង់ចង់អោយគាត់និយាយ
Numbers 23:7
ព្រះបាទបាឡាក់ហៅទូលបង្គំមកពីស្រុកអើរ៉ាម.....ស្តេចស្រុកម៉ូអាប់បានហៅទូលបង្គំពីភ្នំទិសបូព៌ា
ឃ្លាទាំងនេះមានន័យដូចគ្នា។
ចូរមកដាក់បណ្តាសាយ៉ាកុបឲ្យយើង.....ចូរមកប្រទេចផ្តាសាកូនចៅអ៊ីស្រាអែល
សេចក្តីថ្លែងទាំងពីរនេះមានន័យដូចគ្នា។ ពួកគេសង្កត់ធ្ងន់ថា
ព្រះបាទបាឡាក់ចង់អោយលោកបាឡាមដាក់បណ្តាសាប្រជាជនអ៊ីស្រាអែល។
តើឲ្យទូលបង្គំដាក់បណ្តាសាអ្នកដែលព្រះជាម្ចាស់មិនដាក់បណ្តាសាដូចម្តេចកើត? តើឲ្យទូលបង្គំ
រារាំងអ្នកដែលព្រះអម្ចាស់មិនរារាំងដូចម្តេចបាន?
សំណួរទាំងនេះសង្កត់ធ្ងន់ទៅលើការបដិសេធរបស់លោកបាឡាមមិនគោរពព្រះ។
ពួកគេអាចបកប្រែជាសេចក្តីថ្លែង។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែខ្ញុំមិនអាចដាក់បណ្តាសាដល់អ្នកដែលព្រះមិនបានដាក់បណ្តាសាបានទេ។
Numbers 23:9
ពីលើកំពូលថ្មនេះ ទូលបង្គំឃើញពួកគេ.....ពីលើកំពូលភ្នំនេះ ទូលបង្គំសម្លឹងមើលពួកគេ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
លោកបាឡាមបានមើលអ៊ីស្រាអែលពីលើកំពូលភ្នំ។
ទូលបង្គំឃើញពួកគេ.....ទូលបង្គំសម្លឹងមើលពួកគេ
នៅទីនេះ «ពួកគេ» ជាពាក្យដូចគ្នាដែលនិយាយអំពីប្រជាជនអ៊ីស្រាអែល។
មានជនជាតិមួយ
«មានក្រុមមនុស្ស»
ដោយមិនចាត់ទុកពួកគេដូចជនជាតិធម្មតាមួយទេ
សេចក្តីថ្លែងការណ៍បែបអវិជ្ជមាននេះ ត្រូវបានគេប្រើដើម្បីបញ្ជាក់ថា
អ្វីដែលផ្ទុយពីហ្នឹងជាការពិត។ ការបកប្រែផ្សេងទៀត
«ពួកគេចាត់ទុកខ្លួនឯងជាប្រជាជាតិពិសេសមួយ»
Numbers 23:10
តើនរណាអាចរាប់ខ្សាច់របស់លោកយ៉ាកុបឬរាប់ចំនួនមួយភាគបួនរបស់ជនជាតិអ៊ីស្រាអែលបាន?
ទីបួននៃអ៊ីស្រាអែល? នៅទីនេះ «គ្រាប់ខ្សាច់របស់យ៉ាកុប»
គឺជាពាក្យប្រៀបធៀបដែលនិយាយពីចំនួនជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេមានចំនួនច្រើនដូចជាខ្សាច់។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«មានជនជាតិអ៊ីស្រាអែលច្រើនណាស់ដែលមិនអាចរាប់បាន។
គ្មាននរណាម្នាក់អាចរាប់សូម្បីតែមួយភាគបួននៃពួកគេទេព្រោះមានចំនួនច្រើន»។
ស្លាប់ដូចមនុស្សសុចរិតម្នាក់
គេយល់ថានេះជាការស្លាប់ដោយសន្តិភាព។ នេះអាចត្រូវបានបញ្ជាក់។
ការបកប្រែផ្សេងទៀត «ការស្លាប់ដោយសន្តិភាពរបស់មនុស្សសុចរិត«
មនុស្សសុចរិតម្នាក់.....ដូចពួកគេ
ទាំងនេះជាឈ្មោះក្រៅផ្លូវការដែលសំដៅទៅលើប្រជាជនអ៊ីស្រាអែលថាជាមនុស្សតែមួយ។

Numbers 23:11
ព្រះបាទបាឡាក់
នេះជាស្តេចម៉ូអាប់។ សូមមើលការបកប្រែនៅក្នុង ២២:២ ។
ហេតុអ្វីបានជាលោកធ្វើដូច្នេះចំពោះយើង?
ព្រះបាទបាឡាក់ប្រើសំណួរនេះដើម្បីស្តីបន្ទោសលោកបាឡាម។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«យើងមិនជឿថាអ្នកបានធ្វើបែបនេះចំពោះយើងទេ!»
ប៉ុន្តែ មើល!
នេះសង្កត់ធ្ងន់ទៅលើសកម្មភាពគួរឱ្យភ្ញាក់ផ្អើលដែលកើតឡើងជាបន្តបន្ទាប់។
តើមិនគួរឲ្យទូលបង្គំប្រុងប្រយ័ត្ននិយាយតែអ្វីដែលព្រះអម្ចាស់ដាក់ក្នុងមាត់របស់ទូលបង្គំទេឬ?
លោកបាឡាក់ប្រើសំណួរនេះដើម្បីការពារសកម្មភាពរបស់គាត់។
នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ទូលបង្គំត្រូវតែប្រយ័ត្នប្រយែងក្នុងការនិយាយតែអ្វីដែលព្រះអម្ចាស់ប្រាប់ទូលបង្គំអោយនិយាយប៉ុណ្ណោះ»
និយាយតែអ្វីដែលព្រះអម្ចាស់ដាក់ក្នុងមាត់របស់ទូលបង្គំ
សារត្រូវបានគេនិយាយហាក់ដូចជា
[illegible]បានដាក់ចូលទៅក្នុងមាត់របស់គាត់។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ២២:៣៨។ ការបកប្រែផ្សេងទៀត
«និយាយតែអ្វីដែលព្រះអម្ចាស់ចង់អោយទូលបង្គំនិយាយ
Numbers 23:13
នៅទីនោះ លោកត្រូវតែដាក់បណ្តាសាពួកគេឲ្យយើង
«នៅទីនោះអ្នកនឹងដាក់បណ្តាសាជនជាតិអ៊ីស្រាអែលចំពោះយើង»
វាលសូភីម
អ្នកបកប្រែអាចបន្ថែមលេខយោងដែលនិយាយថា ពាក្យ «សូភីម»មានន័យថា
«មើល» ឬ «ស៊ើបការណ៍»
ភ្នំពីសកា
នេះជាឈ្មោះភ្នំមួយ។ សូមមើលការបកប្រែនៅក្នុង ២១:១៩។
Numbers 23:16
បានដាក់ពាក្យនៅក្នុងមាត់របស់គាត់
សារ ត្រូវបានគេនិយាយហាក់ដូចជា
វាជាអ្វីដែលព្រះបានដាក់ចូលទៅក្នុងមាត់របស់គាត់។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ២២:៣៨។ ការបកប្រែផ្សេងទៀត
«បានប្រាប់គាត់ពីអ្វីដែលត្រូវនិយាយ»
ព្រះអង្គបានមានបន្ទូលថា
ព្រះអម្ចាស់មានព្រះបន្ទូលថា៖
ឱព្រះរាជាបាឡាក់អើយ! ....ហើយស្តាប់ទូលបង្គំឲ្យច្បាស់,ដែលជាបុត្រារបស់ព្រះបាទស៊ីបព័រ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយត្រូវបានធ្វើម្តងទៀតដើម្បីបញ្ជាក់ថា
តើព្រះបាទបាឡាក់យកចិត្តទុកដាក់យ៉ាងដូចម្តេច?។
បុត្រានៃព្រះបាទស៊ីបព័រ
នេះសំដៅទៅលើព្រះបាទបាឡាក់។ សូមមើលការបកប្រែនៅក្នុង២:២។
Numbers 23:19
តើព្រះអង្គបានសន្យាអ្វីមួយ ហើយព្រះអង្គមិនធ្វើតាមដែរឬទេ? តើព្រះអង្គធ្លាប់មានបន្ទូលថានឹង
ធ្វើអ្វីមួយ ហើយមិនបានធ្វើឬទេ?
សំណួរទាំងពីរនេះមានន័យដូចគ្នាហើយសង្កត់ធ្ងន់ថា
ព្រះធ្វើតាមអ្វីដែលគាត់បាននិយាយ។
សំណួរទាំងនេះអាចបកប្រែជាសេចក្តីថ្លែងការណ៏។ ការបកប្រែផ្សេងទៀត
«គាត់មិនដែលបានសន្យារឿងណាមួយដោយមិនបានបំពេញតាមអ្វីដែលគាត់បានសន្យានោះទេ»។
គាត់តែងតែធ្វើអ្វីដែលគាត់បាននិយាយ គាត់នឹងធ្វើ ។
ទូលបង្គំបានទទួលបញ្ជាឲ្យពរ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះបានបញ្ជាឱ្យទូលបង្គំឲ្យពរដល់ជនជាតិអ៊ីស្រាអែល»
Numbers 23:21
[illegible]ការលំបាកនៅក្នុងពួកយ៉ាកុបឡើយ..... ឬទុក្ខវេទនាណានៅក្នុងកូនចៅអ៊ីស្រាអែលដែរ

generated on Wed Sep 10 16:16:32 2025

ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ អាចមានន័យថា ១)
ព្រះបានប្រទានឱ្យអ៊ីស្រាអែលតែរបស់ល្អៗ ឬ ២)
មិនមានអំពើបាបនៅក្នុងប្រទេសអ៊ីស្រាអែលដែលនឹងធ្វើឱ្យទ្រង់វិនិច្ឆ័យពួកគេឡើយ។
ហើយពួកគេប្រកាសថា មហាក្យត្ររបស់ពួកគេគង់ក្នុងចំណោមពួកគេ
«ពួកគេស្រែកដោយអំណរព្រោះព្រះអម្ចាស់ជាស្តេចរបស់ពួកគេ»
ដោយប្រើកម្លាំងដ៏ខ្លាំង ដូចសត្វគោ
រឿងប្រៀបប្រដូចនេះចែងថា កម្លាំងដ៏អស្ចារ្យរបស់ព្រះអម្ចាស់គឺស្មើនឹងគោ។

Numbers 23:23
គ្មានមន្តអាគមអាចធ្វើប្រឆាំងនឹងយ៉ាកុបបានទេ ....ហើយក៏គ្មានគ្រូទាយណាអាចធ្វើឲ្យកូនចៅអ៊ីស្រាអែលឈឺចាប់បានដែរ
ប្រាប់ធ្វើបាបអ៊ីស្រាអែល ខ្សែទាំងពីរនេះមានន័យដូចគ្នាថា គ្មានបណ្តាសារណាមួយដែលដាក់លើប្រជាជាតិអ៊ីស្រាអែលនឹងមានប្រសិទ្ធភាពឡើយ។ នៅទីនេះ «យ៉ាកុប» គឺជាពាក្យដូចដែលសំដៅទៅលើអ៊ីស្រាអែល។
នឹងមានគេថ្លែងអំពី
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «មនុស្សត្រូវតែនិយាយថា»
ចូរសម្លឹងមើលអ្វីដែលព្រះជាម្ចាស់ធ្វើចុះ!
វាបញ្ជាក់ថាអ្វីដែលព្រះបានធ្វើសម្រាប់ពួកគេគឺល្អ។ ការបកប្រែផ្សេងទៀត
«មើលអ្វីដែលល្អ ដែលព្រះជាម្ចាស់បានធ្វើសម្រាប់ពួកគេ!»

Numbers 23:24
ប្រជាជននេះងើបឡើងដូចសិង្ហញី....ដែលវាបានសម្លាប់
ខគម្ពីរនេះ
គឺជាពាក្យប្រៀបធៀបជាយូរមកហើយដែលនិយាយពីអ៊ីស្រាអែលយកឈ្នះខ្មាំងសត្រូវរបស់ខ្លួន
ហាក់ដូចជាអ៊ីស្រាអែលជាសត្វតោ ដែលកំពុងតែលេបត្រាប់សត្វរបស់ខ្លួន។

Numbers 23:25
ព្រះបាទបាឡាក់
នេះគឺជាស្តេចម៉ូអាប់។ សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ២២:២។
តើទូលបង្គំមិនបានទូលប្រាប់ព្រះករុណារួចហើយទេឬថា ទូលបង្គំត្រូវនិយាយអ្វីដែលព្រះអម្ចាស់ប្រាប់ទូលបង្គំឲ្យនិយាយ
លោកបាឡាមប្រើសំនួរនេះដើម្បីរំលឹកព្រះបាទបាឡាក់ថាលោកបាឡាមបានបដិសេធមិនស្តាប់បង្គាប់ព្រះជ
វាអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ទូលបង្គំបានទូលទ្រង់មុនថា
ទូលបង្គំត្រូវតែនិយាយអ្វីដែលព្រះអម្ចាស់ប្រាប់ទូលបង្គំឱ្យនិយាយ»។

Numbers 23:28
ដែលមើលទៅឃើញវាលរហោស្ថាន។
គេយល់ថា ទីរហោស្ថាននេះជាកន្លែងដែលប្រជាជនអ៊ីស្រាអែលបោះជំរំ។
ការបកប្រែផ្សេងទៀត «មើលទៅទីរហោស្ថានជាកន្លែងដែលអ៊ីស្រាអែលស្ថិតនៅ»

---

24 [1]នៅពេលដែលលោកបាឡាមឃើញថា ព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានពរដល់ជនជាតិអ៊ីស្រាអែល លោកមិនបានចេញទៅធ្វើពិធីមន្តអាគមនដូចមុនៗទេ។ ផ្ទុយទៅវិញ លោកសម្លឹងមើលទៅរកទីរហោស្ថាន។
[2]លោកងើបមុខឡើង ឃើញជនជាតិអ៊ីស្រាអែលបោះជំរំតាមកុលសម្ព័ន្ធរបស់គេរៀងៗខ្លួន។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ក៏យាងមកសណ្ឋិតលើលោកបាឡាម[3]លោកបានទទួលព្រះបន្ទូល ហើយថ្លែងថា៖ «នេះជាពាក្យរបស់លោកបាឡាម កូនរបស់បេអ៊រ នេះជាមនុស្សម្នាក់ដែលបើកភ្នែកយ៉ាងធំ។
[4]ជាអ្នកដែលបាននិយាយ ហើយឮព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ជាអ្នកដែលឃើញនិមិត្តពីព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត ទាំងបានក្រាបចុះនៅចំពោះព្រះអង្គដោយភ្នែករបស់ខ្លួននៅបើក។[5]យ៉ាកុបអើយ ពន្លារបស់លោកស្អាតណាស់! អ៊ីស្រាអែលអើយ! ទីលំនៅរបស់អ្នកក៏ស្អាតដែរ!
[6]គឺប្រៀបដូចជាជ្រលងភ្នំ វាលាតសន្ធឹង ដូចសួនច្បារនៅជាប់ទន្លេ ដូចដើមប្រទាលកន្ទុយក្រពើ ដែលព្រះអម្ចាស់បានដាំ ដូចដើមតាត្រៅនៅជិតទឹក។
[7]ទឹកនឹងហូរចេញពីធុងរបស់គេ ហើយគ្រាប់ពូជរបស់គេនឹងមានទឹកគ្រប់គ្រាន់។ ស្តេចរបស់ពួកគេនឹងខ្ពស់ជាងព្រះបាទអកាក់ ហើយនគររបស់គេនឹងបានថ្កើនថ្កាន។
[8]ព្រះជាម្ចាស់បាននាំពួកគេចេញពីស្រុកអេស៊ីប ដោយកម្លាំងដ៏ខ្លាំង ដូចសត្វរមាស។ ពួកគេស៊ីកម្ទេចប្រជាជាតិនានាដែលច្បាំងតតាំងនឹងពួកគេ។ គឺនឹងបំបាក់ឆ្អឹងសត្រូវជាបំណែក និងបាញ់ព្រួញប្រហារអ្នកទាំងនោះដោយព្រួញទៀតផង។
[9]ពួកគេក្រាបដូចសត្វសិង្ហឈ្មោលញី តើនរណាហ៊ានរំខានពួកគេ? សូមឲ្យអស់អ្នកដែលឲ្យពរគេ បានទទួលពរ ហើយសូមឲ្យអស់អ្នកដែលដាក់បណ្តាគេ ត្រូវបណ្តាសាចុះ!»។
[10]ព្រះបាទបាឡាក់ខឹងលោកបាឡាមយ៉ាងខ្លាំង ស្តេចបានទះព្រះហស្តខ្លាំងៗដោយកំហឹង រួចព្រះបាទឡាក់បានមានរាជឱង្ការទៅលោកបាឡាមថា៖ «យើងបានហៅលោកមក ដើម្បីឲ្យលោកដាក់បណ្តាសាខ្មាំងសត្រូវរបស់យើង ប៉ុន្តែមើល៍! លោកបែរជាឲ្យពរពួកគេរហូតដល់បីដងទៅវិញ!។[11]ឥឡូវនេះ ចូរលោកចេញពីយើង ហើយត្រលប់ទៅផ្ទះរបស់លោកវិញទៅ! យើងបាននិយាយហើយថា យើងនឹងផ្តល់រង្វាន់ដ៏ធំដល់លោក ប៉ុន្តែ ព្រះអម្ចាស់រារាំងលោកមិនឲ្យទទួលរង្វាន់នេះទេ!»។
[12]លោកបាឡាមទូលឆ្លើយទៅព្រះបាទបាឡាក់វិញថា៖ «ទូលបង្គំបានប្រាប់អស់អ្នកនាំសារដែលព្រះករុណាចាត់ឲ្យទៅជួបទូលបង្គំរួចហើយថា[13]ទោះបី ព្រះបាទបាឡាក់ប្រទានវាំងរបស់ព្រះករុណាដែលពេញទៅដោយប្រាក់ និងមាសមកទូលបង្គំក្តី ក៏ទូលបង្គំពុំអាចនិយាយលើសពីព្រះបន្ទូលរបស់ព្រះអម្ចាស់បានទេ ហើយក៏មិនអាចនាំការល្អ ឬការអាក្រក់បានដែរ ឬក៏អ្វីតាមអំពើចិត្តរបស់ទូលបង្គំទេ។ តើទូលបង្គំមិនបាននិយាយពាក្យទាំងនេះទៅពួកគេទេឬ?[14]ឥឡូវនេះ ទូលបង្គំនឹងត្រឡប់ទៅជួបជុំនឹងប្រជាជនរបស់ទូលបង្គំវិញ ប៉ុន្តែទូលបង្គំ សូមដាស់តឿនព្រះអង្គនូវអ្វីដែលជនជាតិនេះនឹងប្រព្រឹត្តចំពោះប្រជាជនរបស់ព្រះករុណា នៅពេលខាងមុខ»។
[15]លោកបាឡាមថ្លែងដូចតទៅ៖ «នេះជាពាក្យរបស់បាឡាម កូនរបស់បេអ៊រ ជាមនុស្សម្នាក់ដែលបើកភ្នែកយ៉ាងធំ[16]នេះជាពាក្យរបស់អ្នកដែលបានឮព្រះបន្ទូលពីព្រះជាម្ចាស់ ជាអ្នកដែលទទួលប្រាជ្ញាពីព្រះដ៏ខ្ពស់បំផុត ជាអ្នកដែលបានឃើញនិមិត្តពីព្រះដ៏មានឫទ្ធានុភាពខ្ពស់បំផុត ទាំងបានក្រាបចុះនៅចំពោះព្រះអង្គដោយភ្នែករបស់ខ្លួននៅបើក។
[17]ខ្ញុំឃើញព្រះអង្គ ប៉ុន្តែឥឡូវនេះព្រះអង្គមិននៅទីនេះទេ។ ខ្ញុំសម្លឹងមើលព្រះអង្គ ប៉ុន្តែ ព្រះអង្គមិននៅជិតនេះទេ។ មានផ្កាយមួយរះចេញពីលោកយ៉ាកុប ហើយមានដំបងរាជ្យមួយចេញពីអ៊ីស្រាអែល។ ព្រះអង្គនឹងវាយបំបែកក្បាលរបស់ពួកមេដឹកនាំជនជាតិម៉ូអាប់ ហើយប្រល័យកូនចៅទាំងអស់របស់សេត។
[18]ស្រុកអេដុមនឹងត្រឡប់កេរអាកររបស់ជនជាតិអ៊ីស្រាអែល ហើយស្រុកសៀរ ដែលជាសត្រូវរបស់ជនជាតិអ៊ីស្រាអែលនឹងត្រឡប់ជាកេរអាកររបស់ពួកគេ ដែលជនជាតិអ៊ីស្រាអែលនឹងវាយដណ្តើមបានដោយកម្លាំង។[19]នឹងមានស្តេចមួយអង្គចេញពីយ៉ាកុបមក ជាស្តេចដែលនឹងគ្រប់គ្រងលើទាំងអស់ ហើយព្រះអង្គនឹងប្រល័យអស់អ្នកដែលនៅសេសសល់ក្នុងទីក្រុងរបស់ពួកគេ»។
[20]បន្ទាប់មក លោកបាឡាមបានសម្លឹងមើលទៅព្រះបាទបាឡាក់ថ្លែងថា៖ «ជនជាតិអាម៉ាឡេកជាប្រជាជាតិមួយធំជាងគេមែន ប៉ុន្តែ នៅទីបំផុត ពួកគេនឹងត្រូវវិនាស»។
[21]បន្ទាប់មក លោកបាឡាមបានសម្លឹងមើលជនជាតិកែន ហើយថ្លែងថា៖ «កន្លែងដែលអ្នករស់នៅគឺរឹងមាំណាស់ ហើយសំបុករបស់អ្នកក៏នៅក្នុងថ្មដា។[22]ក៏ប៉ុន្តែ ជនជាតិកែននឹងត្រូវភ្លើងឆាបឆេះ ហើយជនជាតិអាសស៊ើរនឹងនាំអ្នកទៅជាឈ្លើយ!»។
[23]បន្ទាប់មក លោកបាឡាមថ្លែងទំនាយទៀតចុងក្រោយថា៖ «ទេវនាហើយ តើអ្នកនឹងនៅរស់បានពេលដែលព្រះជាម្ចាស់ធ្វើការនេះ?[24]នឹងមានសំពៅមកពីស្រុកគីទីម ពួកគេនឹងវាយប្រហារជនជាតិអាសស៊ើរ និងជនជាតិហេប៊ើរ ក៏ប៉ុន្តែ អ្នកទាំងនោះក៏នឹងបញ្ចប់ដោយសេចក្តីអន្តរាយដែរ»។[25]បន្ទាប់មក លោកបាឡាមក្រោកឡើងចេញពីទីនោះ ត្រឡប់ទៅស្រុករបស់លោកវិញ រីឯព្រះបាទបាឡាក់ក៏ចាកចេញទៅដែរ។

Numbers 24:1
ដូចពេលមុនៗទេ
«ដូចគាត់បានធ្វើកាលពីលើកមុន»

Numbers 24:2
លោកងើបភ្នែកឡើង
នៅទីនេះ «គាត់ងើបភ្នែកឡើង» គឺជាពាក្យសំដីដែលមានន័យថារកមើល។
ការបកប្រែផ្សេងទៀត «គាត់បានមើលទៅ»
ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ក៏យាងមកសណ្ឋិតលើលោក
នេះមានន័យថា ព្រះវិញ្ញាណរបស់ព្រះបានគ្រប់គ្រងគាត់ ឲ្យចេះទាយ។
លោកបានទទួលព្រះបន្ទូលហើយថ្លែងថា

generated on Wed Sep 10 16:16:32 2025

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះបានប្រទានឱ្យគាត់នូវពាក្យទំនាយនេះ»
បាឡាម កូនរបស់បេអ៊រ
បេអ៊រជាឪពុករបស់លោកបាឡាម។ សូមមើលការបកប្រែនៅក្នុង ២២:៥។
មនុស្សម្នាក់ៗដែលបើកភ្នែកយ៉ាងធំ
នេះសម្គាល់មានន័យថា គាត់មើលឃើញនិងយល់ច្បាស់។
Numbers 24:4
ព័ត៌មានទូទៅ៖
លោកបាឡាមបន្តទាយនៅក្រោមការគ្រប់គ្រងនៃព្រះវិញ្ញាណនៃព្រះជាម្ចាស់។
គាត់និយាយ.....គាត់បានឃើញ....គាតក្រាបចុះ
នៅទីនេះលោកបាឡាមសំដៅលើខ្លួនគាត់ថា «គាត់»។
គាត់បានក្រាបចុះ
នេះជាកាបន្ទាបខ្លួន។
ដោយភ្នែករបស់ខ្លួននៅបើក
ត្រង់នេះ «ភ្នែកបើកចំហ»
គឺជាសំនួរដែលមានន័យថាលោកបាឡាមបានទទួលសមត្ថភាពដឹងពីអ្វីដែលព្រះចង់មានបន្ទូលប្រាប់គាត់។
កូនចៅយ៉ាកុបអើយ ពន្លារបស់អ្នកស្អាតណាស់! កូនចៅអ៊ីស្រាអែលអើយ! ទីលំនៅរបស់អ្នកក៏ស្អាតដែរ!
សេចក្តីថ្លែងទាំងពីរនេះមានន័យដូចគ្នា។
ពួកគេសង្កត់ធ្ងន់លើជំរំអ៊ីស្រាអែលស្រស់ស្អាតចំពោះលោកបាឡាម។
Numbers 24:6
ព័ត៌មានទូទៅ៖
លោកបាឡាមបន្តទាយនៅក្រោមការគ្រប់គ្រងរបស់ព្រះវិញ្ញាណនៃព្រះ។
គឺប្រៀបដូចជាទឹកជ្រោះហូរ
លោកបាឡាមនិយាយអំពីជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេមានចំនួនគ្រប់គ្រាន់ដើម្បីគ្របដណ្តប់លើជ្រលងភ្នំទាំងមូល។
ដូចសួនច្បារនៅជាប់ទន្លេ
លោកបាឡាមនិយាយអំពីជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេមានសួនច្បារដែលមានទឹកផឹកល្អដែលបង្កើតផលបានច្រើន។
ដូចដើមក្រស្នា ដែលព្រះអម្ចាស់បានដាំ
ក្រស្នាគឺជារុក្ខជាតិដែលមានក្លិនក្រអូប
ដែលលូតលាស់ល្អសូម្បីតែនៅក្នុងស្ថានភាពស្ងួត។
លោកបាឡាមនិយាយអំពីជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេលូតលាស់និងរីករាយដូចជារុក្ខជាតិ ក្រស្នា ។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ក្រស្នាដែលព្រះអម្ចាស់បានដាំ» (សូមមើល and និងfigs-activepassive)
ដូចដើមតាត្រៅនៅជិតទឹក
ដើមឈើតាត្រៅគឺជាដើមឈើធំបំផុតនៅអ៊ីស្រាអែល។
លោកបាឡាមនិយាយអំពីជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេធំដូចដើមតាត្រៅដែលនៅជិតទឹក។
Numbers 24:7
ព័ត៌មានទូទៅ៖
លោកបាឡាមបន្តការទាយនៅក្រោមការគ្រប់គ្រងនៃព្រះវិញ្ញាណនៃព្រះជាម្ចាស់។
ទឹកនឹងហូរ.....មានទឹកគ្រប់គ្រាន់
ទឹកផឹក
ទឹកបរិបូណ៌ត្រូវបានផ្សារភ្ជាប់ជាមួយនឹងពរជ័យរបស់ព្រះជាម្ចាស់លើដំណាំនឹងដី។
ការបកប្រែផ្សេងទៀត
«ព្រះនឹងប្រទានពរដល់អ៊ីស្រាអែលនូវទឹកជាច្រើនសម្រាប់ដំណាំរបស់ពួកគេ»
គ្រាប់ពូជរបស់គេនឹងមានទឹកគ្រប់គ្រាន់
ស្រោចទឹក
គ្រាប់ពូជដែលស្រោចទឹកល្អសំដៅទៅលើពរជ័យរបស់ព្រះចំពោះប្រជាជនរបស់ព្រះអង្គ
ដើម្បីពួកគេនឹងមានដំណាំជាច្រើន។ ការបកប្រែផ្សេងទៀត
«ពួកគេនឹងមានទឹកច្រើនសម្រាប់គ្រាប់ពូជរបស់ពួកគេ
ដើម្បីដាំដំណាំដែលមានគ្រាប់ពូជល្អ»
ស្តេចរបស់គេនឹងខ្ពស់ជាង.....នគររបស់គេនឹងបានថ្កើនថ្កាន
ឃ្លាទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា ដោយសង្កត់ធ្ងន់ថា
ព្រះនឹងប្រទានពរដល់ពួកគេយ៉ាងច្រើនបើប្រៀបធៀបទៅនឹងប្រជាជាតិដទៃទៀត។
ស្តេចរបស់គេនឹងខ្ពស់ជាងស្តេចអកាក់
នៅទីនេះ «ខ្ពស់ជាង» សំដៅទៅលើកិត្តិយសនិងអំណាចកាន់តែច្រើន។
នេះមានន័យថា អនាគតស្តេចអ៊ីស្រាអែលនឹងមានកិត្តិយសច្រើនជាង
ហើយនឹងមានអំណាចជាងស្តេចអកាក់ទៅទៀត។
អកាក់ជាស្តេចនៃជនជាតិអាម៉ាលេក។
នគររបស់គេនឹងបានថ្កើនថ្កាន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សផ្សេងទៀតនឹងផ្តល់កិត្តិយសដល់នគររបស់ពួកគេ»
Numbers 24:8
ព័ត៌មានទូទៅ៖
លោកបាឡាមបន្តទាយនៅក្រោមការគ្រប់គ្រងនៃព្រះវិញ្ញាណនៃព្រះ។
ព្រះជាម្ចាស់នាំគាត់
«ព្រះជាម្ចាស់ដឹកនាំប្រជាជនអ៊ីស្រាអែល»
ដោយកម្លាំងដ៏ខ្លាំង ដូចសត្វមាស
រឿងប្រៀបប្រដូចនេះសង្កត់ធ្ងន់ថា ប្រជាជនអ៊ីស្រាអែលមានកម្លាំងខ្លាំង។
ពួកគេស៊ីកម្ទេចប្រជាជាតិនានា
លោកបាឡាមនិយាយអំពីជនជាតិអ៊ីស្រាអែលហាក់ដូចជាពួកគេជាសត្វព្រៃ
ដែលស៊ីសាច់ត្រូវរបស់ពួកគេ។ នេះមានន័យថា ពួកគេនឹងបំផ្លាញសត្រូវរបស់ពួកគេ។
Numbers 24:9
ព័ត៌មានទូទៅ៖
លោកបាឡាមបានបញ្ចប់ការទាយរបស់គាត់នៅក្រោមការគ្រប់គ្រងនៃព្រះវិញ្ញាណនៃព្រះ។
ពួកគេក្រាបដូចសត្វសិង្ហឈ្មោលញី,ដូចជាសឹង្ហញី
ក្នុងរឿងប្រៀបប្រដូចនេះលោកបាឡាមប្រៀបធៀបជនជាតិអ៊ីស្រាអែលទៅនឹងសត្វសឹង្ហទាំងពីរ
គឺឈ្មោលនិងញី។ នេះមានន័យថា
ពួកគេមានគ្រោះថ្នាក់ហើយតែងតែត្រៀមខ្លួនវាយប្រហារ។
តើនរណាហ៊ានរំខានពួកគេ?
លោកបាឡាមប្រើសំនួរមួយ
ដើម្បីដាស់តឿនប្រជាជនទាំងអស់កុំធ្វើឱ្យជនជាតិអ៊ីស្រាអែលខឹង។
នេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«គ្មាននរណាហ៊ានរំខានពួកគេទេ!»
សូមឲ្យអស់អ្នកដែលឲ្យពរគេ បានទទួលពរ ហើយសូមឲ្យអស់អ្នកដែលដាក់បណ្តាគេ ត្រូវបណ្តាសាចុះ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«សូមព្រះជាម្ចាស់ប្រទានពរដល់អស់អ្នកដែលប្រទានពរដល់ជនជាតិអ៊ីស្រាអែល
សូមអោយព្រះអង្គដាក់បណ្តាសាដល់អស់អ្នកណាដែលដាក់បណ្តាសាជនជាតិអ៊ីស្រាអែលផង»
Numbers 24:10
ព្រះបាទបាឡាក់ខឹងយ៉ាងខ្លាំង
ការកើនឡើងកំហឹងរបស់ព្រះបាទបាឡាក់ត្រូវបានគេនិយាយថា
វាជាការចាប់ផ្តើមឆេះ។ អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «ព្រះបាទបាឡាក់ខឹងខ្លាំងណាស់»
បានទះព្រះហស្តខ្លាំងៗដោយកំហឹង
នេះជាសញ្ញានៃការខកចិត្តនិងកំហឹងយ៉ាងខ្លាំង។
Numbers 24:12
ទោះបី ព្រះបាទបាឡាក់ប្រទានវាំងរបស់ស្តេចដែលពេញទៅដោយប្រាក់ និងមាសមកទូលបង្គំក្តី
លោកបាឡាមកំពុងពិពណ៌នាអំពីអ្វីមួយដែលនឹងមិនកើតឡើង។
សេចក្តីថ្លែងការណ៍នេះសង្កត់ធ្ងន់ថា
គ្មានអ្វីដែលអាចធ្វើឱ្យលោកបាឡាមមិនស្តាប់បង្គាប់ព្រះជាម្ចាស់ឡើយ។
តើទូលបង្គំមិនបាននិយាយពាក្យទាំងនេះទៅពួកគេទេឬ?
លោកបាឡាមប្រើសំនួរដើម្បីរំលឹកព្រះបាទបាឡាក់អំពីអ្វីដែលគាត់បាននិយាយមុន។
សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំបាននិយាយរឿងនេះទៅពួកគេ» ។
ជនជាតិនេះ
«គឺប្រជាជនអ៊ីស្រាអែល»
Numbers 24:15
បាឡាម កូនរបស់បេអ៊រ
បេអ៊រជាឪពុករបស់លោកបាឡាម។ សូមមើលការបកប្រែនៅក្នុង ២២:៥។
ជាមនុស្សម្នាក់ដែលបើកភ្នែកយ៉ាងធំ
ការសម្គាល់នេះមានន័យថា គាត់មើលឃើញនិងយល់ច្បាស់។
សូមមើលការបកប្រែនៅក្នុង ២៤:២។
ជាអ្នកដែលទទួលប្រាជ្ញាពីព្រះដ៏ខ្ពស់បំផុត
ពាក្យអរូបី «ចំណេះដឹង» អាចបញ្ជាក់ជាសកម្មភាព។ ការបកប្រែផ្សេងទៀត

«អ្នកណាស្គាល់រឿងដែលព្រះដ៏ខ្ពស់បំផុតបានសម្តែងដល់គាត់»
ក្រាបចុះ
នេះជាសញ្ញានៃការចុះចូលចំពោះព្រះ។
Numbers 24:17
ព័ត៌មានទូទៅ៖
លោកបាឡាមបន្តជាពាក្យទីមួយនៃទំនាយទាំងបួនរបស់គាត់។
ខ្ញុំឃើញព្រះអង្គ ប៉ុន្តែឥឡូវនេះព្រះអង្គមិននៅទីនេះទេ។ ខ្ញុំសម្លឹងមើលព្រះអង្គ ប៉ុន្តែ ព្រះអង្គមិននៅជិតនេះទេ
សេចក្តីថ្លែងទាំងពីរនេះមានន័យដូចគ្នា។
លោកបាឡាមកំពុងមានចក្ខុវិស័យនៃព្រឹត្តិការណ៍នាពេលអនាគត។ ពាក្យថា «គាត់» សំដៅទៅលើអ្នកដឹកនាំអ៊ីស្រាអែលនាពេលអនាគត។
មានផ្កាយមួយរះចេញពីយ៉ាកុប
នៅទីនេះ «ផ្កាយ» សំដៅទៅលើស្តេចអ៊ីស្រាអែលមួយអង្គដែលនឹងឡើងកាន់អំណាច។
ចេញពីយ៉ាកុប
នៅទីនេះ «យ៉ាកុប» សំដៅទៅលើកូនចៅរបស់យ៉ាកុប។
«មកពីក្នុងចំណោមកូនចៅរបស់យ៉ាកុប»
មានដំបងរាជ្យមួយចេញពីអ៊ីស្រាអែល
នេះមានន័យដូចគ្នានឹងផ្នែកដំបូងនៃប្រយោគ។ នៅទីនេះ «ដំបងរាជ» សំដៅទៅលើស្តេចដែលមានអំណាច។
ចេញពីអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែលសំដៅទៅលើជនជាតិអ៊ីស្រាអែលនាពេលអនាគត»។
ការបកប្រែផ្សេងទៀត «មកពីក្នុងចំណោមជនជាតិអ៊ីស្រាអែលនាពេលអនាគត»
វាយបំបែកក្បាលរបស់ពួកមេដឹកនាំជនជាតិម៉ូអាប់
អាចមានន័យថា ១) គាត់នឹងបំបាក់ក្បាលមេដឹកនាំម៉ូអាប់។ ២) គាត់នឹងបំផ្លាញមេដឹកនាំម៉ូអាប់។
កូនចៅទាំងអស់របស់សេត
នេះក៏សំដៅទៅលើជនជាតិម៉ូអាប់ដែលជាកូនចៅរបស់សេតដែរ។
Numbers 24:18
ព័ត៌មានទូទៅ៖
លោកបាឡាមបញ្ចប់ការទាយទីមួយនៃទំនាយទាំងបួនរបស់គាត់។
ស្រុកអេដុមនឹងត្រឡប់កេរអាកររបស់ជនជាតិអ៊ីស្រាអែល
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ជនជាតិអ៊ីស្រាអែលនឹងកាន់កាប់ស្រុកអេដុម»
សៀរក៏នឹងក្លាយជាកម្មសិទ្ធិរបស់ពួកគេដែរ
នៅទីនេះ «សៀរ» សំដៅទៅលើប្រជាជនដែលរស់នៅក្បែរភ្នំសៀរ។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «អ៊ីស្រាអែលក៏នឹងយកឈ្នះប្រជាជនសៀរ»
នឹងមានស្តេចមួយអង្គចេញពីយ៉ាកុបមក
លោកយ៉ាកុបជាបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែល។ «យ៉ាកុប» គឺសំដៅទៅលើក្រុមមនុស្សទាំងមូល។
ទីក្រុងរបស់ពួកគេ
នេះសំដៅទៅលើទីក្រុង អ៊ើរ ដែលព្រះបាទបាឡាក់បានជួបលោកបាឡាម។
Numbers 24:20
លោកបាឡាមបានសម្លឹងមើលជនជាតិអាម៉ាឡេក
នៅទីនេះ «អាម៉ាឡេក» ជាពាក្យដូចដែលនិយាយអំពីប្រជាជនអាម៉ាឡេក។ នេះនៅតែបន្តចក្ខុវិស័យរបស់លោកបាឡាម
នៅពេលងាកទៅរកទិសដៅនៃជនជាតិអាម៉ាឡេកហើយបន្ទាប់មកគាត់បានទាយអំពីជនជាតិអាម៉ាឡេក។
នៅទីបំផុត ពួកគេ
សព្វនាមឯកវចនៈ ត្រូវបានប្រើពីព្រោះអាម៉ាឡេកត្រូវបានគេនិយាយថាជាមនុស្សតែម្នាក់។
Numbers 24:21
ជនជាតិកែន
នេះជាឈ្មោះក្រុមមនុស្សដែលមកពីពូជអំបូរកែន។
កន្លែងដែលអ្នករស់នៅគឺរឹងមាំណាស់
«កន្លែងដែលអ្នករស់នៅគឺត្រូវបានការពារយ៉ាងល្អ»
ហើយសំបុករបស់អ្នកក៏នៅក្នុងថ្មដា
នេះជាការប្រៀបធៀបដែលមានន័យថា ពួកគេរស់នៅកន្លែងដែលមានសុវត្ថិភាព។
ការបកប្រែផ្សេងទៀត «ទីតាំងរបស់អ្នកមានសុវត្ថិភាពដូចសំបុកខ្ពស់នៅក្នុងថ្ម»
ក៏ប៉ុន្តែ ជនជាតិកែននឹងត្រូវភ្លើងឆាបឆេះ ហើយជនជាតិអាសស៊ើរនឹងនាំអ្នកទៅជាឈ្លើយ!
កែនជាទីក្រុងដ៏ធំមួយ ដែលជនជាតិកែនរស់នៅ។
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ទោះយ៉ាងណាជនជាតិអាសស៊ើរនឹងបំផ្លាញជនជាតិកែនហើយយកពួកគេធ្វើជាឈ្លើយ»
Numbers 24:23
តើអ្នកនឹងនៅរស់បានពេលដែលព្រះជាម្ចាស់ធ្វើការនេះ?
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់អាចរស់បានទេនៅពេលដែលព្រះធ្វើការនេះ!»
ស្រុកគីទីម
នេះជាឈ្មោះទីក្រុងនៅលើកោះមួយ នៅសមុទ្រមេឌីទែរ៉ាណេ។
អ្នកទាំងនោះក៏នឹងបញ្ចប់ដោយសេចក្តីអន្តរាយដែរ
នាមអរូបី «ការបំផ្លាញ» អាចបញ្ជាក់ជាសកម្មភាព។ ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់នឹងបំផ្លាញពួកគេផងដែរ»

---

25 [1]ជនជាតិអ៊ីស្រាអែលស្នាក់នៅស្រុកស៊ីទីម ហើយពួកប្រុសៗចាប់ផ្តើមសាហាយស្មន់ជាមួយស្ត្រីជនជាតិម៉ូអាប់។[2]ដ្បិត ជនជាតិម៉ូអាប់បានអញ្ជើញប្រជាជន
អ៊ីស្រាអែលថ្វាយយញ្ញបូជាដល់ព្រះរបស់ពួកគេ។ បន្ទាប់មក ពួកគេនាំគ្នាបរិភោគ ហើយថ្វាយបង្គំព្រះទាំងនោះ។[3]ពួកប្រុសៗរបស់អ៊ីស្រាអែលនាំគ្នាចូលរួមថ្វាយ
បង្គំព្រះបាលនៃស្រុកពេអ៊ើរ ព្រះអម្ចាស់ព្រះពិរោធទាស់នឹងពួកគេយ៉ាងខ្លាំង។
[4]ព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកម៉ូសេថា៖ «ចូរសម្លាប់ពួកមេដឹកនាំទាំងប៉ុន្មានរបស់ប្រជាជន ហើយព្យួរពួកគេហាលថ្ងៃនៅចំពោះមុខយើង ដើម្បីឲ្យពិរោធ
របស់យើងអាចបែរចេញពីជនជាតិអ៊ីស្រាអែល»។[5]ដូច្នេះ លោកម៉ូសេបានមានប្រសាសន៍ទៅពួកមេដឹកនាំរបស់ជនអ៊ីស្រាអែលថា៖ «អ្នករាល់គ្នាត្រូវ
សម្លាប់ប្រជាជនរបស់ខ្លួនដែលចូលរួមថ្វាយបង្គំព្រះព្រះបាលពេអ៊ើរចោល!»។
[6]ពេលនោះ មានបុរសជាតិអ៊ីស្រាអែលម្នាក់បាននាំស្ត្រីសាសន៍ម៉ាឌានម្នាក់ ចូលមកក្នុងចំណោមគ្រួសាររបស់ខ្លួន។ ការនេះកើតឡើងនៅមុខលោកម៉ូសេ និងនៅមុខ
សហគមន៍ប្រជាជនអ៊ីស្រាអែលទាំងមូល ក្នុងពេលពួកគេកំពុងតែយំសោកនៅមាត់ទ្វារត្រសាលប្រជុំ។[7]នៅពេលដែលលោកភីនេហាស ជាកូនរបស់លោកអេឡាសារ ដែល
ត្រូវជាកូនរបស់បូជាចារ្យអើរ៉ុនឃើញដូច្នេះ គាត់ក៏ក្រោកឡើងក្នុងចំណោមសហគមន៍ ទាំងកាន់លំពែងនៅដៃរបស់គាត់។
[8]គាត់តាមបុរសជនជាតិអ៊ីស្រាអែលនោះរហូតដល់ក្នុងត្រសាលរបស់គេ ហើយយកលំពែងចាក់ទម្លុះអ្នកទាំងពីរ គឺបុរសអ៊ីស្រាអែល និងស្ត្រីនោះ។ ដូច្នេះ គ្រោះកាចដែល
កើតមានក្នុងចំណោមជនជាតិអ៊ីស្រាអែលក៏ឈប់ទៅវិញ។[9]អ្នកដែលស្លាប់ក្នុងគ្រោះកាចនេះមានចំនួនពីរម៉ឺនបួនពាន់នាក់។
[10]ព្រះអម្ចាស់បានមានបន្ទូលមកលោកម៉ូសេ ហើយមានបន្ទូលថា៖[11]«ភីនេហាស ជាកូនរបស់បូជាចារ្យអេឡាសារ បានបង្វែរកំហឹងរបស់យើងចេញពីប្រជាជនអ៊ីស្រាអែល
ពីព្រោះគាត់បានឈឺឆ្អាលចំពោះក្តីប្រចណ្ឌរបស់យើងក្នុងចំណោមជនជាតិអ៊ីស្រាអែល។ ដូច្នេះ យើងមិនបំផ្លាញកូនចៅអ៊ីស្រាអែលដោយព្រោះកំហឹងរបស់យើងទេ។
[12]ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖ «មើល៍! យើងប្រទានសម្ពន្ធមេត្រីដែលផ្តល់សន្តិភាពដល់ភីនេហាស ជាកូនរបស់អេឡាសារ ដែលជាកូនរបស់
បូជាចារ្យអើរ៉ុន[13]សម្រាប់គេ និងពូជពង្សរបស់គេដែលមកតាមក្រោយ។ នោះគឺជាសម្ពន្ធមេត្រីរបស់បូជាចារ្យដ៏នៅអស់កល្បជានិច្ច ពីព្រោះគេបានប្រចណ្ឌជំនួសយើងជា
ព្រះរបស់គេ។ គេបានធ្វើពិធីលោះបាបសម្រាប់ជនជាតិអ៊ីស្រាអែលហើយ។
[14]បុរសជនជាតិអ៊ីស្រាអែល ដែលត្រូវបានសម្លាប់រួមជាមួយស្ត្រីជនជាតិម៉ាឌាននោះ ឈ្មោះស៊ីមរី ជាកូនប្រុសរបស់លោកសាលូវ និងជាមេដឹកនាំរបស់អំបូរមួយនៃ
កុលសម្ព័ន្ធស៊ីម្មាន។[15]រីឯស្ត្រីជនជាតិម៉ាឌាន ដែលត្រូវបានសម្លាប់នោះ ឈ្មោះនាងកូសប៊ីជាកូនស្រីរបស់លោកស៊ើរ ដែលជាមេលើកុលសម្ព័ន្ធមួយ និងជាមេលើគ្រួសារ
មួយនៅក្នុងជនជាតិម៉ាឌាន។
[16]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[17]«ចូរចាត់ទុកជនជាតិម៉ាឌានជាសត្រូវ ហើយវាយប្រហារពួកគេទៅ[18]ដ្បិត ពួកបានចាត់ទុកអ្នកជាខ្មាំងសត្រូវ
ទាំងបោកបញ្ឆោតផង។ ពួកគេបាននាំអ្នកចូលក្នុងសេចក្តីអាក្រក់ក្នុងព្រឹត្តិការណ៍នៅពេអ៊ើរ និងរឿងនាងកូសប៊ី ជាកូនស្រីរបស់មេដឹកនាំជនជាតិម៉ាឌាន ដែលត្រូវបាន
សម្លាប់ក្នុងថ្ងៃនៃគ្រោះកាចក្នុងព្រឹត្តិការណ៍នៅពេអ៊ើរនោះ»។

generated on Wed Sep 10 16:16:32 2025

Numbers 25:1
ស្រុកស៊ីទីម
នេះជាឈ្មោះទីកន្លែងមួយនៅក្នុងស្រុកម៉ូអាប់។
ថ្វាយបង្គំ
នេះជាសកម្មភាពនៃការថ្វាយបង្គំ។
ពេអរ
ពេអរជាឈ្មោះនៃភ្នំមួយ។ សូមមើលការបកប្រែនៅក្នុង ២៣:២៨។
ព្រះអម្ចាស់ព្រះពិរោធយ៉ាងខ្លាំង
ការកើនឡើងនូវកំហឹងរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយ
ដូចជាកំពុងចាប់ផ្តើមឆេះ។ នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ២១:១៩។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ខឹងយ៉ាងខ្លាំង»
Numbers 25:4
ពួកមេដឹកនាំទាំងប៉ុន្មានរបស់ប្រជាជន
សំដៅទៅលើអ្នកដឹកនាំដែលមានកំហុសក្នុងការគោរពបូជារូបព្រះ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត
«មេដឹកនាំទាំងអស់របស់ប្រជាជនដែលមានកំហុសក្នុងការគោរពបូជារូបព្រះ»
ពួកគេហាលថ្ងៃ
នេះមានន័យថា មេដឹកនាំអ៊ីស្រាអែលនឹងសម្លាប់ប្រជាជនទាំងនេះ
ហើយទុកសាកសពរបស់ពួកគេនៅកន្លែងដែលប្រជាជនទាំងអស់អាចមើលឃើញ។
ទៅពួកមេដឹកនាំរបស់ជនអ៊ីស្រាអែល
«ចំពោះមេដឹកនាំអ៊ីស្រាអែលដែលមិនមានកំហុសក្នុងការគោរពបូជារូបព្រះ»
ពេអរ
ពេអរជាឈ្មោះនៃភ្នំមួយ។ សូមមើលការបកប្រែនៅក្នុង ២៣:២៨។
Numbers 25:6
បាននាំស្ត្រីសាសន៍ម៉ាឌានម្នាក់ ចូលមកក្នុងចំណោមគ្រួសាររបស់ខ្លួន
វាបញ្ជាក់ថា គាត់បាននាំនាងចូលក្នុងជំរំរបស់គាត់ដើម្បីរួមមេត្រីជាមួយនាង។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត
«នាំស្ត្រីជនជាតិម៉ាឌានម្នាក់មកជំរំអ៊ីស្រាអែលដើម្បីដេកជាមួយនាង»
នៅមុខលោកម៉ូសេ និងនៅមុខសហគមន៍កូនចៅអ៊ីស្រាអែលទាំងមូល
ត្រង់នេះ «នៅចំពោះមុខ»
ជាសំគាល់ដែលមានន័យថាពួកគេបានឮអំពីវាឬដឹងអំពីវា។
លោកអេឡាសារ
នេះជាឈ្មោះកូនប្រុសរបស់អើរ៉ុន។ សូមមើលការបកប្រែនៅក្នុង ៣:១។
Numbers 25:8
គាត់តាម
«លោកភីនេហាសដើរតាម»
Numbers 25:10
បានបង្វែរកំហឹងរបស់យើងចេញពីកូនចៅអ៊ីស្រាអែល
កំហឹងរបស់ព្រះត្រូវបានគេនិយាយដូចជា
អ្វីមួយដែលអាចត្រូវបានរុញទៅខាងរាងកាយដើម្បីបញ្ឈប់។ ការបកប្រែផ្សេងទៀត
«ធ្វើឱ្យយើងលែងខឹងនឹងប្រជាជនអ៊ីស្រាអែល»
យើងមិនបំផ្លាញកូនចៅអ៊ីស្រាអែលដោយព្រោះកំហឹងរបស់យើងទេ
ព្រះបានមានព្រះបន្ទូលថា
ទ្រង់ដូចជាសត្វសាហាវមួយដែលអាចស៊ីប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត
«យើងមិនបានបំផ្លាញប្រជាជនអ៊ីស្រាអែលដោយកំហឹងដ៏គួរឱ្យភ័យខ្លាចរបស់យើង»
Numbers 25:12
ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា,«មើល៍! យើងប្រទានសម្ព័ន្ធមេត្រីដែលផ្តល់
សន្តិភាពដល់ភីនេហាស.... សម្រាប់ជនជាតិអ៊ីស្រាអែល!
នេះបន្តការនិយាយរបស់ព្រះអម្ចាស់ពីខមុន។
នេះមានដកស្រង់នៅក្នុងសម្រង់សម្តី។
ការដកស្រង់ដោយផ្ទាល់អាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។
ការបកប្រែផ្សេងទៀត
«ដូច្នេះនិយាយទៅកាន់លោកភីនេហាសថាយើងនឹងប្រគល់ដល់គាត់ ...
ប្រជាជនអ៊ីស្រាអែល» ។
Numbers 25:14
ឥឡូវនេះ
នេះប្តូរពីដំណើររឿងសំខាន់ទៅព័ត៌មានប្រវត្តិអំពីនាងស៊ីមរីនិងនាងកូសប៊ី។
ដែលត្រូវបានសម្លាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលភីនេហាសបានសម្លាប់»
ស៊ីមរី....សាលូវ....ស៊ើរ
ទាំងអស់នេះជាឈ្មោះបុរស។
កូសប៊ី
នេះគឺជាឈ្មោះស្ត្រីម្នាក់។
Numbers 25:16
ទាំងបោកបញ្ឆោត ពួកគេ
នាមអរូបី "ការបោកបញ្ឆោត" អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ អេធី:
"ដោយបញ្ឆោតអ្នក"
ពួកគេបាននាំអ្នកចូលក្នុងសេចក្តីអាក្រក់
«ពួកគេបានបញ្ឆោតបញ្ឆួលអ្នក អោយធ្វើអំពើអាក្រក់នេះ»
ក្នុងព្រឹត្តិការណ៍នៅពេអរ .....គ្រោះកាចក្នុងព្រឹត្តិការណ៍នៅពេអរនោះ
ឃ្លាទាំងពីរនេះមានន័យថា រឿងរ៉ាវទាំងនេះបានកើតឡើងនៅភ្នំពេអរ។
ពេអរ
ពេអរជាឈ្មោះភ្នំមួយ។ សូមមើលការបកប្រែនៅក្នុង ២៣:២៨។
ដែលត្រូវបានសម្លាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលភីនេហាសបានសម្លាប់»

26 [1]បន្ទាប់ពីគ្រោះកាចនោះមក ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេ និងលោកអេឡាសារ ជាកូនរបស់បូជាចារ្យអើរ៉ុនថា៖[2]«ចូររាប់ប្រជាជនក្នុង
សហគមន៍ប្រជាជនអ៊ីស្រាអែលទាំងមូល ដោយគិតចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ តាមអំបូររបស់ពួកគេ គឺអស់អ្នកដែលអាចចេញទៅធ្វើសង្គ្រាមបាន»។
[3]ដូច្នេះ លោកម៉ូសេ និងលោកអេឡាសារ ក៏ប្រាប់ពួកគេ នៅវាលទំនាបស្រុកម៉ូអាប់ ដែលនៅក្បែរទន្លេយ័រដាន់ ទល់មុខនឹងក្រុងយេរីខូថា៖[4]«ចូររាប់ចំនួនប្រជាជនដែលមាន
អាយុម្ភៃឆ្នាំឡើងទៅ ដូចដែលព្រះអម្ចាស់បង្គាប់មកលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល ដែលបានចាកចេញពីស្រុកអេស៊ីបមក»។
[5]ពីកុលសម្ព័ន្ធរូបេន ជាកូនច្បងរបស់លោកអ៊ីស្រាអែលគឺ តាមរយៈលោកហេណុកដែលជាកូនប្រុសរបស់លោក កើតបានជាអំបូរហេណុក តាមរយៈលោកលោកប៉ាលូវ
កើតបានជាអំបូរហេលូវ។[6]តាមរយៈលោកហេស្រុន កើតបានជាអំបូរេស្រុន។ តាមរយៈលោកកើមី កើតបានជាអំបូរកើមី។[7]ទាំងនោះជាអំបូរនៃកូនចៅរបស់លោករូបេន មាន
ចំនួនទាំងអស់ ៤៣, ៧៣០ នាក់។
[8]លោកអេលាប ជាកូនប្រុសរបស់លោកប៉ាលូវ។[9]កូនប្រុសរបស់លោកអេលាប គឺលោកនេមូល លោកដាថាន និងលោកអប៊ីរ៉ាម។ លោកដាថាន និងលោកអប៊ីរ៉ាម នេះ
ហើយចូលដៃជាមួយលោកកូរេ ប្រឆាំងលោកម៉ូសេ និងលោកអើរ៉ុន ហើយបះបោរប្រឆាំងនឹងព្រះអម្ចាស់នោះ។
[10]ផែនដីបានបើកមាត់របស់វា លេបពួកគេជាមួយលោកកូរេ នៅពេលដែលអ្នកដើរតាមគាត់ទាំងអស់បានស្លាប់។ នៅពេលនោះភ្លើងបានឆេះបំផ្លាញពួកគេ អស់ពីររយ
ហាសិបនាក់ ទុកជាការព្រមានដល់ប្រជាជន។[11]ប៉ុន្តែ ពូជពង្សរបស់លោកកូរេស្លាប់មិនអស់ទេ។
[12]កូនចៅរបស់លោកស៊ីម្មាន តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកយេមូអែល បានជាអំបូរយេមូអែល តាមរយៈលោកយ៉ាមីន កើតបានជាអំបូរយ៉ាមីន តាមរយៈ
លោកយ៉ាគីន កើតបានជាអំបូរយ៉ាគីន[13]តាមរយៈលោកសេរ៉ាស កើតបានជាអំបូរសេរ៉ាស តាមរយៈលោកសូល កើតបានជាអំបូរសូល។[14]ទាំងនេះជាអំបូររបស់កុលសម្ព័ន្ធ
ស៊ីម្មាន ដែលរាប់បានមាន ២២, ២០០ នាក់។

generated on Wed Sep 10 16:16:32 2025

[15]កូនចៅរបស់លោកកាដ តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកសេផូន កើតបានជាអំបូរសេផូន។ តាមរយៈលោកហាគី កើតបានជាអំបូរហាគី។[16]តាមរយៈលោក
អូសនី កើតបានជាអំបូរអូសនី។ តាមរយៈលោកអេរី កើតបានជាអំបូរអេរី។[17]តាមរយៈលោកអើរ៉ូដ កើតបានជាអំបូរអើរ៉ូដ។ តាមរយៈលោកអើរេលី កើតបានជាអំបូរអើរេលី។
[18]ទាំងនេះជាអំបូររបស់កុលសម្ព័ន្ធកាដ ដែលរាប់បានមាន ៤០, ៥០០ នាក់។
[19]កូនរបស់លោកយូដាមានអ៊ើរ និងលោកអូណាន ក៏ប៉ុន្តែ អ្នកទាំងពីរបានស្លាប់នៅស្រុកកាណាន។[20]កូនចៅឯទៀតៗរបស់លោកយូដា តាមអំបូររបស់ពួកគេមាន៖
តាមរយៈលោកសេឡា កើតបានជាអំបូរសេឡា។ តាមរយៈលោកពេរេស កើតបានជាអំបូរពេរេស។ តាមរយៈលោកសេរ៉ាស កើតបានជាអំបូរសេរ៉ាស។[21]កូនចៅរបស់ពេរេស
តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកហេស្រុន កើតបានជាអំបូរហេស្រុន។ តាមរយៈលោកហាមូល បានជាអំបូរហាមូល។[22]ទាំងនេះជាអំបូររបស់កុលសម្ព័ន្ធយូដា
ដែលរាប់បានមាន ៧៦, ៥០០ នាក់។
[23]កូនចៅរបស់លោកអ៊ីសាខារ តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកថូឡា កើតបានជាអំបូរថូឡា។ តាមរយៈលោកពូវ៉ា កើតបានជាអំបូរពូវ៉ា។[24]តាមរយៈលោកយ៉ាស៊ូប
កើតបានជាអំបូរយ៉ាស៊ូប។ តាមរយៈលោកស៊ីមរ៉ូន កើតបានជាអំបូរស៊ីមរ៉ូន។[25]ទាំងនេះជាអំបូររបស់កុលសម្ព័ន្ធអ៊ីសាខារ ដែលរាប់បានមាន ៦៤, ៣០០ នាក់។
[26]កូនចៅរបស់លោកសាប់យូឡូន តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកសេរ៉ែដ កើតបានជាអំបូរសេរ៉ែដ។ តាមរយៈលោកអេឡូន កើតបានជាអំបូរអេឡូន។
តាមរយៈលោកយ៉ាលាល កើតបានជាអំបូរយ៉ាលាល។[27]ទាំងនេះជាអំបូររបស់កុលសម្ព័ន្ធសាប់យូឡូន ដែលរាប់បានមាន ៦០, ៥០០ នាក់។
[28]កូនចៅរបស់លោកយ៉ូសែប តាមអំបូររបស់ពួកគេ គឺលោកម៉ាណាសេ និងលោកអេប្រាអ៊ីម។[29]កូនចៅរបស់លោកម៉ាណាសេ តាមអំបូររបស់ពួកគេមាន៖
តាមរយៈលោកម៉ាគៀរ កើតបានជាអំបូរម៉ាគៀរ (លោកម៉ាគៀរ គឺលោកកាឡាដ) តាមរយៈលោកកាឡាដ កើតបានជាអំបូរកាឡាដ។
[30]កូនចៅរបស់លោកកាឡាដមាន៖ តាមរយៈលោកអ៊ើរ កើតបានជាអំបូរអ៊ើរ។ តាមរយៈលោកហេឡេក កើតបានជាអំបូរហេឡេក។[31]តាមរយៈលោកអាសរាល កើតបាន
ជាអំបូរអាសរាល។ តាមរយៈលោកស៊ីគែម កើតបានជាអំបូរស៊ីគែម។[32]តាមរយៈលោកសេមីដា កើតបានជាអំបូរសេមីដា។ តាមរយៈលោកហេភើរ កើតបានជាអំបូរហេភើរ។
[33]លោកស្លូផិហាតដែលត្រូវជាកូនរបស់លោកហេភើរ គ្មានកូនប្រុសទេ គឺមានតែកូនស្រី។ កូនស្រីរបស់លោកស្លូផិហាតមាន៖ នាងម៉ៃសឡា នាងណូហា នាងហុកឡា
នាងមីលកា និងនាងធើសា។[34]ទាំងនេះជាអំបូររបស់កុលសម្ព័ន្ធម៉ាណាសេ ដែលរាប់បានមាន ៥២, ៧០០ នាក់។
[35]កូនចៅរបស់លោកអេប្រាអ៊ីម តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកស៊ូថេឡា កើតបានជាអំបូរស៊ូថេឡា។ តាមរយៈលោកបេគើរ កើតបានជាអំបូរបេគើរ។
តាមរយៈលោកថាហាន កើតបានជាអំបូរថាហាន។[36]កូនចៅរបស់លោកស៊ូថេឡាមាន៖ តាមរយៈលោកអេរ៉ាន កើតបានជាអំបូរអេរ៉ាន។[37]ទាំងនេះជាអំបូររបស់កុលសម្ព័ន្ធ
អេប្រាអ៊ីម ដែលរាប់បានមាន ៣២, ៥០០ នាក់។
[38]កូនចៅរបស់លោកបេនយ៉ាមីន តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកបេឡា កើតជាបានជាអំបូរបេឡា។ តាមរយៈលោកអាសបែល កើតបានជាអំបូរអាសបែល។
តាមរយៈលោកអេហ៊ីរ៉ាម កើតបានជាអំបូរអេហ៊ីរ៉ាម។[39]តាមរយៈលោកស៊ូផាម កើតបានជាអំបូរស៊ូផាម។ តាមរយៈលោកហ៊ូផាម កើតបានជាអំបូរហ៊ូផាម។[40]កូនរបស់លោក
បេឡាមានលោកអើឌ និងលោកណាម៉ាន។ តាមរយៈលោកអើឌ កើតបានជាអំបូរអើឌ។ តាមរយៈលោកណាម៉ាន កើតបានជាអំបូរណាម៉ាន។[41]ទាំងនេះជាកូនចៅរបស់
កុលសម្ព័ន្ធបេនយ៉ាមីន តាមអំបូររបស់ពួកគេ ដែលរាប់បានមាន ៤៥, ៦០០ នាក់។
[42]កូនចៅរបស់លោកដាន់ តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកហ៊ូស៊ីម កើតបានជាអំបូរហ៊ូស៊ីម។ អ្នកទាំងនោះជាកូនចៅរបស់លោកដាន់តាមអំបូររបស់ពួកគេ។
[43]សរុបអំបូរកូនចៅរបស់លោកហ៊ូស៊ីម ដែលរាប់បានមាន ៦៤, ៤០០ នាក់។
[44]កូនចៅរបស់លោកអេស៊ើរ តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកយីមណា កើតបានជាអំបូរយីមណា។ តាមរយៈលោកយីសវ៉ា កើតបានជាអំបូរយីសវ៉ី។
តាមរយៈលោកបេរា កើតបានជាអំបូរបេរា។[45]កូនចៅរបស់លោកបេរ៉ាមាន៖ តាមរយៈលោកហេប៊ើរ កើតបានជាអំបូរហេប៊ើរ។ តាមរយៈលោកម៉ាល់គាល កើតបានជាអំបូរ
ម៉ាល់គាល។[46]កូនស្រីរបស់លោកអេស៊ើរ គឺនាងសេរ៉ា។[47]ទាំងនេះជាកូនចៅរបស់លោកអេស៊ើរ តាមអំបូររបស់ពួកគេ ដែលរាប់បានមាន ៥៣, ៤០០ នាក់។
[48]កូនចៅរបស់លោកណែបថាលី តាមអំបូររបស់ពួកគេមាន៖ តាមរយៈលោកយ៉ាស៊ាល កើតបានជាអំបូរយ៉ាស៊ាល។ តាមរយៈលោកគូនី កើតបានជាអំបូរគូនី។
[49]តាមរយៈលោកយេស៊ើរ កើតបានជាអំបូរយ៉ាស៊ើរ។ តាមរយៈលោកស៊ីឡិម កើតបានជាអំបូរស៊ីឡិម។[50]ទាំងនេះជាកូនចៅរបស់លោកណែបថាលី តាមអំបូររបស់ពួកគេ
ដែលរាប់បានមាន ៤៥, ៤០០ នាក់។
[51]ចំនួនសរុបរបស់ជនជាតិអ៊ីស្រាអែល ដែលបានរាប់បាន មានទាំងអស់ ៦០១, ៧៣០ នាក់។
[52]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖[53]«ត្រូវចែកទឹកដីឲ្យមនុស្សទាំងនេះទុកជាកេរមតក តាមចំនួនឈ្មោះរបស់ពួកគេ។
[54]កុលសម្ព័ន្ធណាដែលធំជាងគេត្រូវចែកមរតកឲ្យច្រើន ហើយកុលសម្ព័ន្ធដែលតូចជាងគេ ត្រូវចែកឲ្យតិចដែរ។ អ្នកត្រូវចែកមរតកឲ្យគ្រប់គ្រួសារ តាមចំនួនប្រុសៗដែល
បានរាប់។[55]ប៉ុន្តែ ការបែងចែកទឹកដីនេះត្រូវធ្វើឡើងដោយចាប់ឆ្នោត។ គឺពួកគេត្រូវបានទទួលទឹកដី ដែលបានបែងចែកតាមកុលសម្ព័ន្ធនៃបុព្វបុរសរបស់ខ្លួន។
[56]មរតករបស់ពួកគេនោះត្រូវបែងចែកតាមអំបូរធំ និងអំបូរតូច គឺត្រូវចែកឲ្យពួកគេដោយការចាប់ឆ្នោត»។
[57]ចំណែក អំបូររបស់ពួកលេវីដែលបានរាប់តាមអំបូររបស់ពួកគេមានដូចតទៅ៖ តាមរយៈលោកគើរសុន កើតបានជាអំបូរគើសុន។ តាមរយៈលោកកេហាត់
កើតបានជាអំបូរកេហាត់។ តាមរយៈលោកម៉្រារី កើតបានជាពូជអំបូរម៉្រារី។[58]អំបូររបស់ពួកលេវីមាន អំបូរលីបនី អំបូរហេប្រូន អំបូរម៉ាស់លី អំបូរមូស៊ី និងអំបូរកូរេ។ លោក
កេហាត់ត្រូវជាដូនតារបស់លោកអាំរ៉ាម។[59]ភរិយារបស់លោកអាំរ៉ាមឈ្មោះនាងយ៉ូកិបិត ជាកូនរបស់លោកលេវីដែលកើតនៅស្រុកអេស៊ីប។ នាងបង្កើតកូនជូនលោកអាំរ៉ាម
បីនាក់ គឺលោកអើរ៉ុន លោកម៉ូសេ និងនាងម៉ារាម ជាបងស្រីរបស់ពួកគេ។
[60]លោកអើរ៉ុនបង្កើតបានលោកណាដាប់ លោកអប៊ីហ៊ូវ លោកអេឡាសារ និងលោកអ៊ីថាម៉ារ។[61]លោកណាដាប់ និងលោកអប៊ីហ៊ូវ បានស្លាប់ នៅពេលពួកគេយកភ្លើងមិន
សក្ការៈទៅថ្វាយព្រះអម្ចាស់។[62]ចំនួនប្រុសៗដែលគេរាប់បានមានចំនួន ២៣, ០០០ នាក់ គឺប្រុសៗទាំងអស់ដែលមានអាយុមួយខែឡើងទៅ ។ ប៉ុន្តែ ពួកគេមិនត្រូវបានរាប់
បញ្ចូលជាមួយកូនចៅអ៊ីស្រាអែលទេ ព្រោះពួកគេមិនបានទទួលកេរមតក ក្នុងចំណោមប្រជាជនអ៊ីស្រាអែលឡើយ។
[63]ទាំងនេះជាអស់អ្នកដែលលោកម៉ូសេ និងបូជាចារ្យអេឡាសារបានរាប់។ ពួកគេបានរាប់ចំនួនប្រជាជនអ៊ីស្រាអែលនៅវាលទំនាបស្រុកម៉ូអាប់ ក្បែរទន្លេយ័រដាន់ ទល់មុខ
នឹងក្រុងយេរីខូ។[64]ប៉ុន្តែ ក្នុងចំណោម ពួកកូនចៅអ៊ីស្រាអែលទាំងនេះ គ្មាននរណាម្នាក់ដែលលោកម៉ូសេ និងបូជាចារ្យអើរ៉ុន បានរាប់លើកមុន នៅទីរហោស្ថានស៊ីណៃ
ឡើយ។
[65]ដ្បិត ព្រះអម្ចាស់បានមានព្រះបន្ទូលថា ពួកគេនឹងត្រូវស្លាប់ក្នុងទីរហោស្ថានទាំងអស់គ្នា។ អស់អ្នកដែលបានរាប់នេះ មិនមែនជាអ្នកដែលនៅសល់ពីចំណោមពួកគេទេ
លើកលែងតែលោកកាលែប ជាកូនរបស់លោកយេភូនេ និងលោកយ៉ូស្វេ ជាកូនរបស់លោកនូនប៉ុណ្ណោះ។

Numbers 26:1
ចូររាប់ប្រជាជនក្នុងសហគមន៍ទាំងអស់
ពួកគេគ្រាន់តែរាប់បុរសប៉ុណ្ណោះមិនមែនស្ត្រីទេ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «រាប់បុរសទាំងអស់នៃសហគមន៍»
ចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ
«អាយុ២០ឆ្នាំឡើងទៅ»
Numbers 26:3
ក៏ប្រាប់ពួកគេ
«បាននិយាយទៅកាន់មេដឹកនាំអ៊ីស្រាអែល»
នៅវាលទំនាប
ធម្មតាជាតំបន់លាតនៃផ្ទៃដីធំ។
ដែលមានអាយុម្ភៃឆ្នាំឡើងទៅ
«អាយុ២០ឆ្នាំឡើងទៅ»
Numbers 26:5
ព័ត៌មានទូទៅ៖

generated on Wed Sep 10 16:16:32 2025

មេដឹកនាំជនជាតិអ៊ីស្រាអែល រាប់បុរសដែលមានអាយុ ២០ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
ជាកូនច្បងរបស់លោកអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើបុរសដែលត្រូវបានគេស្គាល់ថាជាយ៉ាកុប។
កូនប្រុសរបស់គាត់
ពាក្យ «របស់គាត់» សំដៅទៅលើរូបេន។
Numbers 26:8
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
អេលាប...ដាថាន....អប៊ីរ៉ាម
បកប្រែឈ្មោះបុរសទាំងនេះតាមរបៀបដែលបានធ្វើនៅក្នុង 16:1។
Numbers 26:10
ផែនដីបានបើកមាត់របស់វា លេបពួកគេ
នៅទីនេះ ផែនដីត្រូវបានគេនិយាយដូចជាមនុស្សបើកមាត់ហើយញ៉ាំអ្វីមួយ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានធ្វើអោយផែនដីបែកជាចំហ
ហើយពួកបុរសក៏ដួលនៅក្នុងរណ្តៅ»
ភ្លើងបានឆេះបំផ្លាញពួកគេ អស់ពីររយហាសិបនាក់
នៅទីនេះ ភ្លើងគេនិយាយដូចជា វាជាសត្វដ៏ធំដែលលេបត្របាក់អ្វីមួយ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានបង្កអោយមានភ្លើងឆេះមនុស្ស ២៥០ នាក់»
ពូជពង្សរបស់លោកកូរេ
«ក្រុមគ្រួសារកូរេទាំងអស់»
ស្លាប់
«បញ្ចប់»
Numbers 26:12
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:15
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:19
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:23
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។ (សូមមើល និងtranslate-
numbers)
Numbers 26:26
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:28
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:30
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:33
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:35
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។ (សូមមើល និងtranslate-
numbers)
ទាំងនេះគឺជាពូជអំបូរលោកយ៉ូសែប
ពាក្យថា «ទាំងនេះ»
សំដៅទៅលើបុរសទាំងអស់ដែលចុះមកពីកូនប្រុសរបស់យ៉ូសែប
គឺលោកអេប្រាអិមនិងម៉ាណាសេ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «
ទាំងនេះគឺជាកូនចៅរបស់យ៉ូសែបបានមកពីកូនប្រុសរបស់គាត់ម៉ាណាសេនិងលោកអេប្រាអ៊ីម»
ដែលបានរាប់នៃអំបូរពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេបានរាប់ចំនួនពួកគេក្នុងអំបូរនីមួយៗ»
Numbers 26:38
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។ (សូមមើល និងtranslate-
numbers)
Numbers 26:42
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:44
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:48
ព័ត៌មានទូទៅ៖
មេដឹកនាំជនជាតិអ៊ីស្រាអែលរាប់បុរសដែលមានអាយុ ២០ ឆ្នាំឡើងទៅ
តាមកុលសម្ព័ន្ធនិងក្រុមគ្រួសាររបស់គេ។
Numbers 26:51
ដែលបានរាប់បាន មានទាំងអស់
«ចំនួនសរុប»
៦០១,៧៣០ នាក់
«ប្រាំមួយរយមួយពាន់ និងប្រាំពីររយសាមសិប»
Numbers 26:52
ត្រូវចែកទឹកដី
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែបែងចែកដី»
មនុស្សទាំងនេះ
នេះសំដៅទៅលើបុរសទាំងអស់ដែលត្រូវបានគេរាប់នៅក្នុងត្រកូលរបស់ពួកគេ
ដោយចាប់ផ្តើមនៅ ២៦:៥។
តាមចំនួនឈ្មោះរបស់ពួកគេ
«តាមចំនួនមនុស្សក្នុងអំបូរនីមួយៗ»
Numbers 26:54
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ត្រូវចែកមរតក
នៅក្នុងអត្ថបទនេះពាក្យថា «មរតក» សំដៅទៅលើដីដែលទទួលមរតក។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ផ្តល់ដីបន្ថែមទៀតជាមរតក»
ដែលបានរាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលមេដឹកនាំអ៊ីស្រាអែលបានរាប់»
ការបែងចែកទឹកដី
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែបែងចែកដី
ដោយចាប់ឆ្នោត
«ដោយការបោះឆ្នោត»

generated on Wed Sep 10 16:16:32 2025

បានបែងចែក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកនឹងបែងចែកវា»
គឺត្រូវចែកឲ្យពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយអ្នកត្រូវតែចែកចាយដីដល់ពួកគេ»
Numbers 26:57
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមអំបូរលេវី។
លោកម៉ូសេរាប់ពួកលេវីដាច់ដោយឡែកពីកុលសម្ព័ន្ធឯទៀតៗ
ព្រោះពួកគេមិនបានទទួលដីអ្វីទេ។
បានរាប់តាមអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មេដឹកនាំក៏រាប់ត្រកូលតាមអំបូរ»
គើរសុន.....កេហាត់.....ម៉្រារី....អាំរ៉ាម
បកប្រែឈ្មោះបុរសទាំងនេះតាមរបៀបដែលបានធ្វើនៅក្នុង ៣:១៧។
នាងបង្កើតកូនជូនលោកអាំរ៉ាម
«នាងនិងលោកអាំរ៉ាមមានកូន»
Numbers 26:60
លោកណាដាប់.....លោកអប៊ីហ៊ូវ.....លោកអ៊ីថាម៉ារ
បកប្រែឈ្មោះបុរសទាំងនេះតាមរបៀបដែលបានធ្វើក្នុង ៣: ១ ។
ពួកគេយកភ្លើងមិនសក្ការៈទៅថ្វាយព្រះអម្ចាស់
ត្រង់នេះពាក្យ «ភ្លើង» ត្រូវបានប្រើដើម្បីសំដៅទៅលើ« ការដុតធូប» ។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៣:៣។ ការបកប្រែផ្សេងទៀត
«ពួកគេបានដុតគ្រឿងក្រអូបថ្វាយដល់ព្រះជាម្ចាស់
តាមរបៀបដែលទ្រង់មិនសព្វព្រះហឫទ័យ»
អ្នកដែលបានរាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលមេដឹកនាំបានរាប់»
ចំនួន ២៣,០០០ នាក់
«២៣,០០០»
អាយុមួយខែឡើងទៅ
«អាយុមួយខែឡើងទៅ»
"អាយុមួយខែឡើងទៅ"
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែមេដឹកនាំមិនបានរាប់ពួកគេទេ»
ព្រោះពួកគេមិនបានទទួលកេរមតក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ នៅទីនេះ « មរតក»
សំដៅទៅលើដីដែលទទួលមរតក។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ពីព្រោះព្រះអម្ចាស់មានបន្ទូលថា
ពួកគេនឹងមិនទទួលដីជាមរតកទេ»
Numbers 26:63
ជាអស់អ្នកដែលលោកម៉ូសេ និងបូជាចារ្យអេឡាសារបានរាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលលោកម៉ូសេនិងបូជាចារ្យអេឡាសារបានរាប់»
គ្មាននរណាម្នាក់
«គ្មានមនុស្សណាទេ»
នរណាម្នាក់ដែលលោកម៉ូសេ និងបូជាចារ្យអើរ៉ុន បានរាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលលោកម៉ូសេនិងបូជាចារ្យអើរ៉ុនបានរាប់»
នៅពេលដែលកូនចៅអ៊ីស្រាអែលត្រូវបានរាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលពួកគេរាប់កូនចៅអ៊ីស្រាអែល»
Numbers 26:65
អស់អ្នកដែលបានរាប់នេះ មិនមែនជាអ្នកដែលនៅសល់ពីចំណោមពួកគេទេ លើកលែងតែ
ពាក្យថា «ពួកគេ»
សំដៅទៅលើប្រជាជនទាំងអស់ដែលត្រូវបានគេរាប់នៅវាលរហោស្ថានស៊ីណៃ។
នេះអាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«មនុស្សតែម្នាក់ដែលនៅរស»
កូនរបស់លោកយេភូនេ
យេភូនេ គឺជាឪពុករបស់លោកកាលែប។ សូមមើលការបកប្រែនៅក្នុង ១៣:៥។
កូនរបស់លោកនូន
នូនជាឪពុករបស់លោកយ៉ូស្វេ។ សូមមើលការបកប្រែនៅក្នុង ១១:២៨។

27 [1]ពេលនោះ ពួកកូនស្រីរបស់លោកស្លូធិហាតនាំគ្នាចូលមកជួបលោកម៉ូសេ។ លោកស្លូធិហាតជាកូនប្រុសរបស់លោកហេភើរ លោកហេភើរជាកូនប្រុសរបស់លោក
កាឡាដ លោកកាឡាដជាកូនប្រុសរបស់លោកម៉ាកៀរ លោកម៉ាកៀរជាកូនប្រុសរបស់លោកម៉ាណាសេ ក្នុងអំបូរម៉ាណាសេដែលត្រូវជាកូនប្រុសរបស់លោក
យ៉ូសែប។ ទាំងនេះជាឈ្មោះរបស់កូនស្រីគាត់ គឺនាងម័សឡា នាងណូហា នាងហុកឡា នាមីលកា និងនាងធើសា។
[2]ពួកនាងចូលមកឈរនៅចំពោះលោកម៉ូសេ បូជាចារ្យអេឡាសារ ព្រមទាំងពួកមេដឹកនាំ និងនៅចំពោះសហគមន៍អ៊ីស្រាអែលទាំងមូល នៅមាត់ទ្វារត្រសាលប្រជុំ។ ពួកនាង
ពោលថា៖[3]«ឪពុករបស់យើងខ្ញុំបានស្លាប់ នៅទីរហោស្ថាន តែគាត់ពុំបានចូលដៃជាមួយបក្សពួករបស់លោកកូរេដែលងើបបះបោរប្រឆាំងនឹងព្រះអម្ចាស់ឡើយ គឺគាត់ស្លាប់
ព្រោះតែបាបរបស់គាត់ផ្ទាល់ ហើយគាត់មិនមានកូនប្រុសទេ។
[4]ហេតុអ្វីបានជាឈ្មោះរបស់ឪពុកយើងខ្ញុំត្រូវដកចេញពីចំណោមសមាជិកនៃអំបូររបស់គាត់ ព្រោះតែគាត់គ្មានកូនប្រុសនោះមែនទេ? ហេតុនេះ សូមប្រគល់ដីមួយចំណែក
ឲ្យយើងខ្ញុំ នៅក្នុងចំណោមបងប្អូនរបស់ឪពុកយើងខ្ញុំផង»។[5]ដូច្នេះ លោកម៉ូសេបាននាំករណីរបស់ពួកនាងទៅទូលព្រះអម្ចាស់។
[6]ព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកម៉ូសេថា៖[7]«កូនស្រីរបស់ស្លូធិហាតនិយាយត្រូវមែន។ អ្នកត្រូវប្រគល់ដីក្នុងចំណោមបងប្អូនរបស់ឪពុកពួកនាង ឲ្យពួកនាងទុកជា
មរតកផង ហើយអ្នកត្រូវប្រាកដថា មរតករបស់ឪពុកពួកនាង នឹងត្រូវប្រគល់ឲ្យពួកនាង។[8]អ្នកត្រូវប្រាប់កូនចៅអ៊ីស្រាអែលដូចតទៅ៖ «ប្រសិនបើ បុរសណាម្នាក់ស្លាប់ទៅ
តែគ្មានកូនប្រុសទេ ត្រូវប្រគល់មរតករបស់អ្នកនោះទៅឲ្យកូនស្រីរបស់គាត់។
[9]ប្រសិនបើ គាត់គ្មានកូនស្រីទេ ត្រូវប្រគល់មរតកទៅឲ្យបងប្អូនរបស់គាត់។[10]ប្រសិនបើ គាត់គ្មានបងប្អូនទេ ត្រូវប្រគល់មរតកឲ្យទៅបងប្អូនឪពុកគាត់។[11]ប្រសិនបើ ឪពុក
របស់គាត់គ្មានបងប្អូនទេ ត្រូវប្រគល់មរតកនោះទៅឲ្យសាច់ញាតិណាម្នាក់ ដែលជិតជាងគេក្នុងអំបូររបស់គាត់ គឺអ្នកនោះហើយដែលត្រូវទទួលមរតកនេះ។ សេចក្តីនេះ ត្រូវ
ទុកជាច្បាប់បញ្ញត្តិសម្រាប់ប្រជាជនអ៊ីស្រាអែល ដូចដែលព្រះអម្ចាស់បានបង្គាប់មកខ្ញុំ»។
[12]ព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកម៉ូសេថា៖ «ចូរឡើងទៅលើភ្នំអាបារីម ហើយសម្លឹងមើលស្រុកដែលយើងប្រគល់ឲ្យប្រជាជនអ៊ីស្រាអែល។[13]បន្ទាប់ពី អ្នកមើល
ឃើញស្រុកនេះហើយ អ្នកនឹងត្រូវទៅជួបជុំនឹងសាច់ញាតិរបស់អ្នកវិញ ដូចអើរ៉ុនជាបងរបស់អ្នកដែរ។[14]ការនេះព្រោះតែអ្នកទាំងពីរបានបះបោរប្រឆាំងនឹងបញ្ជារបស់
យើងនៅទីរហោស្ថានស៊ីន។ នៅទីនោះ ពេលដែលមានទឹកចេញពីថ្មមក ដោយសារតែអ្នកខឹង អ្នកមិនបានលើកយើងជាបរិសុទ្ធនៅចំពោះភ្នែក
អ្នកនៅក្នុងសហគមន៍ទាំងមូលឡើយ»។ គឺជាទឹកមេរីបា នៅស្រុកកាដេស ក្នុងទីរហោស្ថានស៊ីន។
[15]បន្ទាប់មក លោកម៉ូសេទូលព្រះអម្ចាស់ ហើយទូលថា៖[16]«សូមព្រះអម្ចាស់ ជាព្រះនៃវិញ្ញាណរបស់មនុស្សទាំងអស់ មេត្តាតែងតាំងមនុស្សម្នាក់ឲ្យដឹកនាំសហគមន៍ផង។[17]គឺ
ជាអ្នកដែលនឹងចេញទៅ ហើយមកវិញនៅមុខពួកគេ ជាអ្នកដែលនាំពួកគេចេញទៅ ហើយនាំពួកគេត្រឡប់មកវិញ ដើម្បីកុំឲ្យសហគមន៍របស់ព្រះអង្គប្រៀបបាននឹងហ្វូង
ចៀម ដែលគ្មានគង្វាលនោះឡើយ»។
[18]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖ «ចូរនាំយ៉ូស្វេ ជាកូនរបស់នូន ជាមនុស្សដែលមានវិញ្ញាណរបស់យើងនៅជាមួយមក ហើយដាក់ដៃរបស់អ្នកលើគាត់។[19]ចូរ
នាំគាត់ទៅឈរនៅមុខបូជាចារ្យអេឡាសារ និងនៅចំពោះមុខសហគមន៍ទាំងមូល ហើយបង្គាប់គាត់ នៅចំពោះភ្នែករបស់ពួកគេ។
[20]ចូរផ្ទេរអំណាចរបស់អ្នកមួយចំណែកដល់គាត់ ដើម្បីឲ្យសហគមន៍អ៊ីស្រាអែលទាំងមូលស្តាប់បង្គាប់គាត់។[21]គាត់នឹងទៅនៅមុខបូជាចារ្យអេឡាសារ ដើម្បីឲ្យលោក
អេឡាសារបានស្វែងរកបំណងព្រះហឫទ័យរបស់យើងសម្រាប់គាត់ តាមរយៈការសម្រេចចិត្តរបស់យូរីម។ គឺតាមបង្គាប់របស់គាត់ប្រជាជននឹងចេញទៅ ហើយត្រឡប់មកវិញ
ទាំងយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលទាំងអស់ដែលនៅជាមួយគាត់ គឺសហគមន៍ទាំងមូល»។

generated on Wed Sep 10 16:16:32 2025

[22]ដូច្នេះ លោកម៉ូសេក៏ធ្វើតាមដែលព្រះអម្ចាស់បង្គាប់មកគាត់។ គាត់បាននាំលោកយ៉ូស្វេមកឈរនៅចំពោះមុខបូជាចារ្យអេឡាសារ និងសហគមន៍ទាំងមូល។
[23]គាត់បានដាក់ដៃលើលោកយ៉ូស្វេ ហើយបង្គាប់ទៅលោកយ៉ូស្វេ ដូចដែលព្រះអម្ចាស់បានបង្គាប់គាត់ឲ្យធ្វើ។

Numbers 27:1

ពេលនោះ ពួកកូនស្រីរបស់លោកស្លូធិហាតនាំគ្នាចូលមកជួបលោកម៉ូសេ

កូនស្រីរបស់ស្លូធិហាតជាកូនរបស់លោកហេភើរ

លោកហេភើរជាកូនរបស់លោកកាឡាដ លោកកាឡាដជាកូនរបស់លោកម៉ាកៀរ

លោកម៉ាកៀរជាកូនរបស់លោកម៉ាណាសេ

ក្នុងអំបូរម៉ាណាសេដែលត្រូវជាកូនរបស់យ៉ូសែបបានមកជួបលោកម៉ូសេ។

នេះប្រាប់យើងពីពង្សាវតានៃស្លូធិហាត។

លោកស្លូធិហាតជាកូនប្រុសរបស់លោកហេភើរ .....នាងម៉សឡា នាងណូហា នាងហុកឡា នាមីលកា និងនាងធើសា

ឈ្មោះទាំងនេះបានបកប្រែដូចនៅក្នុង២៦:៣៣។

កាឡាដ.....ម៉ាកៀរ

ឈ្មោះទាំងនេះបានបកប្រែដូចនៅក្នុង២៦:២៩។

Numbers 27:2

ពួកនាងចូលមកឈរ

«ពួកកូនស្រីរបស់លោកស្លូធិហាតបានឈរ»

គាត់ពុំបានចូលដៃជាមួយបក្សពួករបស់លោកកូរេដែលងើបបះបោរប្រឆាំងនឹងព្រះអម្ចាស់ឡើយ

ប្រជាជននៅកូរេប្រមូលផ្តុំគ្នាហើយបះបោរប្រឆាំងនឹងព្រះអម្ចាស់។

ព្រះអម្ចាស់បានធ្វើអោយពួកគេស្លាប់ ព្រោះតែអំពើបាបរបស់ពួកគេ។

អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត

«បានស្លាប់ដោយសារពួកគេស្ថិតនៅក្នុងចំណោមអ្នកដើរតាមលោកកូរេដែលបានបះបោរប្រឆាំងនឹងព្រះអម្ចាស់»

ព្រោះតែបាបរបស់គាត់ផ្ទាល់

ខ្សែក មកថ្វាយព្រះអម្ចាស់ ទុកជាតង្វាយលោះបាប សម្រាប់យើងខ្ញុំទាំងអស់គ្នា នៅចំពោះព្រះអម្ចាស់»។[51]លោកម៉ូសេ និងបូជាចារ្យអេឡាសារ ក៏ទទួលយកមាស និង
គ្រឿងអលង្ការដែលធ្វើដោយដៃទាំងអស់ពីពួកគេ។
[52]មាសដែលពួកមេបញ្ជាការកងពាន់ និងមេបញ្ជាការកងរយ យកមកថ្វាយព្រះអម្ចាស់ មានទម្ងន់ទាំងអស់ ១៦, ៧៥០ សេកែល។[53]រីឯពលទាហានវិញ ម្នាក់ៗបានយក
ជយភណ្ឌទុកសម្រាប់ខ្លួនឯងផ្ទាល់។[54]លោកម៉ូសេ និងបូជាចារ្យអេឡាសារ បានទទួលមាសរបស់ពួកមេបញ្ជាការកងពាន់ និងមេបញ្ជាការកងរយ។ ពួកលោកបានយកទៅ
ដាក់នៅក្នុងត្រសាលប្រជុំទុកជាទីរំឭករបស់ជនជាតិអ៊ីស្រាអែល នៅចំពោះព្រះអង្គ។

Numbers 31:1

ចូរសងសឹកចំពោះជនជាតិម៉ាឌាន សម្រាប់អ្វីដែលពួកគេបានធ្វើចំពោះជនជាតិអ៊ីស្រាអែលដែរ

ព្រះអម្ចាស់បានដាក់ទោសជនជាតិម៉ាឌានចំពោះការបញ្ឆោះបញ្ចូលជនជាតិអ៊ីស្រាអែលឲ្យប្រព្រឹត្តអំពើបាប

អ្នកនឹងស្លាប់ ហើយនឹងបានទៅជួបជុំបងប្អូនរបស់អ្នក

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ នេះជាវិធីគួរសមដើម្បីបញ្ជាក់ថា

ដល់ពេលដែលលោកម៉ូសេត្រូវស្លាប់ហើយវិញ្ញាណរបស់គាត់ត្រូវទៅកន្លែងដែលបុព្វបុរសរបស់គាត់បានទៅ

Numbers 31:3

ចូរឲ្យប្រុសៗខ្លះក្នុងចំណោមអ្នករាល់គ្នារៀបចំខ្លួនប្រដាប់អាវុធសម្រាប់ធ្វើសង្គ្រាម

ផ្តល់អាវុធដល់បុរសខ្លះរបស់អ្នក

ចេញទៅវាយប្រហារជនជាតិម៉ាឌាន ដើម្បីសម្រេចការសងសឹករបស់ព្រះអម្ចាស់លើពួកគេ

ទៅប្រយុទ្ធនឹងជនជាតិម៉ាឌានហើយដាក់ទណ្ឌកម្មពួកគេចំពោះអ្វីដែលពួកគេបានធ្វើមកលើអ៊ីស្រាអែល

មួតពាន់នាក់.....មួយម៉ឺនពីរពាន់នាក់

«១,០០០.....១២,០០០»

ជនជាតិអ៊ីស្រាអែល មួយពាន់និងមនុស្សប្រុសរាប់ពាន់

«បុរសជាច្រើនរបស់អ៊ីស្រាអែល»

ក្នុងមួយកុលសម្ព័ន្ធមួយពាន់នាក់ សម្រាប់ធ្វើសង្គ្រាមនោះ

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«កុលសម្ព័ន្ធនីមួយៗបានបញ្ជូនបុរស ១.០០០ នាក់ទៅធ្វើសង្គ្រាម»

គឺមានទាហានមួយម៉ឺនពីរពាន់នាក់

កុលសម្ព័ន្ធទាំង ១២បានបញ្ជូនបុរសរួមទាំងកុលសម្ព័ន្ធលេវី។

ពួកគេទាំងអស់បានបញ្ជូនបុរស ១.០០០ នាក់ទៅក្នុងសមរភូមិ។

Numbers 31:6

ព្រះបាទស៊ីរ ព្រះបាទហើរ និងព្រះបាទរេបា

ទាំងនេះជាឈ្មោះរបស់ស្តេចនៃស្រុកម៉ាឌាន។

លោកបាឡាម ជាកូនរបស់លោកបេអ៊រ

Numbers 31:9

ពួកគេបានយករបស់ទាំងនោះទុកជយភណ្ឌ

«ពួកគេបានយកទ្រព្យសម្បត្តិរបស់ពួកម៉ាឌានជារបស់គេផ្ទាល់»

ពួកគេបានដុតទីក្រុង និងជំរំទាំងអស់របស់ពួកគេ ដែលពួកគេកំពុងរស់នៅចោលផងដែរ

ជាកន្លែងដែលពួកម៉ាឌានរស់នៅនិងជំរំរបស់ពួកម៉ាឌានទាំងអស់»

Numbers 31:11

ពួកគេបានប្រមូលយក

«កងទ័ពអ៊ីស្រាអែលបានយក»

ជយភណ្ឌ

នេះសំដៅទៅលើទំនិញ

សម្ភារៈដែលពួកគេរកបានពីការសម្លាប់បុរសជនជាតិម៉ាឌាន។

នៅវាលទំនាប

តំបន់ដ៏ធំមួយនៃដីធំល្វឹងល្វើយ។

generated on Wed Sep 10 16:16:32 2025

Numbers 31:13
ពួកមេបញ្ជាការកងពាន់
ទាំងនេះ គឺជាមេដឹកនាំយោធាដែលបានបញ្ជាលើបុរសជាង ១.០០០
នាក់ប៉ុន្តែមានបុរសតិចជាង ១ម៉ឺននាក់។
កងពាន់.....កងរយ
ពាក្យ «ទាហាន» ត្រូវបានយល់។ ការបកប្រែផ្សេងទៀត «ទាហានរាប់ពាន់នាក់ ...
នៃទាហានរាប់រយនាក់»
មេបញ្ជាការកងរយ
ទាំងនេះ គឺជាមេដឹកនាំយោធាដែលបានបញ្ជាលើបុរសជាង ១០០នាក់
ប៉ុន្តែមានបុរសតិចជាង ១០០០នាក់។
ហេតុអ្វីបានជាអ្នករាល់គ្នាទុកជីវិតឲ្យស្ត្រីទាំងនេះ?
ច្បាប់នេះមានភាពច្បាស់លាស់ចំពោះអ្នកណាដែលនឹងត្រូវអនុញ្ញាតឱ្យរស់នៅ។
កងទ័ពបានរំលោភច្បាប់ដោយអនុញ្ញាតឱ្យស្ត្រីនិងកុមារទាំងអស់រស់នៅ។
នេះជាការស្តីបន្ទោសដល់មេដឹកនាំកងទ័ព។
Numbers 31:16
មើល៍!
នេះសំដៅទៅលើការស្តាប់
និងការយល់ពីអ្វីដែលអ្នកនិយាយកំពុងប្រាប់ដល់ទស្សនិកជនរបស់ពួកគេ។
បានរួមរស់ជាមួយប្រុសៗ
មានទំនាក់ទំនងផ្លូវភេទជាមួយបុរសម្នាក់។
Numbers 31:18
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់មេបញ្ជាការកងទ័ពអ៊ីស្រាអែលអំពីការស្អាតស្អំនៅចំពោះព្រះ
ដែលមិនធ្លាប់រួមដំណេកជាមួយបុរសណាសោះ
នេះសំដៅទៅលើក្មេងស្រីដែលជាស្ត្រីព្រហ្មចារី។
ក្នុងចំណោមអ្នករាល់គ្នា
លោកម៉ូសេចង់សំដៅទៅលើអ្នកណាដែលបានច្បាំងក្នុងសមរភូមិមិនត្រឹមតែមេបញ្ជាការប៉ុណ្ណោះ។
ត្រូវធ្វើពិធីជម្រះខ្លួនរបស់អ្នក
ពួកគេត្រូវតែស្អាតស្អំខាងវិញ្ញាណម្តងទៀតមុនពេលចូលជំរំ។
វត្ថុទាំងប៉ុន្មានធ្វើពីស្បែកសត្វ និងពីរោមពពែ ព្រមទាំងអ្វីៗទាំងអស់ដែលធ្វើពីឈើដែរ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្វីគ្រប់យ៉ាងដែលនរណាម្នាក់បានធ្វើពីស្បែកសត្វ រោមពពែឬឈើ»
Numbers 31:21
ព័ត៌មានទូទៅ៖
អេឡាសារបង្រៀនទាហានអោយមានទម្លាប់ស្អាតស្អំនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់
ក្រោយពេលធ្វើសង្គ្រាម។
មាស ប្រាក់ លង្ហិន ដែក ស្ពាន់ និងសំណ
លោហធាតុដែលត្រូវបានប្រើក្នុងកំឡុងពេលនោះ
ដុតមិនឆេះ
«នោះនឹងមិនឆេះទេ»
ដាក់វាដុតនៅក្នុងភ្លើង
«ដាក់វាទៅក្នុងភ្លើង»
លាងនៅក្នុងទឹក
នេះសំដៅទៅលើទឹកដែលមនុស្សម្នាក់បានលាយជាមួយផេះ ពីដង្វាយលោះបាប។
សូមមើល១៩:១៧ ។
នោះអ្នករាល់គ្នានឹងបានស្អាត
នេះជាទំនៀមទម្លាប់ដើម្បីធ្វើពិធីបរិសុទ្ធ នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់។
Numbers 31:25
ចូរអ្នករាប់ជយភណ្ឌដែលរឹបអូសបាន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«រាប់ទ្រព្យសម្បត្តិទាំងអស់ដែលទាហានបានយក»
ជយភណ្ឌ
នេះសំដៅទៅលើរបស់របរទាំងអស់ ដែលយកពីប្រជាជនអ៊ីស្រាអែល
ដែលបានសម្លាប់ឬចាប់យកនៅក្នុងសមរភូមិ។
ទាំងមេដឹកនាំរបស់សហគមន៍នៃអំបូរ
«មេដឹកនាំនៃអំបូរនីមួយៗ»
Numbers 31:28
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ព័ត៌មានទូទៅ៖
«យើង» សំដៅទៅលើព្រះអម្ចាស់។
ត្រូវដកពន្ធពីចំណែករបស់អ្នកទៅច្បាំងមួយផ្នែកសម្រាប់យើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រមូលពន្ធពីការរឹបអូសរបស់ទាហានហើយប្រគល់ឱ្យយើង»
ក្នុងចំណោមប្រាំរយ
«រាល់ ៥០០ នាក់»
ចំណែកពន្ធពីពួកអ្នក
«ពីពាក់កណ្តាលរបស់ទាហាន»
សម្រាប់ថ្វាយដល់យើង
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលគាត់នឹងបង្ហាញដល់យើង»
Numbers 31:30
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
ពាក់កណ្តាលដែលត្រូវបានជាចំណែករបស់កូនចៅអ៊ីស្រាអែល
«ពីប្រជាជនរបស់អ៊ីស្រាអែលនៃជយភណ្ឌពាក់កណ្តាលផងដែរ»
មួយភាគហាសិប
»រៀងរាល់ ៥០»
ដែលទទួលភារកិច្ចបម្រើការងារ
អស់អ្នកដែលថែរក្សា និងថែរក្សាព្រះពន្លានិងយញ្ញបូជាថ្វាយព្រះអម្ចាស់
Numbers 31:32
ជូនដំណឹងដល់អ្នកនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ការសម្រាកនៅក្នុងការបង្រៀន។
នៅទីនេះលោកម៉ូសេចាប់ផ្តើមរាប់ចំនួនប្រាក់ដែលរឹបអូសបាន
ហើយចំនួនប្រាក់ដែលបានទៅទាហាននិងប្រជាជននិងចំពោះព្រះអម្ចាស់។
ចំនួនសរុបនៃ៣៣,៥០០ក្បាល,លាចំនួន ៦១,០០០ ក្បាលនិងស្ត្រីចំនួន៣២,០០០នាក់
គោចំនួនពីរពាន់ក្បាល លាប្រាំមួយម៉ឺនមួយពាន់ក្បាល
និងស្ត្រីសាមសិបពីរពាន់នាក់ «គោចំនួន ៧២,០០០ សត្វលា ៦១,០០០ និងស្ត្រី
៣២,០០០»
ស្ត្រីដែលមិនធ្លាប់រួមដំណេកជាមួយបុរសសោះ
នេះសំដៅទៅលើស្ត្រីដែលជាស្ត្រីព្រហ្មចារី។
Numbers 31:36
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់អំពីការរឹបអូសយករបស់ទាហាននិងពន្ធដែលទៅព្រះអម្ចាស់។
ពាក់កណ្តាលដែលទុកសម្រាប់ពួកទាហាន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ទាហាននិងផ្នែករបស់ចៀម»
៣៦,០០០ ក្បាល
ប្រាំមួយពាន់ - ៣៦,០០០
៧២ក្បាល
ពីរ - ៧២
Numbers 31:39
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់អំពីការរឹបអូសយករបស់ទាហាននិងពន្ធដែលទៅព្រះអម្ចាស់។
៦១
មួយ ៦១
១៦,០០០
១៦,០០០
៣២
ពីរ - ៣២
ដែលសម្រាប់ថ្វាយដល់ព្រះអម្ចាស់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ថ្វាយជាតង្វាយដល់ព្រះអម្ចាស់»
Numbers 31:42
ព័ត៌មានទូទៅ៖
លោកម៉ូសេបានរៀបរាប់អំពីការរឹបអូសយកទ្រព្យសម្បត្តិរបស់ប្រជាជននិងពន្ធដែលធ្វើទៅថ្វាយព្រះអម្ចាស
សត្វគោចំនួន៣៦,០០០ ក្បាល
គោប្រាំមួយពាន់ - ៣៦.០០០ គោ

generated on Wed Sep 10 16:16:32 2025

មនុស្សស្រី ១៦,០០០ នាក់
«ស្ត្រី ១៦,០០០»
ត្រូវបានគេនិយាយនៅមុននេះថាបុរសនិងស្ត្រីដែលរៀបការទាំងអស់ត្រូវបានគេសម្លាប់
Numbers 31:47
ព័ត៌មានទូទៅ
លោកម៉ូសេបានរៀបរាប់អំពីការរឹបអូសយកទ្រព្យសម្បត្តិរបស់ប្រជាជននិងពន្ធដែលថ្វាយទៅកាន់លោកម៉ូសេ។
ព័ត៌មានទូទៅ៖
ពន្ធលើចំណែករបស់ប្រជាជនខ្ពស់ជាងពន្ធលើចំណែករបស់ទាហាន។
Numbers 31:48
ពួកមេទ័ព មេបញ្ជាការកងពាន់
ទាំងនេះ គឺជាមេដឹកនាំយោធាដែលបានបញ្ជាលើបុរសជាង ១.០០០
នាក់ប៉ុន្តែមានបុរសតិចជាង ១ម៉ឺននាក់។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៣១:១៣។
មេបញ្ជាការកងពាន់ .....និងមេបញ្ជាការកងរយ
ពាក្យ «ទាហាន» ត្រូវបានយល់។ ការបកប្រែផ្សេងទៀត
«ទាហានជាងរាប់ពាន់នាក់ ... លើទាហានរាប់រយនាក់»
មេបញ្ជាការកងរយ
ទាំងនេះគឺជាមេដឹកនាំយោធាដែលបានបញ្ជាលើបុរសជាង ១០០
នាក់ប៉ុន្តែមានបុរសតិចជាង ១០០០ នាក់។
សូមមើលពីរបៀបដែលបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៣១:១៣
អ្នកបម្រើរបស់លោកបានរាប់
មេបញ្ជាការចាត់ទុកខ្លួនគេថាជា «អ្នកបំរើរបស់អ្នក»។
នេះជាវិធីគួរសមក្នុងការនិយាយទៅកាន់នរណាម្នាក់ដែលមានសិទ្ធិអំណាចខ្ពស់។

ពុំឃើញមានបាត់នរណាម្នាក់សោះឡើយ
អាចបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍វិជ្ជមាន។
«យើងដឹងច្បាស់ថាបុរសគ្រប់រូបនៅទីនេះ»
Numbers 31:50
ព័ត៌មានទូទៅ៖
មេទ័ពបានបង្ហាញ
គឺគ្រឿងអលង្ការធ្វើពីមាស គឺមានខ្សែក ខ្សែដៃ ចិញ្ចៀនត្រា ក្រវិល និងបន្ទោងខ្សែក
ទាំងនេះគឺជាគ្រឿងអលង្ការគ្រប់ប្រភេទដែលមនុស្សពាក់។
ទុកជាតង្វាយលោះបាប សម្រាប់យើងខ្ញុំទាំងអស់គ្នា នៅចំពោះព្រះអម្ចាស់
«អរគុណដល់ព្រះជាម្ចាស់ដែលបានជួយសង្គ្រោះជីវិតយើង»
ក៏ទទួលយកមាស និងគ្រឿងអលង្ការដែលធ្វើដោយដៃ
«រាល់អត្ថបទមាស» ឬ «គ្រឿងអលង្ការជាមាសទាំងអស់»
Numbers 31:52
មាសដែលពួកមេបញ្ជាការកងពាន់ និងមេបញ្ជាការកងរយ យកមកថ្វាយព្រះអម្ចាស់ មានទម្ងន់ទាំង
អស់
មាសទាំងអស់ដែលមេបញ្ជាការកងទ័ពប្រគល់អោយព្រះអម្ចាស់មានទំងន់»។
១៦,៧៥០
«ដប់ប្រាំពីរពាន់ប្រាំពីររយហាសិប»
សេកែល
មួយសេកែលគឺ ១១ក្រាម។
ទុកជាទីរឭករបស់ជនជាតិអ៊ីស្រាអែល នៅចំពោះព្រះអង្គ
មាសនឹងរំលឹកប្រជាជនថា ព្រះអម្ចាស់បានប្រទានជ័យជំនះដល់ពួកគេ។
ក៏នឹងរំលឹកដល់ព្រះអម្ចាស់ថាប្រជាជនបានបំពេញការសងសឹករបស់ទ្រង់លើជនជាតិម៉ាឌាន។

---

32 [1]នៅពេលនេះ កូនចៅរូបេន និងកូនចៅកាដ មានហ្វូងសត្វយ៉ាងច្រើន។ នៅពេលពួកគេឃើញថាស្រុកយ៉ាស៊ើរ និងស្រុកកាឡាដ ជាកន្លែងល្អសម្រាប់ហ្វូងសត្វ[2]ដូច្នេះ
កូនចៅកាដ និងកូនចៅរូបេន បានមកមកប្រាប់លោកម៉ូសេ និងបូជាចារ្យអេឡាសារ ព្រមទាំងពួកមេដឹកនាំរបស់សហគមន៍ថា៖[3]«នេះគឺជាបញ្ជីរនៃទីកន្លែងដែលពួក
យើងបានធ្វើការសង្កេតមើល គឺក្រុងអាថារ៉ុត ក្រុងឌីបូន ក្រុងយ៉ាស៊ើរ ក្រុងនីមរ៉ា ក្រុងហែសបូន ក្រុងអេឡាលេ ក្រុងសេបាំ ក្រុងនេបូ និងក្រុងបេអូន។
[4]ទាំងនេះជាស្រុកដែលព្រះអម្ចាស់វាយយកបាននៅចំពោះមុខសហគមន៍អ៊ីស្រាអែល ហើយស្រុកទាំងនោះជាកន្លែងដ៏ល្អសម្រាប់ហ្វូងសត្វ។ យើងខ្ញុំជាអ្នកបម្រើលោក
មានហ្វូងសត្វច្រើនណាស់»។[5]ពួកគេនិយាយទៀតថា៖ «ប្រសិនបើ លោកមេត្តាយើងខ្ញុំ សូមលោកប្រគល់ស្រុកនេះឲ្យយើងខ្ញុំជាអ្នកបម្រើលោកមក។ មិនបាច់ឲ្យយើងខ្ញុំ
ឆ្លងទន្លេយ័រដាន់ទេ»។
[6]លោកម៉ូសេបានឆ្លើយទៅកូនចៅកាដ និងកូនចៅរូបេនវិញថា៖ «តើគួរឲ្យបងប្អូនរបស់អ្នករាល់គ្នាចេញទៅធ្វើសង្គ្រាម ហើយអ្នករាល់រស់ទីនៅទីនេះឬ?[7]ហេតុអ្វីបានជាអ្នក
បំបាក់ទឹកចិត្តប្រជាជនអ៊ីស្រាអែលលែងចង់ចូលទៅក្នុងទឹកដីដែលព្រះអម្ចាស់ប្រទានមកពួកគេដូច្នេះ?
[8]ឪពុករបស់អ្នករាល់គ្នាក៏ធ្លាប់ធ្វើដូច្នេះដែរ នៅពេលខ្ញុំចាត់ពួកគេ ពីស្រុកកាដេសបារនាឲ្យទៅពិនិត្យមើលស្រុក។ ពួកគេបានឡើងទៅដល់ជ្រលងភ្នំអេសកុល[9]បានឃើញ
ស្រុកនោះ ពួកគេបានធ្វើឲ្យជនជាតិអ៊ីស្រាអែលបាក់ទឹកចិត្ត ហើយពួកគេក៏បដិសេធមិនព្រមចូលទៅក្នុងទឹកដីដែលព្រះអម្ចាស់ប្រទានមកពួកគេនោះឡើយ។
[10]នៅថ្ងៃនោះ ព្រះអម្ចាស់ព្រះពិរោធជាខ្លាំង។ ព្រះអង្គបានស្បថថា៖[11]«អស់អ្នកដែលបានចេញពីស្រុកអេស៊ីបមក ដែលមានអាយុពីម្ភៃឆ្នាំឡើងទៅ នឹងមិនឃើញទឹកដី ដែល
យើងបានស្បថប្រគល់ឲ្យអប្រាហាំ អ៊ីសាក និងយ៉ាកុបឡើយ ពីព្រោះពួកគេពុំបានដើរតាមយើងដោយអស់ពីចិត្តទេ លើកលែងតែ[12]កាលែប ជាកូនរបស់យេភូនេ ជា
ជនជាតិគេណាស និងយ៉ូស្វេ ជាកូនរបស់នូន។ គឺមានតែកាលែប និងយ៉ូស្វេទេ ដែលបានបានដើរតាមដោយចិត្តស្មោះ»។
[13]ដូច្នេះ ព្រះពិរោធរបស់ព្រះអម្ចាស់ បានឆេះឡើងទាស់នឹងជនជាតិអ៊ីស្រាអែល។ ព្រះអង្គបានធ្វើឲ្យពួកគេដើរវិលវល់ នៅក្នុងទីរហោស្ថាន អស់រយៈពេលសែសិបឆ្នាំ រហូត
ទាល់តែមនុស្សមួយជំនាន់ដែលបានប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះនេត្ររបស់ព្រះអង្គត្រូវវិនាសអស់។[14]មើល៍! អ្នករាល់គ្នាបានងើបឡើងនៅកន្លែងឪពុករបស់អ្នករាល់
គ្នាហើយ គឺមនុស្សបាបមានកាន់តែច្រើន ដើម្បីបន្ថែមលើកំហឹងដ៏ខ្លាំងរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែលកាន់តែខ្លាំង។[15]ប្រសិនបើ អ្នករាល់គ្នាបែរចេញលែងដើរ
តាមព្រះអង្គ នោះព្រះអង្គនឹងបណ្តោយឲ្យជនជាតិអ៊ីស្រាអែលរស់នៅក្នុងទីរហោស្ថានម្តងទៀត ហើយអ្នករាល់គ្នានឹងធ្វើឲ្យជាជននេះត្រូវវិនាសទាំងអស់!»។
[16]ដូច្នេះ ពួកគេបានចូលមកជិតលោកម៉ូសេ ហើយប្រាប់ថា៖ «សូមអនុញ្ញាតិឲ្យយើងខ្ញុំសង់របងនៅទីនេះ សម្រាប់ហ្វូងសត្វរបស់យើងខ្ញុំ ហើយសង់ក្រុងសម្រាប់គ្រួសារ
របស់យើងខ្ញុំ។[17]ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំនឹងរៀបចំខ្លួនជាស្រេចនិងប្រដាប់ដោយអាវុធទៅជាមួយកូនចៅអ៊ីស្រាអែល រហូតទាល់តែយើងខ្ញុំនាំពួកគេចូលទៅ
ដល់ទឹកដីរបស់ពួកគេ។ ប៉ុន្តែ កូនចៅរបស់យើងខ្ញុំនឹងរស់នៅក្នុងក្រុងដែលមានកំពែងរឹងមាំ ការពារ ពីព្រោះនៅមានជនជាតិផ្សេងទៀតដែលរស់នៅក្នុងស្រុក។
[18]យើងខ្ញុំមិនវិលត្រឡប់មកផ្ទះវិញឡើយ ទាល់តែកូនចៅអ៊ីស្រាអែលគ្រប់គ្នាបានទទួលមរតករបស់គេរៀងៗខ្លួន។[19]យើងខ្ញុំនឹងមិនទទួលទឹកដីនៅខាងត្រើយម្ខាងនៃទន្លេ
យ័រដាន់ ទុកជាមរតក ពីព្រោះមរតករបស់យើងខ្ញុំនៅខាងកើតទន្លេយ័រដាន់នេះហើយ»។
[20]លោកម៉ូសេបានឆ្លើយទៅពួកគេថា៖ «ប្រសិនបើ អ្នករាល់គ្នាធ្វើតាមអ្វីដែលអ្នករាល់គ្នានិយាយមែន គឺបើអ្នករាល់គ្នាត្រៀមខ្លួនធ្វើសង្គ្រាម នៅចំពោះព្រះអម្ចាស់[21]ហើយ
ពួកអ្នកទាំងអស់គ្នាដែលប្រដាប់អាវុធ បានឆ្លងទន្លេយ័រដាន់ នៅចំពោះព្រះអម្ចាស់ រហូតទាល់តែព្រះអង្គបណ្តេញខ្មាំងសត្រូវចេញពីមុខព្រះអង្គអស់[22]ហើយស្រុកនោះបាន
ទទួលចុះចាញ់នៅចំពោះព្រះអម្ចាស់ នោះអ្នករាល់គ្នាអាចត្រឡប់ទៅវិញបាន។ អ្នករាល់គ្នានឹងគ្មានទោសនៅចំពោះព្រះអម្ចាស់ និងចំពោះជនជាតិអ៊ីស្រាអែលឡើយ។
ហើយស្រុកនេះនឹងបានជាកម្មសិទ្ធិរបស់អ្នករាល់គ្នា នៅចំពោះព្រះអម្ចាស់។
[23]ប៉ុន្តែ ប្រសិនបើអ្នករាល់គ្នាមិនធ្វើដូច្នេះទេ មើល៍! អ្នករាល់គ្នាមានបាបទាស់នឹងព្រះអម្ចាស់ហើយ។ ត្រូវដឹងថា អំពើបាបរបស់អ្នករាល់គ្នានឹងតាមទាន់អ្នករាល់គ្នា។[24]ចូរ
សង់ក្រុងសម្រាប់គ្រួសាររបស់អ្នករាល់គ្នា និងសង់ក្រោលសម្រាប់ហ្វូងចៀមរបស់អ្នករាល់គ្នា រួចធ្វើតាមពាក្យដែលអ្នករាល់គ្នាបាននិយាយនោះចុះ!»។[25]កូនចៅកាដ និងកូន
ចៅរូបេន បានប្រាប់លោកម៉ូសេថា៖ «អ្នកបម្រើលោកនឹងធ្វើតាមពាក្យដែលលោកម្ចាស់បង្គាប់។
[26]ចំណែក កូនចៅ ប្រពន្ធ ព្រមទាំងហ្វូងចៀម និងហ្វូងគោរបស់យើងខ្ញុំនឹងនៅតាមក្រុងនានា ក្នុងស្រុកកាឡាដនេះ[27]ហើយអ្នកបម្រើរបស់លោក នឹងឆ្លងទៅនៅចំពោះ
ព្រះអម្ចាស់ដើម្បីធ្វើសង្គ្រាម គឺប្រុសៗទាំងអស់នឹងប្រដាប់អាវុធជាស្រេចសម្រាប់ធ្វើសង្គ្រាមតាមបង្គាប់របស់លោកម្ចាស់»។
[28]លោកម៉ូសេបានចេញបញ្ជាទៅបូជាចារ្យអេឡាសារ លោកយ៉ូស្វេ ជាកូនរបស់លោកនូន និងមេដឹកនាំអំបូរក្នុងកុលសម្ព័ន្ធរបស់ប្រជាជនអ៊ីស្រាអែល។[29]លោកម៉ូសេបាន
មានប្រសាសន៍ទៅពួកគេថា៖ «ប្រសិនបើ កូនចៅកាដ និងកូនចៅរូបេន ឆ្លងទន្លេយ័រដាន់ជាមួយអ្នករាល់គ្នា ហើយប្រុសៗទាំងអស់ដែលប្រដាប់អាវុធដើម្បីធ្វើសង្គ្រាមនៅ
ចំពោះព្រះអម្ចាស់ ហើយប្រសិនបើ អ្នករាល់គ្នាដណ្តើមយកបានស្រុកនោះហើយ ចូរប្រគល់ទឹកដីនៅស្រុកកាឡាដឲ្យពួកគេ ទុកជាកម្មសិទ្ធិចុះ។[30]ក៏ប៉ុន្តែ ប្រសិនបើ ពួកគេ
មិនប្រដាប់អាវុធឆ្លងទៅជាមួយអ្នករាល់គ្នាទេ នោះពួកគេនឹងទទួលបានកម្មសិទ្ធិក្នុងស្រុកកាណានជាមួយអ្នករាល់គ្នាវិញ»។

generated on Wed Sep 10 16:16:32 2025

[31]ដូច្នេះ កូនចៅកាដ និងកូនចៅរូបេន ឆ្លើយឡើងថា៖ «យើងខ្ញុំនឹងធ្វើតាមអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលមកយើងខ្ញុំជាអ្នកបម្រើរបស់លោក។[32]យើងខ្ញុំនឹងប្រដាប់អាវុធឆ្លងទៅស្រុកកាណានៅចំពោះព្រះអម្ចាស់ តែទឹកដីដែលជាចំណែកមរតករបស់យើងខ្ញុំ នឹងនៅឯត្រើយទន្លេយ័រដាន់នេះ»។
[33]ដូច្នេះ លោកម៉ូសេក៏ប្រគល់នគររបស់ព្រះបាទស៊ីហុន ជាស្តេចសាសន៍អាម៉ូរី និងនគររបស់ព្រះបាទអុក ជាស្តេចបាសាន ដល់កូនចៅកាដ និងកូនចៅរូបេន ហើយដល់ពាក់កណ្តាលនៃចំនួនមនុស្សក្នុងកុលសម្ព័ន្ធរម៉ាណាសេ កូនលោកយ៉ូសែប។ គាត់បានឲ្យស្រុកនោះដល់ពួកគេ ហើយគាត់បានចែកតាមចំនួនទីក្រុងដែលមានព្រំប្រទល់ ព្រមទាំងទីក្រុងទាំងប៉ុន្មានដែលនៅក្នុងស្រុកជុំវិញពួកគេ។
[34]កូនចៅកាដបានសង់ក្រុងឌីបូន ក្រុងអាថារ៉ូត ក្រុងអារ៉ូអ៊ើរ[35]ក្រុងអាត្រូតសូផាន ក្រុងយ៉ាស៊ើរ ក្រុងយ៉ុកបិហា ក្រុងបេតនីមរ៉ា[36]និងក្រុងបេតហារ៉ានឡើងវិញ ដែលសុទ្ធសឹងជាក្រុងមានកំពែងរឹងមាំ និងធ្វើក្រោលសម្រាប់ហ្វូងសត្វពួកគេផងដែរ។
[37]កូនចៅរូបេនបានសង់ក្រុងហែសបូន ក្រុងអេឡាលេ ក្រុងគារយ៉ាថែម[38]ក្រុងនេបូ និងក្រុងបាលមេយ៉ូន ដែលគេបានដូរឈ្មោះ ព្រមទាំងក្រុងស៊ីបម៉ាឡើងវិញ។ ពួកគេដាក់ឈ្មោះថ្មីឲ្យក្រុងទាំងឡាយ ដែលពួកគេបានសង់។[39]ពូជពង្សរបស់លោកម៉ាកៀរ ជាកូនរបស់លោកម៉ាណាសេ បានឡើងទៅស្រុកកាឡាដ ហើយដណ្តើមយកបានទឹកដីនោះពីជនជាតិអាម៉ូរីដែលរស់នៅក្នុងស្រុកនោះ។
[40]បន្ទាប់មក លោកម៉ូសេបានប្រគល់ស្រុកកាឡាដឲ្យលោកម៉ាកៀរ ជាកូនរបស់លោកម៉ាណាសេ ហើយកូនចៅរបស់ពួកគេក៏តាំងទីលំនៅក្នុងស្រុកនោះ។[41]លោកយ៉ាអ៊ៀរ ជាកូនរបស់លោកម៉ាណាសេ បានចេញទៅវាយដណ្តើមយកក្រុងនានា ហើយដាក់ឈ្មោះក្រុងទាំងនោះថាហាវ៉ុតយ៉ាអ៊ៀរ។[42]លោកណូបាសបានចេញទៅវាយដណ្តើមយកក្រុងកេណាត និងភូមិនៅជុំវិញ ហើយដាក់ឈ្មោះក្រុងនោះថា ក្រុងណូបាស តាមឈ្មោះរបស់គាត់។

Numbers 32:1
នៅពេលនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់។
នៅទីនេះលោកម៉ូសេប្រាប់អំពីប្រវត្តិអំពីកុលសម្ព័ន្ធរូបេននិងកាដ។
ក្រុងអាថារ៉ូត ក្រុងឌីបូន ក្រុងយ៉ាស៊ើរ ក្រុងនីមរ៉ា ក្រុងហែសបូន ក្រុងអេឡាលេ ក្រុងសេបាំ ក្រុងនេបូ និងក្រុងបេអូន
ទាំងអស់នេះជាឈ្មោះទីក្រុង។
Numbers 32:4
ព័ត៌មានទូទៅ៖
ប្រជាជនមកពីកុលសម្ព័ន្ធរូបេននិងកាដ បន្តនិយាយទៅកាន់លោកម៉ូសេ អេឡាសារ និងមេដឹកនាំដទៃទៀត។
ស្រុកដែលព្រះអម្ចាស់វាយយកបាននៅចំពោះមុខសហគមន៍អ៊ីស្រាអែល
ព្រះអម្ចាស់ជួយឱ្យជនជាតិអ៊ីស្រាអែល វាយយកបានប្រជាជន
ដែលរស់នៅលើទឹកដីនេះ គឺដូចជាព្រះអម្ចាស់បានយាងពីមុខពួកអ៊ីស្រាអែល
ហើយវាយប្រហារពួកគេដែរ។ ការបកប្រែផ្សេងទៀត
«ទឹកដីដែលព្រះអម្ចាស់បានជួយយើងឱ្យយកឈ្នះប្រជាជនដែលរស់នៅទីនោះ» (សូមមើល Metaphor)
យើងខ្ញុំជាអ្នកបម្រើលោក
ប្រជាជនកុលសម្ព័ន្ធរូបេននិងកាដ សំដៅលើខ្លួនគេតាមរបៀបនេះ
ដើម្បីបង្ហាញការគោរពដល់មនុស្សដែលមានអំណាចខ្ពស់។
ប្រសិនលោកមេត្តាយើងខ្ញុំ
ឃ្លា «នៅក្នុងការមើលឃើញរបស់អ្នក» សម្រាប់គំនិតឬយោបល់។
ការបកប្រែផ្សេងទៀត «បើយើងបានពេញចិត្តនឹងអ្នក» ឬ
«បើអ្នកពេញចិត្តនឹងយើង» (សូមមើល|Metonymy)
សូមលោកប្រគល់ស្រុកនេះឲ្យយើងខ្ញុំ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រគល់ទឹកដីនេះដល់ពួកយើង» (សូមមើល|Active or Passive)
មិនបាច់ឲ្យយើងខ្ញុំឆ្លងទន្លេយ័រដាន់ទេ
ពួកគេចង់បានដីនៅត្រើយខាងកើតទន្លេយ័រដាន់ជំនួសវិញដោយឆ្លងទៅទិសខាងលិច និងទាមទារដីនៅទីនោះ។ ការបកប្រែផ្សេងទៀត
«កុំឱ្យយើងឆ្លងទន្លេយ័រដាន់ដើម្បីកាន់កាប់ទឹកដីនៅខាងនោះ» (សូមមើល|Assumed Knowledge and Implicit Information)
Numbers 32:6
គួរឲ្យបងប្អូនរបស់អ្នករាល់គ្នាចេញទៅធ្វើសង្គ្រាម ហើយអ្នករាល់រស់នៅទីនេះឬ?
លោកម៉ូសេសួរសំណួរនេះដើម្បីស្តីបន្ទោសប្រជាជនពីកុលសម្ព័ន្ធកាដនិងរូបេន។
ការបកប្រែផ្សេងទៀត «វាមិនត្រឹមត្រូវទេ ដែលអ្នកតាំងទីលំនៅនៅលើទឹកដីនេះ ខណៈពេលដែលបងប្អូនរបស់អ្នកទៅធ្វើសង្គ្រាម»។
ហេតុអ្វីបានជាអ្នកបំបាក់ទឹកចិត្ត.....ទឹកដីដែលព្រះអម្ចាស់ប្រទានមកពួកគេដូច្នេះ?
លោកម៉ូសេសួរសំណួរនេះដើម្បីកែតម្រង់ប្រជាជន ពីកុលសម្ព័ន្ធកាដនិងរូបេន។
ការបកប្រែផ្សេងទៀត «កុំបាក់ទឹកចិត្ត ...
ទឹកដីដែលព្រះអម្ចាស់បានប្រទានដល់ពួកគេ» ឬ
«សកម្មភាពរបស់អ្នកនឹងធ្វើឱ្យចិត្ត ... ដីដែលព្រះអម្ចាស់បានប្រទានដល់ពួកគេ»។
ហេតុអ្វីបានជាអ្នកបំបាក់ទឹកចិត្តកូនចៅអ៊ីស្រាអែលលែងចង់ចូលទៅក្នុង
នៅទីនេះពាក្យ «ទឹកចិត្ត»
តំណាងឱ្យប្រជាជនខ្លួនឯងហើយសំដៅទៅលើអារម្មណ៍របស់ពួកគេ។
ការបកប្រែផ្សេងទៀត «បាក់ទឹកចិត្តប្រជាជនអ៊ីស្រាអែលមិនឱ្យទៅ» ឬ
«បណ្តាលឱ្យប្រជាជនអ៊ីស្រាអែលមិនចង់ទៅ»
Numbers 32:8
ព័ត៌មានទូទៅ៖
ម៉ូសេបន្តនិយាយទៅកាន់ប្រជាជនរូបេននិងកាដ។
ជ្រលងភ្នំអេសកុល
នេះជាឈ្មោះកន្លែងមួយ។ សូមមើលការបកប្រែនៅក្នុង ១៣:២៣ ។
ពួកគេបានឃើញស្រុកនោះ
សំដៅទៅលើការមើលឃើញអ្វី ដែលមាននៅក្នុងដី។ ការបកប្រែផ្សេងទៀត
«ពួកគេបានឃើញប្រជាជននិងទីក្រុងមាំៗ នៅលើទឹកដី»
ពួកគេបានធ្វើឲ្យជនជាតិអ៊ីស្រាអែលបាក់ទឹកចិត្ត
នៅទីនេះពាក្យ «ដួងចិត្ត» តំណាងឱ្យប្រជាជន
ហើយសំដៅទៅលើអារម្មណ៍របស់ពួកគេ។ សូមមើលការបកប្រែនៅក្នុង ៣២:៦។
ការបកប្រែផ្សេងទៀត «បាក់ទឹកចិត្តប្រជាជនអ៊ីស្រាអែល»
Numbers 32:10
ព្រះអម្ចាស់ទ្រង់ព្រះពិរោធជាខ្លាំង
ព្រះជាម្ចាស់មានកំហឹង ត្រូវបានគេនិយាយហាក់ដូចជាកំហឹងរបស់ទ្រង់
គឺជាភ្លើងដែលចាប់ផ្តើមឆេះ។ អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ខ្ញាល់យ៉ាងខ្លាំង»
អស់អ្នក
«គ្មានមនុស្សណាម្នាក់ទេ»។ ឃ្លានេះសំដៅទៅលើទាំងបុរសនិងស្ត្រី។
ដែលមានអាយុពីម្ភៃឆ្នាំឡើងទៅ
"អាយុ២០ឆ្នាំ ឬចាស់ជាងនេះ
ដែលបានបានដើរតាមដោយចិត្តស្មោះ
គេបានឧទ្ទិសថ្វាយដល់ព្រះអម្ចាស់ ហើយស្តាប់បង្គាប់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «ស្តាប់បង្គាប់ទ្រង់ទាំងស្រុង» ឬ
«ត្រូវបានលះបង់ទាំងស្រុងសម្រាប់ព្រះជាម្ចាស់»
យេភូនេ.....នុន
នេះជាឈ្មោះបុរស។
ជាជនជាតិគេណាស
នេះជាឈ្មោះប្រជាជនមួយក្រុម។
Numbers 32:13
ព្រះពិរោធរបស់ព្រះអម្ចាស់ បានឆេះឡើងទាស់នឹងជនជាតិអ៊ីស្រាអែល
ព្រះជាម្ចាស់មានកំហឹង ត្រូវបានគេនិយាយហាក់ដូចជាកំហឹងរបស់ទ្រង់
គឺជាភ្លើងដែលចាប់ផ្តើមឆេះ។ អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ខឹងនឹងជនជាតិអ៊ីស្រាអែល»
អស់រយៈពេលសែសិបឆ្នាំ
«៤០ឆ្នាំ»
ហួតទាល់តែមនុស្សមួយជំនាន់.....ត្រូវវិនាសអស់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ទ្រង់បានបំផ្លាញគ្រប់ជំនាន់...ការមើលឃើញ» ឬ «មនុស្សជំនាន់ទាំងអស់... មើលឃើញការស្លាប់»

generated on Wed Sep 10 16:16:32 2025

បានប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះនេត្ររបស់ព្រះអង្គ
នៅចំពោះមុខនរណាម្នាក់មានន័យថា នៅពីមុខមនុស្សម្នាក់
ដែលគាត់អាចមើលឃើញ។ ការបកប្រែផ្សេងទៀត
«អ្នកណាបានធ្វើអំពើអាក្រក់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់» ឬ
«អ្នកដែលបានប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»
អ្នករាល់គ្នាបានងើបឡើងនៅកន្លែងឪពុក
ប្រជាជនរូបេននិងកាដប្រព្រឹត្តដូចដូនតារបស់ពួកគេដែរដូចជាពួកគេឈរនៅកន្លែង
ដែលដូនតារបស់ពួកគេបានធ្វើ។ ការបកប្រែផ្សេងទៀត
«អ្នកបានចាប់ផ្តើមធ្វើដូចជីដូនជីតារបស់អ្នក»
ដើម្បីបន្ថែមលើកំហឹងដ៏ខ្លាំងរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែលកាន់តែខ្លាំង
ប្រជាជនដែលធ្វើឱ្យព្រះអម្ចាស់ក្រេវក្រោធត្រូវបានគេនិយាយដូចជាកំហឹងរបស់ទ្រង់កំពុងឆេះ
ហើយប្រជាជនកំពុងតែបន្ថែមឥន្ធនៈបន្ថែមទៅក្នុងភ្លើងនោះ។
ការបកប្រែផ្សេងទៀត «ធ្វើឱ្យព្រះអម្ចាស់រឹតតែខឹងនឹងអ៊ីស្រាអែលថែមទៀត»
ឲ្យជាជននេះ
«ប្រជាជនទាំងមូលនេះ» ឬ «មនុស្សជំនាន់នេះទាំងអស់»
Numbers 32:16
រៀបចំខ្លួនជាស្រេចដើម្បីប្រដាប់អាវុធ
«នឹងត្រៀមខ្លួនជាស្រេចជាមួយអាវុធ» ឬ
«ត្រៀមខ្លួនជាស្រេចដើម្បីប្រយុទ្ធនឹងសង្គ្រាម»
ក្នុងក្រុងដែលមានកំពែងរឹងមាំ
«នៅក្នុងទីក្រុងមានសុវត្ថិភាព»
Numbers 32:18
ព័ត៌មានទូទៅ៖
មេដឹកនាំកាដនិងរូបេនបន្តនិយាយ។
បានទទួលមរតករបស់គេរៀងៗខ្លួន
ដីដែលប្រជាជនត្រូវទទួលជាកម្មសិទ្ធិអចិន្ត្រៃយ៍ ត្រូវបានគេនិយាយថាជាមរតក
ដែលពួកគេត្រូវទទួល។ ការបកប្រែផ្សេងទៀត «បានកាន់កាប់ដីរបស់គាត់»
Numbers 32:20
បើអ្នករាល់គ្នាត្រៀមខ្លួនធ្វើសង្គ្រាម
«បើអ្នកយកអាវុធរបស់អ្នក»
នៅចំពោះព្រះអម្ចាស់
មានន័យថា ព្រះអម្ចាស់នឹងទៅជាមួយពួកគេ
ដើម្បីធ្វើសង្គ្រាមហើយជួយពួកគេឱ្យយកឈ្នះខ្មាំងសត្រូវរបស់ពួកគេ
ហើយកាន់កាប់ទឹកដីរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«នៅក្នុងវត្តមានរបស់ព្រះអម្ចាស់»
រហូតទាល់តែព្រះអង្គបណ្តេញខ្មាំងសត្រូវចេញពីមុខព្រះអង្គអស់
«ទាល់តែព្រះអម្ចាស់ដេញខ្មាំងសត្រូវចេញពីព្រះភ័ក្ត្ររបស់ព្រះអង្គ»។
សព្វនាមនៅទីនេះទាំងអស់សំដៅទៅលើព្រះអម្ចាស់។
ព្រះជាម្ចាស់ជួយពួកអ៊ីស្រាអែល ឱ្យយកឈ្នះខ្មាំងសត្រូវរបស់ពួកគេ
ដូចជាព្រះអម្ចាស់កំពុងវាយប្រយុទ្ធ។ ការបកប្រែផ្សេងទៀត
«រហូតដល់ព្រះអម្ចាស់បានជួយទាហានរបស់អ្នក
វាយឈ្នះសត្រូវហើយបង្ខំពួកគេឱ្យចាកចេញពីព្រះភ័ក្ត្ររបស់ព្រះអង្គ»
ហើយស្រុកនោះបានទទួលចុះចាញ់នៅចំពោះព្រះអម្ចាស់
ត្រង់នេះពាក្យថា «ទឹកដី» សំដៅលើប្រជាជនដែលរស់នៅទីនោះ។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយនៅចំពោះមុខគាត់ប្រជាជនអ៊ីស្រាអែលបានបង្ក្រាបប្រជាជន
ដែលរស់នៅលើទឹកដីនេះ»។
អ្នករាល់គ្នាអាចត្រឡប់ទៅវិញបាន
បញ្ជាក់ថា ពួកគេនឹងវិលត្រឡប់ទៅខាងកើតទន្លេយ័រដាន់វិញ។
ការបកប្រែផ្សេងទៀត
«អ្នកអាចត្រឡប់ទៅទឹកដីនេះនៅត្រើយខាងនាយទន្លេយ័រដាន់»
អ្នករាល់គ្នានឹងគ្មានទោសនៅចំពោះព្រះអម្ចាស់ និងចំពោះជនជាតិអ៊ីស្រាអែលឡើយ
អាចមានន័យថា ១)
«អ្នកនឹងបំពេញកាតព្វកិច្ចរបស់អ្នកចំពោះព្រះអម្ចាស់និងអ៊ីស្រាអែល» ឬ ២)
គ្មានអ្វីដែលព្រះអម្ចាស់ឬប្រជាជនអ៊ីស្រាអែល អាចស្តីបន្ទោសអ្នកបានឡើយ។
Numbers 32:23
ត្រូវដឹងថា អំពើបាបរបស់អ្នករាល់គ្នានឹងតាមទាន់អ្នករាល់គ្នា
លោកម៉ូសេនិយាយអំពីអំពើបាប ដូចមនុស្សដែលនឹងថ្កោលទោសអ្នកមានទោស។
មានន័យថា ប្រជាជនមិនអាចរួចផុតពីទណ្ឌកម្ម
ដែលសមនឹងអំពើបាបរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «ដឹងច្បាស់ថា
ព្រះអម្ចាស់នឹងដាក់ទោសអ្នកចំពោះអំពើបាបរបស់អ្នក»
អ្នកបម្រើលោក
ប្រជាជនកាដនិងរូបេនបានហៅខ្លួនគេថា «ជាអ្នកបម្រើរបស់អ្នក»។
នេះជាវិធីគួរសមក្នុងការនិយាយទៅកាន់នរណាម្នាក់ ដែលមានសិទ្ធិអំណាចខ្ពស់។
Numbers 32:26
នឹងឆ្លង
ឆ្លងកាត់យ៉ាងច្បាស់ថា ពួកគេនឹងឆ្លងទន្លេយ័រដាន់។ ការបកប្រែផ្សេងទៀត
«នឹងឆ្លងទន្លេយ័រដាន់»
គឺប្រុសៗទាំងអស់នឹងប្រដាប់អាវុធជាស្រេចសម្រាប់ធ្វើសង្គ្រាម
«មនុស្សគ្រប់រូបបានត្រៀមខ្លួនធ្វើសង្គ្រាម»
Numbers 32:28
ហើយប្រុសៗទាំងអស់ដែលប្រដាប់អាវុធដើម្បីធ្វើសង្គ្រាម
«បុរសគ្រប់រូបដែលត្រៀមខ្លួនជាស្រេច ដោយមានអាវុធ»
ហើយប្រសិនបើ អ្នករាល់គ្នាដណ្តើមយកបានស្រុកនោះហើយ
ត្រង់នេះពាក្យថា «ទឹកដី» សំដៅលើប្រជាជនដែលរស់នៅទីនោះ។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បើព្រះអម្ចាស់បង្ក្រាបអ្នកនៅមុខប្រជាជន» ឬ «បើពួកគេជួយអ្នកបង្ក្រាបប្រជាជន
ដែលរស់នៅលើទឹកដីនេះ»
នោះពួកគេនឹងទទួលបានកម្មសិទ្ធិក្នុងស្រុកកាណានជាមួយអ្នករាល់គ្នាវិញ
កូនចៅរបស់កាដនិងរូបេននឹងទទួលបានទឹកដី ជាមួយអ្នកនៅស្រុកកាណាន។
Numbers 32:31
យើងខ្ញុំនឹងប្រដាប់អាវុធ ឆ្លងទៅ
អាចបញ្ជាក់យ៉ាងច្បាស់ថា ពួកគេនឹងឆ្លងទន្លេយ័រដាន់។ ការបកប្រែផ្សេងទៀត
«យើងនឹងឆ្លងទន្លេយ័រដាន់ត្រៀមខ្លួនដើម្បីប្រយុទ្ធ»
ជាចំណែកមរតករបស់យើងខ្ញុំ
ដីដែលប្រជាជនត្រូវទទួលជាកម្មសិទ្ធិអចិន្ត្រៃយ៍ ត្រូវបានគេនិយាយថា
ជាមរតកដែលពួកគេត្រូវទទួល។ ការបកប្រែផ្សេងទៀត
«ចំណែកទឹកដីដែលយើងនឹងកាន់កាប់»
នឹងនៅជាមួយយើង
លេខសម្គាល់នេះសំដៅទៅលើកម្មសិទ្ធិ។ ការបកប្រែផ្សេងទៀត
«នឹងក្លាយជារបស់យើង»
Numbers 32:33
នគររបស់ព្រះបាទស៊ីហុន .....និងនគររបស់ព្រះបាទអុក
ទាំងនេះជាឈ្មោះស្តេចដែលគ្រប់គ្រងនគរពីរដាច់ដោយឡែកពីគ្នា។
ការបកប្រែផ្សេងទៀត «នគរព្រះបាទស៊ីហុន ... និងនគរព្រះបាទអុក»
Numbers 32:34
ក្រុងឌីបូន,ក្រុងអាថារ៉ុត ក្រុងអារ៉ូអ៊ើរ ក្រុងអាត្រូតសូផាន ក្រុងយ៉ាស៊ើរ ក្រុងយ៉ុកបិហា ក្រុងបេតនីមរ៉ា
និងក្រុងបេតហារ៉ន
ទាំងអស់នេះជាឈ្មោះទីក្រុង។
Numbers 32:37
ក្រុងហែសបូន ក្រុងអេឡាលេ ក្រុងគារយ៉ាថែម ក្រុងនេបូ និងក្រុងបាលមេយ៉ូន ....ក្រុងស៊ីបម៉ា
ទាំងអស់នេះជាឈ្មោះទីក្រុង។
ដែលគេបានដូរឈ្មោះ
អាចបកប្រែជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ក្រោយមកប្រជាជនបានប្តូរឈ្មោះទីក្រុងទាំងនេះ»
លោកម៉ាកៀរ
នេះជាឈ្មោះបុរស។ សូមមើលការបកប្រែឈ្មោះនេះនៅក្នុង ២៦:២៨។
Numbers 32:40
លោកយ៉ាអ៊ៀរ ....លោកណូបាស
ទាំងអស់នេះជាឈ្មោះរបស់បុរស។
ហារ៉ុតយ៉ាអ៊ៀរ.....ក្រុងកេណាត
ទាំងអស់នេះជាឈ្មោះទីក្រុង។

33

generated on Wed Sep 10 16:16:32 2025

[1]នេះជាការធ្វើដំណើររបស់កូនចៅអ៊ីស្រាអែល បន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប តាមក្រុមទ័ពរបស់ពួកគេ ក្រោមការដឹកនាំរបស់លោកម៉ូសេ និងលោកអើរ៉ុន។[2]លោកម៉ូសេបានកត់ត្រាទុកពីកន្លែងមួយទៅកន្លែងមួយ ដែលពួកគេធ្វើដំណើរតាមបង្គាប់របស់ព្រះអម្ចាស់។ នេះជាការធ្វើដំណើរបស់ពួកគេពីកន្លែងមួយទៅកន្លែងមួយ៖
[3]ពួកគេបានធ្វើដំណើរចេញពីក្រុងរ៉ាមសេស នៅកំឡុងខែទីមួយ គឺនៅថ្ងៃទីដប់ប្រាំ ខែទីមួយ។ នៅព្រឹកព្រលឹមបន្ទាប់ពីពិធីបុណ្យចម្លងមួយថ្ងៃ ជនជាតិអ៊ីស្រាអែលបានចេញដោយមានសេរីភាព នៅចំពោះមុខជនជាតិអេស៊ីបទាំងអស់។[4]ការនេះកើតឡើងក្នុងពេលដែលជនជាតិអេស៊ីបកំពុងបញ្ចុះសពកូនច្បងទាំងអស់របស់ពួកគេ ដែលព្រះអម្ចាស់សម្លាប់នៅក្នុងចំណោមពួកគេ ហើយព្រះអម្ចាស់ក៏បានដាក់ទោសដល់អស់ទាំងព្រះរបស់ពួកគេដែរ។
[5]ប្រជាជនអ៊ីស្រាអែលបានធ្វើដំណើរចេញពីក្រុងរ៉ាមសេស មកបោះជំរំនៅស៊ូកូត។[6]ពួកគេចាកចេញពីស៊ូកូត មកបោះជំរំនៅអេថាម ដែលស្ថិតនៅជាយទីរហោស្ថាន។[7]ពួកគេចាកចេញពីអេថាម វាងទៅពីហាហ៊ីរ៉ុត ដែលស្ថិតនៅទល់មុខនឹងបាលសេផុន ហើយកន្លែងដែលពួកគេបោះជំរំនោះទល់មុខនឹងមីគដួល។
[8]បន្ទាប់មក ពួកគេចាកចេញពីមុខពីហាហ៊ីរ៉ុត ឆ្លងកាត់កណ្តាលសមុទ្រ ឆ្ពោះទៅទីរហោស្ថាន។ ពួកគេធ្វើដំណើរអស់រយៈពេលបីថ្ងៃ ក្នុងទីរហោស្ថានអេថាម មកបោះជំរំនៅម៉ារ៉ា។[9]ពួកគេចាកចេញពីម៉ារ៉ា មកដល់អេលីម។ នៅអេលីមនេះមានប្រភពទឹកចំនួនដប់ពីរ និងដើមលម៉ើចិតសិបដើម ពួកគេក៏បោះជំរំនៅទីនោះ។[10]ពួកគេចាកចេញពីអេលីម ទៅបោះជំរំនៅក្បែរសមុទ្រក់។
[11]ពួកគេចាកចេញពីសមុទ្រក់ មកបោះជំរំនៅទីរហោស្ថានស៊ីន។[12]ពួកគេចាកចេញពីទីរហោស្ថានស៊ីន មកបោះជំរំនៅដូបកា។[13]ពួកគេចាកចេញពីដូបកា មកបោះជំរំនៅអាលូស។[14]ពួកគេចាកចេញពីអាលូស មកបោះជំរំនៅរេផិឌីម។ នៅកន្លែងនោះគេរកទឹកឲ្យប្រជាជនរកទឹកផឹកមិនបានទេ។
[15]ពួកគេចាកចេញពីរេផិឌីម មកបោះជំរំនៅទីរហោស្ថានស៊ីណៃ។[16]ពួកគេចាកចេញពីទីរហោស្ថានស៊ីណៃ មកបោះជំរំនៅគីប្រូតហាត់តាវ៉ា។[17]ពួកគេចាកចេញពីគីប្រូតហាត់តាវ៉ា មកបោះជំរំនៅហាសិរ៉ូត។[18]ពួកគេចាកចេញពីហាសិរ៉ូត មកបោះជំរំនៅរីតម៉ា។
[19]ពួកគេចាកចេញពីរីតម៉ា មកបោះជំរំនៅរីម៉ូនពេរេស។[20]ពួកគេចាកចេញពីរីម៉ូន-ពេរេស មកបោះជំរំនៅលីបណា។[21]ពួកគេចាកចេញពីលីបណា មកបោះជំរំនៅរីសា។[22]ពួកគេចាកចេញពីរីសា មកបោះជំរំនៅកេហេឡាថា។
[23]ពួកគេចាកចេញពីកេហេឡាថា មកបោះជំរំនៅភ្នំសេភើរ។[24]ពួកគេចាកចេញពីភ្នំសាភើរ មកបោះជំរំនៅហារ៉ាដា។[25]ពួកគេចាកចេញពីហារ៉ាដា មកបោះជំរំនៅម៉ាកហេឡូត។
[26]ពួកគេចាកចេញពីម៉ាកហេឡូត មកបោះជំរំនៅតាហាត់។
[27]ពួកគេចាកចេញពីតាហាត់ មកបោះជំរំនៅតារ៉ាស។[28]ពួកគេចាកចេញពីតារ៉ាស មកបោះជំរំនៅមីតកា។[29]ពួកគេចាកចេញពីមីតកា មកបោះជំរំនៅហាស្មូណា។[30]ពួកគេចាកចេញពីហាស្មូណា មកបោះជំរំនៅម៉ូសេរ៉ូត។
[31]ពួកគេចាកចេញពីម៉ូសេរ៉ូត មកបោះជំរំនៅបេនេយ៉ាកាន។[32]ពួកគេចាកចេញពីបេនេយ៉ាកាន មកបោះជំរំនៅហោគីតកាត់។[33]ពួកគេចាកចេញពីហាគីតកាត់ មកបោះជំរំនៅយ៉ុតបាថា។[34]ពួកគេចាកចេញពីយ៉ុតបាថា មកបោះជំរំនៅអាប្រូណា។
[35]ពួកគេចាកចេញពីអាប្រូណា មកបោះជំរំនៅអេស៊ានគេប៊ើរ។[36]ពួកគេចាកចេញពីអេស៊ានគេប៊ើរ មកបោះជំរំនៅទីរហោស្ថានស៊ីន នៅត្រង់កាដេស។[37]ពួកគេចាកចេញពីកាដេស មកបោះជំរំនៅភ្នំហោរ ដែលនៅជាយស្រុកអេដុម។
[38]បូជាចារ្យអើរ៉ុនបានឡើងទៅលើភ្នំហោរ តាមបង្គាប់របស់ព្រះអម្ចាស់ ហើយគាត់បានស្លាប់នៅទីនោះ ក្នុងឆ្នាំទីសែសិប បន្ទាប់មក ជនជាតិអ៊ីស្រាអែលចាកចេញពីស្រុកអេស៊ីប នៅថ្ងៃទីមួយ ខែទីប្រាំ។[39]ពេលលោកអើរ៉ុនស្លាប់នៅលើភ្នំហោរ គាត់មានអាយុមួយរយម្ភៃបីឆ្នាំ។
[40]ស្តេចក្រុងអើរ៉ាត គឺស្តេចជនជាតិកាណានដែលរស់នៅទីរហោស្ថានខាងត្បូង ក្នុងស្រុកកាណាន បានឮថាកូនចៅអ៊ីស្រាអែលមកដល់ទីនោះ។
[41]ពួកគេក៏ចេញពីភ្នំហោរ មកបោះជំរំនៅត្រង់សាលម៉ូណា។[42]ពួកគេចាកចេញពីសាលម៉ូណា មកបោះជំរំនៅពូណូន។[43]ពួកគេចាកចេញពីពូណូន មកបោះជំរំនៅអូបូត។
[44]ពួកគេចាកចេញពីអូបូត មកបោះជំរំនៅអ៊ីយេអាបារីម ដែលនៅជាយស្រុកម៉ូអាប់។[45]ពួកគេចាកចេញពីអ៊ីយេអាបារីម មកបោះជំរំនៅឌីបូនកាដ។[46]ពួកគេចាកចេញពីឌីបូនកាដ មកបោះជំរំនៅអាល់ម៉ូនឌីប្លាថែម។
[47]ពួកគេចាកចេញពីអាល់ម៉ូនឌីប្លាថែម មកបោះជំរំនៅតំបន់ភ្នំអាបារីម ទល់មុខនឹងក្រុងនេបូរ។[48]ពួកគេចាកចេញពីតំបន់ភ្នំអាបារីម មកបោះជំរំនៅវាលទំនាបស្រុកម៉ូអាប់ ជិតទន្លេយ័រដាន់ នៅក្រុងយេរីខូ។[49]ពួកគេបោះជំរំជិតទន្លេយ័រដាន់ ចាប់ពីបេតយេស៊ីម៉ូត រហូតដល់អេបិលស៊ីទីម ក្នុងវាលទំនាបស្រុកម៉ូអាប់។
[50]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេ នៅវាលទំនាបស្រុកម៉ូអាប់ ក្បែរទន្លេយ័រដាន់ នៅក្រុងយេរីខូ ដោយមានបន្ទូលថា៖[51]«ចូរប្រាប់ប្រជាជនអ៊ីស្រាអែលថា៖ «នៅពេលអ្នករាល់គ្នាឆ្លងទន្លេយ័រដាន់ ចូលទៅក្នុងស្រុកកាណាន[52]នោះ អ្នករាល់គ្នាត្រូវបណ្តេញប្រជាជនដែលរស់នៅក្នុងស្រុកនោះឲ្យអស់ពីមុខអ្នករាល់គ្នា។ អ្នករាល់គ្នាត្រូវបំផ្លាញរូបឆ្លាក់ទាំងអស់របស់ពួកគេ។ អ្នករាល់គ្នាត្រូវបំផ្លាញរូបសិតទាំងអស់របស់ពួកគេ ព្រមទាំងកម្ទេចទីខ្ពស់ៗទាំងអស់របស់ពួកគេផងដែរ។
[53]អ្នករាល់គ្នាត្រូវចាប់យកស្រុកនោះទុកជាកម្មសិទ្ធិ ហើយរស់នៅទីនោះ ពីព្រោះយើងបានឲ្យអ្នករាល់គ្នា ទុកជាកម្មសិទ្ធិហើយ។[54]អ្នករាល់គ្នាត្រូវទទួលស្រុកនោះ ទុកជាមរតក ដោយចាប់ឆ្នោត តាមអំបូរនីមួយៗ។ អំបូរណាដែលធំជាងគេ ត្រូវឲ្យចំណែកដីធំជាងគេដែរ ហើយអំបូរណាតូចជាងគេ ត្រូវចំណែកដីតូចជាងគេដែរ។ បើចាប់ឆ្នោតប៉ះចំអំបូរណា ដីនោះនឹងបានជាកម្មសិទ្ធិរបស់អំបូរនោះ។ អ្នករាល់គ្នាទទួលមរតកតាមឈ្មោះកុលសម្ព័ន្ធដូនតារបស់អ្នករាល់គ្នា។
[55]ប៉ុន្តែ ប្រសិនបើអ្នករាល់គ្នាមិនបណ្តេញប្រជាជននៅក្នុងស្រុកចេញពីមុខអ្នករាល់គ្នាទេ នោះប្រជាជនដែលអ្នករាល់គ្នាអនុញ្ញាតិឲ្យរស់នៅនោះ ពួកគេនឹងប្រៀបដូចជាកម្ទេចឈើនៅក្នុងភ្នែករបស់អ្នករាល់គ្នា និងជាបន្លាជាប់នៅចំហៀងរបស់អ្នករាល់គ្នា គឺពួកគេនឹងធ្វើឲ្យជីវិតរបស់អ្នករាល់គ្នាលំបាក នៅក្នុងស្រុកដែលអ្នករាល់គ្នារស់នៅនោះ។[56]ត្រូវដឹងថា យើងប្រព្រឹត្តចំពោះជនជាតិនោះយ៉ាងណា នោះយើងនឹងប្រព្រឹត្តចំពោះអ្នករាល់គ្នាយ៉ាងនោះដែរ»។

Numbers 33:1
តាមក្រុមទ័ពរបស់ពួកគេ
«ដោយការបែងចែកយោធារបស់ពួកគេ»
មានន័យថាកុលសម្ព័ន្ធនីមួយៗមានបុរសផ្ទាល់ខ្លួន
ដែលប្រដាប់ដោយអាវុធដើម្បីការពារខ្លួន។ សូមមើលការបកប្រែ
«ក្រុមប្រដាប់អាវុធ» នៅក្នុង ១:១។
តាមបង្គាប់របស់ព្រះអម្ចាស់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដូចដែលព្រះអម្ចាស់បានបង្គាប់»
នេះជាការធ្វើដំណើរបស់ពួកគេពីកន្លែងមួយទៅកន្លែងមួយ
«ពីកន្លែងមួយទៅកន្លែងមួយទៀត»
Numbers 33:3
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
នៅកំឡុងខែទីមួយ គឺនៅថ្ងៃទីដប់ប្រាំ ខែទីមួយ
នៅទីនេះ «ដំបូង» ជាលេខធម្មតា ហើយលេខដប់ប្រាំជាលេខធម្មតាដប់ប្រាំ។
នេះជាខែដំបូងតាមប្រតិទិនហេប្រឺ។ ថ្ងៃទីដប់ប្រាំ
ដើមខែមេសានៅលើប្រតិទិនលោកខាងលិច។
ជនជាតិអ៊ីស្រាអែលបានចេញដោយមានសេរីភាព នៅចំពោះមុខជនជាតិអេស៊ីបទាំងអស់
«ជនជាតិអ៊ីស្រាអែលបានចាកចេញពីទិដ្ឋភាពធម្មតានៃជនជាតិអេស៊ីប»
កូនច្បងទាំងអស់របស់ពួកគេ
សំដៅទៅលើកូនប្រុសច្បង។ ការបកប្រែផ្សេងទៀត «កូនប្រុសច្បងរបស់ពួកគេ»
ព្រះអម្ចាស់ក៏បានដាក់ទោសដល់អស់ទាំងព្រះរបស់ពួកគេដែរ
ព្រះអម្ចាស់បង្ហាញថា ព្រះអង្គមានអំណាចខ្លាំងជាងព្រះក្លែងក្លាយទាំងអស់
ដែលជនជាតិអេស៊ីបបានថ្វាយបង្គំដូចជាព្រះអង្គបានដាក់ទោសព្រះក្លែងក្លាយទាំងនោះដែរ។
ការបកប្រែផ្សេងទៀត «ទ្រង់ក៏បានបង្ហាញថា ទ្រង់ធំជាងព្រះរបស់ពួកគេផង»
Numbers 33:5
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
បានធ្វើដំណើរចេញពី

generated on Wed Sep 10 16:16:32 2025

«បានចាកចេញពី»
ដែលស្ថិតនៅជាយទីរហោស្ថាន
«នៅតាមព្រំដែននៃទីរហោស្ថាន»
Numbers 33:8
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
ឆ្លងកាត់កណ្តាលសមុទ្រ
សំដៅទៅលើពេលដែលព្រះអម្ចាស់បានបែងចែកសមុទ្រក្រហម
ដើម្បីឱ្យជនជាតិអ៊ីស្រាអែលអាចរួចផុតពីកងទ័ពអេស៊ីប។
ទឹកចំនួនដប់ពីរ និងដើមលម៉ើចិតសិបដើម
«ប្រភពទឹកចំនួន១២ ... ដើមលម៉ើចំនួន៧០ដើម»
Numbers 33:11
ព័ត៌មានទូទៅ
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
នៅកន្លែងនោះគេរកទឹកឲ្យប្រជាជនរកទឹកផឹកមិនបានទេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«កន្លែងដែលប្រជាជនមិនអាចរកទឹកពិសាបាន»
Numbers 33:15
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:19
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:23
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:27
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:31
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:35
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:38
ក្នុងឆ្នាំទីសែសិប បន្ទាប់មក
នៅទីនេះ «សែសិប» ជាលេខធម្មតាសម្រាប់សែសិប។ ការបកប្រែផ្សេងទៀត «៤០
ឆ្នាំក្រោយ»
នៅថ្ងៃទីមួយ ខែទីប្រាំ
ពាក្យ «ទីប្រាំ» ជាលេខធម្មតាសម្រាប់ប្រាំ។ «ដំបូង»
គឺជាលេខធម្មតាសម្រាប់លេខមួយ។ នេះជាខែទីប្រាំតាមប្រតិទិនហេប្រឺ។
ថ្ងៃដំបូងពាក់កណ្តាលខែកក្កដាតាមប្រតិទិនលោកខាងលិច។
Numbers 33:40
ជនជាតិកាណាន,ស្តេចក្រុងអើរ៉ាត
«ស្តេចស្រុកកាណាននៃស្រុកអើរ៉ាត»
អើរ៉ាត
នេះជាឈ្មោះរបស់ក្រុងកាណាន។
បានឮថាកូនចៅអ៊ីស្រាអែលមកដល់ទីនោះ
«បានឮថា ជនជាតិអ៊ីស្រាអែលកំពុងតែមក»
Numbers 33:41
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:44
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
Numbers 33:47
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់កន្លែងដែលជនជាតិអ៊ីស្រាអែល
បានធ្វើដំណើរបន្ទាប់ពីពួកគេចាកចេញពីស្រុកអេស៊ីប។
វាលទំនាប
តំបន់ធំទូលាយនៃទឹកដីធំល្វឹងល្វើយ។
Numbers 33:50
កម្ទេចទីខ្ពស់ៗទាំងអស់របស់ពួកគេផងដែរ
«បំផ្លាញកន្លែងខ្ពស់ៗទាំងអស់របស់ពួកគេ»
Numbers 33:53
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេអំពីអ្វី ដែលប្រជាជនត្រូវធ្វើ។
ទទួលស្រុកនោះ ទុកជាមរតក
ជនជាតិអ៊ីស្រាអែលដែលទាមទារយកដីនោះ
ជាកម្មសិទ្ធិកាន់កាប់ជាអចិន្ត្រៃយ៍របស់ពួកគេ
គឺហាក់ដូចជាពួកគេបានទទួលទឹកដីជាមរតក។
បើចាប់ឆ្នោតប៉ះចំអំបូរណា ដីនោះនឹងបានជាកម្មសិទ្ធិរបស់អំបូរនោះ
«ត្រកូលនីមួយៗនឹងទទួលបានដីយោងតាមចំនួនដីធ្លី»
Numbers 33:55
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេអំពីអ្វី ដែលប្រជាជនត្រូវធ្វើ។
ដូចជាកម្ទេចឈើនៅក្នុងភ្នែករបស់អ្នករាល់គ្នា និងជាបន្លាជាប់នៅចំហៀងរបស់អ្នករាល់គ្នា
ដូចជាវត្ថុតូចមួយនៅក្នុងភ្នែករបស់មនុស្សម្នាក់
ឬបន្លាតូចមួយដែលជាប់នឹងស្បែករបស់មនុស្សម្នាក់
អាចបណ្តាលឱ្យមានការរលាកយ៉ាងខ្លាំង ដូច្នេះ
សូម្បីតែជនជាតិកាណានមួយផ្នែកតូចក៏ដោយ
បើទុកចោលនៅលើទឹកដីនោះវានឹងបង្កការលំបាកយ៉ាងខ្លាំងដល់ប្រជាជនអ៊ីស្រាអែល។

---

34 [1]ព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[2]«ចូរបង្គាប់កូនចៅអ៊ីស្រាអែលថា៖ «ពេលអ្នករាល់គ្នាចូលទៅក្នុងស្រុកកាណាន ជាស្រុកដែលត្រូវ
បានជាកម្មសិទ្ធិរបស់អ្នករាល់គ្នា គឺស្រុកកាណាន និងព្រំប្រទល់របស់វា[3]គឺព្រំប្រទល់ខាងត្បូងគិតចាប់ពីទីរហោស្ថានស៊ីន ជាប់នឹងស្រុកអេដុម។ ព្រំប្រទល់
ខាងកើតឈៀងខាងត្បូងនឹងបញ្ចប់នៅចុងខាងត្បូងនៃសមុទ្រអំបិល។
[4]រួចបត់ទៅខាងត្បូងចាប់ពីទួលក្រាបីម ឆ្លងកាត់ទីរហោស្ថានស៊ីន ហើយពីទីនោះបន្តទៅដល់ខាងត្បូងកាដេសបារនា និងបន្តរហូតដល់ទៅហាសាអាដា ហួសទៅដល់
អាសម៉ូន[5]ពីទីនោះ ព្រំប្រទល់ត្រូវបត់ពីអាសម៉ូន ឆ្ពោះទៅស្ទឹងស្រុកអេស៊ីបរហូតទៅទល់នឹងសមុទ្រ។
[6]ព្រំប្រទល់ខាងលិច នោះគឺតាមបណ្តោយសមុទ្រធំ។ នេះត្រូវបានជាព្រំដែនខាងលិចរបស់អ្នករាល់គ្នា។
[7]ព្រំប្រទល់ខាងជើងរបស់អ្នករាល់គ្នា ដែលអ្នករាល់គ្នាត្រូវកំណត់នោះគឺចាប់ពីសមុទ្រធំ រហូតដល់ភ្នំហោរ។[8]ហើយពីភ្នំហោរ រហូតដល់ក្រុងហាម៉ាត់ ហើយបន្តទៅដល់
សេដាដ។[9]ហើយព្រំប្រទល់នេះត្រូវបន្តទៅដល់ស៊ីប្រុន រួចបញ្ចប់នៅហាសារអេណាន។ នេះត្រូវជាព្រំប្រទល់ខាងជើងរបស់អ្នករាល់គ្នា។
[10]បន្ទាប់មក អ្នករាល់គ្នាក៏ត្រូវកំណត់ព្រំប្រទល់ខាងកើតរបស់អ្នករាល់គ្នាចាប់ពីហាសារអេណានទៅសេផាម។[11]ហើយពីព្រំប្រទល់ខាងកើតនេះត្រូវចុះពីសេផាមទៅរីមឡា
ដែលនៅខាងកើតអាយ៉ីន រួចបន្តចុះទៅតាមបណ្តោយត្រើយខាងកើតសមុទ្រគេនេសារ៉ែត[12]រួចបន្តចុះទៅក្រោមរហូតដល់ព្រំដែនខាងកើតនៃសមុទ្រអំបិល។ នេះគឺជាស្រុក
របស់អ្នករាល់គ្នាដែលព្រំប្រទល់ជុំវិញ»។

generated on Wed Sep 10 16:16:32 2025

[13]បន្ទាប់មក លោកម៉ូសេបានបង្គាប់ដល់ជនជាតិអ៊ីស្រាអែល ហើយប្រាប់ថា៖ «នេះហើយជាស្រុកដែលអ្នករាល់គ្នានឹងបានទទួលដោយការចាប់ឆ្នោត ដែលព្រះអម្ចាស់
បង្គាប់ឲ្យប្រគល់ដល់កុលសម្ព័ន្ធប្រាំបួន និងកុលសម្ព័ន្ធពាក់កណ្តាលទៀត។[14]ចំណែក កុលសម្ព័ន្ធនៃកូនចៅរូបេន តាមរយៈការបែងចែកមរតកក្នុងកុលសម្ព័ន្ធនៃ
ដូនតារបស់ពួកគេ និងកុលសម្ព័ន្ធកូនចៅកាដ តាមរយៈការបែងចែកមរតកក្នុងកុលសម្ព័ន្ធនៃដូនតារបស់ពួកគេ ព្រមទាំងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលទៀត
បានទទួលទឹកដីរបស់ពួកគេអស់ហើយ។[15]កុលសម្ព័ន្ធទាំងពីរ និងកុលសម្ព័ន្ធពាក់កណ្តាល បានទទួលទឹកដីជាចំណែករបស់ខ្លួន នៅផ្នែកខាងលើទន្លេយ័រដាន់ ខាងលិចក្រុង
យេរីខូ គឺបែរមុខទៅទិសខាងកើត»។
[16]ព្រះអម្ចាស់មានព្រះបន្ទូលមកម៉ូសេ ដោយមានបន្ទូលថា៖[17]«ឈ្មោះពួកអ្នកដែលត្រូវចែកស្រុកនោះ ទុកជាមរតកសម្រាប់អ្នករាល់គ្នា នោះគឺបូជាចារ្យអេឡាសារ និងយ៉ូស្វេ
ជាកូននូន[18]ហើយអ្នកត្រូវជ្រើសរើសមេដឹកនាំម្នាក់ពីគ្រប់កុលសម្ព័ន្ធ ដើម្បីបែងចែកទឹកដីឲ្យអំបូររបស់ពួកគេ។
[19]ទាំងនេះជាឈ្មោះរបស់ពួកគេ៖ ពីកុលសម្ព័ន្ធយូដា លោកកាលែប គឺកូនរបស់លោកយេភូនេ។[20]ពីកុលសម្ព័ន្ធកូនចៅរបស់ស៊ីម្មាន គឺលោកសាំយូអែល ជាកូនរបស់
លោកអាំមីហ៊ូដ ។
[21]ពីកុលសម្ព័ន្ធបេនយ៉ាមីន គឺលោកអេលីដាដ ជាកូនរបស់លោកគីសឡូន ។[22]មេដឹកនាំពីកុលសម្ព័ន្ធកូនចៅដាន់ គឺលោកប៊ូ ជាកូនរបស់លោកយុកលី។[23]ពីកូនចៅ
របស់យ៉ូសែប មេដឹកនាំកូនចៅនៃកុលសម្ព័ន្ធម៉ាណាសេ គឺលោកហានាល ជាកូនរបស់លោកអេផូដ។
[24]មេដឹកនាំពីកុលសម្ព័ន្ធនៃកូនចៅរបស់អេប្រាអ៊ីម គឺលោកកេមយួល ជាកូនរបស់លោកស៊ីបតាន ។[25]មេដឹកនាំពីកុលសម្ព័ន្ធនៃកូនចៅរបស់សាប់យូឡូន
គឺលោកអេលីសាផាន ជាកូនរបស់លោកប៉ាណាក់។[26]មេដឹកនាំពីកុលសម្ព័ន្ធនៃកូនចៅរបស់អ៊ីសាខារ គឺលោកប៉ាលទាល ជាកូនរបស់លោកអាស្សាន។
[27]មេដឹកនាំពីកុលសម្ព័ន្ធនៃកូនចៅរបស់អេស៊ើរ គឺលោកអហ៊ីហ៊ូដ ជាកូនរបស់លោកសេឡូមី ។[28]មេដឹកនាំពីកុលសម្ព័ន្ធនៃកូនចៅរបស់ណែបថាលី គឺលោកពេដាហិល ជា
កូនរបស់លោកអាំមីហ៊ូដ»។[29]ព្រះអម្ចាស់បង្គាប់អ្នកទាំងនេះឲ្យបែងចែកទឹកដីនៃស្រុកកាណាន ចែកឲ្យកុលសម្ព័ន្ធនីមួយៗរបស់ជនជាតិអ៊ីស្រាអែលទុកជាមរតក។

Numbers 34:1
ទីរហោស្ថានស៊ីន
បកប្រែឃ្លានេះដូចនៅក្នុង ៣៣:១១ ។
Numbers 34:4
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់លោកម៉ូសេ អំពីព្រំប្រទល់ដី
ដែលលោកប្រគល់ឱ្យជាតិអ៊ីស្រាអែល។
Numbers 34:6
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់លោកម៉ូសេ អំពីព្រំប្រទល់ដី
ដែលលោកប្រគល់ឱ្យជាតិអ៊ីស្រាអែល។
Numbers 34:7
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់លោកម៉ូសេ អំពីព្រំប្រទល់ដី
ដែលលោកប្រគល់ឱ្យជាតិអ៊ីស្រាអែល។
ភ្នំហោរ
បកប្រែដូចនៅក្នុង ២០:២២។
Numbers 34:10
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់លោកម៉ូសេ អំពីព្រំប្រទល់ដី
ដែលលោកប្រគល់ឱ្យជាតិអ៊ីស្រាអែល។
Numbers 34:13
ប្រគល់ដល់កុលសម្ព័ន្ធប្រាំបួន និងកុលសម្ព័ន្ធពាក់កណ្តាលទៀត
មានន័យថា កុលសម្ព័ន្ធអ៊ីស្រាអែលដែលនៅសល់
នឹងរស់នៅខាងលិចទន្លេយ័រដាន់ក្នុងស្រុកកាណាន។ កុលសម្ព័ន្ធរូបេន និងកាដ
និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលបានទទួលដីនៅខាងកើតទន្លេយ័រដាន់រួចហើយ។
បែងចែកមរតកក្នុងកុលសម្ព័ន្ធនៃដូនតារបស់ពួកគេ ព្រមទាំងកុលសម្ព័ន្ធ
«យោងទៅតាមរបៀប ដែលព្រះអម្ចាស់បានប្រគល់ទ្រព្យសម្បត្តិ
ទៅកុលសម្ព័ន្ធដូនតារបស់ពួកគេ»
កុលសម្ព័ន្ធទាំងពីរ និងកុលសម្ព័ន្ធពាក់កណ្តាល
«កុលសម្ព័ន្ធរូបេន និងកាដ និងពាក់កណ្តាលនៃកុលសម្ព័ន្ធម៉ាណាសេ»
Numbers 34:16
ត្រូវចែកស្រុកនោះ ទុកជាមរតកសម្រាប់អ្នករាល់គ្នា
នៅទីនេះ «របស់អ្នក» ជាពហុវចន: ហើយសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
បុរសទាំងនេះនឹងបោះឆ្នោតចែកដី។
បន្ទាប់មកពួកគេនឹងចែកចាយដីទៅកុលសម្ព័ន្ធ។
Numbers 34:19
ព័ត៌មានទូទៅ៖
នេះជាបញ្ជីឈ្មោះបុរស ដែលជួយបែងចែកដីក្នុងចំណោមកុលសម្ព័ន្ធ។
Numbers 34:21
ព័ត៌មានទូទៅ៖
នេះជាបញ្ជីឈ្មោះបន្តរបស់បុរស ដែលជួយបែងចែកដីក្នុងចំណោមកុលសម្ព័ន្ធ។
Numbers 34:24
ព័ត៌មានទូទៅ៖
នេះបញ្ជីឈ្មោះបន្តរបស់បុរស ដែលនឹងជួយបែងចែកដីក្នុងចំណោមកុលសម្ព័ន្ធ។
Numbers 34:27
ព័ត៌មានទូទៅ៖
នេះបញ្ជីឈ្មោះបន្តរបស់បុរស ដែលនឹងជួយបែងចែកដីក្នុងចំណោមកុលសម្ព័ន្ធ។

---

35 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេ នៅវាលទំនាបស្រុកម៉ូអាប់ ជិតទន្លេយ័រដាន់ ទល់មុខនឹងក្រុងយេរីខូ ដោយបន្ទូលថា៖[2]«ចូរបង្គាប់ប្រជាជនអ៊ីស្រាអែលឲ្យ
ប្រគល់ទឹកដីខ្លះដែលជាចំណែករបស់ពួកគេឲ្យពួកលេវីផង។ ពួកគេត្រូវឲ្យក្រុងដើម្បីពួកលេវីបានរស់នៅ ហើយវាលស្មៅនៅជុំវិញក្រុងទាំងនោះផងដែរ។
[3]ដូច្នេះ ពួកលេវីនឹងមានក្រុងទាំងនេះសម្រាប់រស់នៅ។ ចំណែក វាលស្មៅនឹងបានសម្រាប់ហ្វូងសត្វ និងសម្រាប់សត្វពាហនៈឯទៀតៗរបស់ពួកគេ ដែលជាកម្មសិទ្ធិរបស់
ពួកគេ។[4]វាលស្មៅនៅជុំវិញទីក្រុងដែលប្រគល់ឲ្យពួកលេវីនោះ ត្រូវគិតចាប់ពីកំពែងក្រុងចេញទៅក្រៅ ចម្ងាយមួយពាន់ហត្ថគ្រប់ទិសទាំងអស់។
[5]អ្នករាល់គ្នាត្រូវវាស់ខាងក្រៅទីក្រុងនៅទិសខាងកើតពីរពាន់ហត្ថ នៅទិសខាងត្បូងពីរពាន់ហត្ថនៅ នៅទិសខាងលិចពីរពាន់ហត្ថ និងនៅទិសខាងជើងពីរពាន់ហត្ថ។ នេះជា
វាលស្មៅសម្រាប់ក្រុងរបស់ពួកគេ។ ទីក្រុងត្រូវស្ថិតនៅចំកណ្តាលដីនោះ។
[6]ទីក្រុងទាំងប្រាំមួយ ដែលអ្នករាល់គ្នាឲ្យដល់ពួកលេវី នោះត្រូវឲ្យមានទីក្រុងសម្រាប់ជាជម្រក។ អ្នករាល់គ្នាត្រូវទុកកន្លែងទាំងនេះសម្រាប់ឲ្យអ្នកណាដែលសម្លាប់មនុស្ស
បានរត់ភៀសខ្លួនទៅ។[7]អ្នករាល់គ្នាត្រូវឲ្យទីក្រុងសែសិបពីរទៀតដល់ពួកគេ។ ដូច្នេះ ទីក្រុងទាំងអស់ដែលត្រូវឲ្យដល់ពួកលេវី នោះមានចំនួនសែសិបប្រាំបី។ អ្នករាល់គ្នា
ក៏ត្រូវប្រគល់វាលស្មៅសម្រាប់ក្រុងនីមួ្ួៗផងដែរ។
[8]កុលសម្ព័ន្ធធំជាងគេរបស់កូនចៅអ៊ីស្រាអែល គឺកុលសម្ព័ន្ធដែលមានដីច្រើន ត្រូវប្រគល់ក្រុងឲ្យច្រើន ហើយកុលសម្ព័ន្ធតូច ត្រូវឲ្យក្រុងតិច»។
កុលសម្ព័ន្ធនីមួយៗត្រូវប្រគល់ឲ្យពួកលេវី តាមចំណែកដែលពួកគេទទួលបាន។
[9]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេ ដោយបន្ទូលថា៖[10]«ចូរប្រាប់ប្រជាជនអ៊ីស្រាអែលថា៖ «នៅពេលអ្នករាល់គ្នាឆ្លងទន្លេយ័រដាន់ ចូលទៅក្នុងស្រុកកាណានរួច
ហើយ[11]នោះអ្នករាល់គ្នាត្រូវជ្រើសរើសយកក្រុងខ្លះសម្រាប់ទុកជាកន្លែងឲ្យអ្នកណាដែលបានសម្លាប់មនុស្សដោយអចេតនាភៀសខ្លួនមកជ្រក។
[12]ក្រុងទាំងនោះជាជម្រករបស់អ្នករាល់គ្នា ឲ្យរួចពីអ្នកសងសឹក។ ធ្វើដូច្នេះ អ្នកដែលត្រូេវជាប់ចោទនោះនឹងមិនត្រូវសម្លាប់មុនពេលឈរកាត់ក្តីនៅចំពោះ
មុខសហគមន៍ឡើយ។[13]អ្នករាល់គ្នាត្រូវជ្រើសរើសក្រុងប្រាំមួយសម្រាប់ធ្វើជាក្រុងជម្រក។

generated on Wed Sep 10 16:16:32 2025

[14]អ្នកត្រូវផ្តល់ឲ្យក្រុងជម្រកបីស្ថិតនៅឯនាយទន្លេយ័រដាន់ និងក្រុងបីទៀតនៅក្នុងស្រុកកាណាន។ ក្រុងទាំងនេះគឺសម្រាប់ជាក្រុងជម្រក។ សម្រាប់ប្រជាជនអ៊ីស្រាអែល
សម្រាប់ជនបរទេស និងសម្រាប់អស់អ្នកកំពុងរស់នៅជាមួយអ្នករាល់គ្នា។[15]ក្រុងទាំងប្រាំមួយនេះគឺសម្រាប់ទុកជាកន្លែងឲ្យអ្នកណាដែលបានសម្លាប់មនុស្សដោយអចេតនា
ភៀសខ្លួនមកជ្រក។
[16]ប៉ុន្តែ ប្រសិនបើជនជាប់ចោទនោះ យករបស់អ្វីមួយធ្វើពីដែក វាយជនរងគ្រោះ ហើយប្រសិនបើជនរងគ្រោះនោះស្លាប់ ជនជាប់ចោទនោះគឺជាឃាតក។ គេត្រូវតែទទួល
ទោសដល់ស្លាប់។[17]ប្រសិនបើ ជនជាប់ចោទនោះកាន់ដុំថ្មវាយជនរងគ្រោះ ដែលអាចធ្វើឲ្យជនរងគ្រោះស្លាប់បាន ហើយប្រសិនបើជនរងគ្រោះនោះស្លាប់ ជនជាប់ចោទនោះ
គឺជាឃាតក។ គេត្រូវតែទទួលទោសដល់ស្លាប់។[18]ប្រសិនបើជនជាប់ចោទយករបស់អ្វីមួយធ្វើពីឈើ វាយអ្នកវាយគ្រោះ ដែលអាចធ្វើឲ្យជនរងគ្រោះស្លាប់បាន
ហើយប្រសិនបើ ជនរងគ្រោះនោះស្លាប់ ជនជាប់ចោទនោះ គឺជាឃាតក។ គេត្រូវតែទទួលទោសដល់ស្លាប់។
[19]អ្នកដែលត្រូវសងសឹកនឹងឈាម នោះត្រូវតែសម្លាប់ឃាតកនោះវិញ។ នៅពេលអ្នកសងសឹកជួបប្រទះឃើញអ្នកនោះវេលាណា អ្នកត្រូវសងសឹកនឹងឈាមនោះត្រូវតែ
សម្លាប់ឃាតកនោះ[20]ប្រសិនបើអ្នកនោះបានវាយគេដោយចិត្តស្អប់ ឬបានលបចោលគេនឹងអ្វីមួយ ដែលធ្វើឲ្យជនរងគ្រោះស្លាប់[21]ឬបានវ៉ៃគេនឹងដៃដោយចិត្តស្អប់ ដែលធ្វើ
ឲ្យជនរងគ្រោះស្លាប់ នោះជនជាប់ចោទដែលវ៉ៃគេនោះ ត្រូវតែទទួលទោសដល់ស្លាប់។ គេគឺជាឃាតក អ្នកដែលត្រូវសងសឹកនឹងឈាមនោះត្រូវសម្លាប់ឃាតកនោះវិញ ក្នុង
វេលាដែលជួបឃាតកនោះ។
[22]ប៉ុន្តែ ប្រសិនបើជនជាប់ចោទស្រាប់តែវាយជនរងគ្រោះដោយអចេតនា ទាំងគ្មានចិត្តសម្អប់សោះ ឬមិនបានលបចោលរបស់អ្វីមួយទៅលើជនរងគ្រោះ[23]ដែលអាចធ្វើឲ្យ
ជនរងគ្រោះស្លាប់ ជនជាប់ចោទនោះមិនមែនជាសត្រូវរបស់ជនរងគ្រោះទេ គាត់គ្មានបំណងធ្វើឲ្យជនរងគ្រោះឈឺចាប់ទេ។ ប៉ុន្តែ នេះជាអ្វីដែលអ្នករាល់គ្នាត្រូវធ្វើ
បើជនរងគ្រោះនោះស្លាប់។
[24]ក្នុងករណីសហគមន៍ត្រូវសម្រុះសម្រួលរវាងជនជាប់ចោទ និងអ្នកសងសឹកនឹងឈាម តាមមូលដ្ឋានច្បាប់[25]សហគមន៍ត្រូវរំដោះជនជាប់ចោទនោះ ពីកណ្តាប់ដៃរបស់អ្នក
សងសឹកនឹងឈាម។ សហគមន៍ត្រូវនាំអ្នកនោះវិលត្រឡប់ទៅក្រុងជម្រក ដែលខ្លួនបានរត់ភៀសខ្លួនទៅ ហើយគាត់ត្រូវរស់នៅក្នុងក្រុងនោះ រហូតដល់ពេលមហាបូជាចារ្យ
ដែលបានតែងតាំងដោយប្រេងបរិសុទ្ធក្នុងជំនាន់នោះស្លាប់។
[26]ប៉ុន្តែ ប្រសិនបើជនជាប់ចោទចេញហួសព្រំប្រទល់ក្រុងជម្រកដែលខ្លួនរត់ភៀសខ្លួនទៅនោះ[27]ហើយអ្នកសងសឹកនឹងឈាម ជួបគាត់នៅខាងក្រៅព្រំប្រទល់ក្រុងជម្រក រួច
សម្លាប់គាត់ជនជាប់ចោទ អ្នកសងសឹកនឹងឈាមនោះគ្មានទោសជាឃាតកទេ។[28]នេះព្រោះតែជនជាប់ចោទត្រូវរស់នៅក្នុងក្រុងជម្រក រហូតដល់មហាបូជាចារ្យស្លាប់។
បន្ទាប់ពីមហាបូជាចារ្យស្លាប់ ទើបជនជាប់ចោទអាចវិលត្រឡប់ទៅស្រុកដែលគាត់មានលំនៅដ្ឋានរបស់ខ្លួនវិញបាន។
[29]ទាំងនេះជាច្បាប់បញ្ញត្តសម្រាប់អ្នករាល់នៅគ្រប់ជំនាន់ និងគ្រប់ទីកន្លែងដែលអ្នករាល់គ្នារស់នៅ។[30]អ្នកណាក៏ដោយដែលសម្លាប់មនុស្សម្នាក់ គេត្រូវសម្លាប់ឃាតក
នោះវិញ នៅពេលដែលមានសាក្សីជាច្រើនធ្វើបន្ទាល់។ ប៉ុន្តែ បើមានសាក្សីតែម្នាក់ គេមិនអាចសម្លាប់ជននោះបានឡើយ។
[31]អ្នករាល់គ្នាក៏មិនត្រូវទទួលសំណូកអ្វីនឹងលោះជីវិតឃាតករដែលជាប់ចោទពីបទមនុស្សឃាតឡើយ។ ត្រូវតែសម្លាប់អ្នកនោះកុំខាន[32]ក៏មិនត្រូវទទួលសំណូកអ្វីនឹងលោះ
អ្នកដែលបានរត់ទៅជ្រកក្នុងក្រុងជម្រកនោះដែរ។ អ្នករាល់គ្នាមិនត្រូវឲ្យគេត្រឡប់មកនៅក្នុងស្រុករបស់គាត់វិញ រហូតដល់មមហាបូជាចារ្យស្លាប់។
[33]មិនត្រូវបំពុលស្រុកដែលអ្នករាល់គ្នាទៅរស់នៅតាមរបៀបនេះឡើយ ដ្បិត ឈាមរបស់ឃាតកនឹងបំពុលស្រុកនោះ។ គ្មានតង្វាយធួនណាអាចលោះស្រុកនោះបានឡើយ
នៅពេលឈាមបានស្រក់លើស្រុកនោះហើយ គឺមានតែឈាមនៃអ្នកដែលបានកម្ចាយឈាមនោះប៉ុណ្ណោះ។[34]ដូច្នេះ អ្នករាល់គ្នាមិនត្រូវធ្វើឲ្យស្រុកដែលអ្នករាល់គ្នាចូលទៅ
រស់នៅទៅជាសៅហ្មងឡើយ ពីព្រោះយើងក៏នៅក្នុងស្រុកនោះដែរ។ ដ្បិត យើងជាព្រះអម្ចាស់ ដែលរស់នៅក្នុងចំណោមកូនចៅអ៊ីស្រាអែល»។

Numbers 35:1
នៅវាលទំនាប
តំបន់ដ៏ធំមួយមានដីធំល្វឹងល្វើយ។
ប្រគល់ទឹកដីខ្លះដែលជាចំណែករបស់ពួកគេឲ្យពួកលេវីផង
ព្រះអម្ចាស់មិនបានប្រគល់ទឹកដីរបស់ពួកលេវីទេ ដូច្នេះ
ពួកគេត្រូវរស់នៅក្នុងក្រុងនានា ដែលជាកម្មសិទ្ធិរបស់កុលសម្ព័ន្ធដទៃទៀត។
វាលស្មៅ
តំបន់មួយនៃដីដែលសត្វចិញ្ចឹមនៅលើស្មៅ
Numbers 35:3
មួយពាន់ហត្ថ
«១០០០ ហត្ថ» ។ បើចាំបាច់ត្រូវប្រើឯកតាចម្ងាយទំនើបនេះជាវិធីល្អមួយ។
ការបកប្រែផ្សេងទៀត «៤៥៧ ម៉ែត្រ
Numbers 35:5
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេអំពីអ្វី ដែលប្រជាជនត្រូវធ្វើ។
ពីរពាន់ហត្ថ
«២,០០០ ហត្ថ» ។ មួយហត្ថស្មើ ៤៦ សង់ទីម៉ែត្រ។
Numbers 35:6
អ្នកណាដែលសម្លាប់មនុស្ស
សំដៅទៅលើមនុស្ស ដែលបានសម្លាប់នរណាម្នាក់ ប៉ុន្តែមិនទាន់បានកំណត់ថាតើ
ពួកគេបានសម្លាប់មនុស្សដោយចេតនា ឬដោយចៃដន្យទេ។
សែសិបពីរ.....សែសិបប្រាំបី
ពីរ ... សែសិបប្រាំបី។ «៤២ ... ៤៨»
Numbers 35:8
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេអំពីអ្វី ដែលប្រជាជនត្រូវធ្វើ។
Numbers 35:9
ដោយអចេតនា
«ចៃដន្យ»
Numbers 35:12
អ្នកសងសឹក
សំដៅទៅលើសាច់ញាតិជិតស្និទ្ធ ដែលស្វែងរកការសងសឹក
ដោយសម្លាប់បុរសជាប់ចោទ។
ធ្វើដូច្នេះ អ្នកដែលត្រូវជាប់ចោទនោះនឹងមិនត្រូវសម្លាប់មុនពេលឈរកាត់ក្តីនៅចំពោះ
មុខសហគមន៍ឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីកុំឱ្យមាននរណាម្នាក់សម្លាប់បុរស ដែលត្រូវបានចោទប្រកាន់មុន
ពេលសហគមន៍អាចវិនិច្ឆ័យគាត់នៅក្នុងតុលាការ»
Numbers 35:14
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេអំពីអ្វី ដែលប្រជាជនត្រូវធ្វើ។
Numbers 35:16
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេអំពីអ្វី ដែលប្រជាជនត្រូវធ្វើ។
គេត្រូវតែទទួលទោសដល់ស្លាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រាកដជាត្រូវប្រហារជីវិតគាត់»
Numbers 35:19
ត្រូវសងសឹកនឹងឈាម
នៅទីនេះពាក្យ «ឈាម» ជាពាក្យទាក់ទងសម្រាប់ឃាតកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកសងសឹកអំពើឃាតកម្ម» ឬ «សាច់ញាតិស្វែងរកការសងសឹក»
នោះជនជាប់ចោទដែលវ៉ៃគេនោះ ត្រូវតែទទួលទោសដល់ស្លាប់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«សាច់ញាតិពិតជាត្រូវកាត់ទោសបុរស ដែលត្រូវគេចោទប្រកាន់» ឬ
«បុរសដែលត្រូវចោទប្រកាន់ត្រូវតែស្លាប់»
Numbers 35:22
ទាំងគ្មានចិត្តសម្អប់សោះ
«ដោយមិនមានគម្រោងស្អប់ជាមុន»
ដោយមិននិយាយកុហកនៅក្នុងការរង់ចាំ
នរណាម្នាក់មានចេតនាស្វែងរកមធ្យោបាយ ដើម្បីធ្វើបាបមនុស្សម្នាក់ផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

ត្រូវបានគេនិយាយដូចជានរណាម្នាក់កំពុងលាក់ខ្លួន
ដើម្បីវាយឆ្មក់មនុស្សម្នាក់ទៀត។ ការបកប្រែផ្សេងទៀត
«ដោយគ្មានចេតនាព្យាយាមធ្វើបាបជនរងគ្រោះ»
Numbers 35:24
សងសឹកនឹងឈាម
នៅទីនេះពាក្យ «ឈាម» ជាពាក្យទាក់ទងសម្រាប់ឃាតកម្ម។
បកប្រែពាក្យដូចនៅក្នុង ៣៥:១៩។ ការបកប្រែផ្សេងទៀត
«អ្នកដែលសងសឹកអំពើឃាតកម្ម» ឬ «សាច់ញាតិស្វែងរកការសងសឹក»
សហគមន៍ត្រូវតែជួយសង្គ្រោះជនជាប់ចោទ
មានន័យថា បើសហគមន៍វិនិច្ឆ័យថាការស្លាប់ដោយចៃដន្យ
នោះពួកគេត្រូវតែជួយសង្គ្រោះបុរសជាប់ចោទពីសាច់ញាតិ ដែលចង់សម្លាប់គាត់។
បើសហគមន៍វិនិច្ឆ័យថាការស្លាប់មិនមែនដោយចៃដន្យទេ
នោះសាច់ញាតិត្រូវតែកាត់ទោសបុរសដែលត្រូវចោទប្រកាន់។
ដែលបានតែងតាំងដោយប្រេងបរិសុទ្ធ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលអ្នកបានចាក់ប្រេងដោយប្រេងបរិសុទ្ធ»
Numbers 35:26
សងសឹកនឹងឈាម
នៅទីនេះពាក្យ «ឈាម» ជាពាក្យទាក់ទងសម្រាប់ឃាតកម្ម។
បកប្រែពាក្យដូចនៅក្នុង ៣៥:១៩។ ការបកប្រែផ្សេងទៀត
«អ្នកដែលសងសឹកអំពើឃាតកម្ម» ឬ «សាច់ញាតិស្វែងរកការសងសឹក»)
Numbers 35:29
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តប្រាប់លោកម៉ូសេអំពីអ្វី ដែលប្រជាជនត្រូវធ្វើ។
នៅគ្រប់ជំនាន់
«និងកូនចៅរបស់អ្នកទាំងអស់ ដែលនឹងរស់នៅក្រោយអ្នក»
គេត្រូវសម្លាប់ឃាតកនោះវិញ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នរណាម្នាក់ត្រូវតែសម្លាប់ឃាតករ»
នៅពេលដែលមានសាក្សីជាច្រើនធ្វើបន្ទាល់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«យោងទៅតាមសក្ខីកម្មរបស់សាក្សី» ឬ
«ក្នុងនាមជាសាក្សីផ្តល់សក្ខីកម្មចំពោះឃាតកម្ម»
ប៉ុន្តែ បើមានសាក្សីតែម្នាក់ គេមិនអាចសម្លាប់ជននោះបានឡើយ
សក្ខីកម្មរបស់សាក្សីម្នាក់មិនគ្រប់គ្រាន់ទេ
ក្នុងការប្រហារជីវិតមនុស្សម្នាក់ពីបទឃាតកម្ម។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែពាក្យរបស់សាក្សីតែម្នាក់គត់
មិនគ្រប់គ្រាន់ទេសម្រាប់អ្នកដើម្បីកាត់ទោសមនុស្សម្នាក់»
Numbers 35:31
ត្រូវតែសម្លាប់អ្នកនោះកុំខាន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែសម្លាប់គាត់»
ក៏មិនត្រូវ....ត្រឡប់មកនៅក្នុងស្រុករបស់គាត់វិញ
បានន័យថា បុរសនោះនឹងចាកចេញពីទីក្រុងភៀសខ្លួនហើយត្រឡប់ទៅផ្ទះវិញ។
ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវ ... អនុញ្ញាតឱ្យគាត់ចាកចេញពីទីក្រុងភៀសខ្លួន
និងត្រឡប់ទៅផ្ទះ ដើម្បីរស់នៅលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គាត់»
ក្នុងផ្លូវនេះ
«ដោយទទួលយកតម្លៃលោះ»
Numbers 35:33
មិនត្រូវបំពុលស្រុកដែលអ្នករាល់គ្នាទៅរស់នៅតាមរបៀបនេះឡើយ ដ្បិតឈាមរបស់ឃាតកនឹង
បំផុលស្រុកនោះ
ការធ្វើឱ្យដីមិនអាចទទួលយកបា នចំពោះព្រះអម្ចាស់ត្រូវបានគេនិយាយ
ដូចជាវាកំពុងបំពុលដី។ ការបកប្រែផ្សេងទៀត
«កុំធ្វើឱ្យដីដែលអ្នករស់នៅមិនអាចទទួលយកបាន ចំពោះទ្រង់តាមរបៀបនេះ
ព្រោះឈាមពីឃាតកម្មធ្វើឱ្យដីមិនអាចទទួលយកបានចំពោះព្រះជាម្ចាស់»
តាមវិធីនេះ
មានន័យថា ដោយមិនគោរពច្បាប់ទាក់ទងនឹងមនុស្ស ដែលសម្លាប់នរណាម្នាក់។
គ្មានតង្វាយធួននាអាចលោះស្រុកនោះបានឡើយ នៅពេលឈាមបានស្រក់លើស្រុកនោះហើយ
គឺមានតែឈាមនៃអ្នកដែលបានកម្ចាយឈាមនោះប៉ុណ្ណោះ
សំដៅទៅលើពេលមនុស្សម្នាក់សម្លាប់មនុស្សម្នាក់ទៀតដោយចេតនា។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលមាននរណាម្នាក់បង្ហូរឈាមនៅលើទឹកដី
មានតែការប្រហារជីវិតឃាតករប៉ុណ្ណោះ
ដែលអាចធ្វើតង្វាយលោះសម្រាប់ទឹកដីនេះ»

---

36 [1]បន្ទាប់មក ពួកមេដឹកនាំរបស់ក្រុមគ្រួសារផ្សេងៗនៃអំបូរកាឡាដ ជាកូនរបស់លោកម៉ាកៀរ (ជាកូនរបស់លោកម៉ាណាសេ) ដែលមកពីអំបូរកូនចៅរបស់លោក
យ៉ូសែប បានចូលមក ហើយបាននិយាយនៅចំពោះលោកម៉ូសេ និងនៅចំពោះមុខពួកមេដឹកនាំ ដែលជាមេលើកុលសម្ព័ន្ធរបស់ប្រជាជនអ៊ីស្រាអែលថា៖
[2]«ព្រះអម្ចាស់បានបង្គាប់លោក ដែលជាម្ចាស់របស់យើងខ្ញុំ ឲ្យប្រគល់ចំណែកដីដល់ប្រជាជនអ៊ីស្រាអែល ដោយការចាប់ឆ្នោត។ ហើយព្រះអម្ចាស់ក៏បានបង្គាប់លោក
ឲ្យប្រគល់ទឹកដីជាចំណែករបស់លោកស្ដេធិហាត ជាបងប្អូនរបស់យើងខ្ញុំ ទៅឲ្យកូនស្រីរបស់គាត់ដែរ។
[3]ប៉ុន្តែ ប្រសិនបើកូនស្រីរបស់គាត់រៀបការជាមួយកូនប្រុសរបស់កុលសម្ព័ន្ធណាមួយទៀតនៃជនជាតិអ៊ីស្រាអែល នោះចំណែកទឹកដីរបស់ពួកនាងនឹងត្រូវកាត់ចេញពី
ចំណែកមរតកនៃដូនតារបស់យើងខ្ញុំ។ ដីនោះនឹងត្រូវបន្ថែមនៅក្នុងចំណែកកុលសម្ព័ន្ធដែលនាងបានទៅចូលរួមជាមួយ។ ក្នុងករណីនោះ ដីនោះនឹងត្រូវដកចេញ
ពីចំណែកមរតករបស់យើងខ្ញុំ។[4]ហើយក្នុងករណីនោះ នៅពេលឆ្នាំនៃមេត្តាករុណារបស់ប្រជាជនអ៊ីស្រាអែលមកដល់ នោះចំណែកមរតករបស់ពួកនាងនឹងត្រូវដាក់ចូលក្នុង
ចំណែកមរតកនៃកុលសម្ព័ន្ធដែលពួកនាងបានចូលរួម។ ដូច្នេះ ចំណែកមរតករបស់ពួកនាងនឹងត្រូវដកចេញពីចំណែកមរតកនៃដូនតារបស់យើងខ្ញុំ»។
[5]ដូច្នេះ លោកម៉ូសេបានបង្គាប់ដល់ប្រជាជនអ៊ីស្រាអែល តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ថា៖ «អ្វីដែលកុលសម្ព័ន្ធរបស់កូនចៅលោកយ៉ូសែបគេបាននិយាយនៅពេលនេះ
គឺត្រឹមត្រូវ។[6]នេះជាអ្វីដែលព្រះអម្ចាស់បានបង្គាប់ ពីដំណើរនៃពួកកូនស្រីស្ដេធិហាត។ ព្រះអង្គបានមានបន្ទូលថា៖ «ចូរឲ្យពួកគេរៀបការជាមួយអ្នកណាដែលគេគិតថា
ល្អបំផុត ប៉ុន្តែ គេត្រូវរៀបការជាមួយអ្នកនៅក្នុងកុលសម្ព័ន្ធនៃឪពុករបស់ពួកគេតែប៉ុណ្ណោះ»។
[7]មិនត្រូវឲ្យមានមរតករបស់កូនចៅអ៊ីស្រាអែល ប្ដូរពីកលសម្ព័ន្ធមួយ ទៅកុលសម្ព័ន្ធមួយទៀតឡើយ។ ប្រជាជនអ៊ីស្រាអែលម្នាក់ៗ ត្រូវនៅជាប់នឹងចំណែកមរតកនៃ
កុលសម្ព័ន្ធដូនតារបស់ខ្លួន។
[8]កូនស្រីទាំងអស់របស់ប្រជាជនអ៊ីស្រាអែលដែលមានចំណែកមរតកក្នុងកុលសម្ព័ន្ធរបស់នាង នោះនាងត្រូវតែរៀបការជាមួយនរណាម្នាក់ដែលស្ថិតនៅក្នុង
កុលសម្ព័ន្ធឪពុករបស់នាង។ ធ្វើបែបនេះ គឺដើម្បីឲ្យប្រជាជនអ៊ីស្រាអែលបានគ្រប់គ្រងមរតកពីដូនតារបស់ពួកគេ[9]មិនត្រូវមានចំណែកមរតកណាមួយ ប្ដូរពី
កុលសម្ព័ន្ធមួយ ទៅកុលសម្ព័ន្ធមួយទៀតឡើយ។ កុលសម្ព័ន្ធនៃប្រជាជនអ៊ីស្រាអែលទាំងអស់ត្រូវថែរក្សាចំណែកមរតករបស់ខ្លួន។
[10]ដូច្នេះ ពួកកូនស្រីរបស់លោកស្ដេធិហាតក៏ធ្វើដូចដែលព្រះអម្ចាស់បានបង្គាប់មកលោកម៉ូសេ[11]នាងម៉ាសឡា នាងធើសា នាងហុកឡា នាងមីលកា និងនាងណូហា ជាកូន
ស្រីរបស់លោកស្ដេធិហាត បានរៀបការជាមួយកូនចៅរបស់ម៉ាណាសេ។[12]ពួកគេបានរៀបការចូលទៅក្នុងអំបូរនៃកូនចៅរបស់លោកម៉ាណាសេ ជាកូនលោកយ៉ូសែប។
ដូច្នេះ មរតករបស់ពួកគេក៏នៅតែស្ថិតក្នុងកុលសម្ព័ន្ធនៃអំបូររបស់ឪពុកពួកគេ។
[13]ទាំងនេះគឺជាបញ្ញត្ត និងច្បាប់ដែលព្រះអម្ចាស់បានប្រទានដល់ពួកកូនចៅអ៊ីស្រាអែល តាយរយៈលោកម៉ូសេ នៅវាលទំនាបស្រុកម៉ូអាប់ ជិតទន្លេយ័រដាន់ នៅក្រុង
យេរីខូ។

Numbers 36:1
លោកម៉ាកៀរ
នេះជាឈ្មោះបុរស។ បកប្រែឈ្មោះនេះដូចនៅក្នុង ២៦:២៨។
ព្រះអម្ចាស់បានបង្គាប់លោក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានប្រាប់អ្នក»

generated on Wed Sep 10 16:16:32 2025

លោកស្លូធិហាត
នេះជាឈ្មោះបុរស។ បកប្រែឈ្មោះនេះដូចនៅក្នុង ២៦:៣៣។
Numbers 36:3
ត្រូវកាត់ចេញពីដូនតារបស់យើងខ្ញុំ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នឹងលែងជាចំណែករបស់ដូនតាយើង»
នឹងត្រូវបន្ថែម
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«វានឹងជាកម្មសិទ្ធិរបស់អ្នក»
ត្រូវកាត់ចេញពីចំណែកមរតក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«វានឹងលែងជាចំណែកមរតករបស់យើងទៀតហើយ»
នៅពេលឆ្នាំនៃមេត្តាករុណារបស់កូនចៅ
សំដៅទៅលើការប្រារព្ធពិធីដែលកើតឡើងរៀងរាល់ ៥០ ឆ្នាំម្តង។
នៅក្នុងការប្រារព្ធពិធីនេះដីទាំងអស់ ដែលនរណាម្នាក់បានលក់
ឬជួញដូរត្រូវតែវិលត្រឡប់ទៅម្ចាស់ដើមវិញ។
ចំណែករបស់ពួកគេនឹងត្រូវចូលរួម
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ចំណែករបស់ពួកគេនឹងក្លាយជាកម្មសិទ្ធិ»
ចំណែកមរតករបស់ពួកនាងនឹងត្រូវដកចេញពីចំណែកមរតកនៃដូនតារបស់យើងខ្ញុំ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេនឹងកាន់កាប់ដីរបស់កុលសម្ព័ន្ធរបស់យើង»
Numbers 36:5
តាមព្រះបន្ទូលរបស់ព្រះអម្ចាស់
«យោងទៅតាមអ្វីដែលព្រះអម្ចាស់មានបន្ទូល»
ចូរឲ្យពួកគេរៀបការជាមួយអ្នកណាដែលគេគិតថាល្អបំផុត
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ឱ្យពួកគេរៀបការជាមួយអ្នកណា ដែលពួកគេចង់បាន»
ប៉ុន្តែ គេត្រូវរៀបការជាមួយអ្នកនៅក្នុងកុលសម្ព័ន្ធនៃឪពុករបស់ពួកគេតែប៉ុណ្ណោះ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ប៉ុន្តែ
ពួកគេអាចរៀបការជាមួយនរណាម្នាក់ មកពីកុលសម្ព័ន្ធឪពុករបស់ពួកគេ»
Numbers 36:7
មិនត្រូវឲ្យ
ពាក្យ «ចំណែក» តំណាងឱ្យចំណែកដី
ដែលកុលសម្ព័ន្ធនីមួយៗទទួលបានជាមរតក។ ការបកប្រែផ្សេងទៀត
«គ្មានចំណែកដី»
Numbers 36:8
មានចំណែកមរតកក្នុងកុលសម្ព័ន្ធរបស់នាង
«អ្នកណាជាម្ចាស់ដីលើកុលសម្ព័ន្ធរបស់នាង»
មានចំណែកមរតក
ដីដែលត្រកូលនីមួយៗមាន ត្រូវបានគេនិយាយថា
ជាមរតកដែលពួកគេបានទទួល។
មិនត្រូវមានចំណែកមរតកណាមួយ ប្តូរពីកុលសម្ព័ន្ធមួយ ទៅកុលសម្ព័ន្ធមួយទៀតឡើយ
ការផ្ទេរកម្មសិទ្ធិពីកុលសម្ព័ន្ធមួយ ទៅកុលសម្ព័ន្ធមួយ ត្រូវបានគេនិយាយថា
ទ្រព្យសម្បត្តិបានផ្ទេរពីដៃរបស់មនុស្សម្នាក់ ទៅដៃរបស់មនុស្សម្នាក់ទៀត។
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់អាចផ្ទេរកម្មសិទ្ធិកាន់កាប់ដីណាមួយ
ពីកុលសម្ព័ន្ធមួយទៅកុលសម្ព័ន្ធមួយបានឡើយ»
Numbers 36:10
នាងម័សឡា នាងធើសា នាងហុកឡា នាងមីលកា និងនាងណូហា
ទាំងនេះជាឈ្មោះស្ត្រី។ បកប្រែឈ្មោះទាំងនេះដូចនៅ ក្នុង ២៦:៣៣ ។
មរតករបស់ពួកគេ
ទឹកដីដែលកូនស្រីរបស់ស្លូធិហាតម្នាក់ៗកាន់កាប់ ត្រូវបានគេនិយាយថាជាមរតក
ដែលពួកគេបានទទួល។ ការបកប្រែផ្សេងទៀត
«ទឹកដីដែលពួកគេបានទទួលជាមរតក»
Numbers 36:13
វាលទំនាប
តំបន់ដ៏ធំមួយមានដីដ៏ល្វឹងល្វើយ។

ចោទិយកថា

1 [1]នេះជាពាក្យដែលលោកម៉ូសេបានមានប្រសាសន៍ទៅកាន់ជនជាតិអ៊ីស្រាអែលទាំងអស់ នៅឯខាងនាយទន្លេយ័រដាន់ ក្នុងទីរហោស្ថានតំបន់អារ៉ាបា
នៅទល់មុខនឹងស៊ូភ ត្រង់ចន្លោះប៉ារ៉ាន តូផែល ឡាបាន់ ព្រមទាំងហាសេរ៉ូត និងឌីសាហាប។[2]បន្ទាប់ពីបានធ្វើដំណើរអស់រយៈពេលដប់មួយថ្ងៃចេញពីហោរែប
នៅតាមតំបន់ភ្នំសៀរ ទៅកាន់កាដេស បារនា។
[3]ការនេះកើតឡើងនៅក្នុងឆ្នាំសែសិប នៅខែទីដប់មួយ នៅថ្ងៃទីមួយនៃខែនោះ លោកម៉ូសេបានមានប្រសាសន៍ទៅកាន់ជនជាតិអ៊ីស្រាអែល
អំពីព្រះបន្ទូលដែលព្រះជាម្ចាស់បង្គាប់ដល់លោកឲ្យប្រាប់គេពួកគេ។[4]ការនេះកើតឡើងបន្ទាប់ពីព្រះជាម្ចាស់បានប្រហារលើព្រះបាទស៊ីហុន ជាស្តេចជនជាតិអាម៉ូរី
ដែលគង់នៅក្រុងហេសបូន និងព្រះបាទអុក ជាស្តេចស្រុកបាសាន ដែលគង់នៅក្រុងអាសថារ៉ូត និងអេទ្រី។
[5]កាលលោកម៉ូសេចាប់ផ្តើមបង្រៀនក្រឹត្យវិន័យ នៅខាងនាយទន្លេយ័រដាន់ ក្នុងស្រុកម៉ូអាប់ថា៖[6]«ព្រះអម្ចាស់ជាព្រះនៃយើងបានមានព្រះបន្ទូលមកកាន់ពួកយើង
នៅលើហោរែបថា អ្នករាល់គ្នាបានរស់នៅនៅលើភ្នំនេះជាយូរណាស់មកហើយ។
[7]ចូរចេញទៅហើយបន្តដំណើររបស់អ្នក ហើយឆ្ពោះទៅកាន់តំបន់ភ្នំជនជាតិអាម៉ូរី ហើយទៅកាន់គ្រប់ទីកន្លែងដែលនៅជិតទីនោះនៅ
ព្រមទាំងវាលទំនាបជ្រលងទន្លេយ័រដាន់នៅតំបន់ភ្នំ តំបន់វាលទំនាប ក្នុងតំបន់ណេកិប និងឆ្នេរសមុទ្រ ស្រុកកាណាន និងនៅក្នុងប្រទេសលីបង់ រហូតដល់ទន្លេធំអឺប្រាត។
[8]មើល៍ យើងប្រគល់ស្រុកឲ្យអ្នករាល់គ្នាហើយ ចូរកាន់កាប់ទឹកដីនោះទៅ ជាទឹកដីដែលព្រះជាម្ចាស់បានសន្យាប្រគល់ឲ្យលោកអ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប
ជាបុព្វបុរសរបស់អ្នករាល់គ្នា ព្រមទាំងពូជពង្សដែលកើតមកតាមក្រោយផ្សេងទៀត។
[9]នៅពេលនោះយើងបានប្រាប់អ្នករាល់គ្នាថា ខ្ញុំមិនអាចទទួលខុសត្រូវអ្នករាល់គ្នាតែម្នាក់ឯងបានទេ។[10]ព្រះជាម្ចាស់ជាព្រះនៃអ្នកបានធ្វើឲ្យអ្នករាលគ្នាកើនគ្នាច្រើន
ហើយមើល៍ សព្វថ្ងៃនេះ អ្នករាល់គ្នាមានចំនួនច្រើនដូចជាផ្កាយនៅលើមេឃ។[11]សូមព្រះជាម្ចាស់ ជាព្រះនៃបុព្វបុរសអ្នករាល់គ្នា ប្រទានឲ្យអ្នករាល់គ្នាមានចំនួនច្រើន
មួយពាន់ដងលើសជាងនេះ ហើយប្រទានពរអ្នករាល់គ្នា ដូចព្រះបានសន្យានឹងអ្នករាល់គ្នារួចហើយ!
[12]ប៉ុន្តែ តើធ្វើដូចម្តេចឲ្យខ្ញុំតែម្នាក់ អាចទទួលបន្ទុកដ៏ច្រើន និងដោះស្រាយជម្លោះឲ្យអ្នករាល់គ្នាបានទៅ?[13]ចូរយកមនុស្សដែលមានប្រាជ្ញា មនុស្សដែលមានការយល់ដឹង
និងមនុស្សដែលមានកេរ្តិ៍ឈ្មោះល្អ ក្នុងកុលសម្ព័ន្ធនីមួយៗ ហើយយើងនឹងឲ្យពួកគេធ្វើជាមេដឹកនាំលើអ្នករាល់គ្នា។[14]អ្នករាល់គ្នាឆ្លើយតមមកខ្ញុំថា៖
«កិច្ចការដែលលោកបានប្រាប់នោះប្រសើរណាស់សម្រាប់ពួកយើង»។
[15]ដូច្នេះ ខ្ញុំបានជ្រើសរើសមេដឹកនាំនៃកុលសម្ពន្ធ៍របស់អ្នក គឺមនុស្សមានប្រាជ្ញា និងមនុស្សដែលមានកេរ្តិ៍ឈ្មោះល្អ ហើយតែងតាំងឲ្យពួកគេធ្វើជាមេដឹកនាំលើអ្នករាល់គ្នា
ជាមេដឹកនាំលើមួយពាន់នាក់ ជាមេដឹកនាំលើមួយរយនាក់ ជាមេដឹកនាំលើហាសិបនាក់ ជាមេដឹកនាំលើដប់នាក់ និងជាពួកមេដឹកនាំ តាមកុលសម្ព័ន្ធ។
[16]ខ្ញុំបានបង្គាប់ទៅពួកចៅក្រមរបស់អ្នករាល់គ្នានៅគ្រានោះថា ចូរស្តាប់ជម្លោះរបស់បងប្អូនរបស់អ្នករាល់គ្នា ហើយកាត់ក្តីដោយយុត្តិធម៌រវាងមនុស្សម្នាក់
និងបងប្អូនរបស់គាត់ ហើយនិងជនបរទេសដែលរស់នៅគាត់ផង។
[17]អ្នករាល់គ្នានឹងមិនត្រូវបង្ហាញភាពលំអៀងទៅលើនរណាម្នាក់នៅេពលមានជម្លោះកើតឡើងនោះទេ អ្នករាល់គ្នានឹងត្រូវស្តាប់ទាំងអ្នកតូច និងអ្នកធំដូចគ្នា។
អ្នករាល់គ្នានឹងមិនត្រូវភ័យខ្លាចមុខនៃមនុស្សណាឡើយ ដ្បិត ការកាត់ក្តីគឺស្ថិតលើព្រះជាម្ចាស់ បើរឿងនោះអ្នករាល់គ្នាពិបាកកាត់ក្តីពេក នោះអ្នករាល់គ្នានឹងនាំមកឯខ្ញុំ
ហើយខ្ញុំនឹងស្តាប់រឿងនោះ។[18]ខ្ញុំបង្គាប់អ្នករាល់គ្នានៅគ្រានោះថា គ្រប់កិច្ចការទាំងអស់ដែលអ្នករាល់គ្នាគួរធ្វើ។
[19]យើងធ្វើដំណើរចេញពីភ្នំហោរែប ហើយបានឆ្លងកាត់វាលរហោស្ថានដ៏ធំ គួរស្ញែងខ្លាចទាំងនោះ ដែលអ្នករាល់គ្នាបានឃើញ
នៅតាមផ្លូវរបស់ពួកយើងទៅកាន់ភ្នំរបស់ជនជាតិអាម៉ូរី ដូចព្រះអម្ចាស់ជាព្រះជាម្ចាស់របស់យើងបានបង្គាប់ដល់យើង ហើយយើងបានទៅដល់កាដេស បារនា។

generated on Wed Sep 10 16:16:32 2025

[20]ខ្ញុំបានប្រាប់អ្នករាល់គ្នាថា៖ «អ្នករាល់គ្នាបានមកដល់ភ្នំរបស់ជនជាតិអាម៉ូរី ដែលព្រះអម្ចាស់ជាព្រះជាម្ចាស់នៃយើង ប្រទានដល់យើង។[21]មើល៍
ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា បានរៀបចំទឹកដីនៅមុខអ្នករាល់គ្នាហើយ ចូរឡើងទៅកាន់កាប់
ដូចព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់អ្នករាល់គ្នាបានមានបន្ទូលមកអ្នករាល់គ្នាថារួចហើយថា កុំភ័យខ្លាច ឬតក់ស្លុតអ្វីឡើយ»។
[22]អ្នកទាំងអស់គ្នាបានចូលមកជួបខ្ញុំ ហើយនិយាយថា៖ «ចូរឲ្យពួកយើងចាត់មនុស្សឲ្យទៅមុខពួកយើង ដូច្នេះ ពួកគេអាចនឹងស្វែងរកទឹកដីសម្រាប់ពួកយើង
ហើយនាំពាក្យមកប្រាប់ពួកយើងអំពីផ្លូវដែលពួកយើងគួរតែវាយប្រហារ ព្រមទាំងទីក្រុងណាដែលយើងនឹងទៅដល់។[23]ខ្ញុំយល់ឃើញថាគំនិតនេះល្អ
ខ្ញុំបានចាត់មនុស្សដប់ពីរពីអ្នករាល់គ្នា គឺក្នុងកុលសម្ព័ន្ធមួយត្រូវយកមនុស្សម្នាក់។[24]ពួកគេបានចេញទៅ ហើយឡើងទៅកាន់តំបន់ភ្នំ រហូតដល់ភូមិអែលកុល
ហើយក៏ស៊ើបការណ៍នៅស្រុកនោះ។
[25]ពួកគេបានយកផលរបស់ដីនៅក្នុងដៃរបស់ពួកគេ និងបាននាំយកវាចុះដល់ពួកយើង។ ពួកគេព្រមទាំងនាំពាក្យមកប្រាប់ពួកយើងថា៖
«ស្រុកនោះគឺជាទឹកដីដែលព្រះអម្ចាស់ជាព្រះជាម្ចាស់នៃយើងប្រទានដល់ពួកយើង»។
[26]អ្នករាល់គ្នាមិនព្រមវាយប្រហារ តែបែរជាប្រឆាំងបះបោរនឹងសេចក្ដីបង្គាប់របស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នាវិញ។
[27]អ្នករាល់គ្នាត្អូញត្អែក្នុងត្រសាលរបស់អ្នករាល់គ្នា ហើយនិយាយថា៖ «ដោយព្រោះ ព្រះអម្ចាស់ស្អប់ពួកយើង បានជាព្រះអង្គនាំពួកយើងចាកចេញពីទឹកដីអេស៊ីប
ដើម្បីឲ្យពួកយើងធ្លាក់ចូលក្នុងដៃរបស់ជនជាតិអាម៉ូរី ហើយបំផ្លាញពួកយើង។[28]តើពួកយើងអាចទៅកន្លែងណាបាន? បងប្អូនរបស់យើងបានបំភ័យយើង
ដោយនិយាយថា៖ «ប្រជាជនទាំងនោះធំជាង និងខ្ពស់ជាងពួកយើង ក្រុងរបស់ពួកគេធំជាងយើង ហើយមានកំពែងការពារខ្ពស់ដល់មេឃ មួយទៀត
យើងបានឃើញកូនចៅអណាក់ នៅទឹកដីនោះដែរ»។
[29]បន្ទាប់មក ខ្ញុំនិយាយទៅកាន់អ្នករាល់គ្នាថា៖ «កុំភ័យខ្លាចឲ្យសោះ ហើយក៏មិនត្រូវខ្លាចពួកគេដែរ។[30]ព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា ជាព្រះដែលយាងនៅមុខអ្នករាល់គ្នា
ព្រះអង្គនឹងប្រយុទ្ធជំនួសអ្នករាល់គ្នា ដូចជាអ្វីៗដែលព្រះអង្គបានធ្វើលើទឹកដីអេស៊ីបនៅចំពោះមុខអ្នករាល់គ្នា[31]ព្រមទាំងនៅក្នុងទីរហោស្ថាន
ជាកន្លែងដែលអ្នករាល់គ្នាបានឃើញថា ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា បាននាំអ្នករាល់គ្នា ដូចជានាំបុត្ររបស់ព្រះអង្គ
ទៅគ្រប់កន្លែងដែលអ្នករាល់គ្នាទៅរហូតមកដល់កន្លែងនេះ។
[32]ប៉ុន្តែ ទោះបីយ៉ាងនោះក្តី អ្នករាល់គ្នានៅតែមិនជឿលើព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា[33]ជាព្រះដែលបានយាងនៅមុខអ្នកនៅតាមផ្លូវ
ដើម្បីស្វែងរកទីកន្លែងសម្រាប់អ្នករាល់គ្នាតម្លើងត្រសាល ដោយភ្លើងនៅពេលយប់ និងដោយពពកនៅពេលថ្ងៃ។
[34]ព្រះអម្ចាស់ឮសម្លេងរបស់អ្នករាល់គ្នាហើយ ព្រះអង្គព្រះពិរោធ ហើយមានព្រះបន្ទូលថា៖[35]«ក្នុងចំណោមមនុស្សអាក្រក់នៅជំនាន់នេះ
គ្មានអ្នកណាម្នាក់អាចឃើញទឹកដីល្អ ដែលយើងបានស្បថថា នឹងឲ្យបុព្វបុរសរបស់អ្នករាល់គ្នាឡើយ[36]លើកលែងតែកាលែប ជាកូនរបស់យេភូនេ
លោកនឹងឃើញទឹកដីនោះ។ យើងនឹងប្រទានទឹកដីណាដែលលោកបានដើរកាត់ ហើយកូនចៅរបស់លោកព្រោះលោកបានដើរតាមព្រះអម្ចាស់ទាំងស្រុង»។
[37]ហើយព្រះអម្ចាស់ក៏ព្រះពិរោធនឹងខ្ញុំដោយព្រោះតែអ្នករាល់គ្នា ព្រះអង្គមានបន្ទូលថា៖ «អ្នកក៏មិនបានចូលទៅក្នុងទឹកដីនោះដែរ[38]លោកយ៉ូស្វេ ជាកូនរបស់លោកនួន
ជាអ្នកដែលឈរនៅពីមុខអ្នករាល់គ្នា លោកនឹងទៅដល់ទីនោះ ចូរលើកទឹកចិត្តលោក ដ្បិត លោកនឹងដឹកនាំអ៊ីស្រាអែល ដើម្បីទៅយកវាជាមរតក។
[39]មួយវិញទៀត កូនតូចៗរបស់អ្នករាល់គ្នា ដែលអ្នករាល់គ្នានិយាយថា ពួកគេអាចទៅជាជនរងគ្រោះ ដែលសព្វថ្ងៃគេមិនទាន់យល់ដឹងអំពីការល្អ ឬអាក្រក់នៅឡើយ
ពួកគេនឹងទៅកាន់ទឹកដីនោះដែរ។ យើងនឹងប្រគល់ទឹកដីនោះឲ្យទៅពួកគេ ហើយពួកគេនឹងកាន់កាប់ទឹកដីនោះ។[40]ប៉ុន្តែ អ្នករាល់គ្នាវិញ ចូរត្រឡប់
និងធ្វើដំណើរទៅក្នុងទីរហោស្ថាន ឆ្ពោះទៅកាន់សមុទ្រកក់វិញ។
[41]បន្ទាប់មក អ្នករាល់គ្នាឆ្លើយមកខ្ញុំថា៖ «យើងបានធ្វើបាបទាស់នឹងព្រះអម្ចាស់ យើងនឹងឡើងទៅប្រយុទ្ធ ហើយយើងនឹងដើរតាមអ្វីៗទាំងអស់
ដែលព្រះអម្ចាស់ជាព្រះនៃយើងបានបង្គាប់យើងឲ្យធ្វើ។ បុរសគ្រប់រូប នៅក្នុងចំណោមអ្នករាល់គ្នាត្រូវកាន់អាវុធរៀងៗខ្លួន ហើយអ្នករាល់គ្នាបានត្រៀមខ្លួនរួចជាស្រេច
ដើម្បីប្រយុទ្ធនៅតំបន់ភ្នំនោះ។[42]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា៖ «ចូរប្រាប់ពួកគេកុំវាយប្រហារ និងប្រយុទ្ធឡើយ ដ្បិត
យើងនឹងមិនគង់នៅជាមួយអ្នករាល់គ្នាឡើយ ហើយខ្មាំងសត្រូវរបស់អ្នករាល់គ្នានឹងយកឈ្នះលើអ្នករាល់គ្នាជាមិនខាន»។
[43]ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ តែអ្នករាល់គ្នាមិនបានស្តាប់ខ្ញុំទេ។ អ្នករាល់គ្នាបះបោរប្រឆាំងនឹងសេចក្ដីបង្គាប់របស់ព្រះអម្ចាស់ អ្នករាល់គ្នាបានក្រអឺតក្រទម
ហើយបានទៅវាយលុកនៅតំបន់ភ្នំ។[44]ប៉ុន្តែ ជនជាតិអាម៉ូរីដែលរស់នៅក្នុងតំបន់ភ្នំនោះ ចេញមកប្រយុទ្ធនឹងអ្នករាល់គ្នា ហើយដេញប្រហារអ្នករាល់គ្នាដូចជាសត្វឃ្មុំ
ហើយបានវាយអ្នករាល់គ្នារហូតដល់តំបន់ភ្នំសៀរ និងរហូរដល់ហោម៉ាផងដែឬ។
[45]អ្នករាល់គ្នាបានត្រឡប់មកវិញ ហើយបានយំសោកនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ប៉ុន្តែ ព្រះអម្ចាស់មិនបានស្តាប់សម្លេងរបស់អ្នករាល់គ្នាទេ
ហើយព្រះអង្គក៏មិនបានផ្ទៀងព្រះកាណ៌ស្តាប់អ្នករាល់គ្នាដែរ។[46]ដូច្នេះ អ្នករាល់គ្នារស់នៅក្នុងកាដេសនោះអស់រយៈជាយូរថ្ងៃ។

Deuteronomy 1:1

នៅឯខាងនាយទន្លេយ័រដាន់

សំដៅទៅលើទឹកដី ដែលឆ្លងកាត់ទន្លេយ័រដាន់នៅខាងកើតអ៊ីស្រាអែល។

ពេលលោកមានប្រសាសន៍ទៅកាន់ជនជាតិអ៊ីស្រាអែល

លោកម៉ូសេនៅខាងកើតទន្លេយ័រដាន់។ ការបកប្រែផ្សេងទៀត

«ខាងកើតទន្លេយ័រដាន់»

ស៊ូភ ... ប៉ារ៉ាន ... តូផែល ... ឡាបាន់... ហាសិរ៉ូត... ឌីសាហាប

ទាំងនេះជាឈ្មោះទីកន្លែង។ (សូមមើល|How to Translate Names)

បន្ទាប់ពីបានធ្វើដំណើរអស់រយៈពេលដប់មួយថ្ងៃចេញពីហោរែប ... ទៅកាន់កាដេស បារនា។

«គឺត្រូវចំណាយពេល១១ថ្ងៃ ដើរពីហោរែប... ទៅកាន់កាដេស បារនា»

ភ្នំសៀរ

នេះជាតំបន់ភ្នំមួយនៅខាងត្បូងសមុទ្រមរណៈ។ តំបន់នេះត្រូវបានគេហៅថា
«អេដុម» ផងដែរ។

ដប់មួយ

«១១» (សូមមើល|Numbers)

Deuteronomy 1:3

ការនេះកើតឡើងនៅក្នុងឆ្នាំសែសិប នៅខែទីដប់មួយ នៅថ្ងៃទីមួយនៃខែនោះ

លោកម៉ូសេបានមានប្រសាសន៍ទៅ

ចំនួនធម្មតានៅទីនេះអាចបកប្រែជាចំនួនរាប់។ ការបកប្រែផ្សេងទៀត

«ពួកគេបានរស់នៅក្នុងទីរហោស្ថានអស់រយៈពេល ៤០ឆ្នាំ ១ខែ និង១ថ្ងៃ
នៅពេលលោកម៉ូសេនិយាយ»

ឆ្នាំសែសិប

ឆ្នាំទី៤០

នៅខែទីដប់មួយ នៅថ្ងៃទីមួយនៃខែនោះ

នេះជាខែទី១១តាមប្រតិទិនហេប្រឺ។

ថ្ងៃដំបូងគឺជិតពាក់កណ្តាលខែមករាតាមប្រតិទិនលោកខាងលិច។

ទីដប់មួយ

ទី១១

ព្រះអម្ចាស់

នេះជាព្រះនាមរបស់ព្រះជាម្ចាស់
ដែលទ្រង់បានបង្ហាញប្រាប់ប្រជារាស្ត្ររបស់ព្រះអង្គនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់។
សូមមើលការបកប្រែទំព័រនេះ
ស្តីអំពីព្រះអម្ចាស់ដែលទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។

ព្រះជាម្ចាស់បានប្រហារ

«ព្រះអម្ចាស់បានជួយជនជាតិអ៊ីស្រាអែលឲ្យទទួលជ័យជម្នះ»

ព្រះបាទស៊ីហុន ... ព្រះបាទអុក

ទាំងនេះជាព្រះនាមរបស់ស្តេច។

ស្រុកបាសាន ... ក្រុងអាសថារ៉ូត និងអេទ្រី។

ទាំងនេះជាឈ្មោះទីក្រុង។

Deuteronomy 1:5

generated on Wed Sep 10 16:16:32 2025

នៅខាងនាយទន្លេយ័រដាន់
សំដៅទៅលើទឹកដី ដែលទល់មុខទន្លេយ័រដាន់នៅខាងកើតអ៊ីស្រាអែល។
នៅពេលលោកម៉ូសេនិយាយដូច្នេះលោកម៉ូសេនៅខាងកើតទន្លេយ័រដាន់។
ការបកប្រែផ្សេងទៀត «ខាងកើតទន្លេយ័រដាន់» ។ បកប្រែដូចនៅក្នុង ១:១។
បានមានព្រះបន្ទូលមកកាន់ពួកយើង
ពាក្យថា «យើង» សំដៅទៅលើលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែលផ្សេងទៀត។
អ្នករាល់គ្នាបានរស់នៅនៅលើភ្នំនេះជាយូរណាស់មកហើយ។
នេះជាឃ្លាសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាមិនចាំបាច់នៅក្បែរភ្នំនេះតទៅទៀតទេ»
Deuteronomy 1:7
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលនូវអ្វី
ដែលព្រះអម្ចាស់មានបន្ទូលប្រាប់ពួកគេ។
ចូរចេញទៅហើយបន្តដំណើររបស់អ្នក
ពាក្យថា «ចូរចេញ» ជាឃ្លាសម្រាប់ចាប់ផ្តើមសកម្មភាព។ ការបកប្រែផ្សេងទៀត
«ចូរចាប់ផ្តើមម្តងទៀតក្នុងដំណើររបស់អ្នក»
នៅតំបន់ភ្នំ ... ទន្លេធំអឺប្រាត
ព្រះអម្ចាស់កំពុងរៀបរាប់ទីកន្លែងនៅក្នុងស្រុក ដែលទ្រង់បានសន្យាថា
នឹងប្រទានឲ្យដល់ជនជាតិអ៊ីស្រាអែល។
នៅតំបន់ភ្នំ
នេះជាតំបន់មួយនៅលើភ្នំក្បែរកន្លែង ដែលជនជាតិអាម៉ូរីរស់នៅ។
តំបន់វាលទំនាប
តំបន់មួយមានដីទាបនិងរាបស្មើ
មើល៍
«ចូរយកចិត្តទុកដាក់ចំពោះអ្វី ដែលយើងមានបន្ទូល»
យើងប្រគល់ស្រុកឲ្យអ្នករាល់គ្នាហើយ
ឥឡូវយើងប្រទានទឹកដីនេះឲ្យដល់អ្នកហើយ
ដែលព្រះជាម្ចាស់បានសន្យា
ព្រះអម្ចាស់កំពុងមានបន្ទូល ដូចជាព្រះអង្គជាមនុស្សម្នាក់ទៀត។
ការបកប្រែផ្សេងទៀត «យើងជាព្រះអម្ចាស់បានស្បថ»
លោក
ពាក្យថា «លោក» ជាពាក្យរួមមួយសម្រាប់បុព្វបុរសទាំងអស់។
ការបកប្រែផ្សេងទៀត «បុព្វបុរស»
Deuteronomy 1:9
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលនូវអ្វី
ដែលព្រះអម្ចាស់បានមានបន្ទូលមកពួកគេ។
នៅពេលនោះយើងបានប្រាប់អ្នករាល់គ្នាថា
នៅទីនេះ «យើង» សំដៅទៅលើលោកម៉ូសេ។ ឃ្លា «នៅពេលនោះ»
សំដៅទៅលើពេល ដែលជនជាតិអ៊ីស្រាអែលនៅឯភ្នំហោរែប
ដែលមានដូចគ្នានឹងភ្នំស៊ីណៃដែរ។ ការបកប្រែផ្សេងទៀត
«នៅពេលយើងនៅហោរែបយើងបានមានបន្ទូលទៅកាន់អ្នករាល់គ្នា»
ខ្ញុំមិនអាចទទួលខុសត្រូវអ្នករាល់គ្នាតែម្នាក់ឯងបានទេ។
នៅទីនេះ «ទទួលខុសត្រូវអ្នករាល់គ្នា» មានន័យថា « ដឹកនាំអ្នករាល់គ្នា» ឬ
«គ្រប់គ្រងអ្នករាល់គ្នា»។ ការបកប្រែផ្សេងទៀត «វាច្រើនពេកសម្រាប់យើង
ដើម្បីដឹកនាំអ្នករាល់គ្នាដោយផ្ទាល់»
ច្រើនដូចជាផ្កាយនៅលើមេឃ។
នេះជាការនិយាយបំផ្លើសមួយ
ដែលមានន័យថាព្រះជាម្ចាស់បានបង្កើនចំនួនជនជាតិអ៊ីស្រាអែលយ៉ាងច្រើន។
ការបកប្រែផ្សេងទៀត «មនុស្សមួយហ្វូងយ៉ាងច្រើន»
មួយពាន់ដង
ឃ្លា «មួយពាន់» ជាពាក្យប្រៀបធៀបសម្រាប់ «ច្រើនណាស់» ។
ការបកប្រែផ្សេងទៀត «ច្រើនដងណាស់»
មួយពាន់
១០០០
Deuteronomy 1:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប៉ុន្តែ តើធ្វើដូចម្តេចឲ្យខ្ញុំតែម្នាក់ អាចទទួលបន្ទុកដ៏ច្រើន
និងដោះស្រាយជម្លោះឲ្យអ្នករាល់គ្នាបានទៅ?
លោកម៉ូសេប្រើសំណួរមួយដើម្បីបញ្ជាក់ថា
លោកមិនអាចដោះស្រាយបញ្ហាទាំងអស់របស់ពួកគេបានទេ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនអាចផ្ទុកបន្ទុករបស់អ្នក និង ជម្លោះរបស់អ្នកដោយខ្លួនឯងបានទេ» ។ :
អាចទទួលបន្ទុកដ៏ច្រើន
លោកម៉ូសេនិយាយដូចជាបញ្ហានិងការអ៊ូរទាំរបស់ប្រជាជន
ដែលគាត់ត្រូវយកចិត្តទុកដកាក់ ជារបស់ធ្ងន់យួរនឹងដៃ។ ការបកប្រែផ្សេងទៀត
«យកចិត្តទុកដាក់បញ្ហារបស់អ្នក និងពាក្យការអ៊ូរទាំរបស់អ្នក»
ជម្លោះឲ្យអ្នករាល់គ្នា
«ការឈ្លោះគ្នា» ឬ «ការមិនយល់ស្របរបស់អ្នក»
មនុស្សដែលមានកេរ្តិ៍ឈ្មោះល្អ ក្នុងកុលសម្ព័ន្ធនីមួយៗ
«មនុស្សមកពីកុលសម្ព័ន្ធនីមួយៗ ដែលប្រជាជនអ៊ីស្រាអែលគោរព»
Deuteronomy 1:15
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
និងមនុស្សដែលមានកេរ្តិ៍ឈ្មោះល្អ
មនុស្សដែលប្រជាជនរបស់អ្នកគោរព។ សូមមើលការប្រែនៅក្នុង ១:១២។
មួយពាន់នាក់ ...មួយរយនាក់ ... ហាសិបនាក់...ដប់នាក់
«ក្រុម ១០០០ ... ក្រុម ១០០ ... ក្រុម ៥០ ... និងក្រុម ១០»
ជាមេដឹក ... ពួកមេដឹកនាំ
ទាំងនេះជាតួនាទីសម្រាប់អ្នកដឹកនាំផ្សេងៗគ្នា នៅក្នុងរដ្ឋាភិបាលអ៊ីស្រាអែល។
តាមកុលសម្ព័ន្ធ។
«ពីកុលសម្ព័ន្ធនីមួយៗរបស់អ្នក»
ហើយកាត់ក្តីដោយយុត្តិធម៌រវាងមនុស្សម្នាក់ និងបងប្អូនរបស់គាត់
«ធ្វើការសម្រេចចិត្តត្រឹមត្រូវ និងសមរម្យអំពីជម្លោះ
ដែលអ៊ីស្រាអែលមានជាមួយគ្នា»
Deuteronomy 1:17
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ចៅក្រម ដូច្នេះ ពាក្យបង្គាប់ជាពហុវចនៈ។
អ្នករាល់គ្នានឹងមិនត្រូវបង្ហាញភាពលំអៀង
«កុំបង្ហាញភាពលំអៀង»
អ្នករាល់គ្នានឹងត្រូវស្តាប់ទាំងអ្នកតូច
ទាំងពីរ «អ្នកតូច» និង «អ្នកធំ» តំណាងឲ្យមនុស្សទាំងអស់។
ការបកប្រែផ្សេងទៀត «អ្នកនឹងប្រព្រឹត្តចំពោះមនុស្សទាំងអស់ដូចគ្នា»
អ្នករាល់គ្នានឹងមិនត្រូវភ័យខ្លាចមុខនៃមនុស្សណាឡើយ
ពាក្យថា «មុខ» ជាពាក្យប្រៀបធៀបសម្រាប់មនុស្សទាំងមូល។
«អ្នករាល់គ្នានឹងមិន» ជាពាក្យបង្គាប់។ «កុំភ័យខ្លាចមនុស្សណាម្នាក់ឡើយ»
នៅគ្រានោះថា
មានន័យថា ពេលវេលាដែលពួកគេនៅហោរែប នៅលើភ្នំស៊ីណៃ។
Deuteronomy 1:19
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
វាលរហោស្ថានដ៏ធំ គួរស្វែងខ្លាចទាំងនោះ ដែលអ្នករាល់គ្នាបានឃើញ
«វាលរហោស្ថានដ៏ធំ និងគ្រោះថ្នាក់ ដែលអ្នករាល់គ្នាបានឆ្លងកាត់»
Deuteronomy 1:20
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
មើល៍ ...ព្រះជាម្ចាស់របស់អ្នករាល់គ្នា ... នៅមុខអ្នករាល់គ្នា
ចូរឡើងទៅកាន់កាប់ ...បុព្វបុរសរបស់អ្នករាល់គ្នា... មកអ្នករាល់គ្នា; កុំភ័យខ្លាច ឬតក់ស្លុតអ្វីឡើយ។
លោកម៉ូសេកំពុងតែនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ដូចជាគាត់កំពុងតែនិយាយទៅកាន់មនុស្សតែមួយ
ដូច្នេះទម្រង់ទាំងនេះគួរតែជាឯកវចនៈ មិនមែនជាពហុវចនៈទេ។ .
បានរៀបចំទឹកដីនៅមុខអ្នករាល់គ្នាហើយ
ឥឡូវនេះ យើងកំពុងប្រគល់ដីនេះដល់អ្នករាល់គ្នាហើយ។
សូមមើលការបកប្រែនៅក្នុង ១:៧។
Deuteronomy 1:22

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
មនុស្សដប់ពីរ
«មនុស្ស១២នាក់»
ពួកគេបានចេញទៅ
«ពួកគេបានចាកចេញពីកន្លែងនោះ ហើយបានទៅ»
ភូមិអែលកុល
នេះជាជ្រលងភ្នំក្នុងតំបន់ហេប្រុន ដែលនៅខាងត្បូងក្រុងយេរូសាឡឹម។
ស៊ើបការណ៍នៅស្រុកនោះ។
«បានរកមើលកន្លែង ដែលពួកគេអាចវាយប្រហារ»
Deuteronomy 1:25
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
ពួកគេបានយក
«មនុស្សទាំង ១២នាក់បានយក»
បានយកផលរបស់ដីនៅក្នុងដៃរបស់ពួកគេ
«បានជ្រើសរើសផលខ្លះរបស់ដី»
នាំពាក្យមកប្រាប់ពួកយើង
អ្នកនាំពាក្យនិយាយដូចជា «ពាក្យ»
ជាវត្ថុជាប់រាងកាយដែលមនុស្សណាម្នាក់អាចយកមកបាន។ ការបកប្រែផ្សេងទៀត
«ប្រាប់យើង»
«ស្រុកនោះគឺជាទឹកដីដែលព្រះអម្ចាស់ជាព្រះជាម្ចាស់នៃយើងប្រទានដល់ពួកយើង»។
ការដកស្រង់ផ្ទាល់អាចបកប្រែជាការដកស្រង់ ដោយប្រយោល។
ការបកប្រែផ្សេងទៀត «បាននិយាយថា ទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់យើង
ប្រទានឲ្យយើងជាដីល្អ»
Deuteronomy 1:26
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
អ្នករាល់គ្នាមិនព្រមវាយប្រហារ
ព្រះជាម្ចាស់បានបង្គាប់ជនជាតិអ៊ីស្រាអែល ឲ្យវាយប្រហារនិងបំផ្លាញជនជាតិអាម៉ូរី
ប៉ុន្តែ ជនជាតិអ៊ីស្រាអែលភ័យខ្លាច ហើយមិនព្រមធ្វើសង្គ្រាមជាមួយពួកគេទេ។
ធ្លាក់ចូលក្នុងដៃរបស់ជនជាតិអាម៉ូរី
ត្រង់នេះ «ទៅក្នុងដៃ» មានន័យថា ផ្តល់អំណាចដល់ជនជាតិអាម៉ូរីលើពួកគេ។
ការបកប្រែផ្សេងទៀត «ចូលទៅក្នុងអំណាចរបស់ជនជាតិអាម៉ូរី»
តើពួកយើងអាចទៅកន្លែងណាបាន?
នេះជាសំណួរបញ្ជាក់ពីការភ័យខ្លាចរបស់ពួកគេ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«យើងគ្មានកន្លែងដែលត្រូវទៅទេ» ។
បានបំភ័យយើង
មានន័យថា ពួកគេបានភ័យខ្លាច។ ការបកប្រែផ្សេងទៀត «ធ្វើឲ្យយើងភ័យខ្លាច»
ហើយមានកំពែងការពារខ្ពស់ដល់មេឃ
នេះជាការនិយាយបំផ្លើសមួយ ដែលសង្កត់ធ្ងន់ទៅលើការភ័យខ្លាចរបស់ប្រជាជន
ព្រោះទីក្រុងធំនិងខ្លាំង។
ហើយមានកំពែងការពារខ្ពស់ដល់
«មានកំពែងដែលខ្ពស់ដូច»
កូនចៅអណាក់
ទាំងនេះជាកូនចៅរបស់ប្រជាជនអណាក់ ដែលមានមាឌធំនិងកាចសាហាវ។
Deuteronomy 1:29
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
ខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា
«ខ្ញុំបាននិយាយទៅកាន់បុព្វបុរសរបស់អ្នករាល់គ្នា»
នៅចំពោះមុខអ្នករាល់គ្នា
នៅទីនេះជាពាក្យប្រៀបធៀប «នៅចំពោះមុខអ្នករាល់គ្នា » សំដៅទៅលើអ្វីៗ
ដែលពួកគេបានឃើញ។ ការបកប្រែផ្សេងទៀត
«ដែលអ្នកបានឃើញដោយខ្លួនឯង»
អ្នករាល់គ្នាបានឃើញថា ... ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា បាននាំអ្នករាល់គ្នា ...
អ្នករាល់គ្នាទៅ ... មកដល់
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេមានមនុស្សតែម្នាក់
ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» ជាឯកវចនៈ។
ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា បាននាំអ្នករាល់គ្នា ដូចជានាំបុត្ររបស់ព្រះអង្គ
នៅទីនេះ ការយកចិត្តទុកដាក់របស់ព្រះអម្ចាស់ចំពោះប្រជារាស្ត្រ
ប្រៀបបានទៅនឹងឪពុក។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះរបស់អ្នកថែរក្សាអ្នក ដូចជាឪពុកថែរក្សាកូនរបស់គាត់»
រហូតមកដល់កន្លែងនេះ។
«រហូតដល់អ្នករាល់គ្នាបានមកដល់ទឹកដីនេះ
ដែលព្រះជាម្ចាស់បានសន្យាថានឹងប្រទានឲ្យអ្នករាល់គ្នា»
Deuteronomy 1:32
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
ព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា ... ជាព្រះដែលបានយាងនៅមុខអ្នក
លោកម៉ូសេរម្លឹកពួកគេអំពីគ្រប់ទាំងផ្លូវ
ដែលព្រះអម្ចាស់បានយាងពីមុខពួកអ៊ីស្រាអែល
ក្នុងដំណើរដែលពួកគេធ្លាប់ធ្វើនៅអតីតកាល។
តម្លើងត្រសាល
«ដំឡើងត្រសាលរបស់អ្នក»
Deuteronomy 1:34
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលព្រះអម្ចាស់បានមានបន្ទូលមកពួកគេ។
ឮសម្លេងរបស់អ្នករាល់គ្នាហើយ
«បានឮនូវអ្វីដែលអ្នករាល់គ្នាបានកំពុងនិយាយ»
ហើយមានព្រះបន្ទូលថា
ព្រះជាម្ចាស់បានស្បថថា
នឹងមិនអនុញ្ញាតឱ្យអស់អ្នកដែលបះបោរប្រឆាំងនឹងព្រះអង្គចូលទឹកដី
ដែលទ្រង់បានសន្យាថានឹងប្រទានឱ្យពួកគេទេ។
អ្នកណាម្នាក់អាចឃើញ
«នឹងចូល»
លើកលែងតែកាលែប
«លើកលែងកាលែប»
យេភូនេ
នេះជាឈ្មោះរបស់ឪពុកកាលែប។
លោកបានដើរតាមព្រះអម្ចាស់ទាំងស្រុង។
ព្រះអម្ចាស់មានព្រះបន្ទូលដូចព្រះអង្គជានរណាម្នាក់ផ្សេងទៀត។
ការបកប្រែផ្សេងទៀត «លោកបានស្តាប់បង្គាប់យើងទាំងស្រុង»
Deuteronomy 1:37
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
ព្រះអម្ចាស់ក៏ព្រះពិរោធនឹងខ្ញុំដោយព្រោះតែអ្នករាល់គ្នា
សំដៅទៅលើពេលលោកម៉ូសេមិនគោរពតាមអ្វី
ដែលព្រះអម្ចាស់បានប្រាប់គាត់ឲ្យធ្វើ ព្រោះលោកម៉ូសេខឹងនឹងជនជាតិអ៊ីស្រាអែល។
លោកនួន
នេះជាឈ្មោះរបស់ឪពុកលោកយ៉ូស្វេ។
ជាអ្នកដែលឈរនៅពីមុខអ្នករាល់គ្នា
មូលហេតុដែលលោកយ៉ូស្វេឈរនៅមុខលោកម៉ូសេ អាចថ្លែងយ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «អ្នកដែលឈរនៅមុខអ្នករាល់គ្នា
ក្នុងនាមជាអ្នកបម្រើរបស់អ្នករាល់គ្នា» ឬ «អ្នកដែលជួយអ្នករាល់គ្នា»
Deuteronomy 1:39
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
គេមិនទាន់យល់ដឹងអំពីការល្អ ឬអាក្រក់

generated on Wed Sep 10 16:16:32 2025

ពួកគេមិនទាន់ដឹងពីអ្វី ដែលល្អនិងអ្វីដែលអាក្រក់។
ចូរត្រឡប់ និងធ្វើដំណើរទៅ
«ចូរបែរក្រោយហើយត្រឡប់ក្រោយតាមផ្លូវ ដែលអ្នកបានចូលមក»
Deuteronomy 1:41
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
ធ្វើបាបទាស់នឹងព្រះអម្ចាស់
យើងបានបះបោរប្រឆាំងនឹងព្រះអម្ចាស់ ដោយមិនស្តាប់បង្គាប់ព្រះអង្គ។
យើងនឹងដើរតាម
«យើងនឹងស្តាប់បង្គាប់»
ដើម្បីប្រយុទ្ធនៅតំបន់ភ្នំនោះ។
នៅទីនេះពាក្យប្រៀបធៀប «នៅតំបន់ភ្នំ»តំណាងឱ្យប្រជាជនដែលរស់នៅទីនោះ។
ការបកប្រែផ្សេងទៀត « ដើម្បីវាយប្រហារប្រជាជន ដែលរស់នៅតំបន់ភ្នំ»
ដ្បិត យើងនឹងមិនគង់នៅជាមួយអ្នករាល់គ្នាឡើយ
ហើយខ្មាំងសត្រូវរបស់អ្នករាល់គ្នានឹងយកឈ្នះលើអ្នករាល់គ្នាជាមិនខាន។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«សត្រូវរបស់អ្នករាល់គ្នានឹងកម្ចាត់អ្នករាល់គ្នា
ព្រោះយើងនឹងមិននៅជាមួយអ្នករាល់គ្នា»
Deuteronomy 1:43
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ហើយបានទៅវាយលុកនៅតំបន់ភ្នំ។
ពាក្យប្រៀបធៀប «នៅតំបន់ភ្នំ» តំណាងឱ្យប្រជាជន ដែលរស់នៅទីនោះ។
ការបកប្រែផ្សេងទៀត «បានវាយប្រហារប្រជាជន ដែលរស់នៅតំបន់ភ្នំ»
ដេញប្រហារអ្នករាល់គ្នាដូចជាសត្វឃ្មុំ
«សត្វឃ្មុំ» ជាសត្វល្អិតតូចមួយ ដែលហោះហើរជាក្រុមៗ និង
ទិចមនុស្សដែលគំរាមកំហែងពួកវា។ មានន័យថា
ជនជាតិអាម៉ូរីច្រើនណាស់បានវាយប្រហារទាហានអ៊ីស្រាអែល
ដែលពួកគេត្រូវចាកចេញពីសមរភូមិ។
ភ្នំសៀរ
នេះជាឈ្មោះរបស់ដីមួយផ្នែក។
ហោម៉ា
នេះជាឈ្មោះទីក្រុងមួយ។
បានវាយអ្នករាល់គ្នាដល់
«បានសម្លាប់ទាហានរបស់អ្នករាល់គ្នាជាច្រើន»
Deuteronomy 1:45
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
បានត្រឡប់មកវិញ
«បានត្រឡប់ទៅកាដេស»

---

2 [1]បន្ទាប់មក យើងចេញដំណើរទៅទីរហោស្ថាន តាមផ្លូវសមុទ្រកក់ ដូចជាព្រះអម្ចាស់បានមានបន្ទូលមកខ្ញុំ នៅពេលយើងបានដើរជុំវិញតំបន់ភ្នំសៀរ ជាច្រើនថ្ងៃ។
[2]ព្រះអម្ចាស់បានមានព្រះបន្ទូលមកកាន់ខ្ញុំថា៖[3]អ្នករាល់គ្នាបានធ្វើដំណើរជុំវិញភ្នំនេះយូរណាស់ហើយ ចូរចេញដំណើរទៅទិសខាងជើងចុះ។
[4]ចូរបង្គាប់ដល់ប្រជាជន ដោយនិយាយថា៖ «អ្នករាល់គ្នាត្រូវដើរឆ្លងកាត់តាមទឹកដីបងប្អូនរបស់អ្នករាល់គ្នា គឺកូនរបស់អេសាវ ជាអ្នកដែលរស់នៅក្នុងតំបន់ភ្នំសៀរ
ពួកគេនឹងខ្លាចអ្នករាល់គ្នា។ ហេតុនេះហើយ ចូរប្រយ័ត្ន[5]កុំប្រយុទ្ធជាមួយពួកគេឡើយ ដ្បិត យើងនឹងមិនប្រគល់ទឹកដីគេឲ្យមកអ្នករាល់គ្នាទេ សូម្បីតែ
ស្នាមបាត់ជើងក៏មិនបានផង ដ្បិត យើងបានប្រគល់ភ្នំសៀរនេះ ទៅឲ្យអេសាវ ទុកដូចជាទ្រព្យសម្បត្តិហើយ។
[6]អ្នករាល់គ្នាត្រូវយកប្រាក់ទៅទិញអាហារពីពួកគេ ដើម្បីឲ្យអ្នករាល់គ្នាអាចបរិភោគបាន អ្នករាល់គ្នាត្រូវយកប្រាក់ទៅទិញទឹកពីពួកដែរ ទើប អ្នករាល់គ្នាអាចនឹងផឹកបាន។
[7]ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានប្រទានព្រះពរដល់អ្នករាល់គ្នា ក្នុងគ្រប់កិច្ចការទាំងអស់ដែលអ្នករាល់គ្នាធ្វើ
ព្រះអង្គជ្រាបពីការដែលអ្នករាល់គ្នាដើរឆ្លងកាត់នៅទីរហោស្ថានដ៏ធំនេះ។ ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានគង់នៅជាមួយអ្នករាល់គ្នា
អស់រយៈពេលសែសិបឆ្នាំមកហើយ ហើយអ្នករាល់គ្នាមិនខ្វះខាតអ្វីសោះឡើយ»។
[8]ដូច្នេះ យើងបានដើរឆ្លងកាត់ទឹកដីបងប្អូនរបស់យើង ជាកូនចៅរបស់លោកអេសាវដែលរស់នៅលើតំបន់ភ្នំសៀរ ហើយយើងក៏បានចេញពីទឹកដីតំបន់ភ្នំអារ៉ាបា អេឡាត
និងអេស៊ាន គេបើរដែរ។ បន្ទាប់មក យើងធ្វើដំណើរ ហើយបានឆ្លងកាត់តាមផ្លូវទៅទីរហោស្ថានទឹកដីម៉ូអាប់។
[9]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «កុំបង្កបញ្ហាដល់ជនជាតិម៉ូអាប់ ហើយកុំប្រយុទ្ធជាមួយពួកគេនៅក្នុងសង្គ្រាមឡើយ។ ដ្បិត
យើងនឹងមិនឲ្យទឹកដីរបស់ពួកគេទៅជាកម្មសិទ្ធិរបស់អ្នករាល់គ្នាឡើយ ព្រោះយើងបានប្រគល់ក្រុងអើរ ឲ្យកូនចៅរបស់លោកឡុតទុកជាកម្មសិទ្ធិរួចទៅហើយ។
[10](ពីមុន ជនជាតិអេមីមរស់ទឹកដីនោះ ជាជនជាតិដែលមានគ្នាច្រើន ហើយមានមាឌធំខ្ពស់ ដូចជាជនជាតិអណាក់ដែរ[11]អ្នកផ្សេងទៀតចាត់ទុកពួកនោះជាជនជាតិរេផែម
ដូចជនជាតិអណាក់ដែរ ប៉ុន្តែ ជនជាតិម៉ូអាប់ហៅពួកគេថា ជនជាតិអេមីម។
[12]ពីមុន ជនជាតិហូរីក៏រស់នៅក្នុងតំបន់ភ្នំសៀរដែរ ប៉ុន្តែ កូនចៅរបស់លោកអេសាវបានទទួលជ័យជម្នះលើពួកគេ។ ពួកគេបំផ្លាញជនជាតិហូរីចេញពីមុខពួកគេ
ហើយបានរស់នៅទីកន្លែងរបស់ពួកគេ ដូចជាអ៊ីស្រាអែលបានធ្វើ ក្នុងទឹកដី ដែលព្រះអម្ចាស់បានប្រគល់ដល់ពួកគេដែរ)។
[13]«ឥឡូវនេះ ចូរក្រោកឡើង ហើយទៅឆ្លងកាត់ជ្រោះសេរេដចុះ»។ ដូច្នេះ យើងក៏បានទៅឆ្លងកាត់ជ្រោះសេរេដទៅ។[14]ឥឡូវ ចាប់ពីថ្ងៃដែលពួកយើងបានធ្វើដំណើរពីកាដេស
បារនារហូតដល់យើងឆ្លងកាត់ជ្រោះសេរេដ គឺមានរយៈពេលសាមសិបប្រាំបីឆ្នាំហើយ។ គឺរហូតដល់អស់អ្នកដែលមានអាយុពេញវ័យធ្វើសង្គ្រាមនៅជំនាន់នោះ បានបាត់
បង់ជីវិតអស់ ដូចព្រះអម្ចាស់បានស្បថនឹងពួកគេ។[15]ម៉្យាងវិញទៀត ព្រះហស្តរបស់ ព្រះអម្ចាស់ទាស់ប្រឆាំងនឹងមនុស្សជំនាន់នោះ ដើម្បីបំផ្លាញពួកគេចេញជំរំ
រហូតដល់គេវិនាសអស់។
[16]ការនេះបានកើតឡើងនៅពេលដែលមានអាយុពេញវ័យធ្វើសង្គ្រាម ហើយបានស្លាប់បាត់អស់ចេញពីក្នុងចំណោមប្រជាជន[17]នោះ
ព្រះអម្ចាស់បានមានព្រះបន្ទូលមកកាន់ខ្ញុំថា៖[18]«ថ្ងៃនេះ អ្នកបានត្រូវឆ្លងកាត់ក្រុងអើរ ជាព្រំប្រទល់ទឹកដីម៉ូអាប់ហើយ។
[19]នៅពេលអ្នករាល់គ្នាធ្វើដំណើរជិតដល់ទឹកដីរបស់ប្រជាជនអាំម៉ូន នោះកុំបង្កបញ្ហា ឬប្រយុទ្ធនឹងពួកគេឡើយ ដ្បិត
យើងនឹងមិនឲ្យទឹកដីរបស់ពួកគេធ្វើជាកម្មសិទ្ធិរបស់អ្នករាល់គ្នាទេ ព្រោះយើងបានប្រគល់ទឹកដីនេះ ឲ្យទៅកូនចៅរបស់លោកឡុត ធ្វើជាកម្មសិទ្ធិរួចហើយ»។
[20](ទឹកដីនោះ ក៏ចាត់ទុកជាទឹកដីរបស់ពួកជនជាតិរេផែមដែរ។ ជនជាតិរេផែមធ្លាប់បានរស់នៅលើទឹកដី ប៉ុន្តែ
ជនជាតិអាំម៉ូនហៅគេថាជាជនជាតិសាំស៊ូមីម[21]ជាប្រជាជនមួយដែលខ្លាំងពូកែ មានគ្នាច្រើន ហើយមានមាឌខ្ពស់ៗដូចជា ជនជាតិអណាក់។ ប៉ុន្តែ
ព្រះអម្ចាស់បានបំផ្លាញពួកគេនៅពីមុខប្រជាជនអាំម៉ូន ពួកគេ ទទួលបានជ័យជម្នះ ហើយបានរស់នៅទីនោះទៅ។
[22]ព្រះអម្ចាស់ក៏បានធ្វើការដល់ប្រជាជនរបស់លោកអេសាវដែរ ជាអ្នកដែលរស់នៅតំបន់ភ្នំសៀរ នៅពេលដែលព្រះអង្គបានបំផ្លាញប្រជាជនហូរី ចេញពីមុខរបស់ពួកគេ
ហើយកូនចៅរបស់លោកអេសាវក៏ទទួលបានជ័យជម្នះ ក្រោយមកពួកគេបានរស់នៅលើទឹកដីនោះ រហូតមកដល់ថ្ងៃនេះ។
[23]ឯជនជាតិអាវីមដែលរស់នៅក្នុងភូមិនានា រហូតដល់កាសា ជនជាតិកាប់ថោរ ដែលចេញមកពីទឹកដីកាប់ថោរ បានបំផ្លាញពួកគេ និងតាំងទីលំនៅក្នុងទឹកដីនោះទៅ)។
[24]ឥឡូវនេះ ចូរក្រោកឡើង ហើយបន្តដំណើររបស់អ្នករាល់គ្នាទៅមុខទៀត ត្រូវដើរកាត់ស្ទឹងអើណូន មើល៍ យើងបានប្រគល់ទឹកដីនោះទៅក្នុងដៃរបស់អ្នករាល់គ្នាហើយ
ព្រះបាទស៊ីហុន ជាស្តេចរបស់ជនជាតិអាម៉ូរី និងជាស្តេចក្រុងហែលបូន ព្រមទាំងទឹកដីរបស់គេផង។ ចូរចាប់ផ្តើមកាន់កាប់ទឹកដីនោះទៅ
ហើយប្រយុទ្ធជាមួយពួកគេក្នុងសង្គ្រាម។[25]នៅថ្ងៃនេះយើងនឹងចាប់ផ្តើមឲ្យជនជាតិនៅក្រោមមេឃទាំងមូលភ័យខ្លាច និងកោតខ្លាចចំពោះអ្នករាល់គ្នា
ហើយពួកគេនឹងឮអំពីអ្នករាល់គ្នា ហើយគេនឹងភ័យខ្លាច ព្រមទាំងមានចិត្តព្រួយបារម្ភចំពោះអ្នករាល់គ្នាផង។
[26]ខ្ញុំបានចាត់អ្នកនាំសារមកពីទីរហោស្ថានកេដ្ម៉ូតឲ្យទៅជួបព្រះបាទស៊ីហុន ជាស្តេចក្រុងហែលបូន ជាមួយនឹងពាក្យសន្តិភាព ដោយនិយាយថា៖
[27]«សូមអនុញ្ញាតឲ្យយើងខ្ញុំដើរឆ្លងកាត់ទឹកដីរបស់អ្នកផង យើងខ្ញុំនឹងធ្វើដំណើរតាមផ្លូវប៉ុណ្ណោះ យើងខ្ញុំនឹងមិនងាកខាងស្តាំ ឬទៅខាងឆ្វេងនោះទេ។

generated on Wed Sep 10 16:16:32 2025

[28]ប្រសិនបើ ព្រះករុណាផ្តល់អាហារ និងទឹកដោយគិតប្រាក់នោះយើងខ្ញុំនឹងបង់ប្រាក់ថ្វាយ
គ្រាន់តែអនុញ្ញាតឲ្យយើងខ្ញុំដើរឆ្លងកាត់ទឹកដីរបស់ព្រះករុណាប៉ុណ្ណោះ[29]ដូចជាកូនចៅរបស់លោកអេសាវ ជាអ្នកដែលរស់នៅក្នុងតំបន់ភ្នំសៀរ និងដូចជាជនជាតិម៉ូអាប់
ជាអ្នកដែលរស់នៅក្រុងអើរ បានអនុញ្ញាតឲ្យយើងដែរ រហូតដល់យើងខ្ញុំឆ្លងទន្លេយ័រដាន់ទៅដល់ទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់យើងខ្ញុំប្រគល់ឲ្យយើងខ្ញុំផង។
[30]ប៉ុន្តែ ព្រះបាទស៊ីហុន ជាស្តេចក្រុងហែលបូនមិនអនុញ្ញាតឲ្យយើងឆ្លងកាត់ទឹកដីរបស់ព្រះអង្គទេ ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានធ្វើឲ្យគំនិតរបស់ស្តេចមាន
និងចិត្តរឹងចចេស ដើម្បីប្រគល់គេមកឲ្យអ្នករាល់គ្នា ដូចដែលអ្នករាល់គ្នាបានឃើញថ្ងៃនេះ។[31]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «មើល៍
យើងបានចាប់ផ្តើមប្រគល់ស្តេចស៊ីហុន និងទឹកដីរបស់គេដាក់នៅមុខអ្នកហើយ ចូរចាប់ផ្តើមកាន់កាប់ទឹកដីនេះ ទុកជាមរតកចុះ»។
[32]បន្ទាប់មក ស្តេចស៊ីហុនចេញមកប្រឆាំងនឹងពួកយើង ហើយស្តេច និងប្រជាជនរបស់ស្តេចទាំងអស់មកប្រយុទ្ធនៅត្រង់យ៉ាហាស។
[33]ព្រះអម្ចាស់ជាព្រះរបស់យើងបានប្រគល់ស្តេចមកក្នុងកណ្តាប់ដៃរបស់យើង ហើយយើងបានយកឈ្នះលើស្តេច យើងបានដេញប្រហារសម្លាប់ស្តេចរហូតដល់ទ្រង់សុគត
ទាំងបុត្រធីតា និងប្រជាជនរបស់ស្តេចទាំងអស់ផង។
[34]យើងបានចាប់យកក្រុងរបស់ស្តេចទាំងអស់នៅពេលនោះ ហើយបានបំផ្លាញគ្រប់ក្រុងទាំងអស់ ព្រមទាំងមនុស្សប្រុសស្រី និងក្មេងតូចៗ
យើងមិនបានទុកអ្នកណាម្នាក់ឲ្យរួចជីវិតឡើយ។[35]យើងយកតែហ្វូងសត្វទុកសម្រាប់ខ្លួន ជារបស់ដែលយើងដណ្តើមយកបាន ពីក្រុងនានាដែលយើងចាប់បាន។
[36]ចាប់ពីក្រុងអារ៉ូអ៊ើរ ដែលនៅតាមមាត់ស្ទឹងអើណូន និងក្រុងផ្សេងៗនៅក្នុងជ្រលងភ្នំរហូតដល់កាឡាដ គ្មានក្រុងមួយណាខ្ពស់ជាងយើងទេ។
ព្រះអម្ចាស់ជាព្រះរបស់យើងបានប្រទានជ័យជម្នះដល់យើង លើគ្រប់សត្រូវទាំងអស់ដែលនៅមុខយើង។[37]លើកលែងតែទឹកដីរបស់កូនចៅរបស់ជនជាតិអាំម៉ូនទេ
ដែលយើងមិនទៅដល់ ព្រមទាំងក្រុងប៉ុន្មានដែលនៅតាមមាត់ស្ទឹងយ៉ាកុប និងក្រុងនៅតាមតំបន់ភ្នំ
ហើយគ្រប់កន្លែងណាដែលព្រះអម្ចាស់ជាព្រះរបស់យើងបានហាមឃាត់ពួកយើងមិនឲ្យទៅ។

Deuteronomy 2:1
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលជំនាន់មុនបានធ្វើ។
បន្ទាប់មក យើងចេញដំណើរទៅ
«បន្ទាប់មកយើងបានត្រឡប់ក្រោយហើយបានចេញទៅ»
នៅពេលយើងបានដើរជុំវិញតំបន់ភ្នំសៀរ ជាច្រើនថ្ងៃ។
អាចមានន័យថា ១)
ជនជាតិអ៊ីស្រាអែលធ្វើដំណើរជុំវិញភ្នំហៅថាភ្នំសៀរអស់ពេលយ៉ាងយូរ ឬ២)
ជនជាតិអ៊ីស្រាអែលបានដើរវង្វេងនៅតំបន់មួយហៅថា
ភ្នំសៀរអស់រយៈពេលជាយូរមកហើយ។
តំបន់ភ្នំសៀរ
នេះជាតំបន់ភ្នំមួយនៅភាគខាងត្បូងសមុទ្រមរណៈ។ តំបន់នេះត្រូវបានគេហៅថា
«អេដុម» ផងដែរ។ សូមមើលការបកប្រែនៅក្នុង ១:១
ជាច្រើនថ្ងៃ
ភាសាខ្លះបកប្រែដូចនេះ «ច្រើនរាត្រី»។
Deuteronomy 2:4
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
បងប្អូនរបស់អ្នករាល់គ្នា គឺកូនរបស់អេសាវ
«នៃសាច់ញាតិរបស់អ្នករាល់គ្នា ដែលជាកូនចៅរបស់លោកអេសាវ»
យើងបានប្រគល់ភ្នំសៀរនេះ ទៅឲ្យអេសាវ ទុកដូចជាទ្រព្យសម្បត្តិហើយ។
ព្រះអម្ចាស់កំពុងរម្លឹកជនជាតិអ៊ីស្រាអែលថា
ទ្រង់បានប្រទានទឹកដីនេះឱ្យកូនចៅរបស់លោកអេសាវ។
Deuteronomy 2:6
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តបង្រៀនជនជាតិអ៊ីស្រាអែលអំពីរបៀប
ដែលពួកគេត្រូវប្រព្រឹត្តចំពោះកូនចៅលោកអេសាវ។
អ្នករាល់គ្នាត្រូវយកប្រាក់ទៅទិញអាហារពីពួកគេ
ព្រះអម្ចាស់កំពុងប្រទានការអនុញ្ញាតដល់ពួកគេ ឬការបង្រៀនមិនមែនបង្គាប់ទេ
ហើយទ្រង់កំពុងប្រាប់ពួកគេកុំឱ្យលួច។
«យើងអនុញ្ញាតឱ្យអ្នករាល់គ្នាទិញម្ហូបពីពួកគេ» ឬ «បើអ្នករាល់គ្នាត្រូវការអាហារ
អ្នករាល់គ្នាត្រូវទិញវាពីពួកគេ»
ពីពួកគេ
«ពីកូនចៅលោកអេសាវ»
យកប្រាក់
បើពាក្យទាំងនេះមិនចាំបាច់ ឬធ្វើឱ្យការបកប្រែមិនច្បាស់លាស់
អ្នកអាចលុបវាចោល។
ព្រះរបស់អ្នករាល់គ្នាបានប្រទានព្រះពរដល់អ្នករាល់គ្នា ...អ្នករាល់គ្នាធ្វើ ... ដើរឆ្លងកាត់ ...
ព្រះរបស់អ្នករាល់គ្នា ... ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានគង់នៅជាមួយអ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលដូចជាពួកគេមនុស្សតែម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» ជាឯកវចនៈ។
ក្នុងគ្រប់កិច្ចការទាំងអស់ដែលអ្នករាល់គ្នាធ្វើ
«គ្រប់កិច្ចការទាំងអស់ដែលអ្នករាល់គ្នាធ្វើ »សំដៅទៅលើការងារទាំងអស់
ដែលពួកគេបានធ្វើ។ ការបកប្រែផ្សេងទៀត «រាល់ការងាររបស់អ្នករាល់គ្នា»
ព្រះអង្គជ្រាបពីការដែលអ្នករាល់គ្នាដើរឆ្លងកាត់
នេះជាពាក្យមួយសម្រាប់ «ព្រះអង្គជ្រាបអ្វីៗ ដែលបានកើតឡើងចំពោះអ្នករាល់គ្នា
នៅពេលអ្នករាល់គ្នាកំពុងដើរ»។
សែសិបឆ្នាំ
«៤០ឆ្នាំ»
អ្នករាល់គ្នាមិនខ្វះខាតអ្វីសោះឡើយ។
នេះជាការនិយាយបញ្ជោស «អ្នករាល់គ្នាមានអ្វីៗគ្រប់យ៉ាងដែលអ្នកត្រូវការ»។
Deuteronomy 2:8
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
បងប្អូនរបស់យើង
«សាច់ញាតិរបស់យើង»
អេឡាត ...អេស៊ាន គេប៊ើរ
ទាំងនេះជាឈ្មោះទីក្រុង។
យើងធ្វើដំណើរ
នេះជាឃ្លាបែបសំនួនវោហារ។ ការបកប្រែផ្សេងទៀត
«យើងបន្តដំណើរទៅមុខទៀត»
Deuteronomy 2:9
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
កុំបង្កបញ្ហាដល់ជនជាតិម៉ូអាប់
ពាក្យ «ជនជាតិម៉ូអាប់» ជាពាក្យរួមមួយសម្រាប់ប្រជាជនម៉ូអាប់។
ការបកប្រែផ្សេងទៀត «កុំបង្កបញ្ហាជាមួយប្រជាជនម៉ូអាប់»
ក្រុងអើរ
នេះជាឈ្មោះទីក្រុងមួយនៅម៉ូអាប់។
ឲ្យកូនចៅរបស់លោកឡុត
ប្រជាជនអ៊ីស្រាអែលមានទំនាក់ទំនងជាមួយកូនចៅម៉ូអាប់។
ម៉ូអាប់ជាកូនរបស់លោកឡុត។ លោកឡុតជាក្មួយប្រុសរបស់លោកអប្រាហាំ។
Deuteronomy 2:10
ព័ត៌មានទូទៅ៖
អ្នកនិពន្ធចាប់ផ្តើមផ្តល់ព័ត៌មានសង្ខេបអំពីប្រជាជននៅលើទឹកដី។
ពាក្យសម្តីទាំងនេះមិនមែនជាផ្នែកមួយ នៃពាក្យសម្តីរបស់លោកម៉ូសេ
ចំពោះជនជាតិអ៊ីស្រាអែលទេ។
ជនជាតិអេមីមរស់ ... ហៅពួកគេថា ជនជាតិអេមីម។
ពាក្យទាំងនេះផ្តល់ពត៌មានសង្ខេបអំពីប្រជាជនអេមីម
ដែលបានរស់នៅក្នុងស្រុកមុនជនជាតិម៉ូអាប់។
ភាសារបស់អ្នកអាចមានរបៀបពិសេស ដើម្បីសម្គាល់ព័ត៌មានសង្ខេប។
ជនជាតិអេមីម... ជាជនជាតិរេផែម
ទាំងនេះជាឈ្មោះក្រុមមនុស្ស ដែលត្រូវបានគេចាត់ទុកថាជាមនុស្សមានឧត។

generated on Wed Sep 10 16:16:32 2025

ជនជាតិអណាក់
ទាំងនេះជាកូនចៅរបស់ប្រជាជនអណាក់ ដែលមានមាឌធំនិងកាចសាហាវ។ សូមមើលការបកប្រែនៅក្នុង ១:២៦ ។
Deuteronomy 2:12
ព័ត៌មានទូទៅ៖
នេះបន្តព័ត៌មានសង្ខេបអំពីក្រុមមនុស្សផ្សេងៗគ្នា ដែលធ្លាប់រស់នៅលើទឹកដី។ ។
ជនជាតិហូរី
នេះជាឈ្មោះក្រុមមនុស្ស។
ពួកគេបំផ្លាញជនជាតិហូរីចេញពីមុខពួកគេ
«បានសម្លាប់ពួកគេទាំងអស់ ដូច្នេះ គ្មាននរណាម្នាក់ក្នុងចំណោមពួកគេ ត្រូវបានទុកឱ្យរស់នៅជាមួយពួកគេ» ឬ «បានយកពួកគេចេញពីមុខរបស់ពួកគេ តាមរយៈការសម្លាប់ពួកគេទាំងអស់»
Deuteronomy 2:13
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកជនជាតិអ៊ីស្រាអែលអំពីអ្វី ដែលបានកើតឡើងចំពោះពួកគេនៅទីរហោស្ថាន។
«ឥឡូវនេះ ចូរក្រោកឡើង ...សេរេដចុះ»។ ដូច្នេះ
បន្ទាប់មក ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ចូរក្រោកឡើង! សេរេដចុះ»។ ដូច្នេះ អាចបកប្រែជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត «បន្ទាប់មកព្រះអម្ចាស់បានប្រាប់យើងឱ្យក្រោកឡើង ... .សេរេដចុះ»
ចូរក្រោកឡើង
ចាប់ផ្តើមធ្វើអ្វីមួយ
ជ្រោះសេរេដ
ទឹកអូរនេះហូរចូលសមុទ្រស្លាប់ពីភាគអាគ្នេយ៍ ហើយបង្កើតជាព្រំប្រទល់រវាងស្រុកអេដុម និងម៉ូអាប់។
ឥឡូវ ចាប់ពីថ្ងៃ
ពាក្យថា «ឥឡូវនេះ» សម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាព័ត៌មានសង្ខេបអំពីរយៈពេល ដែលប្រជាជនអ៊ីស្រាអែលធ្វើដំណើរ និងអំពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ចំពោះជំនាន់នោះ។ បើភាសារបស់អ្នកមានរបៀបបង្ហាញថា អ្វីដែលនៅពីក្រោយគឺជាព័ត៌មានសង្ខេប អ្នកគួរតែប្រើវានៅទីនេះ។
មានរយៈពេលសាមសិបប្រាំបីឆ្នាំ
ប្រាំបីឆ្នាំ «៣៨ ឆ្នាំ»
បានបាត់បង់ជីវិតអស់
នេះជារបៀបគួរសមក្នុងការនិយាយថា «បានស្លាប់» ។
ព្រះហស្តរបស់ព្រះអម្ចាស់ទាស់ប្រឆាំង
នៅទីនេះ «ព្រះហស្តរបស់ព្រះអម្ចាស់» សំដៅទៅលើឫទ្ធានុភាពរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត « ព្រះអម្ចាស់បានប្រើឫទ្ធានុភាពរបស់ព្រះអង្គទាស់ប្រឆាំង» ឬ« ព្រះអម្ចាស់ដាក់ទោស»
Deuteronomy 2:16
ព័ត៌មានទូទៅ:
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
អ្នកបាន ... អ្នករាល់គ្នាធ្វើដំណើរ ... កុំបង្កបញ្ហា... ឲ្យទឹកដី
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់ ដូច្នេះ ការកើតមានឡើងទាំងអស់នៃពាក្យ «អ្នក» និងបង្គាប់ដែលថា «កុំបង្កបញ្ហា» ជាឯកវចនៈ។
បានត្រូវឆ្លងកាត់ក្រុងអើរ
នេះជាឈ្មោះទីក្រុងមួយនៅម៉ូអាប់។ សូមមើលការបកប្រែ «ក្រុងអើរ» នៅក្នុង ២:៩។
ឲ្យទៅកូនចៅរបស់លោកឡុត
ប្រជាជនអ៊ីស្រាអែលមានទំនាក់ទំនងជាមួយកូនចៅអាំម៉ូន។ អាំម៉ូនជាកូនរបស់លោកឡុត។ លោកឡុតគឺជាក្មួយប្រុសរបស់អ្រាហាំ។
Deuteronomy 2:20
ព័ត៌មានទូទៅ៖
ខគម្ពីរទាំងនេះចាប់ផ្តើមផ្តល់ព័ត៌មានសង្ខេបអំពីក្រុមមនុស្ស ដែលរស់នៅលើទឹកដី។ បើភាសារបស់អ្នកមានរបៀបបង្ហាញថា អ្វីដែលមកតាមក្រោយជាព័ត៌មានសង្ខេប ដែលអ្នកគួរតែប្រើវានៅទីនេះ។
ទឹកដីនោះ ក៏ចាត់ទុកជាទឹកដី
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «ប្រជាជនក៏ចាត់ទុកថា»
ជនជាតិរេផែម
នេះជាឈ្មោះក្រុមមនុស្ស។ សូមមើលការបកប្រែនៅ ២:១០ ។
ជាជនជាតិសាំស៊ូមីម
នេះជាឈ្មោះមួយផ្សេងទៀត សម្រាប់ក្រុមជនជាតិសាំស៊ូមីម។
ជនជាតិអណាក់
នេះជាឈ្មោះក្រុមមនុស្ស។ សូមមើលការបកប្រែនៅក្នុង ១:២៦ ។
បានបំផ្លាញពួកគេនៅពីមុខប្រជាជនអាំម៉ូន
«បានអនុញ្ញាតឱ្យពួកអាំម៉ូនកម្ចាត់ពួកគេ» ឬ «អនុញ្ញាតឱ្យពួកអាំម៉ូនសម្លាប់ពួកគេទាំងអស់»
ពួកគេ ទទួលបានជ័យជម្នះ ហើយបានរស់នៅទីនោះទៅ។
ជនជាតិអាំម៉ូនបានកាន់កាប់លើអ្វីៗទាំងអស់ ដែលជនជាតិរេផែមបានកាន់កាប់ និងបានរស់នៅកន្លែង ដែលជនជាតិរេផែមបានរស់នៅ»
ប្រជាជនហូរី
នេះជាឈ្មោះក្រុមមនុស្ស។ សូមមើលការបកប្រែនៅ ២:១២ ។
ទទួលបានជ័យជម្នះ ហើយបានរស់នៅទីនោះទៅ។
«កាន់កាប់អ្វីៗទាំងអស់ ដែលប្រជាជនហូរីបានកាន់កាប់ និងបានរស់នៅកន្លែង ដែលប្រជាជនហូរីបានរស់នៅ»
Deuteronomy 2:23
ព័ត៌មានទូទៅ៖
អ្នកនិពន្ធបញ្ចប់ការរៀបរាប់អំពីរបៀប ដែលព្រះជាម្ចាស់បានជួយលោកអេសាវយកឈ្នះលើទឹកដី ដែលលោកអេសាវរស់នៅឥឡូវនេះ។
ជនជាតិអារីម ... ជនជាតិកាប់ថោរ
ទាំងនេះជាឈ្មោះក្រុមមនុស្ស។
កាប់ថោរ
នេះជាឈ្មោះទីកន្លែង។ អាចជាឈ្មោះមួយទៀតសម្រាប់កោះក្រេត ដែលមានទីតាំងនៅសមុទ្រមេឌីទែរ៉ាណេ។
បានបំផ្លាញពួកគេ
«បំផ្លាញជនជាតិអារីម»
តាំងទីលំនៅក្នុងទឹកដីនោះទៅ។
«បានរស់នៅកន្លែង ដែលជនជាតិអារីមធ្លាប់រស់នៅ»
Deuteronomy 2:24
ព័ត៌មានទូទៅ៖
អ្នកនិពន្ធបានប្រាប់ពត៌មានសង្ខេប ហើយឥឡូវកំពុងប្រាប់ម្តងទៀតនូវអ្វី ដែលលោកម៉ូសេបាននិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ឥឡូវនេះ ចូរក្រោកឡើង
ព្រះអម្ចាស់កំពុងប្រាប់លោកម៉ូសេនូវនូវអ្វី ដែលប្រជាជនគួរធ្វើ។ «ឥឡូវនេះ ចូរក្រោកឡើង» ឬ «ឥឡូវនេះ ចូរចេញទៅ» ។
ហើយបន្តដំណើររបស់អ្នករាល់គ្នា
«បន្តដំណើររបស់អ្នករាល់គ្នា»
ស្ទឹងអើណូន
នេះជាឈ្មោះស្ទឹងអើណូន។ បង្កើតជាព្រំដែនរវាងជនជាតិម៉ូអាប់ និងជនជាតិអាម៉ូរី។
យើងបានប្រគល់ទឹកដីនោះទៅក្នុងដៃរបស់អ្នករាល់គ្នា
ពាក្យប្រៀបធៀប «ទៅក្នុងដៃរបស់អ្នក» មានន័យថា «ចូលទៅក្នុងការគ្រប់គ្រងឬអំណាចរបស់អ្នករាល់គ្នា» ។ ការបកប្រែផ្សេងទៀត«យើងបានប្រគល់ឱ្យអ្នករាល់គ្នានូវអំណាចដើម្បីទទួលជ័យជម្នះ»
ទៅក្នុងដៃរបស់អ្នករាល់គ្នា...ចូរចាប់ផ្តើមកាន់កាប់ទឹកដីនោះទៅ ... ប្រយុទ្ធ ... កោតខ្លាចចំពោះអ្នករាល់គ្នា ... ឮអំពីអ្នករាល់គ្នា ... ពោះអ្នករាល់គ្នាផង។
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេមានមនុស្សម្នាក់ ដូច្នេះ ការកើតមានឡើងរបស់អ្នកនិង «អ្នក» និង «រប់អ្នក» ហើយបង្គាប់ «ចាប់ផ្តើមកាន់កាប់» និង «ប្រយុទ្ធ» មានលក្ខណៈឯកវចនៈ។
ព្រះបាទស៊ីហុន
នេះជានាមរបស់ស្តេច។ សូមមើលការបកប្រែនៅក្នុង ១: ៣។
ក្រុងហែលពូន
នេះជាឈ្មោះទីក្រុងមួយ។ សូមមើលការបកប្រែនៅក្នុង ១:៣។
ប្រយុទ្ធជាមួយពួកគេ

generated on Wed Sep 10 16:16:32 2025

«ប្រយុទ្ធប្រឆាំងនឹងពួកគេ និងកងទ័ពរបស់ពួកគេ»
ភ័យខ្លាច និងកោតខ្លាច
ពាក្យថា «ភ័យខ្លាច» និង «កោតខ្លាច» មានន័យថាជារួមដូចគ្នា
ហើយបញ្ជាក់ថាការភ័យខ្លាចគឺខ្លាំងណាស់។ ការបកប្រែផ្សេងទៀត
«ដាក់ការភ័យខ្លាចដ៏អាក្រក់»
ជនជាតិនៅក្រោមមេឃទាំងមូលភ័យខ្លាច
នេះជាសំនួនវោហារស័ព្ទ។ ការបកប្រែផ្សេងទៀត
«ប្រជាជននៅគ្រប់តំបន់ទាំងអស់»
ភ័យខ្លាច ព្រមទាំងមានចិត្តព្រួយបារម្ភ
នេះជាឃ្លាហើយសង្កត់ធ្ងន់ថា ប្រជាជននឹង«ភ័យញាប់ញ័រព្រមទាំងព្រួយបារម្ភ»។
Deuteronomy 2:26
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ខ្ញុំបានចាត់
នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកម៉ូសេ។
ទីរហោស្ថានក្តេម៉ូត
នេះជាឈ្មោះទីកន្លែងក្បែរជ្រលងភ្នំអើណូន។
ព្រះបាទស៊ីហុន ... ហែលបូន
ទាំងនេះជាឈ្មោះមនុស្សប្រុសនិងទីកន្លែង។ សូមមើលការបកប្រែនៅក្នុង ១: ៣។
ជាមួយនឹងពាក្យសន្តិភាព
នៅទីនេះពាក្យប្រៀបធៀប «ពាក្យនៃសន្តិភាព» មានន័យថា
«ជាមួយនឹងការផ្តល់ជូនរបស់ខ្ញុំចំពោះសន្តិភាព» ឬ «ជាមួយសារពីខ្ញុំសុំសន្តិភាព»
។
យើងខ្ញុំនឹងមិនងាកខាងស្តាំ ឬទៅខាងឆ្វេងនោះទេ។
ឃ្លានេះបញ្ជាក់ថា ពួកគេនឹងដើរតាមទិសដៅតែមួយជានិច្ច។
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ «យើងនឹងមិនផ្លាស់ប្តូរទិសដៅ» ឬ
«យើងនឹងស្ថិតនៅលើផ្លូវជានិច្ច»
Deuteronomy 2:28
ព័ត៌មានទូទៅ៖
នៅតែបន្តសាររបស់លោកម៉ូសេទៅកាន់ស្តេចស៊ីហុន។
ប្រសិនបើ ព្រះករុណាផ្តល់អាហារ និងទឹកដោយគិតប្រាក់នោះយើងខ្ញុំនឹងបង់ប្រាក់ថ្វាយ
លោកម៉ូសេបានប្រាប់ព្រះបាទស៊ីហុនថា
ជនជាតិអ៊ីស្រាអែលនឹងមិនលួចពីជនជាតិអាម៉ូរីទេ ហើយស្នើសុំឱ្យព្រះបាទស៊ីហុន
និងប្រជាជនរបស់ព្រះអង្គលក់ស្បៀងអាហារ និងទឹកឱ្យជនជាតិអ៊ីស្រាអែល។
ទ្រង់មិនបានផ្តល់ការបង្គាប់ទេ។ ការបកប្រែផ្សេងទៀត «ខ្ញុំរំពឹងទុកថា
នឹងត្រូវបង់ប្រាក់សម្រាប់អាហារ ដូច្នេះ ខ្ញុំអាចបរិភោគនិងបង់ប្រាក់សម្រាប់ទឹក
ដូច្នេះ ខ្ញុំអាចពិសាទឹកបាន»
ផ្តល់អាហារ ... ខ្ញុំនឹងបរិភោគ... ផ្តល់ជូនខ្ញុំ ... ខ្ញុំអាចផឹក
លោកម៉ូសេចង់សំដៅទៅលើជនជាតិអ៊ីស្រាអែល ដូចជាពួកគេជាលោកម៉ូសេដែរ។
ការបកប្រែផ្សេងទៀត «លក់ឱ្យខ្ញុំនិងប្រជាជនខ្ញុំ...យើងអាចបរិភោគ...
ផ្តល់ឱ្យយើង...យើងអាចពិសាទឹក»
គ្រាន់តែអនុញ្ញាតឲ្យយើងខ្ញុំដើរឆ្លងកាត់ទឹកដីរបស់ព្រះករុណាប៉ុណ្ណោះ
«ឱ្យតែយើងដើរកាត់ទឹកដីរបស់ព្រះករុណា»
ក្រុងអើរ
នេះជាឈ្មោះកន្លែងមួយ។ សូមមើលការបកប្រែនៅក្នុង ២:៩។
Deuteronomy 2:30
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
ព្រះបាទស៊ីហុន ... ក្រុងហែលបូន
ទាំងនេះជាឈ្មោះមនុស្សប្រុស និងទីកន្លែង។ សូមមើលការបកប្រែនៅក្នុង ១:៣។
ជាព្រះរបស់អ្នករាល់គ្នា ... អ្នករាល់គ្នាបាន
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេមានមនុស្សម្នាក់
ដូច្នេះ រាល់ការកើតឡើងមានឡើងនៃពាក្យ «របស់អ្នក» មានលក្ខណៈឯកវចនៈ។
បានធ្វើឲ្យគំនិតរបស់ស្តេចមានៈ និងចិត្តរឹងចចេស
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ថាព្រះអម្ចាស់
«ធ្វើឱ្យស្តេចត្រឡប់ជារឹងរូសចចេសខ្លាំងណាស់»។
ប្រគល់ស្តេចស៊ីហុន និងទឹកដីរបស់គេដាក់នៅមុខអ្នកហើយ
«ប្រគល់ព្រះបាទស៊ីហុននិងទឹកដីរបស់ស្តេច មកឱ្យអ្នករាល់គ្នា»
ចូរចាប់ផ្តើមកាន់កាប់ទឹកដីនេះ ទុកជាមរតកចុះ។
«ចូរកាន់កាប់ទឹកដីរបស់ស្តេចទុកជាមរតក»
Deuteronomy 2:32
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
ស្តេចស៊ីហុន
នេះជាឈ្មោះមនុស្សប្រុស។ សូមមើលការបកប្រែនៅក្នុង ១:៣។
យ៉ាហាស់
នេះជាឈ្មោះទីក្រុងមួយនៅម៉ូអាប់
Deuteronomy 2:34
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
យើងបានចាប់យកក្រុងរបស់ស្តេចទាំងអស់
«យើងបានដណ្តើមបានទីក្រុងទាំងអស់របស់ស្តេចស៊ីហុន»
ហើយបានបំផ្លាញគ្រប់ក្រុងទាំងអស់
«បានសម្លាប់ប្រជាជនទាំងអស់ ដែលរស់នៅក្នុងទីក្រុងទាំងអស់»
Deuteronomy 2:36
ក្រុងអារ៉ូអ៊ើរ
នេះជាឈ្មោះទីក្រុងមួយនៅភាគខាងជើងទន្លេអើណូន។
ស្ទឹងអើណូន
«ស្ទឹងអើណូន» ជាឈ្មោះទន្លេ។ បកប្រែដូចនៅក្នុង ២:២៤។
គ្មានក្រុងមួយណាខ្ពស់ជាងយើងទេ។
សេចក្តីថ្លែងការណ៍អវិជ្ជមាននេះត្រូវបានប្រើ
ដើម្បីបញ្ជាក់ពីជោគជ័យរបស់ពួកគេនៅក្នុងសមរភូមិ។
អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «
យើងអាចទទួលជ័យជម្នះពីប្រជាជននៅគ្រប់តំបន់
ទោះបីទីក្រុងមានកំពែងព័ទ្ធជុំវិញក៏ដោយ»
យើងមិនទៅដល់
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេមានមនុស្សម្នាក់
ដូច្នេះ «អ្នក» មានលក្ខណៈឯកវចនៈ។
តាមមាត់ស្ទឹងយ៉ាកុប
នេះជាឈ្មោះទន្លេដែលបានបង្កើតព្រំដែន រវាងទឹកដីរបស់ព្រះបាទស៊ីហុន
និងទឹកដីរបស់ជនជាតិអាំម៉ូន។

---

3 [1]បន្ទាប់មក យើងបានចេញដំណើរតាមផ្លូវឡើងទៅទឹកដីបាសាន។ ព្រះបាទអុក ជាស្តេចនៃទឹកដីបាសាន បានចេញមកប្រយុទ្ធជាមួយពួកយើង ស្តេច
និងប្រជាជនទាំងមូលរបស់ស្តេច បានចេញមកប្រយុទ្ធនៅត្រង់អេទ្រី។[2]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា៖ «កុំភ័យខ្លាចឲ្យសោះ ដ្បិត
យើងបានប្រគល់ជ័យជម្នះដល់អ្នករាល់គ្នា ហើយប្រគល់ប្រជាជន និងទឹកដីរបស់ស្តេចទាំងអស់មកអ្នករាល់គ្នាឲ្យស្ថិតក្នុងក្រោមការគ្រប់គ្រងរបស់អ្នកហើយ។
អ្នករាល់គ្នានឹងប្រព្រឹត្តចំពោះស្តេចនោះ ដូចជាអ្នករាល់គ្នាបានប្រព្រឹត្តចំពោះស្តេចស៊ីហុក ជាស្តេចនៃជនជាតិអាម៉ូរី ជាអ្នកដែលរស់នៅក្រុងហែលបូនដែរ។
[3]ដូច្នេះ ព្រះអម្ចាស់ជាព្រះនៃយើងក៏បានប្រទានជ័យជម្នះដល់យើងលើស្តេចអុក ជាស្តេចនៃទឹកដីបាសាន
ព្រមទាំងប្រជាជនទាំងអស់របស់ស្តេចក៏ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើងដែរ។ យើងដេញប្រហារពួកគេរហូតគ្មានសល់អ្នកណាម្នាក់ឡើយ។
[4]យើងបានចាប់យកក្រុងរបស់គេនៅពេលនោះ គ្មានក្រុងណាមួយដែលរួចផុតពីការចាប់យករបស់យើងទេ គឺហុកសិបក្រុង គ្រប់ទាំងតំបន់អើកុប
ដែលជានរគនៃស្តេចអុកនៅក្នុងទឹកដីបាសាន។
[5]ក្រុងទាំងអស់នោះ មានកំពែងការពារយ៉ាងខ្ពស់ មានទ្វារ និងរនុក ក្រៅពីនោះ មានភូមិជាច្រើនគ្មានកំពែងទេ។[6]យើងបានបំផ្លាញពួកគេទាំងស្រុង
ដូចជាយើងបានធ្វើចំពោះព្រះបាទស៊ីហុក ជាស្តេចនៃទឹកដីហែលបូន គឺបានបញ្ចប់ការបំផ្លាញក្រុងទាំងអស់ ទាំងមនុស្សប្រុសស្រី និងក្មេងតូចៗ។[7]ប៉ុន្តែ ហ្វូងសត្វ
និងរបស់ដែលបានមកពីក្រុងនានា យើងយកទុកជារបស់ជ័យភ័ណ្ឌសម្រាប់យើងផ្ទាល់។

generated on Wed Sep 10 16:16:32 2025

[8]នៅពេលនោះ យើងបានយកទឹកដីនោះ ពីស្តេចពីរអង្គរបស់ជាជនអាម៉ូរី ជាស្តេចដែលនៅខាងនាយទន្លេយ័រដាន់
ចាប់តាំងពីស្ទឹងអើណូនរហូតដល់ភ្នំហ៊ើរម៉ូន[9](ជនជាតិស៊ីដូនហៅភ្នំហ៊ើរម៉ូនថា ភ្នំស៊ីរាន ហើយប្រជាជននៅទឹកដីអាម៉ូរីហៅភ្នំនេះថា ភ្នំសេនារ)[10]ព្រមទាំងក្រុងនៅតំបន់វាល
និងទឹកដីកាឡាដ ទឹកដីបាសានទាំងមូល រហូតដល់សាល់កា និងអេទ្រី ជាក្រុងរបស់នរគនៃស្តេចអុកនៅក្នុងទឹកដីបាសាន»។
[11](ជនជាតិរេមផែមដែលនៅសល់ចុងក្រោយគឺមានតែព្រះបាទអុក ជាស្តេចទឹកដីបាសាន។ មើល៍! គ្រែធ្មុំរបស់ព្រះអង្គ គឺជាគ្រែដែក។ តើគ្រែនោះមិននៅក្រុងរ៉ាបាត
ជាកន្លែងដែលកូនចៅរបស់ពួកអាំម៉ូនទេឬ? គ្រែនោះមានបណ្តាោយប្រាំបួនហត្ថ និងទទឹងបួនហត្ថ តាមហត្ថរបស់មនុស្ស)។
[12]«នេះគឺជាទឹកដីដែលយើងបានចាប់យកធ្វើជាកម្មសិទ្ធិនៅពេលនោះ ចេញពីទឹកដីអារ៉ូអ៊ើរ ដែលនៅមាត់ស្ទឹងអើណូន និងពាក់កណ្តាលតំបន់ភ្នំនៃកាឡាត
ព្រមទាំងក្រុងនៅទឹកដីនោះ ខ្ញុំប្រគល់ឲ្យកុលសម្ព័ន្ធរូបេន និងកុលសម្ព័ន្ធកាដ។[13]ហើយទឹកដីដែលនៅពីកាឡាត និងទឹកដីទាំងអស់នៅបាសាន ជានរគនៃស្តេចអុក
ខ្ញុំបានប្រគល់កណ្តាលទៅឲ្យកុលសម្ព័ន្ធម៉ាណាសេ តំបន់ទាំងអស់អើកុប និងបាសានទាំងមូល។ (គេក៏ហៅតំបន់នេះថា ទឹកដីរេផែមដែរ។
[14]អំបូរយ៉ាអ៊ារ ដែលត្រូវកូនចៅរបស់ម៉ាណាសេ បានយកតំបន់ទាំងមូលនៃអើកុប ទៅដល់ព្រំប្រទល់នៃទឹកដីជនជាតិកេស៊ូរី និងជនជាតិម៉ាកាធី។ គេបានហៅតំបន់
ទឹកដីបាសាដែរ គឺហៅតាមឈ្មោះលោកហាវ៉ុត យ៉ាអ៊ារ រហូតមកទល់សព្វថ្ងៃនេះ)។
[15]ខ្ញុំបានប្រគល់ទឹកដីកាឡាដទៅឲ្យអំបូរម៉ាគារ។[16]ចំពោះកូនចៅរូបេន និងកូនចៅកាដវិញ ខ្ញុំបានប្រគល់ទឹកដីចាប់ពីកាឡាដ រហូតដល់ស្ទឹងអើណូន
ពាក់កណ្តាលនៃស្ទឹងគឺតំបន់នៃព្រំប្រទល់ ហើយពីស្ទឹងយ៉ាបុក ដែលជាព្រំប្រទល់ដែនដីរបស់កូនចៅអាំម៉ូន។
[17]ហើយព្រំប្រទល់មួយទៀតក៏ជាវាលទំនាបនៃទន្លេយ័រដាន់ ចាប់ពីគេនេសារ៉ែត ទៅសមុទ្រអារ៉ាបា (ជាសមុទ្រអំបិល) រហូតដល់ជម្រាលភ្នំពីសកាភាគខាងកើត។
[18]ខ្ញុំបានបង្គាប់អ្នករាល់គ្នានៅពេលនោះថា៖ «ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានប្រទានទឹកដីនេះដល់ ដើម្បីឲ្យកាន់កាប់
អ្នករាល់គ្នាដែលអ្នកចម្បាំងនឹងត្រូវដើរកាន់ទីនោះ ដោយមានអាវុធជាប់ខ្លួន នៅពីមុខបងប្អូនរបស់អ្នករាល់គ្នា ជាប្រជាជនអ៊ីស្រាអែល។
[19]ប៉ុន្តែ ប្រពន្ធកូន និងហ្វូងសត្វរបស់អ្នករាល់គ្នា (ខ្ញុំដឹងថា អ្នករាល់គ្នាមានហ្វូងសត្វច្រើនណាស់) នឹងត្រូវស្នាក់នៅក្នុងក្រុងរបស់អ្នករាល់គ្នា
ដែលខ្ញុំបានប្រគល់ឲ្យ[20]រហូតដល់ព្រះអម្ចាស់ប្រទានឲ្យបងប្អូនរបស់អ្នករាល់គ្នាទាំងអស់សម្រាក ដូចជាព្រះអង្គប្រទានដល់អ្នករាល់គ្នាដែរ
ហើយរហូតដល់ពួកគេកាន់កាប់ទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យពួកគេនៅត្រើយខាងនាយទន្លេយ័រដាន់ បន្ទាប់មក
អ្នករាល់គ្នានឹងត្រឡប់ទៅទឹកដីដែលខ្ញុំបានប្រគល់ឲ្យអ្នករាល់គ្នាវិញ។
[21]ខ្ញុំបានបង្គាប់ទៅលោកយ៉ូស្វេនៅពេលនោះ ដោយប្រាប់ថា៖ «ភ្នែករបស់អ្នកបានឃើញការទាំងអស់ដែលព្រះអម្ចាស់ជាព្រះរបស់អ្នកបានធ្វើ
ចំពោះស្តេចទាំងពីរអង្គនេះស្រាប់ហើយ ព្រះអម្ចាស់នឹងធ្វើដល់នគរទាំងអស់ដូចគ្នាដែរ នៅពេលអ្នកឆ្លងចូលទៅក្នុងទឹកដីនោះ។ ។[22]អ្នកមិនភ័យខ្លាចពួកគេទេ ដ្បិត
ព្រះអម្ចាស់ព្រះរបស់អ្នក ហើយព្រះអង្គនឹងប្រយុទ្ធជំនួសអ្នកដែរ»។
[23]ខ្ញុំបានអង្វរករព្រះអម្ចាស់នៅពេលនោះថា៖[24]«ឱព្រះអម្ចាស់ ព្រះអង្គបានចាប់ផ្តើមបង្ហាញឲ្យអ្នកបម្រើរបស់ព្រះអង្គ ឃើញពីភាពអស្ចារ្យ និងឫទ្ធិបារមីរបស់ព្រះអង្គ ដ្បិត
តើមានព្រះឯណានៅស្ថានសួគ៌ ឬនៅលើផែនដី ដែលអាចធ្វើការអស្ចារ្យ ហើយកិច្ចការដ៏អស្ចារ្យដូចព្រះអង្គបាន?[25]សូមប្រទានឲ្យទូលបង្គំចេញទៅ
សុំឲ្យឃើញទឹកដីល្អដែលនៅត្រើយខាងទន្លេយ័រដាន់ ព្រមទាំងតំបន់ភ្នំល្អៗ និងទឹកដីលើបង់ផង។
[26]ប៉ុន្តែ ព្រះអម្ចាស់បានព្រះពិរោធនឹងខ្ញុំ ពីព្រោះតែអ្នករាល់គ្នា ព្រះអង្គមិនបានស្តាប់ខ្ញុំឡើយ។ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា៖ «ប៉ុណ្ណឹងបានហើយ
កុំនិយាយជាមួយយើងពីការទាំងនេះទៀត។[27]ចូរចេញទៅលើកំពូលភ្នំពីសកា ហើយក្រឡេកភ្នែករបស់អ្នកមើលភាគខាងលិច ភាគខាងជើង និងភាគខាងកើត
ចូរដោយភ្នែករបស់អ្នក ដ្បិត អ្នកនឹងមិនឆ្លងកាត់ទន្លេយ័រដាន់ទេ។
[28]ផ្ទុយទៅវិញ ចូរបង្រៀនលោកយ៉ូស្វេ ហើយលើកទឹកចិត្ត និងចម្រើនកម្លាំងឲ្យគាត់វិញ ដ្បិត លោកនឹងនាំមុខប្រជាជនឆ្លង
ហើយលោកនឹងចែកទឹកដីដែលអ្នករាល់គ្នានឹងមើលឃើញនេះ ទុកជាកេរមត៌ក។[29]ដូច្នេះ យើងបាននៅក្នុងជ្រលងភ្នំដែលទល់មុខនឹងបេតពេអរ។

Deuteronomy 3:1

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។

ព្រះបាទអុក... ស្តេចស៊ីហុន

ទាំងនេះជាឈ្មោះរបស់ស្តេច។ សូមមើលការបកប្រែនៅក្នុង ១:៣។

អេទ្រី ... ក្រុងហែលបូន

ទាំងនេះជាឈ្មោះទីក្រុងនានា។ សូមមើលការបកប្រែនៅក្នុង ១:៣។

ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា៖ «កុំភ័យខ្លាចឲ្យសោះ ...

បានប្រគល់ជ័យជម្នះដល់អ្នករាល់គ្នា ... ក្រោមការគ្រប់គ្រង់របស់អ្នកហើយ។ ...

អ្នករាល់គ្នានឹងប្រព្រឹត្តចំពោះ ... ជាស្តេចនៃ ...នៅក្រុងហែលបូនដែរ។

ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់លោកម៉ូសេដូចជាលោកម៉ូសេជាជនជាតិអ៊ីស្រាអែលដែរ

ដូច្នេះបង្គាប់ «កុំភ័យខ្លាចឲ្យសោះ» និងការកើតមានឡើងនៃពាក្យ «អ្នក» និង
«របស់អ្នក» មានលក្ខណៈជាពហុវចនៈ។

ភ័យខ្លាចស្តេច...ប្រគល់ជ័យជម្នះ ... ប្រជាជន និងទឹកដីរបស់ស្តេច

នៅទីនេះពាក្យ «ស្តេច» និង «របស់ស្តេច» សំដៅទៅលើព្រះបាទអុក។

យើងបានប្រគល់ជ័យជម្នះដល់អ្នករាល់គ្នា

ព្រះអម្ចាស់មានបន្ទូលអំពីអ្វី ដែលព្រះអង្គនឹងធ្វើដូចជាព្រះអង្គបានធ្វើរួចហើយ។

អ្នករាល់គ្នានឹងប្រព្រឹត្តចំពោះស្តេចនោះ ដូចជាអ្នករាល់គ្នាបានប្រព្រឹត្តចំពោះស្តេចស៊ីហុន

ពាក្យថា «ស្តេច» ជាពាក្យប្រៀបធៀបសម្រាប់ «ប្រជារាស្ត្ររបស់ព្រះអង្គ» ។
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នានឹងបំផ្លាញស្តេចអុក និងប្រជារាស្ត្ររបស់ព្រះអង្គ
ដូចដែលអ្នកបានធ្វើចំពោះស្តេចស៊ីហុន»

Deuteronomy 3:3

ព្រមទាំងប្រជាជនទាំងអស់របស់ស្តេចក៏ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើងដែរ។

អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយព្រះអម្ចាស់បានដាក់ប្រជារាស្ត្រទាំងអស់របស់ស្តេចអុក
ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើង»

គ្មានសល់អ្នកណាម្នាក់ឡើយ។

នេះជាកម្លាំងដែលត្រូវបានប្រើដើម្បីបញ្ជាក់ថា
ជនជាតិអ៊ីស្រាអែលមិនបានទុកឱ្យនរណាម្នាក់រស់ឡើយ។ ការបកប្រែផ្សេងទៀត
«ប្រជាជនរបស់ស្តេចទាំងអស់ត្រូវបានស្លាប់»

គ្មានក្រុងណាមួយដែលរួចផុតពីការចាប់យករបស់យើងទេ

នេះជាការអវិជ្ជមានទ្វេដង ដែលបញ្ជាក់ថាពួកគេបានកាន់កាប់ទីក្រុងទាំង៦០។
ការបកប្រែផ្សេងទៀត «យើងបានយកទីក្រុងទាំងអស់»

ហុកសិបក្រុង

«ទីក្រុង៦០»

គ្រប់ទាំងតំបន់អើកុប

នេះជាឈ្មោះតំបន់មួយនៅក្នុងស្រុកបាសាន។

Deuteronomy 3:5

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។

ក្រុងទាំងអស់នោះ មានកំពែងការពារ

«ទីក្រុងទាំងអស់នេះត្រូវបានការពារដោយ»

ក្រៅពីនោះ

«បន្ថែមពីលើ» ឬ «មិនរាប់បញ្ចូល»

ព្រះបាទស៊ីហុន

នេះជាឈ្មោះរបស់ស្តេច។ សូមមើលការបកប្រែនៅក្នុង ១:៣។

ហែលបូន

នេះជាឈ្មោះទីក្រុងមួយ។ សូមមើលការបកប្រែនៅក្នុង ១:៣។

បានបំផ្លាញពួកគេទាំងស្រុង

«ការសម្លាប់មនុស្សទាំងអស់ ដែលរស់នៅក្នុងទីក្រុងទាំងអស់»

Deuteronomy 3:8

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

ពីស្តេចពីរអង្គ

generated on Wed Sep 10 16:16:32 2025

នៅទីនេះជាពាក្យប្រៀបធៀប «ពីស្តេច» មានន័យថា «ពីការគ្រប់គ្រង»។
ការបកប្រែផ្សេងទៀត «ពីការគ្រប់គ្រងរបស់ស្តេចទាំងពីរ» ឬ «ពីស្តេចទាំងពីរអង្គ»
អាម៉ូរី ... បាសាន ... អេទ្រី ... ស្តេចអុក
«ប្រជាជនអាម៉ូរី ... ដីស្រុកបាសាន ... ក្រុងអេទ្រី ... ស្តេចអុក» បកប្រែដូចនៅក្នុង ១:៣។
នៅខាងនាយទន្លេយ័រដាន់
សំដៅទៅលើទឹកដីដែលនៅទល់មុខទន្លេយ័រដាន់ នៅខាងកើតអ៊ីស្រាអែល។
នៅពេលលោកម៉ូសេនិយាយដូច្នេះ លោកម៉ូសេនៅខាងកើតទន្លេយ័រដាន់។
ការបកប្រែផ្សេងទៀត «ខាងកើតទន្លេយ័រដាន់» បកប្រែនៅក្នុង ១:១ ។
ស្ទឹងអើណូន
ចូរបកប្រែដូចនៅក្នុង ២:២៤ ។
ភ្នំហ៊ើរម៉ូន ... ភ្នំស៊ីរាន ... ភ្នំសេនារ
ទាំងនេះជាឈ្មោះភ្នំតែមួយ ដែលនៅខាងជើងព្រំប្រទល់បាសាន។
នៅតំបន់វាល
ជាដីរាបស្មើនៅចន្លោះទន្លេអើណូន និងភ្នំកាឡាដ។
សាល់កា
នេះជាឈ្មោះទីក្រុងមួយនៅជិតអេទ្រី។
Deuteronomy 3:11
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ជនជាតិរេមផែមដែលនៅសល់ ... តាមហត្ថរបស់មនុស្ស។
នេះជាព័ត៌មានសង្ខេបអំពីស្តេច ។
ជនជាតិរេមផែម
ចូរបកប្រែដូចនៅក្នុង ២:១០ ។
មើល៍!
«ចូរយកចិត្តទុកដាក់លើរឿងសំខាន់ ដែលយើងនឹងប្រាប់អ្នករាល់គ្នា»។
តើគ្រែនោះមិននៅក្រុងរ៉ាបាត ... ទេឬ?
អ្នកនិពន្ធប្រើសំណួរមួយ ដើម្បីរម្លឹកប្រជាជនអ៊ីស្រាអែលថា
ពួកគេអាចទៅក្រុងរ៉ាបាត ហើយដឹងថាស្តេចអុកពិតជាធំប៉ុនណា។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ អាចមានន័យថា ១) វាស្ថិតនៅក្រុងរ៉ាបាត ... រស់នៅទេឬ?»។ ឬ ២) ស្ថិតនៅក្រុងរ៉ាបាត ... រស់នៅទេឬ?»។
ហត្ថ
មួយហត្ថស្មើ ៤៦ សង់ទីម៉ែត្រ។ :
តាមហត្ថរបស់មនុស្ស។
«ទៅតាមហត្ថ មនុស្សភាគច្រើនប្រើ»
Deuteronomy 3:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
អារ៉ូអ៊ើរ
បកប្រែដូចនៅក្នុង ២:៣៦។
ស្ទឹងអើណូន
បកប្រែដូចនៅក្នុង ២:២៤ ។
តំបន់ទាំងអស់អើកុប
បកប្រែដូចនៅក្នុង ៣:៣។
គេក៏ហៅតំបន់នេះថា ទឹកដីរេផែមដែរ។
អ្នកនិពន្ធចាប់ផ្តើមបង្ហាញព័ត៌មានសង្ខេបអំពីទឹកដី
ដែលប្រជាជនអ៊ីស្រាអែលកាន់កាប់។ បើភាសារបស់អ្នកមានរបៀបបង្ហាញថា
អ្វីដែលនៅពីក្រោយគឺជាព័ត៌មានសង្ខេបអ្នកគួរតែប្រើវានៅទីនេះ។
រេផែម
បកប្រែដូចនៅក្នុង ២:១០។
Deuteronomy 3:14
ព័ត៌មានទូទៅ៖
នេះបន្តព័ត៌មានសង្ខេបអំពីទឹកដី ដែលប្រជាជនអ៊ីស្រាអែលកាន់កាប់។ (សូមមើល ៣:១២)
អំបូរយ៉ាអ៊ារ
នេះជាឈ្មោះមនុស្សប្រុស។
ជនជាតិកេស៊ូរី និងជនជាតិម៉ាកាធី។
ទាំងនេះជាក្រុមមនុស្ស សដែលរស់នៅខាងលិចបាសាន។
លោកហាវ៉ុត យ៉ាអ៊ារ
អ្នកបកប្រែអាចធ្វើកំណត់សម្គាល់ដែលថា «លោកហាវ៉ុត យ៉ាអ៊ារ» មានន័យថា «ភូមិជំរំរបស់លោកយ៉ាអ៊ារ» ឬ« អាណាចក្រយ៉ាអ៊ារ» ។
Deuteronomy 3:15
ព័ត៌មានទូទៅ៖
ម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ខ្ញុំបានប្រគល់
នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកម៉ូសេ។
អំបូរម៉ាគារ
អំបូរម៉ាគារជាកូនរបស់ម៉ាណាសេ។
គាត់បានស្លាប់មុនពេលលោកម៉ូសេប្រគល់ទឹកដីនេះ។
ឈ្មោះនេះជាឈ្មោះហៅក្រៅសម្រាប់កូនចៅរបស់មនុស្ស។ ការបកប្រែផ្សេងទៀត «ដល់កូនចៅអំបូរម៉ាគារ»។
ស្ទឹងអើណូន
នេះជាឈ្មោះជ្រលងភ្នំអាណូន។ ជាព្រំដែនរវាងម៉ូអាប់និងជនជាតិអាម៉ូរី។
សូមមើលការបកប្រែនៅក្នុង ២:២៤ ។
ស្ទឹងយ៉ាបុក
នេះជាឈ្មោះទន្លេដែលបានជាប់ព្រំដែនរវាងដីរបស់ស៊ីហុន
និងទឹកដីរបស់ជនជាតិអាំម៉ូន។ សូមមើលការបកប្រែនៅក្នុង ២:៣៦។
Deuteronomy 3:17
ព័ត៌មានទូទៅ៖
ម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ហើយព្រំប្រទល់មួយទៀតក៏ជាវាលទំនាប
«ព្រំប្រទល់ខាងលិចនៃទឹកដីរូបេន និងកុលសម្ព័ន្ធកាដ»
គេនេសារ៉ែត
«សមុទ្រគេនេសារ៉ែត»។ នេះជាកន្លែងតែមួយដែលជា« សមុទ្រកាលីឡេ» ឬ« បឹងគេនេសារ៉ែត»។
ភ្នំពីសកា
នេះជាឈ្មោះភ្នំមួយនៅភាគខាងជើងនៃជួរភ្នំអាបារីម។
Deuteronomy 3:18
ព័ត៌មានទូទៅ៖
ម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ខ្ញុំបានបង្គាប់អ្នករាល់គ្នា
លោកម៉ូសេរម្លឹកកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ
និងកុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាលថា
ពួកគេត្រូវជួយជនជាតិអ៊ីស្រាអែលឯទៀតៗដណ្តើមទឹកដី
ដែលព្រះជាម្ចាស់បានសន្យាជាមួយពួកគេ។
ដោយមានអាវុធជាប់ខ្លួន នៅពីមុខ
«នឹងយកអាវុធរបស់អ្នកព្រមទាំងនាំមុខឆ្លងទន្លេយ័រដាន់»
បងប្អូនរបស់អ្នករាល់គ្នា ជាប្រជាជនអ៊ីស្រាអែល។
«បងប្អូនអ៊ីស្រាអែលរបស់អ្នករាល់គ្នា»
Deuteronomy 3:19
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់កុលសម្ព័ន្ធរូបេន
និងកាដនិងកុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាល។
ព្រះអម្ចាស់ប្រទានឲ្យបងប្អូនរបស់អ្នករាល់គ្នាទាំងអស់សម្រាក
អ្នកនិពន្ធនិយាយដូចជាសមត្ថភាពក្នុងការសម្រាក
ជាវត្ថុដែលអាចត្រូវបានផ្តល់ជាអំណោយ។ ពាក្យថា
ឈប់សម្រាកក៏ជាពាក្យប្រៀបធៀបមួយសម្រាប់ជីវិតប្រកបដោយសន្តិភាព
ដែលក្នុងនោះគ្មានសង្គ្រាមទេ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់អនុញ្ញាតឱ្យបងប្អូនរបស់អ្នកសម្រាក» ឬ
«ព្រះអម្ចាស់អនុញ្ញាតឱ្យបងប្អូនរបស់អ្នកឈប់ធ្វើសង្គ្រាម
ហើយរស់នៅដោយសន្តិភាព»
នៅត្រើយខាងនាយទន្លេយ័រដាន់
នេះសំដៅទៅលើទឹកដី ដែលឆ្លងកាត់ទន្លេយ័រដាន់នៅខាងកើតអ៊ីស្រាអែល។
នៅពេលលោកម៉ូសេនិយាយដូច្នេះ លោកម៉ូសេនៅខាងកើតទន្លេយ័រដាន់។
ការបកប្រែផ្សេងទៀត «ខាងកើតទន្លេយ័រដាន់» ។ បកប្រាដូចនៅក្នុង ១:១។
អ្នករាល់គ្នានឹងត្រឡប់ទៅ
លោកម៉ូសេបញ្ជាក់ថា កុលសម្ព័ន្ធដទៃទៀតត្រូវតែកាន់កាប់ទឹកដីរបស់ខ្លួន

generated on Wed Sep 10 16:16:32 2025

មុនពេលព្រះអម្ចាស់អនុញ្ញាតឱ្យកុលសម្ព័ន្ធទាំងបីនេះកាន់កាប់ទឹកដីរបស់ខ្លួន។
មានតែពេលនោះទេ ដែលអ្នកត្រូវត្រឡប់មកវិញ។
Deuteronomy 3:21
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
ភ្នែករបស់អ្នកបានឃើញ
នៅទីនេះ «ភ្នែក» សំដៅទៅលើលោកយ៉ូស្វេ។ ការបកប្រែផ្សេងទៀត
«អ្នកបានឃើញហើយ»
Deuteronomy 3:23
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
ខ្ញុំបានអង្វរក
នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកម៉ូសេ។
មានន័យថាគាត់បានទូលសួរព្រះជាម្ចាស់ដោយស្មោះអស់ពីចិត្ត។
របៀបបង្ហាញអារម្មណ៍។
បង្ហាញឲ្យអ្នកបម្រើរបស់ព្រះអង្គ
នៅទីនេះ «អ្នកបម្រើរបស់ព្រះអង្គ»
ជារបៀបគួររសមក្នុងការនិយាយទៅកាន់មនុស្សណាម្នាក់ ដែលមានអំណាចខ្ពស់។
ការបកប្រែផ្សេងទៀត «ដើម្បីបង្ហាញថាខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ»
ឫទ្ធិបារមីរបស់ព្រះហស្តព្រះអង្គ
នៅទីនេះ ពាក្យប្រៀបធៀប «ព្រះហស្ត» មានន័យថាការគ្រប់គ្រងឬអំណាច។
ការបកប្រែផ្សេងទៀត «អំណាចរបស់ព្រះអង្គ»
ដ្បិត តើមានព្រះឯណានៅស្ថានសួគ៌ ...បាន?
លោកម៉ូសេប្រើសំណួរមួយដើម្បីបញ្ជាក់ថា មានតែព្រះអម្ចាស់ប៉ុណ្ណោះ
ដែលមានអំណាចធ្វើកិច្ចការដែលគាត់បានធ្វើ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ដ្បិតគ្មានព្រះទេ ... បាន»។
នៅស្ថានសួគ៌ ឬនៅលើផែនដី
ទាំងពីររួមគ្នាមានន័យថា «គ្រប់ទីកន្លែង»។
នៅត្រើយខាងទន្លេយ័រដាន់
«ភាគខាងលិចទន្លេយ័រដាន់»។
ពេលលោកម៉ូសេនិយាយពាក្យទាំងនេះទៅកាន់ព្រះអម្ចាស់
គាត់នៅខាងកើតទន្លេយ័រដាន់នៅម៉ូអាប់។
Deuteronomy 3:26
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលបានកើតឡើងកាលពីអតីតកាល។
ព្រះអម្ចាស់បានព្រះពិរោធនឹងខ្ញុំ ពីព្រោះតែអ្នក
សំដៅទៅលើពេលដែលលោកម៉ូសេមិនគោរពតាមអ្វី
ដែលព្រះអម្ចាស់បានប្រាប់គាត់ឲ្យធ្វើ ព្រោះលោកម៉ូសេខឹងនឹងជនជាតិអ៊ីស្រាអែល។
បកប្រែដូចនៅក្នុង ១:៣៧ ។
ភ្នំពីសកា
បកប្រែដូចនៅក្នុង ៣:១៧។
ហើយក្រឡេកភ្នែករបស់អ្នក
ពាក្យថា« ក្រឡេកភ្នែករបស់អ្នក» ជាឃ្លាមួយ ដែលមានន័យថាសូមមើល។
ការបកប្រែផ្សេងទៀត «សូមមើល
Deuteronomy 3:28
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
បេតពេអរ
ជាឈ្មោះក្រុងមួយ នៅស្រុកម៉ូអាប់ក្បែរភ្នំពីសកា។

---

4 [1]ឥឡូវនេះ អ៊ីស្រាអែលអើយ ចូរស្តាប់តាមក្រឹត្យវិន័យ និងច្បាប់ដែលខ្ញុំបានបង្រៀនដល់អ្នករាល់គ្នា ចូរប្រតិបត្តិតាម ដូច្នេះហើយ អ្នករាល់គ្នាអាចនឹងរស់
ហើយចូលទៅកាន់កាប់ទឹកដីដែលព្រះអម្ចាស់ ជាព្រះដូនតារបស់អ្នករាល់គ្នា បានប្រទានឲ្យអ្នករាល់គ្នា។[2]អ្នករាល់គ្នានឹងមិនត្រូវបន្ថែម
ទៅលើពាក្យដែលខ្ញុំបានបង្គាប់អ្នក ឬបន្ថយពាក្យទាំងនោះឡើយ ដូច្នេះហើយ អ្នករាល់គ្នាអាចនឹងកាន់តាមសេចក្តីបង្គាប់ នៃព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា។
[3]ភ្នែករបស់អ្នករាល់គ្នាបានឃើញនូវអ្វីដែលព្រះអម្ចាស់បានធ្វើ ដោយព្រោះព្រះបាល ពេអរ សម្រាប់អស់អ្នកណាដែលដើរតាមព្រះបាល ពេអរនោះ
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបំផ្លាញពួកគេចេញពីក្នុងចំណោមអ្នករាល់គ្នា។[4]ប៉ុន្តែ
អ្នករាល់គ្នាដែលកាន់តាមព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាគឺមានជីវិតរស់នៅសព្វថ្ងៃនេះ។
[5]មើល៍ ខ្ញុំបានបង្រៀនអ្នករាល់គ្នាអំពីក្រឹត្យវិន័យ និងច្បាប់ ដូចជាព្រះអម្ចាស់ជារបស់ខ្ញុំបានបង្គាប់មកខ្ញុំ ដែលអ្នករាល់គ្នាគួរតែប្រតិបត្តិតាមដូចគ្នា
នៅក្នុងទឹកដីដែលអ្នករាល់គ្នាត្រូវទៅក្នុងគោលបំណងដើម្បីកាន់កាប់។[6]ហេតុនេះ ចូររក្សា ហើយប្រតិបត្តិតាមក្រឹត្យវិន័យ និងច្បាប់នោះចុះ ដ្បិត
នេះគឺជាប្រាជ្ញាដល់អ្នករាល់គ្នា ហើយជាការយល់ដឹងដល់អ្នករាល់គ្នា នៅចំពោះមុខមនុស្ស ដែលនឹងឮអំពីក្រឹត្យក្រមទាំង ឡាយនេះ គេនឹងនិយាយថា
ប្រជាជាតិដែលអស្ចារ្យ ពិតជាមនុស្សដែលមានប្រាជ្ញា និងមានការចេះដឹងមែន។
[7]ដ្បិត តើមានប្រជាជាតិធំណាមួយ ដែលមានព្រះគង់នៅជិត ដូចជាព្រះអម្ចាស់ជាព្រះនៃយើងគង់នៅជិត គ្រប់ពេលដែលយើងអំពាវនាវរកព្រះអង្គ?
[8]តើមានប្រជាជាតិធំណាមួយ ដែលមានក្រឹត្យវិន័យ និងច្បាប់សុចរិត ដូចជាក្រឹត្យវិន័យ និងច្បាប់ដែលខ្ញុំបានដាក់នៅចំពោះមុខអ្នករាល់គ្នានៅថ្ងៃនេះទេ?
[9]ត្រូវប្រុងស្មារតី និងប្រយ័ត្នខ្លួនរបស់អ្នករាល់គ្នា ដូច្នេះ អ្នករាល់គ្នានឹងមិនភ្លេចកិច្ចការដែលភ្នែករបស់អ្នករាល់គ្នាបានឃើញនោះទេ ដូច្នេះហើយ
ការនោះនឹងមិនឃ្លាតឆ្ងាយពីចិត្តរបស់អ្នករាល់គ្នាបានឡើយ រហូតពេញមួយជីវិតរបស់អ្នករាល់គ្នា។ ផ្ទុយទៅវិញ ចូរប្រាប់ដល់កូន និងចៅរបស់អ្នករាល់គ្នា។
[10]នៅថ្ងៃនោះអ្នករាល់គ្នាឈរនៅមុខព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា នៅភ្នំហោរែប នៅពេលដែលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា៖
«ចូរប្រមូលប្រជាជនមកឯយើង ហើយយើងនឹងធ្វើឲ្យពួកគេឮពាក្យរបស់យើង ហើយពួកគេអាចនឹងរៀនកោតខ្លាចយើង ក្នុងជីវិតរស់នៅរបស់ពួកគេលើផែនដី
ហើយពួកគេអាចបង្រៀនដល់កូនចៅរបស់ពួកគេផងដែរ។
[11]អ្នករាល់គ្នាបានចូលមកជិត ហើយឈរនៅក្បែរជើងភ្នំ។ ភ្នំមានភ្លើងឆេះឡើងដល់ផ្ទៃមេឃ មានភាពខ្មៅងងឹត ហើយពពក និងអ័ព្ទងងឹតសូន្យសុង។
[12]ព្រះអម្ចាស់មានព្រះបន្ទូលមកអ្នករាល់គ្នាចេញពីក្នុងភ្លើង អ្នករាល់គ្នាបានឮព្រះបន្ទូលរបស់ព្រះអង្គ ប៉ុន្តែ អ្នករាល់គ្នាមិនបានឃើញព្រះអង្គឡើយ
អ្នករាល់គ្នាឮតែសម្លេងប៉ុណ្ណោះ។
[13]ព្រះអង្គបានបង្ហាញអ្នករាល់គ្នាពីសម្ពន្ធមេត្រីរបស់ព្រះអង្គ ដែលព្រះអង្គបានបង្គាប់អ្នករាល់គ្នា ដើម្បីប្រតិបត្តិតាមក្រឹត្យវិន័យទាំងដប់ប្រការនោះ។
ព្រះអង្គបានសរសេរច្បាប់ និងវិន័យនេះឡើង នៅលើបន្ទះថ្មពីរដុំ។[14]ព្រះអម្ចាស់បានបង្គាប់ខ្ញុំនៅពេលនោះ ឲ្យបង្រៀនដល់អ្នករាល់គ្នាអំពីច្បាប់ និងបញ្ញាតិ
ដើម្បីឲ្យអ្នករាល់គ្នានឹងអាចប្រតិបត្តិច្បាប់ និងបញ្ញាតិនោះនៅក្នុងទឹកដីដែលអ្នករាល់គ្នាបានដើរឆ្លង ដើម្បីកាន់កាប់។
[15]ដូច្នេះ ចូរយកចិត្តទុកដាក់ឲ្យខ្លាំងចំពោះខ្លួនឯង ដ្បិត អ្នករាល់គ្នាមិនបានឃើញព្រះអង្គមានរូបរាងបែបណាឡើយ
ពេលដែលព្រះអម្ចាស់បានមានព្រះបន្ទូលចេញពីក្នុងភ្លើងមកកាន់អ្នករាល់គ្នា ពេលនៅភ្នំហោរែប[16]ហើយអ្នករាល់គ្នាមិនត្រូវបង្ខូចខ្លួន
និងធ្វើរូបចម្លាក់តំណាងឲ្យដូចបុគ្គលណាម្នាក់ ដូចជាមនុស្សស្រី ឬមនុស្សប្រុសឡើយ[17]ឬដូចសត្វដែលនៅលើផែនដី
ឬដូចជាសត្វស្លាបដែលហើរលើអាកាស[18]ឬដូចជាអ្វីៗដែលលូនវារនៅក្នុងដី ឬដូចជាត្រីផ្សេងៗដែលនៅក្នុងទឹកក្រោមផែនដីឡើយ។
[19]អ្នករាល់គ្នាមិនត្រូវក្រឡេកភ្នែករបស់អ្នកមើលទៅលើមេឃ ហើយមើលទៅព្រះអាទិត្យ និងព្រះច័ន្ទ ឬផ្កាយ ព្រមទាំងផ្ទៃមេឃទាំងមូល នឹងត្រូវបណ្តាយខ្លួនទៅថ្វាយបង្គំ
និងគោរពរបស់ទាំងនោះឡើយ វាជារបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គបានប្រទានដល់មនុស្សគ្រប់គ្នាដែលក្រោមមេឃទាំងមូល។[20]ប៉ុន្តែ ព្រះអម្ចាស់បានដក
និងបាននាំអ្នករាល់គ្នាចេញពីឡដែករបស់អេស៊ីប ដើម្បីក្លាយជាប្រជារាស្ត្រដ៏ជាកេរអារករបស់ព្រះអង្គផ្ទាល់ ដូចជាអ្នករាល់គ្នាសព្វថ្ងៃនេះ។

generated on Wed Sep 10 16:16:32 2025

[21]ព្រះអម្ចាស់បានព្រះពិរោធនឹងខ្ញុំ ដោយសារតែអ្នករាល់គ្នា ព្រះអង្គបានស្បថថា ខ្ញុំមិនបានទៅដល់ទន្លេយ័រដាន់ទេ ហើយខ្ញុំមិនគួរបានចូលទៅក្នុងទឹកដីល្អ
ជាទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានដល់អ្នករាល់គ្នាទុកជាមរតកឡើយ។[22]ផ្ទុយទៅវិញ ខ្ញុំនឹងត្រូវតែស្លាប់នៅក្នុងទឹកដីនេះ
ខ្ញុំមិនអាចទៅដល់ទន្លេយ័រដាន់ទេ ប៉ុន្តែ អ្នករាល់គ្នាអាចនឹងទៅដល់ ហើយកាន់កាប់ទឹកដីដែលល្អនោះវិញ។
[23]ចូរប្រុងស្មារតីរបស់អ្នករាល់គ្នា ដូច្នេះហើយ អ្នករាល់គ្នាកុំភ្លេចនូវសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដែលព្រះអង្គបានធ្វើជាមួយអ្នករាល់គ្នា
ហើយកុំឆ្លាក់រូបអ្វីសម្រាប់អ្នករាល់គ្នា ចេញពីអ្វីៗផ្សេង ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានហាមឃាត់ឡើយ។[24]ដ្បិត
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាជាភ្លើងដែលឆេះសន្ធោសន្ធៅ ព្រះអង្គជាព្រះជាម្ចាស់ដែលប្រច័ណ្ឌ។
[25]នៅពេលអ្នករាល់គ្នាបង្កើតកូន និងចៅ ហើយនៅពេលអ្នករាល់គ្នានឹងបានទៅក្នុងទឹកដីនោះជាយូរអង្វែង ហើយប្រសិនបើ អ្នករាល់គ្នាបង្ខូចខ្លួនរបស់អ្នករាល់គ្នា
ព្រមទាំងឆ្លាក់រូបតំណាងចេញពីអ្វីៗផ្សេង ហើយធ្វើអ្វីដែលអាក្រក់នៅចំពោះព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា
ដើម្បីធ្វើឲ្យព្រះអង្គមានសេចក្តីក្រោធឡើ[illegible]យ[26]នោះខ្ញុំហៅមេឃ និងផែនដីមកធ្វើជាសាក្សីទាស់ប្រឆាំងនឹងអ្នករាល់អ្នកនៅថ្ងៃនេះ ហើយអ្នករាល់គ្នានឹងត្រូវវិនាសអស់ពី
ស្រុកដែលអ្នករាល់គ្នាឆ្លងទន្លេយ័រដាន់ទៅកាន់កាប់នោះ អ្នករាល់គ្នាមិនអាចរស់នៅក្នុងស្រុកនោះយូរអង្វែងឡើយ ប៉ុន្តែ អ្នករាល់គ្នានឹងត្រូវបំផ្លាញចោលទាំងស្រុង។
[27]ព្រះអម្ចាស់នឹងកម្ចាត់កម្ចាយអ្នករាល់គ្នាក្នុងចំណោមមនុស្សនានា ហើយអ្នករាល់គ្នានឹងត្រូវនៅចំនួនតិចតួចក្នុងចំណោមប្រជាជាតិទាំងឡាយ
ជាកន្លែងដែលព្រះអម្ចាស់នឹងដឹកនាំអ្នករាល់គ្នាទៅរស់នៅ។[28]នៅទីនោះ អ្នករាល់គ្នានឹងបម្រើព្រះផ្សេងៗ ជាព្រះដែលធ្វើឡើងដោយដៃរបស់មនុស្សពីឈើ និងថ្ម
ជារូបដែលមិនចេះមើល មិនចេះស្តាប់ មិនចេះបរិភោគ ឬមិនចេះហិតក្លិនដែរ។
[29]ប៉ុន្តែ នៅទីនោះអ្នករាល់គ្នានឹងស្វែងរកព្រះរបស់អ្នករាល់គ្នា ហើយអ្នករាល់គ្នានឹងរកឃើញព្រះអង្គ នៅពេលដែលអ្នករាល់គ្នាស្វែងរកព្រះអង្គដោយអស់អំពីចិត្ត
និងអស់អំពីប្រលឹងរបស់អ្នករាល់គ្នា។
[30]នៅពេលអ្នករាល់គ្នានៅក្នុងសេចក្តីទុក្ខព្រួយ ហើយនៅពេលគ្រប់កិច្ចការទាំងអស់នេះនឹងកើតលើអ្នករាល់គ្នា
នៅគ្រាចុងក្រោយអ្នករាល់គ្នានឹងវិលត្រលប់ទៅរកព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា ហើយស្តាប់តាមព្រះបន្ទូលរបស់ព្រះអង្គ។[31]ដ្បិត ព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា
ជាព្រះដែលប្រកបដោយព្រះហឫទ័យមេត្តាករុណា ព្រះអង្គនឹងមិនបោះបង់ ឬបំផ្លាញ ឬបំភ្លេចសម្ពន្ធមេត្រីនៃដូនតារបស់អ្នករាល់គ្នា
ដែលព្រះអង្គបានស្បថជាមួយពួកគេឡើយ។
[32]ដ្បិត ចូរសួរឥឡូវនេះ អំពីថ្ងៃដែលមានកន្លងមក ជាថ្ងៃដែលកើតមុនអ្នករាល់គ្នា តាំងពីថ្ងៃដែលព្រះបានបង្កើតមនុស្សនៅលើផែនដី ហើយចេញពីជើងម្ខាងទៅជើងម្ខាង
សួរថាតើមានអ្វីអស្ចារ្យបែបនេះកើតឡើង ឬដូចអ្វីដែលធ្លាប់បានឮបែបនេះដែរឬទេ?[33]តើមាននរណាដែលធ្លាប់បានឮព្រះសូរសៀងរបស់ព្រះ
ដែលមានបន្ទូលចេញពីកណ្តាលភ្លើង ដូចជាអ្នករាល់គ្នាបានឮ ហើយរស់បានដែរឬទេ?
[34]ឬ តើមានព្រះឯណាធ្លាប់ព្យាយាមដើម្បីចេញទៅរំដោះប្រជាជាតិរបស់ព្រះអង្គ ចេញពីកណ្តាលចំណោមប្រជាជាតិផ្សេងៗ ដោយការសាកល្បង ដោយទីសម្គាល់
និងដោយការអស្ចារ្យ ហើយដោយការធ្វើសង្គ្រាម ដោយព្រះហស្តខ្លាំងពូកែ និងដោយពាហុលើកសម្រេច ហើយដោយការគួរស្ញែងខ្លាចយ៉ាងខ្លាំង
ដូចជាអ្វីៗដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានធ្វើសម្រាប់អ្នករាល់គ្នានៅអេស៊ីប ចំពោះមុខអ្នករាល់គ្នាដែរឬទេ?
[35]ការទាំងនេះបានបើកសម្តែងមកឲ្យអ្នករាល់គ្នាបានឃើញ ដូច្នេះហើយ អ្នករាល់គ្នាអាចនឹងដឹងថាព្រះអម្ចាស់គឺជាព្រះ ហើយគ្មាននរណាម្នាក់ក្រៅពីព្រះអង្គឡើយ។
[36]ព្រះអង្គធ្វើឲ្យអ្នករាល់គ្នាឮព្រះសូរសៀងរបស់ព្រះអង្គចេញពីលើមេឃមក ដើម្បីឲ្យព្រះអង្គអាចណែនាំអ្នករាល់គ្នា
ហើយព្រះជាម្ចាស់បានធ្វើឲ្យអ្នករាល់គ្នាឃើញភ្លើងដ៏អស្ចារ្យរបស់ព្រះអង្គ នៅលើផែនដី ហើយអ្នករាល់គ្នាបានឮព្រះបន្ទូលរបស់ព្រះអង្គចេញពីកណ្តាលភ្លើងនោះមក។
[37]ពីព្រោះព្រះអង្គបានស្រឡាញ់ដូនតារបស់អ្នករាល់គ្នា ព្រះអង្គបានជ្រើសរើសកូនចៅរបស់ពួកគេនៅជំនាន់ក្រោយ ហើយបាននាំអ្នករាល់គ្នាចេញទឹកដីអេស៊ីប
ដោយព្រះវត្តមានរបស់ព្រះអង្គ ជាមួយនឹងព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះអង្គ[38]ក្នុងគោលបំណង ដើម្បីបណ្តេញប្រជាជាតិនានា ដែលមានគ្នាច្រើន
និងមានកម្លាំងខ្លាំងជាងអ្នករាល់គ្នា ដើម្បីនាំអ្នករាល់គ្នាចូលទៅ និងប្រទានទឹកដីរបស់ពួកគេឲ្យអ្នករាល់គ្នាទុកដូចមរតក ដូចនៅថ្ងៃនេះ។
[39]ដូច្នេះ ចូរដឹងនៅថ្ងៃ ហើយដាក់ការនេះក្នុងចិត្តរបស់អ្នករាល់គ្នាថា ព្រះអម្ចាស់ពិតជាព្រះដែលគង់នៅស្ថានសួគ៌ និងនៅលើផែនដី
ហើយគ្មានអង្គណាក្រៅពីព្រះអង្គឡើយ។[40]អ្នករាល់គ្នានឹងកាន់តាមច្បាប់ និងសេចក្តីបង្គាប់របស់ព្រះអង្គ ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ
ដែលការនេះនឹងល្អប្រសើរសម្រាប់អ្នក និងកូនចៅរបស់អ្នករាល់គ្នាដែលនៅជំនាន់ក្រោយ
ហើយឲ្យអ្នករាល់អាចនឹងមានអាយុវែងនៅលើទឹកដីដែលព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នានឹងប្រទានឲ្យអ្នករាល់គ្នាជារៀងរហូត»។
[41]បន្ទាប់មក លោកម៉ូសេបានជ្រើសរើសយកក្រុងចំនួនបីនៅខាងកើតនៃត្រើយទន្លេ[42]ដើម្បីឲ្យអ្នកម្នាក់ដែលរត់គេចខ្លួន ប្រសិនបើអ្នកនោះបានសម្លាប់នរណាម្នាក់
ដោយអចេតនា ដែលមិនជាសត្រូវនឹងគ្នាមុននោះទេ។ ដោយរត់គេចខ្លួនចូរទៅក្នុងក្រុងណាមួយនៃក្រុងទាំងបីនេះ ដើម្បីឲ្យអ្នកនោះបានរួចជីវិត។[43]ក្រុងទាំងបីនោះ
នៅទីរហោស្ថាននៃតំបន់ខ្ពង់រាបក្នុងទឹកដីរូបេន ក្រុងរ៉ាម៉ូត នៅទឹកដីកាឡាដ ក្នុងទឹកដីកាដ និងក្រុងកូឡាន នៅទឹកដីបាសាន ក្នុងទឹកដីម៉ាណាសេ។
[44]នេះគឺជាក្រឹត្យវិន័យដែលលោកម៉ូសេបានប្រគល់ឲ្យជនជាតិអ៊ីស្រាអែល[45]ទាំងនេះគឺជាដំបូន្មាន ច្បាប់ និងវិន័យ ដែលលោកម៉ូសេបាននិយាយប្រាប់ ប្រជាជនអ៊ីស្រាអែល
នៅពេលពួកគេចាកចេញពីទឹកដីអេស៊ីប[46]នៅពេលដែលពួកគេនៅត្រើយខាងកើតនៃទន្លេយ័រដាន់ ក្នុងជ្រលងភ្នំទល់មុខនឹងបេតពេអរ ក្នុងទឹកដីរបស់ព្រះបាទស៊ីហុន
ជាស្តេចនៃជនជាតិអាម៉ូរី នៅទឹកដីដែលបូន លោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល បានយកឈ្នះនៅពេលដែលពួកគេបានចាក់ចេញពីទឹកដីអេស៊ីប។
[47]ពួកគេបានដកយកទឹកដីរបស់ស្តេចនោះ ធ្វើជាកម្មសិទ្ធិ និងទឹកដីរបស់ព្រះបាទអុក ជាស្តេចទឹកដីបាសាន ទាំងពីរជាស្តេចនៃជនជាតិអាម៉ូរី
ជាម្ចាស់ដែលកាន់កាប់ត្រើយទន្លេយ័រដាន់តាមទិសខាងកើតពីមុន។[48]គឺចាប់តាំងពីក្រុងអារ៉ូអ៊ើរ ដែលនៅតាមមាត់ស្ទឹងអើណូន រហូតដល់ភ្នំស៊ីអូន
(ឬភ្នំហ៊ើរម៉ូន)[49]និងរួមទាំងវាលទំនាបនៅត្រើយខាងកើតទន្លេយ័រដាន់ រហូតដល់សមុទ្រអារ៉ាបា ដែលនៅជើងភ្នំពិសកា។

Deuteronomy 4:1
ខ្ញុំបានបង្រៀនដល់អ្នករាល់គ្នា
លោកម៉ូសេកំពុងប្រាប់ប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលព្រះជាម្ចាស់ចង់ឱ្យពួកគេធ្វើ។
ចូរប្រតិបត្តិតាម
«ព្រមទាំងគោរពពួកគេ»
អ្នករាល់គ្នានឹងមិនត្រូវបន្ថែម ទៅលើពាក្យ ... ឬបន្ថយពាក្យទាំងនោះឡើយ
ព្រះអម្ចាស់មិនចង់ឱ្យប្រជារាស្ត្ររបស់ព្រះអង្គ បង្កើតក្រឹត្យវិន័យថ្មី
ឬក៏មិនអើពើនឹងក្រឹត្យវិន័យដែលព្រះអង្គប្រទានឱ្យគេ។
Deuteronomy 4:3
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ភ្នែករបស់អ្នករាល់គ្នាបានឃើញ
នៅទីនេះ «ភ្នែក» សំដៅលើប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«អ្នកបានឃើញ»
ដោយព្រោះព្រះបាល ពេអរ
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ដោយសារតែបាបដែលអ្នកបានប្រព្រឹត្តចំពោះព្រះបាល
ពេអរ »
ពេអរ
បកប្រែដូចនៅក្នុង ៣:២៨។
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបំផ្លាញពួកគេចេញពីក្នុងចំណោមអ្នករាល់គ្នា។
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សតែម្នាក់
ដូច្នេះ «របស់អ្នក» និង «អ្នក» មានលក្ខណៈឯកវចនៈ។
អ្នករាល់គ្នាដែលកាន់តាមព្រះអម្ចាស់
អ្នកនិពន្ធនិយាយដូចជាការទុកចិត្តលើព្រះអម្ចាស់

generated on Wed Sep 10 16:16:32 2025

និងស្តាប់បង្គាប់ព្រះអង្គដូចជាកាន់ជាប់នឹងរាងកាយមនុស្សម្នាក់។
ការបកប្រែផ្សេងទៀត «អ្នកដែលយកចិត្តទុកដាក់ស្តាប់បង្គាប់ព្រះអម្ចាស់»
Deuteronomy 4:5
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
មើល៍
«ចូរយកចិត្តទុកដាក់»
ដែលអ្នករាល់គ្នាគួរតែប្រតិបត្តិតាមដូចគ្នា នៅក្នុងទឹកដី
«ដែលអ្នកគួរតែគោរពពួកគេ នៅពេលអ្នករស់នៅលើទឹកដី»
នេះគឺជាប្រាជ្ញាដល់អ្នករាល់គ្នា ហើយជាការយល់ដឹងដល់អ្នករាល់គ្នា នៅចំពោះមុខមនុស្ស
នាមអរូបី «ប្រាជ្ញា» និង «ការយល់ដឹង» អាចបកប្រែជាឃ្លាគុណនាម ហើយនាម
«អរូបី» ដែលមើលឃើញអរូបីសំដៅទៅលើរបៀប ដែលប្រជាជនវិនិច្ឆ័យ
ឬសម្រេចចិត្តលើតម្លៃអ្វីមួយ។ ការបកប្រែផ្សេងទៀត
«នេះគឺជាអ្វីដែលនឹងបង្ហាញដល់ប្រជាជនថា
អ្នកមានប្រាជ្ញាហើយអ្នកយល់ពីអ្វីដែលសំខាន់»
ប្រជាជាតិដែលអស្ចារ្យ ពិតជាមនុស្សដែលមានប្រាជ្ញា និងមានការចេះដឹងមែន។
ពាក្យថា «ប្រជាជាតិ» ជាពាក្យប្រៀបធៀបសម្រាប់ប្រជាជននៃប្រជាជាតិនោះ។
ការបកប្រែផ្សេងទៀត « ប្រជាជននៃប្រជាជាតិដ៏អស្ចារ្យនេះ
មានប្រាជ្ញានិងការចេះដឹង»
Deuteronomy 4:7
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដ្បិត តើមានប្រជាជាតិធំណាមួយ ដែលមាន ... ព្រះអង្គ? តើមានប្រជាជាតិធំណាមួយ ដែលមាន ...
នៅថ្ងៃនេះទេ?
សំណួរដ៏ប៉ិនប្រសព្វទាំងនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ដ្បិត មិនមានប្រជាជាតិដ៏អស្ចារ្យផ្សេងទៀតទេ ... ព្រះអង្គ។
មិនមានប្រជាជាតិដ៏អស្ចារ្យផ្សេងទៀតទេ ... នៅថ្ងៃនេះ»។
Deuteronomy 4:9
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវប្រុងស្មារតី ... ប្រយ័ត្នខ្លួនរបស់អ្នករាល់គ្នា ... អ្នករាល់គ្នានឹងមិនភ្លេច ...ភ្នែករបស់អ្នករាល់គ្នា ...
ចិត្តរបស់អ្នករាល់គ្នា ...ពេញមួយជីវិតរបស់អ្នករាល់គ្នា ... ចូរប្រាប់ដល់កូន
និងចៅរបស់អ្នករាល់គ្នា។ ... អ្នករាល់គ្នាឈរនៅមុខព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់ ដូច្នេះ
រាល់ការកើតឡើងនៃពាក្យ «អ្នក» និង «របស់អ្នក» ក៏ដូចជាបង្គាប់
«ចូរយកចិត្តទុកដាក់» «ចូរប្រយ័ត្ន» និង «ធ្វើឱ្យគេស្គាល់»
មានលក្ខណៈជាឯកវចនៈ។
ត្រូវប្រុងស្មារតី និងប្រយ័ត្នខ្លួនរបស់អ្នករាល់គ្នា
«ចូរយកចិត្តទុកដាក់ និងប្រាកដថាចងចាំរឿងទាំងនេះជានិច្ច»
អ្នករាល់គ្នានឹងមិនភ្លេច...ការនោះនឹងមិនឃ្លាតឆ្ងាយពីចិត្តរបស់អ្នករាល់គ្នា
ឃ្លាទាំងនេះមានន័យដូចគ្នា ហើយបញ្ជាក់ថា
ប្រជាជនអ៊ីស្រាអែលត្រូវតែចងចាំអំពីអ្វី ដែលពួកគេបានឃើញ។
ភ្នែករបស់អ្នករាល់គ្នាបានឃើញនោះទេ
នៅទីនេះ «ភ្នែក» ជាឃ្លាសម្រាប់មនុស្ស។ ការបកប្រែផ្សេងទៀត
«អ្នកបានឃើញហើយ»
ចូរប្រមូលប្រជាជនមកឯយើង
«នាំប្រជាជនរួមគ្នាហើយនាំពួកគេមកឯយើង»
Deuteronomy 4:11
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកជនជាតិអ៊ីស្រាអែល អំពីប្រវត្តិរបស់ពួកគេ។
មានភ្លើងឆេះឡើងដល់ផ្ទៃមេឃ
នេះជាឃ្លាសំនួនវោហាស័ព្ទ។ «ឡើងដល់ផ្ទៃមេឃ» មានន័យថា «ពាក់កណ្តាល» ឬ
«ផ្នែកខាងក្នុងបំផុត» និង «ឋានសួគ៌» នៅទីនេះសំដៅទៅលើមេឃ។
ការបកប្រែផ្សេងទៀត «ដោយភ្លើងដែលបានឡើងទៅលើមេឃ»
មានភាពខ្មៅងងឹត ហើយពពក, និងអ័ព្ទងងឹតសូន្យសុង។
នៅទីនេះ «អ័ព្ទងងឹតសូន្យសុង» ពិពណ៌នាអំពីពពក។ ការបកប្រែផ្សេងទៀត
«ជាមួយពពកក្រាស់និងងងឹត»
អ័ព្ទងងឹតសូន្យសុង។
មានន័យមួយទៀតថា «ពពកក្រាស់ឃ្មឹក» ។
Deuteronomy 4:13
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ព្រះអង្គបានបង្ហាញ
«ព្រះអម្ចាស់បានប្រកាស»
អ្នករាល់គ្នា
នៅទីនេះ «អ្នក» សំដៅទៅលើជនជាតិអ៊ីស្រាអែលដែលនៅភ្នំហោរែប។
នៅក្នុងទឹកដីដែលអ្នករាល់គ្នាបានដើរឆ្លង ដើម្បីកាន់កាប់។
«បន្ទាប់ពីអ្នកបានឆ្លងទន្លេយ័រដាន់ ហើយកាន់កាប់ទឹកដីនោះ»
Deuteronomy 4:15
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដូច្នេះ ចូរយកចិត្តទុកដាក់ឲ្យខ្លាំងចំពោះខ្លួនឯង
អាចមានន័យថា ១) «ដូច្នេះអ្នកត្រូវប្រយ័ត្នប្រយែងពីរបៀបដែលអ្នកធ្វើ» ឬ ២)
«ការពារព្រលឹងអ្នកដោយប្រុងប្រយ័ត្ន» ។
មិនត្រូវបង្ខូចខ្លួន
«មិនធ្វើអ្វីដែលខុស»
ដែលលូនវារនៅក្នុងដី
«វារនៅលើដី»
Deuteronomy 4:19
អ្នករាល់គ្នាមិនត្រូវក្រឡេកភ្នែករបស់អ្នកមើលទៅ ... ហើយមើល ... នឹងត្រូវបណ្តាយខ្លួន ...
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់ ដូច្នេះ
រាល់ការកើតឡើងទាំងអស់នៃពាក្យ «អ្នក» និងពាក្យ «របស់អ្នក» និងពាក្យ
«មើលទៅ» «មើល» និង «ត្រូវបណ្តាយខ្លួន» មានលក្ខណៈជាឯកវចនៈ។
អ្នករាល់គ្នាមិនត្រូវ ...នឹងត្រូវបណ្តាយខ្លួនទៅថ្វាយបង្គំ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «កុំ ...
ហើយកុំឱ្យមនុស្សណាម្នាក់ធ្វើឱ្យអ្នកចង់ថ្វាយបង្គំ» ឬ «កុំ ...
ហើយកុំអនុញ្ញាតឱ្យខ្លួនអ្នកថ្វាយបង្គំ»
ព្រមទាំងផ្ទៃមេឃទាំងមូល
«អ្វីគ្រប់យ៉ាងដែលអ្នកអាចមើលឃើញនៅលើមេឃ» ។ នេះជារបៀបមួយទៀត
សំដៅទៅលើព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ»។
វាជារបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គបានប្រទានដល់មនុស្សគ្រប់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ លោកម៉ូសេនិយាយអំពីផ្កាយដូចជាវត្ថុតូចៗ
ដូចជាអាហារដែលព្រះអម្ចាស់កំពុងបែងចែក និងប្រទានឱ្យក្រុមប្រជាជន។
ការបកប្រែផ្សេងទៀត « ដែលព្រះអម្ចាស់ជាព្រះរបស់អ្នកបានដាក់នៅទីនោះ
ដើម្បីជួយក្រុមមនុស្សទាំងអស់»
បាននាំអ្នករាល់គ្នាចេញពីឡដែករបស់អេស៊ីប
លោកម៉ូសេនិយាយអំពីស្រុកអេស៊ីប
និងការខិតខំដែលប្រជាជនអ៊ីស្រាអែលបានធ្វើនៅទីនោះ
ប្រៀបដូចជាឡដែលកំដៅដែកហើយប្រជាជនអ៊ីស្រាអែលជាដែក។
ការបកប្រែផ្សេងទៀត «បាននាំអ្នកចេញពីទឹកដី
ដែលមនុស្សបានធ្វើឱ្យអ្នកធ្វើការយ៉ាងលំបាក»
ដើម្បីក្លាយជាប្រជារាស្ត្រដ៏ជាកេរអាករបស់ព្រះអង្គផ្ទាល់
នេះជាសំណួរដ៏ប៉ិនប្រសប់ ដែលអាចបកប្រែថា
«មនុស្សដែលជាកម្មសិទ្ធិរបស់ព្រះអង្គប៉ុណ្ណោះ»។
Deuteronomy 4:21
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ព្រះអម្ចាស់បានព្រះពិរោធនឹងខ្ញុំ
សំដៅទៅលើពេលលោកម៉ូសេមិនបានស្តាប់បង្គាប់តាមអ្វី
ដែលព្រះអម្ចាស់បានប្រាប់គាត់ឲ្យធ្វើ ព្រោះលោកម៉ូសេខឹងនឹងជនជាតិអ៊ីស្រាអែល។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចបញ្ជាក់យ៉ាងច្បាស់។
បកប្រែដូចនៅក្នុង ១:៣៧ ។
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានដល់អ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលដូចជាពួកគេមានមនុស្សម្នាក់
ដូច្នេះ «អ្នក» និង «របស់អ្នក» គឺមានលក្ខណៈឯកវចនៈ។
Deuteronomy 4:23
ចូរប្រុងស្មារតីរបស់អ្នករាល់គ្នា

generated on Wed Sep 10 16:16:32 2025

«ចូរយកចិត្តទុកដាក់»
ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានហាមឃាត់ ... ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលដូចជា ពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាជាភ្លើងដែលឆេះសន្ធោសន្ធៅ
ព្រះអង្គជាព្រះជាម្ចាស់ដែលប្រច័ណ្ឌ។
លោកម៉ូសេប្រៀបធៀបរបៀបដែលព្រះអម្ចាស់ប្រព្រឹត្តពេលទ្រង់ក្រោធ ដូចជាភ្លើងឆេះបំផ្លាញ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងដាក់ទោសយ៉ាងធ្ងន់ធ្ងរ និងបំផ្លាញអ្នកដូចភ្លើងធ្វើ ព្រោះទ្រង់មិនចង់ឱ្យអ្នកថ្វាយបង្គំព្រះដទៃទេ»
Deuteronomy 4:25
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
អ្នករាល់គ្នាបង្កើត ... ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា
ពាក្យ «អ្នករាល់គ្នា» និង «របស់អ្នករាល់គ្នា» នៅទីនេះមានលក្ខណៈឯកវចនៈ។
បង្កើតកូន
ក្លាយជាឪពុក ឬបុព្វបុរស
អ្នករាល់គ្នាបង្ខូចខ្លួនរបស់អ្នករាល់គ្នា
«បើអ្នករាល់គ្នាធ្វើអ្វីខុស» ។ ពាក្យស្រដៀងគ្នានេះអាចកើតមាននៅក្នុង ៤:១៥ ។
ហើយធ្វើអ្វីដែលអាក្រក់នៅចំពោះព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា
ដើម្បីធ្វើឲ្យព្រះអង្គមានសេចក្តីក្រោធឡើ ុយ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ហើយអ្នករាល់គ្នាធ្វើឱ្យព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាមានសេចក្តីក្រោធ ដោយធ្វើអ្វីៗដែលទ្រង់មានបន្ទូលថា ជាអំពើអាក្រក់»
នោះខ្ញុំហៅមេឃ និងផែនដីមកធ្វើជាសាក្សី
អាចមានន័យថា ១) លោកម៉ូសេកំពុងតែអំពាវនាវដល់អស់អ្នក ដែលរស់នៅលើមេឃនិងផែនដី ឲ្យធ្វើជាសាក្សីចំពោះអ្វីដែលគាត់បាននិយាយ ឬ ២) លោកម៉ូសេកំពុងតែនិយាយទៅកាន់មេឃ និងផែនដីដូចជាពួកគេជាមនុស្ស ហើយគាត់កំពុងហៅពួកគេធ្វើជាសាក្សីនូវអ្វី ដែលគាត់និយាយ។
អ្នករាល់គ្នាមិនអាចរស់នៅក្នុងស្រុកនោះយូរអង្វែងឡើយ
យូរអង្វែងគឺជាពាក្យប្រៀបធៀបសម្រាប់ជីវិតរស់នៅយូរ។ ការបកប្រែផ្សេងទៀត « អ្នករាល់គ្នានឹងមិនអាចរស់នៅបានយូរទេ»
ប៉ុន្តែ អ្នករាល់គ្នានឹងត្រូវបំផ្លាញចោលទាំងស្រុង។
ដូចបានចង្អុលបង្ហាញបញ្ជាក់នៅក្នុង ៤:២៧
មិនមែនជនជាតិអ៊ីស្រាអែលទាំងអស់នឹងត្រូវស្លាប់ឡើយ។ នៅទីនេះ« បំផ្លាញទាំងស្រុង» គឺជាការនិយាយមិនពិត ហើយបញ្ជាក់ថា ប្រជាជនអ៊ីស្រាអែលជាច្រើននឹងត្រូវស្លាប់។ ការបកប្រែផ្សេងទៀត «ប៉ុន្តែ ព្រះអម្ចាស់នឹងបំផ្លាញអ្នករាល់គ្នាជាច្រើន»
Deuteronomy 4:27
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ព្រះអម្ចាស់នឹងកម្ចាត់កម្ចាយអ្នករាល់គ្នាក្នុងចំណោមមនុស្សនានា
លោកម៉ូសេនិយាយហាក់បីដូចជាប្រជាជន ជាគ្រាប់ពូជដែលព្រះអម្ចាស់នឹងព្រោះនៅវាលស្រែ។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងបញ្ជូនអ្នកទៅកន្លែងផ្សេងៗគ្នាជាច្រើន ហើយបង្ខំអ្នកឱ្យរស់នៅទីនោះ»
នឹងដឹកនាំអ្នករាល់គ្នាទៅរស់នៅ។
«នឹងបញ្ជូនអ្នក» ឬ «នឹងធ្វើឱ្យសត្រូវរបស់អ្នកនាំអ្នករាល់គ្នាទៅឆ្ងាយ»
ជាព្រះដែលធ្វើឡើងដោយដៃរបស់មនុស្សពីឈើ និងថ្ម
នៅទីនេះ «ដៃរបស់មនុស្ស» សំដៅទៅលើមនុស្សខ្លួនឯងហើយ «ធ្វើ ... ឈើនិងថ្ម» ទៅរូបចម្លាក់ ដែលពួកគេបានបង្កើត។ ការបកប្រែផ្សេងទៀត «រូបចម្លាក់ធ្វើពីឈើនិងថ្មដែលមនុស្សបានធ្វើ»
Deuteronomy 4:29
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
គាត់និយាយដូចជាពួកគេជាមនុស្សម្នាក់ដូច្នេះរាល់ការកើតឡើងនៃពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈជាឯកវចនៈ។
ប៉ុន្តែ នៅទីនោះ
«ប៉ុន្តែនៅពេលអ្នកស្ថិតនៅក្នុងប្រជាជាតិផ្សេងទៀត!»
អ្នករាល់គ្នានឹងស្វែងរក
ពាក្យ «អ្នករាល់គ្នា» នៅទីនេះជាពហុវចនៈ។
នៅពេលដែលអ្នករាល់គ្នាស្វែងរកព្រះអង្គ
«នៅពេលអ្នករាល់គ្នាពិតជាព្យាយាមស្វែងរកព្រះអង្គ» ឬ «ពេលណាអ្នករាល់គ្នាពិតជាព្យាយាមចង់ស្គាល់ព្រះអង្គ»
ដោយអស់អំពីចិត្ត និងអស់អំពីប្រលឹងរបស់អ្នករាល់គ្នា។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ «ដោយអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង «ដោយអស់ពីព្រលឹង» មានន័យថា «ជាមួយទាំងអស់ ... មនុស្ស» ។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ការបកប្រែផ្សេងទៀត « ដោយអស់ពីសមត្ថភាពរបស់អ្នករាល់គ្នា» ឬ «ដោយអស់ពីកម្លាំងរបស់អ្នករាល់គ្នាទាំងអស់»
Deuteronomy 4:30
នឹងកើតលើអ្នករាល់គ្នា
«បានកើតឡើងចំពោះ»
នៅគ្រាចុងក្រោយ
«ក្រោយមកទៀត» ឬ «បន្ទាប់មក»
ស្តាប់តាមព្រះបន្ទូលរបស់ព្រះអង្គ។
នៅទីនេះ« ស្តាប់» មានន័យថាឮ និងស្តាប់បង្គាប់ហើយ « ព្រះបន្ទូលរបស់ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់ និងអ្វីដែលព្រះអង្គមានបន្ទូល។ ការបកប្រែផ្សេងទៀត «ស្តាប់តាមព្រះអង្គមានបន្ទូល»
Deuteronomy 4:32
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់ ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និងបង្គាប់ «សួរឥឡូវនេះ» មានលក្ខណៈជាឯកវចនៈ។
តើមាននរណាដែលធ្លាប់បានឮព្រះសូរសៀងរបស់ព្រះ ដែលមានបន្ទូលចេញពីកណ្តាលភ្លើង ដូចជាអ្នករាល់គ្នាបានឮ ហើយរស់បានដែរឬទេ?
នៅទីនេះជនជាតិអ៊ីស្រាអែលរម្លឹកអំពីរបៀប ដែលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ពួកគេ តាមរបៀបដ៏អស្ចារ្យកាលពីអតីតកាល។ សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«គ្មាននរណាក្រៅពីអ្នកបានឮព្រះជាម្ចាស់មានបន្ទូលពីពាក់កណ្តាលភ្លើង ហើយនៅរស់ទេ» ។
បានឮព្រះសូរសៀងរបស់ព្រះ
ពាក្យថា« ព្រះសូរសៀង» ជាពាក្យប្រៀបធៀបសម្រាប់ព្រះជាម្ចាស់ ដែលកំពុងមានបន្ទូល។ ការបកប្រែផ្សេងទៀត
«ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ដូចដែលព្រះអង្គបានមានបន្ទូល»
Deuteronomy 4:34
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដោយព្រះហស្តខ្លាំងពូកែ និងដោយពាហុលើកសម្រេច
នៅទីនេះ «ព្រះហស្តខ្លាំងពូកែ» និង «ពាហុលើកសម្រេច » ជារឿងប្រៀបប្រដូចសម្រាប់អំណាចរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត «និងដោយបង្ហាញអំណាចដ៏អស្ចារ្យរបស់ព្រះអង្គ»
ចំពោះមុខអ្នករាល់គ្នា
នៅទីនេះ «មុខ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត «នៅពីមុខអ្នករាល់គ្នា»
Deuteronomy 4:35
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាពួកគេជាមនុស្សម្នាក់ ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈជាឯកវចនៈ។
ការទាំងនេះបានបើកសម្តែងមកឲ្យអ្នករាល់គ្នាបានឃើញ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានបង្ហាញការទាំងនេះដល់អ្នករាល់គ្នា»
ព្រះអង្គធ្វើឲ្យអ្នករាល់គ្នាឮព្រះសូរសៀង ... ធ្វើឲ្យអ្នករាល់គ្នាឃើញ
«ព្រះអង្គបានធ្វើឱ្យប្រាកដថាអ្នកបានឮ ... ធ្វើឱ្យប្រាកដថា អ្នករាធ្វើឲ្យអ្នករាល់គ្នាឃើញ»

generated on Wed Sep 10 16:16:32 2025

ព្រះជាម្ចាស់បានធ្វើ ... អ្នករាល់គ្នាបានឮ
លោកម៉ូសេនិយាយដូចជាមនុស្ស ដែលគាត់កំពុងនិយាយ
ជាមនុស្សដែលគាត់បាននិយាយនៅឯភ្នំស៊ីណាយជាច្រើនឆ្នាំមុន។
ប្រជាជននៅភ្នំស៊ីណៃពិតជាបុព្វបុរសរបស់ប្រជាជន
ដែលទ្រង់កំពុងមានព្រះបន្ទូល។ ការបកប្រែផ្សេងទៀត
«ធ្វើឱ្យឪពុករបស់អ្នករាល់គ្នា...ឪពុករបស់អ្នករាល់គ្នាបានឮ»
Deuteronomy 4:37

ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈជាឯកវចនៈ។

ដូនតារបស់អ្នករាល់គ្នា
សំដៅទៅលើកូនប្រុសរបស់លោកអប្រាហាំ លោកអ៊ីសាក លោកយ៉ាកុប និង
កូនរបស់លោកយ៉ាកុប។

ដោយព្រះវត្តមានរបស់ព្រះអង្គ ជាមួយនឹងព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះអង្គ
«ដោយឫទ្ធានុភាពដ៏ខ្លាំងក្លាដែលកើតចេញពីព្រះភក្ត្ររបស់ព្រះអង្គ» ឬ
«ដោយឫទ្ធានុភាពដ៏ខ្លាំងក្លារបស់ព្រះអង្គ»
Deuteronomy 4:39

ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈជាឯកវចនៈ។

ដាក់ការនេះក្នុងចិត្តរបស់អ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ចូរចងចាំវា»

ដែលគង់នៅស្ថានសួគ៌ និងនៅលើផែនដី
ឃ្លាទាំងពីរ «នៅស្ថានសួគ៌» និង «នៅលើផែនដី» បង្ហាញពីភាពជ្រាលជ្រៅពីរ
និងមានន័យថា «គ្រប់ទីកន្លែង»។ការបកប្រែផ្សេងទៀត «លើអ្វីៗទាំងអស់»

អាចនឹងមានអាយុវែង
មានអាយុវែងជាពាក្យប្រៀបធៀបសម្រាប់ជីវិតដ៏រស់នៅយូរ។ ការបកប្រែផ្សេងទៀត
«អាចរស់នៅមានអាយុវែង» ។ បកប្រែដូចនៅក្នុង ៤:២៥ ។
Deuteronomy 4:41

ព័ត៌មានទូទៅ៖
សុន្ទរកថារបស់លោកម៉ូសេ ដែលបានចាប់ផ្តើមនៅក្នុង ១: ៥ បានបញ្ចប់
ហើយអ្នកនិពន្ធបន្តនិទានកថាដែលបញ្ចប់នៅក្នុង ១:៥។

បេស៊ើរ ... ក្រុងរ៉ាម៉ូត ... កូឡាន
ទាំងនេះជាឈ្មោះទីក្រុង។
Deuteronomy 4:44

នេះគឺជាក្រឹត្យវិន័យ
សំដៅទៅលើក្រឹត្យវិន័យ ដែលលោកម៉ូសេនឹងឲ្យនៅក្នុងជំពូកបន្ទាប់។

បេតពេអរ
នេះជាឈ្មោះក្រុងមួយនៅស្រុកម៉ូអាប់ក្បែរភ្នំពីសកា។
សូមមើលការបកប្រែដូចនៅក្នុង ៣:២៨។

ព្រះបាទស៊ីហុន ... ជនជាតិអាម៉ូរី... ហេសបូន
«ស្តេចស៊ីហុន ... ប្រជាជនអាម៉ូរី ... ទីក្រុងហេសបូន» ។ បកប្រែដូចនៅក្នុង ១:៣។
Deuteronomy 4:47

ទឹកដីរបស់ស្តេច
ដីរបស់ស្តេចស៊ីហុន

ព្រះបាទអុក ជាស្តេចទឹកដីបាសាន
បកប្រែដូចនៅក្នុង ១:៣។

ត្រើយទន្លេយ័រដាន់តាមទិសខាងកើតពីមុន ... នៅត្រើយខាងកើតទន្លេយ័រដាន់
សំដៅទៅលើទឹកដីដែលឆ្លងកាត់ទន្លេយ័រដាន់ នៅខាងកើតអ៊ីស្រាអែល។
នៅពេលលោកម៉ូសេនិយាយដូច្នេះ លោកម៉ូសេនៅខាងកើតទន្លេយ័រដាន់។
ការបកប្រែផ្សេងទៀត «ពីម្ខាងនៃទន្លេយ័រដាន់ឆ្ពោះទៅខាងកើត ...
ខាងកើតពីចំហៀងទន្លេយ័រដាន់»

ក្រុងអារ៉ូអ៊ែរ
នេះជាឈ្មោះទីក្រុងមួយ។ បកប្រែដូចនៅក្នុង ២:៣៦ ។

នៅតាមមាត់ស្ទឹងអើណូន
នេះជាឈ្មោះកន្លែងមួយ។ បកប្រែដូចនៅក្នុង ២:២៤ ។

ភ្នំស៊ីអូន ... ភ្នំហ៊ើរម៉ូន)
ទាំងនេះជាឈ្មោះភ្នំ។ បកប្រែទាំងនេះដូចនៅក្នុង ៣:៨។

សមុទ្រអារ៉ាបា ... ភ្នំពីសកា
បកប្រែទាំងនេះដូចនៅក្នុង ៣:១៧។

5

[1]លោកម៉ូសេបានហៅប្រជាជនអ៊ីស្រាអែល ហើយមានប្រសាសន៍ទៅកាន់ពួកគេថា៖ «ចូរស្តាប់ អ៊ីស្រាអែលអើយ នេះជាច្បាប់
និងវិន័យដែលខ្ញុំនឹងប្រាប់ដល់អ្នករាល់គ្នានៅថ្ងៃនេះ គឺថាអ្នករាល់គ្នានឹងអាចរៀន ហើយកាន់តាមពីច្បាប់ និងវិន័យទាំងនេះបាន។
[2]ព្រះអម្ចាស់ជាព្រះនៃយើងបានចងសម្ពន្ធមេត្រីជាមួយពួកយើង នៅភ្នំហោរែប។[3]ព្រះអម្ចាស់មិនបានចងសម្ពន្ធមេត្រីរបស់ព្រះអង្គជាមួយបុព្វបុរសទេ
តែជាព្រះអង្គចងជាសម្ពន្ធមេត្រីជាមួយពួកយើង ជាអ្នកដែលមានជីវិតរស់នៅថ្ងៃនេះ។
[4]ព្រះអម្ចាស់មានព្រះបន្ទូលជាមួយអ្នករាល់គ្នាដោយមុខទល់នឹងមុខ នៅលើភ្នំចេញពីកណ្តាលភ្លើង[5](នៅពេលនោះ ខ្ញុំបានឈរនៅចន្លោះព្រះអម្ចាស់ និងអ្នករាល់គ្នា
ដើម្បីប្រកាសព្រះបន្ទូលរបស់ព្រះអង្គប្រាប់អ្នករាល់គ្នា ដ្បិត អ្នករាល់គ្នាបានភ័យខ្លាច ដោយព្រោះភ្លើង ហើយអ្នករាល់គ្នាមិនបានឡើងទៅលើភ្នំទេ)។
ព្រះអម្ចាស់មានព្រះបន្ទូលថា៖[6]«យើងគឺជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ជាព្រះដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីប និងចេញពីផ្ទះនៃភាពជាទាសករ។
[7]អ្នករាល់គ្នាមិនត្រូវមានព្រះឯណាក្រៅពីយើងឡើយ។[8]អ្នករាល់គ្នាមិនត្រូវឆ្លាក់រូបណាសម្រាប់អ្នករាល់គ្នា ឬដូចជាអ្វីៗដែលនៅលើមេឃ ឬអ្វីដែលលើផែនដី ក្រោមដី
ឬអ្វីដែលនៅក្នុងទឹកឡើយ។
[9]អ្នកមិនត្រូវក្រាបថ្វាយបង្គំ ឬបម្រើរូបទាំងនោះឡើយ ដ្បិត យើងគឺជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា យើងជាព្រះដែលប្រចណ្ឌ។
យើងដាក់ទោសអំពើទុច្ចរិតរបស់បុព្វបុរស ដោយនាំការដាក់ទោសដល់កូនចៅ រហូតដល់បី
និងបួនជំនាន់ដល់អ្នកណាដែលស្អប់យើង[10]តែសម្តែងសេចក្តីសប្បុរសដល់មួយរយដល់អ្នកណាដែលស្រឡាញ់យើង និងកាន់តាមសេចក្តីបង្គាប់របស់យើង។
[11]អ្នករាល់គ្នាមិនត្រូវបញ្ចេញព្រះនាមរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាជាការអសារឥតការឡើយ ដ្បិត
ព្រះអម្ចាស់នឹងមិនអត់ឱនឲ្យអ្នកណាដែលបញ្ចេញព្រះនាមព្រះអង្គជាការអសារឥតការឡើយ។
[12]ចូរគោរពថ្ងៃសប្ប័ទ ហើយរក្សាថ្ងៃនោះជាបរិសុទ្ធ ដូចដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា បានបង្គាប់ដល់អ្នករាល់គ្នា។[13]ក្នុងរយៈពេលប្រាំមួយថ្ងៃ
ត្រូវឲ្យអ្នករាល់គ្នាបំពេញកិច្ចការ និងធ្វើគ្រប់ការងាររបស់អ្នករាល់គ្នាចុះ[14]ប៉ុន្តែ ថ្ងៃទីប្រាំពីរគឺជាថ្ងៃសប្ប័ទ ថ្វាយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។ នៅថ្ងៃនោះ
អ្នករាល់គ្នាមិនត្រូវធ្វើកិច្ចការទាំងអស់ ទាំងអ្នករាល់គ្នា ទាំងកូនប្រុស ឬកូនស្រីរបស់អ្នករាល់គ្នា ឬបាវបម្រើស្រី ឬបាវបម្រើប្រុសរបស់អ្នករាល់គ្នា ឬគោ ឬសត្វលា
ឬអស់ទាំងហ្វូងសត្វរបស់អ្នករាល់គ្នា ឬជនបរទេសដែលរស់នៅជាមួយអ្នករាល់គ្នាឡើយ។ ដូច្នេះហើយ បាវបម្រើស្រី
និងប្រុសរបស់អ្នករាល់គ្នាអាចសម្រាក់ដូចអ្នករាល់គ្នាដែរ។
[15]អ្នករាល់គ្នាត្រូវនឹកចាំថា អ្នករាល់គ្នាក៏ធ្លាប់ជាបាវបម្រើកាលនៅក្នុងទឹកដីរបស់អេស៊ីប ហើយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបាននាំអ្នករាល់គ្នាចាក់ចេញពីទឹកដីនោះ
ដោយឫទ្ធិបារមី និងតេជានុភាពរបស់ព្រះអង្គ។ ដូច្នេះហើយ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា បានបង្គាប់ដល់អ្នករាល់គ្នាឲ្យរក្សាថ្ងៃសប្ប័ទនេះ។
[16]ចូរគោរពដល់មាតា និងបិតារបស់អ្នករាល់គ្នា ដូចជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា បានបង្គាប់អ្នករាល់ឲ្យប្រតិបត្តិតាម នោះអ្នករាល់គ្នាអាចនឹងរស់នៅបានអាយុវែង
នៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានប្រទាន ហើយអាចជួយអ្នករាល់គ្នាមានសុភមង្គលផងដែរ។
[17]អ្នករាល់គ្នាមិនត្រូវសម្លាប់មនុស្ស។[18]អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តអំពើផិតក្បត់។[19]អ្នករាល់គ្នាមិនត្រូវលួចប្លន់។[20]អ្នករាល់គ្នាមិនត្រូវធ្វើសាក្សីក្លែងក្លាយ
ប្រឆាំងទាស់នឹងអ្នកជិតខាងរបស់អ្នករាល់គ្នាឡើយ។

generated on Wed Sep 10 16:16:32 2025

[21]អ្នករាល់គ្នាមិនត្រូវលោភលន់ចង់បានប្រពន្ធអ្នកជិតខាងរបស់អ្នករាល់គ្នាឡើយ អ្នករាល់គ្នាក៏មិនត្រូវចង់បានផ្ទះរបស់អ្នកជិតខាងរបស់អ្នករាល់គ្នាដែរ ទាំងដីស្រែ
ឬបាវបម្រើស្រីប្រុស ឬគោ ឬសត្វលា ឬរបស់អ្វីៗដែលជាកម្មសិទ្ធិរបស់អ្នកជិតខាងអ្នករាល់គ្នាឡើយ។
[22]ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលមានព្រះបន្ទូលដោយព្រះសូរសៀងយ៉ាងខ្លាំងៗ មកក្នុងការប្រជុំរបស់អ្នករាល់គ្នាដែលនៅលើភ្នំ ចេញពីកណ្តាលភ្លើង
និងភាពងងឹតយ៉ាងក្រាស់ដែលចេញពីពពកមក ព្រះអង្គមិនបានបន្ថែមពាក្យអ្វីទៀតឡើយ។ ព្រះអង្គបានចារសេចក្តីទាំងនេះនៅលើបន្ទះថ្មពីរដុំ
ហើយបានប្រទានមកឲ្យខ្ញុំ។
[23]នៅពេលអ្នករាល់គ្នាបានឮសម្លេងចេញពីកណ្តាលភាពងងឹត នៅពេលដែលភ្នំកំពុងឆេះ នោះ ពួកចាស់ទុំ និងពួកមេនៃកុសម្ព័ន្ធរបស់អ្នករាល់គ្នាទាំងអស់បានមកជិតខ្ញុំ ។
[24]អ្នករាល់គ្នានិយាយថា៖ «មើល៍ ព្រះអម្ចាស់ជាព្រះរបស់យើងបានសម្តែងសិរីល្អ និងភាពធំអស្ចារ្យរបស់ព្រះអង្គឲ្យយើងឃើញ
ហើយយើងបានឮព្រះសូរសៀងរបស់ព្រះអង្គចេញពីកណ្តាលភ្លើង យើងបានឃើញនៅថ្ងៃនេះ
នៅពេលដែលព្រះជាម្ចាស់បានមានព្រះបន្ទូលជាមួយប្រជាជនដែលនៅរស់។
[25]ប៉ុន្តែ ហេតុអ្វីបានជាយើងត្រូវស្លាប់? ដ្បិត ភ្លើងដ៏អស្ចារ្យនេះនឹងឆាបឆេះយើង ប្រសិនបើ យើងឮព្រះសូរសៀងរបស់ព្រះអម្ចាស់ជាព្រះរបស់យើងទៀត
នោះយើងនឹងស្លាប់មិនខាន។[26]ដ្បិត តើមាននរណាក្រៅពីយើងដែលនៅក្នុងចំណោមមនុស្សទាំងអស់បានឮព្រះសូរសៀងរបស់ព្រះដែលមានព្រះជន្មរស់
ចេញពីកណ្តាលភ្លើង ហើយនៅរស់បាន ដូចជាយើងបានឮដូច្នេះ?[27]ដូច្នេះ សូមលោកចូលទៅជិត ហើយស្តាប់អ្វីៗដែលព្រះអម្ចាស់ជារបស់យើងបានមានព្រះបន្ទូល
ហើយនិយាយប្រាប់ពួកយើងអំពីអ្វីៗដែលព្រះអម្ចាស់ជាព្រះរបស់យើងបានមានព្រះបន្ទូលមកកាន់លោក យើងនឹងស្តាប់ ហើយប្រតិបត្តិតាមផង។
[28]ព្រះអម្ចាស់បានឮពាក្យរបស់អ្នករាល់គ្នា នៅពេលដែលអ្នកនិយាយជាមួយខ្ញុំ។ ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា៖ «យើងបានឮពាក្យរបស់ប្រជាជនទាំងនេះ
ឮអ្វីដែលពួកគេនិយាយជាមួយអ្នក។ អ្វីដែលពួកគេនិយាយសុទ្ធតែត្រឹមត្រូវ។[29]អូ ប្រសិនបើ ពួកគេមានចិត្តយ៉ាងដូច្នេះ ពួកគេអាចនឹងគោរពកោតខ្លាចយើង
ហើយកាន់តាមគ្រប់ទាំងសេចក្តីបង្គាប់របស់យើង ដើម្បីឲ្យគេ និងកូនចៅរបស់គេមានសុភមង្គលជារៀងរហូត![30]ចូរចេញទៅប្រាប់ពួកគេថា៖
«ចូរត្រឡប់ទៅត្រសាលរបស់អ្នករាល់គ្នាវិញចុះ»។
[31]ប៉ុន្តែសម្រាប់អ្នកវិញ ចូរឈរនៅទីនោះជិតយើង ហើយយើងនឹងប្រាប់អ្នកអស់ទាំងសេចក្តីបង្គាប់ អស់ទាំងច្បាប់ និងវិន័យដែលអ្នកនឹងត្រូវបង្រៀនដល់ពួកគេ ដូច្នេះ
ពួកគេអាចនឹងកាន់តាមសេចក្តីទាំងនេះ នៅក្នុងទឹកដីដែលយើងនឹងប្រទានឲ្យពួកគេឲ្យកាន់កាប់។
[32]ដូច្នេះហើយ អ្នករាល់គ្នាត្រូវកាន់តាមអ្វីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបង្គាប់ដល់អ្នករាល់គ្នា នោះអ្នករាល់គ្នានឹងមិនត្រូវងាកចេញទៅខាងស្តាំដៃ
ខាងឆ្វេងដៃឡើយ។[33]អ្នករាល់គ្នាត្រូវដើរនៅក្នុងផ្លូវដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបង្គាប់មកអ្នករាល់គ្នាឡើយ ដូច្នេះ អ្នករាល់គ្នាអាចនឹងរស់នៅ
និងមានសុភមង្គល ហើយអ្នករាល់គ្នាអាចនឹងមានអាយុវែងនៅលើទឹកដីដែលអ្នករាល់គ្នានឹងកាន់កាប់។

Deuteronomy 5:1
ព័ត៌មានទូទៅ៖
ម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
បានហៅប្រជាជនអ៊ីស្រាអែល
លោកម៉ូសេចង់ឱ្យប្រជាជនអ៊ីស្រាអែលគ្រប់ៗគ្នាឮ និងស្តាប់តាមសម្តីរបស់គាត់
ប៉ុន្តែ សំឡេងរបស់គាត់ប្រហែលជាមិនឮខ្លាំងទេ ដូច្នេះ
តាមពិតមនុស្សគ្រប់គ្នាបានឮសំឡេងគាត់។
ដែលខ្ញុំនឹងប្រាប់ដល់អ្នករាល់គ្នានៅថ្ងៃនេះ
នៅទីនេះ «ប្រាប់» សំដៅទៅលើមនុស្សទាំងមូល។ ការប្រៀបធៀបនេះបញ្ជាក់ថា
ប្រជាជនដឹងនូវអ្វីដែលលោកម៉ូសេបាននិយាយទៅកាន់ពួកគេ ដូច្នេះ
ពួកគេមិនអាចធ្វើបាប ហើយបន្ទាប់មកពួកគេនិយាយថា
ពួកគេមិនដឹងថាពួកគេកំពុងធ្វើបាបទេ។ ការបកប្រែផ្សេងទៀត
«ដែលខ្ញុំនឹងនិយាយទៅកាន់អ្នកនៅថ្ងៃនេះ»
ព្រះអម្ចាស់មិនបានចងសម្ពន្ធមេត្រីរបស់ព្រះអង្គជាមួយបុព្វបុរសទេ
អាចមានន័យថា ១)
ព្រះអម្ចាស់មិនត្រឹមតែបានចងសម្ពន្ធមេត្រីជាមួយអ្នកនៅហោរែបប៉ុណ្ណោះទេ។
សម្ពន្ធមេត្រីនេះក៏ស្ថិតនៅជាមួយកូនចៅអ៊ីស្រាអែលជំនាន់ក្រោយៗដែរ។ ឬ ២)
ព្រះជាម្ចាស់ពុំបានចងសម្ពន្ធមេត្រីជាមួយបុព្វបុរស
ដែលនៅឆ្ងាយដូចលោកអប្រាហាំលោកអ៊ីសាក និងលោកយ៉ាកុបទេ។ ផ្ទុយទៅវិញ
សម្ពន្ធមេត្រីនេះបានចាប់ផ្តើមជាមួយជនជាតិអ៊ីស្រាអែលនៅហោរែប។
Deuteronomy 5:4
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
មុខទល់នឹងមុខ
ប្រើឃ្លាបែបសំនួនវោហាស័ព្ទរបស់អ្នកសម្រាប់មនុស្សពីរនាក់
ដែលជិតស្និទ្ធចំពោះគ្នាទៅវិញទៅមក ហើយមើលគ្នាទៅវិញទៅមក
ពេលពួកគេកំពុងនិយាយជាមួយគ្នាទៅវិញមក។
នៅលើភ្នំ
«នៅលើភ្នំ»
នៅពេលនោះ
លោកម៉ូសេកំពុងសំដៅទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងប្រហែលជា
៤០ឆ្នាំមុន។
និងចេញពីផ្ទះនៃភាពជាទាសករ។
នៅទីនេះពាក្យប្រៀបធៀប «ផ្ទះនៃភាពជាទាសករ» សំដៅទៅលើប្រទេសអេស៊ីប
ដែលប្រជាជនអ៊ីស្រាអែលធ្លាប់ជាទាសករ។ ការបកប្រែផ្សេងទៀត
«ចេញពីកន្លែងដែលអ្នករាល់គ្នាធ្លាប់ធ្វើជាទាសករ»
Deuteronomy 5:7
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអំពីអ្វី ដែលព្រះអម្ចាស់បានបង្គាប់ពួកគេ។ ឃ្លា
«អ្នកនឹង» និង «អ្នកនឹងមិន» ជាពាក្យបង្គាប់។
គាត់និយាយទៅកាន់ជនជាតិអ៊ីស្រាអែលហាក់ដូចជាពួកគេជាមនុស្សម្នាក់។
អ្នករាល់គ្នាមិនត្រូវមានព្រះឯណាក្រៅពីយើងឡើយ។
«អ្នករាល់គ្នាមិនត្រូវថ្វាយបង្គំព្រះដទៃ ក្រៅពីយើងទេ»
ដូចជាអ្វីៗដែលនៅលើមេឃ ឬអ្វីដែលលើផែនដី ក្រោមដី ឬអ្វីដែលនៅក្នុងទឹកឡើយ។
អាចធ្វើឱ្យកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត «
អ្វីដែលនៅលើផែនដីក្រោមបាតជើងរបស់អ្នក ឬអ្វីដែលក្នុងទឹកក្រោមដី»
Deuteronomy 5:9
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្ យ«អ្នក» និងបង្គាប់ «សួរឥឡូវនេះ»
មានលក្ខណៈជាឯកវចនៈ។
អ្នកមិនត្រូវក្រាបថ្វាយបង្គំ ឬបម្រើរូបទាំងនោះឡើយ
«អ្នកនឹងមិនត្រូវថ្វាយបង្គំរូបចម្លាក់ ឬធ្វើដូចដែលពួកគេបង្គាប់»
អ្នកមិនត្រូវ
«មិនដែល»
យើង ... ដែលប្រចណ្ឌ។
«យើង ... ចង់អោយអ្នកថ្វាយបង្គំយើងតែមួយគត់»
មួយរយដល់អ្នកណាដែលស្រឡាញ់យើង
ការបកប្រែខ្លះអាន «ដល់មនុស្សរាប់ពាន់ជំនាន់នៃណាអ្នកដែលស្រឡាញ់យើង» ។
ពាក្យថា «រាប់ពាន់» ជាពាក្យប្រៀបធៀប ឬនិយាយបំផ្លើសសម្រាប់ចំនួន
ដែលមិនអាចរាប់បាន។ ការបកប្រែផ្សេងទៀត «ចំពោះមនុស្សរាប់ពាន់នាក់
ដែលស្រឡាញ់យើង»
Deuteronomy 5:11
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។ ដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតឡើងនៃពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈជាឯកវចនៈ។
អ្នករាល់គ្នាមិនត្រូវបញ្ចេញព្រះនាមរបស់ព្រះអម្ចាស់
«អ្នកនឹងមិនប្រើព្រះនាមរបស់ព្រះអម្ចាស់»
ជាការអសារឥតការឡើយ

generated on Wed Sep 10 16:16:32 2025

«ធ្វេសប្រហែស» ឬ «ដោយគ្មានការគោរពត្រឹមត្រូវ» ឬ
«សម្រាប់គោលបំណងខុស»
ព្រះអម្ចាស់នឹងមិនអត់ឱនឲ្យអ្នក
អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងចាត់ទុកគាត់ថា ជាមនុស្សមានកំហុស» ឬ
«ព្រះអម្ចាស់នឹងដាក់ទោសគាត់»
Deuteronomy 5:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈជាឯកវចនៈ។
រក្សាថ្ងៃនោះជាបរិសុទ្ធ
«ថ្វាយទៅព្រះជាម្ចាស់»
បានបង្គាប់ដល់អ្នករាល់គ្នា។
«បំពេញភារកិច្ចធម្មតារបស់អ្នក»
ទីប្រាំពីរ
«ថ្ងៃទី៧»។ នៅទីនេះ «ទីប្រាំពីរ» ជាលេខធម្មតាសម្រាប់ប្រាំពីរ។
នៅថ្ងៃនោះ អ្នករាល់គ្នាមិនត្រូវធ្វើ
«នៅថ្ងៃនោះមិនត្រូវធ្វើ»
ដែលរស់នៅជាមួយអ្នករាល់គ្នាឡើយ។
នៅទីនេះ «ច្រកទ្វារចូល» ជាឯកសារយោងទៅទីក្រុងនោះឯង។
ការបកប្រែផ្សេងទៀត «នៅក្នុងសហគមន៍របស់អ្នក» ឬ
«នៅខាងក្នុងទីក្រុងរបស់អ្នក» ឬ «រស់នៅជាមួយអ្នក»
Deuteronomy 5:15
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈជាឯកវចនៈ។
អ្នករាល់គ្នាត្រូវនឹកចាំថា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត«អ្នកត្រូវតែចងចាំ»
ដោយឫទ្ធិបារមី និងតេជានុភាពរបស់ព្រះអង្គ។
នៅទីនេះ «ឫទ្ធិបារមី» និង «តេជានុភាពរបស់ព្រះអង្គ»
ជារឿងប្រៀបប្រដូចសម្រាប់អំណាចរបស់ព្រះអម្ចាស់។ បកប្រែដូចនៅក្នុង ៤:៣៤។
ការបកប្រែផ្សេងទៀត «ដោយបង្ហាញអំណាចដ៏ខ្លាំងក្លារបស់ព្រះអង្គ»
Deuteronomy 5:16
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈជាឯកវចនៈ។
Deuteronomy 5:17
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «អ្នករបស់អ្នក»
មានលក្ខណៈជាឯកវចនៈ។
អ្នករាល់គ្នាមិនត្រូវ
បកប្រែដូចនៅក្នុង ៥:៩ ។
អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តអំពើផិតក្បត់។
«អ្នកនឹងមិនត្រូវគេងជាមួយអ្នកផ្សេង ក្រៅពីប្តី ឬប្រពន្ធរបស់អ្នកឡើយ»
អ្នករាល់គ្នាមិនត្រូវធ្វើសាក្សីក្លែងក្លាយ ប្រឆាំងទាស់នឹងអ្នកជិតខាងរបស់អ្នករាល់គ្នាឡើយ។
«អ្នកនឹងមិនត្រូវនិយាយកុហកមនុស្សណាឡើយ»
Deuteronomy 5:21
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាពួកគេជាមនុស្សម្នាក់
ដូច្នេះ រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈជាឯកវចនៈ។
អ្នករាល់គ្នាមិនត្រូវ
បកប្រែដូចនៅក្នុង ៥:៩។
Deuteronomy 5:22
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី ដែលព្រះអម្ចាស់បានមានបន្ទូល។
Deuteronomy 5:23
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី ដែលព្រះអម្ចាស់បានមានបន្ទូល។
បានឮសំឡេង
ពាក្យថា« សំឡេង» ជាពាក្យប្រៀបធៀបសូរសំឡេង
ឬសម្រាប់មនុស្សដែលបានកំពុងតែនិយាយ។ ការបកប្រែផ្សេងទៀត
«បានឮសូរនៃសំឡេង» ឬ «បានឮព្រះអម្ចាស់កំពុងមានបន្ទូល»
Deuteronomy 5:25
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តរម្លឹកជនជាតិអ៊ីស្រាអែលអំពីអ្វី
ដែលជនជាតិអ៊ីស្រាអែលបាននិយាយទៅកាន់លោកម៉ូសេ។
ប៉ុន្តែ ហេតុអ្វីបានជាយើងត្រូវស្លាប់?
ពួកគេខ្លាចថាពួកគេនឹងត្រូវស្លាប់ បើព្រះអម្ចាស់មានបន្ទូលមកពួកគេ។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«យើងភ័យខ្លាចថាយើងនឹងស្លាប់» ។
ដ្បិត តើមាននរណាក្រៅពីយើងដែល ... បានឮដូច្នេះ?
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«មិនមានមនុស្សផ្សេងទៀតក្រៅពីយើងទេ ... បានធ្វើរួច» ។
មនុស្សទាំងអស់
នេះជាពាក្យប្រៀធៀបសម្រាប់ «មនុស្សទាំងអស់» ឬ «របស់មានជីវិតទាំងអស់» ។
Deuteronomy 5:28
នៅពេលដែលអ្នកនិយាយជាមួយខ្ញុំ។
នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកម៉ូសេ។
អូ ប្រសិនបើ ពួកគេមាន
បើភាសារបស់អ្នកមានឃ្លាសម្តាល់
សម្រាប់បង្ហាញពីបំណងប្រាថ្នាយ៉ាងខ្លាំងចំពោះអ្វីមួយ
អ្នកប្រហែលជាចង់ប្រើវានៅទីនេះ។ ការបកប្រែផ្សេងទៀត «ខ្ញុំនឹងសប្បាយចិត្ត
បើមាន»
Deuteronomy 5:31
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
អ្នកនឹងត្រូវបង្រៀនដល់ពួកគេ
«អ្នកនឹងបង្រៀនប្រជាជនអ៊ីស្រាអែល»
Deuteronomy 5:32
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
អ្នករាល់គ្នាត្រូវកាន់តាម
លោកម៉ូសេកំពុងបង្គាប់ទៅប្រជាជនអ៊ីស្រាអែល។
អ្នករាល់គ្នានឹងមិនត្រូវងាកចេញទៅខាងស្តាំដៃ ខាងឆ្វេងដៃឡើយ។
ប្រៀបធៀបមនុស្សដែលមិនស្តាប់បង្គាប់ព្រះជាម្ចាស់ទៅនឹងមនុស្សម្នាក់
ដែលងាកចេញពីផ្លូវត្រូវ។ ការបកប្រែផ្សេងទៀត
«អ្នកនឹងមិនត្រូវមិនស្តាប់បង្គាប់ព្រះអង្គ ទោះតាមរបៀបណាក៏ដោយ» ឬ
«អ្នកនឹងធ្វើអ្វីគ្រប់យ៉ាងដែលព្រះអង្គមានបន្ទូល»
មានអាយុវែង
មានអាយុវែងជាពាក្យប្រៀបធៀបសម្រាប់ជីវិតដ៏យូរមួយ។ បកប្រែវាដូចនៅក្នុង
៤:៣៩ ។ ការបកប្រែផ្សេងទៀត «អាចរស់នៅបានរយៈពេលយូរអង្វែង»

---

6 [1]ទាំងនេះគឺជាសេចក្តីបង្គាប់ ជាច្បាប់ និងជាបទបញ្ជាដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបង្គាប់ដល់ខ្ញុំ ឲ្យបង្រៀនអ្នករាល់គ្នា
ដើម្បីឲ្យអ្នករាល់គ្នាត្រូវកាន់តាមសេចក្តីទាំងនេះនៅលើទឹកដីដែលអ្នករាល់គ្នានឹងឆ្លងកាត់ទៅទន្លេយ័រដាន់ ដើម្បីកាន់កាប់[2]ធ្វើដូច្នេះ
អ្នករាល់គ្នានឹងគោរពព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ហើយកាន់តាមគ្រប់ទាំងច្បាប់ និងសេចក្តីបង្គាប់របស់ព្រះអង្គ ដូចដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ទាំងអ្នករាល់គ្នា
ទាំងកូនប្រុស ទាំងចៅប្រុសរបស់អ្នករាល់គ្នា រហូតអស់មួយជីវិតរបស់អ្នករាល់គ្នា ដូច្នេះ អ្នករាល់គ្នានឹងមានអាយុវែង។

generated on Wed Sep 10 16:16:32 2025

[3]ដូច្នេះ អ៊ីស្រាអែលអើយ ចូរស្តាប់ ហើយកាន់តាមសេចក្តីទាំងនេះចុះ ធ្វើដូច្នេះ អ្នករាល់គ្នានឹងមានសុភមង្គល ធ្វើដូច្នេះ អ្នករាល់គ្នានឹងកើនចំនួនជាច្រើន
នៅក្នុងទឹកដីដែលមានទឹកដោះគោ និងទឹកឃ្មុំយ៉ាងហូរហៀរ ដូចជាព្រះអម្ចាស់ ជាព្រះនៃដូនតារបស់អ្នករាល់គ្នា បានសន្យានឹងអ្នករាល់គ្នា ។
[4]ឱអ៊ីស្រាអែល ចូរស្តាប់ ព្រះអម្ចាស់ជាព្រះតែមួយរបស់យើង។[5]អ្នករាល់គ្នាត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ឲ្យអស់អំពីចិត្តរបស់អ្នករាល់គ្នា
ឲ្យអស់អំពីប្រលឹងរបស់អ្នករាល់គ្នា និងឲ្យអស់អំពីកម្លាំងរបស់អ្នករាល់គ្នា។
[6]គ្រប់ពាក្យដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ ត្រូវនៅជាប់ក្នុងចិត្តរបស់អ្នករាល់គ្នា[7]ហើយអ្នករាល់គ្នាត្រូវឧស្សាហ៍បង្រៀនសេចក្តីទាំងនេះ ដល់កូនៗរបស់អ្នករាល់គ្នា។
អ្នករាល់គ្នាត្រូវនិយាយអំពីសេចក្តីទាំងនេះ នៅពេលអ្នករាល់គ្នាអង្គុយនៅក្នុងផ្ទះរបស់អ្នករាល់គ្នា នៅពេលអ្នករាល់គ្នាដើរនៅតាមផ្លូវ នៅពេលអ្នករាល់គ្នាដេក
និងនៅពេលអ្នករាល់គ្នាក្រោកឡើង។
[8]អ្នករាល់គ្នាត្រូវចងសេចក្តីទាំងនេះ ទុកជាទីសម្គាល់នៅលើដៃរបស់អ្នករាល់គ្នា ហើយត្រូវចងសេចក្តីទាំងនោះនៅលើថ្ងាសរបស់អ្នករាល់គ្នា។
[9]អ្នករាល់គ្នាត្រូវសរសេរសេចក្តីទាំងនេះ នៅលើក្របទ្វារផ្ទះ និងនៅលើទ្វារក្រុងរបស់អ្នករាល់គ្នា។
[10]នៅពេលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា នាំអ្នករាល់គ្នាចូលទៅទឹកដីដែលព្រះអង្គបានស្បថជាមួយនឹងដូនតារបស់អ្នករាល់គ្នា គឺចំពោះលោកអប្រាហាំ លោកអ៊ីសាក
និងលោកយ៉ាកុបថា ព្រះអង្គបានស្បថថានឹងប្រទានឲ្យអ្នករាល់គ្នាមានទីក្រុងយ៉ាងធំ ហើយល្អ ជាទីក្រុងដែលអ្នករាល់គ្នាមិនបានសាងសង់[11]ហើយផ្ទះជាច្រើន
ពេញដោយរបស់ល្អៗគ្រប់មុខ ដែលអ្នករាល់គ្នាមិនបានបង្កើត ព្រមទាំងស្រះដែលអ្នករាល់គ្នាមិនបានជីក ហើយទាំងចម្ការទំពាំងបាយជូរ និងដើមអូលីវ
ដែលអ្នករាល់គ្នាមិនបានដាំ អ្នករាល់គ្នានឹងបរិភោគ ហើយនឹងពេញចិត្ត[12]បន្ទាប់មក ត្រូវប្រយ័ត្ន ក្រែងអ្នករាល់គ្នាភ្លេចព្រះអម្ចាស់
ជាព្រះដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីប ចាកចេញពីផ្ទះនៃទេសករ។
[13]អ្នករាល់គ្នាត្រូវកោតខ្លាចព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា អ្នករាល់គ្នាត្រូវគោរពបម្រើព្រះអង្គ ហើយអ្នករាល់គ្នាត្រូវស្បថក្នុងព្រះនាមរបស់ព្រះអង្គដែរ។
[14]អ្នករាល់គ្នាមិនត្រូវទៅរកព្រះណាទៀតឡើយ ជាព្រះរបស់ប្រជាជនដែលនៅជុំវិញអ្នករាល់គ្នាឡើយ[15]ដ្បិត
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាដែលគង់នៅកណ្តាលអ្នករាល់គ្នា ព្រះអង្គជាព្រះដែលប្រចណ្ឌ ប្រសិនបើ អ្នករាល់គ្នាធ្វើដូច្នោះ
នោះសេចក្តីកោធរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងឆួលឡើងប្រឆាំងនឹងអ្នករាល់គ្នា ហើយព្រះអង្គនឹងបំផ្លាញអ្នករាល់គ្នាចេញពីលើផែនដីនេះទៅ។
[16]អ្នករាល់គ្នាមិនត្រូវល្បងលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដូចដែលអ្នករាល់គ្នាបានល្បងលព្រះអង្គនៅម៉ាសានោះឡើយ។
[17]អ្នករាល់គ្នាព្យាយាមកាន់តាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ព្រមទាំងបន្ទាល់ និងច្បាប់ទាំងឡាយរបស់ព្រះអង្គ
ដែលព្រះអង្គបានបង្គាប់អ្នករាល់គ្នា។
[18]អ្នករាល់គ្នាប្រព្រឹត្តតាមអ្វីដែលសុចរិត ហើយត្រឹមត្រូវ នៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់ ដើម្បីឲ្យអ្នករាល់គ្នាមានសុភមង្គល ហើយអ្នករាល់គ្នាអាចនឹងចូលទៅ
និងកាន់កាប់ទឹកដីល្អ ដែលព្រះអម្ចាស់បានស្បថចំពោះដូនតារបស់អ្នករាល់គ្នា[19]ដើម្បីបណ្តេញខ្មាំងសត្រូវទាំងអស់របស់អ្នករាល់គ្នា ចេញពីមុខអ្នករាល់គ្នា
ដូចជាព្រះអម្ចាស់បានមានព្រះបន្ទូល។
[20]កាលណាថ្ងៃក្រោយ កូនប្រុសអ្នករាល់គ្នាសួរថា តើអ្វីជាបទបញ្ជា ច្បាប់ និងបញ្ញាតិទាំងឡាយ ដែលព្រះអម្ចាស់ជាព្រះរបស់យើងបានបង្គាប់ដល់អ្នករាល់គ្នា?[21]បន្ទាប់មក
អ្នករាល់គ្នានឹងឆ្លើយទៅកាន់កូនប្រុសរបស់អ្នករាល់គ្នាថា ពីដើមយើងជាទាសកររបស់ផារ៉ោននៅទឹកដីអេស៊ីប ព្រះអម្ចាស់បាននាំពួកយើងចេញពីអេស៊ីប
ដោយព្រះហស្តដ៏ខ្លាំងអស្ចារ្យ[22]ហើយព្រះអង្គបានធ្វើទីសម្គាល់ ព្រមទាំងការអស្ចារ្យយ៉ាងធំ និងយ៉ាងខ្លាំង នៅលើទឹកដីអេស៊ីប ចំពោះស្តេចផារ៉ោន
ព្រមទាំងដំណាក់របស់ព្រះអង្គ នៅចំពោះមុខរបស់ពួកយើង[23]ហើយព្រះអង្គបាននាំពួកយើងចេញពីទីនោះ ដើម្បីឲ្យព្រះអង្គនាំពួកយើងចូលមក
ហើយប្រទានទឹកដីដែលព្រះអង្គបានស្បថចំពោះដូនតារបស់យើង។
[24]ព្រះអម្ចាស់បានបង្គាប់ពួកយើង ដើម្បីកាន់តាមច្បាប់ទាំងអស់ ដើម្បីឲ្យកោតខ្លាចព្រះអង្គជាព្រះរបស់ពួកយើងសម្រាប់ឲ្យយើងមានសុភមង្គល ធ្វើដូច្នេះ
ព្រះអង្គនឹងទុកជីវិតរបស់ពួកយើង ដូចជាយើងរស់នៅថ្ងៃនេះ។[25]ប្រសិនបើ យើងកាន់តាមគ្រប់ទាំងសេចក្តីបង្គាប់ទាំងនេះ នៅចំពោះព្រះនេត្រព្រះអម្ចាស់ជាព្រះនៃយើង
ដូចជាព្រះអង្គបានបង្គាប់នោះ ពួកយើងនឹងបានរាប់ជាសុចរិត។

Deuteronomy 6:1

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តសុន្ទរកថាទៅកាន់ប្រជាជនអ៊ីស្រាអែល
ដែលគាត់បានចាប់ផ្តើមនៅក្នុង ៥:១។ ចាប់ផ្តើមពីខ ២
គាត់និយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សតែម្នាក់។

ត្រូវកាន់តាម ... កាន់តាម

«អាចស្តាប់បង្គាប់ ... ស្តាប់បង្គាប់»

keep them

«នឹងឆ្លងទៅត្រើយម្ខាងទៀតនៃទន្លេយ័រដាន់»

ដូច្នេះ អ្នករាល់គ្នានឹងមានអាយុវែង។

អាយុវែងជាពាក្យប្រៀបធៀប សម្រាប់ជីវិតរស់នៅដ៏យូរ។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ អាចបកប្រែស្រដៀងគ្នាទៅនឹង
«មានអាយុវែង» នៅក្នុង ៤:២៥ ។ការបកប្រែផ្សេងទៀត «ដូច្នេះ
ខ្ញុំអាចឲ្យអ្នកមានអាយុជីវិត» ឬ «ដែលខ្ញុំអាចឱ្យអ្នករស់នៅបានយូរអង្វែង»

Deuteronomy 6:3

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។

អ៊ីស្រាអែលអើយ ចូរស្តាប់

នៅទីនេះ «ស្តាប់» មានន័យថា ត្រូវគោរពតាម ហើយ « ពួកគេ»
សំដៅទៅលើបទបញ្ញត្តិរបស់ព្រះអម្ចាស់។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចពន្យល់ឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ចូរស្តាប់បទបញ្ញត្តិ លក្ខន្តិក:
និងក្រឹត្យវិន័យរបស់ព្រះអម្ចាស់»

កាន់តាមសេចក្តីទាំងនេះចុះ

«ស្តាប់បង្គាប់ពួកគេ»

នៅក្នុងទឹកដីដែលមានទឹកដោះគោ និងទឹកឃ្មុំយ៉ាងហូរហៀរ

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ដីដែលមានទឹកដោះគោនិងទឹកឃ្មុំហូរច្រើន» ឬ «ដីល្អប្រសើរសម្រាប់ចិញ្ចឹមសត្វ
និងធ្វើកសិកម្ម»

Deuteronomy 6:4

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។

ព្រះអម្ចាស់ជាព្រះតែមួយរបស់យើង។

«ព្រះអម្ចាស់ជាព្រះតែមួយគត់របស់យើង»

ឲ្យអស់អំពីចិត្តរបស់អ្នករាល់គ្នា ឲ្យអស់អំពីប្រលឹងរបស់អ្នករាល់គ្នា
និងឲ្យអស់អំពីកម្លាំងរបស់អ្នករាល់គ្នា។

ឃ្លាទាំងនេះរួមបញ្ចូលគ្នាបញ្ជាក់ថា មនុស្សម្នាក់ត្រូវបានគេសន្មតថា
ស្រឡាញ់ព្រះជាម្ចាស់ទាំងស្រុង ហើយត្រូវបានថ្វាយខ្លួនដល់ព្រះអង្គទាំងស្រុង។

Deuteronomy 6:6

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។

ខ្ញុំបង្គាប់អ្នករាល់គ្នា

លោកម៉ូសេកំពុងថ្លែងបទបញ្ញត្តិរបស់ព្រះជាម្ចាស់ ទៅកាន់ប្រជាជនអ៊ីស្រាអែល។

ត្រូវនៅជាប់ក្នុងចិត្តរបស់អ្នករាល់គ្នា

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត«អ្នកត្រូវតែចងចាំជានិច្ច»

ហើយអ្នករាល់គ្នាត្រូវឧស្សាហ៍បង្រៀន ... អ្នករាល់គ្នាត្រូវនិយាយ

«ខ្ញុំបង្គាប់ឱ្យអ្នកបង្រៀនដោយឧស្សាហ៍ ... ខ្ញុំបង្គាប់ឱ្យអ្នកនិយាយ» ។

generated on Wed Sep 10 16:16:32 2025

អ្នកអានគួរយល់ពីបង្គាប់ទាំងនេះ។
Deuteronomy 6:8
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
ត្រូវចងសេចក្តីទាំងនេះ
នេះជាពាក្យប្រៀបធៀបសម្រាប់ «សរសេរពាក្យទាំងនេះនៅលើផ្ទាំងស្បែក
ដាក់ផ្ទាំងស្បែកក្នុងថង់មួយហើយចងមាត់ថង់»។
ពាក្យប្រៀធៀបនេះអាចជាពាក្យប្រៀបធៀបសម្រាប់ «ចូរគោរពតាមពាក្យទាំងនេះ
ដូច្នេះ វាដូចជាពួកគេនៅទីនោះដែរ» ។ ការបកប្រែផ្សេងទៀត
«ចងភ្ជាប់ពាក្យទាំងនេះ»
ទុកជាទីសម្គាល់នៅលើដៃរបស់អ្នករាល់គ្នា
«ជាអ្វីមួយធ្វើឱ្យអ្នករាល់គ្នាចងចាំក្រឹត្យវិន័យរបស់យើង»
ហើយត្រូវចងសេចក្តីទាំងនោះនៅលើថ្ងាសរបស់អ្នករាល់គ្នា។
នេះជាពាក្យប្រៀបធៀបសម្រាប់
«សរសេរពាក្យទាំងនេះនៅលើផ្ទាំងស្បែកដាក់ផ្ទាំងស្បែក
នៅក្នុងថង់មួយហើយចងមាត់ថង់ទៅនឹងក្បាលរបស់អ្នក ដូច្នេះ វាអង្គុយចុះ» ។
នេះជាពាក្យប្រៀបធៀបអាចជាពាក្យប្រៀបធៀបសម្រាប់ «ចូរគោរពពាក្យទាំងនេះ
ដូច្នេះ ដូចជាពួកគេមានវត្តមាននៅទីនោះដែរ។»។ ការបកប្រែផ្សេងទៀត
«ពាក្យរបស់យើងនឹងនៅលើថ្ងាស»
ថ្ងាស
គ្រឿងលម្អមនុស្សពាក់នៅលើថ្ងាស
អ្នករាល់គ្នាត្រូវសរសេរ
នេះជាការបង្គាប់។
Deuteronomy 6:10
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
ទីក្រុងយ៉ាងធំ ហើយល្អ ជាទីក្រុងដែលអ្នករាល់គ្នាមិនបានសាងសង់
ក្រុងទាំងអស់នេះជាកម្មសិទ្ធិរបស់ជនជាតិអ៊ីស្រាអែល
ពេលពួកគេច្បាំងឈ្នះជនជាតិកាណាន។
ចាកចេញពីផ្ទះនៃទេសករ។
នៅទីនេះពាក្យប្រៀធៀប «ផ្ទះរបស់ទាសករ» សំដៅទៅលើប្រទេសអេស៊ីបជាកន្លែង
ដែលប្រជាជនអ៊ីស្រាអែលធ្លាប់ជាទាសករ។ ការបកប្រែផ្សេងទៀត
«ចេញពីកន្លែងដែលអ្នកធ្លាប់ធ្វើជាទាសករ»
Deuteronomy 6:13
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
អ្នករាល់គ្នាត្រូវកោតខ្លាចព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា អ្នករាល់គ្នាត្រូវគោរពបម្រើព្រះអង្គ
ហើយអ្នករាល់គ្នាត្រូវស្បថក្នុងព្រះនាមរបស់ព្រះអង្គដែរ។
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ហើយគ្មានមនុស្សណាដែលអ្នករាល់គ្នាគួរគោរពឡើយ
គឺព្រះអង្គតែមួយគត់ដែលអ្នករាល់គ្នាត្រូវថ្វាយបង្គំ។
ហើយជាព្រះនាមរបស់ទ្រង់ហើយ
គឺព្រះនាមព្រះអង្គតែមួយគត់ដែលអ្នករាល់គ្នានឹងត្រូវស្បថ។
ភាសារបស់អ្នកអាចមានរបៀបផ្សេងទៀតក្នុងការបញ្ជាក់ថា
ព្រះអម្ចាស់កំពុងប្រាប់ប្រជាជនអ៊ីស្រាអែល កុំឱ្យថ្វាយបង្គំ ឬគោរពបម្រើព្រះដទៃ។
អ្នករាល់គ្នាត្រូវស្បថក្នុងព្រះនាមរបស់ព្រះអង្គដែរ។
ដើម្បីស្បថក្នុងនាមព្រះអម្ចាស់មានន័យថា
យកព្រះអម្ចាស់ធ្វើជាគោលឬអំណាចលើពាក្យសម្បថ។ ការពាក្យប្រៀបធៀប
«ព្រះនាមរបស់ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នានឹងស្បថ ហើយសុំឱ្យព្រះអម្ចាស់បញ្ជាក់ពីវា» ឬ
«នៅពេលអ្នករាល់គ្នាស្បថអ្នករាល់គ្នា ហើយប្រកាសព្រះនាមរបស់ព្រះអង្គ»
ដែលគង់នៅកណ្តាលអ្នករាល់គ្នា
«អ្នកដែលរស់នៅក្នុងចំណោមអ្នករាល់គ្នា»
នោះសេចក្តីកោធរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងឆួលឡើងប្រឆាំងនឹងអ្នករាល់គ្នា
លោកម៉ូសេប្រៀបធៀបសេចក្តីក្រោធរបស់ព្រះអម្ចាស់
ទៅនឹងអ្នកដែលកំពុងដុតបំផ្លាញអ្វីៗ។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបញ្ឆេះកំហឹងគឺជាការប្រៀបធៀបមួយសម្រាប់ការខឹងខ្លាំង។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងបញ្ឆេះសេចក្តីកោធរបស់ព្រះអង្គយ៉ាងខ្លាំង»
ឬ «ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងខ្ញាល់យ៉ាងខ្លាំង»
បំផ្លាញអ្នករាល់គ្នាចេញពី
«បំផ្លាញអ្នករាល់គ្នា ដូច្នេះ គ្មានសល់កន្លែងណាផ្សេងទៀតទេ»
Deuteronomy 6:16
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
អ្នករាល់គ្នាមិនត្រូវល្បងលព្រះអម្ចាស់
នៅទីនេះ« ល្បងល» មានន័យថា ប្រជែងនឹងព្រះអម្ចាស់ហើយបង្ខំឲ្យព្រះអង្គ
បង្ហាញអង្គទ្រង់ផ្ទាល់។
ម៉ាសា
នេះជាឈ្មោះទីកន្លែងមួយនៅទីរហោស្ថាន។ អ្នកបកប្រែអាចបន្ថែមលេខយោង
ដែលនិយាយថា៖« ឈ្មោះម៉ាសាថា» មានន័យថា« ការសាកល្បងល» ។
Deuteronomy 6:18
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
អ្នករាល់គ្នាប្រព្រឹត្តតាមអ្វីដែលសុចរិត ហើយត្រឹមត្រូវ នៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
ឃ្លានេះជាពាក្យបង្គាប់និងប្រទានពរ។
បើជនជាតិអ៊ីស្រាអែលស្តាប់បង្គាប់ព្រះអម្ចាស់ ពួកគេនឹងទទួលពរពីព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ធ្វើអ្វីដែលព្រះអម្ចាស់មានបន្ទូលថា ត្រឹមត្រូវនិងល្អ»
Deuteronomy 6:20
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
តើអ្វីជាបទបញ្ជា ច្បាប់ ... បានបង្គាប់ដល់អ្នករាល់គ្នា?
សំណួរនេះជាការប្រៀធៀប។ ការបកប្រែផ្សេងទៀត «តើអ្វីជាបទបញ្ជា
ច្បាប់ ...បានបង្គាប់មានអត្ថន័យយ៉ាងដូចម្តេចដល់អ្នករាល់គ្នា?» ឬ
«ហេតុអ្វីបានជាអ្នកគួរគោរពតាមបទបញ្ជា ច្បាប់ ... បានបង្គាប់ដល់អ្នករាល់គ្នា?
កូនប្រុសរបស់អ្នករាល់គ្នា
សំដៅទៅលើកូនចៅរបស់ប្រជាជនអ៊ីស្រាអែល
ដែលលោកម៉ូសេបានកំពុងថ្លែងព្រះបន្ទូលរបស់ព្រះអម្ចាស់។
ដោយព្រះហស្តដ៏ខ្លាំងអស្ចារ្យ
នៅទីនេះ «ព្រះហស្តដ៏ខ្លាំងអស្ចារ្យ» សំដៅទៅលើឫទ្ធានុភាពរបស់ព្រះអម្ចាស់។
សូមមើលពីរបៀប ដែលអ្នកបានបកប្រែនៅក្នុង ៤:៣៤។ ការបកប្រែផ្សេងទៀត «
ដោយព្រះចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ»
ព្រមទាំងដំណាក់របស់ព្រះអង្គ
នៅទីនេះពាក្យប្រៀបធៀប «ដំណាក់របស់ព្រះអង្គ»
សំដៅទៅលើប្រជារាស្ត្ររបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រមទាំងប្រជារាស្ត្ររបស់ព្រះអង្គទាំងអស់»
នៅចំពោះមុខរបស់ពួកយើង
នៅទីនេះពាក្យ «មុខ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«កន្លែងដែលយើងអាចមើលឃើញពួកគេ»
បាននាំពួកយើងចេញពីទីនោះ
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត«អាចនាំយើងចូលទៅស្រុកកាណាន»
Deuteronomy 6:24
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
នៅចំពោះព្រះនេត្រព្រះអម្ចាស់
«នៅចំពោះព្រះវត្តមានរបស់ព្រះអម្ចាស់» ឬ
«កន្លែងដែលព្រះអម្ចាស់អាចមើលឃើញយើង»
កាន់តាម
«គោរពតាម»
ពួកយើងនឹងបានរាប់ជាសុចរិត។

generated on Wed Sep 10 16:16:32 2025

នេះជាពាក្យប្រៀបធៀបមួយ។ ការបកប្រែផ្សេងទៀត«ព្រះអង្គនឹងចាត់ទុកយើងថា
ជាមនុស្សសុចរិត»

---

7 [1]នៅពេលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានាំអ្នករាល់គ្នាចូលទៅទឹកដីដែលអ្នករាល់គ្នាទៅកាន់កាប់ ព្រះអង្គបានបណ្តេញប្រជាជាតិជាច្រើនដែលនៅពីមុខអ្នករាល់គ្នា
ដូចជាជនជាតិហេត ជនជាតិគើកាស៊ី ជនជាតិអាម៉ូរី ជនជាតិកាណាន ជនជាតិពេរិស៊ីត ជនជាតិហេវី និងជនជាតិយេប៊ូស ប្រជាជាតិទាំងប្រាំពីរនេះ ធំជាង
និងមានកម្លាំងខ្លាំងជាងអ្នករាល់គ្នា។
[2]គឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ជាព្រះដែលប្រទានពួកគេមកដល់អ្នករាល់គ្នា ពេលដែលអ្នករាល់គ្នាយកជ័យជម្នះលើពួកគេហើយ នោះ
អ្នករាល់គ្នាត្រូវតែបំផ្លាញពួកគេឲ្យខ្ទេច។ អ្នករាល់គ្នាមិនត្រូវចងសម្ពន្ធមេត្រីជាមួយពួកគេ ហើយអ្នករាល់គ្នាមិនត្រូវផ្តល់សេចក្តីមេត្តាករុណាដល់ពួកគេឡើយ។
[3]អ្នករាល់គ្នាក៏មិនត្រូវរៀបការជាមួយនឹងពួកគេដែរ។ អ្នករាល់គ្នាមិនត្រូវលើកកូនស្រីៗរបស់អ្នករាល់គ្នាទៅឲ្យកូនប្រុសៗរបស់ពួកគេ
ហើយអ្នករាល់គ្នាក៏មិនត្រូវយកកូនស្រីៗរបស់ពួកគេឲ្យកូនប្រុសៗរបស់អ្នករាល់គ្នាដែរ។
[4]ដ្បិត ពួកគេនឹងបង្វែរកូនប្រុសៗរបស់អ្នករាល់គ្នាចេញពីយើងដើម្បីឲ្យពួកគេបែរទៅថ្វាយបង្គំព្រះដទៃវិញ។ នោះសេចក្តីកោធរបស់ព្រះអម្ចាស់នឹងឆួលឡើង
ទាស់ប្រឆាំងនឹងអ្នករាល់គ្នា ហើយព្រះអង្គនឹងបំផ្លាញអ្នករាល់គ្នាយ៉ាងរហ័ស។[5]នេះគឺជារបៀបដែលអ្នករាល់គ្នាត្រូវប្រព្រឹត្តជាមួយពួកគេ
គឺអ្នករាល់គ្នានឹងត្រូវផ្តួលរំលំកន្លែងថ្វាយយញ្ញបូជារបស់ពួកគេ បំបាក់សសរថ្មគ្រឹះជាចំណែកៗ ត្រូវកាត់ផ្តាច់បង្គោលរបស់ព្រះអាសេរ៉ា
ហើយត្រូវដុតកម្ទេចរូបព្រះរបស់ពួកគេដែរ។
[6]ដ្បិត អ្នករាល់គ្នាគឺជាប្រជាជាតិ ដែលត្រូវបានជ្រើសរើសជាប្រជាជាតិរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
ព្រះអង្គបានជ្រើសរើសអ្នករាល់គ្នាឲ្យធ្វើជាប្រជារាស្ត្រថ្វាយព្រះអង្គផ្ទាល់ ច្រើនជាងប្រជាជនផ្សេងៗទៀត ដែលនៅលើផែនដីនេះ។
[7]ព្រះអម្ចាស់មិនបានកំណត់សេចក្តីស្រឡាញ់របស់ព្រះអង្គមកលើអ្នករាល់គ្នា ឬជ្រើសរើសដោយព្រោះអ្នកមានគ្នាច្រើនជាងប្រជាជាតិដទៃទេ ដ្បិត
អ្នករាល់គ្នាជាប្រជាជាតិដែលមានគ្នាតិចជាងគេបង្អស់នៃប្រជាជាតិទាំងអស់[8]ប៉ុន្តែ ដោយសារព្រះអង្គស្រឡាញ់អ្នករាល់គ្នា ហើយព្រះអង្គចង់គោរពតាមសេចក្តីសម្បថ
ដែលព្រះអង្គបានស្បថចំពោះដូនតារបស់អ្នករាល់គ្នា។ នេះគឺជាហេតុផល ដែលព្រះអម្ចាស់បាននាំអ្នករាល់គ្នាចេញ ដោយព្រះហស្តដ៏ខ្លាំងអស្ចារ្យ
និងបានរំដោះអ្នករាល់គ្នាចេញពីផ្ទះនៃភាពជាទាសករ ចេញពីកណ្តាប់ដៃរបស់ព្រះចៅផារ៉ោន ជាស្តេចនៃអេស៊ីប។
[9]ដូច្នេះហើយ ចូរដឹងថា ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គគឺជាព្រះ ជាព្រះស្មោះត្រង់ ជាព្រះដែលគោរពតាមសម្ពន្ធមេត្រី
និងមានសេចក្តីសប្បុរសដល់មួយពាន់តំណរជាមួយអ្នកណាដែលស្រឡាញ់ព្រះអង្គ ហើយកាន់តាមសេចក្តីបង្គាប់របស់ព្រះអង្គ[10]ប៉ុន្តែ ព្រះអង្គសងដល់អស់អ្នកណា
ដែលស្អប់ព្រះអង្គនៅចំពោះមុខរបស់ពួកគេ ដើម្បីបំផ្លាញពួកគេ ព្រះអង្គនឹងមិនបង្អង់ឡើយ ចំពោះអ្នកណាដែលស្អប់ព្រះអង្គ ព្រះអង្គនឹងសងដល់គេនៅចំពោះមុខ។
[11]ដូច្នេះ អ្នករាល់គ្នាត្រូវកាន់តាមសេចក្តីបង្គាប់ ច្បាប់ និងបទបញ្ជាទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ ដើម្បីឲ្យអ្នករាល់គ្នាបានប្រតិបត្តិតាម។
[12]ប្រសិនបើ អ្នករាល់គ្នាស្តាប់តាមច្បាប់ទាំងនេះ ហើយកាន់តាម និងប្រតិបិត្តតាម នោះព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងរក្សាសម្ពន្ធមេត្រី
និងសេចក្តីសប្បុរសចំពោះអ្នករាល់គ្នា ដែលព្រះអង្គបានស្បថ ចំពោះដូនតារបស់អ្នករាល់គ្នា។[13]ព្រះអង្គនឹងស្រឡាញ់អ្នករាល់គ្នា ហើយនឹងប្រទានពរ
និងធ្វើឲ្យអ្នករាល់គ្នាចម្រុងចម្រើន ព្រះអង្គនឹងប្រទានពរផលផ្លែនៃអ្នករាល់គ្នា និងផលផ្លែពីដីរបស់អ្នករាល់គ្នា គឺជាស្រូវ ទឹកទំពាំងបាយជូរថ្មី និងប្រេង
ព្រមទាំងផលចម្រើននៃហ្វូងសត្វ ព្រមទាំងកូនហ្វូងចៀមរបស់អ្នករាល់គ្នា នៅក្នុងទឹកដីដែលព្រះអង្គបានស្បថ
ចំពោះដូនតារបស់អ្នករាល់គ្នាថានឹងប្រទានដល់អ្នករាល់គ្នា។
[14]អ្នករាល់គ្នានឹងបានទទួលព្រះពរថែមទៀតច្រើនជាងប្រជាជាតិផ្សេងៗ នឹងមិនមានបុរស ឬស្ត្រីអារណាក្នុងចំណោមអ្នករាល់គ្នា
ឬក្នុងចំណោមហ្វូងសត្វរបស់អ្នករាល់គ្នាគ្មានកូនឡើយ។[15]ព្រះអម្ចាស់នឹងដកយកចេញអស់ទាំងជំងឺពីអ្នករាល់គ្នា គ្មានគ្រោះកាចណាដែលកើតនៅក្នុងទឹកដីអេស៊ីប
ដែលអ្នកធ្លាប់បានដឹង នឹងកើតឡើងលើអ្នករាល់គ្នាឡើយ ប៉ុន្តែ ព្រះអង្គនឹងដាក់គ្រោះកាចនោះទាំងនេះ នៅលើអស់អ្នកដែលស្អប់អ្នករាល់គ្នាវិញ។
[16]អ្នករាល់គ្នានឹងបំផ្លាញអស់ទាំងប្រជាជាតិណាដែលព្រះអម្ចាស់ជាព្រះរបស់ឲ្យអ្នករាល់គ្នា បានប្រគល់ជ័យជម្នះដល់អ្នករាល់គ្នា ហើយភ្នែករបស់ឲ្យអ្នករាល់គ្នា
នឹងមិនត្រូវអាណិតពួកគេឡើយ។ អ្នករាល់គ្នាមិនត្រូវថ្វាយបង្គំព្រះរបស់ពួកគេទេ បើមិនដូច្នេះទេ អ្នករាល់គ្នានឹងត្រូវជាប់អន្ទាក់ជាមិនខានឡើយ។
[17]ប្រសិនបើ អ្នករាល់គ្នានិយាយទៅកាន់ដួងចិត្តរបស់អ្នករាល់គ្នាថា៖ «ប្រជាជាតិទាំងនេះមានគ្នាច្រើនជាងខ្ញុំ តើធ្វើដូចម្តេចឲ្យខ្ញុំអាចបំបែកពួកគេបាន?
[18]ចូរកុំភ័យខ្លាចពួកគេឡើយ អ្នករាល់គ្នាត្រូវនឹកចាំពីអ្វីដែលព្រះអម្ចាស់ជាព្រះរបស់ឲ្យអ្នករាល់គ្នា បានធ្វើចំពោះស្តេចផារ៉ោន
និងចំពោះជនជាតិអេស៊ីបទាំងអស់[19]ការងទុក្ខលំបាកយ៉ាងខ្លាំង ដែលអ្នករាល់គ្នាបានឃើញ ពីទីសម្គាល់ ពីការអស្ចារ្យ ពីព្រះហស្តដែលខ្លាំងពូកែ និងឫទ្ធិបារមី
ដោយព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នាបាននាំអ្នកចេញមក។ ព្រះអម្ចាស់ជាព្រះនៃឲ្យអ្នករាល់គ្នា
នឹងប្រព្រឹត្តបែបនេះចំពោះប្រជាជាតិទាំងអស់ណាដែលអ្នករាល់គ្នាខ្លាចដែរ។
[20]លើសពីទៀត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងបញ្ជូនសត្វឪម៉ាល់មកក្នុងចំណោមពួកគេ រហូតដល់អស់អ្នកណាដែលនៅសល់
ហើយដល់អ្នកដែលលាក់ខ្លួនត្រូវវិនាសចេញពីចំពោះមុខអ្នករាល់គ្នា។[21]អ្នករាល់គ្នាមិនត្រូវភ័យខ្លាចពួកគេទេ ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ព្រះអង្គគង់នៅក្នុងចំណោមអ្នករាល់គ្នា ព្រះអង្គជាព្រះដ៏ធំ ហើយជាព្រះដែលគួរស្ញែងខ្លាច។[22]ព្រះអម្ចាស់ជាព្រះនៃឲ្យអ្នករាល់គ្នា
នឹងបណ្តេញអស់ទាំងប្រជាជាតិណាដែលនៅមុខអ្នករាល់គ្នាចេញបន្តិចម្តងៗ។ អ្នករាល់គ្នានឹងមិនត្រូវបំផ្លាញពួកគេទាំងអស់នៅក្នុងពេលតែមួយបានទេ
ឬសត្វព្រៃជាច្រើនអាចនឹងចម្រើនឡើង នៅជំវិញអ្នករាល់គ្នា។
[23]ប៉ុន្តែ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងប្រទានជ័យជម្នះដល់អ្នករាល់គ្នា នៅពេលដែលអ្នករាល់គ្នាប្រឈមមុខនឹងពួកគេក្នុងចម្បាំង
ព្រះអង្គនឹងធ្វើឲ្យពួកគេភានច្រឡំយ៉ាងខ្លាំង រហូតដល់ពួកគេត្រូវបំផ្លាញ។[24]ព្រះអង្គនឹងដាក់ស្តេចរបស់ពួកគេឲ្យនៅក្រោមការគ្រប់គ្រង់របស់ឲ្យអ្នករាល់គ្នា
ហើយអ្នករាល់គ្នានឹងត្រូវធ្វើឲ្យឈ្មោះរបស់គេវិនាសចេញពីផែនដី។ គ្មានអ្នកណាអាចឈរនៅចំពោះមុខអ្នករាល់គ្នាពបានទេ រហូតដល់អ្នករាល់គ្នាបំផ្លាញពួកគេអស់។
[25]អ្នករាល់គ្នាត្រូវដុតបំផ្លាញរូបចំលាក់ដែលតំណាងព្រះរបស់ពួកគេ មិនត្រូវចង់បានប្រាក់ និងមាសដែលស្រោមរូបព្រះទាំងនោះឡើយ
និងកុំយករូបព្រះទាំងនេះជារបស់អ្នករាល់គ្នាឡើយ ពីព្រោះ ប្រសិនបើ អ្នករាល់គ្នាធ្វើដូច្នេះ អ្នករាល់គ្នានឹងអាចជាប់អន្ទាក់ដោយសារពួកគេ
ដ្បិតរបស់ទាំងនេះគឺជាទីស្អប់ខ្ពើមចំពោះព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។[26]អ្នករាល់គ្នានឹងមិនត្រូវនាំទីស្អប់ខ្ពើមទាំងឡាយណាចូលទៅក្នុងផ្ទះ
ហើយថ្វាយបង្គំរបស់ទាំងនោះឡើយ។ អ្នករាល់គ្នានឹងត្រូវស្អប់ខ្ពើមរបស់ទាំងនេះទាំងស្រុង ដ្បិត របស់ទាំងនេះគឺត្រូវបំផ្លាញ។

Deuteronomy 7:1
ព័ត៌មានទូទៅ:
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
Deuteronomy 7:2
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
ប្រទានពួកគេមកដល់អ្នករាល់គ្នា
លោកម៉ូសេនិយាយអំពីជ័យជម្នះដូចជាវត្ថុ
ដែលមនុស្សម្នាក់អាចផ្តល់ឱ្យដល់អ្នកដទៃ។ ការបកប្រែផ្សេងទៀត «
អាចឱ្យអ្នកយកជ័យជម្នះលើពួកគេ»

generated on Wed Sep 10 16:16:32 2025

អ្នករាល់គ្នាយកជ័យជម្នះលើពួកគេ
នៅទីនេះ «ពួកគេ» សំដៅទៅលើប្រជាជាតិទាំង៧ នៅក្នុង៧: ១ ។
Deuteronomy 7:4
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
ដ្បិត ពួកគេនឹង
«បើអ្នកអនុញ្ញាតឱ្យកូនរបស់អ្នករៀបការជាមួយប្រជាជនមកពីប្រជាជាតិផ្សេង
គឺប្រជាជនមកពីប្រទេសផ្សេងទៀតនឹង»
នោះសេចក្តីកោធរបស់ព្រះអម្ចាស់នឹងឆួលឡើង ទាស់ប្រឆាំងនឹងអ្នករាល់គ្នា
ម៉ូសេប្រៀបធៀបសេចក្តីក្រោធរបស់ព្រះអម្ចាស់ ទៅនឹងអ្នកដែលកំពុងបង្កាត់ភ្លើង។
នេះបញ្ជាក់ទៅលើអំណាចរបស់ព្រះអម្ចាស់
ដើម្បីបំផ្លាញអ្វីដែលធ្វើឱ្យព្រះអង្គខ្ញាល់។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងសម្តែងព្រះពិរោធនឹងអ្នករាល់គ្នា» ឬ
«ពេលនោះព្រះអម្ចាស់នឹងខ្ញាល់នឹងអ្នករាល់គ្នា យ៉ាងខ្លាំង»
ទាស់ប្រឆាំងនឹងអ្នករាល់គ្នា
ពាក្យ «អ្នករាល់គ្នា »សំដៅទៅលើជនជាតិអ៊ីស្រាអែលទាំងអស់
ហើយដូច្នេះវាជាពហុវចន:។
អ្នករាល់គ្នាត្រូវប្រព្រឹត្តជាមួយ ... គឺអ្នករាល់គ្នានឹងត្រូវផ្តួលរំលំ ... បំបាក់... ត្រូវកាត់ផ្តាច់ ... ដុត
លោកម៉ូសេកំពុងនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលទាំងអស់ នៅទីនេះ
ដូច្នេះពាក្យទាំងនេះមានលក្ខណៈជាពហុវចន:។
Deuteronomy 7:6
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
ដ្បិត អ្នករាល់គ្នាគឺជាប្រជាជាតិ ដែលត្រូវបានជ្រើសរើស
ព្រះអម្ចាស់បានជ្រើសរើសជនជាតិអ៊ីស្រាអែល
ឱ្យធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គតាមរបៀបដ៏ពិសេសមួយ
គឺដូចជាព្រះអម្ចាស់បានញែកពួកគេចេញពីប្រជាជាតិនានា។
ដែលនៅលើផែនដីនេះ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ដែលរស់នៅលើផែនដី»
Deuteronomy 7:7
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
មិនបានកំណត់សេចក្តីស្រឡាញ់របស់ព្រះអង្គមកលើអ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«មិនបានស្រឡាញ់អ្នករាល់គ្នា ជាងព្រះអង្គស្រឡាញ់អ្នកដទៃ»
ដោយព្រះហស្តដ៏ខ្លាំងអស្ចារ្យ
នៅទីនេះ «ព្រះហស្តដ៏ខ្លាំងអស្ចារ្យ »សំដៅទៅលើឫទ្ធានុភាពរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ដោយព្រះហស្តដ៏ខ្លាំងអស្ចារ្យរបស់ព្រះអង្គ»។
ពាក្យទាំងនេះមាននៅក្នុង ៤:៣៤។
បានរំដោះអ្នករាល់គ្នាចេញពីផ្ទះនៃភាពជាទាសករ
លោកម៉ូសេនិយាយអំពីព្រះអម្ចាស់ជួយសង្គ្រោះប្រជាជនអ៊ីស្រាអែលឱ្យរួចផុតពីភាពជាទាសករ
ដូចជាព្រះអម្ចាស់បានបង់ប្រាក់ទៅម្ចាស់ទាសករផ្ទាល់ដែរ។ ការបកប្រែផ្សេងទៀត
«បានជួយសង្គ្រោះអ្នកពីទាសភាព»
ផ្ទះនៃភាពជាទាសករ
នៅទីនេះពាក្យប្រៀបធៀប «ផ្ទះទាសភាព» សំដៅទៅលើប្រទេសអេស៊ីបជាកន្លែង
ដែលប្រជាជនអ៊ីស្រាអែលធ្លាប់ធ្វើជាទាសករ។ ការបកប្រែផ្សេងទៀត
«ចេញពីកន្លែងដែលអ្នកធ្លាប់ធ្វើជាទាសករ»។ បកប្រែពាក្យទាំងនេះដូចនៅក្នុង ៦:
១០ ។
ចេញពីកណ្តាប់ដៃរបស់ព្រះចៅផារ៉ោន
នៅទីនេះ «ដៃ» មានន័យថា «ការគ្រប់គ្រង»។ ការបកប្រែផ្សេងទៀត
«ការគ្រប់គ្រងរបស់ព្រះចៅផារ៉ោន»
Deuteronomy 7:9
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
មួយពាន់តំណរ
«សម្រាប់ ១០០០ជំនាន់»
សងដល់អស់អ្នកណា ដែលស្អប់ព្រះអង្គនៅចំពោះមុខរបស់ពួកគេ
ឃ្លានេះមានន័យថា «សងពួកគេយ៉ាងឆាប់រហ័សជាសាធារណៈ ដូច្នេះ ពួកគេដឹងថា
ព្រះជាម្ចាស់បានដាក់ទោសពួកគេ»។
ព្រះអង្គនឹងមិនបង្អង់ឡើយ ចំពោះអ្នកណាដែលស្អប់ព្រះអង្គ
«ព្រះអម្ចាស់នឹងដាក់ទោសយ៉ាងធ្ងន់ធ្ងរ ដល់អស់អ្នកណាដែលស្អប់ព្រះអង្គ»
Deuteronomy 7:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ប្រជាជនអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
គាត់និយាយដូចជាជនជាតិអ៊ីស្រាអែលជាមនុស្សម្នាក់ នៅក្នុងខ១២
ហើយចំពោះពួកគេទាំងអស់ជាក្រុម នៅក្នុងខ១៣។
និងធ្វើឲ្យអ្នករាល់គ្នាចម្រុងចម្រើន
«និងបង្កើនចំនួនប្រជាជនរបស់អ្នករាល់គ្នា»
ផលផ្លែនៃអ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទសម្រាប់ «កូនៗរបស់អ្នករាល់គ្នា»។
ផលផ្លែពីដីរបស់អ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទសម្រាប់ «ផលដំណាំរបស់អ្នករាល់គ្នា»
ផលចម្រើននៃហ្វូងសត្វ ព្រមទាំងកូនហ្វូងចៀមរបស់អ្នករាល់គ្នា
«កូនហ្វូងចៀមរបស់អ្នករាល់គ្នា ដូច្នេះ ពួកវានឹងត្រឡប់ជាមានចំនួនច្រើន»
Deuteronomy 7:14
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
អ្នករាល់គ្នានឹងបានទទួលព្រះពរថែមទៀតច្រើនជាងប្រជាជាតិផ្សេងៗ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«យើងនឹងឱ្យពរអ្នករាល់គ្នា ច្រើនជាងយើងឱ្យពរដល់មនុស្សផ្សេងទៀត»
នឹងមិនមានបុរស ឬស្ត្រីអារណាក្នុងចំណោមអ្នករាល់គ្នា
ឬក្នុងចំណោមហ្វូងសត្វរបស់អ្នករាល់គ្នាគ្មានកូនឡើយ។
លោកម៉ូសេប្រើពាក្យអវិជ្ជមានដើម្បីបញ្ជាក់ថា ពួកគេទាំងអស់នឹងអាចមានកូន។
អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«អ្នកទាំងអស់គ្នានឹងអាចមានកូន
ហើយសត្វរបស់អ្នកនឹងអាចបង្កើតកូនឡើងវិញបាន»
ចំណោមអ្នករាល់គ្នា ... ក្នុងចំណោមហ្វូងសត្វរបស់អ្នករាល់គ្នា
ពាក្យ «អ្នក» និង «របស់អ្នក» ជាពហុវចន:នៅទីនេះ។
ដកយកចេញអស់ទាំងជំងឺពីអ្នករាល់គ្នា
«ធ្វើឱ្យប្រាកដថា អ្នកមិនឈឺ» ឬ «ធ្វើឱ្យអ្នកមានសុខភាពល្អពេញទី»
គ្មានគ្រោះកាចណាដែលកើតនៅក្នុង ... នឹងកើតឡើងលើអ្នករាល់គ្នាឡើយ ប៉ុន្តែ
ព្រះអង្គនឹងដាក់គ្រោះកាចនោះទាំងនេះ នៅលើអស់អ្នកដែលស្អប់អ្នករាល់គ្នាវិញ។
លោកម៉ូសេនិយាយដូចជាជំងឺជាវត្ថុធ្ងន់មួយ ដែលព្រះអម្ចាស់នឹងដាក់លើមនុស្ស។
ការបកប្រែផ្សេងទៀត «ព្រះអង្គនឹងមិនធ្វើឱ្យអ្នករាល់គ្នាឈឺ
ដោយជំងឺអាក្រក់ណាមួយទេ ... ប៉ុន្តែ ព្រះអង្គនឹងធ្វើឱ្យសត្រូវរបស់អ្នករាល់គ្នាឈឺ»
Deuteronomy 7:16
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
អ្នករាល់គ្នានឹងបំផ្លាញអស់ទាំងប្រជាជាតិ
«យើងបញ្ជាឱ្យអ្នកបំផ្លាញក្រុមមនុស្សទាំងអស់»
ហើយភ្នែករបស់ឲ្យអ្នករាល់គ្នា នឹងមិនត្រូវអាណិតពួកគេឡើយ។
នេះជាបទបញ្ជា។ លោកម៉ូសេនិយាយដូចជាភ្នែកមើលឃើញ។
ការបកប្រែផ្សេងទៀត «កុំអនុញ្ញាតឱ្យអ្វីដែលអ្នកឃើញធ្វើឱ្យអ្នកអាណិតពួកគេ» ឬ
«កុំអាណិតពួកគេព្រោះអ្នកឃើញថា អ្វីដែលអ្នកកំពុងធ្វើគឺកំពុងធ្វើ
ឱ្យពួកគេឈឺចាប់»
អ្នករាល់គ្នាមិនត្រូវថ្វាយបង្គំព្រះ
«មិនត្រូវថ្វាយបង្គំ»
នឹងត្រូវជាប់អន្ទាក់ជាមិនខានឡើយ។
បើប្រជាជនថ្វាយបង្គំព្រះដទៃ
ពួកគេនឹងដូចជាសត្វដែលជាប់អន្ទាក់របស់អ្នកប្រមាញ់
ហើយពួកគេមិនអាចរត់គេចបានឡើយ។
Deuteronomy 7:17

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
ប្រសិនបើ អ្នករាល់គ្នានិយាយទៅកាន់ដួងចិត្តរបស់អ្នករាល់គ្នាថា ... ចូរកុំភ័យខ្លាចពួកគេឡើយ
ប្រជាជនមិនគួរភ័យខ្លាចទេ ទោះបីជាពួកគេកត់សម្គាល់ថា
ប្រជាជាតិនានាខ្លាំងជាងពួកគេក៏ដោយ។ ការបកប្រែផ្សេងទៀត
«ទោះបីអ្នករាល់គ្នានិយាយទៅកាន់ដួងចិត្តរបស់អ្នករាល់គ្នា»
និយាយទៅកាន់ដួងចិត្តរបស់អ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «សូមគិត»
តើធ្វើដូចម្តេចឲ្យខ្ញុំអាចបំបែកពួកគេបាន?
លោកម៉ូសេប្រើសំណួរមួយដើម្បីបញ្ជាក់ថា
ប្រជាជនអាចមានអារម្មណ៍ភ័យខ្លាចប្រជាជាតិដទៃទៀត។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនអាចយកជ័យជម្នះលើពួកគេបានទេ»
អ្នករាល់គ្នាត្រូវនឹកចាំ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែចងចាំ»
ដែលភ្នែកអ្នករាល់គ្នាបានឃើញ
នៅទីនេះ «ភ្នែក» សំដៅទៅលើអ្វីដែលប្រជាជនបានឃើញ។ ការបកប្រែផ្សេងទៀត
«ដែលអ្នកបានឃើញ»
ពីព្រះហស្តដែលខ្លាំងពូកែ និងឫទ្ធិបារមី
នៅទីនេះ «ព្រះហស្តដែលខ្លាំងពូកែ» និង «ឫទ្ធិបារមី»
ជារឿងប្រៀបប្រដូចសម្រាប់អំណាចរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«និងអំណាចដ៏ខ្លាំងអស្ចារ្យ» ។ បកប្រែដូចនៅក្នុង ៤:៣៤។
Deuteronomy 7:20
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
លើសពីទៀត
«ហើយផងដែរ»
បញ្ជូនសត្វឪម៉ាល់
អាចមានន័យថា ១) ព្រះជាម្ចាស់នឹងបញ្ជូនសត្វល្អិតដែលទិចមនុស្ស
ហើយបណ្តាលឱ្យមនុស្សឈឺចុកចាប់ ឬ ២) ព្រះជាម្ចាស់នឹងធ្វើឱ្យមនុស្សភ័យខ្លាច
និងរត់គេចចេញទៅឆ្ងាយ។
ត្រូវវិនាសចេញពីចំពោះមុខអ្នករាល់គ្នា។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ត្រូវស្លាប់
ដូច្នេះអ្នករាល់គ្នានឹងមិនឃើញពួកគេទៀតទេ»
អ្នករាល់គ្នាមិនត្រូវ
«មិនដែល»
ព្រះអង្គជាព្រះដ៏ធំ ហើយជាព្រះដែលគួរស្ញែងខ្លាច។
«ព្រះជាម្ចាស់ដ៏ធំ និងអស្ចារ្យ» ឬ
«ព្រះជាម្ចាស់ដ៏អស្ចារ្យដែលធ្វើឲ្យប្រជាជនភ័យខ្លាច»
បន្តិចម្តងៗ
«យឺតៗ»
Deuteronomy 7:23
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជនជាតិអ៊ីស្រាអែលជាមនុស្សតែម្នាក់។
ប្រទានជ័យជម្នះដល់អ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ជួយឱ្យអ្នកមានជ័យជម្នះ»
ជ័យជម្នះដល់អ្នករាល់គ្នា
«ជ័យជម្នះលើកងទ័ពពីប្រជាជាតិដទៃទៀត»
ព្រះអង្គនឹងធ្វើឲ្យពួកគេភាន់ច្រឡំយ៉ាងខ្លាំង
«ព្រះអង្គនឹងធ្វើឱ្យពួកគេភាន់ច្រឡំ ដូច្នេះ ពួកគេមិនអាចគិតបានច្បាស់»
រហូតដល់ពួកគេត្រូវបំផ្លាញ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«រហូតដល់អ្នកបានបំផ្លាញពួកគេ»
អ្នករាល់គ្នានឹងត្រូវធ្វើឲ្យឈ្មោះរបស់គេវិនាសចេញពីផែនដី។
ប្រជាជនជាតិអ៊ីស្រាអែលនឹងបំផ្លាញប្រជាជនទាំងអស់ ពីជាតិសាសន៍ទាំងនោះ
ហើយនៅថ្ងៃអនាគតគ្មាននរណាម្នាក់នឹកចាំពួកគេទេ។
អាចឈរនៅចំពោះមុខអ្នករាល់គ្នា
«ឈរប្រឆាំងនឹងអ្នករាល់គ្នា» ឬ «ការពារខ្លួនពួកគេប្រឆាំងនឹងអ្នករាល់គ្នា»
Deuteronomy 7:25
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ប្រជាជនអ៊ីស្រាអែល អំពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
នៅក្នុងខ២៥ គាត់និយាយទៅកាន់ក្រុមជាក្រុម ដូច្នេះទម្រង់ «អ្នក» ជាពហុវចន:
ប៉ុន្តែ នៅក្នុងខ២៦ គាត់និយាយដូចជាជនជាតិអ៊ីស្រាអែល ជាមនុស្សតែម្នាក់ ដូច្នេះ
ទម្រង់មានលក្ខណៈឯកវចន:។
អ្នករាល់គ្នាត្រូវដុត
នេះជាការបង្គាប់។
ព្រះរបស់ពួកគេ
«ព្រះនៃប្រជាជាតិដទៃទៀត»
មិនត្រូវចង់បានប្រាក់ ...ជាប់អន្ទាក់ដោយសារពួកគេ
ពាក្យទាំងនេះបន្ថែមការណែនាំដើម្បីដុតរូបព្រះ។
អ្នករាល់គ្នានឹងអាចជាប់អន្ទាក់ដោយសារពួកគេ
សូម្បីតែការយកមាស ឬប្រាក់ទៅថ្វាយរូបព្រះក្លែងក្លាយ
អាចធ្វើឱ្យប្រជាជនចាប់ផ្តើមថ្វាយបង្គំពួកគេ។ តាមរយៈការធ្វើបែបនេះ
ពួកគេនឹងក្លាយជាសត្វដែលជាប់អន្ទាក់។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «វានឹងក្លាយជាអន្ទាក់សម្រាប់អ្នក»
ដ្បិតរបស់ទាំងនេះគឺជាទីស្អប់ខ្ពើមចំពោះព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
ពាក្យទាំងនេះប្រាប់ពីមូលហេតុ ដែលព្រះអម្ចាស់ចង់ឱ្យប្រជាជនដុតរូបព្រះ។
«ធ្វើដូចនេះ ព្រោះព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាស្អប់ខ្លាំងណាស់»
អ្នករាល់គ្នានឹងត្រូវស្អប់ខ្ពើមរបស់ទាំងនេះទាំងស្រុង
ពាក្យ «ស្អប់ខ្ពើម» និង «ទាំងស្រុង»
មានន័យជារួមដូចគ្នាហើយបញ្ជាក់ទៅលើកម្លាំងនៃការស្អប់។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នានឹងស្អប់ការនេះទាំងស្រុង»
ដ្បិត របស់ទាំងនេះគឺត្រូវបំផ្លាញ។
ព្រះអម្ចាស់ដាក់បណ្តាសាអ៊ីម៉្យាង ហើយសន្យាថានឹងបំផ្លាញវាចោល។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដ្បិត
ព្រះអម្ចាស់បានញែកវាទុកដោយឡែកសម្រាប់ការបំផ្លាញ»

---

8 [1]អ្នករាល់គ្នាត្រូវតែកាន់តាមគ្រប់ទាំងសេចក្តីបង្គាប់ ដែលខ្ញុំប្រគល់ឲ្យអ្នករាល់គ្នានៅថ្ងៃនេះ ធ្វើដូច្នេះអ្នករាល់គ្នានឹងមានជីវិត និងមានភាពចម្រុងចម្រើន ហើយអាចចូល
ហើយកាន់កាប់ទឹកដីដែលព្រះអម្ចាស់បានស្បថចំពោះដូនតារបស់អ្នករាល់គ្នា។[2]អ្នករាល់គ្នាត្រូវរំលឹកខ្លួនឯង ពីគ្រប់ទាំងផ្លូវដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
បានណែនាំអស់រយៈពេលសែសិបឆ្នាំ នៅក្នុងទីរហោស្ថាន ដើម្បីបន្ទាបចិត្តរបស់អ្នករាល់គ្នា ហើយព្រះអង្គចង់ល្បងលអ្នករាល់គ្នា ដើម្បីឲ្យដឹងថាអ្វីដែលមាននៅក្នុងចិត្ត
ហើយឲ្យដឹងថាតើអ្នករាល់គ្នាកាន់តាមសេចក្តីបង្គាប់របស់ព្រះអង្គបាន ឬមិនបាន។
[3]ព្រះអង្គបានបន្ទាបចិត្តរបស់អ្នករាល់គ្នា ហើយធ្វើឲ្យអ្នករាល់គ្នាស្រែកឃ្លាន ព្រមទាំងបានចិញ្ចឹមអ្នករាល់គ្នាដោយនំម៉ាណា ជានំដែលអ្នករាល់គ្នាមិនបានស្គាល់
និងជានំដែលដូនតារបស់អ្នករាល់គ្នាមិនបានស្គាល់ដែរ។ ព្រះអង្គបានប្រទាននំនេះ ដើម្បីឲ្យអ្នករាល់គ្នាដឹងថាមនុស្សមិនមែនរស់ដោយសារតែនំប៉័ងប៉ុណ្ណោះទេ
គឺរស់ដោយសារព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះអម្ចាស់មកដែរ។
[4]សម្លៀកបំពាក់របស់អ្នករាល់គ្នាមិនបានសឹក និងបាត់ចេញពីអ្នករាល់គ្នាទេ ហើយជើងរបស់អ្នករាល់គ្នាមិនបានហើមដែរ ក្នុងរយៈពេលសែសិបឆ្នាំនោះ។
[5]អ្នករាល់គ្នានឹងនឹកគិតក្នុងចិត្តរបស់អ្នករាល់គ្នាថាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានអប់រំអ្នករាល់គ្នាដូចជាឪពុកអប់រំកូន។
[6]អ្នករាល់គ្នាត្រូវកាន់តាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ធ្វើដូច្នេះ អ្នករាល់គ្នាអាចនឹងដើរនៅក្នុងផ្លូវរបស់ព្រះអង្គ ហើយកោតខ្លាចព្រះអង្គ។
[7]ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា គឺនាំអ្នកចូលទៅក្នុងទឹកដីល្អ ជាទឹកដីសម្បូរស្ទឹង អណ្តូង និងប្រភពទឹក ហូរចេញមកចាក់ទៅជ្រលងភ្នំ
និងចំណោមភ្នំ[8]ជាទឹកដីនៃស្រូវសាលី និងស្រូវ ហើយស្រាទំពាំងបាយជូរ ព្រមទាំងផ្លែឧទុម្ពរ និងផ្លែទទឹម ជាទឹកដីនៃដើមអូលីវ និងទឹកឃ្មុំ។

generated on Wed Sep 10 16:16:32 2025

[9]ជាទឹកដីដែលអ្នករាល់គ្នានឹងបរិភោគនំបុ័ង ដោយគ្មានការខ្វះខាត់ឡើយ ហើយជាកន្លែងដែលអ្នករាល់គ្នានឹងមិនខ្វះខាត់អ្វីឡើយ
ជាទឹកដីដែលសម្បូរដោយថ្មដែលធ្វើចេញពីដែក និងចេញពីភ្នំដែលអ្នករាល់គ្នាអាចជីករកបាន។[10]អ្នករាល់គ្នានឹងបរិភោគ ហើយនឹងបានឆ្អែត
ហើយអ្នករាល់គ្នានឹងថ្វាយព្រះពរព្រះអម្ចាស់ជាព្រះរបស់សម្រាប់ទឹកដីល្អដែលព្រះអង្គបានប្រទានឲ្យអ្នករាល់គ្នា។
[11]ត្រូវប្រុងប្រយ័ត្នក្រែងអ្នករាល់គ្នាភ្លេចព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា និងមិនបានកាន់តាមសេចក្ដីបង្គាប់របស់ព្រះអង្គ ដូចជាវិន័យ និងច្បាប់របស់ព្រះអង្គ
ដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ[12]ធ្វើដូច្នេះ នៅពេលអ្នករាល់គ្នាបរិភោគឆ្អែតហើយ និងនៅនៅពេលអ្នករាល់គ្នាសង់ផ្ទះល្អ សម្រាប់រស់នៅ
នោះចិត្តរបស់អ្នករាល់គ្នានឹងត្រូវលើកឡើង។
[13]ត្រូវប្រុងប្រយ័ត្ន នៅពេលហ្វូងគោ និងហ្វូងសត្វរបស់អ្នករាល់គ្នារីកចម្រើនឡើង ហើយនៅពេលប្រាក់ និងមាសរបស់អ្នករាល់គ្នាកើនឡើង
ព្រមទាំងអ្វីៗដែលអ្នករាល់គ្នាមានបានចម្រើនឡើង[14]បន្ទាបចិត្តរបស់អ្នកនឹងអាចលើកឡើង ហើយអ្នករាល់គ្នានឹងភ្លេចព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា
ដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីប ចេញពីផ្ទះនៃភាពជាទាសករ។
[15]មិនត្រូវភ្លេចព្រះអង្គ ជាព្រះដែលបាននាំអ្នករាល់គ្នាដើរឆ្លងកាត់ទីរហោស្ថានដ៏ធំ និងគួរឲ្យស្ញែងខ្លាច ជាកន្លែងដែលមានពស់ភ្លើង និងខ្យាដំរី ព្រមទាំងដីហួតហែង
ជាកន្លែងគ្មានទឹក ជាព្រះដែលបាននាំឲ្យអ្នករាល់គ្នាទឹកចេញពីផ្នាំងថ្មដ៏រឹងបំផុត។[16]ព្រះអង្គបានចម្អែតអ្នករាល់គ្នានៅក្នុងទីរហោស្ថាន ដោយនំម៉ាណា
ដែលដូនតារបស់អ្នករាល់គ្នាមិនធ្លាប់បានស្គាល់ ធ្វើដូច្នេះ ព្រះអង្គអាចនឹងបន្ទាបចិត្តរបស់អ្នករាល់គ្នា ហើយល្បងលអ្នករាល់គ្នា
ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្ដីល្អនៅចុងក្រោយ[17]ប៉ុន្តែ អ្នករាល់គ្នាអាចនឹងនិយាយក្នុងចិត្តថា ខ្ញុំមានទ្រព្យសម្បត្តិទាំងនេះ ដោយសារកម្លាំង និងឥទ្ធិឫទ្ធិដៃរបស់ខ្ញុំ។
[18]ប៉ុន្តែ អ្នករាល់គ្នាត្រូវរំលឹកខ្លួនឯងថាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដ្បិត គឺព្រះអង្គហើយដែលប្រទានកម្លាំងឲ្យអ្នករាល់គ្នា បានទទួលទ្រព្យសម្បត្តិ
ដើម្បីឲ្យដឹងថាព្រះអង្គបានបង្កើតសម្ពន្ធមេត្រីរបស់ព្រះអង្គដែលបានស្បថចំពោះដូនតារបស់អ្នករាល់គ្នា ដូចនៅថ្ងៃនេះ។[19]ការនេះនឹងកើតឡើងយ៉ាងដូច្នេះ
បើសិនអ្នករាល់គ្នាបំភ្លេចព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ហើយដើរតាមព្រះដទៃ ព្រមទាំងថ្វាយបង្គំ ព្រមទាំងគោរពដល់ព្រះទាំងនោះ
ខ្ញុំធ្វើជាសាក្សីប្រឆាំងទាស់នឹងអ្នករាល់គ្នានៅថ្ងៃនេះថា អ្នករាល់គ្នានឹងត្រូវវិនាសជាមិនខាន។
[20]គឺដូចជាប្រជាជាតិដែលព្រះអម្ចាស់បានកំពុងធ្វើឲ្យពួកគេវិនាសនៅចំពោះមុខអ្នករាល់គ្នា ដូច្នេះ អ្នករាល់គ្នានឹងវិនាស
ពីព្រោះអ្នករាល់គ្នាមិនបានស្តាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។

Deuteronomy 8:1
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សម្នាក់។
អ្នករាល់គ្នាត្រូវតែកាន់តាម ... អ្នករាល់គ្នានឹងមានជីវិត និងមានភាពចម្រុងចម្រើន ហើយអាចចូល
ហើយកាន់កាប់ ... ដូនតារបស់អ្នករាល់គ្នា។
រាល់ការកើតមានឡើងនៃពាក្យ «អ្នក» និង «របស់អ្នក» ជាពហុវចនៈ។
អ្នករាល់គ្នាត្រូវរំលឹកខ្លួនឯង
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែចងចាំ»
សែសិបឆ្នាំ
«៤០ ឆ្នាំ»
បន្ទាបចិត្តរបស់អ្នករាល់គ្នា
«ព្រះអង្គអាចបង្ហាញថា
អ្នករាល់គ្នាជាមនុស្សខ្សោយនិងពោរពេញដោយអំពើបាបយ៉ាងណា»
ឲ្យដឹងថា
«បើកសម្តែង» ឬ «បង្ហាញ»
អ្វីដែលមាននៅក្នុងចិត្ត
ចិត្ត គឺជានិមិត្តរូបនៃចរិតរបស់មនុស្សម្នាក់។ ការបកប្រែផ្សេងទៀត
«អ្នកជាមនុស្សប្រភេទណា» ឬ «អ្នកនឹងមានអាកប្បកិរិយាយ៉ាងណា»
Deuteronomy 8:3
ព័ត៌មានទូទៅ៖
ម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
គាត់បន្តរម្លឹកពួកគេពីអ្វីដែលពួកគេគួរតែ «ចងចាំ»
ព្រះអង្គបានបន្ទាបចិត្តរបស់អ្នករាល់គ្នា
«ព្រះអម្ចាស់បានបង្ហាញអ្នកពីភាពទន់ខ្សោយ និងអំពើបាបរបស់អ្នករាល់គ្នា»។
សូមមើលពីរបៀបដែល «ព្រះអង្គអាចបន្ទាបខ្លួនអ្នករាល់គ្នា»
ត្រូវបានបកប្រែនៅក្នុង ៨:១។
បានចិញ្ចឹមអ្នករាល់គ្នាដោយនំម៉ាណា
«បានប្រទាននំម៉ាណាឱ្យអ្នកបរិភោគ»
មនុស្សមិនមែនរស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ
នៅទីនេះ «នំបុ័ង» តំណាងឱ្យអាហារទាំងអស់។ ការបកប្រែផ្សេងទៀត
«មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ ដូច្នេះ ពួកគេអាចរស់នៅបាន»
មនុស្សមិនមែនរស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ
គឺរស់ដោយសារព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះអម្ចាស់មកដែរ។
នៅទីនេះ «ព្រះឱស្ឋរបស់ព្រះអម្ចាស់» ជាពាក្យប្រៀបធៀបសម្រាប់ពាក្យ
ដែលព្រះអម្ចាស់មានព្រះបន្ទូល។ ការបកប្រែផ្សេងទៀត
«ប្រជាជនត្រូវតែគោរពតាមបង្គាប់របស់ព្រះអម្ចាស់ ដូច្នេះ ពួកគេអាចរស់នៅបាន»
ឬ «ប្រជាជនត្រូវតែធ្វើអ្វីដែលព្រះអម្ចាស់បានប្រាប់ពួកគេឲ្យធ្វើ
ដើម្បីពួកគេអាចរស់នៅបាន»
Deuteronomy 8:4
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
សម្លៀកបំពាក់របស់អ្នករាល់គ្នា ...សែសិបឆ្នាំ
នេះជារបស់ប្រើប្រាស់ចុងក្រោយ ដែលពួកគេគួរតែ «ចងចាំ» (៨:១)។
សែសិបឆ្នាំ
«៤០ឆ្នាំ»
អ្នករាល់គ្នានឹងនឹកគិត ... អ្នករាល់គ្នាត្រូវកាន់តាមសេច... ដើរនៅក្នុងផ្លូវរបស់ព្រះអង្គ
ហើយកោតខ្លាចព្រះអង្គ។
នេះជាបញ្ជីបន្តនៃពាក្យបង្គាប់ ដែលចាប់ផ្តើមនៅ ៨: ១។
អ្នករាល់គ្នានឹងនឹកគិតក្នុងចិត្តរបស់អ្នករាល់គ្នា
នៅទីនេះពាក្យប្រៀបធៀប «ចិត្ត» តំណាងឱ្យគំនិត
និងការយល់ដឹងរបស់មនុស្សម្នាក់។ ការបកប្រែផ្សេងទៀត «អ្នកនឹងយល់»
Deuteronomy 8:7
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
ជាទឹកដី
«ទឹកដីមាន» ឬ «ទឹកដីដែលមាន»
Deuteronomy 8:9
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
ទឹកដីដែលអ្នករាល់គ្នានឹងបរិភោគនំបុ័ង ដោយគ្មានការខ្វះខាត់ឡើយ
អំណាចនេះអាចបកប្រែជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ទឹកដីមួយដែលនឹងមានស្បៀងអាហារច្រើនសម្រាប់អ្នករាល់គ្នា»
ជាកន្លែងដែលអ្នករាល់គ្នានឹងមិនខ្វះខាត់អ្វីឡើយ
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«កន្លែងដែលអ្នករាល់គ្នានឹងមានអ្វីគ្រប់យ៉ាង ដែលអ្នកត្រូវការ»
ដោយថ្មដែលធ្វើចេញពីដែក
ដុំថ្មនេះពេញទៅដោយរ៉ែដែក។ ដែកជាលោហៈរឹង ដែលមានប្រយោជន៍សម្រាប់ដាវ
និងនង្គ័ល។
អាចជីករកបាន
«ទង់ដែង»។ ទង់ដែងជាលោហៈទន់
ដែលមានប្រយោជន៍សម្រាប់ផលិតឧបករណ៍ប្រើប្រាស់ក្នុងផ្ទះបាយ។
អ្នករាល់គ្នានឹងបរិភោគ ហើយនឹងបានឆ្អែត

generated on Wed Sep 10 16:16:32 2025

«អ្នករាល់គ្នានឹងមានអាហារគ្រប់គ្រាន់ សម្រាប់បរិភោគរហូតដល់អ្នកឆ្អែត»
ថ្វាយព្រះពរព្រះអម្ចាស់
«អ្នកនឹងសរសើរព្រះជាម្ចាស់» ឬ «អ្នកនឹងថ្វាយការព្រះអរគុណ»
Deuteronomy 8:11
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
មិនបានកាន់តាមសេចក្តីបង្គាប់របស់ព្រះអង្គ
«មិនត្រូវឈប់ធ្វើតាមសេចក្តីបង្គាប់របស់ព្រះអង្គ» ឬ
«បន្តធ្វើតាមសេចក្តីបង្គាប់របស់ព្រះអង្គ»
នៅពេលអ្នករាល់គ្នាបរិភោគឆ្អែតហើយ
«នៅពេលអ្នកមានអាហារគ្រប់គ្រាន់បរិភោគ»
នោះចិត្តរបស់អ្នករាល់គ្នានឹងត្រូវលើកឡើង។
នៅទីនេះ «ចិត្ត» តំណាងឱ្យមនុស្សខាងក្នុង។
ការក្លាយជាមនុស្សអំនួតហើយមិនស្តាប់តាមព្រះអម្ចាស់
ត្រូវបាននិយាយដូចជាចិត្តរបស់មនុស្សនោះ ត្រូវបានលើកឡើង។
ការបកប្រែផ្សេងទៀត «
អ្នកនឹងក្លាយជាមនុស្សអំនួតហើយលែងគោរពតាមព្រះអម្ចាស់ទៀតហើយ»
Deuteronomy 8:13
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
ហ្វូងគោ និងហ្វូងសត្វរបស់អ្នករាល់គ្នា
«ហ្វូងសត្វ និងហ្វូងចៀម និងពពែរបស់អ្នករាល់គ្នា»
រីកចម្រើន
«ការកើនឡើងនៃចំនួន» ឬ «ក្លាយជាមានចំនួនច្រើន»
ព្រមទាំងអ្វីៗដែលអ្នករាល់គ្នាមានបានចម្រើនឡើង
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាមានរបស់ជាច្រើនទៀត» ឬ
«អ្នករាល់គ្នាមានទ្រព្យសម្បត្តិជាច្រើនទៀត»
ចិត្តរបស់អ្នកនឹងអាចលើកឡើង
នៅទីនេះ «ចិត្ត» តំណាងឱ្យមនុស្សខាងក្នុង។ ដើម្បីក្លាយជាមនុស្សអំនួត
ហើយមិនស្តាប់តាមព្រះអម្ចាស់ ត្រូវបាននិយាយដូចជាចិត្តរបស់មនុស្ស
នោះត្រូវបានលើកឡើង។ សូមមើលពីរបៀបបប្រែឃ្លាស្រដៀងគ្នានៅក្នុង ៨:១១ ។
ការបកប្រែផ្សេងទៀត «អ្នកក្លាយជាមនុស្សអំនួត
ហើយលែងគោរពតាមព្រះអម្ចាស់ទៀតហើយ»
ដែលបាននាំអ្នករាល់គ្នាចេញពី
លោកម៉ូសេចាប់ផ្តើមរម្លឹកជនជាតិអ៊ីស្រាអែលអំពីអ្វី
ដែលពួកគេដឹងអំពីព្រះអម្ចាស់។
ចេញពីផ្ទះនៃភាពជាទាសករ។
នេះជាពាក្យប្រៀបធៀបសម្រាប់ពេល ដែលពួកគេជាទាសកររនៅអេស៊ីប។
ការបកប្រែផ្សេងទៀត «ចេញពីកន្លែងដែលអ្នកធ្លាប់ជាទាសករ»
Deuteronomy 8:15
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
ជាព្រះដែលបាននាំអ្នករាល់គ្នា... នៅចុងក្រោយ
ម៉ូសេបន្តរម្លឹកជនជាតិអ៊ីស្រាអែលអំពីអ្វី ដែលពួកគេដឹងអំពីព្រះអម្ចាស់
ជាព្រះដែលបាននាំ ... ជាព្រះដែលបាននាំ ... ព្រះអង្គបានចម្អែត
«ព្រះអម្ចាស់ដែលបាននាំ ... ព្រះអម្ចាស់ ដែលបាននាំ ... ព្រះអម្ចាស់បានចិញ្ចឹម»
ពស់ភ្លើង
«ពស់មានពិស»
ដីហួតហែង
ឃ្លានេះពិពណ៌នាអំពីដីថា
ស្រេកទឹកដូចជាមនុស្សស្រេកទឹកនៅពេលគាត់ត្រូវការទឹក។ ការបកប្រែផ្សេងទៀត
«ដីស្ងួត»
ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្តីល្អ
«ដើម្បីជួយអ្នករាល់គ្នា» ឬ «ព្រោះ វាល្អសម្រាប់អ្នករាល់គ្នា»
ប៉ុន្តែ អ្នករាល់គ្នាអាចនឹងនិយាយក្នុងចិត្ត
នេះជារឿងទីបីដែលមនុស្សអាចធ្វើបាន នៅពេលដែលចិត្តរបស់ពួកគេ
«បានក្រោកឡើង» ហើយពួកគេ «ភ្លេចព្រះអម្ចាស់»
ខ្ញុំមានទ្រព្យសម្បត្តិទាំងនេះ ដោយសារកម្លាំង និងឥទ្ធិឫទ្ធិដៃរបស់ខ្ញុំ។
ទៅទីនេះ «កម្លាំង» សំដៅទៅលើអំណាច ឬសមត្ថភាពរបស់មនុស្ស។
ការបកប្រែផ្សេងទៀត «ខ្ញុំទទួលបានទ្រព្យសម្បត្តិនេះ ពីព្រោះ
ខ្ញុំខ្លាំងនិងមានអំណាច» ឬ «ខ្ញុំបានទទួលរបស់ទាំងអស់នេះ
ដោយអំណាចនិងសមត្ថភាពផ្ទាល់ខ្លួន»
Deuteronomy 8:18
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
ប៉ុន្តែ អ្នករាល់គ្នាត្រូវរំលឹកខ្លួនឯង
នេះជាឃ្លាបង្គាប់។ ការបកប្រែផ្សេងទៀត «តែត្រូវចាំ»
ដើម្បីឲ្យដឹងថាព្រះអង្គបានបង្កើត
អាចមានន័យថា ១) «តាមរបៀបនេះព្រះអង្គបង្កើត» ឬ ២)
«តាមរបៀបនេះព្រះអង្គស្មោះត្រង់ ចំពោះការបង្កើត» ។
ព្រះអង្គបាន
«ដូច្នេះ ព្រះអង្គអាច»
បង្កើត
«បំពេញ» ឬ «ថែរក្សា»
ដូចនៅថ្ងៃនេះ។
«ដូចដែលព្រះអង្គកំពុងធ្វើឥឡូវនេះ» ឬ
«ដូចដែលព្រះអង្គចងសម្ពន្ធមេត្រីរបស់ព្រះអង្គ ឥឡូវនេះ»
ហើយដើរតាមព្រះដទៃ
ការដើរជាការប្រៀបធៀបមួយសម្រាប់ការស្តាប់បង្គាប់។ ការបកប្រែផ្សេងទៀត
«បម្រើព្រះដទៃ»
ប្រឆាំងទាស់នឹងអ្នករាល់គ្នា ... អ្នករាល់គ្នាបំភ្លេច ...
ចំពោះមុខអ្នករាល់គ្នា ...អ្នករាល់គ្នានឹងវិនាស ... អ្នករាល់គ្នាមិន...ព្រះរបស់អ្នករាល់គ្នា។
រាល់ការកើតមានឡើងនៃពាក្យ «អ្នក» ជាពហុវចនៈ។
ខ្ញុំធ្វើជាសាក្សីប្រឆាំងទាស់នឹងអ្នករាល់គ្នា
«ខ្ញុំព្រមានអ្នករាល់គ្នា» ឬ «ខ្ញុំប្រាប់អ្នករាល់គ្នានៅចំពោះមុខសាក្សី»
ដូច្នេះ អ្នករាល់គ្នានឹងវិនាស
«អ្នករាល់គ្នាប្រាកដជាស្លាប់»
នៅចំពោះមុខអ្នករាល់គ្នា
«នៅពីមុខអ្នករាល់គ្នា»
មិនបានស្តាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់
នៅទីនេះ «ព្រះសូរសៀងរបស់ព្រះអម្ចាស់» មានន័យថា
អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលប្រាប់ប្រជាជនរបស់ព្រះអង្គឱ្យធ្វើ។
ការបកប្រែផ្សេងទៀត «នឹងមិនគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់»

---

9 [1]ឱអ៊ីស្រាអែល ចូរស្តាប់ អ្នករាល់គ្នាត្រូវឆ្លងកាត់ទន្លេយ័រដាន់នៅថ្ងៃនេះ ចូលទៅទីនោះ ដើម្បីបណ្តេញប្រជាជាតិដែលធំជាង និងមានកម្លាំងខ្លាំងជាងអ្នករាល់គ្នា
និងក្រុងជាច្រើនដែលធំ ហើយមានកំពែងខ្ពស់កប់មេឃ[2]ជាប្រជាជនដែលមានមាឌធំ និងខ្ពស់ គឺកូនចៅអណាក់ ដែលអ្នករាល់គ្នាបានស្គាល់
ហើយជាមនុស្សដែលអ្នករាល់គ្នាបានឮពីមនុស្សដទៃនិយាយប្រាប់ តើនរណាអាចឈរនៅចំពោះមុខពួកកូនចៅរបស់អណាក់បាន?
[3]ដូច្នេះ នៅថ្ងៃនេះ ចូរដឹងថា ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា គឺព្រះអង្គហើយដែលយាងនាំមុខអ្នករាល់គ្នា ដូចជាភ្លើងដែលឆេះបន្សុស ព្រះអង្គនឹងបំផ្លាញពួកគេ
ហើយព្រះអង្គនឹងបង្ក្រាបពួកគេនៅចំពោះមុខអ្នករាល់គ្នា ដូច្នេះ អ្នករាល់គ្នានឹងបណ្តេញពួកគេចេញ និងធ្វើឲ្យពួកគេវិនាសយ៉ាងលឿនបំផុត
ដូចជាព្រះអម្ចាស់បានមានព្រះបន្ទូលនឹងអ្នករាល់គ្នា។
[4]មិនត្រូវនិយាយក្នុងចិត្តរបស់អ្នករាល់គ្នា បន្ទាប់ពី ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបណ្តេញពួកគេចេញនៅចំពោះមុខអ្នករាល់គ្នាថា៖
«ព្រះអម្ចាស់ប្រទានទឹកដីនេះឲ្យអ្នករាល់គ្នាកាន់កាប់ ដោយសារតែអ្នករាល់គ្នាសុចរិតឡើយ ដ្បិត ព្រះអម្ចាស់ដេញប្រជាជាតិទាំងនេះនៅចំពោះមុខអ្នករាល់គ្នា
ដោយសារតែអំពើអាក្រក់របស់ពួកគេទេ។

generated on Wed Sep 10 16:16:32 2025

[5]មិនមែនដោយសារតែសេចក្ដីសុចរិត ឬចិត្តទៀងត្រង់របស់អ្នករាល់គ្នា ដែលអ្នករាល់គ្នាអាចកាន់កាប់ទឹកដីរបស់ពួកគេនោះទេ ប៉ុន្តែ
ដោយសារតែអំពើអាក្រក់នៃប្រជាជាតិទាំងនេះ ទើបព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបណ្តេញពួកគេចេញនៅចំពោះមុខអ្នករាល់គ្នា
ដើម្បីនឹងបញ្ជាក់ពីព្រះបន្ទូលរបស់ព្រះអង្គដែលបានស្បថនឹងបុព្វបុរសរបស់អ្នករាល់គ្នា គឺចំពោះលោកអប្រាហាំ លោកអ៊ីសាក លោកនិងយ៉ាកុប។
[6]ដូច្នេះ ត្រូវដឹងថា ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាមិនបានប្រទានទឹកដីល្អ ដើម្បីឲ្យអ្នករាល់គ្នាកាន់កាប់នេះ ដោយសារតែសេចក្ដីសុចរិតរបស់អ្នករាល់គ្នាទេ ដ្បិត
អ្នករាល់គ្នាគឺជាមនុស្សដែលមានចិត្តរឹងរូស។
[7]ចូរចង់ចាំ ហើយមិនត្រូវភ្លេចថា អ្នករាល់គ្នាបានធ្វើឲ្យព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាមានសេចក្ដីក្រោធ នៅទីរហោស្ថាន
ចាប់ពីថ្ងៃដែលអ្នករាល់គ្នាបានចាក់ចេញពីទឹកដីអេស៊ីប រហូតដល់អ្នករាល់គ្នាមកដល់ទីនេះ អ្នករាល់គ្នាបានចេះតែបះបោរនឹងប្រឆាំងនឹងព្រះអម្ចាស់។[8]នៅភ្នំហោរែប
អ្នករាល់គ្នាក៏បានធ្វើឲ្យព្រះអម្ចាស់មានសេចក្ដីក្រោធដែរ ហើយព្រះអម្ចាស់បានក្រោធរហូតដល់បំផ្លាញអ្នករាល់គ្នា។
[9]នៅពេលដែលខ្ញុំ បានឡើងទៅលើភ្នំ ដើម្បីទទួលបន្ទះថ្ម គឺបន្ទះថ្មនៃសម្ពន្ធមេត្រី ដែលព្រះអម្ចាស់បានចងជាមួយនឹងអ្នករាល់គ្នា ខ្ញុំបាននៅលើភ្នំនោះ
អស់រយៈពេលសែសិបថ្ងៃ និងសែបសិបយប់ ដោយមិនបានបរិភោគនំប៉័ង ឬផឹកទឹកទេ។[10]ព្រះអម្ចាស់បានប្រទានបន្ទះថ្មពីរដុំមកឲ្យខ្ញុំ
ដែលចារដោយព្រះអង្គុលីរបស់ព្រះអង្គ លើថ្មនោះបានចារអំពីសេចក្ដីទាំងប៉ុន្មាន ដែលព្រះអម្ចាស់មានព្រះបន្ទូលនឹងអ្នករាល់គ្នានៅលើភ្នំ
ចេញពីកណ្តាលភ្លើងនៅថ្ងៃដែលអ្នករាល់គ្នាជួបប្រជុំគ្នា។
[11]ការនេះបានកើតឡើងនៅថ្ងៃចុងក្រោយនៃសែបសិបយប់សែបសិនថ្ងៃ ពេលដែលព្រះអម្ចាស់បានប្រទានបន្ទះថ្មពីរដុំមកឲ្យខ្ញុំ គឺជាបន្ទះថ្មនៃសម្ពន្ធមេត្រី។
[12]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា៖ «ចូរក្រោកឡើង ហើយចុះទៅយ៉ាងឆាប់ចេញពីទីនេះ ដ្បិត ប្រជាជនរបស់អ្នក ជាប្រជាជនដែលអ្នកបាននាំចេញពីអេស៊ីប
បានប្រព្រឹត្តអំពើអាក្រក់។ ពួកគេបង្វែរចេញពីផ្លូវដែលយើងបានបង្គាប់ពួកគេយ៉ាងលឿន។ ពួកគេបានបង្កើតធ្វើរូបព្រះសម្រាប់គេ។
[13]ម៉្យាងទៀត ព្រះអម្ចាស់បានមានព្រះបន្ទូលមកកាន់ខ្ញុំថា យើងបានឃើញប្រជាជនទាំងនេះ ពួកគេជាមនុស្សចចេសរឹងរូស។[14]ចូរទុកឲ្យយើង ដើម្បីឲ្យយើងបំផ្លាញពួកគេ
និងលុបឈ្មោះរបស់ពួកគេចេញពីលើផែន ហើយយើងនឹងបង្កើតប្រជាជាតិមួយចេញមួយដែលខ្លាំងពូកែ និងច្រើនជាងពួកគេចេញពីអ្នក។
[15]ដូច្នេះ ខ្ញុំបានវិលត្រលប់មកវិញ និងចុះពីលើភ្នំ ហើយភ្នំបានឆាបឆេះឡើង។ បន្ទះថ្មនៃសម្ពន្ធមេត្រីទាំងពីរដុំបាននៅលើដៃរបស់ខ្ញុំ។[16]ខ្ញុំបានមើលហើយឃើញថា
អ្នករាល់គ្នាបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។ អ្នករាល់គ្នាបានសូនធ្វើរូបកូនគោសម្រាប់ខ្លួនឯង។
អ្នករាល់គ្នាបានឆាប់ងាកចេញពីផ្លូវដែលព្រះអម្ចាស់បានបង្គាប់អ្នករាល់គ្នា។
[17]ខ្ញុំបានយកបន្ទះថ្មទាំងពីរដុំនេះ[18]ហើយក្រវែងបន្ទះថ្មទាំងពីរដុំនេះចោលចេញពីដៃរបស់ខ្ញុំ។ ខ្ញុំបានធ្វើឲ្យបន្ទះថ្មទាំងនោះបាក់នៅចំពោះភ្នែកអ្នករាល់គ្នា។
ហើយខ្ញុំបានឱនមុខចុះនៅចំពោះព្រះអម្ចាស់រយៈពេលសែបសិបថ្ងៃសែបសិបយប់ ដោយមិនបានបរិភោគនំប៉័ង ឬផឹកទឹកទេ
ដោយព្រោះតែអំពើបាបដែលអ្នករាល់គ្នាបានប្រព្រឹត្ត ជាអំពើអាក្រក់នៅចំពោះព្រះអម្ចាស់ ធ្វើឲ្យព្រះអង្គមានសេចក្ដីក្រោធ។
[19]ដ្បិត ខ្ញុំបានភ័យខ្លាចសេចក្ដីក្រោធនោះ ហើយសេចក្ដីក្រេវក្រោធដែលព្រះអម្ចាស់បានអស់ទ្រាំនឹងអ្នករាល់គ្នា រហូតដល់ព្រះអង្គបំផ្លាញអ្នករាល់គ្នា។ ប៉ុន្តែ
ព្រះអម្ចាស់បានស្តាប់ឮខ្ញុំនៅពេលនោះដែរ។[20]ព្រះអម្ចាស់បានមានសេចក្ដីក្រោធនឹងលោកអើរ៉ុនជាងខ្លាំង រហូតដល់ចង់បំផ្លាញលោក នៅពេលនោះ
ខ្ញុំក៏បានអធិស្ឋានសម្រាប់លោកអើរ៉ុនផងដែរ។
[21]ខ្ញុំបានទទួលយកអំពើបាបរបស់អ្នករាល់គ្នា រូបកូនគោដែលអ្នករាល់គ្នាបានសូន ហើយបានដុតវាចោល ព្រមទាំងវាយបំបែក
ហើយកិនឲ្យម៉ដ្តរហូតម៉ដ្តដល់ដូចជាធូលីដី។ ខ្ញុំបានបោះធូលីនោះទៅក្នុងស្ទឹងដែលហូរចេញពីមកពីភ្នំមក។
[22]នៅតាបេរ៉ា នៅម៉ាសា និងនៅគីប្រូត ហាតាវ៉ា អ្នករាល់គ្នាក៏បានធ្វើឲ្យព្រះអម្ចាស់ព្រះពិរោធដែរ។[23]នៅពេលព្រះអម្ចាស់បានបញ្ជូនអ្នករាល់គ្នាចេញពីកាដេស
បារនាដោយមានព្រះបន្ទូលថា ចូរចេញទៅ ហើយកាន់កាប់ទឹកដីដែលយើងបានប្រទានដល់អ្នករាល់គ្នា ក្រោយមក
អ្នករាល់គ្នាបានប៉ះបោរប្រឆាំងនឹងសេចក្ដីបង្គាប់របស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ហើយអ្នករាល់គ្នាមិនបានជឿជាក់ ឬស្តាប់ព្រះសូរសៀងរបស់ព្រះអង្គឡើយ។
[24]អ្នករាល់គ្នាបានបះបោរប្រឆាំងនឹងព្រះអម្ចាស់តាំងពីថ្ងៃដែលខ្ញុំបានស្គាល់អ្នករាល់គ្នា។
[25]ដូច្នេះ ខ្ញុំបានឱនមុខចុះនៅចំពោះព្រះអម្ចាស់អស់រយៈពេលសែបសិបថ្ងៃសែបសិបយប់ ដោយព្រោះតែព្រះអង្គបានមានព្រះបន្ទូលថា ព្រះអង្គនឹងបំផ្លាញអ្នក។
[26]ខ្ញុំបានអធិស្ឋានទៅកាន់ព្រះអម្ចាស់ដោយទូលថា ឱ ព្រះអម្ចាស់ សូមកុំបំផ្លាញប្រជាជន ឬប្រជាជាតិជាមរតករបស់ព្រះអង្គឡើយ
ជាប្រជាជាតិដែលមានសេរីភាពដោយសារតែព្រះចេស្តារបស់ព្រះអង្គ ជាប្រជាជាតិដែលចាក់ចេញពីអេស៊ីប ដោយសារតែព្រះហស្តដ៏ខ្លាំងពូកែរ។
[27]ចូរនឹកចាំពីលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប ជាអ្នកបម្រើរបស់ព្រះអង្គ សូមកុំទតមើលចំពោះសេចក្ដីរឹងរូសរបស់ប្រជាជន ឬអំពើអាក្រក់
ឬអំពើបាបរបស់ពួកគេទាំងនេះឡើយ[28]ធ្វើដូច្នេះទឹកដីដែលព្រះអង្គបាននាំពួកយើងចេញមកនោះអាចនិយាយថា៖ «ដោយសារតែព្រះអម្ចាស់មិនអាចនាំពួកគេ
ចូរទៅទឹកដីដែលព្រះអង្គបានសន្យាចំពោះពួកគេ និងដោយសារតែ ព្រះអង្គស្អប់ពួកគេ ព្រះអង្គបាននាំពួកគេចេញមក ដើម្បីសម្លាប់ពួកគេនៅក្នុងទីរហោស្ថាន»។[29]ដ្បិត
ពួកគេជាប្រជាជន និងជាប្រជាជាតិមរតករបស់ព្រះអង្គ ដែលព្រះអង្គបាននាំចេញពីដោយព្រះចេស្តាដ៏អស្ចារ្យ និងដោយព្រះពាហុលើសម្រេច។

Deuteronomy 9:1

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។

ឱអ៊ីស្រាអែល ចូរស្តាប់

ពាក្យ «អ៊ីស្រាអែល» ជាពាក្យសម្តីសម្រាប់ប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ចូរស្តាប់ប្រជាជនអ៊ីស្រាអែលអើយ»

ដើម្បីបណ្តេញ

«ដើម្បីយកទឹកដីពី»

ហើយមានកំពែងខ្ពស់កប់មេឃ

នេះជាការនិយាយបំផ្លើសមួយ ដែលបញ្ជាក់ទៅលើការភ័យខ្លាចរបស់ប្រជាជន
ពីព្រោះទីក្រុងធំនិងរឹងមាំ។ មើលរបៀបបកប្រែពាក្យស្រដៀងគ្នានៅក្នុង ១:២៦ ។
ការបកប្រែផ្សេងទៀត «មានកំពែងខ្ពស់ណាស់»

គឺកូនចៅអណាក់

កូនចៅកូនចៅអណាក់ដែលមានមាឌធំ និងកាចសាហាវ។
មើលរបៀបបកប្រែពាក្យស្រដៀងគ្នានៅក្នុង ១:២៦។

តើនរណាអាចឈរនៅចំពោះមុខពួកកូនចៅរបស់អណាក់បាន?

នេះមានន័យថា
កូនប្រុសរបស់អណាក់មានអំណាចហើយប្រជាជនភ័យខ្លាចពួកគេ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្ដីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«គ្មាននរណាអាចការពារខ្លួនគេប្រឆាំងនឹងកូនប្រុសរបស់អណាក់បានទេ»។

Deuteronomy 9:3

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។

នៅថ្ងៃនេះ

ឥឡូវនេះ

ដូចជាភ្លើងដែលឆេះបន្សុស

ព្រះអម្ចាស់មានអំណាចខ្លាំងពូកែ
និងអាចបំផ្លាញកងទ័ពរបស់ប្រជាជាតិផ្សេងៗនានា។

នឹងបង្ក្រាបពួកគេនៅចំពោះមុខអ្នករាល់គ្នា

«ធ្វើឱ្យពួកគេខ្សោយ ដូច្នេះ អ្នកអាចគ្រប់គ្រងពួកគេ»

Deuteronomy 9:4

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។

generated on Wed Sep 10 16:16:32 2025

មិនត្រូវនិយាយក្នុងចិត្តរបស់អ្នករាល់គ្នា
នៅទីនេះ «នៅក្នុងចិត្តរបស់អ្នករាល់គ្នា» មានន័យថា «
នៅក្នុងគំនិតរបស់អ្នករាល់គ្នា» ។ ការបកប្រែផ្សេងទៀត «មិនត្រូវគិតអំពីខ្លួនឯង»
បានបណ្តេញពួកគេចេញ
«បានបណ្តេញប្រជាជនផ្សេងទៀតចេញ»
Deuteronomy 9:5
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
ចិត្តទៀងត្រង់របស់អ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ «ពីព្រោះអ្នករាល់គ្នា តែងតែគិត
និងចង់បានអ្វីដែលត្រឹមត្រូវ»
ដើម្បីនឹងបញ្ជាក់ពីព្រះបន្ទូលរបស់ព្រះអង្គ
នៅទីនេះជាពាក្យប្រៀបធៀប «ព្រះបន្ទូល» សំដៅទៅលើអ្វី
ដែលព្រះជាម្ចាស់បានសន្យា។ ការបកប្រែផ្សេងទៀត
«ដើម្បីឱ្យព្រះអង្គបំពេញតាមព្រះបន្ទូលសន្យា»
បុព្វបុរសរបស់អ្នករាល់គ្នា គឺចំពោះលោកអប្រាហាំ លោកអ៊ីសាក លោកនិងយ៉ាកុប។
លោកអប្រាហាំ លោកអ៊ីសាកនិង លោកយ៉ាកុបជា «បុព្វបុរស»
ដែលលោកម៉ូសេកំពុងនិយាយ។
Deuteronomy 9:6
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
Deuteronomy 9:7
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
ចូរចង់ចាំ ហើយមិនត្រូវភ្លេច
លោកម៉ូសេរម្លឹកបង្គាប់ដដែលនេះ ទាំងវិជ្ជមាន
និងអវិជ្ជមានដើម្បីបញ្ជាក់ពីសារៈសំខាន់នៃការចងចាំ។ ការបកប្រែផ្សេងទៀត
«ត្រូវយកចិត្តទុកដាក់ក្នុងការចងចាំ» (សូមមើល [[rc://*/ta;vol2/translate/figs-doublet]])
អ្នករាល់គ្នាបានធ្វើឲ្យព្រះអម្ចាស់
នៅទីនេះ «អ្នករាល់គ្នា» សំដៅទៅលើជនជាតិអ៊ីស្រាអែល
ដែលមានវត្តមានជាមួយលោកម៉ូសេនិងជនជាតិអ៊ីស្រាអែលពីជំនាន់មុន។
អ្នករាល់គ្នាមកដល់ទីនេះ អ្នករាល់គ្នាបានចេះតែបះបោរ... អ្នករាល់គ្នាក៏បានធ្វើឲ្យព្រះអម្ចាស់ ...
ដល់បំផ្លាញអ្នករាល់គ្នា។
រាល់ការកើតមានឡើងនៃពាក្យ «អ្នករាល់គ្នា» ជាពហុវចនៈ។
មកដល់ទីនេះ
នេះសំដៅទៅលើជ្រលងទន្លេយ័រដាន់។
Deuteronomy 9:9
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។
បន្ទះថ្ម គឺបន្ទះថ្មនៃសម្ពន្ធមេត្រី ដែលព្រះអម្ចាស់បានចងជាមួយនឹងអ្នករាល់គ្នា
នៅទីនេះឃ្លាទី២ បានបញ្ជាក់យ៉ាងច្បាស់ថា «បន្ទះថ្ម»
ជាអ្វីដែលព្រះជាម្ចាស់បានសរសេរក្រឹត្យវិន័យទាំង ១០ ប្រការ។
សែសិបថ្ងៃ និងសែបសិបយប់
«៤០ថ្ងៃ និង៤០យប់»
លើថ្មនោះបានចារអំពីសេចក្តីទាំងប៉ុន្មាន ដែលព្រះអម្ចាស់មានព្រះបន្ទូលនឹងអ្នករាល់គ្នា
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានសរសេរពាក្យដដែលៗនៅលើផ្ទាំងថ្ម
ដែលព្រះអង្គបានបន្ទូលដល់អ្នករាល់គ្នា»
ព្រះអម្ចាស់មានព្រះបន្ទូល ... ចេញពីកណ្តាលភ្លើង
ហាក់ដូចជាព្រះអម្ចាស់ជាមនុស្សម្នាក់ឈរនៅកណ្តាលភ្លើង
ហើយមានបន្ទូលដោយសំឡេងខ្លាំងៗ។
នៅថ្ងៃដែលអ្នករាល់គ្នាជួបប្រជុំគ្នា។
នាមអរូបី «ការជួបប្រជុំគ្នា» អាចត្រូវបានបង្ហាញនៅពេលកិរិយាស័ព្ទ
«ប្រមូលផ្តុំគ្នា»។ ការបកប្រែផ្សេងទៀត «នៅថ្ងៃដែលប្រជាជនអ៊ីស្រាអែលទាំងអស់
បានមកជួបជុំគ្នានៅកន្លែងតែមួយ»
Deuteronomy 9:11
សែសិបថ្ងៃ និងសែបសិបយប់
«៤០ ថ្ងៃនិង ៤០យប់»
បន្ទះថ្មពីរដុំមកឲ្យខ្ញុំ គឺជាបន្ទះថ្មនៃសម្ពន្ធមេត្រី។
ឃ្លាទីពីរបញ្ជាក់យ៉ាងច្បាស់ថា «ផ្ទាំងថ្មពីរដុំ»
ជាផ្ទាំងថ្មដែលព្រះជាម្ចាស់បានសរសេរក្រឹត្យវិន័យទាំង១០ ប្រការ។
ប្រជាជនរបស់អ្នក ... បានប្រព្រឹត្តអំពើអាក្រក់។
ប្រជាជនរបស់អ្នក ... កំពុងធ្វើអ្វីដែលខុស។ ពាក្យស្រដៀងគ្នានេះកើតមាននៅក្នុង ៤:១៥។
ពួកគេបង្វែរចេញពីផ្លូវដែលយើងបានបង្គាប់ពួកគេយ៉ាងលឿន។
លោកម៉ូសេនិយាយដូចជាការស្តាប់តាមបង្គាប់របស់ព្រះជាម្ចាស់
គឺបានដើរតាមផ្លូវមួយ។ ការបកប្រែផ្សេងទៀត
«ពួកគេមិនបានគោរពតាមបង្គាប់របស់យើងរួចហើយ»
Deuteronomy 9:13
លុបឈ្មោះរបស់ពួកគេចេញពីលើផែន
«ធ្វើឱ្យឈ្មោះរបស់ពួកគេបាត់ទាំងស្រុង» ឬ «សម្លាប់ពួកគេទាំងអស់ ដូច្នេះ
គ្មាននរណាម្នាក់អាចចងចាំពួកគេបានទេ»។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៧:២៣ ។
Deuteronomy 9:15
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។
មើល
ពាក្យថា «មើល» ត្រង់នេះបង្ហាញថា លោកម៉ូសេមានការភ្ញាក់ផ្អើលចំពោះអ្វី
ដែលគាត់បានឃើញ។
បានសូនធ្វើរូបកូនគោសម្រាប់ខ្លួនឯង។
ជនជាតិអ៊ីស្រាអែលនៅជំនាន់មុន បានសុំលោកអ៊ើរ៉ុនធ្វើរូបកូនគោមាសមួយ
ដើម្បីពួកគេអាចថ្វាយបង្គំរូបនោះ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចធ្វើឱ្យច្បាស់។
អ្នករាល់គ្នាបានឆាប់ងាកចេញពីផ្លូវដែលព្រះអម្ចាស់បានបង្គាប់អ្នករាល់គ្នា។
លោកម៉ូសេនិយាយដូចជាការស្តាប់តាមបង្គាប់របស់ព្រះជាម្ចាស់
បានដើរតាមផ្លូវមួយ។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាឆាប់មិនស្តាប់បង្គាប់តាមអ្វី ដែលព្រះអម្ចាស់បានបង្គាប់អ្នករាល់គ្នា»។
ពាក្យស្រដៀងគ្នានេះកើតមានឡើងនៅក្នុង ៩:១១ ។
Deuteronomy 9:17
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។
ខ្ញុំបានធ្វើឲ្យបន្ទះថ្មទាំងនោះបាក់នៅចំពោះភ្នែកអ្នករាល់គ្នា។
នៅទីនេះ «ភ្នែកអ្នករាល់គ្នា» ជាឃ្លាសម្រាប់ប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ខ្ញុំបានបំបែកបន្ទះថ្មនៅពីមុខអ្នករាល់គ្នា» ឬ
«ខ្ញុំបានបំបែកបន្ទះថ្មជាក់ស្តែង ដែលអ្នករាល់គ្នាអាចមើលឃើញ»
បានឱនមុខចុះ
«ដាក់មុខខ្ញុំនៅលើដី»។ នេះជារបៀបបង្ហាញថា ព្រះអម្ចាស់អស្ចារ្យ
ហើយមិនមែនលោកម៉ូសេ។
សែសិបថ្ងៃ និងសែបសិបយប់
«៤០ថ្ងៃ និង៤០យប់»
Deuteronomy 9:19
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។
ខ្ញុំបានភ័យខ្លាចសេចក្តីក្រោធនោះ
ហើយសេចក្តីក្រេវក្រោធដែលព្រះអម្ចាស់បានអស់ទ្រាំនឹងអ្នករាល់គ្នា
រហូតដល់ព្រះអង្គបំផ្លាញអ្នករាល់គ្នា។
ពាក្យថា «សេចក្តីក្រោធនិងសេចក្តីក្រេវក្រោធ» ជាពាក្យប្រៀបធៀបសម្រាប់អ្វី
ដែលព្រះអម្ចាស់នឹងធ្វើដោយសារព្រះអង្គមានសេចក្តីក្រោធ
និងសេចក្តីក្រេវក្រោធ»។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ក្រោធដាក់អ្នករាល់គ្នា
-ព្រះអង្គក្រេវក្រោធអ្នករាល់គ្នាខ្លាំងណាស់ -

generated on Wed Sep 10 16:16:32 2025

ព្រះអង្គក្រោធល្មមដើម្បីបំផ្លាញអ្នករាល់គ្នា ដូច្នេះ
ខ្ញុំភ័យខ្លាចនូវអ្វីដែលព្រះអង្គនឹងធ្វើ»
Deuteronomy 9:21
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។
ខ្ញុំបានទទួលយក ... បានដុត ... បំបែក ... ធូលីដី... បានបោះ
លោកម៉ូសេប្រហែលជាបានបង្គាប់បុរសឯទៀត ឱ្យធ្វើកិច្ចការជាក់ស្តែង។
ការបកប្រែផ្សេងទៀត «ខ្ញុំមានមនុស្សយក ... ដុត ... បំបែក ... កិន ... បោះ»
អំពើបាបរបស់អ្នករាល់គ្នា
រូបគោមាស។ ការបកប្រែផ្សេងទៀត «អ្នករាល់គ្នាបានប្រព្រឹត្តអំពើបាប
តាមរយៈការធ្វើរូបគោមាស»
Deuteronomy 9:22
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។
តាបេរ៉ា ... ម៉ាសា ... ប្លេត ហាតាវ៉ា
ទាំងនេះជាឈ្មោះកន្លែង ដែលជនជាតិអ៊ីស្រាអែលបានឆ្លងកាត់
ពេលពួកគេនៅទីរហោស្ថាន។
ចូរចេញទៅ
ពួកគេស្ថិតនៅលើដីទាប ហើយដីដែលព្រះអម្ចាស់បានប្រាប់ពួកគេឱ្យយកនៅលើភ្នំ
ដូច្នេះ ពួកគេត្រូវឡើងទៅលើភ្នំ។
បានប៉ះបោះប្រឆាំងនឹងសេចក្តីបង្គាប់
ពាក្យថា «សេចក្តីបង្គាប់» ជាពាក្យប្រៀបធៀបសម្រាប់ព្រះអម្ចាស់ផ្ទាល់។
ការបកប្រែផ្សេងទៀត «បានបះបោរប្រឆាំងនឹងព្រះអម្ចាស់
អ្នកមិនបានធ្វើតាមសេចក្តីបង្គាប់»
ស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ
នៅទីនេះ« សំឡេងរបស់ព្រះអង្គ» មានន័យថា អ្វីដែលព្រះជាម្ចាស់មានបន្ទូល។
ការបកប្រែផ្សេងទៀត «ចូរគោរពតាមអ្វី ដែលព្រះអង្គបានមានបន្ទូល»
ពីថ្ងៃដែលខ្ញុំបានស្គាល់អ្នករាល់គ្នា។
«ពេលដែលខ្ញុំចាប់ផ្តើមដឹកនាំអ្នករាល់គ្នា» ការបកប្រែខ្លះអានថា «ចាប់ពីថ្ងៃ
ដែលគាត់បានស្គាល់អ្នករាល់គ្នា» ជាថ្ងៃ ដែលព្រះអម្ចាស់ស្គាល់ពួកគេដំបូង។
Deuteronomy 9:25
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។
បានឱនមុខចុះនៅចំពោះព្រះអម្ចាស់អស់
«ឱនមុខរបស់ខ្ញុំដល់ដី»។ បកប្រែដូចនៅក្នុង ៩:១៧ ។
សែសិបថ្ងៃ និងសែបសិបយប់
«៤០ថ្ងៃ និង៤០យប់»
ជាប្រជាជាតិដែលមានសេរីភាព
លោកម៉ូសេនិយាយដូចជាព្រះអម្ចាស់បានជួយសង្គ្រោះជនជាតិអ៊ីស្រាអែល
តាមរយៈបង់ប្រាក់ដើម្បីរំដោះពួកគេពីទាសករ។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាបានជួយសង្គ្រោះ»
ដោយសារតែព្រះចេស្តារបស់ព្រះអង្គ
ពាក្យថា «ព្រះចេស្តា»
ជាពាក្យប្រៀបធៀបសម្រាប់អំណាចដ៏អស្ចារ្យរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «តាមរយៈអំណាចដ៏អស្ចារ្យរបស់ព្រះអង្គ»
ដោយសារតែព្រះហស្តដ៏ខ្លាំងពូកែរ។
នៅទីនេះ «ព្រះហស្តដ៏ខ្លាំងពូកែ» សំដៅទៅលើឫទ្ធានុភាពរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ដោយអំណាចចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ»។
ពាក្យស្រដៀងគ្នានេះកើតមានឡើងនៅ ៤:៣៤ ដែរ។
Deuteronomy 9:27
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តអធិស្ឋានទៅព្រះអម្ចាស់
ដើម្បីឱ្យព្រះអង្គមិនបំផ្លាញជនជាតិអ៊ីស្រាអែល។
ចូរនឹកចាំ
នេះជាលេខសម្គាល់។ ការបកប្រែផ្សេងទៀត «ចូរចងចាំ»
ធ្វើដូច្នេះទឹកដីដែលព្រះអង្គបាននាំពួកយើង
ពាក្យថា «ទឹកដី» ជាពាក្យប្រៀបធៀបសម្រាប់ប្រជាជនអេស៊ីប។
ការបកប្រែផ្សេងទៀត «ដូច្នេះ ប្រជាជនរបស់អេស៊ីប»
អាចនិយាយថា
«អាចនិយាយបាន»
បាននាំចេញពីដោយព្រះចេស្តាដ៏អស្ចារ្យ និងដោយព្រះពាហុលើសម្រេច។
ឃ្លាទាំងនេះមានន័យថា
ជារួមដូចគ្នានិងបញ្ជាក់ពីភាពអស្ចារ្យនៃតេជានុភាពរបស់ព្រះអម្ចាស់
ដែលព្រះអង្គបានប្រើដើម្បីជួយសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ។

---

10 [1]នៅពេលនោះ ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «ចូរឆ្លាក់ថ្មពីរបន្ទះ ដូចបន្ទះថ្មពីមុន រួចឡើងយកមកជួបយើងនៅលើភ្នំ ហើយត្រូវធ្វើហឹបមួយពីឈើ។
[2]យើងនឹងសរសេរពាក្យនៅលើបន្ទះថ្មនេះ តាមសេចក្តីដែលបានសរសេរលើបន្ទះថ្មពីមុន ដែលអ្នកបានបំបែក ហើយត្រូវទុកបន្ទះថ្មនេះនៅក្នុងហឹប។
[3]ដូច្នេះ ខ្ញុំបានធ្វើហឹបមួយពីឈើនាងនួន ហើយខ្ញុំបានឆ្លាក់ថ្មពីបន្ទះ ដូចបន្ទះថ្មពីមុន ហើយខ្ញុំក៏បានឡើងទៅលើភ្នំ ដោយកាន់ថ្មពីរបន្ទះនោះនៅនឹងដៃ។
[4]ព្រះអង្គបានសរសេរនៅលើបន្ទះថ្មនោះ តាមសេចក្តីដែលបានសរសេរពីមុន គឺក្រឹត្យវិន័យទាំងដប់ប្រការ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលនៅកណ្តាលភ្លើងមកកាន់អ្នក
នៅលើភ្នំ ក្នុងថ្ងៃប្រជុំ បន្ទាប់មក ព្រះអម្ចាស់ក៏បានប្រគល់បន្ទះថ្មនោះមកខ្ញុំ។
[5]ខ្ញុំក៏ចុះពីភ្នំមកវិញ ហើយទុកបន្ទះថ្មនោះនៅក្នុងហឹបដែលខ្ញុំបានធ្វើ ហើយបន្ទះថ្មនោះនៅក្នុងហឹបរហូត ដូចដែលព្រះអម្ចាស់បានបង្គាប់មកខ្ញុំ»។
[6](ប្រជាជនអ៊ីស្រាអែលបានចេញដំណើរពីប្អៀរ៉ូត បេនយ៉ាកាន ឆ្ពោះទៅម៉ូសេរ៉ា។ លោកអើរ៉ុនក៏ស្លាប់នៅទីនោះហើយគេក៏បញ្ចុះសពលោកនៅទីនោះ
ហើយលោកអេឡាសារ ជាកូនរបស់លោក បានទទួលមុខងារជាបូជាចារ្យជំនួសលោក។[7]ពួកគេបានចេញដំណើរពីទៅនោះ ឆ្ពោះទៅកាន់គុតកូថា ហើយចេញពីគុតកូថា
ឆ្ពោះទៅកាន់យ៉ុតបាថា ជាទឹកដីដែលមានស្ទឹងច្រើន។
[8]នៅគ្រានោះ ព្រះអម្ចាស់បានញែកកុលសម្ព័ន្ធលេវីចេញ ដើម្បីឲ្យពួកគេសែងហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ ហើយឲ្យឈរធ្វើការងារនៅចំពោះព្រះអម្ចាស់
ព្រមទាំងជូនពរដល់ប្រជាជនក្នុងមានព្រះអង្គ រហូតមកដល់សព្វថ្ងៃនេះ។[9]ហេតុនេះហើយ បានជាពួកលេវីគ្មានចំណែកមរតកជាមួយបងប្អូនរបស់ខ្លួនទេ ដ្បិត
ព្រះអម្ចាស់ជាមរតករបស់ពួកគេ ដូចដែលព្រះអម្ចាស់ ជាព្រះរបស់អ្នកបានមានព្រះបន្ទូលទៅពួកគេហើយ)។
[10]ខ្ញុំនៅលើភ្នំអស់ចំនួនសែសិបថ្ងៃសែសិបយប់ ដូចពីមុន។ នៅពេលនោះ ព្រះអម្ចាស់ព្រមស្តាប់តាមពាក្យទូលអង្វររបស់ខ្ញុំ គឺព្រះអម្ចាស់មិនចង់បំផ្លាញអ្នករាល់គ្នាទេ។
[11]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «ចូរក្រោកឡើង ហើយដើរនាំមុខប្រជាជននេះ ដើម្បីឲ្យពួកគេចាប់យកទឹកដី ដែលយើងបានស្បថជាមួយបុព្វបុរសរបស់ពួកគេ
ថានឹងប្រគល់ឲ្យទៅពួកគេ»។
[12]ឥឡូវនេះ អ៊ីស្រាអែលអើយ តើព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ទាមទារចង់បានអ្វីពីអ្នករាល់គ្នា គឺចង់ឲ្យអ្នករាល់គ្នាគោរពកោតខ្លាចព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ចូរដើតាមផ្លូវរបស់ព្រះអង្គ ហើយត្រូវស្រឡាញ់ព្រះអង្គ ព្រមទាំងថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ឲ្យអស់ពីចិត្ត
និងអស់ពីព្រលឹងរបស់អ្នករាល់គ្នា[13]ហើយត្រូវកាន់តាមបទបញ្ជា និងច្បាប់ទាំងប៉ុន្មានរបស់ព្រះអម្ចាស់ ដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ
សម្រាប់ជាសេចក្តីល្អដល់អ្នករាល់គ្នា?
[14]មើល៍ ផ្ទៃមេឃ ហើយអស់ទាំងអាកាសវេហាស៍ដ៏ខ្ពស់បំផុត និងផែនដី ព្រមទាំងរបស់សព្វសារពើដែលនៅទីនោះ សុទ្ធតែជាកម្មសិទ្ធិរបស់ព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នា។[15]ព្រះអម្ចាស់ជាប់ព្រះហឫទ័យស្រឡាញ់តែបុព្វបុរសរបស់អ្នករាល់គ្នា ហើយបានជ្រើសរើសអ្នករាល់គ្នា ដែលជាពូជពង្សរបស់ពួកគេ
និងអ្នកដែលនៅបន្ទាប់ពីពួកគេ លើសជាងជាតិសាសន៍ទាំងប៉ុន្មាន ដូចព្រះអង្គបានធ្វើសព្វថ្ងៃនេះ។

generated on Wed Sep 10 16:16:32 2025

[16]ដូច្នេះ ចូរអ្នករាល់គ្នាកាត់ស្បែកចិត្តរបស់អ្នករាល់គ្នាចេញ ហើយកុំមានចិត្តរឹងរូសឲ្យសោះ។[17]ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
គឺជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ជាព្រះដ៏ធំឧត្តម ព្រះអង្គជាព្រះដ៏មានព្រះចេស្តា ហើយគួឲ្យស្ញែងខ្លាច ហើយព្រះអង្គមិនយោគយល់នរណាឡើយ
ក៏មិនទទួលសំណូកពីនរណាដែរ។
[18]ព្រះអង្គរកសេចក្តីយុត្តិធម៌ឲ្យក្មេងកំព្រា និងស្ត្រីមេម៉ាយ ហើយព្រះអង្គបានបង្ហាញក្តីស្រឡាញ់ដល់ជនបរទេស ព្រមទាំងប្រទានអាហារ និងសម្លៀកបំពាក់ដល់ពួកគេ។
[19]ដូច្នេះ ចូរស្រឡាញ់ជនបរទេស ដ្បិត អ្នករាល់គ្នាក៏ធ្លាប់ជាជនបរទេសនៅទឹកដីអេស៊ីបដែរ។
[20]ត្រូវគោរពកោតខ្លាចដល់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ហើយត្រូវគោរពប្រតិបត្តិដល់ព្រះអម្ចាស់ ហើយនៅជាប់ជាមួយនឹងព្រះអង្គ
ហើយអ្នករាល់គ្នាត្រូវស្បថក្នុងនាមព្រះអង្គតែមួយប៉ុណ្ណោះ។[21]ចូរលើកតម្កើងដល់ព្រះអង្គ ហើយព្រះអង្គជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គបានធ្វើការអស្ចារ្យដ៏ធំ
គួរឲ្យស្ញែងខ្លាច នៅក្នុងចំណោមអ្នករាល់គ្នា ដូចដែលភ្នែករបស់អ្នករាល់គ្នាបានឃើញស្រាប់ហើយ។
[22]កាលបុព្វបុរសរបស់អ្នករាល់គ្នាបានចុះទៅនៅទឹកដីអេស៊ីប ពួកគេមានគ្នាចិតសិបនាក់តែប៉ុណ្ណោះ តែឥឡូវ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
បានចម្រើនឲ្យអ្នករាល់គ្នាមានគ្នាច្រើនដូចជាផ្កាយនៅលើមេឃ។

Deuteronomy 10:1

ព័ត៌មានទូទៅ៖

លោកម៉ូសេកំពុងរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។

នៅពេលនោះ

«បន្ទាប់ពីខ្ញុំបានអធិស្ឋានចប់»

ពីមុន

«ពីមុន» ជាលេខធម្មតាសម្រាប់លេខមួយ។ សំដៅទៅលើបន្ទះថ្មពីមុន
ដែលលោកម៉ូសេបានបំបែក។

នៅលើភ្នំ

នៅទីនេះ «ភ្នំ» សំដៅទៅលើភ្នំស៊ីណាយ។ (សូមមើលfigs-metonymy)

Deuteronomy 10:3

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តអធិស្ឋានទៅព្រះអម្ចាស់
ដើម្បីព្រះអង្គមិនបំផ្លាញជនជាតិអ៊ីស្រាអែល។

ដូចបន្ទះថ្មពីមុន

នៅទីនេះ «ពីមុន» សំដៅទៅលើបន្ទះថ្មដំបូង។ ការបកប្រែផ្សេងទៀត
«ដូចថ្ម២បន្ទះដំបូង»

បានឡើងទៅលើភ្នំ

«បានឡើងទៅលើភ្នំស៊ីណាយ»

នៅកណ្តាលភ្លើង

ហាក់ដូចជាព្រះអម្ចាស់ជាមនុស្សម្នាក់ ឈរនៅកណ្តាលភ្លើង
ហើយមានបន្ទូលដោយសំឡេងខ្លាំងៗ។ បកប្រែដូចនៅក្នុង ៩:៩។

ក្នុងថ្ងៃប្រជុំ

នាមអរូបី «ប្រជុំ » អាចបង្ហាញនៅពេលកិរិយាស័ព្ទ «ប្រមូលផ្តុំគ្នា»។
ការបកប្រែផ្សេងទៀត «នៅថ្ងៃដែលអ្នកអ៊ីស្រាអែលទាំងអស់បានមកជួបជុំគ្នា
នៅទីកន្លែងតែមួយ»។ បកប្រែដូចនៅក្នុង ៩:៩។

Deuteronomy 10:5

ព័ត៌មានទូទៅ៖

ម៉ូសេនៅតែបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។

ខ្ញុំក៏ចុះ

នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកម៉ូសេ។

ចុះពីភ្នំមកវិញ

«ចុះពីលើភ្នំស៊ីណាយ»

នៅក្នុងហឹប

«នៅក្នុងប្រអប់» ឬ «នៅក្នុងហឹប»

Deuteronomy 10:6

ព័ត៌មានទូទៅ៖

អ្នកនិពន្ធរៀបរាប់យ៉ាងខ្លីអំពីកន្លែង ដែលជនជាតិអ៊ីស្រាអែលបានធ្វើដំណើរទៅ។

ប្រជាជនអ៊ីស្រាអែល ... ជាទឹកដីដែលមានស្ទឹងច្រើន។

ផ្តល់ព័ត៌មានសង្ខេបអំពីកន្លែង ដែលប្រជាជនអ៊ីស្រាអែលធ្វើដំណើរ។
វាគ្របដណ្តប់លើការស្លាប់របស់លោកអ៊ើរ៉ុនតាមដំណើរធម្មជាតិ
នៅម៉ូសារ៉ាផងដែរ។

ប្លៀរ៉ូត បេនេយ៉ាកាន ឆ្ពោះទៅម៉ូសេរ៉ា។ ... គុតកូថា ... យ៉ុតបាថា

ទាំងនេះជាឈ្មោះកន្លែងផ្សេងៗ
ដែលប្រជាជនអ៊ីស្រាអែលបានឆ្លងកាត់នៅទីរហោស្ថាន។

ប្លៀរ៉ូត បេនេយ៉ាកាន

អ្នកបកប្រែអាចបន្ថែមលេខយោង «ឈ្មោះ» ប្លៀរ៉ូត បេនេយ៉ាកានមានន័យថា
«អណ្តូងដែលជាកម្មសិទ្ធិរបស់ប្រជាជនយ៉ាកាន»។

ហើយគេក៏បញ្ចុះសពលោកនៅទីនោះ

អាចបកប្រែជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នោះជាកន្លែងដែលពួកគេបានបញ្ចុះគាត់» ឬ
«ជនជាតិអ៊ីស្រាអែលបានបញ្ចុះគាត់នៅទីនោះ»

អេឡាសារ

នេះជាឈ្មោះកូនប្រុសរបស់លោកអ៊ើរ៉ុន។

Deuteronomy 10:8

ព័ត៌មានទូទៅ៖

អ្នកនិពន្ធផ្តល់ព័ត៌មានសង្ខេបអំពីកុលសម្ព័ន្ធលេវី។

ហើយឲ្យឈរធ្វើការងារនៅចំពោះព្រះអម្ចាស់

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ «ដើម្បីថ្វាយយញ្ញបូជាដែលព្រះអម្ចាស់តម្រូវ»

ក្នុងមានព្រះអង្គ

«ដោយអំណាចរបស់ព្រះអម្ចាស់» ឬ «ក្នុងនាមជាអ្នកតំណាងរបស់ព្រះអម្ចាស់»

រហូតមកដល់សព្វថ្ងៃនេះ។

«ដូចដែលពួកគេកំពុងធ្វើនៅថ្ងៃនេះ»

គ្មានចំណែកមរតកជាមួយបងប្អូនរបស់ខ្លួនទេ

កុលសម្ព័ន្ធលេវីមិនបានទទួលចំណែកទឹកដី ដែលបានសន្យាទេ
នៅពេលពួកគេទៅដល់ទីនោះ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចធ្វើឱ្យច្បាស់។

ព្រះអម្ចាស់ជាមរតករបស់ពួកគេ

ព្រះអម្ចាស់មានបន្ទូលអំពីទំនាក់ទំនងពិសេស ដែលលោកអ៊ើរ៉ុន
និងកូនចៅរបស់គាត់នឹងមានជាមួយគាត់ដូចជាព្រះអម្ចាស់ជារបស់អ្វីម៉្យាង
ដែលពួកគេនឹងទទួល។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាអ្វីដែលពួកគេនឹងមាន» ឬ
«ព្រះអម្ចាស់នឹងអនុញ្ញាតឱ្យពួកគេបម្រើព្រះអង្គ ហើយព្រះអង្គនឹងផ្គត់ផ្គង់ពួកគេ
តាមរយៈការបម្រើនោះ»

ព្រះអម្ចាស់ ជាព្រះរបស់អ្នក

លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេមនុស្សម្នាក់ ដូច្នេះ
ពាក្យ «របស់អ្នក» នៅទីនេះជាឯកវចនៈ។

មានព្រះបន្ទូលទៅពួកគេហើយ

«បាននិយាយទៅកាន់កុលសម្ព័ន្ធលេវី»

Deuteronomy 10:10

ព័ត៌មានទូទៅ៖

ម៉ូសេនៅតែបន្តរម្លឹកប្រជាជនអ៊ីស្រាអែលអំពីអ្វី
ដែលបានកើតឡើងកាលពីអតីតកាល។

ដូចពីមុន។

«ដំបូង» ជាលេខធម្មតាសម្រាប់លេខមួយ។ សំដៅទៅលើលើកទីមួយ
ដែលលោកម៉ូសេឡើងទៅលើភ្នំស៊ីណាយ ដើម្បីទទួលបន្ទះថ្មពីព្រះអម្ចាស់។
«ដូចដែលខ្ញុំបានធ្វើជាលើកដំបូង»

សែសិបថ្ងៃសែសិបយប់

«៤០ថ្ងៃ ៤០យប់»

បំផ្លាញអ្នករាល់គ្នាទេ។

លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលដូចជាពួកគេមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» នៅទីនេះមានលក្ខណៈជាឯកវចនៈ។

generated on Wed Sep 10 16:16:32 2025

ចាប់យកទឹកដី
«យកទឹកដី» ឬ «កាន់កាប់ទឹកដី»
បុព្វបុរសរបស់ពួកគេ
សំដៅទៅលើលោកអប្រាហាំ លោកអ៊ីសាក និង លោកយ៉ាកុប។
ប្រគល់ឲ្យទៅពួកគេ។
«ដែលយើងនឹងផ្តល់ដល់អ្នក គឺកូនចៅរបស់ពួកគេ»
Deuteronomy 10:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបាននិយាយទៅកាន់ជនជាតិអ៊ីស្រាអែលហាក់ដូចជាពួកគេជាមនុស្សតែម្នាក់
ឥឡូវនេះ អ៊ីស្រាអែលអើយ
នៅទីនេះឈ្មោះ «អ៊ីស្រាអែល» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ឥឡូវនេះ ប្រជាជនអ៊ីស្រាអែល»
តើព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ទាមទារចង់បានអ្វីពីអ្នករាល់គ្នា
គឺចង់ឲ្យអ្នករាល់គ្នាគោរពកោតខ្លាច ... សម្រាប់ជាសេចក្តីល្អដល់អ្នករាល់គ្នា?
លោកម៉ូសេប្រើសំណួរដើម្បីបង្រៀនប្រជាជនអ៊ីស្រាអែល។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«នេះជាអ្វីដែលព្រះអម្ចាស់ជាព្រះរបស់អ្នក តម្រូវឲ្យអ្នករាល់គ្នាធ្វើ ...
ឲ្យអ្នករាល់គ្នាគោរពកោតខ្លាច ... សម្រាប់ជាសេចក្តីល្អដល់អ្នករាល់គ្នា»។
ចូរដើរតាមផ្លូវរបស់ព្រះអង្គ
លោកម៉ូសេនិយាយដូចជាការស្តាប់បង្គាប់ព្រះអម្ចាស់ កំពុងដើរតាមផ្លូវមួយ។
ការបកប្រែផ្សេងទៀត «ត្រូវគោរពតាមសេចក្តីបង្គាប់របស់ព្រះអង្គ»
ឲ្យអស់ពីចិត្ត និងអស់ពីព្រលឹងរបស់អ្នករាល់គ្នា
ឃ្លា «ឲ្យអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង
«អស់ពីព្រលឹងរបស់អ្នករាល់គ្នា» មានន័យថា «អស់ពីខ្លួនអ្នក»។
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ សូមមើលការបកប្រែនៅក្នុង ៤:២៩។
ការបកប្រែផ្សេងទៀត «ដោយអស់ពីសមត្ថភាពរបស់អ្នករាល់គ្នា» ឬ
«ដោយថាមពលទាំងអស់របស់អ្នករាល់គ្នា»។
Deuteronomy 10:14
ព័ត៌មានទូទៅ៖
លោកម៉ូសេបាននិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
មើល៍
ពាក្យថា «មើល៍» បញ្ជាក់ថា អ្វីដែលត្រូវនិយាយបន្ទាប់ មានសារៈសំខាន់ណាស់។
«ចូរយកចិត្តទុកដាក់» ឬ «ចូរមើលទៅ» ឬ «ចូរស្តាប់»
អាកាសវេហាស៍ ... ផែនដី
ពាក្យទាំងនេះបង្ហាញចំនុចជ្រាលជ្រៅពីរ ហើយត្រូវបានបញ្ចូលគ្នាដើម្បីមានន័យថា
អ្វីៗទាំងអស់នៅគ្រប់ទីកន្លែងជារបស់ព្រះអម្ចាស់។
ដ៏ខ្ពស់បំផុត និងផែនដី
សំដៅទៅលើកន្លែងខ្ពស់បំផុតនៅលើមេឃ។
អ្វីៗទាំងអស់នៅលើផែនដីរបស់ព្រះជាម្ចាស់។
បានជ្រើសរើសអ្នករាល់គ្នា
នៅទីនេះពាក្យថា «អ្នករាល់គ្នា »សំដៅទៅលើជនជាតិអ៊ីស្រាអែលទាំងអស់
ហើយជាពហុវចនៈ។
Deuteronomy 10:16
ដូច្នេះ
«ដោយសាររឿងនេះ»
កាត់ស្បែកចិត្តរបស់អ្នករាល់គ្នាចេញ
ពាក្យ «ស្បែកគ្របក្បាលលិង្គ»
សំដៅទៅលើផ្នត់ស្បែកនៅលើផ្នែកឯកជនរបស់បុរស
ដែលត្រូវបានយកចេញក្នុងអំឡុងពេលកាត់ស្បែក។
នៅទីនេះលោកម៉ូសេនិយាយអំពីការកាត់ស្បែក។ មានន័យថា
ប្រជាជនត្រូវតែដកអំពើបាបចេញពីជីវិតរបស់ពួកគេ។
គឺជាព្រះអម្ចាស់លើអស់ទាំង
«ព្រះដ៏ឧត្តមបំផុត» ឬ «ព្រះពិតតែមួយ»
ព្រះអម្ចាស់ ជាព្រះដ៏ធំឧត្តម
«ព្រះអម្ចាស់ដ៏ឧត្តុង្គឧត្តម» ឬ «ព្រះអម្ចាស់ដ៏ឧត្តុង្គឧត្តមបំផុត»
ហើយគួឲ្យស្ញែងខ្លាច
«ព្រះជាម្ចាស់ដែលបណ្តាលឱ្យមនុស្សភ័យខ្លាច»
Deuteronomy 10:18
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ព្រះអង្គរកសេចក្តីយុត្តិធម៌ឲ្យក្មេងកំព្រា
ព្រះអម្ចាស់ធ្វើឲ្យប្រាកដថា មនុស្សប្រព្រឹត្តដោយយុត្តិធម៌ចំពោះក្មេងកំព្រា»
ក្មេងកំព្រា
ទាំងនេះជាកូនៗ ដែលឪពុកម្តាយបានស្លាប់
ហើយមិនមានសាច់ញាតិមើលថែពួកគេទេ។
ស្ត្រីមេម៉ាយ
ស្ត្រីមេម៉ាយពិតគឺជាស្ត្រីម្នាក់
ដែលប្តីរបស់គាត់បានស្លាប់ហើយមិនមានកូនដើម្បីមើលថែរក្សាគាត់ពេលគាត់ចាស់ជរា។
ដូច្នេះ
«ដោយសាររឿងនេះ»
Deuteronomy 10:20
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សតែម្នាក់
ដូច្នេះ រាល់ការកើតឡើងនៃពាក្យ «អ្នក» និង «របស់អ្នក» ជាឯកវចនៈ។
ហើយត្រូវគោរពប្រតិបត្តិដល់ព្រះអម្ចាស់
«ព្រះអង្គជាព្រះដែលអ្នកត្រូវគោរពប្រតិបត្តិ»
ហើយនៅជាប់ជាមួយនឹងព្រះអង្គ
មានគេនិយាយថា
មានទំនាក់ទំនងល្អជាមួយព្រះអម្ចាស់និងពឹងផ្អែកលើព្រះអង្គទាំងស្រុង
ត្រូវបាននិយាយដូចជាមនុស្សនៅជាប់ជាមួយព្រះអម្ចាស់ដែរ។
ការបកប្រែផ្សេងទៀត «អ្នកត្រូវតែពឹងផ្អែកព្រះអង្គ» ឬ
«ព្រះអង្គជាព្រះដែលអ្នកត្រូវតែពឹងផ្អែកលើ»
ហើយអ្នករាល់គ្នាត្រូវស្បថក្នុងនាមព្រះអង្គតែមួយប៉ុណ្ណោះ។
ការស្បថក្នុងនាមព្រះអម្ចាស់មានន័យថា យកព្រះអម្ចាស់ធ្វើជាគោល
ឬអំណាចលើពាក្យសម្បថ។ នៅទីនេះ «ព្រះនាម» តំណាងឱ្យព្រះអម្ចាស់ផ្ទាល់។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៦:១៣ ។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នានឹងស្បថ ហើយសុំឱ្យព្រះអម្ចាស់បញ្ជាក់ពីវា» ឬ
«នៅពេលអ្នករាល់គ្នាស្បថអ្នករាល់គ្នានឹងប្រកាសព្រះនាមរបស់ព្រះអង្គ»
ដូចដែលភ្នែករបស់អ្នករាល់គ្នាបានឃើញស្រាប់ហើយ។
នៅទីនេះ «ភ្នែក» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«ដែលអ្នករាល់គ្នាបានឃើញ»
ចូរលើកតម្កើងដល់ព្រះអង្គ
អាចមានន័យថា ១) «ព្រះអង្គជាព្រះដែលអ្នកត្រូវសរសើរតម្កើង» ឬ ២)
«គឺដោយសារតែអ្នកថ្វាយបង្គំព្រះអង្គ ដូច្នេះ
មនុស្សផ្សេងទៀតនឹងលើកតម្កើងដល់ព្រះអង្គ»
Deuteronomy 10:22
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាពួកគេមនុស្សតែម្នាក់
ដូច្នេះ «អ្នក» និង «របស់អ្នក» មានលក្ខណៈជាឯកវចនៈ។)
បានចុះទៅនៅទឹកដីអេស៊ីប
«ធ្វើដំណើរទៅភាគខាងត្បូងប្រទេសអេស៊ីប» ឬ «បានទៅប្រទេសអេស៊ីប»
ចិតសិបនាក់
«៧០នាក់»
មានគ្នាច្រើនដូចជាផ្កាយនៅលើមេឃ។
នេះបញ្ជាក់ពីជនជាតិអ៊ីស្រាអែលមួយចំនួន ដែលនៅជាមួយលោកម៉ូសេ។
ការបកប្រែផ្សេងទៀត «លើសពីអ្វីដែលអ្នករាល់អាចរាប់បាន»

---

11 [1]ហេតុដូច្នេះ ត្រូវស្រលាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ហើយត្រូវស្តាប់បង្គាប់ កាន់តាមច្បាប់ បញ្ញត្តិ និងបទបញ្ជារបស់ព្រះអង្គជានិច្ច។
[2]ចូរចាំថា ខ្ញុំមិនបាននិយាយទៅកូនចៅរបស់អ្នករាល់គ្នាដែលមិនបានដឹង ហើយគេក៏មិនបានឃើញការដាក់ទោសរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ឃើញពីភាពដ៏ឧត្តុង្គឧត្តម ឫទ្ធិបារមី និងតេជានុភាព ព្រះហស្តដ៏មានគ្រប់ទាំងព្រះចេស្តា ឬព្រះពាហុដែលលើកសម្រេចរបស់ព្រះអង្គ[3]ទីសម្គាល់ និងការអស្ចារ្យទាំងប៉ុន្មាន
ដែលព្រះអង្គបានធ្វើនៅទឹកដីអេស៊ីប ទាស់ប្រឆាំងនឹងព្រះចៅផារ៉ោន ជាស្តេចនៃទឹកដីអេស៊ីប និងប្រជាជនក្នុងទឹកដីនោះទាំងមូលផង។

generated on Wed Sep 10 16:16:32 2025

[4]ទាំងពីការដែលព្រះអង្គបានប្រហារដល់កងទ័ពអេស៊ីប ទាំងកងពលសេះ និងរទេះចម្បាំងរបស់ពួកគេ ព្រះអង្គបានធ្វើឲ្យទឹកសមុទ្រដើមត្រែងហូរគ្របពីលើពួកគេ
នៅពេលដែលពួកគេដេញតាមអ្នករាល់គ្នា ហើយព្រះអម្ចាស់បានបំផ្លាញពួកគេរហូតមកដល់សព្វថ្ងៃនេះ[5]ព្រះអង្គបានជួយអ្នករាល់គ្នានៅទីរហោស្ថាន
រហូតមកដល់ទីនេះ។
[6]ពួកគេមិនបានឃើញការដែលព្រះអម្ចាស់បានធ្វើចំពោះ លោកដាថាន និងលោកអប៊ីរ៉ាម ជាកូនរបស់លោកអេលាប ជាពូជពង្សរូបេន ដែលឲ្យដីស្រូបពួកគេ
ព្រមទាំងក្រុមគ្រួសារ និងជំរំរបស់គេ និងអស់អ្នកដែលរួមគំនិតជាមួយពួកគេ នៅកណ្ដាលចំណោមជនជាតិអ៊ីស្រាអែលទាំងមូល។[7]ដ្បិត
អ្នករាល់គ្នាបានឃើញផ្ទាល់នឹងភ្នែកពីការអស្ចារ្យដ៏ធំៗដែលព្រះអម្ចាស់បានធ្វើ។
[8]ដូច្នេះ ត្រូវកាន់តាមបទបញ្ជាទាំងប៉ុន្មាន ដែលយើងបានបង្គាប់មកអ្នករាល់គ្នានៅថ្ងៃនេះ នោះ អ្នករាល់គ្នានឹងមានកម្លាំង ហើយទៅចាប់យកទឹកដី
ដែលអ្នករាល់គ្នាត្រូវឆ្លងកាត់
ហើយកាន់កាប់ជាកម្មសិទ្ធិ[9]និងដើម្បីឲ្យអ្នករាល់គ្នាមានអាយុយឺនយូរក្នុងទឹកដីដែលព្រះអម្ចាស់បានស្បថថានឹងប្រទានឲ្យបុព្វបុរសរបស់អ្នករាល់គ្នា
និងដល់ពូជពង្សរបស់ពួកគេ ជាទឹកដីដែលសម្បូរទឹកដោះ និងទឹកឃ្មុំហូរហៀរ។
[10]ដ្បិត ទឹកដីដែលអ្នករាល់គ្នាចាប់ទៅយកនោះ វាមិនដូចជាទឹកដីអេស៊ីប ដែលអ្នករាល់គ្នាចេញមកនោះទេ ហើយជាទឹកដីដែលអ្នកករាល់គ្នាសាបព្រោះ
ត្រូវបាចទឹកបញ្ចូលស្រែ ដូចជានៅសួនបន្លែនោះដែរ[11]ប៉ុន្តែ ទឹកដី ដែលអ្នករាល់គ្នាទៅកាន់កាប់នោះ ជាទឹកដីដែលមានភ្នំ និងជ្រលងភ្នំ
ហើយក៏មានភ្លៀងធ្លាក់ស្រោចស្រពដីស្រែចម្ការ[12]ជាទឹកដីដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាយកព្រះហឫទ័យទុកដាក់
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាតែងតែទតមើលទឹកដីនោះជានិច្ច គឺចាប់ពីដើមឆ្នាំរហូតដល់ចុងឆ្នាំ។
[13]ប្រសិនបើ អ្នករាល់គ្នាយកចិត្តទុកដាក់ធ្វើតាមបទបញ្ជារបស់ព្រះ ដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ គឺត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ហើយត្រូវគោរពបម្រើព្រះអង្គឲ្យអស់ពីចិត្ត អស់ពីព្រលឹងរបស់អ្នករាល់គ្នា[14]នោះ ព្រះអង្គនឹងប្រទានឲ្យមានភ្លៀងធ្លាក់មកលើទឹកដីរបស់អ្នកតាមរដូវកាល
គឺជាភ្លៀងនៅដើមរដូវ និងភ្លៀងនៅចុងរដូវ ដើម្បីឲ្យអ្នករាល់គ្នាអាចប្រមូលផលស្រូវ ស្រាទំពាំងបាយជូរថ្មី និងប្រេង។[15]យើងនឹងធ្វើឲ្យមានស្មៅដុះនៅតាមទីវាលស្រែ
សម្រាប់ហ្វូងសត្វរបស់អ្នករាល់គ្នា ហើយអ្នកនឹងមានអាហារបរិភោគយ៉ាងហូរហៀរ។
[16]ចូរប្រយ័ត្ន ចំពោះខ្លួនឯង ដើម្បីកុំឲ្យចិត្តអ្នករាល់គ្នាត្រូវសេចក្ដីល្បួង ហើយបែរទៅគោរពបម្រើ ហើយក្រាបថ្វាយបង្គំព្រះដទៃ និងលុតជង្គង់ចំពោះព្រះទាំងនោះឡើយ
[17]បើមិនដូច្នេះទេ សេចក្ដីក្រោធនៃព្រះអម្ចាស់ទាស់នឹងអ្នករាល់គ្នា ហើយព្រះអង្គនឹងបង្ខាំងមេឃមិនឲ្យមានភ្លៀង ហើយដីក៏មិនបង្កើតផលផ្លែដែរ
នោះអ្នករាល់គ្នានឹងត្រូវវិនាសយ៉ាងឆាប់ពីទឹកដីដ៏ល្អ ដែលព្រះអម្ចាស់ប្រទានឲ្យអ្នករាល់គ្នា។
[18]ដូច្នេះ ត្រូវរក្សាទុកព្រះបន្ទូលដែលខ្ញុំថ្លែងប្រាប់ ឲ្យដក់ជាប់នៅក្នុងចិត្ត ក្នុងព្រលឹងរបស់អ្នករាល់គ្នា ហើយត្រូវចងព្រះបន្ទូលទាំងនេះ ទុកជាទីសម្គាល់ ជាប់នៅនឹងដៃ
ហើយជាស្លាកនៅលើថ្ងាសអ្នករាល់គ្នា។[19]ចូរបង្រៀនសេចក្ដីទាំងនេះដល់កូនចៅអ្នករាល់គ្នា ដោយនិយាយប្រាប់ពួកគេ នៅពេលអ្នករាល់គ្នានៅផ្ទះ
ពេលអ្នករាល់គ្នាធ្វើដំណើរតាមផ្លូវ ពេលអ្នករាល់គ្នាចូលដំណេក និងពេលអ្នករាល់គ្នាក្រោកពីដំណេកផង។
[20]ចូរសរសេរសេចក្ដីទាំងនេះ នៅលើក្របទ្វារផ្ទះរបស់អ្នករាល់គ្នា និងនៅលើខ្លោងទ្វារក្រុងរបស់អ្នករាល់គ្នាដែរ។[21]ដើម្បីឲ្យអ្នករាល់គ្នា
ព្រមទាំងកូនចៅរបស់អ្នករាល់គ្នាមានអាយុវែង នៅក្នុងទឹកដីដែលព្រះអម្ចាស់ស្បថ និងប្រគល់ឲ្យបុព្វបុរសរបស់អ្នករាល់គ្នា គឺវែងដូចជាផ្ទៃមេឃដែលនៅលើផែនដីដែរ។
[22]ប្រសិនបើ អ្នករាល់គ្នាយកចិត្តទុកដាក់កាន់តាម និងប្រតិបត្តិតាមបទបញ្ជាទាំងអស់ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ព្រមទាំងដើរតាមផ្លូវរបស់ព្រះអង្គ ហើយនៅជាប់ជាមួយនឹងព្រះអង្គ[23]នោះ ព្រះអម្ចាស់នឹងបណ្ដេញប្រជាជាតិទាំងនេះចេញពីមុខអ្នករាល់គ្នា
ហើយអ្នករាល់គ្នានឹងចាប់យកទឹកដីរបស់ប្រជាជាតិនានាដែលធំ ហើយខ្លាំងពូកែជាងអ្នករាល់គ្នា។
[24]ទីកន្លែងណាដែលអ្នករាល់គ្នាដាក់ជើងជាន់ នោះនឹងបានជាកម្មសិទ្ធិរបស់អ្នករាល់គ្នា ព្រំប្រទល់របស់អ្នករាល់គ្នានឹងបានចាប់តាំងពីទីវាលហោស្ថាន
រហូតដល់ទឹកដីលីបង់ និងពីទន្លេ គឺទន្លេអឺប្រាតរហូតដល់សមុទ្រមេឌីទែរ៉ាណេ។[25]គ្មាននរណាម្នាក់នឹងអាចឈរតទល់នឹងអ្នករាល់គ្នាបានឡើយ។ ព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នានឹងធ្វើឲ្យប្រជាជននៅក្នុងទឹកដីទាំងប៉ុន្មាន ដែលអ្នករាល់គ្នាឆ្លងកាត់ ភិតភ័យ ហើយខ្លាចអ្នករាល់គ្នា ដូចព្រះអង្គបានសន្យានឹងអ្នករាល់គ្នា។
[26]មើល៍ នៅថ្ងៃនេះ ខ្ញុំដាក់ព្រះពរ និងបណ្ដាសានៅមុខអ្នករាល់គ្នា[27]ប្រសិនបើ អ្នករាល់គ្នាគោរពតាមបទបញ្ជារបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ នោះអ្នករាល់គ្នានឹងទទួលបានព្រះពរ[28]តែប្រសិនបើ អ្នករាល់គ្នាមិនគោរពតាមបទបញ្ជារបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាទេ
ហើយងាកចេញពីផ្លូវដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ ហើយទៅតាមព្រះដទៃដែលអ្នករាល់គ្នាមិនស្គាល់ នោះនឹងត្រូវបណ្ដាសាជាមិនខាន។
[29]ពេលណាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា បាននាំអ្នករាល់គ្នាទៅក្នុងទឹកដីដែលអ្នករាល់គ្នាត្រូវទៅចាប់យក នោះអ្នករាល់គ្នាត្រូវប្រកាសអំពីព្រះពរនៅលើភ្នំកេរិស៊ីម
និងបណ្ដាសានៅលើភ្នំអេបាល។[30]តើអ្នករាល់គ្នាបានស្គាល់ហើយថា ភ្នំទាំងពីរនេះ ស្ថិតនៅត្រើយខាងនាយទន្លេយ័រដាន់ គឺនៅតាមផ្លូវទៅទិសខាងលិច
ក្នុងទឹកដីរបស់ជនជាតិកាណាន ដែលរស់នៅតាមវាលទំនាបអារ៉ាបា ទល់មុខទៅគីកាល់ ជិតដើមម៉ៃសាក់នៅម៉ូរេ?
[31]ដ្បិត អ្នករាល់គ្នាត្រូវឆ្លងទន្លេយ័រដាន់ ដើម្បីឆ្ពោះទៅចាប់យកទឹកដីដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ប្រទានឲ្យអ្នករាល់គ្នា ហើយត្រូវរស់នៅក្នុងទឹកដីនោះ
ដែលអ្នករាល់គ្នាបានចាប់យក។[32]អ្នករាល់គ្នាត្រូវតាមអស់ទាំងច្បាប់ និងបញ្ញត្តិទាំងប៉ុន្មាន ដែលខ្ញុំប្រគល់ឲ្យទៅអ្នករាល់គ្នានៅថ្ងៃនេះ។

Deuteronomy 11:1
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវស្តាប់បង្គាប់
«ស្តាប់តាមជានិច្ច»
Deuteronomy 11:2
ដែលមិនបានដឹង ហើយគេក៏មិនបានឃើញ
«អ្នកដែលមិនមានបទពិសោធន៍»
ព្រះហស្តដ៏មានគ្រប់ទាំងព្រះចេស្តា ឬព្រះពាហុដែលលើកសម្រេចរបស់ព្រះអង្គ
នេះជា «ព្រះហស្តដ៏មានគ្រប់ទាំងព្រះចេស្តា» និង «ព្រះពាហុដែលលើកសម្រេច
របស់ព្រះអង្គ» ជានិមិត្តរូបនៃអំណាចរបស់ព្រះអម្ចាស់។
ពាក្យស្រដៀងគ្នានេះកើតមាននៅក្នុង ៤:៣៤។ ការបកប្រែផ្សេងទៀត
«ឬអំណាចដ៏ខ្លាំងពូកែរបស់ព្រះអង្គ»
នៅទឹកដីអេស៊ីប
«នៅអេស៊ីប »
ប្រជាជនក្នុងទឹកដីនោះទាំងមូលផង។
នៅទីនេះ «ទឹកដី »តំណាងឱ្យប្រជាជន។ ការបកប្រែផ្សេងទៀត
«ទៅកាន់ប្រជាជនរបស់ព្រះអង្គទាំងអស់»
Deuteronomy 11:4
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដែលជាមនុស្សពេញវ័យ
មានអាយុល្មមនឹងឃើញនូវអ្វីដែលព្រះជាម្ចាស់បានធ្វើនៅស្រុកអេស៊ីប។
ទាំងពីការដែលព្រះអង្គបានប្រហារដល់
«កូនៗរបស់អ្នកក៏មិនបានឃើញអំពីអ្វី ដែលព្រះអម្ចាស់បានធ្វើដែរ»
កងទ័ពអេស៊ីប
«ទាហានអេស៊ីប»
ពួកគេដេញតាមអ្នករាល់គ្នា
នៅទីនេះ «អ្នករាល់គ្នា» មានន័យថា
ប្រជាជនអ៊ីស្រាអែលមានអាយុប្រហែល៤០ឆ្នាំ។
រហូតមកដល់ទីនេះ។
មានន័យថា ជ្រលងភ្នំនៃទន្លេយ័រដាន់ជាកន្លែង
ដែលលោកម៉ូសេកំពុងនិយាយទៅកាន់ពួកគេ
មុនពេលពួកគេឆ្លងទៅស្រុកកាណាន។
Deuteronomy 11:6

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែបន្តរម្លឹកមនុស្សពេញវ័យ ឱ្យបង្រៀនកូនៗរបស់ពួកគេ
អំពីការអស្ចារ្យរបស់ព្រះជាម្ចាស់។
លោកដាថាន និងលោកអប៊ីរ៉ាម ជាកូនរបស់លោកអេលាប
លោកម៉ូសេកំពុងតែសំដៅទៅលើព្រឹត្តិការណ៍មួយ កាលពីអតីតកាល
នៅពេលលោកដាថាន និងលោកអប៊ីរ៉ាមបានបះបោរប្រឆាំងនឹងលោកម៉ូសេ
និងលោកអ៊ើរ៉ុន។ អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចធ្វើឱ្យច្បាស់។
លោកដាថាន ...លោកអប៊ីរ៉ាម...លោកអេលាប
ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។
ជាកូនរបស់លោកអេលាប
«កូនចៅរបស់លោករូបេន»
ដែលឲ្យដីស្រូបពួកគេ
ព្រះអម្ចាស់ធ្វើឱ្យដីញែកពីគ្នា ដើម្បីប្រជាជនធ្លាក់ចូលក្នុងដីដូចគេនិយាយថា
ដីមានមាត់និងសមត្ថភាពលេបប្រជាជន។
អស់អ្នកដែលរួមគំនិតជាមួយពួកគេ
សំដៅទៅលើអ្នកបម្រើ និងសត្វរបស់ពួកគេ។
នៅកណ្តាលចំណោមជនជាតិអ៊ីស្រាអែលទាំងមូល។
នេះមានន័យថា ប្រជាជនអ៊ីស្រាអែលទាំងអស់បានឃើញផ្ទាល់នឹងភ្នែកអំពីអ្វី
ដែលបានកើតឡើងចំពោះលោកដាថាន លោកអប៊ីរ៉ាម គ្រួសាររបស់ពួកគេ
និងទ្រព្យសម្បត្តិរបស់ពួកគេ។
ដ្បិត អ្នករាល់គ្នាបានឃើញ
នៅទីនេះ «ឃើញ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត «ប៉ុន្តែ
អ្នករាល់គ្នាបានឃើញ»
Deuteronomy 11:8
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចាប់យកទឹកដី
«យកទឹកដី»
ដែលអ្នករាល់គ្នាត្រូវឆ្លងកាត់ ហើយកាន់កាប់ជាកម្មសិទ្ធិ
ឃ្លាដែលថា «ត្រូវឆ្លងកាត់» ត្រូវបានប្រើ
ពីព្រោះប្រជាជនអ៊ីស្រាអែលនឹងត្រូវឆ្លងកាត់ទន្លេយ័រដាន់
ដើម្បីចូលទៅស្រុកកាណាន។
អ្នករាល់គ្នាមានអាយុយឺនយូរ
អាយុយឺនយូរជាពាក្យប្រៀបធៀបសម្រាប់ជីវិតដ៏យឺនយូរ។ ការបកប្រែផ្សេងទៀត
«អាចរស់នៅបានយូរអង្វែង» បកប្រែពាក្យទាំងនេះដូចនៅក្នុង ៤:២៥។
ជាទឹកដីដែលសម្បូរទឹកដោះ និងទឹកឃ្មុំហូរហៀរ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ទឹកដីដែលមានទឹកដោះ
និងទឹកឃ្មុំហូរច្រើន» ឬ «ទឹកដីល្អសម្រាប់សត្វនិងការធ្វើកសិកម្ម»
សូមមើលការបកប្រែនៅក្នុង ៦:៣។
Deuteronomy 11:10
ត្រូវបាចទឹកបញ្ចូលស្រែ
អាចមានន័យថា ១) «ជើង» នៅខាងលើតំណាងឱ្យការខិតខំដើរ
ដើម្បីនាំទឹកទៅដល់វាលស្រែ ឬ២)
ពួកគេនឹងប្រើជើងរបស់ពួកគេដើម្បីបង្វិលរហាត់ទឹក ដែលផ្គត់ផ្គង់ទឹកដល់ទីវាល។
ដូចជានៅសួនបន្លែនោះដែរ
«សួនបន្លែ» ឬ «សួននៃបន្លែ»
ហើយក៏មានភ្លៀងធ្លាក់ស្រោចស្រពដីស្រែចម្ការ
ទឹកដីទទួលនិងស្រូបយកទឹកភ្លៀងច្រើនត្រូវបានគេនិយាយ
ដូចជាដីកំពុងស្រូបទឹក។ ការបកប្រែផ្សេងទៀត
«ភ្លៀងពីលើមេឃផ្តល់ទឹកបានច្រើន»
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាតែងតែទតមើលទឹកដីនោះជានិច្ច
នៅទីនេះ «ទតមើល» តំណាងឱ្យការយកចិត្តទុកដាក់ និងការថែរក្សា។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
តែងតែឃ្លាំមើលទឹកដីជានិច្ច»
គឺចាប់ពីដើមឆ្នាំរហូតដល់ចុងឆ្នាំ។
នៅទីនេះសំខាន់បំផុតពីរ «ដើម» និង «ចុង» ត្រូវបានប្រើរួមគ្នាដើម្បីមានន័យថា
ពេញមួយឆ្នាំ។ ការបកប្រែផ្សេងទៀត «បន្តពេញមួយឆ្នាំ»
Deuteronomy 11:13
ប្រសិនបើ
មានន័យថា អ្វីដែលព្រះអម្ចាស់សន្យានឹងកើតឡើង
បើជនជាតិអ៊ីស្រាអែលធ្វើតាមការបង្គាប់របស់ព្រះអង្គ។
ដែលខ្ញុំបង្គាប់
នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកម៉ូសេ។
ឲ្យអស់ពីចិត្ត អស់ពីព្រលឹងរបស់អ្នករាល់គ្នា
ឃ្លា «ឱ្យអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង «អស់ពី ... ព្រលឹង»
មានន័យថា «អស់ពីខ្លួនអ្នក»។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
សូមមើលការបកប្រែនៅក្នុង ៤:២៩ ។ ការបកប្រែផ្សេងទៀត
«ដោយអស់ពីសមត្ថភាពរបស់អ្នករាល់គ្នា» ឬ
«ដោយថាមពលរបស់អ្នករាល់គ្នាទាំងអស់» (សូមមើល and
ព្រះអង្គនឹងប្រទានឲ្យមានភ្លៀងធ្លាក់មកលើទឹកដីរបស់អ្នកតាមរដូវកាល
«ព្រះអង្គនឹងធ្វើឱ្យមានភ្លៀងនៅលើទឹកដីរបស់អ្នក តាមរដូវកាលល្អ»
ព្រះអង្គនឹងប្រទានឲ្យ
នៅទីនេះ «ព្រះអង្គ»នឹងប្រទានឱ្យសំដៅទៅលើព្រះអម្ចាស់។
អាចបញ្ជាក់ជាបុរសទីបី។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងប្រទានឲ្យ» ឬ
«ព្រះអង្គនឹងប្រទានឱ្យ»
គឺជាភ្លៀងនៅដើមរដូវ និងភ្លៀងនៅចុងរដូវ
សំដៅទៅលើទឹកភ្លៀងនៅដើមរដូវសាបព្រោះ
និងភ្លៀងសម្រាប់ការប្រមូលផលដំណាំ។ ការបកប្រែផ្សេងទៀត
«ភ្លៀងរដូវស្លឹកឈើជ្រុះ និងរដូវផ្ការីក» ឬ «ភ្លៀងទៀងទាត់តាមរដូវ»
Deuteronomy 11:16
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចូរប្រយ័ត្ន ចំពោះខ្លួនឯង
«ចូរប្រយ័ត្ន» ឬ «ប្រយ័ត្នខ្លួន»
ដើម្បីកុំឲ្យចិត្តអ្នករាល់គ្នាត្រូវសេចក្តីល្បួង
នៅទីនេះ «ចិត្ត» តំណាងឱ្យបំណងប្រាថ្នា ឬគំនិតរបស់មនុស្សម្នាក់។
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីកុំឱ្យសេចក្តីប៉ងប្រាថ្នារបស់អ្នកបោកបញ្ឆោតអ្នករាល់គ្នា» ឬ
«ដើម្បីកុំឱ្យអ្នករាល់គ្នាបោកបញ្ឆោតខ្លួនឯង»
ហើយបែរទៅគោរពបម្រើ ហើយក្រាបថ្វាយបង្គំព្រះដទៃ
ការបដិសេធព្រះអម្ចាស់ និងក្រាបថ្វាយបង្គំព្រះដទៃ ត្រូវបានគេនិយាយថា
មនុស្សនោះបែរខ្លួនទៅរកទិសដៅខុសពីព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«អ្នកចាប់ផ្តើមក្រាបថ្វាយបង្គំព្រះដទៃ»
បើមិនដូច្នេះទេ សេចក្តីក្រោធនៃព្រះអម្ចាស់ទាស់នឹងអ្នករាល់គ្នា
ព្រះជាម្ចាស់ត្រឡប់ជាមានសេចក្តីក្រោធ
ត្រូវបានគេនិយាយដូចជាភ្លើងដែលកំពុងឆេះ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីកុំឱ្យព្រះអម្ចាស់ត្រឡប់ជាមានសេចក្តីក្រោធ នឹងអ្នករាល់គ្នា»
ហើយព្រះអង្គនឹងបង្ខាំងមេឃមិនឲ្យមានភ្លៀង ហើយដីក៏មិនបង្កើតផលផ្លែដែរ
ព្រះជាម្ចាស់មិនឱ្យមានភ្លៀងធ្លាក់ពីលើមេឃ
ត្រូវបានគេនិយាយដូចជាព្រះអង្គកំពុងបិទផ្ទៃមេឃ។ ការបកប្រែផ្សេងទៀត «ដូច្នេះ
ព្រះអង្គបង្ខាំងមិនឲ្យមានភ្លៀងធ្លាក់ពីលើមេឃ
ដើម្បីកុំឱ្យដំណាំរីកលូតលាស់ឡើងនៅលើដី» សូមមើល
Deuteronomy 11:18
ត្រូវរក្សាទុកព្រះបន្ទូលដែលខ្ញុំថ្លែងប្រាប់ ឲ្យដក់ជាប់នៅក្នុងចិត្ត ក្នុងព្រលឹងរបស់អ្នករាល់គ្នា
មនុស្សតែងតែគិត និងពិចារណាអំពីអ្វី ដែលលោកម៉ូសេបានបង្គាប់
គឺត្រូវនិយាយដូចជាចិត្ត និងព្រលឹងជាអ្នកទទួល
ហើយពាក្យរបស់លោកម៉ូសេជាមាតិកា ដែលត្រូវបំពេញក្នុងអ្នកទទួល។
ការបកប្រែផ្សេងទៀត «សូមប្រយ័ត្នដើម្បីចងចាំពាក្យទាំងនេះ
ដែលខ្ញុំកំពុងនិយាយទៅកាន់អ្នក»
ព្រះបន្ទូលដែលខ្ញុំថ្លែងប្រាប់
នៅទីនេះ «ព្រះបន្ទូល» តំណាងឱ្យបទបញ្ជាដែលលោកម៉ូសេកំពុងនិយាយ។
នៅក្នុងចិត្ត ក្នុងព្រលឹងរបស់អ្នករាល់គ្នា
នៅទីនេះ «ចិត្ត» និង «ព្រលឹង» តំណាងឱ្យគំនិត ឬការគិតរបស់មនុស្សម្នាក់។
ហើយត្រូវចងព្រះបន្ទូលទាំងនេះ
«ចងព្រះបន្ទូលទាំងនេះ»។
ពាក្យនៅខាងលើនេះតំណាងឱ្យមនុស្សម្នាក់សរសេរព្រះបន្ទូលនៅលើក្រាំងស្បែកមួយ
ដាក់ក្រាំងស្បែកនៅក្នុងថង់មួយ ហើយចងមាត់ថង់។ ហើយចងមាត់ថង់ដូច្នេះ

generated on Wed Sep 10 16:16:32 2025

វានៅចន្លោះភ្នែករបស់អ្នក។
ខាងលើនេះអាចជាពាក្យប្រៀបធៀបមួយដែលមានន័យថា
ប្រជាជនត្រូវប្រុងប្រយ័ត្នគោរពតាមបទបញ្ជារបស់លោកម៉ូសេ។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៦:៨។
ទុកជាទីសម្គាល់ ជាប់នៅនឹងដៃ
«ជាអ្វីមួយដើម្បីធ្វើឱ្យអ្នកចងចាំក្រឹត្យវិន័យរបស់យើង
ហើយជាស្លាកនៅលើថ្ងាសអ្នករាល់គ្នា។
« សូមឱ្យពាក្យរបស់យើងនៅពីលើថ្ងាសរបស់អ្នករាល់គ្នា»។ ពាក្យខាងលើនេះ
តំណាងឱ្យមនុស្សម្នាក់
ដែលសរសេរពាក្យរបស់លោកម៉ូសេនៅលើឆែកឆេរដាក់ឆ័ត្រក្នុងកាបូបហើយចងខ្សែក្រវាត់
ដូច្នេះ វាស្ថិតនៅចន្លោះភ្នែករបស់គាត់។
ពាក្យមេតាណុលនេះអាចជាពាក្យប្រៀបធៀប ដែលមានន័យថា
មនុស្សត្រូវតែប្រុងប្រយ័ត្នគោរពតាមរាល់បទបញ្ជារបស់ម៉ូសេ។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៦:៨។
ថ្ងាស
លម្អមនុស្សពាក់នៅលើថ្ងាស។
នៅពេលអ្នករាល់គ្នានៅផ្ទះ ពេលអ្នករាល់គ្នាធ្វើដំណើរតាមផ្លូវ ពេលអ្នករាល់គ្នាចូលដំណេក
និងពេលអ្នករាល់គ្នាក្រោកពីដំណេកផង។
ការប្រើកន្លែងផ្សេងៗគ្នា «អ្នករាល់គ្នានៅផ្ទះ» និង «តាមផ្លូវ» និងនៅក្រៅផ្ទះ
«ពេលអ្នករាល់គ្នាចូលដំណេក »និង«ក្រោកពីដំណេក»
តំណាងឱ្យគ្រប់ទីកន្លែងគ្រប់ពេលវេលា។
ប្រជាជនអ៊ីស្រាអែលត្រូវពិភាក្សាបទបញ្ជារបស់ព្រះជាម្ចាស់
ហើយបង្រៀនពួកគេគ្រប់ពេល និងគ្រប់ទីកន្លែង។
Deuteronomy 11:20
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចូរសរសេរសេចក្តីទាំងនេះ នៅលើក្របទ្វារផ្ទះរបស់អ្នករាល់គ្នា
និងនៅលើខ្លោងទ្វារក្រុងរបស់អ្នករាល់គ្នាដែរ។
បកប្រែពាក្យទាំងនេះដូចនៅក្នុង ៦: ៨ ។
ដើម្បីឲ្យអ្នករាល់គ្នា ព្រមទាំងកូនចៅរបស់អ្នករាល់គ្នាមានអាយុវែង
នៅទីនេះ «ថ្ងៃ» តំណាងឱ្យរយៈពេលយូរជាងនេះ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងធ្វើឱ្យអ្នករាល់គ្នា និងកូនរបស់អ្នករាល់គ្នារស់នៅមានអាយុវែង»
ប្រគល់ឲ្យបុព្វបុរសរបស់អ្នករាល់គ្នា
នេះសំដៅទៅលើលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប។
គឺវែងដូចជាផ្ទៃមេឃដែលនៅលើផែនដីដែរ។
នេះការប្រៀបធៀបរយៈពេលដែលប្រជាជនអាចរស់នៅលើផែនដីបានយូរ
ដូចផ្ទៃមេឃមាននៅលើពីផែនដី។ នេះជាវិធីនៃការនិយាយថា «ជារៀងរហូត» ។
ការបកប្រែផ្សេងទៀត «ប្រគល់ឱ្យពួកគេនូវកម្មសិទ្ធិជារៀងរហូត»ឬ
«ដើម្បីអនុញ្ញាតឱ្យពួកគេរស់នៅទីនោះជារៀងរហូត»
Deuteronomy 11:22
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប្រសិនបើ អ្នករាល់គ្នាយកចិត្តទុកដាក់កាន់តាម
និងប្រតិបត្តិតាមបទបញ្ជាទាំងអស់ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា
«ប្រសិនបើអ្នករាល់គ្នាប្រុងប្រយ័ត្នធ្វើអ្វីគ្រប់យ៉ាង ដែលខ្ញុំបទបញ្ជាអ្នករាល់គ្នា»
ដើរតាមផ្លូវរបស់ព្រះអង្គ
បៀបដែលព្រះអម្ចាស់សព្វព្រះហឫទ័យឱ្យមនុស្សរស់នៅ និងប្រព្រឹត្តតាម
គឺត្រូវបានគេនិយាយដូចជាពួកគេជាមាគ៌ារបស់ព្រះអម្ចាស់ ឬផ្លូវ។
មនុស្សស្តាប់បង្គាប់ព្រះអម្ចាស់ត្រូវបានគេនិយាយដូចជាកំពុងដើរតាមមាគ៌ារបស់ព្រះអម្ចាស់ឬផ្លូវ។
នៅជាប់ជាមួយនឹងព្រះអង្គ
មានគេនិយាយថាដើម្បីមានទំនាក់ទំនងល្អជាមួយព្រះអម្ចាស់
និងពឹងផ្អែកលើព្រះអង្គ
ទាំងស្រុងគឺប្រៀបដូចជាមនុស្សនៅជាប់ជាមួយនឹងព្រះអម្ចាស់ដែរ។
ការបកប្រែផ្សេងទៀត «ពឹងផ្អែកលើព្រះអង្គ » ឬ
«ឱ្យមានទំនាក់ទំនងល្អជាមួយព្រះអង្គ»
មើលរបៀបដែលពាក្យស្រដៀងគ្នាត្រូវបានបកប្រែនៅក្នុង ១០:២០ ។
បណ្តេញប្រជាជាតិទាំងនេះចេញពីមុខអ្នករាល់គ្នា
ហើយអ្នករាល់គ្នានឹងចាប់យកទឹកដីរបស់ប្រជាជាតិនានា
នៅទីនេះ «ប្រជាជាតិ» តំណាងឱ្យក្រុមប្រជាជន
ដែលរស់នៅក្នុងទឹកដីកាណានរួចហើយ។ ការបកប្រែផ្សេងទៀត
«ក្រុមមនុស្សទាំងអស់នេះពីមុខអ្នករាល់គ្នា
ហើយអ្នករាល់គ្នានឹងយកទឹកដីពីក្រុមមនុស្ស»
ដែលធំ ហើយខ្លាំងពូកែជាងអ្នករាល់គ្នា។
ទោះបីកងទ័ពអ៊ីស្រាអែលតិចជាង
និងខ្សោយជាងក្រុមប្រជាជនដែលរស់នៅស្រុកកាណានក៏ដោយ
ក៏ព្រះអម្ចាស់នឹងជួយអោយជនជាតិអ៊ីស្រាអែលមានជ័យជម្នះលើពួកគេបានដែរ។
Deuteronomy 11:24
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ទីកន្លែងណាដែលអ្នករាល់គ្នាដាក់ជើងជាន់
នៅទីនេះ «ដាក់ជើងជាន់» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«គ្រប់ទីកន្លែងដែលអ្នករាល់គ្នាទៅ»
ពីទន្លេ គឺទន្លេអឺប្រាត
«ចាប់ពីទន្លេអឺប្រាត»
គ្មាននរណាម្នាក់នឹងអាចឈរតទល់នឹងអ្នករាល់គ្នាបានឡើយ។
ឃ្លាថា «ឈរតទល់នឹងអ្នករាល់គ្នា» ជាឃ្លាបែបសំនួនវោហាស័ព្ទ។
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់អាចបញ្ឈប់អ្នកបាន» ឬ
«គ្មាននរណាម្នាក់អាចប្រឆាំងនឹងអ្នករាល់គ្នាបានទេ»
ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នានឹងធ្វើឲ្យប្រជាជននៅក្នុងទឹកដីទាំងប៉ុន្មាន
ដែលអ្នករាល់គ្នាឆ្លងកាត់ ភិតភ័យ ហើយខ្លាចអ្នករាល់គ្នាtread on
ព្រះអម្ចាស់ធ្វើឱ្យប្រជាជនភ័យរន្ធត់ ដោយគេនិយាយថាដូចជាការភ័យខ្លាច
និងភិតភ័យដែលព្រះអង្គដាក់លើប្រជាជន។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា នឹងធ្វើឱ្យប្រជាជននៅគ្រប់ទីកន្លែង
ដែលអ្នកទៅ គេនឹងភ័យខ្លាចអ្នករាល់គ្នា»
ភិតភ័យ ហើយខ្លាចអ្នករាល់គ្នា
ពាក្យថា «ភិតភ័យ» ហើយ «ខ្លាច»
មានន័យដូចគ្នាហើយបញ្ជាក់ទៅលើកម្លាំងនៃការភ័យខ្លាច។ ការបកប្រែផ្សេងទៀត
«ការភ័យខ្លាចដ៏អាក្រក់ខ្លាចរបស់អ្នករាល់គ្នា»
នៅក្នុងទឹកដីទាំងប៉ុន្មាន ដែលអ្នករាល់គ្នាឆ្លងកាត់
នៅទីនេះពាក្យ «ទឹកដី» នៅខាងលើសម្រាប់ប្រជាជនទាំងអស់នៅក្នុងទឹកដី។
ការបកប្រែផ្សេងទៀត «លើប្រជាជនទាំងអស់នៅគ្រប់ទីកន្លែង
ដែលអ្នករាល់គ្នាទៅ»
Deuteronomy 11:26
ព័ត៌មានទូទៅ៖
នៅទីនេះ
លោកម៉ូសេសង្ខេបពីជម្រើសពីរដែលប្រជាជនអ៊ីស្រាអែលអាចជ្រើសរើសបាន។
ពួកគេអាចជ្រើសរើសធ្វើតាម និងទទួលព្រះពរពីព្រះជាម្ចាស់
ឬពួកគេអាចជ្រើសរើសមិនស្តាប់បង្គាប់ និងទទួលការដាក់ទោសពីព្រះជាម្ចាស់។
មើល៍
«យកចិត្តទុកដាក់»
ទទួលបានព្រះពរ
នាមអរូបីនេះអាចបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់នឹងប្រទានពរអ្នក»
នៅថ្ងៃនេះ ខ្ញុំដាក់ព្រះពរ និងបណ្តាសានៅមុខអ្នករាល់គ្នា
ការអនុញ្ញាតឱ្យប្រជាជនជ្រើសរើស ថាតើពួកគេចង់ឱ្យព្រះជាម្ចាស់ប្រទានពរ
ឬដាក់បណ្តាសាអ្នករាល់គ្នា គឺត្រូវបាននិយាយដូចជាព្រះពរ និងបណ្តាសា
គឺជាវត្ថុដែលលោកម៉ូសេកំពុងដាក់នៅចំពោះមុខអ្នករាល់គ្នា។
នាមអរូបីនេះអាចបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់នឹងដាក់បណ្តាសាអ្នករាល់គ្នា»
ហើយងាកចេញពីផ្លូវដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ ហើយទៅតាមព្រះដទៃ
បទបញ្ជារបស់ព្រះអម្ចាស់ ដែលលោកម៉ូសេកំពុងប្រាប់ប្រជាជន
ត្រូវបានគេនិយាយដូចពួកវាជាមាគ៌ារបស់ព្រះជាម្ចាស់ ឬជាផ្លូវ។
ការមិនគោរពតាមបទបញ្ជារបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយ
ដូចជាមនុស្សដែលបង្វិលខ្លួនបែរទិសដៅពីព្រះអម្ចាស់ ដើរតាមព្រះដទៃទៀត។
ការបកប្រែផ្សេងទៀត «ប៉ុន្តែ មិនស្តាប់បង្គាប់តាមអ្វី
ដែលខ្ញុំបង្គាប់ដល់អ្នករាល់គ្នាថ្ងៃនេះ ដើម្បីថ្វាយបង្គំដល់ព្រះដទៃ»

generated on Wed Sep 10 16:16:32 2025

ព្រះដទៃដែលអ្នករាល់គ្នាមិនស្គាល់
សំដៅទៅលើព្រះដទៃ ដែលមនុស្សថ្វាយបង្គំ។
ជនជាតិអ៊ីស្រាអែលស្គាល់ព្រះអម្ចាស់ ព្រោះព្រះអង្គបានបង្ហាញអង្គទ្រង់ឱ្យគេឃើញ
ហើយគេក៏បានស្គាល់ឫទ្ធានុភាពរបស់ព្រះអង្គ។
Deuteronomy 11:29
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
អ្នករាល់គ្នាត្រូវប្រកាសអំពីព្រះពរនៅលើភ្នំកេរិស៊ីម និងបណ្តាសានៅលើភ្នំអេបាល។
ការប្រទានពរ និងការដាក់បណ្តាសាត្រូវបាននិយាយដូចជាវត្ថុមួយ
ដែលមនុស្សណាម្នាក់នឹងដាក់នៅលើភ្នំ។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាខ្លះត្រូវឈរនៅលើកំពូលភ្នំកេរ៉ាស៊ីម
ហើយប្រកាសអំពីអ្វីដែលនឹងធ្វើឱ្យព្រះអម្ចាស់ប្រទានពរដល់អ្នក
ហើយអ្នកខ្លះទៀតត្រូវឈរនៅលើកំពូលភ្នំអេបាល
ហើយប្រកាសនូវអ្វីដែលនឹងធ្វើឱ្យព្រះអម្ចាស់ដាក់បណ្តាសាដល់អ្នករាល់គ្នា»
ភ្នំកេរិស៊ីម ... ភ្នំអេបាល
ទាំងនេះជាឈ្មោះភ្នំនៅត្រើយខាងលិចទន្លេយ័រដាន់។
តើអ្នករាល់គ្នាបានស្គាល់ហើយថា ភ្នំទាំងពីរនេះ ស្ថិតនៅត្រើយខាងនាយទន្លេយ័រដាន់ ... នៅម៉ូរេ?
ជនជាតិអ៊ីស្រាអែលស្ថិតនៅត្រើយខាងកើតទន្លេយ័រដាន់។
លោកម៉ូសេប្រើសំណួរមួយដើម្បីរម្លឹកប្រជាជនដែលស្ថិតលើភ្នំទាំងនេះ។
សំណួរនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ដូចដែលអ្នកបានដឹងហើយថា ពួកគេនៅត្រើយខាងនាយទន្លេយ័រដាន់ ...
នៅម៉ូរេ»។
នៅត្រើយខាងនាយទន្លេយ័រដាន់
«នៅខាងលិចទន្លេយ័រដាន់»
គឺនៅតាមផ្លូវទៅទិសខាងលិច
«នៅភាគខាងលិច»
ទល់មុខទៅគីកាល់
«នៅជិតគីលកាល់» នេះប្រហែលជាមិនដូចកន្លែងនៅជិតទីក្រុងយេរីខូទេ។
លោកម៉ូសេប្រហែលជាចង់សំដៅទៅលើកន្លែង ដែលនៅជិតស៊ីគែម។
ជិតដើមម៉ៃសាក់នៅម៉ូរេ
ទាំងនេះជាដើមឈើដ៏ពិសិដ្ឋនៅជិតគីលកាល់។
Deuteronomy 11:31
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ច្បាប់ និងបញ្ញត្តិទាំងប៉ុន្មាន
ទាំងនេះជាច្បាប់និងបញ្ញត្តិ ដែលលោកម៉ូសេនឹងផ្តល់ជូននៅក្នុងចោទិយកថា ១២-២៦ ។
ដែលខ្ញុំប្រគល់ឲ្យទៅអ្នករាល់គ្នានៅថ្ងៃនេះ។
នេះមិនមានន័យថា ទាំងនេះជារបស់ច្បាប់ទេ។ លោកម៉ូសេកំពុងពិនិត្យមើលច្បាប់
និងបញ្ញត្តិដដែលដែលគាត់បានឱ្យ ៤០ឆ្នាំមុន។
ខ្ញុំប្រគល់ឲ្យទៅអ្នករាល់គ្នា
ច្បាប់របស់ព្រះជាម្ចាស់
និងបញ្ញត្តិដែលលោកម៉ូសេកំពុងប្រាប់ប្រជាជនត្រូវបានគេនិយាយ
ដូចជាវត្ថុដែលលោកម៉ូសេកំពុងតែដាក់នៅមុខប្រជាជន។ ការបកប្រែផ្សេងទៀត
«ខ្ញុំកំពុងឱ្យអ្នករាល់គ្នា»

---

12 [1]នេះជាច្បាប់ និងបញ្ញត្តិទាំងប៉ុន្មានដែលអ្នករាល់គ្នាត្រូវកាន់ ហើយប្រព្រឹត្តតាម នៅក្នុងទឹកដីដែលជាព្រះអម្ចាស់ ជាព្រះនៃបុព្វបុរសរបស់អ្នករាល់គ្នា
បានប្រទានឲ្យអ្នករាល់ទុកជាកម្មសិទ្ធិ ជារៀងរាល់ថ្ងៃអស់មួយជីវិតដែលអ្នករាល់គ្នាដែលរស់នៅលើផែនដី។[2]ត្រូវបំផ្លាញទីកន្លែងដែលប្រជាជាតិទាំងប៉ុន្មាន
ថ្វាយសក្ការបូជាដល់ព្រះរបស់ពួកគេ នៅលើភ្នំធំភ្នំតូច និងនៅក្រោមដើមឈើមានស្លឹកខៀវខ្ចី កុំឲ្យនៅសល់ឡើយ។
[3]ចូរផ្តួលរលំអាសនៈរបស់ពួកគេ កម្ទេចស្តូបរបស់ពួកគេ ហើយត្រូវដុតបំផ្លាញបង្គោលរបស់ព្រះអាសេរ៉ា។ ត្រូវកាប់រំលំរូបព្រះបដិមារបស់ពួកគេ
ហើយត្រូវបំផ្លាញឈ្មោះព្រះទាំងនោះ ឲ្យអស់ពីកន្លែងនោះផង។[4]ហើយអ្នកមិនថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា តាមបែបដូច្នេះឡើយ។
[5]ប៉ុន្តែ អ្នករាល់គ្នាត្រូវតែថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា នៅកន្លែងដែលព្រះអង្គបានជ្រើសរើស នៅក្នុងចំណោមទឹកដីនៃកុលសម្ព័ន្ធទាំងប៉ុន្មានរបស់អ្នករាល់គ្នា
ដើម្បីតាំងព្រះនាមព្រះអង្គ និងទុកជាដំណាក់របស់ព្រះអង្គនៅទីនោះ ហើយអ្នករាល់គ្នានឹងត្រូវទៅទីនោះ។[6]ហើយត្រូវនាំយកអស់ទាំងតង្វាយដុត តង្វាយយញ្ញបូជា
តង្វាយមួយភាគដប់ តង្វាយពិសេស តង្វាយលាបំណន់ តង្វាយស្ម័គ្រពីចិត្ត និងកូនដំបូងនៃកូនគោ និងហ្វូងចៀមរបស់អ្នករាល់គ្នានៅទីនោះដែរ។
[7]នៅទីនេាះ អ្នករាល់គ្នាត្រូវបរិភោគនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ហើយត្រូវអរសប្បាយ ជាមួយក្រុមគ្រួសាររបស់អ្នករាល់គ្នា
ក្នុងគ្រប់ទាំងការដែលអ្នករាល់គ្នា សម្រេចបាន ដោយសារព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា បានប្រទានពរឲ្យអ្នករាល់គ្នា។
[8]អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តការទាំងអស់នោះទេ ដូចយើងប្រព្រឹត្តពេលនេះឡើយ គឺនៅថ្ងៃនេះ អ្នករាល់គ្នាប្រព្រឹត្តតាមដែលខ្លួនយល់ថាត្រឹមត្រូវនៅចំពោះភ្នែករបស់ខ្លួន[9]ដ្បិត
អ្នករាល់គ្នាមិនទាន់បានចូលទៅកន្លែងសម្រាក ជាទឹកដីដែលព្រះអង្គម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យជាកេរមរតកនៅឡើយទេ។
[10]ប៉ុន្តែ នៅពេលដែលអ្នករាល់គ្នាឆ្លងកាត់ទៅទន្លេយ័រដាន់ ហើយទៅរស់នៅក្នុងទឹកដីដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា បានប្រទានឲ្យអ្នករាល់គ្នាទុកជាកេមរតក
ហើយពេលព្រះអង្គប្រទានឲ្យអ្នករាល់គ្នាសម្រាកពីខ្មាំងសត្រូវទាំងប៉ុន្មានដែលនៅជុំវិញអ្នករាល់គ្នា
ហើយអ្នករាល់គ្នានឹងរស់នៅដោយសុខសាន្ត[11]ហើយនៅកន្លែងណាដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា បានជ្រើសរើសជាព្រះដំណាក់ សម្រាប់តាំងព្រះនាមព្រះអង្គ
ពេលនោះអ្នករាល់គ្នាត្រូវនាំយកតង្វាយទាំងប៉ុន្មានដែលខ្ញុំបង្គាប់ទៅអ្នករាល់គ្នា គឺមានទាំងតង្វាយដុត តង្វាយយញ្ញបូជា តង្វាយមួយភាគដប់ តង្វាយពិសេស
និងតង្វាយផ្សេងៗដែលអ្នករាល់គ្នាសន្យាថ្វាយព្រះអម្ចាស់។
[12]អ្នករាល់គ្នានឹងត្រូវអរសប្បាយចំពោះព្រះភក្ត្រព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ព្រមទាំងកូនប្រុស និងកូនស្រីរបស់អ្នករាល់គ្នា និងអ្នកបម្រើប្រុសស្រី
ព្រមទាំងពួកលេវីដែលរស់នៅក្នុងក្រុងជាមួយអ្នករាល់គ្នាដែរ ដ្បិត ពួកលេវីមិនមានទឹកដីជាចំណែកកេមរតកក្នុងចំណោមអ្នករាល់គ្នាទេ។
[13]ចូរប្រយ័ត្ន កុំថ្វាយតង្វាយដុតរបស់អ្នករាល់គ្នានៅតាមទីកន្លែងណាដែលអ្នករាល់គ្នាឃើញនោះឡើយ[14]ប៉ុន្តែ
ត្រូវថ្វាយតង្វាយដុតនៅកន្លែងដែលព្រះអម្ចាស់បានជ្រើសរើស ក្នុងទឹកដីនៃកុលសម្ព័ន្ធមួយរបស់អ្នករាល់គ្នា
ហើយនៅទីនោះអ្នករាល់គ្នាត្រូវធ្វើអ្វីៗដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។
[15]ក៏ប៉ុន្តែ អ្នករាល់គ្នាអាចសម្លាប់សត្វបរិភោគ នៅក្នុងក្រុងណាមួយរបស់អ្នករាល់គ្នា តាមតែចិត្តប៉ងប្រាថ្នា តាមដែលព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាបានប្រទានពរអ្នករាល់គ្នា មនុស្សមិនបរិសុទ្ធ និងមនុស្សបរិសុទ្ធ អាចបរិភោគសាច់នេះបានទាំងអស់គ្នា ដូចជាបរិភោគសាច់ឈ្លូស និងសាច់ក្តាន់។
[16]ប៉ុន្តែ មិនត្រូវបរិភោគឈាមឡើយ ត្រូវចាក់ឈាមនោះចោលទៅលើដី ដូចជាចាក់ទឹកវិញ។
[17]នៅក្នុងក្រុងរបស់អ្នករាល់គ្នាមិនត្រូវបរិភោគតង្វាយមួយភាគដប់ចេញគ្រាប់ធញ្ញជាតិ ស្រូវ ស្រាទំពាំងថ្មី ប្រេង ឬកូនដំបូងពីហ្វូងចៀមរបស់អ្នករាល់គ្នាឡើយ
និងតង្វាយលាបំណន់ ឬតង្វាយស្ម័គ្រពីចិត្ត ព្រមទាំងតង្វាយពិសេសដែលថ្វាយដោយដៃរបស់អ្នករាល់គ្នានោះឡើយ។
[18]ឯតង្វាយទាំងនោះ អ្នករាល់គ្នាត្រូវបរិភោគនៅចំពោះមុខព្រះភក្ត្រព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា នៅត្រង់កន្លែងដែលព្រះអង្គជ្រើសរើស គឺបរិភោគជាមួយកូនប្រុសកូនស្រី អ្នកបម្រើប្រុសស្រីរបស់អ្នករាល់គ្នា និងពួកលេវីដែលនៅក្នុងទីក្រុងរបស់អ្នករាល់គ្នា
ហើយអ្នករាល់គ្នាត្រូវអរសប្បាយនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ក្នុងគ្រប់ទាំងការដែលអ្នករាល់គ្នាសម្រេចបាន។[19]ចូរប្រយ័ត្នកុំបំភ្លេចពួកលេវីឡើយ
ដរាបណាអ្នករាល់គ្នារស់នៅលើទឹកដីរបស់អ្នករាល់គ្នា។
[20]ពេលណាដែលព្រះអម្ចាស់ ជាព្រះនៃអ្នករាល់គ្នា ពង្រីកទឹកដីអ្នករាល់គ្នាឲ្យធំឡើង ដូចព្រះអង្គបានសន្យាជាមួយអ្នករាល់គ្នា ហើយអ្នករាល់គ្នានឹកក្នុងចិត្តថា
ខ្ញុំចង់បរិភោគសាច់ ព្រោះខ្ញុំចង់បរិភោគសាច់នោះ នោះអ្នកអ្នករាល់គ្នាអាចបរិភោគសាច់តាមចិត្តប៉ងប្រថ្នារបស់អ្នករាល់គ្នា។
[21]ប្រសិនបើ នៅកន្លែងដែលព្រះអម្ចាស់ ជាព្រះនៃអ្នករាល់គ្នា បានជ្រើសរើសសម្រាប់តាំងព្រះនាមព្រះអង្គ ស្ថិតនៅឆ្ងាយពីផ្ទះរបស់អ្នករាល់គ្នា
នោះអ្នករាល់គ្នាអាចសម្លាប់គោ ឬចៀមដែលព្រះអម្ចាស់ប្រទានមកអ្នករាល់គ្នា គឺដូចដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា

generated on Wed Sep 10 16:16:32 2025

នោះអ្នករាល់គ្នាអាចបរិភោគនៅក្នុងទីក្រុងរបស់អ្នករាល់គ្នាតាមចិត្តប្រាថ្នារបស់អ្នករាល់គ្នា។[22]អ្នករាល់គ្នាអាចបរិភោគសាច់សត្វទាំងអស់នោះបាន
ដូចជាបរិភោគសាច់ឈ្លូស និងសាច់ក្តាន់ គឺទាំងអ្នកបរិសុទ្ធ និងទាំងអ្នកមិនបរិសុទ្ធ អាចបរិភោគបានដូចគ្នា។
[23]ប៉ុន្តែ ចូរឲ្យប្រយ័ត្នថា អ្នករាល់គ្នាមិនត្រូវបរិភោគឈាមជាដាច់ខាត ដ្បិត ឈាមជាជីវិត ដូច្នេះ អ្នករាល់គ្នាមិនត្រូវបរិភោគជីវិតជាមួយសាច់ឡើយ។
[24]មិនត្រូវបរិភោគឈាមឡើយ អ្នករាល់គ្នាត្រូវចាក់ឈាម ចោលនៅលើដី ដូចជាចាក់ទឹក។[25]មិនត្រូវបរិភោគឈាមឡើយ ធ្វើដូច្នេះ អ្នករាល់គ្នា
និងកូនចៅរបស់អ្នករាល់គ្នានៅជំនាន់ក្រោយនឹងបានសុខសប្បាយ ព្រោះអ្នករាល់គ្នាបានប្រព្រឹត្តសេចក្តីត្រឹមត្រូវនៅចំពោះព្រះនេត្រព្រះអង្គម្ចាស់។
[26]ប៉ុន្តែ អស់ទាំងតង្វាយបរិសុទ្ធដែលអ្នកញែកទុកដោយឡែកថ្វាយព្រះអម្ចាស់ និងតង្វាយលាបំណន់របស់អ្នករាល់គ្នា
ត្រូវនាំយកទៅថ្វាយនៅកន្លែងដែលព្រះអម្ចាស់ជ្រើសរើស។[27]ចំពោះតង្វាយដុតទាំងអស់នោះ
ត្រូវយកទាំងសាច់ទាំងឈាមដើម្បីយកទៅថ្វាយនៅលើអាសនៈរបស់ព្រះអម្ចាស់ ជាព្រះនៃអ្នករាល់គ្នា រីឯឈាមនៃតង្វាយយញ្ញបូជារបស់អ្នករាល់គ្នា
នឹងត្រូវប្រោះនៅលើអាសនៈរបស់ព្រះអម្ចាស់ ជាព្រះនៃអ្នករាល់គ្នា ហើយអ្នករាល់គ្នាអាចបរិភោគសាច់បាន។
[28]ចូរប្រតិបត្តិ និងស្តាប់តាមអស់ទាំងព្រះបន្ទូលដែលខ្ញុំបង្គាប់មកអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នា និងកូនចៅរបស់អ្នករាល់គ្នានៅជំនាន់ក្រោយបានសុខសប្បាយរហូតតទៅ
ដោយប្រព្រឹត្តអំពើល្អ និងសេចក្តីត្រឹមត្រូវនៅចំពោះព្រះនេត្រព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
[29]កាលណាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា កាត់ប្រជាជាតិនៅចំពោះមុខអ្នករាល់គ្នាចេញ នៅក្នុងទឹកដីដែលអ្នករាល់គ្នាទៅចាប់យកពីគេ
ហើយអ្នករាល់គ្នាអាចបណ្តេញគេចេញពីទឹកដីនោះ រួចចូលទៅរស់នៅក្នុងទឹកដីរបស់គេ[30]ចូរប្រយ័ត្ន ក្រែងលោអ្នករាល់គ្នាធ្លាក់ទៅក្នុងអន្ទាក់ដោយយកតម្រាប់តាមគេ
ក្រោយពេលដែលគេបំផ្លាញឲ្យសូន្យបាត់ពីមុខអ្នករាល់គ្នា មិនត្រូវសាកសួរចង់ដឹងពីព្រះរបស់ពួកគេ ដោយពាក្យថា
តើប្រជាជាតិទាំងនោះគោរពប្រតិបត្តិដល់ព្រះរបស់ពួកគេយ៉ាងដូចម្តេច? ដើម្បីឲ្យខ្ញុំបានធ្វើដូចគេដែរ។
[31]អ្នករាល់គ្នាមិនត្រូវថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា តាមបែបដូច្នេះឡើយ ដ្បិត គេប្រព្រឹត្តដល់ព្រះរបស់ពួកគេ តាមសេចក្តីដែលព្រះម្ចាស់ប្រព្រឹត្តគួរស្អប់ខ្ពើម
សូម្បីតែ កូនប្រុសកូនស្រីរបស់ពួកគេ គេក៏យកទៅដុតជាសក្ការបូជាដល់ព្រះទាំងនោះដែរ។ អស់ទាំងសេចក្តីដែលខ្ញុំបង្គាប់មកអ្នករាល់គ្នា។[32]នោះត្រូវប្រយ័ត្ន
និងប្រព្រឹត្តតាមចុះ មិនត្រូវបន្ថែម ឬបន្ថយអ្វីឡើយ។

Deuteronomy 12:1

ព័ត៌មានទូទៅ៖

លោកម៉ូសេកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

អ្នករាល់គ្នាត្រូវកាន់

«អ្នករាល់គ្នាត្រូវតែគោរពតាម»

ជារៀងរាល់ថ្ងៃអស់មួយជីវិតដែលអ្នករាល់គ្នាដែលរស់នៅលើផែនដី។

នៅទីនេះ «ថ្ងៃ» តំណាងឱ្យរយៈពេលយូរជាង។ គួរបញ្ជាក់ផងដែរថា
«រស់នៅលើផែនដី» ជាឃ្លាដែលមានន័យថា ដរាបណាមនុស្សរស់នៅ។
ការបកប្រែផ្សេងទៀត «ដរាបណាអ្នករាល់គ្នានៅរស់»

ត្រូវបំផ្លាញ

«អ្នកត្រូវតែបំផ្លាញ»

ប្រជាជាតិទាំងប៉ុន្មាន

នៅទីនេះ «ប្រជាជាតិ» តំណាងឱ្យក្រុមប្រជាជន ដែលរស់នៅក្នុងទឹកដីកាណាន។
ការបកប្រែផ្សេងទៀត «ក្រុមមនុស្សដែលទឹកដីរបស់ពួកគេ អ្នករាល់គ្នានឹងយក»

Deuteronomy 12:3

ព័ត៌មានទូទៅ៖

លោកម៉ូសេកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

ចូរផ្តួលរលំអាសនៈរបស់ពួកគេ

«អ្នកត្រូវដកអាសនៈរបស់ប្រជាជាតិទាំងនោះចេញ» ឬ
«អ្នកត្រូវបំផ្លាញអាសនៈរបស់ប្រជាជាតិទាំងនោះ»

កម្ទេចសូប

«បំបែកជាបំណែក»ឬ «កំទេច»

ហើយត្រូវបំផ្លាញឈ្មោះព្រះទាំងនោះ

នៅទីនេះ «បំផ្លាញឈ្មោះព្រះទាំងនោះ» តំណាងឱ្យ «ការចងចាំរបស់ពួកគេ»។
ការបកប្រែផ្សេងទៀត «បំផ្លាញពួកវាចោលឱ្យខ្ទេច
ដើម្បីកុំឱ្យមានមនុស្សណាម្នាក់ចងចាំពួកគេ» ឬ
«បំផ្លាញអ្វីៗដែលតំណាងឱ្យព្រះមិនពិតទាំងនេះ»

កន្លែងនោះ

សំដៅទៅលើកន្លែងនីមួយៗ ដែលប្រជាជាតិនានាថ្វាយបង្គំជាព្រះរបស់ពួកគេ។

ហើយអ្នកមិនថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា តាមបែបដូច្នេះឡើយ។

«អ្នករាល់គ្នាមិនគួរថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ដូចប្រជាជាតិទាំងនោះថ្វាយបង្គំព្រះរបស់គេនោះឡើយ»។

Deuteronomy 12:5

អ្នករាល់គ្នាត្រូវតែថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា នៅកន្លែងដែលព្រះអង្គបានជ្រើសរើស

នៅក្នុងចំណោមទឹកដីនៃកុលសម្ព័ន្ធទាំងប៉ុន្មានរបស់អ្នករាល់គ្នាដើម្បីតាំងព្រះនាមព្រះអង្គ

នៅទីនេះ «ព្រះនាមព្រះអង្គ » សំដៅទៅលើព្រះជាម្ចាស់ផ្ទាល់។

ព្រះអម្ចាស់នឹងជ្រើសរើសទីតាំងមួយ ដែលព្រះអង្គនឹងគង់នៅ
ហើយប្រជាជននឹងនាំគ្នាមកក្រាបថ្វាយបង្គំព្រះអង្គនៅទីនោះ។

ហើយអ្នករាល់គ្នានឹងត្រូវទៅទីនោះ។

ពួកគេនឹងទៅថ្វាយបង្គំកន្លែង ដែលព្រះជាម្ចាស់សម្រេច។

តង្វាយពិសេស

នៅទីនេះ «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«តង្វាយដែលអ្នកបង្ហាញ»

តង្វាយលាបំណន់ តង្វាយស្ម័គ្រពីចិត្ត

«ការថ្វាយរបស់អ្នកដើម្បីបំពេញតាមពាក្យសម្បថ និងតង្វាយស្ម័គ្រចិត្តរបស់អ្នក»។
ទាំងនេះគឺជាប្រភេទនៃការថ្វាយ។

កូនដំបូងនៃកូនគោ និងហ្វូងចៀមរបស់អ្នករាល់គ្នានៅទីនោះដែរ។

ព្រះជាម្ចាស់តម្រូវឱ្យប្រជាជន
ផ្តល់សត្វឈ្មោលដំបូងទាំងអស់ចេញពីហ្វូងសត្វរបស់ពួកគេ ថ្វាយព្រះអង្គ។

Deuteronomy 12:7

នៅទីនេោះ

សំដៅទៅលើកន្លែងដែលព្រះអម្ចាស់នឹងជ្រើសរើស
ឱ្យជនជាតិអ៊ីស្រាអែលថ្វាយបង្គំ។

ហើយត្រូវអរសប្បាយ ជាមួយក្រុមគ្រួសាររបស់អ្នករាល់គ្នា ក្នុងគ្រប់ទាំងការដែលអ្នករាល់គ្នា

នៅទីនេះ «គ្រប់ទាំងការដែលអ្នករាល់គ្នា» តំណាងឱ្យមនុស្សទាំងមូល
និងការងារដែលគាត់បានធ្វើ។ ការបកប្រែផ្សេងទៀត
«អរសប្បាយចំពោះការងារទាំងអស់ដែលអ្នករាល់គ្នាបានធ្វើ»

Deuteronomy 12:8

អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តការទាំងអស់នោះទេ ដូចយើងប្រព្រឹត្តពេលនេះឡើយ គឺនៅថ្ងៃនេះ

«អ្នករាល់គ្នានឹងមិនធ្វើដូចយើងកំពុងធ្វើនៅថ្ងៃនេះទេ» មានន័យថា
ពួកគេនឹងថ្វាយបង្គំនៅក្នុងទឹកដីសន្យាខុសពីរបៀប
ដែលពួកគេកំពុងថ្វាយបង្គំនៅពេលនោះ។

អ្នករាល់គ្នាប្រព្រឹត្តតាមដែលខ្លួនយល់ថាត្រឹមត្រូវនៅចំពោះភ្នែករបស់ខ្លួន

នៅទីនេះ «ភ្នែក» តំណាងឱ្យគំនិត ឬយោបល់របស់មនុស្សម្នាក់។
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នាកំពុងធ្វើអ្វីដែលគាត់ចាត់ទុកថាត្រឹមត្រូវ»

សម្រាក

នាមអរូបី «សម្រាក» អាចបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ទៅកាន់ទឹកដីដែលអ្នករាល់គ្នានឹងសម្រាក»

ជាទឹកដីដែលព្រះអង្គម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យជាកេរមរតកនៅឡើយទេ។

ទឹកដីដែលព្រះជាម្ចាស់បានប្រទានដល់ជនជាតិអ៊ីស្រាអែល
ត្រូវបាននិយាយថាដូចជាទ្រព្យសម្បត្តិ
ដែលឪពុកទុកជាចំណែកមរតកសម្រាប់កូនរបស់គាត់។ ការបកប្រែផ្សេងទៀត
«ទៅកាន់ទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
កំពុងប្រទានឱ្យអ្នករាល់គ្នាទុកជាកេរមរតកជារៀងរហូត»

Deuteronomy 12:10

ហើយទៅរស់នៅក្នុងទឹកដី

សំដៅទៅលើទឹកដីស្រុកកាណាន។

ហើយទៅរស់នៅក្នុងទឹកដីដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា

generated on Wed Sep 10 16:16:32 2025

បានប្រទានឲ្យអ្នករាល់គ្នាទុកជាកេមរតក
ព្រះជាម្ចាស់ប្រទានទឹកដីកាណានទៅប្រជាជនអ៊ីស្រាអែល
ដូចជាព្រះអង្គជាឪពុកម្នាក់ដែលចែកមរតកដល់កូនរបស់គាត់។
ហើយពេលព្រះអង្គប្រទានឲ្យអ្នករាល់គ្នាសម្រាកពីខ្មាំងសត្រូវទាំងប៉ុន្មានដែលនៅជុំវិញអ្នករាល់គ្នាt
«ពេលព្រះអង្គប្រទានឱ្យអ្នករាល់គ្នានូវសន្តិភាពពីសត្រូវទាំងអស់
ដែលនៅជុំវិញអ្នករាល់គ្នា»
ហើយនៅកន្លែងណាដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា បានជ្រើសរើសជាព្រះដំណាក់
សម្រាប់តាំងព្រះនាមព្រះអង្គ
នៅទីនេះ «ព្រះនាម» តំណាងឱ្យព្រះជាម្ចាស់ផ្ទាល់។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកទៅកន្លែងដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាគង់នៅ»
តង្វាយពិសេសធ្វើដោយដៃ
នៅទីនេះ «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«តង្វាយដែលអ្នករាល់គ្នាបង្ហាញ»
តង្វាយផ្សេងៗដែលអ្នករាល់គ្នាសន្យា
«រាល់ការថ្វាយដោយស្ម័គ្រចិត្តរបស់អ្នករាល់គ្នា ដើម្បីបំពេញតាមពាក្យសម្បថ»
Deuteronomy 12:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវអរសប្បាយចំពោះព្រះភក្ត្រព្រះអម្ចាស់
«អរសប្បាយនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់»
ព្រមទាំងពួកលេវីដែលរស់នៅក្នុងក្រុងជាមួយអ្នករាល់គ្នាដែរ
នៅទីនេះ «ច្រកទ្វារក្រុង» ជាឯកសារយោងទៅទីក្រុង។ ការបកប្រែផ្សេងទៀត
«ពួកលេវីដែលរស់នៅក្នុងទីក្រុងរបស់អ្នករាល់គ្នា» ឬ
«ពួកលេវីដែលរស់នៅជាមួយអ្នករាល់គ្នា»
ពួកលេវីមិនមានទឹកដីជាចំណែកកេមរតកក្នុងចំណោមអ្នករាល់គ្នាទេ។
ការពិតព្រះអម្ចាស់នឹងមិនប្រទានទឹកដីណាមួយ ដល់ពួកលេវីទេ
ត្រូវបាននិយាយដូចជាឪពុកមិនប្រគល់ដីជាមរតកដល់កូន។
ពួកលេវីមិនមានទឹកដីជាចំណែក
នៅទីនេះ «ពួក» សំដៅទៅលើលេវី។
ពួកលេវីតំណាងឱ្យកូនចៅទាំងអស់របស់គាត់។ ការបកប្រែផ្សេងទៀត
«ពួកគេមិនមានចំណែក»
Deuteronomy 12:13
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចូរប្រយ័ត្ន
«ត្រូវប្រុងប្រយ័ត្ន»
មទីកន្លែងណាដែលអ្នករាល់គ្នាឃើញនោះឡើយ
«កន្លែងណាដែលអ្នករាល់គ្នាពេញចិត្ត» ឬ «កន្លែងណាដែលអ្នករាល់គ្នាចង់បាន»
ប៉ុន្តែ ត្រូវថ្វាយតង្វាយដុតនៅកន្លែងដែលព្រះអម្ចាស់បានជ្រើសរើស
តង្វាយដុតទាំងនោះត្រូវធ្វើនៅព្រះពន្លា។ ព្រះអម្ចាស់ផ្ទាល់នឹងជ្រើសរើសកន្លែង
ដែលព្រះពន្លាស្ថិតនៅ។
Deuteronomy 12:15
ក៏ប៉ុន្តែ អ្នករាល់គ្នាអាចសម្លាប់សត្វបរិភោគ នៅក្នុងក្រុងណាមួយរបស់អ្នករាល់គ្នា
ប្រជាជនអាចសម្លាប់សត្វធ្វើជាយញ្ញបូជានៅកន្លែង ដែលព្រះអម្ចាស់ជ្រើសរើស។
ពួកគេអាចសម្លាប់សត្វសម្រាប់ចំណីអាហារនៅកន្លែង ដែលពួកគេចង់បាន។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចបញ្ជាក់ឱ្យច្បាស់។
នៅក្នុងក្រុងណាមួយរបស់អ្នករាល់គ្នា
នៅទីនេះ «ទ្វារក្រុង» តំណាងឱ្យទីក្រុងទាំងមូល។ ការបកប្រែផ្សេងទៀត
«នៅខាងក្នុងទីក្រុងរបស់អ្នករាល់គ្នា» ឬ «នៅផ្ទះរបស់អ្នករាល់គ្នា»
មនុស្សមិនបរិសុទ្ធ ... មនុស្ស
មនុស្សដែលមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះជាម្ចាស់
ត្រូវបានគេនិយាយដូចជាមនុស្សនោះមានរូបកាយមិនស្អាត។
មនុស្សបរិសុទ្ធ
មនុស្សដែលអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះជាម្ចាស់
ត្រូវបាននិយាយដូចជាមនុស្សនោះស្អាតខាងរូបកាយ។
ឈ្លូស និងសាច់ក្តាន់។
ទាំងនេះគឺជាសត្វព្រៃមានជើងតូចវែង ដែលអាចរត់បានយ៉ាងឆាប់រហ័ស។
ការបកប្រែផ្សេងទៀត «ឈ្លូសនិងសត្វក្តាន់»
ប៉ុន្តែ មិនត្រូវបរិភោគឈាមឡើយ
ឈាមតំណាងឱ្យជីវិត
ហើយព្រះជាម្ចាស់មិនអនុញ្ញាតឱ្យប្រជាជនបរិភោគឈាមរួមជាមួយសាច់ទេ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចបញ្ជាក់ឱ្យច្បាស់។
Deuteronomy 12:17
ព័ត៌មានទូទៅ៖
លោកម៉ូសេរៀបរាប់ប្រាប់ប្រជាជន នូវរាល់តង្វាយពិសេសនិងយញ្ញបូជា
ដែលត្រូវធ្វើនៅត្រសាល។
នៅក្នុងក្រុងរបស់អ្នករាល់គ្នា
នៅទីនេះ «ទ្វារក្រុង» តំណាងឱ្យទីក្រុងទាំងមូល។ ការបកប្រែផ្សេងទៀត
«នៅខាងក្នុងទីក្រុងរបស់អ្នករាល់គ្នា» ឬ «នៅផ្ទះរបស់អ្នករាល់គ្នា»
ព្រមទាំងតង្វាយពិសេសដែលថ្វាយដោយដៃរបស់អ្នករាល់គ្នានោះឡើយ។
នៅទីនេះ «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«តង្វាយដែលអ្នករាល់គ្នាយកមកថ្វាយព្រះអម្ចាស់»
Deuteronomy 12:18
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
អ្នករាល់គ្នាត្រូវបរិភោគ
«អ្នករាល់គ្នានឹងបរិភោគតង្វាយរបស់អ្នករាល់គ្នា»
នៅចំពោះមុខព្រះភក្ត្រព្រះអម្ចាស់
«នៅចំពោះព្រះភក្ត្រព្រះអម្ចាស់»
ពួកលេវីដែលនៅក្នុងទីក្រុងរបស់អ្នករាល់គ្នា
នៅទីនេះ «ទ្វារក្រុង» តំណាងឱ្យទីក្រុង។ ការបកប្រែផ្សេងទៀត
«កុលសម្ព័ន្ធលេវីណាម្នាក់ ដែលរស់នៅក្នុងទីក្រុងរបស់អ្នករាល់គ្នា»
ក្នុងគ្រប់ទាំងការដែលអ្នករាល់គ្នាសម្រេចបាន។
នៅទីនេះ «សម្រេចបាន» តំណាងឱ្យមនុស្សទាំងមូល
និងការងារដែលគាត់បានធ្វើ។ ការបកប្រែផ្សេងទៀត «
អរសប្បាយចំពោះការងារទាំងអស់ ដែលអ្នករាល់គ្នាបានធ្វើ»
ចូរប្រយ័ត្ន
«ត្រូវប្រុងប្រយ័ត្ន»
កុំបំភ្លេច
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាត្រូវថែរក្សាឱ្យបានល្អ»
Deuteronomy 12:20
ពង្រីកទឹកដីអ្នករាល់គ្នាឲ្យធំឡើង
«ពង្រីកទឹកដីរបស់អ្នករាល់គ្នា» ឬ«ផ្តល់ឱ្យអ្នករាល់គ្នានូវទឹកដីកាន់តែច្រើន»
អ្នករាល់គ្នានឹកក្នុងចិត្តថា ខ្ញុំចង់បរិភោគសាច់ ព្រោះខ្ញុំចង់បរិភោគសាច់នោះ
នេះជាការដកស្រង់នៅក្នុងការដកស្រង់។ ការដកស្រង់នេះអាចបញ្ជាក់ថា
ជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«ហើយអ្នករាល់គ្នាសម្រេចថាអ្នករាល់គ្នាចង់ញ៉ាំសាច់»
តាមចិត្តប៉ងប្រថ្នារបស់អ្នករាល់គ្នា។
នៅទីនេះ «ប៉ងប្រថ្នា» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«ដូចដែលអ្នករាល់គ្នាចង់បាន» ឬ «ដូចដែលអ្នករាល់គ្នាចង់បាន»
Deuteronomy 12:21
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
បានជ្រើសរើសសម្រាប់តាំងព្រះនាមព្រះអង្គ
នៅទីនេះ «ព្រះនាម»សំដៅទៅលើព្រះជាម្ចាស់ផ្ទាល់។
ព្រះអម្ចាស់នឹងជ្រើសរើសកន្លែង ដែលព្រះអង្គនឹងគង់នៅ
ហើយប្រជាជននឹងនាំគ្នាមកក្រាបថ្វាយបង្គំព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ជ្រើសរើសរស់នៅក្នុង»
នៅក្នុងទីក្រុងរបស់អ្នករាល់គ្នា
នៅទីនេះ «ទ្វារក្រុង» តំណាងឱ្យទីក្រុងទាំងមូល។ ការបកប្រែផ្សេងទៀត
«នៅខាងក្នុងទីក្រុងរបស់អ្នករាល់គ្នា» ឬ «នៅក្នុងសហគមន៍របស់អ្នករាល់គ្នា»
តាមចិត្តប្រាថ្នារបស់អ្នករាល់គ្នា។
នៅទីនេះ «ចិត្តប្រាថ្នា» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«តាមដែលអ្នករាល់គ្នាចង់បាន»
អ្នករាល់គ្នាអាចបរិភោគសាច់សត្វទាំងអស់នោះបាន
អាចបកប្រែជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដូចអ្នកបរិភោគសត្វឈ្លូសនិងសត្វក្តាន់»

generated on Wed Sep 10 16:16:32 2025

ឈ្លូស និងសាច់ក្តាន់
ទាំងនេះជាសត្វព្រៃមានជើងតូចវែង ដែលអាចរត់បានយ៉ាងឆាប់រហ័ស។
សូមមើលការបកប្រែនៅក្នុង ១២:១៥។
អ្នកមិនបរិសុទ្ធ ... អ្នកបរិសុទ្ធ
មនុស្សដែលមិនអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះជាម្ចាស់
ត្រូវបានគេនិយាយដូចជាមនុស្សរាងកាយមិនស្អាត។
អ្នកមិនបរិសុទ្ធ
មនុស្សដែលអាចទទួលយកបានសម្រាប់គោលបំណងរបស់ព្រះជាម្ចាស់
ត្រូវបាននិយាយដូចជាមនុស្សមនុស្សរាងកាយស្អាត។ ។
Deuteronomy 12:23
ឈាមជាជីវិត
នៅទីនេះរបៀបដែលឈាមទ្រទ្រង់ជីវិត ត្រូវបានគេនិយាយដូចជាឈាមគឺជាជីវិត។
ការបកប្រែផ្សេងទៀត « ឈាមជួយទ្រទ្រង់ជីវិត» ឬ«
ឈាមបណ្តាលឱ្យសត្វនិងមនុស្សរស់នៅ»
អ្នករាល់គ្នាមិនត្រូវបរិភោគជីវិតជាមួយសាច់ឡើយ។
ពាក្យថា «ជីវិត» នៅទីនេះតំណាងឱ្យឈាមដែលទ្រទ្រង់ជីវិត។
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នានឹងមិនបរិភោគអ្វី
ដែលទ្រទ្រង់ជីវិតជាមួយសាច់» ឬ «អ្នករាល់គ្នានឹងមិនបរិភោគឈាម
ដែលទ្រទ្រង់ជីវិតជាមួយសាច់»
សេចក្តីត្រឹមត្រូវនៅចំពោះព្រះនេត្រព្រះអង្គម្ចាស់។
នៅទីនេះ «ព្រះនេត្រ» តំណាងឱ្យគំនិតឬយោបល់។ ការបកប្រែផ្សេងទៀត
«នូវអ្វីដែលត្រូវតាមព្រះអម្ចាស់» ឬ «នូវអ្វីដែលព្រះអម្ចាស់មានបន្ទូលត្រឹមត្រូវ»
Deuteronomy 12:26
តង្វាយលាបំណន់របស់អ្នករាល់គ្នា
«ការថ្វាយដើម្បីបំពេញតាមពាក្យសម្បថ» ឬ «ការថ្វាយពាក្យសច្ចា»
រីឯឈាមនៃតង្វាយយញ្ញបូជារបស់អ្នករាល់គ្នា នឹងត្រូវប្រោះ
អាចថ្លែងថាជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បូជាចារ្យនឹងប្រោះឈាមនៃយញ្ញបូជា»
អ្នករាល់គ្នាអាចបរិភោគសាច់បាន។
ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់បានបញ្ជាក់ថា
ផ្នែកណាមួយនៃសត្វគឺសម្រាប់តង្វាយដុត ដែលជាចំណែកសម្រាប់បូជាចារ្យ
និងផ្នែកខ្លះសម្រាប់អ្នកធ្វើខុសបរិភោគ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចបញ្ជាក់ឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នានឹងបរិភោគសាច់ខ្លះ»
Deuteronomy 12:28
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចូរប្រតិបត្តិ និងស្តាប់តាមអស់ទាំងព្រះបន្ទូលដែលខ្ញុំបង្គាប់មកអ្នករាល់គ្នា
នៅទីនេះ «ព្រះបន្ទូល»តំណាងឱ្យអ្វីដែលលោកម៉ូសេកំពុងនិយាយ។
ការបកប្រែផ្សេងទៀត «ចូរស្តាប់ដោយយកចិត្តទុកដាក់និងស្តាប់នូវរាល់អ្វី
ដែលខ្ញុំកំពុងបង្គាប់អ្នករាល់គ្នា »
ដើម្បីឲ្យអ្នករាល់គ្នា និងកូនចៅរបស់អ្នករាល់គ្នានៅជំនាន់ក្រោយ
នៅទីនេះ «កូនចៅ» មានន័យថាកូនចៅទាំងអស់របស់ពួកគេ។
ការបកប្រែផ្សេងទៀត
«ដើម្បីឱ្យអ្នករាល់គ្នានិងកូនចៅរបស់អ្នករាល់គ្នានឹងរីកចម្រើន»
ដោយប្រព្រឹត្តអំពើល្អ និងសេចក្តីត្រឹមត្រូវ
ពាក្យថា «ល្អ» និង «ត្រឹមត្រូវ»
មានអត្ថន័យស្រដៀងគ្នាហើយបញ្ជាក់លើសារៈសំខាន់នៃអាកប្បកិរិយាត្រឹមត្រូវ។
ការបកប្រែផ្សេងទៀត «នៅពេលអ្នករាល់គ្នាធ្វើអ្វី ដែលត្រឹមត្រូវ»
ចំពោះព្រះនេត្រព្រះអម្ចាស់
នៅទីនេះ «ព្រះនេត្រ» តំណាងឱ្យគំនិតឬយោបល់។ ការបកប្រែផ្សេងទៀត
«ស្របទៅតាមព្រះអម្ចាស់»
Deuteronomy 12:29
កាត់ប្រជាជាតិ
ព្រះអម្ចាស់បានបំផ្លាញក្រុមប្រជាជននៅស្រុកកាណាន
ត្រូវបាននិយាយដូចជាព្រះអង្គកំពុងកាត់ពួកគេដែរ ដូចជាមនុស្សនឹងកាត់ក្រណាត់
ឬកាត់មែកឈើ។
ប្រជាជាតិ
នៅទីនេះ «ប្រជាជាតិ» តំណាងឱ្យប្រជាជនដែលរស់នៅស្រុកកាណាន។
នៅក្នុងទឹកដីដែលអ្នករាល់គ្នាទៅចាប់យកពីគេ ហើយអ្នករាល់គ្នាអាចបណ្តេញគេចេញពីទឹកដីនោះ
«នៅពេលអ្នករាល់គ្នាយកអ្វីៗពីពួកគេ»
ចូរប្រយ័ត្ន
«ត្រូវប្រុងប្រយ័ត្ន»
ក្រែងលោអ្នករាល់គ្នាធ្លាក់ទៅក្នុងអន្ទាក់ដោយយកតម្រាប់តាមគេ ...
មិនត្រូវសាកសួរចង់ដឹងពីព្រះរបស់ពួកគេ
មនុស្សម្នាក់ដែលរៀនអំពីរឿងសំខាន់ និងការថ្វាយបង្គំព្រះដទៃទៀត
ត្រូវបានគេនិយាយដូចជាពួកគេត្រូវបានជាប់ក្នុងអន្ទាក់របស់អ្នកប្រមាញ់។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាមិនធ្វើដូចពួកគេ ...
ដែលអ្នករាល់គ្នាព្យាយាមរៀនអំពីព្រះរបស់ពួកគេដោយចោទសួរ»
ក្រែងលោអ្នករាល់គ្នាធ្លាក់ទៅក្នុងអន្ទាក់ដោយយកតម្រាប់តាមគេ
ជនជាតិអ៊ីស្រាអែលថ្វាយបង្គំរូបព្រះ
ដូចជាប្រជាជននៅស្រុកកាណានថ្វាយបង្គំរូបព្រះ
ដូចជាជនជាតិអ៊ីស្រាអែលដើរតាមពីក្រោយក្រុមមនុស្សដទៃទៀតដែរ។
ក្រោយពេលដែលគេបំផ្លាញឲ្យសូន្យបាត់ពីមុខអ្នករាល់គ្នា
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីព្រះអម្ចាស់បំផ្លាញពួកគេពីមុខអ្នករាល់គ្នា»
សាកសួរចង់ដឹងពីព្រះរបស់ពួកគេ ដោយពាក្យថា
តើប្រជាជាតិទាំងនោះគោរពប្រតិបត្តិដល់ព្រះរបស់ពួកគេយ៉ាងដូចម្តេច?
នេះជាការដកស្រង់នៅក្នុងស្រង់។
ការដកស្រង់ផ្ទាល់អាចបញ្ជាក់ការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«សួរអំពីរបៀបដែលក្រុមមនុស្សទាំងនោះ
ថ្វាយបង្គំព្រះរបស់ពួកគេដើម្បីអ្នកអាចធ្វើដូចគ្នា»
Deuteronomy 12:31
មិនត្រូវបន្ថែម ឬបន្ថយអ្វីឡើយ។
ពួកគេមិនត្រូវបង្កើតច្បាប់ថែមទៀតទេ ហើយក៏មិនត្រូវព្រងើយកន្តើយនឹងច្បាប់
ដែលព្រះបានប្រទានដល់ពួកគេដែរ។

---

13 [1]ប្រសិនបើ មានព្យាការី ឬគ្រូទាយណាម្នាក់ កើតឡើងក្នុងចំណោមអ្នករាល់គ្នា ហើយបើអ្នកនោះប្រាប់ពីទីសម្គាល់ ឬការអស្ចារ្យអ្វីមួយ[2]បើទីសម្គាល់
ឬការអស្ចារ្យកើតមានឡើងមែន ហើយគេនិយាយថា ចូរយើងទៅតាមព្រះដទៃ ហើយគោរពប្រតិបត្តិដល់ព្រះទាំងនោះវិញ
ជាព្រះដែលអ្នករាល់គ្នាមិនបានស្គាល់[3]នោះមិនត្រូវស្តាប់តាមពាក្យព្យាការី ឬគ្រូទាយនោះឡើយ ដ្បិត ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
ព្រះអង្គគ្រាន់តែចង់ល្បងលអ្នករាល់គ្នា ដើម្បីឲ្យដឹងថា តើអ្នករាល់គ្នាស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាអស់ពីចិត្ត ហើយអស់ពីព្រលឹង ឬយ៉ាងណា។
[4]អ្នករាល់គ្នាត្រូវដើរតាមព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ត្រូវកោតខ្លាចព្រះអង្គ ហើយកាន់តាមបញ្ញត្តិទាំងប៉ុន្មានរបស់ព្រះអង្គ ស្តាប់បង្គាប់ព្រះអង្គ
ហើយគោរពបម្រើព្រះអង្គ និងនៅជាប់នឹងព្រះអង្គ។[5]រីឯព្យាការី ឬគ្រូទាយនោះវិញ នឹងត្រូវស្លាប់ ដោយព្រោះបានល្បួងបះបោរទាស់ប្រឆាំងនឹងព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីប និងរំដោះអ្នករាល់គ្នាឲ្យរួចពីទាសករ។ រីឯព្យាការីនោះចង់ទាញអ្នករាល់គ្នាឲ្យចេញពីផ្លូវដែលព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាបង្គាប់ឲ្យអ្នករាល់គ្នាដើរតាម។ ដូច្នេះ ចូរដកអំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
[6]ប្រសិនបើ បងប្អូនប្រុសរបស់អ្នករាល់គ្នា ដែលត្រូវជាកូនប្រុសរបស់ម្តាយអ្នករាល់គ្នា ឬកូនប្រុសរបស់ឪពុកអ្នករាល់គ្នា ឬកូនប្រុសស្រីរបស់អ្នករាល់គ្នា
និងប្រពន្ធជាទីស្រឡាញ់របស់អ្នករាល់គ្នា និងមិត្តសម្លាញ់ដ៏ជិតស្និទ្ធរបស់អ្នករាល់គ្នាមកបបួលអ្នករាល់គ្នាដោយស្ងាត់ៗថា តោះយើងទៅថ្វាយបង្គំព្រះដទៃទៀត
ជាព្រះដែលអ្នករាល់គ្នា និងដូនតារបស់អ្នករាល់គ្នាដែលមិនស្គាល់[7]គឺព្រះរបស់ជនជាតិនានាដែលនៅជុំវិញអ្នករាល់គ្នា ទោះនៅជិត ឬនៅឆ្ងាយពីអ្នករាល់គ្នាក្តី
ចាប់តាំងពីចុងផែនដីម្ខាង ដល់ចុងផែនដីម្ខាង។
[8]នោះកុំយល់ព្រមជាមួយគេ ឬស្តាប់តាមគេឡើយ។ កុំអាណិតអាសូរ ឬត្រាប្រណីដល់គេឲ្យសោះ ហើយក៏មិនត្រូវការពារគេឡើយ។[9]ផ្ទុយទៅវិញ ត្រូវសម្លាប់អ្នកនោះចោល
គឺរាល់គ្នាលើកដៃប្រហារអ្នកនោះមុនគេ បន្ទាប់មក ប្រជាជនប្រហារគេតាមក្រោយ។

generated on Wed Sep 10 16:16:32 2025

[10]ត្រូវយកដុំថ្មគប់សម្លាប់អ្នកនោះ ព្រោះគេចង់ទាញអ្នករាល់គ្នាឲ្យបែរចេញពីព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នករាល់គ្នាចេញពីទឹកដីអេស៊ីប
គឺជាទឹកដីដែលអ្នករាល់គ្នាធ្វើជាទាសករ។[11]ប្រជាជនអ៊ីស្រាអែលទាំងមូលនឹងឮ រួចភ័យខ្លាច ហើយនឹងលែងប្រព្រឹត្តអំពើអាក្រក់បែបនេះ
នៅក្នុងចំណោមអ្នករាល់គ្នាទៀត។
[12]ប្រសិនបើ អ្នករាល់គ្នាឮនរណាម្នាក់និយាយអំពីទីក្រុងរបស់អ្នករាល់គ្នា ថាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គប្រទានឲ្យអ្នករាល់គ្នារស់នៅ។
[13]មានមនុស្សអាក្រក់ខ្លះ បានចេញពីក្នុងចំណោមអ្នករាល់គ្នា ហើយនាំគ្នាបបួលអ្នកក្រុងនោះចេញឲ្យទៅថ្វាយបង្គំព្រះដទៃទៀត ដែលអ្នករាល់គ្នាមិនស្គាល់។
[14]នោះត្រូវស៊ើបសួរ និងតាមដានមើល ឲ្យឃើញប្រាកដ។ ព្រមទាំងសាកសួរដំណឹងឲ្យច្បាស់ថា តើការនោះពិត ឬមិនពិត ប្រសិនបើ មានភស្តុតាងថា
អំពើដ៏គួរស្អប់ខ្ពើមនោះកើតឡើងនៅក្នុងចំណោមអ្នករាល់គ្នាមែន នោះត្រូវចាត់វិធានការ។
[15]នោះត្រូវប្រហារពួកអ្នកក្រុងនោះដោយមុខដាវ ហើយត្រូវបំផ្លាញចោលឲ្យអស់កុំឲ្យនៅសល់ គឺមនុស្សទាំងអស់នៅក្នុងទីក្រុង ព្រមទាំងកម្ទេចរបស់របរនៅក្នុងទីក្រុង
និងសម្លាប់ហ្វូងសត្វដោយមុខដាវផង។[16]ត្រូវប្រមូលទ្រព្យសម្បត្តិទាំងអស់ដែលនៅក្នុងទីក្រុងនោះ មកដាក់ចំកណ្តាលទីលានក្រុង រួចដុតកម្ទេចទីក្រុង និងទ្រព្យសម្បត្តិ
ដើម្បីថ្វាយព្រះអម្ចាស់។ ទីក្រុងនោះនឹងក្លាយជាគំនរអហូតទៅ ឥតមាននរណាសង់ឡើងវិញឡើយ។
[17]មិនត្រូវយករបស់អ្វីៗដែលត្រូវបំផ្លាញនោះ នៅក្នុងដៃរបស់អ្នករាល់គ្នាឡើយ។ ដើម្បីឲ្យព្រះអម្ចាស់ងាកចេញពីសេចក្តីក្រោធ
ហើយព្រះអង្គនឹងសម្តែងព្រះហឫទ័យសេចក្តីមេត្តាករុណា និងសេចក្តីអាណិតអាសូរដល់អ្នករាល់គ្នាវិញ ព្រមទាំងប្រទានឲ្យអ្នករាល់គ្នាចម្រើនឡើង
ដូចព្រះអង្គបានស្បថចំពោះបុព្វបុរសរបស់អ្នករាល់គ្នា។[18]ព្រះអង្គនឹងធ្វើបែបនេះ ដោយសារ អ្នករាល់គ្នាស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
ហើយកាន់តាមបញ្ញត្តិរបស់ព្រះអង្គទាំងប៉ុន្មាន ដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ ហើយប្រព្រឹត្តអំពើត្រឹមត្រូវនៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។

Deuteronomy 13:1

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

ប្រសិនបើ មាន កើតឡើងក្នុងចំណោមអ្នករាល់គ្នា

«ប្រសិនបើមានកើតឡើងក្នុងចំណោមអ្នករាល់គ្នា» ឬ
«ប្រសិនបើនរណាម្នាក់ក្នុងចំណោមអ្នកអះអាងថា»

គ្រូទាយណាម្នាក់

នេះជាអ្នកដែលទទួលសារពីព្រះជាម្ចាស់ តាមរយៈក្តីសុបិន្ត។

ទីសម្គាល់ ឬការអស្ចារ្យអ្វីមួយ

ពាក្យទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា និងសំដៅទៅលើការអស្ចារ្យផ្សេងៗ។

កើតមានឡើងមែន

«កើតឡើង» ឬ «កើតមាន»

ហើយគេនិយាយថា ចូរយើងទៅតាមព្រះដទៃ ហើយគោរពប្រតិបត្តិដល់ព្រះទាំងនោះវិញ

ជាព្រះដែលអ្នករាល់គ្នាមិនបានស្គាល់

អាចបកប្រែជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«ហើយគាត់ប្រាប់អ្នកឱ្យអ្នកបម្រើ និងថ្វាយបង្គំព្រះដទៃទៀត
ដែលអ្នករាល់គ្នាមិនធ្លាប់ស្គាល់»

ចូរយើងទៅតាមព្រះដទៃ

ការថ្វាយបង្គំព្រះដទៃទៀត ត្រូវបានគេនិយាយថាពួកគេកំពុងដើរតាម
ឬដើរតាមផ្លូវព្រះដទៃទៀត។ ការបកប្រែផ្សេងទៀត
«ចូរយើងដើរតាមព្រះដទៃទៀត»

ទៅតាមព្រះដទៃ ជាព្រះដែលអ្នករាល់គ្នាមិនបានស្គាល់

ឃ្លាថា «ព្រះដែលអ្នកមិនធ្លាប់ស្គាល់» សំដៅទៅលើព្រះ
ដែលមនុស្សដទៃទៀតថ្វាយបង្គំ។ ជនជាតិអ៊ីស្រាអែលស្គាល់ព្រះអម្ចាស់
ព្រោះព្រះអង្គបានបង្ហាញឱ្យគេឃើញហើយគេក៏បានស្គាល់ឫទ្ធានុភាពរបស់ព្រះអង្គ។

នោះមិនត្រូវស្តាប់តាមពាក្យព្យាការី ឬគ្រូទាយនោះឡើយ

នៅទីនេះ «ពាក្យ» តំណាងឱ្យអ្វីដែលត្រូវបានគេនិយាយ។ ការបកប្រែផ្សេងទៀត
«កុំស្តាប់អ្វីដែលព្យាការីនិយាយ ឬគ្រូទាយនិយាយ»

អស់ពីចិត្ត ហើយអស់ពីព្រលឹង ឬយ៉ាងណា។

ឃ្លា «ដោយអស់ពីដួងចិត្ត» មានន័យថា «ទាំងស្រុង» និង «ជាមួយ ... ព្រលឹង»
មានន័យថា «ជាមួយខ្លួនអ្នកទាំងអស់»។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
សូមមើលការបកប្រែនៅក្នុង ៤:២៩។ ការបកប្រែផ្សេងទៀត
«ដោយអស់ពីសមត្ថភាពរបស់អ្នក» ឬ « ដោយថាមពលរបស់អ្នកទាំងអស់»

Deuteronomy 13:4

អ្នករាល់គ្នាត្រូវដើរតាមព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា

ការស្តាប់បង្គាប់និងថ្វាយបង្គំព្រះអម្ចាស់
ត្រូវបានគេនិយាយដូចជាប្រជាជនបានដើរតាម ឬដើរតាមព្រះអម្ចាស់ដែរ។
ការបកប្រែផ្សេងទៀត « អ្នកនឹងស្តាប់តាមព្រះអម្ចាស់»

ស្តាប់បង្គាប់ព្រះអង្គ

នៅទីនេះ «ស្តាប់បង្គាប់» តំណាងឱ្យអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «ស្តាប់តាមនូវអ្វីដែលព្រះអង្គមានបន្ទូល»

នៅជាប់នឹងព្រះអង្គ។

មានគេនិយាយថា ដើម្បីមានទំនាក់ទំនងល្អជាមួយព្រះអម្ចាស់
និងពឹងផ្អែកលើព្រះអង្គទាំងស្រុង
គឺប្រៀបដូចជាមនុស្សនោះនៅជាប់នឹងព្រះអម្ចាស់ដែរ។ ការបកប្រែផ្សេងទៀត
«ពឹងផ្អែកលើព្រះអង្គ»

នឹងត្រូវស្លាប់

អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែសម្លាប់»

បានល្បួងបះបោរ

នាមអរូបី «ការបះបោរ» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«គាត់បានព្យាយាមធ្វើឱ្យអ្នកបះបោរ»

និងរំដោះអ្នករាល់គ្នាឲ្យរួចពីទាសករ។

ព្រះអម្ចាស់បានជួយសង្គ្រោះប្រជាជនអ៊ីស្រាអែលពីទាសភាពនៅស្រុកអេស៊ីប
គឺដូចជាព្រះអម្ចាស់បានបង់ប្រាក់ដើម្បីរំដោះប្រជារាស្ត្ររបស់ព្រះអង្គ
ឱ្យរួចផុតពីទាសករ។ ការបកប្រែផ្សេងទៀត
«ដែលបានជួយសង្គ្រោះអ្នកចេញពីកន្លែង ដែលអ្នកធ្លាប់ជាទាសករ»

ឲ្យរួចពីផ្ទះនៃទាសករ។

នៅទីនេះ «ពីផ្ទះនៃទាសភាព
»តំណាងឱ្យប្រទេសអេស៊ីបដែលប្រជាជនរបស់ព្រះអម្ចាស់ធ្លាប់ធ្វើជាទាសករ។
ការបកប្រែផ្សេងទៀត «អេស៊ីបដែលជាកន្លែង ដែលអ្នកធ្លាប់ធ្វើជាទាសករ»

ទាញអ្នករាល់គ្នាឲ្យចេញពីផ្លូវដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាបង្គាប់ឲ្យអ្នករាល់គ្នាដើរតាម។

របៀបដែលព្រះជាម្ចាស់ចង់ឲ្យមនុស្សរស់នៅ ឬប្រព្រឹត្ត ត្រូវបានគេនិយាយថា
ជាវិធីឬផ្លូវដែលព្រះជាម្ចាស់ចង់ឲ្យ ប្រជារាស្ត្ររបស់ព្រះអង្គដើរតាម។

មនុស្សម្នាក់ដែលព្យាយាមធ្វើឱ្យអ្នកផ្សេងទៀត ឈប់ស្តាប់បង្គាប់ព្រះជាម្ចាស់
ត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងព្យាយាមធ្វើឱ្យមនុស្សម្នាក់ទៀត
ឈប់ដើរតាមព្រះជាម្ចាស់ឬផ្លូវ។ ការបកប្រែផ្សេងទៀត
«ធ្វើឱ្យអ្នករាល់គ្នាមិនស្តាប់តាមនូវអ្វី
ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបង្គាប់»

ចូរដកអំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។

នៅទីនេះ «អំពើអាក្រក់» សំដៅទៅលើមនុស្សអាក្រក់ ឬអាកប្បកិរិយាអាក្រក់។
គុណនាមបន្ទាប់បន្សំនេះអាចត្រូវបានបញ្ជាក់ជាគុណនាម។ ការបកប្រែផ្សេងទៀត
«ដូច្នេះអ្នករាល់គ្នាត្រូវដកខ្លួនចេញពីចំណោមប្រជាជនអ៊ីស្រាអែល
អ្នករាល់គ្នាបានធ្វើអំពើអាក្រក់នេះ» ឬ « ដូច្នេះ
អ្នករាល់គ្នាត្រូវសម្លាប់មនុស្សអាក្រក់នេះ»

Deuteronomy 13:6

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

និងប្រពន្ធជាទីស្រឡាញ់របស់អ្នករាល់គ្នា

ដើមទ្រូងជាទ្រូងរបស់មនុស្សម្នាក់។ នេះជាឃ្លាដែលគាត់កាន់ជិតទ្រូងរបស់គាត់
ដែលមានន័យថាគាត់ស្រឡាញ់និងថ្នាក់ថ្នមនាង។ ការបកប្រែផ្សេងទៀត
«ប្រពន្ធដែលអ្នកស្រឡាញ់» ឬ «ប្រពន្ធដែលអ្នកឱបក្រសោប»

មិត្តសម្លាញ់ដ៏ជិតស្និទ្ធរបស់អ្នករាល់គ្នាមកបបួលអ្នករាល់គ្នា

នៅទីនេះ «ជិតស្និទ្ធ» តំណាងឱ្យជីវិតរបស់មនុស្ស។ នេះមានន័យថា
មនុស្សនោះយកចិត្តទុកដាក់ចំពោះមិត្តរបស់គាត់
ដូចជាគាត់យកចិត្តទុកដាក់ចំពោះជីវិតផ្ទាល់ខ្លួនរបស់គាត់។ ការបកប្រែផ្សេងទៀត
«មិត្តជាទីស្រឡាញ់របស់អ្នក» ឬ «មិត្តដែលអ្នកស្រឡាញ់ដូចអ្នកស្រឡាញ់ខ្លួនឯង»

generated on Wed Sep 10 16:16:32 2025

មកបបួលអ្នករាល់គ្នាដោយស្ងាត់ៗថា តោះយើងទៅថ្វាយបង្គំព្រះដទៃទៀត ... ដល់ចុងផែនដីម្ខាង។
អាចបកប្រែជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«ដោយសម្ងាត់ព្យាយាមបញ្ចុះបញ្ចូលអ្នករាល់គ្នាឱ្យទៅថ្វាយបង្គំ ...
ដល់ចុងផែនដីម្ខាង»។
ដែលនៅជុំវិញអ្នករាល់គ្នា
«ដែលនៅជុំវិញអ្នករាល់គ្នា »
ចាប់តាំងពីចុងផែនដីម្ខាង ដល់ចុងផែនដីម្ខាង។
នៅទីនេះឯកសារយោងទៅចុងបំផុតនៃផែនដីមានន័យថា
«គ្រប់ទីកន្លែងលើផែនដី»។ ការបកប្រែផ្សេងទៀត «ពាសពេញលើផែនដីទាំងមូល»
Deuteronomy 13:8
នោះកុំយល់ព្រមជាមួយគេ
«មិនយល់ព្រមនឹងអ្វីដែលគាត់ចង់បាន»
កុំអាណិតអាសូរ
នៅទីនេះ «ភ្នែករបស់អ្នក» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«អ្នកនឹងមិនមើលទៅគាត់ដោយអាណិត» ឬ
«អ្នកនឹងមិនបង្ហាញសេចក្តីមេត្តាដល់គាត់»
ឬត្រាប្រណីដល់គេឲ្យសោះ ហើយក៏មិនត្រូវការពារគេឡើយ។
«អ្នកនឹងមិនបង្ហាញសេចក្តីមេត្តាដល់គេ ឬលាក់បាំងពីអ្វីដែលគាត់បានធ្វើឡើយ»
គឺរាល់គ្នាលើកដៃប្រហារអ្នកនោះមុនគេ បន្ទាប់មក ប្រជាជនប្រហារគេតាមក្រោយ។
មានន័យថា គាត់ត្រូវគប់ដុំថ្មដំបូងដាក់អ្នកមានទោស។ ពាក្យថា« ដៃ»
តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត «
អ្នកត្រូវតែជាអ្នកដំបូងគេដែលធ្វើបាបគាត់ដើម្បីសម្លាប់គាត់»
ប្រជាជនប្រហារគេតាមក្រោយ។
នៅទីនេះ «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«មនុស្សផ្សេងទៀតនឹងចូលរួមជាមួយអ្នក»
Deuteronomy 13:10
ព្រោះគេចង់ទាញអ្នករាល់គ្នាឲ្យបែរចេញពីព្រះអម្ចាស់
«ដើម្បីបង្វែរអ្នកចេញពីព្រះអម្ចាស់»។
មនុស្សម្នាក់ដែលព្យាយាមធ្វើឱ្យអ្នកណាម្នាក់ឈប់គោរពប្រតិបត្តិដល់ព្រះអម្ចាស់
ត្រូវបានគេនិយាយដូចជាមនុស្សម្នាក់ ដែលកំពុងព្យាយាមធ្វើឱ្យនរណាម្នាក់
បង្វែរខ្លួនហើយចាកចេញពីព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«គាត់បានព្យាយាមធ្វើឱ្យអ្នកមិនស្តាប់បង្គាប់ព្រះអម្ចាស់»
ចេញពីទឹកដីអេស៊ីប
នៅទីនេះ «ដំណាក់នៃភាពជាទាសភាព» តំណាងឱ្យប្រទេសអេស៊ីប
ដែលប្រជាជនរបស់ព្រះអម្ចាស់ធ្លាប់ជាទាសករ។ ការបកប្រែផ្សេងទៀត
«ចេញពីកន្លែងដែលអ្នកធ្លាប់ជាទាសករ»
ប្រជាជនអ៊ីស្រាអែលទាំងមូលនឹងឮ រួចភ័យខ្លាច
បញ្ជាក់ថា នៅពេលប្រជាជនបានឮអំពីមនុស្ស
ដែលត្រូវបានគេសម្លាប់ពួកគេនឹងភ័យខ្លាច ចំពោះសកម្មភាពដូចគាត់បានធ្វើ។
Deuteronomy 13:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
មានមនុស្សអាក្រក់ខ្លះ បានចេញពីក្នុងចំណោមអ្នករាល់គ្នា
ឃ្លា «ពីក្នុងចំណោមអ្នករាល់គ្នា» មានន័យថា មនុស្សអាក្រក់ទាំងនេះ
ជាជនជាតិអ៊ីស្រាអែល ដែលរស់នៅក្នុងសហគមន៍របស់ពួកគេ។
ហើយនាំគ្នាបបួលអ្នកក្រុងនោះចេញឲ្យទៅថ្វាយបង្គំព្រះដទៃទៀត ដែលអ្នករាល់គ្នាមិនស្គាល់។
អាចបកប្រែជាដកស្រងដោយប្រយោល។ ការបកប្រែផ្សេងទៀត
«បានបញ្ចុះបញ្ចូលអស់អ្នកដែលរស់នៅក្នុងទីក្រុងរបស់ពួកគេ
ឱ្យទៅថ្វាយបង្គំព្រះដទៃទៀត ដែលពួកគេមិនស្គាល់»
ហើយនាំគ្នាបបួលអ្នកក្រុងនោះចេញឲ្យទៅ
មនុស្សម្នាក់ដែលធ្វើឱ្យមនុស្សម្នាក់ទៀត ឈប់គោរពប្រតិបត្តិដល់ព្រះអម្ចាស់
ត្រូវបានគេនិយាយថា បើមនុស្សម្នាក់បានធ្វើឱ្យមនុស្សត្រឡប់ក្រោយ
ហើយចាកចេញពីព្រះអម្ចាស់។
នោះត្រូវស៊ើបសួរ និងតាមដានមើល ឲ្យឃើញប្រាកដ។
ឃ្លាទាំងអស់នេះមានន័យដូចគ្នា។ លោកម៉ូសេកំពុងបញ្ជាក់ថា
ពួកគេត្រូវតែស្វែងរកដោយប្រុងប្រយ័ត្ននូវអ្វី ដែលបានកើតឡើងនៅទីក្រុង។
អំពើដ៏គួរស្អប់ខ្ពើមនោះកើតឡើងនៅក្នុងចំណោមអ្នករាល់គ្នាមែន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជននៅទីក្រុងបានធ្វើរឿងដ៏អាក្រក់បែបហ្នឹង»
Deuteronomy 13:15
ដោយមុខដាវផង។
នៅទីនេះ «មុខ» តំណាងឱ្យដាវទាំងមូល។ ការបកប្រែផ្សេងទៀត
«ដោយដាវរបស់អ្នក»
ទាំងអស់ដែលនៅក្នុងទីក្រុងនោះ
«ការប្រមូលជ័យភណ្ឌយកទាំងអស់»។ សំដៅទៅលើកម្មសិទ្ធនិងទ្រព្យសម្បត្តិ
ដែលកងទ័ពប្រមូលបន្ទាប់ពីឈ្នះសមរភូមិ។
ក្លាយជាគំនរ
«គំនរបាក់បែក»
ឥតមាននរណាសង់ឡើងវិញឡើយ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គ្មានមនុស្សណាម្នាក់ត្រូវកសាងទីក្រុងឡើងវិញទេ»
Deuteronomy 13:17
មិនត្រូវយករបស់អ្វីៗដែលត្រូវបំផ្លាញនោះ នៅក្នុងដៃរបស់អ្នករាល់គ្នាឡើយ។
ព្រះអម្ចាស់ដាក់បណ្តាសាអ្វីមួយ ហើយសន្យាថានឹងបំផ្លាញវា
ត្រូវបានគេនិយាយដូចជាព្រះអម្ចាស់បានដាក់វត្ថុផ្សេងពីរបស់ផ្សេងទៀតដាច់ពីគ្នា។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាមិនត្រូវរក្សាទុករបស់អ្វី
ដែលព្រះជាម្ចាស់បានបញ្ជាឲ្យអ្នករាល់គ្នាបំផ្លាញឡើយ»
នៅក្នុងដៃរបស់អ្នករាល់គ្នា
នេះជារបៀបនិយាយថា មនុស្សម្នាក់រក្សាអ្វីមួយ។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាត្រូវតែរក្សាទុក»
ព្រះអម្ចាស់ងាកចេញពីសេចក្តីក្រោធ
ព្រះអម្ចាស់លែងមានព្រះពិរោធដូចសេចក្តីក្រោធ របស់ព្រះអង្គ
ត្រូវបានគេនិយាយជាវត្ថុ ហើយព្រះអម្ចាស់បែរចេញពីគេ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងឈប់មានសេចក្តីក្រោធ »
ចំពោះបុព្វបុរសរបស់អ្នករាល់គ្នា។
នៅទីនេះ «បុព្វបុរស» មានន័យថាជីដូនជីតា ឬបុព្វបុរស។
អ្នករាល់គ្នាស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់
នៅទីនេះ «សំឡេង» តំណាងឱ្យអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នាកំពុងធ្វើតាមអ្វី ដែលព្រះអម្ចាស់មានព្រះបន្ទូល»
អំពើត្រឹមត្រូវនៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
នៅទីនេះ សំឡេង» តំណាងឱ្យអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នាកំពុងធ្វើតាមអ្វី
ដែលព្រះអម្ចាស់ចាត់ទុកថាត្រឹមត្រូវ»

---

14 [1]អ្នករាល់គ្នាជាប្រជារាស្ត្ររបស់ព្រះអម្ចាស់ ជាព្រះនៃអ្នករាល់គ្នា។ ដូច្នេះ នៅពេលអ្នករាល់គ្នាកាន់ទុក្ខ មិនត្រូវធ្វើពិធីអារសាច់
ហើយក៏មិនត្រូវកោរសក់នៅផ្នែកខាងមុខដែរ។[2]ដ្បិត អ្នករាល់គ្នាជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ហើយព្រះអម្ចាស់
បានជ្រើសរើសអ្នករាល់គ្នាពីក្នុងចំណោមជនជាតិនានានៅលើផែនដី មកធ្វើជាប្រជារាស្ត្រមួយដែលជាកម្មសិទ្ធិរបស់ព្រះអង្គផ្ទាល់។
[3]អ្នករាល់គ្នាមិនត្រូវបរិភោគអាហារណាដែលមិនបរិសុទ្ធឡើយ។[4]ទាំងនេះជាសត្វដែលអ្នករាល់គ្នាអាចបរិភោគបានគឺ សត្វគោ សត្វចៀម សត្វពពែ[5]សត្វឈ្លូស សត្វប្រើស
សត្វក្តាន់ សត្វម៉ាង សត្វទ្រាយ សត្វទន្សោង និងសត្វពពែភ្នំឡើយ។
[6]អ្នករាល់គ្នាអាចបរិភោគសត្វទាំងអស់ដែលមានជើងឆែកជាពីរ ហើយជាសត្វដែលទំពាអៀង។[7]ប៉ុន្តែ ក្នុងចំណោមសត្វដែលទំពាអៀង ឬមានក្រចកឆែកនោះ
មិនត្រូវបរិភោគឡើយ គឺមានសត្វអូដ្ឋ ទន្សាយគល់ និងទន្សាយថ្មឡើយ ព្រោះសត្វទាំងនោះទំពាអៀង តែគ្មានក្រចកជើងឆែកទេ
ហើយសត្វទាំងនោះមិនបរិសុទ្ធដល់អ្នករាល់គ្នាឡើយ។
[8]រីឯជ្រូកក៏មិនបរិភោគដែរ ព្រោះវាមានក្រចកឆែក តែមិនទំពាអៀងទេ វាជាសត្វមិនបរិសុទ្ធដល់អ្នករាល់គ្នា។ មិនត្រូវបរិភោគសាច់វាឡើយ
ហើយក៏មិនត្រូវប៉ះពាល់ខ្មោចវាដែរ។

generated on Wed Sep 10 16:16:32 2025

[9]ក្នុងចំណោមសត្វដែលរស់នៅក្នុងទឹក អ្នករាល់គ្នាអាចបរិភោគបាន គឺអ្នករាល់គ្នាអាចបរិភោគត្រីណាដែលមានព្រុយ
និងស្រកា[10]តែមិនត្រូវបរិភោគត្រីណាដែលគ្មានមានព្រុយ និងមានស្រកាឡើយ ដ្បិត វាជាសត្វមិនបរិសុទ្ធដល់អ្នករាល់គ្នា។
[11]សត្វស្លាបដែលបរិសុទ្ធអ្នករាល់គ្នាអាចបរិភោគបានទាំងអស់។[12]ប៉ុន្តែ សត្វស្លាបដែលអ្នករាល់គ្នាមិនអាចបរិភោគបាននោះគឺសត្វខ្លែងស្រោក សត្វត្មាត
សត្វប្រមង់[13]សត្វល្មូត សត្វរអាត និងពពួកប្រភេទសត្វស្មាំង។
[14]អ្នករាល់គ្នាមិនត្រូវបរិភោគប្រភេទសត្វក្អែក[15]និងសត្វអូទ្រុស សត្វខ្លែងស្រោក សត្វរំពេ និងសត្វស្មាំងគ្រប់ប្រភេទ[16]សត្វម៉ៀម សត្វគូក សត្វទីទុយ[17]សត្វទុង សត្វក្អែកទឹក
សត្វស្មោញឡើយ ។
[18]អ្នករាល់គ្នាមិនត្រូវបរិភោគ សត្វកុក សត្វក្រសា គ្រប់ប្រភេទ ព្រមទាំងសត្វត្រសេះ និងសត្វប្រចៀវ។[19]អស់ទាំងសត្វល្អិត ដែលមានស្លាប
សុទ្ធតែជាសត្វមិនបរិសុទ្ធសម្រាប់អ្នកគ្រប់គ្នា គឺមិនត្រូវបរិភោគឡើយ។[20]អ្នករាល់គ្នាអាចបរិភោគសត្វស្លាបណាដែលបរិសុទ្ធ។
[21]អ្នករាល់គ្នាមិនត្រូវបរិភោគសាច់សត្វណាដែលងាប់ដោយឯកឯងឡើយ គឺអ្នករាល់គ្នាអាចឲ្យសត្វនោះទៅជនបរទេសដែលរស់នៅក្នុងទីក្រុងរបស់រាល់គ្នាបរិភោគបាន
ឬលក់ឲ្យទៅសាសន៍ដទៃបាន។ ព្រោះអ្នករាល់គ្នាជាប្រជាជនដ៏បរិសុទ្ធរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
អ្នករាល់គ្នាមិនត្រូវស្ងោរកូនពពែក្នុងទឹកដោះរបស់មេវាឡើយ។
[22]អ្នករាល់គ្នាត្រូវញែកតង្វាយមួយភាគដប់ គ្រប់ទាំងភោគផលពីស្រែចម្ការរបស់អ្នករាល់គ្នាជារៀងរាល់ឆ្នាំ។[23]អ្នករាល់គ្នាត្រូវបរិភោគតង្វាយមួយភាគដប់
ដែលអ្នករាល់គ្នាញែកចេញពីស្រូវ ស្រាទំពាំងបាយជូរថ្មី ប្រេង ព្រមទាំងកូនដំបូងនៃកូនគោ
និងហ្វូងចៀមរបស់អ្នករាល់គ្នានៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា កន្លែងដែលព្រះអង្គនឹងជ្រើសរើស សម្រាប់នឹងតាំងព្រះនាមព្រះអង្គ
ដើម្បីឲ្យអ្នករាល់គ្នារៀនគោរពកោតខ្លាចព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
[24]ប្រសិនបើ ជាផ្លូវនោះឆ្ងាយពេក អ្នករាល់គ្នាមិនអាចដឹកតង្វាយមួយភាគដប់នោះទៅបាន ដោយសារព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាជ្រើសរើសកន្លែង
សម្រាប់នឹងតាំងព្រះនាមព្រះអង្គ នៅឆ្ងាយពីអ្នករាល់គ្នា ដូច្នេះ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានប្រទានពរដល់អ្នករាល់គ្នា។
[25]អ្នករាល់គ្នាត្រូវលក់តង្វាយមួយភាគដប់របស់អ្នករាល់គ្នា រួចយកប្រាក់វេចកាន់ជាប់នៅដៃ ហើយត្រូវទៅកន្លែងដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាបានជ្រើសរើស។
[26]អ្នករាល់គ្នាអាចចំណាយលុយ ដើម្បីទិញអ្វីៗដែលអ្នករាល់គ្នាប្រាថ្នាចង់បាន ដូចជាគោ ឬចៀម ស្រាទំពាំងបាយជូរ ឬស្រាផ្សេងៗទៀត
ឬអ្វីៗដែលអ្នករាល់គ្នាចូលចិត្តចង់បាន អ្នករាល់គ្នាត្រូវបរិភោគនៅទីនោះ ចំពោះព្រះភក្ត្រព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
ហើយត្រូវអរសប្បាយជាមួយក្រុមគ្រួសាររបស់អ្នករាល់គ្នា។[27]រីឯពួកលេវីដែលនៅក្នុងទីក្រុងរបស់អ្នករាល់គ្នា នោះមិនត្រូវបំភ្លេចគេឡើយ ដ្បិត
ពួកគេគ្មានចំណែកដីជាកេមរតកដូចអ្នករាល់គ្នាទេ។
[28]នៅចុងឆ្នាំ រៀងរាល់បីឆ្នាំម្តង អ្នករាល់គ្នាត្រូវយកតង្វាយមួយភាគដប់ទាំងអស់ដែលញែកចេញពីភោគផលដែលអ្នករាល់គ្នាទទួលបានក្នុងឆ្នាំនោះ
ហើយអ្នករាល់គ្នាត្រូវយកមកដាក់នៅក្នុងក្រុងរបស់អ្នករាល់គ្នា[29]ហើយពួកលេវី ដែលគ្មានដីជាចំណែកកេមរតកជាមួយអ្នករាល់គ្នា ព្រមទាំងជនបរទេស ក្មេងកំព្រា
និងស្ត្រីមេម៉ាយ ដែលនៅក្នុងក្រុងជាមួយអ្នករាល់គ្នា នឹងនាំគ្នាមកបរិភោគយ៉ាងឆ្អែតបរិបូរ។ កាលណាអ្នករាល់គ្នាប្រព្រឹត្តដូច្នេះ នោះព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
នឹងប្រទានពរឲ្យអ្នករាល់គ្នាបានចម្រុងចម្រើន គ្រប់ទាំងកិច្ចការដែលអ្នករាល់គ្នាធ្វើ។

Deuteronomy 14:1

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

អ្នករាល់គ្នាជាប្រជារាស្ត្រ ... អ្នករាល់គ្នាជាប្រជារាស្ត្រ ... បានជ្រើសរើសអ្នករាល់គ្នា

ការកើតឡើងទាំងអស់នៃពាក្យ «អ្នករាល់គ្នា» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
លោកម៉ូសេត្រូវបានរួមបញ្ចូលជាផ្នែកមួយនៃប្រជាជន។ ការបកប្រែផ្សេងទៀត
«យើងជាប្រជារាស្ត្រ ... យើងជាប្រជាជាតិមួយ ... បានជ្រើសរើសយើង»

មិនត្រូវធ្វើពិធីអារសាច់ ហើយក៏មិនត្រូវកោរសក់នៅផ្នែកខាងមុខដែរ។

សូមកុំឲ្យយើងខ្ញុំឮព្រះសូរសៀងរបស់ព្រះអម្ចាស់ ជាព្រះនៃយើងខ្ញុំតទៅទៀត
នៅទីនេះសំឡេង «តំណាងឱ្យព្រះអម្ចាស់កំពុងមានព្រះបន្ទូល»។
ការបកប្រែផ្សេងទៀត
«កុំឲ្យយើងខ្ញុំឮព្រះអម្ចាស់ជាព្រះនៃយើងមានបន្ទូលម្តងទៀត»
Deuteronomy 18:17
យើងនឹងធ្វើឲ្យមានព្យាការីម្នាក់
ព្រះអម្ចាស់តែងតាំងមនុស្សម្នាក់ ឱ្យធ្វើជាព្យាការីត្រូវបានគេនិយាយ
ដូចជាព្រះអម្ចាស់នឹងងើបឡើង ឬលើកគាត់ឡើង។
ពីក្នុងចំណោមបងប្អូនរបស់ខ្លួន។
«ពីក្នុងចំណោមជនរួមជាតិអ៊ីស្រាអែលរបស់ពួកគេ»
យើងនឹងដាក់ព្រះបន្ទូលរបស់យើងក្នុងមាត់ព្យាការីនោះ

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់ប្រាប់ព្យាការីនូវអ្វី ដែលត្រូវនិយាយ
គឺដូចជាព្រះអម្ចាស់នឹងមានបន្ទូលនៅក្នុងមាត់របស់ព្យាការី។
រួចលោកនឹងថ្លែងប្រាប់គេ
«និយាយទៅកាន់ប្រជាជនអ៊ីស្រាអែល»
មិនស្តាប់ពាក្យលោកថ្លែងក្នុងនាមយើងទេ
នេះជាពាក្យដែលតំណាងឱ្យអ្វី ដែលព្រះអម្ចាស់មានបន្ទូល។ នៅទីនេះឃ្លា
«នាមយើង»តំណាងឱ្យព្រះអម្ចាស់និងអំណាចរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «មិនស្តាប់គាត់នៅពេលគាត់និយាយសាររបស់យើង»
យើងនឹងដាក់ទោសអ្នកនោះ។
«យើងនឹងទទួលខុសត្រូវគាត់» ឬ «យើងនឹងដាក់ទោសគាត់»។ នៅទីនេះ «គាត់»
សំដៅទៅលើមនុស្ស ដែលមិនស្តាប់តាមព្យាការី។

Deuteronomy 18:20

ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូល។
ណាម្នាក់ហ៊ានថ្លែងពាក្យអ្វីមួយក្នុងនាមយើង
នៅទីនេះ «ពាក្យ» តំណាងឱ្យសារ។ ការបកប្រែផ្សេងទៀត
«អ្នកដែលហ៊ាននិយាយសារ» ឬ «អ្នកដែលព្រះហើនថ្លែងសារ»
ក្នុងនាមយើង
នៅទីនេះ« នាមយើង» សំដៅទៅលើព្រះអម្ចាស់ផ្ទាល់ និងអំណាចរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «សម្រាប់យើង» ឬ «ជាមួយសិទ្ធិអំណាចរបស់យើង»
ជាពាក្យដែលយើងមិនបានបង្គាប់ឲ្យថ្លែង
នៅទីនេះ «ពាក្យ» តំណាងឱ្យសារ។ ការបកប្រែផ្សេងទៀត
«សារមួយដែលយើងមិនបានបង្គាប់»
គេថ្លែងពាក្យក្នុងនាមព្រះដទៃទៀត
នៅទីនេះ «នាម»តំណាងឱ្យព្រះក្លែងក្លាយខ្លួនឯង ឬអំណាចរបស់ពួកគេ។
មានន័យថា ព្យាការីអះអាងថាព្រះក្លែងក្លាយបានប្រាប់គាត់
ឱ្យនិយាយសារជាក់លាក់។
អ្នករាល់គ្នាប្រហែលជាគិតក្នុងចិត្ត
នៅទីនេះ «ចិត្ត» តំណាងឱ្យគំនិតរបស់មនុស្ស។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាសួរខ្លួនឯង» ឬ «អ្នករាល់គ្នាត្រូវតែនិយាយទៅកាន់ខ្លួនឯង»
តើធ្វើដូចម្តេចឲ្យយើងដឹងថា ពាក្យណាមួយដែលមិនមែនមកពីព្រះអម្ចាស់?
តើយើងអាចដឹងយ៉ាងដូចម្តេច បើសារដែលព្យាការីនិយាយមក គឺមកពីព្រះអម្ចាស់?
នៅទីនេះ «យើង» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។

Deuteronomy 18:22

ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូល។
ព្យាការីណាម្នាក់ថ្លែងពាក្យក្នុងព្រះនាមព្រះអម្ចាស់
នៅទីនេះ «ព្រះនាមព្រះអម្ចាស់» សំដៅទៅលើព្រះអម្ចាស់ផ្ទាល់
និងអំណាចរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ព្យាការីនិយាយប្រកាសជំនួសយើង» ឬ «
ព្យាការីនិយាយប្រកាសដោយអំណាចរបស់យើង»
ព្យាការីនោះមិនហ៊ាននិយាយតាមតែអំពើចិត្តរបស់ខ្លួន
«ព្យាការីបាននិយាយសារនេះ ដោយគ្មានសិទ្ធិអំណាចរបស់យើង»

---

19 [1]កាលណាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា កាត់ប្រជាជាតិចេញពីទឹកដីដែលព្រះអង្គប្រទានឲ្យអ្នករាល់គ្នា ហើយអ្នកបានបណ្តេញគេចេញ ហើយរស់នៅក្នុងក្រុង
និងនៅក្នុងផ្ទះរបស់ពួកគេ[2]នោះ អ្នករាល់គ្នាត្រូវជ្រើសរើសទីក្រុងឲ្យបានបីសម្រាប់ខ្លួនអ្នក នៅក្នុងទឹកដីដែលព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាបានប្រទានឲ្យអ្នករាល់គ្នាកាន់កាប់។[3]អ្នករាល់គ្នាត្រូវរៀបចំផ្លូវ និងបែងចែកទឹកដីដែលព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាទុកជាកេមរតក ជាបីតំបន់ ដើម្បីឲ្យអ្នកណាដែលសម្លាប់គេអាចរត់ទៅជ្រកកោននៅទីនោះ។
[4]នេះគឺជាច្បាប់មួយសម្រាប់ជួយអ្នកដែលសម្លាប់គេ ហើយអាចរត់ទៅជ្រកកោននៅក្រុងនោះបាន ដើម្បីឲ្យបានរួចជីវិត គឺអ្នកសម្លាប់អ្នកជិតខាងរបស់ខ្លួនដោយអចេតនា
និងគ្មានគំនិតស្អប់គ្នាជាមុន[5]ឧទាហរណ៍ថា បើមានបុរសម្នាក់ទៅកាប់ឈើក្នុងព្រៃ ជាមួយអ្នកជិតខាង ហើយពេលដែលគាត់លើកពូថៅទៅកាប់រលំដើមឈើ
ស្រាប់តែផ្លែពូថៅនោះរបូតចេញពីដង ទៅប៉ះអ្នកជិតខាងបណ្តាលឲ្យស្លាប់ ដូច្នេះ គាត់អាចរត់ទៅជ្រកកោននៅក្រុងណាមួយដើម្បីឲ្យរួចជីវិត។
[6]ធ្វើដូច្នេះ បើផ្លូវឆ្ងាយពេក នោះអ្នកដែលមានសិទ្ធិសងសឹក កាលកំពុងមានចិត្តខឹងខ្លាំង ពុំអាចដេញតាមទាន់អ្នកដែលសម្លាប់គេនោះ និងសម្លាប់គាត់ឡើយ ដ្បិត
បុរសនោះមិនត្រូវមានទោសដល់ស្លាប់ទេ ព្រោះគាត់មិនបានសម្លាប់គេដោយចិត្តស្អប់ឡើយ។[7]ហេតុនេះហើយ បានជាខ្ញុំបង្គាប់អ្នកថា ត្រូវញែកក្រុងបីដោយឡែក។
[8]ប្រសិនបើ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ពង្រីកទឹកដីរបស់អ្នករាល់គ្នា ដូចព្រះអង្គបានសន្យាជាមួយបុព្វបុរសរបស់អ្នករាល់គ្នា
ហើយព្រះអង្គប្រទានទឹកដីទាំងមូលមកឲ្យអ្នករាល់គ្នា ជាទឹកដីដែលព្រះអង្គបានសន្យាជាមួយបុព្វបុរសរបស់អ្នករាល់គ្នា[9]ប្រសិនបើ
អ្នករាល់គ្នាប្រព្រឹត្តតាមបទបញ្ជាទាំងប៉ុន្មាន ដែលខ្ញុំបង្គាប់ដល់អ្នករាល់គ្នានៅថ្ងៃនេះ ដើម្បីឲ្យអ្នករាល់គ្នាស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
ហើយដើរតាមផ្លូវរបស់ព្រះអង្គជាដរាប បន្ទាប់មក អ្នករាល់គ្នាត្រូវបន្ថែមក្រុងបីទៀតពីលើក្រុងបីនោះ។[10]ធ្វើដូច្នេះ កុំឲ្យឈាមមនុស្សឥតទោស
ខ្ចាយទៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាទុកជាកេមរតក ហើយកុំឲ្យទោសនៃការខ្ចាយឈាមនោះធ្លាក់មកលើអ្នករាល់គ្នាឡើយ។
[11]ប៉ុន្តែ ប្រសិនបើមាននរណាម្នាក់ស្អប់អ្នកជិតខាងរបស់ខ្លួន ហើយប្រើល្បិចកល ហើយលបចាំស្នាក់វាយប្រហារអ្នកនោះឲ្យស្លាប់
រួចរត់ទៅជ្រកកោននៅក្នុងទីក្រុងណាមួយក៏ដោយ[12]នោះពួកអ្នកចាស់ទុំនៃទីក្រុងនោះ ត្រូវចាត់គេឲ្យទៅចាប់ជនជាតិនោះមកវិញ។
[13]ភ្នែករបស់អ្នករាល់គ្នាមិនត្រូវអាណិតដល់អ្នកនោះឡើយ ផ្ទុយទៅវិញ គឺអ្នកលុបបំបាត់ជនដែលបង្ហូរឈាម ចេញពីទឹកដីអ៊ីស្រាអែល
ដើម្បីឲ្យអ្នករាល់គ្នាបានសប្បាយតទៅ។
[14]មិនត្រូវបង្ខិតបង្គោលរបងចូលទៅក្នុងដីរបស់អ្នកជិតខាង ជារបងដាំដោយមនុស្សជំនាន់ដើម នៅដីដែលគ្រងជាមរតក ក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ប្រទានឲ្យអ្នករាល់គ្នាកាន់កាប់នោះឡើយ។
[15]មិនត្រូវមានសាក្សីតែម្នាក់ ងើបឡើងធ្វើបន្ទាល់ទាស់នឹងអំពើទុច្ចរិត ប្រព្រឹត្តបទឧក្រិដ្ឋ បទល្មើស ឬអំពើបាន ណាមួយឡើយ បើមានសាក្សីពីរ ឬបីនាក់
ទើបសំណុំរឿងនោះអាចយកជាការបាន។[16]ប្រសិនបើ មានសាក្សីក្លែងក្លាយម្នាក់ ងើបឡើងចោទប្រកាន់មនុស្សណាម្នាក់ថា បានប្រព្រឹត្តអំពើអាក្រក់អ្វីមួយ។
[17]នោះត្រូវឲ្យភាគីទាំងពីរដែលទាស់ទែងគ្នា ត្រូវឈរនៅចំពោះព្រះអម្ចាស់ ឈរនៅចំពោះមុខពួកបូជាចារ្យ និងចៅក្រមដែលកាន់មុខតំណែងនៅគ្រានោះ។
[18]ចៅក្រមត្រូវសាកសួរឲ្យហ្មត់ចត់ ហើយប្រសិនបើ ឃើញថាសាក្សីនោះក្លែងក្លាយមែន គឺគាត់ចោទមួលបង្កាច់បងប្អូនរបស់ខ្លួន[19]នោះត្រូវដាក់ទោសគាត់
ដូចដែលគាត់បានគ្រោងនឹងធ្វើដល់បងប្អូនរបស់ខ្លួន ធ្វើដូច្នេះ អ្នករាល់គ្នានឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
[20]ហើយអ្នកឯទៀតឮដំណឹងនេះហើយភ័យខ្លាច នឹងលែងប្រព្រឹត្តអំពើអាក្រក់បែបនេះ នៅក្នុងចំណោមអ្នកទៀតឡើយ។[21]កុំអាណិតអាសូរអ្នកមានទោសឲ្យសោះ
គឺជីវិតសងដោយជីវិត ភ្នែកសងដោយភ្នែក ធ្មេញសងដោយធ្មេញ ដៃសងដោយដៃ ជើងសងដោយជើង។

Deuteronomy 19:1

ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
កាលណាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា កាត់ប្រជាជាតិ
ព្រះអម្ចាស់បានបំផ្លាញប្រជាជន ដែលរស់នៅស្រុកកាណាន
គឺដូចជាព្រះអង្គកំពុងកាត់ពួកគេចេញដែរ
ដូចជាមនុស្សនឹងកាត់ចំណែកសម្លៀកបំពាក់ឬកាត់មែកឈើពីដើម។
ប្រជាជាតិ
នេះតំណាងឱ្យក្រុមមនុស្សដែលរស់នៅស្រុកកាណាន។
ទឹកដីដែលព្រះអង្គប្រទានឲ្យអ្នករាល់គ្នា
«ប្រជាជាតិទាំងនោះដែលបានកំពុងរស់នៅក្នុងស្រុក
ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ប្រទានឱ្យអ្នករាល់គ្នា»
បានបណ្តេញគេចេញ
«យកទឹកដីពីប្រជាជាតិទាំងនោះ» ឬ

generated on Wed Sep 10 16:16:32 2025

«កាន់កាប់ទឹកដីបន្ទាប់ពីប្រជាជាតិទាំងនោះបានបាត់បង់»
ជ្រើសរើសទីក្រុងឲ្យបានបី
«ជ្រើសរើសទីក្រុង៣»
អ្នករាល់គ្នាត្រូវរៀបចំផ្លូវ
ពួកគេត្រូវសាងសង់ផ្លូវដើម្បីងាយស្រួលដល់ប្រជាជន
ក្នុងការធ្វើដំណើរទៅកាន់ទីក្រុងទាំងនេះ។
ជាបីតំបន់
បញ្ជាក់ថា ទីក្រុងមួយក្នុងចំណោមទីក្រុង
ដែលពួកគេជ្រើសរើសត្រូវតែស្ថិតនៅផ្នែកនីមួយៗនៃដី។
ទឹកដីដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាទុកជាកេរមរតក
ព្រះអម្ចាស់បានប្រគល់ទឹកដីដល់ប្រជាជនអ៊ីស្រាអែល
ត្រូវបាននិយាយដូចប្រជាជនបានទទួលទឹកដីជាមរតក។
Deuteronomy 19:4
នេះគឺជាច្បាប់មួយ
«ទាំងនេះជាការណែនាំ» ឬ «ទាំងនេះជាទិសដៅ»
សម្រាប់ជួយអ្នកដែលសម្លាប់គេ
ពាក្យ «គេ» ត្រូវបានយល់។ ការបកប្រែផ្សេងទៀត
«សម្រាប់មនុស្សម្នាក់ដែលសម្លាប់មនុស្សម្នាក់ទៀត»
ហើយអាចរត់ទៅជ្រកកោននៅក្រុងនោះបាន
«ហើយអ្នកដែលរត់ទៅទីក្រុងមួយក្នុងចំណោមទីក្រុងទាំងនេះ» ឬ
«ហើយអ្នកដែលរត់ទៅក្រុងមួយក្នុងចំណោមទីក្រុងទាំងនេះ»
ដើម្បីឲ្យបានរួចជីវិត
«ដើម្បីសង្គ្រោះជីវិតរបស់គាត់»។ អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ
អាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត «ដូច្នេះ
ក្រុមគ្រួសាររបស់មនុស្សដែលបានស្លាប់មិនសម្លាប់គាត់ដើម្បីសងសឹកទេ»
គឺអ្នកសម្លាប់អ្នកជិតខាងរបស់ខ្លួនដោយអចេតនា
នៅទីនេះ «អ្នកជិតខាង» មានន័យថាជាមនុស្សទូទៅ។ ការបកប្រែផ្សេងទៀត
«អ្នកដែលសម្លាប់មនុស្សម្នាក់ទៀតដោយចៃដន្យ»
និងគ្មានគំនិតស្អប់គ្នាជាមុន
«ប៉ុន្តែ មិនបានស្អប់អ្នកជិតខាងមុនពេលគាត់សម្លាប់គាត់»។ បញ្ជាក់ថា
គ្មានមូលហេតុអ្វីដែលគាត់ត្រូវសម្លាប់អ្នកជិតខាងដោយចេតនាឡើយ។
ឧទាហរណ៍ថា បើមានបុរសម្នាក់ទៅកាប់ឈើក្នុងព្រៃ ... កាប់រលំដើមឈើ
អ្នកនិពន្ធផ្តល់នូវការស្មានកាលៈទេស
ដែលមនុស្សម្នាក់សម្លាប់មនុស្សម្នាក់ទៀតដោយចៃដន្យ។
ស្រាប់តែផ្លែពូថៅនោះរបូតចេញពីដង
ផ្នែកដែកនៃពូថៅចេញពីដង។
ទៅប៉ះអ្នកជិតខាងបណ្តាលឲ្យស្លាប់
មានន័យថាក្បាលពូថៅប៉ះ និងសម្លាប់អ្នកជិតខាង។
គាត់អាចត់ទៅជ្រកកោននៅក្រុងណាមួយដើម្បីឲ្យរួចជីវិត។
«ទៅកាន់ទីក្រុងមួយក្នុងចំណោមទីក្រុងទាំងនេះដើម្បីជួយសង្គ្រោះជីវិតរបស់គាត់»
។ បញ្ជាក់ថា ក្រុមគ្រួសាររបស់មនុស្ស ដែលស្លាប់អាចព្យាយាមសងសឹក។
មនុស្សដែលបានសម្លាប់គាត់អាចភៀសខ្លួនទៅទីក្រុងមួយ
ក្នុងចំណោមទីក្រុងទាំងនេះ ហើយប្រជាជននៅទីនោះនឹងការពារគាត់។
Deuteronomy 19:6
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
នោះអ្នកដែលមានសិទ្ធិសងសឹក
នៅទីនេះ «សងសឹក» តំណាងឱ្យមនុស្ស ដែលត្រូវបានគេសម្លាប់។
«អ្នកសងសឹក» ជាសាច់ញាតិជិតស្និទ្ធរបស់មនុស្ស ដែលត្រូវបានគេសម្លាប់។
សាច់ញាតិនេះទទួលខុសត្រូវក្នុងការដាក់ទោសឃាតករ។
អ្នកដែលសម្លាប់គេនោះ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«អ្នកដែលបានសម្លាប់មនុស្សម្នាក់ទៀត»
កាលកំពុងមានចិត្តខឹងខ្លាំង
មនុស្សណាម្នាក់ដែលខឹងខ្លាំងត្រូវបានគេនិយាយ ដូចជាកំហឹងគឺជាអ្វីមួយ
ដែលត្រឡប់ជាមានកំដៅ។ ការបកប្រែផ្សេងទៀត «ហើយខឹងយ៉ាងខ្លាំង»
វាយគាត់ហើយសម្លាប់គាត់
ហើយអ្នកសងសឹកវាយហើយសម្លាប់អ្នកដែលបានសម្លាប់មនុស្សម្នាក់ទៀត»
ដ្បិត បុរសនោះមិនត្រូវមានទោសដល់ស្លាប់ទេ ព្រោះគាត់មិនបានសម្លាប់គេដោយចិត្តស្អប់ឡើយ។
«ទោះបីបុរសនោះមិនសមនឹងស្លាប់ក៏ដោយ
ព្រោះគាត់បានសម្លាប់មនុស្សម្នាក់ទៀត
ដោយចៃដន្យហើយមិនមែនជាសត្រូវរបស់គាត់ទេ
ហើយគាត់ក៏មិនមានគម្រោងធ្វើបាបបុរសនោះដែរ»
Deuteronomy 19:8
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ពង្រីកទឹកដីរបស់អ្នករាល់គ្នា
«ប្រគល់ឱ្យអ្នករាល់គ្នានូវទឹកដីបន្ថែមទៀត ដើម្បីកាន់កាប់»
ដូចព្រះអង្គបានសន្យាជាមួយបុព្វបុរសរបស់អ្នករាល់គ្នា
«ដូចជាព្រះអង្គបានបានសន្យាដល់បុព្វបុរសរបស់អ្នករាល់គ្នាថា ព្រះអង្គនឹងធ្វើ»
ប្រសិនបើ អ្នករាល់គ្នាប្រព្រឹត្តតាមបទបញ្ជាទាំងប៉ុន្មាន
«បើអ្នករាល់គ្នាគោរពតាមបទបញ្ជាទាំងអស់នេះ»
ហើយដើរតាមផ្លូវរបស់ព្រះអង្គជាដរាប
របៀបដែលព្រះជាម្ចាស់ចង់ឲ្យមនុស្សរស់នៅ
ឬប្រព្រឹត្តគឺត្រូវបាននិយាយដូចវិធីរបស់ព្រះអម្ចាស់ឬផ្លូវ។
មនុស្សដែលស្តាប់បង្គាប់ព្រះអម្ចាស់
ត្រូវបាននិយាយដូចបានកំពុងដើរតាមវិធីរបស់ព្រះអម្ចាស់ឬផ្លូវ។
ការបកប្រែផ្សេងទៀត «ត្រូវស្តាប់បង្គាប់ព្រះអង្គជាដរាប»
បន្ទាប់មក អ្នករាល់គ្នាត្រូវបន្ថែមក្រុងបីទៀត
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «បន្ទាប់មកអ្នករាល់គ្នាត្រូវជ្រើសរើសទីក្រុងបីបន្ថែមទៀត
សម្រាប់មនុស្សម្នាក់រត់គេចខ្លួន បើគាត់សម្លាប់មនុស្សណាម្នាក់ដោយចៃដន្យ»
ពីលើក្រុងបីនោះ។
«បន្ថែមពីលើទីក្រុងទាំង៣ ដែលអ្នករាល់គ្នាបានបង្កើតឡើងរួចហើយ»
ធ្វើដូច្នេះ កុំឲ្យឈាមមនុស្សឥតទោស
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ធ្វើដូចនេះដើម្បីឱ្យសមាជិកគ្រួសារមិនសម្លាប់មនុស្សស្លូតត្រង់»
ឈាមមនុស្សឥតទោស ឌ្នាយ
នៅទីនេះ «ឈាម» តំណាងឱ្យជីវិតរបស់មនុស្សម្នាក់។ ការបង្ហូរឈាមមានន័យថា
សម្លាប់មនុស្ស។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គ្មានមនុស្សណាសម្លាប់មនុស្សឥតទោស»
ទៅក្នុងទឹកដី
«នៅក្នុងទឹកដី» ឬ «នៅក្នុងតំបន់»
ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាទុកជាកេរមរតក
ទឹកដីដែលព្រះអម្ចាស់ប្រទានដល់ជនជាតិអ៊ីស្រាអែល
ត្រូវបាននិយាយដូចជាមរតក។ (សូមមើលfigs-metaphor)
ហើយកុំឲ្យទោសនៃការខ្ចាយឈាមនោះធ្លាក់មកលើអ្នករាល់គ្នាឡើយ។
ប្រជាជនអ៊ីស្រាអែលមានទោសចំពោះមនុស្ស
ដែលបានស្លាប់ដោយសារពួកគេមិនបានសាងសង់ទីក្រុងជាទីកន្លែងមួយ
ដែលគាត់នឹងមានសុវត្ថិភាពពី «អ្នកសងសឹក»
ត្រូវបានគេនិយាយដូចជាកំហុសនៃការស្លាប់របស់គេ គឺស្ថិតនៅលើពួកគេ។
ការខ្ចាយឈាម
នៅទីនេះ«ឈាម»តំណាងឱ្យជីវិតមួយហើយ«ការខ្ចាយឈាម
»សំដៅទៅលើកំហុសដែលមនុស្សណាម្នាក់មានចំពោះការសម្លាប់មនុស្សគ្មានទោស។
មកលើអ្នករាល់គ្នាឡើយ។
មានន័យថា បើសមាជិកគ្រួសារម្នាក់សម្លាប់មនុស្សគ្មានទោស
បន្ទាប់មកប្រជាជនអ៊ីស្រាអែលទាំងអស់
នឹងមានទោសចំពោះការអនុញ្ញាតឱ្យរឿងនោះកើតឡើង។
Deuteronomy 19:11
អ្នកជិតខាងរបស់ខ្លួន
នៅទីនេះ «អ្នកជិតខាង» មានន័យថាមនុស្សទូទៅ។
ហើយប្រើល្បិចកល
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «លាក់ខ្លួនហើយរង់ចាំដើម្បីសម្លាប់គាត់» ឬ
«គ្រោងនឹងសម្លាប់គាត់»
ហើយលបចាំស្ទាក់វាយប្រហារ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត « វាយប្រហារគាត់»
វាយប្រហារអ្នកនោះឲ្យស្លាប់

generated on Wed Sep 10 16:16:32 2025

«ហើយធ្វើឱ្យគាត់ឈឺចាប់ ដូច្នេះ គាត់ស្លាប់» ឬ «ហើយសម្លាប់គាត់»
ត្រូវចាត់គេឲ្យទៅចាប់ជនជាតិនោះមកវិញ។
«ត្រូវតែបញ្ជូនមន្ទួណាម្នាក់ឱ្យមកទទួលគាត់
ហើយនាំគាត់ពីទីក្រុងដែលគាត់បានរត់គេចទៅ»
បញ្ជូនគាត់ទៅ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ប្រគល់ឱ្យគាត់»
ទៅក្នុងដៃនៃសាច់ញាតិដែលទទួលខុសត្រូវ
នៅទីនេះ «ដៃ» តំណាងឱ្យសិទ្ធិអំណាចរបស់មនុស្សណាម្នាក់។
ការបកប្រែផ្សេងទៀត «អំណាចនៃសាច់ញាតិដែលទទួលខុសត្រូវ» ឬ
«ចំពោះសាច់ញាតិដែលទទួលខុសត្រូវ»
សាច់ញាតិដែលទទួលខុសត្រូវ
នេះជាសាច់ញាតិរបស់អ្នក ដែលត្រូវគេសម្លាប់។
សាច់ញាតិនេះទទួលខុសត្រូវក្នុងការដាក់ទោសឃាតករ។
គាត់អាចស្លាប់
«ឃាតករអាចនឹងស្លាប់» ឬ
«សាច់ញាតិដែលទទួលខុសត្រូវអាចនឹងសម្លាប់ឃាតករ»
ភ្នែករបស់អ្នករាល់គ្នាមិនត្រូវអាណិតដល់អ្នកនោះឡើយ
នៅទីនេះ «ភ្នែករបស់អ្នករាល់គ្នា» តំណាងឱ្យមនុស្សទាំងមូល។
ការបកប្រែផ្សេងទៀត «កុំបង្ហាញភាពអាណិតដល់គាត់» ឬ «កុំអាណិតគាត់»
គឺអ្នកលុបបំបាត់ជនដែលបង្ហូរឈាម ចេញពីទឹកដីអ៊ីស្រាអែល
នៅទីនេះ «បង្ហូរឈាម» តំណាងឱ្យអ្នកទោសពីបទសម្លាប់មនុស្សគ្មានកំហុស។
ការបកប្រែផ្សេងទៀត «អ្នកត្រូវតែប្រហារជីវិតឃាតករ
ដើម្បីកុំឱ្យប្រជាជនអ៊ីស្រាអែលមានទោស ចំពោះការស្លាប់របស់មនុស្សស្លូតត្រង់»
ចេញពីទឹកដីអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
Deuteronomy 19:14
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
មិនត្រូវបង្ហិតបង្គោលរបងចូលទៅក្នុងដីរបស់អ្នកជិតខាង
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «អ្នកមិនត្រូវយកដីពីអ្នកជិតខាងរបស់អ្នក
ដោយបង្ហិតបង្គោលនៅតាមព្រំដីនៃដីរបស់គាត់»
ជារបងដាំដោយមនុស្សជំនាន់ដើម
«បុព្វបុរសរបស់អ្នកបានដាក់ដាំ»
ដោយមនុស្សជំនាន់ដើម
លោកម៉ូសេមានន័យថា
នៅពេលប្រជាជនបានរស់នៅលើទឹកដីនេះអស់រយៈពេលជាយូរមកហើយ
ពួកគេមិនគួរផ្លាស់ទីព្រំប្រទល់ ដែលដូនតារបស់ពួកគេបានធ្វើ
នៅពេលពួកគេកាន់កាប់ដីដំបូងឡើយ។
នៅដីដែលគ្រងជាមរតក ក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ប្រទានឲ្យអ្នករាល់គ្នាកាន់កាប់នោះឡើយ។
ព្រះអម្ចាស់បានប្រទានទឹកដីដល់ប្រជាជនអ៊ីស្រាអែល
ត្រូវបាននិយាយដូចពួកគេទទួលទឹកដីជាមរតក។ ការបកប្រែផ្សេងទៀត
«នៅក្នុងស្រុកដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ប្រទានឱ្យអ្នករាល់គ្នាកាន់កាប់»
Deuteronomy 19:15
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវមានសាក្សីតែម្នាក់
«មានសាក្សីតែមួយ» ឬ «សាក្សីតែម្នាក់គត់»
ងើបឡើងធ្វើបន្ទាល់ទាស់នឹងអំពើទុច្ចរិត
នៅទីនេះ «ងើបឡើង» មានន័យថាក្រោកឈរឡើងនៅតុលាការ
ហើយនិយាយប្រឆាំងនឹងនរណាម្នាក់ទៅកាន់ចៅក្រម។ ការបកប្រែផ្សេងទៀត
«មិនត្រូវនិយាយទៅកាន់ចៅក្រមអំពីអាក្រក់ ដែលបុរសបានធ្វើ»
អំពើបាបណាមួយឡើយ
«គ្រប់ពេលដែលបុរសធ្វើអំពើអាក្រក់»
បើមានសាក្សីពីរ ឬបីនាក់ ទើបសំណុំរឿងនោះអាចយកជាការបាន។
នៅទីនេះ «សាក្សី» តំណាងឱ្យនូវអ្វីដែលសាក្សីនិយាយ។ បញ្ជាក់ថា
ត្រូវតែមានសាក្សីយ៉ាងហោចណាស់ពីរឬបីនាក់។ ការបកប្រែផ្សេងទៀត
«សាក្សីយ៉ាងហោចណាស់ពីរឬបីនាក់» ឬ
«ផ្អែកទៅលើគោលការណ៍គ្រឹះយ៉ាងហោចណាស់ពីរឬបីនាក់
និយាយថាបានកើតឡើង»
ទើបសំណុំរឿងនោះអាចយកជាការបាន។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «អ្នកនឹងបញ្ជាក់ថា
មនុស្សនោះមានកំហុស»
ប្រសិនបើ
«នៅពេល» ឬ «ប្រសិនបើ»
មានសាក្សីក្លែងក្លាយម្នាក់
«សាក្សីដែលមានបំណងធ្វើបាបអ្នកដទៃ»
ងើបឡើងចោទប្រកាន់មនុស្សណាម្នាក់ថា បានប្រព្រឹត្តអំពើអាក្រក់អ្វីមួយ។
នៅទីនេះ «ងើបឡើង» មានន័យថា
ក្រោកឈរឡើងហើយនិយាយប្រឆាំងនឹងមនុស្សណាម្នាក់ ទៅកាន់ចៅក្រម។
ការបកប្រែផ្សេងទៀត «ប្រាប់ចៅក្រមថាមនុស្សនេះបានធ្វើបាបដើម្បីបង្កបញ្ហា» ឬ
«ប្រាប់ចៅក្រមថាមនុស្សបានធ្វើបាប ដូច្នេះ ចៅក្រមនឹងដាក់ទោសទោសគាត់»
Deuteronomy 19:17
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដែលទាស់ទែងគ្នា ត្រូវឈរនៅ
«អ្នកដែលមិនយល់ស្របនឹងគ្នា»
ឈរនៅចំពោះមុខពួកបូជាចារ្យ និងចៅក្រមដែលកាន់មុខតំណែងនៅគ្រានោះ។
មានន័យថា មនុស្សទាំងពីរនាក់ត្រូវទៅទីសក្ការៈ ដែលព្រះអម្ចាស់គង់នៅ។
នៅទីសក្ការៈបូជាចារ្យនិងចៅក្រមដែលមានសិទ្ធិអំណាចក្នុងការសម្រេចចិត្ត
តាមច្បាប់សម្រាប់ព្រះអម្ចាស់។
ឈរនៅចំពោះមុខពួកបូជាចារ្យ និងចៅក្រមដែលកាន់មុខតំណែងនៅគ្រានោះ។
ឃ្លាថា «ឈរនៅចំពោះមុខ» ជាឃ្លាបែបសំនួនវោហាស័ព្ទ។ មានន័យថា
ទៅរកមនុស្សណាម្នាក់ ដែលមានសិទ្ធិអំណាច
ហើយអនុញ្ញាតិឱ្យគាត់ធ្វើការសម្រេចចិត្តស្របច្បាប់អំពីបញ្ហានោះ។
ចៅក្រមត្រូវសាកសួរឲ្យហ្មត់ចត់
«ចៅក្រមត្រូវតែប្រឹងប្រែងដើម្បីកំណត់នូវអ្វី ដែលបានកើតឡើង»
នោះត្រូវដាក់ទោសគាត់ ដូចដែលគាត់បានគ្រោងនឹងធ្វើដល់បងប្អូនរបស់ខ្លួន
«បន្ទាប់មកអ្នកត្រូវតែផ្តន្ទាទោសសាក្សីក្លែងក្លាយតាមរបៀប
ដែលគាត់ចង់ឱ្យអ្នកដាក់ទោសលើមនុស្សផ្សេងទៀត»
អ្នករាល់គ្នានឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
នាមអរូបី «អំពើអាក្រក់» អាចត្រូវបានបញ្ជាក់ជាគុណនាម។ ការបកប្រែផ្សេងទៀត
«ដោយដាក់ទោសសាក្សីក្លែងក្លាយ
អ្នករាល់គ្នានឹងបញ្ឈប់ការអនុវត្តន៍អំពើអាក្រក់នេះ
នៅក្នុងប្រជាជាតិរបស់អ្នករាល់គ្នា»
Deuteronomy 19:20
ហើយអ្នកឯទៀត
«នៅពេលអ្នកដាក់ទោសសាក្សីក្លែងក្លាយប្រជាជន ដែលនៅសេសសល់»
ឮដំណឹងនេះហើយភ័យខ្លាច
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «នឹងឮអំពីការដាក់ទោសហើយភ័យខ្លាចទទួលទោស»
លែងប្រព្រឹត្តអំពើអាក្រក់បែបនេះ
«ឈប់ដែលធ្វើអ្វីអាក្រក់បែបហ្នឹង»
កុំអាណិតអាសូរអ្នកមានទោសឲ្យសោះ
នៅទីនេះ «ភ្នែក» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរអាណិតគាត់ទេ» ឬ «អ្នកមិនត្រូវបង្ហាញសេចក្តីមេត្តាដល់គាត់ទេ»
គឺជីវិតសងដោយជីវិត ... ជើងសងដោយជើង។
នៅទីនេះឃ្លាខ្លី ព្រោះអត្ថន័យត្រូវបានយល់។ មានន័យថា
ប្រជាជនត្រូវតែដាក់ទោសមនុស្សនោះតាមរបៀប
ដែលគាត់ធ្វើបាបមនុស្សម្នាក់ផ្សេងទៀត។

20 [1]ពេលណាអ្នករាល់គ្នាចេញទៅច្បាំងនឹងខ្មាំងសត្រូវ ហើយឃើញថាសត្រូវមានទ័ពសេះ រទេះចម្បាំង និងកងទ័ពច្រើនជាងខ្លួន អ្នករាល់គ្នាមិនត្រូវភ័យខ្លាចឡើយ ដ្បិត
ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ដែលបាននាំអ្នកចេញពីទឹកដីអេស៊ីប ហើយព្រះអង្គគង់នៅជាមួយអ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

[2]មុនពេលអ្នករាល់គ្នាចូលទៅច្បាំង នោះពួកបូជាចារ្យត្រូវចេញមកនិយាយទៅកាន់ពលទាហានថា។[3]អ៊ីស្រាអែលអើយ ចូរស្តាប់
ថ្ងៃនេះអ្នករាល់គ្នាត្រូវចូលទៅប្រយុទ្ធនឹងខ្មាំងសត្រូវ។ មិនត្រូវមានចិត្តតក់ស្លុត។ កុំភ័យខ្លាច ញ័ររន្ធត់។ និងភ័យខ្លាចនៅចំពោះមុខគេឡើយ។[4]ដ្បិត ព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គយាងទៅជាមួយនឹងអ្នករាល់គ្នា ដើម្បីច្បាំងនឹងខ្មាំងសត្រូវជំនួសអ្នករាល់គ្នា ហើយប្រទានឲ្យអ្នករាល់គ្នាមានជ័យជម្នះ។
[5]បន្ទាប់មក ពួកមេដឹកត្រូវនិយាយទៅពួកបណ្តាជនថា តើមាននរណាទើបនឹងសង់ផ្ទះថ្មី ហើយមិនទាន់បានឡើងទៅលើផ្ទះដែរឬទេ? ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ
ក្រែងលោគេស្លាប់នៅក្នុងចម្បាំង រួចមានម្នាក់ទៀតឡើងផ្ទះជំនួស។
[6]ប្រសិនបើ មាននរណាម្នាក់បានដាំទំពាំងបាយជូរ ហើយមិនទាន់ទទួលផលឬទេ។ ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ ក្រែងលោកគេត្រូវស្លាប់នៅក្នុងចម្បាំង
រួចមានម្នាក់ទៀតទទួលផលជំនួស។[7]តើមាននរណាម្នាក់មានគូរដណ្តឹង ហើយមិនទាន់បានរៀបការជាមួយនាងនៅឡើយឬទេ? ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ
ក្រែងលោកគេត្រូវស្លាប់នៅក្នុងចម្បាំង រួចមានម្នាក់ទៀតរៀបការនឹងនាង។
[8]ពួកមេដឹកនាំត្រូវនិយាយទៅកាន់ពលទ័ពទៀតថា តើមាននរណាភ័យខ្លាច ហើយមានចិត្តតក់ស្លុតឬទេ? ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ
ក្រែងលោគេនាំឲ្យបងប្អូនតក់ស្លុតដូចខ្លួនដែរ។[9]ពេលពួកមេដឹកនាំបាននិយាយទៅកាន់ពលទាហានរួចហើយ នោះត្រូវចាត់តាំងឲ្យមានមេទ័ព
ដើម្បីនាំមុខពលទាហានទាំងនោះ។
[10]ពេលណាអ្នករាល់គ្នាចូលទៅជិតក្រុងមួយ ដើម្បីច្បាំងយកក្រុងនោះ ត្រូវស្នើឲ្យពួកគេចុះចូលជាមុនសិន។[11]ប្រសិនបើ អ្នកក្រុងនោះយល់ព្រមទទួលសំណើ
ហើយបើកទ្វាក្រុងឲ្យអ្នកចូល នោះប្រជាជនទាំងប៉ុន្មានដែលមានឃើញនៅក្រុងនោះត្រូវតែចំណុះអ្នក ហើយធ្វើការបម្រើអ្នករាល់គ្នា។
[12]ប្រសិនបើ អ្នកក្រុងនោះមិនព្រមទទួលសំណើ ហើយចង់ច្បាំងជាមួយអ្នករាល់គ្នាវិញ
នោះត្រូវឡោមព័ទ្ធក្រុងនោះ[13]ហើយកាលណាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នករាល់គ្នានោះ
អ្នករាល់គ្នាត្រូវប្រហារប្រុសៗទាំងអស់ដោយមុខដាវ។
[14]ចំណែកឯស្ត្រីៗ កូនក្មេង ហ្វូងសត្វ និងរបស់អ្វីទាំងប៉ុន្មាននៅក្នុងទីក្រុង ព្រមទាំងទ្រព្យសម្បត្តិទាំងប៉ុន្មាន ត្រូវរឹបអូសយកមកសម្រាប់ខ្លួនអ្នករាល់គ្នា។
ហើយត្រូវបរិភោគសាច់របស់សត្វដែលរឹបអូសយកពីខ្មាំងសត្រូវ ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានប្រទានមកឲ្យអ្នករាល់គ្នា។[15]អ្នករាល់គ្នាត្រូវប្រព្រឹត្តបែបនេះ
ដល់គ្រប់ទាំងក្រុងដែលនៅឆ្ងាយពីអ្នករាល់គ្នាមិនមែនជាក្រុងរបស់ប្រជាជាតិទាំងនេះទេ។
[16]រីឯក្រុងរបស់ជាតិសាសន៍ទាំងនេះ ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាទុកជាមរតក
ហើយអ្នករាល់គ្នាមិនត្រូវទុកជីវិតនរណាម្នាក់ឲ្យនៅរស់ឡើយ។[17]ផ្ទុយទៅវិញ អ្នករាល់គ្នាត្រូវបំផ្លាញគេឲ្យអស់ មានជនជាតិហេត ជនជាតិអាម៉ូរី ជនជាតិកាណាន
ជនជាតិពេរិស៊ីត ជនជាតិហេវី និងជនជាតិយេប៊ូស ដូចដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបង្គាប់។[18]ធ្វើដូច្នេះ ដើម្បីកុំឲ្យគេបង្រៀនអ្នករាល់គ្នា
ឲ្យប្រព្រឹត្តអំពើគួរស្អប់ខ្ពើម ដែលគេបានប្រព្រឹត្តចំពោះព្រះរបស់ពួកគេ។ បើអ្នកប្រព្រឹត្តដូច្នោះ នោះអ្នករាល់គ្នាធ្វើបាបទាស់នឹងព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាហើយ។
[19]កាលណាអ្នករាល់គ្នាឡោមព័ទ្ធទីក្រុងមួយ អស់រយៈពេលយ៉ាងយូរ ដើម្បីវាយដណ្តើមយកក្រុងនោះ អ្នករាល់គ្នាមិនត្រូវយកពូថៅកាប់រំលំដើមឈើនោះឡើយ។ ដ្បិត
អ្នករាល់គ្នាអាចបរិភោគពីផ្លែឈើនោះបាន ដូច្នេះ អ្នករាល់គ្នាមិនត្រូវកាប់រំលំដើមឈើនោះឡើយ។ តើដើមឈើនៅក្នុងចម្ការជាមនុស្ស ឬបានជាអ្នកច្បាំងនឹងវាដូច្នេះ?
[20]ក៏ប៉ុន្តែ អ្នករាល់គ្នាអាចកាប់ដើមឈើណា ដែលអ្នករាល់គ្នាឃើញថាមិនមែនជាដើមឈើស៊ីផ្លែ អ្នករាល់គ្នាអាចកាប់ដើមឈើនោះ យកទៅធ្វើជារបាំង
ដើម្បីវាយលុកក្រុងដែលអ្នកធ្វើសឹក រហូតដល់អ្នកក្រុងនោះចុះចាញ់។

Deuteronomy 20:1

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

ពេលណាអ្នករាល់គ្នាចេញទៅច្បាំងនឹងខ្មាំងសត្រូវ

«ពេលណាអ្នករាល់គ្នាចេញទៅប្រយុទ្ធនៅក្នុងសង្គ្រាម ប្រឆាំងនឹងសត្រូវរបស់អ្នករាល់គ្នា»

ហើយឃើញថាសត្រូវមានទ័ពសេះ រទេះចម្បាំង

ប្រជាជនបានចាត់ទុកកងទ័ពដែលមានសេះ និងរទេះចម្បាំង
ជាច្រើនមានកម្លាំងខ្លាំង។ អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ
អាចបញ្ជាក់ឱ្យច្បាស់។

ដែលបាននាំអ្នកឡើងចេញពីទឹកដីអេស៊ីប

ព្រះអម្ចាស់នាំប្រជាជនពីស្រុកអេស៊ីបមកស្រុកកាណាន។
ជារឿងធម្មតាទេដែលប្រើពាក្យ «ឡើង»
ដើម្បីសំដៅទៅលើការធ្វើដំណើរពីស្រុកអេស៊ីប ទៅស្រុកកាណាន។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ដែលបាននាំអ្នកចេញពីស្រុកអេស៊ីប»

Deuteronomy 20:2

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

និយាយទៅកាន់ពលទាហាន

«និយាយទៅកាន់ទាហានអ៊ីស្រាអែល»

មិនត្រូវមានចិត្តតក់ស្លុត។ កុំភ័យខ្លាច ញ័ររន្ធត់។ និងភ័យខ្លាចនៅចំពោះមុខគេឡើយ។

ការបញ្ចេញមតិទាំងបួននេះ មានន័យដូចគ្នាហើយបញ្ជាក់យ៉ាងមុតមាំថា
ពួកគេមិនត្រូវភ័យខ្លាចឡើយ។ បើភាសារបស់អ្នកមិនមានវិធីទាំងបួន
ដើម្បីបង្ហាញគំនិតនេះអ្នកអាចប្រើតិចជាងបួន។

មិនត្រូវមានចិត្តតក់ស្លុត។

នៅទីនេះ «ចិត្ត» តំណាងឱ្យភាពក្លាហានរបស់មនុស្ស។ សម្រាប់ចិត្តដែលតក់ស្លុត
ជាឃ្លាដែលមានន័យថា «កុំភ័យខ្លាច» ។

ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គយាងទៅជាមួយនឹងអ្នករាល់គ្នា

ដើម្បីច្បាំងនឹងខ្មាំងសត្រូវជំនួសអ្នករាល់គ្នា

ព្រះអម្ចាស់បានកម្ចាត់ខ្មាំងសត្រូវរបស់ជនជាតិអ៊ីស្រាអែល
ត្រូវបាននិយាយដូចព្រះអម្ចាស់អ្នកចម្បាំង
ដែលប្រយុទ្ធជាមួយជនជាតិអ៊ីស្រាអែល។

អ្នករាល់គ្នាមានជ័យជម្នះ។

«ប្រទានឱ្យអ្នករាល់គ្នានូវជ័យជម្នះ»

Deuteronomy 20:5

ព័ត៌មានទូទៅ៖

លោកម៉ូសេបាននិយាយនូវអ្វី
ដែលពួកមេដឹកត្រូវនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល មុនពេលប្រយុទ្ធ។

បន្ទាប់មក ពួកមេដឹកត្រូវនិយាយ

ការងាររបស់ពួកមេដឹកគឺត្រូវសម្រេចចិត្តថា អ្នកណាអាចចាកចេញពីកងទ័ព។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។

តើមាននរណា ... ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ

បើទាហានម្នាក់នៅទីនេះបានសង់ផ្ទះថ្មី ហើយមិនបានឡើងទៅលើផ្ទះ
គាត់គួរតែត្រឡប់ទៅផ្ទះវិញ»

ក្រែងលោគេស្លាប់នៅក្នុងចម្បាំង រួចមានម្នាក់ទៀតឡើងផ្ទះជំនួស។

ពួកមេដឹកកំពុងពិពណ៌នាអំពីស្ថានភាពមួយដែលអាចកើតឡើងចំពោះទាហានម្នាក់។
ការបកប្រែផ្សេងទៀត: «ដូច្នេះ
បើគាត់ស្លាប់ក្នុងសមរភូមិមនុស្សផ្សេងទៀតនឹងមិនឡើងទៅលើផ្ទះរបស់គាត់
ជំនួសគាត់ទេ»

Deuteronomy 20:6

ព័ត៌មានទូទៅ៖

លោកម៉ូសេបន្តពិពណ៌នាពីស្ថានភាព
ដែលអនុញ្ញាតឱ្យមនុស្សចាកចេញទៅធ្វើទាហាន។

ប្រសិនបើ មាននរណាម្នាក់បានដាំទំពាំងបាយជូរ ... ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ

«បើទាហានម្នាក់នៅទីនេះមានចម្ការទំពាំងបាយជូរថ្មី ប៉ុន្តែ
មិនទាន់បានប្រមូលផលទំពាំងបាយជូរនៅឡើយ
គាត់គួរតែត្រលប់ទៅផ្ទះរបស់គាត់វិញ»

ក្រែងលោគេត្រូវស្លាប់នៅក្នុងចម្បាំង រួចមានម្នាក់ទៀតទទួលផលជំនួស។

ពួកមេដឹកនាំកំពុងពិពណ៌នាអំពីស្ថានភាពមួយ
ដែលអាចកើតឡើងចំពោះទាហានម្នាក់។ ការបកប្រែផ្សេងទៀត «ដូច្នេះ

generated on Wed Sep 10 16:16:32 2025

បើគាត់ស្លាប់នៅក្នុងសមរភូមិមនុស្សម្នាក់ទៀតនឹងមិនប្រមូលផលផ្លែជំនួសគាត់ទេ»
តើមាននរណាម្នាក់មានគូរដណ្តឹង
ហើយមិនទាន់បានរៀបការជាមួយនាងនៅឡើយ...ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ
«បើទាហាននៅទីនេះបានសន្យាថានឹងរៀបការជាមួយនាង ប៉ុន្តែ
មិនទាន់រៀបការជាមួយនាងគាត់គួរតែត្រឡប់ទៅផ្ទះរបស់គាត់វិញ»
ក្រែងលោកគេត្រូវស្លាប់នៅក្នុងចម្បាំង រួចមានម្នាក់ទៀតរៀបការនឹងនាង។
ពួកមេដឹកនាំកំពុងពិពណ៌នាអំពីស្ថានភាពមួយ
ដែលអាចកើតឡើងចំពោះទាហានម្នាក់។ ការបកប្រែផ្សេងទៀត «ដូច្នេះ
បើគាត់ស្លាប់ក្នុងសមរភូមិមនុស្សម្នាក់ផ្សេងទៀតមិនរៀបការជាមួយនាងជំនួសគាត់ទេ»
Deuteronomy 20:8
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តពិពណ៌នាពីស្ថានភាព
ដែលអនុញ្ញាតឱ្យមនុស្សចាកចេញទៅធ្វើទាហាន។
តើមាននរណាភ័យខ្លាច ហើយមានចិត្តតក់ស្លុតឬទេ? ចូរឲ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ
«បើទាហានណាមួយនៅទីនេះ
ខ្លាចហើយមិនក្លាហានគាត់គួរតែត្រឡប់ទៅផ្ទះរបស់គាត់វិញ»
ភ័យខ្លាច ហើយមានចិត្តតក់ស្លុត
ពាក្យទាំងពីរនេះមានន័យថា ជារួមដូចគ្នា។ ការបកប្រែផ្សេងទៀត
«ភ័យខ្លាចក្នុងការប្រយុទ្ធនៅក្នុងសមរភូមិ»
ក្រែងលោគេនាំឲ្យបងប្អូនតក់ស្លុតដូចខ្លួនដែរ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ជនជាតិអ៊ីស្រាអែលផ្សេងទៀត មិនត្រឡប់ជាភ័យខ្លាចដូចគាត់ភ័យខ្លាចទេ»
នាំឲ្យចិត្តបងប្អូនតក់ស្លុត ... ដូចខ្លួនដែរ
នៅទីនេះ «ចិត្ត »តំណាងឱ្យភាពក្លាហានរបស់មនុស្សម្នាក់។
នោះត្រូវចាត់តាំងឲ្យមានមេទ័ព ដើម្បីនាំមុខពលទាហានទាំងនោះ។
«ពួកមេដឹកនាំត្រូវចាត់តាំងប្រជាជន
ឱ្យធ្វើជាមេបញ្ជាការនិងដឹកនាំប្រជាជនអ៊ីស្រាអែល» ។
Deuteronomy 20:10
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ពេលណាអ្នករាល់គ្នាចូលទៅជិតក្រុងមួយ
នៅទីនេះ «ក្រុង» តំណាងឱ្យប្រជាជន។ ការបកប្រែផ្សេងទៀត
«នៅពេលអ្នករាល់គ្នាទៅវាយប្រហារប្រជាជននៃទីក្រុង»
ដើម្បីច្បាំងយកក្រុងនោះ ត្រូវស្នើឲ្យពួកគេចុះចូលជាមុនសិន។
«ប្រគល់ដល់ប្រជាជននៅក្នុងទីក្រុង នៅឱកាសប្រគល់ឲ្យ»
ហើយបើកទ្វាក្រុងឲ្យអ្នកចូល
នៅទីនេះ «ទ្វារក្រុង» សំដៅទៅលើច្រកទ្វារទីក្រុង។ ឃ្លា« បើកទ្វាក្រុងឲ្យអ្នកចូល»
តំណាងឱ្យប្រជាជនដែលចុះចាញ់និងអនុញ្ញាតិឱ្យជនជាតិអ៊ីស្រាអែល
ចូលទីក្រុងរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«អនុញ្ញាតិឱ្យអ្នកចូលទៅក្នុងទីក្រុងរបស់ពួកគេ ដោយសន្តិភាព»
នោះប្រជាជនទាំងប៉ុន្មានដែលមានឃើញនៅក្រុង
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនទាំងអស់នៅក្នុងទីក្រុង»
នោះត្រូវតែចំណុះអ្នក ហើយធ្វើការបម្រើអ្នករាល់គ្នា។
«ត្រូវតែក្លាយជាទាសកររបស់អ្នករាល់គ្នា»
Deuteronomy 20:12
ប្រសិនបើ អ្នកក្រុងនោះមិនព្រមទទួលសំណើ
នៅទីនេះ «អ្នក »សំដៅទៅលើទីក្រុងដែលតំណាងឱ្យប្រជាជន។
ការបកប្រែផ្សេងទៀត «ប៉ុន្តែ បើប្រជាជនទីក្រុងមិនព្រមប្រគល់» ឬ «ប៉ុន្តែ
បើប្រជាជនទីក្រុងមិនទទួលយកការផ្តល់ជូនសន្តិភាពរបស់អ្នករាល់គ្នា»
Deuteronomy 20:14
កូនក្មេង
«កុមារ»
ព្រមទាំងទ្រព្យសម្បត្តិទាំងប៉ុន្មាន
«និងរបស់មានតម្លៃទាំងអស់»
រឹបអូសយក
ទាំងនេះគឺជារបស់មានតម្លៃដែលមនុស្ស
ដែលឈ្នះការធ្វើសង្គ្រាមយកចេញពីប្រជាជន ដែលពួកគេបានវាយប្រហារ។
ដល់គ្រប់ទាំងក្រុង
នៅទីនេះ «ទីក្រុង» តំណាងឱ្យប្រជាជន។ ការបកប្រែផ្សេងទៀត
«ប្រជាជនទាំងអស់ដែលរស់នៅក្នុងទីក្រុង»
Deuteronomy 20:16
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
រីឯក្រុងរបស់ជាតិសាសន៍ទាំងនេះ
ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាទុកជាមរតក
ក្រុងនានានៅស្រុកកាណាន ដែលព្រះអម្ចាស់កំពុងប្រគល់ឱ្យប្រជាជន
ត្រូវបាននិយាយដូចជាក្រុងនានាដែលជាចំណែកមរតករបស់ប្រជាជន។
ហើយអ្នករាល់គ្នាមិនត្រូវទុកជីវិតនរណាម្នាក់ឲ្យនៅរស់ឡើយ។
«អ្នករាល់គ្នាមិនត្រូវទុកទោះបីជាអ្វីក៏ដោយឱ្យមានជីវិតរស់នៅទេ»។
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាត្រូវតែសម្លាប់អ្វីៗដែលមានជីវិត»
អ្នករាល់គ្នាត្រូវបំផ្លាញគេឲ្យអស់
«អ្នករាល់គ្នាត្រូវតែបំផ្លាញក្រុមមនុស្សទាំងនេះទាំងស្រុង»
ធ្វើដូច្នេះ ដើម្បីកុំឲ្យគេ
«បំផ្លាញប្រជាជាតិទាំងនេះដើម្បីពួកគេ»
ឲ្យប្រព្រឹត្តអំពើគួរស្អប់ខ្ពើម ...ដែលគេបានប្រព្រឹត្តចំពោះព្រះរបស់ពួកគេ។
«ប្រព្រឹត្តតាមរបៀបគួរស្អប់ខ្ពើមដូចជាប្រជាជននៅប្រទេសទាំងនេះបានធ្វើជាមួយព្រះរបស់ពួកគេ»
បើអ្នកប្រព្រឹត្តដូច្នោះ នោះអ្នករាល់គ្នាធ្វើបាបទាស់នឹងព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាហើយ។
«បើអ្នករាល់គ្នាធ្វើដូចមនុស្សទាំងនេះ អ្នករាល់គ្នានឹងធ្វើបាបប្រឆាំងនឹង
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា»
Deuteronomy 20:19
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ឡោមព័ទ្ធទីក្រុងមួយ
«ប្រយុទ្ធនៅក្នុងសមរភូមិ»
មិនត្រូវយកពូថៅកាប់រំលំដើមឈើនោះឡើយ។
«ដោយកាប់ដើមឈើជាមួយពូថៅ»
តើដើមឈើនៅក្នុងចម្ការជាមនុស្ស ឬបានជាអ្នកច្បាំងនឹងវាដូច្នេះ?
សំណួរដ៏ប៉ិនប្រសព្វនេះរម្លឹកប្រជាជនអំពីអ្វី ដែលពួកគេគួរតែដឹង។
សំណួរនេះអាចបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត:
«សម្រាប់ដើមឈើហូបផ្លែមិនមែនជាមនុស្សទេ ដូច្នេះ
ពួកគេមិនមែនជាសត្រូវរបស់អ្នកទេ» ។
អ្នករាល់គ្នាអាចកាប់ដើមឈើណា ដែលអ្នករាល់គ្នាឃើញថាមិនមែនជាដើមឈើស៊ីផ្លែ
«អ្នកដឹងហើយដើមឈើណា
ដែលផ្លែមិនស៊ីបានហើយដើមឈើណាដែលផ្លែស៊ីបាន»
យកទៅធ្វើជារបាំង
ទាំងនេះជាឧបករណ៍និងរចនាសម្ព័ន្ធដូចជាជណ្តើរ
និងប៉មដែលត្រូវការដាក់ព័ទ្ធជុំវិញទីក្រុង។
រហូតដល់អ្នកក្រុងនោះចុះចាញ់។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«រហូតទាល់តែប្រជាជនទីក្រុងចាញ់សង្គ្រាម»
អ្នកក្រុងនោះចុះចាញ់។
នៅទីនេះ «អ្នកក្រុង» សំដៅទៅលើទីក្រុងដែលតំណាងឱ្យប្រជាជនក្នុងទីក្រុង។

---

21 [1]ប្រសិនបើ ឃើញមានមនុស្សដែលគេសម្លាប់ ហើយដេកស្លាប់នៅទីវាល នៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាកាន់កាប់
ហើយគេមិនដឹងមុខឃាតក[2]នោះពួកចាស់ទុំ និងពួកចៅក្រម ត្រូវចេញទៅវាស់ចម្ងាយពីកន្លែងសាកសពនោះ ទៅក្រុងនានាដែលនៅជុំវិញ។
[3]កាលដឹងថា ក្រុងណាមួយដែលនៅជិតសាកសពជាងគេ នោះពួកចាស់ទុំរបស់ក្រុងនោះ ត្រូវយកគោស្ទាវមួយ គឺគោដែលគេមិនដែលធ្លាប់ទឹម ឬប្រើឲ្យធ្វើការនៅឡើយ។
[4]បន្ទាប់មក ត្រូវដឹកចុះទៅក្នុងជ្រោះដែលមានទឹកហូរ ជាកន្លែងមិនដែលភ្ជួររាស់ ឬសាបព្រោះ ដាំដំណាំទេ ហើយត្រូវវាយបំបាក់កគោនោះនៅក្នុងជ្រោះ។
[5]ពួកបូជាចារ្យ ជាកូនចៅពួកលេវី ត្រូវចូលទៅជិត ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានជ្រើសរើសឲ្យបម្រើព្រះអង្គ និងឲ្យពរក្នុងព្រះនាមព្រះអម្ចាស់
ហើយគ្រប់ទាំងការទាស់ទែងគ្នា ហើយវាយតប់គ្នារហូតដល់របួស នោះស្រេចនឹងអ្នកទាំងនោះសម្រេចចុះ។

generated on Wed Sep 10 16:16:32 2025

[6]ពួកចាស់ទុំទាំងអស់របស់ទីក្រុងណាមួយដែលនៅជិតសាកសព ត្រូវនាំគ្នាលាងដៃពីលើគោស្ទេវ ដែលគេវាយបំបាក់កនៅក្នុងជ្រោះនោះ[7]ហើយត្រូវប្រកាសថា
ដៃរបស់ខ្ញុំមិនបានធ្វើឃាតជននោះទេ ហើយភ្នែករបស់យើងខ្ញុំក៏មិនបានឃើញនរណាធ្វើឃាតគេដែរ។
[8]ឱព្រះអម្ចាស់អើយ សូមលើកលែងទោសអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់ព្រះអង្គ ឲ្យរួចពីបាបផង សូមកុំឲ្យអ៊ីស្រាអែល ជាប្រជារាស្ត្រដែលព្រះអង្គបានរំដោះ
ត្រូវទទួលទោស ដោយព្រោះឃាតកម្មទៅលើជនស្លូតត្រង់នេះឡើយ។ ធ្វើដូច្នេះ ពួកគេនឹងគ្មានទោសឡើយ។[9]នោះ
អ្នករាល់គ្នាត្រូវលុបបំបាត់ការសម្លាប់ជនស្លូតត្រង់ចេញពីក្នុងចំណោមអ្នករាល់គ្នា ហើយប្រព្រឹត្តតែអំពើត្រឹមត្រូវដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។
[10]ពេលណាអ្នករាល់គ្នាចេញទៅច្បាំងនឹងពួកខ្មាំងសត្រូវ ហើយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា និងប្រគល់ពួកគេមកក្នុងកណ្តាប់ដៃរបស់អ្នករាល់គ្នា
ហើយអ្នករាល់គ្នាបានចាប់ពួកគេមកជាឈ្លើយ[11]ប្រសិនបើ ក្នុងចំណោមពួកឈ្លើយនោះ មានស្ត្រីម្នាក់ដែលមានរូបឆោមស្អាត
ហើយអ្នករាល់គ្នាមានចិត្តចង់យកនាងមកធ្វើជាភរិយា[12]នោះត្រូវនាំនាងចូលមកក្នុងផ្ទះរបស់អ្នករាល់គ្នា រួចឲ្យនាងកោសក់ ហើយកាត់ក្រចកដៃ ក្រចកជើងរបស់នាង។
[13]នាងត្រូវប្តូរសម្លៀកបំពាក់ ដែលនាងស្លៀក នៅពេលដែលគេចាប់នាងមកជាឈ្លើយសឹកចេញ
ត្រូវឲ្យនាងនៅក្នុងផ្ទះរបស់អ្នករាល់គ្នាហើយយំកាន់ទុក្ខឪពុកម្តាយរបស់ខ្លួន រយៈពេលពេញមួយខែ។ បន្ទាប់មក អ្នករាល់គ្នាអាចចូលទៅជិតនាង ហើយធ្វើជាប្តីរបស់នាង
ហើយនាងនឹងក្លាយជាប្រពន្ធរបស់អ្នករាល់គ្នា។[14]ប្រសិនបើ អ្នករាល់គ្នាមិនពេញចិត្តនឹងនាង ត្រូវដោះលែងនាងឲ្យមានសេរីភាពចុះ។ អ្នករាល់គ្នាមិនត្រូវលក់នាង
ឬទុកនាងជាខ្ញុំបម្រើទេ ព្រោះអ្នករាល់គ្នាបានរួមរស់ជាមួយនាងរួចទៅហើយ។
[15]ប្រសិនបើ បុរសម្នាក់មានភរិយាពីរ គាត់ស្រឡាញ់ភរិយាមួយខ្លាំងជាភរិយាមួយទៀត ហើយនាងទាំងពីរមានកូនប្រុសដូចគ្នា តែកូនច្បង
ជាកូនរបស់នាងដែលគាត់មិនសូវស្រឡាញ់[16]ដូច្នេះ នៅពេលដែលគាត់ចែកមរតកឲ្យកូនរបស់គាត់ គាត់មិនអាចយកចំណែកមរតកដែលត្រូវបានទៅកូនច្បង
ឲ្យទៅកូនប្រុសរបស់ភរិយា ដែលគាត់ស្រឡាញ់ជាងនោះឡើយ មរតកនេះត្រូវបានទៅលើកូនរបស់ភរិយា ដែលគាត់មិនសូវស្រឡាញ់ ព្រោះគាត់ជាកូនច្បង។[17]ផ្ទុយទៅវិញ
គាត់ត្រូវទទួលស្គាល់ថា កូនច្បងជាកូនរបស់ភរិយាដែលគាត់មិនសូវស្រឡាញ់ ដោយចែកទ្រព្យសម្បត្តិដល់កូននោះពីរដងច្រើនជាងកូនឯទៀត ដ្បិត
កូននេះជាផលដំបូងនៃកម្លាំង ដូច្នេះ សិទ្ធិរបស់កូនច្បងជារបស់កូននោះឯង។
[18]ប្រសិនបើ បុរសម្នាក់មានកូនដែលរឹងរូស ហើយបះបោរ មិនស្តាប់បង្គាប់របស់ឪពុកម្តាយ ទោះបីឪពុកម្តាយវាយប្រដៅ
ក៏នៅតែមិនស្តាប់បង្គាប់[19]នោះឪពុកម្តាយត្រូវនាំយកទៅជួបពួកចាស់ទុំរបស់ទីក្រុងនោះ នៅត្រង់ទ្វាក្រុងរបស់ខ្លួន។
[20]រួចឪពុកម្តាយត្រូវជម្រាបទៅពួកចាស់ទុំរបស់ទីក្រុងថា កូនប្រុសរបស់យើងខ្ញុំជាមនុស្សរឹងរូសណាស់ ហើយបះបោរ មិនស្តាប់បង្គាប់យើងខ្ញុំទេ វាជាមនុស្សល្មោភស៊ី
ហើយជាមនុស្សប្រមឹក។[21]ប្រជាជនទាំងអស់ដែលនៅទីក្រុងនោះ ត្រូវចោលសម្លាប់កូននោះនឹងថ្មទៅ ធ្វើដូច្នេះ អ្នកនឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
ជនជាតិអ៊ីស្រាអែលទាំងអស់ដឹងរឿងនេះ ហើយគេភ័យខ្លាច។
[22]ប្រសិនបើ អ្នកណាម្នាក់ប្រព្រឹត្តអំពើឧក្រិដ្ឋត្រូវមានទោសដល់ស្លាប់ ហើយត្រូវគេយកទៅប្រហារជីវិត
ដោយព្យួរកនៅលើដើមឈើ[23]ហើយមិនត្រូវទុកសាកសពរហូតដល់យប់ឡើយ។ ផ្ទុយទៅវិញ អ្នករាល់គ្នាត្រូវយកសពទៅបញ្ចុះក្នុងថ្ងៃដែលគេស្លាប់នោះ ដ្បិត
អ្នកណាដែលត្រូវព្យួរកនៅលើដើមឈើ ជាអ្នកដែលព្រះដាក់បណ្តាសា។ ដូច្នេះ ត្រូវធ្វើយ៉ាងនោះ
មិនត្រូវធ្វើឲ្យទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាទុកជាមរតក ក្លាយទៅជាសៅហ្មងឡើយ។

Deuteronomy 21:1
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប្រសិនបើ ឃើញមានមនុស្សដែលគេសម្លាប់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បើនរណាម្នាក់រកឃើញមនុស្ស ដែលមានម្នាក់ផ្សេងទៀតបានសម្លាប់»
ហើយដេកស្លាប់នៅទីវាល
អ្នកស្លាប់កំពុងដេកនៅឯវាល។
ហើយគេមិនដឹងមុខឃាតក
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយគ្មាននរណាម្នាក់ដឹងថា អ្នកណាវាយប្រហារគាត់ទេ»
ត្រូវចេញទៅវាស់ចម្ងាយពីកន្លែងសាកសពនោះ ទៅក្រុងនានា
«ពួកគេត្រូវវាស់ចម្ងាយទៅទីក្រុងនានា»
អ្នកដែលត្រូវគេសម្លាប់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គាត់ដែលនរណាម្នាក់បានសម្លាប់» ឬ «សាកសព»
Deuteronomy 21:3
គឺគោដែលគេមិនដែលធ្លាប់ទឹម
«មិនបានពាក់នឹមទេ»
ដែលមានទឹកហូរ
នេះជាឃ្លាសម្រាប់ទឹកកំពុងធ្វើចលនា។ ការបកប្រែផ្សេងទៀត «អូរ»
ជាកន្លែងមិនដែលភ្ជួររាស់ ឬសាបព្រោះ ដាំដំណាំទេ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ជ្រលងភ្នំដែលគ្មានមនុស្សណាម្នាក់ភ្ជួររាស់ដី ឬដាំគ្រាប់ពូជ»
Deuteronomy 21:5
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវចូលទៅជិត
«ត្រូវតែមកដល់ជ្រលងភ្នំ»
ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានជ្រើសរើសឲ្យបម្រើព្រះអង្គ
«ពីព្រោះ
បូជាចារ្យជាអ្នករាល់គ្នាដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានជ្រើសរើស
ឱ្យបម្រើព្រះអង្គ»
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ដូចជាគាត់កំពុងតែនិយាយជាមួយមនុស្សម្នាក់ ដូច្នេះពាក្យ «របស់អ្នក»
មានលក្ខណៈឯកវចនៈ។
ឲ្យពរ
«ប្រទានពរដល់ប្រជាជនអ៊ីស្រាអែល»
ក្នុងព្រះនាមព្រះអម្ចាស់
នៅទីនេះឃ្លា «ក្នុងព្រះនាម» សំដៅទៅលើព្រះអម្ចាស់និងអំណាចរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «ក្នុងនាមជាព្រះអង្គ ដែលមានបន្ទូលហើយធ្វើអ្វី
ដែលព្រះអម្ចាស់អង្គទ្រង់ផ្ទាល់ មានបន្ទូលនិងធ្វើការអស្ចារ្យ»
ហើយគ្រប់ទាំងការទាស់ទែងគ្នា
«ចូរស្តាប់នូវអ្វីដែលពួកបូជាចារ្យនិយាយ»
ហើយវាយតប់គ្នារហូតដល់របួស
នៅទីនេះឃ្លា «ពាក្យរបស់ពួកគេ» សំដៅទៅលើអ្វីដែលពួកបូជាចារ្យនិយាយ។
ការបកប្រែផ្សេងទៀត «ពីព្រោះអ្វីក៏ដោយដែលពួកបូជាចារ្យនិយាយ
នោះនឹងជាការសម្រេចចិត្ត»
នោះស្រេចនឹងអ្នកទាំងនោះសម្រេចចុះ។
«គ្រប់ពេលដែលមនុស្សស្ថិតនៅក្នុងតុលាការដោយសារតែពួកគេមិនយល់ស្របនឹងគ្នា
ឬនរណាម្នាក់ធ្វើបាបមនុស្សផ្សេងទៀត»
Deuteronomy 21:6
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
គោស្ទេវ ដែលគេវាយបំបាក់ក
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គោស្ទាវដែលពួកបូជាចារ្យវាយបំបាក់ក»
ហើយត្រូវប្រកាសថា
«ហើយពួកគេត្រូវផ្តល់សក្ខីភាពដល់ព្រះអម្ចាស់អំពីករណីនេះ»
ដៃរបស់ខ្ញុំមិនបានធ្វើឃាតជននោះទេ
នៅទីនេះ« ដៃ» គឺសម្រាប់មនុស្សទាំងមូលហើយ«បានធ្វើឃាត»

generated on Wed Sep 10 16:16:32 2025

គឺជាពាក្យទាក់ទងសម្រាប់សម្លាប់មនុស្សគ្មានកំហុស។ ការបកប្រែផ្សេងទៀត
«យើងមិនបានសម្លាប់មនុស្សស្លូតត្រង់នេះទេ»
ខ្ញុំក៏មិនបានឃើញនរណាធ្វើឃាតគេដែរ។
នៅទីនេះ «ឃើញ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«ហើយយើងមិនឃើញមាននរណាសម្លាប់មនុស្សនេះទេ»
Deuteronomy 21:8
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ពួកចាស់ទុំអំពីអ្វី ដែលពួកគេគួរនិយាយ
ពេលពួកគេលាងដៃលើសត្វគោ។ គាត់និយាយទៅកាន់ពួកគេ
ដូចជាគាត់បានកំពុងនិយាយជាមួយមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង
«របស់អ្នក» មានលក្ខណៈជាឯកវចនៈ។
ជាប្រជារាស្ត្ររបស់ព្រះអង្គ ឲ្យរួចពីបាបផង
ព្រះអម្ចាស់បានជួយសង្គ្រោះប្រជាជនអ៊ីស្រាអែលពីទាសករនៅស្រុកអេស៊ីប
គឺដូចជាព្រះអម្ចាស់បានបង់ប្រាក់លោះប្រជារាស្ត្ររបស់ព្រះអង្គ
ឱ្យរួចផុតពីទាសករ។
សូមកុំឲ្យអ៊ីស្រាអែល ជាប្រជារាស្ត្រដែលព្រះអង្គបានរំដោះ ត្រូវទទួលទោស
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ហើយកុំប្រព្រឹត្តចំពោះអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ
ដូចជាពួកគេមានទោសពីបទសម្លាប់មនុស្សស្លូតត្រង់»
ធ្វើដូច្នេះ ពួកគេនឹងគ្មានទោសឡើយ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ពេលនោះព្រះអម្ចាស់នឹងអត់ទោសប្រជារាស្ត្រអ៊ីស្រាអែល
ជាប្រជារាស្ត្ររបស់ព្រះអង្គ ព្រោះតែការស្លាប់របស់មនុស្សស្លូតត្រង់»។
អ្នករាល់គ្នាត្រូវលុបបំបាត់ការសម្លាប់ជនស្លូតត្រង់ចេញពីក្នុងចំណោមអ្នករាល់គ្នា
«អ្នករាល់គ្នានឹងមិនមានកំហុសទៀតទេ ក្នុងការសម្លាប់មនុស្សគ្មានទោស»
អំពើត្រឹមត្រូវដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។
ពាក្យថា «គាប់ព្រះហឫទ័យព្រះអម្ចាស់» ជាឃ្លាសម្រាប់
«នូវអ្វីដែលព្រះអម្ចាស់គិតថាត្រឹមត្រូវ»។
Deuteronomy 21:10
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាគាត់បានកំពុងតែនិយាយទៅ[illegible]
ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
អ្នករាល់គ្នាចេញទៅ
«អ្នកដែលជាទាហានចេញទៅក្រៅ»
អ្នករាល់គ្នាមានចិត្តចង់យកនាង
ប្រើឃ្លាគួរសមសម្រាប់ «អ្នកចង់រួមដំណេកជាមួយនាង» ។
មកធ្វើជាភរិយា
«ចង់រៀបការជាមួយនាង»
រួចឲ្យនាងកោសក់
«នាងនឹងកោរសក់ចេញពីក្បាលរបស់នាង»
ហើយកាត់ក្រចកដៃ ក្រចកជើងរបស់នាង។
«កាត់ក្រចកដៃ»
Deuteronomy 21:13
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាគាត់បានកំពុងតែនិយាយទៅ[illegible]
ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
នាងត្រូវបួរសម្លៀកបំពាក់ ដែលនាងស្លៀក
នាងនឹងធ្វើដូចនេះ បន្ទាប់ពីបុរសនោះយកនាងទៅផ្ទះរបស់នាង
ហើយពេលនាងកោរសក់និងកាត់ក្រចកដៃនិងម្រាមជើងរបស់នាង
ដូចដែលបានរៀបរាប់នៅ ២១:១០ ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «នាងនឹងដោះសម្លៀកបំពាក់របស់ប្រជាជនរបស់នាង
ហើយស្លៀកសម្លៀកបំពាក់របស់ជនជាតិអ៊ីស្រាអែល»
ដែលគេចាប់នាងមកជាឈ្លើយសឹកចេញ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលអ្នកបានយកនាងជាឈ្លើយ»
រយៈពេលពេញមួយខែ។
«ចូលមួយខែ» ឬ «ពេញមួយខែ»
ប្រសិនបើ អ្នករាល់គ្នាមិនពេញចិត្តនឹងនាង
អ្នកប្រហែលជាត្រូវបញ្ជាក់ឱ្យច្បាស់ថា បុរសនោះដេកជាមួយស្ត្រី។
ការបកប្រែផ្សេងទៀត «ប៉ុន្តែ បើអ្នកគេងជាមួយនាង
ហើយបន្ទាប់មកសម្រេចចិត្តថា អ្នកមិនចង់បាននាងជាប្រពន្ធរបស់អ្នក»
ត្រូវដោះលែងនាងឲ្យមានសេរីភាពចុះ។
«ឱ្យនាងទៅកន្លែងណាក៏ដោយ ដែលនាងចង់ទៅ»
ព្រោះអ្នករាល់គ្នាបានរួមរស់ជាមួយនាងរួចទៅហើយ។
«ពីព្រោះ
អ្នកខ្មាស់អៀននាងដោយដេកជាមួយនាងហើយបន្ទាប់មកបញ្ជូននាងចេញទៅ»
Deuteronomy 21:15
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
គាត់ស្រឡាញ់ភរិយាមួយខ្លាំងជាភរិយាមួយទៀត
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត អាចមានន័យថា ១)
«ហើយបុរសស្រឡាញ់ប្រពន្ធរបស់គាត់ម្នាក់ ហើយគាត់ស្អប់ប្រពន្ធមួយទៀត» ឬ
២) «ហើយបុរសនោះស្រឡាញ់ប្រពន្ធម្នាក់
ច្រើនជាងគាត់ស្រឡាញ់ប្រពន្ធផ្សេងទៀត»
ហើយនាងទាំងពីរមានកូនប្រុសដូចគ្នា
«ហើយប្រពន្ធទាំងពីរមានកូនជាមួយគាត់»
តែកូនច្បង ជាកូនរបស់នាងដែលគាត់មិនសូវស្រឡាញ់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បើកូនប្រុសច្បងជាកម្មសិទ្ធិរបស់ប្រពន្ធ ដែលបុរសស្អប់»
ដូច្នេះ នៅពេលដែលគាត់
«ពេលបុរសនោះ»
គាត់ចែកមរតកឲ្យកូនរបស់គាត់
«បុរសនោះប្រគល់ទ្រព្យសម្បត្តិរបស់គាត់ ដល់កូនប្រុសរបស់គាត់ទុកជាមរតក»
គាត់មិនអាចយកចំណែកមរតកដែលត្រូវបានទៅកូនច្បង ឲ្យទៅកូនប្រុសរបស់ភរិយា
ដែលគាត់ស្រឡាញ់ជាងនោះឡើយ
«គាត់ប្រហែលជាមិនប្រព្រឹត្តចំពោះកូនប្រុសរបស់ប្រពន្ធជាទីស្រឡាញ់
ដូចគាត់ជាកូនប្រុសច្បងជំនួសកូនប្រុសរបស់ប្រពន្ធដែលស្អប់»
កូននោះពីរដង
[illegible]
កូននេះជាផលដំបូងនៃកម្លាំង
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«កូនប្រុសនោះជាអ្នកដែលបង្ហាញថា បុរសនេះអាចក្លាយជាឪពុករបស់កូនប្រុស»
Deuteronomy 21:18
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
បុរសម្នាក់មានកូនដែលរឹងរូស ហើយបះបោរ មិនស្តាប់បង្គាប់របស់ឪពុកម្តាយ
នៅទីនេះ «សំឡេង» ជាឃ្លាសម្រាប់អ្វីដែលមនុស្សម្នាក់និយាយ។
ការបកប្រែផ្សេងទៀត «អ្នកណានឹងមិនគោរពតាមអ្វី
ដែលឪពុកឬម្តាយរបស់គាត់និយាយ»
ទោះបីឪពុកម្តាយវាយប្រដៅ
«ពួកគេដាក់ទោសគាត់ចំពោះការធ្វើខុសរបស់គាត់» ឬ
«ពួកគេបានហ្វឹកហ្វឺននិងណែនាំគាត់»
[illegible]ចាស់ទុំរបស់ទីក្រុងនោះ
«ត្រូវតែបង្ខំឱ្យគាត់ចេញមកក្រៅ»
Deuteronomy 21:20
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល
ដូចជាគាត់បានកំពុងតែនិយាយទៅកាន់មនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង
«របស់អ្នក» មានលក្ខណៈឯកវចនៈ។
កូនប្រុសរបស់យើងខ្ញុំ
«កូនប្រុសយើង»
មិនស្តាប់បង្គាប់យើងខ្ញុំទេ
នៅទីនេះ «សំឡេង» ជាពាក្យប្រៀបធៀបសម្រាប់អ្វី ដែលមនុស្សម្នាក់និយាយ
ឬឃ្លាសម្រាប់មនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«គាត់នឹងមិនធ្វើអ្វីដែលយើងប្រាប់គាត់ឱ្យធ្វើទេ» ឬ
«គាត់នឹងមិនគោរពតាមយើងទេ»
មនុស្សល្មោភស៊ី

អ្នកដែលញ៉ាំនិងផឹកច្រើនពេក
មនុស្សប្រមឹក
អ្នកផឹកស្រាច្រើន ហើយស្រវឹងញឹកញាប់
ត្រូវចោលសម្លាប់កូននោះនឹងថ្មទៅ
«គប់ដុំថ្មលើគាត់ រហូតដល់គាត់ស្លាប់»
អ្នកនឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
គុណនាម «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លានាម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែដកមនុស្សអាក្រក់ចេញពីចំណោមប្រជាជនអ៊ីស្រាអែល
ដែលធ្វើអំពើអាក្រក់នេះ» ឬ «អ្នកត្រូវតែប្រហារជីវិតមនុស្សអាក្រក់នេះ»
ជនជាតិអ៊ីស្រាអែលទាំងអស់
ពាក្យ «អ៊ីស្រាអែល» ជាពាក្យសម្តីសម្រាប់ប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ប្រជាជននៃអ៊ីស្រាអែលទាំងអស់»
ដឹងរឿងនេះ ហើយគេភ័យខ្លាច។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «នឹងឮអំពីអ្វីដែលបានកើតឡើងចំពោះកូនប្រុស
ហើយនឹងភ័យខ្លាចថា ប្រជាជននឹងដាក់ទោសពួកគេផងដែរ»
Deuteronomy 21:22
ព័ត៌មានទូទៅ៖
ប្រសិនបើ អ្នកណាម្នាក់ប្រព្រឹត្តអំពើឧក្រិដ្ឋត្រូវមានទោសដល់ស្លាប់
«បើណាម្នាក់បានធ្វើអ្វីដែលអាក្រក់
ដែលអ្នកត្រូវដាក់ទោសគាត់ដោយសម្លាប់គាត់»
ត្រូវមានទោសដល់ស្លាប់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកប្រហារជីវិតគាត់»ឬ «អ្នកសម្លាប់គាត់»
ដោយព្យួរកនៅលើដើមឈើ
អាចមានន័យថា ១) «ហើយបន្ទាប់ពីគាត់បានស្លាប់
អ្នកបានព្យួរគាត់នៅលើដើមឈើ» ឬ ២)«ហើយអ្នកសម្លាប់គាត់
ដោយព្យួរគាត់នៅលើបង្គោលឈើ»
ត្រូវយកសពទៅបញ្ចុះក្នុងថ្ងៃដែលគេស្លាប់នោះ
«បញ្ចុះគាត់នៅថ្ងៃដែលអ្នកសម្លាប់គាត់»
ដ្បិត អ្នកណាដែលត្រូវព្យួរកនៅលើដើមឈើ ជាអ្នកដែលព្រះដាក់បណ្តាសា។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត អាចមានន័យថា
១)«ពីព្រោះព្រះជាម្ចាស់ដាក់បណ្តាសារមនុស្សគ្រប់គ្នា
ដែលមនុស្សព្យួរលើដើមឈើ» និង ២)«មនុស្សព្យួរលើដើមឈើ
ដែលព្រះជាម្ចាស់បានដាក់បណ្តាសា»។
មិនត្រូវធ្វើឲ្យទឹកដីដែល
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាគាត់បានកំពុងតែនិយាយទៅកាន់មនុស្សម្នាក់ អ្នកមានអ្វីមួយ ដែលព្រះជាម្ចាស់បានដាក់បណ្តាសាព្យួរនៅលើដើមឈើ
ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

---

22 [1]ប្រសិនបើ អ្នករាល់គ្នាឃើញគោ ឬចៀមរបស់បងប្អូនរបស់អ្នករាល់គ្នាវង្វេង កុំធ្វើពើដូចជាមិនឃើញនោះឡើយ ត្រូវនាំសត្វនោះទៅឲ្យម្ចាស់វាវិញកុំខានឡើយ។
[2]ប្រសិនបើ ម្ចាស់សត្វនោះនៅឆ្ងាយ ហើយអ្នករាល់គ្នាមិនស្គាល់ម្ចាស់ នោះត្រូវនាំសត្វនោះទៅផ្ទះរបស់អ្នករាល់គ្នា ហើយទុកវានៅជាមួយអ្នករាល់គ្នា
រហូតដល់ម្ចាស់វាមកសុំយកទៅវិញ រួចត្រូវប្រគល់វាឲ្យទៅគេវិញចុះ។
[3]ត្រូវប្រព្រឹត្តបែបដូច្នោះ ចំពោះសត្វលា ឬសម្លៀកបំពាក់ និងអ្វីៗទាំងអស់ដែលបងប្អូនអ្នកបាត់ ហើយប្រសិនបើ អ្នករាល់គ្នារកឃើញ
នោះមិនត្រូវធ្វើពើដូចជាមិនឃើញសោះឡើយ។[4]ប្រសិនបើ អ្នករាល់គ្នាឃើញលា ឬគោរបស់បងប្អូនអ្នកដួលតាមផ្លូវ នោះមិនត្រូវធ្វើពើដូចជាមិនឃើញសោះឡើយ
តែត្រូវជួយគាត់លើកសត្វនោះឡើងមកវិញ។
[5]ស្ត្រីមិនត្រូវស្លៀកពាក់ដូចបុរសឡើយ ហើយបុរសក៏មិនត្រូវស្លៀកពាក់ដូចស្ត្រីដែរ ដ្បិត អ្នកណាដែលប្រព្រឹត្តបែបដូច្នោះ
នោះជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាហើយ។
[6]ប្រសិនបើ អ្នករាល់គ្នាឃើញសំបុកសត្វ នៅលើដើមឈើ ឬនៅលើដី ហើយឃើញកូនសត្វ ឬពងសត្វ ដែលមានមេវាកំពុងតែក្រាប នោះមិនត្រូវយកទាំងមេ
ទាំងកូនឡើយ។[7]ត្រូវលែងមេឲ្យហើរទៅចុះ គឺយកតែកូនរបស់វាបានហើយ។ ធ្វើដូច្នេះ ដើម្បីឲ្យអ្នករាល់គ្នាបានសប្បាយ ហើយមានអាយុយឺនយូរ។
[8]នៅពេលអ្នករាល់គ្នាសង់ផ្ទះថ្មី ត្រូវធ្វើបង្កាន់ដៃនៅលើដំបូលផ្ទះ ក្រែងលោមាននរណាម្នាក់ធ្លាក់ពីលើដំបូលនោះមក ហើយបណ្តាលឲ្យអ្នករាល់គ្នាមានទោស
ព្រោះតែផ្ទះនោះ។
[9]មិនត្រូវព្រោះពូជពីរប្រភេទនៅក្នុងចម្ការរបស់អ្នករាល់គ្នាឡើយ ក្រែងលោផលទាំងអស់នោះត្រូវខូចខាត គឺទាំងពូជផ្សេងៗដែលអ្នករាល់គ្នាព្រោះ ទាំងផលទំពាំងបាយជូរ។
[10]មិនត្រូវទឹមគោ និងលា ឲ្យអូសនង្គ័លជាមួយគ្នាឡើយ។[11]មិនត្រូវស្លៀកពាក់សំពត់ត្បាញដោយអំបោះរោមចៀម និងអំបោះសូតទេសជាមួយគ្នាឡើយ។
[12]ត្រូវដេរខ្សែរំយោលភ្ជាប់នឹងជាយទាំងបួនរបស់ក្រណាត់ដែលអ្នករាល់គ្នាគ្របដណ្តប់ខ្លួន។
[13]ប្រសិនបើ បុរសណាយកប្រពន្ធ ហើយរួមរស់ជាមួយនាង តែក្រោយមក បែរជាឈប់ស្រឡាញ់នាង[14]ហើយចាប់តាំងនិយាយបរិហារកេរ្តិ៍នាងថា
ខ្ញុំបានយកនាងនេះមកធ្វើជាភិយា ហើយខ្ញុំឃើញថា នាងមិនមែនជាស្ត្រីព្រហ្មចារីទេ។
[15]ពេលនោះ ឪពុកម្តាយរបស់នាងត្រូវនាំយកភស្តុតាងពីភាពព្រហ្មចារីរបស់នាង ទៅបង្ហាញពួកចាស់ទុំរបស់ទីក្រុង នៅត្រង់ទ្វារក្រុង។
[16]នោះ ឪពុករបស់នាងត្រូវជម្រាបទៅកាន់ពួកចាស់ទុំថា ខ្ញុំបានលើកកូនស្រីរបស់ខ្ញុំឲ្យរៀបការជាមួយបុរសម្នាក់នេះ តែគេបែរជាលែងស្រឡាញ់នាង។[17]ហើយមើល៍
គេបាននិយាយបរិហារកេរ្តិ៍នាងថា៖ «ខ្ញុំឃើញថាកូនស្រីរបស់លោកមិនមែនជាស្ត្រីព្រហ្មចារីទេ»។ ប៉ុន្តែ សូមអស់លោកមើល៍ចុះ នេះជាភស្តុតាង ដែលបញ្ជាក់ថា
កូនស្រីរបស់ខ្ញុំពិតជាព្រហ្មចារីមែន។ ពេលនោះ ឪពុកម្តាយត្រូវលាសំពត់នោះនៅមុខពួកចាស់ទុំរបស់ទីក្រុង។
[18]ពេលនោះ ពួកចាស់ទុំរបស់ទីក្រុងនោះ ត្រូវចាប់បុរសនោះមកផ្តន្ទាទោស[19]ហើយត្រូវពិន័យអ្នកនោះឲ្យបង់ប្រាក់ មួយរយណែន ឲ្យទៅឪពុករបស់នាង
ដោយព្រោះបុរសនោះបានបង្ខូចកេរ្តិ៍ឈ្មោះស្ត្រីព្រហ្មចារីម្នាក់នៃជនជាតិអ៊ីស្រាអែល។ រីឯនាងវិញ នៅតែជាភរិយារបស់អ្នកនោះរហូតទៅ មិនអាចលែងនាងបានឡើយ
រហូតអស់មួយជីវិត។
[20]ប៉ុន្តែ ប្រសិនបើរឿងនោះជាការពិតមែន ហើយរកភស្តុតាងបានថា នាងមិននៅព្រហ្មចារីទេ[21]នោះត្រូវនាំស្ត្រីនោះទៅមាត់ទ្វារផ្ទះរបស់ឪពុកនាង
ហើយអ្នកស្រុកត្រូវនាំគ្នាយកដុំថ្មគប់សម្លាប់នាង ដោយព្រោះនាងបានប្រព្រឹត្តអំពើថោកទាបនៅក្នុងទឹកដីអ៊ីស្រាអែល ដោយបានបង្ខូចខ្លួននៅក្នុងផ្ទះរបស់ឪពុក ធ្វើដូច្នេះ
អ្នកនឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
[22]ប្រសិនបើឃើញបុរសណាម្នាក់ដែលកំពុងរួមដំណេកជាមួយប្រពន្ធអ្នកដ៏ទៃ នោះអ្នកទាំងពីរត្រូវទទួលទោសដល់ស្លាប់ គឺទាំងបុរសដែលរួមដំណេកជាមួយស្ត្រីនោះ
ទាំងស្ត្រីដែលផិតក្បត់ ធ្វើដូច្នេះ អ្នកនឹងលុបបំបាត់អំពើអាក្រក់ចេញពីអ្នករាល់គ្នា។
[23]ប្រសិនបើ មានស្ត្រីព្រហ្មចារីម្នាក់ដែលមានគូរដណ្តឹងហើយ ហើយបើមានបុរសម្នាក់ទៀតជួបនាងនៅទីក្រុង
រួចរួមដំណេកជាមួយនាង[24]នោះត្រូវនាំអ្នកទាំងពីរនោះចេញទៅទ្វារក្រុង ហើយយកដុំថ្មគប់សម្លាប់ចោលទៅ។ នាងមានទោស
ដោយព្រោះមិនបានស្រែកហៅអ្នកនៅក្នុងទីក្រុងឲ្យជួយ។ ឯបុរសនោះមានទោស ដោយព្រោះបានរំលោភប្រពន្ធអ្នកជិតខាងរបស់ខ្លួន ធ្វើដូច្នេះ
អ្នកនឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
[25]ប៉ុន្តែ ប្រសិនបើបុរសនោះបានជួបនាងក្រមុំដែលមានគូរដណ្តឹងហើយនៅឯវាលស្រែ ហើយចាប់នាងរំលោភ
នោះបុរសដែលចាប់នាងរំលោភនឹងត្រូវទទួលទោសដល់ស្លាប់។[26]តែឯស្ត្រីក្រមុំនោះវិញ មិនត្រូវធ្វើទោសអ្វីដល់នាងឡើយ
ដ្បិតនាងគ្មានកំហុសអ្វីដែលត្រូវទទួលទោសដល់ស្លាប់ឡើយ។ ដ្បិតក្នុងករណីនេះ ប្រៀបដូចជាមនុស្សម្នាក់ប្រព្រឹត្តអំពើឃាតកម្មមួយដែរ។
[27]ព្រោះបុរសនោះចាប់រំលោភនាងនៅឯវាលស្រែ ទោះបើស្ត្រីក្រមុំមានគូរដណ្តឹងនោះ ខំប្រឹងស្រែកយ៉ាងណាក្តី ក៏គ្មាននរណាជួយនាងដែរ។

generated on Wed Sep 10 16:16:32 2025

[28]ប្រសិនបើ បុរសណាម្នាក់ប្រទះឃើញស្ត្រីក្រមុំព្រហ្មចារី ដែលពុំទាន់មានគូរដណ្តឹងនៅឡើយ ហើយចាប់នាងរំលោភ ហើយមានគេតាមទាន់[29]នោះបុរសដែលរំលោភនាង
ត្រូវបង់ប្រាក់ហាសិបណែនឲ្យទៅឪពុករបស់នាង ហើយនាងនឹងក្លាយទៅជាភរិយារបស់អ្នកនោះ ដោយព្រោះបុរសនោះបានរំលោភនាង។
ហើយបុរសនោះមិនអាចលែងនាងបានឡើយ រហូតអស់មួយជីវិត។
[30]មិនត្រូវឲ្យនរណាម្នាក់រួមដំណេកជាមួយប្រពន្ធចុងរបស់ឪពុកខ្លួនឡើយ ដ្បិត ធ្វើដូច្នេះ គេបានប្រមាថឪពុករបស់ខ្លួន។

Deuteronomy 22:1
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
គ្មានង្វែង
«ដើរចេញឆ្ងាយពីម្ចាស់របស់វា»
កុំធ្វើពើដូចជាមិនឃើញនោះឡើយ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ធ្វើដូចជាអ្នកមិនឃើញពួកវា» ឬ «ទៅឆ្ងាយដោយមិនធ្វើអ្វីទាំងអស់»
ប្រសិនបើ ម្ចាស់សត្វនោះនៅឆ្ងាយ
«បើម្ចាស់សត្វជាបងប្អូនរបស់អ្នក រស់នៅឆ្ងាយពីអ្នក»
ហើយអ្នករាល់គ្នាមិនស្គាល់ម្ចាស់
«បើអ្នករាល់គ្នាមិនដឹងថាតើ អ្នកណាជាម្ចាស់សត្វនេះ»
ហើយទុកវានៅជាមួយអ្នករាល់គ្នា រហូតដល់ម្ចាស់វាមកសុំយកទៅវិញ
«ហើយអ្នករាល់គ្នាត្រូវរក្សាសត្វនេះ
ឱ្យនៅជាមួយអ្នករាល់គ្នារហូតដល់ម្ចាស់មករកវា»
Deuteronomy 22:3
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ត្រូវប្រព្រឹត្តបែបដូច្នោះ ចំពោះសត្វលា
«អ្នកត្រូវតែប្រគល់សត្វលារបស់គាត់ នៅក្នុងរបៀបដូចគ្នា»
សម្លៀកបំពាក់ និងអ្វីៗទាំងអស់ដែលបងប្អូនអ្នកបាត់
«អ្នកត្រូវតែប្រគល់សម្លៀកបំពាក់របស់គាត់ នៅក្នុងរបៀបដូចគ្នា»
នោះមិនត្រូវធ្វើពើដូចជាមិនឃើញសោះឡើយ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវធ្វើដូចអ្នកមិនបានឃើញថា គាត់បានបាត់បង់របស់អ្វីមួយ» ឬ
«អ្នកមិនត្រូវទៅណាដោយមិនធ្វើអ្វីឡើយ»
តែត្រូវជួយគាត់លើកសត្វនោះឡើងមកវិញ។
អ្នកត្រូវជួយបងប្អូនរបស់អ្នក លើកសត្វឡើងនិងលើកជើងឡើង»។
Deuteronomy 22:5
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដូចបុរសឡើយ
«សម្លៀកបំពាក់បុរស»
Deuteronomy 22:6
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
សំបុកសត្វ
ផ្ទះដែលបក្សីបង្កើតសម្រាប់ខ្លួនវាចេញពី ដើមឈើស្មៅ រុក្ខជាតិ និង ដីទន់
ហើយឃើញកូនសត្វ ឬពងសត្វ
«ជាមួយបក្សី ឬពងសត្វនៅក្នុងសំបុក»
ដែលមានមេវាកំពុងតែក្រាប
«ហើយមេកំពុងក្រាបលើកូនសត្វ»
មានអាយុយឺនយូរ។
មានអាយុវែងជាពាក្យប្រៀបធៀបសម្រាប់ជីវិតដ៏យឺនយូរ។ ការបកប្រែផ្សេងទៀត
«អាចរស់នៅបានយូរ» ។ បកប្រែពាក្យទាំងនេះដូចនៅក្នុង ៤:២៥ ។
Deuteronomy 22:8
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
បង្កាន់ដៃនៅលើដំបូលផ្ទះ
របងទាបនៅជុំវិញដំបូលផ្ទះ ដូច្នេះ មនុស្សនឹងមិនធ្លាក់ពីលើដំបូល
ហើយបណ្តាលឲ្យអ្នករាល់គ្នាមានទោស ព្រោះតែផ្ទះនោះ។
ឈាមជានិមិត្តរូបនៃសេចក្តីស្លាប់។ ការបកប្រែផ្សេងទៀត «ដូច្នេះ
វានឹងមិនមែនជាកំហុសរបស់គ្រួសារអ្នកទេ បើមាននរណាម្នាក់ស្លាប់»
ក្រែងលោមាននរណាម្នាក់ធ្លាក់ពីលើដំបូលនោះមក
«បើនរណាម្នាក់ធ្លាក់ពីលើដំបូល ព្រោះអ្នកមិនបានធ្វើឱ្យមានរនាំង»
Deuteronomy 22:9
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ក្រែងលោផលទាំងអស់នោះត្រូវខូចខាត
ពាក្យថា «កន្លែងបរិសុទ្ធ» ជាឃ្លាសម្រាប់បូជាចារ្យ ដែលធ្វើការនៅក្នុងទីបរិសុទ្ធ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីកុំឱ្យបូជាចារ្យនៅកន្លែងបរិសុទ្ធរបស់ព្រះអម្ចាស់
មិនដកហូតផលដំណាំទាំងអស់» ឬ «ដូច្នេះ
អ្នកមិនធ្វើឱ្យបង្ខូចការប្រមូលផលទាំងមូល
ហើយបូជាចារ្យមិនអនុញ្ញាតឱ្យអ្នកប្រើវាទេ»
ទាំងផលទំពាំងបាយជូរ។
«និងផ្លែឈើដែលដុះនៅក្នុងចម្ការ»
អំបោះរោមចៀម
រោមទន់ រោមរួញអង្កាញ់ដែលមាននៅលើចៀម
អំបោះសូតទេស
អំបោះធ្វើពីសរសៃរុក្ខជាតិ
Deuteronomy 22:12
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ជាយ
«រំយោល»។ ទាំងនេះគឺជាអំបោះដែលចងភ្ជាប់គ្នា
ហើយព្យួរពីចុងនៃជ្រុងនីមួយៗនៃក្រណាត់។
ក្រណាត់
សម្លៀកបំពាក់វែង ដែលមនុស្សម្នាក់ពាក់លើសម្លៀកបំពាក់ផ្សេងទៀត
Deuteronomy 22:13
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ហើយបន្ទាប់មកចោទនាងពីរឿងគួរឱ្យអាម៉ាស់
«ហើយបន្ទាប់មកចោទប្រកាន់នាងថា
បានរួមរស់ជាមួយនរណាម្នាក់មុនពេលនាងរៀបការ»
ហើយចាប់តាំងនិយាយបរិហារកេរ្តិ៍នាង
នាមអរូបី «ការបរិហារកេរ្តិ៍» អាចត្រូវបានបកប្រែជាឃ្លាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «និងធ្វើឱ្យមនុស្សផ្សេងទៀតគិតថានាងជាមនុស្សអាក្រក់»
ហើយខ្ញុំឃើញថា
នេះជារបៀបគួរសមក្នុងការនិយាយថា
«មានទំនាក់ទំនងផ្លូវភេទជាមួយនរណាម្នាក់»។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែនៅពេលដែលខ្ញុំគេងជាមួយនាង»
នាងមិនមែនជាស្ត្រីព្រហ្មចារីទេ។
នាមអរូបី «ភ័ស្តុតាង» អាចបកប្រែជាឃ្លាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«នាងមិនអាចបង្ហាញខ្ញុំថា នាងជាស្ត្រីព្រហ្មចារីទេ»
Deuteronomy 22:15
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែបន្តកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវនាំយកភស្តុតាងពីភាពព្រហ្មចារីរបស់នាង
នាមអរូបី «ភ័ស្តុតាង» អាចបកប្រែជាឃ្លាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«ត្រូវតែយកអ្វីមួយដែលបង្ហាញថានាង ជាស្រីព្រហ្មចារី»
Deuteronomy 22:16
ព័ត៌មានទូទៅ៖
លោកម៉ូសេនៅតែបន្តកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
គេបាននិយាយបរិហារកេរ្តិ៍នាង
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «គាត់បានចោទប្រកាន់នាងថា បានដេកជាមួយនរណាម្នាក់
មុនពេលគាត់រៀបការជាមួយនាង»
«ខ្ញុំឃើញថាកូនស្រីរបស់លោកមិនមែនជាស្ត្រីព្រហ្មចារីទេ»។
នាមអរូបី «ភស្តុតាង» និង «ព្រហ្មចារី» អាចបកប្រែជាឃ្លាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «កូនស្រីរបស់អ្នកមិនអាចបង្ហាញថា នាងជាស្ត្រីព្រហ្មចារីទេ»
ប៉ុន្តែ សូមអស់លោកមើល៍ចុះ នេះជាភស្តុតាង ដែលបញ្ជាក់ថា កូនស្រីរបស់ខ្ញុំពិតជាព្រហ្មចារីមែន។
នាមអរូបី «ភស្តុតាង» និង «ព្រហ្មចារី» អាចបកប្រែជាឃ្លាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «ប៉ុន្តែ បង្ហាញថា កូនស្រីរបស់ខ្ញុំជាស្ត្រីព្រហ្មចារីម្នាក់»
ពេលនោះ ឪពុកម្តាយត្រូវលាសំពត់នោះនៅមុខពួកចាស់ទុំរបស់ទីក្រុង។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត
«ហើយបន្ទាប់មកម្តាយនិងឪពុកនឹងបង្ហាញសម្លៀកបំពាក់មានឈាមដល់ពួកព្រឹទ្ធាចារ្យ
ដើម្បីជាភ័ស្តុតាងបញ្ជាក់ថា នាងជាស្ត្រីក្រមុំព្រហ្មចារីមួយ»
Deuteronomy 22:18
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ហើយត្រូវពិន័យអ្នកនោះឲ្យបង់ប្រាក់
«ហើយពួកគេត្រូវតែធ្វើឱ្យគាត់បង់ប្រាក់ជាការដាក់ទោស»
មួយរយណែន
«១០០ណែន»
ឲ្យទៅឪពុករបស់នាង
«ហើយឱ្យប្រាក់ទៅឪពុកនាង»
ដោយព្រោះបុរសនោះបានបង្ខូចកេរ្តិ៍ឈ្មោះស្ត្រីព្រហ្មចារីម្នាក់នៃជនជាតិអ៊ីស្រាអែល។ រ
នាមអរូបី «កេរ្តិ៍ឈ្មោះ» អាចបកប្រែជាឃ្លាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«បានធ្វើឱ្យមនុស្សគិតថា ស្ត្រីព្រហ្មចារីនៃជនជាតិអ៊ីស្រាអែលម្នាក់
ជាមនុស្សអាក្រក់»
មិនអាចលែងនាងបានឡើយ
«មិនដែលអនុញ្ញាតឱ្យគាត់លែងលះនាង»
រហូតអស់មួយជីវិត។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ពេញមួយជីវិតរបស់គាត់»
Deuteronomy 22:20
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប៉ុន្តែ ប្រសិនបើរឿងនោះជាការពិតមែន
«ប៉ុន្តែ បើវាជាការពិត» ឬ «ប៉ុន្តែ បើអ្វីដែលមនុស្សនោះនិយាយ គឺជាការពិត»
ហើយរកភស្តុតាងបានថា នាងមិននៅព្រហ្មចារីទេ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បុរសនោះមិនបានរកភ័ស្តុតាងបញ្ជាក់ថា ស្ត្រីនោះជាស្ត្រីព្រហ្មចារីទេ»
ហើយរកភស្តុតាង
នាមអរូបី «ភ័ស្តុតាង» និង «ព្រហ្មចារី» អាចបកប្រែជាឃ្លាកិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «អ្វីមួយដែលបង្ហាញថា ក្មេងស្ត្រីនេះគឺជាស្ត្រីព្រហ្មចារី»
នោះត្រូវនាំស្ត្រីនោះ
«បន្ទាប់មកពួកព្រឹទ្ធាចារ្យត្រូវនាំក្មេងស្រីនោះចេញ»
យកដុំថ្មគប់សម្លាប់នាង
«គប់ដុំថ្មដាក់នាងរហូតដល់ស្លាប់»
ដោយព្រោះនាងបានប្រព្រឹត្តអំពើថោកទាបនៅក្នុងទឹកដីអ៊ីស្រាអែល
«ពីព្រោះនាងបានធ្វើរឿងគួរឱ្យអាម៉ាស់នៅស្រុកអ៊ីស្រាអែល»
ដោយបានបង្ខូចខ្លួននៅក្នុងផ្ទះរបស់ឪពុក
«ធ្វើដូចស្រីពេស្យាពេលរស់នៅក្នុងផ្ទះឪពុកនាង»
អ្នកនឹងលុបបំបាត់អំពើអាក្រក់ចេញ
គុណនាម «អាក្រក់» អាចបកប្រែជាឃ្លានាម។ ការបកប្រែផ្សេងទៀត «
អ្នកត្រូវដកខ្លួនចេញពីចំណោមជនជាតិអ៊ីស្រាអែល ដែលអ្នកធ្វើអំពើអាក្រក់នេះ»
ឬ «អ្នកត្រូវតែប្រហារជីវិតមនុស្សអាក្រក់នេះ»
Deuteronomy 22:22
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប្រសិនបើឃើញបុរសណាម្នាក់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បើនរណាម្នាក់រកឃើញបុរសម្នាក់»
អ្នកនឹងលុបបំបាត់
«តាមរបៀបនេះអ្នកនឹងដកចេញ» (សូមមើល យូឌីបី)
Deuteronomy 22:23
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មានគូរដណ្តឹង
«ដែលត្រូវបានសន្យាថា នឹងរៀបការជាមួយបុរសម្នាក់»
នាំ ... ហើយយកដុំថ្មគប់
ទោសបញ្ជាទាំងនេះត្រូវបាននិយាយទៅប្រជាជនអ៊ីស្រាអែលជាក្រុមៗ ដូច្នេះ
វាជាពហុវចនៈ។
នោះត្រូវនាំអ្នកទាំងពីរនោះ
"បន្ទាប់មកអ្នកត្រូវនាំយកទាំងក្មេងស្រី និងបុរសដែលបានដេកជាមួយនាង"
ដោយព្រោះមិនបានស្រែកហៅ
«ដោយសារតែនាងមិនបានអំពាវនាវរកជំនួយ»
ដោយព្រោះបានរំលោភប្រពន្ធអ្នកជិតខាងរបស់ខ្លួន
ជនជាតិអ៊ីស្រាអែលនៅពេលនោះបានគិតអំពីបុរស
និងស្ត្រីដែលបានរៀបការជាមួយគ្នាជាប្តីប្រពន្ធ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ពីព្រោះគាត់បានដេកជាមួយស្ត្រីម្នាក់
ដែលជាកម្មសិទ្ធិរបស់ជនជាតិអ៊ីស្រាអែលម្នាក់ទៀត»
អ្នកនឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
គុណនាម «អាក្រក់» អាចបកប្រែជាឃ្លានាម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែដកមនុស្សអាក្រក់ចេញពីចំណោមជនជាតិអ៊ីស្រាអែល
ដែលបានធ្វើអំពើអាក្រក់នេះ» ឬ «អ្នកត្រូវតែប្រហារជីវិតមនុស្សអាក្រក់នេះ»
Deuteronomy 22:25
មានគូរដណ្តឹង
មានន័យថា
ស្ត្រីដែលឪពុកម្តាយបានយល់ព្រមឱ្យនាងរៀបការជាមួយបុរសម្នាក់ពិតប្រាកដ
ប៉ុន្តែ នាងមិនទាន់រៀបការជាមួយគាត់នៅឡើយទេ។
នឹងត្រូវទទួលទោសដល់ស្លាប់។
«បន្ទាប់មកអ្នកត្រូវតែសម្លាប់តែបុរស ដែលដេកជាមួយនាងប៉ុណ្ណោះ»
ដ្បិតនាងគ្មានកំហុសអ្វីដែលត្រូវទទួលទោសដល់ស្លាប់ឡើយ។
«អ្នកមិនត្រូវដាក់ទោសនាងដោយសម្លាប់នាង ចំពោះទង្វើនាងបានប្រព្រឹត្ត»
ដ្បិតក្នុងករណីនេះ ប្រៀបដូចជាមនុស្សម្នាក់ប្រព្រឹត្តអំពើឃាតកម្មមួយដែរ។
«ពីព្រោះស្ថានភាពនេះគឺដូចជាស្ថានភាព
នៅពេលមាននរណាម្នាក់វាយប្រហារមនុស្សម្នាក់ទៀត ហើយសម្លាប់គាត់»
ព្រោះបុរសនោះចាប់រំលោភនាងនៅឯវាលស្រែ
«ដោយសារតែបុរសបានជួបនាងកំពុងធ្វើការ នៅវាលស្រែ»
Deuteronomy 22:28
ដែលពុំទាន់មានគូរដណ្តឹងនៅឡើយ
«ប៉ុន្តែ ឪពុកម្តាយរបស់ពួកគេមិនបានសន្យាជាមួយបុរសផ្សេងទៀតថា
នាងនឹងរៀបការជាមួយគាត់ទេ»
ហើយមានគេតាមទាន់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយបើនរណាម្នាក់ឃើញអ្វី ដែលបានកើតឡើង»
បង់ប្រាក់ហាសិបណែន
មួយណែនមានទម្ងន់ដប់មួយក្រាម។ ការបកប្រែផ្សេងទៀត
«ប្រាក់ចំនួនហាសិបណែន» ឬ «ប្រាក់៥៥០ ណែន»
ហើយបុរសនោះមិនអាចលែងនាងបានឡើយ រហូតអស់មួយជីវិត។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«គាត់មិនអាចលែងលះនាង ពេញមួយជីវិតរបស់គាត់បានឡើយ»
Deuteronomy 22:30
មិនត្រូវឲ្យនរណាម្នាក់រួមដំណេកជាមួយប្រពន្ធចុងរបស់ឪពុកខ្លួនឡើយ

អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «មិនត្រូវរៀបការជាមួយអតីតភរិយារបស់ឪពុកឡើយ
ទោះបីនាងមិនមែនជាម្តាយរបស់គាត់ក៏ដោយ»

---

23 [1]អ្នកដែលបែកពងលិង្គ ឬត្រូវគេកាត់លិង្គ នោះមិនអាចចូលរួមអង្គប្រជុំរបស់ព្រះអម្ចាស់បានឡើយ។
[2]កូនដែលកើតឥតខាន់ស្លាមិនអាចចូលរួមក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់បានទេ ទោះបីកូនចៅរបស់គេរហូតដប់តំណ
ក៏មិនអាចចូលរួមក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់បានដែរ។
[3]ជនជាតិអាំម៉ូន និងជនជាតិម៉ូអាប់ មិនអាចចូលរួមក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់បានទេ ទោះបីកូនចៅរបស់ពួកគេរហូតដល់ដប់តំណ
ក៏មិនអាចចូលរួមក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់ដែរ។[4]ព្រោះកាលដែលអ្នកចេញពីទឹកដីអេស៊ីបមក ពួកគេមិនបានយកអាហារ និងទឹកមកទទួលអ្នកតាមផ្លូវទេ
ហើយពួកគេបានជួលលោកបាឡោម ជាកូនរបស់លោកបេអ៊រ មកពីពេថោរ អ្នកស្រុកមេសូប៉ូតាមា ដើម្បីដាក់បណ្តាសាអ្នករាល់គ្នា។
[5]ប៉ុន្តែ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាមិនព្រមស្តាប់តាមពាក្យលោកបាឡោមទេ ផ្ទុយទៅវិញ
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបង្វែបណ្តាសារបស់អ្នករាល់គ្នាឲ្យទៅជាព្រះពរដល់អ្នករាល់គ្នាវិញ
ដ្បិតព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានស្រឡាញ់អ្នករាល់គ្នា។[6]ដូច្នេះ អ្នកមិនត្រូវរកសេចក្តីសុខឲ្យគេ ឬភាចម្រុងចម្រើនឲ្យគេឡើយ រហូតអស់មួយរបស់ជីវិត។
[7]មិនត្រូវស្អប់ខ្ពើមជនជាតិអេដុមឡើយ ដ្បិត ពួកគេជាបងប្អូនរបស់អ្នករាល់គ្នា ហើយមិនត្រូវស្អប់ខ្ពើមជនជាតិអេស៊ីបដែរ ដ្បិត ពីដើមឡើយ
អ្នករាល់គ្នាធ្លាប់រស់នៅក្នុងទឹកដីរបស់គេ។[8]កូនចៅរបស់ពួកគេនៅជំនាន់ទីបី ដែលកើតពីពូជពួកគេ អាចចូលរួមក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់បាន។
[9]ពេលណា អ្នករាល់គ្នាទៅបោះទ័ព ធ្វើសឹកនឹងខ្មាំងសត្រូវ ចូររក្សាខ្លួនចេញពីសេចក្តីអាក្រក់។[10]ប្រសិនបើ នរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាមិនបរិសុទ្ធ
ព្រោះតែកើតហេតុអ្វីមួយនៅពេលយប់ ត្រូវឲ្យអ្នកនោះចេញទៅក្រៅ មិនត្រូវចូលមកក្នុងជំរំទេ។[11]លុះដល់ពេលល្ងាច គេត្រូវធ្វើពិធីជម្រះកាយ លុះដល់ថ្ងៃលិច
គេអាចចូលទៅក្នុងជំរំវិញបាន។
[12]ត្រូវរៀបចំឲ្យមានកន្លែងមួយនៅក្រៅជំរំ ដែលអ្នករាល់គ្នាអាចចេញទៅបត់ជើងបាន[13]ត្រូវមានចបជីកមួយជាប់នឹងខ្លួន ហើយពេលណា អ្នកចេញទៅបត់ជើងនៅខាងក្រៅ
នោះត្រូវជីករណ្តៅកប់លាមករបស់អ្នករាល់គ្នា។[14]ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាយាងចំកណ្តាលជំរំរបស់អ្នករាល់គ្នា ដើម្បីការពារអ្នករាល់គ្នា
ហើយប្រគល់ខ្មាំងសត្រូវមកក្នុងកណ្តាប់ដៃរបស់អ្នករាល់គ្នា។ ហេតុនេះហើយ ជំរំរបស់អ្នករាល់គ្នាត្រូវតែបរិសុទ្ធ
ដើម្បីកុំឲ្យព្រះអង្គទតឃើញអ្វីដែលស្មោកគ្រោកក្នុងចំណោមអ្នករាល់គ្នា ហើយចាកចេញពីអ្នករាល់គ្នាឡើយ។
[15]ប្រសិនបើ មានបាវបម្រើណាដែលបានរត់ចេញពីចៅហ្វាយរបស់ខ្លួន មកជ្រកកោនជាមួយអ្នករាល់គ្នា នោះមិនត្រូវប្រគល់ទៅឲ្យចៅហ្វាយគេវិញឡើយ។
[16]ចូរឲ្យគាត់នៅស្នាក់នៅជាមួយអ្នករាល់គ្នា ក្នុងក្រុមគ្រួសាររបស់អ្នករាល់គ្នា ក្នុងក្រុងណាមួយដែលគេជ្រើសរើស ពេញចិត្តស្នាក់នៅ។ កុំជិះជាន់គេឡើយ។
[17]មិនត្រូវឲ្យមានស្រីពេស្យាណាមួយ ក្នុងចំណោមកូនស្រីនៃកូនចៅអ៊ីស្រាអែលឡើយ ឬប្រុសពេស្យាណាមួយ ក្នុងចំណោមកូនប្រុសនៃកូនចៅអ៊ីស្រាអែលដែរ។
[18]មិនត្រូវយកថ្លៃឈ្នួលពីការធ្វើស្រីពេស្យា ឬប្រាក់ឈ្នួលពីការធ្វើប្រុសពេស្យា ចូលមកក្នុងដំណាក់របស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាឡើយ
ដើម្បីលាបំណន់អ្វីមួយក៏ដោយ ដ្បិត ទាំងពីរមុខនេះ គឺជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[19]បើបងប្អូនរបស់អ្នករាល់គ្នាខ្ចីប្រាក់ ឬស្បៀងអាហារ ឬរបស់អ្វីៗផ្សេងទៀត មិនត្រូវយកការប្រាក់ពីគេឡើយ។[20]អ្នករាល់គ្នាអាចយកការប្រាក់ពីជនបរទេសបាន
តែមិនត្រូវយកការប្រាក់ពីបងប្អូនរបស់អ្នករាល់គ្នាឡើយ ធ្វើដូច្នេះ
ដើម្បីឲ្យព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងប្រទានពរដល់អ្នករាល់គ្នាក្នុងគ្រប់ទាំងកិច្ចការដែលអ្នករាល់គ្នាធ្វើនៅក្នុងទឹកដីដែលអ្នករាល់គ្នាចូលទៅកាន់កាប់។
[21]កាលណាអ្នករាល់គ្នាបន់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា អំពីរឿងអ្វីមួយ នោះមិនត្រូវបង្អង់នឹងលាបំណន់ឡើយ ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
នឹងទាបំណន់ពីអ្នករាល់គ្នា ហើយនឹងរាប់ជាបាបដល់អ្នករាល់គ្នាទៀតផង។[22]ប៉ុន្តែ ប្រសិនបើ អ្នករាល់គ្នាមិនបានបន់ទេ នោះអ្នករាល់គ្នានឹងមិនមានបាបឡើយ។
[23]សេចក្តីណាដែលចេញពីបបូរមាត់របស់អ្នករាល់គ្នា នោះត្រូវប្រយ័ត្ននឹងធ្វើតាមបំណន់ដែលអ្នករាល់គ្នាបានបន់ព្រះអម្ចាស់ព្រះរបស់អ្នករាល់គ្នា ជាតង្វាយស្ម័គ្រពីចិត្ត
ដែលមាត់របស់អ្នករាល់គ្នាបានសន្យា។
[24]ប្រសិនបើ អ្នករាល់គ្នាដើរកាត់ក្នុងចម្ការទំពាំងបាយជូររបស់អ្នកជិតខាងរបស់អ្នករាល់គ្នា អ្នករាល់គ្នាអាចបេះផ្លែទំពាំងបាយជូរបរិភោគតាមចិត្ត រហូតដល់ឆ្អែត ប៉ុន្តែ
មិនត្រូវបេះដាក់ថង់យកទៅជាមួយឡើយ។[25]ពេលណា អ្នករាល់គ្នាដើរកាត់ស្រែរបស់អ្នកជិតខាង អ្នករាល់គ្នាអាចយកដៃបូតគួរស្រូវបាន ប៉ុន្តែ
មិនត្រូវយកកណ្តៀវទៅច្រូតស្រូវរបស់អ្នកជិតខាងឡើយ។

Deuteronomy 23:1
អ្នកដែលបែកពងលិង្គ ឬត្រូវគេកាត់លិង្គ
បុរសដែលមានផ្នែករាងកាយឯកជនរបស់គាត់ ត្រូវបានមនុស្សណាម្នាក់កាត់ចេញ ឬបែក
អាចចូលរួមអង្គប្រជុំរបស់ព្រះអម្ចាស់បានឡើយ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«អាចជាសមាជិកពេញលេញនៃសហគមន៍អ៊ីស្រាអែល»
កូនដែលកើតឥតខាន់ស្លា
អាចមានន័យថា ១) កុមារកើតពីឪពុកម្តាយ ដែលប្រព្រឹត្តអំពើពេស្យាចារ ឬផិតក្បត់ ឬ ២) កូនកើតមកជាស្រីពេស្យា។
ទោះបីកូនចៅរបស់គេរហូតដប់តំណ
ពាក្យ «ដប់ » ជាលេខធម្មតាសម្រាប់ដប់។ ការបកប្រែផ្សេងទៀត «សូម្បីតែកូនចៅដប់ជំនាន់នៃកូនចៅ ដែលកើតឥតខាន់ស្លា»
ក៏មិនអាចចូលរួមក្នុងអង្គប្រជុំ
«គ្មានកូនចៅទាំងនេះទេ»
Deuteronomy 23:3
មិនអាចចូលរួមក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់បានទេ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ប្រហែលជាមិនមែនជាសមាជិកពេញលេញនៃសហគមន៍អ៊ីស្រាអែល»
ទោះបីកូនចៅរបស់ពួកគេរហូតដល់ដប់តំណ

ពាក្យ «ដប់» ជាលេខធម្មតាសម្រាប់ដប់។ ការបកប្រែផ្សេងទៀត «សូម្បីតែបន្ទាប់ពីដប់ជំនាន់នៃកូនចៅរបស់គាត់»
ពួកគេមិនបានយកអាហារ និងទឹកមកទទួលអ្នកតាមផ្លូវទេ
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ពួកគេមិនបានស្វាគមន៍អ្នកដោយនាំយកអាហារ
និងទឹកមកទទួលអ្នកទេ»
បានជួលលោក ... ដាក់បណ្តាសាអ្នករាល់គ្នា។
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
Deuteronomy 23:5
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មិនព្រមស្តាប់តាម
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«មិនបានយកចិត្តទុកដាក់»
បានបង្វែបណ្តាសារបស់អ្នករាល់គ្នាឲ្យទៅជាព្រះពរដល់អ្នករាល់គ្នាវិញ
«គាត់បានប្រទានពរឲ្យអ្នករាល់គ្នា ហើយមិនដាក់បណ្តាសារអ្នករាល់គ្នា»
អ្នកមិនត្រូវរកសេចក្តីសុខឲ្យគេ ឬភាចម្រុងចម្រើនឲ្យគេឡើយ
អាចមានន័យថា ១)« អ្នកមិនគួរបង្កើតសន្ធិសញ្ញាសន្តិភាពជាមួយជនជាតិអាំម៉ូន

generated on Wed Sep 10 16:16:32 2025

និងម៉ូអាប់» ឬ ២) « អ្នកមិនត្រូវធ្វើអ្វី
ដែលបណ្តាលឱ្យមានរឿងល្អសម្រាប់ក្រុមមនុស្សទាំង២នោះទេ
ដែលអាចឱ្យពួកគេរីកចម្រើន»
រហូតអស់មួយរបស់ជីវិត។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ដរាបណាអ្នកជាប្រជាជាតិមួយ»
Deuteronomy 23:7
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មិនត្រូវស្អប់ខ្ពើមជនជាតិអេដុមឡើយ
«មិនត្រូវជជនជាតិអេដុម»
ដ្បិត ពួកគេជាបងប្អូនរបស់អ្នករាល់គ្នា
«ពីព្រោះគាត់ជាសាច់ញាតិរបស់អ្នករាល់គ្នា »
ហើយមិនត្រូវស្អប់ខ្ពើមជនជាតិអេស៊ីបដែរ
«មិនត្រូវជនជាតិអេស៊ីបដែរ»
កូនចៅរបស់ពួកគេនៅជំនាន់ទីបី ដែលកើតពីពូជពួកគេ
អាចចូលរួមក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់បាន។
ពាក្យ «ទីបី» ជាលេខធម្មតាសម្រាប់បី។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត
«បើជនជាតិអេដុមឬជនជាតិអេស៊ីបមករស់នៅក្នុងសហគមន៍អ៊ីស្រាអែល
នោះចៅៗរបស់គាត់អាចនឹងក្លាយជាសមាជិកពេញលេញនៃសហគមន៍នោះ»
Deuteronomy 23:9
ពេលណា អ្នករាល់គ្នាទៅបោះទ័ព ធ្វើសឹកនឹងខ្មាំងសត្រូវ ចូររក្សាខ្លួនចេញពីសេចក្តីអាក្រក់។
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ធ្វើសឹកនឹងខ្មាំងសត្រូវ
«ដើម្បីប្រយុទ្ធប្រឆាំងនឹងសត្រូវរបស់អ្នក»
ចូររក្សាខ្លួនចេញពីសេចក្តីអាក្រក់។
«ចូររក្សាខ្លួនឆ្ងាយពីរបស់អាក្រក់ទាំងអស់»
នរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាមិនបរិសុទ្ធ ព្រោះតែកើតហេតុអ្វីមួយនៅពេលយប់
នេះជារបៀបគួរសមក្នុងការនិយាយថា គាត់បញ្ចេញទឹកកាម។
ការបកប្រែផ្សេងទៀត «អ្នកណាដែលមិនស្អាតដោយសារគាត់បញ្ចេញទឹកកាម
នៅពេលគាត់ដេកលក់»
Deuteronomy 23:12
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ត្រូវមានចបជីកមួយជាប់នឹងខ្លួន
«ហើយអ្នកគួរតែមានឧបករណ៍ ដែលអ្នកអាចប្រើដើម្បីជីកជាមួយបាន»
ហើយពេលណា អ្នកចេញទៅបត់ជើងនៅខាងក្រៅ
នេះជារបៀបសមក្នុងការនិយាយបត់ជើង។ ការបកប្រែផ្សេងទៀត
«នៅពេលអ្នកអង្គុយចុះដើម្បីបត់ជើងធំ»
នោះត្រូវជីករណ្តៅកប់លាមករបស់អ្នករាល់គ្នា។
«អ្នករាល់គ្នាត្រូវតែជីករណ្តៅជាមួយឧបករណ៍»
អ្វីដែលចេញពីអ្នក
«គ្រប់បាំងលាមករបស់អ្នករាល់គ្នា»
ដើម្បីកុំឲ្យព្រះអង្គទតឃើញអ្វីដែលស្មោកគ្រោកក្នុងចំណោមអ្នករាល់គ្នា
«ដូច្នេះ ព្រះអម្ចាស់នឹងមិនទតឃើញរបស់អ្វីមិនបរិសុទ្ធនៅក្នុងចំណោមអ្នករាល់គ្នា
»។
Deuteronomy 23:15
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មានបាវបម្រើណាដែលបានរត់ចេញពីចៅហ្វាយរបស់ខ្លួន
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត
«បាវបម្រើមកពីប្រទេសផ្សេងដែលបានរត់គេចពីម្ចាស់របស់គាត់
ហើយបានមកដល់ស្រុកអ៊ីស្រាអែល»
ចូរឲ្យគាត់នៅស្នាក់នៅជាមួយអ្នករាល់គ្នា
«សូមឱ្យទាសកររស់នៅក្នុងចំណោមប្រជាជនរបស់អ្នករាល់គ្នា »
Deuteronomy 23:17
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មានស្រីពេស្យាណាមួយ ... ប្រុសពេស្យាណាមួយ ... ស្រីពេស្យា ... ប្រុសពេស្យា
ព្រះអម្ចាស់ផ្តល់នូវបញ្ជីពេញលេញនៃទម្រង់ទាំងពីររបស់ពេស្យាចារទាំងបុរស
និងស្ត្រីដើម្បីហាមឃាត់មិនឱ្យមានពេស្យាដោយមនុស្សណាម្នាក់
ដោយហេតុផលណាមួយ។
មានស្រីពេស្យាណាមួយ ... ក្នុងចំណោមកូនស្រីនៃកូន ... ក្នុងចំណោមកូនប្រុសនៃកូន
អាចមានន័យថា លោកម៉ូសេ ១)
ហាមស្ត្រីនិងបុរសឲ្យធ្វើសកម្មភាពផ្លូវភេទជាផ្នែកមួយនៃការបម្រើព្រះវិហារ ឬ២)
ប្រើពាក្យសមរម្យដើម្បីហាមឃាត់ស្ត្រីនិងបុរសធ្វើសកម្មភាពផ្លូវភេទដើម្បីទទួលប្រាក់។
មិនត្រូវយកថ្លៃឈ្នួលពីការធ្វើស្រីពេស្យា ... ចូលមកក្នុងដំណាក់
«ស្ត្រីដែលរកលុយធ្វើជាស្រីពេស្យាមិនត្រូវយកលុយនោះមក ...
ចូលមកក្នុងដំណាក់»
ប្រុសពេស្យាណាមួយ
បុរសដែលអនុញ្ញាតឱ្យបុរសរួមភេទជាមួយគាត់ដើម្បីប្រាក់
ចូលមកក្នុងដំណាក់របស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាឡើយ
«ចូលព្រះវិហារ»
ដើម្បីលាបំណន់អ្វីមួយក៏ដោយ
«ដើម្បីបំពេញពាក្យសម្បថ»
ទាំងពីរមុខនេះ
ប្រាក់ឈ្នួលរបស់ស្រីពេស្យានិងប្រុសពេស្យា។
Deuteronomy 23:19
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
បើបងប្អូនរបស់អ្នករាល់គ្នាខ្ចីប្រាក់
បើអ្នករាល់គ្នាអោយអ្វីមួយដល់បងប្អូនអ៊ីស្រាអែល
អ្នករាល់គ្នាមិនត្រូវឱ្យគាត់សងអ្នករាល់គ្នាច្រើនជាងអ្វី ដែលគាត់បានខ្ចីនោះឡើយ។
ខ្ចីប្រាក់
ឱ្យខ្ចីទៅនរណាម្នាក់ ហើយបង្ខំឱ្យមនុស្សនោះសងច្រើនជាងអ្វីដែលបានខ្ចី
ខ្ចីប្រាក់ ... មិនត្រូវយកការប្រាក់ពីគេឡើយ។
«អ្នកមិនត្រូវគិតការប្រាក់ទេ នៅពេលអ្នកឱ្យគេខ្ចីប្រាក់ អាហារ ឬ
របស់អ្វីផ្សេងទៀត»
ក្នុងគ្រប់ទាំងកិច្ចការដែលអ្នករាល់គ្នាធ្វើ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«អ្វីៗទាំងអស់ដែលអ្នករាល់គ្នាធ្វើ»
Deuteronomy 23:21
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
នោះមិនត្រូវបង្អង់នឹងលាបំណន់ឡើយ
«អ្នកមិនត្រូវចំណាយពេលយូរដើម្បីបំពេញពាក្យសម្បថ»
ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា នឹងទាបំណន់ពីអ្នករាល់គ្នា
«ពីព្រោះ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
នឹងស្តីបន្ទោសនិងដាក់ទោសអ្នករាល់គ្នា
បើអ្នករាល់គ្នាមិនបំពេញតាមពាក្យសម្បថរបស់អ្នករាល់គ្នា »
ប៉ុន្តែ ប្រសិនបើ អ្នករាល់គ្នាមិនបានបន់ទេ នោះអ្នករាល់គ្នានឹងមិនមានបាបឡើយ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «តែបើអ្នករាល់គ្នាមិនស្បថទេ អ្នករាល់គ្នានឹងមិនធ្វើបាបទេ
ព្រោះអ្នករាល់គ្នានឹងមិនមានពាក្យសម្បថដើម្បីបំពេញ»
ប៉ុន្តែ ប្រសិនបើ អ្នករាល់គ្នាមិនបានបន់ទេ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ពាក្យដែលអ្នករាល់គ្នាបាននិយាយ»
ធ្វើតាមបំណន់ដែលអ្នករាល់គ្នាបានបន់ព្រះអម្ចាស់ព្រះរបស់អ្នករាល់គ្នា

generated on Wed Sep 10 16:16:32 2025

«អ្វីក៏ដោយដែលអ្នករាល់គ្នាបានស្បថនឹងព្រះអម្ចាស់
ជាព្រះរបស់អ្នកថាអ្នករាល់គ្នានឹងធ្វើ»
ជាតង្វាយស្ម័គ្រពីចិត្ត ដែលមាត់របស់អ្នករាល់គ្នាបានសន្យា។
«អ្វីៗដែលប្រជាជនបានឮអ្នករាល់គ្នាសន្យានឹងធ្វើ ព្រោះអ្នកចង់ធ្វើវា»
ដែលមាត់របស់អ្នករាល់គ្នាបានសន្យា។
«ដូច្នេះប្រជាជនបានឮអ្នករាល់គ្នានិយាយ»
Deuteronomy 23:24
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
អ្នករាល់គ្នាអាចបេះផ្លែទំពាំងបាយជូរបរិភោគតាមចិត្ត
«បន្ទាប់មក អ្នកអាចរីករាយនឹងការបរិភោគទំពាំងបាយជូររហូតដល់អ្នកឆ្អែត»
ប៉ុន្តែ មិនត្រូវបេះដាក់ចង់យកទៅជាមួយឡើយ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ប៉ុន្តែ អ្នកមិនអាចដាក់ផ្លែទំពាំងបាយជូរណាមួយ
នៅដាក់ក្នុងថង់របស់អ្នកដើម្បីយកវាទៅជាមួយអ្នកបានទេ»
ពេលណា អ្នករាល់គ្នាដើរកាត់ស្រែរបស់អ្នកជិតខាង អ្នករាល់គ្នាអាចយកដៃបូតគួរស្រូវបាន
«នៅពេលអ្នករាល់គ្នាដើរកាត់វាល
អ្នករាល់គ្នាជិតខាងដែលជាកន្លែងដែលមានស្រូវទុំកំពុងលូតលាស់»
អ្នករាល់គ្នាអាចយកដៃបូតគួរស្រូវបាន
«បន្ទាប់មកអ្នកអាចបរិភោគ្រាប់ស្រូវដោយដៃរបស់អ្នក »
ប៉ុន្តែ មិនត្រូវយកកណ្តៀវទៅច្រូតស្រូវរបស់អ្នកជិតខាងឡើយ។
«ប៉ុន្តែ មិនត្រូវកាត់គ្រាប់ស្រូវទុំរបស់អ្នកជិតខាង ហើយយកវាទៅជាមួយអ្នក»
កណ្តៀវ
ឧបករណ៍មុតស្រួចដែលកសិករប្រើ ដើម្បីច្រូតស្រូវសាលី

---

24 [1]ពេលណាបុរសម្នាក់រៀបការជាមួយស្ត្រីម្នាក់ ហើយក្រោយមក បែរជាឈប់ស្រឡាញ់នាង ព្រោះគេមិនពេញចិត្តនឹងនាងត្រង់កន្លែងណាមួយ
នោះត្រូវសរសេរខិលិតលែងលះ ហើយត្រូវប្រគល់លិខិតនោះឲ្យទៅនាង រួចឲ្យនាងចេញពីផ្ទះទៅចុះ។
[2]ក្រោយពីនាងបានចាកចេញពីផ្ទះរបស់អ្នករាល់គ្នានោះផុតហើយ នោះនាងអាចរៀបការជាមួយបុរសម្នាក់ទៀត។
[3]ប្រសិនបើ ប្តីក្រោយឈប់ស្រឡាញ់នាង នោះត្រូវសរសេរលិខិតលែងលះប្រគល់ឲ្យនាង រួចឲ្យនាងចេញពីផ្ទះទៅចុះ ប្រសិនបើ
ប្តីទីពីរដែលបានយកនាងធ្វើជាប្រពន្ធនោះស្លាប់ទៅ[4]នោះប្តីដើមដែលបានលែងនាង មិនអាចយកនាងធ្វើជាប្រពន្ធវិញឡើយ ហើយត្រូវចាត់ទុកនាងថាជាស្រីសៅហ្មង ដ្បិត
នោះជាទីស្អប់ខ្ពើមចំពោះព្រះអម្ចាស់។ មិនត្រូវធ្វើឲ្យមានអំពើបាបបែបនេះ កើតមាននៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ប្រទានឲ្យអ្នករាល់គ្នាទុកជាមរតកឡើយ។
[5]ប្រសិនបើ បុរសណាម្នាក់ទើបនឹងរៀបការថ្មីៗ នោះមិនត្រូវឲ្យបុរសនោះទៅច្បាំងឡើយ ហើយមិនត្រូវដាក់បន្ទុកអ្វីឲ្យគេធ្វើការដែរ ត្រូវឲ្យគេទំនេរនៅផ្ទះរយៈពេលមួយឆ្នាំ
ដើម្បីឲ្យគេបានរីករាយជាមួយភរិយាដែលគេបានរៀបការ។
[6]មិនត្រូវឲ្យនរណាទទួលយកត្បាល់កិនជារបស់បញ្ចាំឡើយ សូម្បីតែថ្មផ្នែកខាងលើរបស់ត្បាល់កិន ក៏មិនត្រូវទទួលយកដែរ ដ្បិត ធ្វើដូច្នេះ ដូចជាបង្កត់អាហារម្ចាស់ត្បាល់។
[7]ប្រសិនបើ ឃើញជនជាតិអ៊ីស្រាអែលណាម្នាក់ចាប់យកបងប្អូនរបស់ខ្លួន យកទៅធ្វើជាទាសករ ឬយកទៅលក់ អ្នកនោះនឹងត្រូវស្លាប់ ធ្វើដូច្នេះ
អ្នករាល់គ្នានឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
[8]ចូរប្រយ័ត្ន ក្នុងករណីមានរោគឃ្លង់ ចូរប្រយ័ត្ននឹងធ្វើតាមសេចក្តីទាំងប៉ុន្មានរបស់ពួកបូជាចារ្យ លេវីបង្រៀនអ្នករាល់គ្នា ត្រូវធ្វើតាមពាក្យ
ដូចដែលខ្ញុំបានបង្គាប់ដល់ពួកបូជាចារ្យទាំងនោះ។[9]ចូរនឹកចាំពីសេចក្តីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា បានធ្វើចំពោះនាងម៉ារាម
នៅតាមផ្លូវពេលដែលអ្នករាល់គ្នាចាកចេញពីទឹកដីអេស៊ីប។
[10]ប្រសិនបើ អ្នករាល់គ្នាឲ្យអ្វីមួយទៅអ្នកជិតខាងខ្ចី នោះមិនត្រូវចូលទៅក្នុងផ្ទះរបស់គេ ដើម្បីយកវត្ថុបញ្ចាំឡើយ។[11]អ្នករាល់គ្នាត្រូវឈរចាំនៅខាងក្រៅផ្ទះ
ហើយទុកឲ្យអ្នកដែលខ្ចីនោះ យកវត្ថុបញ្ចាំមកឲ្យអ្នកនៅខាងក្រៅវិញ។
[12]ប្រសិនបើ អ្នកនោះជាអ្នកក្រីក្រ អ្នករាល់គ្នាមិនត្រូវចូលដំណេក ដោយទុកវត្ថុបញ្ចាំជាប់នឹងខ្លួនឡើយ។[13]ពេលថ្ងៃលិច
ត្រូវប្រគល់អាវធំដែលគេយកមកបញ្ចាំនោះប្រគល់ឲ្យគេវិញ ដើម្បីឲ្យគេមានអាវដណ្តប់ខ្លួន ហើយគេនឹងឲ្យពរអ្នករាល់គ្នា។ ដ្បិត ប្រព្រឹត្តដូច្នេះ
នឹងបានរាប់ជាសេចក្តីសុចរិតដល់អ្នករាល់គ្នា ដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[14]អ្នករាល់គ្នាមិនត្រូវជិះជាន់កូនឈ្នួលដែលក្រីក្រ ហើយកម្សត់ទុគ៌តឡើយ ទោះបីអ្នកនោះជាបងប្អូនរបស់អ្នករាល់គ្នា
ឬជនបរទេសដែលរស់នៅក្នុងទឹកដីរបស់អ្នករាល់គ្នាក៏ដោយ[15]ត្រូវបើកប្រាក់ឈ្នួលឲ្យគេមុនពេលថ្ងៃលិច ដ្បិត គេទាល់ក្រ ហើយត្រូវការប្រាក់ឈ្នួលរបស់ខ្លួនជាចាំបាច់។
ក្រែងលោគេទូលអង្វរព្រះអម្ចាស់ប្រឆាំងនឹងអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងមានបាបមិនខាន។
[16]មិនត្រូវប្រហារជីវិតឪពុក ដោយព្រោះតែទោសរបស់កូន ហើយក៏មិនត្រូវប្រហារជីវិតកូន ដោយព្រោះទាសរបស់ឪពុកដែរ គឺត្រូវប្រហារជីវិតម្នាក់ៗ
តាមអំពើបាបដែលខ្លួនគេប្រព្រឹត្ត។
[17]មិនត្រូវរំលោភបំពានលើសិទ្ធិរបស់ជនបរទេស ឬក្មេងកំព្រាឡើយ ក៏មិនត្រូវយកសម្លៀកបំពាក់របស់ស្ត្រីមេម៉ាយទុកជាវត្ថុបញ្ចាំដែរ។[18]ផ្ទុយទៅវិញ ត្រូវនឹកចាំថា
អ្នករាល់គ្នាក៏ធ្លាប់ធ្វើជាទាសកររនៅក្នុងទឹកដីអេស៊ីបដែរ ហើយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានរំដោះអ្នករាល់គ្នាចេញពីទីនោះមក។ ហេតុនេះហើយ
បានជាខ្ញុំបង្គាប់ឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមសេចក្តីបង្គាប់នេះ។
[19]ពេលណា អ្នករាល់គ្នាច្រូតស្រូវនៅក្នុងស្រែរបស់អ្នករាល់គ្នា ហើយអ្នករាល់គ្នាភ្លេចស្រូវមួយកណ្តាប់នៅក្នុងស្រែ នោះមិនត្រូវវិលត្រឡប់ទៅយកវិញឡើយ
គឺត្រូវទុកស្រូវនោះឲ្យជនបរទេស ក្មេងកំព្រា ឬស្ត្រីមេម៉ាយវិស ដើម្បីឲ្យព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាប្រទានពរឲ្យអ្នករាល់គ្នាក្នុងគ្រប់កិច្ចការដែលអ្នករាល់គ្នាធ្វើ។
[20]ពេលណា អ្នករាល់គ្នាបេះផ្លែពីដើមអូលីវរួចរាល់ហើយ នោះមិនត្រូវវិលទៅបេះផ្លែដែលនៅសល់ម្តងទៀតឡើយ ត្រូវទុកផ្លែទាំងនោះឲ្យជនបរទេស ក្មេងកំព្រា
ឬស្ត្រីមេម៉ាយវិញ។
[21]ពេលណា អ្នករាល់គ្នាបេះផ្លែទំពាំងបាយជូររួចរាល់ហើយ នោះមិនត្រូវវិលទៅបេះម្តងទៀតឡើយ។ គឺត្រូវទុកផ្លែដែលនៅសល់នោះឲ្យទៅជនបរទេស ក្មេងកំព្រា
ឬស្ត្រីមេម៉ាយ។[22]ត្រូវនឹកចាំថា ពីដើមអ្នករាល់គ្នាក៏ធ្លាប់ធ្វើជាទាសករនៅក្នុងទឹកដីអេស៊ីបដែរ ហេតុនេះហើយ បានជាខ្ញុំបង្គាប់ឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមដូច្នេះ។

Deuteronomy 24:1
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ពេលណាបុរសម្នាក់រៀបការជាមួយស្ត្រីម្នាក់
ឃ្លា «យកប្រពន្ធ» និង «រៀបការជាមួយនាង» មានន័យដូចគ្នា។
ការបកប្រែផ្សេងទៀត «នៅពេលបុរសរៀបការជាមួយស្ត្រី»
ហើយក្រោយមក បែរជាឈប់ស្រឡាញ់នាង
នៅទីនេះ «ស្រឡាញ់នាង» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«បើគាត់សម្រេចថាគាត់មិនចូលចិត្តនាង»
ព្រោះគេមិនពេញចិត្តនឹងនាងត្រង់កន្លែងណាមួយ
«ដោយសារតែហេតុផលខ្លះ គាត់បានសម្រេចថាគាត់មិនចង់ថែរក្សានាង»
ត្រូវសរសេរខិលិតលែងលះ
«គាត់ត្រូវតែផ្តល់ឱ្យប្រពន្ធនូវក្រដាសផ្លូវការមួយ
ដែលនិយាយថាពួកគេមិននៅជាមួយគ្នាទៀតទេ»
នោះនាងអាចរៀបការជាមួយបុរសម្នាក់ទៀត។
«នាងអាចទៅរៀបការជាមួយបុរសផ្សេង»
Deuteronomy 24:3
ព័ត៌មានទូទៅ៖

generated on Wed Sep 10 16:16:32 2025

លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលអំពីស្ត្រី
ដែលលែងលះហើយរៀបការជាមួយបុរសម្នាក់ទៀត។
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប្រសិនបើ ប្តីក្រោយឈប់ស្រឡាញ់នាង
«បើប្តីទី២សម្រេចចិត្តថា គាត់ស្អប់ស្ត្រីនោះ»
លិខិតលែងលះ
នេះជាក្រដាសផ្លូវការដែលនិយាយថា បុរសនិងស្ត្រីមិនអាចនៅជាមួយគ្នាទៀតទេ។
បកប្រែដូចនៅក្នុង ២៤:១។
ប្រគល់ឲ្យនាង
«ផ្តល់ឱ្យស្ត្រី»
ប្តីទីពីរដែលបានយកនាងធ្វើជាប្រពន្ធ
«បុរសទី២ ដែលរៀបការនឹងស្ត្រី»
ហើយត្រូវចាត់ទុកនាងថាជាស្រីសៅហ្មង
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត
«បន្ទាប់ពីនាងបានក្លាយទៅជាមិនស្អាតដោយសារការលែងលះ
និងរៀបការម្តងទៀតជាមួយបុរសម្នាក់ទៀត»
មិនត្រូវធ្វើឲ្យមានអំពើបាបបែបនេះ កើតមាននៅក្នុងទឹកដី
ទឹកដីនេះត្រូវបានគេនិយាយថា អាចធ្វើបាបបាន។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវឲ្យកំហុសរីករាលដាលនៅជុំវិញស្រុកទេ»
Deuteronomy 24:5
ព័ត៌មានទូទៅ៖
លោកម៉ូសេកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប្រសិនបើ បុរសណាម្នាក់ទើបនឹងរៀបការថ្មីៗ
«នៅពេលបុរសទើបរៀបការជាមួយស្ត្រី»
ហើយមិនត្រូវដាក់បន្ទុកអ្វីឲ្យគេធ្វើការដែរ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយគ្មានមនុស្សណាម្នាក់បង្ខំគាត់ឱ្យរស់នៅឆ្ងាយពីផ្ទះរបស់គាត់
ហើយធ្វើការងារណាមួយឡើយ»
ត្រូវឲ្យគេទំនេរនៅផ្ទះ
«គាត់នឹងមានសេរីភាពរស់នៅក្នុងផ្ទះ»
Deuteronomy 24:6
ត្បាល់កិន
ឧបករណ៍សម្រាប់ធ្វើម្សៅដោយកិនគ្រាប់ស្រូវ នៅចន្លោះថ្មសំប៉ែតធ្ងន់ចំនួនពីរ។
តែថ្មផ្នែកខាងលើរបស់ត្បាល់កិន
កំពូលនៃថ្មនៅលើត្បាល់កិន
ដ្បិត ធ្វើដូច្នេះ ដូចជាបង្កត់អាហារម្ហាស់ត្បាល់។
ពាក្យ «បង្កត់អាហារ » ជាឃ្លាសម្រាប់អ្វីដែលមនុស្សម្នាក់ត្រូវការ
ដើម្បីឱ្យខ្លួនគាត់មានជីវិត។ ការបកប្រែផ្សេងទៀត
«ពីព្រោះគាត់នឹងយកពីមនុស្សនូវអ្វី ដែលមនុស្សត្រូវការ
ដើម្បីធ្វើអាហារសម្រាប់គ្រួសាររបស់គាត់»
Deuteronomy 24:7
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប្រសិនបើ ឃើញជនជាតិអ៊ីស្រាអែលណាម្នាក់ចាប់យក
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ «បើបុរសម្នាក់ចាប់យក» ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បើអ្នករកឃើញបុរសម្នាក់កំពុងចាប់យក»
ចាប់យក
ប្រើកម្លាំងរាងកាយបង្ខំដើម្បីយកមនុស្សស្លូត
ត្រង់ចេញពីផ្ទះរបស់គាត់ហើយដាក់គុកគាត់
ជនជាតិអ៊ីស្រាអែលណាម្នាក់ចាប់យកបងប្អូនរបស់ខ្លួន យកទៅធ្វើជាទាសករ
«ជនរួមជាតិអ៊ីស្រាអែលណាម្នាក់»
អ្នកនោះនឹងត្រូវស្លាប់ ធ្វើដូច្នេះ
«បន្ទាប់មកជនជាតិអ៊ីស្រាអែលផ្សេងទៀត
គួរតែសម្លាប់នោះជាការដាក់ទោសចំពោះអ្វីដែលគាត់បានធ្វើ»
អ្នករាល់គ្នានឹងលុបបំបាត់អំពើអាក្រក់ចេញពីចំណោមអ្នករាល់គ្នា។
គុណនាម «អាក្រក់» អាចបកប្រែជាឃ្លានាម។ ការបកប្រែផ្សេងទៀត
«ហើយអ្នកត្រូវដកខ្លួនចេញពីក្នុងចំណោមជនអ៊ីស្រាអែល
ដែលបានធ្វើអំពើអាក្រក់នេះ» ឬ «ហើយអ្នកត្រូវតែប្រហារជីវិតមនុស្សអាក្រក់នេះ»
Deuteronomy 24:8
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចូរប្រយ័ត្ន ... ចូរប្រយ័ត្ននឹងធ្វើតាមសេចក្តីទាំងប៉ុន្មាន ...
ចូរនឹកចាំពីសេចក្តីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
លោកម៉ូសេមានប្រសាសន៍ទៅកាន់ជនជាតិអ៊ីស្រាអែលនៅទីនេះ
ដូចពួកគេជាមនុស្សតែម្នាក់ ដូច្នេះ ពាក្យ «អ្នក»និង «របស់អ្នក» និងបង្គាប់
«ចូរប្រយ័ត្ន» និង «ចូរនឹកចាំ» ជាឯកវចនៈ។
ចូរប្រយ័ត្ន ក្នុងករណីមានរោគឃ្លង់
«ចូរយកចិត្តទុកដាក់ បើអ្នករងទុក្ខវេទនាពីជំងឺឃ្លង់» ឬ «ចូរយកចិត្តទុកដាក់
បើអ្នកមានជំងឺឃ្លង់»
ធ្វើតាមសេចក្តីទាំងប៉ុន្មានរបស់ពួកបូជាចារ្យ លេវីបង្រៀនអ្នករាល់គ្នា
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ការបង្រៀនទាំងអស់
ដែលខ្ញុំបានឱ្យអ្នក និងថាបូជាចារ្យដែលជាក្រុមលេវីបង្រៀនឱ្យអ្នកធ្វើ»
បង្រៀនអ្នករាល់គ្នា ... ត្រូវធ្វើតាម ... អ្នករាល់គ្នាចាកចេញពីទឹកដីអេស៊ីប។
នៅទីនេះលោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលជាក្រុម ដូច្នេះ
ឧទាហរណ៍នៃពាក្យថា «អ្នក» ជាពហុវចនៈ។
ដូចដែលខ្ញុំបានបង្គាប់ដល់ពួកបូជាចារ្យទាំងនោះ។
«អ្នកត្រូវតែធ្វើឱ្យប្រាកដថា អ្នកធ្វើអ្វីដែលខ្ញុំបានង្គាប់ពួកគេ»
ខ្ញុំបានបង្គាប់ដល់ពួកបូជាចារ្យ
ពាក្យថា «ពួកគេ» សំដៅទៅលើពួកសង្ឃដែលជាពួកលេវី។
ចូរនឹក
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ចូរចងចាំ»
ពេលដែលអ្នករាល់គ្នាចាកចេញពីទឹកដីអេស៊ីប។
«អំឡុងពេលដែលអ្នករាល់គ្នាចាកចេញពីអេស៊ីប»
Deuteronomy 24:10
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប្រសិនបើ អ្នករាល់គ្នាឲ្យអ្វីមួយទៅអ្នកជិតខាងខ្ចី
«នៅពេលអ្នករាល់គ្នាខ្ចីអ្វីមួយ ពីអ្នកជិតខាង»
ដើម្បីយកវត្ថុបញ្ចាំឡើយ។
«ដើម្បីទទួលយកវត្ថុបញ្ចាំរបស់គាត់»
វត្ថុបញ្ចាំ
នេះជាឃ្លាសម្រាប់ «នូវអ្វីដែលគាត់បានសន្យាថា គាត់នឹងផ្តល់ឱ្យអ្នក
បើគាត់មិនសងប្រាក់កម្ចី»
អ្នករាល់គ្នាត្រូវឈរចាំនៅខាងក្រៅផ្ទះ
«អ្នករាល់គ្នាគួរតែរង់ចាំនៅខាងក្រៅផ្ទះរបស់គាត់»
Deuteronomy 24:12
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
អ្នករាល់គ្នាមិនត្រូវចូលដំណេក ដោយទុកវត្ថុបញ្ចាំជាប់នឹងខ្លួនឡើយ។
«អ្នករាល់គ្នាមិនត្រូវទុកអាវធំគាត់ពេញមួយយប់ទេ»
ទុកវត្ថុបញ្ចាំ
នេះជាឃ្លាសម្រាប់ «នូវអ្វីដែលគាត់បានសន្យាថា គាត់នឹងឱ្យអ្នក
បើគាត់មិនសងប្រាក់កម្ចីនោះទេ»។ បកប្រែដូចនៅក្នុង ២៤:១០។
ត្រូវប្រគល់អាវធំដែលគេយកមកបញ្ចាំនោះប្រគល់ឲ្យគេវិញ
«ឱ្យគាត់ត្រឡប់ទៅវិញនូវអ្វី ដែលគាត់បានឱ្យអ្នកដើម្បីបង្ហាញថា
គាត់នឹងសងប្រាក់ខ្ចីត្រឡប់មកវិញ»
ដើម្បីឲ្យគេមានអាវដណ្តប់ខ្លួន ហើយគេនឹងឲ្យពរអ្នករាល់គ្នា។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ដូច្នេះគាត់នឹងមានអាវធំរបស់គាត់ ដើម្បីឱ្យខ្លួនគាត់កក់ក្តៅ
នៅពេលគាត់ដេកហើយគាត់នឹងដឹងគុណអ្នករាល់គ្នា»
អាវដណ្តប់ខ្លួន

generated on Wed Sep 10 16:16:32 2025

អាវធំឬសម្លៀកបំពាក់ផ្សេងទៀត ដែលធ្វើឱ្យមនុស្សកក់ក្តៅនៅពេលយប់។ នេះប្រហែលជា «ការសន្យា» ដែលលោកម៉ូសេបានកំពុងនិយាយនៅក្នុង ២៤:១០។
ដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
«ព្រះអម្ចាស់ជាព្រះរបស់អ្នកគាប់ព្រះហឫទ័យ
នឹងរបៀបដែលអ្នកដោះស្រាយរឿងនេះ»
Deuteronomy 24:14
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
អ្នករាល់គ្នាមិនត្រូវជិះជាន់កូនឈ្នួលដែលក្រីក្រ
«អ្នករាល់គ្នាមិនត្រូវប្រព្រឹត្ត ចំពោះកូនឈ្នួលដែលក្រីក្រ»
កូនឈ្នួល
មនុស្សម្នាក់ដែលទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃសម្រាប់ការងាររបស់គេ
ក្រីក្រ ហើយកម្សត់ទុគ៌ត
ពាក្យទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា ហើយបញ្ជាក់ថា នេះជាមនុស្សដែលមិនអាចជួយខ្លួនឯងបាន។
នៅក្នុងក្រុងរបស់អ្នករាល់គ្នាក៏ដោយ
នៅទីនេះ «ទ្វារក្រុង» មានន័យថាទីក្រុង ឬទីប្រជុំជន។ ការបកប្រែផ្សេងទៀត «នៅក្នុងទីក្រុងមួយក្នុងចំណោមទីក្រុងរបស់អ្នករាល់គ្នា»
ត្រូវបើកប្រាក់ឈ្នួលឲ្យគេ
«អ្នកគួរតែផ្តល់ឱ្យគេនូវប្រាក់ ដែលគាត់រកបានរាល់ថ្ងៃ»
មុនពេលថ្ងៃលិច
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ជនជាតិអ៊ីស្រាអែលបានចាត់ទុកថ្ងៃថ្មីជាការចាប់ផ្តើម នៅពេលព្រះអាទិត្យលិច។ ការបកប្រែផ្សេងទៀត «អ្នកគួរតែបង់ប្រាក់ឱ្យគេនៅថ្ងៃតែមួយដែលគាត់ធ្វើការ»
ដ្បិត គេទាល់ក្រ ហើយត្រូវការប្រាក់ឈ្នួលរបស់ខ្លួនជាចាំបាច់។ អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«ដោយសារតែគាត់ក្រីក្រហើយពឹងផ្អែកលើប្រាក់ឈ្នួលរបស់គាត់ដើម្បីទិញអាហាររបស់គាត់នៅថ្ងៃបន្ទាប់»
ក្រែងលោគេទូលអង្វរព្រះអម្ចាស់ប្រឆាំងនឹងអ្នករាល់គ្នា
«គេមិនអំពាវនាវរកព្រះអម្ចាស់ ហើយសុំឱ្យព្រះអង្គដាក់ទោសអ្នករាល់គ្នា»
Deuteronomy 24:16
មិនត្រូវប្រហារជីវិតឪពុក ដោយព្រោះតែទោសរបស់កូន
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវប្រហារជីវិតឪពុកម្តាយដោយសារតែអំពើអាក្រក់ ដែលកូនរបស់ពួកគេបានធ្វើ»
ហើយក៏មិនត្រូវប្រហារជីវិតកូន ដោយព្រោះទាសរបស់ឪពុកដែរ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយអ្នកមិនត្រូវប្រហារជីវិតកូនដោយសារតែអំពើអាក្រក់ ដែលឪពុកម្តាយរបស់ពួកគេបានធ្វើ»
គឺត្រូវប្រហារជីវិតម្នាក់ៗ តាមអំពើបាបដែលខ្លួនគេប្រព្រឹត្ត។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកគួរតែប្រហារជីវិតបុគ្គលដោយសារតែអំពើអាក្រក់ ដែលគេបានធ្វើដោយខ្លួនគេផ្ទាល់»
Deuteronomy 24:17
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មិនត្រូវរំលោភបំពានលើសិទ្ធិរបស់ជនបរទេស ឬក្មេងកំព្រាឡើយ
លោកម៉ូសេនិយាយអំពីយុត្តិធម៌ដូចជាវត្ថុ ដែលមនុស្សខ្លាំងពូកែអាចដកយកចេញពីមនុស្សទន់ខ្សោយបាន។
ការបកប្រែផ្សេងទៀត « អ្នកមិនត្រូវធ្វើបាបជនបរទេស ឬក្មេងកំព្រាដោយអយុត្តិធម៌ឡើយ»
កំព្រា
នេះសំដៅទៅលើកូនៗ ដែលឪពុកម្តាយបានស្លាប់ហើយមិនមានសាច់ញាតិមើលថែពួកគេ។
ក៏មិនត្រូវយកសម្លៀកបំពាក់របស់ស្ត្រីមេម៉ាយទុកជាវត្ថុបញ្ចាំដែរ។
អ្នកឱ្យគេខ្ចីនឹងយកអ្វីមួយពីអ្នកខ្ចីដើម្បីធានាថា នាងនឹងសងគាត់វិញ។ គាត់មិនត្រូវបានអនុញ្ញាតឱ្យយកអាវធំរបស់នាងទេ ពីព្រោះនាងត្រូវការវាដណ្តប់ឲ្យកក់ក្តៅ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត «ហើយកុំយកអាវធំរបស់ស្ត្រីមេម៉ាយទុកជាការសន្យា ព្រោះនាងត្រូវការវាដណ្តប់ឱ្យកក់ក្តៅ»
ត្រូវនឹកចាំ
នេះជាលេខសម្គាល់។ ការបកប្រែផ្សេងទៀត «ចូរចងចាំ»
Deuteronomy 24:19
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ពេលណា អ្នករាល់គ្នាច្រូតស្រូវនៅក្នុងស្រែរបស់អ្នករាល់គ្នា
«នៅពេលអ្នកកាត់ស្រូវនៅក្នុងស្រែរបស់អ្នករាល់គ្នា »
ស្រូវមួយកណ្តាប់
ស្រូវដែលអ្នកច្រូតកាត់បានចងជាមួយគ្នា
គឺត្រូវទុកស្រូវនោះឲ្យជនបរទេស ក្មេងកំព្រា ឬស្ត្រីមេម៉ាយរើស
អ្នកអាចត្រូវផ្តល់ព័ត៌មានឱ្យច្បាស់ ដែលងាយយល់។ ការបកប្រែផ្សេងទៀត «អ្នកត្រូវទុកវាចោលដើម្បីឱ្យជនបរទេសក្មេងកំព្រា ឬស្ត្រីមេម៉ាយអាចយកវាបាន»
ក្នុងគ្រប់កិច្ចការដែលដៃអ្នករាល់គ្នាធ្វើ។
នៅទីនេះ «ដៃ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត «នៅក្នុងការងារទាំងអស់ដែលអ្នកធ្វើ»
«គាត់នៅថ្ងៃបន្ទាប់» ដែលមនុស្សខ្លាំងពូកែអាចដកយកចេញពីមនុស្សទន់ខ្សោយបាន។ ការបកប្រែផ្សេងទៀត « អ្នកមិនត្រូវធ្វើបាបជនបរទេស ឬក្មេងកំព្រាដោយអយុត្តិធម៌ឡើយ»
កំព្រា
នេះសំដៅទៅលើកូនៗ ដែលឪពុកម្តាយបានស្លាប់ហើយមិនមានសាច់ញាតិមើលថែពួកគេ។
ក៏មិនត្រូវយកសម្លៀកបំពាក់របស់ស្ត្រីមេម៉ាយទុកជាវត្ថុបញ្ចាំដែរ។
អ្នកឱ្យគេខ្ចីនឹងយកអ្វីមួយពីអ្នកខ្ចីដើម្បីធានាថា នាងនឹងសងគាត់វិញ។ គាត់មិនត្រូវបានអនុញ្ញាតឱ្យយកអាវធំរបស់នាងទេ ពីព្រោះនាងត្រូវការវាដណ្តប់ឲ្យកក់ក្តៅ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត «ហើយកុំយកអាវធំរបស់ស្ត្រីមេម៉ាយទុកជាការសន្យា ព្រោះនាងត្រូវការវាដណ្តប់ឱ្យកក់ក្តៅ»
ត្រូវនឹកចាំ
នេះជាលេខសម្គាល់។ ការបកប្រែផ្សេងទៀត «ចូរចងចាំ»
Deuteronomy 24:19
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ពេលណា អ្នករាល់គ្នាច្រូតស្រូវនៅក្នុងស្រែរបស់អ្នករាល់គ្នា
«នៅពេលអ្នកកាត់ស្រូវនៅក្នុងស្រែរបស់អ្នករាល់គ្នា »
ស្រូវមួយកណ្តាប់
ស្រូវដែលអ្នកច្រូតកាត់បានចងជាមួយគ្នា
គឺត្រូវទុកស្រូវនោះឲ្យជនបរទេស ក្មេងកំព្រា ឬស្ត្រីមេម៉ាយរើស
អ្នកអាចត្រូវផ្តល់ព័ត៌មានឱ្យច្បាស់ ដែលងាយយល់។ ការបកប្រែផ្សេងទៀត «អ្នកត្រូវទុកវាចោលដើម្បីឱ្យជនបរទេសក្មេងកំព្រា ឬស្ត្រីមេម៉ាយអាចយកវាបាន»
ក្នុងគ្រប់កិច្ចការដែលដៃអ្នករាល់គ្នាធ្វើ។
នៅទីនេះ «ដៃ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត «នៅក្នុងការងារទាំងអស់ដែលអ្នកធ្វើ»
«នៅពេលដែលអ្នកបេះផ្លែពីដើមអូលីវរបស់អ្នករាល់គ្នា បណ្តាលឱ្យដើមអូលីវដួលទៅនឹងដី ដូច្នេះអ្នកអាចបេះវាបាន»
នោះមិនត្រូវវិលទៅបេះផ្លែដែលនៅសល់ម្តងទៀតឡើយ
«មិនត្រូវបេះផ្លែអូលីវពីគ្រប់ដើមឈើ»
ត្រូវទុកផ្លែទាំងនោះឲ្យជនបរទេស ក្មេងកំព្រា ឬស្ត្រីមេម៉ាយវិញ។
អ្នកអាចព័ត៌មានឱ្យច្បាស់ ដែលងាយយល់។ ការបកប្រែផ្សេងទៀត « អូលីវដែលនៅលើមែកគឺសម្រាប់ជនបរទេសក្មេងកំព្រា និងស្ត្រីមេម៉ាយ ដើម្បីរើសនិងយកទៅជាមួយ»
Deuteronomy 24:21
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
គឺត្រូវទុកផ្លែដែលនៅសល់នោះឲ្យទៅជនបរទេស ក្មេងកំព្រា ឬស្ត្រីមេម៉ាយ។
«ផ្លែទំពាំងបាយជូរដែលអ្នកមិនបេះនឹងទុកសម្រាប់ជនបរទេស ក្មេងកំព្រា និងស្ត្រីមេម៉ាយបេះ»
គឺត្រូវទុកផ្លែដែលនៅសល់នោះឲ្យទៅជនបរទេស ក្មេងកំព្រា ឬស្ត្រីមេម៉ាយ។
ទាំងនេះសំដៅទៅលើក្រុមមនុស្ស។ ការបកប្រែផ្សេងទៀត «សម្រាប់ជនបរទេសសម្រាប់អ្នក ដែលគ្មានឪពុក ឬ ស្ត្រីមេម៉ាយ»
ត្រូវនឹកចាំ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ចូរចងចាំ»

---

25 [1]ប្រសិនបើ មានមនុស្សទាស់ទែងគ្នា ហើយឡើងទៅតុលាការ រួចចៅក្រមកាត់ក្តីឲ្យពួកគេ ដោយប្រកាសថា ម្នាក់ជាអ្នកស្លូតត្រង់ឈ្នះក្តី ហើយម្នាក់ទៀតមានទោស។ [2]ប្រសិនបើ អ្នកមានទោសនោះទទួលរំពាត់ នោះចៅក្រមត្រូវឲ្យគាត់ដេកនៅលើដី ហើយឲ្យគេវាយនៅចំពោះមុខលោក ឲ្យសមនឹងកំហុស ដែលខ្លួនបានប្រព្រឹត្ត។ [3]ប៉ុន្តែ មិនត្រូវវាយគាត់ឲ្យលើសពីសែសិបរំពាត់ឡើយ ហើយប្រសិនបើគេវាយគាត់លើសពីនោះ ក្រែងលោបងប្អូនរបស់អ្នករាល់គ្នាបាត់បង់កិត្តិយសនៅចំពោះមុខអ្នករាល់គ្នា។
[4]អ្នករាល់គ្នាមិនត្រូវឃ្លុំមាត់គោដែលកំពុងបញ្ជាន់ស្រូវឡើយ។

generated on Wed Sep 10 16:16:32 2025

[5]ប្រសិនបើ បងប្អូនប្រុសៗរស់នៅជាមួយគ្នា ហើយម្នាក់ស្លាប់ទៅដោយគ្មានកូនប្រុសទេ នោះ ប្រពន្ធរបស់អ្នកស្លាប់ មិនអាចរៀបការជាមួយអ្នកដទៃបានឡើយ។
ផ្ទុយទៅវិញ ប្អូនថ្លៃរបស់នាង ត្រូវយកនាងមកធ្វើជាភរិយា ហើយត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្អូនថ្លៃ។[6]កូនប្រុសដំបូងដែលនាងបង្កើតមក
ត្រូវបន្តឈ្មោះជាកូនរបស់ប្តីដែលស្លាប់ទៅហើយនោះ ដើម្បីកុំឲ្យឈ្មោះរបស់គាត់បាត់ពីចំណោមជនជាតិអ៊ីស្រាអែលឡើយ។
[7]ប្រសិនបើ អ្នកនោះមិនសុខចិត្តរៀបការជាមួយបងថ្លៃរបស់ខ្លួនទេ នាងត្រូវចូលទៅជួបពួកចាស់ទុំនៅត្រង់មាត់ទ្វារក្រុង ហើយជម្រាបថា
ប្អូនថ្លៃនាងខ្ញុំមិនព្រមរក្សាឈ្មោះឲ្យបងប្អូនប្រុសរបស់ខ្លួន ឲ្យគង់វង្ស នៅក្នុងចំណោមជនជាតិអ៊ីស្រាអែលទេ គាត់មិនចង់បំពេញកាតព្វកិច្ចរបស់គាត់ជាប្អូនថ្លៃឡើយ។
[8]ពេលនោះពួកចាស់ទុំរបស់ទីក្រុងត្រូវហៅអ្នកនោះមកសួរ។ ហើយគាត់នៅតែបដិសេធមិនព្រមរៀបការជាមួយនាងទេ។
[9]ពេលនោះ បងថ្លៃត្រូវចូលទៅជិតគាត់ នៅមុខពួកចាស់ទុំ ហើយនាងត្រូវដោះស្បែកជើងចេញពីជើងរបស់គាត់ ព្រមទាំងស្តោះទឹកមាត់ដាក់មុខគាត់។ ហើយប្រកាសថា
មនុស្សដែលមិនព្រមបន្តពូជឲ្យបងប្រុសរបស់ខ្លួនគឺត្រូវបាក់មុខដូចនេះឯង។[10]រួចនៅក្នុងទឹកដីអ៊ីស្រាអែលទាំងមូល គេនឹងដាក់ឈ្មោះក្រុមគ្រួសារអ្នកនោះថា
ពូជអត់ស្បែកជើង។
[11]នៅពេលបុរសពីរនាក់កំពុងវាយតប់គ្នា ហើយប្រពន្ធរបស់បុរសម្នាក់ចូលទៅជួយប្តីឲ្យរួចពីកណ្តាប់ដៃរបស់អ្នកដែលវាយនោះ
ដោយចាប់ទាញកេរ្តិ៍ខ្មាស់របស់បុរសម្នាក់ទៀត[12]នោះត្រូវកាត់ដៃរបស់ស្ត្រីនោះចោល គឺមិនត្រូវអាណិតមេត្តានាងឡើយ។
[13]ក្នុងថង់របស់អ្នករាល់គ្នាមិនត្រូវមានកូនជញ្ជីងពីខុសគ្នា គឺមួយធ្ងន់ មួយស្រាលឡើយ។[14]ក្នុងផ្ទះរបស់អ្នករាល់គ្នាក៏មិនត្រូវមានរង្វាស់ពីរខុសគ្នា គឺមួយធំ មួយតូចដែរ។
[15]អ្នករាល់គ្នាត្រូវមានកូនជញ្ជីងត្រឹមត្រូវពេញទម្ងន់ និងរង្វាស់ត្រឹមត្រូវ ដើម្បីឲ្យអ្នករាល់គ្នាបានអាយុយឺនយូរ នៅក្នុងទឹកដីដែលព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យ។[16]ដ្បិត អ្នកណាដែលប្រព្រឹត្តដូច្នោះ គឺអស់អ្នកដែលប្រព្រឹត្តមិនទៀងត្រង់ ជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[17]ចូរនឹកចាំពីការដែលជនជាតិអាម៉ាឡេក បានប្រព្រឹត្តចំពោះអ្នករាល់គ្នានៅតាមផ្លូវ
ក្រោយពេលអ្នករាល់គ្នាចាកចេញពីទឹកដីអេស៊ីប[18]ពួកគេបានទាស់នឹងអ្នករាល់គ្នានៅតាមផ្លូវ ហើយពេល អ្នករាល់គ្នាអស់កម្លាំង ហើយល្វើយ
ពួកគេបានវាយអស់អ្នកដែលដើរយឺតជាងគេនៅតាមក្រោយ ពួកគេមិនកោតខ្លាចព្រះជាម្ចាស់សោះ។[19]ហេតុដូច្នេះ កាលណាព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាបានកម្ចាត់ខ្មាំងសត្រូវទាំងអស់ដែលនៅជុំវិញអ្នករាល់គ្នា ហើយបានប្រទានឲ្យអ្នករាល់គ្នាបានសម្រាក នៅក្នុងទឹកដីដែលព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នាបានកាន់កាប់ជាមរតក នោះត្រូវលុបការនឹកចាំរបស់ជនជាតិអាម៉ាឡេកចេញពីក្រោមមេឃ។ ចូរកុំភ្លេចឲ្យសោះ។

Deuteronomy 25:1
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប្រសិនបើ អ្នកមានទោសនោះទទួលរំពាត់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បើចៅក្រមបង្គាប់ឱ្យពួកគេ ជាមនុស្សដែលមានកំហុស»
ហើយឲ្យគេវាយនៅចំពោះមុខលោក
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយលោកនឹងមើលពួកគេវាយគាត់»
ឲ្យសមនឹងកំហុស ដែលខ្លួនបានប្រព្រឹត្ត។
«ចំនួនដងដែលគាត់បាននឹកនាំដោយសារតែអំពើអាក្រក់ដែលគាត់បានធ្វើ»
Deuteronomy 25:3
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចៅក្រមអាចឱ្យគេវាយគាត់ក្រោមចំនួនសែសិបរំពាត់
«ចៅក្រមអាចនិយាយថា ពួកគេគួរតែវាយអ្នកដែលមានកំហុស៤០ដង»
ហើយប្រសិនបើគេវាយគាត់លើសពីនោះ
«ប៉ុន្តែ ចៅក្រមមិនអាចនឹងបញ្ជាឱ្យពួកគេវាយគាត់ច្រើនជាង៤០ដងទេ»
ចៅក្រមអាចឱ្យគេវាយគាត់ក្រោមចំនួនសែសិបរំពាត់ហើយប្រសិនបើគេវាយគាត់លើសពីនោះ
«ពីព្រោះ បើចៅក្រមបង្គាប់ឱ្យគេវាយគាត់ច្រើនជាង៤០ ដង»
ក្រែងលោបងប្អូនរបស់អ្នករាល់គ្នាបាត់បង់កិត្តិយស
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកចៅក្រមនឹងធ្វើឱ្យបាត់បង់កិត្តិយស
នៅមុខបងប្អូនអ៊ីស្រាអែលរបស់អ្នករាល់គ្នា
នៅចំពោះមុខប្រជាជនអ៊ីស្រាអែលទាំងអស់»
បាត់បង់កិត្តិយស នៅចំពោះមុខអ្នករាល់គ្នា។
នៅទីនេះឃ្លា «មុខអ្នករាល់គ្នា» សំដៅទៅលើអ្វីដែលពួកគេនឹងឃើញ។
ការបកប្រែផ្សេងទៀត
«ធ្វើឱ្យអាម៉ាស់មុខហើយអ្នករាល់គ្នាទាំងអស់គ្នានឹងឃើញវា»។
ពាក្យស្រដៀងគ្នាកើតមានឡើងក្នុង ១:៧
Deuteronomy 25:4
អ្នករាល់គ្នាមិនត្រូវឃ្លុំមាត់គោ
«អ្នករាល់គ្នាមិនត្រូវដាក់អ្វីមួយលើមាត់គោ»
ដែលកំពុងបញ្ជាន់ស្រូវឡើយ។
ពេលគេញែកស្រូវចេញពីអង្កាម ដោយដើរលើវា ឬអូសឈើធ្ងន់ៗ
Deuteronomy 25:5
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប្រសិនបើ បងប្អូនប្រុសៗរស់នៅជាមួយគ្នា
អាចមានន័យថា ១)«បើបងប្អូនរស់នៅផ្ទះតែមួយ» ឬ ២)
«បើបងប្អូនរស់នៅក្បែរគ្នា»។
នោះ ប្រពន្ធរបស់អ្នកស្លាប់ មិនអាចរៀបការជាមួយអ្នកដទៃបានឡើយ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ក្រុមគ្រួសាររបស់បុរសស្លាប់
មិនត្រូវឱ្យស្ត្រីមេម៉ាយរៀបការជាមួយមនុស្សណាម្នាក់ឡើយ»
ហើយត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្អូនថ្លៃ។
«និងធ្វើអ្វីដែលប្អូនថ្លៃរបស់ប្តីស្លាប់ ត្រូវធ្វើ»
ត្រូវបន្តឈ្មោះជាកូនរបស់ប្តីដែលស្លាប់ទៅហើយនោះ
ពាក្យ «ឈ្មោះ» ជាឃ្លាសម្រាប់ខ្សែស្រឡាយគ្រួសាររបស់មនុស្ស។
ការបកប្រែផ្សេងទៀត «នឹងបន្តវង្សត្រកូលរបស់បងប្រុសដែលបានស្លាប់នោះ»
ដើម្បីកុំឲ្យឈ្មោះរបស់គាត់បាត់ពីចំណោមជនជាតិអ៊ីស្រាអែលឡើយ។
ពាក្យ «ឈ្មោះ» ជាឃ្លាសម្រាប់ខ្សែស្រឡាយគ្រួសាររបស់មនុស្ស។
ការបកប្រែផ្សេងទៀត «ដើម្បីកុំឱ្យវង្សត្រកូលរបស់គាត់មិនបាត់ពីអ៊ីស្រាអែល»
Deuteronomy 25:7
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវចូលទៅជួបពួកចាស់ទុំនៅត្រង់មាត់ទ្វារក្រុង
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ត្រូវឡើងទៅទ្វារក្រុង ដែលពួកចាស់ទុំវិនិច្ឆ័យករណីនេះ»
មិនព្រមរក្សាឈ្មោះឲ្យបងប្អូនប្រុសរបស់ខ្លួន
នៅទីនេះ «ឈ្មោះ» សំដៅទៅលើការចងចាំរបស់មនុស្សណាម្នាក់
តាមរយៈកូនចៅរបស់គាត់។ ការបកប្រែផ្សេងទៀត
«បដិសេធមិនផ្តល់ឱ្យបងប្រុសរបស់គាត់នូវកូនប្រុសម្នាក់»
គាត់មិនចង់បំពេញកាតព្វកិច្ចរបស់គាត់ជាប្អូនថ្លៃឡើយ។
«គាត់នឹងមិនធ្វើអ្វីដែលប្អូនថ្លៃត្រូវបានគិតថា ធ្វើនិងរៀបការជាមួយខ្ញុំ»
គាត់នៅតែបដិសេធមិនព្រមរៀបការជាមួយនាងទេ។
«ខ្ញុំមិនចង់រៀបការជាមួយនាងទេ»
Deuteronomy 25:9
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ត្រូវចូលទៅជិតគាត់ នៅមុខពួកចាស់ទុំ
«ត្រូវតែដើរទៅជិតគាត់ជាមួយពួកចាស់ទុំ ដែលឃ្លាំមើលនៅទីនោះ»
មនុស្សដែលមិនព្រមបន្តពូជឲ្យបងប្រុសរបស់ខ្លួន
នៅទីនេះ «បន្តពូជ» ជាឃ្លាសម្រាប់គ្រួសារ។ ការបកប្រែផ្សេងទៀត
«អ្នកណាដែលមិនបង្កើតកូនប្រុស និងបន្តត្រកូលគ្រួសារបងប្រុសរបស់គាត់»
រួចនៅក្នុងទឹកដីអ៊ីស្រាអែលទាំងមូល

generated on Wed Sep 10 16:16:32 2025

ប្រជាជនអ៊ីស្រាអែលនឹងស្គាល់គ្រួសាររបស់គាត់
គេនឹងដាក់ឈ្មោះក្រុមគ្រួសារអ្នកនោះថា ពូជអត់ស្បែកជើង។
នៅទីនេះ ការដោះស្បែកជើងជានិមិត្តរូប
ដែលថាប្អូនប្រុសនឹងមិនទទួលបានទ្រព្យសម្បត្តិណាមួយរបស់បងប្រុស
ដែលបានស្លាប់ទេ។ អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ
អាចត្រូវបានធ្វើឱ្យច្បាស់។ អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្មផងដែរ។
ការបកប្រែផ្សេងទៀត «ផ្ទះរបស់គាត់ដែលស្ត្រីមេម៉ាយបានដោះស្បែកជើង
ចេញពីជើងប្អូនរបស់គាត់» ឬ
«ក្រុមគ្រួសាររបស់មនុស្សដែលមិនបានរៀបការជាមួយប្រពន្ធរបស់បងប្រុស
ដែលស្លាប់របស់គាត់» ឬ «គ្រួសារដែលមនុស្សគ្រប់គ្នាមើលងាយ» ឬ
«គ្រួសារដែលមានភាពអាម៉ាស់»
Deuteronomy 25:11
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ឲ្យរួចពីកណ្តាប់ដៃរបស់អ្នកដែលវាយនោះ
នៅទីនេះ «ដៃ» សំដៅទៅលើអំណាចឬការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ដូច្នេះ អ្នកដែលវាយគាត់នឹងមិនធ្វើបាបគាត់ម្តងទៀត» ឬ
«ពីមនុស្សដែលវាយគាត់»
គឺមិនត្រូវអាណិតមេត្តានាងឡើយ។
នៅទីនេះ «ភ្នែក» មានន័យថាមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរអាណិតនាងទេ» ឬ «អ្នកមិនត្រូវបង្ហាញសេចក្តីមេត្តាដល់នាងទេ»
Deuteronomy 25:13
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ក្នុងថង់របស់អ្នករាល់គ្នាមិនត្រូវមានកូនជញ្ជីងពីខុសគ្នា គឺមួយធ្ងន់ មួយស្រាលឡើយ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
អ្នកក៏អាចផ្តល់ព័ត៌មានឱ្យច្បាស់ ដែលងាយយល់។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវបោកប្រាស់មនុស្សដោយប្រើទំងន់ធ្ងន់ជាង នៅពេលអ្នកទិញរបស់របរ
និងដោយប្រើទម្ងន់ស្រាលជាង ពេលអ្នកលក់របស់របរ»
ជញ្ជីង
ជញ្ជីងត្រូវបានប្រើដោយថ្មដើម្បីឲ្យមានតុល្យភាព
ហើយកំណត់របស់មួយមានទំងន់ប៉ុន្មាន។
ក្នុងផ្ទះរបស់អ្នករាល់គ្នាក៏មិនត្រូវមានរង្វាស់ពីរខុសគ្នា គឺមួយធំ មួយតូចដែរ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
អ្នកក៏អាចផ្តល់ព័ត៌មានឱ្យច្បាស់ ដែលងាយយល់។ ការបកប្រែផ្សេងទៀត
«អ្នកមិនត្រូវបោកប្រាស់មនុស្សដោយប្រើរង្វាស់
ដែលធំជាងនៅពេលអ្នកទិញរបស់របរ និងដោយប្រើរង្វាស់តូចជាង
ពេលអ្នកលក់របស់របរ»
រង្វាស់
រង្វាស់គឺជាធុង ឬរបស់ដាក់ផ្សេងទៀតសម្រាប់វាស់តើវាមានចំនួនប៉ុន្មាន។
Deuteronomy 25:15
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល អំពីការប្រើប្រាស់ជញ្ជីង
និងរង្វាស់ត្រឹមត្រូវនៅពេលទិញនិងលក់។ គាត់និយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ដូចពួកគេជាមនុស្សតែម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក»
មានលក្ខណៈឯកវចនៈ។
ត្រូវមានកូនជញ្ជីងត្រឹមត្រូវពេញទម្ងន់
«ត្រឹមត្រូវនិងយុត្តិធម៌»
កូនជញ្ជីង ... រង្វាស់
ចូរបកប្រែពាក្យទាំងនេះដូចនៅក្នុង ២៥:១៣ ។
ដើម្បីឲ្យអ្នករាល់គ្នាបានអាយុយឺនយូរ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាអាចរស់នៅបានយូរ»
ដ្បិត អ្នកណាដែលប្រព្រឹត្តដូច្នោះ គឺអស់អ្នកដែលប្រព្រឹត្តមិនទៀងត្រង់
«ពីព្រោះមនុស្សគ្រប់គ្នា ដែលបោកបញ្ឆោតមនុស្សដោយប្រើកូនជញ្ជីង
និងរង្វាស់ផ្សេងៗគ្នា។
Deuteronomy 25:17
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ចូរនឹកចាំពីការដែលជនជាតិអាម៉ាឡេក
នេះជាឃ្លា «ជនជាតិអាម៉ាឡេក » ជាឃ្លាសម្រាប់ប្រជាជនអាម៉ាឡេក។
ការបកប្រែផ្សេងទៀត «ចូរចងចាំអ្វីដែលអាម៉ាឡេកបានធ្វើចំពោះអ្នក»
ពេលអ្នករាល់គ្នាចាកចេញ
ពាក្យ «អ្នករាល់គ្នា» នៅទីនេះគឺពហុវចនៈ។
ពួកគេបានទាស់នឹងអ្នករាល់គ្នានៅតាមផ្លូវ
«របៀបដែលពួកគេបានជួបអ្នករាល់គ្នានៅតាមផ្លូវ»
ពួកគេបានវាយអស់អ្នកដែលដើរយឺតជាងគេនៅតាមក្រោយ
«និងបានវាយប្រហារប្រជាជនរបស់អ្នកដែលនៅជួរក្រោយ»
ហើយពេល អ្នករាល់គ្នាអស់កម្លាំង ហើយល្វើយ
«មនុស្សទាំងអស់ដែលខ្សោយនៅជួរក្រោយ»
អស់កម្លាំង ហើយល្វើយ
ពាក្យទាំងនេះមានអត្ថន័យស្រដៀងគ្នា
ហើយបញ្ជាក់ថាប្រជាជនអស់កម្លាំងខ្លាំងប៉ុណ្ណា។ ការបកប្រែផ្សេងទៀត
«អស់កម្លាំងនិងល្វើយ»
ពួកគេមិនកោតខ្លាចព្រះជាម្ចាស់សោះ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត « គាត់មិនភ័យខ្លាចការដាក់ទោសរបស់ព្រះជាម្ចាស់ទេ» ឬ
«គាត់មិនគោរពព្រះជាម្ចាស់»
នោះត្រូវលុបការនឹកចាំរបស់ជនជាតិអាម៉ាឡេកចេញពីក្រោមមេឃ។ ចូរកុំភ្លេចឲ្យសោះ។
«អ្នកត្រូវតែសម្លាប់ជនជាតិអាម៉ាឡេកទាំងអស់
ដើម្បីកុំឱ្យមានមនុស្សណាម្នាក់ចងចាំពួកគេទៀត»

---

26 [1]កាលណា អ្នករាល់គ្នាបានចូលទៅក្នុងទឹកដីដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាបានប្រទានឲ្យអ្នករាល់គ្នាជាមរតក ព្រមទាំងកាន់កាប់ទឹកដី
ហើយនិងរស់នៅក្នុងទឹកដីនោះ[2]នោះត្រូវយកផលដំបូងនៃភោគផលទាំងអស់ ដែលកើតពីដីនៅក្នុងទឹកដីដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យ។
រួចដាក់នៅក្នុងកញ្ជើមួយ ហើយនាំយកទៅកន្លែងដែលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នានឹងជ្រើសរើសសម្រាប់តាំងព្រះនាមព្រះអង្គ។
[3]អ្នករាល់គ្នាត្រូវទៅជួបពួកបូជាចារ្យដែលនៅបំពេញមុខងារនៅទីនោះ ហើយជម្រាបលោកថា នៅថ្ងៃនេះ ខ្ញុំបាទសូមប្រកាស
នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់លោកថា ខ្ញុំបាទបានមកដល់ទឹកដី ដែលព្រះអង្គសន្យាជាមួយបុព្វបុរសរបស់យើងថា នឹងឲ្យមកយើងខ្ញុំហើយ។[4]ពេលនោះ
ពួកបូជាចារ្យនឹងទទួលកញ្ជើពីដៃរបស់អ្នករាល់គ្នាយកទៅដាក់នៅមុខអាសនៈព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
[5]ពេលនោះ ត្រូវទូលនៅចំពោះព្រអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាថា បុព្វបុរសរបស់ខ្ញុំបាទគឺជនជាតិអើរ៉ាម។ លោកបានទៅស្នាក់នៅក្នុងទឹកដីអេស៊ីប
ហើយមានគ្នាមួយចំនួនត្រូវនៅជាមួយលោក។ នៅទីនោះ លោកបានក្លាយជាប្រជាជាតិមួយក៏ធំខ្លាំងពូកែ ហើយមានគ្នាជាច្រើន។
[6]ជនជាតិអេស៊ីបបានធ្វើបាន និងជិះជាន់យើងខ្ញុំ។ ពួកគេប្រើយើងខ្ញុំឲ្យធ្វើការជាទាសករ។[7]ពេលនោះ យើងខ្ញុំបានស្រែកទូលអង្វរទៅព្រះអម្ចាស់
ជាព្រះនៃបុព្វបុរសរបស់យើងខ្ញុំ ហើយព្រះអម្ចាស់ ព្រះសណ្តាប់ឮពាក្យរបស់យើងខ្ញុំ ព្រះអង្គទតឃើញពីការទុក្ខលំបាក និងការនឿយហត់របស់យើងខ្ញុំ
ព្រមទាំងការដែលគេជិះជាន់ដល់យើងខ្ញុំ។
[8]ព្រះអម្ចាស់បាននាំយើងខ្ញុំចាកចេញពីទឹកដីអេស៊ីប ដោយព្រះហស្តដ៏ខ្លាំងពូកែ និងតេជានុភាពដ៏ខ្លាំងពូកែរបស់ព្រះអង្គសម្តែងមហិទ្ធិឫទ្ធិគួរឲ្យស្ញែងខ្លាច ទីសម្គាល់
និងការអស្ចារ្យផ្សេងៗ[9]ព្រះអង្គបាននាំយើងខ្ញុំចូលមកដល់ទីនេះ ហើយបានប្រទានទឹកដីដ៏សម្បូរសប្បាយឲ្យយើងខ្ញុំ។
[10]ឥឡូវនេះ ឱព្រះអម្ចាស់អើយ ទូលបង្គំសូមថ្វាយផលដំបូងពីដីដែលព្រះអង្គបានប្រទានមកទូលបង្គំ។ អ្នករាល់គ្នាត្រូវដាក់តង្វាយនោះចុះនៅចំពោះព្រះភក្ត្រព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នា ហើយក្រោបថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា[11]បន្ទាប់មក ត្រូវជប់លៀងយ៉ាងអរសប្បាយជាមួយពួកលេវី
និងជនបរទេសដែលរស់នៅជាមួយអ្នករាល់គ្នាព្រោះព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ប្រទានភោគផលទាំងប៉ុន្មានមកឲ្យអ្នករាល់គ្នា និងគ្រួសាររបស់អ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

[12]កាលណា អ្នករាល់គ្នាថ្វាយតង្វាយមួយភាគដប់ ពីការប្រមូលភោគផលទាំងប៉ុន្មានរបស់អ្នករាល់គ្នា នៅឆ្នាំទីបី គឺជាឆ្នាំដែលថ្វាយមួយភាគដប់ទុកដោយឡែក
ហើយត្រូវប្រគល់តង្វាយនោះឲ្យទៅពួកលេវី ជនបរទេស ក្មេងកំព្រា និងស្ត្រីមេម៉ាយ ដើម្បីឲ្យពួកគេបានអាហារបរិភោគឆ្អែតបរិបូរនៅក្នុងក្រុងរបស់អ្នករាល់គ្នា។[13]ពេលនោះ
អ្នករាល់គ្នាត្រូវទូលព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាថា ទូលបង្គំបាននាំយកតង្វាយទាំងអស់ ចេញពីផ្ទះរបស់ទូលបង្គំមក ហើយបានប្រគល់ឲ្យទៅពួកលេវី ជនបរទេស
ក្មេងកំព្រា និងស្ត្រីមេម៉ាយ តាមបទបញ្ជាទាំងប៉ុន្មានដែលព្រះអង្គបង្គាប់មកទូលបង្គំ។ ទូលបង្គំមិនបានបំពានបទបញ្ជាណាមួយរបស់ព្រះអង្គ
ឬភ្លេចបទបញ្ជារបស់ព្រះអង្គឡើយ។
[14]ទូលបង្គំមិនបានបរិភោគតង្វាយមួយភាគដប់ ក្នុងពេលដែលទូលបង្គំកាន់ទុក្ខឡើយ ទូលបង្គំមិនបានយកទៅប្រើសម្រាប់ការអ្វីដែលមិនបរិសុទ្ធ ឬយកអ្វីមួយឲ្យទៅគេ
នៅពេលលមានមនុស្សស្លាប់ដែរ។ ទូលបង្គំបានស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះនៃទូលបង្គំ ហើយទូលបង្គំបានធ្វើតាមបទបញ្ជាទាំងប៉ុន្មាន
ដែលព្រះអង្គបានបង្គាប់មកទូលបង្គំ។[15]សូមព្រះអង្គទតពីស្ថានបរមសុខ ជាព្រះដំណាក់ដ៏បរិសុទ្ធ របស់ព្រះអង្គនៅស្ថានសួគ៌ ហើយប្រទានពរដល់អ៊ីស្រាអែល
ដែលជាប្រជារាស្ត្ររបស់ព្រះអង្គ និងទឹកដីដែលព្រះអង្គប្រទានមកយើងខ្ញុំ ដូចដែលព្រះអង្គបានសន្យាជាមួយបុព្វបុរសរបស់យើងខ្ញុំ គឺទឹកដីដ៏សម្បូរសប្បាយនេះ។
[16]នៅថ្ងៃនេះ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានបង្គាប់ឲ្យអ្នករាល់គ្នាប្រតិបត្តិតាមច្បាប់ និងបញ្ញត្តិទាំងនេះ។ ចូរកាន់ និងប្រព្រឹត្តតាម ឲ្យអស់ពីចិត្ត
អស់ពីព្រលឹងរបស់អ្នករាល់គ្នា។[17]នៅថ្ងៃនេះ អ្នករាល់គ្នាបានប្រកាសថា ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា និងដើរតាមផ្លូវរបស់ព្រះអង្គ ព្រមទាំងកាន់តាមបញ្ញត្តិ
គោរពច្បាប់ និងបទបញ្ជារបស់ព្រះអង្គ ព្រមទាំងស្តាប់បង្គាប់ព្រះអង្គទៀតផង។
[18]នៅថ្ងៃនេះ ព្រះអម្ចាស់បាប្រកាសថា អ្នករាល់គ្នាជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ ដូចដែលព្រះអង្គបានសន្យានឹងអ្នករាល់គ្នា
ហើយត្រូវឲ្យអ្នករាល់គ្នាប្រតិបត្តិតាមបទបញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ[19]ព្រះអង្គនឹងឲ្យអ្នករាល់គ្នាក្លាយទៅជាប្រជាជាតិមួយ មានកិត្តិយស កេរ្តិ៍ឈ្មោះ
ខ្ពស់លើសអស់ទាំងប្រជាជាតិ ដែលព្រះអង្គបានបង្កើតមក ដើម្បីឲ្យអ្នករាល់គ្នាបានធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធសម្រាប់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ដូចព្រះអង្គមានព្រះបន្ទូលទុក»។

Deuteronomy 26:1
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
យកផលដំបូងនៃភោគផលទាំងអស់
«ផលដំបូងនៃការប្រមូលផល» ឬ «ផលដំបូងខ្លះនៃការប្រមូលផល» ។ ពាក្យ
«ដំបូង» ជាលេខធម្មតាសម្រាប់លេខមួយ។
Deuteronomy 26:3
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
Deuteronomy 26:5
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
បុព្វបុរសរបស់ខ្ញុំបាទគឺជនជាតិអើរ៉ាម។
នេះជាការចាប់ផ្តើមនៃសេចក្តីថ្លែងការណ៍ ដែលបុរសជនជាតិអ៊ីស្រាអែលគួរតែធ្វើ
ពេលដឹកធុងរបស់គាត់។
ជនជាតិអើរ៉ាម
នេះសំដៅទៅលើលោកយ៉ាកុប
ដែលជាបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែលទាំងអស់។
គាត់បានរស់នៅអស់រយៈពេលជាច្រើនឆ្នាំនៅអើរ៉ាម -
ណាហារ៉ាមដែលជាតំបន់មួយស្ថិតនៅក្នុងប្រទេសស៊ីរី។
បានទៅស្នាក់នៅ
«ហើយបានរស់នៅពេញមួយជីវិតរបស់គាត់នៅទីនោះ»
នៅទីនោះ លោកបានក្លាយ
ពាក្យថា «លោក» ជាឃ្លាសម្រាប់« កូនចៅរបស់លោកយ៉ាកុប»។
ជាប្រជាជាតិមួយក៏ធំខ្លាំងពូកែ
ពាក្យទាំងនេះមានន័យថាជាមូលដ្ឋានដូចគ្នា។
ពួកគេសង្កត់ធ្ងន់ថាអ៊ីស្រាអែលបានក្លាយជាប្រជាជាតិដ៏ធំមួយនិងមានអំណាច។
ការបកប្រែផ្សេងទៀត «អស្ចារ្យណាស់»
Deuteronomy 26:6
ព័ត៌មានទូទៅ៖
ជនជាតិអ៊ីស្រាអែលត្រូវនិយាយដូចតទៅនេះនៅពេលដែលគាត់នាំភោគផលដំបូងថ្វាយព្រះអម្ចាស់។
បានធ្វើបាបនិងជិះជាន់យើងខ្ញុំ។
ឃ្លាទាំងពីរនេះនិយាយជារួមដូចគ្នា។
ពួកគេបញ្ជាក់ថាប្រជាជនអេស៊ីបបានប្រព្រឹត្តយ៉ាងសាហាវ។
ជិះជាន់យើងខ្ញុំ
នៅទីនេះ «យើងខ្ញុំ»
សំដៅទៅលើប្រជាជនអ៊ីស្រាអែលដែលកំពុងរស់នៅក្នុងប្រទេសអេស៊ីប។
អ្នកនិយាយរាប់បញ្ចូលខ្លួនគាត់ជាមនុស្សម្នាក់ក្នុងចំណោមប្រជាជន
ទោះបីជាគាត់រស់នៅក្នុងប្រទេសអេស៊ីបឬអត់។
ព្រះអម្ចាស់ ព្រះសណ្តាប់ឮពាក្យរបស់យើងខ្ញុំ
នៅទីនេះ «ព្រះសណ្តាប់» សំដៅទៅលើមនុស្សទាំងមូលនិងការស្រែកយំ
ឬការអធិស្ឋានរបស់គាត់។ ការបកប្រែផ្សេងទៀត
«ព្រះអង្គបានឮសម្រែករបស់យើងខ្ញុំ» ឬ
«ព្រះអង្គបានឮការអធិស្ឋានរបស់យើងខ្ញុំ»
ការទុក្ខលំបាក និងការនឿយហត់របស់យើងខ្ញុំ ព្រមទាំងការដែលគេជិះជាន់ដល់យើង។
«ប្រជាជនអេស៊ីបកំពុងធ្វើបាបយើង ដែលយើងខ្ញុំកំពុងធ្វើការយ៉ាងនឿយហត់
ហើយប្រជាជនអេស៊ីបកំពុងជិះជាន់លើយើងខ្ញុំ»
Deuteronomy 26:8
ព័ត៌មានទូទៅ៖
ជនជាតិអ៊ីស្រាអែលត្រូវនិយាយដូចតទៅនេះ
នៅពេលដែលគាត់នាំភោគផលដំបូងថ្វាយព្រះអម្ចាស់។
ព្រះអម្ចាស់បាននាំយើងខ្ញុំ
នៅទីនេះ «យើងខ្ញុំ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល
ដែលកំពុងរស់នៅក្នុងប្រទេសអេស៊ីប។
អ្នកនិយាយរាប់បញ្ចូលខ្លួនគាត់ជាមនុស្សម្នាក់ ក្នុងចំណោមប្រជាជន
ទោះបីជាគាត់រស់នៅក្នុងប្រទេសអេស៊ីប ឬអត់។
ដោយព្រះហស្តដ៏ខ្លាំងពូកែ និងតេជានុភាពដ៏ខ្លាំងពូកែ
នៅទីនេះ «ព្រះហស្តដ៏ខ្លាំងពូកែ» និង «តេជានុភាពដ៏ខ្លាំងពូកែ»
គឺការប្រៀបប្រដូចសម្រាប់អំណាចរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត:«ដោយបង្ហាញអំណាចដ៏ខ្លាំងក្លារបស់គាត់» ។
ពាក្យស្រដៀងគ្នានេះលេចចេញនៅក្នុង ៤:៣៤ ។
ព្រះអង្គសម្តែងមហិទ្ធិឫទ្ធិគួរឲ្យស្ញែងខ្លាច
«ជាមួយនឹងសកម្មភាព ដែលធ្វើឱ្យប្រជាជនបានឃើញភ័យខ្លាច»
ហើយបានប្រទានទឹកដីដ៏សម្បូរសប្បាយឲ្យយើងខ្ញុំ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ សូមមើលការបកប្រែនៅក្នុង ៦:៣។
ការបកប្រែផ្សេងទៀត «ទឹកដីដែលមានទឹកដោះ និងទឹកឃ្មុំច្រើន» ឬ
«ដីល្អសម្រាប់សត្វនិងកសិកម្ម»
Deuteronomy 26:10
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ជនជាតិអ៊ីស្រាអែលអំពីអ្វី
ដែលពួកគេត្រូវនិយាយនៅពេលពួកគេនាំយកផលដំបូងរបស់ពួកគេមកថ្វាយព្រះអម្ចាស់។
ការនិយាយទៅកាន់ពួកគេ ដូចជាពួកគេជាមនុស្សតែម្នាក់ ដូច្នេះ ពាក្យ «អ្នក»
និង«របស់អ្នក» មានលក្ខណៈឯកវចនៈ។
ផលដំបូង
«ផលដំបូងនៃការប្រមូលផល» ឬ «ផលដំណាំដំបូងនៃការប្រមូលផល»
អ្នករាល់គ្នាត្រូវដាក់តង្វាយនោះចុះ
«អ្នករាល់គ្នាត្រូវតែដាក់ធុងចុះ»។
ត្រូវជប់លៀងយ៉ាងអរសប្បាយជាមួយពួកលេវី
និងជនបរទេសដែលរស់នៅជាមួយអ្នករាល់គ្នាព្រោះព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា

generated on Wed Sep 10 16:16:32 2025

«អ្នករាល់គ្នាត្រូវតែអរសប្បាយ និងដឹងគុណចំពោះការល្អទាំងអស់
ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា បានធ្វើដើម្បីអ្នករាល់គ្នា»។
Deuteronomy 26:12
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
នៅឆ្នាំទីបី
ពាក្យ «ទីបី» ជាលេខធម្មតាសម្រាប់បី។ រៀងរាល់បីឆ្នាំម្តងប្រជាជនអ៊ីស្រាអែល
ផ្តល់ភោគផលមួយភាគដប់ដល់ជនក្រីក្រ។
ក្មេងកំព្រា
ទាំងនេះជាក្មេងដែលឪពុកម្តាយបានស្លាប់
ហើយមិនមានសាច់ញាតិមើលថែពួកគេទេ។
ស្ត្រីមេម៉ាយ
មានន័យថា ស្ត្រីដែលប្តីរបស់គាត់បានស្លាប់ទៅហើយគ្មានកូនមើលថែគាត់ទេ
ឥឡូវគាត់ចាស់ហើយ។
នៅក្នុងក្រុងរបស់អ្នករាល់គ្នា។
នៅទីនេះ« ទ្វារក្រុង» មានន័យថាទីប្រជុំជន ឬទីក្រុង។ ការបកប្រែផ្សេងទៀត
«ដើម្បីឱ្យអ្នករាល់គ្នានៅតាមទីប្រជុំជនរបស់អ្នករាល់គ្នា
មានអាហារបរិភោគគ្រប់គ្រាន់»
ទូលបង្គំបាននាំយកតង្វាយទាំងអស់
ទាំងនេះជាពាក្យដំបូងនៃសេចក្តីថ្លែងការណ៍មួយផ្សេងទៀត
ដែលជនជាតិអ៊ីស្រាអែលត្រូវបានគេគិតថាត្រូវនិយាយ។
ឬភ្លេចបទបញ្ជារបស់ព្រះអង្គឡើយ។
មានន័យថា គាត់បានគោរពតាមបទបញ្ជាទាំងអស់របស់ព្រះជាម្ចាស់។
Deuteronomy 26:14
ព័ត៌មានទូទៅ៖
នេះជាការបន្តនូវអ្វីដែលជនជាតិអ៊ីស្រាអែល ត្រូវតែនិយាយទៅកាន់ព្រះអម្ចាស់
នៅពេលព្រះអង្គប្រទានចំណែកមួយភាគដប់ដល់ជនក្រីក្រ។
ទូលបង្គំមិនបានបរិភោគតង្វាយមួយភាគដប់
«ខ្ញុំមិនបានបរិភោគមួយភាគក្នុងដប់ នៅពេលខ្ញុំបានកំពុងកាន់ទុក្ខ»
សម្រាប់ការអ្វីដែលមិនបរិសុទ្ធ
នៅទីនេះ «មិនបរិសុទ្ធ» មានន័យថា មនុស្សនោះមិនស្អាតយោងតាមច្បាប់។
ព្រះជាម្ចាស់មិនអនុញ្ញាតឱ្យមនុស្សមិនស្អាតប៉ះពាល់តង្វាយមួយភាគដប់
ដែលគាត់កំពុងថ្វាយដល់ព្រះជាម្ចាស់ឡើយ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «នៅពេលខ្ញុំមិនស្អាតយោងតាមច្បាប់។» ឬ
«នៅពេលដែលច្បាប់និយាយថាខ្ញុំមិនអាចប៉ះវាបាន»
ទូលបង្គំបានស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះនៃទូលបង្គំ
ហើយទូលបង្គំបានធ្វើតាមបទបញ្ជាទាំងប៉ុន្មាន ដែលព្រះអង្គបានបង្គាប់មកទូលបង្គំ។
នេះជា «សំឡេងរបស់ព្រះអម្ចាស់» ជាឃ្លាម្រាប់អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។
សេចក្តីថ្លែងការណ៍ទាំងពីរមានអត្ថន័យស្រដៀងគ្នា។ ពួកគេបញ្ជាក់ថា
មនុស្សនោះបានគោរពតាមបទបញ្ជាទាំងអស់របស់ព្រះជាម្ចាស់។
ពីស្ថានបរមសុខ ជាព្រះដំណាក់ដ៏បរិសុទ្ធ របស់ព្រះអង្គនៅស្ថានសួគ៌
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ការបកប្រែផ្សេងទៀត
«ពីស្ថានសួគ៌ជាកន្លែងដ៏បរិសុទ្ធរបស់ព្រះអង្គ»
គឺទឹកដីដ៏សម្បូរសប្បាយនេះ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ សូមមើលការបកប្រែនៅក្នុង ៦:៣។
ការបកប្រែផ្សេងទៀត «ទឹកដីដែលមានទឹកដោះនិងទឹកឃ្មុំហូរច្រើន» ឬ
«ដីល្អសម្រាប់សត្វនិងកសិកម្ម»
Deuteronomy 26:16
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ឲ្យអស់ពីចិត្ត អស់ពីព្រលឹងរបស់អ្នករាល់គ្នា។
ឃ្លា «អស់ពី ... ចិត្ត»មានន័យថា «ទាំងស្រុង» និង «អស់ពី ... ព្រលឹង»
មានន័យថា «អស់ពីខ្លួន»។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ការបកប្រែផ្សេងទៀត «អស់ពីសមត្ថភាពរបស់អ្នករាល់គ្នា» ឬ
«អស់ពីថាមពលទាំងអស់របស់អ្នករាល់គ្នា»។ បកប្រែនៅក្នុង ៤:២៩។
និងដើរតាមផ្លូវរបស់ព្រះអង្គ ព្រមទាំងកាន់តាមបញ្ញត្តិ គោរពច្បាប់ និងបទបញ្ជារបស់ព្រះអង្គ
ព្រមទាំងស្តាប់បង្គាប់ព្រះអង្គទៀតផង។
ពាក្យថា «ដើរ» «រក្សា» និង«ស្តាប់» មានអត្ថន័យស្រដៀងគ្នានៅទីនេះ។ នៅទីនេះ
«សំឡេង» សំដៅទៅលើអ្វីដែលព្រះជាម្ចាស់មានបន្ទូល។ ការបកប្រែផ្សេងទៀត
«អ្នកនឹងស្តាប់បង្គាប់ទាំងស្រុងនូវអ្វីៗទាំងអស់ ដែលព្រះអម្ចាស់បញ្ជារ»
Deuteronomy 26:18
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
អ្នករាល់គ្នាជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់
«ប្រជាជនដែលជាកម្មសិទ្ធិរបស់ព្រះអង្គ»
ព្រះអង្គនឹងឲ្យអ្នករាល់គ្នាក្លាយទៅ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គនឹងធ្វើឱ្យអ្នករាល់គ្នាសំខាន់ជាង» ឬ «ព្រះអង្គនឹងធ្វើឱ្យអ្នករាល់គ្នាធំជាង»
ព្រះអង្គនឹងឲ្យអ្នករាល់គ្នាក្លាយទៅជាប្រជាជាតិមួយ មានកិត្តិយស កេរ្តិ៍ឈ្មោះ
អាចមានន័យថា ១)«
ព្រះអង្គនឹងធ្វើឱ្យអ្នករាល់គ្នាក្លាយជាប្រជាជាតិមួយដ៏ធំជាងប្រជាជាតិដទៃទៀត
ដែលព្រះអង្គបានបង្កើតឡើង ហើយព្រះអង្គនឹងអាចឱ្យអ្នករាល់គ្នាសរសើរព្រះអង្គ
និងផ្តល់កិត្តិយសដល់ព្រះអង្គ» ឬ ២)«
ព្រះអង្គនឹងមានប្រជារាស្ត្រសរសើរព្រះអង្គច្រើនជាងពួកគេសរសើរដល់ប្រជាជាតិទាំងអស់
ដែលព្រះអង្គបានបង្កើតមក
ប្រជាជននឹងនិយាយថាព្រះអង្គគឺប្រសើរជាងប្រជាជាតិមួយផ្សេងទៀត
ហើយពួកគេនឹងផ្តល់កិត្តិយសដល់ព្រះអង្គ ។
ដើម្បីឲ្យអ្នករាល់គ្នាបានធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធសម្រាប់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ព្រះអម្ចាស់បានជ្រើសរើសជនជាតិអ៊ីស្រាអែល
ឱ្យធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គតាមរបៀបដ៏ពិសេសមួយ
គឺដូចជាព្រះអម្ចាស់បានញែកពួកគេចេញពីប្រជាជាតិនានា។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងធ្វើឱ្យអ្នករាល់គ្នាឃ្លាតឆ្ងាយពីប្រជាជាតិដ៏ទៃ»

---

27 [1]លោកម៉ូសេ និងពួកចាស់ទុំនៃជនជាតិអ៊ីស្រាអែល បានបង្គាប់ប្រជាជនថា៖ «ចូរកាន់តាមបទបញ្ជាទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នានៅថ្ងៃនេះ។
[2]នៅថ្ងៃដែលអ្នករាល់គ្នាឆ្លងទន្លេយ័ដាន់ ចូលទៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យ ចូរបញ្ឈរថ្មធំៗឡើង ហើយលាបកំបោរពណ៌ស។
[3]ចូរចារឹកអស់ទាំងពាក្យក្នុងក្រឹត្យវិន័យនេះនៅលើថ្មនោះ នៅពេលដែលអ្នករាល់គ្នាឆ្លងចូលទៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យ
គឺជាទឹកដីដែលសម្បូរសប្បាយ ដូចដែលព្រះអម្ចាស់ ជាព្រះនៃបុព្វបុរសរបស់អ្នករាល់គ្នាបានសន្យានឹងអ្នករាល់គ្នា។
[4]ពេលណាដែលអ្នករាល់គ្នាបានឆ្លងទន្លេយ័ដាន់រួចហើយ ចូរបញ្ឈរថ្មដែលខ្ញុំបានបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ នៅលើភ្នំអេបាល ហើយលាបកំបោរពណ៌សផង។[5]បន្ទាប់មក
អ្នករាល់គ្នាត្រូវសង់អាសនៈមួយដើម្បីថ្វាយព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាជាអាសនៈដែលធ្វើពីថ្ម ប៉ុន្តែ មិនត្រូវយកដែលពន្លាកទៅដាប់ថ្មនោះឡើយ។
[6]ត្រូវសង់អាសនៈមួយថ្វាយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាគឺជាថ្មដែលមិនទាន់ដាប់ ហើយថ្វាយតង្វាយដុតដល់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
[7]ត្រូវថ្វាយយញ្ញបូជាជាតង្វាយមេត្រី ហើយត្រូវបរិភោគនៅកន្លែងនោះ ហើយត្រូវអរសប្បាយនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
[8]ត្រូវចារឹកអស់ទាំងពាក្យក្នុងក្រឹត្យវិន័យនេះ នៅលើថ្មឲ្យច្បាស់ៗ»។
[9]បន្ទាប់មក លោកម៉ូសេ ពួកបូជាចារ្យ និងពួកលេវី បានថ្លែងទៅកាន់ប្រជាជនអ៊ីស្រាអែលទាំងអស់ថា៖ «ឱអ៊ីស្រាអែលអើយ ចូរស្ងៀមស្ងាត់ ហើយស្តាប់ចុះ
ថ្ងៃនេះអ្នករាល់គ្នាបានក្លាយទៅជាប្រជារាស្ត្ររបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។[10]ដូច្នេះ ត្រូវតែស្តាប់បង្គាប់ព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នាហើយប្រតិបត្តិតាមបទបញ្ជា និងច្បាប់របស់ព្រះអង្គ ដែលខ្ញុំបង្គាប់ដល់អ្នករាល់គ្នានៅថ្ងៃនេះ»។
[11]លោកម៉ូសេបានបង្គាប់ប្រជាជន នៅថ្ងៃដដែលនោះថា៖[12]«អំបូរទាំងនោះត្រូវឈរនៅលើភ្នំការិស៊ីម ដើម្បីប្រកាសអំពីព្រះពរដល់ប្រជាជន
បន្ទាប់ពីពួកគេបានឆ្លងទន្លេយ័ដាន់រួចហើយ គឺកុលសម្ព័ន្ធស៊ីម្មាន លេវី យូដា អ៊ីុសាខារ យ៉ូសែប និងបេនយ៉ាមីន។

generated on Wed Sep 10 16:16:32 2025

[13]ក៏មានអំបូរដែលត្រូវឈរនៅលើភ្នំអេបាល ដើម្បីប្រកាសអំពីបណ្តាសា គឺមានកុលសម្ព័ន្ធរូបេន កាដ អេស៊ើរ សាប់យូឡូន ដាន់ និងណែបថាលី។[14]បន្ទាប់មក
ពួកលេវីត្រូវប្រកាសយ៉ាងខ្លាំង ប្រាប់ប្រជាជនអ៊ីស្រាអែលទាំងអស់គ្នាថា
[15]ត្រូវដាក់បណ្តាសាអ្នកណាដែលឆ្លាក់រូបបដិមា ឬសិតធ្វើរូបព្រះក្លែងក្លាយ ដែលជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់ ហើយយករូបដែលជាស្នាដៃរបស់មនុស្ស
រួចយកទៅដាក់នៅកន្លែងសម្ងាត់ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។
[16]ត្រូវបណ្តាសាហើយ អ្នកណាដែលប្រមាថមើលងាយឪពុកម្តាយរបស់ខ្លួន។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។[17]ត្រូវបណ្តាសាហើយ
អ្នកណាដែលបង្ខិតបង្គោលរបងចូលទៅក្នុងដីធ្លីរបស់អ្នកជិតខាងខ្លួន។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។
[18]ត្រូវបណ្តាសាហើយ អ្នកណាដែលធ្វើឲ្យមនុស្សខ្វាក់ដើរខុសផ្លូវ។ នោះប្រជានជទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។[19]ត្រូវបណ្តាសាហើយ
អ្នកណាដែលរំលោភបំពានសេចក្តីយុត្តិធម៌ លើជនបរទេស ក្មេងកំព្រា និងស្ត្រីមេម៉ាយ។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។
[20]ត្រូវបណ្តាសាហើយ អ្នកណាដែលរួមដំណេកជាមួយប្រពន្ធចុងរបស់ឪពុកខ្លួន ព្រោះគេបានប្រមាថកិត្តិយសរបស់ឪពុកខ្លួន។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា
អាមែន។[21]ត្រូវបណ្តាសាហើយ អ្នកណាដែលរួមដំណេកជាមួយសត្វណាមួយ។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។
[22]ត្រូវបណ្តាសាហើយ អ្នកណាដែលរួមដំណេកជាមួយបងប្អូនស្រី ជាកូនរបស់ឪពុក ឬម្តាយតែមួយ។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។
[23]ត្រូវបណ្តាសាហើយ អ្នកណាដែលរួមដំណេកជាមួយម្តាយក្មេករបស់ខ្លួន។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។
[24]ត្រូវបណ្តាសាហើយ អ្នកណាដែលលួចប្រហារជីវិតអ្នកជិតខាងរបស់ខ្លួន។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។[25]ត្រូវបណ្តាសាហើយ
អ្នកណាដែលស៊ីសំណូកដើម្បីសម្លាប់ជនស្លូតត្រង់។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។
[26]ត្រូវបណ្តាសាហើយ អ្នកណាដែលមិនគោរពសេចក្តីដែលមានចែងទុកក្នុងក្រឹត្យវិន័យនេះ ហើយមិនប្រព្រឹត្តតាម។ នោះប្រជាជនទាំងអស់ត្រូវឆ្លើយព្រមគ្នាថា អាមែន។

Deuteronomy 27:1

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

បានបង្គាប់មកអ្នករាល់គ្នានៅថ្ងៃនេះ ... អ្នករាល់គ្នាឆ្លង

លោកម៉ូសេកំពុងនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលជាក្រុម ដូច្នេះឧទាហរណ៍ទាំងពីរនៃពាក្យថា« អ្នក» ជាពហុវចនៈ។

ខ្ញុំបានបង្គាប់

នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកម៉ូសេ។ ពួកចាស់ទុំនៅទីនោះយល់ស្របនឹងលោកម៉ូសេ ប៉ុន្តែ គាត់ជាមនុស្សតែម្នាក់គត់ដែលនិយាយ។

ហើយលាបកំបោរពណ៌ស

កំបោរជាទូទៅគឺជាល្បាយនៃកំបោរអរ និងទឹកដែលត្រូវបានលាបទៅលើអ្វីមួយ។ វាស្អួតដើម្បីបង្កើតជាផ្ទៃរឹងនិងរលោងដែលមនុស្សម្នាក់អាចសរសេរបាន។ ការបកប្រែផ្សេងទៀត «លាបកំបោរលើពួកវា» ឬ «ធ្វើឱ្យអ្នកអាចសរសេរនៅលើវា»

គឺជាទឹកដីដែលសម្បូរសប្បាយ

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ សូមមើលការបកប្រែនៅក្នុង ៦:៣។ ការបកប្រែផ្សេងទៀត «ទឹកដីដែលមានទឹកដោះនិងទឹកឃ្មុំហូរច្រើន» ឬ« ដីល្អសម្រាប់សត្វនិងការធ្វើស្រែចម្ការ»

Deuteronomy 27:4

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ពេលណាដែលអ្នករាល់គ្នាបានឆ្លង ... ចូរបញ្ជរ ... ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា

លោកម៉ូសេកំពុងនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ជាក្រុម ដូច្នេះ រាល់ពាក្យ «អ្នក» និងពាក្យបង្គាប់ «ចូរបញ្ជរ» ជាពហុវចនៈ។

ហើយលាបកំបោរពណ៌សផង។

«លាបកំបោរលើពួកវា» ឬ «ធ្វើឲ្យអ្នកអាចសរសេរនៅលើវា» ។ បកប្រែដូចនៅក្នុង ២៧:១។

ភ្នំអេបាល

នេះជាភ្នំនៅជិតស៊ីគែម។ សូមមើលការបកប្រែនៅក្នុង ១១:២៩។

មិនត្រូវយកដែកពន្លាកទៅដាប់ថ្មនោះឡើយ។

សំដៅទៅលើកំណាត់ដែលធ្វើឱ្យថ្មរលោង ដើម្បីឱ្យវាអាចដាក់ជាមួយគ្នាបានល្អជាង។ អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត «អ្នកនឹងមិនត្រូវដាប់ថ្មអាសនៈដោយប្រើឧបករណ៍ធ្វើពីដែកទេ»

Deuteronomy 27:6

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

គឺជាថ្មដែលមិនទាន់ដាប់ថ្មមានរាងធម្មតា ដែលគ្មាននរណាម្នាក់បានដុសខាត់ដោយប្រើឧបករណ៍ដែកទេ។

ត្រូវចារឹកនៅលើថ្ម

សំដៅទៅលើថ្ម ដែលពួកគេបានបញ្ជរនៅលើភ្នំអេបាលនិងលាបកំបោរ។ សូមមើលការបកប្រែនៅក្នុង ២៧:១ និង២៧:៤)

Deuteronomy 27:9

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ត្រូវតែស្តាប់បង្គាប់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា

នៅទីនេះឃ្លាថា«សំឡេងរបស់ព្រះអម្ចាស់» សំដៅទៅលើអ្វីដែលព្រះអង្គមានបន្ទូល។ ការបកប្រែផ្សេងទៀត «ស្តាប់បង្គាប់តាមអ្វី ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា មានបន្ទូល»

ខ្ញុំបង្គាប់

លោកម៉ូសេកំពុងបង្គាប់។ ពួកលេវីយល់ស្របនឹងលោកម៉ូសេ ប៉ុន្តែមានតែលោកប៉ុណ្ណោះដែលនិយាយ។

Deuteronomy 27:11

អំបូរទាំងនោះ

នៅទីនេះឃ្លា« អំបូរ» ដែលសំដៅទៅលើប្រជាជនមកពីអំបូរស៊ីម្មាន លេវី យូដា អ៊ីសាខារ យ៉ូសែបនិងបេនយ៉ាមីន។ ការបកប្រែផ្សេងទៀត «ប្រជាជនមកពីអំបូរទាំងនេះ»

ភ្នំការិស៊ីម

ភ្នំតូចមួយនៅខាងជើងភ្នំអេបាល។ បកប្រែដូចនៅក្នុង១១:២៩ ។

យ៉ូសែប

នេះរួមបញ្ចូលអំបូរ អេប្រាអ៊ីម និង ម៉ាណាសេ ដែលជាកូនចៅរបស់យ៉ូសែប។

Deuteronomy 27:13

ភ្នំអេបាល

បកប្រែដូចនៅក្នុង ១១:២៩ ។

ប្រកាសអំពីបណ្តាសា

«បន្លឺសំឡេងខ្លាំងៗតាមរបៀប ដែលព្រះអម្ចាស់នឹងដាក់បណ្តាសាអ៊ីស្រាអែល»

Deuteronomy 27:15

ត្រូវដាក់បណ្តាសាអ្នកណាដែល ...រួចយកទៅដាក់នៅកន្លែងសម្ងាត់

នេះជាសេចក្តីថ្លែងរបស់ពួកលេវី ដែលត្រូវស្រែកប្រាប់ប្រជាជនអ៊ីស្រាអែលទាំងអស់។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «សូមឱ្យព្រះអម្ចាស់ដាក់បណ្តាសាដល់មនុស្ស ... រួចចយកទៅដាក់នៅកន្លែងសម្ងាត់»

ដែលជាស្នាដៃរបស់មនុស្ស

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «អ្វីមួយដែលមនុស្សម្នាក់បានបង្កើត»

ជាស្នាដៃរបស់មនុស្ស

មនុស្សម្នាក់ដែលចេះធ្វើអ្វីៗឱ្យបានល្អ

Deuteronomy 27:16

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ពួកលេវីនិងប្រជាជននូវអ្វី ដែលពួកគេត្រូវនិយាយ។
ត្រូវបណ្តាសាហើយ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«សូមឱ្យព្រះអម្ចាស់ដាក់បណ្តាសារមនុស្សនោះ»
អ្នកណាដែលបង្ហិតបង្គោលរបងចូលទៅក្នុងដីធ្លីរបស់អ្នកជិតខាងខ្លួន។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «អ្នកណាដែលយកដីពីអ្នកជិតខាងបង្ហិតបង្គោលរបង
នៅតាមព្រំប្រទល់ដីរបស់គាត់»
Deuteronomy 27:18
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ពួកលេវី និងប្រជាជននូវអ្វីដែលពួកគេត្រូវនិយាយ។
ត្រូវបណ្តាសាហើយ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ សូមមើលការបកប្រែនៅក្នុង ២៧:១៦ ។
ការបកប្រែផ្សេងទៀត «សូមឱ្យព្រះអម្ចាស់ដាក់បណ្តាសាមនុស្សនោះ»
អ្នកណាដែលរំលោភបំពានសេចក្តីយុត្តិធម៌ លើជនបរទេស ... ស្ត្រីមេម៉ាយ។
លោកម៉ូសេនិយាយអំពីយុត្តិធម៌ដូចជាវត្ថុ
ដែលមនុស្សខ្លាំងពូកែអាចដកចេញពីមនុស្សទន់ខ្សោយបាន។
ភាសារបស់អ្នកអាចមានមួយពាក្យដែលមានន័យថា« ប្រើកម្លាំងដើម្បីដកយក»។
ពាក្យស្រដៀងគ្នានេះមាននៅក្នុង ២៤:១៧ ។ ការបកប្រែផ្សេងទៀត
«ធ្វើបាបជនបរទេស...ស្ត្រីមេម៉ាយដោយអយុត្តិធម៌»
ក្មេងកំព្រា
ទាំងនេះជាក្មេងកំព្រា ដែលឪពុកម្តាយបានស្លាប់
ហើយមិនមានសាច់ញាតិមើលថែពួកគេទេ។
ស្ត្រីមេម៉ាយ
មានន័យថា ស្ត្រីដែលប្តីរបស់នាងបានស្លាប់
ហើយគ្មានកូនមើលថែនាងក្នុងអាយុចាស់ទេ។
Deuteronomy 27:20
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ពួកលេវីនិងប្រជាជននូវអ្វីដែលពួកគេត្រូវនិយាយ។
ត្រូវបណ្តាសាហើយ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ សូមមើលការបកប្រែនៅក្នុង ២៧:១៦ ។
ការបកប្រែផ្សេងទៀត «សូមឱ្យព្រះអម្ចាស់ដាក់បណ្តាសាមនុស្សនោះ»
ជាមួយប្រពន្ធចុងរបស់ឪពុកខ្លួន
នេះមិនសំដៅទៅលើម្តាយរបស់បុរសនោះទេ ប៉ុន្តែ
ជាភរិយាផ្សេងទៀតរបស់ឪពុកគាត់។
គេបានប្រមាថកិត្តិយសរបស់ឪពុកខ្លួន។
នៅពេលបុរសរៀបការជាមួយស្ត្រី
មានតែគាត់ប៉ុណ្ណោះដែលមានសិទ្ធិស្របច្បាប់ក្នុងការរួមដំណេកជាមួយនាង។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «គាត់បានដកសិទ្ធិស្របច្បាប់របស់ឪពុកគាត់»
អ្នកណាដែលរួមដំណេកជាមួយសត្វណាមួយ។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះ អាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត «ដែលដេកជាមួយសត្វគ្រប់ប្រភេទតាមរបៀប
ដែលបុរសរួមដំណេកជាមួយស្ត្រី»
Deuteronomy 27:22
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ពួកលេវី និងប្រជាជននូវអ្វីដែលពួកគេត្រូវនិយាយ។
ត្រូវបណ្តាសាហើយ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ សូមមើលការបកប្រែនៅក្នុង ២៧:១៦ ។
ការបកប្រែផ្សេងទៀត «សូមឱ្យព្រះអម្ចាស់ដាក់បណ្តាសាមនុស្សនោះ»
ជាកូនរបស់ឪពុក ឬម្តាយតែមួយ។
មានន័យថា មនុស្សមិនអាចរួមដំណេកជាមួយប្អូនស្រីរបស់គាត់បានទេ
ទោះបីនាងមានម្តាយ ឬឪពុកផ្សេងក៏ដោយ។
Deuteronomy 27:24
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ពួកលេវី និងប្រជាជននូវអ្វីដែលពួកគេត្រូវនិយាយ។
ត្រូវបណ្តាសាហើយ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ សូមមើលការបកប្រែនៅក្នុង ២៧:១៦។
ការបកប្រែផ្សេងទៀត «សូមឱ្យព្រះអម្ចាស់ដាក់បណ្តាសាមនុស្សនោះ»
Deuteronomy 27:26
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តប្រាប់ពួកលេវី និងប្រជាជននូវអ្វីដែលពួកគេត្រូវនិយាយ។
ត្រូវបណ្តាសាហើយ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ សូមមើលការបកប្រែនៅក្នុង ២៧:១៦។
ការបកប្រែផ្សេងទៀត « សូមឱ្យព្រះអម្ចាស់ដាក់បណ្តាសារមនុស្សនោះ»

---

28 [1]ប្រសិនបើ អ្នករាល់គ្នាយកចិត្តទុកដាក់ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាដោយកាន់ និងប្រព្រឹត្តតាមបទបញ្ជា
ដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ នោះព្រអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងលើកអ្នករាល់គ្នាខ្ពស់ឡើងលើសអស់ទាំងប្រជាជាតិនៅលើផែនដី។
[2]ព្រះពរទាំងអស់នេះនឹងធ្លាក់មកលើអ្នករាល់គ្នា ប្រសិនបើ អ្នករាល់គ្នាស្តាប់តាមព្រះបន្ទូលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[3]ព្រអង្គនឹងប្រទានពរដល់អ្នករាល់គ្នានៅតាមទីក្រុង ហើយនឹងមានពរនៅតាមស្រែចម្ការ។[4]ព្រះអង្គនឹងប្រទានពរឲ្យអ្នករាល់គ្នាមានកូនចៅច្រើន
ហើយឲ្យដីរបស់អ្នករាល់គ្នាកើតភោគផលច្រើនហូរហៀរ ហើយហ្វូងសត្វរបស់អ្នករាល់គ្នាគឺគោ និងចៀមក៏កើនចំនួនឡើងជាច្រើនដែរ។
[5]ព្រះអង្គនឹងប្រទានពរឲ្យអ្នករាល់គ្នាមានផ្លែឈើពេញកន្ត្រក់ និងមានស្រូវពេញជង្រុក។[6]ព្រះអង្គនឹងប្រទានពរក្នុងកាលដែលអ្នករាល់គ្នាចូលមក
ហើយនឹងមានពរក្នុងគ្រប់កិច្ចការដែលអ្នករាល់គ្នាធ្វើ។
[7]ព្រះអម្ចាស់នឹងធ្វើឲ្យខ្មាំងសត្រូវដែលលើកគ្នាមកទាស់នឹងអ្នករាល់គ្នា ហើយត្រូវចុះចាញ់នៅមុខអ្នករាល់គ្នា គេនឹងចេញមកទាស់នឹងអ្នករាល់គ្នានៅតាមផ្លូវតែមួយ ប៉ុន្តែ
ពួកគេនឹងរត់នៅមុខអ្នករាល់គ្នា នៅតាមផ្លូវប្រាំពីរ។[8]ព្រះអម្ចាស់នឹងប្រទានពរអ្នករាល់គ្នាឲ្យមានស្រូវពេញជង្រុក និងប្រទានពរក្នុងគ្រប់កិច្ចការដែលអ្នករាល់គ្នាបានធ្វើ
ព្រះអម្ចាស់នឹងប្រទានពរអ្នករាល់គ្នា ក្នុងទឹកដីដែលព្រះអង្គប្រទានឲ្យអ្នករាល់គ្នា។
[9]ព្រះអម្ចាស់នឹងធ្វើឲ្យអ្នករាល់គ្នាទៅជាប្រជារាស្ត្រដ៏វិសុទ្ធ ដូចដែលព្រះអង្គបានសន្យានឹងអ្នករាល់គ្នា ប្រសិនបើ អ្នករាល់គ្នាប្រតិបត្តិតាមអស់ទាំងបទបញ្ជារបស់ព្រះអម្ចាស់
ជាព្រះរបស់អ្នករាល់គ្នា ហើយដើរតាមផ្លូវរបស់ព្រះអង្គ។[10]ពេលនោះ គ្រប់ទាំងមនុស្សដែលនៅលើផែនដីនឹងឃើញថា
ព្រះអង្គបានជ្រើសរើសអ្នករាល់គ្នាជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ ហើយពួកគេនឹងកោតខ្លាចអ្នករាល់គ្នា។
[11]ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងចម្រើនឲ្យអ្នករាល់គ្នាមានជាបរិបូរឡើង មានកូនចៅជាច្រើន និងហ្វូងសត្វរបស់អ្នករាល់គ្នាក៏កើនចំនួនច្រើនឡើង
ហើយកធ្វើឲ្យអ្នករាល់គ្នាទទួលភោគផលជាច្រើន នៅលើទឹកដីដែលព្រះអម្ចាស់ បានសន្យាដល់បុព្វបុរសរបស់អ្នករាល់គ្នាថា នឹងប្រទានឲ្យដល់អ្នករាល់គ្នា។
[12]ព្រះអម្ចាស់នឹងបើកផ្ទៃមេឃ ឲ្យមានភ្លៀងធ្លាក់ចុះមកស្រោចស្រពទឹកដីរបស់អ្នករាល់គ្នា តាមរដូវកាល ហើយប្រទានពរដល់កិច្ចការទាំងប៉ុន្មានដែលអ្នករាល់គ្នាធ្វើ
អ្នករាល់គ្នានឹងឲ្យប្រជាជាតិជាច្រើនខ្ចី តែអ្នករាល់គ្នានឹងមិនខ្ចីពីគេឡើយ។
[13]ព្រះអម្ចាស់ នឹងធ្វើឲ្យអ្នករាល់គ្នាបានថ្កុំថ្កើងជាងគេ គឺមិនមែនអន់ជាងគេទេ អ្នករាល់គ្នានឹងទទួលកិត្តិយសខ្ពង់ខ្ពស់ជានិច្ច ប្រសិនបើ
អ្នករាល់គ្នាស្តាប់តាមបទបញ្ជារបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ដែលខ្ញុំបង្គាប់ដល់អ្នករាល់គ្នានៅថ្ងៃនេះ ដោយប្រុងប្រយ័ត្ន និងប្រតិបត្តិតាម[14]មិនត្រូវងាកទៅឆ្វេង
ឬទៅស្តាំ ចេញពីព្រះបន្ទូលណាមួយ ដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នានៅថ្ងៃនេះ ហើយបែរទៅតាមព្រះដទៃ និងគោរពថ្វាយបង្គំព្រះដ៏ទៃទៀតឡើយ។
[15]ប៉ុន្តែ ប្រសិនបើ អ្នករាល់គ្នាមិនស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
ហើយមិនកាន់នឹងប្រព្រឹត្តតាមអស់ទាំងបទបញ្ជាដែលខ្ញុំបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះទេ នោះអស់ទាំងបណ្តាសានេះ
និងធ្លាក់មកលើអ្នករាល់គ្នាហើយនៅតាមអ្នករាល់គ្នាជាប់។
[16]អ្នករាល់គ្នានឹងត្រូវបណ្តាសានៅតាមទីក្រុង ហើយនឹងត្រូវបណ្តាសានៅតាមស្រែចម្ការ។[17]អ្នករាល់គ្នានឹងត្រូវបណ្តាសាដោយគ្មានផ្លែឈើនៅក្នុងល្ពី
និងគ្មានស្រូវនៅក្នុងជង្រុក។

generated on Wed Sep 10 16:16:32 2025

[18]អ្នករាល់គ្នានឹងត្រូវបណ្តាសាដោយគ្មានកូនចៅ ដីរបស់អ្នករាល់គ្នានឹងមិនបង្កើតភោគផល ហ្វូងគោ និងហ្វូងចៀមរបស់អ្នករាល់គ្នាក៏មិនកើនចំនួនដែរ។
[19]អ្នករាល់គ្នានឹងត្រូវបណ្តាសាក្នុងគ្រប់កិច្ចការដែលអ្នករាល់គ្នាធ្វើ។
[20]ព្រះអម្ចាស់នឹងដាក់បណ្តាសាអ្នករាល់គ្នាឲ្យជួបប្រទះទុក្ខវេទនា និងសេចក្តីថប់ព្រួយមកលើអ្នករាល់គ្នា ហើយអ្វីៗដែលអ្នករាល់គ្នាធ្វើនឹងត្រូវខូចបង់
រហូតទាល់តែអ្នករាល់គ្នាត្រូវវិនាសសូន្យ ដោយព្រោះតែអំពើអាក្រក់ដែលអ្នករាល់គ្នាបានប្រព្រឹត្ត ដែលអ្នកបានបោះបង់ចោលព្រះអង្គ។
[21]ព្រះអង្គនឹងធ្វើឲ្យមានគ្រោះកាចកើតឡើងដល់អ្នករាល់គ្នារហូតដល់អ្នករាល់គ្នាវិនាសសាបសូន្យពីទឹកដីដែលអ្នករាល់គ្នាចូលទៅកាន់កាប់។
[22]ព្រះអម្ចាស់នឹងប្រហារអ្នករាល់គ្នាដោយជំងឺរាតត្បាត ជំងឺគ្រុនក្តៅ កើតពិស និងកើតមានការរាំងស្ងួតស្រូវស្កក ហើយមានក្រាស៊ី
ទុក្ខវេទនានេះនឹងកើតមានដល់អ្នករាល់គ្នា រហូតទាល់តែអ្នករាល់គ្នាវិនាស។
[23]មេឃដែលនៅលើពីអ្នករាល់គ្នានឹងក្តៅដូចជាលង្ហិន ហើយដីដែលនៅពីក្រោមអ្នករាល់គ្នានឹងរឹងដូចដែក។[24]ព្រះអម្ចាស់នឹងធ្វើឲ្យធូលីដី ព្រមទាំងផេះធ្លាក់ពីលើមេឃ
មកលើទឹកដីរបស់អ្នករាល់គ្នាជំនួសភ្លៀង រហូតទាល់តែអ្នករាល់គ្នាវិនាស។
[25]ព្រះអម្ចាស់នឹងធ្វើឲ្យអ្នករាល់គ្នាបាន់ទ័ព រត់នៅមុខខ្មាំងសត្រូវ អ្នករាល់គ្នានឹងចេញទៅទាស់នឹងគេតាផ្លូវតែមួយ តែអ្នករាល់គ្នានឹងរត់នៅមុខពួកគេ តាមផ្លូវប្រាំពីរ។
ហើយនរគទាំងប៉ុន្មានដែលនៅលើផែនដីឮដំណឹងនេះ គេនឹងនាំគ្នាភ័យខ្លាច។[26]សាកសពរបស់អ្នករាល់គ្នានឹងក្លាយទៅជាចំណីដល់សត្វស្លាបហើរនៅលើអាកាស
និងសត្វព្រៃ ហើយគ្មាននរណាមកដេញពួកវាឡើយ។
[27]ព្រះអម្ចាស់នឹងវាយប្រហារអ្នករាល់គ្នាដោយបូស ដែលកើតនៅក្នុងទឹកដីអេស៊ីប ដោយរោគឫដូងបាត កមរមាស់ ដែលមិនអាចមើលជាឡើយ។
[28]ព្រះអម្ចាស់នឹងវាយប្រហារអ្នករាល់គ្នាឲ្យវង្វេងស្មារតី ឲ្យពិការភ្នែក ហើយនឹងវិកលចរិត។[29]អ្នករាល់គ្នានឹងដើរស្ទាបនៅពេលថ្ងៃត្រង់
ដូចមនុស្សខ្វាក់ដើរស្ទាបរាវរកផ្លូវនៅទីងងឹត ហើយអ្នករាល់គ្នាមិនអាចសម្រេចតាមផែនការដែលអ្នករាល់គ្នារៀបចំឡើយ អ្នករាល់គ្នានឹងត្រូវគេជិះជាន់
ឬរឹបអូសយកទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា រៀងរាល់ថ្ងៃ ហើយគ្មាននរណាមកជួយអ្នករាល់គ្នាឡើយ។
[30]ពេលអ្នករាល់គ្នាមានគូរដណ្តឹង តែនឹងមានបុរសម្នាក់ទៀតរួមដំណេកជាមួយនាង។ អ្នករាល់គ្នានឹងសង់ផ្ទះ តែអ្នកដែលមិនបានសង់នឹងបានរស់នៅក្នុងផ្ទះនោះវិញ
ពេលអ្នករាល់គ្នាដាំផ្លែទំពាំងបាយជូរ តែអ្នករាល់គ្នាមិនបានបរិភោគផលឡើយ។[31]គេនឹងសម្លាប់គោរបស់អ្នករាល់គ្នា នៅចំពោះមុខអ្នករាល់គ្នា
តែអ្នកមិនបានបរិភោគសាច់ឡើយ គេនឹងរឹបអូសយកលារបស់អ្នករាល់គ្នា នៅចំពោះមុខអ្នករាល់គ្នា តែគេមិនបានប្រគល់មកអ្នករាល់គ្នាវិញឡើយ។
គេនឹងប្រគល់ហ្វូងចៀមរបស់អ្នករាល់គ្នា ទៅខ្មាំងសត្រូវ តែគ្មាននរណាមកជួយអ្នករាល់គ្នាឡើយ។
[32]គេនឹងលក់កូនប្រុសកូនស្រីរបស់អ្នករាល់គ្នាឲ្យទៅសាសន៍ដទៃ ហើយអ្នករាល់គ្នានឹងទន្ទឹងរង់ចាំគេត្រឡប់មកវិញ រហូតដល់ស្រវាំងភ្នែក
តែអ្នករាល់គ្នាមិនអាចសម្រេចដូចប្រាថ្នាឡើយ។
[33]ប្រជាជាតិមួយដែលអ្នករាល់គ្នាមិនស្គាល់ ហើយគេនឹងបរិភោគដំណាំដោយដុះចេញពីដីរបស់អ្នករាល់គ្នា
គឺភោគផលទាំងប៉ុន្មានដែលអ្នករាល់គ្នាខំប្រឹងធ្វើដោយនឿយហត់ ហើយអ្នករាល់គ្នានឹងត្រូវគេសង្កត់សង្កិន និងជិះជាន់ជារៀងរាល់ថ្ងៃ[34]ដើម្បីឲ្យអ្នករាល់គ្នាឃើញនឹងភ្នែក
ដល់ម្លេះបានជាអ្នករាល់គ្នាវង្វេងស្មារតី។[35]ព្រះអម្ចាស់នឹងវាយប្រហារអ្នករាល់គ្នាឲ្យកើតដំបៅរីកនៅក្បាលជង្គង់ នៅត្រង់ជើង ហើយអ្នករាល់គ្នាមិនអាចមើលជាបានឡើយ
ចាប់ពីបាតជើងរហូតដល់ក្បាល។
[36]ព្រះអម្ចាស់នឹងនាំអ្នករាល់គ្នា ស្តេចដែលអ្នករាល់គ្នាតាំងឡើងឲ្យសោយរាជ្យលើអ្នករាល់គ្នា ទៅកាន់សាសន៍មួយ ដែលអ្នករាល់គ្នា
និងដូនតារបស់អ្នករាល់គ្នាមិនដែលបានស្គាល់ នៅទឹកដីនោះ អ្នករាល់គ្នានឹងគោរពបម្រើព្រះដទៃ ដែលគេធ្វើពីឈើ និងពីថ្ម។[37]អ្នករាល់គ្នានឹងនាំគ្នាភ្ញាក់ផ្អើល
ហើយយករឿងរបស់អ្នករាល់គ្នាទៅនិទានប្រាប់គ្នា ព្រមទាំងប្រមាថមាក់ងាយអ្នករាល់គ្នា ក្នុងចំណោមអស់ទាំងមនុស្សដែលព្រះអម្ចាស់នាំអ្នករាល់គ្នាចេញ។
[38]អ្នករាល់គ្នានឹងនាំយកគ្រាប់ពូជជាច្រើននៅព្រោះក្នុងស្រែរបស់អ្នករាល់គ្នា តែអ្នករាល់គ្នានឹងច្រូតបានផលបន្តិចបន្តួច នឹងមានកណ្តូបស៊ីបំផ្លាញអស់។
[39]អ្នករាល់គ្នានឹងដាំទំពាំងបាយជូរនៅក្នុងស្រែចម្ការ ហើយខំមើលថែទាំ ប៉ុន្តែ អ្នករាល់គ្នាមិនអាចបេះផ្លែ ឬផឹកស្រាទំពាំងបាយជូរឡើយ ដ្បិត
មានដង្កូវស៊ីផ្លែទំពាំងបាយជូរនោះអស់។
[40]អ្នករាល់គ្នានឹងមានដើមអូលីវ នៅពាសពេញទឹកដីរបស់អ្នករាល់គ្នា ប៉ុន្តែ អ្នករាល់គ្នានឹងមិនប្រេងសម្រាប់លាបខ្លួនឡើយ ដ្បិត ផ្លែអូលីវនឹងជ្រុះអស់។
[41]អ្នករាល់គ្នានឹងបង្កើតបានកូនប្រុសកូនស្រី តែពួកគេមិនបានរស់នៅជាមួយអ្នករាល់គ្នាឡើយ ព្រោះខ្មាំងសត្រូវនឹងនាំពួកគេទៅជាឈ្លើយ។
[42]អស់ទាំងដើមឈើ និងផលផ្លែដែលកើតពីដីរបស់អ្នករាល់គ្នា នោះនឹងត្រូវសត្វកណ្តូបស៊ីបង្ហិនអស់។
[43]ជនបរទេសដែលរស់នៅជាមួយអ្នករាល់គ្នានឹងមានអំណាចកាន់តែខ្លាំងឡើងៗលើអ្នករាល់គ្នា ហើយអ្នករាល់គ្នានឹងចុះខ្សោយកាន់តែទាបទៅៗ។[44]គេនឹងឲ្យអ្នករាល់គ្នាខ្ចី
តែអ្នករាល់គ្នាមិនបានឲ្យគេខ្ចីទេ គេនឹងបានខ្ពង់ខ្ពស់បំផុត ហើយអ្នករាល់គ្នាវិញអន់ជាងគេបំផុត។
[45]បណ្តាសាទាំងនេះនឹងធ្លាក់មកលើអ្នករាល់គ្នា ហើយនឹងនៅជាប់ជាមួយអ្នករាល់គ្នាជានិច្ច រហូតទាល់តែអ្នករាល់គ្នាវិនាស។
ព្រោះអ្នករាល់គ្នាមិនបានស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាឡើយ អ្នករាល់គ្នាមិនបានកាន់តាមបទបញ្ជា និងច្បាប់របស់ព្រះអង្គ
ដែលព្រះអង្គបានបង្គាប់អ្នកឡើយ។[46]បណ្តាសាទាំងនេះនឹងនៅជាប់ជាមួយអ្នករាល់គ្នា និងលើពូជពង្សរបស់អ្នករាល់គ្នាជាទីសម្គាល់ និងការអស្ចារ្យរហូតតទៅ។
[47]នៅពេលអ្វីៗទាំងអស់ដែលសម្បូរសប្បាយ ដោយព្រោះអ្នករាល់គ្នាមិនបានគោរពបម្រើព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាដោយចិត្តអរសប្បាយ
និងដោយស្មោះអស់ពីចិត្តឡើយ[48]ហេតុនេះ អ្នករាល់គ្នានឹងត្រូវបម្រើខ្មាំងសត្រូវ ដែលព្រះអម្ចាស់នឹងចាត់ឲ្យមកទាស់នឹងអ្នករាល់គ្នា
គឺអ្នករាល់គ្នានឹងបម្រើគេទាំងស្រេកឃ្លាន ទាំងអាក្រាត ហើយខ្វះខាតអ្វីៗទាំងអស់។ ព្រះអង្គនឹងដាក់នឹមដែកនៅលើកអ្នករាល់គ្នា រហូតទាល់តែអ្នករាល់គ្នាវិនាសសូន្យ។
[49]ព្រះអម្ចាស់នឹងនាំប្រជាជាតិមួយពីស្រុកឆ្ងាយ គឺពីចុងផែនដីមក ដូចជាសត្វឥន្ទ្រីហើរ មកប្រហារអ្នករាល់គ្នា
ហើយអ្នករាល់គ្នាស្តាប់ភាសារបស់ប្រជាជាតិនោះមិនបានទេ[50]ពួកគេមានទឹកមុខសាហាវ ហើយមិនគោរពចាស់ទុំ ហើយក៏គ្មានចិត្តមេត្តាដល់កូនក្មេងដែរ។
[51]ពួកគេនឹងបរិភោគសត្វ និងភោគផលដែលកើតមកពីដីរបស់អ្នករាល់គ្នា រហូតទាល់តែអ្នករាល់គ្នាវិនាសអស់។ ពួកគេមិនទុកឲ្យអ្នករាល់គ្នាមានស្រូវ
ឬស្រាទំពាំងបាយជូរថ្មី ប្រេង កូនគោ កូនចៀមឲ្យនៅសល់សម្រាប់អ្នកឡើយ រហូតទាល់តែគេធ្វើឲ្យអ្នករាល់គ្នាវិនាស។
[52]ពួកគេនឹងឡោមព័ទ្ធទីក្រុងរបស់អ្នករាល់គ្នាទាំងអស់ដែលអ្នករាល់គ្នារស់នៅ ពួកគេនឹងរលំកំពែងក្រុងដ៏ខ្ពស់ ហើយមាំនៅក្នុងទឹកដីរបស់អ្នករាល់គ្នា
ដែលកំពែងជាទីទុកចិត្តរបស់អ្នករាល់គ្នា។ គេនឹងឡោមព័ទ្ធទាំងអស់នៅក្នុងទីក្រុងរបស់អ្នករាល់គ្នា
ពាសពេញក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យអ្នករាល់គ្នា។[53]ក្នុងពេលសត្រូវឡោមព័ទ្ធអ្នកជុំវិញ អ្នករាល់គ្នានឹងរងទុក្ខវេទនាយ៉ាងខ្លាំង
រហូតដល់ស៊ីសាច់កូនរបស់ខ្លួន គឺកូនប្រុសកូនស្រីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាប្រទានឲ្យ។
[54]បុរសណាដែលមានចិត្តទន់ភ្លន់ជាងគេ ហើយមានចិត្តស្លូតបូតក្នុងចំណោមអ្នករាល់គ្នា អ្នកនោះបែរជាសម្លក់សម្លឹង បងប្អូន និងប្រពន្ធជាទីស្រឡាញ់របស់អ្នករាល់គ្នា
និងកូនរបស់ខ្លួនដែលនៅសេសសល់។[55]ដូច្នេះ គេមិនព្រមចែកសាច់កូនរបស់ខ្លួន ដែលកំពុងតែបរិភោគ ឲ្យនរណាម្នាក់ឡើយ ដ្បិត គ្មានអ្វីនៅសេសសល់
ពេលខ្មាំងសត្រូវឡោមព័ទ្ធទីក្រុងទាំងប៉ុន្មានរបស់អ្នករាល់គ្នា និងគ្រាដែលអ្នករាល់គ្នាជួបការលំបាក រងទុក្ខវេទនាជាខ្លាំង។
[56]ស្ត្រីណាដែលទន់ភ្លន់ស្លូតបូតហើយមានចិត្តមេត្តាក្នុងចំណោមអ្នករាល់គ្នា ជាស្ត្រីដែលមិនហ៊ានយកជើងជាន់នឹងដីផងនោះ ដោយព្រោះនាងទន់ភ្លន់ និងថ្នមខ្លួន
នោះបែជាសម្លក់សម្លឹងប្តីជាទីស្រឡាញ់ និងកូនប្រុសកូនស្រីរបស់ខ្លួន[57]ហើយទារកដែលទើបនឹងចេញពីផ្ទៃរបស់នាង ទៅធ្វើម្ហូបបរិភោគស្ងាត់ៗតែម្នាក់ឯង
ដោយព្រោះខ្វះខាត ក្នុងគ្រាដែលខ្មាំងសត្រូវឡោមព័ទ្ធទីក្រុងទាំងប៉ុន្មានរបស់អ្នក ក្នុងគ្រាដែលរងទុក្ខវេទនាយ៉ាងខ្លាំង។

generated on Wed Sep 10 16:16:32 2025

[58]ប្រសិនបើ អ្នករាល់គ្នាមិនកាន់តាមព្រះបន្ទូលទាំងប៉ុន្មានក្នុងក្រឹត្យវិន័យ ដែលបានកត់ទុកក្នុងគម្ពីរនេះ ដើម្បីឲ្យអ្នករាល់គ្នាកោតខ្លាចព្រះនាមដ៏រុងរឿង
និងគួរស្ញែងខ្លាចរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាទេ[59]នោះ ព្រះអម្ចាស់នឹងប្រហារអ្នករាល់គ្នា និងពូជពង្សរបស់អ្នករាល់គ្នា ដោយសម្តែងការអស្ចារ្យ ធ្វើឲ្យកើតដំបៅ
និងជំងឺធ្ងន់ៗ ដែលមិនអាចមើលជាបាន។
[60]ព្រះអង្គនឹងធ្វើឲ្យកើតមានជំងឺផ្សេងៗ ដែលធ្លាប់កើតចំពោះជនជាតិអេស៊ីប ដែលអ្នករាល់គ្នាភ័យខ្លាចនោះ ហើយជំងឺទាំងនោះនឹងនៅជាប់ជាមួយអ្នករាល់គ្នា។
[61]ព្រះអម្ចាស់នឹងទម្លាក់គ្រប់ទាំងជំងឺ និងគ្រោះកាចគ្រប់យ៉ាង ដែលមិនបានកត់ទុកក្នុងគម្ពីរក្រឹត្យវិន័យនេះ រហូតទាល់តែវិនាស។[62]ទោះពីដើមអ្នករាល់គ្នាមានគ្នាច្រើន
ដូចជាផ្កាយនៅលើមេឃ និងក្លាយទៅជាប្រជាជនមួយដ៏តូច ដោយព្រោះអ្នករាល់គ្នាមិនបានស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា។
[63]ព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានឲ្យអ្នករាល់គ្នាមានសេចក្តីល្អ ហើយឲ្យអ្នករាល់គ្នាកើនចំនួនច្រើនឡើងយ៉ាងណា
នោះព្រះអង្គក៏សព្វព្រះហឫទ័យធ្វើឲ្យអ្នករាល់គ្នាវិនាស ហើយបំផ្លាញអ្នករាល់គ្នាយ៉ាងនោះដែរ។ ព្រះអង្គនឹងដកអ្នករាល់គ្នាចេញពីទឹកដី
ដែលអ្នករាល់គ្នាចូលទៅកាន់កាប់។[64]ព្រះអម្ចាស់នឹងកម្ចាត់កម្ចាយអ្នករាល់គ្នាទៅក្នុងចំណោមប្រជាជនទាំងអស់ ចាប់ពីជើងមេឃម្ខាង ទៅជើងមេឃម្ខាង នៅទីនោះ
អ្នករាល់គ្នានឹងគោរពបម្រើព្រះដទៃ ជាព្រះដែលអ្នករាល់គ្នា និងដូចតារបស់អ្នករាល់គ្នាមិនដែលស្គាល់ គឺព្រះធ្វើពីឈើ និងថ្ម។
[65]ក្នុងចំណោមប្រជាជាតិទាំងនោះ អ្នករាល់គ្នានឹងមិនបានសុខសាន្ត ហើយក៏មិនមែនជាកន្លែងដែលអ្នករាល់គ្នាសម្រាកដែរ ផ្ទុយទៅវិញ
ព្រះអម្ចាស់នឹងធ្វើឲ្យចិត្តអ្នករាល់គ្នាញ័ររន្ធត់ ធ្វើឲ្យភ្នែករបស់អ្នករាល់គ្នាស្រវាំង ហើយធ្វើឲ្យព្រលឹងរបស់អ្នករាល់គ្នាទុក្ខព្រួយលំបាក។
[66]ជីវិតរបស់អ្នករាល់គ្នានឹងគ្មានទីកំណត់នៅចំពោះមុខអ្នករាល់គ្នា អ្នករាល់គ្នាភ័យខ្លាចទាំងយប់ទាំងថ្ងៃ ហើយគ្មានសង្ឃឹមនឹងរស់នៅទៀតឡើយ។
[67]នៅពេលព្រឹក អ្នករាល់គ្នានឹងពោលថា សូមឲ្យល្ងាចឆាប់មកដល់! ហើយដល់ពេលល្ងាច នោះអ្នករាល់គ្នាពោលថា សូមឲ្យព្រឹកឆាប់មកដល់!
ព្រោះតែក្នុងចិត្តរបស់អ្នករាល់គ្នាភ័យខ្លាច ដោយព្រោះហេតុការណ៍ដែលអ្នករាល់គ្នាឃើញផ្ទាល់នឹងភ្នែក បណ្តាលឲ្យអ្នករាល់គ្នាភ័យខ្លាច។[68]ព្រះអម្ចាស់នឹងនាំអ្នករាល់គ្នា
ចូលទៅក្នុងទឹកដីអេស៊ីបវិញតាមនាវា នៅតាមផ្លូវដែលខ្ញុំបានប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នានឹងមិនបានឃើញផ្លូវនោះទៀតឡើយ។ នៅទីនោះ
អ្នករាល់គ្នានឹងលក់ខ្លួនឲ្យទៅខ្មាំងសត្រូវ ដើម្បីធ្វើជា បាវបម្រើប្រុសស្រីរបស់គេ តែគ្មាននរណាទិញអ្នករាល់គ្នាឡើយ»។

Deuteronomy 28:1

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ស្តាប់តាមព្រះបន្ទូលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា

នៅទីនេះឃ្លាថា «ស្តាប់តាមព្រះបន្ទូលព្រះអម្ចាស់» សំដៅទៅលើអ្វីដែលព្រះអង្គមានបន្ទូល។ ការបកប្រែផ្សេងទៀត «ចំពោះអ្វីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាមានព្រះបន្ទូល»

ដោយកាន់

«ហើយស្តាប់បង្គាប់តាម»

លើកអ្នករាល់គ្នាខ្ពស់ឡើងលើស

លោកម៉ូសេនិយាយពីអ្វីដែលសំខាន់ ឬពីអ្វីដែលអស្ចារ្យដូចជាងរាងកាយដែលខ្ពស់ដូចនៅលើភ្នំខ្ពស់។ ការបកប្រែផ្សេងទៀត «ធ្វើឱ្យអ្នកកាន់តែសំខាន់ជាង» ឬ «ធ្វើឱ្យអ្នកធំជាង»

ព្រះពរទាំងអស់នេះនឹងធ្លាក់មកលើអ្នករាល់គ្នា

លោកម៉ូសេពិពណ៌នាអំពីព្រះពរដល់មនុស្ស ដែលនឹងវាយប្រហារពួកគេដោយការភ្ញាក់ផ្អើល ឬដេញតាមហើយចាប់ពួកគេ។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងប្រទានពរដល់អ្នករាល់គ្នាតាមរបៀប ដែលធ្វើឱ្យអ្នករាល់គ្នាភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយដូចជាអ្នករាល់គ្នាមិនអាចគេចផុតពីការឱ្យព្រះអង្គប្រទានពរដល់អ្នករាល់គ្នា»

Deuteronomy 28:3

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ព្រះអង្គនឹងប្រទានពរដល់អ្នករាល់គ្នា

អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងប្រទានពរដល់អ្នករាល់គ្នា»

នៅតាមទីក្រុង ... នៅតាមស្រែចម្ការ។

ការរួមបញ្ចូលគ្នានេះមានន័យថា ព្រះអម្ចាស់នឹងប្រទានពរដល់ពួកគេគ្រប់ទីកន្លែង។

មានកូនចៅច្រើន ហើយឲ្យដីរបស់អ្នករាល់គ្នាកើតភោគផលច្រើនហូរហៀរ

ហើយហ្វូងសត្វរបស់អ្នករាល់គ្នា

ទាំងនេះជាឃ្លាសម្រាប់ «កូនចៅរបស់អ្នករាល់គ្នា និង ដំណាំរបស់អ្នករាល់គ្នា និង សត្វទាំងអស់របស់អ្នករាល់គ្នា» បង្កើតជាការរួមបញ្ចូលគ្នាសម្រាប់អ្វីៗទាំងអស់ដែលមានតម្លៃចំពោះជនជាតិអ៊ីស្រាអែល។

ហើយហ្វូងសត្វរបស់អ្នករាល់គ្នាគឺគោ និងចៀមក៏កើនចំនួនឡើងជាច្រើនដែរ។

ការសង្ស័យនេះជាវិធីបីយ៉ាងក្នុងការនិយាយថា ព្រះអម្ចាស់នឹងធ្វើឱ្យសត្វរបស់ជនជាតិអ៊ីស្រាអែល មានចំនួនច្រើន។ ការបកប្រែផ្សេងទៀត «សត្វរបស់អ្នករាល់គ្នាទាំងអស់រួមជាមួយកូនគោ និងកូនចៀមរបស់ហ្វូងចៀម»

Deuteronomy 28:5

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ព្រះអង្គនឹងប្រទានពរឲ្យ

អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងប្រទានពរឲ្យ»

អ្នករាល់គ្នាមានផ្លែឈើពេញកន្ត្រក់ និងមានស្រូវពេញជង្រុក។

ជនជាតិអ៊ីស្រាអែលបានប្រើកន្ត្រកមួយ ដើម្បីដាក់ស្រូវ។ « ការច្របាច់ម្សៅ» ជាចានដែលគេប្រើដើម្បីលាយម្សៅនិងធ្វើនំបុ័ង។ ការបកប្រែផ្សេងទៀត «រាល់ស្បៀងអាហារអ្នករាល់គ្នាកើនឡើង និងអាហារដែលអ្នករាល់គ្នាបរិភោគ»

កាលដែលអ្នករាល់គ្នាចូលមក ... កាលដែលអ្នករាល់គ្នាចេញទៅ

ការរួមបញ្ចូលគ្នានេះសំដៅទៅលើរាល់សកម្មភាពជីវិត នៅគ្រប់ទីកន្លែងដែលពួកគេទៅ។

Deuteronomy 28:7

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ធ្វើឲ្យខ្មាំងសត្រូវដែលលើកគ្នាមកទាស់នឹងអ្នករាល់គ្នា ហើយត្រូវចុះចាញ់នៅមុខអ្នករាល់គ្នា

អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «បណ្តាលឱ្យអ្នករាល់គ្នាមានជ័យជម្នះ លើកងទ័ពខ្មាំងសត្រូវ ដែលវាយប្រហារអ្នករាល់គ្នា»

ពួកគេនឹងរត់នៅមុខអ្នករាល់គ្នា នៅតាមផ្លូវប្រាំពីរ។

«ប៉ុន្តែ ពួកគេនឹងរត់ចេញពីអ្នករាល់គ្នា នៅតាមផ្លូវប្រាំពីរ»

នៅតាមផ្លូវ

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ចំនួនពិតអាចច្រើនជាង ឬតិចជាងប្រាំពីរ។ ការបកប្រែផ្សេងទៀត «នៅតាមផ្លូវផ្សេងៗគ្នាជាច្រើន»

ព្រះអម្ចាស់នឹងប្រទានពរអ្នករាល់គ្នាឲ្យមានស្រូវពេញជង្រុក

លោកម៉ូសេបានពណ៌នាអំពីព្រះអម្ចាស់ប្រទានពរ ដល់ជនជាតិអ៊ីស្រាអែល ដូចជាព្រះអម្ចាស់កំពុងតែបញ្ជាឱ្យមនុស្សម្នាក់វាយប្រហារពួកគេ ដោយការភ្ញាក់ផ្អើល។ ការបកប្រែផ្សេងទៀត «នៅពេលដែលព្រះអម្ចាស់ប្រទានពរដល់អ្នករាល់គ្នា។ អ្នករាល់គ្នានឹងភ្ញាក់ផ្អើលពីចំនួនស្រូវ ដែលអ្នករាល់គ្នាមាននៅក្នុងជង្រុករបស់អ្នករាល់គ្នា»

និងប្រទានពរក្នុងគ្រប់កិច្ចការដែលអ្នករាល់គ្នាបានធ្វើ

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «និងគ្រប់ៗអ្វីទាំងអស់ដែលអ្នករាល់គ្នាធ្វើ»

Deuteronomy 28:9

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់នឹងធ្វើឲ្យអ្នករាល់គ្នាទៅជាប្រជារាស្ត្រដ៏វិសុទ្ធ ដូចដែលព្រះអង្គ
ព្រះអម្ចាស់បានជ្រើសរើសប្រជាជនអ៊ីស្រាអែល
ឱ្យធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គតាមរបៀបដ៏ពិសេសមួយ ត្រូវបានគេនិយាយថា
បើព្រះអម្ចាស់ដាក់ពួកគេនៅកន្លែងផ្សេងពីកន្លែង ដែលប្រជាជាតិដទៃរស់នៅ។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងធ្វើឱ្យអ្នករាល់គ្នាជាមនុស្សបរិសុទ្ធដែលជាកម្មសិទ្ធិរបស់ព្រះអង្គ»។
ព្រះអង្គបានជ្រើសរើសអ្នករាល់គ្នាជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់
នៅទីនេះឃ្លា «ដែលត្រូវបានជ្រើសរើសតាមព្រះនាមរបស់ព្រះអម្ចាស់»
មានន័យថាជាកម្មសិទ្ធិរបស់ព្រះអង្គ។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានហៅអ្នករាល់គ្នាថា ជារបស់ព្រះអង្គផ្ទាល់»
Deuteronomy 28:11
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មានកូនចៅជាច្រើន និងហ្វូងសត្វរបស់អ្នករាល់គ្នាក៏កើនចំនួនច្រើនឡើង
ហើយកធ្វើឲ្យអ្នករាល់គ្នាទទួលភោគផលជាច្រើន
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ពាក្យស្រដៀងគ្នានេះកើតមាននៅក្នុង ២៨:៣។
ការបកប្រែផ្សេងទៀត «ជាមួយកូនចៅ ហ្វូងសត្វនិង ភោគផល»។
បើកផ្ទៃមេឃ
លោកម៉ូសេនិយាយអំពីពពកឲ្យមានភ្លៀងធ្លាក់ចុះ
ដូចជាអគារដែលរក្សាទុកទឹកភ្លៀង។ ការបកប្រែផ្សេងទៀត «ពពក»
តាមរដូវកាល
«នៅពេលដំណាំត្រូវការ»
ដល់កិច្ចការទាំងប៉ុន្មានដែលដៃអ្នករាល់គ្នាធ្វើ
ពាក្យថា «ដៃ» តំណាងឱ្យមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«រាល់ការងារដែលអ្នករាល់គ្នាធ្វើ»
Deuteronomy 28:13
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
បានថ្កុំថ្កើងជាងគេ គឺមិនមែនអន់ជាងគេទេ
ពាក្យប្រៀបធៀបនេះពិពណ៌នាអំពីប្រជាជាតិអ៊ីស្រាអែលថា
ជាសត្វមួយហើយមានន័យថា
ប្រជាជនអ៊ីស្រាអែលនឹងក្លាយជាអ្នកដឹកនាំលើប្រជាជាតិនានាហើយមិនដែលមានអ្នកធ្លាក់ចុះ
ជនជាតិអ៊ីស្រាអែលនឹងមានឋានៈខ្ពស់ខាងអំណាចប្រាក់ និងកិត្តិយស។
មិនមែនអន់ជាងគេទេ ... នឹងទទួលកិត្តិយសខ្ពង់ខ្ពស់ជានិច្ច
ជនជាតិអ៊ីស្រាអែលនឹងគ្រប់គ្រងលើអ្នកដទៃ ប៉ុន្តែ
មិនដែលមានអ្នកផ្សេងគ្រប់គ្រងពួកគេឡើយ។
ដែលខ្ញុំបង្គាប់ដល់អ្នករាល់គ្នា
លោកម៉ូសេកំពុងតែនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលទាំងអស់ ដូច្នេះ ពាក្យ
«អ្នក» ជាពហុវចនៈ។
មិនត្រូវងាកទៅឆ្វេង ឬទៅស្តាំ ចេញពីព្រះបន្ទូលណាមួយ
ដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នានៅថ្ងៃនេះ ហើយបែរទៅតាមព្រះដទៃ
និងគោរពថ្វាយបង្គំព្រះដ៏ទៃទៀតឡើយ។
ការមិនគោរពដល់ព្រះអម្ចាស់ និងការថ្វាយបង្គំព្រះដទៃទៀត
ត្រូវបានគេនិយាយដូចជាមនុស្សម្នាក់បានងាកទៅរកទិសដៅផ្សេង
ពីព្រះបន្ទូលរបស់ព្រះអម្ចាស់។ការបកប្រែផ្សេងទៀត
«បើអ្នករាល់គ្នាមិនគោរពតាមអ្វី ដែលយើងកំពុងបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ
ដោយគោរពបម្រើព្រះដទៃ»
Deuteronomy 28:15
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប៉ុន្តែ ប្រសិនបើ
នៅទីនេះលោកម៉ូសេចាប់ផ្តើមពិពណ៌នាអំពីបណ្តាសា ដែលប្រជាជននឹងទទួល
បើពួកគេមិនគោរពតាម។
ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា
នៅទីនេះឃ្លា «ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់» មានន័យថា
អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា កំពុងតែមានព្រះបន្ទូល»
នោះអស់ទាំងបណ្តាសានេះ និងធ្លាក់មកលើអ្នករាល់គ្នាហើយនៅតាមអ្នករាល់គ្នាជាប់។
លោកម៉ូសេពិពណ៌នាបណ្តាសាដូចជាមនុស្ស
ដែលវាយប្រហារពួកគេដោយការភ្ញាក់ផ្អើល ឬដេញតាមហើយចាប់ពួកគេ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងដាក់បណ្តាសារអ្នកតាមរបៀបបនេះ
ដែលធ្វើឱ្យអ្នករាល់គ្នាភ្ញាក់ផ្អើលយ៉ាងខ្លាំង
ហើយវាដូចជាអ្នករាល់គ្នាមិនអាចគេចផុតពីការដាក់បណ្តាសា»
មកលើអ្នករាល់គ្នាហើយនៅតាមអ្នករាល់គ្នាជាប់។
បកប្រែដូចនៅក្នុង ២៨: ១ ។
Deuteronomy 28:16
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ព័ត៌មានទូទៅ៖
ឃ្លាទាំងនេះត្រូវបានបង្ហាញនៅដើមជំពូក។ សូមមើលការបកប្រែនៅក្នុង ២៨:៣
និង ២៨:៥។
អ្នករាល់គ្នានឹងត្រូវបណ្តាសា
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងដាក់បណ្តាសាអ្នករាល់គ្នា»
នៅតាមទីក្រុង ...នៅតាមស្រែចម្ការ។
ការរួមបញ្ចូលគ្នានេះមានន័យថា ព្រះអម្ចាស់នឹងប្រទានពរដល់ពួកគេគ្រប់ទីកន្លែង។
បកប្រែដូចនៅក្នុង ២៨:៣។
ផ្លែឈើនៅក្នុងល្អី និងគ្មានស្រូវនៅក្នុងជង្រុក។
ជនជាតិអ៊ីស្រាអែលប្រើល្អី ដើម្បីសែងស្រូវ។ «ការច្រចាច់ម្សៅ»
ជាចានគោមដែលគេប្រើដើម្បីលាយម្សៅ និងធ្វើនំបុ័ង។ បកប្រែដូចនៅក្នុង ២៨:៥។
ការបកប្រែផ្សេងទៀត «រាល់ស្បៀងអាហារអ្នកកើនឡើង
និងរាល់អាហារដែលអ្នកបរិភោគ»
Deuteronomy 28:18
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ព័ត៌មានទូទៅ៖
ឃ្លាទាំងនេះត្រូវបានបង្ហាញនៅដើមជំពូក។ សូមមើលការបកប្រែនៅក្នុង ២៨:៣
និងការបកប្រែនៅពីក្រោយពួកគេទៀតឡើយ។
អ្នករាល់គ្នានឹងត្រូវបណ្តាសា
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងដាក់បណ្តាសា»
កូនចៅ ដីរបស់អ្នករាល់គ្នានឹងមិនបង្កើតភោគផល
នេះជាឃ្លាសម្រាប់ «កូនចៅរបស់អ្នករាល់គ្នា និងភោគផល របស់អ្នក»។
បកប្រែដូចនៅក្នុង ២៨:៣។
បង្កើតភោគផល ហ្វូងគោ និងហ្វូងចៀមរបស់អ្នករាល់គ្នាក៏កើនចំនួនដែរ។
ការសង្ស័យនេះជារបៀបពីរយ៉ាងក្នុងការនិយាយថា
ព្រះអម្ចាស់នឹងធ្វើឱ្យសត្វរបស់ជនជាតិអ៊ីស្រាអែល មានចំនួនច្រើននិងរឹងមាំ។
ការបកប្រែផ្សេងទៀត «កូនគោនិងកូនចៀមរបស់ហ្វូងចៀម»
Deuteronomy 28:20
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ដាក់បណ្តាសាអ្នករាល់គ្នាឲ្យជួបប្រទះទុក្ខវេទនា និងសេចក្តីថប់ព្រួយ
«គ្រោះមហន្តរាយ ការភ័យខ្លាច និង ការខកចិត្ត»
ហើយអ្វីៗដែលអ្នករាល់គ្នាធ្វើ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«នៅក្នុងអ្វីគ្រប់យ៉ាងដែលអ្នករាល់គ្នាធ្វើ»
អ្នករាល់គ្នាធ្វើនឹងត្រូវខូចបង់
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«រហូតដល់សត្រូវរបស់អ្នករាល់គ្នា បំផ្លាញអ្នករាល់គ្នា»
អ្នកបានបោះបង់ចោលព្រះអង្គ។
នៅទីនេះ «ខ្ញុំ» សំដៅទៅលើព្រះអម្ចាស់។
កើតឡើងដល់អ្នករាល់គ្នា

generated on Wed Sep 10 16:16:32 2025

«ស្ថិតនៅលើអ្នករាល់គ្នា»
Deuteronomy 28:22
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ដោយជំងឺរាតត្បាត ជំងឺគ្រុនក្តៅ កើតពិស
ជំងឺនិងគ្រុនក្តៅដែលនឹងធ្វើឱ្យអ្នកខ្សោយ។ ទាំងអស់នេះសំដៅទៅលើជំងឺ ដែលបណ្តាលឱ្យមនុស្សចុះខ្សោយនិងស្លាប់។
កើតមានការរាំងស្ងួតស្រូវស្កក
«កង្វះទឹកភ្លៀង»
មានក្រាស៊ី
ដុះផ្សិតលើដំណាំហើយបណ្តាលឱ្យរលួយ
រហូតទាល់តែអ្នករាល់គ្នាវិនាស។
លោកម៉ូសេនិយាយអំពីរឿងអាក្រក់ ដែលនឹងកើតឡើងចំពោះជនជាតិអ៊ីស្រាអែល ហាក់ដូចជាពួកគេជាមនុស្សឬសត្វដែលដេញតាមជនជាតិអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «អ្នករាល់គ្នានឹងរងទុក្ខពីពួកគេ»
Deuteronomy 28:23
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
មេឃ... នឹងក្តៅដូចជាលង្ហិន
លោកម៉ូសេនិយាយអំពីមេឃដូចជាលង្ហិន ពីព្រោះគ្មានភ្លៀងទេ។ ការបកប្រែផ្សេងទៀត «មេឃ ... នឹងមិនមានភ្លៀងទេ»
ដី ... នឹងរឹងដូចដែក។
លោកម៉ូសេនិយាយថា ផែនដីប្រៀបបាននឹងដែក ព្រោះគ្មានដំណាំណាអាចដុះលូតលាស់បានឡើយ។ ការបកប្រែផ្សេងទៀត «គ្មានអ្វីនឹងដុះចេញពីដីទេ»
ព្រះអម្ចាស់នឹងធ្វើឲ្យធូលីដី ព្រមទាំងផេះធ្លាក់ពីលើ
"ជំនួសឱ្យភ្លៀងព្រះអម្ចាស់នឹងបញ្ជូនព្យុះខ្សាច់"
រហូតទាល់តែអ្នករាល់គ្នាវិនាស។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «រហូតដល់វាបំផ្លាញអ្នករាល់គ្នា»
Deuteronomy 28:25
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ព្រះអម្ចាស់នឹងធ្វើឲ្យអ្នករាល់គ្នាបាន់ទ័ព រត់នៅមុខខ្មាំងសត្រូវ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងធ្វើឱ្យខ្មាំងសត្រូវរបស់អ្នករាល់គ្នាវាយប្រហារអ្នករាល់គ្នា»
បាន់ទ័ព រត់នៅមុខ
បកប្រែដូចនៅក្នុង ២៨:៧។
នឹងរត់នៅមុខពួកគេ តាមផ្លូវប្រាំពីរ។
មានន័យថា ប្រជាជនអ៊ីស្រាអែលនឹងភ័យខ្លាច និងភ័យស្លន់ស្លោរ ហើយរត់ចេញពីសត្រូវរបស់ពួកគេ។ សូមមើលពាក្យស្រដៀងគ្នានៅក្នុង ២៨:៧។ ការបកប្រែផ្សេងទៀត «អ្នកនឹងរត់គេចតាមផ្លូវប្រាំពីរ»
តាមផ្លូវប្រាំពីរ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «នៅក្នុងទិសដៅផ្សេងៗគ្នាជាច្រើន»
ហើយនរគទាំងប៉ុន្មានដែលនៅលើផែនដីឮដំណឹងនេះ គេនឹងនាំគ្នាភ័យខ្លាច។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ប្រជាជននៃប្រជាជាតិផ្សេងទៀតនឹងជំរុញអ្នក ពីប្រជាជាតិមួយទៅប្រជាជាតិផ្សេងមួយទៀត»
Deuteronomy 28:27
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ដោយបូស ដែលកើតនៅក្នុងទឹកដីអេស៊ីប
«ជំងឺស្បែកដូចគ្នាដែលយើងបានដាក់បណ្តាសាដល់ជនជាតិអេស៊ីប»
បូស ...ដោយរោគឬដូងបាត កមរមាស់
ទាំងនេះគឺជាប្រភេទជំងឺកើតលើស្បែកផ្សេងៗគ្នា។
ដែលមិនអាចមើលជាឡើយ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដែលគ្មាននរណាម្នាក់អាចព្យាបាលអ្នកជាបានឡើយ»
អ្នករាល់គ្នានឹងដើរស្ទាបនៅពេលថ្ងៃត្រង់ ដូចមនុស្សខ្វាក់ដើរស្ទាបរាវរកផ្លូវនៅទីងងឹត
«អ្នកនឹងដូចជាមនុស្សខ្វាក់
ដែលដើរនៅក្នុងភាពងងឹតសូម្បីតែពេលថ្ងៃត្រង់ក៏ដោយ»។
ប្រជាជនអ៊ីស្រាអែលនឹងមានជីវិតដ៏លំបាក
សូម្បីតែនៅពេលដែលមនុស្សគ្រប់គ្នារីករាយនឹងជីវិតក៏ដោយ។
អ្នករាល់គ្នានឹងត្រូវគេជិះជាន់ ឬរឹបអូស
«ប្រជាជនដែលខ្លាំងជាងគេនឹងជិះជាន់ និងរឹបអូសអ្នកជានិច្ច»
Deuteronomy 28:30
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
គេនឹងសម្លាប់គោរបស់អ្នករាល់គ្នា នៅចំពោះមុខអ្នករាល់គ្នា
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «អ្នករាល់គ្នានឹងមើលមនុស្សម្នាក់សម្លាប់គោរបស់អ្នករាល់គ្នា»
គេនឹងរឹបអូសយកលារបស់អ្នករាល់គ្នា នៅចំពោះមុខអ្នករាល់គ្នា
តែគេមិនបានប្រគល់មកអ្នករាល់គ្នាវិញឡើយ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «មនុស្សណាម្នាក់នឹងយកលារបស់អ្នករាល់គ្នាដោយបង្ខំ ហើយនិងមិនប្រគល់វាមកវិញទេ»
គេនឹងប្រគល់ហ្វូងចៀមរបស់អ្នករាល់គ្នា ទៅខ្មាំងសត្រូវ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «យើងនឹងឱ្យចៀមរបស់អ្នករាល់គ្នា ទៅសត្រូវរបស់អ្នករាល់គ្នា » ឬ «យើងនឹងឱ្យសត្រូវរបស់អ្នករាល់គ្នា យកចៀមរបស់អ្នករាល់គ្នា»
Deuteronomy 28:32
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
គេនឹងលក់កូនប្រុសកូនស្រីរបស់អ្នករាល់គ្នាឲ្យទៅសាសន៍ដទៃ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «យើងនឹងឱ្យកូនប្រុសនិងកូនស្រីរបស់អ្នករាល់គ្នាទៅឱ្យប្រជាជនផ្សេងទៀត» ឬ «សត្រូវរបស់អ្នករាល់គ្នានឹងយកកូនប្រុស និងកូនស្រីរបស់អ្នករាល់គ្នា»
ហើយអ្នករាល់គ្នានឹងទន្ទឹងរង់ចាំគេត្រឡប់មកវិញ រហូតដល់ស្រវាំងភ្នែក
នៅទីនេះ «ភ្នែករបស់អ្នក» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត «អ្នករាល់គ្នានឹងអស់កម្លាំង នៅពេលអ្នករាល់គ្នាចាំមើលពួកគេជានិច្ច ហើយនិងចង់ជួបពួកគេម្តងទៀត»
តែអ្នករាល់គ្នាមិនអាចសម្រេចដូចប្រាថ្នាឡើយ។
នៅទីនេះឃ្លា «កម្លាំងនៅក្នុងដៃរបស់អ្នករាល់គ្នា» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត អ្នករាល់គ្នានឹងគ្មានអំណាចធ្វើអ្វីៗទាំងអស់ពីវាទេ»
Deuteronomy 28:33
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប្រជាជាតិ
នៅទីនេះឃ្លា «ប្រជាជាតិមួយ» មានន័យថា ប្រជាជនមកពីប្រជាជាតិមួយ។ ការបកប្រែផ្សេងទៀត «ប្រជាជនមកពីជាតិសាសន៍មួយ»
អ្នករាល់គ្នានឹងត្រូវគេសង្កត់សង្កិន និងជិះជាន់
ពាក្យថា« សង្កត់សង្កិន» និង «ជិះជាន់» មានន័យថា ដូចគ្នា។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេនឹងគាបសង្កត់និងបង្ក្រាបអ្នកជានិច្ច» ឬ« ពួកគេនឹងគាបសង្កត់អ្នកជារឿងរហូត»
អ្នករាល់គ្នាឃើញនឹងភ្នែក ដល់ម្លេះបានជាអ្នករាល់គ្នាវង្វេង
«អ្វីដែលអ្នករាល់គ្នាឃើញ នឹងធ្វើឱ្យអ្នករាល់គ្នាឆ្កួត»
ហើយអ្នករាល់គ្នាមិនអាចមើលជាបានឡើយ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «គ្មានអ្នកណានឹងអាចព្យាបាលបានទេ»

generated on Wed Sep 10 16:16:32 2025

Deuteronomy 28:36
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ភ្ញាក់ផ្អើល ហើយយករឿងរបស់អ្នករាល់គ្នាទៅនិទានប្រាប់គ្នា ព្រមទាំងប្រមាថមាក់ងាយអ្នករាល់គ្នា
ក្នុងចំណោមអស់ទាំងមនុស្សដែលព្រះអម្ចាស់នាំអ្នករាល់គ្នាចេញ។
នៅទីនេះពាក្យ «យករឿង» និង «ប្រមាថមាក់ងាយ» មានន័យថាជារួមដូចគ្នា។
អាចបកប្រែជាប្រយោគថ្មី។ ការបកប្រែផ្សេងទៀត
«ភាពតក់ស្លុតនៃប្រជាជននៅកន្លែង ដែលព្រះអម្ចាស់នឹងចាត់អ្នករាល់គ្នាឱ្យទៅ
បង្កើតពាក្យសម្តីនិងពាក្យពេចន៍អំពីអ្នករាល់គ្នា» ឬ« ភាពតក់ស្លុត។
ព្រះអម្ចាស់នឹងចាត់អ្នករាល់គ្នាឱ្យទៅរកប្រជាជន
ដែលសើចចំអកដាក់អ្នករាល់គ្នា»។
ប្រមាថមាក់ងាយ
ប្រមាថមាក់ងាយ ឬឃ្លាដែលមនុស្សប្រើដើម្បីធ្វើឱ្យអ្នកដទៃអាម៉ាស់មុខ។
Deuteronomy 28:38
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
តែអ្នករាល់គ្នានឹងច្រូតបានផលបន្តិចបន្តួច
«ប៉ុន្តែ នឹងប្រមូលផលបានតិចតួចណាស់»
Deuteronomy 28:40
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប៉ុន្តែ អ្នករាល់គ្នានឹងមិនលាបប្រេងសម្រាប់លាបខ្លួនឡើយ
មនុស្សអាចលាបប្រេងអូលីវលើខ្លួនគេ
ដើម្បីធ្វើឱ្យស្បែករបស់ពួកគេមានសុខភាពល្អ។
ផ្លែអូលីវនឹងជ្រុះអស់។
អ្នកប្រហែលជាត្រូវបញ្ជាក់ឱ្យច្បាស់ថា ផ្លែឈើជ្រុះមុនពេលវាទុំ។
ការបកប្រែផ្សេងទៀត «ផ្លែអូលីវនឹងជ្រុះមុនពេលផ្លែទុំ» ឬ«
ផ្លែអូលីវនឹងជ្រុះពីដើមអូលីវមុនពេលវាទុំ»
Deuteronomy 28:42
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ជនបរទេសដែល ... គេនឹង ... ឲ្យគេខ្ជីខ្ជា
នេះមិនមែនមានន័យថា ជនបរទេសជាក់លាក់នោះទេប៉ុន្តែ
វាសំដៅទៅលើជនបរទេសជាទូទៅ។ ការបកប្រែផ្សេងទៀត «ជនបរទេសដែល ...
ពួកគេនឹង ... ទៅពួកគេ»
នឹងមានអំណាចកាន់តែខ្លាំងឡើងៗលើអ្នករាល់គ្នា
ហើយអ្នករាល់គ្នានឹងចុះខ្សោយកាន់តែទាបទៅៗ។
ឃ្លានេះមានន័យថា ជនបរទេសនឹងមានអំណាច ប្រាក់ និង កិត្តិយស
ច្រើនជាងជនជាតិអ៊ីស្រាអែល។
គេនឹងបានខ្ពង់ខ្ពស់បំផុត ហើយអ្នករាល់គ្នាវិញអន់ជាងគេបំផុត។
នេះមានន័យថា
ជនបរទេសនឹងមានអំណាចនិងសិទ្ធអំណាចច្រើនជាងជនជាតិអ៊ីស្រាអែល។
សូមមើលការបកប្រែនៅក្នុង ២៨:១៣។
Deuteronomy 28:45
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
បណ្តាសាទាំងនេះនឹងធ្លាក់មកលើអ្នករាល់គ្នា ហើយនឹងនៅជាប់ជាមួយអ្នករាល់គ្នាជានិច្ច
រហូតទាល់តែអ្នករាល់គ្នាវិនាស។
លោកម៉ូសេពិពណ៌នាបណ្តាសានេះថា
ជាមនុស្សដែលវាយប្រហារពួកគេដោយការភ្ញាក់ផ្អើល
ឬដេញតាមហើយចាប់ពួកគេ។ សូមមើលការបកប្រែនៅក្នុង ២៨:១។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងដាក់បណ្តាសាអ្នករាល់គ្នាតាមរបៀបនេះ
ដែលធ្វើឱ្យអ្នករាល់គ្នាភ្ញាក់ផ្អើលយ៉ាងខ្លាំង
គឺដូចជាព្រះអង្គកំពុងដេញតាមអ្នករាល់គ្នា
ហើយអ្នករាល់គ្នាមិនអាចគេចផុតពីការដាក់បណ្តាសារឡើយ»
ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
នៅទីនេះពាក្យ «សំឡេងរបស់ព្រះអម្ចាស់» ជាពាក្យទាក់ទងនឹងអ្វី
ដែលព្រះអម្ចាស់មានព្រះបន្ទូល។ ការបកប្រែផ្សេងទៀត
«ទៅនឹងអ្វីដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាមានព្រះបន្ទូល»
តាមបទបញ្ជា និងច្បាប់របស់ព្រះអង្គ
ពាក្យ «បទបញ្ជា » និង «ច្បាប់» គឺដូចគ្នាសម្រាប់
«អ្វីដែលព្រះអម្ចាស់បានបញ្ជាឱ្យអ្នកឲ្យធ្វើ»។
Deuteronomy 28:47
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ដោយចិត្តអរសប្បាយ និងដោយស្មោះអស់ពីចិត្តឡើយ
នៅទីនេះ «ចិត្តអរសប្បាយ» និង «ដោយស្មោះអស់ពីចិត្ត» មានន័យដូចគ្នា។
ពួកគេបញ្ជាក់ថាប្រជាជនគួរតែរីករាយណាស់ក្នុងការថ្វាយបង្គំព្រះជាម្ចាស់។
ព្រះអង្គនឹងដាក់នឹមដែកនៅលើកអ្នករាល់គ្នា
នេះជាពាក្យប្រៀបធៀបសម្រាប់ព្រះអម្ចាស់
ដែលអនុញ្ញាតឱ្យសត្រូវធ្វើបាបប្រជាជនអ៊ីស្រាអែលយ៉ាងសាហាវ
ហើយធ្វើឱ្យពួកគេក្លាយជាទាសករ។
Deuteronomy 28:49
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ពីស្រុកឆ្ងាយ គឺពីចុងផែនដីមក
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ថាសត្រូវនឹងមកពីប្រជាជាតិមួយ
ដែលនៅឆ្ងាយពីអ៊ីស្រាអែល។
គឺពីចុងផែនដីមក
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ពីកន្លែងដែលអ្នកមិនស្គាល់»
ដូចជាសត្វឥន្ទ្រីហើរ មកប្រហារអ្នករាល់គ្នា
នេះមានន័យថាសត្រូវនឹងមកដល់ភ្លាមៗ
ហើយប្រជាជនអ៊ីស្រាអែលនឹងមិនអាចបញ្ឈប់ពួកគេបានឡើយ។
ពួកគេមានទឹកមុខសាហាវ ហើយមិនគោរពចាស់ទុំ ហើយក៏គ្មានចិត្តមេត្តាដល់កូនក្មេងដែរ។
ពាក្យថា «ពួគគេ» ជាឃ្លាសម្រាប់ប្រជាជននៃប្រជាជាតិនោះ។
ការបកប្រែផ្សេងទៀត «ប្រជាជាតិមួយដែលប្រជាជនបង្ហាញទឹកមុខយ៉ាងសាហាវ
ដែលមិនគោរពមនុស្សចាស់ ហើយក៏គ្មានចិត្តមេត្តាដល់កូនក្មេងដែរ។
រហូតទាល់តែអ្នករាល់គ្នាវិនាសអស់។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«រហូតដល់ពួកគេបំផ្លាញអ្នករាល់គ្នា» ឬ
«រហូតដល់ពួកគេចាកចេញពីអ្នករាល់គ្នាដោយគ្មានអ្វីសល់សោះ»
Deuteronomy 28:52
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តពីពណ៌នាអំពីកងទ័ព ដែលនឹងវាយប្រហារជនជាតិអ៊ីស្រាអែល
បើពួកគេមិនស្តាប់បង្គាប់តាមព្រះអម្ចាស់។
ព្រះអង្គនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេមានមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» នៅទីនេះមានលក្ខណៈឯកវចនៈ។
ទីក្រុងរបស់អ្នករាល់គ្នាទាំងអស់
នៅទីនេះឃ្លា «ទ្វារទីក្រុង» តំណាងឱ្យទីក្រុងមួយ។ ការបកប្រែផ្សេងទៀត
«ទីក្រុងរបស់អ្នករាល់គ្នា»
រហូតដល់ស៊ីសាច់កូនរបស់ខ្លួន គឺកូនប្រុសកូនស្រី
នៅទីនេះ «សាច់កូនប្រុសនិងកូនស្រីរបស់អ្នក» ពន្យល់ពីពាក្យប្រៀបធៀបថា
«ផលផ្លែនៃរាងកាយរបស់អ្នក» ។ ប្រជាជននឹងឃ្លានយ៉ាងខ្លាំង
បន្ទាប់ពីកងទ័ពសត្រូវឡោមព័ទ្ធទីក្រុងរបស់ពួកគេ
ហើយពួកគេនឹងស៊ីកូនចៅរបស់ពួកគេ។
ហូតដល់ស៊ីសាច់កូនរបស់ខ្លួន
និយាយអំពីកូនដូចពួកគេជាផ្លែឈើ ដែលត្រូវបានផលិតដោយឪពុកម្តាយ។
ការបកប្រែផ្សេងទៀត «កូនៗរបស់អ្នកផ្ទាល់»
Deuteronomy 28:54
ព័ត៌មានទូទៅ៖

generated on Wed Sep 10 16:16:32 2025

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ដែលមានចិត្តទន់ភ្លន់ជាងគេ ហើយមានចិត្តស្លូតបូតក្នុងចំណោមអ្នករាល់គ្នា
«អ្នកណាមានចរិតទន់ភ្លន់ និងហើយមានចិត្តស្លូតបូតក្នុងចំណោមអ្នក
សូម្បីតែគាត់ដែរ»។ លោកម៉ូសេបាននិយាយថា
មិនត្រឹមតែអ្នកដែលរំពឹងថានឹងបរិភោគកូនៗប៉ុណ្ណោះទេ ប៉ុន្តែ
ថែមទាំងមនុស្សចុងក្រោយដែលរំពឹងថា
នឹងបរិភោគកូនរបស់គាត់ផ្ទាល់នឹងបរិភោគកូនរបស់គាត់។
ទ្វារទីក្រុងរបស់អ្នកទាំងអស់
នៅទីនេះ «ទ្វារទីក្រុង» តំណាងឱ្យទីក្រុង។ ការបកប្រែផ្សេងទៀត
«ទីក្រុងទាំងអស់របស់អ្នក»

Deuteronomy 28:56

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ស្ត្រីណាដែលទន់ភ្លន់ស្លូតបូតហើយមានចិត្តមេត្តាក្នុងចំណោមអ្នករាល់គ្នា ... នាងទន់ភ្លន់
ស្ត្រីទន់ភ្លន់ស្លូតបូតនិងទន់ភ្លន់ក្នុងចំណោមអ្នក ... ភាពទន់ភ្លន់
សូម្បីតែនាងផងដែរ។
លោកម៉ូសេបាននិយាយថាពួកគេមិនត្រឹមតែរំពឹងថានឹងបរិភោគកូនរបស់ពួកគេប៉ុណ្ណោះទេ
ប៉ុន្តែ សូម្បីតែស្ត្រីដែលមានភាពថ្លៃថ្នូរហើយជាធម្មតាសុភាពរាបសា
ដែលគ្មានមនុស្សណាម្នាក់ដែលរំពឹងថា នឹងបរិភោគកូនរបស់ពួកគេ។ ពាក្យថា «អ្នក»
នៅទីនេះជាឯកវចនៈ។
ជាស្ត្រីដែលមិនហ៊ានយកជើងជាន់នឹងដីផងនោះ ដោយព្រោះនាងទន់ភ្លន់ និងថ្នមខ្លួន
លោកម៉ូសេកំពុងនិយាយបំផ្លើស។ គាត់កំពុងបញ្ជាក់ថា
ស្ត្រីដ៏ថ្លៃថ្នូនេះមានទ្រព្យសុកស្គម្ភណាស់ ហើយរស់នៅក្នុងភាពប្រណីតបែបនេះ
ដែលនាងនឹងមិនអនុញ្ញាតឱ្យខ្លួននាងកខ្វក់ឡើយ។
ដោយព្រោះនាងទន់ភ្លន់ និងថ្នមខ្លួន
នាមអរូបី «ថ្នមខ្លួន »និង «ទន់ភ្លន់» អាចត្រូវបានបញ្ជាក់ជាឃ្លា។
ការបកប្រែផ្សេងទៀត «ព្រោះនាងថ្នមខ្លួន និងទន់ភ្លន់»
ទីក្រុងទាំងប៉ុន្មានរបស់អ្នក
នៅទីនេះ «ទ្វារទីក្រុង» តំណាងឱ្យទីក្រុង។ ការបកប្រែផ្សេងទៀត
«នៅក្នុងទីក្រុងរបស់អ្នក»

Deuteronomy 28:58

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ដែលបានកត់ទុក
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដែលខ្ញុំបានសរសេរ»
ព្រះនាមដ៏រុងរឿង និងគួរស្ញែងខ្លាចរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាទេ
នៅទីនេះឃ្លា «ព្រះនាម» សំដៅទៅលើព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដែលមានសិរីរុងរឿងនិងគួរឱ្យស្ញប់ស្ញែង»
ព្រះអម្ចាស់នឹងប្រហារអ្នករាល់គ្នា និងពូជពង្សរបស់អ្នករាល់គ្នា
ព្រះអម្ចាស់នឹងបញ្ជូនគ្រោះកាចដ៏គួរឱ្យស្ញែងខ្លាច កើតមានដល់អ្នករាល់គ្នា
និងកូនចៅរបស់អ្នករាល់គ្នា» ឬ «ព្រះអម្ចាស់នឹងធ្វើឱ្យប្រាកដថា អ្នករាល់គ្នា
និងកូនចៅរបស់អ្នកទទួលរងពីគ្រោះកាចដ៏គួរឱ្យភ័យខ្លាច»

Deuteronomy 28:60

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ព្រះអង្គនឹងធ្វើឲ្យកើតមានជំងឺផ្សេងៗ ដែលធ្លាប់កើតចំពោះជនជាតិអេស៊ីប
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គនឹងធ្វើឲ្យប្រាកដថា អ្នកនឹងរងទុក្ខពីជំងឺនៅស្រុកអេស៊ីប»
ជំងឺទាំងនោះនឹងនៅជាប់ជាមួយអ្នករាល់គ្នា។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ជំងឺនឹងមិនឈប់
ហើយគ្មាននរណាម្នាក់អាចជាសះស្បើយពីជំងឺទាំងនោះបានទេ»
គ្រប់ទាំងជំងឺ និងគ្រោះកាចគ្រប់យ៉ាង ដែលមិនបានកត់ទុកក្នុង
នេះជាការនិយាយបំផ្លើស។ អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «សូម្បីតែជំងឺនិងគ្រោះកាចដែលខ្ញុំមិនបានសរសេរ»
រហូតទាល់តែវិនាស។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«រហូតដល់វាបានបំផ្លាញអ្នក»
រហូតទាល់តែវិនាស។ ... ដូចជា ... អ្នករាល់គ្នាមិនបានស្តាប់
លោកម៉ូសេកំពុងនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលជាក្រុម ដូច្នេះ រាល់ពាក្យ
«អ្នក» ជាពហុវចនៈ។
ដូចជាផ្កាយនៅលើមេឃ
មានន័យថា កាលពីមុនមានជនជាតិអ៊ីស្រាអែលជាច្រើន។
ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់
នៅទីនេះឃ្លា «ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់»
សំដៅទៅលើអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។ ការបកប្រែផ្សេងទៀត
«ចំពោះអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល»

Deuteronomy 28:63

ព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានឲ្យអ្នករាល់គ្នា ... ឲ្យអ្នករាល់គ្នាកើនចំនួនច្រើនឡើង ...
សព្វព្រះហឫទ័យធ្វើឲ្យអ្នករាល់គ្នាវិនាស ហើយបំផ្លាញអ្នករាល់គ្នាយ៉ាងនោះដែរ។ ព្រះអង្គនឹងដក
លោកម៉ូសេកំពុងនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលជាក្រុម ដូច្នេះ រាល់ពាក្យ
«អ្នក»ជាពហុវចនៈ។
ព្រះអម្ចាស់សព្វព្រះហឫទ័យប្រទានឲ្យអ្នករាល់គ្នាមានសេចក្តីល្អ
ហើយឲ្យអ្នករាល់គ្នាកើនចំនួនច្រើនឡើងយ៉ាងណា
ព្រះអម្ចាស់មានអំណរចំពោះអ្នក ដែលធ្វើល្អនិងធ្វើឲ្យអ្នកកើនចំនួនច្រើនឡើង
ព្រះអង្គក៏សព្វព្រះហឫទ័យធ្វើឲ្យអ្នករាល់គ្នាវិនាស
«ព្រះអង្គនឹងរីករាយធ្វើឱ្យអ្នករាល់គ្នាស្លាប់»
ព្រះអង្គនឹងដកអ្នករាល់គ្នាចេញពីទឹកដី ដែលអ្នករាល់គ្នាចូលទៅកាន់កាប់។
លោកម៉ូសេប្រើពាក្យប្រៀបធៀប ដើម្បីនិយាយអំពីប្រជាជនដូចពួកគេជាផ្លែឈើ
ដែលព្រះអម្ចាស់នឹងដកយកចេញពីគុម្ព។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «ព្រះអង្គនឹងដកអ្នករាល់គ្នាចេញពីទឹកដី
ដែលអ្នករាល់គ្នាកំពុងកាន់កាប់»
អ្នករាល់គ្នាចូលទៅ ...កម្ចាត់កម្ចាយអ្នករាល់គ្នា ... អ្នករាល់គ្នានឹងគោរពបម្រើ ...
អ្នករាល់គ្នាមិនដែលស្គាល់ ...ដូចតារបស់អ្នករាល់គ្នាមិនដែលស្គាល់
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ចាប់ពីជើងមេឃម្ខាង ទៅជើងមេឃម្ខាង
ជ្រុលទាំងពីររួមគ្នាមានន័យថា គ្រប់ទិសទីលើផែនដី។ ការបកប្រែផ្សេងទៀត
«ពាសពេញផែនដី» ឬ «គ្រប់ទីកន្លែងលើផែនដី»

Deuteronomy 28:65

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ហើយក៏មិនមែនជាកន្លែងដែលអ្នករាល់គ្នាសម្រាកដែរ
នៅទីនេះឃ្លា «បាតជើងរបស់អ្នក» សំដៅទៅលើមនុស្សទាំងមូល។
ការបកប្រែផ្សេងទៀត «អ្នកនឹងត្រូវវង្វេងវង្វាន់ជានិច្ច
ព្រោះអ្នកមិនមានផ្ទះអចិន្ត្រៃយ៍ ដែលអ្នកអាចសម្រាកបាន»
ព្រះអម្ចាស់នឹងធ្វើឲ្យចិត្តអ្នករាល់គ្នាញ័ររន្ធត់ ធ្វើឲ្យភ្នែករបស់អ្នករាល់គ្នាស្រវាំង
ហើយធ្វើឲ្យព្រលឹងរបស់អ្នករាល់គ្នាទុក្ខព្រួយលំបាក។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងធ្វើឱ្យអ្នករាល់គ្នាភ័យខ្លាច ដោយគ្មានសង្ឃឹមនិងសោកស្តាយ»
ជីវិតរបស់អ្នករាល់គ្នានឹងគ្មានទីកំណត់នៅចំពោះមុខអ្នករាល់គ្នា
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «អ្នកនឹងមិនដឹងថា
អ្នកនឹងរស់ឬស្លាប់»

Deuteronomy 28:67

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ព្រោះតែក្នុងចិត្តរបស់អ្នករាល់គ្នាភ័យខ្លាច
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ដោយសារតែការភ័យខ្លាច ដែលអ្នករាល់គ្នាកំពុងមានអារម្មណ៍»
ដោយព្រោះហេតុការណ៍ដែលអ្នករាល់គ្នាឃើញផ្ទាល់នឹងភ្នែក
នៅទីនេះ «ភ្នែក» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«រឿងគួរឱ្យភ័យខ្លាចដែលយើងនឹងបង្ខំអ្នករាល់គ្នាឱ្យមើល»
ខ្ញុំបានប្រាប់

generated on Wed Sep 10 16:16:32 2025

29 [1]ទាំងនេះគឺជាពាក្យនៃសេចក្ដីសញ្ញា ដែលព្រះអម្ចាស់បានបង្គាប់ឲ្យលោកម៉ូសេកោះហៅជនជាតិអ៊ីស្រាអែលនៅក្នុងទឹកដី ម៉ូអាប់
ក្រៅពីសេចក្ដីសញ្ញាដែលព្រះអង្គបានតាំងជាមួយពួកគេនៅ ភ្នំហោរែប។
[2]លោកម៉ូសេបានកោះហៅជនជាតិអ៊ីស្រាអែលទាំងអស់មក ហើយមានប្រសាសន៍ថា៖ «អ្នករាល់គ្នាបានឃើញផ្ទាល់នឹងភ្នែក
គ្រប់ទាំងហេតុការណ៍ដែលព្រះអម្ចាស់បានធ្វើនៅក្នុងទឹកដីអេស៊ីបនៅចំពោះស្តេចផារ៉ោន និងពួកមហាតលិក
ព្រមទាំងប្រជារាស្ត្រទាំងអស់នៅទឹកដីអេស៊ីប[3]អ្នករាល់គ្នាបានឃើញព្រះអង្គដាក់ទោសពួកគេយ៉ាងធ្ងន់ធ្ងរ ព្រមទាំងទីសម្គាល់ និងការអស្ចារ្យដ៏ធំ។[4]ប៉ុន្តែ
រហូតមកដល់សព្វថ្ងៃនេះ ព្រះអម្ចាស់មិនបានប្រទានឲ្យអ្នករាល់គ្នាមានចិត្តដែលអាចស្វែងយល់ មានភ្នែកដែលអាចមើលឃើញ ឬមានត្រចៀកដែលស្តាប់ឮនៅឡើយ។
[5]យើងបាននាំអ្នករាល់គ្នាក្នុងទីរហោស្ថានអស់រយៈពេលសែសិបឆ្នាំ សម្លៀកបំពាក់របស់អ្នករាល់គ្នាមិនចេះសឹក រេចរឹល ហើយស្បែកជើងរបស់អ្នកក៏មិនបានសឹកដែរ។
[6]អ្នករាល់គ្នាមិនបានបរិភោគនំបុ័ង ឬផឹកស្រាទំពាំងបាយជូរ ឬគ្រឿងស្រវឹងណាសោះឡើយ ដើម្បីឲ្យអ្នករាល់គ្នាដឹងថា ខ្ញុំគឺជាព្រះអម្ចាស់ជាព្រះរបស់អ្នក។
[7]ពេលអ្នករាល់គ្នាមកដល់ទីនេះ ព្រះបាទស៊ីហុនជាស្តេចក្រុងហែសបូន និងព្រះបាទអុកជាស្តេចនៃទឹកដីបាសាន បានចេញមកច្បាំងនឹងយើង
ហើយយើងក៏បានវាយឈ្នះពួកគេ។[8]ពួកយើងដណ្តើមបានទឹកដីរបស់ពួកគេ ហើយក៏ចែកមរតកដល់ពួកកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេ
ចំនួនពាក់កណ្តាល។[9]ដូច្នេះ ចូរកាន់ ហើយប្រព្រឹត្តតាមសេចក្ដីដែលមានចែងទុកក្នុងសម្ពន្ធមេត្រី ដើម្បីឲ្យអ្នករាល់គ្នាបានចម្រើនឡើង ក្នុងគ្រប់កិច្ចការដែលអ្នករាល់គ្នាធ្វើ។
[10]នៅថ្ងៃនេះ អ្នកទាំងអស់គ្នាកំពុងឈរនៅចំពោះព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា គឺមានពួកមេដឹកនាំ មានទាំងកុលសម្ពន្ធ ពួកចាស់ទុំរបស់អ្នករាល់គ្នា ពួកមេទ័ព
និងបុរសនៃជនជាតិអ៊ីស្រាអែលទាំងអស់[11]ពួកកូនតូចៗរបស់អ្នករាល់គ្នា ប្រពន្ធរបស់អ្នករាល់គ្នា និងជនបរទេសដែលរស់នៅក្នុងជំរំជាមួយគ្នា
គឺចាប់ពីពួកអ្នកពុះអុសរហូតដល់អ្នករាល់គ្នារែកទឹក។
[12]ត្រូវចងសម្ពន្ធមេត្រីជាមួយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដោយសច្ចាថា ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាព្រះអង្គស្បថនឹងអ្នកនៅថ្ងៃនេះ[13]ធ្វើដូច្នេះ
ដើម្បីឲ្យអ្នករាល់គ្នានឹងទៅជាប្រជារាស្ត្ររបស់ព្រះអង្គនៅថ្ងៃនេះ ហើយព្រះអង្គនឹងធ្វើជាព្រះរបស់អ្នករាល់គ្នា ដូចដែលព្រះអង្គមានព្រះបន្ទូលជាមួយនឹងអ្នករាល់គ្នា
ដូចព្រះអង្គបានស្បថនឹងលោកអប្រាហាំ លោកអ៊ីុសាក លោកយ៉ាកុបជាបុព្វបុរសរបស់អ្នករាល់គ្នា។
[14]ព្រះអង្គម្ចាស់មិនគ្រាន់តែចងសម្ពន្ធមេត្រីជាមួយអ្នករាល់គ្នា ដែលបានសច្ចាថាអនុវត្តតាមប៉ុណ្ណោះទេ[15]គឺជាមួយអស់អ្នកដែលឈរនៅទីនេះ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់
ជាព្រះរបស់យើង នៅថ្ងៃនេះ ព្រមទាំងអ្នកទាំងអស់ដែលមិនទាន់កើតដែរ។[16]អ្នករាល់គ្នាដឹងស្រាប់ហើយថា យើងធ្លាប់រស់នៅក្នុងទឹកដីអេស៊ីបរបៀបណា
ហើយយើងបានឆ្លងកាត់ទឹកដីរបស់ប្រជាជាតិនានាដោយរបៀបណា។
[17]អ្នករាល់គ្នាបានឃើញការគួរស្អប់ខ្ពើមរបស់គេ គឺព្រះដែលធ្វើពីឈើ និងពីថ្ម ពីប្រាក់ និងពីមាស ដែលនៅក្នុងចំណោមពួកគេ។[18]ដូច្នេះ
មិនត្រូវឲ្យនរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ទោះបីមានបុរស ឬស្ត្រីណា ឬពូជអំបូរណា ឬកុលសម្ព័ន្ធណាមួយក្តី ដែលមានចិត្តបែរចេញពីព្រះអម្ចាស់ជាព្រះរបស់យើង
ហើយទៅគោរពបម្រើព្រះនានារបស់ប្រជាជាតិទាំងនោះ។ ចូរប្រយ័ត្នក្រែងលោក្នុងចំណោមអ្នករាល់គ្នា មាននរណាម្នាក់ក្លាយទៅជាឫសគល់
ដែលបង្កជាតិពុលល្វីងជូរចត់ឡើយ។[19]ក្រោយពីបានឮពាក្យសម្បថនេះហើយ ត្រូវឲ្យពរដល់ខ្លួននៅក្នុងចិត្តថា ខ្ញុំនឹងមានសេចក្ដីសុខ
ទោះបីខ្ញុំដើរតាមចិត្តរឹងចចេសរបស់ខ្ញុំក៏ដោយ។ គំនិតដូច្នេះ នឹងធ្វើឲ្យពួកគេអន្តរាយទាំងអស់គ្នា ទាំងមនុស្សល្អ ទាំងមនុស្សអាក្រក់។
[20]ព្រះអម្ចាស់នឹងមិនអត់ទោសឲ្យមនុស្សបែបនេះឡើយ ផ្ទុយទៅវិញ សេចក្ដីខ្ញាល់ និងសេចក្ដីប្រច័ណ្ឌរបស់ព្រះអម្ចាស់ មុខជាឆាបឆេះគេ
ហើយគ្រប់ទាំងបណ្តាសាដែលកត់ទុកក្នុងគម្ពីរនេះក៏នឹងកើតមានដល់គេ រួចព្រះអម្ចាស់នឹងលុបបំបាត់ឈ្មោះរបស់ពួកគេពីផែនដីនេះ។[21]ព្រះអម្ចាស់នឹងញែកអ្នកនោះ
ពីចំណោមកុលសម្ព័ន្ធនានានៃជនជាតិអ៊ីស្រាអែល ដើម្បីឲ្យរងទុក្ខវេទនា ស្របតាមពាក្យអស់ទាំងបណ្តាសានៃសម្ពន្ធមេត្រី ដែលមានចែងទុកក្នុងគម្ពីរក្រឹត្យវិន័យនេះ។
[22]ឯកូនចៅរបស់អ្នករាល់គ្នាដែលកើតនៅជំនាន់ក្រោយ មានពួកជនបរទេសដែលមកពីស្រុកឆ្ងាយ កាលណាគេឃើញសេចក្ដីវេទនានៅក្នុងទឹកដីនោះ
និងជំងឺផ្សេងៗដែលព្រះអម្ចាស់ធ្វើឲ្យកើតមានចំពោះទឹកដីនេះ[23]គឺទឹកដីទាំងមូលត្រូវឆេះដោយស្ពាន់ធ័រ និងអំបិល គ្មាននរណាអាចសាបព្រោះ គ្មានដំណាំអ្វីដុះ
សូម្បីតែស្មៅក៏គ្មានផង ហើយត្រូវបំផ្លាញដូចក្រុងសូដុម ក្រុងកូម៉ូរ៉ា ក្រុងអាដម៉ា និងក្រុងសេបោម ដែរជាទីក្រុងដែលព្រះអម្ចាស់បំផ្លាញ ដោយសេចក្ដីខ្ញាល់
និងព្រះពិរោធរបស់ព្រះអង្គ[24]ប្រជាជាតិទាំងអស់ពោលថា ហេតុអ្វីបានជាព្រះអម្ចាស់ប្រព្រឹត្តបែបដូច្នេះចំពោះទឹកដីនេះ? ហេតុអ្វីបានជាព្រះអង្គខ្ញាល់បែបនេះ?
[25]នោះគេនឹងឆ្លើយតបវិញថា គឺដោយសារពួកគេបានបោះបង់ចោលសម្ពន្ធមេត្រី ដែលព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេ ដែលព្រះអង្គបានចងជាមួយពួកគេ
នៅពេលដែលព្រះអង្គបាននាំពួកគេចេញពីទឹកដីអេស៊ីប[26]ហើយពួកគេបាននាំគ្នាទៅគោរពបម្រើព្រះដទៃ ជាព្រះដែលគេមិនបានស្គាល់
ហើយព្រះអង្គក៏មិនអនុញ្ញាតឲ្យពួកគេថ្វាយបង្គំដែរ។
[27]ហេតុនេះហើយ បានជាព្រះអម្ចាស់ព្រះពិរោធយ៉ាងខ្លាំងទាស់នឹងទឹកដីនេះ ហើយទម្លាក់អស់ទាំងបណ្តាសាដែលបានចែងទុកក្នុងគម្ពីរនេះ កើតមានដល់ពួកគេ។
[28]ព្រះអម្ចាស់បានដកពួកគេចេញពីទឹកដីរបស់ខ្លួន ដោយព្រះហឫទ័យខ្ញាល់យ៉ាងខ្លាំងបំផុត ហើយព្រះអង្គបានបោះពួកគេចោលទៅក្នុងទឹកដីមួយទៀត
រហូតមកដល់សព្វថ្ងៃនេះ។
[29]មានតែព្រះអម្ចាស់ជាព្រះរបស់យើងតែប៉ុណ្ណោះ ដែលជ្រាបនូវអ្វីៗដែលលាក់កំបាំងនេះ ព្រះអង្គបើកឲ្យយើង និងកូនចៅរបស់យើងគ្រប់ជំនាន់តទៅ
ដើម្បីឲ្យយើងប្រព្រឹត្តតាមអស់ទាំងពាក្យក្នុងក្រឹត្យវិន័យនេះ។

Deuteronomy 29:1

ទាំងនេះគឺជាពាក្យនៃសេចក្ដីសញ្ញា ដែលព្រះអម្ចាស់បានបង្គាប់ឲ្យលោកម៉ូសេកោះហៅ

នេះសំដៅទៅលើពាក្យដែលលោកម៉ូសេកំពុងនិយាយ។

នៅក្នុងទឹកដីម៉ូអាប់

នៅត្រើយខាងកើតទន្លេយ័រដាន់ជាកន្លែង ដែលជនជាតិអ៊ីស្រាអែលបានស្នាក់នៅ

មុនពេលពួកគេចូលទឹកដីកាណាន។ «ពេលពួកគេនៅស្រុកម៉ូអាប់»

ក្រៅពីសេចក្ដីសញ្ញាដែលព្រះអង្គបានតាំង ... ភ្នំហោរែប។

បទបញ្ជាបន្ថែមទាំងនេះត្រូវបានផ្តល់ឱ្យ

ដើម្បីធ្វើឱ្យសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់អនុវត្តបានល្អប្រសើរ សម្រាប់ប្រជាជន

នៅពេលពួកគេបានតាំងទីលំនៅនៅក្នុងទឹកដីថ្មីរបស់ពួកគេ។

បទបញ្ជាថ្មីទាំងនេះមិនមែនជាសម្ពន្ធមេត្រីផ្សេងទេតែជាការបន្ថែមលើសម្ពន្ធមេត្រីចាស់

Deuteronomy 29:2

អ្នករាល់គ្នាបានឃើញផ្ទាល់នឹងភ្នែក គ្រប់ទាំងហេតុការណ៍ដែលព្រះអម្ចាស់បានធ្វើ

នៅទីនេះ «ភ្នែក» បញ្ជាក់ថា

ព្រះអម្ចាស់សង្ឃឹមទុកថាពួកគេចងចាំអ្វីពួកគេបានឃើញ។ ការបកប្រែផ្សេងទៀត

«អ្នករាល់គ្នាបានឃើញអ្វីៗ ដែលព្រះអម្ចាស់បានធ្វើដើម្បីឲ្យអ្នកបានឃើញ

និងចងចាំនូវអ្វី ដែលព្រះអង្គបានធ្វើ»

អ្នករាល់គ្នាបានឃើញផ្ទាល់នឹងភ្នែកព្រះអង្គដាក់ទោសពួកគេយ៉ាងធ្ងន់ធ្ងរ

នៅទីនេះ «ភ្នែក» បញ្ជាក់ថា ព្រះអម្ចាស់រំពឹងទុកថា

ពួកគេចងចាំអ្វីពួកគេបានឃើញ។ ការបកប្រែផ្សេងទៀត

«អ្នករាល់គ្នាបានឃើញដោយខ្លួនឯងថា ប្រជាជនរងគ្រោះយ៉ាងធ្ងន់ធ្ងរ»

ផ្ទាល់នឹងភ្នែក

លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ

ពាក្យ «របស់អ្នក» នៅទីនេះជាឯកវចនៈ។

ព្រមទាំងទីសម្គាល់ និងការអស្ចារ្យដ៏ធំ។

ពាក្យថា« ទីសម្គាល់» និង«ការអស្ចារ្យដ៏ធំ» ទាំងពីរសំដៅទៅលើគ្រោះកាច

ដែលព្រះអម្ចាស់បានចាត់មកស្រុកអេស៊ីប។ ការបកប្រែផ្សេងទៀត

«និងរបស់ដ៏មានឥទ្ធិឫទ្ធិទាំងប៉ុន្មាន ដែលព្រះអម្ចាស់បានធ្វើ»

ព្រះអម្ចាស់មិនបានប្រទានឲ្យអ្នករាល់គ្នាមានចិត្តដែលអាចស្វែងយល់

មានភ្នែកដែលអាចមើលឃើញ ឬមានត្រចៀកដែលស្តាប់ឮនៅឡើយ។

generated on Wed Sep 10 16:16:32 2025

ប្រជាជនពិតជាមានចិត្ត ភ្នែក និងត្រចៀក។ នេះជាឃ្លានិយាយថា
ព្រះអម្ចាស់មិនបានជួយពួកគេឱ្យយល់ពីអ្វី ដែលពួកគេបានឃើញនិងឮ
ដែលព្រះអម្ចាស់ជានរណា និងពីមូលហេតុ
និងរបៀបដែលពួកគេគួរតែស្តាប់បង្គាប់ព្រះអង្គឡើយ។
មានចិត្តដែលអាចស្វែងយល់
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «អាចឱ្យអ្នកយល់»
Deuteronomy 29:5
យើងបានដឹកនាំអ្នករាល់គ្នា
ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
សែសិបឆ្នាំ
«៤០ឆ្នាំ»
ស្បែកជើង ... របស់អ្នក
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ«របស់អ្នក» នៅទីនេះមានលក្ខណៈឯកវចនៈ។
គ្រឿងស្រវឹង
ជាតិអាល់កុលប្រហែលជាមកពីបាយស្រា។ ពួកវាមិនមែនជាស្រាបិតទេ។
Deuteronomy 29:7
ព្រះបាទស៊ីហុនជាស្តេចក្រុងហែសបូន និងព្រះបាទអុកជាស្តេចនៃទឹកដីបាសាន
បកប្រែឈ្មោះទាំងនេះដូចនៅក្នុង ១:៣។
បានចេញមកច្បាំងនឹងយើង
នៅទីនេះ «យើង» សំដៅទៅលើលោកម៉ូសេ និងប្រជាជនអ៊ីស្រាអែល។
ចូរកាន់ ហើយប្រព្រឹត្តតាមសេចក្តីដែលមានចែងទុកក្នុងសម្ពន្ធមេត្រី
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយសង្កត់ធ្ងន់ថាប្រជាជនត្រូវស្តាប់បង្គាប់តាមបង្គាប់របស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ស្តាប់បង្គាប់តាមតាមពាក្យទាំងអស់នៃក្នុងសម្ពន្ធមេត្រីនេះ»
Deuteronomy 29:10
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដែលរស់នៅក្នុងជំរំជាមួយគ្នា ...អ្នកពុះអុស ... រែកទឹក
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ជនបរទេសដែលរស់នៅក្នុងជំរំជាមួយគ្នា គឺចាប់ពីពួកអ្នកពុះអុសរហូតដល់អ្នករាល់គ្នារែកទឹក។
មានជនបរទេសជាច្រើនក្នុងចំណោមជនជាតិអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ជនបរទេសដែលនៅក្នុងចំណោមអ្នករាល់គ្នា នៅក្នុងជំរំរបស់អ្នករាល់គ្នាចាប់ពីអ្នក
ដែលពុះអុសទាំងអស់នេះដល់អ្នករែកទឹក»
Deuteronomy 29:12
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ត្រូវចងសម្ពន្ធមេត្រីជាមួយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដោយសច្ចាថា
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាព្រះអង្គស្បថនឹងអ្នកនៅថ្ងៃនេះ
«យល់ព្រមនឹងសម្ពន្ធមេត្រីហើយស្បថថា
អ្នករាល់គ្នានឹងស្តាប់បង្គាប់តាមអ្វីៗទាំងអស់
ដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបង្គាប់»
ទៅជាប្រជារាស្ត្ររបស់ព្រះអង្គ
«ក្រុមប្រជារាស្ត្រដែលជាកម្មសិទ្ធិរបស់ព្រះអង្គតែមួយគត់»
Deuteronomy 29:14
ព្រះអង្គម្ចាស់មិនគ្រាន់តែចងសម្ពន្ធមេត្រីជាមួយអ្នករាល់គ្នា
នៅទីនេះ «ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។ «ព្រះអម្ចាស់កំពុងតែបង្កើត»
ដែលឈរនៅទីនេះ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់យើង
នៅទីនេះ «យើង» សំដៅទៅលើលោកម៉ូសេនិងប្រជាជនអ៊ីស្រាអែល។
ព្រមទាំងអ្នកទាំងអស់ដែលមិនទាន់កើតដែរ។
«កូនចៅនាអនាគតរបស់យើងដែលមិននៅទីនេះ»
យើងធ្លាប់រស់នៅ
«យើងជាទាសករ»
Deuteronomy 29:17
ដែលមានចិត្តបែរចេញពីព្រះអម្ចាស់ជាព្រះរបស់យើង
នៅទីនេះ «ចិត្ត» សំដៅទៅលើមនុស្សទាំងមូល ហើយ « បែរចេញ»
មានន័យថាឈប់ស្តាប់បង្គាប់តាម។ ការបកប្រែផ្សេងទៀត
«អ្នកដែលមិនស្តាប់បង្គាប់ព្រះអម្ចាស់ជាព្រះរបស់យើង»
មាននរណាម្នាក់ក្លាយទៅជាឫសគល់ ដែលបង្កជាតិពុលល្វីងជូរចត់ឡើយ។
លោកម៉ូសេនិយាយអំពីនរណាម្នាក់ ដែលថ្វាយបង្គំព្រះមួយទៀតដោយលួចលាក់
ដូចគាត់ចាក់ឫសហើយអំពើអាក្រក់គាត់ ដែលគាត់គោរពបម្រើព្រះក្លែងក្លាយ
ហើយគាត់លើកទឹកចិត្តអ្នកដទៃឱ្យធ្វើដូចជារុក្ខជាតិពុលល្វីងជូរចត់
ដែលបំពុលមនុស្ស។ ការបកប្រែផ្សេងទៀត «មនុស្សណាដែលថ្វាយបង្គំរូបព្រះ
ហើយធ្វើឱ្យអ្នកដទៃមិនស្តាប់ស្តាប់តាមដល់ព្រះអម្ចាស់»
មនុស្ស
មនុស្សដែលបានពិពណ៌នានៅក្នុងខ១៨ ។
ត្រូវឲ្យពរដល់ខ្លួននៅក្នុងចិត្ត
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «អបអរសាទរខ្លួនឯង» ឬ
«លើកទឹកចិត្តខ្លួនឯង»
ខ្ញុំដើរតាមចិត្តរឹងចចេសរបស់ខ្ញុំក៏ដោយ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ទោះបីខ្ញុំនៅតែបដិសេធមិនស្តាប់បង្គាប់ព្រះអម្ចាស់»
នឹងធ្វើឲ្យពួកគេអន្តរាយទាំងអស់គ្នា ទាំងមនុស្សល្អ ទាំងមនុស្សអាក្រក់។
នៅទីនេះពាក្យ «សើម»និង«ស្ងួត»
គឺជាពាក្យប្រៀបធៀបសម្រាប់មនុស្សល្អនិងមនុស្សអាក្រក់។
បង្កើតបានជាការរួមបញ្ចូលគ្នាសម្រាប់ «មនុស្សគ្រប់គ្នា»។ ការបកប្រែផ្សេងទៀត
«នឹងធ្វើឱ្យព្រះអម្ចាស់បំផ្លាញទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតនៅក្នុងស្រុក»
មនុស្សល្អ ... មនុស្សអាក្រក់
គុណនាមបន្ទាប់បន្សំទាំងនេះអាចត្រូវបានបកប្រែជានាម។
ដោយសារតែដីនេះស្ងួតជាធម្មតាហើយប្រជាជនត្រូវការភ្លៀង
ដើម្បីឱ្យដំណាំរបស់ពួកគេលូតលាស់ពាក្យទាំងនេះ គឺជាពាក្យប្រៀបធៀបសម្រាប់
«រស់ ... ស្លាប់» ឬ «ល្អ ... អាក្រក់»។ ការបកប្រែផ្សេងទៀត «វត្ថុសើម ...
វត្ថុស្ងួត» ឬ «មនុស្សល្អ ... មនុស្សអាក្រក់»
Deuteronomy 29:20
សេចក្តីខ្ញាល់ និងសេចក្តីប្រចណ្ឌរបស់ព្រះអម្ចាស់ មុខជាឆាបឆេះគេ
ដូចជាភ្លើងអាចឆេះខ្លាំងឡើងដែរ ដូច្នេះ
សេចក្តីក្រោធនិងការប្រចណ្ឌរបស់ព្រះជាម្ចាស់កាន់តែខ្លាំងឡើង។
ការបកប្រែផ្សេងទៀត
«សេចក្តីក្រោធព្រមទាំងការប្រចណ្ឌរបស់ព្រះអម្ចាស់នឹងឆេះដូចជាភ្លើង»
សេចក្តីខ្ញាល់ និងសេចក្តីប្រច័ណ្ឌរបស់ព្រះអម្ចាស់
នៅទីនេះពាក្យថា «សេចក្តីប្រចណ្ឌ» ពិពណ៌នាអំពី «ការខ្ញាល់របស់ព្រះអម្ចាស់»។
ការបកប្រែផ្សេងទៀត «សេចក្តីក្រោធព្រមទាំងការប្រចណ្ឌរបស់ព្រះអម្ចាស់»
ដែលកត់ទុក
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដែលខ្ញុំបានសរសេរ»
ហើយគ្រប់ទាំងបណ្តាសាដែលកត់ទុកក្នុងគម្ពីរនេះក៏នឹងកើតមានដល់គេ
លោកម៉ូសេពិពណ៌នាបណ្តាសានេះ
ដូចជាមនុស្សម្នាក់ដែលនឹងវាយប្រហារពួកគេដោយការភ្ញាក់ផ្អើល។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងដាក់បណ្តាសាគាត់ដោយបណ្តាសា
ដែលមានកត់ទុកនៅក្នុងគម្ពីរ តាមរបៀបដែលធ្វើឱ្យគាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង»។
ពាក្យស្រដៀងគ្នានេះកើតមានឡើងនៅក្នុង ២៨:១៥។
រួចព្រះអម្ចាស់នឹងលុបបំបាត់ឈ្មោះរបស់ពួកគេពីផែនដីនេះ។
នេះមានន័យថា ព្រះជាម្ចាស់នឹងបំផ្លាញមនុស្ស និងក្រុមគ្រួសាររបស់គេទាំងស្រុង។
នៅពេលអនាគតមនុស្សនឹងមិនចងចាំគាត់ទេ។
ឃ្លាស្រដៀងគ្នានេះកើតមានឡើងនៅក្នុង ៧:២៣។
Deuteronomy 29:22
ឯកូនចៅរបស់អ្នករាល់គ្នាដែលកើតនៅជំនាន់ក្រោយ
ពាក្យថា «កូនចៅរបស់អ្នក ... នៅជំនាន់ក្រោយ»
«ប្រាប់ថានរណាជាមនុស្សជំនាន់ក្រោយ»។
សេចក្តីវេទនានៅក្នុងទឹកដីនោះ និងជំងឺផ្សេងៗដែលព្រះអម្ចាស់ធ្វើឲ្យកើតមានចំពោះទឹកដីនេះ
«របៀបដែលព្រះជាម្ចាស់បានដាក់បណ្តាសាទឹកដីកាណាន
ដោយគ្រោះកាចនិងជម្ងឺ»
គឺទឹកដីទាំងមូលត្រូវឆេះដោយស្ពាន់ធ័រ និងអំបិល
មនុស្សដាក់ស្ពាន់ធ័រនិងអំបិល ទៅលើដីកុំឱ្យមានអ្វីដុះលូតលាស់ឡើង។
«នៅពេលពួកគេឃើញថា ព្រះអម្ចាស់បានដុតទឹកដី ដោយស្ពាន់ធ័រនិងអំបិល»
គ្មាននរណាអាចសាបព្រោះ គ្មានដំណាំអ្វីដុះ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«កន្លែងដែលគ្មាននរណាម្នាក់អាចសាបព្រោះគ្រាប់ពូជ
ហើយដំណាំមិនបង្កើតផល»
ហើយត្រូវបំផ្លាញដូចក្រុងសូដុម ក្រុងកូម៉ូរ៉ា
នាមអរូបី «បំផ្លាញ »អាចត្រូវបានបកប្រែជាឃ្លាមួយ។ ការបកប្រែផ្សេងទៀត
«ដូចជានៅពេលព្រះអម្ចាស់បំផ្លាញទីក្រុងសូដុម និងកូម៉ូរ៉ាទាំងស្រុង»
ក្រុងអាដម៉ា និងក្រុងសេប៉ោម
នេះជាឈ្មោះក្រុងនានា ដែលព្រះអម្ចាស់បានបំផ្លាញជាមួយក្រុងសូដុម និងកូម៉ូរ៉ា។
ដោយសេចក្តីខ្ញាល់ និងព្រះពិរោធរបស់ព្រះអង្គ
នាមអរូបី «សេចក្តីខ្ញាល់ » និង «ព្រះពិរោធ» មានន័យថាជារួមដូចគ្
នាហើយអាចបកប្រែជាឃ្លាគុណនាម។ ការបកប្រែផ្សេងទៀត
«នៅពេលព្រះអង្គព្រះពិរោធ»
ប្រជាជាតិទាំងអស់ពោលថា ... ខ្ញាល់បែបនេះ?
អាចបកប្រែជាការដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«ពួកគេនឹងសួរទៅកាន់ប្រជាជាតិដទៃទៀតថា ហេតុអ្វីបានជាព្រះអម្ចាស់ធ្វើដូច្នេះ
ចំពោះស្រុកនេះនិងថាតើកំដៅនៃព្រះពិរោធដ៏ខ្លាំងនេះមានន័យយ៉ាងណា?»
ប្រជាជាតិទាំងអស់ពោលថា
«កូនចៅរបស់អ្នកនិងប្រជាជននៃប្រជាជាតិផ្សេងៗទាំងអស់នឹងនិយាយ»
ហេតុអ្វីបានជាព្រះអង្គខ្ញាល់បែបនេះ?
អ្នកនិពន្ធកំពុងបញ្ជូនគំនិតមួយតាមរយៈពាក្យពីរ។ ការបកប្រែផ្សេងទៀត
«តើសេចក្តីខ្ញាល់ ដ៏គួរឱ្យភ័យខ្លាចនេះមានន័យយ៉ាងណា?»
Deuteronomy 29:25
គឺដោយសារពួកគេបានបោះបង់ចោលសម្ពន្ធមេត្រី ដែលព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេ
នេះជាចម្លើយ «ហេតុអ្វីបានជាព្រះអម្ចាស់ធ្វើដូច្នេះ ចំពោះស្រុកនេះ?» (២៩:២២)។
«ព្រះអម្ចាស់បានធ្វើដូច្នេះ
ចំពោះស្រុកនេះព្រោះជនជាតិអ៊ីស្រាអែលមិនបានគោរពតាមការសន្យា
និងក្រឹត្យវិន័យនៃសម្ពន្ធមេត្រីរបស់ព្រះអង្គទេ»។
នាំគ្នាទៅគោរពបម្រើព្រះដទៃ
«ស្តាប់ស្តាប់ព្រះដទៃ ហើយគោរពបម្រើព្រះដទៃ»
Deuteronomy 29:27
ព្រះអម្ចាស់ព្រះពិរោធយ៉ាងខ្លាំងទាស់នឹងទឹកដីនេះ
លោកម៉ូសេបានប្រៀបធៀបការ
ដែលព្រះអម្ចាស់ព្រះពិរោធទៅនឹងនរណាម្នាក់ដុតភ្លើង។
សង្កត់ធ្ងន់លើអំណាចរបស់ព្រះជាម្ចាស់
ដើម្បីបំផ្លាញអ្វីៗដែលធ្វើឱ្យព្រះអង្គទ្រង់ពិរោធ
ហើយអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ព្រះពិរោធជាមួយនឹងទឹកដីនេះណាស់»
ទឹកដីនេះ ហើយទម្លាក់អស់ទាំង
នៅទីនេះ «ទឹកដី» ជាឃ្លាតំណាងឱ្យប្រជាជន។ ការបកប្រែផ្សេងទៀត
«ប្រជាជននៅលើទឹកដីនេះដើម្បីនាំពួកគេ»
បានចែងទុក
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដែលខ្ញុំបានសរសេរ»
ព្រះអម្ចាស់បានដកពួកគេចេញពីទឹកដីរបស់ខ្លួន ដោយព្រះហឫទ័យខ្ញាល់យ៉ាងខ្លាំងបំផុត
ហើយព្រះអង្គបានបោះពួកគេចោល
អ៊ីស្រាអែលត្រូវបានគេប្រៀបធៀបទៅនឹងរុក្ខជាតិអាក្រក់មួយ
ដែលព្រះអម្ចាស់បានដកនិងបោះចេញពីសួនច្បារ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានដកពួកគេចេញពីទឹកដីរបស់ពួកគេ...ហើយបានបង្ខំពួកគេឱ្យទៅ»
ដោយព្រះហឫទ័យខ្ញាល់យ៉ាងខ្លាំងបំផុត
ពាក្យថា «ខ្ញាល់» «ព្រះពិរោធ» និង «កំហឹង»មានន័យថាជារួមដូចគ្នា
និងបញ្ជាក់ពីអំណាចនៃព្រះពិរោធរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រះពិរោធយ៉ាងខ្លាំងបំផុត» ឬ «ព្រោះព្រះអង្គខ្ញាល់ខ្លាំងណាស់»។
Deuteronomy 29:29
មានតែព្រះអម្ចាស់ជាព្រះរបស់យើងតែប៉ុណ្ណោះ
«មានរឿងខ្លះដែលព្រះអម្ចាស់ជាព្រះនៃយើង មិនបានបើកសម្តែងឱ្យគេស្គាល់
ហើយមានតែព្រះអង្គមួយគត់ប៉ុណ្ណោះ ដែលជ្រាបអ្វីៗទាំងអស់»
ដែលជ្រាបនូវអ្វីៗដែលលាក់កំបាំងនេះ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលព្រះអង្គបានបង្ហាញ»
យើងប្រព្រឹត្តតាមអស់ទាំងពាក្យក្នុងក្រឹត្យវិន័យនេះ។
ពាក្យថា «ពាក្យ» ជាឃ្លាសម្រាប់ «ពាក្យបញ្ជា» ។ ការបកប្រែផ្សេងទៀត
«យើងអាចធ្វើអ្វីគ្រប់យ៉ាងដែលក្រឹត្យវិន័យបង្គាប់ឱ្យយើងធ្វើ»

30

[1]នៅពេលសេចក្តីទាំងនេះបានកើតលើអ្នករាល់គ្នា គឺការប្រទានព្រះពរ និងបណ្តាសា ដែលខ្ញុំបានដាក់នៅមុខអ្នករាល់គ្នា
ហើយនៅពេលអ្នករាល់គ្នានឹកឃើញសេចក្តីទាំងនេះ នៅក្នុងចំណោមប្រជាជាតិដទៃទាំងអស់
ជាកន្លែងដែលព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នាបានបណ្តេញអ្នករាល់គ្នា[2]ព្រមទាំងនៅពេលអ្នករាល់គ្នាវិលត្រលប់មកកាន់ព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នាវិញ
ហើយស្តាប់តាមព្រះសូរសៀងរបស់ព្រះអង្គ ក្នុងគ្រប់ការទាំងអស់ដែលខ្ញុំកំពុងបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ ទាំងអ្នករាល់គ្នា និងកូនចៅរបស់អ្នករាល់គ្នាដោយអស់អំពីចិត្ត
និងអស់អំពីព្រលឹងរបស់អ្នករាល់គ្នា[3]នោះព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នានឹងស្តារស្ថានភាពរបស់អ្នករាល់គ្នា
និងមានព្រះហឫទ័យអាណិតអាសូរដល់អ្នករាល់គ្នាព្រះអង្គនឹងបែរមក ហើយប្រមូលផ្តុំអ្នករាល់គ្នាវិញ
ចេញពីប្រជាជនទាំងអស់ជាកន្លែងដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានកម្ចាត់កម្ចាយអ្នករាល់ទៅនោះ។
[4]ប្រសិនបើ ប្រជាជនដែលត្រូវខ្ចាត់ខ្ចាយទៅកន្លែងឆ្ងាយបំផុតនៅលើផែនដី ក៏ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងប្រមូលអ្នករាល់គ្នា
ហើយព្រះអង្គនឹងនាំអ្នករាល់គ្នាចេញពីទីនោះ។[5]ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងនាំអ្នករាល់គ្នាចូលទៅកាន់ទឹកដីដែលដូនតារបស់អ្នករាល់គ្នាបានកាន់កាប់
ហើយអ្នករាល់គ្នានឹងកាន់កាប់ទឹកដីនោះម្តងទៀត ព្រះអង្គនឹងធ្វើការល្អ ហើយនឹងចម្រើនអ្នករាល់គ្នាបន្ថែមទៀត
គឺច្រើនជាងព្រះអង្គបានប្រទានដល់ដូនតារបស់អ្នករាល់គ្នាទៅទៀត។
[6]ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងកាត់ស្បែកចិត្តរបស់អ្នករាល់គ្នា ហើយចិត្តរបស់ពូជពង្សអ្នករាល់គ្នា ដូច្នេះ
អ្នករាល់គ្នាត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាដោយអស់អំពីចិត្ត និងអស់អំពីព្រលឹងរបស់អ្នករាល់គ្នា ធ្វើដូច្នេះ អ្នករាល់គ្នាអាចរស់នៅបាន។
[7]ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាទម្លាក់បណ្តាសាទាំងអស់នេះលើសត្រូវ និងលើអ្នកណាដែលស្អប់អ្នករាល់គ្នា ព្រមទាំងអស់អ្នកណាដែលបៀតបៀនអ្នករាល់គ្នា។
[8]អ្នករាល់គ្នានឹងត្រឡប់មកវិញ ហើយស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់ អ្នករាល់គ្នានឹងប្រព្រឹត្តតាមសេចក្តីបង្គាប់ទាំងអស់
ដែលខ្ញុំកំពុងបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ។
[9]ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងធ្វើប្រទានឲ្យអ្នករាល់គ្នាបានចម្រុងចម្រើនកិច្ចការដែលដៃអ្នករាល់គ្នាបានធ្វើ ទាំងផលផ្លែនៃអ្នករាល់គ្នា
ទាំងផលនៃហ្វូងសត្វរបស់អ្នក ព្រមទាំងផលដែលកើតចេញដីរបស់អ្នករាល់គ្នា ដ្បិត ព្រះអម្ចាស់នឹងរីករាយប្រោសឲ្យអ្នករាល់គ្នាម្តងទៀត
ដូចជាព្រះអង្គបានរីករាយនឹងដូនតារបស់អ្នករាល់គ្នាដែរ។[10]ព្រះអង្គនឹងកាន់តាមសេចក្តីនេះ ប្រសិនបើ
អ្នករាល់គ្នាស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា គឺកាន់តាមសេចក្តីបង្គាប់របស់ព្រះអង្គ និងបទបញ្ជាដែលបានចារនៅក្នុងគម្ពីរក្រឹតវិន័យនេះ
ប្រសិនបើ អ្នករាល់គ្នាបែរមកព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាវិញ ដោយអស់អំពីចិត្ត និងអស់អំពីព្រលឹងរបស់អ្នករាល់គ្នា។
[11]ដ្បិត សេចក្តីបង្គាប់ ដែលខ្ញុំកំពុងតែបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ គឺមិនពិបាកខ្លាំងពេកសម្រាប់អ្នករាល់គ្នាទេ ហើយក៏មិនមែននៅឆ្ងាយដែរ។
[12]សេចក្តីនេះមិនមែននៅលើស្ថានសួគ៌ទេ ដូច្នេះហើយ អ្នករាល់គ្នាគួរតែនិយាយថា តើអ្នកណានឹងឡើងទៅដើម្បីពួកយើង និងនាំសេចក្តីទាំងនេះចុះមកឲ្យយើង
ព្រមទាំងធ្វើឲ្យយើងអាចនឹងស្តាប់ឮផង ដើម្បីឲ្យយើងប្រតិបត្តិតាម?

generated on Wed Sep 10 16:16:32 2025

[13]ក៏មិនមែននៅត្រើយខាងនាយសមុទ្រ ដូច្នេះ អ្នករាល់គ្នាគួរនិយាយថា តើអ្នកណានឹងឆ្លងសមុទ្រសម្រាប់ពួកយើង និងនាំយកព្រះបន្ទូលមកកាន់ពួកយើង
ហើយធ្វើឲ្យពួកយើងបានឮ ដើម្បីឲ្យយើងអាចនឹងប្រតិបិត្តតាមផង?[14]ប៉ុន្តែ ព្រះបន្ទូលគឺនៅក្បែរនឹងអ្នករាល់គ្នា គឺនៅក្នុងមាត់ និងចិត្តរបស់អ្នករាល់គ្នា
ដើម្បីឲ្យអ្នករាល់គ្នាអាចប្រតិបត្តិតាមបាន។
[15]មើល៍ ថ្ងៃនេះខ្ញុំបានដាក់ជីវិត និងសេចក្តីល្អ នៅពីមុខអ្នករាល់គ្នា ព្រមទាំងសេចក្តី និងអំពើអាក្រក់។[16]ប្រសិនបើ
អ្នករាល់គ្នាស្តាប់តាមច្បាប់នៃព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាដែលខ្ញុំកំពុងតែបង្គាប់អ្នករាល់គ្នានៅថ្ងៃនេះ ដើម្បីស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ដោយដើរតាមផ្លូវរបស់ព្រះអង្គ និងកាន់តាមសេចក្តីបង្គាប់របស់អង្គ ព្រមទាំងបទបញ្ជា និងបញ្ញាតិទាំងឡាយរបស់ព្រះអង្គ នោះអ្នករាល់គ្នានឹងមានជីវិតរស់នៅ
និងចម្រើនឡើង ហើយព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងប្រទានព្រះពរដល់អ្នករាល់គ្នា នៅក្នុងទឹកដីដែលអ្នករាល់គ្នានឹងចូលទៅកាន់កាប់នោះ។
[17]ប៉ុន្តែ ប្រសិនបើ ចិត្តរបស់អ្នករាល់គ្នាងាកចេញ និងមិនព្រមស្តាប់ តែបណ្តោយឲ្យគេទាញអ្នករាល់គ្នាទៅថ្វាយបង្គំ
និងគោរពប្រតិបត្តិដល់ព្រះដទៃ[18]នោះសូមខ្ញុំប្រកាសប្រាប់អ្នករាល់គ្នានៅថ្ងៃនេះថា អ្នករាល់គ្នានឹងត្រូវវិនាសជាប្រាកដ អ្នករាល់គ្នានឹងមិនមានអាយុវែងនៅលើទឹកដី
ដែលអ្នករាល់គ្នានឹងឆ្លងកាត់ទន្លេយ័រដាន់ ដើម្បីចូលទៅកាន់កាប់ឡើយ។
[19]ខ្ញុំហៅមេឃ និងផែនដីធ្វើជាសាក្សីប្រឆាំងនឹងអ្នករាល់គ្នានៅថ្ងៃនេះថា ខ្ញុំបានដាក់ជីវិត និងសេចក្តីស្លាប់ ព្រះពរ និងបណ្តាសា នៅពីមុខអ្នករាល់គ្នា ដូច្នេះ
ចូរជ្រើសរើសជីវិត ដើម្បីឲ្យអ្នករាល់គ្នាអាចរស់នៅបាន ទាំងអ្នក និងពូជពង្សរបស់អ្នករាល់គ្នា។[20]ធ្វើយ៉ាងនេះ ដើម្បីបញ្ជាក់ថា
អ្នករាល់គ្នាស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដើម្បីស្តាប់តាមព្រះសូរសៀង និងនៅជាប់នឹងព្រះអង្គ។ ដ្បិតព្រះអង្គគឺជាជីវិតរបស់អ្នករាល់គ្នា
និងជាអាយុយឺនយូររបស់អ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីឲ្យអ្នករាល់គ្នាអាចរស់នៅក្នុងទឹកដី ដែលព្រះអម្ចាស់បានស្បថចំពោះដូនតារបស់អ្នក គឺចំពោះលោកអប្រាហាំ
លោកអ៊ីសាក និងលោកយ៉ាកុប ថានឹងប្រទានដល់ពួកលោក»។

Deuteronomy 30:1

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

នៅពេលសេចក្តីទាំងនេះបានកើតលើអ្នករាល់គ្នា

នៅទីនេះ «របស់ទាំងនេះ» សំដៅទៅលើព្រះពរ និងបណ្តាសា
ដែលបានពិពណ៌នានៅក្នុងជំពូក ២៨-២៩ ។ ឃ្លាថា «បានកើតលើអ្នករាល់គ្នា» ជាពាក្យសម្តីដែលមានន័យថាកើតឡើង។ ការបកប្រែផ្សេងទៀត
«នៅពេលដែលរឿងទាំងអស់នេះកើតឡើង ចំពោះអ្នករាល់គ្នា»

ដែលខ្ញុំបានដាក់នៅមុខអ្នករាល់គ្នា

និយាយអំពីព្រះពរ និងបណ្តាសា ដែលលោកម៉ូសេបានប្រាប់ប្រជាជនដូចវាជាវត្ថុ
ដែលគាត់បានដាក់នៅចំពោះមុខពួកគេ។ ការបកប្រែផ្សេងទៀត
«ដែលខ្ញុំទើបតែបានប្រាប់អ្នករាល់គ្នាឥឡូវនេះ»

នឹកឃើញសេចក្តីទាំងនេះ

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ចងចាំពួកគេ»

នៅក្នុងចំណោមប្រជាជាតិដទៃ

«ខណៈពេលដែលអ្នកកំពុងរស់នៅក្នុងប្រជាជាតិផ្សេងទៀត»

បានបណ្តេញអ្នករាល់គ្នា

«បានបង្ខំអ្នករាល់គ្នាឱ្យទៅ»

ហើយស្តាប់តាមព្រះសូរសៀងរបស់ព្រះអង្គ

នៅទីនេះ «សំឡេង» សំដៅទៅលើអ្វី ដែលព្រះអម្ចាស់មានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «ស្តាប់បង្គាប់តាមអ្វី ដែលព្រះអង្គមានបន្ទូល»

ដោយអស់អំពីចិត្ត និងអស់អំពីព្រលឹងរបស់អ្នករាល់គ្នា

ឃ្លា «ដោយអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង «ដោយអស់ពីព្រលឹង» មានន័យថា «អស់ពីខ្លួនអ្នក» ។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ការបកប្រែផ្សេងទៀត «ដោយភាពអស់ពីសមត្ថភាពរបស់អ្នក» ឬ
«ដោយថាមពលទាំងអស់របស់អ្នក»។ បកប្រែពាក្យទាំងនេះដូចនៅក្នុង ៤:២៩។

ស្តារស្ថានភាពរបស់អ្នករាល់គ្នា

«ដោះលែងអ្នកពីការឃុំឃាំងខ្លួនឯង»។ នាមអរូបី «ការចាប់យក»
អាចត្រូវបានបកប្រែជាឃ្លាមួយ។ ការបកប្រែផ្សេងទៀត
«ដោះលែងអ្នកពីអ្នកដែលចាប់អ្នក»

Deuteronomy 30:4

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ប្រសិនបើ ប្រជាជនដែលត្រូវខ្ចាត់ខ្ចាយទៅកន្លែងឆ្ងាយបំផុត

«សូម្បីតែប្រជាជនដែលនិរទេសខ្លួន ទៅនៅកន្លែងឆ្ងាយបំផុត»

បំផុតនៅលើផែនដី

«នៅក្រោមមេឃ»ឬ «នៅលើផែនដី»

Deuteronomy 30:6

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

កាត់ស្បែកចិត្តរបស់អ្នករាល់គ្នា

នេះមិនមែនជាការដកសាច់ចេញតាមន័យត្រង់ទេ។មានន័យថា
ព្រះជាម្ចាស់នឹងដកអំពើបាបរបស់ពួកគេចេញ ហើយជួយឱ្យពួកគេអាចស្រឡាញ់
និងស្តាប់បង្គាប់ព្រះអង្គ។

ដោយអស់អំពីចិត្ត និងអស់អំពីព្រលឹងរបស់អ្នករាល់គ្នា

ឃ្លា «ដោយអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង «ដោយអស់ពីព្រលឹង» មានន័យថា «អស់ពីខ្លួនអ្នក» ។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ការបកប្រែផ្សេងទៀត «ដោយភាពអស់ពីសមត្ថភាពរបស់អ្នក» ឬ
«ដោយថាមពលទាំងអស់របស់អ្នក»។ បកប្រែដូចនៅក្នុង ៤:២៩។

ហើយស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់

នៅទីនេះ« សំឡេង» មានន័យថា អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «ស្តាប់បង្គាប់តាមអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល»

ទម្លាក់បណ្តាសាទាំងអស់នេះលើសត្រូវ

លោកម៉ូសេនិយាយអំពីការដាក់បណ្តាសា ដូចជាបន្ទុកឬ
ការគ្រប់បាំងពីលើដែលនរណាម្នាក់ អាចដាក់លើខ្លួនមនុស្សបាន។
ការបកប្រែផ្សេងទៀត «នឹងធ្វើឱ្យសត្រូវរបស់អ្នករងទុក្ខពីបណ្តាសារទាំងនេះ»

Deuteronomy 30:9

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

កិច្ចការដែលដៃអ្នករាល់គ្នាបានធ្វើ

នៅទីនេះ «ដៃ» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«នៅក្នុងការងារទាំងអស់ដែលអ្នករាល់គ្នាធ្វើ»

ទាំងផលផ្លែនៃអ្នករាល់គ្នា ... ទាំងផលនៃហ្វូងសត្វរបស់អ្នក ...

ព្រមទាំងផលដែលកើតចេញដីរបស់អ្នករាល់គ្នា

ឃ្លាទាំងបីនេះជាសំនួនវោហាស័ព្ទសម្រាប់ «នៅក្នុងកូនចៅ ... នៅក្នុងហ្វូងសត្វ ...
នៅក្នុងផលដំណាំ» ។ ពាក្យស្រដៀងគ្នានេះកើតមានឡើងនៅក្នុង ២៨:៣។

ដែលបានចារនៅ

អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ដែលខ្ញុំបានសរសេរ»

ដោយអស់អំពីចិត្ត និងអស់អំពីព្រលឹងរបស់អ្នករាល់គ្នា។

ឃ្លា «ដោយអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង «ដោយអស់ពីព្រលឹង» មានន័យថា «អស់ពីខ្លួនអ្នក» ។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ការបកប្រែផ្សេងទៀត «ដោយភាពអស់ពីសមត្ថភាពរបស់អ្នក» ឬ
«ដោយថាមពលទាំងអស់របស់អ្នក»។ បកប្រែដូចនៅក្នុង ៤:២៩ ។

Deuteronomy 30:11

ព័ត៌មានទូទៅ៖

លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។

ហើយក៏មិនមែននៅឆ្ងាយដែរ។

លោកម៉ូសេនិយាយអំពីបទបញ្ជា ដែលតម្រូវឱ្យមនុស្សអនុវត្តតាម
ដូចមនុស្សដែលអាចឈោងចាប់វត្ថុបានខាងរាងកាយ។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«វាក៏មិនពិបាកពេកសម្រាប់ឲ្យអ្នកយល់នូវអ្វី ដែលព្រះអម្ចាស់តម្រូវឱ្យអ្នកធ្វើ»
តើអ្នកណានឹងឡើងទៅដើម្បីពួកយើង និងនាំសេចក្តីទាំងនេះចុះមកឲ្យយើង
ព្រមទាំងធ្វើឲ្យយើងអាចនឹងស្តាប់ឮផង ដើម្បីឲ្យយើងប្រតិបត្តិតាម?
នៅទីនេះលោកម៉ូសេប្រើសំនួនវោហាស័ព្ទ ដើម្បីបញ្ជាក់ថា
ប្រជាជនអ៊ីស្រាអែលគិតថា បទបញ្ជារបស់ព្រះអម្ចាស់ពិបាកពេក
សម្រាប់ពួកគេស្គាល់។ សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ម្នាក់ត្រូវតែធ្វើដំណើរទៅស្ថានបរមសុខ
ដើម្បីរៀនបទបញ្ជារបស់ព្រះជាម្ចាស់
ហើយបន្ទាប់មកត្រឡប់មកប្រាប់យើងនូវអ្វីដែលពួកគេធ្វើ
ដើម្បីឱ្យយើងអាចស្តាប់បង្គាប់តាមពួកគេ»។
Deuteronomy 30:13
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
តើអ្នកណានឹងឆ្លងសមុទ្រសម្រាប់ពួកយើង និងនាំយកព្រះបន្ទូលមកកាន់ពួកយើង
ហើយធ្វើឲ្យពួកយើងបានឮ ដើម្បីឲ្យយើងអាចនឹងប្រតិបត្តិតាមផង?
សំណួរដ៏ប៉ិនប្រសប់នេះបន្តគំនិត ដែលប្រជាជនអ៊ីស្រាអែលគិតថា
បទបញ្ជារបស់ព្រះអម្ចាស់ពិបាកនឹងស្គាល់ណាស់។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកណាម្នាក់ត្រូវធ្វើដំណើរឆ្លងកាត់សមុទ្រ ដើម្បីរៀនបទបញ្ជារបស់ព្រះជាម្ចាស់
រួចត្រឡប់មកវិញហើយប្រាប់យើងថាពួកវាបែបណា»
គឺនៅក្នុងមាត់ និងចិត្តរបស់អ្នករាល់គ្នា
មានន័យថា ប្រជាជនស្គាល់បទបញ្ជារបស់ព្រះជាម្ចាស់
រួចហើយនិងអាចប្រាប់អ្នកដទៃទៀត។
Deuteronomy 30:15
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ខ្ញុំបានដាក់ជីវិតនៅពីមុខអ្នករាល់គ្នា
ការដាក់អ្វីមួយជាកន្លែង ដែលមនុស្សផ្សេងទៀតអាចមើលឃើញវា
គឺការប្រៀបធៀបសម្រាប់ប្រាប់នរណាម្នាក់អំពីអ្វីមួយ។ ការបកប្រែផ្សេងទៀត
«ខ្ញុំបានប្រាប់អ្នកអំពី»
ជីវិត និងសេចក្តីល្អ ព្រមទាំងសេចក្តី និងអំពើអាក្រក់។
អ្នកអាចផ្តល់ព័ត៌មាននេះឱ្យកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត
«អ្វីដែលល្អហើយនឹងធ្វើឱ្យអ្នករស់នៅ
ហើយអ្វីដែលអាក្រក់ហើយនឹងធ្វើឱ្យអ្នកស្លាប់»
ចម្រើនឡើង
«និងមានកូនចៅជាច្រើន»
Deuteronomy 30:17
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ប្រសិនបើ ចិត្តរបស់អ្នករាល់គ្នាងាកចេញ ... តែបណ្តោយឲ្យគេទាញអ្នករាល់គ្នាទៅថ្វាយបង្គំ
និងគោរពប្រតិបត្តិដល់ព្រះដទៃ
នៅទីនេះ «ចិត្ត» សំដៅទៅលើមនុស្សទាំងមូល។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«បើអ្នកឈប់ស្មោះត្រង់នឹងព្រះជាម្ចាស់ ... ហើយប្រជាជន
ដែលរស់នៅលើទឹកដីនេះបញ្ចុះបញ្ចូលអ្នករាល់គ្នា ទៅថ្វាយបង្គំព្រះក្លែងក្លាយ!»
អ្នករាល់គ្នានៅថ្ងៃនេះថា ... អ្នករាល់គ្នានឹងមិនមានអាយុវែង
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលជាក្រុម។
អ្នករាល់គ្នានឹងមិនមានអាយុវែង
អាយុវែងជាពាក្យប្រៀបធៀបសម្រាប់ជីវិតរស់នៅយូរអង្វែង។ ការបកប្រែផ្សេងទៀត
«អាចរស់នៅបានយូរ» ។ បកប្រែដូចនៅក្នុង ៤:២៥។
Deuteronomy 30:19
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ខ្ញុំហៅមេឃ និងផែនដីធ្វើជាសាក្សី
អាចមានន័យថា ១) លោកម៉ូសេកំពុងតែអំពាវនាវដល់អស់អ្នក
ដែលរស់នៅក្រោមមេឃនិងលើផែនដី ឲ្យធ្វើជាសាក្សីចំពោះអ្វី
ដែលគាត់បាននិយាយ ឬ ២)
លោកម៉ូសេកំពុងតែនិយាយទៅកាន់ផ្ទៃមេឃនិងផែនដី ដូចពួកគេជាមនុស្ស
ហើយលោកកំពុងហៅពួកគេធ្វើជាសាក្សីនូវអ្វី ដែលគាត់និយាយ
ធ្វើជាសាក្សីប្រឆាំងនឹងអ្នករាល់គ្នា
«មានឆន្ទៈក្នុងការនិយាយថា អ្នករាល់គ្នាបានធ្វើរឿងអាក្រក់»
ប្រឆាំងនឹងអ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលជាក្រុម។
ដើម្បីស្តាប់តាមព្រះសូរសៀង
នៅទីនេះពាក្យ «ព្រះសូរសៀង» សំដៅទៅលើអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «ស្តាប់បង្គាប់តាមអ្វីដែលគាត់និយាយ»
និងនៅជាប់នឹងព្រះអង្គ។
«ហើយត្រូវពឹងផ្អែកលើព្រះអង្គ»
ដ្បិតព្រះអង្គគឺជាជីវិតរបស់អ្នករាល់គ្នា និងជាអាយុយឺនយូររបស់អ្នករាល់គ្នា
«ជីវិតរបស់អ្នករាល់គ្នា» និង «អាយុយឺនយូររបស់អ្នករាល់គ្នា»
ជាឃ្លាសម្រាប់អ្នកដែលអាចផ្តល់ជីវិត និងមានអាយុយឺនយូរ។
អ្នកអាចបញ្ចូលឃ្លាទាំងពីរ បើអ្នកត្រូវការ។ ការបកប្រែផ្សេងទៀត
«មានតែព្រះអម្ចាស់ប៉ុណ្ណោះ ដែលអាចជួយអ្នកឱ្យរស់នៅបានយូរអង្វែង»
បានស្បថចំពោះដូនតារបស់អ្នក
ចន្លោះប្រហោងអាចបំពេញនៅទីនេះ។ ការបកប្រែផ្សេងទៀត «ស្បថថា
គាត់នឹងផ្តល់ឱ្យបុព្វបុរសអ្នក» (សូមមើល figslips-elis)

---

31 [1]លោកម៉ូសេបានមានប្រសាសន៍ទៅកាន់ប្រជាជនអ៊ីស្រាអែលទាំងមូល។[2]លោកមានប្រសាន៍ទៅកាន់ពួកគេថា៖ «ខ្ញុំឥឡូវ មានអាយុមួយរយម្ភៃឆ្នាំហើយ
ខ្ញុំមិនអាចបន្តដឹកនាំអ្នករាល់គ្នាទៀតទេ[3]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា ខ្ញុំនឹងមិនអាចឆ្លងទន្លេយ័រដាន់បានទេ។ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
ព្រះអង្គនឹងយាងនៅមុខអ្នករាល់គ្នា ព្រះអង្គនឹងបំផ្លាញប្រជាជាតិទាំងនេះ ចេញពីមុខអ្នករាល់គ្នា ហើយអ្នកនឹងដកហូតយកទឹកដីរបស់ពួកគេ។
លោកយ៉ូស្វេនឹងឆ្លងទន្លេនៅពីមុខអ្នករាល់គ្នា ដូចជាព្រះអម្ចាស់មានព្រះបន្ទូល។
[4]ព្រះអម្ចាស់នឹងប្រព្រឹត្តជាមួយពួកគេ ដូចដែលព្រះអង្គបានប្រព្រឹត្តជាមួយនឹងស៊ីហុន និងអុកជាស្តេចនៃជនជាតិអាម៉ូរី ព្រមទាំងទឹកដីរបស់ពួកគេ
ជាទឹកដីដែលព្រះអង្គបានបំផ្លាញ។[5]ព្រះអម្ចាស់នឹងប្រទានជ័យជម្នះដល់អ្នករាល់គ្នាឲ្យយកឈ្នះពួកគេ នៅពេលអ្នករាល់គ្នាប្រឈមមុខនឹងពួកគេ នៅក្នុងការប្រយុទ្ធ
ហើយអ្នករាល់គ្នានឹងប្រព្រឹត្តចំពោះពួកគេ តាមសេចក្តីដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។[6]ចូរមានកម្លាំង និងចិត្តក្លាហានឡើង កុំភ័យខ្លាច
ហើយតក់ស្លុតនៅចំពោះពួកគេឲ្យសោះ ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ព្រះអង្គគឺជាព្រះដែលយាងទៅជាមួយអ្នកហើយ ព្រះអង្គនឹងមិនចាកចេញ
ឬបោះបង់អ្នករាល់គ្នាចោលឡើយ»។
[7]លោកម៉ូសេបានហៅលោកយ៉ូស្វេហើយមានប្រសាសន៍ទៅលោកនៅចំមុខប្រជាជនអ៊ីស្រាអែលថា៖ «ចូរមានកម្លាំង និងចិត្តក្លាហានឡើយ ដ្បិត
អ្នកនឹងនាំប្រជាជនទាំងនេះ ចូលទៅកាន់ទឹកដីដែលព្រះអម្ចាស់បានស្បថចំពោះដូនតារបស់ពួកគេ ថានឹងប្រទានឲ្យពួកគេ។
អ្នកនឹងត្រូវឲ្យពួកគេចាប់យកទឹកដីនោះជាមរតករបស់ពួកគេ។[8]ព្រះអម្ចាស់ ព្រះអង្គគឺជាព្រះដែលនាំមុខអ្នក ព្រះអង្គនឹងគង់នៅជាមួយអ្នក ព្រះអង្គនឹងមិនចាកចេញ
ឬបោះបង់អ្នកចោលឡើយ ចូរកុំភ័យខ្លាចឲ្យសោះ ចូរកុំបំបាក់ទឹកចិត្តឲ្យសោះ»។
[9]លោកម៉ូសេបានសរសេរក្រឹត្យវិន័យនេះ ហើយបានប្រគល់ឲ្យទៅកាន់ពួកបូជាចារ្យជាកូនចៅពួកលេវី ជាអ្នកដែលសែងហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
លោកក៏បានប្រគល់ជូនចំពោះពួកចាស់ទុំនៃអ៊ីស្រាអែលផងដែរ។[10]លោកម៉ូសេបានបង្គាប់ពួកគេ ហើយមានប្រសាសន៍ថា៖ «នៅចុងឆ្នាំ រាល់ប្រាំពីរឆ្នាំម្តង
គឺនៅពេលកំណត់នៃឆ្នាំដែលត្រូវដោះលែង ក្នុងពេលបុណ្យបារាំ[11]ពេលដែលប្រជាជនអ៊ីស្រាអែលទាំងអស់បានបង្ហាញខ្លួននៅចំពោះព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា
នៅកន្លែងដែលព្រះអង្គនឹងជ្រើសរើសសម្រាប់ជាទីសក្ការ ហើយអ្នកនឹងត្រូវអានក្រឹត្យវិន័យនេះនៅមុខប្រជាជនអ៊ីស្រាអែលទាំងអស់ ឲ្យគេពួកគេបានឮ។

generated on Wed Sep 10 16:16:32 2025

[12]ចូរប្រមូលផ្តុំប្រជាជន ទាំងប្រុស ទាំងស្រី ព្រមទាំងកូនក្មេង និងជនជាតិដ៏ទៃដែលរស់នៅក្នុងក្រុងរបស់អ្នក ដើម្បីឲ្យពួកគេអាចឮ ហើយបានរៀនផង
ហើយដើម្បីឲ្យពួកគេអាចនឹងកោតខ្លាចព្រះអម្ចាស់ជាព្រះនៃអ្នក ព្រមទាំងកាន់តាមសេចក្តីដែលបានចែងក្នុងក្រឹត្យវិន័យនេះផង។[13]ចូរធ្វើដូច្នេះ ដើម្បីឲ្យកូនៗរបស់ពួកគេ
ដែលមិនបានស្គាល់ អាចនឹងឮ ហើយរៀនដើម្បីកោតខ្លាចព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ដូចជាអ្នករស់នៅក្នុងទឹកដីដែលអ្នកនឹងឆ្លងកាត់ទន្លេដើម្បីកាន់កាប់នោះ»។
[14]ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់លោកម៉ូសេថា៖ «មើល៍ ថ្ងៃដែលអ្នកត្រូវស្លាប់ជិតមកដល់ហើយ ចូរហៅលោកយ៉ូស្វេ ហើយចូលមកក្នុងត្រសាលនៃការប្រជុំ
ដើម្បីយើងនឹងប្រទានសេចក្តីបង្គាប់ដល់លោក»។ លោកម៉ូសេ និងលោកយ៉ូស្វេបានចូលរួមក្នុងត្រសាលប្រជុំ។[15]ព្រះអម្ចាស់បានលេចមកក្នុងត្រសាល
នៅក្នុងបង្គោលពពក បង្គោលពពកនោះឈរនៅពីលើទ្វារត្រសាល។
[16]ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់លោកម៉ូសេថា៖ «មើល៍ អ្នកនឹងត្រូវដេកលក់ទៅជាមួយដូនតារបស់អ្នក ហើយប្រជាជននេះនឹងលើកគ្នា
ហើយប្រព្រឹត្តអំពើផិតក្បត់ទៅតាមព្រះដទៃ ក្នុងទឹកដីដែលពួកគេចូលទៅរស់នៅ។ ពួកគេនឹងបោះបង់ចោលយើង
ហើយបានកាត់ផ្តាច់សម្ពន្ធមេត្រីដែលយើងបានចងជាមួយពួកគេ។
[17]បន្ទាប់មក នៅថ្ងៃនោះ សេចក្តីក្រោធរបស់យើងនឹងត្រូវឆួលឡើងប្រឆាំងនឹងពួកគេ ហើយយើងនឹងបោះបង់ពួកគេ។ យើងនឹងគេចព្រះចេញពីពួកគេ
នោះពួកគេនឹងត្រូវលេបត្របាក់អស់ទៅ។ គ្រោះមហន្តរាយ និងបញ្ហាជាច្រើននឹងកើតឡើងចំពោះពួកគេ ដូច្នេះហើយ នៅថ្ងៃនោះពួកគេនិយាយថា
គ្រោះមហន្តរាយទាំងនេះ បានកើតឡើងលើពួកយើង តើមិនមែនដោយសារតែព្រះជាម្ចាស់មិនគង់ក្នុងចំណោមយើងទេឬ?
[18]យើងនឹងពិតជាគេចមុខចេញពីពួកគេនៅថ្ងៃនោះ ដោយសារតែសេចក្តីអាក្រក់ទាំងអស់ដែលពួកគេបានប្រព្រឹត្ត ព្រោះពួកគេបានងាកបែរទៅរកព្រះដទៃ។
[19]ដូច្នេះ ឥឡូវនេះ ចូរសរសេរចម្រៀងនេះ សម្រាប់ខ្លួនអ្នក ហើយបង្រៀនចម្រៀងនេះទៅដល់ប្រជាជនអ៊ីស្រាអែល។ ចូរដាក់ចម្រៀងនេះនៅក្នុងមាត់
ដើម្បីឲ្យចម្រៀងនេះធ្វើជាសាក្សីដល់យើង ប្រឆាំងនឹងប្រជាជនអ៊ីស្រាអែល។
[20]ដ្បិតនៅពេលដែលយើងបាននាំពួកគេចូលទៅទឹកដីដែលយើងបានស្បថចំពោះបុព្វបុរសពួកគេថានឹងប្រទានដល់គេ ទឹកដីដែលពេញដោយទឹកដោះគោ ទឹកឃ្មុំ
និងពេលពួកគេបរិភោគហើយ គេបានធំធាត់ នោះពួកគេនឹងងាកបែរទៅរកព្រះដទៃ ហើយពួកគេនឹងបម្រើព្រះទាំងនោះ ហើយពួកគេនឹងមើលងាយ
ពួកគេនឹងកាត់ផ្តាច់សម្ពន្ធមេត្រីរបស់យើង។
[21]ពេលដែលអំពើអាក្រក់ និងបញ្ហាជាច្រើនកើតឡើងលើប្រជាជននេះ នោះចម្រៀងនេះនឹងធ្វើជាសាក្សីទាស់នឹងពួកគេ (ដ្បិត
ចម្រៀងនេះនឹងមិនអាចលុបចេញពីមាត់របស់ពូជពង្សពួកគេឡើយ)។ ដ្បិត យើងដឹងអំពីផែនការដែលពួកគេបង្កើតនៅថ្ងៃនេះ
សូម្បីតែមុនពេលដែលយើងបាននាំពួកគេចូលទៅក្នុងទឹកដីដែលយើងបានសន្យានឹងពួកគេ»។
[22]ដូច្នេះ លោកម៉ូសេបានសរសេរចម្រៀងនេះ នៅថ្ងៃនោះ ហើយបានបង្រៀនចម្រៀងនេះដល់ប្រជាជនអ៊ីស្រាអែល។
[23]ព្រះអម្ចាស់បានប្រទានសេចក្តីបង្គាប់មួយឲ្យលោកយ៉ូស្វេជាកូនរបស់លោកនូន ហើយមានព្រះបន្ទូលថា៖ «ចូរមានកម្លាំង និងចិត្តក្លាហានឡើង ដ្បិត
អ្នកនឹងត្រូវនាំប្រជាជនអ៊ីស្រាអែលចូលទៅទឹកដីដែលយើងបានស្បថចំពោះអ្នក ហើយយើងនឹងគង់នៅជាមួយអ្នក»។
[24]សេចក្តីនេះកើតឡើងនៅពេលដែលលោកម៉ូសេបានបញ្ចប់ការសរសេរព្រះបន្ទូលនៃក្រឹត្យវិន័យនេះទុកក្នុងគម្ពីរ[25]លោកម៉ូសេបង្គាប់ពួកលេវី
ដែលសែងហឹបសម្ពន្ធមេត្រីនៃព្រះអម្ចាស់ ហើយលោកមានប្រសាសន៍ថា៖[26]«ចូរយកគម្ពីរក្រឹត្យវិន័យ
ហើយដាក់ដាក់ក្បែរហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នក ដូច្នេះ គម្ពីរក្រឹត្យវិន័យនេះអាចធ្វើជាសាក្សីទាស់នឹងអ្នក។
[27]ដ្បិត ខ្ញុំដឹងអំពីចិត្តបះបោរ និងចិត្តរឹងរុសរបស់អ្នក មើល៍ កាលណាខ្ញុំរស់នៅជាមួយអ្នករាល់គ្នានៅឡើយ អ្នកបានបះបោរ ប្រឆាំងនឹងព្រះអម្ចាស់ ចុះទម្រាំតែខ្ញុំស្លាប់ទៀត
តើអ្នករាល់គ្នានឹងបះបោរខ្លាំងយ៉ាងណាទៅ?[28]ចូរប្រមូលពួកចាស់ទុំនៃកុលសម្ព័ន្ធរបស់អ្នករាល់គ្នា និងមេដឹកនាំទាំងអស់របស់អ្នករាល់គ្នា មកឯខ្ញុំ
ដើម្បីឲ្យខ្ញុំបាននិយាយប្រាប់ពាក្យទាំងនេះដល់ពួកគេ ព្រមទាំងយកមេឃ និងផែនដីធ្វើជាសាក្សីប្រឆាំងនឹងអ្នករាល់គ្នា។[29]ដ្បិត ខ្ញុំដឹងថា បន្ទាប់ពីខ្ញុំស្លាប់ទៅ
នោះអ្នករាល់គ្នានឹងបង្ខូចខ្លួន ហើយងាកបែរចេញពីផ្លូវដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា នោះគ្រោះមហន្តរាយនឹងកើតឡើងលើអ្នករាល់គ្នា ពេញមួយជីវិតរបស់អ្នក។
ការនេះនឹងកើតឡើង ដោយសារតែអ្នករាល់គ្នានឹងទៅប្រព្រឹត្តអ្វីដែលជាអំពើអាក្រក់នៅចំពោះព្រះអម្ចាស់ បណ្តាលឲ្យព្រះអង្គមានសេចក្តីក្រោធ
ដោយអំពើដែលអ្នកបានប្រព្រឹត្ត។
[30]លោកម៉ូសេបានសូត្រដាក់ក្នុងត្រចៀករបស់ប្រជាជនអ៊ីស្រាអែលទាំងអស់ដែលកំពុងជួបប្រជុំ គឺជាពាក្យដែលនៅក្នុងចម្រៀងនេះរហូតចប់។

Deuteronomy 31:1
មានអាយុមួយរយម្ភៃឆ្នាំហើយ
«អាយុ១២០ឆ្នាំ»
ខ្ញុំមិនអាចបន្តដឹកនាំអ្នករាល់គ្នាទៀតទេ
នៅទីនេះបំផុត «បន្ត» និង« មក»បានប្រើជាមួយគ្នាមានន័យថា
លោកម៉ូសេមិនអាចធ្វើអ្វី ដែលមនុស្សមានសុខភាពល្អអាចធ្វើបានទៀតទេ។
ការបកប្រែផ្សេងទៀត «ខ្ញុំមិនអាចទៅគ្រប់ទីកន្លែង ដែលអ្នករាល់គ្នាត្រូវទៅបានទេ
ដូច្នេះ ខ្ញុំមិនអាចក្លាយជាអ្នករាល់គ្នាដឹកនាំរបស់អ្នកទៀតទេ»
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំ ... មុខអ្នករាល់គ្នា...មុខអ្នករាល់គ្នា ... you
ដកហូតយកទឹកដី... មុខអ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ហើយអ្នកនឹងដកហូតយកទឹកដីរបស់ពួកគេ។
«អ្នកនឹងយកដីរបស់ពួកគេ»
លោកយ៉ូស្វេនឹងឆ្លងទន្លេនៅពីមុខអ្នករាល់គ្នា ដូចជាព្រះអម្ចាស់មានព្រះបន្ទូល។
«លោកយ៉ូស្វេនឹងនាំអ្នកឆ្លងទន្លេ ដូចព្រះអម្ចាស់បានសន្យា»
Deuteronomy 31:4
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល។
ដូចដែលព្រះអង្គបានប្រព្រឹត្តជាមួយនឹងស៊ីហុន និងអុកជាស្តេចនៃជនជាតិអាម៉ូរី
នៅទីនេះ «ស្តេចស៊ីហុន» និង «ស្តេចអុក»
សំដៅទៅលើស្តេចពីររបស់ជនជាតិអាម៉ូរី និងកងទ័ពរបស់ពួកគេ។
បកប្រែឈ្មោះទាំងនេះដូចនៅក្នុង ១:៣។ ការបកប្រែផ្សេងទៀត
«គាត់បានធ្វើចំពោះស្តេចស៊ីហុន និងស្តេចអុកជាស្តេចរបស់ជនជាតិអាម៉ូរី
និងកងទ័ពរបស់ពួកគេ»
ចូរមានកម្លាំង និងចិត្តក្លាហានឡើង
«ចូរមានកម្លាំង និងក្លាហាន»
កុំភ័យខ្លាច ហើយតក់ស្លុតនៅចំពោះពួកគេឲ្យសោះ
«មិនត្រូវខ្លាចពួកគេទាល់តែសោះ»
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ...យាងទៅជាមួយអ្នក ...មិនចាកចេញ
ឬបោះបង់អ្នករាល់គ្នាចោលឡើយ។
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ព្រះអង្គនឹងមិនចាកចេញ ឬបោះបង់អ្នករាល់គ្នាចោលឡើយ។
អាចត្រូវបានគេចាត់ទុកជាការបំភ្លឺ និងបកប្រែជាវិជ្ជមាន។ការបកប្រែផ្សេងទៀត
«ព្រះអង្គនឹងបំពេញការសន្យារបស់ព្រះអង្គចំពោះអ្នករាល់គ្នា
ហើយនឹងនៅជាមួយអ្នករាល់គ្នាជានិច្ច»
Deuteronomy 31:7
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
នៅចំមុខប្រជាជនអ៊ីស្រាអែល
មានន័យថា ប្រជាជនអ៊ីស្រាអែលទាំងអស់មានវត្តមាន។ ការបកប្រែផ្សេងទៀត
«នៅចំពោះមុខប្រជាជនអ៊ីស្រាអែលទាំងអស់»
ចូរមានកម្លាំង និងចិត្តក្លាហានឡើយ
«ចូររឹងមាំនិងក្លាហាន»។ បកប្រែដូចនៅក្នុង ៣១: ៤។

generated on Wed Sep 10 16:16:32 2025

អ្នកនឹងត្រូវឲ្យពួកគេចាប់យកទឹកដីនោះជាមរតករបស់ពួកគេ។
«អ្នកនឹងជួយពួកគេយកទឹកដី»
Deuteronomy 31:9
ហើយបានប្រគល់ឲ្យទៅកាន់ពួកបូជាចារ្យជាកូនចៅពួកលេវី
«បានប្រគល់វាទៅពួកលេវីដែលជាបូជាចារ្យ»
ប្រាំពីរឆ្នាំ
«៧ឆ្នាំ»
គឺនៅពេលកំណត់នៃឆ្នាំដែលត្រូវដោះលែង
«សម្រាប់ការលុបបំណុល»
ក្នុងពេលបុណ្យបារាំ
ឈ្មោះផ្សេងទៀតសម្រាប់ពិធីបុណ្យនេះគឺ «បុណ្យព្រះពន្លា »«បុណ្យស្តង់» និង «បុណ្យនៃការជួបជុំ»។
ក្នុងអំឡុងពេលប្រមូលផលកសិករនឹងរៀបចំជម្រកបណ្តោះអាសន្ន នៅក្នុងចម្ការ។ ពិធីបុណ្យនេះបានកើតឡើងបន្ទាប់ពីការប្រមូលផលចុងឆ្នាំ។ បកប្រែវាដូចគ្នានឹង ១៦:១៣។
ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ... អ្នកនឹងត្រូវអាន
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលដូចពួកគេជាមនុស្សម្នាក់ដូច្នេះពាក្យ«អ្នក» និង«រប់អ្នក»នៅទីនេះគឺជាឯកវចនៈ។ (សូមមើលfigs-you)
ឲ្យគេពួកគេបានឮ។
«ដូច្នេះ ពួកគេអាចស្តាប់បាន»
Deuteronomy 31:12
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅកាន់ពួកបូជាចារ្យ និងពួកចាស់ទុំ។
និងជនជាតិដ៏ទៃដែលរស់នៅក្នុងក្រុងរបស់អ្នក
នៅទីនេះ «ទ្វារទីក្រុង» តំណាងឱ្យទីក្រុង។
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះពាក្យ «រប់អ្នក» នៅទីនេះជាឯកវចនៈ។ ការបកប្រែផ្សេងទៀត «ជនបរទេសរបស់អ្នកដែលរស់នៅក្នុងទីក្រុងរបស់អ្នក»
ព្រមទាំងកាន់តាមសេចក្តីដែលបានចែងក្នុងក្រឹត្យវិន័យ
«គោរពតាមរាល់បទបញ្ជាទាំងអស់ នៅក្នុងក្រឹត្យវិន័យដោយយកចិត្តដាក់»
Deuteronomy 31:14
មើល៍
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក។ »
បង្គោលពពក
នេះជាពពកក្រាស់មានផ្សែង ដែលមានរាងជាជួរឈរត្រង់។
Deuteronomy 31:16
មើល៍ អ្នក
«យកចិត្តទុកដាក់នូវអ្វី ដែលខ្ញុំនឹងប្រាប់អ្នក។»
អ្នកនឹងត្រូវដេកលក់ទៅជាមួយដូនតារបស់អ្នក
នេះជារបៀបគួរសមក្នុងការនិយាយថា «អ្នកនឹងត្រូវស្លាប់»។ ការបកប្រែផ្សេងទៀត «អ្នកនឹងស្លាប់ហើយចូលរួមជាមួយបុព្វបុរសរបស់អ្នក ដែលបានស្លាប់មុនពេលអ្នក»
ហើយប្រជាជននេះនឹងលើកគ្នា ហើយប្រព្រឹត្តអំពើផិតក្បត់ទៅតាមព្រះដទៃ
ធ្វើជាស្រីពេស្យា ជាការប្រៀបធៀបសម្រាប់ការថ្វាយបង្គំព្រះក្លែងក្លាយ ក្រៅពីព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត «នឹងចាប់ផ្តើមមិនស្មោះត្រង់នឹងយើង»
Deuteronomy 31:17
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ។
សេចក្តីក្រោធរបស់យើងនឹងត្រូវឆួលឡើងប្រឆាំងនឹងពួកគេ
ព្រះអម្ចាស់ប្រៀបធៀបសេចក្តីក្រោធរបស់ព្រះអង្គ ទៅនឹងនរណាម្នាក់ដែលចាប់ផ្តើមដុតភ្លើង។
នេះសង្កត់ធ្ងន់លើអំណាចរបស់ព្រះជាម្ចាស់ ដើម្បីបំផ្លាញអ្វីៗដែលធ្វើឱ្យព្រះអង្គក្រោធ។ អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «យើងនឹងបញ្ឆេះសេចក្តីក្រោធប្រឆាំងនឹងពួកគេ» ឬ «យើងនឹងសេចក្តីក្រោធនឹងពួកគេ»
យើងនឹងគេចព្រះចេញពីពួកគេ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «យើងនឹងមិនជួយពួកគេទេ»
នោះពួកគេនឹងត្រូវលេបត្របាក់អស់ទៅ។
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «យើងនឹងលេបត្របាក់ពួកវា» ឬ «យើងនឹងអនុញ្ញាតឱ្យសត្រូវរបស់ពួកគេលេបត្របាក់ពួកគេ»
លេបត្របាក់
នេះជាពាក្យប្រៀបធៀបសម្រាប់ «បំផ្លាញទាំងស្រុង»។
គ្រោះមហន្តរាយ និងបញ្ហាជាច្រើននឹងកើតឡើងចំពោះពួកគេ
ពិពណ៌នាអំពីគ្រោះមហន្តរាយ និងបញ្ហាដូចជាពួកគេជាមនុស្ស។ ការបកប្រែផ្សេងទៀត «ពួកគេនឹងជួបបទពិសោធន៍គ្រោះមហន្តរាយ និងបញ្ហាជាច្រើន»
តើមិនមែនដោយសារតែព្រះជាម្ចាស់ ... ក្នុងចំណោមយើងទេឬ?
ពិពណ៌នាអំពីគ្រោះមហន្តរាយ និងបញ្ហាដូចពួកគេជាមនុស្ស។ សំណួរប៊ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «គ្រោះមហន្តរាយទាំងនេះកំពុងបំផ្លាញខ្ញុំ ... នៅក្នុងចំណោម»។
ព្រះជាម្ចាស់មិនគង់ក្នុងចំណោមយើង
«ព្រះជាម្ចាស់លែងការពារយើង» ឬ «ព្រះជាម្ចាស់បានទុកយើងចោល»
Deuteronomy 31:19
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកម៉ូសេ អំពីជនជាតិអ៊ីស្រាអែល។
ចូរដាក់ចម្រៀងនេះនៅក្នុងមាត់
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ធ្វើឱ្យពួកគេទន្ទេញនិងច្រៀង»
ទឹកដីដែលពេញដោយទឹកដោះគោ ទឹកឃ្មុំ
នេះជាលេខសម្គាល់។ ការបកប្រែផ្សេងទៀត «ទឹកដីដែលមានទឹកដោះនិងទឹកឃ្មុំហូរច្រើន» ឬ «ដីល្អសម្រាប់សត្វនិងការធ្វើកសិកម្ម» សូមមើលការបកប្រែនៅក្នុង ៦:៣។
Deuteronomy 31:21
ពេលដែលអំពើអាក្រក់ និងបញ្ហាជាច្រើនកើតឡើងលើប្រជាជននេះ
នៅទីនេះ អំពើអាក្រក់និងបញ្ហាត្រូវបានពិពណ៌នា ដូចជាពួកគេជាមនុស្សអាចរកឃើញ។ ការបកប្រែផ្សេងទៀត «នៅពេលដែលប្រជាជននេះជួបប្រទះ និងបញ្ហាអាក្រក់និងបញ្ហាជាច្រើន»
នោះចម្រៀងនេះនឹងធ្វើជាសាក្សីទាស់នឹងពួកគេ
បង្ហាញថាបទចម្រៀងនេះដូចជាមនុស្សធ្វើជាសាក្សី ផ្តល់ភ័ស្តុតាងនៅក្នុងតុលាការប្រឆាំងនឹងអ៊ីស្រាអែល។
ដ្បិត ចម្រៀងនេះនឹងមិនអាចលុបចេញពីមាត់របស់ពូជពង្សពួកគេឡើយ)
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «កូនចៅរបស់ពួកគេនឹងមិនភ្លេចទុកវានៅក្នុងមាត់របស់ពួកគេទេ»
ដ្បិត ចម្រៀងនេះនឹងមិនអាចលុបចេញពីមាត់របស់ពូជពង្សពួកគេឡើយ)
អាចថ្លែងជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត «កូនចៅរបស់ពួកគេនឹងចងចាំចងចាំវានៅក្នុងមាត់របស់ពួកគេ»
ដ្បិត ចម្រៀងនេះនឹងមិនអាចលុបចេញពីមាត់របស់ពូជពង្សពួកគេឡើយ)
ឃ្លា «លុបចេញពីមាត់» មានន័យថា ឈប់និយាយអំពីវា។ ការបកប្រែផ្សេងទៀត «កូនចៅរបស់ពួកគេនឹងមិនឈប់និយាយអំពីវា»
អំពីផែនការដែលពួកគេបង្កើត
អ្វីដែលមនុស្សមានគម្រោងធ្វើ គឺដូចជាវត្ថុខាងរាងកាយ។ ការបកប្រែផ្សេងទៀត «អ្វីដែលពួកគេគ្រោងនឹងធ្វើ»
យើងបានសន្យានឹងពួកគេ។
«ដីដែលយើងបានសន្យាយើងនឹងផ្តល់ឱ្យពួកគេ»
Deuteronomy 31:22
ចូរមានកម្លាំង និងចិត្តក្លាហានឡើង
«ចូររឹងមាំនិងក្លាហាន»។ សូមមើលការបកប្រែនៅក្នុង ៣១:៤។
Deuteronomy 31:24
ធ្វើជាសាក្សីទាស់នឹងអ្នក។
លោកម៉ូសេនិយាយទៅកាន់ពួកលេវី ដូចជាពួកគេជាមនុស្សម្នាក់ ដូច្នេះ ពាក្យ«អ្នក» ជាឯកវចនៈ។
Deuteronomy 31:27
ព័ត៌មានទូទៅ៖
លោកម៉ូសេបន្តនិយាយទៅពួកលេវី អំពីជនជាតិអ៊ីស្រាអែលទាំងអស់។
អំពីចិត្តបះបោរ និងចិត្តរឹងរូសរបស់អ្នក
លោកម៉ូសេនិយាយទៅកាន់ពួកលេវី ដូចជាពួកគេមានមនុស្សម្នាក់ ដូច្នេះ ពាក្យ

generated on Wed Sep 10 16:16:32 2025

«របស់អ្នក» ជាឯកវចន:
ចិត្តរឹងរូសរបស់អ្នក
បកប្រែពាក្យនេះ «ចិត្តរឹងរូស» ដូចនៅក្នុង ៩:៦។
តើអ្នករាល់គ្នានឹងបះបោរខ្លាំងយ៉ាងណាទៅ?
សំណួរដ៏ប៉ិនប្រសព្វនេះបញ្ជាក់ពីការបះបោររបស់ប្រជាជនយ៉ាងណា។
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកនឹងកាន់តែបះបោរថែមទៀតបន្ទាប់ពីខ្ញុំស្លាប់»។
ដើម្បីឲ្យខ្ញុំបាននិយាយប្រាប់ពាក្យទាំងនេះដល់ពួកគេ
នៅទីនេះ «នៅក្នុងត្រចៀករបស់ពួកគេ» មានន័យថាប្រជាជនខ្លួនឯង។
ការបកប្រែផ្សេងទៀត «ដើម្បីឱ្យខ្ញុំអាចនិយាយជាបទចំរៀងនេះទៅកាន់ពួកគេ»
ព្រមទាំងយកមេឃ និងផែនដីធ្វើជាសាក្សីប្រឆាំងនឹងអ្នករាល់គ្នា។
អាចមានន័យថា ១) លោកម៉ូសេកំពុងតែអំពាវនាវដល់អស់អ្នក
ដែលរស់នៅលើមេឃនិងផែនដី ឱ្យធ្វើជាសាក្សីចំពោះអ្វីដែលគាត់បាននិយាយ ឬ
២) លោកម៉ូសេកំពុងតែនិយាយទៅកាន់មេឃនិងផែនដី ដូចជាពួកគេជាមនុស្ស
ហើយគាត់កំពុងហៅពួកគេធ្វើជាសាក្សី ចំពោះអ្វី គាត់និយាយ។
ឃ្លាស្រដៀងគ្នានេះលេចចេញក្នុង ៣០:១៩ ។
នោះអ្នករាល់គ្នានឹងបង្ខូចខ្លួន
អ្នករាល់គ្នានឹងធ្វើអ្វីដែលខុសទាំងស្រុង។
ពាក្យស្រដៀងគ្នានេះកើតមានឡើងនៅក្នុង ៤:១៥។
ហើយងាកបែរចេញពីផ្លូវដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា
«ឈប់ធ្វើតាមការណែនាំដែលខ្ញុំបានផ្តល់ដល់អ្នករាល់គ្នា»។
ពាក្យស្រដៀងគ្នានេះលេចឡើងក្នុង ៩:១១។
ដោយសារតែអ្នករាល់គ្នានឹងទៅប្រព្រឹត្តអ្វីដែលជាអំពើអាក្រក់នៅចំពោះព្រះអម្ចាស់
នៅទីនេះ «នៅចំពោះព្រះអម្ចាស់» មានន័យថា «តាមយោបល់របស់ព្រះអម្ចាស់»។
ការបកប្រែផ្សេងទៀត «ពីព្រោះ អ្នករាល់គ្នានឹងធ្វើអ្វី
ដែលព្រះអម្ចាស់មានព្រះបន្ទូលថា អាក្រក់»
ដោយអំពើដែលអ្នកបានប្រព្រឹត្ត។
នៅទីនេះ «ដៃរបស់អ្នក» មានន័យថា ប្រជាជនខ្លួនឯង។ ការបកប្រែផ្សេងទៀត
«ដោយសារតែអ្វីដែលអ្នកបានបង្កើត»
Deuteronomy 31:30
លោកម៉ូសេបានសូត្រដាក់ក្នុងត្រចៀករបស់ប្រជាជនអ៊ីស្រាអែលទាំងអស់ដែលកំពុងជួបប្រជុំ
នៅទីនេះ «ត្រចៀក» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«លោកម៉ូសេបាននិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលទាំងអស់»
បានសូត្រ
អាចមានន័យថា ១) «បានច្រៀង» ឬ ២) «បាននិយាយ»។
គឺជាពាក្យដែលនៅក្នុងចម្រៀងនេះរហូតចប់។
អ្នកអាចផ្តល់ព័ត៌មានកាន់តែច្បាស់ងាយយល់។ ការបកប្រែផ្សេងទៀត
«បទចម្រៀងដែលព្រះអម្ចាស់បានបង្រៀនគាត់»

---

32 [1]ឱផ្ទៃមេឃអើយ ចូរស្តាប់សេចក្តីដែលខ្ញុំនិយាយ។ ផែនដីអើយ ចូរស្តាប់ពាក្យដែលខ្ញុំនិយាយ។[2]សូមឲ្យការបង្រៀនរបស់ខ្ញុំហូរចុះមកដូចជាភ្លៀង
សូមឲ្យពាក្យសំដីរបស់ខ្ញុំ ដូចជាទឹកសន្សើម ដូចជាភ្លៀងរលឹម ធ្លាក់លើស្មៅខៀវខ្ចី ហើយដូចជាទឹកស្រោចលើដំណាំ។
[3]ដ្បិត ខ្ញុំនឹងប្រកាសពីព្រះនាមព្រះអម្ចាស់ និងលើកតម្កើងភាពថ្កុំថ្កើងនៃព្រះរបស់យើង។[4]ព្រះអង្គជាថ្មដា កិច្ចការរបស់ព្រះអង្គគឺល្អគ្រប់លក្ខណ៍ ដ្បិត
អស់ទាំងផ្លូវរបស់ព្រះអង្គគឺទៀងត្រង់។ ព្រះអង្គគឺជាព្រះដែលស្មោះត្រង់ ព្រះអង្គគ្មានសេចក្តីទុច្ចរិតទេ។ ព្រះអង្គជាព្រះដែលសុចរិត និងយុត្តិធម៌។
[5]ពួកគេបានប្រព្រឹត្តយ៉ាងអាក្រក់ប្រឆាំងនឹងព្រះអង្គ។ ពួកគេមិនមែនជាកូនរបស់ព្រះអង្គទេ។ នេះគឺជាសៅហ្មងរបស់ពួកគេ។ ពួកគេគឺជាជំនាន់មនុស្សអាក្រក់
ហើយរៀចវេរ។[6]មនុស្សល្ងីល្ងើ និងឥតប្រាជ្ញាអើយ តើអ្នករាល់គ្នាសង់គុណព្រះអម្ចាស់ដោយប្រព្រឹត្តបែបនេះមែនទេ? តើព្រះអង្គមិនជាព្រះបិតា
ជាព្រះតែមួយអង្គដែលបានបង្កើតអ្នករាល់គ្នាមកទេឬ? ព្រះអង្គបានបង្កើតអ្នករាល់គ្នា និងតាំងអ្នកឡើងផង។
[7]ចូរនឹកចាំពីថ្ងៃពីចាស់បុរាណ ចូរពិចារណាពីអាយុច្រើនឆ្នាំដែលកន្លងទៅ។ ចូរសួរឪពុករបស់អ្នករាល់គ្នា នោះលោកនឹងបង្ហាញអ្នករាល់គ្នាឲ្យដឹង ហើយសួរពួកចាស់ទុំ
នោះពួកគេនឹងប្រាប់អ្នករាល់គ្នាហើយ។[8]នៅពេលព្រះដ៏ខ្ពស់បំផុតបានប្រទានទឹកដីឲ្យប្រជាជាតិទាំងឡាយ ទុកជាមរតក
ពេលដែលព្រះអង្គបានបែងចែកមនុស្សលោកទាំងអស់ចេញពីគ្នា ហើយព្រះអង្គបានកំណត់ព្រំដែនឲ្យប្រជាជននានា តាមចំនួននៃព្រះរបស់ពួកគេ។
[9]ដ្បិត ចំណែករបស់ព្រះអម្ចាស់គឺជាប្រជារាស្ត្ររបស់ព្រះអង្គ លោកយ៉ាកុបគឺជាចំណែកមរតករបស់ព្រះអង្គ។[10]ព្រះអង្គបានរកឃើញលោកនៅទឹកដីដែលស្ងាត់ ហួតហែង
ក្នុងទីរហោស្ថាន គ្មានជីជាតិ និងឮតែសម្លេងស្រែកយំ ព្រះអង្គបានការពារលោក ហើយថែទាំលោក ព្រះអង្គបានការពារលោកដូចជាព្រះកែវព្រះនេត្ររបស់ព្រះអង្គ។
[11]ដូចសត្វឥន្ទ្រីដែលការពារសំបុក និងហើរការពារពីលើកូន ព្រះអម្ចាស់ត្រដាងស្លាបរបស់ព្រះអង្គ ហើយទទួលពួកគេ និងទ្រនៅលើចំអេងស្លាបរបស់ព្រះអង្គ។
[12]ព្រះអម្ចាស់តែមួយព្រះអង្គបាននាំលោក គ្មានព្រះដទៃណាដែលបាននៅជាមួយលោកឡើយ។
[13]ព្រះអង្គបានធ្វើឲ្យលោកនៅលើទឹកដីដែលមានទីខ្ពស់ ហើយព្រះអង្គបានចម្អែតលោកដោយផលផ្លែចេញពីស្រែចម្ការ ព្រះអង្គបានចិញ្ចឹមលោកដោយទឹកឃ្មុំចេញពីថ្ម
និងប្រេងដែលចេញពីច្រាំងថ្មដ៏រឹង។
[14]លោកបរិភោគខ្លាញ់ចេញពីហ្វូងសត្វ ហើយផឹកទឹកដោះចេញពីហ្វូងចៀម ជាមួយនឹងខ្លាញ់របស់កូនចៀម និងចៀមឈ្មោលនៃទឹកដីបាសាន ព្រមទាំងពពែផង
ហើយស្រូវសាលីល្អបំផុត ហើយអ្នករាល់គ្នាក៏បានផឹកស្រាដែលធ្វើពីទំពាំងបាយជូរដែរ។
[15]ប៉ុន្តែ យេស៊ូរុនបានធំធាត់ និងមានកម្លាំងរឹងប៉ឹង អ្នកបានធំធាត់ អ្នកបានធំធាត់ខ្លាំង ហើយអ្នកបានបរិភោគ លោកបានបោះបង់ព្រះជាម្ចាស់ដែលបានបង្កើតលោកមក
ហើយលោកបានមិនទទួលយកថ្មដានៃសេចក្តីសង្គ្រោះរបស់លោក។[16]ពួកគេធ្វើឲ្យព្រះអម្ចាស់មានសេចក្តីប្រចណ្ឌ ដោយព្រះដទៃរបស់ពួកគេ
ហើយដោយអំពើគួរស្អប់ខ្ពើមរបស់ពួកគេ ពួកគេធ្វើឲ្យព្រះអង្គព្រះពិរោធ។
[17]ពួកគេថ្វាយយញ្ញបូជាដល់ពួកអារក្ស ដែលមិនជាព្រះពិត ព្រះដែលពួកគេមិនបានស្គាល់ ជាព្រះដែលទើបតែនឹងកើតមក ជាព្រះរបស់ដូនតារបស់អ្នកមិនបានភ័យខ្លាច។
[18]អ្នករាល់គ្នាបានមិនបានខ្វល់ពីព្រះអង្គជាថ្មដា ដែលជាព្រះបិតា ហើយបានភ្លេចព្រះអង្គជាព្រះដែលបានបង្កើតអ្នករាល់គ្នាមក។
[19]ព្រះអម្ចាស់បានទតឃើញការនេះ ហើយព្រះបានបដិសេធពួកគេ ដោយព្រោះបុត្រធីតារបស់ព្រះអង្គបានធ្វើឲ្យព្រះអង្គព្រះពិរោធ។[20]ព្រះអង្គមានព្រះបន្ទូលថា៖
«យើងនឹងបែរព្រះភក្ត្រចេញពីពួកគេ» «យើងនឹងចាំទតមើលចុងក្រោយរបស់ពួកគេជាយ៉ាងណា ដ្បិត ពួកគេជាតំណរមនុស្សរឹងចចេស
ជាកូនចៅដែលគ្មានចិត្តស្មោះត្រង់។
[21]ពួកគេបានធ្វើឲ្យយើងប្រចណ្ឌ ដោយសាររបស់ដែលមិនមែនជាព្រះ និងបានធ្វើឲ្យយើងខឹងដោយសារការឥតប្រយោជន៍របស់ពួកគេ។ យើងនឹងធ្វើឲ្យពួកគេច្រណែន
ដោយសារពួកអ្នកដែលមិនមែនជាប្រជាជនណាមួយ ហើយដោយប្រជាជាតិមួយដែលល្ងីល្ងើ យើងនឹងធ្វើឲ្យពួកគេខឹង។
[22]ដ្បិត ភ្លើងកំហឹងរបស់យើងបានឆាបឆួលឡើង ហើយឆេះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ គឺលេបត្របាក់ផែនដី និងភោគផលរបស់ផែនដី
ហើយឆាបឆេះគ្រឹះភ្នំនានា។
[23]យើងនឹងបង្ករមហន្តរាយដល់ពួកគេ យើងនឹងបាញ់ព្រួញរបស់យើងទាំងអស់ទៅលើគេ[24]ពួកគេនឹងចុះខ្សោយដោយការស្រេកឃ្លាន
ហើយលេបត្របាក់ដោយសារភ្លើងឆេះ និងការបំផ្លាញយ៉ាងជូរចត់ យើងនឹងបញ្ជូនពួកគេទៅក្នុងចង្កូមរបស់សត្វព្រៃ និងសត្វលូនវារនៅលើដីឲ្យចឹកគេផង។
[25]នៅខាងក្រៅផ្ទះ ពួកគេនឹងស្លាប់ដោយសារមុខដា ហើយនៅក្នុងបន្ទប់ដេកពួកគេនឹងស្លាប់ដោយភ័យខ្លាំង។ ការនេះនឹងបំផ្លាញទាំងកំលោះ និងក្រមុំ ទាំងទារកនៅបៅ
ទាំងចាស់សក់ស្កូវផង។[26]យើងបាននិយាយថា យើងនឹងកម្ចាត់កម្ចាយពួកគេឲ្យវិនាសទៅឆ្ងាយ យើងនឹងលុបបំបាត់ការនឹកចាំអំពីពួកគេ ចេញពីមនុស្សលោកទៅ។
[27]ប៉ុន្តែ យើងខ្លាចថាខ្មាំងសត្រូវរបស់ពួកគេអួតអាង ហើយសត្រូវរបស់ពួកគេអាចនឹងកាត់សេចក្តីខុស ហើយគេអាចនឹងនិយាយថា ដៃរបស់ពួកយើងខ្លាំង
យើងអាចនឹងសម្រេចការងារទាំងអស់បាន។
[28]ដ្បិត អ៊ីស្រាអែលគឺជាប្រជាជាតិមួយគ្មានប្រាជ្ញា ហើយគ្មានអ្នកចេះដឹងទេ។[29]អូ បើសិនពួកគេជាមនុស្សមានប្រាជ្ញា និងជាមនុស្សចេះដឹង
នោះពួកគេអាចពិចារណាអំពីវាសនាដែលនឹងកើតមានចំពោះពួកគេហើយ!

generated on Wed Sep 10 16:16:32 2025

[30]តើមនុស្សម្នាក់អាចនឹងដេញមនុស្សមួយពាន់នាក់ ហើយដាក់មនុស្សពីរនាក់ប្រយុទ្ធជាមួយម៉ឺននាក់ដូចម្តេចទៅ បើព្រះដ៏ជាថ្មដារបស់គេមិនបានលក់គេ
ហើយព្រះអម្ចាស់មិនបានប្រគល់ពួកគេទៅខ្មាំងសត្រូវទេនោះ?[31]ដ្បិត ថ្មដាខ្មាំងសត្រូវរបស់ពួកយើងគឺមិនដូចជាថ្មដារបស់ពួកយើងឡើយ
សូម្បីតែខ្មាំងសត្រូវរបស់ពួកយើង ក៏ទទួលស្គាល់ដូច្នេះដែរ។
[32]ដ្បិត ដើមទំពាំងបាយជូររបស់ពួកគេ ចេញមកពីដើមទំពាំងបាយជូរនៃក្រុងសូដុម ហើយចេញចម្ការនៃក្រុងកូម៉ូរ៉ា ផ្លែទំពាំងបាយជូររបស់ពួកគេគឺជាផ្លែទំពាំងបាយជូរពុល
ហើយចង្កោមរបស់ពួកគេក៏ល្វីងដែរ។
[33]ស្រាទំពាំងបាយជូររបស់ពួកគេគឺមានជាតិពុលនៃពស់ និងដូចជាពិសដ៏សាហាវរបស់ពួកគេពស់វែក។[34]តើមិនមានគម្រោងការដែលលាក់កំបាំង
ដោយយើងទាំងបិទត្រានៅក្នុងឃ្លាំងរបស់យើងទេឬ?
[35]ការសងសឹក និងការតបទៅវិញគឺស្រេចតែលើយើង នៅពេលនោះ ជើងរបស់ពួកគេរអិល ដ្បិត ថ្ងៃនៃអន្តរាយសម្រាប់ពួកគេគឺជិតមកដល់
ហើយថ្ងៃដែលពួកគេទទួលការអាក្រក់ក៏នឹងកើតឡើងយ៉ាងរហ័សដែរ»។
[36]ដ្បិត ព្រះអម្ចាស់នឹងប្រទានភាពត្រឹមត្រូវដល់ប្រជារាស្ត្ររបស់ព្រះអង្គ ហើយព្រះអង្គនឹងអាណិតមេត្តាដល់អ្នកបម្រើរបស់ព្រះអង្គ។
ព្រះអង្គនឹងទតឃើញថាកម្លាំងរបស់ពួកគេគឺបាត់អស់ហើយ ហើយគ្មានអ្នកណាម្នាក់នៅសល់ឡើយ ទាំងទាសករ ឬអ្នកជាផង។
[37]បន្ទាប់មក ព្រះអង្គនឹងមានព្រះបន្ទូលថា៖ «តើព្រះរបស់ពួក ជាថ្មដាដែលពួកគេបានយកចាទីពឹងនោះ នៅឯណាទៅ?
[38]ព្រះដែលបានទទួលទានខ្លាញ់នៃយញ្ញបូជារបស់ពួកគេ និងផឹកស្រាទំពាំងបាយជូរនៃតង្វាយច្រួចរបស់ពួកគេ? ចូរឲ្យពួកគេក្រោកឡើង និងជួយអ្នកចុះ
ចូរឲ្យពួកគេធ្វើជាអ្នកការពារអ្នកចុះ។
[39]ឥឡូវនេះ មើល៍ គឺយើងនេះហើយដែលជាព្រះ គ្មានព្រះឯណាក្រៅពីយើងទេ យើងសម្លាប់ ហើយប្រោសឲ្យរស់ យើងធ្វើឲ្យរបួស ហើយយើងប្រោសឲ្យជា
គ្មានអ្នកណាម្នាក់អាចសង្គ្រោះអ្នករាល់គ្នាចេញពីដៃរបស់យើងបានទេ។[40]ដ្បិតយើងលើកដៃរបស់យើងទៅលើស្ថានសួគ៌
ហើយស្បថក្នុងនាមយើងដែលមានព្រះជន្មអស់កល្បជានិច្ច។
[41]នៅពេលយើងសំរួចមុខដាវដែលភ្លឺចាំងរបស់យើង ហើយដៃរបស់យើងចាប់កាន់សេចក្តីត្រឹមត្រូវ យើងនឹងសងសឹកខ្មាំងសត្រូវរបស់យើង
ហើយយើងនឹងសងវិញដល់អស់អ្នកណាដែលស្អប់យើង។
[42]យើងនឹងធ្វើឲ្យគ្រាប់ព្រួញរបស់យើងស្រវឹងជាមួយឈាម ហើយដាវរបស់យើងនឹងលេបត្របាក់សាច់ និងឈាមនៃអ្នកដែលស្លាប់ ព្រមទាំងពួកឈ្លើយ
ហើយចាប់ពីក្បាលរបស់អ្នកដឹកនាំរបស់ពួកខ្មាំងសត្រូវ»។
[43]ចូរឲ្យប្រជាជាតិរបស់អ្នក អរសប្បាយឡើង ជាមួយនឹងប្រជាជននៃព្រះ ដ្បិត ព្រះអង្គនឹងសងសឹកជួសអ្នកបម្រើរបស់ព្រះអង្គ ព្រះអង្គនឹងសងសឹកចំពោះពួកខ្មាំងសត្រូវ
ហើយព្រះអង្គនឹងធ្វើឲ្យទឹកដី និងប្រជារាស្ត្ររបស់ព្រះអង្គរួចផុតពីភាពសៅហ្មង។
[44]លោកម៉ូសេ និងលោកយ៉ូស្វេ ជាកូនរបស់លោកនូន បាននាំយក ព្រះបន្ទូលទាំងប៉ុន្មាននៅក្នុងចម្រៀងនេះទៅប្រាប់ប្រជាជនទាំងអស់ឲ្យបានឮ។
[45]លោកម៉ូសេបានសូត្រព្រះបន្ទូលទាំងអស់នោះ ទៅកាន់ប្រជាជនអ៊ីស្រាអែល។
[46]លោកម៉ូសេបាននិយាយទៅកាន់ពួកគេថា «ចូរនឹកចាំគ្រប់ទាំងពាក្យដែលខ្ញុំបានទូន្មានអ្នករាល់គ្នានៅថ្ងៃនេះ
ដើម្បីឲ្យអ្នករាល់គ្នាអាចបង្គាប់ដល់កូនចៅរបស់អ្នកដើម្បីឲ្យពួកគេកាន់តាមគ្រប់ទាំងព្រះបន្ទូលនៅក្នុងក្រឹត្យវិន័យនេះ។[47]ដ្បិតនេះមិនមែនជាបញ្ហាតូចតាចសម្រាប់អ្នកទេ
ពីព្រោះសេចក្តីនេះគឺជាជីវិតរបស់អ្នករាល់គ្នាវិញ
ហើយតាមរយៈការនេះអ្នករាល់គ្នានឹងរស់នៅបានយូរអង្វែងនៅក្នុងទឹកដីដែលអ្នករាល់គ្នានឹងឆ្លងកាត់ទន្លេយ័ដាន់ចូរទៅកាន់កាប់»។
[48]ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់លោកម៉ូសេនៅថ្ងៃនោះដែរថា[49]«ចូរឡើងទៅកំពូលភ្នំនេបូដែលស្ថិតនៅជួរភ្នំអាបារីនក្នុងទឹកដីម៉ូអាប់ទល់មុខនឹងទន្លេយ័ដាន់ហើយសម្លឹងមើលទឹកដីកាណានដែ
[50]អ្នកនឹងស្លាប់នៅភ្នំដែលអ្នកឡើងទៅនោះហើយអ្នកនឹងបានជួបជុំជាមួយនឹងដូនតារបស់អ្នក ដូចលោកអើរ៉ុន ដែលបានស្លាប់នៅលើភ្នំហោរ
ហើយបានជួបជុំដូនតារបស់គាត់ដែរ។
[51]ការនេះនឹងកើតឡើងដោយសារអ្នកមិនបានស្មោះត្រង់ចំពោះខ្ញុំក្នុងចំណោមប្រជាជនអ៊ីស្រាអែលកាលនៅក្បែរប្រភពទឹកមេរីបានៅកាដេសក្នុងទីហោរស្ថានស៊ីន
ពីព្រោះអ្នកមិនបានលើកតម្កើងយើង និងគោរពយើងនៅចំពោះមុខប្រជាជនអ៊ីស្រាអែលទេ។[52]ដ្បិត អ្នកនឹងឃើញទឹកដីដែលនៅចំពោះមុខអ្នក ប៉ុន្តែ
អ្នកនឹងមិនអាចទៅទីនោះបានទេ ដែលជាទឹកដីដែលយើងបានប្រគល់ឲ្យទៅប្រជាជនអ៊ីស្រាអែលឡើយ»។

Deuteronomy 32:1
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងជាកំណាព្យមួយ ទៅកាន់ប្រជាជនអ៊ីស្រាអែល។
ឱផ្ទៃមេឃអើយ ចូរស្តាប់ ...ផែនដីអើយ ចូរស្តាប់
ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ផ្ទៃមេឃ និងផែនដីដូចពួកវាកំពុងស្តាប់ទីនោះ។
អាចមានន័យថា ១) ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់ប្រជាជន
នៅលើមេឃនិងផែនដី ឬ ២)
ព្រះអម្ចាស់កំពុងមានបន្ទូលទៅកាន់ផ្ទៃមេឃនិងផែនដី ដូចពួកវាជាមនុស្ស។
សូមឲ្យការបង្រៀនរបស់ខ្ញុំហូរចុះមកដូចជាភ្លៀង ... ហើយដូចជាទឹកស្រោចលើដំណាំ។
មានន័យថា
ព្រះអម្ចាស់ចង់ឲ្យប្រជាជនទទួលយកការបង្រៀនដ៏មានប្រយោជន៍របស់ព្រះអង្គ
ដោយចិត្តរីករាយ។
ទឹកសន្សើម
ប្រើពាក្យជាភាសារបស់អ្នកសម្រាប់ដំណើរការ ដែលទឹកសន្សើមកើតមានឡើង។
ភ្លៀងរលឹម
ទឹកដែលបង្កើតនៅលើស្លឹកឈើនិងស្មៅនៅពេលព្រឹកត្រជាក់
ស្មៅខៀវខ្ចី
«រុក្ខជាតិថ្មី»
ទឹកស្រោចលើដំណាំ
ភ្លៀងខ្លាំង
Deuteronomy 32:3
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងកំណាព្យមួយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប្រកាសពីព្រះនាមព្រះអម្ចាស់
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ «ចូរប្រាប់ពីសេចក្តីល្អរបស់ព្រះអម្ចាស់»
លើតម្កើងភាពថ្កុំថ្កើងនៃព្រះរបស់យើង។
«ធ្វើឱ្យប្រាកដថា មនុស្សដឹងថាព្រះរបស់យើងអស្ចារ្យ»
ព្រះអង្គជាថ្មដា
នេះជាឈ្មោះត្រឹមត្រូវ ដែលលោកម៉ូសេហៅព្រះអម្ចាស់ដែលប្រៀបដូចជាថ្មដាមួយ
ដែលរឹងមាំនិងមានសមត្ថភាពអាចការពារប្រជាជនរបស់ព្រះអង្គ។
កិច្ចការរបស់ព្រះអង្គ
«អ្វីគ្រប់យ៉ាងដែលព្រះអង្គធ្វើ»
អស់ទាំងផ្លូវរបស់ព្រះអង្គគឺទៀងត្រង់។
«ព្រះអង្គធ្វើអ្វីៗគ្រប់យ៉ាងតាមរបៀបត្រឹមត្រូវ»
ព្រះអង្គជាព្រះដែលសុចរិត និងយុត្តិធម៌។
ពាក្យទាំងពីរនេះមានអត្ថន័យដូចគ្នា
ហើយបញ្ជាក់ថាព្រះអម្ចាស់ពិតជាយុត្តិធម៌និងធ្វើនូវៗអ្វីត្រឹមត្រូវ។
Deuteronomy 32:5
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងកំណាព្យមួយទៅកាន់ប្រជាជនអ៊ីស្រាអែល។
លោកម៉ូសេនៅតែបន្តប្រើភាពស្របគ្នា ដើម្បីបញ្ជាក់នូវអ្វីដែលគាត់កំពុងនិយាយ។
បានប្រព្រឹត្តយ៉ាងអាក្រក់ប្រឆាំងនឹងព្រះអង្គ។
«ប្រឆាំងនឹងព្រះអង្គដោយធ្វើនូវអ្វីដែលខុស»។ ពាក្យស្រដៀងគ្នាកើតមាននៅក្នុង
៤:១៥។

generated on Wed Sep 10 16:16:32 2025

គឺជាជំនាន់មនុស្សអាក្រក់ ហើយរៀចវេរ។
ពាក្យថា «មនុស្សអាក្រក់ »និង« រៀចវេរ» មានន័យថា រួមតែមួយ។
លោកម៉ូសេប្រើពួកវាដើម្បីបញ្ជាក់ពីជំនាន់អាក្រក់។ ការបកប្រែផ្សេងទៀត
«ជំនាន់អាក្រក់ទាំងស្រុង»
តើអ្នករាល់គ្នាសង់គុណព្រះអម្ចាស់ដោយប្រព្រឹត្តបែបនេះ ... មនុស្សល្ងីល្ងើ?
លោកម៉ូសេប្រើសំណួរមួយដើម្បីស្តីបន្ទោសប្រជាជន។ ការបកប្រែផ្សេងទៀត
«អ្នករាល់គ្នាគួរតែផ្តល់ការសរសើរដល់ព្រះអម្ចាស់ឱ្យបានត្រឹមត្រូវ ...
មនុស្សល្ងីល្ងើ។
មនុស្សល្ងីល្ងើ និងឥតប្រាជ្ញាអើយ
ពាក្យថាល្ងីល្ងើនិងឥតប្រាជ្ញាមានន័យដូចគ្នា ហើយបញ្ជាក់ថា
ប្រជាជនគឺល្ងីល្ងើចំពោះការមិនស្តាប់បង្គាប់ព្រះអម្ចាស់យ៉ាងណា។
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នាជាប្រជារាស្ត្រល្ងីល្ងើបំផុត»
ព្រះអង្គមិនជាព្រះបិតា ...បានបង្កើតអ្នករាល់គ្នា... បង្កើតអ្នករាល់គ្នា និងតាំងអ្នកឡើងផង។
លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដូចជាពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» នៅទីនេះជាឯកវចនៈ។
តើព្រះអង្គមិនជាព្រះបិតា ជាព្រះតែមួយអង្គដែលបានបង្កើតអ្នករាល់គ្នាមកទេឬ?
លោកម៉ូសេប្រើសំណួរមួយដើម្បីស្តីបន្ទោសប្រជាជន។ សំណួរដ៏ប៉ិនប្រសប់នេះ
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះបិតារបស់អ្នករាល់គ្នា ហើយជាអ្នកបង្កើតអ្នករាល់គ្នា»។
Deuteronomy 32:7
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងកំណាព្យមួយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ចូរនឹកចាំ ... ចូរពិចារណា ... ឪពុករបស់អ្នករាល់គ្នា ... បង្ហាញអ្នករាល់គ្នា ... ពួកចាស់ទុំ ...
ប្រាប់អ្នករាល់គ្នា
លោកម៉ូសេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល ដូចពួកគេជាមនុស្សម្នាក់ ដូច្នេះ
ពាក្យ «អ្នក» និង «របស់អ្នក» មានលក្ខណៈឯកវចនៈ។
ចូរនឹកចាំ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ចងចាំ»
ពីថ្ងៃពីចាស់បុរាណ
«ថ្ងៃដែលកន្លងហួស» លោកម៉ូសេសំដៅទៅលើពេលវេលា
អំឡុងពេលបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែលបានរស់នៅឡើយ។
ចូរពិចារណាពីអាយុច្រើនឆ្នាំដែលកន្លងទៅ។
នេះជាពាក្យដដែលៗ ដែលលោកម៉ូសេទើបតែបាននិយាយនៅក្នុងផ្នែកមុន។
លោកម៉ូសេចង់ឱ្យប្រជាជនអ៊ីស្រាអែលផ្តោតលើប្រវត្តិសាស្ត្ររបស់ខ្លួន
ក្នុងនាមជាប្រជាជាតិមួយ។
លោកនឹងបង្ហាញអ្នករាល់គ្នាឲ្យដឹង
«គាត់នឹងប្រាប់អ្នកឱ្យបានច្បាស់» ឬ «គាត់នឹងឱ្យអ្នកយល់ពីវា»
បានប្រទានទឹកដីឲ្យប្រជាជាតិទាំងឡាយ ទុកជាមរតក
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។«ដាក់ប្រជាជាតិនានានៅកន្លែង
ដែលពួកគេនឹងរស់នៅ» ។ ពាក្យស្រដៀងគ្នានេះ «ផ្តល់ឱ្យអ្នកនូវមរតក»
មាននៅក្នុង ៤:២១។
ព្រះអង្គបានកំណត់ព្រំដែនឲ្យប្រជាជននានា តាមចំនួននៃព្រះរបស់ពួកគេ។
ព្រះជាម្ចាស់តែងតាំងក្រុមមនុស្សនីមួយៗ
រួមគ្នាជាមួយព្រះរបស់ខ្លួនទៅទឹកដីរបស់ខ្លួន។
តាមរបៀបនេះព្រះអង្គបានដាក់កម្រិត
នៃឥទ្ធិពលរបស់រូបព្រះក្លែងក្លាយរបស់ក្រុមមនុស្ស។
Deuteronomy 32:9
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងកំណាព្យមួយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ពេលគាត់និយាយទៅកាន់ជនជាតិអ៊ីស្រាអែល
គាត់និយាយអំពីពួកគេដូចជាពួកគេជាមនុស្សម្នាក់ទៀត
ហើយដូចពួកគេជាមនុស្សម្នាក់។
ដ្បិត ចំណែករបស់ព្រះអម្ចាស់គឺជាប្រជារាស្ត្ររបស់ព្រះអង្គ
លោកយ៉ាកុបគឺជាចំណែកមរតករបស់ព្រះអង្គ។
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយអាចត្រូវបានបញ្ចូលគ្នា។ការបកប្រែផ្សេងទៀត
«កូនចៅរបស់យ៉ាកុបជាមរតករបស់ព្រះអម្ចាស់»
ព្រះអង្គបានរកឃើញលោក ...ព្រះអង្គបានការពារលោក
ហើយថែទាំលោក ...ព្រះអង្គបានការពារលោក
«ព្រះអង្គបានរកឃើញយ៉ាកុប ... បានការពារគាត់ហើយថែរក្សាគាត់ ...
ការពារគាត់» អ្នកប្រហែលជាត្រូវបកប្រែរឿងនេះ
ដូចជាលោកម៉ូសេកំពុងនិយាយអំពីជនជាតិអ៊ីស្រាអែលដូចមនុស្សជាច្រើនដែរ។
«ព្រះអង្គបានរកឃើញបុព្វបុរសរបស់យើង ...
បានការពារពួកគេហើយថែរក្សាពួកគេ ... ការពារពួកគេ» (សូមមើល UDB)
ក្នុងទីរហោស្ថាន គ្មានជីជាតិ និងឮតែសម្លេងស្រែកយំ
នៅទីនេះ «សំឡេងស្រែកយំ» សំដៅទៅលើសំឡេងខ្យល់បក់
នៅពេលវាបក់មកលើដីទំនេរ។
ព្រះអង្គបានការពារលោកដូចជាព្រះកែវព្រះនេត្ររបស់ព្រះអង្គ។
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ដូចជាព្រះនេត្ររបស់ព្រះអង្គ។ខាងក្នុងកែវភ្នែក
ដែលអាចឱ្យមនុស្សមើលឃើញ។ នេះជាផ្នែកសំខាន់និងរសើបរបស់រាងកាយ។
មានន័យថា ប្រជាជនអ៊ីស្រាអែលមានសារៈសំខាន់ណាស់
ចំពោះព្រះជាម្ចាស់និងអ្វីដែលព្រះអង្គការពារ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គបានការពារគាត់ដូចជាវត្ថុមួយ ដែលមានតម្លៃនិងថ្លៃបំផុត»
Deuteronomy 32:11
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងកំណាព្យមួយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដូចសត្វឥន្ទ្រីដែលការពារសំបុក និងហើរការពារពីលើកូន ព្រះអម្ចាស់ត្រដាងស្លាបរបស់ព្រះអង្គ
ហើយទទួលពួកគេ និងទ្រនៅលើចំអេងស្លាបរបស់ព្រះអង្គ។
មានន័យថា ព្រះអម្ចាស់បានឃ្លាំមើល និងការពារប្រជាជនអ៊ីស្រាអែល
ពេលពួកគេនៅវាលរហោស្ថាន។
ចំអេងស្លាប
ខាងក្រៅនៃស្លាបរបស់បក្សី
បាននាំលោក ... នៅជាមួយលោកឡើយ។
លោកម៉ូសេនិយាយម្តងទៀតអំពីជនជាតិអ៊ីស្រាអែល ថាជា«យ៉ាកុប»
Deuteronomy 32:13
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងកំណាព្យមួយទៅកាន់ប្រជាជនអ៊ីស្រាអែល។
ព្រះអង្គបានធ្វើឲ្យលោកនៅលើទឹកដីដែលមានទីខ្ពស់
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ពាក្យថា «លោក»
សំដៅទៅលើប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានឱ្យពួកគេលើទឹកន្លែងខ្ពស់នៅលើដី»
ឬ«ព្រះអម្ចាស់បានជួយពួកគេឱ្យយក និងកាន់កាប់ទឹកដីនេះ»
បានធ្វើឲ្យលោកនៅលើ ... បានចម្អែតលោក ... បានចិញ្ចឹមលោក
លោកម៉ូសេបន្តនិយាយអំពីជនជាតិអ៊ីស្រាអែលថា ជា« យ៉ាកុប»
ព្រះអង្គបានចម្អែតលោកដោយផលផ្លែ ចេញពីស្រែចម្ការ
«ព្រះអង្គបាននាំលោកទៅដីមួយ ដែលមានដំណាំជាច្រើនដែលគាត់អាចបរិភោគ»
ព្រះអង្គបានចិញ្ចឹមលោកដោយទឹកឃ្មុំចេញពីថ្ម និងប្រេងដែលចេញពីច្រាំងថ្មដ៏រឹង។
ទឹកដីនេះមានឃ្មុំព្រៃជាច្រើន
ដែលបង្កើតជាទឹកឃ្មុំជាមួយសំបុកនៅខាងក្នុងប្រហោងថ្ម។
វាក៏មានដើមអូលីវជាច្រើន ដែលផ្តល់ប្រេងហើយដុះនៅលើថ្ម ទួល និងភ្នំ។
បានចិញ្ចឹមលោកដោយទឹកឃ្មុំ
ដូចជាម្តាយបំបៅដោះកូន។ «បានអនុញ្ញាតឱ្យគាត់បឺតទឹកឃ្មុំ»
Deuteronomy 32:14
ព័ត៌មានទូទៅ៖
លោកម៉ូសេនិយាយចម្រៀងកំណាព្យមួយទៅកាន់ប្រជាជនអ៊ីស្រាអែល។
[12]ឥឡូវនេះ សូមស្បថចំពោះនាងខ្ញុំដោយនូវព្រះនាមព្រះអម្ចាស់ថា ដោយសារនាងខ្ញុំមានចិត្តសប្បុរសចំពោះពួកលោក ដូច្នេះ
សូមពួកលោកប្រព្រឹត្តជាមួយគ្រួសារឪពុកនាងខ្ញុំដោយសប្បុរសវិញផង។ សូមផ្តល់ទីសម្គាល់មួយដល់នាងខ្ញុំថា[13]ពួកលោកនឹងទុកជីវិតឲ្យឪពុក ម្តាយ
បងប្អូនប្រុសស្រីរបស់នាងខ្ញុំ និងគ្រួសាររបស់ពួកគេ ហើយពួកលោកពិតជាសង្គ្រោះជីវិតឲ្យពួកយើងពីសេចក្តីស្លាប់មែន»។
[14]ពួកគេបាននិយាយទៅនាងថា៖ «យើងយកជីវិតរបស់យើងមកធានា ប្រសិនបើ នាងមិននិយាយប្រាប់នរណាពីពួកយើងទេ ដូច្នេះ
នៅពេលដែលព្រះអម្ចាស់ប្រទានទឹកដីនេះមកយើង នោះយើងនឹងផ្តល់សេចក្តីមេត្តា និងសេចក្តីស្មោះត្រង់ដល់នាងមិនខាន»។
[15]ដូច្នេះ នាងបានប្រើខ្សែដើម្បីសម្រូតពួកគេចុះតាមបង្អួច។ ផ្ទះដែលនាងស្នាក់នៅបានសង់នៅលើរបងក្រុង។[16]នាងបាននិយាយទៅកាន់ពួកគេថា៖ «ចូរឡើងទៅលើភ្នំ
ហើយលាក់ខ្លួននៅទីនោះទៅ ដើម្បីកុំឲ្យអ្នកដែលដេញតាមរកអ្នកឃើញ។ សូមលាក់ខ្លួននៅទីនោះបីថ្ងៃ រហូតដល់អ្នកដែលដេញតាមត្រឡប់មកវិញ។
រួចសឹមទៅតាមផ្លូវរបស់អ្នកចុះ»។[17]ពួកគេក៏បាននិយាយនឹងនាងថា៖ «យើងនឹងមិនរក្សាសេចក្តីសន្យា ដែលយើងបានស្បថជាមួយនាងទេ បើនាងមិនធ្វើការនេះ»។
[18]នៅពេលដែលយើងចូរមកកាន់ទឹកដីនេះ អ្នកត្រូវតែចងខ្សែក្រហមនេះនៅមាត់បង្អួចដែលនាងបានសម្រូតពួកយើងចុះ ហើយអ្នកត្រូវប្រមូលឪពុកម្តាយបងប្អូន
និងគ្រួរបស់ឪពុករបស់នាងមកក្នុងផ្ទះនេះ។[19]អ្នកណាក៏ដោយដែលចេញក្រៅទ្វារផ្ទះទៅផ្លូវខាងក្រៅ នោះឈាមរបស់ពួកគេនឹងស្ថិតនៅលើក្បាលរបស់ពួកគេផ្ទាល់
ហើយយើងនឹងមិនទទួលខុសត្រូវឡើយ។ ប៉ុន្តែ បើមានដៃនរណាម្នាក់បានប៉ះពាល់ដល់អស់អ្នកដែលនៅក្នុងផ្ទះ យើងនឹងទទួលខុសត្រូវ។
[20]ប៉ុន្តែ បើអ្នកនិយាយពីយើង នោះយើងនឹងបានរួចពីសម្បថដែលយើងបានស្បថជាមួយនាងហើយ»។[21]នាងរ៉ាហាបបានឆ្លើយថា៖
«សូមឲ្យបានដូចពាក្យលោកមានប្រសាសន៍ចុះ»។ នាងក៏ឲ្យពួកគេចេញទៅ ហើយពួកគេក៏ចេញបាត់ទៅ។ បន្ទាប់មក នាងក៏បានចងខ្សែក្រហមនោះនៅមាត់បង្អួច។
[22]ពួកគេចាកចេញទៅ ហើយឡើងទៅលើភ្នំ គឺពួកគេបានស្នាក់នៅទីនោះបីថ្ងៃរហូតដល់ពួកអ្នកដែលដេញតាមត្រឡប់មកវិញ។ អ្នកដែលដេញតាមរកតាមផ្លូវ
តែរកមិនឃើញសោះ។

generated on Wed Sep 10 16:16:32 2025

[23]បុរសទាំងពីរនាក់បានត្រឡប់មកវិញ ហើយឆ្លងទន្លេយ័រដាន់ និងត្រឡប់ទៅឯលោកយ៉ូស្វេជាកូនរបស់នូនវិញ
រួចពួកគេបានរៀបរាប់រឿងគ្រប់យ៉ាងដែលបានកើតឡើងចំពោះពួកគេ។[24]ពួកគេបាននិយាយទៅកាន់លោកយ៉ូស្វេថា៖
«ព្រះអម្ចាស់ពិតជាប្រគល់ទឹកដីនេះដល់ពួកយើងមែន។ ប្រជាជនទាំងអស់នៅក្នុងទឹកដីនោះមានការភ័យខ្លាចជាខ្លាំងដោយសារពួកយើង»។

Joshua 2:1

នូន

នេះជាឪពុករបស់លោកយ៉ូស្វេ។

ស៊ីទីម

នេះជាឈ្មោះកន្លែងមួយនៅខាងកើតទន្លេយ័រដាន់។ វាមានន័យថា
«ដើមឈើអាកាស្យា»

ស៊ើបការណ៍

បុរសទាំងនេះត្រូវទៅមើលទឹកដីម្តងទៀត ដើម្បីទទួលបានព័ត៌មានអំពីរបៀប
ដែលអ៊ីស្រាអែលគួរតែដណ្តើមយកទឹកដីបាន។

Joshua 2:4

ព័ត៌មានទូទៅ

រ៉ាហាបដែលជាស្រីពេស្យា ការពារបុរសអ្នកស៊ើបការ
ជនជាតិអ៊ីស្រាអែលទាំងពីរនាក់ពីគ្រោះថ្នាក់។

ប៉ុន្តែ ស្ត្រីនោះបាននាំបុរសទាំងពីរនាក់នោះទៅ ហើយលាក់ពួកគេទុក។
រឿងនេះបានកើតឡើងមុនពេលដែលអ្នកនាំសាររបស់ស្តេចបាននិយាយទៅកាន់នាង។

ស្ត្រី

នេះសំដៅទៅលើរ៉ាហាបដែលជាស្រីពេស្យា.

ងងឹត

នេះគឺជាពេលល្ងាចឈានចូលប្រលប់ងងឹត។

Joshua 2:6

ប៉ុន្តែ នាងបាននាំពួកគេ... ឡើងទៅលើដំបូលផ្ទះ

នេះគឺជាព័ត៌មានសង្ខេប និងពន្យល់ពីរបៀបដែលនាងបានលាក់បុរសនៅក្នុងជំពូក
២: ៤ ។

ដំបូលផ្ទះ

ដំបូលមានរាងសំប៉ែត និងរឹងមាំដូច្នេះមនុស្សអាចដើរជុំវិញបាន។

ចំបើង

រុក្ខជាតិដែលត្រូវបានដាំដុះសម្រាប់សរសៃ
របស់វាដែលត្រូវបានប្រើក្នុងការធ្វើក្រណាត់

អ្នកទាំងនោះក៏ដេញតាមពួកគេ

បុរសបានដេញតាមអ្នកស៊ើបការណ៍
ដោយសារតែអ្វីដែលរ៉ាហាបបានប្រាប់ពួកគេនៅក្នុង ២: ៤ ។

ផ្លូវ

ទឹកន្លែងដែលទឹកទន្លេ
ឬដងទន្លដែលមានទឹករាក់ល្មមសម្រាប់ប្រជាជនអាចឆ្លងទៅម្ខាងទៀតដើរតាមបាន

Joshua 2:8

មិនទាន់ចូលដំណេកនៅឡើយ

នេះសំដៅទៅលើការចូលគេងពេលយប់។

ខ្ញុំដឹងថាព្រះជាម្ចាស់បានប្រគល់ទឹកដីនេះដល់ពួកលោក

ពាក្យថា «អ្នក» គឺសំដៅទៅលើប្រជាជនអ៊ីស្រាអែលទាំងអស់។

ហើយសេចក្តីភ័យខ្លាចបានកើតមានដល់ពួកយើង។

«ការភ័យខ្លាចអាចត្រូវបានបង្ហាញខុសគ្នា»។ ការបកប្រែផ្សេងទៀត
«យើងខ្លាចអ្នក»

មានការភ័យខ្លាចនៅចំពោះពួកលោកជាខ្លាំង។

នេះគឺប្រៀបធៀបមនុស្សដែលមានការភ័យខ្លាចទៅនឹងទឹកកករលាយនិងហូរឆ្ងាយ។
អាចមានន័យថា ១) ពួកគេនឹងខ្សោយនៅក្នុងវត្តមានរបស់អ៊ីស្រាអែលឬ ២)
ពួកគេនឹងខ្ចាត់ខ្ចាយ។ ការបកប្រែផ្សេងទៀត
«នឹងភ័យខ្លាចខ្លាំងណាស់ដែលពួកគេនឹងមិនទប់ទល់នឹងអ្នក»

Joshua 2:10

ព័ត៌មានទូទៅ

រ៉ាហាបបន្តនិយាយ ជាមួយអ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែល។

សមុទ្ររីងសួត

នេះគឺជាឈ្មោះមួយទៀតសម្រាប់សមុទ្រក្រហម។

ស្តេចស៊ីហុន ... ស្តេចអុក

ទាំងនេះគឺជាឈ្មោះរបស់ស្តេចអាម៉ូរី។

ដួងចិត្តរបស់យើងក៏តក់ស្លុត ហើយម្នាក់ៗក៏មានការភ័យខ្លាចជាខ្លាំង

ឃ្លាទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា រួមបញ្ចូលគ្នាដើម្បីសង្កត់ធ្ងន់។

ឃ្លាដែលថា « ដួងចិត្តរបស់យើងរលាយ»
ប្រៀបធៀបដួងចិត្តរបស់ប្រជាជនដ៏គួរអោយខ្លាចនៃក្រុងយេរីខូ
ទៅនឹងការរលាយទឹកកកនិងហូរចេញ។

Joshua 2:12

ព័ត៌មានទូទៅ

រ៉ាហាបបន្តនិយាយជាមួយអ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែល។

សូមស្បថចំពោះនាងខ្ញុំ ... សូមផ្តល់ទីសម្គាល់មួយដល់នាងខ្ញុំថា

ទាំងនេះគឺជាសេចក្តីថ្លែងស្រដៀងគ្នារបស់រ៉ាហាបសុំការធានា ពីអ្នកស៊ើបការណ៍។

ខ្ញុំមានចិត្តសប្បុរសចំពោះពួកលោក

ពាក្យ «អ្នក» សំដៅទៅលើអ្នកស៊ើបការណ៍ទាំងពីរនាក់។

ទុកជីវិតឲ្យ ... សង្គ្រោះជីវិតឲ្យពួកយើងពីសេចក្តីស្លាប់មែន»។

ពាក្យគួរសមនៃការនិយាយថា «កុំសម្លាប់យើង»

Joshua 2:14

ព័ត៌មានទូទៅ

អ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែល ធ្វើការសន្យាដែលរ៉ាហាបបានស្នើរសុំ នៅ
២:១២

យើងយកជីវិតរបស់យើងមកធានា

ព្រះនឹងដាក់បណ្តាសាដល់ពួកគេប្រសិន បើពួកគេមិនរក្សាការសន្យារបស់ពួកគេ។

ការបកប្រែផ្សេងទៀត «ប្រសិនបើយើងមិនធ្វើអ្វីដែលយើងបានសន្យាទេ
ព្រះអម្ចាស់អាចនឹងធ្វើឲ្យពួកយើងស្លាប់...»

Joshua 2:15

ព័ត៌មានទូទៅ

អ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែល បន្តនិយាយជាមួយនាងរ៉ាហាប។

បើនាងមិនធ្វើការនេះ»

នេះបង្ហាញពីលក្ខខណ្ឌសម្រាប់ការសន្យា
ដែលអ្នកស៊ើបការណ៍បានធ្វើចំពោះនាងរ៉ាហាប។ ពាក្យថា « នេះ» សំដៅទៅលើ «
ខ្សែក្រហមចងនៅតាមបង្អួច» ក្នុង២:១៨។

Joshua 2:18

ឃ្លាភ្ជាប់

អ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែល
បញ្ជាក់ពីលក្ខខណ្ឌដែលពួកគេបានបង្ហាញក្នុង ២ :១៥ ។

ព័ត៌មានទូទៅ

អ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែល បន្តនិយាយជាមួយនាងរ៉ាហាប។

អ្នកណាក៏ដោយដែលចេញក្រៅទ្វារផ្ទះទៅផ្លូវខាងក្រៅ

ឃ្លានេះបង្ហាញពីលក្ខខណ្ឌបង្កើតឡើងផ្អែកទៅកាលៈទេសៈ។

នោះឈាមរបស់ពួកគេនឹងស្ថិតនៅលើក្បាលរបស់ពួកគេផ្ទាល់

នៅទីនេះ «ឈាម» តំណាងឲ្យការស្លាប់របស់មនុស្សម្នាក់។

អ្នកត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ពួកគេ។

គេនិយាយថាដូចជាឈាមរបស់ពួកគេនឹងនៅលើក្បាលរបស់ពួកគេ។

ការបកប្រែផ្សេងទៀត «ការស្លាប់របស់ពួកគេនឹងក្លាយជាកំហុសរបស់ពួកគេ»

យើងនឹងមិនទទួលខុសត្រូវឡើយ

«យើងនឹងគ្មានកំហុស»

បើមានដៃនរណាម្នាក់បានប៉ះពាល់ដល់អស់អ្នក

នៅទីនេះ « ដៃដាក់លើ»
គឺជាវិធីគួរសមមួយក្នុងការសំដៅទៅលើការបង្កឲ្យមាននរណាម្នាក់រងរបួស។
ការបកប្រែផ្សេងទៀត «ប្រសិនបើយើងបង្កឲ្យនរណាម្នាក់រងរបួស»

Joshua 2:20

ព័ត៌មានទូទៅ

អ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែលទាំងពីរនាក់ និយាយជាមួយនាងរ៉ាហាប
អំពីសេចក្តីសន្យារបស់ពួកគេចំពោះនាង។

ព័ត៌មានទូទៅ

អ្នកស៊ើបការណ៍បានតម្រូវឲ្យរ៉ាហាបរក្សាភាពស្ងៀមស្ងាត់

generated on Wed Sep 10 16:16:32 2025

អំពីការទៅមើលរបស់ពួកគេ
ឬពួកគេនឹងអាចរួចផុតពីសម្បថដើម្បីការពារគ្រួសាររបស់នាង។
បើអ្នកនិយាយពីយើង
«អ្នក» សំដៅទៅលើនាងរ៉ាហាប។
សូមឲ្យបានដូចពាក្យលោកមានប្រសាសន៍ចុះ
នាងរ៉ាហាបបានយល់ព្រមតាមលក្ខខណ្ឌសម្បថរបស់ពួកគេ
ដើម្បីការពារគ្រួសាររបស់នាង។
Joshua 2:22
ព័ត៌មានទូទៅ
អ្នកស៊ើបការណ៍ជនជាតិអ៊ីស្រាអែលទាំងពីរនាក់ចាកចេញពីក្រុងយេរីខូ។
ពួកអ្នកដែលដេញតាមត្រឡប់មកវិញ
អ្នកដែលដេញតាមពួកគេបានត្រឡប់ទៅក្រុងយេរីខូវិញ។
រកមិនឃើញសោះ
នេះសំដៅទៅលើបុរសដែលមិនបានរកឃើញអ្នកស៊ើបការណ៍។
Joshua 2:23
បុរសទាំងពីរនាក់បានត្រឡប់មកវិញ
បុរសទាំងពីរនាក់ បានវិលត្រឡប់ទៅជំរំជនជាតិអ៊ីស្រាអែលវិញ។
បានត្រឡប់មកវិញ ហើយឆ្លងទន្លេយ័រដាន់ និងត្រឡប់ទៅ
ទាំងនេះគឺជាការបង្ហាញស្រដៀងគ្នាដែលសំដៅទៅលើការវិលត្រឡប់ទៅ
កន្លែងដែលប្រជាជនអ៊ីស្រាអែលត្រូវបានបោះជំរុំ។
ឆ្លង
«ឆ្លងកាត់» មានន័យថាទៅច្រាំងទន្លេទល់មុខ។ការបកប្រែផ្សេងទៀត
«បានធ្វើដំណើរពីត្រើយម្ខាងទៅត្រើយម្ខាងទៀត នៃទន្លេយ័រដាន់»
នូន
នេះជាឈ្មោះមនុស្សប្រុស ឪពុករបស់លោកយ៉ូស្វេ។
គ្រប់យ៉ាងដែលបានកើតឡើងចំពោះពួកគេ
«អ្វីទាំងអស់ដែលពួកគេបានឆ្លងកាត់ និងបានឃើញ»
ពួកយើង
ពាក្យនេះ «យើង» សំដៅទៅលើអ៊ីស្រាអែល។
ប្រជាជនទាំងអស់នៅក្នុងទឹកដីនោះមានការភ័យខ្លាចជាខ្លាំងដោយសារពួកយើង»។
ប្រជាជននៃស្រុកនោះឆ្ពោះទៅកាន់អ៊ីស្រាអែល
គឺដូចជាសារធាតុដែលរលាយពេលមានកម្តៅ។

---

3 [1]លោកយ៉ូស្វេបានក្រោកឡើងពីព្រលឹម ហើយពួកគេបានចេញដំណើរចេញពីស៊ីទីម។ ពួកគេបានមកដល់ទន្លេយ័រដាន់ លោក
និងប្រជាជនអ៊ីស្រាអែលទាំងអស់បានបោះជំរំនៅទីនោះមុនពេលដែលពួកគេឆ្លងកាត់ទន្លេយ័រដាន់។
[2]បីថ្ងៃក្រោយមក អ្នកដឹកនាំបានដើរកាត់កណ្តាលជំរំ[3]ពួកគេបានបញ្ជាដល់ប្រជាជនទាំងអស់ថា៖
«នៅពេលដែលអ្នកបានឃើញហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នករាល់គ្នា ហើយមានពួកបូជាចារ្យមកពីកុលសម្ព័ន្ធលេវីសែងហិបនោះ
អ្នករាល់គ្នាត្រូវតែចេញពីទីនេះ ហើយដើរតាមហិបនោះ។[4]អ្នកត្រូវតែនៅឆ្ងាយពីហិបប្រមាណពីរពាន់ហត្ថ។ កុំឲ្យមកជិតហិបឲ្យសោះ នោះអ្នកនឹងដឹងថា ត្រូវទៅផ្លូវណា
ព្រោះអ្នករាល់គ្នាមិនធ្លាប់ស្គាល់ផ្លូវនោះពីមុនមកឡើយ»។
[5]លោកយ៉ូស្វេបានមានប្រសាសន៍ទៅកាន់ប្រជាជនថា៖ «ថ្ងៃស្អែកចូរជម្រះខ្លួនឲ្យបានបរិសុទ្ធ ព្រោះព្រះអម្ចាស់នឹងធ្វើការយ៉ាងអស្ចារ្យនៅក្នុងចំណោមអ្នករាល់គ្នា»។
[6]បន្ទាប់មក លោកយ៉ូស្វេបានមានប្រសាសន៍ទៅកាន់ពួកបូជាចារ្យថា៖ «ចូរសែងហិបនៃសម្ពន្ធមេត្រី ហើយដើរនៅខាងមុខបណ្តាជនទៅ»។ ដូច្នេះ
ពួកគេក៏បានសែងហិបនៃសម្ពន្ធមេត្រី ហើយដើរនៅខាងមុខប្រជាជន។
[7]ព្រះអម្ចាស់បានមានបន្ទូលមកកាន់លោកយ៉ូស្វេថា៖ «ថ្ងៃនេះយើងនឹងធ្វើឲ្យអ្នកក្លាយជាមនុស្សអស្ចារ្យនៅចំពោះមុខជនជាតិអ៊ីស្រាអែល។
ពួកគេនឹងដឹងថាយើងគង់នៅជាមួយអ្នកដូចជាយើងគង់នៅជាមួយម៉ូសេដែរ។[8]អ្នកនឹងបញ្ជាពួកបូជាចារ្យដែលសែងហិបនៃសម្ពន្ធមេត្រី
«នៅពេលដែលអ្នកមកដល់ច្រាំងនៃទន្លេយ័រដាន់ អ្នកត្រូវតែឈរឲ្យស្ងៀមនៅក្នុងទន្លេយ័រដាន់នេះ»។
[9]បន្ទាប់មក លោកយ៉ូស្វេបានមានប្រសាសន៍ទៅកាន់ជនជាតិអ៊ីស្រាអែលថា៖ «សូមមកទីនេះ ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នក។
[10]តាមរយៈការនេះ អ្នកនឹងដឹងថាព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ សណ្ឋិតជាមួយអ្នករាល់គ្នា ហើយព្រះអង្គនឹងបណ្តេញជនជាតិកាណាន ជនជាតិហេត ជនជាតិហេវី
ជនជាតិពេរីស៊ីត ជនជាតិគើរកាស៊ី ជនជាតិអាម៉ូរី និងជនជាតិយេប៊ូសចេញពីមុខអ្នករាល់គ្នា។[11]មើល!
ហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់នៃផែនដីទាំងមូលនឹងឆ្លងកាត់ទន្លេយ័រដាន់នៅមុខអ្នករាល់គ្នា។
[12]ឥឡូវនេះ ចូរជ្រើសរើសមនុស្សប្រុសដប់ពីរនាក់ចេញពីកុលសម្ព័ន្ធទាំងដប់ពីរ គឺម្នាក់ក្នុងមួយកុលសម្ព័ន្ធ។
[13]នៅពេលដែលជើងរបស់ពួកបូជាចារ្យដែលសែងហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់នៃផែនដីទាំងមូលបានប៉ះទឹកទន្លេយ័រដាន់
នោះទឹកទន្លេយ័រដាន់នឹងត្រូវញែកចេញពីគ្នា ហើយសូម្បីតែទឹកដែលហូរមកពីខាងលើក៏ត្រូវឈប់នឹងមួយកន្លែងដែរ»។
[14]ដូច្នេះ នៅពេលដែលប្រជាជនត្រៀមក្នុងការឆ្លងទន្លេយ័រដាន់ ពួកបូជាចារ្យដែលត្រូវសែងហិបនៃសម្ពន្ធមេត្រីដើរខាងមុខប្រជាជន។
[15]នៅពេលអ្នកដែលបានសែងហិបមកដល់ទន្លេយ័រដាន់ ហើយនៅពេលដែលជើងរបស់ពួកគេបានជាន់ប៉ះទឹក
(ឥឡូវនេះទឹកទន្លេយ័រដាន់បានជន់លិចមាត់ច្រាំងនារដូវច្រូវ)[16]ទឹកដែលហូរពីខាងលើនៅនឹងមួយកន្លែង។ ទឹកបានឈប់ហូរពីចម្ងាយ។
ទឹកឈប់ហូរតាំងពីក្រុងអាដាំជាក្រុងនៅក្បែរសាថាន រហូតដល់សមុទ្រនេកេវ ជាសមុទ្រទឹកប្រៃ។ ប្រជាជនបានឆ្លងនៅជិតក្រុងយេរីខូ។
[17]ពួកបូជាចារ្យដែលសែងហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ឈរនៅលើដីស្ងួតកណ្តាលទន្លេយ័រដាន់រហូតដល់ប្រជាជនអ៊ីស្រាអែលទាំងអស់ឆ្លងកាត់ទន្លេនៅលើដីស្ងួត។

Joshua 3:1
បានក្រោកឡើង
ឃ្លាថា «ក្រោកឡើង» មានន័យថា «ភ្ញាក់ឡើង»។
ស៊ីទីម
កន្លែងមួយនៅស្រុកម៉ូអាប់
នៅខាងលិចទន្លេយ័រដាន់ជាកន្លែងដែលជនជាតិអ៊ីស្រាអែល
បានបោះជំរុំមុនពេលពួកគេចូលទឹកដីកាណាន ដែលជាទឹកដីសន្យា។
Joshua 3:2
អ្នកដឹកនាំ
ទាំងនេះគឺជាមនុស្សដែលមានតួនាទី ជាអ្នកបញ្ជា ឬមានសិទ្ធិអំណាច។
ប្រជាជន
នេះគឺជាប្រជាជាតិអ៊ីស្រាអែល។
ប្រមាណពីរពាន់ហត្ថ
«២០០០ ហត្ថ» ។ ពាក្យថា «ហត្ថ»
គឺជារង្វាស់ដែលស្មើនឹងចម្ងាយពីកែងដៃទៅចុងម្រាមដៃ។
Joshua 3:5
ចូរជម្រះខ្លួនឲ្យបានបរិសុទ្ធ
នេះសំដៅទៅលើការរៀបចំពិសេស នៃការសម្អាតខាងសាសនាចំពោះព្រះអម្ចាស់។
ព្រះអម្ចាស់នឹងធ្វើការយ៉ាងអស្ចារ្យនៅក្នុងចំណោមអ្នករាល់គ្នា
ព្រះអម្ចាស់នឹងធ្វើការអស្ចារ្យដើម្បី អោយមនុស្សទាំងអស់បានឃើញ
និងមានបទពិសោធន៍។
ចូរសែងហិបនៃសម្ពន្ធមេត្រី
នេះគឺសំដៅទៅលើពួកលេវីដែលយកហិបនៃសម្ពន្ធមេត្រី
សម្រាប់គោលបំណងសែងពីទីតាំងមួយទៅទីតាំងមួយទៀត។
Joshua 3:7
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រាប់លោកយ៉ូស្វេ អំពីអ្វីដែលបូជាចារ្យត្រូវធ្វើ។
យើងនឹងធ្វើឲ្យអ្នកក្លាយជាមនុស្សអស្ចារ្យនៅចំពោះមុខជនជាតិអ៊ីស្រាអែល។
នៅទីនេះ «ភ្នែក» តំណាងឲ្យមនុស្សដែលមើលឃើញនិងយល់។
ការបកប្រែផ្សេងទៀត «ប្រជាជននឹងឃើញអ្វីដែលខ្ញុំធ្វើ
និងទទួលស្គាល់ថាខ្ញុំបានធ្វើឲ្យអ្នកក្លាយជាមនុស្សអស្ចារ្យ»
ច្រាំងនៃទន្លេយ័រដាន់

generated on Wed Sep 10 16:16:32 2025

លោកយ៉ូស្វេត្រូវទៅជិតច្រាំងទន្លេយ័រដាន់។
Joshua 3:9
ព័ត៌មានទូទៅ
លោកយ៉ូស្វេប្រាប់ជនជាតិអ៊ីស្រាអែល នូវអ្វីដែលព្រះអម្ចាស់នឹងធ្វើ
ចេញពីមុខអ្នករាល់គ្នា
ព្រះអម្ចាស់នឹងបង្ខំប្រជាជនផ្សេងទៀតដែលរស់នៅលើទឹកដី ដើម្បីឲ្យចាកចេញ
ឬត្រូវសម្លាប់។
ឆ្លងកាត់
«ឆ្លងកាត់» មានន័យថាទៅច្រាំងទន្លេទល់មុខ។ ការបកប្រែផ្សេងទៀត «
នឹងធ្វើដំណើរទៅត្រើយម្ខាងទៀត»
Joshua 3:12
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តប្រាប់អ៊ីស្រាអែល អំពីការអស្ចារ្យដែលព្រះអម្ចាស់នឹងធ្វើ។
ព័ត៌មានទូទៅ
ដូចជាបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែលធ្លាប់មានបទពិសោធន៍ឆ្លងកាត់សមុទ្រក្រហម
ប្រជាជនទាំងនេះនឹងឆ្លងកាត់ទន្លេយ័រដាន់នៅលើដីស្ងួត។
ជើង
នេះសំដៅទៅលើបាតជើងរបស់ពួកគេ។
ទឹកដែលហូរមក
ពាក្យនេះសំដៅទៅលើទិសដៅទឹកទន្លេយ័រដាន់កំពុងហូរឆ្ពោះ
ទៅប្រទេសអ៊ីស្រាអែល។
មួយកន្លែង
ទឹកនឹងស្ថិតនៅមួយកន្លែងឬកន្លែងមួយ។ វានឹងមិនហូរនៅជុំវិញបូជាចារ្យទេ។
Joshua 3:14
ហិបនៃសម្ពន្ធមេត្រី
ពាក្យថា «ហឹប» នៅទីនេះសំដៅទៅលើដើមទ្រូងដែលមានថ្មចារឹក។
ប៉ះទឹក
នេះអាចសំដៅទៅលើផ្នែកទឹក ក៏ដូចជាច្រាំងដែលទឹកហូរទៅដីស្ងួត។
ឥឡូវនេះទឹកទន្លេយ័រដាន់បានជនលិចមាត់ច្រាំងនារដូវចម្រូរ
នេះគឺជាពត៌មានសង្ខេប ហើយវាសង្កត់ធ្ងន់លើទំហំនៃអ្វីដែលព្រះអម្ចាស់កំពុងធ្វើ។
Joshua 3:17
ព័ត៌មានទូទៅ
ការអស្ចារ្យនៅតែបន្ត ក្នុងការឆ្លងកាត់ទន្លេយ័រដាន់។
ទន្លេយ័រដាន់
នេះសំដៅទៅលើជ្រលងទន្លេយ័រដាន់។
ឆ្លងកាត់
ឃ្លានេះមានន័យថាត្រូវទៅច្រាំងទន្លេទល់មុខ។ ការបកប្រែផ្សេងទៀត
«បានធ្វើដំណើរពីត្រើយម្ខាងទៅត្រើយម្ខាងទៀត»

---

4 [1]នៅពេលដែលប្រជាជនទាំងអស់បានឆ្លងកាត់ទន្លេយ័រដាន់រួចហើយ ព្រះអម្ចាស់បានមានបន្ទូលមកកាន់លោកយ៉ូស្វេថា៖
[2]«ចូរជ្រើសរើសមនុស្សប្រុសដប់ពីរនាក់ពីក្នុងចំណោមកុលសម្ព័ន្ធទាំងដប់ពីរ គឺក្នុងមួយកុលសម្ព័ន្ធម្នាក់។[3]ចូរបញ្ជាគេថា៖ «ចូរយកថ្មដប់ពីរដុំពីកណ្តាលទន្លេយ័រដាន់
គឺពីកន្លែងដែលពួកបូជាចារ្យកំពុងឈរនៅលើដីស្ងួត ហើយយកវាទៅជាមួយអ្នក ដើម្បីដាក់នៅកន្លែងដែលអ្នកនឹងសម្រាកនៅយប់នេះ»។
[4]បន្ទាប់មក លោកយ៉ូស្វេហៅមនុស្សប្រុសដប់ពីរនាក់ដែលលោកបានជ្រើសរើសចេញពីកុលសម្ព័ន្ធទាំងដប់ពីរ គឺក្នុងមួយកុលសម្ព័ន្ធម្នាក់។
[5]លោកយ៉ូស្វេមានប្រសាសន៍ទៅពួកគេថា៖ «ចូរដើរនៅខាងមុខហិបរបស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នកទៅក្នុងកណ្តាលទន្លេយ័រដាន់ទៅ។
អ្នកទាំងអស់គ្នាម្នាក់ៗត្រូវរើសថ្មម្នាក់មួយដុំដាក់លើស្មា តាមចំនួនកុលសម្ព័ន្ធរបស់ប្រជាជនអ៊ីស្រាអែល។
[6]ការនេះនឹងជាសញ្ញាក្នុងចំណោមអ្នករាល់គ្នានៅពេលដែលកូនចៅរបស់អ្នកសួរនៅពេលក្រោយថា៖ «តើថ្មនេះមានអត្ថន័យដូចម្តេច»?[7]នោះ
អ្នករាល់គ្នាអាចឆ្លើយទៅគេវិញថា៖ «ទឹកនៅក្នុងទន្លេយ័រដាន់បានកាត់ផ្តាច់នៅពីមុខហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។ នៅពេលដែលហិបបានឆ្លងកាត់ទន្លេយ័រដាន់
ហើយទឹកទន្លេយ័រដាន់ក៏រីងដែរ។ ដូច្នេះ ថ្មទាំងនេះនឹងក្លាយជាការរំឭកដល់ប្រជាជនអ៊ីស្រាអែលជារៀងរហូត»។
[8]ប្រជាជនអ៊ីស្រាអែលបានធ្វើអ្វីដែលលោកយ៉ូស្វេបានបង្គាប់ ហើយពួកគេបានរើសថ្មដប់ពីរដុំពីកណ្តាលទន្លេយ័រដាន់ ដូចដែលព្រះអម្ចាស់បានប្រាប់ដល់លោកយ៉ូស្វេដែរ។
ពួកគេបានរៀបចំថ្មទាំងនោះ ទៅតាមចំនួនកុលសម្ព័ន្ធរបស់ប្រជាជនអ៊ីស្រាអែល។ ពួកគេបានយកថ្មរៀងៗខ្លួន ទៅកាន់កន្លែងដែលពួកគេបោះជំរំហើយដាក់នៅទីនោះ។
[9]បន្ទាប់មកលោកយ៉ូស្វេបានបញ្ឈរថ្មទាំងដប់ពីរដុំដែលបានយកពីកណ្តាលទន្លេយ័រដាន់នៅកន្លែងដែលពួកបូជាចារ្យបានឈរសែងហិបនៃសម្ពន្ធមេត្រី។
សេចក្តីរឭកនេះមានរហូតមកដល់សព្វថ្ងៃ។
[10]ពួកបូជាចារ្យដែលបានសែងហិបបានឈរនៅកណ្តាលទន្លេយ័រដាន់រហូតដល់អ្វីៗដែលព្រះអម្ចាស់បានបង្គាប់ដល់លោកយ៉ូស្វេឲ្យប្រាប់ដល់ជនជាតិអ៊ីស្រាអែលបានសម្រេច
ដូចអ្វីដែលលោកម៉ូសេបានបង្គាប់ដល់លោកយ៉ូស្វេដែរ។ ប្រជាជនបានឆ្លងកាត់ទន្លេយ៉ាងប្រញាប់។[11]ក្រោយពេលដែលប្រជាជនបានឆ្លងកាត់រួចហើយ
នោះហិបរបស់ព្រះអម្ចាស់ និងពួកបូជាចារ្យបានដើរនាំមុខប្រជាជន។
[12]កុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលបានដើរខាងមុខប្រជាជនអ៊ីស្រាអែល ដែលមានរបៀបដូចជាទាហាន
ដូចដែលលោកម៉ូសេបានបង្គាប់ដល់ពួកគេ។[13]មានបុរសប្រហែលបួនម៉ឺននាក់បំពាក់គ្រឿងសឹកសង្គ្រាមដើរខាងមុខព្រះអម្ចាស់ដើម្បីធ្វើសង្គ្រាមនៅទីវាលក្រុងយេរីខូ។
[14]នៅថ្ងៃនោះព្រះអម្ចាស់បានធ្វើឲ្យលោកយ៉ូស្វេក្លាយជាមនុស្សខ្លាំងពូកែនៅមុខប្រជាជនអ៊ីស្រាអែល។
ពួកគេបានគោរពលោកអស់មួយជីវិតដូចជាគេគោរពដល់លោកម៉ូសេដែរ។
[15]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកកាន់លោកយ៉ូស្វេថា៖[16]«ចូរបង្គាប់ពួកបូជាចារ្យដែលសែងហិបនៃទីបន្ទាល់ឡើងមកពីទន្លេយ័រដាន់»។
[17]ដូច្នេះ លោកយ៉ូស្វេបានបង្គាប់ដល់ពួកបូជាចារ្យថា៖ «ចូរឡើងពីទន្លេយ័រដាន់មក»។
[18]នៅពេលដែលពួកបូជាចារ្យដែលសែងហិបរបស់ព្រះអម្ចាស់បានឡើងពីកណ្តាលទន្លេយ័រដាន់មក ហើយនៅពេលដែលជើងរបស់ពួកគេបានដាក់នៅលើដីស្ងួត
ពេលនោះទឹកទន្លេយ័រដាន់បានហូរមកកន្លែងរបស់វាវិញ ហើយបានពេញច្រាំង ដូចដែលធ្លាប់មានកាលពីបួនថ្ងៃមុនដែរ។
[19]ប្រជាជនបានឡើងពីទន្លេយ័រដាន់នៅថ្ងៃទីដប់ ខែទីមួយ។ ពួកគេបានស្នាក់នៅគីលកាល នៅខាងកើតក្រុងយេរីខូ។
[20]ថ្មទាំងដប់ពីរដុំដែលពួកគេបានយកចេញពីទន្លេយ័រដាន់មក លោកយ៉ូស្វេបានដាក់នៅត្រង់គីលកាល។[21]លោកបានមានប្រសាសន៍ទៅកាន់ប្រជាជនអ៊ីស្រាអែលថា៖
«នៅពេលដែលកូនចៅរបស់អ្នករាល់គ្នាសួរថា តើថ្មទាំងនេះជាអ្វី?
[22]ចូរប្រាប់ដល់កូនចៅរបស់អ្នករាល់គ្នាថា៖ «នេះគឺជាកន្លែងដែលជនជាតិអ៊ីស្រាអែលបានឆ្លងកាត់ទន្លេយ័រដាន់តាមដីស្ងួត»។
[23]ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានធ្វើឲ្យទឹកទន្លេយ័រដាន់រីងសម្រាប់អ្នករាល់គ្នា រហូតដល់អ្នករាល់គ្នាបានឆ្លងកាត់ទន្លេទាំងអស់គ្នា
ដូចដែលព្រះជាម្ចាស់បានធ្វើនៅសមុទ្រដើមត្រែងរីង ដែលទ្រង់បានធ្វើឲ្យទឹករីងរហូតយើងឆ្លងកាត់រួច។[24]ដូច្នេះ
មនុស្សទាំងអស់នៅលើផែនដីទាំងមូលនឹងដឹងថាព្រះហស្តរបស់ព្រះអម្ចាស់មានពេញដោយចេស្តា នោះអ្នកនឹងគោរពព្រះអម្ចាស់ជាព្រះរបស់អ្នករៀងរហូតទៅ។

Joshua 4:1
ព័ត៌មានទូទៅ
ទោះបីព្រះអម្ចាស់មានព្រះបន្ទូលផ្ទាល់ទៅកាន់លោកយ៉ូស្វេ
គឺការកើតឡើងទាំងអស់រួមបញ្ចូលទាំងអ៊ីស្រាអែលដែរ។
ឆ្លងកាត់
ពាក្យថា «ឆ្លងកាត់» សំដៅទៅឯច្រាំងទន្លេទល់មុខ។ ការបកប្រែផ្សេងទៀត
«បានឆ្លងកាត់»
ទន្លេយ័រ
«ទន្លេយ័រដាន់»
ចូរបញ្ជាគេថា៖ ' ... '
ប្រើការដកស្រងអាចត្រូវបានបញ្ជាក់ជាការដោយប្រយោល។ ការបកប្រែផ្សេងទៀត
«សូមបញ្ជាពួកគេថា៖ ចូរយកថ្មដប់ពីរដុំពីកណ្តាលទន្លេយ័រដាន់

generated on Wed Sep 10 16:16:32 2025

គឺពីកន្លែងដែលពួកបូជាចារ្យកំពុងឈរនៅលើដីស្ងួត ហើយយកវាទៅជាមួយអ្នក
ដើម្បីដាក់នៅកន្លែងដែលអ្នកនឹងសម្រាកនៅយប់នេះ»។
Joshua 4:4
ព័ត៌មានទូទៅ
លោកយ៉ូស្វេប្រាប់ដល់បុរសទាំង១២នាក់ នូវអ្វីដែលត្រូវធ្វើ។
ទៅក្នុងកណ្តាលទន្លេយ័រដាន់ទៅ។ អ្នកទាំងអស់គ្នាម្នាក់ៗត្រូវរើសថ្មម្នាក់មួយដុំដាក់លើស្មា
បុរសទាំងដប់ពីរនាក់ម្នាក់ៗ ត្រូវរើសដុំថ្មធំមួយ ពីជ្រលងទន្លេយ័រដាន់
ហើយសែងហឹបទៅត្រើយម្ខាងទៀតដើម្បីសង់ស្ងួបមួយ។
Joshua 4:6
ព័ត៌មានទូទៅ
លោកយ៉ូស្វេប្រាប់ជនជាតិអ៊ីស្រាអែលថា តើគំនរថ្មដប់ពីរដុំមានន័យយ៉ាងណា។
ទឹកនៅក្នុងទន្លេយ័រដាន់បានកាត់ផ្តាច់នៅពីមុខហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។
នេះអាចបញ្ជាក់ជាទម្រង់កិរិយាសព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានផ្តាច់ទឹកទន្លេយ័រដាន់ នៅមុខហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអង្គ»
ទឹកទន្លេយ័រដាន់
«គឺទន្លេយ័រដាន់»
ទឹកនៅក្នុងទន្លេយ័រដាន់បានកាត់ផ្តាច់នៅពីមុខហឹប
ព្រះបានការពារទន្លេយ័រដាន់មិនឲ្យ ហូរទៅលើហឹបដែលក្រុមបូជាចារ្យសែង។
ហើយទឹកទន្លេយ័រដាន់ក៏រីងដែរ
ទឹកហូរចុះតាមទន្លេយ័រដាន់បានឈប់នៅមុខហឹប។
ដូច្នេះមនុស្សគ្រប់គ្នារួមទាំងហឹបបានធ្វើដំណើរនៅលើជ្រលងទន្លេដីស្ងួត។
Joshua 4:8
ព័ត៌មានទូទៅ
លោកយ៉ូស្វេនិងអ៊ីស្រាអែល បន្តធ្វើដូចព្រះអម្ចាស់បានបង្គាប់។
ពួកគេបានរើសថ្មដប់ពីរដុំពីកណ្តាលទន្លេយ័រដាន់
នេះសំដៅទៅលើបុរសទាំង១២នាក់ ដែលរើសដុំថ្មពីកណ្តាលទន្លេយ័រដាន់។
បន្ទាប់មកលោកយ៉ូស្វេបានបញ្ជារថ្មទាំងដប់ពីរដុំដែលបានយកពីកណ្តាលទន្លេយ័រ
ទាំងនេះជាថ្មដប់ពីរដុំទៀត
មិនមែនជាថ្មដែលបុរសទាំងដប់ពីររូបនេះសែងចេញពីបាតទន្លេទេ។
សេចក្តីរំឭកនេះមានរហូតមកដល់សព្វថ្ងៃ
នេះមានន័យថារំលឹកនៅទីនោះ
រហូតដល់ថ្ងៃដែលអ្នកនិពន្ធបានកំពុងសរសេរសៀវភៅនេះ។
Joshua 4:10
ទន្លេយ័រដាន់
នេះសំដៅទៅលើទន្លេយ័រដាន់។
ប្រជាជន
នេះសំដៅទៅលើប្រជាជាតិអ៊ីស្រាអែល។ (សូមមើលfigs-metonymy)
បានឆ្លងកាត់រួចហើយ
នេះមានន័យថាទៅច្រាំងទន្លេទល់មុខ។ ការបកប្រែផ្សេងទៀត
«បានធ្វើដំណើរពីត្រើយម្ខាងទៅត្រើយម្ខាងទៀត»
នាំមុខប្រជាជន។
នេះសំដៅទៅលើការឈរនៅចំពោះមុខប្រជាជន
ឬនៅចំពោះមុខប្រជាជនទាំងអស់។
មនុស្សគ្រប់គ្នាបានឃើញហឹបសែងដោយបូជាចារ្យ។
Joshua 4:12
កុលសម្ព័ន្ធរូបន កុលសម្ព័ន្ធកាដ
និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលបានដើរខាងមុខប្រជាជនអ៊ីស្រាអែល
ដែលមានរបៀបដូចជាទាហាន
ទាំងនេះជាទាហាននៃកុលសម្ព័ន្ធទាំង៣ក្រុម
ដែលបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការដឹកនាំជនជាតិអ៊ីស្រាអែលអោយធ្វើសង្គ្រាម
ដើម្បីតាំងទីលំនៅនៅត្រើយខាងកើតនៃទន្លេយ័រដាន់។
ពួកគេបានគោរព
ពាក្យថា« ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
គោរពដល់លោកម៉ូសេ
នេះមិនគ្រាន់តែសំដៅទៅលើការគោរពប៉ុណ្ណោះទេ
តែត្រូវចុះចូលនឹងបទបញ្ជារបស់គាត់
និងចាត់ទុកគាត់ជាមេបញ្ជាការកងទ័ពរបស់ពួកគេដូចដែលពួកគេបានដើរតាមលោកម៉ូសេ។
Joshua 4:15
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រាប់យ៉ូស្វេ ឲ្យពួកបូជាចារ្យចេញពីទន្លេយ័រដាន់។
Joshua 4:17
ព័ត៌មានទូទៅ
អ្នកនិពន្ធបានបញ្ជាក់វាយ៉ាងច្បាស់ថា ការបែងចែកជាផ្នែកនៃទន្លេយ័រដាន់
គឺមិនខុសគ្នាពីការបែងចែកសមុទ្រក្រហមសម្រាប់ជំនាន់មុនទេ។
ទឹកទន្លេយ័រដាន់បានហូរមកកន្លែងរបស់វាវិញ ហើយបានពេញច្រាំង
ទន្លេយ័រដាន់បានជន់លិចច្រាំងហើយជន់លិចតំបន់នោះមុន
និងបន្ទាប់ពីអ៊ីស្រាអែលឆ្លងកាត់លើដីស្ងួត។
បួនថ្ងៃ
«៤ថ្ងៃ»
Joshua 4:19
បានឡើងពីទន្លេយ័រដាន់
នេះសំដៅទៅលើពេលដែលអ៊ីស្រាអែលឆ្លងទន្លេយ័រដាន់លើដីស្ងួត។
នៅថ្ងៃទីដប់ ខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេព្រើរ។ ថ្ងៃទី១០
ជិតដល់ចុងខែមីនាតាមប្រតិទិនលោកខាងលិច។
ថ្មទាំងដប់ពីរដុំដែលពួកគេបានយកចេញពីទន្លេយ័រដាន់
កុលសម្ព័ន្ធនីមួយៗត្រូវយកថ្មមួយពីទន្លេយ័រដាន់មកដូច្នេះលោកយ៉ូស្វេអាចកសាងស្ងួប
ដើម្បីរំលឹកពីព្រឹត្តិការណ៍ដែលឆ្លងកាត់។
Joshua 4:22
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តរំលឹកប្រជាជន អំពីគោលបំណងនៃគំនរថ្ម។
ចូរប្រាប់ដល់កូនចៅរបស់អ្នករាល់គ្នា
វាគឺសម្រាប់ជនជាតិអ៊ីស្រាអែលត្រូវបង្រៀនកូនចៅរបស់ពួកគេ
នូវការអស្ចារ្យដែលពួកគេ នឹងគោរពកោតខ្លាចព្រះអម្ចាស់ជារៀងរហូត។
ព្រះហស្តរបស់ព្រះអម្ចាស់មានពេញដោយចេស្តា
នេះសំដៅទៅលើអំណាច ឫទ្ធានុភាព របស់ព្រះអម្ចាស់ដែលខ្លាំង។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់គឺពេញដោយអំណាចស្តាខ្លាំងពូកែ»

---

5 [1]នៅពេលដែលស្តេចអាម៉ូរីដែលនៅខាងលិចទន្លេយ័រដាន់

និងស្តេចទាំងអស់របស់ជនជាតិកាណានដែលនៅតាមមាត់សមុទ្របានឮថាព្រះអម្ចាស់បានធ្វើឲ្យទឹកទន្លេយ័រដាន់បានរីងរហូតដល់ជនជាតិអ៊ីស្រាអែលបានឆ្លងផុតនោះ
ពួកគេបានស្លុតស្មារតី ហើយហាក់បីដូចជាគ្មានវិញ្ញាណនៅក្នុងខ្លួនរបស់ពួកគេទៀតទេ ដោយសារតែជនជាតិអ៊ីស្រាអែល។
[2]នៅពេលនោះព្រះអម្ចាស់បានមានបន្ទូលមកកាន់លោកយ៉ូស្វេថា៖ «ចូរយកថ្មមកធ្វើជាកាំបិត ហើយត្រូវធ្វើពិធីកាត់ស្បែកឲ្យប្រុសៗជនជាតិអ៊ីស្រាអែលទាំងអស់»។
[3]បន្ទាប់មក លោកយ៉ូស្វេក៏បានធ្វើកាំបិតពីថ្ម ហើយធ្វើពិធីកាត់ស្បែកឲ្យប្រុសៗជនជាតិអ៊ីស្រាអែលទាំងអស់នៅគីបេត ហារ៉ាឡុត។
[4]នេះជាមូលហេតុដែលព្រះអម្ចាស់បានធ្វើពិធីកាត់ស្បែកឲ្យពួកគេ៖ ប្រុសៗទាំងអស់ដែលចេញពីស្រុកអេស៊ីបមក ទាំងអ្នកចម្បាំង
បានស្លាប់នៅកណ្តាលផ្លូវក្រោយពីពួកគេបានចេញពីអេស៊ីបមក។[5]ដូច្នេះប្រុសៗទាំងអស់ដែលចេញពីអេស៊ីបបានធ្វើពិធីកាត់ស្បែករួចហើយ
នៅតែអ្នកដែលកើតក្នុងទីរហោស្ថានតាមផ្លូវពីអេស៊ីបមកត្រូវធ្វើពិធីកាត់ស្បែកនៅពេលនេះ។
[6]ចាប់ពីជនជាតិអ៊ីស្រាអែលដែលបានដើរអស់សែសិបឆ្នាំនៅក្នុងទីរហោស្ថានរហូតដល់ប្រុសៗដែលជាទាហានដែលចេញពីអេស៊ីបបានស្លាប់ទាំងអស់ដោយសារពួកគេមិនស្តាប់តាមព្រះបន្ទូលរប
ព្រះអម្ចាស់បានស្បថជាមួយពួកគេថា ព្រះអង្គនឹងមិនអនុញ្ញាតឲ្យពួកគេឃើញទឹកដីដែលបានស្បថនឹងពួកដូនតារបស់ពួកគេថា ព្រះអង្គនឹងប្រទានដល់យើង
ជាទឹកដីដែលពេញដោយទឹកដោះ និងទឹកឃ្មុំឡើយ។[7]គឺកូនចៅរបស់ពួកគេទៅវិញទេ ដែលព្រះអម្ចាស់បានចម្រើនពួកគេឡើង គឺលោកយ៉ូស្វេត្រូវធ្វើពិធីកាត់ស្បែកឲ្យពួកគេ
ព្រោះពួកគេមិនបានធ្វើពិធីកាត់ស្បែកនៅតាមផ្លូវនៅឡើយ។

generated on Wed Sep 10 16:16:32 2025

[8]នៅពេលដែលពួកគេទាំងអស់បានទទួលពិធីកាត់ស្បែករួចហើយ ពួកគេនៅក្នុងជំរំដែលពួកគេស្នាក់នៅរហូតដល់បានជា។[9]បន្ទាប់មក
ព្រះអម្ចាស់មានបន្ទូលមកលោកយ៉ូស្វេថា៖ «នៅថ្ងៃនេះយើងបានដកសេចក្តីអាម៉ាស់ដែលអ្នកមាននៅស្រុកអេស៊ីបចេញពីអ្នករាល់គ្នាហើយ»។ ដូច្នេះ
គេក៏ហៅកន្លែងនោះថាគីលកាលរហូតមកដល់សព្វថ្ងៃនេះ។
[10]ប្រជាជនអ៊ីស្រាអែលបានបោះជំរំនៅគីកាល។ ពួកគេបានធ្វើពិធីបុណ្យចម្លងនៅល្ងាចថ្ងៃទីដប់បួនក្នុងខែនោះនៅក្នុងតំបន់ក្រុងយេរីខូ។
[11]ពួកគេបានបរិភោគផលពីដីនៅក្រោយថ្ងៃបុណ្យចម្លង គឺនំប៉័ងឥតមេ និងគ្រាប់រុក្ខជាតិលីង។
[12]នំម៉ាណាក៏លែងមានទៀតដែរក្រោយពេលដែលពួកគេបានបរិភោគផលពីដី។ លែងមាននំម៉ាណាសម្រាប់ប្រជាជនអ៊ីស្រាអែលទៀតទេ
ប៉ុន្តែពួកគេបរិភោគផលពីដីក្នុងស្រុកកាណាននៅឆ្នាំនោះវិញ។
[13]នៅពេលដែលលោកយ៉ូស្វេទៅដល់ជិតក្រុងយេរីខូ គាត់ងើបមុខឡើង ហើយសម្លឹងមើល បានឃើញបុរសម្នាក់ឈរនៅពីមុខគាត់ លោកមានកាន់ដាវនៅនឹងដៃ។
លោកយ៉ូស្វេបានទៅជួបបុរសនោះហើយនិយាយថា៖ «តើអ្នកនៅខាងខ្ញុំ ឬនៅខាងសត្រូវរបស់ខ្ញុំ»?
[14]លោកនិយាយថា៖ «មិនមែនទេ ខ្ញុំជាមេទ័ពរបស់ព្រះអម្ចាស់។ ឥឡូវនេះខ្ញុំបានមកដល់ហើយ»។ បន្ទាប់មក លោកយ៉ូស្វេក៏ក្រាបមុខចុះដើម្បីថ្វាយបង្គំ
និងនិយាយទៅលោកថា៖ «តើលោកម្ចាស់មានអ្វីនិយាយមកកាន់អ្នកបម្រើលោក»?[15]មេទ័ពរបស់ព្រះជាម្ចាស់និយាយមកលោកយ៉ូស្វេថា៖
«ចូរដោះស្បែកជើងរបស់អ្នកចេញ ព្រោះកន្លែងដែលអ្នកជាន់នេះគឺជាកន្លែងបរិសុទ្ធ»។ នេះជាអ្វីដែលលោកយ៉ូស្វេបានធ្វើ។

Joshua 5:1
ពួកគេបានស្លុតស្មារតី ...ហើយហាក់បីដូចជាគ្មានវិញ្ញាណនៅក្នុងខ្លួនរបស់ពួកគេទៀតទេ
ឃ្លាទាំងពីរនេះមានន័យថាជារួមដូចគ្នា
និងផ្តោតទៅលើទំហំនៃការភ័យខ្លាចរបស់ពួកគេ។
ពួកគេបានស្លុតស្មារតី
ត្រង់នេះ « ចិត្ត» សំដៅទៅលើភាពក្លាហានរបស់ពួកគេ។
ពួកគេភ័យខ្លាចយ៉ាងខ្លាំងរាងគឺដូចជាភាពក្លាហានរបស់ពួកគេរលាយដូចក្រមួននៅក្នុងភ្លើង។
ការបកប្រែផ្សេងទៀត «ពួកគេបាត់បង់ភាពក្លាហានទាំងអស់»
ហើយហាក់បីដូចជាគ្មានវិញ្ញាណនៅក្នុងខ្លួនរបស់ពួកគេទៀតទេ
នៅទីនេះ « វិញ្ញាណ» សំដៅទៅលើឆន្ទៈរបស់ពួកគេដើម្បីប្រយុទ្ធ។
ការបកប្រែផ្សេងទៀត «ពួកគេលែងមានឆន្ទៈប្រយុទ្ធតទៅទៀតហើយ»
Joshua 5:2
លោកយ៉ូស្វេក៏បានធ្វើកាំបិតពីថ្ម ... ហើយធ្វើពិធីកាត់ស្បែកឲ្យប្រុសៗជនជាតិអ៊ីស្រាអែលទាំងអស់
មានបុរសជាង ៦០០,០០០នាក់
ដូច្នេះគេយល់ថានៅពេលដែលលោកយ៉ូស្វេទទួលបន្ទុកភារកិច្ចនេះមនុស្សជាច្រើនបានឆ្លងកាត់
ប្រសិនបើវាធ្វើឲ្យអ្នកអានរបស់អ្នកច្របូកច្របល់
អ្នកប្រហែលជាចង់និយាយឲ្យច្បាស់។ការបកប្រែផ្សេងទៀត
«លោកយ៉ូស្វេនិងជនជាតិអ៊ីស្រាអែលបានធ្វើកាំបិតដោយខ្លួនឯង ...
ពួកគេបានកាត់ស្បែកប្រុសៗទាំងអស់»
គីបេត ហារ៉ាឡុត
នេះជាឈ្មោះកន្លែងដែលរំលឹកដល់ជនជាតិអ៊ីស្រាអែលថ្វាយខ្លួនរបស់ពួកគេម្តងទៀតដល់ព្រះជាម្ចាស់។ ឈ្មោះ
វាមានន័យថា «គម្របស្បែកគ្របក្បាលលិង្គ»។
Joshua 5:4
ព័ត៌មានទូទៅ
មូលហេតុដែលប្រុសៗអ៊ីស្រាអែលទាំងអស់ ត្រូវកាត់ស្បែកគឺត្រូវបានពន្យល់។
អ្នកចម្បាំង
បុរសដែលមានអាយុគ្រប់គ្រាន់ដើម្បីធ្វើជាទាហាន
Joshua 5:6
ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់
ត្រង់នេះ «សម្លេង» សំដៅទៅលើអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «គោរពតាមអ្វីដែលព្រះអម្ចាស់បានបញ្ជាពួកគេ»
ជាទឹកដីដែលពេញដោយទឹកដោះ និងទឹកឃ្មុំឡើយ។
ព្រះជាម្ចាស់បានមានព្រះបន្ទូលអំពីដីដែលល្អសម្រាប់សត្វ
និងរុក្ខជាតិដូចជាទឹកដោះគោ
និងទឹកឃ្មុំពីសត្វទាំងនោះនិងបានហូរឆ្លងកាត់ទឹកដីនោះ។ ការបកប្រែផ្សេងទៀត
«ដីមួយដែលល្អសម្រាប់ចិញ្ចឹមសត្វនិងដាំដំណាំ»
Joshua 5:8
នៅថ្ងៃនេះយើងបានដកសេចក្តីអាម៉ាស់ដែលអ្នកមាននៅស្រុកអេស៊ីបចេញពីអ្នករាល់គ្នាហើយ
ភាពអាម៉ាស់របស់ពួកគេត្រូវបានគេនិយាយដូចជាដុំថ្មធំមួយដែលរារាំងផ្លូវរបស់ពួកគេ។
នៅទីនេះ «រមៀលចេញ» មានន័យថា «បានដកចេញ»។ ការបកប្រែផ្សេងទៀត
«ថ្ងៃនេះខ្ញុំបានបំបាត់ភាពអាម៉ាស់របស់អេស៊ីបចេញពីអ្នក» ឬ
«អ្នកត្រូវបានគេធ្វើឲ្យអាម៉ាស់នៅពេលអ្នកធ្វើជាទាសករនៅអេស៊ីប។
ប៉ុន្តែថ្ងៃនេះខ្ញុំបានធ្វើឲ្យអ្នកលែងត្រូវអាម៉ាស់»
Joshua 5:10
ថ្ងៃទីដប់បួនក្នុងខែ
នេះគឺនៅជិតចុងខែមីនានៅលើប្រតិទិនលោកខាងលិច។ ការបកប្រែផ្សេងទៀត
«ថ្ងៃទីដប់បួននៃខែទីមួយ»
Joshua 5:12
នំម៉ាណា
នំម៉ាណាជាអាហារធ្វើពីគ្រាប់ធញ្ញជាតិពណ៌ស
ដែលព្រះជាម្ចាស់ប្រទានដល់ប្រជាជនអ៊ីស្រាអែល បរិភោគកំឡុងពេល៤០ឆ្នាំ
ពួកគេរស់នៅក្នុងវាលរហោស្ថាន បន្ទាប់ពីពួកគេចាកចេញពីប្រទេសអេស៊ីប។
នំម៉ាណាមានរាងស្តើងពណ៌ស
ដែលធ្លាក់នៅលើដីរាល់ពេលព្រឹកក្រោមទឹកសន្សើម។ មានរសជាតិផ្អែមដូចទឹកឃ្មុំ។
ជនជាតិអ៊ីស្រាអែលរើសនំម៉ាណារាល់ថ្ងៃ លើកលែងតែថ្ងៃសប្ប័ទ។
នៅមុនថ្ងៃសប្ប័ទមួយថ្ងៃ
ព្រះជាម្ចាស់បានបង្គាប់ជនជាតិអ៊ីស្រាអែលរើសនំម៉ាណាពីរដង
ដូច្នេះពួកគេមិនចាំបាច់ទៅរើសនៅថ្ងៃសម្រាក។ ពាក្យ «នំម៉ាណា» មានន័យថា
«វាជាស្អី?» នៅក្នុងព្រះគម្ពីរ នំម៉ាណាសំដៅទៅលើ «នំប៉័ងមកពីស្ថានបរមសុខ»
ដែលព្រះជាម្ចាស់ផ្តល់ជូនដល់ប្រជាជនរបស់ទ្រង់ជារៀងរាល់ថ្ងៃ។ ធញ្ញជាតិមកពីស្ថានបរមសុខ»។
អ៊ីស្រាអែល ជនជាតិអ៊ីស្រាអែល ប្រជាជាតិអ៊ីស្រាអែល
ពាក្យ «អ៊ីស្រាអែល» ជាឈ្មោះដែលព្រះជាម្ចាស់ប្រទានដល់លោកយ៉ាកុប។
មានន័យថា «បោកចំបាប់ជាមួយព្រះជាម្ចាស់»។
បុព្វបុរសរបស់លោកយ៉ាកុបត្រូវគេស្គាល់ថា «ប្រជាជនអ៊ីស្រាអែល»
«ប្រជាជាតិអ៊ីស្រាអែល» ឬ »ជនជាតិអ៊ីស្រាអែល»។
ព្រះជាម្ចាស់បានចងសម្ពន្ធមេត្រីជាមួយប្រជាជនអ៊ីស្រាអែល។
ព្រះជាម្ចាស់បានជ្រើសរើសពួកគេ។
ប្រទេសអ៊ីស្រាអែលផ្សំឡើងដោយកុលសម្ព័ន្ធដប់ពីរ។
ក្រោយពេលស្តេចសាឡូម៉ូនសោយទិវង្គត់
ប្រទេសអ៊ីស្រាអែលត្រូវបែកជារាជាណាចក្រពីរ៖ រាជាណាចក្រខាងត្បូងឈ្មោះថា
«យូដា» ចំណែកឯរាជាណាចក្រខាងជើងឈ្មោះថា «អ៊ីស្រាអែល»។ ពាក្យ
«អ៊ីស្រាអែល» អាចបកប្រែបានថា «ប្រជាជនអ៊ីស្រាអែល» ឬ
«ប្រជាជាតិអ៊ីស្រាអែល» អាស្រ័យលើបរិបទ។
កាណាន ជនជាតិកាណាន
កាណានជាកូនប្រុសរបស់ហាំ ដែលជាកូនប្រុសម្នាក់របស់លោកណូអេ។
ជនជាតិកាណានជាកូនចៅរបស់លោកកាណាន។
ពាក្យ «កាណាន» ឬ «ទឹកដីកាណាន»
សំដៅទៅលើតំបន់មួយនៅចន្លោះទន្លេយ័រដាន់ និងសមុទ្រម៉េឌីទែរ៉ានេ។
វាលាតសន្ធឹងខាងត្បូងទល់នឹងប្រទេសអេស៊ីប និងខាងជើងទល់ព្រំដែនស៊ីរី។
ពួកជនជាតិកាណានបានទទួលទឹកដីនេះកេរមរតក ដូចជាក្រុមមនុស្សដទៃទៀត។
ព្រះជាម្ចាស់សន្យាថានឹងប្រទានទឹកដីកាណាន ឲ្យលោកអប្រាហាំ
និងកូនចៅរបស់លោក គឺជនជាតិអ៊ីស្រាអែល។
Joshua 5:13
លោកយ៉ូស្វេទៅដល់ជិតក្រុងយេរីខូ គាត់ងើបមុខឡើង ហើយសម្លឹងមើល
បានឃើញបុរសម្នាក់ឈរនៅពីមុខគាត់
នៅទីនេះការក្រឡេកមើលទៅខាងលើត្រូវបានគេនិយាយដូចជាលោកយ៉ូស្វេបានងើបមុខឡើងតាមន័យត្រ
ការបកប្រែផ្សេងទៀត «គាត់ក្រឡេកមើលទៅឃើញបុរសម្នាក់បានកំពុងឈរ»
មើល
ពាក្យ«មើល» ដាស់តឿនយើងឲ្យយកចិត្តទុកដាក់ជាពិសេសចំពោះព័ត៌មានថ្មីៗ។
ភាសារបស់អ្នកអាចមានរបៀបនៃការធ្វើបែបនេះ។

generated on Wed Sep 10 16:16:32 2025

លោកមានកាន់ដាវនៅនឹងដៃ
នៅទីនេះពាក្យថា «គាត់» និង « របស់គាត់»
សំដៅទៅលើបុរសដែលឈរនៅពីមុខលោកយ៉ូស្វេ។
Joshua 5:14
លោកនិយាយថា
ពាក្យថា « គាត់» សំដៅទៅលើបុរសដែលលោកយ៉ូស្វេបានឃើញ។
មិនមែនទេ
នេះជាការចាប់ផ្តើមនៃចម្លើយរបស់បុរសចំពោះសំណួររបស់លោកយ៉ូស្វេថា
«តើអ្នកសម្រាប់យើង ឬសត្រូវរបស់យើង»? ចម្លើយខ្លីនេះអាចតបញ្ជាក់ឲ្យច្បាស់។
ការបកប្រែផ្សេងទៀត « ខ្ញុំមិនមែនសម្រាប់អ្នក និងសត្រូវរបស់អ្នកទេ»
លោកយ៉ូស្វេក៏ក្រាបមុខចុះដើម្បីថ្វាយបង្គំ
នេះជាសកម្មភាពថ្វាយបង្គំ។
ចូរដោះស្បែកជើងរបស់អ្នកចេញ
នេះគឺជាទង្វើនៃការគោរព។

---

6 [1]ឥឡូវនេះគ្រប់ច្រកទាំងអស់ទៅកាន់ក្រុងយេរីខូបានបិទដោយសារតែពួកទាហានអ៊ីស្រាអែល។ គ្មាននរណាម្នាក់ចេញក្រៅ ហើយក៏គ្មាននរណាម្នាក់ចូលទៅក្នុងដែរ។
[2]ព្រះអម្ចាស់មានបន្ទូលមកកាន់លោកយ៉ូស្វេថា៖ «ឃើញទេ យើងប្រគល់ក្រុងយេរីខូមកក្នុងកណ្តាប់ដៃអ្នកហើយ ទាំងស្តេចរបស់ក្រុងនេះ
និងទាហានអង់អាចទាំងអស់ផង»។
[3]អ្នកត្រូវដើរជុំវិញទីក្រុង ប្រុសៗដែលធ្វើសឹកទាំងអស់ត្រូវដើរជុំវិញទីក្រុងមួយជុំ។ អ្នកត្រូវធ្វើបែបនេះក្នុងរវាងប្រាំមួយថ្ងៃ។
[4]ពួកបូជាចារ្យប្រាំពីរនាក់ត្រូវប្រដាប់ដោយត្រែប្រាំពីរដែលធ្វើពីស្នែងនៅខាងមុខហិប។ នៅថ្ងៃទីប្រាំពីរអ្នកត្រូវតែដើរជុំវិញទីក្រុងប្រាំពីរជុំ
ហើយពួកបូជាចារ្យត្រូវបន្លឺសម្លេងត្រែឡើង។
[5]បន្ទាប់មក ពួកគេត្រូវតែផ្លុំត្រែពីស្នែងនោះឲ្យវែង ហើយនៅពេលដែលអ្នកបានឮសម្លេងត្រែ ប្រជាជនទាំងអស់ត្រូវតែស្រែកឲ្យខ្លាំងៗ នោះជញ្ជាំងក្រុងនឹងរលំ។
ពួកទាហានត្រូវតែសម្រុកចូល ចូរឲ្យគ្រប់គ្នាដើរទៅមុខត្រង់»។
[6]លោកយ៉ូស្វេកូនរបស់លោកនូនបានហៅពួកបូជាចារ្យមក ហើយនិយាយទៅពួកគេថា៖ «ចូរសែងហិបនៃសម្ពន្ធមេត្រី
ហើយចូរឲ្យពួកបូជាចារ្យប្រាំពីររូបប្រដាប់ដោយត្រែប្រាំពីរធ្វើពីស្នែង ដើរខាងមុខហិបរបស់ព្រះអម្ចាស់។[7]លោកមានប្រសាសន៍ទៅកាន់ប្រជាជនថា៖ «ចូរចេញទៅ
ហើយដើរជុំវិញទីក្រុង ហើយពួកទាហាននឹងដើរនៅខាងមុខហិបរបស់ព្រះអម្ចាស់»។
[8]ដូចអ្វីដែលលោកយ៉ូស្វេបានប្រាប់ដល់ប្រជាជន ពួកបូជាចារ្យប្រាំពីរនាក់បានប្រដាប់ដោយត្រែប្រាំពីរធ្វើពីស្នែងដើរខាងមុខព្រះអម្ចាស់។ នៅពេលដែលគេដើរ
គេក៏បន្លឺសម្លេងត្រែឡើង។ ហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ក៏មកតាមក្រោយពួកគេ។[9]ពួកទាហានដើរនៅខាងមុខពួកបូជាចារ្យ ហើយពួកគេបានបន្លឺសម្លេងត្រែឡើង
ប៉ុន្តែ បន្ទាប់មកក៏មានអ្នកដើរពីក្រោយហិបដែរ ពួកបូជាចារ្យនៅតែបន្តបន្លឺសម្លេងត្រែឡើងដដែល។
[10]ប៉ុន្តែ លោកយ៉ូស្វេបានបង្គាប់ដល់ប្រជាជនថា៖ «កុំឲ្យស្រែកឲ្យសោះ កុំឲ្យអ្នកណាម្នាក់និយាយពាក្យអ្វីមួយឡើយ រហូតដល់ថ្ងៃដែលខ្ញុំឲ្យអ្នកស្រែក
នៅពេលនោះអ្នកត្រូវតែស្រែកឡើង»។[11]ដូច្នេះលោកក៏ឲ្យគេសែងហិបនៃព្រះអម្ចាស់ក្រឡឹងជុំវិញទីក្រុងនោះ មួយថ្ងៃ មួយជុំ។ បន្ទាប់មក
ពួកគេក៏ចូលទៅក្នុងជំរំរបស់ពួកគេវិញ ហើយពួកគេស្នាក់នៅក្នុងជំរំនៅយប់នោះ។
[12]បន្ទាប់មក លោកយ៉ូស្វេក៏ក្រោកឡើងពីព្រលឹម ហើយពួកបូជាចារ្យក៏សែងហិបរបស់ព្រះអម្ចាស់។
[13]ពួកបូជាចារ្យទាំងប្រាំពីរបានប្រដាប់ដោយត្រែធ្វើពីស្នែងចៀមប្រាំពីរដើរនៅខាងមុខហិបរបស់ព្រះអម្ចាស់ ដើរយ៉ាងមានរបៀប ហើយពួកគេក៏ផ្លុំត្រែឡើង។
ពួកទាហានបានដើរនៅខាងមុខពួកគេ។ ប៉ុន្តែ នៅពេលដែលពួកអ្នកដើរខាងក្រោយហិបមកដល់នោះសម្លេងត្រែក៏នៅតែបន្លឺឡើងដែរ។
[14]ពួកគេបានដើរជុំវិញក្រុងមួយជុំនៅក្នុងថ្ងៃទីពីរ ហើយបានត្រឡប់មកជំរំវិញ។ ពួកគេធ្វើរបៀបនេះអស់ប្រាំមួយថ្ងៃ។
[15]នៅថ្ងៃទីប្រាំពីរពួកគេបានក្រោកតាំងពីព្រលឹម ហើយពួកគេបានដើរជុំវិញទីក្រុងដូចដែលពួកគេបានធ្វើ នៅពេលនោះពួកគេដើរប្រាំពីរជុំ។
មានតែថ្ងៃនេះទេដែលពួកគេត្រូវដើរប្រាំពីរជុំ។[16]គឺនៅថ្ងៃទីប្រាំពីរ នៅពេលដែលពួកបូជាចារ្យបានបន្លឺសម្លេងត្រែឡើង នោះលោកយ៉ូស្វេក៏បានបង្គាប់ដល់បណ្តាជនថា៖
«ចូរស្រែកឡើង! ព្រោះព្រះអម្ចាស់បានប្រគល់ក្រុងនេះដល់អ្នកហើយ»។
[17]ទាំងក្រុង និងអ្វីៗដែលមាននៅក្នុងក្រុងត្រូវតែបំផ្លាញទាំងអស់ថ្វាយដល់ព្រះអម្ចាស់។ មានតែនាងរ៉ាហាបជាស្ត្រីពេស្យាទេដែលត្រូវនៅរស់
គឺនាងនិងគ្រប់គ្នានៅក្នុងផ្ទះរបស់នាង ដោយសារនាងបានលាក់មនុស្សដែលយើងបានបញ្ជូនមក។
[18]ប៉ុន្តែអ្នកទាំងអស់គ្នាត្រូវតែប្រយ័ត្នជាមួយនឹងរបស់ដែលត្រូវបំផ្លាញចោល ដូច្នេះ នៅពេលដែលអ្នកត្រូវបំផ្លាញរបស់ទាំងអស់នេះ កុំឲ្យយករបស់ណាមួយឡើយ។ បើយក
នោះអ្នកនឹងធ្វើឲ្យជំរំរបស់ជនជាតិអ៊ីស្រាអែលត្រូវវិនាស និងនាំឲ្យមានបញ្ហា។[19]គ្រប់ទាំងរបស់ដែលធ្វើពីប្រាក់ ពីមាស និងរបស់ធ្វើពីលង្ហិន
និងដែកត្រូវញែកថ្វាយព្រះអម្ចាស់។ របស់ទាំងនោះត្រូវទុកនៅក្នុងឃ្លាំងរបស់ព្រះអម្ចាស់។
[20]នៅពេលដែលពួកគេបន្លឺសម្លេងត្រែឡើង ប្រជាជនក៏បានស្រែកឡើងដែរ ហើយជញ្ជាំងក្រុងក៏រលំ ដូច្នេះ អ្នកដែលនៅទីនោះក៏សម្រុកចូលទៅកាន់កាប់ទីក្រុង។
[21]ពួកគេបំផ្លាញអ្វីៗគ្រប់យ៉ាងដែលនៅក្នុងទីក្រុងដោយមុខដាវ ទាំងមនុស្សប្រុស មនុស្សស្រី កូនក្មេង និងមនុស្សចាស់ គោ ចៀម និងលាផង។
[22]បន្ទាប់មក លោកយ៉ូស្វេបានមានប្រសាសន៍ទៅកាន់បុរសពីរនាក់ដែលបានទៅស៊ើបការណ៍នៅក្នុងទឹកដីនេះថា៖ «ចូរចូលទៅក្នុងផ្ទះរបស់ស្ត្រីពេស្យា។ ចូរនាំស្ត្រីនោះមក
និងអ្នកដែលនៅជាមួយនាងដែរ ដូចអ្វីដែលអ្នកបានស្បថនឹងនាង»។
[23]ដូច្នេះ បុរសវ័យក្មេងដែលបានស៊ើបការណ៍នេះបានចូលទៅក្នុងហើយនាំនាងរ៉ាហាបចេញមក។ ពួកគេបាននាំឪពុករបស់នាង ទាំងម្តាយ បងប្អូនប្រុស
និងសាច់ញាតិរបស់នាងមកជាមួយនាងដែរ។ ពួកគេបាននាំពួកនាងទៅកន្លែងមួយក្រៅជំរំជនជាតិអ៊ីស្រាអែល។[24]ពួកគេបានដុតក្រុង និងអ្វីៗដែលមាននៅក្នុងក្រុងនោះ។
មានតែប្រាក់ មាស និងរបស់ធ្វើពីលង្ហិន និងដែកទេដែលត្រូវបញ្ចូលទៅក្នុងឃ្លាំងរបស់ព្រះអម្ចាស់។
[25]ប៉ុន្តែ លោកយ៉ូស្វេបានទុកឲ្យនាងរ៉ាហាបជាស្ត្រីពេស្យា គ្រួឪពុកនាង និងអ្នកដែលនៅជាមួយនាងមានជីវិត។ នាងរស់នៅក្នុងទឹកដីអ៊ីស្រាអែលរហូតមកដល់ពេលនេះ
ដោយសារតែនាងលាក់បុរសដែលលោកយ៉ូស្វេបានបញ្ជូនឲ្យទៅស៊ើបការណ៍នៅក្រុងយេរីខូ។
[26]បន្ទាប់មក លោកយ៉ូស្វេបានបង្គាប់ពួកគេនៅពេលនោះដោយស្បថថា៖ «មានបណ្តាសារហើយអស់អ្នកដែលសង់ក្រុងយេរីខូនេះឡើងវិញ។ អ្នកដែលចាក់គ្រឹះឡើង
កូនប្រុសច្បងអ្នកនោះនឹងត្រូវបង់ថ្លៃ ហើយអ្នកណាដែលដំឡើងទ្វារវានឹងត្រូវបង់ថ្លៃជីវិតកូនពៅរបស់ខ្លួន។[27]ដូច្នេះ ព្រះអម្ចាស់បានគង់នៅជាមួយលោកយ៉ូស្វេ
ហើយកេរ្តិ៍ឈ្មោះរបស់លោកល្បីក្នុងទឹកដីនោះទាំងមូល។

Joshua 6:1
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់។
នៅទីនេះអ្នកពណ៌នាប្រាប់យើងពីមូលហេតុដែលទ្វារក្រុងយេរីខូត្រូវបានបិទ
និងចាក់សោ។
យើងប្រគល់ក្រុងយេរីខូមកក្នុងកណ្តាប់ដៃអ្នកហើយ ទាំងស្តេចរបស់ក្រុងនេះ
និងទាហានអង់អាចទាំងអស់ផង
ព្រះអម្ចាស់កំពុងប្រាប់លោកយ៉ូស្វេថាព្រះអង្គ នឹងធ្វើប្រាកដណាស់
តាមរយៈព្រះបន្ទូលដែលថាព្រះអង្គបានធ្វើរួចហើយ។
ក្នុងកណ្តាប់ដៃអ្នក
នេះមានន័យថា «ចូលទៅក្នុងការគ្រប់គ្រងរបស់អ្នក»
Joshua 6:3
ឃ្លាភ្ជាប់
ព្រះនៅតែបន្តមានបន្ទូលប្រាប់លោកយ៉ូស្វេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
អ្នកត្រូវធ្វើបែបនេះក្នុងរវាងប្រាំមួយថ្ងៃ
«អ្នកត្រូវធ្វើដូចនេះមួយដងសម្រាប់រយៈពេលប្រាំមួយថ្ងៃ»

generated on Wed Sep 10 16:16:32 2025

ពួកបូជាចារ្យប្រាំពីរនាក់ត្រូវប្រដាប់ដោយត្រែប្រាំពីរដែលធ្វើពីស្នែងនៅខាងមុខហិប
បូជាចារ្យទាំងប្រាំពីរនាក់ត្រូវដើរក្បួននៅចំពោះមុខបូជាចារ្យឯទៀតៗ
ដែលសែងហិបហើយដើរក្បួនជុំវិញទីក្រុង។
Joshua 6:5
ឃ្លាភ្ជាប់
ព្រះជាម្ចាស់នៅតែបន្តមានបន្ទូលប្រាប់លោកយ៉ូស្វេ នូវអ្វីដែលប្រជាជនត្រូវធ្វើ។
ពួកគេត្រូវតែផ្លុំត្រែដែលធ្វើពីស្នែងនោះឲ្យវែង ហើយនៅពេលដែលអ្នកបានឮ... សម្លេងត្រែ
ពាក្យថា « ពួកគេ» សំដៅទៅលើបូជាចារ្យទាំងប្រាំពីររូប។ «ស្នែងចៀម» និង
«ត្រែ» សំដៅទៅលើស្នែងរបស់ចៀមឈ្មោលដែលពួកបូជាចារ្យផ្លុំនៅក្នុង ៦: ៣ ។
ជញ្ជាំងក្រុង
«កំពែងខាងក្រៅនៃទីក្រុង» ឬ «ជញ្ជាំងព័ទ្ធជុំវិញទីក្រុង»
Joshua 6:6
លោកនូន
គឺជាឪពុករបស់លោកយ៉ូស្វេ។
ចូរសែងហិបនៃសម្ពន្ធមេត្រី
«ចូរយកហិបនៃសម្ពន្ធមេត្រី »
Joshua 6:8
ខាងមុខព្រះអម្ចាស់
អាចមានន័យថា ១) «ការស្តាប់បង្គាប់ព្រះអម្ចាស់» ឬទី ២)
«នៅពីមុខហិបរបស់ព្រះអម្ចាស់»
ពួកគេបានបន្លឺសម្លេងត្រែឡើង
«ពួកគេបានផ្លុំត្រែឮៗ » ឬ «ពួកបូជាចារ្យបានផ្លុំត្រែឡើង»
ហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ក៏មកតាមក្រោយពួកគេ
វាអាចត្រូវបានថ្លែងយ៉ាងច្បាស់ថាមានមនុស្សសែងហិប។ ការបកប្រែផ្សេងទៀត «
ពួកបូជាចារ្យដែលសែងហិបសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
បានដើរតាមក្រោយពួកគេ»
Joshua 6:10
កុំឲ្យអ្នកណាម្នាក់និយាយពាក្យអ្វីមួយឡើយ
សំឡេងចេញពីមាត់របស់នរណាម្នាក់សំដៅទៅលើការនិយាយ
ឬស្រែករបស់មនុស្សនោះ។ ការបកប្រែផ្សេងទៀត «កុំស្រែកឬនិយាយ»
ប៉ុន្តែ លោកយ៉ូស្វេបានបង្គាប់ដល់ប្រជាជនថា
លោកយ៉ូស្វេបានង្គាប់ប្រជាជនមុនពេលពួកគេចាប់ផ្តើមដើរជុំវិញទីក្រុង។
ការបកប្រែផ្សេងទៀត «លោកយ៉ូស្វេបានបញ្ជាប្រជាជន»
Joshua 6:12
ពួកបូជាចារ្យទាំងប្រាំពីរ ... ត្រែធ្វើទាំងប្រាំពីរ
«ពួកបូជាចារ្យទាំង៧នាក់ ... ត្រែទាំង៧»
ពួកគេក៏ផ្លុំត្រែឡើង
នេះមានន័យថាពួកគេបានផ្លុំត្រែរបស់ពួកគេបណ្តាលឲ្យពួកគេស្រែកខ្លាំងៗជាច្រើនដង។
ការបកប្រែផ្សេងទៀត «បន្តផ្លុំត្រែៗឮជានិច្ច» ឬ «ផ្លុំត្រែរបស់ស្នែងចៀមជានិច្ច»
ថ្ងៃទីពី
ថ្ងៃបន្ទាប់
ពួកគេធ្វើរបៀបនេះ
ជនជាតិអ៊ីស្រាអែលបានដើរជុំវិញក្រុងយេរីខូ មួយជុំ ជារៀងរាល់ថ្ងៃ។.
ប្រាំមួយថ្ងៃ
«៦ថ្ងៃ»
Joshua 6:15
ពួកគេ
នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
បានបន្លឺសម្លេងត្រែឡើង
«សំឡេងត្រែឡើងខ្លាំង» ឬ «ផ្លុំត្រែស្នែងចៀមឡើង»
ព្រោះព្រះអម្ចាស់បានប្រគល់ក្រុងនេះដល់អ្នកហើយ
លោកយ៉ូស្វេកំពុងមានប្រសាសន៍ថា ៖
ព្រះអម្ចាស់ពិតជានឹងប្រគល់ទីក្រុងដល់ពួកគេ
ដោយប្រាប់ថាព្រះអង្គបានប្រគល់ក្រុងនោះដល់ពួកគេហើយ។
បានប្រគល់ក្រុងនេះដល់អ្នកហើយ
ពាក្យថា «អ្នក» គឺសំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។
Joshua 6:17
ឃ្លាភ្ជាប់
លោកយ៉ូស្វេបន្តមានប្រសាសន៏ទៅកាន់ប្រជាជនអ៊ីស្រាអែល។
ទាំងក្រុង និងអ្វីៗដែលមាននៅក្នុងក្រុងត្រូវតែបំផ្លាញទាំងអស់ថ្វាយដល់ព្រះអម្ចាស់
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
អ្នកត្រូវញែកទីក្រុងជាកម្មសិទ្ធិរបស់ព្រះអម្ចាស់
និងអ្វីៗដែលនៅសេសសល់អោយវិនាសសូន្យ» ឬ « អ្នកត្រូវញែកក្រុង
និងអ្វីៗទាំងអស់ដែលនៅសេសសល់ថ្វាយព្រះអម្ចាស់ ដោយបំផ្លាញក្រុងនោះ»
ប្រយ័ត្នជាមួយនឹងរបស់ដែលត្រូវបំផ្លាញចោល
ការប្រុងប្រយ័ត្នត្រូវបានគេនិយាយដូចជាពួកគេការពារខ្លួនឯង។
«ប្រយ័ត្នកុំយកអ្វីទាំងអស់»
នឹងនាំឲ្យមានបញ្ហា។
ការធ្វើអ្វីមួយដែលធ្វើឲ្យមានរឿងអាក្រក់កើតឡើងចំពោះទីក្រុងត្រូវបានគេនិយាយថា
កំពុងបង្កបញ្ហា។ ការបកប្រែផ្សេងទៀត «
អ្នកនឹងធ្វើឲ្យមានរឿងអាក្រក់កើតឡើងចំពោះវា»
ត្រូវទុកនៅក្នុងឃ្លាំងរបស់ព្រះអម្ចាស់
ការប្រមូលរបស់របរទុកជាទីសក្ការៈថ្វាយព្រះអម្ចាស់
Joshua 6:20
ប្រជាជនក៏បានស្រែកឡើងដែរ
«ប្រជាជនអ៊ីស្រាអែលបានស្រែក»
បន្លឺសម្លេងត្រែឡើង
«បន្លឺសំឡេងត្រែឡើងខ្លាំងៗ» ឬ «ផ្លុំត្រែស្នែងចៀមឡើង»
មុខដាវ
ទោះបីប្រជាជនអ៊ីស្រាអែលភាគច្រើនប្រើដាវក៏ដោយនេះអាចសំដៅទៅលើការវាយប្រហារយ៉ាងសាហាវ
ឬការប្រយុទ្ធគ្នាជាទូទៅ។ ការបកប្រែផ្សេងទៀត «ជាមួយដាវមុតរបស់ពួកគេ» ឬ
«នៅក្នុងការប្រយុទ្ធ»
Joshua 6:23
ពួកគេបានដុតក្រុង
ពាក្យថា« ពួកគេ» សំដៅទៅលើទាហានអ៊ីស្រាអែល។
វាមិនសំដៅទៅលើតែយុវជនពីរនាក់ដែលបាននាំរ៉ាហាបនិងក្រុមគ្រួសាររបស់នាងចេញពីទីក្រុងនោះទេ។
Joshua 6:25
នាងរស់នៅក្នុងទឹកដីអ៊ីស្រាអែល
ពាក្យថា«នាង»សំដៅទៅលើនាងរ៉ាហាប និងតំណាងកូនចៅរបស់នាង។
ការបកប្រែផ្សេងទៀត «កូនចៅរបស់នាងរស់នៅក្នុងអ៊ីស្រាអែល»
រហូតមកដល់ពេលនេះ
«ឥឡូវនេះ» ឬ «សូម្បីតែថ្ងៃនេះ»។
កូនចៅរបស់នាងរ៉ាហាបកំពុងតែរស់នៅក្នុងប្រទេសអ៊ីស្រាអែល
ខណៈដែលអ្នកនិពន្ធដើមសរសេររឿងនេះ។
Joshua 6:26
មានបណ្តាសារហើយអស់អ្នកដែលសង់ក្រុងយេរីខូនេះឡើងវិញ
ការដាក់បណ្តាសានៅចំពោះព្រះភ័ក្ត្ររបស់ព្រះអម្ចាស់
តំណាងឲ្យការដាក់បណ្តាសារតាមរយៈព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត «
សូមព្រះអម្ចាស់ដាក់បណ្តាសាដល់មនុស្សដែលសង់ឡើងវិញ»
អ្នកដែលចាក់គ្រឹះឡើង កូនប្រុសច្បងអ្នកនោះនឹងត្រូវបង់ថ្លៃ
លទ្ធិផលនៃមនុស្សម្នាក់ដែលចាក់គ្រឹះថ្មី សម្រាប់ក្រុងយេរីខូ
គឺកូនប្រុសច្បងរបស់គាត់នឹងត្រូវស្លាប់។
នេះត្រូវបានគេនិយាយថាវាជាការបង់ថ្លៃដែលមនុស្សនឹងចំណាយ។
ការបកប្រែផ្សេងទៀត «បើគាត់ចាក់គ្រឹះគាត់នឹងបាត់បង់កូនប្រុសច្បង» ឬ
«បើគាត់ចាក់គ្រឹះកូនប្រុសច្បងរបស់គាត់នឹងស្លាប់»
កូនប្រុសច្បងអ្នកនោះនឹងត្រូវបង់ថ្លៃ
ហើយអ្នកណាដែលដំឡើងទ្វារវានឹងត្រូវបង់ថ្លៃជីវិតកូនពៅរបស់ខ្លួន
លទ្ធិផលនៃមនុស្សម្នាក់ដែលបង្កើតទ្វារថ្មី សម្រាប់ក្រុងយេរីខូ
គឺថាកូនប្រុសពៅរបស់គេនឹងត្រូវស្លាប់។ នេះត្រូវបានគេនិយាយថាវាជាការបង់ថ្លៃ
ដែលមនុស្សនោះនិងសង។ ការបកប្រែផ្សេងទៀត
«ប្រសិនបើគាត់រៀបចំច្រកទ្វាររបស់គាត់ គាត់និងបាត់បង់កូនប្រុសពៅរបស់គាត់»
ឬ «ប្រសិនបើគាត់បង្កើតទ្វារនោះកូនប្រុសពៅរបស់គាត់និងស្លាប់»
កេរ្តិ៍ឈ្មោះរបស់លោកល្បីក្នុងទឹកដីនោះទាំងមូល
សំដៅទៅលើកិត្តិនាមរបស់យ៉ូស្វេមិនមែនជាកិត្តិនាមរបស់ព្រះអម្ចាស់ទេ។
ការស្គាល់ក្នុងចំណោមប្រជាជននៅទូទាំងប្រទេស ត្រូវបានគេនិយាយ
កិត្តិនាមរបស់គាត់រីករាលដាល។ ការបកប្រែផ្សេងទៀត
«លោកយ៉ូស្វេមានកេរ្តិ៍ឈ្មោះល្បីល្បាញពាសពេញស្រុក» ឬ
«ប្រជាជននៅទូទាំងស្រុកបានរៀនអំពីលោកយ៉ូស្វេ»

generated on Wed Sep 10 16:16:32 2025

7 [1]ប៉ុន្តែ ប្រជាជនអ៊ីស្រាអែលប្រព្រឹត្តមិនស្មោះត្រង់ចំពោះរបស់ដែលត្រូវបំផ្លាញចោល។ លោកអេកាន ជាកូនរបស់លោកកើមើជាចៅរបស់លោកសាបឌី
និងជាចៅទួតរបស់លោកសេរ៉ាពីកុលសម្ព័ន្ធយូដាបានយករបស់មួយចំនួនដែលត្រូវបំផ្លាញចោល
ក្រោយមកព្រះពិរោធរបស់ព្រះអម្ចាស់បានកើតដល់ប្រជារាស្ត្រអ៊ីស្រាអែល។
[2]លោកយ៉ូស្វេបានបញ្ជូនមនុស្សប្រុសពីយេរីខូទៅស្រុកអៃ ដែលនៅជិតបេតអាវែន ខាងកើតបេតអែល។ លោកបានមានប្រសាសន៍ទៅពួកគេថា៖ «ចូរឡើងទៅ
ហើយស៊ើបមើលទឹកដីនោះចុះ»។ ដូច្នេះ ពួកប្រុសៗបានចេញទៅស៊ើបមើលក្រុងអៃ។[3]នៅពេលពួកគេបានត្រឡប់មកជួបលោកយ៉ូស្វេវិញ
ពួកគេបាននិយាយទៅកាន់លោកថា៖ «មិនបាច់បញ្ជូនមនុស្សទាំងអស់ទៅក្រុងអៃធ្វើអ្វី។ សូមបញ្ជូនតែមនុស្សប្រុស ពីរ ឬបីពាន់នាក់ដើម្បីវាយក្រុងអៃបានហើយ។
កុំចំណាយកម្លាំងមនុស្សទាំងអស់នៅក្នុងសមរភូមិធ្វើអ្វី ដោយសារពួកគេមានគ្នាតិចទេ»។
[4]ដូច្នេះ មានមនុស្សប្រុសប្រហែលបីពាន់នាក់ចេញទៅ ប៉ុន្តែ ពួកគេបានរត់នៅចំពោះអ្នកក្រុងអៃ។[5]ពួកក្រុងអៃបានសម្លាប់ជនជាតិអ៊ីស្រាអែលអស់សាមសិបប្រាំមួយនាក់
ហើយពួកគេដេញតាមតាំងពីច្រកទ្វារហូតដល់តំបន់ថ្ម ហើយពួកគេបានសម្លាប់ពួកប្រុសៗនៅត្រង់ជម្រាលភ្នំ។ ប្រជាជនមានចិត្តភ័យភ្លាច ហើយបាក់ទឹកចិត្តយ៉ាងខ្លាំង។
[6]ពេលនោះ លោកយ៉ូស្វេបានហែកសំលៀកបំពាក់របស់លោក។ ទាំងលោក និងចាស់ទុំនៃសាសន៍អ៊ីស្រាអែលបានបាចដីលើក្បាលរបស់ពួកគេ
ហើយក្រាបមុខដល់ដីនៅខាងមុខហិបរបស់ព្រះអម្ចាស់ ពួកគេនៅទីនោះរហូតដល់ពេលល្ងាច។[7]បន្ទាប់មក លោកយ៉ូស្វេបាននិយាយថា៖ «ឱព្រះអម្ចាស់ជាព្រះ
តើហេតុអ្វីបានជាព្រះអង្គនាំប្រជាជនទាំងអស់នេះឆ្លងកាត់ទន្លេយ័រដាន់មក? ដើម្បីចូលមកកាន់ទឹកដីរបស់សាសន៍អាម៉ូរីឲ្យពួកគេបំផ្លាញយើងទៅវិញ?
បើយើងធ្វើការសម្រេចចិត្តស្នាក់ទៅត្រើយម្ខាងនៃទន្លេយ័រដាន់ប្រសើរជាង!
[8]ព្រះអម្ចាស់ តើទូលបង្គំអាចនិយាយអ្វីបាន ក្រោយពេលដែលជនជាតិអ៊ីស្រាអែលរត់នៅចំពោះខ្មាំងសត្រូវរបស់ពួកគេដូច្នេះ?[9]ពួកស្រុកកាណាន
និងជនជាតិទាំងឡាយនឹងឮពីរឿងនេះ។ ពួកគេនឹងឡោមព័ទ្ធយើង ហើយនឹងធ្វើឲ្យមនុស្សនៅលើផែនដីភ្លេចឈ្មោះយើងមិនខាន។
តើព្រះអង្គនឹងធ្វើយ៉ាងណាសម្រាប់ព្រះនាមដ៏ប្រសើររបស់ព្រះអង្គ»?
[10]ព្រះអម្ចាស់បានមានបន្ទូលមកកាន់លោកយ៉ូស្វេថា៖ «ចូរក្រោកឡើង! ហេតុអ្វីបានជាអ្នកក្រាបមុខដល់ដីបែបនេះ?[11]ជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាប។
ពួកគេបានរំលោភលើសម្ពន្ធមេត្រី ដែលយើងបានបង្គាប់ដល់ពួកគេ។ ពួកគេបានលួចរបស់មួយចំនួនដែលត្រូវបំផ្លាញចោល។ ពួកគេបានលួច
ហើយក៏លាក់អំពើបាបរបស់ពួកគេ ដោយដាក់របស់ដែលពួកគេបានយកក្នុងចំណោមរបស់របររបស់ពួកគេថែមទៀតផង។[12]ជាលទ្ធផល
ធ្វើឲ្យជនជាតិអ៊ីស្រាអែលមិនអាចឈរនៅមុខខ្មាំងសត្រូវរបស់ខ្លួនបាន។ ពួកគេត្រូវរត់ពីខ្មាំង ព្រោះពួកគេផ្ទាល់ដែលត្រូវបំផ្លាញចោល។
យើងនឹងមិនគង់ជាមួយអ្នកទៀតឡើយ បើអ្នកមិនបំផ្លាញរបស់ដែលគួរបំផ្លាញដែលស្ថិតនៅក្នុងចំណោមអ្នករាល់គ្នាទេនោះ។
[13]ចូរក្រោកឡើង! ចូរជម្រះប្រជាជននេះឲ្យបានបរិសុទ្ធសម្រាប់យើង ហើយប្រាប់ពួកគេថា៖ «ចូរជម្រះខ្លួនឲ្យបានបរិសុទ្ធសម្រាប់ថ្ងៃស្អែក។
ព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលមានបន្ទូលថា៖ «អ៊ីស្រាអែលអើយ មានរបស់ដែលត្រូវបំផ្លាញចោល នៅក្នុងចំណោមអ្នករាល់គ្នា។
អ្នកមិនអាចឈរនៅចំពោះខ្មាំងសត្រូវរបស់អ្នករាល់គ្នាបានឡើយរហូតដល់អ្នកយករបស់ដែលត្រូវបំផ្លាញចោលចេញពីអ្នករាល់គ្នា»។
[14]នៅពេលព្រឹក អ្នកត្រូវបង្ហាញខ្លួនតាមកុលសម្ព័ន្ធរៀងៗខ្លួន។ កុលសម្ព័ន្ធដែលព្រះអម្ចាស់ជ្រើសរើសត្រូវចូលមកជិតតាមអំបូរបស់ខ្លួន។
អំបូរដែលព្រះអម្ចាស់បានជ្រើសរើសត្រូវចូលមកជិតតាមគ្រួសាររៀងខ្លួន។ គ្រួសារដែលព្រះអម្ចាស់បានជ្រើសរើសត្រូវចូលមកជិតម្តងម្នាក់ៗ។[15]វានឹងត្រូវកើតឡើងដូច្នេះថា
អ្នកដែលត្រូវបានជ្រើសរើស ហើយមានរបស់ទាំងអស់ដែលត្រូវបំផ្លាញចោល ត្រូវដុតអ្នកនោះ គឺទាំងគាត់ និងអ្វីៗដែលគាត់មាន
ព្រោះគាត់បានរំលោភសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ និងដោយសារគាត់បានប្រព្រឹត្តរឿងថោកទាបនៅក្នុងស្រុកអ៊ីស្រាអែល»។
[16]ដូច្នេះ លោកយ៉ូស្វេបានក្រោកពីព្រលឹម ហើយនាំប្រជាជនអ៊ីស្រាអែលមកជិត តាមកុលសម្ព័ន្ធ ហើយកុលសម្ព័ន្ធយូដាត្រូវបានជ្រើសរើស។
[17]លោកយ៉ូស្វេក៏បាននាំអំបូរយូដាមកជិត ហើយអំបូររបស់សេរ៉ាសត្រូវបានជ្រើសរើស។ លោកបាននាំអំបូរសេរ៉ាសមកជិតម្នាក់ម្តងៗ ហើយចំលើគ្រួសារលោកសាបឌី។
[18]លោកបាននាំគ្រួសាររបស់សាបឌីមកជិតម្នាក់ម្តងៗ ហើយអេកានជាកូនរបស់កើមី ជាចៅរបស់សាបឌី ជាចៅទួតរបស់សេរ៉ា ពីកុលសម្ព័ន្ធយូដាត្រូវបានជ្រើសរើស។
[19]បន្ទាប់មក លោកយ៉ូស្វេបាននិយាយទៅលោកអេកានថា៖ «កូនអើយ ចូរនិយាយការពិតនៅចំពោះព្រះអម្ចាស់ គឺព្រះរបស់អ៊ីស្រាអែល
ហើយចូរសារភាពចំពោះព្រះអង្គចុះ។ ចូរនិយាយប្រាប់ខ្ញុំពីអ្វីដែលអ្នកបានធ្វើ។ កុំឲ្យលាក់បាំងខ្ញុំឡើយ»។[20]លោកអេកានបានឆ្លើយទៅលោកយ៉ូស្វេថា៖
«តាមពិតខ្ញុំបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ៊ីស្រាអែលមែន។ នេះជាអ្វីដែលខ្ញុំបានប្រព្រឹត្ត។[21]នៅពេលខ្ញុំបានឃើញអាវធំមកពីបាប៊ីឡូន
និងប្រាក់ពីររយដួង ព្រមទាំងមាសមួយដុំទម្ងន់ហាសិបដួងក្នុងចំណោមជ័យភណ្ឌ នោះខ្ញុំក៏ចង់បាន ហើយក៏យករបស់ទាំងនោះទុក។
ខ្ញុំលាក់របស់ទាំងនោះទុកនៅក្រោមដីក្នុងជំរំរបស់ខ្ញុំ ហើយប្រាក់នៅខាងក្រោមគេ»។
[22]លោកយ៉ូស្វេបានបញ្ជូនអ្នកនាំសារ ឲ្យរត់ទៅជំរំ ហើយបានរកឃើញរបស់ទាំងនោះ។ ពួកគេឃើញថាលោកអេកានបានលាក់វានៅក្នុងតង់ទាំងពីររបស់លោក
ហើយប្រាក់នៅក្រោមគេ។[23]ពួកគេបានយករបស់ទាំងនោះពីកណ្តាលត្រសាលមក ហើយយកទៅជូនលោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែល។
ពួកគេដាក់របស់ទាំងអស់នោះនៅចំពោះព្រះអម្ចាស់។
[24]បន្ទាប់មក លោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលដែលនៅជាមួយលោក បានយកលោកអេកានជាកូនរបស់លោកសេរ៉ា ព្រមទាំងប្រាក់ អាវធំ ដុំមាស កូនប្រុសស្រី គោ
លា ចៀម ពីត្រសាលរបស់គាត់ និងរបស់អ្វីដែលគាត់មាន ហើយនាំពួកគេឡើងទៅជ្រោះអាគ័រ។
[25]បន្ទាប់មក លោកយ៉ូស្វេបានមានប្រសាសន៍ថា៖ «ហេតុអ្វីបានជាអ្នកនាំបញ្ហាមកឲ្យយើងដូច្នេះ? ព្រះអម្ចាស់នឹងដាក់ទោសអ្នកនៅថ្ងៃនេះ»។
ជនជាតិអ៊ីស្រាអែលទាំងអស់បានយកដុំថ្មគប់គាត់។ អ្នកផ្សេងទៀតក៏គប់នឹងដុំថ្មដែរ ហើយបានដុតពួកគេនឹងភ្លើង។[26]ពួកគេបានយកដុំថ្មដ៏ច្រើនមកសង្កត់គាត់
ដែលស្ថិតនៅកន្លែងនោះរហូតមកដល់សព្វថ្ងៃនេះ។ ព្រះអម្ចាស់ក៏ឈប់ព្រះពិរោធ។ ហេតុដូច្នេះហើយ បានជាគេក៏ហៅកន្លែងនោះថា ជ្រោះអាគ័ររហូតដល់សព្វថ្ងៃនេះ។

Joshua 7:1
ចំពោះរបស់ដែលត្រូវបំផ្លាញចោល
«អ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូល
ពួកគេត្រូវតែញែកចំពោះព្រះអង្គដោយបំផ្លាញពួកវា»
លោកអេកាន ... លោកកើមើ.លោកសាបឌី .. លោកសេរ៉ា
ទាំងអស់នេះគឺជាឈ្មោះរបស់បុរស។
ព្រះពិរោធរបស់ព្រះអម្ចាស់បានកើតដល់ប្រជារាស្ត្រអ៊ីស្រាអែល
«កំហឹង» និង «ឆេះ» បង្ហាញពីកំលាំង មិនមែនភ្លើងនោះទេ។
ការបកប្រែផ្សេងទៀត « សេចក្តីក្រេវក្រោធរបស់ព្រះយេហូវ៉ាបានឆេះដូចជាភ្លើង»
ឬ«ព្រះអម្ចាស់ទ្រង់មានព្រះពិរោធខ្លាំងណាស់»
Joshua 7:2
មនុស្សទាំងអស់
នេះសំដៅទៅលើកងទ័ពអ៊ីស្រាអែល។
ពួកគេមានគ្នាតិចទេ
ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនទីក្រុងអៃ។
Joshua 7:4
មានមនុស្សប្រុសប្រហែលបីពាន់នាក់ចេញទៅ
បុរសទាំងនេះគឺជាចំណែកនៃកងទ័ព។ ការបកប្រែផ្សេងទៀត
«ទាហានបីពាន់នាក់ដែលជាកម្មសិទ្ធិរបស់កងទ័ពបានកើនឡើង»
មនុស្សប្រុសប្រហែលបីពាន់នាក់ ...សាមសិបប្រាំមួយនាក់
បុរស ៦ នាក់ - «បុរស ៣,០០០ នាក់ ... បុរស ៣៦ នាក់»
ប្រជាជនមានចិត្តភ័យភ្លាច ហើយបាក់ទឹកចិត្តយ៉ាងខ្លាំង
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា ហើយត្រូវបានបញ្ចូលគ្នាដើម្បីបញ្ជាក់ថា
ប្រជាជនមានការភ័យខ្លាចយ៉ាងខ្លាំង។
ប្រជាជនមានចិត្តភ័យភ្លាច
មនុស្សដែលភ័យខ្លាចត្រូវបានគេនិយាយដូចជា ចិត្តរបស់ពួកគេគឺភ័យខ្លាច។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «ប្រជាជនគឺ ភ័យខ្លាចខ្លាំងណាស់»
ប្រជាជនមានចិត្ត
ឃ្លា « ប្រជាជន» សំដៅទៅលើទាហានអ៊ីស្រាអែល។
ហើយបាក់ទឹកចិត្តយ៉ាងខ្លាំង
« ពួកគេលែងមានភាពក្លាហានទៀតហើយ »
Joshua 7:6
ហែកសំលៀកបំពាក់ ...
បាចដីលើក្បាលរបស់ពួកគេហើយក្រាបមុខដល់ដីនៅខាងមុខហិបរបស់ព្រះអម្ចាស់
ពួកគេបានធ្វើរឿងទាំងនេះ ដើម្បីបង្ហាញព្រះជាម្ចាស់ពីរបៀបដែលពួកគេក្រៀមក្រំ
និងពិបាកចិត្តយ៉ាងណា។
ដើម្បីចូលមកកាន់ទឹកដីរបស់សាសន៍អាម៉ូរីឲ្យពួកគេបំផ្លាញយើងទៅវិញ?
លោកយ៉ូស្វេបានកំពុងសួរថា តើនេះជាហេតុផលដែលព្រះជាម្ចាស់
បាននាំពួកគេឆ្លងទន្លេយ័រដាន់ទេ? ការបកប្រែផ្សេងទៀត
«តើព្រះអង្គបានធ្វើវាដើម្បីប្រគល់យើង
ទៅក្នុងកណ្តាប់ដៃរបស់ជនជាតិអាម៉ូរីដើម្បីបំផ្លាញយើងទេ?»
ដើម្បីចូលមកកាន់ទឹកដីរបស់សាសន៍អាម៉ូរីឲ្យពួកគេបំផ្លាញយើងទៅវិញ?
ដៃរបស់ជនជាតិអាម៉ូរីតំណាងឲ្យការគ្រប់គ្រង និងអំណាចរបស់ពួកគេ។
ការប្រគល់ជនជាតិអ៊ីស្រាអែលទៅក្នុងកណ្តាប់ដៃ
របស់ពួកគេដើម្បីបំផ្លាញពួកគេគឺជាការអនុញ្ញាតឲ្យជនជាតិអាម៉ូរី
បានគ្រប់គ្រងលើជនជាតិអ៊ីស្រាអែល ហើយបំផ្លាញពួកគេ។ ការបកប្រែផ្សេងទៀត
« ដើម្បីអនុញ្ញាតឲ្យជនជាតិអាម៉ូរីបំផ្លាញយើង»?
បើយើងធ្វើការសម្រេចចិត្ត
ពាក្យថា «ប្រសិនបើមានតែ» ដើម្បីបង្ហាញថានេះគឺជាបំណងប្រាថ្នាសម្រាប់អ្វីមួយ
ដែលមិនបានកើតឡើង។ ការបកប្រែផ្សេងទៀត
«ខ្ញុំសង្ឃឹមថាយើងបានធ្វើការសម្រេចចិត្តផ្សេង»
Joshua 7:8
ព័ត៌មានទូទៅ
លោកយ៉ូស្វេបង្ហាញការខកចិត្តទៅចំពោះព្រះជាម្ចាស់។
តើទូលបង្គំអាចនិយាយអ្វីបាន
ក្រោយពេលដែលជនជាតិអ៊ីស្រាអែលរត់នៅចំពោះខ្មាំងសត្រូវរបស់ពួកគេដូច្នេះ!
លោកយ៉ូស្វេបាននិយាយបែបនេះដើម្បីបង្ហាញថាគាត់តូចចិត្តណាស់ដែលគាត់មិនដឹងថាត្រូវ
ការបកប្រែផ្សេងទៀត « ខ្ញុំមិនដឹងថាត្រូវនិយាយអ្វីទេ
អ៊ីស្រាអែលបានងាកបែរទៅរកសត្រូវរបស់ពួកគេ»។
ក្រោយពេលដែលជនជាតិអ៊ីស្រាអែលរត់នៅចំពោះខ្មាំងសត្រូវរបស់ពួកគេដូច្នេះ?
ការធ្វើបែបនេះតំណាងឲ្យការរត់ចេញពីសត្រូវរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «
អ៊ីស្រាអែលបានរត់ចេញពីសត្រូវរបស់ពួកគេ »
ពួកគេនឹងឡោមព័ទ្ធយើង ហើយនឹងធ្វើឲ្យមនុស្សនៅលើផែនដីភ្លេចឈ្មោះយើងមិនខាន
ការធ្វើអោយប្រជាជនភ្លេចឈ្មោះជនជាតិអ៊ីស្រាអែល
តំណាងអោយការធ្វើអោយគេភ្លេចប្រជាជនអ៊ីស្រាអែល។
ក្នុងករណីនេះពួកគេនឹងធ្វើវាដោយសម្លាប់ជនជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត « ពួកគេនឹងឡោមព័ទ្ធយើង
នឹងសម្លាប់យើងហើយប្រជាជននៅលើផែនដីនឹងភ្លេចយើង »
សម្រាប់ព្រះនាមដ៏ប្រសើររបស់ព្រះអង្គ
ឃ្លា « ព្រះនាមដ៏ប្រសើររបស់ព្រះអង្គ » នៅទីនេះតំណាងឲ្យកេរ្តិ៍ឈ្មោះ
និងអំណាចរបស់ព្រះ។ ការបកប្រែផ្សេងទៀត « ហើយដូច្នេះតើព្រះអង្គ
នឹងធ្វើអ្វីដើម្បីឲ្យប្រជាជនដឹងថាព្រះអង្គគឺមហិមា »
តើព្រះអង្គនឹងធ្វើយ៉ាងណាសម្រាប់ព្រះនាមដ៏ប្រសើររបស់ព្រះអង្គ?
លោកយ៉ូស្វេប្រើសំនួរនេះដើម្បីទួលព្រះជាម្ចាស់ថា
ប្រសិនបើជនជាតិអ៊ីស្រាអែលត្រូវបានបំផ្លាញចោលនោះ
ប្រជាជនផ្សេងទៀតនឹងគិតថាព្រះជាម្ចាស់មិនពូកែអស្ចារ្យទេ។
ការបកប្រែផ្សេងទៀត «
បន្ទាប់មកនឹងគ្មានអ្វីដែលព្រះអង្គអាចធ្វើបានសម្រាប់ព្រះនាមដ៏អស្ចារ្យរបស់ទ្រង់ទេ
» ។ ឬ «បន្ទាប់មកប្រជាជន នឹងមិនដឹងថាព្រះអង្គគឺអស្ចារ្យ » ។
Joshua 7:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រាប់លោកយ៉ូស្វេ ពីមូលហេតុដែលអ៊ីស្រាអែលត្រូវបណ្តាសា។
ហេតុអ្វីបានជាអ្នកក្រាបមុខដល់ដីបែបនេះ?
ព្រះជាម្ចាស់បានប្រើសំណួរនេះដើម្បីស្តីបន្ទោសលោកយ៉ូស្វេចំពោះការកុហកនៅលើមុខ
ការបកប្រែផ្សេងទៀត « ឈប់កុហកដោយទឹកមុខរបស់អ្នកនៅក្នុងភាពកខ្វក់!»
របស់មួយចំនួនដែលត្រូវបំផ្លាញចោល
ទាំងនេះគឺជាអ្វីដែល «ត្រូវបានសម្គាល់សម្រាប់ការបំផ្លិចបំផ្លាញ» ពី ៦:១៧ ។
ការបកប្រែផ្សេងទៀត « របស់ដែលត្រូវបណ្តាសា» ឬ «
របស់ទាំងអស់នេះដែលព្រះជាម្ចាស់បានដាក់បណ្តាសា »
ពួកគេបានលួច ហើយក៏លាក់អំពើបាបរបស់ពួកគេ
ការលាក់បាំងអំពើបាបរបស់ពួកគេ
តំណាងឲ្យការព្យាយាមមិនឲ្យអ្នកដទៃដឹងថាពួកគេបានធ្វើបាប។
ការបកប្រែផ្សេងទៀត « ពួកគេបានលួចរបស់ទាំងនោះ
ហើយបន្ទាប់មកពួកគេបានព្យាយាមមិនឲ្យមនុស្សដឹងថាពួកគេបានធ្វើបាប»
មិនអាចឈរនៅមុខខ្មាំងសត្រូវរបស់ខ្លួនបាន
ឈរនៅមុខខ្មាំងសត្រូវរបស់ពួកគេតំណាងឲ្យការប្រយុទ្ធប្រឆាំង
នឹងសត្រូវរបស់ពួកគេដោយជោគជ័យ។ ការបកប្រែផ្សេងទៀត «
មិនអាចប្រយុទ្ធប្រឆាំងនឹងខ្មាំងសត្រូវរបស់ពួកគេដោយជោគជ័យ » ឬ «
មិនអាចបំផ្លាញខ្មាំងសត្រូវរបស់ពួកគេ »
ពួកគេត្រូវរត់ពីខ្មាំង
ការធ្វើបែបនេះតំណាងឲ្យការរត់ចេញពីសត្រូវរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «
ពួកគេបានរត់ចេញពីសត្រូវរបស់ពួកគេ »
យើងនឹងមិនគង់ជាមួយអ្នកទៀតឡើយ
ការនៅជាមួយអ៊ីស្រាអែល តំណាងឲ្យការជួយអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
« យើងនឹងមិនជួយអ្នកទៀតទេ »
Joshua 7:13
ឃ្លាភ្ជាប់
ព្រះអម្ចាស់បន្តនិយាយទៅកាន់លោកយ៉ូស្វេ
ហើយប្រាប់គាត់ពីអ្វីដែលត្រូវប្រាប់ប្រជាជន។
ប្រជាជន
នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
អ្នកមិនអាចឈរនៅចំពោះខ្មាំងសត្រូវរបស់អ្នករាល់គ្នាបានឡើយ
ឈរនៅមុខសត្រូវរបស់ពួកគេ តំណាងឲ្យការប្រយុទ្ធប្រឆាំង
នឹងពួកគេដោយជោគជ័យ។ ការបកប្រែផ្សេងទៀត «
អ្នកមិនអាចប្រយុទ្ធប្រឆាំងនឹងសត្រូវរបស់អ្នកដោយជោគជ័យ » ឬ «
អ្នកមិនអាចឈ្នះសត្រូវរបស់អ្នក »
Joshua 7:14
ឃ្លាភ្ជាប់
ព្រះអម្ចាស់បន្តប្រាប់លោកយ៉ូស្វេពីអ្វីដែលគាត់ត្រូវប្រាប់ប្រជាជន។
អ្នកត្រូវបង្ហាញខ្លួនតាមកុលសម្ព័ន្ធរៀងៗខ្លួន
មានកុលសម្ព័ន្ធទាំងដប់ពីរ ដែលបានបង្កើតជាប្រជាជនអ៊ីស្រាអែល។ ឃ្លា «
ដោយកុលសម្ព័ន្ធរបស់អ្នក » មានន័យថា « កុលសម្ព័ន្ធនីមួយៗ » ។
ការបកប្រែផ្សេងទៀត « កុលសម្ព័ន្ធនីមួយៗត្រូវបង្ហាញខ្លួនដល់ព្រះអម្ចាស់ »
អំបូរដែលព្រះអម្ចាស់បានជ្រើសរើសត្រូវចូលមកជិតតាមគ្រួសាររៀងខ្លួន
កុលសម្ព័ន្ធនេះត្រូវបានបង្កើតឡើងដោយអំបូរជាច្រើន។ ការបកប្រែផ្សេងទៀត «
មកពីកុលសម្ព័ន្ធដែលព្រះអម្ចាស់ជ្រើសរើសកុលសម្ព័ន្ធនីមួយៗនឹងចូលមកជិត »
កុលសម្ព័ន្ធដែលព្រះអម្ចាស់ជ្រើសរើស
មេដឹកនាំអ៊ីស្រាអែលនឹងបោះឆ្នោតជាច្រើនហើយដោយធ្វើដូច្នេះពួកគេនឹងដឹងថាតើកុលសម្ព័ន្ធណាដែលព្រ
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «
កុលសម្ព័ន្ធដែលព្រះអម្ចាស់ជ្រើសរើសនឹងចាប់ឆ្នោត» ឬ
«កុលសម្ព័ន្ធដែលព្រះអម្ចាស់ជ្រើសរើសនៅពេលយើងចាប់ឆ្នោត»
អំបូរដែលព្រះអម្ចាស់បានជ្រើសរើសត្រូវចូលមកជិតតាមគ្រួសាររៀងខ្លួន
កុលសម្ព័ន្ធនេះត្រូវបានបង្កើតឡើងដោយអំបូរជាច្រើន។ ការបកប្រែផ្សេងទៀត «
មកពីកុលសម្ព័ន្ធដែលព្រះអម្ចាស់ជ្រើសរើសកុលសម្ព័ន្ធនីមួយៗ នឹងចូលមកជិត »
គ្រួសារដែលព្រះអម្ចាស់បានជ្រើសរើសត្រូវចូលមកជិតម្តងម្នាក់ៗ។
ត្រកូលត្រូវបានបង្កើតឡើងដោយគ្រួសារជាច្រើន។ ការបកប្រែផ្សេងទៀត
«ពីអំបូរដែលព្រះអម្ចាស់ជ្រើសរើសគ្រួសារនីមួយៗត្រូវតែចូលមកជិត»
អ្នកដែលត្រូវបានជ្រើសរើស
នេះអាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «
អ្នកដែលព្រះអម្ចាស់ជ្រើសរើស »
ព្រោះគាត់បានរំលោភសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
ការបំពានសម្ពន្ធមេត្រីគឺជាការមិនគោរពតាម។ ការបកប្រែផ្សេងទៀត «
ការមិនគោរពតាមសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ »
Joshua 7:16

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ
លោកយ៉ូស្វេធ្វើតាមបញ្ជារបស់ព្រះអម្ចាស់
ដែលនាំជនជាតិអ៊ីស្រាអែលមកគាល់ព្រះអម្ចាស់។
នាំប្រជាជនអ៊ីស្រាអែលមកជិត តាមកុលសម្ព័ន្ធ
ឃ្លា« កុលសម្ព័ន្ធតាមកុលសម្ព័ន្ធ » មានន័យថាកុលសម្ព័ន្ធនីមួយៗ។
ការបកប្រែផ្សេងទៀត « នាំកុលសម្ព័ន្ធអ៊ីស្រាអែលនីមួយៗមកជិតដល់ »
កុលសម្ព័ន្ធ ហើយកុលសម្ព័ន្ធយូដាត្រូវបានជ្រើសរើស
អាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ព្រះអម្ចាស់បានជ្រើសរើសកុលសម្ព័ន្ធយូដា »
លោកបាននាំអំបូរសេរ៉ាសមកជិតម្នាក់ម្តងៗ
ឃ្លាថា « មនុស្សម្នាក់ឯង» គឺជាសំនួរវោហារស័ព្ទដែលមានន័យថាមនុស្សម្នាក់ៗ។
មនុស្សនៅក្នុងប្រយោគនេះគឺជាអ្នកដឹកនាំគ្រួសាររបស់ពួកគេ។
ការបកប្រែផ្សេងទៀត « គាត់បាននាំមនុស្សជិតខាងនៃត្រកូលសេរ៉ាស» ឬ «
មកពីត្រកូលនៃសេរ៉ាសបាននាំបុរស ដែលជាមេដឹកនាំគ្រួសាររបស់គាត់ម្នាក់ៗមក»
។
អំបូររបស់សេរ៉ាស
ត្រកូលនេះត្រូវបានគេដាក់ឈ្មោះតាមបុរសដែលមានឈ្មោះថាសេរ៉ា។
លោកសាបឌី ... លោកអេកាន ... លោកកើមី ... លោកសេរ៉ា
ទាំងអស់នេះគឺជាឈ្មោះបុរស។ បកប្រែដូចដែលអ្នកបានធ្វើនៅក្នុង ៧:១ ។
Joshua 7:19
ចូរសារភាពចំពោះព្រះអង្គចុះ
« ចូរផ្តល់នូវការសារភាពរបស់អ្នក »
អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទសារភាព។ ការបកប្រែផ្សេងទៀត «
សារភាពទៅគាត់»
កុំឲ្យលាក់បាំងខ្ញុំឡើយ
ការលាក់ព័ត៌គឺជាការព្យាយាមមិនឲ្យនរណាម្នាក់ដឹងពីវា។ ការបកប្រែផ្សេងទៀត «
កុំព្យាយាមរារាំងខ្ញុំមិនឲ្យដឹងពីអ្វីដែលអ្នកបានធ្វើ »
ប្រាក់ពីររយដួង
នេះគឺលើសពី ពីរគីឡូក្រាម។
ហាសិបដួងក្នុង
នេះលើសពី ៥០០ ក្រាម។
ខ្ទុំលាក់របស់ទាំងនោះទុកនៅក្រោមដី
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត «
ខ្ញុំបានលាក់ពួកគេនៅក្នុងដី »
Joshua 7:22
ពួកគេឃើញ
« បុរសដែលលោកយ៉ូស្វេបានចាត់អោយមកមើលទៅ »
ពួកគេដាក់របស់ទាំងអស់
ប្រើពាក្យនៅក្នុងភាសារបស់អ្នកសម្រាប់ការចាក់វត្ថុរឹងតូចៗជាច្រើនចេញពីកាបូបធំមួយដាក់លើដី។
Joshua 7:24
ជ្រោះអាគ័រ
ឈ្មោះនេះមានន័យថា « ជ្រលងភ្នំនៃបញ្ហា »
ប៉ុន្តែវាជាការល្អបំផុតក្នុងការបកប្រែថាជ្រោះអាគ័រ តាមរបៀបវាគឺល្អ។
Joshua 7:25
ហេតុអ្វីបានជាអ្នកនាំបញ្ហាមកឲ្យយើងដូច្នេះ?
លោកយ៉ូស្វេប្រើសំណួរនេះដើម្បីស្តីបន្ទោសលោកអេកាន។ ការបកប្រែផ្សេងទៀត «
អ្នកបានធ្វើអោយយើងមានបញ្ហា »
អ្នកផ្សេងទៀតក៏គប់នឹងដុំថ្មដែរ ហើយបានដុតពួកគេនឹងភ្លើង។
អាចមានន័យថា ១)
ជនជាតិអ៊ីស្រាអែលបានដុតក្រុមគ្រួសាររបស់លោកអេកានរហូតដល់ស្លាប់ហើយបន្ទាប់មកគ្របជាមួយថ្ម
ឬ ២)
ជនជាតិអ៊ីស្រាអែលយកដុំថ្មគប់ក្រុមគ្រួសាររបស់លោកអេកានរហូតដល់ស្លាប់
ហើយបន្ទាប់មកបានដុតសាកសព ឬទី ៣) លោកអេកាន
និងទ្រព្យសម្បត្តិរបស់គាត់ត្រូវបានគប់នឹងថ្ម ហើយបន្ទាប់មកបានដុតចោល។
ព្រះអម្ចាស់ក៏ឈប់ព្រះពិរោធ
បែរចេញពីកំហឹងមានន័យថាព្រះអង្គឈប់ព្រះពិរោធ។
ដុតកំហឹងមានន័យថាធ្វើឲ្យខឹងកាន់តែខ្លាំងឡើង។
រហូតដល់សព្វថ្ងៃនេះ
វានៅតែត្រូវបានគេហៅថាជ្រលងភ្នំអាគ័រ
នៅពេលដែលអ្នកនិពន្ធបានសរសេររឿងនេះ។ ការបកប្រែផ្សេងទៀត «
សូម្បីតែថ្ងៃនេះ » ឬ « សូម្បីតែឥឡូវនេះ»

---

8 [1]ព្រះអម្ចាស់បានមានបន្ទូលមកលោកយ៉ូស្វេថា៖ «កុំឲ្យភ័យខ្លាចឡើយ កុំឲ្យបាក់ទឹកចិត្តឲ្យសោះ។ ចូរនាំអ្នកចំបាំងទាំងអស់ទៅជាមួយអ្នក។ ឡើងទៅក្រុងអៃទៅ។
មើល យើងនឹងប្រគល់ស្តេចក្រុងអៃដល់អ្នក ទាំងប្រជាជន ទាំងក្រុង និងទឹកដីរបស់ស្តេចផង។[2]អ្នកនឹងប្រព្រឹត្តជាមួយក្រុងអៃដូចដែលអ្នកបានប្រព្រឹត្តចំពោះក្រុងយេរីខូ
និងស្តេចរបស់ក្រុងនោះដែរ តែអ្នកអាចយកជ័យភណ្ឌ និងហ្វូងសត្វរបស់ពួកគេទុកជារបស់អ្នកបាន។ ចូររៀបទ័ពវាយឆ្មក់ពីក្រោយក្រុង»។
[3]ដូច្នេះ លោកយ៉ូស្វេភ្ញាក់ពីដំណេក ហើយនាំអ្នកចម្បាំងទាំងអស់ទៅក្រុងអៃ។ បន្ទាប់មក លោកយ៉ូស្វេបានជ្រើសរើសមនុស្សប្រុសបីម៉ឺននាក់ ជាអ្នកខ្លាំងពូកែ
និងអង់អាចក្លាហាន រួចពួកគេចេញទៅនៅពេលយប់។[4]លោកបានបង្គាប់ពួកគេថា៖ «មើល អ្នកត្រូវបង្កប់ខ្លួននៅខាងក្រោយក្រុង។ កុំឲ្យទៅឆ្ងាយពីទីក្រុងពេក
តែចូរឲ្យគ្រប់គ្នារួចរាល់។
[5]ខ្ញុំ និងអ្នកដែលនៅជាមួយខ្ញុំនឹងសំដៅទៅទីក្រុង ហើយនៅពេលដែលពួកគេចេញមកវាយពួកយើង យើងនឹងរត់ដូចកាលមុន។
[6]ពួកគេនឹងដេញតាមយើងរហូតដល់យើងនាំគេចេញឆ្ងាយពីទីក្រុង។ ពួកគេនឹងនិយាយថា៖ អ្នកទាំងនេះបានរត់នៅមុខយើងដូចកាលពីមុន។ ដូច្នេះ
យើងនឹងរត់នៅមុខពួកគេ។[7]បន្ទាប់មក អ្នកត្រូវតែចេញពីកន្លែងលាក់ខ្លួនរបស់អ្នកមក ហើយអ្នកត្រូវដណ្តើមយកទីក្រុង។
ព្រះអម្ចាស់នឹងប្រគល់ក្រុងនេះមកក្នុងដៃរបស់អ្នក។
[8]នៅពេលដែលអ្នកកាន់កាប់ទីក្រុងបានហើយ អ្នកត្រូវតែដុតក្រុងនោះចោល។ អ្នកអាចសម្រេចការនេះបានលុះត្រាតែអ្នកស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់។ មើល
យើងបានបង្គាប់អ្នក។[9]«លោកយ៉ូស្វេបានបញ្ជូនពួកគេទៅ ហើយពួកគេទៅកន្លែងលាក់ខ្លួន ហើយពួកគេបានលាក់ខ្លួននៅចន្លោះបេតអែល និងអៃ។ ប៉ុន្តែ
យប់នោះលោកយ៉ូស្វេបានស្នាក់នៅក្នុងចំណោមប្រជាជន។
[10]លោកយ៉ូស្វេបានក្រោកពីព្រលឹម ហើយរៀបចំពួកទាហានរួចរាល់ លោកយ៉ូស្វេ និងពួកចាស់ទុំអ៊ីស្រាអែលបានវាយលុកមនុស្សក្រុងអៃ។
[11]ទាហានទាំងអស់ដែលនៅជាមួយលោកបានឡើងទៅ ហើយសំដៅទៅទីក្រុង។ ពួកគេបានមកជិតទីក្រុង ហើយពួកគេក៏បោះជំរំនៅខាងជើងក្រុងអៃ។
ពួកគេនៅចន្លោះរវាងជ្រោះ និងក្រុងអៃ។[12]លោកបាននាំមនុស្សប្រុសប្រាំពាន់នាក់ ហើយឲ្យគេលាក់ខ្លួននៅខាងលិចទីក្រុងរវាងបេតអែល និងអៃ។
[13]ពួកគេបានរៀបកងទ័ព ទាហានជួរមុខនៅខាងជើងក្រុង ហើយទាហានផ្សេងទៀតនៅខាងលិចក្រុង។ លោកយ៉ូស្វេបានស្នាក់នៅក្នុងជ្រលងភ្នំនៅយប់នោះ។
[14]នៅពេលដែលស្តេចក្រុងអៃបានឃើញកងទ័ព ស្តេច និងពួកគេទាហានរបស់ស្តេចក្រោកពីព្រលឹម ហើយរួសរាន់ចេញទៅវាយប្រហារជនជាតិអ៊ីស្រាអែល។
ស្តេចមិនបានដឹងថាទ័ពដែលលាក់ខ្លួនបានរង់ចាំវាយប្រហារពួកគេពីខាងក្រោយក្រុងនោះទេ។
[15]លោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលទាំងអស់បានអនុញ្ញាតឲ្យគេមានប្រៀបលើខ្លួន ហើយរត់តម្រង់ទៅទីរហោស្ថាន។
[16]មនុស្សទាំងអស់នៅក្នុងក្រុងបានប្រមូលគ្នាដេញតាមពួកគេ រួចពួកគេដេញពីក្រោយលោកយ៉ូស្វេ ហើយពួកគេចេញឆ្ងាយពីក្រុង។[17]គ្មានមនុស្សប្រុសនៅសល់ក្នុងក្រុងអៃ
និងបេតអែលឡើយ ពួកគេបានដេញតាមទ័ពអ៊ីស្រាអែល។ ពួកគេបានទុកទីក្រុងចោល ហើយចំហទ្វារក្រុងចោល ដោយសារពួកគេដេញតាមអ៊ីស្រាអែល។
[18]ព្រះអម្ចាស់មានបន្ទូលមកលោកយ៉ូស្វេថា៖ «ចូរតម្រង់លំពែងនៅក្នុងដៃអ្នកឆ្ពោះទៅក្រុងអៃទៅ យើងនឹងប្រគល់ក្រុងអៃមកក្នុងដៃអ្នក»។
លោកយ៉ូស្វេបានតម្រង់លំពែងដែលនៅក្នុងដៃលោកទៅកាន់ក្រុង។
[19]ពួកទាហានដែលលាក់ខ្លួនក៏ចេញមកយ៉ាងប្រញាប់ពីកន្លែងរបស់ពួកគេចំពេលដែលលោកបានលើដៃឡើង។ ពួកគេរត់ចូលក្នុងក្រុងយ៉ាងប្រញាប់
ហើយក៏ចាប់យកក្រុង។ ពួកគេប្រញាប់ដុតកម្ទេចក្រុងចោល។

generated on Wed Sep 10 16:16:32 2025

[20]ពួកប្រុសៗក្រុងអៃមើលត្រឡប់ក្រោយ។ ពួកគេឃើញផ្សែងហុយឡើងពីទីក្រុងដល់មេឃ ហើយពួកគេមិនអាចរត់ទៅណាបានឡើយ។
ទាហានអ៊ីស្រាអែលដែលរត់ទៅទីរហោស្ថានបានត្រឡប់ក្រោយរកអ្នកដែលបានដេញពួកគេ។[21]នៅពេលដែលលោកយ៉ូស្វេ
និងជនជាតិអ៊ីស្រាអែលបានឃើញថាទាហានដែលលាក់ខ្លួនបានកាន់កាប់ទីក្រុងដោយមានផ្សែងហុយឡើងផង ពួកគេក៏ត្រឡប់ក្រោយ ហើយសម្លាប់ពួកក្រុងអៃ។
[22]ទាហានអ៊ីស្រាអែលផ្សេងទៀត គឺអស់អ្នកដែលបានចូលទៅក្នុងក្រុង ក៏ចេញមកប្រយុទ្ធដែរ។ ដូច្នេះ ប្រុសៗក្រុងអៃក៏ជាប់នៅកណ្តាលរវាងទាហានអ៊ីស្រាអែល
ខ្លះនៅខាងនេះ ខ្លះនៅខាងនោះ។ អ៊ីស្រាអែលបានវាយប្រហារប្រុសៗក្រុងអៃ គ្មាននរណាម្នាក់នៅរស់ ឬរត់រួចឡើយ។[23]ពួកគេបានទុកស្តេចក្រុងអៃ
គឺពួកគេចាប់បានទាំងរស់ ហើយបាននាំស្តេចទៅជួបលោកយ៉ូស្វេ។
[24]នៅពេលដែលអ៊ីស្រាអែលបានសម្លាប់ពួកក្រុងអៃនៅវាលស្រែនៅជិតវាលទីរហោស្ថាននៅកន្លែងដែលពួកគេបានដេញតាមអ្នកទាំងនោះរួចហើយ
គឺនៅពេលដែលពួកគេទាំងអស់បានស្លាប់ដោយមុខដាវ នោះជនជាតិអ៊ីស្រាអែលទាំងអស់ក៏ត្រឡប់ទៅក្រុងអៃវិញ។ ពួកគេបានវាយប្រហារក្រុងអៃដោយមុខដាវ។
[25]មនុស្សទាំងអស់បានស្លាប់នៅថ្ងៃនោះ ទាំងប្រុស ទាំងស្រី គឺមានចំនួនដប់ពីរម៉ឺននាក់ សុទ្ធតែជាអ្នកក្រុងអៃ។
[26]លោកយ៉ូស្វេមិនបានដកដៃរបស់លោកដែលលើកលំពែងនោះឡើយ រហូតដល់គាត់បានបំផ្លាញអ្នកក្រុងអៃបានទាំងស្រុង។
[27]ជនជាតិអ៊ីស្រាអែលបានយកតែហ្វូងសត្វ និងគ្រឿងជ័យភណ្ឌប៉ុណ្ណោះសម្រាប់ខ្លួនពួកគេ ដូចអ្វីដែលព្រះអម្ចាស់បានបង្គាប់មកលោកយ៉ូស្វេ។
[28]លោកយ៉ូស្វេបានដុតកម្ទេចក្រុងអៃ ហើយក្រុងនោះក្លាយជាគំនរបាក់បែករហូតមក។ វាក្លាយជាកន្លែងដែលគេបោះបង់ចោលរហូតដល់សព្វថ្ងៃ។
[29]លោកបានចងស្តេចក្រុងអៃនៅលើដើមឈើរហូតដល់ពេលល្ងាច។ នៅពេលថ្ងៃលិច លោកយ៉ូស្វេបានបញ្ជាឲ្យគេដាក់សាកសពរបស់ស្តេចចុះពីដើមឈើ
ហើយបោះចោលនៅច្រកទ្វារក្រុង។ នៅទៅនោះពួកគេបានដាក់គំនរថ្មលើសាកសពស្តេច។ គំនរនោះបន្សល់មកដល់សព្វថ្ងៃ។
[30]បន្ទាប់មក លោកយ៉ូស្វេបានសង់អាសនាមួយថ្វាយព្រះអម្ចាស់ ដល់ព្រះរបស់អ៊ីស្រាអែលនៅលើភ្នំអេបាល។
[31]ដូចដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានបង្គាប់ដល់ជនជាតិអ៊ីស្រាអែល ហើយវាមានសរសេរទុកនៅក្នុងគម្ពីរវិន័យរបស់លោកម៉ូសេថា៖
«អាសនាពីថ្មទាំងមូល ដែលគ្មាននរណាដាប់ដោយដែកឡើយ»។ លោកបានថ្វាយតង្វាយដុតនៅលើអាសនានោះដល់ព្រះអម្ចាស់
ហើយបន្ទាប់មកគេក៏ថ្វាយដង្វាយមេត្រីដែរ។[32]នៅក្នុងវត្តមានរបស់ប្រជាជនអ៊ីស្រាអែល លោកបានចំលងក្រឹត្យវិន័យរបស់លោកម៉ូសេដាក់លើថ្ម។
[33]គ្រប់ទាំងជនជាតិអ៊ីស្រាអែល ពួកចាស់ទុំរបស់ពួកគេ នាយក្រុម និងពួកចៅហ្វាយរបស់ពួកគេបានឈរនៅទាំងសងខាងនៅហិប នៅមុខពួកបូជាចារ្យ និងពួកលេវី
ដែលបានសែងហិបសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។ ជនបរទេស ក៏ដូចជាអ្នកដែលកើតក្នុងស្រុក និងកើតក្រៅស្រុក ពួកគេពាក់កណ្តាលបានឈរនៅមុខភ្នំកេរីស៊ីម
ហើយពាក់កណ្តាលទៀតឈរនៅមុខភ្នំអេបាល។ ពួកគេបានឲ្យពរដល់ប្រជាជនអ៊ីស្រាអែល
ដូចអ្វីដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានបង្គាប់ដល់ពួកគេតាំងពីដំបូង។
[34]ក្រោយមក លោកយូស្វេបានអានក្រឹត្យវិន័យ គឺព្រះពរ និងបណ្តាសារ ដូចមានចែងទុកនៅក្នុងគម្ពីរក្រឹត្យវិន័យ។
[35]គ្មានពាក្យមួយមាត់ណាដែលចេញពីលោកម៉ូសេដែលលោកយ៉ូស្វេមិនបានអាននៅខាងមុខប្រជាជនអ៊ីស្រាអែល ទាំងស្រីៗ ក្មេងតូចៗ
ជនបរទេសដែលរស់នៅក្នុងចំណោមពួកគេឡើយ។

Joshua 8:1
«កុំឲ្យភ័យខ្លាចឡើយ កុំឲ្យបាក់ទឹកចិត្តឲ្យសោះ»
ឃ្លាទាំងពីរនេះមានអត្ថន័យជារួមដូចគ្នា។
ព្រះអម្ចាស់រួមបញ្ចូលពួកគេដើម្បីបញ្ជាក់ថា គ្មានមូលហេតុត្រូវខ្លាចទេ។
យើងនឹងប្រគល់ស្តេចក្រុងអៃដល់អ្នក ទាំងប្រជាជន ទាំងក្រុង ... និងទឹកដីរបស់ស្តេចផង
ការប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់អ៊ីស្រាអែល មានន័យថា
ផ្តល់ឲ្យអ៊ីស្រាអែលនូវជ័យជំនះ និងគ្រប់គ្រងលើពួកគេ។ការបកប្រែផ្សេងទៀត « យើងបានប្រគល់ជ័យជំនះដល់អ្នកលើស្តេចអៃ
និងប្រជាជនរបស់ទ្រង់ហើយយើងបានប្រគល់អ្នកអោយគ្រប់គ្រងលើក្រុង
និងទឹកដីរបស់ទ្រង់»។
យើងនឹងប្រគល់
ព្រះជាម្ចាស់មានព្រះបន្ទូលអំពីអ្វីដែលព្រះអង្គបានសន្យាថា
នឹងធ្វើដូចជាព្រះអង្គបានធ្វើរួចហើយ ពីព្រោះព្រះអង្គពិតជានឹងធ្វើវាជាមិនខាន ។
ការបកប្រែផ្សេងទៀត « យើងពិតជានឹងប្រទានឲ្យ » ឬ « យើងនឹងប្រទានឲ្យ »
និងស្តេច
ពាក្យថា «នាង» គឺសំដៅលើទីក្រុងអៃ។
ទីក្រុងជាច្រើនត្រូវបានគេនិយាយដូចជាពួកគេជាស្ត្រី។ ការបកប្រែផ្សេងទៀត « ស្តេចរបស់វា » ឬ « ស្តេចរបស់ពួកគេ »
Joshua 8:3
អ្នកចម្បាំង
«កងទ័ពអ៊ីស្រាអែល»
មនុស្សប្រុសបីម៉ឺននាក់
«បុរស ៣០,០០០ នាក់ »
Joshua 8:5
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តពន្យល់ផែនការប្រយុទ្ធដល់ទាហានរបស់គាត់។
នឹងប្រគល់ក្រុងនេះមកក្នុងដៃរបស់អ្នក។
នៅទីនេះ « ដៃ » ជានិមិត្តរូបនៃការគ្រប់គ្រង
និងអំណាចដែលប្រជាជនមានលើសត្រូវរបស់ពួកគេ។
Joshua 8:8
ព័ត៌មានទូទៅ
លោកយ៉ូស្វេបានបញ្ចប់ការពន្យល់អំពីផែនការសង្គ្រាមដល់ទាហានរបស់គាត់។
លោកយ៉ូស្វេបានបញ្ជូនពួកគេទៅ
ឃ្លានេះសំដៅទៅលើលោកយ៉ូស្វេបញ្ជូនបុរសបីម៉ឺននាក់
ដែលត្រូវបានជ្រើសរើសដើម្បីវាយប្រហារទីក្រុងអៃ
ទៅកាន់កន្លែងដែលពួកគេនឹងបង្កប់ខ្លួន
កន្លែងលាក់ខ្លួន
«កន្លែងដែលពួកគេនឹងលាក់ខ្លួនរហូតដល់ពេលដើម្បីវាយប្រហារ»
Joshua 8:10
មនុស្សប្រុសប្រាំពាន់នាក់
«បុរស ៥,០០០ នាក់ »។ ក្រុមនេះហាក់ដូចជាផ្នែកមួយនៃ « បុរសសាមសិបពាន់នាក់ » (៨:៨) ។
ក្រុមតូចមួយនេះនៅតែស្ថិតនៅក្នុងការស្ទាក់វាយប្រហារខណៈពេលដែលបុរស ២៥.០០០ នាក់ផ្សេងទៀតបានវាយប្រហារទីក្រុង។
Joshua 8:13
ព័ត៌មានទូទៅ
ជនជាតិអ៊ីស្រាអែលត្រៀមប្រយុទ្ធ នឹងប្រជាជនទីក្រុងអៃ។
ទាហានជួរមុខ
នេះសំដៅទៅលើក្រុមប្រយុទ្ធដែលធំជាងគេ គឺអ្នកដែលមិននៅក្នុងក្រុមពួនស្ទាក់។
ទាហានផ្សេងទៀត
អ្នកដែលត្រូវបាន « ពួនស្ទាក់វាយឆ្មក់នៅភាគខាងលិចនៃទីក្រុង » (សូមមើល ៨:១០)
Joshua 8:15
អនុញ្ញាត្តឲ្យគេមានប្រៀបលើខ្លួន
ចូរទុកអោយគេចាញ់នៅមុខប្រជាជនទីក្រុងអៃ។ ឃ្លាដែលថា« ពីមុខពួកគេ »
តំណាងឲ្យអ្វីដែលប្រជាជនទីក្រុងអៃនឹងឃើញនិងគិត។ ការបកប្រែផ្សេងទៀត « ទុកឲ្យ ប្រជាជនក្នុងទីក្រុងអៃ គិតថាជនជាតិអ៊ីស្រាអែលត្រូវបានចាញ់»
អនុញ្ញាត្តឲ្យគេមានប្រៀបលើខ្លួន
ឃ្លា « ត្រូវចាញ់ » អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត « អោយប្រជាជនអៃគិតថាពួកគេបានយកឈ្នះជនជាតិអ៊ីស្រាអែល»
ប្រៀបលើខ្លួន ... ពួកគេដេញពីក្រោយ ...ពួកគេចេញឆ្ងាយ
ពាក្យ « ពួកគេ » និង « ពួកគេ » នៅទីនេះសំដៅទៅលើកងទ័ពរបស់ក្រុងអៃ។
ហើយរត់ ... ដេញពីក្រោយ
ពាក្យថា « ពួកគេ » និង « ពួកគេ » នៅទីនេះសំដៅទៅលើកងទ័ពអ៊ីស្រាអែល។

generated on Wed Sep 10 16:16:32 2025

មនុស្សទាំងអស់នៅក្នុងក្រុងបានប្រមូលគ្នាដេញតាមពួកគេ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
មេដឹកនាំទីក្រុងបានហៅប្រជាជនទាំងអស់នៅក្នុងទីក្រុងជាមួយគ្នា »
មនុស្សទាំងអស់នៅក្នុងក្រុង
អ្នកនិពន្ធនិយាយជាទូទៅ
អំពីប្រជាជនទាំងអស់ប៉ុន្តែគឺមនុស្សទាំងអស់ដែលអាចប្រយុទ្ធបាន។
ការបកប្រែផ្សេងទៀត «
ប្រជាជនទាំងអស់នៅក្នុងទីក្រុងដែលអាចជួយដេញតាមកងទ័ពអ៊ីស្រាអែល »
ហើយចំហទ្វារក្រុងចោល
« ទុកឲ្យទ្វារក្រុងបើកចំហ »
Joshua 8:18
យើងនឹងប្រគល់ក្រុងអៃមកក្នុងដៃអ្នក
ការប្រគល់ទីក្រុងអៃទៅក្នុងដៃរបស់អ៊ីស្រាអែលតំណាងឲ្យការផ្តល់ឲ្យអ៊ីស្រាអែលនូវជ័យជំនះ
និងគ្រប់គ្រងលើទីក្រុង។ ការបកប្រែផ្សេងទៀត «
យើងនឹងផ្តល់ឲ្យអ្នកនូវជ័យជំនះលើទីក្រុងអៃ » ឬ «
យើងនឹងធ្វើឲ្យអ្នកចាប់យកទីក្រុង »។
Joshua 8:24
ពេលដែលអ៊ីស្រាអែលបានសម្លាប់ពួកក្រុងអៃ ...
នៅពេលដែលពួកគេ ...អស់បានស្លាប់ដោយមុខដាវ
អ្នកនិពន្ធប្រើប្រយោគទាំងពីរនេះ ដែលស្ទើរតែមានន័យដូចគ្នាដើម្បីនិយាយថា
ប្រជាជនអ៊ីស្រាអែលបានគោរពតាមបញ្ជារបស់ព្រះជាម្ចាស់ដែលបានសម្លាប់មនុស្សទាំងអស់នៅ
បានស្លាប់ដោយមុខដាវ
នៅទីនេះ ការធ្លាក់ចុះនេះតំណាងឲ្យការស្លាប់ ហើយមុខដាវតំណាងឲ្យការប្រយុទ្ធ
ឬកងទ័ពអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត « បានស្លាប់នៅក្នុងសមរភូមិ » ឬ «
បានស្លាប់នៅពេលកងទ័ពអ៊ីស្រាអែលបានវាយប្រហារពួកគេ »
ចំនួនដប់ពីរម៉ឺននាក់
« ១២,០០០នាក់ »
Joshua 8:27
កន្លែងដែលគេបោះបង់ចោល
វាជាកន្លែងដែលមនុស្សធ្លាប់រស់នៅពីមុន
តែពេលនេះគ្មាននរណាម្នាក់រស់នៅទីនោះទេ។
Joshua 8:29
មកដល់សព្វថ្ងៃ
« ថ្ងៃនេះ » ឬ « សូម្បីតែឥឡូវនេះ »
Joshua 8:30
ភ្នំអេបាល
ភ្នំមួយនៅស្រុកកាណាន
Joshua 8:34
គ្មានពាក្យមួយមាត់ណាដែលចេញពីលោកម៉ូសេដែលលោកយ៉ូស្វេមិនបានអាននៅខាងមុខប្រជាជនអ៊ីស្រាអែល
អាចត្រូវបានបង្ហាញជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេអានគ្រប់ពាក្យទាំងអស់ដែលលោកម៉ូសេបានបញ្ជា » ឬ «
លោកយ៉ូស្វេអានច្បាប់ទាំងមូលរបស់លោកម៉ូសេ »
អ៊ីស្រាអែលនៅទីក្រុងអៃ។
នេះសំដៅទៅលើប្រជាជាតិអ៊ីស្រាអែល។

---

9 [1]ស្តេចទាំងអស់ដែលរស់នៅលើភ្នំខាងនាយទន្លេយ័រដាន់ និងស្តេចដែលរស់នៅវាលទំនាបតាមមាត់សមុទ្រហួតដល់ភ្នំល្បាណូន គឺជនជាតិហេត ជនជាតិអាម៉ូរី
ជនជាតិកាណាន ជនជាតិពេរីស៊ីត ជនជាតិហេវី និងជនជាតិយេប៊ូស[2]ស្តេចទាំងអស់នេះបានប្រមូលគ្នាដើម្បីប្រកាសសង្គ្រាមប្រឆាំងនឹងលោកយ៉ូស្វេ
ហើយនិងអ៊ីស្រាអែល។
[3]នៅពេលដែលអ្នកស្រុកគីបៀនបានឮពីអ្វីដែលលោកយ៉ូស្វេបានប្រព្រឹត្តចំពោះក្រុងយេរីខូ និងក្រុងអៃ[4]ពួកគេបានរៀបផែនការបោកប្រាស់។
ពួកគេបានទៅដូចជាអ្នកស្រុកឆ្ងាយ។ ពួកគេបានយកបាវចាស់ៗ ហើយដាក់លើខ្នងលារបស់ពួកគេ។ ពួកគេក៏បានយកថង់ស្រាចាស់ៗ រហែក ដែលបានដេរឡើងវិញ។
[5]ពួកគេបានពាក់ស្បែកជើងចាស់ៗ ហើយក៏ស្លៀកសំលៀកបំពាក់ចាស់ៗ សំលៀកបំពាក់រហែក។ នំប៉័ងសម្រាប់ជាអាហាររបស់ពួកគេស្ងួតហើយដុះផ្សិតដែរ។
[6]បន្ទាប់មក ពួកគេទៅជួបលោកយ៉ូស្វេនៅក្នុងជំរំត្រង់គីលកាល ហើយនិយាយនឹងលោក និងជនជាតិអ៊ីស្រាអែលដែលនៅជាមួយលោកទាំងអស់ថា៖
«យើងបានធ្វើដំណើរពីប្រទេសឆ្ងាយ ដូច្នេះ ចូរចងសម្ពន្ធមេត្រីជាមួយនឹងយើង»។[7]ជនជាតិអ៊ីស្រាអែលបាននិយាយទៅកាន់ជនជាតិហេវីថា៖
«ប្រហែលជាអ្នករស់នៅជិតយើង។ តើមានហេតុផលអ្វីដែលយើងត្រូវចងសម្ពន្ធមេត្រីជាមួយអ្នក»?[8]ពួកគេបាននិយាយជាមួយលោកយ៉ូស្វេថា៖
«យើងជាអ្នកបម្រើរបស់លោក»។ លោកយ៉ូស្វេបានមានប្រសាសន៍ទៅពួកគេថា៖ «អ្នកជាអ្នកណា? តើអ្នកមកពីណា»?
[9]ពួកគេបាននិយាយទៅលោកថា៖ «អ្នកបម្រើរបស់លោកបានមកទីនេះពីទឹកដីដ៏ឆ្ងាយ ដោយសារព្រះនាមរបស់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់លោក។
យើងបានឮពីព្រះអង្គ[10]និងពីអ្វីៗដែលព្រះអង្គបានធ្វើនៅស្រុកអេស៊ីប
ហើយបានឮពីអ្វីៗដែលព្រះអង្គបានធ្វើចំពោះស្តេចទាំងពីរបស់សាសន៍អាម៉ូរីនៅខាងនាយទន្លេយ័រដាន់ គឺចំពោះព្រះបាទស៊ីហុនជាស្តេចក្រុងហែសបូន
និងចំពោះព្រះបាទអុក ជាស្តេចស្រុកបាសាន ដែលគង់នៅក្រុងអាសថារ៉ូត។
[11]ពួកចាស់ទុំរបស់យើង និងប្រជាជនទាំងអស់នៅក្នុងប្រទេសរបស់យើងបាននិយាយនឹងយើងថា៖ «ចូរយកស្បៀងសម្រាប់ការធ្វើដំណើររបស់អ្នក។ ទៅជួបពួកគេ
និងនិយាយនឹងគេថា៖ «យើងជាអ្នកបម្រើរបស់លោក។ ចូរចងសម្ពន្ធមេត្រីនឹងយើង»។[12]នេះជានំប៉័ងរបស់យើង វានៅក្តៅនៅឡើយ ដ្បិត
យើងយកវាចេញពីផ្ទះរបស់យើងមកនៅថ្ងៃដែលយើងចេញដំណើរមកជួបលោក។ ប៉ុន្តែ ឥឡូវនេះមើលវាស្ងួត ហើយដុះផ្សិតផង។
[13]ថងស្បែកទាំងនេះនៅថ្មីនៅឡើយនៅពេលដែលយើងច្រកស្រា ចូរមើល ឥឡូវនេះវាបានលេចធ្លាយបាត់ទៅហើយ។ សំលៀកបំពាក់របស់យើង
និងស្បែកជើងរបស់យើងត្រូវបានរហែកដោយសារដំណើរដ៏វែងឆ្ងាយរបស់យើងដែរ»។
[14]ដូច្នេះ ប្រជាជនអ៊ីស្រាអែលបានយកស្បៀងរបស់ពួកគេខ្លះ ប៉ុន្តែ ពួកគេមិនបានទូលសុំការណែនាំពីព្រះអម្ចាស់ទេ។[15]លោកយ៉ូស្វេបានប្រកាសសន្តិភាព
និងចងសម្ពន្ធមេត្រីជាមួយពួកគេ ហើយទុកឲ្យពួកគេមានជីវិត។ ពួកអ្នកដឹកនាំក៏បានស្បថនឹងពួកគេដែរ។
[16]បីថ្ងៃក្រោយប្រជាជនអ៊ីស្រាអែលបានចងសម្ពន្ធមេត្រីនេះជាមួយអ្នកទាំងនោះ ទើបពួកគេបានដឹងថាអ្នកទាំងនោះជាអ្នកស្រុកដែលរស់នៅជិតពួកគេ។[17]បន្ទាប់មក
ប្រជាជនអ៊ីស្រាអែលក៏បញ្ជូនមនុស្សទៅទីក្រុងរបស់ពួកគេនៅថ្ងៃទីបី។ ទីក្រុងរបស់ពួកគេគឺគីបៀន កេភីរ៉ា បៀរ៉ូតនិងគារយ៉ាត យ៉ារីម។
[18]ប្រជានជនអ៊ីស្រាអែលមិនបានវាយប្រហារពួកគេទេដោយសារតែអ្នកដឹកនាំរបស់ពួកគេបានស្បថជាមួយអ្នកទាំងនោះនៅមុខព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ៊ីស្រាអែល។
ប្រជាជនអ៊ីស្រាអែលទាំងអស់បានរអ៊ូរទាំទាស់នឹងអ្នកដឹកនាំរបស់ពួកគេ។[19]ប៉ុន្តែ អ្នកដឹកនាំបាននិយាយទៅកាន់ប្រជាជនថា៖
«យើងបានស្បថជាមួយពួកគេដោយព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់អ៊ីស្រាអែល ហើយឥឡូវនេះ យើងមិនអាចប៉ះពាល់ពួកគេបានឡើយ។
[20]នេះជាអ្វីដែលយើងអាចប្រព្រឹត្តនឹងពួកគេ៖ ដើម្បីជៀសវាងកុំឲ្យមានកំហឹងធ្លាក់មកលើយើងដោយសារពាក្យដែលយើងបានស្បថនឹងពួកគេ ដូច្នេះ
យើងត្រូវតែទុកជីវិតឲ្យពួកគេ»។[21]ពួកអ្នកដឹកនាំបាននិយាយទៅកាន់ប្រជាជនថា៖ «ដូច្នេះ ពួកគីបៀនត្រូវធ្វើជាអ្នកកាប់អុស
និងរែកទឹកសម្រាប់ប្រជាជនអ៊ីស្រាអែលទាំងអស់ ដូចដែលអ្នកដឹកនាំបាននិយាយជាមួយពួកគេ។
[22]លោកយ៉ូស្វេបានហៅពួកគេមកនិយាយថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាបញ្ឆោតយើងនៅពេលដែលអ្នកនិយាយថា៖ «យើងរស់នៅឆ្ងាយពីអ្នករាល់គ្នាណាស់?[23]ដូច្នេះ
ដោយសាររឿងនេះ អ្នកត្រូវបណ្តាសារហើយ ហើយអ្នកខ្លះក្នុងចំណោមអ្នករាល់គ្នានឹងធ្វើជាទាសករ គឺអ្នកត្រូវកាប់អុស
និងរែកទឹកសម្រាប់ដំណាក់របស់ព្រះជាម្ចាស់របស់យើង។
[24]ពួកគេបានឆ្លើយនឹងលោកយ៉ូស្វេថា៖ «ដោយសារមានគេប្រាប់អ្នកបម្រើរបស់លោកថា
ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់លោកបានបង្គាប់អ្នកបម្រើរបស់ព្រះអង្គគឺលោកម៉ូសេដើម្បីឲ្យទឹកដីទាំងមូលនេះដល់លោក
និងបំផ្លាញជាតិសាសន៍ទាំងអស់នៅលើទឹកដីនេះនៅមុខលោក ដូច្នេះ យើងខ្លាចជាខ្លាំងដោយសារតែលោក។ ដូច្នេះហើយបានជាយើងធ្វើបែបនេះ។[25]ឥឡូវនេះ
យើងនៅក្រោមអំណាចរបស់លោកស្រាប់។ អ្វីដែលលោកគិតថាល្អ ហើយត្រឹមត្រូវ ចូរធ្វើចំពោះពួកយើងចុះ»។

generated on Wed Sep 10 16:16:32 2025

[26]ដូច្នេះ លោកយ៉ូស្វេក៏បានប្រព្រឹត្តបែបនេះចំពោះពួកគេ៖ លោកដោះលែងគេចេញពីការគ្រប់គ្រងរបស់ប្រជាជនអ៊ីស្រាអែល
ហើយប្រជាជនអ៊ីស្រាអែលមិនសម្លាប់ពួកគេទេ។[27]នៅថ្ងៃនោះលោកយ៉ូស្វេបានឲ្យពួកគីបៀនធ្វើជាអ្នកកាប់អុស និងជាអ្នកដងទឹកសម្រាប់សហគមន៍
និងសម្រាប់អាសនារបស់ព្រះអម្ចាស់រហូតដល់សព្វថ្ងៃនេះ នៅកន្លែងដែលព្រះអម្ចាស់បានជ្រើសរើស។

Joshua 9:1
ទន្លេយ័រដាន់
ឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់
បានប្រមូលគ្នា
នៅទីនេះ « ពាក្យបញ្ជា » តំណាងឲ្យអ្នកដែលបានបញ្ជាពួកគេ។ ការនៅក្រោមគាត់
តំណាងឲ្យការគោរពតាមបទបញ្ជារបស់គាត់។ ការបកប្រែផ្សេងទៀត «
គោរពតាមបទបញ្ជារបស់មេដឹកនាំម្នាក់»
Joshua 9:3
ផែនការបោកប្រាស់
ឧបាយកលមានល្បិចកលដើម្បីបញ្ឆោតលោកយ៉ូស្វេ និងជនជាតិអ៊ីស្រាអែល
ស្ងួតហើយដុះផ្សិត
« ស្ងួតនិងពោរពេញទៅដោយផ្សិត » ឬ « ចាស់និងខូច»
Joshua 9:6
ជនជាតិអ៊ីស្រាអែល
នេះសំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។
ជនជាតិហេវី
នេះគឺជាឈ្មោះមួយទៀតសម្រាប់ជនជាតិគីបៀន។
ប្រហែលជាអ្នករស់នៅជិតយើង។ តើមានហេតុផលអ្វីដែលយើងត្រូវចងសម្ពន្ធមេត្រីជាមួយអ្នក»?
លោកយ៉ូស្វេកំពុងសង្កត់ធ្ងន់ថាប្រជាជនអ៊ីស្រាអែលត្រូវតែធ្វើតាមបទបញ្ជារបស់ព្រះអម្ចាស់ទាំងអស់។
ការបកប្រែផ្សេងទៀត « ប្រសិនបើអ្នករស់នៅក្បែរយើង
យើងមិនអាចធ្វើការតាំងសញ្ញាជាមួយអ្នកបានទេ »
Joshua 9:9
ទន្លេយ័រដាន់
នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។
ព្រះបាទស៊ីហុន
នេះជាព្រះនាមស្តេចអាម៉ូរីដែលបរាជ័យ។
ស្តេចក្រុងហែសបូន
នេះគឺជាឈ្មោះនៃរាជវង្ស របស់ប្រជាជាតិម៉ូអាប់។
ព្រះបាទអុក
នេះគឺជាព្រះនាមស្តេចដែលបរាជ័យនៅស្រុកបាសាន។
ក្រុងអាសថារ៉ុត។
នេះជាឈ្មោះទីក្រុងមួយដែលត្រូវបានគេស្គាល់ថាថ្វាយបង្គំអាទិទេពដែលមានឈ្មោះថាអាសថារ៉ុត។
Joshua 9:11
សម្រាប់ការធ្វើដំណើររបស់អ្នក
ឃ្លានេះមានន័យថា»យកទៅជាមួយអ្នក»។
ត្រង់នេះពាក្យថា«ដៃ»តំណាងឲ្យការកាន់កាប់តាមរយៈការផ្គត់ផ្គង់របស់ជនជាតិគីបៀន
ទៅជួយពួកគេ និងនិយាយនឹងគេថា
ពាក្យថា« ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
Joshua 9:14
លោកយ៉ូស្វេបានប្រកាសសន្តិភាព និងចងសម្ពន្ធមេត្រីជាមួយពួកគេ ហើយទុកឲ្យពួកគេមានជីវិត ។
ពួកអ្នកដឹកនាំក៏បានស្បថនឹងពួកគេដែរ ។
ប្រយោគទាំងពីរនេះកំពុងនិយាយថារឿងបានកើតឡើងដដែលនេះ ។
លោកយ៉ូស្វេជាមេដឹកនាំនៃប្រជាជាតិអ៊ីស្រាអែលបានសន្យាថា
នឹងមិនសម្លាប់ជនជាតិគីបៀនឡើយ។
អ្នកដឹកនាំអ៊ីស្រាអែលក៏ធ្វើកិច្ចព្រមព្រៀងដូចគ្នាដែរ ។
ពួកអ្នកដឹកនាំ
នៅទីនេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
Joshua 9:16
ថ្ងៃទីបី
នេះសំដៅទៅលើលេខបីតាមលំដាប់លំដោយ ។
កេភីរ៉ា
នេះគឺជាទីក្រុងមួយក្នុងចំណោមក្រុងរបស់គីបៀន ។
ប៊ៀរ៉ូត
នេះគឺជាឈ្មោះកន្លែងមួយ ។
គារយ៉ាត យ៉ារីម
នេះគឺជាឈ្មោះកន្លែងមួយ ។
Joshua 9:18
ប្រជានជន
ត្រង់នេះឃ្លានេះសំដៅទៅលើប្រជាជាតិអ៊ីស្រាអែល។
Joshua 9:20
ពួកគីបៀនត្រូវធ្វើជាអ្នកកាប់អុស និងរែកទឹកសម្រាប់ប្រជាជនអ៊ីស្រាអែលទាំងអស់
«គីបៀនបានក្លាយជាជាងឈើ និងជញ្ជូនទឹក»
Joshua 9:22
ដំណាក់របស់ព្រះជាម្ចាស់របស់យើង។
ឃ្លានេះសំដៅទៅលើការរស់នៅកន្លែងព្រះអម្ចាស់ គឺរោងឧបោសថ ។
Joshua 9:24
អ្វីដែលលោកគិតថាល្អ ហើយត្រឹមត្រូវ
ពាក្យថា « ល្អ » និង « ត្រឹមត្រូវ »មានន័យថាជារួមដូចគ្នា។ ការបកប្រែផ្សេងទៀត
« អ្វីក៏ដោយដែលហាក់ដូចជាត្រឹមត្រូវនិងយុត្តិធម៌ »
Joshua 9:26
ចំពោះពួកគេ
ពាក្យថា « ពួកគេ » នៅទីនេះសំដៅទៅលើពួកគីបៀន ។
ដល់សព្វថ្ងៃនេះ
ឃ្លា « ថ្ងៃនេះ » តំណាងឱ្យពេលវេលាដែលអ្នកនិពន្ធកំពុងរស់នៅ។
ការបកប្រែផ្សេងទៀត « សូម្បីតែឥឡូវនេះ »

---

10 [1]នៅពេលដែលព្រះបាទអាដូនីសេដេក ស្តេចក្រុងយេរូសាឡិម បានឮថាលោកយ៉ូស្វេបានវាយយកក្រុងអៃ ហើយបានកម្ទេចទីក្រុងទាំងស្រុង
(ដូចដែលអ្វីដែលលោកបានប្រព្រឹត្តចំពោះក្រុងយេរីខូ និងស្តេចក្រុងនោះ) ស្តេចក៏បានឮពីរបៀបដែលប្រជាជនគីបៀនបានចងសន្តិភាពជាមួយអ៊ីស្រាអែល
ហើយរស់នៅក្នុងចំណោមពួកគេ។[2]ប្រជាជនក្រុងយេរូសាឡិមភ័យខ្លាចជាខ្លាំងដោយសារតែគីបៀនជាក្រុងមួយដ៏ធំ ដូចជារាជធានីមួយ។ ក្រុងនោះធំជាងក្រុងអៃ
ហើយប្រុសៗនៅក្រុងនោះក៏ជាមនុស្សអង់អាចក្លាហានដែរ។
[3]ដូច្នេះ ព្រះបាទអដូនីសេដេកជាស្តេចក្រុងយេរូសាឡិម បានផ្ញើសាទៅព្រះបាទហូហាំជាស្តេចក្រុងហេប្រុន ទៅព្រះបាទពារ៉ាមស្តេចក្រុងយ៉ាមុត
ទៅព្រះបាទយ៉ាភាស្តេចក្រុងឡាគីស ព្រះបាទដេបៀរស្តេចក្រុងអេក្លូនថា៖[4]«ចូរឡើងមកជួបខ្ញុំ និងជួយខ្ញុំផង។ ចូរយើងវាយក្រុងគីបៀន
ព្រោះពួកគេបានចងសន្តិភាពជាមួយលោកយ៉ូស្វេ និងជាមួយជនជាតិអ៊ីស្រាអែលហើយ»។
[5]ស្តេចទាំងប្រាំរបស់សាសន៍អាម៉ូរី គឺស្តេចក្រុងយេរូសាឡិម ស្តេចក្រុងហេប្រុន ស្តេចក្រុងយ៉ាមុត ស្តេចក្រុងឡាគីស និងស្តេចក្រុងអេក្លូន ទាំងស្តេចទាំង
និងទាំងពលទាហានរបស់ពួកគេ។ ពួកគេរៀបគ្នាប្រឆាំងជាមួយក្រុងគីបៀន ហើយពួកគេវាយក្រុងនោះ។
[6]អ្នកក្រុងគីបៀនបានផ្ញើសារទៅលោកយ៉ូស្វេ និងទៅពួកទាហាននៅគីលកាល។ ពួកគេនិយាយថា៖ «សូមប្រញាប់ឡើងមក!
កុំឲ្យដកដៃរបស់អ្នកពីអ្នកបម្រើរបស់អ្នកឡើយ។ សូមមកជួយយើងជាប្រញាប់។ សូមជួយយើងផង
ដោយសារស្តេចទាំងឡាយនៃសាសន៍អាម៉ូរីដែលរស់នៅលើភ្នំបានប្រមូលគ្នាវាយប្រហារយើងហើយ»។[7]លោកយ៉ូស្វេបានឡើងពីគីលកាល លោក
និងពួកទាហានរបស់លោកមកជាមួយលោក និងអ្នកដែលប្រយុទ្ធផងដែរ។
[8]ព្រះអម្ចាស់មានបន្ទូលមកកាន់លោកយ៉ូស្វេថា៖ «កុំខ្លាចពួកគេឡើយ។ យើងបានប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នកហើយ។
ក្នុងចំណោមពួកគេគ្មាននរណាម្នាក់អាចបញ្ឈប់ការវាយប្រហាររបស់អ្នកបានឡើយ។

generated on Wed Sep 10 16:16:32 2025

[9]លោកយ៉ូស្វេបានឡើងមកជួយពួកគេយ៉ាងប្រញាប់ អស់រយៈពេលពេញមួយយប់ពីគីលកាល។[10]ព្រះអម្ចាស់បានធ្វើឲ្យសត្រូវភ័ណ្ឌច្រឡំចំពោះជនជាតិអ៊ីស្រាអែល
ហើយជនជាតិអ៊ីស្រាអែលបានសម្លាប់ពួកគេយ៉ាងរង្គាលនៅក្រុងគីបៀន ហើយដេញតាមពួកគេរហូតដល់ផ្លូវទៅបេត ហូរ៉ុន
ហើយពួកគេបានសម្លាប់អ្នកទាំងនោះនៅលើផ្លូវទៅអាសេកា និងម៉ាកេដា។
[11]នៅពេលដែលគេរត់គេចពីជនជាតិអ៊ីស្រាអែល ចុះភ្នំពីបេតហេរ៉ុន ព្រះអម្ចាស់បានទម្លាក់ថ្មមួយយ៉ាងធំពីលើមេឃមកលើពួកគេតាមផ្លូវទៅអាសេកា
ហើយពួកគេស្លាប់នៅទីនោះ។ មានមនុស្សស្លាប់ដោយសារថ្មច្រើនជាងអ្នកដែលត្រូវបានស្លាប់ដោយសារដាវរបស់ជនជាតិអ៊ីស្រាអែលទៅទៀត។
[12]បន្ទាប់មក លោកយ៉ូស្វេបានទូលទៅព្រះអម្ចាស់នៅថ្ងៃដែលព្រះអម្ចាស់បានផ្តល់ជ័យជម្នះដល់ជនជាតិអ៊ីស្រាអែលលើសាសន៍អាម៉ូរី។
នេះជាអ្វីដែលលោកយ៉ូស្វេបានទូលទៅព្រះអម្ចាស់នៅមុខជនជាតិអ៊ីស្រាអែល៖ «ព្រះអាទិត្យ ចូរនៅស្ងៀមនៅត្រង់គីបៀន ហើយព្រះច័ន្ទចូរនៅច្រលងអាយាឡូនចុះ។
[13]ព្រះអាទិត្យក៏នៅស្ងៀម ហើយព្រះច័ន្ទក៏ឈប់ដើររហូតដល់ពួកគេបានសងសឹកនឹងខ្មាំងសត្រូវរបស់ពួកគេចប់។
តើការនេះមិនបានកត់ទុកនៅក្នុងសៀវភៅរបស់យ៉ាស៊ើរទេឬអី? ព្រះអាទិត្យឈរទ្រឹងនៅចំកណ្តាលមេឃ វាមិនបានដើរអស់រយៈពេលប្រហែលមួយថ្ងៃ។
[14]មិនដែលមានថ្ងៃណាដូចថ្ងៃនេះពីមុន ឬទៅក្រោយទៀតឡើយ គឺនៅពេលដែលព្រះអម្ចាស់ស្តាប់ពាក្យរបស់មនុស្ស។
ដ្បិតព្រះអម្ចាស់បានច្បាំងជំនួសសាសន៍អ៊ីស្រាអែល។
[15]លោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលទាំងអស់ដែលនៅជាមួយលោកត្រឡប់ទៅជំរំនៅគីលកាលវិញ។[16]ហើយស្តេចទាំងប្រាំអង្គបានរត់គេច
និងលាក់ខ្លួននៅក្នុងរូងភ្នំមួយនៅឯម៉ាកេដា។[17]គេបានប្រាប់លោកយ៉ូស្វេថា៖ «ពួកគេរកស្តេចទាំងនោះឃើញហើយ!
ស្តេចទាំងប្រាំអង្គបានលាក់ខ្លួននៅក្នុងរូងភ្នំមួយនៅឯម៉ាកេដា!»។
[18]លោកយ៉ូស្វេនិយាយថា៖ «ចូរប្រមៀលថ្មធំមួយដើម្បីបិតមាត់រូងភ្នំ ហើយដាក់ទាហាននៅទីនោះដើម្បីយាមពួកគេ។[19]កុំឲ្យឈប់ឡើយ។ ត្រូវដេញតាមខ្មាំងសត្រូវរបស់អ្នក
និងវាយប្រហារពួកគេ។ កុំអនុញ្ញាតឲ្យពួកគេចូលទៅក្នុងទីក្រុងរបស់ពួកគេឡើយ ដោយសារព្រះអម្ចាស់បានប្រគល់ពួកគេមកក្នុងកណ្តាប់ដៃរបស់អ្នករាល់គ្នាហើយ»។
[20]លោកយ៉ូស្វេ និងកូនចៅអ៊ីស្រាអែលបានបញ្ចប់ជីវិតអ្នកទាំងនេះដោយការសម្លាប់រង្គាល រហូតដល់ពួកគេស្ទើរតែទាំងអស់បានស្លាប់
មានតែមនុស្សពីរបីនាក់ប៉ុណ្ណោះដែលរួចជីវិតគេចខ្លួនទៅក្រុងទាំងឡាយដែលមានកំពែង។[21]បន្ទាប់មក
ពួកទាហានទាំងអស់បានត្រឡប់ទៅវិញដោយសុខសាន្តទៅជួបលោកយ៉ូស្វេនៅម៉ាកេដា។
គ្មាននរណាម្នាក់ហ៊ាននិយាយពាក្យអ្វីមួយម៉ាត់ប្រឆាំងនឹងប្រជាជនអ៊ីស្រាអែលឡើយ។
[22]បន្ទាប់មក លោកយ៉ូស្វេបាននិយាយថា៖ «ចូរបើកម៉ាត់រូងភ្នំ ហើយចូរនាំស្តេចទាំងប្រាំមកជួបខ្ញុំ»។ ពួកគេបានធ្វើតាមអ្វីដែលលោកបាននិយាយ។
[23]ពួកគេបាននាំស្តេចទាំងប្រាំអង្គមកពីក្នុងរូងភ្នំមកជួបលោក មានស្តេចក្រុងយេរូសាឡិម ស្តេចក្រុងហេប្រូន ស្តេចក្រុងយ៉ាមុត ស្តេចក្រុងឡាគីស និងស្តេចក្រុងអេក្លូន។
[24]នៅពេលដែលពួកគេបាននាំពួកស្តេចទាំងអស់មកជួបលោកយ៉ូស្វេ គាត់ក៏បានប្រជុំប្រជាជនអ៊ីស្រាអែលទាំងអស់។
លោកនិយាយទៅកាន់មេដឹកនាំរបស់ពួកទាហានដែលបានប្រយុទ្ធក្នុងសមរភូមិជាមួយលោកថា៖ «ចូរដាក់ជើងរបស់អ្នករាល់គ្នានៅលើករបស់ពួកគេទៅ»។
«ដូច្នេះពួកគេបានឡើងមក ហើយដាក់ជើងរបស់ពួកគេលើករបស់ស្តេចទាំងនោះ»។[25]បន្ទាប់មក លោកបាននិយាយជាមួយពួកគេថា៖ «កុំភ័យខ្លាច
និងកុំឲ្យស្រយុតចិត្តឡើយ។ ចូរមានកម្លាំង និងចិត្តក្លាហានចុះ។
នេះជាអ្វីដែលព្រះអម្ចាស់នឹងធ្វើជាមួយសត្រូវទាំងអស់របស់អ្នករាល់គ្នាដែលអ្នករាល់គ្នាត្រូវប្រយុទ្ធជាមួយពួកគេ។
[26]បន្ទាប់មក លោកយ៉ូស្វេបានវាយប្រហារ និងសម្លាប់ស្តេចទាំងនោះទៅ។ លោកបានព្យួរពួកគេនៅលើដើមឈើរហូតដល់ពេលល្ងាច។[27]នៅពេលថ្ងៃលិច
លោកយ៉ូស្វេបានបញ្ជាឲ្យគេដាក់ស្តេចទាំងនោះចុះពីដើមឈើ ហើយបោះពួកគេទៅក្នុងផ្នូរដែលពួកគេបានលាក់ខ្លួន។ ពួកគេបានដាក់ដុំថ្មមួយយ៉ាងធំនៅមាត់ផ្នូរ។
ថ្មទាំងនោះមានរហូតដល់សព្វថ្ងៃ។
[28]នៅថ្ងៃនោះលោកយ៉ូស្វេបានវាយយកម៉ាកាដាដោយរបៀបនេះឯង ហើយបានសម្លាប់អ្នកទាំងអស់នោះដោយដាវ ទាំងស្តេចរបស់អ្នកទាំងនោះផង។
លោកបានកម្ទេចពួកគេទាំងស្រុង និងកម្ទេចអ្វីៗដែលមានជីវិតនៅទីនោះដែរ។
លោកបានប្រព្រឹត្តចំពោះស្តេចស្រុកម៉ាកាដាដូចដែលលោកបានប្រព្រឹត្តចំពោះស្តេចក្រុងយេរីខូដែរ។
[29]លោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលទាំងអស់បានឆ្លងកាត់ពីម៉ាកាដាទៅលិបណា។[30]ព្រះអម្ចាស់ក៏បានប្រទានក្រុងនោះ
និងស្តេចរបស់ក្រុងនោះដល់ដៃជនជាតិអ៊ីស្រាអែលដែរ។ លោកយ៉ូស្វេបានវាយប្រហារគ្រប់ទាំងជីវិតទាំងអស់ដែលរស់នៅក្នុងក្រុងនោះជាមួយនឹងដាវរបស់លោក។
លោកមិនបានអនុញ្ញាតឲ្យនរណាម្នាក់មានជីវិតឡើយ។ លោកបានប្រព្រឹត្តចំពោះស្តេចក្រុងនោះ ដូចជាស្តេចក្រុងយេរីខូដែរ។
[31]បន្ទាប់មក លោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលទាំងអស់បានឆ្លងកាត់ពីលីបណាទៅឡាគីស។ លោកបានបោះជំរំនៅទីនោះហើយប្រកាសសង្គ្រាមជាមួយក្រុងនោះ។
[32]ព្រះអម្ចាស់បានប្រគល់ក្រុងឡាគីសមកក្នុងដៃរបស់ជនជាតិអ៊ីស្រាអែល។ លោកយ៉ូស្វេបានវាយក្រុងនោះបាននៅថ្ងៃទីពីរ។
លោកបានវាយប្រហារដោយដាវលើគ្រប់ទាំងជីវិតទាំងអស់ដែលនៅក្នុងក្រុង ដូចដែលលោកបានធ្វើចំពោះក្រុងលីបណាដែរ។
[33]បន្ទាប់មក ព្រះបាទហោរ៉ាម ស្តេចស្រុកកេស៊ើរឡើងមកជួយក្រុងឡាគីស។ លោកយ៉ូស្វេវាយប្រហារស្តេច
និងពួកទាហានដែលនៅជាមួយរហូតដល់គ្មាននរណាម្នាក់នៅរស់ឡើយ។
[34]បន្ទាប់មក លោកយ៉ូស្វេ និងជនជាតិអ៊ីស្រាអែលទាំងអស់ដែលនៅជាមួយលោកឆ្លងកាត់ពីឡាគីសទៅអេក្លូន។ ពួកគេបោះជំរំនៅក្បែរនោះ
និងប្រកាសសង្គ្រាមជាមួយក្រុងនោះ[35]ហើយវាយយកក្រុងនោះបាននៅថ្ងៃនោះឯង។ ពួកគេបានកម្ទេចអ្នកក្រុងនោះដោយដាវ
ហើយពួកគេបានកម្ទេចអ្វីៗទាំងអស់នៅក្នុងក្រុងនោះ ដូចដែលលោកបានធ្វើចំពោះក្រុងឡាគីសដែរ។
[36]បន្ទាប់មក លោកយ៉ូស្វេ និងជនជាតិអ៊ីស្រាអែលទាំងអស់ចេញពីអេក្លូនទៅហេប្រុន។[37]ពួកគេបានប្រកាសសង្គ្រាមប្រឆាំងក្រុងនោះ។ ពួកគេវាយក្រុងនោះបាន
ហើយកម្ទេចក្រុងនោះ និងអ្នកនៅក្រុងនោះដោយដាវ រួមទាំងស្តេច និងភូមិដែលនៅជុំវិញ គ្មាននរណាម្នាក់នៅរស់ឡើយ
ដូចដែលលោកយ៉ូស្វេបានប្រព្រឹត្តចំពោះអេក្លូនដែរ។ លោកបានកម្ទេចក្រុងនោះ និងជីវិតដែលមាននៅក្នុងក្រុងនោះទាំងស្រុង។
[38]បន្ទាប់មក លោកយ៉ូស្វេត្រឡប់ក្រោយ ជាមួយពួកទាហានទាំងអស់ដែលទៅជាមួយលោក ហើយពួកគេឆ្លងទៅដេបៀរ ហើយប្រកាសសង្គ្រាមជាមួយក្រុងនោះ។
[39]លោកវាយបានក្រុងនោះ ហើយសម្លាប់ស្តេច ព្រមទាំងកម្ទេចភូមិដែលនៅជិតៗនោះ។ ពួកគេបានកម្ទេចអ្នកក្រុងនោះដោយដាវ
និងបំផ្លាញអ្នកទាំងនោះទាំងស្រុងគ្រប់ទាំងជីវិតដែលនៅក្នុងក្រុងនោះដែរ។ លោកយ៉ូស្វេមិនទុកឲ្យនរណាមានជីវិតឡើយ ដូចដែលលោកបានធ្វើចំពោះហេប្រូន
និងដូចដែលលោកបានធ្វើចំពោះក្រុងលីបណា និងស្តេចក្រុងនោះដែរ។
[40]លោកយ៉ូស្វេកាន់កាប់ទឹកដីទាំងអស់ ទាំងតំបន់ភ្នំនេកេវ តំបន់ទំនាប និងជើងភ្នំ។ លោកមិនទុកឲ្យស្តេចណាមួយរបស់ពួកគេនៅមានជីវិតឡើយ។
លោកបានកម្ទេចគ្រប់ទាំងជីវិត ដូចដែលព្រះអម្ចាស់ជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលបានបង្គាប់។[41]លោកយ៉ូស្វេបានកម្ទេចពួកគេដោយដាវចាប់ពីកាដេសបានា
ដល់កាសា និងចាប់ពីតំបន់កូសែន ដល់គីបៀន។
[42]លោកយ៉ូស្វេបានវាយប្រហារស្តេចទាំងអស់ និងដណ្តើមយកទឹកដីរបស់ពួកគេក្នុងពេលតែមួយដោយសារព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលប្រយុទ្ធជំនួសពួកគេ។
[43]បន្ទាប់មក លោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលទាំងអស់ដែលនៅជាមួយលោកត្រឡប់ទៅជំរំនៅគីលកាលវិញ។

generated on Wed Sep 10 16:16:32 2025

Joshua 10:1
នៅ
ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការឈប់នៅក្នុងសាច់រឿងសំខាន់។ នៅទីនេះអ្នកនិពន្ធប្រាប់អំពីមនុស្សថ្មីនៅក្នុងរឿងព្រះបាទអាដូនីសេដេក។
ព្រះបាទអាដូនីសេដេក
នេះគឺជាឈ្មោះបុរសម្នាក់ដែលជាស្តេចដ៏សំខាន។
Joshua 10:3
ក្រុងយ៉ាមុត ... ក្រុងឡាគីស ... ក្រុងអេក្លូន
ទាំងនេះគឺជាឈ្មោះនៃទីក្រុង។
ព្រះបាទហូហាំ ... ព្រះបាទពារ៉ាម... ព្រះបាទយ៉ាភា... ព្រះបាទដេបៀ
ទាំងនេះគឺជាឈ្មោះស្តេច។
ចូរឡើងមកជួបខ្ញុំ
« ធ្វើដំណើរទៅកន្លែងដែលខ្ញុំនៅ » ។
ក្រុងយេរូសាឡឹមមានកំពស់ខ្ពស់ជាងទីក្រុងឯទៀតនៅស្រុកកាណាន ។
Joshua 10:5
ស្តេចទាំងប្រាំ
« ៥ស្តេច »
ក្រុងយ៉ាមុត ... ក្រុងឡាគីស ... ក្រុងអេក្លូន
ទាំងនេះគឺជាឈ្មោះនៃទីក្រុង។
ពួកគេរៀបគ្នាប្រឆាំងជាមួយក្រុងគីបៀន
នេះមានន័យថា ពួកគេបានបោះជំរំជុំវិញទីក្រុងរបស់ពួកគេ។ នេះជាវិធីធ្វើឲ្យអ្នកនៅទីក្រុងចុះខ្សោយ។ វាការពារប្រជាជនពីការរត់គេចពីទីក្រុង ហើយវាការពារអ្នកដទៃពីការនាំយកអាហារ និងទឹកមកឲ្យពួកគេនៅក្នុងទីក្រុង។
Joshua 10:6
ពួកគេនិយាយថា
ពាក្យថា « ពួកគេ » នៅទីនេះសំដៅលើពួកគីបៀន ។
កុំឲ្យដកដៃរបស់អ្នកពីអ្នកបម្រើរបស់អ្នកឡើយ។
នេះគឺជាសំណូមដោយបន្ទាបខ្លួនពរត្រូវបានថ្លែងដោយភាពអវិជ្ជមានពីរ ដើម្បីបញ្ជាក់ពីភាពចាំបាច់នៃសកម្មភាពវិជ្ជមាន។ ការបកប្រែផ្សេងទៀត « សូមមកហើយប្រើកម្លាំងរបស់អ្នកដើម្បីការពារពួកយើង » ។
ដៃរបស់អ្នក
ពាក្យថា « ដៃ» នៅទីនេះសំដៅទៅលើកម្លាំងរបស់ប្រជាជនអ៊ីស្រាអែល ។ ការបកប្រែផ្សេងទៀត « កម្លាំងរបស់អ្នក »
Joshua 10:8
យើងបានប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នកហើយ
នៅទីនេះ « ដៃ» តំណាងអោយប្រជាជនអ៊ីស្រាអែលនិងកម្លាំងរបស់ពួកគេ ដើម្បីកម្ចាត់សត្រូវរបស់ពួកគេ។ ពាក្យថា « ពួកគេ»
សំដៅទៅលើកងទ័ពដែលកំពុងវាយប្រហារ ។
យើងបានប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នកហើយ
នៅទីនេះពាក្យ « ពួកគេ » សំដៅទៅលើកងទ័ពដែលកំពុងវាយប្រហារ ។
Joshua 10:9
លោកយ៉ូស្វេបានឡើងមក
កងទ័ពអ៊ីស្រាអែលទាំងមូលត្រូវបានគេហៅ
នៅទីនេះតាមរយៈឈ្មោះរបស់មេបញ្ជាការរបស់ពួកគេគឺលោកយ៉ូស្វេ។
ព្រះអម្ចាស់បានធ្វើឲ្យសត្រូវភ័ណ្ឌច្រឡំចំពោះជនជាតិអ៊ីស្រាអែល
ត្រង់នេះ « អ៊ីស្រាអែល » សំដៅទៅលើកងទ័ពអ៊ីស្រាអែលទាំងមូល។
បេត ហូរ៉ុន ..អាសេកា ...ម៉ាកេដា
ទាំងនេះគឺជាឈ្មោះនៃទីក្រុង។
Joshua 10:11
បេត ហូរ៉ុន ..អាសេកា
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
បានទម្លាក់ថ្មមួយយ៉ាងធំពីលើមេឃ
« បានបោះដុំព្រិលធំ ៗ ពីលើមេឃ »
Joshua 10:12
ព្រះអាទិត្យ ចូរនៅស្ងៀមនៅត្រង់គីបៀន ហើយព្រះច័ន្ទចូរនៅច្រលងអាយាឡូនចុះ។
លោកយ៉ូស្វេកំពុងអធិស្ឋានថាព្រះអម្ចាស់
នឹងដំណើរការនៅថ្ងៃនៃពេលវេលាឈប់នៅថ្ងៃនេះ។
ព្រះអាទិត្យ ...ព្រះច័ន្ទ
លោកយ៉ូស្វេបញ្ជាព្រះអាទិត្យ និងព្រះច័ន្ទ ដូចជាទាំងពីរនេះគឺជាមនុស្ស។
ច្រលងអាយ៉ាឡូន
នេះគឺជាឈ្មោះកន្លែងមួយ។ (សូមមើល ការបកtranslate-names)
Joshua 10:13
ពួកគេ
នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
តើការនេះមិនបានកត់ទុកនៅក្នុងសៀវភៅរបស់យ៉ាស៊ើទេឬអី?
អ្នកនិពន្ធប្រើសំណួរនេះជាពត៌មានសង្ខេប ដើម្បីរំលឹកអ្នកអាន ឧបទ្ទវហេតុនេះត្រូវបានគេចងក្រងជាឯកសារយ៉ាងល្អ។ ការបកប្រែផ្សេងទៀត « នេះត្រូវបានសរសេរនៅក្នុងសៀវភៅយ៉ាស៊ើ »។
Joshua 10:15
ម៉ាកេដា
នេះគឺជាឈ្មោះនៃទីក្រុងមួយ។
គេបានប្រាប់លោកយ៉ូស្វេថា
អ្នកនាំសារបានមកនិងទៅប្រាប់លោកយ៉ូស្វេ។ ការបកប្រែផ្សេងទៀត «មានគេប្រាប់យ៉ូស្វេ»
Joshua 10:18
ក្នុងកណ្តាប់ដៃរបស់អ្នករាល់គ្នាហើយ
ឃ្លា « ដៃរបស់អ្នក » នៅទីនេះមានន័យថា « ការគ្រប់គ្រងរបស់អ្នក » ។
Joshua 10:20
ម៉ាកេដា
បកប្រែដូចនៅក្នុងជំពូក១០:៩។
គ្មាននរណាម្នាក់ហ៊ាននិយាយពាក្យអ្វីមួយម៉ាត់ប្រឆាំង
នៅទីនេះ « មួយពាក្យ » សំដៅលើការនិយាយរបស់ខ្មាំងសត្រូវអំពីអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត « គ្មាននរណាម្នាក់ហ៊ានតួញតែ្ពរ ឬតវ៉ាប្រឆាំង »
Joshua 10:22
Open the mouth of the cave
នៅទីនេះ « មាត់ » មានន័យបង្ហាញថា « ច្រកចូល» ការបកប្រែផ្សេងទៀត « បើកច្រកចូលរូងភ្នំ »
ក្រុងយ៉ាមុត ... ក្រុងឡាគីស ... ក្រុងអេក្លូន
ទាំងនេះគឺជាឈ្មោះនៃទីក្រុង។
Joshua 10:24
អ៊ីស្រាអែលទាំងអស់
ទាហានអ៊ីស្រាអែលទាំងអស់
Joshua 10:26
រហូតដល់សព្វថ្ងៃ
« រហូតដល់អ្នកនិពន្ធសរសេររឿងនេះ »
Joshua 10:28
ម៉ាកាដា
នេះគឺជាឈ្មោះនៃទីក្រុងមួយ។ សូមមើលនៅក្នុង ១០: ៩។
លោកបានកម្ទេចពួកគេទាំងស្រុង និងកម្ទេចអ្វីៗដែលមានជីវិតនៅទីនោះដែរ
ប្រយោគទី ២ សង្ខេបប្រយោគទីមួយ
ដើម្បីបញ្ជាក់ថាលោកយ៉ូស្វេមិនបានទុកមនុស្សនិងសត្វអោយនៅរស់ទេ។
Joshua 10:29
លិបណា
នេះគឺជាឈ្មោះនៃទីក្រុងមួយ។
បានប្រទានក្រុងនោះដល់ដៃជនជាតិអ៊ីស្រាអែល
នៅទីនេះ « ដៃ » មានន័យថា « ការគ្រប់គ្រង » ។ ការបកប្រែផ្សេងទៀត « បានប្រគល់ការគ្រប់គ្រងវាទៅអ៊ីស្រាអែល»
Joshua 10:31
ពីលីបណា ... ឡាគីស
ទាំងនេះគឺជាឈ្មោះនៃទីក្រុង.
មកក្នុងដៃរបស់ជនជាតិអ៊ីស្រាអែល
ឃ្លានេះមានន័យថា « ផ្តល់អំណាចដល់ប្រជាជាតិអ៊ីស្រាអែល » ។ ការបកប្រែផ្សេងទៀត « ព្រះអម្ចាស់បានប្រគល់ក្រុងឡាគីស ទៅក្នុងការគ្រប់គ្រងរបស់ប្រជាជាតិអ៊ីស្រាអែល »
Joshua 10:33
ព្រះបាទហោរ៉ាម
នេះគឺជាឈ្មោះបុរសម្នាក់ ដែលជាស្តេច ដ៏សំខាន់។
ស្រុកកេស៊ើរ ... ក្រុងឡាគីស

generated on Wed Sep 10 16:16:32 2025

ទាំងនេះគឺជាឈ្មោះនៃទីក្រុង។
Joshua 10:34
ឡាគីស ... អេក្លូន
ទាំងនេះគឺជាឈ្មោះនៃទីក្រុង។
កម្ទេចអ្នកក្រុងនោះដោយដាវ ...បានកម្ទេចអ្វីៗទាំងអស់នៅក្នុងក្រុង
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ពួកគេរួមគ្នាបង្ហាញការបំផ្លាញទាំងស្រុងនៃក្រុងអេក្លូន។
Joshua 10:36
អេក្លូន
នេះគឺជាឈ្មោះនៃទីក្រុងមួយ។ សូមមើលនៅក្នុង ១០:៣ ។
ពួកគេវាយក្រុងនោះបាន ហើយកម្ទេចក្រុងនោះ និងអ្នកនៅក្រុងនោះដោយដាវ
ដាវតំណាងឲ្យយកងទ័ពអ៊ីស្រាអែល ហើយធ្វើកូដកម្មបង្ហាញពីគំនិតនៃការសម្លាប់
និងការបំផ្លិចបំផ្លាញ។ ការបកប្រែផ្សេងទៀត « ពួកគេបានចាប់
កាប់សម្លាប់និងបំផ្លាញ »
ពួកគេវាយក្រុងនោះបាន ហើយកម្ទេចក្រុងនោះ និងអ្នកនៅក្រុងនោះដោយដាវ រួមទាំងស្តេច
និងភូមិដែលនៅជុំវិញ គ្មាននរណាម្នាក់នៅរស់ឡើយ ... លោកបានកម្ទេចក្រុងនោះ
និងជីវិតដែលមាននៅក្នុងក្រុងនោះទាំងស្រុង។
ប្រយោគទាំងពីរនេះកំពុងនិយាយជារួមដូចគ្នាហើយត្រូវបានរួមបញ្ចូលគ្នា
ដើម្បីផ្តោតទៅលើរឿងតែមួយ។
ពួកគេរួមគ្នាផ្តោតទៅលើការបំផ្លាញទាំងស្រុងនៃក្រុងហេប្រុន។
Joshua 10:38
ដេប៊ៀរ ...ក្រុងលីបណា
ទាំងនេះគឺជាឈ្មោះនៃទីក្រុង។
ពួកគេបានកម្ទេចអ្នកក្រុងនោះដោយដាវ
ដាវតំណាងឲ្យកងទ័ពអ៊ីស្រាអែល ហើយធ្វើកូដកម្មបង្ហាញពីគំនិតនៃការសម្លាប់
និងការបំផ្លិចបំផ្លាញ។ ការបកប្រែផ្សេងទៀត « ពួកគេបានសម្លាប់និងបំផ្លាញពួកគេ
»
Joshua 10:40
លោកមិនទុកឲ្យស្តេចណាមួយរបស់ពួកគេនៅមានជីវិតឡើយ។ លោកបានកម្ទេចគ្រប់ទាំងជីវិត
ឃ្លាទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា
និងបញ្ជាក់ពីការបំផ្លាញទាំងស្រុងដែលប្រជាជន
នៃអ៊ីស្រាអែលបានសម្រេចតាមបញ្ជារបស់ព្រះអម្ចាស់។
លោកយ៉ូស្វេបានកម្ទេចពួកគេដោយដាវ
ដាវតំណាងឲ្យកងទ័ពអ៊ីស្រាអែល និងធ្វើកូដកម្មបង្ហាញពីគំនិតនៃការសម្លាប់
និងការបំផ្លិចបំផ្លាញ។ ការបកប្រែផ្សេងទៀត « យ៉ូស្វេបានសម្លាប់និងបំផ្លាញពួកគេ
»
Joshua 10:42
លោកយ៉ូស្វេបានវាយប្រហារស្តេចទាំងអស់ និងដណ្តើមយកទឹកដីរបស់ពួកគេ
នេះសំដៅទៅលើស្តេច និងទឹកដីដែលត្រូវបានកត់ក្នុងបញ្ជីក្នុងការចាប់ផ្តើមនៅក្នុង
១០:២៨ ។
លោកយ៉ូស្វេបានវាយប្រហារ
នៅទីនេះលោកយ៉ូស្វេតំណាងកងទ័ពទាំងមូលរបស់គាត់។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេនិងទាហានរបស់គាត់បានវាយប្រហារ»
ក្នុងពេលតែមួយ
នេះមិនមានន័យថាក្នុងមួយថ្ងៃទេ។
វាមានន័យថាក្នុងអំឡុងពេលសមយុទ្ធយោធាមួយ
ដែលអាចមានរយៈពេលជាច្រើនថ្ងៃ ឬច្រើនសប្តាហ៍។

11

[1]នៅពេលដែលព្រះបាទយ៉ាប៊ីនជាស្តេចក្រុងហាសោរបានឮដំណឹងនេះ ស្តេចបានផ្ញើសារទៅព្រះបាទយ៉ាូបាប់ជាស្តេចក្រុងម៉ាដូន ទៅស្តេចក្រុងស៊ីមរ៉ូន
និងទៅស្តេចក្រុងអាសាប។[2]ស្តេចក៏បានផ្ញើសារទៅស្តេចទាំងអស់ដែលនៅតំបន់ភ្នំភាគខាងជើង នៅជ្រលងទន្លេយ័រដាន់ខាងត្បូងគីណារ៉ូតនៅតំបន់វាលទំនាប
និងនៅតំបន់ភ្នំនៃក្រុងឌ័រទៅភាគខាងលិច។[3]ស្តេចក៏បានផ្ញើសារទៅស្រុកកាណានពីខាងកើតដល់ខាងលិច ទៅជនជាតិអាម៉ូរី ជនជាតិហេត ជនជាតិពេរីស៊ីត
ជនជាតិយេប៊ូសនៅតំបន់ភ្នំ និងជនជាតិហេវីក្បែរភ្នំហ៊ើរម៉ូន នៅក្នុងទឹកដីមីសបាដែរ។
[4]ទាហានរបស់ពួកគេទាំងអស់ចេញមកជាមួយពួកគេ ទាហានមានចំនួនច្រើនឥតគណនា គឺមានចំនួនដូចខ្សាច់នៅមាត់សមុទ្រ។ ពួកគេមានសេះ
និងរទេះចម្បាំងយ៉ាងច្រើន។[5]ស្តេចទាំងនេះបានណាត់ជួបគ្នាក្នុងពេលតែមួយ ហើយពួកគេបោះជំរំនៅមេរ៉ូម ដើម្បីវាយប្រហារអ៊ីស្រាអែល។
[6]ព្រះអម្ចាស់មានបន្ទូលមកកាន់លោកយ៉ូស្វេថា៖ «កុំឲ្យខ្លាចវត្តមានរបស់ពួកគេឡើយ ព្រោះថ្ងៃស្អែកថ្មើរនេះយើងនឹងប្រគល់ពួកគេមកអ៊ីស្រាអែលជាសាកសព។
ចូរកាត់សរសៃជើងសេះ និងដុតរទេះសេះរបស់ពួកគេចោលទៅ»។[7]លោកយ៉ូស្វេ និងប្រុសៗអ្នកចម្បាំងទាំងអស់បានមក។ រំពេចនោះពួកគេបានមកដល់ត្រង់ជ្រោះមេរ៉ូម
និងវាយប្រហារសត្រូវ។
[8]ព្រះអម្ចាស់បានប្រគល់សត្រូវមកក្នុងកណ្តាប់ដៃរបស់អ៊ីស្រាអែល ហើយពួកគេបានវាយប្រហារអ្នកទាំងនោះដោយដាវ និងដេញតាមពួកគេរហូតដល់ស៊ីដូនក្នុងតំបន់ក្រុង
មីសរិផូតម៉ែមនិងជ្រលងមីសបានៅទិសខាងកើត។ ពួកគេវាយប្រហាររហូតដល់គ្មាននរណាម្នាក់នៅរស់ឡើយ។
[9]លោកយ៉ូស្វេបានប្រព្រឹត្តជាមួយពួកគេដូចដែលព្រះអម្ចាស់បានមានបន្ទូលមកកាន់លោក។ លោកបានកាត់សរសៃកែងជើងសេះ និងបានដុតរទេះចំបាំងចោល។
[10]លោកយ៉ូស្វេបានត្រឡប់ក្រោយនៅពេលនោះ យើងកាន់កាប់ក្រុងហាសោរ។ លោកបានប្រហារស្តេចក្រុងនោះដោយដាវ។
(ហាសោរមេដឹកនាំលើអាណាចក្រទាំងអស់នេះ)។[11]ពួកគេបានកំទេចដោយដាវគ្រប់ទាំងជីវិតដែលមាននៅពេលនោះ ហើយលោកបានកម្ទេចពួកគេ ដូច្នេះ
គ្មានជីវិតណាមួយនៅរស់ឡើយ។ បន្ទាប់មក លោកបានដុតក្រុងហាសោរចោល។
[12]លោកយ៉ូស្វេបានកាន់កាប់ទីក្រុងរបស់ស្តេចទាំងឡាយ។ លោកក៏បានចាប់ស្តេចទាំងអស់ និងសម្លាប់ពួកគេចោលដោយដាវ។
លោកបានកម្ទេចពួកគេចោលដោយសារដាវ ដូចដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានបង្គាប់។[13]អ៊ីស្រាអែលមិនបានដុតក្រុងណាដែលនៅលើភ្នំទេ
លើកលែងក្រុងហាសោរប៉ុណ្ណោះ។ មានតែក្រុងមួយនេះគត់ដែលលោកបានដុត។
[14]ទាហានអ៊ីស្រាអែលបានយកជ័យភណ្ឌពីក្រុងទាំងនេះជាមួយនឹងហ្វូងសត្វសម្រាប់ខ្លួនពួកគេផ្ទាល់។ ពួកគេសម្លាប់មនុស្សទាំងអស់ដោយដាវ
រហូតគ្មាននរណារួចជីវិតឡើយ។ ពួកគេមិនឲ្យជីវិតណាមួយនៅរស់ឡើយ។[15]ដូចដែលព្រះអម្ចាស់បានបង្គាប់លោកម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គ
ដូចគ្នាដែរលោកម៉ូសេក៏បង្គាប់ដល់លោកយ៉ូស្វេ ដូច្នេះហើយលោកយ៉ូស្វេបានធ្វើតាមទាំងអស់។
លោកបានធ្វើសម្រេចទាំងអស់គ្រប់អ្វីដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេឲ្យធ្វើ។
[16]លោកយ៉ូស្វេបានកាន់កាប់ទឹកដីទាំងអស់ ទាំងតំបន់ភ្នំ តំបន់ណេកិប ទឹកដីកូសែន តំបន់ជើងភ្នំ ជ្រលងទន្លេយ័រដាន់ តំបន់ភ្នំរបស់អ៊ីស្រាអែល និងតំបន់វាលទំនាប។
[17]ពីភ្នំហាឡាក់នៅជិតស្រុកអេដុំ និងទៅខាងជើងដល់បាលកាដ នៅក្នុងជ្រោះជិតភ្នំលីបង់ក្រោមភ្នំហ៊ើរម៉ូន លោកចាប់បានស្តេចទាំងអស់ ហើយសម្លាប់ពួកគេចោល។
[18]លោកយ៉ូស្វេបានធ្វើសង្គ្រាមអស់រយៈពេលយ៉ាងយូរជាមួយស្តេចទាំងអស់នេះ។[19]គ្មានក្រុងណាមួយបានប្រកាសសន្តិភាពជាមួយទាហានអ៊ីស្រាអែលឡើយ
លើកលែងតែពួកហេវីដែលរស់នៅក្រុងគីបៀនចេញ។ អ៊ីស្រាអែលកាន់កាប់ទីក្រុងទាំងអស់ដោយធ្វើសង្គ្រាម។[20]ដ្បិត ព្រះអម្ចាស់បានធ្វើឲ្យចិត្តរបស់ពួកគេរឹង
ដើម្បីឲ្យពួកគេធ្វើសង្គ្រាមជាមួយអ៊ីស្រាអែល ដូច្នេះហើយបានជាលោកយ៉ូស្វេកម្ទេចពួកគេដោយគ្មានមេត្តា ដូចអ្វីដែលព្រះអម្ចាស់បានណែនាំដល់លោកម៉ូសេស្រាប់។
[21]នៅគ្រានោះ លោកយ៉ូស្វេបានចេញមក ហើយលោកបានកម្ទេចជនជាតិអាណាក់។ លោកបានធ្វើការនេះនៅតំបន់ភ្នំ នៅហេប្រុន នៅដេប៊ៀរ នៅអាណាក់
និងតំបន់ភ្នំនៅយូដា និងនៅតំបន់ភ្នំស្រុកអ៊ីស្រាអែលទាំងមូល។ លោកយ៉ូស្វេបានសម្លាប់ពួកគេ ហើយកម្ទេចក្រុងរបស់ពួកគេ។
[22]គ្មានពួកអាណាក់ណាម្នាក់បន្តមានជីវិតនៅក្នុងទឹកដីអ៊ីស្រាអែលឡើយ លើកលែងតែនៅក្រុងកាសា ក្រុងកាដ និងក្រុងអាសដូឌប៉ុណ្ណោះ។
[23]ដូច្នេះ លោកយ៉ូស្វេកាន់កាប់ទឹកដីទាំងមូលដូចដែលព្រះអម្ចាស់មានបន្ទូលមកកាន់លោកម៉ូសេ។ លោកយ៉ូស្វេបានចែកទឹកដីនេះទុកជាមរតកសម្រាប់ជនជាតិអ៊ីស្រាអែល
ចែកទៅតាមកុលសម្ព័ន្ធនីមួយៗ។ បន្ទាប់មក ទឹកដីនោះក៏លែងមានសង្គ្រាមទៀតដែរ។

generated on Wed Sep 10 16:16:32 2025

Joshua 11:1
ព្រះបាទយ៉ាបីន ...ព្រះបាទយ៉ាូបាប់
ទាំងនេះគឺជាឈ្មោះស្តេច។
ក្រុងហាសោរ ... ក្រុងម៉ាដូន ...ក្រុងស៊ីមរ៉ូន. ក្រុងអាសាបគីណារ៉ូត ...ក្រុងឌ័រ ... ភ្នំហ៊ើរម៉ូន
ទាំងនេះគឺជាឈ្មោះទីកន្លែង។
Joshua 11:4
ព័ត៌មានទូទៅ
ស្តេចស្រុកកាណានទាំងអស់វាយប្រហារ លោកយ៉ូស្វេ និងប្រជាជាតិអ៊ីស្រាអែល។
ទាហានមានចំនួនច្រើនឥតគណនា គឺមានចំនួនដូចខ្សាច់នៅមាត់សមុទ្រ
នេះការនិយាយបំផ្លើសដែលបញ្ជាក់ទៅលើចំនួនទាហានយ៉ាងច្រើន
ដែលស្តេចទាំងនេះបានប្រមូលផ្តុំ ។ ការបកប្រែផ្សេងទៀត «
ចំនួនទាហានដ៏ច្រើនបែបនេះបានលិចឡើង ដូចជាគ្រាប់ខ្សាច់នៅឆ្នេរសមុទ្រ»
ជ្រោះមេរ៉ូម
នេះគឺជាឈ្មោះកន្លែងមួយ។
Joshua 11:6
យើងនឹងប្រគល់ពួកគេមកអ៊ីស្រាអែលជាសាកសព
ព្រះអម្ចាស់អនុញ្ញាតឲ្យអ៊ីស្រាអែលយកឈ្នះកងទ័ពសត្រូវ
និងសម្លាប់ទាហានទាំងអស់បាន ដូចជាព្រះអម្ចាស់បានសម្លាប់ពួកទាហាន
ហើយបន្ទាប់មកប្រគល់ពួកគេអោយអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «
ខ្ញុំនឹងអនុញ្ញាតឲ្យអ៊ីស្រាអែលសម្លាប់ពួកគេទាំងអស់នៅក្នុងសមរភូមិ »
ចូរកាត់សរសៃជើងសេះ
« ធ្វើឲ្យសេះរបស់ពួកគេពិការដោយកាត់ជើងរបស់ពួកគេ» ។
នេះគឺជាការអនុវត្តដែលសរសៃពួរនៅខាងក្រោយជើងត្រូវបានកាត់
ដើម្បីកុំអោយសេះដើរបាន។
ជ្រោះមេរ៉ូម
នេះគឺជាឈ្មោះកន្លែងមួយ។
Joshua 11:8
ព្រះអម្ចាស់បានប្រគល់សត្រូវមកក្នុងកណ្តាប់ដៃរបស់អ៊ីស្រាអែល
ត្រង់នេះពាក្យថា « ដៃ » តំណាងអោយអំណាច។
ព្រះអម្ចាស់បានជួយកងទ័ពអ៊ីស្រាអែល អោយយកឈ្នះខ្មាំងសត្រូវរបស់ពួកគេ
គឺដូចជាព្រះអម្ចាស់បានប្រគល់កងទ័ពរបស់ខ្មាំងសត្រូវចូលក្នុងកណ្តាប់ដៃរបស់អ៊ីស្រាអែល
ការបកប្រែផ្សេងទៀត « ព្រះអម្ចាស់បានជួយអ៊ីស្រាអែលអោយយកឈ្នះខ្មាំងសត្រូវ
»
ពួកគេបានវាយប្រហារអ្នកទាំងនោះដោយដាវ ... បានវាយប្រហារអ្នកទាំងនោះ
នៅទីនេះពាក្យ « ដាវ » តំណាងឲ្យអាវុធទាំងអស់ដែលពួកគេបាន
ដើម្បីវាយប្រហារសត្រូវរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «
វាយប្រើប្រហារពួកគេដោយអាវុធរបស់ពួកគេ ... វាយប្រហារពួកគេ»
ក្រុងមីសរិផូតម៉ែម
ទាំងនេះគឺជាឈ្មោះកន្លែងមួយ។
កាត់សរសៃកែងជើងសេះ
នេះគឺជាការអនុវត្តដែលសរសៃពួរនៅខាងក្រោយជើងត្រូវបានគេកាត់
ដូច្នេះសេះមិនអាចរត់បានទេ។
បកប្រែពាក្យនេះតាមរបៀបដែលអ្នកបានធ្វើក្នុងម៉ោង ១១: ៦។
Joshua 11:10
ពួកគេបានកំទេចដោយដាវ
« លោកយ៉ូស្វេបានសម្លាប់ស្តេចក្រុងហាសោរ ជាមួយដាវរបស់គាត់ »
ហាសោរមេដឹកនាំលើអាណាចក្រទាំងអស់នេះ
ក្រុងហាសោរជាទីក្រុងសំខាន់បំផុត
ត្រូវបានគេនិយាយថាទីក្រុងហាសោរជាប្រមុខនៃព្រះរាជាណាចក្រដទៃទៀត។
ការបកប្រែផ្សេងទៀត «
ក្រុងហាសោរបានក្លាយជានគរដ៏សំខាន់បំផុតនៃនគរទាំងអស់នេះ »
ពួកគេបានកំទេចដោយដាវគ្រប់ទាំងជីវិតដែលមាននៅពេលនោះ ...ដូច្នេះ
គ្មានជីវិតណាមួយនៅរស់ឡើយ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា និងផ្តោតទៅលើការបំផ្លាញទាំងស្រុង។
លោកបានកម្ទេចពួកគេ ដូច្នេះ គ្មានជីវិតណាមួយនៅរស់ឡើយ
ពាក្យថា « គាត់ »
គឺសំដៅទៅលើលោកយ៉ូស្វេហើយជាពាក្យប្រៀបធៀបសម្រាប់កងទ័ពដែលគាត់ដឹកនាំ។
ការបំផ្លាញអ្វីៗទាំងអស់ដូចជា
របស់ដែលមានជីវិតនៅក្នុងទីក្រុងត្រូវបានគេលះបង់ដើម្បីការបំផ្លាញ។
ការបកប្រែផ្សេងទៀត « កងទ័ពបានបំផ្លាញពួកគេទាំងស្រុង »
Joshua 11:12
សម្លាប់ពួកគេចោលដោយដាវ
« បានសម្លាប់ពួកគេ »
ក្រុងណាដែលនៅលើភ្នំ
« ទីក្រុងបានសាងសង់នៅលើកូនភ្នំតូចៗ »
Joshua 11:14
សម្រាប់ខ្លួនពួកគេផ្ទាល់
ឃ្លានេះសំដៅទៅលើកងទ័ពអ៊ីស្រាអែល។
ពួកគេសម្លាប់មនុស្សទាំងអស់ដោយដាវ រហូតគ្មាននរណារួចជីវិតឡើយ។
ពួកគេមិនឲ្យជីវិតណាមួយនៅរស់ឡើយ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នានិងសង្កត់ធ្ងន់ទៅលើការបំផ្លាញទាំងស្រុងនៃទីក្រុង។
លោកបានធ្វើសម្រេចទាំងអស់គ្រប់អ្វីដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេឲ្យធ្វើ
ឃ្លាអវិជ្ជមាននេះបញ្ជាក់ថា
លោកយ៉ូស្វេបានធ្វើអ្វីទាំងអស់ដែលព្រះអម្ចាស់បានបញ្ជា។ ការបកប្រែផ្សេងទៀត
« លោកយ៉ូស្វេបានធ្វើអ្វីទាំងអស់ដែលព្រះអម្ចាស់បានបញ្ជា»
Joshua 11:16
ភ្នំហាឡាក់ ... បាលកាដ
ទាំងនេះគឺជាឈ្មោះកន្លែងមួយ។
Joshua 11:18
ព្រះអម្ចាស់បានធ្វើឲ្យចិត្តរបស់ពួកគេរឹង
អត្ថន័យ
ន័យ
ន័យ
**

[5]ស្តេចគ្រប់គ្រងភ្នំហ៊ើមូន ក្រុងហាល់កា និងស្រុកបាសានទាំងមូល រហូតដល់ព្រំប្រទល់ស្រុកកេស៊ួរី និងស្រុកម៉ាកាធី និងស្រុកកាឡាដមួយចំហៀង
ទៅដល់ព្រំប្រទល់ស្រុកស្តេចស៊ីហុន និងស្តេចក្រុងហេសបូន។
[6]លោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់ និងប្រជាជនអ៊ីស្រាអែលបានវាយប្រហារពួកគេ
ហើយលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានឲ្យទឹកដីនោះដល់កុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលជាកម្មសិទ្ធិ។
[7]ទាំងនេះជាស្តេចនៅលើទឹកដីដែលលោកយ៉ូស្វេ និងប្រជាជនអ៊ីស្រាអែលវាយដណ្តើមបាននៅលើភាគខាងលិចទន្លេយ័រដាន់
ចាប់តាំងពីបាល់កាដនៅក្នុងជ្រលងភ្នំលីបង់ទៅដល់ភ្នំហាឡាក់ជិតស្រុកអេដុំ។ លោកយ៉ូស្វេបានប្រគល់ទឹកដីទាំងនេះដល់កុលសម្ពន្ធអ៊ីស្រាអែលជាកម្មសិទ្ធិ។
[8]លោកបានប្រគល់តំបន់ភ្នំ តំបន់ទំនាប តំបន់អារ៉ាបា ជំរាលភ្នំ វាលរហោស្ថាន និងតំបន់ណេកិបជាទឹកដីរបស់ជនជាតិហេត ជនជាតិអាម៉ូរី ជនជាតិកាណាន
ជនជាតិពេរីស៊ីត ជនជាតិហេវី និងជនជាតិយេប៊ូសដល់ពួកគេ។
[9]ស្តេចទាំងអស់រួមទាំងស្តេចក្រុងយេរីខូ ស្តេចក្រុងអៃដែលនៅជិតបេតអែល[10]ស្តេចក្រុងយេរូសាឡិម[11]ស្តេចក្រុងអេណាអ៊ីម ស្តេចក្រុងយ៉ាមូត
ស្តេចក្រុងឡាគីស[12]ស្តេចក្រុងអេក្លូន ស្តេចក្រុងកេស៊ើរ
[13]ស្តេចក្រុងដេបៀរ ស្តេចក្រុងកេឌើរ[14]ស្តេចក្រុងហោម៉ា ស្តេចក្រុងអើរ៉ាត[15]ស្តេចក្រុងលីបណា ស្តេចក្រុងអាឌូឡាំ[16]ស្តេចក្រុងម៉ាកេដា ស្តេចក្រុងបេតអែល
[17]ស្តេចក្រុងតាពួរ ស្តេចក្រុងហេភើរ[18]ស្តេចក្រុងអាផេក ស្តេចក្រុងឡាសារ៉ូន[19]ស្តេចក្រុងម៉ាដូន ស្តេចក្រុងហាសោរ[20]ស្តេចក្រុងស៊ីមរ៉ូន មេរ៉ូន ស្តេចក្រុងអាកសាប
[21]ស្តេចក្រុងតាអាណាក់ ស្តេចក្រុងមេគីដោ[22]ស្តេចក្រុងកេដែស ស្តេចក្រុងយ៉ុកនាម នៅភ្នំកើមែល[23]ស្តេចក្រុងដោរនៅវាលរាបដោរ ស្តេចក្រុងកូយីម នៅជិត
គីលកាល់[24]ស្តេចក្រុងធើសា។ ចំនួនស្តេចទាំងអស់មានសាមសិបមួយអង្គ។

Joshua 12:1

ឥឡូវនេះ

ពាក្យនេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ការឈប់នៅក្នុងសាច់រឿងសំខាន់។ នៅទីនេះអ្នកនិពន្ធចាប់ផ្តើមផ្តល់ពត៌មានសង្ខេប។

ទាំងអស់នេះគឺជាស្តេច

នេះសំដៅទៅលើបញ្ជីស្តេចដែលបន្តតាមរយៈខ ២៤ ។

តំបន់អារ៉ាបា ... អារ៉ូអ៊ើរ

ទាំងនេះគឺជាឈ្មោះកន្លែងមួយ។

ព្រះបាទស៊ីហុន ...ក្រុងហេសបូន

បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ៩: ៩។

Joshua 12:3

សមុទ្រគេនេសារ៉ែត

នេះគឺជាកន្លែងមួយ។ បកប្រែដូចរបៀបបកប្រែនៅក្នុង១១: ១ ។

ប៊ែតយេស៊ីមុត ... ភ្នំពីសកា ..ក្រុងអាសថារ៉ូត ... ក្រុងអេទ្រី ... ស្រុកកាឡាដ

ទាំងនេះគឺជាឈ្មោះកន្លែងមួយ។

ព្រះបាទអុកជាស្តេចស្រុកបាសាន

បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ៩: ៩ ។

ជនជាតិរ៉ែផែម ... ស្រុកម៉ាកាធី

ទាំងនេះគឺជាឈ្មោះនៃក្រុមមនុស្ស។

Joshua 12:6

កុលសម្ព័ន្ធរូបេន

ទាំងនេះជាកូនចៅរបស់រូបេន។

កុលសម្ព័ន្ធកាដ

ទាំងនេះជាកូនចៅរបស់កាដ។

កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលជាកម្មសិទ្ធិ

ពួកគេត្រូវបានគេហៅថាកុលសម្ព័ន្ធពាក់កណ្តាលពីព្រោះពាក់កណ្តាលនៃកុលសម្ព័ន្ធនេះបានទទួលមរតកនៅក្នុងទឹកដីនៃស្រុកកាណាន។

Joshua 12:7

បាល់កាដ... ភ្នំហាឡាក់ ...តំបន់អារ៉ាបា

ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។

Joshua 12:9

ស្តេចក្រុងអេណាអ៊ីម ... ស្តេចក្រុងយ៉ាមូត....ស្តេចក្រុងឡាគីស... ស្តេចក្រុងអេក្លូន... ស្តេចក្រុងកេស៊ើរ

ទាំងនេះគឺជាឈ្មោះនៃទីក្រុង។ បកប្រែ « ក្រុងយ៉ាមូត » « ក្រុងឡាគីស» និង « ក្រុងអេក្លូន » នៅក្នុងរបៀបដូចគ្នាដែលអ្នកបានធ្វើ១០:៣។

Joshua 12:13

ក្រុងដេបៀរ ...ក្រុងកេឌើរ ... ក្រុងហោម៉ា ... ក្រុងអើរ៉ាត ... ក្រុងលីបណា ... ក្រុងអាឌូឡាំ... ក្រុងម៉ាកេដា

ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុង។

Joshua 12:17

ក្រុងតាពួរ ... ក្រុងហេភើរ ... ក្រុងអាផេក ... ក្រុងឡាសារ៉ូន ... ក្រុងម៉ាដូន ... ក្រុងហាសោរ ... ក្រុងស៊ីមរ៉ូនមេរ៉ូន... ក្រុងអាកសាប

ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុង។

Joshua 12:21

ក្រុងតាអាណាក់ ... ក្រុងមេគីដោ ...ក្រុងកេដែស ... ក្រុងយ៉ុកនាម ...ក្រុងដោរ ... ក្រុងកូយីម ... ក្រុងធើសា

ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុង ។

សាមសិបមួយអង្គ

មួយនៅក្នុងទាំងអស់ «៣១ អង្គ»

---

13 [1]លោកយ៉ូស្វេមានវ័យចាស់ណាស់ហើយនៅពេលដែលព្រះអម្ចាស់មានបន្ទូលមកកាន់លោកថា៖ «អ្នកកាន់តែចាស់ណាស់ហើយ ប៉ុន្តែ
នៅមានទឹកដីជាច្រើនទៀតដែលត្រូវវាយយក។
[2]នេះជាទឹកដីដែលនៅសេសសល់៖ គឺស្រុកភីលីស្ទីនទាំងមូល និងអស់ទាំងស្រុកកេស៊ូរី[3](ពីស៊ីហោ ដែលនៅខាងកើតអេស៊ីប ភាគខាងជើងជាប់ព្រំប្រទល់អេក្រុន
ដែលជាទឹកដីស្រុកកាណាន អ្នកគ្រប់គ្រងរបស់ស្រុកភីលីស្ទីនទាំងប្រាំ គឺក្រុងកាសា ក្រុងអាសដូឌ ក្រុងអាសកាឡូន ក្រុងកាថ និងក្រុងអេក្រូន ជាទឹកដីរបស់ជនជាតិអាវីម
)។
[4]នៅភាគខាងត្បូង នៅមានទឹកដីទាំងមូលរបស់ជនជាតិកាណាន និងក្រុងមារ៉ា ដែលជាកម្មសិទ្ធិរបស់ជនជាតិស៊ីដូន ដល់ក្រុងអាផែក និងព្រំប្រទល់ស្រុក
អាម៉ូរី[5]ដល់ទឹកដីស្រុកកេបាល និងស្រុកលីបង់ទាំងមូល ដែលនៅទិសខាងកើត ពីបាលកាដ ក្រោមជើងភ្នំហ៊ើរម៉ូន រហូតដល់ឡាបូហាម៉ាត់។
[6]ក៏មានទឹកដីរបស់ជនជាតិស៊ីដូននៅតំបន់ភ្នំពីលីបង់រហូតដល់ក្រុងមីសរិផូត ម៉ែម ព្រមទាំងប្រជាជនស៊ីដូនដែរ។ យើងនឹងដេញពួកគេចេញនៅមុខទាហានអ៊ីស្រាអែល។
ត្រូវបែងចែកទឹកដីនេះជាកម្មសិទ្ធិដល់ជនជាតិអ៊ីស្រាអែលដូចដែលយើងបានបង្គាប់អ្នក។[7]ត្រូវបែងចែកទឹកដីនេះទៅកាន់កុលសម្ព័ន្ធទាំងប្រាំបួន
និងកុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាលទៀត។
[8]សម្រាប់កុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាលទៀត កុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ
បានទទួលមរតករបស់ពួកគេដែលលោកម៉ូសេបានប្រគល់ដល់ពួកគេរួចហើយនៅភាគខាងកើតទន្លេយ័រដាន់[9]ចាប់តាំងពីក្រុងអារ៉ូអ៊ើរ ដែលស្ថិតនៅក្បែរទន្លេអើណូន
(រួមទាំងក្រុងដែលស្ថិតនៅកណ្តាលជ្រលងភ្នំ) ដល់ខ្ពង់រាបមេដេបាទាំងមូល រហូតដល់ក្រុងឌីបូន
[10]ក្រុងទាំងប៉ុន្មានរបស់ស្តេចស៊ីហុន ជាស្តេចអាម៉ូរី ដែលគ្រប់គ្រងនៅក្រុងហេសបូន រហូតដល់ព្រំប្រទល់ស្រុកអាំមូន[11]ស្រុកកាឡាដទឹកដីស្រុកកេស៊ួរី និងម៉ាកាធី ទាំង
តំបន់ភ្នំហ៊ើរម៉ូនទាំងអស់ និងពីបាសានទាំងមូល ដល់សាលកា[12]ទាំងតំបន់ទាំអស់របស់ព្រះបាទអុក នៅស្រុកបាសាន ដែលសោយរាជ្យនៅក្រុងអាសថារ៉ូត និងក្រុងអេទ្រី
ទាំងនេះជាជនជាតិរ៉ែផែមដែលនៅសេសសល់ លោកម៉ូសេបានវាយប្រហារពួកគេ និងដេញពួកគេចេញ។

generated on Wed Sep 10 16:16:32 2025

[13]ប៉ុន្តែ ប្រជាជនអ៊ីស្រាអែលមិនបានបណ្តេញជនជាតិកេស៊ូរី និងជនជាតិម៉ាកាធីចេញឡើយ។ ផ្ទុយទៅវិញ ជនជាតិកេស៊ូរី និងជនជាតិម៉ាកាធី
រស់នៅក្នុងចំណោមជនជាតិអ៊ីស្រាអែលមកទល់សព្វថ្ងៃនេះ។
[14]ចំពោះកុលសម្ព័ន្ធលេវីវិញលោកម៉ូសេមិនបានប្រគល់ទឹកដីជាមរតកទេ។ តង្វាយដុតដែលគេថ្វាយព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលជាមរតករបស់ពួកគេ
ដូចដែលព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេ។
[15]លោកម៉ូសេបានចែកទឹកដីមរតកដល់កុលសម្ព័ន្ធរូបេន តាមអំបូររៀងៗខ្លួន។[16]ទឹកដីរបស់គេចាប់ពីក្រុងអារ៉ូអ៊ើរ ដែលស្ថិតនៅក្បែរទន្លេអើណូន និងក្រុងដែលស្ថិតនៅ
កណ្តាលជ្រលងភ្នំ ព្រមទាំងខ្ពង់រាបទាំងមូលក្បែរមេដេបា។
[17]កុលសម្ព័ន្ធរូបេនក៏ទទួលបានក្រុងហេសបូន និងក្រុងទាំងប៉ុន្មាននៅលើខ្ពង់រាប គឺក្រុងឌីបូន ក្រុងបាមូត បាល ក្រុងបេត បាលមេយ៉ូន[18]ក្រុងយ៉ាហាស ក្រុងកេដេមូត ក្រុង
មេផាត[19]ក្រុងគារយ៉ាថែម ក្រុងស៊ីបម៉ា ក្រុងសេរេត-ហាសាកា ដែលស្ថិតនៅជ្រលងភ្នំ។
[20]កុលសម្ព័ន្ធរូបេនក៏ទទួលបានក្រុងបេតពេអ៊ូរ ជម្រាលភ្នំពីសកា ក្រុងបេតយេស៊ីម៉ុត[21]ក្រុងទាំងអស់នៅតំបន់ខ្ពង់រាប អាណាចក្រទាំងមូលរបស់ព្រះបាទស៊ីហុន ជាស្តេច
របស់ជនជាតិអាម៉ូរី គ្រងរាជ្យនៅក្រុងហេសបូន ដែលលោកម៉ូសេបានវាយប្រហាររួមជាមួយអ្នកដឹកនាំដទៃទៀតរបស់ជនជាតិម៉ាឌាន ជនជាតិអេវី ជនជាតិរេគែម ជនជាតិ
ស៊ើរ ជនជាតិហ៊ើរ និងជនជាតិរេបា ជាបុត្ររបស់ព្រះបាទស៊ីហុន ដែលរស់នៅក្នុងទឹកដីនោះ។
[22]ប្រជាជនអ៊ីស្រាអែលក៏បានសម្លាប់បាឡាមជាកូនរបស់បេអ៊ូរ ដែលជាគ្រូទាយដែរ ក្នុងចំណោមអ្នកផ្សេងទៀតដែលពួកគេបានសម្លាប់។
[23]ព្រំប្រទល់របស់កុលសម្ព័ន្ធរូបេនគឺទន្លេយ័រដាន់គឺជាខ្សែខាន់។ នេះគឺជាមរតករបស់កុលសម្ព័ន្ធរូបេន ដែលចែកដល់គ្រប់អំបូរទាំងអស់របស់ពួកគេ ជាមួយនឹងក្រុង
និងភូមិរបស់ពួកគេ។
[24]នេះគឺជាអ្វីដែលលោកម៉ូសេបានប្រគល់ដល់កុលសម្ព័ន្ធកាដតាមអំបូរនីមួយៗ៖[25]ទឹកដីរបស់ពួកគេ គឺស្រុកយ៉ាស៊ើរ ក្រុងទាំងប៉ុន្មាននៅស្រុកកាឡាដ និងស្រុកអាំម៉ូនពាក់
កណ្តាល រហូតដល់អារ៉ូអ៊ើរ ដែលនៅខាងកើតក្រុងរ៉ាបាត[26]ពីក្រុងហេសបូន រហូតដល់ក្រុងរ៉ាម៉ាត មីសប៉េ និងក្រុងបេថូនីម ពីក្រុងម៉ាហាណែមរហូតដល់ព្រំប្រទល់ស្រុក
ដេបៀរ។
[27]នៅក្នុងជ្រលងភ្នំ លោកម៉ូសេបានឲ្យក្រុងបេតហារ៉ាម ក្រុងបេតនីមរ៉ា ក្រុងស៊ូកុត និងក្រុងសាផូនដែលជាចំណែកទឹកដីចុងក្រោយនៃអាណាចក្ររបស់ព្រះបាទស៊ីហុន ជា
ស្តេចហេសបូន ដែលមានទន្លេយ័រដាន់ជាព្រំប្រទល់ រហូតដល់ចុងសមុទ្រគេនេសារ៉ែតភាគខាងលិចក្រោយទន្លេយ័រដាន់ដល់ពួកគេ។[28]នេះជាមរតករបស់កុលសម្ព័ន្ធកាដ
តាមអំបូរ ជាមួយនឹងទីក្រុង និងភូមិទាំងឡាយ។
[29]លោកម៉ូសេបានឲ្យទឹកដីជាមរតកដល់កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល។
លោកបានផ្តល់ឲ្យប្រជាជនក្នុងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលតាមអំបូររបស់គេ។[30]ទឹកដីរបស់ពួកគេចាប់តាំងពីស្រុកម៉ាហាណែម ស្រុកបាសាន អាណាចក្រ
ទាំងមូលរបស់ព្រះបាទអុក ស្តេចស្រុកបាសាន រួមទាំងក្រុងទាំងឡាយនៅយ៉ាអ៊ៀរ ក្នុងស្រុកបាសាន[31]ដែលមានចំនួនហុកសិបស្រុកកាឡាដពាក់កណ្តាល ក្រុងអាសថារ៉ូត
និងក្រុងអេទ្រី (ជារាជធានីរបស់ព្រះបាទអុកបាសាន)។ ទឹកដីទាំងនេះបានប្រគល់ឲ្យពូជអំបូរពាក់កណ្តាលរបស់លោកម៉ាគៀរនៃកុលសម្ព័ន្ធម៉ាណាសេ
ឲ្យដល់គ្រួសារនីមួយៗរបស់ពួកគេ។
[32]នេះគឺជាទឹកដីដែលលោកម៉ូសេបានប្រគល់ដល់ពួកគេនៅលើវាលទំនាបស្រុកម៉ូអាប់ ក្រោយទន្លេយ័រដាន់ខាងកើតក្រុងយេរីខូ។
[33]លោកម៉ូសេមិនបានប្រគល់ទឹកដីជាមរតកដល់កុលសម្ព័ន្ធលេវីទេ។ ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់ប្រជាជនអ៊ីស្រាអែលជាមរតករបស់ពួកគេ
ដូចដែលលោកបាននិយាយជាមួយពួកគេ។

Joshua 13:2

នេះជាទឹកដីដែលនៅសេសសល់

អ្នកអាចបញ្ជាក់ថា នេះជាទឹកដីដែលអ៊ីស្រាអែលនៅតែត្រូវការចាប់យក។
ការបកប្រែផ្សេងទៀត

«នេះជាទឹកដីដែលនៅសល់សម្រាប់អ៊ីស្រាអែលក្នុងការចាប់យក»

ស៊ីហោ

នេះគឺជាឈ្មោះនៃទីកន្លែង។

ដែលជាទឹកដីស្រុកកាណាន

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ដែលជនជាតិកាណានឥឡូវនេះចាត់ទុកទ្រព្យសម្បត្តិរបស់ពួកគេ »

ជនជាតិអាវីម

នេះគឺជាឈ្មោះនៃក្រុមមនុស្ស។

Joshua 13:4

ក្រុងមារ៉ា ... ក្រុងអាផែក ... បាលកាដ ...ភ្នំហ៊ើរម៉ូន

ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។

ស្រុកកេបាល

នេះគឺជាឈ្មោះក្រុមមនុស្សដែលរស់នៅកេបាល។

Joshua 13:6

ក្រុងមីសរិផូត ម៉ែម

នេះគឺជាឈ្មោះនៃទីកន្លែង។

ទឹកដី ... ជាកម្មសិទ្ធិ

ទឹកដីដែលអ៊ីស្រាអែលនឹងទាមទារត្រូវបានគេនិយាយថា
ជាចំណែកមត៌កដែលពួកគេនឹងទទួលជាមរតកអចិន្ត្រៃយ៍។

Joshua 13:8

ក្រុងអារ៉ូអ៊ើរ ..ខ្ពង់រាបមេដេបា...ក្រុងឌីបូន

ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។

ជ្រលងភ្នំ

ជាកន្លែងដែលទឹកទន្លេគឺនៅឆ្ងាយខាងក្រោមដីនៅសងខាង

ខ្ពង់រាប

ដីខ្ពស់រាបស្មើនៅខាងលើទន្លេ

Joshua 13:10

ក្រុងហេសបូន ... សាលកា ... ក្រុងអាសថារ៉ូត ... ក្រុងអេទ្រី

ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។

ស្រុកកាឡាដទឹកដីស្រុកកេស៊ូរី និងម៉ាកាធី

«ទឹកដីដែលជាកន្លែងជនជាតិកេស៊ួស និងម៉ាកាធីតរស់នៅ»

ម៉ាកាធី ... ជាជនជាតិរ៉ើផែម

ទាំងនេះគឺជាឈ្មោះនៃក្រុមមនុស្ស។

លោកម៉ូសេបានវាយប្រហារពួកគេ

នៅទីនេះ « លោកម៉ូសេ »

តំណាងកងទ័ពអ៊ីស្រាអែលដែលលោកម៉ូសេបានដឹកនាំ។ ការបកប្រែផ្សេងទៀត «
លោកម៉ូសេនិងជនជាតិអ៊ីស្រាអែលបានវាយប្រហារពួកគេ »

Joshua 13:13

ជនជាតិកេស៊ូរី និងជនជាតិម៉ាកាធី

ទាំងនេះគឺជាឈ្មោះនៃក្រុមមនុស្ស។

ជនជាតិកេស៊ូរី និងជនជាតិម៉ាកាធីរស់នៅក្នុងចំណោមជនជាតិអ៊ីស្រាអែល

« ជនជាតិកេស៊ូរី » និង « ជនជាតិម៉ាកាធី » គឺជាឈ្មោះបុព្វបុរសរបស់ « កេស៊ូរី »
និង « ម៉ាកាធី » ឬជាឈ្មោះនៃទីក្រុងដែលពួកគេរស់នៅ។ ការបកប្រែផ្សេងទៀត «
ប្រជាជនទាំងនោះរស់នៅក្នុងចំណោមអ៊ីស្រាអែល »

សព្វថ្ងៃនេះ

នេះសំដៅទៅលើអំឡុងពេលដែលអ្នកនិពន្ធសរសេរកណ្តាលនេះ។

Joshua 13:14

លោកម៉ូសេមិនបានប្រគល់ទឹកដីជាមរតកទេ

ទឹកដីដែលលោកម៉ូសេបានកំណត់ទៅឲ្យកុលសម្ព័ន្ធអ៊ីស្រាអែល
ត្រូវបានគេចាត់ទុកថាជាមរតកដែលពួកគេបានទទួលសិទ្ធិកាន់កាប់ជារៀងរហូត។

តង្វាយដុតដែលគេថ្វាយព្រះអម្ចាស់ ... ជាមរតករបស់ពួកគេ

អ្នកនិពន្ធនិយាយអំពីកិត្តិយសដ៏អស្ចារ្យដែលពួកលេវីបានរបម្រើព្រះអម្ចាស់
ដូចជាការថ្វាយតង្វាយគឺជាអ្វីដែលពួកគេនឹងទទួលមរតក។ ការបកប្រែផ្សេងទៀត
« តង្វាយរបស់ព្រះអម្ចាស់ ...

generated on Wed Sep 10 16:16:32 2025

គឺជាអ្វីដែលគេនឹងមានសម្រាប់ការផ្គត់ផ្គង់របស់ពួកគេ »
តង្វាយដុតដែលគេថ្វាយព្រះអម្ចាស់
« តង្វាយដែលប្រជាជនបាននាំមក ដើម្បីថ្វាយព្រះអម្ចាស់ »
តង្វាយដុត
នេះអាចត្រូវបានថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត «
ដែលពួកបូជាចារ្យបានដុតជាមួយភ្លើង »
Joshua 13:15
ក្រុងអារ៉ូអ៊ែរ ... មេដេបា
ទាំងនេះគឺជាឈ្មោះនៃក្រុមមនុស្ស។
កណ្តាលជ្រលងភ្នំ...ខ្ពង់រាប
ការបកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើក្នុង ១៣:៨ ។
Joshua 13:17
ក្រុងហេសបូន...ក្រុងឌីបូន ... ក្រុងបាមូត ... ក្រុងបេត ...ក្រុងយ៉ាហាស ...ក្រុងកេដេមូត ... ក្រុង
មេផាត ... ក្រុងគារយ៉ាថែម ... ក្រុងស៊ីបម៉ា ... ក្រុងសេរេត-ហាសាកា
ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។
Joshua 13:20
ក្រុងបេតពេអ៊រ ...ភ្នំពីសកា ... ក្រុងបេតយេស៊ីម៉ុត ... ក្រុងហេសបូន
ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។
ព្រះបាទស៊ីហុន...ជនជាតិអេវី ...ជនជាតិរ៉ែគែម...ជនជាតិស៊ើរ...ជនជាតិហ៊ើរ ...ជនជាតិរេបា
ទាំងអស់នេះគឺជាឈ្មោះរបស់មនុស្ស។
រួមជាមួយអ្នកដឹកនាំដទៃទៀតរបស់ជនជាតិម៉ាឌាន
« ពេលគាត់បានកម្ចាត់មេដឹកនាំរបស់ជនជាតិម៉ាឌាន »
Joshua 13:22
គឺជាខ្សែខាន់
ទន្លេយ័រដាន់ភាគខាងលិច ជាជាព្រំដែននៃទឹកដីដែលកុលសម្ព័ន្ធរូបេនបានទទួល។
នេះគឺជាមរតករបស់កុលសម្ព័ន្ធរូបេន
ទឹកដីដែលលោកម៉ូសេបានកំណត់ឲ្យកុលសម្ព័ន្ធរូបេន
គឺដូចជាទឹកដីដែលកុលសម្ព័ន្ធរូបេនទទួលជាមត៌ករហូត។
ដែលចែកដល់គ្រប់អំបូរទាំងអស់របស់ពួកគេ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ដែលលោកម៉ូសេបានអោយទៅអំបូរនីមួយៗរបស់ពួកគេ »
Joshua 13:24
ស្រុកយ៉ាស៊ើរ ... អារ៉ូអ៊ែរ... ក្រុងហេសបូន ... ក្រុងរ៉ាម៉ាត មីសប៉េ ... ក្រុងបេថូនីម ... ក្រុង
បេថូនីម ...ស្រុកដេបៀរ
ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។
Joshua 13:27
ក្រុងបេតហារ៉ាម ... ក្រុងបេតនីមរ៉ា ... ក្រុងសាផូន ... ហេសបូរ
ទាំងអស់នេះគឺជាឈ្មោះទីកន្លែង។
នេះជាមរតករបស់កុលសម្ព័ន្ធកាដ
ទឹកដីដែលលោកម៉ូសេបានប្រគល់អោយកុលសម្ព័ន្ធកាដ
គឺដូចជាទឹកដីដែលកុលសម្ព័ន្ធកាដទទួលជាមរតក។
Joshua 13:29
លោកម៉ូសេបានឲ្យទឹកដីជាមរតកដល់កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល
ទឹកដីដែលលោកម៉ូសេបានប្រគល់ទៅកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល
ត្រូវបានគេនិយាយអំពីវាដូចជាទឹកដីដែលជាចំណែកមត៌កដែលព្រះអង្គបានប្រគល់អោយពួកគេទុកជាកម
ម៉ាណាសេចំនួនពាក់កណ្តាល
មានតែកុលសម្ព័ន្ធពាក់កណ្តាលប៉ុណ្ណោះ
ដែលបានទទួលដីនេះពីព្រោះពាក់កណ្តាលទៀតបានទទួលដីនៅត្រើយម្ខាងនៃទន្លេយ័រដាន់។
លោកបានផ្តល់ឲ្យ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម ។ ការបកប្រែផ្សេងទៀត «
លោកម៉ូសេបានចាត់ខ្ញុំ»
ស្រុកម៉ាហាណែម ... យ៉ាអ៊ៀរ ... ក្រុងអាសថារ៉ូត... ក្រុងអេទ្រី
ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។
លោកបានផ្តល់ឲ្យ
នេះអាចត្រូវបានថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម ។ ការបកប្រែផ្សេងទៀត «
លោកម៉ូសេបានប្រគល់របស់ទាំងនេះ »
លោកម៉ាកៀរ
នេះគឺជាឈ្មោះរបស់មនុស្ស ។
Joshua 13:32
នេះគឺជាទឹកដីដែលលោកម៉ូសេបានប្រគល់ដល់ពួកគេ
ទឹកដីដែលលោកម៉ូសេបានប្រគល់អោយកុលសម្ព័ន្ធអ៊ីស្រាអែល
នៅត្រើយខាងនាយទន្លេយ័រដាន់ត្រូវបានប្រគល់អោយ
ដូចទឹកដីដែលលោកម៉ូសេបានប្រគល់អោយពួកគេទុកជាកម្មសិទ្ធ
ជារៀងរហូតតទៅ។ ការបកប្រែផ្សេងទៀត «
នេះគឺជាទឹកដីដែលលោកម៉ូសេបានកំណត់ប្រគល់ឲ្យពួកគេជាមរតក»។
ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ប្រជាជនអ៊ីស្រាអែលជាមរតករបស់ពួកគេ
ដូចដែលលោកបាននិយាយជាមួយពួកគេ។
អ្នកនិពន្ធនិយាយពីកិត្តិយសដ៏អស្ចារ្យរបស់ពួកលេវីតាមរយៈការបម្រើព្រះអម្ចាស់
ដូចជាបូជាចារ្យដែលព្រះអម្ចាស់ជារបស់អ្វីម៉្យាងដែលពួកគេនឹងទទួល។
ការបកប្រែផ្សេងទៀត « ព្រះអម្ចាស់គឺជាព្រះជាម្ចាស់នៃអ៊ីស្រាអែលជាអ្វី
ដែលពួកគេមាន »

---

14 [1]ទាំងអស់នេះជាតំបន់ដែលប្រជាជនអ៊ីស្រាអែលបានទទួលជាមរតករបស់ពួកគេនៅក្នុងស្រុកកាណាន ដែលមានលោកបូជាចារ្យអេលាសា
លោកយ៉ូស្វេជាកូនរបស់នូន និងដោយមេដឹកនាំកុលសម្ព័ន្ធដូនតារបស់ពួកគេ ជាមួយនឹងប្រជាជនអ៊ីស្រាអែលបានបែងចែកឲ្យពួកគេ។
[2]មរតករបស់ពួកគេត្រូវបានជ្រើសរើសដោយការចាប់ឆ្នោតគឺសម្រាប់កុលសម្ព័ន្ធទាំងប្រាំបួន និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល
ដូចដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ។[3]លោកម៉ូសេក៏បានផ្តល់ទឹកដីជាមរតកដល់កុលសម្ព័ន្ធទាំងពី
និងកុលសម្ព័ន្ធពាក់កណ្តាលទៀតនៅឯត្រោយម្ខាងទន្លេយ័រដាន់ ប៉ុន្តែ ពួកលេវីមិនទទួលបានទឹកដីជាមរតកឡើយ។[4]កុលសម្ព័ន្ធរបស់លោកយ៉ូសែប
តាមពិតទៅគឺពីរកុលសម្ព័ន្ធ គឺម៉ាណាសេ និងអេប្រាអ៊ីម។ កុលសម្ព័ន្ធលេវីមិនទទួលបានទឹកដីជាមរតកទេ ប៉ុន្តែ មានក្រុងសម្រាប់រស់នៅ
ដែលមានកន្លែងសម្រាប់សត្វពាហនៈរបស់ពួគេ និងដាក់ទ្រព្យរបស់ពួកគេ។[5]ប្រជាជនអ៊ីស្រាអែលបានធ្វើទៅតាមអ្វីដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ ដូច្នេះ
គេបានបែងចែកទឹកដីគ្នា។
[6]បន្ទាប់មក កុលសម្ព័ន្ធយូដាមកជួបលោកយ៉ូស្វេនៅគីលកាល។ លោកកាលែបកូនរបស់លោកយេភូនេក្នុងអំបូរកេណាសនិយាយទៅកាន់លោកថា៖
«អ្នកដឹងពីអ្វីដែលព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គដែលទាក់ទងលោក ហើយនឹងខ្ញុំនៅការដេស បារនៀរ។
[7]កាលនោះខ្ញុំអាយុសែសិបឆ្នាំនៅពេលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់ចាត់ខ្ញុំឲ្យទៅកាដេស បារនាដើម្បីស៊ើបការណ៍ក្នុងទឹកដីនេះ។
ខ្ញុំបានរាយការណ៍ដល់លោកនូវអ្វីដែលមាននៅក្នុងចិត្តរបស់ខ្ញុំ។
[8]ប៉ុន្តែ បងប្អូនដែលទៅជាមួយខ្ញុំបានធ្វើឲ្យប្រជាជនបាក់ទឹកចិត្តជាមួយនឹងសេចក្តីភ័យខ្លាច។ ប៉ុន្តែ ខ្ញុំបានដើរតាមព្រះអម្ចាស់ជាព្រះរបស់ខ្ញុំយ៉ាងអស់ពីចិត្ត។
[9]លោកម៉ូសេបានស្បថនៅថ្ងៃនោះថា៖ «ទឹកដីដែលជើងរបស់អ្នកឆ្លងកាត់នឹងក្លាយទៅជាមរតករបស់អ្នក និងរបស់កូនចៅរបស់ជារៀងរហូត
ដោយសារតែអ្នកបានដើរតាមព្រះអម្ចាស់ជាព្រះរបស់ខ្ញុំយ៉ាងអស់ពីចិត្ត»។
[10]ឥឡូវមើលចុះ! ព្រះអម្ចាស់បានទុកជីវិតឲ្យខ្ញុំនៅសែសិបប្រាំឆ្នាំក្រោយមកនេះ ដូចដែលព្រះអង្គមានបន្ទូល
គឺចាប់ពីពេលដែលព្រះអម្ចាស់មានបន្ទូលមកលោកម៉ូសេពេលដែលអ៊ីស្រាអែលដើរនៅក្នុងទីរហោស្ថាន។ ឥឡូវមើលចុះ! នៅថ្ងៃនេះខ្ញុំអាយុបានប៉ែតសិបប្រាំឆ្នាំហើយ។
[11]នៅថ្ងៃនេះ ខ្ញុំនៅតែមានកម្លាំងដូចនៅថ្ងៃដែលលោកម៉ូសេបញ្ជូនខ្ញុំទៅដែរ។ កម្លាំងរបស់ខ្ញុំនៅពេលនេះ គឺខ្លាំងដូចពីមុន សម្រាប់ធ្វើសង្គ្រាម សម្រាប់ទៅ និងមក។
[12]ដូច្នេះ សូមប្រគល់តំបន់ភ្នំនេះមកឲ្យខ្ញុំឥឡូវនេះ ជាកន្លែងដែលព្រះអម្ចាស់បានសន្យាដល់ខ្ញុំនៅថ្ងៃនោះ។ ដូចដែលអ្នកបានឮនៅថ្ងៃនោះថា ជនជាតិអាណាក់
ដែលនៅទីនោះក្រុងរបស់គេជាក្រុងដែលមានកំពែងរឹងមាំ។ ព្រះអម្ចាស់នឹងគង់នៅជាមួយខ្ញុំ ហើយខ្ញុំនឹងដេញអ្នកទាំងនោះចេញដូចដែលព្រះអម្ចាស់បានមានបន្ទូល»។
[13]បន្ទាប់មក លោកយ៉ូស្វេក៏ឲ្យពរលោក ហើយប្រគល់ក្រុងហេប្រូនជាមរតកដល់កាលែបជាកូនរបស់លោកយេភូនេ។[14]ដូច្នេះ
ហេប្រូនក្លាយជាមរតករបស់លោកកាលែបជាកូនរបស់លោកយេភូនេក្នុងអំបូរកេណាសរហូតដល់សព្វថ្ងៃនេះ

generated on Wed Sep 10 16:16:32 2025

ដោយសារលោកបានដើរតាមព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលដោយអស់ពីចិត្ត។[15]ឥឡូវនេះក្រុងពីមុនដែលមានឈ្មោះថា គៀយ៉ាតអេបាបានប្តូរឈ្មោះមកហេប្រូនវិញ។ (អេបាជាក្រុងដែលមានមនុស្សមាឌធំៗក្នុងចំណោមអាណាក់)។ បន្ទាប់មក ទឹកដីនោះលែងមានសង្គ្រាមទៀតហើយ។

Joshua 14:1
ជាតំបន់ដែលប្រជាជនអ៊ីស្រាអែល បានទទួលជាមរតករបស់ពួកគេ
ទឹកដីដែលប្រជាជនអ៊ីស្រាអែល បានទទួលត្រូវបានគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិអចិន្ត្រៃយ៍។
ដែលមានលោកបូជាចារ្យអេលាសា លោកយ៉ូស្វេជាកូនរបស់នូន
និងដោយមេដឹកនាំកុលសម្ព័ន្ធដូនតារបស់ពួកគេ
ជាមួយនឹងប្រជាជនអ៊ីស្រាអែលបានបែងចែកឲ្យពួកគេ។
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ដែលបូជាចារ្យអេឡាសារយ៉ូស្វេជាកូនរបស់នូន
និងមេដឹកនាំកុលសម្ព័ន្ធនៃក្រុមគ្រួសារដូនតារបស់ពួកគេ
នៅក្នុងប្រជាជនអ៊ីស្រាអែលបានប្រគល់ទៅឲ្យពួកគេ »
ដោយមេដឹកនាំ
« មេដឹកនាំកុលសម្ព័ន្ធ »
Joshua 14:2
មរតករបស់ពួកគេត្រូវបានជ្រើសរើស ដោយការចាប់ឆ្នោត
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត « អេឡាសារ
យ៉ូស្វេ និងមេដឹកនាំកុលសម្ព័ន្ធបានបោះឆ្នោតជាច្រើនដើម្បីកំណត់មរតក »
ដូចដែលព្រះអម្ចាស់បានបង្គាប់ដល់លោកម៉ូសេ
ត្រង់នេះពាក្យថា « ដៃ » សំដៅទៅលើលោកម៉ូសេ ហើយមានន័យថា
ព្រះអម្ចាស់បានប្រើលោកម៉ូសេជាភ្នាក់ងារដើម្បីបញ្ជាលោក ។
ការបកប្រែផ្សេងទៀត « តាមរយៈលោកម៉ូសេ »
លោកម៉ូសេក៏បានផ្តល់ទឹកដីជាមរតកដល់កុលសម្ព័ន្ធទាំងពី
និងកុលសម្ព័ន្ធពាក់កណ្តាលទៀតនៅឯត្រោយម្ខាងទន្លេយ័រដាន់ ប៉ុន្តែ
ពួកលេវីមិនទទួលបានទឹកដីជាមរតកឡើយ។
កុលសម្ព័ន្ធពាក់កណ្តាលខាងនាយទន្លេយ័រដាន់
តែកុលសម្ព័ន្ធលេវីពុំបានទទួលទឹកដីជាមរតកឡើយ ។
ទឹកដីដែលលោកម៉ូសេបានប្រគល់អោយកុលសម្ព័ន្ធ ត្រូវបានរាប់បញ្ចូលដូចជាដី
ដែលជាចំណែកមរតក ដែលពួកគេបានទទួលជាមរតកជារៀងរហូត។
កុលសម្ព័ន្ធលេវីមិនទទួលបានទឹកដីជាមរតកទេ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ហើយលោកម៉ូសេមិនបានប្រគល់ចំណែកនៃមរតក
អោយពួកលេវីនៅក្នុងស្រុកនោះទេ »
ទទួលបានទឹកដី
« ផ្នែក »
ប៉ុន្តែ មានក្រុងសម្រាប់រស់នៅ
កិរិយាស័ព្ទអាចត្រូវបានផ្គត់ផ្គង់ពីឃ្លាមុន។ ការបកប្រែផ្សេងទៀត «
ប៉ុន្តែគាត់បានផ្តល់ឲ្យដល់ពួកគេនៅទីក្រុងដើម្បីរស់នៅ »
មានកន្លែងសម្រាប់សត្វពាហនៈ
វាលស្មៅសម្រាប់សត្វពាហនៈស៊ី
ដាក់ទ្រព្យរបស់ពួកគេ
របស់របរដែលពួកគេត្រូវការដូច្នេះ ពួកគេអាចផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេ
Joshua 14:6
លោកយេភូនេ
នេះគឺជាឈ្មោះរបស់មនុស្ស ។
អំបូរកេណាស
នេះគឺជាឈ្មោះរបស់មនុស្សមួយក្រុម ។
ខ្ញុំបានរាយការណ៍ដល់លោកនូវអ្វីដែលមាននៅក្នុងចិត្តរបស់ខ្ញុំ។
នៅទីនេះពាក្យ « ចិត្ត » តំណាងឲ្យគំនិត។ ឃ្លានេះគឺជាឃ្លាដែលមានន័យមិនធម្មតា
ដែលសំដៅទៅលើរបាយការណ៍ដែលត្រូវបានផ្តល់ឲ្យ ដោយស្មោះត្រង់។
ការបកប្រែផ្សេងទៀត « ខ្ញុំបាននាំរបាយការណ៍មកគាត់វិញ ដោយស្មោះត្រង់ »
Joshua 14:8
បានធ្វើឲ្យប្រជាជនបាក់ទឹកចិត្តជាមួយនឹងសេចក្តីភ័យខ្លាច
ធ្វើឲ្យប្រជាជនភ័យខ្លាចខ្លាំងណាស់
ត្រូវបានគេនិយាយថាហាក់ដូចជាធ្វើឲ្យចិត្តរបស់ប្រជាជនរលាយ ។
ការបកប្រែផ្សេងទៀត « ធ្វើឲ្យប្រជាជនភ័យខ្លាចយ៉ាងខ្លាំង »
ខ្ញុំបានដើរតាមព្រះអម្ចាស់ជាព្រះរបស់ខ្ញុំ យ៉ាងអស់ពីចិត្ត។
ត្រូវបានគេនិយាយថាស្មោះត្រង់ចំពោះព្រះអម្ចាស់ ។
ដូចជានិយាយថាដើរតាមព្រះអម្ចាស់ទាំងស្រុង ការបកប្រែផ្សេងទៀត «
ខ្ញុំនៅតែស្មោះត្រង់នឹងព្រះអម្ចាស់ »
ទឹកដី ... ជើងរបស់អ្នកឆ្លងកាត់នឹងក្លាយទៅជាមរតករបស់អ្នក និងរបស់កូនចៅរបស់ជារៀងរហូត
ទឹកដីដែលលោកកាលែប និងកូនចៅរបស់គាត់ នឹងត្រូវបានគេនិយាយនោះ
គឺជាដីដែលពួកគេ នឹងទទួលជាមត៌កជារៀងរហូត ។
ទឹកដីដែលជើងរបស់អ្នកឆ្លងកាត់
នៅទីនេះ « ជើងរបស់អ្នក » តំណាងឲ្យកាលែប។ ការបកប្រែផ្សេងទៀត «
ដីដែលអ្នកបានដើរកាត់ »
Joshua 14:10
ឥឡូវមើលចុះ!
នេះមានន័យថា « ស្តាប់ » ។ ពាក្យនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វី
ដែលត្រូវនិយាយបន្ទាប់។
ពេលដែលអ៊ីស្រាអែលដើរនៅក្នុងទីរហោស្ថាន
« ខណៈពេលដែលប្រជាជនអ៊ីស្រាអែល ធ្វើដំណើរនៅក្នុងទីរហោស្ថាន »
កម្លាំងរបស់ខ្ញុំនៅពេលនេះ គឺខ្លាំងដូចពីមុន
« ខ្ញុំនៅតែខ្លាំងដូចពេលនេះដែរ »
សម្រាប់ទៅ និងមក
នេះគឺជាការសម្គាល់សំដៅទៅលើសកម្មភាពប្រចាំថ្ងៃ។ ការបកប្រែផ្សេងទៀត «
សម្រាប់រឿងដែលខ្ញុំធ្វើរាល់ថ្ងៃ »
Joshua 14:12
តំបន់ភ្នំ
អាចមានន័យថា ១) ទួលធំៗ ឬភ្នំតូចៗ ឬ ២) ភ្នំមួយ។
ជនជាតិអាណាក់
នេះគឺជាឈ្មោះរបស់ក្រុមមនុស្ស។
Joshua 14:13
ប្រគល់ក្រុងហេប្រូនជាមរតកដល់កាលែប
ហេប្រុនត្រូវបានគេនិយាយថា ជាមរតកដែលកាលែបបានទទួល
ជាអ្នកមានសិទ្ធិកាន់កាប់ជារៀងរហូត។
ដល់សព្វថ្ងៃនេះ
នេះសំដៅទៅលើ អំឡុងពេលដែលអ្នកនិពន្ធបានសរសេរកណ្តាលនេះ។
ដោយសារលោកបានដើរតាមព្រះអម្ចាស់អស់ពីចិត្ត
ការរស់នៅស្មោះត្រង់ចំពោះព្រះអម្ចាស់ គឺដូចជាការដើរតាមព្រះអម្ចាស់ទាំងស្រុង ។
ការបកប្រែផ្សេងទៀត « គាត់នៅតែស្មោះត្រង់នឹងព្រះអម្ចាស់ »
គៀយ៉ាតអេបា
នេះគឺជាឈ្មោះរបស់ទីកន្លែង។
បន្ទាប់មក ទឹកដីនោះលែងមានសង្គ្រាមទៀតហើយ។
ប្រជាជនលែងប្រយុទ្ធនឹងសង្គ្រាម
ត្រូវបានគេនិយាយដូចជាទឹកដីដែលមនុស្សបានសម្រាកពីសង្គ្រាម ។
សូមមើលឃ្លានេះនៅ ១១:២៣ ។ ការបកប្រែផ្សេងទៀត «
ពេលនោះប្រជាជនលែងធ្វើសង្គ្រាមលើទឹកដីទៀតហើយ »

---

15 [1]ទឹកដីរបស់កុលសម្ព័ន្ធយូដាដែលប្រគល់តាមអំបូររបស់គេរៀងៗខ្លួនគឺចាប់ពីព្រំប្រទល់ភាគខាងត្បូងស្រុកអេដុំ ជាមួយនឹងវាលរហោស្ថានស៊ីននៅខាងត្បូងបំផុត។
[2]ព្រំប្រទល់របស់ពួកគេនៅខាងត្បូងចាប់ពីចុងសមុទ្រអំបិល ចាប់ពីជ្រោយដែលបែរទៅទិសខាងត្បូង។
[3]ព្រំប្រទល់បន្ទាប់របស់ពួកគេចាប់ពីភាគខាងត្បូងនៃភ្នំអាក្រាប៊ីមរហូតដល់ស៊ីន ហើយបន្តរហូតដល់ភាគខាងត្បូងកាដេស បារនៀរ តាមហេតស្រូន ហើយឡើងទៅអាដា
និងការកា។[4]វាត្រូវឆ្លងកាត់អាសមូន រហូតដល់ស្រុកអស៊ីប ហើយមកទល់នឹងសមុទ្រ។ នេះជាព្រំប្រទល់ខាងត្បូងរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[5]ព្រំប្រទល់ភាគខាងកើតគឺសមុទ្រអំបិល នៅមាត់ទន្លេយ័រដាន់។ ព្រំប្រទល់ភាគខាងជើងចាប់ពីជ្រោយសមុទ្រ នៅឯម៉ាត់ទន្លេយ័រដាន់។[6]ចាប់ពីបេត ហុកឡា កាត់តាមខាងជើងបេតអារ៉ាបា។ បន្ទាប់មកវាទៅជាប់នឹងថ្មដុំបូហានដែលជាឈ្មោះកូនរបស់លោករូបេន។
[7]បន្ទាប់មក ព្រំប្រទល់នេះទៅដល់ក្រុងដេបៀរ តាមជ្រលងភ្នំអាគ័រ និងទៅខាងជើងទៅកាន់គីលកាល់ ដែលនៅទល់មុខភ្នំអាឌូមីម ដែលនៅខាងត្បូងជ្រលងភ្នំ។ បន្ទាប់មក ព្រំប្រទល់ឆ្លងកាត់ប្រភពទឹកអេន សេម៉េស ហើយទៅអេន រ៉ូកែល។[8]បន្ទាប់មក ព្រំប្រទល់ទៅដល់ជ្រលងភ្នំហ៊ិនុម ទៅដល់ខាងត្បូងក្រុងយេប៊ូស (ដែលជាក្រុងយេរូសាឡិម)។ បន្ទាប់មក បន្តរហូតដល់កំពូលភ្នំដែលនៅលើជ្រលងភ្នំហ៊ីនុមភាគខាងលិច ដែលនៅចុងខាងជើងជ្រលងភ្នំរេផែម។
[9]បន្ទាប់មក ព្រំប្រទល់លាតសន្ធឹងពីកំពូលភ្នំទៅដល់ប្រភពទឹកណិបតា ហើយបន្តពីនោះទៅដល់ក្រុងនានានៃភ្នំអេប្រូន។ បន្ទាប់មក ព្រំប្រទល់បត់ជុំវិញក្រុងបាឡា (គឺដូចក្រុងគារយ៉ាត យារីម)។[10]បន្ទាប់មក ព្រំប្រទល់នេះវង់ជុំវិញភាគខាងលិចបាឡាទៅដល់ភ្នំសៀរ កាត់តាមម្ខាងនៃភ្នំយារីមភាគខាងជើង (ដូចគ្នានឹងភ្នំកេសាឡូន) ចុះទៅដល់បេតសេម៉េស និងកាត់ទៅដល់ធីមណា។
[11]ព្រំប្រទល់ចេញទៅភាគខាងជើងភ្នំអេក្រូន ហើយបន្ទាប់មកបត់ជុំវិញស៊ីក្រូន និងឆ្លងកាត់ភ្នំបាឡា ពីទីនោះបន្តទៅដល់យ៉ាប់នាល។[12]ព្រំប្រទល់ចប់ត្រង់សមុទ្រ។ ព្រំប្រទល់ខាងលិចគឺសមុទ្រធំ និងតំបន់ឆ្នេរ។ នេះជាព្រំប្រទល់ជុំវិញកុលសម្ព័ន្ធយូដា តាមអំបូររបស់គេរៀងៗខ្លួន។
[13]ក្នុងការរក្សាបញ្ញត្តរបស់ព្រះអម្ចាស់លោកយ៉ូស្វេបានឲ្យកិច្ចការមួយដល់លោកកាលែបជាកូនរបស់លោកយេភូនេក្នុងការកាន់កាប់ទឹកដីក្នុងចំណោមកុលសម្ព័ន្ធយូដា គារយ៉ាត អើបា គឺក្រុងហេប្រូន អើបាត្រូវជាឪពុករបស់លោកអណាក់)។[14]លោកកាលែបបានបណ្តេញកូនប្រុសៗរបស់លោកអណាក់បីនាក់ គឺលោកសេសាយ លោកអហ៊ីម៉ាន និងលោកតាលម៉ាយ ដែលជាអ្នកជំនាន់ក្រោយរបស់លោកអណាក់។[15]លោកបានចេញពីទីនោះទៅវាយយកក្រុងដេបៀរ (ក្រុងដេបៀរគេធ្លាប់ហៅថាគារយ៉ាតសេភើរ)។
[16]លោកកាលែបនិយាយថា៖ «មនុស្សដែលវាយគារយ៉ាត សេភើរ ហើយដណ្តើមបាន នោះខ្ញុំនឹងប្រគល់កូនស្រីរបស់ខ្ញុំគឺនាងអាក់សាធ្វើជាប្រពន្ធ»។[17]លោកអូធ្នាល ជាកូនរបស់លោកកេណាសជាប្អូនប្រុសរបស់លោកកាលែប វាយយកក្រុងនោះបាន។ លោកកាលែបក៏លើកនាងអាក់សា ជាកូនស្រីរបស់លោក ឲ្យធ្វើជាប្រពន្ធគាត់។
[18]ក្រោយមក លោកអាក់សាបានមកនៅជាមួយលោកអូធ្នាល ហើយនាងទទូចឲ្យគាត់សុំដីពីឪពុករបស់នាង។ នៅពេលដែលនាងចេញលាទៅ
លោកកាលែបបាននិយាយនឹងនាងថា៖ «តើកូនចង់បានអ្វី»?
[19]នាងអាក់សាឆ្លើយថា៖ «សូមធ្វើតាមសំណូមពរកូនផង តាំងពីពុកបានចែកទឹកដីនេកេវឲ្យកូន សូមចែកប្រភពទឹកឲ្យកូនខ្លះផង»។ បន្ទាប់មក
លោកកាលែបក៏ចែកប្រភពទឹកខាងលើ និងប្រភពទឹកខាងក្រោមឲ្យនាង។
[20]នេះជាមរតករបស់កុលសម្ព័ន្ធយូដាដែលបានឲ្យតាមអំបូររបស់គេ។
[21]ក្រុងទាំងឡាយដែលជាកម្មសិទ្ធិរបស់កុលសម្ព័ន្ធយូដានៅខាងត្បូងបំផុត ដល់ព្រំប្រទល់ស្រុកអេដុម មានកាបសៀល អេឌើរ យ៉ាគើរ[22]គីណា ឌីម៉ូណា អាដាដា[23]កេដែស ហាសោរ អ៊ីថ្នាន[24]ស៊ីភ តេលែម បេអាឡូត។
[25]ហាសោរ ហាដាថា កេរីយ៉ូត ហេតស្រូន (គេក៏ហៅថាហាសោរ)[26]អាម៉ាម សេម៉ា ម៉ូឡាដា[27]ហាត់សារ-កាដដា ហេសម៉ូន បេតផាលែត[28]ហាត់សារ សូអាល បៀរសេបា ប៊ីសយ៉ុតយ៉ា។
[29]បាឡា អ៊ីយីម អាត់សែម[30]អែលថូឡាត កេសៀល ហោម៉ា[31]ស៊ីគឡាក់ មាដម៉ាណា សាន សាណា[32]ល្បាអូត ស៊ីលហ៊ីម អាយីន និងរីម៉ូន។ មានម្ភៃប្រាំបួនក្រុងរួមទាំងភូមិរបស់ពួកគេផងដែរ។
[33]នៅតាមភ្នំទាបៗ មាន៖ ក្រុងអែសថោល ក្រុងសូរ៉ាស់[34]ក្រុងអាសណា ក្រុងសាណូអា ក្រុងអេន កានីម ក្រុងតាពួរ ក្រុងអេណាម[35]ក្រុងយ៉ារមូត ក្រុងអាឌូឡាំ ក្រុងសូគរ ក្រុងអាសេកា[36]ក្រុងស្ហារ៉ែម ក្រុងអាឌីថែម និងក្រុងកេដេរ៉ា (គឺក្តេរ៉ូថែម)។ មានដប់បួនក្រុងរួមទាំងភូមិរបស់ពួកគេ។
[37]ក្រុងសេណាន ក្រុងហាដាសា មីគដាល កាដ[38]ក្រុងឌីលាន ក្រុងមីសប៉ា ក្រុងយ៉ុគធាល[39]ក្រុងឡាគីស ក្រុងបូសកាត់ ក្រុងអេក្លូន។
[40]ក្រុងកាបូន ក្រុងឡាម៉ាស ក្រុងគីតលីស[41]ក្រុងកេដេរ៉ូត ក្រុងបេតដាកូន ក្រុងណាអាម៉ា និងក្រុងម៉ាកេដា។ មានចំនួនដប់ប្រាំមួយទីក្រុងរួមទាំងភូមិរបស់ពួកគេផង។
[42]ក្រុងលីបណា ក្រុងអេធើរ ក្រុងអាសាន[43]ក្រុងយីបថា ក្រុងអាសណា ក្រុងនេស៊ីប[44]ក្រុងកៃឡា ក្រុងអាកស៊ីប និងក្រុងម៉ារីសា។
មានចំនួនប្រាំបួនទីក្រុងរួមទាំងភូមិរបស់ពួកគេផង។
[45]ក្រុងអេក្រូន ជួយក្រុងជុំវិញ និងភូមិនានា[46]ពីក្រុងអេក្រូន រហូតដល់សមុទ្រ ព្រមទាំងភូមិទាំងនានានៅជិតក្រុងអាសដូឌរួមទាំងភូមិរបស់ពួកគេ។[47]ក្រុងអាសដូឌ និងស្រុកភូមិនៅជុំវិញ ក្រុងកាសា និងក្រុងនៅជុំវិញទៅដល់ទឹកធ្លាក់នៅអេស៊ីប និងឆ្នេរសមុទ្រ។
[48]នៅក្នុងតំបន់ភ្នំ មានក្រុងសាមៀរ ក្រុងយ៉ាតទៀរ ក្រុងសូគរ[49]ក្រុងដាណា ក្រុងគារយ៉ាត ក្រុងសានណា (គឺក្រុងដេបៀរ)[50]ក្រុងអាណាប ក្រុងអែសធេម៉ូរ ក្រុងអានីម[51]ក្រុងកូសែន ក្រុងហូឡូន និងក្រុងគីឡោ។ មានទាំងអស់ដប់មួយក្រុងរួមទាំងភូមិរបស់ពួកគេ។
[52]ក្រុងអារ៉ាប ក្រុងឌូម៉ា ក្រុងអែសអៀន[53]ក្រុងយ៉ានិម ក្រុងបេត តាពូអា ក្រុងអាផេកា[54]ក្រុងហិមកា ក្រុងគារយ៉ាត អើបា (គឺហេប្រូន) និងស៊ីអោរ។ មានទាំងអស់ប្រាំបួនក្រុងរួមទាំងភូមិរបស់ពួកគេ។
[55]ក្រុងម៉ាអូន ក្រុងកើមែល ក្រុងស៊ីភ ក្រុងយូថា[56]ក្រុងយេសរាល ក្រុងយ៉ុកដាម ក្រុងសាណូអា[57]ក្រុងកាអ៊ីន ក្រុងគីបៀរ និងក្រុងធីមណា។ មានទាំងអស់ដប់ក្រុងរួមទាំងភូមិរបស់ពួកគេ។
[58]ក្រុងហាល់ហ៊ូល ក្រុងបេតសើរ ក្រុងកេដោរ[59]ក្រុងម៉ារ៉ាត ក្រុងបេតអាណូត និងក្រុងអែលទិកុន។ មានទាំងអស់ប្រាំមួយក្រុងរួមទាំងភូមិរបស់ពួកគេ។
[60]ក្រុងគារយ៉ាត បាល (គឺក្រុងគៀរីយ៉ាត យារីម) និងក្រុងរ៉ាបាត គឺមានទាំងអស់ក្រុងពីររួមទាំងភូមិរបស់ពួកគេ។[61]នៅក្នុងវាលរហោស្ថានមានក្រុងបេតអារ៉ាបា ក្រុងមីតឌីន ក្រុងសេកាកា[62]ក្រុងនីបសាន ក្រុងអៀហា ក្រុងមេឡាក់ និងក្រុងអេន-គេឌី។ មានទាំងអស់ដប់ប្រាំមួយក្រុងរួមទាំងភូមិរបស់ពួកគេ។
[63]ប៉ុន្តែ សម្រាប់ជនជាតិយេប៊ូស ការកាន់កាប់ក្រុងយេរូសាឡិមកុលសម្ព័ន្ធយូដាមិនអាចចេញពួកគេចេញបានឡើយ
ដូច្នេះជនជាតិយេប៊ូសរស់នៅទីនោះជាមួយកុលសម្ព័ន្ធយូដារហូតដល់សព្វថ្ងៃនេះ។

Joshua 15:1
វាលរហោស្ថានស៊ីន
នេះគឺជាឈ្មោះនៃតំបន់វាលរហោស្ថាន ។
ចាប់ពីចុងសមុទ្រអំបិល ចាប់ពីជ្រោយដែលបែរទៅទិសខាងត្បូង។
«ពីឈូងសមុទ្រដែលបែរមុខទៅទិសខាងត្បូង នៅចុងសមុទ្រអំបិល» ។
ឃ្លាទាំងពីរនេះសំដៅទៅលើទីតាំងតែមួយ ។
ឃ្លាទីពីរបញ្ជាក់ពីចំណុចដែលព្រំដែនខាងត្បូងចាប់ផ្តើម។
ជ្រោយ
ផ្នែកតូចមួយនៃសមុទ្រដែលលាតសន្ធឹងចូលដី
ដែលបែរទៅទិសខាងត្បូង។
« ដែលបែរទៅទិសខាងត្បូង »

Joshua 15:3
ព្រំប្រទល់បន្ទាប់របស់ពួកគេ
« ព្រំប្រទល់ដីជាកម្មសិទ្ធិរបស់កុលសម្ព័ន្ធយូដា »
ភ្នំអាក្រាប៊ីម ...ស៊ីន... ហេតស្រូន ... កាដេស ... ការកា ... អាសមូន
ទាំងអស់នេះគឺជាឈ្មោះរបស់ទីកន្លែង។
រហូតដល់ស្រុកអេស៊ីប
ទឹកទន្លេតូចមួយនៅចុងនិរតីដ៏ជិតទឹក នៃប្រទេសអេស៊ីប ។
Joshua 15:5
នៅមាត់ទន្លេយ័រដាន់
គាត់ចង្អុលបង្ហាញថាទឹកទន្លេហូរចូលសមុទ្រ
ត្រូវបានគេនិយាយថាដូចជាមាត់ទន្លេ។

generated on Wed Sep 10 16:16:32 2025

ព្រំប្រទល់ ... ចាប់ពី
« ព្រំដែន ... គឺ »
បេត ហុកឡា ... បេតអារ៉ាបា
ទាំងនេះគឺជាឈ្មោះរបស់ទីកន្លែង។
ផ្ទាំងថ្មបូហាន
នេះទំនងជាដុំថ្មធំមួយដែលនរណាម្នាក់ បានបង្កើត ជាសញ្ញាសំគាល់
និងដាក់ឈ្មោះតាមបុរសនោះគឺបូហាន។
Joshua 15:7
ក្រុងដេបៀរ ... ជ្រលងភ្នំអាគ័ ... ភ្នំអាឌូមីម ... អេន សេម៉េស ...អេន រ៉ូកែល ... ជ្រលងភ្នំហ៊ិនុម ...
ជើងជ្រលងភ្នំរេផែម
ទាំងអស់នេះគឺជាឈ្មោះរបស់ទីកន្លែង។
Joshua 15:9
ណិបតា ... ភ្នំអេប្រូន ... ក្រុងបាឡា ... ក្រុងគារយ៉ាត យារីម) ...ភ្នំសៀរ ... ភ្នំយារីម ... ភ្នំ
កេសាឡូន ... បេតសេម៉េស ... ធីមណា
ទាំងអស់នេះគឺជាឈ្មោះរបស់ទីកន្លែង។
Joshua 15:11
ស៊ីក្រូន ... ភ្នំបាឡា ... យ៉ាប់នាល
ទាំងអស់នេះគឺជាឈ្មោះទីកន្លែង។
Joshua 15:13
កុលសម្ព័ន្ធយូដា គារយ៉ាត អើបា ... ក្រុងដេបៀរ... គារយ៉ាត សេភើរ
ទាំងអស់នេះគឺជាឈ្មោះរបស់ទីកន្លែង។
អើបា ... លោកអណាក់ ... លោកសេសាយ ...លោកអហ៊ីម៉ាន ... លោកតាលម៉ាយ
ទាំងអស់នេះគឺជាឈ្មោះរបស់មនុស្សប្រុស។
ប្រុសៗរបស់លោកអណាក់បីនាក់ គឺលោកសេសាយ លោកអហ៊ីម៉ាន និងលោកតាលម៉ាយ
ឈ្មោះទាំងនេះតំណាងឲ្យកុលសម្ព័ន្ធរបស់មនុស្ស ដែលជាកូនចៅលោកសេសាយ
លោកអាហ៊ីម៉ាន និងលោកតាលម៉ាយ ។ ពាក្យ « កូនប្រុស » និង « ពូជពង្ស »
នៅក្នុងបរិបទនេះមានន័យដូចគ្នា។ ការបកប្រែផ្សេងទៀត « ត្រកូលទាំង ៣ គឺ
លោកសេសាយ លោកអហ៊ីម៉ាន និងលោកតាលម៉ាយ
ដែលជាកូនចៅរបស់លោកអាណាក់ »
លោកបានចេញពីទីនោះទៅវាយយកក្រុងដេបៀរ
« គាត់បានឡើងពីទីនោះដើម្បីប្រយុទ្ធប្រឆាំង »
Joshua 15:16
គារយ៉ាត សេភើរ
ទាំងនេះគឺជាឈ្មោះរបស់ទីកន្លែង។
នាងអាក់សា
នេះគឺជាឈ្មោះរបស់ស្ត្រី។
លោកអូធ្នាល ... លោកកេណាស
នេះគឺជាឈ្មោះរបស់បុរស។
Joshua 15:18
លោកអាក់សាបានមកនៅជាមួយលោកអូធ្នាល
នេះគឺជាសម្តីដើម ដែលសំដៅទៅលើអាក់សា ក្លាយជាភរិយារបស់អូធ្នាល។
ការបកប្រែផ្សេងទៀត « នៅពេលដែលអាក់សា ក្លាយជាភរិយារបស់អូធ្នាល »
នាងទទូចឲ្យគាត់សុំដីពីឪពុករបស់នាង។
អាចត្រូវបានបកប្រែជាការនិយាយផ្ទាល់។ ការបកប្រែផ្សេងទៀត «
នាងបានជម្រុញឲ្យគាត់ សុំឲ្យឪពុកខ្ញុំផ្តល់ឲ្យខ្ញុំនូវវាលមួយ»
Joshua 15:19
ប្រភពទឹកខាងលើ និងប្រភពទឹកខាងក្រោម
ពាក្យ « ខាងលើ » និង « ខាងក្រោម» ទំនងជាសំដៅទៅលើកំពស់ភូមិសាស្ត្រ
នៃប្រភពទឹក។
Joshua 15:20
នេះជាមរតករបស់កុលសម្ព័ន្ធយូដា
ទឹកដីដែលកុលសម្ព័ន្ធយូដាទទួលបាន
គឺត្រូវនិយាយដូចជាដីដែលជាចំណែកមរតក
ដែលពួកគេបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត «
នេះជាទឹកដីដែលកុលសម្ព័ន្ធយូដាបានទទួលជាមរតក »
Joshua 15:21
ឃ្លាភ្ជាប់
អ្នកនិពន្ធបានកត់បញ្ជីទីក្រុងខាងត្បូង ដែលស្រុកយូដាបានកាន់កាប់។
បញ្ជីបន្តរហូតដល់ ១៥: ២៩។
Joshua 15:25
ឃ្លាភ្ជាប់
បន្តបញ្ជីឈ្មោះរបស់ទីក្រុង។
Joshua 15:29
ឃ្លាភ្ជាប់
បន្តបញ្ជីឈ្មោះរបស់ទីក្រុង។
Joshua 15:33
ព័ត៌មានទូទៅ
អ្នកនិពន្ធកត់ត្រាអំពីទីក្រុងភាគខាងជើង ដែលប្រទេសយូដាបានកាន់កាប់។
Joshua 15:37
ឃ្លាភ្ជាប់
អ្នកនិពន្ធកត់ត្រាអំពីទីក្រុងភាគខាងជើង ដែលប្រទេសយូដាបានកាន់កាប់។
Joshua 15:40
ឃ្លាភ្ជាប់
អ្នកនិពន្ធកត់ត្រាអំពីទីក្រុងភាគខាងជើង ដែលប្រទេសយូដាបានកាន់កាប់។
Joshua 15:42
ឃ្លាភ្ជាប់
អ្នកនិពន្ធបានសរសេរអំពីទីក្រុងដែលស្រុកយូដាកាន់កាប់។
Joshua 15:45
ឃ្លាភ្ជាប់
អ្នកនិពន្ធបានសរសេរអំពីទីក្រុងដែលស្រុកយូដាកាន់កាប់។
តាំងទីលំនៅ
« ភូមិ »
ទឹកធ្លាក់នៅអេស៊ីប
ទឹកទន្លេតូចមួយនៅចុងទិសនិរតី នៃទឹកដីក្បែរប្រទេសអេស៊ីប
Joshua 15:48
ឃ្លាភ្ជាប់
អ្នកនិពន្ធបានសរសេរអំពីទីក្រុងដែលស្រុកយូដាកាន់កាប់។
Joshua 15:52
ឃ្លាភ្ជាប់
អ្នកនិពន្ធបានសរសេរអំពីទីក្រុងដែលស្រុកយូដាកាន់កាប់។
Joshua 15:55
ឃ្លាភ្ជាប់
អ្នកនិពន្ធបានសរសេរអំពីទីក្រុងដែលស្រុកយូដាកាន់កាប់។
Joshua 15:58
ឃ្លាភ្ជាប់
អ្នកនិពន្ធបានសរសេរអំពីទីក្រុងដែលស្រុកយូដាកាន់កាប់។
Joshua 15:60
ឃ្លាភ្ជាប់
អ្នកនិពន្ធបានសរសេរអំពីទីក្រុងដែលស្រុកយូដាកាន់កាប់។
Joshua 15:63
រហូតដល់សព្វថ្ងៃនេះ
នេះសំដៅទៅលើអំឡុងពេល ដែលអ្នកនិពន្ធបានសរសេរកណ្ឌនេះ។

16 [1]ការបែងចែកទឹកដីដល់កុលសម្ព័ន្ធយូ៉សែបលាតសន្ធឹងចាប់ពីទន្លេយ័រដាននៅក្រុងយេរីខូ តំបន់ទឹកធ្លាក់ខាងកើតក្រុងយេរីខូ ទៅដល់វាលរហៅស្ថាន
ឡើងពីយេរីខូឆ្លងកាត់តំបន់ភ្នំបេតអែល។[2]បន្ទាប់មក ចេញពីបេតអែលទៅដល់ក្រុងលូស និងឆ្លងកាត់តាមក្រុងអាថារ៉ូត ជាទឹកដីស្រុកអើគី។
[3]បន្ទាប់មក ចុះទៅភាគខាងលិចនៃតំបន់របស់ជនជាតិយ៉ាផ្លេទីត រហូតដល់តំបន់បេតហូរ៉ូនភាគខាងក្រោម និងបន្ទាប់មក ទៅកេស៊ើរ ហើយបញ្ចប់នៅត្រង់សមុទ្រ។[4]
កុលសម្ព័ន្ធយ៉ូសែប គឺលោកម៉ាណាសេ និងលោកអេប្រាអ៊ីមបានទទួលទឹកដីជាមរតកបែបនេះឯង។
[5]ទឹកដីរបស់កុលសម្ព័ន្ធអេប្រាអ៊ីមត្រូវបានបែងចែកតាមអំបូរនីមួយៗដូចខាងក្រោម៖ ព្រំប្រទល់ជាមរតករបស់ពួកគេភាគខាងលិចគឺចាប់ពីក្រុងអាថារ៉ូត-អាដើររហូតដល់
បេតហូរ៉ូនផ្នែកខាងលើ[6]ហើយចេញពីនោះបន្តទៅសមុទ្រ។ ចេញពីក្រុងមីគមេថានៅផ្នែកខាងជើង ហើយត្រឡប់ទៅខាងកើតក្រុងតាណាត ស៊ីឡូ ហើយឆ្លងកាត់
ខាងក្រោយក្រុងនោះទៅខាងកើតយ៉ាណូហា។[7]បន្ទាប់មក ព្រំប្រទល់នោះចុះពីយ៉ាណូហាទៅអាថារ៉ូត ទៅណារ៉ាតា ហើយមកដល់ក្រុងយេរីខូ បញ្ចប់ត្រង់ទន្លេយ័រដាន់។

generated on Wed Sep 10 16:16:32 2025

[8]ចេញពីព្រំប្រទល់តាពួរទៅភាគខាងលិច រហូតដល់ទឹកធ្លាក់ខាណា និងបញ្ចប់ត្រឹមសមុទ្រ។ នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធអេប្រាអ៊ីម តាមអំបូររបស់គេ[9]ដោយ
មានទាំងក្រុងនានាដែលជ្រើសរើសសម្រាប់កុលសម្ព័ន្ធអេប្រាអ៊ីម ជាមួយនឹងមរតករបស់កុលសម្ព័ន្ធម៉ាណាសេ រួមទាំងក្រុងទាំងប៉ុន្មាន ក៏ដូចជាភូមិរបស់ពួកគេ។
[10]ពួកគេពុំបានបណ្តេញជនជាតិកាណានដែលរស់នៅក្នុងកេស៊ើរឡើយ ដូច្នេះជនជាតិកាណានបានរស់នៅជាមួយអេប្រាអ៊ីមរហូតដល់សព្វថ្ងៃនេះ ប៉ុន្តែ
អ្នកទាំងនេះត្រូវបានបង្ខំឲ្យធ្វើការយ៉ាងធ្ងន់។

Joshua 16:1
កុលសម្ព័ន្ធលោកយ៉ូសែប
« កុលសម្ព័ន្ធយ៉ូសែប » មានកុលសម្ព័ន្ធនៃកូនប្រុសពីរនាក់របស់លោកយ៉ូសែបគឺ
ម៉ាណាសេ និងអេប្រាអិម។ ចាប់តាំងពីពាក់កណ្តាលនៃកុលសម្ព័ន្ធម៉ាណាសេ
បានតាំងទីលំនៅខាងកើតទន្លេយ័រដាន់ ឃ្លានេះសំដៅទៅលើកុលសម្ព័ន្ធអេប្រាអ៊ីម
និងពាក់កណ្តាលនៃកុលសម្ព័ន្ធម៉ាណាសេ។ ការបកប្រែផ្សេងទៀត «
កុលសម្ព័ន្ធអេប្រាអ៊ីម និងពាក់កណ្តាលផ្សេងទៀតរបស់កុលសម្ព័ន្ធម៉ាណាសេ »
ក្រុងលូស ... ក្រុងអាចារ៉ូត
នេះគឺជាឈ្មោះរបស់ទឹកន្លែង។
ស្រុកអើគី
នេះគឺជាឈ្មោះរបស់ក្រុមមនុស្ស។
Joshua 16:3
ជនជាតិយ៉ាផ្លេទីត
នេះគឺជាឈ្មោះរបស់ទឹកន្លែង។
តំបន់បេតហូរ៉ូនភាគខាងក្រោម ... កេស៊ើរ
នេះគឺជាឈ្មោះរបស់ទឹកន្លែង។
កុលសម្ព័ន្ធយ៉ូសែប គឺលោកម៉ាណាសេ និងលោកអេប្រាអ៊ីម
« កុលសម្ព័ន្ធម៉ាណាសេនិងអេប្រាអ៊ីម ជាកូនរបស់យ៉ូសែប »
បានទទួលទឹកដីជាមរតក
ទឹកដីដែលកុលសម្ព័ន្ធម៉ាណាសេ និងអេប្រាអ៊ីមកាន់កាប់គឺត្រូវចាត់ទុកដូចជាដី
ដែលជាចំណែកមរតកដែលពួកគេបានទទួលជាមរតកជារៀងរហូត។
ការបកប្រែផ្សេងទៀត « បានទទួលទឹកដីនេះជាមរតករបស់ពួកគេ »
Joshua 16:5
ទឹកដី ... បានបែងចែកតាមអំបូរនីមួយៗ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ទឹកដី ...
ដែលយ៉ូស្វេបានប្រគល់ទៅឱ្យអម្បូររបស់ពួកគេ »
ក្រុងអាចារ៉ូត-អាដើរ ...បេតហូរ៉ូនផ្នែកខាងលើ ... ក្រុងមីគមេថា ... ក្រុងតាណាត
ស៊ីឡូ...យ៉ាណូហា... ណារ៉ាតា
ទាំងអស់នេះគឺជាឈ្មោះរបស់ទឹកន្លែង។
Joshua 16:8
តាពួរ ...ខាណា
ទាងនេះគឺជាឈ្មោះរបស់ទឹកន្លែង។
នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធអេប្រាអ៊ីម
ទឹកដីដែលអេប្រាអ៊ីមបានកាន់កាប់គឺ
ត្រូវនិយាយដូចជាទឹកដីដែលជាចំណែកមរតក
ដែលពួកគេបានទទួលជាមរតកជារៀងរហូត។ ការបកប្រែផ្សេងទៀត «
នេះជាទឹកដីដែលកុលសម្ព័ន្ធអេប្រាអ៊ីមបានទទួលជាមរតក »
តាមអំបូររបស់គេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ កាបកប្រែផ្សេងទៀត «
ដែលលោកយ៉ូស្វេបានប្រគល់ទៅឱ្យអំបូររបស់ពួកគេ »
ក្រុងនានាដែលជ្រើសរើស
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម ។ ការបកប្រែផ្សេងទៀត «
ទីក្រុងដែលលោកយ៉ូស្វេបានជ្រើសរើស»
ជាមួយនឹងមរតករបស់កុលសម្ព័ន្ធម៉ាណាសេ
ទឹកដីដែលកុលសម្ព័ន្ធម៉ាណាសេបានកាន់កាប់ គឺ
ត្រូវទុកវាជាមរតកដែលពួកគេបានទទួលជាមរតកជារៀងរហូត។
ការបកប្រែផ្សេងទៀត «
នៅក្នុងទឹកដីដែលកុលសម្ព័ន្ធម៉ាណាសេបានទទួលជាមរតក »
Joshua 16:10
រហូតដល់សព្វថ្ងៃនេះ
នេះសំដៅទៅលើអំឡុងពេលដែលអ្នកនិពន្ធសរសេរកណ្ដាលនេះ។
អ្នកទាំងនេះត្រូវបានបង្ខំឲ្យធ្វើការយ៉ាងធ្ងន់។
នេះអាចត្រូវបានថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ជនជាតិអ៊ីស្រាអែលបង្ខំប្រជាជនទាំងនេះអោយធ្វើជាទាសករ »

---

17 [1]នេះជាការបែងចែកទឹកដីសម្រាប់កុលសម្ព័ន្ធម៉ាណាសេ (ដែលជាកូនច្បងរបស់លោកយ៉ូសែប) ដែលសម្រាប់លោកម៉ាកៀរ ដែលជាកូនច្បងរបស់លោកម៉ាណាសេ
ដែលលោកជាឪពុករបស់លោកកាឡាដ។ កូនចៅរបស់លោកម៉ាកៀរបានទទួលទឹកដីស្រុកកាឡាដ និងស្រុកបាសាន
ដោយសារលោកម៉ាកៀរជាមនុស្សអង់អាចក្លាហាន។[2]ទឹកដីដែលបែងចែកដល់អ្នកផ្សេងទៀតក្នុងកុលសម្ព័ន្ធម៉ាណាសេតាមអំបូរនីមួយៗអបៀស៊ើរ ហេឡេក អាសរាល
ស៊ីគែមហេភើរ និងសេមីដា។ នេះគឺជាកូនចៅប្រុសៗរស់លោកម៉ាណាសេជាកូនរបស់លោកយ៉ូសែប តំណាងដោយអំបូររបស់ពួកគេរៀងៗខ្លួន។
[3]លោកស្លូផិហាត ជាកូនរបស់លោកហេភើរ ជាកូនរបស់លោកកាឡាដ ជាកូនរបស់លោកម៉ាកៀរ ដែលជាកូនរបស់លោកម៉ាណាសេ លោកគ្មានកូនប្រុសទេ មានតែកូនស្រី
។ ឈ្មោះកូនស្រីៗរស់លោក គឺនាងម៉ាឡា នាងណូហា នាងហុកឡា នាងមីលកា និងធើសា។[4]ពួកនាងបានទៅជួបលោកបូជាចារ្យអេឡាសារ និងលោកយ៉ូស្វេ ជាកូនរបស់
លោកនូន ព្រមទាំងជាមេដឹកនាំប្រជាជន ដោយនិយាយថា៖ «ព្រះអម្ចាស់បានបង្គាប់លោកម៉ូសេឲ្យប្រគល់ទឹកដីជាមរតកដល់ពួកយើង ដូចបងប្អូនប្រុសៗរបស់ពួកនាងខ្ញុំ
ដែរ»។ ដូច្នេះ ស្របតាមបទបញ្ជារបស់ព្រះអម្ចាស់ លោកក៏ប្រគល់ទឹកដីជាមរតកដល់ពួកនាងក្នុងចំណោមបងប្អូនប្រុសៗរស់ឪពុកពួកនាង។
[5]ទឹកដីដប់ចំណែកបានចែកឲ្យកុលសម្ព័ន្ធម៉ាណាសេនៅក្នុងស្រុកកាឡាដ និងស្រុកបាសាន
ដែលនៅត្រើយម្ខាងនៃទន្លេយ័រដាន់[6]ដោយសារតែកូនស្រីៗរបស់លោកម៉ាណាសេបានទទួលទឹកដីជាមរតករួចជាមួយកូនប្រុសៗរបស់លោកដែរ។
ទឹកដីកាឡាដត្រូវបានប្រគល់ឲ្យអ្នកផ្សេងទៀតនៅកុលសម្ព័ន្ធម៉ាណាេស។
[7]ទឹកដីនៃកុលសម្ព័ន្ធម៉ាណាសេចាប់ពីស្រុកអេស៊ើរទៅមីគមេថា ដែលនៅខាងកើតស៊ីគែម។ បន្ទាប់មក ព្រំប្រទល់ទៅខាងត្បូងទៅដល់ទឹកធ្លាក់ស្រុកអេន តាពួរ។[8](ទឹកដី
ស្រុកតាពួជាកម្មសិទ្ធិរបស់ម៉ាណាសេ ប៉ុន្តែ ក្រុងតាពួដែលជាប់នឹងព្រំប្រទល់ម៉ាណាសេ ជាកម្មសិទ្ធិរបស់កុលសម្ព័ន្ធអេប្រាអ៊ីម)។
[9]ព្រំប្រទល់ចុះទៅដល់ទឹកធ្លាក់ខាណា។ ទីក្រុងដែលនៅភាគខាងត្បូងទឹកធ្លាក់ក្នុងចំណោមទីក្រុងរបស់ម៉ាណាសេជាកម្មសិទ្ធិរបស់អេប្រាអ៊ីម។
ព្រំប្រទល់របស់ម៉ាណាសេគឺនៅភាគខាងជើងទឹកធ្លាក់ ហើយចប់ត្រឹមសមុទ្រ។[10]ទឹកដីភាគខាងត្បូងជាកម្មសិទ្ធិរបស់អេប្រាអ៊ីម
ហើយទឹកដីភាគខាងជើងជាកម្មសិទ្ធិរបស់ម៉ាណាសេ ដែលមានសមុទ្រជាព្រំប្រទល់។ នៅផ្នែកខាងជើងទៅដល់អេស៊ើរ ហើយខាងកើតមានព្រំប្រទល់ដល់អ៊ីសាខារ។
[11]ទាំងនៅក្នុងទឹកដីរបស់អ៊ីសាខារ និងអេស៊ើរ កុលសម្ព័ន្ធម៉ាណាសេកាន់កាប់ក្រុងបេតសាន និងភូមិរបស់ក្រុងនោះ ក្រុងយីបលាម និងភូមិដែលរបស់ក្រុងនោះ ក្រុងដោរ
ក្រុងអេន ដោរ និងភូមិដែលរបស់ក្រុងនោះ ក្រុងតាណាក់ និងភូមិដែលរបស់ក្រុងនោះ ក្រុងមេគីដោ និងភូមិរបស់ក្រុងនោះ (និងទីក្រុងទីបីគឺនេបហេត)។
[12]តែកុលសម្ព័ន្ធម៉ាណាសេមិនអាចកាន់កាប់ក្រុងទាំងនោះបានទេដោយសារតែជនជាតិកាណានបន្តរស់នៅក្នុងទឹកដីទាំងនោះ។
[13]នៅពេលដែលជនជាតិអ៊ីស្រាអែលមានកម្លាំងខ្លាំងឡើង ពួកគេបានយកជនជាតិកាណានធ្វើការជាទម្ងន់ ប៉ុន្តែ
ពួកគេមិនបានបណ្តេញអ្នកទាំងនោះចេញទាំងស្រុងនោះទេ។
[14]បន្ទាប់មក កូនចៅរបស់លោកយ៉ូសែបនិយាយទៅកាន់លោកយ៉ូស្វេថា៖ «ហេតុអ្វីបានជាលោកចែកទឹកដីតែមួយចំណែកដល់ពួកយើងដូច្នេះ
យើងមានគ្នាច្រើនណាស់ដោយសារព្រះអម្ចាស់បានប្រទានពរដល់យើង»?[15]លោកយ៉ូស្វេបាននិយាយនឹងពួកគេថា៖ «បើអ្នកមានគ្នាច្រើន សូមឡើងទៅលើភ្នំ
ហើយកាប់ឆ្ការដីសម្រាប់ពួកអ្នករាល់គ្នាចុះនៅក្នុងស្រុកពេរីស៊ីត និងស្រុករេផែមទៅ។ ចូរធ្វើដូច្នេះដោយសារតែទឹកដីអេប្រាអ៊ីមតូចពេកសម្រាប់អ្នករាល់គ្នា»។

generated on Wed Sep 10 16:16:32 2025

[16]កូនចៅរបស់លោកយ៉ូសែបនិយាយថា៖ «ភ្នំនោះមិនគ្រប់គ្រាន់សម្រាប់ពួកយើងទេ។ ប៉ុន្តែ ជនជាតិកាណានដែលរស់នៅក្នុងជ្រលងភ្នំនោះមានរទេះចម្បាំងធ្វើពីដែកទាំងអ្នកនៅក្រុងបេតសាន និងភូមិរបស់ក្រុងនោះ ព្រមទាំងអស់អ្នកដែលរស់នៅតាមជ្រលងភ្នំយេសរាលដែរ»។[17]បន្ទាប់មក លោកយ៉ូស្វេនិយាយទៅកុលសម្ព័ន្ធយ៉ូសែប គឺទៅកុលសម្ព័ន្ធអេប្រាអ៊ីម និងកុលសម្ព័ន្ធម៉ាណាសេថា៖ «អ្នកមានគ្នាច្រើន ហើយអ្នកក៏មានកម្លាំងខ្លាំងដែរ។ អ្នកមិនត្រូវមានដីតែមួយចំណែកឡើយ។ [18]ភ្នំនេះនឹងក្លាយជារបស់អ្នក។ ដូច្នេះអ្នកត្រូវឆ្ការព្រៃទាំងនេះដើម្បីធ្វើជាកម្មសិទ្ធ។ អ្នកត្រូវបណ្តេញជនជាតិកាណានចេញ ទោះបីជាពួកគេមានរទេះចំបាំងដែក ហើយទោះបីជាពួកគេខ្លាំងយ៉ាងណាក៏ដោយ»។

Joshua 17:1

កូនច្បងរបស់លោកម៉ាណាសេ ដែលលោកជាឪពុក

« កូនច្បង គាត់ជាកូនច្បង »

លោកម៉ាកៀរ ... អបៀស៊ើរ ហេឡេក អាសរាល ស៊ីគែម ហេភើរ និងសេមីដា

ទាំងអស់នេះគឺជាឈ្មោះរបស់មនុស្ស ។

កូនចៅរបស់លោកម៉ាកៀរបានទទួលទឹកដីស្រុកកាឡាដ និងស្រុកបាសាន

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត « យ៉ូស្វេបានប្រគល់ទឹកដីស្រុកកាឡាដ និងស្រុកបាសានអោយកូនចៅម៉ាកគើរ »

ទឹកដីដែលបែងចែកដល់ ... តាមអំបូរនីមួយៗ

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទកម្ម។ ការបកប្រែផ្សេងទៀត « លោកយ៉ូស្វេបានប្រគល់ដី ... ហើយបានប្រគល់ឲ្យតាមអម្បូរនិមួយៗរបស់ពួកគេ »

Joshua 17:3

លោកស្លូធិហាត ... លោកហេភើរ ... លោកបូជាចារ្យអេឡាសារ

ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស ។

នាងម៉ាឡា,នាងណូហា, នាងហុកឡា , នាងមីលកា, និងធើសា

ទាំងនេះគឺជាឈ្មោះរបស់មនុស្សស្រី។

ប្រគល់ទឹកដីជាមរតកដល់ពួកយើង

ទឹកដីនេះត្រូវបានគេនិយាយថា ជាមរតកដែលប្រជាជនបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត « ដើម្បីផ្តល់ឲ្យយើងនូវដីមួយចំនួនជាមរតក »

លោកក៏ប្រគល់ទឹកដីជាមរតកដល់ពួកនាង

អាចមានន័យថា ១) « លោកយ៉ូស្វេបានប្រគល់មរតក ឲ្យស្ត្រីទាំងនោះ» ឬ ២) អេឡាសារបានប្រគល់ឲ្យស្ត្រីទាំងនោះនូវមរតក។

Joshua 17:5

ទឹកដីដប់ចំណែកបានចែកឲ្យ

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «លោកយ៉ូស្វេបានប្រគល់ដីចំនួន ១០ ចំណែក »

ទឹកដីដប់ចំណែក

«១០ចំណែក»

បានទទួលទឹកដីជាមរតក

ដីនេះត្រូវបានគេនិយាយថា ជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត « បានទទួលបានដីជាមរតក»

ទឹកដីកាឡាដត្រូវបានប្រគល់ឲ្យ

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត «លោកយ៉ូស្វេបានប្រគល់ទឹកដីនៃស្រុកកាឡាដ»

Joshua 17:7

ព្រំប្រទល់ទៅខាងត្បូង

« ឆ្ពោះទៅភាគខាងត្បូង »

មីគមេថា ... ក្រុងតាពួ

ទាំងនេះគឺជាឈ្មោះនៃទឹកន្លែង ។

Joshua 17:9

ព្រំប្រទល់

« ព្រំដែននៃទឹកដីម៉ាណាសេ »

ទឹកធ្លាក់

ទន្លេតូចមួយ

ខាណា

ឈ្មោះនៃកន្លែងទឹកធ្លាក់

នៅផ្នែកខាងជើងទៅដល់អេស៊ើរ ហើយខាងកើតមានព្រំប្រទល់ដល់

អាចមានន័យថា ១) ព្រំដែននៃទឹកដីម៉ាណាសេនៅខាងជើងប៉ះដីដែលជាកម្មសិទ្ធិរបស់កុលសម្ព័ន្ធអេស៊ើរ ឬ ទី២) ដែលម្នាក់អាចធ្វើដំណើរទៅខាងជើងឆ្ពោះទៅដល់ស្រុកអេស៊ើរ។ ការបកប្រែផ្សេងទៀត « អេស៊ើរស្ថិតនៅផ្នែកខាងជើង » ឬ « អ្នកអាចធ្វើដំណើរទៅភាគខាងជើង ដើម្បីទៅដល់ស្រុកអេស៊ើរ »

ខាងកើតមានព្រំប្រទល់ដល់អ៊ីសាខារ។

កិរិយាស័ព្ទអាចត្រូវបានផ្តត់ផ្តង់ពីឃ្លាមុន។ ការបកប្រែផ្សេងទៀត « ទៅខាងកើតមនុស្សម្នាក់អាចទៅដល់អ៊ីសាខារ »

Joshua 17:11

ក្រុងបេតសាន ... ក្រុងយីបលាម ... ដោរ ... ក្រុងអេន...ក្រុងតាណាក់... ក្រុងមេគីដោ ... នេបហេត

ទាំងអស់នេះគឺជាឈ្មោះទឹកន្លែង។

Joshua 17:14

កូនចៅរបស់លោកយ៉ូសែប

នេះសំដៅទៅលើកុលសម្ព័ន្ធអេប្រាអ៊ីម និងម៉ាណាសេ។

ហេតុអ្វីបានជាលោកចែកទឹកដីតែមួយចំណែក ... ព្រះអម្ចាស់បានប្រទានពរដល់យើង»?

ប្រជាជនកុលសម្ព័ន្ធអេប្រាអ៊ីម និងម៉ាណាសេ សួរសំណួរនេះដើម្បីបញ្ជាក់ថា លោកយ៉ូស្វេគួរតែប្រគល់ទឹកដីអោយពួកគេថែមទៀត ។ ការបកប្រែផ្សេងទៀត « អ្នកគួរតែផ្តល់ឲ្យយើងច្រើនជាងមួយ ... ព្រះអម្ចាស់បានប្រទានពរដល់យើង » ។

ចែកទឹកដីតែមួយចំណែកដល់ពួកយើងដូច្នេះ

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ ទីពីរដីនេះត្រូវបានគេនិយាយថាជាមរតក ដែលប្រជាជនបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត « ការប្រគល់ដីមួយជាមរតករបស់យើង »

ចំណែក

ផ្នែក

មានគ្នាច្រើនណាស់

« ចំនួនមនុស្សជាច្រើន »

បើអ្នកមានគ្នាច្រើន

« ដោយសារអ្នកជាប្រជាជនមួយ ដែលមានចំនួនច្រើន »

ស្រុករផែម

នេះគឺជាឈ្មោះនៃក្រុមមនុស្ស។ (សូមមើល ការបកប្រែឈ្មោះ)

Joshua 17:16

ក្រុងបេតសាន ... ភ្នំយេសរាល

ទាំងនេះគឺជាឈ្មោះទឹកន្លែង។

កុលសម្ព័ន្ធយ៉ូសែប

ត្រង់នេះពាក្យ « ផ្ទះ» សំដៅទៅលើកូនចៅ។ ការបកប្រែផ្សេងទៀត « កូនចៅរបស់យ៉ូសែប »

អ្នកត្រូវឆ្ការព្រៃទាំងនេះ

« អ្នកនឹងការព្រៃព្រៃឈើ » ឬ « អ្នកនឹងកាប់ដើមឈើ »

---

18 [1]បន្ទាប់មក ប្រជាជនអ៊ីស្រាអែលទាំងអស់ជួបជុំគ្នានៅស៊ីឡូ។ ពួកគេដំឡើងតង់ជួបជុំគ្នានៅទីនោះ ហើយពួកគេកាន់កាប់ទឹកដីដែលនៅខាងមុខពួកគេ។
[2]នៅមានកុលសម្ព័ន្ធប្រាំពីរទៀតក្នុងចំណោមកុលសម្ព័ន្ធអ៊ីស្រាអែលដែលមិនទាន់បានទទួលទឹកដីជាមរតកនៅឡើយទេ។
[3]លោកយ៉ូស្វេនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលថា៖
«តើដល់ពេលណាទើបអ្នករាល់គ្នាទៅកាន់កាប់ទឹកដីដែលព្រះអម្ចាស់ជាព្រះជាម្ចាស់របស់ដូនតាអ្នករាល់គ្នាប្រទានឲ្យ?
[4]ចូរតែងតាំងមនុស្សប្រុសបីនាក់ពីក្នុងកុលសម្ព័នរបស់អ្នករាល់គ្នា ហើយខ្ញុំនឹងបញ្ជូនពួកគេទៅ។ ពួកគេនឹងចេញទៅ ហើយធ្វើការវាស់វែងទឹកដីទាំងនោះ។
ពួកគេនឹងសរសេរបាយការណ៍អំពីទឹកដីទាំងនោះជាមរតករបស់ពួកគេ ហើយពួកគេនឹងត្រឡប់មកជួបខ្ញុំវិញ។
[5]ពួកគេនឹងបែងចែកជាប្រាំពីរចំណែក។ យូដាត្រូវបន្តនៅក្នុងទឹកដីរបស់ពួកគេនៅខាងត្បូង ហើយកូនចៅលោកយ៉ូសែបត្រូវមានទឹកដីរបស់ពួកគេទៅខាងជើង។
[6]អ្នកត្រូវរៀបរាប់ពីដីនោះជាប្រាំពីរចំណែក ហើយត្រូវយករបាយការណ៍នោះមកឲ្យខ្ញុំនៅទីនេះ។ ខ្ញុំនឹងចាប់ឆ្នោតឲ្យអ្នករាល់គ្នានៅមុខព្រះអម្ចាស់ជាព្រះជាម្ចាស់របស់យើង។

generated on Wed Sep 10 16:16:32 2025

[7]កុលសម្ព័ន្ធលេវីគ្មានចំណែកអ្វីនៅក្នុងចំណោមអ្នករាល់គ្នាទេ ភាពជាបូជាចារ្យនៅមុខព្រះអម្ចាស់ជាមរតករបស់ពួកគេ។ កុលសម្ព័នកាដ រូបេន
និងម៉ាណាសេចំនួនពាក់កណ្តាលទៀតបានទទួលចំណែករបស់ពួកគេនៅត្រើយម្ខាងទន្លេយ័រដាន់។
នេះជាទឹកដីមរតកដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានប្រគល់ដល់ពួកគេ»។
[8]ដូច្នេះ ប្រុសៗទាំងនោះក៏ក្រោកឡើង ហើយចេញទៅ។ លោកយូ៉ាស្វេបានបង្គាប់ឲ្យពួកគេសរសេរបាយការណ៍ពីទឹកដីទាំងនោះដោយនិយាយថា៖
«ចូរទៅមើលទឹកដីទាំងនោះ រួចសរសេរបាយការណ៍ ហើយត្រឡប់មករកខ្ញុំវិញ។ ខ្ញុំនឹងចាប់ឆ្នោតនៅមុខព្រះអម្ចាស់នៅឯស៊ីឡូនេះសម្រាប់អ្នករាល់គ្នា»។[9]ដូច្នេះ
ប្រុសៗទាំងនោះក៏ចេញទៅ ហើយចូរទៅមើលទឹកដីទាំងនោះ រួចសរសេរបាយការណ៍នៅក្នុងក្រាំងមួយតាមចំនួនក្រុងរបស់ទឹកដីនោះជាប្រាំពីរចំណែក
ដោយបានកត់ពីក្រុងទាំងនោះជាចំណែកៗ។ ពួកគេក៏ត្រឡប់មករកលោកយ៉ូស្វេវិញនៅក្នុងជំរំនៅស៊ីឡូ។
[10]បន្ទាប់មក លោកយ៉ូស្វេក៏បានចាប់ឆ្នោតសម្រាប់ពួកគេនៅស៊ីឡូនៅមុខព្រះអម្ចាស់។ គឺនៅទីនោះហើយដែលលោកយ៉ូស្វេបានបែងចែកទឹកដីទៅដល់ជនជាតិអ៊ីស្រាអែល
គឺកុលសម្ព័ន្ធនីមួយៗបានទទួលចំណែកទឹកដីរបស់ពួកគេ។
[11]ការបែងចែកទឹកដីដល់កុលសម្ព័ន្ធបេនយ៉ាមីន គឺបានបែងចែកតាមអំបូររបស់ពួកគេរៀងៗខ្លួន។ ទឹកដីដែលពួកគេទទួលបាន គឺមានទីតាំងចន្លោះកូនចៅយូដា
និងកូនចៅរបស់យ៉ូសែប។[12]នៅភាគខាងជើង ព្រំប្រទល់របស់គេចាប់ផ្តើមពីទន្លេយ័រដាន់។ ព្រំប្រទល់ចាប់ពីភាគខាងជើងក្រុងយេរីខូ ហើយទៅតំបន់ភ្នំភាគខាងលិច
ទៅរហូតដល់វាលរហោស្ថានបេតអាវេន។
[13]ចេញពីទីនោះព្រំប្រទល់ភាគខាងត្បូងក្រុងលូស (គឺនៅកន្លែងដូងបេតអែលដែរ)។ បន្ទាប់មក ព្រំប្រទល់ចុះទៅអាថារ៉ូត អាដើរ ក្បែរភ្នំដែលនៅខាងត្បូងបេតហូរ៉ូនក្រោម។
[14]បន្ទាប់មក ព្រំប្រទល់ចេញទៅទិសមួយទៀត៖ នៅខាងលិចភ្នំនេះ ព្រំប្រទល់បត់ទៅទិសខាងត្បូងទៅដល់ភ្នំដោយឆ្លងកាត់ពី បេតហូរ៉ូន។ ព្រំប្រទល់នេះបញ្ចប់ត្រឹម
គារយ៉ាត បាល (គឺគារយ៉ាតយ៉ារីម) ជាក្រុងដែលជាកម្មសិទ្ធិរបស់កុលសម្ព័ន្ធយូដា។ នេះហើយព្រំប្រទល់ភាគខាងលិចរបស់គេ។
[15]តំបន់ខាងត្បូងចាប់ពីគារយ៉ាត យ៉ារីម។ ព្រំប្រទល់ចេញពីទៅនោះទៅដល់អេប្រុន ទៅដល់ប្រភពទឹកណិបតា។[16]បន្ទាប់មក ព្រំប្រទល់នេះចុះទៅព្រំប្រទល់ភ្នំដែលស្ថិតនៅ
ទល់មុខនឹងជ្រលងភ្នំហ៊ីនណម ដែលនៅខាងជើងជ្រលងរេផែម។ បន្ទាប់មកចុះតាមជ្រលងហ៊ីណម ខាងត្បូងជម្រាលភ្នំយេប៊ូស និងបន្តទៅអេន រ៉ូកែល។
[17]ព្រំប្រទល់ផ្នែកខាងជើងចេញទៅអេន សេម៉េស និងចេញពីទីនោះវាចេញទៅកេលីឡុតដែលនៅទល់មុខនឹងច្រកភ្នំអាឌូមីម។ បន្ទាប់មក ចុះមកផ្ទាំងថ្មរបស់លោក
បូហានជាកូនរបស់លោករូបេន។[18]ព្រំប្រទល់នេះឆ្លងកាត់ភាគខាងជើងតំបន់អារ៉ាបា នឹងចុះទៅតំបន់អារ៉ាបានោះ។
[19]ព្រំប្រទល់ឆ្លងកាត់ភាគខាងជើងបេត ហុកឡា។ ព្រំប្រទល់ចប់ត្រឹមឈូងសមុទ្រអំបិល នៅភាគខាងត្បូងទន្លេយ័រដាន់។ នេះជាព្រំប្រទល់ខាងត្បូង។[20]ទន្លេ
យ័រដាន់ជាព្រំប្រទល់ភាគខាងកើត។ នេះគឺជាទឹកដីមរតករបស់កុលសម្ព័ន្ធបេនយ៉ាមីន ដែលបានប្រគល់ជូនតាមអំបូររបស់គេរៀងៗខ្លួន
ចេញពីព្រំប្រទល់មួយទៅព្រំប្រទល់មួយទៀត។
[21]នេះជាក្រុងរបស់កុលសម្ព័ន្ធបេនយ៉ាមិនតាមអំបូររបស់ពួកគេគឺមាន យេរីខូ បេត ហុកឡា អេមាក់ កេស៊ីស[22]បេត អារ៉ាបា សេម៉ារ៉ែម បេតអែល[23]អាវីម ប៉ារ៉ា អូប្រា[24]កេផា
អាំម៉ូនី អូបនី កេបា។ មានក្រុងដប់ពីរ រួមទាំងភូមិផ្សេងៗរបស់ពួកគេផង។
[25]មានទាំងក្រុងគីបៀន រ៉ាម៉ា បៀរ៉ុត[26]មីសប៉ា កេភីរ៉ា ម៉ូសា[27]រេគែម យារពាល តារ៉ាឡា[28]សេឡា អេឡេប យេប៊ូស (គឺក្រុងយេរូសាឡិម) គីបៀរ គារយ៉ាត។
មានដប់បួនក្រុងរួមទាំងភូមិផ្សេងៗរបស់គេផង។ នេះជាចំណែកមរតកដែលចែកតាមអំបូរនៃកុលសម្ព័ន្ធបេនយ៉ាមីន។

Joshua 18:1

ពួកគេកាន់កាប់ទឹកដី

ពួកគេបានវាយដណ្តើមប្រជាជន ដែលបានរស់នៅក្នុងស្រុកនេះ
មុនពេលពួកគេដំឡើងត្រសាលជំនុំ។ ការបកប្រែផ្សេងទៀត «
បន្ទាប់ពីពួកគេបានកាន់កាប់ទឹកដី »

ដែលមិនទាន់បានទទួលទឹកដីជាមរតកនៅឡើយទេ។

ទឹកដីដែលកុលសម្ព័ន្ធនឹងទទួលបានត្រូវបានគេនិយាយថាជាមរតកដែលពួកគេ
នឹងទទួលជាកម្មសិទ្ធិជារៀងរហូត។ អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត « ដល់អស់អ្នកដែលលោកយ៉ូស្វេមិនបានប្រគល់ដីជាមត៌ក
»

Joshua 18:3

តើដល់ពេលណាទើបអ្នករាល់គ្នាទៅកាន់កាប់ទឹកដី ...ព្រះជាម្ចាស់របស់ដូនតាអ្នករាល់គ្នាប្រទានឲ្យ ?

លោកយ៉ូស្វេសួរសំណួរនេះ ដើម្បីលើកទឹកចិត្តជនជាតិអ៊ីស្រាអែល
ឲ្យកាន់កាប់ទឹកដីជាមរតក។ ការបកប្រែផ្សេងទៀត «
អស់រយៈពេលជាយូរមកហើយអ្នកបានបោះបង់ចោល ... បានផ្តល់ឲ្យអ្នក »។

ការរាស់វែងទឹកដី

ពាក្យថា « ឡើងចុះ » មានន័យថាគ្រប់ទិសដៅ ។ ការបកប្រែផ្សេងទៀត «
ទឹកដីគ្រប់ទីកន្លែង » ឬ «ពាសពេញទឹកដីទាំងមូល»

សរសេរបាយការណ៍អំពីទឹកដីទាំងនោះជាមរតក

នេះមានន័យថាពួកគេនឹងរៀបរាប់ ពីចំណែកទឹកដី ដែលកុលសម្ព័ន្ធនីមួយៗ
នឹងទទួលបានសម្រាប់ជាមរតក។

មរតករបស់ពួកគេ

ទឹកដីដែលពួកគេត្រូវធ្វើការវាស់វែងត្រូវបានគេនិយាយថាជាមរតកដែលកុលសម្ព័ន្ធនីមួយៗ
នឹងទទួលបានជាកម្មសិទ្ធិជារៀងរហូត។

Joshua 18:5

ព័ត៌មានទូទៅ

លោកយ៉ូស្វេកំពុងបន្តនិយាយ ទៅកាន់កូនចៅអ៊ីស្រាអែលរបស់គាត់។

ពួកគេនឹងបែងចែក

« ពួកគេនឹងបែងចែកដី »

លោកយូដាត្រូវបន្តនៅក្នុងទឹកដី

« កុលសម្ព័ន្ធយូដា នឹងនៅបន្តដដែល »

ហើយកូនចៅលោកយ៉ូសែប

នៅទីនេះពាក្យ « ផ្ទះ » តំណាងឲ្យកូនចៅរបស់ លោកយ៉ូសែប។
ឃ្លានេះសំដៅទៅលើកុលសម្ព័ន្ធ អេប្រាអ៊ីម និងម៉ាណាសេ។ ការបកប្រែផ្សេងទៀត
« កុលសម្ព័ន្ធអេប្រាអ៊ីមនិងម៉ាណាសេ » (សូមមើល និង

Joshua 18:7

ព័ត៌មានទូទៅ

លោកយ៉ូស្វេកំពុងបន្តនិយាយ ទៅកាន់កូនចៅនៃអ៊ីស្រាអែលរបស់គាត់។

គ្មានចំណែក

« គ្មានចំណែកនៃទឹកដី »

ភាពជាបូជាចារ្យនៅមុខព្រះអម្ចាស់ជាមរតករបស់ពួកគេ

លោកយ៉ូស្វេនិយាយអំពីកិត្តិយស ដ៏ខ្ពង់ខ្ពស់ដែលពួកលេវីមានតាមរយៈ
ការបម្រើព្រះអម្ចាស់ ដូចជាបូជាចារ្យ ដែលជាអ្វីដែលពួកគេបានទទួលជាមរតក។
ការបកប្រែផ្សេងទៀត « សម្រាប់ភាពជាបូជាចារ្យរបស់ព្រះអម្ចាស់
គឺជាអ្វីដែលពួកគេមាន »

ម៉ាណាសេចំនួនពាក់កណ្តាល

« ពាក់កណ្តាលនៃកុលសម្ព័ន្ធម៉ាណាសេ »

បានទទួលចំណែករបស់ពួកគេ

ទឹកដីដែលកុលសម្ព័ន្ធទទួលបានត្រូវបានគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត «
បានទទួលដីជាមរតករបស់ពួកគេ »

Joshua 18:8

ព័ត៌មានទូទៅ

លោកយ៉ូស្វេនិយាយទៅកាន់បុរស២១នាក់ ដែលត្រូវបានមើលទឹកដី ។

ចូរទៅមើលទឹកដី

ពាក្យថា « ឡើងចុះ » មានន័យថាគ្រប់ទិសដៅ។ សូមមើលនៅក្នុង ១៨: ៣ ។
ការបកប្រែផ្សេងទៀត « នៅគ្រប់ទិសដៅទាំងអស់នៅក្នុងដី » ឬ «
ពាសពេញទឹកដីទាំងមូល»

Joshua 18:10

គឺកុលសម្ព័ន្ធនីមួយៗបានទទួលចំណែកទឹកដីរបស់ពួកគេ។

អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ដល់កុលសម្ព័ន្ធនីមួយៗដែលលោកយ៉ូស្វេ បានចែកចំណែករបស់ខ្លួននៅក្នុងទឹកដី

generated on Wed Sep 10 16:16:32 2025

» (សូមមើល
Joshua 18:11
ការបែងចែកទឹកដីដល់កុលសម្ព័ន្ធបេនយ៉ាមីន គឺបានបែងចែកតាមអំបូររបស់ពួកគេរៀងៗខ្លួន។
អាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត « តាមអំបូរនីមួយៗ
នៃកុលសម្ព័ន្ធបេនយ៉ាមីនបានទទួលទឹកដី »
គឺមានទីតាំងចន្លោះកូនចៅយូដា និងកូនចៅរបស់យ៉ូសែប
« រវាងទឹកដីដែលជាកម្មសិទ្ធិរបស់កូនចៅយូដា
និងទឹកដីដែលជាកម្មសិទ្ធិរបស់កូនចៅយ៉ូសែប»
កូនចៅរបស់យ៉ូសែប
នេះសំដៅទៅលើកុលសម្ព័ន្ធអេប្រាអ៊ីម និងម៉ាណាសេ។
វាលរហោស្ថានបេតអាវេន
នេះគឺជាឈ្មោះទីកន្លែងមួយ។
Joshua 18:13
ព្រំប្រទល់ ... ព្រំប្រទល់
ទាំងនេះសំដៅទៅលើរឿងតែមួយ។
ក្រុងលូស ... អាថារ៉ូត អាដើរ ...បេតហូរ៉ូន... គារយ៉ាត បាល ..គារយ៉ាតយ៉ារីម
ទាំងអស់នេះគឺជាឈ្មោះទីកន្លែង។
Joshua 18:15
គារយ៉ាត យ៉ារីម ...អេប្រុន ... ណិបតា ... Ben ភ្នំហ៊ិនណម ... រេផែម ... ហ៊ីណម ... អេន រ៉ូកែល
ទាំងអស់នេះគឺជាឈ្មោះទីកន្លែង។
Joshua 18:17
អេន សេម៉េស ..កេលីឡូត ... ភ្នំអាឌូមីម ... បេត អារ៉ាបា
ទាំងអស់នេះគឺជាឈ្មោះទីកន្លែង។
ផ្នាំងថ្មរបស់លោកបូហាន
នេះគឺដូចជាដុំថ្មធំមួយ ដែលនរណាម្នាក់បានបង្កើតជាសញ្ញាសម្គាល់
និងបានដាក់ឈ្មោះតាមមនុស្សនោះគឺលោកបូហាន។ សូមមើលនៅក្នុង ១៥: ៥ ។
ព្រំប្រទល់នេះឆ្លងកាត់ភាគខាងជើងតំបន់អារ៉ាបា
ទឹកដីដែលមានទំរង់នៃជម្រាលរាងកោង ឬ រនាំងត្រូវបានគេនិយាយដូចជាស្មា។
ការបកប្រែផ្សេងទៀត « ជម្រាលបេតអារ៉ាបា »
Joshua 18:19
ឆ្លងកាត់ភាគខាងជើងបេត ហុកឡា
ទឹកដីដែលមានទម្រង់នៃជម្រាល ឬរនាំងត្រូវបានគេនិយាយដូចជាស្មា។
ការបកប្រែផ្សេងទៀត « ជម្រាលខាងជើងនៃបេតហុកឡា »
បេត ហុកឡា
នេះគឺជាឈ្មោះទីកន្លែងមួយ។
នេះគឺជាទឹកដីមរតករបស់កុលសម្ព័ន្ធបេនយ៉ាមីន
ទឹកដីដែលកុលសម្ព័ន្ធបេនយ៉ាមីនទទួលបាន
ត្រូវនិយាយដូចជាដីដែលជាចំណែកមរតក
ដែលពួកគេបានទទួលសិទ្ធកាន់កាប់ជារៀងរហូត។ ការបកប្រែផ្សេងទៀត «
នេះជាទឹកដីដែលកុលសម្ព័ន្ធបេនយ៉ាមីនទទួលបានជាមរតក»
ដែលបានប្រគល់ជូនតាមអំបូររបស់គេរៀងៗខ្លួន
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេបានប្រគល់វាទៅឲ្យអំបូរនីមួយៗ»
Joshua 18:21
ព័ត៌មានទូទៅ
អ្នកនិពន្ធបានចុះបញ្ជីទីក្រុងនានា
ដែលមាននៅក្នុងទឹកដីដែលកុលសម្ព័ន្ធបេនយ៉ាមីនទទួលបានជាមរតក។
ទាំងភូមិផ្សេងៗរបស់ពួកគេ
« ភូមិនៅជុំវិញពួកគេ »
Joshua 18:25
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តចុះបញ្ជីទីក្រុងនានាដែលមាននៅក្នុងទឹកដី
ដែលកុលសម្ព័ន្ធបេនយ៉ាមីនទទួលបានជាមរតក។
នេះជាចំណែកមរតកដែលចែកតាមអំបូរនៃកុលសម្ព័ន្ធបេនយ៉ាមីន។
ទឹកដីនិងក្រុងនានាដែលកុលសម្ព័ន្ធបេនយ៉ាមីនទទួលបានត្រូវគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជារៀងរហូត។ ការបកប្រែផ្សេងទៀត «
នេះជាទឹកដីនិងក្រុងដែលកុលសម្ព័ន្ធបេនយ៉ាមីនទទួលបានជាមត៌ក »

---

19 [1]សន្លឹកឆ្នោតទៅពីចំលើកុលសម្ព័ន្ធស៊ីម្មាន ហើយបានបែងចែកតាមអំបូររបស់ពួកគេរៀងៗខ្លួន។
ទឹកដីដែលពួកគេទទួលបានគឺនៅចំកណ្តាលទឹកដីរបស់កុលសម្ព័ន្ធយូដា។
[2]ទឹកដីជាមរតករបស់ពួកគេ គឺបៀរសេបា សេបា ម៉ូឡាដា[3]ហាតសា ស៊ូអាល បាឡា អាសែម[4]អែលថូឡាត បេធូលហោម៉ា។
[5]កុលសម្ព័ន្ធស៊ីម្មានក៏ទទួលបាន៖ ស៊ីគឡាក់ បេត ម៉ាកាបុត ហាតសា ស៊ូសា[6]បេត ល្បាអូត សារូហេន។ មានដប់បីក្រុងរួមទាំងភូមិរបស់ពួកគេ។
[7]កុលសម្ព័ន្ធស៊ីម្មានក៏ទទួលបាន៖ អាយីន រីម៉ូន អេធើរ និងអាសាន។ មានបួនក្រុងរួមទាំងភូមិផ្សេងៗរបស់ពួកគេ។
[8]មានទាំងភូមិដែលនៅជុំវិញនៅឆ្ងាយទៅដល់ក្រុងបាឡាត បៀរ (គឺរ៉ាម៉ាត់នៅក្នុងក្រុងនេកេវ)។ នេះជាទឹកដីដែលជាមរតករបស់កុលសម្ព័ន្ធស៊ីម្មាន
ដែលបានប្រគល់ឲ្យដល់អំបូរនីមួយៗ។[9]ទឹកដីដែលជាមរតករបស់កុលសម្ព័ន្ធស៊ីម្មានចាប់ចេញពីផ្នែកមួយនៃកុលសម្ព័ន្ធយូដា។
ដោយសារតែទឹកដីដែលបែងចែកដល់កុលសម្ព័ន្ធយូដាធំពេកសម្រាប់ពួកគេ ដូច្នេះ កុលសម្ព័ន្ធស៊ីម្មានក៏ទទួលបានទឹកដីជាមរតកនៅកណ្តាលទឹកដីរបស់ពួកគេទៅ។
[10]ឆ្នោតទីបីចំលើកុលសម្ព័ន្ធសាប់យូឡូន ហើយត្រូវបានប្រគល់ឲ្យតាមអំបូររបស់គេរៀងៗខ្លួន។ ព្រំប្រទល់នៃទឹកដីរបស់ពួកគេចាប់ពីសារីដ។
[11]ព្រំប្រទល់របស់ពួកគេចេញពីភាគខាងលិចទៅដល់ម៉ារ៉ាឡា ហើយប៉ះដាបាសែត បន្ទាប់មក លាតសន្ធឹងរហូតដល់ទឹកធ្លាក់ ដែលនៅទល់មុខនឹងយុកនាម។
[12]ចេញពីសារីដព្រំប្រទល់បែរទៅទិសខាងកើតហើយទៅដល់ព្រំប្រទល់ស្រុកគីស្លូត តាបោរ។ ចេញបីទីនោះបន្តទៅដល់ដាប្រាត ហើយឡើងទៅយ៉ាភា។
[13]ចេញពីទីនោះឆ្លងកាត់ភាគខាងកើតទៅដល់គីតា ហេភើរ អ៊ីតា កាស៊ីន ហើយទៅដល់រីម៉ូន និងបត់ទៅណេយ៉ា។
[14]ព្រំប្រទល់បត់ទៅខាងជើងដល់ហាណាថូន និងបញ្ចប់ត្រឹមជ្រលងយីបថា អែល។[15]តំបន់នេះរួមទាំងក្រុងកាថាត ណា ហាឡាល់ ស៊ីមរ៉ូន យីដាឡា និងបេថ្លេហិម។
មានដប់ពីរក្រុង និងរួមទាំងភូមិផ្សេងៗទៀតរបស់ពួកគេ។[16]នេះជាចំណែកទឹកដីមរតករបស់កុលសម្ព័ន្ធសាប់យូឡូន តាមអំបូររបស់ពួកគេ មានទាំងក្រុង
និងភូមិផ្សេងៗទៀតរបស់ពួកគេ។
[17]ឆ្នោតទីបួនចំលើកុលសម្ព័ន្ធអ៊ីសាខា ហើយបានប្រគល់ដល់អំបូររបស់ពួកគេ។[18]ទឹកដីរបស់ពួកគេមានក្រុងយេសរាល គីសាឡូត ស៊ូណែម[19]ហាផារ៉ែម ស៊ីអូន
អាណាក្រាត។
[20]រួមទាំងរ៉ាប៊ីត គីសយ៉ូន អាបេស[21]រេមេត អេន កានីម អេន ហាដា បេតផាសេ។[22]ព្រំប្រទល់របស់ពួកគេក៏ប៉ះនឹងក្រុងតាបោរ សាហាត់ ស៊ីម៉ា បេតសេមែស ហើយ
បញ្ចប់ត្រឹមទន្លេយ័រដាន់។ មានដប់ប្រាំមួយទីក្រុង រួមទាំងភូមិផ្សេងៗទៀតរបស់ពួកគេផងដែរ។
[23]នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធអ៊ីសាខា ហើយត្រូវបានប្រគល់ឲ្យតាមអំបូររបស់ពួកគេ មានទាំងក្រុង រួមទាំងភូមិផ្សេងៗទៀតរបស់ពួកគេ។
[24]ឆ្នោតទីប្រាំចំលើកុលសម្ព័ន្ធអេស៊ើរ ហើយបានប្រគល់ឲ្យអំបូររបស់ពួកគេ។[25]ទឹកដីរបស់ពួកគេរួមទាំងក្រុងហែលកាថ ហាលី បេថែន អាកសាប[26]អាឡាមេឡេក អាម៉ាដ
មីសាល។ នៅភាគខាងលិចព្រប្រទល់លាតសន្ធឹងទៅដល់ភ្នំកើមែល ទៅស៊ីហោរ លីបណាថ។
[27]បន្ទាប់មក បត់ទៅទិសខាងកើតដល់បេតដាកូន រហូតដល់សាប់យូឡូន និងជ្រលងភ្នំយីបថាអែល បន្តទៅទិសខាងជើង ដល់បេតអេមេក និងណេយែល។ បន្ទាប់មក
បន្តទៅក្រុងកាប៊ូល ទៅភាគខាងជើង។[28]បន្តដល់អេប្រូន រេហូប ហាំម៉ូន និងខាណា រហូតដល់ក្រុងស៊ីដូន។
[29]ព្រំប្រទល់ត្រឡប់ទៅរ៉ាម៉ា ហើយទៅដល់ក្រុងទីរ៉ុស។ បន្ទាប់មក ព្រំប្រទល់ត្រឡប់ទៅក្រុងហូសា និងបញ្ចប់ត្រឹមសមុទ្រក្នុងតំបន់អាកស៊ីប[30]ក្រុងអ៊ូម៉ា អាផេក និងរេហូប។
មានម្ភៃពីរក្រុង រួមទាំងភូមិផ្សេងៗទៀតរបស់ពួកគេ។
[31]នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធអាស៊ើរ ដែលបានប្រគល់ដល់អំបូររបស់ពួកគេ ទាំងក្រុង រួមទាំងភូមិផ្សេងៗទៀតរបស់ពួកគេផង។

generated on Wed Sep 10 16:16:32 2025

[32]ឆ្នោតទីប្រាំមួយចំលើកុលសម្ព័ន្ធណែបថាលី និងបានប្រគល់ដល់តាមអំបូររបស់គេ។[33]ព្រំប្រទល់របស់ពួកចាប់ពីហេលេប ពីដើមជ្រៃនៅឯសានណានីម បន្តដល់អាដាមី
ណេកិប និងយ៉ាប់នាល រហូតដល់ឡាក់គូម បញ្ចប់ត្រឹមទន្លេយ័រដាន់។[34]ព្រំប្រទល់ភាគខាងលិចទៅដល់អាសណូត តាបោរ ហើយទៅហ៊ូកុក ប៉ះទឹកដីសាប់យូឡូនផ្នែកខាង
ត្បូង និងទៅដល់ទឹកដីអេស៊ើរនៅភាគខាងលិច និងយូដាផ្នែកនៅភាគខាងកើតឯទន្លេយ័រដាន់។
[35]ក្រុងដែលមានកំពែងរួមមានស៊ីឌីមសេរ ហាំម៉ាត់ រ៉ាកាត់ គីនេរ៉ែត[36]អាដាម៉ា រ៉ាម៉ា ហាសោរ[37]កេដែស អេទ្រី អេន ហាសោរ។
[38]ក៏មានក្រុងយីរ៉ូន មីកដាល អែល ហូរេម បេតអាណាត និងបេត សេមែស។ មានដប់ប្រាំបួនក្រុង រួមទាំងភូមិរបស់ពួកគេ។[39]នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធ
ណែបថាលី ដែលផ្តល់តាមអំបូររបស់ពួកគេ ទាំងទីក្រុង រួមទាំងភូមិផ្សេងៗទៀតរបស់ពួកគេផងដែរ។
[40]ឆ្នោតទីប្រាំពីរចំលើកុលសម្ព័ន្ធដាន ដែលត្រូវប្រគល់តាមអំបូររបស់ពួកគេ។[41]ទឹកដីដែលគេទទួលបានមានក្រុងសូរ៉ាស់ អែសថោល សេមែស[42]សាឡាប៊ីន អាយ៉ាឡូន យីត
ឡា។
[43]ក៏រួមទាំងអេឡូន ធីមណា អេក្រូន[44]អែលថ្កេរ គីថោន បាឡាត[45]យេហ៊ូដ បេន បេរ៉ាក់ កាថ រីម៉ូន[46]មេយ៉ារកូន និងរ៉ាកូនជាមួយនឹងទឹកដីចេញពីយ៉ុបប៉េ។
[47]នៅពេលដែលកុលសម្ព័ន្ធដាន់បាត់ទឹកដីរបស់ពួកគេ ពួកគេបានវាយយកក្រុងលេសែម វាយប្រឆាំងនឹងក្រុងនោះ និងកាន់កាប់ក្រុងនោះបាន។
ពួកគេបានសម្លាប់អ្នកទាំងនោះដោយដាវ ប្រមូលយកជ័យភណ្ឌ ហើយស្នាក់នៅទីនោះទៅ។ ពួកគេបានប្តូរឈ្មោះលេសែម
ដោយហៅថាដាន់តាមឈ្មោះបុព្វបុរសរបស់ពួកគេ។[48]នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធដាន់ ហើយបានប្រគល់ឲ្យអំបូរបស់ពួកគេ ទាំងក្រុង
រួមទាំងភូមិផ្សេងៗទៀតរបស់គេ។
[49]ក្រោយពួកគេបានបញ្ចប់ក្នុងការបែងចែកទឹកដីជាមរតករួចហើយ ប្រជាជនអ៊ីស្រាអែលបានប្រគល់មរតករបស់ពួកគេជូនលោកយ៉ូស្វេជាកូនរបស់លោកនូន។
[50]ស្របតាមបង្គាប់របស់ព្រះអម្ចាស់ពួកគេបានប្រគល់ជូនលោកនូវក្រុងណាដែលលោកសំណូមពរគឺក្រុងធីម្នាត សេរ៉ា នៅតំបន់ភ្នំអេប្រាអ៊ីម។
លោកបានសង់ក្រុងនោះឡើងវិញហើយស្នាក់នៅទីនោះ។
[51]នេះជាទឹកដីមរតកដែលលោកបូជាចារ្យអេឡាសារ លោកយ៉ូស្វេ ជាកូនរបស់លោកនូន និងអ្នកដឹកនាំកុលសម្ព័ន្ធនៃបុព្វបុរសរបស់ពួកគេ
ជាមួយនឹងប្រជាជនអ៊ីស្រាអែលចែកគ្នាដោយការចាប់ឆ្នោតនៅស៊ីឡូមុខព្រះអម្ចាស់ នៅឯច្រកចូលជំរំដែលគេប្រជុំគ្នា។ ដូច្នេះ គេក៏បានបញ្ចប់ការបែងចែកទឹកដីគ្នា។

Joshua 19:1
សន្លឹកឆ្នោតទៅពីចំលើកុលសម្ព័ន្ធស៊ីម្មាន
« លោកយ៉ូស្វេបានបោះឆ្នោតលើកទីពីរ
ហើយបានចង្អុលបង្ហាញពីកុលសម្ព័ន្ធស៊ីម្មាន »
ទីពីរ
លេខពីរនៅក្នុងតារាងមួយ
ហើយបានបែងចែកតាមអំបូររបស់ពួកគេរៀងៗខ្លួន
អាចបញ្ជាក់ជាទម្រង់កម្ម។ ការបកប្រែផ្សេងទៀត « លោកយ៉ូស្វេបានប្រគល់ទឹកដី
ដល់កុលសម្ព័ន្ធនីមួយៗ »
ទឹកដីដែលពួកគេទទួលបានគឺនៅចំកណ្តាលទឹកដីរបស់កុលសម្ព័ន្ធយូដា។
ដីនេះត្រូវបានគេនិយាយថា
ជាមរតកដែលកុលសម្ព័ន្ធទទួលបានជាកម្មសិទ្ធិជារៀងរហូត។
ការបកប្រែផ្សេងទៀត « ទឹកដីដែលពួកគេបានទទួលជាមត៌ក
គឺនៅចំកណ្តាលទឹកដីដែលកុលសម្ព័ន្ធយូដាទទួលបានជាមរតក »
Joshua 19:2
ព័ត៌មានទូទៅ
អ្នកនិពន្ធបានចុះបញ្ជីទីក្រុងនានា
ដែលមាននៅក្នុងទឹកដីដែលកុលសម្ព័ន្ធស៊ីម្មានទទួលបានជាមរតក។
ទឹកដីជាមរតករបស់ពួកគេ
ទឹកដីនិងក្រុងដែលកុលសម្ព័ន្ធស៊ីម្មាន បានទទួល ត្រូវបានគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិអចិន្ត្រៃយ៍។ ការបកប្រែផ្សេងទៀត «
ពួកគេមានទីក្រុងដូចខាងក្រោម សម្រាប់មរតករបស់ពួកគេ »
Joshua 19:5
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តចុះបញ្ជីទីក្រុងនានាដែលមាននៅលើទឹកដី
ដែលកុលសម្ព័ន្ធស៊ីម្មានទទួលបានជាមរតក។
ស៊ីគឡាក់
ការបកប្រែនេះគឺដូចគ្នានៅក្នុង១ម:២៩។
Joshua 19:8
នេះជាទឹកដីដែលជាមរតករបស់កុលសម្ព័ន្ធស៊ីម្មាន
ទឹកដីនិងក្រុងនានា ដែលកុលសម្ព័ន្ធស៊ីម្មានបានទទួល ត្រូវបានគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត «
នេះជាទឹកដីនិងក្រុងនានា ដែលកុលសម្ព័ន្ធស៊ីម្មានទទួលបានជាមរតក »
ប្រគល់ឲ្យដល់អំបូរនីមួយៗ
អាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ដែលលោកយ៉ូស្វេបានអោយទៅអំបូររបស់គាត់ » (សូមមើល activepassive)
ដោយសារតែទឹកដីដែលបែងចែកដល់កុលសម្ព័ន្ធយូដា
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ចំណែកដីដែលលោកយ៉ូស្វេប្រគល់អោយកុលសម្ព័ន្ធយូដា »
ទឹកដីជាមរតកនៅកណ្តាលទឹកដីរបស់ពួកគេ
« ពាក់កណ្តាលទឹកដីជាចំណែករបស់យូដា »
Joshua 19:10
ឆ្នោតទីបីចំលើ
បកប្រែឃ្លានេះតាមរបៀបដែលបានធ្វើក្នុង ១៩: ១។
ទីបី
ចំនួនលេខ៣នៅក្នុងតារាងបញ្ជី
សារីដ ... ម៉ារ៉ាឡា ... ប៉ះដាបាសែត ... យុកនាម
ទាំងអស់នេះគឺជាឈ្មោះទីកន្លែង។
ទល់មុខនឹងយុកនាម
« ឆ្លងកាត់ពីយុកនាម »
Joshua 19:12
សារីដ ... ស្រុកគីស្លូត តាបោរ ...ដាប្រាត... យ៉ាភា ... គីតា ហេភើ ... អ៊ីតា កាស៊ីន ... រីម៉ូន ...
ណេយ៉ា
ទាំងអស់នេះគឺជាឈ្មោះទីក្រុងនានា។
Joshua 19:14
ហាណាថូន ...យើបថា អែល ... កាថាត ...ណា ហាឡាល់ ... ស៊ីមរ៉ូន ... យីដាឡា ... បេថ្លេហិម
ទាំងអស់នេះគឺជាឈ្មោះទីកន្លែង។
បេថ្លេហិម
នេះមិនមែនដូចជា « បេថ្លេហិម »
ដែលនៅខាងត្បូងក្រុងយេរូសាឡិមនៅស្រុកយូដាទេ។
នេះជាចំណែកទឹកដីមរតករបស់កុលសម្ព័ន្ធសាប់យូឡូន
ទឹកដីនិងក្រុងនានា ដែលកុលសម្ព័ន្ធសាប់យូឡូនទទួលបាន
ត្រូវគេនិយាយថាជាមរតកដែលពួកគេបានទទួលជាជារៀងរហូត។
ការបកប្រែផ្សេងទៀត « នេះជាទឹកដីនិងក្រុងនានា
ដែលកុលសម្ព័ន្ធសាប់យូឡូនបានទទួលជាមរតក»
តាមអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត «
ដែលលោកយ៉ូស្វេបានប្រគល់ឱ្យអម្បូររបស់ពួកគេ »
Joshua 19:17
ឆ្នោតទីបួន
បកប្រែឃ្លានេះតាមរបៀបដែលបានធ្វើក្នុង ១៩:១ ។
ទីបួន
ចំនួនលេខ៤នៅក្នុងបញ្ជីតារាង
គីសាឡូត ... ស៊ូណែម ... ហាផារ៉ែម ...ស៊ីអូន ... អាណាក្រាត
ទាំងអស់នេះគឺជាឈ្មោះទីក្រុង។
Joshua 19:20
រ៉ាប៊ីត ... គីសយ៉ូន ... អាបេស ... រេមេត ... កានីម ... អេន ហាដា ...បេតផាសេ... សាហាត់ ស៊ីម៉ា
ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុ។

generated on Wed Sep 10 16:16:32 2025

ក្រុងតាបោរ
នេះគឺជាឈ្មោះរបស់ភ្នំមួយ ។
Joshua 19:23
នេះជាទឹកដីមរតករបស់ កុលសម្ព័ន្ធអ៊ីសាខា
ទឹកដីនិងក្រុងនានា ដែលកុលសម្ព័ន្ធអ៊ីសាខារទទួលបានត្រូវគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត «
នេះជាទឹកដី និងទីក្រុងដែលកុលសម្ព័ន្ធអ៊ីសាខារទទួលបានជាមរតក »
ត្រូវបានប្រគល់ឲ្យតាមអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេបានប្រគល់វាទៅឲ្យអំបូររបស់ពួកគេ »
Joshua 19:24
ឆ្នោតទីប្រាំ
ប្រែឃ្លានេះតាមរបៀបដែលបានធ្វើក្នុង ១៩: ១ ។
ទីប្រាំ
ចំនួនលេខ៥នៅក្នុងបញ្ជីតារាង
បានប្រគល់ឲ្យអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេបានប្រគល់វាទៅឲ្យអំបូររបស់ពួកគេ »
ក្រុងហែលកាថ, ហាលី, បេថែន, អាកសាប, អាឡាមេឡេក , អាម៉ាដ, និង មីសាល ... ស៊ីហោរ លីបណាថ
ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុង។
Joshua 19:27
បេតដាកូន ... ជ្រលងភ្នំយីបថាអែល ... បេតអេមេក ... ណេយែល ... ក្រុងកាប៊ូល ... អេប្រួន ... រេហូប ... ហាំម៉ូន ... ខាណា
ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង ។
Joshua 19:29
ក្រុងហូសា ... អាកស៊ីប ... ក្រុងអ៊ូម៉ា... អាផេក ... រេហូប
ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង ។
Joshua 19:31
នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធអាស៊ើរ
ទឹកដីនិងក្រុងដែលកុលសម្ព័ន្ធអេស៊ើរបានទទួល
ត្រូវបានគេនិយាយថាជាមរតកដែលពួកគេបានទទួលជារៀងរហូត។
ការបកប្រែផ្សេងទៀត « នេះជាទឹកដី
និងទីក្រុងដែលកុលសម្ព័ន្ធអេស៊ើរទទួលបានជាមរតក»
បានប្រគល់ឲ្យអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេបានប្រគល់វាទៅឲ្យអំបូររបស់ពួកគេ »
Joshua 19:32
ឆ្នោតទីប្រាំមួយ
ប្រែឃ្លានេះតាមរបៀបដែលបានធ្វើក្នុង ១៩: ១ ។
ទីប្រាំមួយ
ចំនួនលេខ៦នៅក្នុងបញ្ជីតារាង
បានប្រគល់ឲ្យអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេបានប្រគល់វាទៅឲ្យអំបូររបស់ពួកគេ »
ពីហេលេប ...សានណានីម ... អាដាមី ណេកិប ... យ៉ាប់នាល ...ឡាក់គូម ... អាសណូត តាបោរ ... ហ៊ូកុក
ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុង។
Joshua 19:35
ស៊ីឌីម ... សេរ ...ហាំម៉ាត់ ... រ៉ាកាត់ ... គីនេរ៉ែត ... អាដាម៉ា ... រ៉ាម៉ា ... ហាសោរ ...អេទ្រី ... អេនហាសោរ
ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុងនានា។
ហាំម៉ាត់
នេះគឺមិនមែនទីតាំងដូចគ្នានឹង « ហាម៉ាត់ » ប៉ុន្តែមានទីតាំងនៅច្រាំងខាងលិច
នៃសមុទ្រកាលីឡេ ។
Joshua 19:38
ក្រុងយីរ៉ូន...មីកដាល... ហូរេម ...បេតអាណាត
ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុង។ (សូមមើល)
នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធណែបថាលី
ទឹកដីនិងក្រុងដែលកុលសម្ព័ន្ធណាប៉ូលីលទទួលបាន ត្រូវបានគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិជារៀងរហូត។ ការបកប្រែផ្សេងទៀត «
នេះគឺជាទឹកដីនិងទីក្រុងនានាដែលកុលសម្ព័ន្ធណែបថាលី ទទួលបានជាមរតក »
បានប្រគល់ឲ្យអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទំរង់សកម្ម។ ការបកប្រែផ្សេងទៀត «
លោកយ៉ូស្វេបានប្រគល់វាទៅឲ្យអំបូររបស់ពួកគេ »
Joshua 19:40
ឆ្នោតទីប្រាំពីរ
ប្រែឃ្លានេះតាមរបៀបដែលបានធ្វើក្នុង ១៩: ១ ។
ទីប្រាំពីរ
ចំនួនលេខ៧នៅក្នុងបញ្ជីតារាង
ទឹកដីដែលគេទទួលបាន
ទឹកដីដែលកុលសម្ព័ន្ធដាន់ទទួលបាន
ត្រូវនិយាយថាជាមរតកដែលពួកគេបានទទួលជាអចិន្ត្រៃយ៍។ ការបកប្រែផ្សេងទៀត
« ទឹកដីនៃទឹកដីដែលកុលសម្ព័ន្ធដាន់ទទួលបានជាមរតក »
ក្រុងសូរ៉ាស់,អែសថោល,សេមែស, សាឡាប៊ីន, អាយ៉ាឡូន , និង យីតឡា
ទាំងអស់នេះគឺជាឈ្មោះនៃទីកន្លែង។
Joshua 19:43
អេឡូន ធីមណា អេក្រូន អែលថ្កេ គីថោន បាឡាត យេហ៊ូដ បេន បេរ៉ាក់ កាថ រីម៉ូន មេយ៉ាកូន និង រ៉ាកូន
ទាំងអស់នេះគឺជាឈ្មោះនៃទីក្រុង។
ទឹកដីចេញពីយ៉ុបប៉េ
« ទល់មុខនឹងយ៉ុបប៉េ » ឬ « នៅក្បែរក្រុងយ៉ុបប៉េ »
Joshua 19:47
ក្រុងលេសែម
នេះគឺជាឈ្មោះនៃទីក្រុង។
នេះជាទឹកដីមរតករបស់កុលសម្ព័ន្ធដាន់
ទឹកដីនិងក្រុងនានាដែលកុលសម្ព័ន្ធដាន់ ទទួលបាន ត្រូវគេនិយាយថា
ជាមរតកដែលពួកគេបានទទួលជារៀងរហូត។ការបកប្រែផ្សេងទៀត
«នេះជាទឹកដីនិងទីក្រុងនានាដែលកុលសម្ព័ន្ធដាន់ទទួលបានជាមរតក»
បានប្រគល់ឲ្យអំបូររបស់ពួកគេ
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត
«លោកយ៉ូស្វេបានប្រគល់វាទៅឲ្យអំបូររបស់ពួកគេ»
Joshua 19:49
បានប្រគល់មរតករបស់ពួកគេជូនលោកយ៉ូស្វេ ជាកូនរបស់លោកនូន។
ទីក្រុងដែលលោកយ៉ូស្វេទទួលបាន
ត្រូវនិយាយដូចជាទឹកដីដែលគាត់បានទទួលជាមរតករហូត។ ការបកប្រែផ្សេងទៀត
« បានប្រគល់ទីក្រុងមួយនៅក្នុងទឹកដីរបស់ពួកគេ ទុកជាមរតកដល់លោកយ៉ូស្វេ
ជាកូនរបស់នូន »។
ក្រុងធីម្នាត សេរ៉ា
នេះគឺជាឈ្មោះនៃទីក្រុង។
Joshua 19:51
នេះជាទឹកដីមរតក ... ចែកគ្នាដោយ
ទឹកដីនិងក្រុងនានាដែលកុលសម្ព័ន្ធផ្សេងៗបានទទួល
ត្រូវបាននិយាយថាជាមរតកដែលពួកគេបានទទួលជាកម្មសិទ្ធិជារៀងរហូត។
ការបកប្រែផ្សេងទៀត « ទាំងនេះគឺជាចំណែកដីនិងទីក្រុង ...
ដែលត្រូវបានប្រគល់ជាមរតក»

---

20 [1]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកលោកយ៉ូស្វេថា៖[2]«ចូរប្រាប់ទៅប្រជាជនអ៊ីស្រាអែលថា៖
«ចូរជ្រើសរើសក្រុងជម្រកដែលយើងធ្លាប់បានបង្គាប់មកអ្នករាល់គ្នាតាមលោកម៉ូសេ។
[3]ចូរធ្វើបែបនេះដើម្បីឲ្យអ្នកណាដែលបានសម្លាប់គេដោយអចេតនាអាចទៅស្នាក់នៅទីនោះបាន។
ក្រុងទាំងនេះជាកន្លែងសម្រាប់ជាជម្រកដល់អ្នកដែលរត់គេចពីការសងសឹក។

generated on Wed Sep 10 16:16:32 2025

[4]គេអាចរត់ទៅក្រុងណាមួយ ហើយត្រូវឈរនៅមុខទ្វារក្រុង និងត្រូវពន្យល់រៀបរាប់ដំណើររឿងរបស់គាត់ទៅដល់ចាស់ទុំក្នុងក្រុងនោះ។ បន្ទាប់មក
ពួកគេនឹងយកគាត់ទៅក្នុងទីក្រុង និងផ្តល់កន្លែងសម្រាប់គាត់រស់នៅក្នុងចំណោមពួកគេ។
[5]បើមាននរណាម្នាក់ព្យាយាមមកសងបំណុលឈាមដល់អ្នកដែលបានសម្លាប់គេនេះ នោះប្រជាជនក្រុងនោះមិនត្រូវប្រគល់អ្នកដែលបានសម្លាប់គេដល់អ្នកនោះឡើយ។
គេមិនត្រូវប្រគល់ឡើយ ដោយសារអ្នកនោះបានសម្លាប់អ្នកជិតខាងខ្លួនដោយអចេតនា ហើយគាត់មិនមានចិត្តស្អប់គេពីមុនមកទេ។
[6]គាត់ត្រូវស្នាក់នៅក្នុងក្រុងនោះរហូតដល់គាត់បានឈរនៅមុខការជំនុំជម្រះ រហូតដល់បូជាចារ្យនៅជំនាន់នោះបានស្លាប់។ បន្ទាប់មក
អ្នកដែលបានសម្លាប់គេដោយអចេតនានោះអាចត្រឡប់ទៅក្រុង និងផ្ទះរបស់ខ្លួនវិញ គឺទៅក្រុងដែលគាត់បានរត់ចេញមក»។
[7]ដូច្នេះ ប្រជាជនអ៊ីស្រាអែលបានជ្រើសរើស កេដែស នៅស្រុកកាលីឡេ ក្នុងតំបន់ភ្នំណែបថាលី ស៊ីគែមនៅក្នុងតំបន់ភ្នំអេប្រាអ៊ីម និងគារយ៉ាត អើបា (គឺក្រុងហេប្រូន) ក្នុង
តំបន់ភ្នំយូដា។[8]នៅត្រើយទន្លេយ័រដាន់ខាងកើតក្រុងយេរីខូ ពួកគេបានជ្រើសរើសយកបេស៊ើរ នៅវាលរហោស្ថាន ក្នុងតំបន់ខ្ពង់រាបពីកុលសម្ព័ន្ធរូបេន ក្រុងរ៉ាម៉ូតកាឡាដ
ពីកុលសម្ព័ន្ធកាដ និងក្រុងកូឡាន នៅស្រុកបាសានពីកុលសម្ព័ន្ធម៉ាណាសេ។
[9]ក្រុងទាំងនេះសុទ្ធតែជាក្រុងដែលបានជ្រើសរើសសម្រាប់ប្រជាជនអ៊ីស្រាអែល និងសម្រាប់ជនបរទេសដែលរស់នៅក្នុងចំណោមពួកគេ ដូច្នេះ
បើនរណាម្នាក់សម្លាប់មនុស្សដោយអចេតនាអាចរត់ទៅក្រុងទាំងនោះដើម្បីរួចជីវិត។
អ្នកនោះនឹងមិនត្រូវស្លាប់ដោយដៃរបស់អ្នកដែលចង់សងសឹកឈាមដែលអ្នកនោះបានបង្ហូរឡើយ
រហូតដល់អ្នកដែលត្រូវគេចោទប្រកាន់នោះបានជួបចៅក្រមកាត់ក្តីជាមុន។

Joshua 20:1

តាមលោកម៉ូសេ

នៅទីនេះ « ដៃលោកម៉ូសេ » សំដៅទៅលើបទគម្ពីរដែលលោកម៉ូសេបានសរសេរ។

ការបកប្រែផ្សេងទៀត «តាមរយៈបទគម្ពីរដែលលោកម៉ូសេបានសរសេរ»

សម្លាប់គេដោយអចេតនា

រឿងនេះកើតឡើង នៅពេលមនុស្សម្នាក់សម្លាប់មនុស្សម្នាក់ទៀតដោយចៃដន្យ
គ្មានបំណងដើម្បីធ្វើបែបហ្នឹង។

កន្លែងសម្រាប់ជាជម្រកដល់អ្នកដែលរត់គេចពីការសងសឹក

នៅទីនេះឈាមស្រក់របស់មនុស្សតំណាងឲ្យការស្លាប់របស់ពួកគេ។
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
សងសឹកការស្លាប់របស់មនុស្ស »

Joshua 20:4

គេអាចរត់ទៅ

នៅទីនេះពាក្យថា « គាត់ »
សំដៅទៅលើមនុស្សដែលបានសម្លាប់នរណាម្នាក់ដោយអចេតនា។

រាប់ដំណើររឿងរបស់គាត់ទៅដល់ចាស់ទុំក្នុងក្រុងនោះ

«បញ្ចុះបញ្ចូលពួកចាស់ទុំនៅទីក្រុងនោះថា
គាត់មិនបានសម្លាប់មនុស្សដោយចេតនាទេ» ។

បន្ទាប់មក ពួកគេនឹងយកគាត់

ពាក្យថា « ពួកគេ » សំដៅទៅលើពួកអែលឌើរ « គាត់ »
សំដៅទៅលើមនុស្សដែលបានសម្លាប់នរណាម្នាក់ដោយអចេតនា។

រស់នៅក្នុងចំណោមពួកគេ

នេះសំដៅទៅលើទីក្រុងទាំងមូល មិនមែនសំដៅទៅលើតែពួកចាស់ទុំប៉ុណ្ណោះទេ។

Joshua 20:5

សងបំណុលឈាមដល់អ្នកដែលបានសម្លាប់គេនេះ

អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ សូមមើលនៅក្នុង ២០: ១ ។
ការបកប្រែផ្សេងទៀត « សងសឹកការស្លាប់របស់មនុស្ស »

បានសម្លាប់អ្នកជិតខាងខ្លួនដោយអចេតនា ... បានសម្លាប់គេដោយអចេតនានោះ

ឃ្លាទាំងនេះមានន័យដូចគ្នា។

ឈរនៅមុខការជំនុំជម្រះ

នេះគឺជាឃ្លាដែលពិពណ៌នាអំពីជំហរ ដើម្បីស្វែងរកយុត្តិធម៌ពីតុលាការ
នៃការជួបប្រជុំគ្នារបស់បងប្អូនជនរួមជាតិរបស់គាត់។

Joshua 20:7

ព័ត៌មានទូទៅ

មានឈ្មោះមនុស្សជាច្រើននៅក្នុងផ្នែកនេះ។

ទន្លេយ័រដាន់

នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។

Joshua 20:9

នឹងមិនត្រូវស្លាប់ដោយដៃរបស់អ្នក

នៅទីនេះ « ដោយដៃ » មានន័យថា
មនុស្សនេះជាភ្នាក់ងារផ្ទាល់ដែលបានសម្លាប់អ្នករត់គេចខ្លួន។ ការបកប្រែផ្សេងទៀត
« នឹងមិនត្រូវបានសម្លាប់ដោយម្នាក់នោះទេ »

សងសឹកឈាមដែលអ្នកនោះបានបង្ហូរឡើយ

អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ សូមមើលនៅក្នុង ២០: ១ ។
ការបកប្រែផ្សេងទៀត « សងសឹកការស្លាប់របស់មនុស្ស »

---

21 [1]បន្ទាប់មក មេដឹកនាំតាមអំបូររបស់កុលសម្ព័ន្ធលេវីបានមកជួបលោកបូជាចារ្យអេឡាសារ និងលោកយ៉ូស្វេ ជាកូនរបស់លោកនូន ព្រមទាំងអ្នកដឹកនាំរបស់
កុលសម្ព័ន្ធនានានៃជនជាតិអ៊ីស្រាអែល។[2]ពួកគេបាននិយាយទៅពួកលោកនៅស៊ីឡូនៅក្នុងទឹកដីកាណានថា៖
«ព្រះអម្ចាស់បានបង្គាប់ដល់អ្នកតាមរយៈលោកម៉ូសេថាឲ្យទីក្រុងឲ្យពួកយើងស្នាក់នៅ និងកន្លែងសម្រាប់ហ្វូងសត្វរបស់ពួកយើង»។
[3]ដូច្នេះ ស្របតាមបង្គាប់របស់ព្រះអម្ចាស់ ប្រជាជនអ៊ីស្រាអែលបានចែកទឹកដីជាមរតករបស់ពួកគេមានទីក្រុង និងរួមទាំងដីសម្រាប់ហ្វូងសត្វដូចតទៅដល់កុលសម្ព័ន្ធលេវី។
[4]ការចាប់ឆ្នោតសម្រាប់អំបូរកេហាត់មានដូចតទៅ: បូជាចារ្យដែលជាកូនចៅរបស់លោកអើរ៉ុន ដែលកើតចេញពីកុលសម្ព័ន្ធលេវី
បានទទួលក្រុងសាមសិបដែលបានទទួលពីកុលសម្ព័ន្ធយូដា ពីកុលសម្ព័ន្ធស៊ីម្មាន និងពីកុលសម្ព័ន្ធបេនយ៉ាមីន។
[5]អ្នកផ្សេងទៀតនៅក្នុងអំបូរកេហាត់ទទួលបានទឹកដីពីកុលសម្ព័ន្ធអេប្រាអ៊ីមក្រោយការចាប់ឆ្នោត គឺបានក្រុងដប់ចេញពីអំបូរនៃកុលសម្ព័ន្ធអេប្រាអ៊ីម ដាន់
និងចេញពីកុលស្ព័ន្ធពាក់កណ្តាលរបស់ម៉ាណាសេ។
[6]បន្ទាប់មក ប្រជាជនដែលជាកូនចៅរបស់លោកគើសុនត្រូវបានប្រគល់ទឹកដីឲ្យដោយការចាប់ឆ្នោត គឺបានក្រុងសាមសិបចេញពីអំបូរនៃកុលសម្ព័ន្ធអ៊ីសាខារ កុលសម្ព័ន្ធ
អេស៊ើរ កុលសម្ព័ន្ធណែបថាលី និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល ដែលស្ថិតនៅក្នុងស្រុកបាសាន។[7]ប្រជាជនដែលជាកូនចៅរបស់លោកម៉្រារីទទួលបានក្រុង
ចំនួនដប់ពីរចេញពីកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធសាប់យូឡូន។
[8]ដូច្នេះ ប្រជាជនអ៊ីស្រាអែលចែកទឹកដីគ្នាដោយការចាប់ឆ្នោត ក្រុងទាំងនេះ (រួមទាំងទឹកដីសម្រាប់ហ្វូងសត្វ) ទៅដល់កុលសម្ព័ន្ធលេវី
ដូចដែលព្រះអម្ចាស់បានបង្គាប់តាមរយៈលោកម៉ូសេ។[9]ចាប់ពីកុលសម្ព័ន្ធយូដា និងកុលសម្ព័ន្ធស៊ីម្មាន បានចែកទឹកដីដែលមានក្រុងដែលមានកត់តាមឈ្មោះ។
[10]ទីក្រុងទាំងនេះបានប្រគល់ឲ្យកូនចៅលោកអើរ៉ុនដែលនៅក្នុងចំណោមអំបូរលោកកេហាត់ ដែលចេញពីកុលសម្ព័ន្ធលេវី ។ ដោយសារការចាប់ឆ្នោតលើកដំបូងចំលើពួក
គេ។
[11]ជនជាតិអ៊ីស្រាអែលបានឲ្យក្រុងគារយ៉ាត អើបាពោល (អើបាជាឪពុករបស់អណាក់) គឺក្រុងហេប្រូនដែលស្ថិតនៅក្នុងតំបន់ភ្នំយូដា ព្រមទាំងវាលស្មៅដែលនៅជុំវិញនោះ។
[12]ប៉ុន្តែ វាលស្រែ និងភូមិរបស់ក្រុងនោះ គេបានប្រគល់ជូនលោកកាលែប ជាកូនរបស់លោកយេភូនេ ទុកជាកម្មសិទ្ធិរបស់លោក។
[13]កូនចៅរបស់លោកអើរុនជាបូជាចារ្យបានទទួលហេប្រូន និងវាលស្មៅរបស់ក្រុងនោះ ដែលជាក្រុងជម្រកសម្រាប់អស់អ្នកដែលសម្លាប់មនុស្សដោយអចេតនា
ព្រមទាំងក្រុងលីបណា និងវាលស្មៅរបស់ក្រុងនោះ[14]ក្រុងយ៉ាទៀរ និងវាលស្មៅរបស់ក្រុងនោះ ក្រុងអែសធេម៉ូរ និងវាលស្មៅរបស់ក្រុងនោះ។[15]ពួកគេក៏ឲ្យក្រុងហូឡូន និង

generated on Wed Sep 10 16:16:32 2025

វាលស្មៅរបស់ក្រុងនោះ ក្រុងដេបៀរ និងវាលស្មៅរបស់ក្រុងនោះ[16]ក្រុងអាយីន និងវាលស្មៅរបស់ក្រុងនោះ ក្រុងយូថា និងវាលស្មៅរបស់ក្រុងនោះ ព្រមទាំងក្រុងបេតសេមែស និងវាលស្មៅរបស់ក្រុងនោះ។ មានប្រាំបួនក្រុងដែលបានទទួលពីកុលសម្ព័ន្ធទាំងពីរនេះ។
[17]ចេញពីកុលសម្ព័ន្ធបេនយ៉ាមីន ពួកគេទទួលបានក្រុងគីបៀន និងវាលស្មៅរបស់ក្រុងនោះ ក្រុងកេបា និងវាលស្មៅរបស់ក្រុងនោះ[18]ក្រុងអាណាថោត និងវាលស្មៅរបស់ក្រុងនោះ ក្រុងអាល់ម៉ូន និងវាលស្មៅរបស់ក្រុងនោះ មានបួនក្រុង។[19]ក្រុងដែលប្រគល់ជូនពួកបូជាចារ្យដែលជាកូនចៅលោកអើរ៉ុនទទួល គឺដប់បីក្រុង ព្រមទាំងវាលស្មៅរបស់ក្រុងនោះផង។
[20]ដូច្នេះ អ្នកផ្សេងទៀតក្នុងគ្រួសាររបស់លោកកេហាត់ គឺពួកលេវីដែលនៅក្នុងគ្រួសាររបស់កេហាត់ ពួកគេទទួលបានក្រុងក្នុងទឹកដីរបស់កុលសម្ព័ន្ធអេប្រាអ៊ីម ដោយការចាប់ឆ្នោត។[21]ពួកគេទទួលបានក្រុងស៊ីគែម និងវាលស្មៅរបស់ក្រុងនោ ដែលនៅក្នុងតំបន់ភ្នំអេប្រាអ៊ីម ជាក្រុងជម្រកសម្រាប់អ្នកណាដែលសម្លាប់មនុស្សដោយអចេតនា ក្រុងកេស៊ើរ និងវាលស្មៅរបស់ក្រុងនោះ[22]ក្រុងគីបសែម និងវាលស្មៅរបស់ក្រុងនោះក្រុងបេតហូរ៉ុន និងវាលស្មៅរបស់ក្រុងនោះ ទាំងអស់មានបួនក្រុង។
[23]ពីកុលសម្ព័ន្ធដាន់អំបូរកេហាត់បានទទួលក្រុង និងវាលស្មៅរបស់ក្រុងនោះ ក្រុងគីបថោន និងវាលរបស់ក្រុងនោះ[24]ក្រុងអាយ៉ាឡូន និងវាលស្មៅរបស់ក្រុងនោះ ព្រមទាំងក្រុងកាថ រីម៉ូន និងវាលស្មៅរបស់ក្រុងនោះ មានទាំងអស់បួនក្រុង។
[25]អំបូរកេហាត់បានទទួលក្រុងពីរពីកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលគឺក្រុងតាណាក់ និងវាលស្មៅរបស់ក្រុងនោះ ក្រុងអ៊ីតឡាម និងវាលស្មៅរបស់ក្រុងនោះ។
[26]អំបូរកូនចៅរបស់កេហាត់ទាំងអស់មានក្រុងដប់ រួមទាំងវាលស្មៅរបស់ពួកគេ។
[27]អំបូរគើសុន ដែលជាអំបូរផ្សេងទៀតរបស់កុលសម្ព័ន្ធលេវីទទួលបានក្រុង និងវាលស្មៅរបស់ក្រុងនោះ ក្នុងទឹកដីពីកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល ដែលនៅខាងកើត សម្រាប់ជាក្រុងជម្រកដល់អ្នកសម្លាប់គេដោយអចេតនា ក្រុងកូឡាន និងវាលស្មៅនៅជុំវិញ ក្នុងស្រុកបាសាន ព្រមទាំងក្រុងបេសត្រា និងវាលស្មៅនៅជុំវិញ គឺមានទាំងអស់ក្រុងពីរ។
[28]ពួកគេក៏ឲ្យក្រុងគើសុនពីកុលសម្ព័ន្ធអ៊ីសាខារដល់អំបូរគើសុន ជាមួយនឹងវាលរបស់ក្រុងនោះ ក្រុងដាប្រាត និងវាលស្មៅរបស់ក្រុងនោះដែរ[29]ក្រុងយ៉ាមូត និងវាលស្មៅរបស់ក្រុងនោះ ក្រុងអេនកានីន និងវាលស្មៅរបស់ក្រុងនោះ គឺមានក្រុងបួន។[30]ចេញពីកុលសម្ព័ន្ធស៊ើរ គេបានឲ្យក្រុងមីសាល់ និងវាលស្មៅរបស់ក្រុងនោះ ក្រុងអាប់ដូន និងវាលស្មៅរបស់ក្រុងនោះ[31]ក្រុងហែលកាថ និងវាលស្មៅរបស់ក្រុងនោះ ក្រុងរេហូប និងវាលស្មៅរបស់ក្រុងនោះ គឺមានក្រុងបួន។
[32]ចេញពីកុលសម្ព័ន្ធណែបថាលី អំបូរគើសុន បានទទួលក្រុងកាដេស និងវាលស្មៅរបស់ក្រុងនោះ នៅក្នុងស្រុកកាលីឡេជាក្រុងជម្រកដល់អ្នកសម្លាប់គេដោយអចេតនា ក្រុងហាម៉ាត ដោរ និងវាលស្មៅរបស់ក្រុងនោះ ក្រុងការថាន និងវាលស្មៅរបស់ក្រុងនោះ គឺមានក្រុងបី។[33]ពួកលេវីជាកូនចៅរបស់លោកគើសុនមានក្រុងទាំងអស់ដប់បីតាមអំបូររបស់ពួកគេ ព្រមទាំងវាលស្មៅរបស់ក្រុងនោះផង។
[34]ពួកលេវីផ្សេងទៀតអំបូរលោកម៉្រារី ទទួលបានពីកុលសម្ព័ន្ធសាប់យូឡូន មានក្រុងយ៉ុកនាម និងវាលស្មៅរបស់ក្រុងនោះ ក្រុងការថា និងវាលស្មៅរបស់ក្រុងនោះ[35]ក្រុងឌីមណា និងវាលស្មៅរបស់ក្រុងនោះ ព្រមទាំងក្រុងណា ហាឡាល់ និងវាលស្មៅរបស់ក្រុងនោះ មានទាំងអស់បួនក្រុង។
[36]អំបូរម៉្រារី បានទទួលពីកុលសម្ព័ន្ធរូបេនមានក្រុងបេសស៊ើរ និងវាលស្មៅរបស់ក្រុងនោះ ក្រុងយ៉ាហាស និងវាលស្មៅរបស់ក្រុងនោះ[37]ក្រុងកេដ្ដេម៉ូត និងវាលស្មៅរបស់ក្រុងនោះ ព្រមទាំងក្រុងមេផ្អាត និងវាលស្មៅរបស់ក្រុងនោះ គឺមានទាំងអស់បួនក្រុង។[38]ពីកុលសម្ព័ន្ធកាដ គេទទួលបានក្រុងរ៉ាម៉ូត ក្នុងស្រុកកាឡាដ និងវាលស្មៅរបស់ក្រុងនោះ ជាជម្រកសម្រាប់អ្នកដែលសម្លាប់គេដោយអចេតនា និងក្រុងម៉ាហាណែម និងវាលស្មៅរបស់ក្រុងនោះ។
[39]អំបូរម៉្រារីក៏ទទួលបានក្រុងហេសបូន និងវាលស្មៅរបស់ក្រុងនោះ និងក្រុងយ៉ាស៊ើរ និងវាលស្មៅរបស់ក្រុងនោះ។ មានទាំងអស់ក្រុងបួន។
[40]ក្រុងទាំងអស់នេះជាក្រុងរបស់អំបូរបីបួនរបស់លោកម៉្រារី មកពីកុលសម្ព័ន្ធលេវី ដែលមានទាំងអស់ដប់ពីរក្រុង ដែលបានចាប់ឆ្នោតសម្រាប់ពួកគេ។
[41]ក្រុងដែលពួកលេវីបានទទួលពីកណ្តាលទឹកដីអ៊ីស្រាអែលមានចំនួនសែសិបប្រាំបីក្រុង រួមទាំងវាលស្មៅរបស់ក្រុងនោះផង។[42]ក្រុងនីមួយៗមានវាលស្មៅព័ទ្ធជុំវិញ។ គ្រប់ក្រុងទាំងអស់មានដូចគ្នា។
[43]ដូច្នេះ ព្រះអម្ចាស់បានប្រទានទឹកដីដល់កូនចៅអ៊ីស្រាអែលជាទឹកដីដែលព្រះអង្គបានស្បថថានឹងប្រទានដល់បុព្វបុរសរបស់ពួកគេ។[44]បន្ទាប់មក ព្រះអម្ចាស់ឲ្យពួកគេសម្រាកតាមកន្លែងរបស់ពួកគេរៀងៗខ្លួន ដូចដែលបានស្បថជាមួយដូនតារបស់ពួកគេ។ គ្មានសត្រូវណាមួយរបស់ពួកគេអាចយកឈ្នះពួកគេបានឡើយ។ ព្រះអម្ចាស់បានប្រទានសត្រូវរបស់ពួកគេមកក្នុងកណ្តាប់ដៃរបស់ពួកគេ។
[45]គ្មានសេចក្តីសន្យាណាមួយដែលព្រះអម្ចាស់បានសន្យាជាមួយនឹងអ៊ីស្រាអែលមិនបានសម្រេចនោះឡើយ។ អ្វីៗគ្រប់យ៉ាងបានសម្រេចទាំងអស់។

Joshua 21:1

លោកបូជាចារ្យអេឡាសារ ... លោកនូន

ទាំងនេះគឺជាឈ្មោះនៃបុរស។

ពួកគេបាននិយាយទៅពួកលោក

« ពួកលេវីបាននិយាយទៅកាន់ពួកគេថា »

ព្រះអម្ចាស់បានបង្គាប់ដល់អ្នកតាមរយៈលោកម៉ូសេថា

ឃ្លាថា « ដោយដៃ » មានន័យថា

ព្រះអម្ចាស់បានប្រើលោកម៉ូសេជាភ្នាក់ងារដើម្បីផ្តល់ឲ្យ
នូវពាក្យបង្គាប់បញ្ជារបស់ទ្រង់។ ការបកប្រែផ្សេងទៀត «
ព្រះអម្ចាស់បានប្រាប់លោកម៉ូសេ ដើម្បីបង្គាប់បញ្ជាអ្នក »

Joshua 21:3

ពួកគេមានទីក្រុង

នេះសំដៅទៅលើទីក្រុងដែលត្រូវបានចុះបញ្ជីនៅក្នុងខបន្ទាប់។

Joshua 21:4

ការចាប់ឆ្នោត

វិធីសាស្ត្រស្មានៃការជ្រើសរើស យកជម្រើសចេញពីឆន្ទៈរបស់មេដឹកនាំ
ជាញឹកញាប់ត្រូវបានធ្វើដោយគំនិតថា ព្រះជាម្ចាស់នឹងសម្រេចលទ្ធផល។
សូមមើលនៅក្នុង ១៩: ១ ។

អំបូរកេហាត់

បូជាចារ្យនៅក្នុងក្រុមនេះគឺជាកូនចៅរបស់កូលី ដែលជាកូនប្រុសរបស់លេវី។
មួយចំណែកនៃពួកគេក៏ជាកូនចៅរបស់អើរ៉ុន ដែលជាចៅប្រុសរបស់កេហាត់ដែរ។

ក្រុងដប់បី ... ក្រុងដប់

ចំនួននៃទីក្រុងនានា (សូមមើលtranslate-numbers)

កុលស្ព័ន្ធពាក់កណ្តាល

កុលសម្ព័ន្ធពាក់កណ្តាលពីព្រោះពាក់កណ្តាលទៀតបានទទួលមរតករបស់ពួកគេមុនពេលឆ្លងទន្លេយ័រដាន់

Joshua 21:6

លោកគើសុន

លោកគើសុនជាកូនរបស់លេវី។

ការចាប់ឆ្នោត

វិធីសាស្ត្រនៃការជ្រើសរើសយក ជម្រើសចេញពីឆន្ទៈរបស់មេដឹកនាំ
ជាញឹកញាប់ត្រូវបានធ្វើដោយគំនិតថា ព្រះជាម្ចាស់នឹងសម្រេចលទ្ធផល។
សូមមើលនៅក្នុង ១៩: ១ ។

លោកម៉្រារី

លោកម៉្រារី ជាកូនរបស់លេវី។

Joshua 21:8

ដូចដែលព្រះអម្ចាស់បានបង្គាប់តាមរយៈលោកម៉ូស

ឃ្លាថា « ដោយដៃ » មានន័យថា

ព្រះអម្ចាស់បានប្រើលោកម៉ូសេជាភ្នាក់ងារដើម្បីផ្តល់ឲ្យ
នូវពាក្យបង្គាប់បញ្ជារបស់ទ្រង់។ ការបកប្រែផ្សេងទៀត «
ព្រះអម្ចាស់បានប្រាប់លោកម៉ូសេដើម្បីបង្គាប់បញ្ជាអ្នក »

អំបូរលោកកេហាត់

ក្រុមបូជាចារ្យនៅក្នុងក្រុមនេះ
គឺជាកូនចៅរបស់លេវីដែលជាកូនប្រុសរបស់កេហាត់។
មួយចំណែកនៃពួកគេក៏ជាកូនចៅរបស់អើរ៉ុន ដែលជាចៅប្រុសរបស់កេហាត់ដែរ។
សូមមើលនៅក្នុង ២១:៤ ។

ការចាប់ឆ្នោត

generated on Wed Sep 10 16:16:32 2025

វិធីសាស្ត្រនៃការជ្រើសរើសដោយយកជម្រើសចេញពីឆន្ទៈរបស់មេដឹកនាំ
ជាញឹកញាប់ត្រូវបានធ្វើដោយគំនិតថា ព្រះជាម្ចាស់នឹងសម្រេចលទ្ធផល។
សូមមើលនៅក្នុង ១៩: ១ ។
Joshua 21:11
អើបាជាឪពុករបស់អណាក់
នេះគឺជាពត៌មានសង្ខេបអំពីឈ្មោះបុរសដែលបានបង្កើតទីក្រុងគីរីយ៉ាតអើបា។
អណាក់
នេះគឺជាឈ្មោះនៃបុរសម្នាក់។
តំបន់ភ្នំយូដា
តំបន់ដីមួយដែលមានកម្ពស់ទាបជាងភ្នំ។
វាលស្មៅ
តំបន់គ្របដណ្តប់ដោយស្មៅ ឬរុក្ខជាតិសមស្របសម្រាប់សត្វពាហនៈឬគោក្របី
ដែលស៊ីស្មៅជាអាហារ។
វាលស្រែ និងភូមិរបស់ក្រុងនោះ
តំបន់វាលសំរាប់ដាំដំណាំ ដែលជាកម្មសិទ្ធិរបស់ប្រជាជននៅជុំវិញទីក្រុង។
ភូមិ
សហគមន៍តូចៗជាទូទៅតូចជាងទីក្រុង។
Joshua 21:13
ក្រុងលីបណា ... ក្រុងយ៉ាទៀរ ... ក្រុងអែសធេម៉ូរ ... ក្រុងហូឡូន ... ក្រុងដេបៀរ ... ក្រុងអាយីន ... ក្រុងយូថា
ទាំងអស់នេះគឺឈ្មោះនៃទីក្រុង។
មានប្រាំបួនក្រុង ...កុលសម្ព័ន្ធទាំងពីរ
ចំនួននៃទីក្រុងនានា និងអំបូរនៅអេត្ថបទគម្ពីរ។
Joshua 21:17
ចេញពីកុលសម្ព័ន្ធបេនយ៉ាមីន ពួកគេទទួលបានក្រុងគីបៀន
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
កុលសម្ព័ន្ធបេនយ៉ាមីន បានអោយគីបៀន »។
ក្រុងកេបា ...ក្រុងអាណាថោត ... ក្រុងអាល់ម៉ូន
ទាំងនេះគឺឈ្មោះនៃទីក្រុង។
គឺដប់បីក្រុង
«១៣ទីក្រុង »
Joshua 21:20
គ្រួសាររបស់លោកកេហាត់
ក្រុមបូជាចារ្យនៅក្នុងក្រុមនេះ គឺជាកូនចៅនៃលោកលេវី កូនរបស់លោកកេហាត់។
មួយចំណែកនៃពួកគេក៏ជាកូនចៅនៃអើរ៉ុន ដែលជាចៅប្រុសរបស់លោក
កេហាត់ដែរ។
ពួកគេទទួលបានក្រុង
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ពួកគេទទួលបានទីក្រុងនានា »
ការចាប់ឆ្នោត
វិធីសាស្ត្រចាប់ឆ្នោតជ្រើសរើស ដែលមិនចេញពីឆន្ទៈរបស់មេដឹកនាំ
ជាញឹកញាប់ជាគំនិតរបស់ព្រះជាម្ចាស់ ដែលនឹងសម្រេចលទ្ធផល។
សូមមើលនៅក្នុង ១៩: ១ ។
ក្រុងកេស៊ើរ ... ក្រុងគីបសែម ... ក្រុងបេតហូរ៉ូន
ឈ្មោះនៃទីក្រុងនានា
ទាំងអស់មានបួនក្រុង
នេះសំដៅទៅលើការកត់ក្នុងបញ្ជីតាមរយៈការសរុបចំនួន។
Joshua 21:23
អំបូរកេហាត់បានទទួលក្រុង និងវាលស្មៅរបស់ក្រុងនោះ ក្រុងគីបថោន
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត «
កុលសម្ព័ន្ធដាន់បានប្រគល់ឲ្យអំបូរកេហាត់ ក្រុងគីបថោន »
អំបូរកេហាត់
ក្រុមបូជាចារ្យនៅក្នុងក្រុមនេះ គឺជាកូនចៅរបស់កូលីដែលជាកូនប្រុសរបស់លេវី។
មួយចំណែកនៃពួកគេក៏ជាកូនចៅរបស់អើរ៉ុនដែ
លជាចៅប្រុសរបស់អំបូរកេហាត់ដែរ។ សូមមើលនៅក្នុង ២១:២០។
ក្រុងគីបថោន ... ហ្គីបបេតថុន។.. ក្រុងអាយ៉ាឡូន ... ក្រុងកាថ រីម៉ូន
ទាំងអស់នេះគឺឈ្មោះនៃទីក្រុង។
បួនក្រុង
នេះសំដៅទៅលើចំនួនទីក្រុង។
Joshua 21:25
អំបូរកេហាត់បានទទួលក្រុងពីរពីកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលគឺក្រុងតាណាក់
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត «
កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលបានប្រគល់អោយអំបូរកេហាត់ ក្រុង
តាណាក់ »
ក្រុងតាណាក់ ... ក្រុងកាថ រីម៉ូន
ទាំងនេះគឺឈ្មោះនៃទីក្រុងនានា។
ក្រុងនោះ ... ទាំងអស់មានក្រុងដប់
ចំនួននៃទីក្រុងបានចុះនៅក្នុងបញ្ជី។
អំបូរកូនចៅរបស់កេហាត់ ... កូនចៅរបស់កេហាត់
ក្រុមបូជាចារ្យនៅក្នុងក្រុមនេះ គឺជាកូនចៅរបស់លេវីនៃកូនប្រុសរបស់កេហាត់។
មួយចំណែកនៃពួកគេក៏ជាកូនចៅរបស់លោកអើរ៉ុន
ដែលជាចៅប្រុសរបស់កេហាត់ដែរ។ សូមមើលនៅក្នុង ២១: ៤ ។
Joshua 21:27
អំបូរគើសុន ដែលជាអំបូរផ្សេងទៀតរបស់កុលសម្ព័ន្ធលេវីទទួលបានក្រុង និងវាលស្មៅរបស់ក្រុងនោះ
ក្នុងទឹកដីពីកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល ដែលនៅខាងកើត សម្រាប់ជាក្រុងជម្រកដល់
អ្នកសម្លាប់គេដោយអចេតនា ក្រុងកូឡាន
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
កុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាលកុលសម្ព័ន្ធលេវីដទៃទៀត
ទទួលបានពីកុលសម្ព័ន្ធម៉ាណាសេកូលូន»
ក្រុងកូឡាន ... ក្រុងបេសត្រា
ឈ្មោះនៃទីក្រុងនានា។
ក្រុងជម្រកដល់អ្នកសម្លាប់គេដោយអចេតនា
នេះសំដៅទៅលើការស្លាប់ ដែលបណ្តាលមកពីសកម្មភាព
ដែលមិនមានបំណងធ្វើបាបមនុស្ស។
ក្រុងពីរ
ឈ្មោះនៃទីក្រុងនានា។
Joshua 21:28
ពួកគេក៏ឲ្យក្រុងគើសុនពីកុលសម្ព័ន្ធអ៊ីសាខារដល់អំបូរគើសុន
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
អំបូរគើសុនក៏បានទទួលយកកុលសម្ព័ន្ធអ៊ីសាខារ »
គើសុន ... ក្រុងដាប្រាត ... ក្រុងយ៉ាមូត ... ក្រុងអេនកានីន ... ក្រុងមីសាល់ ... ក្រុងអាប់ដូន ...
ក្រុងហែលកាថ ... ក្រុងរេហូប
ឈ្មោះនៃទីក្រុងនានា។
ចេញពីកុលសម្ព័ន្ធស៊ើរ គេបានឲ្យក្រុងមីសាល់
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ពួកគេបានទទួលពីកុលសម្ព័ន្ធស៊ើរក្រុងមីសាល់»។
គឺមានក្រុងបួន
នេះសំដៅទៅលើចំនួននៃទីក្រុងនានា
Joshua 21:32
ចេញពីកុលសម្ព័ន្ធណែបថាលី អំបូរគើសុន បានទទួលក្រុងកាដេស
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត «
ត្រកូលរបស់ហ្គើរសុនទទួលបាន ពីកុលសម្ព័ន្ធណាប៉ូធីលីកាដេស »
អំបូរគើសុន
នេះគឺឈ្មោះនៃមនុស្សម្នាក់។
ក្រុងហាម៉ាត ដោរ ... ក្រុងការថាន
ទាំងនេះគឺជាមនុស្សនៃទីក្រុងនានា។
ក្រុងទាំងអស់ដប់បី
« ទីក្រុងសរុបទាំងអស់១៣ »
Joshua 21:34
ពួកលេវីផ្សេងទៀតអំបូរលោកម៉្រារី ទទួលបានពីកុលសម្ព័ន្ធសាប់យូឡូន មានក្រុងយ៉ុកនាម
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
កុលសម្ព័ន្ធលេវីដែលជាអំបូរម៉្រារី
ដែលបានទទួលពីកុលសម្ព័ន្ធសាប់យូឡូនក្រុងយ៉ុកនាម »
អំបូរលោកម៉្រារី
ឈ្មោះរបស់មនុស្សម្នាក់
ក្រុងយ៉ុកនាម ... ក្រុងការថា ... ក្រុងឌីម ណា ... ក្រុងណា ហាឡាល់
ឈ្មោះនៃទីក្រុងនានា
មានទាំងអស់បួនក្រុង

generated on Wed Sep 10 16:16:32 2025

ទីក្រុងគឺយោងទៅតាមចំនួនសរុប។
Joshua 21:36
អំបូរម៉្រារី បានទទួលពីកុលសម្ព័ន្ធរូបេនមានក្រុងបេសស៊ើ
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ការបកប្រែផ្សេងទៀត « អំបូរ
ម៉្រារីបានទទួលពីកុលសម្ព័ន្ធរូបេនក្រុងបេសស៊ើ »
មានទាំងអស់បួនក្រុង
នេះសំដៅទៅលើចំនួនសរុបនៃទីក្រុង។
បេសស៊ើរ ... ក្រុងយ៉ាហាស ...ក្រុងកេដ្ដេម៉ូត... ក្រុងមេផ្អាត ... ក្រុងរ៉ាម៉ូត
ឈ្មោះនៃទីក្រុង
ពីកុលសម្ព័ន្ធកាដ គេទទួលបានក្រុងរ៉ាម៉ូត
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ពួកគេបានទទួលពីកុលសម្ព័ន្ធកាដក្រុងរ៉ាម៉ូត »
ក្រុងម៉ាហាណែម
នេះគឺឈ្មោះនៃទីក្រុង
Joshua 21:39
អំបូរម៉្រារីក៏ទទួលបានក្រុងហេសបូន
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
អំបូរម្រារីក៏បានទទួលក្រុងហេសបូន»
ក្រុងហេសបូន ... ក្រុងយ៉ាស៊ើរ
ទាំងនេះគឺឈ្មោះនៃទីក្រុង
មានទាំងអស់ដប់ពីរក្រុង
"១២ទីក្រុងសរុបទាំងអស់"
ដប់ពីរក្រុង ដែលបានចាប់ឆ្នោតសម្រាប់ពួកគេ។
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ពួកគេទទួលបានទីក្រុងទាំងដប់ពីរនេះដោយការចាប់ឆ្នោតជាច្រើន »
ការចាប់ឆ្នោត
វិធីសាស្ត្រចាប់ឆ្នោតនៃការជ្រើសរើស យកជម្រើសចេញពីឆន្ទៈរបស់មេដឹកនាំ
ជាញឹកញាប់ត្រូវបានធ្វើដោយគំនិតថា ព្រះជាម្ចាស់នឹងសម្រេចលទ្ធផល។
សូមមើលនៅក្នុង ១៩: ១ ។
Joshua 21:41
ក្រុងដែលពួកលេវីបានទទួលពីកណ្តាលទឹកដី
អាចបញ្ជាក់ជាទំរង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ពួកលេវីបានទទួលទីក្រុងរបស់ពួកគេ ពីពាក់កណ្តាលទឹកដី »
មានចំនួនសែសិបប្រាំបីក្រុង
ទីក្រុងប្រាំបី « ទីក្រុង៤៨ »
Joshua 21:43
ព្រះអង្គបានស្បថ
« ព្រះអង្គបានប្រទានពាក្យសម្បថ »
គ្មានសត្រូវណាមួយរបស់ពួកគេអាចយកឈ្នះពួកគេបានឡើយ
បញ្ជាក់តាមបែបអវិជ្ជមាន ដើម្បីពង្រឹងសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
« bពួកគេបានជ័យជម្នះលើសត្រូវរបស់ពួកគេ»
បានប្រទានសត្រូវរបស់ពួកគេមកក្នុងកណ្តាប់ដៃរបស់ពួកគេ
នៅទីនេះ « នៅក្នុងដៃរបស់ពួកគេ » មានន័យថា «
ចូលទៅក្នុងអំណាចរបស់ពួកគេ » ។ ការបកប្រែផ្សេងទៀត «
ផ្តល់អំណាចឲ្យពួកគេ កម្ចាត់សត្រូវរបស់ពួកគេទាំងអស់ »
គ្មានសេចក្តីសន្យាណាមួយដែលព្រះអម្ចាស់បានសន្យាជាមួយនឹងអ៊ីស្រាអែលមិនបានសម្រេចនោះឡើយ។
អ្វីៗគ្រប់យ៉ាងបានសម្រេចទាំងអស់។
បញ្ជាក់តាមបែបអវិជ្ជមាន ដើម្បីពង្រឹងសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
« រាល់ការសន្យាល្អៗ
ដែលព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ពួកកូនចៅអ៊ីស្រាអែលបានសម្រេច »

---

22 [1]ក្រោយមក លោកយ៉ូស្វេហៅកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលមក។[2]លោកបានមានប្រសាសន៍ទៅពួកគេថា៖
«អ្នកបានធ្វើអ្វីគ្រប់យ៉ាងដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានបង្គាប់ដល់អ្នក។ អ្នកបានស្តាប់បង្គាប់រាល់ពាក្យរបស់ខ្ញុំដែលបានប្រាប់អ្នករាល់គ្នា។
[3]អ្នកមិនបានបោះបង់ចោលបងប្អូនរបស់អ្នកឡើយតាំងពីមុនរហូតមកដល់ថ្ងៃនេះ អ្នកបានបំពេញកាតព្វកិច្ចដែលព្រះអម្ចាស់បានបង្គាប់ដល់អ្នករាល់គ្នា។
[4]ឥឡូវនេះ ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាឲ្យបងប្អូនរបស់អ្នករាល់គ្នាសម្រាក ដូចដែលព្រះអង្គបានសន្យាជាមួយពួកគេ។ ដូច្នេះ ចូរត្រឡប់ទៅជំរំរបស់អ្នករាល់គ្នាវិញ
ជាកន្លែងដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានផ្តល់ឲ្យអ្នករាល់គ្នានៅត្រើយម្ខាងទន្លេយ័រដាន់។[5]ប៉ុន្តែ ត្រូវប្រយ័ត្នក្នុងការប្រព្រឹត្តតាមរាល់បទបញ្ជា
និងក្រឹត្យវិន័យដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអម្ចាស់បានបង្គាប់ដល់អ្នករាល់គ្នា ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក ត្រូវដើរតាមផ្លូវរបស់ព្រះអង្គ
ត្រូវរក្សាបញ្ញត្តរបស់ព្រះអង្គ ត្រូវជាប់ចិត្តជាមួយព្រះអង្គ ហើយត្រូវថ្វាយបង្គំព្រះអង្គឲ្យអស់ពីចិត្ត និងអស់ពីព្រលឹងរបស់អ្នករាល់គ្នា»។[6]ដូច្នេះ
លោកយ៉ូស្វេក៏ឲ្យពរដល់ពួកគេ ហើយឲ្យពួកគេចេញទៅ ពួកគេក៏ត្រឡប់ទៅជំរំរបស់ពួកគេវិញ។
[7]ឥឡូវនេះ កុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាលទៀតបានទទួលទឹកដីជាមរតកនៅក្រុងបាសាន ប៉ុន្តែ
កុលសម្ព័ន្ធពាក់កណ្តាលទៀតបានទទួលទឹកដីជាមរតកនៅទល់មុខបងប្អូនរបស់ពួកគេនៅតំបន់ខាងលិចទន្លេយ័រដាន់។
លោកយ៉ូស្វេបានបញ្ជូនពួកគេទៅជំរំរបស់ពួកគេវិញ លោកក៏បានឲ្យពរពួកគេ[8]ហើយនិយាយទៅពួកគេថា៖ «ចូរត្រឡប់ទៅជំរំរបស់អ្នករាល់គ្នាវិញជាមួយនឹងទ្រព្យដ៏ច្រើន
និងហ្វូងសត្វយ៉ាងច្រើន ជាមួយមាស និងប្រាក់ ជាមួយលង្ហិន និងដែក និងមានសំលៀកបំពាក់ដ៏ច្រើនទាំងនេះចុះ។
ចូរចែកជ័យភណ្ឌដែលបានពីពួកខ្មាំងសត្រូវជាមួយនឹងបងប្អូនរបស់អ្នករាល់គ្នាចុះ។
[9]ដូច្នេះ កូនចៅកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល បានវិលត្រឡប់ទៅផ្ទះរបស់ពួកគេវិញ គឺចាកចេញពីជនជាតិអ៊ីស្រាអែលនៅ
ស៊ីឡូ ដែលនៅទឹកដីកាណាន។ ពួកគេចាកចេញឆ្ពោះទៅស្រុកកាឡាដ ជាទឹកដីរបស់ពួកគេ ដែលធ្វើតាមបញ្ជាដែលព្រះអម្ចាស់បានបង្គាប់មកលោកម៉ូសេ។
[10]នៅពេលដែលពួកគេបានមកដល់ទន្លេយ័រដាន់នៅក្នុងទឹកដីកាណាន កុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល
បានសង់អាសនាមួយនៅត្រើយទន្លេយ័រដាន់ជាអាសនាមួយយ៉ាងធំ និងអស្ចារ្យ។[11]ប្រជាជនអ៊ីស្រាអែលបានឮពីរឿងនេះ ហើយបាននិយាយថា៖ «មើល! កុលសម្ព័ន្ធរូបេន
កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល បានសង់អាសនានៅខាងមុខទឹកដីកាណានគីលីយ៉ូត នៅតំបន់ក្បែរទន្លេយ័រដាន់
នៅត្រើយម្ខាងដែលជាកម្មសិទ្ធិរបស់ប្រជាជនអ៊ីស្រាអែល។
[12]នៅពេលដែលប្រជាជនអ៊ីស្រាអែលឮអំពីរឿងនេះ ប្រជាជនទាំងអស់បានប្រជុំគ្នានៅក្រុងស៊ីឡូ ដើម្បីឡើងទៅធ្វើសង្គ្រាមជាមួយពួកគេ។
[13]បន្ទាប់មក ប្រជាជនអ៊ីស្រាអែលបានបញ្ជូនអ្នកនាំសារ ទៅកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល នៅឯទឹកដីគីឡាត។
ពួកគេក៏បានបញ្ជូនលោកភីនេហាស ជាកូនលោកបូជាចារ្យអេឡាសារទៅដែរ[14]និងអ្នកដឹកនាំដប់អ្នកទៀតទៅជាមួយពួកគេដែរ គឺក្នុងមួយកុលសម្ព័ន្ធម្នាក់
ហើយពួកគេម្នាក់ៗសុទ្ធតែជាអ្នកដឹកនាំនៃអំបូររបស់ប្រជាជនអ៊ីស្រាអែល។
[15]ពួកគេបានមកជួបប្រជាជនកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល នៅស្រុកកាឡាដ ហើយពួកគេនិយាយថា៖
[16]«សហគមន៍ទាំងមូលរបស់ព្រះអម្ចាស់បាននិយាយថា៖ «តើហេតុអ្វីបានជាអ្នករាល់គ្នាបានប្រព្រឹត្តរឿងមិនស្មោះត្រង់ប្រឆាំងនឹងព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែល
ដោយនៅថ្ងៃនេះអ្នកបានឈប់ដើរតាមព្រះអម្ចាស់ដោយបានសង់អាសនាមួយសម្រាប់ខ្លួនអ្នករាល់គ្នាដើម្បីប្រឆាំងនឹងព្រះអម្ចាស់ដូច្នេះ?
[17]តើអំពើបាបរបស់យើងនៅពេអមិនគ្រប់គ្រាន់សម្រាប់យើងទេឬអី? នៅពេលនេះយើងមិនទាន់បានសម្អាតខ្លួនរបស់យើងពីអំពើទាំងនោះនៅឡើយ។
អំពើបាបនៅទីនោះបានធ្វើឲ្យសហគមន៍អ៊ីស្រាអែលវេទនាយ៉ាងខ្លាំង។[18]តើអ្នកត្រូវឈប់ដើរតាមការដឹកនាំរបស់ព្រះអម្ចាស់នៅថ្ងៃនេះឬ?
បើអ្នករាល់គ្នាបះបោរប្រឆាំងនឹងព្រះអម្ចាស់នៅថ្ងៃនេះ នៅថ្ងៃស្អែកព្រះអង្គនឹងព្រះពិរោធជាមួយនឹងសហគមន៍អ៊ីស្រាអែលទាំងមូលមិនខាន។
[19]បើទឹកដីដែលជាកម្មសិទ្ធិរបស់អ្នករាល់គ្នាមិនបរិសុទ្ធទេ ដូច្នេះ អ្នកគួរតែឆ្លងទៅកាន់ទឹកដីដែលមានដំណាក់របស់ព្រះអម្ចាស់
ហើយទទួលចំណែកទឹកដីក្នុងចំណោមយើងរាល់គ្នាទៅ។ កុំឲ្យបះបោរប្រឆាំងនឹងព្រះអម្ចាស់
ក៏កុំឲ្យបះបោរប្រឆាំងនឹងយើងដោយសង់អាសនាសម្រាប់អ្នករាល់គ្នាជំនួសអាសនារបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាឡើយ។

generated on Wed Sep 10 16:16:32 2025

[20]តើលោកអាកានជាកូនរបស់លោកសេរ៉ាមិនបានប្រព្រឹត្តបាបលើរបស់ដែលត្រូវថ្វាយព្រះជាម្ចាស់ទេឬអី?
តើព្រះពិរោធរបស់ព្រះអម្ចាស់មិនបានធ្លាក់មកលើប្រជាជនអ៊ីស្រាអែលទេឬអី? តើគាត់វិនាសតែម្នាក់ឯងទេឬ»។
[21]បន្ទាប់មក កុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល ឆ្លើយទៅមេដឹកនាំអំបូរនៃជនជាតិអ៊ីស្រាអែលថា៖[22]«ព្រះជាម្ចាស់
ដ៏មានគ្រប់ព្រះចេស្តាគឺព្រះអម្ចាស់! ព្រះជាម្ចាស់ដ៏មានគ្រប់ព្រះចេស្តាគឺព្រះអម្ចាស់! ព្រះអង្គជ្រាប ហើយក៏សូមឲ្យប្រជាជនអ៊ីស្រាអែលទាំងអស់ដឹងដែរថា!
បើយើងបះបោរប្រឆាំងនឹងព្រះអម្ចាស់ សូមកុំឲ្យយើងនៅមានជីវិតដល់ថ្ងៃនេះឡើយ។[23]បើយើងសង់អាសនៈធ្វើឲ្យយើងដាច់ឆ្ងាយពីការដើរតាមព្រះអម្ចាស់។
បើយើងសង់អាសនាដើម្បីថ្វាយតង្វាយដុត តង្វាយម្សៅ ឬក៏តង្វាយមេត្រីភាព នោះសូមឲ្យព្រះអម្ចាស់ដាក់ទោសពួកយើងចុះ។
[24]ទេ! យើងធ្វើបែបនេះដោយយើងភ័យខ្លាចថាថ្ងៃក្រោយកូនចៅរបស់អ្នកទាំងអស់គ្នានឹងនិយាយមកកាន់កូនចៅរបស់យើងថា៖ «តើអ្នកបានធ្វើអ្វីខ្លះចំពោះព្រះអម្ចាស់
ជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែល»?
[25]ដោយសារព្រះអម្ចាស់បានដាក់ទន្លេយ័រដាន់ជាព្រំប្រទល់រវាងយើង និងអ្នករាល់គ្នា។ អ្នកទាំងអស់គ្នាដែលជាពួករូបេន និងពួកកាដអើយ អ្នករាល់គ្នាគ្មានសិទ្ធិទាក់ទងជា
មួយព្រះអម្ចាស់ទេ»។ ដូច្នេះ កូនចៅរបស់អ្នករាល់គ្នាអាចមិនឲ្យកូនចៅរបស់យើងថ្វាយបង្គំព្រះអម្ចាស់។
[26]ដូច្នេះ យើងនិយាយថា៖ «ចូរយើងសង់អាសនៈមួយ មិនមែនសម្រាប់ថ្វាយដង្វាយដុត ឬសម្រាប់តង្វាយអ្វីផ្សេងៗឡើយ[27]ប៉ុន្តែ ជាបន្ទាល់រវាងយើង និងអ្នករាល់គ្នា
និងរវាងកូនចៅរបស់យើង និងយើងដែរ ដែលយើងមានសិទ្ធិក្នុងការថ្វាយបង្គំព្រះអម្ចាស់នៅមុខព្រះអង្គ ជាមួយនឹងការថ្វាយតង្វាយដុត និងតង្វាយមេត្រី ដូច្នេះ
កូនចៅរបស់អ្នករាល់គ្នានៅពេលក្រោយនឹងមិននិយាយថា៖ «អ្នកគ្មានសិទ្ធិអ្វីជាមួយព្រះអម្ចាស់ឡើយ»។
[28]ដូច្នេះ យើងនិយាយថា៖ «បើការនេះត្រូវនិយាយជាមួយយើង ឬជាមួយកូនចៅរបស់យើងនៅពេលក្រោយ យើងគួរនិយាយថា៖ «មើល!
នេះជាអាសនារបស់ព្រះអម្ចាស់ដែលបានចម្លងមក ដែលដូនតារបស់យើងបានសង់ មិនមែនសម្រាប់តង្វាយដុត ក៏មិនមែនសម្រាប់ថ្វាយតង្វាយដែរ ប៉ុន្តែ
ជាបន្ទាល់រវាងយើង និងអ្នករាល់គ្នា»។[29]យើងមិនចង់បះបោរប្រឆាំងនឹងព្រះអម្ចាស់ទេ ក៏មិនចង់បែរចិត្តចេញពីព្រះអង្គនៅថ្ងៃនេះដោយសង់អាសនៈសម្រាប់ថ្វាយតង្វាយ
ដុតទាំងមូល និងថ្វាយមេត្រីភាព ក្រៅពីអាសនារបស់ព្រះអម្ចាស់ ជាព្រះរបស់យើង ដែលស្ថិតនៅមុខដំណាក់របស់ព្រះអង្គឡើយ។
[30]នៅពេលលោកបូជាចារ្យភីនេហាស មេដឹកនាំប្រជាជន ដែលជាមេដឹកនាំអំបូរជនជាតិអ៊ីស្រាអែលដែលនៅជាមួយលោកបានឮពាក្យពីកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ
និងកុលសម្ព័ន្ធម៉ាណាសេ រៀបរាប់រួចមក ពួកគេគិតថាល្អ។[31]លោកភីនេហាស ជាកូនរបស់លោកបូជាចារ្យអេឡាសារ បាននិយាយទៅកាន់ប្រជាជនក្នុងកុលសម្ព័ន្ធរូបេន
កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេថា៖ «នៅថ្ងៃនេះយើងដឹងថាព្រះអម្ចាស់គង់នៅក្នុងចំណោមយើងរាល់គ្នា
ដោយសារអ្នកមិនបានប្រព្រឹត្តដោយឥតជំនឿប្រឆាំងនឹងព្រះអង្គឡើយ។ ឥឡូវនេះ អ្នកបានសង្គ្រោះប្រជាជនអ៊ីស្រាអែលចេញពីព្រះហស្តរបស់ព្រះអម្ចាស់ហើយ»។
[32]បន្ទាប់មក លោកភីនេហាស ជាកូនរបស់លោកបូជាចារ្យអេឡាសារ និងអ្នកដឹកនាំផ្សេងទៀតបានចាកចេញពីកុលសម្ព័ន្ធរូបេន និងកុលសម្ព័ន្ធកាដ ចេញពីទឹកដីស្រុក
កាឡាដ វិលមកស្រុកកាណាន ទៅជួបនឹងប្រជាជនអ៊ីស្រាអែល និងនាំពាក្យទាំងអស់ត្រឡប់ទៅប្រាប់ពួកគេវិញ។
[33]របាយការណ៍របស់ពួកគេក៏ធ្វើឲ្យប្រជាជនអ៊ីស្រាអែលពេញចិត្តដែរ។ ប្រជាជនអ៊ីស្រាអែលថ្វាយព្រះពរដល់ព្រះជាម្ចាស់
ហើយក៏មិននិយាយរឿងធ្វើសង្គ្រាមប្រឆាំងនឹងកុលសម្ព័ន្ធរូបេន និងកុលសម្ព័ន្ធកាដ ដើម្បីបំផ្លាញទឹកដីដែលពួកគេរស់នៅទៀតឡើយ។
[34]កុលសម្ព័ន្ធរូបេន និងកុលសម្ព័ន្ធកាដ បានហៅអាសនានោះថា៖ «សក្ខីភាព» ដោយនិយាយថា៖ «វាជាសក្ខីភាពរវាងយើងទាំងអស់គ្នាថា ព្រះអម្ចាស់គឺជាព្រះជាម្ចាស់»។

Joshua 22:1
កុលសម្ព័ន្ធរូបេន
ប្រជាជនកុលសម្ព័ន្ធរូបេន
កុលសម្ព័ន្ធកាដ
ប្រជាជនកុលសម្ព័ន្ធកាដ
បានស្តាប់បង្គាប់រាល់ពាក្យរបស់ខ្ញុំ
ត្រង់នេះ « សំឡេងរបស់ខ្ញុំ » សំដៅទៅលើអ្វីដែលយ៉ូស្វេបាននិយាយ។
ការបកប្រែផ្សេងទៀត « គោរពតាមអ្វីគ្រប់យ៉ាងដែលខ្ញុំបាននិយាយ »
អ្នកមិនបានបោះបង់ចោលបងប្អូនរបស់អ្នកឡើយ
នេះអាចត្រូវបានបញ្ជាក់តាមរបៀបវិជ្ជមាន។ ការបកប្រែផ្សេងទៀត «
អ្នកនៅតែជាមួយបងប្អូនរបស់អ្នក »
Joshua 22:4
ត្រូវដើរតាមផ្លូវរបស់ព្រះអង្គ
មនុស្សម្នាក់ដែលស្តាប់បង្គាប់ព្រះអម្ចាស់
ត្រូវបានគេនិយាយដូចជាកំពុងដើរតាមផ្លូវរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
« ដើម្បីគោរពតាមអ្វីគ្រប់យ៉ាង ដែលគាត់និយាយ »
ត្រូវជាប់ចិត្តជាមួយព្រះអង្គ ហើយត្រូវថ្វាយបង្គំព្រះអង្គឲ្យអស់ពីចិត្ត
និងអស់ពីព្រលឹងរបស់អ្នករាល់គ្នា
ពាក្យ « បេះដូង » និង « ព្រលឹង »
នៅទីនេះត្រូវបានប្រើរួមគ្នាដើម្បីសំដៅទៅលើមនុស្សទាំងមូល។
ការបកប្រែផ្សេងទៀត « ជាមួយអ្វីទាំងអស់ដែលអ្នកគិតនិងមានអារម្មណ៍ » ឬ «
ដោយខ្លួនអ្នកទាំងមូល »
Joshua 22:7
ទន្លេយ័រដាន់
នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។
ដែក
ខ្លាំង រឹង គឺ មេដែក
ជ័យភណ្ឌ
កងទ័ពដែលឈ្នះនឹងយកអ្វីៗទាំងអស់ ដែលមានតម្លៃពីប្រជាជន
ដែលពួកគេបានច្បាំងដណ្តើមយក។
Joshua 22:9
ដែលធ្វើតាមបញ្ជាដែលព្រះអម្ចាស់បានបង្គាប់មកលោកម៉ូសេ។
ឃ្លា « ដោយដៃ» នៅទីនេះមានន័យថា ព្រះអម្ចាស់បានប្រើលោកម៉ូសេជាភ្នាក់ងារ
ដើម្បីបញ្ជូនការបញ្ជារបស់ទ្រង់។ ការបកប្រែផ្សេងទៀត «
បទបញ្ជាដែលព្រះអម្ចាស់បានប្រាប់លោកម៉ូសេ អោយប្រគល់មកអ្នក »
Joshua 22:10
ទន្លេយ័រដាន់
នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។
នៅក្នុងទឹកដីកាណាន
កុលសម្ព័ន្ធអ៊ីស្រាអែលដែលរស់នៅទន្លេយ័រដាន់ នឹងចូលទៅស្រុកកាណាន
នៅកន្លែងដែលពួកគេសង់អាសនៈ។ កន្លែងនេះត្រូវបានគេនិយាយថាដូចជា «
ខាងមុខ » ឬ « ច្រកចូល » ទៅកាន់ទឹកដីកាណាន
ដែលជាកន្លែងមានកុលសម្ព័ន្ធផ្សេងទៀតរស់នៅ។ ការបកប្រែផ្សេងទៀត «
នៅច្រកចូលទៅកាន់ទឹកដីកាណាន »
គីលីយ៉ូត
ឈ្មោះនៃទីក្រុង
Joshua 22:12
សង្គ្រាម
ជម្លោះប្រដាប់អាវុធ រវាងប្រជាជាតិពីរ ឬមនុស្សពីរក្រុម។
Joshua 22:13
លោកបូជាចារ្យអេឡាសារ
ឈ្មោះនៃបុរសម្នាក់
Joshua 22:15
សហគមន៍ទាំងមូលរបស់ព្រះអម្ចាស់បាននិយាយថា៖
ប្រជាជនអ៊ីស្រាអែលទាំងអស់ ត្រូវបានគេនិយាយជាមួយគ្នានៅក្នុងពហុវចនៈហាក់
ដូចជាពួកគេតែមួយ។ ការបកប្រែផ្សេងទៀត «
ជនជាតិអ៊ីស្រាអែលទាំងអស់កំពុងតែសួរ»
Joshua 22:17
តើអំពើបាបរបស់យើងនៅពេអ៊ិមិនគ្រប់គ្រាន់សម្រាប់យើងទេឬអី?
សំណួរនេះសង្កត់ធ្ងន់ថា តើអំពើបាបពីមុនរបស់ពួកគេធ្ងន់ធ្ងរប៉ុណ្ណា?
នេះអាចត្រូវបានសរសេរជាឃ្លា។ ការបកប្រែផ្សេងទៀត «
យើងបានធ្វើបាបយ៉ាងធ្ងន់ធ្ងររួចទៅហើយនៅពេអ៊ិ »

generated on Wed Sep 10 16:16:32 2025

ពេអ៊ែ
នេះគឺជាឈ្មោះនៃទីកន្លែង ដូចគ្នាបកប្រែរបៀបនៅក្នុង១៣:២០
នៅពេលនេះយើងមិនទាន់បានសម្អាតខ្លួនរបស់យើងពីអំពើទាំងនោះនៅឡើយ។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «
យើងកំពុងដោះស្រាយជាមួយ នឹងកំហុសនៃអំពើបាបនោះ »
តើអ្នកត្រូវឈប់ដើរតាមការដឹកនាំរបស់ព្រះអម្ចាស់នៅថ្ងៃនេះឬ?
សំណួរនេះត្រូវបានប្រើដើម្បីស្តីបន្ទោសប្រជាជន សម្រាប់អំពើបាបរបស់ពួកគេ។
នេះអាចត្រូវបានសរសេរជាឃ្លា។ការបកប្រែផ្សេងទៀត «
អ្នកមិនត្រូវងាកចេញពីការដើរតាមព្រះអម្ចាស់នៅថ្ងៃនេះទេ! »
Joshua 22:19
លោកអាកាន ...លោកសេរ៉ា
ឈ្មោះនៃបុរស
តើលោកអាកានជាកូនរបស់លោកសេរ៉ាមិនបានប្រព្រឹត្តបាបលើរបស់ដែលត្រូវថ្វាយព្រះជាម្ចាស់ទេឬអី? ព័ត៌មានទូទៅ
តើព្រះពិរោធរបស់ព្រះអម្ចាស់មិនបានធ្លាក់មកលើប្រជាជនអ៊ីស្រាអែលទេឬអី?
សំណួរទាំងនេះត្រូវបានប្រើដើម្បីរំលឹកប្រជាជន
អំពីការដាក់ទណ្ឌកម្មចំពោះអំពើបាបពីអតីតកាល។
សំណួរទាំងនេះអាចត្រូវបានសរសេរជាឃ្លា។ ការបកប្រែផ្សេងទៀត «
លោកអេកានជាកូនរបស់លោកសេរ៉ា
បានធ្វើបាបតាមរយៈការយករបស់ដែលបានបម្រុងទុកសម្រាប់ព្រះជាម្ចាស់។
ហើយដោយសារបែបហ្នឹង
ព្រះជាម្ចាស់បានដាក់ទណ្ឌកម្មប្រជាជនអ៊ីស្រាអែលទាំងអស់! »
Joshua 22:21
បើយើងបះបោរ ... នោះសូមឲ្យព្រះអម្ចាស់ដាក់ទោសពួកយើងចុះ។
កុលសម្ព័ន្ធទាំងបីកំពុងធ្វើសេចក្តីថ្លែងការណ៍
សម្មតិកម្មពីរដែលពួកគេទទូចថាមិនពិត។
ពួកគេមិនបានសាងសង់អាសនៈដើម្បីថ្វាយបង្គំព្រះក្លែងក្លាយដទៃទៀតទេ។
Joshua 22:24
ព័ត៌មានទូទៅ
កុលសម្ព័ន្ធរូបេនកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលផ្តល់ចម្លើយ។
កូនចៅរបស់អ្នកទាំងអស់គ្នានឹងនិយាយមកកាន់កូនចៅរបស់យើងថា ...
ព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែល?
នេះគឺជាការចោទប្រកាន់ដោយសន្មត់ថា កុលសម្ព័ន្ធទាំងបី
គិតថាកូនរបស់កុលសម្ព័ន្ធផ្សេងទៀត អាចនឹងធ្វើឲ្យមានបញ្ហានៅពេលអនាគត។
តើអ្នកបានធ្វើអ្វីខ្លះចំពោះព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែល»?
កុលសម្ព័ន្ធទាំងបី
ប្រើសំណួរដ៏ប៉ិនប្រសប់ដើម្បីបញ្ជាក់ពីស្ថានភាពដែលពួកគេកំពុងព្យាយាមចៀសវាង។
នេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «
អ្នកមិនមានអ្វីដែលត្រូវធ្វើជាមួយព្រះអម្ចាស់
គឺព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែលទេ! »
Joshua 22:25
ព័ត៌មានទូទៅ
កុលសម្ព័ន្ធរូបេនកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល
នៅតែបន្តឆ្លើយចម្យលើរបស់ពួកគេ។
ដោយសារព្រះអម្ចាស់បានដាក់ទន្លេយ័រដាន់ ...គ្មានសិទ្ធិទាក់ទងជាមួយព្រះអម្ចាស់ទេ
នេះគឺជាការបន្ត ការចោទប្រកាន់ដោយសន្មតថាកុលសម្ព័ន្ធទាំងបីគិតថា
កូនចៅរបស់កុលសម្ព័ន្ធផ្សេងទៀតអាច នឹងធ្វើនៅពេលណាមួយនាពេលអនាគត។
ទន្លេយ័រដាន់
នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។
ដូច្នេះ កូនចៅរបស់អ្នករាល់គ្នាអាចមិនឲ្យកូនចៅរបស់យើងថ្វាយបង្គំព្រះអម្ចាស់។
កុលសម្ព័ន្ធទាំងបី បានកសាងអាសនៈ
ដើម្បីជៀសវាងស្ថានភាពដែលអាចកើតមានឡើងនាពេលអនាគត។
Joshua 22:26
ព័ត៌មានទូទៅ៖
កុលសម្ព័ន្ធរូបេនកាដនិងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលផ្តល់ចម្លើយ។
ជាបន្ទាល់រវាងយើង និងអ្នករាល់គ្នា
អាសនៈនេះត្រូវបានគេនិយាយថា ជាសាក្សីដែលអាចផ្តល់ទីបន្ទាល់
ពីសិទ្ធិនៃកុលសម្ព័ន្ធទាំងបី។
ដូច្នេះ កូនចៅរបស់អ្នករាល់គ្នានៅពេលក្រោយនឹងមិននិយាយថា៖
«អ្នកគ្មានសិទ្ធិអ្វីជាមួយព្រះអម្ចាស់ឡើយ»។
នេះគឺជាការសន្មត ពីស្ថានភាពដែលកុលសម្ព័ន្ធទាំងបីមិនចង់ឲ្យកើតឡើង។
គ្មានសិទ្ធិ
«គ្មានចំណែក»ឬ «គ្មានមរតក»
Joshua 22:28
ព័ត៌មានទូទៅ
កុលសម្ព័ន្ធរូបេន កាដ និង
កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលឥឡូវចប់ចម្លើយរបស់ពួកគេ។
បើការនេះត្រូវនិយាយ ... ជាបន្ទាល់រវាងយើង និងអ្នករាល់គ្នា
កុលសម្ព័ន្ធទាំងបីកំពុងពិពណ៌នាចម្លើយ ដែលមានសក្តានុពលរបស់ពួកគេ
ចំពោះការចោទប្រកាន់ដែលអាចនឹងកើតមាន
ឬមិនអាចកើតមានឡើងនាពេលអនាគត។
យើងមិនចង់បះបោរប្រឆាំងនឹងព្រះអម្ចាស់ទេ
មិនទំនងទេដែលពួកគេអាចបះបោរ ព្រោះពួកគេនៅឆ្ងាយពីគ្នា។
ការបកប្រែផ្សេងទៀត « យើងប្រាកដជាមិនបះបោរ »
ចង់បែកចិត្តចេញពីព្រះអង្គ
ការបញ្ឈប់ការដើរតាមព្រះអម្ចាស់
ត្រូវបានគេនិយាយដូចជាពួកគេបានកំពុងងាកចេញពីព្រះអង្គ។
ការបកប្រែផ្សេងទៀត « ឈប់ដើរតាមគាត់ »
Joshua 22:30
បានឮពាក្យ
នៅទីនេះ « ពាក្យ » សំដៅទៅលើសារដែលត្រូវបានបង្កើតឡើងពីពាក្យ។
ការបកប្រែផ្សេងទៀត « បានឮសារ »
ពួកគេគិតថាល្អ
នៅទីនេះ «នៅក្នុងភ្នែករបស់ពួកគេ» មានន័យថា «
នៅក្នុងគំនិតយោបល់របស់ពួកគេ »
ដោយសារអ្នកមិនបានប្រព្រឹត្តដោយឥតជំនឿប្រឆាំងនឹងព្រះអង្គឡើយ
« បានផ្តាច់ការសន្យារបស់អ្នកទៅកាន់ព្រះអង្គ »
អ្នកបានសង្គ្រោះប្រជាជនអ៊ីស្រាអែលចេញពីព្រះហស្តរបស់ព្រះអម្ចាស់ហើយ»។
នៅទីនេះ « ព្រះហស្តរបស់ព្រះអម្ចាស់ » សំដៅទៅលើការដាក់ទណ្ឌកម្មរបស់ទ្រង់។
ការពារប្រជាជន គេនិយាយថាជាការជួយសង្គ្រោះពួកគេពីកណ្តាប់ដៃរបស់ទ្រង់។
ការបកប្រែផ្សេងទៀត « អ្នកបានរក្សាការពារព្រះអម្ចាស់ពីការដាក់ទោសយើង »
Joshua 22:32
របាយការណ៍របស់ពួកគេក៏ធ្វើឲ្យប្រជាជនអ៊ីស្រាអែលពេញចិត្តដែរ។
នៅទីនេះ «ល្អនៅក្នុងភ្នែក» មានន័យថា «ទទួលយក» ។ ការបកប្រែផ្សេងទៀត
ប្រជាជនទទួលយករបាយការណ៍របស់មេដឹកនាំ។
ដើម្បីបំផ្លាញទឹកដី
«បំផ្លាញអ្វីៗគ្រប់យ៉ាងនៅក្នុងដី»
Joshua 22:34
ដោយនិយាយថា
នេះសំដៅទៅលើរូបេន និងកាដ។
វាជាសក្ខីភាពរវាងយើង
អាសនៈនេះត្រូវបានគេនិយាយថាជាសក្ខីភាពដែលអាចថ្លែងទីបន្ទាល់សម្រាប់កុលសម្ព័ន្ធទាំងបី។

23

[1]ជាច្រើនថ្ងៃក្រោយមក ព្រះអម្ចាស់បានឲ្យប្រជាជនអ៊ីស្រាអែលបានសម្រាកពីពួកខ្មាំងសត្រូវរបស់ពួកគេ ហើយលោកយ៉ូស្វេមានអាយុកាន់តែចាស់ និងមានអាយុវែង។
[2]លោកយ៉ូស្វេបានហៅប្រជាជនអ៊ីស្រាអែលទាំងអស់មក មានពួកចាស់ទុំ អ្នកដឹកនាំ ពួកចៅក្រម និងពួកនាយកក្រុមមក ហើយនិយាយទៅពួកគេថា៖
«ខ្ញុំកាន់តែចាស់ហើយ។[3]អ្នករាល់គ្នាបានឃើញអ្វីៗដែលព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នកបានប្រព្រឹត្តចំពោះជាតិសាសន៍ទាំងអស់សម្រាប់អ្នករាល់គ្នា
គឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានប្រយុទ្ធដើម្បីអ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

[4]មើល! ខ្ញុំបានបែងចែកទឹកដីរបស់ជាតិសាសន៍នានាដែលអ្នករាល់គ្នាបានដណ្តើមបានដល់អ្នករាល់គ្នា សម្រាប់កុលសម្ព័ន្ធរបស់អ្នករាល់គ្នា
ក្នុងនោះមានជាតិសាសន៍ដែលខ្ញុំបានបំផ្លាញរួចហើយ ចាប់ពីទន្លេយ័រដាន់ដល់សមុទ្រធំនៅខាងលិច។[5]ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នានឹងដេញពួកគេចេញ។
ព្រះអង្គនឹងបង្ខំឲ្យគេចេញពីទឹកដីនោះសម្រាប់អ្នករាល់គ្នា។ ព្រះអង្គនឹងរឹបអូសយកទឹកដីរបស់ពួកគេ ហើយអ្នកនឹងទទួលទឹកដីនោះជាកម្មសិទ្ធិ
ដូចដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានសន្យាដល់អ្នក។
[6]ចូរមានកម្លាំង ដើម្បីឲ្យអ្នកអាចរក្សា និងធ្វើតាមអ្វីដែលបានសរសេរទុកនៅក្នុងសៀវភៅក្រឹត្យវិន័យរបស់លោកម៉ូសេ កុំឲ្យងាកឆ្វេង ឬងាកស្តាំពីក្រឹត្យវិន័យនេះឡើយ[7]ដូច្នេះ
អ្នកនឹងមិនពាក់ព័ន្ធជាមួយជាតិសាសន៍ទាំងនេះដែលនៅសេសសល់ក្នុងចំណោមអ្នករាល់គ្នា ឬក៏រឭកពីឈ្មោះព្រះរបស់ពួកគេ មិនត្រូវស្បថក្នុងនាមព្រះទាំងនោះ
មិនត្រូវថ្វាយបង្គំ ឬក៏គោរពពួកគេឡើយ។[8]ផ្ទុយទៅវិញ អ្នកត្រូវតែស្មោះត្រង់ជាមួយព្រះអម្ចាស់ជាព្រះរបស់អ្នកដូចដែលអ្នកបានធ្វើនៅថ្ងៃនេះស្រាប់។
[9]ព្រះអម្ចាស់បានបណ្តេញជាតិសាសន៍ដ៏ធំ និងខ្លាំងពូកែពីមុខអ្នករាល់គ្នា។ សម្រាប់អ្នករាល់គ្នា គ្មាននរណាអ្នកអាចឈរនៅមុខអ្នករាល់គ្នាបានទេរហូតមកដល់ថ្ងៃនេះ។
[10]បុរសតែម្នាក់ក្នុងចំណោមអ្នករាល់គ្នា នឹងធ្វើឲ្យមនុស្សរាប់ពាន់អ្នករត់ខ្ចាត់ខ្ចាយ ដោយសារព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាជាអ្នកប្រយុទ្ធសម្រាប់អ្នករាល់គ្នា
ដូចដែលព្រះអង្គបានសន្យា។[11]ចូរយកចិត្តទុកដាក់ ដូច្នេះ អ្នកនឹងស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា។
[12]ប៉ុន្តែ បើអ្នកត្រឡប់ក្រោយ និងជំពាក់ចិត្តនឹងអ្នកដែលនៅសេសសល់នៃជាតិសាសន៍នៅក្នុងចំណោមអ្នករាល់គ្នានេះឬក៏អ្នករៀបការជាមួយពួកគេ
ឬក៏អ្នកចូលរួមជាមួយពួកគេ ហើយពួកគេនៅជាមួយអ្នក[13]ដូច្នេះ ចូរចាំឲ្យបានច្បាស់ថា
ព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងមិនបណ្តេញជាតិសាសន៍ទាំងនេះពីក្នុងចំណោមអ្នករាល់គ្នាឡើយ។ ផ្ទុយទៅវិញ ពួកគេនឹងក្លាយជាឧបសគ្គ
និងជាអន្ទាក់សម្រាប់អ្នករាល់គ្នា ជារំពាត់នៅលើខ្នងអ្នក និងជាបន្លានៅក្នុងភ្នែករបស់អ្នករហូតដល់អ្នកវិនាសពីទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នកបានប្រគល់ដល់អ្នក។
[14]ឥឡូវនេះ ខ្ញុំជិតអស់ជីវិតនៅលើផែនដីនេះហើយ ហើយអ្នកត្រូវដឹងឲ្យច្បាស់នៅក្នុងចិត្ត
និងព្រលឹងរបស់អ្នកថាគ្មានពាក្យណាមួយនឹងមិនបានសម្រេចក្នុងចំណោមរឿងល្អដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាបានសន្យាជាមួយអ្នកឡើយ។
របស់ទាំងអស់នេះគឺសម្រាប់អ្នករាល់គ្នា។ គ្មានអ្វីមួយដែលនឹងមិនបានសម្រេចនោះទេ។[15]ប៉ុន្តែ
គឺដូចគ្រប់ព្រះបន្ទូលដែលព្រះអម្ចាស់ជាព្រះរបស់អ្នកបានសន្យាដល់អ្នកបានសម្រេចដូច្នេះដែរ ដូច្នេះ
ព្រះអម្ចាស់នឹងនាំការអាក្រក់មកលើអ្នករហូតដល់ព្រះអង្គបានបំផ្លាញអ្នកពីទឹកដីដ៏ល្អរបស់ព្រះអង្គ ដែលព្រះអម្ចាស់ជាព្រះរបស់អ្នកបានប្រគល់ដល់អ្នក។
[16]ព្រះអង្គនឹងធ្វើការនេះបើអ្នកផ្តាច់សម្ពន្ធមេត្រីជាមួយព្រះអម្ចាស់ជាព្រះរបស់អ្នក ជាសម្ពន្ធមេត្រីដែលព្រះអង្គបានបង្គាប់ឲ្យអ្នករក្សា។
បើអ្នករាល់គ្នាទៅថ្វាយបង្គំព្រះផ្សេងទៀត និងគោរពព្រះទាំងនោះ នោះព្រះពិរោធរបស់ព្រះអម្ចាស់នឹងបញ្ឆេះប្រឆាំងនឹងអ្នក
ហើយអ្នកនឹងវិនាសយ៉ាងទាន់ហន់ពីទឹកដីដ៏ល្អដែលព្រះអង្គបានប្រទានដល់អ្នក»។

Joshua 23:1

ចាស់ហើយ

បានរស់នៅច្រើនឆ្នាំហើយ

Joshua 23:4

ទន្លេយ័រដាន់

នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។

នៅខាងលិច

នេះចង្អុលបង្ហាញពីទិសដៅនៃព្រះអាទិត្យកំណត់។

Joshua 23:6

កុំឲ្យងាកឆ្វេង ឬងាកស្តាំពីក្រឹត្យវិន័យនេះឡើយ

ការមិនគោរពបទបញ្ជានៃក្រិត្យវិន័យរបស់លោកម៉ូសេ ត្រូវបានគេនិយាយថា
ងាកទៅស្តាំឬទៅខាងឆ្វេងពីផ្លូវមួយ។

អ្នកនឹងមិនពាក់ព័ន្ធ

អាចមានន័យថា ១) មានភាពស្និទ្ធស្នាលជាមួយពួកគេ ឬ ២)
រៀបការជាមួយសាសន៍ដទៃ។

រំឭក

និយាយអំពី

ព្រះរបស់ពួកគេ

នេះសំដៅទៅលើព្រះនៃប្រជាជាតិដែលនៅសល់។

ស្មោះត្រង់ជាមួយព្រះអម្ចាស់

« ចូរកាន់ខ្ជាប់នឹងព្រះអម្ចាស់ » ។ ការនិយាយអំពីការជឿដល់ព្រះអម្ចាស់
ហាក់ដូចជាពួកគេកាន់ខ្ជាប់យ៉ាងខ្លាំងទៅលើទ្រង់។ ការបកប្រែផ្សេងទៀត «
ចូរបន្តជឿដល់ព្រះអម្ចាស់ »

នៅថ្ងៃនេះ

« រហូតដល់ពេលបច្ចុប្បន្ន »

Joshua 23:9

ឈរនៅមុខអ្នករាល់គ្នា

នៅទីនេះ «ឈរ» តំណាងឲ្យការកាន់កាប់ដីនៅក្នុងសមរភូមិមួយ។ ពាក្យថា «អ្នក»
គឺសំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។

តែម្នាក់

«មួយ»

រាប់ពាន់

«១០០០»

Joshua 23:12

ជំពាក់ចិត្តនឹងអ្នកដែលនៅសេសសល់នៃជាតិសាសន៍

ការទទួលយកជំនឿរបស់ប្រជាជាតិទាំងនេះ ត្រូវបានគេនិយាយថា
ប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ចំពោះពួកគេ។ ការបកប្រែផ្សេងទៀត «
ទទួលយកជំនឿរបស់អ្នកដែលនៅរស់រានមានជីវិត ពីប្រជាជាតិទាំងនេះ »

អន្ទាក់សម្រាប់អ្នករាល់គ្នា ជារំពាត់

ពាក្យថា «អន្ទាក់» និង «អន្ទាក់» មានន័យថាជារឿងដូចគ្នា។
ពួកគេនិយាយជាមួយគ្នាអំពីប្រជាជាតិផ្សេងទៀតដូចជាពួកគេជាអន្ទាក់ដ៏សាហាវដែល
នឹងបង្កបញ្ហាដល់អ៊ីស្រាអែល។

ជារំពាត់នៅលើខ្នងអ្នក និងជាបន្លានៅក្នុងភ្នែករបស់អ្នក

ឃ្លាទាំងនេះលើកឡើងពីបញ្ហា ដែលប្រជាជាតិទាំងនេះនឹងធ្វើឲ្យអ៊ីស្រាអែល
ដូចជាពួកគេឈឺចាប់នឹងរំពាត់ និងបន្លា។

Joshua 23:14

ខ្ញុំជិតអស់ជីវិតនៅលើផែនដីនេះហើយ

លោកយ៉ូស្វេប្រើពាក្យគួរសម ដើម្បីសំដៅលើមរណភាពរបស់គាត់។
ការបកប្រែផ្សេងទៀត « ខ្ញុំនឹងស្លាប់ »

ត្រូវដឹងឲ្យច្បាស់នៅក្នុងចិត្ត និងព្រលឹងរបស់អ្នក

នៅទីនេះពាក្យ «ចិត្ត» និង «ព្រលឹង» មានអត្ថន័យដូចគ្នា។
ពួកគេសង្កត់ធ្ងន់ទៅលើចំណេះដឹងផ្ទាល់ខ្លួន។

គ្មានអ្វីមួយដែលនឹងមិនបានសម្រេចនោះទេ។

ពាក្យទាំងនេះផ្តោតទៅលើ ការសន្យារបស់ព្រះអម្ចាស់បានកើតឡើងទាំងអស់។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «
គ្រប់ពាក្យទាំងអស់បានក្លាយជាការពិត »

Joshua 23:16

ព្រះអង្គនឹងធ្វើការនេះ

នេះសំដៅទៅលើការដាក់ទណ្ឌកម្ម ដែលបានគំរាមកំហែងនៅក្នុងខមុន។

ទៅថ្វាយបង្គំព្រះផ្សេងទៀត និងគោរពព្រះទាំងនោះ

ឃ្លាទាំងពីរនេះមានអត្ថន័យរួមដូចគ្នា។ ការពិពណ៌នាទី២ អំពីរបៀបដែលប្រជាជន
«ថ្វាយបង្គំព្រះដទៃទៀត» ។

នោះព្រះពិរោធរបស់ព្រះអម្ចាស់នឹងបញ្ឆេះប្រឆាំងនឹងអ្នក

«ដុតបំភ្លឺ»

គឺជាពាក្យប្រៀបធៀបមួយសម្រាប់ការចាប់ផ្តើមនៃសេចក្តីក្រោធរបស់ព្រះអម្ចាស់
ដូចជាភ្លើងត្រូវបាន «បង្កាត់ភ្លើង» ឬចាប់ផ្តើមជាមួយ "ការដុតបំភ្លឺ"
ឬងាយស្រួលដើម្បីចាប់ផ្តើមដុតដូចជាស្មៅស្ងួត ឬមែកតូចៗ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ចាប់ផ្តើមខឹងនឹងអ្នក»

---

generated on Wed Sep 10 16:16:32 2025

24 [1]បន្ទាប់មក លោកយ៉ូស្វេបានប្រមូលកុលសម្ព័ន្ធទាំងអស់របស់អ៊ីស្រាអែលទៅស៊ីគែម និងបានហៅពួកចាស់ទុំ ពួកអ្នកដឹកនាំ ពួកចៅក្រម
និងពួកនាយកក្រុមរបស់ពួកគេមក ហើយពួកគេបានឈរនៅចំពោះព្រះជាម្ចាស់។[2]លោកយ៉ូស្វេបាននិយាយទៅប្រជាជនទាំងអស់ថា៖
«នេះជាអ្វីដែលព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលមានបន្ទូលថា៖ «អស់រយៈពេលយ៉ាងយូរកន្លងមកបុព្វបុរសរបស់អ្នកបានរស់នៅក្រោយទន្លេអឺប្រាតគឺថេរ៉ា ជាឪពុក
របស់អប្រាហាំ និងណាហ៊ារពួកគេគោរពបម្រើព្រះដទៃ។
[3]ប៉ុន្តែ យើងបាននាំឪពុករបស់អ្នករាល់គ្នាពីខាងនាយទន្លេអឺប្រាតមក និងនាំគាត់មកកាន់ទឹកដីកាណាន
ហើយបានប្រទានកូនចៅជាច្រើនដល់គាត់តាមរយៈកូនរបស់គាត់គឺអ៊ីសាក។[4]បន្ទាប់មក យើងប្រទានយ៉ាកុប និងអេសាវដល់អ៊ីសាក។ យើងបានប្រគល់តំបន់ភ្នំ
សៀរឲ្យអេសាវគ្រប់គ្រង ប៉ុន្តែ យ៉ាកុប និងកូនៗរបស់គាត់បានទៅអេស៊ីប។
[5]យើងបានបញ្ជូនម៉ូសេ និងអើរ៉ុនហើយយើងបានប្រហារអ្នកស្រុកអេស៊ីប ដោយសារគ្រោះកាច។ ក្រោយមកទៀតយើងបាននាំអ្នករាល់គ្នាចេញមក។
[6]យើងបាននាំបុព្វបុរសរបស់អ្នករាល់គ្នាចេញពីអេស៊ីប ហើយអ្នកមកដល់សមុទ្រ។ ពួកជនជាតិអេស៊ីបបានដេញតាមពួកគេដោយមានទាំងរទេះចម្បាំង
និងទ័ពសេះវែងដូចសមុទ្រត្រែង។
[7]នៅពេលដែលបុព្វបុរសរបស់អ្នករាល់គ្នាបានស្រែករកព្រះអម្ចាស់ ព្រះអង្គបានដាក់ភាពងងឹតនៅចន្លោះអ្នក និងជនជាតិអេស៊ីប។
ព្រះអង្គបាននាំទឹកសមុទ្រមកគ្របលើពួកគេ។ អ្នកបានឃើញអ្វីដែលយើងបានធ្វើនៅស្រុកអេស៊ីបហើយ។ បន្ទាប់មក
អ្នកបានរស់នៅក្នុងវាលរហោស្ថានអស់រយៈពេលយ៉ាងយូរ។
[8]យើងបាននាំអ្នកទៅកាន់ទឹកដីអាម៉ូរី ដែលរស់នៅត្រើយម្ខាងនៃទន្លេយ័រដាន់។ ពួកគេបានប្រយុទ្ធជាមួយអ្នករាល់គ្នា
ហើយយើងបានប្រគល់ពួកគេទៅក្នុងកន្តាប់ដៃអ្នករាល់គ្នា។ អ្នកបានកាន់កាប់ទឹកដីរបស់ពួកគេ ហើយយើងបានបំផ្លាញពួកគេនៅមុខអ្នករាល់គ្នា។
[9]បាឡាក់ជាកូនរបស់ស៊ីបព័រ ជាស្តេចស្រុកម៉ូអាប់ បានលើកទ័ពមកវាយជនជាតិអ៊ីស្រាអែល។ លោកបានឲ្យគេទៅហៅបាឡាម ជាកូនរបស់បេអ៊រ មកដាក់បណ្តាសាអ្នក
រាល់គ្នា។[10]ប៉ុន្តែ យើងមិនព្រមស្តាប់បាឡាមទេ ផ្ទុយទៅវិញគាត់បែរជាឲ្យពរអ្នករាល់គ្នាទៅវិញ។ ដូច្នេះ យើងបានរំដោះអ្នករាល់គ្នាចេញពីកណ្តាប់ដៃស្តេច។
[11]អ្នករាល់គ្នាបានឆ្លងទន្លេយ័រដាន់ ហើយមកដល់ក្រុងយេរីខូ។ អ្នកដឹកនាំក្រុងយេរីខូបានវាយប្រឆាំងនឹងអ្នករាល់គ្នា ដោយរួមជាមួយជនជាតិអាម៉ូរី ជនជាតិពេរិស៊ីត
ជនជាតិកាណាន ជនជាតិហេត ជនជាតិគើកាស៊ី ជនជាតិហេវី និងជនជាតិយេប៊ូស។ យើងបានឲ្យអ្នកមានជ័យជម្នះលើពួកគេ
ហើយឲ្យពួកគេស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នករាល់គ្នា។[12]យើងបានបញ្ជូនសត្វឪម៉ាល់ទៅមុនអ្នករាល់គ្នា ដើម្បីដេញពួកគេ
និងស្តេចទាំងពីររបស់សាសន៍អាម៉ូរីចេញពីមុខអ្នករាល់គ្នា។ វាមិនបានកើតឡើងដោយសារដាវ ឬដោយសារធ្នូរបស់អ្នករាល់គ្នាឡើយ។
[13]យើងបានប្រគល់ទឹកដីដែលអ្នកមិនបានកាប់គាស់ និងទីក្រុងដែលអ្នករាល់គ្នាមិនបានសង់ដល់អ្នករាល់គ្នា ហើយឥឡូវនេះអ្នករស់នៅក្នុងក្រុងទាំងនោះ។ អ្នករាល់គ្នា
បរិភោគផ្លែទំពាំងបាយជូរ និងផ្លែអូលីវ ពីចម្ការដែលអ្នករាល់គ្នាមិនបានដាំ»។
[14]ឥឡូវនេះ ចូរកោតខ្លាចព្រះអម្ចាស់ និងថ្វាយបង្គំព្រះអង្គដោយស្មោះត្រង់ និងដោយជំនឿ
ចូរបោះបង់ចោលព្រះដែលបុព្វបុរសរបស់អ្នករាល់គ្នាបានថ្វាយបង្គំនៅនាយទន្លេអឺប្រាត និងនៅអេស៊ីបទៅ និងថ្វាយបង្គំព្រះអម្ចាស់វិញ។
[15]បើអ្នកគិតថាការថ្វាយបង្គំព្រះអម្ចាស់ខុស នោះចូរជ្រើសរើសព្រះដែលអ្នករាល់គ្នាចង់បម្រើនៅថ្ងៃនេះ
ទោះបីពីព្រះរបស់បុព្វបុរសរបស់អ្នករាល់គ្នាដែលបានថ្វាយបង្គំនៅនាយទន្លេអឺប្រាត ឬព្រះពីសាសន៍អាម៉ូរីនៅក្នុងទឹកដីដែលអ្នករស់នៅ។ ប៉ុន្តែ សម្រាប់ខ្ញុំ
និងគ្រួសាររបស់ខ្ញុំ យើងនឹងថ្វាយបង្គំព្រះអម្ចាស់»។
[16]ប្រជាជនទាំងអស់បានឆ្លើយថា៖ «យើងនឹងមិនបោះបង់ចោលព្រះអម្ចាស់ទៅបម្រើព្រះណាផ្សេងឡើយ[17]ព្រោះព្រះអម្ចាស់ជាព្រះរបស់យើង ដែលបាននាំយើង
និងបុព្វបុរសរបស់យើងចេញពីទឹកដីអេស៊ីប ចេញពីផ្ទះនៃទាសករ ហើយព្រះអង្គបានធ្វើការយ៉ាងអស្ចារ្យនៅចំពោះយើងរាល់គ្នា ហើយព្រះអង្គបានការពារយើងខ្ញុំតាម
ផ្លូវដែលយើងបានធ្វើដំណើរឆ្លងកាត់ទឹកដីរបស់ជាតិសាសន៍នានា។[18]បន្ទាប់មក ព្រះអម្ចាស់បានបណ្តេញមនុស្សទាំងអស់ចេញពីមុខយើង រួមទាំងសាសន៍អាម៉ូរី
ដែលរស់នៅក្នុងទឹកដីនោះ។ ដូច្នេះ យើងក៏ថ្វាយបង្គំព្រះអម្ចាស់ ព្រោះព្រះអង្គជាព្រះរបស់យើង»។
[19]ប៉ុន្តែ លោកយ៉ូស្វេបាននិយាយទៅកាន់ប្រជាជនថា៖ «អ្នករាល់គ្នាមិនអាចបម្រើព្រះអម្ចាស់បានទេ ព្រោះព្រះអង្គជាព្រះដ៏បរិសុទ្ធ ព្រះអង្គជាព្រះដែលប្រចណ្ឌ
ព្រះអង្គមិនអាចអត់ទោសចំពោះការបះបោរ និងអំពើបាបរបស់អ្នករាល់គ្នាបានទេ។[20]បើអ្នករាល់គ្នាបោះបង់ចោលព្រះអម្ចាស់ និងទៅបម្រើព្រះបរទេស
នោះព្រះអង្គនឹងងាកមកបំផ្លាញអ្នករាល់គ្នាវិញ។ ព្រះអង្គនឹងបំផ្លាញអ្នករាល់គ្នា ទោះបីព្រះអង្គធ្លាប់ធ្វើល្អជាមួយអ្នករាល់គ្នាក៏ដោយ»។
[21]ប៉ុន្តែ ប្រជាជនឆ្លើយទៅលោកយ៉ូស្វេថា៖ ទេ យើងនឹងថ្វាយបង្គំព្រះអម្ចាស់»។[22]បន្ទាប់មក លោកយ៉ូស្វេនិយាយទៅកាន់ប្រជាជនថា៖
«អ្នករាល់គ្នាជាបន្ទាល់សម្រាប់ខ្លួនអ្នករាល់គ្នាស្រាប់ហើយ គឺអ្នកបានជ្រើសរើសព្រះអម្ចាស់ដើម្បីថ្វាយបង្គំព្រះអង្គ»។ ពួកគេនិយាយថា៖ «យើងជាបន្ទាល់ហើយ»។
[23]ឥឡូវនេះ ចូរបោះចោលព្រះដទៃដែលនៅជាប់ជាមួយអ្នករាល់គ្នា ហើយចូរបែរចិត្តរបស់អ្នករាល់គ្នាមកព្រះអម្ចាស់ ជាព្រះរបស់ជនជាតិអ៊ីស្រាអែល»។
[24]ប្រជាជននិយាយទៅលោកយ៉ូស្វេថា៖ «យើងនឹងថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់យើង។ យើងនឹងស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ»។[25]លោកយ៉ូស្វេបានចងសម្ពន្ធមេត្រី
ជាមួយប្រជាជននៅថ្ងៃនោះ។ លោកបានដាក់ច្បាប់ចេញ និងវិន័យនៅត្រង់ស៊ីគែម។
[26]លោកយ៉ូស្វេបានសរសេរព្រះបន្ទូលទាំងអស់នេះនៅក្នុងសៀវភៅនៃច្បាប់របស់ព្រះអម្ចាស់។ លោកបានយកថ្មមួយយ៉ាងធំ ហើយដាក់បញ្ឈរនៅទីនោះក្រោមដើមជ្រៃ
ដែលស្ថិតក្បែរទីសក្ការៈរបស់ព្រះអម្ចាស់។
[27]លោកយ៉ូស្វេបាននិយាយទៅកាន់ប្រជាជនថា៖ «មើល! ថ្មនេះជាទីបន្ទាល់ប្រឆាំងនឹងយើងរាល់គ្នា។ ថ្មនេះបានឮគ្រប់ទាំងព្រះបន្ទូលដែលព្រះអម្ចាស់
ដែលបានមានបន្ទូលមកកាន់យើងរាល់គ្នា។ ដូច្នេះ វានឹងជាបន្ទាល់ប្រឆាំងនឹងអ្នករាល់គ្នា ដើម្បីកុំឲ្យអ្នករាល់គ្នាបដិសេធព្រះរបស់អ្នករាល់គ្នា»។[28]ដូច្នេះ
លោកយ៉ូស្វេបានឲ្យពួកគេចេញទៅ គឺទៅតាមទឹកដីមរតករបស់ពួកគេវិញ។
[29]ក្រោយពីនោះមក លោកយ៉ូស្វេ កូនរបស់លោកនូន ជាអ្នកបម្រើរបស់ព្រះអម្ចាស់បានស្លាប់ទៅ ដែលមានអាយុមួយរយដប់ឆ្នាំ។
[30]ពួកគេបានកប់លោកនៅព្រំប្រទល់ទឹកដីជាមរតករបស់លោក នៅធីម៉ាត សេរ៉ា ក្នុងតំបន់ភ្នំអេប្រាអ៊ីម ខាងជើងភ្នំកាអាស។
[31]ជនជាតិអ៊ីស្រាអែលបានថ្វាយបង្គំព្រះអម្ចាស់គ្រប់ពេលក្នុងថ្ងៃអាយុរបស់លោកយ៉ូស្វេ និងនៅក្នុងអំឡុងពេលពួកចាស់ទុំនៅរស់នៅឡើយដែរ
អ្នកដែលមានអាយុវែងជាងលោកយ៉ូស្វេ គឺអ្នកដែលមានបទពិសោធន៍ជាមួយអ្វីៗដែលព្រះអម្ចាស់បានធ្វើសម្រាប់អ៊ីស្រាអែល។
[32]ឆ្អឹងរបស់លោកយ៉ូសែបដែលប្រជាជនអ៊ីស្រាអែលបានយកពីស្រុកអេស៊ីបមក
ពួកគេបានកប់នៅស៊ីគែមក្នុងដីមួយចំណែកដែលលោកយ៉ាកុបបានទិញពីកូនរបស់លោកហាម៉ោរជាឪពុករបស់ស៊ីគែម។ លោកទិញវាក្នុងតំលៃមួយរយដួងជាប្រាក់
ហើយទីនោះក្លាយជាទឹកដីមរតករបស់កូនចៅលោកយ៉ូសែប។[33]លោកអេឡាសារ ជាកូនលោកអើរ៉ុន ក៏បានទទួលមរណភាពដែរ។ ពួកគេបានបញ្ចុះសពលោកនៅលើភ្នំ
ជាក្រុងរបស់លោកភីនេហាសជាកូនរបស់លោក ដែលលោកបានឲ្យដល់កូនប្រុសលោក។ ទីនោះគឺតំបន់ភ្នំនៃកុលសម្ព័ន្ធអេប្រាអ៊ីម។

Joshua 24:1

លោកយ៉ូស្វេបានប្រមូលកុលសម្ព័ន្ធទាំងអស់របស់អ៊ីស្រាអែល
ការកោះហៅរបស់លោកយ៉ូស្វេ ទៅកាន់កុលសម្ព័ន្ធគឺ
ដូចជាគាត់បានប្រមូលពួកគេដាក់ក្នុងកន្ត្រក។ ការបកប្រែផ្សេងទៀត
«លោកយ៉ូស្វេបានស្នើដល់កុលសម្ព័ន្ធអ៊ីស្រាអែលទាំងអស់ ដើម្បីមកជួបគាត់»

ពួកគេបានឈរនៅចំពោះព្រះជាម្ចាស់
« បានមកឈរនៅខាងមុខ» ឬ « បានមកពីមុខ»
អស់រយៈពេលយ៉ាង
« ជាច្រើនឆ្នាំកន្លងមក »
នេះជាអ្វី

generated on Wed Sep 10 16:16:32 2025

លោកយ៉ូស្វេចាប់ផ្តើមដកស្រង់អ្វីដែលព្រះអម្ចាស់បានមានបន្ទូលពីមុន។
ការដកស្រង់បន្តរហូតដល់ចុងបញ្ចប់នៃខទី ១៣ ។
ថេរ៉ា ... ណាហរ
ទាំងនេះគឺឈ្មោះនៃបុរស។
Joshua 24:3
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តដកស្រង់អ្វី
ដែលព្រះអម្ចាស់មានបន្ទូលអំពីកិច្ចព្រមព្រៀងជាមួយប្រជាជនរបស់ទ្រង់។
ភ្នំសៀរ
ឈ្មោះនៃទីកន្លែង ឬទីតាំង
បានទៅ
ស្រុកអេស៊ីបមានកម្ពស់ទាបជាង ស្រុកកាណាន។ ការបកប្រែផ្សេងទៀត «
បានធ្វើដំណើរ »
Joshua 24:5
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តដកស្រង់អ្វី ដែលព្រះអម្ចាស់មានបន្ទូលអំពីកិច្ចព្រមព្រៀង
ជាមួយប្រជាជនរបស់ទ្រង់។
បាននាំអ្នករាល់គ្នាចេញមក ...បាននាំបុព្វបុរសរបស់អ្នករាល់គ្នាចេញ
ព្រះអម្ចាស់តែងតែឆ្លាស់គ្នារវាងឃ្លាទាំងពីរនេះ
ដែលសំដៅទៅលើជនជាតិអ៊ីស្រាអែលទាំងអស់ ពីអតីតកាល និងបច្ចុប្បន្នកាល។
ពាក្យថាអ្នកគឺជាពហុវចន:
សុន្ទរកថាពីដើមដល់ចប់ហើយសំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។
Joshua 24:7
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តដកស្រង់អ្វី ដែលព្រះអម្ចាស់មានបន្ទូលអំពីកិច្ចព្រមព្រៀង
ជាមួយប្រជាជនរបស់ទ្រង់។
បុព្វបុរសរបស់អ្នករាល់គ្នា ... អ្នក
ព្រះអម្ចាស់តែងតែឆ្លាស់គ្នារវាងឃ្លាទាំងពីរនេះ
ដែលសំដៅទៅលើជនជាតិអ៊ីស្រាអែលទាំងអស់ ពីអតីតកាល និងបច្ចុប្បន្នកាល។
ពាក្យថាអ្នកគឺជាពហុវចន: សុន្ទរកថាពីដើមដល់ចប់ហើយសំដៅទៅលើ
ប្រជាជាតិអ៊ីស្រាអែលទាំងមូល។
ទឹកសមុទ្រ
នេះសំដៅទៅលើសមុទ្រេដ ។
ក្នុងវាលរហោស្ថាន
តំបន់គ្មានមនុស្សរស់នៅ វាលខ្សាច់។
Joshua 24:8
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តដកស្រង់អ្វី
ដែលព្រះអម្ចាស់មានបន្ទូលអំពីកិច្ចព្រមព្រៀងជាមួយប្រជាជនរបស់ទ្រង់។
អ្នក
ពាក្យថា «អ្នក» គឺជាពហុវចន: នៅក្នុងសុន្ទរកថាពីដើមដល់ចប់នេះ
សំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។
ទន្លេយ័រដាន់
នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។
បានប្រគល់ពួកគេទៅក្នុងកន្លាប់ដៃអ្នករាល់គ្នា
នៅទីនេះ « ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេង «
អាចឲ្យអ្នកយកឈ្នះលើពួកគេ »
Joshua 24:9
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តដកស្រង់អ្វី ដែលព្រះអម្ចាស់មានបន្ទូល
អំពីកិច្ចព្រមព្រៀងជាមួយប្រជាជនរបស់ទ្រង់។
បាឡាម ...ស៊ីបព័រ
ឈ្មោះរបស់បុរស
អ្នក
ពាក្យថា «អ្នក» គឺជាពហុវចន: នៅក្នុងសុន្ទរកថាពីដើមដល់ចប់
ហើយសំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។
បានរំដោះអ្នករាល់គ្នាចេញពីកណ្តាប់ដៃស្តេច
នៅទីនេះ « ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត «
អាចឲ្យអ្នកយកឈ្នះលើគាត់ »
Joshua 24:11
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តដកស្រង់អ្វី
ដែលព្រះអម្ចាស់មានបន្ទូលអំពីកិច្ចព្រមព្រៀងជាមួយប្រជាជនរបស់ទ្រង់។
អ្នក
ពាក្យថា «អ្នក» គឺជាពហុវចន: នៅក្នុងសុន្ទរកថាពីដើមដល់ចប់
ហើយសំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។
ទន្លេយ័រដាន់
នេះគឺជាឈ្មោះខ្លីសម្រាប់ទន្លេយ័រដាន់។
សត្វឪម៉ាល់
សត្វល្អិតហើរលឿនមានត្រនិច ដែលរស់នៅជាក្រុម។ នៅទីនេះ «សត្វឪម៉ាល់ »
ជាច្រើនត្រូវបានគេនិយាយថាមានតែមួយ។
Joshua 24:13
ព័ត៌មានទូទៅ
លោកយ៉ូស្វេបន្តដកស្រង់អ្វី
ដែលព្រះអម្ចាស់មានបន្ទូលអំពីកិច្ចព្រមព្រៀងជាមួយប្រជាជនរបស់ទ្រង់។
Joshua 24:14
បើអ្នកគិតថាការថ្វាយបង្គំព្រះអម្ចាស់ខុស
នៅទីនេះ « ភ្នែករបស់អ្នក » គឺការប្រៀបធៀប។
គឺដំបូងវាសំដៅទៅលើការមើលឃើញរបស់ពួកគេ
ប៉ុន្តែការមើលឃើញត្រូវបានជាប់ទាក់ជាមួយ នឹងបំណងប្រាថ្នា។
ការបកប្រែផ្សេងទៀត «ប្រសិនបើអ្នកមិនចង់បាន»
គ្រួសាររបស់ខ្ញុំ
នេះតំណាងឲ្យគ្រួសាររបស់គាត់ ដែលរស់នៅក្នុងផ្ទះរបស់គាត់។
ការបកប្រែផ្សេងទៀត «គ្រួសាររបស់ខ្ញុំ»
Joshua 24:16
យើង និងបុព្វបុរសរបស់យើង ... យើង
ប្រជាជននិយាយ ដូចជាពួកគេមានវត្តមានជាមួយបុព្វបុរសរបស់ពួកគេ
ហើយផ្លាស់ប្តូរពាក្យថា «របស់យើង» និង «យើង» ជាមួយ
«បុព្វបុរសរបស់យើង»។
ផ្ទះនៃទាសករ
នៅទីនេះ «ផ្ទះ» គឺជាពាក្យដែលសំដៅទៅលើទីតាំងនៃទាសភាពរបស់ពួកគេ។
ការបកប្រែផ្សេងទៀត «កន្លែងដែលយើងធ្វើជាទាសករ»
បានធ្វើដំណើរឆ្លងកាត់ទឹកដីរបស់ជាតិសាសន៍នានា
« ប្រជាជាតិដែលយើងបានឆ្លងកាត់ »
Joshua 24:19
ប្រជាជន
នេះសំដៅទៅលើជនជាតិអ៊ីស្រាអែល។
ព្រះអង្គជាព្រះដែលប្រចណ្ឌ
ព្រះជាម្ចាស់ចង់ឲ្យប្រារ្ថរបស់ទ្រង់ថ្វាយបង្គំតែព្រះអង្គប៉ុណ្ណោះ។
ព្រះអង្គនឹងបំផ្លាញអ្នករាល់គ្នា
ព្រះពិរោធរបស់ព្រះអម្ចាស់ត្រូវបាននិយាយដូចជាព្រះអង្គគឺជាភ្លើង
ដែលនឹងបំផ្លាញពួកគេ។ ការបកប្រែផ្សេងទៀត « ព្រះអង្គនឹងបំផ្លាញអ្នកដូចជាភ្លើង
»
Joshua 24:21
ប្រជាជន
នេះសំដៅទៅលើជនជាតិអ៊ីស្រាអែល។
ហើយចូរបែរចិត្តរបស់អ្នករាល់គ្នាមកព្រះអម្ចាស់
ការសម្រេចចិត្តដើម្បីស្តាប់បង្គាប់ព្រះអម្ចាស់តែមួយប៉ុណ្ណោះ
គឺនិយាយអំពីការបង្វែរចិត្តពួកគេទៅរកព្រះអង្គ។ នៅទីនេះ «ចិត្ត»
តំណាងឲ្យមនុស្សទាំងមូល។ ក្នុងករណីនេះ «ចិត្ត»
ជាពហុវចន:ពីព្រោះវាសំដៅទៅលើជនជាតិអ៊ីស្រាអែលទាំងអស់ជាក្រុមតែមួយ។
ទោះយ៉ាងណាក៏ដោយ វាប្រហែលល្អបំផុតដើម្បីបកប្រែវាជាពហុវចន:ចាប់តាំងពី
«របស់អ្នក» គឺពហុវចន:។ ការបកប្រែផ្សេងទៀត «បែរទៅរកព្រះអម្ចាស់» ឬ
«សម្រេចចិត្តដើម្បីស្តាប់បង្គាប់ព្រះអម្ចាស់»
Joshua 24:24
ប្រជាជន
នេះសំដៅទៅលើជនជាតិអ៊ីស្រាអែល។
យើងនឹងស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ

generated on Wed Sep 10 16:16:32 2025

នៅទីនេះ « ស្តាប់» មានន័យថា ស្តាប់បង្គាប់។ ការបកប្រែផ្សេងទៀត
«យើងនឹងស្តាប់បង្គាប់អ្វីគ្រប់យ៉ាង ដែលព្រះអង្គបានប្រាប់យើងឲ្យធ្វើ »
លោកបានដាក់ច្បាប់ចេញ និងវិន័យ
ការបង្កើតច្បាប់ត្រូវបានគេនិយាយថា
ដូចជាលោកយ៉ូស្វេបានកំណត់វាដូចជារូបវិមានដែរ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គបានបង្កើតវិន័យ និងច្បាប់» ឬ «ព្រះអង្គបានផ្តល់ឲ្យពួកគេនូវច្បាប់
និងវិន័យដើម្បីគោរពតាម»
សៀវភៅនៃច្បាប់របស់ព្រះអម្ចាស់
នេះគឺជាការបង្ហាញដើម្បីបន្ត សំណេររបស់លោកម៉ូសេ។
ហើយដាក់បញ្ឈរនៅទីនោះ
« ដាក់វានៅទីនោះ »
Joshua 24:27
ប្រជាជន
នេះសំដៅទៅលើជនជាតិអ៊ីស្រាអែល។
ថ្មនេះជាទីបន្ទាល់ប្រឆាំងនឹងយើងរាល់គ្នា ... ថ្មនេះបានឮគ្រប់ទាំងព្រះបន្ទូលដែលព្រះអម្ចាស់
ដុំថ្មដែលលោកយ៉ូស្វេបានដំឡើងត្រូវបានគេនិយាយថា ដូចជាមនុស្សម្នាក់
ដែលបានឮអ្វីដែលត្រូវនិយាយ
ហើយនឹងអាចធ្វើបន្ទាល់អំពីអ្វីដែលត្រូវបាននិយាយ។
ដើម្បីកុំឲ្យអ្នករាល់គ្នា
« ប្រសិនបើអ្នកធ្លាប់ »
Joshua 24:29
ដែលមានអាយុមួយរយដប់ឆ្នាំ
« អាយុមួយរយដប់ឆ្នាំ »
ធីម៉ូថេ សេរ៉ា ... ភ្នំកាអាស
ឈ្មោះរបស់ទីកន្លែង
Joshua 24:31
គ្រប់ពេលក្នុងថ្ងៃអាយុរបស់លោកយ៉ូស្វេ
នេះគឺជាឃ្លាដើមដែលសំដៅទៅលើជីវិតទាំងមូលរបស់លោកយ៉ូស្វេ។
អាយុរបស់លោកយ៉ូស្វេ
«បានរស់នៅបានយូរជាងលោកយ៉ូស្វេ»
Joshua 24:32
ឆ្អឹងរបស់លោកយ៉ូសែប ... ពួកគេបានកប់នៅស៊ីគែម
វាអាចមានប្រយោជន៍ក្នុងការផ្លាស់ប្តូរលំដាប់លំដោយការចាប់ផ្តើមនៃប្រយោគនេះ។
ការបកប្រែផ្សេងទៀត «ប្រជាជនអ៊ីស្រាអែលបាននាំយកឆ្អឹងរបស់លោកយ៉ូសែប
ចេញពីស្រុកអេស៊ីបមកបញ្ចុះនៅស៊ីគែម»
មួយរយដួង
« ១០០ ចំណែក »
លោកអេឡាសារ
ឈ្មោះរបស់បុរស
គេបៀរ
ឈ្មោះរបស់ទីកន្លែង

ចៅហ្វាយ

1 [1]បន្ទាប់ពី លោកយ៉ូស្វេទទួលមរណភាព ជនជាតិអ៊ីស្រាអែលបានទូលសួរព្រះអម្ចាស់ថា៖ «ក្នុងចំណោមយើង តើកុលសម្ព័ន្ធណាមួយ
ដែលត្រូវទៅច្បាំងនឹងជនជាតិកាណានមុនគេ?»[2]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «កុលសម្ព័ន្ធយូដាត្រូវទៅមុន។
មើលយើងបានប្រគល់ឲ្យពួកគេគ្រប់គ្រងលើទឹកដីនេះ»។[3]កុលសម្ព័ន្ធយូដាបាននិយាយទៅកាន់កុលសម្ព័ន្ធស៊ីម្មាន ជាបងប្អូនរបស់ពួកគេថា «ចូរឡើងមកជាមួយយើង
ឆ្ពោះទៅកាន់ទឹកដីជាចំណែកមរតករបស់យើងខ្ញុំ យើងច្បាំងនឹងជនជាតិកាណានជាមួយគ្នា។
យើងខ្ញុំនឹងចេញទៅច្បាំងយកចំណែកទឹកដីជាមរតករបស់បងប្អូនជាមួយបងប្អូនដែរ។ ដូច្នេះ កុលសម្ព័ន្ធស៊ីម្មានក៏ឡើងទៅជាមួយពួកគេ។
[4]ជនជាតិយូដាបានវាយប្រហារ ហើយព្រះអម្ចាស់បានប្រទានឲ្យពួកគេមានជ័យជម្នះលើជនជាតិកាណាន និងជនជាតិពេរីស៊ិត។ ពួកគេបានសម្លាប់ខ្មាំងសត្រូវអស់
មួយម៉ឺននាក់នៅបេសេក។[5]ហើយនៅបេសេក ពួកគេបានរកឃើញស្តេចអាដូនី បេសេក ពួកគេបានច្បាំងតតាំងនឹងទ្រង់ ហើយពួកគេច្បាំងឈ្នះជនជាតិកាណាន
និងជនជាតិពេរីស៊ិត។
[6]ប៉ុន្តែ ស្តេចអាដូនី - បេសេកបានរត់ភៀសខ្លួន ហើយពួកគេបានដេញតាមទ្រង់និងចាប់ទ្រង់បាន ហើយពួកគេបានកាត់មេដៃ និងមេជើងរបស់ទ្រង់។[7]ស្តេចអាដូនី -
បេសេកបានមានបន្ទូលថា៖ «ខ្ញុំបានកាត់មេដៃនិងមេជើងស្តេចចិតសិបអង្គ ហើយពួកគេបានរើសសំណល់ពីក្រោមតុរបស់ខ្ញុំធ្វើជាអាហារ។ ឥឡូវនេះ
ព្រះអម្ចាស់បានសងមកខ្ញុំវិញតាមអំពើដែលខ្ញុំបានប្រព្រឹត្ត»។ ពួកគេបាននាំស្តេចទៅក្រុង យេរូសាឡឹម ហើយស្តេចបានចូលទិវង្គតនៅទីនោះ។
[8]កុលសម្ព័ន្ធយូដាបានច្បាំងនឹងក្រុងយេរូសាឡឹមហើយបានវាយយកបានវា។ ពួកគេបានបំផ្លាញក្រុងនេះ ដោយមុខដាវនិងដុតកម្ទេចដោយភ្លើង។
[9]បន្ទាប់មកកុលសម្ព័ន្ធយូដា បានចុះទៅប្រយុទ្ធនឹងជនជាតិកាណានដែលរស់នៅតាមតំបន់ភ្នំ តំបន់ណេកិប និងតំបន់វាលទំនាបទៀតផង។
[10]ពួកគេបានវាយប្រហារជនជាតិកាណានដែលរស់នៅក្នុងទីក្រុងហេប្រុន (ពីដើមក្រុងហេប្រុនមានឈ្មោះថា គារយ៉ាត អើបា) ហើយពួកគេបានប្រហារអំបូរ សេសាយ
អំបូរអហីម៉ាន និងអំបូរតាល់ម៉ាយផងដែរ។
[11]ចាប់ពីនោះ ពួកគេវាយប្រហារប្រជាជនដែលរស់នៅក្នុងក្រុង ដេបៀរ (ពីដើមក្រុងដេបៀរមានឈ្មោះថា គារយ៉ាត សេភើរ)។[12]កាលនោះ លោកកាលែប
បានមានប្រសាសន៍ថា៖ «ប្រសិនបើ នរណាម្នាក់ វាយយកបានក្រុងគារយ៉ាត ក្រុងសេភើរ ខ្ញុំនឹងលើកកូនស្រីរបស់ខ្ញុំនាង អាក់សា ឲ្យធ្វើជាប្រពន្ធរបស់គេ»។[13]ពេលនោះ
លោកអូថ្នាល ជាកូនប្រុសរបស់លោកកេណាស ដែលជាប្អូនប្រុសរបស់លោកកាលែប វាយយកបានក្រុងដេបៀរ ដូច្នេះ លោកកាលែបបានលើកនាង អាក់សា
ជាកូនស្រីរបស់លោក ឲ្យធ្វើជាភរិយារបស់គាត់។
[14]ពេលដែលនាងអាក់សា បានទៅរស់នៅជាមួយលោកអាថ្នាល នាងបានបបួលលោកឲ្យសុំចំណែកដីស្រែពីឪពុករបស់នាង។ នៅពេលដែលនាងចុះពីលើខ្នងលា
លោកកាលែបបានសួរនាងថា៖ «តើកូនមានការអ្វី?»[15]នាងបានតបវិញថា៖ «សូមលោកពុកមេត្តាឲ្យពរមួយដល់ខ្ញុំ។ ព្រោះ
លោកឪពុកបានប្រគល់ដីនៅតំបន់ណេកិបដល់ខ្ញុំ ដូច្នេះ សូមមេត្តាឲ្យអណ្តូងទឹកមកខ្ញុំផង»។ ដូច្នេះ លោកកាលែប បានឲ្យអណ្តូងទឹកដែលនៅខាងលើ
និងអណ្តូងទឹកនៅខាងក្រោមដល់នាង។
[16]ជនជាតិកែន ជាពូជពង្សរបស់ឪពុកក្មេករបស់លោកម៉ូសេ បានចាកចេញពីក្រុងដើមលម៉ើ ជាមួយកូនចៅយូដា ឆ្ពោះទៅកាន់វាលរហោស្ថាននៃទឹកដីកុលសម្ព័ន្ធយូដា
ដែលនៅក្នុងតំបន់ណេកិប ជិត អ៊ើរ៉ាត ដើម្បីតាំងលំនៅក្នុងចំណោមប្រជាជននៅទីនោះ។[17]បន្ទាប់មកកុលសម្ព័ន្ធយូដា រួមគ្នាជាមួយកុលសម្ព័ន្ធស៊ីម្មាន
ជាបងប្អូនរបស់ពួកគេ ចេញទៅវាយប្រហារជនជាតិកាណានដែលរស់នៅតំបន់ សេផាត ហើយពួកគេបានបំផ្លាញទីក្រុងនោះទាំងស្រុង ថ្វាយដល់ព្រះអម្ចាស់។
រួចបានដាក់ឈ្មោះក្រុងនោះដា ហោម៉ា។
[18]កុលសម្ព័ន្ធយូដា ក៏វាយដណ្តើមបានតំបន់កាសា ទីក្រុងអាសកេឡូន និងអេក្រុនរួមទាំងតំបន់ជុំវិញទីក្រុងទាំងនោះផងដែរ។[19]ព្រះអម្ចាស់បានគង់ជាមួយកុលសម្ព័ន្ធយូដា
ហើយពួកគេបានត្រួតត្រាលើតំបន់ភ្នំ ប៉ុន្តែ កុលសម្ព័ន្ធយូដាមិនអាចបណ្តេញប្រជាជនដែលរស់នៅតាមតំបន់ជ្រលងភ្នំបានទេ ព្រោះពួកគេមានរទេះចម្បាំងដែលធ្វើពីដែក។
[20]ទីក្រុងហេប្រុនត្រូវបានប្រគល់ឲ្យលោកកាលែប ដូចដែលលោកម៉ូសេ បានបង្គាប់ទុក ហើយលោកបានបណ្តេញអំបូរអណាក់ទាំងបី។[21]ប៉ុន្តែកុលសម្ព័ន្ធបេនយ៉ាមីន
មិនបានបណ្តេញជនជាតិយេប៊ូសដែលរស់នៅទីក្រុងយេរូសាឡឹមទេ។ ដូច្នេះ ជនជាតិយេប៊ូសក៏រស់នៅជាមួយកុលសម្ព័ន្ធបេនយ៉ាមីនរហូតដល់សព្វថ្ងៃ។
[22]ចំណែកឯ ពូជពង្សរបស់លោកយូ៉សែប ក៏បានចេញទៅច្បាំងនឹងក្រុងបេតអែលដែរ ហើយព្រះជាម្ចាស់គង់នៅជាមួយពួកគេ។[23]ដំបូង
ពួកគេបានបញ្ជូនមនុស្សទៅស៊ើបមើលទីក្រុងបេតអែល ដែលពីដើមឡើយក្រុងនោះមានឈ្មោះថា លូស។
[24]ពេលដែលអ្នកស៊ើបការណ៍បានឃើញមនុស្សចេញពីទីក្រុងនោះមក ពួកគេនិយាយទៅកាន់បុរសនោះថា៖ «ចូរបង្ហាញយើង តើគេអាចចូលទៅក្នុងទីក្រុងតាមផ្លូវណា
យើងនឹងប្រណីដល់អ្នក»។

generated on Wed Sep 10 16:16:32 2025

[25]បុរសនោះក៏បានបង្ហាញផ្លូវចូលទីក្រុងដល់ពួកគេ ដូច្នេះ ពួកគេបានប្រហារប្រជាជននៅក្រុងនោះដោយមុខដាវ តែទុកឲ្យបុរសនោះ
និងគ្រួសាររបស់គាត់ទាំងមូលចាក់ចេញទៅ។[26]បន្ទាប់មក បុរសនោះក៏ចាកចេញទៅស្រុកហេត ហើយសង់ក្រុងមួយដែលគាត់បានដាក់ឈ្មោះថា លូស
ដែលគេហៅរហូតមកដល់សព្វថ្ងៃ។
[27]រីឯកុលសម្ព័ន្ធម៉ាណាសេ ក៏មិនបានបណ្តេញពួកអ្នកស្រុកដែលរស់នៅក្រុងបេតសៀន ក្រុងតាណាក់ ក្រុងដោរ ក្រុងយីបឡាម ក្រុងមេគីដោរ
ព្រមទាំងតំបន់នានាដែលនៅជុំវិញក្រុងទាំងនោះ ដូច្នេះ ជនជាតិកាណានក៏រស់នៅក្នុងតំបន់ទាំងនោះតទៅទៀត។[28]នៅពេលដែលជនជាតិអ៊ីស្រាអែលមានកម្លាំង
គេបានបង្ខំឲ្យជនជាតិកាណានធ្វើការជាទម្ងន់ ប៉ុន្តែ ពួកគេមិនបានបណ្តេញជនជាតិនេះចេញនោះទេ។
[29]សូម្បីតែ កុលសម្ព័ន្ធអេប្រាអ៊ីម ក៏មិនបានបណ្តេញជនជាតិកាណានដែលរស់នៅក្រុងកេស៊ើរដែរ ដូច្នេះ
ជនជាតិកាណានបន្តរស់នៅក្នុងក្រុងកេស៊ើរក្នុងចំណោមកុលសម្ព័ន្ធអេប្រាអ៊ីមតទៅទៀត។
[30]កុលសម្ព័ន្ធសាប់យ៉ូឡូនក៏មិនបានបណ្តេញប្រជាជនដែលរស់នៅក្រុងគីត្រុន ឬមនុស្សដែលរស់នៅក្នុងក្រុង ណាហាឡូល ចេញពីស្រុកនោះដែរ
ដូច្នេះហើយជនជាតិកាណានបន្តរស់នៅក្នុងចំណោមពួកគេ ប៉ុន្តែ កុលសម្ព័ន្ធសាប់យ៉ូឡូនបានបង្ខំពួកគេឲ្យធ្វើការជាទម្ងន់។
[31]ហើយកុលសម្ព័ន្ធអាស៊ើរ ពួកគេក៏មិនបានបណ្តេញជនជាតិអាក់កូ ស៊ីដូន អាស់ឡាប់ អាក់ស៊ីប ហែលបា អាផែក និងរេហូបចេញដែរ។[32]ដូច្នេះ
កុលសម្ព័ន្ធអាស៊ើរក៏រស់នៅជាមួយជនជាតិទាំងនោះលើទឹកដីកាណាន ព្រោះពួកគេមិនបានបណ្តេញជនជាតិទាំងនោះចេញទេ។
[33]កុលសម្ព័ន្ធណែបថាលី ក៏មិនបានបណ្តេញជនជាតិកាណានដែលរស់នៅក្នុងក្រុងបេតសេម៉ស និងក្រុងបេតអាណាតចេញដែរ ដូច្នេះ
កុលសម្ព័ន្ធណែបថាលីរស់នៅក្នុងចំណោមជនជាតិកាណានដែលរស់នៅក្នុងស្រុកវិញ។ ប៉ុន្តែ ពួកគេបានបង្ខំអ្នកដែលរស់នៅក្នុងក្រុងបេតសេម៉ស
និងក្រុងបេតអាណាតធ្វើការជាទម្ងន់។
[34]ជនជាតិអាម៉ូរីបានរុញច្រាន កុលសម្ព័ន្ធដាន់ ឲ្យរស់នៅតំបន់ភ្នំ ដោយមិនអនុញ្ញាតឲ្យពួកគេចុះមករស់នៅតាមជ្រលងភ្នំឡើយ។[35]ជនជាតិអាម៉ូរីរស់នៅក្រុងហេរេស
អាយ៉ាឡូន និងក្នុងក្រុងសាលប៊ីម ប៉ុន្តែ ក្រោយមកពេលដែលពូជពង្សលោកយូសែបមានកម្លាំងគ្រប់គ្រងលើពួកគេ និងបង្ខំឲ្យពួកគេធ្វើការជាទម្ងន់។
[36]ដែនដីរបស់ជនជាតិអាម៉ាវីគឺលាតសន្ធឹងចាប់ពីច្រកភ្នំអាក្រាប៊ីម គឺចាប់ពីសេឡាឡើងទៅ។

Judges 1:1

ប្រយោគភ្ជាប់

កណ្ឌគម្ពីរចៅហ្វាយបន្តសាច់រឿងពីលោកយ៉ូស្វេ
ហើយក៏ជាការចាប់ផ្តើមសាច់រឿងថ្មីដែរ។

ព្រះអម្ចាស់

នេះគឺជាព្រះនាមរបស់ព្រះជាម្ចាស់ដែលបានបើកសម្តែងដល់ប្រជារាស្ត្ររបស់ព្រះអង្គនៅក្នុងសម្ពន្ធមេត្រីជាមួយ
សូមមើលទំព័របកប្រែពាក្យទាក់ទងនឹងព្រះអម្ចាស់
ថាតើគេបកប្រែយ៉ាងដូចម្តេចជាមួយនឹងពាក្យនេះ។

ដែលត្រូវទៅច្បាំងនឹងជនជាតិកាណានមុនគេ

ពាក្យ «យើង» សំដៅលើប្រជាជនអ៊ីស្រាអែល»។ (សូមមើល: | Exclusive "We")

កុលសម្ព័ន្ធយូដាត្រូវទៅមុន

ពាក្យ «យូដា» នៅទីនេះ សំដៅលើបុរសៗនៃកុលសម្ពន្ធយូដា។
ព្រះអម្ចាស់បានបង្គាប់បុរសៗទាំងនោះឲ្យចេញទៅច្បាំងមុនគេ»។
របៀបផ្សេងទៀតនៃការបកប្រែ: «បុរសនៃកុលសម្ព័ន្ធយូដាត្រូវចេញច្បាំងមុនគេ»។
(សូមមើល: | Metonymy)

មើល៍

«មើល៍» ឬ «ពិតណាស់» ពាក្យនេះ
បន្ថែមមកដើម្បីបញ្ជាក់ពីអ្វីដែលកើតឡើងបន្ទាប់។

ទឹកដីនេះ

ពាក្យនេះសំដៅលើទឹកដីដែលជនជាតិកាណានរស់នៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទឹកដីរបស់ជនជាតិកាណាន»។ (សូមមើល: | Assumed Knowledge and Implicit Information)

បងប្អូនរបស់ពួកគេ

«បងប្អូនជនជាតិអ៊ីស្រាអែល» ឬ «សាច់ញាតិរបស់ពួកគេ»។

ឡើងមកជាមួយយើង

ប្រជាជននៃកុលសម្ព័ន្ធយូដា
និងស៊ីម្មានបានបោះជំរំជាមួយជនជាតិអ៊ីស្រាអែលនៅជ្រលងភ្នំទន្លេយ័រដាន់។
ទឹកដីនេះ ដែលបានប្រគល់ឲ្យកុលសម្ព័ន្ធយូដាគឺនៅលើភ្នំតាមជ្រលងភ្នំ។
ភាសាខ្លះមិនបានប្រើពាក្យបញ្ជាក់ច្បាស់លាស់ទេ ថាតើប្រជាជនរស់នៅលើភ្នំ
ឬនៅក្រោមតាមជ្រលងភ្នំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមមកជាមួយយើង» ឬ «ទៅជាមួយយើង»។

យើងច្បាំងនឹងជនជាតិកាណានជាមួយគ្នា...ដូចបងប្អូនត្រូវបានចេញទៅច្បាំងដែរ។

ឃ្លានេះស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានចាត់តាំងយើង...ដូចព្រះអម្ចាស់បានចាត់តាំងបងប្អូនដែរ»។
(សូមមើល: | Active or Passive)

យើងខ្ញុំនឹងចេញទៅច្បាំងយកចំណែកទឹកដីជាមរតករបស់បងប្អូនជាមួយបងប្អូនដែរ។

«យើងនឹងទៅជាមួយបងប្អូនដែរ» ឬ «យើងនឹងទៅបែបយ៉ាងនោះដែរ»។

Judges 1:4

ជនជាតិយូដាបានវាយប្រហារ

ឃ្លានេះសំដៅលើកុលសម្ព័ន្ធស៊ីម្មានបានរួមជាមួយកុលសម្ព័ន្ធយូដាដើម្បីវាយប្រហារដែរ។

ពួកគេបានសម្លាប់ខ្មាំងសត្រូវអស់ មួយម៉ឺននាក់

«ពួកគេបានសម្លាប់ ១០,០០០នាក់» ឬ «ពួកបានសម្លាប់មនុស្សជាច្រើន»។

ខ្មាំងសត្រូវអស់

ក្នុងសម្ពន្ធមេត្រីជាមួយ

បេសេក

មានទីតាំងនៅក្នុងតំបន់ភ្នំរបស់ទឹកដីកាណាន។

ស្តេចអាដូនី បេសេក

បុរសម្នាក់នេះគឺជាអ្នកដឹកនាំនៃទាហានរបស់ជនជាតិកាណាន
និងជនជាតិពេរីស៊ិត។

ពួកគេបានច្បាំងតតាំងនឹងទ្រង់

ពាក្យ «ទ្រង់» នៅទីនេះ សំដៅលើ ស្តេចអាដូនីបេសេក និងទាហានរបស់ទ្រង់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានតយុទ្ធទាស់នឹងទ្រង់
និងទាហានរបស់ទ្រង់»។

Judges 1:6

ពួកគេបានដេញតាមទ្រង់

«បានប្រដេញតាមទ្រង់»។

ស្តេចចិតសិបអង្គ

«ស្តេច ៧០អង្គ»

ពួកគេបានកាត់មេដៃ និងមេជើងរបស់ទ្រង់។

ឃ្លានេះស្ថិតក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានប្រាប់កងទ័ពរបស់យើងឲ្យកាត់មេដៃនិងមេជើងរបស់ស្តេចទាំងនោះ» ឬ
«យើងបានកាត់មេដៃមេជើងរបស់ពួកគេ»។

ពួកគេបានរើសសំណល់ពីក្រោមតុរបស់ខ្ញុំធ្វើជាអាហារ។

«បរិភោគកម្ទេចអាហារពីក្រោមតុរបស់យើង»។
បានបង្ខំស្តេចទាំងនោះឲ្យសោយកម្ទេចអាហារ សំដៅលើការគ្រប់យ៉ាងស្តេចអាដូនី-
បេសេកធ្វើមកលើស្តេចទាំងនោះ។

Judges 1:8

ក្រុងយេរូសាឡឹមហើយបានវាយយកបានវា

ពាក្យ «ទីក្រុង» នៅទីនេះ តំណាងឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សដែលរស់នៅក្នុងក្រុងយេរូសាឡឹម ហើយបានយកឈ្នះលើពួកគេ»។

ពួកគេបានបំផ្លាញក្រុងនេះ

ពាក្យ «វា» នៅទីនេះ សំដៅលើទីក្រុងដែលតំណាងឲ្យមនុស្សនៅក្នុងទីក្រុងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានវាយប្រហារមនុស្សនៅក្នុងទីក្រុងនោះ»។

ដោយមុខដាវនិងដុតកម្ទេចដោយភ្លើង។

«ដោយមុខដាវ»។ ពាក្យ «ដាវ» នៅទីនេះ សំដៅលើដាវ និងអាវុធផ្សេងទៀត
ដែលទាហានប្រើនៅក្នុងសមរភូមិ។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«ជាមួយនឹងដាវរបស់ពួកគេ» ឬ «ជាមួយនឹងអាវុធរបស់ពួកគេ»។
កុលសម្ព័ន្ធយូដា បានចុះទៅប្រយុទ្ធ
វាគឺជារឿងធម្មតាក្នុងការប្រើពាក្យ «ចុះទៅ»
គឺសំដៅលើការធ្វើដំណើរចុះពីក្រុងយេរូសាឡឹម។ របៀបផ្សេងទៀតនៃការបកប្រែ:
«កុលសម្ព័ន្ធយូដាបានចេញទៅច្បាំង»។
នៅតាមតំបន់ភ្នំ តំបន់ណេកិប
«នៅភាគខាងត្បូងនៃទីរហោស្ថានយ័រដាន់» (UDB)។
តំបន់វាលទំនាប
កូនភ្នំដែលនៅតាមជើងភ្នំ ឬជួរភ្នំ។
ទីក្រុងហេប្រុន (ពីដើមក្រុងហេប្រុនមានឈ្មោះថា គារយ៉ាត អើបា)
នេះគឺជាប្រវត្តិ។ អ្នកខ្លះអានកណ្ឌគម្ពីរនេះលើកទីមួយ ប្រហែលជាធ្លាប់បានឮ
គារយ៉ាត អើបា ប៉ុន្តែ មិនបានដឹងថាវាគឺជាទីក្រុងដែលពួកគេហៅថាហេប្រុនដែរ។
សេសាយ អំបូរអហីម៉ាន និងអំបូរតាល់ម៉ាយ
ទាំងបីនេះគឺជាឈ្មោះរបស់អ្នកដឹកនាំរបស់ជនជាតិកាណាននៅហេប្រុន។
អ្នកដឹកនាំម្នាក់ៗតំណាងឲ្យទាហានរបស់ខ្លួន។ របៀបលផ្សេងទៀតនៃការបកប្រែ:
«លោកសេសាយ លោកអហីម៉ាន និងលោកតាល់ម៉ាយ និងទាហានរបស់ពួកគេ»។
សូមមើល: និង
Judges 1:11
ក្រុង ដេបៀរ ពីដើមក្រុងដេបៀរមានឈ្មោះថា គារយ៉ាត សេភើរ
អ្នកនិពន្ធសរសេរការនេះ
ប្រហែលជាដោយសារអ្នកអានរបស់គាត់បានដឹងថាទីក្រុងនោះគឺជាទីក្រុងដេបៀរ។
ប៉ុន្តែ នៅសម័យដែលជនជាតិអ៊ីស្រាអែលវាយលុកទីក្រុងនោះ គេហៅទីក្រុងនោះថា
គារយ៉ាត សេភើរ។ របៀបផ្សេងទៀតនៃការបកប្រែ: «ពីដើមគេហៅថា គារយ៉ាត
សេភើរ»។ (សូមមើល: | Background Information និង | How to
Translate Names)
ពីមុន
«កាលពីមុន» ឬ «នៅសម័យមុន»។
ប្រសិនបើ នរណាម្នាក់ វាយយកបានក្រុងគារយ៉ាត ក្រុងសេភើរ ហើយយកវាបាន
ពាក្យ «គារយ៉ាត ក្រុងសេភើរ» តំណាងឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកណាដែលវាយប្រហារ ហើយយកឈ្នះគារយ៉ាត ក្រុងសេភើរ
ហើយយកទីក្រុងរបស់ពួកគេបាន»។ (សូមមើល: | Metonymy)
នាងអាក់សា
នេះគឺជាឈ្មោះរបស់កូនស្រីលោកកាលែប។ (សូមមើល: | How to Translate
Names)
លោកអូធ្នាល ជាកូនប្រុសរបស់លោកកេណាស
នេះគឺជាឈ្មោះរបស់បុរស។ (សូមមើល: | How to Translate Names)
Judges 1:14
នាងបានបបួលលោក
«នាងអាក់សាបបួលលោកអាធ្នាល«។
ចំណែកដីស្រែពីឪពុករបស់នាង...ប្រគល់ដីនៅតំបន់ណេកិបដល់ខ្ញុំ
ឃ្លានេះសំដៅលើលោកកាលែបបានប្រគល់ដីស្រែដល់នាង នៅពេលនាងសុំពីគាត់
នៅក្នុងខ១៤។ ហើយនៅក្នុងខ១៥
នាងបានសុំអណ្តូងទឹកបន្ថែមពីលើដីស្រែទៀតផង។
សូមលោកពុកមេត្តាឲ្យពរមួយដល់ខ្ញុំ
«សូមមេត្តាដល់ខ្ញុំផង» ឬ «សូមធ្វើការនេះដល់ខ្ញុំ»។
ព្រោះ លោកឪពុកបានប្រគល់ដីនៅតំបន់ណេកិបដល់ខ្ញុំ
លោកកាលែបបានប្រគល់នាងអាក់សាឲ្យរៀបការជាមួយលោកអាធ្នាល ដូច្នេះ
នាងបានរស់នៅក្នុងទីក្រុងដែលលោកបានចាប់យកបានពីតំបន់ណេកិប។
អត្ថន័យពេញលេញនៅក្នុងប្រយោគនេះអាចធ្វើឲ្យមានភាពច្បាស់លាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកឪពុកបានឲ្យខ្ញុំរៀបការ
ហើយឲ្យរស់នៅក្នុងណេកិប»។
Judges 1:16
ឪពុកក្មេករបស់លោកម៉ូសេ
ឪពុកក្មេក- «ឪពុករបស់ប្រពន្ធលោកម៉ូសេ»។
ឪពុកក្មេកជាជនជាតិកែនបានឡើងទៅ
ឪពុកក្មេកជាជនជាតិកែនបានឡើងទៅ - «ឪពុកក្មេក ជាម្នាក់ដែលជាជនជាតិកែន
បានឡើងទៅ»។
ចេញពីក្រុងដើមលម៉ើ...ឆ្ពោះទៅកាន់វាលរហោស្ថាននៃ
«ចេញពីទីក្រុងដើមលម៉ើ...ហើយបានចុះទៅទីរហោស្ថាន»។
ទីក្រុងដើមលម៉ើ
នេះគឺជាឈ្មោះមួយទៀតសម្រាប់ទីក្រុងយេរីខូ។
អ៊ើរ៉ាត
នេះគឺជាឈ្មោះទីក្រុងកាណាន។
កុលសម្ព័ន្ធស៊ីម្មាន ជាបងប្អូនរបស់ពួកគេ
ពាក្យ «បងប្អូន» នៅទីនេះ មានន័យថា សាច់ញាតិ
ដែលនៅក្នុងអំបូរផ្សេងទៀតរបស់អ៊ីស្រាអែល។
តំបន់ សេផាត
នេះគឺជាឈ្មោះរបស់ទីក្រុងមួយនៅក្នុងស្រុកកាណាន។
ឈ្មោះក្រុងនោះថា ហោម៉ា
បន្ទាប់ពី អ៊ីស្រាអែលបំផ្លាញក្រុងសេផាត ពួកគេបានប្តូរឈ្មោះវាទៅជាក្រុង
«ហោម៉ា» វិញ។ ឈ្មោះ «ហោម៉ា» មានន័យថា «បំផ្លាញទាំងស្រុង»។
Judges 1:18
ព្រះអម្ចាស់បានគង់ជាមួយកុលសម្ព័ន្ធយូដា
ពាក្យ «គង់នៅជាមួយ» នៅទីនេះ មានន័យថា: «ព្រះអម្ចាស់ជួយជនជាតិយូដា»។
តាមតំបន់ជ្រលងភ្នំ
ជាជ្រលងភ្នំមួយយ៉ាងធំ គ្មានដើមឈើទេ។
Judges 1:20
ទីក្រុងហេប្រុនត្រូវបានប្រគល់ឲ្យលោកកាលែបដូចដែលលោកម៉ូសេបានបង្គាប់ទុក
ឃ្លានេះស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកម៉ូសេបានប្រគល់ក្រុងហេប្រុនដល់លោកកាលែប»។
លោកបានបណ្តេញអំបូរអណាក់ទាំងបី
គេប្រើអ្នកដឹកនាំរបស់ក្រុមមនុស្ស ដើម្បីសំដៅលើក្រុមមនុស្សទាំងស្រុង។
របៀបផ្សេងទៀតនៃការបកប្រែ: «កូនប្រុសបីរបស់លោកអណាក់
និងប្រជាជនរបស់ពួកគេ»។
លោកអណាក់
នេះគឺជាឈ្មោះរបស់បុរសម្នាក់។ លោកអណាក់
និងកូនចៅរបស់គាត់មានឈ្មោះល្បីដោយសារគាត់ខ្ពស់ពេក។
រហូតដល់សព្វថ្ងៃ
«រហូតមកដល់ពេលនេះ»
សំដៅលើពេលវេលានៅសម័យសរសេរកណ្ឌគម្ពីរចៅហ្វាយ។
Judges 1:22
ពូជពង្សរបស់លោកយូ៉សែប
ពាក្យ «ផ្ទះ» សំដៅលើពូជពង្ស។ លោកម៉ាណាសេ
និងលោកអេប្រាអិមជាកូនរបស់លោកយ៉ូសែប។ ហើយ «ផ្ទះរបស់លោកយ៉ូសែប»
អាចសំដៅលើកូនចៅរបស់លោកម៉ាណាសេ និងលោកអេប្រាអ៊ិម។
របៀបផ្សេងទៀតនៃការបកប្រែ: «កូនចៅរបស់លោកម៉ាណាសេ
និងលោកអេប្រាអ៊ិម» ឬ «បុរសមកពីម៉ាណាសេ និងអេប្រាអ៊ិម»។
ចេញទៅច្បាំងនឹងក្រុងបេតអែល
ពាក្យ «បេតអែល» សំដៅលើមនុស្សដែលរស់នៅបេតអែល។
ស៊ើប
ទៅរកព័ត៌មានដោយសម្ងាត់។
ទីក្រុង ដែលពីដើមឡើយគេហៅក្រុងនោះមានឈ្មោះថា លូស។
នេះគឺជាព័ត៌មានពីប្រវត្តិ។ នរណាម្នាក់ដែលអានសៀវភៅនេះលើកទីមួយ
ប្រហែលជាបានឮពីលូសនេះ ប៉ុន្តែ មិនដឹងថា វាជាទីក្រុងដែលគេហៅថា
បេតអែល។ (សូមមើល: និងtranslate-names)
ស៊ើប
ទៅរកព័ត៌មានដោយសម្ងាត់។
Judges 1:25
ពួកគេបានប្រហារទីក្រុង
ពាក្យ «ទីក្រុង» នៅទីនេះ សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានប្រហារមនុស្សនៅក្នុងទីក្រុង»។
ដោយមុខដាវ
«ដោយមុខដាវ»។ ពាក្យ «ដាវ» នៅទីនេះ សំដៅលើដាវ និងអាវុធផ្សេងទៀត
ដែលទាហានប្រើនៅក្នុងសមរភូមិ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជាមួយនឹងដាវរបស់ពួកគេ» ឬ «ជាមួយនឹងអាវុធរបស់ពួកគេ»។
ចាក់ចេញទៅ
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «គេច»។
លូស

generated on Wed Sep 10 16:16:32 2025

ជាទីក្រុងថ្មី ចាប់ផ្តើមនៅក្នុងទឹកដីស្រុកហេត បានដាក់ឈ្មោះទីក្រុងនោះថា លូស
នៅជិតបេតអែល បុរសនោះបានចាកចេញពីទីនោះ។
គេហៅរហូតមកដល់សព្វថ្ងៃ
«ឈ្មោះនោះនៅតែហៅរហូតមកដល់សព្វថ្ងៃនេះ» «រហូតដល់សព្វថ្ងៃនេះ»
សំដៅលើសម័យនៃការសរសេរកណ្ឌគម្ពីរចៅហ្វាយនេះ។
Judges 1:27
ក្រុងបេតសៀន...ក្រុងតាណាក់... ក្រុងដោរ...ក្រុងយីបឡាម...ក្រុងមេគីដោរ
ទាំងនេះគឺជាឈ្មោះរបស់ទីក្រុង។
ដោយសារជនជាតិកាណានតាំងចិត្តចង់រស់នៅក្នុងតំបន់ទាំងនោះ
«ប្តេជ្ញាចិត្ត» សម្រេចចិត្តយ៉ាងមុតមាំចំពោះអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយសារជនជាតិកាណានបានសម្រេចចិត្តយ៉ាងមុតមាំក្នុងការមិនចាកចេញពីទឹកដីនិងក្រុងបេតអាណាតធ្វើការឲ្យពួកគេដូចជាទាសករ»។
នៅពេលដែលជនជាតិអ៊ីស្រាអែលមានកម្លាំង
ពាក្យ «អ៊ីស្រាអែល» សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលជនជាតិអ៊ីស្រាអែលមានកម្លាំងកាន់តែខ្លាំងឡើង»។
គេបានបង្ខំឲ្យជនជាតិកាណានធ្វើការជាទម្ងន់
«ពួកគេបានបង្ខំជនជាតិកាណានឲ្យធ្វើការយ៉ាងខ្លាំងដល់ពួកគេ»។
Judges 1:29
កុលសម្ព័ន្ធអេប្រាអ៊ីម ក៏មិនបាន
ពាក្យ «អេប្រាអ៊ីម» តំណាងឲ្យពួកប្រុសៗ ឬ ជាទាហានរបស់អំបូរអេប្រាអ៊ីម។
ក្រុងកេស៊ើរ
ជាឈ្មោះមួយនៃទីក្រុងនៅក្នុងតំបន់អេប្រាអ៊ីម។
Judges 1:30
កុលសម្ព័ន្ធសាប់យ៉ូឡូមក៏មិនបានបណ្តេញ
ពាក្យ «សាប់យ៉ូឡូម» នៅទីនេះ សំដៅលើពួកប្រុសៗ ឬ
ជាទាហានរបស់អំបូរសាប់យ៉ូឡូម។
ក្រុងគីត្រុន...ណាហាឡូល
ទាំងនេះគឺជាឈ្មោះរបស់ទីក្រុងនៅក្នុងទឹកដីកាណាន។
ប៉ុន្តែ កុលសម្ព័ន្ធសាប់យ៉ូឡូមបានបង្ខំ
ពាក្យ «កុលសម្ព័ន្ធសាប់យ៉ូឡូម» សំដៅលើមនុស្សនៃអំបូររបស់សាប់យ៉ូឡូន។
ធ្វើការជាទម្ងន់
«ធ្វើការលំបាក»
Judges 1:31
កុលសម្ព័ន្ធអាស៊ើរ មិនបានបណ្តេញ
ពាក្យ «អាស៊ើរ» នៅទីនេះ តំណាងឲ្យពួកប្រុសៗ ឬ
ទាហានរបស់អំបូររបស់អាស៊ើរ។
ទីក្រុងអាក់កូ...ស៊ីដូន...អាស់ឡាប់... អាក់ស៊ីប...ហែលបា...អាផែក... រេហូប
ទាំងនេះគឺជាឈ្មោះរបស់ទីក្រុងនៃទឹកដីកាណាន។
Judges 1:33
ក្រុងបេតសេម៉េស...ក្រុងបេតអាណាត
ទាំងនេះគឺជាឈ្មោះរបស់ទីក្រុង។
អ្នកដែលរស់នៅក្នុងក្រុងបេតសេម៉េស
និងក្រុងបេតអាណាតត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់ដល់កុលសម្ព័ន្ធណែបថាលី
នេះអាចជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនកុលសម្ព័ន្ធណែបថាលីបានបង្ខំប្រជាជននៅក្នុងក្រុងបេតសេម៉េស
Judges 1:34
មិនអនុញ្ញាតឲ្យពួកគេចុះមករស់នៅតាមជ្រលងភ្នំឡើយ
«បានបញ្ជាប់ពួកគេមិនឲ្យចុះក្រោម»។
ទីវាល
ជាវាលរាបយ៉ាងធំ គ្មានដើមឈើ
ភ្នំហេរេស
នេះគឺជាឈ្មោះរបស់ភ្នំដ៏ធំមួយដែលជាទីក្រុងរបស់អាយ៉ាឡូនបានសង់នៅទីនោះ។
អាយ៉ាឡូន...សាលប៊ីម
ទាំងនេះជាឈ្មោះរបស់ទីក្រុងផ្សេងៗ។
ពូជពង្សលោកយូសែបមានកម្លាំងគ្រប់គ្រងលើពួកគេ
អំបូររបស់មនុស្សដែលជាពូជពង្សមកពីលោកយ៉ូសែបបានយកឈ្នះលើពួកគេដោយសារទាហានរបស់ពួក
ពូជពង្សលោកយូសែប
ពាក្យ «ផ្ទះ» សំដៅលើពូជពង្ស។ លោកម៉ាណាសេ
និងលោកអេប្រាអិមជាកូនរបស់លោកយ៉ូសែប។ ហើយ «ផ្ទះរបស់លោកយ៉ូសែប»
អាចសំដៅលើកូនចៅរបស់លោកម៉ណាសេ និងលោកអេប្រាអ៊ីម។
របៀបផ្សេងទៀតនៃការបកប្រែ: «កូនចៅរបស់លោកម៉ាណាសេ
និងលោកអេប្រាអ៊ិម» ឬ «បុរសមកពីម៉ាណាសេ និងអេប្រាអ៊ិម»។
ភ្នំអាក្រាប៊ីម
ទីនេះ គឺជាច្រកផ្លូវភាគខាងត្បូងនៃសមុទ្រស្លាប់។ គេក៏ហៅកន្លែងនេះថា៖
«ច្រកភ្នំខ្យាដំរី»។
សេឡា
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។

---

2 [1]នៅពេលទេវតានៃព្រះអម្ចាស់បានឡើងពីគីលកាល់ទៅបូគីម ហើយពោលទៅកាន់ជនជាតិអ៊ីស្រាអែលថា ៖ «យើងបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីបមក
ហើយក៏បាននាំអ្នកទៅកាន់ទឹកដីដែលយើងបានសន្យានឹង បុព្វបុរសរបស់អ្នកថានឹងឲ្យទៅអ្នករាល់គ្នា។ យើងបាននិយាយថា យើងនឹងមិនផ្តាច់សម្ព័ន្ធមេត្រី
ដែលយើងបានចងជាមួយអ្នកឡើយ។[2]រីឯអ្នករាល់គ្នាវិញ គឺមិនត្រូវចងសម្ព័ន្ធមេត្រីជាមួយប្រជាជនដែលរស់នៅក្នុងស្រុកនេះដែរ។
អ្នកត្រូវតែរំលំអាសនៈទាំងឡាយរបស់គេចោល។ ប៉ុន្តែ អ្នករាល់គ្នាមិនបានស្តាប់ពាក្យរបស់យើងទេ! ហេតុអ្វីបានជាអ្នករាល់គ្នាប្រព្រឹត្តបែបនេះ?
[3]ដូច្នេះ យើងសុំប្រាប់អ្នករាល់គ្នាថា «យើងនឹងមិនបណ្តេញជនជាតិកាណានទាំងនេះចេញពីមុខរបស់អ្នកទេ ពួកគេនឹងក្លាយទៅជាសត្រូវរបស់អ្នករាល់
ហើយអ្នករាល់គ្នានឹងធ្លាក់ទៅក្នុងអន្ទាក់នៃព្រះនានារបស់ពួកគេ»។[4]នៅពេលដែលប្រជាជនអ៊ីស្រាអែល បានឮទេវតារបស់ព្រះអម្ចាស់ពោលដូច្នេះ
ពួកគេបានស្រែកទ្រហោរយំ។[5]ពួកគេបានដាក់ឈ្មោះទីកន្លែងនោះថា បូគីម។ នៅទីនោះ ពួកគេបានថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់។
[6]លោកយ៉ូស្វេបានឲ្យជនជាតិអ៊ីស្រាអែលត្រឡប់ទៅវិញ ពួកគេបានចាប់យកចំណែកទឹកដីដែលជាមរតករបស់គេរៀងៗខ្លួន។
[7]អំឡុងពេលដែលលោកយ៉ូស្វេនៅមានជីវិតនៅឡើយ ពួកគេគោរពបម្រើព្រះអម្ចាស់។ ក្រោយលោក ទទួលមរណភាពទៅ ពួកគេក៏នៅតែគោរពបម្រើព្រះអង្គបន្តទៅទៀត
គឺអំឡុងពេលដែលពួកចាស់ទុំនៅមានជីវិតនៅឡើយ គឺចាស់ទុំដែលបានឃើញពីការអស្ចារ្យ ដ៏ឧដុង្គឧត្តមដែលព្រះអម្ចាស់បានធ្វើចំពោះជនជាតិអ៊ីស្រាអែល។
[8]លោកយ៉ូស្វេ ជាកូនរបស់នូន ជាអ្នកបម្រើរបស់ព្រះជាម្ចាស់ បានទទួលមរណភាពក្នុងជន្មាយុមួយរយដប់ឆ្នាំ។
[9]ពួកគេបានបញ្ចុះសពរបស់លោកនៅក្នុងទឹកដីដែលជាចំណែកមរតករបស់លោក នៅធីមណាត ហេរេស នៅក្នុងតំបន់ភ្នំអេប្រាអ៊ីម នៅខាងជើងភ្នំកាអាស។
[10]មនុស្សជំនាន់នោះក៏បានទៅជួបនឹងដូនតារបស់គេដែលបានចែកឋានទៅ។ ហើយមនុស្សជំនាន់មួយជំនាក់ទៀតក៏កើតមកតាមក្រោយ
ពួកគេមិនបានស្គាល់ព្រះជាម្ចាស់និងកិច្ចការដ៏អស្ចារ្យដែលព្រះអង្គបានធ្វើចំពោះជនជាតិអ៊ីស្រាអែលនោះទេ។
[11]ប្រជាជនអ៊ីស្រាអែលបានប្រព្រឹត្តអំពើអាក្រក់ដែលមិនគាប់ព្រះហឫទ័យព្រះអម្ចាស់ ហើយពួកគេបានគោរពបម្រើព្រះបាល។
[12]ពួកគេបានបែកចេញពីមាគ៌ារបស់ព្រះអម្ចាស់ គឺព្រះនៃបុព្វបុរសរបស់គេ ព្រះដែលបាននាំគេចេញពីស្រុកអេស៊ីបមក។
គេបែរទៅគោរពព្រះផ្សេងៗទៀតក្នុងចំណោមព្រះនានារបស់ប្រជាជនដែលរស់នៅជុំវិញពួកគេ ពួកគេក្រាបថ្វាយបង្គំព្រះទាំងនោះ
ដែលជាហេតុនាំឲ្យព្រះអម្ចាស់ព្រះពិរោធ[13]ដោយសារតែពួកគេបានបែរចេញពីផ្លូវរបស់ទ្រង់ ហើយគោរពបម្រើព្រះបាល និងអាសថារ៉ូត។
[14]ព្រះអម្ចាស់ទ្រង់ព្រះពិរោធនឹងជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង ព្រះអង្គបានប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃពួកចោរព្រៃ ដែលប្លន់យកទ្រព្យសម្បត្តិរបស់ពួកគេ។
ព្រះអង្គបានលក់ពួកគេឲ្យទៅខ្មាំងសត្រូវដែលនៅជុំវិញធ្វើជាទាសករ ដូច្នេះហើយពួកគេមិនអាចទប់ទល់នឹងខ្មាំងសត្រូវរបស់ពួកគេបានទៀតទេ។
[15]នៅគ្រប់ទីកន្លែងដែលជនជាតិអ៊ីស្រាអែលចេញទៅច្បាំង ព្រះអម្ចាស់ធ្វើឲ្យពួកគេបរាជ័យជានិច្ច ដូចដែលព្រះអង្គមានព្រះបន្ទូលព្រមានពួកគេរួចស្រេចហើយ។
[16]ក្រោយមក ព្រះអម្ចាស់បានធ្វើឲ្យមានពួកចៅហ្វាយ ក្រោកឡើង ដែលរំដោះពួកគេឲ្យរួចពីកណ្តាប់ដៃពួកចោរព្រៃ។[17]ប៉ុន្តែ
ពួកគេនៅតែមិនស្តាប់បង្គាប់ពួកចៅហ្វាយរបស់ពួកគេ។ ជនជាតិអ៊ីស្រាអែលបានក្បត់ព្រះអម្ចាស់ ហើយបែរទៅគោរពថ្វាយបង្គំព្រះដទៃ។
ពួកគេឆាប់បែរចេញពីមាគ៌ារបស់បុព្វបុរស គឺពួកគេមិនប្រតិបត្តិតាមបទបញ្ជារបស់ព្រះអម្ចាស់ ដូចបុព្វបុរសរបស់ពួកគេទេ។

generated on Wed Sep 10 16:16:32 2025

[18]កាលព្រះអម្ចាស់បានធ្វើឲ្យពួកចៅហ្វាយក្រោកឡើងសម្រាប់ពួកគេ ព្រះអម្ចាស់បានគង់ជាមួយចៅហ្វាយនោះ និងសង្គ្រោះពួកគេពីកណ្តាប់ដៃខ្មាំងសត្រូវរបស់ពួកគេ
ពេញមួយជីវិតរបស់ចៅហ្វាយនោះ។ ព្រះអម្ចាស់មានសេចក្តីអាណិតអាសូរដល់ពួកគេ នៅពេលដែលពួកគេស្រែកថ្ងូរដោយសារតែពួកខ្មាំងសត្រូវសង្កត់សង្កិន
និងធ្វើបាបពួកគេ។[19]ប៉ុន្តែ ពេលដែលចៅហ្វាយនោះទទួលមរណភាពផុតទៅ ពួកគេបានបែរទៅប្រព្រឹត្តការអាក្រក់សារជាថ្មី
លើសជាងពួកដូនតារបស់ពួកគេដែលធ្លាប់ប្រព្រឹត្តទៅទៀត។ ពួកគេបានដើរតាមព្រះដទៃដោយគោរពបម្រើ និងថ្វាយបង្គំព្រះទាំងនោះ
ពួកគេមិនបានបោះបង់ចោលការប្រព្រឹត្តអាក្រក់ ឬចរិតដែលរឹងចចេសរបស់ពួកគេចោលទេ។
[20]ពេលនោះ ព្រះអម្ចាស់ព្រះពិរោធនឹងជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង ព្រះអង្គមានព្រះបន្ទូលថា៖ «ដោយសារតែប្រជាជាតិនេះបានផ្តាច់
សម្ព័ន្ធមេត្រីដែលយើងបានចងជាមួយដែលយើងបានចងជាមួយបុព្វបុរសរបស់ពួកគេ
ដោយសារតែពួកគេមិនស្តាប់ពាក្យរបស់យើង[21]នោះយើងនឹងមិនបណ្តេញប្រជាជាតិណាមួយ ដែលលោកយ៉ូស្វេបានបន្សល់ទុក ក្រោយពេលគាត់ស្លាប់នៅទៅដែរ។
[22]យើងនឹងល្បងលមើលជនជាតិអ៊ីស្រាអែលឲ្យដឹងថា តើអ៊ីស្រាអែលនឹងដើរតាមផ្លូវដែលបុព្វបុរសរបស់គេដើរដែរឬទេ»។[23]ដូច្នេះហើយ
ព្រះអម្ចាស់បានទុកជាតិសាសន៍នានា គឺព្រះអង្គមិនប្រញាប់បណ្តេញពួកគេចេញពីទឹកដីរបស់ពួកគេ ហើយក៏មិនប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់លោកយ៉ូស្វេដែរ។

Judges 2:1

ទេវតានៃព្រះអម្ចាស់

ទីមួយ អាចមានន័យថា៖ «ទេវតា ដែលតំណាងឲ្យព្រះអម្ចាស់» ឬ ទី២) «អ្នកនាំសារ ដែលបម្រើព្រះអម្ចាស់» ឬ ទី៣) អាចសំដៅលើព្រះអម្ចាស់ផ្ទាល់ ដែលមើលទៅដូចជាទេវតា នៅពេលព្រះអង្គមានបន្ទូលទៅកាន់មនុស្ស។ ន័យនីមួយៗរបស់ន័យទាំងនេះ អាចពន្យល់ពីទេវតា ដោយប្រើពាក្យ «ខ្ញុំ» ដូចជាព្រះអម្ចាស់ជាអ្នកមានបន្ទូល»។

បានឡើងពីគីលកាល់ទៅបូគីម

«បានចាកចេញពីគីលកាល់ ហើយឡើងទៅបូគីម»។

បូគីម

នេះជាអ្វីដែលជនជាតិអ៊ីស្រាអែលដាក់ឈ្មោះនៅកន្លែងនេះ នៅក្នុងខ ២:៥ បន្ទាប់មកទេវតាបានដាស់តឿនប្រជាជន។ «បូគីម» មានន័យ «យំ»។

ហើយពោល

ពាក្យនេះមានន័យថា
ទេវតារបស់ព្រះអម្ចាស់គឺជាអ្នកនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយពោលទៅកាន់ជនជាតិអ៊ីស្រាអែល»។

បាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីបមក

«នាំអ្នករាល់គ្នាចេញពីអេស៊ីប»។

បុព្វបុរសរបស់អ្នក

«ដូនតារបស់អ្នករាល់គ្នា» ឬ «បុព្វបុរសរបស់អ្នករាល់គ្នា»។

ផ្តាច់សម្ព័ន្ធមេត្រីរបស់យើងជាមួយអ្នករាល់គ្នា

នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«បរាជ័យក្នុងការធ្វើអ្វីដែលយើងបាននិយាយ ថាយើងនឹងធ្វើសម្រាប់អ្នក»។

អ្នករាល់គ្នាមិនបានស្តាប់ពាក្យរបស់យើងទេ

ពាក្យ «ពាក្យ» នៅទីនេះ សំដៅលើអ្វីដែលព្រះអម្ចាស់មានបន្ទូល។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករាល់គ្នាមិនបានស្តាប់បង្គាប់តាមបញ្ញត្តិរបស់យើង»។

ហេតុអ្វីបានជាអ្នករាល់គ្នាប្រព្រឹត្តបែបនេះ?

សំណួរនេះ ត្រូវបានសួរ ដើម្បីធ្វើឲ្យប្រជាជនអ៊ីស្រាអែលដឹងថា
ពួកគេមិនបានស្តាប់បង្គាប់ព្រះអម្ចាស់ទេ ហើយពួកគេនឹងវេទនាដោយសារវា។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកបានធ្វើការដ៏អាក្រក់»។

Judges 2:3

ព័ត៌មានទូទៅ

ទេវតារបស់ព្រះជាម្ចាស់បន្តក្នុងការនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល។

ដូច្នេះ យើងសុំប្រាប់អ្នករាល់គ្នាថា៖ «យើងនឹងមិន...ធ្លាក់ទៅក្នុងអន្ទាក់របស់ពួកគេ»។

នេះគឺជាការដកស្រង់ពាក្យនៅក្នុងពាក្យដកស្រង់។ ការដកស្រង់ពាក្យត្រង់ៗនេះ
អាចជាស្ថិតនៅក្នុងទម្រង់នៃការដកស្រង់មិនផ្ទាល់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ ឥឡូវនេះ ខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងមិន... ធ្លាក់ទៅក្នុងអន្ទាក់របស់អ្នកឡើយ»។

ពួកគេនឹងក្លាយទៅជាបន្លាចាក់នៅចំហៀងរបស់អ្នករាល់គ្នា

ជនជាតិកាណានធ្វើឲ្យជនជាតិអ៊ីស្រាអែល
គឺនិយាយពីជនជាតិកាណានប្រៀបដូចជាបន្លាចាក់នៅចំហៀងរបស់ជនជាតិអ៊ីស្រាអែល
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងធ្វើឲ្យអ្នករាល់គ្នាមានបញ្ហា»។

បន្លា

ជាបន្លាដែលមុតស្រួច មានប្រវែងប្រាំពីរសងទីម៉ែត្រ
ហើយលៀនចេញមកក្រៅពីរុក្ខជាតិមួយចំនួន។

អ្នករាល់គ្នានឹងធ្លាក់ទៅក្នុងអន្ទាក់នៃព្រះនានារបស់ពួកគេ

ជនជាតិអ៊ីស្រាអែលថ្វាយបង្គំព្រះរបស់ជនជាតិកាណានគឺនិយាយសំដៅលើព្រះក្លែងក្លាយដែលដូចជាអន្ទ
ហើយធ្វើឲ្យគេគ្រោះថ្នាក់។

ស្រែកទ្រហោរយំ

«យំដោយមានទឹកភ្នែកជាច្រើន»។

Judges 2:6

ឥឡូវនេះ នៅពេលលោកយ៉ូស្វេ

ពាក្យ «ឥឡូវនេះ» ត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ពីការសម្រាកពីសាច់រឿងចម្បង។ នៅទីនេះ ចាប់ផ្តើមសង្ខេប
ហើយពន្យល់ពីប្រជាជនអ៊ីស្រាអែលនៅជំនាន់ក្រោយលោកយ៉ូស្វេ បានធ្វើបាប
ហើយបានថ្វាយបង្គំព្រះក្លែងក្លាយ ដូច្នេះហើយបានជាព្រះអម្ចាស់ដាក់ទោសពួកគេ
ប៉ុន្តែ បន្ទាប់មក ព្រះអង្គបានចាត់ពួកចៅហ្វាយមកសង្គ្រោះពួកគេ។
នេះគឺជាការសង្ខេបពេលបញ្ចប់នៅក្នុង ជំពូក ២:២៣។

នៅពេលលោកយ៉ូស្វេ...បានទទួលមរណភាពក្នុងជន្មាយុមួយរយដប់ឆ្នាំ។

ព្រឹត្តការណ៍នៅក្នុង ជំពូក ១:១-២:៥ បានកើតឡើង បន្ទាប់ពី
លោកយ៉ូស្វេទទួលមរណភាព។
ព្រឹត្តការណ៍បានរាប់ចាប់តាំងពីចុងបញ្ចប់នៃកណ្ឌគម្ពីរយ៉ូស្វេ។

ចាប់យកចំណែកទឹកដី

នៅក្នុងប្រយោគអាចធ្វើឲ្យមើលឃើញច្បាស់ជាង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទៅកន្លែងដែលព្រះអម្ចាស់ប្រទានដល់ពួកគេ»។

អំឡុងពេលដែលលោកយ៉ូស្វេនៅមានជីវិតនៅឡើយ

ឃ្លានេះមានន័យថា គឺនៅក្នុងអំឡុងពេលនៃជីវិតរស់នៅរបស់អ្នកណាម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅអំឡុងពេលមានជីវិត»។

ពួកចាស់ទុំ

នៅទីនេះ សំដៅលើអ្នកដែលដឹកនាំជនជាតិអ៊ីស្រាអែល
ចូលរួមក្នុងការដោះស្រាយបញ្ហាយុត្តិធម៌នៅក្នុងសង្គម និងនៅក្នុងសាសន៍
ក៏ដូចជាការរក្សាបញ្ញត្តិរបស់លោកម៉ូសេដែរ។

មានជីវិតនៅឡើយ

នេះមានន័យថា មានអាយុវែងជាអ្នកដទៃ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានអាយុវែងជាគាត់»។

នូន

នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។

Judges 2:9

លោកនៅក្នុងទឹកដីដែលជាចំណែកមរតករបស់លោក

ឃ្លានេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលព្រះជាម្ចាស់បានប្រទានដល់លោក»។

នៅធីមណាត ហេរេស

នេះគឺជាឈ្មោះនៅទឹកដីនៅក្នុងតំបន់។

ភ្នំកាអាស

នេះគឺជាឈ្មោះរបស់ភ្នំ។

មនុស្សជំនាន់នោះក៏បានទៅជួបនឹងដូនតារបស់គេដែលបានចែកឋានទៅ
ឃ្លាថា: ក៏បានទៅជួបជុំនឹងដូនតារបស់ពួកគេ» មានន័យថា
មនុស្សដែលស្លាប់នៅក្នុងជំនាន់នោះ
ព្រលឹងរបស់ពួកគេបានឡើងទៅនៅកន្លែងដូចដូនតាគេដែលស្លាប់ទៅមុនគេនៅដែរ។
នេះគឺជាវិធីគួរសមក្នុងការនិយាយជំនួសពាក្យថា គេស្លាប់។

ដូនតា

ដូនតានៅទីនេះ សំដៅលើដូនតារបស់បុគ្គលឬ ក្រុមមនុស្សណាមួយច្បាស់លាស់។

កើតមក

generated on Wed Sep 10 16:16:32 2025

«ធំឡើង» ឬ «ក្លាយជាចាស់ទុំ»។
ពួកគេមិនបានស្គាល់ព្រះជាម្ចាស់
ពាក្យ «មិនស្គាល់» នៅទីនេះ មានន័យថា
ពួកគេមិនមានបទពិសោធន៍ជាមួយព្រះអម្ចាស់ ឬ
ជាមួយអំណាចនៃអ្នកជំនាន់មុនធ្លាប់មាន។
Judges 2:11
បានប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់
ពាក្យ «នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»
សំដៅលើអ្វីដែលព្រះអម្ចាស់យកព្រះទ័យទុកដាក់ ឬមានព្រះតម្រិះលើអ្វីមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលព្រះអម្ចាស់មានបន្ទូលថាអាក្រក់
មិនត្រូវធ្វើ»។
ព្រះបាល
នៅទីនេះ ព្រះបាលប្រើជាពហុវចន។ ដែលជាទូទៅ «ព្រះបាល»
ជាឈ្មោះរបស់ព្រះក្លែងក្លាយ ពាក្យនេះក៏ប្រើសំដៅលើព្រះផ្សេងៗដែលជារឿយៗ
គេថ្វាយបង្គំជាមួយព្រះបាល។
ពួកគេបានបែកចេញពីមាគ៌ារបស់ព្រះអម្ចាស់
ជនជាតិអ៊ីស្រាអែលលែងស្តាប់បង្គាប់ព្រះអម្ចាស់ បើនិយាយតាមបែបសាច់ឈាម
ពួកគេបែកផ្លូវពីព្រះអង្គ ហើយចាក់ចេញពីព្រះអង្គ។
បុព្វបុរស
«ដូនតា» ឬ «ពួកអយ្យកោ»។
គេបែរទៅគោរពព្រះផ្សេងៗ
ជនជាតិអ៊ីស្រាអែលចាប់ផ្តើមថ្វាយបង្គំព្រះក្លែងក្លាយ គឺជនជាតិអ៊ីស្រាអែលដើរ
និងដេញតាមព្រះក្លែងក្លាយ។
ពួកគេក្រាបថ្វាយបង្គំព្រះទាំងនោះ
នេះគឺជាសកម្មភាពនៃការថ្វាយបង្គំ ហើយថ្វាយកិត្តិយសដល់អ្នកណាម្នាក់។
ជាហេតុនាំឲ្យព្រះអម្ចាស់ព្រះពិរោធ
«ពួកគេបានធ្វើឲ្យព្រះអម្ចាស់មានសេចក្តីក្រោធ»។
អាសថារ៉ូត
នៅទីនេះ អាសថារ៉ូតប្រើជាពហុវចន:
ជាព្រះដែលពួកគេថ្វាយបង្គំដូចជាព្រះនៅក្នុងទម្រង់ផ្សេងៗខុសពីគ្នា។
Judges 2:14
ព្រះអម្ចាស់ទ្រង់ព្រះពិរោធនឹងជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង
ព្រះពិរោធរបស់ព្រះអម្ចាស់ត្រូវបានគេពណ៌នាថា ឆេះដូចជាភ្លើង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់មានសេចក្តីក្រោធជាខ្លាំងជាមួយនឹងជនជាតិអ៊ីស្រាអែល»។
ព្រះអង្គបានប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃពួកចោរព្រៃ ដែលប្លន់យកទ្រព្យសម្បត្តិរបស់ពួកគេ
«ព្រះអង្គអនុញ្ញាតឲ្យចោរព្រៃលួចទ្រព្យសម្បត្តិរបស់ពួកគេ»។
ព្រះអង្គបានលក់ពួកគេឲ្យទៅខ្មាំងសត្រូវដែលនៅជុំវិញធ្វើជាទាសករ
ដូច្នេះហើយពួកគេមិនអាចទប់ទល់នឹងខ្មាំងសត្រូវរបស់ពួកគេបានទៀតទេ
ព្រះអម្ចាស់បានអនុញ្ញាតឲ្យខ្លាំងសត្រូវ ចាប់យកជនជាតិអ៊ីស្រាអែលធ្វើជាឈ្លើយ
និយាយទៅគឺព្រះអង្គលក់ពួកគេឲ្យទៅធ្វើជាឈ្លើយ។ ឃ្លា «មិនអាចទប់ទល់»
អាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គអនុញ្ញាតឲ្យពួកខ្មាំងសត្រូវរបស់ពួកគេយកឈ្នះលើពួកគេ
ហើយយកពួកគេទៅធ្វើជាឈ្លើយ
ហើយពួកគេមិនអាចតទល់នឹងអំណាចរបស់ខ្មាំងសត្រូវឡើយ»។
ព្រះហស្តរបស់ព្រះអម្ចាស់ទាស់ជាមួយពួកគេ ធ្វើឲ្យពួកគេបរាជ័យជានិច្ច។
«ព្រះហស្ត» នៅទីនេះ តំណាងឲ្យអំណាចរបស់ព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់ជួយសត្រូវរបស់ពួកគេឲ្យយកឈ្នះលើពួកគេ»។
ពួកគេកើតទុក្ខវេទនាយ៉ាងខ្លាំង
«ពួកគេរងការឈឺចាប់ជាខ្លាំង»។
Judges 2:16
ក្រោយមក ព្រះអម្ចាស់បានធ្វើឲ្យមានពួកចៅហ្វាយ
ព្រះអម្ចាស់បានជ្រើសរើសមនុស្សឲ្យធ្វើជាពួកចៅហ្វាយ បើនិយាយទៅ
គឺព្រះអង្គរើសតាំង ឬ ជ្រើសរើសមនុស្សឲ្យក្រោកឡើង។
រំដោះពួកគេឲ្យរួចពីកណ្តាប់ដៃ
ពាក្យ «កណ្តាប់ដៃ» នៅទីនេះ សំដៅលើអំណាច។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចេញពីកណ្តាប់ដៃរបស់ពួកខ្មាំងសត្រូវ»។
ពួកគេនៅតែមិនស្តាប់បង្គាប់ពួកចៅហ្វាយរបស់ពួកគេ
«ពួកគេមិនស្តាប់បង្គាប់ពួកចៅហ្វាយរបស់ពួកគេទេ»។
ពួកគេបានប្រគល់ខ្លួនរបស់ពួកគេ ដូចជាស្រីពេស្យាទៅព្រះដទៃ ហើយថ្វាយបង្គំព្រះទាំងនោះ។
ប្រជាជនបានក្បត់ព្រះអម្ចាស់ ហើយថ្វាយបង្គំព្រះផ្សេង
បើនិយាយទៅប្រជាជនគឺដូចជាស្រីពេស្យា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានក្បត់ព្រះអង្គ ដោយថ្វាយបង្គំព្រះក្លែងក្លាយ»។
ពួកគេឆាប់បែរចេញពីមាគ៌ារបស់បុព្វបុរសបានដើរតាម
ប្រជាជនមិនបានប្រព្រឹត្តដូចជាបុព្វបុរសរបស់ពួកគេដែលថ្វាយបង្គំព្រះអម្ចាស់
និយាយទៅគឺប្រជាជនបានបែរ
ហើយដើរតាមផ្លូវផ្សេងខុសពីបុព្វបុរសរបស់ពួកគេ។
បុព្វបុរសរបស់ពួកគេ
«ដូនតារបស់ពួកគេ» ឬ «ពួកអយ្យកោរបស់ពួកគេ។
Judges 2:18
កាលព្រះអម្ចាស់បានធ្វើឲ្យពួកចៅហ្វាយក្រោកឡើង
ព្រះអម្ចាស់បានរើសតាំងមនុស្សឲ្យធ្វើជាចៅហ្វាយ បើនិយាយទៅ គឺរើស
ឬតាំងមនុស្សឡើង។
ពួកចៅហ្វាយសម្រាប់ពួកគេ...សង្គ្រោះពួកគេ
ពាក្យ «ពួកគេ» សំដៅលើជនជាតិអ៊ីស្រាអែល។
ពីកណ្តាប់ដៃខ្មាំងសត្រូវរបស់ពួកគេ
ពាក្យ «កណ្តាប់ដៃ» នៅទីនេះ
សំដៅលើអំណាចរបស់ពួកខ្មាំងសត្រូវដែលធ្វើទុក្ខដល់អ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ: «អំណាចពួកខ្មាំងសត្រូវរបស់ពួកគេ»។
ពេញមួយជីវិតរបស់ចៅហ្វាយនោះ
«ដរាបណាចៅហ្វាយនៅរស់»។
សេចក្តីអាណិតអាសូរ
មានក្តីមេត្តាដល់នរណាម្នាក់ ឬអ្វីមួយ។
នៅពេលដែលពួកគេស្រែកថ្ងូរ
ជាសម្លេងដែលមនុស្សធ្វើឡើង គឺត្រូវបានប្រើសំដៅលើអ្នកដែលរងការឈឺចាប់
ពណ៌នាពីការឈឺចាប់របស់ជនជាតិអ៊ីស្រាអែល នៅពេលពួកគេរងការឈឺចាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលពួកគេឈឺចាប់»។
ពួកគេបានបែរទៅ
មនុស្សលែងស្តាប់បង្គាប់ព្រះអម្ចាស់ទៀតហើយ
បើនិយាយទៅគឺពួកគេបែរខាងឯសាច់ឈាមពីព្រះអម្ចាស់តែម្តង។
បុព្វបុរសរបស់ពួកគេ
«ដូនតារបស់ពួកគេ» ឬ «ពួកអយ្យកោរបស់ពួកគេ។
ពួកគេបានដើរតាមព្រះដទៃដោយគោរពបម្រើ និងថ្វាយបង្គំព្រះទាំងនោះ
ជនជាតិអ៊ីស្រាអែលថ្វាយបង្គំព្រះផ្សេង បើនិយាយទៅ ពួកគេដើរ
ហើយដេញតាមព្រះផ្សេង។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួគគេបម្រើ
ហើយថ្វាយបង្គំព្រះផ្សេង»។
ពួកគេមិនបានបោះបង់ចោលការប្រព្រឹត្តអាក្រក់ ឬចរិតដែលរឹងចចេសរបស់ពួកគេចោលទេ
«ពួកគេបដិសេធមិនព្រមឈប់ប្រព្រឹត្តអំពើអាក្រក់ ហើយមានភាពរឹងចចេស»។
នេះអាចជាទម្រង់អសកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបន្តប្រព្រឹត្តការអាក្រក់ និងមានភាពរឹងចចេស»។
Judges 2:20
ព្រះអម្ចាស់ព្រះពិរោធនឹងជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង
សេចក្តីក្រោធរបស់ព្រះអង្គាស់គឺពណ៌នាថា ឆេះដូចជាភ្លើង។ សូមមើល
ពីរបៀបដែលអ្នកបកប្រែឃ្លានេះនៅក្នុង ជំពូក ២:១៤។
ប្រជាជាតិនេះបានផ្តាច់
ពាក្យ «ប្រជាជាតិ» នៅទីនេះ តំណាងឲ្យ ប្រជាជន។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជននេះបានកាត់ផ្តាច់» ឬ
«ជនជាតិអ៊ីស្រាអែលបានកាត់ផ្តាច់»។
ពួកបុព្វបុរស
បុព្វបុរសនៅទីនេះសំដៅលើដូនតារបស់ប្រជាជន
ឬក្រុមមនុស្សណាមួយច្បាស់លាស់។
ពួកគេមិនស្តាប់ពាក្យរបស់យើង
«ពាក្យ» តំណាងឲ្យអ្វីដែលព្រះអម្ចាស់មានបន្ទូល។ របៀបផ្សេងទៀតនៃការបកប្រែ:
ពួកគេលែងស្តាប់បង្គាប់អ្វីដែលយើងបានបង្គាប់ដល់ពួកគេ» ឬ
«ពួកគេមិនស្តាប់បង្គាប់យើងទេ»។
ជាតិសាសន៍នានា
«ជាតិសាសន៍នានា»

generated on Wed Sep 10 16:16:32 2025

តំណាងឲ្យក្រុមមនុស្សដែលរស់នៅក្នុងទឹកដីកាណានមុនជនជាតិអ៊ីស្រាអែល។
ពួកគេនឹងរក្សាផ្លូវរបស់ព្រះអម្ចាស់ ហើយដើរក្នុងផ្លូវមាគ៌ានោះ
វិធីដែលព្រះអម្ចាស់ចង់ឲ្យប្រជាជនរស់នៅ ឬប្រព្រឹត្តគឺនិយាយធៀបទៅនឹងផ្លូវ ឬមាគ៌ា។ មនុស្សដែលស្តាប់បង្គាប់ព្រះអម្ចាស់
គឺនិយាយសំដៅលើអ្នកដែលដើរតាមផ្លូវរបស់ព្រះអង្គ។
ព្រះអង្គមិនប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់លោកយ៉ូស្វេ
«ព្រះអង្គមិនអនុញ្ញាតឲ្យលោកយ៉ូស្វេយកឈ្នះលើពួកគេ»។
មិនអនុញ្ញាតឲ្យលោកយ៉ូស្វេ
«យ៉ូស្វេ» នៅទីនេះ តំណាងឲ្យទាហានរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនអនុញ្ញាតឲ្យលោកយ៉ូស្វេ
និងទាហានរបស់លោកយ៉ូស្វេ»។

3

[1]ព្រះអម្ចាស់បានទុកជាតិសាសន៍នានាដើម្បីល្បងលអ៊ីស្រាអែលទាំងប៉ុន្មានដែលមិនបានចូលរួមធ្វើសង្គ្រាមវាយដណ្តើមទឹកដីពីជនជាតិកាណាន។
[2]ព្រះអង្គបានបង្រៀនការធ្វើសង្គ្រាមនេះដល់ជនជាតិអ៊ីស្រាអែលជំនាន់ក្រោយដែលមិនបានស្គាល់វាពីមុន។[3]ប្រជាជាតិទាំងនោះមានដូចជា៖ ជនជាតិភីលីស្ទីនទាំងប្រាំនគរ
ជនជាតិកាណានទាំងអស់ ជនជាតិស៊ីដូន និងជនជាតិហេវី ដែលរស់នៅតាមតំបន់ភ្នំលីបង់ ចាប់តាំងពីភ្នំបាល ហ៊ើរម៉ូន រហូតដល់ហាម៉ាត់។
[4]ព្រះអម្ចាស់ទុកជាតិសាសន៍ទាំងនោះដើម្បីល្បងលមើលឲ្យដឹងថា
តើជនជាតិអ៊ីស្រាអែលគោរពតាមបទបញ្ជាដែលព្រះអង្គបានប្រទានមកបុព្វបុរសរបស់ពួកគេតាមរយៈលោកម៉ូសេដែរឬទេ។[5]ដូច្នេះ
ជនជាតិអ៊ីស្រាអែលរស់នៅក្នុងចំណោមជនជាតិកាណាន ជនជាតិហេត ជនជាតិអាម៉ូរី ជនជាតិពេរីស៊ីត និងជនជាតិយេប៊ូស។
[6]ពួកគេយកកូនស្រីជាតិសាសន៍ទាំងនោះធ្វើជាប្រពន្ធ និងលើកកូនស្រីរបស់ខ្លួនអោយរៀបការជាមួយកូនប្រុសជនជាតិទាំងនោះ
ហើយពួកគេនាំគ្នាគោរពថ្វាយបង្គំព្រះរបស់ជនជាតិទាំងនោះទៀតផង។
[7]ជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តអំពើអាក្រក់ដែលមិនគាប់ព្រះហឫទ័យព្រះអម្ចាស់ ពួកគេបានបំភ្លេចព្រះអង្គ ហើយបែរទៅថ្វាយបង្គំព្រះ បាល និង អាសថារ៉ូតវិញ។
[8]ព្រះអម្ចាស់ទ្រង់ព្រះពិរោធនឹងជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង ព្រះអង្គបានប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃ របស់ព្រះបាទ គូសាន-រីសាថែម ជាស្តេចស្រុកអើរ៉ាម-ណាហារេម។ ជនជាតិអ៊ីស្រាអែលបានបម្រើស្តេចគូសាន-រីសាថែម អស់រយៈពេលប្រាំបីឆ្នាំ។
[9]ពេលដែលជនជាតិអ៊ីស្រាអែលស្រែកអង្វររកព្រះអម្ចាស់ ព្រះអង្គបានធ្វើឲ្យមានអ្នកសង្គ្រោះម្នាក់ក្រោកឡើងសង្គ្រោះជនជាតិអ៊ីស្រាអែល គឺលោកអូធ្នាល
ជាកូនរបស់លោកកេណាស ដែលត្រូវជាប្អូនរបស់លោកកាលែប។[10]ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានសណ្ឋិតលើលោកអូធ្នាល
លោកក៏បានធ្វើជាមេដឹកនាំរបស់អ៊ីស្រាអែល លោកអូធ្នាលបានចេញទៅច្បាំង ហើយព្រះអម្ចាស់បានប្រទានឲ្យលោកមានជ័យជម្នះលើព្រះបាទគូសាន-រីសាថែម។
[11]ទឹកដីរបស់គេមានសេចក្តីសុខសាន្តអស់រយៈពេលសែសិបឆ្នាំ។ ក្រោយមក លោកអូធ្នាល ជាកូនរបស់លោកកេណាស បានទទួលមរណភាពទៅ។
[12]ក្រោយមក ជនជាតិអ៊ីស្រាអែលបានត្រឡប់មកប្រព្រឹត្តការណ៍អាក្រក់ដែលមិនសព្វព្រះទ័យព្រះអម្ចាស់ ហេតុនេះ ព្រះអង្គបានពង្រឹងអំណាចព្រះបាទអេក្លូន
ស្តេចរបស់ជនជាតិម៉ូអាប់ ឲ្យប្រឆាំងនឹងជនជាតិអ៊ីស្រាអែល។[13]ព្រះបាទអេក្លូនបាន រួមដៃគ្នាជាមួយជនជាតិអាំម៉ូន និងជនជាតិអាម៉ាឡេក
ទៅច្បាំងនឹងជនជាតិអ៊ីស្រាអែល ហើយពួកគេដណ្តើមបានទីក្រុងដើមលម៉ើរ។[14]ជនជាតិអ៊ីស្រាអែលបម្រើព្រះបាទអេក្លូន ជាស្តេចស្រុកម៉ូអាប់អស់រយៈពេលដប់ប្រាំបីឆ្នាំ។
[15]ជនជាតិអ៊ីស្រាអែល បានស្រែកអង្វររកព្រះអម្ចាស់ ព្រះអង្គបានធ្វើឲ្យមានអ្នកសង្គ្រោះម្នាក់ក្រោកឡើងសង្គ្រោះពួកគេ។ លោកអេហ៊ូដ ជាកូនរបស់លោកកេរ៉ា
ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន លោកអេហ៊ូដ ប្រើតែដៃឆ្វេងប៉ុណ្ណោះ។ ពេលនោះជនជាតិអ៊ីស្រាអែលបានចាត់លោក ឲ្យនាំយកសួយសារអាករទៅថ្វាយព្រះបាទអេក្លូន
ជាស្តេចស្រុកម៉ូអាប់។
[16]លោកអេហ៊ូដបានធ្វើអាវុធដែលមានមុខពីរ និងប្រវែងប្រហែលមួយហត្ថសម្រាប់ខ្លួនរបស់លោក ហើយចងឱបនឹងភ្លៅស្តាំ លាក់ក្រោមសម្លៀកបំពាក់របស់លោក។
[17]លោកបាន ថ្វាយសួយសារអាករ ទៅព្រះបាទអេក្លូន ជាស្តេចស្រុកម៉ូអាប់។[18]ព្រះបាទអេក្លូនគឺធាត់ខ្លាំងណាស់។ បន្ទាប់ពីលោកអេហ៊ូដបានថ្វាយសួយសារអាករហើយ
លោកក៏ត្រឡប់ទៅវិញជាមួយអ្នកដែលបានកាន់សួយសារអាករមក។
[19]ពេលដែលលោកអេហ៊ូដបានមកដល់ត្រង់រូបបដិមាករ ដែលនៅជិត គីលកាល លោកបានត្រឡប់ក្រោយ ហើយទូលស្តេចថា៖ «បពិត ព្រះករុណា
ទូលបង្គំមានកិច្ចការសម្ងាត់មួយទូលថ្វាយព្រះអង្គ» ព្រះបាទអេក្លូនមានព្រះបន្ទូលថា៖ «ចូលស្ងាត់!» ដូច្នេះ
ព្រះអង្គបានបញ្ជាឲ្យអ្នកបម្រើរបស់ព្រះអង្គទាំងអស់ចាកចេញពីព្រះដំណាក់។[20]លោក អេហ៊ូដបានចូលទៅរកស្តេច។
ពេលនោះព្រះបាទអេក្លូនគង់នៅក្នុងបន្ទប់ត្រជាក់ខាងលើ ជាកន្លែងលំហែកាយរបស់ស្តេចផ្ទាល់។ លោកអេហ៊ូដទូលស្តេចថា៖ «ទូលបង្គំមានព្រះបន្ទូលមកពីព្រះអម្ចាស់
សម្រាប់ទូលថ្វាយព្រះករុណា»។ ស្តេចក៏ក្រោកចេញពីកៅអី។
[21]លោកអេហ៊ូដបានលូកដៃឆ្វេងទៅដកកាំបិតដែលចងផ្អើបនៅភ្លៅស្តាំ រួចចាក់ទៅក្នុងខ្លួនរបស់ស្តេច។[22]ដងកាំបិតបានកប់បាត់ទៅក្នុង
ហើយខ្លាញ់ពោះក៏បិតជិតកាំបិតនោះ លោកអេហ៊ូដ មិនបានដកយកកាំបិតចេញមកវិញទេ។[23]បន្ទាប់មក
លោកអេហ៊ូដបានចេញទៅរានហាលហើយបិទទ្វារទាំងអស់នៃបន្ទប់ខាងលើពីក្រោយលោក និងចាក់សោរទ្វារផង។
[24]បន្ទាប់ពីលោកអេហ៊ូដចាកចេញទៅ អ្នកបម្រើរបស់ស្តេចបានចូលមក ពួកគេឃើញទ្វារបន្ទប់ខាងលើត្រូវបានចាក់សោរ ដូច្នេះ ពួកគេគិតថា៖
«ព្រះអង្គប្រាកដជាកំពុងដោះទុក្ខរបស់ទ្រង់ នៅក្នុងបន្ទប់ត្រជាក់ខាងលើ»។[25]ពួកគេនាំគ្នារង់ចាំ រហូតទាល់តែមានអារម្មណ៍បារម្ភ
ព្រោះតែស្តេចនៅតែមិនព្រមបើកទ្វារទៅកាន់បន្ទប់ខាងលើ។ ដូច្នេះ ពួកគេបានយកកូនសោរទៅបើកទ្វារបន្ទប់ ហើយឃើញម្ចាស់របស់គេសុគតនៅលើកម្រាលឥដ្ឋ។
[26]អំឡុងពេលដែលពួកអ្នកបម្រើកំពុងរង់ចាំ តើពួកគេធ្វើអ្វី! លោកអេហ៊ូដបានភៀសខ្លួន ហើយរត់ហួសរូបបដិមាករ ហើយទៅដល់តំបន់សៃរ៉ា។
[27]ពេលដែលលោកទៅដល់តំបន់ភ្នំអេប្រាអ៊ីម លោកបានផ្លុំត្រែ។ បន្ទាប់មក លោកបានដឹកនាំប្រជាជនអ៊ីស្រាអែល ហើយនាំពួកគេចុះពីភ្នំទៅជាមួយគាត់។
[28]លោកបានមានប្រសាសន៍ទៅកាន់ពួកគេថា ៖ «ចូរមកតាមខ្ញុំ ដ្បិត ព្រះអម្ចាស់បានប្រគល់ជនជាតិម៉ូអាប់ ជាសត្រូវរបស់អ្នករាល់គ្នា
មកក្នុងកណ្តាប់ដៃរបស់អ្នករាល់គ្នាហើយ»។ ពួកគេបានតាមលោក ហើយវាយយកកន្លែងទឹករាក់សម្រាប់ឆ្លងនៃទន្លេយ័រដានពីជនជាតិម៉ូអាប់
ពួកគេមិនអនុញ្ញាតឲ្យជនជាតិម៉ូអាប់ឆ្លងទន្លេទេ។[29]នៅគ្រានោះពួកគេបានសម្លាប់ជនជាតិម៉ូអាប់អស់ប្រហែលមួយម៉ឺននាក់ ដែលសុទ្ធតែជាមនុស្សខ្លាំងពូកែ និងក្លាហាន
ដោយមិនលើកលែងឲ្យអ្នកណាម្នាក់ឡើយ។[30]ហើយស្រុកទេសបានសុខសាន្តអស់រយៈពេលប៉ែតសិបឆ្នាំ។
[31]ចៅហ្វាយបន្ទាប់ពីលោកអេហ៊ូដ គឺលោកសាំកើរ ជាកូនលោកអណាត ដែលបានសម្លាប់ជនជាតិភីលីស្ទីនអស់ប្រាំមួយរយនាក់ ដោយប្រើជន្លួញគោ។

Judges 3:1
ឥឡូវនេះ ព្រះអម្ចាស់
ពាក្យ «ឥឡូវនេះ» នៅទីនេះ គឺជាការចាប់ផ្តើមវគ្គថ្មីនៃសាច់រឿង។
ជាតិសាសន៍នានា
នេះសំដៅលើក្រុមមនុស្សដែលអ្នកនិពន្ធរៀបរាប់នៅក្នុងជំពូក ៣:៣
ដែលមិនបានចូលរួមធ្វើសង្គ្រាមវាយដណ្តើមទឹកដីពីជនជាតិកាណាន
នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលមិនធ្លាប់តយុទ្ធនៅក្នុងសង្គ្រាមណាមួយនៅក្នុងស្រុកកាណានឡើយ»។
ព្រះអង្គបានធ្វើការនេះ
ដើម្បីបង្រៀនពីការធ្វើសង្គ្រាមនេះដល់ជនជាតិអ៊ីស្រាអែលជំនាន់ក្រោយដែលមិនបានស្គាល់វាពីមុន
រឿងនេះដាច់ចេញដោយឡែកពីដំណើររឿង។ អ្នកនិពន្ធបានផ្តល់ព័ត៌មានពីប្រវត្តិ
ហេតុអ្វីបានជាព្រះអម្ចាស់ទុកមនុស្សខ្លះឲ្យនៅសល់ក្នុងទឹកដីកាណាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានទុកប្រជាជាតិនានាឲ្យនៅក្នុងចំណោមជនជាតិអ៊ីស្រាអែល

generated on Wed Sep 10 16:16:32 2025

ដើម្បីបង្រៀនយុវជន ដែលមិនធ្លាប់ធ្វើសង្គ្រាមជាមុន ពីរបៀបនៃការធ្វើសង្គ្រាម។
ប្រាំនគរ
ស្តេចទាំងប្រាំនេះ តំណាងឲ្យប្រជាជនរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្តេចទាំងប្រាំ និងប្រជារាស្ត្ររបស់ពួកគេ»។
ភ្នំបាល ហ៊ើរម៉ូន
នេះគឺជាភ្នំដែលខ្ពស់ជាងគេបំផុតនៅក្នុងអ៊ីស្រាអែល។
ហាម៉ាត់
នេះគឺជាតំបន់នភភាគខាងជើងនៃព្រំប្រទល់នៃទឹកដីកាណាន។
Judges 3:4
ជាតិសាសន៍ទាំងនេះត្រូវបានទុកឲ្យនៅសល់
នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានទុកប្រជាជាតិទាំងនេះនៅក្នុងទឹកដីកាណាន» ឬ
«ព្រះអម្ចាស់បានអនុញ្ញាតឲ្យប្រជាជាតិទាំងនេះបន្តរស់នៅក្នុងទឹកដីកាណាន»។
ដើម្បីល្បងលមើល
«ជាមធ្យោបាយ»
ថាតើពួកគេ...ប្រទានមកបុព្វបុរសរបស់ពួកគេ
ពាក្យថា: «ពួកគេ» និង «របស់ពួកគេ» សំដៅលើជនជាតិអ៊ីស្រាអែល។
បទបញ្ជាដែលព្រះអង្គបានប្រទាន
«បទបញ្ជាដែលព្រះអម្ចាស់បានប្រទាន»។
Judges 3:7
តើអំពើអាក្រក់ដែលមិនគាប់ព្រះហឫទ័យព្រះអម្ចាស់?
ពាក្យ «នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់» តំណាងឲ្យអ្វីដែលជាព្រះតម្រិះ
និងព្រះហឫទ័យរបស់ព្រះអង្គលើអ្វីមួយ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ជំពូក ២:១១។
បានបំភ្លេចព្រះអម្ចាស់ជាព្រះជាម្ចាស់របស់ពួកគេ
ពាក្យ «បំភ្លេច» នៅទីនេះ គឺជាពាក្យប្រៀបធៀបដែលមានន័យថា
«ពួកគេឈប់ស្តាប់បង្គាប់»។
ព្រះពិរោធរបស់ព្រះអម្ចាស់ជាបានឆួលឡើងជាខ្លាំង
ព្រះអម្ចាស់មានព្រះពិរោធយ៉ាងខ្លាំង
និយាយពីសេចក្តីក្រោធរបស់ព្រះអង្គលើអ្វីមួយដែលល្មមសមនឹងដុតនឹងភ្លើង។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់មានសេចក្តីក្រោធជាខ្លាំង»។
បានប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ព្រះបាទ គូសាន-រីសាថែម ជាស្តេចស្រុកអើរ៉ាម-ណាហារែម
ពាក្យ «កណ្តាប់ដៃ» នៅទីនេះ គឺជាន័យប្រៀបធបៀបដែលតំណាងឲ្យអំណាច
ឬការគ្រប់គ្រង។ ហើយ «ព្រះបាទ គូសាន-រីសាថែម»
គឺជាកើតឡើងនៅពេលតែមួយជាមួយទាហានរបស់ទ្រង់។
ព្រះបាទ គូសាន-រីសាថែម
នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។
អើរ៉ាម-ណាហារែម
នេះគឺជាឈ្មោះរបស់ប្រទេសមួយ។
Judges 3:9
ព្រះអម្ចាស់បានធ្វើឲ្យមានអ្នកសង្គ្រោះម្នាក់ក្រោកឡើង
ព្រះអម្ចាស់បានរើសតាំងនរណាឲ្យធ្វើការអ្វីមួយពិសេសសម្រាប់ព្រះអង្គ
បើនិយាយទៅគឺព្រះអម្ចាស់បានជ្រើសរើស និងតាំងនរណាឡើង។
លោកអូថ្នាល...លោកកេណាស
សូមបកប្រែឈ្មោះនេះ ឲ្យដូចនៅក្នុងជំពូក ១:១១។
សណ្ឋិតលើលោក
ឃ្លានេះមានន័យថា ព្រះអម្ចាស់បានជួយលោកអូថ្នាលឲ្យមាន
និងអភិវឌ្ឍគុណភាពដែលគាត់ត្រូវមាន ដើម្បីធ្វើជាអ្នកដឹកនាំដ៏អម្ចាស់។
ទឹកដីរបស់គេមានសេចក្តីសុខសាន្ត
«ទឹកដី» ត្រូវបានប្រើ សំដៅលើមនុស្សដែលរស់នៅក្នុងទឹកដី។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សរស់នៅដោយសុខសាន្ត»។
លោកជាចៅហ្វាយរបស់អ៊ីស្រាអែល
ពាក្យ «ចៅហ្វាយ» នៅទីនេះ មានន័យថា គាត់ដឹកនាំជនជាតិអ៊ីស្រាអែល។
លោកបានចេញទៅច្បាំង
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកអូថ្នាល
ដែលតំណាងឲ្យទាហានរបស់អ៊ីស្រាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកអូថ្នាល
និងទាហានរបស់អ៊ីស្រាអែលបានចេញទៅច្បាំងទាស់នឹងទាហានរបស់ព្រះបាទ
គូសាន-រីសាថែម»។
ព្រះអម្ចាស់បានប្រទានឲ្យលោកមានជ័យជម្នះលើព្រះបាទគូសាន-រីសាថែម
ស្តេចរបស់ជនជាតិអារ៉ាម។
«ព្រះបាទគូសាន-រីសាថែម» នៅទីនេះ តំណាងឲ្យទាហានរបស់ទ្រង់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់ជួយទាហានរបស់អ៊ីស្រាអែលយកឈ្នះលើទាហានរបស់ព្រះបាទគូសាន-
រីសាថែម ស្តេចរបស់ជនជាតិអារ៉ាម។
កណ្តាប់ដៃរបស់លោកអូថ្នាល
ពាក្យ «កណ្តាប់ដៃ» នៅទីនេះ គឺជាពាក្យប្រៀបធៀបទៅនឹងទាហាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ទាហានរបស់លោកអូថ្នាល»។
ទឹកដីរបស់គេមានសេចក្តីសុខសាន្ត
«ទឹកដី» ត្រូវបានប្រើ សំដៅលើមនុស្សដែលរស់នៅក្នុងទឹកដី។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សរស់នៅដោយសុខសាន្ត»។
រយៈពេលសែសិបឆ្នាំ
«៤០ឆ្នាំ»
Judges 3:12
បានធ្វើអ្វីដែលអាក្រក់ក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់
ពាក្យ «ព្រះនេត្ររបស់ព្រះជាម្ចាស់»
តំណាងឲ្យអ្វីដែលជាព្រះឫទ័យរបស់ព្រះអម្ចាស់ ឬព្រះតម្រិះអំពីមួយ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២:១១។
ព្រះជាម្ចាស់បានប្រទានកម្លាំងដល់ព្រះបាទអេក្លូន ស្តេចរបស់ជនជាតិម៉ូអាប់
ពាក្យ «កម្លាំង» ជានាមអរូប អាចនិយាយជាគុណនាមក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់បានធ្វើឲ្យ ព្រះបាទអេក្លូន
ស្តេចរបស់ជនជាតិម៉ូអាប់រឹងមាំ» ។
ដល់ព្រះបាទអេក្លូន ស្តេចរបស់ជនជាតិម៉ូអាប់ ឲ្យមានអំណាចលើជនជាតិអ៊ីស្រាអែល
ពាក្យ «ដល់ព្រះបាទអេក្លូន ស្តេចរបស់ជនជាតិម៉ូអាប់»
តំណាងឲ្យទាហានរបស់ទ្រង់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដល់ព្រះបាទអេក្លូន ស្តេចរបស់ជនជាតិម៉ូអាប់ និងទាហានរបស់ទ្រង់
នៅពេលពួកគេវាយលុកទាហានអ៊ីស្រអែល»។
ព្រះបាទអេក្លូន
នេះគឺជាឈ្មោះរបស់ស្តេចមួយអង្គ។
ទីក្រុងដើមលម៉ើរ
នេះគឺជាឈ្មោះមួយទៀតរបស់ទីក្រុងយេរេខូ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ១:១៦។
អស់រយៈពេលដប់ប្រាំបីឆ្នាំ
«១៨ ឆ្នាំ»
Judges 3:15
បានស្រែកអំពាវនាវរកព្រះជាម្ចាស់
ឃ្លានេះមានន័យថាស្រែក ឬនិយាយឮៗទៅកាន់នរណាម្នាក់ដែលនៅឆ្ងាយ។
អាចមានន័យថាសូមនរណាម្នាក់ឲ្យជួយ។ ជាពិសេសព្រះជាម្ចាស់។
បានលើកមនុស្សម្នាក់
ព្រះអម្ចាស់បានជ្រើសរើសមនុស្សម្នាក់ដើម្បីធ្វើការងារពិសេសមួយសម្រាប់ព្រះអង្គ
និយាយដូចជាព្រះអង្គលើក ឬ លើកនរណាម្នាក់ឡើង។
លោកអេហ៊ូដ...លោកកេរ៉ា
នេះគឺជាឈ្មោះរបស់មនុស្សពីរនាក់។
ដៃឆ្វេង
ឆ្វេង - លោកអេហ៊ូដ ពូកែប្រើដាវរបស់គាត់ជាមួយដៃឆ្វេង។
Judges 3:16
មួយហត្ថ
ប្រសិនបើ វាចាំបាច់ប្រើរង្វាស់សម័យទំនើប នៅទីនេះ
មានរបៀបពីយ៉ាងក្នុងការវាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «៤៦សង់ទីម៉ែត្រ»
ឬ «ប្រហែលជាកន្លះម៉ែត្រ»
គាត់បានចងឱបវានឹងភ្លៅស្តាំ លាក់ក្រោមសម្លៀកបំពាក់របស់លោក
«លោកចងវានឹងភ្លៅស្តាំនៅក្នុងសម្លៀកបំពាក់»។
ភ្លៅ
«ជើងខាងលើ»
ឥឡូវ ព្រះបាទអេក្លូន ជាមនុស្សធាត់យ៉ាងខ្លាំង។
ពាក្យ «ឥឡូវនេះ» ប្រើនៅទីនេះ ដើម្បីសម្គាល់ពីការសម្រាកពីសាច់រឿងចម្បង។
នៅទីនេះ អ្នកអត្ថាធិប្បាយ ប្រាប់ព័ត៌មានពីសាវតារបស់ព្រះបាទអេក្លូន។

generated on Wed Sep 10 16:16:32 2025

Judges 3:19
នៅពេលដែលគាត់បានមកដល់កន្លែងដែលរូបចម្លាក់ត្រូវបានបង្កើត នៅជិត គីលកាល
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលលោកបានមកដល់កន្លែងមួយជិតគីលកាល
ជាកន្លែងដែលមនុស្សធ្វើរូបចម្លាក់ផ្សេងៗ»។
នៅក្នុងបន្ទប់ត្រជាក់ខាងលើ
នេះគឺជាបន្ទប់មួយដែលនៅកន្លែងទាបជាង ដែលប្រើដើម្បីសម្រាក
និងនៅត្រជាក់ទោះបីជាថ្ងៃក្តៅក្តី។
ស្តេចបានក្រោកឡើងចេញពីកៅអីរបស់ទ្រង់
ក្រោកឡើង គឺជាសញ្ញានៃការគោរពកោតខ្លាចព្រះជាម្ចាស់
គឺស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ។
Judges 3:21
ចុងនៃដាវបានចេញមកក្រៅពីខ្លួង
«ចង់ដាវយ៉ាងមុតបានធ្លុះទៅដល់ខ្នងរបស់ស្តេច»។
រនហាល
នៅខាងក្រៅបន្ទប់ មានជញ្ជាំងទាប និងដំបូលគ្របពីលើ។
Judges 3:24
ព្រះអង្គប្រាកដជាកំពុងដោះទុក្ខរបស់ទ្រង់
នេះគឺជាសុភាពក្នុងការនិយាយអំពីនរណាម្នាក់ដែលកំពុងបត់ជើងធំ
រហូតទាល់តែមានអារម្មណ៍ថា ពួកគេបានកំពុងមានការឆ្វេងប្រហែស ភារកិច្ចរបស់ពួកគេ
ពួកគេបានរង់ចាំ រហូតដល់ពួកគេបារម្ភថា មានអ្វីខុសពីធម្មតា
ហើយគឺជាភារកិច្ចរបស់ពួកគេក្នុងការបើកទ្វារ
ចូរទៅទីឯកជនរបស់ស្តេចរបស់ពួកគេ។
បានយកកូនសោរ ហើយបានបើកទ្វារ
«បានយកកូនសោរ ហើយបានបើកទ្វារ»។
Judges 3:26
អំឡុងពេលដែលពួកអ្នកបម្រើកំពុងរង់ចាំ... លោកអេហ៊ូដបានភៀសខ្លួន
ឃ្លានេះប្រាប់ពីអ្វីដែលបានកើតឡើងមុនពេលអ្នកបម្រើបើកទ្វារ
ហើយឃើញថាស្តេចសុគត។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលនោះ
ពេលអ្នកបម្រើកំពុងរង់ចាំនៅខាងក្រៅបន្ទប់ខាងលើ...លោកអេហ៊ូដបានគេចខ្លួន»។
តំបន់សៃរ៉ា
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
នៅពេលដែលគាត់បានទៅដល់
ឃ្លានេះនិយាយកាន់តែច្បាស់ថែមទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលលោកមកដល់តំបន់សៃរ៉ា»។
Judges 3:28
ប្រយោគភ្ជាប់
លោកអេហ៊ូដមានប្រសាសន៍ទៅប្រជាជនអ៊ីស្រាអែលនៅអេប្រាអិម។
ដ្បិត ព្រះជាម្ចាស់រៀបនឹងរាយយកឈ្នះជនជាតិម៉ូអាប់ ជាសត្រូវរបស់អ្នករាល់គ្នា
ព្រះអម្ចាស់ជួយជនជាតិអ៊ីស្រាអែលឲ្យយកឈ្នះខ្មាំងសត្រូវរបស់ពួកគេ
បើនិយាយទៅព្រះអម្ចាស់គឺជាអ្នកចំបាំង ដែលតយុទ្ធ
ហើយយកឈ្នះខ្មាំងសត្រូវរបស់ពួកគេ។
វាយយកកន្លែងទឹករាក់
«គ្រប់គ្រងបានកន្លែងទឹករាក់»។
ទឹករាក់
ជាតំបន់របស់ទន្លេដែលមានកន្លែងទឹករាក់ ហើយងាយដើរឆ្លើទៅកន្លែងម្ខាងទៀត។
មិនអនុញ្ញាតឲ្យអ្នកណាម្នាក់ឆ្លងទន្លេទេ
«មិនអនុញ្ញាតឲ្យអ្នកណាម្នាក់ឆ្លងទន្លេឡើយ»។
មួយម៉ឺននាក់
«១០,០០០នាក់»
សុទ្ធតែជាមនុស្សខ្លាំងពូកែ
«មានសមត្ថភាព» ឬ «មនុស្សដែលខ្លាំងពូកែ»។
ម៉ូអាប់បានបង្ក្រាបដោយកម្លាំងរបស់អ៊ីស្រាអែល
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទាហានរបស់ជនជាតិអ៊ីស្រាអែលបានយកឈ្នះជនជាតិម៉ូអាប់»។
ដោយកម្លាំងរបស់អ៊ីស្រាអែល
ពាក្យ «កម្លាំង» នៅទីនេះ តំណាងឲ្យទាហានរបស់ជនជាតិអ៊ីស្រាអែល»។
ស្រុកទេសបានសុខសាន្ត
ពាក្យ «ទឹកដី» តំណាងឲ្យប្រជាជន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជនជាតិអ៊ីស្រាអែលរស់នៅប្រកបដោយសេចក្តីសុខសាន្ត»។
អស់រយៈពេលប៉ែតសិបឆ្នាំ
«៨០ ឆ្នាំ»
Judges 3:31
ចៅហ្វាយ
ព្រះជាម្ចាស់បានរើសតាំងចៅហ្វាយដើម្បីនាំជនជាតិអ៊ីស្រាអែលនៅសម័យដែលមានបញ្ហា
បន្ទាប់ពីពួកគេបានចូលទៅក្នុងទឹកដីសន្យា និងមុនពេលពួកគេមានស្តេច។
ជាញឹកញាប់ចៅហ្វាយតែងតែសង្គ្រោះជនជាតិអ៊ីស្រាអែលពីខ្មាំងត្រូវ។
លោកសាំកើរ
ជាឈ្មោះរបស់មនុស្សម្នាក់។
លោកអណាត
ជាឈ្មោះរបស់មនុស្សម្នាក់។
ចាក់
«ធ្វើចលនា» ឬ «ផ្ទាល់» ។
គាត់ក៏បានរំដោះអ៊ីស្រាអែលពីភាពអន្តរាយ
ពាក្យ «អន្តរាយ»
សំដៅលើខ្មាំងសត្រូវដែលព្យាយាមធ្វើទុក្ខដល់ប្រជាជនអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកក៏បានរំដោះជនជាតិអ៊ីស្រាអែលពីខ្មាំងសត្រូវរបស់ពួកគេ» ។

---

4 [1]បន្ទាប់ពី លោកអេហ៊ូដទទួលមរណភាពទៅ ប្រជាជនអ៊ីស្រាអែលបានត្រឡប់ទៅប្រព្រឹត្តការអាក្រក់ទាស់នឹងព្រះហឫទ័យព្រះអម្ចាស់ជាថ្មី។
[2]ព្រះអម្ចាស់បានប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ព្រះបាទយ៉ាប៊ីន ជាស្តេចស្រុកកាណាន ដែលសោយរាជ្យនៅក្រុង ហាសោរ។ មេទ័ពរបស់ទ្រង់គឺលោកស៊ីសេរ៉ា
ដែលរស់នៅហារ៉ូសេត-កូយីម។[3]ជនជាតិអ៊ីស្រាអែលបានស្រែកអង្វររកព្រះអម្ចាស់ឲ្យសង្គ្រោះពួកគេ ព្រោះស៊ីសេរ៉ា មានរទេះចម្បាំងប្រាំបួនរយ
ហើយសង្កត់សង្កិនជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំងអស់រយៈពេលម្ភៃឆ្នាំ។
[4]នៅជំនាន់នោះ លោកស្រីដេបូរ៉ា ជាព្យាការិនី ជាភរិយារបស់លោកឡាពីដូត បានដឹកនាំជនជាតិអ៊ីស្រាអែល។[5]លោកស្រីដេបូរ៉ាតែងតែអង្គុយក្រោមដើមលម៉ើ
ដែលគេហៅថាដើមលម៉ើលោកស្រីដេបូរ៉ា ដែលស្ថិតនៅចន្លោះភូមិរ៉ាម៉ា និងបេតអែល នៅតំបន់ភ្នំអេប្រាអ៊ីម ហើយជនជាតិអ៊ីស្រាអែលតែងតែឡើងមករកលោកស្រី
ដើម្បីជំនុំជម្រះក្តីរបស់ពួកគេ។
[6]លោកស្រីបានកោះហៅ លោកបារ៉ាក់ ជាកូនរបស់លោកអប៊ីណោម ដែលរស់នៅភូមិកេដេស ក្នុងតំបន់ណែបថាលី លោកស្រីមានប្រសាសន៍ថា៖ «ព្រះអម្ចាស់
ជាព្រះនៃជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលមកលោកដូចតទៅ៖ «ចូរចេញទៅភ្នំតាបោរ ហើយនាំយកមនុស្សប្រុសចំនួនមួយម៉ឺននាក់ពីកុលសម្ព័ន្ធណែបថាលី
និងកុលសម្ព័ន្ធសាប់យូឡូនទៅជាមួយ។[7]យើងនឹងទាក់ទាញស៊ីសេរ៉ា មេទ័ពរបស់ស្តេចយ៉ាប៊ីន ជាមួយនឹងរទេះចម្បាំងព្រមទាំងកងទ័ពរបស់គេ
អោយមកច្បាំងជាមួយនឹងអ្នកនៅត្រង់ជ្រោះគីសូន យើងនឹងប្រគល់គេមកក្នុងកណ្តាប់ដៃរបស់អ្នក»។
[8]លោកបារ៉ាក់តបទៅកាន់លោកស្រីថា៖ «ប្រសិនបើ លោកស្រីធ្វើដំណើរទៅជាមួយខ្ញុំ ខ្ញុំនឹងទៅ តែបើលោកស្រីមិនទៅជាមួយទេ ខ្ញុំក៏មិនទៅដែរ»។
[9]លោកស្រីក៏មានប្រសាសន៍ថា៖ «ខ្ញុំប្រាកដជាទៅជាមួយលោក តែអ្វីដែលលោកធ្វើនឹងមិនបានកិត្តិយសមកលោកទេ
ព្រោះព្រះអម្ចាស់នឹងប្រគល់សេសារ៉ាទៅក្នុងកណ្តាប់ដៃរបស់មនុស្សស្រី»។ បន្ទាប់មកលោកស្រីដេបូរ៉ាបានក្រោកឡើង
ហើយធ្វើដំណើរទៅភូមិកេដេសជាមួយលោកបារ៉ាក់។
[10]លោកបារ៉ាក់បានកោះហៅកុលសម្ព័ន្ធសាយូឡូន និងណែបថាលីឲ្យមកជួបជុំគ្នានៅកេដេស។ មនុស្សមួយម៉ឺននាក់បានតាមលោក ហើយលោកស្រី ដេបូរ៉ា
ក៏ធ្វើដំណើរជាមួយលោកដែរ។
[11]ឥឡូវនេះ លោកហេប៊ែរ ជាជនជាតិកែន បានបែកចេញពីជនជាតិកែនដទៃទៀត ដែលពួកគេជាពូជពង្សរបស់លោកហូបាប ជាបងថ្លៃរបស់លោកម៉ូសេ
ហើយគាត់បានបោះជំរំរបស់គាត់នៅក្បែរដើមជ្រៃស្មាណានីម ជិតភូមិកេដេស។

generated on Wed Sep 10 16:16:32 2025

[12]ពេលដែលពួកគេប្រាប់លោកស៊ីសេរ៉ាថា លោកបារ៉ាក់ កូនរបស់អប៊ីណោម បានឡើងពីភ្នំតាបោរ[13]លោកស៊ីសេរ៉ា
បានប្រមូលរទេះដែកទាំងប្រាំបួនរយគ្រឿងហើយនិងទាហានទាំងអស់ដែលនៅជាមួយលោកពី ហារ៉ូសែតកូយីម ហើយឆ្ពោះទៅកាន់ទន្លេគីសូន។
[14]លោកស្រីដេបូរ៉ាមានប្រសាសន៍ទៅកាន់លោកបារ៉ាក់ថា៖ «ចូរចេញទៅ! នេះគឺជាថ្ងៃដែលព្រះអម្ចាស់ប្រទានឲ្យអ្នកមានជ័យជម្នះលើស៊ីសេរ៉ា។
តើព្រះអម្ចាស់មិននាំមុខលោកទេឬ?» ដូច្នេះ លោកបារ៉ាក់បានចុះពីភ្នំតាបោរជាមួយនឹងមនុស្សដែលតាមលោកមួយម៉ឺននាក់។
[15]ព្រះអម្ចាស់បានធ្វើឲ្យលោកស៊ីសេរ៉ា ទាំងរទេះចម្បាំង និងទាហានទាំងអស់បាក់ទ័ព មនុស្សរបស់លោកបារ៉ាក់បានចាប់ពួកគេ
ហើយស៊ីសេរ៉ាបានលោតចុះពីរទេះចម្បាំងរបស់គាត់ ហើយរត់ដោយជើងទទេ[16]លោកបារ៉ាក់បានដេញតាមរទេះចម្បាំង និងទាហានរហូតដល់ហារ៉ូសេតកូយីម
ហើយទាហានទាំងអស់របស់លោកស៊ីសេរ៉ា ត្រូវបានសម្លាប់ដោយមុខដាវ គ្មានសល់អ្នកណាម្នាក់ឡើយ។
[17]លោកស៊ីសេរ៉ា បានរត់ទៅត្រសាលរបស់នាងយ៉ូអែល ហើយភរិយារបស់លោកហេប៊ើរ ជាសាសន៍កែន ដោយព្រះបាទយ៉ាប៊ីន ជាស្តេចក្រុងហាសោរ
និងក្រុមគ្រួសារលោកហេបើរជនជាតិកែនមានទំនាក់ទំនងមេត្រីភាពជាមួយគ្នា។[18]នាងយ៉ូអែលបានចេញមកជួបជាមួយលោកស៊ីសេរ៉ា
ហើយមានប្រសាសន៍ទៅកាន់គាត់ថា៖ «សូមលោកម្ចាស់អញ្ជើញចូលមកចុះ សូមកុំមានការភ័យខ្លាចអ្វីឡើយ!» ដូច្នេះ លោកបានចូលទៅក្នុងត្រសាលរបស់នាង
ហើយនាងបានលាក់លោកនៅក្នុងភួយ។
[19]លោកនិយាយទៅនាងថា៖ «ខ្ញុំស្រេកទឹកណាស់ សូមឲ្យទឹកបន្តិចមកខ្ញុំផឹក! «នាងក៏បើកធ្នុកថង់ស្បែកហើយឲ្យទឹកទៅលោកផឹក បន្ទាប់មក
នាងយកភួយគ្របលោកវិញ។[20]លោកបាននិយាយទៅនាងថា៖ «សូមរង់ចាំនៅមាត់ទ្វារត្រសាល! ហើយប្រសិនបើមានអ្នកណាមកសួរថា
«តើមានអ្នកណាមកទីនេះដែរឬទេ? ចូរឆ្លើយថា៖ «គ្មានទេ!»។
[21]បន្ទាប់មក នាងយ៉ូអែល ភរិយាលោក ហេបើរបានកាន់ចម្រឹងដែក និងញញួរយ៉ាងសម្ងាត់ទៅរកលោកស៊ីសេរ៉ា នៅពេលដែលលោកដេកលង់លក់
នាងបានបោះចម្រឹងដែលត្រង់សៀតផ្ការបស់លោកធ្លុះទៅជាប់នឹងដី ហើយលោកក៏ស្លាប់ទៅ។[22]ពេលនោះ លោកបារ៉ាក់បានតាមរកលោកស៊ីសេរ៉ាទាន់នៅទីនោះ
នាងយ៉ូអែលបានចេញទៅជួបលោក ហើយពោល៖ «សូមចូលមក ខ្ញុំនឹងបង្ហាញលោកនូវមនុស្ស ដែលលោកតាមរក»។ ដូច្នេះ លោកបានចូលទៅក្នុងត្រសាលជាមួយនាង
ហើយលោកក៏បានឃើញលោកស៊ីសេរ៉ា ស្លាប់នៅទីនោះ ដោយមានចម្រឹងដែកជាប់នឹងសៀតផ្ការបស់លោក។
[23]នៅថ្ងៃនោះព្រះអម្ចាស់បានបំបាក់មុខព្រះបាទយ៉ាប៊ីន ជាស្តេចស្រុកកាណា ចំពោះមុខជនជាតិអ៊ីស្រាអែល។
[24]អំណាចរបស់ជនជាតិអ៊ីស្រាអែលកាន់តែខ្លាំងឡើងៗលើព្រះបាទយ៉ាប៊ីន ស្តេចស្រុកកាណាន រហូតពួកគេអាចសម្លាប់ស្តេចបាន។

Judges 4:1
លោកអេហ៊ូដ
ចូរបលបកប្រែពាក្យនេះឲ្យដូចពាក្យដែលអ្នកបានបកប្រែនៅក្នុងជំពូក ៣:១៥។
ប្រព្រឹត្តការអាក្រក់នៅក្នុងព្រះនេត្រព្រះជាម្ចាស់
ពាក្យ «នៅក្នុងព្រះនេត្រព្រះជាម្ចាស់» តំណាងឲ្យអ្វីដែលព្រះអម្ចាស់រិះគិត
ឬព្រះតម្រិះរបស់ព្រះអង្គអំពីអ្វីមួយ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២:១១។
ព្រះជាម្ចាស់បានលក់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ព្រះបាទយ៉ាប៊ីន ស្តេចរបស់កាណាន
ពាក្យ «ដៃ» សំដៅលើអំណាចរបស់ព្រះបាទយ៉ាប៊ីនមកលើជនជាតិអ៊ីស្រាអែល។
ព្រះអម្ចាស់បានសម្រេចព្រះទ័យប្រទានអំណាចដល់ព្រះបាទយ៉ាប៊ីនឲ្យមានអំណាចលើពួកគេ
ប្រៀបដូចជាព្រះអង្គលក់ពួកគេឲ្យទៅព្រះបាទយ៉ាប៊ីន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់អនុញ្ញាតឲ្យពួកគេបរាជ័យនៅក្រោមអំណាចរបស់ព្រះបាទយ៉ាប៊ីន
ស្តេចរបស់ស្រុកកាណាន»។
ព្រះបាទយ៉ាប៊ីន...លោកស៊ីសេរ៉ា
នេះគឺជាឈ្មោះរបស់មនុស្ស។
ក្រុងហាសោរ...ស្រុកហារ៉ូសេត
នេះគឺឈ្មោះរបស់ទីក្រុង និងទីកន្លែងផ្សេងៗ។
មានរទេះចម្បាំងប្រាំបួនរយ
«៩០០រទេះដែកចម្បាំង»
អស់រយៈពេលម្ភៃឆ្នាំ
«២០ឆ្នាំ»
Judges 4:4
ឥឡូវ
ពាក្យនេះប្រើនៅទីនេះ ដើម្បីបញ្ជាក់ពីការសម្រាកនៅក្នុងសាច់រឿងចម្បង។
នៅទីនេះ អ្នកអត្ថាធិប្បាយប្រាប់ពីព័ត៌មានសារតាអំពីអ្នកស្រីដេបូរ៉ា។
អ្នកស្រីដេបូរ៉ា
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
លោកឡាពីដូត
នេះគឺជាឈ្មោះរបស់បុរសម្នាក់។
ចៅហ្វាយ
ព្រះជាម្ចាស់បានរើសតាំងធ្វើជាចៅហ្វាយដើម្បីដឹកនាំជនជាតិអ៊ីស្រាអែលចេញពីបញ្ហា។
ជាញឹកញាប់ពួកចៅហ្វាយសង្គ្រោះពួកគេពីខ្មាំងសត្រូវរបស់ពួកគេ។
ដើមលម៉ើរបស់លោកស្រីដេបូរ៉ា
នេះគឺជាដើមឈើដែលដាក់ឈ្មោះតាមអ្នកស្រីដេបូរ៉ា។
Judges 4:6
ព័ត៌មានទូទៅ
អ្នកនិពន្ធរបស់ចៅហ្វាយសំដៅលើបុរស ទីក្រុង ភ្នំ និងទន្លេ
តាមឈ្មោះរបស់ពួកគេ។
លោកបារ៉ាក់...លោកអប៊ីណោម
នេះគឺជាឈ្មោះរបស់មនុស្ស។
ភ្នំតាបោរ
នេះគឺជាឈ្មោះរបស់ភ្នំ។
មនុស្សប្រុសចំនួនមួយម៉ឺននាក់
«បុរស ១០,០០០នាក់»
យើងនឹងទាក់ទាញស៊ីសេរ៉ាចេញមក
ពាក្យ «យើង» នៅទីនេះ សំដៅលើព្រះជាម្ចាស់»។
ទាក់ទាញស៊ីសេរ៉ាចេញមក
ពាក្យ «ស៊ីសេរ៉ា» តំណាងឲ្យទាហាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទាក់ទាញចេញពីស៊ីសេរ៉ា និងពីទាហានរបស់លោក»។
ទាក់ទាញចេញ
ធ្វើឲ្យមនុស្សចេញពីកន្លែងដែលមានសុវត្ថិភាព។
ស៊ីសេរ៉ា...យ៉ាប៊ីន
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១។
គីហុន
នេះគឺជាឈ្មោះរបស់ទន្លេ។
Judges 4:8
ព័ត៌មានទូទៅ
លោកបារ៉ាក់ពិភាក្សាជាមួយនាងដេបូរ៉ា។
លោកបារ៉ាក់
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៦។
ផ្លូវដែលដែលអ្នកកំពុងទៅ នឹងមិនកិត្តិយសមកអ្នកទេ
ជម្រើសរបស់លោកបារ៉ាក់គឺបៀបដូចជាផ្លូវដែលពួកគេដើរ។ ហើយពាក្យ
«កិត្តិយស» ប្រៀបដូចជាជោគវាសនា ដែលមនុស្សម្នាក់ធ្វើដំណើរ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាឲ្យកិត្តិយសដល់អ្នក
ដោយព្រោះអ្នកធ្វើដូច្នេះ»។
ដ្បិត ព្រះអម្ចាស់នឹងលក់ស៊ីសេរ៉ាទៅក្នុងកណ្តាប់ដៃរបស់មនុស្សស្រី
ពាក្យ «ដៃ» នៅទីនេះ សំដៅលើអំណាចរបស់នាងក្នុងការសម្លាប់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត
ព្រះអម្ចាស់នឹងធ្វើឲ្យមនុស្សយកឈ្នះស៊ីសេរ៉ា»។
ស៊ីសេរ៉ា
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១។
ដេបូរ៉ា
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៤។

generated on Wed Sep 10 16:16:32 2025

Judges 4:10
មនុស្សមួយម៉ឺននាក់
«បុរស ១០,០០០នាក់»
Judges 4:11
ឥឡូវនេះ
ពាក្យនេះ ប្រើដើម្បីបញ្ជាក់ពីការសម្រាកពីសាច់រឿងចម្បង។ នៅទីនេះ
អ្នកអត្ថាធិប្បាយប្រាប់ព័ត៌មានពី លោកហេប័រ ជនជាតិកែន។
លោកហេប័រ...លោកហូបាប
នេះគឺជាឈ្មោះរបស់មនុស្សប្រុស។
ជនជាតិកែន
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ១:១៦។
ឪពុកក្មេករបស់លោកម៉ូសេ
សាច់ថ្លៃ - «ជាឪពុកប្រពន្ធរបស់លោកម៉ូសេ»។
អាណានីម
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
Judges 4:12
ពេលដែលពួកគេប្រាប់លោកស៊ីសេរ៉ា
ពាក្យ «ពួកគេ» នៅទីនេះ មិនបញ្ជាក់ថានរណាពិតប្រាកដទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលមានអ្នកប្រាប់ដល់លោកស៊ីសេរ៉ា» ។
ស៊ីសេរ៉ា
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១។
លោកបារ៉ាក់...លោកអប៊ីណោម...ភ្នំតាបោរ
សូមបកប្រែពាក្យទាំងនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៦។
លោកស៊ីសេរ៉ា បានប្រមូលរទេះដែកទាំងអស់
ពាក្យ «រទេះដែក» តំណាងឲ្យពួកទាហានដែលបររទេះដែកនោះ។
ចំនួនប្រាំបួនរយគ្រឿង
«៩០០រទេះដែក»
ហារ៉ូសែត
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១។
ទន្លេគីសូន
សូមបកប្រែពាក្យទាំងនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៦។
Judges 4:14
ព្រះអម្ចាស់បានប្រទានឲ្យអ្នកមានជ័យជម្នះ
ដោយសារអ្នកស្រីដេបូរ៉ាទើបមានជ័យជម្នះ នាងនិយាយ
ដូចដែលលោកបារ៉ាក់បានឈ្នះសមរភូមិរួចទៅហើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់នឹងប្រទានជ័យជម្នះដល់លោក»។
តើព្រះជាម្ចាស់មិននាំមុខអ្នកទេឬ?
អ្នកស្រីដេបូរ៉ាសួរសំណួរមួយដើម្បីរំលឹកលោកបារ៉ាក់ថា
ពួកគេប្រយុទ្ធនៅខាងព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ចូរចាំថា
ព្រះអម្ចាស់នឹងនាំមុខលោក» ។
មនុស្សមួយម៉ឺននាក់
«ជាមួយទាហាន ១០,០០០នាក់»
Judges 4:15
ព្រះអម្ចាស់បានធ្វើឲ្យទាហានរបស់លោកស៊ីសេរ៉ាច្របូកច្របល់
«ព្រះអម្ចាស់បានធ្វើឲ្យទាហានរបស់លោកស៊ីសេរ៉ារង្វេងស្មារតី» ឬ
«ព្រះអម្ចាស់បានធ្វើឲ្យទាហានរបស់លោកស៊ីសេរ៉ាបាក់ទ័ព»។
រទេះចម្បាំងទាំងអស់
ពាក្យ «រទេះចម្បាំង» នៅទីនេះ តំណាងឲ្យ ពួកទាហានដែលបររទេះ»។
លោកបារ៉ាក់បានដេញតាម
ពាក្យ «បារ៉ាក់» នៅទីនេះ តំណាងឲ្យទាហានរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកបារ៉ាក់
និងពួកទាហានរបស់លោកបានដេញតាម»។
ហារ៉ូសេត
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១។
ទាហានទាំងអស់របស់លោកស៊ីសេរ៉ា ត្រូវបានសម្លាប់ដោយមុខដាវ
ពាក្យ «ដាវ» តំណាងឲ្យដាវ និងអាវុធដែលពួកទាហានប្រើនៅក្នុងសមរភូមិ។
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកបារ៉ាក
និងទាហានរបស់លោកបានសម្លាប់ពួកទាហានរបស់លោកស៊ីសេរ៉ាទាំងអស់ដោយដាវរបស់ពួកគេ»។
Judges 4:17
លោកស៊ីសេរ៉ា...ព្រះបាទយ៉ាប៊ីន... លោកហេប័រ
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១។
បានរត់ដោយជើង
នេះគឺជាពាក្យប្រៀបធៀបដែលមានន័យថា ដើរជាជាងជិះសេះ ឬជិះរទេះចម្បាំង។
នាងយ៉ូអែល
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
លោកហេប័រ
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១១។
ជនជាតិកែន
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១៦។
ផ្ទះរបស់លោកហេប៊ើរជនជាតិកែន
ពាក្យ «ផ្ទះ» តំណាងឲ្យគ្រួសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រួសាររបស់លោកហេប៊ើរ ជនជាតិកែន»។
បែរមក
ពាក្យនេះ មានន័យថាប្តូរទិសដៅ អំឡុងពេលធ្វើដំណើរ ដើម្បីបានសម្រាក។
របៀបផ្សេងទៀតនៃការបកប្រែ: «មកទីនេះ»។
ភួយ
ជាក្រណាត់មួយយ៉ាងធំដើម្បីដណ្តប់រូបកាយពេលគេង ដើម្បីឲ្យកក់ក្តៅ
ធ្វើពីរោមសត្វ ឬស្បែកសត្វ។
Judges 4:19
លោកនិយាយទៅនាង
«លោកស៊ីសេរ៉ានិយាយនាងយ៉ូអែល»។
Judges 4:21
ចម្រឹងជំរំ
យកឈើ ឬដែកមកដាក់ជាមួយគ្នា ដូចជាដែកគោលមួយយ៉ាងធំ
ដែលបានដំចុះចូលទៅតាមជ្រុងនៃជំរំ។
ញញួរ
ជាវត្ថុដ៏ធំមួយធ្វើពីឈើដើម្បីវាយចម្រឹងរបស់ជំរំចូលទៅក្នុងដី។
លង់លក់ក្នុងដំណេក
ប្រៀបដូចជាបុរសម្នាក់ដែលនៅក្នុងរណ្តៅមួយដ៏ជ្រៅ មិនអាចចេញបាន។
មនុស្សដែលគេងលង់លក់ក៏ពិបាកក្នុងការក្រោកឡើងដូច្នោះដែរ។
បានទម្លុះ
«ធ្វើឲ្យមានរន្ធ»
លោកបារ៉ាក់បានដេញតាម
«លោកបារ៉ាកដេញតាម» ឬ លោកបារ៉ាកដេញតាមក្រោយ»។
Judges 4:23
ព្រះជាម្ចាស់បានបំបាក់ព្រះបាទយ៉ាប៊ីន ជាស្តេចស្រុកកាណា នៅចំពោះមុខប្រជាជនអ៊ីស្រាអែល
ព្រះជាម្ចាស់បានធ្វើឲ្យជនជាតិអ៊ីស្រាអែលមានជ័យជម្នះលើព្រះបាទយ៉ាប៊ីន
ដូចដែលជនជាតិបានឃើញ។
អំណាច
«អំណាចរបស់យោធា»
ពួកគេអាចសម្លាប់ស្តេចបាន
ពាក្យ «ស្តេច» នៅទីនេះ សំដៅលើព្រះបាទយ៉ាប៊ីន និងទាហានរបស់ស្តេច»។

---

5 [1]នៅថ្ងៃនោះលោកស្រីដេប៉ូរ៉ា និងលោកបារ៉ាក់ជាកូនលោកអប៊ីណោម បានសរសើរតម្កើងព្រះជាម្ចាស់ថា៖[2]«ពេលដែលអ្នកដឹកនាំ ដឹកនាំក្នុងស្រុកអ៊ីស្រាអែល
ពេលដែលប្រជាជនស្ម័គ្រចិត្តធ្វើសង្គ្រាម យើងសសើរតម្កើងព្រះអម្ចាស់!
[3]ស្តេចទាំងឡាយចូរស្តាប់! អ្នកដឹកនាំទាំងឡាយចូរយកចិត្តទុកដាក់! យើងនឹងច្រៀងសសើរតម្កើងព្រះអម្ចាស់! យើងនឹងច្រៀងសសើរតម្កើងព្រះអម្ចាស់!
ជាព្រះនៃប្រជាជនអ៊ីស្រាអែល។[4]ព្រះអម្ចាស់អើយ! ពេលដែលព្រះអង្គយាងចាកចេញពីស្រុកសៀរ! ពេលដែលព្រះអង្គយាងមកពីស្រុកអេដុម នោះផែនដីបានញាប់ញ័រ
ផ្ទៃមេឃប្រែទៅជាខ្មៅងងឹត ហើយពពកក៏បង្អុលភ្លៀងធ្លាក់មក។
[5]ភ្នំទាំងឡាយញ័ររញ្ជួយនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ហើយភ្នំស៊ីណៃក៏ញ័ររញ្ជួយនៅចំពោះទ្រង់ ជាព្រះនៃជនជាតិអ៊ីស្រាអែល![6]កាលនោះលោកសាំកើរ
ជាកូនលោកអណាត នៅជំនាន់នាងយ៉ាអែល មិនមានអ្នកណាដើរតាមផ្លូវត្រង់ទេ គឺពួកគេដើរតាមផ្លូវវាង។

generated on Wed Sep 10 16:16:32 2025

[7]មានតែអ្នកចម្បាំងមួយចំនួនតូចតែប៉ុណ្ណោះនៅក្នុងស្រុកអ៊ីស្រាអែល រហូតដល់ខ្ញុំ ដេបូរ៉ា ធ្វើជាម្តាយ បញ្ជាដល់អ៊ីស្រាអែល![8]នៅពេលដែលប្រជាជនជ្រើសរើសព្រះថ្មីៗ
នោះមានសង្គ្រាមកើតឡើងនៅមាត់ទ្វារក្រុង ហើយក្នុងចំណោមជនជាតិអ៊ីស្រាអែលបួនម៉ឺននាក់ ពួកគេមិនអាចរកបានសូម្បីតែខែល ឬរ៉ែពងមួយក៏គ្មានផង។
[9]ខ្ញុំពេញចិត្តនឹងមេទ័ពទាំងឡាយក្នុងអ៊ីស្រាអែល ហើយក្នុងចំណោមមនុស្សទាំងឡាយខ្ញុំពេញចិត្តនឹងអ្នកដែលស្ម័គ្រចិត្តណាស់ យើងសូមសរសើរតម្កើងព្រះអម្ចាស់!
[10]អស់អ្នកដែលជិះលើលាសម្បុរស និងអស់អ្នកដែលអង្គុយលើកម្រាលព្រំអើយ ចូរពិចារណាមើលចុះ!
[11]ស្តាប់សូរសម្លេងនៃអ្នកដងទឹកដែលច្រៀងនៅក្បែរអណ្តូងទឹក។ ពួកគេរៀបរាប់អំពីព្រះហឫទ័យសុចរិតរបស់ព្រះអម្ចាស់
គឺព្រះអង្គប្រទានឲ្យជនជាតិអ៊ីស្រាអែលមានជ័យជម្នះ។ ពេលនោះ ប្រជាជនរបស់ព្រះអង្គបានចុះទៅទ្វារក្រុង។
[12]ចូរភ្ញាក់ឡើង! ចូរភ្ញាក់ឡើង! ដេបូរ៉ាអើយ ចូរភ្ញាក់ឡើង! ចូរភ្ញាក់ឡើង! ច្រៀងចម្រៀងមួយបទ! ក្រោកឡើង លោកបារ៉ាក់ កូនរបស់លោកអប៊ីណោម
នាំប្រជាជនដែលជាប់ជាឈ្លើយមកវិញ។[13]អស់អ្នកដែលរួចពីស្លាប់បានចុះមករកពួកអភិជនរបស់ខ្លួន ប្រជាជនរបស់ព្រះអម្ចាស់ក៏នាំគ្នាមកជាមួយវីរជនឯទៀតៗ។
[14]ពួកគេមកពីកុលសម្ព័ន្ធអេប្រាអ៊ីម ដែលនៅជាប់នឹងស្រុកអាម៉ាឡេក ហើយមនុស្សមកពីកុលសម្ព័ន្ធបេនយ៉ាមីនក៏មកតាមដែល។ មានមេទ័ពមកពីអំបូរម៉ាគៀរ
ហើយនាយទាហានមកពីកុលសម្ព័ន្ធសាប់យ៉ូឡូម។
[15]ពួកប្រមុខនៃកុលសម្ព័ន្ធអ៊ីសាខា បានទៅជាមួយដេបូរ៉ា ហើយអ៊ីសាខាក៏ទៅជាមួយបារ៉ាក់ដែរ ពួកគេរត់ពីក្រោយលោករហូតដល់ជ្រលងភ្នំ។
ក្នុងចំណោមកុលសម្ព័ន្ធរ៉ូបេនវិញ គេគិតតែពីជជែកវែកញែកមិនឈប់ឈរ។
[16]ហេតុអ្វីបានជាអ្នកនៅអង្គុយក្បែរភ្នក់ភ្លើង ស្តាប់ពួកគង្វាលលេងប៉ីរបស់ពួកគេអោយហ្វូងចៀមស្តាប់ដូច្នេះ? មែនហើយក្នុងចំណោមកុលសម្ព័ន្ធរ៉ូបេន
គឺគេគិតតែពីជជែកគ្នាឥតឈប់ឈរ។
[17]ឯកាឡាត គេនៅតែខាងនាយទន្លេយ័រដាន ហើយកុលសម្ព័ន្ធដាន់ ហេតុអ្វីបានជាសំងំតែនៅលើកនាវា? ឯអាស៊ើរ
ក៏នៅសំងំតាមឆ្នេរសមុទ្រហើយរស់នៅជិតកំពង់ផែរបស់ពួកគេ។[18]មានតែសាប់យ៉ូឡូនប៉ុណ្ណោះ ដែលប្រថុយជីវិតដល់ស្លាប់
ហើយណែបថាលីក៏បានចូលរួមក្នុងចម្បាំងនេះដែរ។
[19]ពួកស្តេចបានមក គឺពួកស្តេចរបស់ស្រុកកាណានច្បាំងនៅតាណាក ក្បែរប្រភពទឹកមេគីដោ។ ប៉ុន្តែ ពួកគេមិនបានយកជ័យភ័ណ្ឌដ៏មានតម្លៃអ្វីឡើយ។[20]សូម្បីតែ
ហ្វូងផ្កាយក៏ច្បាំងពីលើមេឃ តាមគោចរ ប្រឆាំងនឹងស៊ីសេរ៉ាដែរ។
[21]ទន្លេគីសុនបានហូរនាំគេទៅ គឺទន្លេគីសុននេះហើយជាទន្លេចាស់ពីបុរាណ។ ឱ ព្រលឹងខ្ញុំអើយ ចូររឹងមាំឡើង![22]គ្រានោះបានឮសន្ធឹកជើងសេះកំពុងតែរត់
គឺពួកខ្លាំងពូកែដែលផាយយ៉ាងលឿន។
[23]នោះទេវតានៃព្រះអម្ចាស់មានប្រសាសន៍ថា៖ «ចូរដាក់បណ្តាសារពួក មេរ៉ូស! ប្រាកដណាស់ ចូរដាក់បណ្តាសាអ្នកស្រុក ដ្បិត
ពួកគេមិនបានមកជួយដល់កិច្ចការរបស់ព្រះអម្ចាស់ គឺជួយដល់ការរបស់ទ្រង់ច្បាំងនឹងពួកខ្លាំងពូកែទេ»។
[24]នាងយ៉ូអែល ជាស្ត្រីដែលមានពរ លើសទាំងស្ត្រីនានា នាងយ៉ូអែល ភរិយាលោកហេបើរ ជាសាសន៍កែន
នាងគឺជាស្ត្រីដែលមានពរលើសទាំងស្ត្រីនានាដែលរស់នៅក្នុងត្រសាល។[25]មនុស្សបានសុំទឹកពីនាង តែនាងបានផ្តល់ទឹកដោះឲ្យគេ
នាងបាននាំយកខ្លាញ់នៃទឹកដោះដែលជាអាហារ សម្រាប់ពួករាជ្យបុត្រទៅឲ្យគាត់។
[26]ប៉ុន្តែ នាងបានចាប់ចម្រឹងតង់ ហើយដៃស្តាំរបស់នាងគឺកាន់ញញួររបស់ពួកជាង នាងបានវាយស៊ីសេរ៉ា ហើយនាងបានទម្លុះក្បាលរបស់គាត់ គឺនាងវាយទម្លុះក្បាលលោក
គឺនាងទម្លុះត្រង់សៀតផ្តា។[27]គាត់ឱនចុះនៅចន្លោះជើងរបស់នាង គាត់ដួល ហើយក៏ដេកនៅទីនោះ។ គឺនៅចន្លោះជើងរបស់នាងដែលគាត់បានដួលចុះ
គាត់បានស្លាប់នៅកន្លែងដែលគាត់បានដួលចុះនោះ។
[28]នៅខាងក្រៅម្តាយរបស់ស៊ីសេរ៉ាបានសម្លឹងមើលទៅបង្អួច នាងសម្លឹងមើលតាមចម្រឹងបង្អួច ហើយនាងសួរទៅយ៉ាងក្រៀមក្រំថា៖ «ហេតុអ្វីបានជាកូនក្រមកម្លេ?
ហេតុអ្វីកង់រទេះរបស់កូនយឺតមកដល់ម្លេះ?»
[29]ពួកស្ត្រីអ្នកប្រាជ្ញរបស់គាត់ឆ្លើយឡើង ហើយក៏ឆ្លើយទៅកាន់ខ្លួននាងថា ៖[30]«តើពួកគេរកមិនបានជ័យភ័ណ្ឌ ហើយពួកគេមិនបានចែកគ្នាទេឬ? គឺស្ត្រីក្រមុំម្នាក់
ឬស្ត្រីក្រមុំពីរនាក់ សម្រាប់ពួកគេ ហើយសម្រាប់ស៊ីសេរ៉ាគឺជ័យភ័ណ្ឌ ជាអាវដែលជ្រលក់ពណ៌ទេឬអី? គឺអាវប៉ាក់មានពណ៌ពីជ័យភ័ណ្ឌ
ជាអាវប៉ាក់ទាំងសងខាងដែលសាកសមនឹងអ្នកដែលចាប់យកជ័យភ័ណ្ឌនោះទេឬអី?
[31]ឱព្រះអម្ចាស់អើយ! សូមឲ្យអស់ទាំងខ្មាំងសត្រូវរបស់ទ្រង់វិនាសទៅ តែសូមឲ្យអស់អ្នកដែលស្រឡាញ់ទ្រង់បានភ្លឺដូចថ្ងៃ ក្នុងកាលដែលរះឡើងពេញកំដៅ»។ បន្ទាប់មក
ស្រុកទេសបានសាន្តត្រាណអស់រយៈពេលសែសិបឆ្នាំ។

Judges 5:1
នៅថ្ងៃនោះ
អត្ថន័យពេញនៅក្នុងប្រយោគនេះ អាចធ្វើឲ្យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ថ្ងៃមួយជនជាតិអ៊ីស្រាអែលបានយកឈ្នះលើទាហានរបស់ស្តេចយ៉ាប៊ីន»។
លោកស្រីដេបូរ៉ា
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៤។
លោកបារ៉ាក់...លោកអប៊ីណោម
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៦។
ពេលដែលប្រជាជនស្ម័គ្រចិត្តសម្រាប់ធ្វើសង្គ្រាម
«ពេលដែលពួកប្រុសយល់ព្រមចេញទៅធ្វើសង្គ្រាម» ។
Judges 5:3
ព័ត៌មានទូទៅ
ចម្រៀងរបស់លោកស្រីដេបូរ៉ា និងលោកបារ៉ាក់បន្តប្រើជាកំណាព្យ។
ចូរស្តាប់ ស្តេចទាំងឡាយ! ចូរយកចិត្តទុកដាក់ អ្នកដឹកនាំទាំងឡាយ!
លោកស្រីដេបូរ៉ា និងលោកបារ៉ាក់និយាយទៅកាន់ស្តេច និងអ្នកដឹកនាំ
ប្រៀបដូចជាពួកគេស្តាប់ចម្រៀង។
ស្តេចទាំងឡាយ...អ្នកដឹកនាំទាំងឡាយ
ការទាំងនេះ សំដៅលើស្តេច និងអ្នកដឹកនាំទូទៅ មិនសំដៅលើស្តេច
ឬអ្នកដឹកនាំណាមួយជាក់លាក់ឡើយ។
ពេលដែលព្រះអង្គបានយាងចេញពីស្រុកសៀរ ពេលដែលព្រះអង្គបានដាក់ព្រំប្រទល់ពីស្រុកអេដុម
ឃ្លានេះ សំដៅលើពេលវេលាពេលជនជាតិអ៊ីស្រាអែលចាកចេញពីស្រុកអេដុម
ដើម្បីចាប់ផ្តើមយកឈ្នះប្រជាជនកាណាន។
ព្រះអម្ចាស់ប្រទានអំណាចដល់ប្រជារាស្ត្ររបស់ព្រះអង្គ
ឲ្យយកឈ្នះលើមនុស្សនៅក្នុងស្រុកកាណាន
ប្រៀបដូចព្រះអង្គជាអ្នកចម្បាំងដែលនាំមុខទាហានអ៊ីស្រាអែល។
ស្រុកសៀរ
ស្រុកសៀរ ជាភ្នំមួយដែលមានព្រំប្រទល់ជាប់អ៊ីស្រាអែល និងស្រុកអេដុម។
ផែនដីបានញាប់ញ័រ ផ្ទៃមេឃបានញ័ររញ្ជួយ ពពកក៏បង្កលទឹកចុះមក
អាចមានន័យពីរ ទី១) អ្នកគឺជាភាសាកំណាព្យ ដែលបញ្ជាក់ថា
អំណាចរបស់ព្រះអម្ចាស់បានប្រាប់ថា វាបានធ្វើឲ្យផែនដីរញ្ជួយ និងព្យុះផង។ ឬ
ទី២) មនុស្សនៅស្រុកកាណានមានការភ័យខ្លាចជាខ្លាំង
ដែលជនជាតិអ៊ីស្រាអែលវាយលុកពួកគេ វាប្រៀបដូចជាផែនដី
ឬផ្ទៃមេឃរញ្ជួយដូច្នោះដែរ។
Judges 5:5
ព័ត៌មានទូទៅ
ចម្រៀងរបស់លោកស្រីដេបូរ៉ា និងលោកបារ៉ាក់បន្តប្រើជាកំណាព្យ។
ភ្នំទាំងឡាយបានកក្រើក
ប្រហែលជាសំដៅលើផែនដីរញ្ជួយ ហើយបានបញ្ជាក់ថា
ភ្នំទាំងឡាយរញ្ជួយដោយសារពួកគេខ្លាចព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ភ្នំទាំងឡាយញាប់ញ័រ»។
នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់

generated on Wed Sep 10 16:16:32 2025

ពាក្យ «ព្រះភ័ក្ត្រ» សំដៅលើព្រះវត្តមានរបស់ព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់»។
ដូចគ្នានឹងភ្នំស៊ីណៃដែលបានកក្រើក
ពេលលោកម៉ូសេ និងជនជាតិអ៊ីស្រាអែលនៅភ្នំស៊ីណាយ។ វារញ្ជួយ។
របៀបផ្សេងទៀតនៃការបកប្រែ៖ «យូរមកហើយ
សូម្បីតែភ្នំស៊ីណាយក៏រញ្ជួយដែរ»។
ក្នុងថ្ងៃនោះ
ពាក្យ «ថ្ងៃ» នៅទីនេះ តំណាងឲ្យពេលវេលាដ៏យូរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅក្នុងសម័យរបស់»។
លោកសាំគើរ...លោកអណាត...នាងយ៉ាអែល
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះ
លោកសាំគើរ លោកអណាតនៅក្នុងជំពូក ៣:៣១ និងនាងយ៉ាអែល ៤:១៧។
កូនលោកអណាត
ឪពុករបស់លោកសាំគើរនិយាយនៅត្រង់នេះ ដើម្បីបញ្ជាក់ថាលោកសាំគើរ
ពេលគាត់នៅរស់។
ផ្លូវសំខាន់ៗ ត្រូវបានបោះបង់
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម
ហើយអ្នកអាចបញ្ជាក់ពីហេតុដែលគេបោះបង់ផ្លូវធំចោល។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សឈប់ប្រើផ្លូវធំ
ដោយសារពួកគេខ្លាចទាហានរបស់ជនជាតិអ៊ីស្រាអែល។
ផ្លូវបត់បែន
សំដៅលើផ្លូវតូចជាង ដែលមានតែមនុស្សពីរបីនាក់ប៉ុណ្ណោះដែរ។
Judges 5:7
ម្តាយម្នាក់ដែលកាន់បញ្ជាក្នុងអ៊ីស្រាអែល!
ឃ្លានេះនិយាយពីភាពជាអ្នកដឹកនាំរបស់ជនជាតិអ៊ីស្រអែល
ប្រៀបដូចជាម្តាយរបស់ជនជាតិអ៊ីស្រាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំយកចិត្តទុកដាក់ជាមួយអ៊ីស្រាអែល ដូចជាម្តាយដែលមើលថែកូនរបស់នាង»។
នៅពេលដែលពួកគេបានជ្រើសរើសព្រះថ្មីៗ
អត្ថន័យពេញនៅក្នុងប្រយោគនេះបញ្ជាក់ពីអត្ថន័យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជានអ៊ីស្រាអែលបានថ្វាយបង្គំព្រះក្លែងក្លាយជាច្រើន»។
មានសង្គ្រាមកើតឡើងនៅមាត់ទ្វារក្រុង
ពាក្យ «ទ្វារ» នៅទីនេះ តំណាងឲ្យទីក្រុងទាំងមូល។
អត្ថន័យពេញនៅក្នុងប្រយោគនេះបញ្ជាក់ពីអត្ថន័យកាន់តែច្បាស់។
របៀផ្សេងទៀតនៃការបកប្រែ:
«ខ្មាំងសត្រូវបានវាយប្រហារមនុស្សនៅក្នុងទីក្រុងអ៊ីស្រាអែលទាំងមូល។
សូម្បីតែខែល ឬរ៉ែពែងមួយក៏គ្មានផងក្នុងចំណោមប្រជាជនអ៊ីស្រាអែលបួនម៉ឺននាក់
ប្រយោគនេះប្រហែលជានិយាយបំផ្លើសអំពីជនជាតិអ៊ីស្រាអែលមានអាវុធតិច។
របៀបផ្សេងទៀតនៃការបកប្រែ: «អាវុធនៅសល់តិច
តែសង្គ្រោះនៅតែមាននៅអ៊ីស្រាអែល»។
ប្រជាជនអ៊ីស្រាអែលបួនម៉ឺននាក់
«៤០,០០០នៅក្នុងអ៊ីស្រាអែល»
Judges 5:9
បេះដូងរបស់ខ្ញុំបានចេញទៅឯមេទ័ពទាំងឡាយនៃអ៊ីស្រាអែល
ពាក្យ «ដួងចិត្ត» តំណាងឲ្យមនោសញ្ចេតនារបស់មនុស្សម្នាក់។ ឃ្លា
«ដួងចិត្តរបស់ខ្ញុំបានចេញទៅ»
គឺជារបៀបនៃការដែលលោកស្រីដេបូរ៉ាថ្លែងពីការដឹងគុណ និងកោតសរសើរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំកោតសរសើរចំពោះមេទ័ពរបស់អ៊ីស្រាអែលណាស់»។ ។
អ្នកដែលជិះលើលាសម្បុរស...អ្នកដែលកំពុងដើរអើយ
ពាក្យផ្ទួយគ្នានេះ ប្រហែលជាសំដៅលើ អ្នកមាន
និងអ្នកក្រដែលជិះលាសរ...ហើយអ្នកក្រគឺជាអ្នកដែលដើរនៅលើផ្លូវ។
កំពុងអង្គុយលើកម្រាលព្រំ
ព្រំទាំងនេះ ប្រហែលជាប្រើដើម្បីក្រាលនៅលើខ្នងលា ដើម្បីធ្វើឲ្យអង្គុយស្រួល។
Judges 5:11
ប្រយោគភ្ជាប់
ចម្រៀងរបស់លោកស្រីដេបូរ៉ា និងលោកបារ៉ាក់នៅតែបន្ត។
ស្តាប់សូរសម្លេងនៃអស់អ្នកដែល
ពាក្យ «សម្លេង» នៅទីនេះ តំណាងឲ្យការច្រៀងរបស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្តាប់អស់អ្នកដែល»។
បានចុះទៅទ្វារក្រុង
ពាក្យ «ទ្វារ» តំណាងឲ្យទីក្រុងទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
បានបែរទៅរកទីក្រុងរបស់ពួកគេ»។
Judges 5:12
ប្រយោគភ្ជាប់
ចម្រៀងរបស់លោកស្រីដេបូរ៉ា
និងលោកបារ៉ាក់នៅតែបន្តច្រៀងដោយប្រើកំណាព្យ។
ចូរភ្ញាក់ឡើង! ចូរភ្ញាក់ឡើង!
អាចមានន័យបី។ ទី១) ប្រជាជនអ៊ីស្រាអែល។ ទី២)
លោកស្រីដេបូរ៉ានិយាយពីខ្លួនរបស់នាងផ្ទាល់។ ទី៣)
ជាកំណាព្យដែលសរសេរជាចម្រៀង។
លោកស្រីដេបូរ៉ា
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៤។
លោកបារ៉ាក់...លោកអប៊ីណោម
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៦។
មកឯខ្ញុំជាមួយអ្នកចម្បាំង
ពាក្យ «ខ្ញុំ» សំដៅលើលោកស្រីដេបូរ៉ា។
Judges 5:14
ពីអេប្រាអ៊ីម គឺអស់អ្នកដែលមានឫសនៅក្នុងអាម៉ាឡេក
ប្រជាជនអេប្រាអ៊ីមរស់នៅក្នុងទឹកដីដែលបុព្វបុរសរបស់អាម៉ាឡេក។
ជាអ្នករស់នៅទីនោះតាំងពីដើម បើនិយាយទៅ កុលសម្ព័ន្ធ
អេប្រាអ៊ីមទើបតែមករស់នៅក្នុងទឹកដីនេះ។ របៀបផ្សេងទៀតនៃការបកប្រែ: «
ពីកុលសម្ព័ន្ធអេប្រាអ៊ីម
ទឹកដីនោះជាទឹកដីរបស់បុព្វបុរសរបស់អាម៉ាឡេកធ្លាប់រស់នៅ»។
បានតាមអ្នក
ពាក្យ «អ្នក» សំដៅលើកុលសម្ព័ន្ធអេប្រាអ៊ីម។ អាចនិយាយជាបុរសទីបី។
របៀបផ្សេងទៀតនៃការបកប្រែ: «បានដើរតាមពួកគេ»។
ម៉ាកៀរ
នេះគឺជាទីកន្លែងដែលដូនតារបស់ម៉ាកៀរ រស់នៅ។
ម៉ាកៀរជាកូនរបស់កុលសម្ព័ន្ធម៉ាណាសេ និងជាចៅរបស់លោកយ៉ូសែប។
អស់អ្នកដែលដឹកនាំនាយទាហានពីសាប់យ៉ូឡូម
អ្នកដឹកនាំទាហានបានពណ៌នាដូចជាវត្ថុជានិមិត្តរូបនៃសិទ្ធិអំណាចរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹកនាំយោធារបស់កុលសម្ព័ន្ធសាប់យ៉ូឡូម»។
Judges 5:15
ព្រះអង្គម្ចាស់របស់ខ្ញុំក្នុងកុលសម្ព័ន្ធអ៊ីសាខា បាននៅជាមួយលោកស្រីដេបូរ៉ា
ពាក្យ «របស់ខ្ញុំ» សំដៅលើលោកស្រីដេបូរ៉ា។
នៅក្នុងប្រយោគនេះទាំងមូលអាចបកប្រែជាបុរសទីមួយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គម្ចាស់នៅក្នុងកុលសម្ពន្ធអ៊ីសាខានៅជាមួយខ្ញុំ។
លោកស្រីដេបូរ៉ា
សូមបកប្រែពាក្យនេះ ឲ្យដូចការដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៤។
លោកអ៊ីសាខាក៏បាននៅជាមួយបារ៉ាក់
ពាក្យ «លោកអ៊ីសាខា» សំដៅលើកុលសម្ព័ន្ធអ៊ីសាខា។
របៀបផ្សេងទៀតនៃការបកប្រែ: «កុលសម្ព័ន្ធអ៊ីសាខាជាមួយនឹងលោកបារ៉ាក់។
ប្រញាប់ប្រញាល់តាមលោកចូលទៅក្នុងជ្រលងភ្នំតាមការបញ្ជារបស់លោក
«ស្តាប់បង្គាប់បញ្ជា ហើយប្រញាប់ទៅតាមលោកចូលទៅក្នុងជ្រលងភ្នំ»។
ប្រញាប់ប្រញាល់តាម
«ដើរតាម» ឬ «ប្រញាប់ដើរតាម» ។
មានតែការរែកញែកនៃដួងចិត្ត
ពាក្យ «ដួងចិត្ត» តំណាងឲ្យគំនិត។ មនុស្សពិភាក្សាជាមួយគ្នា ប៉ុន្តែ
មិនអាចសម្រេចចិត្ត អ្វីដែលពួកគេត្រូវធ្វើ និយាយដូចជាពួកគេស្វែងយល់ចិត្តគ្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «មានការពិភាក្សាជាច្រើន
អំពីអ្វីដែលពួកគេត្រូវធ្វើ»។
Judges 5:16
ហេតុអ្វីបានជាអ្នកអង្គុយក្នុងភ្នក់ភ្លើង
ស្តាប់ពួកគង្វាលលេងប៊ីរបស់ពួកគេសម្រាប់ហ្វូងសត្វរបស់ពួកគេដូច្នេះ?
សំណួរនេះ សួរទៅកាន់ប្រជាជនកុលសម្ព័ន្ធរូបេន
ដោយសារពួកគេមិនចង់ចេញទៅប្រយុទ្ធនៅក្នុងសមរភូមិ។

generated on Wed Sep 10 16:16:32 2025

ឃ្លានេះអាចបកប្រែជាប្រយោគមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកត្រូវជួយយើងតយុទ្ធ តែអ្នកបែរជានៅផ្ទះ
ហើយស្តាប់សត្វចៀមលេងបំពង់សម្រាប់ហ្វូងសត្វរបស់ពួកគេ»។
ភ្នក់ភ្លើង
នៅក្នុងកំណែព្រះគម្ពីរខ្លះ បានបកប្រែថា «ក្រោលចៀម» ឬ «ក្រោលសត្វ» ។
មានតែការវែកញែកនៃដួងចិត្ត
ពាក្យ «ដួងចិត្ត» តំណាងឲ្យគំនិត។ មនុស្សពិភាក្សាជាមួយគ្នា ប៉ុន្តែ
មិនអាចសម្រេចចិត្ត អ្វីដែលពួកគេត្រូវធ្វើ និយាយដូចជាពួកគេស្វែងយល់ចិត្តគ្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «មានការពិភាក្សាជាច្រើន
អំពីអ្វីដែលពួកគេត្រូវធ្វើ»។
Judges 5:17
កាឡាតនៅឯ
នៅទីនេះ «កាឡាត» តំណាងឲ្យមនុស្សដែលមកពីកាឡាត
ដែលត្រូវចេញទៅច្បាំងនៅក្នុងសមរភូមិ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកប្រុសរបស់ស្រុកកាឡាតនៅផ្ទះ»
នៅឯខាងនាយទន្លេយ័រដាន
សំដៅលើភាគខាងកើតទន្លេយ័រដាន។
ដាន់ ហេតុអ្វីបានជាសំងំតែនៅលើកនាវា?
នេះជាសំណួរសួរដើម្បីបញ្ជាក់ពីកំហឹង
ដោយសារប្រជាជននៅក្នុងកុលសម្ព័ន្ធដាន់មៅក្នុងសំពៅរបស់ពួកគេ
មិនព្រមប្រយុទ្ធជាមួយអ៊ីស្រាអែលទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកប្រុសៗកុលសម្ព័ន្ធដាក នៅតែក្នុងសំពៅ» ឬ
«ពួកប្រុសៗនៅកុលសម្ព័ន្ធដានមិនបានជួយយើងច្បាំងនៅក្នុងសមរភូមិទេ។
ផ្ទុយទៅវិញ ពួកគេជិះសំពៅខ្ជាត់ព្រាត់នៅតាមសមុទ្រទៅវិញ»។
ដាន់ ហេតុអ្វីបានជា
ពាក្យ «ដាន់» តំណាងឲ្យពួកប្រុសៗមកពីកុលសម្ព័ន្ធដាន់
ដែលគួរតែចេញទៅច្បាំងនៅក្នុងសមរភូមិ។ របៀបផ្សេងទៀតនៃការបកប្រែ:
«កុលសម្ព័ន្ធដាន់ ហេតុអ្វីបានជាពួកគេ»។
សំងំតែនៅលើកនាវា
កុលសម្ព័ន្ធដាន់មានទីតាំងនៅជិតសមុទ្រមេឌីទែរ៉ាណេ។
ពួកគេជិះសំពៅនៅតាមសមុទ្រ ដើម្បីរកប្រាក់ និងធ្វើជំនួញ ហើយនេសាទផងដែរ។
ឯអេស៊ើរ ក៏នៅសំងំតាមឆ្នេរសមុទ្រហើយបានរស់នៅជិតកំពង់ផែរបស់ពួកគេ
អត្ថន័យពេញនៅក្នុងប្រយោគនេះ អាចបញ្ជាក់កាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សនៅក្នុងកុលសម្ព័ន្ធ
អេស៊ើរក៏មិនបានជួយយើងដែរ ពួកគេនៅតែលើកោះជិតកំពង់ផែរបស់ពួកគេ»។
អេស៊ើរនៅសំងំ
«អេស៊ើរ» តំណាងឲ្យមនុស្សប្រុសដែលគួរតែទៅច្បាំងនៅក្នុងសមរភូមិ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកប្រុសៗអេស៊ើរនៅសំងំ»។
កំពង់ផែ
ជាកន្លែងនៅតាមឈូងសមុទ្រ ជាកន្លែងដែលមានទឹកជ្រៅ
ហើយសំពៅអាចចតបាន។
កុលសម្ព័ន្ធណែបថាលីក៏ដូចគ្នាដែរ
អ្នកអាចធ្វើឲ្យគេយល់កាន់តែច្បាស់តាមរយៈព័ត៌មាន។
របៀបផ្សេងទៀតនៃការបកប្រែ: «
ណែបថាលីកុលសម្ព័ន្ធមួយដែលប្រថុយជីវិតរបស់ពួកគេដល់ចំណុចអាយុជីវិត។
Judges 5:19
ពួកស្តេចបានមក គឺពួកគេបានច្បាំង ... ស្តេចរបស់ស្រុកកាណានក៏ច្បាំង
ស្តេចរបស់ក្រុមប្រជាជនធ្លាប់ប្រើទាហាន ទ្រង់បានបង្គាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្តេច និងទាហានរបស់ពួកគេមក
ហើយប្រយុទ្ធ...ស្តេចរបស់សាសន៍កាណាន និងទាហានរបស់ពួកគេក៏តយុទ្ធដែរ»។
ពួកគេបានច្បាំង...ចម្បាំង
ពាក្យ «យើង» អាចយល់បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេប្រយុទ្ធជាមួយយើង...យើងក៏តយុទ្ធវិញ»។
តាណាក...មេគីដោ។
ចូរបកប្រែឈ្មោះទាំងនេះ ដូចអ្នកបានបកប្រែនៅក្នុងជំពូក ១:២៧។
មិនបានយកប្រាក់ដូចជារបស់លូចនោះទេ
ពាក្យ «ប្រាក់» នៅទីនេះ តំណាងឲ្យទ្រព្យសម្បត្តិទូទៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានប្រាក់
ឬទ្រព្យសម្បត្តិផ្សេងទៀតជាការប្លន់ឡើយ»។
ប្លន់
របស់ដែលបានចាប់យកដោយកម្លាំង ជាទូទៅតាមរយៈសង្គ្រាម ឬ
ដោយសារពួកចោរប្លន់។
ហ្វូងផ្កាយក៏បានច្បាំងពីលើមេឃ ពីផ្លូវឆ្លងកាត់របស់ពួកគេ មេឃបានច្បាំងប្រឆាំងនឹងស៊ីសេរ៉ា
ព្រះអម្ចាស់ជួយអ៊ីស្រាអែលឲ្យយកឈ្នះស៊ីសេរ៉ា និងទាហានរបស់លោក
គឺប្រៀបដូចជាផ្កាយនៅលើមេឃ ច្បាំងជាមួយនឹងស៊ីសេរ៉ា
និងទាហានរបស់លោក។ នេះប្រហែលជាសំដៅលើព្រះអម្ចាស់ប្រើធម្មជាតិ
ជាពិសេសខ្យល់ព្យុះ ដើម្បីយកឈ្នះស៊ីសេរ៉ា។
ទាស់នឹងស៊ីសេរ៉ា
ពាក្យ «ស៊ីសេរ៉ា» តំណាងឲ្យទាហានរបស់លោកទាំងអស់។
ស៊ីសេរ៉ា
ចូរបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៤:១។
Judges 5:21
ទន្លេគីសុនបានហូរនាំពួកគេទៅ
ដោយសារភ្លៀងខ្លាំងពេក ទន្លេក៏ជន់ឡើងយ៉ាងលឿនធ្វើឲ្យរទេះចម្បាំង
ជាប់គាំងនៅក្នុងភក់ ហើយទាហានជាច្រើនក៏លង់ទឹកដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទន្លេគីសុនបានជន់លិច
ហើយហូរបក់ទាហានរបស់ស៊ីសេរ៉ាទៅឆ្ងាយ»។
ទន្លេគីសុន
ចូរបកប្រែពាក្យនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៤:៦។
សូមចម្រើនព្រលឹងរបស់ខ្ញុំ ឲ្យរឹងមាំឡើង!
ពាក្យ «ព្រលឹង» នៅទីនេះ សំដៅលើមនុស្សទាំងមូល»។ ពាក្យ «របស់ខ្ញុំ»
សំដៅលើលោកស្រីដេបូរ៉ា។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំប្រាប់ខ្លួនឯងថា
សូមចម្រើនព្រលឹងរបស់ខ្ញុំ អោយរឹងមាំឡើង»។
បន្ទាប់មកសូរសន្ធឹកនៃជើងសេះ កំពុងផាយ គឺពួកដែលរត់យ៉ាងលឿននៃពួកខ្លាំងពូកែរបស់គាត់
ឃ្លានេះពណ៌នាពីសម្លេងរបស់សេះរត់ទៅក្នុងសមរភូមិ។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មក ខ្ញុំឮសម្លេងសេះរត់ទៅឆ្ងាយ។
សេះដ៏ខ្លាំងពូកែរបស់លោកស៊ីសេរ៉ារត់ទៅឆ្ងាយ»។
លោតផ្លោះ
«រត់យ៉ាងលឿន»
Judges 5:23
ចូរដាក់បណ្តាសារ មេរ៉ូស!
ពាក្យ «មេរ៉ូស» តំណាងឲ្យមនុស្សដែលរស់នៅទីនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ត្រូវបណ្តាសាហើយប្រជាជនមេរ៉ូស»។
មេរ៉ូស
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
អ្នកស្រុក
ប្រជាជនដែលរស់នៅទីកន្លែងនោះ។
Judges 5:24
នាងយ៉ូអែល
ចូរបកប្រែឈ្មោះនេះឲ្យដូច អ្នកបានបកប្រែនៅក្នុងជំពូក ៤:១៧។
លោកហេបើរ
ចូរបកប្រែឈ្មោះនេះឲ្យដូច អ្នកបានបកប្រែនៅក្នុងជំពូក ៤:១១។
ជនជាតិកែន
ចូរបកប្រែឈ្មោះមនុស្សក្រុមនេះឲ្យដូច អ្នកបានបកប្រែនៅក្នុងជំពូក ១:១៦។
បាននាំយកខ្លាញ់នៃទឹកដោះ
ពាក្យ «ខ្លាញ់ទឹកដោះ» សំដៅលើទឹកដោះគោកក។
នេះគឺជាទឹកដោះគោដែលល្អបំផុត
ហើយជាចំណូលចិត្តប្រជាជនរបស់នាងយ៉ាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរយកទឹកដោះគោជូឲ្យគាត់» ឬ «ចូរយកទឹកដោះគោកកឲ្យគាត់»។
ដែលជាអាហារ សម្រាប់ពួករាជ្យបុត្រ
ឃ្លានេះ មានន័យថា ជាអាហារដ៏ល្អបំផុត
ព្រោះជាអាហារដែលថ្វាយទៅព្រះអង្គម្ចាស់។
Judges 5:26
នាងបានចាប់ចម្រឹងតង់នឹងដៃរបស់នាង
«នាងយ៉ាអែលបានចាប់យកចម្រឹងតង់ដោយដៃរបស់នាង»។
ចម្រឹងតង់
ពាក្យនេះ គឺការផ្គុំឡើងដោយឈើ ឬដែកមួយដុំ ដូចជាក្បាលដែកគោក
ដែលដំដោយញញួរនៅតាមកាច់ជ្រុងរបស់តង់។

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៤:២១។
ញញួរ
ញញួរគឺជាវត្ថុមួយដ៏ធ្ងន់ ធ្វើពីឈើ ដើម្បីវាយចម្រឹងរបស់តង់ចូលទៅក្នុងដី។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៤:២១។
ស៊ីសេរ៉ា
ចូរបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៤:១។
បានដេក
គ្មានកម្លាំង ឬ ចលនា។
គាត់ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នាងបានសម្លាប់លោក» ឬ «លោកបានស្លាប់»។
Judges 5:28
ចម្រឹងបង្ហួច
នេះគឺជាគ្របបង្ហួចធ្វើពីឈើចាក់ផ្ទុយគ្នា។
ហេតុអ្វីបានជាកូនរទេះរបស់គាត់ក្រមកម្ល៉ះ? ហេតុអ្វីក៏មានក្រចកជើងសេះ
ដែលទាញរទេះរបស់គេអោយមកយឺត?
សំណួរទាំងពីរនេះ មានន័យដូចគ្នា។ ប្រយោគពីរនេះអាចបញ្ចូលគ្នាបាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុអ្វីបានជាលោកស៊ីសេរ៉ាទៅដល់ផ្ទះយូរយ៉ាងនេះ»។
កូនរទេះរបស់គាត់...ហេតុអ្វីក៏មានក្រចកជើងសេះ ដែលទាញរទេះរបស់គេ
ទាំងពីរនេះ តំណាងឲ្យលោកស៊ីសេរ៉ា។ របៀបផ្សេងទៀតនៃការបកប្រែ:
«យកលោកស៊ីសេរ៉ា...ហេតុអ្វីបានជាលោក»។
Judges 5:29
ស្ត្រីបម្រើដែលឆ្លាតជាងគេ
«ម្ចាស់ក្សត្រីយ៍» សំដៅលើបុត្រីរបស់ស្តេច ប៉ុន្តែ
ពាក្យនេះក៏អាចមានន័យថាស្ត្រីដែលផ្តល់យោបល់ ដើម្បីក្រុមគ្រួសាររបស់ស្តេច។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្ត្រីដែលឆ្លាតជាងគេ
បានឲ្យចម្លើយដូចគ្នាទៅកាន់ខ្លួនគាត់
«នាងនិយាយថា ទៅកាន់ខ្លួនឯងដូចគ្នាដែរ»
តើពួកគេមិនបានរកឃើញ ហើយចែកជ័យភណ្ឌដែលរកបានទេឬ?
ស្ត្រីម្នាក់នេះបានប្រើសំណួរដើម្បីបញ្ជាក់ថា ពួកគេជឿថា
ការនេះប្រាកដជាបានកើតឡើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេក៏បានជ័យភណ្ឌដែលចំណាយពេលជាយូរដើម្បីបែងចែកគ្នា»
គឺស្ត្រីក្រមុំពីរនាក់ សម្រាប់ពួកគេម្នាក់ៗ
ពាក្យ «ផ្នែពោះ» សំដៅលើស្ត្រីម្នាក់។ ម្តាយរបស់លោកស៊ីសេរ៉ា ជឿថា
ទាហានរបស់លោកស៊ីសេរ៉ាអាចចាប់បានស្រីៗជាច្រើន។
របៀបផ្សេងទៀតនៃការបកប្រែ: «ទាហានម្នាក់ៗត្រូវទទួលស្ត្រីម្នាក់ ឬពីរនាក់»
ជ្រលក់ពណ៌
«ជ្រលក់ពណ៌» ឬ «សម្លៀកបំពាក់ជ្រលក់ពណ៌»
ក្រណាត់ប៉ាក់
«ដែលមានថ្នេរស្អាត»
សម្រាប់អ្នកដែលរឹបអូសយក
ពាក្យ «ក» នៅទីនេះ តំណាងឲ្យ ទាហានរបស់លោកស៊ីសេរ៉ា។
របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិតទាហានដែលរឹមអូសបាននឹងពាក់វា»។
Judges 5:31
សូមឲ្យមិត្តសម្លាញ់របស់ទ្រង់
«សូមឲ្យអ្នកដែលស្រឡាញ់ព្រះអម្ចាស់»។
ដូចថ្ងៃ ក្នុងកាលដែលរះឡើងពេញកម្តៅ
ប្រជាជនអ៊ីស្រាអែលចង់បានដូចជាថ្ងៃ ដែលរះ
ព្រោះគ្មានប្រជាជាតិណាមានអំណាចអាចបញ្ឈប់ខ្ញុំមិនឲ្យរះបានទេ។
ស្រុកទេសបានសាន្តត្រាណ
ពាក្យ «ទឹកដី» តំណាងឲ្យប្រជាជនអ៊ីស្រាអែលរបស់នៅដោយសុខសាន្ត»។
អស់រយៈពេលសែសិបឆ្នាំ
«អស់រយៈពេល៤០សិបឆ្នាំ»។

---

6 [1]ជនជាតិអ៊ីស្រាអែល បានធ្វើការអាក្រក់ទាស់នឹងព្រះហឫទ័យព្រះអម្ចាស់សារជាថ្មី ហើយទ្រង់បានប្រគល់ពួកគេចហតទៅជនជាតិម៉ាឌានរយៈពេលប្រាំពីរឆ្នាំ។
[2]ពួកជនជាតិម៉ាឌានក៏មានអំណាចកាន់តែខ្លាំងឡើងលើជនជាតិអ៊ីស្រាអែល។ ដោយសារតែហេតុនោះហើយជនជាតិអ៊ីស្រាអែលបានធ្វើរូងនៅក្នុងភ្នំ ល្អាង
ហើយនិងទីមាំមួនសម្រាប់ខ្លួន។
[3]នៅពេលដែលជនជាតិអ៊ីស្រាអែលសាបព្រោះ នោះជនជាតិម៉ាឌាន ជនជាតិអាម៉ាឡេក និងពួកសាសន៍ពីប្រទេសខាងកើតបានឡើងមកប្រឆាំងជាមួយនឹងគេ។
[4]ហើយបំផ្លាញផលដែលកើតពីដី រហូតដល់កាសា។ ពួកគេមិនបន្សល់ទុកទាំងស្បៀងអាហារ ទាំងចៀម ទាំងគោ ឬសូម្បីតែសត្វលាក្តីក្នុងទឹកដីអ៊ីស្រាអែល។
[5]គឺពួកគេឡើងមកទាំងនាំយកហ្វូងសត្វហើយនិងត្រសាលរបស់គេមកដែរ គឺចូលមកដូចជាហ្វូងកណ្តូបនៃវាលស្មៅ សូម្បីតែខ្លួនគេ
និងសត្វអូដ្ឋរបស់គេក៏មិនអាចរាប់អស់ដែរ គឺពួកគេមកប្រយោជន៍តែបំផ្លាញទឹកដីតែប៉ុណ្ណោះ។[6]ជនជាតិអ៊ីស្រាអែលបានរងទុរគតដោយសារតែជនជាតិម៉ាឌានយ៉ាងខ្លាំង
ដូច្នេះហើយ គេបានស្រែកអង្វររកព្រះអម្ចាស់។
[7]ពេលនោះប្រជាជនអ៊ីស្រាអែលបានស្រែកអង្វររកព្រះអម្ចាស់ ដោយសារតែជនជាតិម៉ាឌាន។[8]នោះព្រះអម្ចាស់បានចាត់ព្យាការីម្នាក់ទៅរកគេ
ព្យាការីបានមានប្រសាសន៍ថា៖ «ព្រះអម្ចាស់ ជាព្រះនៃសាសន៍អ៊ីស្រាអែលមានព្រះបន្ទូលថា៖ យើងបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីព្ទមក
យើងបាននាំអ្នកចេញពីភាពជាទាសករ។
[9]យើងបានរំដោះអ្នកចេញពីកណ្តាប់ដៃជនជាតិអេស៊ីព្ទ ហើយចេញពីកណ្តាប់ដៃរបស់អ្នកដែលសង្កត់សង្កិនអ្នក យើងបណ្តេញពួកគេចេញពីមុខរបស់អ្នក
ហើយយើងក៏ប្រគល់ទឹកដីរបស់គេមកឲ្យអ្នករាល់គ្នា។[10]យើងបានប្រាប់អ្នករាល់គ្នាថា៖ «យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា យើងបានបង្គាប់អ្នករាល់គ្នាថា
កុំថ្វាយបង្គំព្រះរបស់ជនជាតិអាម៉ូរី! ជាស្រុកដែលអ្នករាល់គ្នារស់នៅនេះឡើយ!» ប៉ុន្តែអ្នករាល់គ្នាមិនបានស្តាប់បង្គាប់របស់យើងទេ។
[11]គ្រានោះ ទេវតានៃព្រះអម្ចាស់បានមកអង្គុយនៅក្រោមដើមម៉ៃសាក់ ត្រង់អូប្រា ដែលជារបស់លោកយ៉ូអាស ក្នុងគ្រួសារអបៀស៊ី នៅពេលដែលលោកគេឌាន
ជាកូនរបស់លោកយ៉ូអាស កំពុងតែបោកស្រូវនៅក្នុងធុងបញ្ចាន់ទំពាំងបាយជូរ ដើម្បីលាក់ខ្លួនពីជនជាតិម៉ាឌាន។[12]នោះ
ទេវតានៃព្រះអម្ចាស់បានមកបង្ហាញខ្លួនចំពោះលោកហើយប្រាប់លោកថា៖ «លោកជាវីរជន ដ៏អង់អាចក្លាហានអើយ! ព្រះអម្ចាស់គង់នៅជាមួយលោកហើយ!»។
[13]លោកគេឌានតបវិញថា៖ «ឱលោកម្ចាស់អើយ! ប្រសិនបើ ព្រះអម្ចាស់គង់ជាមួយពួកទូលបង្គំរាល់គ្នាពិតមែន
ហេតុអ្វីបានជារឿងទាំងអស់នេះកើតឡើងចំពោះទូលបង្គំរាល់គ្នា? ហើយការអស្ចារ្យរបស់ទ្រង់ដែលបុព្វបុរសរបស់យើងបានថ្លែងប្រាប់តគ្នាមកថា
ព្រះអម្ចាស់បាននាំយើងរាល់គ្នាចេញពីស្រុកអេស៊ីព្ទមក នៅឯណាទៅ? ហើយឥឡូវនេះ ព្រះអង្គបានបោះបង់យើងរាល់គ្នា
ហើយបានប្រគល់យើងរាល់គ្នាទៅក្នុងកណ្តាប់ដៃរបស់ជនជាតិម៉ាឌាន»។
[14]ព្រះអម្ចាស់បានទតមើលទៅលោកហើយមានព្រះបន្ទូលថា៖ «តើយើងមិនបានចាត់អ្នកទេឬ? ចូរឯងចេញទៅដោយកម្លាំងឯងចុះ
ហើយរំដោះអ៊ីស្រាអែលពីកណ្តាប់ដៃរបស់ជនជាតិម៉ាឌាន»[15]លោកក៏ទូលទ្រង់ថា៖ «ឱព្រះអម្ចាស់អើយ! តើទូលបង្គំរំដោះអ៊ីស្រាអែលដោយរបៀបណា? សូមទតមើលចុះ
គ្រួសាររបស់ទូលបង្គំតូចទាបជាងគេក្នុងអំបូរម៉ាណាសេ ឯទូលបង្គំក៏ជាអ្នកតូចទាបជាងគេក្នុងផ្ទះរបស់ឪពុកទូលបង្គំដែរ»។
[16]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «យើងនឹងនៅជាមួយអ្នក ហើយអ្នកនឹងវាយជនជាតិម៉ាឌានដូចជាវាយមនុស្សតែម្នាក់»។[17]«ប្រសិនបើ
ទូលបង្គំប្រកបដោយគុណរបស់ព្រះអង្គមែន សូមប្រទាននូវទីសម្គាល់ថា ព្រះអង្គនេះហើយដែលមានព្រះបន្ទូលមកកាន់ទូលបង្គំ។[18]សូមកុំចាកចេញពីទីនេះឡើយ
រហូតដល់ទូលបង្គំត្រឡប់មកវិញទាំងនាំយកតង្វាយមកថ្វាយដល់ព្រះអង្គ»។ ព្រះអង្គមានព្រះបន្ទូលថា៖ «យើងនឹងរង់ចាំ រហូតដល់អ្នកត្រឡប់មកវិញ»។
[19]លោកគេឌានបានចាកចេញទៅ ហើយរៀបចំកូនពពែមួយ និងនំបុ័ងឥតមេធ្វើពីម្សៅមួយចាំង។ លោកដាក់សាច់នៅក្នុងកញ្ជ្រែង ហើយដាក់ទឹកសម្លក្នុងចាន
ហើយនាំយកមកថ្វាយព្រះអង្គនៅក្រោមដើមម៉ៃសាក់នោះ។[20]នោះទេវតានៃព្រះអម្ចាស់ប្រាប់លោកថា៖ «ចូរយកសាច់ និងនំបុ័ងឥតមេទៅដាក់នៅលើថ្មនេះ
ហើយចាក់ទឹកសម្លពីលើវា»។ លោកគេឌានក៏ធ្វើតាម។

generated on Wed Sep 10 16:16:32 2025

[21]បន្ទាប់មក ទេវតានៃព្រះអម្ចាស់ក៏លូកចុងដំបងដែលកាន់នឹងដៃរបស់លោក។ លោកពាល់សាច់ និងនំបុ័ងឥតមេ នោះភ្លើងក៏ចេញពីថ្មនោះមកដុតបញ្ឆេះសាច់
និងនំបុ័ងនោះអស់រលីងទៅ។ បន្ទាប់មក ទេវតានៃព្រះអម្ចាស់បានចេញពីទីនោះបាត់ទៅ លោកគេឌានមិនបានឃើញលោកទៀតទេ។
[22]លោកគេឌានបានដឹងថា នេះគឺជាទេវតានៃព្រះអម្ចាស់។ លោកនិយាយថា៖ «ហ្អា! ព្រះអម្ចាស់ដ៏ជាព្រះ
ទូលបង្គំបានមើលឃើញទេវតារបស់ព្រះអង្គមុខទល់នឹងមុខ!»[23]ព្រះអម្ចាស់មានបន្ទូលថា៖ «ចូរសេចក្តីសុខសាន្តកើតមានដល់អ្នកចុះ កុំភ័យខ្លាចអ្វីឡើយ
អ្នកនឹងមិនស្លាប់ទេ»។[24]លោកគេឌានបានសង់កន្លែងថ្វាយយញ្ញបូជាមួយថ្វាយដល់ព្រះអម្ចាស់។ លោកបានដាក់ឈ្មោះថា៖ «ព្រះអម្ចាស់នៃសេចក្តីសុខសាន្ត»។
កន្លែងថ្វាយយញ្ញបូជានោះ នៅត្រង់អូប្រា នៃអំបូរអ័បៀស៊ើររហូតដល់សព្វថ្ងៃនេះ។
[25]នៅយប់នោះព្រះអម្ចាស់មានព្រះបន្ទូលទៅគាត់ថា៖ «ចូរយកគោឈ្មោលរបស់ឪពុកអ្នក និងគោឈ្មោលទីពីរ ដែលមានអាយុប្រាំពីរឆ្នាំទៅជាមួយ
ហើយរលំកន្លែងថ្វាយយញ្ញបូជារបស់ព្រះបាលរបស់ឪពុកអ្នកចោលទៅ ព្រមទាំងកាប់បំផ្លាញបង្គោលព្រះអាសេរ៉ា ដែលនៅក្បែរនោះចេញដែរ។
[26]ចូរសង់កន្លែងថ្វាយយញ្ញបូជាមួយថ្វាយដល់ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នកនៅលើទីខ្ពស់នៃកន្លែងពឹងជ្រក ហើយសង់វាឲ្យបានត្រឹមត្រូវ។
ចូរថ្វាយគោឈ្មោលទីពីរនោះ ជាយញ្ញបូជា ដោយប្រើឈើដែលមកពីកន្លែងថ្វាយយញ្ញបូជាព្រះអាសេរ៉ា ដែលអ្នកបានកាប់បំផ្លាញនោះ»។
[27]លោកគេឌានបាននាំអ្នកបម្រើរបស់លោកដប់នាក់ទៅជាមួយ ហើយធ្វើតាមអ្វីដែលព្រះអម្ចាស់បានបង្គាប់គាត់។
ប៉ុន្តែដោយសារគាត់មានការភ័យខ្លាចចំពោះអ្នកផ្ទះរបស់ឪពុកគាត់ និងមនុស្សនៅក្រុងនោះ ហេតុដូច្នេះហើយ បានជាគាត់មិនធ្វើវានៅពេលថ្ងៃទេ ប៉ុន្តែ
គាត់ធ្វើវានៅពេលយប់វិញ។
[28]នៅពេលដែលមនុស្សក្នុងក្រុងក្រោកឡើងនៅពេលព្រឹក ពួកគេបានឃើញកន្លែងថ្វាយយញ្ញបូជារបស់ព្រះបាលបានរលំ
ហើយបង្គោលនៃព្រះអាសេរ៉ាបានកាប់ចោលនៅក្បែរនោះដែរ ចំណែកឯ គោឈ្មោលទីពីរនៅបានដុតជាយញ្ញបូជានៅលើកន្លែងថ្វាយយញ្ញបូជាដែលបានសង់ឡើងនោះ។
[29]មនុស្សនៅក្រុងនោះបានសួរគ្នាទៅវិញទៅមកថា៖ «តើអ្នកណាដែលធ្វើកិច្ចការទាំងនេះ?» ពួកគេក៏ស៊ើបរក រួចមានគេប្រាប់ថា៖
«លោកគេឌានកូនប្រុសរបស់លោកយ៉ូអាស ជាអ្នកធ្វើការទាំងនេះ»។
[30]ដូច្នេះ មនុស្សប្រុសដែលនៅក្រុងនោះ បាននិយាយទៅលោកយ៉ូអាសថា៖ «ចូរនាំកូនរបស់អ្នកមក ហើយឲ្យគេស្លាប់ទៅ
ព្រោះគេបានរលំកន្លែងថ្វាយយញ្ញបូជាថ្វាយព្រះបាល ហើយកាប់បំផ្លាញកន្លែងថ្វាយយញ្ញបូជារបស់ព្រះអាសេរ៉ា»។
[31]លោកយ៉ូអាសក៏ឆ្លើយទៅមនុស្សដែលទាស់នឹងគាត់ថា៖ «តើអ្នករាល់គ្នាចង់តវ៉ាជំនួសព្រះបាលឬ? តើអ្នករាល់គ្នាជួយសង្គ្រោះព្រះបាលឬ?
អ្នកណាដែលចង់តវ៉ាជំនួសព្រះបាល អស់អ្នកដែលតវ៉ាជំនួសព្រះបាល ត្រូវសម្លាប់អ្នកនោះចោលមុនពេលព្រឹកមកដល់ទៅចុះ។ ប្រសិនបើ ព្រះបាលពិតជាព្រះពិតមែន
ចូរឲ្យព្រះបាលតវ៉ាសម្រាប់ខ្លួនឯងទៅ ដោយព្រោះគេបានរលំកន្លែងថ្វាយយញ្ញបូជារបស់ខ្លួន»។[32]ហេតុនោះហើយបានជានៅថ្ងៃនោះ គេហៅលោកគេឌានថា៖ «យេរូប
បាល» ដោយព្រោះពាក្យដែលថា៖ «ចូរឲ្យព្រះបាលតវ៉ាដោយខ្លួនឯងចុះ» គឺពីព្រោះលោកគេឌានបានរលំកន្លែងថ្វាយយញ្ញបូជារបស់ព្រះបាល»។
[33]គ្រានោះ ពួកជនជាតិមេឌាន ជនជាតិអាម៉ាឡេក ព្រមទាំងជនជាតិនានាពីទិសខាងកើតក៏មូលគ្នាឆ្លងទន្លេយ័រដាន មកបោះទ័ពនៅត្រង់វាលច្រកភ្នំយេសរាល។
[34]នោះព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានសណ្ឋិតលើលោកគេឌាន។ គាត់បានផ្លុំត្រែឡើង
នោះពួកអ័បៀស៊ើរក៏មូលគ្នាមកតាមលោក[35]រួចលោកចាត់មនុស្សឲ្យទៅគ្រប់ស្រុកម៉ាណាសេ គេក៏មូលគ្នាមកតាមលោកដែរ។ លោកក៏បានចាត់គេទៅកុលសម្ព័ន្ធអាស៊ើរ
កុលសម្ព័ន្ធសាប់យ៉ូឡូន និងពួកណែបថាលី ហើយពួកគេក៏បានឡើងមកជួបជាមួយលោក។
[36]លោកគេឌានទូលទៅព្រះអម្ចាស់ថា៖ «ប្រសិនបើ ព្រះអង្គ សព្វព្រះហឫទ័យនឹងជួយសង្គ្រោះប្រជាជនអ៊ីស្រាអែលតាមរយៈទូលបង្គំ
ដូចដែលព្រះអង្គមានព្រះបន្ទូលមែន[37]នោះមើល ទូលបង្គំដាក់រោមចៀមនេះនៅទីលានបោកស្រូវ ប្រសិនបើ ឃើញមានសន្សើមនៅតែលើរោមចៀម ហើយផ្ទៃដីជុំវិញស្ងួត
នោះទូលបង្គំនឹងដឹងថា ព្រះអង្គពិតជាប្រើទូលបង្គំឲ្យសង្គ្រោះប្រជាជនអ៊ីស្រាអែល ដូចដែលព្រះអង្គមានព្រះបន្ទូលមែន»។
[38]នៅពេលព្រឹកព្រលឹមបន្ទាប់ ក៏កើតមានដូច្នោះ កាលលោកក្រោកឡើង ទៅច្របាច់ពូតរោមចៀមនោះ បានទឹកសន្សើមពេញមួយចាន។
[39]បន្ទាប់មក លោកទូលព្រះអង្គថា៖ «សូមកុំខ្ញាល់នឹងទូលបង្គំឡើយ ទូលបង្គំនឹងសូមព្រះអង្គតែម្តងទៀតប៉ុណ្ណោះ។ សូមអនុញ្ញាតឲ្យទូលបង្គំ
សាកល្បងដោយរោមចៀមនេះម្តងទៀត! លើកនេះសូមឲ្យរោមចៀមស្ងួត ហើយសូមឲ្យដីជុំវិញសើមវិញម្តង»។[40]ព្រះអង្គបានធ្វើតាមការសុំរបស់លោកនៅក្នុងយប់នោះ។
រោមចៀមបែរជាស្ងួត តែនៅលើដីជុំវិញនោះបានសើម។

Judges 6:1
បានធ្វើអ្វីដែលអាក្រក់នៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់
ពាក្យ «នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់» តំណាងឲ្យអ្វីដែលព្រះអម្ចាស់ព្រះតម្រិះ
ឬ រិះគិត។ សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះនៅក្នុងជំពូក ២:១១។
បានប្រទានពួកគេទៅក្នុងដៃនៃជនជាតិម៉ាឌាន
ពាក្យ «ម៉ាឌាន» តំណាងឲ្យជនជាតិម៉ាឌាន។ ហើយ «ដៃ»
តំណាងឲ្យការគ្រប់គ្រង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ក្រោមការគ្រប់គ្រងរបស់ជនជាតិម៉ាឌាន» ឬ
«ការគ្រប់គ្រងរបស់ជនជាតិម៉ាឌាន»។
អំណាចរបស់ជនជាតិម៉ាឌានបានសង្កត់សង្កិនលើអ៊ីស្រាអែល
ពាក្យ «អំណាចរបស់ជនជាម៉ាឌាន» សំដៅលើប្រជាជនម៉ាឌាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ជនជាតិម៉ាឌាន
មានអំណាចជាងជនជាតិអ៊ីស្រាអែល
ហើយពួកគេបានសង្កត់សង្កិនជនជនជាតិអ៊ីស្រាអែល» ។ សូមមើល:
រូង
កន្លែងនៅក្នុងរូងថ្មដែលអាចធ្វើជាជម្រកបាន។
Judges 6:3
ពួកគេនឹងតាំងទ័ពរបស់ពួកគេ
«ពួកគេបោះជំរំទ័ពរបស់ពួកគេ» ឬ «ពួកទាហានរៀបចំបោះជំរំរបស់ពួកគេ»។
Judges 6:5
រាល់ពេលពួកគេ និងសត្វចិញ្ចឹមរបស់ពួកគេ ហើយនិងជំរំរបស់ពួកគេបានមក
ទឹកដីរបស់សាសន៍ម៉ាឌាននៅភាគខាងត្បូងរបស់អ៊ីស្រាអែល
នៅជិតសមុទ្រក្រហម។ គឺជារឿងធម្មតានៅក្នុងការប្រើពាក្យ «ឡើងមក»
នៅពេលនិយាយពីការធ្វើដំណើរពីស្រុកម៉ាឌានមកអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលជនជាតិម៉ាឌាននាំហ្វូងសត្វ
និងជំរំរបស់ពួកគេមកក្នុងទឹកដីអ៊ីស្រាអែល»។
ពួកគេនឹងមកដូចជាហ្វូងកណ្តូប
ជនជាតិម៉ាឌានត្រូវបានប្រៀបធៀបទៅនឹងហ្វូងរបស់កណ្តូប
ព្រោះពួកគេមានគ្នាច្រើន ហើយហ្វូងសត្វស៊ីអ្វីៗគ្រប់យ៉ាងដែលគេដាំ»។
មិនអាចរាប់អស់
នេះគឺជាពាក្យបំផ្លើស ទិដ្ឋភាពជាក់ស្តែង បង្ហាញពីចំនួនដ៏ច្រើនមហិមា។
ជនជាតិម៉ាឌានចុះខ្សោយ
ពាក្យ «ជនជាតិម៉ាឌាន» តំណាងឲ្យប្រជាជនម៉ាឌាន។
បានជាស្រែកស្រែកអំពាវនាវរកព្រះអម្ចាស់
នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«អធិស្ឋានសូមព្រះអម្ចាស់ជួយ»។
Judges 6:7
បានស្រែកអំពាវនាវរកព្រះជាម្ចាស់
នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«អធិស្ឋានសូមព្រះអម្ចាស់ជួយ»។
ដោយសារតែជនជាតិម៉ាឌាន
ពាក្យ «ម៉ាឌាន» តំណាងឲ្យប្រជាជនម៉ាឌាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយសារជនជាតិម៉ាឌាន»។
បាននាំអ្នកឡើងពីស្រុកអេស៊ីព្ទមក
«ខ្ញុំនឹងនាំអ្នកចេញពីស្រុកអេស៊ីប» ។
ផ្ទះនៃភាពជាទាសករ

generated on Wed Sep 10 16:16:32 2025

លោកម៉ូសេមានប្រសាសន៍ពីស្រុកអេស៊ីប
ដូចជាផ្ទះមួយដែលដាក់មនុស្សឲ្យធ្វើជាទាសករ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទីកន្លែងដែលអ្នកធ្លាប់ធ្វើជាឈ្លើយ»។ ។
Judges 6:9
ពីដៃ
នៅក្នុងឃ្លា «ដៃ» តំណាងឲ្យ អំណាច ឬការគ្រប់គ្រង។
បានគោរពសម្លេងរបស់យើង
ពាក្យ «សម្លេងរបស់យើង» តំណាងឲ្យអ្វីដែលព្រះអម្ចាស់បានបង្គាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្តាប់តាមបង្គាប់របស់យើង» ឬ «ស្តាប់យើង»។
Judges 6:11
ឥឡូវ
ពាក្យនេះ ប្រើនៅទីនេះ ដើម្បីសម្គាល់ពីការសម្រាកពីសាច់រឿងចម្បង។
អ្នកអត្ថាធិប្បាយចាប់ផ្តើមប្រាប់ពីផ្នែកថ្មីនៃសាច់រឿង។
ទេវតានៃព្រះជាម្ចាស់
នៅក្នុងជំពូក ៦:១១-២៤ ព្រះអម្ចាស់បានបង្ហាញឲ្យលោកគេឌានឃើញ
ជាទម្រង់ទេវតា។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់
ដែលបានបង្ហាញអង្គទ្រង់ជាទេវតា» ឬ «ព្រះអម្ចាស់» ។
អូប្រា
នេះគឺជាឈ្មោះរបស់ទីក្រុង។
អបៀស៊ី
នេះគឺជាក្រុមមនុស្ស បន្ទាប់ពីដូនតារបស់ពួកគេឈ្មោះ លោកអបៀស៊ើរ។
បានកំពុងបំបែកស្រូវសាលីដោយដាល់វានៅលើក្តារ
នេះគឺជាដំណើរការដែលហៅថា « បញ្ជាន់»។ លោកគេឌាន
វាយស្រូវនឹងក្តារដើម្បីយកស្រូវចេញពីចំបើង។
បង្ហាញខ្លួនចំពោះគាត់
«បានទៅជួបគាត់»។
Judges 6:13
ឱលោកម្ចាស់របស់ខ្ញុំអើយ
លោកគេឌានប្រើពាក្យ «លោកម្ចាស់»
ជាពាក្យជម្រាបសួរគួរសមសម្រាប់មនុស្សមិនស្គាល់មុខ។ លោកមិនបានស្គាល់ថា
អ្នកដែលលោកនិយាយជាមួយជាព្រះអម្ចាស់ ដែលនៅក្នុងទម្រង់ជាទេវតា
ឬជាមនុស្សនោះទេ។
ឯណាទៅការអស្ចារ្យដ៏មហិមារបស់ទ្រង់ ដែលឪពុករបស់យើងបានប្រាប់យើងនោះ
នៅពេលដែលពួកគេបាននិយាយថា «តើព្រះជាម្ចាស់មិនបាននាំយើងឡើងពីស្រុកអេស៊ីបមកទេឬ?
លោកគេឌានប្រើសំនួរនេះដើម្បីសួរមនុស្សដែលលោកមិនស្គាល់ថា
ព្រះអម្ចាស់គង់ជាមួយលោក។ ហើយបានដកស្រង់សំដីផ្ទាល់ដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងមិនបានឃើញការអស្ចារ្យណាមួយ
ដែលដូនតារបស់យើងបានដំណាលប្រាប់យើងអំពីព្រះអម្ចាស់នាំពួកគេចេញពីអេស៊ីបទេ
។
បានប្រគល់យើងទៅក្នុងកណ្តាប់ដៃរបស់ជនជាតិម៉ាឌាន
ឃ្លា «បានប្រគល់យើងទៅក្នុង» មានន័យថា
ព្រះអម្ចាស់អនុញ្ញាតឲ្យអ៊ីស្រាអែលចាញ់សង្គ្រាមគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អនុញ្ញាតឲ្យជនជាតិម៉ាឌានយកឈ្នះលើយើង»។
បានប្រគល់យើងទៅក្នុងកណ្តាប់ដៃ
ពាក្យ «ដៃ» នៅទីនេះ តំណាងឲ្យអំណាច ឬ ការគ្រប់គ្រង។
របស់ជនជាតិម៉ាឌាន
ពាក្យ «ម៉ាឌាន» តំណាងឲ្យជនជាតិម៉ាឌាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«របស់ជនជាតិម៉ាឌាន»។
Judges 6:14
ព្រះអម្ចាស់បានទតមើលទៅលោក
«ព្រះអម្ចាស់បានទត់មើលលោកគេឌាន»។
ពីកណ្តាប់ដៃ
ពាក្យ «ដៃ» នៅទីនេះ តំណាងឲ្យអំណាច ឬ ការគ្រប់គ្រង។
របស់ជនជាតិម៉ាឌាន
ពាក្យ «ម៉ាឌាន» តំណាងឲ្យជនជាតិម៉ាឌាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«របស់ជនជាតិម៉ាឌាន»។
តើយើងមិនបានប្រាប់អ្នកទេឬ?
ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ដល់លោកគេឌានថា ព្រះអង្គបានចាត់លោក។
ពាក្យ «ចាត់» មានន័យថា ព្រះអម្ចាស់បានជ្រើសរើសលោកគេឌាន
ជាមួយនឹងភារកិច្ច។ របៀបផ្សេងទៀតនៃការបកប្រែ: «យើង គឺជាព្រះអម្ចាស់
យើងចាត់អ្នកឲ្យទៅ!»
ឱព្រះជាម្ចាស់អើយ
ឥឡូវនេះ លោកគេឌានបានហៅអ្នកនោះថា «ព្រះអម្ចាស់» ជំនួសឲ្យ
«លោកម្ចាស់» នៅក្នុងជំពូក ៦:៣។ នៅទីត្រង់នេះ
លោកគេឌានហាក់បីដូចជាស្គាល់ ឬសន្និដ្ឋានថា ព្រះអង្គជាព្រះអម្ចាស់។
តើទូលបង្គំរំដោះអ៊ីស្រាអែលដោយរបៀបណា?
លោកគេឌានប្រើសំណួរមួយនេះ ដើម្បីបញ្ជាក់ថា លោកមិនគិតថា
លោកអាចសង្គ្រោះជនជាតិអ៊ីស្រាអែលបានទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំមិនអាចសង្គ្រោះជនជាតិអ៊ីស្រាអែលបានទេ»។
សូមទតមើលចុះ
«សូមយល់» ឬ «សូមស្តាប់» ។
ក្នុងម៉ាណាសេ
«ក្នុងកុលសម្ព័ន្ធម៉ាណាសេ»។
គ្រួសាររបស់ទូលបង្គំ
ពាក្យ «ផ្ទះ» តំណាងឲ្យគ្រួសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅក្នុងគ្រួសាររបស់ទូលបង្គំ» ឬ «ក្នុងគ្រួសារទូលបង្គំ»។
Judges 6:16
យើងនឹងនៅជាមួយអ្នក
ពាក្យ «យើងនឹងនៅជាមួយអ្នក» នេះគឺជាពាក្យប្រៀបធៀបដែលមានន័យថា
ព្រះអម្ចាស់នឹងជួយ និងឲ្យពរដល់គេឌាន។
មនុស្សតែម្នាក់
អ្នកអាចនិយាយពេញដោយអត្ថន័យបញ្ជាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ងាយសម្រាប់អ្នកតយុទ្ធមានតែបុរស»
រៀបចំនៅចំពោះ
«បានដាក់នៅចំពោះអ្នក»។
Judges 6:19
និងនំបុ័ងឥតមេធ្វើពីម៉្យាំមួយចាំង
ប្រសិនបើ ចាំបាច់ប្រើរង្វាស់សម័យថ្មី នេះគឺជាវិធីមួយក្នុងការធ្វើការនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «មានចំណុះចំនួន ២២លិត្រ»។
ទឹកសាច់រាំងាស់
ទឹកដែលមានសាច់ ដូចជាសាច់ ចម្អិនវា។
ពួកគេដល់គាត់
«ពួកគេដល់ទេវតារបស់ព្រះជាម្ចាស់» ។
ទេវតានៃព្រះអម្ចាស់
នេះគឺជាទេវតារបស់ព្រះអម្ចាស់ដដែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ ដែលនៅក្នុងទម្រង់ជាទេវតា» ឬ «ព្រះជាម្ចាស់»។
Judges 6:21
ទេវតានៃព្រះជាម្ចាស់
នៅក្នុងជំពូក ៦:១១-២៤ ព្រះអម្ចាស់បង្ហាញអង្គទ្រង់ដល់លោកគេឌាន
នៅក្នុងទម្រង់ជាទេវតា។ សូមមើលពីរបៀបដែលដែលអ្នកបកប្រែនៅក្នុងជំពូក
៦:១១។
បានចេញទៅ
«ចេញទៅបាត់»
Judges 6:22
ទេវតានៃព្រះជាម្ចាស់
នៅក្នុងជំពូក ៦:១១-២៤ ព្រះអម្ចាស់បង្ហាញអង្គទ្រង់ដល់លោកគេឌាន
នៅក្នុងទម្រង់ជាទេវតា។ សូមមើល:ពីរបៀបដែលដែលអ្នកបកប្រែនៅក្នុងជំពូក
៦:១១។
ហ្អា! ព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់អើយ
ពាក្យ «ហ្អា» នៅទីនេះ បង្ហាញថាលោកគេឌានភ័យខ្លាចជាខ្លាំង។
បានមើលឃើញទេវតារបស់ព្រះជាម្ចាស់មុខទល់នឹងមុខ!
ឃ្លានេះ សំដៅលើមនុស្សពីរនាក់ចូលទៅជិតគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានមើលឃើញទេវតារបស់ព្រះអម្ចាស់មុខទល់នឹងមុខ!»
ព្រះអម្ចាស់មានបន្ទូលទៅលោក
ព្រះអម្ចាស់មានបន្ទូលទៅលោកគេឌានពីស្ថានសួគ៌មក។
រហូតដល់សព្វថ្ងៃនេះ
ឃ្លានេះ មានន័យថាជាពេលវេលាដែលកណ្ឌកម្ពីរចៅហ្វាយបានសរសេរឡើង។
អូប្រា

generated on Wed Sep 10 16:16:32 2025

ចូរបកប្រែឈ្មោះទីក្រុងនេះ ដូចអ្នកបានបកប្រែនៅក្នុងជំពូក ៦:១១។
កុលសម្ព័ន្ធអ័បៀស៊ើរ
ចូរបកប្រែឈ្មោះនេះ ដូចអ្នកបានបកប្រែនៅក្នុងជំពូក ៦:១១។
Judges 6:25
គោឈ្មោលទីពីរ
ពាក្យ «ទីពីរ» គឺលំដាប់របស់លេខ «ពីរ» របៀបផ្សេងទៀតនៃការបកប្រែ:
«គោឈ្មោលមួយទៀត»។
ដែលនៅក្បែរនោះ
«ដែលនៅក្បែរកន្លែងថ្វាយយញ្ញបូជារបស់ព្រះបាល»។
នៅលើទីខ្ពស់នៃកន្លែងលាក់ខ្លួន
ទីក្រុងអូប្រានៅលើកំពូលភ្នំ។
ជនជាតិអ៊ីស្រាអែលរត់ទៅជ្រកកោននៅទីនោះពីជនជាតិម៉ាឌាន។
សង់វាឲ្យបានត្រឹមត្រូវ
«ដាក់ថ្មឲ្យមានរបៀបរៀបរយ» ឬ «សង់វាឲ្យបានត្រឹមត្រូវ»។
Judges 6:27
ធ្វើដូចដែលព្រះជាម្ចាស់បានបង្គាប់គាត់
សំដៅលើសេចក្ដីបង្គាប់របស់ព្រះអម្ចាស់នៅក្នុងជំពូក ៦:២៥។
Judges 6:28
ក្រោកឡើង
«ក្រោកចេញពីគ្រែ» ឬ «ភ្ញាក់ឡើង»។
ទីគោរពបូជារបស់ព្រះបាលបានរលំ ហើយបង្គោលនៃព្រះអាសេរ៉ានៅក្បែរនោះបានកាប់ចោលដែរ
ហើយគោឈ្មោលទីពីរនៅបានដុតជាយញ្ញបូជានៅលើទីគោរពបូជាដែលបានសង់ឡើងនោះ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេសង្កេតឃើញថា
មាននរណាម្នាក់បានវាយកម្ទេចកន្លែងថ្វាយយញ្ញបូជារបស់ព្រះបាល
បំបាក់បង្គោលនៃព្រះអាសេរ៉ាដែលនៅជិតនោះ ហើយសង់កន្លែងថ្វាយយញ្ញបូជា
ហើយថ្វាយគោឈ្មោះជាលើកទីពីរលើវា»។
Judges 6:30
គេសមនឹងស្លាប់ទៅ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងអាចសម្លាប់គាត់ ទុកជាការដាក់ទោស»។
Judges 6:31
តើអ្នករាល់គ្នាចង់តវ៉ាជំនួសព្រះបាលឬ?
លោកយ៉ូអាសបានប្រើសំណួរដើម្បីបញ្ជាក់ថា មនុស្សមិនគួរការពារព្រះឡើយ។
របៀបនៃការបកប្រែ: «អ្នកមិនអាចការពារជំនួសព្រះបាលទេ»។ ។
តើអ្នករាល់គ្នាជួយនឹងសង្គ្រោះព្រះគាត់ឬ?
លោកយ៉ូអាសប្រើសំណួរនេះ ដើម្បីបញ្ជាក់ថា មនុស្សមិនអាចសង្គ្រោះព្រះបានទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាមិនអាចសង្គ្រោះព្រះបាលបានទេ»។
យេរូបបាល
នេះគឺជាឈ្មោះមួយទៀតសម្រាប់លោកគេឌាន។ មានន័យថា
«សូមឲ្យព្រះបាលការពារខ្លួនឯងទៅ»។
ព្រោះលោកបាននិយាយថា
«ព្រោះលោកយ៉ូអាសនិយាយ»។
Judges 6:33
ឥឡូវនេះ
ពាក្យនេះប្រើនៅទីនេះ ដើម្បីបញ្ជាក់ពីការសម្រាប់នៅក្នុងសាច់រឿងចម្បង។
នៅទីនេះ អ្នកអត្ថាធិប្បាយចាប់ផ្តើមប្រាប់ពីសាច់រឿងថ្មី។
បានប្រមូលផ្តុំគ្នា
អត្ថន័យពេញលេញនៅក្នុងប្រយោគនេះរឹតតែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បានប្រមូលផ្តុំគ្នាដូចជាទាហាន»។
Judges 6:34
បានមកលើលោកគេឌាន
នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រប់គ្រងលើលោកគេឌាន»។
កុលសម្ព័ន្ធអបៀស៊ើរ
ចូរបកប្រែឈ្មោះនេះ ដូចអ្នកបានបកប្រែនៅក្នុងជំពូក ៦:១១។
ដូច្នេះ ពួកគេអាចតាមលោក
ពាក្យ «សមរភូមិ» អាចយល់បាន។ របៀបផ្សេងទៀតនៃការបកប្រែ:«ដូច្នេះ
ពួកគេបានតាមលោកទៅក្នុងសមរភូមិ»។
ក៏បានហៅឲ្យមកតាមលោកដែរ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានហៅពួកគេចេញមកដើម្បីដើរតាមលោក»។
កុលសម្ព័ន្ធអាស៊ើរ កុលសម្ព័ន្ធសាប់យ៉ូឡូន និងពួកណែបថាលី។
នេះគឺជាតំណាងមនុស្សនៅក្នុងកុលសម្ពន្ធនីមួយៗ។
របៀបផ្សេងទៀតនៃការបកប្រែ: «ចំពោះកុលសម្ព័ន្ធអាស៊ើរ កុលសម្ព័ន្ធសាប់យ៉ូឡូន
និងពួកណែបថាលី។
Judges 6:36
ដាក់រោមចៀមនេះនៅទីលានបោកស្រូវ
អាវធំរោមចៀមមួយ
សន្សើម
ទឹកដែលធ្លាក់លើស្លឹកឈើ នៅក្នុងពេលយប់។
នោះទូលបង្គំនឹងដឹងថា ព្រះអង្គពិតជាប្រើ
អត្ថន័យពេញនៃប្រយោគនេះអាចធ្វើឲ្យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «នេះគឺជាទីសម្គាល់ពីព្រះអង្គ
ហើយបន្ទាប់មកទូលបង្គំនឹងដឹងថាព្រះអង្គប្រើទូលបង្គំមែន»។
Judges 6:38
លោកគេឌានក្រោកឡើង
«លោកគេឌានក្រោកឡើងចេញពីគ្រែ»។
បានមួល
មួល និងច្របាច់អ្វីមួយដើម្បីបញ្ចេញទឹក។

---

7 [1]ដូច្នេះ លោកយេរូបបាល គឺលោកគេឌាន ហើយនិងមនុស្សទាំងអស់ដែលនៅជាមួយគាត់ បានក្រោកឡើងពីព្រលឹម ពួកគេបាននាំគ្នាទៅបោះជំរំនៅក្បាលទឹកហារ៉ុដ។
ចំណែកឯ ពួកមេឌានគេបោះជំរំនៅខាងជើងពួកគេ នៅក្បែរភ្នំម៉ូរ៉េត្រង់វាលច្រកភ្នំ។
[2]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកគេឌានថា៖ «ចំនួនមនុស្សដែលនៅជាមួយឯងច្រើនពេកហើយ
នឹងឲ្យយើងប្រគល់ជនជាតិម៉ាឌានមកក្នុងកណ្តាប់ដៃរបស់អ្នកមិនបានទេ ក្រែងពួកអ៊ីស្រាអែលអួតខ្លួនទាស់នឹងឯងវិញ
ដោយនិយាយថាយើងបានសង្គ្រោះខ្លួនយើងទេតើ។[3]ដូច្នេះ ចូរប្រកាសដល់ត្រចៀកមហាជនជន ហើយប្រាប់ថា អស់អ្នកណាដែលភ័យខ្លាច និងញាប់ញ័រ
ចូរឲ្យអ្នកនោះវិលត្រឡប់ ចាកចេញពីភ្នំកាឡាតទៅវិញចុះ»។ នោះមានមនុស្សពីរម៉ឺននាក់បានត្រឡប់ទៅវិញ ហើយនៅសល់តែមួយម៉ឺននាក់ប៉ុណ្ណោះ។
[4]ព្រះអម្ចាស់មានព្រះបន្ទូលទៅលោកគេឌានថា៖ «មនុស្សនៅតែមានចំនួនច្រើននៅឡើយ។ ដូច្នេះ ចូរនាំពួកគេទៅឯទឹក
ហើយយើងនឹងធ្វើឲ្យមានចំនួនតិចជាងមុនសម្រាប់អ្នក។ ប្រសិនបើ យើងនិយាយថា ម្នាក់នេះនឹងទៅជាមួយអ្នក គេនឹងទៅជាមួយអ្នក ប៉ុន្តែ បើយើងនិយាយថា
ម្នាក់នេះនឹងមិនទៅជាមួយអ្នកទេ នោះគេនឹងមិនទៅទេ»។
[5]ដូច្នេះ លោកគេឌានបាននាំមនុស្សទាំងអស់ទៅមាត់ទឹក ហើយព្រះអម្ចាស់មានព្រះបន្ទូលទៅគាត់ថា៖ «ចូរដាក់មនុស្សដែលលិតទឹកនឹងអណ្តាតដូចឆ្កែមួយឡែក
និងមនុស្សដែលលុតជង្គង់ដើម្បីផឹកទឹកមួយឡែក»។[6]មនុស្សបីរយនាក់ដែលផឹកទឹកលិតនឹងអណ្តាតដូចឆ្កែ ឯអ្នកដែលនៅសល់គឺលុតជង្គង់ផឹកទឹក។
[7]ព្រះអម្ចាស់មានព្រះបន្ទូលទៅគេឌានថា៖ «យើងនឹងសង្គ្រោះអ្នកហើយអោយអ្នកមានជ័យជម្នះលើសាសន៍ម៉ាឌាន ដោយសារមនុស្សបីរយនាក់ដែលក្បង់ទឹកផឹក
ឯមនុស្សឯទៀតត្រូវឲ្យពួកគេត្រឡប់ទៅកន្លែងរបស់គេវិញចុះ»។[8]ដូច្នេះ អស់អ្នកដែលបានជ្រើសរើសពួកគេចាប់គ្រឿងសព្វាវុធ និងត្រែរបស់គេ
លោកគេឌានបានបញ្ជូនមនុស្សទាំងអស់ត្រឡប់ទៅត្រសាលរបស់ពួកគេវិញ លើកលែងតែមនុស្សបីរយនាក់ដែលលោកទុកនៅជាមួយលោក។
ឯពួកម៉ាឌានបានបោះជំរំនៅត្រង់វាលច្រកភ្នំខាងក្រោមលោក។
[9]នៅយប់នោះឯងព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់លោកថា៖ «ចូរក្រោកឡើង! ចុះទៅឯទីបោះជំរំរបស់គេទៅ ព្រោះយើងនឹងអោយឯងមានជ័យជំនះលើវា[10]ប្រសិនបើ
ឯងភ័យខ្លាចនឹងចុះទៅ នោះចូរនាំ ពូរ៉ា ជាអ្នកបម្រើរបស់ឯងទៅជាមួយផងចុះ[11]ហើយឯងនឹងបានឮ អ្វីដែលគេបាននិយាយគ្នា
ការណ៍នោះនឹងនាំឲ្យឯងមានកម្លាំងខ្លាំងឡើង អាចចុះទៅទាស់នឹងគេបាន» ដូច្នេះ លោកគេឌាន និង ពូរ៉ា ជាអ្នកបម្រើបានចុះទៅដល់ប៉មយាមជំរំ។

generated on Wed Sep 10 16:16:32 2025

[12]ជនជាតិម៉ាឌាន ជនជាតិអាម៉ាឡេក និងជនជាតិនានាដែលនៅក្នុងច្រកភ្នំភាគខាងកើត ពួកគេមានគ្នាច្រើនដេរដាស់ដូចជាហ្វូងកណ្តូប។
ហើយសត្វអូដ្ឋរបស់ពួកគេមានច្រើនឥតគណនា ដូចជាគ្រាប់ខ្សាច់នៅតាមឆ្នេរសមុទ្រហួសការដែលអាចរាប់បាន។
[13]កាលដែលលោកទៅដល់ហើយ មានមនុស្សម្នាក់កំពុងតែនិយាយពីសុបិនរបស់គាត់ប្រាប់ដល់គូកនរបស់ខ្លួនថា៖ «មើល! ខ្ញុំយល់សុបិនឃើញថា
ខ្ញុំបានឃើញនំប៉័ងមួយដុំមូលរមៀលចូលក្នុងជំរំរបស់ពួកម៉ាឌាន។ វាបានចូលទៅក្នុងជំរំ ហើយបានវាយតង់ទាំងឡាយយ៉ាងខ្លាំង ដែលធ្វើអោយវាដួលរលំរាបស្មើរដល់ដី។
[14]បុរសម្នាក់ទៀតតបថា៖ «នេះគ្មានអ្វីក្រៅពីអាវុធរបស់លោកគេឌាន កូនលោក យ៉ូអាស ជនជាតិអ៊ីស្រាអែលនោះទេ
ព្រះបានប្រទានឲ្យលោកមានជ័យជម្នះលើជនជាតិម៉ាឌាន និងទាហានរបស់ពួកគេ»។
[15]កាលលោកគេឌាន បានឮរឿងនៃសុបិន ហើយនិងការបកស្រាយសុបិននោះ លោកបានក្រាបចុះថ្វាយបង្គំព្រះអម្ចាស់។
លោកបានត្រឡប់ទៅកាន់ជំរំរបស់ពួកគេវិញហើយនិយាយថា៖ «ចូរក្រោកឡើង! ព្រះអម្ចាស់បានប្រទានឲ្យយើងមានជ័យជម្នះលើទាហានរបស់ម៉ាឌាន»។
[16]លោកបានបែងចែកមនុស្សទាំងបីរយនាក់ជាបីក្រុម ហើយប្រគល់ត្រែ និងខ្ទមទទេឲ្យពួកគេគ្រប់ៗគ្នា ជាមួយនឹងចន្លុះនៅក្នុងនោះផងដែរ។
[17]ហើយគាត់និយាយថា៖ «ចូលមើលខ្ញុំ ហើយធ្វើតាមខ្ញុំ។ មើល! កាលណាខ្ញុំទៅដល់កន្លែងបោះជំរំ អ្នករាល់ត្រូវធ្វើអ្វីដែលខ្ញុំធ្វើ។[18]នៅពេលដែលខ្ញុំផ្លុំត្រែឡើង
អ្នកទាំងគ្នាដែលនៅជាមួយខ្ញុំ ត្រូវផ្លុំត្រែឡើង ដូច្នេះ អ្នករាល់គ្នាដែលនៅគ្រប់ទិសទាំងអស់ត្រូវផ្លុំត្រែឡើងទាំងស្រែកប្រកាសថា «សម្រាប់ព្រះអម្ចាស់
និងសម្រាប់លោកគេឌាន!»
[19]ដូច្នេះ លោកគេឌាន និងមនុស្សមួយរយនាក់ដែលនៅជាមួយគាត់បានមកដល់ទីបោះជំរំក្រៅបំផុត នៅពាក់កណ្តាលអាធ្រាត កាលពួកម៉ាឌានកំពុងផ្លាស់ប្តូរវេនយាម
ពួកគេបានផ្លុំត្រែ និងវាយបំបែកខ្ទមដែលនៅក្នុងដៃរបស់ពួកគេ។
[20]ពួកគេទាំងបីក្រុមបានផ្លុំត្រែឡើង និង បំបែកខ្ទមរបស់ពួកគេ។ រួចកាន់ចន្លុះនៅដៃឆ្វេង ហើយត្រែនៅដៃស្តាំដើម្បីផ្លុំ។ ពួកគេស្រែកឡើងថា៖ «អាវុធនៃព្រះអម្ចាស់
និងរបស់លោកគេឌាន»។[21]មនុស្សទាំងអស់ឈរនៅកន្លែងរបស់ពួកគេ ព័ន្ធជុំវិញទីបោះជំរំ ចំណែកឯទាហានម៉ាឌានវិញទាំងនោះវិញ
ពួកគេខំតែរត់និងស្រែកយ៉ាងណាឲ្យបានរួចខ្លួន។
[22]ពេលដែលពួកគេផ្លុំត្រែទាំងបីរយឡើង ព្រះអម្ចាស់បានធ្វើឲ្យជនជាតិម៉ាឌានកាប់សម្លាប់គ្នាទៅវិញទៅមក។ ទាហានរបស់គេបានរត់ទៅដល់ បេត ស៊ីតា ខាងសេរេរ៉ា
ហើយរហូតទៅដល់ព្រំប្រទល់មេហូឡា ដែលនៅជិត តាបាត។[23]នោះ ជនជាតិអ៊ីស្រាអែលប្រមូលគ្នាមកពីកុលសម្ព័ន្ធ ណែបថាលី អាស៊ើរ
និងកុលសម្ព័ន្ធម៉ាណាសេទាំងអស់ ហើយពួកគេដេញតាមពួកជនជាតិម៉ាឌាន។
[24]លោកគេឌាន បានចាត់មនុស្សឲ្យនាំដំណឹងទៅកាន់កុលសម្ព័ន្ធអេប្រាអ៊ីម និយាយថា៖ «ចូលចុះមកប្រឆាំងនឹងពួកម៉ាឌាន ហើយកាន់កាប់នៅត្រង់ទន្លេយ័រដាន
រហូតដល់ បេត បារ៉ា ហើយស្កាត់ពួកគេ»។ ពួកអេប្រាអ៊ីមទាំងប៉ុន្មាន បានមូលគ្នាទៅចាំស្កាត់ត្រង់ផ្លូវទឹកទាំងអស់ តាមទន្លេយ័រដានរហូតដល់បេត បារ៉ា។[25]ពួកគេចាប់បាន
មេដឹកនាំពីរនាក់របស់សាសន៍ម៉ាឌាន គឺ អូរិប និង សៀប។ ពួកគេបានសម្លាប់លោកអូរិប នៅត្រង់ថ្មរបស់លោកអូរិប ហើយ លោកសៀប
ត្រូវបានសម្លាប់នៅត្រង់ធុងគៀបផែ្លទំពាំងបាយជូររបស់លោកសៀប។ ពួកគេក៏ដេញតាមជនជាតិម៉ាឌាន ហើយពួកគេនាំយកក្បាលរបស់លោកអូរិប និង ក្បាលរបស់
លោកសៀប ទៅប្រគល់ឲ្យលោកគេឌាន ដែលនៅខាងនាយទន្លេយ័រដាន។

Judges 7:1
លោកយេរូបាល
នេះគឺជាឈ្មោះមួយផ្សេងទៀតសម្រាប់លោកគេឌាន។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនេះ នៅក្នុងជំពូក ៦:៣១។
ពួកគេបាននាំគ្នាទៅបោះជំរំ
«ពួកគេបានរៀបចំបោះជំរំរបស់ពួកគេ»។
ក្បាលទឹកហារ៉ុដ...ភ្នំម៉ូរ៉េតភ្នំ
នេះគឺជាឈ្មោះទីកន្លែង
ជំរំរបស់ជនជាតិមេឌានគេបោះតាំងនៅខាងជើងពួកគេ
ពាក្យ «មេឌាន» តំណាងឲ្យទាហានរបស់ជនជាតិមេឌាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទាហានរបស់ជនជាតិមេឌានបានបោះជំរំរបស់ពួកគេនៅភាគខាងជើងទាហានរបស់អ៊ីស្រាអែល»

Judges 7:2
នឹងឲ្យអ្នកមានជ័យជម្នះលើជនជាតិម៉ាឌាន
ពាក្យ «ជ័យជម្នះ» គឺជានាមអរូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីខ្ញុំបានអនុញ្ញាតឲ្យអ្នកយកឈ្នះលើសាសន៍ម៉ាឌាន»
ដោយអំណាចរបស់យើង ដែលបានសង្គ្រោះយើង
ពាក្យ «អំណាច» តំណាងឲ្យមនុស្សខ្លួនឯង។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានសង្គ្រោះខ្លួនយើង ដោយគ្មានជំនួយមកពីព្រះជាម្ចាស់ទេ»
ឥឡូវនេះ
ពាក្យនេះ មិនមែនមានន័យថាឥឡូវនេះទេ» ប៉ុន្តែ ពាក្យនេះ
ប្រើដើម្បីទាញចំណាប់អារម្មណ៍ទៅរកចំណុចសំខាន់ក្នុងការដើរតាម។
ចូរប្រកាសដល់ត្រចៀករបស់មនុស្សទាំងអស់
ពាក្យ «ត្រចៀក» សំដៅលើរូបកាយរបស់មនុស្សទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រកាសទៅដល់មនុស្ស»។
អស់អ្នកណាដែលភ័យខ្លាច អ្នកណាម្នាក់ដែលញាប់ញ័រ
ឃ្លាទាំងពីរនេះ មានន័យដូចគ្នា។
ញាប់ញ័រ
ពាក្យនេះប្រាប់អំពីការភ័យខ្លាចដែលធ្វើឲ្យមនុស្សម្នាក់ញ័រខ្លួន។
របៀបផ្សេងទៀតនៃការបកប្រែ: «ញ័រដោយភាពភ័យខ្លាច»។
ចូរឲ្យគេវិលត្រឡប់
អ្នកអាចធ្វើឲ្យវាកាន់តែច្បាស់ថាពួកគេទៅណា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរឲ្យគាត់ត្រឡប់ទៅផ្ទះគាត់វិញទៅ» ។
ភ្នំកាឡាត
នេះគឺជាឈ្មោះរបស់ភ្នំមួយនៅក្នុងតំបន់ភ្នំកាឡាត។
ពីរម៉ឺនពីរពាន់នាក់
«ពីរពាន់ «២២,០០០»
សល់តែមួយម៉ឺននាក់
ពាក្យ «ប្រជាជន» ឬ «មនុស្ស» ងាយយល់។ របៀបផ្សេងទៀតនៃការបកប្រែ:
«១០,០០០ នាក់ នៅសល់»។
មួយម៉ឺននាក់
«១០,០០០ នាក់»

Judges 7:4
ដែលនឹងមានចំនួនតិចជាងមុនសម្រាប់អ្នកនៅទីនោះ
ពាក្យ «ចំនួន» តំណាងឲ្យទាហាន។
អត្ថន័យពេញនឹងធ្វើឲ្យប្រយោគនេះកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយនៅទីនោះ យើងនឹងបង្ហាញអ្នក ថាត្រូវឲ្យនរណាទៅផ្ទះខ្លះ
ដើម្បីឲ្យទាហានមានគ្នាតិច»។

Judges 7:5
លោកគេឌានបាននាំ
ពាក្យ «នាំ» អាចប្រែជា «យក» ឬ «នាំមុខ»។
លិណ
ផឹកទឹកដោយលិណជាមួយនឹងអណ្តាត។
មនុស្សបីរយនាក់
«៣០០នាក់»

Judges 7:7
មនុស្សបីរយនាក់
«៣០០នាក់»
យើងនឹងសង្គ្រោះអ្នក ហើយឲ្យអ្នកមានជ័យជម្នះ
ពាក្យ «អ្នក» នៅទីនេះ ជាពហុវចន សំដៅលើលោកគេឌាន
និងជនជាតិអ៊ីស្រាអែល។
ដូច្នេះ អស់អ្នកដែលបានជ្រើសរើស
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
អស់អ្នកដែលព្រះអម្ចាស់បានជ្រើសរើស»។

generated on Wed Sep 10 16:16:32 2025

យកស្បៀងអាហារ និងត្រែរបស់ពួកគេ
ពាក្យ «ពួកគេ» សំដៅលើទាហានជនជាតិអ៊ីស្រាអែល ដែលចាកចេញពីទាហាន។
ឥឡូវនេះ
ពាក្យនេះ ប្រើនៅទីនេះ ដើម្បីសង្កាល់ពីការផ្អាកពីសាច់រឿងចម្បង។ នៅទីនេះ អ្នកអត្ថាធិប្បាយចាប់ផ្តើមប្រាប់ផ្នែកថ្មីសាច់រឿង។
Judges 7:9
វាយប្រហារជំរំ ព្រោះយើងនឹងឲ្យមានជ័យជម្នះលើវា
ពាក្យ «ជំរំ» សំដៅលើទាហានរបស់ជនជាតិម៉ាឌានទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «វាយប្រហារជំរំរបស់ជនជាតិម៉ាឌាន ដ្បិតយើងនឹងជួយអ្នកឲ្យយកឈ្នះលើពួកគេ»។
ឯងភ័យខ្លាចនឹងចុះទៅ
អ្នកអាចធ្វើឲ្យវាកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្លាចក្នុងការចុះទៅវាយលុក»។
ពូរ៉ា
នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។
ហើយសេចក្តីក្លាហានរបស់អ្នកនឹងចម្រើនកម្លាំងឡើង
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយអ្វីដែលអ្នកឮនឹងបានលើកទឹកចិត្តដល់អ្នក»។
ប៉មយាម
ទីកន្លែងដែលនៅតាមកាច់ជ្រុងនៅក្នុងតំបន់នោះ ជាកន្លែងដែលពួកទាហានឈរដើម្បីយាមមើលខ្មាំងសត្រូវ។
Judges 7:12
មានកណ្តូបក្រាស់ដូចជាពពក
ពាក្យ «ពពក» មានន័យថាមួយហ្វូង។ អ្នកនិពន្ធនិយាយពីទាហានជាហ្វូងប្រៀបដូចជាហ្វូងកណ្តូប ដើម្បីបញ្ជាក់ថាមានទាហានច្រើននៅទីនោះ។
សត្វអូដ្ឋរបស់ពួកគេមានច្រើនជាង... គ្រាប់ខ្សាច់នៅតាមឆ្នេរសមុទ្រទៅទៀត
អ្នកនិពន្ធប្រើទិដ្ឋភាពជាក់ស្តែង ជាការបំផ្លើស ដើម្បីបញ្ជាក់ថាមានសត្វអូដ្ឋជាច្រើន។
សត្វអូដ្ឋរបស់ពួកគេមានច្រើនជាងដែលអាចរាប់ចំនួនបាន
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «អូដ្ឋរបស់ពួកគេដែលគ្មាននរណាអាចរាប់អស់»។ ។
Judges 7:13
នេះគឺគ្មានអ្វីក្រៅពីអាវុធរបស់គេឌាន
ពាក្យ «ដាវរបស់គេឌាន» សំដៅលើការវាយប្រហាររបស់ទាហានលោកគេឌាន។
របៀបផ្សេងទៀតនៃការបកប្រែ: «នំប៉័ងមួយដុំនៅក្នុងសុបិនរបស់អ្នកគឺជាទាហានរបស់លោកគេឌាន»។
ព្រះអម្ចាស់បានប្រទានឲ្យគាត់មានជ័យជម្នះលើជនជាតិម៉ាឌាន
ព្រឹត្តការណ៍អនាគត និយាយប្រៀបដូចជាព្រឹត្តការណ៍ដែលបានកើតឡើងហើយ។ ឃ្លានេះ ដើម្បីបញ្ជាក់ថា វានឹងកើតឡើង។
«ព្រះជាម្ចាស់នឹងជួយអ៊ីស្រាអែលឲ្យយកឈ្នះលើជនជាតិម៉ាឌាន។
Judges 7:15
មនុស្សទាំងបីរយនាក់
«៣០០នាក់»
Judges 7:17
សម្រាប់ព្រះជាម្ចាស់ និងសម្រាប់លោកគេឌាន!
ពាក្យ «យើងប្រយុទ្ធ» ប្រើដើម្បីបញ្ជាក់។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងប្រយុទ្ធ ដើម្បីព្រះអម្ចាស់ និង ដើម្បីលោកគេឌាន!»
Judges 7:19
មនុស្សមួយរយនាក់
«១០០នាក់»
គឺវេលាខាងស្តាំក្នុងការចាប់ផ្តើមនៃពាក់កណ្តាលនាឡិកា។
ចាប់ផ្តើមនៅចំពាក់កណ្តាលនាឡិកា អាចនៅត្រង់ម៉ោង ១០យប់។
Judges 7:20
ដាវរបស់ព្រះជាម្ចាស់ និងដាវរបស់លោកគេឌាន
ពាក្យ «ដាវ» សំដៅលើការប្រយុទ្ធរបស់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងប្រយុទ្ធដើម្បីព្រះជាម្ចាស់ និងដើម្បីលោកគេឌាន»។
Judges 7:22
ផ្លុំត្រែទាំងបីរយ
«ត្រែ៣០០»
ព្រះជាម្ចាស់បានធ្វើឲ្យជនជាតិម៉ាឌានកាប់សម្លាប់គ្នាដៃគូរបស់គេ
ពាក្យ «ដាវ» សំដៅលើការប្រយុទ្ធរបស់ពួកគេដោយប្រើដាវ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់បានធ្វើឲ្យទាហានជនជាតិម៉ាឌានប្រយុទ្ធជាមួយនឹងទាហានគ្នាឯង»។
បេត ស៊ីតា...សេរេរ៉ា...អេបិលមេហូឡា...តាបាត។
ទាំងនេះគឺជាឈ្មោះរបស់ទីក្រុងផ្សេងៗ។
ជនជាតិអ៊ីស្រាអែលប្រមូលគ្នាមកពីកុលសម្ព័ន្ធ ណែបថាលី អាស៊ើរ
និងកុលសម្ព័ន្ធម៉ាណាសេទាំងអស់ ហើយពួកគេដេញតាម
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកគេឌានបានហៅទាហានអ៊ីស្រាអែលទាំងអស់ឲ្យចេញពីពីកុលសម្ព័ន្ធ ណែបថាលី អាស៊ើរ និងកុលសម្ព័ន្ធម៉ាណាសេ»។
Judges 7:24
បេត បារ៉ា
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
កាន់កាប់នៅត្រង់ទន្លេយ័រដាន រហូតដល់ បេត បារ៉ា ដើម្បីបញ្ឈប់ពួកគេ
«គ្រប់គ្រងនៅតំបន់ទន្លេយ័រដាន់ រហូតដល់បេត បារ៉ា»។
នៅត្រង់ថូរបស់លោកអូរិប...នៅត្រង់ធុងគៀបផ្លែទំពាំងបាយជូររបស់លោកសៀប
ឈ្មោះទាំងនេះ
បានដាក់បន្ទាប់ពីជនជាតិអ៊ីស្រាអែលបានសម្លាប់លោកអូរិបនិងលោកសៀបនៅទីនោះ។
លោកអូរិប...លោកសៀប
នេះគឺជាឈ្មោះរបស់បុរស។

---

8 [1]មនុស្សពីកុលសម្ព័ន្ធអេប្រាអ៊ីមនិយាយទៅកាន់លោកគេឌានថា៖ «តើអ្នកបានធ្វើអ្វីយ៉ាងនេះ ចំពោះយើង? ហេតុអ្វីបានជាអ្នកមិនហៅយើង
ពេលដែលអ្នកចេញទៅច្បាំងនឹងពួកម៉ាឌាន»។ ពួកគេបានបន្ទោសលោកយ៉ាងខ្លាំង។
[2]លោកតបទៅពួកគេថា៖ «តើខ្ញុំបានធ្វើអ្វី ដែលល្មមប្រៀបផ្ទឹមនឹងអ្នកបាន? តើការបេះសន្សំផ្លែទំពាំងបាយជូររបស់អេប្រាអ៊ីម
វាប្រសើរជាងការប្រមូលផលទំពាំងបាយជូររបស់អ័ប៊ីស៊ើរយ៉ាងណាទៅ?[3]ព្រះអម្ចាស់បានប្រទានឲ្យអ្នករាល់គ្នាមានជ័យជម្នះលើ អូរិប និង សៀប ជាមេលើជនជាតិម៉ាឌាន!
ដូច្នេះ តើខ្ញុំបានធ្វើអ្វីដែលអាចប្រៀបនឹងកិច្ចការរបស់អ្នករាល់គ្នាបាន?» បន្ទាប់ពី លោកមានប្រសាសន៍យ៉ាងនេះហើយ នោះកំហឹងរបស់ពួកគេក៏បានអន់ថយ។
[4]លោកគេឌាន និងមនុស្សទាំងបីរយនាក់ដែលនៅជាមួយលោកបានមកកាន់ទន្លេយ័រដាន់ ហើយឆ្លងទន្លេទៅ។ ពួកគេមានការនឿយហត់យ៉ាងខ្លាំង ប៉ុន្តែ
ពួកគេនៅតែបន្តដេញតាមពួកម៉ាឌាន។[5]លោកបាននិយាយទៅកាន់មនុស្សដែលនៅស៊ូកូតថា៖ «សូមមេត្តាចែកនំប៉័ងដល់មនុស្សដែលមកជាមួយខ្ញុំផង ដ្បិត
ពួកគេហត់នឿយណាស់ហើយ ហើយខ្ញុំកំពុងដេញតាមសេបា និងសាលមូណា ជាស្តេចរបស់ជនជាតិម៉ាឌាន»។
[6]នោះមេដឹកនាំនៃស៊ូកូតបានមានប្រសាសន៍ថា៖ «តើឥឡូវនេះ សេបា និងសាលមូណា បានធ្លាក់ក្នុងកណ្តាប់ដៃរបស់អ្នកហើយឬ?
ហេតុអ្វីបានជាយើងត្រូវឲ្យនំប៉័ងទៅទាហានរបស់អ្នក?»[7]លោកគេឌានតបវិញថា៖ «នៅពេលដែលព្រះអម្ចាស់ប្រទានឲ្យយើងមានជ័យជម្នះលើ សេបា និង សាលមូណា
ខ្ញុំនឹងក្រចៅសាច់របស់អ្នកដោយបន្លាពីវាលរហោស្ថាន និងបន្លាស្ពឺត»។
[8]រួចលោកក៏ចាកចេញពីទីនោះទៅ ពេនួល ហើយសូមពួកគេ ដូចដែលបានសូមនៅស៊ូកូតដែរ ប៉ុន្តែ ពួកអ្នកនៅ ពេនួល នោះបានឆ្លើយដូចគ្នានឹងអ្វីដែលពួកអ្នក
ស៊ូកូតបានឆ្លើយ។[9]លោកក៏បានមានប្រសាសន៍ទៅកាន់អ្នកស្រុកពេនួលថា៖ «នៅពេលដែលខ្ញុំត្រឡប់មកវិញដោយសុខសាន្ត ខ្ញុំនឹងរលំប៉មនេះចោល»។
[10]ចំណែកឯ សេបា និង សាលមូណាពួកគេបានចូលទៅក្នុងក្រុង កើរកូ ទាំងមានកងទ័ពប្រហែល មួយម៉ឺនប្រាំពាន់នាក់នៅជាមួយផង
គឺអស់អ្នកទាំងប៉ុន្មានដែលសល់ពីទាហានរបស់ពួកមនុស្សនៅស្រុកខាងកើត ពីព្រោះមនុស្សរបស់ពួកគេ ចំនួនមួយសែនពីរម៉ឺននាក់ដែលកាន់ដាវ
បានដួលស្លាប់អស់ហើយ។

generated on Wed Sep 10 16:16:32 2025

[11]ដូច្នេះ លោកគេឌានបានឡើងទៅតាមផ្លូវរបស់ពួករស់ក្នុងតង់ ត្រង់ស្រុកខាងកើតណូបា និង យ៉ូបេហា។ លោកបានវាយប្រហារពលទាហានរបស់ឃ្មាំងសត្រូវ
ព្រោះពួកគេមិនបានរំពឹងថាមានការវាយប្រហារនោះទេ។[12]សេបា និង សាលមូណាបានរត់គេចខ្លួន ប៉ុន្តែ លោកគេឌានបានដេញតាម និង
ចាប់ពួកគេបានស្តេចទាំងពីរអង្គរបស់ម៉ាឌានបាន ព្រមទាំងបំបាក់ទ័ពទាំងមូលរបស់គេផង។
[13]លោកគេឌាន កូនប្រុសលោកយ៉ូអាស បានត្រឡប់ពីធ្វើសង្គ្រាមវិញ ឆ្លងកាត់ឡើងទៅភ្នំ ហេរេស។[14]លោកបានចាប់ក្មេងជំទង់ម្នាក់ពីក្នុងពួកសិកូត
ហើយសុំយោបល់ពីក្មេងនោះ។ ក្មេងជំទង់នោះបានពណ៌នាអំពីមេដឹកនាំ និងចាស់ទុំរបស់សិកូត ថាមានចំនួន ចិតសិបប្រាំពីរនាក់។
[15]លោកក៏មកឯពួកអ្នកនៅសិកូត និងប្រាប់ថា៖ «មើល៍នេះណែ! សេបា និងសាលមូណាដែរ ដោយសាគេ អ្នករាល់គ្នាបានមើលងាយដល់ខ្ញុំថា តើសេបា និងសាលមូណា
បានធ្លាក់មកក្នុងកណ្តាប់ដៃអ្នកហើយឬនៅ បានជាយើងត្រូវចែកនំប៉័ងឲ្យដល់ទាហានរបស់អ្នកដែលអត់ហត់នឿយនោះ?[16]លោកគេឌាន បានចាប់ចាស់ទុំរបស់ក្រុងនេះ
ហើយនិងមនុស្សទាំងប៉ុន្មាននៃក្រុងសិកូតមកវាយផ្ចាល់ដោយបន្លាពីវាលរហាស្ថាន និងបន្លារស្មិត។[17]បន្ទាប់មកលោករលំប៉មនៅពេនួល
និងសម្លាប់មនុស្សដែលនៅក្រុងនោះ។
[18]បន្ទាប់មក លោកគេឌានបានសួរសេបា និងសាលមូណា ថា៖ «តើមនុស្ស ប្រភេទណាដែលអស់លោកសម្លាប់នៅតាបោរ? ពួកគេឆ្លើយថា៖
«ពួកគេមើលទៅប្រហាក់ប្រហែលនឹងលោកដែរ! គ្រប់គ្នាមានចរិតលក្ខណដូចជាបុត្ររបស់ស្តេច»។[19]លោកគេឌានឆ្លើយថា៖ «ពួកគេគឺជាបងប្អូនរបស់យើង
គឺជាកូនប្រុសរបស់ម្តាយយើង។ យើងស្បថនឹងព្រះអម្ចាស់ដែលមានជីវិតគង់នៅ ប្រសិនបើឯង បានទុកឲ្យគេមានជីវិត នោះយើងនឹងមិនសម្លាប់ឯងទេ។
[20]ដូច្នេះ លោកបង្គាប់ទៅយេធើ ជាកូនច្បងរបស់លោកថា៖ «ចូរក្រោកឡើងហើយសម្លាប់ពួកគេទៅ!» ប៉ុន្តែ បុរសវ័យក្មេងនោះមិនហ៊ានដកដាវរបស់គេទេ
ដោយសារតែភាពភ័យខ្លាច ព្រោះតែលោកនៅជាក្មេងប្រុសម្នាក់នៅឡើយ។[21]សេបា និងសាលមូណាបាននិយាយថា៖ «ចូរក្រោកឡើង
ហើយសម្លាប់យើងដោយដៃរបស់អ្នកផ្ទាល់ទៅ ដ្បិតគួរឲ្យមនុស្សពេញកម្លាំងសម្លាប់យើងវិញ»។ នោះ លោកគេឌានបានក្រោកឡើង ហើយសម្លាប់ សេបា
និងសាមូលណាទៅ ព្រមទាំងដោះយកគ្រឿងលំអដែលគេបំពាក់សត្វអូដ្ឋនោះមកផង។
[22]គ្រានោះ ប្រជាជនអ៊ីស្រាអែល និយាយទៅកាន់លោកគេឌានថា៖ «សូមលោក ទាំងកូន និងចៅរបស់លោក ឡើងគ្រងរាជ្យលើយើងខ្ញុំ!
ព្រោះលោកបានរំដោះយើងចេញពីកណ្តាប់ដៃរបស់ម៉ាឌាន»។[23]លោកគេឌានឆ្លើយវិញថា៖ «ខ្ញុំនឹងមិនគ្រងរាជ្យលើអ្នករាល់ទេ ហើយទោះបីជាកូនរបស់ខ្ញុំក៏ដោយ
ក៏មិនគ្រងរាជ្យលើអ្នករាល់គ្នាដែរ គឺព្រះអម្ចាស់នឹងគ្រងរាជ្យលើអ្នករាល់គ្នា»។
[24]លោកគេឌានមានប្រសាសន៍ទៀតថា៖ «សូមអនុញ្ញាតឲ្យខ្ញុំសុំអ្វីមួយពីអ្នករាល់គ្នា: ចូរអ្នកគ្រប់គ្នាប្រគល់ក្រវិលដែលបានពីរបឹបនោះមកឲ្យខ្ញុំ
(ជនជាតិម៉ាឌានទាំងអស់សុទ្ធតែមានក្រវិលមាស ព្រោះគេជាកូនចៅអ៊ីស្មាអែល)[25]ពួកគេឆ្លើយថា៖ «យើងនឹងជូនលោកដោយស្ម័គ្រពីចិត្ត»។ ពួកគេបានត្រដាងអាវ
រួចយកក្រវិលដែលបានពីរបឹបរបស់ពួកគេដាក់លើអាវនោះ។
[26]ក្រវិលមាសទាំងអស់មានទម្ងន់សរុប មួយពាន់ប្រាំពីររយស៊ីគែលមាស។ របឹបទាំងនេះមិនរាប់បញ្ចូល បណ្តោង ក្រវិល ហើយនឹងសម្លៀកបំពាក់ពណ៌ស្វាយ
ដែលពួកស្តេចម៉ាឌានស្លៀកពាក់ និងខ្សែច្រវ៉ាក់ដែលពាក់នៅនឹងករសត្វអូដ្ឋរបស់ពួកគេនោះទេ។
[27]លោកគេឌានបានយកក្រវិលនោះទៅសិតធ្វើជារូបបដិមាមួយដាក់នៅក្នុងក្រុងរបស់គេ គឺនៅអូប្រា
ដូច្នេះហើយជនជាតិអ៊ីស្រាអែលទាំងអស់ក៏ក្បត់នឹងព្រះអម្ចាស់ដោយថ្វាយបង្គំបដិមាករនោះ ហើយវាបានត្រឡប់ទៅជាអន្ទាក់សម្រាប់គាត់និងមនុស្សគ្រួសារគាត់។
[28]ចំណែកឯជនជាតិម៉ាឌានត្រូវក្រាបមុខចំពោះជនជាតិអ៊ីស្រាអែលឥតងើបក្បាលរួចនោះទេ ដូច្នេះ ទឹកដីក៏បានសុខសាន្តអស់រយៈពេលសែសិបឆ្នាំ។
[29]លោកយេរូប បាល កូនរបស់លោកយ៉ូអាស រីលត្រឡប់ទៅរស់នៅក្នុងផ្ទះរបស់គាត់វិញ។[30]លោកគេឌាន មានកូនប្រុសទាំងអស់ចិតសិបនាក់ ដែលជាពូជពង្សរបស់លោក
ព្រោះលោកមានប្រពន្ធច្រើន។[31]ប្រពន្ធចុងរបស់លោកដែលនៅស៊ីគែម បានបង្កើតកូនប្រុសម្នាក់អោយលោក ដែលលោកបានដាក់ឈ្មោះថា អប៊ីម៉ាឡេក។
[32]លោកគេឌាន កូនរបស់លោកយ៉ូអាសបានរស់នៅយ៉ាងយូរ ហើយក៏ទទួលមរណភាពទៅ សពរបស់លោកត្រូវបានគេបញ្ចុះនៅក្នុងផ្នូររបស់លោកយ៉ូអាស
ជាឪពុករបស់លោក នៅអូប្រា ជាភូមិរបស់អំបូរអ័បៀសើរ។[33]ក្រោយពីលោកទទួលមរណភាពទៅ ជនជាតិអ៊ីស្រាអែល បានក្បត់នឹងព្រះអម្ចាស់
គឺពួកគេត្រឡប់ទៅថ្វាយបង្គំព្រះបាល។ ពួកគេយកព្រះ បាល - បេរិត ធ្វើជាព្រះរបស់ពួកគេ។
[34]ជនជាតិអ៊ីស្រាអែល លែងចងចាំ នឹងស្មោះត្រង់ជាមួយព្រះអម្ចាស់ ជាព្រះដែលបានរំដោះពួកគេចេញពីដៃខ្មាំងសត្រូវនៅគ្រប់ទិសទីរបស់ពួកគេទៀតហើយ។
[35]ពួកគេមិនបានរក្សាពាក្យសន្យារបស់ពួកគេនឹងលោកយេរូប បាល គឺលោកគេឌាន គឺពួកគេបានបែរចេញពីការល្អគ្រប់យ៉ាងដែលគាត់បានធ្វើចំពោះជាជាតិអ៊ីស្រាអែល។

Judges 8:1
តើនេះជាអ្វីដែលអ្នកបានធ្វើចំពោះយើងឬ?
ប្រជាជននៃក្នុងកុលសម្ពន្ធអេប្រាអ៊ីម
បានស្តីបន្ទោសលោកគេឌានដោយសំណួរដែលមិនទាមទារចម្លើយ
ដោយមិនបានរួមបញ្ចូលពួកគេទៅក្នុងទាហានទេ។
ឃ្លានេះនិយាយជាប្រយោគក៏បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកប្រព្រឹត្តនឹងយើងមិនស្មើរភាពទេ»។
ប្រយុទ្ធប្រឆាំងនឹងជនជាតិម៉ាឌាន
ពាក្យ «ម៉ាឌាន» តំណាងឲ្យទាហានរបស់ម៉ាឌាន។
ពួកគេបានបន្ទោសលោកយ៉ាងខ្លាំង
ពួកគេបានបន្ទោសលោកយ៉ាងខ្លាំង ពួកគេខឹងឈ្លោះជាមួយលោក» ឬ
«ពួកគេស្តីបន្ទោសលោកយ៉ាងខ្លាំង» ។
Judges 8:2
ព័ត៌មានទូទៅ
លោកគេឌានឆ្លើយតបទៅពួកគេពីអេប្រាអ៊ីម។
ឥឡូវតើខ្ញុំបានធ្វើអ្វី ដែលប្រៀបផ្ទឹមនឹងអ្នកបាន?
លោកគេឌានប្រើសំណួរនេះ ដើម្បីផ្តល់កិត្តិយសដល់ប្រជាជនអេប្រាអ៊ីម។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានធ្វើការតិចតួចណាស់
បើប្រៀបធៀបទៅនឹងអ្វីដែលបងប្អូនបានធ្វើ»
តើការបេះសន្សំផ្លែទំពាំងបាយជូររបស់អេប្រាអ៊ីម
វាប្រសើរជាងការប្រមូលផលទំពាំងបាយជូររបស់លោកអបៀស៊ើរយ៉ាងណាទៅ?
លោកគេឌានបានរំងាប់អារម្មណ៍របស់ប្រជាជនអេប្រាអ៊ីមដោយប្រើសំណួរដែលមិនទាមទារចម្លើយ
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាកដណាស់
ទំពាំងបាយជូររបស់ប្រជាជនអេប្រាអ៊ីម ប្រសើរជាងអ្វីដែលកូនចៅរបស់លោក
អបៀស៊ើរប្រមូលផលពេញមួយរដូវ»។ (សូមមើល:
លោកអបៀស៊ើរ
នេះគឺជាឈ្មោះពូជពង្សរបស់លោកគេឌាន។
លោកគេឌានប្រើឈ្មោះរបស់គាត់ដើម្បីសំដៅលើពូជពង្សលោកអបៀស៊ើរ
និងទឹកដីរបស់ពួកគេ។
អូរិប និងសៀប
សូមបកប្រែឈ្មោះទាំងនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៧:២៤។
តើខ្ញុំបានសម្រេចអ្វីខ្លះ បើប្រៀបផ្ទឹមនឹងបងប្អូន?
លោកគេឌានប្រើសំណួរនេះដើម្បីផ្តល់កិត្តិយសដល់ប្រជាជនអេប្រាអ៊ីម។ ឃ្លានេះ
អាចបញ្ជាក់ដូចជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលបងប្អូនបានធ្វើ សំខាន់ជាអ្វីដែលខ្ញុំបានធ្វើ»។
បានអន់ចិត្ត
«លែងសំខាន់»។
Judges 8:4
បីរយនាក់
«មនុស្ស៣០០នាក់»
បន្តការដេញតាម
ពាក្យ «ដេញតាម» ជានាមអរូប អាចនិយាយជាកិរិយាសព្ទក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្តដេញតាមខ្មាំងសត្រូវរបស់ពួកគេ»។ ។
សេបា និងសាលមូណា
ឈ្មោះរបស់មនុស្ស។
Judges 8:6

generated on Wed Sep 10 16:16:32 2025

តើឥឡូវនេះដៃរបស់ សេបា និងសាលមូណា បាននៅធ្លាក់ក្នុងកណ្តាប់ដៃរបស់អ្នកហើយឬ?
អ្នកដឹកនាំប្រើសំណួរនេះ ដើម្បីបញ្ជាក់ថាអ៊ីស្រាអែលមិនបានចាប់ខ្លួន សេបា
និងសាលមូណា នៅឡើយទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនទាន់ចាប់ខ្លួនសេបា និងសាលមូណា នៅឡើយទេ»។
ដៃរបស់ សេបា និងសាលមូណា
ពាក្យ «ដៃ» នៅទីនេះ សំដៅលើ រូបកាយទាំងមូល។
ឥឡូវនេះ ធ្លាក់ក្នុងកណ្តាប់ដៃរបស់អ្នកហើយ
ពាក្យ «ដៃ» នៅទីនេះ សំដៅលើអំណាច និងការគ្រប់គ្រង។
ហេតុអ្វីបានជាយើងត្រូវឲ្យនំប៉័ងទៅទាហានរបស់អ្នក?
អ្នកដឹកនាំប្រើសំណួរនេះ ដើម្បីបញ្ជាក់ថា
ពួកគេគ្មានហេតុនឹងឲ្យនំប៉័ងទៅជនជាតិអ៊ីស្រាអែលទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងគ្មានហេតុនឹងឲ្យនំប៉័ងទៅទាហានរបស់លោកទេ»។
ខ្ញុំនឹងក្រចៅស្បែករបស់អ្នកមួយបន្លាពីវាលរហោស្ថាន និងបន្លាស្ពឹត
អត្ថន័យពេញនៅក្នុងសេចក្តីថ្លែង ដើម្បីឲ្យច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងខ្វារដោយបន្លាពីទីរហោស្ថាន និងបន្លាស្ពឹត
ហើយប្រើពួកគេឲ្យវាយអ្នកហើយកាត់អ្នកជាដុំៗ។
បន្លា និងបន្លាស្ពឹត
ស្រួច លេចចេញមកក្រៅ នៅលើដើមទំពាំងបាយជូរ ឬ
ដើម្បីក្រួចដែលលេចចេញមកក្រៅ ហើយអាចមុតដល់មនុស្សឬសត្វ។
Judges 8:8
លោកបានចាកចេញពីទីនោះទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកគេឌាន។
លោកគេឌានតំណាងឲ្យពួកទាហានដែលតាមលោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានចេញពីទីនោះ» ឬ
«លោកគេឌាននិងទាហានរបស់លោក ៣០០នាក់បានចេញពីទីនោះ»។
ពេនួល
ជាឈ្មោះរបស់ទីកន្លែងមួយ។
បាននិយាយទៅកាន់មនុស្សដែលនៅទីនោះ ដូចគ្នាដែរ
អ្នកអាធ្វើឲ្យព័ត៌មាននេះកាន់តែយល់ច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«សួររកអាហារនៅទីនោះ ដូចគ្នាដែរ» ឬ
«លោកបានសួររកអាហារពីពួកគេដូចគ្នាដែរ»។
នៅពេលដែលខ្ញុំត្រឡប់មកវិញដោយសុខសាន្ត
ឃ្លានេះនិយាយដោយសុភាព សំដៅលើការយកឈ្នះលើខ្មាំងសត្រូវរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់ពីខ្ញុំបានយកឈ្នះទាហានរបស់ជនជាតិម៉ាឌានរួចហើយ»។
ខ្ញុំនឹងរលំប៉មនេះចោល
ពាក្យ «ខ្ញុំ» នៅទីនេះ សំដៅលើលោកគេឌាន និងទាហានរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ទាហានរបស់ខ្ញុំ
ហើយនិងខ្ញុំនឹងរំលំប៉មនេះចោល»។
Judges 8:10
ឥឡូវ
ពាក្យនេះ ប្រើនៅទីនេះ ដើម្បីសម្គាល់ពីការសម្រាកនៅក្នុងសាច់រឿងចម្បង។
អ្នកអត្ថាធិប្បាយបានចាប់ផ្តើមប្រាប់ពីផ្នែកថ្មីនៃសាច់រឿង។
សេបា និង សាលមូណា
សូមបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៨:៤។
ក្រុងកើរកូ
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
មួយម៉ឺនប្រាំពាន់នាក់
«១៥,០០០នាក់»
បានដួលស្លាប់
នេះគឺជាវិធីគួរសមក្នុងការនិយាយសំដៅលើមនុស្សដែលស្លាប់ក្នុងសង្គ្រាម។
របៀបផ្សេងទៀតនៃការបកប្រែ: «ដែលបានស្លាប់» ឬ
«ដែលបានស្លាប់នៅក្នុងសមរភូមិ»។
ដែលបានហ្វឹកហាត់ប្រយុទ្ធជាមួយដាវ
នេះគឺជាវិធីក្នុងការសំដៅលើទាហាន។ របៀបផ្សេងទៀតនៃការបកប្រែ:«ទាហាន»។
ជាមួយដាវ
ពាក្យ «ដាវ» តំណាងឲ្យដាវ
និងអាវុធផ្សេងទៀតដែលពួកទាហានប្រើនៅក្នុងសមរភូមិ។
Judges 8:11
លោកគេឌានក៏បានឡើងទៅ
ពាក្យ «គេឌាន» តំណាងឲ្យទាហានរបស់លោកគេឌានទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកគេឌាន
និងទាហានរបស់លោកបានឡើងទៅ»
លោកបានវាយប្រហារ
ពាក្យ «លោក» សំដៅលើលោកគេឌាន
ដែលតំណាងឲ្យទាហានទាំងអស់របស់លោក។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកគេឌាន និងទាហានរបស់លោកទាំងអស់បានយកឈ្នះ»។
ណូបា និង យ៉ូបេហា
នេះគឺជាឈ្មោះរបស់ទីក្រុង។
សេបា និង សាលមូណា
សូមបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៨:៤។
បំបាក់ទ័ព
មានការភ័យខ្លាចយ៉ាងខ្លាំង ដែលធ្វើឲ្យមនុស្សមិនអាចគិត ឬធ្វើអ្វីដូចធម្មតាឡើយ។
Judges 8:13
ឆ្លងកាត់ឡើងទៅភ្នំហេរេស
នេះគឺជាឈ្មោះផ្លូវដែលឆ្លងកាត់ភ្នំពីរ។
លោកបានរត់ទៅរកក្មេងជំទង់ម្នាក់
ឃ្លានេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានជួបយុវជនម្នាក់»។
សុំយោបល់ពីគាត់
ឃ្លានេះអាចបញ្ជាក់យ៉ាងច្បាស់ពីអ្វីដែលលោកគេឌានបានសូមពីយុវជនម្នាក់នោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកសូមគាត់ឲ្យបង្ហាញអត្តសញ្ញាណឈ្មោះរបស់អ្នកដឹកនាំនៅក្នុងទីក្រុង»។
មានចំនួន ចិតសិបប្រាំពីរនាក់
បុរសចិតសិបប្រាំពីរនាក់ «៧៧នាក់»។
Judges 8:15
សេបា និង សាលមូណា
សូមបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៨:៤។
តើអ្នកបានច្បាំងដណ្តើម សេបា និងសាលមូណា រួចរាល់ហើយឬ?
លោកគេឌានបានដកស្រង់សម្តីរបស់ប្រជាជនសូកូត ដោយប្រើសំណួរមួយនេះ
ដើម្បីចំអក់ឲ្យគាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនទាន់យកឈ្នះ សេបា
និងសាលមូណាទេឬ?
លោកគេឌាន បានចាប់...ធ្វើទោសលោកបានរុញ
ពាក្យ «គេឌាន» នៅទីនេះ តំណាងឲ្យពួកទាហានរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកគេឌាន
និងទាហានរបស់លោកបានចាប់...ពួកគេដាក់ទោស...ពួកគេបានរុញ»។
បន្លានិងបន្លារស្ពឹត
ស្រួច លេចចេញមកក្រៅ នៅលើដើមទំពាំងបាយជូរ ឬ
ដើម្បីក្រួចដែលលេចចេញមកក្រៅ ហើយអាចមុតដល់មនុស្សឬសត្វ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៨:៦។
ពេនួល
សូមបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៨:៨។
Judges 8:18
សេបា និង សាលមូណា
សូមបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៨:៤។
ក្រុងតាបោរ
សូមបកប្រែឈ្មោះក្រុងនេះ ឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៤:៦។
ពួកគេមើលទៅដូចគ្នានឹងលោក
«ពួកគេមើលទៅដូចលោកដែរ» ។
ព្រះអម្ចាស់ដែលមានជីវិតគង់នៅ
នេះគឺជាពាក្យប្រៀបធៀប
គឺជាការស្បថបែបសាសនាដែលថាអ្វីដែលគាត់និយាយគឺជាសេចក្តីពិត។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំសន្យាជាមួយលោកថា»។
Judges 8:20
យេធើរ
នេះគឺជាឈ្មោះកូនប្រុសរបស់លោកគេឌាន។
ដ្បិតគួរឲ្យមនុស្សពេញវ័យ ដូច្នេះគឺជាកម្លាំង

generated on Wed Sep 10 16:16:32 2025

នេះគឺជាពាក្យ ប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះគឺជាការងារសម្រាប់ឲ្យមនុស្សធ្វើ»។ ។
គ្រឿងលំអ
គ្រឿងលំអនេះមានរាងជារង្វង់ ដែលមានចំណុចពីភ្ជាប់គ្នា។
រាងនេះអាចឃើញដូចជាដួងចន្ទគ្រប់ដោយស្រមោល។
តុបតែង
«តែងលំអ»
Judges 8:22
ចេញពីកណ្តាប់ដៃរបស់ជនជាតិម៉ាឌាន
ពាក្យ «ដៃ» តំណាងឲ្យអំណាចរបស់ជនជាតិម៉ាឌាននៅលើអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីអំណាចរបស់ជនជាតិម៉ាឌាន» ឬ
«ពីជនជាតិម៉ាឌាន»។
ពីជនជាតិម៉ាឌាន
ពាក្យ «ម៉ាឌាន» នៅទីនេះ តំណាងឲ្យជនជាតិម៉ាឌាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីជនជាតិម៉ាឌាន»។
Judges 8:24
លោកគេឌានបាននិយាយទៅពួកគេ
«លោកគេឌានបាននិយាយទៅប្រជាជនអ៊ីស្រាអែល»។
ក្រវិល
គ្រឿងអលង្ការ ពាក់នៅនឹងត្រចៀក។
រមឹប
របស់របរដែលលួចបាន ដោយប្រើកម្លាំង
ឬយកពីនរណាម្នាក់ដោយសម្លាប់នៅក្នុងសង្គ្រាម។
ជនជាតិម៉ាឌានមានក្រវិលមាស ពីព្រោះគេជាជនជាតិអ៊ីស្មាអែល
នៅទីនេះ អ្នកអត្ថាធិប្បាយប្រាប់ព័ត៌មានពីប្រវត្តិរបស់ជនជាតិម៉ាឌាន។
អាវ
អាវដែលធ្វើពីក្រណាត់មួយយ៉ាងធំ ហើយពាក់ពីលើស្មាដូចជាអាវធំដែរ។
Judges 8:26
មួយពាន់ប្រាំពីររយស៊ីគែលមាស
ប្រសិនបើចាំបាច់ត្រូវប្រើរង្វាស់បច្ចុប្បន្ន នៅទីនេះមានវិធីពីរយ៉ាងក្នុងការវាស់វា។
របៀបផ្សេងទៀតនៃការបកប្រែ: «មាស១៨.៧គីឡូក្រាម» ឬ
«ប្រហែលជាមាស២០គីឡូក្រាម»។
គ្រឿងលំអ
សូមបកប្រែឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ៨:២០។
បណ្តោង
ជុំតូចៗរបស់គ្រឿងអលង្ការដែលព្យួរនៅចុងនៃខ្សែ ឬ ខ្សែករ
បានពាក់ដោយពួកស្តេចម៉ាឌាន
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងតៀតនៃការបកប្រែ:
«ដែលស្តេចរបស់សាសន៍ម៉ាឌានពាក់» ។
Judges 8:27
លោកគេឌានបានធ្វើអេផូឌពីក្រវិលទាំងនោះ
«លោកគេឌានបានយកមាសពីក្រវិលនោះទៅធ្វើជាអេផូឌមួយ»។
អូប្រា
សូមបកប្រែឈ្មោះទីក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ៦:១១។
ជនជាតិអ៊ីស្រាអែលទាំងអស់បានប្រព្រឹត្តពេស្យាចារដោយរូបកាយរបស់គេដោយថ្វាយបង្គំវានោះ
ឃ្លានេះ ប្រៀបប្រដូចការថ្វាយបង្គំព្រះកន្លែងក្លាយ ទៅនឹងអំពើពេស្យាចារ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ជនជាតិអ៊ីស្រាអែលបានធ្វើបាបទាស់នឹងព្រះអម្ចាស់ដោយថ្វាយបង្គំអេផូតនៅទីនោះ»
ជនជាតិអ៊ីស្រាអែលទាំងអស់
ពាក្យ «ទាំងអស់» នៅទីនេះ គឺជាពាក្យបំផ្លើស ដើម្បីបញ្ជាក់ថា
មានមនុស្សជាច្រើនបានថ្វាយបង្គំអាវនោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានជនជាតិអ៊ីស្រាអែលជាច្រើនបានថ្វាយបង្គំអាវនោះ»។
វាបានត្រឡប់ទៅជាអន្ទាក់សម្រាប់គេឌាននិងសម្រាប់អស់អ្នកដែលនៅក្នុងផ្ទះរបស់គាត់។
ឃ្លានេះ និយាយពីលោកគេឌាន
និងគ្រួសាររបស់លោកដែលធ្លាប់ល្បួងទៅក្នុងការថ្វាយបង្គំអេផូតនោះ។
គឺប្រៀបដូចជាអន្ទាក់របស់ព្រានដែលធ្វើឲ្យពួកគេជាប់អន្ទាក់នោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាបានត្រឡប់ជាសេចក្តីល្បួងសម្រាប់លោកគេឌាន និងគ្រួសាររបស់លោក» ឬ
«លោកគេឌាន និងគ្រួសាររបស់គាត់បានធ្វើបាបដោយថ្វាយបង្គំវា»។
និងគ្រួសាររបស់លោក
ពាក្យ «ផ្ទះរបស់លោក» តំណាងឲ្យគ្រួសាររបស់លោកគេឌាន។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្រាប់គ្រួសាររបស់គាត់»។
ដូច្នេះជនជាតិម៉ាឌានត្រូវក្រាបមុខចំពោះជនជាតិអ៊ីស្រាអែល
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
ព្រះអម្ចាស់បានធ្វើឲ្យជនជាតិម៉ាឌានក្រាបចុះនៅចំពោះប្រជាជនអ៊ីស្រាអែល» ឬ
«ដូច្នេះ ព្រះអម្ចាស់បានជួយអ៊ីស្រាអែលឲ្យយកឈ្នះជនជាតិម៉ាឌាន»។
ពួកគេមិនបានងើបក្បាលរបស់ពួកគេម្តងទៀតនោះទេ
នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេមិនអាចវាយលុយអ៊ីស្រាអែលទៀតបានទេ»។
ដូច្នេះ ទឹកដីក៏បានសុខសាន្ត
ពាក្យ «ទឹកដី» តំណាងឲ្យប្រជាជនអ៊ីស្រាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះ ជនជាតិអ៊ីស្រាអែលបានរស់នៅដោយសុខសាន្ត»។
អស់រយៈពេលសែសិបឆ្នាំ
«៤០សិបឆ្នាំ»
នៅក្នុងថ្ងៃរបស់លោកគេឌាន
ពាក្យ «ថ្ងៃ» នៅទីនេះ សំដៅលើខ្សែជីវិតរបស់លោកគេឌាន។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងអំឡុងពេលលោកគេឌានរស់នៅ»។
Judges 8:29
លោកយេរូប បាល
នេះគឺជាឈ្មោះរបស់លោកគេឌានមួយទៀត។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះរបស់គាត់នៅក្នុងជំពូក ៦:៣១។
មានកូនប្រុសទាំងអស់ចិតសិបនាក់
«កូនប្រុស ៧០សិបនាក់»
Judges 8:32
ក្នុងអាយុដ៏ល្អ
នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលលោកអាយុច្រើន»។
បានបញ្ឆោះ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានបញ្ឆោះលោក»។
អូប្រា
សូមបកប្រែឈ្មោះទីក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ៦:១១។
អំបូរអបៀស៊ើរ
សូមបកប្រែឈ្មោះនេះនៅក្នុងក្រុមមនុស្សនេះ ដូចអ្នកបានបកប្រែនៅក្នុងជំពូក
៦:១១។
ក្រោយមក
ឃ្លានេះ ប្រើនៅទីនេះ ដើម្បីសម្គាល់ពីការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង។ ប្រសិនបើ
ភាសារបស់អ្នកមានវិធីនៃការធ្វើបែបនេះ អ្នកអាចប្រើវានៅទីនេះបាន។
បានត្រឡប់ម្តងទៀត
មនុស្សបានបដិសេធព្រះអម្ចាស់ និយាយប្រៀបដូចជាពួកគេបែរចេញពីព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេឈប់ថ្វាយបង្គំព្រះអម្ចាស់»។
បានប្រព្រឹត្តពេស្យាចារខ្លួនរបស់គេដោយថ្វាយបង្គំព្រះបាល
ឃ្លានេះ និយាយពីការថ្វាយបង្គំព្រះក្លែងក្លាយ
គឺប្រៀបដូចជាការប្រព្រឹត្តអំពើេេពស្យាចារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានធ្វើបាបទាស់នឹងព្រះអម្ចាស់ ដោយថ្វាយបង្គំព្រះបាល។
ព្រះបាល-បេរិត
ឃ្លានេះគឺជាឈ្មោះរបស់ព្រះក្លែងក្លាយ។
Judges 8:34
ចេញពីដៃខ្មាំងសត្រូវរបស់ពួកគេ
ពាក្យ «ដៃ» តំណាងឲ្យអំណាច ឬការគ្រប់គ្រង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីអំណាចខ្មាំងសត្រូវរបស់ពួកគេ» ឬ «ពីខ្មាំងសត្រូវទាំងអស់របស់ពួកគេ»។
នៅគ្រប់ទិសទី
«ដែលបានព័ទ្ធពួកគេ» ។
ផ្ទះរបស់លោកយេរូប បាល
ពាក្យ «ផ្ទះរបស់» តំណាងឲ្យគ្រួសាររបស់មនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ៖
«គ្រួសាររបស់លោកយេរូប បាល»។
លោកយេរូប បាល
នេះគឺជាឈ្មោះមួយផ្សេងទៀតរបស់លោកគេឌាន។

generated on Wed Sep 10 16:16:32 2025

9 [1]លោកអប៊ីម៉ាឡេក កូនប្រុសរបស់លោកយេរូប បាល បានទៅរកបងប្អូន និង សាច់ញាតិម្តាយរបស់លោកនៅស៊ីគែម ហើយគាត់បាននិយាយទៅកាន់បងប្អូន
និងសាច់ញាត់ទាំងអស់របសើម្តាយគាត់ថា៖[2]«សូមអ្នករាល់គ្នានិយាយមក! ដើម្បីឲ្យអ្នកមុខអ្នកការចាស់ទុំនៅស៊ីគែមទាំងអស់បានឮថា
តើអស់លោកចង់ឲ្យកូនរបស់លោកយេរូបបាលទាំងចិតសិបនាក់ គ្រប់គ្រងលើអ្នករាល់គ្នាឬ ក៏ចង់ឲ្យមានតែម្នាក់? សូមចងចាំថា ខ្ញុំជាសាច់ឈាមរបស់អស់លោកដែរ»។
[3]សាច់ញាតិខាងម្តាយរបស់លោកអប៊ីម៉ាឡេកបាននាំយកពាក្យនេះទៅជម្រាបដល់ចាស់ទុំអ្នកមុខអ្នកការរបស់ស៊ីគែម ហើយពួកគេបានគាំទ្រលោក ដោយនិយាយ៖
«លោកជាបងប្អូនរបស់យើង»។[4]ពួកគេបានយកប្រាក់ចិតសិបតម្លឹងពីព្រះវិហាររបស់ព្រះបាល បេរិតមកឲ្យលោក លោកបានយកប្រាក់នេះទៅជួលមនុស្សគ្មានច្បាប់ទម្លាប់
និងមនុស្សពាល់ឲ្យមកតាមលោក។
[5]លោកអប៊ីម៉ាឡេកបានត្រឡប់ទៅផ្ទះឪពុករបស់គាត់នៅអូរប្រា នៅទីនោះលោកបានសម្លាប់បងប្អូនប្រុសទាំងចិតសិបនាក់
ដែលជាកូនរបស់លោកយេរូបបាលក្នុងពេលតែមួយ មានតែលោកយ៉ូថាម ដែលជាកូនប្រុសពៅរបស់លោកយេរូបាលប៉ុណ្ណោះទេ ដែលនៅរស់
គឺលោកបានលាក់ខ្លួនរបស់លោក។[6]ចាស់ទុំនៅស៊ីគែម និង បេតមីឡូទាំងអស់ បានមកជួបជុំគ្នាហើយពួកគេបានលើកលោកអប៊ីម៉ាឡេកឡើងជាស្តេច គឺនៅជិតដើមជ្រៃ
ក្បែរស្តូបថ្ម ក្នុងស៊ីគែម។
[7]ពេលដែលលោកយ៉ូថាមបានទទួលដំណឹងនេះ នោះលោកក៏ឡើងទៅលើកំពូលភ្នំ កេរីស៊ីន ទាំងស្រែកយ៉ាងខ្លាំងថា៖ «ពួកចាស់ទុំនៃស៊ីគែមអើយចូលស្តាប់ ដូច្នេះ
សូមព្រះជាម្ចាស់ស្តាប់អ្នករាល់គ្នាដែរ។[8]ថ្ងៃមួយដើមឈើទាំងឡាយបានចេញស្វែងរកស្តេចគ្រងរាជ្យលើពួកគេ។ ពួកគេបាននិយាយទៅកាន់ដើមអូលីវថា៖
«ចូរគ្រងរាជ្យលើយើង»។
[9]ប៉ុន្តែ ដើមអូលីវតបវិញថា៖ «តើខ្ញុំគួរនឹងបោះបង់ប្រេងរបស់ខ្ញុំ ដែលប្រើសម្រាប់តែងតាំងព្រះនិងមនុស្ស ចោល
ហើយអោយខ្ញុំត្រឡប់ទៅយោលខ្លួនជាមួយដើមឈើឯទៀតៗឬអី?[10]រួចមកដើមឈើទាំងឡាយនិយាយទៅកាន់ដើមឧទុម្ពរថា «សូមមក ហើយគ្រងរាជ្យលើយើង!»[11]ប៉ុន្តែ
ដើមឧទុម្ពរតបវិញថា «តើគួរឲ្យខ្ញុំបោះបង់ផ្លែដ៏ល្អនិងមានរស់ជាតិដ៏ផ្អែមឆ្ងាញ់របស់ខ្ញុំចោល ហើយត្រឡប់ទៅយោលខ្លួនជាមួយដើមឈើឯទៀតៗឬ?»
[12]ពេលនោះដើមឈើទាំងឡាយនិយាយទៅកាន់ដើមទំពាំងបាយជូរថា «ចូរមកហើយគ្រងរាជ្យលើយើង!»[13]ដើមទំពាំងបាយជូរតបវិញថា៖
«តើគួរឲ្យខ្ញុំបោះបង់ស្រាបរបស់ខ្ញុំ ដែលធ្វើឲ្យព្រះ និងមនុស្សសប្បាយចិត្តគ្រប់គ្នានោះ ហើយត្រឡប់ទៅយោលខ្លួនជាមួយដើមឈើទាំងឡាយនោះឬអី»។
[14]ពួកឈើទាំងឡាយក៏និយាយទៅកាន់គុម្ពបន្លាថា «ចូរមក ហើយគ្រងរាជ្យលើយើង»។
[15]គុម្ពបន្លាក៏តបទៅវិញថា៖ «ប្រសិនបើ អ្នករាល់គ្នាពិតជាចង់អភិសេកខ្ញុំធ្វើជាស្តេចសោយរាជ្យលើអ្នករាល់គ្នាមែន ដូច្នេះ ចូរចូលមក ហើយជ្រកក្រោមម្លប់របស់ខ្ញុំចុះ។
បើមិនដូចទេ ចូរឲ្យមានភ្លើងចេញពីគុម្ពបន្លា ហើយបញ្ឆេះដើមតាត្រៅនៅស្រុកលីបង់ថែមទៀតចុះ»។[16]ឥឡូវនេះ តើអ្នករាល់គ្នាបានលើក លោកអប៊ីម៉ាឡេក
ជាស្តេចដោយទៀងត្រង់និងស្មោះអស់ពីចិត្តឬ ហើយតើអ្នករាល់គ្នាបានប្រព្រឹត្តចំពោះលោកយេរូបបាល
និងគ្រួសាររបស់លោកដោយការដឹងគុណលោកចំពោះកិច្ចការដែលលោកបានធ្វើដល់អ្នករាល់គ្នាឬ?
[17]ឥឡូវចូលគិតមើលចុះ ឪពុករបស់ខ្ញុំបានច្បាំងដើម្បីអ្នករាល់គ្នា គាត់ស៊ូប្តូរជីវិតរំដោះអ្នករាល់គ្នាចេញពីកណ្តាប់ដៃរបស់ពួកម៉ាឌាន[18]ប៉ុន្តែ
ថ្ងៃនេះអ្នករាល់គ្នាបានក្រោកឡើងប្រឆាំងនឹងក្រុមគ្រួសារលោក ហើយបានសម្លាប់កូនប្រុសរបស់លោកទាំងចិតសិបនាក់ក្នុងពេលតែមួយ បន្ទាប់មក
អ្នករាល់គ្នាបានលើកលោកអប៊ីម៉ាឡេក ជាកូនរបស់ស្រីបម្រើឲ្យធ្វើជាស្តេចសោយរាជ្យលើចាស់ទុំរបស់ស៊ីគែម ព្រោះគេជាសាច់ញាតិរបស់អ្នករាល់គ្នា។
[19]ប្រសិនបើ អ្នករាល់គ្នាបានប្រព្រឹត្តដោយស្មោះត្រង់ និងសុចរិតជាមួយលោកយេរូបបាល និងក្រុមគ្រួសាររបស់លោក ដូច្នេះ
សូមឲ្យអ្នករាល់គ្នាបានរីករាយជាមួយលោកអប៊ីម៉ាឡេក ហើយសូមឲ្យគេរីករាយជាមួយអ្នករាល់គ្នាដែរ។[20]ប៉ុន្តែប្រសិនបើ មិនដូច្នោះទេ សូមឲ្យមានភ្លើងចេញពី
លោកអប៊ីម៉ាឡេកមកបញ្ឆេះមនុស្សទាំងអស់នៃស៊ីគែម និង បេត មីឡូទៅចុះ ហើយក៏សូមឲ្យភ្លើងចេញពីមនុស្សនៅស៊ីគែម និងបេត មីឡូមកបញ្ឆេះលោកអប៊ីម៉ាឡេក។
[21]បន្ទាប់មកលោកយ៉ូថាមក៏គេចខ្លួនរត់ទៅស្រុកបៀរ ហើយគាត់រស់នៅទីនោះឆ្ងាយពីលោកអប៊ីម៉ាឡេក បងប្រុសរបស់លោក។
[22]លោកអប៊ីម៉ាឡេកបានសោយរាជ្យលើជនជាតិអ៊ីស្រាអែលអស់រយៈពេលបីឆ្នាំ។[23]ព្រះអម្ចាស់បានបញ្ជូនវិញ្ញាណអាក្រក់មក ដែលបណ្តាលអោយអប៊ីម៉ាឡេក
និងចាស់ទុំនៅស៊ីគែមបាក់បែកគ្នា គឺពួកចាស់ទុំបានក្បត់អប៊ីម៉ាឡេក។[24]ព្រះអម្ចាស់បានធ្វើអោយពួកគេទទួលទោសចំពោះឃាតកម្មដែលគេបានប្រព្រឹត្ត
គឺសម្លាប់កូនប្រុសទាំងចិតសិបរបស់យេរូបបាល ចំណែកលោកអប៊ីម៉ាឡេក បានទទួលទោស ព្រោះបានសម្លាប់បងប្អូនរបស់គាត់ រីឯពួកចាស់ទុំរបស់ស៊ីគែម
ទទួលទោសព្រោះតែរួមគំនិតជាមួយគាត់ ក្នុងឃាតកម្មនេះ។
[25]ចាស់ទុំនៃស៊ីគែម បានដាក់មនុស្សទៅបង្កប់ខ្លួននៅកំពូលភ្នំដើម្បីវាយឆ្មក់គេ ហើយពួកគេបានប្លន់អស់អ្នកដែលធ្វើដំណើរឆ្លងកាត់តាមផ្លូវនោះ។
មានគេនាំដំណឹងនេះទៅប្រាប់ដល់អប៊ីម៉ាឡេក។
[26]លោកកាអាល ជាកូនរបស់លោកអេបេត បានឡើងទៅស៊ីគែម ជាមួយសាច់ញាតិរបស់គាត់។ ពួកចាស់ទុំនៅស៊ីគែម ទុកចិត្តលោក។
[27]ពួកគេបានចេញទៅវាលបេះផ្លែទំពាំងបាយជូរ ហើយកៀបយកទឹក និងធ្វើបុណ្យយ៉ាងសប្បាយ។ ពួកគេបានប្រារព្ធពិធីនៅក្នុងវិហារនៃព្រះរបស់ពួកគេ ពួកគេស៊ីផឹក
ហើយដាក់បណ្តាសារអប៊ីម៉ាឡេក។
[28]លោកកាអាល កូនប្រុសរបស់លោកអេបេតបានសួរថា៖ «តើលោកអប៊ីម៉ាឡេកជាអ្នកណា? ហើយស៊ីគែមជាអ្នកណា បានជាយើងត្រូវសង្គ្រោះពួកគេ?
តើគេមិនមែនជាកូនប្រុសរបស់លោកយេរូប បាល ទេឬអី? តើសេបូល មិនមែនជាតំណាងរបស់គេទេឬ? ហេតុអ្វីត្រូវបម្រើលោកអប៊ីម៉ាឡេក? ចូរបម្រើលោកហាម៉ោ
ឪពុកស៊ីគែមដោយស្មោះត្រង់!
[29]ខ្ញុំរំពឹងថាមនុស្សទាំងនេះនឹងនៅក្រោមការដឹកនាំរបស់ខ្ញុំ! បន្ទាប់មកខ្ញុំនឹងរលំអប៊ីម៉ាឡេក។ ខ្ញុំនឹងស្រែកទៅអប៊ីម៉ាឡេកថា៖
«អប៊ីម៉ាឡេកអើយ ចូរប្រមូលកងទ័ពទាំងអស់របស់អ្នកមក។»
[30]នៅពេលដែលលោកសេបូល តំណាងក្រុង បានឮពាក្យរបស់លោកកាអាល កូនប្រុសរបស់លោក អេបេត គាត់ខឹងយ៉ាងខ្លាំង។
[31]គាត់បានបញ្ជូនអ្នកនាំសារជាសម្ងាត់ទៅប្រាប់លោកអប៊ីម៉ាឡេកថា៖ «មើល កាអាលកូនប្រុសរបស់អេបេតនិងសាច់ញាតិរបស់គេកំពុងតែមកស៊ីគែម
ហើយពួកគេក៏ពុងញុះញង់អ្នកក្រុងឲ្យប្រឆាំងនឹងអ្នក។
[32]ឥឡូវនេះចូរលោកក្រោកឡើងទាំងយប់ ទៅលាក់ខ្លួននៅវាលស្រែជាមួយទាហានរបស់លោក។ ហើយនៅពេលព្រឹកព្រលឹម ព្រះអាទិត្យរះឡើងសឹមវាយចូលទីក្រុង។
[33]នៅពេលដែលគាត់និងមនុស្សរបស់គាត់ចេញមកប្រយុទ្ធជាមួយលោក លោកត្រូវធ្វើគ្រប់យ៉ាងដែលលោកអាចធ្វើបាន»។
[34]ដូច្នេះ ក្នុងវេលាយប់នោះ លោកអប៊ីម៉ាឡេក និងមនុស្សទាំងអស់ដែលនៅជាមួយ បានរៀបចំបង្កប់ខ្លួនប្រឆាំងនឹងស៊ីគែម ដោយបែងចែកជាបួនក្រុម។[35]លោកកាអាល
កូនលោកអេបេត បានចេញទៅហើយឈរនៅច្រកទ្វារទីក្រុង។ ចំណែកឯ លោកអប៊ីម៉ាឡេក និងមនុស្សដែលនៅជាមួយលោកបានចេញពីកន្លែងពួនរបស់ពួកគេ។
[36]នៅពេលដែលលោកកាអាលបានឃើញមនុស្ស គាត់និយាយទៅលោកសេបូលថា «មើល! មានមនុស្សចុះមកពីកំពូលភ្នំ!» លោកសេបូលតបថា៖
«អ្នកកំពុងឃើញស្រមោលពីលើភ្នំ ដែលពួកវាដូចជាមនុស្ស។»[37]លោកកាអាលនិយាយម្តងទៀតថា៖ «មើលន៎ មនុស្សកំពុងចុះពីភ្នំនៅពាក់កណ្តាលនោះមែន
ហើយមានមួយក្រុមដែលកំពុងមកតាមផ្លូវដើមជ្រៃរបស់ពួកព្យាការីដែរ»។
[38]នោះលោកសេបូលឆ្លើយទៅគាត់ថា «តើពាក្យអំនួតរស់អ្នកនៅឯណា! អ្នកបាននិយាយថា តើលោកអប៊ីម៉ាឡេក ជាអ្នកណា ដែលយើងត្រូវបម្រើគេនោះ?
តើទាំងនេះមិនមែនជាមនុស្សដែលអ្នកបានស្អប់ទេឬ? ចូរចេញទៅឥឡូវនេះ ហើយប្រយុទ្ធជាមួយនឹងពួកគេ។»[39]លោកកាអាលបានដឹកនាំពួកស៊ីគែមចេញទៅ
ហើយបានប្រយុទ្ធនឹងអប៊ីម៉ាឡេក។[40]លោកកាអាលបាត់ទ័ព ហើយអប៊ីម៉ាឡេក បានដេញតាមគាត់ មនុស្សមួយចំនួនធំត្រូវរបួស
ហើយដួលស្លាប់មុនទៅដល់មាត់ទ្វារក្រុង។

generated on Wed Sep 10 16:16:32 2025

[41]លោកអប៊ីម៉ាឡេក ស្នាក់នៅភូមិអារូម៉ា ចំណែកលោកសេប៊ូល បានបណ្តេញលោកកាអាល និងសាច់ញាតិរបស់គាត់ចេញពីស៊ីគែម។
[42]អ្នកក្រុងស៊ីគែមបានរៀបចំខ្លួនចេញទៅវាល។[43]គាត់បានបែងចែកមនុស្សរបស់គាត់ជាបីក្រុម ហើយពួកគេបានលាក់ខ្លួននៅតាមទីវាល។
គាត់បានមើលទៅឃើញមនុស្សកំពុងចេញពីក្រុងមក គាត់បានស្ទុះទៅវាយប្រហារនិងសម្លាប់ពួកគេ។
[44]លោកអប៊ីម៉ាឡេក និងក្រុមរបស់គាត់បានវាយប្រហារ និងបិទច្រកចូលក្រុង ចំណែកពីរក្រុមផ្សេងទៀតបានវាយប្រហារនិងសម្លាប់មនុស្សទាំងអស់ដែលនៅទីវាល។
[45]លោកអប៊ីម៉ាឡេកបានវាយទីក្រុងពេញមួយថ្ងៃ។ គាត់ដណ្តើមបានទីក្រុង និងសម្លាប់មនុស្សដែលនៅក្នុងក្រុង។ គាត់បានរលំជញ្ជាំងក្រុង
ព្រមទាំងបាចអំបិលលើក្រុងទៀតផង។
[46]នៅពេលដែលបានឮដំណឹងនេះ ចាស់ទុំទាំងអស់ដែលនៅក្នុងប៉មស៊ីគែម នាំគ្នាទៅជ្រកនៅក្នុងគុហារ ដែលនៅក្រោមវិហារព្រះបេរិត។[47]អប៊ីម៉ាឡេក
បានទទួលដំណឹងថាចាស់ទុំទាំងអស់ប្រមូលគ្នានៅប៉មស៊ីគែម។
[48]ពេលនោះលោកអប៊ីម៉ាឡេក និងអស់អ្នកដែលនៅជាមួយគាត់បានឡើងទៅលើភ្នំសាលម៉ូន គាត់បានយកពូថៅហើយកាប់មែនឈើមួយមែក។
គាត់លើវាមកហើយក៏បញ្ជាទៅអ្នកដែលនៅជាមួយគាត់ «ប្រញាប់ឡើង ចូរធ្វើអ្វីដែលអ្នករាល់គ្នាបានឃើញខ្ញុំធ្វើនេះ»។[49]ដូច្នេះ គ្រប់គ្នាបានកាប់ឈើមួយមែក
ហើយលីមកតាមគាត់។ ពួកគេបានគរវានៅខាងមុខច្រកចូលប៉ម ហើយក៏បានដុតភ្លើង ដូច្នេះ មនុស្សទាំងអស់នៃប៉មស៊ីគែមបានស្លាប់ដោយរបៀបនេះ
គឺមានទាំងបុរសនិងស្ត្រីប្រហែលជាមួយពាន់នាក់។
[50]បន្ទាប់មក លោកអប៊ីម៉ាឡេក បានឡើងទៅក្រុងថេរេបេស គាត់ព័ទ្ធក្រុងនោះ ហើយវាយយកបាន។[51]ប៉ុន្តែ ក្នុងក្រុងនោះមានប៉មមួយយ៉ាងរឹងមាំ មនុស្សទាំងអស់
ទាំងប្រុសទាំងស្រី ទាំងអ្នកមុខអ្នកការ បាននាំគ្នាទៅជ្រកក្នុងប៉មនោះ ពួកគេបានបិទទ្វារហើយឡើងទៅលើដំបូលប៉ម។
[52]លោកអប៊ីម៉ាឡេកចូលទៅវាយយកប៉មនោះ គឺគាត់ទៅជិតមាត់ទ្វារប៉មហើយដុតវា។[53]ប៉ុន្តែ មានស្ត្រីម្នាក់បានទម្លាក់ត្បាល់លើក្បាលរបស់អប៊ីម៉ាឡេក
ដែលធ្វើឲ្យក្បាលរបស់គាត់បែក។[54]ភ្លាមនោះគាត់បានហៅយុវជនដែលកាន់អាវុធរបស់គាត់រួចបង្គាប់ថា៖ «ដកអាវុធរបស់ឯងហើយសម្លាប់យើងឥឡូវនេះ
នោះនឹងមិនមានអ្នកណានិយាយពីយើងថា មនុស្សស្រីម្នាក់បានសម្លាប់គាត់ យុវជននោះបានចាក់ទម្លុះគាត់ ហើយគាត់ក៏ស្លាប់ទៅ។
[55]នៅពេលដែលជនជាតិអ៊ីស្រាអែលបានឃើញថា លោកអប៊ីម៉ាឡេកស្លាប់បាត់ហើយនោះ ពួកគេក៏វិលត្រឡប់ទៅផ្ទះវិញ។[56]ដូច្នេះឯង
ដែលព្រះអម្ចាស់បានដាក់ទោសអប៊ីម៉ាឡេក ដែលគាត់បានធ្វើចំពោះឪពុករបស់គាត់ ដោយបានសម្លាប់បងប្អូនទាំងចិតសិបនាក់របស់គាត់។
[57]ព្រះអម្ចាស់ធ្វើឲ្យការអាក្រក់នៃអ្នកស្រុកស៊ីគែមទាំងអស់ត្រឡប់ទៅលើក្បាលរបស់ពួកគេ ស្របតាមពាក្យបណ្តាសាររបស់យ៉ូថាម កូនរបស់យេរូប បាល។

Judges 9:1
លោកយេរូប បាល
នេះគឺជាឈ្មោះមួយផ្សេងទៀតរបស់លោកគេឌាន។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ៦:៣១។
សូមនិយាយយ៉ាងនេះ! ដូច្នេះអ្នកដឹកនាំនៅក្នុងស៊ីគែមទាំងអស់នឹងអាចបានឮ ថា៖
«តើមួយណាដែលប្រសើរសម្រាប់អ្នក៖ គួរមានកូនរបស់លោកយេរូបបាលទាំងចិតសិបនាក់
គ្រប់គ្រងលើអ្នករាល់គ្នា ឬក៏គួរឲ្យមានតែម្នាក់?
នេះគឺជាការដកស្រង់នៅក្នុងការដកស្រង់។ ជាការដកស្រង់ដោយផ្ទាល់
អាចនិយាយដកស្រង់ដោយផ្ទាល់តែម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមសួរអ្នកដឹកនាំស៊ីគែម ថាតើពួកគេចង់ឲ្យកូនទាំងចិតសិបរបស់លោកយេរូប
បាលគ្រប់គ្រងលើពួកគេ ឬ
ពួកគេចង់បានកូនប្រុសតែម្នាក់របស់គាត់គ្រប់គ្រងលើពួកគេ»។
ចិតសិប
«៧០»
ខ្ញុំជាឆ្អឹងរបស់អ្នក ហើយក៏ជាសាច់របស់អ្នកដែរ
ពាក្យ «ខ្ញុំជាឆ្អឹងរបស់អ្នក ហើយក៏ជាសាច់របស់អ្នកដែរ»
តំណាងឲ្យជាសាច់ញាតិរបស់នរណាម្នាក់ដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំក៏ជាសមាជិករបស់គ្រួសារអ្នកដែរ»។
Judges 9:3
សាច់ញាតិម្តាយរបស់គាត់បានទៅកាន់ដឹកនាំ
ឃ្លានេះមានន័យថា
សាច់ញាតិម្តាយរបស់លោកអប៊ីម៉ាឡេកនិយាយជាមួយនឹងអ្នកដឹកនាំ
ស្នើឲ្យតាំងលោកអប៊ីម៉ាឡេកជាស្តេច។
ពួកគេបានយល់ព្រមធ្វើតាមលោកអប៊ីម៉ាឡេក
«ពួកគេបានយល់ព្រមអនុញ្ញាតឲ្យលោកអប៊ីម៉ាឡេកធ្វើជាអ្នកដឹកនាំរបស់ពួកគេ»
។
ព្រះវិហារ (ផ្ទះ)
ពាក្យ «ព្រះវិហារ
ប្រាក់ចិតសិបតម្លឹង
នេះមានន័យថាប្រាក់ចិតសិបសែកគែល។ មួយសែកគែលទម្ងន់១១ក្រាម។
ប្រសិនបើ វាចាំបាច់បកប្រែពាក្យនេះ ជាមួយនឹងរង្វាល់សម័យថ្មី
អ្នកអាចបកប្រែបែបនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាក់ស្មើរតែមួយគីឡូក្រាម»។
ចិតសិប
«៧០»
ព្រះបាល បេរិត
នេះគឺជាឈ្មោះរបស់ព្រះក្លែងក្លាយ។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះនៅក្នុងជំពូក ៨:៣២។
មនុស្សគ្មានច្បាប់ទម្លាប់ និងមនុស្សពាល
«ហិង្សា និងចោលម្សៀត»។
Judges 9:5
អូប្រា
សូមបកប្រែឈ្មោះទីក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ៦:១១។
ស្លបថ្ម
«ថ្មមួយដុំ»
ចិតសិប
«៧០»
លោកយេរូប បាល
នេះគឺជាឈ្មោះមួយផ្សេងទៀតរបស់លោកគេឌាន។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ៦:៣១។
ប៊េតមីឡូ
នេះគឺជាឈ្មោះរបស់ទីកន្លែងមួយ។
Judges 9:7
ព័ត៌មានទូទៅ
លោកយ៉ូថាមបានចាប់ផ្តើមប្រាប់ពីពាក្យប្រស្នាមួយ
ដែលដើមឈើតំណាងឲ្យក្រុមមនុស្សផ្សេងៗ។
នៅពេលដែលលោកយ៉ូថាមបានទទួលដំណឹងនេះ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលលោកយ៉ូថាមបានឮថា
លោកអប៊ីម៉ាឡេកបានសម្លាប់ប្អូនប្រុសៗរបស់លោក» ។
ភ្នំកេរិស៊ីម
នេះគឺជាភ្នំមួយ។
ដើមឈើទាំងឡាយបានចេញទៅដើម្បីតែងតាំងស្តេចអោយគ្រងរាជ្យលើពួកគេ។
ពួកគេបាននិយាយទៅកាន់ដើមអូលីវថា៖ «ចូរគ្រងរាជ្យលើយើង»
នៅក្នុងប្រស្នានេះ លោកយ៉ូថាមបានពណ៌នាដើមឈើបានធ្វើអ្វីដែលមនុស្សធ្វើដែរ។
តែងតាំងស្តេចឲ្យគ្រងរាជ្យលើពួកគេ
នៅទីនេះ
ចាក់ប្រេងតាំងជាមួយនឹងប្រេងគឺជានិមិត្តរូបដែលតំណាងឲ្យការចាក់ប្រេងតាំងមនុស្សម្នាក់ឲ្យធ្វើជាស្តេច។
របៀបផ្សេងទៀតនៃការបកប្រែ: «ចាក់ប្រេងតាំងស្តេចមួយអង្គ
ដើម្បីសោយរាជ្យលើពួកគេ»។
ចូរគ្រងរាជ្យលើយើង
«សូមធ្វើជាស្តេចរបស់ពួកយើង»។
Judges 9:9
ព័ត៌មានទូទៅ

generated on Wed Sep 10 16:16:32 2025

លោកយ៉ូថាមបន្តប្រាប់ពីប្រស្នា ដើមឈើតំណាងឲ្យមនុស្សតាមក្រុមផ្សេងៗ។
ដើមអូលីវតបទៅពួកគេវិញថា...ដើមឧទុម្ពរតបទៅពួកគេថា
នៅក្នុងប្រស្នានេះ
លោកយ៉ូថានពណ៌នាមានពីដើមឈើអាចធ្វើអ្វីៗដូចមនុស្សធ្វើដែរ។ (សូមមើល: និង|Personification
តើខ្ញុំគួរនឹងបោះបង់ប្រេងរបស់ខ្ញុំ ...ត្រឡប់ទៅយោលខ្លួនលើដើមឈើឯទៀតៗឬ?
ដើមអូលីវសួរសំណួរនេះ ដើម្បីបដិសេធការធ្វើជាស្តេច។
សំណួរនេះអាចបញ្ជាក់ជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងមិនបោះបង់ចោល ប្រេងរបស់ខ្ញុំទេ...ប្រគល់ឲ្យទៅដើមឈើផ្សេងឡើយ»។ (សូមមើល:|Rhetorical Question)
យោលចុះឡើង
«យោលចុះឡើង» មានន័យថាយោលចុះ យោលឡើងនៅក្នុងខ្យល់។
ពាក្យដើមឈើនៅទីនេះ ប្រើឃ្លានេះ ដើម្បីមានន័យថា «គ្រប់គ្រង» ។
តើគួរឲ្យខ្ញុំបោះបង់រស់ជាតិដ៏ផ្អែម ...យោលខ្លួនលើដើមឈើឯទៀតៗឬ?
ដើមឧទម្ពរសួរសំណួរនេះ ដើម្បីបញ្ជាក់ដូចជាសេចក្តីថ្លែង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងមិនបោះបង់ចោលជាតិផ្អែមរបស់ខ្ញុំ...ទៅឲ្យដើមឈើផ្សេងឡើយ»។ (សូមមើល:|Rhetorical Question)។
រស់ជាតិដ៏ផ្អែមនិងផ្លែដ៏ល្អរបស់ខ្ញុំចោល
ពាក្យ «ជាតិផ្អែម» គឺជានាមអរូបី។ អាចប្រែជាគុណនាម
ដើម្បីពណ៌នាពីផ្លែដែលដុះនៅលើដើមឈើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ផ្លែដ៏ផ្អែមរបស់ខ្ញុំ» (UDB)។ (សូមមើល:|Abstract Nouns)
Judges 9:12
ព័ត៌មានទូទៅ
លោកយ៉ូថាមបន្តប្រាប់ពីប្រស្នា ដើមឈើតំណាងឲ្យមនុស្សតាមក្រុមផ្សេងៗ។
ដើមឈើទាំងឡាយនិយាយទៅកាន់ដើមទំពាំងបាយជូរ
នៅក្នុងប្រស្នានេះ
លោកយ៉ូថានពណ៌នាមានពីដើមឈើអាចធ្វើអ្វីៗដូចមនុស្សធ្វើដែរ។ (សូមមើល: និង|Personification)
តើគួរឲ្យខ្ញុំបោះបង់ស្រាថ្មីរបស់ខ្ញុំ ...ទៅយោលខ្លួនលើដើមឈើទាំងឡាយនោះឬអី
ដើមទំពាំងបាយជូរសួរសំណួរនេះដើម្បីបដិសេធមិនព្រមធ្វើស្តេច។
សំណួរនេះអាចបញ្ជាក់ជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងមិនបោះបង់ស្រាថ្មីរបស់ខ្ញុំ ទៅឲ្យដើមឈើផ្សេងឡើយ»។
គុម្ពបន្លា
បន្លាមុនស្រួចឬមានមែកដែលមុតឈឺ។ ដើមឈើនេះ
មានបន្លាជាច្រើនទៅតាមមែករបស់វា។
Judges 9:15
ព័ត៌មានទូទៅ
លោកយ៉ូថាម ប្រាប់ពីប្រស្នា ពីដើមឈើដែលតំណាងឲ្យក្រុមមនុស្សផ្សេងៗ ហើយយកមកអនុវត្ត។
គុម្ពបន្លាបានតបទៅដើមឈើវិញថា
នេះគឺជាប្រស្នា លោកយ៉ូថាមពណ៌នា ពីគុម្ពបន្លា
និងដើមឈើអាចធ្វើការដូចមនុស្សធ្វើការដែរ។
ឥឡូវនេះ
មិនមែនមានន័យថា «នៅខណៈនេះ» ទេ ប៉ុន្តែ
ប្រើដើម្បីទាញចំណាប់អារម្មណ៍ទៅរកចំណុចសំខាន់ដែលនឹងមកតាមក្រោយ។
អ្នករាល់គ្នាបានប្រព្រឹត្តចំពោះលោកយេរូបបាល
និងផ្ទះរបស់លោកដោយការដឹងគុណលោកចំពោះកិច្ចការដែលលោកបានធ្វើដល់អ្នករាល់គ្នាឬ?
លោកយ៉ូថាមបានផ្តល់យោបល់ថា អ្វីដែលពួកគេធ្វើនោះល្អ
ប៉ុន្តែលោកយ៉ូថាមមិនបានជឿថា ពួកគេបានធ្វើល្អទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នកបានធ្វើអ្វីដែលត្រឹមត្រូវ
ហើយតើអ្នករាល់គ្នាគួរនឹងសម្លាប់កូនប្រុសទាំងអស់លោកយេរូប បាលឬ?»
លោកយេរូប បាល
នេះគឺជាឈ្មោះមួយផ្សេងទៀតរបស់លោកគេឌាន។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ៦:៣១។
ផ្ទះរបស់លោក
ពាក្យ «ផ្ទះ» តំណាងឲ្យ គ្រួសាររបស់លោកគេឌាន។
Judges 9:17
ព័ត៌មានទូទៅ
លោកយ៉ូថាមបានអនុវត្តជាមួយនឹងស្ថានភាពនៅពេល និងកន្លែងនោះ។
ហើយចូលគិតមើលចុះ ឪពុករបស់ខ្ញុំបានច្បាំងដើម្បីអ្នករាល់គ្នា...ចេញពីកណ្តាប់ដៃរបស់ពួកម៉ាឌាន
នៅទីនេះ លោកយ៉ូថាមបានបញ្ជាក់ថា លោកមិនជឿថា
អ្នកស្រុកស៊ីគែមប្រព្រឹត្តមិនល្អដាក់លោកគេឌាន និងគ្រួសាររបស់លោក
ទោះបីជាលោកបានតយុទ្ធដើម្បីសង្គ្រោះអ្នកស្រុកស៊ីគែម។
ចេញពីកណ្តាប់ដៃរបស់ពួកម៉ាឌាន
ពាក្យ «ដៃ» តំណាងឲ្យអំណាច និងការគ្រប់គ្រង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីអំណាចរបស់ជនជាតិម៉ាឌាន»។
អ្នករាល់គ្នាបានក្រោកឡើងប្រឆាំងនឹង
នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករាល់គ្នាបានប្រឆាំង» ឬ «អ្នកអាចប៉ះបោរប្រឆាំង»។
ផ្ទះឪពុករបស់ខ្ញុំ
ពាក្យ «ផ្ទះ» តំណាងឲ្យគ្រួសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រួសាររបស់ឪពុកខ្ញុំ»។
ចិតសិប
«៧០»
ថ្មតែមួយដុំ
«ថ្ម១ដុំ»
ស្រីបម្រើរបស់គាត់
ពាក្យ «របស់គាត់» សំដៅលើលោកគេឌាន។
Judges 9:19
ប្រសិនបើ អ្នករាល់គ្នាបានប្រព្រឹត្តដោយស្មោះត្រង់ និងដោយសេចក្តីសុចរិតជាមួយលោកយេរូបបាល និងផ្ទះរបស់លោក
លោកយ៉ូថាមបានផ្តល់យោបល់ថា អ្វីដែលពួកគេធ្វើនោះល្អ
ប៉ុន្តែលោកយ៉ូថាមមិនបានជឿថា ពួកគេបានធ្វើល្អទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នកបានធ្វើអ្វីដែលត្រឹមត្រូវ
ហើយតើអ្នករាល់គ្នាគួរនឹងសម្លាប់កូនប្រុសទាំងអស់លោកយេរូប បាលឬ?»
លោកយេរូប បាល
នេះគឺជាឈ្មោះមួយផ្សេងទៀតរបស់លោកគេឌាន។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ៦:៣១។
ផ្ទះឪពុករបស់លោក
ពាក្យ «ផ្ទះ» តំណាងឲ្យ គ្រួសាររបស់លោក»
ប៉ុន្តែប្រសិនបើ មិនដូច្នោះទេ
លោកយ៉ូថាមបានផ្តល់យោបល់ថា អ្វីដែលពួកគេធ្វើនោះមិនល្អ
នោះនឹងត្រូវបណ្តាសា។ ប៉ុន្តែ លោកយ៉ូថែមមិនជឿថាពួកគេធ្វើអាក្រក់ទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ បើអ្នកបានប្រព្រឹត្តជាមួយលោកយេរូប បាល
និងគ្រួសាររបស់លោក នូវអ្វីដែលមិនគួរប្រព្រឹត្តនោះ?»
សូមឲ្យមានភ្លើងចេញពី លោកអប៊ីម៉ាឡេកមក ហើយដុតបញ្ឆេះមនុស្សទាំងអស់នៃស៊ីគែម
លោកយ៉ូថាមនិយាយពីបណ្តាសា។
លោកនិយាយពីលោកអប៊ីម៉ាឡេកបំផ្លាញអ្នកស្រុកស៊ីគែម
ប្រៀបដូចជាគាត់ដុតពួកគេដោយភ្លើង។
សូមឲ្យភ្លើងចេញពីមនុស្សនៅស៊ីគែម និងបេត មីឡូមកដុតបញ្ឆេះអប៊ីម៉ាឡេកដែរ។
លោកយ៉ូថាមនិយាយពីបណ្តាសា។ លោកនិយាយពីអ្នកស្រុកស៊ីគែម
និងបេតមីឡូដែលបំផ្លាញលោកអប៊ីម៉ាឡេក
ប្រៀបដូចជាពួកគេដុតលោកដោយភ្លើងដូច្នោះដែរ។
បេតមីឡូ
នេះគឺជាឈ្មោះរបស់ទីកន្លែង។ ចូរបកប្រែដូចអ្នកបានបកប្រែនៅក្នុងជំពូក ៩:៥។
ស្រុកបៀរ
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
Judges 9:22
បី
«៣»
ព្រះអម្ចាស់បានចាត់វិញ្ញាណអាក្រក់មករវាងអប៊ីម៉ាឡេក និងពួកមេដឹកនាំនៃស៊ីគែម។
ឃ្លានេះ មានន័យថាព្រះជាម្ចាស់នឹងដាក់បណ្តាសាលើលោកយ៉ូថាម
ដោយចាត់វិញ្ញាណអាក្រក់ធ្វើឲ្យមានបញ្ហា ហើយប្រឆាំងរវាងលោកអប៊ីម៉ាឡេក
និងអ្នកដឹកនាំរបស់អ្នកស្រុកស៊ីគែម។
ព្រះបានធ្វើការនេះ ដូច្នេះអំពើឃោរឃៅ...អាចបានសងសឹក ហើយអប៊ីម៉ាឡេកបងប្អូនរបស់ពួកគេ
ជាឃ្លាអកម្ម និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«ព្រះជាម្ចាស់បានធ្វើការនេះ ដើម្បីសងសឹកនឹងកូនទាំងចិតសិប
ដែលលោកអប៊ីម៉ាឡេកបានសម្លាប់ និងអ្នកស្រុកស៊ីគែមក៏បានជួយសម្លាប់ដែរ»។
ចិតសិប
«៧០»
លោកយេរូប បាល
នេះគឺជាឈ្មោះមួយផ្សេងទៀតរបស់លោកគេឌាន។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ៦:៣១។
Judges 9:25
បានដាក់មនុស្សទៅបង្កប់ខ្លួននៅកំពូលភ្នំ ដែលពួកគេអាចលបវាយប្រហារគាត់
«បានចាត់មនុស្សទៅបង្កប់ខ្លួននៅលើកំពូលភ្នំ
ហើយរង់ចាំប្រហារលោកអប៊ីម៉ាឡេក»។
មានគេនាំដំណឹងនេះទៅប្រាប់ដល់អប៊ីម៉ាឡេក
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានគេប្រាប់លោកអប៊ីម៉ាឡេក អំពីមនុស្សដែលរង់ចាំប្រហារលោក»។
Judges 9:26
លោកកាអាល...លោកអេបេត
នេះគឺជាឈ្មោះរបស់មនុស្ស។
បានមានទុកចិត្តគាត់
ពាក្យ «ទំនុកចិត្ត» គឺជានាមអរូប: ដែលនិយាយជាកិរិយាសព្ទ «ទុកចិត្ត»។
របៀបផ្សេងទៀតនៃការបកប្រែ: «បានទុកចិត្តលើគាត់»។
ពួកគេបានចេញទៅវាល
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកកាអាល និងសាច់ញាតិរបស់លោក
ព្រមទាំងអ្នកស្រុកស៊ីគែម។
បានបញ្ជាន់
«កម្មេច» ឬ «កុងក្តាំង»
ពួកគេបានបញ្ជានវា
ពួកគេធ្វើដូច្នេះ ដើម្បីគាបទឹកទំពាំងបាយជូរធ្វើជាស្រាទំពាំងបាយជូរ។
ក្នុងផ្ទះ
ពាក្យ «ផ្ទះ» នៅទីនេះ តំណាងឲ្យព្រះវិហារ។
Judges 9:28
លោកកាអាល...លោកអេបេត
សូមបកប្រែឈ្មោះនេះ ដូចជាបកប្រែនៅក្នុងជំពូក ៩:២៦។
តើលោកអប៊ីម៉ាឡេកជាអ្នកណា ហើយស៊ីគែមជាអ្នកណា ដែលយើងគួរបម្រើគេនោះ?
កាអាលប្រើសំណួរមួយដើម្បីបញ្ជាក់ប្រាប់អ្នកស្រុកស៊ីគែមថា
មិនគួរបម្រើលោកអប៊ីម៉ាឡេកឡើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមិនត្រូវបម្រើអប៊ីម៉ាឡេកឡើយ»។
តើលោកអប៊ីម៉ាឡេកជាអ្នកណា ហើយស៊ីគែមជាអ្នកណា ដែលយើងគួរបម្រើគេនោះ?
សំណួរទាំងពីរនេះមានន័យដូចគ្នា។
លោកកាអាលសំដៅលើលោកអប៊ីម៉ាឡេកដូចជា «ស៊ីគែម»
ព្រោះម្តាយរបស់លោកអប៊ីម៉ាឡេកមកពីស៊ីគែម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមិនគួរបម្រើលោកអប៊ីម៉ាឡេកទេ នោះគឺស៊ីគែម!»
តើគេមិនមែនជាកូនប្រុសរបស់លោកយេរូប បាល ទេឬអី? តើសេបូល
មិនមែនជានាយទាហានរបស់គេទេឬ?
លោកកាអាលប្រើសំណួរមួយដើម្បីបញ្ជាក់ថា
អ្នកស្រុកស៊ីគែមមិនត្រូវបម្រើលោកអប៊ីម៉ាឡេកទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកគ្រាន់តែជាកូនរបស់លោកយេរូប បាល ហើយលោកសេបូល
គ្រាន់តែជាជានាយទាហាន»។
លោកសេបូល
នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។
បម្រើលោកហាម៉ោ ឪពុករបស់ស៊ីគែម
លោកកាអាលចង់និយាយពីអ្នកស្រុងស៊ីគែម
គួរបម្រើកូនចៅដែលមកពីលោកហាម៉ោនេះឯង
អស់អ្នកដែលជាជនជាតិកាណានពិតប្រាកដ
ហើយមិនបម្រើនរណាម្នាក់ដែលឪពុករបស់គេជាជនជាតិអ៊ីស្រាអែលឡើយ។
ហេតុអ្វីយើងគួរបម្រើអប៊ីម៉ាឡេក?
លោកកាអាលប្រើសំណួរនេះ ដើម្បីបញ្ជាក់ថា
អ្នកស្រុកស៊ីគែមមិនគួរបម្រើលោកអប៊ីម៉ាឡេកឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ:«យើងមិនគួរបម្រើលោកអប៊ីម៉ាឡេកឡើយ»។
ខ្ញុំរំពឹងថាមនុស្សទាំងនេះនឹងនៅក្រោមបញ្ជារបស់ខ្ញុំ!
«ខ្ញុំសង្ឃឹមថា ខ្ញុំនឹងគ្រប់គ្រងអ្នកស្រុកស៊ីគែម» ។
Judges 9:30
លោកសេបូល
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៨។
លោកកាអាល កូនប្រុសរបស់លោក អេបេត កំហឹងរបស់គាត់បានកកើតឡើង
ពាក្យ «ពាក្យ» តំណាងឲ្យអ្វីដែលបាននិយាយ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានឮអ្វីដែលលោកកាអាល ដែលជាកូនប្រុសរបស់លោកអេបេតបាននិយាយ»។
លោកកាអាល...លោក អេបេត
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៦។
កំហឹងរបស់គាត់បានកកើតឡើង
មានកំហឹង និយាយប្រៀបដូចជាភ្លើងបានចាប់ផ្តើមឆេះឡើង។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកមានកំហឹងជាខ្លាំង»។
ដើម្បីបំភាន់
លោកសេបូល បានបោកប្រាស់លោកកាអាល និងអ្នកស្រុកស៊ីគែម។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយសង្វាត់» ។
ពួកគេកំពុងញុះញង់អ្នកក្រុងឲ្យប្រឆាំងនឹងអ្នក
ឃ្លានេះ និយាយពីមនុស្សនៅក្នុងទីក្រុងមិនសប្បាយចិត្ត
របៀបដូចជាវត្ថុរាវនៅក្នុងឆ្នាំងក្រឡុកចុះឡើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានបញ្ចុះបញ្ចូលមនុស្សនៅក្នុងទីក្រុងឲ្យប្រឆាំងជាមួយអ្នក»។
អ្នកក្រុង
ពាក្យ «ទីក្រុង» តំណាងឲ្យមនុស្សរស់នៅទីក្រុងនោះ។
Judges 9:32
ព័ត៌មានទូទៅ
អ្នកនាំសាររបស់លោកសេបូលបន្តនិយាយពីលោកអប៊ីម៉ាឡេក។
ឥឡូវនេះ
នេះមិនមែនមានន័យ «នៅក្នុងខណៈពេលនេះ» ទេ ប៉ុន្តែ ប្រើនៅទីនេះ
ដើម្បីទាញចំណាប់អារម្មណ៍ទៅកាន់ចំណុចសំខាន់ដើម្បីមកតាមក្រោយ។
លាក់ខ្លួន
«លាក់ខ្លួ ហើយប្រហារលើពួកគេភ្លាម»។
ធ្វើគ្រប់យ៉ាងដែលលោកអាចធ្វើបានចំពោះពួកគេ
ឃ្លានេះ មានន័យថា
ពួកគេអាចធ្វើអ្វីដែលពួកគេចង់បំផ្លាញអ្នកដើរតាមលោកកាអាល។
Judges 9:34
និងមនុស្សទាំងអស់ដែលនៅជាមួយ
«ហើយមនុស្សទាំងអស់ដែលចូលរួមជាមួយលោកអប៊ីម៉ាឡេក» ឬ
«និងទាហានទាំងអស់ដែលច្បាំងដើម្បីលោកអប៊ីម៉ាឡេក»។
បានរៀបចំបង្កប់ខ្លួនប្រឆាំងនឹងស៊ីគែម
ពាក្យ «ស៊ីគែម» តំណាងឲ្យអ្នកស្រុកស៊ីគែម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានលាក់ខ្លួន ដើម្បីវាយលុកអ្នកស្រុកស៊ីគែម ដោយភ្ញាក់ផ្អើល»
ដោយបែងចែកជាបួនក្រុម
«បែងចែកជា ៤ក្រុម»
លោកកាអាល...លោក អេបេត
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៦។
Judges 9:36
លោកកាអាល
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៦។
លោកសេបូល
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៨។
អ្នកកំពុងឃើញស្រមោលនៅលើភ្នំ ដែលពួកវាដូចជាមនុស្ស
លោកសេបូលព្យាយាមបន្លំលោកកាអាល ហើយរារាំងលោកមិនឲ្យទៅធ្វើសង្គ្រាម។
របៀបផ្សេងទៀតនៃការបកប្រែ: «នោះមិនមែនជាមនុស្សទេ
វាគ្រាន់តែជាស្រមោលនៅលើភ្នំប៉ុណ្ណោះ» ។
មួយក្រុម
«១ក្រុម» ឬ «១កងពល»។
Judges 9:38
លោកសេបូល
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៨។
ឥឡូវនេះ តើពាក្យអំនួតរបស់អ្នកនៅឯណា!
លោកសេបូសបន្ទោសលោកកាអាល ដោយសំណួរគ្រាមភាសា។ «ពាក្យ»

generated on Wed Sep 10 16:16:32 2025

តំណាងឲ្យអ្វីដែលគេនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនត្រូវនិយាយអួតនៅពេលនេះទេ!» ឬ
«អ្នកមិនត្រូវមានមោទនភាពនៅពេលនេះទេ!» ។
អ្នកបាននិយាយថា «តើអប៊ីម៉ាឡេកជាអ្នកណា ដែលយើងគួរបម្រើគេនោះ?
លោកសេប៊ូសបានស្រង់សំដី អំនួតរបស់លោកកាអាលត្រឡប់មកវិញ។ ឃ្លានេះ
អាចបកប្រែការស្រង់សំដីដោយប្រយោល។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលនិយាយថាយើងមិនគួរសម្រាប់លោកអប៊ីម៉ាឡេកទេ»។ ។
តើទាំងនេះមិនមែនជាមនុស្សដែលអ្នកបានស្អប់ទេឬ?
លោកសេប៊ូលបានជជែកជាមួយលោកកាអាលជាមួយនឹងសំណួរទាំងនេះ។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះគឺជាមនុស្សដែលអ្នកស្អប់»។
បានស្អប់
«ស្អប់» ឬ «មិនចូលចិត្ត» ។
លោកកាអាល
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៦។
មនុស្សជាច្រើនត្រូវរបួស ហើយដួលស្លាប់
នេះគឺជាពាក្យប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានមនុស្សជាច្រើនបានស្លាប់ដោយសាររបួស» ។
Judges 9:41
អារូម៉ា
នេះគឺជាឈ្មោះរបស់ទីក្រុង។
លោកសេប៊ូល
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៨។
លោកកាអាល
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ៩:២៦។
មានគេរាយការណ៍ ប្រាប់អប៊ីម៉ាឡេក
ឃ្លានេះ អាចបកប្រែជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានមនុស្សប្រាប់ការនេះ ដល់លោកអប៊ីម៉ាឡេក»។ ។
បានបែងចែកមនុស្សរបស់គាត់ជាបីក្រុម
«បែងចែកពួកគេជាបីក្រុម»។
ពួកគេបានលាក់ខ្លួននៅក្នុងទីវាល
«ពួកគេបានលាក់ខ្លួននៅក្នុងទីវាល ដើម្បីប្រហារប្រជាជនដោយភ្ញាក់ផ្អើល»។
គាត់បានវាយប្រហារ
ពាក្យ «គាត់» នៅទីនេះ សំដៅលើលោកអប៊ីម៉ាឡេក
ដែលតំណាងឲ្យទាហានទាំងអស់របស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានប្រហារ»។
Judges 9:44
ក្រុម
«ក្រុមទាហាន»
ពីរក្រុមផ្សេងទៀត
«២ផ្សេងទៀត»
លោកអប៊ីម៉ាឡេកបានវាយប្រហារ... គាត់បានរលំជញ្ជាំងក្រុង
ពាក្យ «អប៊ីម៉ាឡេក» តំណាងឲ្យទាហានរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកអប៊ីម៉ាឡេក
និងទាហានរបស់លោកបានប្រហារ... គាត់បានរលំជញ្ជាំងក្រុង»។
ប្រហារទីក្រុង
ពាក្យ «ទីក្រុង» តំណាងឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រឆាំងនឹងអ្នកស្រុងស៊ីគែម»។
បានរលំ
«បានបំផ្លាញ»
បានបាចអំបិលលើវាទៀតផង
«បានបាចអំបិលលើទឹកដី»។
បាចអំបិលលើទឹកដីដើម្បីកុំឲ្យមានអ្វីដុះនៅទីនោះឡើយ។
Judges 9:46
ផ្ទះ
ពាក្យនេះ តំណាងឲ្យព្រះវិហារ។
ព្រះបេរិត
ពាក្យ «អែល» មានន័យថា «ព្រះ»។ នេះគឺដូចជាព្រះក្លែងក្លាយដូចជា «ព្រះបាល
បេរីត» នៅក្នុងជំពូក ៨:៣២ ដែរ។
អប៊ីម៉ាឡេក ត្រូវបានប្រាប់ថា
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានគេប្រាប់លោកអប៊ីម៉ាឡេក»។ ។
Judges 9:48
ភ្នំសាលម៉ូន
នេះគឺជាឈ្មោះរបស់ភ្នំមួយ។
បង្គោល
ពាក្យនេះមានន័យថាមែកឈើដ៏ធំមួយ។
ប្រហែលជាមួយពាន់នាក់
«ប្រហែលជា១,០០០នាក់»។
Judges 9:50
ក្រុងថេរេបេស
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
គាត់ព័ទ្ធក្រុងថេរេបេស និងវាយយកវាបាន
«បោះទ័ពនៅខាងក្រៅក្រុងថេរេបេស»។
Judges 9:52
និងវាយយកវាបាន
«បានប្រហារវា»
ត្បាល់
ថ្មមូល ពីរធំៗ រាបស្មើ ដើម្បីកិនម្សៅ។ ត្បាល់ដែលនៅខាងលើ បានដាក់ផ្ដុបពីលើគ្នា
ដើម្បីកិនម្សៅ។
កាន់អាវុធ
កាន់អាវុធ នេះគឺជាមនុស្សដែលលីសែងអាវុធរបស់លោកអប៊ីម៉ាឡេក។
បានចាក់ទម្ពុះគាត់
ឃ្លានេះ មានន័យថា
យុវជននោះបានយកដាវចាក់ទម្ពុះចំហៀងខាងស្តាំរូបកាយរបស់លោកអប៊ីម៉ាឡេក។
Judges 9:55
ចិតសិប
«៧០»
បានធ្វើឲ្យការអាក្រក់ទាំងអស់នៃអ្នកស្រុកស៊ីគែមត្រឡប់ទៅលើក្បាលរបស់ពួកគេ
«ការអាក្រក់ទាំងអស់បានធ្លាក់ទៅលើក្បាលរបស់ពួកគេ»
របៀបផ្សេងទៀតនៃការបកប្រែ: «បានដាក់ទោសអ្នកស្រុកស៊ីគែម
ដោយព្រោះតែអំពើអាក្រក់ទាំងអស់ដែលពួកគេបានធ្វើ»។ ។
ពាក្យបណ្តាសាររបស់យ៉ូថាម កូនរបស់យេរូប បាលបានធ្លាក់មកលើពួកគេ
ឃ្លានេះគឺជាពាក្យប្រៀបធៀម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បណ្តាសាររបស់យ៉ូថាន កូនប្រុសរបស់លោកសេរូបបាល បានធ្លាក់លើពួកគេ»។
លោកយេរូប បាល
នេះគឺជាឈ្មោះមួយទៀតរបស់លោកគេឌាន។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនេះនៅក្នុងជំពូក ៦:៣១។

---

10 [1]ក្រោយពី លោកអេប៊ីម៉ាឡេក ទទួលមរណភាពទៅលោកថូឡា ជាកូនលោកពូវ៉ា និងជាចៅរបស់លោកដូដូ មកពីកុលសម្ព័ន្ធអ៊ីសាខារ ជាអ្នកស្រុកសាមារ
ក្នុងតំបន់ភ្នំអេប្រាអ៊ីម បានងើបឡើងរំដោះជនជាតិអ៊ីស្រាអែល។[2]គាត់ដឹកនាំអ៊ីស្រាអែលអស់រយៈពេលម្ភៃបីឆ្នាំ។ ពេលដែលលោកទទួលមរណភាព
សពរបស់លោកត្រូវបានបញ្ជុះនៅសាមារ។
[3]ក្រោយពីលោកថូឡា ទទួលមរណភាពទៅលោកយ៉ាអ៊ៀរ ជាអ្នកស្រុកកាឡាដ បានដឹកនាំអ៊ីស្រាអែលអស់រយៈពេលម្ភៃពីរឆ្នាំ។
[4]គាត់មានកូនប្រុសសាមសិបនាក់ដែលមានលាសាមសិបជាជំនិះ ហើយគ្រប់គ្រងលើទីក្រុងចំនួនសាមសិប នៅលើទឹកដីកាឡាត ដែលហៅថាបុរីយ៉ាអ៊ៀរ
រហូតដល់សព្វថ្ងៃនេះ។[5]លោកយ៉ាអ៊ៀរក៏ទទួលមរណភាព សពរបស់លោកត្រូវបានបញ្ជុះនៅកាម៉ូន។
[6]ប្រជាជនអ៊ីស្រាអែលបានធ្វើការអាក្រក់ទាស់ព្រះហឫទ័យព្រះអម្ចាស់ជាថ្មី ហើយពួកគេថ្វាយបង្គំព្រះបាល ព្រះអាសថេរ៉ូត ព្រមទាំងព្រះនានារបស់ជនជាតិអារ៉ាម
ព្រះរបស់ស៊ីដូន ព្រះរបស់ម៉ូអាប់ ព្រះនៃជនជាតិអាំម៉ូន និងព្រះនៃជនជាតិភីលីស្ទីន។ ពួកគេបានបំភ្លេចព្រះអម្ចាស់ហើយមិនថ្វាយបង្គំទ្រង់តទៅទៀតទេ។
[7]ព្រះអម្ចាស់ព្រះពិរោធនឹងជាមួយជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង ព្រះអង្គបានប្រគល់ពួកគេទៅក្នុងដៃសាសន៍ភីលីស្ទីន ហើយទៅក្នុងដៃជនជាតិអាំម៉ូន។

generated on Wed Sep 10 16:16:32 2025

[8]តាំងពីឆ្នាំនោះមកអស់រយៈពេលដប់ប្រាំបីឆ្នាំ ពួកគេបានជិះជាន់សង្កត់សង្កិនជនជាតិអ៊ីស្រាអែល ដែលរស់នៅខាងទន្លេយ័រដាន់ក្នុងទឹកដីរបស់ជនជាតិអាម៉ូរី
ដែលនៅក្នុងស្រុកកាឡាដ។[9]រីឯជនជាតិអាំម៉ូន បានឆ្លងទន្លេយ័រដានមកវាយកុលសម្ព័ន្ធយូដា កុលសម្ព័ន្ធបេនយ៉ាមីន និងគ្រួនៃកុលសម្ព័ន្ធអេប្រាអ៊ីម
ដែលធ្វើអោយជនជាតិអ៊ីស្រាអែលរងទុក្ខលំបាកយ៉ាងខ្លាំង។
[10]ពេលនោះជនជាតិអ៊ីស្រាអែលបានទូលអង្វររកព្រះអម្ចាស់ថា៖ «យើងបានធ្វើទាស់នឹងទ្រង់ ព្រោះយើងបានបោះបង់ព្រះរបស់យើងហើយបែរទៅថ្វាយបង្គំព្រះបាល»។
[11]ព្រះអម្ចាស់តបទៅពួកគេថា៖ «តើយើងមិនបាននាំអ្នករាល់គ្នាពីជនជាតិអេស៊ីព្ទ ជនជាតិអាម៉ូរី ជនជាតិអាំម៉ូន
និងពីជនជាតិភីលីស្ទីន[12]ហើយនិងពីជនជាតិស៊ីដូនមកទេឬ? ជនជាតិអាម៉ាឡេក និងជនជាតិម៉ាអូនបានជិះជាន់សង្កត់សង្កិនអ្នករាល់គ្នា
អ្នករាល់គ្នាបានស្រែកហៅរកយើង ហើយយើងបានរំដោះអ្នករាល់គ្នាពីអំណាចរបស់ពួកគេ។
[13]ប៉ុន្តែ ដោយអ្នករាល់គ្នាបានបោះបង់យើង ទៅថ្វាយបង្គំព្រះផ្សេងៗទៀត ដូច្នេះយើងនឹងមិនសង្គ្រោះអ្នករាល់គ្នាទៀតទេ។
[14]ចូរទៅសូមព្រះទាំងឡាយដែលអ្នករាល់គ្នាបានថ្វាយបង្គំនោះ ឲ្យពួកគេសង្គ្រោះអ្នករាល់គ្នាពេលដែលអ្នករាល់គ្នាមានបញ្ហាចុះ»។
[15]ប្រជាជនអ៊ីស្រាអែលទូលព្រះអម្ចាស់ថា៖ «ឱព្រះអម្ចាស់អើយ! យើងបានធ្វើបាបទាស់នឹងព្រះអង្គ សូមទ្រង់ដាក់ទោសយើងខ្ញុំតាមព្រះឫទ័យទ្រង់ចុះ
តែសូមទ្រង់រំដោះទូលបង្គំនៅថ្ងៃនេះផង»។[16]ពួកគេបានយកព្រះនានាចេញពីក្នុងចំណោមពួកគេ ហើយបែរមកថ្វាយបង្គំព្រះអម្ចាស់វិញ។ ពេលនោះ
ព្រះអម្ចាស់រញ្ជួលព្រះហឫទ័យដោយឃើញទុក្ខលំបាករបស់ពួកគេ។
[17]គ្រានោះ ជនជាតិអាំម៉ូនបានប្រមូលផ្តុំគ្នា ហើយបោះទ័ពនៅកាឡាត។ ជនជាតិអ៊ីស្រាអែលក៏បានមកហើយបោះជំរំរបស់ពួកគេនៅមីសប៉ាដែរ។
[18]ពួកអ្នកដឹកនាំនៃប្រជាជននៅស្រុកកាឡាតបានពិភាក្សាគ្នាថា៖ «តើអ្នកណាដែលគួរនឹងចេញទៅច្បាំងនឹងជនជាតិអាំម៉ូនមុនគេ
អ្នកនោះនឹងធ្វើជាមេដឹកនាំលើប្រជាជនកាឡាតមុនគេ។

Judges 10:1

លោកថូឡា...លោកពូវ៉ា...លោកដូដូ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

ស្រុកសាមារ

នេះគឺជាឈ្មោះរបស់ទីកន្លែង។

បានក្រោកឡើងរំដោះជនជាតិអ៊ីស្រាអែល

«មករំដោះអ៊ីស្រាអែល» ឬ «បានក្លាយជាអ្នកដឹកនាំដើម្បីរំដោះអ៊ីស្រាអែល»។

រំដោះជនជាតិអ៊ីស្រាអែល

ពាក្យ «អ៊ីស្រាអែល» តំណាងឲ្យប្រជាជនអ៊ីស្រាអែល។

គាត់ជាចៅហ្វាយលើអ៊ីស្រាអែល

ពាក្យ «ចៅហ្វាយ» មានន័យថាលោកជាអ្នកដឹកនាំជនជាតិអ៊ីស្រាអែល។

អស់រយៈពេលម្ភៃបីឆ្នាំ

បីឆ្នាំ «២៣ឆ្នាំ»

បានបញ្ចុះ

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកគេបានបញ្ចុះគាត់»។

Judges 10:3

អ្នកដែលមកបន្ទាប់គាត់ គឺលោកយ៉ាអ៊ៀរ ជាអ្នកស្រុកកាឡាដ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកយ៉ាអ៊ៀរ
អ្នកស្រុកកាឡាដ ជាអ្នកដឹកនាំបន្ទាប់លោកថូឡា»។

លោកយ៉ាអ៊ៀរ

នេះគឺជាឈ្មោះរបស់បុរសម្នាក់។

អ្នកស្រុកកាឡាដ

លោកយ៉ាអ៊ៀរមកពីអំបូររបស់កាឡាដ។

គាត់បានជាចៅហ្វាយ

ពាក្យ «ចៅហ្វាយ» មានន័យថា លោកជាអ្នកដឹកនាំប្រជាជនអ៊ីស្រាអែល។

អ៊ីស្រាអែល

ពាក្យ «អ៊ីស្រាអែល» តំណាងឲ្យប្រជាជនអ៊ីស្រាអែល។

ម្ភៃពីរឆ្នាំ

ពីរឆ្នាំ «២២ឆ្នាំ»

សាមសិប

«៣០»

ហារូត យ៉ាអ៊ៀរ

នេះគឺជាឈ្មោះរបស់តំបន់ ដែលដាក់ឈ្មោះតាមមនុស្សម្នាក់។

រហូតដល់សព្វថ្ងៃនេះ

ឃ្លានេះ មានន័យថា ជាពេលដែលកណ្ឌគម្ពីរចៅហ្វាយបានសរសេរឡើង។

ត្រូវបានបញ្ចុះ

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានបញ្ចុះលោក»។

កាម៉ូន

នេះគឺជាឈ្មោះរបស់ទីកន្លែង។

Judges 10:6

បានបន្ថែមការអាក្រក់ ដែលពួកគេបានធ្វើក្នុងព្រះនេត្រព្រះជាម្ចាស់ជាថ្មី

ឃ្លានេះ និយាយពីការអាក្រក់ របៀបដូចជាវត្ថុដែលមនុស្សម្នាក់អាចបន្ថែម
ហើយធ្វើឲ្យវាកាន់តែធំឡើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្តធ្វើអ្វីដែលព្រះអម្ចាស់មានបន្ទូលថាអាក្រក់» ។

ព្រះនេត្រព្រះអម្ចាស់

ពាក្យ «ព្រះនេត្រព្រះអម្ចាស» តំណាងឲ្យអ្វីដែលព្រះអម្ចាស់ព្រះតម្រិះ
និងគិតអំពីអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ស្របទៅតាមព្រះអម្ចាស»។

ព្រះអាសថារ៉ូត

ពាក្យព្រះអាសថារ៉ូតនេះប្រើពហុវចន
ជាព្រះដែលពួកគេថ្វាយបង្គំជាព្រះនៅក្នុងទម្រង់ជាច្រើន។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២:១១។

ពួកគេបានបំភ្លេចព្រះជាម្ចាស់ហើយមិនថ្វាយបង្គំទ្រង់តទៅទៀតទេ

អ្នកនិពន្ធ និយាយការដូចគ្នាពីរដង ដើម្បីបញ្ជាក់។
ឃ្លាទាំងពីរនេះអាចរួមបញ្ចូលគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេឈប់ថ្វាយបង្គំព្រះអម្ចាស់ទាំងស្រុង»។ ។

ព្រះជាម្ចាស់ព្រះពិរោធយ៉ាងខ្លាំងជាមួយជនជាតិអ៊ីស្រាអែល

ព្រះអម្ចាស់ព្រះពិរោធ ប្រៀបដូចជាឆេះភ្លើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់ព្រះពិរោធជាខ្លាំងជាមួយជនជាតិអ៊ីស្រាអែល» ។

ព្រះអង្គបានលក់ពួកគេទៅក្នុងដៃសាសន៍ភីលីស្ទីន ហើយទៅក្នុងដៃជនជាតិអាំម៉ូន

ព្រះអម្ចាស់បានអនុញ្ញាតឲ្យសាសន៍ភីលីស្ទីន និងសាសន៍អាំម៉ូន
យកឈ្នះលើអ៊ីស្រាអែល របៀបដូចជាព្រះអង្គលក់អ៊ីស្រាអែលឲ្យទៅពួកគេ។

ទៅក្នុងដៃ

ពាក្យ «ដៃ» តំណាងឲ្យអំណាច និងការគ្រប់គ្រង។

Judges 10:8

បានជិះជាន់ និងសង្កត់សង្កិន

ពាក្យពីរនេះមានន័យដូចគ្នា ដើម្បីបញ្ជាក់ថាពួកគេរងទុក្ខខ្លាំងប៉ុណ្ណោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានសង្កត់សង្កិនយ៉ាងខ្លាំង»

ដប់ប្រាំបីឆ្នាំ

«១៨ឆ្នាំ»

ដែលរស់នៅខាងទន្លេយ័រដាន់

ឃ្លានេះមាននន័យថា នៅខាងកើតទន្លេយ័រដាន់។

ដែលនៅក្នុងស្រុកកាឡាដ

«ទឹកដីនេះ ហៅថា ស្រុកកាឡាដ»

កុលសម្ព័ន្ធយូដា...កុលសម្ព័ន្ធបេនយ៉ាមីន

«កុលសម្ព័ន្ធយូដា» និង
«កុលសម្ព័ន្ធបេនយ៉ាមីន»សំដៅលើការស្ថិតនៅក្នុងកុលសម្ព័ន្ធទាំងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សដែលនៅក្នុងកុលសម្ព័ន្ធយូដា...មនុស្សដែលនៅក្នុងកុលសម្ព័ន្ធបេនយ៉ាមីន» ។

ផ្ទះនៃអេប្រាអ៊ីម

ពាក្យ «ផ្ទះ» សំដៅលើប្រជាជននៅក្នុងកុលសម្ពន្ធអេប្រាអ៊ីម។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សនៅក្នុងកុលសម្ព័ន្ធអេប្រាអ៊ីម»។ ។

generated on Wed Sep 10 16:16:32 2025

ដូច្នេះហើយជនជាតិអ៊ីស្រាអែលរងទុក្ខលំបាកយ៉ាងខ្លាំង
«អ៊ីស្រាអែល» សំដៅលើប្រជាជនអ៊ីស្រាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះ ប្រជាជនអ៊ីស្រាអែលរងទុក្ខយ៉ាងខ្លាំង»។
Judges 10:10
ពេលនោះជនជាតិអ៊ីស្រាអែលបានស្រែកអំពាវនាវរកព្រះជាម្ចាស់
ឃ្លានេះ មានន័យថាប្រជាជនអ៊ីស្រាអែលបានទូលអង្វរដល់ព្រះអម្ចាស់ឲ្យជួយ។
ព្រោះយើងបានបោះបង់ព្រះជាម្ចាស់របស់យើង
មនុស្សលែងស្តាប់បង្គាប់ ហើយថ្វាយបង្គំដល់ព្រះអម្ចាស់
និយាយប្រៀបដូចជាពួកគេចេញពីព្រះអម្ចាស់ ហើយទៅកន្លែងផ្សេងទៀត។
បានបោះបង់ព្រះជាម្ចាស់របស់យើង
មនុស្សដែលនិយាយពីព្រះអម្ចាស់ ហើយសំដៅលើព្រះអង្គជា
«ព្រះជាម្ចាស់របស់យើង»។ ឃ្លានេះអាចនិយាយជាបុរសទីពីរ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាបានបោះបង់ ព្រះជាម្ចាស់នៃយើង»។
តើយើងមិនបានយកអ្នករាល់គ្នាពី... ជនជាតិស៊ីដូនមកទេឬ?
ព្រះជាម្ចាស់បានស្តីបន្ទោសដល់ប្រជាជនអ៊ីស្រាអែល
ដោយព្រោះពួកគេថ្វាយបង្គំព្រះផ្សេងទៀត។
នេះគឺជាសំណួរដែលមិនទាមទារចម្លើយ ដែលអាចបកប្រែជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងគឺជាអ្នកដែលរំដោះអ្នករាល់គ្នាពី...ជនជាតិស៊ីដូន»។
ជនជាតិម៉ាអូន
អ្នកទាំងនេះគឺជាមនុស្សដែលមកពីអំបូរ ឬ គ្រួសាររបស់ម៉ាអូន។
ពីអំណាចរបស់ពួកគេ
ពាក្យ «អំណាច» តំណាងឲ្យជនជាតិអាម៉ាឡេក និងជនជាតិម៉ាអូន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីពួកគេ»។
Judges 10:13
អ្នករាល់គ្នាបានបោះបង់យើងម្តងទៀត
មនុស្សលែងស្តាប់បង្គាប់ ហើយថ្វាយបង្គំដល់ព្រះអម្ចាស់
និយាយប្រៀបដូចជាពួកគេចេញពីព្រះអម្ចាស់ ហើយទៅកន្លែងផ្សេងទៀត។
យើងនឹងមិនបន្តបន្ថែមពេលវេលារំដោះអ្នករាល់គ្នាទៀតឡើយ
ឃ្លា «បន្តបន្ថែមពេលវេលា» គឺជាពាក្យប្រៀបធៀបដែលមានន័យថាបន្តធ្វើអ្វីមួយ។
អ្នកអាចបញ្ជាក់សំដៅលើព្រះអម្ចាស់មានបន្ទូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងមិនបន្តរំដោះអ្នករាល់គ្នាម្តងហើយម្តងទៀតនោះទេ» ឬ
«អ្នកអាចប្រាកដថា យើងឈប់រំដោះអ្នក»។
Judges 10:15
ព្រះនានារបស់ជនបរទេសចេញពីក្នុងចំណោមពួកគេ
អ្នកអាចបញ្ជាក់ច្បាស់លាស់ពីប្រយោគនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនានាសាសន៍ដទៃ រូបព្រះទាំងនោះ ធ្វើជាសម្បត្តិរបស់ពួកគេ»។
ព្រះជាម្ចាស់មិនអាចទ្រាំនឹងទុក្ខលំបាករបស់អ៊ីស្រាអែលបានទៀតទេ
អ៊ីស្រាអែលនៅទីនេះ សំដៅលើប្រជាជនអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយព្រះអម្ចាស់មិនចង់ឲ្យជនជាតិអ៊ីស្រាអែលរងទុក្ខតទៅទៀត»។ ។
Judges 10:17
តើអ្នកណាដែលគួរនឹងចេញទៅច្បាំងនឹងជនជាតិអាំម៉ូនមុនគេ?
«តើអ្នកណាដឹកនាំទាហានរបស់យើងចេញទៅច្បាំងនឹងជនជាតិអាំម៉ូនមុនគេ?»

---

11 [1]គ្រានោះ លោកយ៉ែបថា ជាអ្នកចម្បាំងដ៏ខ្លាំងពូកែម្នាក់នៅកាឡាត ជាកូនប្រុសរបស់ស្ត្រីពេស្យា និងបុរសម្នាក់ឈ្មោះកាឡាត។
[2]ភរិយារបស់លោកកាឡាតក៏បានបង្កើតកូនប្រុសដទៃទៀតឲ្យលោកដែរ។ នៅពេលដែលកូនប្រុសភរិយារបស់លោកកាឡាតធំឡើង
ពួកគេបានបណ្តេញលោកយ៉ែបថា ចេញពីផ្ទះ ហើយបាននិយាយទៅគាត់ថា៖ «ឯងគ្មានសិទ្ធិនឹងទទួលមរតករបស់ឪពុកយើងទេ ព្រោះឯងជាកូនរបស់ស្រីផ្សេង»។[3]ដូច្នេះ
លោកយ៉ែបថា បានភៀសខ្លួនចេញពីបងប្អូនរបស់គាត់ហើយទៅរស់នៅក្នុងស្រុក ថូប។ មានពួកមនុស្សពាលបានមកចូលរួមជាមួយគាត់
ហើយពួកគេបាននាំគ្នាចេញទៅប្លន់។
[4]ប៉ុន្មានថ្ងៃក្រោយមក ជនជាតិអាំម៉ូន បានធ្វើសង្គ្រាមទាស់នឹងជនជាតិអ៊ីស្រាអែល។[5]នៅពេលដែលជនជាតិអាំម៉ូន ប្រឆាំងទាស់នឹងអ៊ីស្រាអែល
ពួកចាស់ទុំកាឡាតបាននាំគ្នាចេញទៅអញ្ជើញលោកយ៉ែបថា ឲ្យត្រឡប់ពីទឹកដីថូប មកវិញ។[6]ពួកគេនិយាយទៅកាន់លោកយ៉ែបថាថា៖ «សូមមក
ហើយធ្វើជាមេដឹកនាំលើយើង នោះយើងនឹងប្រយុទ្ធជាមួយជនជាតិអាំម៉ូន»។
[7]លោកយ៉ែបថាឆ្លើយទៅពួកចាស់ទុំវិញថា៖ «អ្នករាល់គ្នាបានស្អប់ខ្ញុំ ហើយបានបណ្តេញខ្ញុំចេញពីផ្ទះឪពុករបស់ខ្ញុំ។ ហេតុអ្វីពេលដែលអ្នករាល់គ្នាមានបញ្ហា
អ្នករាល់គ្នាមករកខ្ញុំ?»[8]ចាស់ទុំនៃស្រុកកាឡាត តបថា៖ «នោះជាហេតុផលដែលយើងមករកលោកពេលនេះ សូមមកជាមួយយើង ហើយច្បាំងជាមួយជនជាតិអាំម៉ូន
នោះលោកនឹងក្លាយជាអ្នកដឹកនាំលើគ្រប់គ្នាដែលនៅក្នុងស្រុកកាឡាតនេះ»។
[9]លោកយ៉ែបថាបានតបទៅចាស់ទុំស្រុកកាឡាតថា៖ «ខ្ញុំនឹងធ្វើជាមេដឹកនាំលើអ្នករាល់គ្នា ប្រសិនបើ អ្នករាល់គ្នានាំខ្ញុំត្រឡប់ទៅផ្ទះម្តងទៀត
ដើម្បីប្រយុទ្ធជាមួយជនជាតិអាំម៉ូន ហើយប្រសិនបើ ព្រះអម្ចាស់ប្រទានឲ្យយើងមានជ័យជម្នះលើពួកគេ»។
[10]ពួកចាស់ទុំនៃស្រុកកាឡាតនិយាយទៅកាន់លោកយ៉ែបថាថា៖ «ព្រះអម្ចាស់ជាសាក្សីរវាងលោក និងពួកយើង ប្រសិនបើ
យើងមិនធ្វើតាមការដែលយើងនិយាយទេនោះ!»[11]ដូច្នេះ លោកយ៉ែបថាបានទៅជួបពួកចាស់ទុំនៅស្រុកកាឡាដ ហើយពួកគេបានលើកគាត់ឲ្យធ្វើជាអ្នកដឹកនាំ
និងជាមេទ័ពរបស់ពួកគេ។ នៅចំពោះព្រះអម្ចាស់ នៅស្រុកមីសប៉ា លោកយ៉ែបថាបាននិយាយអ្វីដែលគាត់បានសន្យាសារថ្មីឡើយវិញ។
[12]បន្ទាប់មក លោកយ៉ែបថាបានចាត់អ្នកនាំសារទៅស្តេចរបស់ជនជាតិអាំម៉ូន ទូលថា៖ «តើនេះជាជម្លោះអ្វីរវាងពួកយើង?
ហេតុអ្វីបានជាអ្នកមកបណ្តេញយកទឹកដីរបស់យើង?»[13]ស្តេចជនជាតិអាំម៉ូនបានឆ្លើយទៅអ្នកនាំសាររបស់លោកយ៉ែបថាថា៖
«ព្រោះនៅពេលដែលជនជាតិអ៊ីស្រាអែលចេញពីអេស៊ីព្ទមក ពួកគេបានចាប់យកដីចាប់តាំងពីស្រុកអាណូណដល់ស្រុកយ៉ាបបុក នៅខាងជើងទន្លេយ័រដាន់។ ឥឡូវនេះ
ចូរប្រគល់ទឹកដីទាំងនោះមកវិញដោយសន្តិភាពមក»។
[14]លោកយ៉ែបថា បានបញ្ជូនអ្នកនាំសារម្តងទៀតទៅកាន់ស្តេចនៃជនជាតិអាំម៉ូន[15]ហើយគាត់បាននិយាយថា៖ «នេះជាអ្វីដែលលោកយ៉ែបថានិយាយ៖
ជនជាតិអ៊ីស្រាអែលមិនបានយកទឹកដីរបស់ជនជាតិម៉ូអាប់ និងជនជាតិអាំម៉ូនទេ[16]ប៉ុន្តែ ពួកគេបានចេញមកអេស៊ីព្ទ ឆ្លងកាត់តាមវាលរហោស្ថានទៅសមុទ្រត្រែង
ហើយក៏មកដល់កាដេស។
[17]នៅពេលដែលអ៊ីស្រាអែលបញ្ជូនអ្នកនាំសារទៅស្តេចនៃស្រុកអេដុំ ដោយទូលថា៖ «សូមអនុញ្ញាតឲ្យយើងឆ្លងកាត់ទឹកដីរបស់ទ្រង់ តែស្តេចអេដុំមិនស្តាប់ការសូមនោះទេ
ពួកគេក៏បានបញ្ជូនអ្នកនាំសារទៅស្តេចម៉ូអាប់ដូចគ្នា ប៉ុន្តែ ស្តេចបានបដិសេធ។ ដូច្នេះ អ៊ីស្រាអែលបានស្នាក់នៅកាដេស។[18]នោះ ពួកគេបានធ្វើដំណើរវាងទឹកដីអេដុម
និងទឹកដីម៉ូអាប់ ដោយឆ្លងកាត់វាលរហោស្ថាន ពួកគេធ្វើដំណើរតាមភាគខាងកើតទឹកដីម៉ូអាប់ ហើយពួកគេបោះជំរំនៅទិសផ្សេងទៀតនៃស្ទឹងអើណូណ ប៉ុន្តែ
ពួកគេមិនបានចូលទៅទឹកដីម៉ូអាប់ទេ។ ស្ទឹងអើណូណជាព្រំប្រទល់នៃទឹកដីរបស់ជនជាតិម៉ូអាប់។
[19]ជនជាតិអ៊ីស្រាអែលក៏បានចាត់អ្នកនាំសារទៅទូលព្រះបាទស៊ីហុន ជាស្តេចនៃជនជាតិអាម៉ូរី ដែលគ្រងរាជ្យនៅហេប្រុនថា
«សូមអនុញ្ញាតឲ្យយើងខ្ញុំឆ្លងកាត់ទឹកដីរបស់ទ្រង់ឆ្ពោះទៅកាន់ទឹកដីដែលជារបស់យើង។»[20]ប៉ុន្តែ ព្រះបាទស៊ីហុន
មិនទុកចិត្តឲ្យជនជាតិអ៊ីស្រាអែលឆ្លងកាត់ទឹកដីរបស់ទ្រង់ទេ។ ដូច្នេះ ហើយបានជាពេលនោះព្រះបាទស៊ីហុន ប្រមូលផ្តុំ កងទ័ពទាំងអស់របស់ទ្រង់នៅយ៉ាហាស
ច្បាំងជាមួយជនជាតិអ៊ីស្រាអែល។
[21]គ្រានោះព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែលបានប្រទានស៊ីហុន និងមនុស្សទាំងអស់របស់ទ្រង់មកក្នុងកណ្តាប់ដៃជនជាតិអ៊ីស្រាអែល
នោះជនជាតិអ៊ីស្រាអែលក៏មានជ័យជម្នះលើពួកគេ ហើយបានយកទឹកដីរបស់ជនជាតិអាម៉ូរីទាំងអស់។
[22]ជនជាតិអ៊ីស្រាអែលបានកាន់កាប់ទឹកដីរបស់ជនជាតិអាម៉ូរីចាប់ពីស្ទឹងអ័ណូណរហូតដល់យ៉ាបបុក ហើយពីវាលរហោស្ថានដល់ទន្លេយ័រដាន។
[23]គឺព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលបានបណ្តេញជនជាតិអាម៉ូរីចេញពីមុខរាស្ត្ររបស់ទ្រង់ ឥឡូវនេះ តើព្រះករុណាចង់ដណ្តើមទឹកដីរបស់ពួកគេឬ?
[24]តើព្រះករុណាមិនបានកាន់កាប់ទឹកដីដែលព្រះកេម៉ូស ជាព្រះរបស់ព្រះរុណាបានប្រគល់ឲ្យទេឬ? ដូច្នេះ

generated on Wed Sep 10 16:16:32 2025

តើយើងមិនអាចកាន់កាប់ទឹកដីដែលព្រះអម្ចាស់ជាព្រះនៃយើងបានប្រគល់ឲ្យយើងដែរទេឬ?[25]តើឥឡូវនេះ ព្រះអង្គពិតជាប្រសើរជាងព្រះបាទបាឡាក់ ប្រុតរបស់ស៊ីបព័រ
ជាស្តេចនៃជនជាតិម៉ូអាប់ឬអី? ព្រះបាទបាឡាក់មិនបានរករឿងប្រជាជាតិអ៊ីស្រាអែល ហើយក៏មិនបានធ្វើសង្គ្រាមជាមួយពួកគេដែរ។
[26]អស់រយៈពេលបីរយឆ្នាំមកហើយ ដែលប្រជាជនអ៊ីស្រាអែលបានរស់នៅក្នុងក្រុងហេសបូន និង ក្រុងអារ៉ូអើ ព្រមទាំងតំបន់ជុំវិញ
និងភូមិស្រុកនានានៅតាមដងស្ទឹងអើណូណ ចុះហេតុដូចម្តេចបានជាទ្រង់មិនរំដោះយកទឹកដីទាំងនោះក្នុងពេលនោះទៅ?[27]ទូលបង្គំមិនបានធ្វើអ្វីខុសនឹងទ្រង់ទេ
គឺទ្រង់ទេតើដែលបានប្រព្រឹត្តខុសដោយទាស់នឹងទូលបង្គំ សូមឲ្យព្រះអម្ចាស់ជាចៅក្រម សម្រេចក្តីនៅថ្ងៃនេះរវាងជនជាតិអ៊ីស្រាអែលនិងជនជាតិអាំម៉ូននៅថ្ងៃនេះចុះ»។
[28]ប៉ុន្តែ ស្តេចនៃជនជាតិអាំម៉ូន មិនបានអើពើនឹងសំដីតីដែលលោកយ៉ែបថាបានចាត់អ្នកនាំពាក្យទៅទូលទ្រង់នោះទេ។
[29]គ្រានោះ ព្រះវិញ្ញាណនៃព្រះអម្ចាស់បានមកសណ្ឋិតលើលោកយ៉ែបថា រួចលោកបានធ្វើដំណើរឆ្លងកាត់ស្រុកកាឡាតនិងស្រុកម៉ាណាសេ
ហើយឆ្លងកាត់ទៅដល់ក្រុងមីសប៉ាក្នុងស្រុកកាឡាត បន្ទាប់មកលោកធ្វើដំណើរពីក្រុងមីសប៉ានៃស្រុកកាឡាតទៅដល់ស្រុកអាំម៉ូន។[30]លោកយ៉ែបថា
បានសច្ចានៅចំពោះព្រះជាម្ចាស់ថា៖ «ប្រសិនបើ
ព្រះអម្ចាស់ប្រទានឲ្យទូលបង្គំមានជ័យជម្នះលើជនជាតិអាំម៉ូននេះ[31]ហើយនៅពេលដែលទូលបង្គំត្រឡប់មកវិញដោយសុខសាន្ត
អ្នកណាដែលចេញពីទ្វារផ្ទះរបស់ទូលបង្គំមកទទួលទូលបង្គំមុនគេ ទូលបង្គំនឹងយកអ្នកនោះធ្វើជាយញ្ញបូជាថ្វាយដល់ព្រះអម្ចាស់»។
[32]ដូច្នេះ លោកយ៉ែបថាចូលទៅវាយជនជាតិអាំម៉ូន ហើយព្រះអម្ចាស់បានប្រទានឲ្យលោកមានជ័យជម្នះ។[33]លោកយ៉ែបថាបានវាយប្រហារ
និងសម្លាប់រង្គាលពួកគេចាប់ពីក្រុងអារ៉ូអ៊ើ រហូតដល់តំបន់ជិតខាងក្រុងមេនីត សរុបទាំងអស់ម្ភៃក្រុង និងដល់ក្រុងអាបែល ការ៉ូមីម។
ដូច្នេះជនជាតិអ៊ីស្រាអែលបានគ្រប់គ្រងលើជនជាតិអាំមូន។
[34]លោកយ៉ែបថាបានត្រឡប់មកផ្ទះរបស់លោកនៅក្រុងមីសប៉ាវិញ ពេលនោះកូនស្រីរបស់លោកបានចេញមកទទួលលោកទាំងវាយក្រាប់ និងរាំផង។
នាងជាកូនតែម្នាក់គត់របស់លោក ក្រៅពីនាង លោកមិនមានកូនប្រុស ស្រីឯណាទៀតទេ។[35]ពេលដែលលោកបានឃើញនាងភ្លាម
លោកបានហែកសម្លៀកបំពាក់របស់លោកហើយនិយាយថា៖ «ឱ កូនស្រីមាសឪពុក! កូនបានធ្វើឲ្យឪពុកកើតទុក្ខហើយ ហើយកូនបានធ្វើឲ្យឪពុកមានសេចក្តីឈឺចាប់!
ព្រោះឪពុកបានស្បថនឹងព្រះអម្ចាស់ ហើយពុកមិនអាចក្បត់សេចក្តីសន្យានោះបានទេ»។
[36]នាងក៏និយាយទៅកាន់លោកថា៖ «លោកឪពុកអើយ លោកបានស្បថចំពោះព្រះអម្ចាស់ហើយ ដូច្នេះ
សូមលោកឪពុកប្រព្រឹត្តតាមសេចក្តីគ្រប់យ៉ាងដែលបានស្បថនោះចុះ ពីព្រោះព្រះអម្ចាស់បានប្រទានឲ្យពុកមានជ័យជន្នះលើសត្រូវរបស់ឪពុក គឺលើជនជាតិអាំម៉ូន»។
[37]នាងនិយាយទៅកាន់ឪពុករបស់នាងទៀតថា «សូមអនុញ្ញាតទុកពេលឲ្យកូនបានពីរខែសិន
ឲ្យកូនបានចុះពីលើភ្នំទៅយំសោកស្តាយព្រហ្មចារីរបស់កូនជាមួយមិត្តភក្តិស្រីៗរបស់កូន»។
[38]លោកនិយាយថា៖ «ចូរទៅចុះកូន!» លោកបានអនុញ្ញាតឲ្យនាងចេញទៅពីរខែ ហើយនាងក៏ចាកចេញពីគាត់ ទៅជាមួយមិត្តភក្តិស្រីៗរបស់នាង។
[39]គ្រប់ពីរខែហើយនាងក៏ត្រឡប់ទៅរកឪពុកវិញ រួចលោកក៏យកនាងធ្វើជាយញ្ញបូជាតាមពាក្យសន្យារបស់លោក។ នាងមិនដែលស្គាល់បុរសណាឡើយ
ចាប់ពីពេលនោះមក ជនជាតិអ៊ីស្រាអែលបានប្រកាន់ទំនៀមទម្លាប់នេះ គឺ[40]ជារៀងរាល់ឆ្នាំកូនក្រមុំជនជាតិអ៊ីស្រាអែលត្រូវនាំគ្នាទៅយំរំលឹកដល់កូនស្រីរបស់លោកយ៉ែបថា
ជាអ្នកស្រុកកាឡាតរយៈពេលបួនថ្ងៃ។

Judges 11:1
កាឡាត
នេះគឺជាមនុស្សដែលមកពីតំបន់កាឡាត។
នេះគឺជារឿងចៃដន្យដែលឪពុករបស់លោកឈ្មោះកាឡាតដែរ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ១០:៣ ។
នៅពេលដែលកូនប្រុសភរិយារបស់គាត់ធំឡើង
«នៅពេលដែលកូនប្រុសភរិយារបស់កាឡាតធំឡើង»។
ទឹកដីថូប
ថូបគឺជាឈ្មោះរបស់តំបន់។
ពួកគេបាននាំគ្នាមកនិងទៅជាមួយគាត់
«ពួកគេបាននាំគ្នាមកតាមគាត់» ឬ «ពួកគេទៅតាមគាត់គ្រប់កន្លែង»។
Judges 11:4
ប៉ុន្មានថ្ងៃក្រោយមក
«ប៉ុន្មានខែក្រោយ» (UDB)
បានធ្វើសង្គ្រាមទាស់នឹងជនជាតិអ៊ីស្រាអែល
ឃ្លា «ធ្វើសង្គ្រាម» គឺជាពាក្យប្រៀបធៀប ដែលមានន័យថាប្រហារអ៊ីស្រាអែល
ហើយធ្វើសង្គ្រាមជាមួយពួកគេ។ ពាក្យ «អ៊ីស្រាអែល» នៅទីនេះ
សំដៅលើប្រជាជនអ៊ីស្រាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រហារជនជាតិអ៊ីស្រាអែល»។
នោះយើងអាចប្រយុទ្ធជាមួយ
«ដើម្បីឲ្យយើងអាចប្រយុទ្ធជាមួយ»។
Judges 11:7
ផ្ទះឪពុករបស់ខ្ញុំ
ពាក្យ «ផ្ទះ» សំដៅលើមនុស្សដែលរស់នៅក្នុងផ្ទះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រួសាររបស់ខ្ញុំ»។
នោះជាហេតុផលដែលយើងមករកលោកពេលនេះ
ពាក្យ «នោះ» សំដៅលើអ្វីដែលលោកយ៉ែបថានិយាយពីពួកគេនឹងមានបញ្ហា។
អត្ថន័យពេញនៃសេចក្តីថ្លែងនេះអាចធ្វើឲ្យច្បាស់ថែមទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងមករកលោកឥឡូវនេះ
ដោយសារយើងកំពុងតែជួបបញ្ហា»។ ។
ច្បាំងជាមួយជនជាតិអាំម៉ូន
«ប្រយុទ្ធជាមួយជនជាតិអាំម៉ូន»។
Judges 11:9
អ្នកដឹកនាំ និងជាមេបញ្ជាការ
ពាក្យទាំងពីរនេះ និយាយម្តងហើយម្តងទៀត
ដើម្បីបញ្ជាក់ពីភាពសំខាន់របស់លោកយ៉ែបថា។
អ្នកអាចបូកបញ្ចូលពាក្យទាំងពីរនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មេបញ្ជាការ»
នៅពេលនោះ គាត់បាននៅចំពោះព្រះជាម្ចាស់ នៅស្រុកមីសប៉ា
លោកយ៉ែបថាបាននិយាយអ្វីដែលគាត់បានសន្យាសារឡើយវិញម្តងទៀត។
នេះគឺជាពាក្យប្រៀបធៀប។ ឃ្លានេះ «នៅចំពោះព្រះអម្ចាស់»
មានន័យថាលោកនិយាយសន្យាដោសស្បថនៅចំពោះព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលលោកយ៉ែបថានៅស្រុកមីសប៉ា
លោកបាននិយាយសន្យា ប្រៀបដូចជាសម្បថនៅចំពោះព្រះអម្ចាស់»។
បានសន្យាសារឡើយវិញម្តងទៀត
សំដៅលើសេចក្តីសន្យា ដែលលោកបានសន្យាជាមួយពួកចាស់ទុំនៅកាឡាត
អំពីការដែលគាត់នឹងធ្វើជាអ្នកដឹកនាំពួកគេ។
Judges 11:12
តើនេះជាជម្លោះអ្វីរវាងពួកយើង?
«ហេតុអ្វីបានជាយើងជម្លោះនឹងគ្នា?» លោកយ៉ែបថាសួរសំណួរនេះទៅកាន់ស្តេច
ហេតុអ្វីបានជាពួកគេខឹងនឹងអ៊ីស្រាអែល។
ហេតុអ្វីបានជាអ្នកមកបណ្តេញយកទឹកដីរបស់យើងដូច្នេះ?
ពាក្យនេះ សំដៅលើសេចក្តីស្តេចរបស់ជនជាតិអាំម៉ូន
ដែលនិយាយនៅទីនេះជាពាក្យប្រៀបធៀបសម្រាប់ទាហានជនជាតិអាំម៉ូន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុអ្វីបានជាទាហានរបស់ទ្រង់មកដណ្តើមទឹកដីរបស់យើងដូច្នេះ?»
មកបណ្តេញយក
«មកដោយបង្ខំយក»។
ស្រុកអាណូណ...ស្រុកយ៉ាបុក
ទាំងនេះគឺជាឈ្មោះទន្លេពីរ។
នៅខាងលើទន្លេយ័រដាន់
«នៅប៉ែកម្ខាងទៀតនៃទន្លេយ័រដាន់»។

generated on Wed Sep 10 16:16:32 2025

ដោយសន្តិភាព
«ដោយសន្តិភាព» ឬ «ហើយមិនបានការពារពួកគេ»។
Judges 11:14
គាត់បាននិយាយថា
ពាក្យ «គាត់» សំដៅលើអ្នកនាំសារ ដែលនិយាយជាមួយស្តេច។
នេះអាចសរសេរជាពាក្យ «ពួកគេ» ដូចនៅក្នុង UDB សំដៅលើក្រុមអ្នកនាំសារ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកយ៉ែបថាបានប្រាប់ដល់អ្នកនាំសារដោយនិយាយថា» ឬ «ពួកគេនិយាយ»។
ពួកគេបានមកអេស៊ីប
នៅពេលណាមនុស្សធ្វើដំណើរមកក្នុងទឹកដីសន្យា ដោយប្រើពាក្យ «ឡើងទៅ»
ទឹកដីសន្យា។ នៅពេលជនជាតិអ៊ីស្រាអែលចេញពីអេស៊ីប
ពួកគេនៅតាមផ្លូវទៅទឹកដីសន្យា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេចេញពីអេស៊ីប»។
Judges 11:17
ព័ត៌មានទូទៅ
អ្នកនាំសាររបស់លោកយ៉ែបថាបន្តនិយាយ។
នៅពេលដែលអ៊ីស្រាអែលបញ្ជូនអ្នកនាំសារទៅ
អ្នកនាំសារចាត់ទៅដោយអ្នកដឹកនាំរបស់ជនជាតិអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលអ្នកដឹកនាំជនជាតិអ៊ីស្រាអែលចាត់អ្នកនាំសារ។
ឆ្លងកាត់
«ដើរឆ្លងកាត់» ឬ «ឆ្លងកាត់» ។
មិនបានស្តាប់ទេ
ឃ្លានេះ និយាយជាពាក្យប្រៀបធៀបដែលមានន័យថា «បដិសេធ»
របៀបផ្សេងទៀតនៃការបកប្រែ: «បានបដិសេធ» ឬ
«បដិសេធសំណើរបស់ពួកគេ»។
ពួកគេក៏បានបញ្ជូនអ្នកនាំសារទៅស្តេចម៉ូអាប់ដូចគ្នា
ហេតុផលដែលជនជាតិអ៊ីស្រាអែលចាត់អ្នកនាំសារទៅកាន់ស្តេចម៉ូអាប់ដើម្បីឲ្យកាន់តែច្បាស់
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានចាត់អ្នកនាំសារទៅជួបស្តេចម៉ូអាប់តាមសំណើដូចគ្នាដែរ»។
ប៉ុន្តែ ស្តេចបានបដិសេធ។
ស្តេចម៉ូអាប់បានបដិសេធសំណើរបស់ជនជាតិអ៊ីស្រាអែលក្នុងការឆ្លងកាត់ស្រុកម៉ូអាប់។
អត្ថន័យពេញនៃប្រយោគនេះអាចធ្វើឲ្យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ស្តេចបានបដិសេធ
ហើយមិនអនុញ្ញាតឲ្យពួកគេឆ្លងកាត់ទឹកដីស្រុកម៉ូអាប់ឡើយ»។
អើណូណ
នេះគឺជាឈ្មោះរបស់ទន្លេ។ សូមបកប្រែពាក្យនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក
១១:១២។
Judges 11:19
ព័ត៌មានទូទៅ
អ្នកនាំសាររបស់លោកយ៉ែបថាបន្តនិយាយ។
ជនជាតិអ៊ីស្រាអែលក៏បានចាត់អ្នកនាំសារទៅព្រះបាទស៊ីហុន
អ្នកដឹកនាំជនជាតិអ៊ីស្រាអែលបានចាត់អ្នកនាំសារឲ្យទៅ។
របៀបផ្សេងតៀតនៃការបកប្រែ:
«អ្នកដឹកនាំជនជាតិអ៊ីស្រាអែលបានចាត់អ្នកនាំសារឲ្យទៅ»
ព្រះបាទស៊ីហុន...យ៉ាហាស
នេះគឺជាឈ្មោះរបស់ទីក្រុង។
ប៉ុន្តែ ព្រះបាទស៊ីហុន មិនទុកចិត្តឲ្យជនជាតិអ៊ីស្រាអែលឆ្លងកាត់ទឹកដីរបស់ទ្រង់ទេ
ព្រះបាទស៊ីហុនមិនទុកចិត្តទន់ជាតិអ៊ីស្រាអែលឆ្លងកាត់ទឹកដីរបស់ទ្រង់ដោយសុខសាន្ត
អត្ថន័យពេញនៃប្រយោគនេះធ្វើឲ្យកាន់តែច្បាស់ថែមទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
ព្រះបាទស៊ីហុនមិនទុកចិត្តអ៊ីស្រាអែលឆ្លងកាត់ទឹកដីរបស់ទ្រង់ដោយសុខសាន្តទេ»
ទ្រង់បានច្បាំង
ពាក្យ «ស្តេច» សំដៅលើព្រះបាទស៊ីហុន
ហើយពាក្យប្រៀបធៀបសម្រាប់ទាហានរបស់ទ្រង់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេប្រយុទ្ធនៅទីនោះ» ឬ
«ទាហានរបស់ស្តេចបានប្រយុទ្ធនៅទីនោះ»។
Judges 11:21
ព័ត៌មានទូទៅ
អ្នកនាំសាររបស់លោកយ៉ែបថាបន្តនិយាយ។
ព្រះបាទស៊ីហុន
សូមបកប្រែឈ្មោះនេះឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១១:១៩។
បានប្រគល់ព្រះបាទស៊ីហុន និងមនុស្សទាំងអស់របស់ទ្រង់មកក្នុងកណ្តាប់ដៃជនជាតិអ៊ីស្រាអែល
ពាក្យ «ដៃ» សំដៅលើអំណាចយកឈ្នះនៅក្នុងសង្គ្រាម។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រគល់អំណាចឲ្យអ៊ីស្រាអែលលើព្រះបាទស៊ីហុន
និងទាហានរបស់ទ្រង់ទាំងមូល»។ ។
អ៊ាណូណ...យ៉ាបបុក
សូមបកប្រែឈ្មោះរបស់ទន្លេទាំងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១១:១២។
Judges 11:23
ព័ត៌មានទូទៅ
អ្នកនាំសាររបស់លោកយ៉ែបថាបន្តនិយាយ។
តើព្រះករុណាចង់ដណ្តើមទឹកដីរបស់ពួកគេឬ?
លោកយ៉ែបថាបានស្តីបន្ទោសដល់ស្តេចអាម៉ូរី
ដោយប្រើសំណួរដែលមិនទាមទារចម្លើយ។ ពាក្យ «ពួកគេ»
សំដៅលើអ៊ីស្រាអែល។ សំណួរនេះអាចបកប្រែជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
អ្នកមិនត្រូវយកទ្រព្យសម្បត្តិនៅក្នុងទឹកដីរបស់ពួកគេឡើយ»។
តើព្រះករុណាមិនបានកាន់កាប់ទឹកដីដែលព្រះកេម៉ូស ជាព្រះរបស់ព្រះរុណាបានប្រគល់ឲ្យទេឬ?
លោកយ៉ែបថាបានស្តីបន្ទោសដល់ស្តេចជនជាតិអាំម៉ូន
ដោយសំណួរដែលមិនទាមទារចម្លើយ។ សំណួរនេះអាចបកប្រែជាប្រយោគ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនត្រូវកាន់កាប់ទឹកដីដែលព្រះកេម៉ូស
ព្រះរបស់អ្នក ប្រគល់ឲ្យអ្នក»។
កាន់កាប់
ឃ្លានេះគឺជាពាក្យប្រៀបធៀបដែលមានន័យថា គ្រប់គ្រងលើអ្វីមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្រប់គ្រង» ឬ «កាន់កាប់»។
ព្រះកេម៉ូស
ឈ្មោះនេះគឺជាឈ្មោះរបស់ព្រះក្លែងក្លាយ។
តើឥឡូវនេះ ព្រះអង្គពិតជាប្រសើរជាងព្រះបាទបាឡាក់ បុត្ររបស់ស៊ីបព័រ
ជាស្តេចនៃជនជាតិម៉ូអាប់ឬអី?
លោកយ៉ែបថាបានស្តីបន្ទោសស្តេចម៉ូអាប់ជាមួយនឹងសំណួរដែលមិនទាមទារចម្លើយ។
សំណួរនេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនល្អជាងព្រះបាទបាឡាក់ បុត្ររបស់ស៊ីបព័រ
ជាស្តេចនៃជនជាតិម៉ូអាប់ឬអី»។ ។
ព្រះបាទបាឡាក់...ស៊ីបព័រ
ទាំងនេះគឺជារបស់មនុស្ស។
តើទ្រង់បានរករឿងប្រជាជាតិអ៊ីស្រាអែល
លោកយ៉ែបថាបានស្តីបន្ទោសស្តេចម៉ូអាប់ជាមួយនឹងសំណួរដែលមិនទាមទារចម្លើយ។
សំណួរនេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
ទ្រង់មិនហ៊ានឈ្លោះជាមួយអ៊ីស្រាអែលឡើយ»។
ហើយក៏មិនបានធ្វើសង្គ្រាមជាមួយពួកគេដែរ
លោកយ៉ែបថាបានស្តីបន្ទោសស្តេចម៉ូអាប់ជាមួយនឹងសំណួរដែលមិនទាមទារចម្លើយ។
សំណួរនេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើព្រះអង្គហ៊ានធ្វើសង្គ្រាមទាស់នឹងពួកគេទេ»។
Judges 11:26
ព័ត៌មានទូទៅ
អ្នកនាំសាររបស់លោកយ៉ែបថាបន្តនិយាយ។
អស់រយៈពេលបីរយឆ្នាំ
ឃ្លានេះគឺជាឈ្មោះរបស់ទីក្រុង។
ក្រុងហែសបូន
សូមបកប្រែឈ្មោះទីក្រុងនេះឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១១:១៩
ក្រុងអារ៉ូអ៊ែរ
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
អើណូន
សូមបកប្រែឈ្មោះរបស់ទីក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១១:១២។
ហេតុដូចម្តេចបានជាទ្រង់មិនយកពួកវាទាំងនោះក្នុងពេលនោះទៅ?
លោកយ៉ែបថាបានស្តីបន្ទោសស្តេចម៉ូអាប់ជាមួយនឹងសំណួរដែលមិនទាមទារចម្លើយ។
សំណួរនេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកគួរតែយកពួកគេត្រឡប់ទៅវិញនៅពេលនេះ» ឬ «ឥឡូវនេះ យឺតពេលហើយ

generated on Wed Sep 10 16:16:32 2025

អ្នកគួរតែយកពួកគេទៅជាមួយ»។
ទូលបង្គំមិនបានធ្វើអ្វីខុសនឹងទ្រង់ទេ ប៉ុន
្តែទ្រង់ទេតើដែលបានប្រព្រឹត្តខុសដោយទាស់នឹងទូលបង្គំដោយវាយប្រហារទូលបង្គំ។
លោកយ៉ែបថាបានស្តីបន្ទោសស្តេចម៉ូអាប់ជាមួយនឹងសំណួរដែលមិនទាមទារចម្លើយ។
សំណួរនេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជនជាតិអ៊ីស្រាអែលមិនបានធ្វើអ្វីខុសជាមួយប្រជារាស្ត្ររបស់ទ្រង់ឡើយ ប៉ុន្តែ
ប្រជារាស្ត្ររបស់ព្រះអង្គទេ ដែលវាយប្រហារយើងខ្ញុំ»។
មិនបានធ្វើអ្វីខុសនឹងទ្រង់ទេ...បានប្រព្រឹត្តខុស
លោកយ៉ែបថាបានស្តីបន្ទោសស្តេចម៉ូអាប់ជាមួយនឹងសំណួរដែលមិនទាមទារចម្លើយ។
សំណួរនេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រព្រឹត្តខុសនឹងទ្រង់ ...ទ្រង់ប្រព្រឹត្តខុសនឹងទូលបង្គំ» ឬ «
ប្រព្រឹត្តនឹងទ្រង់មិនត្រឹមត្រូវ...ទ្រង់ប្រព្រឹត្តនឹងទូលបង្គំមិនត្រឹមត្រូវ»។
Judges 11:29
ព្រះវិញ្ញាណនៃព្រះជាម្ចាស់បានមកលើលោកយ៉ែបថា
នេះគឺជាពាក្យប្រៀបធៀបមានន័យថា
ព្រះវិញ្ញាណមានឥទ្ធិពលលើការសម្រេចចិត្តរបស់លោកយ៉ែបថា។
របៀបផ្សេងទៀតនៃការបកប្រែ: «
ព្រះវិញ្ញាណនៃព្រះជាម្ចាស់គ្រប់គ្រងលើលោកយ៉ែបថា»
លោកបានធ្វើដំណើរឆ្លងកាត់ស្រុកកាឡាតនិងស្រុកម៉ាណាសេ...ក្នុងស្រុកកាឡាត
លោកយ៉ែបថាបានដើរឆ្លងទីកន្លែងទាំងនេះជ្រើសរើសទាហានសម្រាប់ធ្វើជាទាហានរបស់ខ្លួន
ដើម្បីចូលទៅច្បាំងជាមួយនឹងជនជាតិអាំម៉ូន។
អត្ថន័យពេញអាចធ្វើឲ្យប្រយោគនេះកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានប្រមូលមនុស្សឲ្យធ្វើជាទាហានរបស់លោក
នៅពេលលោកឆ្លងកាត់ស្រុកកាឡាតនិងស្រុកម៉ាណាសេ...ក្រុងមីសប៉ា
ស្រុកកាឡាត»។
ទូលបង្គំនឹងថ្វាយ
នេះគឺជាពាក្យប្រៀបធៀប ដែលមានន័យដូចជាតង្វាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទូលបង្គំនឹងថ្វាយវាដល់ព្រះអង្គ» ឬ
«ទូលបង្គំនឹងថ្វាយជាយញ្ញបូជាដល់ព្រះអង្គ»។
Judges 11:32
ដូច្នេះ
លោកយែ៉ូបថាឆ្លង...ព្រះអម្ចាស់បានប្រទានឲ្យលោកមានជ័យជម្នះ...លោកយ៉ែបថាបានវាយប្រហារពួកគេ
លោកយ៉ែបថាជាមេទាហានលើទាហានរបស់គាត់ លោក និងទាហានរបស់លោក
និយាយដូចជាតែលោកយ៉ែបថាម្នាក់ឯង។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
លោកយែ៉ូបថា
និងទាហានរបស់លោកបានឆ្លង...ព្រះអម្ចាស់បានប្រទានឲ្យពួកគេមានជ័យជម្នះ...ពួកគេ
ក្រុងអារ៉ូអ៊ើរ
សូមបកប្រែឈ្មោះទីក្រុងនេះដូចអ្នកបានបកប្រែនៅក្នុងជំពូក ១១:២៦។
ក្រុងមេនីត...អេបិលកេរ៉ាមីម
នេះគឺជាឈ្មោះរបស់ទីក្រុងផ្សេងៗ។
ម្ភៃក្រុង
សរុបទាំងអស់ ២០ក្រុង»។
Judges 11:34
ក្រាប់
ជាឧបករណ៍តន្ត្រីជាមួយក្បាលស្គរ ដែលអាចវាយ ដោយរបស់រឹងនៅក្បាលរបស់វា
ហើយមានសម្លេងនៅពេលឧបករណ៍នេះរញ្ជួយ។ ។
លោកបានហែកសម្លៀកបំពាក់របស់លោក
នេះគឺជាសកម្មភាពនៃការកាន់ទុក។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានហែកសម្លៀកបំពាក់របស់លោកដោយសារសោយស្តាយ»។
ឱ កូនស្រីមាសឪពុក! កូនបានធ្វើឲ្យឪពុកកើតទុក្ខហើយ
ហើយកូនបានធ្វើឲ្យឪពុកមានសេចក្តីឈឺចាប់!
លោកយ៉ែបថានិយាយពាក្យនេះពីរដង ដើម្បីបញ្ជាក់ថា
លោកសោយស្តាយយ៉ាងខ្លាំង»។
កូនបានធ្វើឲ្យឪពុកកើតទុក្ខហើយ
នៅត្រង់នេះ លោកយ៉ែបថានិយាយពីការកើតទុក្ខយ៉ាងខ្លាំង
ប្រៀបដូចជាមានអ្វីកម្ទេចខ្ញុំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«កូនធ្វើឲ្យឪពុកកើតទុក្ខជាខ្លាំង»។
កូនបានធ្វើឲ្យឪពុកមានសេចក្តីឈឺចាប់
នៅត្រង់នេះ លោកយ៉ែបថានិយាយអំពីទុក្ខព្រួយ និងទុក្ខវេទនា
ប្រៀបដូចជាការឈឺចាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«កូនបានធ្វើឲ្យឪពុកវេទនាហើយ» ឬ «កូនធ្វើឲ្យឪពុកកើតទុក្ខជាខ្លាំង»។
ឪពុកមិនអាចងាកចេញពីការសន្យារបស់ឪពុកបានទេ
នេះគឺជាពាក្យប្រៀបធៀប។ ការងាកចេញពីពាក្យសន្យា មានន័យថា
មិនធ្វើតាមអ្វីដែលខ្លួនបានសន្យាថានឹងធ្វើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឪពុកត្រូវធ្វើអ្វីដែលឪពុកបានសន្យា» ឬ
«ឪពុកមិនអាចក្បត់ពាក្យសន្យាបានទេ»។
Judges 11:36
បានប្រទានឲ្យពុកមានជ័យជន្ទះលើសត្រូវរបស់ឪពុក គឺលើជនជាតិអាំម៉ូន
ព្រះអម្ចាស់បានសងសឹកដោយព្រះអង្គបានយកឈ្នះលើខ្មាំងសត្រូវរបស់ទ្រង់។
អត្ថន័យរបស់វាអាចធ្វើឲ្យកាន់តែច្បាស់ទៀតបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានសងសឹកខ្មាំងសត្រូវរបស់អ្នក គឺជនជាតិអាំម៉ូន ដោយយកឈ្នះលើពួកគេ»។
។
សូមរក្សាការសន្យានេះសម្រាប់កូន
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមរក្សាការសន្យានេះសម្រាប់កូន» ឬ «សូមរក្សាសន្យានេះ ចំពោះកូន»។
សោកសង្រេងអំពីព្រហ្មចារី
«យំដោយសារព្រហ្មចារីរបស់នាង» ឬ «យំដោយសារខ្ញុំមិនដែលបានរៀបការ»។
Judges 11:38
អ្នកស្រុកកាឡាត
ឃ្លានេះសំដៅលើមនុស្សណាម្នាក់ដែលមកពីស្រុកកាឡាត។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះនៅក្នុងជំពូក ១០:៣។

---

12 [1]អ្នកស្រុកអេប្រាអ៊ីម បានលើកគ្នាឆ្លងទន្លេយ័រដាន់សំដៅទៅក្រុងសាផូន ហើយនិយាយទៅកាន់លោកយ៉ែបថាថា៖
«ហេតុអ្វីបានជាលោកទៅច្បាំងជាមួយជនជាតិអាំម៉ូន ដោយមិនហៅយើងទៅជាមួយ? យើងនឹងដុតផ្ទះរបស់លោកចោល រួមទាំងរូបលោកផងដែរ។
[2]តបទៅពួកគេថា៖ «ខ្ញុំនិងមនុស្សរបស់ខ្ញុំមានជម្លោះយ៉ាងខ្លាំងជាមួយជនជាតិអាំម៉ូន ពេលដែលខ្ញុំហៅអ្នករាល់គ្នា តែអ្នករាល់គ្នាមិនបានជួយសង្គ្រោះខ្ញុំពីពួកគេនោះទេ។
[3]នៅពេលដែលខ្ញុំឃើញថា បងប្អូនមិនសង្គ្រោះខ្ញុំទេនោះ ខ្ញុំសុខចិត្តប្តូរជីវិតរបស់ខ្ញុំ ហើយឆ្លងទៅច្បាំងជាមួយជនជាតិអាំម៉ូន ព្រះអម្ចាស់បានប្រទានជ័យជម្នះមកឲ្យខ្ញុំ។
ហេតុអ្វីបានជាបងប្អូនមកធ្វើសឹកនឹងខ្ញុំនៅថ្ងៃនេះ»។[4]ហើយប្រយុទ្ធជាមួយពួកអេប្រាអ៊ីម។ អ្នកស្រុកកាឡាតប្រយុទ្ធជាមួយពួកអេប្រាអ៊ីមព្រោះពួកនេះបាននិយាយថា៖
«ពួកកាឡាតអើយ អ្នករាល់គ្នាគឺជាពួកដែលរត់ចោលអេប្រាអ៊ីម ទៅចុះចូលនឹងពួកម៉ាណាសេ»។
[5]អ្នកស្រុកកាឡាតវាយយកបានកន្លែងឆ្លងនៃទន្លេយ័រដាន់ ទៅកាន់កាប់ច្រកចូលអេប្រាអ៊ីម។ ពេលនោះពួកអេប្រាអ៊ីមដែលបាក់ទ័ព បានរត់មកសុំពួកគេឆ្លង
អ្នកស្រុកកាឡាតសួរពួកគេថា៖ «តើអ្នកជាពួកអេប្រាអ៊ីមឬ?» គេឆ្លើយតបថា៖ «ទេ»[6]នោះពួកកាឡាតបង្គាប់ថា៖ «ចូរនិយាយថា ស៊ីបូលេត ហើយប្រសិនបើ
គេនិយាយថា៖ «ឈីបូលេត» (ព្រោះពួកគេនិយាយពាក្យនេះមិនច្បាស់ទេ) នោះពួកកាឡាតនឹងចាប់ហើយសម្លាប់ពួកគេនៅត្រង់កន្លែងឆ្លងនៃទន្លេយ័រដាន់។
ពួកអេប្រាអ៊ីមចំនួនបួនម៉ឺនពីរពាន់នាក់ត្រូវបានសម្លាប់នៅគ្រានោះ។
[7]លោកយ៉ែបថា បានដឹកនាំអ៊ីស្រាអែលអស់រយៈពេលប្រាំមួយឆ្នាំ
បន្ទាប់មកលោកយ៉ែបថាអ្នកស្រុកកាឡាតក៏ទទួលមរណភាពហើយគេបញ្ចុះសពលោកនៅក្នុងក្រុងមួយនៃស្រុកកាឡាត។
[8]បន្ទាប់ពី លោកកាឡាត លោកអ៊ីបសាន ជាអ្នកស្រុកបេថ្លេហិមបានដឹកនាំលើអ៊ីស្រាអែល។[9]លោកមានកូនប្រុសសាមសិបនាក់ និងកូនស្រីសាមសិបនាក់។
លោកបានលើកកូនលោកស្រីរបស់លោកឲ្យរៀបការនិងបុរសក្នុងកុលសម្ព័ន្ធដទៃ
ហើយក៏បានជ្រើសរើសនារីពីកុលសម្ព័ន្ធដទៃមករៀបការនឹងកូនប្រុសរបស់លោកទាំងសាមសិប។ លោកបានគ្រប់គ្រងលើអ៊ីស្រាអែលអស់រយៈពេលប្រាំពីរឆ្នាំ

generated on Wed Sep 10 16:16:32 2025

[10]លោកអ៊ីបសាន បានទទួលមរណភាពហើយសពរបស់លោកត្រូវបានបញ្ចុះក្នុងភូមិបេថ្លេហិម។[11]បន្ទាប់ពី លោកអ៊ីបសាន លោកអេឡូនពីកុលសម្ព័ន្ធសាប់យូឡូន
គ្រប់គ្រងលើអ៊ីស្រាអែល លោកដឹកនាំអស់រយៈពេលដប់ឆ្នាំ។[12]លោកអេឡូនក៏បានទទួលមរណភាព
ហើយសពរបស់លោកត្រូវបានគេបញ្ចុះនៅភូមិអាយូឡូនក្នុងទឹកដីសាប់យូឡូន។
[13]បន្ទាប់ពី លោកអេឡូន គឺលោកអាប់ដូន ជាកូនប្រុសរបស់លោកហ៊ីលេលអ្នកស្រុកពីរ៉ាថូន បានឡើងគ្រប់គ្រងលើអ៊ីស្រាអែល។
[14]លោកមានកូនប្រុសសែសិបនាក់និងចៅសាមសិបនាក់។ ពួកគេមានលាចំនួនចិតសិបជាជំនិះ លោកបានគ្រប់គ្រងលើអ៊ីស្រាអែលរយៈពេលប្រាំបីឆ្នាំ។[15]លោកអាប់ដូន
ជាកូនរបស់លោកហ៊ីលេល ជាអ្នកស្រុកពីរ៉ាថូន បានទទួលមរណភាព ហើយសពរបស់លោកត្រូវបានបញ្ចុះក្នុងស្រុកពីរ៉ាថូន ក្នុងទឹកដីអេប្រាអ៊ីម
នោះលើភ្នំរបស់ជនជាតិអាម៉ាឡេក។

Judges 12:1

បានហៅប្រជាជនអេប្រាអ៊ីមឲ្យចេញមក

ពាក្យ «ហៅ» នេះគឺជានាមអរូប អាចបង្ហាញជាកិរិយាសព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានហៅអ្នកស្រុកអេប្រាអ៊ីមចេញមកទាំងអស់គ្នា» ឬ
«អ្នកស្រុកអេប្រាអ៊ីមបានហៅទាហានរបស់ពួកគេចេញមកទាំងអស់គ្នា»

ក្រុងហេសបូន

នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។

ឆ្លងកាត់...កាត់តាម

ឬ «ធ្វើដំណើរឆ្លងកាត់...ធ្វើដំណើរ» ឬ«បានធ្វើដំណើរឆ្លងកាត់...ធ្វើដំណើរ»

យើងនឹងដុតផ្ទះរបស់លោកចោល រួមទាំងរូបលោកផងដែរ

ពាក្យប្រៀបធៀបនេះមានន័យថា ដុតផ្ទះជាមួយនឹងមនុស្សនៅក្នុងនោះដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: យើងនឹងដុតផ្ទះរបស់អ្នក
ហើយអ្នកក៏នៅក្នុងផ្ទះនោះដែរ»

ពេលដែលខ្ញុំបានហៅអ្នក

ពាក្យ «អ្នក» នៅទីនេះ គឺជាពហុវចន សំដៅលើប្រជាជនអេប្រាអ៊ីម។

មិនបានជួយសង្គ្រោះខ្ញុំ

នៅត្រង់នេះ លោកយ៉ែបថាកំពុងសំដៅលើប្រជាជនកាឡាត ដូចជាគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនសង្គ្រោះយើង»

Judges 12:3

បងប្អូនមិនសង្គ្រោះខ្ញុំទេនោះ

ពាក្យ «អ្នក» ជាពហុវចន ហើយសំដៅលើមនុស្សរបស់អេប្រាអ៊ីម។
លោកយ៉ែបថាកំពុងសំដៅលើប្រជាជនកាឡាត រួមបញ្ចូលខ្លួនគាត់
ពេលគាត់និយាយពាក្យថា «ខ្ញុំ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករាល់គ្នាមិនបានសង្គ្រោះខ្ញុំទេ»។

ខ្ញុំបានជីវិតរបស់ខ្ញុំក្នុងកម្លាំងផ្ទាល់ខ្លួនរបស់ខ្ញុំ

នេះគឺជាប្រយោគមួយមានន័យថា ប្រថុយជីវិតរបស់ខ្លួន
ហើយនិងទុកចិត្តលើកម្លាំងខ្លួនឯង។
លោកយ៉ែបថាបន្តសំដៅលើប្រជាជនកាឡាតដូចជាខ្លួនគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានប្រថុយជីវិតរបស់យើង
ហើយទុកចិត្តលើកម្លាំងរបស់យើងផ្ទាល់»។ ។

ព្រះជាម្ចាស់បានប្រទានជ័យជម្នះមកឲ្យខ្ញុំ

លោកយ៉ែបថាកំពុងសំដៅលើព្រះអម្ចាស់ប្រទានឲ្យអ្នកស្រុកកាឡាតឈ្នះជនជាតិអាំម៉ូន។
អត្ថន័យនៅក្នុងប្រយោគនេះ អាចធ្វើឲ្យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ:ព្រះអម្ចាស់បានប្រទានជ័យជន្នះលើពួកគេ» ឬ
«ព្រះអម្ចាស់អនុញ្ញាតឲ្យយើងយកឈ្នះលើពួកគេនៅក្នុងសមរភូមិ។

គាត់បានប្រយុទ្ធប្រឆាំងនឹងពួកអេប្រាអ៊ីម

ពាក្យ «គាត់» សំដៅលើលោកយ៉ែបថា និងអ្នកប្រយុទ្ធនៅក្នុងកាឡាតដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានប្រយុទ្ធប្រឆាំងទាស់នឹងអេប្រាអ៊ីម»។

ហេតុអ្វីបានជាអ្នកមកធ្វើសឹកនឹងខ្ញុំ

ពាក្យ «អ្នក» ជាពហុវចន ហើយសំដៅលើទាហានរបស់អេប្រាអ៊ីម។
លោកយ៉ែបថាកំពុងសំដៅលើប្រជាជនកាឡាត រួមបញ្ចូលទាំងខ្លួនលោកដែរ
ពេលលោកនិយាយថា «ខ្ញុំ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុអ្វីបានជាអ្នកមកប្រយុទ្ធនឹងខ្ញុំ»។

ពួកកាឡាតអើយ អ្នករាល់គ្នាគឺជាពួកដែលរត់គេច

អ្នកអាចធ្វើឲ្យន័យនេះបញ្ជើចកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកកាឡាតអើយ អ្នកមិនមែនជាមនុស្សនៅទីនេះទេ។
អ្នកគ្រាន់តែជាមនុស្សមករស់នៅទីនេះប៉ុណ្ណោះ»។

ឆ្លងទៅច្បាំងជាមួយប្រជាជនអាំម៉ូន

ឃ្លានេះ មានន័យថា ពួកគេប្រយុទ្ធទាស់នឹងអាំម៉ូន
នៅពេលពួកគេឆ្លងកាត់ស្រុកអាំម៉ូន។ អត្ថន័យពេញ អាចធ្វើឲ្យរឹតតែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រយុទ្ធទាស់នឹងប្រជាជនអាំម៉ូន
ពេលយើងឆ្លងកាត់តំបន់របស់ពួកគេ»។ ។

ជនជាតិកាឡាត

«ប្រជាជនមកពីស្រុកកាឡាត»។

ក្នុងអេប្រាអ៊ីម គឺក្នុងអេប្រាអ៊ីមនឹងម៉ាណាសេ

«នៅក្នុងតំបន់អេប្រាអ៊ីម និងម៉ាណាសេ» ឬ
«នៅក្នុងទឹកដីរបស់អេប្រាអ៊ីមនឹងម៉ាណាសេ។ ពាក្យ «អេប្រាអ៊ីម» និង
«ម៉ាណាសេ» នៅទីនេះសំដៅលើតំបន់
និងឈ្មោះដែលបានដាក់ឈ្មោះតាមកុលសម្ព័ន្ធដែលរស់នៅទីនោះ។

Judges 12:5

ទៅអេប្រាអ៊ីម

«ទៅកាន់ទឹកដីរបស់អេប្រាអ៊ីម»។

ជនជាតិកាឡាតចាប់យកបាន

«ជនជាតិកាឡាតបានគ្រប់គ្រង» ឬ «ជនជាតិកាឡាតបានកាន់កាប់»។

ឆ្លងកាត់

នេះគឺជាកន្លែងដែលអ្នកអាចឆ្លងទន្លេដោយថ្មើជើង ព្រោះមានទឹករក។

អ្នកស្រុកអេប្រាអ៊ីម

«មនុស្សដែលមកពីកុលសម្ព័ន្ធអេប្រាអ៊ីម»។

ស៊ីបូលេត...ឈីបូលេត

ពាក្យទាំងនេះគ្មានន័យទេ។ សូមចម្លងពាក្យនេះទៅជាភាសារបស់អ្នក
ហើយសូមឲ្យប្រាកដថា ការផ្តើមនៃពាក្យនីមួយៗគឺជា «ស្ស» និង «ស»
បកប្រែផ្សេងគ្នា។

ប្រកាស

«និយាយ»

បួនម៉ឺនពីរពាន់នាក់

ពីរពាន់អ្នក «៤២,០០០»

ចំនួនបួនម៉ឺនពីរពាន់នាក់ត្រូវបានសម្លាប់

ជនជាតិអេប្រាអ៊ីមពីរពាន់ត្រូវបានសម្លាប់។ ឃ្លានេះអាចកប្រែក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានសម្លាប់ទាហានអេប្រាអ៊ីម
បួនមឺនពីរពាន់អ្នក»។

Judges 12:7

លោកយ៉ែបថាជនជាតិកាឡាតក៏ទទួលមរណៈហើយបានបញ្ចុះ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:«លោកយ៉ែបថា
កាឡាតបានស្លាប់ ហើយពួកគេបានបញ្ចុះលោក»។

Judges 12:8

លោកអ៊ីបសាន នៃបេថ្លេហិម

នេះគឺជាឈ្មោះរបស់បុរសម្នាក់មកពីបេថ្លហិម។

លោកបានអោយកូនស្រីសាមសិបនាក់រៀបការចេញទៅ

ពាក្យ «ផ្តល់ឲ្យ...រៀបការ»។
ជាប្រយោគមួយដែលកូនស្រីរបស់លោកបានរៀបការ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកចង់ឃើញកូនស្រីរបស់លោករៀបការជាមួយពួកគេណាម្នាក់។

Judges 12:10

ត្រូវបានបញ្ចុះក្នុងភូមិបេថ្លេហិម

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានបញ្ចុះគាត់នៅក្នុងបេថ្លេហិម»។

អេឡូន

នេះគឺជាឈ្មោះរបស់បុរសម្នាក់។

ជនជាតិសាប់យ៉ូឡូន

generated on Wed Sep 10 16:16:32 2025

អ្នកណាម្នាក់មកពីកុលសម្ព័ន្ធសាប់យ៉ូឡូន។
អាយូឡូន
សូមបកប្រែឈ្មោះទីកន្លែងនេះឲ្យដូចអ្នកបកប្រែនៅក្នុងជំពូក ១:៣៤។
ត្រូវបានគេបញ្ចុះនៅភូមិអាយូឡូនក្នុងទឹកដីសាប់យូឡូន
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានបញ្ចុះគាត់នៅក្នុងនៅភូមិអាយូឡូន»។
Judges 12:13
លោកអាប់ដូន...លោកហ៊ីលេល
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
អ្នកស្រុកពីរ៉ាថូន...ស្រុកពីរ៉ាថូន
ស្រុកពីរ៉ាថូនគឺជាឈ្មោះរបស់ទីកន្លែង
មានមនុស្សមកពីកន្លែងនោះដែលហៅថាអ្នកស្រុកពីរ៉ាថូន។
សែសិបនាក់...និងចៅសាមសិបនាក់...សត្វលាចំនួនចិតសិប
«កូន៤០នាក់...ចៅ៣០នាក់...លា៧០ក្បាល។ ។

---

13 [1]ជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តការអាក្រក់ដែលមិនគាប់ព្រះហឫទ័យព្រះអម្ចាស់ ដូច្នេះហើយព្រះអង្គបានប្រគល់ពួកគេទៅក្នុងដៃរបស់សាសន៍ភីលីស្ទីន
អស់រយៈពេលសែសិបឆ្នាំ។[2]មានបុរសម្នាក់ពីក្រុងសូរ៉ាស់ ពីកុលសម្ព័ន្ធដាន់ ឈ្មោះថា ម៉ាណូអា ភរិយារបស់គាត់ជាស្ត្រីអារ គាត់មិនអាចមានកូនបានទេ។
[3]ទេវតានៃព្រះអម្ចាស់បានបង្ហាញខ្លួនចំពោះភរិយារបស់គាត់ ហើយប្រាប់ថា៖ «មើល៍ៗ នាងជាស្ត្រីអារ មិនអាចមានកូនបានទេ ប៉ុន្តែឥឡូវនេះ
នាងនឹងមានទម្ងន់ហើយបង្កើតបានកូនប្រុសមួយ។[4]ប៉ុន្តែ ត្រូវប្រុងប្រយ័ត្ន នាងមិនអាចផឹកទឹកទំពាំងបាយជូរ ឬស្រាខ្លាំងបានទេ
ហើយក៏មិនត្រូវបរិភោគអាហារដែលមិនបរិសុទ្ធដែរ។[5]មើល៍! នាងនឹងពរពោះ ហើយបង្កើតបានកូនប្រុសមួយ។ មិនត្រូវកាត់ ឬកោរសក់របស់គេទេ
ព្រោះកូននេះនឹងត្រូវញែកថ្វាយព្រះអម្ចាស់តាំងពីចាប់កំណើតក្នុងផ្ទៃ កូននេះនឹងរំដោះប្រជាជនអ៊ីស្រាអែលពីដៃជនជាតិភីលីស្ទីន»។
[6]បន្ទាប់មក នាងបានរត់ទៅប្រាប់ប្តីរបស់នាងថា៖ «មានអ្នកបម្រើមួយរូបរបស់ព្រះអម្ចាស់បានមកឯខ្ញុំ គាត់បានបង្ហាញខ្លួនដូចជាទេវតានៃព្រះ
ដែលគួរឲ្យស្ញែងខ្លាចក្រៃលែង។ ខ្ញុំមិនបានសួរថាគាត់មកពីណានោះទេ ហើយគាត់ក៏មិនបានឈ្មោះរបស់គាត់ដល់ខ្ញុំដែរ។[7]គាត់បាននិយាយថា មើល! នាងនឹងមានផ្ទៃពោះ
ហើយបង្កើតបានកូនប្រុសមួយ។ ដូច្នេះ នាងមិនអាចផឹកទឹកទំពាំងបាយជូរ ឬស្រាខ្លាំងបានទេ ក៏មិនអាចបរិភោគអាហារដែលច្បាប់ចែងថាមិនបរិសុទ្ធនោះដែរ
ព្រោះក្មេងនេះនឹងត្រូវញែកថ្វាយព្រះអម្ចាស់ចាប់តាំងពីពេលគេចាប់កំណើតនៅក្នុងផ្ទៃ រហូតដល់ថ្ងៃដែលគាត់ស្លាប់»។
[8]ពេលនោះ លោកម៉ាណូអា បានអធិស្ឋានទៅព្រះអម្ចាស់ថា៖ «ឱព្រះអម្ចាស់អើយ! សូមព្រះអង្គមេត្តាប្រោសប្រទានឲ្យអ្នកបម្រើរបស់ព្រះអង្គវិលត្រឡប់មកវិញ
ដើម្បីឲ្យលោកបង្រៀនយើងពីអ្វីដែលយើងត្រូវធ្វើសម្រាប់កុមារដែលនឹងកើតមកក្នុងពេលយ៉ាងឆាប់ខាងមុខនោះ។»[9]ព្រះអម្ចាស់បានឮពាក្យទូលសូមរបស់លោកម៉ាណូអា
ហើយទេវតារបស់ព្រះអម្ចាស់បានមកឯស្ត្រីម្តងទៀត នៅពេលដែលនាងកំពុងអង្គុយនៅឯវាលស្រែ។ ប៉ុន្តែ លោកម៉ាណូអា មិនបាននៅជាមួយគាត់ទេ។
[10]ដូច្នេះ ស្ត្រីបានរត់យ៉ាងលឿនទៅប្រាប់ប្តីរបស់គាត់ថា៖ «បុរសដែលខ្ញុំបានជួបថ្ងៃមុន គាត់បានមកទៀតហើយ!»[11]លោកម៉ាណូអាក្រោកឡើងហើយតាមប្រពន្ធគាត់ទៅ។
នៅពេលដែលគាត់បានឃើញបុរសម្នាក់នោះ គាត់និយាយថា៖ «តើលោកគឺជាម្នាក់ដែលបាននិយាយជាមួយប្រពន្ធខ្ញុំនោះឬ?» ទេវតារបស់ព្រះអម្ចាស់ឆ្លើយថា៖
«គឺខ្ញុំមែន»។
[12]លោកម៉ាណូអាមានប្រសាសន៍ថា៖ «សូមឲ្យគ្រប់ពាក្យរបស់លោកបានសម្រេច។ តើក្មេងនោះត្រូវកាន់តាមច្បាប់ទម្លាប់អ្វីខ្លះ ហើយតើក្មេងនោះនឹងទៅជាអ្វី?
[13]នោះទេវតានៃព្រះតបទៅលោកថា៖ «ភរិយារបស់លោកត្រូវប្រុងប្រយ័ត្នគ្រប់យ៉ាងដែលយើងបានប្រាប់នាង។[14]នាងមិនត្រូវបរិភោគអ្វីដែលធ្វើពីផ្លែទំពាំងបាយជូរទេ
មិនត្រូវផឹកស្រាឬគ្រឿងស្រវឹងឡើយ ហើយក៏មិនត្រូវបរិភោគអ្វីដែលមិនបរិសុទ្ធឡើយ។ នាងត្រូវតែប្រព្រឹត្តតាមគ្រប់ពាក្យទាំងប៉ុន្មានដែលយើងបានប្រាប់នាង»។
[15]លោកម៉ាណូអាពោលទៅកាន់ទេវតារបស់ព្រះអម្ចាស់ថា៖ «សូមមេត្តារង់ចាំនៅទីនេះបន្តិចសិន យើងនឹងរៀបចំកូនពពែមួយជូនលោក»។
[16]ទេវតានៃព្រះអម្ចាស់តបទៅលោកថា៖ «ទោះបីជាយើងនៅ ក៏យើងមិនបរិភោគអាហាររបស់អ្នកដែរ។ ប៉ុន្តែ បើអ្នកចង់ថ្វាយតង្វាយដុតទាំងមូល ថ្វាយព្រះអម្ចាស់
ចូរធ្វើចុះ»។ លោកម៉ាណូអាមិនដឹងថាជាទេវតារបស់ព្រះអម្ចាស់នោះទេ។
[17]លោកម៉ាណូអាពោលទៅកាន់ទេវតានៃព្រះអម្ចាស់ថា៖ «តើលោកមានឈ្មោះអ្វី ដូច្នេះ យើងនឹងអាចដឹងគុណលោក
នៅពេលដែលហេតុការណ៍នោះបានសម្រេចតាមពាក្យរបស់លោក?[18]ទេវតានៃព្រះអម្ចាស់តបទៅលោកថា៖ «ហេតុអ្វីបានជាអ្នកចង់ដឹងឈ្មោះរបស់ខ្ញុំ?
ឈ្មោះនេះប្លែកអស្ចារ្យណាស់!»។
[19]បន្ទាប់មក លោកម៉ាណូអាបានយកកូនពពែ និងម្សៅដែលត្រូវថ្វាយជាមួយ មកដុតនៅលើថ្មថ្វាយជាតង្វាយដុតទាំងមូលថ្វាយដល់ព្រះអម្ចាស់។
ពេលដែលលោកម៉ាណូអា និងភរិយាកំពុងសម្លឹងមើល ស្រាប់តែមានហេតុការដ៏អស្ចារ្យមួយ[20]គឺនៅពេលដែលភ្លើងបានចេញពីអាសនៈឡើងទៅលើមេឃ
ទេវតារបស់ព្រះអម្ចាស់ក៏បានឡើងទៅជាមួយភ្លើងដែលចេញពីអាសនៈនោះទៅដែរ។ នៅពេលដែលលោកម៉ាណូអា និងភរិយារបស់លោកបានឃើញដូច្នេះ
ពួកគេក៏ក្រាបចុះឱនមុខដល់ដី។
[21]កាលអ្នកទាំងពីរមើលទេវតារបស់ព្រះអម្ចាស់លែងឃើញហើយ ទើបពួកគេដឹងថានោះជាទេវតានៃព្រះអម្ចាស់។
[22]លោកម៉ាណូអាបានមានប្រសាន៍ទៅកាន់ភរិយារបស់គាត់ថា៖ «យើងប្រាកដជាស្លាប់ ព្រោះយើងបានឃើញព្រះអម្ចាស់!»
[23]ប៉ុន្តែ ភរិយារបស់គាត់តបថា៖ «ប្រសិនបើ ព្រះអម្ចាស់ចង់ឲ្យយើងស្លាប់មែន នោះព្រះអង្គពិតជាមិនទទួលយកតង្វាយដុតទាំងមូល
និងម្សៅដែលយើងថ្វាយទៅព្រះអង្គទេ។ ហើយព្រះអង្គប្រាកដជាមិនបង្ហាញ ឬក៏ប្រាប់អំពីកិច្ចការទាំងអស់នេះដល់យើងនោះទេ»។
[24]ក្រោយមក ភរិយារបស់លោកម៉ាណូអា បង្កើតកូនប្រុសមួយ ដែលគាត់ដាក់ឈ្មោះថា សាំសុន។ កុមារនោះមានវ័យចម្រើនឡើង ហើយព្រះអម្ចាស់បានប្រទានពរគាត់។
[25]ព្រះវិញ្ញាណនៃព្រះអម្ចាស់ចាប់ផ្តើមធ្វើការក្នុងជីវិតរបស់លោក នៅពេលដែលលោកនៅក្នុងជំរំដាន់ ដែលនៅត្រង់ចន្លោះសូរ៉ាស់ និង អែសថោល។

Judges 13:1
បានប្រព្រឹត្តអ្វីដែលអាក្រក់ក្នុងព្រះនេត្ររបស់ព្រះអម្ចាស់សាជាថ្មី
ពាក្យ «ក្នុងព្រះនេត្ររបស់ព្រះអម្ចាស់»
តំណាងឲ្យអ្វីដែលជាការគិតរបស់ព្រះអម្ចាស់អំពីអ្វីមួយ។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ២:១១។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលព្រះអម្ចាស់មានបន្ទូលថាអាក្រក់ក្នុងការធ្វើ»។
ព្រះអង្គបានប្រគល់ពួកគេទៅក្នុងដៃរបស់ជនជាតិភីលីស្ទីន
ពាក្យ «ដៃ» សំដៅលើអំណាចយកឈ្នះលើសមរភូមិ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គអនុញ្ញាតឲ្យជនជាតិភីលីស្ទីនយកឈ្នះលើពួកគេ» ឬ
«ព្រះអង្គបានអនុញ្ញាតឲ្យជនជាតិភីលីស្ទីនសង្កត់សង្កិនលើពួកគេ»។
សែសិបឆ្នាំ។
«៤០សិបឆ្នាំ»
ក្រុងសូរ៉ាស់
នេះគឺជាឈ្មោះរបស់ទីក្រុងនៅក្នុងប្រទេសអ៊ីស្រាអែល។
វាស្ថិតនៅក្នុងតំបន់យូដាជិតព្រំប្រទល់ដាន់។
គ្រួសារដាន់
មនុស្សដែលមកពីកុលសម្ព័ន្ធដាន់។
ម៉ាណូអា
នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។
Judges 13:3
នឹងផ្តល់កំណើតកូនប្រុសមួយ
ឃ្លានេះសំដៅលើបង្កើតកូន។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានកូនប្រុសមួយ»។
កុំបរិភោគអ្វីដែលមិនស្អាត
ជាអ្វីមួយដែលព្រះអម្ចាស់បានបង្គាប់គឺមិនត្រូវបរិភោគ
និយាយទាក់ទងនឹងភាពមិនស្អាតខាងរូបកាយ។

generated on Wed Sep 10 16:16:32 2025

មើល៍
«យកចិត្តទុកដាក់» ឬ «ស្តាប់»។
មិនត្រូវកាត់ ឬកោរសក់របស់គេទេ
ពាក្យ «ក្បាល» សំដៅលើសក់របស់គាត់។ ឃ្លានេះនិយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាអាចកាត់សក់គាត់បានឡើយ»។
កាំបិតកោរ
ជាកាំបិតមុត ប្រើដើម្បីកោរសក់ឲ្យខ្លី។
នឹងធ្វើជាពួកណាសារីតថ្វាយព្រះជាម្ចាស់
ឃ្លានេះមានន័យថា លោកនឹងឧទ្ទិសថ្វាយដល់ព្រះជាម្ចាស់ជាពួកណាសារីត។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាណាសារីតឧទ្ទិសថ្វាយដល់ព្រះជាម្ចាស់» ឬ
«ឧទ្ទិសថ្វាយដល់ព្រះជាម្ចាស់ជាណាសារីត»។
តាំងពីចាប់កំណើតក្នុងផ្ទៃ
ពាក្យ «ផ្ទៃ» សំដៅលើពេលវេលាមុនកូននោះកើតមក។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីមុនគាត់កើតមក» ។
ពីដៃជនជាតិភីលីស្ទីន
ពាក្យ «ដៃ» នៅទីនេះ មានន័យថាគ្រប់គ្រង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការគ្រប់គ្រងរបស់ជនជាតិភីលីស្ទីន» ឬ
«ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាតិភីលីស្ទីន»។
Judges 13:6
មានអ្នកបម្រើមួយរូបរបស់ព្រះអម្ចាស់
ឃ្លានេះមានន័យថាអ្នកដែលព្រះជាម្ចាស់ចាត់មក។
ឃ្លានេះអាចធ្វើឲ្យរឹតតែច្បាស់បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សម្នាក់ដែលព្រះជាម្ចាស់ចាត់មក» ។
គាត់បានបង្ហាញខ្លួនដូចជាទេវតានៃព្រះ ដែលគួរឲ្យស្ញែងខ្លាចក្រៃលែង
ពាក្យ «ស្ញែងខ្លាច» មានន័យថា «ភ័យខ្លាច»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមានការភ័យខ្លាចគាត់យ៉ាងខ្លាំង
ព្រោះគាត់មានលក្ខណៈដូចជាទេវតារបស់ព្រះជាម្ចាស់»។
មើល៍
«យកចិត្តទុកដាក់» ឬ «ស្តាប់»។
នាងនឹងមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយ
ឃ្លានេះ សំដៅលើបង្កើតកូន។ របៀបផ្សេងទៀតនៃការបកប្រែ: «កើតកូន» ឬ
«មានកូនប្រុសមួយ»។
អាហារដែលច្បាប់ចែងថាមិនបរិសុទ្ធ
អ្វីមួយដែលព្រះអម្ចាស់បានរាប់ថាមិនត្រូវបរិភោគ
សំដៅលើភាពមិនស្អាតខាងសាច់ឈាម។
ជាណាសារីតថ្វាយព្រះអម្ចាស់
ឃ្លានេះមានន័យថា
គាត់ជាអ្នកដែលឧទ្ទិសថ្វាយទៅព្រះជាម្ចាស់ជាអ្នកណាសារីត។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះនៅក្នុងជំពូក ១៣:៣។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាណាសារីតថ្វាយដល់ព្រះជាម្ចាស់» ឬ
«ថ្វាយដល់ព្រះជាម្ចាស់ក្នុងនាមជាអ្នកណាសារីត»។
ចាប់តាំងពីពេលគេចាប់កំណើតនៅក្នុងផ្ទៃ រហូតដល់ថ្ងៃដែលគាត់ស្លាប់
ឃ្លានេះបញ្ជាក់ថា ពេញមួយជីវិតរបស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេញមួយជីវិតរបស់គាត់»។
Judges 13:8
លោកម៉ាណូអា
សូមបកប្រែឈ្មោះនេះដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:១។
បានមកឯស្ត្រី
អ្នកអាចធ្វើឃ្លានេះ ឲ្យកាន់តែច្បាស់ ពីពាក្យដែលអ្នកនិពន្ធនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានមកជួបភរិយារបស់លោកម៉ាណូអា»។
Judges 13:10
មើល៍
«សូមស្តាប់» ឬ «ចូរយកយកចិត្តទុកដាក់អ្វីដែលខ្ញុំនឹងនិយាយជាមួយអ្នក»។
បុរសម្នាក់នោះ
ពាក្យនេះ សំដៅទៅលើទេវតារបស់ព្រះជាម្ចាស់ នៅក្នុងជំពូក ១៣:៣។
ឃ្លានេះអាចនិយាយកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកបម្រើរបស់ព្រះជាម្ចាស់»។
Judges 13:12
ពាក្យរបស់លោក
ឃ្លានេះ សំដៅលើអ្វីដែលបុរសនោះនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលលោកមានប្រសាសន៍»។
អ្វីមួយដែលមកពីផ្លែទំពាំងបាយជូរ
ពាក្យ ទេវតានិយាយនៅទីនេះ សំដៅលើអាហារណាដែលទំពាំងបាយជូរ
ដែល«មកពី» ទំពាំងបាយជូរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីៗដែលចេញពីទំពាំងបាយជូរ»។
បរិភោគអាហារអ្វីដែលច្បាប់ប្រកាសថាមិនស្អាត
អ្វីមួយដែលព្រះជាអម្ចាស់បានរាប់ថាមិនត្រូវបរិភោគ
ប្រៀបដូចជាអាហារដែលមិនស្អាតខាងសាច់ឈាម។
សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លានេះនៅក្នុងជំពូក ១៣:៦។
Judges 13:15
បីរៀបចំកូនពពែមួយសម្រាប់លោក
អ្នកអាចធ្វើឲ្យឃ្លានេះកាន់តែច្បាស់ថែមទៀត ចំពោះសំដីរបស់លោកម៉ាណូអា។
របៀបផ្សេងទៀតនៃការបកប្រែ: «ចម្អិនកូនពពែមួយសម្រាប់លោកពិសា»។ ។
Judges 13:17
ពាក្យរបស់លោកមកជាការពិត
ពាក្យ «ពាក្យរបស់លោក» សំដៅលើអ្វីដែលទេវតាបាននិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលលោកនិយាយបានក្លាយជាការពិត»។
ហេតុអ្វីបានជាអ្នកសួរឈ្មោះរបស់ខ្ញុំ?
ទេវតាសួរសំណួរនេះក្នុងសភាពជាការស្តីបន្ទោស។
សំណួរនេះអាចសរសេរជាប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនគួរសួរខ្ញុំ ថាខ្ញុំឈ្មោះអ្វីនោះទេ»។
វាប្លែកអស្ចារ្យណាស់
ប្រសិនបើពន្យល់បន្ថែមដើម្បីឲ្យបានច្បាស់
ពីហេតុដែលពួកគេមិនត្រូវសួរឈ្មោះគាត់ទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាគឺជាការដ៏ល្អសម្រាប់អ្នកក្នុងការយល់ពីការនេះ»។
Judges 13:19
ជាមួយដង្វាយម្សៅ
ច្បាប់នេះតម្រូវឲ្យថ្វាយតង្វាយម្សៅ ពេលថ្វាយតង្វាយដុត។
របៀបផ្សេងទៀតនៃការបកប្រែ: «ត្រូវបានតម្រូវឲ្យថ្វាយជាមួយតង្វាយម្សៅ» ឬ
«រួមជាមួយតង្វាយម្សៅផងដែរ»។
លើថ្ម
«នៅលើកន្លែងថ្វាយតង្វាយ»
កន្លែងថ្វាយតង្វាយយញ្ញបូជារបស់លោកម៉ាណូអាគឺថ្វាយនៅលើថ្ម។
លោកបានធ្វើអ្វីមួយ
«ទេវតាបានធ្វើអ្វីមួយ» ។
ទេវតារបស់ព្រះជាម្ចាស់ក៏បានឡើងទៅក្នុងអណ្តាតភ្លើងនៃអាសនៈ
«ទេវតារបស់ព្រះអម្ចាស់បានឡើងទៅក្នុងអណ្តាតភ្លើងនៃអាសន»។
ក្រាបចុះឱនមុខដល់ដី
«ក្រាបចុះឱនមុខរបស់ពួកគេដល់ដី»។ នេះគឺជាសញ្ញានៃការគោរព និងថ្វាយបង្គំ
ប៉ុន្តែក៏បង្ហាញពីការកោតខ្លាចដល់ព្រះអម្ចាស់ដែរ»។ ។
Judges 13:21
ថានោះជាទេវតានៃព្រះអម្ចាស់
ពាក្យ «លោក» សំដៅលើបុរសដែលលោកម៉ូណូអា
និងប្រពន្ធរបស់គាត់បានឃើញ។
យើងប្រាកដជាស្លាប់ ព្រោះយើងបានឃើញព្រះជាម្ចាស់
ឃ្លានេះ បញ្ជាក់ថា ពួកគេគិតថាព្រះជាម្ចាស់នឹងធ្វើឲ្យពួកគេស្លាប់។
ឃ្លានេះអាចធ្វើឲ្យកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងធ្វើឲ្យយើងស្លាប់ ដោយសារយើងបានឃើញព្រះអង្គ»។ ។
Judges 13:23
ព្រះអង្គប្រាកដជាមិនបង្ហាញកិច្ចការទាំងនេះ
ហើយក៏មិនអោយយើងបានឮកិច្ចការទាំងអស់នេះនៅពេលនេះដែរ
ភរិយារបស់លោកម៉ាណូអានិយាយដូចគ្នាពីរដងដើម្បីបញ្ជាក់។
ប្រយោគពីរនេះអាចរួមបញ្ចូលគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកប្រាកដជាមិនប្រាប់យើង នូវអ្វីដែលលោកចង់ឲ្យយើងធ្វើឡើយ»។
Judges 13:24
ស្ត្រី
«ភរិយារបស់លោកម៉ាណូអា»។
ឲ្យកំណើតកូនប្រុសម្នាក់

generated on Wed Sep 10 16:16:32 2025

ឃ្លានេះ សំដៅលើបង្កើតកូន។ របៀបផ្សេងទៀតនៃការបកប្រែ:
«កើតបានកូនប្រុស» ឬ «មានកូនប្រុសមួយ»។
ចម្រើនវ័យឡើង
«ចម្រើនវ័យឡើង » ឬ «ធំពេញវ័យ»។
ព្រះវិញ្ញាណនៃព្រះជាម្ចាស់ចាប់ផ្តើមបណ្តាលចិត្តលោក
នេះគឺជាវិធីដែលវិញ្ញាណរបស់ព្រះអម្ចាស់មានឥទ្ធិពលលើលោកសាំសុន
ប្រៀបដូចជារបៀបដែលកូមួបនៅក្នុងឆ្នាំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ចាប់ផ្តើមមានឥទ្ធិពលលើលោកសាំសុន»។
ម៉ាហានេ-ដាន់... អែសថោល
ម៉ាហានេ-ដាន់គឺជាឈ្មោះបណ្តោះអាសន្នរបស់ជំរំមួយដែលកុលសម្ព័ន្ធដាន់រស់នៅ
អំឡុងពេលពួកគេស្វែងរកកន្លែងរស់នៅអចិន្ត្រៃយ៍។
អែសថោលគឺជាឈ្មោះរបស់ទីក្រុងមួយ។
សូរ៉ាស់
សូមបកប្រែឈ្មោះក្រុងនេះ ដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:១។

14 [1]ថ្ងៃមួយ លោកសាំសុន បានចុះទៅធីមណា នៅទីនោះលោកបានឃើញស្ត្រីក្រមុំម្នាក់ ជាកូនស្រីរបស់ជនជាតិភីលីស្ទីន។[2]នៅពេលដែលលោកត្រឡប់មកវិញ
លោកប្រាប់ឪពុកនឹងម្តាយរបស់លោកថា៖ «ខ្ញុំបានឃើញស្ត្រីក្រមុំម្នាក់នៅធីមណា ជាកូនស្រីរបស់ជនជាតិភីលីស្ទីន។ ឥឡូវនេះ
សូមទៅស្តីដណ្តឹងនាងមកជាប្រពន្ធរបស់ខ្ញុំ»។
[3]ឪពុក និងម្តាយរបស់លោកតបវិញថា៖ «តើក្នុងចំណោមញាតិ ឬ ជនជាតិរបស់ឯងមិនមានស្ត្រីក្រមុំទេឬអី
បានជាឯងនឹងយកប្រពន្ធពីចំណោមពួកភីលីស្ទីនមិនកាត់ស្បែកនោះ?» លោកសាំសុនឆ្លើយថា៖ «សូមពុកស្តីដណ្តឹងនាងមកឲ្យខ្ញុំ
ព្រោះខ្ញុំពេញចិត្តតែនាងម្នាក់ប៉ុណ្ណោះ»។[4]ប៉ុន្តែ ឪពុក និងម្តាយរបស់គាត់មិនបានដឹងទេថា ព្រះអម្ចាស់បណ្តាលឲ្យលោកសាំសុនមានចិត្តដូច្នេះ
ដើម្បីបង្កជម្លោះជាមួយពួកភីលីស្ទីន ព្រោះពេលនោះភីលីស្ទីនត្រួតត្រាលើស្រុកអ៊ីស្រាអែល។
[5]លោកក៏ធ្វើដំណើរទៅធីមណាជាមួយឪពុក និងម្តាយរបស់លោក ហើយពួកគេបានមកដល់ចម្ការទំពាំងបាយជូរក្បែរធីមណា
ក៏មានសិង្ហស្ទាវមួយបានហក់មករកលោកទាំងគ្រហឹម។[6]ភ្លាមនោះព្រះវិញ្ញាណនៃព្រះអម្ចាស់បានសណ្ឋិតលើលោក
លោកក៏ចាប់ហែកសត្វសិង្ហជាចំណែកៗងាយដូចជាហែកកូនពពែ ដោយដៃទទេ។ ប៉ុន្តែ លោកមិនបានប្រាប់ឪពុកម្តាយរបស់លោកឲ្យដឹងពីអ្វីដែលលោកបានធ្វើនោះទេ។
[7]លោកធ្វើដំណើរបន្តទៀតទៅដល់ធីមណា រួចនិយាយជាមួយស្ត្រីក្រមុំនោះ លោកពេញចិត្តនាងយ៉ាងខ្លាំង។[8]ប៉ុន្មានថ្ងៃក្រោយមកលោកត្រឡប់មកទៅធីមណាវិញ
ដើម្បីរៀបការជាមួយនាង គាត់បានឈៀងចូលទៅមើលសាកសពសិង្ហនោះ ហើយឃើញមានសំបុកឃ្មុំ ពេញទៅដោយទឹកឃ្មុំនៅក្នុងខ្មោចសត្វនោះ។
[9]លោកបានបេះឃ្មុំនៅនឹងដៃ ដើរបណ្តើរ បរិភោគបណ្តើរ។ ពេលជួបឪពុកម្តាយ លោកបានយកឃ្មុំនោះអោយឪពុកម្តាយរបស់លោកបរិភោគដែរ
តែមិនបានប្រាប់ថាពួកគាត់ថាលោកយកឃ្មុំមកពីខ្មោចសត្វសិង្ហនោះទេ។
[10]ឪពុករបស់លោកបានទៅផ្ទះខាងស្រី នៅទីនោះលោកសាំសុនបានរៀបចំពិធីជប់លៀងតាមទម្លាប់ដែលកូនកម្លោះត្រូវធ្វើ។[11]សាច់ញាតិរបស់នាងបានឃើញលោក
គេបានជ្រើសរើសយុវជនចំនួនសាមសិបនាក់ អោយមកកំដរលោក។
[12]លោកបានពោលទៅកាន់ពួកគេថា៖ «ខ្ញុំមានប្រស្នាមួយសម្រាប់អ្នករាល់គ្នា។ ប្រសិនបើ
អ្នករាល់គ្នាអាចដោះប្រស្នានេះបានក្នុងអំឡុងពេលប្រាំពីរថ្ងៃនៃពិធីអាពាហ៍ពិពាហ៍នេះ ខ្ញុំនឹងជូនអាវចំនួនសាមសិប និងអាវសម្រាប់ពិធីបុណ្យចំនួនសាមសិបបន្លាស់។
[13]ប៉ុន្តែ ប្រសិនបើអ្នករាល់គ្នាមិនអាចដោះប្រស្នានេះបានទេ អ្នករាល់គ្នាត្រូវឲ្យអាវចំនួនសាមសិប និងអាវសម្រាប់ពិធីបុណ្យចំនួនសាមសិបបន្លាស់មកខ្ញុំវិញ»។
ពួកគេឆ្លើយថា៖ «ចូរចោទប្រស្នារបស់អ្នកមកយើង ពួកយើងនឹងចាំស្តាប់!»។
[14]គាត់ចោទឡើងថា៖ «មានចំណីចេញពីអ្នកឆី មានអាផ្អែមចេញពីអាខ្លាំង»។ ប៉ុន្តែ ក្នុងអំឡុងពេលបីថ្ងៃពួកគេមិនអាចស្រាយប្រស្នានេះបានទេ។
[15]នៅថ្ងៃទីបួនពួកគេបាននិយាយទៅភរិយារបស់លោកសាំសុនថា៖ «ចូរទៅល្បួងប្តីរបស់នាង ឲ្យគាត់ប្រាប់ចម្លើយនៃប្រស្នានេះហើយមកប្រាប់យើង
មិនដូច្នេះទេយើងនឹងដុតសម្លាប់គ្រួសាររបស់នាងទាំងខ្លួននាងផង។ តើនាងហៅយើងមក ដើម្បីប្លន់យើងរាល់គ្នាឬ?»
[16]ប្រពន្ធរបស់លោកសាំសុនចាប់ផ្តើមនិយាយជាមួយលោកទាំងយំថា៖ «បងមិនបានស្រឡាញ់អូនទេ! បងស្អប់អូន! បងបានចោទប្រស្នាទៅប្រជាជនរបស់អូន
តែបងមិនបានប្រាប់ចម្លើយនៃប្រស្នានោះអោយអូនដឹងសោះ»។ លោកសាំសុនតបទៅនាងវិញថា៖ «មើល៍! សូម្បីឪពុកម្តាយរបស់បង ក៏បងមិនប្រាប់អោយគាត់ដឹងផង
ហេតុអ្វីបងត្រូវបកស្រាយប្រស្នាប្រាប់អូន?»[17]នាងយំរអុកលោកក្នុងអំឡុងប្រាំពីរថ្ងៃនៃពិធីជប់លាងនោះ។ នៅថ្ងៃទីប្រាំពីរលោកបានប្រាប់ចម្លើយទៅនាង
ដោយនាងចេះតែយំរអុកលោកខ្លាំងពេក។ នាងក៏ប្រញាប់នាំចម្លើយនោះទៅប្រាប់សាច់ញាតិរបស់នាង។
[18]មុនពេលថ្ងៃលិចនៅថ្ងៃទីប្រាំពីរមនុស្សនៅក្នុងក្រុងនិយាយទៅលោកថា៖ តើមានអ្វីដែលផ្អែមជាងទឹកឃ្មុំ? ហើយតើមានអ្វីដែលខ្លាំងជាងសិង្ហស្ទាវទៀតនោះ?
លោកសាំសុនតបទៅពួកគេវិញថា៖ «នែប្រសិនបើ អ្នករាល់គ្នាមិនបានភ្ជួរដីដោយប្រើគោញីរបស់ខ្ញុំទេនោះ អ្នករាល់គ្នាមិនអាចរកចម្លើយនៃប្រស្នានេះឃើញឡើយ»។
[19]រំពេចនោះ ព្រះវិញ្ញាណនៃព្រះអម្ចាស់បានសណ្ឋិតលើលោក ធ្វើឲ្យលោកមានកម្លាំងខ្លាំងក្លា។ លោកសាំសុនបានចុះទៅអាស់កេឡូន
ហើយបានសម្លាប់មនុស្សអស់សាមសិបនាក់។ លោកបានយកសម្លៀកបំពាក់របស់ពួកគេឲ្យបុរសទាំងសាមសិននាក់ដែលបានបកស្រាយប្រស្នា។ បន្ទាប់មក
លោកខឹងយ៉ាងខ្លាំង ហើយលោកបានត្រឡប់ទៅផ្ទះឪពុករបស់លោកវិញ។[20]គេក៏លើកភរិយារបស់លោកទៅឲ្យបុរសម្នាក់ដែលជាអ្នកកំដររបស់លោក។

Judges 14:1
លោកសាំសុន បានចុះទៅធីមណា
ឃ្លា «ចុះទៅ»
ប្រើនៅទីនេះដោយសារធីមណាមានកម្ពស់ទាបជាងផ្ទះរបស់ឪពុកគាត់។
លោកធីមណាគឺជាឈ្មោះរបស់ទីក្រុងនៅត្រង់ច្រកភ្នំសូរេក។
ស្ត្រីម្នាក់ ជាកូនស្រីម្នាក់របស់ជនជាតិភីលីស្ទីន
ពាក្យ «កូនស្រី» គឺជាពាក្យគួរសម សំដៅលើក្មេងស្រីដែលមិនទាន់រៀបការ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មានក្មេងស្រីម្នាក់ដែលមិនទាន់រៀបការនៅក្នុងចំណោមប្រជាជនភីលីស្ទីន» ឬ
«ក្មេងស្រីជនជាតិភីលីស្ទីន» ។
ឥឡូវនេះ សូមយកនាងមកជាប្រពន្ធរបស់ខ្ញុំ
នេះគឺជាប្រយោគមួយ។
លោកសាំសុនកំពុងតែទាមទារឲ្យឪពុកម្តាយរបស់គាត់ទៅស្តីដណ្តឹងពីឪពុកម្តាយស្ត្រីសាសន៍ភីលីស្ទីនជាសម្រាប់ការយោគមួយ។
របៀបផ្សេងទៀតនៃការបកប្រែ:«ឥឡូវនេះ
សូមរៀបចំនាងឲ្យក្លាយជាប្រពន្ធរបស់ខ្ញុំ» ឬ
«សូមរៀបចំឲ្យខ្ញុំបានរៀបការជាមួយនាង»។
Judges 14:3
តើមិនមានស្ត្រីក្នុងចំណោមកូនស្រីទាំងឡាយនៃសាច់ញាតិ ឬក្នុងចំណោមប្រជាជនរបស់ឯងទេឬអី?
ពួកគេសួរសំណួរនេះដើម្បីស្នើថា
ពួកគេរកប្រពន្ធឲ្យលោកសាំសុនពីស្ត្រីក្នុងចំណោមប្រជាជនរបស់គេផ្ទាល់។
សំណួរនេះសរសេរជាប្រយោគមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាកដណាស់ ពិតជាមានស្ត្រីនៅក្នុងចំណោមប្រជាជនរបស់អ្នក
ដែលអ្នកអាចរៀបការបាន»។
កូនស្រីទាំងឡាយនៃសាច់ញាតិ
ពាក្យ «កូនស្រី» គឺជាពាក្យគួរសម សំដៅលើក្មេងស្រីដែលមិនទាន់រៀបការ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មានក្មេងស្រីម្នាក់ដែលមិនទាន់រៀបការនៅក្នុងចំណោមសាច់ញាតិរបស់កូន»។
តើឯងនឹងយកប្រពន្ធពីចំណោមពួកភីលីស្ទីនមិនកាត់ស្បែកនោះឬ?
សំណួរនេះ សួរដើម្បីស្តីបន្ទោសដល់សាំសុន។
សំណួរភីលីស្ទីនដើម្បីស្នើការយោគមួយ។
អ្នកអាចបញ្ជាក់ពីហេតុផលដែលឪពុកម្តាយរបស់លោកសាំសុនមិនចង់ឲ្យគាត់រៀបការជាមួយសាសន៍ភី
របៀបផ្សេងទៀតនៃការបកប្រែ:
«កូនមិនត្រូវរៀបការជាមួយស្ត្រីសាសន៍ភីលីស្ទីនឡើយ
ព្រោះសាសន៍ភីលីស្ទីនមិនថ្វាយបង្គំព្រះអម្ចាស់»។

generated on Wed Sep 10 16:16:32 2025

សូមពុកយកនាងឲ្យខ្ញុំ
នេះគឺជាប្រយោគមួយ។
លោកសាំសុនទាមទារឲ្យឪពុកម្តាយរបស់លោកទៅនិយាយជាមួយឪពុកម្តាយរបស់ស្រីសាសន៍ភីលីស្ទីន
សូមពុកយកនាងឲ្យខ្ញុំ
របៀបផ្សេងទៀតនៃការបកប្រែ: «សូមដណ្តឹងនាងនោះឲ្យធ្វើជាប្រពន្ធរបស់ខ្ញុំកុំ
ខាន»។
នាងពេញចិត្តខ្ញុំណាស់
ឃ្លានេះ មានន័យថា លោកសាំសុនគិតថា នាងស្អាតណាស់។
«ខ្ញុំស្រឡាញ់នាងព្រោះនាងស្អាតណាស់» ឬ «នាងស្អាតណាស់»។
បញ្ហានេះ
ឃ្លានេះ សំដៅលើសំណើរបស់លោកសាំសុន
ចង់រៀបការជាមួយស្រីសាសន៍ភីលីស្ទីន។
សម្រេចចិត្ត ដើម្បីបង្កជម្លោះ
ពាក្យ «ព្រះអង្គ» សំដៅលើព្រះអម្ចាស់។
Judges 14:5
កាលនោះលោកសាំសុន បានធ្វើដំណើរទៅធីមណា
ឃ្លា «ចុះទៅ»
ប្រើនៅទីនេះដោយសារធីមណាមានកម្ពស់ទាបជាងផ្ទះរបស់ឪពុកគាត់។
ធីមណាគឺជាឈ្មោះរបស់ទីក្រុងនៅត្រង់ច្រកភ្នំសូរេក។
សូមបកប្រែឈ្មោះទីក្រុងនេះដូចអ្នកបានបកប្រែក្នុងជំពូក ១៤:១។
ហើយ មើល នៅទីនោះមានសិង្ហស្ទាវមួយបានហក់មករកហើយគ្រហឹមដាក់លោក
ពាក្យ «មើល» ប្រើនៅទីនេះ
ដើម្បីទាញចំណាប់អារម្មណ៍របស់អ្នកអានឲ្យភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍ដែលបានកើតឡើង
ដើម្បីទាញចំណាប់អារម្មណ៍របស់អ្នកអានឲ្យភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍ដែលបានកើតឡើង
ឃ្លា «ឡើងមក» មានន័យថាតោមកជិតគាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«រំពេចនោះ តោស្ទាវបានចូលមកជិតគាត់»។
គ្រហឹមដាក់លោក
«គ្រហឹមដាក់លោក» នេះគឺជាសម្លេងដែលតោគ្រហឹម
ដើម្បីគំរាមនឹងប្រហារលើអ្វីមួយ។
ព្រះវិញ្ញាណនៃព្រះជាម្ចាស់បានមកលើលោក
ឃ្លា «យាងមក» មានន័យថា
ព្រះវិញ្ញាណរបស់ព្រះអម្ចាស់មានឥទ្ធិពលលើលោកសាំសុង។ នៅក្នុងករណីនេះ
ព្រះអង្គធ្វើឲ្យគាត់មានកម្លាំងខ្លាំង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ធ្វើឲ្យគាត់មានកម្លាំងខ្លាំង»។
ចាប់ហែក...ជាចំណែកៗ
ហែកជាពីរចំណែក
លោកមិនមានអ្វីនៅក្នុងដៃរបស់លោកទេ
នៅត្រង់នេះនិយាយថា លោកគ្មានអ្វីនៅក្នុងដៃរបស់លោកទេ
ដើម្បីបញ្ជាក់ថាលោកមិនបានកាត់អាវុធអ្វីឡើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានអាវុធ»។
Judges 14:7
លោកពេញចិត្តនាងយ៉ាងខ្លាំង
ឃ្លានេះ មានន័យថា លោកគិតថានាងស្អាតខ្លាំងណាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកពេញចិត្តដោយសារនាងស្អាត» ឬ
«លោកគិតថានាងស្អាតខ្លាំងណាស់»។
គាត់បានឈៀងចូល
នេះមានន័យថាលោកបានចេញពីផ្លូវរបស់គាត់ទៅធ្វើអ្វីមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានចេញពីផ្លូវ»។
ខ្មោចសត្វ
«សាកសព»។
ហើយឃើញ មានសំបុកឃ្មុំ
ពាក្យ «មើល» នៅទីនេះ ប្រើដើម្បីទាញចំណាប់អារម្មណ៍
លើអ្វីមួយដែលភ្ញាក់ផ្អើលបានកើតឡើងនៅក្នុងសាច់រឿង។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានរកឃើញសំបុកឃ្មុំ»។
សំបុក
ឃ្មុំមួយហ្វូងធំ។
បានបេះ
«ប្រមូល»
Judges 14:10
ឪពុករបស់លោកសាំសុនបានចុះទៅកន្លែងដែលស្ត្រីនោះនៅ
ឃា «ចុះទៅ» ប្រើដើម្បីពណ៌នាពីក្រុង
ធីមណានៅទាបជាងកន្លែងដែលឪពុករបស់លោកសាំសុនរស់នៅ។
របៀបផ្សេងទៀតនៃការបកប្រែ:
ឪពុករបស់លោកសាំសុនបានចុះទៅកន្លែងដែលស្ត្រីនោះនៅ
ពួកគេបាននាំយុវជនរបស់ពួកគេចំនួនសាមសិបនាក់
«មិត្តភក្តិទាំង៣០នាក់របស់ពួកគេ»។
Judges 14:12
ប្រស្នា
ជាល្បែងកម្សាន្តដែលលេងដើម្បីស្វែងរកចម្លើយដោយប្រើសំនួរពិបាក។
អាចស្វែងរកវាឃើញ
ន័យពាក្យនេះ ដើម្បីស្វែងរកអត្ថន័យរបស់ប្រស្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«អាចរកឃើញអត្ថន័យរបស់វា»។
អាវចំនួនសាមសិប និងអាវសម្រាប់ពិធីបុណ្យចំនួនសាមសិបបន្លាស់
«អាវ៣០សិប និង សម្លៀកបំពាក់ ៣០សិបបន្លាស់»។ ។
ប៉ុន្តែ ប្រសិនបើអ្នករាល់គ្នាមិនអាចដោះប្រស្នានេះបានទេ
ពាក្យ «អ្នក» ជាពហុវចន សំដៅលើភ្ញៀវនៅក្នុងពិធីជប់លៀង។
Judges 14:14
ព័ត៌មានទូទៅ
លោកសាំសុនប្រាប់ពីប្រស្នារបស់គាត់។ ជាពាក្យដែលពិបាកក្នុងការយល់
មិនបាច់បកប្រែវាឲ្យមនុស្សយល់ពីអត្ថន័យភ្លាមនោះទេ។
មានចំណីចេញពីអ្នកឆី
«ចេញពីអ្នកដែលបានហូបអ្វីមួយដែលគេបានហូប» ឬ
«អ្វីមួយដែលភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍ដែលបានកើតឡើងបានចេញពីអ្វីមួយដែលបានហូប»។
អ្នកឆី
ពាក្យ «អ្នកឆី» ជានាមអរូបី អាចបង្ហាញជាកិរិយាសព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលបានហូប» ។
មានអ្វីដែលផ្អែមចេញពីអ្វីដែលខ្លាំង
«មានអ្វីដែលផ្អែមចេញពីអ្វីដែលខ្លាំង» ឬ
«អ្វីមួយដែលផ្អែមចេញពីអ្វីមួយដែលខ្លាំង»។
ខ្លាំង
ឃ្លានេះសំដៅលើអ្វីមួយដែលខ្លាំង។ របៀបផ្សេងទៀតនៃការបកប្រែ:
«របស់មួយខ្លាំង»។
ភ្ញៀវរបស់លោក
«ភ្ញៀវនៅក្នុងពិធីជប់លៀងរបស់លោក»។
មិនអាចរកចម្លើយបានទេ
ស្វែងរកចម្លើយរបស់ប្រស្នា ប្រៀបដូចជាអ្វីមួយដែលបានលាក់ ឲ្យភ្ញៀវបានស្វែងរក
និងរកឲ្យឃើញ។ របៀបផ្សេងទៀតនៃការបកប្រែ: «មិនអាចរកចម្លើយឃើញទេ»។
Judges 14:15
នៅថ្ងៃទីបួន
«នៅថ្ងៃទី៤»
ល្បិច
បន្លំ ឬបោកប្រាសនរណាម្នាក់ ឲ្យធ្វើអ្វីមួយដែលពួកគេមិនចង់ធ្វើ។
ផ្ទះឪពុករបស់នាង
អាចមានន័យពីរ។ ទី១) ឃ្លានេះសំដៅលើផ្ទះពិត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ផ្ទះរបស់ឪពុកអ្នក ហើយគ្រួសាររបស់អ្នកដែលកំពុងរស់នៅ»។ ទី២) «ផ្ទះ»
សំដៅលើមនុស្សដែលរស់នៅក្នុងនោះ» របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រួសាររបស់អ្នក»។
នឹងដុត
ឃ្លា «នឹងដុត» មានន័យថាដុតអ្វីមួយចោល។ ប្រសិនបើ មនុស្សម្នាក់ «ដុត»
មានន័យថាមនុស្សដែលដុតនឹងត្រូវស្លាប់។
តើនាងអញ្ជើញយើងមកទីនេះ ដើម្បីធ្វើឲ្យយើងក្រឬ
ពួកគេសួរនាងនូវសំណួរនេះ ដើម្បីចោទប្រកាន់នាងពីការដែលអញ្ជើញពួកគេ
ហើយធ្វើឲ្យពួកគេធ្លាក់ខ្លួនក្រ។ នេះគឺជាសំណួរដែលអាចសរសេរជាប្រយោគ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកបាននាំយើងមកទីនេះ ដើម្បីធ្វើឲ្យយើងក្រ»។
ដើម្បីធ្វើឲ្យយើងក្រ
ពួកគេបានត្រឡប់ទៅជាក្រ ប្រសិនបើ ពួកគេទិញសម្លៀកបំពាក់ឲ្យលោក
ដោយសារគេឆ្លើយប្រស្នាមិនរួច។ របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើឲ្យយើងក្រដោយបង្ខំយើងឲ្យទិញសម្លៀកបំពាក់ថ្មីដល់គាត់»។
Judges 14:16
អ្នកធ្វើទាំងអស់នេះគឺស្អប់ខ្ញុំ! អ្នកមិនបានស្រឡាញ់ខ្ញុំទេ

generated on Wed Sep 10 16:16:32 2025

ប្រពន្ធរបស់លោកសាំសុននិយាយការនេះដដែលពីរដងដើម្បីបញ្ជាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «បងមិនស្រឡាញ់អូនទាល់តែសោះ»។
ប្រស្នា
ជាល្បែងកម្សាន្តដែលលេងដើម្បីស្វែងរកចម្លើយដោយប្រើសំណួរពិបាក។
មើល៍ទីនេះ
ប្រយោគនេះដើម្បីទាញចំណាប់អារម្មណ៍របស់មនុស្ស។ ពាក្យ «មើល៍» នៅទីនេះ
មានន័យថា «ស្តាប់»។ របៀបផ្សេងទៀតនៃការបកប្រែ: «សូមស្តាប់ខ្ញុំ» ឬ
«សូមយកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំនឹងនិយាយ»។
សូម្បីឪពុកម្តាយរបស់ខ្ញុំ ក៏ខ្ញុំមិនប្រាប់ឲ្យគាត់ដឹងផង ហេតុអ្វីខ្ញុំត្រូវបកស្រាយប្រស្នាប្រាប់នាង?
លោកសាំសុងបានស្តីបន្ទោសដល់នាងដោយសារនាងទាមទារឲ្យលោកប្រាប់ចម្លើយ។
សំណួរនេះអាចសរសេរជាប្រយោគក៏បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូម្បីតែឪពុក និងម្តាយរបស់ខ្ញុំ ខ្ញុំមិនប្រាប់ផង។
ឲ្យខ្ញុំប្រាប់ដល់នាងម្តេចនឹងកើត»។ ឬ «អ្នកមិនត្រូវទាមទារឲ្យខ្ញុំប្រាប់ទេ
សូម្បីតែឪពុកម្តាយរបស់ខ្ញុំ ក៏ខ្ញុំមិនប្រាប់ផង ហើយពួកគេនៅជិតជាងអ្នកទៀត»។
។
អំឡុងប្រាំពីរថ្ងៃនៃពិធីជប់លៀងរបស់ពួកគេនោះ
អាចមានន័យពីរ។ ទី១) «ក្នុងអំឡុងពេលប្រាំពីរថ្ងៃនៃពិធីជប់លៀងរបស់ពួកគេ»។
ឬ ទី២) ក្នុងអំឡុងពេលទាំងប្រាំពីរថ្ងៃនៃពិធីជប់លៀងរបស់ពួកគេ»។
ប្រាំពីរថ្ងៃ
«ថ្ងៃទី៧»
យំរអ៊ុកលោកខ្លាំងពេក
ពាក្យ «យំរអ៊ុក» មានន័យថា «អង្វរ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«នាងបានបន្តអង្វរគាត់ឲ្យប្រាប់នាង»។
Judges 14:18
មនុស្សនៅក្នុងក្រុង
ឃ្លានេះសំដៅលើសាច់ញាតិប្រពន្ធរបស់លោកសាំសុន។
នេះគឺជាការនិយាយយ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «យុវជន» ឬ
«សាច់ញាតិរបស់នាង»។ ។
ថ្ងៃទីប្រាំពីរ
«ថ្ងៃទី៧»
តើមានអ្វីដែលផ្អែមជាងទឹកឃ្មុំ? ហើយតើមានអ្វីដែលខ្លាំងជាងសិង្ហស្មារទៀតនោះ?
នេះគឺជាចម្លើយរបស់ប្រស្នានេះ។ អាចសរសេរជាប្រយោគជំនួយឲ្យសំណួរ។
ចាំបាច់ណាស់ក្នុងការបញ្ជាក់ឲ្យច្បាស់
ពីការដែលទាក់ទងនឹងប្រស្នាដោយបន្ថែមពណ៌មាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ទឹកឃ្មុំផ្អែម ហើយសិង្ហស្មារខ្លាំង» ឬ «ទឹកឃ្មុំផ្អែម
វាចេញពីសិង្ហមក»។
ប្រសិនបើ អ្នកមិនបានភ្ជួរដីជាមួយគោញីរបស់ខ្ញុំទេនោះ
លោកសាំសុនប្រៀបធៀបការប្រើប្រពន្ធរបស់គាត់
ដើម្បីទទួលចម្លើយដល់នរណាម្នាក់ដោយប្រើគោញីរបស់គាត់នៅស្រែ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នកមិនប្រើប្រពន្ធរបស់ខ្ញុំ»។
បានភ្ជួរ
ភ្ជួរនៅទីនេះប្រើសំដៅលើសត្វដែលទាញភ្ជួរស្រែ
ដើម្បីរៀបចំដីសម្រាប់ព្រោះគ្រាប់ពូជ។
Judges 14:19
មកលើលោកសាំសុនជាមួយអំណាច
ឃ្លា «មកលើ» មានន័យថា
ព្រះវិញ្ញាណរបស់ព្រះអម្ចាស់មានឥទ្ធិពលលើលោកសាំសុន។ នៅក្នុងករណីនេះ
ព្រះអង្គធ្វើឲ្យគាត់ខ្លាំង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើឲ្យលោកសាំសុនមានកម្លាំងខ្លាំង» ឬ
«ធ្វើឲ្យលោកសាំសុនមានអំណាចជាខ្លាំង»។
បានសម្លាប់មនុស្សអស់សាមសិបនាក់
«បានសម្លាប់មនុស្ស ៣០នាក់»។
មនុស្សរបស់ពួកគេ
«មនុស្សដែលរស់នៅទីនោះ»។
ជ័យភណ្ឌ
អ្វីៗដែលយកបានដោយប្រើកម្លាំង បន្ទាប់ពីធ្វើសង្គ្រាម ឬធ្វើសមរភូមិ។
សម្លៀកបំពាក់របស់ពួកគេ
ទាំងនេះបានមកពីជ័យភណ្ឌ ដែលលោកបានយកពីអាស់កេឡូន។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្លៀកបំពាក់ដែលពួកគេយកបាន»។
កំហឹងបានឆេះឡើង
«ខ្លាំងជាខ្លាំង»
បានឡើងទៅផ្ទះឪពុករបស់លោក
ឃ្លា «ឡើងទៅ» ប្រើនៅទីនេះ ដោយសារលោកសាំសុននៅក្រុង
ធីមណាដែលទាបជាកន្លែងដែលឪពុករបស់គាត់រស់នៅ។
គេបានលើកភរិយារបស់លោកសាំសុនឲ្យទៅមិត្តដ៏ល្អបំផុតរបស់លោក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឪពុកក្មេករបស់គាត់បានប្រគល់នាងឲ្យទៅមិត្តភក្តិជិតស្និទរបស់គាត់»។
មិត្តដ៏ល្អបំផុត
មិត្តភក្តិជិតស្និទ្ធ។

---

15 [1]បន្តិចក្រោយមក អំឡុងពេលប្រមូលផលស្រូវសាលី លោកសាំសុនបានលីពពែស្ទាវមួយទៅសួរសុខទុក្ខភរិយារបស់គាត់។ លោកនិយាយទៅកាន់ខ្លួនលោកថា៖
«ខ្ញុំនឹងទៅបន្ទប់ប្រពន្ធរបស់ខ្ញុំ»។ ប៉ុន្តែ ឪពុកក្មេករបស់លោកមិនអនុញ្ញាតឲ្យលោកចូលទៅទេ។[2]ឪពុកក្មេករបស់លោកមានប្រសាសន៍ថា៖
«ពុកពិតជាគិតថាកូនបានស្អប់នាង ដូច្នេះ ពុកបានលើកនាងទៅឲ្យអ្នកកំដររបស់កូន។ ប្អូនស្រីរបស់នាងស្អាតជាងនាងទៅទៀត តើកូនអាចយកនាងជំនួសបានឬទេ?»។
[3]លោកសាំសុនតបទៅពួកគេថា៖ «ពេលនេះខ្ញុំនឹងធ្វើបាបពួកភីលីស្ទីន ហើយក៏គ្មានអ្នកណាចោទប្រកាន់
ខ្ញុំបានទេ។»[4]លោកសាំសុនបានចេញទៅចាប់សត្វកញ្ជ្រោងចំនួនបីរយក្បាល ហើយលោកបានចងកន្ទុយវាជាប់គ្នាមួយគូរៗ។
រួចយកចន្លុះដោតនៅកណ្តាលចំណងនៃគូរនីមួយៗ។
[5]ក្រោយពេលលោករៀបចំចន្លុះរួចរាល់ហើយ លោកក៏លែងសត្វកញ្ជ្រោងទាំងនោះឲ្យចូលទៅក្នុងស្រែរបស់ពួកភីលីស្ទីន ធ្វើឲ្យឆេះស្រូវដែលច្រូតហើយ
និងស្រូវដែលមិនទាន់ច្រូតទាំងអស់នៅក្នុងស្រែ ព្រមទាំងឆេះចំការអូលីវទៀតផង។[6]ពួកភីលីស្ទីនបានសួរគ្នាថា៖ «តើអ្នកណាដែលបានធ្វើការនេះ?» មានគេប្រាប់ថា
«គឺសាំសុន! គាត់ធ្វើបែបនេះ ព្រោះតែឪពុកក្មេករបស់គាត់ជាអ្នកស្រុកធីមណា ដែលបានលើកប្រពន្ធរបស់គាត់ ទៅឲ្យបុរសជាអ្នកកំដររបស់គាត់»។
ជនជាតិភីលីស្ទីនបានលើកគ្នាទៅសម្លាប់នាងព្រមទាំងឪពុករបស់នាង។
[7]លោកសាំសុននិយាយទៅកាន់ពួកគេថា៖ «ដោយអ្នករាល់គ្នាបានប្រព្រឹត្តដូច្នេះ ខ្ញុំមិនអាចនៅស្ងៀមបានទេ គឺខ្ញុំនឹងសងសឹកអ្នករាល់គ្នា»។
[8]លោកវាយប្រហារពួកគេឲ្យបរាជ័យយ៉ាងដំណំ ឥតត្រាប្រណីទេ។ បន្ទាប់មក លោកភៀសខ្លួនទៅរស់នៅក្នុងរូងភ្នំអេតាំ។
[9]ជនជាតិភីលីស្ទីន បានឡើងមកបោះទ័ពក្នុងទឹកដីយូដា ហើយដាក់ទាហានរបស់ពួកគេឡោមព័ទ្ធលេហ៊ី។[10]អ្នកស្រុកយូដាសួរពួកគេថា៖
«ហេតុអ្វីបានជាអ្នកឡើងមកប្រយុទ្ធនឹងយើង?» ពួកគេឆ្លើយថា៖ «យើងមកដើម្បីចាប់សាំសុន ហើយនឹងធ្វើចំពោះគេដូចដែលគេបានធ្វើចំពោះយើង»។
[11]អ្នកបានចុះទៅរូងភ្នំអេតាំ ហើយនិយាយនឹងសាំសុនថា៖ «តើលោកមិនដឹងទេឬថាពួកភីលីស្ទីន ជាអ្នកគ្រប់គ្រងលើយើង? តើអ្នកបានធ្វើអ្វីដាក់យើង?
សាំសុនតបទៅពួកគេថា៖ «ខ្ញុំប្រព្រឹត្តចំពោះគេដូចដែលគេបានប្រព្រឹត្តចំពោះខ្ញុំ»។ ដូចដែលគេបានធ្វើចំពោះយើង»។
[12]ពួកគេក៏តបទៅលោកវិញថា៖ «យើងមកដើម្បីចាប់លោក ប្រគល់ទៅអោយជនជាតិភីលីស្ទីន»។ លោកសាំសុនមានប្រសាសន៍ទៀតថា៖ «សូមអ្នករាល់គ្នាស្បថនឹងខ្ញុំ
ថាអ្នករាល់គ្នានឹងមិនសម្លាប់ខ្ញុំដោយខ្លួនអ្នកផ្ទាល់ទេ»។[13]ពួកគេឆ្លើយថា៖ «ទេ! យើងគ្រាន់តែសុំចងលោកនឹងខ្សែហើយនាំលោកទៅឲ្យពួកគេ។
យើងស្បថថាយើងមិនសម្លាប់លោកទេ»។ បន្ទាប់មក ពួកគេបានចងលោកនឹងខ្សែពួរថ្មីពីរខ្សែហើយនាំលោកចេញពីរូងភ្នំ។
[14]ពេលដែលលោកមកដល់លេហ៊ី ជនជាតិភីលីស្ទីនបានឃើញលោកហើយពួកគេស្រែកហ៊ោឡើង។ គ្រានោះព្រះវិញ្ញាណនៃព្រះអម្ចាស់បានសណ្ឋិតលើលោក
ដែលនាំឲ្យលោកមានកម្លាំងយ៉ាងខ្លាំង។ ខ្សែពួរនៅលើដៃលោក ដូចជាអំបោះត្រូវភ្លើង ហើយបានរបូតចេញពីដៃលោក។
[15]លោកសាំសុនបានឃើញឆ្អឹងថ្គាមមួយរបស់សត្វលាដែលទើបសម្លាប់ថ្មីៗ លោកក៏បានរើសវាមកហើយប្រើវាសម្លាប់មនុស្សអស់មួយពាន់នាក់។[16]លោកនិយាយថា៖
«ដោយសារឆ្អឹងថ្គាមរបស់សត្វលា ខ្ញុំបានប្រមូលខ្មោចដាក់គរលើគ្នា ដោយសារឆ្អឹងថ្គាមរបស់សត្វលា ខ្ញុំបានសម្លាប់មនុស្សអស់មួយពាន់នាក់។»

generated on Wed Sep 10 16:16:32 2025

[17]ពេលដែលលោកនិយាយចប់ លោកក៏ប្រវាត់ឆ្អឹងនោះចោល ហើយគាត់ដាក់ឈ្មោះកន្លែងនោះថា រ៉ាម៉ា -លេហ៊ី។
[18]លោកស្រែកទឹកយ៉ាងខ្លាំងហើយគាត់ក៏ទូលទៅព្រះអម្ចាស់ថា «ព្រះអម្ចាស់អើយ ព្រះអង្គបានប្រទានអោយអ្នកបម្រើរបស់ទ្រង់ទទួលជ័យជំនះយ៉ាងឧត្តម។ ប៉ុន្តែឥឡូវនេះ តើទូលបង្គំនឹងត្រូវស្លាប់ដោយសារស្រេកទឹកឬ ហើយទូលបង្គំនឹងត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកជនមិនកាត់ស្បែកនេះឬអី?»។
[19]ព្រះអម្ចាស់បានបំបែកបើកថ្មនៅលេហ៊ី ធ្វើឲ្យមានទឹកហូរចេញមក។ នៅពេលដែលលោកផឹកទឹកហើយ លោកក៏ត្រឡប់មកមានទឹកចិត្តនិងមានកម្លាំងឡើងវិញ។ ដូច្នេះ លោកដាក់ឈ្មោះកន្លែងនោះថា អេន-ហាកូរេ ហើយប្រភពទឹកនោះនៅលេហ៊ីរហូតដល់សព្វថ្ងៃ។[20]លោកសាំសុនដឹកនាំលើជនជាតិអ៊ីស្រាអែល
នៅជំនាន់ដែលជនជាតិភីលីស្ទីនត្រួតត្រាលើស្រុកអ៊ីស្រាអែល អស់រយៈពេលម្ភៃឆ្នាំ។

Judges 15:1
លោកបាននិយាយទៅកាន់ខ្លួនលោកថា
ឃ្លានេះសំដៅលើការគិត។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកគិតពីខ្លួនឯង»។
ខ្ញុំនឹងទៅបន្ទប់ប្រពន្ធរបស់ខ្ញុំ
លោកសាំសុនមានបំណងចង់គេជាមួយប្រពន្ធរបស់គាត់។
ឃ្លានេះអាចនិយាយយ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងទៅបន្ទប់ប្រពន្ធខ្ញុំ ដើម្បីឲ្យយើងអាចគេងជាមួយគ្នា»។
មិនបានអនុញ្ញាតឲ្យលោកចូលទៅក្នុងទេ
វាអាចជួយឲ្យកាន់តែយល់ថែមទៀតក្នុងការបន្ថែមពាក្យដែលបាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនអនុញ្ញាតឲ្យគាត់ទៅបន្ទប់នាងទេ»។
បានលើកនាងទៅឲ្យមិត្តរបស់កូនហើយ
ឃ្លានេះមានន័យថា លោកបានប្រគល់នាងឲ្យទៅធ្វើជាប្រពន្ធមិត្តភក្តិរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
យើងបានឲ្យនាងទៅការជាមួយមិត្តភក្តិរបស់ឯងហើយ»។
នាងមិនស្អាតទេ?
លោកសួរសំណួរដើម្បីបញ្ជាក់ថា លោកសាំសុនយល់ស្របជាមួយគាត់។
សំណួរនេះអាចសរសេរជាប្រយោគមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពុកសង្ឃឹមថាកូនយល់ព្រម»។
ចូរយកនាងជំនួសទៅ
លោកកំពុងស្នើឲ្យលោកសាំសុនយកនាងធ្វើជាប្រពន្ធរបស់លោក។
ឃ្លានេះអាចនិយាយកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរយកនាងធ្វើជាប្រពន្ធអ្នកជំនួសទៅ»។
Judges 15:3
ខ្ញុំនឹងគ្មានទោសអ្វីឡើយ នៅពេលដែលខ្ញុំធ្វើបាបពួកភីលីស្ទីន
លោកសាំសុនគិតថា លោកនឹងមិនមានទោសទេ ប្រសិនបើ
លោកវាយប្រហារជនជាតិភីលីស្ទីន ព្រោះពួកគេបានធ្វើខុសជាមួយលោក។
ឃ្លានេះអាចបញ្ជាក់ឲ្យរឹតតែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងមិនមានកំហុសទេ ប្រសិនបើខ្ញុំធ្វើឲ្យជនជាតិភីលីស្ទីនឈឺចាប់
ព្រោះពួកគេបានធ្វើបាបខ្ញុំ»។
ចាប់សត្វកញ្ជ្រោងចំនួនបីរយក្បាល
«សត្វកញ្ជ្រោង៣០០ក្បាល»។
សត្វកញ្ជ្រោង
សត្វកញ្ជ្រោងគឺជាសត្វដែលមានរាងដូចឆ្កែ ដែលមានកន្ទុយវែង
ហើយស៊ីសត្វដែលនៅសំបុក និងសត្វតូចៗផ្សេងទៀត។
មួយគូៗ
មួយគូ គឺមានពីរ ដូចជា កញ្ជ្រោងពីរ ឬ កន្ទុយពីរ។
ចងកន្ទុយជាប់គ្នា
«ចង់កន្ទុយរបស់ពួកវាជាប់គ្នា» ។
ចន្ទុះ
ចន្ទុះ គឺជាឈើមួយដុំ ដែលមានអ្វីមួយជាប់ជាមួយ ដែលអាចដុតភ្លើងបាន
ភ្ជាប់នៅខាងចុង។ ចន្ទុះជាញឹកញាប់គេប្រើដើម្បីបំភ្លឺរបស់ផ្សេងទៀត ឬ
ដើម្បីផ្ទុកភ្លើង។
Judges 15:5
ដើមស្រូវដែលមិនទាន់ច្រូត
គ្រាប់ស្រូវដែលនៅនឹងដើមនៅក្នុងស្រែ។
ដើមស្រូវដែលច្រូតហើយ
ដើមស្រូវដែលបានច្រូតហើយបន្ទាប់ពីបានច្រូតហើយ។
ចម្ការ
ចម្ការគឺជាកន្លែងដែលគេដាំដើមឈើ។
កូនប្រសាររបស់អ្នកស្រុកធីមណា
សាច់ថ្លៃ- ជាប្តីរបស់កូនស្រីរបស់នោះ «កូនប្រសារ»។
អ្នកស្រុកធីមណា
នេះគឺជាអ្នកដែលមកពីស្រុកធីមណា។
បានយកប្រពន្ធរបស់សាំសុន ហើយឲ្យទៅមិត្តរបស់គេ
ឪពុកក្មេងរបស់លោកសាំសុន
បានប្រគល់នាងឲ្យទៅរៀបការជាមួយមិត្តភក្តិរបស់លោកសាំសុន។
ឃ្លានេះអាចបញ្ជាក់កាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានយកប្រពន្ធរបស់លោកសាំសុន
ហើយអនុញ្ញាតឲ្យនាងទៅរៀបការជាមួយមិត្តភក្តិរបស់លោកសាំសុន»។
បានដុត
ឃ្លា «ដុត» មានន័យថាថាដុតកម្ទេចអ្វីមួយទាំងស្រុង។ ប្រសិនបើ មនុស្សម្នាក់
«ឆេះអស់» នោះមានន័យថា អ្នកនោះបានឆេះស្លាប់។
Judges 15:7
និយាយទៅកាន់ពួកគេ
«និយាយទៅកាន់ជនជាតិភីលីស្ទីន»។
ដោយអ្នករាល់គ្នាបានប្រព្រឹត្តដូច្នេះ
«ដោយសារអ្នកបានធ្វើយ៉ាងដូច្នេះ»។
លោកបានកាត់ពួកគេជាចំណែកៗ
ពាក្យ «ត្រគាកនិងភ្លៅ» សំដៅលើរូបកាយទាំងមូល។
នេះគឺជាក្រាហ្វិកពណ៌នាពីរបៀបដែលលោកសាំសុនសម្លាប់ជនជាតិភីលីស្ទីន។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានកាត់ខ្លួនរបស់ពួកគេជាកំណាត់ៗ»។
លោកបានចុះទៅ
ឃ្លា «បានចុះទៅ» មិនទាក់ទងនឹងកំពស់ទេ ប៉ុន្តែ
ជាវិធីក្នុងការពណ៌នាពីនរណាម្នាក់ទៅកន្លែងមួយទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: គាត់បានទៅ»។
រូងភ្នំ
ជាភ្នំដែលមានប្រហោង ឬនៅលើភ្នំ។
ច្រាំងថ្ម
ខ្ពស់ ថ្មភ្នំ ឬនៅលើភ្នំ។
អេតាំ
គឺជាឈ្មោះរបស់ថ្មភ្នំ ជាប្រទេសដែលនៅជិតក្រុងយេរូសាឡិម។
Judges 15:9
ជនជាតិភីលីស្ទីនបានឡើងមក ...ក្នុងយូដា
ឃ្លា «ឡើងមក» ប្រើនៅទីនេះ ដោយសារភីលីស្ទីនទៅយូដា
នៅទាបជាងកន្លែងដែលពួកគេធ្វើដំណើរទៅ។
បានរៀបចំសម្រាប់ការធ្វើសង្គ្រាម
«បានរៀបចំខ្លួនរបស់ពួកគេដើម្បីធ្វើសង្គ្រាម»។
លេហ៊ី
នេះគឺជាឈ្មោះរបស់ទីក្រុងមួយរបស់ស្រុកយូដា។
នឹងធ្វើចំពោះគេដូចដែលគេបានធ្វើចំពោះយើង
ជនជាតិភីលីស្ទីនបានប្រៀបធៀបពីការដែលពួកគេចង់សម្លាប់លោកសាំសុន
ដូចកាលដែលលោកសាំសុនបានសម្លាប់ជនជាតិភីលីស្ទីនច្រើនប៉ុណ្ណោះដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរសម្លាប់គាត់
ឲ្យដូចគាត់បានសម្លាប់ប្រជាជនរបស់យើងជាច្រើនដែរ»។
Judges 15:11
អ្នកស្រុកយូដាបីពាន់នាក់
«អ្នកស្រុកយូដា៣,០០០នាក់» ។
រូងភ្នំក្នុងច្រាំងថ្មនៃអេតាំ
សូមបកប្រែឃ្លានេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៥:៧។
តើលោកមិនដឹងទេឬថាពួកភីលីស្ទីន ជាអ្នកគ្រប់គ្រងលើយើង? តើអ្នកបានធ្វើអ្វីដាក់យើង?
អ្នកស្រុកយូដាសួរសំណួរទាំងនេះទៅកាន់លោកសាំសុន
ដើម្បីស្តីបន្ទោសដល់គាត់។ សំណួរនេះអាចសរសេរជាប្រយោគ។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា ជនជាតិភីលីស្ទីន
គ្រប់គ្រងលើយើង ប៉ុន្តែ អ្នកធ្វើដូចជាពួកគេមិនបានគ្រប់គ្រងលើយើងអ៊ីចឹង។
តើលោកធ្វើដូច្នេះ ដែលធ្វើឲ្យយើងរងទុក្ខវេទនាជាខ្លាំង»។
គេបានប្រព្រឹត្តចំពោះខ្ញុំ ហើយដូច្នេះខ្ញុំប្រព្រឹត្តចំពោះពួកគេដែរ
លោកសាំសុនសំដៅអំពីរបៀបដែលពួកគេសម្លាប់ប្រពន្ធរបស់គាត់
និងពីរបបៀបដែលគាត់បានសម្លាប់ពួកគេដើម្បីសងសឹក។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានសម្លាប់ភរិយារបស់ខ្ញុំ ដូច្នេះ
ខ្ញុំនឹងសម្លាប់ពួកគេវិញ»។
Judges 15:12
ដៃនៃជនជាតិភីលីស្ទីន
ពាក្យ «ដៃ» សំដៅលើអំណាច។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជនជាតិភីលីស្ទីនគ្រប់គ្រង»។
ប្រគល់លោកទៅក្នុងដៃរបស់ពួកគេ
ឃ្លានេះ មានន័យថាធ្វើឲ្យនរណាម្នាក់ស្ថិតនៅក្រោម
ការគ្រប់គ្រងរបស់មនុស្សម្នាក់ទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រគល់លោកទៅក្នុងដៃនៃជនជាតិភីលីស្ទីន»។
ចងលោកនឹងខ្សែពួរ
ឃ្លានេះ សំដៅលើរុងភ្នំ នៅក្នុងច្រកភ្នំអេឡំ ជាកន្លែងដែលលោកសាំសុនទៅ
មានន័យថាគេបាននាំលោកចេញពីកន្លែងរូបភ្នំ។
Judges 15:14
ពេលដែលលោកមកដល់
លោកសាំសុនមិនបានធ្វើដំណើរម្នាក់ឯងទេ
គាត់បាននាំមនុស្សដែលបានចងគាត់នឹងខ្សែមកជាមួយដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលពួកគេមកដល់»។
លេហ៊ី
នេះគឺជាឈ្មោះរបស់ទីក្រុងមួយនៅក្នុងយូដា។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ១៥:៩។
បានមកលើលោកដោយអំណាច
ឃ្លា «យាងមកសណ្ឋិត» មានន័យថា ព្រះវិញ្ញាណមានឥទ្ធិពលលើលោកសាំសុន។
នៅក្នុងករណីនេះ ព្រះអង្គបានធ្វើឲ្យលោកមានកម្លាំងខ្លាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «បានធ្វើឲ្យលោកសាំសុនមានកម្លាំងខ្លាំង»។
ខ្សែពួរនៅលើដៃលោក ក្លាយមកដូចជាអំបោះត្រូវភ្លើង
លោកសាំសុនបានផ្តាច់ខ្សែពួរដែលចង់នៅនឹងដៃរបស់លោកបានយ៉ាងងាយ។
អ្នកនិពន្ធពណ៌នាពីភាពងាយស្រួលនៃការផ្តាច់ចំណងរបស់កាត់ ដោយនិយាយថា
ខ្សែពួរនោះដូចជាអំបោះត្រូវភ្លើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានផ្តាច់ខ្សែនៅលើដៃរបស់លោក ដូចជាបំបោះត្រូវភ្លើង»
ធ្មៃ
សរសៃអំបោះពីដើមធ្មៃប្រើដើម្បីដេរ និងធ្វើជាសម្លៀកបំពាក់។
Judges 15:15
ឆ្អឹងថ្គាមស្រស់មួយ
ឃ្លានេះមានន័យថា សត្វលាដែលបានស្លាប់ទៅថ្មីៗ
ហើយឆ្អឹងរបស់វាមិនទាន់រលួយអស់តេ។
ឆ្អឹងថ្គាមគឺជាឆ្អឹងដែលនៅជួរធ្មេញខាងក្រោមមួយស្មិត។
មនុស្សអស់មួយពាន់នាក់
«១,000 នាក់»
ឆ្អឹងថ្គាមរបស់សត្វលាមួយ
«ឆ្អឹងថ្គាមរបស់សត្វលា» ។
បានប្រមូលខ្មោចដាក់គរលើគ្នា
ឃ្លានេះពណ៌នាពីការដែលលោកសាំសុនបានសម្លាប់មនុស្ស។
មានរូបការជាច្រើនដែលធ្វើជាសរសេរពាក្យបាន។
របៀបផ្សេងទៀតនៃការបកប្រែ: ខ្ញុំបានសម្លាប់មនុស្សជាច្រើន»
Judges 15:17
រ៉ាម៉ា -លេហ៊ី
នេះគឺជាឈ្មោះរបស់ទីកន្លែង។ ឈ្មោះរបស់វាមានន័យថា: «ភ្នំឆ្អឹកថ្គាម»។
ស្រេកទឹកយ៉ាងខ្លាំង
«ត្រូវការទឹកផឹក»។
ប៉ុន្តែឥឡូវនេះ តើទូលបង្គំនឹងត្រូវស្លាប់ដោយសារស្រេកទឹក
អាចមានន័យពីរ។ ទី១) លោកសាំសុនស្រេកទឹកជាខ្លាំង គាត់អាចស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ទូលបង្គំស្លាប់ឥឡូវហើយ
ដោយសារស្រេកទឹក រូបកាយរបស់ទូលបង្គំនឹងដួលចុះ» ទី២)
លោកសាំសុននិយាយបំផ្លើសពីការដែលគាត់ស្រេកទឹក ដោយនិយាយថា
គាត់ស្រេកទឹកចង់ងាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «ឥឡូវនេះ
តើព្រះអង្គអនុញ្ញាតឲ្យទូលបង្គំទៅជាខ្សោយ ដោយសារការស្រេកទឹករបស់ទូលបង្គំ
ហើយដួលចុះទៅ»។
ស្លាប់ដោយសារស្រេកទឹក
ឃ្លានេះមានន័យថា ស្លាប់ដោយសារអ្នកមិនបានផឹកទឹកគ្រប់គ្រាន់
ហេតុដូច្នេះហើយ អ្នកមិនមានទឹកគ្រប់គ្រាន់នៅក្នុងរូបកាយរបស់អ្នក។
ធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកជនមិនកាត់ស្បែកនេះទាំងនោះឬអី?
ឃ្លា «ធ្លាក់ទៅក្នុងកណ្តាប់ដៃ» មានន័យថាត្រូវគេចាប់ខ្លួន។
«អស់អ្នកដែលមិនបានកាត់ស្បែក» សំដៅលើជនជាតិភីលីស្ទីន ហើយពាក្យ
«មិនកាត់ស្បែក» បញ្ជាក់ថា ពួកគេមិនថ្វាយបង្គំព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ត្រូវចាប់ខ្លួនដោយសារជនជាតិភីលីស្ទីនដែលគ្មានព្រះ»។
Judges 15:19
បានបំបែកបើករន្ធ កន្លែងដែល
«បានបើករន្ធទឹកក្នុងដី» ឬ «បានបើកកន្លែងដែលទាប»។
ឃ្លានេះសំដៅលើតំបន់ដែលនៅទាបនឹងដី
ដែលព្រះអម្ចាស់ប្រើធ្វើឲ្យមានទឹកផុសលេចឡើង។
អេន-ហាកូរេ
នេះគឺជាឈ្មោះរបស់ប្រភពទឹក។ ឈ្មោះនោះមានន័យថា
«ប្រភពទឹករបស់ព្រះអង្គដែលខ្ញុំបានអធិស្ឋាន»។
វាគឺជាប្រភពទឹកនោះនៅលេហ៊ីរហូតដល់សព្វថ្ងៃ
ឃ្លានេះមានន័យថាប្រភពទឹកមិនបានរីងស្ងួតឡើយ ប៉ុន្តែ វានៅតែមានរហូត។ ឃ្លា
«រហូតដល់សព្វថ្ងៃ» សំដៅលើសម័យ «បច្ចុប្បន្ន»។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រភពទឹកអាចនៅមាននៅលេស៊ី
សូម្បីតែសព្វថ្ងៃ»
នៅជំនាន់ដែលជនជាតិភីលីស្ទីន
ឃ្លានេះ សំដៅលើសម័យដែលជនជាតិភីលីស្ទីនគ្រប់គ្រងទឹកដីអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ:
«អំឡុងពេលជនជាតិភីលីស្ទីនគ្រប់គ្រងអ៊ីស្រាអែល»។
អស់រយៈពេលម្ភៃឆ្នាំ
«អស់រយៈពេល ២០ឆ្នាំ»។

---

16 [1]លោកសាំសុនបានធ្វើដំណើរទៅក្រុងកាសា នៅទីនោះលោកបានឃើញស្ត្រីពេស្យាម្នាក់ ក៏ចូលទៅក្នុងបន្ទប់របស់នាង។[2]មានគេប្រាប់អ្នកក្រុងកាសាថា៖
«សាំសុននៅទីនេះ»។ ពួកគេបានដាក់គ្នាយាមល្បាត និងចាំឃ្លាំមើលលោកនៅមាត់ទ្វារក្រុង ពេញមួយយប់។ ពួកគេសំងំពេញមួយយប់។ ពួកគេនិយាយគ្នាថា៖
«ចូរយើងរង់ចាំរហូតដល់ភ្លឺ ចាំយើងសម្លាប់វា»។
[3]លោកសាំសុនសម្រាន្តដល់ពាក់កណ្តាលអធ្រាត្រ។ លុះកណ្តាលអធ្រាត្រលោកបានក្រោកឡើង ហើយលោកចាប់ទាញទ្វារក្រុងទាំងមូល និងសសរក្លោងទ្វារទាំងពីរ។
លោកទាញវាឡើង ទាំងរនុក និងលីវាលើស្មា ហើយយកវាទៅដាក់នៅលើកំពូលភ្នំ ទល់មុខក្រុងហេប្រូន។
[4]បន្ទាប់ពីនោះមកលោកសាំសុនស្រឡាញ់ស្ត្រីម្នាក់ទៀតដែលរស់នៅត្រង់ច្រកភ្នំសូរេក។ នាងឈ្មោះថា ដេលីឡា។[5]អ្នកគ្រប់គ្រងជនជាតិភីលីស្ទីន បានមករកនាង
ហើយនិយាយថា៖ «ចូរលោកល្បួងសាំសុន ឲ្យបានដឹងថាតើគាត់មានកម្លាំងដ៏ខ្លាំងក្លានេះមកពីណា ហើយតើធ្វើដូចម្តេចទើបយើងអាចយកឈ្នះគាត់បាន?
ដែលយើងអាចចាប់ចង និងបង្ក្រាបគាត់បាន។ រួចហើយយើងនឹងឲ្យប្រាក់នាងក្នុងម្នាក់មួយពាន់មួយរយស្លឹង»។
[6]នាងដេលីឡា ក៏លួងលោមលោកសាំសុនដោយថា៖«បងអើយ សូមអ្នកប្រាប់ខ្ញុំផង តើបងអាចមានកម្លាំងខ្លាំងយ៉ាងនេះដូចម្តេចបាន
ហើយតើអ្នកណាម្នាក់អាចនឹងចាប់ចង បង្ក្រាបបងយ៉ាងដូចម្តេចបាន?[7]លោកក៏ឆ្លើយនឹងនាងថា៖ «ប្រសិនបើ គេយកខ្សែពួរស្រស់ដែលមិនទាន់ហាលស្ងួតនៅឡើយ
ចំនួនប្រាំពីរខ្សែមកចងបង នោះបងនឹងទៅជាខ្សោយ ដូចជាមនុស្សធម្មតា»។

generated on Wed Sep 10 16:16:32 2025

[8]ដូច្នេះ អ្នកត្រួតត្រាសាសន៍ភីលីស្ទីន បានយកខ្សែពួរស្រស់ហាលមិនទាន់ស្ងួតប្រាំពីរចង្វាយមកឲ្យដេលីឡា ហើយនាងបានចងលោកសាំសុន ជាមួយខ្សែទាំងនោះ។
[9]នាងបានឲ្យមនុស្សលាក់ខ្លួនចាសម្ងាត់ក្នុងផ្ទះ ក្នុងបន្ទប់ខាងក្នុង។ បន្ទាប់មក នាងស្រែកប្រាប់គាត់ថា «បងសាំសុនអើយ ពួកភីលីស្ទីន មកចាប់បងហើយ!» ប៉ុន្តែ
លោកផ្តាច់ខ្សែពួរនោះ ដូចជាខ្សែអំបោះដែលត្រូវភ្លើង។ ដូច្នេះ គេនៅតែពុំដឹងពីអាថ៌កំបាំងនៃកម្លាំងរបស់លោកដដែល។
[10]នាងដេលីឡានិយាយទៅលោកសាំសុនថា៖ «បងបានបញ្ឆោត និងកុហកអូន។ សូមប្រាប់ខ្ញុំ តើធ្វើយ៉ាងណាទើបអាចចងបងបាន?»[11]លោកប្រាប់នាងថា៖ «ប្រសិនបើ
គេចងខ្ញុំនឹងខ្សែពួរដែលមិនដែលប្រើពីមុន នោះខ្ញុំនឹងទៅជាខ្សោយដូចជាមនុស្សធម្មតា»។[12]ដូច្នេះនាងដេលីឡាយកខ្សែពួរថ្មីមកចងលោក ហើយស្រែកប្រាប់លោកថា៖
«ពួកភីលីស្ទីនមកចាប់បងហើយ សាំសុនអើយ!» មានមនុស្សលាក់ខ្លួននៅក្នុងបន្ទប់ខាងក្នុង។ ប៉ុន្តែ លោកផ្តាច់ពួរដែលចងដៃលោក ដូចជាផ្តាច់ខ្សែអំបោះ។
[13]នាងដេលីឡាពោលទៅកាន់លោកសាំសុនថា៖ «រហូតមកដល់ពេលនេះបងនៅតែបញ្ឆោត និងនិយាយកុហកខ្ញុំ។ សូមប្រាប់ខ្ញុំមក តើធ្វើដូចម្តេចទើបអាចចងបងបាន?»
លោកប្រាប់នាងថា៖ «ប្រសិនបើ នាងក្រងសក់ខ្ញុំប្រាំពីរកម្រងភ្ជាប់ទៅនឹងកីតម្បាញ នោះខ្ញុំនឹងទៅជាខ្សោយដូចមនុស្សធម្មតា»។[14]នៅពេលដែលលោកសម្រាន្តលក់
នាងដេលីឡាបានក្រងសក់លោកប្រាំពីរកម្រង ហើយចងភ្ជាប់សក់របស់លោកទៅនឹងកីដតម្បាញ ហើយនាងស្រែកប្រាប់លោកថា៖ «បងសាំសុនអើយ ពួកភីលីស្ទីន
មកចាប់បងហើយ!» លោកសាំសុនភ្ញាក់ឡើង ហើយកន្ត្រាក់របើកទាំងស្ទឹង ទាំងកីតម្បាញទៀតផង។
[15]នាងពោលទៅគាត់ថា៖ «តើបងនិយាយថា បងស្រឡាញ់អូន ដូចម្តេច នៅពេលដែលបងមិនប្រាប់ពីការសម្ងាត់របស់បងអោយអូនដឹង? មើល៍!
បងបានបញ្ឆោតខ្ញុំបីដងហើយ ហើយមិនបានប្រាប់ខ្ញុំថា បងមានកម្លាំងដ៏អស្ចារ្យនេះយ៉ាងដូចម្តេច»។[16]ជារៀងរាល់ថ្ងៃនាងរំអុកលោកយ៉ាងខ្លាំងជាមួយនឹងសំដីរបស់នាង
ដែលធ្វើឲ្យលោកធុញថប់ស្ទើរដាច់ខ្យល់ស្លាប់។
[17]ដូច្នេះ លោកបានប្រាប់នាងគ្រប់យ៉ាង និងនិយាយទៅកាន់នាងថា៖ «បងមិនដែលកាត់ឬកោរសក់លើក្បាលរបស់បងទេ
គឺបងត្រូវបានញែកថ្វាយព្រះអម្ចាស់តាំងពីបងចាប់កំណើតក្នុងផ្ទៃម្តាយរបស់បងម្លេះ។ បើបងកោរសក់ចេញ នោះកម្លាំងរបស់បងនឹងចេញពីខ្លួនរបស់បង
ហើយបងនឹងទៅជាខ្សោយ និងដូចជាមនុស្សធម្មតា»។
[18]នៅពេលដែលដេលីឡា ឃើញថាលោកបានប្រាប់អាថ៌កំបាំងគ្រប់យ៉ាងដល់នាងហើយ នាងបានហៅអ្នកត្រួតត្រាភីលីស្ទីនមកដោយនិយាយថា៖ «សូមមកម្តងទៀតចុះ
គាត់បានប្រាប់អាថ៌កំបាំងគ្រប់យ៉ាងដល់ខ្ញុំហើយ។ នោះអ្នកត្រួតត្រាបានមកឯនាង ទាំងយកប្រាក់នៅនឹងដៃមកជាមួយពួកគេផង។
[19]នាងបានដាក់អោយលោកសាំសុនសម្រាន្តលើភ្លៅរបស់នាង រហូតដល់លក់។ នាងបានហៅមនុស្សម្នាក់មកកោរកម្រង់សក់ទាំងប្រាំពីររបស់លោក លោកចាប់ផ្តើមខ្សោយ
កម្លាំងរបស់លោកក៏ចេញពីខ្លួនរបស់លោកទៅ។
[20]នាងស្រែកឡើងថា៖ «ពួកភីលីស្ទីនមកចាប់បងហើយ សាំសុនអើយ!» លោកបានក្រោកពីដំណេកហើយនិយាយថា៖ «បងនឹងក្រោកឡើងដូចជារាល់ដង
ហើយបងនឹងរលាស់ខ្លួនរបស់បងអោយមានសេរីភាព»។ ប៉ុន្តែលោកមិនបានដឹងទេថា ព្រះអម្ចាស់បានចាកចេញពីលោកហើយនោះទេ។
[21]ពួកភីលីស្ទីនបានចាប់លោកហើយខ្វេះភ្នែកទាំងពីររបស់លោក។ ពួកគេនាំលោកទៅក្រុងកាសា ដោយយកច្រវាក់លង្ហិនមកដាក់លោក
និងបង្ខំលោកឲ្យបង្វិលត្បាល់នៅក្នុងគុក។[22]សក់របស់គាត់ចាប់ផ្តើមដុះឡើងវិញបន្ទាប់ពីគេកោរនោះ។
[23]ពួកត្រួតត្រាភីលីស្ទីនបានប្រមូលគ្នា ធ្វើពិធីបុណ្យអបអរសាទរជ័យជម្នះរបស់ពួកគេ ព្រមទាំងថ្វាយយញ្ញបូជាដល់ព្រះដាកុនរបស់ពួកគេផង។ ពួកគេនិយាយថា៖
«ព្រះរបស់យើងបានប្រគល់សាំសុនដែលជាសត្រូវរបស់យើងមកក្នុងកណ្តាប់ដៃរបស់យើង»។[24]ពេលឃើញរូបព្រះរបស់គេ ពួកគេសរសើរតម្កើងព្រះរបស់គេ និយាយថា៖
«ព្រះរបស់យើង បានបង្ក្រាបសត្រូវរបស់យើង គឺអ្នកដែលបានបំផ្លាញប្រទេស និងបានសម្លាប់ប្រជាជនជាច្រើនរបស់យើង ហើយក៏ប្រគល់គេមកឲ្យយើង»។
[25]ពេលដែលកំពុងសប្បាយរីករាយនោះពួកគេនិយាយថា៖ «ចូរហៅសាំសុនមក អើយវាឡកកំប្លែងឲ្យយើងសើច»។
ពួកគេក៏បានហៅលោកចេញមកដើម្បីធ្វើឲ្យពួកគេសើច។ ពួកគេបានដាក់លោកឲ្យឈរនៅចន្លោះសសរ។
[26]លោកសាំសុនបាននិយាយទៅកាន់ក្មេងដែលកាន់ដៃលោកនោះថា៖ «សូមនាំខ្ញុំទៅក្បែរសសរដែលទ្រវិហារ ដើម្បីឲ្យខ្ញុំអាចផ្អែកខ្លួនលើសសរនោះផង»។
[27]ពេលនោះក្នុងវិហារពេញទៅដោយមនុស្សទាំងប្រុសទាំងស្រី រួមទាំងពួកអ្នកគ្រប់គ្រងរបស់សាសន៍ភីលីស្ទីនទាំងអស់ក៏នៅទីនោះដែរ។
ហើយមានមនុស្សប្រមាណជាបីពាន់នាក់ផ្សេងទៀតដែលឈរ ដើម្បីមើលលោកសាំសុនឡក។
[28]លោកសាំសុនស្រែកអង្វរព្រះអម្ចាស់ថា៖ «ឱព្រះអម្ចាស់អើយ សូមកុំភ្លេចទូលបង្គំឡើយ! សូមព្រះអម្ចាស់ប្រទានកម្លាំងដល់ទូលបង្គំម្តងនេះទៀតចុះ
គឺក្នុងពេលមួយប៉ប្រិចភ្នែក ដែលទូលបង្គំអាចសងសឹកចំពោះពួកភីលីស្ទីន
ដែលបានខ្វេះភ្នែកទាំងពីររបស់ទូលបង្គំនោះផង។»[29]លោកសាំសុនដាក់ដៃលើសសរកណ្តាលទាំងពីរដែលទ្រវិហារ ហើយលោកសង្កត់ដៃស្តាំទៅលើសសរនៅខាងស្តាំ
ហើយដៃឆ្វេងសង្កត់ទៅលើសសរដែលនៅខាងឆ្វេង។
[30]លោកស្រែកឡើងថា៖ «សូមឲ្យខ្ញុំស្លាប់រួមជាមួយពួកភីលីស្ទីននេះទៅចុះ!» លោកបញ្ចេញកម្លាំងច្រានសសរអស់ទំហឹង ហើយវិហារក៏រលំសង្កត់ពួកអ្នកគ្រប់គ្រង
និងមនុស្សទាំងអស់ដែលនៅទីនោះ។ ដូច្នេះ មនុស្សដែលលោកបានសម្លាប់នៅពេលលោកស្លាប់មានច្រើនជាង
មនុស្សដែលលោកបានសម្លាប់នៅអំឡុងពេលដែលលោកនៅរស់។[31]បងប្អូន និងសាច់ញាតិរបស់លោកបានទៅយកសពរបស់លោក
ហើយគេបញ្ចុះសពរបស់លោកនៅក្នុងផ្នូរលោកម៉ាណូអា ដែលជាឪពុករបស់លោក នៅចន្លោះសូអា និងអេសថោល។
លោកសាំសុនដឹកនាំជនជាតិអ៊ីស្រាអែលអស់រយៈពេលម្ភៃឆ្នាំ។

Judges 16:1

លោកក៏បានចូលទៅគ្រែជាមួយនាង

ឃ្លា «ចូលគេងជាមួយនាង» គឺជាវិធីគួរសមសំដីលើការរួមភេទ។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានរួមភេទជាមួយនាង» ឬ
«លោកបានគេងជាមួយនាង»។ (សូមមើល: |Euphemism)

អ្នកក្រុងកាសាបានប្រាប់ថា

ពាក្យ «ក្រុងកាសា» សំដៅលើមនុស្សមកពីកាសា។
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានគេប្រាប់អ្នកក្រុងកាសាថា»។ (សូមមើល: |How to Translate Names
និង |Active or Passive)

ពួកគេរក្សាភាពស្ងៀមស្ងាត់ពេញមួយយប់

អាចមានន័យពីរ។ ទី១) «ពួកគេមិនបាននិយាយអ្វីមួយមាត់ពេញមួយយប់» ទី២)
«ពួកគេគ្មានការប៉ុនប៉ងវាយប្រហារលោកពេញមួយយប់ទេ»។

Judges 16:3

ពាក់កណ្តាលអធ្រាត្រ

«នៅពាក់កណ្តាលយប់»។

សសរភ្លោងទ្វារទាំងពីរ

សសរខ្លោងពីរសម្រាប់ទ្វារក្រុង។ ខ្លោងទ្វារប្រហែលជាធ្វើពីដើមឈើ
ហើយកប់យ៉ាងជ្រៅទៅក្នុងដី។ ទ្វារក្រុងបានទប់ជាប់នឹងសសរ។

ទាំងរនុក

រនុកប្រហែលជាសសរដែកដេលភ្ជាប់ទ្វារនឹងសសរ។
ទ្វារក្រុងប្រហែលជាធ្វើឡើងដោយឈើឆ្នឹម ឬជារនុកដែក។

ស្មា

នេះគឺជាផ្នែកនៃរូបកាយរបស់មនុស្ស ដែលមានដៃ និងក ភ្ជាប់នឹងរូបកាយ។

ក្រុងហេប្រូន

គឺជាឈ្មោះរបស់ទីក្រុងមួយ។

Judges 16:4

ច្រកភ្នំសូរេក

នេះគឺជាឈ្មោះរបស់ច្រកភ្នំនៅជិតផ្ទះរបស់លោកសាំសុន។

ល្បួង

នាំឲ្យរង្វេង ឬបោកប្រាស់នរណាម្នាក់ ធ្វើអ្វីមួយដែលពួកគេមិនចង់ធ្វើ។

ដើម្បីមើលថា

generated on Wed Sep 10 16:16:32 2025

នេះគឺជាប្រយោគដែលមានន័យថារៀនអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីយល់» ឬ «រៀន»។

តើកម្លាំងដ៏ខ្លាំងក្លារបស់គាត់នេះមកពីណា

នេះគឺជាប្រយោគដែលសំដៅលើ កម្លាំងរបស់គាត់បានមកពីណា។ របៀបផ្សេងទៀតនៃការបកប្រែ៖ «តើអ្វីទៅដែលធ្វើឲ្យគាត់មានកម្លាំងខ្លាំងយ៉ាងនេះ»។

ដោយសារអ្វីទើបយើងអាចយកឈ្នះគាត់បាន

«តើយើងអាចយកឈ្នះគាត់បានយ៉ាងដូចម្តេច» ។

Judges 16:6

អាចនឹងចាប់ចង បង្ក្រាបបងយ៉ាងដូចម្តេចបាន?

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ចងបង ដើម្បីគ្រប់គ្រងបង»។

ខ្សែពួរស្រស់

ខ្សែពួរស្រស់ជាទូទៅគេធ្វើវាពីស្បែកសត្វ គឺចេញពីស្បែក។ ពាក្យ «ខ្សែពួរស្រស់» សំដៅលើអ្វីៗដែលបានមកពីសត្វដែលត្រូវបានគេសម្លាប់ថ្មីៗ ហើយមិនទាន់ស្ងួត។

ដែលមិនទាន់ហាលស្ងួតនៅឡើយ

ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដែលមិនទាន់ស្ងួតនៅឡើយ»។ (UDB)

Judges 16:8

មិនទាន់ស្ងួតប្រាំពីរចង្វាយមកឲ្យដេលីឡា

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដែលមិនទាន់ស្ងួត» ឬ «ដែលមិនទាន់ស្ងួតនៅឡើយ»។

នាងបានចងលោកសាំសុនជាមួយខ្សែទាំងនោះ

«នាងដេលីឡាបានចងលោកសាំសុនជាមួយខ្សែទាំងនោះ»។

ឥឡូវ

ពាក្យនេះប្រើដើម្បីបញ្ជាក់ពីការសម្រាកនៅក្នុងសាច់រឿងចម្បង។ នៅទីនេះ អ្នកនិពន្ធប្រាប់ព័ត៌មានពីសាវតារបស់បុរសជនជាតិភីលីស្ទីន ដែលនាងដេលីឡារង់ចាំដើម្បីចាប់ខ្លួនលោកសាំសុន។

ពួកភីលីស្ទីនមកចាប់បងហើយ

ឃ្លា «មកចាប់» មានន័យថាពួកគេរួចរាល់នឹងចាប់ខ្លួនគាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «ជនជាតិភីលីស្ទីនមកចាប់បងហើយ»។

គាត់ផ្តាច់ខ្សែពួរនោះ ដូចជាខ្សែអំបោះដែលត្រូវភ្លើង។

អ្នកនិពន្ធពណ៌នារបៀបដែលលោកផ្តាច់ខ្សែ

របៀបដូចជាសរសៃអំបោះដែលត្រូវភ្លើង។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានផ្តាច់ខ្សែពួរយ៉ាងងាយដូចជាខ្សែអំបោះត្រូវភ្លើង»។

Judges 16:10

នេះគឺជាការដែលបងបានបញ្ឆោតខ្ញុំ និងកុហកអូន

ការបោកប្រាស់ និងការកុហកមានន័យថាដូចគ្នា និងជាប្រយោគបញ្ជាក់ពីអារម្មណ៍ដែលនាងដេលីឡាមាន។ របៀបផ្សេងទៀតនៃការបកប្រែ: «បងបានបញ្ឆោតខ្ញុំ និងកុហកអូន»។

អាចគ្រប់គ្រងអ្នកបាន

ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «គេអាចយកឈ្នះបងបាន»។

ជនជាតិភីលីស្ទីនមកចាប់បងហើយ

ឃ្លា «មកចាប់បងហើយ» មានន័យថា ពួកគេមកដល់ចាប់ខ្លួនលោក។ របៀបផ្សេងទៀតនៃការបកប្រែ: «ជនជាតិភីលីស្ទីនមកចាប់បង មកដល់ហើយ»។

មានមនុស្សលាក់ខ្លួននៅក្នុងបន្ទប់ខាងក្នុង

ឃ្លានេះ មានន័យថាលាក់ខ្លួន ហើយរងចាំឱកាសវាយប្រហារគាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «រង់ចាំវាយប្រហារគាត់»។

លោកផ្តាច់ពួរពីដៃលោក ដូចជាផ្តាច់ខ្សែអំបោះ។

អ្នកនិពន្ធពណ៌នាពីភាពងាយស្រួលរបស់លោកសាំសុនបានផ្តាច់ខ្សែពួរដោយរបៀបដូចជាសរសៃអំបោះ។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកផ្តាច់ខ្សែពួរងាយដូចផ្តាច់ខ្សែអំបោះ»។

Judges 16:13

បងនៅតែបញ្ឆោតខ្ញុំ និងនិយាយកុហកខ្ញុំ

បោកប្រាស់ និងកុហកមានន័យដូចគ្នា ហើយឃ្លានេះនិយាយដើម្បីបញ្ជាក់ថានាងដេលីឡាមានអារម្មណ៍ខឹងខ្លាំងយ៉ាងណា។ របៀបផ្សេងទៀតនៃការបកប្រែ: «បងកុហកអូនទៀតហើយ»។

អាចគ្រប់គ្រងអ្នកបាន

ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «គេអាចយកឈ្នះបងបាន»។

តម្បាញ

ខ្សែវិញចូលគ្នា ដើម្បីឲ្យខ្សែទាំងនោះភ្ជាប់គ្នាមកកន្លែងតែមួយ។

ក្រងសក់ខ្ញុំ

ក្រងសក់ជាបំណែកតូច។

អំបោះ

សម្លៀកបំពាក់ធ្វើពីការត្បាញសម្ភារជាមួយគ្នា។

កីត្បាញ

ជាម៉ាស៊ីនប្រើសម្រាប់ភ្ជាប់អំបោះធ្វើជាក្រណាត់។

បន្ទាប់មកបោះភ្ជាប់ទៅនឹងកីតម្បាញ

«បន្ទាប់មកបោះដែកគោលទៅនឹងក្រណាស់ភ្ជាប់ទៅនឹងកីតម្បាញ»។

ដែកគោល

ញញួររាដែកគោលដើម្បីភ្ជាប់អ្វីមួយនៅនឹងកន្លែងមួយ។

នោះខ្ញុំនឹងទៅជាខ្សោយដូចមនុស្សធម្មតា

អត្ថន័យពេញរបស់ឃ្លានេះអាចធ្វើឲ្យវាកាន់តែច្បាស់បាន។ របៀបផ្សេងទៀតនៃការបកប្រែ: «បងនឹងខ្សោយដូចជាបុរសផ្សេងទៀតដែរ»។

ពួកភីលីស្ទីនមកចាប់បងហើយ

ឃ្លា «មកចាប់» មានន័យថាពួកគេរួចរាល់នឹងចាប់ខ្លួនគាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «ជនជាតិភីលីស្ទីនមកចាប់បងហើយ»។

លោកសាំសុនភ្ញាក់ឡើង ហើយកន្ត្រាក់របើកទាំងក្រណាត់ ហើយនឹងកន្លាស់ពីកីតម្បាញទៀតផង

លោកសាំសុនបានទាញក្រណាត់ពីកីតម្បាញ ហើយទាញសក់របស់គាត់ពីកីតម្បាញនោះ។ ឃ្លានេះអាចបញ្ជាក់ច្បាស់ថែមទៀត។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានទាញសក់របស់លោក ដោយមកជាមួយកន្លាស់លោកពីកីតម្បាញ និងក្រណាត់ពីកីតម្បាញដែរ» (UDB)។

កន្លាស់

នេះគឺជាដែកគោលឈើ ឬទម្ពក់ ប្រើដើម្បីភ្ជាប់ក្រណាត់និងកីតម្បាញ។

Judges 16:15

តើបងនិយាយថា បងស្រឡាញ់អូន ដូចម្តេច

នៅពេលដែលបងមិនចែករំលែកការសម្ងាត់របស់បងជាមួយខ្ញុំ?

នាងដេឌីឡាសួរសំណួរនេះ ប្រាប់ថា បើលោកសាំសុនស្រឡាញ់នាងមែន ហេតុអ្វីបានជាលោកមិនប្រាប់នាងពីរឿងសម្ងាត់ដូច្នេះ។ សំណួរនេះអាចសរសេរជាប្រយោគបាន» របៀបផ្សេងទៀតនៃការបកប្រែ: «ពេលបងនិយាយ «បងស្រឡាញ់អូន» អ្នកកំពុងកុហកហើយ ព្រោះបងមិនបានប្រាប់ពីរឿងសម្ងាត់ដល់អូនទេ»។

នាងរំអុកលោកយ៉ាងខ្លាំង...បានរំអុកលោកយ៉ាងខ្លាំង

នៅត្រង់នេះ អ្នកនិពន្ធនិយាយពីការដែលនាងដេលីឡាបញ្ចុះបញ្ចូលលោកសាំសុន របៀបដូចជាដាក់សម្ពាធលើគាត់ ដើម្បីជំរុញគាត់ឲ្យប្រាប់នាងពីអ្វីដែលនាងចង់ដឹង។ របៀបផ្សេងទៀតនៃការបកប្រែ: «ខំព្យាយាមយ៉ាងខ្លាំងបញ្ចុះបញ្ចូលគាត់ហើយ...បញ្ចុះបញ្ចូលទៀត»។

នឹងសំដីរបស់នាង

ពាក្យ «សំដី» នៅត្រង់នេះ សំដៅលើអ្វីដែលនាងដេលីឡានិយាយជាមួយលោកសាំសុន។ របៀបផ្សេងទៀតនៃការបកប្រែ: «ដោយសារអ្វីដែលនាងបាននិយាយជាមួយគាត់»។

លោកសង្ឃឹមថាលោកអាចនឹងស្លាប់

អ្នកនិពន្ធប្រើទិដ្ឋភាពជាក់ស្តែង និងការនិយាយបំផ្លើស ដើម្បីបញ្ជាក់ពីអារម្មណ៍លំបាកដែលលោកសាំសុងមាន។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកមានទុក្ខលំបាកជាខ្លាំង» ឬ «លោកមិនជាពិបាកចិត្តជាខ្លាំង»។

Judges 16:17

ចាប់ចង...គ្រប់យ៉ាង

ពាក្យ «គ្រប់យ៉ាង» នៅត្រង់នេះ សំដៅលើគ្រប់យ៉ាងអំពីប្រភពនៃកម្លាំងរបស់គាត់។ ឃ្លានេះ អាចបញ្ជាក់ឲ្យកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាប់នាងពីប្រភពនៃកម្លាំងរបស់គាត់» ឬ «ប្រាប់នាងពីការពិត»

កាំបិតកោរ

កាំបិតកោរប្រើដើម្បីកាត់សក់ឲ្យខ្លីដល់ស្បែកក្បាលរបស់មនុស្ស។

បានញែកថ្វាយព្រះ

ឃ្លានេះមានន័យថា លោកបានឧទ្ទិសខ្លួនថ្វាយដល់ព្រះក្នុងនាមជាណាសារីត។

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលអ្នកបកប្រែប្រហាក់ប្រហែលនឹងឃ្លានៅក្នុងជំពូក ១៣:៣។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកណាសារីតបានឧទ្ទិសថ្វាយដល់ព្រះជាម្ចាស់» ឬ «ឧទ្ទិសថ្វាយព្រះជាម្ចាស់ក្នុងនាមជាអ្នកណាសារីត»។
តាំងពីខ្ញុំចាប់កំណើតក្នុងផ្ទៃម្តាយរបស់បងម្លេ៉ះ
ពាក្យ «តាំងពីខ្ញុំចាប់កំណើតក្នុងផ្ទៃម្តាយរបស់បងម្លេ៉ះ» សំដៅលើពេញមួយជីវិតរបស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «ពេញមួយជីវិតរបស់ខ្ញុំ»។
ប្រសិនបើក្បាលរបស់ខ្ញុំត្រូវបានកោរ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើនរណាម្នាក់កោរក្បាលបង» ។
កោរ
កាត់សក់ឲ្យខ្លីដល់ស្បែកក្បាលដោយកាំបិតកោរ។
កម្លាំងរបស់បងនឹងចេញពីខ្លួនរបស់បង
លោកសាំសុននិយាយអំពីកម្លាំងរបស់គាត់ ប្រៀបដូចជាមនុស្សដែលចាកចេញពីគាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «បងនឹងលែងខ្លាំងដូចមុនទៀតហើយ» ។
Judges 16:18
នាងដេលីឡាឃើញ
ពាក្យ «បានឃើញ» នៅទីនេះ ជាពាក្យដែលមានន័យថា បានយល់ពីអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «នាងដេលីឡាបានយល់»
អាថ៌កំបាំងគ្រប់យ៉ាងដល់នាង
ពាក្យ «គ្រប់យ៉ាង» នៅទីនេះ សំដៅលើអ្វីដែលជាេហតុធ្វើឲ្យលោកសាំសុនខ្លាំង។ របៀបផ្សេងទៀតនៃការបកប្រែ: «សេចក្តីពិតអំពីហេតុដែលលោកខ្លាំង»។
សូមមកម្តងទៀតចុះ
នាងដេលីឡាប្រាប់អ្នកដឹកនាំឲ្យមកកន្លែងដែលនាងរស់នៅម្តងទៀត។ កន្លែងដែលនាងរស់នៅខ្ពស់ជាងកន្លែងដែលអ្នកដឹកនាំធ្វើដំណើរមក។
យកប្រាក់នៅនឹងដៃមកជាមួយពួកគេផង
ឃ្លានេះ មានន័យថាពួកគេបានយកប្រាក់មកឲ្យនាង ដូចដែលពួកគេបានសន្យាថានឹងឲ្យនាង ប្រសិនបើនាងជួយពួកគេចាប់លោកសាំសុនបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «យកប្រាក់ដែលពួកគេបានសន្យាថាឲ្យនាងមកផង»។
នាងបានដាក់ឲ្យលោកសម្រាន្ត
«នាងបានបានធ្វើឲ្យលោកគេងលក់»។
លើភ្លៅរបស់នាង
ពាក្យនេះមានន័យថាលោកគេងដាក់ក្បាលនៅលើភ្លៅរបស់នាង។ ឃ្លានេះអាចនិយាយឲ្យកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ដាក់ក្បាលរបស់គាត់លើភ្លៅរបស់នាង»។
ភ្លៅ
ភ្លៅនៅម្ខុជើងខាងលើ ពេលមនុស្សអង្គុយ។
សក់ទាំងប្រាំពីររបស់លោក
លោកសាំសុនមានមានសក់ក្រងប្រាំពីរនៅលើក្បាលរបស់គាត់។ សក់ក្រង់គឺជាសក់ក្រងជាបាច់តូចៗ។ សក់ក្រង់របស់គាត់នៅទីនេះ ពណ៌នាជា «ជាកម្មសិទ្ធិ» របស់ក្បាល់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «មានសក់ក្រងនៅលើក្បាលរបស់ក្បាលរបស់គាត់»។ ។
បង្ក្រាប កម្លាំងរបស់លោក
«គ្រប់គ្រងលើគាត់»។
កម្លាំងរបស់លោកក៏ចេញពីខ្លួនរបស់លោកទៅ
កម្លាំងរបស់លោកសាំសុននៅទីនេះ ពណ៌នាដូចជាមនុស្សម្នាក់ដែលចាក់ចេញពីគាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «កម្លាំងរបស់គាត់បានចាកចេញពីគាត់» ឬ «លោកលែងមានកម្លាំងទៀត»។
Judges 16:20
ពួកភីលីស្ទីនមកចាប់បងហើយ សាំសុនអើយ
ឃ្លា «មកចាប់» មានន័យថា ពួកគេរួចរាល់នឹងចាប់ខ្លួនលោក។ របៀបផ្សេងទៀតនៃការបកប្រែ: «ជនជាតិភីលីស្ទីនបានមកចាប់ខ្លួនបងហើយ»។
ក្រោកឡើង
«ភ្ញាក់ឡើង»
ចាកចេញពី
«រត់គេច»
ប៉ុន្តែ លោកមិនបានដឹងទេថា ព្រះជាម្ចាស់បានចាកចេញពីលោកហើយនោះទេ
ឃ្លានេះ បញ្ជាក់ថា ប្រសិនបើ ព្រះអម្ចាស់ចាកចេញពីគាត់ លោកនឹងលែងមានកម្លាំងទៀត។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ លោកមិនបានដឹងថាព្រះអម្ចាស់ចាកចេញពីគាត់ទេ ហើយថាគាត់មិនមានកម្លាំងគ្រប់គ្រាន់ដើម្បីយកឈ្នះជនជាតិភីលីស្ទីនដែរ»។
បានចាប់លោកហើយខ្វេះភ្នែករបស់លោក
ឃ្លានេះមានន័យថា ពួកគេខ្វេះភ្នែកចេញពីភ្នែករបស់គេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្វេះភ្នែករបស់គាត់» ។
ទៅក្រុងកាសា
ឃ្លា «ចុះទៅ» ប្រើនៅទីនេះ ដោយសារពួកគេនាំលោកសាំសុនចុះទៅកាសា ដែលទាបជាងផ្ទះរបស់គាត់ ជាកន្លែងដែលពួកគេចាប់គាត់។
យកច្រវាក់លង្ហិនមកដាក់លោក
«យកច្រវាក់លង្ហិនមកដាក់លោក» ឬ «ចងលោកដោយប្រើច្រវាក់លង្ហិន» ។
ច្រវាក់
ចាក់សោរនឹងច្រវាក់ដើម្បីចងអ្នកទោសនៅត្រង់ដៃ និងជើងរបស់គេទាំងពីរ។
ជាអ្នកបង្វិលត្បាល់នៅក្នុងគុក
«ជាអ្នកបង្វិលត្បាល់ជារវង្វង់»។
ត្បាល់
ត្បាល់ធ្ងន់ខ្លាំងណាស់ ជាថ្មដែលមានរាងមូល។ ជាទូទៅគេប្រើសត្វដើម្បីទាញវានៅជុំវិញដើម្បីកិនស្រូវ។ នៅទីនេះជនជាតិភីលីស្ទីនមើលងាយលោកសាំសុន ដោយបង្ខំគាត់ឲ្យទាញត្បាលនោះ។
បន្ទាប់ពីគេកោរនោះ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: បន្ទាប់ពីជនជាតិភីលីស្ទីនកោរសក់គាត់»។
Judges 16:23
ព្រះដាកុន
ជាព្រះក្លែងក្លាយដ៏ធំមួយរបស់ជនជាតិភីលីស្ទីន។
បានប្រគល់
«បានយកឈ្នះ»
ក្នុងកណ្តាប់ដៃរបស់យើង
នៅត្រង់នេះ អ្នកនិពន្ធនិយាយពីលោកសាំសុន នៅក្រោមការគ្រប់គ្រងរបស់អ្នកដឹកនាំ ប្រៀបដូចជាចាប់ជាប់នៅនឹងដៃរបស់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដាក់គាត់នៅក្រោមការគ្រប់គ្រងរបស់យើង»។
អ្នកដែលបានបំផ្លាញប្រទេស
ឃ្លានេះ សំដៅលើលោកសាំសុន។ ពាក្យ «អ្នកបំផ្លាញ» អាចនិយាយជាកិរិយាសព្ទ «បំផ្លាញ» របៀបផ្សេងទៀតនៃការបកប្រែ: «ជាម្នាក់ដែលបំផ្លាញប្រទេសរបស់យើង»។ ។
ដែលបានសម្លាប់ប្រជាជនជាច្រើនរបស់យើង
ពាក្យ «យើង» នៅត្រង់នេះ សំដៅលើប្រជាជនភីលីស្ទីន។ អ្នកដែលនិយាយនេះមិនបានរាប់បញ្ចូលពួកគេចូលទៅក្នុងចំនួនមនុស្សដែលលោកសាំសុនបានសម្លាប់នោះទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដែលសម្លាប់ប្រជាជនរបស់យើងជាច្រើន»។
Judges 16:25
ចូរហៅសាំសុនមក...ពួកគេក៏បានហៅសាំសុន
លោកសាំសុនជាអ្នកទោស លោកមិនអាចត្រូវបានគេហៅដោយផ្ទាល់នោះទេ។ ប៉ុន្តែ ប្រាប់អ្នកដែលមើលខុសត្រូវគុកឲ្យនាំលោកមករកពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ចូរហៅលោកសាំសុនឲ្យគាត់ចេញមក...ពួកគេក៏ទៅនាំលោកសាំសុនមក»។ ។
ក្មេងប្រុស
«ក្មេងប្រុស» នេះមិនមែនជាកូនក្មេងទេ ប៉ុន្តែជាយុវជនច្រើនជាង។
សូមនាំខ្ញុំទៅក្បែរសសរដែលទ្រវិហារ ដើម្បីឲ្យខ្ញុំអាចផ្អែកខ្លួនលើសសរនោះផង
«សូមអនុញ្ញាតឲ្យខ្ញុំទៅប៉ះសសរដែលទ្រវិហារ»។
Judges 16:27
ឥឡូវ
ពាក្យដែលប្រើទីនេះ ដើម្បីបង្ហាញពីការសម្រាកពីសាច់រឿងចម្បង ចំណែកអ្នកនិពន្ធវិញប្រាប់ពណ៌មានពីសាវតាវិញ។
មានមនុស្សប្រមាណជាបីពាន់នាក់ផ្សេងទៀតទាំងប្រុសទាំងស្រី
«៣,០០០នាក់ ទាំងប្រុសទាំងស្រី»។
ឈរមើល

generated on Wed Sep 10 16:16:32 2025

«សម្លឹងមើល»
លោកសាំសុនឡកសម្រាប់ពួកគេ
ពាក្យនេះ មិនច្បាស់ពីអ្វីដែលលោកសាំសុនធ្វើ ដើម្បីសម្តែងដល់ពួកគេ។
វាដូចជាជនជាតិភីលីស្ទីនធ្វើដាក់គាត់ដូចជាអ្វីមួយដែលបន្ទាបបន្ថោកលោក
ដើម្បីពួកគេអាចសើចគាត់។
Judges 16:28
ស្រែកហៅព្រះអម្ចាស់
«បានអធិស្ឋានទៅរកព្រះអម្ចាស់» ។
សូមកុំភ្លេចទូលបង្គំឡើយ
ឃ្លានេះមានន័យថា សូមនឹកចាំពីគាត់ ហើយនឹងស្ថានភាពរបស់គាត់ផង។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមនឹកចាំពីទូលបង្គំផង»។
ម្តងនេះទៀតចុះ
«សូមតែម្តងទៀតទេ» ។
ក្នុងពេលមួយប៉ប្រិចភ្នែក ដែលទូលបង្គំអាចសងសឹកចំពោះពួកភីលីស្ទីន
ប្រយោគនេះមានន័យថា
លោកចង់មានអំណាចម្តងទៀតដើម្បីប្រឆាំងនឹងជនជាតិភីលីស្ទីនចំពោះអ្វីដែលពួកគេបានធ្វើចំពោះគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រហារជនជាតិភីលីស្ទីនតែម្តងទៀតប៉ុណ្ណោះ» ឬ
«មានអំណាចដែលម្តងទៀត ដើម្បីប្រឆាំងនឹងជនជាតិភីលីស្ទីន»។
ទៅលើសសរទាំងពីរ
«ដែលទប់អគារ»
Judges 16:30
លោកបញ្ចេញកម្លាំងរបស់លោក ហើយច្រាន
លោកសាំសុនបានលើកដៃរបស់គាត់ឡើង លោកទាញសសរអគារទម្លាក់។
របៀបផ្សេងទៀតនៃការបកប្រែ៖ «លោកប្រើកម្លាំងរបស់លោក ទាញទម្លាក់សសរ»
ឬ «លោកប្រើកម្លាំងរបស់គាត់ដើម្បីទាញទម្លាក់សសរនោះ»។
ស្លាប់
សំដៅលើមនុស្សដែលបានស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សស្លាប់»។
មានចំនួនច្រើនជាង
«មានចំនួនច្រើនជាង»។
អ្នកផ្ទះឪពុករបស់លោក
ពាក្យ «ផ្ទះ» នៅទីនេះ សំដៅលើគ្រួសាររបស់គាត់»។
សូអា...អេសថោល
សូមបកប្រែឈ្មោះទីកន្លែងទាំងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:១ និង
១៣:២៤។
គេបញ្ចុះសពរបស់លោកនៅក្នុងផ្នូរលោកម៉ាណូអា ដែលជាឪពុករបស់លោក
«គេបញ្ចុះសពរបស់លោកនៅក្នុងផ្នូរលោកម៉ាណូអា ដែលជាឪពុករបស់លោក»។
លោកម៉ាណូអា
សូមធ្វើចំពោះឈ្មោះនេះ។ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:១។
លោកសាំសុនបានជាចៅក្រមលើជនជាតិអ៊ីស្រាអែលអស់រយៈពេលម្ភៃឆ្នាំ
ឃ្លានេះដូចគ្នាទៅនឹងប្រយោគនៅក្នុងជំពូក ១៥:១៩។ វាបានសរសេរសារជាថ្មី
ដើម្បីរំលឹកអ្នកអាន ថាចៅហ្វាយរបស់អ៊ីស្រាអែលដឹកនាំបានវែងឆ្ងាយរហូតដល់ម្ភៃឆ្នាំ
មុនពេលលោកស្លាប់»។
ម្ភៃឆ្នាំ
«២០ឆ្នាំ»

---

17 [1]គ្រានោះមានបុរសម្នាក់នៅតំបន់ភ្នំ អេប្រាអ៊ីម ឈ្មោះមីកា។[2]គាត់ពោលទៅម្តាយរបស់គាត់ថា៖ «តើម៉ែមាននឹកចាំទេ
ពេលដែលគេលួចលុយម៉ែមួយពាន់មួយរយស្លឹងនោះ ម៉ែបានដាក់បណ្តាសាចោរនៅចំពោះមុខខ្ញុំ! មើល៍! នេះនែប្រាក់នៅជាមួយនឹងខ្ញុំ។ គឺខ្ញុំបានយកវា»។
ម្តាយរបស់គាត់ពោលថា «សូមព្រះអម្ចាស់ប្រទានពរកូន!»។
[3]លោកក៏បានប្រគល់ប្រាក់មួយពាន់មួយរយស្លឹងទៅឲ្យម្តាយរបស់គាត់វិញ ហើយម្តាយរបស់គាត់និយាយ៖ «ម្តាយបានសម្រេចថ្វាយប្រាក់នេះទៅព្រះអម្ចាស់ហើយ
ដើម្បីឲ្យកូនយកប្រាក់នេះទៅរំលាយហើយសិតធ្វើជារូបព្រះ។ ដូច្នេះ ម៉ែប្រគល់ប្រាក់នេះទៅឲ្យកូន»។[4]នៅពេលដែលលោកប្រគល់ប្រាក់នោះទៅឲ្យម្តាយរបស់លោក
ម្តាយគាត់បានដកប្រាក់ពីររយស្លឹងប្រគល់ទៅឲ្យពួកជាងស្មិតរំលាយ និងសិតធ្វើរូបព្រះ ព្រមទាំងរូបសំណាក រួចពួកគេយករូបនោះទៅដាក់ក្នុងផ្ទះរបស់លោកមីកា។
[5]ដូច្នេះ លោកមីកាមានកន្លែងមួយថ្វាយបង្គំព្រះនៅក្នុងផ្ទះរបស់គាត់ គាត់ក៏បានធ្វើរូបព្រះ និងរូបសំណាកជាច្រើនសម្រាប់គោរពបូជា
ហើយគាត់បានតែងតាំងកូនប្រុសរបស់គាត់ម្នាក់ឲ្យធ្វើជាបូជាចារ្យ។[6]នៅជំនាន់នោះមិនមានស្តេចគ្រងរាជ្យលើប្រជាជនអ៊ីស្រាអែលទេ
ម្នាក់ៗធ្វើអ្វីតាមទំនើងចិត្តដែលគេគិតថាត្រឹមត្រូវសម្រាប់គេ។
[7]មានយុវជនម្នាក់រស់នៅភូមិបេថ្លេហិម ក្នុងស្រុកយូដា។ គាត់រស់នៅទីនោះដើម្បីបំពេញភារកិច្ចរបស់គាត់។[8]គាត់បានចាកចេញពីបេថ្លេហិម ក្នុងស្រុកយូដា
ហើយស្វែងរកកន្លែងរស់នៅផ្សេងទៀត។ នៅពេលដែលគាត់ធ្វើដំណើរដល់ផ្ទះរបស់លោកមីកា ក្នុងតំបន់ភ្នំអេប្រាអ៊ីម។[9]លោកមីកាមានប្រសាសន៍ថា៖
«តើលោកអញ្ជើញមកពីណា?» បុរសនោះតបថា «ខ្ញុំជាពួកលេវី មកពីភូមិបេថ្លេហិម ក្នុងស្រុកយូដា ខ្ញុំកំពុងធ្វើដំណើរស្វែងរកកន្លែងដែលខ្ញុំអាចរស់នោះបាន»។
[10]លោកមីកាពោលថា៖ «សូមស្នាក់នៅជាមួយនឹងខ្ញុំចុះ ហើយមកធ្វើជាបូជាចារ្យគ្រប់គ្រងលើផ្ទះរបស់ខ្ញុំ ខ្ញុំនឹងជូនលោកដប់ស្លឹងក្នុងមួយឆ្នាំ សម្លៀកបំពាក់ និង
អាហារសម្រាប់លោក»។ បុរសលេវីនោះក៏យល់ព្រមរស់នៅផ្ទះរបស់លោក។[11]បុរសលេវីបានរស់នៅជាមួយលោកមីកា ហើយលោកមីកាចាត់ទុកគាត់ដូចជាកូនបង្កើត។
[12]លោកមីកាបានតែងតាំងបុរសនោះជាបូជាចារ្យ ហើយឲ្យរស់នៅក្នុងផ្ទះរបស់គាត់។[13]លោកមីកាពោលថា៖ «ឥឡូវនេះខ្ញុំដឹងថា ព្រះអម្ចាស់នឹងប្រទានពរដល់ខ្ញុំមិនខាន
ពីព្រោះមានបុរសលេវីម្នាក់ជាបូជាចារ្យរបស់ខ្ញុំ»។

Judges 17:1
គ្រានោះមានបុរសម្នាក់
នេះគឺជារបៀបនៃការណែនាំមនុស្សថ្មីមកក្នុងសាច់រឿង។
មីកា
នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។
មិនមែនឈ្មោះរបស់អ្នកដែលសរសេរកណ្ឌគម្ពីរមីកាទេ។
ដែលគេបានយកពីម៉ែ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលគេបានលួចពីអ្នកម្តាយ»។
ខ្ញុំបានលួចវា
«កូនគឺជាអ្នកយកវា» ។
Judges 17:3
បានយកផ្នែក
មានន័យថា ថ្វាយអ្វីមួយជាពិសេសដោយមានគោលបំណងជាក់លាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ឧទ្ទិសដល់»។
សិតធ្វើជារូបព្រះ
លោហៈដែលបានរំលាយ ហើយចាក់ទៅក្នុងពុម្ព
ដើម្បីបង្កើតជារូបភាពពិសេសណាមួយ។
ម៉ែប្រគល់ប្រាក់នេះទៅឲ្យកូន
«ម៉ែនឹងឲ្យវាត្រឡប់ទៅកូនវិញ»។
បានដកប្រាក់ពីររយស្លឹង
«ប្រាក់២០០ស្លឹង»
ពួកគេយករូបនោះទៅដាក់ក្នុងផ្ទះរបស់លោកមីកា
ពាក្យ «ពួកគេ» សំដៅលើ រូបចម្លាក់។ ឃ្លានេះនិយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «មីកាដាក់រូបព្រះទាំងនោះនៅក្នុងផ្ទះរបស់គាត់»។
Judges 17:5
ផ្ទះនៃរូបព្រះ
ឃ្លានេះ សំដៅលើផ្ទះ ជាពិសេសសម្រាប់ថ្វាយបង្គំរូបព្រះ។
ឃ្លានេះនិយាយយ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ផ្ទះសម្រាប់ថ្វាយបង្គំរូបព្រះ»។
ហើយម្នាក់ៗធ្វើអ្វីតាមការយល់ឃើញថាត្រឹមត្រូវនៅក្នុងភ្នែករបស់គេ
«ភ្នែក» របស់មនុស្សម្នាក់ៗ គឺជាពាក្យប្រៀបធៀបសម្រាប់ការយល់ឃើញ
និងការសម្រេចចិត្ត។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សម្នាក់ៗធ្វើអ្វីដែលខ្លួនគិតថាត្រឹមត្រូវ»។

generated on Wed Sep 10 16:16:32 2025

Judges 17:7
នៅភូមិបេថ្លេហិម
«ពីភូមិបេថ្លេហិម»
នៃគ្រួសាររបស់យូដា
ឃ្លានេះមានន័យថា លោករស់នៅក្នុងចំណោមជនជាតិយូដា
ដែលជាកុលសម្ព័ន្ធយូដា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជាអ្នកដែលរស់នៅក្នុងចំណោមកុលសម្ព័ន្ធយូដា»។
គាត់បានរស់នៅទីនោះពេញភារកិច្ចរបស់គាត់
«លោករស់នៅ ហើយធ្វើការនៅទីនោះ»។
ស្វែងរកកន្លែងរស់នៅ
«ស្វែងរកកន្លែងផ្សេងទៀតរស់នៅ»។
កន្លែងដែលខ្ញុំអាចរស់បាន
វាបញ្ជាក់ថា លោកស្វែងរកកន្លែងរស់នៅ និងធ្វើការ។
របៀបផ្សេងទៀតនៃការបកប្រែ: «កន្លែងដែលខ្ញុំអាចរស់ និងមានការងារធ្វើបាន»។
Judges 17:10
ធ្វើជាឪពុកនិងជាបូចារ្យ
ពាក្យ «ឪពុក» នៅទីនេះ ប្រើក្នុងន័យអ្នកប្រឹក្សាយោបល់
មិនមែនជាឪពុកពិតប្រាកដទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើជាអ្នកប្រឹក្សាយោបល់និងជាបូចារ្យ» ។
សម្លៀកបំពាក់
«សម្លៀកបំពាក់មួយសម្រាប់»។ បានទទួលរៀងរាល់ឆ្នាំ។
អាចបន្ថែមពាក្យដែលបាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«សម្លៀកបំពាក់មួយសម្រាប់រាល់ឆ្នាំ»។
ដូច្នេះ បុរសលេវីនោះក៏យល់ព្រមរស់នៅផ្ទះរបស់គាត់
វាបង្ហាញថា លេវីបានទទួលសំណើរបស់លោកមីកា ដូច្នេះហើយ
បានជាលោកចូលទៅក្នុងផ្ទះរបស់លោក។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
លេវីបានយល់ព្រមសំណើរបស់លោក ហើយបានចូលទៅក្នុងផ្ទះរបស់គាត់»។
ហើយចំពោះលោកមីការយុវជននេះបានក្លាយទៅដូចជាកូនប្រុសបង្កើតរបស់គាត់
ទំនាក់ទំនងរវាងលេវី និងលោកមីកាដូចជាទំនាក់ទំនងរវាងឪពុក និងកូន។
របៀបផ្សេងទៀតនៃការបកប្រែ: «យុវជននោះមានភាពជិតស្និទជាមួយលោកមីកា
ដូចឪពុកនិងកូន»។
Judges 17:12
លោកមីកាបានញែកពួកលេវី
ពាក្យ «ញែកដោយឡែក» មានន័យថា លោកមីកា «ឧទ្ទិស» ឬ «តែងតាំង» គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកមីកាបានឧទ្ទិសថ្វាយខ្លួនលេវីដល់ព្រះ»។
នៅក្នុងផ្ទះរបស់មីកា
រស់នៅក្នុងផ្ទះរបស់លោកមីកា គឺនិយាយពី «រស់នៅ» ក្នុងផ្ទះរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «បានរស់នៅក្នុងផ្ទះរបស់លោកមីកា»។

---

18 [1]គ្រានោះមិនមានស្តេចគ្រប់គ្រងលើប្រជាជនអ៊ីស្រាអែលទេ។ កូនចៅនៃកុលសម្ព័ន្ធដាន់បានសម្លឹងមើលទឹកដីសម្រាប់ពួកគេរស់នៅ
កាលគ្រានោះពួកគេមិនទាន់មានទឹកដីដូចកុលសម្ព័នដទៃនៅឡើយទេ។[2]កូនចៅដាន់បានជ្រើសរើសមនុស្សចំនួនប្រាំនាក់តាមចំនួនមេគ្រួរបស់ពួកគេ
ដែលជាអ្នកចម្បាំងដ៏មានជំនាញពី សូអា និងពីអេសថោល ឲ្យស៊ើបពិនិត្យមើលទឹកដី។ អ្នកទាំងនោះនិយាយថា៖ «ចូរទៅហើយពិនិត្យមើលទឹកដី»។
ពួកអ្នកសើុបបានមកដល់ នៅតំបន់ភ្នំអេប្រាអ៊ីម នៅយប់នោះពួកគេបានចូលទៅសម្រាកនៅផ្ទះរបស់លោកមីកា។
[3]នៅពេលពួកគេនៅក្បែរផ្ទះលោកមីកា ពួកគេបានឮសម្លេងរបស់យុវជនលេវី ដូច្នេះ ពួកគេបានឈប់នៅទីនោះហើយសួរគាត់ថា៖ «តើអ្នកណាបាននាំអ្នកមកទីនេះ?
តើអ្នកកំពុងធ្វើអ្វីនៅទីកន្លែងនេះ? ហេតុអ្វីបានជាអ្នកនៅទីនេះ?»[4]គាត់ក៏ឆ្លើយថា «គឺលោកមីកាបានតែងតាំងខ្ញុំជាបូជាចារ្យ»។
[5]ពួកគេពោលថា៖ «ដូច្នេះ ចូរទូលសួរព្រះអម្ចាស់ថា តើយើងអាចដឹងថា ដំណើរដែលយើងធ្វើនឹងបានជោគជ័យឬយ៉ាងណា»។[6]លោកបូជាចារ្យតបទៅពួកគេថា៖
«សូមទៅដោយក្តីសុខសាន្តចុះ ព្រះអម្ចាស់នឹងគង់ជាមួយអស់លោកក្នុងដំណើររបស់អស់លោកហើយ»។
[7]បន្ទាប់មក បុរសទាំងប្រាំនាក់បានចាកចេញពីទីនោះទៅដល់ក្រុងឡាអ៊ីស នៅទីនោះពួកគេបានឃើញប្រជាជនរស់នៅដោយឥតបារម្ភអ្វីឡើយ គឺគេរស់នៅយ៉ាងសុខសាន្ត
និងស្ងៀមស្ងាត់ដូចជាអ្នកស្រុកស៊ីដូនដែរ។ នៅទីនោះ មិនមានអ្នកណាជិះជាន់សង្កត់សង្កិនពួកគេទេ។ ប៉ុន្តែ ពួកគេរស់នៅឆ្ងាយពីស៊ីដូន
ហើយគ្មានទំនាក់ទំនងជាមួយអ្នកផ្សេងទេ។[8]ពួកគេបាននាំគ្នាត្រឡប់សូអា និងអេសថោលវិញ។ បងប្អូនរបស់គេបានសួរ៖ «តើដំណើររបស់ពួកគេនោះយ៉ាងណាហើយ?»
[9]ពួកគេឆ្លើយថា៖ «មក! ចូរយើងទៅវាយពួកគេ! យើងបានឃើញទឹកដីនោះហើយ វាល្អខ្លាំងណាស់។ តើអ្នករាល់គ្នានឹងមិនធ្វើអ្វីមួយទេឬ?
កុំនៅយឺតយ៉ាវក្នុងការវាយប្រហារ និងដណ្តើមទឹកដីនោះឡើយ។
[10]ពេលដែលអ្នករាល់គ្នាទៅដល់អ្នករាល់គ្នានឹងឃើញមនុស្សមួយក្រុមដែលរស់នៅដោយឥតមានបារម្ភអ្វីឡើយ ហើយទឹកដីក៏ធំទូលាយ!
គឺព្រះអម្ចាស់ប្រគល់វាមកឲ្យអ្នករាល់គ្នាហើយ គឺជាទឹកដីដ៏សម្បូរសប្បាយ ឥតខ្វះអ្វីឡើយ»។
[11]ដូច្នេះ មនុស្សប្រាំមួយរយនាក់នៃកុលសម្ព័ន្ធដាន់ ប្រដាប់ដោយអាវុធ ហើយចាកចេញពីសូអា និងអេសថោលទៅ។[12]ពួកគេបានឡើងទៅបោះទ័ពនៅខាងលិច គារីយ៉ាត-
យារីម ក្នុងស្រុកយូដា។ ហេតុនេះហើយ ពួកគេបានហៅកន្លែងនោះថា «ជំរំដាន់» រហូតដល់សព្វថ្ងៃនេះ ។
[13]ពួកគេបានចាកចេញពីទីនោះទៅកាន់តំបន់ភ្នំអេប្រាអ៊ីម ហើយមកដល់ផ្ទះលោកមីកា។[14]បន្ទាប់មក មនុស្សទាំងប្រាំនាក់ដែលបានទៅស៊ើបនៅឡាអ៊ីស
ហើយនិយាយទៅកាន់បងប្អូនរបស់គេថា៖ «តើអ្នករាល់គ្នាដឹងឬទេថាក្នុងចំណោមផ្ទះទាំងនេះ មានផ្ទះមួយដែលមានរូបបដិមា និងរូបចំលាក់ជាច្រើន ព្រមទាំងរូបព្រះមួយ
និងរូបសំណាកមួយទៀតធ្វើពីប្រាក់? ដូច្នេះ បងប្អូនដឹងហើយថាគួរធ្វើយ៉ាងណា?»
[15]ដូច្នេះ ពួកគេបានត្រឡប់ទៅផ្ទះរបស់លោកមីកា ហើយសួរសុខទុក្ខបុរសលេវីដែលស្នាក់នៅក្នុងផ្ទះនោះ។[16]ឥឡូវនេះពួកដាន់ទាំងប្រាំមួយរយនាក់
ដែលប្រដាប់ដោយអាវុធនៅនឹងដៃ បានឈរនៅមុខច្រកចូលផ្ទះដែរ។
[17]បុរសទាំងប្រាំនាក់ដែលបានទៅស៊ើបមើលទឹកដីនោះ ក៏បានចូលទៅក្នុងផ្ទះហើយពួកគេបានយករូបសំណាក រូបបដិមា និងរូបព្រះផ្សេងៗ
ព្រមទាំងរូបចម្លាក់ដែលធ្វើពីប្រាក់ នៅពេលដែលបូជាចារ្យឈរក្បែរច្រកចូលជាមួយមនុស្សទាំងប្រាំមួយរយនាក់ដែលប្រដាប់ដោយអាវុធ។
[18]ពេលដែលពួកគេចូលទៅក្នុងផ្ទះលោកមីកា ហើយយករូបសំណាក រូបបដិមា និងរូបព្រះផ្សេងៗ ព្រមទាំងរូបចម្លាក់ដែលធ្វើពីប្រាក់ បូជាចារ្យពោលទៅកាន់ពួកគេថា៖
«តើអ្នករាល់គ្នាកំពុងធ្វើអ្វី?»
[19]ពួកគេឆ្លើយថា៖ «ចូរស្ងៀមស្ងាត់ទៅ! យកដៃបិតមាត់របស់អ្នកហើយមកជាមួយយើង ចូរមកធ្វើជាឪពុក និងជាបូជាចារ្យរបស់យើង! តើវាមិនប្រសើរទេឬ
ដែលអ្នកមកធ្វើជាបូជាចារ្យសម្រាប់អំបូរមួយក្នុងកុលសម្ព័ន្ធនៃជនជាតិអ៊ីស្រាអែល ជំនួសការធ្វើជាបូជាចារ្យសម្រាប់មនុស្សតែម្នាក់ក្នុងគ្រួសារតែមួយ»។
[20]បូជាចារ្យមានចិត្តត្រេកអរជាខ្លាំងនឹងសំណើនេះ។ លោកបានយករូបសំណាក រូបបដិមា និងរូបព្រះផ្សេងៗ ព្រមទាំងរូបចម្លាក់ដែលធ្វើពីប្រាក់
ហើយចាកចេញទៅជាមួយពួកគេ។
[21]ពួកគេបន្តដំណើរទៀត ដោយដាក់ក្មេងៗ ហ្វូងសត្វ និងទ្រព្យសម្បត្តិរបស់ពួកគេនៅខាងមុខ។[22]លុះពួកគេធ្វើដំណើរចេញឆ្ងាយពីផ្ទះលោកមីកាបន្តិចហើយ
ទើបលោកមីកា និងអ្នកជិតខាងប្រមូលគ្នាដេញតាម ពួកគេតាមទាន់ហើយស្រែកសួរកូនចៅដាន់[23]កូនចៅដាន់ក៏តបទៅលោកមីកាវិញថា៖
«តើមានការអ្វីបានជាប្រមូលគ្នាមកដូច្នេះ?»
[24]លោកមីកាឆ្លើយថា៖ «អ្នករាល់គ្នាបានលួចព្រះដែលយើងបានធ្វើ អ្នករាល់គ្នាបានយកបូជាចារ្យរបស់យើង ហើយអ្នករាល់គ្នាកំពុងតែចាក់ចេញ។
តើមានអ្វីផ្សេងទៀតដែលខ្ញុំភ្លេច? តើអ្នកអាចសួរខ្ញុំម្តេចបានថា តើយើងរំខានអ្វីដល់អ្នក?»[25]ដូច្នេះ កូនចៅដាន់តបទៅគាត់ថា៖
«លោកមិនគួរឲ្យយើងបានឮអ្វីដែលលោកបាននិយាយនោះទេ ព្រោះប្រសិនបើមានអ្នកណាក្នុងចំណោមយើងខឹងសប្បារឡើង គេអាចនឹងសម្លាប់លោក
និងគ្រួសាររបស់លោកផង»។[26]បន្ទាប់មក កូនចៅដាន់ធ្វើដំណើរបន្តទៅមុខ។ នៅពេលដែលលោកមីកាឃើញថាកូនចៅដាន់មានកម្លាំងខ្លាំងជាងលោក
លោកក៏បកក្រោយត្រឡប់ទៅផ្ទះវិញ។

generated on Wed Sep 10 16:16:32 2025

[27]កូនចៅដាន់បានដណ្តើមយកអ្វីៗដែលលោកមីកាបានបង្កើត សូម្បីតែបូជាចារ្យក៏នាំយកទៅជាមួយដែរ ហើយពួកគេវាយលុកក្រុងឡាអ៊ីស
ទាំងសម្លាប់រង្គាលប្រជាជនដែលរស់នៅយ៉ាងសុខសាន្ត និងស្ងប់ស្ងៀម ព្រមទាំងដុតក្រុងចោលទៀតផង។[28]ក្រុងឡាអ៊ីសជាក្រុងដែលស្ថិតនៅក្នុងជ្រលងភ្នំបេត-រេហូប
ដែលនៅឆ្ងាយពីក្រុងស៊ីដូន ហើយពួកគេក៏មិនមានទំនាក់ទំនងជាមួយអ្នកណាដែរ ដូច្នេះហើយ ទើបមិនមានអ្នកណាសង្គ្រោះពួកគេឡើយ។
កូនចៅដាន់បានសង់ទីក្រុងឡើងវិញ ហើយរស់នៅទីនោះ។[29]ពួកគេបានប្តូរឈ្មោះក្រុងឡាអ៊ីស ដែលធ្លាប់ប្រើពីមុនទៅជា «ក្រុងដាន់» តាមឈ្មោះបុព្វបុរសរបស់គេវិញ
ដែលត្រូវជាកូនរបស់លោកយ៉ាកុប។
[30]កូនចៅបានយករូបព្រះមកតម្កល់សម្រាប់ពួកគេថ្វាយបង្គំ។ ពួកគេបានតែងតាំងលោកយ៉ូណាថាន់ កូនប្រុសរបស់លោកគែរសូម ដែលត្រូវជាពូជពង្សរបស់លោកម៉ូសេ
ឲ្យធ្វើជាបូជាចារ្យ សម្រាប់កុលសម្ព័ន្ធដាន់ រហូតដល់ជំនាន់ដែលប្រជាជនត្រូវកៀរទៅជាឈ្លើយ។[31]ដូច្នេះ ពួកគេនៅតែថ្វាយបង្គំរូបព្រះរបស់លោកមីកា
ក្នុងអំឡុងពេលដែលពួកគេមានព្រះដំណាក់របស់ព្រះអម្ចាស់នៅស៊ីឡូ។

Judges 18:1

នៅគ្រានោះ

ីឃ្លានេះណែនាំពីព្រឹត្តិការណ៍ថ្មីនៅក្នុងសាច់រឿង។

នៅគ្រានោះ...ប្រជាជនអ៊ីស្រាអែល

នេះគឺជាព័ត៌មានអំពីសាវតារបស់អ៊ីស្រាអែល និងមនុស្សនៅក្នុងកុលសម្ព័ន្ធដាន់។

មិនទាន់បានទទួលចំណែកទឹកដីពីចំណោមកុលសម្ព័នដទៃនៃអ៊ីស្រាអែលនៅឡើយទេ

ឃ្លានេះ សំដៅលើចំណែកទឹកដី ដែលពួកគេរស់នៅ។

របៀបផ្សេងទៀតនៃការបកប្រែ: «មិនបានទទួលចំណែកទឹកដីមរតកពី»។

មិនទាន់បានទទួលចំណែកទឹកដីពីចំណោមកុលសម្ព័ន្ធដទៃនៃអ៊ីស្រាអែលនៅឡើយទេ

ឃ្លានេះ «សមាជិកទាំងមូល» សំដៅលើកុលសម្ព័ន្ធទាំងអស់។

របៀបផ្សេងទៀតនៃការបកប្រែ:

«ពីក្នុងចំណោមមនុស្សនៅក្នុងកុលសម្ព័ន្ធទាំងអស់»។

មានបទពិសោធន៍ចម្បាំង

«មានបទពិសោធន៍ក្នុងប្រយុទ្ធ»។

សូអា

សូមបកប្រែឈ្មោះក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:១។

អេសថោល

សូមបកប្រែឈ្មោះក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:២៤។

ទៅស៊ើបមើលទឹកដីដោយថ្មើរជើង

ឃ្លា «ដោយថ្មើរជើង» មានន័យថា ដើរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទៅស៊ើបមើលទឹកដីដោយដើរ»។

មីកា

សូមបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៧:១។

Judges 18:3

ពួកគេបានឮសម្លេងរបស់យុវជនលេវី

ពួកគេស្គាល់យុវជននេះ ដោយសម្លេងរបស់គាត់។ ពាក្យ «សម្តី» នៅទីនេះ
សំដៅលើ «សម្លេង» របស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានឮយុវជនលេវីនិយាយ ហើយពួកគេបានស្គាល់សម្លេងរបស់គាត់»។

Judges 18:7

ក្រុងឡាអ៊ីស

នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។

ជិះជាន់សង្កត់សង្កិនពួកគេ

«គ្មានខ្មាំងសត្រូវណារស់នៅក្នុងទឹកដីដែលពួកគេវាយបាននោះទេ»។

គ្មានទំនាក់ទំនងជាមួយអ្នកផ្សេងទេ

«គ្មានទំនាក់ទំនាងជាមួយអ្នកនៅខាងក្រៅណាឡើយ»។

មានន័យថារស់នៅឆ្ងាយពីក្រុងផ្សេងៗ
ដែលពួកគេបានរស់នៅដាច់ពីមនុស្សផ្សេងទៀត។

សូអា

សូមបកប្រែពាក្យទីក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:១។

អេសថោល

សូមបកប្រែពាក្យទីក្រុងនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:២៤។

Judges 18:9

តើអ្នករាល់គ្នាមិនធ្វើអ្វីមួយទេឬ?

សំណួរដែលមិនទាមទារចម្លើយ សួរដើម្បីចំអក
ហើយមានន័យថាពួកគេធ្វើអ្វីដែលផ្ទុយវិញ។

សំណួរនេះអាចសរសេរជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកត្រូវធ្វើអ្វីមួយនៅពេលនេះ»។

កុំនៅយឺតយ៉ាវក្នុងការវាយប្រហារ

ពាក្យអវិជ្ជមានពីរនេះ «មិន» និង «យឺតយ៉ាវ» ជាមួយគ្នា
ដើម្បីបញ្ជាក់ពីគំនិតវិជ្ជមានក្នុងការវាយប្រហារជាប្រញាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រញាប់ឡើង! វាប្រហារទៀត»។

ទឹកដីក៏ធំទូលាយ!

«ទឹកដីក៏ធំទូលាយ!» ឃ្លានេះពណ៌នាពីទំហំរបស់ទឹកដី។

គឺទីកន្លែងដែលឥតខ្វះអ្វីឡើយក្នុងស្រុក

គេប្រើទិដ្ឋភាពជាក់ស្តែង និងពាក្យបំផ្លើសនេះ ដើម្បីបញ្ជាក់ថា
គឺជាទឹកដីដែលគួរឲ្យចង់រស់នៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជាកន្លែងដែលយើងនឹងមានអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការ»។

ឥតខ្វះអ្វីឡើយក្នុងស្រុក

ពាក្យអវិជ្ជមានពីរជាមួយគ្នាដើម្បីបញ្ជាក់ពីគំនិតស្របៗ
របៀបផ្សេងទៀតនៃការបកប្រែ: «មានអ្វីៗគ្រប់យ៉ាង» ។ ។

Judges 18:11

មនុស្សប្រាំមួយរយនាក់

«៦០០នាក់»

គារីយ៉ាត-យារីម

នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។

ម៉ាហានេ-ដាន់

សូមបកប្រែឈ្មោះទីកន្លែងនេះឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៣:៤។

រហូតដល់សព្វថ្ងៃនេះ

ឃ្លានេះ មានន័យថាអ្វីមួយស្ថិតស្ថេរជាដរាប។ វាសំដៅលើពេល «បច្ចុប្បន្ន»។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅតែឈ្មោះនោះដដែល»

Judges 18:13

ក្រុងឡាអ៊ីស

សូមបកប្រែឈ្មោះទីកន្លែងនេះឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៨:៧។

ផ្ទះទាំងនេះ មានផ្ទះមួយដែលមានអេផូតមួយ...រូបសំណាកមួយទៀតធ្វើពីប្រាក់?

ចូរបងប្អូនសម្រេច...គួរធ្វើ?

បុរសប្រាំនាក់សួរសំណួរនេះជាសំណើ
និងជាការលើកទឹកចិត្តដល់បុរសដែលពួកគេបានលួចរូបព្រះនោះ។
ឃ្លានេះអាចសរសេរជាប្រយោគ ហើយបញ្ជាក់ព័ត៌មានដាក់នៅក្នុងរង្វង់ក្រចក។
របៀបផ្សេងទៀតនៃការបកប្រែ: «ផ្ទះទាំងនេះ មានផ្ទះមួយដែលមានអេផូតមួយ...
រូបសំណាកមួយទៀតធ្វើពីប្រាក់?

ក្នុងចំណោមផ្ទះទាំងនេះ មានផ្ទះមួយដែលមាន

«ក្នុងចំណោមផ្ទះទាំងនេះ មានផ្ទះមួយដែលមាន» ឬ
«នៅក្នុងចំណោមផ្ទះទាំងនេះមាន»។

Judges 18:15

ពួកគេបានត្រឡប់ទៅកន្លែងនោះ

«ពួកគេបានត្រឡប់» ។

ពួកគេបានស្វាគមន៍គាត់

ពាក្យ «គាត់» សំដៅលើលេវី។

ពួកដាន់ទាំងប្រាំមួយរយនាក់

«ពួកដាន់ ៦០០នាក់»។

Judges 18:17

ប្រាំមួយរយនាក់

«៦០០នាក់»

Judges 18:19

ប្រសើរសម្រាប់អ្នកក្នុងការធ្វើជាបូជាចារ្យសម្រាប់ផ្ទះរបស់មនុស្សម្នាក់...ដែលជាកុលសម្ព័ន្ធមួយនៃជនជាតិអ៊ីស្រាអែល

ពួកគេសួរសំណួរតែមិនទាមទារចម្លើយនេះ ដើម្បីបង្ហាញថាវាគឺជាការពិត។
សំណួរនេះអាចសរសេរជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
វាគឺជាការប្រសើរសម្រាប់អ្នក ក្នុងការធ្វើជាបូជាចារ្យនៅក្នុងអំបូរអ៊ីស្រាអែល

generated on Wed Sep 10 16:16:32 2025

ជាងនៅផ្ទះរបស់មនុស្សម្នាក់»។
បូជាចារ្យមានចិត្តត្រេកអរជាខ្លាំង
នៅត្រង់នេះបូជាចារ្យសំដៅលើទៅ «ដួងចិត្ត» របស់គាត់
ដើម្បីបញ្ជាក់ពីអារម្មណ៍របស់គាត់»។
Judges 18:21
ពួកគេបានថាក្មេងៗនៅខាងមុខក្បួនរបស់ពួកគេ ទាំងហ្វូងសត្វ និងទ្រព្យសម្បត្តិរបស់ពួកគេ
ពួកគេបានធ្វើដំណើរបែបនេះ ដើម្បីការពារក្មេងរបស់ពួកគេ។
ប្រសិនបើលោកមីកា និងកូនចៅរបស់លោកវាយប្រហារពួកគេ
នឹងបានជួបអ្នកចម្បាំងមុនគេ មិនមែនកូនចៅឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានដាក់ក្មេងតូចៗនៅខាងមុខពួកគេ
ដើម្បីការពារពួកគេ»។
ដំណើរចេញឆ្ងាយពីផ្ទះលោកមីកាបន្តិចហើយ
«ឆ្ងាយបន្តិចហើយ»។ សំដៅលើមិនឆ្ងាយប៉ុន្មាន ប៉ុន្តែ ក៏ឆ្ងាយល្មមដែរ
ប្រសិនបើគិតពីចម្ងាយ។
អ្នកជិតខាងផ្ទះរបស់លោកមីកាបានប្រមូលគ្នាដេញតាម
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានប្រមូលអ្នកដែលនៅជិតផ្ទះរបស់គាត់មកជុំគ្នា»។
បានប្រមូលគ្នាដេញតាម ហើយពួកគេតាមទាន់កូនចៅដាន់
ឃ្លានេះ បញ្ជាក់ថា ពួកគេដេញតាមកូនចៅដាន់។ ឃ្លានេះអាចនិយាយយ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដេញតាមកូនចៅដាន់
ពួកគេដេញតាមកូនចៅដាន់ពីក្រោយ»។
ពួកគេក៏បានងាកក្រោយ
«កូនចៅដាន់បានងាកក្រោយ»។
ហេតុអ្វីបានជាលើកគ្នាមកដូច្នេះ?
នេះជាសំនួរស្ដីបន្ទោស។ វាអាចបកប្រែជាប្រយោគមួយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនត្រូវប្រមូលមនុស្សរបស់អ្នកដេញតាមយើងទេ»។
បានជាលើកគ្នា
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រមូលមនុស្សរបស់អ្នកមកជុំគ្នា»។
Judges 18:24
ព្រះដែលយើងបានធ្វើ
លោកមីកាមិនបានធ្វើព្រះរបស់គាត់ទេ តែជាជាងស្មូនជាអ្នកធ្វើរូបព្រះទាំងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះដែលខ្ញុំបានធ្វើសម្រាប់ខ្ញុំ» ឬ
«ព្រះដែលជាងស្មូនបានធ្វើសម្រាប់ខ្ញុំ»។
តើមានអ្វីផ្សេងទៀតដែលខ្ញុំភ្លេច
លោកមីកាសួរសំណួរនេះ ដើម្បីបញ្ជាក់ថា
លោកលែងមានអ្វីដែលសំខាន់សម្រាប់គាត់ទៀតហើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានអ្វីនៅសល់ទេ» ឬ
«អ្នកបានយកអ្វីទាំងអស់ដែលសំខាន់សម្រាប់ខ្ញុំអស់ហើយ» ។
តើអ្នកអាចសួរខ្ញុំម្ដេចបានថា: តើយើងរំខានអ្វីដល់អ្នក?
លោកមីកាសួរសំណួរនេះ ដើម្បីបញ្ជាក់ថា
កូនចៅដាន់ប្រាកដជាដឹងអ្វីដែលរំខានដល់គាត់ហើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងថាខ្ញុំមានទុក្ខព្រួយជាខ្លាំង» ឬ
«អ្នកដឹងថាខ្ញុំរំខានដល់ខ្ញុំខ្លាំងប៉ុណ្ណានូវអ្វីដែលអ្នកបានធ្វើចំពោះខ្ញុំ»។
លោកមិនគួរឲ្យយើងបានឮអ្វីដែលលោកបាននិយាយនោះទេ
ឃ្លា «យើងបានឮអ្វីដែលលោកបាននិយាយ»
សំដៅលើកូនចៅដាន់ឮពីលោកមីកានិយាយអំពីអ្វីដែលបានកើតឡើង ប៉ុន្តែ
បានរួមបញ្ចូលជាមួយអ្វីផ្សេងទៀតដែលបានកើតឡើងដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរយើងស្ដាប់ថាអ្នកនឹងនិយាយអំពីអ្វីខ្លះ » ឬ
«និយាយអ្វីអំពីការនេះ»។
ឮអ្វីដែលលោកបាននិយាយ
ពាក្យ «អ្វីមួយ» សំដៅលើព័ត៌មានអំពីកូនចៅដាន់បានមកផ្ទះរបស់មីកា
ហើយលួចរូបព្រះរបស់លោក។ ឃ្លានេះអាចនិយាយកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ឮអ្នកនិយាយអ្វីមួយពីបញ្ហានេះ» ឬ
«ឮអ្វីមួយអំពីអ្វីដែលបានកើតឡើង»។
លោក និងគ្រួសាររបស់លោក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «សម្លាប់អ្នក
និងគ្រួសាររបស់អ្នក»។
ចេញទៅតាមផ្លូវរបស់ពួកគេ
ឃ្លានេះមានន័យថាពួកគេបន្តដំណើរទៅមុខទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្តដំណើរបស់ពួកគេទៅមុខទៀត» ឬ «បន្តធ្វើដំណើរទៅមុខទៀត»។
ពួកគេមានកម្លាំងខ្លាំងជាងលោក
ឃ្លានេះសំដៅលើប្រជាជនដាន់ខ្លាំងជាងលោកមីកា
និងមនុស្សដែលគាត់នាំទៅឡាំង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេខ្លាំងជាងគាត់ ហើយមនុស្សរបស់គាត់ក្នុងការប្រយុទ្ធ»។
Judges 18:27
អ្វីៗដែលលោកមីកាបានបង្កើត
លោកមីកាមិនបានធ្វើព្រះរបស់គាត់ទេ តែជាងស្មូនជាអ្នកធ្វើរូបព្រះទាំងនោះ។
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីៗដែលបានធ្វើសម្រាប់លោកមីកា» ឬ «របស់លោកមីកា»។ ។
ក្រុងឡាអ៊ីស
សូមបកប្រែឲ្យដូច អ្នកបានបកប្រែនៅក្នុងជំពូក ១៨:៧។
ជាមួយដាវ
«ពាក្យជាមួយដាវ» នៅទីនេះ «ដាវ» តំណាងឲ្យដាវ
និងអាវុធផ្សេងទៀតដែលទាហានប្រើនៅក្នុងសមរភូមិ។ សូមមើល:
ពួកគេមិនមានទំនាក់ទំនងជាមួយអ្នកណាឡើយ
ឃ្លានេះមានន័យថា ពួកគេបានរស់នៅឆ្ងាយពីទីក្រុងផ្សេងទៀត
ដែលពួកគររស់ដាច់ដោយឡែកពីអ្នកដទៃ។
សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លានេះនៅក្នុង ១៨:៧។
បេត-រេហូប
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
Judges 18:30
លោកយ៉ូណាថាន់ កូនប្រុសរបស់លោកគែរសូម ដែលត្រូវជាពូជពង្សរបស់លោកម៉ូសេ
នេះគឺជាឈ្មោះរបស់ក្មេងប្រុសលេវី ដែលធ្លាប់បម្រើជាបូជាចារ្យសម្រាប់លោកមីកា។
ឃ្លានេះអាចបញ្ជាក់ច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«យុវជនលេវីម្នាក់ឈ្មោះយ៉ូណាថាន ជាកូនរបស់គែរសូម កូនរបស់លោកម៉ូសេ
និង»។
រហូតដល់ថ្ងៃដែលទឹកដីត្រូវបានចាប់យក
ឃ្លានេះសំដៅលើសម័យកាលក្រោយមក
នៅពេលប្រជាជនដាន់បានចាប់ខ្លួនដោយសារខ្មាំងសត្រូវរបស់ពួកគេ
ឲ្យធ្វើជាអ្នកទោស និងជាចំណាត់ខ្មាងរបស់សត្រូវពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«រហូតដល់ថ្ងៃដែលខ្មាំងសត្រូវរបស់ពួកកគេចាប់យកទឹកដីរបស់ពួកគេ» ឬ «
រហូតដល់ថ្ងៃដែលខ្មាំងសត្រូវរបស់ពួកគេចាប់ពួកគេយកទៅជាឈ្លើយ»។
គាត់បានធ្វើ
ើលោកមីកាមិនបានធ្វើព្រះរបស់គាត់ទេ ប៉ុន្តែ
ជាជាងស្មូនវិញដែលធ្វើសម្រាប់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបានធ្វើសម្រាប់គាត់» ឬ «គឺជាជាងស្មូនដែលបានធ្វើសម្រាប់គាត់»។

---

19 [1]នៅគ្រានោះក្នុងស្រុកអ៊ីស្រាអែលមិនមានស្តេចសោយរាជ្យទេ កាលនោះមានបុរសម្នាក់ពីកុលសម្ព័ន្ធលេវី រស់នៅប៉ែកខាងចុងតំបន់ភ្នំអេប្រាអ៊ីម។
គាត់បានយកស្ត្រីម្នាក់ពីភូមិបេថ្លេហិម ក្នុងស្រុកយូដា មកធ្វើជាប្រពន្ធចុង។[2]ប៉ុន្តែ នាងបានក្បត់ចិត្តប្តី ហើយនាងបានចាកចេញពីប្តី ត្រឡប់ទៅផ្ទះឪពុករបស់នាង
នៅភូមិបេថ្លេហិម ក្នុងស្រុកយូដាវិញ ហើយនាងរស់នៅទីនោះអស់រយៈពេលបួនខែ។
[3]ប្តីរបស់នាងបានធ្វើដំណើរទៅតាមក្នុងគោលបំណងលួងលោមនាងអោយត្រឡប់មកវិញ។ គាត់បានយកអ្នកបម្រើ និងលាមួយគូរទៅជាមួយ។
ប្រពន្ធរបស់គាត់បាននាំគាត់ចូលទៅក្នុងផ្ទះឪពុករបស់នាង។ ពេលដែលឪពុកនាងបានឃើញគាត់បានទទួលដោយអំណរ។
[4]ឪពុកក្មេករបស់គាត់បានឃាត់គាត់ឲ្យស្នាក់នៅទីនោះចំនួនបីថ្ងៃ។ បុរសនោះបរិភោគអាហារ និងស្រា ហើយសម្រាន្តនៅទីនោះ។

generated on Wed Sep 10 16:16:32 2025

[5]នៅថ្ងៃទីបួន បុរសនោះនិងអ្នកបម្រើបានក្រោកពីព្រលឹម រៀបចំនឹងចាកចេញ ប៉ុន្តែឪពុករបស់ស្ត្រីបានពោលទៅកាន់កូនប្រសារថា
«ចូរទទួលទានអាហារអោយមានកម្លាំងសិន សឹមចេញដំណើរទៅ។»[6]ដូច្នេះទាំងពីរនាក់ ក៏អង្គុយចុះ បរិភោគអាហារនិងស្រាជាមួយគ្នា។
បន្ទាប់មកឪពុករបស់ស្ត្រីបាននិយាយទៅកាន់កូនប្រសារថា៖ «សូមកូនសម្រាកនៅទីនេះមួយយប់ទៀតសិនទៅ។»
[7]បុរសលេវីក្រោកឡើងរៀបនឹងចាកចេញ តែដោយឪពុកក្មេកចេះទទូចអង្វរពេក គាត់ក៏ប្តូរគំនិតហើយព្រមស្នាក់នៅទីនោះមួយយប់ទៀត។[8]នៅព្រលឹមថ្ងៃទីប្រាំ
បុរសលេវីបានក្រោកឡើងរៀបចំចេញដំណើរ ប៉ុន្តែ ឪពុករបស់ស្ត្រីនិយាយទៅគាត់ថា៖ «សូមកូនពិសារអាហារសិន ចាំដល់ថ្ងៃជ្រេរសឹមចេញដំណើរទៅចុះ»។ ដូច្នេះ
ពួកគេនាំគ្នាបរិភោគ។
[9]នៅពេលដែលបុរសលេវី ប្រពន្ធចុងរបស់គាត់ ហើយនិងនាក់បម្រើរៀបចេះដំណើរ ឪពុកក្មេករបស់គាត់និយាយថា៖ «មើល៍ ឥឡូវនេះជ្រុលពេលហើយ
ហើយថ្ងៃក៏ជិតលិចដែរ។ សម្រាកនៅទីនេះលេងសិនចុះ ស្អែកសឹមនាំគ្នាចេញដំណើរពីព្រលឹមត្រឡប់ទៅផ្ទះ»។
[10]ប៉ុន្តែ គាត់មិនបានយល់ព្រមសម្រាកនៅទីនោះទេ គឺគាត់បានក្រោកឡើង នាំប្រពន្ធចុងរបស់គាត់ និងសត្វលាទាំងពីររបស់គាត់ដែលមានចងកែបរួចជាស្រេច
ហើយចាកចេញទៅ។ គាត់បានធ្វើដំណើរទៅទល់មុននឹងទីក្រុងយេប៊ូស គឺក្រុងយេរូសាឡឹម។[11]ពេលដែលពួកគេទៅជិតដល់យេប៊ូស ថ្ងៃក៏ជិតលិចទៅហើយ
អ្នកបម្រើនិយាយទៅកាន់ម្ចាស់របស់គាត់ថា៖ «យើងគួរតែចូលទៅក្នុងក្រុងយេប៊ូល ហើយសម្រាកនៅក្នុងក្រុងនៅយប់នេះ»។
[12]ចៅហ្វាយរបស់គាត់ឆ្លើយទៅគាត់ថា «យើងនឹងមិនចូលទៅក្នុងក្រុងរបស់ជនបរទេសដែលមិនមែនជារបស់ជនជាតិអ៊ីស្រាអែលនោះទេ។
យើងនឹងធ្វើដំណើរទៅក្រុងគីបៀរ»។[13]គាត់និយាយទៅយុវជននេះថា៖ «តោះយើងទៅកន្លែងផ្សេងទៀតដែល ហើយយើងនឹងសម្រាកនៅក្រុងគីបៀរ ឬក្រុងរ៉ាម៉ា»។
[14]ដូច្នេះ ពួកគេបន្តដំណើរទៅទៀត ហើយថ្ងៃបានលិចនៅពេលដែលពួកគេមកជិតដល់គីបៀរ នៅក្នុងទឹកដីបេនយ៉ាមីន។
[15]ពួកគេចូលទៅក្នុងទីក្រុងហើយហើយសម្រាកនៅក្នុងក្រុងគីបៀរ។ ពួកគេអង្គុយនៅតាមផ្លូវក្រុង ប៉ុន្តែ
មិនមានអ្នកណាម្នាក់មកអញ្ជើញពួកគេឲ្យទៅសម្រាកនៅក្នុងផ្ទះរបស់ខ្លួនឡើយ។
[16]នៅពេលល្ងាចមានលោកតាម្នាក់ដែលត្រឡប់មកពីចម្ការរបស់គាត់។ គាត់មានដើមកំណើតពីតំបន់ភ្នំអេប្រាអ៊ីម ហើយគាត់មករស់នៅគីបៀរ
ដែលមានសុទ្ធតែមនុស្សពីកុលសម្ព័ន្ធបេនយ៉ាមីន។[17]នៅពេលដែលគាត់ក្រឡេកឃើញអ្នកដំណើរអង្គុយនៅតាមផ្លូវដូច្នេះ លោកតានិយាយថា៖ «តើអ្នកធ្វើដំណើរទៅណា
មកពីណាដែរ?»។
[18]បុរសលេវីតបវិញថា៖ «យើងខ្ញុំមកពីភូមិបេថ្លេហិម ក្នុងស្រុកយូដា ហើយខ្ញុំកំពុងធ្វើដំណើរទៅផ្ទះរបស់ខ្ញុំ ដែលជាព្រះដំណាក់របស់ព្រះអម្ចាស់វិញ ប៉ុន្តែ
មិនមានអ្នកណាម្នាក់ទទួលយើងឲ្យស្នាក់នៅក្នុងផ្ទះរបស់គេឡើយ។[19]យើងមានចំបើងនិងស្មៅសម្រាប់សត្វលារបស់យើង ហើយនេះជាអាហារសម្រាប់ខ្ញុំ ប្រពន្ធរបស់ខ្ញុំ
និងអ្នកបម្រើរបស់ខ្ញុំដែរ យើងមិនត្រូវការអ្វីឡើយ»។
[20]លោកតាក៏ពោលទៅកាន់គាត់ថា៖ «ខ្ញុំសូមស្វាគមន៍អ្នក នៅផ្ទះរបស់ខ្ញុំ ហើយខ្ញុំនឹងប្រគល់នូវអ្វីៗដែលអ្នកត្រូវការ។ ដូច្នេះ
មិនត្រូវសម្រាកនៅតាមផ្លូវដូច្នេះទេ។»[21]លោកតាក៏នាំបុរសលេវីទៅផ្ទះរបស់គាត់ ហើយឲ្យចំណីសត្វលារបស់គាត់។ ពួកគេបានលាងជើង ហើយបរិភោគអាហារនិងស្រា។
[22]នៅពេលដែលពួកគេកំពុងតែបរិភោគយ៉ាងរីករាយ មានមនុស្សពាលក្នុងក្រុងនោះ បានមកឡោមព័ទ្ធផ្ទះ ហើយគោះទ្វារផ្ទះខ្លាំងៗ។ ពួកគេស្រែកហៅលោកតាថា៖
«ចូរនាំអ្នកដែលស្នាក់នៅក្នុងផ្ទះរបស់អ្នកមកក្រៅ ដើម្បីឲ្យយើងរួមដំណេកជាមួយគេ»។[23]លោកតាម្ចាស់ផ្ទះបានចេញទៅ ហើយនិយាយជាមួយគេថា៖ «ទេ! បងប្អូនអើយ
សូមកុំប្រព្រឹត្តអំពើអាក្រក់នេះឡើយ! បុរសនេះជាភ្ញៀវនៅក្នុងផ្ទះរបស់ខ្ញុំ សូមកុំប្រព្រឹត្តអំពើថោកទាបនេះឡើយ!
[24]មើល៍ កូនស្រីរបស់ខ្ញុំគឺនៅព្រហ្មចារីយ៍នៅឡើង ហើយប្រពន្ធចុងរបស់លោកក៏នៅទីនេះដែរ។ សូមនាំពួកគេទៅជាមួយចុះ។ ខ្ញុំនឹងនាំពួកនាងចេញមក
ហើយសូមធ្វើចំពោះពួកនាងស្រេចតែចិត្តអ្នកចង់ទៅចុះ។ ប៉ុន្តែ សូមកុំប្រព្រឹត្តការថោកទាបជាមួយបុរសនេះឡើយ។[25]តែមនុស្សទាំងនោះមិនស្តាប់គាត់ទេ ដូច្នេះ
បុរសលេវីក៏នាំប្រពន្ធចុងរបស់គាត់ទៅខាងក្រៅប្រគល់ឲ្យពួកគេ។ ពួកវានាំគ្នារំលោភលើនាង ហើយធ្វើបាបនាងមួយយប់រហូតទាល់ភ្លឺ ទើបលែងនាងត្រឡប់មកវិញ។
[26]ពេលព្រលឹមស្រាងៗ ស្ត្រីបានដើរមកដួលនៅមាត់ច្រកចូលផ្ទះលោកតា ដែលប្តីនាងស្នាក់នៅ។ នាងនៅទីនោះរហូតដល់ថ្ងៃរះ។
[27]លុះព្រឹកឡើងប្តីរបស់នាងបើកទ្វារផ្ទះ ហើយចេញទៅក្រៅ ដើម្បីបន្តដំណើរទោះទៀត។ គាត់ក៏ឃើញប្រពន្ធចុងរបស់គាត់ដួលដេកនៅច្រកទ្វារចូល
ដោយដៃទាំងពីរតោងមាត់ទ្វារបងផង។[28]បុរសលេវីហៅនាងថា៖ «ក្រោកឡើង យើងទៅមុនទៀត!» ប៉ុន្តែ មិនមានចម្លើយទេ។ លោកលើកនាងដាក់នៅលើខ្នងលា
ហើយវិលត្រឡប់ទៅផ្ទះរបស់គាត់វិញ។
[29]ពេលដែលបុរសលេវីបានមកដល់ផ្ទះ គាត់បានយកកាំបិតមកកាត់សាកសពប្រពន្ធចុងរបស់គាត់ជាដប់ពីរកំណាត់
ហើយផ្ញើកំណាត់នីមួយៗទៅកាន់កុលសម្ព័ន្ធទាំងដប់ពីរនៃជនជាតិអ៊ីស្រាអែល។[30]គ្រប់គ្នាបានឃើញហើយក៏និយាយថា៖
«តាំងពីអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទមកដល់សព្វថ្ងៃនេះមិនដែលមានហេតុការណ៍បែបនេះកើតឡើងឡើយ។ ដូច្នេះ ត្រូវតែពិចារណាអោយបានល្អិតល្អន់
ហើយពិភាក្សាគ្នា តើយើងគួរសម្រេចបែបណា!»។

Judges 19:1
នៅគ្រានោះ
ឃ្លានេះណែនាំពីការចាប់ផ្តើមព្រឹត្តការណ៍ថ្មីមួយទៀតនៅក្នុងសាច់រឿង។
នៅប៉ែកខាងចុងតំបន់ភ្នំ
នៅឆ្ងាយពីកន្លែងដែលមានមនុស្សនៅ។
បានក្បត់ចិត្តគាត់
ឃ្លានេះមានន័យថាក្បត់ចិត្តគាត់នៅក្នុងទំនាក់ទំនងរបស់ពួកគេ
ហើយនាងបានទៅគេងជាមួយបុរសផ្សេង។ ឃ្លានេះអាចបញ្ជាក់ឲ្យកាន់តែច្បាស់
ប្រសិនបើចាំបាច់។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានចាប់ផ្តើមគេងជាមួយបុរសផ្សេងទៀត»។
Judges 19:3
អ្នកបម្រើរបស់គាត់និងលាមួយគូបានមកជាមួយគាត់
«លោកបានយកអ្នកបម្រើរបស់គាត់មកជាមួយ និងលាពីរ»។
ឪពុកក្មេករបស់គាត់ ឪពុករបស់ស្រីបានឃាត់គាត់
ឪពុកក្មេក បានឃាត់។ «ឪពុកក្មេករបស់គាត់ នោះគឺជាឪពុករបស់នាង
បានឃាត់គាត់» ឬ «ឪពុករបស់នាង បានឃាត់គាត់»។
ឃាត់គាត់ឲ្យស្នាក់នៅទីនោះ
«បាននិយាយជាមួយគាត់ ដូច្នេះ គាត់ក៏សម្រេចចិត្តនៅ»។
Judges 19:5
គាត់បានរៀបចំចាកចេញ
លេវីបានរៀបចំចេញ
ចូរទទួលទានអាហារឲ្យមានកម្លាំងសិន
ពាក្យ «នំប៉័ង» សំដៅលើ «អាហារ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«បរិភោគអាហារខ្លះ ដើម្បីឲ្យមានកម្លាំងអាចធ្វើដំណើរទៅមុខទៀត»។
សូមចំណាយពេលមួយយប់និងមានពេលល្អសិនទៅ
«សូមស្នាក់នៅមួយយប់ទៀតសិនទៅ» (UDB)។
Judges 19:7
សូមកូនពិសារឲ្យមានកម្លាំងសិន ចាំដល់ថ្ងៃជ្រេរសឹមចេញដំណើរទៅចុះ
ឪពុកក្មេកបានណែនាំថា គាត់ត្រូវចម្រើនកម្លាំងខ្លួនឯងដោយហូបអាហារ។
គាត់ក៏បានសូមគាត់ឲ្យនៅរហូតដល់រសៀលចាំចេញទៅ។
ឃ្លានេះបាននិយាយកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរហូបអាហារ ដើម្បីឲ្យមានកម្លាំងគ្រប់គ្រាន់ធ្វើដំណើរ
ហើយរង់ចាំរហូតដល់ពេលរសៀលចាំចេញដំណើរ»។
Judges 19:9
ឥឡូវនេះជ្រុលពេលហើយ ហើយថ្ងៃក៏ជិតលិចដែរ
«ថ្ងៃជិតលិចហើយ» ឬ «ជិលល្ងាចហើយ» ។
Judges 19:10
ក្រុងយេរូសាឡិម

generated on Wed Sep 10 16:16:32 2025

«ដែលក្រោយមកបានហៅថា ក្រុងយេរូសាឡិម»។
គាត់បានចងកែបលាទាំងពីរ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានដាក់កែបលើលាទាំងពីររបស់លោក»។
មក សូមយើង
ឃ្លានេះ ប្រើដើម្បីបង្កើតជាការស្នើ។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងស្នើថា
យើងត្រូវ»។
សម្រាកនៅ
ឃ្លានេះមានន័យថា ឈប់សម្រាកពីការធ្វើដំណើររបស់ពួកគេ
ហើយបានឈប់នៅកន្លែងណាមួយនៅតាមផ្លូវ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឈប់នៅត្រង់»។
Judges 19:12
សម្រាកនៅ
ឃ្លានេះមានន័យថា ឈប់សម្រាកពីការធ្វើដំណើររបស់ពួកគេ
ហើយបានឈប់នៅកន្លែងណាមួយនៅតាមផ្លូវ។
សូមមើលពីរបៀបដែលអ្នកបកប្រែប្រហាក់ប្រហែលឃ្លានៅក្នុងជំពូក ១៩:១០។
របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់នៅត្រង់»។
មក សូមយើង
ឃ្លានេះ ប្រើដើម្បីបង្កើតជាការស្នើ។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងស្នើថា
យើងត្រូវ»។
Judges 19:14
សម្រាកនៅ
ឃ្លានេះមានន័យថា ឈប់សម្រាកពីការធ្វើដំណើររបស់ពួកគេ
ហើយបានឈប់នៅកន្លែងណាមួយនៅតាមផ្លូវ។
សូមមើលពីរបៀបដែលអ្នកបកប្រែប្រហាក់ប្រហែលឃ្លានៅក្នុងជំពូក ១៩:១០។
របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់នៅត្រង់»។
តាមផ្លូវក្រុង
នៅតាមផ្សារ ដែលមនុស្សជុំគ្នានៅពេលថ្ងៃ។
អញ្ជើញពួកគេចូលទៅក្នុងផ្ទះរបស់ខ្លួន
ឃ្លានេះមានន័យថា នរណាម្នាក់អញ្ជើញពួកគេឲ្យចូលទៅក្នុងផ្ទះរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានអញ្ជើញពួកគេឲ្យស្នាក់នៅក្នុងផ្ទះរបស់ពួកគេនៅយប់នោះ»។
Judges 19:16
មនុស្សពីកុលសម្ព័ន្ធបេនយ៉ាមីន
មនុស្សពីកុលសម្ព័ន្ធបេនយ៉ាមីនគឺជាពូជពង្សរបស់កុលសម្ព័ន្ធបេនយ៉ាមីន។
សូមបកប្រែឈ្មោះនេះ ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ៣:១៥។
គាត់បានងើបភ្នែកឡើង
នៅត្រង់នេះ បុរសនោះបានងើបមុខឡើង
ហើយផ្តោតអារម្មណ៍ទៅលើអ្វីដែលនៅជុំវិញគាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានសម្លឹងមើល»។
តាមផ្លូវក្រុង
នៅតាមផ្សារ ដែលមនុស្សជុំគ្នានៅពេលថ្ងៃ។ សូមបកប្រែឈ្មោះនេះ
ឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៩:១៤។
Judges 19:18
មានអ្នកណាម្នាក់ទទួលយើងឲ្យស្នាក់នៅក្នុងផ្ទះរបស់គេ
ឃ្លានេះ សំដៅលើនរណាម្នាក់អញ្ជើញមនុស្សផ្សេងទៀត
ចូលទៅក្នុងផ្ទះដើម្បីស្នាក់នៅទីនោះមួយយប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបានអញ្ជើញខ្ញុំចូលទៅស្នាក់នៅផ្ទះរបស់គាត់»។
ទទួលយើង
លេវីនិយាយនៅត្រង់នេះ «ខ្ញុំ» ប៉ុន្តែ លោកសំដៅលើលោកខ្លួនឯង
និងអ្នកបម្រើស្រីរបស់គាត់ និងស្តីស្នំរបស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងទទួលយើង»។
ហើយនេះជាអាហារ និងស្រា
ប្តូរទៅជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយយើងមាននំបុ័ង
និងស្រាយជាច្រើន»។
សម្រាប់ខ្ញុំ និងអ្នកបម្រើស្រីរបស់អ្នកនៅទីនេះ
និងសម្រាប់ក្មេងប្រុសនេះជាមួយអ្នកបម្រើរបស់អ្នកដែរ។
លេវីនិយាយពាក្យនេះពីខ្លួនគាត់ និងពីអ្នកបម្រើផ្សេងទៀត នៅក្នុងបុរសទីបី
ដើម្បីបង្ហាញពីការគោរព។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបាទផ្ទាល់ ព្រមទាំង
ស្ត្រី និងអ្នកបម្រើដែលនៅជាមួយខ្ញុំបាទហើយ»។
យើងមិនត្រូវការអ្វីឡើយ
ឃ្លានេះនិយាយក្នុងភាពជាវិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមានអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការហើយ»។
Judges 19:20
សូមតែ កុំសម្រាក
«កុំ» ពាក្យ «សូមតែ» ប្រើនៅទីនេះ
ដើម្បីបញ្ជាក់ពីអ្វីដែលកាត់និយាយមិនចង់ឲ្យលេវីធ្វើ។
នៅតាមផ្លូវ
ឃ្លានេះសំដៅលើតាមទីធ្លាក្រុង។
សូមបកប្រែពាក្យនេះឲ្យដូចអ្នកបានបកប្រែនៅក្នុងជំពូក ១៩:១៦។
នាំបុរសលេវីទៅផ្ទះរបស់គាត់
មានន័យថា គាត់បានអញ្ជើញលេវីទៅគេងនៅផ្ទះរបស់គាត់។
ហើយក៏បានអញ្ជើញស្រីបម្រើ និងអ្នកបម្រើប្រុសរបស់គាត់ផងដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានអញ្ជើញលេវី
និងអ្នកបម្រើរបស់លោកឲ្យស្នាក់នៅផ្ទះរបស់គាត់»។
Judges 19:22
កាលគេកំពុងតែធ្វើឲ្យចិត្តរបស់គេសប្បាយរីករាយ
ឃ្លា «ធ្វើឲ្យចិត្តរបស់គេសប្បាយរីករាយ»
គឺជាប្រយោគដែលមានន័យថាមានពេលវេលាល្អជាមួយនរណាម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេសប្បាយរីករាយជាមួយគ្នា»
មនុស្សមួយចំនួននៃ...បានមកឡោមព័ទ្ធផ្ទះ ហើយគោះទ្វារផ្ទះខ្លាំងៗ។
មានមនុស្សមួយចំនួនបានមកឈរនៅជុំវិញផ្ទះគាត់។
Judges 19:24
មើល៍
ពាក្យនេះប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមស្តាប់»។ ។
មនុស្សទាំងនោះមិនស្តាប់គាត់ទេ
នៅទីនេះ អ្នកនិពន្ធនិយាយពី «ការយល់ព្រម» ប្រៀបដូចជា «ការស្តាប់»។
របៀបផ្សេងទៀតនៃការបកប្រែ:
«បុរសទាំងនោះមិនបានយល់ព្រមជាមួយនឹងសំណើរបស់គាត់ទេ»។
ដូច្នេះ បុរសនោះក៏នាំប្រពន្ធចុងរបស់គាត់
អាចមានការយល់ច្រឡំ ពីអត្តសញ្ញាណរបស់មនុស្សប្រុស។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ បុរសលេវីក៏នាំប្រពន្ធចុងរបស់គាត់»។
ពេលព្រលឹមស្រាងៗ
«នៅពេលថ្ងៃរះឡើង» ឬ «ពេលមានពន្លឺរះឡើង» ឃ្លានេះមានន័យថា
ពេលថ្ងៃចាប់ផ្តើមរះឡើង។
ដល់ថ្ងៃរះ
ឃ្លានេះ សំដៅលើពេលព្រឹក នៅពេលវាមានពន្លឺរះឡើង។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអាទិត្យចាប់ផ្តើមរះឡើង»។
Judges 19:27
ប៉ុន្តែ មិនមានចម្លើយទេ
ស្ត្រីនោះមិនបានឆ្លើយទេ ដោយសារនាងបានស្លាប់បាត់ទៅហើយ។
ឃ្លានេះអាចបញ្ជាក់ឲ្យកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
នាងមិនបានឆ្លើយទេ ដោយសារនាងបានស្លាប់បាត់ទៅហើយ»។
Judges 19:29
កាត់ជាកំណាត់ៗ
«កាត់ជាកង់ៗ»
អ្នកនិពន្ធប្រើរូបភាពនេះដើម្បីពណ៌នាពីលេវីកាត់រូបកាយរបស់នាងជាដុំៗ
គឺបញ្ជាក់ពីអ្វីដែលគាត់ធ្វើ។ «អវយវៈ» សំដៅលើទៅលើដៃ និងជើងរបស់មនុស្ស។
ប្រសិនបើវាមិនដូចជាភាសារបស់អ្នក
ចូរទុកការពណ៌នានេះនៅក្នុងការបកប្រែរបស់អ្នកចុះ។
ដប់ពីរកំណាត់
«១២កំណាត់»
ហើយផ្ញើកំណាត់នីមួយៗទៅកាន់កុលសម្ព័ន្ធទាំងដប់ពីរនៃជនជាតិអ៊ីស្រាអែល
មានន័យថា
លោកបានផ្ញើបំណែកផ្សេងៗគ្នាទៅកាន់កុលសម្ព័ន្ធអ៊ីស្រាអែលតាមតំបន់ផ្សេងៗគ្នា។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានផ្ញើកំណាត់នីមួយៗទៅកន្លែងផ្សេងៗពេញទូទាំងអ៊ីស្រាអែល»។

generated on Wed Sep 10 16:16:32 2025

20

[1]ប្រជាជនអ៊ីស្រាអែលទាំងអស់បានប្រមូលគ្នាមកដូចជាមនុស្សតែម្នាក់ ចាប់ពីក្រុងដាន់រហូតដល់បៀសេបា រួមទាំងប្រជាជនពីទឹកដីកាឡាត
ហើយពួកគេមកប្រជុំគ្នានៅចំពោះព្រះអម្ចាស់នៅមីសប៉ា។
[2]ពួកមេដឹកនាំនៃកុលសម្ព័ន្ធទាំងប៉ុន្មានរបស់ប្រជាជនអ៊ីស្រាអែលក៏មានវត្តមាននៅក្នុងអង្គប្រជុំរបស់ព្រះអម្ចាស់ដែរ គឺមានពលថ្មើរជើងចំនួន
បួនសែននាក់ដែលប្រដាប់ដោយអាវុធ។
[3]កូនចៅបេនយ៉ាមីនបានទទួលដំណឹងថា ប្រជាជនអ៊ីស្រាអែលបានមកដល់មីសប៉ាហើយ។ ពេលនោះប្រជាជនអ៊ីស្រាអែលបានសួរថា៖
«ចូរប្រាប់យើងមកមើលតើឧក្រិដ្ឋកម្មនេះកើតឡើងយ៉ាងដូចម្តេច»។[4]បុរសលេវីជាប្តីរបស់ស្ត្រីដែលត្រូវបានសម្លាប់នោះឆ្លើយថា៖ «ខ្ញុំបានធ្វើដំណើរទៅគីបៀរ
នៅក្នុងទឹកដីបេនយ៉ាមីន ខ្ញុំនិងប្រពន្ធចុងរបស់ខ្ញុំបានសម្រាកនៅទីនោះ។
[5]នៅយប់នោះពួកមេដឹកនាំនៃគីបៀរបានមកវាយប្រហារខ្ញុំដោយឡោមព័ទ្ធផ្ទះដែលខ្ញុំស្នាក់នៅ និងចង់សម្លាប់ខ្ញុំផង។
ពួកគេបានចាប់រំលោភប្រពន្ធចុងរបស់ខ្ញុំរហូតដល់នាងស្លាប់។[6]ដូច្នេះ ខ្ញុំក៏យកសពរបស់នាងមកកាត់ជាកំណាត់ៗ ហើយផ្ញើទៅគ្រប់តំបន់នៅស្រុកអ៊ីស្រាអែលទាំងអស់
ព្រោះពួកគេបានប្រព្រឹត្តអំពើដ៏ឃោរឃៅបំផុតក្នុងទឹកដីអ៊ីស្រាអែល។[7]«ឥឡូវនេះ សូមបងប្អូនជាប្រជាជនអ៊ីស្រាអែលទាំងអស់ពិភាក្សាគ្នា ហើយសម្រេចចិត្តទៅចុះ»។
[8]ប្រជាជនអ៊ីស្រាអែលទាំងអស់បានក្រោកឡើងដូចមនុស្សតែម្នាក់ ពួកគេនិយាយថា៖ «នឹងមិនមានអ្នកណាម្នាក់ក្នុងចំណោមយើង ត្រឡប់ទៅទីលំនៅរបស់ខ្លួនវិញទេ
ទោះបីអ្នកនោះរស់ក្នុងតង់ឬជំរំក្តី!»[9]គឺយើងត្រូវប្រព្រឹត្តបែបនេះចំពោះពួកគេ គឺយើងត្រូវវាយប្រហារពួកគេដោយចាប់ឆ្នោត។
[10]យើងត្រូវជ្រើសរើសមនុស្សមួយភាគដប់ ពីកុលសម្ព័ន្ធទាំងប៉ុន្មាននៃជនជាតិអ៊ីស្រាអែល ដើម្បីឲ្យគេទទួលខុសត្រូវក្នុងការរកស្បៀងអាហារសម្រាប់ពលទ័ព
ដែលចេញទៅវាយពួកបេនយ៉ាមីននៅក្រុងគីបៀរ ដើម្បីដាក់ទណ្ឌកម្មពួកគេសម្រាប់អំពើឃោរឃៅដែលពួកគេបានប្រព្រឹត្តក្នុងទឹកដីអ៊ីស្រាអែល»។[11]ដូច្នេះ
ប្រជាជនអ៊ីស្រាអែលទាំងមូលមានចិត្តតែមួយលើគ្នាប្រឆាំងនឹងអ្នកក្រុងគីបៀរ។
[12]កុលសម្ព័ន្ធទាំងឡាយនៃជនជាតិអ៊ីស្រាអែលបានបញ្ជូនអ្នកនាំសារទៅកាន់គ្រប់អំបូរទាំងអស់នៃកុលសម្ព័ន្ធបេនយ៉ាមីន ហើយសួរថា៖
«ហេតុអ្វីបានជាមានប្រព្រឹត្តអំពើអ្វីឃោរឃៅយ៉ាងដូច្នេះ ក្នុងចំណោមអ្នករាល់គ្នា?[13]ឥឡូវនេះចូរប្រគល់មនុស្សឃោរឃៅទាំងនោះមក ដើម្បីឲ្យយើងសម្លាប់ពួកគេ
និងបោសសម្អាតការអាក្រក់ទាំងឡាយចេញពីចំណោមប្រជាជនអ៊ីស្រាអែល»។ ប៉ុន្តែ ពួកបេនយ៉ាមីនមិនស្តាប់សម្តីជនជាតិអ៊ីស្រាអែលដែលជាបងប្អូនរបស់ពួកគេនោះទេ
។[14]កូនចៅបេនយ៉ាមីនទាំងអស់បានប្រមូលផ្តុំគ្នានៅគីបៀរដើម្បីប្រឆាំងជាមួយនឹងប្រជាជនអ៊ីស្រាអែលទាំងអស់។
[15]នៅថ្ងៃនោះទាហានបេនយ៉ាមីនដែលគេកេណ្ឌមកពីក្រុងនានាដែលប្រដាប់ដោយអាវុធ មានចំនួនពីរម៉ឺនប្រាំមួយពាន់នាក់
ដោយមិនរាប់បញ្ចូលទាហានដ៏ជំនាញប្រាំពីររយនាក់ទៀតដែលពួកគេជ្រើសរើសមកពីក្រុងគីបៀរនោះទេ។
[16]ក្នុងចំណោមទាហានទាំងនោះមានប្រាំពីររយនាក់ជាទាហានជំនាញៗ ដែលពួកគេប្រើដៃឆ្វេង។ អ្នកទាំងនោះអាចប្រើដង្ហក់ចោលគ្រាប់គ្រួស
ដែលសូម្បីតែសក់មួយសរសៃក៏ពួកគេចោលមិនខុសដែរ។
[17]រីឯទាហានរបស់កុលសម្ព័ន្ធអ៊ីស្រាអែលផ្សេងៗទៀតដោយមិនរាប់បញ្ចូលពួកបេនយ៉ាមីន សរុបមានចំនួន សែសិបម៉ឺននាក់ដែលប្រដាប់ដោយអាវុធ
និងសុទ្ធតែជាអ្នកចម្បាំងដ៏ជំនាញ។[18]ប្រជាជនទាំងអស់បានចុះទៅ បេតអែល ហើយទូលសួរព្រះអម្ចាស់ថា៖ «តើក្នុងចំណោមយើង
អ្នកណាត្រូវចេញទៅច្បាំងនឹងពួកបេនយ៉ាមីនមុនគេ?» ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «កុលសម្ព័ន្ធយូដាត្រូវចេញទៅមុនគេ»។
[19]ជនជាតិអ៊ីស្រាអែលទាំងអស់បានក្រោកពីព្រលឹម នាំគ្នាទៅបោះទ័ពក្បែរគីបៀរ។[20]បន្ទាប់មក ពួកគេចេញទៅច្បាំងជាមួយនឹងពួកបេនយ៉ាមីន
ដោយបោះជំរំទ័ពទល់មុខគីបៀរ។[21]នៅថ្ងៃនោះ កូនចៅបេនយ៉ាមីនបានចេញពីគីបៀរមកហើយសម្លាប់សត្រូវរបស់គេគឺកូនចៅអ៊ីស្រាអែល អស់ពីរម៉ឺនពីរពាន់នាក់។
[22]ប៉ុន្តែ ទាហានអ៊ីស្រាអែលបានពង្រឹងទឹកចិត្តគេឡើងវិញ ហើយបោះទីតាំងទ័ពនៅកន្លែងដដែល ដែលគេបានបោះនៅថ្ងៃដំបូង។[23]បន្ទាប់ពី
កូនចៅអ៊ីស្រាអែលបានឡើងទៅយំសោកចំពោះព្រះអម្ចាស់រហូតដល់ល្ងាច ដោយទូលសួរទ្រង់ថា៖ «តើទូលបង្គំរាល់គ្នាត្រូវទៅច្បាំងនឹងពួកបេនយ៉ាមីន
ជាបងប្អូនទូលបង្គំទៀតឬ?» ព្រះអម្ចាស់មានបន្ទូលថា៖ «ចូរឡើងទៅវាយគេចុះ!»។
[24]ដូច្នេះ ជនជាតិអ៊ីស្រាអែលក៏វាយលុកពួកបេនយ៉ាមីននៅថ្ងៃទីពីរ។[25]នៅថ្ងៃនោះ ពួកបេនយ៉ាមីនបានចេញទៅច្បាំងជាមួយជនជាតិអ៊ីស្រាអែល
ហើយសម្លាប់ជនជាតិអ៊ីស្រាអែលអស់មួយម៉ឺនប្រាំបីពាន់នាក់ ដែលពួកគេសុទ្ធសឹងតែជាទាហានប្រដាប់ដោយដាវ។
[26]ដូច្នេះ ទាហាននិងប្រជាជនអ៊ីស្រាអែលទាំងអស់បានទៅឯបេតអែល ហើយយំសោក ពួកគេអង្គុយនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ហើយតមអាហាររហូតដល់ល្ងាច
ទើបពួកគេថ្វាយតង្វាយដុតទាំងមូល និងជាយញ្ញបូជាមេត្រីភាពនៅចំពោះព្រះអម្ចាស់។
[27]ប្រជាជនអ៊ីស្រាអែលទូលសួរព្រះអម្ចាស់ ដ្បិតកាលនោះ ហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់នៅបេតអែល[28]កាលគ្រានោះ លោកភីនេហាស កូនប្រុសលោកអេឡាសា
និងជាចៅរបស់លោកអ៊ីរ៉ុន ជាអ្នកបម្រើព្រះអង្គនៅទីនោះ គេសួរព្រះអង្គថា៖ «តើយើងត្រូវចេញទៅច្បាំងនឹងពួកបេនយ៉ាមីនជាបងប្អូនរបស់យើងទៀត ឬត្រូវឈប់?»
ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ចូរទៅចុះ ថ្ងៃស្អែកយើងនឹងប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នករាល់គ្នា»។
[29]ជនជាតិអ៊ីស្រាអែលបានដាក់មនុស្សឲ្យលាក់ខ្លួនជុំវិញក្រុងគីបៀរ។[30]នៅថ្ងៃទីបីពួកគេក៏បានបោះទីតាំងទ័ព នៅទល់មុខគីបៀរដូចពីមុន ហើយច្បាំងនឹងពួកបេនយ៉ាមី។
[31]ពេលនោះ កូនចៅបេនយ៉ាមីនបានចេញមកប្រយុទ្ធនឹងជនជាតិអ៊ីស្រាអែល ហើយទ័ពអ៊ីស្រាអែលបាននាំពួកគេទៅឆ្ងាយពីទីក្រុង។ ពួកបេនយ៉ាមីន
បានសម្លាប់ជនជាតិអ៊ីស្រាអែលដូចពេលមុន គឺគេសម្លាប់មនុស្សអស់សាមសិបនាក់ នៅក្នុងស្រែ និងតាមផ្លូវទៅបេតអែល ព្រមទាំងតាមផ្លូវទៅក្រុងគីបៀរ។
[32]នោះ កូនចៅបេនយ៉ាមីនពោលឡើងថា៖ «មើល៍! ពួកវាបាត់ទ័ពហើយរត់ពីមុខយើងដូចគ្រាមុនអ៊ីចឹង» ប៉ុន្តែ ទាហានអ៊ីស្រាអែលបាននិយាយថា៖ «តោះ
ពួកយើងរត់ទៅដើម្បីបញ្ឆោតពួកវាឲ្យចេញឆ្ងាយពីក្រុង»។[33]កងទ័ពអ៊ីស្រាអែលទាំងអស់បានចេញមកពីកន្លែងរបស់គេរៀងៗខ្លួន មកផ្តុំគ្នានៅបាល-តាម៉ារ
រីឯទាហានដែលបង្កប់ខ្លួនក៏ស្ទុះចេញមកពីកន្លែងលាក់ខ្លួននៅត្រង់វាលទំនាបគីបៀរ។
[34]ទាហានជំនាញៗចំនួនមួយម៉ឺននាក់ ដែលបានជ្រើសរើសពីចំណោមទាហានអ៊ីស្រាអែលទាំងមូល បានលោកគ្នាមកដល់មុខគីបៀរ ប៉ុន្តែ ពួកបេនយ៉ាមីន
មិនបានដឹងនោះទេថាមហន្តរាយកំពុងចូលមកគៀកខ្លួនពួកគេនោះទេ។[35]ព្រះអម្ចាស់បានធ្វើឲ្យកូនចៅបេនយ៉ាមីន បាក់ទ័ពនៅចំពោះមុខអ៊ីស្រាអែល។ នៅថ្ងៃនោះ
ទាហានអ៊ីស្រាអែលបានសម្លាប់ទាហានបេនយ៉ាមីនអស់ ពីរម៉ឺនប្រាំពាន់មួយរយនាក់ ពួកគេសុទ្ធសឹងជាទាហានដែលប្រដាប់ដោយអាវុធ។
[36]ដូច្នេះ កូនចៅបេនយ៉ាមីន បានដឹងខ្លួនថាពួកគេចាញ់ហើយ
ជនជាតិអ៊ីស្រាអែលដែលបានរត់នោះដោយសារគេបានទុកចិត្តដល់ទាហានដែលបង្កប់ខ្លួននៅខាងក្រៅក្រុងគីបៀរ។
[37]បន្ទាប់មកអស់អ្នកដែលលាក់ខ្លួនបានស្ទុះចេញមកហើយសម្រុកចូលទៅក្នុងក្រុង ហើយពួកគេបានចាប់យកទីក្រុង និងសម្លាប់រង្គាលអ្នកក្រុងនោះទៀតផង។
[38]កងទ័ពអ៊ីស្រាអែលទាំងមូល និងពួកទាហានវាយឆ្មក់ដែលបានបង្កប់ខ្លួនបានធ្វើការសន្មត់គ្នា នៅពេលដែលមានផ្សែងហុយហើរឡើងពីទីក្រុង។
[39]នោះកងទ័ពដែលរត់នៅខាងមុខពួកបេនយ៉ាមីន ត្រូវរត់ត្រឡប់ក្រោយវិញ។ ពួកបេនយ៉ាមីនបានដេញតាមអ៊ីស្រាអែល ហើយសម្លាប់ទាហានអស់សាមសិបនាក់
ហើយពួកគេគិតថា «មើល៍! ពួកវាបាក់ទ័ពនៅចំពោះមុខយើងដូចពីមុនទៀតហើយ»។
[40]នៅពេលដែលផ្សែងខ្មួលខ្មាញ់ហើយចេញពីក្រុង ពួកបេនយ៉ាមីនងាកក្រោយហើយឃើញផ្សែងខ្មួលខ្មាញចេញពីក្រុងទាំងមូល។
[41]ពេលនោះកងទ័ពអ៊ីស្រាអែលបានត្រឡប់ក្រោយមកច្បាំងជាមួយពួកគេ។ កូនចៅបេនយ៉ាមីភ័យតក់ស្លុតយ៉ាងខ្លាំង ដោយឃើញមហន្តរាយចូលមកដល់ពួកគេ។
[42]ដូច្នេះ ពួកគេបានរត់គេចពីជនជាតិអ៊ីស្រាអែល សំដៅទៅរកវាលរហោស្ថាន។ ប៉ុន្តែ ទាហានអ៊ីស្រាអែលដែលរត់នោះបានត្រឡប់មកលើពួកគេ
ហើយទាហានវាយឆ្មក់ក៏បានចេញពីទីក្រុងមក និងបានសម្លាប់ពួកគេនៅទីនោះ។

generated on Wed Sep 10 16:16:32 2025

[43]ពួកគេបានឡោមព័ទ្ធពួកបេនយ៉ាមីននិងដេញតាមសម្លាប់ពួកគេ ចុះទៅណូអា រហូតដល់ខាងកើតក្រុងគីបៀរ។[44]ទានហានរបស់បេនយ៉ាមីន សុទ្ធតែខ្លាំងពូកែ
បានបាត់បង់ជីវិតអស់មួយម៉ឺនប្រាំបីពាន់នាក់។
[45]មានពួកទាហានបេនយ៉ាមីនដែលរត់គេចសំដៅទៅវាលរហោស្ថាន តាមផ្លូវទៅផ្នាំងថ្ម រីមម៉ូន ត្រូវបានជនជាតិអ៊ីស្រាអែលសម្លាប់អស់ ប្រាំពាន់នាក់។ ជនជាតិអ៊ីស្រាអែល
បន្តដេញតាមពួកគេរហូតដល់គីដូន ហើយសម្លាប់បានពីរពាន់នាក់ទៀត។[46]ទាហានចំណានៗរបស់បេនយ៉ាមីនដែលបានបាត់បង់ជីវិតនៅថ្ងៃនោះ មានចំនួន
ពីរម៉ឺនប្រាំពាក់នាក់។
[47]ប៉ុន្តែ ទាហានប្រាំមួយពាន់អ្នកបានរត់រួចទៅដល់ផ្នាំងថ្ម រីមម៉ូន ហើយពួកគេបានរស់នៅទីនោះអស់រយៈពេលបួនខែ។
[48]ទាហានអ៊ីស្រាអែលបានត្រឡប់ទៅវិញប្រយុទ្ធជាមួយពួកបេនយ៉ាមីនដែលនៅសល់ ហើយប្រហារពួកគេដោយមុខដាវ ទាំងមនុស្ស ទាំងសត្វ
ព្រមទាំងសម្បត្តិគ្រប់យ៉ាងដែលគេបានជួប ពួកគេក៏ដុតកម្ទេចទីក្រុងទាំងប៉ុន្មានដែលនៅទីនោះចោលទៀតផង។

Judges 20:1

ដូចជាមនុស្សតែម្នាក់

ការនិយាយបៀបធៀបនេះ និយាយជាក្រុមតែសម្មភាពមនុស្សតែម្នាក់។
វាសំដៅលើមនុស្សដែលធ្វើអ្វីៗគ្រប់យ៉ាងដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«បៀបដូចជាមនុស្សម្នាក់»។

ចាប់ពីក្រុងដាន់រហូតដល់បៀសេបា

ឃ្លានេះសំដៅលើទឹកដីទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីគ្រប់ទាំងដប់មួយកុលសម្ព័ន្ធ»។

ព្រះជាម្ចាស់ - មានពលថ្មើរជើងចំនួន បួនសែននាក់

ព្រះជាម្ចាស់ - មានពលថ្មើរជើងចំនួន ៤00,000នាក់»។

រួចជាស្រេចដើម្បីប្រយុទ្ធ

«រួចរាល់នឹងចេញទៅធ្វើសង្គ្រាម»។ ពួកគេនឹងច្បាំងរវាងគ្នានឹងគ្នា។

Judges 20:3

ឥឡូវ

ប្រើនៅទីនេះ ដើម្បីបញ្ជាក់ពីការសម្រាកពីសាច់រឿងចម្បង។ នៅត្រង់នេះ
អ្នកនិពន្ធសៀវភៅនេះប្រាប់ព័ត៌មានពីសាវតារបស់ប្រជាជនបេនយ៉ាមីនបានដឹង។

បានឡើងទៅដល់មីសប៉ា

មីសប៉ាមានទីតាំងនៅលើភ្នំ។

សម្រាកនៅពេលយប់

«មួយយប់» ឬ «ស្នាក់នៅមួយយប់»។

Judges 20:5

បានប្រព្រឹត្តអំពើយង់ឃ្នង និង គួរឲ្យស្អប់ខ្ពើមបំផុត

ពាក្យ «អំពើយង់ឃ្នង» ពណ៌នាពី «អំពើអាក្រក់» របៀបផ្សេងទៀតនៃការបកប្រែ:
«បានប្រព្រឹត្តអំពើដ៏ឃោរឃៅបំផុត»។

ឥឡូវនេះ

ពាក្យនេះ ប្រើដើម្បីណែនាំពីការសរុបសេចក្តីរបស់លេវី។

ផ្តល់នូវយោបល់និងពិភាក្សាគ្នានៅទីនេះចុះ

ពាក្យ «ឲ្យយោបល់» និង «ប្រឹក្សា» សំដៅលើន័យតែមួយ
ហើយនិយាយដដែលៗដើម្បីបញ្ជាក់ន័យ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សម្រេចចិត្តថាយើងត្រូវធ្វើដូចម្តេចទាក់ទងនឹងរឿងនេះ។

Judges 20:8

តែម្នាក់

ការនិយាយបៀបធៀបនេះ និយាយជាក្រុមតែសកម្មភាពមនុស្សតែម្នាក់។
ពួកគេទាំងអស់គ្នាមានប្រត្តិកម្មដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«បៀបដូចជាមនុស្សម្នាក់»។

នឹងមិនមានអ្នកណាម្នាក់ក្នុងចំណោមយើង

ត្រឡប់ទៅទីត្រសាលរបស់គេ...ហើយក៏មិនមានអ្នកណាត្រឡប់ទៅលំនៅរបស់គេវិញដែរ

ឃ្លាទាំងពីរនេះ និយាយរឿងដូចគ្នាពីរដង ដើម្បីបញ្ជាក់ន័យ។
ឃ្លាទាំងពីរនេះអាចរួមបញ្ចូលគ្នាបាន។ «ត្រឡប់ទៅ»...«ត្រឡប់ទៅ» ដើម្បីបញ្ជាក់
ពីការដដែលមនុស្សបន្តនៅទីនោះ។ ពួកគអាចនិយាយក្នុងទម្រង់វិជ្ជមាន។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងទាំងអស់គ្នានឹងស្នាក់»។

ប៉ុន្តែឥឡូវនេះ

ពាក្យនេះ
ណែនាំសាច់រឿងសំខាន់នៃអ្វីដែលមនុស្សនិយាយបន្ទាប់ពីបាននិយាយហើយ។

ចាប់ឆ្នោត

ទាក់នឹងការបង្ខិល ឬបោះថ្ម ដើម្បីធ្វើតាមអ្វីដែលព្រះជាម្ចាស់ចង់បាន។

Judges 20:10

យើងត្រូវជ្រើសរើសមនុស្សដប់នៃមួយរយ...មួយរយនៃមួយពាន់...និងមួយពាន់នៃមួយម៉ឺន

«១0 នៃ ១00 ...១00 នៃ ១,000... ១,000 នៃ ១0,000»។

ទទួលខុសត្រូវ

«អាហារ» និង «សម្ភារផ្សេងៗ» ។

ប្រមូលផ្តុំគ្នាប្រឆាំងនឹងទីក្រុង

«ប្រមូលផ្តុំគ្នាប្រឆាំងនឹងទីក្រុង»។

Judges 20:12

នឹងដាក់គេទៅក្នុងសេចក្តីស្លាប់

នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «សម្លាប់ពួកគេ»
«ប្រហារជីវិតពួកគេ»

ស្តាប់សម្លេងបងប្អូនរបស់ពួកគេនោះទេ

ពាក្យ «សម្លេង» នៅទីនេះ សំដៅលើសារដែលពួកគេនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលបងប្អូនរបស់ពួកគេនិយាយ»។

Judges 20:15

ពីរម៉ឺនប្រាំមួយពាន់នាក់

ប្រាំមួយពាន់នាក់ «២៦,000»។

ប្រាំពីររយនាក់

«៧,0ooនាក់»

ដៃឆ្វេង

ដៃឆ្វេង - ដៃឆ្វេងរបស់មនុស្សម្នាក់ដែលជំនាញខាងដៃឆ្វេងនោះ
ជាងដៃស្តាំរបស់ពួកគេ។

អាចប្រើដង្ហក់ចោលគ្រាប់គ្រួស ដែលសូម្បីតែសក់មួយសរសៃក៏ពួកគេចោលមិនខុសដែរ។

នេះបង្ហាញពីភាពអស្ចារ្យ ដែលពួកគេអាចគប់ចំរបស់ដែលគេចង់គប់។
ឃ្លានេះអាចនិយាយក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អាចចោលគ្រាប់គ្រួសទៅលើអ្វីមួយដែលតូចប៉ុនសរសៃសក់ ហើយប៉ះវា»។

Judges 20:17

មិនរាប់បញ្ចូល

«មិនបូកបញ្ចូល»

បានទូលសូមយោបល់ពីព្រះ

«បានទូលទៅព្រះជាម្ចាស់អ្វីដែលត្រូវធ្វើ» ឬ
«បានទូលសូមដល់ព្រះជាម្ចាស់ថាត្រូវបន្តយ៉ាងដូចម្តេច»។

Judges 20:19

ពួកគេផ្លាស់ជំរំរបស់ពួកគេទៅក្បែរគីបៀរ

មានសំណួរខ្លះទាក់ទងនឹងអត្ថបទរបស់ភាសាហេព្រើរ។
ជំនួសឲ្យអត្ថន័យដែលពួកគេសង់ជំរំរបស់ពួកគេនៅជិតគីបៀរ មានន័យថា
ទាហានបានចេញទៅ
ហើយបានឈរជើងនៅគីបៀរដើម្បីប្រយុទ្ធរួចបាត់ទៅហើយ។

ពីរម៉ឺនពីរពាន់នាក់

ពីរពាន់នាក់ - «២២,000»

Judges 20:22

បានពង្រឹងខ្លួនរបស់គេ

ពាក្យ «ពង្រឹងកម្លាំង» នេះគឺជាគ្រាមភាសា ដែលមានន័យថា
ពួកគេលើកទឹកចិត្តគ្នាទៅវិញទៅមក។

គេបានបោះទីតាំងទ័ព

នេះប្រហែលជាមានន័យថា អ៊ីស្រាអែលបានរៀបចំខ្សែប្រយុទ្ធ
ដើម្បីថ្ងៃប្រយុទ្ធរួចហើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេរួចរាល់នឹងប្រយុទ្ធនៅថ្ងៃស្អែកហើយ» (UDB)។

ពួកគេសូមការតម្រង់ពីព្រះជាម្ចាស់

ពួកគេមិនបានបញ្ជាក់ពីវិធីសាស្ត្រដែលពួកគេបានប្រើទេ។
បូជាចារ្យអាចចាប់ឆ្នោតដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

Judges 20:24

generated on Wed Sep 10 16:16:32 2025

មួយម៉ឺនប្រាំបីពាន់នាក់
«១៨,០០០នាក់»
Judges 20:26
នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់
«នៅចំពោះព្រះវត្តមានរបស់ព្រះអម្ចាស់» ឬ «នៅចំពោះព្រះអម្ចាស់»។
Judges 20:27
ហិបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់...អ្នកបម្រើនៅចំពោះហិបនៃសម្ពន្ធមេត្រីនៅសម័យនោះ
នេះគឺជាព័ត៌មានពីប្រវត្តិដែលអ្នកនិពន្ធបានបញ្ចូល ដើម្បីជួយអ្នកអានឲ្យយល់ពីរបៀបនៃការទូលសូមដល់ព្រះយ៉ាងដូចម្តេច ដើម្បីព្រះអម្ចាស់អាចឆ្លើយបាន។
នៅទីនោះ
«គឺនៅបេតអែល នៅក្នុងគ្រានោះ»។
ជាអ្នកបម្រើនៅចំពោះហិបនៃសម្ពន្ធមេត្រី
អត្ថន័យពេញរបស់ប្រយោគនេះអាចបញ្ជាក់ន័យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បម្រើនៅចំពោះហិបក្នុងនាមជាបូជាចារ្យ»។ ។
វាយប្រហារ
អត្ថន័យពេញរបស់ប្រយោគនេះអាចបញ្ជាក់ន័យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «វាយប្រហារទាហានរបស់បេនយ៉ាមីន»។
Judges 20:29
អ៊ីស្រាអែលបានដាក់មនុស្ស
ពាក្យ «អ៊ីស្រាអែល» នៅត្រង់នេះ សំដៅលើប្រជាជនអ៊ីស្រាអែល។
របៀបផ្សេងមួយទៀតនៃការបកប្រែ: «ជនជាតិអ៊ីស្រាអែល»។
ជាសម្ងាត់នៅទីកន្លែង
«បង្កប់ខ្លួន»
Judges 20:31
ប្រយុទ្ធប្រឆាំងនឹងមនុស្សទាំងនេះ
អត្ថន័យពេញរបស់ប្រយោគនេះអាចបញ្ជាក់ន័យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រយុទ្ធប្រឆាំងនឹងប្រជាជនអ៊ីស្រាអែល»។
ពួកគេបានចុះទៅឆ្ងាយពីទីក្រុង
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនអ៊ីស្រាអែលបានកៀរពួកគេទៅក្រៅក្រុង»។
ពួកគេបានចាប់ផ្តើមសម្លាប់មនុស្សមួយចំនួន
អត្ថន័យពេញរបស់ប្រយោគនេះអាចបញ្ជាក់ន័យកាន់តែច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនបេនយ៉ាមីនចាប់ផ្តើមសម្លាប់ប្រជាជនអ៊ីស្រាអែលខ្លះ»។
Judges 20:32
ដូចគ្រាមុនអ៊ីចឹង
«ដូចគ្រាមុនអ៊ីចឹង» ឬ «ដូចពីរលើកដំបូងអ៊ីចឹង»។
បាល-តាម៉ារ
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
នៅវាលទំនាបគីបៀរ
នេះគឺជាឈ្មោះរបស់ទីកន្លែង។ ការបកប្រែផ្សេងទៀតអាចប្រែថា «នៅវាលទំនាបគីបៀរ» ឬ «ភាគខាងលិចនៃគីបៀរ» ឬ «ម៉ាអារេស គេបា»។
Judges 20:34
ចំនួនមួយម៉ឺននាក់
«១0,000»
បានជ្រើសរើសពីចំណោមទាហាន
នេះគឺជាគ្រាមភាសាដែលមានន័យថា ជាទាហានល្អៗ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទាហានដែលហ្វឹកហាត់យ៉ាងល្អ»។
មហន្តរាយកំពុងចូលមកជៀកខ្លួនពួកគេ
មហន្តរាយនៅជិតបង្កើយគឺនិយាយអំពីទាហានឈរនៅជិតពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងចាញ់សង្គ្រាមទាំងស្រុង»។
Judges 20:36
ជនជាតិអ៊ីស្រាអែលដែលបានរត់នោះ
ដោយសារគេបានទុកចិត្តដល់ទាហានដែលបង្កប់ខ្លួននៅខាងក្រៅក្រុងគីបៀរ
ពីប្រយោគនេះ រហូតដល់ចុងបញ្ចប់នៃខ៤១
គឺជាព័ត៌មានអំពីប្រវត្តិដែលអ្នកនិពន្ធបញ្ចូល ដើម្បីពន្យល់ដល់អ្នកអានពីរបៀបដែលពួកគេពួនយកឈ្នះលើប្រជាជនបេនយ៉ាមីន។
បានថយចេញពីពួកបេនយ៉ាមីន
នេះគឺជាគ្រាមភាសាដែលមានន័យថា ពួកគេចង់ដកថយ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានអនុញ្ញាតឲ្យបេនយ៉ាមីនធ្វើដំណើរទៅមុខ»។
ដោយសារគេបានទុកចិត្តដល់ទាហានដែលបង្កប់ខ្លួន
នេះគឺជាគ្រាមភាសាដែលមានន័យថា ពួកគេទុកចិត្តទាហានរបស់ពួកគេ។
Judges 20:39
ព័ត៌មានទូទៅ
ខនេះបន្តផ្តល់ព័ត៌មានពីប្រវត្តិដែលអ្នកនិពន្ធបញ្ចូលដើម្បីពន្យល់អ្នកអានពីការវាយឆ្មក់យកឈ្នះលើបេនយ៉ាមីន។
នឹងត្រឡប់ពីសមរភូមិវិញ។
«នឹងត្រឡប់មកប្រយុទ្ធវិញ។
ពួកគេពិតជាបាក់ទ័ពនៅចំពោះមុខយើង
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានយកឈ្នះលើពួកគេ»។
Judges 20:40
ព័ត៌មានទូទៅ
ខនេះបន្តផ្តល់ព័ត៌មានពីប្រវត្តិដែលអ្នកនិពន្ធបញ្ចូលដើម្បីពន្យល់អ្នកអានពីការវាយឆ្មក់យកឈ្នះលើបេនយ៉ាមីន។
ភាពមហន្តរាយ
«ខូចបង់ជាខ្លាំង» ឬ «មានបញ្ហា» ឬ «ទុក្ខលំបាក»។
មកដល់ពួកគេ
នេះគឺជាគ្រាមភាសា មានន័យថា វាបានកើតឡើងលើពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានកើតឡើងលើពួកគេ»។
Judges 20:42
ប៉ុន្តែ ការវាយប្រហារបានធ្លាក់មកលើពួកគេ។
ឃ្លានេះនិយាយពីការប្រយុទ្ធ
ប្រៀបដូចជាមនុស្សម្នាក់ដែលអាចយកឈ្នះលើមនុស្សម្នាក់ទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
ទាហានរបស់អ៊ីស្រាអែលបានដេញតាមពួកគេ» ឬ «ប៉ុន្តែ
ពួកគេមិនអាចគេចផុតពីការវាយប្រហារបានទេ»។
Judges 20:43
ណូហា
នេះគឺជាឈ្មោះរបស់ទីកន្លែង
ដេញតាមនិងជាន់ឈ្លីពួកគេ
បានបំផ្លាញពួកបេនយ៉ាមីនទាំងស្រុង
គឺនិយាយដូចជាជនជាតិអ៊ីស្រាអែលឡើងជាន់លើរូបកាយរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបំផ្លាញពួកបេនយ៉ាមីនទាំងស្រុង»។
មួយម៉ឺនប្រាំបីពាន់នាក់
«១៨,000»
ពួកគេសុទ្ធតែល្បីល្បាញក្នុងសមរភូមិ
«បានប្រយុទ្ធយ៉ាងក្លាហាននៅក្នុងសមរភូមិ»។
Judges 20:45
ពួកគេបានត្រឡប់ ហើយរត់គេច
«ពួកបេនយ៉ាមីនដែលនៅសល់បានត្រឡប់ ហើយរត់ទៅ»
ប្រាំពាន់នាក់...ពីរពាន់នាក់
«៥,000 ... ២,000»
គីដូម
នេះគឺជាឈ្មោះរបស់ទីកន្លែងមួយ។
ពីរម៉ឺនប្រាំពាក់នាក់
ប្រាំពាក់នាក់ - «២៥,000»
Judges 20:47
ប្រាំមួយរយ
«៦00»
បានត្រឡប់ទៅវិញប្រយុទ្ធជាមួយប្រជជនបេនយ៉ាមីន
ពួកបេនយ៉ាមីននេះមិនមែនជាទាហានដែលរត់ទៅផ្នាំងថ្មរីម៉ូន
ប៉ុន្តែមានអ្នកខ្លះនៅទីក្រុងដដែល។
ទីក្រុងទាំងប៉ុន្មាន
ពាក្យ «ទីក្រុង...» សំដៅមនុស្សដែលនៅក្នុងទីក្រុងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សគ្រប់គ្នាដែលនៅក្នុងទីក្រុង»។
ដែលគេប្រទះឃើញដែរ
នេះគឺជាគ្រាមភាសា សំដៅលើអ្វីៗដែលពួកគេបានរកឃើញ

generated on Wed Sep 10 16:16:32 2025

នៅពេលពួកគេចូលទៅកាន់ទីក្រុងនោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានចូលទៅ»។

21 [1]គ្រានោះ ប្រជាជនអ៊ីស្រាអែលបានជួបជុំគ្នានៅមីសប៉ា ហើយស្បថថា៖ «ក្នុងចំណោមយើង
មិនត្រូវឲ្យមានអ្នកណាលើកកូនស្រីខ្លួនអោយឲ្យពួកបេនយ៉ាមីនធ្វើជាប្រពន្ធទេ។»[2]ដូច្នេះ ពួកគេបានធ្វើដំណើរទៅបេតអែល ហើយអង្គុយនៅទីនោះរហូតដល់ល្ងាច
ទាំងយំសោកសង្រេងយ៉ាងខ្លាំង។[3]ពួកគេទូលថា៖ «ឱព្រះអម្ចាស់! ឱព្រះនៃជនជាតិអ៊ីស្រាអែលអើយ! ហេតុអ្វីបានជារឿងនេះកើតឡើងចំពោះអ៊ីស្រាអែល?
ហេតុអ្វីបានជាថ្ងៃនេះអ៊ីស្រាអែលត្រូវបាត់បង់កុលសម្ព័ន្ធដូច្នេះ?»។
[4]ស្អែកឡើង ប្រជាជនទាំងអស់ក្រោកពីព្រលឹមសង់អាសនៈនៅទីនោះ រួចថ្វាយតង្វាយដុតទាំងមូល និងយញ្ញបូជាមេត្រីភាព។[5]ប្រជាជនទាំងអស់ពោលឡើងថា៖
«ក្នុងចំណោមកុលសម្ព័ន្ធអ៊ីស្រាអែលទាំងមូល តើមានក្រុមណាមួយដែលមិនបានមកចូលរួមប្រជុំ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ នៅមីសប៉ានេះឬទេ?»
កាលដែលគេសួរដូច្នេះ ព្រោះពួកគេបានធ្វើការស្បថជាឧឡារិកថា ចំពោះអ្នកណាដែលមិនបានមករួមប្រជុំនៅមីសប៉ានេះថា៖ «អ្នកដែលមិនបានមកចូលរួមប្រជុំ
នឹងត្រូវសម្លាប់ជាប្រាកដ»។
[6]ជនជាតិអ៊ីស្រាអែល មានសេចក្តីស្តាយស្រណោះចំពោះកុលសម្ព័ន្ធបេនយ៉ាមីន ដែលជាបងប្អូនរបស់គេ ហើយនិយាយថា៖ «ថ្ងៃនេះកុលសម្ព័ន្ធមួយ
ត្រូវបានកាត់ចេញពីជនជាតិអ៊ីស្រាអែល។[7]តើអ្នកណានឹងរកប្រពន្ធឲ្យពួកគេដែលនៅរស់ ព្រោះថាយើងបានស្បថចំពោះព្រះអម្ចាស់ថា
យើងមិនលោកកូនស្រីរបស់យើងអោយធ្វើជាប្រពន្ធរបស់គេទេ?»
[8]ពួកគេឆ្លើយឡើងថា៖ «តើកុលសម្ព័ន្ធណាមួយដែលមិនបានឡើងមកប្រជុំនៅមីសប៉ា ចំពោះព្រះភក្ត្រព្រះអម្ចាស់?» គេរកឃើញថា មិនមានអ្នកណាម្នាក់ពីភូមិយ៉ាបេស
ក្នុងស្រុកកាឡាត បានមកចូលរួមប្រជុំទេ។[9]ព្រោះពេលដែលរាប់ចំនួនមនុស្សឲ្យមានរបៀបនោះ មិនឃើញមាននរណាម្នាក់ពីភូមិយ៉ាបេសនោះទេ។
[10]នោះអង្គប្រជុំបានចាត់មនុស្សដែលអង់អាចក្លាហានចំនួនមួយម៉ឺនពីរពាន់នាក់ ឲ្យទៅភូមិយ៉ាបេស ដោយបញ្ជាឲ្យប្រហារអ្នកភូមិយ៉ាបេស ក្នុងស្រុកកាឡាតទាំងមនុស្ស
ទាំងកូនក្មេងដោយមុខដាវ។
[11]គឺត្រូវធ្វើដូច្នេះ គឺត្រូវសម្លាប់មនុស្សប្រុសទាំងអស់ និងស្ត្រីដែលមានប្តីហើយ»។[12]ក្នុងចំណោមអ្នកភូមិយ៉ាបេស ស្រុកកាឡាត
គេឃើញមានស្ត្រីក្រមុំព្រហ្មចារីចំនួនបួនរយនាក់ ហើយពួកគេក៏នាំស្ត្រីក្រមុំទាំងនោះទៅជំរំស៊ីឡូ ក្នុងស្រុកកាណាន។
[13]បន្ទាប់មក អ្នកនាំសហគមន៍ទាំងមូលបានចាត់អ្នកនាំសារទៅប្រាប់កូនចៅបេនយ៉ាមីនដែលរស់នៅត្រង់ផ្នាំងថ្មរីម៉ូន នោះថា
អ៊ីស្រាអែលបានលើកលែងទោសឲ្យពួកគេហើយ។[14]ពេលនេះកូនចៅបេនយ៉ាមីន អាចត្រឡប់ទៅរស់នៅក្នុងភូមិរបស់គេបានវិញបាន
ហើយជនជាតិអ៊ីស្រាអែលបានប្រគល់ស្ត្រីអ្នកភូមិយ៉ាបេសឲ្យពួកគេជាប្រពន្ធ ប៉ុន្តែ មានចំនួនមិនគ្រប់គ្រាន់សម្រាប់ពួកគេនោះទេ។
[15]ជនជាតិអ៊ីស្រាអែលសោកស្តាយចំពោះកុលសម្ព័ន្ធបេនយ៉ាមីនណាស់ ព្រោះព្រះអម្ចាស់បានបំបាត់ពួកគេពីក្នុងកុលសម្ព័ន្ធអ៊ីស្រាអែល។
[16]ពួកមេដឹកនាំនៃសហគមន៍ទាំងមូល ពោលថា៖ «តើយើងធ្វើដូចម្តេចដើម្បីឲ្យពួកបេនយ៉ាមីនដែលនៅរស់ អាចមានប្រពន្ធ
ព្រោះថាស្ត្រីពួកបេនយ៉ាមីនត្រូវបានសម្លាប់អស់ហើយដូច្នេះ?»[17]ពួកគេនិយាយថា៖ «ពួកបេនយ៉ាមីនត្រូវបន្តពូជពង្សរបស់ខ្លួន
ដើម្បីកុំឲ្យកុលសម្ព័ន្ធនេះរលាយបាត់ពីជនជាតិអ៊ីស្រាអែល។
[18]យើងមិនអាចឲ្យកូនស្រីរបស់យើងរៀបការជាមួយពួកគេទេ ព្រោះយើងបានស្បថថា អ្នកណាដែលលើកកូនស្រីឲ្យធ្វើជាប្រពន្ធកូនចៅបេនយ៉ាមីន នឹងត្រូវបណ្តាសារ»។
[19]នោះពួកគេឆ្លើយថា៖ «តើអស់លោកដឹងទេថា យើងតែងតែប្រារព្ធពិធីបុណ្យមួយថ្វាយព្រះអម្ចាស់នៅស៊ីឡូជារៀងរាល់ឆ្នាំ» (ស៊ីឡូ មានស្ថិតនៅខាងជើងបេតអែល
ខាងត្បូងផ្លូវដែលភ្ជាប់ពីបេតអែលទីស៊ីគែម និងខាងត្បូងលេបូណា)»។
[20]ពួកគេបញ្ជាកូនចៅបេនយ៉ាមីនថា៖ «ចូរទៅលាក់ខ្លួន និងរង់ចាំក្នុងចម្ការទំពាំងបាយជូរ។[21]ឃ្លាំចាំមើល នៅពេលដែលមានស្ត្រីចេញពីស៊ីឡូមករាំលេង
អ្នករាល់គ្នាត្រូវស្ទុះចេញពីមកចម្ការទំពាំងបាយជូរ ហើយចាប់ពួកនាងទាំងនោះមួយម្នាក់ៗយកទៅទឹកដីរបស់អ្នករាល់គ្នាធ្វើជាប្រពន្ធចុះ។
[22]នៅពេលដែលឪពុក ឬបងប្រុសរបស់ពួកនាងមកប្តឹងយើង យើងនឹងអង្វរពួកគេ សូមមេត្តាអនុគ្រោះដល់កូនចៅបេនយ៉ាមីនផងចុះ!
ព្រោះនៅពេលដែលយើងទៅវាយប្រហារភូមិយ៉ាបេស យើងរកស្ត្រីមិនបានគ្រប់គ្រាន់ឲ្យធ្វើជាប្រពន្ធរបស់ពួកគេទេ។
ហើយអ្នករាល់គ្នាក៏មិនបានលើកកូនស្រីអោយទៅពួកគេដែរ ដូច្នេះ អ្នករាល់គ្នាមិនបានធ្វើខុសពាក្យសម្បថទេ»។
[23]កូនចៅបេនយ៉ាមីនក៏ធ្វើតាមការបង្គាប់។ គឺពួកគេបានចាប់ស្ត្រីក្នុងចំណោមស្ត្រីក្រមុំដែលចេញមករាំតាមចំនួនដែលពួកគេត្រូវការ ហើយនាំយកទៅជាមួយខ្លួន។
ពួកគេបានត្រឡប់ទៅកាន់ទឹកដីដែលជាមរតករបស់ពួកគេ ហើយសាងសង់ក្រុងឡើងវិញនិងរស់នៅទីនោះ។[24]បន្ទាប់មក ជនជាតិអ៊ីស្រាអែលបានចាកចេញពីទីនោះ
វិលត្រឡប់ទៅកុលសម្ព័ន្ធ ក្រុមគ្រួសារ និងទឹកដីជាមរតករបស់ពួកគេរៀងៗខ្លួនវិញ។
[25]ក្នុងគ្រានោះក្នុងស្រុកអ៊ីស្រាអែលមិនមានស្តេចសោយរាជ្យទេ។ គ្រប់គ្នាធ្វើអ្វីៗតាមដែលខ្លួនយល់ឃើញថាល្អ។

Judges 21:1

ឥឡូវ ប្រជាជនអ៊ីស្រាអែលបានធ្វើការសន្យា...ឲ្យរៀបការជាមួយពួកបេនយ៉ាមីន

នេះគឺជាព័ត៌មានអំពីប្រវត្តិដែលអ្នកនិពន្ធប្រាប់ដល់អ្នកអានអំពីសេចក្តីសន្យាដែលអ៊ីស្រាអែលបានសន្យានៅក្រុងមីសប៉ា

ពួកបេនយ៉ាមីន

នេះគឺជាឈ្មោះរបស់ពូជពង្សបេនយ៉ាមីន។

សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៣:១៥។

ឱព្រះអម្ចាស់! ឱព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែលអើយ!

ហេតុអ្វីបានជារឿងនេះកើតឡើងចំពោះអ៊ីស្រាអែល?

ហេតុអ្វីបានជាថ្ងៃនេះអ៊ីស្រាអែលត្រូវបាត់បង់កុលសម្ព័ន្ធដូច្នេះ?

ជនជាតិអ៊ីស្រាអែលប្រើសំណួរដែលមិនទាមទារចម្លើយនេះ
ដើម្បីបង្ហាញពីទុក្ខសោករបស់ពួកគេ។ សំណួរនេះអាចបកប្រែជាប្រយោគបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ឱ ព្រះអម្ចាស់អើយ
យើងខ្ញុំសោកស្តាយខ្លាំងណាស់
ដែលកុលសម្ព័ន្ធមួយរបស់ជនជាតិអ៊ីស្រាអែលត្រូវបំផ្លាញទាំងស្រុង»។

Judges 21:4

ប្រជាជនអ៊ីស្រាអែលបានពោលឡើងថា៖ «ក្នុងចំណោមកុលសម្ព័ន្ធអ៊ីស្រាអែលទាំងមូល

តើមានក្រុមណាមួយដែលមិនបានមកចូលរួមប្រជុំ នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់?

មនុស្សសំដៅលើប្រជាជនអ៊ីស្រាអែលដែលនៅក្រុង
មីសប៉ាមុនពេលពួកគេប្រយុទ្ធជាមួយពួកបេនយ៉ាមីន។

ដ្បិត

ពួកគេបានធ្វើការសន្យាដ៏សំខាន់មួយអំពីអ្នកណាដែលមិនបានមករកព្រះជាម្ចាស់នៅមីសប៉ានេះ។

[illegible]

នេះគឺជាព័ត៌មានពីប្រវត្តិ

ដើម្បីពន្យល់អ្នកអានពីសេចក្តីសន្យាដែលជនជាតិអ៊ីស្រាអែលបានសន្យានៅក្រុងមីសប៉ា
មុនពេលពួកគេប្រយុទ្ធជាមួយពួកបេនយ៉ាមីន។

គេនឹងត្រូវសម្លាប់ជាប្រាកដ

ពាក្យ «លោក» សំដៅលើមនុស្សគ្រប់គ្នាដែលមិនបានទៅក្រុងមីសប៉ា។

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងសម្លាប់អ្នកនោះចោល»។

Judges 21:6

ចំពោះបេនយ៉ាមីន ដែលជាបងប្អូនរបស់គេ

ពាក្យ «បេនយ៉ាមីន ដែលជាបងប្អូនរបស់គេ»
សំដៅលើពូជពង្សបេនយ៉ាមីនដែលនៅរស់។

កុលសម្ព័ន្ធមួយ ត្រូវបានកាត់ចេញពីអ៊ីស្រាអែល

ការបំផ្លាញកុលសម្ព័ន្ធបេនយ៉ាមីន
គឺនិយាយពីការកាត់ចោលពីអ៊ីស្រាអែលដូចកាំបិត។
របៀបផ្សេងទៀតនៃការបកប្រែ: «កាត់ចោលកុលសម្ព័ន្ធមួយចោល»។

នេះគឺជាការនិយាយបំផ្លើសដោយសារមនុស្ស៦០០នាក់នៅសល់។ ប៉ុន្តែ

generated on Wed Sep 10 16:16:32 2025

ស្ត្រីបេនយ៉ាមីនត្រូវគេសម្លាប់អស់ ដូច្នេះ នោះជាបញ្ហានៃអនាគតរបស់ពួកគេ។
តើអ្នកណាផ្តល់ប្រពន្ធឲ្យពួកគេដែលនៅរស់ ចាប់តាំងពីយើងបានស្បថចំពោះព្រះជាម្ចាស់ថា
យើងនឹងមិនអនុញ្ញាតអោយពួកគេណាម្នាក់រៀបការជាមួយកូនស្រីរបស់ទេ?
ជនជាតិអ៊ីស្រាអែលផ្តល់ប្រពន្ធសម្រាប់ពួកបេនយ៉ាមីនមួយចំនួនដែលនៅសល់
ប៉ុន្តែ សេចក្តីសន្យារបស់ពួកគេនៅក្រុងមីសម៉ាបានរារាំងពួកគេពីការធ្វើការនេះ។
Judges 21:8
យ៉ាបេស កាឡាត
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
ដ្បិត ពេលដែលរៀបចំនួនមនុស្សឲ្យមានរបៀបនោះ
«មនុស្សដែលបានចូលរួមប្រជុំនៅក្រុងមីសម៉ាជាអ្នកទទួលខុសត្រូវ»។
មិនមានប្រជាជនណាម្នាក់ពីភូមិយ៉ាបេស នៃស្រុកកាឡាត នៅទីនោះទេ
ឃ្លានេះ សំដៅលើអ្នកចូលរួមប្រជុំនៅក្រុងមីសប៉ា។ អត្ថន័យពេញនៃប្រយោគនេះ
អាចធ្វើឲ្យវាកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានប្រជាជនណាម្នាក់ពីភូមិយ៉ាបេស កាឡាត
មានវត្តមាននៅក្រុងមីសម៉ាទេ»។
មួយម៉ឺនពីរពាន់នាក់
«១២,000»
សម្លាប់ពួកគេ ទាំងមនុស្សស្រី ទាំងកូនក្មេង
នៅខបន្ទាប់នឹងរួមបញ្ចូល លើកលែងតែសេចក្តីណែនាំផ្សេងៗ។
Judges 21:11
យ៉ាបេស កាឡាត
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។ សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក
២១:៨។
រួមដំណេកជាមួយបុរស
នេះគឺជាពាក្យមានសុជីវធម៌សម្រាប់ទំនាក់ទំនងផ្លូវភេទ។
ចំនួនបួនរយនាក់
«ស្រីវ័យក្មេង៤០០នាក់»។
Judges 21:13
ផ្តល់សន្តិភាពឲ្យពួកគេ
«សន្តិភាព» ជានាមអរូប អាចនិយាយក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ចង់សាងសន្តិភាពជាមួយពួកគេ»។
យ៉ាបេស កាឡាត
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។ សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក
២១:៨។
មានចំនួនស្ត្រីមិនគ្រប់សម្រាប់ពួកគេនោះទេ
ប្រុសៗរបស់ពួកបេនយ៉ាមីនមានចំនួន៦០០នាក់
ហើយមានតែស្ត្រីបួនរយនាក់ពីក្រុងយ៉ាបេស កាឡាតតែប៉ុណ្ណោះ។
បានបំបែកពួកគេពីកុលសម្ព័ន្ធអ៊ីស្រាអែល
«បានធ្វើឲ្យកុលសម្ព័ន្ធអ៊ីស្រាអែលគ្មានការរួបរួម»។
Judges 21:16
ពួកបេនយ៉ាមីន
ឃ្លានេះ សំដៅលើពូជពង្សរបស់បេនយ៉ាមីន។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៣:១៥។
ស្ត្រីនៃបេនយ៉ាមីនត្រូវបានសម្លាប់អស់ហើយ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងសម្លាប់ស្ត្រីពួកបេនយ៉ាមីនអស់ហើយ»។
ដូច្នេះ កុលសម្ព័ន្ធនេះនឹងមិនត្រូវបំផ្លាញទេពីជនជាតិអ៊ីស្រាអែល។
ជនជាតិអ៊ីស្រាអែលគឺជាការនិយាយបំផ្លើស។
ពួកគេបានផ្តល់ប្រពន្ធបួនរយនាក់ឲ្យពួកបេនយ៉ាមិន ដូច្នេះ
កុលសម្ព័ន្ធនេះមិនត្រូវបំផ្លាញទាំងស្រុងទេ។
Judges 21:18
ប្រពន្ធបេនយ៉ាមីន
ពាក្យ បេនយ៉ាមីននៅទីនេះ សំដៅលើប្រុសៗរបស់កូនចៅបេនយ៉ាមីន។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាប្រពន្ធម្នាក់របស់មនុស្សនៅបេនយ៉ាមីន»។
ដែលស្ថិតនៅខាងជើងបេតអែល ខាងកើតនៃផ្លូវដែលឡើងពីប៊ែតអែលទៅស៊ីគែម
និងខាងត្បូងនៃលេបូណា
នេះគឺជាព័ត៌មានអំពីប្រវត្តិ ដើម្បីពន្យល់ដល់អ្នកអាន
ថាតើស៊ីឡូមានទីតាំងនៅត្រង់ណា។
លេបូណា
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
Judges 21:20
អ្នករាល់គ្នាគួរតែចាប់យកប្រពន្ធ... ត្រឡប់ទៅទឹកដីបេនយ៉ាមីនវិញចុះ
យល់ថាពួកបេនយ៉ាមីនបានយកស្រីទាំងនេះទៅរស់នៅក្នុងទឹកដីរបស់ពួកគេ។
អត្ថន័យពេញរបស់ប្រយោគនេះអាចបញ្ជាក់ច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាត្រូវចាប់យកស្រីៗនៅស៊ីឡូម្នាក់មួយ
ហើយយកនាងត្រឡប់ទៅទឹកដីបេនយ៉ាមីនវិញជាមួយអ្នករាល់ទៅ
ដើម្បីធ្វើជាប្រពន្ធរបស់អ្នករាល់គ្នា»។
Judges 21:22
សូមមេត្តាអនុគ្រោះ
ពាក្យ «សូមមេត្តា» គឺជានាមអរូប។ អាចនិយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមមេត្តាចំពោះយើងខ្ញុំ
និងចំពោះមនុស្សនៅកុលសម្ព័ន្ធបេនយ៉ាមីនផង»។
ព្រោះយើងរកប្រពន្ធមិនបានគ្រប់ឲ្យពួកគេម្នាក់ៗទេក្នុងកុំឡុងពេលសង្គ្រាម
អត្ថន័យពេញនៅក្នុងប្រយោគនេះអាចធ្វើឲ្យកាន់តែច្បាស់បាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយសារយើងមិនបានទទួលប្រពន្ធសម្រាប់ពួកគេ
ក្នុងពេលមានសង្គ្រាមនៅក្នុងក្រុងយ៉ាបេស កាឡាត»។
អ្នករាល់គ្នាមិនមានកំហុសទេ...មិនបានលើកកូនស្រីអោយទៅពួកគេដែរ»
ឃ្លានេះសំដៅលើមនុស្សដែលរស់នៅស៊ីឡូ។
ពួកគេបានបានស្ម័គ្រចិត្តលើកកូនពួកបេនយ៉ាមីនទេ ហេតុដូច្នេះហើយ
ពួកគេបានក្បត់ពាក្យសន្យារបស់ពួកគេឡើយ។
Judges 21:23
តាមចំនួនប្រពន្ធដែលពួកគេត្រូវការ
ឃ្លានេះសំដៅលើប្រពន្ធមួយសម្រាប់មនុស្សម្នាក់ នៅក្នុងពួកបេនយ៉ាមីនពីររយនាក់
ដែលមិនបានទទួលប្រពន្ធនៅក្រុងយ៉ាបេស កាឡាត។ (សូមមើល: ២១:១៣)
Judges 21:25
ក្នុងគ្រានោះ មិនមានស្តេចក្នុងស្រុកអ៊ីស្រាអែល
«អ៊ីស្រាអែលមិនទាន់មានស្តេចនៅឡើយទេ»។
ដែលខ្លួនយល់ឃើញថាត្រឹមត្រូវក្នុងភ្នែករបស់ខ្លួន
ពាក្យ «ភ្នែក» នៅទីនេះ តំណាងឲ្យការគិត និងយោបល់របស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលគេគិតថាត្រឹមត្រូវ»។

នាងរស់

1 [1]នៅជំនាន់ដែលពួកចៅហ្វាយដឹកនាំ ស្រុក មានកើតទុរ្ភិក្សយ៉ាងខ្លាំង ហើយកាលនោះមានបុរសម្នាក់ជាអ្នកភូមិបេថ្លេហិម ក្នុងស្រុកយូដា គាត់បាននាំប្រពន្ធ
និងកូនប្រុសទាំងពីរនាក់របស់គាត់ធ្វើដំណើរទៅរស់នៅក្នុងស្រុកម៉ូអាប់។[2]បុរសនោះមានឈ្មោះថា លោកអេលីម៉ាឡេក ហើយភរិយារបស់គាត់មានឈ្មោះថា
នាងណាអូមី។ កូនប្រុសទាំងពីររបស់គាត់គឺ លោកម៉ាឡូន និង លោកគីលីយ៉ូន ដែលគ្រួសារនេះជាអំបូរអេប្រាតា ក្នុងភូមិបេថ្លេហិមនៃស្រុកយូដា។
ពួកគេបានទៅដល់ស្រុកម៉ូអាប់ហើយរស់នៅទីនោះ។
[3]បន្ទាប់ពីលោកអេលីម៉ាឡេក ដែលជាស្វាមីរបស់ណាអូមីទទួលមរណភាពទៅ គាត់រស់នៅជាមួយកូនប្រុសទាំងពីររបស់គាត់។
[4]កូនប្រុសទាំងពីរបានយកស្ត្រីសាសន៍ម៉ូអាប់ធ្វើភរិយា ម្នាក់ឈ្មោះនាងអ័របា និងម្នាក់ទៀតឈ្មោះនាងរស់។ ពួកគេរស់នៅទីនោះអស់រយៈពេលប្រហែលដប់ឆ្នាំ។[5]បន្ទាប់មក
លោកម៉ាឡូន និងលោកគីលីយ៉ូនបានស្លាប់ទាំងពីរនាក់ ដោយទុកឲ្យនាងណាអូមីរស់នៅតែម្នាក់ឯងគ្មានប្តីគ្មានកូន។
[6]ពេលនោះ នាងណាអូមីបានសម្រេចចិត្តចាកចេញពីស្រុកម៉ូអាប់ ត្រឡប់ទៅស្រុកយូដា ជាមួយនឹងកូនប្រសារទាំងពីររបស់គាត់វិញ
ដោយគាត់បានឮគេនិយាយថាព្រះអម្ចាស់បានប្រណីសណ្តោសដល់ប្រជាជនរបស់ព្រះអង្គ ដោយប្រទានឲ្យពួកគេមានអាហារបរិភោគគ្រប់គ្រាន់។[7]ដូច្នេះ
នាងបានចាកចេញពីស្រុកដែលនាងធ្លាប់រស់នៅជាមួយនឹងកូនប្រសារទាំងពីរនាក់ ហើយធ្វើដំណើរតាមផ្លូវត្រឡប់ទៅស្រុកយូដាវិញ។

generated on Wed Sep 10 16:16:32 2025

[8]នាងណាអូមីនិយាយទៅកូនប្រសារទាំងពីររបស់គាត់ថា៖ «ចូរកូនៗត្រឡប់ទៅផ្ទះម្តាយរៀងៗខ្លួនវិញចុះ! សូមព្រះអម្ចាស់សម្តែងព្រះហឫទ័យសប្បុរសចំពោះនាង
ដូចដែលនាងធ្លាប់មានចិត្តសប្បុរសចំពោះកូនប្រុសរបស់ម្តាយដែលបានស្លាប់ទៅ ហើយនិងម្តាយដែរ។[9]សូមព្រះអម្ចាស់ប្រទានឲ្យមានប្តីថ្មី មានសុភមង្គល
ក្នុងគ្រួសាររៀងៗខ្លួនផងចុះ»។ បន្ទាប់មកគាត់ថើបលាពួកនាង ហើយគេទ្រហោយំទាំងអស់គ្នា។[10]កូនប្រសារទាំងពីរពោលទៅកាន់ម្តាយក្មេកថា៖ «ទេ!
ពួកយើងនឹងទៅជាមួយម៉ែ ជាមួយជនជាតិរបស់ម៉ែដែរ»។
[11]ប៉ុន្តែ នាងណាអូមីតបថា៖ «ចូរត្រឡប់ទៅវិញចុះកូនស្រី! ហេតុអ្វីកូនចង់ទៅជាមួយម្តាយ? តើម្តាយនៅអាចបង្កើតកូនប្រុស ដែលអាចរៀបការជាមួយពួកឯងបានឬ?
[12]ចូរត្រឡប់ទៅវិញចុះកូនស្រី! ចូរទៅតាមផ្លូវរៀងៗខ្លួន! ម្តាយចាស់ណាស់ហើយ មិនអាចមានប្តីទៀតបានទេ។ បើម្តាយនិយាយថា ម្តាយមានសង្ឃឹមមានប្តីនៅយប់នេះ
ហើយបង្កើតបានកូនប្រុស[13]តើនាងអាចនៅចាំរហូតដល់គេពេញវ័យបានទេ? តើសុខចិត្តរស់នៅដោយឥតមានប្តីយ៉ាងនេះឬ? ទេ! កូនស្រីម្តាយ ធ្វើដូច្នេះមិនបានទេ!
ព្រះអម្ចាស់ច្បាស់ជាងាកមកប្រឆាំងនឹងម្តាយ ធ្វើឲ្យម្តាយមានវាសនាជូរចត់ជាងកូនទាំងពីរទៅទៀត។
[14]ដូច្នេះ កូនប្រសារស្រីទាំងពីរក៏ទ្រហោយំសាជាថ្មី។ នាងអ័រប៉ាបានថើបលាម្តាយក្មេកទៅ ចំណែកឯនាងរស់វិញ នាងសម្រេចចិត្តនៅជាមួយម្តាយក្មេក។
[15]នាងណាអូមីនិយាយទៅកាន់នាងថា៖ «ចូរស្តាប់ម្តាយ! ប្អូនថ្លៃរបស់កូន នាងបានត្រឡប់ទៅជនជាតិរបស់នាង និងទៅបម្រើព្រះរបស់នាងវិញហើយ
ចូរកូនត្រឡប់ទៅជាមួយប្អូនស្រីរបស់កូនចុះ»។
[16]ប៉ុន្តែ នាងរស់បានតបថា៖ «សូមកុំឲ្យកូនចាកចេញពីអ្នកម្តាយឡើយ! ខ្ញុំនឹងទៅទីកន្លែងណាដែលអ្នកម្តាយទៅ! ខ្ញុំនឹងនៅកន្លែងដែលអ្នកម្តាយនៅដែរ!
ជនជាតិរបស់អ្នកម្តាយគឺជាជនជាតិរបស់កូន ព្រះជាម្ចាស់របស់អ្នកម្តាយ គឺជាព្រះជាម្ចាស់របស់កូន។[17]អ្នកម្តាយស្លាប់នៅទីណា កូនក៏ស្លាប់នៅទីនោះដែរ
ហើយគេនឹងបញ្ចុះសពកូននៅទីនោះ។ បើមិនពិតទេ សូមព្រះអម្ចាស់ដាក់ទោសមកលើកូនចុះ!»[18]ដោយឃើញនាងរស់ ប្តេជ្ញាចិត្តទៅជាមួយដូច្នេះ
នាងណាអូមីក៏ឈប់ប្រកែកនឹងនាង។
[19]ដូច្នេះ ទាំងពីរនាក់ក៏ធ្វើដំណើររហូតដល់ភូមិបេថ្លេហិម។ នៅពេលដែលពួកគេទៅដល់ នោះអ្នកស្រុកទាំងអស់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ស្ត្រីៗនិយាយគ្នាថា៖
«តើនេះគឺជាណាអូមីឬ?»[20]ប៉ុន្តែ គាត់ឆ្លើយទៅកាន់ពួកគេថា៖ «សូមកុំហៅខ្ញុំថា ណាអូមីទៀតអី! សូមហៅខ្ញុំថា «ម៉ារ៉ា» វិញ ដ្បិត
ព្រះអម្ចាស់ដ៏មានឫទ្ធានុភាពខ្លាំងបំផុតបានធ្វើឲ្យជីវិតរបស់ខ្ញុំជូរចត់យ៉ាងខ្លាំង។[21]ពេលខ្ញុំចាកចេញទៅ ខ្ញុំមានអ្វីគ្រប់យ៉ាង ប៉ុន្តែ ព្រះអង្គបានធ្វើឲ្យខ្ញុំទៅជាបាតដៃទទេ។
ដូច្នេះ ហេតុអ្វីបានជាអ្នកហៅខ្ញុំថា ណាអូមី! មើល៍ព្រះអម្ចាស់បានកាត់ទោសខ្ញុំ ព្រះដ៏មានឫទ្ធានុភាពខ្ពស់បំផុតបានធ្វើឲ្យខ្ញុំរងទុក្ខបំផុត»។
[22]ដូច្នេះ នាងណាអូមី និងនាងរស់ដែលជាសាសន៍ម៉ូអាប់ ត្រូវជាកូនប្រសារបានចាកចេញពីស្រុកម៉ូអាប់។ ពួកគេបានមកដល់ភូមិបេថ្លេហិមនៅដើមរដូវចម្រូត។

Ruth 1:1

វាបានកើតឡើង

វាជាអ្វីដែលបានកើតឡើង។ នេះជារបៀបទូទៅនៃការចាប់ផ្តើមរឿងរ៉ាវប្រវត្តិសាស្ត្រ។

នៅជំនាន់ដែលពួកចៅហ្វាយដឹកនាំ

«ក្នុងអំឡុងពេលដែលពួកចៅហ្វាយដឹកនាំ និងគ្រប់គ្រងអ៊ីស្រាអែល»

ក្នុងស្រុក

«នៅក្នុងទឹកដីអ៊ីស្រាអែល»

មានបុរសម្នាក់

«បុរសម្នាក់» នេះជារបៀបទូទៅមួយក្នុងការណែនាំតួអង្គក្នុងរឿងមួយ។

អេប្រាតា ក្នុងភូមិបេថ្លេហិមនៃស្រុកយូដា

ពួកគេជាប្រជាជនមកពីកុលសម្ព័ន្ធអេប្រាអ៊ីម
ដែលមកតាំងទីលំនៅនៅបេថ្លេហិមក្នុងតំបន់យូដា។

Ruth 1:3

គាត់រស់នៅជាមួយកូនប្រុសទាំងពីររបស់គាត់

«ណាអូមីមានកូនប្រុសតែពីរនាក់គត់នៅជាមួយនាង»

ធ្វើភរិយា

«ស្ត្រីរៀបការ» នេះជាពាក្យសម្រាប់ស្ត្រីដែលរៀបការហើយ។
ពួកគេមិនបានយកស្ត្រី ដែលបានរៀបការរួចហើយទេ។

ស្ត្រីសាសន៍ម៉ូអាប់

កូនប្រុសៗរបស់នាងណាអូមីបានរៀបការជាមួយស្ត្រី ដែលមកពីកុលសម្ព័ន្ធម៉ូអាប់។
ជនជាតិម៉ូអាប់បានគោរពបូជាព្រះដទៃ។

ម្នាក់ឈ្មោះ

«ឈ្មោះរបស់ស្ត្រីម្នាក់»

ម្នាក់ទៀតឈ្មោះ

«ឈ្មោះរបស់ស្ត្រីម្នាក់ផ្សេងទៀត»

អស់រយៈពេលប្រហែលដប់ឆ្នាំ

១០ ឆ្នាំក្រោយលោកអេលីម៉ាលេក និងនាងណាអូមីបានមកដល់ស្រុកម៉ូអាប់
កូនប្រុសរបស់ពួកគេឈ្មោះលោកម៉ាឡូន និងលោកគីលីយ៉ូនបានស្លាប់។

ទុកឲ្យនាងណាអូមី

នាងណាអូមីជាស្ត្រីមេម៉ាយ។

Ruth 1:6

គាត់បានឮគេនិយាយថា

«ពេលនាងណាអូមីរស់នៅស្រុកម៉ូអាប់នាងបានឮ»។
នេះបញ្ជាក់ថាព័ត៌មាននេះបានឮមកពីអ៊ីស្រាអែល។ បកប្រែផ្សេងទៀត
«នាងបានឮពីអ៊ីស្រាអែលពេល ដែលនៅក្នុងតំបន់ម៉ូអាប់» ។

ព្រះអម្ចាស់

នេះជាឈ្មោះរបស់ព្រះ
ដែលទ្រង់បានបង្ហាញដល់ប្រជាជនរបស់ទ្រង់នៅក្នុងគម្ពីរសញ្ញាចាស់។
សូមមើលការបកប្រែទំព័រពាក្យ
អំពីព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។

បានប្រណីសណ្តោសដល់ប្រជាជនរបស់ព្រះអង្គ

ព្រះបានទតឃើញពីតម្រូវការរបស់ពួកគេ ហើយ
បានប្រមូលផលល្អសម្រាប់ពួកគេ។

កូនប្រសារ

នៅក្នុងច្បាប់ ស្ត្រីដែលបានរៀបការជាមួយកូនប្រុសរបស់នាងណាអូមី។

ធ្វើដំណើរតាមផ្លូវ

«ពួកគេបានដើរនៅតាមផ្លូវ»។
ការដើរតាមផ្លូវគឺជាការបង្ហាញសម្រាប់ការដើរចេញទៅ។

Ruth 1:8

កូនប្រសារទាំងពីរ

នៅក្នុងច្បាប់ «ភរិយារបស់កូនប្រុស» ឬ "កូនប្រុសរបស់ស្ត្រីមេម៉ាយ" ។

ចូរកូនៗ

នាងណាអូមីបាននិយាយជាមួយមនុស្សពីរនាក់ ដូច្នេះភាសាដែលមានទម្រង់ពីរនៃ
«អ្នក» អាចប្រើបាននៅក្នុងការនិយាយរបស់នាងនៅទីនេះ។

ផ្ទះម្តាយរៀងៗខ្លួន

«ទៅផ្ទះម្តាយរាងៗខ្លួន»

សម្តែងព្រះហឫទ័យសប្បុរស

«បង្ហាញថាអ្នកជាមនុស្សស្មោះត្រង់»

សប្បុរស

«សេចក្តីសប្បុរស» រួមបញ្ចូលទាំងគំនិតនៃសេចក្តីស្រឡាញ់ សេចក្តីសប្បុរស
និងភាពស្មោះត្រង់។

ចំពោះកូនប្រុសរបស់ម្តាយដែលបានស្លាប់ទៅ

«ចំពោះប្តីរបស់អ្នកដែលបានស្លាប់»

នាងណាអូមីកំពុងសំដៅទៅលើកូនប្រុសពីរនាក់របស់នាង ដែលបានស្លាប់ទៅ។

ប្រទានឲ្យ

«ផ្តល់ឲ្យអ្នក» ឬ «អនុញ្ញាតឲ្យអ្នកមាន»

សម្រាក

«សម្រាក» នៅទីនេះរួមបញ្ចូលទាំងសន្តិសុខក្នុងអាពាហ៍ពិពាហ៍។

មានសុភមង្គល ក្នុងគ្រួសាររៀងៗខ្លួនផងចុះ

ជាមួយប្តីថ្មីរបស់ពួកគេ មិនមែនប្តីរបស់នរណាម្នាក់ទេ។ នេះសំដៅទៅលើ
ទាំងគេហដ្ឋានរូបវន្ត ដែលជាកម្មសិទ្ធិរបស់ប្តី
និងការពារពីការខ្មាស់អៀនដោយរៀបការ។

គេទ្រហោយំទាំងអស់គ្នា

នេះមានន័យថាកូនស្រីស្រែកយំខ្លាំង ៗ ឬយំយ៉ាងខ្លាំង។

generated on Wed Sep 10 16:16:32 2025

ពួកយើងនឹងទៅ
នៅពេលនាងអ័រប៉ា និងនាងរស់បាននិយាយថា «យើង»
ពួកគេកំពុងសំដៅលើខ្លួនឯងហើយមិនមែននាងណាអូមីទេ។
ដូច្នេះភាសាដែលមាន «យើង» រាប់បញ្ចូល
និងផ្តាច់មុខនឹងប្រើទម្រង់ផ្តាច់មុខនៅទីនេះ។
ជាមួយម៉ែ
នៅទីនេះ «អ្នក» គឺជាទម្រង់ឯកវចន:ដែលសំដៅទៅលើនាងណាអូមី។
Ruth 1:11
ហេតុអ្វីកូនចង់ទៅជាមួយម្តាយ?
នេះគឺជាសំណួរវោហារស័ព្ទ។ «វាមិនសមហេតុផលទេដែលកូនទៅជាមួយម្តាយ»
ឬ «កូនមិនគួរទៅជាមួយម្តាយទេ» ។
តើម្តាយនៅអាចបង្កើតកូនប្រុស ដែលអាចរៀបការជាមួយពួកឯងបានឬ?
នាងណាអូមីប្រើសំណួរនេះដើម្បីនិយាយថា
នាងមិនអាចមានកូនប្រុសផ្សេងទៀតឲ្យពួកគេរៀបការបានទេ។
«ជាក់ស្តែងខ្ញុំមិនអាចមានកូនប្រុសទៀត ដែលអាចក្លាយជាប្តីរបស់កូនទេ» ។
ម្តាយចាស់ណាស់ហើយ មិនអាចមានប្តីទៀតបានទេ
ហេតុផលដែលបញ្ជាក់ពីភាពចាំបាច់របស់ស្វាមី អាចបញ្ជាក់យ៉ាងច្បាស់នៅទីនេះ។
«ចាស់ពេកមិនអាចរៀបការម្តងទៀត ហើយបង្កើតកូនថែមទៀត»
បង្កើតបានកូនប្រុស
«បង្កើតកូន» ឬ « សម្រាលកូនប្រុសៗ»
តើនាងអាចនៅចាំរហូតដល់គេពេញវ័យបានទេ? តើសុខចិត្តរស់នៅដោយឥតមានប្តីយ៉ាងនេះឬ?
ទាំងនេះគឺជាសំណួរវោហារស័ព្ទដែលមិនរំពឹងថានឹងមានចម្លើយទេ។
«អ្នកនឹងមិនរង់ចាំរហូតដល់ពួកគេធំឡើង
ដូច្នេះអ្នកមិនអាចរៀបការជាមួយពួកគេបានទេ។
អ្នកនឹងចង់រៀបការជាមួយបុរសឥឡូវនេះ» ។ (សូមមើលfigs-rquestion)
ធ្វើដូច្នេះមិនបានទេ
អ្វីដែលធ្វើឲ្យនាងឈឺចាប់អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ «
វាធ្វើឲ្យខ្ញុំសោកសៅខ្លាំងណាស់ដែលកូនគ្មានប្តី»
ព្រះអម្ចាស់ច្បាស់ជាងាកមកប្រឆាំងនឹងម្តាយ
ពាក្យថា« ដៃ» សំដៅទៅលើអំណាច ឬឥទ្ធិពលរបស់ព្រះអម្ចាស់។
«ព្រះអម្ចាស់បានធ្វើឲ្យមានរឿងអាក្រក់កើតឡើងចំពោះរូបម្តាយ»
Ruth 1:14
កូនប្រសារស្រីទាំងពីរក៏ទ្រហោយំសាជាថ្មី
នេះមានន័យថាពួកគេស្រែកខ្លាំង ៗ ឬយំយ៉ាងជូរចត់។
ចូរស្តាប់ម្តាយ
«ស្តាប់» នៅទីនេះមានន័យថា «សូមកត់សម្គាល់» ។
នាងរស់វិញ នាងសម្រេចចិត្តនៅជាមួយម្តាយក្មេក
«នាងរស់នៅជាប់នឹងនាងណាអូមី» ។ បកប្រែផ្សេងទៀត «
រស់បានបដិសេធមិនព្រមចាកចេញពីនាងណាអូមីទេ» ឬ «
នាងរស់នឹងមិនចាកចេញពីនាងណាអូមីឡើយ»
ប្អូនថ្លៃរបស់កូននាង
នៅក្នុងច្បាប់ «ប្អូនថ្លៃប្រុស» ឬ «លោកអ័រប៉ា»
ព្រះរបស់នាងវិញហើយ
មុននាងអ័រប៉ានិងនាងរស់រៀបការជាមួយកូនប្រុសរបស់ណាអូមី
ពួកគេគោរពបូជាព្រះរបស់ម៉ូអាប់។ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍
ពួកគេចាប់ផ្តើមគោរពបូជាព្រះរបស់នាងណាអូមីវិញ។
Ruth 1:16
កន្លែងដែលអ្នកម្តាយនៅដែរ
«កន្លែងដែលអ្នកម្តាយរស់នៅ»
ជនជាតិរបស់អ្នកម្តាយគឺជាជនជាតិរបស់កូន
នាងរស់កំពុងសំដៅទៅលើប្រជាជនអ៊ីស្រាអែលរបស់នាងណាអូមី
ដែលជាជនជាតិអ៊ីស្រាអែល។ បកប្រែផ្សេងទៀត
«ខ្ញុំនឹងចាត់ទុកប្រជាជននៃប្រទេសរបស់អ្នកម្តាយថា ជាប្រជាជនរបស់ខ្ញុំ» ឬ
«ខ្ញុំនឹងចាត់ទុកសាច់ញាតិរបស់អ្នកម្តាយជាសាច់ញាតិរបស់ខ្ញុំដែរ»
អ្នកម្តាយស្លាប់នៅទីណា កូនក៏ស្លាប់នៅទីនោះដែរ
នេះសំដៅទៅលើបំណងប្រាថ្នារបស់នាងរស់
ដើម្បីចំណាយពេលពេញមួយជីវិតរបស់នាង
នាងរស់នៅកន្លែងនិងក្រុងតែមួយជាមួយនាងណាអូមី។
សូមព្រះអម្ចាស់ដាក់ទោសមកលើកូនចុះ
សំដៅទៅលើនាងរស់ សុំព្រះដាក់ទណ្ឌកម្មនាង បើនាងមិនធ្វើអ្វីដែលនាងនិយាយ
ដូចជាពាក្យភាសាអង់គ្លេសនិយាយថា «ព្រះជាម្ចាស់មិនដាក់ទោសទេ» ។
នាងណាអូមីក៏ឈប់ប្រកែកនឹងនាង
«នាងណាអូមីឈប់ឈ្លោះ ជាមួយនាងរស់»
Ruth 1:19
នៅពេល
វាបានកើតឡើង។ នេះជាសញ្ញាណនៃដំណើររឿងថ្មី។
ស្រុកទាំងអស់
«អ្នករាល់គ្នានៅក្នុងទីក្រុង»
តើនេះគឺជាណាអូមីឬ?
ជាច្រើនឆ្នាំមកហើយ ដែលនាងណាអូមីរស់នៅភូមិបេថ្លេហិម
ហើយលែងមានប្តីនិងកូនប្រុសពីរទៀត
ទំនងជាស្ត្រីទាំងនោះកំពុងបង្ហាញការសង្ស័យថា
តើស្ត្រីនេះពិតជានាងណាអូមីមែនឬអត់។
សូមកុំហៅខ្ញុំថា ណាអូមីទៀតអី
ឈ្មោះ «ណាអូមី» មានន័យថា «ការរីករាយរបស់ខ្ញុំ» ។
ដោយសារនាងណាអូមីបានបាត់បង់ស្វាមី និងកូនប្រុស នាងមិនមានអារម្មណ៍ថា
ជីវិតរបស់នាងត្រូវនឹងឈ្មោះនាងទៀតឡើយ។
ជូរចត់
នេះជាការបកប្រែអត្ថន័យនៃឈ្មោះ។
វាក៏ត្រូវបានបកប្រែជាញឹកញាប់យោងទៅតាមសំឡេងរបស់វាថា «ម៉ារ៉ា» ។
ពេលខ្ញុំចាកចេញទៅ ខ្ញុំមានអ្វីគ្រប់យ៉ាង ប៉ុន្តែ ព្រះអង្គបានធ្វើឲ្យខ្ញុំទៅជាបាតដៃទទេ
ពេលនាងណាអូមីចាកចេញពីភូមិបេថ្លេហិម
ប្តីនិងកូនប្រុសពីរនាក់នៅរស់នាងសប្បាយចិត្តណាស់។
នាងណាអូមីបន្ទោសព្រះអម្ចាស់ ចំពោះការស្លាប់របស់ស្វាមីនិងកូនប្រុស
ដោយនិយាយថា ទ្រង់បានធ្វើឲ្យនាងវិលត្រឡប់ទៅភូមិបេថ្លេហិម ដោយគ្មានពួកគេ
ហើយឥឡូវនេះនាងមានចិត្តជូរចត់ និងមិនសប្បាយចិត្ត។
កាត់ទោសខ្ញុំ
«វិនិច្ឆ័យទោសខ្ញុំថាមានកំហុស»
ធ្វើឲ្យខ្ញុំរងទុក្ខបំផុត
«បាននាំមកនូវទុក្ខវេទនាមកលើខ្ញុំ» ឬ «បាននាំមកនូវសោកនាដកម្មដល់ខ្ញុំ» ។
Ruth 1:22
នាងណាអូមី និងនាងរស់
នេះជាសេចក្តីសង្ខេប។ ភាសាអង់គ្លេសសម្គាល់ការនេះដោយពាក្យថា «ដូច្នេះ» ។
កំណត់វិធីដែលសញ្ញាសម្គាល់ភាសារបស់អ្នក ប្រើសេចក្តីសន្និដ្ឋាន
ឬសង្ខេបហើយដែលមានន័យដូចគ្នា។
នៅដើមរដូវចម្រូត
«នៅពេលដែលកសិករទើបតែចាប់ផ្តើមច្រូតកាត់ស្រូវរបស់ពួកគេ»

---

2 [1]លោកអេលីម៉ាឡេក ជាស្វាមីនាងណាអូមីមានសាច់ញាតិម្នាក់ឈ្មោះ លោកបូអូសជាអ្នកមានសម្បត្តិស្តុកស្តម្ភ និងមានឥទ្ធិពល។
[2]នាងរស់ជាសាសន៍ម៉ូអាប់ពោលទៅនាងណាអូមីថា៖ «សូមអ្នកម្តាយអនុញ្ញាតឲ្យកូនទៅរើសកួរស្រូវតាមស្រែនានាទៅ
គង់តែមានគេអាណិតទុកឲ្យកូនរើសតាមក្រោយគេមិនខាន»។ នាងណាអូមីឆ្លើយថា៖ «ទៅចុះកូនស្រី!»។
[3]នាងរស់ចេញទៅរើសកួរស្រូវតាមក្រោយពួកអ្នកច្រូតនៅក្នុងស្រែមួយ។ គាប់ជួននាងបានទៅរើសប៉ះចំស្រែរបស់លោកបូអូស ដែលជាសាច់ញាតិរបស់
លោកអេលីម៉ាឡេក។[4]ពេលនោះ លោកបូអូសបានមកពីភូមិបេថ្លេហិម លោកពោលទៅកាន់ពួកអ្នកច្រូតថា៖ «សូមព្រះអម្ចាស់គង់ជាមួយអ្នករាល់គ្នា»។ គ្រប់គ្នាតបវិញថា៖
«សូមព្រះប្រទានពរលោក»។
[5]លោកបូអូសសួរទៅកាន់អ្នកបម្រើរបស់គាត់ ដែលអ្នកត្រួតលើពួកអ្នកច្រូតថា៖ «តើនាងជាអ្នកណា?»[6]អ្នកបម្រើជាមេត្រួតលើអ្នកច្រូតឆ្លើយថា៖ «នាងគឺជាសាសន៍ម៉ូអាប់
ដែលមកពីស្រុកម៉ូអាប់ ជាមួយណាអូមី។[7]នាងបានសុំខ្ញុំថា សូមអនុញ្ញាតឲ្យខ្ញុំរើសគួរស្រូវដែលជ្រុះនៅក្នុងស្រែពីក្រោយពួកអ្នកច្រូតស្រូវផងចុះ នាងបានមកទីនេះ
តាំងពីព្រឹករហូតមកដល់ពេលនេះ នាងបានទៅសម្រាក់នៅផ្ទះតែមួយស្របក់តែប៉ុណ្ណោះ»។

generated on Wed Sep 10 16:16:32 2025

[8]លោកបូអូសនិយាយទៅនាងរស់ថា៖ «នាងអើយ សូមស្តាប់ខ្ញុំ! កុំទៅរើសស្រូវក្នុងស្រែណាផ្សេងឡើយ! ហើយកុំទៅណាឆ្ងាយពីស្រែនេះដែរ។
ចូរនៅទីនេះជាមួយអ្នកបម្រើស្រីៗរបស់ខ្ញុំចុះ។[9]ចូរឃ្លាំមើលតែក្នុងស្រែ បើអ្នកច្រូតទៅណាចូរទៅតាមក្រោយស្រីៗទាំងនោះទៅ។
ខ្ញុំបានហាមអ្នកបម្រើប្រុសៗមិនឲ្យគេប៉ះពាល់នាងទេ។ ហើយប្រសិនបើនាងស្រេកទឹក ចូរទៅពិសាទឹកក្នុងឧមដែលអ្នកបម្រើរបស់ខ្ញុំបានដងទុកនោះចុះ»។
[10]ពេលនោះនាងរស់បានឱនមុខក្រាបដល់ដីពីមុខលោកបូអូស ហើយនិយាយទៅកាន់លោកថា៖ «ហេតុអ្វីបានជាលោកប្រណីមេត្តាដល់
ដែលខ្ញុំជាជនបរទេសដូច្នេះ?»[11]លោកឆ្លើយតបទៅនាងវិញថា៖ «មានគេប្រាប់ខ្ញុំ ពីកិច្ចការគ្រប់យ៉ាងដែលនាងបានប្រព្រឹត្តចំពោះម្តាយក្មេក
ចាប់តាំងពីប្តីនាងស្លាប់ចោលទៅ។ នាងបានចាកចេញពីឪពុក ម្តាយ និងទឹកដីកំណើតរបស់នាងមកតាមម្តាយក្មេក
ហើយមករស់នៅក្នុងចំណោមជនជាតិដែលនាងមិនស្គាល់។[12]សូមព្រះអម្ចាស់តបស្នងមកនាងវិញស្របតាមការដែលនាងប្រព្រឹត្ត។
សូមព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលប្រទានរង្វាន់ដល់នាងជាបរិបូរ ព្រោះនាងបានមកជ្រកក្រោមម្លប់បារមីរបស់ព្រះអង្គ»។
[13]បន្ទាប់មក នាងពោលថា៖ «លោកម្ចាស់មានចិត្តប្រណីសណ្តោសមកលើនាងខ្ញុំពន់ប្រមាណ លោកបានមានប្រសាសន៍សម្រាលទុក្ខ និងលើកទឹកចិត្តនាងខ្ញុំ
ទោះបីនាងខ្ញុំមានឋានៈទាបជាអ្នកបម្រើរបស់លោកក្តី»។
[14]នៅពេលបរិភោគអាហារ លោកនិយាយទៅកាន់នាងរស់ថា៖ «អញ្ជើញមកពិសានំបុ័ង ហើយជ្រលក់ដុំនំបុ័ងរបស់នាងមកក្នុងទឹកជ្រលក់នេះទៅ»។
នាងរស់អង្គុយជិតពួកអ្នកច្រូត ហើយលោកហុចលាជទៅឲ្យនាង នាងហូបរហូតឆ្អែត ហើយទុលលាជដែលនៅសល់នោះផង។
[15]បន្ទាប់មក នាងក៏ក្រោកឡើងរើសស្រូវទៀត លោកបូអូសបានបញ្ជាអ្នកបម្រើប្រុសៗរបស់គាត់ថា៖ «ទុកឲ្យនាងរើសស្រូវនៅកន្លែងដែលមានកណ្តាប់ស្រូវផង
កុំឃាត់នាងអី។[16]ហើយក៏ទម្លាក់កួរស្រូវខ្លះពីកណ្តាប់ឲ្យនាងផង កុំបន្ទោសនាងអី»។
[17]ដូច្នេះ នាងបានរើសកួរស្រូវនៅក្នុងស្រែរហូតដល់ពេលល្ងាច។ ហើយនាងក៏បែនស្រូវដែលនាងបានរើសនោះ បានជិតមួយថាំង។
[18]នាងបានលើកវាទូលហើយត្រឡប់ទៅភូមិវិញ។ ម្តាយក្មេករបស់នាងបានឃើញស្រូវដែលបានរើសបាន
ហើយនាងរស់ក៏បានយកលាជដែលនាងយកពីអាហាររបស់នាងមកឲ្យម្តាយក្មេកដែរ។
[19]ម្តាយក្មេករបស់នាងបានសួរនាងថា៖ «តើថ្ងៃនេះកូនបានទៅរើសស្រូវនៅឯណា តើកូនបានទៅធ្វើការនៅទីណា? សូមព្រះប្រទានពរដល់អ្នកដែលបានជួយកូន»។
បន្ទាប់មក នាងរស់ក៏បានប្រាប់ម្តាយក្មេកអំពីម្ចាស់ស្រែដែលនាងបានទៅរើសកួរស្រូវនោះ។ នាងប្រាប់ថា៖ «ម្ចាស់ស្រែដែលកូនបានចូលទៅរើសកួរស្រូវនៅថ្ងៃនេះ
គាត់មានឈ្មោះថា បូអូស»។[20]នាងណាអូមីបានតបទៅកូនប្រសារថា៖ «សូមព្រះអម្ចាស់ប្រទានពរដល់គាត់
គឺដល់អ្នកដែលមិនបានបោះបង់ភក្តីភាពរបស់គាត់ទាំងចំពោះអ្នកនៅរស់ និងអ្នកដែលបានស្លាប់»។ នាងណាអូមីបានពោលទៅកាន់នាងរស់ទៀតថា៖
«បុរសនេះគឺជាញាតិជិតដិតរបស់យើង គាត់ក៏ជាម្នាក់ដែលមានភារកិច្ចទទួលបន្ទុកថែរក្សាយើង»។
[21]នាងរស់ជាសាសន៍ម៉ូអាប់ពោលថា៖ «គាត់បានប្រាប់ខ្ញុំថា នាងត្រូវនៅរើសកួរស្រូវក្បែរស្រីបម្រើរបស់ខ្ញុំ រហូតទាល់តែផុតរដូវចម្រូត»។
[22]នាងណាអូមីនិយាយទៅនាងរស់ជាកូនប្រសារស្រីរបស់នាងថា៖ «គឺជាការល្អណាស់! ដែលកូននៅរើសស្រូវជាមួយអ្នកស្រីបម្រើរបស់លោក ដូច្នេះ
កូននឹងមិនត្រូវគេធ្វើបាប នៅពេលដែលកូនទៅរើសស្រូវក្នុងស្រែដទៃនោះទេ»។
[23]ដូច្នេះ នាងរស់ក៏នៅរើសស្រូវជាមួយស្រីបម្រើរបស់លោកបូអូសរហូតទាល់តែផុតរដូវចម្រូត។ នាងរស់បានបន្តរស់នៅជាមួយម្តាយក្មេកបន្តទៅទៀត។

Ruth 2:1

ស្វាមីនាងណាអូមី

ឃ្លានេះណែនាំព័ត៌មានថ្មីមុនពេលរឿងបន្ត។
ភាសារបស់អ្នកអាចមានវិធីដើម្បីណែនាំព័ត៌មានថ្មី។

ជាអ្នកមានសម្បត្តិស្តុកស្តម្ភ និងមានឥទ្ធិពល

«ជាបុរសមានទ្រព្យស្តុកស្តម្ភម្នាក់»។ នេះមានន័យថា លោកបូអូសមានភាពរុងរឿង
និងល្បីល្បាញនៅក្នុងសហគមន៍របស់គាត់ ដែលមានកេរ្តិ៍ឈ្មោះល្អ។

នាងរស់ជាសាសន៍ម៉ូអាប់

នេះជារឿងរ៉ាវបន្ត។ អ្នកត្រូវមើលពីរបៀប
ដែលភាសារបស់អ្នកចាប់ផ្តើមរឿងឡើងវិញបន្ទាប់ពីសម្រាក។

សាសន៍ម៉ូអាប់

នេះជាវិធីមួយទៀតដើម្បីនិយាយថា ស្ត្រីនោះមកពីស្រុក ឬកុលសម្ព័ន្ធម៉ូអាប់។

រើសកួរស្រូវតាមស្រែនានា

«ប្រមូលគ្រាប់ធញ្ញជាតិដែលនៅសល់ដោយអ្នកច្រូតកាត់» ឬ
«រើសកួរស្រូវដែលនៅសល់ពីអ្នកច្រូតកាត់»

កួរ

«ក្បាល» ឬ «ដើម» «ត្រចៀក»
គឺជាផ្នែកនៃគ្រាប់ធញ្ញជាតិដែលផ្ទុកគ្រាប់ធញ្ញជាតិ។

គង់តែមានគេអាណិតទុកឲ្យកូនរើសតាមក្រោយគេមិនខាន

នាងរស់និយាយពីការគាប់ព្រះហឫទ័យ នឹងការទទួលបានការអនុញ្ញាត
ឬការយល់ព្រម។ «ដែរនឹងផ្តល់ការអនុញ្ញាតឲ្យខ្ញុំដើម្បីរើសកួរស្រូវ»

កូនស្រី

នាងរស់កំពុងមើលថែណាអូមី ដូចជានាងណាអូមីជាម្តាយរបស់នាងផ្ទាល់។
ត្រូវប្រាកដថា ភាសារបស់អ្នកអាចប្រើពាក្យនេះ
សម្រាប់មនុស្សម្នាក់ដែលមិនមែនជាកូនស្រីពិតប្រាកដ។

Ruth 2:3

គាប់ជួននាងបានទៅ

នាងរស់មិនបានដឹងថា វាលស្រែដែលនាងបានរើសទៅប្រមូលកួរស្រូវ
វាជាកម្មសិទ្ធិរបស់បូអូសដែលជាសាច់ញាតិរបស់ណាអូមីទេ។

ពេលនោះ លោកបូអូស

ពាក្យថា« មើល»
រំលឹកយើងអំពីព្រឹត្តិការណ៍ដ៏សំខាន់របស់បូអូសមកដល់វាលស្រែ។
ភាសារបស់អ្នកក៏អាចមានវិធីជាក់លាក់មួយ ក្នុងការណែនាំព្រឹត្តិការណ៍
ឬតួអង្គសំខាន់ៗនេះ។

មកពីភូមិបេថ្លេហិម

ទីវាលទាំងនោះជាចម្ងាយដែលមិនបានបញ្ជាក់នៅខាងក្រៅក្រុងបេថ្លេហិម។

សូមព្រះប្រទានពរលោក

«ផ្តល់ឲ្យអ្នកនូវអ្វីដែលល្អ» ឬ «ធ្វើឲ្យអ្នកសប្បាយចិត្ត»

Ruth 2:5

តើនាងជាអ្នកណា?

អាចមានន័យថា ១) លោកបូអូសបានសួរអំពីប្តីរបស់នាងរស់ ឬ ២)
លោកបូអូសបានសួរអំពីឪពុកម្តាយរបស់នាងរស់។

មេត្រួតលើអ្នកច្រូត

«ទទួលបន្ទុក» ឬ «គ្រប់គ្រង»

ផ្ទះ

«ឧម» ឬ «ជម្រក» ។ នេះគឺជាជម្រកបណ្តោះអាសន្ន ឬឧមសួននៅក្នុងវាល
ដែលផ្តល់ម្លប់ពីព្រះអាទិត្យ។

Ruth 2:8

នាងអើយ សូមស្តាប់ខ្ញុំ!

អាចប្រើឡើងវិញជាពាក្យបញ្ជា។ បកប្រែផ្សេងទៀត «សូមស្តាប់ខ្ញុំកូនស្រី!» ឬ
«កត់ចំណាំបានច្បាស់នូវអ្វីដែលខ្ញុំកំពុងប្រាប់អ្នក កូនស្រីរបស់ខ្ញុំអើយ!»

នាងអើយ

នេះជាវិធីល្អក្នុងការនិយាយទៅកាន់ស្ត្រីវ័យក្មេង។
នាងរស់មិនមែនជាកូនស្រីពិតរបស់លោកបូអូស ដូច្នេះត្រូវប្រាកដថាការបកប្រែនេះ
មិនមានន័យដូចនាងជាកូនស្រីនោះឡើយ។

ចូរឃ្លាំមើលតែក្នុងស្រែ

ភ្នែកតំណាងឲ្យការមើលអ្វីមួយ ឬយកចិត្តទុកដាក់លើអ្វីមួយ។ បកប្រែផ្សេងទៀត
«មើលតែវាលស្រែទៅ» ឬ «យកចិត្តទុកដាក់តែលើវាលស្រែប៉ុណ្ណោះ»

ខ្ញុំបានហាមអ្នកបម្រើប្រុសៗមិនឲ្យគេប៉ះពាល់នាងទេ

លោកបូអូសបានប្រើសំណួរនេះ
ដើម្បីបញ្ជាក់ពីអ្វីដែលគាត់បានធ្វើរួចហើយដើម្បីជួយនាងរស់។
«ខ្ញុំបានផ្តល់ការណែនាំដល់បុរសយ៉ាងតឹងរ៉ឹង ... អ្នក» ។

generated on Wed Sep 10 16:16:32 2025

តាមក្រោយស្រីៗទាំងនោះ
«កម្មករវ័យក្មេង ... កម្មការីនីវ័យក្មេង» ពាក្យ «បុរស»
ត្រូវបានប្រើបីដងដើម្បីសំដៅទៅលើបុរសវ័យក្មេងដែលកំពុងប្រមូលផលនៅតាមចម្ការ។
ភាសាខ្លះអាចនិយាយពាក្យនេះដោយប្រើពាក្យមួយ
ហើយពួកគេមានពាក្យផ្សេងដែលមានន័យថានារីវ័យក្មេង។
មិនឲ្យគេប៉ះពាល់នាងទេ
អាចមានន័យថា ១) បុរសមិនត្រូវធ្វើបាបនាងរស់ ឬ ២)
បុរសមិនត្រូវបញ្ឈប់នាងពីការរើសកួរស្រូវនៅវាលស្រែរបស់គាត់ឡើយ។
ទឹកក្នុងខ្ទមដែលអ្នកបម្រើរបស់ខ្ញុំបានដងទុកនោះចុះ
ដើម្បីដងទឹកមានន័យថាទាញទឹកពីអណ្តូង ឬយកវាចេញពីក្អម។
Ruth 2:10
នាងរស់បានឱនមុខក្រាបដល់ដីពីមុខលោកបូអូស
ទាំងនេះគឺជាសកម្មភាពនៃការគោរព។ នាងបង្ហាញការគោរពចំពោះលោកបូអូស
ដោយសារការដឹងគុណចំពោះអ្វីដែលគាត់បានធ្វើចំពោះនាង។ វាក៏ជាវិធីបន្ទាបខ្លួនដែរ។
ហេតុអ្វីបានជាលោកប្រណីមេត្តាដល់ ដែលខ្ញុំ?
នាងរស់កំពុងសួរសំណួរពិត។
ជាជនបរទេស
នាងរស់បានសន្យានឹងភក្តីភាពចំពោះព្រះនៃអ៊ីស្រាអែល ជាឯកជន ប៉ុន្តែ
នាងត្រូវបានគេស្គាល់ជាសាធារណៈថា «ជនជាតិម៉ូអាប់» ។
មានគេប្រាប់ខ្ញុំ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «ប្រជាជនបានរាយការណ៍មកខ្ញុំ» ឬ
«ប្រជាជនបានប្រាប់ខ្ញុំ»
មករស់នៅក្នុងចំណោមជនជាតិ
លោកបូអូសកំពុងសំដៅទៅលើនាងរស់ ដែលមករស់នៅជាមួយនាងណាអូមី
នៅក្នុងភូមិនិងសហគមន៍ ប្រទេសមួយនិងសាសនាដែលនាងមិនស្គាល់។
តបស្នងមកនាងវិញ
«សងអ្នកវិញ» ឬ «សងអ្នកវិញ»
ស្របតាមការដែលនាងប្រព្រឹត្ត
នេះជាទង្វើនៃជំនឿ ដោយជ្រើសរើសរស់នៅជាមួយណាអូមីនៅភូមិបេថ្លេហិម
ហើយជឿទុកចិត្តលើព្រះរបស់ណាអូមី។
សូមព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលប្រទានរង្វាន់ដល់នាងជាបរិបូរ
នេះជាកំណាព្យដែលស្រដៀងនឹងប្រយោគពីមុន។ បកប្រែផ្សេងទៀត «
សូមឲ្យព្រះអម្ចាស់ប្រគល់មកអ្នកវិញលើសពីអ្វី ដែលអ្នកបានឲ្យទៅទៀត»
នាងបានមកជ្រកក្រោមម្លប់បារមីរបស់ព្រះអង្គ
លោកបូអូសប្រើរូបភាពបក្សីជាម្តាយក្រុងកូនមាន់នៅក្រោមស្លាបជាការ
ការពារដល់ពួកគេ នេះដើម្បីពិពណ៌នាអំពីការការពាររបស់ព្រះចំពោះអ្នក
ដែលទុកចិត្តលើព្រះអង្គ។ បកប្រែផ្សេងទៀត
«នៅក្នុងការថែរក្សាប្រកបដោយសុវត្ថិភាពរបស់ព្រះអង្គ ដែលអ្នកបានទុកចិត្តលើ»
Ruth 2:13
លោកម្ចាស់មានចិត្តប្រណីសណ្តោសមកលើនាងខ្ញុំពន់ប្រមាណ
នេះសំដៅទៅលើការសុំព្រះពរ។ បកប្រែផ្សេងទៀត
«សូមឲ្យខ្ញុំទទួលបានព្រះគុណពីអ្នក» ឬ «សូមទទួលយកខ្ញុំ»
ទោះបីនាងខ្ញុំមានឋានៈទាបជាអ្នកបម្រើរបស់លោកក្តី
អាចមានន័យថា ១) នាងរស់មិនមែនជាអ្នកបម្រើស្រីរបស់លោកបូអូសទេ ឬ ២)
នាងរស់មិនបានគិតថាអាពាហ៍ពិពាហ៍របស់នាង
នឹងកូនប្រុសរបស់ណាអូមីបានផ្តល់សិទ្ធិឲ្យនាង នៅឯភូមិបេថ្លេហិមទេ។
Ruth 2:14
នៅពេលបរិភោគអាហារ
នេះសំដៅទៅលើអាហារពេលថ្ងៃត្រង់។
ជ្រលក់ដុំនំបុ័ងរបស់នាងមកក្នុងទឹកជ្រលក់នេះទៅ
នេះជាអាហារសាមញ្ញដែលបរិភោគនៅទីវាល។
មនុស្សអង្គុយនៅលើដីជុំវិញក្រណាត់
ដែលមានចានទឹកខ្មេះនិងចានដាក់ចំណិតនំបុ័ង។
ពួកគេនឹងជ្រលក់នំបុ័ងនៅក្នុងចានទឹកខ្មេះនោះ
ដើម្បីឲ្យសើមហើយបន្ថែមរសជាតិមុនពេលពួកគេបរិភោគ។
ទឹកជ្រលក់
ជនជាតិអ៊ីស្រាអែលបន្ថែមស្រារបស់ពួកគេថែមទៀត ដើម្បីធ្វើទឹកខ្មេះ។
Ruth 2:15
នាងក៏ក្រោកឡើងរើសស្រូវទៀត លោកបូអូសបានបញ្ជាអ្នកបម្រើប្រុសៗរបស់គាត់ថា
នៅក្នុងបរិបទនៃបទបញ្ជានេះ ទំនងជានាងរស់
នៅឆ្ងាយល្មមមិនឲ្យស្តាប់សេចក្តីណែនាំរបស់លោកបូអូស។ បកប្រែផ្សេងទៀត
«ហើយនៅពេលនាងរស់ក្រោកឡើង ដើម្បីប្រមូលគ្រាប់ស្រូវ
ដែលលោកបូអូសបានប្រាប់យុវជនរបស់គាត់ ជាលក្ខណៈឯកជនថា »
បន្ទាប់មក នាងក៏ក្រោកឡើង
«ពេលនាងក្រោកឈរឡើង»
នៅកន្លែងដែលមានកណ្តាប់ស្រូវផង
នៅទីនេះ «សូម្បីតែ» តំណាងឲ្យខាងលើនិងលើសពីអ្វីដែលធម្មតាគេធ្វើ។
លោកបូអូសណែនាំកម្មកររបស់គាត់ទុកកន្តាប់ស្រូវឲ្យនាងរស់រើស។
ជាធម្មតាមនុស្សដែលរើសកួរស្រូវ
គេហាមឃាត់មិនឲ្យរើសនៅជិតកន្លែងប្រមូលផលឡើយ។
ទម្លាក់កួរស្រូវខ្លះពីកណ្តាប់ឲ្យនាងផង
«យកគ្រាប់ធញ្ញជាតិមួយចំនួនចេញពីកណ្តាប់ហើយទុកវាឲ្យនាងរើស» ឬ
«ទុកកួរស្រូវនៅពីក្រោយសម្រាប់ឲ្យនាងប្រមូល»
កុំបន្ទោសនាងអី
«កុំធ្វើឲ្យនាងអាម៉ាស់» ឬ «កុំធ្វើឲ្យនាងអាប់ឱន»
Ruth 2:17
បែនស្រូវដែលនាងបានរើសនោះ
នាងបានបំបែកផ្នែកនៃសម្បកគួរស្រូវដែលគេបានបោះចោល។
បែនស្រូវ
នេះសំដៅទៅលើផ្នែកដែលអាចបរិភោគបាននៃគ្រាប់ធញ្ញជាតិ។
បានជិតមួយចាំង
"ប្រហែល ១៣ គក។
នាងបានលើករវាទូលហើយត្រឡប់ទៅភូមិវិញ
វាបញ្ជាក់ថានាងរស់បានដឹកគ្រាប់ធញ្ញជាតិទៅផ្ទះ។
ម្តាយក្មេករបស់នាង
ម្តាយក្មេកបានឃើញ - «ណាអូមីបានឃើញ»
Ruth 2:19
តើថ្ងៃនេះកូនបានទៅរើសស្រូវនៅឯណា តើកូនបានទៅធ្វើការនៅទីណា?
នាងណាអូមីបាននិយាយស្ទើរតែដូចគ្នា នៅក្នុងវិធីពីរផ្សេងគ្នាដើម្បីបង្ហាញថា
នាងចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការដឹងពីអ្វី
ដែលបានកើតឡើងចំពោះនាងរស់នៅថ្ងៃនោះ។
សូមព្រះអម្ចាស់ប្រទានពរដល់គាត់
នាងណាអូមីកំពុងតែសុំព្រះ
ឲ្យប្រទានរង្វាន់ដល់លោកបូអូសសម្រាប់សេចក្តីសប្បុរសរបស់គាត់ ចំពោះនាងរស់
និងនាងផ្ទាល់។
អ្នកដែលមិនបានបោះបង់ភក្តីភាពរបស់គាត់
«អ្នកណាបានបន្តស្មោះត្រង់»។ អាចមានន័យថា ១)
បូអូសនឹកចាំពីកាតព្វកិច្ចរបស់គាត់ ចំពោះនាងណាអូមីក្នុងនាមជាសមាជិកគ្រួសារ
ឬ ២) នាងណាអូមីកំពុងសំដៅទៅលើព្រះអម្ចាស់
ដែលបានធ្វើសកម្មភាពតាមរយៈលោកបូអូស ឬ ៣)
ព្រះអម្ចាស់បានបន្តស្មោះត្រង់ចំពោះមនុស្សរស់និងមនុស្សស្លាប់។
ចំពោះអ្នករស់
«ដល់ប្រជាជនដែលកំពុងរស់នៅ» ។
នាងណាអូមីនិងនាងរស់ជាអ្នកដែល«រស់នៅ»។
អ្នកដែលបានស្លាប់
«ប្រជាជនដែលបានស្លាប់ទៅហើយ»។
ប្តីនិងកូនប្រុសរបស់នាងណាអូមីគឺជា«អ្នកបានស្លាប់»។
បុរសនេះគឺជាញាតិជិតដិតរបស់យើង គាត់ក៏ជាម្នាក់ដែលមានភារកិច្ចទទួលបន្ទុកថែរក្សាយើង
អ្នករំដោះ៖ ឃ្លាទីពីរនិយាយឡើងវិញ និងពង្រីកឃ្លាទីមួយ។
នេះជារបៀបនៃការសង្កត់ធ្ងន់របស់ភាសារហេព្រើរ។
ទទួលបន្ទុកថែរក្សាយើង
អ្នករំដោះ៖ ញាតិសន្តានសាច់ញាតិគឺជាសាច់ញាតិបុរសដ៏ជិតស្និទ្ធម្នាក់
ដែលអាចជួយសង្គ្រោះស្ត្រីមេម៉ាយ ដែលគ្មានកូនពីការលំបាកខាងហិរញ្ញវត្ថុ
ដោយរៀបការជាមួយនាង និងមានកូនជាមួយនាង។
គាត់ក៏នឹងទាមទារដីដែលសាច់ញាតិរបស់គាត់បានបាត់បង់
ដោយសារភាពក្រីក្រនិងជួយលោះសមាជិកគ្រួសារ
ដែលបានលក់ខ្លួនទៅក្នុងទាសភាព។

generated on Wed Sep 10 16:16:32 2025

Ruth 2:21
គាត់បានប្រាប់ខ្ញុំថា
«គាត់ថែមទាំងនិយាយមកខ្ញុំទៀតផង»។ នេះបញ្ជាក់ថា អ្វីដែលនៅខាងក្រោម
គឺជាផ្នែកសំខាន់បំផុតនៃពាក្យរបស់លោកបូអូសមកនាងរស់។
ត្រូវនៅរើសកួរស្រូវក្បែរស្រីបម្រើរបស់ខ្ញុំ
លោកបូអូសបានសំដៅលើការការពាររាងកាយ
ដែលអ្នកបម្រើរបស់គាត់អាចការពារដល់នាងបាន។
រើសស្រូវជាមួយ
«ធ្វើការជាមួយ»
មិនត្រូវគេធ្វើបាប
អាចមានន័យថា ១) កម្មករផ្សេងទៀតអាចរំលោភបំពាននាងរស់
ឬព្យាយាមចាប់នាង និងដេកជាមួយនាង ឬ ២)
នៅក្នុងវាលស្រែផ្សេងទៀតម្ចាស់អាចជ្រៀតជ្រែក
ឬបញ្ឈប់នាងពីការរើសផលដំណាំរហូតដល់ចុងបញ្ចប់នៃការប្រមូលផល។
Ruth 2:23
នាងរស់ក៏នៅរើសស្រូវជាមួយ
នាងរស់ធ្វើការនៅស្រែរបស់លោកបូអូស ជាមួយកម្មកររបស់គាត់ពេលថ្ងៃ ដូច្នេះ
នាងនឹងមានសុវត្ថិភាព។
នាងរស់បានបន្តរស់នៅជាមួយម្តាយក្មេកបន្តទៅទៀត
ម្តាយក្មេក៖ នាងរស់បានទៅផ្ទះរបស់នាងណាអូមីដើម្បីដេកនៅពេលយប់។

---

3 [1]នាងណាអូមី ម្តាយក្មេករបស់នាងប្រាប់នាងថា៖ «កូនស្រី តើមុំមិនគួរនឹងរកកន្លែងមួយសម្រាប់កូន ដែលអាចឲ្យកូនមានសុភមង្គលទេឬ?
[2]លោកបូអូសដែលកូនធ្វើការជាមួយស្រីបម្រើរបស់គាត់នោះ ជាប់ជាសាច់ញាតិនឹងយើងដែរ។ មើល៍! លោកនឹងទៅលានបោកស្រូវនៅយប់នេះដែរ។
[3]ចូរតុបតែងខ្លួនរបស់កូនឲ្យបានស្អាត លាបទឹកអប់ និងស្លៀកសម្លៀកបំពាក់ដ៏ល្អបំផុតរបស់កូន រួចដើរទៅលានដែលគាត់បោកស្រូវ។ ប៉ុន្តែ
មិនត្រូវឲ្យគាត់ស្គាល់កូនឡើយរហូតការផឹកស៊ីត្រូវបញ្ចប់។[4]ពេលគាត់ចូលសម្រាន្ត កូនត្រូវចំណាំកន្លែងដែលគាត់សម្រាន្តឲ្យបានច្បាស់ បន្ទាប់មក
កូនត្រូវទៅបើកភួយចុងជើងរបស់គាត់ ហើយចូលដេកនៅទីនោះទៅ។ ដូច្នេះ គាត់នឹងប្រាប់កូនថា តើកូនត្រូវធ្វើអ្វី»។[5]នាងរស់តបទៅម្តាយក្មេកថា៖
«កូននឹងធ្វើគ្រប់យ៉ាងតាមអ្នកម៉ែប្រាប់»។
[6]នាងរស់ក៏ដើរទៅលានបោកស្រូវ និងធ្វើតាមការបង្គាប់របស់ម្តាយក្មេកដែលបានបង្គាប់មកនាង។[7]នៅពេលលោកបូអូស បរិភោគមួបអាហារ និងស្រារួចហើយ
គាត់ក៏សប្បាយចិត្ត លោកក៏គេងនៅក្បែរគំនរស្រូវ។ នាងរស់ក៏ចូលលបៗ មកបើកភួយនៅចុងជើងរបស់គាត់ ហើយដេកនៅទីនោះ។
[8]ពេលពាក់កណ្តាលអាធាត្រលោកបូអូសផ្តើមភ្ញាក់ឡើង។ គាត់ប្រែខ្លួន ហើយនៅទីនោះមានស្ត្រីម្នាក់ដេកនៅចុងជើងរបស់គាត់![9]គាត់សួរថា៖ «តើនាងជាអ្នកណា?»
នាងតបថា៖ «នាងខ្ញុំឈ្មោះរស់ ស្រីបម្រើរបស់លោក។ សូមលោកម្ចាស់មេត្តាទទួលនាងខ្ញុំជាភរិយាផង ដ្បិត លោកមានភារកិច្ចទទួលបន្ទុកថែរក្សានាងខ្ញុំស្រាប់ហើយ»។
[10]លោកបូអូសតបថា៖ «សូមព្រះអម្ចាស់ប្រទានពរដល់នាង! នាងបានបង្ហាញភាពស្មោះត្រង់លើសពីលើកមុនទៅទៀត
ព្រោះនាងមិនបានទៅតាមបុរសក្មេងៗទោះជាក្រឬមានក្តី។[11]ឥឡូវនេះ សូមនាងកុំភ័យខ្លាចអ្វីឡើយ! អ្វីដែលនាងសុំ នោះខ្ញុំនឹងធ្វើតាមទាំងអស់
ព្រោះមនុស្សក្នុងក្រុងទាំងអស់គេបានដឹងថា នាងជាស្ត្រីថ្លៃថ្នូរ។
[12]ជាការពិតណាស់ដែលខ្ញុំជាអ្នកដែលមានភារកិច្ចទទួលបន្ទុកមើលថែរក្សានាង ប៉ុន្តែ មានបុរសម្នាក់ដែលជាសាច់ញាតិជិតជាងខ្ញុំទៅទៀត។[13]យប់នេះ
សូមនាងសម្រាកនៅទីនេះហើយ ចាំព្រឹកស្អែក ប្រសិនបើ គេចង់ទទួលខុសត្រូវលើនាង ឲ្យគេទទួលចុះ។ ប៉ុន្តែ បើគេមិនព្រមទទួលទេ
ខ្ញុំមុខជាទទួលខុសត្រូវលើនាងពុំខាន ខ្ញុំសូមសន្យាដោយយកព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅធ្វើជាសាក្សី! សូមនាងសម្រាកនៅទីនេះរហូតដល់ព្រឹកចុះ»។
[14]ដូច្នេះ នាងក៏ដេកនៅចុងជើងលោករហូតដល់ព្រឹក ហើយនាងក្រោកតាំងពីព្រលឹមស្រាងៗ មុនពេលមើលស្គាល់គ្នា។ លោកបូអូសក៏និយាយថា៖
«កុំឲ្យអ្នកណាដឹងថាស្ត្រីបានមកលានបោកស្រូវនេះឡើយ»។[15]លោកពោលថា៖ «ចូរដោះអាវធំរបស់នាង ហើយកាន់វាឲ្យជាប់»។ នាងក៏ធ្វើតាម
ហើយលោកក៏ចាក់ស្រូវមួយតៅទៅក្នុងអាវធំរបស់នាង ព្រមទាំងជួយលើកឲ្យនាងទូលផង។ បន្ទាប់មកលោកក៏វិលចូលទៅភូមិវិញ។
[16]ពេលនាងរស់ទៅដល់ផ្ទះវិញ ម្តាយក្មេកសួរថា៖ «តើយ៉ាងដូចម្តេចហើយកូនស្រី?» នាងក៏ប្រាប់អំពីអ្វីដែលលោកបូអូសបានធ្វើចំពោះនាង។[17]នាងប្រាប់ថា៖
«នេះជាស្រូវមួយតៅដែលលោកបានឲ្យមកខ្ញុំ ហើយគាត់បាននិយាយថា នាងមិនត្រូវទៅផ្ទះវិញដៃទទេឡើយ។[18]ណាអូមីនិយាយថា៖ «ចូរកូននៅរង់ចាំសិន
រហូតទាល់តែដឹងថា ការនេះនឹងទៅជាយ៉ាងណា លោកបូអូសនឹងមិននៅស្ងៀមទេ គាត់នឹងគិតគូររហូតទាល់តែបានសម្រេចនៅថ្ងៃនេះមិនខាន»។

Ruth 3:1
ម្តាយក្មេក
សាច់ថ្លៃ៖ នាងណាអូមីជាម្តាយប្តីរបស់នាងរស់ ដែលបានស្លាប់។
កូនស្រី
នាងរស់បានក្លាយជាកូនស្រីរបស់នាងណាអូមី
ដោយរៀបការជាមួយកូនប្រុសរបស់នាង
និងដោយសកម្មភាពរបស់នាងក្នុងការមើលថែនាងណាអូមី
ក្រោយពីត្រឡប់ទៅភូមិបេថ្លេហិមវិញ។
តើមុំមិនគួរនឹងរកកន្លែងមួយសម្រាប់កូន?
នាងណាអូមីបានប្រើសំណួរនេះដើម្បីប្រាប់នាងរស់ នូវអ្វីដែលនាងគ្រោងនឹងធ្វើ។
«ខ្ញុំត្រូវតែរកកន្លែងសម្រាប់កូន!» ឬ «ខ្ញុំត្រូវរកប្តីដើម្បីថែទាំកូន!»
កន្លែងមួយសម្រាប់កូន
អាចមានន័យថា ១) តាមន័យត្រង់គឺថាស្វែងរកផ្ទះឲ្យនាងរស់នៅ ឬ ២)
ក្នុងន័យប្រៀបធៀបគឺថា ស្វែងរកប្តីដើម្បីមើលថែនាង។
នាងណាអូមីប្រហែលជាមានអារម្មណ៍ទាំងពីរនេះនៅក្នុងចិត្ត។
ដែលកូនធ្វើការជាមួយស្រីបម្រើរបស់គាត់នោះ
«កម្មការីនីដែលកូនបានធ្វើការជាមួយ»
ជាប់ជាសាច់ញាតិនឹងយើងដែរ
នាងណាអូមីប្រហែលជាបានប្រើសំណួរនេះ ដើម្បីរំលឹកនាងរស់អំពីអ្វីមួយ
ដែលនាងបានប្រាប់នាងរួចហើយ។ ការបកប្រែផ្សេងទៀត
«គាត់គឺជាសាច់ញាតិរបស់យើង» ។
មើល៍!
ពាក្យនេះបញ្ជាក់ថា ឃ្លាខាងក្រោមគឺមានសារៈសំខាន់ណាស់។
ទៅលានបោកស្រូវ
ដើម្បីបោកស្រូវមានន័យថា ត្រូវបំបែកគ្រាប់ធញ្ញជាតិពីអង្កាម
ដោយបោះធញ្ញជាតិនិងអង្កាមទៅក្នុងខ្យល់ ដែលធ្វើឲ្យខ្យល់បក់បោកចេញពីស្រូវ។
Ruth 3:3
លាបទឹកអប់
ប្រហែលជាទាក់ទងនឹងការលាបប្រេង ដែលមានក្លិនក្រអូបលើខ្លួនឯង
ដូចជាស្ត្រីបានលាបទឹកអប់លើខ្លួនសព្វថ្ងៃនេះ។
រួចដើរទៅលានដែលគាត់បោកស្រូវ
សំដៅទៅលើការចាកចេញពីទីក្រុង និងឆ្ពោះទៅកាន់កន្លែងដែលកំពុងបោកបែន។
បើកភួយចុងជើងរបស់គាត់
មានន័យថា យកអាវឬភួយដែលគ្របលើជើងរបស់គាត់ចេញ
ដូច្នេះពួកគេប្រឈមនឹងការត្រជាក់។
ចូលដេកនៅទីនោះទៅ
«ដេកនៅទៀបជើងលោក»
ដូច្នេះ គាត់នឹងប្រាប់កូនថា តើកូនត្រូវធ្វើអ្វី
ទំនៀមទម្លាប់ជាក់លាក់នៅគ្រានោះមិនច្បាស់លាស់ទេប៉ុន្តែ ជាទូទៅ
នេះត្រូវបានគេយល់ថាជាវិធី ដែលអាចទទួលយកបានសម្រាប់ស្ត្រី
ដើម្បីប្រាប់បុរសថា នាងសុខចិត្តរៀបការជាមួយគាត់។
លោកបូអូសនឹងយល់ពីទំនៀមទម្លាប់ហើយព្រមទទួល
ឬបដិសេធការស្នើសុំរបស់នាង។
ដូច្នេះ គាត់នឹងប្រាប់
«នៅពេលគាត់ភ្ញាក់ឡើង គាត់នឹង»
Ruth 3:6
គាត់ក៏សប្បាយចិត្ត
«គាត់ពេញចិត្ត» ឬ «គាត់មានអារម្មណ៍ល្អ» ។ នេះមិនបានន័យថា

generated on Wed Sep 10 16:16:32 2025

លោកបូអូសស្រឡឹងខ្លាំងពេកទេ។
នាងរស់ក៏ចូលលបៗ
«នាងលួចចូលក្នុង» ឬ «នាងចូលមកស្ងាត់ដូច្នេះគ្មាននរណាឮនាងទេ»
មកបើកភួយនៅចុងជើងរបស់គាត់
«យកភួយរបស់គាត់ចេញ ពីជើងរបស់គាត់»
ដេកនៅទីនោះ
«ក្រាបទៀបនៅជើងរបស់លោក»
Ruth 3:8
វាបានកើតឡើង
ឃ្លានេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
បើភាសារបស់អ្នក មានមធ្យោបាយសម្រាប់បកប្រែពាក្យនេះ
អ្នកអាចពិចារណាប្រើវានៅទីនេះបាន។
ពេលពាក់កណ្តាលអាធ្រាត្រ
«នៅពាក់កណ្តាលយប់»
ផ្តើមភ្ញាក់ឡើង
គេមិនទាន់ដឹងច្បាស់អំពីអ្វី ដែលលោកបូអូសបានភ្ញាក់ផ្អើលនោះទេ។
ប្រហែលជាភ្លាមៗគាត់មានអារម្មណ៍ថាមានខ្យល់ត្រជាក់នៅលើជើងរបស់គាត់។
គាត់ប្រែខ្លួន
គាត់សម្លឹងមើលអ្វីដែល ធ្វើឲ្យគាត់ភ្ញាក់ឡើង។
មានស្ត្រីម្នាក់ដេកនៅចុងជើងរបស់គាត់
ស្ត្រីនោះគឺនាងរស់ ប៉ុន្តែលោកបូអូសមិនអាចស្គាល់នាងរស់ទេ ព្រោះងងឹត។
ស្រីបម្រើរបស់លោក
នាងរស់បាននិយាយដោយចិត្តរាបសារចំពោះលោកបូអូស។
សូមលោកម្ចាស់មេត្តាទទួលនាងខ្ញុំជាភរិយាផង
នេះគឺជានិមិត្តរូបវប្បធម៌ សម្រាប់អាពាហ៍ពិពាហ៍។ ការបកប្រែផ្សេងទៀត
"រៀបការជាមួយខ្ញុំ"
លោកមានភារកិច្ចទទួលបន្ទុកថែរក្សា
ជាសាច់ញាតិជិតស្និទ្ធ ដែលមានទំនួលខុសត្រូវពិសេសចំពោះក្រុមគ្រួសារ
Ruth 3:10
នាងអើយ
លោកបូអូសបានប្រើពាក្យនេះជាសញ្ញាសម្គាល់ នៃការគោរពចំពោះនាងរស់
ដែលជាស្ត្រីវ័យក្មេង។
ភាពស្មោះត្រង់លើសពីលើកមុនទៅទៀត
"រឹតតែមានសេចក្តីសប្បុរសច្រើនជាងមុនទៅទៀត"
ស្មោះត្រង់លើសពីលើកមុន
នេះសំដៅទៅលើនាងរស់ សុំឲ្យលោកបូអូសរៀបការជាមួយនាង។
ដោយរៀបការជាមួយញាតិសន្តានរបស់នាងណាអូមី
នាងរស់នឹងផ្គត់ផ្គង់ដល់នាងណាអូមី
ហើយបង្ហាញសេចក្តីសប្បុរសដ៏អស្ចារ្យចំពោះនាងណាអូមី។
លើកមុនទៅទៀត
សំដៅទៅលើរបៀបដែលនាងរស់ បានផ្គត់ផ្គង់ម្តាយក្មេករបស់នាងមុន
ដោយស្នាក់នៅជាមួយនាង និងប្រមូលគ្រាប់ធញ្ញជាតិជាអាហារសម្រាប់ពួកគេ។
ព្រោះនាងមិនបានទៅតាម
«អ្នកមិនបានរៀបការជាមួយទេ»។
នាងរស់អាចមិនអើពើនឹងតម្រូវការរបស់នាងណាអូមី
ហើយបានរកមើលស្វាមីនៅខាងក្រៅសាច់ញាតិរបស់នាងណាអូមី។
Ruth 3:12
មានបុរសម្នាក់ដែលជាសាច់ញាតិជិតជាងខ្ញុំទៅទៀត
វាជាកាតព្វកិច្ចរបស់សាច់ញាតិប្រុស ដែលជិតស្និទ្ធបំផុតដើម្បីជួយស្ត្រីមេម៉ាយ។
ប្រសិនបើ គេចង់ទទួលខុសត្រូវលើនាង
«បើគាត់មិនរៀបការជាមួយស្ត្រីមេម៉ាយ
និងកូនប្រសារប្រុសរបស់គាត់សម្រាប់សាច់ញាតិ ដែលស្លាប់នោះ»
ដោយយកព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅ
«ព្រះអម្ចាស់ដែលមានព្រះជន្មរស់»។ នេះជាពាក្យសច្ចាភាសាហេព្រើរធម្មតា។
Ruth 3:14
នាងក៏ដេកនៅចុងជើងលោក
នាងរស់ដេកនៅជើងលោកបូអូស។ ពួកគេមិនបានរួមភេទទេ។
មុនពេលមើលស្គាល់គ្នា
ពេលវេលានៃថ្ងៃនេះអាចនិយាយអំពីភាពងងឹត។ ការបកប្រែផ្សេងទៀត
«ខណៈពេលដែលវានៅតែងងឹត»
អាវធំ
ក្រណាត់មួយដែលពាក់នៅលើស្មា
មួយតៅទៅក្នុងអាវធំរបស់នាង
ចំនួនពិតប្រាកដមិនត្រូវបានបញ្ជាក់ទេ។
វាគ្រប់គ្រាន់ហើយដែលត្រូវបានគេចាត់ទុកថាជាសប្បុរស ប៉ុន្តែ
តូចល្មមសម្រាប់នាងរស់ដើម្បីដឹកតែម្នាក់ឯង។
អ្នកខ្លះគិតថាវាប្រហែល៣០គីឡូក្រាម។
ព្រមទាំងជួយលើកឲ្យនាងទូលផង
បរិមាណគ្រាប់ធញ្ញជាតិគឺធំធេងណាស់
ដែលនាងរស់ត្រូវការជំនួយដើម្បីលើកវាឡើងដើម្បីយកទៅ។
បន្ទាប់មកលោកក៏វិលចូលទៅភូមិវិញ
ច្បាប់ចម្លងបុរាណភាគច្រើនមាន «គាត់បានទៅ» ប៉ុន្តែខ្លះមាន «នាងបានទៅ» ។
ភាសាអង់គ្លេសមានទាំងពីរ។ ជម្រើសល្អប្រសើរគឺ "គាត់បានទៅ" ។
Ruth 3:16
តើយ៉ាងដូចម្តេចហើយ កូនស្រី?
អ្វីដែលនាងរស់ចង់និយាយត្រង់សំណួរនេះ អាចបញ្ជាក់កាន់តែច្បាស់។
ការបកប្រែផ្សេងទៀត "តើមានអ្វីកើតឡើងកូនស្រី?" ឬ
«លោកបូអូសបានប្រព្រឹត្តយ៉ាងណាចំពោះកូន?
អំពីអ្វីដែលលោកបូអូសបានធ្វើចំពោះនាង
«អ្វីៗទាំងអស់ដែលលោកបូអូសបានធ្វើ»
នាងមិនត្រូវទៅផ្ទះវិញដៃទទេឡើយ
«កុំទៅដោយដៃទទេ» ឬ «កុំទៅដោយគ្មានអ្វីសោះ» ឬ «ត្រូវប្រាកដថា
យកអ្វីមួយ»
បានសម្រេចនៅថ្ងៃនេះ
សំដៅទៅលើការសម្រេចចិត្តថា តើអ្នកណានឹងទិញទ្រព្យសម្បត្តិរបស់នាងណាអូមី
ហើយរៀបការជាមួយនាងរស់។

---

4 [1]លោកបូអូសបានទៅដល់ទ្វារក្រុង ហើយអង្គុយនៅទីនោះ។ ពេលនោះបុរសជាញាតិជិតបំផុត ដែលលោកបាននិយាយបានមកដល់។
លោកបូអូសមានប្រសាសន៍ទៅគាត់ថា៖ «សូមចូលមកហើយអង្គុយទីនេះសិន»។ បុរសនោះបានមកហើយអង្គុយចុះ។
[2]លោកបូអូសបានអញ្ជើញចាស់ទុំនៃក្រុងនេះចំនួនដប់នាក់មក រួចពោលឡើងថា «សូមអញ្ជើញអង្គុយនៅទីនេះសិន»។ ដូច្នេះពួកគេបានអង្គុយចុះ។
[3]លោកបូអូសមានប្រសាសន៍ទៅកាន់ញាតិជិតបំផុតនោះថា៖ «បងស្រីណាអូមី ដែលបានត្រឡប់មកពីស្រុកម៉ូអាប់វិញ
ហើយគាត់ចង់លក់ដីស្រែដែលជាកម្មសិទ្ធិរបស់បងអេលីម៉ាឡេក។[4]ខ្ញុំគិតថាគួរតែជម្រាបបង សូមឲ្យបងទិញដីស្រែនោះ ដោយមានចាស់ទុំនៅទីនេះជាសាក្សី
និងបងប្អូនឯទៀតៗដែលមានវត្តមាននៅទីនេះជួយដឹងឮផង។ ប្រសិនបើបងចង់ទិញ បងទិញចុះ! ប៉ុន្តែ ប្រសិនបើបងមិនទិញទេ សូមប្រាប់ខ្ញុំឲ្យដឹងផង
ព្រោះនៅទីនេះមិនមានអ្នកណាមានសិទ្ធិទិញទេ គឺមានតែបង បន្ទាប់ពីបងគឺខ្ញុំ។ បុរសនោះពោលថា៖ «ខ្ញុំចង់ទិញ»។
[5]លោកបូអូសក៏មានប្រសាសន៍ទៀតថា៖ «នៅថ្ងៃដែលបងទិញដីស្រែពីបងស្រីណាអូមី នោះបងត្រូវតែយកនាងរស់សាសន៍ម៉ូអាប់ធ្វើជាភរិយាដែរ
ដើម្បីឲ្យដីនៅតែជាកម្មសិទ្ធិរបស់បងប្អូនតយើងដែលស្លាប់ទៅហើយនៅ»។[6]សាច់ញាតិនោះក៏ពោលថា៖ «បើដូច្នេះខ្ញុំមិនអាចទិញបានទេ
ព្រោះវាធ្វើឲ្យខូចប្រយោជន៍និងបាត់បង់មរតកផ្ទាល់ខ្លួនរបស់ខ្ញុំ។ ដូច្នេះ ប្អូនអាចមានសិទ្ធិទិញយកដីនេះ ប្អូនទិញចុះ»។
[7]កាលដើមឡើយនៅក្នុងស្រុកអ៊ីស្រាអែលនៅពេលដែលគេទិញទ្រព្យសម្បត្តិ ឬផ្ទេរកម្មសិទ្ធិអ្វីមួយ ពួកគេមានទម្លាប់ដោះស្បែកជើងហុចឲ្យគ្នាទៅវិញទៅមក
ដើម្បីទុកជាសញ្ញាបញ្ជាក់ថា គេបានព្រមព្រៀងគ្នា ក្នុងស្រុកអ៊ីស្រាអែល។[8]ដូច្នេះ បុរសជាញាតិជិតបំផុតមានប្រសាសន៍ទៅលោកបូអូសថា៖ «សូមប្អូនទិញវាចុះ!»
ហើយលោកក៏ដោះស្បែកជើងរបស់លោក។
[9]លោកបូអូសក៏មានប្រសាសន៍ទៅកាន់ចាស់ទុំនិងមនុស្សទាំងអស់ថា៖ «ថ្ងៃនេះអ្នករាល់គ្នាគឺជាសាក្សី ថាខ្ញុំបានទិញអ្វីៗទាំងអស់ដែលជារបស់បងប្រុសអេលីម៉ាឡេក
រួមទាំងអ្វីៗដែលជារបស់គីលីយ៉ូន និងម៉ាឡូន ពីបងស្រីណាអូមី។[10]ខ្ញុំក៏សូមយកនាងរស់សាសន៍ម៉ូអាប់ ជាប្រពន្ធរបស់ម៉ាឡូន មកធ្វើជាប្រពន្ធរបស់ខ្ញុំដែល

generated on Wed Sep 10 16:16:32 2025

ដើម្បីឲ្យកេរ្តិ៍មរតករបស់គាត់នៅតែជារបស់គាត់ដដែល ហើយខ្ញុំនឹងបន្តពូជពង្សឲ្យទាត់ដើម្បីរក្សាឈ្មោះរបស់គាត់
ដើម្បីរក្សាឈ្មោះរបស់គាត់ឲ្យនៅគង់វង្សក្នុងចំណោមបងប្អូនរបស់គាត់និង នៅទ្វារក្រុងនេះតទៅ។
[11]មនុស្សទាំងអស់ និងចាស់ទុំដែលនៅទីនោះក៏និយាយថា៖ «យើងទាំងអស់គ្នាសាក្សីហើយ!
សូមព្រះអម្ចាស់ប្រោសប្រទានឲ្យស្ត្រីដែលចូលមកក្នុងផ្ទះរបស់លោកបានដូចជានាងរ៉ាជែល និងនាងលេអា
គឺដូចជាស្ត្រីទាំងពីរនាក់ដែលបានបង្កើតជនជាតិអ៊ីស្រាអែលដែរ! សូមឲ្យលោកមានទ្រព្យសម្បត្តិស្តុកស្តម្ភនៅអេប្រាតា និងមានកេរ្តិ៍ឈ្មោះល្បីនៅភូមិបេថ្លេហិម។
[12]សូមព្រះអម្ចាស់ប្រទានពរឲ្យលោក និងនាងមានកូនចៅច្រើន ដូចជាគ្រួសាររបស់លោកពេរេស ជាកូនរបស់លោកយូដា និងនាងតាម៉ារដែរ!»
[13]នោះលោកបូអូសបានយកនាងរស់ធ្វើជាភរិយា។ លោកបានរួមរស់នឹងនាង ហើយព្រះអម្ចាស់បានប្រទានឲ្យនាងមានផ្ទៃពោះ និងសម្រាលបានកូនប្រុសមួយ។
[14]ពួកស្ត្រីៗនិយាយទៅកាន់នាងណាអូមីថា៖ «សូមអរព្រះគុណព្រះអម្ចាស់ ដែលបានប្រទានចៅប្រុសមកឲ្យនាង
ដោយមិនបានទុកឲ្យនាងរស់នៅដោយមិនមានសាច់ញាតិ។ សូមឲ្យចៅរបស់អ្នកមានឈ្មោះល្បីក្នុងស្រុកអ៊ីស្រាអែល។
[15]សូមឲ្យចៅនេះស្តារជីវិតរបស់អ្នកឲ្យមានសុភមង្គលឡើងវិញ ដ្បិត កូននេះបានកើតពីកូនប្រសារដែលនាងស្រឡាញ់
ជាកូនដែលប្រសើរជាងកូនប្រុសប្រាំពីរនាក់ទៅទៀត។
[16]នាងណាអូមីយកទារក ទៅផ្តេកនៅក្នុងដើមទ្រូងរបស់គាត់ ហើយបីបាច់ថែរក្សាទារកនោះ។[17]ស្ត្រីអ្នកជិតខាងទាំងនោះបានពោលថា៖ «នាងណាអូមីមានកូនប្រុសមួយ»។
គេហៅគាត់ថា៖ «អូបេឌ»។ លោកអូបេឌនេះហើយជាឪពុករបស់លោកអ៊ីសាយ ដែលជាបិតារបស់ព្រះបាទដាវីឌ។
[18]នេះជាពូជពង្សលោកពេរេស លោកពេរេសជាឪពុកលោកហេតស្រុន[19]លោកហេតស្រុនជាឪពុកលោករ៉ាម
លោករ៉ាមជាឪពុកលោកអមីណាដាប់[20]លោកអមីណាដាប់ជាឪពុកលោកណាសូន លោកណាសូនជាឪពុកលោកសាលម៉ូន[21]លោកសាលម៉ូនជាឪពុកលោកបូអាស
លោកបូអាសជាឪពុកលោកអូបេដ[22]លោកអូបេដជាឪពុកលោកអ៊ីសាយ លោកអ៊ីសាយជាឪពុកព្រះបាទដាវីឌ។

Ruth 4:1

ទ្វារក្រុង

«ច្រកទ្វារទីក្រុង» ឬ «ទ្វារក្រុងបេថ្លេហិម» ។
នេះជាច្រកចូលសំខាន់ទៅក្រុងបេថ្លេហិម ដែលមានកំពែងព័ទ្ធជុំវិញ។
មានកន្លែងមួយនៅជិតខ្លោងទ្វារ
ដែលត្រូវបានប្រើជាកន្លែងប្រជុំពិភាក្សាអំពីបញ្ហាសហគមន៍។

បុរសជាញាតិជិតបំផុត

នេះជាសាច់ញាតិរស់នៅជិតបំផុតជាមួយលោកអេលីម៉ាលេក។

ចាស់ទុំនៃក្រុង

«មេដឹកនាំទីក្រុង»

Ruth 4:3

ណាអូមី....លក់ដីស្រែ

វាជាទំនួលខុសត្រូវរបស់ញាតិសន្តាន ក្នុងការទិញដីរបស់ញាតិសន្តាន
និងថែរក្សាគ្រួសាររបស់គាត់។ ក្នុងករណីនេះ
មានន័យថាបុរសនោះត្រូវទិញដីរបស់នាងណាអូមី រៀបការជាមួយនាងរស់
និងមើលថែនាងណាអូមី។

មានចាស់ទុំនៅទីនេះជាសាក្សី

នឹងធ្វើឲ្យដំណើរមានលក្ខណៈស្របច្បាប់ និងចងសម្ព័ន្ធ។

ចង់ទិញ

មានន័យថា ទិញដីដើម្បីទុកវានៅក្នុងគ្រួសាររបស់ពួកគេ។

ពីបងគឺខ្ញុំ

លោកបូអូសជាញាតិសន្តានជិតជាងគេ ដើម្បីលោះដី។

Ruth 4:5

នៅថ្ងៃដែលបងទិញដីស្រែពីបងស្រីណាអូមី នោះបងត្រូវតែ

លោកបូអូសប្រើការបញ្ចេញមតិនេះ ដើម្បីជូនដំណឹងដល់សាច់ញាតិរបស់គាត់
អំពីទំនួលខុសត្រូវបន្ថែម ដែលគាត់នឹងមាន បើគាត់ទិញដី។

ដីស្រែពីបងស្រីណាអូមី

«ពីភាពជាកម្មសិទ្ធិរបស់នាងណាអូមី»

បងត្រូវតែយកនាងរស់សាសន៍ម៉ូអាប់ធ្វើជាភរិយាដែរ

«បងក៏ត្រូវរៀបការជាមួយនាងរស់ដែរ»

នាងរស់..ជាកម្មសិទ្ធិរបស់បងប្អូនតយើងដែលស្លាប់ទៅហើយនៅ

«នាងរស់...ស្ត្រីមេម៉ាយដែលការជាមួយកូនប្រុសរបស់លោកអេលីម៉ាលេក»

ដើម្បីឲ្យដីនៅតែជាកម្មសិទ្ធិរបស់បងប្អូនតយើងដែលស្លាប់ទៅហើយនៅ

«ដើម្បីឲ្យនាងអាចមានកូនប្រុសម្នាក់
ដើម្បីទទួលមរតកនិងយកឈ្មោះប្តីដែលបានស្លាប់ទៅ»

ធ្វើឲ្យខូចប្រយោជន៍ និងបាត់បង់មរតកផ្ទាល់ខ្លួនរបស់ខ្ញុំ

គាត់ត្រូវតែប្រគល់ទ្រព្យសម្បត្តិខ្លះដល់កូនៗ ដែលនាងរស់មាន។

ប្អូនអាចមានសិទ្ធិទិញយកដីនេះ ប្អូនទិញចុះ

«ប្អូនលោះវាដោយខ្លួនឯង» «ប្អូនខ្លួនឯងលោះវាជំនួសបងចុះ»

Ruth 4:7

ឥឡូវនេះជាទំនៀមទម្លាប់

អ្នកនិពន្ធកណ្ឌគម្ពីរនេះពន្យល់ពីទំនៀមទម្លាប់
នៃការផ្លាស់ប្តូរកំឡុងពេលរបស់នាងរស់

កាលដើមឡើយ

«នៅសម័យមុន» បញ្ជាក់ថាទំនៀមទម្លាប់បានផ្លាស់ប្តូរពីរឿងរ៉ាវកើតឡើង
រហូតដល់កណ្ឌគម្ពីរនេះត្រូវបានសរសេរ។

ស្បែកជើង

«ស្បែកជើង»

អ្នកជិតខាងរបស់គាត់

សំដៅទៅលើបុគ្គលដែលគាត់បានព្រមព្រៀង។ ក្នុងស្ថានភាពនេះ
ញាតិសន្តានជិតជាងគេឲ្យស្បែកជើងដល់លោកបូអូស។

Ruth 4:9

ចាស់ទុំនិងមនុស្សទាំងអស់

សំដៅទៅលើមនុស្សទាំងអស់ ដែលមានវត្តមាននៅកន្លែងប្រជុំ
មិនមែនសម្រាប់អ្នករាល់គ្នានៅក្នុងទីក្រុងនោះទេ។

ទាំងអស់ដែលជារបស់បងប្រុសអេលីម៉ាឡេក រួមទាំងអ្វីៗដែលជារបស់គីលីយ៉ូន និងម៉ាឡូន

សំដៅទៅលើដី និងទ្រព្យសម្បត្តិទាំងអស់របស់ប្តីនាង
និងកូនប្រុសរបស់នាងណាអូមី ដែលបានស្លាប់។

ពីបងស្រីណាអូមី

ដៃរបស់នាងណាអូមីតំណាងឲ្យនាងណាអូមី។
នាងទទួលខុសត្រូវចំពោះការប្តូរប្រាក់។ការបកប្រែផ្សេងទៀត «មកពីនាងណាអូមី»

ដើម្បីឲ្យកេរមរតករបស់គាត់នៅតែជារបស់គាត់ដដែល

កូនប្រុសទីមួយ ដែលនាងរស់បង្កើតនឹងត្រូវចាត់ទុកជាកូនប្រុសរបស់លោកម៉ាឡូន
ហើយនឹងទទួលដីជាមរតក ដែលលោកបូអូសបានទិញពីនាងណាអូមី។
ការបកប្រែផ្សេងទៀត «ដូច្នេះ ខ្ញុំអាចផ្តល់ឲ្យកូនប្រុសរបស់នាង
ដែលនឹងទទួលមរតកជាទ្រព្យសម្បត្តិរបស់អ្នកដែលបានស្លាប់»

ដើម្បីរក្សាឈ្មោះរបស់គាត់ឲ្យនៅគង់វង្សក្នុងចំណោមបងប្អូនរបស់គាត់និង នៅទ្វារក្រុងនេះតទៅ

ការដែលគេភ្លេចត្រូវបានគេនិយាយ
ដូចជាឈ្មោះរបស់មនុស្សម្នាក់ត្រូវបានគេកាត់ចេញពីបញ្ជីមនុស្ស
ដែលបានរស់នៅមុននេះ។ ការបកប្រែផ្សេងទៀត
«ដើម្បីកុំឲ្យគាត់ភ្លេចកូនចៅរបស់បងប្អូនគាត់ និងប្រជាជនក្នុងទីក្រុងនេះ»

នៅទ្វារក្រុងនេះតទៅ

ច្រកទ្វារទីក្រុងជាកន្លែង ដែលមានការសម្រេចចិត្តស្របច្បាប់សំខាន់ៗ
ដូចជាការសម្រេចចិត្តថាតើ អ្នកណាជាម្ចាស់ដីមួយចំណែក។

Ruth 4:11

មនុស្សទាំងអស់ និងចាស់ទុំដែលនៅទីនោះ

"មនុស្សដែលកំពុងជួបជុំគ្នានៅជិតខ្លោងទ្វារ"

ចូលមកក្នុងផ្ទះរបស់លោក

មានទាំងន័យត្រង់ និងន័យធៀប។ កាលណានាងរស់រៀបការជាមួយលោកបូអូស
នាងនឹងរើផ្ទះទៅរស់នៅជាមួយគាត់។ ផ្ទះក៏អាចសំដៅទៅលើការក្លាយជាសមាជិក
នៃក្រុមគ្រួសាររបស់លោកបូអូស ដោយធ្វើជាភរិយារបស់គាត់។

ដូចជានាងរ៉ាជែល និងនាងលេអា

អ្នកទាំងពីរនាក់នេះជាភរិយារបស់លោកយ៉ាកុប
ដែលបានប្តូរឈ្មោះទៅជាអ៊ីស្រាអែល។

generated on Wed Sep 10 16:16:32 2025

បង្កើតជនជាតិអ៊ីស្រាអែល
«បង្កើតបានកូនជាច្រើន ដែលបានក្លាយជាប្រជាជាតិអ៊ីស្រាអែល»
សូមឲ្យលោកមានទ្រព្យសម្បត្តិស្តុកស្តុម្តនៅអេប្រាតា
អេប្រាតាជាឈ្មោះរបស់ត្រកូល ដែលលោបូអូសជាកម្មសិទ្ធិនៅភូមិបេថ្លេហិម។
សូមព្រះអម្ចាស់ប្រទានពរឲ្យលោក
ព្រះជាម្ចាស់បានប្រទានពរយ៉ាងបរិបូណ៌ដល់ស្រុកយូដាតាមរយៈកូនប្រុសរបស់គាត់ឈ្មោះ**ពេរេស**
ប្រជាជនសូមឲ្យព្រះជាម្ចាស់ប្រទានពរដល់លោកបូអូស តាមរបៀបស្រដៀងគ្នា
គឺតាមរយៈកូនៗរបស់នាងរស់។
លោកយូដា និងនាងតាម៉ារ
នាងតាម៉ាក៏ជាស្ត្រីមេម៉ាយដែរ។ កុលសម្ព័ន្ធយូដាបានបង្កើតកូនប្រុសមួយឲ្យនាង។
ព្រះអម្ចាស់ប្រទានពរឲ្យលោក និងនាងមានកូនចៅច្រើន
ព្រះអម្ចាស់នឹងប្រទានកូនចៅលោកបូអូសតាមរយៈនាងរស់។
Ruth 4:13
លោកបូអូសបានយកនាងរស់ធ្វើជាភរិយា
« លោកបូអូសបានរៀបការជាមួយនាងរស់» ឬ«
លោកបូអូសបានយកនាងរស់ធ្វើជាប្រពន្ធ»
លោកបានរួមរស់នឹងនាង
«គាត់បានរួមភេទជាមួយនាង»
ដោយមិនបានទុកឲ្យនាងរស់នៅដោយមិនមានសាច់ញាតិ
«អ្នកដែលបានផ្តល់ឲ្យអ្នក នូវសាច់ញាតិជិតស្និទ្ធិនាពេលបច្ចុប្បន្ននេះ»
សូមឲ្យចៅរបស់អ្នកមានឈ្មោះល្បីក្នុងស្រុកអ៊ីស្រាអែល
សំដៅទៅលើកេរ្តិ៍ឈ្មោះ និងចរិតរបស់ចៅប្រុសនាងណាអូមី។
សូមឲ្យចៅនេះស្តារជីវិត
ឃ្លានេះប្រហែលជាសំដៅទៅលើរបៀប ដែលនាងណាអូមីនឹងមានអំណរ
និងក្តីសង្ឃឹមម្តងទៀតនៅក្នុងជីវិតរបស់នាង
ដែលជាលទ្ធផលនៃទទួលបានចៅប្រុសថ្មី។
«អ្នកដែលនាំសេចក្តីអំណរដល់អ្នកម្តងទៀត» ឬ
«អ្នកដែលធ្វើឲ្យអ្នកមានអារម្មណ៍ថា ក្មេងម្តងទៀត»
ឲ្យមានសុភមង្គលឡើងវិញ
«គាត់នឹងមើលថែអ្នកពេលអ្នកចាស់»
ប្រសើរជាងកូនប្រុសប្រាំពីរនាក់ទៅទៀត
«ប្រាំពីរ» ជាចំនួនក្នុងភាសាហេព្រើរ មានន័យថាពេញលេញ។
ពេរេសបានស្លាប់ មុនពេលពួកគេបង្កើតកូនចៅ
ប៉ុន្តែ នាងរស់បានបង្កើតចៅប្រុសឲ្យនាងណាអូមី តាមរយៈលោកបូអូស។
ការបកប្រែផ្សេងទៀត «ប្រសើរជាងកូនប្រុស»
Ruth 4:16
នាងណាអូមីយកទារក
សំដៅទៅលើនាងណាអូមីកាន់កូននោះ។ ត្រូវប្រាកដថា វាមិនស្តាប់ទៅដូចជា
នាងណាអូមីយកកូនចេញពីនាងរស់ឡើយ។
ទៅផ្តេកនៅក្នុងដើមទ្រូងរបស់គាត់
«បានឱបកូននោះជាប់នឹងទ្រូងរបស់នាង» នេះជាការបង្ហាញសេចក្តីស្រឡាញ់
និងការថ្នាក់ថ្នមចំពោះកុមារ។
នាងណាអូមីមានកូនប្រុសមួយ
«កូននេះដូចជាកូនប្រុសរបស់នាងណាអូមី» ។ គេយល់ថា
ក្មេងនោះជាចៅប្រុសរបស់នាងណាអូមី មិនមែនជាកូនប្រុសបង្កើតរបស់នាងទេ។
ជាបិតារបស់ព្រះបាទដាវីឌ
«ឪពុករបស់ស្តេចដាវីឌ» ។ ទោះបីជា «ស្តេច» មិនត្រូវបានបញ្ជាក់ក៏ដោយ
ក៏អ្នកអានកាលដើមដឹងច្បាស់ថាដាវីឌ គឺជាស្តេចដាវីឌ។
Ruth 4:18
ជាពូជពង្សលោកពេរេស
"កូនចៅបន្តបន្ទាប់" ។ ដោយសារតែបានបញ្ជាក់ខាងដើមថា
លោកលោកពេរេសជាកូនប្រុសរបស់យូដា អ្នកនិពន្ធបន្តចុះបញ្ជីត្រកូល
ដែលកើតចេញមកពីលោកពេរេស។
ហេតស្រុន..លោករ៉ាម

១ សាំយូអែល

1 [1]មានបុរសម្នាក់ដែលរស់នៅភូមិរ៉ាម៉ាថែម-សូភីម នៃតំបន់ភ្នំអេប្រាអ៊ីម គាត់ឈ្មោះលោកអែលកាណា ជាកូនប្រុសរបស់លោកយេរ៉ូហាំ ជាចៅរបស់លោកអេលីហ៊ូវ
ជាចៅទួតរបស់លោកថូហ៊ូវ និងជាចៅលួតរបស់លោកស៊ូភ ជាអ្នកកុលសម្ព័ន្ធអេប្រាអ៊ីម។[2]លោកមានប្រពន្ធពីរនាក់ ប្រពន្ធទីមួយឈ្មោះនាងហាណា
ហើយប្រពន្ធទីពីរឈ្មោះនាងពេនីណា។ នាងពេនីណាមានកូន តែនាងហាណាគ្មានកូនទេ។
[3]បុរសនេះបានចាកចេញពីក្រុងរបស់គាត់នៅឆ្នាំបន្ទាប់ ដើម្បីទៅថ្វាយបង្គំ និងថ្វាយតង្វាយដល់ព្រះអម្ចាស់នៃពួកពលបរិវារនៅឯស៊ីឡូផង។ កាលនោះ
លោកអេលីមានកូនប្រុសពីរនាក់ ម្នាក់ឈ្មោះហុបនី និងម្នាក់ទៀតឈ្មោះភីនេហាស ជាបូជាចារ្យរបស់ព្រះអម្ចាស់នៅទីនោះ។[4]កាលថ្ងៃដែលលោកអែលកាណា
ត្រូវថ្វាយដង្វាយរៀងរាល់ឆ្នាំបានមកដល់ ហើយលោកតែងឲ្យចំណែកនៃសាច់ខ្លះទៅនាងពីនេណា ភរិយារបស់គាត់ និងកូនប្រុសៗ និងកូនស្រីៗរបស់នាងផងដែរ។
[5]ចំណែកឯនាងហាណាវិញ លោកតែងឲ្យនាងទ្វេដង ពីព្រោះលោកស្រឡាញ់នាងហាណាជាង ថ្វីបើព្រះអម្ចាស់បានខ្ទប់ផ្ទៃនាងមិនឲ្យមានកូនក្តី។
[6]គូប្រជែងរបស់នាងបានបង្ករឿងនឹងនាងយ៉ាងខ្លាំងដើម្បីឲ្យនាងខឹង ដ្បិត ព្រះអម្ចាស់បានខ្ទប់ផ្ទៃនាងមិនឲ្យមានកូនបាន។
[7]រៀងរាល់ឆ្នាំនៅពេលនាងធ្វើដំណើរទៅព្រះដំណាក់នៃព្រះអម្ចាស់ជាមួយគ្រួសាររបស់នាង គូប្រជែងរបស់នាងតែងតែបង្ករឿងដាក់នាងជានិច្ច។ ហេតុដូច្នេះហើយ
ទើបនាងយំ ហើយមិនទទួលទានអ្វីទាំងអស់។[8]ឯលោកអែលកាណាជាប្តី តែងនិយាយទៅនាងថា ៖ «ហាណា ហេតុអ្វីអូនយំដូច្នេះ? ហេតុអ្វីអូនមិនទទួលទាន?
ហេតុអ្វីបានជាចិត្តរបស់អូនមិនរីករាយ? តើបងមិនប្រសើរជាងអូនមានកូនប្រុសដប់នាក់ទេឬអី?»
[9]ក្នុងឱកាសនោះ បន្ទាប់ពីទទួលទានអាហារ និងពិសាទឹកនៅឯស៊ីឡូរួច នាងហាណាក៏បានក្រោកឡើង។ លោកអេលីជា
បូជាចារ្យកំពុងអង្គុយនៅកន្លែងរបស់គាត់ជិតមាត់ទ្វារចូលព្រះវិហារ របស់ព្រះអម្ចាស់នៅពេលនោះ។[10]នាងតូចចិត្តយ៉ាងខ្លាំង
ហើយនាងបានទូលអង្វរដល់ព្រះអម្ចាស់ទាំងទឹកភ្នែកហូរយ៉ាងជូរចត់។
[11]នាងបានស្បថដោយនិយាយថា៖ «ឱព្រះអម្ចាស់នៃពួកពលបរិវារអើយ បើព្រះអង្គទតមកខ្ញុំម្ចាស់ជាអ្នកបម្រើរបស់ព្រះអង្គដែលកំពុងមានទុក្ខនេះ
សូមព្រះអង្គនឹកដល់ខ្ញុំម្ចាស់ សូមកុំភ្លេចខ្ញុំម្ចាស់ជាអ្នកបម្រើរបស់ព្រះអង្គឡើយ ប៉ុន្តែ សូមប្រទានកូនប្រុសមួយដល់ ខ្ញុំម្ចាស់វិញ
នោះខ្ញុំម្ចាស់នឹងយកកូននោះមកថ្វាយព្រះអម្ចាស់ដើម្បីបម្រើព្រះអង្គអស់មួយជីវិត ហើយសក់របស់កូននោះនឹងមិនត្រូវកាត់ ឬកោរឡើយ»។
[12]ខណៈនាងនៅតែទូលនៅចំពោះព្រះអម្ចាស់នៅឡើយ លោកអេលីបានសម្លឹងមើលមាត់របស់នាង។[13]នាងហាណាបាននិយាយនៅក្នុងចិត្តរបស់នាង
បបូរមាត់របស់នាងហើបតិចៗ ប៉ុន្តែ មិនឮសម្លេងឡើយ។ ហេតុដូច្នេះហើយ ទើបលោកអេលីបានគិតថា នាងស្រវឹង។[14]លោកអេលីបានមានប្រសាសន៍ទៅនាងថា៖
«តើនាងនៅស្រវឹងដល់កាលណាទៀត? ចូរឈប់ផឹកស្រាទៅ»។
[15]នាងហាណាបានតបថា៖ «ទេ លោកម្ចាស់ នាងខ្ញុំជាស្ត្រីរងទុក្ខ។ នាងខ្ញុំមិនស្រវឹង ក៏ពុំបានសេពសុរាដែរ ប៉ុន្តែ
ខ្ញុំគ្រាន់តែទូលថ្វាយព្រះអម្ចាស់នូវភាពតានតឹងនៃព្រលឹងនាងខ្ញុំប៉ុណ្ណោះ។[16]សូមកុំគិតអ្វីអាក្រក់ចំពោះនាងខ្ញុំឡើយ
នាងខ្ញុំបាននិយាយចេញពីកង្វល់ដ៏លើសលប់របស់នាងខ្ញុំចេញមកទេតើ»។
[17]ក្រោយមក លោកអេលីក៏បានឆ្លើយដោយនិយាយថា៖ «ចូរត្រឡប់ទៅវិញដោយសុខសាន្តចុះ សូមព្រះជាម្ចាស់នៃអ៊ី
ស្រាអែលប្រទានតាមសំណូមពរដែលនាងបានទូលសុំពីព្រះអង្គចុះ»។[18]រួចនាងតបថា៖ «សូមឲ្យនាងខ្ញុំទទួលក្តីមេត្តានៅចំពោះមុខលោកផងចុះ»។
បន្ទាប់មកនាងក៏ចេញទៅ ហើយទទួលទាន ទឹកមុខរបស់នាងស្រស់បស់ គ្មានទុក្ខព្រួយទៀតទេ។
[19]ពួកគេបានក្រោកពីព្រឹកព្រលឹម ហើយបានថ្វាយបង្គំព្រះអម្ចាស់ រួចបានត្រឡប់ទៅផ្ទះរបស់ពួកគេវិញនៅឯរ៉ាម៉ា។ លោកអែលកាណា បានរួមរស់ជាមួយនាងហាណា
ជាប្រពន្ធ ហើយព្រះអម្ចាស់ក៏បាននឹកចាំពីនាង។[20]គ្រានោះក៏មកដល់ នាងហាណាបានមានផ្ទៃពោះ ហើយសម្រាលបានកូនប្រុសមួយ។ នាងបានហៅឈ្មោះកូននោះថា
សាំយូអែល ដោយពោលថា៖ «ដោយព្រោះខ្ញុំបានទូលសុំកូននេះពីព្រះអម្ចាស់»។

generated on Wed Sep 10 16:16:32 2025

[21]ជាថ្មីម្តងទៀត លោកអែលកាណាព្រមទាំងអ្នកផ្ទះរបស់លោកបាន ធ្វើដំណើរទៅថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ជាតង្វាយប្រចាំឆ្នាំ ហើយដើម្បីលាបំណន់របស់លោក។
[22]ប៉ុន្តែ នាងហាណាពុំបានទៅទេ ដោយនាងបានប្រាប់ទៅប្តីរបស់នាងថា៖ «ខ្ញុំនឹងមិនទៅទេ រហូតដល់កូននេះផ្តាច់ដោះសិន ទើបខ្ញុំយកកូនឡើងទៅដែរ ដូច្នេះ
កូននេះនឹងបាននៅទីនោះជាមួយព្រះអម្ចាស់ជារៀងរហូត»។[23]លោកអែលកាណាជាប្តីបានតបទៅនាងវិញថា៖ «ចូរធ្វើអ្វីដែលអូនគិតថាល្អចុះ។
ចូររង់ចាំរហូតដល់ផ្តាច់ដោះកូនចុះ ហើយសូមឲ្យព្រះអម្ចាស់សម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គ»។ ដូច្នេះ នាងក៏បាននៅ
រួចមើលថែកូនប្រុសរបស់នាងរហូតដល់ផ្តាច់ដោះ។
[24]ពេលនាងបានផ្តាច់ដោះកូន នាងក៏បានយកកូននោះតាម រួមទាំងកូនគោឈ្មោល៣ខួបទៅជាមួយ និងអាហារមួយចាំង ស្រាទំពាំងបាយជូរមួយដបផង។
រួចបានធ្វើដំណើរទៅព្រះដំណាក់របស់ព្រះអម្ចាស់នៅឯស៊ីឡូ។ ពេលនោះកូននៅតូចនៅឡើយ។[25]គេក៏បានយកកូនគោទៅសម្លាប់ ហើយយកកូននោះទៅជូនលោកអេលី។
[26]នាងបាននិយាយថា៖ «លោកម្ចាស់ ដូចលោកម្ចាស់នៅមានជីវិតនៅឡើយ គឺនាងខ្ញុំនេះហើយជាស្ត្រីដែលបានឈរជិតលោកហើយទូលអង្វរទៅព្រះអម្ចាស់។
[27]គឺទូលសុំកូននេះ ហើយព្រះអម្ចាស់បានប្រទានមកតាមពាក្យរបស់នាងខ្ញុំ[28]ខ្ញុំក៏យកកូននេះមកឲ្យនៅជាមួយព្រះអម្ចាស់អស់មួយជីវិតដែរ»។ បន្ទាប់មក
លោកក៏បានថ្វាយបង្គំព្រះអម្ចាស់នៅទីនោះ។

---

1 Samuel 1:1

ភូមិរ៉ាម៉ាថែម

នេះជាឈ្មោះភូមិតូចមួយ ដែលអាចមានចម្ងាយ៨
គីឡូម៉ែត្រភាគពាយព្យនៃក្រុងយេរូសាឡឹម។

សូភីម

នេះជាឈ្មោះក្រុមមនុស្ស ដែលមានកំណើតពីលោកស៊ូភ

លោកអែលកាណា ... លោកយេរ៉ូហាំ ... លោកអេលីហ៊ូវ... លោកថូហ៊ូវ ... លោកស៊ូភ

ទាំងនេះជាឈ្មោះរបស់បុរស។

នាងពេនីណា

នេះជាឈ្មោះរបស់ស្ត្រី។

1 Samuel 1:3

បុរសនេះ

«បុរសនេះ»សំដៅទៅលើលោកអែលកាណា។

ព្រះអម្ចាស់

នេះជាព្រះនាមរបស់ព្រះជាម្ចាស់ ដែលទ្រង់បានបង្ហាញដល់ប្រជាជនរបស់ព្រះអង្គ
នៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់។ សូមមើលការបកប្រែពាក្យនៅទំព័រ
ដែលនិយាយទាក់ទងអំពីព្រះអម្ចាស់ ដើម្បីដឹងពីរបៀបបកប្រែពាក្យនេះ។

លោកអេលី, ហូបនី និង ហ្វូបនី

ទាំងនេះជាឈ្មោះរបស់បុរស។

1 Samuel 1:5

នាងហាណា

នេះជាឈ្មោះរបស់ស្ត្រី។ បកប្រែដូចក្នុង១:១។

បានខ្ទប់ផ្ទៃនាងមិនឲ្យមានកូនបាន

"ធ្វើឲ្យនាងគ្មានកូន" ឬ "រារាំងនាងមិនឲ្យមានផ្ទៃពោះ"

គូប្រជែងរបស់នាងបានបង្ករឿងនឹងនាងយ៉ាងខ្លាំង

ភរិយាម្នាក់ទៀតតែងតែធ្វើឲ្យហាណា ក្រៀមក្រំចិត្ត និងអាម៉ាសមុខ។

1 Samuel 1:7

គូប្រជែងរបស់នាង

គឺជានាងពេនីណា ដែលជាភរិយាម្នាក់ទៀតរបស់លោកអែលកាណា។
គូប្រជែងគឺជាអ្នកប្រកួតប្រជែងនឹងមនុស្សម្នាក់ទៀត។ ក្នុងករណីនេះ
នាងពេនីណាបានប្រកួតប្រជែងជាមួយនាងហាណា
ដើម្បីព្យាយាមធ្វើឲ្យលោកអែលកាណាស្រឡាញ់នាងខ្លាំងជាងគេ។

ហាណា ហេតុអ្វីអូនយំដូច្នេះ? ហេតុអ្វីអូនមិនទទួលទាន? ហេតុអ្វីបានជាចិត្តរបស់អូនមិនរីករាយ?
តើបងមិនប្រសើរជាងអូនមានកូនប្រុសដប់នាក់ទេឬអី?»

សំណួរបែបវោហាស័ព្ទទាំងនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍ បើចាំបាច់។
ការបកប្រែផ្សេងទៀត «នាងហាណា អូនមិនគួរយំទេ។
អូនគួរតែញ៉ាំហើយចិត្តអូនគួរតែរីករាយព្រោះបងប្រសើរដល់អូនជាងមានកូនប្រុសដប់នាក់ទៀត»
ឬ «មានហេតុផលខ្លះនាំឲ្យអូនព្រួយចិត្ត។ បងពេញចិត្តអូន
វាគួរតែគ្រប់គ្រាន់ហើយ» ។

កូនប្រុសដប់នាក់

លោកអែលកាណាបានប្រើឃ្លានេះ
ដើម្បីបញ្ជាក់ពីសារសំខាន់របស់នាងហាណាចំពោះគាត់។ ការបកប្រែផ្សេងទៀត
«អាចប្រសើរជាងកូនប្រុសណាម្នាក់»

1 Samuel 1:9

ព័ត៌មានទូទៅ៖

នាងហាណាចាប់ផ្តើមអធិស្ឋានដល់ព្រះអម្ចាស់ ហើយលោកអេលីសម្លឹងមើល។

នាងហាណាក៏បានក្រោកឡើង។

ព័ត៌មានច្បាស់លាស់អាចបញ្ជាក់នៅទីនេះ។
ត្រសាលរបស់នាងហាណានៅជាប់នឹងព្រះពន្លា
ឬនាងដើរពីត្រសាលរបស់នាងទៅកាន់ព្រះពន្លាដើម្បីអធិស្ឋាន។
ការបកប្រែផ្សេងទៀត «នាងហាណាក្រោកឡើងទៅព្រះដំណាក់របស់ព្រះអម្ចាស់
ដើម្បីអធិស្ឋាន ក្រោយមកទៀត»

លោកអេលីជា បូជាចារ្យ

«ឥឡូវនេះ»ប្រើនៅទីនេះដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងដំណើររឿងទាំងមូល។
នៅទីនេះអ្នកនិពន្ធប្រាប់អំពីតួអង្គថ្មីនៅក្នុងសាច់រឿង។
មនុស្សនេះគឺលោកបូជាចារ្យអេលី។

នាងតូចចិត្តយ៉ាងខ្លាំង

នាងហាណាមានអារម្មណ៍តប់ប្រមល់ ឬក្រៀមក្រំជាខ្លាំងដោយសារមិនមានកូន
ហើយត្រូវបាននាងពេនីណា ដែលជាភរិយាម្នាក់ទៀតរបស់ស្វាមីនាង
សើចចំអកដាក់នាងជាប្រចាំ។

1 Samuel 1:11

ឃ្លាភ្ជាប់៖

ការអធិស្ឋានរបស់នាងហាណាទៅកាន់ព្រះអម្ចាស់ បន្តទៀត។

អ្នកបម្រើរបស់ព្រះអង្គដែលកំពុងមានទុក្ខនេះ

សំដៅទៅលើ ១) នាងហាណាដែលពុំអាចមានផ្ទៃពោះបាន ឬ ២)
វិធីដែលពេនីណាបានប្រមាថនាងជាប្រចាំ។ នាមអរូបី «ទុក្ខវេទនា»
អាចបកប្រែជាកន្សោមកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«តើខ្ញុំឈឺចាប់យ៉ាងណាព្រោះខ្ញុំមិនអាចមានផ្ទៃពោះ» ឬ
«ស្ត្រីនោះកំពុងធ្វើឲ្យខ្ញុំរងទុក្ខវេទនាយ៉ាងណា»

សូមព្រះអង្គនឹកដល់ខ្ញុំម្ចាស់

នេះជាការអង្វរដ៏ពិសេសដល់ព្រះជាម្ចាស់ ឲ្យធ្វើការជំនួសនាងហាណា។
ព្រះជាម្ចាស់ជ្រាបពីអ្វី ដែលកំពុងកើតឡើងចំពោះនាងហាណា។
ព្រះអង្គមិនបានភ្លេចនាងទេ។

សូមកុំភ្លេចខ្ញុំម្ចាស់ជាអ្នកបម្រើរបស់ព្រះអង្គឡើយ

ឃ្លានេះនិយាយស្ទើរតែដូចគ្នានឹង «សូមព្រះអង្គនឹកដល់ខ្ញុំម្ចាស់» ។

1 Samuel 1:12

លោកអេលីបានសម្លឹងមើល

លោកអេលីជានាយកបូជាចារ្យ ដូច្នេះគាត់ស្ថិតនៅក្នុងព្រះពន្លារបស់ព្រះជាម្ចាស់
និងជាអ្នកមើលខុសត្រូវលើព្រះពន្លា។

1 Samuel 1:15

នាងខ្ញុំជាស្ត្រីរងទុក្ខ

«ខ្ញុំជាស្ត្រីម្នាក់ ដែលកំពុងព្រួយចិត្តជាខ្លាំង»

ថ្វាយព្រះអម្ចាស់នូវភាពតានតឹងនៃព្រលឹងនាងខ្ញុំប៉ុណ្ណោះ

ឃ្លានេះប្រើវោហាស័ព្ទនេះមានន័យថា
«ទូលថ្វាយព្រះអម្ចាស់អស់ពីជម្រៅចិត្តរបស់នាងខ្ញុំ» ។

សូមកុំគិតអ្វីអាក្រក់ចំពោះនាងខ្ញុំឡើយ

នាងហាណានិយាយអំពីខ្លួននាងផ្ទាល់ ជាបុរសទីពីរ ដើម្បីបង្ហាញការបន្ទាបខ្លួន។
អាចបញ្ជាក់ជាបុរសទីមួយ។ ការបកប្រែផ្សេងទៀត
«កុំចាត់ទុកខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ» ឬ «កុំគិតពីខ្ញុំ»

សូមកុំគិតអ្វីអាក្រក់ចំពោះនាងខ្ញុំឡើយ

នាងខ្ញុំបាននិយាយចេញពីកង្វល់ដ៏លើសលប់របស់នាងខ្ញុំចេញមកទេតើ។
អាចនិយាយម្យ៉ាងទៀតថា នាងមាន«ទុក្ខព្រួយ»ដូចនៅក្នុង ១:១៥។ នាមអរូបី
«ភាពបរិបូរណ៍» «ការព្រួយបារម្ភ» និង
«ការបង្កហេតុ»អាចត្រូវបានបកប្រែជាគុណនាម និងកិរិយាស័ព្ទ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «សូមកុំគិតអ្វីអាក្រក់ចំពោះនាងខ្ញុំឡើយ
នាងខ្ញុំបាននិយាយចេញពីទុក្ខព្រួយដ៏លើសលប់របស់នាងខ្ញុំ
ហើយគូរប្រជែងរបស់នាងខ្ញុំរករឿងខ្ញុំណាស់»។
ការព្រួយបារម្ភនិងការបង្កហេតុ
ពាក្យទាំងពីរនេះមានន័យថា នាងហាណាមានទុក្ខព្រួយនិងរំខាន
ដោយសារតែគូប្រជែងរបស់នាងបានធ្វើឲ្យនាងខឹង។
កង្វល់
នាងពេនីណាធ្វើឲ្យនាងឆាប់ខឹង និងរំខាននាង។
ការបង្កហេតុ
នាងហាណាកំពុងសំដៅទៅលើទុក្ខព្រួយ និងភាពអាម៉ាស ដែលនាងទទួល
ព្រោះពេនីណាកំពុងធ្វើបាបនាង។
1 Samuel 1:17
ក្រោយមក លោកអេលី
លោកអេលីជាមេលើបូជាចារ្យដែលរស់នៅក្នុងព្រះពន្លា។
សូមឲ្យនាងខ្ញុំទទួលក្តីមេត្តា
នាងហាណានិយាយអំពីខ្លួនឯងជាបុរសទីពីរ
ដើម្បីបង្ហាញការគោរពដល់លោកអេលី ដែលជាបូជាចារ្យ។
អាចបញ្ជាក់ជាបុរសទីមួយ។ ការបកប្រែផ្សេងទៀត «សូមឲ្យនាងខ្ញុំទទួលក្តីមេត្តា"
ឬ "អនុញ្ញាតឲ្យខ្ញុំទទួលក្តីមេក្តា»
នៅចំពោះមុខលោកផងចុះ
ការមើលឃើញនៅទីនេះតំណាងឲ្យការវិនិច្ឆ័យ ឬការសម្រេចចិត្តអំពីតម្លៃអ្វីមួយ។
ការបកប្រែផ្សេងទៀត «នៅក្នុងការវិនិច្ឆ័យរបស់អ្នក»
ហើយទទួលទាន ទឹកមុខរបស់នាង
«មុខរបស់នាង»នៅទីនេះតំណាងឲ្យនាងហាណាខ្លួនឯង។
អ្នកអាចសរសេរប្រយោគនេះដាច់ដោយឡែក បើចាំបាច់។ ការបកប្រែផ្សេងទៀត
«ហើយបានញ៉ាំ។ នាងគឺ»ឬ «ហើយញ៉ាំ។ មនុស្សអាចឃើញថានាងគឺជា»
1 Samuel 1:19
បាននឹកចាំពីនាង
ព្រះជាម្ចាស់ជ្រាបអំពីអ្វី ដែលកំពុងកើតឡើងចំពោះនាងហាណា។
ទ្រង់មិនបានភ្លេចទេ។ ពាក្យស្រដៀងគ្នាលេចឡើងក្នុង ១:១១ ។
នាងហាណាបានមានផ្ទៃពោះ
«នាងហាណាមានផ្ទៃពោះ»
1 Samuel 1:21
អ្នកផ្ទះរបស់លោក
ពាក្យថា«ផ្ទះ»គឺជាពាក្យប្រៀបធៀបសម្រាប់មនុស្ស ដែលរស់នៅក្នុងផ្ទះ។
ការបកប្រែផ្សេងទៀត «គ្រួសាររបស់គាត់»
ផ្តាច់ដោះសិន
លែងបំបៅដោះ ហើយចាប់ផ្តើមបរិភោគតែអាហាររឹង
កូននេះនឹងបាននៅទីនោះជាមួយព្រះអម្ចាស់ជារៀងរហូ
នាងហាណាបានសន្យាជាមួយព្រះជាម្ចាស់ថា
នាងនឹងអនុញ្ញាតឲ្យសាំយូអែលរស់នៅ
និងធ្វើការជាមួយបូជាចារ្យអេលីនៅក្នុងព្រះវិហារ (១:១១)។
មើលថែកូនប្រុសរបស់នាង
«បំបៅដោះកូនប្រុសនាង»
1 Samuel 1:24
អាហារមួយចាំង
មួយចាំងប្រហែល ២២លីត្រនៃវត្ថុធាតុដើមស្ងួត។
ស្រាទំពាំងបាយជូរមួួយដប
ស្រាត្រូវបានរក្សាទុកនៅក្នុងស្បែកសត្វ មិនមែនដបកែវទេ។
1 Samuel 1:26
លោកម្ចាស់ ដូចលោកម្ចាស់នៅមានជីវិតនៅឡើយ
នៅទីនេះពាក្យ«ដូចលោកម្ចាស់នៅមានជីវិត»បង្ហាញថានាងហាណាពិតជាចិត្តស្មោះត្រង់
និងត្រឹមត្រូវ។ ការបកប្រែផ្សេងទៀត «លោកម្ចាស់ អ្វីដែលខ្ញុំនឹងប្រាប់លោក
គឺជាការពិត»
ហើយព្រះអម្ចាស់បានប្រទានមកតាមពាក្យរបស់នាងខ្ញុំ
នាងហាណានិយាយ ដូចជាការទូលអង្វរគឺវត្ថុមួយ
ដែលមនុស្សម្នាក់អាចផ្តល់ឲ្យម្នាក់ទៀត ហើយនាងនិយាយអំពីការទូលអង្វរដូចជា
គឺជាចម្លើយចំពោះការទូលអង្វរដែលនាងបានធ្វើ។ នាមអរូបី "ការទូលអង្វរ"
អាចបកប្រែជាកន្សោមកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត «បានយល់ព្រមធ្វើអ្វី
ដែលខ្ញុំបានស្នើសុំយ៉ាងមុតមាំថា គាត់ត្រូវធ្វើ»
នៅជាមួយព្រះអម្ចាស់អស់មួយជីវិតដែរ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ខ្ញុំកំពុងប្រគល់គាត់ទៅព្រះអម្ចាស់»
លោកក៏បានថ្វាយបង្គំព្រះអម្ចាស់
«គាត់»សំដៅទៅលើលោកអែលកាណា ប៉ុន្តែយូឌីប៊ី និងការបកប្រែផ្សេងទៀត
ជាច្រើនចាត់ទុកនេះជាការប្រៀបធៀបសម្រាប់លោកអែលកាណា
និងគ្រួសាររបស់គាត់។

---

2 [1]នាងហាណាបានអធិស្ឋានដោយនិយាយថា៖ «ព្រះអម្ចាស់ធ្វើឲ្យដួងចិត្តខ្ញុំម្ចាស់មានអំណរក្រៃលែង។ ស្នែងរបស់ខ្ញុំម្ចាស់ត្រូវបានលើកតម្កើងក្នុងព្រះអម្ចាស់។
មាត់របស់ខ្ញុំម្ចាស់អាចបើកឡើងតទល់នឹងសត្រូវរបស់ខ្ញុំម្ចាស់ ពីព្រោះខ្ញុំម្ចាស់មានអំណរក្នុងសេចក្តីសង្គ្រោះរបស់ព្រះអង្គ។
[2]គ្មាននរណាបរិសុទ្ធដូចព្រះអម្ចាស់ឡើយ គឺគ្មាននរណាដូចទ្រង់ឡើយ ហើយក៏គ្មានថ្មដាណាដូចព្រះជាម្ចាស់របស់យើងដែរ។
[3]ចូរកុំឲ្យមានអំនួតអួតបំបោងទៀតទៅ ក៏កុំពោលពាក្យក្រអឺតក្រទមចេញពីមាត់ផងដែរ។ ដ្បិត ព្រះអម្ចាស់គឺជាព្រះដែលជ្រាបគ្រប់ទាំងអស់
ហើយព្រះអង្គនឹងវាល់ទៅតាមអំពើដែលបានប្រព្រឹត្ត។[4]ធ្នូរបស់អ្នកខ្លាំងពូកែព្រះអង្គនឹងកាច់បំបាក់ តែព្រះអង្គបំពាក់កម្លាំងដូចក្រវ៉ាត់ចង្កេះដល់អ្នកដែលភ្លាត់ដួលវិញ។
[5]អ្នកដែលធ្លាប់ឆ្អែតបែរជាខ្វះខាតស្វែងរកអាហារ រីឯអ្នកដែលឃ្លានវិញនឹងបានចម្អែតក្រពះ។ សូម្បី ស្ត្រីអារអាចសម្រាលបានកូនប្រាំពីរនាក់ ឯស្ត្រីដែលមានកូនជាច្រើន
នឹងទៅជាស្លោកស្រពោនវិញ។
[6]ព្រះអម្ចាស់ដកជីវិត ហើយព្រះអង្គក៏ជាអ្នកប្រទានជីវិតដែរ។ ព្រះអង្គយកគេទៅស្ថានមនុស្សស្លាប់ ហើយក៏ជាអ្នកលើកគេពីស្លាប់បានដែរ។
[7]ព្រះអម្ចាស់ធ្វើឲ្យអ្នកមានទៅជាក្រហាម ហើយលើកអ្នកខ្វះខាតឲ្យទៅជាមាន។ ព្រះអង្គជាអ្នកបន្ទាប និងជាអ្នកដែលលើកគេឡើង។
[8]ព្រះអង្គលើកអ្នកទាល់ក្រចេញពីធូលីដី។ ព្រះអង្គលើកអ្នកក្រខ្សត់ពីគំនរផេះ ហើយដាក់ឲ្យគេអង្គុយជាមួយអ្នកមានអំណាច ព្រមទាំងគ្រងរាជ្យលើកន្លែងដ៏កិត្តិយសផង។
ដ្បិត សសរគ្រឹះផែនដីជារបស់ព្រះអម្ចាស់ ហើយព្រះអង្គបានតាំងពិភពលោកនៅលើគ្រឹះនេះ។
[9]ព្រះអង្គនឹងការពារជើងមនុស្សស្មោះត្រង់របស់ព្រះអង្គ ប៉ុន្តែ មនុស្សអាក្រក់នឹងត្រូវវេទនាក្នុងភពសូន្យសុង ពីព្រោះគ្មានអ្នកណាទទួលជ័យជម្នះដោយកម្លាំងបាយឡើយ។
[10]អស់អ្នកដែលប្រឆាំងនឹងព្រះអម្ចាស់នឹងត្រូវបែកជាចំណែកតូចៗ ដ្បិត ព្រះអង្គនឹងបញ្ជាឲ្យរន្ទះបាញ់ប្រឆាំងនឹងអ្នកទាំងនោះពីស្ថានសួគ៌។
ព្រះអម្ចាស់នឹងជំនុំជម្រះរហូតដល់ទីបញ្ចប់នៃផែនដី ព្រះអង្គនឹងប្រទានអំណាចដល់ស្តេច ដែលព្រះអង្គបានចាក់ប្រេងអភិសេក»។
[11]ក្រោយមកលោកអែលកាណាក៏បានត្រឡប់ទៅផ្ទះរបស់លោកនៅឯរ៉ាម៉ា។ ឯកុមារតូចបាននៅបម្រើព្រះអម្ចាស់ជាមួយនឹងលោកបូជាចារ្យអេលីនៅទីនោះ។
[12]ពេលនេះកូនប្រុសៗរបស់លោកអេលីជាមនុស្សគ្មានបានការ។ ពួកគេពុំស្គាល់ព្រះអម្ចាស់ទេ។[13]តាមទម្លាប់របស់ពួកបូជាចារ្យជាមួយប្រជាជនគឺដូច្នេះ
នៅពេលមានអ្នកណា យកយញ្ញបូជាមកថ្វាយ បាវបម្រើរបស់បូជាចារ្យចូលមកទាំងមានសមមុខបីនៅនឹងដៃ ខណៈកំពុងចម្អិនសាច់នោះ។[14]បាវនោះយកសមចាក់ក្នុងខ្នះ
ឆ្នាំង ថ្លាង ឬកំសៀវនោះ រួចចាក់សាច់នឹងសមយកទៅជាចំណែករបស់បូជាចារ្យទាំងអស់នោះ។
ពួកគេធ្វើដូច្នេះចំពោះជនជាតិអ៊ីស្រាអែលដែលយកតង្វាយមកស៊ីឡូនោះគ្រប់ៗគ្នា។
[15]ការនោះកាន់តែអាក្រក់ឡើង គឺមុនពេលគេដុតខ្លាញ់ នោះបាវរបស់បូជាចារ្យបានចូលមក ហើយនិយាយទៅបុរសដែលកំពុងថ្វាយយញ្ញបូជាថា៖
«ចូរឲ្យសាច់ដែលត្រូវអាំងនោះមកបូជាចារ្យឯណេះ ព្រោះលោកនឹងមិនទទួលសាច់ដែលបានស្ងោររួចពីអ្នកទេ ប៉ុន្តែ លោកទទួលតែសាច់ឆៅប៉ុណ្ណោះ»។
[16]បើបុរសនោះនិយាយថា៖ «គេត្រូវតែដុតខ្លាញ់ជាមុនសិន រួចសូមលោកយកតាមចិត្តចុះ»។ នោះបាវរបស់បូជាចារ្យនឹងនិយាយថា៖ «ទេ
ចូរឲ្យសាច់នោះមកយើងឥឡូវនេះ បើមិនដូច្នោះទេ យើងនឹងប្រើកម្លាំងបាយទាំងបង្ខំ»។[17]អំពើបាបរបស់ពួកគេកាន់តែអាក្រក់ឡើងៗនៅចំពោះព្រះអម្ចាស់
ដោយពួកគេបានបន្ថោកតង្វាយរបស់ព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

[18]ឯកុមារសាំយូអែលបាននៅបម្រើព្រះអម្ចាស់ ដោយស្លៀកពាក់ក្រណាត់ទេសឯកជាមួយនឹងអាវអេផូដផង។[19]រៀងរាល់ឆ្នាំម្តាយរបស់កុមារបានធ្វើរ៉ូបតូចឲ្យ
គឺនៅពេលដែលនាងបានឡើងមកថ្វាយយញ្ញបូជាប្រចាំឆ្នាំជាមួយប្តីរបស់នាង។
[20]លោកអេលីបានឲ្យពរលោកអែលកាណា និងប្រពន្ធដោយប្រសាសន៍ថា៖ «សូមព្រះអម្ចាស់ប្រទានឲ្យអ្នកមានកូនថែមទៀតតាមរយៈស្ត្រីនេះ
ពីព្រោះតែការទូលសូមរបស់នាងដែលបានធ្វើចំពោះព្រះអម្ចាស់»។ ក្រោយមក ពួកគេក៏ត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ។[21]ព្រះអម្ចាស់បានជួយនាងហាណាម្តងហើយម្តងទៀត
នាងក៏មានផ្ទៃពោះថែមទៀត។ នាងបានបង្កើតកូនប្រុសបីនាក់ និងកូនស្រីពីរនាក់ទៀត។ ឯកុមារសាំយូអែលក៏បានចម្រើនវ័យនៅចំពោះព្រះអម្ចាស់ដែរ។
[22]ពេលនោះ លោកអេលីកាន់តែចាស់ គាត់បានឮអំពីទង្វើអាក្រក់របស់កូនៗគាត់ចំពោះជនជាតិអ៊ីស្រាអែលទាំងអស់
ហើយនិងអំពើដែលពួកគេបានដេកជាមួយស្ត្រីៗដែលបម្រើនៅឯច្រកទ្វារចូលទៅកាន់ព្រះពន្លា។[23]គាត់បានមានប្រសាសន៍ទៅពួកគេថា៖ «ហេតុអ្វីបានជាពួកគេធ្វើដូច្នេះ?
យើងបានឮអំពើទាំងប៉ុន្មានដែលពួកឯងបានប្រព្រឹត្តពីមនុស្សទាំងអស់នេះ»។[24]ទេ កូនអើយ អ្វីដែលយើងបានឮពីពួកឯងនោះ មិនល្អទេ។
ពួកឯងធ្វើឲ្យប្រជារាស្ត្ររបស់ព្រះអម្ចាស់លែងស្តាប់តាមហើយ។
[25]«បើម្នាក់ប្រព្រឹត្តបាបចំពោះម្នាក់ទៀត នោះព្រះជាម្ចាស់នឹងជំនុំជម្រះឲ្យ ប៉ុន្តែ បើម្នាក់ប្រព្រឹត្តបាបប្រឆាំងនឹងព្រះអម្ចាស់វិញ តើនរណាជាអ្នករកខុសត្រូវឲ្យ?»
ទោះយ៉ាងណា ពួកគេមិនស្តាប់តាមឪពុករបស់ពួកគេដែរ ពីព្រោះព្រះអម្ចាស់ចង់សម្លាប់ពួកគេហើយ។[26]រីឯកុមារសាំយូអែលក៏បានចម្រើនវ័យ
ហើយថែមទាំងបានគាប់ព្រះទ័យដល់ព្រះអម្ចាស់ និងចំពោះមនុស្សផងដែរ។
[27]មានមនុស្សរបស់ព្រះជាម្ចាស់បានចូលមកឯលោកអេលី ហើយមានប្រសាន៍ទៅគាត់ថា៖ «ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ៖
តើយើងមិនបានសម្តែងខ្លួនយើងដល់ដូនតារបស់ឯង ខណៈពួកគេស្ថិតនៅស្រុកអេស៊ីប ជាទាសកររបស់ស្តេចផារ៉ោនទេឬអី?
[28]យើងបានជ្រើសរើសឯងពីកុលសម្ព័ន្ធអ៊ីស្រាអែលទាំងអស់ឲ្យធ្វើជាបូជាចារ្យរបស់យើង គឺឲ្យបម្រើអាសនារបស់យើង ហើយដុតគ្រឿងក្រអូប
ទាំងពាក់អាវអេផូដនៅចំពោះមុខយើងផង។
យើងបានផ្តល់ចំណែកនៃយញ្ញបូជាទាំងអស់ដែលប្រជាជនអ៊ីស្រាអែលបានយកមកឲ្យយើងជាមួយនឹងភ្លើងដល់ដូនតារបស់ឯង។
[29]ចុះហេតុដូចម្តេចបានជាឯងប្រមាថយញ្ញបូជា និងតង្វាយដែលយើងបានតម្រូវឲ្យមាននៅក្នុងដំណាក់របស់យើងដូច្នេះ? ហេតុអ្វីបានជាឯងលើកកូនប្រុសៗខ្ពស់ជាងយើង
ដោយយកខ្លាញ់ និងចំណែកដ៏ល្អបំផុតនៃតង្វាយដែលប្រជាជនអ៊ីស្រាអែលយកមកឲ្យយើងមកទុកខ្លួនឯង។[30]នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះរបស់អ៊ីស្រាអែល
យើងបានសន្យាថា គ្រួសាររបស់ឯង និងដូនតារបស់ឯងត្រូវដើរចំពោះយើងជារៀងរហូត។ ប៉ុន្តែ ពេលនេះ ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ យើងលុបចោល
សេចក្តីសន្យានេះហើយ ព្រោះយើងផ្តល់កិត្តិយសដល់អស់អ្នកដែលគោរពយើង ប៉ុន្តែ អស់អ្នកណាដែលមិនគោរពយើង យើងនឹងឈប់នឹកនាអ្នកនោះវិញដែរ។
[31]មើល គ្រាមួយនឹងមកដល់ គឺយើងនឹងធ្វើឲ្យកម្លាំងរបស់ឯង និងគ្រួសារឯងចមថយ ហើយគ្រួសាររបស់ឯងក៏ត្រូវបន្ថយអាយុផងដែរ។
[32]ឯងនឹងឃើញតែសេចក្តីទុក្ខព្រួយនៅក្នុងដំណាក់របស់យើង។ អ្វីៗដែលល្អនឹងត្រូវប្រទានឲ្យដល់កូនចៅអ៊ីស្រាអែល
ឯគ្រួសាររបស់ឯងនឹងលែងមានមនុស្សចាស់ទៀតហើយ។[33]អស់អ្នកដែលយើងមិនបានកាត់ចេញពីអាសនារបស់យើង យើងនឹងឲ្យភ្នែករបស់គេទៅជាអន់
គេនឹងជួបតែការបាក់ទឹកចិត្តនៅក្នុងជីវិត។ ឯកូនចៅដែលកើតមកទៀតក្នុងគ្រួសាររបស់ឯងនឹងត្រូវស្លាប់។
[34]នេះជាទីសម្គាល់សម្រាប់អ្នក គឺវានឹងកើតទៅលើកូនប្រុសទាំងពីររបស់ឯង គឺហូបនី និងភីនេហាស។ ពួកគេទាំងពីរនឹងស្លាប់ក្នុងថ្ងៃតែមួយ។[35]ឯយើង
យើងនឹងលើកបូជាចារ្យដ៏ស្មោះត្រង់មួយរូបសម្រាប់យើង គេនឹងធ្វើតាមអ្វីដែលមាននៅក្នុងចិត្ត និងព្រលឹងរបស់យើង។ យើងនឹងឲ្យគ្រួសាររបស់គេរឹងមាំ
ហើយគេនឹងបម្រើដល់ស្តេចដែលយើងបានតាំងឡើងជារៀងរហូត។
[36]អ្នកណាដែលនៅមានជីវិតពីក្នុងគ្រួសាររបស់ឯងនឹងមកលត់ជង្គង់នៅមុខអ្នកនោះដើម្បីសុំប្រាក់ និងអាហារពីអ្នកនោះដោយនិយាយថា៖
«សូមទុកឲ្យខ្ញុំធ្វើជាបូជាចារ្យម្នាក់ ដូច្នេះ ខ្ញុំនឹងមានអាហារបរិភោគ»។

---

1 Samuel 2:1
ព័ត៌មានទូទៅ៖
នាងហាណាច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
ធ្វើឲ្យដួងចិត្តខ្ញុំម្ចាស់មានអំណរក្រៃលែង
«ខ្ញុំមានអំណរជាខ្លាំង»
ព្រះអម្ចាស់
«ដោយសារតែព្រះអម្ចាស់ជានរណា» ឬ »ពីព្រោះព្រះអម្ចាស់ជាព្រះដ៏អស្ចារ្យ»
ស្នែងរបស់ខ្ញុំម្ចាស់ត្រូវបានលើកតម្កើង
ស្នែងជានិមិត្តរូបនៃកម្លាំង។ ការបកប្រែផ្សេងទៀត «ឥឡូវនេះ ខ្ញុំខ្លាំង»
1 Samuel 2:2
ឃ្លាភ្ជាប់៖
នាងហាណានៅតែបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
ហើយក៏គ្មានថ្មដាណាដូចព្រះជាម្ចាស់របស់យើងដែរ។
នេះជារបៀបនិយាយមួយផ្សេងទៀតថា ព្រះជាម្ចាស់ខ្លាំងហើយស្មោះត្រង់។
ថ្មដា
នេះជាថ្មដាធំល្មមអាចលាក់ខ្លួននៅពីក្រោយ ឬឈរនៅលើ
និងខ្ពស់ជាងសត្រូវរបស់ខ្លួន។
1 Samuel 2:3
ឃ្លាភ្ជាប់៖
នាងហាណានៅតែបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
នាងនិយាយដូចជាមនុស្សផ្សេងទៀតកំពុងស្តាប់នាង។
កុំពោលពាក្យក្រអឺតក្រទម
«គ្មានពាក្យក្រអឺតក្រទម»
ហើយព្រះអង្គនឹងវាស់ទៅតាមអំពើដែលបានប្រព្រឹត្ត។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអង្គថ្លឹងថ្លែងពីសកម្មភាពរបស់មនុស្ស» ឬ «ព្រះអង្គឈ្វេងយល់ពីមូលហេតុ
ដែលមនុស្សធ្វើអ្វីដូចពួកគេធ្វើ» សូមមើល
ធ្នូរបស់អ្នកខ្លាំងពូកែព្រះអង្គនឹងកាច់បំបាក់
អាចមានន័យថា ១) ធ្នូខូចខ្លួនឯង ឬ២)
បុរសដែលកាន់ធ្នូត្រូវបានរារាំងមិនឲ្យបាញ់ចេញ។ ការបកប្រែផ្សេងទៀត
«ធ្នូដែលមានអំណាចត្រូវបានរារាំងមិនឲ្យធ្វើសកម្មភាព»
ធ្នូរបស់អ្នកខ្លាំងពូកែព្រះអង្គនឹងកាច់បំបាក់
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បំបែកធ្នូរបស់បុរសខ្លាំងពូកែ» ឬ
«ព្រះអម្ចាស់អាចធ្វើឲ្យកម្លាំងរបស់មនុស្សទន់ខ្សោយ»។
តែព្រះអង្គបំពាក់កម្លាំងដូចក្រវាត់ចង្កេះដល់អ្នកដែលភ្លាត់ដួលវិញ។
ការប្រៀបធៀបនេះមានន័យថា ពួកគេនឹងមិនជំពប់ដួលទៀតទេ
ប៉ុន្តែកម្លាំងរបស់ពួកគេនឹងនៅជាប់នឹងពួកគេដូចជាខ្សែក្រវាត់។
ការបកប្រែផ្សេងទៀត «គាត់នឹងធ្វើឲ្យអ្នកជំពប់ដួល»
បំពាក់ ... ក្រវាត់ចង្កេះ
នេះជាពាក្យទូទៅសម្រាប់ដាក់អ្វីមួយនៅជុំវិញចង្កេះរបស់អ្នក
ដើម្បីត្រៀមបំពេញការងារ។
1 Samuel 2:5
ឃ្លាភ្ជាប់៖
នាងហាណានៅតែបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
អាចសម្រាលបានកូនប្រាំពីរនាក់
«ផ្តល់កំណើតឲ្យកូនប្រាំពីរនាក់»
ស្លោកស្រពោន
«ក្លាយជាខ្សោយ និងក្រៀមក្រំ និងឯកោ»
1 Samuel 2:6
ឃ្លាភ្ជាប់៖
នាងហាណានៅតែបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
ព្រះអម្ចាស់ដកជីវិត ... ព្រះអង្គក៏ជាអ្នកប្រទានជីវិត ... យកគេទៅ ...អ្នកលើក ...
អ្នកមានទៅជាក្រហាម ហើយលើកអ្នកខ្វះខាតឲ្យទៅជាមាន។

generated on Wed Sep 10 16:16:32 2025

ព្រះអង្គជាអ្ន...ទៅជាមាន ...អ្នកបន្ទាប... លើកគេឡើង
ព្រះអម្ចាស់គ្រប់គ្រងអ្វីៗទាំងអស់។
1 Samuel 2:8
ឃ្លាភ្ជាប់៖
នាងហាណាទៅតែបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
ចេញពីធូលីដី ... ពីគំនរផេះ
ទាំងនេះការប្រៀបធៀបអំពីឋានៈទាបបំផុតនៅក្នុងសង្គម។
អ្នកក្រខ្សត់
មនុស្សពុំដែលមានអ្វី ដែលខ្លួនត្រូវការ
1 Samuel 2:9
ឃ្លាភ្ជាប់៖
នាងហាណាទៅតែបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
ការពារជើងមនុស្សស្មោះត្រង់របស់ព្រះអង្គ
«ជើង»នៅទីនេះជាពាក្យសម្គាល់ផ្លូវ ដែលមនុស្សម្នាក់ដើរនិងប្រៀបធៀបអំពីរបៀប
ដែលមនុស្សម្នាក់សម្រេចចិត្តពីរបៀបរស់នៅរបស់គាត់។ ការបកប្រែផ្សេងទៀត
«ចូររក្សាមនុស្សស្មោះត្រង់របស់គេ ពីការសម្រេចចិត្តល្ងីល្ងើ» ឬ
«ជួយឲ្យមនុស្សស្មោះត្រង់របស់គាត់ធ្វើការសម្រេចចិត្តប្រកបដោយប្រាជ្ញា
មនុស្សអាក្រក់នឹងត្រូវវេទនាក្នុងភពសូន្យសុង
របៀបគួរសមក្នុងការនិយាយថា ព្រះអម្ចាស់នឹងសម្លាប់មនុស្សអាក្រក់
អាចបង្ហាញជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងធ្វើឲ្យមនុស្សអាក្រក់ស្ងាត់ស្ងៀមក្នុងទីងងឹត» ឬ
«ព្រះអម្ចាស់នឹងធ្វើឲ្យមនុស្សអាក្រក់នៅក្នុងទីងងឹត និងលោកីយ៍នៃសេចក្តីស្លាប់»។
មនុស្សអាក្រក់នឹងត្រូវវេទនា
ពាក្យថា «ត្រូវដាក់ឲ្យនៅស្ងៀម» គឺជាពាក្យសម្រាប់ «ធ្វើឲ្យស្ងាត់ស្ងៀម» ។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងធ្វើឲ្យពួកគេនៅស្ងៀម»
ដោយកម្លាំងបាយឡើយ
«ពីព្រោះគាត់ខ្លាំង»
1 Samuel 2:10
ឃ្លាភ្ជាប់៖
នាងហាណានៅតែបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
អស់អ្នកដែលប្រឆាំងនឹងព្រះអម្ចាស់នឹងត្រូវបែក
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងបំបែកអស់អ្នកដែលប្រឆាំងនឹងព្រះអង្គ»
បែកជាចំណែកតូចៗ
លេខសម្គាល់នេះមានន័យថា «ចាញ់» ។
រហូតដល់ទីបញ្ចប់នៃផែនដី
នេះជាលេខសម្គាល់ដែលមានន័យថា គ្រប់ទីកន្លែង។ ការបកប្រែផ្សេងទៀត
«ផែនដីទាំងមូល»
ដែលព្រះអង្គបានចាក់ប្រេងអភិសេក
ស្នែងជានិមិត្តរូបនៃកម្លាំង។ សូមមើលការបកប្រែពាក្យស្រដៀងគ្នានៅក្នុង ២:១។
ការបកប្រែផ្សេងទៀត «គាត់នឹងធ្វើឲ្យមេដឹកនាំ
ដែលគាត់បានជ្រើសរើសខ្លាំងជាងសត្រូវរបស់គាត់»
បានចាក់ប្រេងអភិសេក
និយាយអំពីមនុស្សដែលព្រះអម្ចាស់បានជ្រើសរើស
និងផ្តល់អំណាចបម្រើគោលបំណងរបស់ព្រះអង្គ
ដូចជាព្រះអម្ចាស់បានចាក់ប្រេងលើមនុស្សនោះ។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ម្នាក់ដែលទ្រង់បានចាក់ប្រេង» ឬ «អ្នកដែលទ្រង់បានជ្រើសរើស«
1 Samuel 2:12
ព័ត៌មានទូទៅ៖
នៅពេលមនុស្សថ្វាយសត្វជាយញ្ញបូជា ពួកគេនឹងដុតខ្លាញ់សត្វជាមុនគេ
បន្ទាប់មកស្ងោសាច់ រួចហើយបរិភោគវា។
ពុំស្គាល់ព្រះអម្ចាស់ទេ
«មិនបានស្តាប់ព្រះអម្ចាស់» ឬ «មិនបានស្តាប់បង្គាប់ព្រះអម្ចាស់»
តាមទម្លាប់
ទម្លាប់ជាសកម្មភាពដែលមនុស្សធ្វើជាប្រចាំទៀងទាត់។
ចាក់ក្នុងខ្ទះ ឆ្នាំង ថ្លាង ឬកំសៀវនោះ
ទាំងនេះជាធុងដែលដាក់អាហារចម្អិនរួច។
បើភាសារបស់អ្នកមិនមានពាក្យដាច់ដោយឡែកសម្រាប់របស់ទាំងនេះអ្នកអាចបញ្ជាក់ជាទូទៅបាន។
ការបកប្រែផ្សេងទៀត «ចូលទៅក្នុងអ្វីដែលប្រជាជនបានកំពុងចម្អិនសាច់នៅក្នុង»
ខ្ទះ
ធុងដែកតូចមួយសម្រាប់ដាំឲ្យពុះ និងចម្អិនអាហារ។
កំសៀវ
ធុងដែកធំមួយសម្រាប់ដាក់ទឹកដាំ ហើយដាំឲ្យពុះ
ថ្លាង
ធុងដែកធំមួយសម្រាប់ដាក់ទឹកដាំ ហើយដាំឲ្យពុះ
ឆ្នាំង
ឆ្នាំងដីឥដ្ឋសម្រាប់ចម្អិនអាហារ
1 Samuel 2:15
ព័ត៌មានទូទៅ៖
នៅពេលមនុស្សបូជាសត្វជាតង្វាយ ពួកគេត្រូវដុតខ្លាញ់សត្វ រួចយកទៅស្ងោរសាច់
យកសាច់ខ្លះជូនបូជាចារ្យហើយបរិភោគសាច់ដែលនៅសល់។
ការនោះកាន់តែអាក្រក់ឡើង គឺមុនពេល
«ពួកគេថែមទាំងបានធ្វើអ្វីដែលអាក្រក់ជាងមុនទៀតផង»។
គេដុតខ្លាញ់
មនុស្សដែលបានថ្វាយតង្វាយដុតពិតប្រាកដ
អាចត្រូវបានគេបង្ហាញឲ្យឃើញច្បាស់។ ការបកប្រែផ្សេងទៀត
«មនុស្សដែលបានកំពុងថ្វាយយញ្ញបូជា
ដែលយកយញ្ញបូជារបស់គាត់ទៅកាន់បូជាចារ្យ និងបូជាចារ្យបានដុត»
ចូរឲ្យសាច់ដែលត្រូវអាំងនោះមកបូជាចារ្យឯណេះ
សូមឲ្យសាច់ខ្ញុំខ្លះ ខ្ញុំអាចឲ្យវាទៅបូជាចារ្យ ដូច្នេះគាត់អាចអាំងវា"
អាំង
ចម្អិននៅលើភ្លើង
ស្ងោរ
ចម្អិនក្នុងទឹក
សាច់ឆៅ
មិនឆ្អិន
ពួកគេបានបន្ថោកតង្វាយរបស់ព្រះអម្ចាស់។
យុវជនមិនចូលចិត្តការណែនាំរបស់ព្រះអម្ចាស់ ចំពោះការថ្វាយតង្វាយ
ហើយមិនយកចិត្តទុកដាក់ចំពោះពួកគេទេ។
1 Samuel 2:20
ពីព្រោះតែការទូលសូមរបស់នាងដែលបានធ្វើចំពោះព្រះអម្ចាស់
នាងហាណាបានទូលសូមព្រះអម្ចាស់ប្រទានទារកមួយ
ហើយបានសន្យានឹងព្រះអង្គថា នាងនឹងឲ្យទារកនោះនៅបម្រើព្រះវិហារ។
នៅចំពោះព្រះអម្ចាស់
មានន័យថា
កន្លែងដែលព្រះអម្ចាស់អាចមើលឃើញគាត់ហើយសាំយូអែលអាចរៀនអំពីព្រះអម្ចាស់បាន។
1 Samuel 2:22
ហេតុអ្វីបានជាពួកគេធ្វើដូច្នេះ?
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «វាគួរឲ្យភ័យខ្លាចណាស់ ដែលអ្នកធ្វើរឿងបែបនេះ!»
1 Samuel 2:25
តើនរណាជាអ្នករកខុសត្រូវឲ្យ?
នេះជាសំណួរដ៏ប៉ិនប្រសព្វអាចត្រូវបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
«ប្រាកដជាគ្មាននរណាម្នាក់អាចនិយាយជំនួសគាត់បានទេ»។
រកខុសត្រូវឲ្យ
«សូមព្រះអម្ចាស់មានក្តីមេត្តាករុណាលើគាត់»
ស្តាប់តាមឪពុករបស់ពួកគេ
នេះជាឈ្មោះពាក្យដែលសំឡេងតំណាងឲ្យមនុស្ស។ ការបកប្រែផ្សេងទៀត
«ឪពុករបស់ពួកគេ» ឬ «អ្វីដែលឪពុករបស់ពួកគេបាននិយាយ»
1 Samuel 2:27
មានមនុស្សរបស់ព្រះជាម្ចាស់
ឃ្លានេះ ជាធម្មតាតែងមានន័យថា ព្យាការីរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«មនុស្សម្នាក់ដែលស្តាប់ហើយ និងប្រាប់ព្រះបន្ទូលពីព្រះជាម្ចាស់»។
តើយើងមិនបានសម្តែង ...ខ្លួនយើង?
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបកប្រែជាសេចក្តីថ្លែងការណ៍។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «អ្នកគួរតែដឹងថាយើងបានបង្ហាញខ្លួនយើង ... ផ្ទះ» ។
ដល់ដូនតារបស់ឯង
ពាក្យថា«ផ្ទះ» គឺជាពាក្យកាត់សម្រាប់មនុស្សដែលរស់នៅក្នុងផ្ទះ។
ការបកប្រែផ្សេងទៀត «ក្រុមគ្រួសារដូនតាអ្នក»
ដូនតារបស់ឯង
លោកអើរ៉ុន
គឺឲ្យបម្រើអាសនារបស់យើង ហើយដុតគ្រឿងក្រអូប
សំដៅទៅលើការថ្វាយតង្វាយដល់ព្រះអម្ចាស់។
ទាំងពាក់អាវអេផូដនៅចំពោះមុខយើងផង
ពាក្យថា« ពាក់អាវអេផូដ»គឺជាពាក្យសម្រាប់ការបំពេញមុខងាររបស់បូជាចារ្យ ដែលពាក់អាវអេផូដ។ សូមមើល «ធ្វើអ្វីដែលយើងបានបញ្ជាឲ្យពួកបូជាចារ្យធ្វើ»
1 Samuel 2:29
ឃ្លាភ្ជាប់៖
មនុស្សរបស់ព្រះជាម្ចាស់បន្តនិយាយទៅកាន់លោកអេលី។
ចុះហេតុដូចម្តេចបានជាឯងប្រមាថយញ្ញបូជា ... ក្នុងដំណាក់របស់យើងដូច្នេះ?
សំណួរដ៏ប៉ិនប្រសព្វនេះគឺជាការស្តីបន្ទោស។ អាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «អ្នកមិនគួរមើលងាយយញ្ញបូជារបស់យើង ... កន្លែងដែលយើងរស់នៅ»។
ក្នុងដំណាក់របស់យើងដូច្នេះ
កន្លែងដែលប្រជាជនយើងថ្វាយតង្វាយមកយើង
ដោយយកខ្លាញ់
និងចំណែកដ៏ល្អបំផុតនៃតង្វាយដែលប្រជាជនអ ីុស្រាអែលយកមកឲ្យយើងមកទុកខ្លួនឯង។
ចំណែកដ៏ល្អបំផុតនៃតង្វាយនោះ ត្រូវដុតជាតង្វាយថ្វាយព្រះអម្ចាស់
តែក្រុមបូជាចារ្យបានបរិភោគសាច់នោះ។
ដូនតារបស់ឯង
ពាក្យថា“ ផ្ទះ” គឺជាពាក្យសម្រាប់មនុស្ស ដែលបានរស់នៅក្នុងផ្ទះ។
បកប្រែដូចក្នុង២:២៧ ។ ការបកប្រែផ្សេងទៀត «ក្រុមគ្រួសារនៃដូនតារបស់អ្នក»
របស់ឯងត្រូវដើរចំពោះយើង
នេះជាសំនួនវោហាស័ព្ទដែលមានន័យថា «រស់នៅក្នុងការស្តាប់បង្គាប់ខ្ញុំ»។
យើងលុបចោលសេចក្តីសន្យានេះហើយ
«យើងពិតជានឹងមិនអនុញ្ញាតឲ្យក្រុមគ្រួសាររបស់អ្នកដើម្បីបម្រើយើងជារៀងរហូត»
អស់អ្នកណាដែលមិនគោរពយើង យើងនឹងឈប់នឹកនាអ្នកនោះវិញដែរ។
ពាក្យថា« ឈប់នឹកនា»គឺជាពាក្យនិយាយចំអកសម្រាប់ប្រើកុំឲ្យអាក្រក់ស្តាប់ពេក« ស្អប់ខ្ពើមណាស់» ។ អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «យើងនឹងមិននឹកនាទៅលើអ្នក ដែលមើលងាយយើង» ឬ «យើងនឹងមើលងាយដល់អស់អ្នក ដែលមើលងាយយើង» (សូមមើលលានិងផ្លែផ្កា និងលានិងសកម្ម)
1 Samuel 2:31
មើល
"ស្តាប់ដោយយកចិត្តទុកដាក់ នូវអ្វីដែលខ្ញុំនឹងនិយាយ" ឬ "អ្វីដែលខ្ញុំនិយាយគឺសំខាន់ណាស់"
យើងនឹងធ្វើឲ្យកម្លាំងរបស់ឯង និងគ្រួសារឯងថមថយ
ពាក្យថា «កាត់ចេញ ... កម្លាំង» ប្រហែលជាពាក្យប្រើកុំឲ្យអាក្រក់ស្តាប់ពេក សម្រាប់សេចក្តីស្លាប់បុរសវ័យក្មេង។ ពាក្យថា «ផ្ទះឪពុករបស់អ្នក» ជាពាក្យប្រៀបធៀបសម្រាប់ «គ្រួសារអ្នក» ។ ការបកប្រែផ្សេងទៀត «យើងនឹងសម្លាប់អ្នក និងកូនចៅប្រុសៗវ័យក្មេង ដែលរឹងមាំទាំងអស់នៅក្នុងគ្រួសាររបស់អ្នក»
ក៏ត្រូវបន្ថយអាយុផងដែរ
«ធ្វើជាមនុស្សចាស់ៗ»ឬ «ជាមនុស្សដែលចាស់ទៅ»
យើងនឹងឲ្យភ្នែករបស់គេទៅជាអន់
«ធ្វើឲ្យអ្នកបាត់បង់ការមើលឃើញ» ឬ «បណ្តាលឲ្យអ្នកងងឹតភ្នែក»
1 Samuel 2:34
យើងនឹងលើក ... បូជាចារ្យដ៏ស្មោះត្រង់មួយរូប
ជាពាក្យសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «យើងនឹងធ្វើឲ្យម្នាក់មនុស្សក្លាយជាបូជាចារ្យ»
សម្រាប់យើង
ជាពាក្យសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ដើម្បីបម្រើយើង»
ធ្វើតាមអ្វីដែលមាននៅក្នុងចិត្ត និងព្រលឹងរបស់យើង។
អ្វីដែលយើងចង់ឲ្យគាត់ធ្វើ និងអ្វីដែលយើងប្រាប់គាត់ឲ្យធ្វើ
យើងនឹងឲ្យគ្រួសាររបស់គេរឹងមាំ
នៅទីនេះ «ផ្ទះ»គឺជាពាក្យដែលត្រូវបានប្រើសម្រាប់ «កូនចៅ» ។ ការបកប្រែផ្សេងទៀត «យើងនឹងធានាថា គាត់តែងតែមានកូនចៅដែលមម្រើជាមហាបូជាចារ្យ»
1 Samuel 2:36
អ្នក
បូជាចារ្យស្មោះត្រង់ ដែលព្រះជាម្ចាស់នឹងលើកឡើង
ដូច្នេះ ខ្ញុំនឹងមានអាហារបរិភោគ
នៅទីនេះ «នំប័ុងមួយដុំ» ត្រូវបានប្រើសម្រាប់ «អាហារ» ការបកប្រែផ្សេងទៀត «ដូច្នេះខ្ញុំអាចមានអ្វីដើម្បីបរិភោគ»

---

3 [1]កុមារសាំយូអែលបានបម្រើព្រះអម្ចាស់ជិតលោកអេលី។ នៅគ្រានោះ ព្រះអម្ចាស់កម្រមានព្រះបន្ទូល ហើយក៏កម្របើកឲ្យព្យាការីឃើញនិមិត្តអ្វីដែរ។[2]ពេលនោះ
ភ្នែករបស់លោកអេលីចុះអន់ថយមើលមិនច្បាស់ទេ លោកបានសម្រាកនៅលើគ្រែរបស់លោក។[3]ចង្កៀងរបស់ព្រះជាម្ចាស់មិនទាន់រលត់នៅឡើយ
ហើយកុមារសាំយូអែលកំពុងគេងនៅក្នុងព្រះវិហារនៃព្រះអម្ចាស់ ជាកន្លែងដែលបានតម្កល់ហឹបរបស់ព្រះជាម្ចាស់។[4]ព្រះអម្ចាស់បានហៅកុមារសាំយូអែល
ហើយកុមារសាំយូអែលបានតបវិញថា៖ «បាទ»។
[5]កុមារសាំយូអែលក៏បានរត់ទៅឯលោកអេលីទាំងនិយាយថា៖ «បាទ ខ្ញុំមកដល់ហើយលោកតា»។ លោកអេលីបានមានប្រសាសន៍ថា៖ «តាមិនបានហៅឯងទេ
ចូរទៅគេងវិញចុះ»។ រួចកុមារសាំយូអែលបានត្រឡប់ទៅគេងវិញ។[6]ព្រះអម្ចាស់បានហៅម្តងទៀតថា៖ «សាំយូអែល»។
កុមារសាំយូអែលក៏បានក្រោកឡើងរត់ទៅរកលោកអេលីទាំងនិយាយថា៖ «បាទលោកតា ខ្ញុំមកដល់ហើយ»។ លោកអេលីបានឆ្លើយវិញថា៖ «យើងមិនបានហៅឯងទេ
កូនប្រុសអើយ ចូរទៅគេងវិញចុះ»។
[7]ពេលនោះកុមារសាំយូអែលមិនធ្លាប់ជួបព្រះអម្ចាស់ទេ ហើយក៏មិនធ្លាប់ទទួលសារអ្វីពីព្រះអម្ចាស់បើកសម្តែងដល់ខ្លួនដែរ។
[8]ព្រះអម្ចាស់បានហៅកុមារសាំយូអែលជាលើកទីបី រួចកុមារសាំយូអែលក៏បានក្រោកឡើងម្តងទៀត ហើយរត់ទៅលោកអេលីដោយនិយាយថា៖ «បាទលោកតា
ខ្ញុំមកដល់ហើយ»។ នោះលោកអេលីយល់ឃើញថា គឺព្រះអម្ចាស់បានហៅក្មេងប្រុសនេះហើយ។
[9]រួចលោកអេលីបានប្រាប់កុមារសាំយូអែលថា ចូរទៅគេងវិញចុះ បើមានឮសម្លេងហៅឯងម្តងទៀត ឯងត្រូវឆ្លើយថា៖ «ព្រះអម្ចាស់អើយ សូមមានព្រះបន្ទូលមក
ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គកំពុងចាំស្តាប់ហើយ»។ ដូច្នេះ កុមារសាំយូអែលក៏បានវិលទៅគេងវិញនៅកន្លែងរបស់ខ្លួន។
[10]ព្រះអម្ចាស់ក៏បានយាងមកគង់នៅទីនោះ ព្រះអង្គបានហៅដូចលើកមុនៗថា៖ «សាំយូអែល សាំយូអែលអើយ»។ នោះ កុមារសាំយូអែលបានទូលតបវិញថា៖
«សូមមានព្រះបន្ទូលមក ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គកំពុងចាំស្តាប់ហើយ»។[11]ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកុមារសាំយូអែលថា មើល
យើងនឹងធ្វើឲ្យហេតុការណ៍ដ៏រន្ធត់មួយកើតឡើងនៅពេលដែលត្រចៀកគ្រប់គ្នាបានឮ។
[12]នៅថ្ងៃនោះ យើងនឹងប្រព្រឹត្តទាស់នឹងអេលីតាមអ្វីគ្រប់យ៉ាងដែលយើងបាននិយាយអំពីក្រុមគ្រួសាររបស់គាត់ គឺតាំងពីចាប់ផ្តើមរហូតដល់ទីបញ្ចប់។
[13]យើងធ្លាប់បានប្រាប់គាត់រួចហើយ ថាយើងនឹងជំនុំជម្រះគ្រួសាររបស់គាត់ គឺដោយសារអំពើបាបដែលគាត់បានដឹងច្បាស់រួចមកហើយ
កូនប្រុសៗរបស់គាត់បាននាំបណ្តាសាមកដាក់លើខ្លួនឯង ហើយគាត់ក៏ពុំបានបញ្ឈប់ពួកគេទេ។[14]ដោយព្រោះតែការនេះហើយ យើងបានស្បថចំពោះគ្រួសាររបស់អេលីថា
បាបរបស់គ្រួសារគាត់នឹងមិនអាចអត់ឱនឲ្យដោយយញ្ញបូជា ឬដោយតង្វាយណាមួយបានឡើយ»។
[15]កុមារសាំយូអែលបានគេងលង់លក់រហូតដល់ព្រឹក បន្ទាប់មក ភ្ញាក់ឡើងកុមារបានបើកទ្វារព្រះដំណាក់របស់ព្រះអម្ចាស់។ ប៉ុន្តែកុមារសាំយូអែល
ខ្លាចមិនហ៊ាននិយាយប្រាប់លោកអេលីអំពីនិមិត្តដែលបានឃើញនោះទេ។[16]ក្រោយមក លោកអេលីបានហៅកុមារសាំយូអែលហើយសួរថា៖ «សាំយូអែល កូនអើយ»។
កុមារសាំយូអែលក៏បានតបវិញថា៖ «បាទលោកតា»។

generated on Wed Sep 10 16:16:32 2025

[17]គាត់បានសួរថា៖ «តើព្រះអង្គបានមានបន្ទូលអ្វីខ្លះមកឯង? កុំលាក់បាំងនឹងគាឲ្យសោះ។ បើឯងលាក់នឹងគានូវពាក្យណាមួយដែលព្រះអង្គបានមានបន្ទូលនឹងឯង
សូមឲ្យព្រះជាម្ចាស់ប្រព្រឹត្តចំពោះឯងដូច្នោះ ហើយរឹតតែលើសនោះទៀតចុះ»។[18]កុមារសាំយូអែលបានប្រាប់គាត់គ្រប់យ៉ាង គឺមិនលាក់បាំងអ្វីឡើយ។
លោកអេលីបានមានប្រសាសន៍ថា៖ «ព្រះអម្ចាស់ជាព្រះ សូមឲ្យព្រះអង្គប្រព្រឹត្តតាមតែព្រះអង្គគាប់ព្រះហឫទ័យចុះ»។
[19]សាំយូអែលបានចម្រើនឡើង ហើយព្រះអង្គគង់ជាមួយ ទាំងធ្វើឲ្យសេចក្តីដែលបានថ្លែងទុកនោះកើតឡើងទាំងអស់។[20]ជនជាតិអ៊ីស្រាអែលទាំងអស់
ចាប់តាំងពីក្រុងដាន់រហូតដល់ក្រុងបៀរសេបា សុទ្ធតែបានដឹងថា សាំយូអែលគឺជាព្យាការីដែលព្រះអម្ចាស់បានរើសតាំង។[21]ព្រះអម្ចាស់បានយាងមកនៅឯស៊ីឡូម្តងទៀត
គឺព្រះអង្គបានសម្តែងព្រះបន្ទូលរបស់ព្រះអង្គដល់លោកសាំយូអែលនៅឯងស៊ីឡូនោះ។

---

1 Samuel 3:1
ព្រះអម្ចាស់កម្រមានព្រះបន្ទូល
«ព្រះអម្ចាស់មិនបានមានព្រះបន្ទូលជាញឹកញាប់ដល់មនុស្សទេ»
ចង្កៀងរបស់ព្រះជាម្ចាស់
នេះជាជើងចង្កៀងប្រាំពីរនៅក្នុងទីសក្ការៈនៃព្រះពន្លាដែលបានដុតរាល់ថ្ងៃ
និងពេលយប់រហូតដល់វាអស់។
ព្រះវិហារនៃព្រះអម្ចាស់
«ព្រះវិហារ»ពិតជាព្រះពន្លា ប៉ុន្តែវាជាកន្លែងដែលប្រជាជនថ្វាយបង្គំ
ដូច្នេះវាជាការល្អបំផុតដើម្បីបកប្រែពាក្យពាក្យថា «ព្រះវិហារ» នៅទីនេះ។
បកប្រែដូចក្នុង ១:៩ ។
1 Samuel 3:5
កូនប្រុសអើយ
លោកអេលីមិនមែនជាឪពុកពិតរបស់សាំយូអែលទេ។
លោកអេលីនិយាយដូចជាឪពុករបស់សាំយូអែល ដើម្បីបង្ហាញសាំយូអែលថា
គាត់មិនខឹងទេ ប៉ុន្តែ សាំយូអែលចាំបាច់ត្រូវស្តាប់គាត់។
1 Samuel 3:7
ហើយក៏មិនធ្លាប់ទទួលសារអ្វីពីព្រះអម្ចាស់បើកសម្តែងដល់ខ្លួនដែរ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយព្រះអម្ចាស់ក៏មិនធ្លាប់បើកសម្តែងសារស្តីអំពីព្រះអម្ចាស់ណាមួយ
ដល់គាត់ដែរ» ឬ«ហើយព្រះអម្ចាស់ក៏មិនដែលបង្ហាញសារណាមួយ ដល់គាត់ដែរ»
1 Samuel 3:9
ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ
លោកអេលីប្រាប់ទៅសាំយូអែលឲ្យនិយាយទៅកាន់ព្រះអម្ចាស់
ដូចជាសាំយូអែលជាមនុស្សម្នាក់ផ្សេងទៀតដើម្បីឲ្យសាំយូអែលបង្ហាញការគោរពដល់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ខ្ញុំនៅទីនេះ»
1 Samuel 3:10
ព្រះអម្ចាស់ក៏បានយាងមកគង់នៅទីនោះ
អាចមានន័យថា ១)
តាមពិតព្រះអម្ចាស់បានលេចមកហើយឈរនៅមុខសាំយូអែល ឬ ២)
ព្រះអម្ចាស់បានបង្ហាញព្រះវត្តមានឲ្យសាំយូអែលស្គាល់។
អ្នកបម្រើរបស់ព្រះអង្គ
លោកអេលីប្រាប់ទៅសាំយូអែលឲ្យនិយាយទៅកាន់ព្រះអម្ចាស់
ដូចជាសាំយូអែលជាមនុស្សម្នាក់ផ្សេងទៀតដើម្បីឲ្យសាំយូអែលបង្ហាញការគោរព
ដល់ព្រះអម្ចាស់។ការបកប្រែផ្សេងទៀត «ខ្ញុំនៅទីនេះ»
មើល យើងនឹងធ្វើឲ្យហេតុការណ៍ដ៏រន្ធត់មួយកើតឡើងនៅពេលដែលត្រចៀកគ្រប់គ្នាបានឮ។
នៅទីនេះ «ត្រចៀក ... នឹងឈឺចាប់»ជាពាក្យដែលមានន័យថា
អ្នករាល់គ្នានឹងភ្ញាក់ផ្អើលនឹងអ្វី ដែលពួកគេបានឮ។។ ការបកប្រែផ្សេងទៀត
«ដែលនឹងធ្វើឲ្យមនុស្សគ្រប់គ្នាភ្ញាក់ផ្អើល ពេលបានឮវា»
កើតឡើង
មានន័យថា មានអារម្មណ៍ថាដូចជានរណាម្នាក់កំពុងប៉ះតិចៗជាមួយនឹងវត្ថុស្រួច
ជាធម្មតាដោយសារតែភាពត្រជាក់
ឬដោយសារនរណាម្នាក់បានទះផ្នែកមួយនៃរាងកាយនោះ ដោយដៃរបស់ពួកគេ។
1 Samuel 3:12
តាំងពីចាប់ផ្តើមរហូតដល់ទីបញ្ចប់។
នេះជាការរួមបញ្ចូលគ្នាពេញលេញ។ ការបកប្រែផ្សេងទៀត
«អ្វីៗគ្រប់យ៉ាងពីតប្រាកដ»
បាននាំបណ្តាសាមកដាក់លើខ្លួនឯង
"បានធ្វើរឿងទាំងនោះដល់អស់អ្នកណា ដែលព្រះអម្ចាស់បានមានបន្ទូលថា
ទ្រង់នឹងដាក់ទណ្ឌកម្មអស់អ្នក ដែលបានធ្វើ"
បាបរបស់គ្រួសារគាត់នឹងមិនអាចអត់ឱនឲ្យដោយយញ្ញបូជា ឬដោយតង្វាយណាមួយបានឡើយ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«គ្មានយញ្ញបូជាឬការថ្វាយតង្វាយណា ដែលនរណាម្នាក់អាចផ្តល់ឲ្យ
ដែលនឹងធ្វើឲ្យធួនសម្រាប់អំពើបាបក្នុងផ្ទះរបស់គាត់ទេ»
បាបរបស់គ្រួសារគាត់
«បាបដែលមនុស្សក្នុងគ្រួសារគាត់បានប្រព្រឹត្ត»
1 Samuel 3:15
ព្រះដំណាក់របស់ព្រះអម្ចាស់។
ពាក្យថា«ព្រះដំណាក់»ពិតជាត្រសាល ប៉ុន្តែវាជាការល្អបំផុតដើម្បីបកប្រែថា
«ផ្ទះ»នៅទីនេះ។
1 Samuel 3:17
ព្រះអង្គបានមានបន្ទូល
ព្រះរាជសារដែលព្រះអម្ចាស់បានប្រទានមក។
សូមឲ្យព្រះជាម្ចាស់ប្រព្រឹត្តចំពោះឯងដូច្នោះ ហើយរឹតតែលើសនោះទៀតចុះ
ការបកប្រែជាសកម្ម ដើម្បីបញ្ជាក់ពីភាពធ្ងន់ធ្ងររបស់លោកអេលី។ ការបកប្រែផ្សេងទៀត
«សូមឲ្យព្រះជាម្ចាស់ដាក់ទណ្ឌកម្មអ្នក ដូចគ្នារបៀបដែលទ្រង់បានមានបន្ទូលថា
ទ្រង់នឹងដាក់ទណ្ឌកម្មខ្ញុំ ហើយរឹតតែច្រើនទៀត»
1 Samuel 3:19
ទាំងធ្វើឲ្យសេចក្តីដែលបានថ្លែងទុកនោះកើតឡើងទាំងអស់។
អាចបញ្ជាក់ជាទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «ធ្វើអ្វីៗទាំងអស់
ដែលព្យាការីបានថ្លែងទំនាយ បានកើតឡើង»
ជនជាតិអ៊ីស្រាអែលទាំងអស់
«ប្រជាជនទាំងអស់នៅក្នុងអ៊ីស្រាអែល»
ចាប់តាំងពីក្រុងដាន់រហូតដល់ក្រុងបៀរសេបា
នេះជាការរួមបញ្ចូលគ្នាសម្រាប់ «នៅគ្រប់តំបន់ទាំងអស់នៃទឹកដី»។
ការបកប្រែផ្សេងទៀត «ពីចុងម្ខាងនៃទឹកដីទៅចុងម្ខាងទៀត» ឬ
«ពីដាន់នៅភាគខាងជើងដល់បៀរសេបានៅចុងខាងត្បូង»
សាំយូអែលគឺជាព្យាការីដែលព្រះអម្ចាស់បានរើសតាំង
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត«
ព្រះអម្ចាស់បានតែងតាំង»

---

4 [1]ព្រះបន្ទូលរបស់ព្រះតាមរយៈលោកសាំយូអែលបានទៅដល់អ៊ីស្រាអែលទាំងអស់។ គ្រានោះ អ៊ីស្រាអែលបានចេញទៅច្បាំងនឹងពួកជនជាតិភីលីស្ទីន។
ពួកគេបានបោះជំរំទ័ពនៅឯអេបេនអេសុើរ ហើយពួកជនជាតិភីលីស្ទីនក៏បោះជំរំទ័ពនៅឯអាផេកដែរ។
[2]ពួកភីលីស្ទីនបានរៀបជួរទ័ពដើម្បីប្រយុទ្ធប្រឆាំងនឹងអ៊ីស្រាអែល។ ការប្រយុទ្ធគ្នាក៏កើតឡើង អ៊ីស្រាអែលបានចាញ់ទ័ពភីលីស្ទីន
ហើយបានបាត់បង់ជីវិតអស់បួនពាន់នាក់នៅឯសមរភូមិ។
[3]អ្នកដែលរួចពីស្លាប់បានមកជំរំវិញ ពួកចាស់ទុំរបស់អ៊ីស្រាអែលបាននិយាយថា «ហេតុអ្វីព្រះអម្ចាស់ធ្វើឲ្យយើងចាញ់នៅចំពោះមុខពួកភីលីស្ទីនថ្ងៃនេះ?
ចូរយើងយកហឹបនៃសម្ពន្ធរបស់ព្រះអម្ចាស់ពីស៊ីឡូមកទីនេះ ដើម្បីឲ្យហឹបនោះនៅជាមួយពួកយើង ហើយយើងនឹងសុវត្ថិភាព រួចពីកណ្តាប់ដៃសត្រូវរបស់យើង»។[4]ដូច្នេះ
គេក៏បញ្ជូនមនុស្សទៅឯស៊ីឡូ ពួកគេបាននាំយកហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់នៃពួកពលបរិវារដែលគង់ពីលើចេរូប៊ីន។ កូនប្រុសទាំងពីររបស់លោកអេលី គឺហូបនី
និងភីនេហាស ក៏មកជាមួយហឹបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ដែរ។

generated on Wed Sep 10 16:16:32 2025

[5]នៅពេលហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់បានមកដល់ជំរំហើយ ទ័ពអ៊ីស្រាអែលទាំងអស់បានស្រែកឡើងយ៉ាងខ្លាំងរហូតដល់ខ្សែផែនដី។
[6]ពេលទ័ពភីលីស្ទីនបានឮសម្លេងស្រែកដូច្នេះ ពួកគេបាននិយាយគ្នាថា៖ «តើសម្រែករបស់ពួកសាសន៍ហេព្រើរក្នុងជំរំនោះមានន័យដូចម្តេច»? បន្ទាប់មក
ពួកគេបានដឹងថា ហឹបនៃព្រះអម្ចាស់បានមកដល់ជំរំហើយ។
[7]ពួកទ័ពភីលីស្ទីនបានភ័យខ្លាចជាខ្លាំងដោយនិយាយថា៖ «ព្រះរបស់ពួកវាបានមកដល់ជំរំហើយ»។ ខ្លះថា៖ «វេទនាហើយយើង! មិនដែលធ្លាប់មានដូច្នេះពីមុនទេ!
[8]វេទនាហើយយើង! តើអ្នកណានឹងការពារពួកយើងពីអំណាចនៃព្រះដ៏ខ្លាំងក្លាទាំងនោះទៅ? ដ្បិត ព្រះទាំងនោះហើយ
ដែលបានវាយប្រហារពួកអេស៊ីបឲ្យវិនាសដោយគ្រោះកាចផ្សេងៗនៅឯវាលរហោស្ថាន។[9]ចូរមានកម្លាំងឡើង អូហ៎ ទ័ពភីលីស្ទីន បើមិនដូច្នោះទេ
អ្នករាល់គ្នានឹងទៅជាទាសកររបស់ជនជាតិហេព្រើរ ដូចដែលពួកគេធ្លាប់ជាទាសករមិនខាន ចូររឹងប៉ឹងឡើង ហើយចេញទៅប្រយុទ្ធចុះ»។
[10]ទ័ពភីលីស្ទីនបានចេញមកប្រយុទ្ធ ហើយវាយទ័ពអ៊ីស្រាអែលឲ្យចាញ់។ ពួកគេបានរត់បាក់ទ័ពទៅតាមផ្ទះរៀងៗខ្លួន មានទ័ពជាច្រើនទៀតត្រូវបានសម្លាប់
គឺមានទ័ពថ្មើជើងរបស់អ៊ីស្រាអែលបីម៉ឺននាក់បានស្លាប់។[11]ឯហឹបនៃព្រះជាម្ចាស់ក៏ត្រូវរឹបអូស ហើយកូនប្រុសទាំងពីររបស់លោកអេលី គឺហូបនី និងភីនេហាស
បានស្លាប់នៅទីនោះផងដែរ។
[12]មានបុរសម្នាក់ពីកុលសម្ព័ន្ធបេនយ៉ាមីនដែលរួចជីវិតពីសមរភូមិបានរត់មកដល់ស៊ីឡូនៅថ្ងៃដដែលនោះ ទាំងសម្លៀកបំពាក់រហែកហើយក្បាលប្រលាក់។
[13]ពេលមកដល់នោះ លោកអេលីកំពុងតែអង្គុយនៅលើកៅអីរបស់លោកនៅជិតផ្លូវដើម្បីចាំមើល ពីព្រោះចិត្តរបស់គាត់អន្ទះអន្ទែងនឹងហឹបនៃព្រះជាម្ចាស់ណាស់។
ពេលបុរសនោះបានចូលដល់ទីក្រុង ក៏រៀបរាប់នូវហេតុការណ៍ ហើយអ្នកក្រុងទាំងមូលក៏បានស្រែកយំទាំងអស់គ្នា។
[14]ពេលលោកអេលីបានឮសម្រែកឡើងខ្លាំង លោកបាននិយាយថា «តើសម្រែកត្រហោយំនេះមានន័យដូចម្តេច?» បុរសនោះបានរត់ប្រញាប់មកឯលោកអេលី
ដើម្បីប្រាប់គាត់។[15]ពេលនោះលោកអេលី មានអាយុកៅសិបប្រាំបីឆ្នាំហើយ ភ្នែករបស់លោកងងឹត គាត់មើលមិនឃើញទេ។
[16]បុរសនោះបាននិយាយទៅលោកអេលីថា៖ «ខ្ញុំជាម្នាក់ដែលបានរត់រួចពីសមរភូមិ។ ខ្ញុំបានគេចរួចខ្លួននៅថ្ងៃនេះ»។ លោកអេលីបានសួរថា៖ «តើវាកើតឡើងយ៉ាងដូចម្តេច
កូនប្រុសអើយ?»[17]បុរសដែលនាំដំណឹងនោះបានប្រាប់វិញថា៖ «ទ័ពអ៊ីស្រាអែលបានរត់បាក់ទ័ពពីទ័ពភីលីស្ទីន។ ហើយថែមទាំងបានបាត់បង់ជីវិតយ៉ាងសម្បើមផង។
ឯកូនប្រុសទាំងពីររបស់លោក គឺហូបនី និងភីនេហាស ក៏បានស្លាប់ដែរ ហើយហឹបនៃព្រះជាម្ចាស់ត្រូវបានគេរឹបអូសយកទៀត»។
[18]ខណៈបុរសនោះនិយាយអំពីហឹបនៃព្រះអម្ចាស់ នោះលោកអេលីក៏បានធ្លាក់ផ្អាក្រោយពីកៅអីរបស់លោកនៅជិតក្លោងទ្វារ។ ករបស់គាត់បានបាក់ ហើយក៏ស្លាប់
ដោយព្រោះលោកចាស់ និងធ្ងន់ផង។ លោកបានដឹកនាំជនជាតិអ៊ីស្រាអែលអស់រយៈពេលសែសិបឆ្នាំមកហើយ។
[19]ពេលនោះ កូនប្រសារស្រីរបស់លោក ដែលជាប្រពន្ធរបស់ភីនេហាសមានផ្ទៃពោះរៀបនឹងសម្រាល។ នាងបានឮដំណឹងថា ហឹបនៃព្រះជាម្ចាស់ត្រូវបានសត្រូវរឹបអូស
ហើយឪពុកក្មេក និងប្តីបានស្លាប់ទៀត នោះនាងបានលុតជង្គង់ចុះរួចក៏សម្រាលកូន រូបកាយរបស់នាងមានការឈឺចាប់ក្រៃលែងនៅពេលនោះ។
[20]ខណៈនាងជិតដាច់ខ្យល់ស្លាប់ មានស្ត្រីៗមកមើល ហើយនិយាយទៅនាងថា៖ «កុំភ័យខ្លាចអ្វី ព្រោះនាងសម្រាលបានកូនប្រុសមួយហើយ»។ ប៉ុន្តែ
នាងមិនបានតបតឬយកពាក្យរបស់គេនិយាយមកដាក់ក្នុងចិត្តទេ។
[21]នាងបានដាក់ឈ្មោះកូននោះថា អ៊ីកាបុដ ដោយពោលថា៖ «សិរីរុងរឿងត្រូវបានដកចេញពីអ៊ីស្រាអែលហើយ!» ដោយព្រោះហឹបនៃព្រះជាម្ចាស់ត្រូវគេកាន់កាប់
ដោយសារតែឪពុកក្មេក និងប្តីរបស់នាង[22]នាងបានពោលឡើងថា៖ «សិរីរុងរឿងបាន ចេញឆ្ងាយពីអ៊ីស្រាអែល ពីព្រោះហឹបនៃព្រះជាម្ចាស់ត្រូវបានគេកាន់កាប់ហើយ»។

---

1 Samuel 4:1

អេបេនអេសុើរ...អាផេក

ទាំងនេះជាឈ្មោះនៃទីកន្លែង។

អ៊ីស្រាអែលបានចាញ់ទ័ពភីលីស្ទីន ហើយបានបាត់បង់ជីវិត

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកភីលីស្ទីនបានវាយឈ្នះជនជាតិអ៊ីស្រាអែលហើយបានសម្លាប់ចោល»

បួនពាន់នាក់នៅឯសមរភូមិ

នៅទីនេះលេខបួនពាន់គឺជាលេខរំលងជុំ។ ប្រហែលជាចំនួនច្រើនជាងនោះ
ឬពីរបីតិចជាងនេះ។ ពាក្យ «អំពី» បង្ហាញថា វាមិនមែនជាចំនួនពិតប្រាកដទេ។
ការបកប្រែផ្សេងទៀត «ប្រហែល៤០០០ នាក់»

1 Samuel 4:3

អ្នកដែល

ទាហានដែលបានប្រយុទ្ធនៅសមរភូមិ

ហេតុអ្វីព្រះអម្ចាស់ធ្វើឲ្យយើងចាញ់នៅចំពោះមុខពួកភីលីស្ទីនថ្ងៃនេះ ចូរយើងយក...សត្រូវ

ពួកចាស់ទុំពិតមិនបានដឹងពីមូលហេតុ ដែលព្រះអម្ចាស់បានវាយពួកគេទេ ប៉ុន្តែ
ពួកគេបានគិតខុសថា ពួកគេដឹងពីរបៀបធ្វើឲ្យប្រាកដថា
វាមិនបានកើតឡើងម្តងទៀតដោយយកហឹបទៅជាមួយពួកគេ។ (សូមមើល UDB)

ពួកពលបរិវារដែលគង់ពីលើចេរូប៊ីន

ទោះបី ព្រះអម្ចាស់មានវត្តមាននៅគ្រប់ទីកន្លែងក៏ដោយ
ក៏ព្រះអង្គបង្ហាញឲ្យប្រជារាស្ត្ររបស់ព្រះអង្គឃើញ
ពីលើរូបរបស់ចេរូប៊ីននៅពីលើហឹប។

ភីនេហាស

ភីនេហាសមិនដូចចៅប្រុសរបស់អើរ៉ុន នៅក្នុងនិក្ខមនំនិងជនគណនាទេ។

ក៏មកជាមួយ

គឺនៅស៊ីឡូ

1 Samuel 4:5

នៅពេលរបស់ព្រះអម្ចាស់បានមកដល់ជំរំហើយ

«នៅពេលប្រជាជនយកហឹបរបស់ព្រះអម្ចាស់ចូលក្នុងជំរំ»

ការបកប្រែខ្លះប្រហែលជាត្រូវការបន្ថែមព័ត៌មាន ដែលងាយយល់
និងមានន័យច្បាស់ជាងមុន។ ការបកប្រែផ្សេងទៀត «ប្រជាជនរួមជាមួយហុបនី
និងភីនេហាសបានលើកហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
ហើយយកទៅក្នុងជំរំ។ នៅពេលដែលប្រជាជនបានសែងហឹបចូលទៅក្នុងជំរំ»

ហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់បានមកដល់ជំរំ

«ប្រជាជនបានយកហឹបរបស់ព្រះអម្ចាស់ទៅដល់ជំរំ»

1 Samuel 4:7

និយាយថា ... ខ្លះថា

«ពួកគេបាននិយាយទៅកាន់ខ្លួនឯង ... ពួកគេបាននិយាយដាក់គ្នា» ឬ
«ពួកគេបាននិយាយទៅកាន់គ្នា ... ពួកគេបាននិយាយជាមួយគ្នា» ។ ឃ្លាទីពីរ
សំដៅទៅលើអ្វីមួយ ដែលពួកភីលីស្ទីនបាននិយាយជាមួយគ្នា។
ឃ្លាទីមួយប្រហែលជាសំដៅទៅលើអ្វីមួយ ដែលពួកគេបានគិត
ទោះបីជាវាអាចសំដៅទៅលើអ្វី ដែលពួកគេបាននិយាយជាមួយគ្នា។ បើអាចធ្វើបាន
សូមចៀសវាងនិយាយពីអ្នកណា ដែលបាននិយាយជាមួយ។

ព្រះរបស់ពួកវាបានមក

ជនជាតិភីលីស្ទីនបានថ្វាយបង្គំព្រះជាច្រើន ដូច្នេះ ពួកគេប្រហែលជាជឿថា
មានព្រះមួយអង្គ ឬព្រះមួយអង្គដែលពួកគេមិនថ្វាយបង្គំបានចូលមកក្នុងជំរំ។
អត្ថន័យមួយទៀតគឺថា
ពួកគេកំពុងនិយាយឈ្មោះរបស់ព្រះជាម្ចាស់នៃអ៊ីស្រាអែលថា«ព្រះអម្ចាស់បានយាងមកហើយ»។
ដោយសារតែ៤:៨ ចែងថា« ព្រះជាម្ចាស់» ការបកប្រែខ្លះអានថា
«ព្រះជាម្ចាស់បានយាងមកដល់» មានន័យថា «គឺជាព្រះដែលបានមកហើយ»។

តើអ្នកណានឹងការពារពួកយើងពីអំណាចនៃព្រះដ៏ខ្លាំងក្លាទាំងនោះទៅ?

សំនួនវោហាស័ព្ទនេះគឺជាការបង្ហាញ ការភ័យខ្លាចយ៉ាងខ្លាំង។
អាចសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់អាចការពារយើង ពីព្រះដ៏អស្ចារ្យទាំងនេះបានទេ»។

អំណាចនៃព្រះដ៏ខ្លាំងក្លាទាំងនោះ ... ព្រះទាំងនោះហើយ ដែលបានវាយប្រហារ

ដោយសារតែពាក្យថា «ព្រះ»

ចូររឹងប៉ឹងឡើង

នេះជាសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ចូររឹងមាំនិងចូរប្រយុទ្ធ»

1 Samuel 4:10

ទ័ពអ៊ីស្រាអែលឲ្យចាញ់

អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ពាក្យ «អ៊ីស្រាអែល» គឺជាពាក្យសម្រាប់
«កងទ័ពអ៊ីស្រាអែល»។ ការបកប្រែផ្សេងទៀត «ពួកគេបានវាយឈ្នះអ៊ីស្រាអែល»

ហឹបនៃព្រះជាម្ចាស់ក៏ត្រូវរឹបអូស

generated on Wed Sep 10 16:16:32 2025

អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកភីលីស្ទីនក៏បានយកហឹបរបស់ព្រះជាម្ចាស់»
1 Samuel 4:12
នោះ ទាំងសម្លៀកបំពាក់រហែកហើយក្បាលប្រលាក់។
នេះជារបៀបបង្ហាញពីការកាន់ទុក្ខយ៉ាងជ្រាលជ្រៅ នៅក្នុងវប្បធម៌អ៊ីស្រាអែល។
ពីព្រោះចិត្តរបស់គាត់អន្ទះអន្ទែងនឹងហឹប
នេះជាឃ្លាមួយមានន័យថា គាត់មានការភ័យខ្លាច
ឬព្រួយបារម្ភយ៉ាងខ្លាំងអំពីអ្វីមួយ។
អ្នកក្រុងទាំងមូល
នេះជាពាក្យសម្រាប់ «ប្រជាជនទាំងអស់នៅក្នុងទីក្រុង» ។
1 Samuel 4:14
បុរសនោះ
«បុរសបេនយ៉ាមីន»
1 Samuel 4:16
កូនប្រុស
លោកអេលីមិនមែនជាឪពុកបង្កើតរបស់ទាហានផ្សេងទៀតទេ។
អេលីនិយាយដូចជាគាត់ជាឪពុករបស់ទាហាន ដើម្បីបង្ហាញទាហាននោះថា
គាត់មិនខឹងទេ ប៉ុន្តែ ទាហាននោះចាំបាច់ត្រូវឆ្លើយប្រាប់គាត់។
ទ័ពអ៊ីស្រាអែលបានរត់បាក់ទ័ពពីទ័ពភីលីស្ទីន
នេះជាសេចក្តីថ្លែងការណ៍ទូទៅអំពីអ្វីៗ ដែលបានកើតឡើង។
ពាក្យនៅសល់របស់ទាហានផ្តល់ព័ត៌មានលម្អិត។
ហើយថែមទាំងបានបាត់បង់ ... ឯកូនប្រុសទាំងពីររបស់លោក
«ឥឡូវនេះ យើងនឹងប្រាប់អ្នកពីអ្វីដែលអាក្រក់ជាងមុន ...
យើងនឹងប្រាប់អ្នកពីអ្វីដែលអាក្រក់ជាងនេះ» ឬ «មិនត្រឹមតែមាន ... មនុស្សទេ
ប៉ុន្តែកូនប្រុសទាំងពីររបស់អ្នក»
ហឹបនៃព្រះជាម្ចាស់ត្រូវបានគេរឹបអូសយកទៀត»។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកភីលីស្ទីនបានយកហឹបរបស់ព្រះជាម្ចាស់»
1 Samuel 4:18
ខណៈបុរសនោះនិយាយអំពី
«ពេលបុរសបេនយ៉ាមីនបានលើកឡើង»
និយាយ
«និយាយពី»
ករបស់គាត់បានបាក់
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ករបស់គាត់បែកដោយសារតែគាត់ដួល» ឬ «គាត់ករបស់គាត់នៅពេលគាត់ដួល»
1 Samuel 4:19
កូនប្រសារស្រីរបស់លោក
ប្រសារ គឺកូនប្រសារស្រីរបស់លោកអេលី
ហឹបនៃព្រះជាម្ចាស់ត្រូវបានសត្រូវរឹបអូស
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «
ពួកភីលីស្ទីនបានកាន់កាប់ហឹបរបស់ព្រះជាម្ចាស់»
យកពាក្យរបស់គេនិយាយមកដាក់ក្នុងចិត្តទេ។
«យកចិត្តទុកដាក់ទៅលើអ្វីៗ ដែលពួកគេបាននិយាយ» ឬ
«អនុញ្ញាតឲ្យខ្លួននាងមានអារម្មណ៍ធូរស្រាល»
1 Samuel 4:21
អ៊ីកាបុដ
ឈ្មោះនេះពិតជាឃ្លាដែលមានន័យថា «គ្មានសិរីរុងរឿង»។
ជួនកាលឈ្មោះរបស់មនុស្សបង្ហាញព័ត៌មានអំពីមនុស្ស ទីកន្លែង ឬវត្ថុ
ដែលវាសំដៅទៅលើ។
ដោយព្រោះហឹបនៃព្រះជាម្ចាស់ត្រូវគេកាន់កាប់ ...ហឹបនៃព្រះជាម្ចាស់ត្រូវបានគេកាន់កាប់ហើយ
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត « ដ្បិត
ពួកភីលីស្ទីនបានកាន់កាប់ហឹបនៃព្រះជាម្ចាស់...ពីព្រោះ
ពួកភីលីស្ទីនបានកាន់កាប់ហឹបនៃព្រះជាម្ចាស់»

---

5 [1]គ្រានោះ ពួកភីលីស្ទីនបានយកហឹបរបស់ព្រះជាម្ចាស់ទៅ ពួកគេបានយកពីអេបេនអេស៊ើរ ទៅដាក់នៅឯអាសដូឌ។[2]ពួកភីលីស្ទីនបានយកហឹបរបស់ព្រះជាម្ចាស់
ទៅដាក់នៅក្នុងដំណាក់នៃព្រះដាកុនហើយដាក់នៅក្បែររូបសំណាកព្រះដាកុន។[3]នៅព្រឹកថ្ងៃបន្ទាប់ អ្នកក្រុងអាសដូឌ
បានឃើញព្រះដាកុនរលំមុខដល់ដីនៅចំពោះហឹបរបស់ព្រះអម្ចាស់។ ដូច្នេះ ពួកគេបានលើករូបព្រះដាកុនទៅដាក់កន្លែងដើមវិញ។
[4]ក៏ប៉ុន្តែ នៅព្រឹកបន្ទាប់ទៀតគេបានក្រោកឡើងពីព្រលឹម បានឃើញរូបព្រះដាកុននោះដួលមុខនឹងដីនៅចំពោះហឹបរបស់ព្រះអម្ចាស់ទៀត។ ក្បាលរបស់រូបព្រះដាកុន
និងដៃទាំងពីរបានដាច់ចេញពីខ្លួននៅឯមាត់ទ្វារដំណាក់នោះ គឺនៅសល់តែដងខ្លួនរូបព្រះដាកុនប៉ុណ្ណោះ។[5]ហេតុនេះហើយ មកទល់ថ្ងៃនេះពួកបូជាចារ្យ
និងអស់អ្នកដែលមកដំណាក់នៃព្រះដាកុនមិនដើរជាន់លើមាត់ទ្វារដំណាក់របស់ព្រះដាកុននៅក្រុងអាសដូឌទេ។
[6]ព្រះហស្តរបស់ព្រះអម្ចាស់បានប្រហារអ្នកក្រុងអាសដូឌ។ ព្រះអង្គបានធ្វើឲ្យពួកគេអន្តរាយដោយដុះដុំសាច់ចំពោះអ្នកក្រុងអាសដូឌ
និងអស់អ្នកដែលនៅតំបន់ជិតៗនោះ។[7]ពួកអ្នកក្រុងអាសដូឌបានយល់ឃើញអំពីអ្វីដែលកំពុងកើតឡើង ដោយពួកគេនិយាយថា៖
«ហឹបរបស់ព្រះជាម្ចាស់នៃជនជាតិអ ុស្រាអែលមិនត្រូវនៅជាមួយពួកយើងទេ ពីព្រោះព្រះហស្តរបស់ព្រះអង្គបានប្រហារយើង
និងប្រឆាំងព្រះដាកុនរបស់យើងធ្ងន់ធ្ងរណាស់»។
[8]ដូច្នេះ ពួកគេបានអញ្ជើញអ្នកដឹកនាំភីលីស្ទីនទាំងអស់មកជួបជុំគ្នា ដោយចោទសួរទៅកាន់អ្នកដឹកនាំទាំងនោះថា៖
«តើយើងត្រូវធ្វើដូចម្តេចជាមួយនឹងហឹបនៃព្រះរបស់ជនជាតិអ៊ីស្រាអែល?» ក្រុមអ្នកដឹកនាំទាំងនោះឆ្លើយថា៖
«ចូរយកហឹបនៃព្រះរបស់ជនជាតិអ៊ីស្រាអែលនោះទៅដាក់នៅក្រុងកាដវិញ»។ ពួកគេក៏សែងហឹបរបស់ព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលត្រឡប់ទៅទីនោះ។
[9]កាលពួកគេបានយកទៅទីនោះហើយ ព្រះហស្តនៃព្រះអម្ចាស់ក៏នៅតែធ្វើឲ្យអ្នកក្រុងនោះអន្តរាយ គឺធ្វើឲ្យមានការភាន់ច្រឡំយ៉ាងខ្លាំងចំពោះអ្នកក្រុងនោះ។
ព្រះអង្គបង្កឲ្យអ្នកក្រុងនោះ ទាំងតូចទាំងធំកើតដុំសាច់លើពួកគេ។
[10]បន្ទាប់មក ពួកគេបានបញ្ជូនហឹបរបស់ព្រះជាម្ចាស់ទៅឯក្រុងអេក្រូន។ ប៉ុន្តែ ពេលហឹបរបស់ព្រះជាម្ចាស់មកដល់ក្រុងអេក្រូន នោះអ្នកក្រុងបានស្រែកឆោឡោថា៖
«គេបានយកហឹបរបស់ព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលមកដល់យើងហើយ ដើម្បីសម្លាប់យើង និងប្រជាជននៅទីនេះ»។
[11]ក្រោយមក ពួកគេបានអញ្ជើញពួកអ្នកដឹកនាំក្នុងស្រុកភីលីស្ទីនមកជុំគ្នា ហើយនិយាយទៅកាន់ពួកនោះថា៖ «ចូរបញ្ជូនហឹបនៃព្រះរបស់ជនជាតិអ៊ីស្រាអែលចេញ
ត្រូវឲ្យហឹបនេះត្រឡប់ទៅកន្លែងដើមវិញ ធ្វើដូច្នេះពួកយើង និងប្រជាជនរបស់យើងនឹងមិនស្លាប់ទេ»។ ដោយហេតុ ភាពជ្រួលច្របល់ស្លន់ស្លោផ្ទុះឡើងតាមទីក្រុង
ឫទ្ធានុភាពនៃព្រះនេះធ្ងន់ធ្ងរពេកហើយ។[12]អស់អ្នកដែលរួចពីស្លាប់ ត្រូវកើតដុំសាច់ ហើយសម្រែករបស់អ្នកក្រុងបានលាន់ឮដល់មេឃ។

---

1 Samuel 5:1
គ្រានោះ
ជាពាក្យសម្គាល់ការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង។ បើភាសារបស់អ្នកមានពាក្យ
ឬឃ្លាដែលដូចគ្នា អ្នកអាចប្រើវានៅទីនេះ។
ហឹបរបស់ព្រះជាម្ចាស់
បកប្រែដូចនៅក្នុង ៣:១។ ដូចគ្នានឹង«ហឹបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់»
នៅក្នុង ៤:៣ ។
ដំណាក់នៃព្រះដាកុន
សំដៅទៅលើព្រះវិហាររបស់ព្រះដាកុន ដែលជាព្រះរបស់ពួកភីលីស្ទីន។
បានឃើញព្រះដាកុន
ពួកគេភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលឃើញព្រះដាកុន
បានឃើញព្រះដាកុនរលំមុខដល់ដី នៅចំពោះហឹបរបស់ព្រះអម្ចាស់។
អ្នកអានគួរយល់ថា ព្រះអម្ចាស់បានធ្វើឲ្យរូបចម្លាក់បានធ្លាក់មុខរបស់វាមក
ដោយខ្លួនឯងនៅពេលយប់។ (សូមមើល|Assumed Knowledge and
Implicit Information)
1 Samuel 5:4
បានឃើញរូបព្រះដាកុននោះដួល
អ្នកអានគួរយល់ថា ព្រះអម្ចាស់បានបណ្តាលឲ្យព្រះដាកុនដួលរលំ។

generated on Wed Sep 10 16:16:32 2025

ក្បាលរបស់រូបព្រះដាកុន និងដៃទាំងពីរបានដាច់ចេញព
ដូចជាព្រះអម្ចាស់ជាទាហាន ដែលបានឈ្នះខ្មាំងសត្រូវរបស់ព្រះអង្គ
ហើយកាត់ក្បាលនិងដៃសត្រូវ។
ហេតុនេះហើយ មកទល់ថ្ងៃនេះ
អ្នកនិពន្ធនិយាយអំពីការផ្តល់ព័ត៌មានមួយចំនួន មិនជាប់សាច់រឿងសំខាន់។
មកទល់ថ្ងៃនេះ
នៅទីនេះ «ថ្ងៃនេះ» មានន័យថា
រហូតដល់ថ្ងៃដែលអ្នកនិពន្ធកំពុងសរសេរកណ្តាលនេះ។
1 Samuel 5:6
ព្រះហស្តរបស់ព្រះអម្ចាស់បានប្រហារ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ «ព្រះអម្ចាស់វិនិច្ឆ័យយ៉ាងខ្លាំង»
ដុះដុំសាច់
អាចមានន័យថា ១) ឈឺចាប់ស្បែកហើមជាំ ឬ ២) ជំងឺឬសដូងបាត។
អ្នកក្រុងអាសដូឌ និងអស់អ្នកដែលនៅតំបន់ជិតៗនោះ។
«ឈ្មោះទីក្រុងគឺជាពាក្យសម្រាប់ប្រជាជន ដែលរស់នៅក្នុងទីក្រុង។
ទាំងប្រជាជនក្រុងអាសដូឌ និងប្រជាជននៅជុំវិញក្រុងអាសដូឌ»
បានយល់ឃើញ
«បានយល់»
ហឹបរបស់ព្រះជាម្ចាស់នៃជនជាតិអ៊ីុស្រាអែល
បកប្រែដូចនៅក្នុង ៣:១។ ដូចគ្នានឹង «ហឹបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់» ក្នុង ៤:៣ ។
1 Samuel 5:8
ព្រះហស្តនៃព្រះអម្ចាស់ក៏នៅតែធ្វើឲ្យអ្នកក្រុងនោះអន្តរាយ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានដាក់ទណ្ឌកម្ម»
ទាំងតូចទាំងធំ
អាចមានន័យថា ១) ជាការរួមបញ្ចូលគ្នាដែលសំដៅទៅលើអាយុ។
ការបកប្រែផ្សេងទៀត «បុរសគ្រប់វ័យទាំងអស់» ឬ ២)
ជាការរួមបញ្ចូលគ្នាដែលសំដៅទៅលើវណ្ណៈសង្គម។ ការបកប្រែផ្សេងទៀត
«ពីមនុស្សក្រីក្របំផុត និងខ្សោយបំផុតរហូតដល់មនុស្ស
ដែលមានជាងគេបំផុតនិងអ្នកមានអំណាចបំផុត»
ដុះដុំសាច់
អាចមានន័យថា ១) ឈឺចាប់ស្បែកហើមជាំ ឬ ២) ជំងឺឬសដូងបាត។
បកប្រែដូចនៅក្នុង ៥:៦
1 Samuel 5:10
បានស្រែក
ហេតុអ្វីបានជាពួកគេស្រែក អាចថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ស្រែកដោយភ័យខ្លាច»
1 Samuel 5:11
ហឹបនៃព្រះរបស់ជនជាតិអ៊ីស្រាអែល
បកប្រែដូចក្នុង 3:1 ។ គឺដូចគ្នានឹង «ហឹបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់» ក្នុង ៤:៣ ។
ព្រះរបស់ជនជាតិអ៊ីស្រាអែល
អាចមានន័យថា ១) ពួកគេហៅចំឈ្មោះព្រះជាម្ចាស់របស់អ៊ីស្រាអែលឬ ២)
ពួកគេជឿថា អ៊ីស្រាអែលបានថ្វាយបង្គំព្រះមួយ ក្នុងចំណោមអាទិទេពជាច្រើនគឺ
“ព្រះរបស់អ៊ីស្រាអែល” ។ បកប្រែដូចនៅក្នុង ៥:៦។
ភាពជ្រួលច្របល់ស្លន់ស្លោផ្ទុះឡើងតាមទីក្រុង
«ប្រជាជនទូទាំងទីក្រុងភ័យខ្លាចថា ពួកគេនឹងត្រូវស្លាប់»
ឫទ្ធានុភាពនៃព្រះនេះធ្ងន់ធ្ងរពេកហើយ។
ព្រះហស្តគឺជាពាក្យប្រៀបធៀបសម្រាប់ព្រះជាម្ចាស់ ដាក់ទណ្ឌកម្មប្រជាជន។
«ព្រះអម្ចាស់ដាក់ទោសប្រជាជននៅទីនោះយ៉ាងខ្លាំង»
អស់អ្នកដែលរួចពីស្លាប់
បញ្ជាក់ថាមនុស្សជាច្រើនពិតជាបានស្លាប់។
ដុះដុំសាច់
អាចមានន័យថា ១) ឈឺចាប់ស្បែកហើមជាំឬ ២) ជំងឺឬសដូងបាត។
បកប្រែដូចនៅក្នុង ៥:៦
ហើយសម្រែករបស់អ្នកក្រុងបានលាន់ឮដល់មេឃ។
ពាក្យថា« ទីក្រុង» ជាពាក្យប្រៀបធៀបសម្រាប់ប្រជាជនក្នុងទីក្រុង។
អាចមានន័យថា ១) ពាក្យថា «បានឡើងទៅលើមេឃ» គឺជាឃ្លាសម្រាប់
«អស្ចារ្យណាស់»។ ការបកប្រែផ្សេងទៀត ប្រជាជននៅទីក្រុងស្រែកខ្លាំង ៗ ឬ២)
ពាក្យថា« មេឃ» គឺជាពាក្យប្រៀបធៀបនៃព្រះរបស់ប្រជាជន។
ការបកប្រែផ្សេងទៀត «ប្រជាជននៅទីក្រុងស្រែករកព្រះរបស់ពួកគេ»។

---

6 [1]គ្រានោះហឹបរបស់ព្រះអម្ចាស់ស្ថិតនៅលើទឹកដីភីលីស្ទីនអស់រយៈពេលប្រាំពីរខែ។[2]ក្រោយមកពួកភីលីស្ទីនបានអញ្ជើញពួកបូជាចារ្យ និងពួកគ្រូទាយមកហើយសួរថា៖
«តើយើងត្រូវប្រព្រឹត្តដូចម្តេចចំពោះហឹបរបស់ព្រះអម្ចាស់នេះ? សូមប្រាប់ពួកយើងនូវរបៀបបញ្ជូនហឹបនេះទៅកន្លែងដើមវិញយ៉ាងដូចម្តេច?»
[3]ពួកបូជាចារ្យ និងគ្រូទាយបានឆ្លើយថា «បើអស់លោកបញ្ជូនហឹបរបស់ព្រះជាម្ចាស់របស់អ៊ីស្រាអែលត្រឡប់ទៅវិញ កុំបញ្ជូនទៅដោយគ្មានតង្វាយឲ្យសោះ
គឺត្រូវមានទាំងតង្វាយទទួលកំហុសដល់ព្រះអង្គទៅជាមួយដែរ។ នោះអស់លោកនឹងបានជាស្បើយពីគ្រោះកាច ហើយមុខជាដឹងថា
មូលហេតុអ្វីបានជាព្រះហស្តរបស់ព្រះអង្គមិនដកចេញពីអស់លោករហូតមកដល់ពេលនេះ»។[4]ពួកគេបានសួរតបវិញថា៖
«តើអ្វីទៅជាតង្វាយទទួលកំហុសដែលយើងត្រូវថ្វាយត្រឡប់ទៅព្រះអង្គវិញ?»។ ពួកគ្រូឆ្លើយថា៖ «ចូរធ្វើដុំសាច់មាសប្រាំដុំ កណ្តុរមាសប្រាំ
លេខប្រាំនេះជាតំណាងឲ្យមេដឹកនាំនៃជនជាតិភីលីស្ទីនទាំងប្រាំរូប។ ដ្បិត ទាំងមេដឹកនាំ ទាំងពួកអស់លោកសុទ្ធបានរងគ្រោះកាចដូចគ្នា។
[5]អស់លោកត្រូវធ្វើគំរូដុំសាច់ និងកណ្តុរដែលរាតត្បាតក្នុងស្រុក ហើយថ្វាយសេរីល្អដល់ព្រះនៃជនជាតិអ៊ីស្រាអែល។ ធ្វើដូច្នេះ ប្រហែលជាព្រះអង្គដកព្រះហស្តចេញពីព្រះ
ពីស្រុក និងពីអស់លោក។[6]ហេតុអ្វីបានជាអស់លោកធ្វើចិត្តរឹងរូសដូចជាជនជាតិអេស៊ីប និងស្តេចផារ៉ោនដែលបានធ្វើចិត្តរឹងរូសដូច្នេះ? ធ្វើដូច្នោះហើយ
ដែលព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តចំពោះពួកគេយ៉ាងធ្ងន់ធ្ងរបែបនោះ។ តើមិនមែនជនជាតិអេស៊ីបអនុញ្ញាតឲ្យពួកគេចាកចេញ
ហើយពួកគេបានចាកចេញទៅទេឬអី?
[7]ពេលនេះ ចូររៀបចំរទេះថ្មីមួយជាមួយ ហើយមេគោពីរក្បាលដែលនៅបំបៅកូន ជាគោមិនធ្លាប់ទឹមសោះ។ ចងគោនោះទឹមនឹងរទេះ
ឯកូនរបស់វាត្រូវយកទៅក្រោលចេញពីមេដែលទឹមនោះ។[8]រួចយកហឹបរបស់ព្រះអម្ចាស់មកដាក់លើរទេះនោះ។ ដាក់រូបដែលធ្វើពីមាសទាំងនោះ
ដែលត្រូវបញ្ជូនទៅថ្វាយព្រះអង្គជាតង្វាយដឹងកំហុសនៅក្នុងប្រអប់មួយហើយដាក់ទៅម្ខាង។ បន្ទាប់មក ចូរបណ្តាយឲ្យវាចេញទៅដោយខ្លួនវាចុះ។[9]ឯអស់លោក
ចូរឃ្លាំមើល បើរទេះនោះតម្រង់ទៅឯបេតសេម៉េសដោយខ្លួនវា នោះមានន័យថា គឺព្រះអម្ចាស់ហើយដែលបានវាយប្រហារឲ្យមានមហន្តរាយដ៏សម្បើមនេះ។ ប៉ុន្តែ
បើមិនដូច្នោះទេ គឺមិនមែនព្រះអង្គទេដែលវាយប្រហារពួកយើង តែគ្រោះកាចនោះបានកើតឡើងលើពួកយើងដោយឯកឯងវិញ»។
[10]ពួកគេបានធ្វើតាមអ្វីដែលបានបង្គាប់ ពួកគេបានយកមេគោដែលកំពុងបំបៅកូនដាក់ទឹមនឹងរទេះ ហើយយកូនវាទៅឯក្រោល។
[11]ពួកគេបានដាក់ហឹបរបស់ព្រះអម្ចាស់នៅលើរទេះ ជាមួយនឹងប្រអប់ដែលដាក់កណ្តុរមាស និងដុំសាច់មាសក្នុងនោះដែរ។[12]គោបានតម្រង់ទៅឯបេតសេម៉េស។
គោបានដើរលើផ្លូវ ដើរទៅយឺតៗដោយមិនងាកទៅស្តាំ ឬទៅឆ្វេងឡើយ។ ពួកអ្នកដឹកនាំភីលីស្ទីនបានដើរតាមក្រោយរទេះទៅព្រំប្រទល់របស់បេតសេម៉េស។
[13]ខណៈនោះអ្នកនៅបេតសេម៉េសកំពុងប្រមូលផលស្រូវរបស់ពួកគេនៅជ្រលងភ្នំ។ ពេលពួកគេបានឃើញហឹបដូច្នេះ ពួកគេមានអំណរជាខ្លាំង។
[14]រទេះបានមកចម្ការរបស់លោកយ៉ូស្វេជាអ្នករស់នៅបេតសេម៉េស ហើយឈប់ទីនោះ។ នៅទីនោះមានផ្ទាំងថ្មធំមួយ ពួកគេបានដោះឈើរទេះនោះ
ព្រមទាំងយកមេគោទាំងពីរនោះថ្វាយជាតង្វាយដុតដល់ព្រះអម្ចាស់ផង។[15]ពួកលេវីបានយកហឹបរបស់ព្រះអម្ចាស់ និងប្រអប់ដែលដាក់កណ្តុរមាស និងដុំសាច់មាស
ហើយដាក់នៅលើផ្ទាំងថ្មដ៏ធំនោះ។ ឯអ្នករស់នៅបេតសេម៉េសក៏បានថ្វាយតង្វាយដុត និងធ្វើយញ្ញបូជាក្នុងថ្ងៃតែមួយនោះផងដែរ។
[16]នៅពេលអ្នកដឹកនាំទាំងប្រាំរូបរបស់ពួកភីលីស្ទីនបានឃើញដូច្នេះ ពួកគេក៏បានវិលត្រឡប់ទៅឯក្រុងអេក្រូនវិញនៅថ្ងៃដដែរ។
[17]ទាំងនេះគឺជារូបដុំសាច់មាសដែលពួកភីលីស្ទីនដាក់មកជាមួយ ជាតង្វាយលុបលាងកំហុសដល់ព្រះអម្ចាស់៖ មួយសម្រាប់ក្រុងអាដូឌ មួយសម្រាប់ក្រុងកាសា
មួយសម្រាប់ក្រុងអាសកាឡូន មួយសម្រាប់ក្រុងកាដ និងមួយទៀតសម្រាប់ក្រុងអេក្រូនផងដែរ។[18]ឯកណ្តុរមាសទាំងប្រាំ
ក៏ដូចជាចំនួននៃទីក្រុងទាំងប្រាំរបស់ស្រុកភីលីស្ទីនដែលស្ថិតនៅក្រោមការដឹកនាំនៃអ្នកដឹកនាំទាំងប្រាំរូបនោះដែរ គឺទាំងក្រុងដែលរឹងមាំ និងទាំងភូមិតូចៗ។

generated on Wed Sep 10 16:16:32 2025

គេបានយកហឹបរបស់ព្រះអម្ចាស់ ទៅដាក់នៅជិតផ្ទាំងថ្មដ៏ធំសម្បើមនោះ ហើយថ្មនោះគឺជាបន្ទាល់អំពីហឹបនៅក្នុងចម្ការរបស់លោកយ៉ូស្វេ
អ្នកបេតសេម៉ែសរហូតដល់សព្វថ្ងៃនេះ។
[19]ព្រះអម្ចាស់បានប្រហារមនុស្សដែលរស់នៅបេតសេម៉ែស ដោយសារតែពួកគេបានសម្លឹងមើលហឹបរបស់ព្រះអម្ចាស់។ ព្រះអង្គបានប្រហារពួកគេឲ្យស្លាប់ ៥០,
០៧០នាក់។ ពួកគេបានយំសោក ដោយពួកគេត្រូវបានព្រះអម្ចាស់ដាក់ទោស។[20]អ្នករស់នៅបេតសេម៉ែសខ្លះបាននិយាយថា៖
«តើមាននរណាអាចឈរនៅចំពោះព្រះអម្ចាស់បាន ដ្បិតព្រះអង្គជាព្រះដ៏វិសុទ្ធ? តើអ្នកណានឹងយកហឹបទៅឆ្ងាយពីយើងបាន?»
[21]ពួកគេបានបញ្ជូនអ្នកនាំសារទៅឯអ្នកស្រុកគារយ៉ាតយ៉ារីម ដោយនិយាយថា៖ «ពួកភីលីស្ទីបានបញ្ជូនហឹបនៃព្រះអម្ចាស់មកវិញហើយ
សូមអស់លោកអញ្ជើញមកយកទៅជាមួយអស់លោកវិញចុះ»។

---

1 Samuel 6:1

ពួកបូជាចារ្យ និងពួកគ្រូទាយ

ពួកគេជាបូជាចារ្យនិងគ្រូទាយ ដែលបានថ្វាយបង្គំព្រះដាកុន។

សូមប្រាប់ពួកយើងនូវរបៀបបញ្ជូនហឹបនេះ

ពួកភីលីស្ទីនចង់ដឹងពីរបៀបយកហឹបចេញ ដោយពុំធ្វើឲ្យ
ព្រះអម្ចាស់ព្រះពិរោធទៀតឡើយ។

1 Samuel 6:3

ព្រះរបស់ជនជាតិអ៊ីស្រាអែល

អាចមានន័យថា ១) ពួកគេហៅចំឈ្មោះព្រះជាម្ចាស់របស់អ៊ីស្រាអែល ឬ ២)
ពួកគេជឿថាអ៊ីស្រាអែលបានថ្វាយបង្គំព្រះមួយ ក្នុងចំណោមអាទិទេពជាច្រើនគឺ«
ព្រះនៃអ៊ីស្រាអែល»។ បកប្រែដូចនៅក្នុង ៥:៦។

គឺត្រូវមានទាំងតង្វាយទទួលកំហុសដល់ព្រះអង្គ

ពាក្យថា «តាមគ្រប់មធ្យោបាយ»ជាវិធីបង្ខំក្នុងការនិយាយអ្វីមួយ។
ការបកប្រែផ្សេងទៀត «អ្នកត្រូវតែថ្វាយតង្វាយដោះពិរុទ្ធ»

អស់នឹងបានជាស្បើយ

"អ្នកនឹងលែងឈឺទៀតហើយ"

លោក

សព្វនាម «អ្នក» ជាពហុវចនៈសំដៅទៅលើពួកភីលីស្ទីនទាំងអស់។

មូលហេតុអ្វីបានជាព្រះហស្តរបស់ព្រះអង្គមិនដកចេញពីអស់លោក

នៅទីនេះ« ដៃ» គឺជាពាក្យប្រៀបធៀប
ដែលត្រូវបានប្រើតំណាងអំណាចរបស់ព្រះជាម្ចាស់ ដើម្បីធ្វើឲ្យរងទុក្ខវេទនា
ឬដាក់ពិន័យ។ ការបកប្រែផ្សេងទៀត
«ហេតុអ្វីបានជាព្រះអង្គមិនបានបន្ថយការឈឺចាប់របស់អ្នក»

ដុះដុំសាច់

អាចមានន័យថា ១) ឈឺចាប់ស្បែកហើមជាំ ឬ ២) ជំងឺឬសដូងបាត។
បកប្រែដូចនៅក្នុង ៥:៦

កណ្តុរ

«កណ្តុរច្រើនជាងមួយ»

1 Samuel 6:5

គំរូ

គំរូជាអ្វីមួយដែលមើលទៅដូចជាវត្ថុពិត។

ដុះដុំសាច់

អាចមានន័យថា ១) ឈឺចាប់ស្បែកហើមជាំ ឬ ២) ជំងឺឬសដូងបាត។
បកប្រែដូចនៅក្នុង ៥:៦

ដែលរាតត្បាត

ដែលកំពុងបំផ្លាញ

ព្រះរបស់ជនជាតិអ៊ីស្រាអែល

អាចមានន័យថា ១) ពួកគេហៅចំឈ្មោះព្រះជាម្ចាស់របស់អ៊ីស្រាអែល ឬ ២)
ពួកគេជឿថាអ៊ីស្រាអែលបានថ្វាយបង្គំព្រះមួយ ក្នុងចំណោមអាទិទេពជាច្រើនគឺ
«ព្រះនៃអ៊ីស្រាអែល»។ បកប្រែដូចនៅក្នុង ៥:៦។

ប្រហែលជាព្រះអង្គដកព្រះហស្តចេញពីអ្នក ចេញពីព្រះអ្នក និងពីស្រុករបស់អស់លោក។

នៅទីនេះ« ដៃ»គឺជាពាក្យប្រៀបធៀប
ដែលត្រូវបានប្រើតំណាងឲ្យអំណាចរបស់ព្រះជាម្ចាស់ ដើម្បីធ្វើឲ្យរងទុក្ខវេទនា
ឬដាក់ពិន័យ។ ការបកប្រែផ្សេងទៀត «ឈប់ដាក់ទណ្ឌកម្មអ្នក
ព្រះរបស់អ្នកនិងស្រុករបស់អ្នក»

ហេតុអ្វីបានជាអស់លោកធ្វើចិត្តរឹងរូសដូចជាជនជាតិអេស៊ីប
និងស្តេចផារ៉ោនដែលបានធ្វើចិត្តរឹងរូសដូច្នេះ?

ពួកបូជាចារ្យ និងពួកគ្រូទាយប្រើសំណួរដ៏ប្រសព្វដើម្បីជម្រុញពួកភីលីស្ទីន
ឲ្យគិតឲ្យហ្មត់ចត់អំពីអ្វី ដែលនឹងកើតឡើង បើពួកគេមិនស្តាប់តាមព្រះជាម្ចាស់។
អាចបកប្រែជាការព្រមាន។ ការបកប្រែផ្សេងទៀត «កុំរឹងចចេសដូចជនជាតិអេស៊ីប
និងព្រះចៅផារ៉ោន!»

លោកធ្វើចិត្តរឹងរូស

នេះជាឃ្លាដែលមានន័យថា រឹងរូសឬមិនចង់ស្តាប់បង្គាប់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «បដិសេធមិនស្តាប់បង្គាប់ព្រះជាម្ចាស់»

តើមិនមែនជនជាតិអេស៊ីបអនុញ្ញាតឲ្យពួកគេចាកចេញ ហើយពួកគេបានចាកចេញទៅទេឬអី?

នេះជាសំណួរដ៏មានប៉ិនប្រសព្វមួយទៀត
ដែលត្រូវបានប្រើដើម្បីរម្លឹកដល់ពួកភីលីស្ទីនពីរបៀប
ដែលជនជាតិអេស៊ីបបានបញ្ជូនជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីបដើម្បីឲ្យព្រះជាម្ចាស់ឈប់ធ្វើបាប
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ចូរចាំថាជនជាតិអេស៊ីបបានបញ្ជូនជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីប»។

1 Samuel 6:7

មេគោពីរក្បាលដែលនៅបំបៅកូន

«គោពីរក្បាលមានកូន ដែលនៅតែកំពុងបំបៅកូន»

ចូរបណ្តាយឲ្យវាចេញទៅដោយខ្លួនវាចុះ។

ជាធម្មតា សត្វគោទាំងពីរក្បាលនឹងត្រឡប់មកផ្ទះវិញ ជាមួយកូនវា។

បើរទេះនោះតម្រង់... ទៅឯបេតសេម៉ែសដោយខ្លួនវា, នោះមានន័យថា គឺព្រះអម្ចាស់
មិនទំនងថា សត្វគោនឹងវង្វេងទៅបេតសេម៉ែស
ពេលកូនគោវិលត្រឡប់មកតំបន់ភីលីស្ទីនវិញ។

1 Samuel 6:10

មេគោពីរក្បាលដែលនៅបំបៅកូន

«គោពីរក្បាលដែលកំពុងបៅកូន» បកប្រែដូចនៅក្នុង ៦: ៧។

កណ្តុរ

បកប្រែដូចនៅក្នុង ៦: ៣។

ដុំសាច់មាសក្នុងនោះដែរ

«គំរូនៃដុំសាច់របស់ពួកគេ»

ដុះដុំសាច់

អាចមានន័យថា ១) ឈឺចាប់ស្បែកហើមជាំ ឬ ២) ជំងឺឬសដូងបាត។
បកប្រែដូចនៅក្នុង ៥:៦។

គោបានតម្រង់ទៅឯបេតសេម៉ែស។

ជាធម្មតាគោដែលបំបៅកូននឹងត្រលប់ទៅកូនរបស់ពួកវាវិញ ប៉ុន្តែ
គោទាំងនេះបានទៅបេតសេម៉ែស។

ដើរទៅយឺតៗ

ការដើរយឺតៗគឺជាសំឡេងរំខាន ដែលគោបង្កើតឡើងជាមួយនឹងសំឡេងរបស់វា។

ដោយមិនងាកទៅស្តាំ ឬទៅឆ្វេងឡើយ។

«ពួកវាមិនបានវង្វេងចេញពីផ្លូវទេ«។ អាចថ្លែងជាទម្រង់វិជ្ជមាន។
ការបកប្រែផ្សេងទៀត «ពួកវារស់នៅលើផ្លូវ»ឬ «ពួកគេដើរទៅមុខ»

1 Samuel 6:13

ខណៈនោះ

អ្នកនិពន្ធកំពុងបង្ហាញផ្នែកថ្មីនៃសាច់រឿង។
បើភាសារបស់អ្នកមានរបៀបសម្គាល់ការចាប់ផ្តើមថ្មីនៃសាច់រឿង
អ្នកអាចប្រើវាបាននៅទីនេះ។

អ្នកនៅបេតសេម៉ែស

ទាំងនេះជាជនជាតិអ៊ីស្រាអែល។

បានឃើញ

នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ក្រឡេកមើល»

1 Samuel 6:14

នៅទីនោះមានផ្ទាំងថ្មធំមួយ

ប្រជាជនបានប្រើថ្មនេះធ្វើជាអាសនៈ ពេលពួកគេថ្វាយគោជាយញ្ញបូជា។

ពួកលេវីបានយកហឹបរបស់ព្រះអម្ចាស់

រឿងនេះពិតជាបានកើតឡើងមុន

generated on Wed Sep 10 16:16:32 2025

ពេលពួកគេកាប់រទេះធ្វើជាអុសដុតសត្វទៅថ្វាយព្រះអម្ចាស់។
ពួកលេវីបានយកហឹប
យោងទៅតាមច្បាប់របស់លោកម៉ូសេ
មានតែពួកលេវីប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យកាន់ហឹប។
ប្រអប់ដែលដាក់កណ្តុរមាស និងដុំសាច់មាស
«ប្រអប់ដាក់គំរូមាសកណ្តុរនិងដុំសាច់» ។
1 Samuel 6:16
អ្នកដឹកនាំទាំងប្រាំរូបរបស់ពួកភីលីស្ទីន
«ស្តេចភីលីស្ទីនទាំងប្រាំអង្គ»
1 Samuel 6:17
ដុះដុំសាច់
អាចមានន័យថា ១) ឈឺចាប់ស្បែកហើមជាំ ឬ ២) ជំងឺឬសដូងបាត។
បកប្រែដូចនៅក្នុង ៥:៦។
កណ្តុរ
បកប្រែដូចនៅក្នុង ៦:៣។
ក្រុងដែលរឹងមាំ
ទាំងនេះគឺជាទីក្រុងនានា ដែលមានជញ្ជាំងខ្ពស់ព័ទ្ធជុំវិញពួកគេ
ដើម្បីការពារប្រជាជននៅខាងក្នុង ពីការវាយប្រហារពីសត្រូវរបស់ពួកគេ។
ផ្នាំងថ្មដ៏ធំសម្បើម ... គឺជាបន្ទាល់
ថ្មសំដៅទៅដូចជាមនុស្សដែលអាចមើលឃើញ។ ការបកប្រែផ្សេងទៀត
«ថ្មដ៏អស្ចារ្យ ... នៅតែមានហើយមនុស្សចងចាំអ្វី ដែលបានកើតឡើងនៅលើវា»
លោកយ៉ូស្វេ
ឈ្មោះរបស់មនុស្សប្រុស
អ្នកបេតសេម៉ស
ជាអ្វីដែលមនុស្សម្នាក់មកពីបេតសេម៉សហៅ។ ការបកប្រែផ្សេងទៀត
«មកពីបេតសេម៉ស»
រហូតដល់សព្វថ្ងៃនេះ
ពេលដែលអ្នកនិពន្ធបានសរសេរកណ្ឌគម្ពីរនេះ
1 Samuel 6:19
ពួកគេបានសម្លឹងមើលហឹបរបស់ព្រះអម្ចាស់
ហឹបមានលក្ខណៈវិសុទ្ធ គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យមើលនៅក្នុងនោះទេ។
មានតែពួកបូជាចារ្យប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យមើលហឹប។
ស្លាប់ ៥០,០៧០នាក់
«ប្រាំម៉ឺនចិតសិបនាក់»
តើមាននរណាអាចឈរនៅចំពោះព្រះអម្ចាស់បាន ដ្បិតព្រះអង្គជាព្រះដ៏វិសុទ្ធ?
អាចមានន័យថា ១) នេះគឺជាសំណួរដ៏ប៉ិនប្រសព្វ
ដែលបង្ហាញពីការភ័យខ្លាចរបស់ប្រជាជនចំពោះព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់អាចទប់ទល់នឹងព្រះអម្ចាស់បានទេ ព្រោះព្រះអង្គវិសុទ្ធ!» ឬ ២)
នេះគឺជាសំណួរដែលស្នើសុំព័ត៌មាន។ ឃ្លាថា «ឈរនៅចំពោះព្រះអម្ចាស់»
អាចសំដៅទៅលើពួកបូជាចារ្យ ដែលបម្រើព្រះអម្ចាស់។
បញ្ជាក់ថាប្រជាជនកំពុងស្វែងរកបូជាចារ្យម្នាក់
ដែលព្រះអម្ចាស់នឹងអនុញ្ញាតឲ្យសែងហឹប។ ការបកប្រែផ្សេងទៀត
«តើមានបូជាចារ្យណាម្នាក់ក្នុងចំណោមពួកយើង ដែលបម្រើព្រះជាម្ចាស់ដ៏វិសុទ្ធ
គឺព្រះអម្ចាស់ហើយអាចកាន់ហឹបនេះទេ»?
តើអ្នកណានឹងយកហឹបទៅឆ្ងាយពីយើងបាន?»
នេះជាសំណួរដែលស្នើសុំព័ត៌មាន។ មានន័យថា ប្រជាជនចង់ឲ្យព្រះអម្ចាស់
និងហឹបទៅកន្លែងផ្សេងទៀតដូច្នេះ ព្រះអង្គនឹងមិនដាក់ទោសពួកគេទៀតទេ។
ការបកប្រែផ្សេងទៀត «តើយើងអាចបញ្ជូនហឹបនេះទៅកន្លែងណា
ដើម្បីកុំឲ្យព្រះអម្ចាស់ដាក់ទោសយើងទៀត»?
1 Samuel 6:21
អ្នកស្រុកគារយ៉ាតយ៉ារីម
នេះជាទីក្រុងមួយនៅអ៊ីស្រាអែល។

---

7 [1]អ្នកស្រុកគារយ៉ាតយ៉ារីមបានចុះមក ហើយយកហឹបរបស់ព្រះអម្ចាស់ ទៅឯផ្ទះរបស់លោកអប៊ីណាដាប់ នៅលើទួល។ ពួកគេបានជ្រើសរើសកូនប្រុសរបស់លោក
គឺអេឡាសារ ឲ្យមើលថែហឹបរបស់ព្រះអម្ចាស់។[2]ហឹបត្រូវបានទុកនៅឯគារយ៉ាតយ៉ារីមជាយូ គឺប្រហែលជាម្ភៃឆ្នាំ។
ឯពួកកូនចៅអ៊ីស្រាអែលបានស្រែកអង្វរទៅរកព្រះអម្ចាស់វិញ។
[3]លោកសាំយូអែលបានមានប្រសាសន៍ទៅជនជាតិអ៊ីស្រាអែលទាំងមូលថា៖ «បើអ្នករាល់គ្នាវិលមករកព្រះអម្ចាស់វិញឲ្យអស់ពីចិត្ត គឺត្រូវរើរូបព្រះនៃសាសន៍ដទៃ
និងព្រះអាស្តារ៉ូតចេញពីចំណោមអ្នករាល់គ្នា ហើយបែរចិត្តរបស់អ្នករាល់គ្នាមករកព្រះអម្ចាស់ និងថ្វាយបង្គំព្រះអង្គតែមួយព្រះអង្គវិញ
នោះព្រះអង្គនឹងសង្គ្រោះអ្នករាល់គ្នាពីកណ្តាប់ដៃពួកភីលីស្ទីនមិនខាន»។[4]បន្ទាប់មក ពួកជនជាតិអ៊ីស្រាអែលបានរើព្រះបាល និងព្រះអាស្តារ៉ូតចេញ
ហើយបែរមកថ្វាយបង្គំព្រះអម្ចាស់តែមួយព្រះអង្គវិញ។
[5]លោកសាំយូអែលបានមានប្រសាសន៍ថា៖ «ចូរប្រមូលជនជាតិអ៊ីស្រាអែលទាំងអស់មកមីសប៉ា ខ្ញុំនឹងទូលអង្វរដល់ព្រះអម្ចាស់សម្រាប់អ្នករាល់គ្នា»។
[6]ពួកគេបានប្រមូលគ្នីគ្នានៅឯមីសប៉ា និងបានយកទឹកមកចាក់នៅចំពោះព្រះអម្ចាស់។ នៅថ្ងៃនោះ ពួកគេនាំគ្នាតមអាហារ ហើយសារភាពថា៖
«ទូលបង្គំយើងខ្ញុំបានប្រព្រឹត្តបាបទាស់នឹងព្រះអម្ចាស់ហើយ»។ នៅទីនោះហើយ ដែលលោកសាំយូអែលបានដោះស្រាយវិវាទឲ្យ ហើយដឹកនាំរបស់ប្រជាជនអ៊ីស្រាអែល។
[7]នៅពេលនោះ ពួកភីលីស្ទីនបានឮថា ប្រជាជនអ៊ីស្រាអែលបានមកប្រមូលគ្នានៅឯមីសប៉ា នោះអ្នកដឹកនាំភីលីស្ទីនក៏បានវាយប្រហារអ៊ីស្រាអែល។
ពេលប្រជាជនអ៊ីស្រាអែលបានឮដូច្នេះ ពួកគេភ័យខ្លាចដល់ពួកភីលីស្ទីន។[8]បន្ទាប់មក ពួកគេបាននិយាយទៅលោកសាំយូអែលថា៖
«សូមកុំបញ្ឈប់ការស្រែករកព្រះអម្ចាស់ជាព្រះរបស់យើងជំនួសពួកយើងឲ្យសោះ នោះព្រះអង្គនឹងសង្គ្រោះពួកយើងពីដៃរបស់ពួកភីលីស្ទីនមិនខាន»។
[9]លោកសាំយូអែលក៏បានយកកូនចៀមដែលកំពុងនៅបៅមកថ្វាយជាតង្វាយដុតទាំងមូលដល់ព្រះអម្ចាស់។
រួចលោកបានស្រែកអង្វរព្រះអម្ចាស់សម្រាប់ជនជាតិអ៊ីស្រាអែល ហើយព្រះអម្ចាស់ក៏បានឆ្លើយតបមកវិញផងដែរ។
[10]ខណៈលោកសាំយូអែលកំពុងថ្វាយតង្វាយដុត ពួកទ័ពភីលីស្ទីនបានចូលមកដល់វាយជនជាតិអ៊ីស្រាអែល។ ប៉ុន្តែ
ព្រះអម្ចាស់បានបញ្ជាឲ្យកើតមានផ្គរលាន់ឮឡើងនៅថ្ងៃនោះប្រឆាំងនឹងពួកភីលីស្ទីនវិញ ជាហេតុធ្វើឲ្យពួកគេមានការភាន់ច្រឡំ
ហើយក៏បានបាក់ទ័ពនៅចំពោះមុខជនជាតិអ៊ីស្រាអែល។[11]ទ័ពអ៊ីស្រាអែលក៏បានចេញពីមីសប៉ា តាមសម្លាប់ពួកភីលីស្ទីនទៅដល់បេតកា។
[12]ក្រោយមក លោកសាំយូអែលបានយកថ្មមួយមកដាក់ចន្លោះមីសប៉ា និងសេន។ លោកបានដាក់ឈ្មោះកន្លែងនោះថា អេបេន អេសុើរ ដោយថ្លែងថា៖
«មកទល់ពេលនេះ ព្រះអម្ចាស់នៅតែជួយយើង»។
[13]ដូច្នេះ ពួកភីលីស្ទីនបានបញ្ឈប់ការឈ្លានពាន ហើយលែងចូលរាតត្បាតដល់ព្រំប្រទល់អ៊ីស្រាអែលទៀតដែរ។
ព្រះហស្តរបស់ព្រះអម្ចាស់បានប្រឆាំងនឹងពួកភីលីស្ទីនរហូតអស់មួយជីវិតរបស់លោកសាំយូអែល។
[14]តំបន់ទាំងប៉ុន្មានដែលពួកភីលីស្ទីនបានវាយយកពីអ៊ីស្រាអែលក៏ត្រូវបានមកអ៊ីស្រាអែលវិញ គឺចាប់ពីក្រុងអេក្រុនមកដល់កាថ
នោះគឺជាតំបន់ដែលបានយកមកកាន់កាប់វិញពីពួកភីលីស្ទីន។ ក្រោយនោះមក មានសុខសន្តិភាពរវាង ជនជាតិអ៊ីស្រាអែល និងជនជាតិអាម៉ូរី។
[15]លោកសាំយូអែលបានរកខុសត្រូវឲ្យជនជាតិអ៊ីស្រាអែលអស់មួយជីវិតរបស់លោក។[16]រៀងរាល់ឆ្នាំ លោកបានធ្វើដំណើរទៅបេតអែល ទៅគីលកាល់ និងទៅមីសប៉ា។
លោកបានកាត់ក្តីឲ្យជនជាតិអ៊ីស្រាអែលនៅតំបន់ទាំងអស់នេះ។[17]ក្រោយមកលោកបានត្រឡប់ទៅរ៉ាម៉ាវិញ ពីព្រោះផ្ទះរបស់លោកនៅទីនោះ
ហើយលោកក៏ជម្រះក្តីឲ្យកូនចៅអ៊ីស្រាអែលនៅទីនោះផងដែរ លោកថែមទាំងបានសង់អាសនាមួយថ្វាយដល់ព្រះអម្ចាស់ទៀតផង។

---

1 Samuel 7:1
ស្រុកគារយ៉ាតយ៉ារី
នេះជាឈ្មោះទីកន្លែងមួយ។
លោកអប៊ីណាដាប់ ... លោក គឺអេឡាសារ
ទាំងនេះជាឈ្មោះរបស់បុរស។
ម្ភៃឆ្នាំ

generated on Wed Sep 10 16:16:32 2025

«២០ឆ្នាំ»
1 Samuel 7:3
មានប្រសាសន៍ទៅជនជាតិអ៊ីស្រាអែលទាំងមូល
ពាក្យថា«ផ្ទះ»ជាពាក្យកាត់សម្រាប់ប្រជាជន ដែលរស់នៅក្នុងផ្ទះ
និងកូនចៅរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «កូនចៅអ៊ីស្រាអែលទាំងអស់» ឬ
«ប្រជាជនអ៊ីស្រាអែលទាំងអស់»
វិលមករកព្រះអម្ចាស់វិញឲ្យអស់ពីចិត្ត
នៅទីនេះ«ដោយអស់ពីចិត្តរបស់អ្នក»គឺជាពាក្យសម្តីដែលមានន័យថា
ត្រូវលះបង់ទាំងស្រុងចំពោះអ្វីមួយ។ ការបកប្រែផ្សេងទៀត
«លះបង់ទាំងស្រុងចំពោះការគោរពបូជានិងគោរពប្រតិបត្តិដល់ព្រះអម្ចាស់តែមួយគត់»
1 Samuel 7:5
ជនជាតិអ៊ីស្រាអែលទាំងអស់
«ប្រជាជនអ៊ីស្រាអែលទាំងអស់» ឬ «ជនជាតិអ៊ីស្រាអែលទាំងអស់»
បានយកទឹកមកចាក់នៅចំពោះព្រះអម្ចាស់។
អាចមានន័យថា ១) ប្រជាជនបដិសេធមិនទទួលទឹកមួយចំណែកនៃការតមអាហារ
ឬ ២) ពួកគេបានយកទឹកចេញពីអូរ ឬអណ្តូងហើយចាក់វានៅលើដី
ជាសញ្ញាខាងក្រៅនៃការសោកស្តាយចំពោះអំពើបាបរបស់ពួកគេ។
1 Samuel 7:7
នោះអ្នកដឹកនាំភីលីស្ទីនក៏បានវាយប្រហារអ៊ីស្រាអែល។
គេអាចនិយាយបានយ៉ាងច្បាស់ថា គឺកងទ័ពហើយមិនមែនមេដឹកនាំពួកគេទេ
ដែលបានវាយប្រហារអ៊ីស្រាអែលនោះ។ ការបកប្រែផ្សេងទៀត
«ពួកមេដឹកនាំជនជាតិភីលីស្ទីនបានដឹកនាំកងទ័ពរបស់ពួកគេ
ហើយវាយប្រហារលើអ៊ីស្រាអែល»។
សង្គ្រោះពួកយើងពីដៃរបស់ពួកភីលីស្ទីនមិនខាន»
«ដៃ»គឺជាពាក្យប្រៀបធៀបសម្រាប់អំណាចរបស់មនុស្ស។ ការបកប្រែផ្សេងទៀត
«ជួយសង្គ្រោះយើងពីកងទ័ពភីលីស្ទីន» ឬ
«ការពារកងទ័ពភីលីស្ទីនពីការធ្វើបាបយើង»
1 Samuel 7:9
កូនចៀមដែលកំពុងនៅបៅ
កូនចៀមដែលកំពុងនៅបៅមេរបស់វា
ស្រែកអង្វរ
«បានស្រែករកជំនួយ»
ព្រះអម្ចាស់ក៏បានឆ្លើយតបមកវិញ
«ព្រះអម្ចាស់បានធ្វើអ្វី ដែលសាំយូអែលសុំទ្រង់ឲ្យធ្វើ»
1 Samuel 7:10
ខណៈលោកសាំយូអែល ...បេតកា
ពន្យល់ពីអត្ថន័យរបស់អ្នកនិពន្ធ ដែលមានចំណងជើងថា«
ព្រះអម្ចាស់បានឆ្លើយនឹងគាត់» នៅក្នុង (៧:៩)។
ពួកគេមានការភាន់ច្រឡំ
ពាក្យថា«ការភាន់ច្រឡំ»នៅទីនេះ
ត្រូវបានប្រើជារបៀបនិយាយដោយប្រុងប្រយ័ត្នថា
ពួកភីលីស្ទីនមិនបានគិតឲ្យបានច្បាស់លាស់ទេ។ ការបកប្រែផ្សេងទៀត
«ធ្វើឲ្យពួកគេមិនអាចគិតបានច្បាស់លាស់»
ហើយក៏បានបាក់ទ័ពនៅចំពោះមុខជនជាតិអ៊ីស្រាអែល។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ អាចមានន័យថា ១)
«ព្រះអម្ចាស់ផ្តួលពួកគេពីមុខអ៊ីស្រាអែល»ឬ ២) «អ៊ីស្រាអែលបានផ្តួលពួកគេ»
បាក់ទ័ព
ដើម្បីផ្តួលមនុស្សបានត្រូវកម្ចាត់ពួកគេមុន ពេលពួកគេអាចបង្កគ្រោះថ្នាក់។
បេតកា
នេះជាឈ្មោះរបស់ទីកន្លែងមួយ។
1 Samuel 7:12
បានយកថ្មមួយមកដាក់
ជនជាតិអ៊ីស្រាអែលនិងប្រជាជនដទៃទៀតនៅស្រុកនោះ នឹងដាក់ថ្មធំមួយ
ដែលព្រឹត្តិការណ៍សំខាន់ៗនេះបានកើតឡើងជាការរំឭកអំពីជំនួយរបស់ព្រះជាម្ចាស់។
មីសប៉ា ... សេន
ទាំងនេះជាឈ្មោះរបស់ទីកន្លែង។
1 Samuel 7:13
ដូច្នេះ ពួកភីលីស្ទីនបានបញ្ឈប់ការឈ្លានពាន
អ្នកនិពន្ធទើបតែបានបញ្ចប់ការរៀបរាប់អំពីរបៀប
ដែលពួកភីលីស្ទីនត្រូវបានបញ្ឈប់ការឈ្លានពាន។
បើភាសារបស់អ្នកមានរបៀបសម្គាល់ការបញ្ចប់នៃការពិពណ៌នា
អ្នកអាចប្រើវានៅទីនេះ។
ពួកភីលីស្ទីនបានបញ្ឈប់ការឈ្លានពាន
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានបញ្ឈប់ការឈ្លានពានរបស់ពួកភីលីស្ទីន» ឬ
«ព្រះអម្ចាស់បានការពារពួកភីលីស្ទីនមិនឲ្យបង្កគ្រោះថ្នាក់»
លែងចូលរាតត្បាតដល់ព្រំប្រទល់អ៊ីស្រាអែលទៀត
ពួកភីលីស្ទីនមិនបានចូលដល់ព្រំប្រទល់របស់អ៊ីស្រាអែលដើម្បីវាយប្រហារពួកគេឡើយ។
ព្រះហស្តរបស់ព្រះអម្ចាស់បានប្រឆាំងនឹងពួកភីលីស្ទីន
ពាក្យថា«ព្រះហស្ត»ជាពាក្យប្រៀបធៀបសម្រាប់អំណាច។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានប្រើអំណាចរបស់ទ្រង់ប្រឆាំងនឹងពួកភីលីស្ទីន»
តំបន់...អ៊ីស្រាអែលក៏ត្រូវបានមកអ៊ីស្រាអែលវិញ
អាចមានន័យថា ១) «ព្រះអម្ចាស់បានស្តារទឹកដីនានារបស់អ៊ីស្រាអែល ទីក្រុង...
ពីអ៊ីស្រាអែល»ឬ ២)
«ប្រជាជនអ៊ីស្រាអែលអាចយកតំបន់នានា ...ពីប្រទេសអ៊ីស្រាអែល»
1 Samuel 7:15
បានធ្វើដំណើរទៅ
បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ នៅផ្លូវកោងមានថ្មរដិបរដុប
លោកបានកាត់ក្តី
ជម្លោះគឺជាការឈ្លោះប្រកែកគ្នា ឬការមិនចុះសម្រុងគ្នារវាងមនុស្សពីរនាក់
ឬច្រើននាក់។

---

8 [1]នៅពេលលោកសាំយូអែលមានវ័យចាស់បន្តិច លោកបានតាំងឲ្យកូនប្រុសៗរបស់លោកជម្រះក្តីឲ្យជនជាតិអ៊ីស្រាអែល។[2]កូនប្រុសទីមួយរបស់លោកឈ្មោះ យ៉ូអែល
ទីពីរឈ្មោះ អប៊ីយ៉ា។ ពួកគេទាំងពីរគឺជាចៅហ្វាយនៅឯបៀរសេបា។[3]ប៉ុន្តែ កូនប្រុសរបស់លោក ពុំបានដើរក្នុងផ្លូវរបស់លោកទេ ផ្ទុយទៅវិញអ្នកទាំងពីរគិតពីចង់បាន។
ពួកគេទាំងពីរបានទទួលសំណូក ហើយកាត់ក្តីដោយអយុត្តិធម៌។
[4]ក្រោយមក ពួកចាស់ទុំអ៊ីស្រាអែលបានប្រមូលគ្នា ហើយទៅឯលោកសាំយូអែលនៅរ៉ាម៉ា។[5]ពួកគេបាននិយាយទៅលោកថា៖ «មើល លោកមានវ័យចាស់ហើយ
ហើយកូនប្រុសៗរបស់លោកមិនដើរតាមផ្លូវរបស់លោកទេ។ ដូច្នេះ សូមជ្រើសរើសស្តេចមួយអង្គមក សម្រាប់ដឹកនាំពួកយើងខ្ញុំដូចជាប្រជាជាតិនានាផងដែរ»។
[6]ប៉ុន្តែ លោកសាំយូអែលមិនសប្បាយចិត្តពេលពួកគេនិយាយថា៖ «សូមជ្រើសរើសស្តេចមួយអង្គមក សម្រាប់ដឹកនាំពួកយើងខ្ញុំ»។ ដូច្នេះហើយ
ទើបលោកសាំយូអែលទូលអង្វរកព្រះអម្ចាស់។[7]ព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកសាំយូអែលថា៖ «ចូរធ្វើតាមអ្វីៗគ្រប់យ៉ាងដែលពួកគេសុំអ្នកចុះ
ពួកគេពុំបានបដិសេធអ្នកចោលទេ គឺពួកគេបដិសេធយើងជាមហាក្សត្រដឹកនាំពួកគេទេតើ។
[8]ពួកគេកំពុងប្រព្រឹត្តនៅពេលនេះ ដូចពួកគេបានប្រព្រឹត្តតាំងពីថ្ងៃដែលយើងបាននាំពួកគេចេញពីស្រុកអេស៊ីបដែរ គឺបោះបង់យើង ហើយទៅបំរើព្រះដទៃវិញ ដូច្នេះ
ពួកគេក៏ប្រព្រឹត្តដូច្នោះដែរ។[9]ចូរស្តាប់តាមពួកគេចុះ ប៉ុន្តែ ត្រូវព្រមានពួកគេឲ្យច្បាស់ ហើយឲ្យពួកគេដឹងថា ស្តេចនឹងត្រួតត្រាលើពួកគេ»។
[10]ដូច្នេះ លោកសាំយូអែលក៏ប្រាប់នូវព្រះបន្ទូលទាំងអស់របស់ព្រះអម្ចាស់ដល់ពួកអ្នកដែលសុំចង់បានស្តេចនោះ។[11]លោកបានមានប្រសាសន៍ថា៖
«ស្តេចដែលនឹងសោយរាជ្យលើអ្នករាល់គ្នានឹងប្រព្រឹត្តដូច្នេះ ចំពោះអ្នករាល់គ្នា គឺស្តេចនឹងយកកូនប្រុសៗរបស់អ្នករាល់គ្នាឲ្យធ្វើជាទាហានសេះ
និងអ្នកបរទេសចម្បាំងរបស់ស្តេច និងខ្លះជាទាហានផងដែរ។[12]ស្តេចនឹងតាំងឲ្យមានមេបញ្ជាការលើទាហានរាប់ពាន់នាក់ និងមេបញ្ជាការលើហាសិបនាក់ផងដែរ។
ស្តេចនឹងចាត់អ្នកខ្លះឲ្យព្យួរដីស្រែរបស់ស្តេច ខ្លះឲ្យច្រូតកាត់ចម្រូតរបស់ស្តេច ខ្លះធ្វើអាវុធសម្រាប់សង្គ្រាម និងគ្រឿងបំពាក់រទេះចម្បាំង។
[13]ស្តេចនឹងយកកូនស្រីៗរបស់អ្នករាល់គ្នា ឲ្យផលិតទឹកអប់ ខ្លះចម្អិនម្ហូប និងខ្លះទៀតជាអ្នកដុតនំប៉័ង។[14]ស្តេចនឹងយកអ្វីៗដែលល្អបំផុតពីស្រែ ពីចម្ការទំពាំងបាយជូរ
ពីចម្ការអូលីវរបស់អ្នករាល់គ្នា ឲ្យទៅមន្ត្រីជារាជ្យបម្រើស្តេច។[15]ស្តេចនេះយកមួយភាគដប់នៃផលដំណាំ ពីទំពាំងបាយជូររបស់អ្នករាល់គ្នាទៅឲ្យមន្ត្រី
និងរាជ្យបម្រើរបស់ស្តេចទៀតផង។

generated on Wed Sep 10 16:16:32 2025

[16]ស្តេចក៏នឹងយកបាវប្រុសស្រី និងបុរសដែលពេញកម្លាំងខ្លាំងបំផុតរបស់អ្នករាល់គ្នា ថែមទាំងយកលារបស់អ្នករាល់គ្នាឲ្យមកធ្វើការឲ្យស្តេច។
[17]ស្តេចនឹងយកមួយភាគដប់នៃពីហ្វូងសត្វ ហើយឯអ្នករាល់គ្នាធ្វើជាទាសកររបស់ស្តេចផងដែរ។[18]ពេលថ្ងៃនោះមកដល់
អ្នករាល់គ្នានឹងស្រែកអង្វររកជំនួយព្រះអម្ចាស់ដោយសារស្តេចដែលអ្នករាល់គ្នាបានជ្រើសតាំងសម្រាប់ខ្លួនឯង ប៉ុន្តែ
ព្រះអម្ចាស់នឹងមិនឆ្លើយតបនឹងអ្នករាល់គ្នាឡើយនៅថ្ងៃនោះឡើយ។
[19]ទោះយ៉ាងនោះក្តី ប្រជាជនមិនស្តាប់លោកសាំយូអែលទេ ពួកគេបាននិយាយថា៖ «ទេ! យើងត្រូវតែមានស្តេចមួយអង្គ[20]ធ្វើដូច្នេះ
ពួកយើងនឹងបានដូចជាប្រជាជាតិនានាដែរ ហើយស្តេចនឹងដឹកនាំរកខុសត្រូវជូនពួកយើង ព្រមទាំងនាំមុខពួកយើងទៅច្បាំងនោះសមរភូមិផង»។
[21]ពេលលោកសាំយូអែលបានឮសំដីរបស់ប្រជាជន លោកក៏បានទូលទៅព្រះអម្ចាស់ម្តងទៀត។[22]ព្រះអម្ចាស់បានតបទៅលោកសាំយូអែលវិញថា៖
«ចូរធ្វើតាមសម្តីពួកគេចុះ ចូររកមើលម្នាក់ឲ្យធ្វើជាស្តេចសម្រាប់ពួកគេទៅ»។ បន្ទាប់មក លោកសាំយូអែលក៏ប្រាប់ឲ្យប្រជាជនអ៊ីស្រាអែលថា៖
«ចូរអ្នករាល់គ្នាត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញសិនចុះ»។

---

1 Samuel 8:1
ពួកគេទាំងពីរបានទទួលសំណូក
អ្នកនិពន្ធនិយាយអំពីប្រាក់ ដែលមនុស្សនឹងឲ្យកូនប្រុសរបស់សាំយូអែល
ដូចជាមនុស្ស ឬសត្វដែលរត់ចេញពីកូនប្រុសរបស់សាំយូអែល
ហើយគាត់និយាយអំពីកូនប្រុសរបស់សាំយូអែល
ដូចជាពួកគេកំពុងតែដេញតាមចាប់រាងកាយមនុស្ស ឬសត្វនោះ។
ការបកប្រែផ្សេងទៀត «ពួកគេរកលុយទាំងលំបាក ដោយមិនស្មោះត្រង់»
កាត់ក្តីដោយអយុត្តិធម៌។
«ត្រូវបានវិនិច្ឆ័យឲ្យសក្តិសមនឹងអស់អ្នកណា ដែលបានធ្វើអំពើអាក្រក់»
1 Samuel 8:4
មិនដើរតាមផ្លូវរបស់លោកទេ
របៀបដែលមនុស្សរស់នៅ ប្រៀបបីដូចជាការដើរលើផ្លូវមួយ។ ការបកប្រែផ្សេងទៀត
«មិនធ្វើអ្វីដែលអ្នកធ្វើ» ឬ «មិនធ្វើអ្វីដែលគ្រាន់តែជារបៀប ដែលអ្នកធ្វើ»
«សូមជ្រើសរើសស្តេចមួយអង្គមក សម្រាប់ដឹកនាំពួកយើងខ្ញុំដូចជាប្រជាជាតិនានាផងដែរ»។
អាចមានន័យថា ១) «តែងតាំងយើងជាស្តេចដូចជាស្តេចនៃប្រជាជាតិទាំងអស់
ដើម្បីឲ្យព្រះអង្គអាចវិនិច្ឆ័យយើងបាន» ឬ ២) «តែងតាំងយើងជាស្តេច
ដែលនឹងវិនិច្ឆ័យយើងតាមរបៀបស្តេចរបស់ប្រជាជាតិនានាវិនិច្ឆ័យពួកគេ»
សូមជ្រើសរើសស្តេចមួយអង្គមក សម្រាប់ដឹកនាំពួកយើងខ្ញុំ
មេដឹកនាំជឿខុសថា ស្តេចមួយអង្គនិងបុត្រារបស់ទ្រង់នឹងគ្រប់គ្រងដោយយុត្តិធម៌។
1 Samuel 8:6
ប៉ុន្តែ លោកសាំយូអែលមិនសប្បាយចិត្ត ... សូមជ្រើសរើសស្តេចមួយអង្គមក
លោកសាំយូអែលមិនសប្បាយចិត្ត
ដែលប្រជាជនមិនត្រឹមតែចង់ឲ្យគាត់ដកកូនប្រុស
ដែលពុករលួយរបស់គាត់ចេញហើយតែងតាំងដឹកនាំស្មោះត្រង់នោះទេ ប៉ុន្តែ
ពួកគេចង់បានស្តេចមួយអង្គគ្រប់គ្រងលើពួកគេ ដូចប្រទេសដទៃទៀតដែរ។
ចូរធ្វើតាមអ្វីៗគ្រប់យ៉ាងដែលពួកគេ
នៅទីនេះ «សំឡេង»ជាពាក្យសម្តីតំណាងឆន្ទៈ ឬបំណងប្រាថ្នារបស់ប្រជាជន។
ការបកប្រែផ្សេងទៀត «ធ្វើអ្វីដែលប្រជាជននិយាយ»
គឺពួកគេបដិសេធយើង
ព្រះអម្ចាស់ជ្រាបថា ប្រជាជនមិនត្រឹមតែបដិសេធអ្នកដឹកនាំ
ដែលពុករលួយប៉ុណ្ណោះទេ ប៉ុន្តែ
ពួកគេបានបដិសេធព្រះអម្ចាស់ជាស្តេចរបស់ពួកគេ។
1 Samuel 8:8
យើងបាននាំពួកគេចេញពីស្រុកអេស៊ីប
សំដៅទៅលើព្រះអម្ចាស់ ដែលបានរំដោះជនជាតិអ៊ីស្រាអែលពីទាសភាព
នៅស្រុកអេស៊ីបជាច្រើនឆ្នាំមុន។
ចូរស្តាប់តាមពួកគេចុះ
«ឥឡូវនេះធ្វើអ្វី ដែលពួកគេស្នើសុំឲ្យអ្នកធ្វើ»
ត្រូវព្រមានពួកគេឲ្យច្បាស់
«យ៉ាងហ្មត់ចត់បំផុត ពេលអ្នកព្រមានពួកគេ»
1 Samuel 8:10
ស្តេចដែលនឹងសោយរាជ្យលើអ្នករាល់គ្នា ... ស្តេចនឹងយក
ការសោយរាជ្យរបស់ស្តេច។ ចាប់ផ្តើមចេញពីបញ្ជីនៃអ្វីៗដែលស្តេចនឹងយក។
ស្តេចដែលនឹងសោយរាជ្យលើអ្នករាល់គ្នានឹងប្រព្រឹត្តដូច្នេះ ចំពោះអ្នករាល់គ្នា
នាមអរូបី «ការអនុវត្ត»អាចបកប្រែជាទម្រង់កិរិយាស័ព្ទ។ការបកប្រែផ្សេងទៀត
«នេះជារបៀបដែលស្តេចនឹងសោយរាជ្យលើអ្នក ហើយនឹងប្រព្រឹត្ត» ឬ
«នេះគឺជាអ្វីដែលស្តេចនឹងសោយរាជ្យលើអ្នកនឹងធ្វើ»
ឲ្យធ្វើជាទាហានសេះ
«ឲ្យគេបរទេះសេះទៅក្នុងសមរភូមិ»
អ្នកបររទេះចម្បាំងរបស់ស្តេច
ពួកគេនឹងជិះសេះទៅក្នុងសមរភូមិ។
1 Samuel 8:13
ឃ្លាភ្ជាប់៖
លោកសាំយូអែលបន្តប្រាប់ពីអ្វីដែលស្តេចនឹងយក។
ឲ្យផលិតទឹកអប់
«ធ្វើឲ្យមានក្លិនល្អដាក់លើព្រះកាយរបស់ទ្រង់»
ចម្ការអូលីវ
«ចម្ការអូលីវ»
យកមួយភាគដប់នៃផលដំណាំ
ពួកគេត្រូវបែងចែកផលដំណាំរបស់ពួកគេ ជាដប់ចំណែកស្មើៗគ្នា
ហើយចែកមួយចំណែកទៅឲ្យពួកមន្ត្រីរបស់ស្តេច និងពួកអ្នកបម្រើ។
មួយភាគដប់ ... ពីទំពាំងបាយជូររបស់អ្នករាល់គ្នា
ពួកគេត្រូវចែកស្រា ដែលពួកគេផលិតក្នុងចម្ការទំពាំងបាយជូររបស់ពួកគេ
ជាដប់ចំណែកស្មើៗគ្នា និងចែកមួយចំណែកទៅឲ្យមន្ត្រី និងពួកមន្ត្រីរបស់ស្តេច។
មន្ត្រី
ទាំងនេះជាមេដឹកនាំនៃកងទ័ពរបស់ស្តេច។
1 Samuel 8:16
ឃ្លាភ្ជាប់៖
លោកសាំយូអែលបន្តប្រាប់ពីអ្វីដែលស្តេចនឹងយក។
មួយភាគដប់នៃពីហ្វូងសត្វ
ពួកគេត្រូវបែងចែកផលដំណាំរបស់ពួកគេ ជាដប់ចំណែកស្មើៗគ្នា
ហើយចែកមួយចំណែកទៅឲ្យពួកមន្ត្រីរបស់ស្តេច និងពួកអ្នកបម្រើ។
សូមមើលការបកប្រែ« មួយភាគដប់» នៅក្នុង ៨:១៣។
ឯអ្នករាល់គ្នាធ្វើជាទាសកររបស់ស្តេចផងដែរ។
«អ្នកនឹងមានអារម្មណ៍ ដូចជាអ្នកជាទាសកររបស់គាត់»
អ្នករាល់គ្នានឹងស្រែកអង្វរក
អាចមានន័យថា ១) ប្រជាជននឹងស្នើសុំព្រះអម្ចាស់ឲ្យជួយសង្គ្រោះពួកគេពីស្តេច ឬ
២) ប្រជាជននឹងស្នើសុំស្តេចឲ្យឈប់ធ្វើបាបពួកគេយ៉ាងធ្ងន់ធ្ងរ។
1 Samuel 8:21
លោកក៏បានទូលទៅព្រះអម្ចាស់ម្តងទៀត។
នៅទីនេះមានពាក្យប្រៀបធៀប«ព្រះកាណ៌របស់ព្រះអម្ចាស់»សំដៅទៅលើព្រះអម្ចាស់។
សាំយូអែលបានអធិស្ឋានដល់ព្រះអម្ចាស់ម្តងហើយម្តងទៀតនូវអ្វី
ដែលប្រជាជនបាននិយាយ។ ការបកប្រែផ្សេងទៀត
«គាត់បានប្រាប់ពួកគេម្តងទៀតដល់ព្រះអម្ចាស់»
ចូរធ្វើតាមសម្តីពួកគេចុះ
នៅទីនេះពាក្យប្រៀបធៀប«សំឡេងរបស់ពួកគេ»សំដៅទៅលើឆន្ទៈរបស់ប្រជាជន។
ការបកប្រែផ្សេងទៀត «ស្តាប់ប្រជាជន»
ចូររកមើលម្នាក់ឲ្យធ្វើជាស្តេចសម្រាប់ពួកគេទៅ
«តែងតាំងនរណាម្នាក់ឲ្យធ្វើជាស្តេចលើពួកគេ»ប្រើពាក្យទូទៅនៅក្នុងភាសារបស់អ្នកសម្រាប់តែងតាំងនរ
ត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញសិនចុះ
«ទៅផ្ទះ»

---

[1]មានបុរសម្នាក់ពីកុលសម្ព័ន្ធបេនយ៉ាមីន ជាអ្នកមានឥទ្ធិពល គាត់ឈ្មោះថា គីស ជាកូនប្រុសរបស់លោកអបៀល ជាចៅរបស់លោកសេរោ និងជាចៅទួតរបស់លោកបេកូរ៉ា
ហើយត្រូវជាចៅទួតរបស់លោកអភីយ៉ា ជាអ្នកក្នុងកុលសម្ព័ន្ធបេនយ៉ាមីន។[2]គាត់មានកូនប្រុសម្នាក់ឈ្មោះ សូល ជាបុរសមានរាងសង្ហា។
គ្មានបុរសណាក្នុងចំណោមប្រជាជនអ៊ីស្រាអែលដែលសង្ហាជាងបុរសម្នាក់នោះឡើយ។ ពីស្មាឡើងលើ ជាមនុស្សដែលមានមាឌធំខ្ពស់ជាងអ្នកផ្សេងទាំងអស់។
[3]ពេលនោះ លារបស់លោកគីស ជាឪពុករបស់លោកសូលបានវង្វេង។ ដូច្នេះ លោកគីស បានប្រាប់ឲ្យកូនប្រុស គឺសូល ថា៖ «ចូរយកបាវម្នាក់ទៅជាមួយកូន
ហើយក្រោកឡើងចេញទៅរកលាដែលវង្វេងបាត់នោះ»។[4]លោកសូលបានធ្វើដំណើរដល់ភ្នំអេប្រាអ៊ីម ហើយបានឆ្លងកាត់ស្រុកសាលីសា ប៉ុន្តែ មិនឃើញលាទាំងនោះទេ។
បន្ទាប់មក ក៏ឆ្លងកាត់ស្រុកសាលីម ក៏នៅតែមិនឃើញ។ ពេលបានឆ្លងកាត់ស្រុកបេនយ៉ាមីន ក៏ពុំមានដំណឹងអ្វីដែរ។
[5]ពេលបានមកដល់ទឹកដីស៊ូភ លោកសូលបានមានប្រសាសន៍ទៅបាវរបស់គាត់ដែលមកជាមួយថា៖ «តោះ យើងត្រឡប់ទៅវិញ
ក្រែងឪពុកខ្ញុំលែងខ្វល់ខ្វាយនឹងលាទាំងនោះ ហើយបែរជាមកព្រួយបារម្ភពីយើងវិញ»។[6]ប៉ុន្តែ បាវនោះបាននិយាយមកលោកវិញថា៖ «សូមស្តាប់ខ្ញុំសិន
មានអ្នកជំនិតរបស់ព្រះជាម្ចាស់ម្នាក់រស់នៅក្នុងក្រុងនេះ។ គាត់ជាមនុស្សដែលគេគោរព ហើយអ្វីៗដែលលោកបាននិយាយសុទ្ធតែកើតឡើង។ តោះយើងគួរទៅទីនោះ
ប្រហែលជាគាត់អាចប្រាប់យើងនូវផ្លូវណាដែលយើងគួរទៅ»។
[7]នោះលោកសូលក៏តបទៅបាវវិញថា៖ «បើយើងទៅ តើយើងមានអ្វីទៅជូនលោកនោះ? ព្រោះនំបុ័ងក៏អស់ពីថង់
ហើយយើងក៏គ្មានអំណោយអ្វីជូនអ្នកជំនិតរបស់ព្រះជាម្ចាស់ដែរ។ តើយើងមានអ្វី?»[8]បាវបានតបលោកសូលវិញថា៖ «នេះនែ
ខ្ញុំមានប្រាក់មួយកាក់ដែលអាចយកជូនអ្នកជំនិតរបស់ព្រះជាម្ចាស់បាន ដើម្បីសុំឲ្យគាត់ប្រាប់យើងនូវផ្លូវដែលយើងត្រូវទៅ»។
[9](នៅក្នុងស្រុកអ៊ីស្រាអែលកាលពីមុន នៅពេលនរណាម្នាក់ចង់ស្វែងរកព្រះហឫទ័យនៃព្រះជាម្ចាស់ អ្នកនោះនិយាយថា៖ «មក ចូរយើងទៅរកគ្រូទាយ»។
ដោយព្រោះព្យាការីសព្វថ្ងៃនេះ អ្នកពីមុនហៅថាជា គ្រូទាយ)។[10]នោះលោកសូលបានមានប្រសាសន៍ទៅបាវថា៖ «និយាយល្អណាស់ តោះយើងចេញទៅ»។ ដូច្នេះ
ពួកគេចេញដំណើរទៅក្រុងដែលអ្នកជំនិតរបស់ព្រះជាម្ចាស់ធ្លាប់រស់នៅ។[11]ពេលទៅដល់ទីទួលនៃក្រុង ពួកគេឃើញនារីក្មេងៗកំពុងចេញមកដងទឹក
លោកសូលនិងបាវបាននិយាយទៅពួកនាងថា៖ «តើមានគ្រូទាយនៅទីនេះឬទេ?»
[12]ពួកនាងបានឆ្លើយថា៖ «ចាំ មើល គាត់នៅនឹងមុខលោកស្រាប់ហើយ។ ចូរទៅប្រញាប់ ពីព្រោះគាត់កំពុងមកទីក្រុងថ្ងៃនេះហើយ
ដោយប្រជាជនត្រូវថ្វាយយញ្ញបូជានៅលើទីទួលខ្ពស់ថ្ងៃនេះដែរ។[13]ពេលលោកចូលដល់ក្រុង លោកនឹងឃើញគាត់
មុនពេលគាត់ឡើងទៅទទួលទានអាហារនៅទីទួលខ្ពស់នោះ។ ប្រជាជនមិនបរិភោគអ្វីទាំងអស់ទាល់តែលោកមកសិន ពីព្រោះគាត់ជាអ្នកថ្វាយយញ្ញបូជានោះ
ក្រោយមកអ្នកដែលត្រូវបានអញ្ជើញអាចបរិភោគបាន។ ចូរចេញទៅចុះ នោះអស់លោកនឹងឃើញគាត់មិនខាន»។
[14]ឮដូច្នេះពួកគេបានចេញដំណើរទៅឯទីក្រុង ពេលចូលដល់ក្រុង ពួកគេបានឃើញលោកសាំយូអែលដើរតម្រង់មកពួកគេ ទៅឯទីទួលខ្ពស់នោះ។
[15]ពេលវេលារបស់លោកសូលបានមកដល់ ព្រះអម្ចាស់បានបើកសម្តែងដល់លោកសាំយូអែលដូចតទៅថា៖[16]«ស្អែកពេលថ្មើនេះ
យើងនឹងបញ្ជូនបុរសម្នាក់ពីទឹកដីបេនយ៉ាមីនមកឯអ្នក ហើយអ្នកនឹងចាក់ប្រេងតាំងបុរសនោះឲ្យធ្វើជាស្តេចលើប្រជាជនអ៊ីស្រាអែល។
បុរសនេះនឹងរំដោះប្រជាជនរបស់យើងពីដៃរបស់ពួកភីលីស្ទីន។ ពីព្រោះយើងបានមើលឃើញ ហើយអាណិតដល់ប្រជាជនរបស់យើង
ដោយសម្រែងទូលអង្វររបស់ពួកគេរកជំនួយបានមកដល់យើង»។
[17]ពេលលោកសាំយូអែលបានឃើញលោកសូល ព្រះអម្ចាស់បានប្រាប់គាត់ថា៖ «គឺបុរសនេះហើយដែលយើងបានប្រាប់អ្នក! បុរសនេះនឹងដឹកនាំប្រជាជនរបស់យើង»។
[18]បន្ទាប់មក លោកសូលបានចូលមកជិតលោកសាំយូអែលនៅឯខ្លោងទ្វារ ហើយបានមានប្រសាសន៍ថា៖ «សូមលោកប្រាប់ខ្ញុំពីផ្ទះគ្រូទាយផង
តើនៅទីណា?»[19]លោកសាំយូអែលបានតបនឹងលោកសូលវិញថា៖ «គឺខ្ញុំហើយជាគ្រូទាយ។ ចូរឡើងទៅទីទួលខ្ពស់មុនខ្ញុំចុះ ព្រោះថ្ងៃនេះលោកនឹងរួមអាហារជាមួយខ្ញុំ។
ព្រឹកឡើងខ្ញុំនឹងអនុញ្ញាតឲ្យលោកទៅវិញ ហើយខ្ញុំនឹងប្រាប់លោកគ្រប់យ៉ាងដែលមាននៅនឹងគំនិតរបស់លោក។
[20]រឿងបាត់សត្វលាពីបីថ្ងៃមុននោះ កុំបារម្ភទៀតឡើយ ព្រោះគេបានរកឃើញពួកវាវិញហើយ។ តើមិនមែនលោកទេឬជាបំណងប្រាថ្នារបស់ជនជាតិអ៊ីស្រាអែល?
តើមិនមែនលោក និងគ្រួសាររបស់ឪពុកលោកទេឬអី?»[21]លោកសូលបានតបវិញថា «តើខ្ញុំមិនមែនមកពីកុលសម្ព័ន្ធបេនយ៉ាមីនទេឬអី
ជាកុលសម្ព័ន្ធតូចជាងគេបំផុតរបស់អ៊ីស្រាអែល? តើមិនមែនអំបូររបស់ខ្ញុំរឹតតែតូចជាងអំបូរផ្សេងៗនៃកុលសម្ព័ន្ធបេនយ៉ាមីនទេឬអី?
ហេតុអ្វីបានជាលោកនិយាយមកដូចជាខ្ញុំនឹងអស្ចារ្យយ៉ាងនេះ?»
[22]លោកសាំយូអែលបានយកលោកសូល និងបាវរបស់លោកទៅឯវាល ហើយដាក់នៅកន្លែងអង្គុយពីមុខអ្នកផ្សេងៗដែលត្រូវបានអញ្ជើញមកប្រមាណជាសាមសិបនាក់។
[23]លោកសាំយូអែលបានមានប្រសាសន៍ទៅអ្នកចម្អិនម្ហូបថា៖ «ចូរយកចំណែកដែលខ្ញុំបានប្រគល់ឲ្យអ្នក ដែលខ្ញុំនិយាយថា ចូរដាក់ដោយឡែកនោះ»។
[24]អ្នកចម្អិនក៏យកសាច់ភ្លៅដែលបានញែកទុកនោះ មកដាក់នៅមុខលោកសូល។ បន្ទាប់មក លោកសាំយូអែលបានមានប្រសាសន៍ថា៖ «មើល
អ្វីដែលបានរក្សាទុកនោះត្រូវបានដាក់នៅមុខរបស់លោកហើយ។ ចូរពិសារចុះ ពីព្រោះ ចំណែកនេះ ត្រូវបានរក្សាទុក ចាំរហូតពេលនេះមកដល់
គឺតាំងពីពេលដែលខ្ញុំបាននិយាយថា ខ្ញុំបានអញ្ជើញមនុស្ស»។ នោះ លោកសូលបានបរិភោគអាហារជាមួយនឹងលោកសាំយូអែលនៅថ្ងៃនោះ។
[25]ពេលពួកគេបានចុះពីទីទួលខ្ពស់ចូលទីក្រុងវិញ លោកសាំយូអែលបានមានប្រសាសន៍ជាមួយលោកសូលនៅលើដំបូលផ្ទះ។[26]ពេលថ្ងៃរះឡើង
លោកសាំយូអែលបានហៅលោកសូលនៅលើដំបូលផ្ទះថា៖ «ចូរក្រោកឡើង នោះខ្ញុំអាចបញ្ជូនអ្នកឲ្យទៅ»។ លោកសូលបានក្រោកឡើង អ្នកទាំងពីរ ទាំងលោកសូល
និងលោកសាំយូអែលបានចេញទៅឯផ្លូវ។
[27]កាលពួកលោកបានដើរដល់ជាយក្រុងហើយ លោកសាំយូអែលបានប្រាប់លោកសូលថា៖ «ឲ្យបាវលោកទៅមុនយើងចុះ» បាវក៏បានចេញទៅមុន
«តែលោកត្រូវនៅទីនេះបន្តិចសិន នោះខ្ញុំនឹងប្រាប់ព្រះរាជសាររបស់ព្រះជាម្ចាស់ដល់លោក»។

---

1 Samuel 9:1

ព័ត៌មានទូទៅ៖

បើភាសារបស់អ្នកមានរបៀបប្រាប់អ្នកអានថា
អ្នកនិពន្ធកំពុងផ្តល់ព័ត៌មានសង្ខេបនៅក្នុងខទាំងនេះ អ្នកអាចប្រើវានៅទីនេះ។

ជាអ្នកមានឥទ្ធិពល

អាចមានន័យថា ១) គាត់ជាអ្នកមានទ្រព្យសម្បត្តិ ឬ ២) គាត់ជាអភិជន ឬ ៣)
គាត់ជាមនុស្សពូកែនិងក្លាហាន។

គីស ... លោកអបៀល ... លោកសេរោ ...លោកបេកូរ៉ា ... លោកអភីយ៉ា

ទាំងនេះជាឈ្មោះរបស់វង្សត្រកូលរបស់សូល។

កុលសម្ព័ន្ធបេនយ៉ាមីន

កុលសម្ព័ន្ធបេនយ៉ាមីនគឺជាមនុស្សម្នាក់
ដែលជាកម្មសិទ្ធិរបស់កុលសម្ព័ន្ធបេនយ៉ាមីន

បុរសមានរាងសង្ហា

មនុស្សម្នាក់ដែលរូបរាងសង្ហា

ពីស្មាឡើងលើ ជាមនុស្សដែលមានមាឌធំខ្ពស់ជាងអ្នកផ្សេងទាំងអស់។

ប្រជាជនមានកម្ពស់ខ្ពស់ផ្សេងទៀតនៅស្រុកអ៊ីស្រាអែលមិនបានស្មោះ
សូម្បីតែស្មារបស់គាត់ផង។

1 Samuel 9:3

ពេលនោះ

អ្នកនិពន្ធបានបញ្ចប់ព័ត៌មានអំពីសាវតា (៩: ១)
ហើយចាប់ផ្តើមផ្នែកសំខាន់ថ្មីនៃសាច់រឿង។

ក្រោកឡើង

«បញ្ឈប់អ្វីដែលអ្នកកំពុងធ្វើ»

ធ្វើដំណើរដល់ភ្នំអេប្រាអ៊ីម... ស្រុកសាលីសា... ស្រុកសាលីម ... ស្រុកបេនយ៉ាមីន

ទាំងនេះគឺជាតំបន់ទាំងអស់នៅអ៊ីស្រាអែល។

មិនឃើញលាទាំងនោះទេ ... ក៏នៅតែមិនឃើញ។ ... ក៏ពុំមានដំណឹងអ្វីដែរ។

generated on Wed Sep 10 16:16:32 2025

ពាក្យ«របស់ពួកគេ»និង«ពួកគេ»សំដៅទៅលើសត្វលា។
1 Samuel 9:5
ដល់ទឹកដីស៊ូភ
នេះជាតំបន់មួយនៅក្នុងអ៊ីស្រាអែល ខាងជើងក្រុងយេរូសាឡឹម។
អ្នកជំនិតរបស់ព្រះជាម្ចាស់
ឃ្លានេះច្រើនតែមានន័យថា ព្យាការីរបស់ព្រះអម្ចាស់។ ចូរបកប្រែដូចនៅក្នុង ២:២៧ ។ ការបកប្រែផ្សេងទៀត «មនុស្សម្នាក់ដែលស្តាប់
ហើយប្រាប់ព្រះបន្ទូលពីព្រះជាម្ចាស់»
ផ្លូវណាដែលយើងគួរទៅ
«ផ្លូវណាដែលយើងគួរទៅរកសត្វលា»
1 Samuel 9:7
តើយើងមានអ្វីទៅជូនលោកនោះ?
ការឲ្យអំណោយជាសញ្ញានៃការគោរព ចំពោះអ្នកជំនិតរបស់ព្រះជាម្ចាស់។
អ្នកជំនិតរបស់ព្រះជាម្ចាស់
ឃ្លានេះច្រើនតែមានន័យថា ព្យាការីរបស់ព្រះអម្ចាស់។ បកប្រែដូចនៅក្នុង ២:២៧ ។ ការបកប្រែផ្សេងទៀត «បុរសម្នាក់ដែលស្តាប់ ហើយប្រាប់ព្រះបន្ទូលពីព្រះជាម្ចាស់»
មានប្រាក់មួយកាក់
មួយភាគបួននៃប្រាក់មួយកាក់ ១/៤ នៃកាក់។ »កាក់គឺប្រភេទប្រាក់
ដែលត្រូវបានប្រើក្នុងព្រះគម្ពីរសម័្ពន្ធមេត្រីចាស់។
1 Samuel 9:9
នៅក្នុងស្រុកអ៊ីស្រាអែលកាលពីមុន ...គ្រូទាយ
នេះជាព័ត៌មានផ្នែកប្បធម៌បន្ថែម ដោយអ្នកនិពន្ធហេប្រឺ។
បើវាមិនមែនជារឿងធម្មតាទេ នៅក្នុងភាសារបស់អ្នក
អ្នកអាចត្រូវបានផ្លាស់ប្តូរទៅចុងខ១១ ។
ដោយព្រោះព្យាការីសព្វថ្ងៃនេះ អ្នកពីមុនហៅថាជា គ្រូទាយ។
«គ្រូទាយជាឈ្មោះពីបុរាណ ដែលយើងហៅព្យាការីនៅថ្ងៃនេះ»
1 Samuel 9:12
ដោយប្រជាជនត្រូវថ្វាយយញ្ញបូជានៅលើទីទួលខ្ពស់ថ្ងៃនេះដែរ។
ទំនងជាពិធីបុណ្យ ឬការថ្វាយផលដំបូង មិនមែនជាយញ្ញបូជាលោះបាប
ដែលត្រូវតែធ្វើព្រះពន្លាឡើយ។
1 Samuel 9:14
ទៅឯទីទួលខ្ពស់នោះ។
នេះជាកន្លែងដែលប្រជាជនបានកំណត់ទុកជាទីសក្ការៈសម្រាប់ធ្វើយញ្ញបូជា
និងតង្វាយថ្វាយទៅព្រះអម្ចាស់។ អ្នកនិពន្ធសរសេរហាក់ដូចជានៅខាងក្រៅជញ្ជាំង
ដែលនៅជុំវិញទីក្រុង។
1 Samuel 9:15
ឃ្លាភ្ជាប់៖
អ្នកនិពន្ធឈប់និយាយសាច់រឿង ហើយផ្តល់ព័ត៌មានសង្ខេប ដូច្នេះ
អ្នកអានអាចយល់ពីអ្វីដែលនឹងកើតឡើងបន្ទាប់ទៀត។
ហើយអ្នកនឹងចាក់ប្រេងតាំងបុរសនោះឲ្យធ្វើជាស្តេច
ពាក្យថាស្តេចត្រូវបានប្រើនៅទីនេះ ជំនួសព្រះរាជា។
នេះជាមនុស្សដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យធ្វើជាស្តេចនៃស្រុកអ៊ីស្រាអែល។
ទឹកដីបេនយ៉ាមីន
«ទឹកដីដែលប្រជាជនមកពីកុលសម័្ពន្ធបេនយ៉ាមីនរស់នៅ»
ប្រជាជនរបស់យើងពីដៃរបស់ពួកភីលីស្ទីន។
នៅទីនេះពាក្យថា«ដៃ»ជាពាក្យប្រៀបធៀបសម្រាប់ការគ្រប់គ្រង។
ការបកប្រែផ្សេងទៀត «ពីការគ្រប់គ្រងរបស់ពួកភីលីស្ទីន» ឬ
«ដូច្នេះពួកភីលីស្ទីននឹងលែងគ្រប់គ្រងពួកគេតទៅទៀត»
ពីព្រោះយើងបានមើលឃើញ ហើយអាណិត
«ប្រជាជនរបស់យើងកំពុងរងទុក្ខ ហើយយើងចង់ជួយពួកគេ»
1 Samuel 9:17
ព្រះអម្ចាស់បានប្រាប់គាត់
«ព្រះអម្ចាស់បានប្រាប់លោកសាំយូអែល»
គ្រូទាយ
«ព្យាការីរបស់ព្រះអម្ចាស់»
1 Samuel 9:20
តើមិនមែនលោកទេឬជាបំណងប្រាថ្នារបស់ជនជាតិអ៊ីស្រាអែល? តើមិនមែនលោក
និងគ្រួសាររបស់ឪពុកលោកទេឬអី?
សំណួរទាំងនេះជាការបង្ហាញនូវការជឿជាក់យ៉ាងមុតមាំថា
លោកសូលជាអ្នកដែលព្រះអម្ចាស់ចង់ឲ្យធ្វើជាស្តេច
ដែលជនជាតិអ៊ីស្រាអែលកំពុងស្វែងរក។
សំណួរអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «អ្នកគួរតែដឹងថា
វាស្ថិតនៅលើអ្នកហើយដែលបំណងប្រាថ្នាទាំងអស់របស់អ៊ីស្រាអែល
ត្រូវបានកំណត់។ ពួកគេកំណត់លើអ្នក និងគ្រួសារឪពុករបស់អ្នក»
តើខ្ញុំមិនមែនមកពីកុលសម័្ពន្ធបេនយ៉ាមីនទេ ... របស់អ៊ីស្រាអែល? តើមិនមែនអំបូររបស់ខ្ញុំ ...
នៃកុលសម័្ពន្ធបេនយ៉ាមីនទេ?ហេតុអ្វីបានជាលោកនិយាយមកដូចជាខ្ញុំនឹងអស្ចារ្យយ៉ាងនេះ?
លោកសូលកំពុងបង្ហាញការភ្ញាក់ផ្អើល
ពីព្រោះបេនយ៉ាមីនជាកុលសម័្ពន្ធតូចជាងគេបំផុត នៅអ៊ីស្រាអែល
ហើយប្រជាជនអ៊ីស្រាអែលផ្សេងទៀតបានគិតថាកុលសម័្ពន្ធនេះមិនសំខាន់ទេ។
ដូចគ្នានេះដែរ បេនយ៉ាមីនបានចាត់ទុកត្រកូល
ដែលលោកសូលជាសមាជិកមិនសំខាន់។
សំណួរទាំងនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំមកពីកុលសម័្ពន្ធបេនយ៉ាមីន ដែលជាកុលសម័្ពន្ធសំខាន់បំផុត។
ហើយត្រកូលរបស់ខ្ញុំ គឺជាអំបូរសំខាន់បំផុតនៅក្នុងកុលសម័្ពន្ធរបស់យើង។
ខ្ញុំមិនយល់ពីមូលហេតុ ដែលអ្នកកំពុងនិយាយថា ប្រជាជនអ៊ីស្រាអែលចង់ឲ្យខ្ញុំ
និងគ្រួសារខ្ញុំធ្វើអ្វីដែលសំខាន់នោះទេ។ »
1 Samuel 9:22
ឯវាល
អ្នកនិពន្ធសន្មតថា អ្នកអានដឹងថានៅជិតទីកន្លែង
ដែលពួកគេនឹងថ្វាយយញ្ញបូជាមានអាគារដ៏ធំមួយ
ដែលប្រជាជននឹងបរិភោគជាមួយគ្នាទាំងអស់។
អង្គុយពីមុខ
នេះជាកៅអីកិត្តិយស។
សាមសិបនាក់
«៣០»
1 Samuel 9:23
មកដាក់នៅ
អាចមានន័យថា ១) អាហារផ្សេងទៀតដែលសូលត្រូវបរិភោគរួមជាមួយសាច់ ឬ ២)
ផ្នែកផ្សេងទៀតនៃគោ។
បន្ទាប់មក លោកសាំយូអែលបានមានប្រសាសន៍ថា
នៅក្នុងភាសាដើម វាមិនច្បាស់ទេថា អ្នកណាកំពុងនិយាយ។ វាអាចទៅរួច
ដែលចុងភៅកំពុងនិយាយជាមួយលោកសូល។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកអ្នកចម្អិនបាននិយាយថា»
1 Samuel 9:25
នៅលើដំបូលផ្ទះ
នេះជាកន្លែងធម្មតាសម្រាប់ក្រុមគ្រួសារ និងភ្ញៀវមកអង្គុយលេង បរិភោគ និងគេង។
ពេលល្ងាច វាហាក់ដូចជាត្រជាក់ជាង ហើយពេលយប់ក៏ត្រជាក់ជាងក្នុងផ្ទះដែរ។
លោកសាំយូអែលបានហៅលោកសូលនៅលើដំបូលផ្ទះថា
អ្វីដែលលោកសូលកំពុងធ្វើនៅលើដំបូលផ្ទះ អាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ពេលលោកសូលបានកំពុងដេកនៅលើដំបូលផ្ទះ
លោកសាំយូអែលបានហៅគាត់ ហើយបាននិយាយថា»។
1 Samuel 9:27
ឲ្យបាវលោកទៅមុនយើងចុះ «បាវក៏បានចេញទៅមុន» តែលោកត្រូវនៅទីនេះបន្តិចសិន
លោកសាំយូអែលអាចនិយាយពាក្យទាំងអស់នេះ។ ការបកប្រែផ្សេងទៀត
«នៅពីមុនយើងចុះ ហើយនៅពេលលោកទៅមុខបាត់ អ្នកត្រូវតែនៅទីនេះសិន»
នោះខ្ញុំនឹងប្រាប់ព្រះរាជសាររបស់ព្រះជាម្ចាស់ដល់លោក។
«ដូច្នេះខ្ញុំអាចប្រាប់អ្នកពីសាររបស់ព្រះជាម្ចាស់សម្រាប់អ្នក»

---

10 [1]លោកសាំយូអែលបានយកដបប្រេងមក ហើយចាក់ពីលើក្បាលរបស់លោកសូល រួចថើបលោក។ លោកបានមានប្រសាសន៍ថា៖ «តើមិនមែនព្រះអម្ចាស់ទេឬអី
ជាអ្នករើសតាំងអ្នកឲ្យធ្វើជាអ្នកដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គ?[2]ពេលដែលលោកចាកចេញពីខ្ញុំទៅថ្ងៃនេះ
លោកនឹងឃើញបុរសពីរនាក់នៅក្បែរផ្នូររបស់លោកស្រីរ៉ាជែល ពួកគេនឹងនិយាយប្រាប់អ្នកថា លាដែលលោកកំពុងស្វែងរកនោះ បានរកឃើញវិញហើយ»។ ខណៈនេះ
ឪពុករបស់លោកលែងខ្វល់ខ្វាយនឹងលាទាំងនោះហើយ គឺគាត់ខ្វល់ខ្វាយពីលោកដោយនិយាយថា៖ «តើកូនប្រុសរបស់ខ្ញុំយ៉ាងដូចម្តេចហើយ?»។

generated on Wed Sep 10 16:16:32 2025

[3]បន្ទាប់មក អ្នកដើរទៅឆ្ងាយបន្តិច នោះអ្នកនឹងដល់ដើមឈើតាបោរ។ នឹងមានបុរសបីនាក់ដែលទៅឯទីសក្ការៈរបស់ព្រះជាម្ចាស់នៅបេតអែលជួបអ្នក
ពួកគេម្នាក់កាន់ពពែបី ម្នាក់ទៀតកាន់នំប៉័យបីដុំ និងម្នាក់ទៀតកាន់ថង់ស្រាទំពាំបាយជូរ។[4]ពួកគេនឹងជម្រាបសួរអ្នក ហើយឲ្យនំប៉័ងពីរដុំដល់អ្នក
រួចអ្នកត្រូវយកពីដៃរបស់ពួកគេ។
[5]បន្ទាប់មក អ្នកនឹងទៅដល់ទីទួលសក្ការៈរបស់ព្រះជាម្ចាស់ ដែលជាកន្លែងដាក់ទ័ពរបស់ពួកភីលីស្ទីន។ ពេលអ្នកទៅដល់ក្រុង
អ្នកនឹងជួបព្យាការីមួយក្រុមចេញមកពីទីទួលខ្ពស់ជាមួយនឹងពិន ស្គរ ខ្លុយ និងចាប៉ីផង ពួកគេនឹងថ្លែងព្រះបន្ទូល។[6]ព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងយាងមកសណ្ឋិតលើអ្នក
អ្នកក៏នឹងថ្លែងព្រះបន្ទូលជាមួយពួកគេផងដែរ ហើយអ្នកនឹងប្តូរទៅជាម្នាក់មួយផ្សេងទៀត។
[7]មើល ទីសម្គាល់ទាំងនេះនឹងកើតមានដល់អ្នក ចូរធ្វើអ្វីតាមតែអ្នកចង់ធ្វើចុះ ដ្បិត ព្រះជាម្ចាស់គង់នៅជាមួយអ្នកហើយ។[8]ចូរទៅឯគីលកាល់មុនខ្ញុំចុះ
ខ្ញុំនឹងចុះទៅឯអ្នកហើយថ្វាយតង្វាយដុត និងថ្វាយយញ្ញបូជាមេត្រីភាពនៅទីនោះ។ ចូររង់ចាំប្រាំពីរថ្ងៃ រហូតទាល់តែខ្ញុំទៅដល់ ហើយបង្ហាញអ្នកនូវអ្វីដែលអ្នកត្រូវធ្វើ។
[9]ពេល លោកសូលបែរខ្នងចាកចេញពីលោកសាំយូអែលទៅ ព្រះជាម្ចាស់បានប្រទានចិត្តមួយផ្សេងទៀតដល់លោក។ ហើយទីសម្គាល់ទាំងនោះបានកើតឡើងនៅថ្ងៃនោះ។
[10]ពេលពួកគេបានទៅដល់ទីទួល មានព្យាការីមួយក្រុមបានជួបពួកលោក ហើយព្រះវិញ្ញាននៃព្រះជាម្ចាស់បានយាងមកសណ្ឋិតលើលោក
ហើយលោកក៏បានថ្លែងព្រះបន្ទូលជាមួយពួកគេផងដែរ។
[11]ពេលអស់អ្នកដែលធ្លាប់ស្គាល់លោកឃើញលោកថ្លែងព្រះបន្ទូលជាមួយក្រុមព្យាការី អ្នកទាំងនោះនិយាយគ្នាថា៖ «តើមានរឿងអ្វីកើតឡើងចំពោះកូនប្រុសលោកគីស?
តើឥឡូវលោកសូលជាអ្នកក្នុងក្រុមព្យាការីដែរឬ?»[12]មានបុរសនៅស្រុកជាមួយបានឆ្លើយថា៖ «ដូច្នេះ តើនរណាជាឪពុករបស់ពួកគេ?» ដោយសារហេតុការណ៍ទាំងនេះ
គេនិយាយថា៖ «តើសូលជាម្នាក់ក្នុងក្រុមព្យាការីដែរឬ?»[13]ពេលលោកបានបញ្ចប់ថ្លែងព្រះបន្ទូល លោកបានមកឯទីទួលខ្ពស់។
[14]ក្រោយមកឪពុកមាររបស់លោកសូលបានមានប្រសាសន៍មកលោក និងបាវលោកថា «តើពួកគេឯងបានទៅឯណា?» លោកបានតបថា «ទៅរកសត្វលា។
ពេលពួកយើងដឹងថា ពួកយើងមិនអាចរកវាឃើញទេ ពួកយើងបានទៅជួបលោកសាំយូអែល»។[15]ឪពុកមាររលោកសូលបានមានប្រសាសន៍ថា៖ «សូមប្រាប់ឪពុកមារផង
តើលោកសាំយូអែលបានមានប្រសាសន៍អ្វីដល់ឯង»។[16]លោកសូលបានតបទៅគាត់វិញថា៖ «លោកបានប្រាប់ពួកយើងជាច្រើនថា សត្វលាបានរកឃើញវិញហើយ»។
ប៉ុន្តែ លោកមិនបានប្រាប់រឿងរាជ្យសម្បត្តិដែលលោកសាំយូអែលបានមានប្រសាសន៍នោះទេ។
[17]ពេលនោះ លោកសាំយូអែលបានកោះហៅប្រជាជនឲ្យជួបជុំគ្នានៅចំពោះព្រះអម្ចាស់នៅឯមីសប៉ា។[18]លោកបានថ្លែងទៅជនជាតិអ៊ីស្រាអែលថា នេះជាអ្វីដែលព្រះអម្ចាស់
ជាព្រះរបស់អ៊ីស្រាអែលមានព្រះបន្ទូលថា យើងបាននាំអ៊ីស្រាអែលចេញពីអេស៊ីប ហើយយើងបានសង្គ្រោះអ្នករាល់គ្នាពីដៃរបស់ពួកអេស៊ីប
និងពីដៃរបស់អាណាចក្រទាំងអស់ដែលបានយាយីអ្នករាល់គ្នា។[19]ប៉ុន្តែ ថ្ងៃនេះ អ្នករាល់គ្នាបានបដិសេធយើងជាព្រះរបស់អ្នករាល់គ្នា ដែលសង្គ្រោះអ្នករាល់គ្នាពីទុក្ខភ័យ
និងគ្រោះថ្នាក់ទាំងអស់របស់អ្នករាល់គ្នា តែអ្នករាល់គ្នាបែរជានិយាយទៅសាំយូអែលថា៖ «ចូរតែងតាំងស្តេចមួយអង្គឲ្យដឹកនាំយើង។ ឥឡូវនេះ
ចូរបង្ហាញខ្លួនអ្នករាល់គ្នានៅចំពោះព្រះអម្ចាស់ទៅតាមកុលសម្ព័ន្ធ និងតាមអំបូររបស់អ្នករាល់គ្នាចុះ»។
[20]ដូច្នេះ លោកសាំយូអែលបាននាំកុលសម្ព័ន្ធរបស់អ៊ីស្រាអែលទាំងអស់ឲ្យចូលជិត ហើយបានរើសប៉ះចំកុលសម្ព័ន្ធបេនយ៉ាមីន។[21]បន្ទាប់មក
លោកបានឲ្យកុលសម្ព័ន្ធបេនយ៉ាមីនមកជិតតាមអំបូររបស់ពួកគេ បានរើសប៉ះចំអំបូរម៉ាទ្រី ហើយក៏រើសបានកូនរបស់លោកគីស គឺលោកសូល។ ប៉ុន្តែ ពេលគេទៅរកលោក
គេមិនឃើញលោកទេ។
[22]បន្ទាប់មក ប្រជាជនចង់សាកសួរព្រះជាម្ចាស់ថែមទៀតថា៖ «តើមានបុរសណាផ្សេងនឹងមកឬទេ?» ព្រះអម្ចាស់បានមានព្រះបន្ទូលថា៖
«គេបានរត់ទៅពួននៅក្បែរឥវ៉ាន់ឯណោះ»។[23]នោះគេបានរត់ទៅទីនោះ ហើយនាំលោកសូលពីទីនោះមក។ ពេលលោកឈរក្នុងចំណោមមនុស្ស
លោកខ្ពស់ជាងគេទាំងអស់ តាំងពីស្មាឡើងទៅ។
[24]ក្រោយមកលោកសាំយូអែលបានប្រសាសន៍ទៅប្រជាជនថា៖ «តើអ្នករាល់គ្នាបានឃើញបុរសដែលព្រះជាម្ចាស់បានរើសនោះហើយឬនៅ?
ក្នុងចំណោមប្រជាជនទាំងអស់គ្មាននរណាដូចលោកម្នាក់នេះទេ!» ប្រជាជនទាំងអស់បានស្រែកឡើងថា៖ «សូមឲ្យស្តេចមានអាយុយឺនយូរ!»។
[25]នោះ លោកសាំយូអែលបានប្រាប់ប្រជាជននូវច្បាប់ និងរបៀបរបបរបស់ស្តេច រួចកត់ទុកចូលក្នុងសៀវភៅមួយ ហើយដាក់នៅចំពោះព្រះអម្ចាស់។ ចុងក្រោយ
លោកសាំយូអែលបានឲ្យប្រជាជនទាំងអស់ទៅផ្ទះរបស់គេរៀងៗខ្លួន។
[26]លោកសូលក៏បានទៅផ្ទះរបស់លោកនៅគីបៀវិញដែរ ហើយក៏មានបុរសខ្លាំងខ្លះដែលព្រះជាម្ចាស់បានប៉ះពាល់ចិត្តបានទៅជាមួយលោកដែរ។[27]ប៉ុន្តែ
មានមនុស្សឥតបានការខ្លះនិយាយថា៖ «តើឲ្យបុរសនេះជួយសង្គ្រោះយើងយ៉ាងដូចម្តេច?» អ្នកទាំងនោះ ជាអ្នកស្អប់លោកសូល
ហើយពុំបានយកអំណោយអ្វីឲ្យលោកឡើយ។ ប៉ុន្តែ លោកសូលមិនមាត់អ្វីទេ។

---

1 Samuel 10:1

បានយកដបប្រេងមក ហើយចាក់ពីលើក្បាលរបស់លោកសូល

នៅក្នុងវប្បធម៌អ៊ីស្រាអែល ពេលព្យាការីចាក់ប្រេងលើក្បាលរបស់នរណាម្នាក់ មនុស្សនោះបានទទួលព្រះពរពីព្រះអម្ចាស់។

ដប

ដបតូចមួយធ្វើពីដីឥដ្ឋដុតនំ

តើមិនមែនព្រះអម្ចាស់ទេឬអី ជាអ្នករើសតាំងអ្នកឲ្យធ្វើជាអ្នកដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គ?

លោកសាំយូអែលដឹងចម្លើយនេះ។ គាត់បានរំលឹកលោកសូលថា ព្រះអម្ចាស់បានជ្រើសរើសគាត់ឲ្យធ្វើជាស្តេចអ៊ីស្រាអែល។ ការបកប្រែផ្សេង «ព្រះអម្ចាស់ពិតជាបានចាក់ប្រេងអភិសេកអ្នកឲ្យធ្វើជាអ្នកគ្រប់គ្រង លើប្រជារាស្ត្ររបស់ព្រះអង្គ»

ភូមិសេលសា

នេះជាឈ្មោះកន្លែងមួយ។

តើកូនប្រុសរបស់ខ្ញុំយ៉ាងដូចម្តេចហើយ?

ឥឡូវនេះ ឪពុករបស់សូលបារម្ភពីលោកសូលហើយចង់រកគាត់។

1 Samuel 10:3

តាបោរ

នេះជាឈ្មោះទីកន្លែងមួយ។

ត្រូវយកពីដៃរបស់ពួកគេ

ដៃជាពាក្យប្រៀបធៀបសម្រាប់មនុស្ស។ «យកពីពួកគេ» ឬ «ទទួលយក»

1 Samuel 10:5

ស្គរ

នេះជាឧបករណ៍តន្ត្រី មានក្បាលដូចជាស្គរ ដែលអាចវាយនិងមានបំណែកលោហធាតុព័ទ្ធជុំវិញគែម ដែលបង្កើតបានជាសូរសំឡេង ពេលឧបករណ៍រង្គើ។

ព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងយាងមកសណ្ឋិតលើអ្នក

ឃ្លា«យាងមកសណ្ឋិតលើអ្នក»មានន័យថា ព្រះវិញ្ញាណរបស់ព្រះអម្ចាស់នឹងមានឥទ្ធិពលលើលោកសូល។ ក្នុងករណីនេះ មានន័យថាព្រះអង្គនឹងធ្វើឲ្យសូលថ្លែងនាយ និងប្រព្រឹត្តដូចជាមនុស្សផ្សេង។

1 Samuel 10:7

ចូរធ្វើអ្វីតាមតែអ្នកចង់ធ្វើចុះ

នៅទីនេះលោកសាំយូអែលនិយាយពីដៃរបស់លោកសូល ដូចជាមនុស្សម្នាក់កំពុងព្យាយាមរករបស់អ្វីមួយ។ ការបកប្រែផ្សេងទៀត «ធ្វើអ្វីដែលអ្នកគិតថាត្រូវធ្វើ»

1 Samuel 10:9

ព្រះជាម្ចាស់បានប្រទានចិត្តមួយផ្សេងទៀតដល់លោក។

ព្រះជាម្ចាស់បានជួយលោកសាំយូអែល ឲ្យគិតខុសពីអ្វីដែលគាត់បានគិតពីមុន។

ហើយព្រះវិញ្ញាននៃព្រះជាម្ចាស់បានយាងមកសណ្ឋិតលើលោក

លោកសាំយូអែលនិយាយដូចជាព្រះវិញ្ញាណរបស់ព្រះអម្ចាស់ជាមនុស្ស ដែលរត់មករកលោកសូល ហើយត្រួតត្រាលើគាត់ទាំងស្រុង។ បកប្រែដូចនៅក្នុង ១០:៥ ។ ការបកប្រែផ្សេងទៀត «ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានត្រួតត្រាគេទាំងស្រុង»

generated on Wed Sep 10 16:16:32 2025

1 Samuel 10:11
តើមានរឿងអ្វីកើតឡើងចំពោះកូនប្រុសលោកគីស?
អាចមានន័យថា ១) ប្រជាជនកំពុងស្មើសុំព័ត៌មាន ឬ ២)
នេះជាសំណួរដ៏ប៉ិនប្រសព្វដែលមានន័យថា លោកសូលមិនសំខាន់ទេ។
ការបកប្រែផ្សេងទៀត «លោកគីសមិនមែនជាមនុស្សសំខាន់ទេ ដូច្នេះ
វាមិនអាចជាការពិតដែលថា កូនប្រុសរបស់គាត់បានក្លាយជាព្យាការីទេ!»
កូនប្រុសលោកគីស
«សូលជាកូនរបស់លោកគីស»
ដូច្នេះ តើនរណាជាឪពុករបស់ពួកគេ?
បុរសនេះប្រើសំនួរដ៏ប៉ិនប្រសព្វដើម្បីរំលឹកប្រជាជនថា ក្នុងនាមជាព្យាការីមិនមានអ្វី
ដែលត្រូវធ្វើជាមួយឪពុកម្តាយរបស់នរណាម្នាក់ឡើយ។
សំណួរអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«វាមិនសំខាន់ទេថា ឪពុកម្តាយរបស់ព្យាការីផ្សេងទៀត គឺជានរណា។
ហើយអ្វីដែលសំខាន់នោះគឺសូលកំពុងនិយាយសារមកពីព្រះជាម្ចាស់»។
ដោយសារហេតុការណ៍ទាំងនេះ គេនិយាយថា៖ តើសូលជាម្នាក់ក្នុងក្រុមព្យាការីដែរឬ?
ឃ្លានេះក្លាយជាសុភាសិតក្នុងចំណោមជនជាតិអ៊ីស្រាអែល។
តាមមើលទៅមនុស្សនិយាយរឿងនេះ ដើម្បីបង្ហាញការភ្ញាក់ផ្អើល
ពេលមនុស្សម្នាក់មិនបានធ្វើអ្វីដែលមិនបានធ្វើពីមុន។
សំណួរនេះអាចបញ្ជាក់អត្ថន័យបង្កប់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«នេះហើយជាមូលហេតុ ដែលប្រជាជនមិនអាចជឿសេចក្តីរាយការណ៍
ដែលពួកគេបានគិតអំពីអ្វីដែលបានកើតឡើង ចំពោះលោកសូល ហើយនិយាយថា
«តើសូលពិតជាព្យាការីមែនឬ»?
1 Samuel 10:14
ក្រោយមកឪពុកមាររបស់លោកសូលបានមានប្រសាសន៍មកលោក
«បន្ទាប់មកប្អូនប្រុសរបស់ឪពុកលោកសូលបានមានប្រសាសន៍ទៅលោកសូលថា»
លោកមិនបានប្រាប់រឿងរាជ្យសម្បត្តិ
«លោកសូលមិនបានប្រាប់ពូរបស់គាត់ថា
ព្រះជាម្ចាស់បានតែងតាំងគាត់ឲ្យធ្វើជាស្តេចរបស់អ៊ីស្រាអែលឡើយ»
1 Samuel 10:17
យើងបាននាំអ៊ីស្រាអែលចេញពីអេស៊ីប
ឈ្មោះ«អ៊ីស្រាអែល»ជាពាក្យប្រៀបធៀបសម្រាប់ប្រជាជនអ៊ីស្រាអែល។
យើងបាននាំប្រជាជនអ៊ីស្រាអែលចេញពីស្រុកអេស៊ីប»
ថ្ងៃនេះ
«ឥឡូវនេះ»
ពីដៃរបស់ពួកអេស៊ីប ...ពីដៃរបស់អាណាចក្រទាំងអស់
ពាក្យថា«ដៃ» ជាពាក្យប្រៀបធៀបសម្រាប់អំណាច។ ការបកប្រែផ្សេងទៀត
«អំណាចរបស់ប្រជាជនអេស៊ីប ... អំណាចនៃអាណាចក្រទាំងអស់»
ចូររើសតាំងស្តេចមួយអង្គឲ្យដឹកនាំយើង
«ឲ្យស្តេចមួយអង្គគ្រប់គ្រងយើង»
ចូរបង្ហាញខ្លួនអ្នករាល់គ្នា នៅចំពោះព្រះអម្ចាស់ទៅតាមកុលសម្ព័ន្ធ និងតាមអំបូររបស់អ្នករាល់គ្នាចុះ។
«ប្រមូលផ្តុំគ្នាតាមកុលសម្ព័ន្ធ
និងអំបូរហើយមកឈរនៅចំពោះព្រះភក្ត្រព្រះអម្ចាស់»
1 Samuel 10:20
ហើយបានរើសប៉ះចំកុលសម្ព័ន្ធបេនយ៉ាមីន ...
បានរើសប៉ះចំអំបូរម៉ាទ្រី ...ហើយក៏រើសបានកូនរបស់លោកគីស គឺលោកសូល
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានជ្រើសរើសកុលសម្ព័ន្ធបេនយ៉ាមីន ...
ព្រះអម្ចាស់បានជ្រើសរើសអំបូររបស់ម៉ាទ្រី...
ព្រះអម្ចាស់បានជ្រើសរើសសូលជាកូនរបស់លោកគីស»
គឺប្រហែលជាមិនត្រូវនិយាយពីរបៀប ប្រជាជនបានស្គាល់អ្នក
ដែលព្រះអម្ចាស់បានជ្រើសរើស។
1 Samuel 10:22
លោកខ្ពស់ជាងគេទាំងអស់ តាំងពីស្មាឡើងទៅ។
ប្រជាជនមានកម្ពស់ខ្ពស់ផ្សេងទៀត
នៅស្រុកអ៊ីស្រាអែលមិនស្មើត្រឹមស្មារបស់គាត់ផង។ បកប្រែដូចក្នុង ៩:១។
1 Samuel 10:25
ច្បាប់ និងរបៀបរបបរបស់ស្តេច
នាមអរូបី«របៀបរបបរបស់ស្តេច»អាចបកប្រែជាឃ្លាមួយ។
ការបកប្រែផ្សេងទៀត«អ្វីដែលព្រះរាជានឹងបង្ខំឲ្យពួកគេធ្វើហើយ
អ្វីៗទាំងអស់ដែលស្តេចតម្រូវឲ្យធ្វើ»
1 Samuel 10:26
ដែលព្រះជាម្ចាស់បានប៉ះពាល់ចិត្ត
ព្រះជាម្ចាស់ដែលប៉ះពាល់ចិត្តមនុស្ស គឺជាឃ្លាដែលមានន័យថា
ព្រះជាម្ចាស់ដាក់អ្វីមួយនៅក្នុងគំនិតរបស់ពួកគេ ឬជម្រុញពួកគេឲ្យធ្វើអ្វីមួយ។
ការបកប្រែផ្សេងទៀត «អ្នកដែលចង់ទៅជាមួយលោកសូល
ព្រោះព្រះជាម្ចាស់បានផ្លាស់ប្តូរការគិតរបស់ពួកគេ»
តើឲ្យបុរសនេះជួយសង្គ្រោះយើងយ៉ាងដូចម្តេច?
នេះជាសំណួរដ៏ប៉ិនប្រសព្វមួយ ត្រូវប្រើដើម្បីបង្ហាញការសើចចំអក ឬបញ្ឈឺចិត្ត។
ការបកប្រែផ្សេងទៀត «មនុស្សនេះគ្មានអំណាចជួយសង្គ្រោះយើងទេ! »
ស្អប់
«មិនចូលចិត្តខ្លាំងណាស់»

---

11 [1]ព្រះបាទណាហាស ជាស្តេចរបស់ជនជាតិអាំម៉ូនបានដឹកនាំទ័ពព័ទ្ធក្រុងយ៉ាបេស ស្រុកកាឡាដ។ អ្នកក្រុងយ៉ាបេសទាំងអស់បាននិយាយទៅព្រះបាទណាហាសថា៖
«សូមចងសម្ព័ន្ធមេត្រីជាមួយពួកយើងខ្ញុំ យើងខ្ញុំនឹងគោរពបម្រើស្តេច»។[2]ព្រះបាទណាហាស ជាស្តេចរបស់អាំម៉ូនបានតបវិញថា៖
«យើងនឹងដាក់លក្ខ័ណប្រព្រឹត្តចំពោះអ្នករាល់គ្នា គឺត្រូវឲ្យយើងខ្វេះភ្នែកស្តាំទាំងអស់របស់អ្នករាល់គ្នា ដើម្បីធ្វើឲ្យអ៊ីស្រាអែលទាំងអស់ត្រូវអាម៉ាស»។
[3]ក្រោយមក ពួកចាស់ទុំនៃក្រុងយ៉ាបេសបានទូលទៅស្តេចវិញថា៖ «សូមទុកពេលឲ្យយើងខ្ញុំប្រាំពីរថ្ងៃ
ដើម្បីឲ្យយើងខ្ញុំអាចបញ្ជូនអ្នកនាំសារទៅគ្រប់តំបន់របស់អ៊ីស្រាអែលសិន។ បើគ្មាននរណាជួយពួកយើងខ្ញុំទេ នោះយើងខ្ញុំនឹងប្រគល់ខ្លួនជូន»។
[4]អ្នកនាំសារបានមកដល់គីបៀរ ជាកន្លែងដែលលោកសូលរស់នៅ ហើយបានប្រាប់ប្រជាជននៅទីនោះនូវអ្វីដែលបានកើតឡើង។ ប្រជាជនទាំងអស់បានស្រែកយំជាខ្លាំង។
[5]ឯលោកសូលបានដឹកគោទៅឯវាល។ លោកសូលបានមានប្រសាសន៍ថា៖ «តើមានរឿងអ្វីកើតឡើងបានជាប្រជាជនស្រែកយំខ្លាំងដូច្នេះ?»
គេបានប្រាប់លោកសូលនូវអ្វីដែលអ្នកក្រុងយ៉ាបេសបានប្រាប់។
[6]ពេលលោកសូលបានឮដូច្នេះ ព្រះវិញ្ញាណនៃព្រះជាម្ចាស់បានយាងមកសណ្ឋិតពីលើលោក ហើយលោកខឹងយ៉ាងខ្លាំង។
[7]លោកបានយកគោមួយនឹមមកកាត់ជាចំណែកតូចៗ ហើយធ្វើទៅគ្រប់តំបន់នៃស្រុកអ៊ីស្រាអែលទាំងមូលជាមួយនឹងអ្នកនាំសារ។ លោកបានមានប្រសាន៍ថា៖
«អ្នកណាដែលមិនចេញមកជាមួយខ្ញុំ សូល និងលោកសាំយូអែលទេ អ្នកនោះនឹងដូចជាចំណែកតូចៗរបស់សាច់គោនេះដូច្នេះដែរ»។
នោះភាពភ័យខ្លាចព្រះអម្ចាស់បានកើតមានលើប្រជាជន ពួកគេបានចេញមករួមគ្នាដូចមនុស្សតែម្នាក់។[8]កាលលោកបានកែនពួកគេនៅបេសេកហើយ
ឃើញថាមានទ័ពអ៊ីស្រាអែលដល់ទៅ សាមសិបម៉ឺននាក់ ហើយជនជាតិយូដាមាន បីម៉ឺននាក់។
[9]ពួកគេបាននិយាយទៅអ្នកនាំសារដែលមកនោះថា៖ «ចូរទៅប្រាប់អ្នកក្រុងយ៉ាបេសនៃស្រុកកាឡាដដូចតទៅ ថ្ងៃស្អែកពេលថ្ងៃពេញកំដៅ
អ្នករាល់គ្នានឹងបានរួចជាមិនខាន»។ ដូច្នេះ អ្នកនាំសារបានចេញទៅហើយប្រាប់អ្នកក្រុងយ៉ាបេស រួចពួកគេរីករាយជាខ្លាំង។[10]ក្រោយមក
អ្នកក្រុងយ៉ាបេសបានទូលទៅព្រះបាទណាហាសថា៖ «ថ្ងៃស្អែក ពួកយើងខ្ញុំនឹងប្រគល់ខ្លួនជូនស្តេច ហើយព្រះអង្គអាចធ្វើអ្វីតាមតែព្រះអង្គយល់ឃើញថាល្អចុះ»។
[11]ថ្ងៃបន្ទាប់ លោកសូលបានរៀបប្រជាជនជាបីក្រុម។ ពួកគេបានមកកណ្តាលជំរំទ័ពពេលព្រឹកដើម្បីឃ្លាំមើល ហើយក៏បានចេញទៅវាយប្រហារ
និងបានជ័យជម្នះលើពួកអាម៉ូនរហូតដល់ថ្ងៃពេញកម្តៅ។ អ្នកដែលបានរួចជីវិត បានរត់គេចខ្លួន ហើយគ្មានអ្នករត់ទាំងគូដែលនៅរស់ទេ។
[12]ក្រោយមក ប្រជាជនបានជម្រាបលោកសាំយូអែលថា៖ «បើនរណាបាននិយាយថា តើឲ្យលោកសូលសោយរាជ្យលើពួកយើងឬ? ចូរនាំពួកនោះចេញមក
យើងនឹងប្រហារជីវិតពួកគេ»។[13]ប៉ុន្តែ ព្រះបាទសូលបានមានរាជឱង្ការថា៖ មិនត្រូវប្រហារជីវិតនរណាក្នុងថ្ងៃនេះឡើយ ពីព្រោះថ្ងៃនេះ
ព្រះអម្ចាស់បានសង្គ្រោះអ៊ីស្រាអែល»។

generated on Wed Sep 10 16:16:32 2025

[14]លោកសាំយូអែលបានថ្លែងទៅប្រជាជនថា៖ «តោះ យើងនាំគ្នាទៅគីលកាល់ ហើយអភិសេកស្តេចជាថ្មីនៅទីនោះ»។
[15]ដូច្នេះប្រជាជនទាំងអស់បានធ្វើដំណើរទៅគីលកាល់ ហើយលើកលោកសូល ជាស្តេចនៅចំពោះព្រះអម្ចាស់នៅគីលកាល់នោះ។ នៅទីនោះ
ពួកគេបានថ្វាយយញ្ញបូជាមេត្រីភាពនៅចំពោះព្រះអម្ចាស់ ទាំងព្រះបាទសូល ទាំងប្រជាជនបានពេញដោយអំណរជាខ្លាំង។

---

1 Samuel 11:1
ព្រះបាទណាហាស
នេះជាមនុស្សមកពីជនជាតិអាំម៉ូន ជាកូនចៅឡុត
ដែលជាក្មួយរបស់លោកអប្រាហាំ។ សូមមើល
ក្រុងយ៉ាបេស ស្រុកកាឡាដ
នេះជាឈ្មោះរបស់ទីកន្លែងមួយ។
យើងខ្វេះ
«ខ្ញុំកាត់ចេញ» ឬ «ខ្ញុំដកចេញ»
ត្រូវអាម៉ាស
«នាំឲ្យអាម៉ាសមុខ» ឬ «នាំឲ្យកេរ្តិ៍ឈ្មោះអាក្រក់ទៅ»
1 Samuel 11:3
ប្រាំពីរថ្ងៃ
«ប្រាំពីរថ្ងៃ»
1 Samuel 11:4
គីបៀរ
នេះជាឈ្មោះរបស់ទីកន្លែងមួយ។
1 Samuel 11:6
ព្រះវិញ្ញាណនៃព្រះជាម្ចាស់បានយាងមកសណ្ឋិតពីលើលោក
ឃ្លាដែលថា«មកសណ្ឋិតពីលើលោក»មានន័យថា
ព្រះវិញ្ញាណរបស់ព្រះអម្ចាស់មានឥទ្ធិពលលើលោកសូល។ ក្នុងករណីនេះ
ទ្រង់បានអនុញ្ញាតឲ្យលោកសូល ធ្វើឱ្យប្រជាជនគោរពគាត់យ៉ាងខ្លាំង
ជាស្តេចរបស់ពួកគេ និងចូលរួមជាមួយកងទ័ពរបស់គាត់។
សូមមើលការបកប្រែនៅក្នុង ១០:៥។
មិនចេញមកជាមួយខ្ញុំ
លោកសូលបានកោះហៅកងទ័ពអ៊ីស្រាអែលទាំងអស់
ឲ្យមកច្បាំងនឹងលោកណាហាស និងជនជាតិអាំម៉ូន។
នោះភាពភ័យខ្លាចព្រះអម្ចាស់បានកើតមានលើប្រជាជន
ព្រះអម្ចាស់បានធ្វើឲ្យប្រជាជនគោរពកោតខ្លាចលោកសូលជាស្តេចរបស់គេ។
ជាលទ្ធផល មនុស្សបានប្រមូលផ្តុំជួបជុំគ្នាទាំងអស់
ជាមួយលោកសូលនៅបេសេក។
បេសេក
នេះជាឈ្មោះរបស់តំបន់មួយនៅជិតបេសេកកាឡាដ។
ឃើញថាមានទ័ពអ៊ីស្រាអែលដល់ទៅ សាមសិបម៉ឺននាក់ ហើយជនជាតិយូដាមាន បីម៉ឺននាក់។
«ប្រជាជនអ៊ីស្រាអែលមាន៣០ម៉ឺននាក់ ហើយជនជាតិយូដាមាន៣ម៉ឺននាក់»
1 Samuel 11:9
ពួកគេបាននិយាយទៅអ្នកនាំសារ
ពាក្យ«ពួកគេ»សំដៅទៅលើលោកសាំយូអែល និងលោកសូល។
ពេលថ្ងៃពេញកំដៅ
«មុនពេលថ្ងៃក្តៅបំផុតជាផ្នែកនៃថ្ងៃ» ឬ «មុនពេលថ្ងៃត្រង់»
ក្រុងយ៉ាបេសនៃស្រុកកាឡាដ ... ក្រុងយ៉ាបេស
ទាំងនេះជាឈ្មោះទីកន្លែង។ សូមមើលការបកប្រែនៅក្នុង ១១:១។
ព្រះបាទណាហាស
នេះជាព្រះនាមស្តេច។ សូមមើលការបកប្រែនៅក្នុង ១១: ១។
1 Samuel 11:11
ពេលព្រឹកដើម្បីឃ្លាំមើល
មុនពេលថ្ងៃរះ ពេលមនុស្សភាគច្រើននៅក្នុងជំរំនៅតែសម្រាន្តលក់នៅឡើយ។
1 Samuel 11:14
ហើយលើកលោកសូល ជាស្តេចនៅចំពោះព្រះអម្ចាស់
«តែងតាំងស្តេចសូល ខណៈដែលព្រះអម្ចាស់បានទតមើល»
នៅទីនោះ ពួកគេបានថ្វាយយញ្ញបូជាមេត្រីភាពនៅចំពោះព្រះអម្ចាស់
ចំណែកនៃការបម្រើរបស់លោកសាំយូអែល គឺថ្វាយយញ្ញបូជាថ្វាយព្រះអម្ចាស់
ទោះបីគាត់មិនមែនជាកូនចៅរបស់អើរ៉ុន ឬលេវីក៏ដោយ។

---

12 [1]លោកសាំយូអែលបានថ្លែងទៅកាន់អ៊ីស្រាអែលទាំងមូលថា៖ «ខ្ញុំបានស្តាប់តាមអ្នករាល់គ្នាគ្រប់យ៉ាង ហើយខ្ញុំក៏បានរើសស្តេចមួយអង្គសម្រាប់អ្នករាល់គ្នាផងដែរ។
[2]ពេលនេះ មានស្តេចមួយអង្គ នៅចំពោះអ្នករាល់គ្នាហើយ ខ្ញុំចាស់ហើយសក់ស្កូវថែមទៀត កូនប្រុសៗរបស់ខ្ញុំក៏នៅជាមួយអ្នករាល់គ្នាដែរ។
ខ្ញុំបាននៅជាមួយអ្នករាល់គ្នាតាំងពីក្មេងរហូតមកដល់សព្វថ្ងៃនេះ។
[3]ខ្ញុំនៅទីនេះហើយ ចូររៀបរាប់ដល់ព្រះអម្ចាស់ប្រឆាំងនឹងខ្ញុំ និងស្តេចដែលព្រះអង្គបានតាំងឡើងនេះចុះ បើខ្ញុំបានយកគោរបស់អ្នកណា ឬបានយកលារបស់អ្នកណា
ឬក៏បានកេងបន្លំរបស់អ្នកណា ហើយបានធ្វើឲ្យអ្នកណាមិនសប្បាយចិត្ត? ឬមួយខ្ញុំបានបិទភ្នែកទទួលសំណូកពីអ្នកណានោះ? ចូរធ្វើបន្ទាល់ប្រឆាំងនឹងខ្ញុំចុះ
ហើយខ្ញុំនឹងទូទាត់សងអ្នករាល់គ្នាវិញ។
[4]ពួកគេនិយាយឡើងថា៖ «លោកពុំបានបោកបញ្ឆោតយើងខ្ញុំទេ មិនដែលនាំទុក្ខ ឬក៏មិនដែលលួចអ្វីពីអ្នកណាដែរ»។[5]លោកបានតបវិញថា៖ «ថ្ងៃនេះ ព្រះអម្ចាស់
និងស្តេចដែលព្រះអង្គបានតាំងជាសាក្សីស្រាប់ គឺថាអ្នករាល់គ្នាគ្មានអ្វីទាស់នឹងខ្ញុំឡើយ»។ ពួកគេបានឆ្លើយវិញថា៖ «មែនហើយ ព្រះអម្ចាស់ជាសាក្សី»។
[6]លោកសាំយូអែលមានប្រសាសន៍ទៅប្រជាជនថា៖ «គឺព្រះអម្ចាស់ហើយ ជាអ្នកដែលរើសតាំងលោកម៉ូសេ
និងលោកអើរ៉ុនឲ្យដឹកនាំដូនតារបស់អ្នករាល់គ្នាចេញពីអេស៊ីបមក។[7]ពេលនេះ ចូរបង្ហាញខ្លួនមកចុះ
ដើម្បីឲ្យខ្ញុំអាចរៀបរាប់នឹងអ្នករាល់គ្នានៅចំពោះព្រះអម្ចាស់អំពីការប្រព្រឹត្តដ៏សុចរិតទាំងអស់របស់ព្រះអម្ចាស់ ដែលព្រះអង្គបានប្រព្រឹត្តចំពោះអ្នករាល់គ្នា
និងដូនតាអ្នករាល់គ្នា។
[8]កាលលោកយ៉ាកុបបានមកដល់អេស៊ីប ហើយបុព្វបុរសរបស់អ្នករាល់គ្នាស្រែកអង្វររកព្រះអម្ចាស់ នោះព្រះអម្ចាស់បានចាត់លោកម៉ូសេ
និងលោកអើរ៉ុនឲ្យដឹកនាំបុព្វបុរសរបស់អ្នករាល់គ្នាចេញពីអេស៊ីបមក ហើយពួកគាត់បានតាំងលំនៅនៅទីនេះ។[9]ប៉ុន្តែ ពួកលោកបានបំភ្លេចព្រះអម្ចាស់ជាព្រះរបស់ពួកលោក
ព្រះអង្គក៏ប្រគល់ពួកលោកទៅឲ្យស៊ីសេរ៉ា ជាមេបញ្ជាការកងទ័ពរបស់ក្រុងហាសោរ ទៅក្នុងដៃរបស់ពួកភីលីស្ទីន និងទៅក្នុងដៃរបស់ស្តេចម៉ូអាប់
ពួកគេទាំងនេះហើយដែលបានវាយប្រហារបុព្វបុរសរបស់អ្នករាល់គ្នា។
[10]ពួកគេបានស្រែករកព្រះអម្ចាស់ថា យើងខ្ញុំបានប្រព្រឹត្តអំពើបាប ពីព្រោះយើងខ្ញុំបានបោះបង់ចោលព្រះអម្ចាស់ ទៅគោរពបម្រើព្រះបាល និងព្រះអាស្តារ៉ូត។ ប៉ុន្តែ ពេលនេះ
សូមព្រះអង្គសង្គ្រោះយើងខ្ញុំពីដៃរបស់សត្រូវនៃយើងខ្ញុំផង នោះយើងខ្ញុំនឹងត្រឡប់មកបម្រើព្រះអង្គវិញ។[11]ដូច្នេះ ព្រះអម្ចាស់បានចាត់លោកយេរូបាល លោកបេដាន
លោកយ៉ែបថា និងលោកសាំយូអែល ហើយបានប្រគល់ជ័យជម្នះដល់អ្នករាល់គ្នាលើពួកសត្រូវទាំងអស់ដែលនៅជុំវិញអ្នករាល់គ្នា
ហើយអ្នករាល់គ្នារស់នៅដោយសុវត្ថិភាព។
[12]ពេលអ្នករាល់គ្នាបានឃើញស្តេចណាហាសរបស់ពួកអាម៉ូនមកប្រហារអ្នករាល់គ្នា អ្នករាល់គ្នាបែរជានិយាយមកខ្ញុំថា ទេ! តែផ្ទុយទៅវិញ
សូមឲ្យស្តេចមួយអង្គសោយរាជ្យលើពួកយើងចុះ ខណៈដែលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាគឺជាស្តេចរបស់អ្នករាល់គ្នាទៅហើយនោះ។[13]ឥឡូវនេះ
មានស្តេចដែលអ្នករាល់គ្នាបានជ្រើសរើសហើយ ជាស្តេចដែលអ្នករាល់គ្នាបានសុំ ហើយដែលព្រះអម្ចាស់បានចង្អុលប្រាប់ពីស្តេចនោះ។
[14]បើអ្នករាល់គ្នាកោតខ្លាចព្រះអម្ចាស់ ចូរបម្រើព្រះអង្គ ស្តាប់តាមព្រះសូរសៀងព្រះអង្គ ហើយមិនត្រូវបះបោរប្រឆាំងនឹងបញ្ជារបស់ព្រះអម្ចាស់ទេ
ទាំងអ្នករាល់គ្នាទាំងស្តេចដែលសោយរាជ្យលើអ្នករាល់គ្នាត្រូវដើរតាមព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាចុះ។[15]បើអ្នករាល់គ្នាមិនស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់
តែបែរជាបះបោរប្រឆាំងនឹងបញ្ជារបស់ព្រះអម្ចាស់ នោះព្រះហស្តរបស់ព្រះអម្ចាស់នឹងប្រឆាំងនឹងអ្នករាល់គ្នា ដូចដែលប្រឆាំងនឹងបុព្វបុរសរបស់អ្នករាល់គ្នាដែរ។

generated on Wed Sep 10 16:16:32 2025

[16]ទោះបីមកដល់ពេលនេះ ចូរបង្ហាញខ្លួនអ្នក ហើយចាំមើលកិច្ចការដ៏សម្បើមដែលព្រះអម្ចាស់នឹងធ្វើនៅចំពោះភ្នែករបស់អ្នករាល់គ្នាចុះ។
[17]តើមិនមែនពេលនេះជារដូវចម្រូតទេឬអី? មើល ខ្ញុំនឹងស្រែករកព្រះអម្ចាស់ នោះព្រះអង្គនឹងធ្វើឲ្យមានផ្គរ និងភ្លៀងមក។ នោះ អ្នករាល់គ្នានឹងដឹង
ហើយឃើញពីភាពអាក្រក់របស់អ្នករាល់គ្នាធំប៉ុណ្ណា ដែលអ្នករាល់គ្នាបានប្រព្រឹត្តនៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់ ដោយទូលសុំស្តេចមួយអង្គសម្រាប់ខ្លួនអ្នករាល់គ្នា។
[18]ដូច្នេះ លោកសាំយូអែលបានស្រែករកព្រះអម្ចាស់ នៅថ្ងៃដដែលនោះ ព្រះអម្ចាស់បានធ្វើឲ្យមានផ្គរ និងភ្លៀងមក
ហើយប្រជាជនទាំងអស់មានសេចក្តីស្ញែងខ្លាចដល់ព្រះអម្ចាស់ និងលោកសាំយូអែលជាខ្លាំង។
[19]ប្រជាជនទាំងអស់បាននិយាយទៅលោកសាំយូអែលថា៖ «សូមទូលអង្វរទៅព្រះអម្ចាស់ជាព្រះរបស់លោកសម្រាប់អ្នកបម្រើលោកផង
នោះយើងខ្ញុំនឹងមិនត្រូវស្លាប់ឡើយ។ ដោយព្រោះ ពួកយើងបានបន្ថែមអំពើបាបដ៏អាក្រក់របស់យើងខ្ញុំ ដោយសុំស្តេចមួយអង្គសម្រាប់យើងខ្ញុំដូច្នេះ»។
[20]លោកសាំយូអែលឆ្លើយថា៖ «កុំភ័យខ្លាចអី អ្នករាល់គ្នាបានប្រព្រឹត្តអំពើអាក្រក់មែន ប៉ុន្តែ មិនត្រូវបែរចិត្តចេញពីព្រះអម្ចាស់ឡើយ
តែត្រូវគោរពបម្រើព្រះអម្ចាស់ឲ្យអស់ពីចិត្តរបស់អ្នករាល់គ្នាចុះ។[21]កុំងាកទៅរកអ្វីដែលគ្មានប្រយោជន៍ ឬមិនអាចសង្គ្រោះអ្នករាល់គ្នា
ពីព្រោះរបស់ទាំងអស់នោះឥតប្រយោជន៍ទេ។
[22]ដោយយល់ដល់ព្រះនាមដ៏អស្ចារ្យរបស់ព្រះអង្គ ព្រះអម្ចាស់នឹងមិនបដិសេធប្រជាជនរបស់ព្រះអង្គឡើយ
ពីព្រោះកាលដែលរើសអ្នករាល់គ្នាឲ្យទៅជាប្រជារាស្ត្ររបស់ព្រះអង្គ នោះគាប់ព្រះទ័យរបស់ព្រះអង្គ។[23]ចំពោះខ្ញុំ
ចូរកុំឲ្យខ្ញុំប្រព្រឹត្តអំពើបាបទាស់នឹងព្រះអម្ចាស់ដោយលែងទូលអង្វរសម្រាប់អ្នករាល់គ្នាឡើយ។ ផ្ទុយទៅវិញ ខ្ញុំនឹងបង្រៀនអ្នករាល់គ្នានូវអ្វីដែលល្អ ហើយសុចរិត។
[24]ដោយគ្រាន់តែកោតខ្លាចព្រះអម្ចាស់ ហើយបម្រើព្រះអង្គក្នុងសេចក្តីពិតឲ្យអស់ពីចិត្តរបស់អ្នករាល់គ្នាចុះ។ ចូរនឹកចាំអំពីការអស្ចារ្យដែលបានធ្វើឡើងសម្រាប់អ្នករាល់គ្នា។
[25]ប៉ុន្តែ បើអ្នកនៅតែប្រព្រឹត្តអាក្រក់ ទាំងអ្នករាល់គ្នាទាំងស្តេចរបស់អ្នករាល់គ្នានឹងត្រូវវិនាសមិនខាន»។

---

1 Samuel 12:1
នៅចំពោះអ្នករាល់គ្នាហើយ... ខ្ញុំបាននៅជាមួយអ្នករាល់គ្នា
ឃ្លាទាំងនេះបង្ហាញអត្ថន័យថា ប្រជាជនពិតជាអាចឃើញជីវិតរស់នៅ
ដែលសូលនិងសាំយូអែលកំពុងរស់នៅ។ ការបកប្រែផ្សេងទៀត
«ជីវិតរបស់ស្តេចត្រូវបានគេមើលឃើញ ... ជីវិតរបស់ខ្ញុំត្រូវបានគេមើលឃើញ»
1 Samuel 12:3
ខ្ញុំនៅទីនេះហើយ ចូររៀបរាប់ដល់ព្រះអម្ចាស់ប្រឆាំងនឹងខ្ញុំ
និងស្តេចដែលព្រះអង្គបានតាំងឡើងនេះចុះ
តាមរយៈសេចក្តីថ្លែងការណ៍នេះ
លោកសាំយូអែលកំពុងតែជម្រុញប្រជាជនឲ្យនិយាយឡើង
បើគាត់បានធ្វើអ្វីខុសនឹងនរណាម្នាក់។ ការបកប្រែផ្សេងទៀត
«ខ្ញុំឈរនៅមុខអ្នកឥឡូវនេះ។ ខ្ញុំសុំឲ្យអ្នកនិយាយនៅចំពោះព្រះភក្ត្រព្រះអម្ចាស់
និងស្តេចដែលព្រះអង្គបានតែងតាំង បើខ្ញុំបានធ្វើអ្វីមួយខុសចំពោះអ្នក»
បើខ្ញុំបានយកគោរបស់អ្នកណា? ឬបានយកលារបស់អ្នកណា?
លោកសាំយូអែលប្រើសំណួរដ៏ប៉ិនប្រសព្វ ដើម្បីរំលឹកប្រជាជនថា
គាត់មិនដែលលួចសត្វរបស់ពួកគេទេ។ការបកប្រែផ្សេងទៀត
«ខ្ញុំមិនដែលលួចសត្វដែលមានតម្លៃពីនរណាម្នាក់ឡើយ»។
ក៏បានកេងបន្លំរបស់អ្នកណា?
លោកសាំយូអែលប្រើសំណួរដ៏ប៉ិនប្រសព្វ ដើម្បីនិយាយថា គាត់តែងតែស្មោះត្រង់។
ការបកប្រែផ្សេងទៀត «ខ្ញុំមិនដែលបោក ឬសូកប៉ាន់មនុស្សណាម្នាក់ឡើយ»។
ចូរធ្វើបន្ទាល់ប្រឆាំងនឹងខ្ញុំចុះ ហើយខ្ញុំនឹងទូទាត់សងអ្នករាល់គ្នាវិញ។
«បើខ្ញុំបានធ្វើអ្វីមួយទាំងនេះអាក្រក់
ចូរនិយាយឥឡូវនេះហើយខ្ញុំនឹងសងអ្វីដែលខ្ញុំជំពាក់។ ខ្ញុំនឹងកែអ្វីដែលខុស»
1 Samuel 12:4
ពីអ្នកណា ... គ្មានអ្វីទាស់នឹងខ្ញុំឡើយ
ឃ្លាទាំងនេះមានន័យថា អ្វីដែលមនុស្សម្នាក់កាន់កាប់
ឬអ្វីដែលពួកគេបានធ្វើដើម្បីទទួលបានការពេញចិត្តពីអ្នកដទៃ។
នេះជារបៀបគួរសមក្នុងការនិយាយថា គាត់មិនបានលួចហើយក៏មិនបានឲ្យ
ឬសូកប៉ាន់ដែរ។
1 Samuel 12:6
អំពីការប្រព្រឹត្តដ៏សុចរិតទាំងអស់របស់ព្រះអម្ចាស់
លោកសាំយូអែលកំពុងហៅពួកគេមក ឲ្យយកចិត្តទុកដាក់ចំពោះប្រវត្តិសាស្ត្រ
នៃការដោះស្រាយរបស់ព្រះអម្ចាស់
ចំពោះអ៊ីស្រាអែលដែលបានបំពេញសេចក្តីសប្បុរស និងគោលបំណង។
1 Samuel 12:8
ព្រះអង្គក៏ប្រគល់ពួកលោកទៅឲ្យស៊ីសេរ៉ា ... ពួកភីលីស្ទីន ... ស្តេចម៉ូអាប់
«ចូលទៅក្នុងអំណាចរបស់ស៊ីសេរ៉ា ... ភីលីស្ទីន ... ស្តេចម៉ូអាប់»
លោកយ៉ាកុប ... លោកម៉ូសេ ... លោកអើរ៉ុន ... លោកស៊ីសេរ៉ា
ទាំងនេះជាឈ្មោះរបស់បុរស។
ក្រុងហាសោរ
នេះជាឈ្មោះទីកន្លែងមួយ។
ព្រះអង្គក៏ប្រគល់ពួកលោក
នេះជាការបង្ហាញរបស់ព្រះជាម្ចាស់ ដែលប្រគល់ពួកគេឲ្យសត្រូវរបស់ពួកគេ
ធ្វើជាទាសករ។
1 Samuel 12:10
ពួកគេបានស្រែករកព្រះអម្ចាស់
«ពួកគេ» សំដៅទៅលើប្រជាជាតិអ៊ីស្រាអែល។
លោកយេរូបាល
ជូនកាលពាក្យនេះបកប្រែថាលោកយេរូបាល។ នេះជាឈ្មោះបានទទួលកិត្តិយស
និងកម្លាំងរបស់ព្រះជាម្ចាស់ដើម្បីប្រយុទ្ធនឹងព្រះក្លែងក្លាយ។
ព្រះអម្ចាស់បានចាត់ ... ហើយបានប្រគល់ជ័យជម្នះដល់អ្នករាល់គ្នា
លោកសាំយូអែលកំពុងប្រាប់រឿងរ៉ាវ
ដែលព្រះជាម្ចាស់បានធ្វើបន្ទាប់ពីប្រជាជនបានសារភាពបាប
និងអង្វររកជំនួយមកពីព្រះអង្គ។
លោកយេរូបាល លោកបេដាន លោកយ៉ែបថា និងលោកសាំយូអែល
ទាំងនេះជាឈ្មោះរបស់ពួកចៅហ្វាយមួយចំនួន ដែលព្រះជាម្ចាស់បានលើកឡើង។
លោកសាំយូអែលបានបញ្ចូលខ្លួនគាត់នៅក្នុងបញ្ជីនេះ។
ទៅគោរពបម្រើព្រះបាល និងព្រះអាស្តារ៉ូត។
ការបម្រើនៅទីនេះ សំដៅទៅលើសកម្មភាពការថ្វាយបង្គំចំពោះព្រះក្លែងក្លាយ។
ការបកប្រែផ្សេងទៀត «បានថ្វាយបង្គំព្រះ និងទេវតាក្លែងក្លាយ»
ពីដៃរបស់សត្រូវនៃយើងខ្ញុំ
សេចក្តីថ្លែងការណ៍នេះកំពុងប្រើ«ដៃ»សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«អំណាច ឬការគ្រប់គ្រងរបស់សត្រូវយើង»
1 Samuel 12:12
ទេ! តែផ្ទុយទៅវិញ សូមឲ្យស្តេចមួយអង្គសោយរាជ្យលើពួកយើងចុះ
នេះជាសេចក្តីថ្លែងការណ៍បង្ហាញពីប្រតិកម្មយ៉ាងខ្លាំង
របស់ប្រជាជាតិអ៊ីស្រាអែលប្រឆាំងនឹងសាំយូអែល
ពេលលោកបានប្រាប់ពួកគេអំពីការជឿទុកចិត្តលើព្រះជាម្ចាស់
ពីព្រោះព្រះជាម្ចាស់បានរំដោះពួកគេកាលពីអតីតាល។
ដែលអ្នករាល់គ្នាបានជ្រើសរើសហើយ ជាស្តេចដែលអ្នករាល់គ្នាបានសុំ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា
ហើយបញ្ជាក់ថានេះជាស្តេចដែលប្រជាជនចង់បាន។
1 Samuel 12:14
កោតខ្លាច ... ចូរបម្រើ ... ស្តាប់តាម ...នត្រូវបះបោរប្រឆាំង
ពាក្យស្រដៀងគ្នាទាំងនេះត្រូវបានប្រើដើម្បីបញ្ជាក់ថា វាសំខាន់យ៉ាងណា។
នោះព្រះហស្តរបស់ព្រះអម្ចាស់នឹងប្រឆាំងនឹងអ្នករាល់គ្នា
ដូចដែលប្រឆាំងនឹងបុព្វបុរសរបស់អ្នករាល់គ្នាដែរ។
ពាក្យថា«ព្រះហស្ត» ត្រង់នេះតំណាងឲ្យអំណាច
និងការគ្រប់គ្រងរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងដាក់ទោសអ្នក ដូចព្រះអង្គបានដាក់ទោសដូនតារបស់អ្នក»
1 Samuel 12:16
នៅចំពោះភ្នែករបស់អ្នករាល់គ្នាចុះ
ពាក្យ«ភ្នែក»នៅទីនេះតំណាងឲ្យប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«នៅខាងក្រៅកន្លែង ដែលប្រជាជាតិអ៊ីស្រាអែលអាចមើលឃើញ»

generated on Wed Sep 10 16:16:32 2025

តើមិនមែនពេលនេះជារដូវចម្រូតទេឬអី?
លោកសាំយូអែលដឹងថា ដល់ពេលចម្រូតហើយ។
គាត់កំពុងប្រើសំណួរដ៏ប៉ិនប្រសព្វដើម្បីបញ្ជាក់ថា ពុំមានភ្លៀងធ្លាក់ទេនៅទីនេះ
ដូច្នេះប្រជាជននឹងដឹងថា ភ្លៀងដែលនឹងបំផ្លាញផលដំណាំរបស់ពួកគេ
គឺជាការកាត់សេចក្តីពីព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ដល់ពេលវេលាប្រមូលផលហើយ ជាធម្មតាមិនមានភ្លៀងធ្លាក់ទេនៅពេលនេះ»
ព្រះអង្គនឹងធ្វើឲ្យមានផ្គរ និងភ្លៀងមក។
លោកសាំយូអែលកំពុងសុំព្រះអម្ចាស់ដាក់ទោសអ៊ីស្រាអែល
ចំពោះការស្នើសុំស្តេចដោយបញ្ជូនព្យុះភ្លៀងនៅពេលរដូវចម្រូតដែលនឹងបំផ្លាញស្រូវ។
1 Samuel 12:19
នោះយើងខ្ញុំនឹងមិនត្រូវស្លាប់ឡើយ។
ការដាក់ទោសចុងក្រោយចំពោះអំពើបាប គឺជាសេចក្តីស្លាប់។
ប្រជាជាតិអ៊ីស្រាអែលបានឃើញព្រះអម្ចាស់បំផ្លាញប្រជាជាតិនានា
ដែលជិះជាន់ពួកគេ។ ពួកគេមានការព្រួយបារម្ភថា ពួកគេត្រូវក្លាយជា
«ប្រធានបទនៃបំផ្លាញ» ដូចប្រជាជាតិទាំងនោះដែរ។
កុំភ័យខ្លាចអី
ប្រជាជនបានធ្វើអំពើអាក្រក់ ហើយពួកគេខ្លាចព្រះជាម្ចាស់បំផ្លាញពួកគេ។
ការបកប្រែផ្សេងទៀត «កុំខ្លាចថា
ព្រះជាម្ចាស់នឹងព្រះពិរោធហើយបំផ្លាញអ្នកដោយសារអំពើបាបនេះ»
ងាកទៅរកអ្វីដែលគ្មានប្រយោជន៍
«ដេញតាមការថ្វាយបង្គំព្រះក្លែងក្លាយ»
1 Samuel 12:22
ដោយយល់ដល់ព្រះនាមដ៏អស្ចារ្យរបស់ព្រះអង្គ
ត្រង់នេះ«ព្រះនាម»សំដៅទៅលើកេរ្តិ៍ឈ្មោះរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ដូច្នេះប្រជាជននឹងបន្តផ្តល់កិត្តិយស
និងគោរពដល់ព្រះអម្ចាស់»
ចំពោះខ្ញុំ
ចូរកុំឲ្យខ្ញុំប្រព្រឹត្តអំពើបាបទាស់នឹងព្រះអម្ចាស់ដោយលែងទូលអង្វរសម្រាប់អ្នករាល់គ្នាឡើយ។
ប្រជាជនពោរពេញដោយការភ័យខ្លាចជាខ្លាំង ព្រោះតែទឹកភ្លៀង
និងផ្គរលាន់ដែលព្រះអម្ចាស់ចាត់មកនៅពេលលោកសាំយូអែលពេលអធិស្ឋាន។
មនុស្សខ្លះជឿថាលោកសាំយូអែលនឹងប្រើការអធិស្ឋានរបស់គាត់
ដើម្បីធ្វើបាបពួកគេ»។

---

13 [1]ព្រះបាទសូលបានឡើងគ្រងរាជ្យកាលពីព្រះជន្មសាមសិបព្រះវស្សា
ហើយព្រះអង្គគ្រងរាជ្យសម្បត្តិលើអ៊ីស្រាអែលរយៈពេលសែសិបឆ្នាំ[2]ព្រះអង្គបានជ្រើសរើសបុរសអ៊ីស្រាអែលបីពាន់អ្នកធ្វើជាកងទ័ព។
មានទ័ពពីរពាន់នាក់នៅជាមួយព្រះអង្គនៅឯមីកម៉ាស់ និងតំបន់ទីទួលបែតអែល ខណៈនោះក៏មានទ័ពមួយពាន់នាក់នៅជាមួយសម្តេចយ៉ូណាថាន នៅឯគីបៀរ
ទឹកដីបេនយ៉ាមីនដែរ។ ទ័ពដែលនៅសេសសល់ ស្តេចឲ្យទៅផ្ទះនិងត្រសាលរៀងៗខ្លួនវិញ។
[3]សម្តេចយ៉ូណាថានបានវាយយកលានដ្ឋានទ័ពរបស់ពួកភីលីស្ទីននៅឯគីបៀរ ហើយពួកភីលីស្ទីនក៏បានដឹងដំណឹងនេះដែរ។
បន្ទាប់មកព្រះបាទសូលបានផ្លុំត្រែឡើងលើទឹកដីទាំងមូល ដោយមានបន្ទូលថា៖ «ចូរឲ្យជនជាតិហេព្រើរឮឡើង»។
[4]កាលជនជាតិអ៊ីស្រាអែលទាំងអស់បានឮថាព្រះបាទសូលបានវាយឈ្នះលានដ្ឋានទ័ពរបស់ពួកភីលីស្ទីន
ហើយអ៊ីស្រាអែលបានក្លាយទៅជាក្លិនមិនស្រួលដល់ពួកភីលីស្ទីន ដូច្នេះ នោះទាហានបានប្រមូលគ្នាមកចូលរួមទាំងអស់គ្នាជាមួយព្រះបាទសូលនៅឯគីលកាល់។
[5]ពួកភីលីស្ទីនបានមកជួបជុំគ្នាដើម្បីវាយប្រឆាំងនឹងអ៊ីស្រាអែលដោយមាន រទេះចម្បាំងបីពាន់គ្រឿង អ្នកបររទេះចម្បាំងប្រាំមួយពាន់នាក់
និងទាហានថ្មើជើងជាច្រើនដូចគ្រាប់ខ្សាច់នៅឆ្នេរសមុទ្រ។ ពួកគេបានឡើងមកបោះជំរំនៅឯមីកម៉ាស់ ខាងកើតបេតអាវេន។
[6]ពេលទាហានអ៊ីស្រាអែលបានឃើញថា ខ្លួនកំពុងវឹកវរហើយ ប្រជាជនមានការភ័យខ្លាច អ្នកខ្លះបានពួនក្នុងរូងភ្នំ តាមគុម្ពោត តាមក្រហែងថ្ម តាមអណ្តូង និងតាមអន្លុង។
[7]មានជនជាតិហេព្រើរខ្លះបានរត់ឆ្លងទៅម្ខាងទៀតនៃទន្លេយ័រដាន់ ទៅឯស្រុកកាដ និងស្រុកកាឡាដ។ ប៉ុន្តែ ព្រះបាទសូលនៅតែគង់នៅឯគីលកាល់
ហើយទាហានទាំងអស់បានទៅតាមព្រះអង្គទាំងភ័យញាប់ញ័រ។
[8]ព្រះអង្គបានរង់ចាំដល់ទៅប្រាំពីរថ្ងៃ ជាពេលដែលលោកសាំយូអែលបានរៀបចំទុក។ ប៉ុន្តែ លោកសាំយូអែលពុំបានមកគីលកាល់ទេ
ហើយទាហានខ្លះបានរត់ចោលព្រះបាទសូល។[9]ព្រះបាទសូលបានមានរាជឱង្ការថា៖ «ចូរយកតង្វាយដុត និងតង្វាយមេត្រីភាពមកឲ្យយើង»។ បន្ទាប់មក
ស្តេចបានថ្វាយតង្វាយដុត។[10]ក្រោយព្រះអង្គថ្វាយតង្វាយដុតចប់សព្វគ្រប់យើង លោកសាំយូអែលបានមកដល់។ ព្រះបាទសូលបានចេញមកទទួលលោក
ហើយជម្រាបសួរលោកផង។
[11]លោកសាំយូអែលបានមានប្រសាសន៍ថា៖ «តើព្រះអង្គបានធ្វើអ្វី?» ព្រះបាទសូលបានតបវិញថា៖ «កាលខ្ញុំបានឃើញពួកទាហានកំពុងរត់ចោលខ្ញុំ
ហើយលោកពុំបានមកដល់ទាន់ពេលដែលបានកំណត់ទៀត ឯពួកទ័ពភីលីស្ទីនបានមកផ្តុំគ្នានៅឯមីកម៉ាស់[12]ខ្ញុំក៏បាននិយាយថា ឥឡូវនេះ
ពួកភីលីស្ទីននឹងចុះមកតទល់នឹងយើងនៅគីលកាល់នេះ ហើយខ្ញុំពុំអាចស្វែងរកព្រះហឫទ័យរបស់ព្រះអម្ចាស់ទៀត។ ដូច្នេះ ខ្ញុំក៏បង្ខំខ្លួនឯងថ្វាយតង្វាយដុតតែម្តងទៅ»។
[13]លោកសាំយូអែលបានតបនឹងព្រះបាទសូលវិញថា៖ «ព្រះអង្គបានប្រព្រឹត្តយ៉ាងទទឹងទិស
ព្រះអង្គពុំបានស្តាប់តាមព្រះរាជបញ្ជារបស់ព្រះអម្ចាស់ជាព្រះរបស់ព្រះករុណាដែលបានប្រទានដល់ព្រះករុណាទេ។ បើមិនដូច្នោះទេ
ព្រះអម្ចាស់នឹងតាំងរាជ្យរបស់ព្រះករុណាឲ្យដឹកនាំលើអ៊ីស្រាអែលរហូតតទៅមិនខាន។[14]ប៉ុន្តែ ពេលនេះ រាជ្យរបស់ព្រះអង្គនឹងមិនបន្តទៅមុខទៀតទេ។
ព្រះអម្ចាស់បានរកបុរសម្នាក់ផ្សេងទៀតចេញពីព្រះទ័យរបស់ព្រះអង្គផ្ទាល់ ហើយព្រះអម្ចាស់ក៏បានតាំងបុរសនោះជាអ្នកដឹកនាំលើប្រជារាស្ត្ររបស់ព្រះអង្គជំនួសវិញ
ពីព្រោះព្រះករុណាពុំបានស្តាប់បង្គាប់អ្វីដែលព្រះអង្គបានបញ្ជាដល់ព្រះករុណាទេ»។
[15]បន្ទាប់មក លោកសាំយូអែលបានក្រោកឡើង ហើយចាកចេញពីគីលកាល់ឆ្ពោះទៅគីបៀរនៃទឹកដីបេនយ៉ាមីន។
ព្រះបាទសូលបានជំរឿនទាហានដែលមានវត្តមានជាមួយព្រះអង្គ ឃើញមានប្រាំមួយរយនាក់។[16]ព្រះបាទសូល សម្តេចយ៉ូណាថានជាបុត្រារបស់ព្រះអង្គ
និងទាហានដែលនៅសេសសល់ទាំងនោះ នៅចាំឯភូមិកេបានៃទឹកដីបេនយ៉ាមីន។ ប៉ុន្តែ ពួកភីលីស្ទីននៅតែបោះទ័ពនៅមីកម៉ាស់ដដែរ។
[17]មានអ្នកប្រយុទ្ធបីក្រុមចេញពីជំរំរបស់ពួកភីលីស្ទីន។ ក្រុមមួយតម្រង់ទៅឯក្រុងអូប្រា គឺទៅស្រុកស៊ូអាល។[18]ក្រុមមួយទៀតតម្រង់ទៅក្រុងបេតហូរ៉ូន
ហើយក្រុមមួយផ្សេងទៀតតម្រង់ទៅព្រំប្រទល់ម្ខាងនៃជ្រលងសេបោម ឯទីរហោស្ថាន។
[19]គេរកពុំឃើញមានជាងដែកណាម្នាក់នៅក្នុងស្រុកអ៊ីស្រាអែលទាំងមូលនោះទេ ពីព្រោះពួកភីលីស្ទីននិយាយថា៖ «បើទុកឲ្យមានជាងដែក នោះ ជនជាតិហេព្រើរនឹងធ្វើដាវ
ឬលំពែងសម្រាប់ខ្លួនគេជាមិនខាន»។[20]ប៉ុន្តែ ជនជាតិអ៊ីស្រាអែលទាំងអស់ បានទៅស្រុកភីលីស្ទីនដើម្បីច្រុងផាលនង្គ័ល ផ្លែចប ផ្លែពូថៅ
និងកណ្តៀរបស់ពួកគេរៀងៗខ្លួន។[21]កាលណោះតម្លៃពីរស្លឹងសម្រាប់ច្រុងផាលនង្គ័ល និងចប ឯតម្លៃមួយស្លឹងគឺ សំលៀងផ្លែពូថៅ និងតម្រង់រនាស់។
[22]ដូច្នេះ នៅថ្ងៃប្រយុទ្ធមនឹងសមរភូមិ ពួកទាហានដែលនៅជាមួយនឹងព្រះបាទសូល និងសម្តេចយ៉ូណាថានគ្មានដាវ ឬលំពែងនៅនឹងដៃ មានតែព្រះបាទសូល
និងបុត្រារបស់ស្តេច គឺសម្តេចយ៉ូណាថានប៉ុណ្ណោះដែលមាន។[23]ទ័ពរបស់ពួកភីលីស្ទីនខ្លះបានបញ្ជូនទៅច្រកមីកម៉ាស់។

---

1 Samuel 13:1
ព័ត៌មានទូទៅ៖
លោកសាំយូអែលបានបន្តរាជ្យរបស់ព្រះបាទសូល នៅគីលកាល់
ហើយលោកបានរំលឹកប្រជាជនឲ្យធ្វើតាមព្រះអម្ចាស់។
ព្រះបាទសូលបានឡើងគ្រងរាជ្យកាលពីព្រះជន្មសាមសិបព្រះវស្សា ... លើអ៊ីស្រាអែល
អត្ថបទនេះនៅក្នុងឯកសារពីបុរាណហាក់ដូចជាត្រូវខ្វេចខ្វី
ដូច្នេះការបកប្រែសម័យទំនើបមានការបកប្រែខុសគ្នាច្រើន។
ពួកគេទាំងអស់ប៉ុនប៉ងបង្ហាញអត្ថន័យ
ដែលអាចមានន័យស្របតាមអត្ថបទដើមទាំងស្រុង។
ជ្រើសរើសបុរសអ៊ីស្រាអែលបីពាន់អ្នកធ្វើជាកងទ័ព។

generated on Wed Sep 10 16:16:32 2025

«ជ្រើសរើសបុរស ៣០០០នាក់»
មានទ័ពពីរពាន់នាក់នៅជាមួយព្រះអង្គនៅឯមីកម៉ាស់
«២០០០នាក់នៅជាមួយព្រះអង្គនៅមីកម៉ាស់»
គីបៀរ ទឹកដីបេនយ៉ាមីន
គីបៀរជាទីក្រុងមួយ។ សូមមើលការបកប្រែនៅក្នុង ១០:២៦ ។
ទ័ពដែលនៅសេសសល់ ស្តេចឲ្យទៅផ្ទះ និងត្រសាលរៀងៗខ្លួនវិញ
«ព្រះអង្គបានបញ្ជូនទាហានដែលនៅសល់ឲ្យទៅផ្ទះវិញ»
1 Samuel 13:3
លានដ្ឋានទ័ពរបស់ពួកភីលីស្ទីន
«មូលដ្ឋានទ័ពរបស់ពួកភីលីស្ទីន» ឬ «ជំរំយោធាភីលីស្ទីន»
គីបៀរ
នេះជាឈ្មោះទីក្រុង ដែលទាហានភីលីស្ទីនបោះទីតាំងនៅទីនោះ។
កាលជនជាតិអ៊ីស្រាអែលទាំងអស់បានឮថា ព្រះបាទសូលបានវាយឈ្នះ
អាចមានន័យថា ១)
ព្រះបាទសូលទទួលខុសត្រូវចំពោះសកម្មភាពរបស់សម្តេចយ៉ូណាថាន ឬ ២)
ព្រះបាទសូលកំពុងតែលើកសរសើរចំពោះសកម្មភាពរបស់សម្តេចយ៉ូណាថាន។
ហើយអ៊ីស្រាអែលបានក្លាយទៅជាក្លិនមិនស្រួល ដល់ពួកភីលីស្ទីន
ពួកភីលីស្ទីនស្អប់ជនជាតិអ៊ីស្រាអែល ធ្វើឲ្យពួកគេនិយាយថា
ពួកអ៊ីស្រាអែលបានធុំក្លិនអាក្រក់ ដែលប្រមាថពួកភីលីស្ទីន។ ការបកប្រែផ្សេងទៀត
«ពួកភីលីស្ទីនស្អប់ជនជាតិអ៊ីស្រាអែល»
នោះទាហានបានប្រមូលគ្នាមកចូលរួមទាំងអស់គ្នាជាមួយព្រះបាទសូលនៅឯគីលកាល់។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះបាទសូលបានកោះហៅទាហានឲ្យមកចូលរួមជាមួយព្រះអង្គនៅគីលកាល់»
1 Samuel 13:5
បីពាន់គ្រឿង...ប្រាំមួយពាន់នាក់
« ៣០០០ ... ៦០០០»
ទាហានថ្មើរជើងជាច្រើនដូចគ្រាប់ខ្សាច់នៅឆ្នេរសមុទ្រ
ទាហានមួយក្រុមធំណាស់ ដែលពិបាកនឹងរាប់ពួកគេ
មីកម៉ាស់
នេះជាឈ្មោះទីកន្លែងមួយ។
បេតអាវេន
នេះជាឈ្មោះទីកន្លែងមួយ។
1 Samuel 13:6
ព័ត៌មានទូទៅ៖
ពួកភីលីស្ទីនបានប្រមូលផ្តុំគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងអ៊ីស្រាអែល។
ប្រជាជន
ឃ្លានេះសំដៅទៅលើប្រជាជាតិអ៊ីស្រាអែល។
ប្រជាជនមានការភ័យខ្លាច
ប្រជាជនមានការព្រួយបារម្ភយ៉ាងខ្លាំង
ព្រះអង្គទាំងភ័យញាប់ញ័រ។
ប្រជាជនមានការភ័យខ្លាចយ៉ាងខ្លាំង
1 Samuel 13:8
ជាពេលដែលលោកសាំយូអែលបានរៀបចំទុក។
«យោងទៅតាមពេលវេលា ដែលលោកសាំយូអែលបានប្រាប់ពួកគេថាគាត់នឹងមក»
ហើយទាហានខ្លះបានរត់ចោលព្រះបាទសូល។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនបានចាប់ផ្តើមចាកចេញពីសូល»
បន្ទាប់មក ស្តេចបានថ្វាយតង្វាយដុត។
មានតែត្រកូលរបស់អើរ៉ុនប៉ុណ្ណោះ
ដែលត្រូវបានអនុញ្ញាតឲ្យថ្វាយតង្វាយដុតដល់ព្រះជាម្ចាស់។
1 Samuel 13:11
តើព្រះអង្គបានធ្វើអ្វី?
លោកសាំយូអែលពិតជាមិនបានសួរសំណួរទេ
តែបានការស្តីបន្ទោសដល់ព្រះបាទសូល។
ព្រះបាទសូលព្យាយាមការពារសកម្មភាពរបស់ទ្រង់
ទោះបីព្រះអង្គបានធ្វើខុសក៏ដោយ។
មីកម៉ាស់
មីកម៉ាស់ជាឈ្មោះកន្លែងមួយ។ សូមមើលការបកប្រែវានៅក្នុង ១៣:១។
1 Samuel 13:13
ព្រះអង្គពុំបានស្តាប់តាមព្រះរាជបញ្ជារបស់ព្រះអម្ចាស់
ព្រះបាទសូលត្រូវរង់ចាំលោកសាំយូអែលមកសិន
រួចសឹមថ្វាយតង្វាយដុតដល់ព្រះជាម្ចាស់។
ព្រះអង្គមិនត្រូវថ្វាយយញ្ញបូជាដោយអង្គទ្រង់ផ្ទាល់ទេ។
តាំងរាជ្យរបស់ព្រះករុណាឲ្យដឹកនាំ
«បង្កើតការដឹកនាំរបស់អ្នក» ឬ «បានអនុញ្ញាតការដឹកនាំរបស់អ្នក» ឬ
«តែងតាំងការដឹកនាំរបស់អ្នក»
ព្រះអង្គនឹងមិនបន្តទៅមុខទៀតទេ
នេះជាពន្លឺដែលអាចបញ្ជាក់ជាទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ការដឹកនាំរបស់អ្នកនឹងចប់ឆាប់ៗ"
បុរសម្នាក់ផ្សេងទៀតចេញពីព្រះទ័យរបស់ព្រះអង្គផ្ទាល់
នៅទីនេះ« ចិត្ត» តំណាងឲ្យបំណងប្រាថ្នា ឬឆន្ទៈរបស់ព្រះអម្ចាស់។ ឃ្លាដែលថា
«មនុស្សដែលមានចិត្តដូចព្រះ» ជាឃ្លាដែលមានន័យថា
ធ្វើជាមនុស្សដែលធ្វើអ្វីដែលព្រះអម្ចាស់សព្វព្រះហឫទ័យ។ ការបកប្រែផ្សេងទៀត
«បុរសដែលជាប្រភេទមនុស្សព្រះអង្គចង់បាន» ឬ
«បុរសម្នាក់ដែលនឹងស្តាប់បង្គាប់ព្រះអង្គ» (សូមមើល និងផ្លែល្វា -idiom)
1 Samuel 13:15
លោកសាំយូអែលបានក្រោកឡើង ហើយចាកចេញ
នេះជាសំនួនវោហាស័ព្ទ «លោកសាំយូអែលបានចាកចេញ ហើយបានឡើងទៅ»។
ចាកចេញពីគីលកាល់
គីលកាល់ជាទីក្រុងមួយ។ សូមមើលការបកប្រែរឿងនេះនៅក្នុង ៧:១៥ ។
ភូមិកេបានៃទឹកដីបេនយ៉ាមីន
ភូមិកេបាជាទីក្រុងមួយ។ សូមមើលការបកប្រែនៅក្នុង ១០:២៦ ។
ឃើញមានប្រាំមួយរយនាក់។
«បុរស ៦០០នាក់»
ភូមិកេបានៃទឹកដីបេនយ៉ាមីន
ភូមិកេបាជាទីក្រុងមួយ។ សូមមើលការបកប្រែនៅក្នុង ១៣:៣ ។
ពួកភីលីស្ទីននៅតែបោះទ័ពនៅមីកម៉ាស់ដដែរ។
មីកម៉ាស់ជាឈ្មោះទីកន្លែងមួយ។ សូមមើលការបកប្រែនៅក្នុង ១៣:១។
1 Samuel 13:17
មានអ្នកប្រយុទ្ធ
ជាធម្មតា អ្នកប្រយុទ្ធជាយោធា ជាមនុស្សដែលវាយប្រហារភូមិសត្រូវ
យកស្បៀងអាហារ និងគ្រឿងផ្គត់ផ្គង់ផ្សេងទៀត។
ក្រុងអូប្រា, ទៅស្រុកស៊ូអាល... ក្រុងបេតហូរ៉ូន ... ជ្រលងសេបោម
ទាំងនេះជាឈ្មោះទីកន្លែង។
1 Samuel 13:19
ឃ្លាភ្ជាប់៖
អ្នកអធិប្បាយផ្លាស់ប្តូរព័ត៌មានសង្ខេប ទាក់ទងនឹងជាងដែកនៅក្នុងអ៊ីស្រាអែល។
គេរកពុំឃើញមានជាងដែក
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេង
«គ្មាននរណាម្នាក់អាចស្វែងរកជាងដែកបានទេ»
ជាងដែក
នៅទីនេះ «ជាងដែក» សំដៅទៅលើនរណាម្នាក់ ដែលបានធ្វើ
ឬធ្វើឲ្យឧបករណ៍មុតស្រួច និងអាវុធដែក។
ច្រុងផាលនង្គ័ល ផ្លែចប
ពាក្យថា«ភ្លូរ»សំដៅទៅលើចំណុចនៃឧបករណ៍ដែក
ប្រើសម្រាប់ជីកគាស់បំបែកដីដាំដំណាំ។
ផាលនង្គ័ល ... ផ្លែពូថៅ ... កណ្តៀវ
ទាំងនេះជាឧបករណ៍ទូទៅនៅសួនច្បារ។
ផាលនង្គ័ល
«ផាលនង្គ័ល»មានរាងសំប៉ែតដូចផ្លែពូថៅ ដែលមានផ្លែផ្តេក
ប្រើសម្រាប់ការបំបែកដីរឹង។
កណ្តៀវ
មានរាងសំប៉ែតកោងសម្រាប់ការកាត់ស្មៅ និងស្រូវ
តម្លៃពីរស្លឹង
មួយភាគបីនៃមួយស្លឹង ស្លឹងដែលចែកជា ៣ចំណែក ២ ភាគ៣ត្រូវបានផ្តល់។
«២/៣ នៃស្លឹង»
តម្រង់រនាស់
«ពុតកន្លែងកោង ហើយធ្វើឲ្យរនាស់គោត្រង់ម្តងទៀត ដូច្នេះ គេអាចប្រើវាបាន»

generated on Wed Sep 10 16:16:32 2025

គ្មានដាវ ឬលំពែងនៅ
នេះជាពន្យល់ពីមូលហេតុ ដែលកងទ័ពរបស់ព្រះបាទសូលភ័យខ្លាច។
ពួកគេពុំមានអាវុធប្រយុទ្ធទេ។

14 [1]ថ្ងៃមួយ សម្តេចយ៉ូណាថាន ជាបុត្រាព្រះបាទសូលបានមានរាជឱង្ការទៅអ្នកកាន់គ្រឿងសឹកឲ្យសម្តេចថា៖ «តោះ
ចូរយើងទៅឯជំរំរបស់ពួកភីលីស្ទីននៅឯម្ខាងណោះ»។ ប៉ុន្តែ សម្តេចមិនបានទូលបិតារបស់សម្តេចទេ។
[2]ព្រះបាទសូលបានគង់នៅឯជាយភូមិគីបៀរ គឺនៅក្រោមដើមទទឹមនៅមីក្រូន។ មានទ័ពប្រហែលជាប្រាំមួយរយនាក់នៅជាមួយស្តេច[3]រួមទាំងលោកអហ៊ីយ៉ា
ជាកូនរបស់លោកអហ៊ីទូប (ជាប្អូនរបស់អ៊ីកាបុដ) ជាចៅរបស់លោកភីនេហាស ដែលជាចៅទួតរបស់លោកអេលី ជាបូជាចារ្យរបស់ព្រះអម្ចាស់នៅឯស៊ីឡូ
ដែលជាអ្នកពាក់អាវអេផូដ។ ពួកទាហានពុំបានដឹងថា សម្តេចយ៉ូណាថានយាងទៅណាទេ។
[4]នៅឯម្ខាងទៀតនៃច្រកដែលសម្តេចយ៉ូណាថានចង់ទៅដើម្បីឲ្យទៅដល់កន្លែងដាក់ទ័ពពួកភីលីស្ទីន មានថ្មរដិរដុបចោតទាំងសងខាង ដែលគេហៅថាបូសេសនិង
មួយទៀតហៅថា សេនេ។[5]ចំណោតថ្មមួយនៅឯទិសខាងជើងខាងមុខមីកម៉ាស់ ហើយចំណោតថ្មម្ខាងទៀតនៅខាងត្បូងចំពីមុខកេបា។
[6]សម្តេចយ៉ូណាថានបានមានរាជឱង្ការទៅអ្នកកាន់គ្រឿងសឹករបស់សម្តេចថា៖ «តោះ ចូរយើងឆ្លងកាត់លានដ្ឋានទ័ពរបស់ពួកមិនកាត់ស្បែកទាំងនេះ។
ព្រះអម្ចាស់អាចនឹងធ្វើការជំនួសយើង ព្រោះគ្មានអ្វីដែលឃាត់ព្រះអម្ចាស់មិនឲ្យជួយបើមានមនុស្សតិច ឬច្រើនក្តី»។[7]អ្នកកាន់គ្រឿងសឹករបស់សម្តេចបានតបវិញថា៖
«សូមសម្តេចធ្វើអ្វីតាមចិត្តរបស់សម្តេចចុះ។ សូមចេញទៅចុះ មើល ទូលបង្គំនៅជាមួយសម្តេចហើយ គឺដើម្បីធ្វើតាមបង្គាប់របស់សម្តេចទាំងអស់»។
[8]សម្តេចយ៉ូណាថានបានមានឱង្ការថា៖ «យើងនឹងឆ្លងទៅរកពួកគេ ហើយបង្ហាញខ្លួនចំពោះពួកគេ។[9]បើពួកគេនិយាយមកយើងថា ចាំទីនោះសិនទៅ
ពួកយើងនឹងទៅរកពួកឯង នោះយើងនឹងឈប់នៅត្រង់កន្លែងរបស់យើង គឺយើងមិនឆ្លងទៅរកពួកគេទេ។[10]ប៉ុន្តែ បើពួកគេឆ្លើយឆ្លងមកយើងថា មករកពួកយើងមក
នោះយើងនឹងឆ្លងទៅ ពីព្រោះព្រះអម្ចាស់បានប្រគល់ពួកគេមកក្នុងកណ្តាប់ដៃរបស់យើងហើយ។ នេះហើយគឺជាទីសម្គាល់សម្រាប់យើង»។
[11]ដូច្នេះ អ្នកទាំងពីរបានបង្ហាញខ្លួននៅឯលានដ្ឋានទ័ពរបស់ពួកភីលីស្ទីន។ ពួកទាហានភីលីស្ទីនបាននិយាយថា៖ «មើល ជនជាតិហេព្រើរ
កំពុងតែចេញមកពីរន្ធដែលពួកគេបានរត់ពួនហើយ»។[12]បន្ទាប់មក ទាហានក្នុងលានដ្ឋាននោះបានស្រែកហៅសម្តេចយ៉ូណាថាន និងអ្នកកាន់គ្រឿងសឹកឲ្យសម្តេចថា៖
«មករកពួកយើងមក យើងនឹងបង្ហាញពួកឯងខ្លះ»។ សម្តេចយ៉ូណាថានបានមានរាជឱង្ការទៅអ្នកកាន់គ្រឿងសឹករបស់សម្តេចថា៖ «មកតាមខ្ញុំ
ពីព្រោះព្រះអម្ចាស់បានប្រគល់ពួកគេមកក្នុងដៃរបស់អ៊ីស្រាអែលហើយ»។
[13]សម្តេចយ៉ូណាថានបានតោងឡើងដោយដៃនឹងជើងរបស់សម្តេច ឯអ្នកកាន់គ្រឿងសឹករបស់សម្តេចបានតាមពីក្រោយសម្តេច។
សម្តេចយ៉ូណាថានបានប្រហារជីវិតរបស់ពួកភីលីស្ទីនទាំងនោះនៅនឹងមុខ ហើយអ្នកកាន់គ្រឿងសឹករបស់សម្តេចក៏បានសម្លាប់ពួកនោះខ្លះនៅចំពោះមុខសម្តេចដែរ។
[14]មុនដំបូងសម្តេចយ៉ូណាថាន និងអ្នកកាន់គ្រឿងសឹករបស់សម្តេចបានស្លាប់ពួកគេប្រហែលម្ភៃនាក់ក្នុងទំហំដីមួយស្រែ។
[15]មានចលាចលនៅជំរំ នៅឯវាល និងក្នុងចំណោមពួកភីលីស្ទីន។ សូម្បីក្នុងលានដ្ឋាន និងអ្នកចម្បាំងរបស់ពួកគេក៏មានការភ័យខ្លាចដែរ។
ផែនដីបានជញ្ជួយភាពភ័យខ្លាចកើតឡើងយ៉ាងខ្លាំង។
[16]ក្រោយមក ពួកអ្នកឃ្លាំមើលរបស់ស្តេចសូលនៅឯគីបៀរនៃទឹកដីបេនយ៉ាមីនបានមើលឃើញថា ពួកទាហានរបស់ភីលីស្ទីនកំពុងរត់ប្រសាច ខ្លះរត់ទៅឯណោះ
ខ្លះរត់ទៅឯណោះ។[17]នោះព្រះបាទសូលមានបន្ទូលទៅទាហានដែលនៅជាមួយព្រះអង្គថា៖ «ចូររាប់គ្នាយើង តើបាត់អ្នកណាខ្លះ»។ ពេលពួកគេរាប់រួចហើយ
គឺបាត់សម្តេចយ៉ូណាថាន និងអ្នកកាន់គ្រឿងសឹករបស់សម្តេច។
[18]ព្រះបាទសូលបានមានរាជឱង្ការទៅលោកអហ៊ីយ៉ាថា៖ «ចូរយកហឹបរបស់ព្រះជាម្ចាស់មកទីនេះ» ព្រោះកាលណោះ ហឹបនោះស្ថិតនៅជាមួយប្រជាជនអ៊ីស្រាអែល។
[19]ខណៈព្រះបាទសូលកំពុងមានរាជឱង្ការទៅបូជាចារ្យ ការវឹកវរនៅក្នុងជំរំរបស់ពួកភីលីស្ទីនកាន់តែបន្តខ្លាំងឡើង។ នោះព្រះបាទសូលមានរាជឱង្ការទៅបូជាចារ្យថា៖
«សូមដកដៃរបស់លោកចេញ»។
[20]ព្រះបាទសូល និងទាហានទាំងអស់ដែលនៅជាមួយស្តេចបានរួមកម្លាំងគ្នាហើយចេញទៅច្បាំង។ ដាវរបស់ពួកទាហានភីលីស្ទីនបានវាយប្រហារគ្នាឯង
ហើយភាពភាន់ច្រឡំបានកើតឡើងក្នុងចំណោមពួកគេ។[21]ជនជាតិហេព្រើរខ្លះដែលពីមុនបាននៅជាមួយនឹងពួកភីលីស្ទីន និងធ្លាប់ជ្រកកោនក្នុងជំរំរបស់ពួកភីលីស្ទីននោះ
បានរត់មករួមដៃជាមួយទាហានអ៊ីស្រាអែល ជាមួយព្រះបាទសូល និងជាមួយសម្តេចយ៉ូណាថានវិញ។
[22]ពួកទាហានអ៊ីស្រាអែលខ្លះដែលបានរត់គេចខ្លួននៅតាមភ្នំជិតអេប្រាអ៊ីមបានឮថា ពួកភីលីស្ទីនបានរត់ភាសខ្លួន
នោះពួកគេក៏ចេញមកដេញតាមប្រហារពួកនោះនៅក្នុងសមរភូមិដែរ។[23]ថ្ងៃនោះ ព្រះអម្ចាស់បានសង្គ្រោះជនជាតិអ៊ីស្រាអែល
ហើយការវាយប្រហារគ្នាបានបន្តដល់បេតអាវេនទៀត។
[24]ថ្ងៃនោះ ទាហានអ៊ីស្រាអែលមិនសប្បាយចិត្ត ដោយព្រះបាទសូលបានយកពួកគេខ្លះដាក់ក្រោមសម្បថថា៖ «អ្នកណាបរិភោគអាហារមុនពេលល្ងាចមកដល់
គឺមុនពេលយើងបានសងសឹកលើសត្រូវរបស់យើង អ្នកនោះមុខជាត្រូវបណ្តាសាមិនខាន»។ ដូច្នេះហើយ ពួកទាហាន គ្មាននរណាម្នាក់ហ៊ានភ្លក់អាហារអ្វីទាំងអស់។
[25]ក្រោយមក ពួកគេដើរចូលព្រៃ ហើយទីនោះមានទឹកឃ្មុំស្រក់មកលើដី។[26]កាលពួកគេបានចូលក្នុងព្រៃ ទឹកឃ្មុំបានស្រក់ចុះ ប៉ុន្តែ
គ្មាននរណាហ៊ានយកម្រាមដៃរបស់ខ្លួនបៀកដាក់ចូលមាត់ឡើយ ព្រោះពួកគេខ្លាចសម្បថ។
[27]សម្តេចយ៉ូណាថានមិនបានឮបិតារបស់ទ្រង់បានចងពួកពលទាហានដោយសម្បថឡើយ សម្តេចក៏បានយកចុងដំបងដែលនៅក្នុងដៃមកជ្រលក់ចូលសំបុកឃ្មុំនោះ
ហើយយកដៃបៀកមកដាក់ក្នុងមាត់របស់សម្តេច ហើយភ្នែករបស់សម្តេចក៏បានភ្លឺស្រស់ថ្លា។[28]ក្រោយមក មានម្នាក់ក្នុងចំណោមនោះបានទូលឆ្លើយថា៖
«ព្រះបិតារបស់សម្តេចបានដាក់ពួកទាហានយ៉ាងតឹងរឹងជាមួយសម្បថថា៖ «អ្នកណាបរិភោគអាហារអ្វីនៅថ្ងៃនេះមុខជាត្រូវបណ្តាសាមិនខាន ដូច្នេះហើយ
ទើបពួកទាហានខ្សោយដោយហេវហត់»។
[29]សម្តេចយ៉ូណាថានបានតបវិញថា៖ «ព្រះបិតារបស់ខ្ញុំបានបង្ករឿងហើយ។ មើលនេះ តើភ្នែករបស់ខ្ញុំបានភ្លឺថ្លាបែបណា ពីព្រោះខ្ញុំបានភ្លក់ទឹកឃ្មុំនឹងតែបន្តិចប៉ុណ្ណោះ។
[30]តើវាមិនប្រសើរជាងនេះទេឬអី បើទាហានបានបរិភោគដោយសេរីនៅថ្ងៃនេះ ពីអាហារនៃជ័យភណ្ឌបានពីសត្រូវដែលពួកយើងរកបាននោះ?
ព្រោះពេលនេះអ្នកដែលប្រហារពួកសត្រូវមើលទៅមិនអស្ចារ្យសោះក្នុងចំណោមពួកភីលីស្ទីន»។
[31]ពួកគេបានវាយពួកភីលីស្ទីននៅថ្ងៃនោះ ពីមីកម៉ាស់រហូតដល់អាយ៉ាឡូន។ ទាហានបានអស់កម្លាំងជាខ្លាំង[32]ពួកគេបានប្រញាប់លោភទៅយកជ័យភណ្ឌ
ដោយបានយកចៀម គោ និងកូនគោ រួចសម្លាប់សត្វទាំងនោះនៅនឹងដី ហើយបានបរិភោគទាំងមាននៅឈាមផង។
[33]ពួកគេបានទូលព្រះបាទសូលថា៖ «មើល ពួកគេបានប្រព្រឹត្តបាបទាស់នឹងព្រះអម្ចាស់ ដោយបរិភោគទាំងនៅឈាម»។ ព្រះបាទសូលបានមានរាជឱង្ការថា៖
«អ្នករាល់គ្នាប្រព្រឹត្តដោយមិនស្មោះត្រង់ទេ។ ចូររមៀលផ្ទាំងថ្មធំមួយមកឲ្យខ្ញុំឥឡូវនេះ[34]ហើយទៅហៅពួកទាហានដោយប្រាប់ទៅ ឲ្យពួកគេរាល់គ្នាយកគោ
និងចៀមរៀងៗខ្លួនមក ហើយសម្លាប់នៅទីនេះ រួចបរិភោគចុះ។ កុំប្រព្រឹត្តបាបទាស់នឹងព្រះអម្ចាស់ដោយបរិភោគទាំងជាមួយឈាមឡើង»។ ដូច្នេះ
ពួកគេបាននាំយកគោរៀងៗខ្លួនមកនៅយប់នោះ ហើយសម្លាប់នៅត្រង់ផ្ទាំងថ្មនោះ។
[35]ព្រះបាទសូលបានសង់អាសនាថ្វាយព្រះអម្ចាស់ ជាអាសនាដំបូងដែលស្តេចបានសង់ថ្វាយព្រះអម្ចាស់។
[36]បន្ទាប់មក ព្រះបាទសូលបានមានរាជឱង្ការថា៖ «ចូរយើងដេញតាមពួកភីលីស្ទីននៅយប់នេះ ហើយរឹបអូសពីពួកគេរហូតដល់ព្រឹក
យើងមិនត្រូវទុកឲ្យពួកគេណាម្នាក់នៅមានជីវិតឡើយ»។ ពួកទាហានបានតបវិញថា៖ «ចូរប្រព្រឹត្តតាមតែព្រះអង្គយល់ថាល្អចុះ»។ ប៉ុន្តែ បូជាចារ្យមានប្រសាសន៍ថា៖

«យើងទូលសួរព្រះជាម្ចាស់សិន»។[37]ព្រះបាទសូលបានទូលសួរព្រះជាម្ចាស់ថា៖ «តើគួរឲ្យទូលបង្គំដេញតាមពួកភីលីស្ទីនឬទេ?
តើព្រះអង្គប្រគល់ពួកគេមកក្នុងកណ្ដាប់ដៃរបស់អ៊ីស្រាអែលឬទេ?» ព្រះជាម្ចាស់មិនបានឆ្លើយតបនឹងស្តេចវិញទេនៅថ្ងៃនោះ។
[38]រួចមកព្រះបាទសូលមានរាជឱង្ការថា៖ «ចូរអស់អ្នកដឹកនាំរបស់ប្រជាជនមកទីនេះ សូមមើលថាតើមាននរណាបានប្រព្រឹត្តបាបបែបណាថ្ងៃនេះ។
[39]យើងសូមស្បថខណៈព្រះអម្ចាស់មានព្រះជន្មគង់នៅ ជាព្រះដែលសង្គ្រោះអ៊ីស្រាអែលថា ទោះបីលោកយ៉ូណាថាន់ជាបុត្រាទូលបង្គំក្តី បើធ្វើបាប គឺត្រូវតែស្លាប់»។ ប៉ុន្តែ
គ្មាននរណាម្នាក់ក្នុងចំណោមពួកទាហានហ៊ានឆ្លើយតបអ្វីទេ។
[40]បន្ទាប់មក ព្រះបាទបានមានបន្ទូលទៅទានហានអ៊ីស្រាអែលទាំងអស់ថា៖ «អ្នករាល់គ្នាត្រូវឈរទៅម្ខាង ហើយយើងនឹងលោកយ៉ូណាថាននឹងឈរនៅម្ខាងទៀត»។
ទាហានបានទូលតបទៅព្រះបាទសូលវិញថា៖ «សូមធ្វើតាមតែព្រះករុណាយល់ថាល្អចុះ»។[41]ហេតុដូច្នេះហើយព្រះបាទសូលទូលទៅព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលថា៖
«សូមបង្ហាញយើងខ្ញុំផង»។ ពេលនោះគេចាប់ប៉ះចំព្រះបាទសូល និងសម្តេចយ៉ូណាថាន ឯពួកទាហានត្រូវបានរួចខ្លួន។[42]បន្ទាប់មក ព្រះបាទសូលមានរាជឱង្ការថា៖
«ចូរសួរបន្តទៀតរវាងយើងនឹងលោកយ៉ូណាថានជាបុត្រារបស់យើង»។ នោះក៏ប៉ះចំសម្តេចយ៉ូណាថាន។
[43]ព្រះបាទសូលបានសួរសម្តេចយ៉ូណាថានថា៖ «ចូរប្រាប់បិតា តើបុត្របានធ្វើអ្វី»។ សម្តេចយ៉ូណាថានបានទូលស្តេចថា៖
«ទូលបង្គំបានភ្លក់ទឹកឃ្មុំបន្តិចពីចុងដំបងដែលនៅក្នុងដៃរបស់ទូលបង្គំ។ ទូលបង្គំនៅទីនេះហើយ ទូលបង្គំនឹងត្រូវស្លាប់»។[44]ព្រះបាទសូលមានរាជឱង្ការថា៖
«បុត្រត្រូវតែស្លាប់ លោកយ៉ូណាថាន បើមិនធ្វើដូច្នេះទេ សូមព្រះជាម្ចាស់ដាក់ទោសបិតាឲ្យខ្លាំងចុះ!»។
[45]បន្ទាប់មក ទាហានបានទូលព្រះបាទសូលថា៖ «តើគួរឲ្យសម្តេចយ៉ូណាថានសុគតឬ ដ្បិតសម្តេចជាអ្នកបានសាងស្នាដៃនៃជ័យជម្នះសម្រាប់អ៊ីស្រាអែល?
សូមកុំឲ្យកើតដូច្នេះឡើយ! ទូលបង្គំសូមស្បថដោយនូវព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅថា នឹងគ្មានសក់មួយសសៃណារបស់សម្តេចជ្រុះដល់ដីឡើង ដ្បិត
សម្តេចបានធ្វើការជាមួយព្រះជាម្ចាស់នៅថ្ងៃនេះ» ដោយការសង្គ្រោះពីពួកទាហានសម្តេចមិនត្រូវបានសម្លាប់ឡើយ។
[46]នោះព្រះបាទសូលក៏បានឈប់ដេញតាមពួកភីលីស្ទីន ហើយពួកភីលីស្ទីនទាំងនោះបានទៅកន្លែងរបស់ខ្លួនវិញ។
[47]កាលព្រះបាទសូលបានចាប់ផ្តើមដឹកនាំជនជាតិអ៊ីស្រាអែល ស្តេចបានច្បាំងនឹងសត្រូវទាំងអស់របស់ស្តេចដែលនៅជុំវិញ។ ស្តេចបានវាយជនជាតិម៉ូអាប់ ជនជាតិអាំម៉ូន
ជនជាតិអេដុម ស្តេចទាំងប៉ុន្មានរបស់សូបា និងពួកភីលីស្ទីនផង។ សមរភូមិណាដែលស្តេចបានចេញទៅ ស្តេចតែងទទួលបានជ័យជម្នះ ដាក់ទោសលើសត្រូវទាំងនោះ។
[48]ស្តេចបានប្រព្រឹត្តដោយចិត្តក្លាហាន ហើយបានវាយឈ្នះលើពួកអាម៉ាឡេក។ ស្តេចបានរំដោះជនជាតិអ៊ីស្រាអែលពីកណ្ដាប់ដៃរបស់សត្រូវពួកគេ។
[49]បុត្រារបស់ព្រះបាទសូលមានដូចជា សម្តេចយ៉ូណាថាន សម្តេចយីសវី និងសម្តេចម៉ាលគីស៊ូអា។ បុត្រីរបស់ព្រះអង្គមានឈ្មោះដូចតទៅ បុត្រីច្បងគឺ ព្រះនាងម៉្រាប
និងព្រះនាងមិកាល់ជាប្អូន។[50]ព្រះជាយារបស់ព្រះបាទសូលគឺ ព្រះនាងអហ៊ីណោម ជាកូនស្រីរបស់អហ៊ីម៉ាស់។ មេបញ្ជាការទាហានរបស់ស្តេចគឺ លោកអប៊ីនើរ
ជាកូនប្រុសរបស់លោកនើរ ដែលជាឪពុកមាររបស់ព្រះបាទសូល។[51]លោកគីស ជាឪពុករបស់ព្រះបាទសូល ហើយលោកនែរ ជាឪពុករបស់លោកអប៊ីនើរ
ដែលត្រូវជាកូនប្រុសរបស់លោកអបៀល។
[52]ព្រះបាទសូលបានប្រយុទ្ធយ៉ាងខ្លាំងក្លាជាមួយនឹងពួកភីលីស្ទីនរហូតនៅក្នុងជីវិត។ ពេលព្រះបាទសូលបានឃើញអ្នកណាខ្លាំង ឬក្លាហាន
ស្តេចតែងយកអ្នកនោះមកជាមួយ។

---

1 Samuel 14:1

ឃ្លាភ្ជាប់៖

សម្តេចយ៉ូណាថានចាប់ផ្តើមវាយឆ្មក់ជាលើកទីពីរលើកងទ័ពភីលីស្ទីន។

បានមានរាជឱង្ការទៅអ្នកកាន់គ្រឿងសឹកឲ្យសម្តេចថា

ក្មេងប្រុសជំទង់ម្នាក់ ដែលទទួលខុសត្រូវចំពោះការថែរក្សាគ្រឿងសឹករបស់មេគាត់

ជំរំរបស់ពួកភីលីស្ទីន

នេះជាកន្លែងឈរជើងរបស់កងទ័ពភីលីស្ទីន។

1 Samuel 14:2

គីបៀរ

នេះជាឈ្មោះភ្នំនៅភាគខាងជើងក្រុងយេរូសាឡឹម។

ក្រោមដើមទទឹម

ដើមឈើដែលមានផ្លែរបស់វា មានសំបកក្រាស់ រាងមូល ក្រហម
និងមានគ្រាប់ច្រើន

នៅមីក្រូន

«នៅមីក្រូន» ជាឈ្មោះទីកន្លែងមួយនៅភាគខាងជើងទីក្រុងយេរូសាឡឹម។

ទ័ពប្រហែលជាប្រាំមួយរយនាក់នៅជាមួយស្តេច

"មានទ័ព៦០០ នាក់នៅជាមួយស្តេច"

កូនរបស់លោកអហ៊ីទូប (ជាប្អូនរបស់អ៊ីកាបុដ)

«លោកអហ៊ីទូប» និង «អ៊ីកាបុដ» ជាឈ្មោះរបស់បុរស។

លោកភីនេហាស ដែលជាចៅទួតរបស់លោកអេលី

លោកភីនេហាសជាបូជាចារ្យម្នាក់។ សូមមើលការបកប្រែនៅក្នុង ១:៣ ។

1 Samuel 14:4

មានថ្មរដិរដុបចោតទាំងសងខាង ដែលគេហៅថាបូសេស

«ជម្រាលថ្មចោទ» ជាកំពស់ថ្មដែលមានជម្រាលថ្ម។ ច្រាំងថ្មចោទត្រូវបានគេស្គាល់
និងបានដាក់ឈ្មោះថា«បូសេស»។

មួយទៀតហៅថា សេនេ។

នេះជាឈ្មោះជម្រាលថ្មចោទផ្សេងទៀត។

មីកម៉ាស់

«មីកម៉ាស» ជាទីក្រុងមួយនៅភាគខាងជើងទីក្រុងយេរូសាឡឹម។

កេបា

«កេបា»ជាក្រុងមួយនៅខាងភាគជើងទីក្រុងយេរូសាឡឹម។

1 Samuel 14:6

អ្នកកាន់គ្រឿងសឹករបស់សម្តេច

នេះជាក្មេងប្រុសជំទង់ម្នាក់
ដែលទទួលខុសត្រូវក្នុងការថែរក្សាគ្រឿងសឹករបស់មេគាត់។
សូមមើលការបកប្រែនៅក្នុង ១៤:១។

ពួកមិនកាត់ស្បែក

ពាក្យថោកទាបត្រូវបានប្រើសម្រាប់បុរស ដែលមិនមែនជាជនជាតិជ្វីហ្វ

ធ្វើការជំនួសយើង

«ធ្វើការដើម្បីគាំទ្រយើង» ឬ «ជួយយើង»

ព្រោះគ្មានអ្វីដែលឃាត់ព្រះអម្ចាស់មិនឲ្យជួយ

នេះការថ្លែងអវិជ្ជមានទ្វេរដង អាចថ្លែងនៅក្នុងទម្រង់វិជ្ជាមានវិញ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់អាចជួយសង្គ្រោះបាន»

បើមានមនុស្សតិច ឬច្រើនក្តី

ចំនួនច្រើនបំផុតទាំងនេះក៏រួមបញ្ចូលអ្វីៗទាំងអស់នៅចន្លោះនោះដែរ។
ការបកប្រែផ្សេងទៀត «តាមរយៈចំនួនប្រជាជន»

សូមសម្តេចធ្វើអ្វីតាមចិត្តរបស់សម្តេចចុះ។

ត្រង់នេះ« ចិត្ត» សំដៅទៅលើបំណងប្រាថ្នារបស់សម្តេចយ៉ូណាថាន។
ការបកប្រែផ្សេងទៀត «អ្វីគ្រប់យ៉ាងដែលព្រះអង្គចង់ធ្វើ»

1 Samuel 14:8

មិនឆ្លងទៅរកពួកគេទេ

«នឹងមិនឆ្លងទៅត្រើយម្ខាងទៀត នៃជ្រលងភ្នំដែលជាកន្លែងពួកភីលីស្ទីននៅទេ»។

បានប្រគល់ពួកគេមកក្នុងកណ្ដាប់ដៃរបស់យើងហើយ។

នៅទីនេះ« ដៃ» សំដៅទៅលើអំណាចដើម្បីកម្ចាត់ពួកគេ។ ការបកប្រែផ្សេងទៀត
«នឹងបើកដៃឲ្យយើងយកឈ្នះពួកគេ»

នេះហើយគឺជាទីសម្គាល់សម្រាប់យើង។

«បញ្ជាក់ថា ព្រះអម្ចាស់នឹងគង់នៅជាមួយយើង»

1 Samuel 14:11

បានបង្ហាញខ្លួននៅឯលានដ្ឋានទ័ពរបស់ពួកភីលីស្ទីន។

«អនុញ្ញាតឲ្យទាហានភីលីស្ទីនឃើញពួកគេ»

លានដ្ឋានទ័ព

ជំរំកងទ័ព

កំពុងតែចេញមកពីរន្ធដែលពួកគេបានរត់ពួនហើយ

ពួកភីលីស្ទីនបានបញ្ជាក់ថា ជនជាតិហេប្រឺបានលាក់ខ្លួននៅក្នុងរូងដីដូចជាសត្វ។

generated on Wed Sep 10 16:16:32 2025

យើងនឹងបង្ហាញពួកឯងខ្លះ
នេះជាសំនួនដ៏ប៉ិនប្រសព្វដែលមានន័យថា
«យើងនឹងបង្រៀនអ្នកនូវមេរៀនមួយ»។
បានប្រគល់ពួកគេមកក្នុងដៃរបស់អ៊ីស្រាអែលហើយ។
នៅទីនេះ« ដៃ»សំដៅទៅលើអំណាចដើម្បីកម្ចាត់ពួកភីលីស្ទីន។
ការបកប្រែផ្សេងទៀត «នឹងបើកដៃឲ្យអ៊ីស្រាអែលយកឈ្នះពួកគេបាន»
1 Samuel 14:13
សម្តេចយ៉ូណាថានបានតោងឡើងដោយដៃនឹងជើងរបស់សម្តេច
ព្រះអង្គបានធ្វើបែបនេះ ព្រោះវាចោតខ្លាំងណាស់។ អាចធ្វើឲ្យកាន់តែច្បាស់។
ការបកប្រែផ្សេងទៀត «ដូច្នេះ សម្តេចយ៉ូណាថានបានឡើងដោយប្រើដៃ
និងជើងរបស់ទ្រង់ព្រោះវាចោតពេក»
សម្តេចយ៉ូណាថានបានប្រហារជីវិតរបស់ពួកភីលីស្ទីនទាំងនោះនៅនឹងមុខ
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«សម្តេចយ៉ូណាថានបានសម្លាប់ពួកភីលីស្ទីន»
ហើយអ្នកកាន់គ្រឿងសឹករបស់សម្តេចក៏បានសម្លាប់ពួកនោះខ្លះនៅចំពោះមុខសម្តេចដែរ។
«អ្នកកាន់គ្រឿងសឹករបស់សម្តេចយ៉ូណាថាន បានដើរតាមទ្រង់
ហើយបានសម្លាប់ទាហានភីលីស្ទីនផងដែរ»
1 Samuel 14:15
មានចលាចលនៅជំរំ នៅឯវាល និងក្នុងចំណោមពួកភីលីស្ទីន។
នាមអរូបី «ចលាចល» អាចថ្លែងជាគុណនាម «ភ័យខ្លាចខ្លាំងណាស់» ។
ការបកប្រែផ្សេងទៀត «ទាហានភីលីស្ទីននៅក្នុងជំរំ និងនៅទីវាល
និងប្រជាជនទាំងអស់ដែលនៅជាមួយពួកគេ ត្រឡប់ជាភ័យខ្លាចយ៉ាងខ្លាំង»
អ្នកចម្បាំង
ពួកភីលីស្ទីនដែលបាននឹងកំពុងច្បាំងនៅទីក្រុងនានារបស់អ៊ីស្រាអែល
ផែនដីបានជញ្ជួយ
អាចមានប្រយោជន៍ក្នុងការថ្លែងពីមូលហេតុ។ ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់បណ្តាលឲ្យដីរញ្ជួយ»
1 Samuel 14:16
គីបៀរ
នេះជាក្រុងដែលស្តេចសូលបានកើត។ បកប្រែ « គីបៀរ» ដូចនៅក្នុង ១០:២៦ ។
កំពុងរត់ប្រសាច .. ខ្លះរត់ទៅឯណេះ ខ្លះរត់ទៅឯណោះ។
ឃ្លាទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា និងសង្កត់ធ្ងន់ថា
ទាហានបានរត់ចេញគ្រប់ទិសដៅ។
1 Samuel 14:18
«ចូរយកហឹបរបស់ព្រះជាម្ចាស់មកទីនេះ»
ការបកប្រែពីរបី«អារអេផូដ»នៅទីនេះជំនួសឲ្យ «ហឹបរបស់ព្រះជាម្ចាស់»។
ការរឹករវ
«សំឡេងឡូឡា និងការភាន់ច្រឡំដ៏អស្ចារ្យ»
«សូមដកដៃរបស់លោកចេញ»។
ហាក់ដូចជាឃ្លាគន្លឹះមានន័យថា «បញ្ឈប់នូវអ្វីដែលអ្នកកំពុងធ្វើ»។
ព្រះបាទសូលមិនចង់ឲ្យអ័ហ៊ីយ៉ា
បន្តប្រើហឹបដើម្បីសុំការណែនាំពីព្រះជាម្ចាស់ឡើយ។ ការបកប្រែផ្សេងទៀត
«កុំនាំយករបស់ពិសិដ្ឋដាក់លើទ្រូង នៅពេលនេះ»
1 Samuel 14:20
ទាហានទាំងអស់ដែលនៅជាមួយស្តេច
កងទ័ពអ៊ីស្រាអែលដែលនៅសេសសល់ នៅជាមួយព្រះបាទសូល
ដាវរបស់ពួកទាហានភីលីស្ទីនបានវាយប្រហារគ្នាឯង
ដាវត្រូវបានគេនិយាយដូចជា មនុស្សមានជីវិត។ ការបកប្រែផ្សេងទៀត
«ទាហានភីលីស្ទីនបានវាយគ្នាទៅវិញទៅមក នឹងដាវរបស់ពួកគេ»
1 Samuel 14:22
ពួកទាហានអ៊ីស្រាអែលខ្លះ ដែលបានរត់គេចខ្លួននៅតាមភ្នំ
នេះមិនសំដៅទៅលើការវាយឆ្នក់ទេ។ ទាហានទាំងនេះកំពុងពួន
ព្រោះពួកគេភ័យខ្លាចពួកភីលីស្ទីន។ អាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ទាហានអ៊ីស្រាអែល
ដែលភ័យខ្លាចហើយលាក់ខ្លួននៅលើភ្នំ»
បេតអាវេន
នេះជាទីកន្លែងមួយនៅក្នុងអ៊ីស្រាអែល។ សូមមើលការបកប្រែនៅក្នុង ១៣:៥ ។
1 Samuel 14:24
ដូច្នេះហើយ ពួកទាហាន គ្មាននរណាម្នាក់ហ៊ានភ្លក់អាហារអ្វីទាំងអស់។
គេយល់ថា កងទ័ពគ្មានការបន្ធូរអារម្មណ៍អ្វីឡើយ ក្រោមការស្បថរបស់សូល។
ពួកគេដើរចូលព្រៃ
ទាហានភីលីស្ទីនបានរត់ពួននៅតាមព្រៃ
ហើយទាហានអ៊ីស្រាអែលបានទៅតាមពួកគេនៅទីនោះ។
ទឹកឃ្មុំបានស្រក់ចុះ
នេះជាការបំផ្លើសមួយ ដើម្បីបញ្ជាក់ថាតើមានទឹកឃ្មុំប៉ុន្មាននៅក្នុងព្រៃ។
ការបកប្រែផ្សេងទៀត «មានទឹកឃ្មុំនៅគ្រប់ទីកន្លែង»
គ្មាននរណាហ៊ានយកម្រាមដៃរបស់ខ្លួនប៉ៀកដាក់ចូលមាត់ឡើយ
នៅទីនេះ«ប្រគល់ទៅមាត់របស់គាត់» ជាមេតាណុលដែលមានន័យថាបរិភោគ។
ការបកប្រែផ្សេងទៀត «គ្មាននរណាហ៊ានបរិភោគទេ»
ព្រោះពួកគេខ្លាចសម្បថ។
ប្រជាជនមិនខ្លាចការស្បថនោះទេ ប៉ុន្តែ ចំពោះការដាក់ទណ្ឌកម្ម
ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងការបំពានសម្បថ។ ការបកប្រែផ្សេងទៀត
«ប្រជាជនភ័យខ្លាចអ្វីដែលស្តេចសូលនឹងធ្វើចំពោះពួកគេ បើពួកគេបានស្បថមែន»
1 Samuel 14:27
ព័ត៌មានទូទៅ៖
សម្តេចយ៉ូណាថានបានរៀនអំពីពាក្យសម្បថរបស់ឪពុកលោក។
បានចងពួកពលទាហានដោយសម្បថឡើយ
នៅទីនេះកាតព្វកិច្ចដើម្បីគោរពតាមពាក្យសម្បថ ត្រូវបានគេនិយាយថា
ដូចជាប្រជាជនត្រូវបានគេចងភ្ជាប់ជាមួយខ្សែពួរ។ ការបកប្រែផ្សេងទៀត
«បានបញ្ជាឲ្យប្រជាជនគោរពតាមពាក្យសម្បថរបស់ទ្រង់»
ហើយយកដៃប៉ៀកមកដាក់ក្នុងមាត់របស់សម្តេច
នៅទីនេះ «ដៃប៉ៀកមកដាក់ក្នុងមាត់របស់សម្តេច»ជាពាក្យប្រៀប
ដែលមានន័យថាសោយ។ ការបកប្រែផ្សេងទៀត «ព្រះអង្គបានសោយទឹកឃ្មុំខ្លះ»
ហើយភ្នែករបស់សម្តេចក៏បានភ្លឺស្រស់ថ្លា។
នេះជាឃ្លាមានន័យថា ព្រះអង្គនឹងមានកម្លាំង។ ការបកប្រែផ្សេងទៀត
«ព្រះអង្គបានទទួលកម្លាំងរបស់ទ្រង់ឡើងវិញ»
1 Samuel 14:29
ស្រុក
នេះជាពាក្យប្រៀបធៀប ដែលតំណាងឲ្យប្រជាជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «សម្រាប់អ៊ីស្រាអែល»
ភ្នែករបស់ខ្ញុំបានភ្លឺថ្លា
ឃ្លាមានន័យថា ព្រះអង្គត្រូវមានកម្លាំង។ ការបកប្រែផ្សេងទៀត
«យើងបានទទួលកម្លាំងរបស់យើងឡើងវិញ»
តើវាមិនប្រសើរជាងនេះទេឬអី បើទាហាន ... ពួកយើងរកបាននោះ?
សម្តេចយ៉ូណាថានប្រើសំណួរប្រតិកម្មនេះ
ដើម្បីថ្លែងថាប្រជាជនគួរតែត្រូវបានអនុញ្ញាតឲ្យបរិភោគ។
អាចបញ្ជាក់ជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ជ័យជម្នះរបស់យើងនឹងកាន់តែប្រសើរ
បើប្រជាជនបានបរិភោគដោយសេរីនៅថ្ងៃនេះ
ពីជ័យភណ្ឌដែលពួកគេបានយកពីសត្រូវមក។
ជ័យភណ្ឌ
ពាក្យនេះសំដៅទៅលើរបស់របរ ដែលប្រជាជនបានយកពីសមរភូមិ
គឺពីសត្រូវរបស់ពួកគេ។
ព្រោះពេលនេះអ្នកដែលប្រហារពួកសត្រូវមើលទៅមិនអស្ចារ្យសោះក្នុងចំណោមពួកភីលីស្ទីន។
ដោយសារតែកងទ័ពមិនអាចបរិភោគក្នុងអំឡុងពេលប្រយុទ្ធបាន
កាលសង្គ្រាមចេះតែបន្តទៅមុខទៀត ដូច្នេះពួកគេកាន់តែខ្សោយទៅ។
ដោយហេតុនេះ ពួកគេមិនមានសម្ថភាពសម្លាប់ពួកភីលីស្ទីនច្រើនឡើីយ។
1 Samuel 14:31
ព័ត៌មានទូទៅ៖
ពាក្យរបស់សម្តេចយ៉ូណាថាននាំកងទ័ពធ្វើបាប ប្រឆាំងនឹងព្រះជាម្ចាស់
ក្នុងពេលពួកគេស្រេកឃ្លានយ៉ាងខ្លាំង។
មីកម៉ាស់
នេះជាឈ្មោះទីក្រុង។ សូមមើលការបកប្រែនៅក្នុង ១៣: ១។
អាយ៉ាឡូន
"អាយ៉ាឡូន" ជាកន្លែងមួយនៅសាប់យូឡូនក្នុងអ៊ីស្រាអែល។
ប្រជាជន
សំដៅទៅលើជនជាតិអ៊ីស្រាអែល។
បានបរិភោគទាំងមាននៅឈាមផង។

generated on Wed Sep 10 16:16:32 2025

ពួកគេឃ្លានខ្លាំងណាស់ ពួកគេមិនអាចបង្ហូរឈាមមុនពេលបរិភោគបានទេ។
នេះជាការបំពានក្រឹត្យវិន័យ
ដែលប្រទានមកលោកម៉ូសេសម្រាប់ប្រជាជាតិអ៊ីស្រាអែល។
អាចធ្វើឲ្យកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត
«បានបរិភោគសត្វដោយគ្មានការបង្ហូរឈាមជាមុន តាមតម្រូវការតាមក្រឹត្យវិន័យ»
1 Samuel 14:33
ដោយបរិភោគទាំងនៅឈាម
នេះជាការបំពានច្បាប់
ដែលបានប្រទានមកលោកម៉ូសេសម្រាប់ប្រជាជាតិអ៊ីស្រាអែល។
អាចធ្វើឲ្យកាន់តែច្បាស់។ ការបកប្រែផ្សេងទៀត
«ដោយបរិភោគសាច់ដោយគ្មានការបង្ហូរឈាមជាមុន
តាមតម្រូវការរបស់ក្រឹត្យវិន័យ»
អ្នករាល់គ្នាប្រព្រឹត្តដោយមិនស្មោះត្រង់ទេ។
ព្រះបាទសូលកំពុងចោទប្រកាន់កងទ័ពទាំងមូលរបស់ទ្រង់ ពីការមិនស្មោះត្រង់
ទោះបីជាវាមិនមែនគ្រប់គ្នាក៏ដោយ។
ចូររមៀលផ្នាំងថ្មធំមួយមកឲ្យខ្ញុំឥឡូវនេះ
ផ្នាំងថ្មនឹងអាចសង្កត់សត្វបានហើយ
ធ្វើឲ្យវាកាន់តែងាយស្រួលក្នុងការបង្ហូរឈាមចេញពីពួកវា។
ហើយសម្លាប់នៅទីនេះ រួចបរិភោគចុះ។
អនុញ្ញាតឲ្យព្រះបាទសូលសង្កេតមើល
ប្រសិនបើឈាមត្រូវបានបង្ហូរចេញពីសត្វត្រឹមត្រូវ។
1 Samuel 14:35
ព័ត៌មានទូទៅ៖
ព្រះបាទសូលបានប្រាប់ប្រជាជន ឲ្យយកសត្វរបស់ពួកគេទៅផ្នាំងថ្មធំមួយ
ដើម្បីសម្លាប់និងបរិភោគ។
ព្រះបាទសូលបានសង់អាសនាថ្វាយព្រះអម្ចាស់
វាមិនស្អាតទេថា តើព្រះបាទសូលបានសង់អាសនៈនេះដោយផ្នាំងដុំថ្មធំ
ដែលប្រជាជនបាននាំមកឯទ្រង់ ក្នុង១៤:៣៣។
1 Samuel 14:36
ព័ត៌មានទូទៅ៖
ព្រះបាទសូលស្វែងរកការបន្តប្រយុទ្ធប្រឆាំង នឹងពួកភីលីស្ទីន។
យើងមិនត្រូវទុកឲ្យពួកគេណាម្នាក់នៅមានជីវិតឡើយ។
នេះជាការត្រូវថ្លែងតាមរបៀបអវិជ្ជមាន ដើម្បីបញ្ជាក់ពីការសម្លាប់។
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
"ចូរយើងសម្លាប់ពួកគេទាំងអស់គ្នា"
ចូរប្រព្រឹត្តតាមតែព្រះអង្គយល់ថាល្អចុះ
ព្រះបាទសូលមានការគាំទ្រពីកងទ័ពរបស់ទ្រង់ ដើម្បីបន្តប្រយុទ្ធ។
យើងទូលសួរព្រះជាម្ចាស់សិន
នៅទីនេះការ«ចូលទៅជិតព្រះ»ជាប់ទាក់ទងនឹងការសុំដំបូន្មានពីទ្រង់។
ការបកប្រែផ្សេងទៀត «ចូរយើងសួរព្រះជាម្ចាស់ពីអ្វីដែលយើងគួរធ្វើ»
តើព្រះអង្គប្រគល់ពួកគេមកក្នុងកណ្តាប់ដៃរបស់អ៊ីស្រាអែលឬទេ?
នៅទីនេះ« ដៃ»សំដៅទៅលើអំណាចកម្ចាត់ពួកគេ។ ការបកប្រែផ្សេងទៀត
"បើកដៃយើងឲ្យយកឈ្នះពួកគេ"
ព្រះជាម្ចាស់មិនបានឆ្លើយតបនឹងស្តេចវិញទេ នៅថ្ងៃនោះ។
បញ្ជាក់ថា ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យជួយព្រះបាទសូលទេ។
1 Samuel 14:38
ប្រជាជន
សំដៅទៅលើជនជាតិអ៊ីស្រាអែល។
សូមមើលថាតើមាននរណាបានប្រព្រឹត្តបាបបែបណា
«ស្វែងរកអ្នកដែលបានប្រព្រឹត្តបាប»
ទោះបីលោកយ៉ូណាថាន់ជាបុត្រាទូលបង្គំក្តី បើធ្វើបាប គឺត្រូវតែស្លាប់
ព្រះបាទសូលបានថ្លែង ដូចជាប៉ាន់ស្មានស្ថានភាព ពីព្រោះព្រះអង្គមិនជឿថា
សម្តេចយ៉ូណាថានមានកំហុសទេ។
ប៉ុន្តែ គ្មាននរណាម្នាក់ក្នុងចំណោមពួកទាហានហ៊ានឆ្លើយតបអ្វីទេ។
ប្រជាជននៅស្ងៀម ព្រោះពួកគេភាគច្រើនបានដឹងថា
សម្តេចយ៉ូណាថានបានធ្វើឲ្យខូចពាក្យស្បថ នឹងព្រះបាទសូល។
អាចបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «ទាហានរបស់ទ្រង់បានដឹងថា
នរណាជាអ្នកមានកំហុស ប៉ុន្តែ
គ្មាននរណាម្នាក់បាននិយាយអ្វីជាមួយព្រះបាទសូលទេ»
1 Samuel 14:40
បន្ទាប់មក ព្រះបាទបានមានបន្ទូលទៅទាហានអ៊ីស្រាអែលទាំងអស់ថា
នេះជាការនិយាយបំផ្លើស ព្រោះមានតែទាហានអ៊ីស្រាអែលប៉ុណ្ណោះ
ដែលមានវត្តមាន។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកព្រះអង្គមានបន្ទូលទៅកាន់ទាហានអ៊ីស្រាអែលនៅទីនោះ»
សូមបង្ហាញយើងខ្ញុំផង
ជនជាតិអ៊ីស្រាអែលនៅគ្រានោះបានប្រើថ្មពិសេស ដែលគេហៅថា
យូរីមនិងធូមីមដើម្បីទទួលការណែនាំពីព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត
«បង្ហាញយើងតាមមធ្យោបាយធូមីម»
ពេលនោះគេចាប់ប៉ះចំព្រះបាទសូល និងសម្តេចយ៉ូណាថាន ឯពួកទាហានត្រូវបានរួចខ្លួន។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
ការបកប្រែផ្សេងទៀត«សន្លឹកឆ្នោតបានបង្ហាញថា ទាំងយ៉ូណាថាន
ឬសូលមានទោស ប៉ុន្តែ ប្រជាជនមិនមានកំហុសទេ»
ធូមីម
នេះជាពាក្យខ្ចីពីភាសាដើម។
ក៏ប៉ះចំសម្តេចយ៉ូណាថាន។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកឆ្នោតជាច្រើនបានបង្ហាញថា យ៉ូណាថានមានកំហុស»
1 Samuel 14:43
ព័ត៌មានទូទៅ៖
ការបោះឆ្នោតទើបតែបានបង្ហាញថា សម្តេចយ៉ូណាថានបានប្រព្រឹត្តបាប។
«ចូរប្រាប់បិតា តើបុត្របានធ្វើអ្វី»។
« ប្រាប់ខ្ញុំពីរបៀប ដែលអ្នកបានប្រព្រឹត្តអំពើបាប» ឬ «
ប្រាប់ខ្ញុំពីនូវអ្វីដែលអ្នកបានធ្វើខុស»
ទូលបង្គំនឹងត្រូវស្លាប់
អាចមានន័យថា ១) «ទូលបង្គំសុខចិត្តស្លាប់» ឬ ២)
«តើទូលបង្គំសមនឹងទទួលទោសប្រហារជីវិតដោយសារតែការធ្វើបែបនេះទេ»?
បុត្រត្រូវតែស្លាប់ លោកយ៉ូណាថាន បើមិនធ្វើដូច្នេះទេ សូមព្រះជាម្ចាស់ដាក់ទោសបិតាឲ្យខ្លាំងចុះ!
ព្រះបាទសូលបានសម្បថលើលើជាលើកទីពីរ ក្នុងរយៈពេលតិចជាងមួយថ្ងៃ។
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់អាចសម្លាប់យើង
បើយើងមិនសម្លាប់លោកយ៉ូណាថាន»
1 Samuel 14:45
ព័ត៌មានទូទៅ៖
កងទ័ពហាមឃាត់ និងការពារសម្តេចយ៉ូណាថានពីព្រះបាទសូល។
តើគួរឲ្យសម្តេចយ៉ូណាថានសុគតឬ
ដ្បិតសម្តេចជាអ្នកបានសាងស្នាដៃនៃជ័យជម្នះសម្រាប់អ៊ីស្រាអែល? សូមកុំឲ្យកើតដូច្នេះឡើយ!
ប្រជាជនស្តីបន្ទោសព្រះបាទសូល។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
សម្តេចយ៉ូណាថានទើបតែបានទទួលជ័យជម្នះដ៏អស្ចារ្យនេះសម្រាប់អ៊ីស្រាអែល។
ព្រះអង្គច្បាស់ជាមិនសុគតទេ។
ទូលបង្គំសូមស្បថដោយនូវព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅថា
ប្រជាជនបានបង្ហាញការជឿជាក់របស់ពួកគេថា
ពួកគេនឹងមិនអនុញ្ញាតឲ្យមានអ្វីកើតឡើង ចំពោះសម្តេចយ៉ូណាថានឡើយ។
នឹងគ្មានសក់មួយសរសៃណារបស់សម្តេចជ្រុះដល់ដីឡើង
នេះជាការនិយាយបំផ្លើសបង្ហាញពីរបៀប
ដែលប្រជាជនអ៊ីស្រាអែលអាចការពារសម្តេចយ៉ូណាថាន
និងរក្សាទ្រង់ឲ្យមានសុវត្ថិភាព។ អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។
ការបកប្រែផ្សេងទៀត «យើងនឹងការពារទ្រង់ពីគ្រោះថ្នាក់ណាមួយ»
1 Samuel 14:47
ព័ត៌មានទូទៅ៖
ក្នុងមួយរយៈខ្លី
ព្រះបាទសូលបានបម្រើដោយចិត្តក្លាហានអស្ចារ្យក្នុងការកម្ចាត់សត្រូវរបស់អ៊ីស្រាអែល។
អ៊ីស្រាអែល
នេះជាពាក្យប្រៀបធៀប ដែលតំណាងឲ្យប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ជនជាតិអ៊ីស្រាអែល»
ជនជាតិម៉ូអាប់
សំដៅទៅលើប្រជាជនម៉ូអាប់។ ការបកប្រែផ្សេងទៀត «ជនជាតិម៉ូអាប់»
ជនជាតិអេដុម
សំដៅទៅលើប្រជាជនអេដុម។ ការបកប្រែផ្សេងទៀត «ជនជាតិអេដុម»

generated on Wed Sep 10 16:16:32 2025

សមរភូមិណាដែលស្តេចបានចេញទៅ
«គ្រប់ទីកន្លែង ដែលទ្រង់បានបញ្ជូនកងទ័ពចេញទៅ»
ពីកណ្តាប់ដៃ
ពាក្យថា« ដៃ» តំណាងឲ្យការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ចេញពីការគ្រប់គ្រង»
1 Samuel 14:49
ព័ត៌មានទូទៅ៖
នេះជាព័ត៌មានសាវតាអំពីក្រុមគ្រួសាររបស់លោកសូល។
សម្តេចយីសវី ...ម្តេចម៉ាលគីស៊ូអា
ទាំងនេះជាឈ្មោះរបស់បុរស។
ព្រះនាងម៉្រាប ...ព្រះនាងមិកាល់
ទាំងនេះគឺជាឈ្មោះរបស់ស្ត្រី។
ព្រះនាងអហ៊ីណោម ... អហ៊ីម៉ាស់
ទាំងនេះជាឈ្មោះរបស់ស្ត្រី។
លោកអប៊ីនើរ ... លោកនែរ ... លោកគីស ... លោកអបៀល
ទាំងនេះជាឈ្មោះរបស់បុរស។
1 Samuel 14:52
រហូតនៅក្នុងជីវិត
«ពេញមួយជីវិតរបស់ព្រះបាទសូល»
ស្តេចតែងយកអ្នកនោះមកជាមួយ។
«ទ្រង់បានបង្ខំគាត់ឲ្យចូលរួមជាមួយកងទ័ពរបស់ព្រះអង្គ»

---

15 [1]លោកសាំយូអែលបានទូលទៅព្រះបាទសូលថា៖ «ព្រះអម្ចាស់បានចាត់ខ្ញុំឲ្យមកចាក់ប្រេងតាំងឲ្យព្រះអង្គធ្វើជាស្តេចលើប្រជារាស្ត្រអ៊ីស្រាអែលរបស់ព្រះអង្គ។
ឥឡូវនេះ ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។ [2]នេះជាអ្វីដែលព្រះអម្ចាស់នៃពួកពលបរិវារមានព្រះបន្ទូល
យើងបានកត់ត្រាទុកនូវអ្វីដែលជនជាតិអាម៉ាឡេកបានប្រព្រឹត្តចំពោះអ៊ីស្រាអែល ដែលប្រឆាំងនឹងពួកគេនៅតាមផ្លូវ ខណៈពួកគេកំពុងចាកចេញពីស្រុកអេស៊ីប។ [3]ដូច្នេះ
ចូរចេញទៅឥឡូវនេះ ដើម្បីវាយប្រហារជនជាតិអាម៉ាឡេក ហើយត្រូវបំផ្លាញអ្វីៗទាំងអស់របស់ពួកគេ។ មិនត្រូវទុកចិត្តទុកជីវិតឲ្យពួកគេឡើយ ប៉ុន្តែ
ត្រូវផ្តាច់ជីវិតទាំងប្រុសទាំងស្រី ទាំងក្មេង ទាំងទារក ទាំងគោ ចៀម អូដ្ឋ និងលា»។
[4]ព្រះបាទសូលបានកេនប្រជាជន ហើយរាប់ពួកគេនៅឯថេឡែម ឃើញមានម្ភៃមឺុននាក់ ជាទ័ពថ្មើជើង ហើយមួយមឺុននាក់ទៀតជាទាហានដែលមកពីកុលសម្ព័ន្ធយូដា។
[5]ក្រោយមក ព្រះបាទសូលបានយាងមកឯក្រុងរបស់ពួកអាម៉ាឡេក ហើយរង់ចាំនៅឯជ្រលងភ្នំ។
[6]រួចព្រះបាទសូលបានមានបន្ទូលទៅជនជាតិកែនថា «ចូរថយចេញឲ្យឆ្ងាយពីចំណោមជនជាតិអាម៉ាឡេក ដើម្បីកុំឲ្យវិនាសជាមួយពួកនោះ។
ដោយព្រោះអ្នករាល់គ្នាបានប្រព្រឹត្តដោយសប្បុរសដល់ប្រជាជនអ៊ីស្រាអែល ខណៈពួកគេបានចាកចេញពីស្រុកអេស៊ីប»។ ដូច្នេះ
ពួកកែនក៏បានជន្លាសចេញពីពួកអាម៉ាឡេក។ [7]បន្ទាប់មក ព្រះបាទសូលបានចេញទៅវាយប្រហារជនជាតិអាម៉ាឡេក ចាប់ពីហាវីឡា រហូតដល់សើុរ
ខាងកើតនៃស្រុកអេស៊ីប។
[8]ព្រះអង្គបានចាប់អកាក់ជាស្តេចរបស់ជនជាតិអាម៉ាឡេកទាំងរស់។ ស្តេចបានប្រហារជីវិតពួកគេទាំងអស់ដោយមុខដាវ។ [9]ប៉ុន្តែ ព្រះបាទសូល
និងទាហានបានទុកជីវិតឲ្យស្តេចអកាក់ ហើយទុកចៀម គោ កូនគោបំប៉ន និងកូនចៀមដែលល្អបំផុត។ អ្វីៗដែលល្អ ពួកគេមិនបានបំផ្លាញចោលទេ។ ប៉ុន្តែ
ពួកគេបានបំផ្លាញអ្វីៗទាំងអស់ដែលគ្មានប្រយោជន៍វិញ។
[10]ក្រោយមក ព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកសាំយូអែលថា៖ [11]«យើងស្តាយណាស់ដែលបានតាំងឲ្យលោកសូលធ្វើជាស្តេច
ពីព្រោះលោកសូលមិនបានស្តាប់តាមយើង ហើយមិនប្រព្រឹត្តតាមបញ្ជារបស់យើងទេ»។ លោកសាំយូអែលខឹងយ៉ាងខ្លាំង
លោកបានទូលអង្វរព្រះអម្ចាស់ពេញមួយយប់នោះ។
[12]លោកសាំយូអែលបានក្រោកពីព្រលឹម ដើម្បីទៅជួបព្រះបាទសូលនៅព្រឹកនោះ។ គេបានប្រាប់លោកសាំយូអែលថា៖ «ព្រះបាទសូលបានយាងមកកើមែល
ហើយបានធ្វើស្តូបមួយសម្រាប់ខ្លួននៅទីនោះ រួចបន្តដំណើរត្រឡប់ទៅគីលកាល់វិញ»។ [13]ដឹងដូច្នោះ លោកសាំយូអែលបានមកជួបព្រះបាទសូលហើយទូលស្តេចថា៖
«សូមព្រះអម្ចាស់ប្រទានពរដល់ព្រះអង្គ! ខ្ញុំបានសម្រេចតាមព្រះរាជ្យបញ្ជារបស់ព្រះអម្ចាស់រួចហើយ»។
[14]លោកសាំយូអែលបានមានប្រសាសន៍ថា៖ «ចុះសម្រែកចៀម និងសម្លេងថ្ងូររបស់គោស្ទីបានឮឡើងមកដល់ត្រចៀករបស់ខ្ញុំដូច្នេះ?» [15]ព្រះបាទសូលបានតបថា៖
«គឺសម្លេងសត្វដែលពួកទាហានបានយកមកពីពួកអាម៉ាឡេក។ ដោយពួកគេបានទុកនូវ ចៀម និងគោដែលល្អបំផុត
ដើម្បីធ្វើយញ្ញបូជាដល់ព្រះអម្ចាស់ជាព្រះរបស់លោក។ អ្វីៗក្រៅពីនេះ ពួកយើងបានបំផ្លាញចោលទាំងស្រុងហើយ»។
[16]រួចលោកសាំយូអែលបាននិយាយទៅព្រះបាទសូលថា៖ «ឈប់សិន ខ្ញុំនឹងទូលព្រះអង្គនូវអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលមកទូលបង្គំកាលពីយប់មិញ»។
ព្រះបាទសូលបានតបវិញថា៖ «ចូរនិយាយមកចុះ!»។
[17]លោកសាំយូអែលមានប្រសាសន៍ថា៖ «ទោះបីព្រះអង្គមើលខ្លួនឯងថា តូចតាចក្តី តើមិនមែនព្រះអង្គត្រូវបានតាំងឲ្យដឹកនាំកុលសម្ព័ន្ធអ៊ីុស្រាអែលទេឬអី?
ព្រះអម្ចាស់បានតាំងឲ្យព្រះអង្គធ្វើជាស្តេចលើអ៊ីុស្រាអែល [18]ហើយព្រះអម្ចាស់បានចាត់ឲ្យព្រះអង្គចេញទៅថា ចូរទៅ ហើយប្រហារពួកមនុស្សបាបទាំងស្រុង
គឺពួកអាម៉ាឡេក ត្រូវវាយពួកគេរហូតឲ្យរាបដល់ដី។ [19]ចុះហេតុដូចម្តេចបានជាព្រះករុណាមិនស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់ តែបែរជាប្រមូលយកជយភណ្ឌ
ហើយធ្វើរឿងអាក្រក់នៅចំពោះព្រះភ័ក្ត្ររបស់ព្រះអម្ចាស់ដូច្នេះទៅវិញ?»
[20]ព្រះបាទសូលបានឆ្លើយតបលោកសាំយូអែលវិញថា៖ «ខ្ញុំបានប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ហើយតើ
ព្រមទាំងបានគោរពតាមរបៀបដែលព្រះអម្ចាស់ចាត់ខ្ញុំឲ្យចេញទៅដែរ។ ខ្ញុំបានចាប់ព្រះបាទអកាក់ស្តេចរបស់ពួកអាម៉ាឡេក រួចបានសម្លាប់ផ្តាច់ទាំងស្រុងពួកអាម៉ាឡេក។
[21]គឺទាហាន ដែលបានយកជយភណ្ឌ មានចៀម និងគោ ជារបស់ល្អបំផុតដែលបានញែកទុក ដើម្បីថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ជាព្រះរបស់លោកនៅគីលកាល់»។
[22]លោកសាំយូអែលបានទូលវិញថា៖ «តើព្រះអម្ចាស់គាប់ព្រះទ័យនឹងតង្វាយដុត ព្រមទាំងយញ្ញបូជាជាជាងការស្តាប់បង្គាប់ព្រះអម្ចាស់ឬ? ការគោរពប្រតិបត្តិតាម
នោះប្រសើរជាងយញ្ញបូជា ហើយឯស្តាប់បង្គាប់ក៏ប្រសើរជាងការថ្វាយខ្លាញ់ចៀមឈ្មោលដែរ។ [23]ព្រោះការបះបោរ គឺស្មើនឹងអំពើបាបនៃការរកគ្រូទស្សទាយដែរ
ឯការធ្វើចិត្តរឹងរូស គឺអាក្រក់ ហើយទុច្ចរិតទៀតផង។ ដោយព្រោះព្រះករុណាបានផាត់ព្រះបន្ទូលរបស់ព្រះអម្ចាស់ចោល
នោះព្រះអង្គក៏បដិសេធព្រះករុណាពីការធ្វើស្តេចដែរ»។
[24]ព្រះបាទសូលបានមានរាជឱង្ការមកលោកសាំយូអែលថា៖ «ខ្ញុំបានប្រព្រឹត្តបាបហើយ ព្រោះបានបំពានព្រះបញ្ជារបស់ព្រះអម្ចាស់ និងសំដីរបស់លោក
ដោយខ្ញុំខ្លាចពួកទាហាន ហើយបានធ្វើតាមពួកគេ។ [25]ឥឡូវនេះ សូមអត់ទោសឲ្យខ្ញុំផង ហើយមកជាមួយខ្ញុំវិញ ដូច្នេះ ខ្ញុំអាចថ្វាយបង្គំព្រះអម្ចាស់បាន»។
[26]លោកសាំយូអែលបានទូលព្រះបាទសូលថា៖ «ទូលបង្គំនឹងមិនទៅជាមួយព្រះករុណាវិញទេ ព្រោះព្រះករុណាបានបោះបង់ព្រះបន្ទូលរបស់ព្រះអម្ចាស់ហើយ
ហើយព្រះអម្ចាស់ក៏បានបោះបង់ព្រះករុណាពីការធ្វើជាស្តេចលើជនជាតិអ៊ីុស្រាអែលវិញដែរ»។ [27]កាលលោកសាំយូអែលបានដើរចាកចេញនោះ
ព្រះបាទសូលបានចាប់ជាយរ៉ូបរបស់លោកជាប់ ហើយវាបានរហែកផង។
[28]លោកសាំយូអែលបានទូលស្តេចថា៖ «ព្រះអម្ចាស់បានហែកអាណាចក្រអ៊ីុស្រាអែលពីព្រះករុណានៅថ្ងៃនេះហើយ រួចបានប្រគល់ដល់ម្នាក់ផ្សេងទៀត
ដែលប្រសើរជាងព្រះករុណា។ [29]ហើយព្រះអម្ចាស់ដែលជាកម្លាំងរបស់អ៊ីុស្រាអែល មិនដែលកុហក មិនប្តូរព្រះទ័យដែរ ព្រះអង្គមិនមែនមនុស្ស
ដែលដូរព្រះទ័យចុះឡើងទេ។
[30]ក្រោយមក ព្រះបាទសូលមានរាជឱង្ការថា៖ «ខ្ញុំពិតជាបានប្រព្រឹត្តបាបមែន។ ប៉ុន្តែ សូមទុកមុខឲ្យខ្ញុំនៅចំពោះមុខចាស់ទុំ និងចំពោះប្រជាជនអ៊ីុស្រាអែលផង។
សូមមកជាមួយខ្ញុំសិន ដើម្បីឲ្យខ្ញុំថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់លោកផង»។ [31]ដូច្នេះ លោកសាំយូអែលក៏មកជាមួយព្រះបាទសូល
ហើយស្តេចបានថ្វាយបង្គំព្រះអម្ចាស់ពេលនោះ។

generated on Wed Sep 10 16:16:32 2025

[32]បន្ទាប់មក លោកសាំយូអែលបានមានប្រសាសន៍ថា៖ «ចូរនាំព្រះបាទអកាក់ ជាស្តេចនៃជនជាតិអាម៉ាឡេកឲ្យខ្ញុំទីនេះ»។ គេបាននាំស្តេចអកាក់មកដល់ទាំងជាប់ច្រវ៉ាក់
រួចព្រះបាទអកាក់បានមានរាជឱង្ការថា៖ «ពិតណាស់ ការឈឺចាប់នោះបានកន្លងផុតទៅហើយ»។[33]លោកសាំយូអែលបានតបវិញថា៖
«ដាវរបស់ឯងបានធ្វើឲ្យស្ត្រីៗព្រាត់កូនយ៉ាងណា ម្តាយរបស់ឯងក៏នឹងព្រាត់កូនយ៉ាងនោះដែរ»។
នោះលោកសាំយូអែលបានកាប់ព្រះបាទអកាក់ជាកង់ៗនៅចំពោះព្រះអម្ចាស់នៅឯគីលកាល់នោះទៅ។
[34]លោកសាំយូអែលបានធ្វើដំណើរទៅរ៉ាម៉ា ឯព្រះបាទសូលបានយាងទៅដំណាក់របស់ស្តេចនៅគីបៀវិញ។
[35]លោកសាំយូអែលលែងជួបព្រះបាទសូលរហូតដល់ថ្ងៃដែលលោកលាចាកលោក ដោយលោកបានកាន់ទុកសម្រាប់ព្រះបាទសូល។
ព្រះអម្ចាស់បានសោកស្តាយដោយបានតាំងឲ្យព្រះបាទសូលឲ្យធ្វើជាស្តេចលើអ៊ីុស្រាអែល។

---

1 Samuel 15:1
ព្រះបន្ទូលរបស់ព្រះអម្ចាស់
នេះសំដៅទៅលើព្រះរាជសារ ដែលព្រះអម្ចាស់បានមានបន្ទូល។
ការបកប្រែផ្សេងទៀត «ព្រះរាជសាររបស់ព្រះអម្ចាស់»
ហើយត្រូវបំផ្លាញអ្វីៗទាំងអស់របស់ពួកគេ។ មិនត្រូវទុកចិត្តទុកជីវិតឲ្យពួកគេឡើយ ប៉ុន្តែ
ត្រូវផ្តាច់ជីវិតទាំងប្រុសទាំងស្រី ទាំងក្មេង ទាំងទារក ទាំងគោ ចៀម អូដ្ឋ និងលា។
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ឃ្លាទីពីរផ្តល់នូវព័ត៌មានលម្អិតជាក់លាក់
អំពីអ្វីដែលពួកគេត្រូវបំផ្លាញទាំងស្រុង។
មិនត្រូវទុកចិត្តទុកជីវិតឲ្យពួកគេឡើយ
នេះជាសេចក្តីថ្លែងការណ៍អវិជ្ជមាន បញ្ជាក់ទៅលើភាពពេញលេញនៃការបំផ្លាញ។
1 Samuel 15:4
ប្រជាជន
«កងទ័ព»
រាប់ពួកគេ
«រាប់ពួកគេ»
ថេលែម
ទីក្រុងមួយនៅភាគខាងត្បូងស្រុកយូដា
ឃើញមានម្តែមីុននាក់ ជាទ័ពថ្មើជើង
ហើយមួយមីុននាក់ទៀតជាទាហានដែលមកពីកុលសម្ព័ន្ធយូដា។
«បុរស២០០,០០០ នាក់ដើរដោយថ្មើរជើង និងបុរសយូដា១០,០០០នាក់»
1 Samuel 15:6
ជនជាតិកែន
ក្រុមមនុស្សពនេចរ ដែលតែងតែរួបរួមជាមួយប្រជាជាតិអ៊ីស្រាអែល
ហាវីឡា ...សើុរ
ទាំងនេះជាឈ្មោះទីកន្លែង។
1 Samuel 15:8
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បានប្រាប់ព្រះបាទសូល ឲ្យបំផ្លាញអ្វីៗទាំងអស់ ប៉ុន្តែ
នៅទីនេះព្រះបាទសូលមិនគោរពបទបញ្ជារបស់ព្រះអម្ចាស់ឡើយ។
ព្រះអង្គបានចាប់អកាក់
"ព្រះអង្គបានចាប់យកអកាក់"
ដោយមុខដាវ
ឃ្លាថា«ដោយមុខដាវ»នៅទីនេះជាការពិពណ៌នា
ដែលតំណាងឲ្យកងទ័ពប្រទេសអ៊ីស្រាអែល។
ព្រះបាទសូ...បានទុកជីវិតឲ្យស្តេចអកាក់
ព្រះបាទសូលមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយទុកឲ្យអាកាក់មានជីវិត។
ហើយទុកចៀម
ព្រះបាទសូលមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយរក្សាហ្វូងសត្វល្អៗបំផុត។
1 Samuel 15:10
ព្រះអម្ចាស់បានមានព្រះបន្ទូលមក
នេះជាឃ្លាមួយដែលមានន័យថា ព្រះអម្ចាស់បានមានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានមានព្រះបន្ទូល»
ព្រះអម្ចាស់បានមានព្រះបន្ទូល
នៅទីនេះ«ពាក្យ»ជាតំណាងឲ្យព្រះរាជសាររបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រះរាជសាររបស់ព្រះអម្ចាស់»
យើងស្តាយណាស់
«យើងសោកស្តាយណាស់»
លោកសូលមិនបានស្តាប់តាមយើង
លោកសូលមិនស្តាប់បង្គាប់ព្រះអម្ចាស់ទេ
គឺដូចជាលោកសូលបានងាកចេញពីការដើរតាមព្រះជាម្ចាស់ដែរ។
ការបកប្រែផ្សេងទៀត «គាត់បានឈប់ដើរតាមយើង»
ហើយមិនប្រព្រឹត្តតាមបញ្ជារបស់យើងទេ
មិនបានធ្វើតាមអ្វី ដែលខ្ញុំបានបញ្ជាឲ្យគាត់ធ្វើទេ»។
លោកសូលត្រូវបំផ្លាញអ្វីៗទាំងអស់ និងមនុស្សគ្រប់គ្នា។
ព្រះជាម្ចាស់បានដាក់បម្រាមលើជនជាតិអាម៉ាឡេក។ ប៉ុន្តែ
លោកសូលបានទុកសត្វខ្លះឲ្យមានជីវិត។
លោកសាំយូអែលខឹងយ៉ាងខ្លាំង
អាចមានន័យថា ១) លោកសាំយូអែលខឹងនឹងលោកសូលចំពោះការមិនស្តាប់បង្គាប់
ឬ ២) សាំយូអែលត្រូវបានរំខាន។
1 Samuel 15:12
គេបានប្រាប់លោកសាំយូអែលថា
«មានគេប្រាប់លោកសាំយូអែល»
ហើយបានធ្វើស្តូបមួយសម្រាប់ខ្លួន
លោកសូលមានអំនួត។
ត្រឡប់ទៅគីលកាល់វិញ
គីលកាល់មានកម្ពស់ទាបជាងខាមេល។
ខ្ញុំបានសម្រេចតាមព្រះរាជ្យបញ្ជារបស់ព្រះអម្ចាស់រួចហើយ។
មិនច្បាស់ថា ក្រែងលោកលោកសូលយល់ថា
លោកមិនបានគោរពតាមបញ្ជារបស់ព្រះជាម្ចាស់ទាំងស្រុង
ដើម្បីបំផ្លាញជនជាតិអាម៉ាលេក។
1 Samuel 15:14
ព័ត៌មានទូទៅ៖
លោកសាំយូអែលមានចម្ងល់ថា
ហេតុអ្វីបានជាលោកសូលមិនបានបំផ្លាញជនជាតិអាម៉ាលេកទាំងស្រុង។
ចុះសម្រែកចៀម ...សម្លេងថ្ងូររបស់គោ
ទាំងនេះជាសំឡេងដែលសត្វទាំងនេះបញ្ចេញមក។
ភាសារបស់អ្នកអាចមានពាក្យផ្សេងពីនេះ។
ដល់ត្រចៀករបស់ខ្ញុំ ... បានឮ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
នៅទីនេះ«ដល់ត្រចៀករបស់ខ្ញុំ»សំដៅទៅលើការស្តាប់ឮ។
គឺសម្លេងសត្វដែលពួកទាហានបានយក... ដោយពួកគេបាន
ពាក្យ«ពួកគេ»និងឃ្លាថា«ប្រជាជន»នៅទីនេះទាំងពីរតំណាងឲ្យកងទ័ពរបស់លោកសូល។
លោកសូលបានស្តីបន្ទោសប្រជាជនជាជាងបន្ទោសខ្លួនឯង។
ដើម្បីធ្វើយញ្ញបូជាដល់ព្រះអម្ចាស់ជាព្រះរបស់លោក។
លោកសូលកំពុងតែប្រកែកថា សត្វសម្រាប់ថ្វាយយញ្ញបូជា
នឹងត្រូវលើកលែងចំពោះបញ្ជារបស់ព្រះអម្ចាស់ដែលចង់បំផ្លាញអ្វីៗទាំងអស់។
ព្រះអម្ចាស់ជាព្រះរបស់លោក
លោកសូលនៅទីនេះមិនបានពិពណ៌នា អំពីព្រះជាម្ចាស់របស់លោកសាំយូអែលថា
ជាព្រះជាម្ចាស់ផ្ទាល់លោកទេ។
1 Samuel 15:17
មើលខ្លួនឯងថា តូចតាចក្តី
នៅទីនេះ« មើលខ្លួន» សំដៅទៅលើគំនិតរបស់គាត់ផ្អែកលើអ្វីៗ
ដែលគាត់បានឃើញ។ ការបកប្រែផ្សេងទៀត «តាមគំនិតផ្ទាល់របស់អ្នក»
តើមិនមែនព្រះអង្គត្រូវបានតាំងឲ្យដឹកនាំកុលសម្ព័ន្ធអ៊ីុស្រាអែលទេឬអី?
លោកសាំយូអែលប្រើសំណួរនេះ ដើម្បីរំលឹកស្តេចសូលពីអ្វីៗ
ដែលព្រះជាម្ចាស់ប្រទានដល់គាត់។ សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានតែងតាំងអ្នកឲ្យធ្វើជាមេដឹកនាំកុលសម្ព័ន្ធនានា
របស់ជនជាតិអ៊ីស្រាអែល! »
ចុះហេតុដូចម្តេចបានជាព្រះករុណាមិនស្តាប់តាម ... ព្រះអម្ចាស់?

generated on Wed Sep 10 16:16:32 2025

លោកសាំយូអែលសួរសំណួរនេះ ដើម្បីស្តីបន្ទោសលោកសូល
ព្រោះមិនស្តាប់បង្គាប់ព្រះអម្ចាស់។ សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «អ្នកគួរតែស្តាប់បង្គាប់... ឱព្រះអម្ចាស់! »
ព្រះសូរសៀងរបស់ព្រះអម្ចាស់
នៅទីនេះសំឡេងសំដៅទៅលើបទបញ្ជា ដែលព្រះអម្ចាស់បានមានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «អ្វីៗដែលព្រះអម្ចាស់បញ្ជា»
តែបែរជាប្រមូលយកជ័យភណ្ឌ
លោកសាំយូអែលកំពុងចោទប្រកាន់លោកសូល ព្រោះមិនស្តាប់បង្គាប់ដោយផ្ទាល់។
ព្រះអម្ចាស់បានបញ្ជាឲ្យលោកសូលបំផ្លាញអ្វីៗទាំងអស់
ដែលជាកម្មសិទ្ធិរបស់ជនជាតិអាម៉ាឡេក
ហើយមិនត្រូវនាំយករបស់អ្វីក៏ដោយចូលក្នុងជំរំវិញឡើយ។
ខ្លួន
«ជ័យភណ្ឌ»ឬ«ទ្រព្យសម្បត្តិដែលអ្នកបានយកពីសត្រូវ»
ហើយធ្វើរឿងអាក្រក់នៅចំពោះព្រះភ័ក្ត្ររបស់ព្រះអម្ចាស់ដូច្នេះទៅវិញ
នៅទីនេះ«មើលឃើញ»សំដៅទៅលើគំនិត ឬយោបល់របស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «អ្វីៗដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»
1 Samuel 15:20
ខ្ញុំបានប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអម្ចាស់
នេះជាសេចក្តីថ្លែងការណ៍ ដែលអាចយល់បាន។ វាមិនច្បាស់ទេ
ថាតើលោកសូលគិតថាពិត ឬថាគាត់គ្រាន់តែរកលេសប្រព្រឹត្តអំពើបាប។
ព្រះបន្ទូលរបស់ព្រះអម្ចាស់
នៅទីនេះ«សំឡេង»សំដៅទៅលើបទបញ្ជា ដែលព្រះអម្ចាស់បានមានព្រះបន្ទូល។
ការបកប្រែផ្សេងទៀត «អ្វីដែលព្រះអម្ចាស់បានបញ្ជា»
ព្រះបាទអកាក់
ជាឈ្មោះស្តេចជាតិអាម៉ាលេក។
គឺទាហាន ដែលបានយក
នេះជាការបង្ហាញ ដើម្បីផ្លាស់ប្តូរការស្តីបន្ទោសទៅប្រជាជនវិញ។
ដែលបានញែកទុក
«សត្វដែលព្រះអម្ចាស់បានបញ្ជាពួកគេឲ្យបំផ្លាញចោល»
គីលកាល់
នេះជាឈ្មោះទីកន្លែងមួយ។
1 Samuel 15:22
តើព្រះអម្ចាស់គាប់ព្រះទ័យនឹងតង្វាយដុត ព្រមទាំងយញ្ញបូជាជាជាងការស្តាប់បង្គាប់ព្រះអម្ចាស់ឬ?
លោកសាំយូអែលសួរសំណួរនេះ ដើម្បីបញ្ជាក់ថាការស្តាប់បង្គាប់
គឺសំខាន់ជាងការថ្វាយយញ្ញបូជាទៅទៀត។ អាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់មិនសព្វព្រះហឫទ័យនឹងតង្វាយដុតនិងយញ្ញបូជាច្រើនដូចការស្តាប់បង្គាប់[illegible]
»
ការស្តាប់បង្គាប់ព្រះអម្ចាស់
នៅទីនេះ«ការស្តាប់បង្គាប់»សំដៅទៅលើបទបញ្ជា
ដែលព្រះអម្ចាស់បានមានបន្ទូល។ ការបកប្រែផ្សេងទៀត
«អ្វីៗដែលព្រះអម្ចាស់បានបញ្ជា»
ការគោរពប្រតិបត្តិតាម នោះប្រសើរជាងយញ្ញបូជា
ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកសូល
ស្តាប់បង្គាប់ទាំងស្រុងក្នុងការបំផ្លាញជនជាតិអាម៉ាលេក។
គ្មានអ្វីនៅក្នុងស្រុកនេះសមសម្រាប់ការថ្វាយការយញ្ញបូជាទេ។
ប្រសើរជាងការថ្វាយខ្លាញ់ចៀមឈ្មោលដែរ។
«ប្រសើរជាងថ្វាយខ្លាញ់ចៀមឈ្មោលជាតង្វាយដុត»
ការបះបោរ គឺស្មើនឹងអំពើបាបនៃការគ្រូទស្សទាយដែរ
នាមអរូបីទាំងនេះអាចថ្លែងជាសកម្មភាព។ ការបកប្រែផ្សេងទៀត
«ការបះបោរគឺជាអំពើបាប ដូចជាធ្វើអំពើអាបធ្មប់ដែរ»
ការធ្វើចិត្តរឹងរូស គឺអាក្រក់ ហើយទុច្ចរិតទៀតផង។
នាមអរូបីទាំងនេះអាចថ្លែងជាសកម្មភាព។ ការបកប្រែផ្សេងទៀត «
រឹងការចចេសគឺជាអំពើបាប ដូចជាគោរពថ្វាយរូបព្រះដែរ»
បានផាត់ព្រះបន្ទូលរបស់ព្រះអម្ចាស់ចោល
នៅទីនេះ« ព្រះបន្ទូល» សំដៅទៅលើបទបញ្ជា ដែលព្រះអម្ចាស់បានមានបន្ទូល។
ការបកប្រែផ្សេងទៀត «បដិសេធមិនធ្វើអ្វី ដែលព្រះអម្ចាស់បានបញ្ជាឡើយ»
ព្រះអង្គក៏បដិសេធព្រះករុណាពីការធ្វើស្តេចដែរ
«សម្រេចចិត្តថា ព្រះករុណានឹងលែងធ្វើជាស្តេចទៀតហើយ»
1 Samuel 15:24
បានបំពានព្រះបញ្ជារបស់ព្រះអម្ចាស់
នេះជាឃ្លាដែលមានន័យថា ព្រះបាទមិនបានគោរពតាមបទបញ្ជា។
ការបកប្រែផ្សេងទៀត «យើងមិនបានគោរពតាមអ្វី ដែលព្រះអម្ចាស់បានបញ្ជាទេ»
ដោយខ្ញុំខ្លាចពួកទាហាន
នេះជាមូលហេតុ
ដែលព្រះបាទសូលផ្តល់ឲ្យចំពោះការមិនស្តាប់បង្គាប់តាមព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «ពីព្រោះខ្ញុំខ្លាចទាហាន»
ហើយបានធ្វើតាមពួកគេ។
នៅទីនេះ« ធ្វើតាម»
សំដៅទៅលើអ្វីដែលពួកទាហានបានស្នើសុំឲ្យព្រះបាទសូលធ្វើ។
ការបកប្រែផ្សេងទៀត «ធ្វើអ្វីដែលពួកគេបានស្នើសុំ»
ហើយមកជាមួយខ្ញុំវិញ
លោកសូលនិងលោកសាំយូអែលកំពុងតែនិយាយគ្នា ដាច់ដោយឡែកពីមហាជន។
1 Samuel 15:26
ព្រោះព្រះករុណាបានបោះបង់ព្រះបន្ទូលរបស់ព្រះអម្ចាស់ហើយ
លោកសាំយូអែលបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះបាទសូលបានយល់ថា
ព្រះបាទសូលបានកំពុងមិនស្តាប់បង្គាប់ព្រះជាម្ចាស់។
ពេលនោះគាត់បានទុកសត្វល្អៗបំផុត ហើយមិនបានសម្លាប់អកាក់។
បោះបង់ព្រះបន្ទូលរបស់ព្រះអម្ចាស់ហើយ
នៅទីនេះ«ព្រះបន្ទូល» សំដៅទៅលើបទបញ្ជាដែលព្រះអម្ចាស់បានមានបន្ទូល។
ព្រះបាទសូលបានចាប់ជាយរ៉ូបរបស់លោកជាប់
«បដិសេធមិនធ្វើអ្វីដែលព្រះអម្ចាស់បានបញ្ជាឡើយ»
ព្រះបាទសូលបានចាប់ជាយរ៉ូបរបស់លោកជាប់
ព្រះបាទសូលបានធ្វើដូច្នេះ ដើម្បីបញ្ឈប់លោកសាំយូអែលមិនឲ្យចាកចេញ។
អាចបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ព្រះបាទសូលបានព្យាយាមបញ្ឈប់គាត់
ដោយចាប់យករ៉ូបរបស់លោកសាំយូអែល»
ជាយរ៉ូបរបស់លោកជាប់
ជាយក្រណាត់រ៉ូបរបស់លោក ឬជាយរ៉ូបរបស់ទ្រង់
1 Samuel 15:28
ព្រះអម្ចាស់បានហែកអាណាចក្រអ៊ីុស្រាអែល
នេះសំដៅទៅលើពេល ដែលព្រះបាទសូលហែករ៉ូបរបស់លោកសាំយូអែលនៅ
១៥:២៦។ នេះអាចធ្វើឲ្យច្បាស់។ការបកប្រែផ្សេងទៀត
«ដូចជាព្រះករុណាហែកអាវខ្ញុំដែរព្រះអម្ចាស់បានហែកអាណាចក្រអ៊ីស្រាអែល»
រួចបានប្រគល់ដល់ម្នាក់ផ្សេងទៀត ដែលប្រសើរជាងព្រះករុណា។
[illegible]ជាម្ចាស់[illegible]ប្រកាសថា
ដែលជាកម្លាំងរបស់អ៊ីុស្រាអែល
ឃ្លានេះសំដៅទៅលើព្រះអម្ចាស់ ដែលប្រទានកម្លាំងដល់ជនជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ជាកម្លាំងរបស់ជនជាតិអ៊ីស្រាអែល»
មិនដែលកុហក មិនប្តូរព្រះទ័យដែរ
អាចថ្លែងជាអវិជ្ជមានដើម្បីបញ្ជាក់ថា ព្រះជាម្ចាស់ទូលប្រាប់សេចក្តីពិត។
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«តែងតែនិយាយសេចក្តីពិតហើយធ្វើអ្វីដែលព្រះអង្គមានបន្ទូល»
ព្រះទ័យ
សំដៅទៅលើគំនិត និងការសម្រេចចិត្តរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអង្គបានសម្រេចព្រះទ័យធ្វើ»
ព្រះអង្គមិនមែនមនុស្ស ដែលដូរព្រះទ័យចុះឡើងទេ។
អាចថ្លែងជាអវិជ្ជមានដើម្បីបញ្ជាក់ថា ព្រះជាម្ចាស់គួរឱ្យទុកចិត្ត។
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «ព្រះអង្គគឺជាព្រះជាម្ចាស់
ហើយនឹងធ្វើអ្វីដែលព្រះអង្គមានបន្ទូល គឺព្រះអង្គនឹងធ្វើ»
1 Samuel 15:30
សូមទុកមុខឲ្យខ្ញុំនៅចំពោះមុខចាស់ទុំ
ព្រះបាទសូលប្រហែលបានកំពុងតែចាប់អារម្មណ៍នឹងការទទួលកិត្តិយសពីប្រជាជន
ជាជាងការថ្វាយបង្គំព្រះជាម្ចាស់។
ចំពោះមុខចាស់ទុំ និងចំពោះប្រជាជនអ៊ីុស្រាអែលផង។
នៅទីនេះ«អ៊ីស្រាអែល» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«នៅចំពោះមុខប្រជាជនអ៊ីស្រាអែល និងពួកចាស់ទុំដែលដឹកនាំពួកគេ»
សូមមកជាមួយខ្ញុំសិន

generated on Wed Sep 10 16:16:32 2025

«ត្រឡប់ក្រោយមកវិញជាមួយខ្ញុំ» ឬ «ត្រឡប់មកវិញជាមួយខ្ញុំ»
ដូច្នេះ លោកសាំយូអែលក៏មកជាមួយព្រះបាទសូល
នេះបញ្ជាក់ថា
លោកសាំយូអែលផ្លាស់ប្តូរគំនិតរបស់គាត់ហើយថាពួកគេបានទៅកន្លែងប្រជាជននៅជាមួយសាំយូអែលជាអ្នកដែលបានបំពេញកិច្ចការ
ការបកប្រែផ្សេងទៀត «ដូច្នេះ នៅទីបំផុតលោកសាំយូអែលបានយល់ព្រមធ្វើដូច្នេះ ដែលព្រះអម្ចាស់បានបញ្ជាឲ្យស្តេចសូលធ្វើ។ ការបកប្រែផ្សេងទៀត
ហើយពួកគេបានត្រឡប់ទៅកន្លែង ដែលប្រជាជននៅវិញ»។ «បន្ទាប់មកសាំយូអែលបានកាត់អកាក់ជាបំណែកដោយដាវគាត់»
1 Samuel 15:32 1 Samuel 15:34
គេបាននាំស្តេចអកាក់មកដល់ទាំងជាប់ច្រវ៉ាក់ រួចព្រះបាទអកាក់បានមានរាជឱង្ការថា រ៉ាម៉ា ... គីបៀរ
«គេបាននាំស្តេចអកាក់មកដោយចងច្រវាក់ហើយនិងស្តេចអកាក់បានមានរាជឱង្ការថា» ទាំងនេះជាឈ្មោះទីកន្លែង។ (សូមមើល)
«ពិតណាស់ ការឈឺចាប់នោះបានកន្លងផុតទៅហើយ»។ យាងទៅដំណាក់របស់ស្តេចនៅគីបៀរវិញ។
ឃ្លានេះមានន័យ ថាស្តេចអកាក់លែងគិតថា គាត់នឹងត្រូវគេសម្លាប់។ នៅគីបៀរខ្ពស់ជាងគីលកាល់ ដែលលោកសូលនិងសាំយូអែលកំពុងតែនិយាយគ្នា។
ការបកប្រែផ្សេងទៀត «ប្រាកដណាស់ខ្ញុំលែងមានគ្រោះថ្នាក់ ឬស្លាប់ហើយ» លោកសាំយូអែលលែងជួបព្រះបាទសូលរហូតដល់ថ្ងៃដែលលោកលាចាកលោក
«ដាវរបស់ឯងបានធ្វើឲ្យស្រីៗព្រាត់កូនយ៉ាងណា ម្តាយរបស់ឯងក៏នឹងព្រាត់កូនយ៉ាងនោះដែរ»។ នេះជាសេចក្តីថ្លែងការណ៍មានលក្ខណៈច្បាស់លាស់
ឃ្លាទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា ហើយមានទម្រង់ជាកំណាព្យ។ ហើយគួរតែត្រូវបានបកប្រែដោយយកចិត្តទុកដាក់។
ការបកប្រែផ្សេងទៀត «ដោយសារអ្នកបានសម្លាប់មនុស្ស លោកសាំយូអែលបានទទួលមរណភាពនៅចំពោះមុខព្រះបាទសូល
អ្នកក៏នឹងត្រូវគេសម្លាប់ដែរ» ហើយមិនបានជួបព្រះបាទសូលម្តងទៀតទេ ពេលលោកនៅរស់នៅឡើយ។
ធ្វើឲ្យស្រីៗព្រាត់កូនយ៉ាងណា ម្តាយរបស់ឯងក៏នឹងព្រាត់កូនយ៉ាងនោះដែរ ទោះយ៉ាងណាលោកសាំយូអែលបានបង្ហាញខ្លួនដល់ព្រះបាទសូល នៅ ២៨:១១
នេះជារបៀបគួរសមសំដៅទៅលើការសម្លាប់មនុស្ស។ ការបកប្រែផ្សេងទៀត ក្រោយមកលោកសាំយូអែលបានស្លាប់។

---

16 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកសាំយូអែលថា៖ «តើអ្នកនៅកាន់ទុកសម្រាប់ព្រះបាទសូល ដែលយើងមិនឲ្យធ្វើជាស្តេចលើអ៊ីស្រាអែលដល់កាលណាទៀត?
ចូរបំពេញប្រេងក្នុងស្នែងរបស់អ្នកហើយចេញទៅ។ យើងនឹងចាត់អ្នកឲ្យទៅផ្ទះលោកអ៊ីសាយនៅភូមិបេថ្លេហិម ដ្បិត
យើងបានជ្រើសរើសម្នាក់ឲ្យធ្វើជាស្តេចចេញពីចំណោមកូនប្រុសៗរបស់គាត់»។
[2]លោកសាំយូអែលបានទូលវិញថា៖ «តើឲ្យទូលបង្គំទៅយ៉ាងដូចម្តេច? បើព្រះបាទសូលជ្រាបពីរឿងនេះ នោះស្តេចមុខជាប្រហារជីវិតទូលបង្គំមិនខាន»។
ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ចូរយកគោស្ទាវមួយក្បាលទៅជាមួយអ្នកហើយនិយាយថា៖ ខ្ញុំមកនេះ ដើម្បីថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់។
[3]ចូរហៅលោកអ៊ីសាយឲ្យថ្វាយយញ្ញបូជា នោះយើងនឹងបង្ហាញអ្នកថាត្រូវធ្វើអ្វីទៀត។ យើងនឹងប្រាប់ដល់អ្នកត្រូវចាក់ប្រេងតាំងលើអ្នកណាដែលយើងនឹងប្រាប់»។
[4]លោកសាំយូអែលបានធ្វើតាមព្រះអម្ចាស់បង្គាប់ ហើយក៏បានចេញទៅភូមិបេថ្លេហិម។ ចាស់ទុំនៅក្រុងនោះមានការភិតភ័យបានចេញមកជួបលោក ទាំងនិយាយថា៖
«តើអ្នកមកនេះក្នុងបំណងសន្តិភាពឬ?»[5]លោកបានតបវិញថា៖ «មែនហើយ ដោយសន្តិភាពទេ ខ្ញុំមកនេះដើម្បីថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់»។
សូមរៀបចំខ្លួនរួចមកជាមួយខ្ញុំដើម្បីថ្វាយយញ្ញបូជា។ រួចមកលោកបានញែកលោកអ៊ីសាយម្តាង និងកូនប្រុសៗរបស់លោកម្តាង ដោយអញ្ជើញពួកគេថ្វាយយញ្ញបូជា។
[6]ពេលកូនៗរបស់គាត់បានមកដល់ លោកបានសម្លឹងទៅឯលោកអេលាប ដោយនិយាយក្នុងចិត្តថា មុខជាម្នាក់នេះហើយដែលព្រះអម្ចាស់បានតាំងឡើងនៅចំពោះព្រះអង្គ។
[7]ប៉ុន្តែ ព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកសាំយូអែលថា៖ «កុំមើលតែរូបរាងខាងក្រៅ ឬកម្ពស់ ពីព្រោះយើងមិនបានរើសម្នាក់នេះទេ។ ដ្បិត
ព្រះអម្ចាស់មិនទតមើលដូចមនុស្សសង្កេតទេ ដោយសារមនុស្សមើលតែសំបកក្រៅប៉ុណ្ណោះ ប៉ុន្តែ ព្រះអម្ចាស់ទតមើលដួងចិត្ត»។
[8]បន្ទាប់មក លោកអ៊ីសាយបានហៅលោកអប៊ីណាដាប់ ហើយឲ្យដើរចូលមកចំពោះលោកសាំយូអែល។ រួចលោកសាំយូអែលបានមានប្រសាសន៍ថា៖
«ព្រះអម្ចាស់ក៏ពុំបានរើសម្នាក់នេះដែរ»។[9]លោកអ៊ីសាយក៏បានឲ្យលោកសាម៉ាដើរកាត់ម្តង ប៉ុន្តែ លោកសាំយូអែលបានមានប្រសាសន៍ថា៖
«ម្នាក់នេះក៏ព្រះអម្ចាស់មិនបានជ្រើសរើសដែរ»។[10]លោកអ៊ីសាយឲ្យកូនប្រុសទាំងប្រាំពីរនាក់ដើរទៅមុខលោកសាំយូអែល។
លោកសាំយូអែលបានថ្លែងទៅលោកអ៊ីសាយថា៖ «ព្រះអម្ចាស់ពុំរើសអ្នកទាំងអស់នេះទេ»។
[11]បន្ទាប់មក លោកសាំយូអែលបានសួរលោកអ៊ីសាយថា៖ «កូនប្រុសៗរបស់លោកនៅទីនេះអស់ហើយមែនទេ?» លោកបានតបថា៖ «នៅមានកូនពៅម្នាក់ទៀត ប៉ុន្តែ
វាកំពុងឃ្វាលចៀម»។ លោកសាំយូអែលបានប្រាប់ថា៖ «ចាត់គេឲ្យទៅហៅវាមក បើមិនដូច្នោះទេ យើងនឹងមិនអង្គុយនៅទីនេះទេ»។
[12]លោកអ៊ីសាយបានចាត់ឲ្យទៅហៅកូននោះមក។ កូននោះមានរូបរាងសង្ហា មានថ្ពាល់ក្រហម និងភ្នែកយ៉ាងស្អាតផង។ ព្រះអម្ចាស់បានមានព្រះបន្ទូលថា៖
«ចូរទៅចាក់ប្រេងតាំងចុះ គឺម្នាក់នេះហើយ»។
[13]ក្រោយមក លោកសាំយូអែលបានយកស្នែងដែលដាក់ប្រេងនោះមក ហើយបានចាក់ប្រេងតាំងម្នាក់នោះនៅកណ្តាលពួកបងៗ។
ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានយាងមកសណ្ឋិតពីលើដាវីឌចាប់តាំងពីថ្ងៃនោះមក រួចលោកសាំយូអែលបានក្រោកឡើង និងបន្តដំណើរទៅឯរ៉ាម៉ាវិញ។
[14]កាលនោះ ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានយាងចេញពីព្រះបាទសូលហើយ ហើយមានវិញ្ញាណពីព្រះអម្ចាស់បានមកធ្វើឲ្យស្តេចច្របូកច្របល់វិញ។
[15]បាវបម្រើរបស់ព្រះបាទសូលបានទូលទ្រង់ថា៖ «មើល គឺវិញ្ញាណដែលមកពីព្រះអម្ចាស់បានមកដើម្បីបង្កបញ្ហាដល់ព្រះអង្គហើយ។
[16]សូមទ្រង់ចាត់បាវរបស់ទ្រង់ឲ្យទៅស្វែងរកអ្នកណាម្នាក់ដែលជំនាញលេងពិនថ្វាយព្រះអង្គ។ នៅពេលវិញ្ញាណនោះមកសណ្ឋិតលើព្រះអង្គ នោះត្រូវឲ្យអ្នកនោះលេងពិន
រួចព្រះអង្គនឹងបានប្រសើរវិញ»។
[17]ព្រះបាទសូលបានចាត់អ្នកបម្រើថា៖ «ចូរស្វែងរកបុរសម្នាក់ដែលអាចលេងភ្លេងបានយ៉ាងល្អ ហើយយកគេមកឲ្យយើង»។[18]រួចក៏មានយុវជនម្នាក់បានទូលស្តេចថា៖
«ខ្ញុំធ្លាប់ឃើញកូនប្រុសរបស់លោកអ៊ីសាយ អ្នកភូមិបេថ្លេហិមម្នាក់ គឺជាអ្នកជំនាញលេង ហើយ ជាក្មេងដែលក្លាហាន រឹងមាំ ជាអ្នកសង្គ្រាម ពូកែនិយាយ
រួចសង្ហាថែមទៀត ហើយព្រះអម្ចាស់ក៏គង់ជាមួយយុវជននោះដែរ»។[19]រួចព្រះបាទសូលក៏បានចាត់គេឲ្យទៅឯលោកអ៊ីសាយ និយាយថា៖ «ចូរប្រគល់កូនប្រុសរបស់លោក
គឺដាវីឌ ដែលនៅឃ្វាលចៀមនោះមកយើង»។
[20]លោកអ៊ីសាយបានយកលាមួយមក ហើយបានដាក់នំប៉័ងផង មានទាំងស្រាទំពាំងបាយជូរ និងកូនពពែមួយ រួចឲ្យវាទៅជាមួយកូនប្រុសរបស់លោក គឺដាវីឌ
ទៅឯព្រះបាទសូល។[21]បន្ទាប់មក ដាវីឌបានមកឯព្រះបាទសូល ហើយនៅបម្រើស្តេច។ ព្រះបាទសូលពេញចិត្តនឹងដាវីឌយ៉ាងខ្លាំង
ថែមទាំងបានតាំងឲ្យដាវីឌធ្វើជាអ្នកកាន់គ្រឿងសស្ត្រាវុធឲ្យស្តេចទៀតផង។
[22]ព្រះបាទសូលបានចាត់គេឲ្យទៅប្រាប់លោកអ៊ីសាយថា៖ «សូមទុកឲ្យដាវីឌនៅជាមួយយើងចុះ ព្រោះយើងគាប់ព្រះទ័យនឹងដាវីឌណាស់»។
[23]រាល់ពេលដែលវិញ្ញាណដែលមកពីព្រះជាម្ចាស់មកសណ្ឋិតលើព្រះបាទសូល ដាវីឌបានយកពិនមកលេង រួចព្រះបាទសូលបានស្រស់ស្រាយ និងប្រសើរឡើងវិញ
ហើយវិញ្ញាណបានចាកចេញពីស្តេចទៅ។

---

1 Samuel 16:1
តើអ្នកនៅកាន់ទុកសម្រាប់ព្រះបាទសូល

ដែលយើងមិនឲ្យធ្វើជាស្តេចលើអ៊ីស្រាអែលដល់កាលណាទៀត?
សំណួរបែបសំនួនវោហានេះ ជាការស្តីបន្ទោសពីព្រះជាម្ចាស់

generated on Wed Sep 10 16:16:32 2025

ហើយអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ឈប់កាន់ទុក្ខព្រះបាទសូល
ដែលយើងបានបដិសេធមិនឲ្យធ្វើជាស្តេចលើអ៊ីស្រាអែល» ។
ចូរបំពេញប្រេងក្នុងស្នែងរបស់អ្នក
ពាក្យថា« ស្នែង» ពេលខ្លះត្រូវបានគេប្រើសំដៅទៅលើ«ដប»
ដែលមានរាងដូចស្នែង ហើយត្រូវបានប្រើសម្រាប់ដាក់ទឹក ឬប្រេង។
ដបដាក់ប្រេងត្រូវបានប្រើសម្រាប់ចាក់ប្រេងជ្រើសតាំងស្តេច។
1 Samuel 16:2
តើឲ្យទូលបង្គំទៅយ៉ាងដូចម្តេច?
លោកសាំយូអែលប្រើសំណួរនេះ
ដើម្បីបញ្ជាក់ថាគាត់ព្រួយបារម្ភអំពីការទៅភូមិបេថ្លេហិម។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនអាចទៅបានទេ!» ឬ «ខ្ញុំមិនហ៊ានទៅទេ»។
ជាមួយអ្នកហើយនិយាយថា
អ្នកអាចបញ្ជាក់ព័ត៌មានដែលងាយយល់។ ការបកប្រែផ្សេងទៀត «ជាមួយអ្នក
ទៅភូមិបេថ្លេហិមហើយនិយាយទៅកាន់ប្រជាជននៅទីនោះ»
ជាមួយអ្នកហើយនិយាយថា៖ ខ្ញុំមកនេះ ដើម្បីថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់។
នេះជាការដកស្រង់មួយនៅក្នុងការដកស្រង់មួយទៀត។
ការដកស្រង់ផ្ទាល់អាចថ្លែងជាការដកស្រង់ ដោយប្រយោល។
ការបកប្រែផ្សេងទៀត «ហើយនិយាយទៅកាន់ប្រជាជននៅទីនោះថា
អ្នកបានមកថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់» ។
1 Samuel 16:4
ចាស់ទុំនៅក្រុងនោះមានការភិតភ័យបានចេញមកជួបលោក
ហាក់ដូចជាពួកចាស់ទុំញាប់ញ័រ
ព្រោះពួកគេបារម្ភថាលោកសាំយូអែលបានមកស្តីបន្ទោសពួកគេ។
ដោយសន្តិភាព
អាចបញ្ជាក់ជាប្រយោគពេញលេញ។ ការបកប្រែផ្សេងទៀត
«បាទខ្ញុំមកដោយសន្តិភាព»
សូមរៀបចំខ្លួន ... ញែក
ដើម្បីញែកនរណាម្នាក់ដាច់ដោយឡែកពីគ្នា
គឺត្រូវរៀបចំខ្លួនជាស្រេចសម្រាប់គោលបំណងរបស់ព្រះអម្ចាស់
ដោយធ្វើយ៉ាងណាឲ្យមនុស្សនោះ
បានស្អាតបរិសុទ្ធស្របតាមក្រឹត្យវិន័យរបស់លោកម៉ូសេ។
1 Samuel 16:6
ពេលកូនៗរបស់គាត់បានមកដល់
នៅទីនេះ «ពួកគេ» សំដៅទៅលើអ៊ីសាយ និងកូនប្រុសរបស់គាត់។
លោកបានសម្លឹងទៅឯលោកអេលាប
នៅទីនេះ« គាត់»សំដៅទៅលើសាំយូអែល។
លោកអេលាប
នេះជាឈ្មោះកូនប្រុសច្បងរបស់អ៊ីសាយ។
តាំងឡើងនៅចំពោះព្រះអង្គ
នៅទីនេះ «ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។
ព្រះអម្ចាស់មិនទតមើលដូចមនុស្សសង្កេតទេ
នៅទីនេះ «មើល» មានន័យថាវាយតម្លៃអ្វីមួយ។
ដ្បិត ព្រះអម្ចាស់មិនទតមើល ... ព្រះអម្ចាស់ទតមើល
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលអំពីព្រះអង្គជាបុរសទី៣។ ការបកប្រែផ្សេងទៀត
«ដ្បិត យើងគឺព្រះអម្ចាស់មិនទតមើល ... យើងគឺព្រះអម្ចាស់ទតមើល
មើលដួងចិត្ត
នៅទីនេះ «មើលដួងចិត្ត» តំណាងឲ្យផ្នែកខាងក្នុងរបស់មនុស្ស។
1 Samuel 16:8
លោកអប៊ីណាដាប់ ... លោកសាម៉ា
ទាំងនេះជាឈ្មោះកូនប្រុសរបស់អ៊ីសាយ។
ហើយឲ្យដើរចូលមកចំពោះលោកសាំយូអែល។
«ប្រាប់គាត់ឲ្យទៅជួបលោកសាំយូអែល»
លោកអ៊ីសាយក៏បានឲ្យលោកសាម៉ាដើរកាត់ម្តង
លោកយល់ថា លោកសាំម៉ាបានដើរកាត់លោកសាំយូអែល។ ការបកប្រែផ្សេងទៀត
« បន្ទាប់មកលោកអ៊ីសាយបានធ្វើឲ្យលោកសាម៉ាដើរកាត់ពីមុខលោកសាំយូអែល»
ឬ« បន្ទាប់មកលោកអ៊ីសាយបានប្រាប់លោកសាម៉ាដើរមករកលោកសាំយូអែល»
1 Samuel 16:11
នៅមានកូនពៅម្នាក់ទៀត
«នៅតែមានកូនប្រុសពៅរបស់ខ្ញុំ»
យើងនឹងមិនអង្គុយ
គេយល់ថា ពួកគេកំពុងរង់ចាំអង្គុយបរិភោគអាហារ។ ការបកប្រែផ្សេងទៀត
«យើងនឹងមិនអង្គុយដើម្បីបរិភោគទេ»
ឥឡូវនេះ ... រូបរាង
ពាក្យ «ឥឡូវ» ត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់នៅក្នុងដំណើររឿងសំខាន់។ នៅទីនេះ
អ្នកពោលប្រាប់អំពីមនុស្សថ្មីនៅក្នុងរឿង។
មានថ្ពាល់ក្រហម
ពាក្យ «ថ្ពាល់ក្រហម» មានន័យថា ដាវីឌមានរូបរាងស្រស់ស្អាត។
1 Samuel 16:13
ស្នែងដែលដាក់ប្រេង
ពាក្យថា «ស្នែង» ពេលខ្លះត្រូវបានគេប្រើសំដៅទៅលើ “ ដប”
ដែលមានរាងដូចស្នែង ហើយត្រូវបានប្រើសម្រាប់ដាក់ទឹក ឬប្រេង។
ប្រេងត្រូវបានប្រើសម្រាប់ចាក់ប្រេងតែងតាំងស្តេច។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១៦:១។
លោកសាំយូអែលបានក្រោកឡើង និងបន្តដំណើរ
បញ្ជាក់ថា លោកបានក្រោកឡើង បន្ទាប់ពីពួកគេបានអង្គុយចុះដើម្បីបរិភោគ។
ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានយាងមកសណ្ឋិតពីលើដាវីឌ
ឃ្លាដែលថា «បានយាងមកសណ្ឋិតពីលើ»
មានន័យថាព្រះវិញ្ញាណរបស់ព្រះអម្ចាស់មានឥទ្ធិពលលើយុវជនដាវីឌ។
ក្នុងករណីនេះមានន័យថា ព្រះអង្គបានជួយឲ្យយុវជនដាវីឌបំពេញអ្វីៗ
ដែលព្រះអម្ចាស់ចង់ឲ្យគាត់ធ្វើ។ សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង
១០:៥។
1 Samuel 16:14
កាលនោះ
ពាក្យនេះត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់។
នៅទីនេះអ្នកពណ៌នាចាប់ផ្តើមប្រាប់ផ្នែកថ្មីនៃសាច់រឿង។
មានវិញ្ញាណ
អាចសំដៅទៅលើ «វិញ្ញាណដែលបង្កបញ្ហា» ឬ «វិញ្ញាណអាក្រក់»។
សូមទ្រង់ចាត់បាវរបស់ទ្រង់
អ្នកបម្រើចាត់ទុកលោកសូលជាបុរសទីបីថា ជាម្ចាស់របស់យើង។
ការបកប្រែផ្សេងទៀត «យើងស្នើសុំឲ្យអ្នកដែលជាម្ចាស់យើង ជាអ្នកបញ្ជាយើង»
បាវរបស់ទ្រង់ឲ្យទៅស្វែងរកអ្នកណាម្នាក់
អ្នកបម្រើបានចាត់ទុកខ្លួនឯងជាបុរសទីបីថា «អ្នកបម្រើរបស់អ្នក»។
ការបកប្រែផ្សេងទៀត «បញ្ជាឲ្យពួកយើងដែលជាអ្នកបម្រើរបស់អ្នក
ដែលយកចិត្តទុកដាក់ទៅលើអ្នក គឺរកមើល»
មកសណ្ឋិតលើព្រះអង្គ
«បង្កបញ្ហាដល់អ្នក»
1 Samuel 16:17
ដែលក្លាហាន រឹងមាំ
អាចមានន័យថា ១) «អ្នកចម្បាំងដ៏អស្ចារ្យ» ឬ ២) »បុរសក្លាហានម្នាក់»។
ពូកែនិយាយ
«អ្នកដែលប្រាជ្ញានៅក្នុងការនិយាយ» ឬ «អ្នកដែលនិយាយប្រកបដោយប្រាជ្ញា»
ព្រះអម្ចាស់ក៏គង់ជាមួយយុវជននោះដែរ
នៅទីនេះ«ជាមួយគាត់» មានន័យថា ព្រះអម្ចាស់ជួយនិងប្រទានពរដល់ដាវីឌ។
1 Samuel 16:20
ដាវីឌបានមកឯព្រះបាទសូល
នៅទីនេះ«បានមក»អាចត្រូវបានបកប្រែជា«បានទៅ»។
ហើយនៅបម្រើស្តេច
នាមអរូបី «ការបម្រើ» អាចត្រូវបានបញ្ជាក់ជាទម្រង់កិរិយាស័ព្ទ។
ការបកប្រែផ្សេងទៀត «ហើយបានចាប់ផ្តើមបម្រើទ្រង់»
ដាវីឌធ្វើជាអ្នកកាន់គ្រឿងសស្ត្រាវុធឲ្យស្តេច
«ដាវីឌបានក្លាយជាអ្នកកាន់គ្រឿងសាស្ត្រាវុធរបស់ព្រះបាទសូល»
1 Samuel 16:22
សូមទុកឲ្យដាវីឌនៅជាមួយយើងចុះ
នៅទីនេះ «ឈរនៅជាមួយយើង» ជាពាក្យសម្តីដែលមានន័យថា
ត្រូវបន្តនៅក្នុងការបម្រើរបស់ព្រះបាទសូល។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«ទុកឲ្យដាវីឌស្នាក់នៅបម្រើយើង»
យើងគាប់ព្រះទ័យនឹងដាវីឌណាស់
នៅទីនេះ «គាប់ព្រះទ័យយើង» តំណាងឲ្យរបៀបដែលព្រះបាទសូលវិនិច្ឆ័យ ឬឲ្យតម្លៃដាវីឌ។ ការបកប្រែផ្សេងទៀត
«ព្រះបាទសូលបានពេញចិត្តនឹងការវិនិច្ឆ័យរបស់ខ្ញុំ» ឬ«យើងពេញចិត្តនឹងគាត់»
វិញ្ញាណ
នៅទីនេះ «វិញ្ញាណអាក្រក់» អាចសំដៅទៅលើ« វិញ្ញាណដែលបង្កបញ្ហា» ឬ « វិញ្ញាណអាក្រក់» ។ សូមមើលពីរបៀបបកប្រែនៅក្នុង ១៦:១៤ ។
មកសណ្ឋិតលើព្រះបាទសូល
«សូលមានបញ្ហា»
សូលបានស្រស់ស្រាយ និងប្រសើរឡើងវិញ
អាចថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«តន្ត្រីនឹងធ្វើឲ្យព្រះបាទសូលស្រស់ស្រាយ ហើយធ្វើឲ្យគាត់ប្រសើរឡើង»

---

17 [1]គ្រានោះ ពួកភីលីស្ទីនបានប្រមូលទ័ពដើម្បីធ្វើសង្គ្រាម។ ពួកគេបានប្រមូលគ្នានៅឯសូកូ ស្រុកយូដា។ ពួកគេបានបោះតង់នៅចន្លោះសូកូ និងអាសេកា
គឺនៅតំបន់អេផេសដាំមីម។
[2]ព្រះបាទសូល និងទ័ពអ៊ីស្រាអែលបានប្រមូលគ្នា ហើយបោះតង់នៅក្នុងជ្រលងអេឡា រួចបានដាក់ទ័ពឲ្យចេញទៅតយុទ្ធនឹងពួកភីលីស្ទីន។
[3]ពួកភីលីស្ទីនបានឈរនៅលើភ្នំមួយម្ខាង ហើយអ៊ីស្រាអែលក៏បានឈរលើភ្នំម្ខាងទៀតដែលមានជ្រលងនៅកណ្តាលពួកគេទាំងពីរ។
[4]មានបុរសខ្លាំងម្នាក់បានចេញមកពីជំរំពួកភីលីស្ទីន ឈ្មោះថា កូលីយ៉ាត មកពីក្រុងកាថ ដែលមានកម្ពស់ប្រហែលបីម៉ែត្រ។[5]បុរសនោះពាក់ពួកលង្ហិនលើក្បាល
និងមានអាវក្រោះផង។ អាវនោះមានទម្ងន់ហាសិបប្រាំពីរគីឡូក្រាម ជាអាវលង្ហិន។
[6]មានស្រោបលង្ហិនលើជើងទាំងពីរ និងស្ពាយលំពែងលង្ហិនលើស្មាផង។[7]លំពែងនោះធំ មានចងខ្សែដើម្បីចោលដូចជាកីតម្បាញ។ ផ្លែលំពែងនោះ
មានទម្ងន់ប្រាំពីរគីឡូក្រាមធ្វើពីដែក និងមានម្នាក់ដែលកាន់ខែលដើរពីមុខផង។
[8]ម្នាក់នោះឈរ ស្រែកទៅទ័ពអ៊ីស្រាអែលថា៖ «ហេតុអ្វីបានជាពួកឯងចេញមកប្រយុទ្ធដូច្នេះ? យើងជាជនជាតិភីលីស្ទីន
តើពួកឯងមិនមែនជាកញ្ចះរបស់ព្រះបាទសូលទេឬអី? ចូររើសបុរសម្នាក់ជាតំណាងពួកឯង ហើយចាត់វាឲ្យចេញមករកយើង។[9]បើឃើញថា វាអាចវាយ
ហើយសម្លាប់យើងបាន នោះយើងនឹងធ្វើជាកញ្ចះពួកឯង។ ប៉ុន្តែ បើយើងវាយ ហើយសម្លាប់វាបាន នោះពួកឯងត្រូវមកបម្រើយើងវិញ»។
[10]ជនភីលីស្ទីននោះបាននិយាយម្តងទៀតថា៖ «ថ្ងៃនេះ យើងចេញមកតតាំងនឹងទ័ពអ៊ីស្រាអែល។ ចូរចាត់ម្នាក់ចេញមក ដើម្បីវាយតទល់គ្នា»។[11]កាលព្រះបាទសូល
និងទាហានអ៊ីស្រាអែលទាំងអស់បានឮសំដីរបស់ទាហានភីលីស្ទីនោះ ពួកគេបានបាក់ទឹកចិត្ត ហើយភ័យញ័រ។
[12]កាលនោះដាវីឌជាកូនអ្នកអំបូរអេប្រាតា ក្នុងភូមិបេថ្លេហិម ស្រុកយូដា គឺជាកូនប្រុសលោកអ៊ីសាយ។ លោកអ៊ីសាយមានកូនប្រុសប្រាំបីនាក់។
ក្នុងរជ្ជកាលរបស់ព្រះបាទសូល លោកអ៊ីសាយមានវ័យចាស់ហើយក្នុងចំណោមប្រជាជន។
[13]មានកូនប្រុសច្បងបីនាក់របស់លោកបានទៅចូលរួមធ្វើសង្គ្រាមជាមួយព្រះបាទសូលដែរ។ អ្នកទាំងបីដែលទៅសមរភូមិនោះមានឈ្មោះថា លោកអេលាប
លោកអប៊ីណាដាប់ និងលោកសាម៉ា។
[14]ដាវីឌ ជាកូនពៅគេបង្អស់ ឯបងបីនាក់បានទៅតាមព្រះបាទសូល។[15]ដាវីឌបានធ្វើដំណើរចុះឡើងទៅឯព្រះបាទសូល
និងត្រឡប់ទៅឃ្វាលចៀមរបស់ឪពុកវិញនៅឯបេថ្លេហិម។[16]សែសិបថ្ងៃហើយ ដែលទាហានភីលីស្ទីនបានមកក្បែរនោះបង្ហាញខ្លួន ដើម្បីវាយប្រយុទ្ធទាំងព្រឹកទាំងល្ងាច។
[17]បន្ទាប់មក លោកអ៊ីសាយបានប្រាប់ដាវីឌ ជាកូនប្រុសថា៖ «ចូរយកលាជមួយថង់ និងនំប៉័ងដប់ ទៅឲ្យបងៗរបស់ឯងនៅឯជំរំជាប្រញាប់។
[18]ហើយយកប្រូម៉ាស់ដប់ដុំទៅឲ្យមេទ័ពរបស់ពួកគេផង។ ចូរមើលថា តើបងៗរបស់ឯសុខសប្បាយទេ
រួចត្រូវយកអ្វីមកបញ្ជាក់ដើម្បីឲ្យដឹងថាពួកគេសុខសប្បាយមកជាមួយផង។
[19]បងៗរបស់ឯងកំពុងនៅជាមួយព្រះបាទសូល ហើយទាហានអ៊ីស្រាអែលទាំងអស់ស្ថិតនៅជ្រលងភ្នំអេឡា ប្រយុទ្ធជាមួយពួកភីលីស្ទីន»។[20]ដាវីឌបានក្រោកពីព្រលឹម
រួចផ្ញើសត្វទាំងប៉ុន្មានទៅឲ្យគង្វាលម្នាក់ផ្សេងទៀត ទាំងបានយកស្បៀងរួចចាកចេញទៅតាមបង្គាប់របស់លោកអ៊ីសាយ។ ដាវីឌបានទៅជំរំ
ខណៈពលទាហានបានចេញទៅសមរភូមិស្រែកហ៊ោ។[21]បន្ទាប់មក ទាំងទាហានអ៊ីស្រាអែល និងពួកភីលីស្ទីនបានចូលខ្សែត្រៀមដើម្បីប្រយុទ្ធ
ក៏ផ្ទុះសង្គ្រាមឡើងរវាងពលទាហាន និងពលទាហាន។
[22]ដាវីឌបានទុករបស់របរនៅនឹងអ្នកមើលថែ រួចរត់ទៅឯកងទ័ព ហើយជម្រាបសួរបងៗ។[23]ពេលបាននិយាយជាមួយបងៗ ទាហានដ៏ខ្លាំងរបស់ភីលីស្ទីន
ជាអ្នកក្រុងកាថដែលមានឈ្មោះថា កូលីយ៉ាតបានចេញមកឈរនៅជួរមុខនៃទ័ពភីលីស្ទីនទាំងនិយាយប្រមាថដូចមុនៗ ហើយដាវីឌបានឮពាក្យសំដីទាំងនោះ។
[24]នៅពេលទ័ពអ៊ីស្រាអែលបានឃើញម្នាក់នោះចេញមកដូច្នេះ ក៏បានរត់គេចដោយមានការភិតភ័យ។
[25]ទាហានរបស់អ៊ីស្រាអែលបាននិយាយថា៖ «តើអ្នកបានឃើញបុរសម្នាក់ដែលបានចេញមកនោះទេ? វាបានមកដើម្បីប្រមាថដល់ជនជាតិអ៊ីស្រាអែល។
ស្តេចនឹងប្រទាននូវទ្រព្យសម្បត្តិជាច្រើនដល់អ្នកណាដែលអាចសម្លាប់វាបាន ថែមទាំងលើកបុត្រីឲ្យរៀបអភិសេកជាមួយអ្នកនោះទៀតផង មិនត្រឹមតែប៉ុណ្ណោះ
គឺស្តេចឲ្យគ្រួសារអ្នកនោះបានរួចពន្ធនៅស្រុកអ៊ីស្រាអែលទាំងមូលដែរ»។
[26]ដាវីឌបាននិយាយទៅទាហានដែលឈរនៅក្បែរនោះថា៖ «តើនឹងទទួលបានអ្វីបើមានអ្នកអាចសម្លាប់ជនភីលីស្ទីនម្នាក់នេះ
ហើយដកយកភាពអាប់ឱនរបស់អ៊ីស្រាអែលចេញ?
តើជនភីលីស្ទីននេះជាស្ពីបានជាហ៊ានមើលងាយកងទ័ពរបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅដូច្នេះ?»[27]បន្ទាប់មក
មានអ្នកនិយាយម្តងទៀតនូវអ្វីដែលបានប្រាប់ហើយមុននោះ «ជារង្វាន់ដែលត្រូវទទួលសម្រាប់អ្នកដែលអាចសម្លាប់ជនភីលីស្ទីននោះបាន»។
[28]អេលាបជាបងបានឮពេលដាវីឌនិយាយគ្នាជាមួយពួកទាហាន។ កំហឹងរបស់អេលាបបានឡើងកំដៅប្រឆាំងនឹងដាវីឌ ដោយនិយាយឡើងថា៖
«ហេតុអ្វីបានជាឯងមកទីនេះ? តើឯងបានទុកចៀមនឹងអ្នកណានៅឯទីវាល? យើងស្គាល់អំនួតរបស់ឯងហើយ គឺដឹងភាពរពិសក្នុងចិត្តឯង
ដោយឯងមកទីនេះគឺដើម្បីមើលគេធ្វើសង្គ្រាមប៉ុណ្ណោះ»។[29]ដាវីឌបានតបវិញថា៖ «តើខ្ញុំបានធ្វើខុសអី? គ្រាន់តែសួរទេតើ»។[30]រួចមកគាត់ក៏ចេញពីបងបែរទៅរកអ្នកផ្សេង
ហើយនិយាយបែបដដែលនោះទៀត។ អ្នកទាំងនោះក៏បានឆ្លើយដូចពីមុនដែរ។
[31]ពេលសំដីរបស់ដាវីឌបានឮទៅដល់ទាហានជាច្រើនហើយ ពួកគេបានរាយការណ៍សំដីទាំងនោះដល់ព្រះបាទសូល ទាំងនាំចូលគាល់ស្តេចផង។[32]បន្ទាប់មក
ដាវីឌបានទូលព្រះបាទសូលថា៖ «សូមកុំបណ្តោយបាក់ទឹកចិត្តទាហានឡើយ ទូលបង្គំនឹងចេញទៅវាយនឹងជនភីលីស្ទីននោះ»។
[33]ព្រះបាទសូលបានមានរាជឱង្ការទៅដាវីឌថា៖ «ឯងមិនអាចចេញទៅប្រឆាំងនឹងជនភីលីស្ទីននេះបានទេ ដ្បិត ឯងនៅក្មេងណាស់ តែឯងវា
វាជាអ្នកធ្វើសង្គ្រាមតាំងពីនៅក្មេងម្លេ៉ះ»។
[34]ប៉ុន្តែ ដាវីឌបានទូលទៅព្រះបាទសូលវិញថា៖ «ទូលបង្គំធ្លាប់មើលថែហ្វូងចៀមឪពុករបស់ទូលបង្គំ។ ពេលសឹង្ហ ឬខ្លាឃ្មុំចូលមកចាប់កូនចៀមណាមួយចេញពីហ្វូង
ទូលបង្គំដេញតាម[35]ហើយប្រហារវា សង្គ្រោះចៀមនោះពីមាត់របស់វា។ កាលវាចូលមកចង់ត្របាក់ទូលបង្គំ នោះទូលបង្គំនឹងចាប់ពុកចង្កាវា វាយវា ហើយសម្លាប់វាផង។
[36]ទូលបង្គំបានសម្លាប់ទាំងសឹង្ហ និងខ្លាឃ្មុំ។ ឯជនមិនកាត់ស្បែកភីលីស្ទីននេះនឹងមានវាសនាដូចវាមួយមិនខាន
ព្រោះវាបានប្រមាថកងទ័ពរបស់ព្រះដ៏មានព្រះជន្មគង់នៅ»។
[37]ដាវីឌបានបន្ថែមថា៖ «ព្រះអម្ចាស់បានសង្គ្រោះទូលបង្គំពីក្រញាំសឹង្ហ និងពីក្រញាំរបស់ខ្លាឃ្មុំ ព្រះអង្គមុខជាសង្គ្រោះទូលបង្គំពីដៃរបស់ជនភីលីស្ទីននេះដែរ»។ បន្ទាប់មក
ព្រះបាទសូលបានមានរាជឱង្ការទៅដាវីឌថា៖ «បើដូច្នេះ ចូរទៅចុះ សូមព្រះអម្ចាស់គង់ជាមួយឯង»។[38]ព្រះបាទសូលបានបំពាក់គ្រឿងសឹករបស់ស្តេចឲ្យដាវីឌ។
ស្តេចបានយកមួយលង្ហិនពាក់លើក្បាលដាវីឌ និងបានបំពាក់អាវក្រោះឲ្យទៀតផង។

generated on Wed Sep 10 16:16:32 2025

[39]ដាវីឌបានយកដាវរបស់ស្តេចមក ប៉ុន្តែ មិនអាចដើរកើតឡើយ ពីព្រោះដាវីឌមិនដែលហ្វឹកហាត់ជាមួយនឹងគ្រឿងសឹកទាំងនោះទេ។ រួចដាវីឌបានទូលព្រះបាទសូលថា៖
«ទូលបង្គំមិនអាចចេញទៅសមរភូមិជាមួយនឹងគ្រឿងទាំងនេះបានឡើង ព្រោះទូលបង្គំមិនធ្លាប់ប្រើវា»។ ដូច្នេះ ក៏ទម្លាក់គ្រឿងទាំងនោះចុះវិញ។
[40]ដាវីឌបានយកតែរបស់របរខ្លួននៅជាប់នឹងដៃ ហើយរើសគ្រួសរលោងៗប្រាំគ្រាប់មកទុកក្នុងថង់អ្នកគង្វាលចៀម។ ដាវីឌបានត្រៀមដង្ហក់នៅនឹងដៃរួចហើយ
ថែមទាំងទៅជិតដល់ជនភីលីស្ទីននោះ។
[41]ជនភីលីស្ទីនបានមកប្រកៀកនឹងដាវីឌ ជាមួយអ្នកនាំមុខដែលកាន់ខែលឲ្យផងដែរ។[42]កាលជនភីលីស្ទីននោះស្វែងរកមើល វាបានឃើញដាវីឌ រួចបានមើលងាយដាវីឌ
ដោយសារឃើញដាវីឌជាក្មេងប្រុសនៅតូច មានថ្ពាល់ក្រហម ហើយសង្ហាផងនោះ។[43]ក្រោយមក ជនភីលីស្ទីននោះបាននិយាយទៅថា៖
«តើយើងជាឆ្កែឬបានជាឯងមកតយុទ្ធនឹងយើងដោយប្រើដំបងដូច្នេះ?» រួចជនភីលីស្ទីននោះបានដាក់បណ្តាសាដោយនាមព្រះរបស់ពួកគេ។
[44]ជនភីលីស្ទីននោះបាននិយាយជាមួយដាវីឌថា៖ «មកនេះ មកទីនេះមក អញនឹងយកសាច់ឯងឲ្យក្អែកស៊ីលើមេឃ ហើយឲ្យសត្វដែលនៅតាមទីវាល»។
[45]ដាវីឌបានតបនឹងជនភីលីស្ទីននោះថា៖ «ឯងមកប្រយុទ្ធជាមួយយើងដោយប្រើដាវ លំពែង និងដែក ប៉ុន្តែ យើងវិញមករកឯងក្នុងព្រះនាមព្រះអម្ចាស់នៃពួកពលបរិវារ
និងជាព្រះនៃកងទ័ពរបស់អ៊ីស្រាអែលដែលឯងបានប្រមាថនោះហើយ។
[46]ថ្ងៃនេះព្រះអម្ចាស់នឹងប្រទានជ័យជម្នះមកយើង ហើយយើងនឹងសម្លាប់ឯងចេញ ថែមទាំងកាត់ក្បាលឯងចេញពីខ្លួនទៀតផង។
ថ្ងៃនេះយើងនឹងយកសាសពរបស់ទ័ពភីលីស្ទីនឲ្យសត្វស្លាប់លើមេឃ និងសត្វព្រៃស៊ីជាអាហារ។ ធ្វើដូច្នេះ អ្វីៗដែលនៅផែនដីនឹងដឹងថា ពិតជាមានព្រះជាម្ចាស់
ជាព្រះនៅអ៊ីស្រាអែលប្រាកដមែន។[47]ហើយពួកគេនឹងមុខជាដឹងថា ព្រះអម្ចាស់ពុំបានផ្តល់ជ័យជម្នះដោយសារមុខដាវ និងលំពែងទេ។
ពីព្រោះព្រះអម្ចាស់នឹងចេញធ្វើសង្គ្រាម ហើយព្រះអង្គ នឹងប្រគល់ពួកឯងមកក្នុងដៃរបស់យើងមិនខាន»។
[48]កាលជនភីលីស្ទីននោះបានក្រោកឡើង ហើយចេញមកប្រឆាំងនឹងដាវីឌ រួចដាវីឌបានរត់យ៉ាងលឿនទៅរកសត្រូវ ដើម្បីទៅជួបវា។
[49]ដាវីឌបានលូកដៃចូលក្នុងហោប៉ៅដើម្បីយកគ្រួសចេញមក រួចក្រវីគ្រួសនោះ ទៅបុកថ្ងាស់ជនភីលីស្ទីននោះ រួចជននោះបានដួលមុខដល់ដី។
[50]ដាវីឌបានយកជ័យជម្នះលើជនភីលីស្ទីននោះដោយដង្ហក់ និងគ្រាប់គ្រួសតូចមួយ។ ដាវីឌបានចោលគ្រួសនោះទៅលើជនភីលីស្ទីននោះ ហើយសម្លាប់វាបង់។
[51]ដាវីឌគ្មានដាវនៅនឹងដៃទេ ក្រោយមកដាវីឌបានរត់ទៅឈរពីមុខជនភីលីស្ទីននោះ និងយកដាវចេញពីស្រោម ហើយបានសម្លាប់ រួចថែមទាំងកាត់ក្បាលជននោះផង។
កាលពួកទាហានភីលីស្ទីនបានឃើញថា អ្នកក្លាហានរបស់ពួកគេបានបាត់បង់ជីវិតដូច្នេះ ពួកគេបានរត់ភាសខ្លួនអស់ទៅ។
[52]បន្ទាប់មក ពលទាហានរបស់អ៊ីស្រាអែល និងពួកយូដាបានក្រោកឡើងទាំងស្រែកខ្លាំងៗដេញតាមពួកភីលីស្ទីនទៅយ៉ាងឆ្ងាយ ដល់ជ្រលងភ្នំ
ជាមាត់ទ្វាររបស់ក្រុងអេក្រូន។ សពរបស់ពួកភីលីស្ទីនដេករាលនៅតាមផ្លូវទៅស្អារ៉ែម រហូតដល់ក្រុងកាថ និងអេក្រូនផង។
[53]ពួកទាហានអ៊ីស្រាអែលបានត្រឡប់មកពីតាមដេញពួកភីលីស្ទីនវិញ ហើយថែមទាំងរឹបអូសយកអ្វីៗដែលនៅក្នុងជំរំពួកភីលីស្ទីននោះ។
[54]ដាវីឌបានយកក្បាលរបស់ជនភីលីស្ទីននោះ ហើយយកមកក្រុងយេរូសាឡិម រួចយកគ្រឿងធ្វើសង្គ្រាមរបស់វាដាក់នៅក្នុងត្រសាលរបស់ខ្លួន។
[55]កាលព្រះបាទសូលបានឃើញថា ដាវីឌបានវាយប្រហារជនភីលីស្ទីនដូច្នេះ ស្តេចមានរាជឱង្ការទៅអប៊ីនើរជាមេទ័ពថា៖ «លោកអប៊ីនើរ
តើយុវជននោះជាកូនប្រុសរបស់អ្នកណា?» លោកអប៊ីនើរបានទូលតបវិញថា៖ «ទូលបង្គំមិនបានដឹងទេព្រះករុណា»។[56]ស្តេចមានរាជឱង្ការថា៖ «ចូរសួរអ្នកផ្សេងទៀត
ក្រែងគេអាចស្គាល់ក្មេងប្រុសនេះជាកូនប្រុសអ្នកណា»។
[57]ពេលដាវីឌបានត្រឡប់ពីសម្លាប់ជនភីលីស្ទីននោះវិញ
លោកអប៊ីនើរបាននាំដាវីឌមកគាល់ព្រះបាទសូលជាមួយនឹងក្បាលរបស់ជនភីលីស្ទីននោះនៅនឹងដៃថែមទៀតផង។[58]ព្រះបាទសូលមានរាជឱង្ការថា៖ «នែអ្នកកម្លោះ
តើឯងជាកូនរបស់អ្នកណា? ដាវីឌបានទូលតបវិញថា៖ «ទូលបង្គំជាកូនប្រុសលោកអ៊ីសាយ ជាអ្នកបម្រើរបស់ព្រះករុណា ជាអ្នកភូមិបេថ្លហិម»។

---

1 Samuel 17:2

ជ្រលងអេឡា

នេះជាឈ្មោះទីកន្លែងមួយ។

1 Samuel 17:4

ដែលមានកម្ពស់ប្រហែលបីម៉ែត្រ។

មួយហត្ថជាឯកតារង្វាស់ស្មើនឹងប្រមាណ៤៦ សង់ទីម៉ែត្រ។
មួយចង្អាមជាឯកតារង្វាស់ស្មើនឹងប្រហែល ២៣សង់ទីម៉ែត្រ។ ការបែងចែក។
ការបកប្រែផ្សេងទៀត «ប្រហែល៣ម៉ែត្រ»

មានអាវក្រោះផង

«អាវក្រោះ»ជាគ្រឿងសាស្ត្រាវុធ
ដែលអាចបត់បែនបានគ្របដណ្តប់ការពាររាងកាយ ដូចជាស្នូកអណ្តើកឬក៏ចាន។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «
គាត់បានការពារខ្លួនគាត់ដោយពាក់អាវក្រោះ» ឬ« គាត់បានពាក់អាវក្រោះ»

មានទម្ងន់ហាសិបប្រាំពីគីឡូក្រាម

ហាសិបជាឯកតាទំងន់ស្មើនឹងប្រហែល១១ក្រាម។ ការបកប្រែផ្សេងទៀត
«ប្រហែល៥៥គីឡូក្រាម»

1 Samuel 17:6

លំពែងលង្ហិន

«លំពែង»ជាលំពែងតូចមួយ ដែលប្រើសម្រាប់គប់។

លំពែងនោះធំ

«លំពែងកាន់នៅដៃរបស់គាត់»

ជាកីតម្បាញ

«ខ្សែពួរមូលឡើងជារង្វង់»

ផ្លែលំពែងនោះ

«ចុងលំពែងរបស់គាត់»

មានទម្ងន់ប្រាំពីគីឡូក្រាមធ្វើពីដែក

ហាបជាឯកតាទំងន់ស្មើនឹងប្រហែល១១ក្រាម។ ការបកប្រែផ្សេងទៀត
«ប្រហែល៧គីឡូក្រាម»

1 Samuel 17:8

ហេតុអ្វីបានជាពួកឯងចេញមកប្រយុទ្ធដូច្នេះ?

ហេតុអ្វីបានជាអ្នកមកច្បាំងប្រឆាំងនឹងយើងដូច្នេះ? » កូលីយ៉ាតប្រើសំណួរនេះ
ដើម្បីចំអកមើលងាយឲ្យជនជាតិអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«អ្នកជាមនុស្សល្ងីល្ងើ បើអ្នកគិតថាអ្នកអាចប្រយុទ្ធប្រឆាំងនឹងយើង! »

យើងជាជនជាតិភីលីស្ទីន តើពួកឯងមិនមែនជាកញ្ជះរបស់ព្រះបាទសូលទេឬអី?

កូលីយ៉ាតប្រើសំណួរនេះ ដើម្បីចំអកឲ្យជនជាតិអ៊ីស្រាអែល។
នៅពេលដែលគាត់និយាយថា គាត់ជាជនជាតិភីលីស្ទីន
គាត់កំពុងតែបង្ហាញថាគាត់ខ្លាំង។ ការបកប្រែផ្សេងទៀត
«ខ្ញុំជាជនជាតិភីលីស្ទីនដ៏អស្ចារ្យម្នាក់
ហើយអ្នកគ្រាន់តែជាអ្នកបម្រើរបស់ព្រះបាទសូលប៉ុណ្ណោះ» ។

1 Samuel 17:10

យើងចេញមកតតាំងនឹងទ័ពអ៊ីស្រាអែល។

«ខ្ញុំតតាំងនឹងកងទ័ពអ៊ីស្រាអែល»

អ៊ីស្រាអែលទាំងអស់

សំដៅទៅលើទាហានអ៊ីស្រាអែល ដែលនៅទីនោះ។

ពួកគេបានបាក់ទឹកចិត្ត ហើយភ័យញ័រ។d

ពាក្យថា« បាក់ទឹកចិត្ត» និង« ការភ័យខ្លាចយ៉ាងខ្លាំង» មានន័យថា
ជារួមមានន័យដូចគ្នា និងបញ្ជាក់ទៅលើកម្រិតនៃការភ័យខ្លាច។

1 Samuel 17:12

លោកអ៊ីសាយមានកូនប្រុសប្រាំបីនាក់។

«គាត់» សំដៅទៅលើលោកអ៊ីសាយ។

លោកអ៊ីសាយមានវ័យចាស់ ... ក្នុងចំណោមប្រជាជន។

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា ហើយត្រូវបានបញ្ចូលគ្នាធ្វើឲ្យងាយយល់។

លោកអប៊ីណាដាប់ និងលោកសាម៉ា។

«អ័ប៊ីណាដាប់ជាកូនទីពីរ និងសាម៉ាជាកូនទីបី»។ ឃ្លានេះបង្ហាញពីកំណើត។

1 Samuel 17:14

បងបីនាក់

generated on Wed Sep 10 16:16:32 2025

ព័ត៌មានបញ្ជាក់ន័យថា អ្នកទាំងនេះជាកូនរបស់លោកអ៊ីសាយ។
ការបកប្រែផ្សេងទៀត «កូនប្រុសច្បងទាំងបីរបស់លោកអ៊ីសាយ»
សែសិបថ្ងៃហើយ
«អស់រយៈពេល៤០ថ្ងៃ»
បង្ហាញខ្លួន ដើម្បីវាយប្រយុទ្ធ
«ដើម្បីបង្ហាញថា គាត់បានត្រៀមខ្លួនរួចរាល់ចូលសមរភូមិ»
1 Samuel 17:17
អេផាស
អេផាសជាឯកតារង្វាស់ស្មើនឹងប្រហែល២២លីត្រ។
មេទ័ពរបស់ពួកគេផង។
«មេបញ្ជាការកងទាហានរបស់ពួកគេមួយពាន់នាក់។
»កងទ័ពត្រូវបានបែងចែកជាក្រុមទាហានមួយពាន់នាក់ ហើយក្រុមនីមួយៗ
មានប្រធានក្រុមដឹកនាំ។
ចូរមើលថា តើបងៗរបស់ឯសុខសប្បាយទេ
«ចូរពិនិត្យនិងស្វែងយល់ពីរបៀប ដែលបងប្អូនរបស់អ្នកកំពុងធ្វើ»
1 Samuel 17:19
ហើយទាហានអ៊ីស្រាអែលទាំងអស់
«ទាហានអ៊ីស្រាអែលទាំងអស់»
ជ្រលងភ្នំអេឡា
នេះជាឈ្មោះកន្លែងមួយ។ សូមមើលការបកប្រែនៅក្នុង ១៧:២ ។
1 Samuel 17:22
ដែលមានឈ្មោះថា កូលីយ៉ាត
«អ្នកដែលមានឈ្មោះថាកូលីយ៉ាត»
ចេញមកឈរនៅជួរមុខនៃទ័ពភីលីស្ទីន
«បោះជំហានទៅមុខចេញខ្សែត្រៀមប្រយុទ្ធរបស់ពួកភីលីស្ទីន»
1 Samuel 17:25
តើអ្នកបានឃើញបុរសម្នាក់ដែលបានចេញមកនោះទេ?
ទាហាននិយាយដូច្នេះ ដើម្បីទាក់ទាញចំណាប់អារម្មណ៍គ្នាទៅវិញទៅមក
ចំពោះទាហាននោះឈ្មោះកូលីយ៉ាត។ ការបកប្រែផ្សេងទៀត
«មើលទាហានម្នាក់នេះ ដែលបានឡើងមកហើយ! »
ស្តេច
សំដៅទៅលើស្តេចអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «ស្តេចរបស់យើង»
បុត្រី
សំដៅទៅលើបុត្រីរបស់ស្តេច។
ជាមួយអ្នកនោះ ... ឲ្យគ្រួសារអ្នកនោះ
ពាក្យ«គាត់» និង «របស់គាត់» សំដៅទៅលើមនុស្សដែលសម្លាប់កូលីយ៉ាត។
គឺស្តេចឲ្យគ្រួសារអ្នកនោះបានរួចពន្ធនៅស្រុកអ៊ីស្រាអែលទាំងមូលដែរ។
ពាក្យថា «ផ្ទះ» សំដៅទៅលើសមាជិកគ្រួសារ ឬគ្រួសារ។ ការបកប្រែផ្សេងទៀត
«នឹងលែងតម្រូវឲ្យគ្រួសាររបស់គាត់បង់ពន្ធ»
1 Samuel 17:26
ហើយដកយកភាពអាប់ឱនរបស់អ៊ីស្រាអែល
អាចបង្ហាញទម្រង់កិរិយាស័ព្ទ«អាប់ឱន»។ ការបកប្រែផ្សេងទៀត
«បញ្ឈប់អ៊ីស្រាអែលពីការអាម៉ាសមុខ» ឬ
«បញ្ឈប់គាត់ពីការធ្វើឲ្យអ៊ីស្រាអែលអាប់ឱន»
តើជនភីលីស្ទីននេះជាស្លឹបានជាហ៊ានមើលងាយកងទ័ពរបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅដូច្នេះ!
ដាវីឌបាននិយាយដូច្នេះ ដើម្បីបង្ហាញពីកំហឹងរបស់គាត់
ដែលភីលីស្ទីនកំពុងតែប្រឆាំងនឹងកងទ័ពរបស់ព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត
«ភីលីស្ទីនដែលមិនបានកាត់ស្បែកនេះ
ប្រាកដជាគ្មានអំណាចដែលអាចប្រឆាំងនឹងកងទ័ពរបស់ព្រះដ៏មានព្រះជន្មរស់នោះទេ!»
ជនភីលីស្ទីននេះជាស្លឹ
ឃ្លានេះជាការប្រមាថហើយបង្ហាញថា
កូលីយ៉ាតមិនមែនជាកម្មសិទ្ធរបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ទេ។
1 Samuel 17:28
កំហឹងរបស់អេលាបបានឡើងកំដៅប្រឆាំងនឹងដាវីឌ
នៅទីនេះកំហឹងប្រៀបបាននឹងភ្លើងដែលឆាបឆេះ។ ការបកប្រែផ្សេងទៀត «
អេលាបត្រឡប់ជាខឹងនឹងដាវីឌ»
ហេតុអ្វីបានជាឯងមកទីនេះ?
អេលាបបានប្រើសំណួរនេះដើម្បីបង្ហាញថា គាត់ខឹងដាវីឌបានចុះមក។
គាត់ប្រហែលជាចង់និយាយថា ដាវីឌគ្មានមូលហេតុត្រឹមត្រូវ ដើម្បីមកទេ។
ការបកប្រែផ្សេងទៀត «អ្នកមិនមានហេតុផលត្រឹមត្រូវដើម្បីមកទីនេះ»
តើឯងបានទុកចៀមនឹងអ្នកណានៅឯទីវាល?
អេលាបប្រើសំណួរនេះដើម្បីប្រមាថដាវីឌ
ដោយធ្វើឲ្យកិច្ចការរបស់គាត់មើលទៅមិនសំខាន់ ហើយដោយចោទប្រកាន់គាត់ថា
មិនបានថែរក្សាចៀមរបស់ឪពុកគាត់។ការបកប្រែផ្សេងទៀត
«អ្នកមានតួនាទីមើលខុសត្រូវថែរក្សាហ្វូងចៀមពីរបី នៅទីរហោស្ថាន។
អ្នកមិនអាចអនុវត្តការទទួលខុសត្រូវដ៏ងាយនោះទេ!»
អំនួតរបស់ឯងហើយ គឺដឹងភាពរពិសក្នុងចិត្តឯង
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា ហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការបញ្ជាក់។
តើខ្ញុំបានធ្វើខុសអី? គ្រាន់តែសួរទេតើ
ដាវីឌបានប្រើសំណួរទាំងនេះ ដើម្បីបង្ហាញពីការមិនសប្បាយចិត្ត
និងបង្ហាញពីភាពត្រឹមត្រូវរបស់គាត់។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនបានធ្វើអ្វីខុសទេ ខ្ញុំគ្រាន់តែសួរសំណួរប៉ុណ្ណោះ!»
រួចមកគាត់ក៏ចេញពីបងបែរទៅ
«គាត់» សំដៅទៅលើដាវីឌ ហើយពាក្យថា «បង» សំដៅទៅលើអេលាប។
1 Samuel 17:31
ពេលសំដីរបស់ដាវីឌបានឮ
អាចថ្លែងនៅក្នុងទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលដែលទាហានបានឮអ្វី ដែលបាននិយាយ»
សូមកុំបណ្តោយបាក់ទឹកចិត្តទាហានឡើយ
ការបាក់ទឹកចិត្តតំណាងឲ្យការភ័យខ្លាច និងបាត់បង់ទំនុកចិត្ត។
ការបកប្រែផ្សេងទៀត «កុំឲ្យនរណាម្នាក់ភ័យខ្លាច» ឬ
«កុំឲ្យនរណាម្នាក់បាត់បង់ទំនុកចិត្ត»
ទូលបង្គំនឹងចេញទៅ
ដាវីឌបាននិយាយអំពីខ្លួនគាត់ថា «ទូលបង្គំជាអ្នកបម្រើ»
ដើម្បីបង្ហាញការគោរពដល់ព្រះបាទសូល។ ការបកប្រែផ្សេងទៀត
«ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ នឹងទៅ»
1 Samuel 17:34
ទូលបង្គំធ្លាប់មើលថែហ្វូងចៀមឪពុករបស់ទូលបង្គំ។
ដាវីឌបាននិយាយអំពីខ្លួនគាត់ថា «អ្នកបម្រើរបស់ព្រះអង្គ»
ដើម្បីបង្ហាញការគោរពដល់ព្រះបាទសូល។ សូមមើលការបកប្រែនៅក្នុងឆ្នាំ
១៧:៣១។ ការបកប្រែផ្សេងទៀត «ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ
ធ្លាប់មើលចៀមរបស់ឪពុកទូលបង្គំ»
ធ្លាប់មើលថែហ្វូងចៀមឪពុក
«ធ្លាប់មើលថែចៀមរបស់ឪពុកគាត់»
ខ្លាឃ្មុំ
ខ្លាឃ្មុំជាសត្វដ៏ធំមួយ ដែលមានរោមក្រាស់ និងក្រញាំវែងហើយដើរជើងបួន
ប៉ុន្តែអាចឈរលើជើងពីរដូចមនុស្សដែរ។
ហើយប្រហារវា
នៅទីនេះ«គាត់»សំដៅទៅលើសត្វតោ ឬខ្លាឃ្មុំ។ ភាសាខ្លះនឹងប្រើពាក្យ «វា»
ជំនួសឲ្យ«គាត់»។
សង្គ្រោះចៀមនោះពីមាត់របស់វា
នៅទីនេះ «វា» សំដៅទៅលើកូនចៀម។
វាចូលមកចង់ត្របាក់ទូលបង្គំ
នៅទីនេះ «វាចូលមកចង់ត្របាក់ទូលបង្គំ »
ជាពាក្យសម្តីដែលសំដៅទៅលើការវាយប្រហារ។ ការបកប្រែផ្សេងទៀត
«វាវាយប្រហារខ្ញុំ»
នោះទូលបង្គំនឹងចាប់ពុកចង្កាវា
ពាក្យ «ពុកចង្ការ» សំដៅទៅលើសត្វតោ ឬសក់នៅលើមុខខ្លាឃ្មុំ។
1 Samuel 17:36
ឃ្លាភ្ជាប់៖
ដាវីឌបន្តទូលទៅស្តេចសូល។
ឯជនមិនកាត់ស្បែកភីលីស្ទីននេះ
ឃ្លានេះជាការប្រមាថ ហើយចង្អុលបង្ហាញថា
កូលីយ៉ាតមិនមែនជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ទេ។
សូមមើលការបកប្រែនៅក្នុង ១៧:២៦ ។
នឹងមានវាសនាដូចវាមួយមិនខាន
ដាវីឌកំពុងតែនិយាយថា គាត់នឹងអាចសម្លាប់ជនជាតិភីលីស្ទីនបាន
ដូចជាគាត់អាចសម្លាប់តោនិងខ្លាឃ្មុំបាន។

generated on Wed Sep 10 16:16:32 2025

1 Samuel 17:37
បានសង្គ្រោះទូលបង្គំពីក្រញាំសឹង្ហ និងពីក្រញាំរបស់ខ្លាឃ្មុំ
សត្វខ្លាឃ្មុំនិងសត្វតោប្រើក្រញាំរបស់ពួកគេ ពេលពួកគេវាយប្រហារដូច្នេះពាក្យថា
«ក្រញាំ» តំណាងឲ្យការវាយប្រហារ។ ការបកប្រែផ្សេងទៀត
«ការវាយប្រហាររបស់សត្វតោ និងការវាយប្រហាររបស់ខ្លាឃ្មុំ» ឬ «ពីតោនិងខ្លាឃ្មុំ»
ទូលបង្គំពីដៃរបស់ជនភីលីស្ទីននេះដែរ
ដៃរបស់ភីលីស្ទីនតំណាងអំណាចរបស់គាត់ក្នុងការប្រយុទ្ធ។ ការបកប្រែផ្សេងទៀត
«អំណាចរបស់ភីលីស្ទីននេះ» ឬ« ពួកភីលីស្ទីន»
បំពាក់អាវក្រោះ
គ្រឿងសឹកគ្រប់បាំងការពារដងខ្លួន
ដែលមួយចំណែកដែលមានរាងដូចស្នូកអណ្តើក ឬចាន។
1 Samuel 17:39
ដាវីឌបានយកដាវរបស់ស្តេចមក
«ដាវរបស់ព្រះបាទសូលនៅលើគ្រឿងសឹក»
របស់របរខ្លួននៅជាប់នឹងដៃ
នៅទីនេះ «របស់គាត់» សំដៅទៅលើដាវីឌ។
ដង្ហក់នៅនឹងដៃរួចហើយ
ដង្ហក់ជាអាវុធសម្រាប់គប់ដុំថ្ម។
1 Samuel 17:41
ជាមួយអ្នកនាំមុខដែលកាន់ខែលឲ្យផងដែរ។
«អ្នកកាន់ខែលរបស់គាត់ដើរនៅពីមុខគាត់»
រួចបានមើលងាយដាវីឌ
«គាត់ស្អប់ដាវីឌ»
មានថ្ពាល់ក្រហម
«មានសុខភាពល្អ»
តើយើងជាឆ្កែឬបានជាឯងមកតយុទ្ធនឹងយើងដោយប្រើដំបងដូច្នេះ?
នៅទីនេះ សត្វឆ្កែតំណាងឲ្យសត្វតូចមួយ
ដែលមនុស្សម្នាក់អាចសម្លាប់បានយ៉ាងងាយស្រួល។ ពាក្យ «ដំបង»
សំដៅទៅលើដំបងរបស់ដាវីឌ ហើយបង្ហាញពីទស្សនៈរបស់កូលីយ៉ាតថា
វាមិនមែនជាអាវុធល្អទេ។ កូលីយ៉ាតប្រើសំណួរនេះ
ដើម្បីចោទប្រកាន់ដាវីឌពីបទប្រមាថគាត់។ ការបកប្រែផ្សេងទៀត
«អ្នកប្រមាថខ្ញុំដោយមករកខ្ញុំដោយគ្រាន់តែមានដំបង ដូចខ្ញុំហ្នឹងជាឆ្កែឬ!»
1 Samuel 17:44
អញនឹងយកសាច់ឯងឲ្យក្អែកស៊ីលើមេឃ ហើយឲ្យសត្វដែលនៅតាមទីវាល។
កូលីយ៉ាតនិយាយពីការសម្លាប់ដាវីឌ ហើយទុកសាកសពរបស់គាត់នៅលើដី
ដើម្បីឲ្យសត្វស៊ីសាកសព ដូចជាគាត់ប្រគល់សាកសពរបស់ដាវីឌដល់សត្វ។
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងសម្លាប់អ្នកហើយបក្សីនៅលើមេឃ
និងសត្វព្រៃនឹងស៊ីសាកសពរបស់អ្នក»
ឲ្យក្អែកស៊ីលើមេឃ
«បក្សីនៅលើមេឃ» ឬ «បក្សី»
ឲ្យសត្វដែលនៅតាមទីវាល
«សត្វព្រៃ»
ក្នុងព្រះនាមព្រះអម្ចាស់
នៅទីនេះ«ឈ្មោះ»តំណាងឲ្យអំណាច ឬសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «ដោយឫទ្ធានុភាពរបស់ព្រះអម្ចាស់» ឬ
«ដោយអំណាចរបស់ព្រះអម្ចាស់»
ដែលឯងបានប្រមាថនោះហើយ។
«អ្នកណាដែលអ្នកបានបង្កហេតុ» ឬ «អ្នកណាដែលអ្នកបានជេរប្រមាថ»
1 Samuel 17:46
ឃ្លាភ្ជាប់៖
ដាវីឌបន្តនិយាយទៅកាន់កូលីយ៉ាត។
យើងនឹងយកសាសពរបស់ ... សត្វស្លាប់លើមេឃ ... និងសត្វព្រៃស៊ីជាអាហារ។
ដាវីឌនិយាយអំពីការនាំមុខជនជាតិអ៊ីស្រាអែល ក្នុងការសម្លាប់ពួកភីលីស្ទីន
ហើយទុកសាកសពរបស់ពួកគេនៅលើដី ដើម្បីឲ្យសត្វស៊ីពួកគេ
ដូចជាគាត់នឹងប្រគល់សាកសពរបស់ពួកគេទៅឲ្យសត្វ។ ការបកប្រែផ្សេងទៀត
«យើងជាអ៊ីស្រាអែលនឹងសម្លាប់កងទ័ពភីលីស្ទីន ហើយបក្សីនៅលើមេឃ
និងសត្វព្រៃនៅលើផែនដីនឹងស៊ីពួកគេ»
អ្វីៗដែលនៅផែនដីនឹងដឹងថា
ពាក្យថា ផែនដីសំដៅលើប្រជាជននៅលើផែនដី។ ការបកប្រែផ្សេងទៀត
«ប្រជាជនទាំងអស់នៅលើផែនដីអាចដឹង»
ព្រះអម្ចាស់ពុំបានផ្តល់ជ័យជម្នះដោយសារមុខដាវ និងលំពែងទេ។
ដាវនិងលំពែងជាឧទាហរណ៍នៃសព្វាវុធ។
ពួកគេតំណាងឲ្យវិធីប្រយុទ្ធរបស់មនុស្ស។ ការបកប្រែផ្សេងទៀត
«ជ័យជម្នះដែលព្រះអម្ចាស់ប្រទាន មិនអាស្រ័យលើដាវនិងលំពែង» ឬ
«ពេលព្រះអម្ចាស់ប្រទានជ័យជម្នះដល់យើង
ទ្រង់មិនពឹងផ្អែកលើការតស៊ូរបស់យើងទេ»
ព្រះអម្ចាស់នឹងចេញធ្វើសង្គ្រាម
ជ័យជម្នះលើសមរភូមិត្រូវបានគេនិយាយថា ជាម្ចាស់នៃសមរភូមិ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់តែងតែឈ្នះការប្រយុទ្ធ» ឬ«
ជ័យជម្នះជារបស់ព្រះអម្ចាស់»
ព្រះអង្គ នឹងប្រគល់ពួកឯងមកក្នុងដៃរបស់យើងមិនខាន។
ការប្រគល់ពួកភីលីស្ទីនទៅក្នុងដៃរបស់អ៊ីស្រាអែលតំណាងឲ្យការជួយអ៊ីស្រាអែល
ឲ្យកម្ចាត់ពួកភីលីស្ទីននៅក្នុងសមរភូមិ។ ការបកប្រែផ្សេងទៀត
«គាត់នឹងជួយយើងកម្ចាត់អ្នក»
1 Samuel 17:50
ដាវីឌបានយកជ័យជម្នះ ...ដាវីឌបានចោល ... សម្លាប់ ... ដាវីឌគ្មានដាវនៅនឹងដៃទេ
ខ៥០ជាសេចក្តីសង្ខេបនៃជ័យជម្នះដ៏អស្ចារ្យរបស់ដាវីឌលើកូលីយ៉ាត។
ព័ត៌មានលម្អិតអំពីរបៀប ដែលគាត់វាយនិងសម្លាប់កូលីយ៉ាតនៅក្នុង ១៧:៤៨
និង១៧:៥១។ ភាសាខ្លះមិនប្រើសេចក្តីសង្ខេបដូចនេះទេ។ ក្នុងស្ថានភាពទាំងនេះ
អ្នកបកប្រែអាចរៀបចំខគម្ពីរឡើងវិញដែលមានស្រាប់។
ក្រោយមកដាវីឌបានរត់ទៅឈរពីមុខជនភីលីស្ទីននោះ
ដាវីឌបានធ្វើដូច្នេះ បន្ទាប់ពីកូលីយ៉ាតបានដួលទៅនឹងដីនៅម៉ោង ១៧:៤៨ ។
យកដាវចេញ
«ដាវរបស់ភីលីស្ទីន»។ នៅទីនេះពាក្យ «របស់គាត់» សំដៅទៅលើកូលីយ៉ាត។
1 Samuel 17:52
សពរបស់ពួកភីលីស្ទីនដេករាលនៅតាមផ្លូវទៅស្អារីម
អាចបញ្ជាក់យ៉ាងច្បាស់ថា ជនជាតិអ៊ីស្រាអែលកំពុងសម្លាប់ជនជាតិភីលីស្ទីន
ពេលពួកគេដេញតាម។ ការបកប្រែផ្សេងទៀត
«ហើយពួកគេបានសម្លាប់ពួកភីលីស្ទីនពេលពួកគេដេញតាមពួកគេ
ហើយសាកសពរបស់ពួកភីលីស្ទីនដែលបានស្លាប់
ស្ថិតនៅលើដីនៅតាមផ្លូវទៅសារ៉ាអ៊ីម»
ហើយថែមទាំងរឹបអូសយកអ្វីៗដែលនៅក្នុងជំរំពួក
«ជនជាតិអ៊ីស្រាអែលបានប្លន់ជំរំរបស់ពួកភីលីស្ទីន»
រួចយកគ្រឿងធ្វើសង្គ្រាមរបស់វាដាក់នៅក្នុងត្រសាលរបស់ខ្លួន។
«គាត់ដាក់គ្រឿងសឹករបស់កូលីយ៉ាតចូលក្នុងតង់របស់គាត់»
1 Samuel 17:55
កាលព្រះបាទសូលបានឃើញថា ដាវីឌ
ការសន្ទនានៅក្នុង១៧:៥៥-៥៦ បានកើតឡើង មុនពេលដាវីឌសម្លាប់កូលីយ៉ាត។
ការបកប្រែផ្សេងទៀត «ពេលព្រះបាទសូលបានទតឃើញដាវីឌ» ឬ
«មុនពេលស្តេចសូលបានទតឃើញដាវីឌ»
ដាវីឌបានវាយប្រហារជនភីលីស្ទីនដូច្នេះ
«ទៅប្រយុទ្ធនឹងជនជាតិភីលីស្ទីន»
តើយុវជននោះជាកូនប្រុសរបស់អ្នកណា?
«តើអ្នកណាជាឪពុករបស់យុវជននេះ»
សូមព្រះអង្គមានជន្មគង់នៅ
នេះជារបៀបស្បថថា អ្វីដែលគាត់បានរៀបរាប់និយាយគឺជាការពិត។
ក្រែងគេអាចស្គាល់ក្មេងប្រុសនេះជាកូនប្រុសអ្នកណា
«តើឪពុករបស់ក្មេងប្រុសនោះជាអ្នកណា»?
1 Samuel 17:57
នៅនឹងដៃ
នៅទីនេះ «របស់គាត់»សំដៅទៅលើដាវីឌ។
តើឯងជាកូនរបស់អ្នកណា?
«នរណាជាឪពុករបស់អ្នក»
ទូលបង្គំជាកូនប្រុសលោកអ៊ីសាយ ជាអ្នកបម្រើរបស់ព្រះករុណា ជាអ្នកភូមិបេថ្លហិម។
«ឪពុកទូលបង្គំអ៊ីសាយជាអ្នកបម្រើរបស់ព្រះករុណា ជាអ្នកបេថ្លេហិម»
ទូលបង្គំជាកូនប្រុសលោកអ៊ីសាយ
ដាវីឌបានហៅឪពុកគាត់ថាជា« អ្នកបម្រើរបស់ព្រះករុណា»
ដើម្បីបង្ហាញថាឪពុករបស់គាត់ស្មោះត្រង់នឹងស្តេចសូល។

generated on Wed Sep 10 16:16:32 2025

18 [1]ក្រោយដាវីឌបានទូលព្រះបាទសូលរួចហើយ ដួងចិត្តរបស់សម្តេចយ៉ូណាថានបានពេញចិត្តនឹងដាវីឌ ថែមទាំងស្រឡាញ់ដាវីឌស្មើជីវិតផង។
[2]ព្រះបាទសូលបានយកដាវីឌឲ្យមកបម្រើស្តេចតាំងពីថ្ងៃនោះមក ស្តេចមិនអនុញ្ញាតឲ្យដាវីឌត្រឡប់ទៅផ្ទះរបស់ឪពុកខ្លួនវិញទេ។
[3]ក្រោយមក សម្តេចយ៉ូណាថានបានចងសម្ពន្ធមេត្រីមិត្តភាពជាមួយនឹងដាវីឌ ព្រោះសម្តេចយ៉ូណាថានពេញចិត្តនឹងដាវីឌស្មើនឹងជីវិត។
[4]សម្តេចយ៉ូណាថានបានយករ៉ូបដែលខ្លួនកំពុងស្លៀក រួមទាំងគ្រឿងសឹក ដូចជាដាវ ធ្នូ និងខ្សែក្រវ៉ាតទៅឲ្យដាវីឌថែមទៀតផង។
[5]ដាវីឌបានទៅគ្រប់ទីកន្លែងដែលព្រះបាទសូលបានចាត់ឲ្យទៅ ព្រមទាំងទទួលបានជោគជ័យទៀតផង។ ព្រះបាទសូលបានឲ្យដាវីឌត្រួតលើកងទ័ពទាំងអស់។ ប្រជាជន និងរាជ្យមប្រើទាំងអស់របស់ព្រះបាទសូលពេញចិត្តគ្រប់ៗគ្នា។
[6]កាលពួកគេបានត្រឡប់មកផ្ទះបន្ទាប់ពីមានជ័យជម្នះលើពួកភីលីស្ទីនវិញ ស្ត្រីៗបានចេញមកពីតាមទីក្រុងទាំងអស់នៃស្រុកអ៊ីស្រាអែល ទាំងច្រៀង ទាំងរាំជាមួយក្រាប និងឧបករណ៍ភ្លេងជាច្រើនដោយអំណរ ដើម្បីជួបព្រះបាទសូល។[7]ស្ត្រីៗបានច្រៀងប្រដាក់គ្នា រួចលេងភ្លេងផងដែរ។ ពួកគេបានច្រៀងថា៖
«ព្រះបាទសូលបានប្រហារសត្រូវរាប់ពាន់នាក់ ឯដាវីឌប្រហារបានមួយម៉ឺននាក់»។
[8]ព្រះបាទសូលមានកំហឹងជាខ្លាំង ដោយស្តេចមិនសព្វព្រះទ័យនឹងចម្រៀងដែលគេច្រៀងនោះទេ។ ស្តេចបានមានរាជឱង្ការថា៖ «គេបានរៀបរាប់ថា
ដាវីឌបានប្រហារដល់មួយម៉ឺននាក់ ប៉ុន្តែ យើងវិញបានត្រឹមរាប់ពាន់នាក់ប៉ុណ្ណោះ។ តើវានឹងទទួលអ្វីលើសនឹងទៀត
តើមិនមែននៅតែអំណាចប៉ុណ្ណោះទេឬអី?»[9]ចាប់ពីពេលនោះមក ព្រះបាទសូលបានកើតការសង្ស័យលើដាវីឌ។
[10]ថ្ងៃបន្ទាប់ វិញ្ញាណដ៏គ្រោះថ្នាក់ដែលមកពីព្រះជាម្ចាស់បានមកសណ្ឋិតលើព្រះបាទសូល ហើយស្តេចបានស្រែកឡូឡាពេញក្នុងដំណាក់។ ដូច្នេះ
ដាវីឌបានយកឧបករណ៍មកលេង ដូចបានធ្វើសព្វដង។[11]ព្រះបាទសូល មានលំពែងមួយនៅក្នុងដំណាក់ ស្តេចបានចោលលំពែងនោះ ដោយបានព្រះតម្រិះថា៖
«យើងនឹងដោតដាវីឌទៅនឹងជញ្ជាំង»។ ប៉ុន្តែ ដាវីឌបានគេចពីព្រះបាទសូល រួចខ្លួនដល់ទៅពីរដង។[12]ព្រះបាទសូលបានភ័យខ្លាចនឹងដាវីឌ
ពីព្រោះព្រះអម្ចាស់គង់នៅជាមួយដាវីឌ ព្រះអង្គលែងគង់នៅជាមួយព្រះបាទសូលទៀតហើយ។
[13]ដូច្នេះហើយ ព្រះបាទសូលបានដកដាវីឌចេញ ហើយតែងតាំងឲ្យដាវីឌធ្វើជាមេបញ្ជាការលើមួយពាន់នាក់ប៉ុណ្ណោះ ដាវីឌបានចេញចូលនៅចំពោះមុខប្រជាជនជានិច្ច។
[14]ដាវីឌបានកំពុងចម្រើនឡើង ដោយសារព្រះអម្ចាស់បានគង់ជាមួយលោក។
[15]កាលព្រះបាទសូលបានឃើញការរីកចម្រើនឡើងរបស់ស្តេច ព្រះអង្គបានក្រោកឡើង។[16]ប៉ុន្តែ អស់ទាំងជនជាតិអ៊ីស្រាអែល និងយូដាបានជាប់ចិត្តនឹងដាវីឌ
ដោយដាវីឌបានធ្វើកិច្ចការជាច្រើននៅកណ្តាលចំណោមពួកគេ។
[17]ក្រោយមក ព្រះបាទសូលបានមានរាជឱង្ការមកដាវីឌថា៖ «នេះនែ ជាបុត្រីច្បងគេបង្អស់របស់យើងឈ្មោះម៉្រាម។ យើងនឹងលើបុត្រនេះឲ្យឯង ដើម្បីឲ្យធ្វើជាប្រពន្ធឯង។
គ្រាន់តែមានកម្លាំងនិងចិត្តក្លាហានដើម្បីប្រយុទ្ធរួមជាមួយនឹងព្រះអម្ចាស់»។ ដោយព្រះបាទសូលបានគិតថា៖ «ចូរកុំឲ្យដៃរបស់យើងនៅលើវាឡើយ ប៉ុន្តែ
ត្រូវទុកឲ្យដៃរបស់ពួកភីលីស្ទីនលើវាវិញចុះ»។[18]ដាវីឌបានទូលព្រះបាទសូលថា៖ «តើទូលបង្គំជាអ្វី ហើយសាច់ញាតិទូលបង្គំជាអ្វី
ឬគ្រួសារឪពុកទូលបង្គំជាអ្វីនៅស្រុកអ៊ីស្រាអែលនេះដែលទូលបង្គំគួរតែជាបុត្រប្រសាររបស់ស្តេច?»។
[19]ប៉ុន្តែ កាលនោះ ពេលម៉្រាមជាបុត្រីរបស់ព្រះបាទសូលដែលត្រូវប្រទានឲ្យដាវីឌ តែនាងបែរជាត្រូវប្រទានឲ្យធ្វើជាប្រពន្ធរបស់អទ្រីអែល ជាអ្នកក្រុងមេហូឡាវិញ។
[20]ប៉ុន្តែ ព្រះនាងមិកាល់ជាបុត្រីរបស់ស្តេចសូលបានជំពាក់ព្រះទ័យនឹងដាវីឌ។ មានគេបានទូលស្តេចសូល ហើយការនេះត្រូវព្រះទ័យព្រះបាទសូលផងដែរ។
[21]រួចព្រះបាទសូលបានគិតថា៖ «យើងនឹងប្រគល់នាងឲ្យវា ដូច្នេះ នាងនឹងទៅជាអន្ទាក់ដល់វា ហើយពួកភីលីស្ទីននឹងលើកដៃប្រយុទ្ធនឹងវាមិនខាន»។
ហើយព្រះបាទសូលបានមានរាជឱង្ការទៅលោកដាវីឌជាលើកទីពីរថា៖ «ឯងនឹងក្លាយទៅជាបុត្រប្រសាររបស់យើង»។
[22]ព្រះបាទសូលបានបញ្ជាទៅរាជបម្រើថា៖ «ចូរនិយាយទៅលោកដាវីឌស្ងាត់ៗថា៖ «មើលចុះ ស្តេចគាប់ព្រះទ័យនឹងអ្នកណាស់
ហើយបាវរបស់ស្តេចទាំងប៉ុន្មានក៏ពេញចិត្តអ្នកដែរ។ ឥឡូវ ចូរឲ្យបានក្លាយជាកូនប្រសារប្រុសរបស់ស្តេចចុះ»។
[23]ក្រោយមក បាវបម្រើរបស់ស្តេចបាននិយាយសំដីទាំងនោះទៅលោកដាវីឌ ហើយលោកដាវីឌបានមានប្រសាសន៍ថា៖ «តើអ្នកយល់ថា ធ្វើជាបុត្រប្រសាររបស់ស្តេច
ងាយខ្លាំងណាស់ឬ? ព្រោះខ្ញុំជាមនុស្សក្រីក្រ ហើយគ្មានស័ក្តិយស[24]រួចបាវរបស់ព្រះបាទសូលបានរាយការណ៍គ្រប់ពាក្យសម្តីទាំងអស់របស់លោកដាវីឌ
ដល់ព្រះបាទសូលវិញ។
[25]ព្រះបាទសូលបានមានរាជឱង្ការថា៖ «ចូរនិយាយទៅលោកដាវីឌថា ស្តេចមិនចង់បានចំណងដៃអ្វីទេ គ្រាន់តែយកស្បែកអង្គជាតិរបស់ពួកភីលីស្ទីន
ដើម្បីសងសឹកខ្មាំងរបស់ស្តេចគ្រប់គ្រាន់ហើយ»។ កាលនោះ ព្រះបាទសូលបានរកឧបាយកលដើម្បីឲ្យលោកដាវីឌធ្លាក់ក្នុងដៃរបស់ពួកភីលីស្ទីន។
[26]ពេលរាជ្យបម្រើរបស់ស្តេចបានប្រាប់លោកដាវីឌនូវរាជសាររបស់ស្តេចហើយ នោះធ្វើឲ្យលោកដាវីឌមានកិត្តិយសដែលអាចធ្វើជាបុត្រប្រសាររបស់ស្តេច។
[27]មុនផុតកំណត់សេចក្តីសន្យារបស់ស្តេចប៉ុន្មានថ្ងៃប៉ុណ្ណោះ លោកដាវីឌបានចេញទៅជាមួយគ្នីគ្នា ហើយបានសម្លាប់ពួកភីលីស្ទីនអស់ពីររយនាក់។
លោកដាវីឌបានយកស្បែកអង្គជាតិរបស់ពួកនោះមក រួចថ្វាយទៅស្តេចគ្រប់ចំនួន ដូច្នេះ លោកដាវីឌក៏បានក្លាយជាបុត្រប្រសាររបស់ស្តេច។
ព្រះបាទសូលបានប្រទានព្រះនាងមិកាល់ឲ្យធ្វើជាភរិយារបស់លោកដាវីឌ។[28]កាលព្រះបាទសូលបានឃើញ ហើយជ្រាបថា ព្រះអម្ចាស់គង់ជាមួយនឹងលោកដាវីឌ
ហើយព្រះនាងមិកាល់ក៏ស្រឡាញ់លោកដាវីឌផងនោះ[29]ស្តេចកាន់តែខ្លាចលោកដាវីឌ។ ព្រះបាទសូលនៅតែចាត់ទុកលោកដាវីឌជាសត្រូវបន្តទៀត។
[30]ក្រោយមក ពួកមេដឹកនាំរបស់ភីលីស្ទីនបានចេញមកដើម្បីធ្វើសង្គ្រាមតាមទម្លាប់។ ឯលោកដាវីឌបានទទួលជ័យជម្នះច្រើនជាងរាជបម្រើរបស់ព្រះបាទសូលទៅទៀត
ដូច្នេះហើយ បានជាឈ្មោះរបស់លោកដាវីឌកាន់តែល្បីជាខ្លាំង។

---

1 Samuel 18:1
ដួងចិត្តរបស់សម្តេចយ៉ូណាថានបានពេញចិត្តនឹងដាវីឌ
មិត្តភាពស្និទ្ធស្នាលខ្លាំងណាស់ត្រូវបានគេនិយាយនៅទីនេះ
ដូចជាផ្សារភ្ជាប់ជាមួយដួងចិត្តមនុស្សពីរនាក់។ អាចថ្លែងជាទម្រង់កិរិយាសកម្ម។
ការបកប្រែផ្សេងទៀត «
សម្តេចយ៉ូណាថានមានអារម្មណ៍ស្រឡាញ់ចំពោះដាវីឌយ៉ាងខ្លាំង» ឬ
«សម្តេចយ៉ូណាថានបានប្តេជ្ញាថា ទ្រង់ផ្ទាល់ពេញចិត្តចំពោះដាវីឌ»
ថែមទាំងស្រឡាញ់ដាវីឌស្មើជីវិតផង។
នៅទីនេះ «ស្រឡាញ់» សំដៅទៅលើសេចក្តីស្រឡាញ់រវាងមិត្តភក្តិ
មិនមែនជាស្នេហារវាងប្រុសនិងមនុស្សស្រីទេ។ ពាក្យថា ជីវិតតំណាងឲ្យមនុស្ស
ឬជីវិតរបស់មនុស្ស។ ការបកប្រែផ្សេងទៀត
«សម្តេចយ៉ូណាថានស្រឡាញ់ដាវីឌដូចស្រឡាញ់អង្គទ្រង់» ឬ«
សម្តេចយ៉ូណាថានស្រឡាញ់ដាវីឌដូចស្រឡាញ់ព្រះជន្មទ្រង់ផ្ទាល់»
1 Samuel 18:3
សម្តេចយ៉ូណាថានពេញចិត្តនឹងដាវីឌស្មើនឹងជីវិត។
នៅទីនេះ «ពេញចិត្ត» សំដៅទៅលើសេចក្តីស្រឡាញ់រវាងមិត្តភក្តិ
មិនមែនស្នេហារវាងមនុស្សប្រុស និងមនុស្សស្រីទេ។ ពាក្យថាជីវិតតំណាងឲ្យមនុស្ស
ឬជីវិតរបស់មនុស្ស។ សូមមើលការបកប្រែនៅក្នុង ១៨:១ ។
ការបកប្រែផ្សេងទៀត «សម្តេចយ៉ូណាថានស្រឡាញ់ដាវីឌដូចស្រឡាញ់អង្គទ្រង់»
ឬ «សម្តេចយ៉ូណាថានស្រឡាញ់ដាវីឌដូចស្រឡាញ់ព្រះជន្មទ្រង់ផ្ទាល់»
1 Samuel 18:5
ព្រមទាំងទទួលបានជោគជ័យ
«ហើយគាត់បានរីកចម្រើន»
ប្រជាជន និងរាជ្យមប្រើទាំងអស់របស់ព្រះបាទសូលពេញចិត្តគ្រប់ៗគ្នា។
ឃ្លា «នៅក្នុងកែវភ្នែក» និង «ពេញចិត្ត» មានន័យដូចគ្នា។
មតិរបស់ប្រជាជនត្រូវបានគេនិយាយថា អ្វីមួយដែលពួកគេចាត់ទុកថាល្អ
ឬអាក្រក់ផងដែរ។ ការបកប្រែផ្សេងទៀត
«នេះជាការពេញចិត្តតាមគំនិតរបស់ប្រជាជនទាំងអស់
និងពួកអ្នកបម្រើរបស់ព្រះបាទសូល» ឬ «ការនេះពេញចិត្តប្រជាជន
និងអ្នកបម្រើរបស់ព្រះបាទសូលទាំងអស់»

generated on Wed Sep 10 16:16:32 2025

1 Samuel 18:6
ចេញមកពីតាមទីក្រុងទាំងអស់នៃស្រុកអ៊ីស្រាអែល
នេះជាការពង្រីកដើម្បីបញ្ជាក់ពីចំនួនស្ត្រីដ៏ច្រើន ដែលបានមក។
ការបកប្រែផ្សេងទៀត «មកពីទីក្រុងជាច្រើនទូទាំងអ៊ីស្រាអែល»
ជាមួយក្រាប និងឧបករណ៍ភ្លេងជាច្រើនដោយអំណរ
«រាំក្រាប និងលេងឧបករណ៍ភ្លេងផ្សេងទៀត ដោយចិត្តរីករាយ»
ជាមួយក្រាប
«ក្រាប» ជាស្គរដៃតូច។
ដាវីឌប្រហារបានមួយម៉ឺននាក់។
កិរិយាស័ព្ទអាចប្រើឆ្លើយតបពីវគ្គមុន។ ការបកប្រែផ្សេងទៀត
«ហើយដាវីឌបានសម្លាប់មនុស្សរាប់ពាន់នាក់»
1 Samuel 18:8
គេបានរៀបរាប់ថា
«ពួកគេបានផ្តល់កិត្តិយស»
តើវានឹងទទួលអ្វីលើសនឹងទៀត តើមិនមែននៅតែអំណាចប៉ុណ្ណោះទេឬអី?
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«រឿងតែមួយគត់ដែលនៅសល់សម្រាប់គាត់ គឺភាពជាស្តេច»
1 Samuel 18:10
វិញ្ញាណដ៏គ្រោះថ្នាក់ដែលមកពីព្រះជាម្ចាស់
នៅទីនេះ «វិញ្ញាណដ៏គ្រោះថ្នាក់» អាចសំដៅទៅលើ « វិញ្ញាណដែលបង្កបញ្ហា» ឬ «វិញ្ញាណអាក្រក់»។ សូមមើលការបកប្រែនៅក្នុង១៦:១៤។
វិញ្ញាណដ៏គ្រោះថ្នាក់ដែលមកពីព្រះជាម្ចាស់បានមកសណ្ឋិតលើព្រះបាទសូល
ឃ្លាថា «មកសណ្ឋិតលើ» មានន័យថា
វិញ្ញាណអាក្រក់មានឥទ្ធិពលលើព្រះបាទសូល។ ក្នុងករណីនេះ មានន័យថា
វាបណ្តាលឲ្យព្រះបាទសូលមានបញ្ហា និងធ្វើឲ្យឆ្គួត។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១០:៥។
ហើយស្តេចបានស្រែក
«ហើយព្រះអង្គបានប្រព្រឹត្តដូចឆ្គួត»
ព្រះអម្ចាស់គង់នៅជាមួយដាវីឌ
«ព្រះអម្ចាស់បានគង់នៅជាមួយដាវីឌ»
1 Samuel 18:13
ដូច្នេះហើយ ព្រះបាទសូលបានដកដាវីឌចេញ
«ដូច្នេះ ព្រះបាទសូលក៏ដេញដាវីឌចេញពីព្រះអង្គ»។
មួយពាន់នាក់
អាចតំណាងជាចំនួនលេខ។ ការបកប្រែផ្សេងទៀត «បុរស១០០០នាក់»
ដាវីឌបានចេញចូលនៅចំពោះមុខប្រជាជនជានិច្ច។
នៅទីនេះ «ប្រជាជន» សំដៅទៅលើទាហាន ដែលស្ថិតនៅក្រោមបញ្ជារបស់ដាវីឌ។
ឃ្លា «បានចេញទៅក្រៅ» និង «បានចូលមកវិញ» ជាឃ្លាសម្គាល់
ដែលសំដៅទៅលើការនាំប្រជាជនឲ្យចូលទៅក្នុងសមរភូមិ
ហើយនាំពួកគេត្រឡប់ពីសមរភូមិទៅផ្ទះវិញ។ ការបកប្រែផ្សេងទៀត
«ដាវីឌបាននាំទាហានរបស់គាត់ចូលទៅក្នុងសមរភូមិ
ហើយបាននាំពួកគេចេញពីសមរភូមិ»
1 Samuel 18:15
ព្រះអង្គបានក្រោកឡើង។
នៅទីនេះ« បានក្រោកឡើង» ជាឃ្លាដែលមានន័យថាខ្លាច។ ការបកប្រែផ្សេងទៀត
«ទ្រង់ភ័យខ្លាចដាវីឌ»
អស់ទាំងជនជាតិអ៊ីស្រាអែល និងយូដាបានជាប់ចិត្តនឹងដាវីឌ
នៅទីនេះ «អ៊ីស្រាអែលនិងយូដា» តំណាងឲ្យប្រជាជននៃកុលសម្ព័ន្ធទាំងអស់។
ការបកប្រែផ្សេងទៀត «ប្រជាជនទាំងអស់នៅអ៊ីស្រាអែល
និងយូដាស្រឡាញ់ដាវីឌ»
ដាវីឌបានធ្វើកិច្ចការជាច្រើននៅកណ្តាលចំណោមពួកគេ។
ឃ្លា «ចេញទៅក្រៅ» និង «ចូលមក» គឺជាឃ្លា
ដែលសំដៅទៅលើការនាំប្រជាជនឲ្យចូលទៅក្នុងសមរភូមិហើយនាំពួកគេត្រឡប់ពីសមរភូមិទៅផ្ទះវិញ។
សូមមើលការបកប្រែនៅក្នុងឆ្នាំ១៨:១៣ ។ ការបកប្រែផ្សេងទៀត
«បានដឹកនាំទាហានរបស់គាត់ចូលទៅក្នុងសមរភូមិ
ហើយបាននាំពួកគេត្រឡប់ពីសមរភូមិទៅផ្ទះវិញ»
1 Samuel 18:17
«ចូរកុំឲ្យដៃរបស់យើងនៅលើវាឡើយ ប៉ុន្តែ ត្រូវទុកឲ្យដៃរបស់ពួកភីលីស្ទីនលើវាវិញចុះ»។
ការធ្វើបាបនរណាម្នាក់ត្រូវបានគេនិយាយដូចជា កំពុងដាក់ដៃលើមនុស្សនោះ។
ត្រង់នេះ សូលកំពុងតែសំដៅទៅលើការសម្លាប់ដាវីឌ។ ការបកប្រែផ្សេងទៀត
«ខ្ញុំនឹងមិនសម្លាប់គាត់ទេ ខ្ញុំនឹងឲ្យពួកភីលីស្ទីនសម្លាប់គាត់វិញ»
តើទូលបង្គំជាអ្វី ហើយសាច់ញាតិទូលបង្គំជាអ្វី
ឬគ្រួសារឪពុកទូលបង្គំជាអ្វីនៅស្រុកអ៊ីស្រាអែលនេះ ... ជាបុត្រប្រសាររបស់ស្តេច?
ដាវីឌប្រើសំណួរដ៏ប៉ិនប្រសព្វនេះ ដើម្បីបញ្ជាក់ថា
គាត់មិនសមនឹងធ្វើជាកូនប្រសាររបស់ព្រះបាទសូលទេ។ ការបកប្រែផ្សេងទៀត
«ខ្ញុំគ្មាននរណាម្នាក់ ហើយទាំងសាច់ញាតិខ្ញុំនិងគ្រួសារឪពុកខ្ញុំ
គឺសំខាន់ណាស់នៅអ៊ីស្រាអែល ... ចំពោះស្តេច»។
ទូលបង្គំគួរតែជាបុត្រប្រសាររបស់ស្តេច
ជាបុត្រសុណិសារបស់ស្តេច «ប្តីរបស់បុត្រីរបស់ស្តេច»
1 Samuel 18:19
ពេលម៉្រាមជាបុត្រីរបស់ព្រះបាទសូល ដែលត្រូវប្រទានឲ្យដាវីឌ
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពេលព្រះបាទសូលបានប្រគល់កូនស្រីរបស់ព្រះអង្គ ព្រះនាងម៉្រាមដល់ដាវីឌ»
តែនាងបែរជាត្រូវប្រទានឲ្យធ្វើជាប្រពន្ធរបស់អេទ្រីអែល
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះបាទសូលបានប្រគល់នាងឲ្យទៅអេទ្រីអែល»
1 Samuel 18:20
ព្រះនាងមិកាល់ ... ជំពាក់ព្រះទ័យនឹងដាវីឌ។
នៅទីនេះ «ជំពាក់ព្រះទ័យ» មានន័យថា នាងមានមនោសញ្ចេតនាចំពោះដាវីឌ។
មានគេបានទូលស្តេចសូល
នៅទីនេះ« មានគេ» សំដៅទៅលើមនុស្ស
ដែលបានដឹងអំពីអារម្មណ៍របស់ព្រះនាងមិកាល់
មិនមែនចំពោះដាវីឌនិងព្រះនាងមិកាល់។
ហើយពួកភីលីស្ទីននឹងលើកដៃប្រយុទ្ធនឹងវាមិនខាន។
ការធ្វើបាបនរណាម្នាក់ត្រូវបានគេនិយាយ ដូចជាកំពុងដាក់ដៃលើមនុស្សនោះ។
នៅទីនេះព្រះបាទសូលកំពុងតែសំដៅទៅលើការសម្លាប់ដាវីឌ។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង១៨:១៧ ។ ការបកប្រែផ្សេងទៀត
«ដូច្នេះ ពួកភីលីស្ទីនអាចសម្លាប់គាត់»
«ឯងនឹងក្លាយទៅជាបុត្រប្រសាររបស់យើង»។
បុត្រសុណិសា «អ្នកនឹងក្លាយជាប្តីរបស់កូនស្រីយើង»
1 Samuel 18:22
ហើយបាវរបស់ស្តេចទាំងប៉ុន្មានក៏ពេញចិត្តអ្នកដែរ។
«បាវរបស់ស្តេចទាំងអស់កោតសរសើរអ្នក»
ឥឡូវ
«សម្រាប់ហេតុផលទាំងនេះ អ្នកគួរតែ»
1 Samuel 18:23
តើអ្នកយល់ថា ធ្វើជាបុត្រប្រសាររបស់ស្តេច ងាយខ្លាំងណាស់ឬ? ព្រោះខ្ញុំជាមនុស្សក្រីក្រ
ហើយគ្មានស័ក្តិយស
បុត្រសុណិសារបស់ស្តេច ខ្ញុំជាមនុស្សក្រីក្រ ហើយគ្មានស័ក្តិយស?
ដាវីឌសួរសំណួរដ៏ប៉ិនប្រសព្វនេះ ដើម្បីបញ្ជាក់ថា
គាត់មិនសក្តិសមនឹងធ្វើជាកូនប្រសាររបស់ស្តេចទេ។ ការបកប្រែផ្សេងទៀត
«ជារឿងដ៏អស្ចារ្យ ដែលត្រូវធ្វើជាកូនប្រសាររបស់ស្តេច
ហើយខ្ញុំក្រីក្រណាស់ហើយមិនសំខាន់នោះទេ»។
1 Samuel 18:25
ស្តេចមិនចង់បានចំណងដៃអ្វីទេ គ្រាន់តែយកស្បែកអង្គជាតិរបស់ពួកភីលីស្ទីន
កិរិយាស័ព្ទសម្រាប់ឃ្លាទីពីរ អាចត្រូវបានឆ្លើយតបពីឃ្លាទីមួយ។
ការបកប្រែផ្សេងទៀត «ស្តេចមិនចង់បានចំណងដៃទេ
ទ្រង់ចង់ឲ្យអ្នកយកស្បែកអង្គជាតិរបស់ពួកភីលីស្ទីនចំនួន១០០នាក់ប៉ុណ្ណោះ»
ចំណងដៃ
«តម្លៃកូនក្រមុំ»។ នៅក្នុងវប្បធម៌នេះ បុរសត្រូវបានគេតម្រូវឲ្យផ្តល់អំណោយ
ដល់ឪពុករបស់កូនក្រមុំ។
ត្រូវនាំមកវិញ
ពាក្យ «ស្បែកគ្របក្បាលលិង្គ»
សំដៅទៅលើស្បែកគ្របនៅលើផ្នែកឯកជនរបស់បុរស
ដែលត្រូវបានយកចេញក្នុងអំឡុងពេលកាត់ស្បែក។
ដើម្បីសងសឹកខ្មាំងរបស់ស្តេចគ្រប់គ្រាន់ហើយ។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីសងសឹកនឹងសត្រូវរបស់ស្តេច»

generated on Wed Sep 10 16:16:32 2025

រកឧបាយកលដើម្បីឲ្យលោកដាវីឌធ្លាក់ក្នុងដៃ របស់ពួកភីលីស្ទីន។
នៅទីនេះ «ធ្លាក់» មានន័យថាស្លាប់។ ពាក្យថា« ដៃ» តំណាងឲ្យពួកភីលីស្ទីន។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីឲ្យពួកភីលីស្ទីនសម្លាប់ដាវីឌ»
1 Samuel 18:27
ពួកភីលីស្ទីនអស់ពីរយនាក់។
អាចបង្ហាញតាមចំនួនលេខ។ ការបកប្រែផ្សេងទៀត «ភីលីស្ទីន២០០នាក់»
រួចថ្វាយទៅស្តេចគ្រប់ចំនួន
«ដាវីឌនិងពួកទាហានរបស់គាត់ បានប្រគល់របស់ទាំងអស់នោះដល់ស្តេច»
កាលព្រះបាទសូលបានឃើញ ហើយជ្រាបថា
នៅទីនេះពាក្យ «បានឃើញ» និង «បានជ្រាប» មានអត្ថន័យស្រដៀងគ្នា
ហើយបញ្ជាក់ថា ព្រះបាទសូលបានជ្រាបយ៉ាងពិតប្រាកដ។ ការបកប្រែផ្សេងទៀត
«ព្រះបាទសូលបានទទួលស្គាល់»
ព្រះនាងមិកាល់ក៏ស្រឡាញ់លោកដាវីឌផងនោះ
នៅទីនេះ« ស្រឡាញ់» មានន័យថា នាងមានអារម្មណ៍ស្រឡាញ់ចំពោះដាវីឌ។
1 Samuel 18:30
ដូច្នេះហើយ បានជាឈ្មោះរបស់លោកដាវីឌកាន់តែល្បីជាខ្លាំង។
នៅទីនេះ «ឈ្មោះ» ជាពាក្យប្រៀបធៀបសម្រាប់ដាវីឌ។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «ដូច្នេះ
ប្រជាជនគោរពដាវីឌយ៉ាងខ្លាំង»

---

19 [1]ព្រះបាទសូលបានបញ្ជាទៅសម្តេចយ៉ូណាថានជាបុត្រា និងពួករាជបម្រើឲ្យសម្លាប់លោកដាវីឌចោល។ ប៉ុន្តែ សម្តេចយ៉ូណាថានជាបុត្រាព្រះបាទសូល
មានការគោរពដល់លោកដាវីឌយ៉ាងខ្លាំង[2]ដូច្នេះ សម្តេចយ៉ូណាថានបានប្រាប់លោកដាវីឌថា៖ «ព្រះបិតារបស់ខ្ញុំ គឺព្រះបាទសូល មានបំណងចង់សម្លាប់លោក។
ហេតុដូច្នេះ ចូរប្រយ័ត្នព្រឹកស្អែក ហើយទៅលាក់ខ្លួននៅកន្លែងដែលសុវត្ថិភាពចុះ។[3]ខ្ញុំនឹងចេញទៅឈរនៅជិតបិតារបស់ខ្ញុំនៅឯវាលកន្លែងដែលលោកនៅនោះ
រួចខ្ញុំនឹងទូលបិតាអំពីលោក។ បើខ្ញុំមានព័ត៌មានអ្វីជាក់លាក់ ខ្ញុំនឹងប្រាប់អ្នក»។
[4]សម្តេចយ៉ូណាថានបានទូលពីស្នាដៃល្អៗរបស់លោកដាវីឌដល់បិតាថា៖ «សូមបិតាកុំធ្វើបានលោកដាវីឌជាអ្នកបម្រើរបស់ព្រះអង្គឡើយ។ ដ្បិត
លោកដាវីឌពុំបានធ្វើអ្វីប្រឆាំងនឹងបិតាទេ ផ្ទុយទៅវិញអ្វីៗដែលលោកដាវីឌបានធ្វើ គឺនាំមកនូវផលប្រយោជន៍ដល់បិតាវិញ។[5]លោកដាវីឌបានយកជីវិតរបស់ខ្លួន
ទៅវាយសម្លាប់ពួកភីលីស្ទីន។ ព្រះអម្ចាស់បានប្រទានជ័យជម្នះដ៏សម្បើមដល់ជនជាតិអ៊ីស្រាអែលទាំងអស់។ ដូចបិតាបានឃើញ និងបានរីករាយព្រះទ័យស្រាប់ហើយ។
ហេតុអ្វីបិតាត្រូវប្រព្រឹត្តបែបនេះចំពោះមនុស្សគ្មានកំហុស ដោយសម្លាប់លោកដាវីឌទាំងគ្មានហេតុផលដូច្នេះទៅវិញ?»។
[6]ព្រះបាទសូលបានស្តាប់សម្តេចយ៉ូណាថាន ទាំងបានស្បថថា៖ «លោកដាវីឌនឹងមិនត្រូវស្លាប់ឡើង យើងស្បថដោយនូវព្រះជន្មរបស់ព្រះអម្ចាស់»។
[7]ក្រោយមកសម្តេចយ៉ូណាថានបានហៅលោកដាវីឌ ហើយរៀបរាប់រឿងទាំងអស់នោះដល់ដាវីឌ។ សម្តេចយ៉ូណាថានបាននាំលោកដាវីឌចូលគាល់ស្តេចសូល
ដូចដែលធ្លាប់នៅគ្រាមុនៗដែរ។
[8]ក្រោយមកមានសង្គ្រាមទៀត លោកដាវីឌបានចេញទៅច្បាំងនឹងពួកភីលីស្ទីន ហើយឈ្នះដោយសម្លាប់ពួកនោះជាច្រើន។ មានពួកគេជាច្រើនបានរត់គេចពីលោកដាវីឌ។
[9]មានវិញ្ញាណដ៏គ្រោះថ្នាក់ពីព្រះអម្ចាស់បានមកឯព្រះបាទសូលខណៈស្តេចកំពុងគង់នៅដំណាក់ទាំងកាន់លំពែងនៅព្រះហស្ត ហើយលោកដាវីឌកំពុងលេងពិន។
[10]ព្រះបាទសូលបានព្យាយាមចោលលោកដាវីឌឲ្យជាប់នឹងជញ្ជាំងដោយលំពែងនោះ ប៉ុន្តែ លោកដាវីឌបានគេចផុត ហើយរត់គេចពីព្រះបាទសូល
ឯលំពែងក៏ទៅជាប់នឹងជញ្ជាំងទៅ។ លោកដាវីឌបានគេចខ្លួននៅយប់នោះ។[11]ហើយព្រះបាទសូលបានបញ្ជូនអ្នកឃ្លាំមើលឲ្យទៅផ្ទះលោកដាវីឌ
ក្រែងលោព្រឹកឡើងស្តេចអាចសម្លាប់លោកដាវីឌបាន។ ព្រះនាងមិកាល់ជាភរិយាលោកដាវីឌបានប្រាប់លោកដាវីឌថា៖ «បើបងមិនរត់យប់នេះទេ
នោះបងមុខជាស្លាប់នៅថ្ងៃស្អែកមិនខាន»។
[12]ដូច្នេះ ព្រះនាងមិកាល់បានសម្រួតលោកដាវីឌតាមបង្អួច។ លោកដាវីឌបានរត់គេចចេញ រួចទៅលាក់ខ្លួន។[13]ព្រះនាងមិកាល់បានយករូបបដិមាមកដាក់នៅលើគ្រែ
រួចយកភួយដែលធ្វើពីរោមពពែគ្របលើក្បាល ហើយបានគ្របនឹងសម្លៀកបំពាក់។
[14]ពេលស្តេចបានបញ្ជូនអ្នកឃ្លាំមើលមកតាមដានលោកដាវីឌ ព្រះនាងបានប្រាប់ថា៖ «ដាវីឌឈឺហើយ»។[15]រួចស្តេចបានបញ្ជូនអ្នកឃ្លាំមើលដោយបន្ទូលថា៖
«ចូរនាំដាវីឌពីគ្រែមកឲ្យយើង ដើម្បីឲ្យយើងសម្លាប់»។
[16]ពេលអ្នកតាមដានមកដល់ ឃើញតែរូបបដិមានៅលើគ្រែជាមួយខ្នើយដែលធ្វើពីរោមពពែនៅនឹងក្បាលទៅវិញ។[17]ព្រះបាទសូលបានថ្លែងទៅព្រះនាងមិកាល់ថា៖
«ហេតុអ្វីបានជាបុត្របញ្ឆោតបិតា ដោយរំដោះសត្រូវបិតាឲ្យទៅ ហើយគេចខ្លួនដូច្នេះ?» ព្រះនាងមិកាល់បានទូលព្រះបាទសូលថា៖ «ដាវីឌបាននិយាយមកខ្ញុំម្ចាស់ថា
ឲ្យបងចេញទៅចុះ បើមិនដូច្នោះទេ តើអ្នកចង់ឲ្យបងសម្លាប់អ្នកចោលឬ?»។
[18]លោកដាវីឌបានរត់គេចខ្លួន ហើយបានធ្វើដំណើរទៅរកលោកសាំយូអែលនៅឯម៉ារ៉ា
និងបានរៀបរាប់ប្រាប់លោកទាំងអស់នូវអ្វីៗដែលព្រះបាទសូលបានប្រព្រឹត្តចំពោះខ្លួន។ បន្ទាប់មក អ្នកទាំងពីរបានចាកចេញទៅស្នាក់នៅឯណាយ៉ូត។
[19]មានគេប្រាប់ព្រះបាទសូលថា៖ «ឃើញដាវីឌ នៅណាយ៉ូត ក្នុងភូមិរ៉ាម៉ា»។[20]ក្រោយមក ព្រះបាទសូលបានបញ្ជូនមនុស្សឲ្យមកចាប់លោកដាវីឌ។
កាលពួកគេបានឃើញមានក្រុមព្យាការីនៅជាមួយដែរ ដែលកំពុងថ្លែងព្រះបន្ទូល ហើយមានលោកសាំយូអែលឈរនាំមុខគេផង
ស្រាប់តែព្រះវិញ្ញាណនៃព្រះបានយាងមកសណ្ឋិតលើក្រុមមនុស្សរបស់ព្រះបាទសូល ហើយពួកគេក៏ស្តុងថ្លែងព្រះបន្ទូលដែរ។
[21]កាលរឿងនេះបានឮដល់ព្រះបាទសូល នោះស្តេចក៏ចាត់ឲ្យមនុស្សមួយក្រុមទៀតឲ្យទៅ រួចពួកគេក៏ស្តុងស្មារតីថ្លែងព្រះបន្ទូលដែរ។
ក្រោយមកព្រះបាទសូលបានបញ្ជូនមនុស្សក្រុមផ្សេងទៀតជាលើកទីបី តែពួកគេស្តុងស្មារតីថ្លែងព្រះបន្ទូលដូចក្រុមមុនៗដែរ។[22]បន្ទាប់មក ព្រះបាទសូលបានយាងមករ៉ាម៉ា
ហើយបន្តទៅឯអណ្តូងជ្រៅដែលនៅភូមិសេគូរដោយផ្ទាល់។ ស្តេចបានរាជឱង្ការសួរថា៖ «តើលោកសាំយូអែល និងដាវីឌនៅឯណា?» មានម្នាក់បានទូលស្តេចថា៖
«ឃើញពួកគេនៅឯណាយ៉ូត ក្នុងភូមិរ៉ាម៉ា»។
[23]ព្រះបាទសូលបានយាងទៅណាយ៉ូត ក្នុងភូមិរ៉ាម៉ា។ នោះព្រះវិញ្ញាណនៃព្រះបានយាងមកសណ្ឋិតលើស្តេច
រួចស្តេចបានស្តុងស្មារតីថ្លែងព្រះបន្ទូលរហូតដល់ណាយ៉ូតក្នុងភូមិរ៉ាម៉ា។[24]ស្តេចបានដោះព្រះភូសាចេញ ហើយថ្លែងព្រះបន្ទូលនៅចំពោះមុខលោកសាំយូអែល។
ស្តេចដេកដួលទាំងខ្លួនទទេទាំងថ្ងៃទាំងយប់។ ហេតុដូច្នេះ ហើយទើបគេសួរថា «តើស្តេចសូលចូលក្នុងព្យាការីដែរឬ?»។

---

1 Samuel 19:1
និងពួករាជបម្រើ
នៅទីនេះ «ពួករាជបម្រើ» សំដៅទៅលើព្រះបាទសូល។
មានការគោរពដល់លោកដាវីឌយ៉ាងខ្លាំង
សម្តេចយ៉ូណាថានមានការរីករាយយ៉ាងខ្លាំងនឹងការនៅជាមួយដាវីឌ។
1 Samuel 19:4
សូមបិតាកុំធ្វើបានលោកដាវីឌជាអ្នកបម្រើរបស់ព្រះអង្គឡើយ។
សម្តេចយ៉ូណាថាននិយាយដូចជា ព្រះបាទសូលជាមនុស្សម្នាក់ផ្សេងទៀត
ដើម្បីបង្ហាញព្រះបាទសូលថា សម្តេចយ៉ូណាថានគោរពព្រះបាទសូល។
ការបកប្រែផ្សេងទៀត «កុំប្រព្រឹត្តអំពើបាបប្រឆាំងនឹងអ្នកបម្រើរបស់ព្រះអង្គ»
លោកដាវីឌបានយកជីវិតរបស់ខ្លួន
នៅទីនេះ «បានយកជីវិតរបស់ខ្លួន»
ជាពាក្យសម្តីដែលសំដៅទៅលើការប្រថុយជីវិតរបស់គាត់។ ការបកប្រែផ្សេងទៀត
«គាត់បានប្រថុយជីវិតរបស់គាត់»
ហេតុអ្វីបិតាត្រូវប្រព្រឹត្តបែបនេះចំពោះមនុស្សគ្មានកំហុស
ដោយសម្លាប់លោកដាវីឌទាំងគ្មានហេតុផលដូច្នេះទៅវិញ?
សម្តេចយ៉ូណាថានសួរសំណួរនេះ ដើម្បីស្តីបន្ទោសព្រះបាទសូល។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ព្រះបិតាមិនគួរប្រព្រឹត្តបាបប្រឆាំងនឹងមនុស្សគ្មានកំហុស ដោយសម្លាប់ដាវីឌ
ដោយគ្មានមូលហេតុនោះឡើយ»។

generated on Wed Sep 10 16:16:32 2025

ប្រព្រឹត្តបែបនេះចំពោះមនុស្សគ្មានកំហុស
នៅទីនេះ «មនុស្សគ្មានកំហុស »
ជាពាក្យប្រៀបធៀបសម្រាប់ជីវិតរបស់មនុស្សស្លូតត្រង់។ ការបកប្រែផ្សេងទៀត
«ប្រព្រឹត្តអំពើបាបនៃឃាតកម្ម»
1 Samuel 19:6
លោកដាវីឌនឹងមិនត្រូវស្លាប់ឡើង
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«យើងនឹងមិនកាត់ទោសគាត់ដល់ស្លាប់ទេ» ឬ «យើងនឹងមិនសម្លាប់គាត់» ឬ
«យើងនឹងធ្វើឲ្យគាត់នៅរស់យ៉ាងពិតប្រាកដ»
លោកដាវីឌចូលគាល់ស្តេចសូល
ដាវីឌនៅចំពោះមុខព្រះបាទសូល។
1 Samuel 19:8
មានវិញ្ញាណដ៏គ្រោះថ្នាក់ពីព្រះអម្ចាស់
នៅទីនេះ «វិញ្ញាណអាក្រក់» អាចសំដៅទៅលើ «វិញ្ញាណដែលបង្កបញ្ហា» ឬ «
វិញ្ញាណអាក្រក់»។ បកប្រែដូចនៅក្នុង ១៦:១៤។
1 Samuel 19:10
ចោលលោកដាវីឌឲ្យជាប់នឹងជញ្ជាំងដោយលំពែងនោះ
ចោលលំពែងរបស់ព្រះអង្គ
ដូច្នេះវានឹងបុកទម្លាយដាវីឌព្រមទាំងទៅជាប់ជាមួយជញ្ជាំង
ក្រែងលោ ព្រឹកឡើងស្តេចអាចសម្លាប់លោកដាវីឌបាន
«ព្រះបាទសូលអាចសម្លាប់ដាវីឌបាន»
ព្រះនាងមិកាល់ ... បានប្រាប់លោកដាវីឌ
ព្រះនាងមិកាល់បានប្រាប់ដាវីឌ
បើបងមិនរត់យប់នេះទេ
នៅទីនេះ «ជួយសង្គ្រោះជីវិតអ្នក» ជាពាក្យសម្តីដែលសំដៅទៅលើការរត់គេចខ្លួន។
ការបកប្រែផ្សេងទៀត «បើបងមិនរត់គេចខ្លួនទេ»
នោះបងមុខជាស្លាប់
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«មាននរណាម្នាក់នឹងសម្លាប់បង»
1 Samuel 19:12
ព័ត៌មានទូទៅ៖
ព្រះនាងមិកាល់ជួយដាវីឌរត់គេចពីស្តេចសូល។ ព្រះនាងប្រើរូបបដិមានៅក្នុងផ្ទះ
ដើម្បីធ្វើឲ្យគ្រែរបស់ដាវីឌមើលទៅដូចជាគាត់កំពុងដេកនៅក្នុងនោះ។
រួចយកភួយដែលធ្វើពីរោមពពែគ្របលើក្បាល ហើយបានគ្របនឹងសម្លៀកបំពាក់។
អាចមានន័យថា ១) ក្បាលរបស់រូបបដិមាកំពុងដេកនៅលើខ្នើយធ្វើពីរោមពពែ
និងព្រះនាងមិកាល់គ្របសម្លៀកបំពាក់របស់ដាវីឌលើរូបបដិមា ឬ
២)ព្រះនាងមិកាល់បានប្រើសម្លៀកបំពាក់របស់ដាវីឌជាភួយ
ដើម្បីគ្របដណ្តប់រូបបដិមាទាំងស្រុង និងធ្វើឲ្យ «ខ្នើយ» ដែលធ្វើពីរោមពពែ
មើលទៅដូចសក់របស់ដាវីឌ ដែលបោះចេញពីក្រោមភួយ។
1 Samuel 19:14
ព័ត៌មានទូទៅ៖
ព្រះបាទសូលមានបំណងសម្លាប់ដាវីឌ។
តាមដានលោកដាវីឌ
«តាមដានលោកដាវីឌ ហើយត្រឡប់ទៅរាយការណ៍ឲ្យព្រះបាទសូលវិញ»
ព្រះនាងបានប្រាប់ថា
នៅទីនេះ«នាង» សំដៅទៅលើមិកាល់។
ចូរនាំដាវីឌពីគ្រែមកឲ្យយើង
មូលហេតុដែលមនុស្សគិតថា ដាវីឌដេកនៅលើគ្រែអាចត្រូវបានថ្លែងឲ្យច្បាស់។
ការបកប្រែផ្សេងទៀត «បើគាត់ពិតជាឈឺខ្លាំងណាស់ក្នុងការមករកខ្ញុំ
ចូរសែងទាំងគ្រែគាត់មកជាមួយគាត់មក»
1 Samuel 19:16
ខ្នើយដែលធ្វើពីរោមពពែ
បកប្រែដូចនៅ ១៩:១២ ។
ឃើញតែរូបបដិមា
ពាក្យថា« ឃើញ» នៅទីនេះបង្ហាញថា អ្នកនាំសារមានការភ្ញាក់ផ្អើលចំពោះអ្វី
ដែលពួកគេបានឃើញ។
«ហេតុអ្វីបានជាបុត្របញ្ឆោតបិតា ដោយរំដោះសត្រូវបិតាឲ្យទៅ ហើយគេចខ្លួនដូច្នេះ?»
អាចមានន័យថា ១) ព្រះបាទសូលពិតជាចង់ដឹងពីមូលហេតុ
ដែលព្រះនាងមិកាល់បានធ្វើអ្វី ដែលនាងបានធ្វើ ឬ ២)
ព្រះបាទសូលប្រើសំណួរនេះ ដើម្បីស្តីបន្ទោសព្រះនាងមិកាល់។
សំណួរដ៏ប៉ិនប្រសព្វនេះ អាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «កូនមិនគួរបញ្ឆោតបិតា
ហើយឲ្យសត្រូវរបស់បិតាចេញទៅដូច្នេះ វាបានរត់គេចខ្លួនហើយ»។
ឲ្យបងចេញទៅចុះ បើមិនដូច្នោះទេ តើអ្នកចង់ឲ្យបងសម្លាប់អ្នកចោលឬ?
ទោះបីដាវីឌមិនបាននិយាយអំពីរឿងពិតប្រាកដនេះក៏ដោយ
ព្រះនាងមីកាល់ទូលប្រាប់ព្រះបាទសូលថា ដាវីឌបានគំរាមនាង
ដោយប្រើសំណួរនេះ។ សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «បងនឹងសម្លាប់អ្នក បើអ្នកមិនជួយបងឲ្យរត់គេចខ្លួន» ។
1 Samuel 19:18
ព័ត៌មានទូទៅ៖
ដាវីឌរត់ភៀសខ្លួនទៅលោកសាំយូអែល។
ឥឡូវ
ពាក្យនេះត្រូវបានប្រើនៅទីនេះ ដើម្បីបង្ហាញថា
អ្នកនិពន្ធបានចាប់ផ្តើមប្រាប់ផ្នែកថ្មីនៃសាច់រឿង។
មានគេប្រាប់ព្រះបាទសូលថា
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«មានគេបានទូលប្រាប់ព្រះបាទសូល»
ឃើញដាវីឌ
«មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វី ដែលខ្ញុំនឹងប្រាប់អ្នក»
ឈរនាំមុខគេផង
នៅទីនេះ «មុខគេ» សំដៅទៅលើរតនាទីនៃសិទ្ធអំណាច។ ការបកប្រែផ្សេងទៀត
«ដើរតួជាអ្នកដឹកនាំរបស់ពួកគេ»
1 Samuel 19:21
កាលរឿងនេះបានឮដល់ព្រះបាទសូល
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពេលនរណាម្នាក់បានទូលប្រាប់ព្រះបាទសូលអំពីរឿងនេះ»
ភូមិរ៉ាម៉ា ... ភូមិសេគូវ ... ណាយ៉ូត
ទាំងនេះជាឈ្មោះរបស់ទីកន្លែង។
1 Samuel 19:23
ហេតុដូច្នេះ ហើយទើបគេសួរថា «តើស្តេចសូលចូលក្នុងព្យាការីដែរឬ?»។
នេះបានក្លាយជាសុភាសិតក្នុងចំណោមជនជាតិអ៊ីស្រាអែល។
មនុស្សបាននិយាយរឿងនេះ ដើម្បីបង្ហាញការភ្ញាក់ផ្អើលយ៉ាងជាក់ស្តែងពិតប្រាកដ
ពេលមនុស្សម្នាក់មិនបានធ្វើអ្វីមួយ ដែលគាត់មិនបានធ្វើពីមុន។
នេះជាការថ្លែងបញ្ជាក់អត្ថន័យនៃសំណួរនេះ។ សូមមើលការបកប្រែនៅក្នុង១០:១១
។ ការបកប្រែផ្សេងទៀត « នេះជាហេតុផលដែលថា
នៅពេលមនុស្សឃើញនរណាម្នាក់ធ្វើអ្វីមួយ
ដែលនឹកស្មានមិនដល់ពួកគេនិយាយថា ៖«តើស្តេចសូលចូលក្នុងព្យាការីឬដែរឬ?»
ហើយទើបគេសួរថា
នៅទីនេះ «ពួកគេ» សំដៅទៅលើមនុស្សទូទៅ។
សំណួរបានក្លាយជាសុភាសិតក្នុងចំណោមប្រជាជន។

20 [1]ក្រោយមក លោកដាវីឌបានភាសខ្លួនពីណាយ៉ូតក្នុងភូមិរ៉ាម៉ា ដើម្បីមកជួបសម្តេចយ៉ូណាថានហើយមានប្រសាសន៍ថា៖ «ទូលបង្គំបានធ្វើអ្វីខុស?
តើអ្វីជាអំពើទុច្ចរិតរបស់ទូលបង្គំ? តើទូលបង្គំបានប្រព្រឹត្តអ្វីខុសនឹងបិតារបស់ព្រះអង្គ
បានជាទ្រង់ស្វះស្វែងចង់យកជីវិតទូលបង្គំបែបនេះ?»[2]សម្តេចយ៉ូណាថានបានថ្លែងទៅលោកដាវីឌវិញថា៖ «សូមកុំឲ្យមានរឿងនេះឡើយ ឯងនឹងមិនស្លាប់ទេ។
បិតារបស់ខ្ញុំធ្វើអ្វី ទោះកិច្ចការតូច ឬធំក្តី មិនដែលលាក់ខ្ញុំទេ។ ហេតុអ្វីបិតារបស់ខ្ញុំលាក់រឿងនេះនឹងខ្ញុំដូច្នេះ? មិនគួរយ៉ាងដូច្នេះសោះ»។
[3]រួចលោកដាវីឌបានស្បថម្តងទៀតថា៖ «បិតារបស់សម្តេចជ្រាបយ៉ាងច្បាស់ថា សម្តេចពេញចិត្តនឹងទូលបង្គំ។ ដោយព្រះអង្គមានបន្ទូលថា
កុំឲ្យរឿងនេះដឹងដល់យ៉ូណាថាន បើមិនដូច្នោះទេទ្រង់មុខជាក្រៀមក្រំមិនខាន។ ប៉ុន្តែ ខ្ញុំសូមស្បថចំពោះព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅ និងនៅមុខសម្តេចថា
សេចក្តីស្លាប់នៅប្រគៀកនឹងទូលបង្គំណាស់»។

generated on Wed Sep 10 16:16:32 2025

[4]បន្ទាប់មក សម្តេចយ៉ូណាថានមានរាជឱង្ការទៅលោកដាវីឌថា៖ «អ្វីក៏ដោយ ឲ្យតែអ្នកនិយាយចេញមក ខ្ញុំនឹងធ្វើឲ្យ»។[5]លោកដាវីឌបានទូលតបវិញថា៖
«ស្អែកជាថ្ងៃបុណ្យដើមខែ តាមទម្លាប់ខ្ញុំត្រូវទទួលទានអាហាររួមតុជាមួយព្រះករុណា។ ប៉ុន្តែ សូមទុកឲ្យទូលបង្គំចេញទៅ
នោះទូលបង្គំអាចលាក់ខ្លួនរហូតដល់ល្ងាចថ្ងៃទីបី។
[6]បើបិតារបស់សម្តេចរកទូលបង្គំ សូមទូលប្រាប់ព្រះអង្គវិញថា៖ «ដាវីឌបានសុំទូលបង្គំចេញទៅស្រុកកំណើត គឺបេថ្លេហិម
ដើម្បីឲ្យទាន់ថ្វាយយញ្ញបូជាជាមួយគ្រួសារទាំងមូល»។ តែបើព្រះករុណាមានរាជឱង្ការថា មិនអីទេ នោះមានន័យថា ទូលបង្គំនឹងមានសេរីភាពហើយ។[7]ប៉ុន្តែ
បើព្រះករុណាខ្ញាល់ខ្លាំង នោះសម្តេចដឹងហើយថា ព្រះករុណាបានសម្រេចចង់ដកជីវិតទូលបង្គំហើយ។
[8]ហេតុដូច្នេះ សូមសម្តែងសេចក្តីសប្បុរសដល់ទូលបង្គំផង។ ព្រោះសម្តេចបានចងសម្ព័ន្ធមេត្រីជាមួយទូលបង្គំដោយនូវព្រះនាមព្រះអម្ចាស់ហើយ។ ប៉ុន្តែ បើសម្តេចឃើញថា
ទូលបង្គំមានកំហុស សូមសម្លាប់ទូលបង្គំដោយផ្ទាល់មកចុះ មិនចាំបាច់យកទូលបង្គំទៅថ្វាយបិតារបស់ព្រះអង្គទេ»។[9]សម្តេចយ៉ូណាថានបានថ្លែងថា៖ «សូមកុំគិតដូច្នេះអី!
បើខ្ញុំដឹងថា បិតាបានសម្រេចធ្វើបាបឯង តើមិនឲ្យខ្ញុំប្រាប់ឯងទេឬអី?»។
[10]លោកដាវីឌក៏បានទូលសម្តេចយ៉ូណាថានវិញថា៖ «តើអ្នកណានឹងប្រាប់ទូលបង្គំ
បើបិតារបស់សម្តេចតបនឹងសម្តេចយ៉ាងតឹងរឹងនោះ?»[11]សម្តេចយ៉ូណាថានបានឆ្លើយវិញថា៖ «មកនេះ ចូរយើងចេញទៅឯវាល»។ រួចអ្នកទាំងពីរក៏បានចេញទៅឯវាល។
[12]សម្តេចយ៉ូណាថានបានមានរាជឱង្ការទៅដាវីឌថា៖ «សូមឲ្យព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលធ្វើជាសាក្សី។ ពេលខ្ញុំទូលសួរបិតារបស់ខ្ញុំថ្ងៃស្អែកថ្មើរនេះ
ឬនៅថ្ងៃទីបី ហើយមើល បើបិតាមានបំណងល្អចំពោះឯង តើមិនឲ្យខ្ញុំបញ្ជូនដំណឹងនេះឲ្យឯងដឹងទេឬ?[13]បើបិតារបស់ខ្ញុំនៅតែមានបំណងបំផ្លាញឯង
ហើយខ្ញុំមិនចាត់គេឲ្យប្រាប់ឯងឲ្យដឹងទេ សូមព្រះអម្ចាស់ដាក់ទោសខ្ញុំឲ្យខ្លាំងមកចុះ ខ្ញុំនឹងឲ្យឯងចេញទៅមានសេរីភាព។ សូមព្រះអម្ចាស់គង់ជាមួយឯង
ដូចព្រះអង្គធ្លាប់គង់ជាមួយបិតារបស់ខ្ញុំដែរ។
[14]បើខ្ញុំនៅមានជីវិតរស់ សូមឯងបង្ហាញសម្ពន្ធមេត្រីភាពយ៉ាងស្មោះត្រង់ដែលបានធ្វើនៅចំពោះព្រះអម្ចាស់ នោះខ្ញុំនឹងមិនស្លាប់ឡើយ។
[15]សូមកុំកាត់ចំណងភាពស្មោះត្រង់នៃសម្ពន្ធមេត្រីនេះពីពូជពង្សវង្សត្រកូលរបស់ខ្ញុំឡើយ
បើទោះពេលណាព្រះអម្ចាស់បំផ្លាញសត្រូវទាំងអស់របស់ដាវីឌចេញពីផែនដីនេះក្តី»។[16]ដូច្នេះ
សម្តេចយ៉ូណាថានបានចងសម្ពន្ធមេត្រីជាមួយវង្សត្រកូលរបស់លោកដាវីឌដោយថ្លែងថា៖ «បើមិនដូច្នោះទេ
សូមព្រះអម្ចាស់ទូទាត់រឿងនេះតាមរយៈដៃរបស់ខ្មាំងសត្រូវលោកដាវីឌចុះ»។
[17]សម្តេចយ៉ូណាថានបានស្នើឲ្យលោកដាវីឌស្បថម្តងទៀត ពីព្រោះតែសេចក្តីស្រឡាញ់របស់សម្តេចចំពោះលោកដាវីឌ
ដោយសម្តេចពេញចិត្តលោកដាវីឌស្មើព្រះជន្មរបស់សម្តេចដែរ។[18]សម្តេចថ្លែងទៅព្រះបាទដាវីឌថា៖ «ស្អែកជាថ្ងៃបុណ្យដើមខែ។ ឯងមុខជាខកខាន
ពីព្រោះកន្លែងរបស់ឯងគ្មានអ្នកអង្គុយទេ។[19]ពេលបានលាក់ខ្លួននៅទីនោះបីថ្ងៃហើយ ចូរចេញពីទៅនោះ ហើយទៅកន្លែងដែលឯងធ្លាប់លាក់ខ្លួនសិន
គឺនៅក្បែរថ្មាំងថ្មឈ្មោះអេសែល។
[20]ខ្ញុំនឹងបាញ់ព្រួញបីគ្រាប់ទៅក្បែរនោះ គឺដូចខ្ញុំបាញ់ទៅរកគោលដៅមួយអ៊ីចឹង។[21]បន្ទាប់មក ខ្ញុំនឹងចាត់បាវម្នាក់ថា៖ «ចូរទៅរកគ្រាប់ព្រួញទាំងនោះមក។
បើខ្ញុំនិយាយប្រាប់វាថា៖ «ចូរមើលគ្រាប់ព្រួញនៅជិតឯងខាងនោះ ចូរយកមកណេះ» នោះចូរចេញមក ឯងមានសុវត្ថិភាព ដោយគ្មានគ្រោះថ្នាក់អ្វីទេ
ខ្ញុំសូមស្បថដោយនូវព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅ។
[22]ក៏ប៉ុន្តែ បើខ្ញុំនិយាយថាទៅបាវនោះថា មើល៍ គ្រាប់ព្រួញធ្លាក់ឆ្ងាយជាងឯង។ ដូច្នេះ ចូរឯងចេញទៅចុះ ដ្បិត ព្រះអម្ចាស់បានឲ្យឯងចេញទៅហើយ។
[23]អ្វីដែលយើងបាននិយាយព្រមព្រៀងគ្នានោះ មានព្រះអម្ចាស់ជាសាក្សីសម្រាប់យើងរហូតហើយ»។
[24]ក្រោយមក លោកដាវីឌបានលាក់ខ្លួននៅឯវាល។ ពេលបុណ្យដើមខែបានចូលមកដល់ នោះស្តេចគង់សោយព្រះស្ងោយ។[25]ស្តេចគង់នៅកន្លែងដូចសព្វមួយដង
នៅជិតជញ្ជាំង។ សម្តេចយ៉ូណាថានបានគង់នៅជិតនោះ លោកអប៊ីនើរអង្គុយនៅក្បែរស្តេចសូល។ ប៉ុន្តែ កន្លែងលោកដាវីឌ គ្មានអ្នកណាអង្គុយទេ។
[26]ព្រះបាទសូលពុំបានមានរាជឱង្ការអ្វីទេនៅថ្ងៃនោះ ពីព្រោះបានគិតថា៖ «មានអ្វីមិនស្រួលបានកើតឡើងដល់លោកដាវីឌហើយ។ លោកដាវីឌមិនបរិសុទ្ធទេ
គឺពិតជាមិនបរិសុទ្ធមែន»។[27]ប៉ុន្តែ នៅថ្ងៃបន្ទាប់ គឺបន្ទាប់ពីថ្ងៃបុណ្យដើមខែ កន្លែងរបស់លោកដាវីឌនៅតែគ្មានអ្នកអង្គុយដដែល។
ព្រះបាទសូលបានសួរសម្តេចយ៉ូណាថានជាបុត្រាថា៖ «ហេតុអ្វីកូនប្រុសរបស់លោកអ៊ីសាយមិនចូលរួមតុអាហារទាំងម្សិលមិញ ឬថ្ងៃនេះដូច្នេះ?»
[28]សម្តេចយ៉ូណាថានបានទូលតបថា៖ «ដាវីឌបានសុំការអនុញ្ញាតពីទូលបង្គំដើម្បីទៅភូមិបេថ្លេហិម[29]ថា សូមអនុញ្ញាតឲ្យទូលបង្គំទៅ។
ព្រោះគ្រួសាររបស់ទូលបង្គំនឹងថ្វាយយញ្ញបូជានៅក្នុងក្រុង ហើយបងប្រុសរបស់ទូលបង្គំឲ្យទូលបង្គំទៅទីនោះ។ ពេលនេះ បើព្រះអង្គមិនយល់ទាស់ទេ
សូមអនុញ្ញាតឲ្យទូលបង្គំទៅជួបជុំបងប្អូនរបស់ទូលបង្គំផង។ ដោយហេតុផលនេះហើយ ទើបដាវីឌមិនអាចមករួមតុអាហារជាមួយព្រះករុណា»។
[30]ព្រះបាទសូលខ្ញាល់យ៉ាងខ្លាំងនឹងសម្តេចយ៉ូណាថាន ដោយមានរាជឱង្ការទៅថា៖ «បុត្រឯងចង្រៃណាស់ អាបុត្រអត់ពូជ!
ស្មានថាបិតាមិនដឹងថាឯងពេញចិត្តកូនអ៊ីសាយមែនទេ ឯងធ្វើបែបនេះនឹងធ្វើឲ្យខ្លួនអាម៉ាសទាំងមាតាឯងថែមទៀត។
[31]ដរាបណាកូនរបស់អ៊ីសាយនៅមានជីវិតលើផែនដីនេះ នោះឯងគ្មានថ្ងៃអាចឡើងគ្រងរាជ្យបានឡើយ។ ដូច្នេះពេលនេះ ចូរចាត់គេឲ្យទៅតាមចាប់វាមកឲ្យយើងវិញ
វាត្រូវតែស្លាប់»។
[32]សម្តេចយ៉ូណាថានបានតបទៅបិតាវិញថា៖ «ដោយហេតុអ្វីទើបត្រូវដាវីឌមានទោសដល់ស្លាប់?
តើដាវីឌបានធ្វើអ្វីខុស?»[33]ពេលនោះព្រះបាទសូលបានចោលលំពែងដាក់សម្តេចដើម្បីសម្លាប់ចោល។[34]សម្តេចយ៉ូណាថានបានជ្រាបថា
បិតាបានសម្រេចថាត្រូវសម្លាប់លោកដាវីឌចោលហើយ ដូច្នេះ សម្តេចបានក្រោកចេញពីតុទាំងកំហឹងដោយមិនបានសោយអ្វីទាំងអស់នៅថ្ងៃបុណ្យដើមខែនោះ
ដោយសារស្តេចបានខ្ញាល់នឹងលោកដាវីឌ ហេតុនេះហើយ បិតារបស់ព្រះអង្គមិនបានទុកមុខឲ្យព្រះអង្គទេ។
[35]ពេលព្រឹកឡើង សម្តេចយ៉ូណាថានបានចាកចេញទៅឯវាលដើម្បីជួបលោកដាវីឌ ទាំងមានក្មេងម្នាក់នៅជាមួយសម្តេចផង។[36]សម្តេចបានប្រាប់ក្មេងនោះថា
ចូររត់ទៅរកគ្រាប់ព្រួញដែលខ្ញុំបាញ់។ ខណៈក្មេងនោះបានរត់ទៅ ព្រះអង្គបានបាញ់មួយគ្រាប់ផ្សេងទៀតឲ្យកាន់តែឆ្ងាយជាងក្មេងនោះ។
[37]ពេលក្មេងនោះទៅដល់កន្លែងគ្រាប់ព្រួញនោះ សម្តេចបានស្រែកទៅក្មេងនោះថា៖ «តើឯងរកឃើញគ្រាប់ព្រួញដែលធ្លាក់ឆ្ងាយជាងឯងទេ?»។
[38]ក្រោយមក សម្តេចយ៉ូណាថានបានស្រែកប្រាប់ក្មេងនោះទៀតថា៖ «ប្រញាប់ឡើង កុំបង្អង់នៅទីនោះឡើយ!» ហេតុនេះ ក្មេងនោះក៏បានប្រមូលគ្រាប់ព្រួញ
រួចត្រឡប់មករកសម្តេចវិញ។[39]ប៉ុន្តែ ក្មេងនោះមិនដឹងអ្វីទាំងអស់។ មានតែសម្តេចយ៉ូណាថាន និងលោកដាវីឌប៉ុណ្ណោះដែលដឹងរឿងនេះ។
[40]សម្តេចយ៉ូណាថានបានប្រទានអាវុធរបស់ព្រះអង្គទៅក្មេងនោះដោយបន្ទូលថា៖ «ចូរយកទៅឯក្រុងវិញចុះ»។
[41]ខណៈក្មេងនោះបានទៅបាត់ លោកដាវីឌបានក្រោកឈរឡើងនៅពីក្រោយពំនូកទម្លាក់មុខទៅដី ហើយឱនចុះបីដង។ ពួកគេបានថើបគ្នាទៅវិញទៅមក
ហើយយំទាំងអស់គ្នា គឺលោកដាវីឌយំយ៉ាងខ្លាំង។[42]សម្តេចយ៉ូណាថានមានរាជឱង្ការទៅលោកដាវីឌថា៖ «ចូរចេញទៅឲ្យបានសុខសាន្តចុះ
ព្រោះយើងបានស្បថក្នុងព្រះនាមព្រះអម្ចាស់ហើយថា សូមព្រះអម្ចាស់ធ្វើជាសាក្សីរវាងយើងទាំងពីរ និងរវាងកូនចៅរបស់ខ្ញុំនិងកូនចៅរបស់ឯងរហូតតទៅ។ បន្ទាប់មក
លោកដាវីឌបានក្រោកឡើងហើយបានចាកចេញទៅ ហើយសម្តេចយ៉ូណាថានបានត្រឡប់មកទីក្រុងវិញ។

---

1 Samuel 20:1

«ទូលបង្គំបានធ្វើអ្វីខុស? តើអ្វីជាអំពើទុច្ចរិតរបស់ទូលបង្គំ?

តើទូលបង្គំបានប្រព្រឹត្តអ្វីខុសនឹងបិតារបស់ព្រះអង្គ
បានជាទ្រង់ស្វះស្វែងចង់យកជីវិតទូលបង្គំបែបនេះ?»

generated on Wed Sep 10 16:16:32 2025

សំណួរទាំងបីនេះមានន័យដូចគ្នា។ ដាវីឌប្រើសំណួរទាំងនេះដើម្បីបញ្ជាក់ថា
គាត់មិនបានធ្វើអ្វីខុសចំពោះព្រះបាទសូលទេ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ទូលបង្គំបានធ្វើអ្វីខុស។ ទូលបង្គំមិនបានប្រព្រឹត្តអំពើទុច្ចរិតណាមួយទេ។
ទូលបង្គំមិនបានធ្វើបាបនឹងបិតារបស់ព្រះអង្គទេ។
ព្រះអង្គគ្មានហេតុផលដើម្បីយកជីវិតទូលបង្គំទេ»។
បានជាទ្រង់ស្វះស្វែងចង់យកជីវិតទូលបង្គំបែបនេះ?
នៅទីនេះ «យកជីវិតទូលបង្គំ» ជាពាក្យសម្តីសម្រាប់ «សម្លាប់ទូលបង្គំ»។
សូមកុំឲ្យមានរឿងនេះឡើយ
នៅទីនេះ« នៅឆ្ងាយពីវា» ជាឃ្លាដែលថា វាមិនជាការពិតទេ។
ការបកប្រែផ្សេងទៀត «មិនមែនជាការពិតទេ»
ទោះកិច្ចការតូច ឬធំក្តី
ពាក្យ «ធំឬតូច» រួមបញ្ចូលអ្វីៗទាំងអស់នៅចន្លោះ។ ការបកប្រែផ្សេងទៀត
«គ្មានអ្វីទាំងអស់»
ហេតុអ្វីបិតារបស់ខ្ញុំលាក់រឿងនេះនឹងខ្ញុំដូច្នេះ?
សម្តេចយ៉ូណាថានប្រើសំណួរនេះដើម្បីបញ្ជាក់ថា ព្រះបាទសូលបានប្រាប់គាត់
បើព្រះបិតាមានផែនការសម្លាប់ដាវីឌ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«បិតាខ្ញុំគ្មានហេតុផលដើម្បីលាក់រឿងនេះពីខ្ញុំទេ»ឬ
«បើរឿងនេះពិតបិតាខ្ញុំនឹងប្រាប់ខ្ញុំឲ្យដឹង»
មិនគួរយ៉ាងដូច្នេះសោះ
«វាមិនមែនជាការពិតទេ»
1 Samuel 20:3
សម្តេចពេញចិត្តនឹងទូលបង្គំ។
នៅទីនេះ ភ្នែកតំណាងឲ្យការមើលឃើញ ហើយការមើលឃើញតំណាងឲ្យគំនិត
ឬការវិនិច្ឆ័យ។ ការបកប្រែផ្សេងទៀត «សម្តេចពេញចិត្តទូលបង្គំ» ឬ
«សម្តេចចាត់ទុកទូលបង្គំថា គួរឲ្យពេញចិត្ត»
ទ្រង់មុខជាក្រៀមក្រំមិនខាន។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«នេះនឹងធ្វើឲ្យព្រះអង្គក្រៀមក្រំ» ឬ «ព្រះអង្គនឹងសោកសៅខ្លាំងបំផុត»
សេចក្តីស្លាប់នៅប្រកៀកនឹងទូលបង្គំណាស់»។
នៅទីនេះ« សេចក្តីស្លាប់នៅប្រកៀកនឹងទូលបង្គំណាស់» ជាឃ្លាមួយ
ដែលសំដៅទៅលើការគៀកនឹងសេចក្តីស្លាប់បំផុត។ ការបកប្រែផ្សេងទៀត
«ទូលបង្គំជិតស្លាប់ហើយ»
1 Samuel 20:4
ព័ត៌មានទូទៅ៖
ដាវីឌស្នើសុំការសាកល្បងប្រឆាំងនឹងស្តេចសូលចំពោះសម្តេចយ៉ូណាថាន។
ស្អែកជាថ្ងៃបុណ្យដើមខែ
នៅថ្ងៃទីមួយនៃខែនីមួយៗ ប្រជាជននាំគ្នាធ្វើបុណ្យ
និងថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់។
រហូតដល់ល្ងាចថ្ងៃទីបី។
«រហូតដល់ថ្ងៃល្ងាចនៅថ្ងៃខានស្អែក»
1 Samuel 20:6
ឃ្លាភ្ជាប់៖
ដាវីឌបន្តរៀបរាប់ពីការសាកល្បង ដែលគាត់ស្នើសុំ។
សុំទូលបង្គំចេញទៅ
«សុំទូលបង្គំ ក្រែងលោកទូលបង្គំអនុញ្ញាតឲ្យគាត់ចាកចេញទៅ»
ព្រះករុណាមានរាជឱង្ការថា ...ព្រះករុណា ... ព្រះករុណាបានសម្រេច
ពាក្យ«ព្រះករុណា»សំដៅទៅលើព្រះបាទសូល។
ទូលបង្គំនឹងមានសេរីភាពហើយ។
ដាវីឌនិយាយអំពីខ្លួនគាត់ដូចជាគាត់ជាមនុស្សម្នាក់ទៀត ដែលបង្ហាញថា
គាត់គោរពសម្តេចយ៉ូណាថាន។ ការបកប្រែផ្សេងទៀត
«ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គនឹងមានសេរីភាព»
1 Samuel 20:8
ឃ្លាភ្ជាប់៖
ដាវីឌបន្តនិយាយជាមួយសម្តេចយ៉ូណាថាន។
ទូលបង្គំផង ... បានចងសម្ព័ន្ធមេត្រីជាមួយទូលបង្គំ
ដាវីឌនិយាយអំពីខ្លួនគាត់ជាបុរសទីបី ជាទម្រង់នៃការបន្ទាបខ្លួន។
ការបកប្រែផ្សេងទៀត «ជាមួយទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ ...
បាននាំទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គមក» ឬ «ជាមួយទូលបង្គំ ...
បាននាំទូលបង្គំមក»
ព្រោះសម្តេចបានចងសម្ព័ន្ធមេត្រីជាមួយទូលបង្គំដោយនូវព្រះនាមព្រះអម្ចាស់ហើយ។
ជាអ្វីដែលបុរសទាំងពីរនាក់បានយល់ព្រមព្រៀងជាមួយគ្នា
អាចត្រូវបានធ្វើឲ្យច្បាស់។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានឮទូលបង្គំ
ពេលទូលបង្គំចងសម្ព័ន្ធមេត្រីយ៉ាងមុតមាំជាមួយព្រះអង្គថា
ទូលបង្គំនឹងធ្វើជាមិត្តល្អជានិច្ច»
មិនចាំបាច់យកទូលបង្គំទៅថ្វាយបិតារបស់ព្រះអង្គទេ?
សំណួរដ៏ប៉ិនប្រសប់នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«បន្ទាប់មក ព្រះអង្គគ្មានហេតុផលដើម្បីនាំទូលបង្គំទៅកាន់បិតារបស់ព្រះអង្គទេ»
សូមកុំគិតដូច្នេះអី!
នេះជាសំនួនវោហា ដែលមានន័យថា វានឹងមិនកើតឡើងចំពោះអ្នកឡើយ។
ការបកប្រែផ្សេងទៀត «រឿងនេះនឹងមិនកើតឡើងចំពោះអ្នកទេ!»
តើមិនឲ្យខ្ញុំប្រាប់ឯងទេឬអី?
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំប្រាកដជាប្រាប់ឯង»។
1 Samuel 20:12
មើល
«មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វី ដែលខ្ញុំរៀបនឹងប្រាប់អ្នក»
បើបិតាមានបំណងល្អ
«បិតាខ្ញុំចង់ធ្វើអ្វី ដែលល្អសម្រាប់អ្នក»
តើមិនឲ្យខ្ញុំបញ្ជូនដំណឹងនេះឲ្យឯងដឹងទេឬ?
សម្តេចយ៉ូណាថានប្រើសំណួរនេះដើម្បីបញ្ជាក់ថា គាត់នឹងប្រាប់ដាវីឌ
បើព្រះបាទសូលមានបំណងធ្វើបាបគាត់។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«បន្ទាប់មក ខ្ញុំប្រាកដជានឹងបញ្ជូនទៅអ្នក ហើយធ្វើឲ្យអ្នកដឹង»
សូមព្រះអម្ចាស់ដាក់ទោសខ្ញុំឲ្យខ្លាំងមកចុះ
នេះជាឃ្លាបែបសំនួនវោហាស័ព្ទ។
សម្តេចយ៉ូណាថានប្រើពាក្យសម្បថនេះដើម្បីបញ្ជាក់ និងនិយាយអំពីខ្លួនគាត់
ដូចជាគាត់ជាមនុស្សម្នាក់ផ្សេងទៀត។ ការបកប្រែផ្សេងទៀត
«សូមព្រះអម្ចាស់ធ្វើចំពោះខ្ញុំនូវអំពើអាក្រក់ ដែលបិតាខ្ញុំមានបំណងធ្វើចំពោះអ្នក
ហើយរឹតតែធ្វើលើសពីនេះទៅទៀត»
1 Samuel 20:14
ព័ត៌មានទូទៅ៖
សម្តេចយ៉ូណាថានស្នើរឲ្យដាវីឌ កុំសម្លាប់កូនចៅទាំងអស់របស់គាត់ ដូច្នេះ
ទុកឲ្យមាននៅសេសសល់បន្តទៀត។
សូមឯងបង្ហាញសម្ពន្ធមេត្រីភាពយ៉ាងស្មោះត្រង់ ដែលបានធ្វើនៅចំពោះព្រះអម្ចាស់
នោះខ្ញុំនឹងមិនស្លាប់ឡើយ។
សម្តេចយ៉ូណាថានសួរសំណួរនេះដើម្បីបញ្ជាក់ថា ដាវីឌនឹងធ្វើដូច្នេះ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«សូមបង្ហាញភាពស្មោះត្រង់នៃសម្ពន្ធមេត្រីភាពរបស់ព្រះអម្ចាស់
ដែលខ្ញុំនឹងមិនស្លាប់ទេ»
បង្ហាញសម្ពន្ធមេត្រីភាពយ៉ាងស្មោះត្រង់ដែលបានធ្វើនៅចំពោះព្រះអម្ចាស់
«ចូរបង្ហាញខ្ញុំពីប្រភេទភាពនៃសម្ពន្ធមេត្រីភាពដែលស្មោះត្រង់ដែលព្រះអម្ចាស់បង្ហាញ»
វង្សត្រកូលរបស់លោកដាវីឌ
ពាក្យថា «ផ្ទះ» ជាពាក្យប្រៀបធៀបសម្រាប់ប្រជាជន ដែលរស់នៅក្នុងផ្ទះ។
ការបកប្រែផ្សេងទៀត «គ្រួសាររបស់ដាវីឌ»
«បើមិនដូច្នោះទេ សូមព្រះអម្ចាស់ទូទាត់រឿងនេះតាមរយៈដៃរបស់ខ្មាំងសត្រូវលោកដាវីឌចុះ»។
ដៃជាផ្នែកមួយសម្រាប់មនុស្ស។ អាចមានន័យថា ១) «
សូមព្រះអម្ចាស់ប្រើសត្រូវរបស់ដាវីឌ ដាក់ទណ្ឌកម្មដាវីឌ
បើដាវីឌបំពានពាក្យសន្យានេះ ឬ ២)
«សូមឲ្យព្រះអម្ចាស់បំផ្លាញខ្មាំងសត្រូវរបស់ដាវីឌ»។
1 Samuel 20:17
សម្តេចពេញចិត្តលោកដាវីឌស្មើព្រះជន្មរបស់សម្តេចដែរ។
នៅទីនេះ «ស្មើព្រះជន្មរបស់សម្តេច» សំដៅទៅលើសម្តេចយ៉ូណាថានផ្ទាល់។
ការបកប្រែផ្សេងទៀត «សម្តេចយ៉ូណាថានស្រឡាញ់ដាវីឌ ដូចស្រឡាញ់ខ្លួនឯង»
ឯងមុខជាខកខាន
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «បិតាខ្ញុំនឹងនឹកអ្នក»
ឯងធ្លាប់លាក់ខ្លួនសិន

generated on Wed Sep 10 16:16:32 2025

នៅទីនេះ «ឯងធ្លាប់លាក់ខ្លួនសិន» ជាឃ្លាសម្គាល់
សំដៅទៅលើអ្វីៗបានកើតឡើង។ ការបកប្រែផ្សេងទៀត «ពេលអ្វីៗបានកើតឡើង»
ផ្នាំងថ្មឈ្មោះអេសែល
«អេសែល» ជាឈ្មោះផ្នាំងថ្ម។ ការបកប្រែផ្សេងទៀត «ផ្នាំងថ្មដែលមនុស្សហៅថា
អេសែល»
1 Samuel 20:20
ឃ្លាភ្ជាប់៖
សម្តេចយ៉ូណាថានបន្តនិយាយទៅកាន់ដាវីឌ។
ទៅក្បែរនោះ
នៅត្រង់នេះពាក្យថា« វា» សំដៅទៅលើថ្ម ដែលដាវីឌត្រូវលាក់ខ្លួន។
ខ្ញុំនឹងចាត់បាវម្នាក់ ...និយាយប្រាប់វាថា
ទាំងនេះសំដៅទៅលើមនុស្សតែមួយ។
ចូរមើល
«ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វី ដែលខ្ញុំរៀបនឹងប្រាប់អ្នក»
នោះចូរចេញមក
«បន្ទាប់មក ដាវីឌចេញមក»
1 Samuel 20:22
ឃ្លាភ្ជាប់៖
យ៉ូណាថានបន្តនិយាយទៅកាន់ដាវីឌ។
មើល៍
ពាក្យ «មើល៍ »នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វី ដែលនៅខាងក្រោម។
ការបកប្រែផ្សេងទៀត «សេចក្តីពិត»
មានព្រះអម្ចាស់ជាសាក្សីសម្រាប់យើងរហូតហើយ។
អាចមានន័យថា ១) «ព្រះអម្ចាស់ជាសាក្សីរវាងអ្នកនិងខ្ញុំ» ឬ
«ព្រះអម្ចាស់នឹងឃ្លាំមើលរបៀប ដែលយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក» ឬ ២)
«សូមឲ្យព្រះអម្ចាស់ធ្វើជាសាក្សីរវាងអ្នកនិងខ្ញុំ» ឬ «សូមព្រះអម្ចាស់ឃ្លាំមើលរបៀប
ដែលយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក»
1 Samuel 20:24
សម្តេចយ៉ូណាថានបានគង់នៅជិតនោះ
ច្បាប់ចម្លងពីបុរាណចែងថា «សម្តេចយ៉ូណាថានបានអង្គុយពីមុខគាត់»។
1 Samuel 20:26
លោកដាវីឌមិនបរិសុទ្ធទេ គឺពិតជាមិនបរិសុទ្ធមែន។
យោងទៅតាមក្រឹត្យវិន័យរបស់លោកម៉ូសេ
មនុស្សមិនបរិសុទ្ធមិនត្រូវចូលរួមក្នុងពិធីនោះឡើយ ដរាបណាបូជាចារ្យប្រកាសថា
គាត់បានបរិសុទ្ធសិន។ ព្រះបាទសូលមានបន្ទូលឃ្លានេះឡើងវិញ
ដូចជាទ្រង់កំពុងព្យាយាមធ្វើឲ្យព្រះអង្គជឿជាក់លើខ្លួនឯង។
1 Samuel 20:28
បានសុំការអនុញ្ញាតពីទូលបង្គំដើម្បីទៅ
«បានសុំឲ្យខ្ញុំអនុញ្ញាតឲ្យគាត់ទៅ»
បើព្រះអង្គមិនយល់ទាស់ទេ
នៅទីនេះ មិនយល់ទាស់
តំណាងឲ្យការយល់ឃើញហើយការយល់ឃើញតំណាងឲ្យគំនិត ឬការវិនិច្ឆ័យ។
បកប្រែដូចនៅក្នុង ២០:៣។ ការបកប្រែផ្សេងទៀត «ខ្ញុំពេញចិត្តអ្នក» ឬ
«អ្នកចាត់ទុកខ្ញុំថា គួរឲ្យពេញចិត្ត»
តុអាហារជាមួយព្រះករុណា
សម្តេចយ៉ូណាថានមានបន្ទូលអំពីព្រះបាទសូល
ហាក់បីដូចជាទ្រង់ជាមនុស្សម្នាក់ទៀត ដែលបង្ហាញថាទ្រង់គោរពស្តេចសូល។
ការបកប្រែផ្សេងទៀត «តុរបស់ព្រះករុណា»
1 Samuel 20:30
ព្រះបាទសូលខ្ញាល់យ៉ាងខ្លាំងនឹងសម្តេចយ៉ូណាថាន
នៅទីនេះ «ខ្ញាល់យ៉ាងខ្លាំង» ជាពាក្យប្រៀបធៀប
ដែលសំដៅទៅលើការខ្ញាល់យ៉ាងខ្លាំង។ ការបកប្រែផ្សេងទៀត
«ព្រះបាទសូលខ្ញាល់នឹងសម្តេចយ៉ូណាថានយ៉ាងខ្លាំង»
បុត្រឯងចង្រៃណាស់ អាបុត្រអត់ពូជ!
នេះជាឃ្លាសំនួនវោហាស័ព្ទ។
ព្រះបាទសូលប្រើឃ្លានេះជាការស្តីបន្ទោសយ៉ាងខ្លាំងដល់សម្តេចយ៉ូណាថាន
និងការយកចិត្តទុកដាក់របស់ទ្រង់ចំពោះដាវីឌ។ ការបកប្រែផ្សេងទៀត
«ឯងជាបុត្រលួងរបស់ស្រីពេស្យា» ឬ «ឯងជាមនុស្សល្ងីល្ងើ អាក្បត់ជាតិ»
ស្មានថាបិតាមិនដឹងថាឯងពេញចិត្តកូនអ៊ីសាយមែនទេ ... អាម៉ាសទាំងមាតាឯងថែមទៀត?
ព្រះបាទសូលប្រើសំណួរនេះដើម្បីបញ្ជាក់ថា ទ្រង់ដឹងថាយ៉ូណាថាន
និងដាវីឌជាមិត្តនឹងគ្នា។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«យើងដឹងថា ឯងបានជ្រើសរើសកូនប្រុសរបស់អ៊ីសាយ ...
អាម៉ាសទាំងមាតាឯងថែមទៀត» ។
ឯងធ្វើបែបនេះនឹងធ្វើឲ្យខ្លួនអាម៉ាសទាំងមាតាឯងថែមទៀត
នៅទីនេះ «ធ្វើឲ្យខ្លួនអាម៉ាសទាំងមាតាឯងថែមទៀត»
ជាឃ្លាដែលសំដៅទៅលើម្តាយ ដែលបានផ្តល់កំណើតឲ្យអ្នក។
ការបកប្រែផ្សេងទៀត «ធ្វើឲ្យអាម៉ាសទាំងម្តាយដែលបានផ្តល់កំណើតឲ្យឯង»
នោះឯងគ្មានថ្ងៃអាចឡើងគ្រងរាជ្យបានឡើយ។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកនឹងមិនក្លាយជាស្តេចទេ ហើយអ្នកក៏នឹងមិនឡើងគ្រងរាជ្យបានដែរ»
1 Samuel 20:32
ដោយហេតុអ្វីទើបត្រូវដាវីឌមានទោសដល់ស្លាប់?
សម្តេចយ៉ូណាថានកំពុងព្យាយាមធ្វើឲ្យព្រះបាទសូល
គិតយ៉ាងប្រុងប្រយ័ត្នអំពីអ្វីដែលទ្រង់កំពុងធ្វើ។ អាចបកប្រែជាសេចក្តីថ្លែងការណ៍
ហើយពាក្យថា «គាត់គួរតែត្រូវគេសម្លាប់» អាចបកប្រែជាទម្រង់កិរិយាសកម្ម។
ការបកប្រែផ្សេងទៀត «អ្នកគ្មានមូលហេតុត្រឹមត្រូវក្នុងការសម្លាប់គាត់ទេ
គាត់មិនបានធ្វើអ្វីខុសទេ»។ ឬ «អ្នកគ្មានមូលហេតុត្រឹមត្រូវក្នុងការសម្លាប់គាត់ទេ។
គាត់មិនបានធ្វើអ្វីខុសទេ»។
នៅថ្ងៃបុណ្យដើមខែនោះ
នៅទីនេះ «ទីពីរ» ជាលេខធម្មតាដែលសំដៅទៅលើពីរ។ ការបកប្រែផ្សេងទៀត
«ថ្ងៃទី២ នៃពិធីបុណ្យសែនព្រះខែ»
ស្តេចបានខ្ញាល់នឹងលោកដាវីឌ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«គាត់សោកសៅចំពោះដាវីឌ»
បានទុកមុខឲ្យព្រះអង្គទេ
នៅទីនេះ «គាត់» សំដៅទៅលើដាវីឌ។
1 Samuel 20:35
ទាំងមានក្មេងម្នាក់នៅជាមួយសម្តេចផង។
នៅទីនេះ «សម្តេច»សំដៅទៅលើសម្តេចយ៉ូណាថាន។
ព្រះអង្គបានបាញ់មួយគ្រាប់ផ្សេងទៀតឲ្យកាន់តែឆ្ងាយជាងក្មេងនោះ។
«សម្តេចយ៉ូណាថានបានបាញ់ព្រួញឆ្ងាយជាងក្មេងនោះ»
«តើឯងរកឃើញគ្រាប់ព្រួញដែលធ្លាក់ឆ្ងាយជាងឯងទេ?»។
សម្តេចយ៉ូណាថានប្រើសំណួរនេះដើម្បីបញ្ជាក់ថា ព្រួញនៅឆ្ងាយជាងក្មេងនោះ។
ការប្រើប្រាស់ឃ្លាខាងលើក៏បញ្ជាក់លើចំណុចនេះដែរ។
សំណួរដ៏ប៉ិនប្រសព្វអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកគួរតែដឹងថា ព្រួញនោះនៅឆ្ងាយជាងព្រួញអ្នក» ឬ «ព្រួញនៅឆ្ងាយជាងអ្នក»
1 Samuel 20:38
បានស្រែកប្រាប់ក្មេងនោះទៀតថា៖ «ប្រញាប់ឡើង»
«បានស្រែករកក្មេងនោះដែលកំពុងរត់ឆ្ងាយពីសម្តេច សូមប្រញាប់ឡើង»
1 Samuel 20:41
ពំនូក
វាហាក់ដូចជាដាវីឌបានលាក់ខ្លួននៅពីក្រោយពំនូក ឬផ្នាំងថ្ម (សូមមើលយូឌីបី).
ទម្លាក់មុខទៅដី ហើយឱនចុះបីដង។
ដាវីឌបានក្រាបថ្វាយបង្គំសម្តេចយ៉ូណាថាន ដែលនៅតែជាបុត្ររបស់ស្តេច
ដែលសមនឹងទទួលការគោរពបែបនេះ។ នេះជាលើកចុងក្រោយ
ដែលដាវីឌបានជួបសម្តេចយ៉ូណាថាន។
សូមព្រះអម្ចាស់ធ្វើជាសាក្សីរវាងយើងទាំងពីរ
អាចមានន័យថា ១)«ព្រះអម្ចាស់ជាសាក្សីរវាងអ្នកនិងខ្ញុំ» ឬ
«ព្រះអម្ចាស់នឹងមើលរបៀប ដែលយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក» ឬ ២)
«សូមឲ្យព្រះអម្ចាស់ធ្វើជាសាក្សីរវាងអ្នកនិងខ្ញុំ» ឬ «សូមព្រះអម្ចាស់ឃ្លាំមើលរបៀប
ដែលយើងប្រព្រឹត្តចំពោះគ្នា។« បកប្រែដូចនៅក្នុង២០:២២។

21 [1]ក្រោយមក លោកដាវីឌបានមកដល់ភូមិណូប ដើម្បីជួបបូជាចារ្យអហ៊ីម៉ាឡេក។ លោកអហ៊ីម៉ាឡេកបានមកជួបលោកដាវីឌទាំងភិតភ័យ ហើយមានប្រសាសន៍ថា៖
«ហេតុអ្វីបានជាលោកនៅតែម្នាក់ឯង គ្មានអ្នកណានៅជាមួយដូច្នេះ?»[2]លោកដាវីឌបានតបទៅលោកអហ៊ីម៉ាឡេកជាបូជាចារ្យវិញថា៖

generated on Wed Sep 10 16:16:32 2025

«ស្តេចបានចាត់ខ្ញុំឲ្យធ្វើបេសកកម្មមួយនេះថា៖ «មិនត្រូវឲ្យនរណាម្នាក់ដឹងពីកិច្ចការងារនៃបេសកកម្មដែលយើងចាត់ឲ្យឯង និងបង្គាប់ឲ្យធ្វើនេះទេ»។
ខ្ញុំក៏បានដឹកនាំទាហាននៅកន្លែងមួយផងដែរ។
[3]ឥឡូវ លោកមានអ្វីខ្លះ? សូមឲ្យនំបុ័ងប្រាំដុំមកខ្ញុំ ឬអ្វីដែលលោកមានមកខ្ញុំផង»។[4]លោកបូជាចារ្យបានតបនឹងលោកដាវីឌវិញថា៖ «នៅទីនេះ គ្មាននំបុ័ងធម្មតាទេ ប៉ុន្តែ
មាននំបុ័ងតាំងថ្វាយព្រះជាម្ចាស់អាចទទួលទានបាន ប្រសិនបើទាហានទាំងនោះមិនបានប៉ះពាល់ជាមួយស្ត្រី»។
[5]លោកដាវីឌបានឆ្លើយតបនឹងបូជាចារ្យវិញថា៖ «មែនហើយ ជាធម្មតា មុនចេញទៅសមរភូមិយើងមិនបានប៉ះពាល់នឹងស្ត្រីណាទេ
ហើយក្នុងកំឡុងបីថ្ងៃមកហើយយើងបាននៅដោយឡែកពីស្ត្រីៗ។ អ្វីៗដែលជារបស់បុរសៗ គឺត្រូវញែកចេញដាច់ បើទោះជាមានបេសកកម្មធម្មតាក៏ដោយ។ តើថ្ងៃនេះ
ពួកយើងមិនញែកខ្លួនដោយឡែកទេឬអី!»[6]ឮដូច្នោះ បូជាចារ្យបានឲ្យនំបុ័ងតាំងថ្វាយព្រះជាម្ចាស់ដែលបានញែកដោយឡែកនោះ ដល់លោកដាវីឌ
ព្រោះគ្មាននំបុ័ងអ្វីធម្មតាផ្សេងទៀតក្រៅពីនំបុ័ងតាំងថ្វាយព្រះជាម្ចាស់ ដែលត្រូវយកពីព្រះហស្តរបស់ព្រះអម្ចាស់
និងដើម្បីដូរដាក់នំបុ័ងក្តៅថ្មីបន្ទាប់ពីរើនំបុ័ងចាស់ចេញហើយ។
[7]ខណៈនោះ មានបាវម្នាក់របស់ស្តេចសូលក៏នៅទីនោះជាវេនបម្រើព្រះអម្ចាស់របស់គាត់ដែរនៅថ្ងៃនោះ។ លោកមានឈ្មោះថា ដូអេក ជាជនជាតិអេដុម
ជាអ្នកគ្រប់គ្រងលើអ្នកមើលហ្វូងសត្វរបស់ព្រះបាទសូល។
[8]លោកដាវីឌបានមានប្រសាសន៍ទៅលោកអហ៊ីម៉ាឡេកថា៖ «តើលោកមានដាវ ឬលំពែងដែរឬទេ? ដោយសារស្តេចបានចាត់ខ្ញុំឲ្យបេសកកម្មនេះបន្ទាន់ ខ្ញុំពុំបានយកដាវ
លំពែងរបស់ខ្ញុំមកជាមួយទេ»។[9]បូជាចារ្យតបថា៖ «នៅទីនេះមានដាវរបស់កូលីយ៉ាត ជាទាហានរបស់ពួកភីលីស្ទីន ដែលលោកបានសម្លាប់នៅឯជ្រោះអេឡា
ដែលរុំនឹងក្រណាត់ នៅពីក្រោយអាវអេផូដ។ ប្រសិនបើ លោកចង់យកដាវនោះ ចូរយកទៅចុះ។ ព្រោះថាគ្មានអ្វីផ្សេងក្រៅពីនេះទេ»។ លោកដាវីឌបានតបវិញថា៖
«តើគ្មានដាវផ្សេងស្រដៀងនេះឬទេ បើមានសូមយកមកប្រគល់ឲ្យខ្ញុំនៅទីនេះចុះ»។
[10]នៅថ្ងៃដដែលនោះ លោកដាវីឌបានគេចខ្លួនពីព្រះបាទសូល ទៅជួបនឹងព្រះបាទអគីស នៅក្រុងកាថ។[11]រាជបម្រើរបស់ព្រះបាទអគីសបានទូលប្រាប់ស្តេចថា៖
«តើនេះមិនមែនជាលោកដាវីឌ ជាស្តេចរបស់អ៊ីស្រាអែលទេឬអី។ មានមនុស្សច្រៀងតគ្នាទៅវិញទៅមកពីលោកដាវីឌនេះថា ព្រះបាទសូលបានសម្លាប់រាប់ពាន់
ឯលោកដាវីឌបានសម្លាប់សត្រូវរាប់ម៉ឺន»។
[12]លោកដាវីឌបានទទួលពាក្យទាំងនោះដាក់ក្នុងចិត្ត ហើយមានសេចក្តីភ័យខ្លាចចំពោះព្រះបាទអគីស ស្តេចក្រុងកាថជាខ្លាំង។[13]លោកបានប្តូរកាយវិការនៅនឹងមុខពួកគេ
ហើយធ្វើពុតជាលីលានៅពេលពួកនោះចាប់លោកផង។ លោកបានធ្វើជាគូសសញ្ញាផ្សេងៗនៅលើខ្លោងទ្វារ រួចបង្ហូរទឹកមាត់ចុះមកលើពុកចង្ការរបស់ខ្លួនឯងទៀតផង។
[14]ឃើញដូច្នេះ ព្រះបាទអគីសបានថ្លែងទៅរាជបម្រើថា៖ «មើលចុះ ឯងឃើញទេ បុរសនេះឆ្កួតហើយ។ ហេតុអ្វីបានជាឯងយកមនុស្សបែបនេះមកជួបយើងដូច្នេះ?
[15]តើយើងខ្វះមនុស្សបែបនេះណាស់ឬ បានជាឯងយកមនុស្សនេះមកសម្តែងកាយវិការលីលានៅចំពោះមុខយើងដូច្នេះ?
ឯងមិនគួរយកមនុស្សបែបនេះមកក្នុងដំណាក់របស់យើងទេ?»។

---

1 Samuel 21:1

ភូមិណូប

ឈ្មោះទីកន្លែង

បូជាចារ្យអហ៊ីម៉ាឡេក

ឈ្មោះរបស់មនុស្សប្រុស

ភិតភ័យ

ភ័យខ្លាចឡើងញ័រ

ឲ្យធ្វើបេសកកម្ម

«បំពេញកិច្ចការថ្វាយស្តេច»

ខ្ញុំក៏បានដឹកនាំទាហាននៅកន្លែងមួយផងដែរ។

«ខ្ញុំបានប្រាប់ទាហានទាំងនោះឲ្យទៅកន្លែងផ្សេងទៀត
ហើយខ្ញុំនឹងជួបពួកគេនៅពេលក្រោយ» (សូមមើល យូឌីប៊ី)

1 Samuel 21:3

ឥឡូវ

ដាវីឌកំពុងចាប់ផ្តើមផ្នែកថ្មីនៃការសន្ទនា។

លោកមានអ្វីខ្លះ?

នៅទីនេះ «នៅលើដៃ» ជាការប្រៀបធៀបដែលមានន័យគ្រប់គ្រាន់។
ការបកប្រែផ្សេងទៀត «តើអ្នកមានអាហារអ្វីដែលអ្នកអាចផ្តល់ឲ្យខ្ញុំ?»

សូមឲ្យនំបុ័ងប្រាំដុំមកខ្ញុំ

នេះជាសំណើគួរសម។

នំបុ័ងធម្មតា

នំបុ័ងដែលពួកសង្ឃមិនបានប្រើក្នុងការថ្វាយបង្គំ

មាននំបុ័ងតាំងថ្វាយព្រះជាម្ចាស់

នំបុ័ងដែលពួកបូជាចារ្យមិនបានប្រើក្នុងការថ្វាយបង្គំ

ប្រសិនបើទាហានទាំងនោះមិនបានប៉ះពាល់ជាមួយស្ត្រី

អាចបកប្រែជាប្រយោគពេញលេញ។ ការបកប្រែផ្សេងទៀត
«ទាហានរបស់អ្នកអាចបរិភោគវា
បើពួកគេមិនបានគេងជាមួយស្ត្រីនាពេលថ្មីៗនេះ»

1 Samuel 21:5

មិនបានប៉ះពាល់នឹងស្ត្រីណាទេ

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«យើងបានរក្សាខ្លួនយើងពីស្ត្រី»

ក្នុងកំឡុងបីថ្ងៃ

«៣ថ្ងៃ

យើងបាននៅដោយឡែកពីស្ត្រីៗ

«ពេលខ្ញុំចាប់ផ្តើមដំណើរ»

អ្វីៗដែលជារបស់បុរសៗ គឺត្រូវញែកចេញដាច់

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«បុរសបានដាក់អ្វីៗដែលជាកម្មសិទ្ធិរបស់ពួកគេដាច់ដោយឡែក»

តើថ្ងៃនេះ ពួកយើងមិនញែកខ្លួនដោយឡែកទេឬអី!

នេះជាសេចក្តីថ្លែងការណ៍មិនមែនជាសំណួរទេ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «វាជាការពិត
ជាពិសេសនៅថ្ងៃនោះ ដែលពួកគេនឹងញែកអ្វីៗដែលពួកគេមាន»

នំបុ័ងតាំងថ្វាយព្រះជាម្ចាស់ ដែលបានញែកដោយឡែកនោះ

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«នំបុ័ងដែលពួកបូជាចារ្យបានញែកចេញ»

ដែលត្រូវយកពីព្រះហស្តរបស់ព្រះអម្ចាស់ និងដើម្បីដូរដាក់

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលពួកបូជាចារ្យបានយកចេញពីព្រះភក្ត្រព្រះអម្ចាស់ ដូច្នេះពួកគេដាក់»

1 Samuel 21:7

ដូអេក ... អ្នកមើលហ្វូងសត្វ

អ្នកប្រហែលជាត្រូវនិយាយយ៉ាងច្បាស់ថា ដូអេកបានឃើញអ្វីដែលដាវីឌបានធ្វើ។
ការបកប្រែផ្សេងទៀត «ដូអេក ... អ្នកមើលហ្វូងចៀម
ហើយគាត់បានឃើញអ្វីដែលបូជាចារ្យអហ៊ីម៉ាឡេកបានធ្វើ»

ដូអេក

ឈ្មោះរបស់មនុស្សប្រុស ។

ជាវេនបម្រើព្រះអម្ចាស់របស់គាត់ដែរនៅថ្ងៃនោះ។

អាចមានន័យថា ១)« ដ្បិតព្រះអម្ចាស់បានឃុំឃាំងគាត់នៅទីនោះ» ដូច្នេះ
ប្រហែលដូអេកអាចបញ្ជាក់អ្វីៗ ដែលគាត់បានសន្យាដល់ព្រះអម្ចាស់ថា គាត់នឹងធ្វើ

អ្នកមើលហ្វូងសត្វ

អ្នកថែរក្សា និងអ្នកការពារហ្វូងសត្វ ជាពិសេសសត្វគោ ឬចៀម

1 Samuel 21:8

តើលោកមានដាវ ឬលំពែងដែរឬទេ?

នៅទីនេះ «មាន» ជាពាក្យប្រៀបធៀប «អាច» ។ ការបកប្រែផ្សេងទៀត
«តើអ្នកមានលំពែង ឬដាវដែលអ្នកអាចផ្តល់ឲ្យខ្ញុំបានទេ?» បកប្រែដូចនៅក្នុង
២១:៣។

គ្រឿងសឹក

ឈ្មោះទូទៅដូចជាដាវកាំបិត ព្រួញ ធ្នូ និងលំពែង

generated on Wed Sep 10 16:16:32 2025

ជ្រោះអេឡា
នេះជាឈ្មោះទីកន្លែងនៅអ៊ីស្រាអែល។
1 Samuel 21:10
តើនេះមិនមែនជាលោកដាវីឌ ជាស្តេចរបស់អ៊ីស្រាអែលទេឬអី?
ពួកគេប្រហែលជានិយាយបំផ្លើស
ពេលពួកគេនិយាយថាដាវីឌជាស្តេចរបស់អ៊ីស្រាអែល។
ពួកគេបានប្រើសំណួរនេះដើម្បីបញ្ជាក់ថា ដាវីឌជាសត្រូវដ៏ខ្លាំងក្លា
ហើយស្តេចអគីសមិនគួរទុកឲ្យគាត់នៅទីនោះទេ។ ការបកប្រែផ្សេងទៀត
«អ្នកដឹងថានេះគឺជាដាវីឌ ជាអ្នកដែលមានគ្រោះថ្នាក់
ដូចជាស្តេចរបស់អ៊ីស្រាអែល»
មានមនុស្សច្រៀងតគ្នាទៅវិញទៅមកពីលោកដាវីឌនេះថា ព្រះបាទសូល ... រាប់ពាន់ ?
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកដឹងទេថា ពេលប្រជាជននៅលើទឹកដីកំពុងរាំ
ពួកគេបានច្រៀងជាមួយគ្នាអំពីព្រះអង្គ «គឺព្រះបាទសូល ... រាប់ពាន់នាក់»។
1 Samuel 21:12
លោកដាវីឌបានទទួលពាក្យទាំងនោះដាក់ក្នុងចិត្ត
នៅទីនេះ «បានយក ... ដាក់ក្នុងចិត្ត» ជាពាក្យប្រៀបធៀប
ដើម្បីគិតឲ្យបានហ្មត់ចត់អំពីអ្វី ដែលត្រូវបានគេនិយាយ។ ការបកប្រែផ្សេងទៀត
«ដាវីឌបានគិតយ៉ាងច្បាស់អំពីអ្វី ដែលពួកអ្នកបម្រើនិយាយ»
ពេលពួកនោះចាប់លោកផង។
នៅទីនេះ «ចាប់» ជាពាក្យប្រៀបធៀបសម្រាប់មនុស្ស។ ការបកប្រែផ្សេងទៀត
«នៅចំពោះមុខរបស់ពួកគេ»
1 Samuel 21:14
មើលចុះ ឯងឃើញទេ បុរសនេះឆ្កួតហើយ។
អាចមានន័យថា ១) ព្រះបាទអគីសទាមទារឲ្យពួកអ្នកបម្រើរបស់ព្រះអង្គ
ពន្យល់អំពីមូលហេតុដែលពួកគេនាំដាវីឌមកឯព្រះអង្គ ឬ
២)ព្រះបាទអគីសកំពុងស្តីបន្ទោសពួកគេ ដោយសំណួរដ៏ប៉ិនប្រសព្វ។
ការបកប្រែផ្សេងទៀត «អ្នកគួរតែបានដឹងថា មិនគួរនាំគាត់មកយើងទេ» ។
តើយើងខ្វះមនុស្សបែបនេះណាស់ឬ
បានជាឯងយកមនុស្សនេះមកសម្តែងកាយវិការលីលានៅចំពោះមុខយើងដូច្នេះ?
សំណួរដ៏ប៉ិនប្រសព្វនេះជាការស្តីបន្ទោស។ ការបកប្រែផ្សេងទៀត
«មានមនុស្សឆ្កួតគ្រប់គ្រាន់នៅទីនេះ ដែលខ្ជះខ្ជាយពេលវេលារបស់យើង។
អ្នកមិនគួរនាំមនុស្សបែបនេះមកចំពោះមុខយើងទេ»។
ឯងមិនគួរយកមនុស្សបែបនេះមកក្នុងដំណាក់របស់យើងទេ?
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«កុំអនុញ្ញាតឲ្យបុរសបែបនេះចូលក្នុងដំណាក់របស់យើង»។

---

22 [1]លោកដាវីឌបានចាកចេញ ហើយភៀសខ្លួនទៅល្អាងភ្នំឈ្មោះអាឌូឡាំ។ ពេលបងៗ និងអ្នកផ្ទះរបស់ឪពុកលោកបានដឹងដំណឹងនេះ
ពួកគេបានចុះទៅទីនោះដើម្បីជួបនឹងលោក។[2]អស់អ្នកដែលមានទុក្ខព្រួយ អ្នកជាប់បំណុល អ្នកដែលខកចិត្តទាំងប៉ុន្មានបានមកជុំគ្នាជួបជាមួយលោកដាវីឌ។
លោកដាវីឌបានក្លាយជាអ្នកដឹកនាំលើពួកគេ ហើយពួកគេមានគ្នាប្រមាណបួនរយនាក់ដែលនៅជាមួយលោកដាវីឌ។
[3]ក្រោយមក លោកដាវីឌបានចេញពីទីនោះទៅឯមីសប៉ា ក្នុងស្រុកម៉ូអាប់។ លោកបានទូលស្តេចម៉ូអាប់ថា៖
«សូមអនុញ្ញាតឲ្យឪពុកម្តាយទូលបង្គំទៅនៅជាមួយព្រះករុណារហូតដល់ទូលបង្គំជ្រាបព្រះទ័យរបស់ព្រះជាម្ចាស់ចំពោះទូលបង្គំយ៉ាងណាសិន»។
[4]នោះលោកបានទុកពួកគាត់នៅនឹងស្តេចម៉ូអាប់។ ឪពុកម្តាយរបស់លោកបាននៅជាមួយលោកគ្រប់ពេល ហើយលោកដាវីឌបានទៅជាទីដ៏មាំមួនសម្រាប់ពួកគេវិញ។
[5]រួចព្យាការីនៅកាដបានប្រាប់លោកដាវីឌថា៖ «កុំស្នាក់នៅទីដែលគិតថាមាំមួននេះឡើយ ចូរចាកចេញពីទីនេះទៅទឹកដីស្រុកយូដា»។ ដូច្នេះ
លោកដាវីឌបានចាកចេញពីទីនោះ រួចបន្តដំណើរទៅឯព្រៃហារេតវិញ។
[6]នោះព្រះបាទសូលបានជ្រាបថា លោកដាវីឌបានដឹងរឿងនេះហើយ ទាំងពួកទាហាននៅជាមួយលោក។
កាលព្រះបាទសូលកំពុងតែគង់ក្រោមម្លប់ដើមម៉ៃសាក់នៅភូមិគីបៀរ ឯរ៉ាម៉ា ទាំងកាន់លំពែងក្នុងដៃផង ក៏មានបាវបម្រើជាច្រើនឈរជុំវិញស្តេចទៀតផង។
[7]ព្រះបាទសូលបានសួរបាវដែលឈរជិតនោះថា៖ «ឱពួកបេនយ៉ាមីនអើយចូលស្តាប់! តើកូនប្រុសរបស់អ៊ីសាយឲ្យស្រែ និងចម្ការទំពាំងបាយជូរទៅអ្នករាល់គ្នាឬ?
តើវាជាអ្នកធ្វើឲ្យអស់លោកទៅជាមេទ័ពលើទាហានរាប់ពាន់នាក់ និងលើរាប់រយនាក់ឬ?[8]តើនោះមិនមែនជាថ្នូរឲ្យអ្នកដាក់អន្ទាក់ប្រឆាំងនឹងយើងទេឬ?
គ្មាននរណាមករាយការណ៍ឲ្យយើងដឹង ពេលបុត្ររបស់យើងចងសម្ពន្ធមេត្រីជាមួយកូនប្រុសលោកអ៊ីសាយទេ។ គ្មាននរណាម្នាក់ស្តាយខ្ញុំទេ
ហើយក៏នរណារាយការណ៍ប្រាប់យើងពីការដែលបុត្ររបស់យើងឃុបឃិតនឹងបាវរបស់យើង គឺជាមួយលោកដាវីឌ ដាក់អន្ទាក់មកយើងទេ។ ថ្ងៃនេះ វាលាក់ខ្លួន
ហើយចាំស្ទាក់យើង ពួកវាត្រៀមវាយប្រហារយើង។
[9]ក្រោយមក លោកដូអេក ជាជនជាតិអេដុម ដែលឈរនៅជិតបាវបម្រើរបស់ព្រះបាទសូលទូលទៅស្តេចថា៖
«ទូលបង្គំបានឃើញកូនប្រុសរបស់លោកអ៊ីសាយមកឯភូមិណូប ជួបនឹងកូនរបស់លោកអហ៊ីទូប ឈ្មោះអហ៊ីម៉ាឡេក។
[10]លោកអហ៊ីម៉ាឡេកបានទូលទៅព្រះអម្ចាស់ដើម្បីជួយដល់លោកដាវីឌ ទាំងបានផ្តល់អាហារឲ្យ ជាមួយនឹងដាវរបស់កូលីយ៉ាត ជាទាហានរបស់ពួកភីលីស្ទីនផង»។
[11]បន្ទាប់មក ស្តេចក៏ចាត់ម្នាក់ឲ្យទៅកោះហៅលោកបូជាចារ្យអហ៊ីម៉ាឡេក នៅឯភូមិណូប ជាកូនរបស់លោកអហ៊ីទូប និងអ្នកផ្ទះរបស់ឪពុករបស់គាត់មក។
ពួកគេទាំងអស់គ្នាបានមកជួបស្តេច។[12]ស្តេចមានរាជឱង្ការថា៖ «ឱកូនលោកអហ៊ីទូបអើយ ចូរស្តាប់យើង»។ លោកអហ៊ីម៉ាឡេកបានទូលស្តេចវិញថា៖ «ក្រាបទូលព្រះអង្គ
ទូលបង្គំនៅទីនេះហើយ»។[13]ព្រះបាទសូលបានមានរាជឱង្ការថា៖ «ឱលោកហើយនិងកូនប្រុសរបស់លោកអ៊ីសាយអើយ
ហេតុអ្វីបានជាលោកត្រឡប់មកប្រឆាំងនឹងយើងដូច្នេះ លោកបានផ្តល់នំបុ័ង និងដាវ ព្រមទាំងទូលអង្វរព្រះជាម្ចាស់ដើម្បីជួយលោកដាវីឌ លាក់វានៅកន្លែងដ៏កំបាំង
គឺដើម្បីឲ្យលោកដាវីឌក្រោកឡើងប្រឆាំងនឹងយើងដូច្នេះ មើលវាធ្វើសព្វថ្ងៃចុះ?»
[14]បន្ទាប់មក លោកអហ៊ីម៉ាឡេកបានឆ្លើយនឹងស្តេចវិញថា៖ «តើមានបាវបម្រើណាមួយរបស់ស្តេចដែលមានភាពស្មោះត្រង់ដូចជាលោកដាវីឌឬទេ
លោកគឺជាបុត្រប្រសារបស់ស្តេច ហើយលើសពីកងការពារ និងត្រូវបានគេគោរពណាស់នៅក្នុងរាជវង្សរបស់ព្រះអង្គ។
[15]តើនេះជាថ្ងៃទីមួយដែលទូលបង្គំបានអធិស្ឋានសូមព្រះជាម្ចាស់ជួយលោកឬ? កុំឲ្យទូលបង្គំធ្វើដូច្នេះឡើយ! សូមស្តេចកុំខ្ញាល់នឹងអ្នកបម្រើព្រះអង្គ
និងពូជពង្សរបស់ទូលបង្គំឡើយ។ ពីព្រោះទូលបង្គំពុំបានដឹងរឿងអ្វីឡើយ»។
[16]ស្តេចបានតបវិញថា៖ «លោកមុខជាស្លាប់មិនខាន លោកអហ៊ីម៉ាឡេក គឺលោក ព្រមទាំងពូជពង្សរបស់លោកផងដែរ»។
[17]ស្តេចបានបញ្ជាកងការពារដែលនៅជុំវិញនោះថា៖ «ចូរប្រហារជីវិតបូជាចារ្យនៃព្រះអម្ចាស់។ ដោយព្រោះដៃរបស់ពួកគេក៏នៅខាងលោកដាវីឌដែរ
ហើយដោយព្រោះពួកគេដឹងថា លោកដាវីឌបានគេចខ្លួន ប៉ុន្តែ មិនរាយការណ៍ដល់យើងទេ»។ ប៉ុន្តែ
មនុស្សរបស់ស្តេចមិនចង់លើកដៃប្រហារជីវិតបូជាចារ្យរបស់ព្រះជាម្ចាស់ទេ។
[18]បន្ទាប់មកស្តេចបានមានបន្ទូលទៅលោកដូអេកថា៖ «ចូរទៅប្រហារជីវិតបូជាចារ្យទាំងនេះទៅ»។ លោកដូអេក ជាជនជាតិអេដុម ក៏បានបែរទៅសម្លាប់បូជាចារ្យទាំងនោះ
គឺបានសម្លាប់អស់ប៉ែតសិបប្រាំនាក់ ជាអស់អ្នកដែលពាក់អាវអេផូដដែលធ្វើពីក្រណាត់ទេសឯកនៅថ្ងៃនោះ។[19]ស្តេចបានសម្លាប់ទាំងមនុស្សប្រុសស្រី ទាំងក្មេង ទាំងទារក
ទាំងគោ ទាំងលា និងចៀមនៅភូមិណូប ដែលរស់នៅក្នុងភូមិនោះ។ ស្តេចបានសម្លាប់ពួកគេទាំងអស់ដោយមុខដាវ។
[20]ក៏ប៉ុន្តែកូនប្រុសម្នាក់ក្នុងចំណោមកូនប្រុសៗរបស់លោកអហ៊ីម៉ាឡេក ដែលជាចៅរបស់លោកអហ៊ីទូប ឈ្មោះអបៀថើរ បានរត់គេចភៀសខ្លួនទៅតាមលោកដាវីឌ។
[21]លោកអបៀថើរបានប្រាប់លោកដាវីឌថា ព្រះបាទសូលបានសម្លាប់បូជាចារ្យរបស់ព្រះអម្ចាស់ជាច្រើន។
[22]លោកដាវីឌបានតបទៅលោកអបៀថើរវិញថា៖ «ខ្ញុំដឹងថា នៅថ្ងៃមួយនោះលោកដូអេកបាននៅទីនោះ ហើយបានឃើញខ្ញុំ រួចគាត់ពិតជាអ្នកប្រាប់ស្តេចសូល។
ដោយសារតែខ្ញុំ គ្រួសាររបស់ឪពុកលោកបានបាត់បង់ជីវិតទាំងអស់។[23]ចូរនៅជាមួយខ្ញុំចុះ ហើយកុំភ័យខ្លាចអ្វីឡើយ។ ព្រោះអ្នកដែលចង់សម្លាប់លោក
ក៏ចង់យកជីវិតរបស់ខ្ញុំដែរ។ លោកនៅជាមួយខ្ញុំ មានសុវត្ថិភាពហើយ»។

generated on Wed Sep 10 16:16:32 2025

1 Samuel 22:1
ល្អាងភ្នំ
ចន្លោះប្រហោងនៅក្រោមដី ជាទូទៅបើកទៅម្ខាងនៃភ្នំ
ដែលមានទំហំធំល្មមសម្រាប់មនុស្សចូល
អាឌូឡាំ
នេះជាឈ្មោះទីក្រុងមួយនៅជិតទីក្រុងកាថ។
បានដឹងដំណឹងនេះ
បានឮថា ដាវីឌបានទៅពួននៅល្អាងភ្នំ
អស់អ្នកដែលមានទុក្ខព្រួយ ... អ្នកដែលខកចិត្តទាំងប៉ុន្មានបានមកជុំគ្នាជួប
នេះជាការនិយាយបំផ្លើសមួយ។ ការបកប្រែផ្សេងទៀត
«មនុស្សជាច្រើនដែលមានទុក្ខព្រួយ ... មនុស្សជាច្រើនដែលមិនសប្បាយចិត្ត»
អ្នកដឹកនាំ
មន្ត្រីយោធាដែលដឹកនាំទាហាន
មានគ្នាប្រមាណបួនរយនាក់
«៤០០នាក់»
1 Samuel 22:3
ក្រោយមក លោកដាវីឌបានចេញពីទីនោះ
«លោកដាវីឌបានចេញពីរូងភ្នំអាឌូឡាំ»
មីសប៉ា
នេះជាឈ្មោះទីក្រុង។
ទៅនៅជាមួយព្រះករុណា
ដាវីឌចង់ឲ្យឪពុកម្តាយគាត់រស់នៅជាមួយស្តេចម៉ូអាប់
ដើម្បីកុំឲ្យស្តេចសូលអាចធ្វើបាបពួកគេ។
អ្នកបកប្រែអាចបង្ហាញអត្ថន័យជាមូលដ្ឋានរបស់គាត់ ដោយប្រើគំនិត
«មករស់នៅជាមួយអ្នក» «នៅជាមួយអ្នក» ឬ «រស់នៅទីនេះជាមួយអ្នក»
ដូចនៅក្នុងយូឌីប៊ី។
ទៅទឹកដីស្រុកយូដា
ទៅស្រុកយូដាដែលជាស្រុកកំណើតរបស់អ្នក
ព្រៃហារេត
នេះជាឈ្មោះទីក្រុង។
1 Samuel 22:6
លោកដាវីឌបានដឹងរឿងនេះហើយ ទាំងពួកទាហាននៅជាមួយលោក។
ព្រះបាទសូលចាប់អារម្មណ៍ខ្លាំងបំផុតចំពោះដាវីឌ
ដូច្នេះអ្នកនិពន្ធបាននិយាយអំពីបុរសផ្សេងទៀត ដាច់ដោយឡែកពីគ្នា។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«មាននរណាម្នាក់បានរកឃើញកន្លែង ដែលដាវីឌនិងទាហានទាំងអស់
នៅជាមួយគាត់ពេលកំពុងលាក់ខ្លួន»
ក្រោមម្លប់ដើមម៉ៃសាក់
នេះជាដើមឈើមួយប្រភេទ។ ការបកប្រែផ្សេងទៀត « ដើមឈើម្លប់ធំមួយ»
រ៉ាម៉ា
រ៉ាម៉ាជាឈ្មោះទីកន្លែងមួយ នៅក្នុងគីបៀរឈ្មោះនេះមានន័យថា« កន្លែងខ្ពស់»។
អាចមានន័យថា ១)សំដៅទៅលើកន្លែង ដែលហៅថារ៉ាម៉ា ឬ ២)
សំដៅទៅលើកន្លែងខ្ពស់ណាមួយនៅ។ ការបកប្រែផ្សេងទៀត « នៅលើភ្នំ»
1 Samuel 22:7
តើកូនប្រុសរបស់អ៊ីសាយឲ្យស្រែ និងចម្ការទំពាំងបាយជូរទៅអ្នករាល់គ្នាឬ?
ព្រះបាទសូលប្រើសំណួរមួយដើម្បីបញ្ជាក់ថា
ដាវីឌមកពីកុលសម្ព័ន្ធយូដាមិនចង់ធ្វើរឿងនេះ
សម្រាប់ប្រជាជនកុលសម្ព័ន្ធបេនយ៉ាមីនទេ។ ការបកប្រែផ្សេងទៀត
«កូនប្រុសអ៊ីសាយនឹងមិនផ្តល់ដីស្រែ ឬចម្ការទំពាំងបាយជូរដល់អ្នកទេ»។
ឲ្យកូនប្រុសរបស់អ៊ីសាយ
ពេលវេលាផ្តល់ឲ្យអាចបញ្ជាក់ច្បាស់។ ការបកប្រែផ្សេងទៀត
«ពេលកូនរបស់លោកអ៊ីសាយនឹងឡើងសោយរាជ្យគាត់នឹងឲ្យ»
កូនប្រុសរបស់អ៊ីសាយ
«ដាវីឌ»
តើវាជាអ្នកធ្វើឲ្យអស់លោកទៅជាមេទ័ព ... យើងទេឬ?
ព្រះបាទសូលប្រើសំណួរដើម្បីបញ្ជាក់ថា
ដាវីឌមកពីកុលសម្ព័ន្ធយូដាមិនមានបំណងធ្វើរឿងនេះ
សម្រាប់ប្រជាជនកុលសម្ព័ន្ធបេនយ៉ាមីនទេ។ ការបកប្រែផ្សេងទៀត
«គាត់នឹងមិនធ្វើឲ្យអ្នកធ្វើជាមេដឹកនាំ ... ប្រឆាំងនឹងខ្ញុំឡើយ»។
តើវាជាអ្នកធ្វើឲ្យអស់លោកទៅជាមេទ័ព
អ្នកប្រហែលជាត្រូវបញ្ជាក់ឲ្យច្បាស់ ពេលគាត់នឹងតែងតាំងពួកគេឲ្យធ្វើជាមេទ័ព។
ការបកប្រែផ្សេងទៀត «ពេលគាត់ឡើងសោយរាជ្យ
តើគាត់នឹងតែងតាំងអ្នកទាំងអស់គ្នាឲ្យធ្វើជាមេទ័ពទេ»
មេទ័ព
មន្ត្រីយោធាដែលដឹកនាំទាហាន
1 Samuel 22:9
លោកដូអេក ជាជនជាតិអេដុម
ការបកប្រែដូចនៅក្នុង ២១:៧។
ភូមិណូប ... លោកអហ៊ីម៉ាឡេក
ឈ្មោះទីកន្លែង ហើយនិងឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុង ២១:១។
លោកអហ៊ីទូប
ឈ្មោះរបស់មនុស្សប្រុស។
លោកអហ៊ីម៉ាឡេកបានទូលទៅព្រះអម្ចាស់ដើម្បីជួយដល់លោកដាវីឌ ទាំងបានផ្តល់
លោកអហ៊ីទូបបានទូលអង្វរព្រះអម្ចាស់ សូមឲ្យព្រះអម្ចាស់ជួយដាវីឌ
ហើយលោកអហ៊ីទូបក៏បានឲ្យដាវីឌដែរ
1 Samuel 22:11
លោកបានផ្តល់
«តាមរយៈការផ្តល់ឲ្យ»
ក្រោកឡើង
«ប្រឆាំង» ឬ «ប្រយុទ្ធ»
1 Samuel 22:14
តើមានបាវបម្រើណាមួយរបស់ស្តេច ដែលមានភាពស្មោះត្រង់ដូចជាលោកដាវីឌ ...ក្នុងរាជ្យវង្ស?
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«គ្មានអ្នកបម្រើណាម្នាក់ស្មោះត្រង់ដូចលោកដាវីឌ ... ក្នុងរាជវង្សទេ»។
កងការពារ
មនុស្សឬក្រុមមនុស្ស ដែលការពារនរណាម្នាក់
ត្រូវបានគេគោរពណាស់នៅក្នុងរាជវង្សរបស់ព្រះអង្គ។
ពាក្យថា «រាជវង្ស» ជាពាក្យប្រៀបធៀបសម្រាប់គ្រួសារ ដែលរស់នៅក្នុងផ្ទះ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកដែលគ្រួសាររបស់ព្រះអង្គគោរព»
តើនេះជាថ្ងៃទីមួយដែលទូលបង្គំបានអធិស្ឋាន សូមព្រះជាម្ចាស់ជួយលោកឬ?
អហ៊ីម៉ាឡេកសួរខ្លួនឯងនូវសំណួរនេះ មុនពេលព្រះបាទសូលអាចសួរ
បន្ទាប់មកឆ្លើយភ្លាម។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍មួយ។
ការបកប្រែផ្សេងទៀត
«នេះមិនមែនជាលើកទីមួយទេដែលខ្ញុំបានអធិស្ឋានទៅកាន់ព្រះជាម្ចាស់
ឲ្យជួយដាវីឌ» ។
កុំឲ្យទូលបង្គំធ្វើដូច្នេះឡើយ!
នេះឃ្លាមានន័យថា «មិនមែនទេ!»
សូមស្តេចកុំខ្ញាល់នឹងអ្នកបម្រើព្រះអង្គ និងពូជពង្សរបស់ទូលបង្គំឡើយ។
ពីព្រោះទូលបង្គំពុំបានដឹងរឿងអ្វីឡើយ»។
អាហ៊ីម៉ាឡេកនិយាយអំពីខ្លួនគាត់ជាបុរសទី៣ ក្នុងនាមជា «អ្នកបម្រើ»។
អហ៊ីម៉ាឡេកក៏ចាត់ទុកព្រះបាទសូលជាបុរសទី៣ ថាជា«ស្តេចដែរ»។
អហ៊ីម៉ាឡេកនិយាយរបៀបនេះ ដើម្បីបង្ហាញការគោរពដល់ព្រះបាទសូល។
ការបកប្រែផ្សេងទៀត «សូមស្តេចសូលកុំចាត់ទុកទូលបង្គំ ជាអ្នកបម្រើរបស់ព្រះអង្គ
ឬ នរណាម្នាក់នៅក្នុងពូជពូងនៃឪពុករបស់ទូលបង្គំមានកំហុសឡើយ។ ដ្បិត
ទូលបង្គំមិនដឹងអ្វីទាំងអស់»
កុំខ្ញាល់
គិតពិចារណាអំពីកំហុសនរណាម្នាក់
ពូជពង្សរបស់ទូលបង្គំឡើយ។
នៅទីនេះ «ពូជពង្ស» តំណាងឲ្យ «គ្រួសារ»។ ការបកប្រែផ្សេងទៀត
«ទៅដល់ពូជពង្សទូលបង្គំទាំងអស់»
1 Samuel 22:16
ពូជពង្សរបស់លោកផងដែរ
ពាក្យថា «ពូជពង្ស» ជាពាក្យប្រៀបធៀបសម្រាប់គ្រួសារ ដែលរស់នៅក្នុងផ្ទះ។
ការបកប្រែផ្សេងទៀត «ពូជពង្សឪពុករបស់អ្នក» ឬ «កូនចៅរបស់ឪពុកអ្នក»
កងការពារដែលនៅជុំវិញនោះ
« ទាហានឈរនៅក្បែរដើម្បីការពារព្រះអង្គ»

generated on Wed Sep 10 16:16:32 2025

ចូរប្រហារជីវិត
នៅទីនេះ «ចូរ» មានន័យថាចូរត្រឡប់ក្រោយ ឬងាកចេញពីព្រះរាជា។
ការបកប្រែផ្សេងទៀត «ទៅហើយសម្លាប់» ឬ «សម្លាប់»
ដៃរបស់ពួកគេក៏នៅខាងលោកដាវីឌដែរ
ពាក្យថា« ដៃ» ជាពាក្យប្រៀបធៀបសម្រាប់ការងារ ដែលបានធ្វើដោយដៃ។
ការបកប្រែផ្សេងទៀត «ពួកគេក៏ជួយដាវីឌផងដែរ»
មិនចង់លើកដៃប្រហារជីវិត
ពាក្យថា «ដៃ» ជាពាក្យប្រៀបធៀបសម្រាប់ការងារ ដែលបានធ្វើដោយដៃ។
ការបកប្រែផ្សេងទៀត «ពុំបានធ្វើអ្វីដើម្បីសម្លាប់» ឬ «បានបដិសេធមិនសម្លាប់»
1 Samuel 22:18
«ចូរទៅប្រហារជីវិតបូជាចារ្យទាំងនេះទៅ»...ក៏បានបែរទៅសម្លាប់បូជាចារ្យទាំងនោះ
ត្រង់នេះ «បង្វែរ» មានន័យថាងាក ឬងាកចេញពីព្រះរាជា។ បកប្រែដូចនៅក្នុង
២២:១៦។ ការបកប្រែផ្សេងទៀត «ទៅសំលាប់ពួកបូជាចារ្យ...
ទៅហើយវាយប្រហារ» ឬ «សម្លាប់បូជាចារ្យ...វាយប្រហារពួកបូជាចារ្យ»
លោកដូអេក ជាជនជាតិអេដុម ក៏បានបែរទៅសម្លាប់ ... គឺបានសម្លាប់ ... ស្តេចបានសម្លាប់ ...
ស្តេចបានសម្លាប់
អាចមានន័យថា ១) ដូអេកបានសម្លាប់បូជាចារ្យទាំងអស់ដោយខ្លួនឯង ឬ ២)
ពាក្យថា ដូអេកជាពាក្យតំណាងសម្រាប់ដូអេក
និងមនុស្សដែលបានទៅជាមួយគាត់។ការបកប្រែផ្សេងទៀត:«
ដូអេកនិងមនុស្សរបស់គាត់បានត្រឡប់ក្រោយ និងវាយប្រហារ...
ពួកគេបានសម្លាប់... ពួកគេបានវាយប្រហារ ... ពួកគេបានសម្លាប់»
ប៉ែតសិបប្រាំនាក់
មនុស្សប្រាំនាក់ «មនុស្ស៨៥នាក់» ឬ «បូជាចារ្យ៨៥ នាក់»
ដោយមុខដាវ
«ដោយដាវ»
ស្តេចបានសម្លាប់នៅភូមិណូប
នៅទីនេះ «វាយប្រហារ» មានន័យថា ត្រូវបានសម្លាប់។» ការបកប្រែផ្សេងទៀត
«គាត់បានសម្លាប់មនុស្សជាច្រើននៅទីក្រុងណូប»
1 Samuel 22:20
អបៀថើរ
ឈ្មោះរបស់មនុស្សប្រុស។

---

23 [1]មានគេប្រាប់លោកដាវីឌថា៖ «មើល ពួកភីលីស្ទីនបានវាយប្រហារក្រុងកៃឡា ហើយប្លន់ពីកន្លែងបោកបែនស្រូវ»។[2]ដូច្នេះ
លុកដាវីឌបានទូលអង្វរព្រះអម្ចាស់សុំជំនួយថា៖ «តើទូលបង្គំត្រូវចេញទៅ ហើយវាយប្រហារពួកភីលីស្ទីនទាំងនោះឬទេ?»
ព្រះអម្ចាស់បានមានព្រះបន្ទូលទៅលោកដាវីឌវិញថា៖ «ចូរចេញទៅចុះ ហើយវាយប្រហារពួកភីលីស្ទីននោះ និងរំដោះក្រុងកៃឡាមកវិញចុះ»។
[3]មនុស្សរបស់លោកដាវីឌបានប្រាប់លោកដាវីឌថា៖ «យើងមានការភ័យខ្លាចនៅស្រុកយូដានេះទៅហើយ។
ចុះទម្រាំបើយើងចេញទៅឯក្រុងកៃឡាដើម្បីវាយពួកទាហានរបស់ភីលីស្ទីន
តើមិនកាន់តែភ័យខ្លាចជាងនេះថែមទៀតទេឬអី?»[4]លោកដាវីឌក៏បានទូលសួរព្រះអម្ចាស់ដើម្បីជួយម្តងទៀត។ ព្រះអម្ចាស់បានតបវិញថា៖ «ចូរក្រោកឡើង
ចុះទៅក្រុងកៃឡាចុះ។ ព្រោះយើងបានឲ្យឯងមានជ័យជម្នះលើពួកភីលីស្ទីនហើយ»។
[5]លោកដាវីឌ និងមនុស្សដែលនៅជាមួយលោកក៏បានចេញទៅក្រុងកៃឡា និងបានវាយជាមួយនឹងពួកភីលីស្ទីន។ លោកបាននាំយកហ្វូងសត្វរបស់ពួកគេមកវិញ
ហើយបានសម្លាប់ពួកភីលីស្ទីនរង្គាលផង ហើយបានរំដោះអ្នកក្រុងកៃឡាមកវិញ។[6]កាលលោកអបៀថើរ ជាកូនប្រុសរបស់លោកអហ៊ីម៉ាឡេក
បានរត់ភៀសខ្លួនទៅចូលរួមជាមួយនឹងលោកដាវីឌ គឺលោកបានយកមកជាមួយនូវអាវអេផូដផងដែរ។
[7]មានគេបានទូលព្រះបាទសូលថា៖ «ដាវីឌបានទៅក្រុងកៃឡា»។ ស្តេចក៏បានមានរាជឱង្ការឡើងថា៖ «ព្រះជាម្ចាស់បានប្រគល់វាមកក្នុងដៃរបស់យើងហើយ។
ពីព្រោះវាបានចូលទៅក្នុងក្រុងដែលមានទ្វារ និងរនាំងផង»។[8]ព្រះបាទសូលបានហៅកម្លាំងទាំងអស់បន្ថែមដើម្បីចេញទៅប្រយុទ្ធ ដោយចុះទៅក្រុងកៃឡា
ព័ទ្ធចាប់លោកដាវីឌ និងមនុស្សរបស់លោកដាវីឌផង។[9]លោកដាវីឌបានជ្រាបថា ព្រះបាទសូលបានរៀបអន្ទាក់ដើម្បីធ្វើបាបលោក
លោកក៏បានប្រាប់ទៅលោកបូជាចារ្យអបៀថើរថា៖ «ចូរយកអាវអេផូដមក»។
[10]បន្ទាប់មក លោកដាវីឌបានទូលថា៖ «ឱព្រះអម្ចាស់ ជាព្រះរបស់អ៊ីស្រាអែលអើយ ទូលបង្គំបានឮថា ព្រះបាទសូលបានមករកទូលបង្គំនៅឯក្រុងកៃឡានេះ
ដើម្បីបំផ្លាញក្រុងនេះព្រោះតែទូលបង្គំ។[11]តើអ្នកក្រុងកៃឡានេះនឹងប្រគល់ទូលបង្គំទៅក្នុងព្រះហស្តរបស់ស្តេចឬទេ? តើព្រះបាទសូលនឹងមកទីនេះដូចទូលបង្គំបានឮឬទេ?
ឱព្រះអម្ចាស់ ជាព្រះនៃអ៊ីស្រាអែលអើយ ទូលបង្គំសូមអង្វរព្រះអង្គ សូមឆ្លើយមកទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គផង»។ ព្រះអម្ចាស់បានតបវិញថា៖
«ស្តេចនឹងចុះមកទីនេះ»។
[12]នោះ លោកដាវីឌបានសួរថា៖ «តើមនុស្សនៅក្រុងកៃឡានេះ នឹងប្រគល់ទូលបង្គំ និងមនុស្សដែលនៅជាមួយទូលបង្គំទៅព្រះហស្តរបស់ព្រះបាទសូលឬទេ?»
ព្រះអម្ចាស់បានតបថា៖ «ពួកគេនឹងប្រគល់ឯងទៅ»។
[13]លោកដាវីឌ និងមនុស្សរបស់លោក ដែលមានគ្នាប្រមាណប្រាំមួយរយនាក់បានក្រោកឡើង ហើយចេញពីក្រុងកៃឡា ពួកគេចេញពីកន្លែងមួយ ទៅកន្លែងមួយទៀត។
មានគេទូលប្រាប់ព្រះបាទសូលថា លោកដាវីឌបានគេចខ្លួនពីក្រុងកៃឡាហើយ រួចស្តេចក៏ឈប់តាម។[14]លោកដាវីឌបានស្នាក់នៅកន្លែងដ៏មាំមួននៅទីរហោស្ថាន
គឺក្នុងស្រុកដែលនៅលើទីទួលនៃទីរហោស្ថានស៊ីភ។ ព្រះបាទសូលបានស្វែងរកលោកដាវីឌរៀងរាល់ថ្ងៃ ប៉ុន្តែ ព្រះជាម្ចាស់ពុំបានប្រគល់លោកទៅក្នុងដៃរបស់ស្តេចឡើយ។
[15]លោកដាវីឌបានជ្រាបថា ព្រះបាទសូលចេញមកតាមរកយកជីវិតរបស់លោកដូច្នេះ លោកបានស្នាក់នៅឯទីរហោស្ថានស៊ីភ នៅហូរ៉េសា។
[16]ឯសម្តេចយ៉ូណាថានជាបុត្រារបស់ ព្រះបាទសូលបានក្រោកឡើង ហើយចេញទៅជួបលោកដាវីឌនៅហូរ៉េសា
ដើម្បីពង្រឹងលោកឲ្យខ្លាំងនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ថែមទៀត។
[17]សម្តេចបានមានរាជឱង្ការទៅលោកដាវីឌថា៖ «កុំភ័យខ្លាចអ្វីឡើយ។ បិតារបស់ខ្ញុំមិនអាចរកឯងឃើញទេ។ ឯងនឹងក្លាយជាស្តេចលើអ៊ីស្រាអែល ហើយខ្ញុំនឹងនៅជិតឯង។
បិតារបស់ខ្ញុំក៏បានដឹងរឿងនេះដែរ»។[18]អ្នកទាំងពីរបានចងសម្ពន្ធមេត្រីនៅចំពោះព្រះអម្ចាស់។ លោកដាវីឌបន្តស្នាក់នៅហូរ៉េសាទៀត
ឯសម្តេចយ៉ូណាថានបានត្រឡប់ទៅដំណាក់របស់ព្រះអង្គវិញ។
[19]អ្នករស់នៅទីរហោស្ថានស៊ីភបានមកទូលស្តេចសូលនៅឯគីបៀរថា៖ «លោកដាវីឌកំពុងលាក់ខ្លួនក្នុងចំណោមយើងខ្ញុំនៅហូរ៉េសា ជាកន្លែងដ៏មាំមួន គឺលើទួលហាគីឡា
ដែលនៅខាងត្បូងយេស៊ីម៉ូន។[20]សូមព្រះអង្គយាងមកឥឡូវនេះចុះ! សូមយាងមកទីនេះ តាមព្រះទ័យរបស់ព្រះអង្គ!
ខាងទូលបង្គំយើងខ្ញុំនឹងប្រគល់លោកដាវីឌមកក្នុងព្រះហស្តរបស់ព្រះអង្គមិនខាន»។
[21]ព្រះបាទសូលមានបន្ទូលថា៖ «សូមព្រះអម្ចាស់ប្រទានពរអស់លោក ដោយអស់លោកមានការឈឺឆ្អាលសម្រាប់យើងដូច្នេះ។[22]ចូរទៅមើលឲ្យប្រាកដចុះ! ចូររកវា
និងឲ្យដឹងកន្លែងដែលវាកំពុងលាក់ខ្លួន ហើយមានអ្នកណាខ្លះបានឃើញវានៅទីនោះ។ មានគេបានប្រាប់យើងថា វាល្បិចខ្លាំងណាស់។[23]ដូច្នេះ
ចូរមើលឲ្យដឹងគ្រប់កន្លែងដែលវាលាក់ខ្លួន។ ត្រូវត្រឡប់មករកយើងជាមួយនឹងព័ត៌មានច្បាស់ការណ៍ នោះយើងនឹងទៅជាមួយពួកអ្នករាល់គ្នា។ បើវានៅទីនោះមែន
យើងនឹងស្វែងរកវាគ្រប់រាប់ពាន់តំបន់ក្នុងស្រុកយូដាមិនខាន»។
[24]ពួកគេក៏បានចេញទៅដល់ទីរហោស្ថានស៊ីភមុនព្រះបាទសូល។ ឯពេលនេះ លោកដាវីឌ និងមនុស្សដែលនៅជាមួយលោកនៅឯទីរហោស្ថានម៉ាអូន ក្នុងអារ៉ាបា
ខាងត្បូងយេស៊ីម៉ូនវិញ។[25]ព្រះបាទសូល និងទាហានបានចេញទៅស្វែងរកលោក ប៉ុន្តែ លោកដាវីឌបានជ្រាបពីដំណឹងទាំងនោះ លោកក៏ចុះទៅទីទួលដែលសំបូរផ្នាំងថ្ម
ហើយលាក់ខ្លួននៅទីរហោស្ថានម៉ាអូននោះ។ ពេលព្រះបាទសូលដឹង ស្តេចក៏បានដេញតាមរកលោកដាវីឌនៅឯទីរហោស្ថានម៉ាអូនដែរ។
[26]ព្រះបាទសូលបានបន្តដំណើរនៅម្ខាងភ្នំ ហើយលោកដាវីឌ និងមនុស្សរបស់លោកក៏បន្តដំណើរនៅឯម្ខាងទៀតនៃភ្នំនោះដែរ។
លោកដាវីឌប្រញាប់ប្រញាលគេចឲ្យផុតពីព្រះបាទសូល។ កាល ព្រះបាទសូល និងទាហានបានកំពុងឡោមព័ទ្ធក្រុមលោកដាវីឌ

generated on Wed Sep 10 16:16:32 2025

ដើម្បីនឹងចាប់ពួកលោកហើយ[27]ស្រាប់តែមានអ្នកនាំសារម្នាក់ចូលមកទូលព្រះបាទសូលថា៖ «សូមព្រះអង្គប្រញាប់យាងទៅ ដ្បិត
ពួកភីលីស្ទីនបានប្រមូលកម្លាំងវាយប្រហារចូលទឹកដីរបស់យើងហើយ»។
[28]ឮដូច្នេះ ព្រះបាទសូលបានបញ្ឈប់ការដេញតាមលោកដាវីឌ ហើយចេញទៅវាយពួកភីលីស្ទីនវិញ។ ហេតុដូច្នេះហើយ ទើបគេហៅកន្លែងនោះថា៖ «ផ្ទាំងថ្មគេចខ្លួន»។
[29]លោកដាវីឌបានចាកចេញពីទីនោះ ហើយបានស្នាក់នៅទីមាំមួនអេនគេឌី។

---

1 Samuel 23:1

បានវាយប្រហារក្រុងកៃឡា

«ក្រុងកៃឡា» ជាឈ្មោះទីក្រុងមួយ នៅទីនេះ «ក្រុងកៃឡា » តំណាងឲ្យប្រជាជនដែលរស់នៅទីនោះ។ ការបកប្រែផ្សេងទៀត «ប្រយុទ្ធប្រឆាំងនឹងប្រជាជនក្រុងកៃឡា »

កន្លែងបោកបែនស្រូវ

ការផ្តាច់ចេញគ្រាប់ស្រូវ ឬ គ្រប់ពូជ ជាទូទៅពីគ្រប់ធញ្ញជាតិ ឬស្រូវសាលីមួយចំនួនតាមរយៈម៉ាស៊ីន។

1 Samuel 23:3

ចុះទម្រាំបើយើងចេញទៅឯក្រុងកៃឡា ដើម្បីវាយពួកទាហានរបស់ភីលីស្ទីន

តើមិនកាន់តែភ័យខ្លាចជាងនេះថែមទៀតទេឬអី?

សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍ ។ ការបកប្រែផ្សេងទៀត «យើងនឹងកាន់តែភ័យខ្លាចថែមទៀត
បើយើងទៅក្រុងកៃឡាដើម្បីប្រយុទ្ធនឹងកងទ័ពរបស់ភីលីស្ទីន»។

1 Samuel 23:5

បានចេញ ... បានវាយ ... បាននាំ ... នសម្លាប់ ... បានរំដោះ

អ្នកនិពន្ធយកចិត្តទុកដាក់បំផុតចំពោះដាវីឌ ដូច្នេះ
ពាក្យទាំងនេះមានលក្ខណៈជាឯកវចនៈ ទោះបីទាហានរបស់ដាវីឌបានជួយគាត់ឲ្យធ្វើអ្វីៗទាំងអស់នេះក៏ដោយ។

លោកអហ៊ីម៉ាឡេក

ជាឈ្មោះរបស់បុរស។ សូមមើលការបកប្រែនៅក្នុង ២១: ១

1 Samuel 23:7

មានគេបានទូលព្រះបាទសូលថា

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «មានគេទូលព្រះបាទសូល» ឬ «ពួកគេបានទូលព្រះបាទសូល»

បានហៅ

«បានអំពាវនាវឲ្យ» ឬ «បានជួបប្រជុំគ្នា»

1 Samuel 23:10

លោកដាវីឌបានទូលថា

«ដាវីឌបានសួរ» ឬ «ដាវីឌបានអធិស្ឋាន»

ទូលបង្គំបានឮថា ព្រះបាទសូល ...

ដូចទូលបង្គំបានឮ ...ឆ្លើយមកទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គផង

ស្តេចដាវីឌមានបន្ទូលដូចជាព្រះអង្គ
ជាអ្នកដទៃទៀតដើម្បីបង្ហាញការគោរពចំពោះព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត «ទូលបង្គំបានឮថា ... ដូចដែលទូលបង្គំបានឮ ... ប្រាប់ទូលបង្គំ»

ប្រគល់ទូលបង្គំទៅក្នុងព្រះហស្តរបស់ស្តេច

នៅទីនេះ «ព្រះហស្ត» តំណាងឲ្យអំណាច ឬការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត « ប្រគល់ទូលបង្គំទៅឲ្យព្រះបាទសូល» សូមមើល

បំផ្លាញ

«ចាញ់ទាំងស្រុង»

1 Samuel 23:12

លោកដាវីឌបានសួរថា

ឬ «ស្តេចដាវីឌបានសួរ» ឬ «ស្តេចដាវីឌបានអធិស្ឋាន»

ប្រគល់ទូលបង្គំ និងមនុស្សដែលនៅជាមួយទូលបង្គំទៅព្រះហស្តរបស់ព្រះបាទសូល

នៅទីនេះ «ព្រះហស្ត» តំណាងឲ្យអំណាច ឬការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត «ប្រគល់ទូលបង្គំនិងពួកទូលបង្គំឲ្យទៅព្រះបាទសូល»។

1 Samuel 23:13

ប្រាំមួយរយនាក់

«៦០០នាក់»

មានគេទូលប្រាប់ព្រះបាទសូលថា

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «មានគេប្រាប់ព្រះបាទសូល» ឬ «ពួកគេបានប្រាប់ព្រះបាទសូល»

បានគេចខ្លួន

«បានរត់គេចពី»

ទីរហោស្ថានស៊ីភ

នេះជាឈ្មោះតំបន់វាលរហោស្ថានមួយ នៅជិតទីក្រុងស៊ីភ

ពុំបានប្រគល់លោកទៅក្នុងដៃរបស់ស្តេចឡើយ។

ពាក្យថា «ដៃ» គឺជាពាក្យប្រៀបធៀបសម្រាប់អំណាច។ ការបកប្រែផ្សេងទៀត «មិនអនុញ្ញាតឲ្យព្រះបាទសូលមានអំណាចលើដាវីឌ» ឬ
«មិនអនុញ្ញាតឲ្យព្រះបាទសូលធ្វើដូច ដែលស្តេចប៉ងប្រាថ្នាទៅលើដាវីឌ» ឬ
«មិនអនុញ្ញាតឲ្យព្រះបាទសូលចាប់ដាវីឌ»

1 Samuel 23:15

តាមរកយកជីវិតរបស់លោក

នេះជាសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ព្យាយាមសម្លាប់គាត់»

ហូរេសា

នេះជាឈ្មោះទីក្រុងមួយនៅជិតស៊ីភ

ពង្រឹងលោកឲ្យខ្លាំងនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ថែមទៀត។

នេះជាសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «បានលើកទឹកចិត្តគាត់ឲ្យជឿទុកចិត្តលើព្រះជាម្ចាស់»

1 Samuel 23:17

បិតារបស់ខ្ញុំមិនអាចរកឯងឃើញទេ។

នៅទីនេះ «ដៃ» ជាពាក្យប្រៀបធៀបសម្រាប់ព្រះបាទសូលនិងអំណាចរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត « ចំពោះព្រះបាទសូល ឪពុកខ្ញុំនឹងមិនអាចរកឃើញអ្នកទេ» ឬ «សូលដែលជាឪពុកខ្ញុំនឹងមិនអាចមានអំណាចលើអ្នកបានទេ»

1 Samuel 23:19

ទីរហោស្ថានស៊ីភ

នេះជាឈ្មោះក្រុមមនុស្ស មកទីរហោស្ថានស៊ីភ

លោកដាវីឌកំពុងលាក់ខ្លួនក្នុងចំណោមយើងខ្ញុំនៅ ... យេស៊ីម៉ូន

សំណួរដ៏ប៉ិនប្រសប់នេះអាចបកប្រែជាការបន្លឺសំឡេងឧទាន។
ការបកប្រែផ្សេងទៀត «ដាវីឌកំពុងលាក់ខ្លួនក្នុងចំណោមយើងនៅ ... យេស៊ីម៉ូន!» សូមមើល

ទួលហាគីឡា

នេះជាឈ្មោះភ្នំមួយ នៅវាលរហោស្ថានស្រុកយូដា។

យេស៊ីម៉ូន

នេះជាឈ្មោះតំបន់វាលខ្សាច់មួយ នៅជិតសមុទ្រស្លាប់ ក៏អាចត្រូវបានបកប្រែថា «វាលរហោស្ថានយូដាស» ឬ «កន្លែងដែលគេបោះបង់ចោល»។

ប្រគល់លោកដាវីឌមកក្នុងព្រះហស្តរបស់ព្រះអង្គមិនខាន

ពាក្យថា «ព្រះហស្ត» ជាពាក្យប្រៀបធៀបសម្រាប់អំណាច។

ជនជាតិស៊ីភទូលថ្វាយព្រះបាទសូល
ហាក់ដូចជាព្រះបាទសូលជាមនុស្សម្នាក់ផ្សេងទៀត ដើម្បីបង្ហាញព្រះអង្គថាពួកគេគោរពព្រះអង្គ។ ការបកប្រែផ្សេងទៀត «ប្រគល់ដាវីឌឲ្យព្រះអង្គ ដូច្នេះទ្រង់អាចធ្វើអ្វីដែលទ្រង់ប៉ងប្រាថ្នាធ្វើលើគាត់ចុះ»

1 Samuel 23:21

សូមព្រះអម្ចាស់ប្រទានពរអស់លោក

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «ខ្ញុំសង្ឃឹមថាព្រះអម្ចាស់ប្រទានពរដល់»

ដោយអស់លោកមានការឈឺឆ្អាលសម្រាប់យើង

«អ្នកបានប្រាប់រឿងនេះដល់ខ្ញុំ» (សូមមើល យូឌីបី)

ចូររកវា និងឲ្យដឹង

ពាក្យទាំងពីរនេះមានន័យសឹងតែដូចគ្នា និងអាចបកប្រែជាឃ្លាតែមួយ។ ការបកប្រែផ្សេងទៀត «ដឹងឲ្យច្បាស់»

អ្នកណាខ្លះបានឃើញវា

«អ្នកណាបានឃើញគាត់»

មានគេបានប្រាប់យើងថា

អាចបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «មនុស្សប្រាប់ខ្ញុំ» ឬ «ខ្ញុំបានឮ»

generated on Wed Sep 10 16:16:32 2025

គ្រប់រាប់ពាន់តំបន់ក្នុងស្រុកយូដាមិនខាន។
នេះជាឃ្លាសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ទោះបីខ្ញុំត្រូវចាប់ខ្លួនមនុស្សគ្រប់គ្នានៅស្រុកយូដា» ឬ
«ក្នុងចំណោមកុលសម្ព័ន្ធយូដាទាំងអស់»
1 Samuel 23:24
ពួកគេក៏បានចេញទៅ
ពួកគេបានបញ្ឈប់អ្វីៗ ដែលពួកគេបានធ្វើ។ អ្នកអានមិនគួរជឿថា ពួកគេអង្គុយ
ឬនិយាយកុហកទេ។
ពួកគេក៏
«បន្ទាប់មកពួកស៊ីភ»
ទីរហោស្ថានស៊ីភ
នេះជាឈ្មោះកន្លែងមួយ។ បកប្រែដូចនៅក្នុង ២៣:១៣។
យេស៊ីម៉ូន
នេះជាឈ្មោះតំបន់វាលខ្សាច់មួយ នៅជិតសមុទ្រស្លាប់។ អាចបកប្រែថា
«ទីរហោស្ថានយូដាស» ឬ «វាលខ្សាច់» ។ បកប្រែដូចនៅក្នុង ២៣:១៩។
លោកដាវីឌបានជ្រាបពីដំណឹងទាំងនោះ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«មានគេប្រាប់លោកដាវីឌថា ពួកគេបានកំពុងមក» ឬ «លោកដាវីឌបានដឹងថា
ពួកគេកំពុងតែមក»
សំបូរផ្នាំងថ្ម
ជាភ្នំដែលគ្របដណ្តប់ដោយផ្នាំងថ្ម ឬដុំថ្មច្រើន
នៅឯទីរហោស្ថានម៉ាអូនដែរ
នេះជាឈ្មោះតំបន់វាលខ្សាច់
ដែលនៅជុំវិញទីក្រុងម៉ាអូននៅភាគខាងត្បូងស្រុកយូដា។
1 Samuel 23:26
សូមព្រះអង្គប្រញាប់យាងទៅ
ពាក្យថា «ប្រញាប់» និង «ទៅ» អាចត្រូវបានផ្សំជាគំនិតតែមួយ។
ការបកប្រែផ្សេងទៀត «មកលឿន»
1 Samuel 23:28
ការដេញតាម
«ដេញតាម» ឬ »ដេញតាមចាប់»
«ផ្នាំងថ្មគេចខ្លួន»
ជាការចង់ចាំ ឬធ្វើសញ្ញាសម្គាល់នៃការរត់គេចរបស់ដាវីឌពីព្រះបាទសូល។

24

[1]ពេលព្រះបាទសូលយាងត្រឡប់ពីចម្បាំងជាមួយពួកភីលីស្ទីនវិញ មានគេទូលស្តេចថា៖ «ដាវីឌនៅឯទីរហោស្ថានអេនគេឌី»។
[2]នោះព្រះបាទសូលបានជ្រើសរើសទាហានពីអ៊ីស្រាអែលទាំងមូលចំនួនបីពាន់នាក់ឲ្យចេញទៅតាមរករកលោកដាវីឌ និងមនុស្សរបស់លោកនៅតំបន់ថ្មពពែព្រៃ។
[3]យាងមកតាមផ្លូវ ស្តេចបានឆ្លងកាត់ក្រោលចៀម ដែលមានល្អាងភ្នំមួយ។ ស្តេចបានចូលទៅក្នុងល្អាងនោះដើម្បីដោះទុក្ខសត្វ។ លោកដាវីឌ
និងក្តីគ្នារបស់លោកស្ថិតនៅក្នុងល្អាងនោះតែនៅជ្រៅទៅទៀតដែរ។[4]មនុស្សរបស់លោកដាវីឌបានជម្រាបលោកថា៖
«នេះគឺជាថ្ងៃដែលព្រះអម្ចាស់បានមានព្រះបន្ទូលមកលោកហើយថា យើងនឹងប្រគល់ខ្មាំងសត្រូវរបស់ឯងមកក្នុងដៃរបស់ឯង
ដើម្បីឲ្យឯងប្រព្រឹត្តចំពោះសត្រូវនោះតាមប្រាថ្នាចុះ»។ នោះលោកដាវីឌបានក្រោកឡើង ហើយលូនចូលទៅយ៉ាងស្ងាត់
ហើយបានកាត់ជាយព្រះភូសារបស់ព្រះបាទសូលមក។
[5]បន្ទាប់មក ចិត្តរបស់លោកដាវីឌបានធ្វើឲ្យលោកដាវីឌក្តៅក្រហាយ ពីព្រោះលោកបានកាត់ជាយព្រះភូសារបស់ស្តេច។[6]លោកបាននិយាយទៅមនុស្សរបស់លោកថា៖
«សូមព្រះអម្ចាស់ឃាត់ខ្ញុំកុំឲ្យប្រព្រឹត្តដូច្នេះចំពោះម្ចាស់ ដែលព្រះអម្ចាស់បានចាក់ប្រេងតាំង គឺឃាត់ដៃរបស់ខ្ញុំមិនឲ្យប្រឆាំងនឹងស្តេចឡើយ តែឲ្យមើលទៅស្តេចថា
ជាអ្នកដែលព្រះបានចាក់ប្រេងអភិសេកវិញ»។[7]ដូច្នេះ លោកដាវីឌបានស្តីបន្ទោសមនុស្សរបស់លោកនឹងពាក្យសំដីទាំងនោះ
ហើយមិនអនុញ្ញាតឲ្យពួកគេប៉ះពាល់ព្រះបាទសូលទេ។ ព្រះបាទសូលបានក្រោកឡើង ហើយចាកចេញបន្តដំណើរទៅមុខទៀត។
[8]បន្ទាប់មក លោកដាវីឌក៏បានក្រោកឈរឡើង ហើយចាកចេញពីល្អាងនោះ រួចស្រែកទៅព្រះបាទសូលថា៖ «ឱព្រះករុណាជាម្ចាស់របស់ទូលបង្គំអើយ»។
ពេលព្រះបាទសូលក្រលែកទៅក្រោយឃើញលោកដាវីឌបានឱនមុខក្រាបដល់ដី និងបានបង្ហាញការគោរពរបស់លោកដល់ស្តេច។[9]លោកដាវីឌបានទូលស្តេចថា៖
«ហេតុអ្វីបានជាព្រះករុណាស្តាប់គេថា ដាវីឌចង់ធ្វើបាបព្រះករុណាដូច្នេះ?»។
[10]ថ្ងៃនេះ ព្រះអង្គបានទតឃើញនឹងព្រះនេត្រហើយថា ព្រះអម្ចាស់ប្រគល់ព្រះករុណាមកក្នុងដៃរបស់ទូលបង្គំនៅក្នុងល្អាងនេះ។
ក៏មានអ្នកប្រាប់ឲ្យទូលបង្គំធ្វើឃាតព្រះអង្គដែរ តែទូលបង្គំបានទុកជីវិតឲ្យព្រះអង្គវិញ។ ដោយទូលបង្គំនិយាយថា ទូលបង្គំនឹងមិនលើកដៃប្រហារម្ចាស់របស់ទូលបង្គំឡើយ
ដ្បិត ព្រះករុណាគឺជាអ្នកដែលព្រះអម្ចាស់បានចាក់ប្រេងអភិសេក។[11]ព្រះករុណាឃើញទេ សូមទតមើលជាយព្រះភូសារបស់ព្រះករុណាចុះ
គឺស្ថិតក្នុងដៃរបស់ទូលបង្គំឯណេះ។ ហេតុផលពិតដែលទូលបង្គំបានកាត់ជាយព្រះភូសារបស់ព្រះករុណា ហើយមិនធ្វើឃាតព្រះករុណាដូច្នេះ ព្រះករុណាអាចនឹងដឹងថា
ទូលបង្គំគ្មានបំណងអាក្រក់ ឬគ្មានអំពើក្បត់នៅក្នុងដៃទូលបង្គំឡើយ ហើយទូលបង្គំក៏ពុំបានធ្វើបាបប្រឆាំងនឹងព្រះករុណាដែរ សូម្បីតែ
ព្រះអង្គកំពុងតាមប្រមាញ់យកជីវិតរបស់ទូលបង្គំក្តី។
[12]សូមព្រះអម្ចាស់រកយុត្តិធម៌រវាងទូលបង្គំ និងព្រះករុណាចុះ។ សូមព្រះអម្ចាស់ដាក់ទោសទូលបង្គំចុះ បើមានការនោះមែន ប៉ុន្តែ
ទូលបង្គំមិនលើដៃប្រហារព្រះករុណាឡើយ។[13]ដូចមានសុភាសិតបុរាណពោលថា៖ មនុស្សអាក្រក់មុខជាប្រព្រឹត្តអាក្រក់។ ប៉ុន្តែ ឯដៃរបស់ទូលបង្គំវិញ
គឺមិនប្រឆាំងនឹងព្រះករុណាឡើយ។
[14]តើស្តេចរបស់អ៊ីស្រាអែលចេញមកប្រយុទ្ធនឹងអ្នកណា? តើព្រះករុណាតាមប្រមាញ់អ្នកណា? តាមឆ្កែងាប់ ឬតាមរកចៃឆ្កែប៉ុណ្ណោះ![15]សូមព្រះអម្ចាស់ធ្វើជាចៅក្រម
និងសម្រេចក្តីរវាងយើងទាំងពីរ ហើយសូមព្រះអង្គទតមើល ហើយការពារក្តីនេះដល់ទូលបង្គំ នោះព្រះអម្ចាស់នឹងអនុញ្ញាតឲ្យទូលបង្គំរួចខ្លួនពីព្រះហស្តរបស់ព្រះករុណា»។
[16]ពេលលោកដាវីឌបានបញ្ចប់នូវពាក្យទាំងនោះចំពោះព្រះបាទសូលហើយ នោះព្រះបាទសូលបានមានបន្ទូលថា៖ «នេះជាសម្លេងរបស់កូន ឬ ដាវីឌកូនប្រុសបិតា?»
រួចព្រះបាទសូលព្រះកន្សែង។
[17]ស្តេចបានមានរាជឱង្ការទៅលោកដាវីឌទៀតថា៖ «បុត្រសុចរិតជាងបិតា ដោយបុត្របានប្រព្រឹត្តអំពើល្អចំពោះបិតា តបនឹងអំពើអាក្រក់ដែលបិតាបានប្រព្រឹត្តដាក់បុត្រ។
[18]បុត្របានប្រកាសថ្ងៃនេះនូវអំពើដ៏សប្បុរសដែលបុត្របានធ្វើចំពោះបិតា
ដោយបុត្រមិនបានសម្លាប់បិតានៅពេលព្រះអម្ចាស់បានប្រគល់បិតាទៅក្នុងកណ្តាប់ដៃរបស់បុត្រក្តី។
[19]កាលណាគេឃើញសត្រូវរបស់ខ្លួនហើយ គេនឹងមិនទុកឲ្យសត្រូវនោះរួចខ្លួនឡើយ។
សូមព្រះអម្ចាស់ប្រទានរង្វាន់ល្អដល់បុត្រដោយព្រោះទង្វើដែលបុត្របានប្រព្រឹត្តចំពោះបិតាថ្ងៃនេះ។[20]ឥឡូវ បិតាជ្រាបច្បាស់ថា បុត្រនឹងទៅជាស្តេច
ហើយរាជ្យអាណាចក្ររបស់អ៊ីស្រាអែលនឹងគង់វង្សក្រោមការគ្រប់គ្រងរបស់បុត្រមិនខាន។
[21]សូមបុត្រស្បថនឹងបិតាដោយនូវព្រះនាមព្រះអម្ចាស់ថា បុត្រនឹងមិនកាត់ផ្តាច់ពូជពង្សវង្សត្រកូលរបស់បិតាទេ
ហើយបុត្រនឹងមិនបំផ្លាញព្រះនាមបិតាចេញពីក្រុមគ្រួសាររបស់បិតាដែរ»។[22]ក្រោយមក ព្រះបាទសូលបានត្រឡប់ទៅព្រះដំណាក់វិញ ប៉ុន្តែ លោកដាវីឌ
និងទាហានដែលនៅជាមួយបានឡើងទៅទីមាំមួនវិញ។

1 Samuel 24:1
មានគេទូលស្តេចថា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «មានគេប្រាប់ស្តេច»
រហោស្ថានអេនគេឌី

generated on Wed Sep 10 16:16:32 2025

អេងឌីដាជាកន្លែងមួយនៅអ៊ីស្រាអែល ខាងលិចនៃសមុទ្រស្លាប់
ដែលជាកន្លែងមានទឹក មានដីស្ងួតនៅជុំវិញ។
បីពាន់នាក់
3,000
បានជ្រើសរើសទាហាន
ទាហានដែលស្តេចបានជ្រើសរើស ដោយសារតែសមត្ថភាពយោធាខ្ពស់របស់ពួកគេ
1 Samuel 24:3
ក្រោលចៀម
«ក្រោលសត្វចៀម» ឬ «របងព័ទ្ធចៀមជុំវិញ»
ដើម្បីដោះទុក្ខសត្វ
នេះជាពាក្យប្រើកុំឲ្យអាក្រក់ស្តាប់ពេក «ធូរស្បើយខ្លួនគាត់» ឬ «បន្ទោរបង់» ឬ «ទុកឲ្យពោះវៀនរបស់ទ្រង់ទទេ»។
ល្អាងភ្នំ
ជាទូទៅជារូងធម្មជាតិមួយនៅក្រោមដី ដែលជាញឹកញាប់មានរបើកនៅចំហៀងភ្នំ ឬច្រាំងថ្មចោទ
លោកដាវីឌបានក្រោកឡើង ហើយលូនចូលទៅយ៉ាងស្ងាត់
ពាក្យថា «បានក្រោកឡើង» ជាសំនួនវោហាស័ព្ទសម្រាប់ធ្វើសកម្មភាព។
ការបកប្រែផ្សេងទៀត «លោកដាវីឌបានធ្វើសកម្មភាព
លោកបានលូនដោយស្ងាត់ៗ»
លូន
ខិតជិតយឺតៗដោយប្រុងប្រយ័ត្ន ឬស្ងៀមស្ងាត់
1 Samuel 24:5
ចិត្តរបស់លោកដាវីឌបានធ្វើឲ្យលោកដាវីឌក្តៅក្រហាយ
នេះជាឃ្លាសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «ស្តេចដាវីឌសោកស្តាយ
ព្រោះទ្រង់បានធ្វើអ្វីមួយខុស»
ព្រះអម្ចាស់បានចាក់ប្រេងតាំង
« អ្នកដែលព្រះអម្ចាស់បានជ្រើសរើសឲ្យដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គ» ឬ
»មួយអង្គដែលព្រះអម្ចាស់បានតែងតាំង»។
គឺឃាត់ដៃរបស់ខ្ញុំមិនឲ្យប្រឆាំងនឹងស្តេចឡើយ
ដៃជាពាក្យប្រៀបធៀបសម្រាប់សមត្ថភាព បង្កឲ្យមានគ្រោះថ្នាក់។
ការបកប្រែផ្សេងទៀត «ធ្វើបាបគាត់តាមរបៀបណាមួយ»
1 Samuel 24:8
«ហេតុអ្វីបានជាព្រះករុណាស្តាប់គេថា ដាវីឌចង់ធ្វើបាបព្រះករុណាដូច្នេះ?»។
នេះជាសំណួរដ៏ប៉ិនប្រសព្វ។ អាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ព្រះករុណាមិនគួរស្តាប់មនុស្ស ដែលនិយាយថា»
ដាវីឌកំពុងស្វែងរកធ្វើបាបព្រះករុណាទេ»។
1 Samuel 24:10
ព្រះអង្គបានទតឃើញនឹងព្រះនេត្រហើយថា
នៅទីនេះ «ព្រះនេត្រ» តំណាងឲ្យព្រះបាទសូល។ ការបកប្រែផ្សេងទៀត
«ព្រះករុណាបានឃើញដោយព្រះនេត្រផ្ទាល់របស់ព្រះករុណា»
ប្រគល់ព្រះករុណាមកក្នុងដៃរបស់ទូលបង្គំ
ពាក្យថា «ដៃ» ជាពាក្យប្រៀបធៀបម្រាប់ការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ដាក់ព្រះករុណានៅកន្លែង ដែលទូលបង្គំអាចសម្លាប់ព្រះករុណា
ឬអនុញ្ញាតឲ្យព្រះករុណារស់នៅ»
ព្រះករុណាឃើញទេ
ព្រះបាទសូលមិនមែនជាឪពុកពិតរបស់ដាវីឌទេ។ ដាវីឌហៅគាត់ថា «ឪពុក»
ដើម្បីបង្ហាញថា គាត់គោរពព្រះបាទសូល។
ទូលបង្គំគ្មានបំណងអាក្រក់ ឬគ្មានអំពើក្បត់នៅក្នុងដៃទូលបង្គំឡើយ
ដាវីឌនិយាយដូចជាអំពើអាក្រក់ និងការក្បត់ជាវត្ថុ
ដែលគាត់អាចកាន់នៅក្នុងដៃរបស់គាត់។ នៅទីនេះ «ដៃ»
តំណាងឲ្យមនុស្សម្នាក់ធ្វើសកម្មភាព ឬធ្វើអ្វីមួយ។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនបានធ្វើអ្វីដែលអាក្រក់ប្រឆាំងនឹងព្រះករុណាទេ
ហើយខ្ញុំក៏មិនបានបះបោរប្រឆាំងនឹងព្រះករុណាដែរ»។
1 Samuel 24:12
ទូលបង្គំមិនលើដៃប្រហារព្រះករុណាឡើយ។
ដៃជាពាក្យប្រៀបធៀប សម្រាប់សមត្ថភាពបង្កឲ្យមានគ្រោះថ្នាក់។
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ២៤:៥។ ការបកប្រែផ្សេងទៀត
«ទូលបង្គំនឹងមិនធ្វើបាបអ្នក តាមរបៀបណាមួយទេ»
បុរាណ
គុណនាមធម្មតានេះអាចបកប្រែជាឃ្លានាម។ ការបកប្រែផ្សេងទៀត
«មនុស្សដែលបានរស់នៅជាយូរមកហើយ»
1 Samuel 24:14
តើស្តេចរបស់អ៊ីស្រាអែលចេញមកប្រយុទ្ធនឹងអ្នកណា? តើព្រះករុណាតាមប្រមាញ់អ្នកណា?
សំណួរដ៏ប៉ិនប្រសប់ទាំងនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។
ពេលដាវីឌសួរសំណួរគាត់ដឹងថា គាត់នឹងឆ្លើយសំណួរដោយខ្លួនឯង។
ការបកប្រែផ្សេងទៀត «ខ្ញុំសូមប្រាប់អ្នកថា ស្តេចអ៊ីស្រាអែលចេញមកតាមក្រោយ។
ខ្ញុំសូមប្រាប់អ្នកថា អ្នកណាដែលអ្នកកំពុងដេញតាម» ។
តាមឆ្កែងាប់
ពាក្យថា“ ឆ្កែងាប់” ជាពាក្យប្រៀបធៀបសម្រាប់មនុស្សគ្មានអំណាច។
ការកាត់ទោសនេះអាចធ្វើឲ្យពេញលេញ។ ការបកប្រែផ្សេងទៀត
«អ្នកកំពុងតែតាមរកមនុស្ស ដែលគ្មានអំណាចដូចឆ្កែងាប់»
តាមរកចៃឆ្កែប៉ុណ្ណោះ!
ពាក្យ «ចៃឆ្កែ» ជាពាក្យប្រៀបធៀបសម្រាប់មនុស្សម្នាក់
ដែលអ្នកដទៃមិនគិតថាសំខាន់។ ការបកប្រែផ្សេងទៀត
«អ្នកកំពុងតាមរកមនុស្សម្នាក់ ដែលមិនសំខាន់ដូចជាចៃឆ្កែ»
ទតមើល ហើយការពារក្តីនេះដល់ទូលបង្គំ
អាចមានន័យថា ១)«ធ្វើអ្វីដែលត្រូវ ហើយការពារទូលបង្គំ» ឬ
២)«សូមមើលថាករណីរបស់ទូលបង្គំ គឺត្រឹមត្រូវហើយតស៊ូសម្រាប់ទូលបង្គំ»។
(សូមមើល យូឌីប៊ី)
ព្រះហស្តរបស់ព្រះករុណា។
ពាក្យថា «ព្រះហស្ត» ជាពាក្យប្រៀបធៀបសម្រាប់អំណាច។ ការបកប្រែផ្សេងទៀត
«ដូច្នេះ អ្នកគ្មានអំណាចលើខ្ញុំទេ»
1 Samuel 24:16
ដាវីឌកូនប្រុសបិតា
ព្រះបាទសូលមានបន្ទូលដូចជាដាវីឌ ជាកូនប្រុសរបស់ទ្រង់ ដើម្បីបង្ហាញដាវីឌថា
ព្រះអង្គស្រឡាញ់គាត់។
បន្លឺសំឡេងរបស់ទ្រង់ឡើងហើយព្រះកន្សែង
អ្នកនិពន្ធសរសេរថាសំឡេងដូចជាអ្វីមួយ
ដែលមនុស្សម្នាក់អាចលើកនឹងដៃឡើងបាន។ ការបកប្រែផ្សេងទៀត
«ព្រះកន្សែងយ៉ាងខ្លាំង»
1 Samuel 24:17
បុត្របានធ្វើចំពោះបិតា
ព្រះបាទសូលទទួលស្គាល់ថា ដាវីឌបានបង្ហាញថាគាត់គាំទ្រស្តេចសូល
ហើយស្មោះត្រង់នឹងព្រះបាទសូលដោយមិនសម្លាប់ព្រះបាទសូល។
ដោយបុត្រមិនបានសម្លាប់បិតានៅពេលព្រះអម្ចាស់បានប្រគល់បិតាទៅក្នុងកណ្តាប់ដៃរបស់បុត្រក្តី។
ព្រះបាទសូលទទួលស្គាល់ថា ដាវីឌបានជ្រើសរើសដោយបង្ហាញសេចក្តីមេត្តា
និងភាពស្មោះត្រង់របស់គាត់ចំពោះស្តេចសូល
ជាអ្នកចាក់ប្រេងតាំងរបស់ព្រះអម្ចាស់។
1 Samuel 24:19
កាលណាគេឃើញសត្រូវរបស់ខ្លួនហើយ គេនឹងមិនទុកឲ្យសត្រូវនោះរួចខ្លួនឡើយ។
សំណួរដ៏ប៉ិនប្រសព្វ ដែលមានចម្លើយរួមបញ្ចូលនៅក្នុងសំណួរនេះ។
ការបកប្រែផ្សេងទៀត «កាលណាគេមនុស្សរកសត្រូវរបស់គេឃើញហើយ
គេនឹងមិនអនុញ្ញាតឲ្យសត្រូវនោះ ទៅដោយស្រួលឡើយ»។
កាលណាគេឃើញសត្រូវរបស់ខ្លួនហើយ គេនឹងមិនទុកឲ្យសត្រូវនោះរួចខ្លួនឡើយ។
នៅកន្លែងដែលព្រះបាទសូលជឿថា ដាវីឌជាសត្រូវរបស់ទ្រង់
ស្តេចដឹងថាទោះបីដាវីឌនឹងឡើងសោយរាជ្យក៏ដោយ
ក៏ដាវីឌនឹងមិនដណ្តើមយករាជបល្ល័ង្កពីព្រះបាទសូលដោយបង្ខំទេ ប៉ុន្តែ
នឹងរង់ចាំពេលវេលាព្រះអម្ចាស់បានកំណត់។
ហើយរាជ្យអាណាចក្ររបស់អ៊ីស្រាអែលនឹងគង់វង្សក្រោមការគ្រប់គ្រងរបស់បុត្រមិនខាន។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ អាចមានន័យថា ១)
ដាវីឌនឹងធ្វើឲ្យរាជាណាចក្រអ៊ីស្រាអែលរីកចម្រើន
តាមរយៈអំណាចរបស់លោកជាស្តេច។ ការបកប្រែផ្សេងទៀត
«រាជាណាចក្រអ៊ីស្រាអែលនឹងរីកចម្រើន
ពេលអ្នកគ្រប់គ្រងលើប្រជាជនអ៊ីស្រាអែល» ឬ ២)
ព្រះអម្ចាស់នឹងធ្វើឲ្យដាវីឌមានអំណាចពេញលេញ
លើព្រះរាជាណាចក្រអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«អ្នកនឹងបានគ្រប់គ្រងទាំងស្រុងលើព្រះរាជាណាចក្រអ៊ីស្រាអែល»
ក្រោមការគ្រប់គ្រងរបស់បុត្រមិនខាន។

generated on Wed Sep 10 16:16:32 2025

ពាក្យថា «ដៃ» ជាពាក្យប្រៀបធៀប ដែលតំណាងឱ្យអំណាច ឬការគ្រប់គ្រង។
1 Samuel 24:21
បុត្រនឹងមិនកាត់ផ្តាច់ពូជពង្សវង្សត្រកូលរបស់បិតាទេ
អ្នកនឹងមិនសម្លាប់កូនប្រុសរបស់យើង និងគ្រួសាររបស់ពួកគេឡើយ។
វាជារឿងធម្មតាទេ ដែលស្តេចថ្មីមិនមែនមកពីត្រកូលមុនៗ បានសម្លាប់កូនៗ
របស់អតីតស្តេច ដើម្បីការពារពួកគេមិនឲ្យប្រជែងឡើងសោយរាជ្យ។
ហើយបុត្រនឹងមិនបំផ្លាញព្រះនាមបិតាចេញពីក្រុមគ្រួសាររបស់បិតាដែរ។

វាមានសារសំខាន់ណាស់សម្រាប់គ្រួសារនីមួយៗ
នៅក្នុងប្រទេសអ៊ីស្រាអែលមានកូនចៅពីជំនាន់មួយទៅជំនាន់មួយ
ដែលមានឈ្មោះត្រកូល និងមរតកទឹកដី។ ការបកប្រែផ្សេងទៀត
«អ្នកនឹងមិនបំផ្លាញគ្រួសារ និងកូនចៅរបស់យើងទេ» ឬ
«អ្នកនឹងអនុញ្ញាតឲ្យគ្រួសាររបស់យើងរស់នៅ»
លោកដាវីឌ និងទាហាន
ដាវីឌនិងកងទ័ពរបស់លោក

---

25 [1]ពេលនោះ លោកសាំយ៊ូអែលបានស្លាប់ទៅហើយ។ កូនចៅអ៊ីស្រាអែលទាំងអស់បានមកជួបជុំគ្នា ហើយកាន់ទុក្ខដល់គាត់
រួចបានបញ្ចុះគាត់ក្នុងផ្ទះរបស់គាត់នៅរ៉ាម៉ា។ ឯលោកដាវីឌបានចុះទៅឯទីរហោស្ថានបារ៉ាសនវិញ។
[2]មានបុរសម្នាក់នៅម៉ាអូន ដែលមានដីធ្លីជាច្រើននៅកើមែល។ បុរសនោះជាអ្នកមានស្តុកស្តម្ភ គាត់មានចៀមបីពាន់ក្បាល និងពពែមួយពាន់ក្បាល។ ពេលនោះ
គាត់កំពុងកោររោមចៀមរបស់គាត់នៅភូមិកើមែល។[3]គាត់មានឈ្មោះថា ណាបាល ហើយប្រពន្ធរបស់គាត់ឈ្មោះ អប៊ីកែល។ ប្រពន្ធជាស្ត្រីដែលមានប្រាជ្ញាវាងវៃ
ហើយរូបសម្រស់ស្អាតល្អ។ ឯបុរសនោះ ជាមនុស្សឆេវឆាវ ហើយអាក្រក់។ គាត់ជាអ្នកមកពីអំបូរលោកកាលែប។
[4]លោកដាវីឌនៅឯទីរហោស្ថានបានឮថា លោកណាបាលកំពុងកោររោមចៀមរបស់លោក។[5]ដូច្នេះ លោកដាវីឌក៏បានចាត់យុវជនរបស់លោកទៅជួបដប់នាក់។
លោកដាវីឌបានប្រាប់ទៅយុវជនទាំងនោះថា៖ «ចូរចេញដំណើរទៅឯភូមិកើមែល ទៅជួបលោកណាបាល ហើយជម្រាបសួរលោកក្នុងនាមខ្ញុំផងចុះ។
[6]អ្នករាល់គ្នាត្រូវនិយាយទៅលោកថា សូមលោកមានអាយុវែង។ សូមឲ្យលោកនិងគ្រួសារបានប្រកបដោយក្តីសុខសាន្ត ហើយអ្វីៗដែលលោកមានបានចម្រើនឡើងដែរ។
[7]ខ្ញុំឮថា លោកកំពុងកោររោមចៀម។ កាលគង្វាលរបស់លោកនៅជាមួយពួកយើង ពួកគេមានសុវត្ថិភាពណាស់
ហើយពួកគេក៏ពុំដែលបាត់អ្វីកាលពួកគេនៅឯកើមែលដែរ។[8]សូមលោកសួរពួកគេមើលចុះ នោះគេនឹងនិយាយការពិតជូនលោកមិនខាន។ ឥឡូវនេះ
សូមលោកមេត្តាដល់យុវជនរបស់ខ្ញុំនៅចំពោះមុខលោកនេះផង ដោយយើងបានមកជួបលោកនៅថ្ងៃបុណ្យនេះ។ សូមមេត្តាផ្តល់នូវអ្វីដែលលោកមានដល់យុវជនទាំងនេះ
និងដល់ខ្ញុំ ដាវីឌនេះផងចុះ»។
[9]ពេលយុវជនរបស់លោកដាវីឌបានមកដល់ ពួកគេបានរៀបរាប់ដល់លោកណាបាលក្នុងនាមលោកដាវីឌ ហើយពួកគេក៏រង់ចាំចម្លើយមកវិញ។
[10]លោកណាបាលបានឆ្លើយតបនឹងយុវជនរបស់លោកដាវីឌវិញថា៖ «តើលោកដាវីឌជានរណា តើកូនប្រុសរបស់លោកអ៊ីសាយជានរណា?
សព្វថ្ងៃនេះមានបាវបម្រើជាច្រើនបានរត់គេចពីចៅហ្វាយរបស់ខ្លួន។[11]តើចង់ឲ្យយើងយកនំបុ័ង និងទឹករបស់យើង ថែមទាំងយកសាច់ដែលយើង
បានត្រៀមទុកសម្រាប់អ្នកកោររោមទៅឲ្យមនុស្សដែលយើងមិនដឹងមកពីណាឬ?»
[12]ឮដូច្នោះហើយ យុវជនទាំងនោះបានត្រឡប់ទៅវិញ ហើយបានរៀបរាប់គ្រប់យ៉ាងដល់លោកដាវីឌ។[13]លោកដាវីឌបានប្រាប់ទៅអ្នកដែលនៅជាមួយថា៖ «អ្នកទាំងអស់គ្នា
ចូរស្ពាយដាវចេញមក»។ មនុស្សទាំងអស់ក៏បានស្ពាយដាវរៀងៗខ្លួន។ លោកដាវីឌក៏ដូច្នោះដែរ។ លោកដាវីឌបានយកមនុស្សប្រហែលបួនរយនាក់ឲ្យមកតាម
ហើយបានទុកពីររយនាក់ផ្សេងទៀតឲ្យមើលថែសម្ភារៈ។
[14]ប៉ុន្តែ មានបាវម្នាក់បានមកជម្រាបលោកស្រីអប៊ីកែល ជាប្រពន្ធរបស់លោកណាបាលថា៖
«លោកដាវីឌបានចាត់អ្នកនាំសារឲ្យទៅទីរហោស្ថានដើម្បីសួរសុខទុក្ខចៅហ្វាយរបស់យើង តែលោកបានជេរប្រមាថពួកគេទៅវិញ។
[15]តាមពិតពួកគេជាមនុស្សល្អដល់យើងណាស់។ យើងមានសុវត្ថិភាពល្អ ហើយមិនដែលបាត់បង់អ្វីឡើយពេលណាយើងបាននៅជាមួយពួកគេនៅឯទីវាល។
[16]ពួកគេជាជញ្ជាំងដែលការពារពួកយើងទាំងថ្ងៃទាំងយប់ គ្រប់ពេលដែលយើងឃ្វាលហ្វូងចៀមនៅជាមួយពួកគេ។[17]ហេតុដូច្នេះ សូមទានជ្រាប ហើយពិចារណាថា
តើលោកស្រីគួរធ្វើដូចម្តេច ព្រោះផលវិបាកដ៏អាក្រក់មកដល់ចៅហ្វាយរបស់យើង និងគ្រួសារទាំងមូលមិនខាន។ លោកណាបាលជាមនុស្សដែលគ្មានហេតុផល
ហើយអាក្រក់ចំពោះអ្នកដទៃណាស់»។
[18]ភ្លាមនោះ លោកស្រីអប៊ីកែលបានប្រញាប់ប្រញាលយកនំបុ័ងពីររយដុំ ស្រាទំពាំងបាយជូរពីរដប ចៀមប្រាំក្បាលដែលបានរៀបចំហើយ លាជប្រាំតៅ
ទំពាំងបាយជូរក្រៀមមួយរយកញ្ចប់ ព្រមទាំងនំដែលធ្វើពីផ្លែឧទម្ពរពីររយដុំ ដាក់លើខ្នងលា។[19]លោកស្រីបាននិយាយទៅបាវបម្រើថា៖ «ចូរចេញទៅមុនខ្ញុំ
ហើយខ្ញុំនឹងចេញទៅតាមក្រោយពួកឯង»។ ប៉ុន្តែ លោកស្រីមិនបានប្រាប់ប្តីលោកស្រី គឺលោកណាបាលទេ។
[20]ខណៈលោកស្រីបានជិះលាចុះតាមចង្កេះភ្នំ លោកដាវីឌ និងមនុស្សរបស់លោកក៏បានចុះតម្រង់មកលោកស្រីដែរ ហើយលោកស្រីបានជួបពួកគេ។
[21]លោកដាវីឌបានមានប្រសាសន៍ថា៖ «ខ្ញុំបានការពារអ្វីៗរបស់គាត់នៅឯទីរហោស្ថានដោយឥតប្រយោជន៍ គាត់មិនបានបាត់បង់អ្វីដែលជារបស់ទ្រព្យគាត់ទេ
តែគាត់បែជាប្រព្រឹត្តអាក្រក់តបនឹងអំពើល្អទៅវិញ។[22]សូមព្រះជាម្ចាស់ដាក់ទោសដាវីឌខ្ញុំនេះចុះ ហើយឲ្យរឹតតែធ្ងន់ចុះ
បើខ្ញុំទុកជីវិតឲ្យប្រុសៗណាដែលនៅផ្ទះរបស់គាត់នៅរស់ដល់ព្រឹក»។
[23]ពេលលោកស្រីអប៊ីកែលបានឃើញលោកដាវីឌ លោកស្រីបានប្រញាប់ប្រញាល់ចុះពីខ្នងលា ហើយក្រាបនៅមុខលោកដាវីឌ ទាំងមុខ ហើយខ្លួនក្រាបដល់ដី។
[24]លោកស្រីបានក្រាបនឹងជើងរបស់លោកដាវីឌ ហើយនិយាយថា៖ «នាងខ្ញុំខុសហើយ លោកម្ចាស់។ សូមទុកឲ្យខ្ញុំជាបាវបម្រើរបស់លោកនិយាយទៅលោកសិន
សូមស្តាប់ពាក្យខ្ញុំ ជាអ្នកបម្រើលោកម្ចាស់ផង។
[25]សូមលោកម្ចាស់កុំរវីរវល់នឹងមនុស្សអត់បានការ លោកណាបាលនេះឡើយ គាត់គឺដូចឈ្មោះរបស់គាត់អីចឹង។ លោកណាបាលជាឈ្មោះរបស់គាត់
ហើយភាពលីលាក៏នៅជាមួយគាត់ដែរ។ ប៉ុន្តែ ខ្ញុំជាអ្នកបម្រើរបស់លោកពុំបានជួបនឹងយុវជនរបស់លោកម្ចាស់ដែលចាត់ឲ្យមកទេ។[26]លោកម្ចាស់អើយ ឥឡូវនេះ
ដោយនូវព្រះជន្មរបស់ព្រះអម្ចាស់ និងលោកម្ចាស់ផ្ទាល់ដែលកំពុងមានជីវិត គឺថា ព្រះអម្ចាស់បានឃាត់លោកម្ចាស់មិនឲ្យបង្ហូរឈាម
ហើយមិនឲ្យសងសឹកដោយដៃលោកម្ចាស់ផ្ទាល់ទេ សូមឲ្យសត្រូវរបស់លោកម្ចាស់ និងអស់អ្នកដែលចង់ប្រព្រឹត្តអាក្រក់ចំពោះលោកម្ចាស់ បានដូចជាលោកណាបាលចុះ។
[27]សូមលោកម្ចាស់ទទួលជំនូនដែលអ្នកបម្រើរបស់លោកម្ចាស់បានយកមកជូនលោកម្ចាស់ បានដល់យុវជនរបស់លោកម្ចាស់ចុះ។
[28]សូមអត់ទោសចំពោះសេចក្តីរំលងរបស់អ្នកបម្រើរបស់លោកម្ចាស់នេះផង ព្រះអម្ចាស់នឹងមុខជាធ្វើឲ្យលោកម្ចាស់រឹងមាំ
ពីព្រោះលោកម្ចាស់បានចេញទៅច្បាំងរួមជាមួយនឹងព្រះអម្ចាស់ ហើយគ្មានអំពើអាក្រក់ណាមួយដែលមានក្នុងលោកម្ចាស់អស់មួយជីវិតឡើយ។
[29]មានអ្នកដែលក្រោកតាមយកជីវិតរបស់លោកម្ចាស់ ប៉ុន្តែ ព្រះអម្ចាស់ជាព្រះរបស់លោកតាមការពារលោកជាប់ជានិច្ច
ព្រះអង្គនឹងគប់ជីវិតរបស់ខ្មាំងសត្រូវលោកម្ចាស់ដូចគប់ខ្សែដង្ហក់ដែរ។
[30]ព្រះអម្ចាស់នឹងបំពេញសេចក្តីសន្យាគ្រប់យ៉ាងដែលព្រះអង្គបានសន្យានឹងលោកម្ចាស់ ហើយនឹងតាំងលោកឲ្យធ្វើជាអ្នកដឹកនាំលើអ៊ីស្រាអែលមិនខាន។
[31]សូមកុំឲ្យនេះក្លាយជាបន្ទុកដ៏ធ្ងន់សម្រាប់លោក ដោយបានបង្ហូរឈាមមនុស្សគ្មានកំហុស ឬដោយព្រោះលោកម្ចាស់បានព្យាយាមសង្គ្រោះខ្លួនឯងឡើយ។
កាលណាព្រះអម្ចាស់ធ្វើការទាំងនោះចំពោះលោកម្ចាស់ហើយ សូមនឹកចាំពីអ្នកបម្រើរបស់លោកនេះផង»។
[32]លោកដាវីឌបានប្រសាសន៍ទៅលោកស្រីអប៊ីកែលថា៖ «សូមព្រះអម្ចាស់ជាព្រះនៃអ៊ីស្រាអែលបានតម្កើងឡើង ព្រះអង្គបានចាត់នាងឲ្យមកជួបខ្ញុំថ្ងៃនេះប្រាកដមែន។
[33]នាងបានប្រកបដោយប្រាជ្ញា និងមានពរហើយ ដោយនាងបានទប់ខ្ញុំជាប់ថ្ងៃនេះពីការបង្ហូរឈាម និងពីការសងសឹកដោយផ្ទាល់ដៃរបស់ខ្ញុំ!

generated on Wed Sep 10 16:16:32 2025

[34]ជាការពិត គឺព្រះអម្ចាស់ជាព្រះនៃអ៊ីស្រាអែលដែលមានព្រះជន្មគង់នៅបានឃាត់ខ្ញុំមិនឲ្យប៉ះពាល់នាងមែន។ បើនាងមិនប្រញាប់មកជួបខ្ញុំទេ
មុខជាគ្មានមនុស្សប្រុសណាម្នាក់មានជីវិតរស់រានដល់ព្រឹកឡើង សូម្បីតែទារក»។[35]ដូច្នេះ លោកដាវីឌព្រមទទួលជំនូនពីដៃលោកស្រីដែលបាននាំយកមកជូនលោក
ហើយនិយាយថា៖ «ចូរត្រឡប់ទៅផ្ទះរបស់នាងវិញដោយសុខសាន្តចុះ ខ្ញុំព្រមស្តាប់សំដីរបស់នាង ហើយទទួលតាមពាក្យនាងហើយ»។
[36]លោកស្រីអប៊ីកែលបានត្រឡប់មកលោកណាបាលវិញ។ គាត់បានធ្វើពិធីជប់លៀងយ៉ាងធំ ដូចជប់លៀងស្តេច លោកណាបាលមានចិត្តរីករាយយ៉ាងខ្លាំង
ព្រោះលោកបានស្រវឹងជោកជាំ។ ហេតុដូចនេះ លោកស្រីមិនបាននិយាយអ្វីជាមួយគាត់រហូតដល់ព្រឹកឡើង។
[37]ពេលព្រឹកឡើង ជាតិស្រាបានសាបអស់ពីលោកណាបាល ប្រពន្ធរបស់លោកបានជម្រាបលោកនូវរឿងរ៉ាវទាំងអស់នោះ លោកក៏គាំងបេះដូង នៅស្តូកស្តឹងដូចថ្ម។
[38]ប្រមាណជាដប់ថ្ងៃក្រោយមកព្រះអម្ចាស់បានប្រហារលោកណាបាល ហើយបានស្លាប់ទៅ។
[39]ពេលលោកដាវីឌបានឮដំណឹងថា លោកណាបាលបានស្លាប់ ក៏បានមានប្រសាសន៍ថា៖ «សូមសរសើរតម្កើងព្រះអម្ចាស់ ដែលបានរកយុត្តិធម៌រវាងទូលបង្គំ
និងណាបាល ហើយបានឃាត់ទូលបង្គំមិនឲ្យប្រព្រឹត្តអាក្រក់។ ដ្បិត ព្រះអង្គបានឆ្លើយតបអំពើអាក្រក់របស់លោកណាបាលធ្លាក់លើក្បាលរបស់គាត់វិញ»។
ក្រោយមកលោកដាវីឌបានចាត់អ្នកបម្រើឲ្យទៅនិយាយនឹងលោកស្រីអប៊ីកែល ស្នើឲ្យលោកស្រីធ្វើជាភរិយារបស់លោក។
[40]ពេលអ្នកបម្រើរបស់លោកដាវីឌបានមកដល់ជួបលោកស្រីអប៊ីកែលនៅភូមិកើមែល ពួកគេបាននិយាយទៅលោកស្រីថា៖
«លោកដាវីឌបានចាត់យើងខ្ញុំឲ្យមកជួបលោកស្រី សូមឲ្យលោកស្រីធ្វើជាភរិយារបស់លោក»។
[41]លោកស្រីបានក្រោកឡើង ឱនមុខដល់ដីហើយនិយាយថា៖ «មើល អ្នកបម្រើស្រីរបស់លោកម្ចាស់
គឺគ្រាន់តែជាអ្នកបម្រើដែលលាងជើងឲ្យពួកអ្នកបម្រើរបស់លោកម្ចាស់ប៉ុណ្ណោះ»។[42]លោកស្រីក៏ប្រញាប់ក្រោកឡើង
ជិះលើខ្នងលាទាំងមានបាវបម្រើស្រីប្រាំនាក់ទៀតទៅជាមួយផង រួចបានទៅតាមអ្នកនាំសាររបស់លោកដាវីឌ ហើយបានក្លាយជាភរិយារបស់លោក។
[43]លោកដាវីឌក៏បានយកនាងអហ៊ីណោម ពីស្រុកយេសរាលធ្វើជាភរិយាដែរ។ ពួកនាងទាំងពីរបានក្លាយជាភរិយារបស់លោក។
[44]ហើយព្រះបាទសូលក៏ធ្លាប់បានលើកព្រះនាងមិកាល់ជាបុត្រីឲ្យធ្វើជាភរិយារបស់លោកដាវីឌដែរ តែក្រោយមកបានលើកនាងឲ្យទៅលោកប៉ាល់ធី
ជាកូនរបស់លោកឡាអ៊ីស ជាអ្នកស្រុកកាលីម។

---

1 Samuel 25:1

កូនចៅអ៊ីស្រាអែលទាំងអស់បានមកជួបជុំគ្នា ហើយកាន់ទុក្ខដល់គាត់

ទំនងជាការធ្វើឲ្យមានលក្ខណៈទូទៅ។ ប្រជាជនអ៊ីស្រាអែលមួយចំនួនធំ
ប្រហែលជានៅទីនោះ ប៉ុន្តែ អ្នកខ្លះប្រហែលជាមិនអាចចូលរួមបានទេ។

បានមកជួបជុំគ្នា

«ប្រមូលផ្តុំជួបជុំគ្នា»

រួចបានបញ្ចុះគាត់ក្នុងផ្ទះរបស់គាត់នៅរ៉ាម៉ា។

អាចមានន័យថា ពួកគេបានបញ្ចុះសពសាំយូអែល ១)
នៅស្រុកកំណើតរបស់លោកក្នុងក្រុងរ៉ាម៉ា ឬ ២) នៅលើដីគ្រួសាររបស់លោក
នៅក្រុងរ៉ាម៉ា តែមិនមែននៅក្នុងផ្ទះ ឬ ៣) នៅក្នុងផ្ទះរបស់លោកនៅរ៉ាម៉ា។

ឯលោកដាវីឌបានចុះទៅ

«ស្តេចដាវីឌនិងពួកទាហានរបស់លោក
បានចេញទៅហើយពួកគេបានចុះទៅ» (សូមមើលយូឌីប៊ី)

1 Samuel 25:2

មានបុរសម្នាក់នៅម៉ាអូន ដែលមានដីធ្លីជាច្រើននៅកើមែល។ បុរសនោះជាអ្នកមានស្តុកស្តម្ភ
គាត់មានចៀមបីពាន់ក្បាល និងពពែមួយពាន់ក្បាល។ ពេលនោះ
គាត់កំពុងកោររោមចៀមរបស់គាត់នៅភូមិកើមែល។ គាត់មានឈ្មោះថា ណាបាល
ហើយប្រពន្ធរបស់គាត់ឈ្មោះ អប៊ីកែល។ ប្រពន្ធជាស្ត្រីដែលមានប្រាជ្ញាវាងវៃ
ហើយរូបសម្រស់ស្អាតល្អ។ ឯបុរសនោះ ជាមនុស្សឆេវឆាវ ហើយអាក្រក់។
គាត់ជាអ្នកមកពីអំបូរលោកកាលែប។

អ្នកបកប្រែខ្លះ ប្រហែលជាត្រូវដាក់គំនិតនៅក្នុងខទាំងនេះតាមលំដាប់លំដោយ។
ការបកប្រែផ្សេងទៀត «មានបុរសម្នាក់ឈ្មោះណាបាលជាកូនចៅរបស់កាលែប
ដែលជាអ្នកមានទ្រព្យសម្បត្តិយ៉ាងច្រើន។ គាត់រស់នៅឯម៉ាអូន
តែទ្រព្យសម្បត្តិរបស់គាត់នៅកើមែល គាត់មានចៀមបីពាន់ក្បាល
និងពពែមួយពាន់ក្បាល។ ភរិយារបស់គាត់ឈ្មោះអប៊ីកែល។ ស្ត្រីមានប្រាជ្ញាវាងវៃ
និងមានរូបរាងស្រស់ស្អាត។ ឥឡូវនេះ គាត់កំពុងកាត់ចៀមនៅកើមែល»។

ម៉ាអូន

នេះជាឈ្មោះទីក្រុង។

កើមែល

នេះជាឈ្មោះទីក្រុង។ ក្រុងនេះខុសគ្នាពីភ្នំកើមែល។

បីពាន់ក្បាល

៣,០០០ក្បាល

មួយពាន់ក្បាល

១,០០០ក្បាល

កំពុងកោររោមចៀមរបស់គាត់

«កោររោមចៀមចេញពីចៀមរបស់គាត់»

ណាបាល

នេះជាឈ្មោះរបស់បុរស។ (សូមមើល
អប៊ីកែល

នេះជាឈ្មោះរបស់ស្ត្រី។

គាត់ជាអ្នកមកពីអំបូរលោកកាលែប។

នៅទីនេះ «ផ្ទះ» តំណាងឲ្យគ្រួសារ។ ការបកប្រែផ្សេងទៀត
«គាត់ជាកូនចៅរបស់គ្រួសារកាលែប» ឬ «គាត់ជាកូនចៅរបស់កាលែប»

1 Samuel 25:4

កោររោមចៀមរបស់លោក

«កោររោមចៀមចេញពីចៀមរបស់គាត់»

ហើយជម្រាបសួរលោកក្នុងនាមខ្ញុំផងចុះ។

«ជម្រាបសួរគាត់ដូចជាខ្ញុំស្វាគមន៍គាត់ បើខ្ញុំនៅទីនោះ»

សូមលោកមានអាយុវែង។

«ខ្ញុំប្រាថ្នាសូមឲ្យអ្នករស់នៅមានអាយុយឺនយូរ» ។ នាមអរូបី«អាយុវែង»
អាចបកប្រែជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ខ្ញុំប្រាថ្នាសូមឲ្យអ្នកមានរបស់ល្អៗជាច្រើន ដរាបណាអ្នកនៅរស់»

សូមឲ្យលោកនិងគ្រួសារបានប្រកបដោយក្តីសុខសាន្ត
ហើយអ្វីៗដែលលោកមានបានចម្រើនឡើងដែរ។

«ខ្ញុំប្រាថ្នាថា សន្តិភាពនឹងកើតមានដល់អ្នក គ្រួសាររបស់អ្នក
និងទ្រព្យសម្បត្តិរបស់អ្នក»

1 Samuel 25:7

លោកកំពុងកោររោមចៀម។

«អ្នកកោរោមចៀមរបស់អ្នកកំពុងធ្វើការ» ឬ
«អ្នកកោររោមចៀមមានចៀមសម្រាប់កោររោម។ »

ដាវីឌចង់ឲ្យពួកទាហានរបស់គាត់និយាយ ដូច្នេះ លោកណាបាលយល់ថា
ចៀមរបស់គាត់សុខសប្បាយ ពីព្រោះទាហានរបស់ដាវីឌបានជួយការពារពួកគេ។

ពួកគេមានសុវត្ថិភាពណាស់ ហើយពួកគេក៏ពុំដែលបាត់អ្វី

ដាវីឌកំពុងតែចង្អុលបង្ហាញពីរបៀប
ដែលគាត់និងពួកទាហានរបស់គាត់បានការពារដល់ពួកអ្នកបម្រើ
និងហ្វូងចៀមរបស់លោកណាបាល។ អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។
ការបកប្រែផ្សេងទៀត «យើងបានការពារពួកគេ
និងទ្រព្យសម្បត្តិទាំងអស់ពីគ្រោះថ្នាក់»

សូមលោកមេត្តាដល់យុវជនរបស់ខ្ញុំ នៅចំពោះមុខលោកនេះផង

នៅទីនេះ ចំពោះមុខតំណាងឲ្យការមើលឃើញ
ហើយការមើលឃើញតំណាងឲ្យគំនិត ឬការវិនិច្ឆ័យ។ ការបកប្រែផ្សេងទៀត
«សូមឲ្យអ្នកពេញចិត្តនឹងយុវជនវ័យក្មេងរបស់ខ្ញុំ» ឬ
«អ្នកអាចពិចារណាយុវជនរបស់ខ្ញុំឲ្យបានល្អ»

ដល់យុវជនទាំងនេះ

ដាវីឌបានបង្ហាញការគោរពចំពោះណាបាល
ដោយហៅអ្នកបម្រើរបស់លោកណាបាល ជាអ្នកបម្រើរបស់គាត់។

ដល់ខ្ញុំ ដាវីឌនេះផងចុះ

ដាវីឌបាននិយាយដូចជា គាត់ជាកូនប្រុសរបស់ណាបាល ដើម្បីបង្ហាញថា

generated on Wed Sep 10 16:16:32 2025

គាត់គោរពណាបាលជាមនុស្សចាស់។
1 Samuel 25:9
យុវជនរបស់លោកដាវីឌ
«កងទ័ពរបស់ដាវីឌ»
បានរៀបរាប់ដល់លោកណាបាលក្នុងនាមលោកដាវីឌ
«បានផ្តល់ឲ្យលោកណាបាលនូវសារទាំងស្រុងរបស់ដាវីឌ»
តើលោកដាវីឌជានរណា តើកូនប្រុសរបស់លោកអ៊ីសាយជានរណា?
លោកណាបាលប្រហែលជាដឹងថា ដាវីឌជានរណា
ប៉ុន្តែគាត់មិនចង់ជួយលោកដាវីឌទេ។
រត់គេចពី
«រត់ចេញពី» ឬ «បះបោរប្រឆាំងនឹង»
យើងយកនំបុ័ង
នៅទីនេះ «នំបុ័ង» ជាឃ្លាសម្រាប់អាហារប្រភេទណាមួយ។
មនុស្សដែលយើងមិនដឹងមកពីណាឬ?
«មនុស្សដែលយើងមិនដឹងថា ពួកគេមកពីណា» ឬ «មនុស្សដែលយើងមិនស្គាល់»
1 Samuel 25:12
បានរៀបរាប់គ្រប់យ៉ាង
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«លោកណាបាលបាននិយាយ»
បានប្រាប់ទៅអ្នកដែលនៅជាមួយថា
«បាននិយាយទៅកាន់កងទ័ពរបស់លោក»
«អ្នកទាំងអស់គ្នា ចូរស្ពាយដាវចេញមក»។ មនុស្សទាំងអស់ក៏បានស្ពាយដាវរៀងៗខ្លួន។
លោកដាវីឌក៏ដូច្នោះដែរ។
បើដាវមិនត្រូវបានគេស្គាល់នៅក្នុងភាសារបស់អ្នក អ្នកអាចចាត់ទុក
«ស្ពាយដាវរបស់គាត់» ជាអត្ថន័យពាក្យប្រៀបធៀប ត្រៀមធ្វើសង្គ្រាម។
ការបកប្រែផ្សេងទៀត «មនុស្សគ្រប់គ្នាត្រៀមខ្លួនធ្វើសង្គ្រាម»។
ហើយមនុស្សគ្រប់រូបបានត្រៀមខ្លួនធ្វើសង្គ្រាម
ស្តេចដាវីឌក៏បានត្រៀមធ្វើសង្គ្រាមដែរ”
បួនរយនាក់
៤០០នាក់
ពីររយនាក់
២០០នាក់
មើលថែសម្ភារៈ
ពួកគេស្ថិតនៅជំរំមូលដ្ឋានរបស់ពួកគេ ដើម្បីការពារអ្នកវាយឆ្មក់ផ្សេងទៀត
ពីការលួចទ្រព្យសម្បត្តិរបស់ពួកគេ។
1 Samuel 25:14
ប៉ុន្តែ មានបាវម្នាក់បានមកជម្រាបលោកស្រីអប៊ីកែល ជាប្រពន្ធរបស់លោកណាបាលថា
អ្នកប្រហែលជាត្រូវបញ្ជាក់ឲ្យច្បាស់ នូវអ្វីដែលយុវជននោះបានធ្វើ
មុនពេលគាត់និយាយជាមួយលោកស្រីអ័ប៊ីកែល។ ការបកប្រែផ្សេងទៀត
«អ្នកបម្រើម្នាក់របស់លោកណាបាលដឹងថា លោកដាវីឌនិងពួកទាហានរបស់លោក
កំពុងមានគម្រោងធ្វើ ដូច្នេះ គាត់បានទៅរកប្រពន្ធរបស់លោកណាបាល
គឺលោកស្រីអ័ប៊ីកែល»។
យើងមានសុវត្ថិភាពល្អ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់ធ្វើបាបយើងទេ» ឬ «យើងមានសុវត្ថិភាព»
ហើយមិនដែលបាត់បង់អ្វីឡើយពេលណាយើងបាននៅជាមួយពួកគេ
«យើងមិនបានបាត់បង់អ្វីទេ ពេលយើងនៅជាមួយពួកគេ» ។
ទាហានរបស់ដាវីឌបានការពារសត្វ
និងមនុស្សផ្សេងទៀតពីការលួចយកហ្វូងសត្វរបស់លោកណាបាល។
1 Samuel 25:16
ពួកគេជាជញ្ជាំង
ទាហានរបស់លោកដាវីឌប្រៀបបាននឹងជញ្ជាំងព័ទ្ធជុំវិញទីក្រុង
ដែលការពារប្រជាជនក្នុងទីក្រុង ឲ្យរួចផុតពីខ្មាំងសត្រូវ។
ព្រោះផលវិបាកដ៏អាក្រក់មកដល់ចៅហ្វាយរបស់យើង
អ្នកនិយាយប្រយ័ត្នប្រយែងមិនបញ្ចេញឈ្មោះ
អ្នកដែលរៀបផែនការអាក្រក់នោះទេ។ អាចបកប្រែជាទម្រង់កិរិយាសកម្ម។
ការបកប្រែផ្សេងទៀត «មាននរណាម្នាក់កំពុងរៀបចំផែនការអាក្រក់
ចំពោះចៅហ្វាយរបស់យើង»
ចៅហ្វាយរបស់យើង
អ្នកនិយាយអំពីលោកដាវីឌ ដូចជាលោកដាវីឌជាមនុស្សម្នាក់ផ្សេងទៀត
ដើម្បីបង្ហាញថា គាត់គោរពលោកដាវីឌ។ ការបកប្រែផ្សេងទៀត «អ្នក»
1 Samuel 25:18
ពីររយដុំ
២០០ដុំ
នំប៉័ង
នំប៉័ងដូចជានំមួយ។ អ្នកប្រហែលជាត្រូវបញ្ជាក់ឲ្យច្បាស់ថា នំប៉័ងមានអ្វីខ្លះ។
ការបកប្រែផ្សេងទៀត «ដុំនៃនំប៉័ង»
ដែលបានរៀបចំហើយ
«នរណាម្នាក់បានចម្អិនរួចហើយ» ឬ «រៀបចំនរណាម្នាក់សម្រាប់ចម្អិន»
ខ្ជាត
នេះជាពាក្យទូទៅ ដែលមិនត្រូវបានគេបញ្ជាក់ឲ្យបានច្បាស់ទេ។
លាជ
«គ្រាប់ស្រូវដែលមាននរណាម្នាក់បានចម្អិន»
ទំពាំងបាយជូរក្រៀមមួយរយកញ្ចប់
«នំក្រៀម»ឬ «នំក្រៀមដុំធំ»
1 Samuel 25:20
លោកដាវីឌ និងមនុស្សរបស់លោក
ដាវីឌនិងកងទ័ពរបស់លោក
ចុះតាមចង្កេះភ្នំ
អាចមានន័យថា ១) ចូលទៅក្នុងតំបន់ទំនាបមានទឹកហូរតិចតួច ឬ ២)
ទៅកន្លែងដែលទាហានលាក់ខ្លួន។
1 Samuel 25:21
ឃ្លាភ្ជាប់៖
អ្នកនិពន្ធផ្តល់ព័ត៌មានសង្ខេប មុនពេលគាត់បន្តរឿង។
លោកដាវីឌបានមានប្រសាសន៍ថា «ខ្ញុំបានការពារ ...គាត់»។
អ្នកអានចាំបាច់ត្រូវយល់ថា លោកដាវីឌបាននិយាយរឿងទាំងនេះ
មុនពេលគាត់និយាយថា «មនុស្សគ្រប់គ្នាស្ពាយដាវរបស់ខ្លួន» នៅក្នុង២៥:១២ ។
ឥឡូវលោកដាវីឌ
ពាក្យថា «ឥឡូវ» បង្ហាញថា អ្នកនិពន្ធបានឈប់សរសេរអំពីលោកស្រីអ័ប៊ីកែល
ហើយចាប់ផ្តើមសរសេរអំពីលោកដាវីឌ។
មិនបានបាត់បង់អ្វីដែលជារបស់ទ្រព្យគាត់ទេ
អាចបញ្ជាក់ជាវិជ្ជមាន និងទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«គាត់នៅតែមានអ្វីគ្រប់យ៉ាង ដែលជារបស់គាត់»
សូមព្រះជាម្ចាស់ដាក់ទោសដាវីឌខ្ញុំនេះចុះ
បទគម្ពីរភាសាហេប្រឺមាន
«សូមព្រះជាម្ចាស់វាយប្រហារខ្មាំងសត្រូវរបស់លោកដាវីឌ»
ហើយមានការបកប្រែខ្លះៗធ្វើតាម។ ទោះជាយ៉ាងណាក៏ដោយ ការអានរបស់
យូអិលប៊ី ធ្វើតាមប្រពៃណីក្រិកបុរាណនៃព្រះគម្ពីរសម័្ពន្ធមេត្រីចាស់
ដូចគ្នានឹងជំនាន់ទំនើបដទៃទៀតដែរ។
ដែលនៅផ្ទះរបស់គាត់
«មនុស្សទាំងអស់ដែលជាកម្មសិទ្ធិរបស់គាត់» ឬ
«អស់អ្នកដែលនៅក្នុងគ្រួសាររបស់គាត់»
1 Samuel 25:23
ឃ្លាភ្ជាប់៖
អ្នកនិពន្ធបានបញ្ចប់ការផ្តល់ព័ត៌មានសង្ខេប ដូច្នេះ គាត់នៅតែបន្តរឿង។
ហើយក្រាបនៅមុខលោកដាវីឌ ទាំងមុខ ហើយខ្លួនក្រាបដល់ដី។
លោកស្រីអ័ប៊ីកែលមានចិត្តបន្ទាបខ្លួន ហើយបង្ហាញថា នាងនឹងគោរពលោកដាវីឌ
ពីព្រោះ លោកជាមេដឹកនាំដែលមានអំណាច។
សូមស្តាប់
«ចិត្ត»
លោកម្ចាស់ ... លោកម្ចាស់ ... ពាក្យខ្ញុំ ជាអ្នកបម្រើលោកម្ចាស់ផង។
«អ្នក ... ពាក្យរបស់ខ្ញុំ»«លោកស្រីអ័ប៊ីកែលនិយាយអំពីខ្លួននាង
និងលោកដាវីឌហាក់ដូចជា ពួកគេជាមនុស្សពីរនាក់ខុសគ្នា
ដើម្បីបង្ហាញថានាងគោរពលោកដាវីឌ»។
1 Samuel 25:25
ឃ្លាភ្ជាប់៖
លោកស្រីអប៊ីកែលនៅតែបន្តផ្តល់យោបល់ដល់លោកដាវីឌ កុំឲ្យសងសឹក។
សូមលោកម្ចាស់កុំរវីរវល់... សូមលោកម្ចាស់កុំរវីរវល់... យុវជនរបស់លោកម្ចាស់ ...

generated on Wed Sep 10 16:16:32 2025

របស់លោកម្ចាស់ ... លោកម្ចាស់អើយ
លោកស្រីអប៊ីកែលនិយាយអំពីខ្លួននាង និងលោកដាវីឌហាក់ដូចជាពួកគេ
ជាមនុស្សពីរនាក់ខុសគ្នា ដើម្បីបង្ហាញថានាងគោរពដាវីឌ។ ការបកប្រែផ្សេងទៀត
«កុំយកចិត្តទុកដាក់ ... ខ្ញុំ ... យុវជនរបស់អ្នក ... របស់លោកម្ចាស់ ... អ្នក»
ប៉ុន្តែ ខ្ញុំ ... ពុំបានជួប ... ដែលចាត់ឲ្យមកទេ
អ្នកប្រហែលជាត្រូវធ្វើឲ្យច្បាស់នូវអ្វី ដែលលោកស្រីអប៊ីកែលបានធ្វើ។
ការបកប្រែផ្សេងទៀត «ប៉ុន្តែប្រសិនបើខ្ញុំ ... បានឃើញ ...
អ្នកដែលអ្នកចាត់ឲ្យមកខ្ញុំនឹងឲ្យអាហារដល់ពួកគេ»
បង្ហូរឈាម
ឃាតករ
ហើយមិនឲ្យសងសឹកដោយដៃលោកម្ចាស់ផ្ទាល់ទេ
ដៃជាពាក្យប្រៀបធៀបសម្រាប់អ្វីៗ ដែលមនុស្សម្នាក់ធ្វើដោយដៃ។
លោកស្រីអប៊ីកែលស្មានថា
លោកដាវីឌគួរតែអនុញ្ញាតឲ្យព្រះអម្ចាស់សងសឹកជំនួសគាត់។
ការបកប្រែផ្សេងទៀត
«ការសងសឹកខ្លួនឯងជំនួសឲ្យការអនុញ្ញាតព្រះអម្ចាស់ធ្វើវិញ»
សូមឲ្យសត្រូវរបស់លោកម្ចាស់ ...ដូចជាលោកណាបាលចុះ។
លោកស្រីអប៊ីកែលនិយាយដូចជា
ព្រះអម្ចាស់បានដាក់ទោសលោកណាបាលរួចហើយ។ ការបកប្រែផ្សេងទៀត
«ខ្ញុំសង្ឃឹមថា ព្រះអម្ចាស់នឹងដាក់ទោសសត្រូវរបស់អ្នក ...
ដូចដែលគាត់នឹងដាក់ទណ្ឌកម្មលោកណាបាល»
1 Samuel 25:27
ឃ្លាភ្ជាប់៖
លោកស្រីអប៊ីកែលបន្តប្រាប់លោកដាវីឌកុំឲ្យខឹង។
ដូចជាលោកណាបាលចុះ។
«អំណោយទាំងនេះ»។ «ជំនួន» មានរបស់ជាច្រើនផ្សេងៗពីគ្នា។
ដូចជាលោកណាបាលចុះ។ ... ជូនលោកម្ចាស់ ...របស់លោកម្ចាស់ ...
សេចក្តីរំលងរបស់អ្នកបម្រើរបស់លោកម្ចាស់ ... លោកម្ចាស់ ... លោកម្ចាស់
លោកស្រីអប៊ីកែលនិយាយអំពីខ្លួនឯង និងលោកដាវីឌហាក់ដូចជាពួកគេ
ជាមនុស្សពីរនាក់ខុសគ្នា ដើម្បីបង្ហាញថា នាងគោរពលោកដាវីឌ។
ការបកប្រែផ្សេងទៀត «ខ្ញុំ ... លោក ... អ្នក ... សេចក្តីរំលងរបស់ខ្ញុំ ... អ្នក ...
អ្នក»
លោកម្ចាស់ ... បានដល់យុវជនរបស់លោកម្ចាស់ចុះ។
លោកស្រីអប៊ីកែលប្រើការស្ងៀមស្ងាត់
ដើម្បីបង្ហាញការគោរពរបស់នាងចំពោះលោកដាវីឌ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «សូមឲ្យវាទៅយុវជន»
ឬ «សូមម្ចាស់របស់ខ្ញុំឲ្យវាទៅយុវជន»
ព្រះអម្ចាស់នឹងមុខជាធ្វើឲ្យលោកម្ចាស់រឹងមាំ
នៅទីនេះ «ផ្ទះ» ជាឃ្លាប្រើសម្រាប់ «កូនចៅ» ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងធានាថា ម្ចាស់របស់ខ្ញុំតែងតែមានកូនចៅឡើងធ្វើជាស្តេច»
ចេញទៅច្បាំងរួមជាមួយនឹងព្រះអម្ចាស់
«ចេញច្បាំងនឹងខ្មាំងសត្រូវរបស់ព្រះអម្ចាស់»
ហើយគ្មានអំពើអាក្រក់ណាមួយដែលមានក្នុងលោកម្ចាស់
អាចកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់នឹងឃើញអ្នកធ្វើអំពើអាក្រក់ណាមួយ»
ឬ«អ្នកនឹងមិនដែលធ្វើអ្វីដែលអាក្រក់ឡើយ»
1 Samuel 25:29
តាម
«ដេញតាម» ឬ«តាមប្រមាញ់»
ជីវិតរបស់លោកម្ចាស់ ប៉ុន្តែ ព្រះអម្ចាស់ជាព្រះរបស់លោកតាមការពារលោកជាប់ជានិច្ច
លោកស្រីអប៊ីកែលនិយាយអំពីជីវិតរបស់លោកដាវីឌ ហាក់ដូចជាវត្ថុវែង
និងស្តើងដែលមនុស្សម្នាក់អាចដាក់ជាមួយវត្ថុវែង និងស្តើងផ្សេងទៀត
ហើយបន្ទាប់មកចងខ្ជាប់នឹងក្រណាត់។ អាចបកប្រែជាទម្រង់កិរិយាសកម្ម។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងចងជីវិតរបស់លោកម្ចាស់ក្នុងការរស់នៅ» ឬ «
ព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងរក្សាអ្នកឲ្យនៅរស់ជាមួយអស់អ្នកដែលនៅរស់»
ព្រះអង្គនឹងគប់ជីវិតរបស់ខ្មាំងសត្រូវលោកម្ចាស់ដូចគប់ខ្សែដង្ហក់ដែរ។
លោកស្រីអប៊ីកែលនិយាយអំពីខ្លួនឯង
និងលោកដាវីឌហាក់ដូចជាពួកគេជាមនុស្សពីរនាក់ខុសគ្នា ដើម្បីបង្ហាញថា
នាងគោរពដាវីឌ។ ការបកប្រែផ្សេងទៀត «ជីវិតរបស់អ្នក»
ជីវិតរបស់លោកម្ចាស់
លោកស្រីអប៊ីកែលប្រៀបប្រដូចជីវិតខ្មាំងសត្រូវរបស់លោកដាវីឌ
ទៅនឹងវត្ថុតូចៗដូចជាថ្មមួយ ដែលអាចដាក់ក្នុងដង្ហក់ហើយបាញ់ចម្ងាយ។
ការបកប្រែផ្សេងទៀត « គាត់នឹងសម្លាប់សត្រូវរបស់អ្នកបានយ៉ាងងាយ
ដូចជាមនុស្សម្នាក់គ្រវែងដង្ហក់ដាក់ដុំថ្មទៅឆ្ងាយ»
ដង្ហក់
ចំណែកស្បែកសត្វមួយ មានខ្សែវែងនៅចុងទាំងពីរ ដែលមនុស្សម្នាក់អាចដាក់ដុំថ្ម
ឬវត្ថុរឹងរឹងផ្សេងទៀត ហើយគ្រវែងវាទៅឆ្ងាយ
1 Samuel 25:30
ឃ្លាភ្ជាប់៖
លោកស្រីអប៊ីកែលបន្តវែកញែកជាមួយនឹងលោកដាវីឌ។
លោកម្ចាស់ ... លោកម្ចាស់ ... លោកម្ចាស់ ... អ្នកបម្រើរបស់លោក
លោកស្រីអប៊ីកែលប្រៀបប្រដូចខ្លួនឯង
និងលោកដាវីឌហាក់ដូចជាពួកគេជាមនុស្សពីរនាក់ខុសគ្នា ដើម្បីបង្ហាញថា
នាងគោរពដាវីឌ។ «លោក ... លោក ... លោក ... ខ្ញុំ»
សូមកុំឲ្យនេះក្លាយជាបន្ទុកដ៏ធ្ងន់សម្រាប់លោក
លោកស្រីអប៊ីកែលកំពុងថ្លែងថា បើលោកដាវីឌជ្រើសរើសមិនសងសឹក
គាត់នឹងមានមនសិកាជ្រះថ្លា ពេលព្រះអម្ចាស់តែងតាំងគាត់ជាស្តេចអ៊ីស្រាអែល។
អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «អ្នកនឹងរីករាយជានិច្ច
ដែលបានប្រព្រឹត្តដូចពាក្យ អ្នកបាននិយាយ»
កាលណាព្រះអម្ចាស់ធ្វើការទាំងនោះចំពោះលោកម្ចាស់ហើយ
គឺនៅពេលព្រះអម្ចាស់បានតែងតាំងគាត់ ជាស្តេចពិតប្រាកដ
បន្ទាប់ពីរាជ្យរបស់ស្តេចសូលបានបញ្ចប់។
1 Samuel 25:32
ព័ត៌មានទូទៅ៖
លោកដាវីឌព្រមទទួលការប្រឹក្សាយោបល់ និងអំណោយរបស់លោកស្រីអប៊ីកែល។
សូមព្រះអម្ចាស់ ... សូមព្រះអម្ចាស់ ព្រះអង្គបានចាត់
អាចត្រូវបានបកប្រែជាទម្រង់សកម្ម។ អាចមានន័យថា ១)
«ខ្ញុំសូមសរសើរដល់ព្រះអម្ចាស់ ... អ្នកដែល» ឬ ២)
«សូមឲ្យប្រជាជនទាំងអស់សរសើរតម្កើងព្រះអម្ចាស់ ... អ្នកដែល»។
នាងបានប្រកបដោយប្រាជ្ញា និងមានពរហើយ ដោយ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ខ្ញុំសូមអរព្រះគុណដល់ព្រះអម្ចាស់ ពីព្រោះព្រះអង្គបានប្រទានពរដល់អ្នក
ដោយធ្វើឲ្យអ្នកមានប្រាជ្ញានិងពីព្រោះ»
ការបង្ហូរឈាម
ឃាតកម្ម។ ពាក្យដដែលមាននៅក្នុង ២៥:២៥ ។
ដោយផ្ទាល់ដៃរបស់ខ្ញុំ!
ពាក្យថា« ដៃ»នៅទីនេះ គឺជាពាក្យប្រៀបធៀបសម្រាប់សកម្មភាព
ដែលធ្វើឡើងដោយដៃ។ ការបកប្រែផ្សេងទៀត
«ដោយសកម្មភាពផ្ទាល់ខ្លួនរបស់ខ្ញុំ»
1 Samuel 25:34
ព័ត៌មានទូទៅ៖
លោកដាវីឌព្រមទទួលអំណោយរបស់លោកស្រីអប៊ីកែលហើយយល់ព្រមធ្វើតាមអ្វី
ដែលនាងបានផ្តល់យោបល់។
មុខជាគ្មានមនុស្សប្រុសណាម្នាក់មានជីវិតរស់រាន ដល់ព្រឹកឡើង សូម្បីតែទារក។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ខ្ញុំនឹងមិនស្លាប់ចោលលោកណាបាល សូម្បីតែទារកម្នាក់»
ព្រមទទួលជំនួនពីដៃលោកស្រី
នេះជាឃ្លាសំនួនវោហាស័ព្ទ។ លោកស្រីអប៊ីកែលមិនបានយកអំណោយទាំងអស់
ពីសត្វលាដោយខ្លួនឯងទេ។ ការបកប្រែផ្សេងទៀត
«ទទួលយកអំណោយទាំងអស់ដែលនាងបាននាំ»
ព្រមស្តាប់សម្តីរបស់នាង
ពាក្យថា «សំឡេង» គឺជាពាក្យប្រៀបធៀបសម្រាប់សារ
សម្រាប់មនុស្សដែលនិយាយ។ ការបកប្រែផ្សេងទៀត
«បានស្តាប់នូវអ្វីដែលអ្នកបានប្រាប់ខ្ញុំ» ឬ «នឹងធ្វើដូចដែលអ្នកបានណែនាំខ្ញុំ»
1 Samuel 25:36
ព្រឹកឡើង
ព្រឹកព្រលឹម

generated on Wed Sep 10 16:16:32 2025

លោកណាបាលមានចិត្តរីករាយយ៉ាងខ្លាំង
លោកណាបាលសប្បាយរីករាយណាស់។
1 Samuel 25:37
ព័ត៌មានទូទៅ៖
ការវិនិច្ឆ័យរបស់ព្រះអម្ចាស់លើលោកណាបាល
ជាតិស្រាបានសាបអស់ពីលោកណាបាល
លោកណាបាលលែងស្រវឹង ហើយលែងសប្បាយចិត្តទៀតហើយ។
លោកក៏តាំងបេះដូង
លោកណាបាលមិនអាចកម្រើកបានទេ ព្រោះភ័យខ្លាចខ្លាំងពេក
ដែលគាត់លែងមានសុខភាពល្អ
ហើយប្រហែលជាមកពីគាត់មានជំងឺស្លាប់មួយចំហៀងខ្លួន។
1 Samuel 25:39
ព័ត៌មានទូទៅ៖
លោកដាវីឌការពារលោកស្រីអ័ប៊ីកែល ដោយរៀបការជាមួយនាង។
សូមសរសើរតម្កើងព្រះអម្ចាស់
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ បកប្រែដូចនៅក្នុង ២៥:៣២។
អាចមានន័យថា ១) ការបកប្រែផ្សេងទៀត « ខ្ញុំសរសើរព្រះអម្ចាស់» ឬ ២)
ការបកប្រែផ្សេងទៀត សូមឲ្យប្រជាជនទាំងអស់សរសើរព្រះអម្ចាស់»
បានរកយុត្តិធម៌រវាងទូលបង្គំ និងណាបាល
នេះជាឃ្លាសំនួនវោហាស័ព្ទ។ ការបកប្រែផ្សេងទៀត «បានការពារខ្ញុំ
បន្ទាប់ពីលោកណាបាលបានប្រមាថខ្ញុំ»
បានរកយុត្តិធម៌រវាងទូលបង្គំ
នាមអរូបី «បានរក»និង «ប្រមាថ» អាចបកប្រែជាកិរិយាស័ព្ទ។ អាចមានន័យថា ១)
ការបកប្រែផ្សេងទៀត «បានបង្ហាញថាអ្វីដែលខ្ញុំកំពុងធ្វើ
គឺត្រឹមត្រូវដោយដាក់ទោសលោកណាបាល ចំពោះការប្រមាថមើលងាយខ្ញុំ» ឬ ២)
ការបកប្រែផ្សេងទៀត «បានប្រព្រឹត្តពេលលោកណាបាលបានប្រមាថទូលបង្គំ
ដូចជាលោកណាបាលបានប្រមាថព្រះអង្គ»
ហើយបានឃាត់ទូលបង្គំមិនឲ្យប្រព្រឹត្តអាក្រក់។
លោកដាវីឌនិយាយដូចជាគាត់ជាមនុស្សម្នាក់ទៀត
ដើម្បីបង្ហាញការគោរពចំពោះព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«បានរារាំងខ្ញុំពីការធ្វើអំពើអាក្រក់»
បានឆ្លើយតបអំពើអាក្រក់របស់លោកណាបាលធ្លាក់លើក្បាលរបស់គាត់វិញ។
នាមអរូបី «សកម្មភាព» អាចបកប្រែជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«បានធ្វើអំពើចំពោះលោកណាបាលនូវអ្វី
ដែលលោកណាបាលបានគ្រោងនឹងធ្វើមកលើខ្ញុំ»
លើក្បាលរបស់គាត់វិញ។
ក្បាលតំណាងឲ្យមនុស្ស។ ការបកប្រែផ្សេងទៀត «លើគាត់»
បានចាត់អ្នកបម្រើឲ្យទៅនិយាយនឹងលោកស្រីអប៊ីកែល ស្នើឲ្យលោកស្រីធ្វើជាភរិយារបស់លោក។
អ្នកអាចធ្វើឲ្យព័ត៌មានកាន់តែច្បាស់ និងងាយយល់។ ការបកប្រែផ្សេងទៀត
«បានចាត់មនុស្សឲ្យនិយាយជាមួយលោកស្រីអ័ប៊ីកែល ហើយប្រាប់លោកស្រី
ថាលោកដាវីឌចង់យកលោកស្រីធ្វើជាប្រពន្ធរបស់គាត់»
1 Samuel 25:41
លោកស្រីបានក្រោកឡើង ឱនមុខ
លោកស្រីអប៊ីកែលបានឆ្លើយតប ដោយឱនក្បាល។ អ្នកអានគួរតែយល់ថា
លោកស្រីប្រហែលជាកំពុងតែឈរ
ហើយនៅពេលមនុស្សកំពុងនិយាយជាមួយលោកស្រីនៅ ក្នុង ២៥:៣៩ ដូច្នេះ
ពាក្យថា« ក្រោកឡើង»គឺជាពាក្យសម្តីសម្រាប់សម្រេចចិត្ត ឱនក្បាលចុះ។
មើល អ្នកបម្រើស្រីរបស់លោកម្ចាស់
គឺគ្រាន់តែជាអ្នកបម្រើដែលលាងជើងឲ្យពួកអ្នកបម្រើរបស់លោកម្ចាស់ប៉ុណ្ណោះ។
លោកស្រីអប៊ីកែលនិយាយដូចជាលោកស្រី ជាមនុស្សម្នាក់ទៀត ដើម្បីបង្ហាញថា
លោកស្រីមានចិត្តសុភាព។ លោកស្រីបង្ហាញថា
លោកស្រីចង់ធ្វើជាភរិយាថ្មីរបស់លោកដាវីឌ
ដោយផ្តល់ការលាងជើងឲ្យពួកអ្នកបម្រើរបស់លោកដាវីឌ។ ការបកប្រែផ្សេងទៀត
«មើល ខ្ញុំនឹងបម្រើអ្នក
គឺជាអ្នកបម្រើរបស់លោកម្ចាស់ដាវីឌរបស់ខ្ញុំដោយលាងជើងរបស់អ្នក»
ប្រញាប់ក្រោកឡើង ជិះ
អ្នកប្រហែលជាត្រូវធ្វើឲ្យច្បាស់នូវអ្វី ដែលលោកស្រីអប៊ីកែលបានធ្វើ
បន្ទាប់ពីលោកស្រីបានក្រោកឡើង ហើយមុនពេលលោកស្រីបានជិះ។
ការបកប្រែផ្សេងទៀត «បានធ្វើអ្វីដែលលោកស្រីត្រូវធ្វើ យ៉ាងឆាប់រហ័ស
ដើម្បីរៀបចំសម្រាប់ដំណើរ ហើយបន្ទាប់មក លោកស្រីក៏បានជិះ»
មានបាវបម្រើស្រីប្រាំនាក់ទៀតទៅជាមួយផង
លោកស្រីអប៊ីកែលបានកំពុងជិះសត្វលា ប៉ុន្តែអ្នកបម្រើស្រីកំពុងដើរ។
1 Samuel 25:43
លោកដាវីឌក៏បានយក ... ព្រះបាទសូលក៏ធ្លាប់បានលើក
ព្រឹត្តិការណ៍ទាំងនេះបានកើតឡើង
មុនពេលលោកដាវីឌរៀបការជាមួយលោកស្រីអប៊ីកែល។
នាងអហ៊ីណោម ...ព្រះនាងមិកាល់
ទាំងនេះជាឈ្មោះរបស់ស្ត្រី។
លោកប៉ាល់ធី ... លោកឡាអ៊ីស
ទាំងនេះជាឈ្មោះរបស់ស្ត្រី។
ស្រុកកាលីម
នេះជាក្រុងមួយស្ថិតនៅខាងជើងក្រុងយេរូសាឡឹម។

---

26 [1]ពួកអ្នករស់នៅទីរហោស្ថានស៊ីភបានមកជួបព្រះបាទសូលនៅឯគីបៀរទូលស្តេចថា៖ «លោកដាវីឌកំពុងលាក់ខ្លួននៅលើទួលហាគីឡា ទល់មុខនឹងវាលយេស៊ីម៉ូន»។
[2]ព្រះបាទសូលបានក្រោកឡើងចេញទៅទីរហោស្ថានស៊ីភ
ដោយបានជ្រើសរើសយកទាហានបីពាន់នាក់ពីអ៊ីស្រាអែលទៅជាមួយដើម្បីតាមរកដាវីឌនៅឯទីរហោស្ថានស៊ីភ។
[3]ព្រះបាទសូលបានបោះជំរំនៅលើទួលហាគីឡាដែលនៅពីមុខវាលយេស៊ីម៉ូន។ ប៉ុន្តែ លោកដាវីឌកំពុងនៅឯវាលរហោស្ថាន ហើយបានឃើញថា
ព្រះបាទសូលកំពុងមកតាមរកចាប់លោកនៅឯទីរហោស្ថាន។[4]ដូច្នេះ លោកដាវីឌក៏បានចាត់អ្នកស៊ើបការណ៍ឲ្យទៅស៊ើប ហើយបានដឹងថា
ព្រះបាទសូលពិតជាបានមកមែន។
[5]លោកដាវីឌបានក្រោកឡើង ហើយចេញទៅកន្លែងដែលព្រះបាទសូលបានបោះជំរំ លោកបានឃើញទីតាំងដែលស្តេចផ្ទំ និងកន្លែងលោកអប៊ីនើរ ជាកូនរបស់លោកនើរ
ជាមេទ័ពរបស់ស្តេចសម្រាកដែរ។ ព្រះបាទសូលផ្ទំនៅក្នុងជំរំហើយទាហានបោះជំរំនៅជំវិញស្តេច ដេកទាំងអស់គ្នា។
[6]លោកដាវីឌបាននិយាយទៅលោកអហ៊ីម៉ាឡេក ជាជនជាតិហេត និងលោកអប៊ីសាយ ជាកូនរបស់អ្នកស្រីសេរូយ៉ា ដែលជាប្អូនរបស់លោកយ៉ូអាប់ថា៖
«តើមានអ្នកណាហ៊ានទៅជំរំព្រះបាទសូលជាមួយខ្ញុំ?» លោកអប៊ីសាយបានតបថា៖ «ខ្ញុំនឹងចុះទៅជាមួយលោក»។[7]ដូច្នេះ លោកដាវីឌ
និងលោកអប៊ីសាយបានចេញទៅជំរំទាហាននោះទាំងយប់។ ព្រះបាទសូលកំពុងផ្ទំក្នុងជំរំ ដែលមានលំពែងដោតជាប់នឹងដីជិតក្បាលដំណេកស្តេចផង។ ឯលោកអប៊ីនើរ
និងទាហានដេកនៅជុំវិញស្តេច។[8]លោកអប៊ីសាយបានប្រសាន៍ទៅលោកដាវីឌថា៖ «ថ្ងៃនេះ ព្រះជាម្ចាស់បានប្រគល់ខ្មាំងសត្រូវរបស់លោកមកក្នុងដៃលោកហើយ។
ឥឡូវនេះ សូមលោកអនុញ្ញាតឲ្យខ្ញុំដោតស្តេចឲ្យជាប់នឹងដីជាមួយនឹងលំពែងតែមួយដងលំពែងប៉ុណ្ណោះ។ ខ្ញុំនឹងមិនដោតស្តេចជាលើកទីពីរទេ»។
[9]លោកដាវីឌបានមានប្រសាសន៍ទៅលោកអប៊ីសាយវិញថា៖ «កុំសម្លាប់ស្តេចឲ្យសោះ ព្រោះគ្មាននរណាលើកដៃសម្លាប់អ្នកដែលព្រះអម្ចាស់ចាក់ប្រេងអភិសេក
រួចមិនទទួលទោសនោះទេ»។[10]លោកដាវីឌបានបន្តថា៖ «ដោយព្រះអម្ចាស់មានព្រះជន្មគង់នៅ គឺព្រះអម្ចាស់ជាអ្នកយកជីវិតស្តេចផ្ទាល់ ឬទុកឲ្យស្តេចរស់នៅឲ្យអស់ជីវិត
ឬធ្វើឲ្យស្តេចអស់ជីវិតនៅពេលចេញសមរភូមិចុះ។
[11]សូមព្រះអម្ចាស់ឃាត់ខ្ញុំមិនឲ្យខ្ញុំលើកដៃប្រហារអ្នកដែលព្រះអង្គបានចាក់ប្រេងអភិសេកឡើយ ប៉ុន្តែ ពេលនេះ សូមលោកចូលទៅយកតែលំពែង
និងថូទឹកដែលនៅក្បាលដំណេករបស់ស្តេច ហើយយើងចេញទៅវិញ»។[12]ដូច្នេះ លោកដាវីឌបានយកលំពែង និងថូទឹកពីក្បាលដំណេកព្រះបាទសូល
ហើយអ្នកទាំងពីរក៏បានចាកចេញទៅ។ គ្មានអ្នកណាម្នាក់បានឃើញអ្នកទាំងពីរ ឬដឹងរឿងនេះទេ ក៏គ្មានអ្នកណាម្នាក់ភ្ញាក់ ព្រោះអ្នកទាំងអស់នោះលង់លក់ទាំងអស់
ដោយសារព្រះអម្ចាស់បានធ្វើឲ្យពួកគេលង់លក់ខ្លាំង។

generated on Wed Sep 10 16:16:32 2025

[13]បន្ទាប់មក លោកដាវីឌបានឆ្លងទៅម្ខាងហើយឈរលើកំពូលភ្នំពីចម្ងាយដែលឆ្ងាយពីជំរំពួកគេ។[14]លោកដាវីឌបានស្រែកទៅទាហាន
និងលោកអប៊ីនើរជាកូនរបស់លោកនើរថា៖ «លោកអប៊ីនើរអើយ ហេតុអ្វីមិនឆ្លើយតបដូច្នេះ?» លោកអប៊ីនើរបានឆ្លើយថា៖ «តើអ្នកជាអ្នកណា
បានជាហ៊ានស្រែកមកព្រះរាជាដូច្នេះ?»
[15]លោកដាវីឌបានប្រសាសន៍ទៅលោកអប៊ីនើរថា៖ «តើលោកមិនមែនជាអ្នកក្លាហានទេឬ? តើមាននរណាខ្លាំងដូចលោកនៅស្រុកអ៊ីស្រាអែល?
ហេតុអ្វីពេលនេះលោកពុំបានការពារចៅហ្វាយរបស់លោក គឺព្រះរាជាឲ្យល្អដូច្នេះ? ព្រោះមានគេបានចូលទៅក្នុងជំរំដើម្បីធ្វើឃាតព្រះរាជា ជាចៅហ្វាយរបស់លោក។
[16]លោកធ្វើនេះមិនល្អទេ។ ខ្ញុំជម្រាបលោកដោយនូវព្រះអម្ចាស់ដ៏មានព្រះជន្មគង់នៅថា លោកសមតែស្លាប់ ពីព្រោះលោកពុំបានការពារចៅហ្វាយរបស់ខ្លួន
ដែលព្រះអម្ចាស់បានចាក់ប្រេងអភិសេកឲ្យល្អទេ។ ឥឡូវ ចូររកមើល ឯណាទៅលំពែង និងថូទឹកនៅក្បាលដំណេកស្តេច?»
[17]ព្រះបាទសូលចាំសម្លេងរបស់លោកដាវីឌ រួចមានបន្ទូលថា៖ «នេះជាសម្លេងឯងឬ បុត្រាបិតា?» លោកដាវីឌបានឆ្លើយថា៖ «មែនហើយ នេះជាសម្លេងទូលបង្គំ។
[18]ហេតុអ្វីបានជាទ្រង់តាមទូលបង្គំដូច្នេះ? តើទូលបង្គំបានធ្វើអ្វី? តើដៃទូលបង្គំបានប្រព្រឹត្តអាក្រក់អ្វី?
[19]ហេតុនេះ ទូលបង្គំសូមទ្រង់ព្រះសណ្តាប់ពាក្យរបស់ទូលបង្គំជាអ្នកបម្រើរបស់ទ្រង់ចុះ។ បើព្រះអម្ចាស់ជាអ្នកធ្វើរឿងនេះចង់ប្រហារទូលបង្គំ
សូមឲ្យព្រះអង្គទទួលយកតង្វាយរបស់ទូលបង្គំផង ប៉ុន្តែ បើជាមនុស្សជាអ្នកដុតដាន់វិញ សូមពួកគេត្រូវបណ្តាសានៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់
ព្រោះពួកគេបានបណ្តេញទូលបង្គំចេញ ដើម្បីមិនឲ្យទូលបង្គំចេញពីស្រុកកំណើតដែលព្រះអម្ចាស់បានប្រទានឲ្យ គឺពួកគេបាននិយាយថា ចេញទៅថ្វាយបង្គំព្រះដទៃទៅ។
[20]ហេតុដូច្នេះ សូមកុំឲ្យគេកំចាយឈាមទូលបង្គំលើដីដែលឆ្ងាយពីព្រះវត្តមានរបស់ព្រះអម្ចាស់ឡើយ
ដោយស្តេចនៃអ៊ីស្រាអែលបានដេញតាមប្រហារទូលបង្គំដូចតាមប្រមាញ់ចៃមួយនៅលើភ្នំដូច្នោះដែរ»។
[21]បន្ទាប់មក ព្រះបាទសូលមានរាជឱង្ការឡើងថា៖ «បិតាបានខុសហើយ។ មករកបិតាវិញមក ដាវីឌបុត្របិតា។ បិតាលែងធ្វើបាបបុត្រទៀតហើយ
ពីព្រោះជីវិតបិតាមានតម្លៃចំពោះបុត្រដល់ថ្ងៃនេះ។ មើល បិតាបានធ្វើទាំងល្ងិតល្ងង់ ហើយបានប្រព្រឹត្តកំហុសមួយយ៉ាងធំ»។
[22]លោកដាវីឌបានឆ្លើយតបវិញថា៖ «មើលចុះ នេះជាលំពែងរបស់ស្តេច! សូមបញ្ជូនយុវជនម្នាក់ឲ្យឆ្លងមកយក ហើយប្រគល់ជូនទ្រង់វិញចុះ។
[23]សូមព្រះអម្ចាស់ឆ្លើយតបនឹងម្នាក់ៗតាមសេចក្តីសុចរិត និងភាពស្មោះត្រង់របស់អ្នកនោះចុះ ពីព្រោះព្រះអម្ចាស់បានប្រគល់ទ្រង់មកក្នុងដៃទូលបង្គំថ្ងៃនេះ ប៉ុន្តែ
ទូលបង្គំមិនប្រហារមនុស្សដែលព្រះអង្គបានអភិសេកឡើយ។
[24]សូមមើលចុះ ជីវិតរបស់ទ្រង់មានតម្លៃខ្លាំងប៉ុណ្ណាក្នុងកែវភ្នែកទាំងពីររបស់ទូលបង្គំថ្ងៃនេះ ដូច្នេះ សូមឲ្យជីវិតរបស់ទូលបង្គំមានតម្លៃនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ដែរ
ហើយសូមព្រះអម្ចាស់សង្គ្រោះទូលបង្គំចេញពីបញ្ហាទាំងអស់ផង»។[25]បន្ទាប់មក ព្រះបាទសូលមានរាជឱង្ការទៅលោកដាវីឌថា៖ «សូមឲ្យបុត្របានពរណាលោកដាវីឌ!
បុត្រពិតជាធ្វើកិច្ចការដ៏សម្បើម ហើយទទួលជោគជ័យមិនខាន»។ លោកដាវីឌក៏បានចាកចេញទៅ ហើយព្រះបាទសូលបានត្រឡប់ទៅរាជ្យវាំងវិញដែរ។

---

1 Samuel 26:1
លោកដាវីឌកំពុងលាក់ខ្លួន ... យេស៊ីម៉ូន?
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាឧទានស័ព្ទ។ ការបកប្រែផ្សេងទៀត
«លោកដាវីឌកំពុងលាក់ខ្លួន ... យេស៊ីម៉ូន!»
ទល់មុខនឹងវាលយេស៊ីម៉ូន
«ពីកន្លែងដែលយើងអាចមើលឃើញយេស៊ីម៉ុន»
យេស៊ីម៉ូន
នេះជាឈ្មោះតំបន់វាលខ្សាច់មួយ នៅជិតសមុទ្រស្លាប់។ អាចបកប្រែថា
«ទីរហោស្ថានយូដាស» ឬ «វាលខ្សាច់» ។ បកប្រែដូចក្នុង ២៣:១៩ ។
ព្រះបាទសូលបានក្រោកឡើងចេញទៅ
ពាក្យថា «ក្រោកឡើង» គឺជាឃ្លាសម្រាប់ធ្វើសកម្មភាព។ការបកប្រែផ្សេងទៀត
«បន្ទាប់មកព្រះបាទសូលបានធ្វើសកម្មភាព ហើយស្តេចបានចេញទៅ»
ទាហានបីពាន់នាក់
៣,០០០នាក់
បានជ្រើសរើស
ទាហានដែលលោកបានជ្រើសរើស
ដោយសារតែសមត្ថភាពទាហានខ្ពស់របស់ពួកគេ
1 Samuel 26:3
ទល់មុខនឹងវាលយេស៊ីម៉ូន
«ពីកន្លែងដែលយើងអាចមើលឃើញយេស៊ីម៉ុន»
យេស៊ីម៉ូន
នេះជាឈ្មោះតំបន់វាលខ្សាច់មួយ នៅជិតសមុទ្រស្លាប់។ អាចបកប្រែថា
«ទីរហោស្ថានយូដាស» ឬ «វាលខ្សាច់» ។ បកប្រែដូចក្នុង ២៣:១៩។
1 Samuel 26:5
លោកដាវីឌបានក្រោកឡើង ហើយចេញ
«លោកដាវីឌបានធ្វើសកម្មភាព ហើយគាត់បានចេញទៅ»
លោកអប៊ីនើរ ... លោកនើរ
ទាំងនេះជាឈ្មោះរបស់បុរស។
1 Samuel 26:6
លោកអហ៊ីម៉ាឡេក ... លោកអប៊ីសាយ
ទាំងនេះជាឈ្មោះរបស់បុរស។
អ្នកស្រីសេរូយ៉ា
ទាំងនេះជាឈ្មោះរបស់ស្ត្រី។
ចុះទៅ ... ទៅ
លោកដាវីឌនិងពួកទាហានរបស់លោក
ប្រហែលជានៅលើទីខ្ពស់ជាងព្រះបាទសូល។
ខ្ញុំនឹងចុះទៅ
«ខ្ញុំចង់ធ្វើជាមនុស្សម្នាក់ ដែលចុះទៅ»
ព្រះជាម្ចាស់បានប្រគល់ខ្មាំងសត្រូវរបស់លោកមកក្នុងដៃលោកហើយ។
លោកអប៊ីសាយប្រៀបប្រដូចសត្រូវទៅនឹងជាវត្ថុតូចមួយ
ដែលព្រះជាម្ចាស់បានដាក់នៅក្នុងដៃរបស់លោកដាវីឌ។ ពាក្យថា «ដៃ»
ជាពាក្យប្រៀបធៀបសម្រាប់អំណាច ដែលដៃអាចប្រើបាន។ ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់បានប្រគល់ឲ្យអ្នកគ្រប់គ្រងទាំងស្រុង លើខ្មាំងសត្រូវរបស់អ្នក»
ដោតស្តេចឲ្យជាប់នឹងដីជាមួយនឹងលំពែង
នេះជាពាក្យប្រៀបធៀប ដែលសំដៅទៅលើ «សម្លាប់ដោយលំពែង»
ខ្ញុំនឹងមិនដោតស្តេចជាលើកទីពីរទេ។
«ខ្ញុំនឹងសម្លាប់ស្តេច ពេលខ្ញុំវាយប្រហារស្តេច» ឬ
«ខ្ញុំនឹងមិនចាំបាច់វាយប្រហារស្តេចជាលើកទីពីរទេ»
1 Samuel 26:9
ព្រោះគ្មាននរណាលើកដៃសម្លាប់អ្នកដែលព្រះអម្ចាស់ចាក់ប្រេងអភិសេក
រួចមិនទទួលទោសនោះទេ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«គ្មានអ្នកណាអាចវាយប្រហារអ្នក ដែលព្រះអម្ចាស់ចាក់ប្រេងតាំង
ហើយគ្មានទោស»។ អាចថ្លែងនៅក្នុងទម្រង់វិជ្ជមានផងដែរ។ ការបកប្រែផ្សេងទៀត
«អ្នកណាវាយប្រហារ អ្នកដែលព្រះអម្ចាស់ចាក់ប្រេងអភិសេក
នឹងមានទោសពីបទឃាតកម្ម»។
ព្រះអម្ចាស់មានព្រះជន្មគង់នៅ
«ដូចព្រះអម្ចាស់មានព្រះជន្មរស់យ៉ាងពិតបាកដ» ឬ
«ដូចព្រះអម្ចាស់មានព្រះជន្មរស់ប្រាកដមែន»
ទុកឲ្យស្តេចរស់នៅឲ្យអស់ជីវិត
«ស្តេចនឹងសុគតតាមធម្មជាតិ»
1 Samuel 26:11
លើកដៃប្រហារ
ដៃជាពាក្យប្រៀបធៀបសម្រាប់គ្រោះថ្នាក់ ដែលដៃអាចធ្វើបាន។
ការបកប្រែផ្សេងទៀត «ធ្វើអ្វីគ្រប់យ៉ាងដើម្បីបង្កគ្រោះថ្នាក់»
ហើយយើងចេញទៅវិញ។
លោកដាវីឌរួមទាំងលោកអប៊ីសាយ ដូច្នេះ «យើង» នៅទីនេះរួមបញ្ចូល។
ព្រះអម្ចាស់បានធ្វើឲ្យពួកគេលង់លក់ខ្លាំង។
ព្រះអម្ចាស់បានបណ្តាលឲ្យពួកគេដេកលង់លក់។
1 Samuel 26:13

generated on Wed Sep 10 16:16:32 2025

«លោកអប៊ីនើរអើយ ហេតុអ្វីមិនឆ្លើយតបដូច្នេះ?»
លោកដាវីឌប្រើសំណួរ ដើម្បីឲ្យលោកអប៊ីនើរឆ្លើយទាំងអាម៉ាស់។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ឆ្លើយប្រាប់យើងលោកអប៊ីនើរ!»
shouted
«បាននិយាយខ្លាំងតាមដែលអាច» ដូច្នេះ
ព្រះបាទសូលនិងពួកទាហានអាចឮគាត់»
1 Samuel 26:15
តើលោកមិនមែនជាអ្នកក្លាហានទេឬ?
លោកដាវីឌប្រើសំណួរមួយ ដើម្បីស្តីបន្ទោសលោកអប៊ីនើរ
ដែលមិនបានការពារព្រះបាទសូល។ការបកប្រែផ្សេងទៀត
«អ្នកជាបុរសក្លាហានណាស់» ។
តើមាននរណាខ្លាំងដូចលោកនៅស្រុកអ៊ីស្រាអែល?
លោកដាវីឌប្រើសំណួរមួយ ដើម្បីស្តីបន្ទោសលោកអប៊ីនើរ
ដែលមិនបានការពារព្រះបាទសូល។ ការបកប្រែផ្សេងទៀត
«អ្នកជាទាហានដ៏អស្ចារ្យបំផុតនៅក្នុងប្រទេសអ៊ីស្រាអែល»។
ហេតុអ្វីពេលនេះលោកពុំបានការពារចៅហ្វាយរបស់លោក គឺព្រះរាជាឲ្យល្អដូច្នេះ?
អាចមានន័យថា ១) នេះជាសំណួរពិត
ហើយលោកដាវីឌចង់ឲ្យលោកអប៊ីនើរឆ្លើយនឹងគាត់ ឬ ២)
នេះជាសំណួរដ៏ប៉ិនប្រសព្វ ហើយលោកដាវីឌកំពុងស្តីបន្ទោសលោកអប៊ីនើរ។
ការបកប្រែផ្សេងទៀត «ដូច្នេះ អ្នកគួរតែឃ្លាំមើលចៅហ្វាយរបស់អ្នក
គឺស្តេចរបស់អ្នក!»
1 Samuel 26:17
បុត្របិតា
ព្រះបាទសូលមិនមែនជាបិតាពិតរបស់លោកដាវីឌទេ។ ព្រះបាទសូលមានបន្ទូល
ដូចជាលោកជាបិតារបស់លោកដាវីឌ ដើម្បីបង្ហាញលោកដាវីឌថា
លោកចង់ឲ្យលោកដាវីឌទុកចិត្ត
និងគោរពលោកដូចជាលោកដាវីឌទុកចិត្តនិងគោរពឪពុកផ្ទាល់ខ្លួនរបស់លោកដែរ។
ហេតុអ្វីបានជាទ្រង់តាមទូលបង្គំដូច្នេះ?
អាចមានន័យថា ១) លោកដាវីឌពិតជាចង់ឲ្យព្រះបាទសូលឆ្លើយសំណួរ ឬ ២)
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ម្ចាស់របស់ខ្ញុំគ្មានហេតុផលអ្វី ដេញតាមអ្នកបម្រើរបស់គាត់ទេ»។
ហេតុអ្វីបានជាទ្រង់តាមទូលបង្គំដូច្នេះ?
នៅទីនេះលោកដាវីឌនិយាយអំពីព្រះបាទសូល នៅក្នុងបុរសទីបីដែលហៅគាត់ថា
«ម្ចាស់របស់ទូលបង្គំ» ហើយគាត់និយាយអំពីខ្លួនគាត់នៅក្នុងបុរសទីបី
ដែលហៅខ្លួនឯងថាជា «អ្នកបម្រើរបស់ស្តេច»។ លោកដាវីឌនិយាយបែបនេះ
ដើម្បីបង្ហាញការគោរពដល់ព្រះបាទសូល។ ការបកប្រែផ្សេងទៀត
«ហេតុអ្វីបានជាលោកម្ចាស់ខ្ញុំកំពុងតាមរកខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់?» ឬ
«ហេតុអ្វីបានជាទ្រង់ដេញតាមទូលបង្គំ?»
តើទូលបង្គំបានធ្វើអ្វី?
អាចមានន័យថា ១) លោកដាវីឌពិតជាចង់ឲ្យព្រះបាទសូលឆ្លើយសំណួរ ឬ ២)
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ព្រះអង្គដឹងថា ទូលបង្គំមិនបានធ្វើអ្វីដើម្បីធ្វើបាបព្រះអង្គទេ»។
តើដៃទូលបង្គំបានប្រព្រឹត្តអាក្រក់អ្វី?
ការនេះលើកឡើងអំពីការអាក្រក់ដូចជាវាជាវត្ថុ ដែលត្រូវបានកាន់នៅក្នុងដៃ។
នៅទីនេះ «ដៃ» តំណាងឲ្យមនុស្សម្នាក់ធ្វើសកម្មភាព ឬធ្វើអ្វីមួយ។
អាចមានន័យថា ១) លោកដាវីឌពិតជាចង់ឲ្យព្រះបាទសូលឆ្លើយសំណួរនេះ។
ការបកប្រែផ្សេងទៀត «តើទូលបង្គំបានធ្វើអ្វីខុស?» ឬ ២)
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ទូលបង្គំមិនបានធ្វើអ្វីខុសទេ!»
1 Samuel 26:19
សូមទ្រង់ព្រះសណ្តាប់ពាក្យរបស់ទូលបង្គំជាអ្នកបម្រើរបស់ទ្រង់ចុះ ... ស្តេចនៃអ៊ីស្រាអែល
លោកដាវីឌនិយាយដូចជាគាត់និងស្តេច ជាមនុស្សផ្សេងទៀត
ដើម្បីគោរពព្រះបាទសូល។ ការបកប្រែផ្សេងទៀត
«ទ្រង់ជាស្តេចរបស់ទូលបង្គំសូមស្តាប់ពាក្យរបស់ទូលបង្គំ ... ទ្រង់»
ចង់ប្រហារទូលបង្គំ
«បណ្តាលឲ្យព្រះអង្គខឹងនឹងទូលបង្គំ»
សូមឲ្យព្រះអង្គទទួលយកតង្វាយ
អ្នកប្រហែលជាត្រូវធ្វើឲ្យច្បាស់នូវមូលហេតុ ដែលគាត់ថ្វាយតង្វាយ។
ការបកប្រែផ្សេងទៀត «ទូលបង្គំនឹងថ្វាយតង្វាយដល់ព្រះអង្គ ដូច្នេះ
ទ្រង់នឹងមិនបណ្តាលឲ្យព្រះអង្គខឹងទូលបង្គំទៀតទេ»
សូមពួកគេត្រូវបណ្តាសា នៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«សូមឲ្យព្រះអម្ចាស់សម្រេចចិត្តដាក់ទោសពួកគេ»
ព្រោះពួកគេបានបណ្តេញទូលបង្គំចេញ ដើម្បីមិនឲ្យទូលបង្គំចេញពីស្រុកកំណើត
ដែលព្រះអម្ចាស់បានប្រទានឲ្យ គឺពួកគេបាននិយាយថា ចេញទៅថ្វាយបង្គំព្រះដទៃទៅ។
«ថ្ងៃនេះពួកគេបណ្តេញទូលបង្គំចេញ។
ដូចជាពួកគេចង់ឲ្យទូលបង្គំបន្តនៅជាប់នឹងមតរករបស់ព្រះអម្ចាស់»
គឺដូចជាពួកគេបាននិយាយមកកាន់ទូលបង្គំ «ចេញទៅថ្វាយបង្គំព្រះដទៃទៅ»។
ដើម្បីមិនឲ្យទូលបង្គំចេញពីស្រុកកំណើតដែលព្រះអម្ចាស់
«ដូច្នេះទូលបង្គំនឹងលែងទុកចិត្តថា ព្រះអម្ចាស់នឹងប្រទានមកទូលបង្គំតាមអ្វី
ដែលព្រះអង្គបានសន្យាជាមួយទូលបង្គំ»
សូមកុំឲ្យគេកំចាយឈាមទូលបង្គំលើដី
នេះជារបៀបគួរសមក្នុងការនិយាយថា «កុំសម្លាប់ទូលបង្គំ» ។
តាមប្រហារ
លោកដាវីឌប្រើពាក្យ «តាមប្រហារ» ជាពាក្យប្រៀបធៀបសម្រាប់មនុស្ស
គឺគាត់ខ្លួនឯង ដែលមិនអាចធ្វើការអាក្រក់ខ្លាំង។ ការបកប្រែផ្សេងទៀត
«ចៃឆ្កែតែមួយ» ឬ «ខ្ញុំ ហើយ
ខ្ញុំមិនអាចធ្វើបាបអ្នកច្រើនជាងចៃឆ្កែមួយអាចធ្វើបានទេ»
ដូចតាមប្រមាញ់ចៃមួយនៅលើភ្នំដូច្នោះដែរ។
ព្រះបាទសូលកំពុងតែដេញតាមលោកដាវីឌ
ហាក់ដូចជាលោកកំពុងតែបរបាញ់សត្វស្លាបដ៏មានតម្លៃ។
1 Samuel 26:21
មករកបិតាវិញមក
អាចមានន័យថា ១) «ត្រឡប់ទៅបម្រើបិតានៅក្នុងរាជវាំងរបស់បិតាវិញ» ឬ ២)
«ត្រឡប់ទៅផ្ទះរបស់អ្នកវិញ» ។
ដាវីឌបុត្របិតា
ព្រះបាទសូលមិនមែនជាបិតាពិតរបស់លោកដាវីឌទេ។
ព្រះបាទសូលមានបន្ទូលដូចលោកជាបិតារបស់លោកដាវីឌ
ដើម្បីបង្ហាញលោកដាវីឌថា លោកចង់ឲ្យលោកដាវីឌទុកចិត្ត និងគោរពលោក
ដូចជាលោកដាវីឌនឹងទុកចិត្ត និងគោរពឪពុកផ្ទាល់ខ្លួនរបស់លោកដែរ។
ពីព្រោះជីវិតបិតាមានតម្លៃចំពោះបុត្រដល់ថ្ងៃនេះ។
នៅទីនេះចំពោះតំណាងឲ្យការមើលឃើញ ហើយការមើលឃើញតំណាងឲ្យគំនិត
ឬការវិនិច្ឆ័យ។ ការបកប្រែផ្សេងទៀត «ថ្ងៃនេះ បុត្របានគិតថា
ជីវិតរបស់បិតាមានតម្លៃណាស់» ឬ «ថ្ងៃនេះ បុត្របានបង្ហាញបិតាថា
បុត្រពិតជាគោរពបិតា»
ធ្វើទាំងល្ងិតល្ងង់
«ល្ងង់ណាស់»
1 Samuel 26:22
ពីព្រោះព្រះអម្ចាស់បានប្រគល់ទ្រង់ មកក្នុងដៃទូលបង្គំថ្ងៃនេះ
ពាក្យថា«ដៃ» ជាពាក្យប្រៀបធៀបសម្រាប់អំណាចរបស់មនុស្សនោះ។
«ព្រះអម្ចាស់បានផ្តល់ឲ្យខ្ញុំនូវឱកាស ដើម្បីវាយប្រហារអ្នកនៅថ្ងៃនេះ» ឬ
«ព្រះអម្ចាស់បានដាក់ទូលបង្គំនៅកន្លែង
ដែលទូលបង្គំអាចសម្លាប់ស្តេចបានយ៉ាងងាយស្រួល»
តប
«កិត្តិយស» ឬ «រង្វាន់»
ព្រះអង្គបានអភិសេក
លោកដាវីឌនិយាយដូចជាព្រះបាទសូល ជាមនុស្សម្នាក់ទៀត ដែលបង្ហាញថា
លោកគោរពព្រះបាទសូលដោយសារព្រះបាទសូលជាស្តេច។ ការបកប្រែផ្សេងទៀត
«ម្នាក់ដែលព្រះអង្គបានជ្រើសរើសជាស្តេច»
1 Samuel 26:24
ជីវិតរបស់ទ្រង់មានតម្លៃខ្លាំងប៉ុណ្ណា ក្នុងកែវភ្នែកទាំងពីររបស់ទូលបង្គំថ្ងៃនេះ
នៅទីនេះភ្នែកតំណាងឲ្យការមើលឃើញ ហើយការមើលឃើញតំណាងឲ្យគំនិត
ឬការវិនិច្ឆ័យ។ ពាក្យស្រដៀងគ្នានេះលេចឡើងនៅ ២៦:២១ ។
ការបកប្រែផ្សេងទៀត «ទូលបង្គំបានចាត់ទុកថា ជីវិតរបស់ទ្រង់មានតម្លៃណាស់» ឬ
»ទូលបង្គំបានបង្ហាញទ្រង់នៅថ្ងៃនេះថា ទូលបង្គំពិតជាគោរពព្រះអង្គ»
ដូច្នេះ សូមឲ្យជីវិតរបស់ទូលបង្គំមានតម្លៃនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ដែរ
នៅទីនេះភ្នែកតំណាងឲ្យការមើលឃើញ ហើយការមើលឃើញតំណាងឲ្យគំនិត

ឬការវិនិច្ឆ័យ។ ការបកប្រែផ្សេងទៀត «ដូច្នេះ
ព្រះអម្ចាស់ចាត់ទុកជីវិតរបស់ទូលបង្គំមានតម្លៃណាស់» ឬ «ដូច្នេះ
ព្រះអម្ចាស់គួរតែឲ្យតម្លៃជីវិតរបស់ទូលបង្គំ
ដូចទូលបង្គំបានឲ្យតម្លៃជីវិតរបស់ព្រះអង្គ»
សូមឲ្យបុត្របានពរ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«សូមព្រះអម្ចាស់ប្រទានពរដល់អ្នក»
លោកដាវីឌ
ព្រះបាទសូលមិនមែនជាបិតាពិតរបស់លោកដាវីឌទេ។
ព្រះបាទសូលមានបន្ទូលដូចជាលោក
ជាបិតារបស់លោកដាវីឌដើម្បីបង្ហាញលោកដាវីឌថា
លោកចង់ឲ្យលោកដាវីឌទុកចិត្ត និងគោរពគាត់ដូចជាលោកដាវីឌទុកចិត្ត
និងគោរពឪពុកផ្ទាល់ខ្លួនរបស់លោកដែរ។

---

27 [1]លោកដាវីឌបានមានប្រសាសន៍ក្នុងចិត្តថា៖ «ថ្ងៃណាមួយ ព្រះបាទសូលមុខជាសម្លាប់ខ្ញុំមិនខាន គ្មានអ្វីប្រសើរជាងរត់ភៀសខ្លួនចូលទៅស្រុកភីលីស្ទីនទេ
នោះព្រះបាទសូលនឹងបោះបង់ការតាមរកខ្ញុំនៅក្នុងទឹកដីអ៊ីស្រាអែលនេះមិនខាន ដោយហេតុនេះ ខ្ញុំនឹងគេចខ្លួនពីព្រះហស្តរបស់ស្តេចទើបរួចជីវិត»។
[2]លោកដាវីឌបានក្រោកឡើង និងចេញទៅជាមួយនឹងមនុស្សដែលនៅជាមួយខ្លួនទាំងប្រាំមួយរយនាក់ ឆ្ពោះទៅរកស្តេចអគីស ជាបុត្ររបស់ព្រះបាទម៉ាអុក
ស្តេចក្រុងកាថ។[3]លោកដាវីឌបានរស់នៅជាមួយនឹងស្តេចអគីសនៅក្រុងកាថ ទាំងលោក និងអ្នកនៅជាមួយលោកបានតាំងទីលំនៅទីនោះ។
លោកដាវីឌក៏បានយកប្រពន្ធទាំងពីរទៅជាមួយដែរ មាននាងអហ៊ីឡោម អ្នកស្រុកយ៉េសរាល និងនាងអប៊ីកែល អ្នកភូមិកើមែល
ដែលជាអតីតប្រពន្ធរបស់លោកណាបាល។[4]មានគេទូលប្រាប់ព្រះបាទសូលថា លោកដាវីឌបានភៀសខ្លួនទៅនៅក្រុងកាថ ស្តេចក៏លែងតាមរកលោកដាវីឌតទៅទៀត។
[5]លោកដាវីឌបានទូលស្តេចអគីសថា៖ «បើព្រះអង្គគាប់ព្រះទ័យ សូមទ្រង់ប្រទានតំបន់ណាមួយនៃទីក្រុងក្នុងស្រុកនេះដល់ពួកទូលបង្គំរស់នៅផង
មិនគួរឲ្យទូលបង្គំយើងខ្ញុំរស់នៅជាមួយស្តេចក្នុងក្រុងរបស់ស្តេចឡើយ»។[6]ឮដូច្នេះ ព្រះបាទអគីសបានប្រទានក្រុងស៊ីគឡាក់ឲ្យនៅថ្ងៃនោះ។ ហេតុដូច្នេះហើយ
ក្រុងស៊ីគឡាក់ជាកម្មសិទ្ធិរបស់ស្តេចយូដាមកដល់សព្វថ្ងៃនេះ។[7]លោកដាវីឌបានស្នាក់នៅក្នុងស្រុកភីលីស្ទីនអស់រយៈពេលមួយឆ្នាំបួនខែពេញ។
[8]លោកដាវីឌ និងអ្នកដែលនៅជាមួយលោកបានទៅវាយប្រហារជាច្រើនកន្លែង ដោយទៅលុកលុយជនជាតិកេស៊ូរី ទឹកដីរបស់ពួកកេស៊ើរ និងទឹកដីរបស់ពួកអាម៉ាឡេក។
ជនជាតិទាំងនោះបានតាំងទីលំនៅចាប់តាំងពីស្រុកស៊ើរ រហូតដល់ស្រុកអេស៊ីប។ ពួកគេរស់នៅតំបន់ទាំងនោះតាំងសម័យបុរាណមកម្ល៉ះ។
[9]លោកដាវីឌបានវាយលុកទឹកដីនោះ ហើយមិនទុកឲ្យមនុស្សប្រុសស្រីណាម្នាក់នៅជីវិតឡើយ លោកដាវីឌក៏បានប្រមូលចៀម គោ លា អូដ្ឋ
និងសម្លៀកបំពាក់រួចត្រឡប់មកជួបព្រះបាទអគីសវិញ។
[10]ព្រះបាទអគីសបានមានរាជឱង្ការសួរថា៖ «តើឯងបានចេញទៅវាយតំបន់ណាខ្លះថ្ងៃនេះ?» លោកដាវីឌទូលឆ្លើយវិញថា៖ «ទៅវាយភាគខាងត្បូងយូដា» ឬ
«វាយភាគខាងត្បូងស្រុករបស់ពួកយេរ៉ាម្អែល» ឬ «វាយនៅភាគខាងត្បូងពួកកែន»។
[11]លោកដាវីឌមិនទុកជីវិតមនុស្សប្រុសស្រីហើយនាំមកក្រុងកាថឡើយ គឺដោយគិតថា មិនចង់ឲ្យអ្នកទាំងនោះនិយាយអ្វីពីពួកយើង
ហើយលោកដាវីឌធ្វើនេះឬធ្វើនោះឡើយ»។ នេះជារបៀបដែលលោកដាវីឌប្រព្រឹត្តកាលលោកកំពុងរស់នៅស្រុកភីលីស្ទីន។[12]ដូច្នេះ
ព្រះបាទអគីសបានជឿជាក់លើលោកដាវីឌដោយគិតថា៖ «លោកដាវីឌបានធ្វើឲ្យប្រជាជនអ៊ីស្រាអែលរបស់ខ្លួនស្អប់ខ្ពើមយ៉ាងខ្លាំង ដូច្នេះ
លោកដាវីឌនឹងនៅធ្វើជាអ្នកបម្រើរបស់យើងជារៀងរហូត»។

---

1 Samuel 27:1
លោកដាវីឌបានមានប្រសាសន៍ក្នុងចិត្តថា
នៅទីនេះ «ក្នុងចិត្ត» ជាពាក្យប្រៀបធៀប ដែលមានន័យថាចំពោះខ្លួនឯង។
ការបកប្រែផ្សេងទៀត «លោកដាវីឌបានគិតដោយខ្លួនឯង»
គេចខ្លួនពីព្រះហស្តរបស់ស្តេចទើបរួចជីវិត។
ពាក្យថា« ដៃ» តំណាងឲ្យមនុស្ស។ ការបកប្រែផ្សេងទៀត «រត់គេចពីស្តេច»
1 Samuel 27:2
លោកដាវីឌបានក្រោកឡើង
«លោកដាវីឌបានធ្វើសកម្មភាព ហើយលោកបានឆ្លងកាត់»
ចេញទៅ
«បានឆ្លងកាត់ព្រំដែនរវាងអ៊ីស្រាអែល និងភីលីស្ទីន»
ប្រាំមួយរយនាក់
៦០០នាក់
ស្តេចអគីស
នេះជាឈ្មោះមនុស្សប្រុស។ បកប្រែដូចនៅក្នុង ២១:១០ ។
ព្រះបាទម៉ាអុក
នេះជាឈ្មោះមនុស្សប្រុស។
នាងអហ៊ីឡោម
នេះជាឈ្មោះរបស់ស្ត្រី។ បកប្រែដូចនៅក្នុង ១៤:៤៩ ។
នាងអប៊ីកែល
នេះជាឈ្មោះរបស់ស្ត្រី។ បកប្រែដូចនៅក្នុង ២៥:២ ។
លោកណាបាល
នេះជាឈ្មោះបុរស។ បកប្រែដូចនៅក្នុង ២៥:២ ។
មានគេទូលប្រាប់ព្រះបាទសូលថា
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«មានគេប្រាប់លោកសូល» ឬ »លោកសូលបាន ឮ»
1 Samuel 27:5
បើព្រះអង្គគាប់ព្រះទ័យ
នៅទីនេះភ្នែកតំណាងឲ្យការមើលឃើញ ហើយការមើលឃើញតំណាងឲ្យគំនិត
ឬការវិនិច្ឆ័យ។ បកប្រែដូចនៅក្នុង ២០:៣ ។ ការបកប្រែផ្សេងទៀត
«បើខ្ញុំពេញចិត្តអ្នក» ឬ «បើអ្នកគិតថា ពេញចិត្តខ្ញុំ»
សូមទ្រង់ប្រទានតំបន់ណាមួយ
ចាប់តាំងពីស្តេចអគីស គឺជាអ្នកដែលនឹង«ប្រទានឲ្យ »
នេះជាពាក្យប្រៀបធៀបសម្រាប់« សូមផ្តល់ឲ្យទូលបង្គំនៅទីកន្លែងមួយ»។
នៃទីក្រុងក្នុងស្រុកនេះ
«ទីក្រុងដាច់ស្រយាលមួយ» ឬ «ភូមិមួយនៅខាងក្រៅទីក្រុង»
មិនគួរឲ្យទូលបង្គំយើងខ្ញុំរស់នៅជាមួយស្តេចក្នុងក្រុងរបស់ស្តេចឡើយ?
សំណួរដ៏ប៉ិនប្រសព្វអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ទូលបង្គំមិនចាំបាច់រស់នៅក្នុងទីក្រុងជាមួស្តេចទេ»។ ឬ
«ទូលបង្គំមិនសំខាន់គ្រប់គ្រាន់ ដើម្បីរស់នៅទីនេះជាមួយស្តេច
នៅក្នុងព្រះបរមរាជវាំងទេ» ។
ទូលបង្គំយើងខ្ញុំ
លោកដាវីឌនិយាយដូចជាគាត់
ជាមនុស្សម្នាក់ផ្សេងទៀតដើម្បីបង្ហាញថាគាត់គោរពស្តេចអគីស។
ក្រុងស៊ីគឡាក់
នេះជាឈ្មោះទីក្រុងមួយ ស្ថិតនៅផ្នែកខាងត្បូងឆៀងខាងកើតស្រុកយូដា។
1 Samuel 27:8
ដោយទៅលុកលុយ
ការវាយប្រហារនិងការយកទ្រព្យសម្បត្តិជាច្រើនដង
ពួកកេស៊ើរ
ក្រុមមនុស្សដែលរស់នៅជាក់ស្តែងកន្លែងណាមួយ រវាងភីលីស្ទីន និងអេស៊ីប។
តាំងទីលំនៅចាប់តាំងពីស្រុកស៊ើរ
ពាក្យ «អ្នក» សំដៅលើនរណាម្នាក់។ ការបកប្រែផ្សេងទៀត
«នៅតាមផ្លូវដែលមនុស្សភាគច្រើនធ្វើដំណើរទៅស្រុកស៊ើរ»
ស្រុកស៊ើរ
តំបន់នៅលើព្រំដែនភាគខាងជើងឆៀងខាងកើតប្រទេសអេស៊ីប (សូមមើល
ព្រះបាទអគីស
ស្តេចនៃទីក្រុងកាថ។
1 Samuel 27:10
ព្រះបាទអគីស

generated on Wed Sep 10 16:16:32 2025

ស្តេចនៃទីក្រុងកាថ។

ពួកយេរ៉ាម្អែល
ត្រកូលមកពីកុលសម្ព័ន្ធយូដា
ពួកកែន
ក្រុមមនុស្សដែលរស់នៅក្នុងស្រុកម៉ាឌាន

1 Samuel 27:11

ក្រុងកាថ
មួយនៃរដ្ឋភីលីស្ទីនទាំងប្រាំ។
ព្រះបាទអគីស
ស្តេចនៃទីក្រុងកាថ។

---

28 [1]ថ្ងៃទាំងនោះក៏បានមកដល់ គឺពួកភីលីស្ទីនបានប្រមូលគ្នាដើម្បីវាយប្រហារអ៊ីស្រាអែល។ ព្រះបាទអគីសបានថ្លែងទៅដាវីឌថា៖ «លោកជ្រាបច្បាស់ហើយថា
លោកនឹងទៅចម្បាំងជាមួយនឹងយើង គឺទាំងលោក និងអ្នកដែលនៅជាមួយលោក»។[2]លោកដាវីឌបានទូលព្រះបាទអគីសវិញថា៖
«ទ្រង់ជ្រាបថាទូលបង្គំជាអ្នកបម្រើទ្រង់អាចធ្វើអ្វីថ្វាយទ្រង់ស្រាប់ហើយ»។ ព្រះបាទអគីសបានមានរាជឱង្ការតបថា៖ «ដូច្នេះ
យើងនឹងតែងតាំងលោកឲ្យធ្វើជាកងការពារយើងជារៀងរហូត»។
[3]ពេលនោះ លោកសាំយូអែលបានលាចាកលោកហើយ ហើយអ៊ីស្រាអែលទាំងមូលបាននាំគ្នាកាន់ទុក្ខលោក និងបានបញ្ចុះលោកនៅក្នុងភូមិរ៉ាម៉ា
ជាកន្លែងកំណើតរបស់លោក។ ឯព្រះបាទសូលបានហាមមិនឲ្យមានអ្នកណាខាបព្រលឹង ឬវិញ្ញាណនៅក្នុងស្រុកឡើយ។[4]ក្រោយមក
ពួកភីលីស្ទីនបានប្រមូលគ្នាមកបោះជំរំនៅស៊ូណែម ហើយព្រះបាទសូលក៏បានកែនទ័ពនៅអ៊ីស្រាអែលទាំងអស់ផងដែរ រួចទៅបោះជំរំនៅគីលបោ។
[5]នៅពេលព្រះបាទសូលបានឃើញទ័ពរបស់ភីលីស្ទីន ស្តេចភ័យខ្លាចជាខ្លាំង ហើយស្តេចមានព្រះហឫទ័យរន្ធត់ជាខ្លាំង។[6]ស្តេចបានទូលអង្វរសុំជំនួយពីព្រះអម្ចាស់ ប៉ុន្តែ
ព្រះអម្ចាស់ពុំបានឆ្លើយតបស្តេចវិញទេ ទោះតាមសុបិន្ត តាមយូរីម ឬតាមព្យាការីក្តី។[7]បន្ទាប់មក ព្រះបាទសូលបានបញ្ជាដល់រាជ្យបម្រើថា៖
«ចូរទៅរកមេមត់ដែលអាចខាបព្រលឹងមនុស្សស្លាប់ ហើយយើងនឹងទៅសួរដើម្បីឲ្យដឹងថាត្រូវធ្វើដូចម្តេច»។ ពួករាជ្យបម្រើបានទូលស្តេចថា៖ «មើល
មានស្ត្រីម្នាក់នៅអេនដោរដែលអាចនិយាយជាមួយព្រលឹងអ្នកស្លាប់បាន»។
[8]ព្រះបាទសូលបានក្លែងខ្លួនឯង ដោយស្លៀកពាក់ជាមនុស្សផ្សេងទៀតហើយបានចេញទៅជាមួយនឹងមនុស្សពីរនាក់ទៀតដើម្បីទៅឯស្ត្រីនោះទាំងយប់។
ស្តេចបានមានរាជឱង្ការថា៖ «សូមទាយឲ្យខ្ញុំ ខ្ញុំសូមអង្វរ គឺហៅវិញ្ញាណឲ្យឡើងមក តាមឈ្មោះដែលខ្ញុំប្រាប់»។[9]ស្ត្រីនោះបានតបទៅស្តេចវិញថា៖ «មើល
តើលោកមិនជ្រាបទេឬថា ព្រះបាទសូលបានប្រព្រឹត្តដូចម្តេចខ្លះ គឺស្តេចបានហាមប្រាមមិនឲ្យនរណាខាបវិញ្ញាណមនុស្សស្លាប់លើទឹកដីនេះទេ។ ដូច្នេះ
ហេតុអ្វីបានជាលោកមកអង្គុយដាក់អន្ទាក់យកជីវិតរបស់ខ្ញុំយ៉ាងនេះ ឬមួយលោកចង់ធ្វើឲ្យអស់ជីវិតឬ?»[10]ព្រះបាទសូលបានស្បថដោយនូវព្រះអម្ចាស់ថា៖
«ព្រះអម្ចាស់មានព្រះជន្មគង់នៅយ៉ាងណា នាងនឹងគ្មានទោសអ្វីដោយសារការនេះទេ»។
[11]បន្ទាប់មក ស្ត្រីនោះបាននិយាយថា៖ «តើចង់ឲ្យខ្ញុំហៅអ្នកណាឲ្យឡើងមក?» ព្រះបាទសូលបានមានរាជឱង្ការតបថា៖ «សូមខាបហៅលោកសាំយូអែលឲ្យខ្ញុំ»។
[12]ពេលនេះ ស្ត្រីនោះបានឃើញលោកសាំយូអែល ហើយបានស្រែកដោយសម្លេងខ្លាំង និងបាននិយាយទៅព្រះបាទសូលថា៖
«ហេតុអ្វីបានជាទ្រង់បោកប្រាស់ខ្ញុំម្ចាស់ដូច្នេះ? គឺព្រះករុណាគឺជាព្រះបាទសូលទេតើ»។
[13]ស្តេចបានថ្លែងទៅស្ត្រីនោះថា៖ «កុំខ្លាចអ្វី តើនាងបានឃើញអ្វី?» នាងបានទូលព្រះបាទសូលថា៖ «ខ្ញុំម្ចាស់បានឃើញមានម្នាក់កំពុងចេញពីផែនដី»។
[14]ស្តេចបានមានរាជឱង្ការសួរស្ត្រីនោះថា៖ «តើលោកនោះមានទ្រង់ទ្រាយបែបណា?» ស្ត្រីនោះបានតបវិញថា៖ «មានបុរសចំណាស់ម្នាក់កំពុងតែមក
លោកស្លៀកពាក់រ៉ូប»។ ព្រះបាទសូលបានយល់ឃើញថា នោះគឺលោកសាំយូអែលហើយ ស្តេចក៏ឱនមុខដល់ដី និងសម្តែងសេចក្តីគោរព។
[15]លោកសាំយូអែលបានទូលសួរព្រះបាទសូលថា៖ «ហេតុអ្វីបានជាព្រះករុណារំខានទូលបង្គំ ហើយហៅទូលបង្គំឡើងមកដូច្នេះ?» ព្រះបាទសូលតបវិញថា៖
«ខ្ញុំបានចប់បារម្ភជាខ្លាំងដោយពួកភីលីស្ទីនបានប្រមូលគ្នាមកវាយប្រហារ ហើយព្រះជាម្ចាស់បានបោះបង់ខ្ញុំចោល ព្រះអង្គពុំឆ្លើយតបនឹងខ្ញុំទៀតទេ
សូម្បីតែតាមរយៈព្យាការី ឬតាមសុបិន្តក្តីក៏គ្មានដែរ។ ហេតុដូច្នេះហើយ ទើបខ្ញុំហៅលោកឡើងមកដើម្បីប្រាប់ខ្ញុំថា ខ្ញុំគួរធ្វើបែបណា»។
[16]លោកសាំយូអែលបានមានប្រសាសន៍ឡើងថា៖ «ព្រះករុណាសួរទូលបង្គំធ្វើអ្វី តាំងពីព្រះអម្ចាស់បោះបង់ព្រះករុណាមក
ព្រះអង្គបានត្រឡប់ទៅជាសត្រូវរបស់ព្រះករុណាហើយទេតើ?»[17]ព្រះអម្ចាស់បានប្រព្រឹត្តដូច្នេះស្របតាមព្រះបន្ទូលរបស់ព្រះអង្គដែលគួរធ្វើហើយ។
ព្រះអម្ចាស់បានហែករាជ្យអាណាចក្រពីព្រះហស្តរបស់ព្រះករុណា រួចបានប្រទានឲ្យអ្នកផ្សេងទៀត គឺដាវីឌ។
[18]ពីព្រោះព្រះករុណាពុំបានស្តាប់បង្គាប់ព្រះសូរ្យសៀងរបស់ព្រះអម្ចាស់ទេ ហើយក៏ពុំបានធ្វើតាមព្រះពិរោធរបស់ព្រះអង្គទៅលើជនជាតិអាម៉ាឡេកដែរ ហេតុដូច្នេះ
ទើបព្រះអង្គប្រព្រឹត្តបែបនេះចំពោះព្រះករុណា។[19]លើសពីនេះទៅទៀត ព្រះអម្ចាស់បានប្រគល់អ៊ីស្រាអែល ព្រមទាំងព្រះករុណាទៅក្នុងដៃរបស់ពួកភីលីស្ទីនថែមទៀតផង។
ថ្ងៃស្អែក ព្រះករុណា ព្រមទាំងបុត្រនឹងមកនៅជាមួយទូលបង្គំហើយ។ ព្រះអម្ចាស់ក៏ប្រគល់កងទ័ពអ៊ីស្រាអែលទៅក្នុងដៃរបស់ពួកភីលីស្ទីនដែរ»។
[20]បន្ទាប់មក ព្រះបាទសូលបានដួលទាំងជំហរភ្លាមៗទៅលើដី ហើយបានតក់ស្លុតជាខ្លាំងពីព្រោះពាក្យទាំងប៉ុន្មានរបស់លោកសាំយូអែល។ ស្តេចគ្មានកម្លាំងកំហែងទៀតទេ
ព្រោះស្តេចពុំបានសោយព្រះស្ងោយអស់ជាច្រើនថ្ងៃច្រើនយប់។[21]ស្ត្រីនោះបានមកឯព្រះបាទសូល ហើយបានឃើញទ្រង់តក់ស្លុតជាខ្លាំង នាងបានទូលទ្រង់ថា៖
«ខ្ញុំម្ចាស់ជាអ្នកបម្រើទ្រង់បានស្តាប់ និងធ្វើតាមព្រះបន្ទូលទ្រង់ហើយ ទូលបង្គំបានដាក់ជីវិតនៅក្នុងព្រះហស្តទ្រង់
និងបានស្តាប់តាមរាជបញ្ជាទាំងប៉ុន្មានដែលទ្រង់បានបង្គាប់ហើយ។
[22]ហេតុដូច្នេះពេលនេះ ខ្ញុំម្ចាស់សូមអង្វរទ្រង់ សូមព្រះសន្ទាប់ខ្ញុំម្ចាស់ជាអ្នកបម្រើទ្រង់ សូមអនុញ្ញាតឲ្យខ្ញុំម្ចាស់រៀបចំព្រះស្ងោយបន្តិចបន្តួចជូនទ្រង់។ សូមទ្រង់សោយសិន
ដើម្បីប្រមូលកម្លាំងហើយអាចយាងត្រឡប់ទៅវិញ»។[23]ប៉ុន្តែ ព្រះបាទសូលបានបដិសេធថា៖ «យើងមិនសោយអាហារនេះទេ»។ តែពួករាជបម្រើទ្រង់
ទាំងស្ត្រីនោះបានទទូចស្តេច ហើយស្តេចក៏ព្រមតាមពាក្យពួកគេ។ ដូច្នេះ ស្តេចបានក្រោកពីដី ហើយគង់នៅលើគ្រែវិញ។
[24]ស្ត្រីនោះបានយកកូនគោដែលបំប៉នក្នុងផ្ទះ ហើយនាងបានប្រញាប់ទៅសម្លាប់វា រួចយកម្សៅមកច្របាច់ដើម្បីធ្វើនំប៉័ងឥតមេជាមួយ។[25]នាងបានយកមកថ្វាយស្តេចសូល
និងពួករាជបម្រើទ្រង់ ហើយពួកគេបានទទួលទានទាំងអស់គ្នា។ បន្ទាប់ពី ទទួលរួចក៏បានក្រោកឡើង ហើយចាកចេញពីទីនោះទាំងយប់។

---

1 Samuel 28:1

ចម្បាំង
ការជួបជុំកងទ័ពដ៏ធំ
ទ្រង់ជ្រាបថា ... ដូច្នេះ យើងនឹង
ពាក្យ «ដូច្នេះ» បង្ហាញថា
អ្នកនិយាយយល់ស្របនឹងអ្វីដែលមនុស្សម្នាក់ទៀតទើបតែបាននិយាយ។
ការបកប្រែផ្សេងទៀត «ក្រាបទូល ទូលបង្គំនឹងទៅជាមួយព្រះអង្គ
ដើម្បីឲ្យទ្រង់ជ្រាប ... ល្អណាស់ទូលបង្គំនឹង»
«ទ្រង់ជ្រាបថាទូលបង្គំជាអ្នកបម្រើទ្រង់អាចធ្វើអ្វីថ្វាយទ្រង់ស្រាប់ហើយ»។
លោកដាវីឌប្រហែលជាចង់ឲ្យព្រះបាទអគីសគិតថា
លោកដាវីឌនឹងសម្លាប់ជនជាតិអ៊ីស្រាអែលជាច្រើននាក់ប៉ុន្តែ
«អ្វីដែលអ្នកបម្រើរបស់ទ្រង់អាចធ្វើបាន» ក៏អាចមានន័យថា
លោកដាវីឌគ្រោងនឹងសម្លាប់ពួកភីលីស្ទីនជំនួសវិញ។
ចូរព្យាយាមបកប្រែដើម្បីឲ្យអ្នកអានអាចយល់អត្ថន័យទាំងពីរនេះ។
ទូលបង្គំជាអ្នកបម្រើទ្រង់
លោកដាវីឌនិយាយប្រដូចគាត់ទៅនឹងមនុស្សម្នាក់ផ្សេងទៀត ដូច្នេះ
ព្រះបាទអគីសនឹងគិតថា លោកដាវីឌគោរពព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ទូលបង្គំ»
លោកឲ្យធ្វើជា
លោកដាវីឌនិយាយប្រដូចជាគាត់នឹងមនុស្សម្នាក់ផ្សេងទៀត ដូច្នេះ
ព្រះបាទអគីសនឹងគិតថា លោកដាវីឌគោរពព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ទូលបង្គំ»

generated on Wed Sep 10 16:16:32 2025

កងការពារ
មនុស្សដែលការពារមនុស្សដទៃផ្សេងទៀត
1 Samuel 28:3
ពេលនោះ លោកសាំយូអែល ... វិញ្ញាណនៅក្នុងស្រុក
អ្នកនិពន្ធផ្តល់ព័ត៌មានសង្ខេប ដើម្បីរៀបចំអ្នកអានសម្រាប់ព្រឹត្តិការណ៍
ដែលកើតតាមក្រោយ។
បានហាមមិនឲ្យមានអ្នក
ដកចេញជាផ្លូវការពីប្រទេស ឬតំបន់ ឬត្រូវបានរារាំងមិនឲ្យចូល។
ការបកប្រែផ្សេងទៀត «បណ្តេញចេញពីអ៊ីស្រាអែល»
មានអ្នកណាខាបព្រលឹង ឬវិញ្ញាណនៅក្នុងស្រុកឡើយ។
ពាក្យថា «អស់អ្នកដែលបាននិយាយជាមួយមនុស្សស្លាប់»
បកប្រែពាក្យជាភាសាដើម ហើយពាក្យថា « អស់អ្នកដែល...
បាននិយាយជាមួយវិញ្ញាណ» ក៏បកប្រែជាជាភាសាដើមដែរ។
បើភាសារបស់អ្នកមានពាក្យមួយសម្រាប់អ្នកដែលនិយាយជាមួយមនុស្សស្លាប់
និងពាក្យមួយសម្រាប់អ្នកដែលនិយាយជាមួយវិញ្ញាណ
ឬបើភាសារបស់អ្នកមានពាក្យមួយសម្រាប់អ្នក ដែលនិយាយជាមួយអ្នកស្លាប់
និងវិញ្ញាណអ្នកគួរតែប្រើពាក្យទាំងនេះ។
ក្រោយមក ពួកភីលីស្ទីនបានប្រមូលគ្នា
បន្ទាប់ពីលោកដាវីឌ និងព្រះបាទអគីសបាននិយាយ (២៨: ១)
បានកែនទ័ពនៅអ៊ីស្រាអែលទាំងអស់ផងដែរ
«បានប្រមូលកងទ័ពទាំងអស់នៅអ៊ីស្រាអែលរួមគ្នា»។
ស៊ូណែម... គីលបោ
ទាំងនេះជាឈ្មោះទីកន្លែង
1 Samuel 28:5
ស្តេចភ័យខ្លាចជាខ្លាំង ហើយស្តេចមានព្រះហឫទ័យរន្ធត់ជាខ្លាំង។
ឃ្លាទាំងពីរនេះមានន័យថា ជារួមដូចគ្នា
និងបញ្ជាក់ទៅលើអំណាចនៃការភ័យខ្លាចរបស់ស្តេច។ ការបកប្រែផ្សេងទៀត
«ស្តេចភ័យខ្លាចណាស់»
យូរីម
លោកមហាបូជាចារ្យកាន់វត្ថុសក្ការៈ ដែលគេហៅថា យូរីម
និងធូមីមដាក់ក្នុងប្រដាប់ពាក់លើទ្រូងរបស់គាត់
គឺដាក់វត្ថុសម្គាល់ដែលស្ថិតនៅក្បែរបេះដូង។
និយាយជាមួយព្រលឹងអ្នកស្លាប់បាន
ពាក្យទាំងនេះប្រែជាពាក្យមួយក្នុងភាសាដើម។
បើភាសារបស់អ្នកមានមួយពាក្យសម្រាប់មនុស្សម្នាក់
ដែលនិយាយទៅកាន់អ្នកស្លាប់ អ្នកគួរតែប្រើវានៅទីនេះ។
ពាក្យស្រដៀងគ្នានេះមាននៅក្នុង ២៨: ៣ ។
អេនដោរ
ឈ្មោះទីកន្លែង
1 Samuel 28:8
ព្រះបាទសូលបានក្លែងខ្លួនឯង ... ហើយបានចេញទៅ... ដើម្បីទៅឯស្ត្រីនោះទាំងយប់។
ព្រះបាទសូលក្លែងខ្លួន ពីព្រោះផ្លូវពីគីលបោ (២៨:៣) ដល់អេនដោរ (២៨:៥)
គឺឆ្លងកាត់ទឹកដីដែលពួកភីលីស្ទីនកំពុងរស់នៅ។
ស្តេចបានធ្វើដំណើរពេញមួយថ្ងៃហើយទៅដល់ស្ត្រីនោះ បន្ទាប់ពីព្រះអាទិត្យលិច។
បានក្លែង
បានផ្លាស់ប្តូររូបរាងធម្មតារបស់ព្រះអង្គ
គ្មាននរណាម្នាក់អាចដឹងថាទ្រង់ជានរណាឡើយ
«សូមទាយឲ្យខ្ញុំ ... គឺហៅវិញ្ញាណឲ្យឡើងមក »
«និយាយជាមួយអ្នកស្លាប់សម្រាប់ខ្ញុំ»
ឲ្យនរណាខាបវិញ្ញាណមនុស្សស្លាប់លើទឹកដីនេះទេ។
ពាក្យ «អស់អ្នកដែលនិយាយជាមួយមនុស្សស្លាប់» បកប្រែជាពាក្យជាភាសាដើម
ហើយពាក្យថា «អ្នកដែល ... និយាយជាមួយវិញ្ញាណ»
ក៏បកប្រែជាពាក្យនៅក្នុងភាសាដើមដែរ។ បើភាសារបស់អ្នកមានពាក្យសម្រាប់អ្នក
ដែលនិយាយជាមួយមនុស្សស្លាប់
និងពាក្យមួយសម្រាប់អ្នកដែលនិយាយជាមួយវិញ្ញាណ
ឬបើភាសារបស់អ្នកមានតែពាក្យសម្រាប់អ្នក
ដែលនិយាយជាមួយអ្នកស្លាប់និងវិញ្ញាណអ្នកគួរតែប្រើពាក្យទាំងនេះ។
ពាក្យស្រដៀងគ្នានេះមាននៅក្នុង ២៨: ៣ ។
ជីវិតរបស់ខ្ញុំ
ពាក្យថា« ជីវិត» គឺជាពាក្យប្រៀបធៀបសម្រាប់មនុស្ស។ ការបកប្រែផ្សេងទៀត«ខ្ញុំ»
1 Samuel 28:13
មានម្នាក់
អាចមានន័យថា ១)« ម្នាក់ដូចជាព្រះជាម្ចាស់» ឬ ២)« ចៅក្រម» (សូមមើល
៧:១៥) ។
1 Samuel 28:16
បានហែករាជ្យអាណាចក្រពីព្រះហស្តរបស់ព្រះកុរណា
លោកសាំយូអែលប្រដូចរាជ្យទៅនឹងវត្ថុមួយ ដែលអាចកាន់នៅក្នុងដៃ
ហើយចាប់បានដោយមនុស្សម្នាក់ទៀត។ ការបកប្រែផ្សេងទៀត
«ធ្វើឲ្យអ្នកក្លាយជាអ្នកលែងជាស្តេច» ឬ «តែងតាំងអ្នកផ្សេងធ្វើជាស្តេចជំនួសអ្នក»
1 Samuel 28:18
ព្រះអម្ចាស់បានប្រគល់អ៊ីស្រាអែល ព្រមទាំងព្រះករុណាទៅក្នុងដៃរបស់ពួកភីលីស្ទីនថែមទៀតផង។
លោកសាំយូអែលប្រដូចជាជនជាតិអ៊ីស្រាអែលនឹងវត្ថុតូចមួយ
ដែលព្រះអម្ចាស់នឹងប្រទានដល់ពួកភីលីស្ទីន
ដែលលោកបាននិយាយដូចជាពួកគេជាមនុស្សតែមួយ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអនុញ្ញាតឲ្យពួកភីលីស្ទីនធ្វើអ្វី ដែលពួកគេចង់ធ្វើចំពោះអ្នក
និងប្រជាជនអ៊ីស្រាអែល»
នឹងមកនៅជាមួយទូលបង្គំហើយ។
នេះជារបៀបគួរសមក្នុងការនិយាយថា ព្រះបាទសូលនឹងត្រូវសុគត។
ការបកប្រែផ្សេងទៀត «នឹងត្រូវសុគត»
ព្រះអម្ចាស់ក៏ប្រគល់កងទ័ពអ៊ីស្រាអែលទៅក្នុងដៃរបស់ពួកភីលីស្ទីនដែរ»។
លោកសាំយូអែលប្រដូចជាកងទ័ពអ៊ីស្រាអែលនឹងវត្ថុតូចមួយ
ដែលព្រះអម្ចាស់នឹងប្រទានដល់ពួកភីលីស្ទីន
ដែលលោកបាននិយាយដូចជាពួកគេជាមនុស្សតែមួយ។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់នឹងអនុញ្ញាតឲ្យពួកភីលីស្ទីនធ្វើអ្វី
ដែលពួកគេចង់ធ្វើដល់កងទ័ពអ៊ីស្រាអែល»
1 Samuel 28:20
ស្តេចពុំបានសោយព្រះស្ងោយអស់ជាច្រើនថ្ងៃច្រើនយប់។
ព្រះបាទសូលមិនបានសោយនៅពេលយប់ មុនពេលទ្រង់ធ្វើដំណើរពីគីលបោ
(២៨:៣) ទៅដល់កោះអេនដោរ (២៨: ៥) ក៏មិនមែនជាពេលថ្ងៃ
ដែលទ្រង់បានធ្វើដំណើរក៏មិនមែនជាពេលយប់
ដែលទ្រង់បានទៅលេងស្ត្រីនោះទេ។
ទូលបង្គំបានដាក់ជីវិតនៅក្នុងព្រះហស្តទ្រង់ និងបានស្តាប់
នេះជាឃ្លាសំនួនវោហាស័ព្ទ។ «ទូលបង្គំអាចស្លាប់ដោយសារទូលបង្គំបានស្តាប់» ឬ
«នរណាម្នាក់អាចសម្លាប់ទូលបង្គំបាន ព្រោះទូលបង្គំបានស្តាប់»
1 Samuel 28:22
សូមព្រះសន្តាប់ខ្ញុំម្ចាស់ជាអ្នកបម្រើទ្រង់
ស្ត្រីនោះនិយាយប្រដូចជានាងជាមនុស្សម្នាក់ទៀត ដែលបង្ហាញថា
នាងគោរពព្រះបាទសូល។ ការបកប្រែផ្សេងទៀត «សំឡេងរបស់ខ្ញុំម្ចាស់»
បដិសេធ
«មិនបានទទួលយក» ឬ «នឹងមិនធ្វើអ្វីដែលពួកគេបានស្នើសុំ»
បានទទូច
«បានបង្ខំ»
1 Samuel 28:24
កូនគោដែលបំប៉ន
កូនគោធំ ដែលត្រូវគេចិញ្ចឹមទុកសម្រាប់ពិធីបុណ្យពិសេស
នាង ... ច្របាច់
នាងលាយម្សៅនិងប្រេង ច្របាច់និងរមៀលយ៉ាងខ្លាំងនឹងដៃរបស់នាង
ដើម្បីផលិតម្សៅធ្វើនំ។

29 [1]គ្រានោះ ពួកភីលីស្ទីនបានប្រមូលគ្នាទាំងអស់មកបោះទ័ពនៅអាផេក ឯអ៊ីស្រាអែលក៏បានមកបោះជំរំនៅក្បែរប្រភពទឹកនៅយេសរាល។
[2]ពួកអ្នកដឹកនាំពួកភីលីស្ទីនបានដឹកនាំទ័ពទាំងរាប់រយ និងរាប់ពាន់នាក់ចេញទៅ
ហើយលោកដាវីឌទាំងអ្នកដែលនៅជាមួយលោកនៅជាមួយទ័ពជួរក្រោយជាមួយព្រះបាទអគីស។

generated on Wed Sep 10 16:16:32 2025

[3]បន្ទាប់មក មានអ្នកដឹកនាំភីលីស្ទីនបានសួរថា៖ «តើពួកហេព្រើរទាំងនេះមកធ្វើអ្វីនៅទីនេះ?» ព្រះបាទអគីសបានតបទៅអ្នកដឹកនាំរបស់ពួកភីលីស្ទីននោះថា៖
«គឺលោកដាវីឌ ជាអ្នកបម្រើរបស់ព្រះបាទសូល ដែលជាស្តេចអ៊ីស្រាអែល បានមករស់នៅជាមួយយើងប៉ុន្មានឆ្នាំនេះមកហើយ
ហើយយើងមិនដែលឃើញលោកមានកំហុសម្តងណាទេរហូតមកដល់ថ្ងៃនេះ»។
[4]ប៉ុន្តែ អ្នកដឹកនាំនោះខឹងនឹងព្រះបាទអគីស ដោយបាននិយាយថា៖ «មិនត្រូវឲ្យអ្នកនេះចូលរួមជាមួយយើងទេ ឲ្យវាត្រឡប់ទៅកន្លែងដើមវាវិញទៅ
កុំឲ្យវាចូលរួមច្បាំងជាមួយយើងជាដាច់ខាត។ ធ្វើដូច្នេះវានឹងមិនក្លាយជាសត្រូវរបស់យើងនៅឯសមរភូមិឡើយ។ តើធ្វើដូចម្តេចថា
គេនឹងជានាជាមួយចៅហ្វាយចាស់របស់គេវិញនោះ? តើវានឹងមិនសម្លាប់ពួកមនុស្សរបស់យើងទេឬអី?
[5]តើនេះមិនមែនជាលោកដាវីឌដែលគេនាំគ្នារាំ និងច្រៀងតគ្នាទៅវិញទៅមកថា៖ «ព្រះបាទសូលបានសម្លាប់រាប់ពាន់នាក់ ឯលោកដាវីឌសម្លាប់បានរាប់ម៉ឺននាក់ទេឬអី?»។
[6]ភ្លាមនោះព្រះបាទអគីសបានហៅលោកដាវីឌ ហើយមានរាជឱង្ការថា៖ «ដោយព្រះអម្ចាស់មានព្រះជន្មគង់នៅ លោកពិតជាល្អនឹងខ្ញុំ ហើយទាំងចេញទៅប្រយុទ្ធ
ទាំងត្រឡប់មកវិញ លោកគ្មានកំហុសអ្វីទេតាំងពីលោកទើបមកនៅជាមួយយើង និងរហូតមកដល់ថ្ងៃនេះ។ ទោះយ៉ាងណាក្តី មេដឹកនាំមិនពេញចិត្តនឹងលោកទេ។
[7]សូមលោកត្រឡប់ទៅវិញដោយសុខសាន្តចុះ ធ្វើដូច្នេះលោកនឹងមិនធ្វើឲ្យមេដឹកនាំភីលីស្ទីនមិនសប្បាយចិត្តឡើយ»។
[8]លោកដាវីឌបានទូលទៅព្រះបាទអគីសវិញថា៖ «តើទូលបង្គំបានធ្វើអ្វីខុស? តើទ្រង់បានទតឃើញទូលបង្គំជាអ្នកបម្រើទ្រង់មានកំហុសអ្វីតាំពីដំបូងរហូតមកទល់ពេលនេះ
ហើយនិងពេលចេញទៅវាយប្រយុទ្ធនឹងសត្រូវរបស់ទ្រង់?»[9]ព្រះបាទអគីសបានតបវិញថា៖ «យើងជ្រាបហើយថា លោកគ្មានកំហុសអ្វីទាំងអស់។ នៅចំពោះមុខយើង
លោកដូចជាទេវតានៃព្រះ ប៉ុន្តែ ទោះយ៉ាងនេះក្តី មេដឹកនាំភីលីស្ទីនបាននិយាយថា៖ «មិនត្រូវឲ្យអ្នកនេះទៅចម្បាំងជាមួយយើងជាដាច់ខាត»។
[10]ដូច្នេះ ចូរក្រោកពីព្រលឹមជាមួយនឹងបាវបម្រើរបស់យើងឯទៀតដែលបានមកជាមួយលោក ហើយភ្លឺឡើងចូរចេញដំណើរទៅចុះ»។[11]លោកដាវីឌបានក្រោកពីព្រលឹម
ទាំងលោក និងមនុស្សដែលនៅជាមួយចាកចេញពេលព្រឹក ត្រឡប់ទៅទឹកដីភីលីស្ទីនវិញ។ ឯពួកទ័ពភីលីស្ទីនបានបន្តដំណើរឡើងទៅយេសរាលតទៀត។

---

1 Samuel 29:1
ប្រភពទឹក
ទឹកហូរតូចហូរតាមធម្មជាតិពីផែនដី
បានដឹកនាំទ័ពទាំងរាប់រយ និងរាប់ពាន់នាក់ចេញទៅ
«បែងចែកទាហានរបស់ពួកគេទៅជាក្រុមៗ ក្រុមខ្លះមានទាហានមួយរយនាក់
និងក្រុមខ្លះមានទាហានមួយពាន់នាក់» (សូមមើល យូឌីបី)
ទាំងរាប់រយ...រាប់ពាន់នាក់
១០០ រាប់រយនាក់ ... ១០០០រាប់ពាន់នាក់
ហើយលោកដាវីឌទាំងអ្នកដែលនៅជាមួយលោកនៅជាមួយទ័ពជួរក្រោយជាមួយព្រះបាទអគីស។
ក្រុមទាហានរាប់រយនាក់ និងរាប់ពាន់នាក់បានឡើងទៅមុន បន្ទាប់មក
ព្រះបាទអគីស និងពួកជំនួយរបស់ព្រះអង្គ
ហើយបន្ទាប់មកលោកដាវីឌទាហានរបស់គាត់ និងទាហានភីលីស្ទីនផ្សេងទៀត
ដែលកំពុងតែការពារព្រះបាទអគីស។
1 Samuel 29:3
«តើពួកហេព្រើរទាំងនេះមកធ្វើអ្វីនៅទីនេះ?»
របៀបដែលអាចធ្វើបាន
ដើម្បីបកប្រែសំណួរដ៏ប៉ិនប្រសព្វនេះជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
១) «អ្នកមិនគួរអនុញ្ញាតិឲ្យពួកហេប្រឺ គឺ
ជាសត្រូវរបស់យើងនៅទីនេះជាមួយយើងឡើយ»។ ឬ ២) «ចូរប្រាប់យើងថាតើ
ពួកហេប្រឺទាំងនោះជានរណា»?
គឺលោកដាវីឌ ...ប៉ុន្មានឆ្នាំនេះមកហើយ ... រហូតមកដល់ថ្ងៃនេះ?
ការបកប្រែផ្សេងទៀតដែលអាចទៅរួចគឺ »តើមិនមែនលោកដាវីឌនេះទេ ...
ប៉ុន្មានឆ្នាំនេះ? ខ្ញុំបានឃើញ ... រហូតដល់ថ្ងៃនេះ» ។
សំណួរដ៏ប៉ិនប្រសព្វអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «អ្នកគួរតែដឹងថា នេះជាលោកដាវីឌ ... ប៉ុន្មានឆ្នាំនេះ។
ខ្ញុំបានឃើញ ... រហូតដល់ថ្ងៃនេះ»។
យើងមិនដែលឃើញលោកមានកំហុសម្តងណាទេ
អាចថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «យើងមិនដឹងអ្វីទាំងអស់
ដែលគាត់បានធ្វើខុស» ឬ »យើងពេញចិត្តនឹងគាត់ណាស់»
1 Samuel 29:4
កុំឲ្យវាចូលរួមច្បាំងជាមួយយើងជាដាច់ខាត។
«កុំឲ្យកងទ័ពរបស់វា
ចូលរួមជាមួយកងទ័ពរបស់យើងប្រឆាំងនឹងសត្រូវរបស់យើង»
តើធ្វើដូចម្តេចថា គេនឹងជានាជាមួយចៅហ្វាយចាស់របស់គេវិញនោះ?
តើវានឹងមិនសម្លាប់ពួកមនុស្សរបស់យើងទេឬអី?
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«វិធីល្អបំផុតសម្រាប់លោកដាវីឌ ដើម្បីធ្វើឲ្យជានាជាមួយម្ចាស់របស់គាត់វិញ
គឺតាមរយៈការសម្លាប់ទាហានរបស់យើង!»
1 Samuel 29:5
តើនេះមិនមែនជាលោកដាវីឌដែលគេនាំគ្នារាំ និងច្រៀងតគ្នាទៅវិញទៅមកថា៖
«ព្រះបាទសូលបានសម្លាប់រាប់ពាន់នាក់ ...រាប់ម៉ឺននាក់ទេឬអី?»
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរជឿទុកចិត្តលើលោកដាវីឌទេ - លោកដាវីឌដែលគេនាំគ្នារាំ
និងច្រៀងតគ្នាទៅវិញទៅមកថា៖ «ព្រះបាទសូល ... .រាប់ម៉ឺននាក់! »
រាប់ម៉ឺននាក់ ... រាប់ម៉ឺននាក់
«រាប់ម៉ឺននាក់ ....រាប់ម៉ឺននាក់»
1 Samuel 29:6
ដោយព្រះអម្ចាស់មានព្រះជន្មគង់នៅ
នេះជាឃ្លាសំនួនវោហាស័ព្ទ។ «ប្រាកដជាព្រះអម្ចាស់មានព្រះជន្មគង់នៅ» ឬ
«នេះជាសេចក្តីពិតដែលថ្លែងការណ៍»
ហើយទាំងចេញទៅប្រយុទ្ធ ទាំងត្រឡប់មកវិញ លោកគ្មានកំហុសអ្វីទេ
«យើងសប្បាយចិត្តណាស់
ដែលមានអ្នកចេញទៅក្រៅហើយចូលជាមួយយើងនិងកងទ័ពរបស់យើង» ឬ
«គឺល្អដែលអ្នកទៅគ្រប់ទីកន្លែងជាមួយយើង និងកងទ័ពរបស់យើង»
1 Samuel 29:8
សត្រូវរបស់ទ្រង់
លោកដាវីឌប្រដូចព្រះបាទអគីសនឹងមនុស្សម្នាក់ផ្សេងទៀត
ដែលព្រះបាទអគីសគិតថា លោកដាវីឌគោរពព្រះអង្គ។ ការបកប្រែផ្សេងទៀត
«អ្នកជាម្ចាស់និងស្តេចរបស់ទូលបង្គំ»
ប៉ុន្តែ ទោះយ៉ាងនេះក្តី មេដឹក
«ទោះបីជាវាជាការពិត គឺសំខាន់ជាងមេដឹកនាំ» ឬ »ទោះយ៉ាងណាក៏ដោយ
គឺព្រះអង្គម្ចាស់»
1 Samuel 29:10
បាវបម្រើរបស់យើង
អ្នកអានគួរយល់ថា ព្រះបាទអគីសកំពុងតែមានបន្ទូលពីព្រះបាទសូល។
ហើយភ្លឺ
«អាចមើលឃើញពន្លឺព្រះអាទិត្យពេលព្រឹក»

---

30 [1]គ្រានោះមកដល់នៅថ្ងៃទីបី ពេលដែលលោកដាវីឌ និងអស់អ្នកដែលនៅជាមួយបានមកដល់ស៊ីគឡាក់ ពួកអាម៉ាឡេកបានមករាតត្បាតតំបន់ណេកិប
និងស៊ីគឡាក់។ ពួកនោះបានវាយប្រហារក្រុងស៊ីគឡាក់និងដុតចោលថែមទៀត[2]រួចបានកៀរស្រីៗ និងគ្រប់គ្នាដែលនៅទីនោះទៅទាំងតូចទាំងធំ។
ពួកគេពុំបានសម្លាប់អ្នកណាម្នាក់ទេ ប៉ុន្តែ កៀរយកទៅជាមួយពួកគេប៉ុណ្ណោះ។
[3]ពេលលោកដាវីឌ និងអ្នកដែលនៅជាមួយបានមកដល់ទីក្រុង ក្រុងនោះត្រូវបានដុតឆេះទៅហើយ ប្រពន្ធ និងកូនប្រុសស្រីរបស់ពួកគេក៏ត្រូវគេចាប់យកទៅទៀត។[4]នោះ
លោកដាវីឌ និងអស់អ្នកដែលនៅជាមួយលោកបានស្រែកយំរហូតអស់កម្លាំងលែងយំកើតទៀត។

generated on Wed Sep 10 16:16:32 2025

[5]ប្រពន្ធទាំងពីររបស់លោកដាវីឌក៏ត្រូវគេចាប់យកទៅដែរ គឺនាងអហ៊ីណោម អ្នកស្រុកយេសរាល និងនាងអប៊ីកែលជាអតីតប្រពន្ធសពណាបាល អ្នកភូមិកើមែល។
[6]លោកដាវីឌបានព្រួយជាខ្លាំង ដោយមនុស្សដែលនៅជាមួយនិយាយគ្នាបម្រុងចោលលោកនឹងថ្ម ពីព្រោះពួកគេមានភាពជូរចត់ក្នុងវិញ្ញាណរបស់ខ្លួនខ្លាំងពេក
ម្នាក់ៗបារម្ភពីកូនប្រុសកូនស្រីរបស់ខ្លួន ប៉ុន្តែ ព្រះអម្ចាស់ជាព្រះរបស់លោកដាវីឌបានពង្រឹងកម្លាំងលោកឡើងវិញ។
[7]លោកដាវីឌបានមានប្រសាសន៍ទៅលោកអបៀថើរជាកូនរបស់លោកអហ៊ីម៉ាឡេកថា៖ «សូមយកអាវអេផូឌមកឲ្យខ្ញុំ»។
លោកអបៀថើរក៏យកអាវអេផូដមកជូនលោកដាវីឌ។[8]លោកដាវីឌបានទូលអង្វរដល់ព្រះអម្ចាស់ដើម្បីបង្ហាញផ្លូវថា៖ «បើទូលបង្គំទៅតាមពួកទាហានទាំងនោះ
តើទូលបង្គំតាមទាន់ពួកគេដែរឬទេ?» ព្រះអម្ចាស់បានឆ្លើយតបវិញថា៖ «ចូរទៅតាមចុះ ឯងមុខជាតាមទាន់ ថែមទាំងយកអ្វីៗទាំងអស់ត្រឡប់មកវិញមិនខាន»។
[9]ដូច្នេះ លោកដាវីឌបានចេញទៅជាមួយនឹងមនុស្សដែលនៅជាមួយទាំងប្រាំមួយរយនាក់ ពួកគេបានទៅដល់ទឹកជ្រោះបេសោរ
ហើយមនុស្សមួយក្រុមត្រូវទុកចាំនៅទីនោះ។[10]ប៉ុន្តែ លោកដាវីឌនៅតែបន្តដេញតាម ទៅជាមួយមនុស្សបួនរយនាក់ប៉ុណ្ណោះ ព្រោះពីររយនាក់ត្រូវទុកឲ្យចាំនោះទីនោះ
ដោយពួកគេអស់កម្លាំងមិនអាចឆ្លងទឹកជ្រោះបេសោរនោះបាន។
[11]ពួកគេបានឃើញជនជាតិអេស៊ីបម្នាក់នៅឯវាលរួចនាំយកមកឯលោកដាវីឌ ពួកគេបាននំប៉័ងមកឲ្យទទួលទាន ហើយបុរសនោះបានទទួលទាន
រួចគេក៏បានយកទឹកមកជូនថែមទៀត។[12]គេយកនំដែលធ្វើពីឧទុម្ពរក្រៀម និងទំពាំងបាយជូរក្រៀមមកជូនផងដែរ គាត់បានទទួលទានរួចមានកម្លាំងឡើងវិញ។
គាត់អត់អាហារ អត់ទឹកទទួលអស់បីថ្ងៃបីយប់មកហើយ។
[13]លោកដាវីឌបានសួរគាត់ថា៖ «តើលោកជានរណា ហើយមកពីណា?» គាត់បានតបវិញថា៖ «ខ្ញុំជាជនជាតិអេស៊ីប ជាបាវបម្រើរបស់ជនជាតិអាម៉ាឡេក
ចៅហ្វាយរបស់ខ្ញុំបានបោះបង់ខ្ញុំចោលបីថ្ងៃហើយ ដោយសារខ្ញុំឈឺ។[14]យើងបានទៅរាតត្បាតនៅតំបន់ណេកិបរបស់ជនជាតិកេរេធីម ជាទឹកដីរបស់ជនជាតិយូដា
និងណេកិប ស្រុកកាលែប ហើយបានដុតក្រុងស៊ីគឡាក់ទៀតផង»។
[15]លោកដាវីឌបានសួរទៀតថា៖ «តើលោកអាចនាំខ្ញុំទៅរកក្រុមរាតត្បាតនោះបានឬទេ?» ជនជាតិអេស៊ីបនោះបានឆ្លើយថា៖ «សូមស្បថនឹងព្រះជាម្ចាស់ថា
លោកនឹងមិនសម្លាប់ខ្ញុំ ឬប្រគល់ខ្ញុំទៅក្នុងដៃម្ចាស់របស់ខ្ញុំវិញទេ នោះខ្ញុំនឹងជូនលោកដេញតាមក្រុមរាតត្បាតនោះ»។
[16]ពេលជនជាតិអេស៊ីបនោះបាននាំលោកដាវីឌទៅដល់ទីនោះ ពួកចោរទាំងនោះបានរស់នៅពាសពេញទីនោះ ទាំងស៊ីផឹក
និងរាំផងដោយព្រោះអ្វីៗដែលបានប្លន់យកមកពីស្រុកភីលីស្ទីន និងស្រុកយូដានោះ។[17]នៅថ្ងៃបន្ទាប់ លោកដាវីឌវាយលុកពួកគេតាំងពីព្រឹករហូតដល់ល្ងាច។
គ្មាននរណាម្នាក់រួចឡើយ លើកលែងតែយុវជនបួនរយនាក់ដែលបានជិះអូដ្ឋគេចខ្លួននោះចេញ។
[18]លោកដាវីឌបានយកមកវិញនូវអ្វីៗដែលពួកអាម៉ាឡេកបានប្លន់យកទៅទាំងអស់ ហើយបានរំដោះប្រពន្ធទាំងពីររបស់លោកមកដែរ។[19]គ្មានអ្វីបាត់បង់ទេ ទាំងតូចទាំងធំ
ក៏គ្មានកូនប្រុសស្រីត្រូវបានបាត់បង់ដែរ។ ប៉ុន្តែ ថែមទាំងបានជយភណ្ឌមកវិញសម្រាប់ខ្លួនថែមទៀតផង។ លោកដាវីឌបានប្រមូលគ្រប់បែបយ៉ាង។
[20]លោកដាវីឌបានរឹបអូសទាំងចៀមទាំងគោ ដែលមានអ្នកដឹកសត្វទាំងនោះផង។ ពួកគេបាននិយាយថា៖ «ជយភណ្ឌទាំងនេះជារបស់ដាវីឌ»។
[21]លោកដាវីឌបានមកជួបអ្នកដែលអស់កម្លាំងរងចាំនៅក្បែរទឹកជ្រោះបេសោរទាំងពីររយនាក់នោះ។ កាលបានឃើញលោកដាវីឌ ពួកគេបានចេញមកទទួលលោកដាវីឌ
និងអស់អ្នកដែលត្រឡប់មកវិញជាមួយនឹងលោក។ ពេលលោកដាវីឌមកដល់ពួកគេ លោកបានសួរសុខទុក្ខពួកគេ។
[22]មានមនុស្សអាក្រក់មិនបានការមួយចំនួនក្នុងចំណោមអស់អ្នកដែលបានទៅជាមួយលោកដាវីឌបានមានប្រសាសន៍ថា៖
«ដោយពួកអ្នកទាំងនេះមិនបានទៅជាមួយពួកយើង យើងមិនគួរចែកជយភណ្ឌឲ្យពួកគេទេ។ គឺគ្រាន់តែប្រគល់ប្រពន្ធ និងកូនៗហើយឲ្យពួកគេចេញទៅ
នោះគ្រប់គ្រាន់ហើយ»។
[23]ភ្លាមនោះ លោកដាវីឌបានមានប្រសាសន៍ថា៖ «អ្នករាល់គ្នាមិនត្រូវប្រព្រឹត្តដូច្នេះឡើយ បងប្អូនអើយ តើព្រះអម្ចាស់បានប្រទានអ្វីខ្លះមកយើង។ ព្រះអង្គបានការពារយើង
ហើយប្រគល់ពួកចោររាតត្បាតទាំងនោះមកក្នុងដៃរបស់យើងហើយ។[24]មិនត្រូវស្តាប់តាមពាក្យអ្នកទាំងនេះឡើយ។ ដូច្នេះ ជយភណ្ឌត្រូវចែកជូនអ្នកគ្រប់គ្នាដែលទៅច្បាំង
ហើយក៏ត្រូវជូនដល់អ្នកដែលរងចាំឥវ៉ានទាំងនេះដែរ គឺពួកគេម្នាក់ៗមានចំណែករៀងៗខ្លួន»។[25]តាំងពីថ្ងៃនោះមក គេបានធ្វើតាមរហូតដល់បច្ចុប្បន្ននេះ ដោយសារ
លោកដាវីឌបានធ្វើការនេះទៅជាច្បាប់សម្រាប់អ៊ីស្រាអែល។
[26]ពេលលោកដាវីឌបានមកដល់ ស៊ីគឡាក់វិញ លោកបានផ្ញើជយភណ្ឌខ្លាំងជូនចាស់ទុំស្រុកយូដាដែលជាមិត្តរបស់លោកទាំងមានប្រសាសន៍ថា៖ «មើលនេះ ទាំងនេះគឺជា
ជយភណ្ឌដែលបានមកពីសត្រូវរបស់ព្រះអម្ចាស់»។[27]លោកក៏បានផ្ញើខ្លះទៀតទៅចាស់ទុំនៅបេតអែល ទៅទិសខាងត្បូងនៃរ៉ាម៉ូត
ចាស់ទុំនៅតំបន់យ៉ាទៀរ[28]ចាស់ទុំដែលរស់នៅអារ៉ូអ៊ើរ អ្នកនៅស៊ីភម៉ូត ចាស់ទុំដែលនៅអែលធេម៉ូទាំងគ្នាផងដែរ។
[29]លោកក៏បានផ្ញើជូនចាស់ទុំដែលរស់នៅរ៉ាកាលក្រុងយេរ៉ាម្អែល និងនៅក្រុងកែនផង[30]ចាស់ទុំនៅឯហោម៉ានិងចាស់ទុំដែលរស់នៅឯកោរអាសាន
ចាស់ទុំដែលរស់នៅអាថាក[31]ជូនអស់អ្នកដែលនៅហេប្រូន និងជូនអស់អ្នកដែលនៅគ្រប់ទីកន្លែងដែលលោកដាវីឌ និងមនុស្សដែលនៅជាមួយលោកបានធ្លាប់ឆ្លងកាត់។

---

1 Samuel 30:1

ស៊ីគឡាក់

ក្រុងស៊ីគឡាក់ជាក្រុងមួយនៅប៉ែកខាងត្បូងស្រុកយូដា ហើយលោកដាវីឌ
និងពលទាហានបានថែរក្សាក្រុមគ្រួសាររបស់ពួកគេ។

ពួកនោះ

ជនជាតិអាម៉ាឡេក

ទាំងតូចទាំងធំ

អាចមានន័យថា ១) «ទាំងមនុស្សមិនសំខាន់ និងមនុស្សសំខាន់» ឬ ២)«
ទាំងមនុស្សមាឌតូចនិងមនុស្សមាឌធំ» ។

1 Samuel 30:3

ប្រពន្ធ... កូនប្រុស ... កូនស្រី

ជាកម្មសិទ្ធិរបស់លោកដាវីឌ និងទាហានរបស់លោក

ក្រុងនោះត្រូវបានដុតឆេះទៅហើយប្រពន្ធ ... កូនប្រុសស្រីរបស់ពួកគេក៏ត្រូវគេចាប់យកទៅទៀត។

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «ពួកគេបានឃើញថា
មាននរណាម្នាក់បានដុតទីក្រុង ហើយយកប្រពន្ធរបស់ពួកគេ...ជាឈ្លើយ»

អស់អ្នកដែលនៅជាមួយលោក

ភាគច្រើនជាកងទ័ពសំខាន់របស់លោកដាវីឌ។

1 Samuel 30:5

ព័ត៌មានទូទៅ៖

លោកដាវីឌទទួលបានកម្លាំងនៅក្នុងព្រះអម្ចាស់ បន្ទាប់ពីការវាយឆ្មក់។

គឺនាងអហ៊ីណោម អ្នកស្រុកយេសរាល

«នាងអហ៊ីណោមមកពីស្រុកយេសរាល»

ណាបាល អ្នកភូមិកើមែល។

«ណាបាលជាមនុស្សមកពីស្រុកកើមែល»

នាងអហ៊ីណោម...នាងអប៊ីកែល

ឈ្មោះរបស់ស្ត្រី

បានព្រួយជាខ្លាំង

ការរងទុក្ខ

ពួកគេមានភាពជូរចត់ក្នុងវិញ្ញាណរបស់ខ្លួនខ្លាំងពេក

ពាក្យថា«ជូរចត់» ជាពាក្យប្រៀបធៀបមួយ សម្រាប់ការចង់បះបោរ។ ពាក្យថា
«វិញ្ញាណ» ជាពាក្យរួមមួយសម្រាប់មនុស្ស។ ការបកប្រែផ្សេងទៀត
«ប្រជាជនទាំងអស់បានត្រៀមខ្លួនបះបោរ ប្រឆាំងនឹងលោកដាវីឌ» ឬ «
ប្រជាជនទាំងអស់មិនសប្បាយចិត្តជាខ្លាំង»

ព្រះអម្ចាស់ជាព្រះរបស់លោកដាវីឌបានពង្រឹងកម្លាំងលោកឡើងវិញ។

អាចមានន័យថា ១) «លោកដាវីឌមានសេចក្តីក្លាហាន ពីព្រោះលោកដឹងថា
ព្រះអម្ចាស់ជាព្រះរបស់លោកនឹងជួយលោក» ឬ ២)
«ព្រះអម្ចាស់ជាព្រះរបស់លោកធ្វើឲ្យស្តេចដាវីឌមានកម្លាំង»។

1 Samuel 30:7

ព័ត៌មានទូទៅ៖

លោកដាវីឌស្វែងរកការណែនាំមកពីព្រះអម្ចាស់

generated on Wed Sep 10 16:16:32 2025

ក្នុងការដោះស្រាយការវាយឆ្មក់លើប្រជាជនរបស់គាត់។
លោកដាវីឌបានទូលអង្វរដល់ព្រះអម្ចាស់ដើម្បីបង្ហាញផ្លូវថា
នាមអរូបី «ការបង្ហាញផ្លូវ» អាចបកប្រែជាឃ្លាមួយ។ ការបកប្រែផ្សេងទៀតត
«លោកដាវីឌបានអធិស្ឋាន ថាព្រះអម្ចាស់នឹងប្រាប់លោកនូវអ្វី
ដែលលោកដាវីឌគួរធ្វើ»
ចូរទៅតាមចុះ
«ចូរដេញតាម» ឬ «ចូរតាម»
1 Samuel 30:9
ប្រាំមួយរយនាក់
មនុស្ស៦០០នាក់
ជ្រោះ
អូរតូច
ដេញតាម
«ការដេញតាម» ឬ «ការតាម»
មនុស្សបួនរយនាក់
មនុស្ស៤០០នាក់
ពីររយនាក់
មនុស្ស២០០នាក់
ដោយពួកគេអស់កម្លាំង
ពួកគេនឿយហត់នឹងការវាយឆ្មក់ ហើយឥឡូវនេះ
ពួកគេដេញតាមជនជាតិអាម៉ាឡេក ពួកគេលែងមានកម្លាំងបន្តទៅមុខទៀត។
1 Samuel 30:11
ជនជាតិអេស៊ីបម្នាក់នៅឯវាល
គាត់ត្រូវបានទុកចោលនៅទីនោះ
ដើម្បីស្លាប់ពីការវាយឆ្មក់របស់ជនជាតិអាម៉ាឡេក។
ទំពាំងបាយជូរក្រៀម
«ដុំទំពាំងបាយជូរស្ងួត»
1 Samuel 30:13
លោកដាវីឌបានសួរគាត់ថា
លោកដាវីឌបានសាកសួរទាសករបម្រើជនជាតិអេស៊ីប។
បីថ្ងៃហើយ
«បីថ្ងៃកន្លងមក»
បីថ្ងៃ
៣ថ្ងៃ
រាតត្បាត
ការវាយប្រហារលើទីក្រុងមួយ ដើម្បីយកទ្រព្យសម្បត្តិ
1 Samuel 30:15
ក្រុមរាតត្បាត
ក្រុមអ្នកប្រយុទ្ធប្រដាប់អាវុធមួយក្រុម ដែលវាយប្រហារមនុស្ស
ឬកន្លែងដែលមិនបានរំពឹងទុក
លោកនឹងមិន ...ប្រគល់ខ្ញុំទៅក្នុងដៃម្ចាស់របស់ខ្ញុំវិញទេ
នៅទីនេះ «ដៃ» សំដៅទៅលើការគ្រប់គ្រង ការគ្រប់គ្រង «លោកនឹងមិន ...
រំលោភលើការទុកចិត្តដែលខ្ញុំមាន ចំពោះអ្នក
ដោយអនុញ្ញាតឲ្យម្ចាស់របស់ខ្ញុំគ្រប់គ្រងខ្ញុំម្តងទៀត»
1 Samuel 30:16
បានប្លន់
របស់របរដែលពួកគេបានលួចនៅក្នុងការវាយឆ្មក់
ល្ងាច
ពេលវេលាបន្ទាប់ពីព្រះអាទិត្យលិច រហូតដល់មេឃងងឹត
បួនរយនាក់
៤០០នាក់
1 Samuel 30:18
បានរំដោះ
«បានសង្គ្រោះ» ឬ«បានដោះលែង»
គ្មានអ្វីបាត់បង់ទេ
«គ្មានរបស់របរណាដែលអាម៉ាឡេកបានលួចត្រូវបានបាត់បង់ទេ»
ទាំងតូចទាំងធំ
អាចមានន័យថា ១) «ទំាងមនុស្សសំខាន់ទាំងមនុស្សមិនសំខាន់» ឬ ២)
«ទាំងអ្នកមាឧតូចទាំងមាឧធំ»។ ពាក្យស្រដៀងគ្នានេះមាននៅក្នុង ៣០:១
ជយភណ្ឌ
របស់ដែលអាម៉ាឡេកបានលួច។ បកប្រែដូចនៅក្នុង ៣០:១៦។
1 Samuel 30:21
ពីររយនាក់
២០០នាក់
ជ្រោះ
អូរតូច ឬ ព្រែក
បេសោរ
នេះជាឈ្មោះអូរតូចមួយ។ បកប្រែជាដូចនៅក្នុង ៣០: ៩ ។
បានសួរសុខទុក្ខ
«ស្វាគមន៍»ឬ «បានធ្វើសារមិត្តភាព»
ជយភណ្ឌ
របស់របរដែលពួកគេបានយកពីសត្រូវនៅក្នុងសមរភូមិ។បកប្រែដូចនៅក្នុង
៣០:១៦។
បានមកវិញ
«បានមកវិញ» ឬ «បានត្រឡប់មកវិញ»
1 Samuel 30:23
មិនត្រូវស្តាប់តាមពាក្យអ្នកទាំងនេះឡើយ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍មួយ។
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់នឹងស្តាប់អ្នក ចំពោះរឿងនេះទេ»។
ជយភណ្ឌត្រូវចែកជូនអ្នកគ្រប់គ្នាដែលទៅ
នាមអរូបី «ចែកជូន» អាចបកប្រែជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«នូវអ្វីដែលជាកម្មសិទ្ធិរបស់នរណាម្នាក់»
អ្នកគ្រប់គ្នាដែលទៅច្បាំង
អ្នកចម្បាំងដែលបានប្រយុទ្ធជាមួយសត្រូវ នៅក្នុងសង្គ្រាមជាក់ស្តែង។
គឺពួកគេម្នាក់ៗមានចំណែករៀងៗខ្លួន
«នឹងធ្វើឲ្យប្រាកដថា ទាំងអស់ទទួលបានចំនួនស្មើៗគ្នា»
អ្នកដែលរងចាំឥវ៉ានទាំងនេះ
ប្រជាជនដែលបានគាំទ្រដល់អ្នកចម្បាំង ដោយការគ្រប់គ្រង
និងការពារគ្រឿងផ្គត់ផ្គង់របស់ពួកគេ។
ឥវ៉ាន់
ជាកម្មសិទ្ធិទាហានបានទុកចោល ពេលពួកគេចូលសមរភូមិ។
1 Samuel 30:26
ឃ្លាភ្ជាប់៖
អ្នកនិពន្ធចាប់ផ្តើមបញ្ជីទីក្រុង ដែលពួកចាស់ទុំបានទទួលអំណោយពីស្តេចដាវីឌ។
ស៊ីគឡាក់ ... បេតអែល ...យ៉ាទៀរ ...អារ៉ូអ៊ើរ ... ស៊ីភម៉ូត ... អែលធេម៉ូ
ឈ្មោះទីក្រុង
បានមកពីសត្រូវ
របស់របរដែលលោកដាវីឌបានយកពីជនជាតិអាម៉ាឡេកក្រោយការប្រយុទ្ធ។
បកប្រែដូចនៅក្នុង ៣០:១៦ ។
ជយភណ្ឌ
«អំណោយ»
1 Samuel 30:29
ឃ្លាភ្ជាប់:
អ្នកនិពន្ធបញ្ចប់បញ្ជីទីក្រុង ដែលពួកចាស់ទុំបានទទួលអំណោយពីស្តេចដាវីដ
ដែលបានចាប់ផ្តើមនៅក្នុង ៣០:២៦។ អ្នកប្រហែលជាអាចបញ្ចូលបញ្ជីឈ្មោះពី
៣០:២៦ ទៅជាបញ្ជីមួយ។
រ៉ាកាល...ហោម៉ា ...កោរអាសាន ... អាថាក
ទាំងនេះជាឈ្មោះក្រុង
ក្រុងយេរ៉ាម្អែល ... ក្រុងកែន
ទាំងនេះជាឈ្មោះក្រុមមនុស្ស។

31 [1]ពេលនោះពួកភីលីស្ទីនបានវាយប្រហារអ៊ីស្រាអែល។ ទាហានរបស់អ៊ីស្រាអែលបានរត់បាក់ទ័ពនៅចំពោះមុខពួកភីលីស្ទីន
ហើយបានបាត់បង់ជីវិតនៅលើភ្នំគីលបោ។[2]ទ័ពភីលីស្ទីនបានដេញតាមព្រះបាទសូល និងបុត្រារបស់ស្តេច។ ពួកភីលីស្ទីនបានសម្លាប់សម្តេចយ៉ូណាថាន

generated on Wed Sep 10 16:16:32 2025

សម្តេចអប៊ីណាដាប់ និងសម្តេចម៉ាល់គីស៊ូអា។[3]សង្គ្រាមកាន់តែធ្ងន់ធ្ងរប្រឆាំងព្រះបាទសូល ហើយទ័ពបាញ់ព្រួញបានតាមទាន់ព្រះបាទសូល។
ស្តេចបានតក់ស្លុតជាខ្លាំងដោយបានឃើញពួកគេដេញយ៉ាងដូច្នេះ។
[4]បន្ទាប់មក ព្រះបាទសូលបានថ្លែងទៅអ្នកកាន់គ្រឿងសឹកស្តេចថា៖ «ចូរដកដាវរបស់ឯង ហើយចាក់សម្លាប់យើងចុះ។
យើងមិនចង់ឃើញហេតុការកំពុងតាមយើងបែបនេះទេ ចូរចាក់យើងមក»។ ប៉ុន្តែអ្នកកាន់គ្រឿងសឹករបស់ស្តេចនោះមិនហ៊ានទេ ដោយភ័យខ្លាចខ្លាំងពេក។
ដូច្នេះព្រះបាទសូលបានហូតដាវហើយផ្តួលខ្លួនឯងនឹងមុខដាវ[5]អ្នកកាន់គ្រឿងសឹកនោះឃើញព្រះបាទសូលសោយទិវង្គតដូច្នេះ
ក៏ផ្តួលខ្លួនលើដាវរួចក៏ស្លាប់ទៅជាមួយស្តេចដែរ។[6]ដូច្នេះ ព្រះបាទសូល និងបុត្រាទាំងបី ព្រមទាំងអ្នកកាន់គ្រឿងសឹករបស់ស្តេច
រួមទាំងអ្នកនៅសមរភូមិទាំងអស់បានស្លាប់ក្នុងថ្ងៃដូចគ្នា។
[7]ពេលទ័ពអ៊ីស្រាអែលដែលនៅម្ខាងទៀតនៃជ្រលងភ្នំ និងអស់អ្នកដែលនៅឯនាយម្ខាងទៀតនៃទន្លេយ័រដាន់បានឃើញថា ទាហានអ៊ីស្រាអែលបានរត់បាក់ទ័ព
ហើយព្រះបាទសូលព្រមទាំងបុត្រារបស់ស្តេចបានសោយទិវង្គត ពួកគេបានបោះបង់ទីក្រុងរបស់ខ្លួន រួចគេចខ្លួនទៅ។
ឯពួកភីលីស្ទីនបានមករស់នៅក្នុងទីក្រុងរបស់ពួកគេ។[8]ថ្ងៃបន្ទាប់ ពួកភីលីស្ទីនបានចេញមកប្រមូលរបរបរចេញពីសព
ហើយពួកគេបានឃើញសាកសពរបស់បុត្រាទាំងបីរបស់ស្តេចសូល និងព្រះបាទសូលនៅលើភ្នំគីលបោ។
[9]ពួកគេបានកាត់ក្បាលរបស់ស្តេច ហើយដកគ្រឿងសឹករបស់ស្តេចចេញ រួចបានបញ្ជូនទៅគ្រប់តំបន់នៃស្រុកភីលីស្ទីន ហើយនាំដំណឹងនេះទៅតាមវិហារនៃព្រះរបស់ពួកគេ
និងដល់ប្រជាជនផង។[10]ពួកគេបានដាក់គ្រឿងសឹករបស់ស្តេចនៅក្នុងវិហាររបស់ព្រះអាស្តារ៉ូត យកសាកសពរបស់ទ្រង់ទៅចងផ្ចាប់នឹងជញ្ជាំងទីក្រុងបេតសាន។
[11]អ្នកក្រុងយ៉ាបេស ក្នុងស្រុកកាឡាដបានឮដំណឹងពីអ្វីដែលពួកភីលីស្ទីនបានធ្វើចំពោះព្រះបាទសូល[12]អ្នកប្រយុទ្ធទាំងអស់បានក្រោកឡើង ហើយចេញទៅទាំងយប់
រួចបានយកព្រះសពរបស់ព្រះបាទសូល និងបុត្រាពីជញ្ជាំងក្រុងបេតសានមកវិញ។ ពួកគេបានត្រឡប់ទៅក្រុងយ៉ាបេស ហើយយកសពទៅបូជានៅទីនោះ។[13]ក្រោយមក
ពួកគេបានយកឆាតុទៅបញ្ចុះនៅក្រោមដើមជ្រៃមួយនៅក្នុងយ៉ាបេស ហើយបានតមអាហារប្រាំពីរថ្ងៃ។

---

1 Samuel 31:1

ពេលនោះពួកភីលីស្ទីនបានវាយប្រហារអ៊ីស្រាអែល។

ការប្រយុទ្ធនេះជាលទ្ធផលនៃជម្លោះ រវាងលោកដាវីឌនិងពួកភីលីស្ទីននៅ ២៩:១០ ។ អ្នកនិពន្ធបានបញ្ចប់រឿងរបស់លោកដាវីឌនៅក្នុង ៣០: ១ ហើយឥឡូវនេះគាត់បានប្រាប់អំពីការប្រយុទ្ធរវាងពួកអ៊ីស្រាអែល និងពួកភីលីស្ទីន។

ពួកភីលីស្ទីនបានវាយប្រហារអ៊ីស្រាអែល។

«ពួកភីលីស្ទីនបានច្បាំងនឹងប្រជាជនអ៊ីស្រាអែល»

ភ្នំគីលបោ

នេះជាឈ្មោះភ្នំមួយ .

បានដេញតាមព្រះបាទសូល និងបុត្រារបស់ស្តេច។

«ដេញតាមព្រះបាទសូល និងបុត្របីអង្គ»

សម្តេចអប៊ីណាដាប់ និងសម្តេចម៉ាល់គីស៊ូអា

ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។ .

សង្គ្រាមកាន់តែធ្ងន់ធ្ងរប្រឆាំងព្រះបាទសូល

នេះជាឃ្លាសំនួនវោហាស័ព្ទ។

«កងទ័ពរបស់ព្រះបាទសូលបានចាប់ផ្តើមបាត់បង់ការប្រយុទ្ធ»

1 Samuel 31:4

អ្នកកាន់គ្រឿងសឹកស្តេច

អ្នកកាន់គ្រឿងសឹកស្តេចកាន់ខែលធំរបស់មេបញ្ជាការរបស់លោក
និងអាវុធផ្សេងទៀត។ លោកបានការពារមេបញ្ជាការអំឡុងពេលប្រយុទ្ធ។

ពួកមិនកាត់ស្បែកទាំងនេះ

គុណនាមធម្មតា «មិនកាត់ស្បែក» អាចត្រូវបានបកប្រែជាគុណនាម។
ការបកប្រែផ្សេងទៀត «មនុស្សទាំងនេះដែលមិនបានកាត់ស្បែក»
ការមិនកាត់ស្បែកគឺជាពាក្យប្រៀបធៀបសម្រាប់ជនបរទេស។
ការបកប្រែផ្សេងទៀត «មនុស្សដែលមិនមែនជាជនជាតិអ៊ីស្រាអែលទាំងនេះ»

មិនហ៊ាន

រាងពងក្រពើអាចបានបំពេញបាន។ ការបកប្រែផ្សេងទៀត
«នឹងមិនធ្វើអ្វីដែលព្រះបាទសូលបានប្រាប់គាត់ ឲ្យ ធ្វើនោះទេ»

បានហូតដាវហើយផ្តួលខ្លួនឯងនឹងមុខដាវ

«បានសម្លាប់ខ្លួនឯង ដោយដាវផ្ទាល់របស់ទ្រង់»

ថ្ងៃដូចគ្នា

«នៅថ្ងៃនោះ»

1 Samuel 31:7

បានមករស់នៅក្នុងទីក្រុងរបស់ពួកគេ។

បានរស់នៅក្នុងទីក្រុងនានា ពេលទ័ពអ៊ីស្រាអែលបានចាកចេញ

ប្រមូលរបស់របរចេញពីសព

ចូរយកគ្រឿងសឹក
និងអាវុធចេញពីសាកសពរបស់ជនជាតិអ៊ីស្រាអែលដែលបានស្លាប់។

ភ្នំគីលបោ

ជួរភ្នំមួយដែលមើលឃើញជ្រលងភ្នំយេសរាល នៅភាគខាងជើងអ៊ីស្រាអែល
និងខាងត្បូងណាសារ៉ែត

1 Samuel 31:9

គ្រប់តំបន់ទាំងអស់នៃស្រុកភីលីស្ទីន

«គ្រប់តំបន់ទាំងអស់នៃស្រុកភីលីស្ទីន»

ហើយនាំដំណឹងនេះទៅតាមវិហារនៃព្រះរបស់ពួកគេ និងដល់ប្រជាជនផង។

«ប្រាប់ព័ត៌មាននៅខាងក្នុងព្រះវិហារ និងប្រជាជន»

ព្រះរបស់ពួកគេ

ព្រះវិហារជាកន្លែង ដែលពួកថ្វាយបង្គំព្រះរបស់ពួកគេ

ព្រះអាស្តារ៉ូត

ព្រះក្លែងក្លាយ និងរូបចម្លាក់បុរាណ ដែលត្រូវបានគេហៅផងដែរថា «អាសេរ៉ា» ឬ «អាស្តាត»

ចងផ្ចាប់

«បានភ្ជាប់» (ប្រហែលជាបោះភ្ជាប់ជាមួយដែកគោលធំ ឬ ច្រវាក់)

ទីក្រុងបេតសាន

ឈ្មោះទីក្រុង

1 Samuel 31:11

ក្រុងយ៉ាបេស

ឈ្មោះក្រុងមួយ។ បកប្រែដូចនៅក្នុង ១១:១។

ពីអ្វីដែលពួកភីលីស្ទីនបានធ្វើចំពោះព្រះបាទសូល

«របៀបដែលពួកភីលីស្ទីនបានប្រមាថដល់ស្តេចសូល»

ទាំងយប់

«ពេញមួយយប់»

ដើមជ្រៃ

នេះជាដើមឈើមួយប្រភេទ។ ការបកប្រែផ្សេងទៀត «ដើមឈើមានម្លប់ធំ»
បកប្រែដូចនៅក្នុង ២២:៦។

---

២ សាំយូអែល

1 [1]បន្ទាប់ពីព្រះបាទសូល សោយទិវង្គតទៅ លោកដាវីឌបានត្រឡប់មកវិញ បន្ទាប់ពី វាយឈ្នះជនជាតិអាម៉ាឡេក ហើយបានស្នាក់នៅក្រុងស៊ីគឡាក់រយៈពេលពីរថ្ងៃ។
[2]នៅថ្ងៃទីបី មានបុរសម្នាក់មកពីជំរំរបស់ព្រះបាទសូល ជាមួយនឹងសម្លៀកបំពាក់រហែក ហើយរោយដីនៅលើក្បាលផង។ ពេលដែលគាត់បានជួបនឹងលោកដាវីឌ
គាត់ឱនមុខចុះ ហើយក្រាបថ្វាយបង្គំដល់ដី។
[3]លោកដាវីឌសួរគាត់ថា៖ «តើអ្នកមកពីណា?» គាត់ឆ្លើយថា៖ «ខ្ញុំបានរត់ចេញពីជំរំអ៊ីស្រាអែល»។[4]លោកដាវីឌមានប្រសាសន៍ទៅគាត់ថា៖ «សូមប្រាប់យើងមកមើល៍
តើមានរឿងអ្វីកើតឡើង?» គាត់ឆ្លើយថា៖ «ពួកទាហានបានបាក់ទ័ពរត់ពីសមរភូមិ។ មានមនុស្សជាច្រើនបានដួលស្លាប់។ ព្រះបាទសូល និងសម្តេចយ៉ូណាថាន់
បុត្ររបស់ទ្រង់ក៏សុគតដែរ»។[5]លោកដាវីឌសួរទៅបុរសវ័យក្មេងនោះថា៖ «ហេតុអ្វីបានជាឯងដឹងថា ព្រះបាទសូល និងសម្តេចយ៉ូណាថាន់ សោយទិវង្គត?»

generated on Wed Sep 10 16:16:32 2025

[6]បុរសនោះរៀបរាប់ថា៖ «នៅពេលកើតហេតុការណ៍នោះ ខ្ញុំក៏នៅលើភ្នំគីលបោរដែរ ហើយព្រះបាទសូលបានច្រត់លើលំពែងរបស់ព្រះអង្គ មានរទេះចម្បាំង
និងទ័ពសេះរបស់សត្រូវតាមមកយ៉ាងប្រកិតនឹងព្រះអង្គ។[7]ព្រះបាទសូលងាកមកបានឃើញខ្ញុំ ហើយបានហៅខ្ញុំ។ ខ្ញុំក៏បានឆ្លើយថា៖ ព្រះករុណាថ្លៃវិសេស
ទូលបង្គំនៅទីនេះ។
[8]ព្រះអង្គបានមានបន្ទូលមកខ្ញុំថា៖ «តើឯងជាអ្នកណា?» ខ្ញុំក៏បានទូលទៅព្រះអង្គថា៖ «ទូលបង្គំជាជនជាតិអាម៉ាឡេក»។[9]ព្រះអង្គក៏បង្គាប់មកខ្ញុំថា៖
«ចូរមកឈរនៅពីមុខយើង ហើយសម្លាប់យើងទៅ ព្រោះសេចក្តីឈឺចាប់ជាមួយនឹងរបួសរបស់យើងណាស់ ប៉ុន្តែ យើងនៅមានជីវិត។[10]ដូច្នេះ
ខ្ញុំក៏បានឈរនៅពីមុខព្រះអង្គហើយបានធ្វើគត់ព្រះអង្គទៅ ព្រោះខ្ញុំបានដឹងថា ព្រះរាជានឹងសោយទិវង្គតបន្ទាប់ពី ព្រះអង្គបរាជ័យ។ បន្ទាប់មក ខ្ញុំបានដោះយកមកុដ
ដែលនៅលើព្រះសិរ របស់ព្រះអង្គ ព្រមទាំងខ្សែដៃរបស់ព្រះអង្គហើយនាំយកមកជូនលោក ជាម្ចាស់របស់ខ្ញុំ»។
[11]បន្ទាប់មក លោកដាវីឌ បានហែកសម្លៀកបំពាក់របស់លោក រីឯមនុស្សទាំងអស់ដែលនៅជាមួយលោកក៏បានហែកសម្លៀកបំពាក់របស់ពួកគេដែរ។[12]ពួកគេកាន់ទុក្ខ
យំសោក និងតមអាហាររហូតដល់ពេលល្ងាច ដើម្បីរំលឹកដល់ព្រះបាទសូល និងសម្តេចយ៉ូណាថាន់ បុត្រារបស់ស្តេច និងសម្រាប់ប្រជាជនរបស់ព្រះអម្ចាស់
ព្រមទាំងសម្រាប់ស្រុកអ៊ីស្រាអែលទាំងមូល ដែលពួកគេបានបាត់បង់ជីវិតដោយសារសង្គ្រាម។[13]លោកដាវីឌបានសួរទៅកាន់បុរសនោះថា៖ «តើអ្នកមកពីណា?»
គាត់ឆ្លើយថា៖ «ខ្ញុំជាកូនរបស់ជនជាតិអាម៉ាឡេក ដែលរស់នៅក្នុងស្រុកនេះ»។
[14]លោកដាវីឌមានប្រសាសន៍ទៅបុរសនោះថា៖ «ហេតុអ្វីបានជាអ្នកមិនមានការភ័យខ្លាច ដែលធ្វើគត់ស្តេចដែលព្រះអម្ចាស់បានចាក់ប្រេងអភិសេធ
ដោយដៃរបស់អ្នកដូច្នេះ?»[15]លោកដាវីឌបានហៅក្មេងអ្នកបម្រើរបស់គាត់ម្នាក់មក ហើយបង្គាប់ថា៖ «ចូរទៅក្បែរគេ! ហើយសម្លាប់គេទៅ»។ ដូច្នេះ
អ្នកបម្រើរបស់លោកដាវីឌបានចូលទៅក្បែរ ហើយសម្លាប់ជនជាតិអាម៉ាឡេកនោះស្លាប់ទៅ។
[16]លោកដាវីឌបានមានប្រសាសន៍ទៅកាន់សាកសពជនជាតិអាម៉ាឡេកនោះថា៖ «ឈាមរបស់អ្នកធ្លាក់ទៅលើក្បាលរបស់អ្នក
ព្រោះមាត់របស់អ្នកបានធ្វើបន្ទាល់ប្រឆាំងនឹងអ្នក ដោយអ្នកបាននិយាយថា៖ «ខ្ញុំបានសម្លាប់ ស្តេចដែលព្រះអម្ចាស់បានចាក់ប្រេងតែងតាំង!»។
[17]លោកដាវីឌបានស្មូតទំនុកចម្រៀងដែលរំលឹកអំពីព្រះបាទសូល និងសម្តេចយ៉ូណាថាន់ ជាបុត្ររបស់ព្រះអង្គ។[18]ហើយលោកក៏បានបញ្ជាឲ្យពួកគេបង្រៀនបទនេះ
គឺជាទំនុកធ្នូរ ដល់កូនចៅយូដា ដែលមានកត់ត្រាទុកក្នុងសៀវភៅ ពួកសុចរិត។[19]«អ៊ីស្រាអែលអើយ!ហេតុអ្វីរីរជនរបស់អ្នក ត្រូវគេសម្លាប់នៅលើកំពូលភ្នំយ៉ាងដូច្នេះ?
[20]អ្នកមិនត្រូវប្រកាសដំណឹងនេះនៅក្រុងកាថឡើយ ហើយក៏មិនត្រូវផ្សព្វផ្សាយដំណឹងនេះនៅតាមផ្លូវនៃក្រុងអេស្កាឡូនដែរ ក្រែងលោកូនស្រីរបស់ពួកភីលីស្ទីន
នាំគ្នាអរសប្បាយ ក្រែងលោពួកកូនស្រីនៃជនជាតិដែលមិនកាត់ស្បែកនាំគ្នាអរសប្បាយ។
[21]ជួរភ្នំគីលបោរអើយ! សូមកុំឲ្យមានភ្លៀង ឬទឹកសន្សើមធ្លាក់លើអ្នកឡើយ ទាំងស្រែចម្ការ សូមកុំឲ្យមានផលសម្រាប់តង្វាយឡើយ
ព្រោះនៅទីនោះខែលរបស់អ្នកខ្លាំងពូកែត្រូវគេបន្ទាបបន្ថោក។ ខែលរបស់ព្រះបាទសូលក៏លែងបានលាបប្រេងតទៅទៀតដែរ។[22]ធ្នូររបស់សម្តេចយ៉ូណាថាន់មិនរុញរាឡើយ
ហើយដាវរបស់ព្រះបាទសូលក៏មិនវិលចូលស្រោមវិញដែរ ប្រសិនបើ មិនបានបង្ហូរឈាមសត្រូវ ដែលបានសម្លាប់គេនោះ។
[23]ព្រះបាទសូល និងសម្តេចយ៉ូណាថាន់ គួរឲ្យស្រឡាញ់ និងគោរពរាប់អាន ពេលដែលនៅរស់ ហើយពេលដែលពួកគេស្លាប់ ក៏ពួកគេមិនបែកគ្នាដែរ។
ពួកគេរហ័សដូចជាឥន្ទ្រី ពួកគេខ្លាំងដូចជាសិង្ហ។[24]ឱកូនស្រីអ៊ីស្រាអែលអើយ! ចូរយំសោកស្រណោះព្រះបាទសូលដែលធ្លាប់ស្លៀកសម្លៀកបំពាក់រុងរឿងដ៏ត្រចះត្រចង់
ព្រមទាំងមានរំយោលធ្វើពីមាសនៅលើសម្លៀកបំពាក់។
[25]ហេតុអ្វីបានជាអ្នកដ៏ខ្លាំងពូកែ ត្រូវស្លាប់នៅកណ្តាលសមរភូមិដូច្នេះ! សម្តេចយ៉ូណាថាន់អើយ! ហេតុអ្វីបានជាសម្តេចត្រូវខ្មាំងសត្រូវចាក់ទម្លុះនៅលើកំពូលភ្នំដូច្នេះ?
[26]ទូលបង្គំខ្លោចផ្សារក្នុងចិត្តដោយសារបាត់បង់សម្តេច! សម្តេចយូណាថាន់អើយ! សម្តេចមានសេចក្តីករុណាណាស់ចំពោះទូលបង្គំណាស់។ ក្តីស្រឡាញ់របស់សម្តេច
គឺវិសេសណាស់ គឺប្រសើរជាងក្តីស្រឡាញ់របស់មនុស្សស្រីទៅទៀត![27]ហេតុអ្វីបានជាវីរបុរសដ៏អង់អាចត្រូវស្លាប់ដូច្នេះ ហេតុអ្វីបានជាគ្រឿងសាស្ត្រាវុធ ត្រូវវិនាសដូច្នេះ!»

---

2 Samuel 1:1

ក្រុងស៊ីគឡាក់

នេះជាឈ្មោះទីក្រុងនៅក្នុងភាគខាងត្បូង នៃស្រុកយូដា។

នៅថ្ងៃទីបី

«បន្ទាប់ពីបីថ្ងៃក្រោយមក»

ជាមួយនឹងសម្លៀកបំពាក់រហែក ហើយរោយដីនៅលើក្បាលផង។

នៅក្នុងវប្បធម៌នេះ ការហែកសម្លៀកបំពាក់ដោយខ្លួនឯង
ហើយដាក់ដីកខ្វក់នៅលើក្បាលរបស់ពួកគេ គឺជាសកម្មភាពកាន់ទុក្ខ។

គាត់ឱនមុខចុះ ហើយក្រាបថ្វាយបង្គំដល់ដី។

នេះជាសកម្មភាពបង្ហាញពីការចុះចូលចំពោះលោកដាវីឌ
ដែលឥឡូវជាស្តេចអ៊ីស្រាអែល។

2 Samuel 1:3

មានមនុស្សជាច្រើនបានដួលស្លាប់»

អាចមានន័យថា ១) «មនុស្សជាច្រើនបានរងរបួស
និងមនុស្សច្រើនត្រូវបានសម្លាប់» ឬ ២) «មនុស្សជាច្រើនបានរងរបួស
និងត្រូវបានសម្លាប់។

2 Samuel 1:6

នៅពេលកើតហេតុការណ៍នោះ ខ្ញុំក៏នៅ

នេះជាសេចក្តីថ្លែងការណ៍
ដែលផ្តោតទៅលើថាបុរសនោះមិនមានគម្រោងជួបស្តេចសូលទេ។

ព្រះបាទសូលបានច្រត់លើលំពែងរបស់ព្រះអង្គ

អាចមានន័យថា១) ស្តេចសូលខ្សោយ
ដោយប្រើលំពែងដើម្បីទ្រទ្រង់ព្រះកាយព្រះអង្គផ្ទាល់ ២)
ស្តេចសូលព្យាយាមសម្លាប់អង្គទ្រង់ផ្ទាល់ ដោយលំពែងព្រះអង្គផ្ទាល់។

2 Samuel 1:8

ព្រះអង្គបានមានបន្ទូលមកខ្ញុំថា?'ខ្ញុំក៏បានទូលទៅព្រះអង្គថា «ទូលបង្គំជាជនជាតិអាម៉ាឡេក»

ការដកស្រង់ដោយផ្ទាល់ ទាំងនេះអាចជាការនិយាយដោយប្រយោល។
ការបកប្រែផ្សេងទៀត «ព្រះអង្គបានសួរទូលបង្គំថា ទូលបង្គំជានរណា
ហើយទូលបង្គំបានទូលព្រះអង្គថា ទូលបង្គំជាជនជាតិអាម៉ាឡេក»

ទូលបង្គំជាជនជាតិអាម៉ាឡេក

ទាំងនេះជាមនុស្សដូចគ្នា ដែលដាវីឌទើបតែបញ្ចប់ការរាយប្រហារក្នុង ១:១ ។

ព្រោះសេចក្តីឈឺចាប់ជាមួយនឹងរបួសរបស់យើងណាស់

ការរងទុក្ខរបស់ស្តេចសូល ត្រូវបានគេនិយាយថាជារឿងគួរឲ្យភ័យខ្លាច
ដែលបានចាប់តោងព្រះអង្គ។ ការបកប្រែផ្សេងទៀត «យើងកំពុងរងទុក្ខយ៉ាងខ្លាំង»

យើងនៅមានជីវិត

ឃ្លានេះមានន័យថា ព្រះអង្គនៅមានព្រះជន្មនៅឡើយ។ ការបកប្រែផ្សេងទៀត
«យើងនៅមានព្រះជន្មនៅឡើយ»

ខ្ញុំបានដឹងថា ព្រះរាជានឹងសោយទិវង្គតបន្ទាប់ពី ព្រះអង្គបរាជ័យ

ទោះជាយ៉ាងណាព្រះអង្គនឹងសោយទីវង្គត

2 Samuel 1:11

លោកដាវីឌ បានហែកសម្លៀកបំពាក់របស់លោក ...

មនុស្សទាំងអស់ដែលនៅជាមួយលោកក៏បានហែកសម្លៀកបំពាក់របស់ពួកគេដែរ។

លោកដាវីឌនិងពួករបស់គាត់ បានហែកសម្លៀកបំពាក់របស់ពួកគេ
ជាសញ្ញានៃការកាន់ទុក្ខចំពោះការសោយទិវង្គតរបស់ស្តេចសូល។

សម្រាប់ប្រជាជនរបស់ព្រះអម្ចាស់ ព្រមទាំងសម្រាប់ស្រុកអ៊ីស្រាអែលទាំងមូល

សេចក្តីថ្លែងការណ៍ទាំងពីរមានន័យដូចគ្នា។ ពាក្យថា «ផ្ទះ»
គឺជាពាក្យប្រៀបធៀបដែលតំណាងឲ្យកូនចៅអ៊ីស្រាអែល។ ប៉ុន្តែទាំង «ប្រជាជន»
និង «ផ្ទះ» ប្រហែលជាក្រុមតំណាងឲ្យទាហានអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«សម្រាប់ទាហានអ៊ីស្រាអែល»

ព្រះអម្ចាស់

នេះគឺព្រះនាមរបស់ព្រះជាម្ចាស់
ដែលព្រះអង្គបានបង្ហាញដល់ប្រជាជនរបស់ទ្រង់នៅក្នុងគម្ពីរសញ្ញាចាស់។
សូមមើលការបកប្រែទំព័រនេះ អំពីព្រះអម្ចាស់នឹងរបៀបបកប្រែអត្ថបទនេះ។

ដែលពួកគេបានបាត់បង់ជីវិតដោយសារសង្គ្រាម

នៅទីនេះ «បានធ្លាក់» គឺជាវិធីគួរសមក្នុងការសំដៅទៅលើការសម្លាប់។
ដូចគ្នានេះផងដែរ "ដាវ" តំណាងឲ្យសមរភូមិ។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«ពួកគេបានស្លាប់នៅក្នុងសមរភូមិ» ឬ «សត្រូវបានសម្លាប់ពួកគេនៅក្នុងសមរភូមិ» នេះមានន័យថា «ត្រូវបានសម្លាប់» ។
តើអ្នកមកពីណា?
បុរសនោះបានប្រាប់រួចហើយថា គាត់ជាជនជាតិអាម៉ាឡេកក្នុង ១:៨ ។
លោកដាវីឌបានសួរបុរសនោះយ៉ាងច្បាស់ ដើម្បីបញ្ជាក់អំពីរឿងនេះ
ពីព្រោះការកាត់ទោសយ៉ាងម៉ឺងម៉ាត់នេះ
លោកដាវីឌបានកំពុងប្រកាសទៅលើបុរសនោះ។
2 Samuel 1:14
ហេតុអ្វីបានជាអ្នកមិនមានការភ័យខ្លាច ដែលធ្វើគត់ស្តេចដែលព្រះអម្ចាស់បានចាក់ប្រេងអភិសេធ ... ដោយដៃ?
នេះជាសំនួរដ៏ប៉ិនប្រសប់មួយ ត្រូវបានប្រើដើម្បីស្តីបន្ទោសបុរសនោះ។
វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ការបកប្រែផ្សេងទៀត
«អ្នកគួរតែគោរពកោតខ្លាចព្រះអម្ចាស់
និងមិនសម្លាប់អ្នកដែលព្រះអង្គបានចាក់ប្រេងតាំង... ដោយដៃ»
ស្តេចដែលព្រះអម្ចាស់បានចាក់ប្រេងអភិសេធ
នេះគឺពាក្យប្រៀបធៀបសម្រាប់ស្តេចសូល
ដែលត្រូវបានជ្រើសរើសដោយព្រះជាម្ចាស់។
ដោយដៃរបស់អ្នក
ឃ្លានេះសំដៅទៅលើការធ្វើអ្វីមួយដោយខ្លួនឯង។ ការបកប្រែផ្សេងទៀត «ខ្លួនឯង» ឬ «ផ្ទាល់ខ្លួន»
សម្លាប់
នេះជាឃ្លាដែលមានន័យថា «សម្លាប់គាត់» ។
ឈាមរបស់អ្នកធ្លាក់ទៅលើក្បាលរបស់អ្នក
នៅទីនេះ «ឈាម» មានន័យថា «ស្រក់ឈាម»
ហើយត្រូវបានផ្សារភ្ជាប់ជាមួយនឹងការស្លាប់។ នៅទីនេះ «ក្បាលរបស់អ្នក»
សំដៅទៅលើបុរសហើយមានន័យថា គាត់ទទួលខុសត្រូវ។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់អ្នក» ឬ
«អ្នកបានបណ្តាលឲ្យស្លាប់ដោយខ្លួនឯង»
មាត់របស់អ្នកបានធ្វើបន្ទាល់ប្រឆាំងនឹងអ្នក
នៅទីនេះ «មាត់ផ្ទាល់របស់អ្នក» សំដៅទៅលើបុរសនោះ។ ការបកប្រែផ្សេងទៀត
«អ្នកបានធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនអ្នក»
2 Samuel 1:17
ព័ត៌មានទូទៅ៖
លោកដាវីឌស្មូតទំនុកចម្រៀងការកាន់ទុក្ខសម្រាប់ស្តេចសូល និងយ៉ូណាថាន។
ជាទំនុកធ្លួរ
នេះជាចំណងជើងនៃបទចម្រៀង។
ដែលមានកត់ត្រាទុកក្នុងសៀវភៅ ពួកសុចរិត
នេះគឺជាព័ត៌មានសង្ខេបបន្ថែម ដើម្បីប្រាប់អ្នកអាននូវអ្វីដែលបានកើតឡើង
ទៅតាមទំនុកចម្រៀងនាពេលអនាគត។
ក្នុងសៀវភៅ ពួកសុចរិត
ពាក្យ «យ៉ាសើរ» មានន័យថា «ត្រង់» ។ ការបកប្រែផ្សេងទៀត
«សៀវភៅនៃភាពសុចរិត»
អ៊ីស្រាអែលអើយ!ហេតុអ្វីវីរជនរបស់អ្នក ត្រូវគេសម្លាប់
«សិរីរុងរឿងរបស់អ៊ីស្រាអែល» សំដៅទៅលើស្តេចសូល។
វីរជន
ឃ្លាថា «អ្នកខ្លាំងពូកែ» សំដៅលើទាំងពីរ គឺទាំងស្តេចសូលនិងសម្តេចយ៉ូណាថាន។
នេះជាគុណនាម គឺពហុវចន:ហើយអាចត្រូវបានថ្លែងថាជា «អ្នកខ្លាំងពូកែ»
បានធ្លាក់ចុះ
ពាក្យថា «ធ្លាក់» នៅទីនេះមានន័យថា «ស្លាប់» ។
អ្នកមិនត្រូវប្រកាសដំណឹងនេះនៅក្រុងកាថ ...
ហើយក៏មិនត្រូវផ្សព្វផ្សាយដំណឹងនេះនៅតាមផ្លូវនៃក្រុងអេស្កាឡូនដែរ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយត្រូវបានធ្វើដដែលជាផ្នែកមួយនៃកំណាព្យរបស់ទំនុកចម្រៀង។
ក្រុងកាថ ... ក្រុងអេស្កាឡូន
ក្រុងកាថនិងក្រុងអាស្កាឡូន គឺជាទីក្រុងធំពីររបស់ពួកភីលីស្ទីន។
ពួកភីលីស្ទីនបានសម្លាប់ស្តេចសូលនិងសម្តេចយ៉ូណាថាន។
ក្រែងលោកូនស្រីរបស់ពួកភីលីស្ទីន នាំគ្នាអរសប្បាយ ... នាំគ្នាអរសប្បាយ
ក្រែងលោពួកកូនស្រីនៃជនជាតិដែលមិនកាត់ស្បែកនាំគ្នាអរសប្បាយ។
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយត្រូវបានធ្វើដដែលជាផ្នែកមួយនៃកំណាព្យរបស់ទំនុកចម្រៀង។
កូនស្រីនៃជនជាតិដែលមិនកាត់ស្បែក
នេះគឺឃ្លាសំដៅទៅលើមនុស្ស ដែលមិនដើរតាមព្រះអម្ចាស់ ដូចជាពួកភីលីស្ទីន
2 Samuel 1:21
ជួរភ្នំគីលបោរអើយ!
លោកដាវីឌនិយាយដោយផ្ទាល់ទៅកាន់ «ភ្នំគីលបោរ »
ដូចជាពួកវាកំពុងស្តាប់ចម្រៀងរបស់គាត់។
សូមកុំឲ្យមានភ្លៀង ឬទឹកសន្សើមធ្លាក់លើអ្នកឡើយ
លោកដាវីឌដាក់បណ្តាសាដី ជាកន្លែងស្តេចសូលបានស្លាប់នៅក្នុងសមរភូមិ។
នេះជាការគោរពចំពោះស្តេចសូល ដែលជាស្តេចព្រះជាម្ចាស់បានជ្រើសរើស។
ខែលរបស់អ្នកខ្លាំងពូកែត្រូវគេបន្ទាបបន្ថោក
«អ្នកខ្លាំងពូកែ» នៅទីនេះសំដៅលើស្តេចសូល។
ខែលត្រូវបានបន្ទាបបន្ថោកព្រោះវាបានដួលនៅលើដី
ហើយដោយសារព្រះលោហិតរបស់ស្តេចបានធ្លាក់មកលើវា។
ខែលរបស់ព្រះបាទសូលក៏លែងបានលាបប្រេងតទៅទៀតដែរ
ខែលរបស់ស្តេចសូលធ្វើមកពីស្បែក។ ដើម្បីថែរក្សាខែល គេត្រូវជូតដោយប្រេង។
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់នឹងថែរក្សាខែលរបស់ស្តេចសូលទៀតទេ» ។
ធ្នូររបស់សម្តេចយ៉ូណាថានមិនរុញរាឡើយ ហើយដាវរបស់ព្រះបាទសូល
ក៏មិនវិលចូលស្រោមវិញដែរ ប្រសិនបើ មិនបានបង្ហូរឈាមសត្រូវ ដែលបានសម្លាប់គេនោះ។
ស្តេចសូលនិងសម្តេចយ៉ូណាថាន ត្រូវបានបង្ហាញនៅទីនេះថា
ជាអ្នកចម្បាំងដ៏ខ្លាំងក្លានិងក្លាហាន។
ដាវរបស់ព្រះបាទសូលក៏មិនវិលចូលស្រោមវិញដែរ ប្រសិនបើ មិនបានបង្ហូរឈាមសត្រូវ
ដែលបានសម្លាប់គេនោះ
ដាវរបស់ស្តេចសូល ត្រូវបានគេនិយាយដូចជា
កំពុងរស់នៅដែលអាចវិលត្រឡប់មកវិញដោយខ្លួនឯង។
ជាជាងត្រឡប់មកវិញដោយទទេ វាបានកំពុងយកឈាមសត្រូវរបស់ព្រះបាទសូល
ដែលវាបានសម្លាប់។
2 Samuel 1:23
ពេលដែលពួកគេស្លាប់ ក៏ពួកគេមិនបែកគ្នាដែរ
ឃ្លា «មិនត្រូវបានបំបែកចេញពីគ្នា» ត្រូវបានប្រើដើម្បីបញ្ជាក់ថា
ពួកគេនៅជាមួយគ្នាជានិច្ច។ ការបកប្រែផ្សេងទៀត
"សូម្បីតែនៅពេលសុគតក៏ពួកគេនៅជាមួយគ្នាដែរ" ។
ពួកគេរហ័សដូចជាឥន្ទ្រី ពួកគេខ្លាំងដូចជាសិង្ហ
ព្រះបាទសូលនិងសម្តេចយ៉ូណាថាន ហាក់ដូចជាលឿនជាងឥន្ទ្រី
ហើយខ្លាំងជាងសត្វតោ។
ដែលធ្លាប់ស្លៀកសម្លៀកបំពាក់រុងរឿងដ៏ត្រចះត្រចង់
ព្រមទាំងមានរំយោលធ្វើពីមាសនៅលើសម្លៀកបំពាក់។
«អ្នកណាបានផ្តល់សម្លៀកបំពាក់ និងគ្រឿងអលង្ការដ៏ស្រស់ស្អាតដល់អ្នក» ។
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា ដែលពិពណ៌នាអំពីការផ្តល់ឲ្យស្ត្រី
នូវសម្លៀកបំពាក់ដែលមានតំលៃថ្លៃនិងទាក់ទាញ។
2 Samuel 1:25
ហេតុអ្វីបានជាអ្នកដ៏ខ្លាំងពូកែ ត្រូវស្លាប់នៅកណ្តាលសមរភូមិដូច្នេះ!
ឃ្លានេះត្រូវបាននិយាយដដែលៗនៅក្នុង ខ ២៧ ដើម្បីបញ្ជាក់ថា
អ្នកចម្បាំងដ៏ខ្លាំងពូកែរបស់អ៊ីស្រាអែលបានស្លាប់ហើយ។ ការបកប្រែផ្សេងទៀត
«វីរជនដ៏ខ្លាំងពូកែបានស្លាប់នៅក្នុងសមរភូមិ»។
ជាអ្នកដ៏ខ្លាំងពូកែ
នៅទីនេះ «អ្នកខ្លាំងពូកែ» ជាពហុវចន:ហើយអាចសំដៅទៅលើតែព្រះបាទសូល
និងសម្តេចយ៉ូណាថាន ឬដល់ទាហានអ៊ីស្រាអែលទាំងអស់។ ការបកប្រែផ្សេងទៀត
«វីរជនដ៏អង់អាចខ្លាហាន»
ត្រូវស្លាប់
នេះគឺជារបៀបគួរសមក្នុងការនិយាយថា «បានស្លាប់ហើយ» ។
សម្តេចយ៉ូណាថានអើយ
នេះអាចជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«សម្តេចយ៉ូណាថានបានសុគតនៅក្នុងសមរភូមិ» ឬ
«សត្រូវបានសម្លាប់សម្តេចយ៉ូណាថាន»
នៅលើកំពូលភ្នំ
លោកដាវីឌបន្តថ្លែងសុន្ទរកថា ផ្នែកនេះនៃទំនុកចម្រៀងទៅកាន់ភ្នំគីលបោរនៅពេល
ដែលគាត់ចាប់ផ្តើមនៅឆ្នាំ ១:២១ ។

generated on Wed Sep 10 16:16:32 2025

សម្តេចមានសេចក្តីករុណាណាស់ចំពោះទូលបង្គំណាស់
នៅទីនេះ «បងប្រុស» ប្រើជាមួយមិត្តជិតស្និទ្ធ។
សម្តេចយូណាថានអើយ! សម្តេចមានសេចក្តីករុណាណាស់ចំពោះទូលបង្គំ។

នៅទីនេះ «សេចក្តីស្រឡាញ់» ត្រូវបានប្រើក្នុងន័យមិត្តភាព និងភាពស្មោះត្រង់។
ភាពស្មោះត្រង់របស់សម្តេចយ៉ូណាថានចំពោះលោកដាវីឌ
គឺអស្ចារ្យជាងភាពស្មោះត្រង់របស់ស្ត្រីចំពោះប្តីនិងកូន។

2 [1]ក្រោយការនោះ លោកដាវីឌបានទូលសួរព្រះអម្ចាស់ថា៖ «តើទូលបង្គំគួរនឹងឡើងទៅក្រុងណាមួយរបស់ស្រុកយូដាឬ?» ព្រះអម្ចាស់បានតបទៅលោកថា៖
«ចូរទៅចុះ!» លោកដាវីឌក៏ទូលទៀតថា៖ «តើក្រុងមួយណាដែលទូលបង្គំគួរនឹងឡើងទៅ?» នោះព្រះអម្ចាស់មានបន្ទូលថា៖ «ត្រូវទៅក្រុងហេប្រុន!»។[2]ដូច្នេះ
លោកដាវីឌបានចេញទៅជាមួយភរិយាទាំងពីរនាក់របស់លោកគឺ៖ នាងអហ៊ីណោម អ្នកស្រុកយេសរាល និងនាងអប៊ីកែល ភរិយារបស់លោកណាបាល
អ្នកស្រុកគើមែល[3]លោកដាវីឌបាននាំមនុស្សទាំងអស់ដែលនៅជាមួយលោក ទាំងគ្រួសាររបស់លោក ទៅកាន់ទីក្រុងហេប្រុន ជាទីកន្លែងដែលពួកគេនឹងត្រូវរស់នៅ។
[4]ពេលនោះ អ្នកស្រុកយូដា បាននាំគ្នាមកក្រុងហេប្រុន ហើយធ្វើការចាក់ប្រេងតាំងលោកដាវីឌឲ្យធ្វើជាស្តេចដឹកនាំលើកស្រុកយូដា។ ពួកគេបានប្រាប់លោកដាវីឌថា៖
«មានបុរសម្នាក់ឈ្មោះយ៉ាបេស ជាអ្នកស្រុកកាឡាត បានបញ្ចុះសពព្រះបាទសូល»។[5]ដូច្នេះ ព្រះបាទដាវីឌបានចាត់អ្នកនាំសារឲ្យទៅជួបនឹងលោកយ៉ាបេស
ជាអ្នកស្រុកកាឡាត ហើយមានរាជឱង្ការទៅលោកថា៖ «សូមព្រះអម្ចាស់ប្រទានពរដល់លោក! ដ្បិត
លោកបានបង្ហាញសេចក្តីស្មោះស្ម័គ្រចំពោះព្រះបាទសូលជាម្ចាស់របស់លោក ហើយបានបញ្ចុះសពរបស់ព្រះអង្គ។
[6]ឥឡូវនេះ សូមព្រះអម្ចាស់សម្តែងព្រះហឫទ័យសប្បុរស និងព្រះហឫទ័យស្មោះស្ម័គ្រចំពោះអ្នករាល់គ្នា។ ហើយយើងក៏នឹងសម្តែងសេចក្តីសប្បុរស
និងភាពស្មោះស្ម័គ្រចំពោះអ្នករាល់គ្នាដែរ ដោយព្រោះអ្នករាល់គ្នាបានធ្វើយ៉ាងដូច្នេះចំពោះម្ចាស់របស់អ្នករាល់គ្នា។[7]ដូច្នេះ ចូរមានកម្លាំងឡើង
ដោយព្រះបាទសូលម្ចាស់របស់អ្នក បានសោយទិវង្គតទៅហើយ ហើយអ្នកស្រុកយូដាក៏បានតែងតាំងខ្ញុំជាស្តេចគ្រប់គ្រងលើពួកគេដែរ។
[8]ប៉ុន្តែ លោកអប៊ីនើរ ជាកូនរបស់លោក នើរ ជាមេទ័ពរបស់ព្រះបាទសូលបាននាំសម្តេចអ៊ីសបូសែត ជាបុត្រព្រះបាទសូល ឆ្លងទៅស្រុកម៉ាហាណាអ៊ីម។
[9]គាត់បានលើកសម្តេចអ៊ីសបូសែត ធ្វើជាស្តេចគ្រងរាជ្យលើស្រុកកាឡាត ស្រុកអេស៊ើរ ស្រុកយេសរាល ស្រុកអេប្រាអ៊ីម ស្រុកបេនយ៉ាមីន
គឺលើស្រុកអ៊ីស្រាអែលទាំងមូល។
[10]សម្តេចអ៊ីសបូសែត បុត្ររបស់ព្រះបាទសូលមានព្រះជន្មសែសិបព្រះវស្សា ពេលដែលព្រះអង្គចាប់ផ្តើមគ្រងរាជ្យលើស្រុកអ៊ីស្រាអែល
ព្រះអង្គគ្រងរាជ្យអស់រយៈពេលពីរឆ្នាំ។ ប៉ុន្តែ មានតែស្រុកយូដាប៉ុណ្ណោះដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្តេចដាវីឌ។[11]ព្រះបាទដាវីឌ បានសោយរាជ្យនៅក្រុងហេប្រុន
និងគ្រប់គ្រងលើជនជាតិយូដា អស់រយៈពេលប្រាំពីរឆ្នាំ និងប្រាំមួយខែ។
[12]លោកអប៊ីនើរ ជាកូនរបស់លោកនើរ ជាអ្នកបម្រើរបស់សម្តេចអ៊ីសបូសែត បុត្រព្រះបាទសូល បានចាកចេញពីម៉ាហាណាអ៊ីមទៅកាន់ក្រុងគីបៀន។[13]លោកយ៉ូអាប់
ជាកូនរបស់លោកស្រីសេរូយ៉ា ព្រមទាំងរាជ្យបម្រើរបស់ស្តេចដាវីឌក៏បានចេញទៅច្បាំងដែរ ហើយពួកគេបានជួបគ្នានៅត្រង់បឹងគីបៀន។ នៅទីនោះ
ពួកគេបានបោះទ័ពប្រឈមមុខគ្នានៅបឹងម្ខាងម្ខាង។
[14]លោកអប៊ីនើរមានប្រសាសន៍ទៅលោកយ៉ូអាប់ថា៖ «ចូរឲ្យពួកយុវជន ក្រោកឡើង ហើយប្រយុទ្ធគ្នានៅខាងមុខយើង»។ លោកយ៉ូអាប់តបទៅវិញថា៖
«ចូរឲ្យគេក្រោកឡើងប្រកួតគ្នាចុះ»។[15]យុវជនទាំងនោះក៏ក្រោកចេញទៅមានចំនួនស្មើគ្នា គឺម្ភៃនាក់ពីពួកបេនយ៉ាមីន និងពីពួកសម្តេចអ៊ីសបូសែតបុត្រព្រះបាទសូល
ហើយម្ភៃនាក់ទៀតពីពួករាជ្យបម្រើរបស់ស្តេចដាវីឌ។
[16]ពួកគេម្នាក់ៗចាប់ក្បាលដៃគូប្រយុតរៀងៗខ្លួន ហើយហូតដាវរបស់គេចាក់ទៅចន្លោះឆ្អឹងជំនីដៃគូរប្រយុទ្ធរបស់ខ្លួន ហើយក៏ដួលស្លាប់ទាំងអស់គ្នា។
កន្លែងដែលពួកគេបានប្រយុទ្ធគ្នានោះក្នុងភាសាហេព្រើរហៅថា៖ «ហេលកាត-ហាស៊ូរីម» ឬ «ទីវាលនៃដាវ» គឺនៅក្នុងក្រុងគីបៀន។
[17]ការប្រយុទ្ធយ៉ាងសាហាវបានកើតឡើងនៅថ្ងៃនោះ។ លោកអប៊ីនើរ និងទាហានរបស់លោក បានប្រយុទ្ធចាញ់អ្នកបម្រើរបស់ស្តេចដាវីឌ។
[18]កូនប្រុសទាំងបីរបស់លោកស្រីសេរូយ៉ា ដែលនៅទីនោះមាន៖ លោកយ៉ូអាប់ លោកអប៊ីសាយ និងលោកអេសាអែល។ លោកអេសាហែល អាចរត់លឿនដូចជាប្រើសព្រៃ។
[19]លោកអេសាអែល បានដេញតាមលោកអប៊ីនើរ យ៉ាងប្រកិតដោយមិនបានងាកឆ្វេង ឬស្តាំឡើយ។
[20]លោកអប៊ីនើរបានក្រឡេកមើលក្រោយហើយសួរថា៖ «តើអ្នកជាេអសាអែលឬ?» គាត់ក៏តបថា៖ «គឺយើងនេះហើយ»។[21]លោកអប៊ីនើរមានប្រសាសន៍ទៅគាត់ថា៖
«ចូរដេញតាមក្មេងណាម្នាក់ដែលនៅខាងស្តាំ ឬនៅខាងឆ្វេងអ្នក ហើយដោះយកគ្រឿងសាស្ត្រាវុធរបស់គេទៅ!
[22]លោកអប៊ីនើរមានប្រសាសន៍ទៅលោកអេសាអែលម្តងទៀតថា៖ «ឈប់ដេញតាមយើងទៅ។ តើចង់ឲ្យយើងវាយផ្តួលឯងទៅលើដីឬអី? បើដូច្នេះ
តើឲ្យយើងប្រឈមមុខនឹងលោកយ៉ូអាប់ជាបងប្រុសរបស់ឯងយ៉ាងដូចម្តេច»។[23]ប៉ុន្តែ លោកអេសាអែលនៅតែមិនព្រមឈប់ដេញតាមគាត់ ដូច្នេះ
លោកអប៊ីនើរបានបុកលោកអេសាអែល នឹងចុងលំពែងរបស់លោក នោះចុងលំពែងបានបុកទំលុះពីពោះធ្លាយដល់ខ្នង។ លោកអេសាអែល
បានដួលហើយស្លាប់នៅកន្លែងនោះទៅ។ នៅពេលដែលពួកអ្នកដែលរត់តាមមកដល់កន្លែងដែលលោកអេសាអែលដួលស្លាប់នោះ ក៏បាននាំគ្នាឈប់ហើយឈរនៅទីនោះ។
[24]ប៉ុន្តែ លោកយ៉ូអាប់ និងលោកអប៊ីសាយនៅតែដេញតាមលោកអប៊ីនើរ។ នៅពេលថ្ងៃលេច ពួកគេបានមកដល់ជំរាលអាំម៉ា ដែលនៅជិតគីយ៉ា
តាមផ្លូវទៅទីរហោស្ថានគីបៀន។[25]ពួកទាហានបេនយ៉ាមីនបានប្រមូលគ្នាមកឈរពីក្រោយលោកអប៊ីនើរ ហើយផុំគ្នាឈរនៅលើកំពូលភ្នំ។
[26]នៅពេលនោះលោកអប៊ីនើរស្រែកសួរទៅលោកយ៉ូអាប់ថា៖ «តើយើងត្រូវច្បាំងគ្នារហូតឬ? តើលោកមិនដឹងថា ការនេះនឹងបញ្ចប់ទៅដោយជូរចត់ទេឬ?
តើរហូតដល់ពេលណាទើបលោកប្រាប់ពលទាហានរបស់លោកឲ្យឈប់ដេញតាមបងប្អូនរបស់ពួកគេ។[27]លោកយ៉ូអាប់តបវិញថា៖ «
ខ្ញុំសូមស្បថក្នុងនាមព្រះអង្គដែលមានព្រះជន្មគង់នៅថា ប្រសិនបើ អ្នកមិនសូមយើងទេ
នោះទាហានរបស់យើងនឹងដេញតាមបងប្អូនរបស់ពួកគេរហូតដល់ព្រឹកមិនខាន!»។
[28]លោកយ៉ូអាប់ផ្លុំត្រែឡើង ហើយទាហានរបស់គាត់ទាំងអស់បានឈប់ដេញតាមពួកទ័ពអ៊ីស្រាអែល ហើយក៏មិនប្រយុទ្ធជាមួយពួកគេទៀតដែរ។
[29]នៅយប់នោះលោកអប៊ីនើរពួកទាហានបន្តធ្វើដំណើរពេញមួយយប់ ដោយធ្វើដំណើរកាត់តាមអារ៉ាបា។ ពួកគេដើរតាមវាលទំនាបទន្លេយ័រដាន រហូតដល់ព្រឹកបន្ទាប់
ទើបពួកគេទៅដល់ម៉ាហាណាអ៊ីម។
[30]លោកយ៉ូអាប់បានត្រឡប់ពីដេញតាមលោកអប៊ីនើរវិញ។ លោកបានប្រមូលទាហានរបស់គាត់ នោះលោកឃើញមានមនុស្សដប់ប្រាំបួននាក់អវត្តមាន
រួមទាំងលោកអសាអែល។[31]ទាហានរបស់ព្រះបាទដាវីឌបានសម្លាប់ទាហានរបស់លោកបេនយ៉ាមីន និងទាហានរបស់លោកអប៊ីនើរទាំងអស់បីរយហុកសិបនាក់។
[32]ពួកគេក៏បានលើកសពរបស់លោកអេសាអែល ហើយបានបញ្ចុះនៅក្នុងផ្នូរឪពុករបស់គាត់ ដែលនៅភូមិបេថ្លេហិម។ លោកយ៉ូអាប់
និងទាហានរបស់គាត់ដើរពេញមួយយប់ រហូតដល់ពេលថ្ងៃរះពួកគេបានទៅដល់ហេប្រុន។

2 Samuel 2:1

ក្រោយការនោះ
«បន្ទាប់ពីលោកដាវីឌបានកាន់ទុក្ខការសុគតរបស់ព្រះបាទសូលនិងសម្តេចយ៉ូណាថានរួចមក
គួរនឹងឡើងទៅក្រុងណាមួយរបស់ស្រុកយូដា
នៅពេលនេះលោកដាវីឌគង់នៅក្រុងស៊ីកឡាក់។ លោកដាវីឌបានប្រើឃ្លាថា
«ឡើងទៅ» ពីព្រោះស៊ីកឡាក់ទាបជាងនៅស្រុកយូដា។ការបកប្រែផ្សេងទៀត
«ធ្វើដំណើរទៅក្រុងមួយនៃស្រុកយូដា»។
លោកដាវីឌបានចេញទៅជាមួយភរិយាទាំងពីរនាក់
ស្តេចសូលសួរដំណឹង លោកដាវីឌគង់នៅក្រុងស៊ីកឡាក់។ អ្នកពណ៌នាប្រើឃ្លាថា
«បានឡើងទៅ» ពីព្រោះស៊ីកឡាក់មានកំពស់ទាបជាងហេប្រុន។
ការបកប្រែផ្សេងទៀត «លោកដាវីឌបានធ្វើដំណើរទៅទីក្រុងហេប្រុន
ជាមួយប្រពន្ធទាំងពីររបស់គាត់»

generated on Wed Sep 10 16:16:32 2025

2 Samuel 2:4
ធ្វើការចាក់ប្រេងតាំងលោកដាវីឌឲ្យធ្វើជាស្តេច
នៅក្នុងសកម្មភាពជានិមិត្តរូបនេះ ពួកគេបានចាក់ប្រេងលើក្បាលលោកដាវីឌ ដើម្បីបង្ហាញថាគាត់ត្រូវបានគេជ្រើសរើសឲ្យធ្វើជាស្តេច។
ដឹកនាំលើកស្រុកយូដា
នៅទីនេះ «ផ្ទះ» ត្រូវបានប្រើសាកសមក្នុងនៃ «កុលសម្ព័ន្ធ» ។
ការបកប្រែផ្សេងទៀត «កុលសម្ព័ន្ធយូដា»
ឈ្មោះយ៉ាបេស ជាអ្នកស្រុកកាឡាត
នេះជាឈ្មោះទីក្រុងមួយ ក្នុងតំបន់របស់កាឡាត។
2 Samuel 2:6
ព័ត៌មានទូទៅ៖
ស្តេចដាវីឌនិយាយទៅកាន់ប្រជាជននៅយ៉ាបេសកាឡាដ។
ធ្វើយ៉ាងដូច្នេះ
ពួកគេបានបញ្ចុះព្រះបាទសូល។
ចូរមានកម្លាំងឡើង
នៅទីនេះ «ដៃ» សំដៅលើប្រជាជនយ៉ាបេសកាឡាដ។ ការបកប្រែផ្សេងទៀត «ចូរមានកម្លាំងឡើង»
អ្នកស្រុកយូដាក៏បានតែងតាំងខ្ញុំជាស្តេច
នៅក្នុងសកម្មភាពជានិមិត្តរូបនេះ ពួកគេបានចាក់ប្រេងលើក្បាលលោកដាវីឌ ដើម្បីបង្ហាញថាគាត់ត្រូវបានគេជ្រើសរើសឲ្យធ្វើជាស្តេច។
2 Samuel 2:8
លោកអប៊ីនើរ ... សម្តេចអ៊ីសបូសែត
ទាំងនេះគឺជាឈ្មោះរបស់បុរស។
ស្រុកម៉ាហាណាអ៊ីម ... ស្រុកកាឡាត ... ស្រុកយេសរាល
ទាំងនេះជាឈ្មោះទីកន្លែង។
2 Samuel 2:10
មានតែស្រុកយូដាប៉ុណ្ណោះដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្តេចដាវីឌ
ការស្តាប់បង្គាប់តាមការគ្រប់គ្រងរបស់ស្តេចដាវីឌ ត្រូវបាននិយាយអំពីការ «ការដើរតាម» ព្រះអង្គ។ ការបកប្រែផ្សេងទៀត «កុលសម្ព័ន្ធយូដាគោរពស្តេចដាវីឌជាស្តេចរបស់ពួកគេ»
មានតែស្រុកយូដា
នៅទីនេះ «ផ្ទះ» មានន័យថា «កុលសម្ព័ន្ធ» ។
2 Samuel 2:12
លោកអប៊ីនើរ ...លោកនើរ... សម្តេចអ៊ីសបូសែត...ព្រះបាទសូល ... លោកស្រីសេរូយ៉ា
ទាំងនេះជាឈ្មោះរបស់បុរស។
2 Samuel 2:16
ហើយក៏ដួលស្លាប់ទាំងអស់គ្នា
នេះគឺជារបៀបគួរសមក្នុងការនិយាយថា ពួកគេបានស្លាប់។ការបកប្រែផ្សេងទៀត «ពួកគេទាំងពីរបានសុគត»
ហេលកាត-ហាស៊ូរីម
នេះជាឈ្មោះដែលត្រូវបានគេផ្តល់ឲ្យ ដើម្បីរំលឹកប្រជាជននូវអ្វីដែលបានកើតឡើងនៅទីនោះ។
ការប្រយុទ្ធយ៉ាងសាហាវបានកើតឡើងនៅថ្ងៃនោះ
វាអាចមានប្រយោជន៍ក្នុងការបញ្ជាក់យ៉ាងច្បាស់ថា នេះគឺជាសមរភូមិដ៏ធំមួយ ដែលកើតឡើងបន្ទាប់ពីការប្រកួតរបស់យុវជន។ ការបកប្រែផ្សេងទៀត «បន្ទាប់មកអ្នកផ្សេងទៀតក៏ចាប់ផ្តើមប្រយុទ្ធដែរ»។
«វាជាសមរភូមិដ៏សាហាវនៅថ្ងៃនោះ»
2 Samuel 2:18
លោកស្រីសេរូយ៉ា ... លោកយ៉ូអាប់ ...លោកអប៊ីសាយ ... លោកអេសាអែល ...លោកអប៊ីនើរ
ទាំងនេះគឺជាឈ្មោះរបស់បុរស។
លោកេអសាហែល អាចរត់លឿនដូចជាប្រើសព្រៃ
នៅទីនេះអេសាហែល ត្រូវបានគេប្រៀបធៀបទៅនឹងសត្វប្រើស ដែលជាសត្វរត់យ៉ាងលឿន។ ការបកប្រែផ្សេងទៀត «លោកអេសាហែលអាចរត់បានយ៉ាងលឿន»
ប្រើសព្រៃ
សត្វមានជើងបួនតូចមួយ មានស្នែងវែងពីរនៅលើក្បាល វារត់លឿន។
យ៉ាងប្រកិតដោយមិនបានងាកឆ្វេង ឬស្តាំឡើយ។
នៅទីនេះ «ដោយមិនងាកចេញ» ត្រូវបានថ្លែងនៅក្នុងទម្រង់អវិជ្ជមាន ដើម្បីបញ្ជាក់ពីរបៀបដែលគាត់បានដើរយ៉ាងជិតស្និទ្ធទៅនឹងផ្លូវរបស់លោកអប៊ីនើរ។ ការបកប្រែផ្សេងទៀត «ដើរតាមគាត់គ្រប់ទីកន្លែងដែលគាត់បានទៅ»
2 Samuel 2:20
អសាអែល
នេះជាឈ្មោះនៃបុរស។
ចូរដេញតាមក្មេងណាម្នាក់ដែលនៅខាងស្តាំ ឬនៅខាងឆ្វេងអ្នក...
«ឈប់ដេញតាមខ្ញុំ ... ឈប់ដេញតាមលោកអប៊ីនើរ»
ហើយដោះយកគ្រឿងសាស្ត្រាវុធរបស់គេទៅ!
លោកអប៊ីនើរបានស្នើសុំអោយអេសាលសម្លាប់
និងប្រមូលជ័យភណ្ឌពីទាហានវ័យក្មេងម្នាក់ទៀត
ដែលនឹងមិនមានគ្រោះថ្នាក់ដូចអប៊ីនើរ។ គាត់មិនចង់សម្លាប់អេសាលទេ។
ការបកប្រែផ្សេងទៀត «ប្រយុទ្ធជាមួយទាហានម្នាក់ទៀត
ហើយយកសម្ភារៈរបស់គាត់ធ្វើជាជ័យភ័ណ្ឌ»
2 Samuel 2:22
តើចង់ឲ្យយើងវាយផ្តួលឯងទៅលើដីឬអី?
នេះគឺសំណួរដ៏ប៊ិុនប្រសប់មួយ ប្រើដើម្បីព្រមានលោកអេសាហែលអំពីគ្រោះថ្នាក់ដែលគាត់បានប្រឈមមុខ។ « ផ្តួលដល់ដី» គឺជារបៀបគួរសមក្នុងការនិយាយថា «សម្លាប់» ។ ការបកប្រែផ្សេងទៀត «ខ្ញុំមិនចង់សម្លាប់អ្នកទេ»
បើដូច្នេះ តើឲ្យយើងប្រឈមមុខនឹងលោកយ៉ូអាប់ជាបងប្រុសរបស់ឯងយ៉ាងដូចម្តេច?
នេះគឺជាសំណួរដ៏ប៊ិុនប្រសប់ ដែលសង្កត់ធ្ងន់ថាលោកអប៊ីនើរមិនចង់ប្រយុទ្ធ និងសម្លាប់លោកអេសាអែលទេ
ព្រោះវានឹងបំផ្លាញទំនាក់ទំនងរបស់លោកអប៊ីនើរជាមួយលោកយ៉ូអាប់។ នៅទីនេះ « ប្រឈមមុខនឹងលោកយ៉ូអាប់» គឺជាឃ្លាដែលមានន័យថា
គាត់អាម៉ាស់ខ្លាំងណាស់ដើម្បីមើលទៅឯលោកយ៉ូអាប់។ ការបកប្រែផ្សេងទៀត «ខ្ញុំអាម៉ាស់ខ្លាំងណាស់ដើម្បីមើលទៅឯបងប្រុសរបស់អ្នក គឺលោកយ៉ូអាប់»
ព្រមឈប់ដេញតាម
នេះមានន័យថា «ផ្អាក» ឬ «ឈប់ដេញតាម» ។
ចុងលំពែងរបស់លោក
នេះសំដៅទៅលើដងដែលមិនមុតស្រួច ឬច្នៃឡើងដើម្បីអ្វីផ្សេងទៀត។
វាអាចបញ្ជាក់ថា លោកអប៊ីនើរកំពុងតែព្យាយាមបញ្ឈប់អេសាល
មិនអោយដើរតាមគាត់តែប៉ុណ្ណោះ ហើយមិនមានបំណងសម្លាប់គាត់ទេ។
2 Samuel 2:24
លោកអប៊ីសាយ
នេះជាឈ្មោះនៃបុរស។
ជំរាលអាំម៉ា ...គីយ៉ា
ទាំងនេះជាឈ្មោះនៃទីកន្លែង. ន
2 Samuel 2:26
ស្រែកសួរ
«ស្រែកឡើង» ឬ «ស្រែកដាក់»
តើយើងត្រូវច្បាំងគ្នារហូតឬ?
នេះគឺសំណួរដ៏ប៊ិុនប្រសប់ ដែលផ្តោតទៅលើសមរភូមិបានបន្តជាយូរមកហើយ។
នៅទីនេះ «ដាវ» សំដៅទៅលើការប្រយុទ្ធគ្នា។ ការសម្លាប់នៅក្នុងសមរភូមិ
ត្រូវបានគេនិយាយដូចជាសត្វព្រៃកំពុងស៊ីទាហាន។ ការបកប្រែផ្សេងទៀត «យើងមិនចាំបាច់ដើម្បីរក្សាការប្រើដាវរបស់យើងដើម្បីប្រយុទ្ធនិងសម្លាប់គ្នាទេ» ។
តើលោកមិនដឹងថា ការនេះនឹងបញ្ចប់ទៅដោយជូរចត់ទេឬ?
នេះជាសំណួរដ៏ប៊ិុនប្រសប់គឺត្រូវបានប្រើដើម្បីបង្ខំឲ្យលោកយ៉ូអាប់ទទួលស្គាល់ថា
ការបន្តប្រយុទ្ធគ្នាជាលទ្ធផលមានការរងទុក្ខវេទនាថែមទៀត។ នៅទីនេះ "ជូរចត់" គឺជាពាក្យសម្រាប់ការរងទុក្ខដ៏គួរឲ្យភ័យខ្លាចដែលនឹងកើតឡើង។
ការបកប្រែផ្សេងទៀត
«អ្នកដឹងច្បាស់ថាវានឹងមានលទ្ធផលគួរឲ្យភ័យខ្លាចប្រសិនបើរឿងនេះនៅតែបន្ត!»
តើរហូតដល់ពេលណាទើបលោកប្រាប់ពលទាហានរបស់លោកឲ្យឈប់ដេញតាមបងប្អូនរបស់ពួកគេ?
នេះជាសំណួរដ៏ប៊ិនប្រសប់ គឺមានបំណងដើម្បីបញ្ចុះបញ្ចូលលោកយ៉ូអាប់
ឲ្យឈប់តាមធ្វើសង្គ្រាមជាមួយប្រជាជនអ៊ីស្រាអែលរបស់ពួកគេ។ នៅទីនេះ «បងប្រុស» ត្រូវបានប្រើដើម្បីតំណាងឲ្យសមាជិកនៃប្រជាជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ឥឡូវនេះបញ្ឈប់ការនេះ
ដូចច្នេះដើម្បីកុំអោយអ៊ីស្រាអែលសម្លាប់គ្នា!»
ខ្ញុំសូមស្បថក្នុងនាមព្រះអង្គដែលមានព្រះជន្មគង់នៅថា
នេះជាពាក្យស្បថរឹងមាំ។ ការបកប្រែផ្សេងទៀត
«ជាមួយព្រះជាម្ចាស់ជាសាក្សីរបស់ខ្ញុំ» ឬ «ព្រះជាម្ចាស់នឹងបញ្ជាក់ថា
ខ្ញុំយល់ន័យអ្វីដែលខ្ញុំនិយាយ»

generated on Wed Sep 10 16:16:32 2025

ប្រសិនបើ អ្នកមិនសូមយើងទេ ... ដេញតាមបងប្អូនរបស់ពួកគេរហូតដល់ព្រឹកមិនខាន!។
សម្មតិកម្មនេះ
ប្រាប់ពីអ្វីដែលអាចនឹងកើតឡើងប្រសិនបើអាអាន់ណើរមិនបាននិយាយជាមួយយ៉ូអាប់
2 Samuel 2:28
ផ្លុំត្រែឡើង
ត្រែត្រូវបានប្រើដើម្បីផ្តល់សញ្ញាដល់កងទ័ពនៅចម្ងាយឆ្ងាយ
ដេញតាមពួកទ័ពអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើបុរសដែលកំពុងប្រយុទ្ធដើម្បីអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «បន្តដេញតាមជនជាតិអ៊ីស្រាអែល»
អារ៉ាបា ... ម៉ាហាណាអ៊ីម
ទាំងនេះគឺជាឈ្មោះទីកន្លែង។
2 Samuel 2:30
លោកអសាអែល
នេះជាឈ្មោះនៃបុរស។
ដោយសម្លាប់ទាហាន
និងទាហានរបស់លោកអប៊ីនើរទាំងអស់បីរយហុកសិបនាក់
«បុរស ៣៦០នាក់មកពីបេនយ៉ាមីន ដែលបានដើរតាមលោកអប៊ីនើរ»។
លោកអប៊ីនើរមិនបានស្លាប់ទេ។
របស់លោកបេនយ៉ាមីន
ឃ្លានេះមានន័យថា «មកពីកុលសម្ព័ន្ធបេនយ៉ាមីន» ។
បានលើកសពរបស់លោកអេសាអែល
«បានដឹកសពរបស់លោកអេសាអែលទៅជាមួយពួកគេ»
រហូតដល់ពេលថ្ងៃរះពួកគេបានទៅដល់ហេប្រុន
«ពួកគេបានទៅដល់ហេប្រុននៅព្រឹកព្រលឹម»

---

3 [1]គ្រានោះ មានកើតសង្គ្រាមអស់រយៈពេលយ៉ាងយូររវាងរវាងរាជវង្សរបស់ព្រះបាទសូល និងរវាងរាជវង្សរបស់ព្រះបាទដាវីឌ។
រាជវង្សរបស់ព្រះបាទដាវីឌកាន់តែមានអំណាចឡើងខ្លាំង ហើយខ្លាំងឡើង ចំណែកឯ រាជវង្សរបស់ព្រះបាទសូលកាន់តែចុះខ្សោយទៅ ចុះខ្សោយទៅ។
[2]បុត្ររបស់ព្រះបាទដាវីឌជាច្រើនអង្គ បានប្រសូតនៅក្នុងហេប្រុន។ បុត្រច្បងរបស់ព្រះអង្គ ព្រះនាមអាំណូន ដែលបានប្រសូតពីព្រះនាងអ័ហីណោម
ជាអ្នកស្រុកយេសរាល។[3]បុត្រទីពីរ ព្រះនាម គីឡាប ដែលប្រសូតពីព្រះនាងអប៊ីកែល ជាភរិយារបស់លោកណាបាល អ្នកស្រុកកាមែល។ បុត្រទីបី ព្រះនាម អាប់សាឡុម
ប្រសូតពីព្រះនាងម៉ាកា ជាបុត្រីព្រះបាទតាលម៉ាយ អ្នកស្រុកហ្គេសួរ។
[4]បុត្រទីបួនរបស់ស្តេចដាវីឌ ព្រះនាមអដូនីយ៉ា ជាបុត្ររបស់ព្រះនាងហាគីត។ បុត្រទីប្រាំ ព្រះនាមសេផាធា ប្រសូតពីព្រះនាងអប៊ីតាល។[5]ហើយបុត្រទីប្រាំមួយ គឺយីតរ៉ាម
ប្រសូតពីព្រះនាងអេកឡា។ ទាំងនេះគឺជាបុត្ររបស់ស្តេចដាវីឌ ដែលបានប្រសូតនៅក្នុងហេប្រុន។
[6]នៅគ្រានោះការធ្វើសង្គ្រាមរវាងរាជវង្សរបស់ព្រះបាទសូល និង រាជវង្សរបស់ព្រះបាទដាវីឌ លោកអប៊ីនើរបានពង្រឹងអំណាចរបស់ខ្លួននៅក្នុងរាជវង្សរសស់ព្រះបាទសូល។
[7]ព្រះបាទសូលមានស្នំឯកម្នាក់ ឈ្មោះនាងរីសប៉ា ដែលជាកូនស្រីរបស់លោកអយ៉ា។ សម្តេចអ៊ីសបូសែត បានមានបន្ទូលទៅកាន់លោកអប៊ីនើរថា៖
«ហេតុអ្វីបានជាលោកដេកជាមួយស្នំឯកបិតារបស់យើងដូច្នេះ?»
[8]ពេលនោះ លោកអប៊ីនើរខឹងយ៉ាងខ្លាំងចំពោះសំនួររបស់សម្តេចអ៊ីសបូសែត រួចតបទៅវិញថា៖ «តើទូលបង្គំជាឆ្កែបម្រើរបស់ពួកយូដាឬក៏អី?
រហូតដល់សព្វថ្ងៃនេះទូលបង្គំបង្ហាញសេចក្តីស្មោះត្រង់ចំពោះញាតិវង្សរបស់ព្រះបាទសូលបិតារបស់ព្រះករុណា ចំពោះបងប្អូន និង មិត្តភក្ត្ររបស់ទ្រង់
ដោយមិនបញ្ជូនព្រះករុណាទៅក្នុងព្រះហស្តស្តេចដាវីឌ។ ប៉ុន្តែ ហេតុអ្វីឥឡូវព្រះករុណាបែរជាស្តីបន្ទោសទូលបង្គំព្រោះតែរឿងមនុស្សស្រីទៅវិញ?
[9]សូមព្រះអម្ចាស់ដាក់ទូលបង្គំ លោកអប៊ីនើរ យ៉ាងធ្ងន់ធ្ងរទៅចុះ ប្រសិនបើទូលបង្គំមិនប្រគល់រាជ្យទៅអោយព្រះបាទដាវីឌ
តាមព្រះបន្ទូលដែលព្រះជាម្ចាស់បានសន្យាទេនោះ[10]គឺព្រះអង្គបានសន្យាថា នឹងផ្ទេររាជ្យពីរាជវង្សរបស់ព្រះបាទសូល
ហើយតាំងបល្ល័ង្ករបស់ព្រះបាទដាវីឌឡើងឲ្យគ្រប់គ្រងលើអ៊ីស្រាអែលនិង យូដា គឺចាប់ពីក្រុងដាន់ រហូតដល់បៀសេបា»។[11]សម្តេចអ៊ីសបូសែត
មិនមានពាក្យអ្វីឆ្លើយតបនឹងពាក្យរបស់លោកអប៊ីនើរបានទេ ព្រោះលោកភ័យខ្លាចលោកអប៊ីនើរ។
[12]លោកអប៊ីនើរបានចាត់អ្នកនាំសារទៅឯព្រះបាទដាវីឌ ដើម្បីទូលព្រះអង្គថា៖ «តើស្រុកនេះជាកម្មសិទ្ធិរបស់អ្នកណា? ចូរចងសម្ពន្ធមិត្តជាមួយទូលបង្គំចុះ
ហើយចូលទតមើលចុះគឺទូលបង្គំប្រមូលជនជាតិអ៊ីស្រាអែលទាំងអស់ឲ្យមកនៅក្រោមការដឹកនាំរបស់ទ្រង់»។ [13]ព្រះបាទដាវីឌតបវិញថា៖ «បាន!
យើងយល់ព្រមចងសម្ពន្ធមេត្រីជាមួយលោក។ ប៉ុន្តែយើងមានរឿងមួយស្នើដល់លោក គឺលោកនឹងមិនបានឃើញមុខរបស់យើងទេ លុះត្រាតែលោកនាំព្រះនាងមិកាល់
ជាបុត្រីស្តេចសូល មកជាមួយនោះលោកនឹងបានជួបជាមួយយើង»។
[14]បន្ទាប់មក ព្រះបាទដាវីឌ បានចាត់អ្នកនាំសារទៅគាល់ព្រះបាទអ៊ីសបូសែត បុត្ររបស់ព្រះបាទសូលមានរាជឱង្ការថា៖ «សូមប្រគល់ព្រះនាងមិកាល់
ជាមហេសីរបស់ទូលបង្គំមកឲ្យទូលបង្គំវិញ គឺមហេសីដែលទូលបង្គំបានយកស្បែកអង្គជាតិពួកភីលីស្ទីន ចំនួនមួយរយមកជូនជាបណ្តាការ»។[15]ដូច្នេះ ព្រះបាទអ៊ីសបូសែត
ចាត់គេឲ្យទៅនាំព្រះនាងមិកាល់ ពីផ្ទះប្តីរបស់នាងមក គឺលោកប៉ាសធាស កូនរបស់លោកឡាអ៊ីស។[16]ប្តីរបស់នាងក៏ចេញទៅតាមពីក្រោយនាង ទាំងយំផង
រហូតដល់បាហ៊ូរីម។ បន្ទាប់មក លោកអប៊ីនើរមានប្រសាសន៍ទៅលោកថា៖ «ចូរត្រឡប់ទៅផ្ទះវិញទៅ!»។ គាត់ក៏ត្រឡប់ទៅវិញ។
[17]លោកអប៊ីនើរបានមានប្រសាសន៍ទៅកាន់ពួកចាស់ទុំរបស់អ៊ីស្រាអែលថា៖ «កាលពីមុនអ្នករាល់គ្នាព្យាយាមដើម្បីឲ្យបានព្រះបាទដាវីឌ ជាស្តេចគ្រងរាជ្យលើអ្នករាល់គ្នា។
[18]ឥឡូវនេះ ចូរនាំគ្នាធ្វើដូច្នេះចុះ! ដ្បិត ព្រះអម្ចាស់បានមានព្រះបន្ទូលអំពីព្រះបាទដាវីឌថា៖ «យើងនឹងសង្គ្រោះអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងពីដៃរបស់ពួកភីលីស្ទីន
និងពីដៃរបស់ខ្មាំងសត្រូវរបស់ពួកគេ តាមរយៈដាវីឌ ជាអ្នកបម្រើរបស់យើង»។
[19]លោកអប៊ីនើរក៏បានមានប្រសាសន៍ដោយផ្ទាល់ជាមួយពួកបេនយ៉ាមីនដែរ។ បន្ទាប់មក លោកអប៊ីនើរបានចូលទៅគាល់ព្រះបាទដាវីឌ នៅទីក្រុងហេប្រុន
និងបានទូលស្តេចឲ្យបានជ្រាបពីសេចក្តីសម្រេចទាំងឡាយរបស់ពួកអ៊ីស្រាអែល និងកុលសម្ព័ន្ធបេនយ៉ាមីន។[20]នៅពេលដែល លោកអប៊ីនើរ
និងទាហានទាំងម្ភៃនាក់របស់លោកមកដល់ទីក្រុងហេប្រុន ដើម្បីជួបព្រះបាទដាវីឌ នោះព្រះបាទដាវីឌបានរៀបចំពិធីជបលៀងសម្រាប់ពួកគេ។
[21]លោកអប៊ីនើរបានទូលព្រះបាទដាវីឌថា៖ «ទូលបង្គំនឹងចេញទៅប្រមូលជនជាតិអ៊ីស្រាអែលទាំងអស់ ឲ្យមកឯព្រះករុណាជាអម្ចាស់នៃទូលបង្គំ
ដូច្នេះពួកគេនឹងចងសម្ពន្ធមេត្រីជាមួយព្រះករុណា ឲ្យព្រះករុណាបានសោយរាជ្យលើគ្រប់ៗទាំងអស់»។
[22]ខណៈនោះ ពួកពលទាហានរបស់ព្រះបាទដាវីឌ និងលោកយ៉ូអាប់បានត្រឡប់មកពីលុកលុយស្រុកក្រៅវិញ ទាំងនាំយករបឹបមកជាមួយផង។ ប៉ុន្តែ ពេលនោះលោក
អប៊ីនើរមិនបានមកនៅជាព្រះបាទដាវីឌ នៅទីក្រុងហេប្រុនទេ។ ព្រះបាទដាវីឌបានបញ្ជូនគាត់ចេញទៅ ហើយលោកលោកអប៊ីនើរបានចេញទៅដោយសុខសាន្ត។
[23]នៅពេលដែលលោកយ៉ូអាប់ និងពួកពលទាហានរបស់លោកមកដល់ មានគេប្រាប់លោកថា៖ «លោកអប៊ីនើរ ជាកូនរបស់លោកនើរ បានមកជួបព្រះរាជា
ហើយព្រះរាជាបានឲ្យគេទៅ លោកអប៊ីនើរក៏ចេញទៅដោយសុខសាន្ត។
[24]ពេលដែលលោកមកដល់លោកបានទូលសួរព្រះបាទដាវីឌថា៖ «តើព្រះរាជាបានធ្វើអ្វី? ទតចុះ! លោកអប៊ីនើរបានមកគាល់ព្រះរាជា
តើហេតុអ្វីបានជាព្រះករុណាអនុញ្ញាតឲ្យគេទៅយ៉ាងស្រួលដូច្នេះ?[25]តើព្រះករុណា មិនជ្រាបទេឬ ថា លោកអប៊ីនើរជាកូនរបស់លោកនើរ
គេមកដើម្បីបោកបញ្ឆោតព្រះករុណា ហើយដើម្បីស៊ើបរកយុទ្ធសាស្ត្ររបស់ព្រះករុណា និងដើម្បីរៀនពីគ្រប់យ៉ាងដែលព្រះករុណាកំពុងធ្វើ?[26]បន្ទាប់ពី
លោកយ៉ូអាប់បានចាកចេញពីព្រះបាទដាវីឌទៅ លោកបានចាត់អ្នកនាំសារទៅតាមលោកអប៊ីនើរ ហើយពួកគេបាននាំលោកអប៊ីនើរត្រឡប់ពីអណ្តូងទឹកស៊ីរ៉ាវិញ ប៉ុន្តែ
ព្រះបាទដាវីឌ មិនបានជ្រាបពីរឿងនេះទេ។
[27]ពេលដែលលោកអប៊ីនើរត្រឡប់មកដល់ក្រុងហេប្រុនវិញ លោកយ៉ូអាប់បាននាំលោកទៅកាន់កណ្តាលច្រកទ្វារ ដើម្បីនិយាយការសម្ងាត់ជាមួយគាត់។
នៅទីនោះលោកយ៉ូអាប់បានចាក់លោកអប៊ីនើរ ត្រង់ពោះហើយលោកក៏ស្លាប់នៅទីនោះ។ លោកយ៉ូអាប់ធ្វើដូច្នេះដើម្បីសងសឹកឲ្យលោកអេសាអែល
ជាប្អូនប្រុសរបស់លោក។

generated on Wed Sep 10 16:16:32 2025

[28]ខណៈដែលព្រះបាទដាវីឌ បានឮដំណឹងនេះ ព្រះអង្គមានរាជឱង្ការថា៖ «យើងនឹងរាជាណាចក្ររបស់យើងគ្មានទោសនៅចំពោះព្រះភក្ត្រព្រះអម្ចាស់
ចំពោះឈាមរបស់លោកអប៊ីនើរ កូនរបស់លោកនើរឡើយ។[29]សូមឲ្យទោសនៃការសម្លាប់លោកអប៊ីនើរនេះ ធ្លាក់ទៅលើលោកយ៉ូអាប់
ហើយនិងញាតិសន្តានរបស់គេទៅចុះ។ សូមឲ្យក្នុុងគ្រួសាររបស់លោកយ៉ូអាប់តែងតែមានមនុស្សកើត ដំបៅងារ ជម្ងឺឃ្លង់ ឬមានមនុស្សពិការ
ហើយសូមឲ្យមានមនុស្សដែលស្លាប់ដោយមុខដាវ ឬស្លាប់ដោយអត់អាហារ»។[30]ដូច្នេះ លោកយ៉ូអាប់ និងលោកអប៊ីសាយ
ជាបងប្អូនប្រុសរបស់គាត់ដែលបានសម្លាប់លោកអប៊ីនើរ ព្រោះតែលោកអប៊ីនើរបានសម្លាប់លោកអេសាអែល ជាបងប្អូនរបស់គាត់នៅគីបៀន នៅក្នុងការប្រយុទ្ធគ្នា។
[31]ព្រះបាទដាវីឌ បានមានរាជឱង្ការទៅកាន់លោកយ៉ូអាប់ និងពួកពលទាហានដែលនៅជាមួយគាត់ថា៖ «ចូរហែកសម្លៀកបំពាក់របស់អ្នករាល់គ្នា រួចស្លៀកបាវជំនួសវិញ
ហើយត្រូវកាន់ទុកចំពោះសពរបស់អប៊ីនើរ»។ ស្តេចបានដើរពីក្រោយពិធីដង្ហែរសព។[32]ពួកគេបានបញ្ចុះសពរបស់លោកអប៊ីនើរនៅក្នុងហេប្រុន។
ព្រះរាជាទ្រង់ព្រះកន្សែងយ៉ាងខ្លាំងនៅផ្នូររបស់លោកអប៊ីនើរ ហើយប្រជាជនទាំងអស់ក៏បានយំសោកដែរ។
[33]ព្រះរាជាបានលើកទំនួញតួញតែរំលឹកពីលោកអប៊ីនើរដូចតទៅ៖ «លោកអប៊ីនើរអើយ
ហេតុអ្វីបានជាលោកស្លាប់ដូចជាមនុស្សលេលាដូច្នេះ[34]ដៃរបស់លោកគ្មានជាប់ចំណងសោះ។ ជើងរបស់លោកក៏មិនជាប់ច្រវាក់ដែរ។ តែលោកបានដួលស្លាប់
ដូចគេដួលស្លាប់នៅមុខជនទុច្ចរិត»។ ប្រជាជនទាំងអស់នាំគ្នាយំសោកស្តាយស្រណោះលោកអប៊ីនើរសារជាថ្មី។
[35]ប្រជាជនបានចូលមកឯព្រះបាទដាវីឌ ដើម្បីថ្វាយព្រះស្ងោយទាន់នៅភ្លឺ ប៉ុន្តែ ព្រះបាទដាវីឌបានស្បថថា៖ «សូមឲ្យព្រះអម្ចាស់ដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅចុះប្រសិនបើ
យើងបរិភោគនំប៉័ង ឬអ្វីក៏ដោយមុនពេលថ្ងៃលិច»។[36]ប្រជាជនបានកត់សម្គាល់ឃើញសេចក្តីសោកសៅរបស់ស្តេច ហើយពួកគេមានការពេញចិត្តណាស់
ដូចដែលពួកគេធ្លាប់ពេញចិត្តនឹងអ្វីដែលស្តេចបានធ្វើ។
[37]ដូច្នេះ ប្រជាជនទាំងអស់ ក៏ដូចជាពួកអ៊ីស្រាអែលបានដឹងថា ការសម្លាប់លោកអប៊ីនើរនៅថ្ងៃនោះ មិនមែនជាការសម្រេចចិត្តរបស់ព្រះរាជានោះទេ។
[38]ព្រះរាជាមានព្រះរាជឱង្ការទៅពួកអ្នកបម្រើរបស់ព្រះអង្គថា៖ «តើអ្នករាល់គ្នាមិនដឹងទេឬថា ថ្ងៃនេះវីរជនមួយរូប ដែលជាមេដឹកនាំដ៏សំខាន់
បានស្លាប់នៅក្នុងទឹកដីអ៊ីស្រាអែល?[39]ទោះបីជាខ្ញុំបានទទួលការចាក់ប្រេងតាំងពីព្រះជាម្ចាស់ក្តី ក៏ខ្ញុំនៅតែជាមនុស្សទន់ខ្សោយដែរ។ ចំណែកឯកូនៗរបស់លោកស្រីសេរូយ៉ា
គេជាមនុស្សឃោរឃៅជាងខ្ញុំ។ សូមឲ្យព្រះអម្ចាស់ ដាក់ទោសមនុស្សឃោរឃៅ ទៅតាមអំពើរឃោរឃៅរបស់គេទៅចុះ»។

---

2 Samuel 3:1

គ្រានោះ

នេះជាពាក្យត្រូវប្រើនៅទីនេះ

ដើម្បីសម្គាល់ការឈប់ផ្អាកនៅក្នុងសាច់រឿងសំខាន់ៗ។

នៅទីនេះសាំយូអែលផ្តល់ព័ត៌មាន

អំពីសង្គ្រាមរវាងព្រះបាទដាវីឌនិងអ្នកគាំទ្រព្រះបាទសូល។

រាជវង្ស

នៅទីនេះ "ផ្ទះ" គឺត្រូវបានប្រើហើយមានន័យថា "អ្នកគាំទ្រ" ។

កាន់តែមានអំណាចឡើងខ្លាំង ហើយខ្លាំងឡើង

ជាការប្រៀបធៀប

មានន័យថាចំនួនប្រជាជនដែលគាំទ្រព្រះបាទដាវីឌបានកើនឡើង។

កាន់តែចុះខ្សោយទៅ ចុះខ្សោយទៅ

នេះគឺការប្រៀបធៀប

មានន័យថាចំនួនប្រជាជនដែលគាំទ្រក្រុមគ្រួសាររបស់ព្រះបាទសូលបានថយចុះ។

2 Samuel 3:2

បុត្ររបស់ព្រះបាទដាវីឌជាច្រើនអង្គ បានប្រសូត

នេះអាចជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត

«ភរិយារបស់ព្រះបាទដាវីឌបានបង្កើតកូនប្រុស ៦ នាក់»

បុត្រច្បង ... បុត្រទីពីរ ... បុត្រទីបី

នេះគឺចំនួនលំដាប់លំដោយនៃបុត្រប្រុសរបស់ព្រះបាទដាវីឌ។

ព្រះនាមអាំណូន ... ព្រះនាងអប៊ីកែល ... ព្រះនាងម៉ាកា

ទាំងនេះគឺជាឈ្មោះរបស់ស្ត្រី។ ពួកគេជាភរិយារបស់ព្រះបាទដាវីឌ។

គីឡាប ... លោកណាបាល ... ព្រះបាទតាលម៉ាយ

ទាំងនេះគឺជាឈ្មោះរបស់បុរស។

2 Samuel 3:4

បុត្រទីបួន ... បុត្រទីប្រាំ ...ហើយបុត្រទីប្រាំមួយ

នេះគឺចំនួនលំដាប់លំដោយនៃបុត្រប្រុសរបស់ព្រះ

ព្រះនាមអដូនីយ៉ា ... ព្រះនាងហាគីត ...យីតរ៉ាម

ទាំងនេះជាចំនួនលំដាប់លំដោយ នៃបុត្រប្រុសរបស់ព្រះបាទដាវីត

ព្រះនាងហាគីត ...ព្រះនាងអប៊ីតាល ... ព្រះនាងអេកឡា

ទាំងនេះជាឈ្មោះមហេសីរបស់ព្រះបាទដាវីឌ

2 Samuel 3:6

នៅគ្រានោះ

នេះបង្ហាញពីព្រឹត្តិការណ៍ថ្មីនៅក្នុងរឿងរ៉ាវ

នៃការតស៊ូរវាងអ្នកគាំទ្ររបស់ព្រះបាទដាវីឌនិងក្រុមគ្រួសាររបស់ព្រះបាទសូល។

រាជវង្សរបស់ព្រះបាទសូល

នេះសំដៅទៅលើក្រុមគ្រួសារ និងអ្នកគាំទ្ររបស់ព្រះបាទសូល

ដែលបានកាន់កាប់ទ្រព្យសម្បត្តិរបស់ទ្រង់ បន្ទាប់ពីព្រះអង្គសុគត។

រាជវង្សរបស់ព្រះបាទដាវីឌ

សំដៅទៅលើអ្នកគាំទ្ររបស់ព្រះបាទដាវីឌ។

លោកអប៊ីនើរបានពង្រឹងអំណាចរបស់ខ្លួននៅក្នុងរាជវង្សរបស់ព្រះបាទសូល

លោកអប៊ីនើរចាប់ផ្តើមពង្រីកអំណាចរបស់ខ្លួនលើ ក្រុមគ្រួសារព្រះបាទសូល

គេនិយាយថាគាត់មានភាពរឹងមាំផ្នែកខាងរាងកាយ។ ការបកប្រែផ្សេងទៀត

«លោកអប៊ីនើរបានទទួលអំណាចច្រើន លើក្រុមគ្រួសារនិងអ្នកគាំទ្រព្រះបាទសូល»

នាងរីសប៉ា ... លោកអយ៉ា

ទាំងនេះជាឈ្មោះរបស់ស្ត្រី។

សម្តេចអ៊ីសបូសែត

នេះជាឈ្មោះកូនប្រុស បុត្ររបស់ព្រះបាទសូល

ហេតុអ្វីបានជាលោកដេកជាមួយស្នំឯកបិតារបស់យើងដូច្នេះ?

សម្តេចអ៊ីសបូសែត បានសួរសំណួរនេះដើម្បីបន្ទោសលោកអប៊ីនើរ

ដែលបានកំពុងធ្វើដូចព្រះអង្គជាស្តេច។ ការបកប្រែផ្សេងទៀត

«អ្នកមិនមានសិទ្ធិដេកជាមួយស្រីស្នំរបស់បិតាយើងទេ!»

លោកដេកជាមួយ

នេះជាការប្រើពាក្យជំនួសការទំនាក់ទំនងផ្លូវភេទ។

2 Samuel 3:8

តើទូលបង្គំជាឆ្កែបម្រើរបស់ពួកយូដាឬក៏អី?

នេះជាសំណួរត្រូវបានប្រើដោយលោកអប៊ីនើរ ជាការបដិសេធដោយកំហឹង

ចំពោះការចោទប្រកាន់របស់សម្តេចអ៊ីសបូសែត។

វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត«

ខ្ញុំមិនមែនជាជនក្បត់ដែលធ្វើការសម្រាប់ព្រះបាទដាវីឌទេ!»

តើទូលបង្គំជាឆ្កែបម្រើរបស់ពួកយូដាឬក៏អី?

លោកអប៊ីនើនិយាយអំពីខ្លួនគាត់ថា

ជាក្បាលឆ្កែដែលប្រជាជាតិអ៊ីស្រាអែលចាត់ទុកថា

ស្មោះត្រង់នឹងអ្នកណាដែលចិញ្ចឹមពួកគេ។ ត្រង់នេះ «ជារបស់កុលសម្ព័ន្ធយូដា»

បញ្ជាក់ថាភាពស្មោះត្រង់របស់លោកអប៊ីនើរ

ចំពោះប្រទេសយូដាដែលជាកម្មសិទ្ធរបស់ព្រះបាទដាវីឌ

ហើយមិនមែនជារបស់រាជវង្សព្រះបាទសូលទេ។ ការបកប្រែផ្សេងទៀត

«តើខ្ញុំជាជនក្បត់សម្រាប់យូដាទេ»? ឬ

«ខ្ញុំមិនមែនជាជនក្បត់ដែលបម្រើអោយព្រះបាទដាវីឌទេ»!

បញ្ជូនព្រះករុណាទៅក្នុងព្រះហស្តស្តេចដាវីឌ

នៅទីនេះ «ដៃ» គឺតំណាងឲ្យអំណាចចំពោះជ័យជំនះ។ ការបកប្រែផ្សេងទៀត

«ត្រូវបានបរាជ័យដោយសារព្រះបាទដាវីឌ»

ប៉ុន្តែ ហេតុអ្វីឥឡូវព្រះករុណាបែរជាស្តីបន្ទោសទូលបង្គំព្រោះតែរឿងមនុស្សស្រីទៅវិញ?

លោកអប៊ីនើសួរសំណួរនេះ ដើម្បីស្តីបន្ទោសសម្តេចអ៊ីសបូសែត ។

វាមិនច្បាស់ទេប្រសិនលោកអប៊ីនើពិតជាបានដេកជាមួយនាងរីសប៉ាប្រាកដមែន

ឬប្រសិនបើគាត់ត្រូវបានគេចោទប្រកាន់ដោយ បង្កាច់បង្ខូចវិញ។ អាចមានន័យថា

១) លោកអប៊ីនើមានទោស។ ការបកប្រែផ្សេងទៀត

«អ្នកមិនគួរតូចចិត្តដែលខ្ញុំបានដេកជាមួយនារីម្នាក់នេះទេ!» ២) លោក

generated on Wed Sep 10 16:16:32 2025

អប៊ីនើមិនមានកំហុសទេ។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរគិតថាខ្ញុំបានដេកជាមួយស្ត្រីនេះទេ!»
2 Samuel 3:9
សូមព្រះអម្ចាស់ដាក់ទូលបង្គំ ... យ៉ាងធ្ងន់ធ្ងរទៅចុះ ប្រសិនបើទូលបង្គំមិនប្រគល់រាជ្យ
នេះជាទម្រង់នៃពាក្យសច្ចាដ៏មាំនៅក្នុងគ្រានោះ។
លោកអប៊ីនើរកំពុងស្នើសុំព្រះជាម្ចាស់ ឲ្យវិនិច្ឆ័យគាត់យ៉ាងខ្លាំង
ប្រសិនបើគាត់មិនគោរពពាក្យសច្ចារបស់គាត់។
ភាសារបស់អ្នកអាចមានរបៀបនៃការសច្ចា។ ការបកប្រែផ្សេងទៀត
«ខ្ញុំកំពុងស្នើសុំព្រះជាម្ចាស់ដាក់ទណ្ឌកម្មចំពោះខ្ញុំប្រសិនបើខ្ញុំមិនធ្វើតាម» ។
រាជវង្សរបស់ព្រះបាទសូល
នៅទីនេះ«ផ្ទះ» សំដៅទៅលើក្រុមគ្រួសារ និងអ្នកគាំទ្ររបស់ព្រះបាទសូល
ដែលបាននៅរស់ក្រោយពីការសុគតរបស់ព្រះបាទសូល។ ការបកប្រែផ្សេងទៀត
«ក្រុមគ្រួសារនិងអ្នកគាំទ្ររបស់ព្រះបាទសូល» ។
បល្ល័ង្ករបស់ព្រះបាទដាវីឌ
ឃ្លានេះសំដៅទៅលើសិទ្ធអំណាចរបស់ព្រះបាទដាវីឌជាស្តេច។
2 Samuel 3:12
ទៅឯព្រះបាទដាវីឌ
ការបកប្រែខ្លះបន្ថែមថា «នៅពេលគាត់នៅហេប្រុន»
និងការបកប្រែផ្សេងទៀតលុបចោល។ អ្នកប្រហែលជាចង់បន្ថែមឃ្លា
ប្រសិនបើវាមាននៅក្នុងការបកប្រែភាសាជាតិរបស់អ្នក។
តើស្រុកនេះជាកម្មសិទ្ធិរបស់អ្នកណា?
អត្ថបទដើមនៃសំណួរនេះមិនច្បាស់ទេ។ អាចមានន័យថា ១)
លោកអប៊ីនើរមានអំណាចប្រគល់ទឹកដីដល់ព្រះបាទដាវីឌ។ ការបកប្រែផ្សេងទៀត
«ដីនេះជារបស់ខ្ញុំ!» ឬ ២) ព្រះបាទដាវីឌត្រូវបានជ្រើសរើសដោយព្រះជាម្ចាស់
ឲ្យគ្រប់គ្រងទឹកដីនេះ។ ការបកប្រែផ្សេងទៀត«
ដីនេះជាកម្មសិទ្ធិរបស់អ្នកស្របច្បាប់»។
ឲ្យមកនៅក្រោមការដឹកនាំរបស់ទ្រង់
នៅទីនេះ«ដៃ»តំណាងអោយជំនួយរបស់លោកអប៊ីនើរដែលគាត់កំពុងតែផ្តល់ជូនដល់ព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត: «ខ្ញុំនឹងជួយអ្នក»
លោកនឹងមិនបានឃើញមុខរបស់យើងទេ លុះត្រាតែលោកនាំព្រះនាងមិកាល់
ព្រះបាទដាវីឌកំពុងថ្លែងអំពីលក្ខខណ្ឌ ដែលគាត់នឹងជួបលោកអប៊ីនើ។ នៅទីនេះ
«មុខ» សំដៅទៅលើព្រះបាទដាវីឌផ្ទាល់។ ការបកប្រែផ្សេងទៀត
«អ្នកមិនអាចជួបខ្ញុំបានទេលើកលែងតែ អ្នកនាំព្រះនាងមិកាល់មកឲ្យខ្ញុំជាមុន»
ព្រះនាងមិកាល់
នេះគឺជាឈ្មោះបុត្រីរបស់ព្រះបាទសូល។ នាងជាមហេសី ទី១ របស់ព្រះបាទដាវីឌ។
2 Samuel 3:14
បានយកស្បែកអង្គជាតពួកភីលីស្ទីន ចំនួនមួយរយមកជូនជាបណ្ដាការ
នេះតំណាងចំនួនបុរសដែលព្រះបាទដាវីឌបានសម្លាប់ដូច្នេះព្រះបាទសូល
នឹងអនុញ្ញាតឲ្យទ្រង់រៀបអភិសេកជាមួយព្រះនាងមិកាល់។
«ស្បែកគ្របក្បាលលិង្គ» គឺជាផ្នត់នៃស្បែកដែលគ្របលើសរីរាង្គបន្តពូជរបស់បុរស។
ចាត់គេឲ្យទៅនាំព្រះនាងមិកាល់ ពីផ្ទះប្តីរបស់នាងមក
លោកប៉ាសធាសគឺជាព្រះស្វាមីទី ២ របស់ ព្រះនាងមិកាល់។
ព្រះបាទសូលប្រគល់នាងអោយគាត់បន្ទាប់ពីព្រះបាទដាវីឌរត់គេចពីព្រះបាទសូល។
លោកប៉ាសធាស ...លោកឡាអ៊ីស
ទាំងនេះជាឈ្មោះរបស់បុរស។
បាហ៊ូរីម
នេះជាឈ្មោះនៃភូមិមួយ ។
2 Samuel 3:17
ឥឡូវនេះ
ដូចច្នេះឥឡូវនេះ សូមឲ្យព្រះបាទដាវីឌធ្វើជាស្តេចរបស់អ្នកចុះ។
តាមរយៈដាវីឌ ជាអ្នកបម្រើរបស់យើង
នៅទីនេះ« ដៃ»
សំដៅទៅលើអំណាចរបស់ព្រះបាទដាវីឌដើម្បីយកឈ្នះពួកភីលីស្ទីន។
ការបកប្រែផ្សេងទៀត «
ខ្ញុំនឹងផ្តល់អំណាចដល់ព្រះបាទដាវីឌជាអ្នកបម្រើរបស់យើងហើយនិង»
ពីដៃរបស់ពួកភីលីស្ទីន
នៅទីនេះ« ដៃ»សំដៅទៅលើអំណាចលើអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«អំណាចរបស់ពួកភីលីស្ទីន»
ពីដៃរបស់ខ្មាំងសត្រូវរបស់ពួកគេ
នៅទីនេះ«ដៃ» សំដៅទៅលើអំណាចលើអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«អំណាចនៃសត្រូវទាំងអស់របស់ពួកគេ»
2 Samuel 3:19
ពួកបេនយ៉ាមីន ...កុលសម្ព័ន្ធបេនយ៉ាមីន
សេចក្តីថ្លែងទាំងពីរនេះ សំដៅទៅលើកូនចៅរបស់បេនយ៉ាមីន
ដែលជាកុលសម្ព័ន្ធមួយនៃកុលសម្ព័ន្ធអ៊ីស្រាអែល។
ទាហានទាំងម្ភៃនាក់
ចំនួនទាហានដែលបានមកជាមួយលោកអប៊ីនើរ។
2 Samuel 3:21
ជនជាតិអ៊ីស្រាអែលទាំងអស់
ឃ្លានេះមានន័យថា « ប្រជាជាតិនៃប្រជាជនអ៊ីស្រាអែលទាំងអស់» ។
ទូលបង្គំនឹងចេញទៅ
ពួកគេបែកគ្នាជាមិត្តភក្តិ។ ព្រះបាទដាវីឌមិនខឹងនឹងលោកអប៊ីនើរទេ។
2 Samuel 3:22
របឹប
ទាំងនេះគឺជារបស់របរដែលយកចេញពីសត្រូវ។
លោកអប៊ីនើរមិនបានមកនៅជាមួយព្រះបាទដាវីឌ
លោកអប៊ីនើរបានចាកចេញត្រឡប់ទៅផ្ទះវិញហើយ។
មានគេប្រាប់លោកថា
«មាននរណាម្នាក់បានមកប្រាប់លោកយ៉ូអាប់»
លោកនើរ
នេះជាឈ្មោះរបស់បុរស។ គាត់ជាជីតារបស់ព្រះបាទសូល។
2 Samuel 3:24
តើព្រះរាជាបានធ្វើអ្វី?
លោកយ៉ូអាប់សួរសំណួរនេះ ដើម្បីស្តីបន្ទោសព្រះបាទដាវីឌ
ចំពោះការអនុញ្ញាតអោយលោកអប៊ីនើរចេញទៅសន្តិភាព។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរធ្វើបែបនេះទេ!»
ព្រះបាទដាវីឌ
តើព្រះករុណាអនុញ្ញាតឲ្យគេទៅយ៉ាងស្រួលដូច្នេះ?
លោកយ៉ូអាប់សួរសំនួរនេះ
ដើម្បីស្តីបន្ទោសព្រះបាទដាវីឌចំពោះការអនុញ្ញាតអោយលោកអប៊ីនើររត់គេចខ្លួន។
នេះត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «លោកអប៊ីនើ
បាននៅទីនេះហើយព្រះអង្គអនុញ្ញាតឲ្យគាត់ចាកចេញ!»
តើព្រះករុណា មិនជ្រាបទេឬ ... ពីគ្រប់យ៉ាងដែលព្រះករុណាកំពុងធ្វើ?
លោកយ៉ូអាប់សួរសំណួរនេះ ដើម្បីបញ្ចុះបញ្ចូលព្រះបាទដាវីឌ
ថាលោកអប៊ីនើរកំពុងរៀបចំផែនការប្រឆាំងនឹងព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «ប្រាកដណាស់អ្នកដឹងទេ ... អ្វីគ្រប់យ៉ាងដែលអ្នកកំពុងធ្វើ»
។
អណ្តូងទឹកស៊ីរ៉ា
«ស៊ីរ៉ា» គឺជាឈ្មោះទីកន្លែងដែលមានទីតាំងជាអណ្តូងទឹក។
2 Samuel 3:27
ទៅកាន់កណ្តាលច្រកទ្វារ
នេះសំដៅទៅលើច្រកទ្វារមួយនៅក្នុងជញ្ជាំងទីក្រុងនៅហេប្រុន។
ដូចដែលយូឌីប៊ីបញ្ជាក់ថា ខ្លោងទ្វារទីក្រុងត្រូវបានសាងសង់
ជាផ្នែកមួយនៃអគារដែលបានដាក់ចូលជញ្ជាំងទីក្រុង។
នៅផ្លូវក្នុងច្រកចេញចូលមានទ្វារដែលនាំទៅបន្ទប់ចំហៀង
ដែលភ្ញៀវអាចទទួលបាន ជាកន្លែងដែលអ្នកជំនួញនិងតុលាការដំណើរការនីតិវិធី។
ប្រហែលជានៅក្នុងបន្ទប់មួយក្នុងចំណោមបន្ទប់ទាំងនេះដែលលោកយ៉ូអាប់បានធ្វើឃាតលោកអប៊ីនើរ។
សងសឹកឲ្យលោកអេសាអែល ជាប្អូនប្រុសរបស់លោក
នៅទីនេះ «ឈាម» ត្រូវបានភ្ជាប់ជាមួយនឹងការស្លាប់របស់លោកអេសាអែល ។
ការបកប្រែផ្សេងទៀត «មរណភាពរបស់ លោកអេសាអែល»
លោកអេសាអែល
នេះគឺជាឈ្មោះនៃបុរស។
2 Samuel 3:28
លោកនើរ ... លោកអប៊ីសាយ ... លោកអេសាអែល
ទាំងនេះជាឈ្មោះរបស់បុរស។
ចំពោះឈាមរបស់លោកអប៊ីនើរ
នៅទីនេះ « ឈាម» សំដៅទៅលើសេចក្តីស្លាប់របស់លោកអប៊ីនើរ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៣:២៧ ។
ការបកប្រែផ្សេងទៀត «សេចក្តីស្លាប់របស់លោកអប៊ីនើរ» ឬ

generated on Wed Sep 10 16:16:32 2025

«ឃាតកម្មរបស់លោកអប៊ីនើរ»
ធ្លាក់ទៅលើលោកយ៉ូអាប់ ហើយនិងញាតិសន្តានរបស់គេទៅចុះ។
ឃ្លានេះមានន័យថា លទ្ធផលនៃកំហុសនឹងកើតឡើងចំពោះលោកយ៉ូអាប់
និងគ្រួសាររបស់គាត់ ដូចជាមានអ្វីមួយធ្ងន់បានដួលរលំមកលើពួកគេ។
ការបកប្រែផ្សេងទៀត
«តែងតែធ្វើទុក្ខជាច្ចិដល់លោកយ៉ូអាប់និងគ្រួសារទាំងអស់របស់ឪពុកគាត់»
ញាតិសន្តានរបស់គេ
នៅទីនេះ «ផ្ទះ» សំដៅទៅលើកូនចៅ។ ការបកប្រែផ្សេងទៀត
«កូនចៅទាំងអស់របស់ឪពុកលោកយ៉ូអាប់»
សូមឲ្យក្នុុងគ្រួសាររបស់លោកយ៉ូអាប់តែងតែមាន
នេះផ្តោតទៅលើភាពអវិជ្ជមានទ្វេដង
ថានឹងមាននរណាម្នាក់ដែលមានបញ្ហាបានកត់ត្រាក្នុងបញ្ជី។ ការបកប្រែផ្សេងទៀត
«សូមឲ្យមានជានិច្ច»
ដែលស្លាប់ដោយមុខដាវ
នៅទីនេះ « ដាវ» សំដៅទៅលើការស្លាប់ដោយអំពើហឹង្សា។ ការបកប្រែផ្សេងទៀត
«ស្លាប់យ៉ាងសាហាវ»
ស្លាប់ដោយអត់អាហារ
« ឃ្លាន »
2 Samuel 3:31
ចូរហែកសម្លៀកបំពាក់របស់អ្នករាល់គ្នា រួចស្លៀកបាវជំនួសវិញ
ទាំងនេះជាសកម្មភាពនៃនិមិត្តរូប
ដើម្បីបង្ហាញពីទុក្ខសោកនិងភាពក្រៀមក្រំរបស់ពួកគេ។
ព្រះរាជាទ្រង់ព្រះកន្សែងយ៉ាងខ្លាំង
ពាក្យ «ព្រះកន្សែង» និង «ស្រែកខ្លាំងៗ
»មានន័យដូចគ្នានិងផ្តោតទៅលើរបៀបដែលព្រះបាទដាវីឌបានកាន់ទុក្ខលោកអប៊ីនើរ។គឺជាពាក្យដែលមានន័យថា «បានស្លាប់»។ អាចបកប្រែជាសេចក្តីថ្លែងការណ៍។
2 Samuel 3:33
លោកអប៊ីនើរអើយ ហេតុអ្វីបានជាលោកស្លាប់ដូចជាមនុស្សលេលាដូច្នេះ
នេះជាសំណួរដ៏ប៉ិនប្រសប់ ត្រូវបានប្រើដើម្បីបញ្ជាក់ថា
ការស្លាប់របស់គាត់គឺមិនយុត្តិធម៌ទេ។ ការបកប្រែផ្សេងទៀត
«លោកអប៊ីនើរមិនគួរស្លាប់ដោយភាពអាម៉ាស់ទេ!»
ដៃរបស់លោកគ្មានជាប់ចំណងសោះ។ ជើងរបស់លោកក៏មិនជាប់ច្រវាក់ដែរ
ប្រយោគទាំងពីរនេះបង្ហាញពីគំនិតស្រដៀងគ្នា។
ពួកវាត្រូវបានរួមបញ្ចូលគ្នាជាប្រយោគមួយ។ ការបកប្រែផ្សេងទៀត
«អ្នកមិនមែនជាឧក្រិដ្ឋជននៅក្នុងគុក» ឬ
«អ្នកគ្មានកំហុសពីការធ្វើខុសទាំងស្រុងទេ»
ដៃរបស់លោកគ្មានជាប់ចំណងសោះ
ត្រូវបានថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់បានចងដៃអ្នកទេ» (សូមមើល)
ជើងរបស់លោកក៏មិនជាប់ច្រវាក់ដែរ
ត្រូវបានថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
"គ្មាននរណាម្នាក់បានភ្ជាប់ជើងរបស់អ្នកទៅនឹងច្រវាក់ទេ"
ដួលស្លាប់នៅមុខជនទុច្ចរិត
នេះសំដៅទៅលើមនុស្សដែលទុច្ចរិត ឬមនុស្សអាក្រក់។ ការបកប្រែផ្សេងទៀត
«មនុស្សអាក្រក់»
2 Samuel 3:35
ប្រជាជនបានចូលមក
នេះគឺការនិយាយបំផ្លើសដោយចេតនា គឺត្រូវបានប្រើដើម្បីបង្ហាញថា
ប្រជាជាតិអ៊ីស្រាអែលចង់មើលថែរក្សាព្រះបាទដាវីឌ នៅក្នុងទុក្ខព្រួយរបស់ទ្រង់។
ការបកប្រែផ្សេងទៀត «មនុស្សជាច្រើនបានមក»
សូមឲ្យព្រះអម្ចាស់ដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅចុះប្រសិនបើ
នេះជាទម្រង់ពាក្យសច្ចាដ៏ខ្លាំងនៅក្នុងគ្រានោះ។
ព្រះបាទដាវីឌកំពុងសុំព្រះជាម្ចាស់វិនិច្ឆ័យទ្រង់ច្រើនដងប្រសិនបើព្រះអង្គបរិភោគអ្វីមុនពេលថ្ងៃលិច។
ភាសារបស់អ្នកមានរបៀបជាច្រើនដើម្បីបង្ហាញការស្បថ។ ការបកប្រែផ្សេងទៀត
«ខ្ញុំកំពុងស្នើសុំឲ្យព្រះដាក់ទណ្ឌកម្មខ្ញុំប្រសិនបើ» ។
2 Samuel 3:37
តើអ្នករាល់គ្នាមិនដឹងទេឬថា ថ្ងៃនេះវីរជនមួយរូប ដែលជាមេដឹកនាំដ៏សំខាន់
បានស្លាប់នៅក្នុងទឹកដីអ៊ីស្រាអែល?
នេះជាសំណួរដ៏ប៉ិនប្រសប់មួយ ដើម្បីបង្ហាញថា
តើព្រះបាទដាវីឌគោរពលោកអប៊ីនើរប៉ុណ្ណា? នៅទីនេះ «ធ្លាក់ចុះ»
ការបកប្រែផ្សេងទៀត «វាជាការពិតដែលថា
មេដឹកនាំដ៏អស្ចារ្យម្នាក់បានស្លាប់នៅថ្ងៃនេះនៅអ៊ីស្រាអែល!»
វីរជនមួយរូប ដែលជាមេដឹកនាំដ៏សំខាន់
ឃ្លាទាំងពីរនេះសំដៅទៅលើអប៊ីនើរ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គម្ចាស់ដ៏អស្ចារ្យ»
លោកអប៊ីនើរ ... លោកស្រីសេរូយ៉ា
ទាំងនេះជាឈ្មោះរបស់បុរស។
មនុស្សឃោរឃៅ
«គ្មានក្តីមេត្តាករុណា»

---

4 [1]ពេលដែលព្រះបាទអ៊ីសបូសែត បុត្រព្រះបាទសូល បានឮដំណឹងថាលោកអប៊ីនើរស្លាប់នៅក្នុងក្រុងហេប្រុន ព្រះអង្គក៏បាក់ទឹកចិត្ត ចំណែក
ប្រជាជនអ៊ីស្រាអែលទាំងអស់ក៏រន្ធត់ចិត្តយ៉ាងខ្លាំងដែរ។[2]ព្រះបាទអ៊ីសបូសែតមានមេទ័ពពីរនាក់។ ម្នាក់ឈ្មោះ លោកបាណា និងម្នាក់ទៀតឈ្មោះ លោករីកាប
អ្នកទាំងពីរជាកូនរបស់លោករីមម៉ូន ជាអ្នកស្រុកបៀតរ៉ុត ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន(បៀតរ៉ុតក៏ជាផ្នែកមួយកុលសម្ព័ន្ធបេនយ៉ាមីនដែរ)[3]ប្រជាជនដែលរស់នៅទីនោះពីមុន
បាននាំគ្នាភៀសខ្លួនទៅគីថែម ហើយរស់នៅទីនោះរហូតដល់សព្វថ្ងៃ)។
[4]សម្តេចយ៉ូណាថាន់ ជាបុត្ររបស់ព្រះបាទសូល មានកូនប្រុសម្នាក់ដែលពិការជើង។ ទ្រង់មានព្រះជន្មប្រាំព្រះវស្សា
នៅពេលទ្រង់បានឮដំណឹងនៃការចូលទិវង្គតរបស់ព្រះបាទសូល និងសម្តេចយ៉ូណាថាន់ពីយេសរាល។ មេដោះរបស់ព្រះអង្គបានលើកទ្រង់ឡើង ហើយរត់
ប៉ុន្តែពេលដែលនាងរត់នោះ កូនប្រុសរបស់សម្តេចយ៉ូណាថាន់ បានធ្លាក់ ជាហេតុធ្វើឲ្យទ្រង់ពិការ។ ឈ្មោះរបស់គាត់គឺ មេភីបូសែត។
[5]ដូច្នេះ កូនៗរបស់លោករីមម៉ូន ជាអ្នកស្រុកបៀតរ៉ុត គឺលោករេកាប និងលោកបាណា បានចូលទៅក្នុងព្រះដំណាក់របស់សម្តេចអ៊ីសបូសែត នៅពេលថ្ងៃត្រង់
ពេលដែលទ្រង់កំពុងផ្ទំ។[6]ស្ត្រីអ្នកយាមទ្វារបានដេកលក់ក្នុងកំឡុងពេលដែលបូតស្រូវ ពេលនោះជាឱកាសលោករេកាប និងលោកបាណា
បានដើរកាត់នាងយ៉ាងស្ងប់ស្ងាត់។[7]បន្ទាប់ពី ពួកគេបានចូលទៅក្នុងដំណាក់ ពួកគេបានវាយប្រហារទ្រង់ ហើយសម្លាប់ទ្រង់
ក្នុងពេលដែលទ្រង់ផ្ទំលើគ្រែក្នុងបន្ទប់របស់ទ្រង់។ បន្ទាប់មកពួកគេបានកាត់ព្រះសិរសាទ្រង់ ហើយកាន់យកចេញទៅ
ពួកគេធ្វើដំណើរពេញមួយយប់តាមផ្លូវទៅកាន់អារ៉ាបា។
[8]ពួកគេបាននាំយកព្រះសិរសាព្រះបាទអ៊ីសបូសែត ទៅថ្វាយព្រះបាទដាវីឌ នៅក្រុងហេប្រុន ហើយពួកគេទូលព្រះរាជាថា៖ «សូមព្រះករុណាទតចុះ!
នេះគឺជាព្រះកេសរបស់អ៊ីសបូសែត បុត្ររបស់ព្រះបាទសូល សត្រូវរបស់ទ្រង់ ដែលតែងតែប៉ុនប៉ងយកជីវិតរបស់ទ្រង់។ ថ្ងៃនេះ ព្រះអម្ចាស់បានសងសឹកចំពោះស្តេចសូល
និងរាជវង្សរបស់ស្តេច ថ្វាយព្រះករុណាជាម្ចាស់នៃយើង»។[9]ព្រះបាទដាវីឌ តបទៅកាន់លោករេកាប និងលោកបាណា ជាកូនៗរបស់រីមម៉ូន ជាអ្នកស្រុកបៀតរ៉ូតថា៖
«យើងសូមស្បថក្នុងនាមព្រះអម្ចាស់ ដែលបាននាំយើងចេញពីគ្រប់ទាំងបញ្ហា[10]នៅពេលដែលមនុស្សម្នាក់នាំដំណឹងមកប្រាប់យើងថា៖ «ទតចុះ! សូល
បានចូលទិវង្គតហើយ គេគិតថា គេបាននាំយកដំណឹងល្អមកប្រាប់យើងហើយ ប៉ុន្តែ យើងបានចាប់គេ ហើយសម្លាប់គេនៅស៊ីគឡាក់។
[11]តើគួរនឹងត្រូវតបស្នងប៉ុន្មាន នៅពេលដែលនរណាម្នាក់បានសម្លាប់មនុស្សដែលគេដេកលើគ្រែក្នុងផ្ទះរបស់គេ
តើយើងគួរទាមទារឈាមរបស់គេពីដៃរបស់លោកហើយសម្លាប់លោកឬទេ?»[12]បន្ទាប់មក ព្រះបាទដាវីឌ បានបញ្ជាឲ្យពួកទាហាន ហើយពួកគេក៏បានយកលោករេកាប
និងលោកបាណាទៅសម្លាប់ ហើយក៏បានកាត់ដៃ និងជើងរបស់ពួកគេ ទាំងយកទៅចងព្យួរនៅក្បែរបឹងហេប្រុន។ រីឯព្រះសិរសារបស់ព្រះបាទអ៊ីសបូសែតវិញ
ពួកគេបានយកទៅបញ្ចុះនៅក្នុងផ្នូររបស់លោកអប៊ីនើរ ក្នុងក្រុងហេប្រុន។

---

generated on Wed Sep 10 16:16:32 2025

2 Samuel 4:1
ព្រះបាទអ៊ីសបូសែត ...លោកបាណា ... លោករីកាប ... លោករីមម៉ូន
ទាំងនេះជាឈ្មោះនៃមនុស្សប្រុស។
ព្រះអង្គក៏បាក់ទឹកចិត្ត
នៅក្នុងឃ្លានេះ « ដៃរបស់គាត់» តំណាងឲ្យព្រះបាទអ៊ីសបូសែត។
ការបកប្រែផ្សេងទៀត «ព្រះបាទអ៊ីសបូសែតបានចុះខ្សោយ» ឬ «ព្រះបាទ
អ៊ីសបូសែតបានបាត់បង់កម្លាំងទាំងអស់»
ព្រះបាទអ៊ីសបូសែតមានមេទ័ពពីរនាក់ ... នោះរហូតដល់សព្វថ្ងៃ
រឿងនេះបង្ហាញពីលោកបាណា និងលោករីកាបនៅក្នុងសាច់រឿង។
(បៀតរ៉ុតក៏ជាផ្នែកមួយនៃកុលសម្ព័ន្ធបេនយ៉ាមីនដែរ) ប្រជាជនដែលរស់នៅទីនោះពីមុន
បាននាំគ្នាភៀសខ្លួនទៅគីថែម ហើយរស់នៅទីនោះរហូតដល់សព្វថ្ងៃ។
នៅទីនេះអ្នកនិពន្ធផ្តល់ព័ត៌មានសង្ខេប អំពីបៀតរ៉ុតសម្រាប់អ្នកអាន។
ទឹកដីរបស់បៀតរ៉ុតជាចំណែកដីរបស់កុលសម្ព័ន្ធបេនយ៉ាមីន។
បៀតរ៉ុត ... គីថែម
ទាំងនេះជាឈ្មេ ោះនៃទីកន្លែង។
2 Samuel 4:4
ព័ត៌មានទូទៅ៖
ខគម្ពីរនេះផ្តាកសាច់រឿងសំខាន់ ដើម្បីផ្តល់ព័ត៌មានសង្ខេបអំពីមេភីបូសែត។
ដែលជាកូនចៅរបស់ព្រះបាទសូលតាមរយៈយ៉ូណាថានជំនួសឲ្យព្រះបាទ
អ៊ីសបូសែត។
មេភីបូសែតនឹងក្លាយជាតួអង្គសំខាន់មួយនៅពេលក្រោយក្នុងសៀវភៅ។
ពិការជើង
ឃ្លានេះមានន័យថា «មិនអាចដើរបាន» ។
មានព្រះជន្មប្រាំព្រះវស្សា
នេះជាអាយុបុត្ររបស់សម្តេចយ៉ូណាថាន នៅពេលដែលបិតាព្រះអង្គសុគត។
ដំណឹងនៃការចូលទិវង្គតរបស់ព្រះបាទសូល និងសម្តេចយ៉ូណាថាន
សំដៅទៅលើព័ត៌មានអំពីការសុគតរបស់ពួកគេ។
មេដោះ
ជាស្ត្រី ឬក្មេងស្រីដែលគេជួលឲ្យមើលថែក្មេងៗ។
ជាហេតុធ្វើឲ្យទ្រង់ពិការ
នេះពន្យល់អំពីរបៀបដែលមេភីបូសែតត្រូវបានរងរបួសដូច្នេះគាត់មិនអាចដើរបានទេ។
មេភីបូសែត។
នេះជាឈ្មោះកូនពៅរបស់យ៉ូណាថាន ដែលជាចៅប្រុសរបស់ព្រះបាទសូល។
2 Samuel 4:5
ព័ត៌មានទូទៅ៖
រឿងនេះត្រឡប់ទៅសកម្មភាពរបស់លោករេកាប
និងលោកបាណាដែលត្រូវបានបង្ហាញនៅក្នុង ៤: ១ ។
នៅពេលថ្ងៃត្រង់
ពាក់កណ្តាលថ្ងៃ ដែលជាពេលមួយក្តៅបំផុត។
កំឡុងពេលដែលបូតស្រូវ
«សំអាតអង្កាមពីស្រូវសាលី»
2 Samuel 4:8
ប៉ុនប៉ងយកជីវិតរបស់ទ្រង់
ឃ្លានេះមានន័យថា «បានកំពុងព្យាយាមសម្លាប់អ្នក»។
យើងសូមស្បថក្នុងនាមព្រះអម្ចាស់
នេះជាពាក្យសម្បថមួយដ៏មុតមាំ ដែលព្រះបាទដាវីឌអាចស្បថ
ដូចព្រះអម្ចាស់ជាសាក្សីដែរ។ ការបកប្រែផ្សេងទៀត
«ខ្ញុំស្បថទៅលើព្រះជន្មរបស់ព្រះអម្ចាស់»
ដែលបាននាំយើងចេញពី
នៅទីនេះ «ជីវិត» សំដៅទៅលើព្រះបាទដាវីឌផ្ទាល់។ ការបកប្រែផ្សេងទៀត
«អ្នកណាជួយសង្គ្រោះខ្ញុំ»
2 Samuel 4:11
តើគួរនឹងត្រូវតបស្នងប៉ុន្មាន ...
តើយើងគួរទាមទារឈាមរបស់គេពីដៃរបស់លោកហើយសម្លាប់លោកឬទេ?
នេះជាសំណួរមួយដើម្បីបង្ហាញថា បុរសទាំងនោះបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «អ្នករឹតតែមានកំហុស!
វាជាកាតព្វកិច្ចរបស់ខ្ញុំ ដែលតម្រូវឲ្យឈាមរបស់អ្នក ហូរចេញពីដៃរបស់អ្នក
ហើយដកអ្នកចេញពីផែនដី» ។
គួរទាមទារឈាមរបស់គេពីដៃរបស់លោក
ឃ្លា « ឈាមរបស់គាត់» តំណាងឲ្យជីវិតរបស់ព្រះបាទអ៊ីសបូសែត។ នៅទីនេះ
«ពីដៃរបស់អ្នក» តំណាងឲ្យលោករេកាប
និងលោកបាណាដែលជាកូនប្រុសរបស់លោករីមម៉ូន
ដែលជាបៀរថីតបានណែនាំនៅក្នុង ៤: ៥ ។ ការបកប្រែផ្សេងទៀត
«ទទួលខុសត្រូវអ្នកចំពោះការស្លាប់របស់ព្រះបាទអ៊ីសបូសែត»
ហើយក៏បានកាត់ដៃ និងជើងរបស់ពួកគេ ទាំងយកទៅចងព្យួរ
ទាំងនេះជាសកម្មភាពនិមិត្តរូប ដើម្បីបង្ហាញការមើលងាយចំពោះបុរស។
ព្រះសិរសារបស់ព្រះបាទអ៊ីសបូសែតវិញ ពួកគេបានយកទៅបញ្ចុះនៅក្នុងផ្នូររបស់លោក
នេះជាសកម្មភាពនិមិត្តរូប ដើម្បីគោរពដល់ព្រះបាទអ៊ីសបូសែត
នេះត្រូវបានថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ពួកគេបានគោរពដល់ព្រះបាទអ៊ីសបូសែតដោយកប់ក្បាលរបស់គាត់នៅក្នុងផ្នូរ»

---

5 [1]កាលនោះកុលសម្ព័ន្ធអ៊ីស្រាអែលទាំងអស់បានមករកព្រះបាទដាវីឌ នៅទីក្រុងហេប្រុន ហើយទូលទ្រង់ថា៖ «សូមទតចុះ! យើងរាល់គ្នាជាសាច់ឈាមរបស់ទ្រង់ដែរ។
[2]កាលពីដើម នៅពេលដែលព្រះបាទសូល គ្រងរាជ្យលើយើង គឺទ្រង់ធ្លាប់ដឹកនាំទ័ពអ៊ីស្រាអែលទៅធ្វើសឹក។ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ទ្រង់ថា៖
អ្នកនឹងឃ្វាលប្រជារាស្ត្ររបស់យើង ហើយអ្នកនឹងក្លាយទៅជាអ្នកដឹកនាំលើអ៊ីស្រាអែល»។
[3]ចាស់ទុំរបស់អ៊ីស្រាអែលទាំងអស់បានមករកព្រះរាជានៅក្រុងហេប្រុន ហើយព្រះរាជាបានចងសម្ព័ន្ធមេត្រីជាមួយពួកចាស់ទុំទាំងអស់នៅចំពោះព្រះអម្ចាស់។
រួចពួកគេចាក់ប្រេងអភិសេកព្រះបាទដាវីឌ ជាស្តេចសោយរាជ្យលើពួកគេ។[4]ពេលដែលព្រះបាទដាវីឌឡើងគ្រងរាជ្យ ទ្រង់មានព្រះជន្មសាមសិបព្រះវស្សា
ហើយទ្រង់សោយរាជ្យបានសែសិបព្រះវស្សា។[5]ទ្រង់សោយរាជ្យលើកុលសម្ព័ន្ធយូដា នៅក្រុងហេប្រុនអស់រយៈពេលប្រាំពីរឆ្នាំ និងប្រាំមួយខែ
ហើយសោយរាជ្យលើអ៊ីស្រាអែលទាំងមូល ព្រមទាំងកុលសម្ព័ន្ធយូដា នៅក្រុងយេរូសាឡិម អស់រយៈពេលសាមសិបបីឆ្នាំ។
[6]ព្រះបាទដាវីឌ និងកងទ័ពរបស់ព្រះអង្គបានចេញទៅវាយយកយេរូសាឡិម ប្រឆាំងនឹងពួកយេប៊ូស ដែលរស់នៅក្នុងតំបន់នោះ។ ពួកគេទូលព្រះបាទដាវីឌថា៖
«អ្នកឯងមិនអាចចូលមកទីនេះបានទេ គ្រាន់តែមនុស្សខ្វាក់ ហើយនិងជនពិការក៏អាចរុញច្រានអ្នកឲ្យត្រឡប់ទៅវិញបានដែរ។
ព្រះបាទដាវីឌមិនអាចចូលក្នុងក្រុងបានទេ»។[7]ប៉ុន្តែ ព្រះបាទដាវីឌ វាយយកបានបន្ទាយនៅស៊ីយ៉ូន ដែលសព្វថ្ងៃនេះហៅថា បុរីព្រះបាទដាវីឌ។
[8]ពេលនោះ ព្រះបាទដាវីឌមានរាជឱង្ការថា៖ «អ្នកណាដែលឡើងទៅវាយពួកយេប៊ូស ត្រូវឡើងទៅតាមប្រឡាយទឹក ដែលនឹងទៅដល់ពួកខ្វាក់
និងពួកពិការដែលជាសត្រូវរបស់ដាវីឌជាមិនខាន»។ ដូច្នោះហើយបានជាពួកគេនិយាយថា៖ «មនុស្សខ្វាក់ និងជនពិការមិនអាចចូលទៅក្នុងព្រះដំណាក់បានទេ»។
[9]នោះព្រះបាទដាវីឌគង់នៅក្នុងបន្ទាយ ដែលហៅថា បុ ីព្រះបាទដាវីឌ។ បន្ទាប់មក ទ្រង់បានពង្រីកទីក្រុងជុំវិញនោះ គឺចាប់ពីផ្នែរហបស្មើទៅខាងក្នុង។
[10]ព្រះបាទដាវីឌមានអំណាចកាន់តែខ្លាំងឡើងៗ ព្រោះព្រះអម្ចាស់ ជាព្រះនៃពិភពទាំងមូល គង់នៅជាមួយព្រះអង្គ។
[11]ព្រះបាទហ៊ីរ៉ាម ស្តេចនៃក្រុងទីរ៉ុស បានចាត់អ្នកនាំសារឲ្យចូលគាល់ព្រះបាទដាវីឌ ទាំងនាំឈើតាត្រៅ ជាងសំណង់ និងជាងដាប់ថ្មមកជាមួយផង។
ពួកគេបានសាងសង់ដំណាក់ថ្វាយព្រះបាទដាវីឌ។[12]ទ្រង់ជ្រាបថា ព្រះអម្ចាស់បានតាំងទ្រង់ឡើងឲ្យធ្វើជាស្តេចគ្រងរាជ្យលើអ៊ីស្រាអែល
ហើយព្រះអង្គក៏ប្រោសប្រទានឲ្យអាណាចក្ររបស់ស្តេចបានចម្រុងចម្រើនឡើង ដោយព្រោះអ៊ីស្រាអែល ជារាស្ត្ររបស់ព្រះអង្គ។
[13]បន្ទាប់ពី ព្រះបាទដាវីឌបានចាកចេញពីក្រុងហេប្រុន មកគង់នៅក្រុងយេរូសាឡិម ទ្រង់បានយកស្រីស្នំ និងមហេសីជាច្រើន ហើយក៏មានបុត្រាបុត្រីជាច្រើន
ដែលបានប្រសូតនៅទីនោះសម្រាប់ព្រះអង្គ។[14]នេះជាព្រះនាមរបស់បុត្រាបុត្រី របស់ព្រះអង្គដែលបានប្រសូត្រនៅយេរូសាឡិមដូចជា៖ សាំមួរ សូបាប់ ណាថាន
សាឡូម៉ូន[15]យីបហារ អេលីសួ នេផេក យ៉ាភា[16]អេលីសាម៉ា អេលាដា និង អេលីផេលេត។
[17]នៅពេលដែលពួកភីលីស្ទីនបានឮថាព្រះបាទដាវីឌត្រូវបានចាក់ប្រេងតាំងអភិសេកជាស្តេចគ្រងរាជ្យលើអ៊ីស្រាអែល ពួកគេក៏បានធ្វើដំណើរទៅតាមរកព្រះអង្គ។
ខណៈដែលព្រះរាជាឮអំពីដំណឹងនេះ ទ្រង់បានចុះទៅឯបន្ទាយ។[18]ពួកភីលីស្ទីន បានមកដល់ ហើយពួកគេបានបោះជំរំទ័ពរបស់ខ្លួននៅក្នុងជ្រលងភ្នំរេផែម។

generated on Wed Sep 10 16:16:32 2025

[19]ព្រះបាទដាវីឌបានទូលសូមឲ្យព្រះអម្ចាស់ជួយដោយទូលថា៖ «តើគួរឲ្យទូលបង្គំច្បាំងជាមួយនឹងពួកភីលីស្ទីនឬ? តើព្រះអង្គនឹងប្រទានជ័យជម្នះមកទូលបង្គំឬទេ?
ព្រះអម្ចាស់ក៏មានព្រះបន្ទូលតបថា៖ «ចូរចេញទៅច្បាំងចុះ! យើងនឹងឲ្យអ្នកមានជ័យជម្នះលើជនជាតិភីលីស្ទីនមិនខាន»។[20]ព្រះបាទដាវីឌ ក៏ចេញទៅរហូតដល់ បាល-
ពេរ៉ាស៊ីម ហើយទ្រង់បានវាយពួកគេឲ្យបាក់ទ័ពនៅទីនោះ។ នោះស្តេចមានរាជឱង្ការថា៖ «ព្រះអម្ចាស់បានធ្វើឲ្យខ្មាំងសត្រូវបាក់ទ័ពនៅចំពោះមុខយើង
ដូចជាទឹកបាក់ទំនប់»។ ដូច្នេះហើយបានជាគេហៅកន្លែងនោះថា បាល-ពេរ៉ាស៊ីម។[21]នៅពេលដែលបាក់ទ័ព ពួកភីលីស្ទីនបានទុកព្រះរបស់ពួកគេចោលនៅទីនោះ
ហើយស្តេចដាវីឌ និងកងទ័ពរបស់ទ្រង់បានប្រមូលយកព្រះទាំងនោះយកទៅបោះចោល។
[22]បន្ទាប់មក ពួកភីលីស្ទីនបាននាំគ្នាមកបោះជំរំទ័ពនៅក្នុងជ្រលងភ្នំ រេផាអ៊ីម។[23]ព្រះបាទដាវីឌបានទូលសូមជំនួយពីព្រះអម្ចាស់ ហើយព្រះអង្គមានព្រះបន្ទូលថា៖
«អ្នកមិនត្រូវវាយប្រហារពួកគេចំពីមុខឡើយ! ប៉ុន្តែ ត្រូវដើរវាងពីក្រោយ ហើយវាយពួកគេនៅម្ពុំដើមស្រល់នោះវិញ។
[24]នៅពេលដែលអ្នកបានឮសន្ធឹកជើងនៃការដើរក្បួនដែលមកតាមខ្យល់នៅលើចុងស្រល់មក ត្រូវប្រញាប់ចេញទៅវាយប្រហារដោយពេញកម្លាំងចុះ។ ចូរធ្វើដូច្នេះចុះ
ព្រោះព្រះអម្ចាស់នឹងយាងទៅខាងមុខអ្នកដើម្បីវាយប្រហារពួកទាហានភីលីស្ទីន»។[25]ព្រះបាទដាវីឌបានធ្វើតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់បានបង្គាប់ដល់ព្រះអង្គ។
ទ្រង់បានសម្លាប់ពួកភីលីស្ទីនចាប់តាំងពីក្រុងកេបា រហូតដល់ក្រុងកេស៊ើរ។

---

2 Samuel 5:1

យើងរាល់គ្នាជាសាច់ឈាមរបស់ទ្រង់ដែរ។

ឃ្លានេះមានន័យថា «សាច់ញាតិ» ។ ការបកប្រែផ្សេងទៀត
«យើងមានទំនាក់ទំនងជាមួយអ្នក» ឬ «យើងជាគ្រួសារតែមួយ»

កាលពីដើម

នេះជាព័ត៌មានប្រវត្តិសាស្ត្រ។ ព្រះបាទសូលជាស្តេចរបស់ពួកគេមុនព្រះបាទដាវីឌ។

អ្នកនឹងឃ្វាលប្រជារាស្ត្ររបស់យើង ហើយអ្នកនឹងក្លាយទៅជាអ្នកដឹកនាំលើអ៊ីស្រាអែល» ។

ឃ្លាទាំងពីរនេះមានន័យរួមដូចគ្នា

ហើយផ្តោតទៅលើព្រះអម្ចាស់បានជ្រើសរើសព្រះបាទដាវីឌធ្វើជាស្តេច។

អ្នកនឹងឃ្វាលប្រជារាស្ត្ររបស់យើង

នៅទីនេះការគ្រប់គ្រងលើប្រជាជន ត្រូវបានគេនិយាយថាជាការឃ្វាលពួកគេ។
ការបកប្រែផ្សេងទៀត «អ្នកនឹងថែរក្សាអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង» ឬ
«អ្នកនឹងគ្រប់គ្រងលើអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង»

2 Samuel 5:3

ពួកគេចាក់ប្រេងអភិសេកព្រះបាទដាវីឌ ជាស្តេចសោយរាជ្យលើពួកគេ

ដើម្បី «ចាក់ប្រេងតាំង» ជាសកម្មភាពនៃនិមិត្តរូបដើម្បីបង្ហាញថា
ពួកគេបានទទួលស្គាល់ថាព្រះជាម្ចាស់បានជ្រើសរើសព្រះបាទដាវីឌជាស្តេច។

2 Samuel 5:6

ព័ត៌មានទូទៅ៖

ព្រះបាទដាវីឌនិងកងទ័ពអ៊ីស្រាអែលវាយប្រហារក្រុងយេរូសាឡិម។

អ្នកឯងមិនអាចចូលមកទីនេះបានទេ គ្រាន់តែមនុស្សខ្វាក់ ហើយនិងជនពិការ
ក៏អាចរុញច្រានអ្នកឲ្យត្រឡប់ទៅវិញបានដែរ។

អាចថ្លែងជាទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នកមកទីនេះសូម្បីតែមនុស្សខ្វាក់និងមនុស្សខ្វិនក៏នឹងអាចបង្វែរអ្នកចេញដែរ
។

មនុស្សខ្វាក់ ហើយនិងជនពិការ

នៅទីនេះ «មនុស្សខ្វាក់» និង «មនុស្សខ្វិន» គឺជាគុណនាមធម្មតា។
ការបកប្រែផ្សេងទៀត
«មនុស្សដែលមើលមិនឃើញនិងអ្នកដែលមិនអាចដើរបាន» (សូមមើល igs-nominaladj)

2 Samuel 5:8

ព្រះបាទដាវីឌមានរាជឱង្ការថា៖ «អ្នកណាដែលឡើងទៅវាយពួកយេប៊ូស»

ដាវីឌកំពុងមានបន្ទូលទៅកាន់ទាហានរបស់គាត់។ ការបកប្រែផ្សេងទៀត
«ដាវីឌបានមានបន្ទូលទៅកាន់ទាហានរបស់គាត់ថា»

«អ្នកដែលចង់កម្ចាត់ប្រជាជនយេប៊ូស »។

មនុស្សខ្វាក់ និងជនពិការ

អាចមានន័យថា ១) នេះសំដៅទៅលើមនុស្សដែលពិតជាជនពិការ
និងមនុស្សពិការភ្នែកឬ ២) នេះគឺជាឈ្មោះហៅក្រៅ
ដែលនិយាយអំពីពួកយេប៊ូសនៅខាងក្នុងក្រុងយេរូសាឡឹម
ហាក់ដូចជាពួកគេទាំងអស់ខ្សោយនិងពិការ។

2 Samuel 5:11

ព្រះបាទហ៊ីរ៉ាម

នេះជាឈ្មោះនៃបុរស។

ជាងសំណង់

អ្នកដែលធ្វើការជាមួយឈើ

ជាងដាប់ថ្ម

អ្នកដែលធ្វើការជាមួយថ្មឬឥដ្ឋ

2 Samuel 5:13

សាំមួរ ... សូបាប់ ... ណាថាន ... សាឡូមូន ... យីបហារ ... អេលីសួ ... នេផេក ... យ៉ាភា ...
អេលីសាម៉ា ... អេលាដា ... អេលីផេលេត

នេះជាឈ្មោះបុត្រារបស់ព្រះបាទដាវីឌ។

បុត្រាបុត្រីជាច្រើន ដែលបានប្រសូតនៅទីនោះសម្រាប់ព្រះអង្គ

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ទ្រង់មានបុត្រានិងបុត្រីជាច្រើន» ឬ «ពួកទ្រង់បង្កើតបានបុត្រាបុត្រីថែមទៀត»

ដែលបានប្រសូត្រ

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដែលប្រពន្ធរបស់គាត់បានបង្កើតសម្រាប់គាត់» ឬ «គាត់មាន»

2 Samuel 5:17

ព្រះបាទដាវីឌត្រូវបានចាក់ប្រេងតាំងអភិសេកជាស្តេចគ្រងរាជ្យលើអ៊ីស្រាអែល

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ៊ីស្រាអែលបានចាក់ប្រេងអភិសេកព្រះបាទដាវីឌជាស្តេច»

ពួកគេក៏បានធ្វើដំណើរទៅតាមរកព្រះអង្គ

ឃ្លានេះសំដៅទៅលើពួកភីលីស្ទីនខ្លះ ដែលកំពុងស្វែងរកព្រះបាទដាវីឌ។
ជាការនិយាយបំផ្លើសដើម្បីបង្ហាញរបៀបដែលពួកភីលីស្ទីនចង់រកព្រះបាទដាវីឌយ៉ាងណា។

ជ្រលងភ្នំរ៉ែផែម

ទាំងនេះជាឈ្មោះនៃទីកន្លែង។ (សូមមើល)

2 Samuel 5:19

បាល-ពេរ៉ាស៊ីម

នេះជាឈ្មោះទីកន្លែង។

ព្រះអម្ចាស់បានធ្វើឲ្យខ្មាំងសត្រូវបាក់ទ័ពនៅចំពោះមុខយើង ដូចជាទឹកបាក់ទំនប់

នៅទីនេះព្រះបាទដាវីឌនិយាយអំពីជ័យជំនះ
ដែលព្រះអម្ចាស់បាននាំមកដូចជាទឹកជំនន់ ដែលហូរជោរជន់មាត់ច្រាំង
និងគ្របលើដីដែលបណ្តាលឲ្យមានការបំផ្លាញ។ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានជាន់ឈ្លីលប់លើខ្មាំងសត្រូវរបស់ខ្ញុំដូចទឹកជំនន់លិចស្រុក»។

2 Samuel 5:22

ពួកភីលីស្ទីនបាននាំគ្នា

ពួកគេបាន "ឡើងមក"

ពីព្រោះពួកភីលីស្ទីនរស់នៅទាបជាងបន្ទាយរបស់ព្រះបាទដាវីឌ។

ជ្រលងភ្នំ រេផាអ៊ីម

នេះជាឈ្មោះនៃទីកន្លែង។

ដើមស្រល់

« ដើមស្រល់» គឺជាដើមឈើមួយប្រភេទ «ឈើ»
ពិពណ៌នាអំពីដើមស្រល់ជាច្រើនដុះជាមួយគ្នា។

2 Samuel 5:24

នៅពេលដែលអ្នកបានឮ ...

ព្រះអម្ចាស់នឹងយាងទៅខាងមុខអ្នកដើម្បីវាយប្រហារពួកទាហានភីលីស្ទីន

នេះជាការដែលព្រះអម្ចាស់បង្រៀនដល់ព្រះបាទដាវីឌដែលបានចាប់ផ្តើមនៅ៥:២២
។ ព្រះអម្ចាស់នៅទីនេះនិយាយអំពីអង្គទ្រង់ផ្ទាល់នៅក្នុងមនុស្សទីបី។

នៅពេលដែលអ្នកបានឮសន្ធឹកជើងនៃការដើរក្បួនដែលមកតាមខ្យល់នៅលើចុងស្រល់មក

នេះនិយាយពីសំឡេងនៃស្លឹកឈើរលួយ
ដូចខ្យល់បក់កាត់ពួកគេដូចជាសម្លេងនៃការដើរក្បួន។ ការបកប្រែផ្សេងទៀត
"នៅពេលដែលខ្យល់បក់កាត់កំពូលដើមស្រល់ស្តាប់ទៅដូចជាបុរសកំពុងដើរក្បួន"

ក្រុងកេបា ... កេស៊ើរ

ទាំងនេះជាឈ្មោះនៃទីកន្លែង។

---

generated on Wed Sep 10 16:16:32 2025

6 [1]ព្រះបាទដាវីឌបានប្រមូលពលទាហានដ៏ចំណានទាំងប៉ុន្មាននៃកងទ័ពអ៊ីស្រាអែល មានចំនួនប្រមាណបីម៉ឺននាក់សារជាថ្មី។[2]ព្រះបាទដាវីឌ
និងពលទ័ពដែលនៅជាមួយទ្រង់បានចេញដំណើរពីបាឡា ក្នុងស្រុកយូដា ដើម្បីហែរហឹបរបស់ព្រះជាម្ចាស់ ដែលឧទ្ទិសដល់ព្រះនាមព្រះអម្ចាស់នៃពិភពទាំងមូល
ដែលគង់នៅកណ្ដាលពួកយេរូប៊ីន។
[3]ពួកគេបានលើកហឹបរបស់ព្រះអម្ចាស់ដាក់លើរទេះថ្មីមួយ។ ពួកគេបានដឹកហឹបចេញពីផ្ទះលោកអប៊ីណាដាប់ ដែលស្ថិតនៅលើភ្នំ។ លោកអ៊ូសា និងលោកអហ៊ីយ៉ូ
ជាកូនរបស់លោកអប៊ីណាដាប់ ជាអ្នកបររទេះថ្មីនោះ។[4]ពួកគេបានបររទេះដែលមានផ្ទុក ហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់នៅលើនោះ ចេញពីផ្ទះរបស់លោក
អប៊ីណាដាប់ដែលនៅលើកំពូលភ្នំ។[5]ព្រះបាទដាវីឌ និងប្រជាជនអ៊ីស្រាអែលទាំងអស់ មានសេចក្ដីអំណរយ៉ាងខ្លាំងនៅចំពោះព្រះអម្ចាស់
ពួកគេបានប្រារព្ធពិធីដោយប្រគុំភ្លេងជាមួយនឹងឧបករណ៍តន្ត្រីគ្រប់ប្រភេទដែលធ្វើពីឈើខ្លឹម ព្រមទាំងពិណ ឃឹម ស្គរ ឆឹង និង ឃ្មោះ។
[6]នៅពេលដែលពួកគេធ្វើដំណើរទៅមកដល់លានស្រូវរបស់លោកណាំកុន គោបានធ្វើឲ្យរទេះផ្អៀង ពេលនោះលោកអ៊ូសា បានលើកដៃទៅប៉ះ
ហើយទប់ហឹបរបស់ព្រះអម្ចាស់។[7]ពេលនោះព្រះអម្ចាស់ព្រះពិរោធនឹងលោកអ៊ូសាយ៉ាងខ្លាំង។ ព្រះអម្ចាស់បានប្រហារលោកដោយសារអំពើបាបរបស់លោក។
លោកអ៊ូសាបានស្លាប់នៅទីនោះដោយសារបានពាល់ហឹបរបស់ព្រះអម្ចាស់។
[8]ព្រះបាទដាវីឌរំជួលព្រះទ័យយ៉ាងខ្លាំងដែលព្រះអម្ចាស់បានប្រហារលោកអ៊ូសា ហើយទ្រង់បានហៅកន្លែងនោះថា ពេរេស-អ៊ូសា។ ទីកន្លែងនោះត្រូវគេហៅថា ពេរេស-
អ៊ូសា រហូតដល់សព្វថ្ងៃ។[9]នៅថ្ងៃនោះ ព្រះបាទដាវីឌភ័យខ្លាចព្រះអម្ចាស់។ ទ្រង់មានរាជឱង្ការថា៖ «តើធ្វើដូចម្ដេច ទើបអាចយកហឹបរបស់ព្រះអម្ចាស់មកឯយើងបាន?»
[10]ដូច្នេះ ព្រះបាទដាវីឌ មិនចង់យកហឹបរបស់ព្រះអម្ចាស់ ចូលទៅក្នុងដំណាក់នៅបុរីព្រះបាទដាវីឌទេ ទ្រង់បានឲ្យគេយកហិបទៅដាក់នៅផ្ទះរបស់លោក អេបេដ អេដុម
ជាអ្នកស្រុកកាថវិញ។[11]ហឹបរបស់ព្រះរបស់ព្រះអម្ចាស់បាននៅផ្ទះរបស់លោកអេបេដ អេដុម ជាអ្នកស្រុកកាថ អស់រយៈពេលបីខែ។ ព្រះអម្ចាស់ប្រទានពរលោក
និងគ្រួសារលោកទាំងមូល។
[12]មានគេទូលព្រះបាទដាវីឌថា៖ «ព្រះអម្ចាស់បានប្រទានពរដល់គ្រួសារ លោកអេបេដ អេដុម និងអ្វីៗដែលគាត់មាន ដោយសារតែហឹបរបស់ព្រះអម្ចាស់»។
ពេលនោះព្រះបាទដាវីឌ បានធ្វើដំណើរទៅផ្ទះរបស់អេបេដ អេដុមដើម្បីនាំយកហឹបទៅកាន់បុរីព្រះបាទដាវីឌដោយអំណរ។
[13]នៅពេលពួកអ្នកសែងហឹបដើរបានប្រាំមួយជំហ៊ាន ព្រះបាទដាវីឌ បានយកគោឈ្មោលមួយ និងគោធាត់មួយមកថ្វាយជាយញ្ញបូជា។
[14]ព្រះបាទដាវីឌ បានរាំលោតកញ្ឆេងថ្វាយព្រះអម្ចាស់ យ៉ាងអស់ពីកម្លាំងរបស់ព្រះអង្គ ដោយស្លៀកតែអេផូដ ដែលធ្វើពីក្រណាត់ទេសឯកតែប៉ុណ្ណោះ។[15]ព្រះបាទដាវីឌ
និងប្រជាជនអ៊ីស្រាអែលទាំងមូលបានដង្ហែហឹបរបស់ព្រះអម្ចាស់ ដោយស្រែកជ័យឃោស និងផ្លុំត្រែយ៉ាងលាន់រំពង។
[16]ពេលដែលហឹបរបស់ព្រះអម្ចាស់បានចូលដល់បុរីព្រះបាទដាវីឌ ព្រះនាងមិកាល បុត្រីព្រះបាទសូល បានក្រឡេកមើលតាមបង្អួច។ ព្រះនាងបានឃើញព្រះបាទដាវីឌ
កុំពុងលោតកញ្ឆេង និងរាំនៅចំពោះព្រះអម្ចាស់។ ពេលនោះព្រះនាងបានមើលងាយស្ដេចនៅក្នុងចិត្តរបស់នាង។
[17]ពួកគេបាននាំយកហិបទៅតម្កល់នៅទីកន្លែងដែលបានរៀបចំ គឺនៅកណ្ដាលព្រះដំណាក់ដែលព្រះបាទដាវីឌ បានបម្រុងទុក។ បន្ទាប់មក
ព្រះបាទដាវីឌបានថ្វាយតង្វាយដុតទាំងមូល និងនៅចំពោះព្រះអម្ចាស់។
[18]ពេលដែលទ្រង់បញ្ចប់ការថ្វាយតង្វាយដុត និងតង្វាយមេត្រីភាព ទ្រង់បានឲ្យពរដល់ប្រជាជនទាំងអស់ក្នុងនាមព្រះអម្ចាស់នៃពិភពទាំងមូល។[19]បន្ទាប់មក
ទ្រង់បានប្រទានអាហារដល់មនុស្សទាំងអស់ ទាំងប្រុស ទាំងស្រី គឺម្នាក់ទទួលបាននំប៉័ងមួយដុំ សាច់មួយដុំ និងនំដំណាប់លមើុមួយដុំ។ បន្ទាប់មក ពួកគេបានចាកចេញ
នឹងត្រឡប់ទៅផ្ទះរបស់ពួករៀងៗខ្លួន។
[20]បន្ទាប់មក ព្រះបាទដាវីឌ បានត្រឡប់ទៅព្រះដំណាក់វិញ ដើម្បីប្រទានពរដល់រាជវង្ស។ ព្រះនាងមីកាល បុត្រីស្ដេចសូល បានចេញមកជួបព្រះបាទដាវីឌ ហើយទូលថា៖
«ថ្ងៃនេះ ស្ដេចនៃអ៊ីស្រាអែលរុងរឿងណាស់ហ្ន៎! ដែលបានបង្ហាញខ្លួនទទេរបស់ព្រះអង្គនៅចំពោះភ្នែកពួករាជបម្រើទាំងប្រុសទាំងស្រី ដូចជាមនុស្សលេលាម្នាក់
ដែលមិនខ្មាស់អៀនដែលខ្លួនគ្មានសម្លៀកបំពាក់!»
[21]ព្រះបាទដាវីឌក៏មានរាជឱង្ការតបទៅនាងវិញថា៖ «យើងបានធ្វើការនោះ ចំពោះព្រះភក្ត្រព្រះអម្ចាស់ ដើម្បីថ្វាយព្រះកិត្តិយសដល់ព្រះអម្ចាស់
ដែលបានជ្រើសរើសយើងជំនួសឪពុករបស់នាង និងលើពួកញាតិរបស់នាង ព្រះអម្ចាស់ដែលបានតាំងយើងឲ្យដឹកនាំលើប្រជារាស្ត្ររបស់ព្រះអង្គ គឺលើរាស្ត្រអ៊ីស្រាអែល។
[22]យើងនឹងដាក់ខ្លួនរបស់យើងឲ្យថោកជាងនេះទៅទៀត ទោះបីជាយើងនឹងអាម៉ាស់មុខក្នុងភ្នែករបស់យើង។ ប៉ុន្តែ
យើងនឹងបានទទួលការលើកតម្កើងដោយពួកបម្រើស្រីៗដែលនាងបាននិយាយអំបាញ់មិញនេះ»។[23]ព្រះនាងមិកាល បុត្រីព្រះបាទសូល
គ្មានបុត្រឡើយរហូតដល់ថ្ងៃដែលព្រះនាងស្លាប់។

---

2 Samuel 6:1

ឥឡូវ

ពាក្យនេះសម្គាល់ផ្នែកថ្មីនៃសាច់រឿង។

បានប្រមូលពលទាហានដ៏ចំណានទាំងប៉ុន្មាននៃកងទ័ពអ៊ីស្រាអែល

ពាក្យប្រៀបធៀបនេះតំណាងឲ្យកងទ័ពអ៊ីស្រាអែល។

មានចំនួនប្រមាណបីម៉ឺននាក់សារជាថ្មី

«៣០,០០០»

ពីបាឡា ក្នុងស្រុកយូដា ដើម្បីហែរហឹបរបស់ព្រះជាម្ចាស់

វាបញ្ជាក់ថាពួកគេកំពុងយកទូកទៅក្រុងយេរូសាឡឹម។ ការបកប្រែផ្សេងទៀត
«ពីបាឡានៅស្រុកយូដាដើម្បីយកហិបរបស់ព្រះទៅក្រុងយេរូសាឡឹម»

ដើម្បីហែរហឹបរបស់ព្រះជាម្ចាស់

ក្រុងយេរូសាឡឹមខ្ពស់ជាងកន្លែងផ្សេងទៀតនៅអ៊ីស្រាអែល។
ដូច្នេះជាការធម្មតាទេដែលជនជាតិអ៊ីស្រាអែល
និយាយពីការឡើងទៅក្រុងយេរូសាឡឹម ហើយចុះពីក្រុងនោះ។

ដើម្បីហែរ

ពាក្យ «នាំយក» អាចត្រូវបានបកប្រែជា «យក» ។

បាឡា

នេះជាឈ្មោះនៃទីកន្លែង។

ដែលឧទ្ទិសដល់ព្រះនាមព្រះអម្ចាស់នៃពិភពទាំងមូល

ឈ្មោះរបស់ព្រះអម្ចាស់ត្រូវបានចារនៅលើហឹប។

ដែលគង់នៅកណ្ដាលពួកយេរូប៊ីន

«ដែលអង្គុយនៅកន្លែងមានសិទ្ធិអំណាចរបស់ទ្រង់រវាងចេរូប៊ីន»។

គង់

អង្គុយលើបល្ល័ង្ក ឬកន្លែងមានសិទ្ធអំណាច។

2 Samuel 6:3

ព័ត៌មានទូទៅ៖

ព្រះបាទដាវីឌនិងកងទ័ពអ៊ីស្រាអែល បានរើហឹបនៃការតាំងសញ្ញា។

លោកអប៊ីណាដាប់ ... លោកអ៊ូសា ... លោកអហ៊ីយ៉ូ

ទាំងនេះជាឈ្មោះនៃមនុស្ស ។

ប្រជាជនអ៊ីស្រាអែលទាំងអស់

នេះជាពាក្យតំណាងឲ្យប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ប្រជនជាតិអ៊ីស្រាអែលទាំងអស់ដែលនៅជាមួយទ្រង់»

ស្គរ

ស្គរគឺជាឧបករណ៍តន្ត្រីដូចជាក្បាលស្គរ
ដែលមានបំណែកលោហៈធាតុព័ទ្ធជុំវិញលើគែម
នៅពេលដែលឧបករណ៍រញ្ជួយឬបុក។

ឆឹង

ឧបករណ៍តន្ត្រីដែលមានវត្ថុតូចៗ
និងវត្ថុរឹងជាច្រើននៅខាងក្នុងសម្បករឹងធ្វើឲ្យមានសម្លេងចង្វាក់នៅពេលលាន់

ឃ្មោះ

ចានស្តើងពីរដែលមានលោហធាតុព័ទ្ធជុំវិញ
ដែលត្រូវបានផ្គុំជាមួយគ្នាដើម្បីបង្កើតជាសម្លេងឮៗ

2 Samuel 6:6

លោកណាំកុន

generated on Wed Sep 10 16:16:32 2025

នេះជាឈ្មោះនៃមនុស្សប្រុស។
ព្រះអម្ចាស់ព្រះពិរោធយ៉ាងខ្លាំង
នៅទីនេះ «សេចក្តីក្រោធរបស់ព្រះអម្ចាស់» ត្រូវបានគេនិយាយដូចជាភ្លើង។
អំពើបាបរបស់លោក
វាជាអំពើបាបមួយ ដែលលោកអ៊ូសាបានប៉ះហឹប ពីព្រោះព្រះអម្ចាស់បានបញ្ជាថា
កុំឲ្យអ្នកណាប៉ះហឹបនោះឡើយ។
2 Samuel 6:8
ពេរេស-អ៊ូសា
នេះជាឈ្មោះកន្លែងមួយ។ អ្នកបកប្រែអាចបន្ថែមលេខយោងដែលនិយាយថា
«ឈ្មោះ ពេរេស-អ៊ូសា មានន័យថា ការដាក់ទណ្ឌកម្មរបស់លោកអ៊ូសា» ។
រហូតដល់សព្វថ្ងៃ
នេះមានន័យថា
ពេលដែលរឿងនេះកំពុងត្រូវបានសរសេរមិនមែនពេលបច្ចុប្បន្ននៅសតវត្សរ៍ទី ២១
ទេ។
តើធ្វើដូចម្តេច ទើបអាចយកហឹបរបស់ព្រះអម្ចាស់មកឯយើងបាន?
ព្រះបាទដាវីឌប្រើសំណួរនេះ
ដើម្បីសង្កត់ធ្ងន់ថាគាត់ខ្លាចយកហឹបទៅក្រុងយេរូសាឡិម។ ការបកប្រែផ្សេងទៀត
"យើងខ្លាចណាស់ ក្នុងការយកហឹបរបស់ព្រះអម្ចាស់ទៅជាមួយយើង
ទៅក្រុងយេរូសាឡិម" ។
2 Samuel 6:10
លោក អេបេដ អេដុម ជាអ្នកស្រុកកាថវិញ
នេះជាឈ្មោះនៃបុរសម្នាក់។
ប្រទានពរលោក
នៅទីនេះ «គាត់» គឺសំដៅទៅលើលោក អេបេដ អេដុម ជាអ្នកស្រុកកាថវិញ។
2 Samuel 6:12
ឥឡូវ
ពាក្យនេះចាប់ផ្តើមផ្នែកថ្មីនៃរឿង។
មានគេទូលព្រះបាទដាវីឌថា
នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សបានប្រាប់ព្រះបាទដាវីឌ»
ដើម្បីនាំយកហឹបនៃព្រះជាម្ចាស់
ក្រុងយេរូសាឡឹមខ្ពស់ជាងកន្លែងផ្សេងទៀតនៅអ៊ីស្រាអែល ដូច្នេះជាការធម្មតាទេ
ដែលជនជាតិអ៊ីស្រាអែលនិយាយពីការឡើងទៅក្រុងយេរូសាឡឹម
ហើយចុះពីក្រុងនោះវិញ។ ការបកប្រែផ្សេងទៀត «រើហឹបរបស់ព្រះជាម្ចាស់» ឬ
«យកហឹបរបស់ព្រះជាម្ចាស់មក» ។
គ្រួសារ លោកអេបេដ អេដុម
នៅទីនេះ «ផ្ទះ» តំណាងឲ្យគ្រួសារមួយ។ ការបកប្រែផ្សេងទៀត «លោកអេបេដ
អេដុមនិងគ្រួសាររបស់គាត់»
ដើម្បីនាំយក
ពាក្យ «បាននាំយក» អាចបកប្រែជា «បានយក»។
2 Samuel 6:14
ព្រះបាទដាវីឌ បានរាំលោតកញ្ឆេងថ្វាយព្រះអម្ចាស់ យ៉ាងអស់ពីកម្លាំងរបស់ព្រះអង្គ
ការរាំនៅទីនេះគឺជាទម្រង់នៃការថ្វាយបង្គំព្រះអម្ចាស់ដ៏រីករាយ។
ក្រណាត់ទេសឯក
សម្លៀកបំពាក់ដែលធ្វើពីសរសៃដែលច្នៃពីរុក្ខជាតិ។
ប្រជាជនអ៊ីស្រាអែលទាំងមូល
នៅទីនេះ «ផ្ទះ» តំណាងឲ្យប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ជនជាតិអ៊ីស្រាអែលទាំងអស់ដែលនៅជាមួយទ្រង់»
2 Samuel 6:16
ពេលដែល ... នៅក្នុងចិត្តរបស់នាង
ពាក្យថា « ឥឡូវនេះ» ជាការសម្រាកនៅក្នុងដំណើររឿង។
នៅទីនេះអ្នកពិពណ៌នាផ្តល់ព័ត៌មានអំពីព្រះនាងមិកាល។
ព្រះនាងមិកាល
ព្រះនាងមិកាល់ជាកូនស្រីរបស់ព្រះបាទសូល និងជាភរិយាទី១
របស់ព្រះបាទដាវីឌផងដែរ។ សូមមើលការបកប្រែឈ្មោះនេះនៅក្នុង ៣:១២ ។
ព្រះនាងបានមើលងាយស្តេចនៅក្នុងចិត្តរបស់នាង
នៅទីនេះ «ចិត្ត» តំណាងឲ្យគំនិត ឬអារម្មណ៍។ ការបកប្រែផ្សេងទៀត
«នាងបានមើលទ្រង់ដោយការមើលងាយ» ឬ
«នាងបាននិយាយមើលងាយដាក់ទ្រង់»
នៅចំពោះព្រះអម្ចាស់
«ទៅព្រះអម្ចាស់»
2 Samuel 6:18
ទ្រង់បានឲ្យពរដល់ប្រជាជនទាំងអស់ក្នុងនាមព្រះអម្ចាស់នៃពិភពទាំងមូល។
ដើម្បីប្រទានពរ «ក្នុងព្រះនាមព្រះអម្ចាស់នៃពិភពទាំងមូល» មានន័យថា
ប្រទានពរដោយឫទ្ធានុភាព និងសិទ្ធិអំណាចរបស់ព្រះអម្ចាស់
ឬក្នុងព្រះនាមតំណាងឲ្យព្រះអង្គ។
ដំណាប់លមើុមួយដុំ
នំប៉័ងផ្អែមធ្វើពីទំពាំងបាយជូរស្ងួត ។
2 Samuel 6:20
បានចេញមក
នៅទីនេះ «បានមក» អាចបកប្រែថា «បានទៅ» ។
ថ្ងៃនេះ ស្តេចនៃអ៊ីស្រាអែលរុងរឿងណាស់ហ្ន៎!
នេះជាសេចក្តីថ្លែងការណ៍បែបពេបជ្រាយ។ ព្រះនាងមិកាល់មានន័យថា
ផ្ទុយពីអ្វីដែលព្រះនាងមានបន្ទូល ហើយព្រះនាងមិនជឿថា
ព្រះបាទដាវីឌបានប្រព្រឹត្តដោយសេចក្តីថ្លៃថ្នូរទេ។
ព្រះនាងមិកាល់មានបន្ទូលដោយមិនគោរពចំពោះព្រះបាទដាវីឌ អំពីសម្លៀកបំពាក់
និងអាកប្បកិរិយារបស់ព្រះអង្គ។
នៅចំពោះភ្នែកពួករាជបម្រើទាំងប្រុសទាំងស្រី
នៅទីនេះ «ភ្នែករបស់ក្មេងស្រីទាសករ» តំណាងឲ្យក្មេងស្រីទាសករ។
ការបកប្រែផ្សេងទៀត «នៅពីមុខក្មេងស្រីដែលជាទាសករ»
មនុស្សលេលា
ព្រះនាងមិកាល់កំពុងប្រៀបធៀបព្រះបាទដាវីឌ ទៅនឹងបុរស
ដែលមានចរិតថោកទាបនិងល្ងង់។
2 Samuel 6:21
ដែលបានជ្រើសរើសយើងជំនួសឪពុករបស់នាង
នៅទីនេះ «របស់អ្នក» សំដៅទៅលើព្រះនាងមិកាល់ ។
ព្រះអម្ចាស់ដែលបានតាំងយើងឲ្យដឹកនាំលើប្រជារាស្ត្ររបស់ព្រះអង្គ គឺលើរាស្ត្រអ៊ីស្រាអែល។
នៅទីនេះ «ប្រជាជនរបស់ព្រះអម្ចាស់» និង» អ៊ីស្រាអែល មានន័យដូចគ្នា។
យើងនឹងដាក់ខ្លួនរបស់យើងឲ្យថោកជាងនេះទៅទៀត
ព្រះបាទដាវីឌកំពុងចំអក និងមានន័យផ្ទុយពីអ្វី ដែលទ្រង់មានបន្ទូល។
ព្រះអង្គមិនជឿថាអ្វីដែលព្រះអង្គបានធ្វើពិតជាថោកទាបទេ
ឬថាសកម្មភាពរបស់ទ្រង់នៅពេលអនាគតនឹងធ្វើឲ្យថោកទាប។
យើងនឹងដាក់ខ្លួនរបស់យើងឲ្យថោកជាងនេះទៅទៀត
នៅទីនេះ «នៅក្នុងភ្នែករបស់ខ្ញុំ» តំណាងឲ្យអ្វីដែលមនុស្សម្នាក់ពិចារណា
ឬគិតអំពីអ្វីមួយ។ ការបកប្រែផ្សេងទៀត
«យើងនឹងចាត់ទុកខ្លួនឯងជាមនុស្សថោកទាប» ឬ
«យើងនឹងចាត់ទុកខ្លួនឯងជាមនុស្សល្ងីល្ងើ»
ប៉ុន្តែ យើងនឹងបានទទួលការលើកតម្កើងដោយពួកបម្រើស្រីៗដែលនាងបាននិយាយអំបាញ់មិញនេះ
អាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែក្មេងស្រីទាសករដែលអ្នកបាននិយាយនឹងគោរពយើង»
គ្មានបុត្រឡើយរហូតដល់ថ្ងៃដែលព្រះនាងស្លាប់។
«មិនអាចមានកូនបានទេ»

---

7 [1]ការនេះបានកើតឡើង បន្ទាប់ពីស្តេចសាងសង់រាជវាំងរបស់ទ្រង់រួចរាល់និងបន្ទាប់ពី ព្រះអម្ចាស់បានប្រទានឲ្យទ្រង់បានសេចក្តីសុខក្សេមក្សាន្ត
រួចផុតពីខ្មាំងសត្រូវគ្រប់ទិសទី[2]ព្រះបាទដាវីឌមានរាជឱង្ការមកកាន់ព្យាការីណាថាន់ថា៖ «សូមលោកពិចារណាចុះ!
យើងបានរស់នៅក្នុងដំណាក់ដែលធ្វើពីឈើដ៏មានតម្លៃ ចំណែកឯហឹបរបស់ព្រះអម្ចាស់ ស្ថិតនៅក្នុងព្រះពន្លាដែលធ្វើពីក្រណាត់នៅឡើយ»។
[3]ព្យាការីណាថាន់តបថា៖ «ការអ្វីដែលព្រះករុណាសព្វព្រះទ័យនឹងធ្វើ ចូរធ្វើចុះ! ព្រោះព្រះអម្ចាស់គង់នៅជាមួយព្រះករុណាហើយ»។[4]ប៉ុន្តែ នៅយប់នោះ
ព្រះអម្ចាស់បានមានព្រះបន្ទូលមកព្យាការីណាថាន់ដោយបន្ទូលថា៖[5]«ចូរទៅហើយប្រាប់ដាវីឌ ជាអ្នកបម្រើរបស់យើងថា នេះជាអ្វីដែលព្រះអម្ចាស់មានបន្ទូល៖
តើអ្នកនឹងសាងសង់ដំណាក់ឲ្យយើងនៅឬ?

generated on Wed Sep 10 16:16:32 2025

[6]យើងមិនបានរស់នៅក្នុងដំណាក់ ចាប់តាំងពីថ្ងៃដែលយើងបាននាំប្រជាជនអ៊ីស្រាអែល ចេញពីស្រុកអេស៊ីបមករហូតដល់សព្វថ្ងៃនេះ
ជំនួសមកវិញគឺយើងបានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ហើយក៏ស្នាក់នៅក្នុងត្រសាល និងក្នុងពន្លា។[7]គ្រប់ទីកន្លែងទាំងអស់ដែលយើងបានធ្វើដំណើរទៅ
ក្នុងចំណោមប្រជាជនអ៊ីស្រាអែល យើងមិនដែលបង្គាប់មេដឹកនាំរបស់កុលសម្ព័ន្ធអ៊ីស្រាអែលណាម្នាក់ថា៖
«ហេតុអ្វីបានជាអ្នករាល់គ្នាមិនសង់ដំណាក់ពីឈើដ៏មានតម្លៃឲ្យយើងនៅ?»
[8]ឥឡូវនេះ ចូរប្រាប់ដាវីឌជាអ្នកបម្រើរបស់យើងថា៖ «នេះគឺជាអ្វីដែលព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូល៖ «យើងបានយកអ្នកចេញពីវាលស្មៅមក
គឺចេញពីភាពជាគង្វាលចៀម ដើម្បីឲ្យធ្វើជាមេដឹកនាំលើជនជាតិអ៊ីស្រាអែលជារាស្ត្ររបស់យើង។[9]យើងបានទៅជាមួយអ្នកគ្រប់កន្លែងដែលអ្នកទៅ។
យើងបានបណ្តេញខ្មាំងសត្រូវរបស់អ្នកចេញពីមុខរបស់អ្នក។ ឥឡូវនេះ យើងក៏បានធ្វើឲ្យអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញ ដូចជាអ្នកធំនៅលើផែនដី។
[10]យើងបានកំណត់ទីកន្លែងសម្រាប់រាស្ត្រអ៊ីស្រាអែលរបស់យើង ហើយយើងបានដាក់ពួកគេនៅកន្លែងនោះ ដូច្នេះ ពួកគេអាចរស់នៅកន្លែងរបស់ពួកគេ
ហើយក៏មិនមានអ្នកណារំខានពួកគេទៀតដែរ។ ក៏នឹងមិនមានជាតិសាសន៍ទុច្ចរិតណាមកជិះជាន់សង្កត់សង្កិនពួកគេ
ដូចពីមុនទៀតដែរ[11]ឬដូចនៅគ្រាដែលយើងបានតែងតាំងពួកចៅហ្វាយអោយដឹកនាំប្រជាជនអ៊ីស្រាអែលរបស់យើង។ ឥឡូវនេះ យើងឲ្យអ្នកបានសុខសាន្ត
រួចផុតពីខ្មាំងសត្រូវរបស់អ្នក។ ជាងនេះ យើងព្រះអម្ចាស់ ធ្វើឲ្យអ្នកមានពូជពង្សមួយផង។
[12]ពេលដែលអ្នកលាចាកលោកនេះទៅ អ្នកនឹងបានទៅជួបជុំជាមួយដូនតារបស់អ្នក យើងនឹងធ្វើអោយមានម្នាក់
គឺពូជពង្សដែលចេញពីសាច់ឈាមរបស់អ្នកផ្ទាល់ឡើងស្នងរាជ្យ ហើយយើងនឹងពង្រឹងរាជ្យរបស់គេ។[13]គឺគេនោះហើយដែលនឹងសង់ដំណាក់សម្រាប់នាមរបស់យើង
យើងនឹងពង្រឹងបល្ល័ង្ករបស់គេ អោយនៅស្ថិតស្ថេររហូតតទៅ។[14]យើងនឹងធ្វើជាឪពុករបស់គេ ហើយគេជាកូនរបស់យើង។ បើគេប្រព្រឹត្តអ្វីខុស
យើងនឹងវាយប្រដៅគេដោយរំពាត់ ដូចជាមនុស្សលោកគេវាយប្រដៅកូនរបស់គេ។
[15]ប៉ុន្តែ សម្ពន្ធមេត្រីនៃសេចក្តីសប្បុរសរបស់យើង យើងនឹងមិនដកចេញ ដូចដែលយើងបានដកចេញសូល អ្នកដែលយើងបានដកចេញពីមុខរបស់អ្នកនោះទេ។[16]ពូជពង្ស
និងរាជសម្បត្តិរបស់អ្នក នឹងស្ថិតស្ថេររហូតតទៅ។ រាជបល្ល័ង្ករបស់អ្នកនឹងរឹងមាំរហូតតទៅដែរ»។[17]ព្យាការីណាថាន់បានទូលថ្វាយព្រះបាទដាវីឌនូវសេចក្តីទាំងប៉ុន្មាន
ដែលព្រះអម្ចាស់មានព្រះបន្ទូលមកលោកនៅក្នុងសុបិន្តនោះ។
[18]ព្រះបាទដាវីឌបានយាងទៅគង់នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ហើយទូលទ្រង់ថា៖ «បពិត្រព្រះអម្ចាស់! តើទូលបង្គំនេះជាអ្នកណា ហើយគ្រួសាររបស់ទូលបង្គំជាអ្វី
បានជាព្រះអង្គនាំទូលបង្គំរាល់គ្នាមកដល់ចំនុចនេះ?[19]ប៉ុន្តែ ព្រះអម្ចាស់អើយ នេះគឺជាកិច្ចការដ៏តូចសម្រាប់ទ្រង់ប៉ុណ្ណោះ។
ព្រះអង្គបានរៀបរាប់ពីគ្រួសារនៃអ្នកបម្រើរបស់ព្រះអង្គ អំពីកិច្ចការដ៏អស្ចារ្យដែលនឹងកើតឡើង ហើយក៏បានបង្ហាញទូលបង្គំអំពីជំនាន់ក្រោយរបស់ទូលបង្គំ!
[20]ឱព្រះអម្ចាស់អើយ! តើមានអ្វីផ្សេងទៀតដែលទូលបង្គំ ដាវីឌ អាចទូលថ្វាយដល់ទ្រង់បាន? គឺទ្រង់បានជ្រាបគ្រប់សព្វពីអ្នកបម្រើរបស់ព្រះអង្គ។
[21]ព្រះអង្គបានសម្តែងកិច្ចការដ៏អស្ចារ្យដល់អ្នកបម្រើរបស់ព្រះអង្គ គឺព្រះអង្គបានសម្រេចបំណងព្រះហឫទ័យរបស់ព្រះអង្គ តាមព្រះបន្ទូលរបស់ព្រះអង្គ។[22]ព្រះអម្ចាស់អើយ!
ព្រះអង្គពិតជាព្រះដ៏ឧត្តុងឧត្តម មិនមានអ្នកណាម្នាក់អាចដូចទ្រង់ទេ ហើយក៏គ្មានព្រះណាប្រៀបផ្ទឹមនឹងទ្រង់បានឡើយ តាមដែលយើងធ្លាប់បានឮគេតំណាលមកនោះ។
[23]តើជាតិសាសន៍ណាដូចជាប្រជាជនអ៊ីស្រាអែលរបស់ព្រះអង្គនោះ គឺប្រជាជាតិមួយនៅលើផែនដី ដែលទ្រង់បានយាងទៅសង្គ្រោះគេ
មកធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់នោះ? គឺព្រះអង្គបានធ្វើកិច្ចការទាំងនោះ ដូច្នេះ ពួកគេបានមកជាប្រជារាស្ត្ររបស់ព្រះអង្គ ដើម្បីឲ្យពួកគេមានកេរ្តិ៍ឈ្មោះទៀតផង
ហើយទ្រង់ក៏បានធ្វើការដ៏អស្ចារ្យ និងគួរឲ្យស្ញែងខ្លាចនៅក្នុងទឹកដីរបស់ទ្រង់។ ព្រះអង្គបានបណ្តេញជាតិសាសន៍នានាព្រមទាំងព្រះរបស់ពួកគេ
ចេញពីមុខប្រជារាស្ត្ររបស់ទ្រង់ ដែលទ្រង់បានរំដោះពីស្រុកអេស៊ីបមក។
[24]ព្រះអម្ចាស់អើយ! ព្រះអង្គបានពង្រឹងអ៊ីស្រាអែល ដើម្បីឲ្យគេធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គរហូតតទៅ ហើយព្រះអង្គ ព្រះអម្ចាស់ ក្លាយជាព្រះរបស់ពួកគេ។
[25]បពិត្រព្រះអម្ចាស់ ដ៏ជាព្រះអើយ! សូមឲ្យព្រះបន្ទូលសន្យា ដែលទ្រង់បានសន្យាជាមួយអ្នកបម្រើរបស់ទ្រង់ និងគ្រួសាររបស់គេបានរឹងមាំរហូតតទៅ
សូមទ្រង់សម្រេចតាមព្រះបន្ទូលសន្យានេះផង។[26]សូមឲ្យព្រះបន្ទូលរបស់ទ្រង់បានឧត្តុង្គឧត្តុមជានិច្ច ដូច្នេះ មនុស្សម្នានឹងពោលថា៖
«ព្រះអម្ចាស់នៃពិភពទាំងមូលគឺជាព្រះនៃជនជាតិអ៊ីស្រាអែល» នៅពេលដែលពូជពង្សរបស់ទូលបង្គំ ដាវីឌ អ្នកបម្រើរបស់ទ្រង់ បានស្ថិតស្ថេរនៅចំពោះព្រះអង្គ
រហូតតទៅ។
[27]បពិត្រព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះនៃជនជាតិអ៊ីស្រាអែលអើយ! ទ្រង់បានប្រទានឲ្យអ្នកបម្រើរបស់ទ្រង់ដឹងថា
ទ្រង់នឹងធ្វើឲ្យមានពូជពង្សរបស់ទូលបង្គំឡើងគ្រងរាជបន្តពីទូលបង្គំ។ ដូច្នេះហើយទូលបង្គំ ជាអ្នកបម្រើរបស់ព្រះអង្គ មានចិត្តក្លាហានអធិស្ឋានពាក្យនេះថ្វាយដល់ទ្រង់។
[28]ឱព្រះអម្ចាស់អើយ ទ្រង់គឺជាព្រះ ហើយព្រះបន្ទូលរបស់ទ្រង់គឺសុទ្ធតែពិត ហើយព្រះអង្គក៏នឹងសម្រេចពាក្យសន្យានេះសម្រាប់អ្នកបម្រើរបស់ទ្រង់។[29]ឥឡូវនេះ
សូមព្រះអង្គប្រទានពរដល់ពូជពង្សរបស់ទូលបង្គំ ដើម្បីឲ្យបានស្ថិតស្ថេរនៅចំពោះព្រះភក្ត្ររបស់ព្រះអង្គរហូតតរៀងទៅ។ ឱព្រះអម្ចាស់អើយ!
ស្របតាមព្រះបន្ទូលទាំងអស់នេះ ពូជពង្សរបស់ទូលបង្គំនឹងទទួលព្រះពរអស់កល្បជានិច្ច»។

---

2 Samuel 7:1

ការនេះបានកើតឡើង

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។

បើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះ អ្នកអាចពិចារណាប្រើវានៅទីនេះ។

បានប្រទានឲ្យទ្រង់បានសេចក្តីសុខក្សេមក្សាន្ត រួចផុតពីខ្មាំងសត្រូវគ្រប់ទិសទី

«បានផ្តល់សុវត្ថិភាពដល់ទ្រង់ពីសត្រូវដែលនៅជុំវិញព្រះអង្គ»។ នៅទីនេះ

«សម្រាក» គឺជានាមអរូបី។ ការបកប្រែផ្សេងទៀត

«បណ្តាលឲ្យសត្រូវឈប់វាយប្រហារអ៊ីស្រាអែល»

យើងបានរស់នៅក្នុងដំណាក់ដែលធ្វើពីឈើដ៏មានតម្លៃ

ដើមតាត្រៅជាដើមឈើមួយប្រភេទ ដែលត្រូវបានគេស្គាល់ព្រោះភាពរឹងមាំរបស់វា។

បើអ្នកមានដើមឈើប្រភេទស្មើគ្នានៅក្នុងវប្បធម៌របស់អ្នក អ្នកប្រើឈ្មោះនោះ

បើមិនដូច្នេះទេអ្នកអាចប្រើវាឡើងវិញបាន។ ការបកប្រែផ្សេងទៀត

«ខ្ញុំរស់នៅក្នុងផ្ទះរឹងមាំជារៀងរហូត»

ហឹបរបស់ព្រះអម្ចាស់ស្ថិតនៅក្នុងព្រះពន្លា ដែលធ្វើពីក្រណាត់នៅឡើយ»។

តង់ជាការដំណាក់បណ្តោះអាសន្ន។ បើអ្នកមិនមានតង់នៅក្នុងវប្បធម៌របស់អ្នក

អ្នកអាចប្រើពាក្យនេះផ្សេងពីគ្នា។ ការបកប្រែផ្សេងទៀត

«ហឹបរបស់ព្រះជាម្ចាស់កំពុងស្នាក់នៅកន្លែងបណ្តោះអាសន្ន»

2 Samuel 7:3

ការអ្វីដែលព្រះករុណាសព្វព្រះទ័យនឹងធ្វើ

នៅទីនេះ «ចិត្ត» តំណាងឲ្យចិត្តគំនិត។ ការបកប្រែផ្សេងទៀត

«ធ្វើអ្វីដែលអ្នកគិតថាអ្នកគួរ»

ព្រះអម្ចាស់គង់នៅជាមួយព្រះករុណាហើយ

នៅទីនេះ «ជាមួយអ្នក» មានន័យថា ព្រះជាម្ចាស់កំពុងជួយ

និងប្រទានពរដល់ព្រះបាទដាវីឌ។

ព្រះអម្ចាស់បានមានព្រះបន្ទូលមក

នេះជាពាក្យមួយដែលមានន័យថា ព្រះអម្ចាស់មានព្រះបន្ទូល។

«ព្រះអម្ចាស់បានមានព្រះបន្ទូលតាមរយៈព្រះរាជសារព្រះអង្គ»។

ព្រះអម្ចាស់បានមានព្រះបន្ទូល

នៅទីនេះ «ពាក្យ» តំណាងឲ្យព្រះរាជសាររបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត

«សាររបស់ព្រះអម្ចាស់»

ដោយបន្ទូលថា៖ «ចូរទៅហើយប្រាប់ដាវីឌ ជាអ្នកបម្រើរបស់យើងថា

នេះជាអ្វីដែលព្រះអម្ចាស់មានបន្ទូល៖ តើអ្នកនឹងសាងសង់ដំណាក់ឲ្យយើងនៅឬ?

នេះមានការដកស្រង់មួយនៅក្នុងពាក្យដកស្រង់មួយទៀត។

ចាំបាច់ត្រូវបកប្រែជាសម្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត

«ហើយបាននិយាយថា» ទៅហើយសួរព្រះបាទដាវីឌ បើទ្រង់គិតថា

ទ្រង់នឹងក្លាយជាអ្នកសាងសង់ព្រះដំណាក់ឲ្យយើងគង់នៅ។

តើអ្នកនឹងសាងសង់ដំណាក់ឲ្យយើងនៅឬ?

ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ថា ព្រះបាទដាវីឌមិនមែនជាអ្នក

generated on Wed Sep 10 16:16:32 2025

ដែលត្រូវសង់ព្រះដំណាក់ថ្វាយព្រះអម្ចាស់ទេ។
សំណួរនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកនឹងមិនសង់ព្រះដំណាក់សម្រាប់យើងទេ»
សាងសង់ដំណាក់ឲ្យយើង
នៅទីនេះ «ផ្ទះ»មានន័យថាព្រះវិហារ។ នៅក្នុង ៧:១១
ព្រះអម្ចាស់មានព្រះបន្ទូលថា ទ្រង់នឹងសង់ដំណាក់មួយថ្វាយព្រះបាទដាវីឌ។
នៅទីនេះ ផ្ទះមានន័យថាគ្រួសារ ។ បើភាសារបស់អ្នកមានពាក្យ
ដែលអាចបង្ហាញគំនិតទាំងពីរ សូមប្រើវានៅទីនេះ និងក្នុង ៧: ១១។
2 Samuel 7:6
យើងមិនដែលបង្គាប់មេដឹកនាំរបស់កុលសម្ព័ន្ធអ៊ីស្រាអែលណាម្នាក់ថា៖
«ហេតុអ្វីបានជាអ្នករាល់គ្នាមិនសង់ដំណាក់ពីឈើដ៏មានតម្លៃឲ្យយើងនៅ»?
មានការដកស្រង់មួយនៅក្នុងការដកស្រង់មួយទៀត។ ការដកស្រង់ផ្ទាល់
អាចថ្លែងជាដកស្រង់ដោយប្រយោល។ ការបកប្រែផ្សេងទៀត
«យើងមិនដែលស្នើសុំមេដឹកនាំណាម្នាក់
ដែលយើងបានតែងតាំងឲ្យសង់ព្រះវិហារថ្វាយយើង ពីឈើតាត្រៅទេ»។
យើងមិនដែលបង្គាប់មេដឹកនាំរបស់កុលសម្ព័ន្ធអ៊ីស្រាអែលណាម្នាក់ថា
ព្រះអម្ចាស់ប្រើសំណួរមួយដើម្បីបញ្ជាក់ថា
ទ្រង់មិនដែលសុំឲ្យមេដឹកនាំអ៊ីស្រាអែលណាម្នាក់
សង់ព្រះដំណាក់ថ្វាយព្រះអង្គឡើយ។ ការបកប្រែផ្សេងទៀត
«យើងមិនដែលនិយាយអ្វីជាមួយមេដឹកនាំអ៊ីស្រាអែលណាមួយឡើយ»
ហេតុអ្វីបានជាអ្នករាល់គ្នាមិនសង់ដំណាក់ពីឈើដ៏មានតម្លៃឲ្យយើងនៅ?
បើព្រះអម្ចាស់បានសួរមេដឹកនាំណានូវសំណួរនេះ ព្រះអង្គនឹងប្រើសំណួរមួយ
ដើម្បីស្តីបន្ទោសពួកគេចំពោះការ ដែលមិនបានសង់ព្រះដំណាក់ពីឈើតាត្រៅ។
ប៉ុន្តែ ពីមុនព្រះអម្ចាស់មានបន្ទូលថា ទ្រង់មិនបានសួរសំណួរនេះដល់ពួកគេទេ។
ការបកប្រែផ្សេងទៀត «អ្នកគួរតែសង់ព្រះដំណាក់ពីឈើតាត្រៅថ្វាយយើង»។
យើងមិនដែលបង្គាប់មេដឹកនាំរបស់កុលសម្ព័ន្ធអ៊ីស្រាអែល
មេដឹកនាំនៃជនជាតិអ៊ីស្រាអែលត្រូវប្រដូច
ទៅនឹងគង្វាលហើយប្រជាជនគឺជាចៀម។
2 Samuel 7:8
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តពិពណ៌នាអំពីការសន្យារបស់ព្រះអង្គ
ចំពោះព្រះបាទដាវីឌតាមរយៈព្យាការីណាថាន់។
ឥឡូវនេះ
នេះមិនមានន័យថា «នៅពេលនេះទេ» ប៉ុន្តែ
ត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះចំណុចសំខាន់ដែលត្រូវអនុវត្តតាម។
ចូរប្រាប់ដាវីឌជាអ្នកបម្រើរបស់យើងថា៖
«នេះគឺជាអ្វីដែលព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូល ...
យើងក៏បានធ្វើឲ្យអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញ ដូចជាអ្នកធំនៅលើផែនដី។
មានការដកស្រង់មួយនៅក្នុងការដកស្រង់មួយទៀត។
ប្រហែលជាចាំបាច់ត្រូវបកប្រែការដកស្រង់ផ្ទាល់នេះ
ជាការដកស្រង់ដោយប្រយោលដូចក្នុងយូឌីប៊ី។ ការបកប្រែផ្សេងទៀត
«ប្រាប់ព្រះបាទដាវីឌជាអ្នកបម្រើរបស់យើងថា យើងបានយកព្រះអង្គ ...
ព្រះនាមរបស់ព្រះអង្គដូចជាឈ្មោះរបស់អ្នកធំៗនៅលើផែនដី»
ចូរប្រាប់ដាវីឌជាអ្នកបម្រើរបស់យើងថា
ព្រះអម្ចាស់នៅតែប្រាប់ព្យាការីណាថាន់អំពីអ្វី ដែលគាត់គួរប្រាប់ព្រះបាទដាវីឌ។
យើងបានទៅជាមួយអ្នក
នៅទីនេះ «ជាមួយអ្នក» មានន័យថា
ព្រះអម្ចាស់បានជួយនិងប្រទានពរដល់ព្រះបាទដាវីឌ។
យើងបានបណ្តេញខ្មាំងសត្រូវរបស់អ្នកចេញពីមុខរបស់អ្នក។
ព្រះអម្ចាស់បានបំផ្លាញសត្រូវរបស់ព្រះបាទដាវីឌ ត្រូវបានគេនិយាយថា
ដូចជាព្រះអម្ចាស់បានកាត់ផ្តាច់ពួកគេដែរ
ដូចជាមនុស្សម្នាក់នឹងកាប់បំណែកសម្លៀកបំពាក់ ឬកាត់មែកឈើ។
បានធ្វើឲ្យអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញ
នៅទីនេះ«ឈ្មោះ» តំណាងឲ្យកេរ្តិ៍ឈ្មោះរបស់មនុស្សម្នាក់។
ដូចជាអ្នកធំ
ឃ្លាថា «អ្នកធំ» មានន័យថាមនុស្សល្បី។
2 Samuel 7:10
ឃ្លាភ្ជាប់៖
ព្រះអម្ចាស់បន្តពិពណ៌នាអំពីការសន្យារបស់ព្រះអង្គ
ចំពោះព្រះបាទដាវីឌតាមរយៈព្យាការីណាថាន់។
យើងបានកំណត់ទីកន្លែង
«ខ្ញុំនឹងជ្រើសរើសកន្លែងមួយ»
យើងបានដាក់ពួកគេនៅកន្លែងនោះ
ព្រះអម្ចាស់បានធ្វើឲ្យប្រជាជនរស់នៅលើទឹកដីនេះ ជារៀងរហូត និងមានសុវត្ថិភាព
គឺត្រូវបាននិយាយដូចជាព្រះអង្គនឹងដាក់ពួកគេក្នុងទឹកដី។
ហើយក៏មិនមានអ្នកណារំខានពួកគេទៀតដែរ
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយគ្មាននរណាម្នាក់នឹងបង្កបញ្ហាដល់ពួកគេ»
ដូចនៅគ្រាដែល
នៅទីនេះ «ថ្ងៃ»តំណាងឲ្យរយៈពេលយូរជាងនេះ។ ការបកប្រែផ្សេងទៀត
«ពីពេលនេះ»
យើងបានតែងតាំងពួកចៅហ្វាយ
បន្ទាប់ពីប្រជាជនអ៊ីស្រាអែលចូលទឹកដីកាណាន
ហើយមុនពេលពួកគេមានស្តេចគ្រប់គ្រងពួកគេ
ព្រះជាម្ចាស់បានតែងតាំងមេដឹកនាំដែលហៅថា «ចៅហ្វាយ»
ដើម្បីដឹកនាំពួកគេនៅពេលមានបញ្ហា។
ឥឡូវនេះ យើងឲ្យអ្នកបានសុខសាន្ត រួចផុតពីខ្មាំងសត្រូវរបស់អ្នក។ ជាងនេះ យើងព្រះអម្ចាស់
ធ្វើឲ្យអ្នកមានពូជពង្សមួយផង។
បើក្នុង ៧:៨ អ្នកបានបកប្រែការដកស្រង់ផ្ទាល់ ជាការដកស្រងដោយប្រយោល
បន្ទាប់មកអ្នកប្រហែលជាត្រូវបកប្រែថា «អ្នក» ជា «គាត់» ឬ «គាត់»។
ការបកប្រែផ្សេងទៀត
«ឥឡូវនេះយើងនឹងឲ្យអ្នកសម្រាកពីសត្រូវទាំងអស់របស់អ្នក ...
ប្រកាសប្រាប់អ្នកថា យើងនឹងធ្វើឲ្យគាត់មានផ្ទះមួយ»
យើងឲ្យអ្នកបានសុខសាន្ត រួចផុតពីខ្មាំងសត្រូវរបស់អ្នក
«យើងនឹងផ្តល់ឲ្យអ្នកមានសុវត្ថិភាព ពីសត្រូវរបស់អ្នកទាំងអស់»។ នៅទីនេះ
«សម្រាក» គឺជានាមអរូបី។ ការបកប្រែផ្សេងទៀត
«យើងនឹងធ្វើឲ្យសត្រូវទាំងអស់របស់អ្នកឈប់វាយប្រហារអ្នក»
ធ្វើឲ្យអ្នកមានពូជពង្សមួយផង
នៅទីនេះពាក្យ «ពូជពង្ស» សំដៅទៅលើជំនួនជីតារបស់ព្រះបាទដាវីឌ
ដែលបន្តធ្វើជាអ្នកគ្រប់គ្រងរបស់អ៊ីស្រាអែល។ នៅក្នុង ៧:៣
ព្រះអម្ចាស់បានសួរព្រះបាទដាវីឌ បើឯងនឹងសង់ព្រះដំណាក់សម្រាប់ព្រះអម្ចាស់។
នៅទីនោះ «ព្រះដំណាក់» តំណាងឲ្យព្រះវិហារមួយ។ បើភាសារបស់អ្នកមានពាក្យ
ដែលអាចបង្ហាញពីគំនិតទាំងពីរសូមប្រើវានៅទីនេះ និងនៅក្នុង ៧:៤ ។
2 Samuel 7:12
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តពិពណ៌នាអំពីការសន្យារបស់ព្រះអង្គចំពោះព្រះបាទដាវីឌតាមរយៈព្យាការីណាថាន់។
ពេលដែលអ្នកលាចាកលោកនេះទៅ អ្នកនឹងបានទៅជួបជុំជាមួយដូនតារបស់អ្នក
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា
ហើយត្រូវបានរួមបញ្ចូលគ្នាដើម្បីបញ្ជាក់ឲ្យបានច្បាស់។
នេះជារបៀបគួរសមនិយាយសំដៅទៅលើសេចក្តីស្លាប់ និងការស្លាប់។
យើងនឹងធ្វើអោយមានម្នាក់
ព្រះអម្ចាស់តែងតាំងកូនចៅរបស់ព្រះបាទដាវីឌ ត្រូវនិយាយដូចជា
ព្រះអម្ចាស់នឹងលើកព្រះអង្គឡើងដែរ។
មានម្នាក់ គឺពូជពង្សដែលចេញពីសាច់ឈាមរបស់អ្នក
នេះជាពាក្យសម្តីដែលមានន័យថា
មនុស្សនោះនឹងក្លាយជាកូនចៅរបស់ព្រះបាទដាវីឌ។
យើងនឹងពង្រឹងរាជ្យរបស់គេ
នៅទីនេះ «ព្រះរាជ្យរបស់ព្រះអង្គ» តំណាងអំណាចគ្រប់គ្រងរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើឲ្យឯងក្លាយជាស្តេច ដែលមានឥទ្ធិពលខ្លាំង»
សង់ដំណាក់សម្រាប់នាមរបស់យើង
នៅទីនេះពាក្យ «ព្រះនាម» សំដៅលើព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រះដំណាក់គង់នៅជារៀងរហូតសម្រាប់យើង»
យើងនឹងពង្រឹងបល្ល័ង្ករបស់គេ អោយនៅស្ថិតស្ថេររហូតតទៅ។
នៅទីនេះ «បល្ល័ង្ក» តំណាងអំណាចរបស់មនុស្ស ដែលត្រូវគ្រប់គ្រងជាស្តេច។
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើឲ្យការគ្រប់គ្រងរបស់ឯង
លើអ៊ីស្រាអែលស្ថិតស្ថេរជារៀងរហូត»
យើងនឹងធ្វើជាឪពុករបស់គេ ហើយគេជាកូនរបស់យើង។
ទំនាយនៅក្នុង ៧:១២-១៤ សំដៅទៅលើព្រះបាទសាឡូម៉ូន

generated on Wed Sep 10 16:16:32 2025

ដែលជាបុត្រារបស់ព្រះបាទដាវីឌ។
ប៉ុន្តែទិដ្ឋភាពនៃទំនាយនឹងត្រូវសម្រេចតាមរយៈព្រះយេស៊ូ។ ដូច្នេះ
នៅទីនេះវាជាការល្អបំផុតដើម្បីបកប្រែពាក្យថា «ឪពុក» និង «កូនប្រុស»
ជាមួយពាក្យធម្មតារបស់អ្នកសម្រាប់ការទាក់ខាងសាច់ឈាមឪពុកនិងកូនប្រុស។
2 Samuel 7:15
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តពិពណ៌នាអំពីការសន្យារបស់ព្រះអង្គ
ចំពោះព្រះបាទដាវីឌតាមរយៈព្យាការីណាថាន់។
ប៉ុន្តែ សម្ពន្ធមេត្រីនៃសេចក្តីសប្បុរសរបស់យើង យើងនឹងមិនដកចេញ
ដូចដែលយើងបានដកចេញសូល
ពាក្យថា «ភាពស្មោះត្រង់» ជានាមអរូបី ដែលអាចត្រូវបានគេនិយាយថា
«ស្មោះត្រង់»។ សេចក្តីថ្លែងការណ៍នេះក៏អាចបកប្រែជាទម្រង់វិជ្ជមានផងដែរ។
ការបកប្រែផ្សេងទៀត «ប៉ុន្តែយើងនឹងនៅតែស្មោះត្រង់នឹងឯងដដែល
មិនដូចយើងធ្វើចំពោះព្រះបាទសូលទេ»
ដកចេញពីមុខរបស់អ្នកនោះទេ។ ពូជពង្ស ... ស្ថិតស្ថេររហូតតទៅ។ រាជបល្ល័ង្ករបស់អ្នក
បើនៅក្នុង ៧:៨
អ្នកបានបកប្រែការដកស្រង់ដោយផ្ទាល់ជាការដកស្រង់ដោយប្រយោល បន្ទាប់មក
នៅទីនេះអ្នកត្រូវបកប្រែ «អ្នក» ទៅជា «ព្រះបាទដាវីឌ» ឬ «ទ្រង់» ឬ «របស់ទ្រង់»
ដូចក្នុងយូឌីបឺ ។ ការបកប្រែផ្សេងទៀត «ពីមុខព្រះបាទដាវីឌ។
ដំណាក់របស់ព្រះបាទដាវីឌ ... នៅមុខបល្ល័ង្ករបស់ព្រះអង្គ»
ពូជពង្ស និងរាជសម្បត្តិរបស់អ្នក នឹងស្ថិតស្ថេររហូតតទៅ។
រាជបល្ល័ង្ករបស់អ្នកនឹងរឹងមាំរហូតតទៅដែរ»។
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា ហើយបញ្ជាក់ថា
រាជវង្សរបស់ព្រះបាទដាវីឌនឹងស្ថិតស្ថេរ ជារៀងរហូត។
ពូជពង្ស និងរាជសម្បត្តិរបស់អ្នក នឹងស្ថិតស្ថេររហូតតទៅ។
នៅទីនេះពាក្យថា «ពូជពង្ស» តំណាងកូនចៅរបស់ព្រះបាទដាវីឌ
ដែលនឹងគ្រប់គ្រងជាស្តេច។ នៅទីនេះ «រាជសម្បត្តិ» មានន័យដូចគ្នាទៅនឹង
«ពូជពង្ស» ដែរ។ អាចថ្លែងជាទម្រង់កិរិយាសកម្មផងដែរ។ ការបកប្រែផ្សេងទៀត
«ទ្រង់នឹងរស់និងឃើញយើងបង្កើតគ្រួសាររបស់ព្រះអង្គ
និងការគ្រប់គ្រងរបស់ពួកគេ លើប្រជាជនអ៊ីស្រាអែលជារៀងរហូត»
រាជបល្ល័ង្ករបស់អ្នកនឹងរឹងមាំរហូតតទៅដែរ។
នៅទីនេះ «បល្ល័ង្ក» តំណាងឲ្យអំណាចគ្រប់គ្រងជាស្តេច។ ការបកប្រែផ្សេងទៀត
«យើងនឹងឲ្យកូនចៅរបស់អ្នកគ្រប់គ្រងលើអ៊ីស្រាអែលជារៀងរហូត»
នូវសេចក្តីទាំងប៉ុន្មាន
នៅទីនេះ «ពាក្យ» តំណាងឲ្យអ្វីៗ ដែលព្រះអម្ចាស់បានមានព្រះបន្ទូល។
ដែលព្រះអម្ចាស់មានព្រះបន្ទូលមកលោកនៅក្នុងសុបិន្តនោះ។
«គាត់បានទូលប្រាប់ព្រះអង្គគ្រប់យ៉ាង នូវអ្វីដែលព្រះអម្ចាស់បានបង្ហាញដល់គាត់»
2 Samuel 7:18
បពិត្រព្រះអម្ចាស់! តើទូលបង្គំនេះជាអ្នកណា ហើយគ្រួសាររបស់ទូលបង្គំជាអ្វី
បានជាព្រះអង្គនាំទូលបង្គំរាល់គ្នាមកដល់ចំនុចនេះ?
ព្រះបាទដាវីឌសួរសំណួរនេះ ដើម្បីបង្ហាញពីអារម្មណ៍ដ៏ជ្រាលជ្រៅ
ដែលព្រះអង្គបានមានអារម្មណ៍ឮពីការអះអាងរបស់ព្រះអម្ចាស់។
សំណួរដ៏ប៉ិនប្រសប់នេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«គ្រួសាររបស់ទូលបង្គំ និងទូលបង្គំមិនសមនឹងទទួលបានកិត្តិយសនេះទេ
ព្រះអម្ចាស់ជាព្រះជាម្ចាស់»។
ប៉ុន្តែ ព្រះអម្ចាស់អើយ នេះគឺជាកិច្ចការដ៏តូចសម្រាប់ទ្រង់ប៉ុណ្ណោះ។
នៅទីនេះ «ការមើលឃើញរបស់អ្នក» តំណាងឲ្យអ្វីៗ ដែលព្រះអម្ចាស់ចាត់ទុកថា
ជាអ្វីមួយត្រូវធ្វើ។ ការបកប្រែផ្សេងទៀត
«នេះហាក់ដូចជាចំពោះអ្នកគឺជារឿងតូចតាចដែលត្រូវធ្វើ»
គ្រួសារនៃអ្នកបម្រើរបស់ព្រះអង្គ
នៅទីនេះព្រះបាទដាវីឌចាត់ទុកខ្លួនព្រះអង្គផ្ទាល់ «អ្នកបម្រើរបស់ព្រះអង្គ»។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងបុរសទីមួយ។ ការបកប្រែផ្សេងទៀត
«គ្រួសាររបស់ព្រះអង្គ»
អំពីកិច្ចការដ៏អស្ចារ្យដែលនឹងកើតឡើង
ប្រដូចពេលវេលាទៅនឹងអ្វីមួយ ដែលធ្វើដំណើរនិងមកដល់កន្លែងណាមួយ។
ការបកប្រែផ្សេងទៀត «និងអ្វីដែលនឹងកើតឡើងចំពោះពួកគេ ពេលអនាគត»
ឱព្រះអម្ចាស់អើយ! តើមានអ្វីផ្សេងទៀតដែលទូលបង្គំ ដាវីឌ អាចទូលថ្វាយដល់ទ្រង់បាន?
ព្រះបាទដាវីឌប្រើសំណួរនេះដើម្បីបញ្ជាក់ថា
ទ្រង់មិនមានអ្វីដែលត្រូវនិយាយទៅកាន់ព្រះអម្ចាស់ទេ។ ការបកប្រែផ្សេងទៀត
«គ្មានអ្វីដែលខ្ញុំអាចនិយាយទៅកាន់ព្រះអង្គទេ»។
អ្នកបម្រើរបស់ព្រះអង្គ
នៅទីនេះស្តេចដាវីឌចាត់ទុកខ្លួនលោកជា «អ្នកបម្រើរបស់ព្រះអង្គ» ។
អាចបញ្ជាក់នៅក្នុងបុរសទីមួយ។ ការបកប្រែផ្សេងទៀត «ខ្ញុំ»
2 Samuel 7:21
ព្រះអង្គបានសម្តែងកិច្ចការដ៏អស្ចារ្យដល់អ្នកបម្រើរបស់ព្រះអង្គ
នៅទីនេះ «ព្រះបន្ទូល» តំណាងឲ្យអ្វីដែលព្រះជាម្ចាស់បានសន្យាដើម្បីធ្វើ។
ការបកប្រែផ្សេងទៀត «ដោយសារតែអ្វី ដែលព្រះអង្គបានសន្យាថានឹងធ្វើ»
គឺព្រះអង្គបានសម្រេចបំណងព្រះហឫទ័យរបស់ព្រះអង្គ
«ដើម្បីសម្រេចនូវអ្វីដែលព្រះអង្គរៀបចំគម្រោងផែនការធ្វើ»
តាមព្រះបន្ទូលរបស់ព្រះអង្គ។
ព្រះបាទដាវីឌចាត់ទុកព្រះអង្គផ្ទាល់ជា «អ្នកបម្រើរបស់ព្រះអង្គ»។
អាចថ្លែងនៅក្នុងបុរសទីមួយ។ ការបកប្រែផ្សេងទៀត «ចំពោះទូលបង្គំ»
ដែលយើងធ្លាប់បានឮគេតំណាលមកនោះ។
ឃ្លា «ជាមួយត្រចៀករបស់យើងផ្ទាល់» ត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
ការបកប្រែផ្សេងទៀត «ដូចដែលខ្លួនយើងបានឮ»
តាមដែលយើងធ្លាប់បានឮ
នៅទីនេះ «យើង» សំដៅទៅលើព្រះបាទដាវីឌ និងប្រជាជាតិអ៊ីស្រាអែល។
តើជាតិសាសន៍ណាដូចជាប្រជាជនអ៊ីស្រាអែលរបស់ព្រះអង្គនោះ គឺប្រជាជាតិមួយនៅលើផែនដី
ដែលទ្រង់បានយាងទៅសង្គ្រោះគេ មកធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់នោះ?
ព្រះបាទដាវីឌប្រើសំណួរមួយបញ្ជាក់ថា
គ្មានប្រជាជាតិណាផ្សេងទៀតដូចអ៊ីស្រាអែលទេ។ ការបកប្រែផ្សេងទៀត
«គ្មានប្រជាជាតិណាដូចអ៊ីស្រាអែល ដែលជាប្រជារាស្ត្ររបស់អ្នកទេ
ជាប្រជាជាតិតែមួយនៅលើផែនដី ដែលព្រះអង្គជាព្រះជាម្ចាស់បានទៅ
ហើយនិងបានជួយសង្គ្រោះដោយព្រះអង្គផ្ទាល់»។
ឬឲ្យពួកគេមានកេរ្តិ៍ឈ្មោះទៀតផង
នៅទីនេះ «ព្រះនាម» តំណាងឲ្យកេរ្តិ៍ឈ្មោះរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ដើម្បីធ្វើឲ្យមនុស្សទាំងអស់ដឹងថា ព្រះអង្គជានរណា»
នៅក្នុងទឹកដីរបស់ទ្រង់
នៅទីនេះ «ដី» តំណាងឲ្យប្រជាជន។ ការបកប្រែផ្សេងទៀត
«សម្រាប់ប្រជាជនរបស់ព្រះអង្គ»
បានបណ្តេញជាតិសាសន៍នានា
នៅទីនេះ «ប្រជាជាតិ» តំណាងឲ្យក្រុមប្រជាជន
ដែលបានកំពុងរស់នៅក្នុងទឹកដីកាណាន។
2 Samuel 7:24
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តមានបន្ទូលទៅកាន់ព្រះអម្ចាស់។
ឥឡូវនេះ
នៅទីនេះ «ឥឡូវនេះ» មិនមានន័យថា «នៅពេលនេះទេ» ប៉ុន្តែ
ត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះចំណុចសំខាន់
ដែលនៅខាងក្រោម។
សូមឲ្យព្រះបន្ទូលសន្យា ដែលទ្រង់បានសន្យាជាមួយអ្នកបម្រើរបស់ទ្រង់
និងគ្រួសាររបស់គេបានរឹងមាំរហូតតទៅ
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «សូមឲ្យព្រះអង្គធ្វើអ្វី
ដែលព្រះអង្គបានសន្យាជាមួយទូលបង្គំ និងគ្រួសាររបស់ទូលបង្គំ
ហើយសូមឲ្យការសន្យារបស់ព្រះអង្គមិនផ្លាស់ប្តូរ»
អ្នកបម្រើរបស់ទ្រង់ និងគ្រួសាររបស់គេ
ព្រះបាទដាវីឌកំពុងមានបន្ទូលអំពីទ្រង់ផ្ទាល់ ជាបុរសទីបី។
អាចបញ្ជាក់នៅក្នុងបុរសទីមួយ។ ការបកប្រែផ្សេងទៀត
«ទូលបង្គំនិងគ្រួសាររបស់ទូលបង្គំ»
សូមឲ្យព្រះបន្ទូលរបស់ទ្រង់បានឧត្តុង្គឧត្តុមជានិច្ច
នៅទីនេះ «ព្រះនាម» តំណាងឲ្យកេរ្តិ៍ឈ្មោះរបស់ព្រះអម្ចាស់។
នៅពេលដែលពូជពង្សរបស់ទូលបង្គំ ដាវីឌ អ្នកបម្រើរបស់ទ្រង់
នៅទីនេះ «ពូជពង្ស» តំណាងឲ្យគ្រួសារ។ ការបកប្រែផ្សេងទៀត «គ្រួសារទូលបង្គំ»
បានស្ថិតស្ថេរនៅចំពោះព្រះអង្គ រហូតតទៅ។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«មានសុវត្ថិភាពដោយសារតែព្រះអង្គ» ឬ «បន្តដោយសារតែព្រះអង្គ»
2 Samuel 7:27
ទ្រង់បានប្រទានឲ្យអ្នកបម្រើរបស់ទ្រង់នឹងធ្វើឲ្យមានពូជពង្សរបស់ទូលបង្គំឡើង

ព្រះបាទដាវីឌសំដៅលើអង្គទ្រង់ផ្ទាល់«អ្នកម្រើទ្រង់»។ ការបកប្រែផ្សេងទៀត: «ចំពោះទូលបង្គំដែលនឹងមានពូជពង្សមួយឱ្យទូលបង្គំ»
ទ្រង់នឹងធ្វើឲ្យមានពូជពង្សរបស់ទូលបង្គំឡើង
នៅទីនេះពាក្យ«ពូជពង្ស»
សំដៅទៅលើជីដូនជីតារបស់ព្រះបាទដាវីឌដែលបន្តធ្វើជាអ្នកគ្រប់គ្រងរបស់អ៊ីស្រាអែលនៅ
ក្នុង ៧: ៣
ព្រះអម្ចាស់បានសួរព្រះបាទដាវីឌប្រសិនបើព្រះអង្គនឹងកសាងព្រះដំណាក់សម្រាប់ព្រះអង្គ
នៅទីនោះ «ផ្ទះ» តំណាងឱ្យព្រះវិហារមួយ។
ប្រសិនបើភាសារបស់អ្នកមានពាក្យដែលអាចបង្ហាញពីគំនិតទាំងពីរសូមប្រើវានៅទីនេះនិង
៧: ៤ ។
ឥឡូវនេះ
នេះមិនមានន័យថា «នៅពេលនេះទេ»
ប៉ុន្តែត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះចំណុចសំខាន់ដែលនៅខាងក្រោម។

ព្រះបន្ទូលរបស់ទ្រង់គឺសុទ្ធតែពិត
នៅទីនេះពាក្យ «តំណាងអោយអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល» ។
ការបកប្រែផ្សេងទៀត: «ខ្ញុំជឿជាក់លើអ្វីដែលព្រះអង្គមានព្រះបន្ទូល»
ពូជពង្សរបស់ទូលបង្គំនឹងទទួលព្រះពរអស់កល្បជានិច្ច»។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត:«ហើយព្រះអង្គនឹងបន្តប្រទានពរដល់គ្រួសារទូលបង្គំជារៀងរហូត»
ពូជពង្សរបស់ទូលបង្គំ
នៅទីនេះព្រះបាទដាវីឌចាត់ទុកអង្គទ្រង់ផ្ទាល់ជា «អ្នកបម្រើរបស់ព្រះអង្គ»។
ការបកប្រែផ្សេងទៀត:«ពូជពង្សរបស់ទូលបង្គំ» ឬ «គ្រួសារទូលបង្គំ»(សូមមើល figs-123person)
ពូជពង្ស
នៅទីនេះ «ពូជពង្ស» តំណាងឲ្យក្រុមគ្រួសាររបស់ព្រះបាទដាវីឌ។

---

8 [1]គ្រានោះព្រះបាទដាវីឌ ត្រឡប់ពីវាយពួកសាសន៍ភីលីស្ទីន ហើយទ្រង់បានយកជ័យជម្នះលើពួកគេ។ ព្រះបាទដាវីឌដណ្តើមបានក្រុងកាថ
និងភូមិនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ជនជាតិភីលីស្ទីន។
[2]ហើយទ្រង់ក៏បានវាឈ្នះជនជាតិម៉ូអាប់ ទ្រង់បានសម្លាប់ពួកគេដោយឲ្យពួកគេដេកលើដី ជាបីខ្សែ។ គឺពីរភាគបីត្រូវសម្លាប់ និងមួយភាគបីទុកឲ្យនៅរស់។
ដូច្នេះជនជាតិម៉ូអាប់ក្លាយទៅជាអ្នកបម្រើរបស់ព្រះបាទដាវីឌ ហើយចាប់ផ្តើមបង់ឈ្នួសារអាករទៅទ្រង់។
[3]ព្រះបាទដាវីឌ ក៏វាយឈ្នះហាដាដេស៊ើរ បុត្ររបស់ព្រះបាទហាដារេស៊ើរ ស្តេចក្រុងសូបា
ក្នុងអំឡុងពេលដែលព្រះបាទហាដាដេស៊ើរកំពុងតែកាន់កាប់តំបន់ទន្លេអ៊ឺប្រាតឡើងវិញ។[4]ព្រះបាទដាវីឌចាប់បានទ័ពសេះរបស់ទ្រង់ចំនួន មួយពាន់ប្រាំពីររយ
និងទ័ពថ្មើរជើងពីរម៉ឺននាក់។ ទ្រង់បានកាត់សរសៃកែងជើងសេះទាំងអស់ ដោយទុកតែមួយរយក្បាលប៉ុណ្ណោះ។
[5]នៅពេលនោះជនជាតិស៊ីរីនៅក្រុងដាម៉ាសបានមកជួយព្រះបាទហាដាដេស៊ើរ បុត្រព្រះបាទសូបា ព្រះបាទដាវីឌសម្លាប់ពួកគេចំនួនពីរម៉ឺននាក់។
[6]ព្រះបាទដាវីឌបានដាក់ទេសាភិបាល ឲ្យត្រួតត្រាលើស្រុកស៊ីរី នៅក្រុងដាម៉ាស់ ហើយជនជាតិស៊ីរីបានធ្លាក់ជាចំណុះព្រះបាទដាវីឌ
ហើយត្រូវនាំសួយសារអាករថ្វាយទ្រង់ផង។ ព្រះអម្ចាស់ប្រទានជ័យជម្នះអោយព្រះបាទដាវីឌ នៅគ្រប់កន្លែងដែលស្តេចទៅ។
[7]ព្រះបាទដាវីឌរឹបអូសយកខែលមាស ពីពួកបរិវាររបស់ព្រះបាទហាដាដេស៊ើរ ហើយនាំរបស់ទាំងនោះទៅក្រុងយេរូសាឡិម។
[8]ព្រះបាទដាវីឌក៏រឹបអូសយកលង្ហិនយ៉ាងច្រើនសន្ធឹកសន្ធាប់ពីក្រុងបេថាស និងក្រុងបេរូថាយ។
[9]កាលនោះ ព្រះបាទថូអ៊ី ជាស្តេចនៃស្រុកហាម៉ាស បានឮថាព្រះបាទដាវីឌបានវាយឈ្នះកងទ័ពទាំងមូលរបស់ព្រះបាទហាដាដេស៊ើរ[10]នោះទ្រង់ក៏ចាត់ព្រះបាទហាដូរ៉ាម
បុត្ររបស់ទ្រង់ឲ្យមកចូលគាល់ព្រះបាទដាវីឌ ដើម្បីអបអរសាទរចំពោះជ័យជម្នះរបស់ទ្រង់ ព្រោះព្រះបាទដាវីឌបានវាយឈ្នះកងទ័ពទាំងមូលរបស់ព្រះបាទហាដាដេស៊ើរ
និងព្រះបាទហាដាដេស៊ើរផង ក៏ដោយសារព្រះបាទហាដាដេស៊ើរ ធ្វើសឹកសង្គ្រាមជាមួយព្រះបាទថូអ៊ី។ ព្រះបាទហាដូយ៉ាបាននាំទៅជាមួយទ្រង់នូវវត្ថុដែលធ្វើពីប្រាក់ មាស
និងលង្ហិន។
[11]ព្រះបាទដាវីឌបានយករបស់ទាំងនោះទៅថ្វាយព្រះអម្ចាស់ ជាមួយគ្នានោះ ស្តេចថ្វាយប្រាក់ មាស ដែលបានពីជាតិសាសន៍នានាដែលបានពីការវាយឈ្នះពី[12]ជនជាតិស៊ីរី
ជនជាតិម៉ូអាប់ ពីប្រជាជនអាំម៉ូន ពីពួកភីលីស្ទីន និង ពួកអាម៉ាឡេក រួមគ្នាជាមួយនឹងជ័យភ័ណ្ឌដែលរឹបអូសបានពីព្រះបាទហាដាដេស៊ើរ បុត្រព្រះបាទរេហូប
ជាស្តេចស្រុកសូបា។
[13]ព្រះកិត្តិនាមរបស់ព្រះបាទដាវីឌកាន់តែល្បីល្បាញថែមទៀត នៅពេលដែលទ្រង់ត្រឡប់ពីច្បាំងឈ្នះជនជាតិស៊ីរី នៅជ្រលងភ្នំអំបិលវិញ
ជាមួយកងទ័ពរបស់ពួកគេប្រាំបីពាន់នាក់។[14]ទ្រង់បានដាក់ទេសាភិបាលត្រួតត្រាលើស្រុកអេដុមទាំងមូល ហើយជនជាតិអេដុមទាំងអស់មកជាចំណុះរបស់ព្រះបាទដាវីឌ។
ព្រះអម្ចាស់ប្រទានឲ្យស្តេចដាវីឌមានជ័យជម្នះគ្រប់ទីកន្លែងដែលទ្រង់ទៅ។
[15]ព្រះបាទដាវីឌសោយរាជ្យលើអ៊ីស្រាអែលទាំងមូល ហើយទ្រង់គ្រប់គ្រងលើប្រជាជនដោយសុចរិតនិងទៀងត្រង់។[16]លោកយ៉ូអាប់ កូនរបស់អ្នកស្រីសេរូយ៉ា
មានមុខងារជាមេបញ្ជាការកងទ័ព ហើយលោកយេហូសាផាត កូនរបស់លោកអហ៊ីលូដ ជាអ្នកនាំព្រះរាជសាររបស់ស្តេច។[17]លោកសាដុក កូនរបស់លោកអហ៊ីទូប
និងលោកអហ៊ីមេឡេក កូនរបស់លោកអបៀថើរ មានមុខងារជាបូជាចារ្យ ចំណែកឯលោកសេរ៉ាយ៉ា ជាលេខាធិការ។[18]លោកបេណាយ៉ាជាកូនរបស់លោកយេហូយ៉ាដា
ជាមេបញ្ជាការលើក្រុមកេរេធីម និង ក្រុមពេលេធីម ចំណែកឯបុត្រាទាំងឡាយរបស់ព្រះបាទដាវីឌ មានមុខងារជាមេក្រុមលើអ្នកណែនាំរបស់ព្រះមហាក្សត្រ។

---

2 Samuel 8:1
ព្រះបាទដាវីឌដណ្តើមបាន
នៅទីនេះព្រះបាទដាវីឌតំណាងឲ្យទាហានរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ព្រះបាទដាវីឌនិងទាហានរបស់ព្រះអង្គបានវាយប្រហារ»
2 Samuel 8:2
ហើយទ្រង់ក៏បានវាឈ្នះ
នៅទីនេះ «ទ្រង់» សំដៅទៅលើព្រះបាទដាវីឌ
ដែលតំណាងឲ្យទាហានរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកពួកគេចុះចាញ់»
ទ្រង់បានសម្លាប់ពួកគេដោយឲ្យពួកគេដេកលើដី ... គឺពីរភាគបីត្រូវសម្លាប់,
និងមួយភាគបីទុកឲ្យនៅរស់
នៅទីនេះ «ខ្សែ» គឺជា «ខ្សែពួរ»។ ព្រះបាទដាវីឌបានឲ្យ ទាហានដេកនៅលើដី
ដើម្បីវាស់និងតម្រៀបជាបីក្រុម។ បុរសពីរក្រុមត្រូវបានសម្លាប់
ហើយក្រុមទីបីនៅរស់។
2 Samuel 8:3
ព្រះបាទដាវីឌ ក៏វាយឈ្នះហាដាដេស៊ើរ
នៅទីនេះ ទាំងពីរគឺ «ព្រះបាទដាវីឌ» និង «ហាដាដេសស៊ើរ»

តំណាងឲ្យកងទ័ពរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «ព្រះបាទដាវីឌ
និងកងទ័ពរបស់ព្រះអង្គ បន្ទាប់មកបានវាយប្រហារកងទ័ពហាដាដេស៊ើរ»
ហាដាដេស៊ើរ ... រ៉េហុប
ទាំងនេះជាឈ្មោះបុរស ។
ក្រុងសូបា
នេះជាឈ្មោះនៃតំបន់មួយនៅក្នុងប្រទេសស៊ីរី។
កាន់កាប់តំបន់
«ដើម្បីគ្រប់គ្រងតំបន់ឡើងវិញ» ឬ «ដើម្បីចាប់យកតំបន់មួយឡើងវិញ»
ទ័ពថ្មើរជើងពីរម៉ឺននាក់
« ២០,០០០ នាក់ជាទ័ពថ្មើជើង»។
ទ្រង់បានកាត់សរសៃកែងជើង
នេះជាការអនុវត្ត កន្លែងដែលសរសៃពួរនៅជើងខាងក្រោយត្រូវបានកាត់
ដើម្បីកុំឲ្យសេះអាចរត់បាន។
ដោយទុកតែ
«ញែកទុកដោយឡែកឲ្យបានគ្រប់គ្រាន់» ឬ «សន្សំទុកឲ្យបានគ្រប់គ្រាន់»
មួយរយក្បាលប៉ុណ្ណោះ
«១០០ រទេះ»

generated on Wed Sep 10 16:16:32 2025

2 Samuel 8:5
ព្រះបាទដាវីឌសម្លាប់
នៅទីនេះ ព្រះបាទដាវីឌតំណាងឲ្យទាហានរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ព្រះបាទដាវីឌនិងទាហានរបស់ព្រះអង្គត្រូវបានសម្លាប់»
ចំនួនពីរម៉ឺននាក់
បុរសជនជាតិស៊ីរីចំនួនពីរពាន់នាក់ «បុរសស៊ីរីចំនួន ២២,០០០ នាក់»
បានដាក់ទេសាភិបាល ឲ្យត្រួតត្រាលើស្រុកស៊ីរី
«បានបញ្ជាឲ្យទាហានកងធំរបស់ព្រះអង្គ ស្ថិតនៅតែក្នុងអារ៉ាម»
2 Samuel 8:7
ព្រះបាទដាវីឌរឹបអូសយក ... ព្រះបាទដាវីឌក៏រឹបអូសយក
នៅទីនេះ ព្រះបាទដាវីឌតំណាងឲ្យទាហានរបស់ព្រះអង្គ។
ក្រុងបេថាស និងក្រុងបេរូថាយ
ទាំងនេះជាឈ្មោះទីកន្លែង ។
2 Samuel 8:9
ព្រះបាទថូអ៊ី ... ហាដូរ៉ាម
ទាំងនេះជាឈ្មោះបុរស ។
ស្រុកហាម៉ាស
នេះជាឈ្មោះទីកន្លែង ។
ព្រះបាទដាវីឌបានវាយឈ្នះ
នៅទីនេះ «ព្រះបាទដាវីឌ» តំណាងឲ្យកងទ័ពរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«កងទ័ពរបស់ព្រះបាទដាវីឌបានវាយឈ្នះ»
2 Samuel 8:11
ពួកអាម៉ាឡេក
«និងអាម៉ាឡេក»
ជយភណ្ឌដែលរឹបអូសបាន
ទាំងនេះជារបស់មានតម្លៃ
ដែលទាហានយកពីប្រជាជនដែលពួកគេបានវាយប្រហារ។
ព្រះបាទហាដាដេស៊ើរ បុត្រព្រះបាទរេហូប ជាស្តេចស្រុកសូបា។
បកប្រែឈ្មោះទាំងនេះដូចនៅក្នុង ៨:៣។
2 Samuel 8:13
ព្រះកិត្តិនាមរបស់ព្រះបាទដាវីឌកាន់តែល្បីល្បាញ
នៅទីនេះ «ព្រះនាម»សំដៅទៅលើកេរ្តិ៍ឈ្មោះរបស់ព្រះបាទដាវីឌ។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះបាទដាវីឌល្បីល្បាញណាស់»
នៅជ្រលងភ្នំអំបិល
នេះជាឈ្មោះកន្លែងមួយ។ ទីតាំងពិតប្រាកដរបស់វាគឺមិនស្គាល់នៅឡើយទេ។
កងទ័ពរបស់ពួកគេប្រាំបីពាន់នាក់
«១៨,០០០ នាក់ជាបុរស»
ទ្រង់បានដាក់ទេសាភិបាលត្រួតត្រាលើស្រុកអេដុមទាំងមូល
«ព្រះអង្គបានបញ្ជាឲ្យក្រុមទាហានរបស់ព្រះអង្គ
ឲ្យស្ថិតនៅក្នុងតំបន់ទូទាំងស្រុកអេដុមទាំងអស់»
2 Samuel 8:15
លោកយ៉ូអាប់ កូនរបស់អ្នកស្រីសេរូយ៉ា
បកប្រែឈ្មោះទាំងនេះដូចនៅក្នុង ២:១២ ។
លោកអហ៊ីលូដ ... លោកអហ៊ីទូប ... លោកអហ៊ីមេឡែក ... លោកសេរ៉ាយ៉ា... លោកយេហូយ៉ាដា
ទាំងនេះជាឈ្មោះបុរស។
លោកអហ៊ីលូដ ជាអ្នកនាំព្រះរាជសារ
អ្នកកត់ត្រាជាមនុស្សម្នាក់ ដែលបាននិយាយទៅកាន់ប្រជាជនហើយ
បានប្រាប់ពួកគេអំពីការប្រកាសរបស់ស្តេច។ ការបកប្រែផ្សេងទៀត
«លោកអហ៊ីទូបជាអ្នកនាំសារ»
ក្រុមកេរេធីម ... ក្រុមពេលេធីម
ទាំងនេះជាឈ្មោះក្រុមមនុស្ស។ ប្រជាជនទាំងនេះជាអង្គរក្សរបស់ព្រះបាទដាវីឌ។

---

9 [1]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «តើមាននរណាម្នាក់ក្នុងញាតិវង្សរបស់ព្រះបាទសូល ដែលនៅរស់រានមានជីវិត ដែលយើងអាចសម្តែងសេចក្តីសប្បុរសចំពោះគេ
ដោយយល់ដល់សម្តេចយ៉ូណាថានឬទេ?»[2]កាលនោះគេបាននាំបុរសម្នាក់មកជួបព្រះរាជា គឺអ្នកបម្រើម្នាក់ក្នុងញាតិវង្សរបស់ព្រះបាទដាវីឌដែលមានឈ្មោះថា ស៊ីបា។
ព្រះបាទដាវីឌមានរាជឱង្ការសួរគាត់ថា៖ «តើអ្នកឬជាស៊ីបា?» គាត់ទូលស្តេចថា៖ «បពិត្រ! គឺទូលបង្គំនេះហើយ»។
[3]នោះ ព្រះរាជាមានរាជឱង្ការថា៖ «តើក្នុងវង្សញាតិរបស់ព្រះបាទសូល មិនមានអ្នកណាម្នាក់នៅមានជីវិត
ដែលយើងអាចសម្តែងសេចក្តីសប្បុរសនៃព្រះចំពោះគេបានទេឬ?» លោកស៊ីបាទូលទៅស្តេចវិញថា៖ «សម្តេចយ៉ូណាថាន់ នៅមានបុត្រាមួយអង្គ ដែលពិការជើង»។
[4]ព្រះរាជាសួរលោកថា៖ «តើគេនៅឯណា?» លោកស៊ីបាទូលថា៖ គឺលោកស្នាក់នៅក្នុងផ្ទះរបស់លោកម៉ាកៀរ ជាកូនប្រុសរបស់លោកអាំមាល ក្នុងក្រុងឡូរដេបា»។
[5]នោះព្រះបាទដាវីឌបានចាត់គេឲ្យទៅរកគាត់ និងនាំពីផ្ទះរបស់លោកម៉ាកៀរ ជាកូនរបស់អាំមាល ពីក្រុងឡូរដេបាមក។[6]សម្តេចមេភីបូសែត ជាបុត្ររបស់សម្តេចយ៉ូណាថាន់
និងជាចៅរបស់ព្រះបាទសូល បានចូលគាល់ព្រះបាទដាវីឌ លោកបានឱនចុះក្រាបមុខដល់ដីថ្វាយបង្គំស្តេច។ ព្រះបាទដាវីឌមានរាជឱង្ការសួរថា៖
«តើអ្នកឬជាមេភីបូសែត?» លោកទូលថា៖ «បពិត្រព្រះករុណា! ទូលបង្គំជាអ្នកបម្រើរបស់ព្រះករុណា!»
[7]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «កុំភ័យខ្លាចយើងធ្វើអ្វី យើងនឹងប្រព្រឹត្តចំពោះអ្នកដោយសប្បុរស ដោយយល់ដល់សម្តេចយ៉ូណាថាន់ ជាបិតារបស់អ្នក
ហើយយើងនឹងប្រគល់ដីធ្លីទាំងប៉ុន្មានដែលជារបស់ព្រះបាទសូល ជាជីតារបស់អ្នកឲ្យទៅអ្នកវិញ នោះអ្នកនឹងបរិភោគរួមតុជាមួយយើងជារៀងរាល់ថ្ងៃរហូតតទៅ»។
[8]សម្តេចមេភីបូសែតក្រាបថ្វាយបង្គំ ហើយទូលស្តេចថា៖ «បពិត្រព្រះករុណា! តើទូលបង្គំនេះមានឋានៈជាអ្វី ដែលព្រះករុណាយកចិត្តទុកដាក់ជាមួយ
ទូលបង្គំប្រៀបបាននឹងឆ្កែងាប់មួយក្បាលតែប៉ុណ្ណោះ?»
[9]ពេលនោះ ស្តេចបានត្រាស់ហៅលោកស៊ីបា ជាអ្នកបម្រើរបស់ព្រះបាទសូលមក ហើយមានរាជឱង្ការថា៖ គ្រប់ទាំងអ្វីៗទាំងអស់
ដែលជាសម្បត្តិរបស់ព្រះបាទសូលនិងញាតិរបស់ទ្រង់ យើងបានប្រគល់ឲ្យទៅចៅរបស់ចៅហ្វាយរបស់លោកហើយ។
[10]លោកនិងកូនចៅរបស់លោកព្រមទាំងអ្នកបម្រើរបស់លោកត្រូវនាំគ្នាធ្វើស្រែចំការនោះឲ្យលោក ហើយប្រមូលភោគផលទុកសម្រាប់គាត់ ដូច្នេះ
ចៅហ្វាយរបស់លោកនឹងមានអាហារសម្រាប់បរិភោគ។ សម្រាប់សម្តេចមេភីបូសែត ចៅប្រុសចៅហ្វាយរបស់លោកត្រូវបរិភោគរួមតុជាមួយយើងជារៀងរាល់ថ្ងៃ»។
លោកស៊ីបាមានកូនប្រុសចំនួនដប់ប្រាំនាក់ និងអ្នកបម្រើម្ភៃនាក់។
[11]នោះគាត់ទូលស្តេចថា៖ «បពិត្រព្រះករុណា ទូលបង្គំជាអ្នកបម្រើរបស់ទ្រង់ នឹងប្រព្រឹត្តតាមបញ្ជាទាំងប៉ុន្មានដែលព្រះករុណាបង្គាប់មកទូលបង្គំ។ ស្តេចបន្ថែមទៀតថា៖
«ឯមេភីបូសែតដែលនឹងត្រូវបរិភោគរួមតុជាមួយយើងរាល់ថ្ងៃ គឺដូចជាបុត្រាមួយអង្គរបស់ពព្រះរាជាដែរ»។[12]លោកមេភីបូសែតមានកូនប្រុសម្នាក់ ឈ្មោះមីកា។
មនុស្សទាំងអស់ដែលរស់នៅក្នុងផ្ទះរបស់លោកស៊ីបា សុទ្ធតែជាអ្នកបម្រើរបស់លោកមេភីបូសែត។[13]លោកមេភីបូសែតបានស្នាក់នៅក្រុងយេរូសាឡឹម
ហើយលោកតែងតែរួមតុអាហារជាមួយស្តេច ជើងរបស់សម្តេចមេភីបូសែតទាំងពីរគឺពិការ។

---

2 Samuel 9:1
ចំពោះគេ ដោយយល់ដល់សម្តេចយ៉ូណាថាន
«ដោយសារទូលបង្គំស្រឡាញ់សម្តេចយ៉ូណាថាន»
យល់ដល់សម្តេចយ៉ូណាថាន
សម្តេចយ៉ូណាថានជាបុត្ររបស់ព្រះបាទសូល
និងជាមិត្តដ៏ល្អបំផុតរបស់ព្រះបាទដាវីឌ។
ស៊ីបា
នេះជាឈ្មោះបុរស។
គឺទូលបង្គំនេះហើយ
ស៊ីបាហៅខ្លួនឯងថា «អ្នកបម្រើរបស់ព្រះអង្គ»
ដើម្បីបង្ហាញការគោរពខ្លាំងដល់ព្រះបាទដាវីឌ។
2 Samuel 9:3
យើងអាចសម្តែងសេចក្តីសប្បុរសនៃព្រះ
នាមអរូបី «សេចក្តីសប្បុរស» អាចបញ្ជាក់ថាជា «ចិត្តល្អ»។ ការបកប្រែផ្សេងទៀត
«ខ្ញុំអាចមានចិត្តល្អដូច ដែលខ្ញុំបានសន្យាជាមួយព្រះជាម្ចាស់ថាខ្ញុំនឹង»
ដែលពិការជើង

generated on Wed Sep 10 16:16:32 2025

«អស់អ្នកដែលជើងត្រូវបានខូច» ពាក្យថា «ជើង»
នៅទីនេះសំដៅទៅលើសមត្ថភាពដើរ។ ការបកប្រែផ្សេងទៀត
«អ្នកណាមិនអាចដើរបាន»
លោកម៉ាគៀរ ... លោកអាំមាល
ទាំងនេះជាឈ្មោះទីកន្លែង។
ក្រុងឡូរដេបា
នេះជាឈ្មោះទីកន្លែង។
2 Samuel 9:5
ព្រះបាទដាវីឌបានចាត់
គេយល់ថា ព្រះបាទដាវីឌបានចាត់អ្នកនាំសារ។
សម្តេចមេភីបូសែត
បកប្រែដូចនៅក្នុង ៤:៤។
បានចូលគាល់ព្រះបាទដាវីឌ
ពាក្យ «បានមក» អាចបកប្រែ «បានទៅ» ។
ទូលបង្គំជាអ្នកបម្រើរបស់ព្រះករុណា!
លោកមេភីបូសែតសំដៅទៅលើអង្គទ្រង់ផ្ទាល់ជា «អ្នកបម្រើរបស់ព្រះអង្គ»
ដើម្បីបង្ហាញការគោរពដ៏ខ្លាំង ដល់ព្រះបាទដាវីឌ។
2 Samuel 9:7
ដោយយល់ដល់សម្តេចយ៉ូណាថាន់ ជាបិតារបស់អ្នក
«ពីព្រោះ ខ្ញុំស្រឡាញ់បិតារបស់ព្រះអង្គ សម្តេចចយ៉ូណាថាន»
អ្នកនឹងបរិភោគរួមតុជាមួយយើងជារៀងរាល់ថ្ងៃរហូតតទៅ
នៅទីនេះ «តុរបស់យើង» តំណាងឲ្យការនៅជាមួយព្រះបាទដាវីឌ
ឬនៅចំពោះព្រះវត្តមានរបស់ព្រះអង្គ។ ការបរិភោគជាមួយស្តេចនៅតុរបស់ទ្រង់
គឺជាកិត្តិយសដ៏ធំធេង។ ការបកប្រែផ្សេងទៀត «អ្នកត្រូវញ៉ាំជាមួយយើងជានិច្ច»
បពិត្រព្រះករុណា! តើទូលបង្គំនេះមានឋានៈជាអ្វី ដែលព្រះករុណាយកចិត្តទុកដាក់ជាមួយ
ទូលបង្គំប្រៀបបាននឹងឆ្កែងាប់មួយក្បាលតែប៉ុណ្ណោះ?
សំណួរដ៏ប៉ិនមប្រសប់នេះបង្ហាញថា សម្តេចមេភីបូសែតយល់ថា
ទ្រង់មិនសំខាន់គ្រប់គ្រាន់ចំពោះស្តេចមើលថែទ្រង់ទេ។
អាចបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត «ទូលបង្គំដូចជាឆ្កែងាប់។
ខ្ញុំទូលបង្គំមិនសមសម្រាប់ព្រះអង្គ មានព្រះហឫទ័យសប្បុរសចំពោះទូលបង្គំទេ»។
ឆ្កែងាប់មួយក្បាលតែប៉ុណ្ណោះ
នៅទីនេះសម្តេចមេភីបូសែតតំណាងវង្សត្រកូលរបស់ព្រះបាទសូល
ហើយទ្រង់ប្រៀបធៀបអង្គទ្រង់ផ្ទាល់ទៅនឹង «ឆ្កែងាប់» ។
សត្វឆ្កែជាសត្វព្រៃមិនត្រូវបានគេយកចិត្តទុកដាក់ និងមានសារៈសំខាន់តិចតួច។
ឆ្កែដែលងាប់នឹងត្រូវបានគេចាត់ទុកថាមិនសូវសំខាន់។ ការបកប្រែផ្សេងទៀត
»មនុស្សបែបហ្នឹងដូចទូលបង្គំ ដែលគ្មានតម្លៃដូចឆ្កែងាប់»
2 Samuel 9:9
លោកត្រូវបរិភោគរួមតុជាមួយយើងជារៀងរាល់ថ្ងៃ
នៅទីនេះ «តុរបស់យើង» តំណាងឲ្យការនៅជាមួយព្រះបាទដាវីឌ
ឬនៅចំពោះព្រះវត្តមានរបស់ព្រះអង្គ។ ការបរិភោគជាមួយស្តេចនៅតុរបស់ព្រះអង្គ
គឺជាកិត្តិយសដ៏ធំធេង។ ការបកប្រែផ្សេងទៀត «អ្នកត្រូវញ៉ាំជាមួយយើងជានិច្ច»
លោកស៊ីបា ... អ្នកបម្រើ
នៅទីនេះ «ឥឡូវនេះ» ធ្វើឲ្យមានការសម្រាកនៅក្នុងសាច់រឿងសំខាន់ៗ។
អ្នកអធិប្បាយផ្តល់ព័ត៌មានសង្ខេបអំពីលោកស៊ីបា។
មានកូនប្រុសចំនួនដប់ប្រាំនាក់ និងអ្នកបម្រើម្ភៃនាក់។
«កូនប្រុស១៥នាក់ និងអ្នកបម្រើ២០នាក់»
2 Samuel 9:11
បពិត្រព្រះករុណា ទូលបង្គំជាអ្នកបម្រើរបស់ទ្រង់
នឹងប្រព្រឹត្តតាមបញ្ជាទាំងប៉ុន្មានដែលព្រះករុណាបង្គាប់មកទូលបង្គំ។
ស៊ីបាសំដៅទៅលើខ្លួនគាត់ថាជា «អ្នកបម្រើរបស់ព្រះអង្គ»
ហើយសំដៅទៅលើព្រះបាទដាវីឌជា «ម្ចាស់របស់ទូលបង្គំ» ។
ការបកប្រែផ្សេងទៀត «ទូលបង្គំអ្នកបម្រើរបស់ព្រះអង្គ នឹងធ្វើអ្វីៗទាំងអស់
ដែលព្រះអង្គជាស្តេចរបស់ទូលបង្គំ បញ្ជាឲ្យទូលបង្គំឲ្យធ្វើ»
មីកា
នេះជាឈ្មោះកូនប្រុសរបស់លោកមេភីបូសែត។
មនុស្សទាំងអស់ដែលរស់នៅក្នុងផ្ទះរបស់លោកស៊ីបា
នៅទីនេះ «ផ្ទះ» តំណាងឲ្យក្រុមគ្រួសារលោកស៊ីបា។ ការបកប្រែផ្សេងទៀត
«គ្រួសារទាំងអស់របស់លោកស៊ីបា»
លោកតែងតែរួមតុអាហារជាមួយស្តេច
នៅទីនេះ «តុរបស់យើង» តំណាងឲ្យការនៅជាមួយព្រះបាទដាវីឌ
ឬនៅចំពោះព្រះវត្តមានរបស់ព្រះអង្គ។ ការបរិភោគជាមួយស្តេចនៅតុរបស់ទ្រង់
គឺជាកិត្តិយសដ៏ធំធេង។ ការបកប្រែផ្សេងទៀត «អ្នកត្រូវញ៉ាំជាមួយយើងជានិច្ច»
ជើងរបស់សម្តេចមេភីបូសែតទាំងពីរគឺពិការ។
ជើងទាំងពីររបស់គាត់ត្រូវខូចខាត។ នៅទីនេះ «ជើង»
តំណាងឲ្យសមត្ថភាពក្នុងការដើរ។ ការបកប្រែផ្សេងទៀត
«ទោះបីជាគាត់មិនអាចដើរ»

---

10 [1]ក្រោយបន្តិចមក ស្តេចនៃជនជាតិអាំម៉ូនបានចូលទិវង្គត ហើយបុត្រារបស់ទ្រង់ព្រះនាមហានូន បានគ្រងរាជ្យបន្ត។[2]ព្រះបាទដាវីឌមានរាជឱង្ការថា៖
«យើងនឹងសម្តែងសេចក្តីសប្បុរស ចំពោះហានូន ជាកូនរបស់ណាហាស ដូចជាបិតាទ្រង់ធ្លាប់បានសម្តែងសេចក្តីសប្បុរសចំពោះយើង»។ ដូច្នេះ ព្រះបាទដាវីឌ
បានចាត់រាជទូតរបស់ទ្រង់ទៅជួយសម្រាលទុក្ខរបស់ទ្រង់ដោយ បិតារបស់ទ្រង់បានសុគត។ ពួករាជទូតបានចូលទៅក្នុងទឹកដីរបស់ពួកអាំម៉ូន។[3]ប៉ុន្តែ
ពួកអ្នកដឹកនាំរបស់សាសន៍អាំម៉ូន បានទូលទៅហានូន ជាចៅហ្វាយរបស់ពួកគេថា៖ «តើទ្រង់ពិតជាជឿថា ស្តេចដាវីឌចង់លើកតម្កើងបិតាទ្រង់
ដោយចាត់រាជទូតមកសម្រាលទុក្ខទ្រង់ឬ? តើដាវីឌ មិនមែនបញ្ជូនទូតរបស់គេមកដើម្បីអង្កេត ស៊ើបមើលទីក្រុង ក្នុងគោលបំណងវាយដណ្តើមទីក្រុងទេឬ?»
[4]ដូច្នេះ លោកហានូនបានចាប់ពួករាជទូតរបស់ស្តេចដាវីឌ កោរពុកចង្ការរបស់ពួកគេមួយចំហៀង និងកាត់សម្លៀកបំពាក់ពួកគេផ្តាច់ត្រឹមគូថ រួចលែងពួកគេទៅ។
[5]នៅពេលដែលពួកគេទូលរឿងនេះដល់ព្រះបាទដាវីឌ ទ្រង់បានចាត់មនុស្សឲ្យទៅទទួលពួកគេ ព្រោះពួកគេមានសេចក្តីអៀនខ្មាស់ជាខ្លាំង។ ស្តេចបានបង្គាប់មកថា៖
«ចូរអ្នករាល់គ្នាស្នាក់នៅក្រុងយេរីខូ រហូតដល់ពុកចង្ការរបស់អ្នករាល់គ្នាបានដុះឡើងវិញ រួចចាំត្រឡប់មកវិញ»។
[6]កាលពួកជនជាតិអាំម៉ូន ឃើញថាពួកគេបានទៅជាទីគួរស្អប់ខ្ពើមរបស់ស្តេចដាវីឌហើយនោះ ជនជាតិអាំម៉ូន បានចាត់អ្នកនាំសារឲ្យទៅជួលជនជាតិស៊ីរី ពីក្រុង បេត
រេហូប និងក្រុងសូបា បានទ័ពថ្មើរជើងចំនួនពីរម៉ឺននាក់ កងទ័ពរបស់ស្តេចម៉ាកា ចំនួនមួយពាន់នាក់។[7]ពេលដែលព្រះបាទដាវីឌ បានឮដំណឹងនេះ
ទ្រង់បានចាត់លោកយ៉ូអាប់ និងកងទ័ពទាំងអស់។[8]ពួកសាសន៍អាំម៉ូន បានចេញមកបោះទីតាំងទ័ព នៅច្រកចូលទីក្រុងរបស់ពួកគេ ដែលពេលនោះទ័ពថ្មើរជើងស៊ីរី
នៃសូបា និង រេហូប និងម៉ាកា បានចេញមកត្រៀមខ្លួននៅតាមទីវាល។
[9]ពេលដែលលោកយ៉ូអាប់បានឃើញថា លោកត្រូវប្រឈមមុខច្បាំងតទល់ទាំងពីរមុខព្រួញដូច្នេះ
លោកក៏បានជ្រើសរើសពួកទាហានដែលជំនាញបំផុតពីកងទ័ពអ៊ីស្រាអែល ហើយរៀបចំពួកគេជាក្បួនទ័ពចេញទៅតទល់នឹងកងទ័ពស៊ីរី។[10]រីឯពួកទាហានដែលនៅសល់
លោកបានប្រគល់ទៅក្នុងការដឹកនាំរបស់លោកអប៊ីសាយ ប្អូនប្រុសរបស់លោក ចេញទៅតទល់នឹងជនជាតិអាំមូន។
[11]លោកយ៉ូអាប់មានប្រសាសន៍ទៅ លោកអប៊ីសាយ ជាប្អូនថា៖ «ប្រសិនបើជនជាតិស៊ីរីមានកម្លាំងខ្លាំងជាងបង នោះប្អូន លោកអប៊ីសាយត្រូវទៅជួយបងផង។
ផ្ទុយទៅវិញជនជាតិអាំម៉ូន ខ្លាំងជាងឯង នោះបងនឹងទៅជួយឯង។[12]ចូរមានកម្លាំង និងចិត្តក្លាហានប្រយុទ្ធ ដើម្បីប្រជារាស្ត្ររបស់យើង និងទីក្រុងរបស់ព្រះនៃយើង
សូមព្រះអម្ចាស់សម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ»។
[13]ដូច្នេះ លោកយ៉ូអាប់ និងពលទាហានរបស់លោក បានចេញទៅប្រយុទ្ធជាមួយជនជាតិស៊ីរី គឺអ្នកដែលបានបាក់ទ័ពរត់នៅខាងមុខពលទ័ពអ៊ីស្រាអែល។
[14]នៅពេលដែលកងទ័ពជនជាតិអាំមូនឃើញថាកងទ័ពស៊ីរី បាក់ទ័ពដូច្នេះ ពួកគេក៏រត់ចេញពីមុខលោកអប៊ីសាយ ត្រឡប់ចូលទៅក្នុងទីក្រុងវិញ។
លោកយ៉ូអាប់ក៏បានត្រឡប់ពីវាយប្រហារជនជាតិអាំម៉ូន ហើយត្រឡប់ទៅក្រុងយេរូសាឡិមវិញ។
[15]ពេលដែលពួកស៊ីរីឃើញថាពួកគេចាប់ផ្តើមចាញ់ដៃជនជាតិអ៊ីស្រាអែល នោះពួកគេក៏ប្រមូលផ្តុំគ្នាឡើងវិញ។[16]ពេលនោះ
ព្រះបាទហាដារេស៊ើបានចាត់គេឲ្យទៅប្រមូលពលទ័ពស៊ីរីដែលនៅឯនាយទន្លេអឺប្រាតមកជួយ។ ពួកគេបានមកដល់ហេឡាម ដែលមានលោកសូបាក់
ជាមេបញ្ជាការកងទ័ពលើពលទាហានរបស់ព្រះបាទហាដារេស៊ើ ជាមេដឹកនាំរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[17]មានគេនាំដំណឹងនេះមកទូលព្រះបាទដាវីឌ ទ្រង់ក៏បានប្រមូលកងទ័ពអ៊ីស្រាអែលទាំងអស់ឆ្លងទន្លេយ័រដាន់ ហើយបានទៅដល់ហេឡាម។
ពួកស៊ីរីបានរៀបចំទ័ពប្រឈមមុខជាមួយនឹងទាហានរបស់ព្រះបាទដាវីឌ ហើយវាយប្រហារទ្រង់។[18]កងទ័ពស៊ីរី បានបាក់ទ័ពរត់នៅមុខទ័ពអ៊ីស្រាអែល។ ព្រះបាទដាវីឌ
សម្លាប់ទាហានបររទេះសេះអស់ប្រាំពីររយនាក់ និងពលទ័ពសេះអស់បួនម៉ឺននាក់។ លោកសូបាក់ជាមេបញ្ជាការរបស់ពួកគេក៏ស្លាប់នៅទីនោះដែរ។
[19]ពេលដែលស្តេចទាំងឡាយដែលជាចំនុះរបស់ព្រះបាទហាដារេស៊ើរ ឃើញថាពួកគេចាញ់កងទ័ពអ៊ីស្រាអែលដូច្នេះ
ពួកគេក៏បែរមកចុះសន្ធិសញ្ញាសន្តិភាពជាមួយអ៊ីស្រាអែល ហើយចុះចូលជាមួយនឹងស្តេច។

---

2 Samuel 10:1

ព្រះនាមហានូន ... ណាហាស

ទាំងនេះជាឈ្មោះបុរស។

ទ្រង់ពិតជាជឿថា ... ទ្រង់?

អ្នកដឹកនាំប្រើសំណួរដើម្បីស្នើដល់ស្តេចថា ព្រះអង្គមិនគួរទុកចិត្តព្រះបាទដាវីឌទេ។
ការបកប្រែផ្សេងទៀត «ព្រះអង្គគិតខុសហើយ ... ព្រះអង្គ!»

ដើម្បីអង្កេត ស៊ើបមើល

ដើម្បីរៀនយកព័ត៌មានអំពីនរណាម្នាក់ ដោយសម្ងាត់

តើដាវីឌ មិនមែន ... វាយដណ្តើមទីក្រុងទេឬ?»

អ្នកដឹកនាំប្រើសំណួរដើម្បីស្នើដល់ស្តេចថា ព្រះអង្គមិនគួរទុកចិត្តព្រះបាទដាវីឌទេ។
ការបកប្រែផ្សេងទៀត «អ្នកត្រូវដឹងថា ព្រះបាទដាវីឌ ... វាយដណ្តើមទីក្រុង»។

ក្នុងគោលបំណងវាយដណ្តើមទីក្រុង

នៅទីនេះ «វា»

និយាយសំដៅទៅលើទីក្រុងដែលតំណាងឲ្យប្រជាជនដែលរស់នៅទីនោះ។
ការបកប្រែផ្សេងទៀត «ដើម្បីយកឈ្នះលើយើង»

ទីក្រុង

នៅទីនេះ «ទីក្រុង» សំដៅទៅលើរ៉ាបា ដែលជារាជធានីរបស់ជនជាតិអាំម៉ូន។

2 Samuel 10:4

កោរពុកចង្ការរបស់ពួកគេមួយចំហៀង

សកម្មភាពនេះមានន័យថា ជាការប្រមាថមួយដើម្បីធ្វើឲ្យមនុស្សអាម៉ាសមុខ។

មានសេចក្តីអៀនខ្មាស់ជាខ្លាំង

នៅទីនេះ «យ៉ាងជ្រាលជ្រៅ» គឺជាពាក្យដែលមានន័យថា «ខ្លាំងណាស់» ។

ត្រឡប់មកវិញ

យល់ថា ពួកគេគួរតែត្រឡប់ទៅក្រុងយេរូសាឡឹមវិញ។

2 Samuel 10:6

ពួកគេបានទៅជាទីគួរស្អប់ខ្ពើមរបស់ស្តេចដាវីឌ

ឃ្លាថា «ក្លាយជាទីគួរស្អប់ខ្ពើម» ជាពាក្យប្រៀបធៀបមួយសម្រាប់
«ពួកគេបានក្លាយជាមនុស្សដែលគួរស្អប់ខ្ពើម»។ ការបកប្រែផ្សេងទៀត
«ពួកគេបានក្លាយទៅជាមនុស្សគួរស្អប់ខ្ពើម ដូចជាក្លិនអាក្រក់ចំពោះស្តេចដាវីឌ»

បេត រេហុប ... សូបា ... ម៉ាកា ... ថូប

ទាំងនេះជាឈ្មោះទីកន្លែង។

ចំនួនពីរម៉ឺននាក់ ... ចំនួនមួយពាន់នាក់... ចំនួនមួយម៉ឺនពីរពាន់នាក់

«២០,០០០ ... ១,០០០ ... ១២,០០០»

នៅច្រកចូលទីក្រុងរបស់ពួកគេ

នៅទីនេះ «ទីក្រុង» សំដៅទៅលើរ៉ាបា ដែលជារាជធានីរបស់ជនជាតិអាំម៉ូន។

2 Samuel 10:9

ព័ត៌មានទូទៅ៖

ការប្រយុទ្ធគ្នាជាមួយពួកស៊ីរី និងអាំម៉ូននៅតែបន្ត។

រីឯពួកទាហានដែលនៅសល់ លោកបានប្រគល់ទៅក្នុងការដឹកនាំរបស់លោកអប៊ីសាយ

បួនប្រុសរបស់លោក

«គាត់ដាក់អប៊ីសាយប្អូនប្រុសរបស់គាត់
ឲ្យមើលខុសត្រូវលើកងទ័ពដែលនៅសល់»។

2 Samuel 10:11

ព័ត៌មានទូទៅ៖

លោកយ៉ូអាប់ត្រៀមកងទ័ពរួចជាស្រេចសម្រាប់ប្រយុទ្ធគ្នា។

នោះប្អូន លោកអប៊ីសាយត្រូវទៅជួយបងផង។

នៅទីនេះ «ខ្ញុំ» សំដៅទៅលើលោកយ៉ូអាប់ ដែលតំណាងឲ្យទាហានរបស់គាត់។
លោកអប៊ីសាយក៏តំណាងទាហានរបស់គាត់ដែរ។ ការបកប្រែផ្សេងទៀត
«សម្រាប់ពួកយើងបន្ទាប់មកអ្នក គឺលោកអប៊ីសាយ
និងកងទ័ពរបស់អ្នកត្រូវតែជួយសង្គ្រោះយើង»

2 Samuel 10:13

ចេញពីមុខលោកអប៊ីសាយ

នៅទីនេះលោកអប៊ីសាយតំណាងទាហានរបស់គាត់។ ការបកប្រែផ្សេងទៀត
«ចេញពីលោកអប៊ីសាយនិងទាហានរបស់គាត់»

ចូលទៅក្នុងទីក្រុងវិញ

នៅទីនេះ« ទីក្រុង»សំដៅទៅលើរ៉ាបាដែលជារាជធានីរបស់ជនជាតិអាំម៉ូន។

ហើយត្រឡប់ទៅក្រុងយេរូសាឡឹមវិញ។
«ហើយបានត្រឡប់ទៅក្រុងយេរូសាឡឹមវិញ»

2 Samuel 10:15

ពេលដែលពួកស៊ីរីឃើញថា ពួកគេចាប់ផ្តើមចាញ់ដៃជនជាតិអ៊ីស្រាអែល

អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលដែលពួកស៊ីរីបានដឹងថា
ជនជាតិអ៊ីស្រាអែលបានកំពុងតែវាយប្រហារពួកគេ»

ព្រះបាទហាដារេស៊ើ ... លោកសូបាក់

ទាំងនេះជាឈ្មោះមនុស្សប្រុស។

នៅឯនាយទន្លេអឺប្រាត

មានន័យថា នៅប៉ែកខាងកើតទន្លេអឺប្រាត។

ពួកគេបានមកដល់ហេឡាម

នៅទីនេះ «បានមកដល់» អាចបកប្រែជា «បានទៅ» ឬ «បានប្រមូលផ្តុំគ្នានៅឯ»

ហេឡាម

នេះជាឈ្មោះទីកន្លែង។

ជាមេដឹកនាំរបស់ពួកគេ

ឃ្លានេះសំដៅទៅលើតួនាទីនៃសិទ្ធអំណាច។ ការបកប្រែផ្សេងទៀត «នាំមុខគេ»

2 Samuel 10:17

មានគេនាំដំណឹងនេះមកទូលព្រះបាទដាវីឌ

អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលព្រះបាទដាវីឌបានឮអំពីរឿងនេះ»

បានប្រមូលកងទ័ពអ៊ីស្រាអែលទាំងអស់

នៅទីនេះ «អ៊ីស្រាអែល» តំណាងឲ្យកងទ័ពអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «
ការប្រមូលផ្តុំកងទ័ពអ៊ីស្រាអែលទាំងអស់»

ហេឡាម

បកប្រែឈ្មោះទាំងនេះដូចនៅក្នុង ១០:១៥ ។

ប្រឈមមុខជាមួយនឹងទាហានរបស់ព្រះបាទដាវីឌ ហើយវាយប្រហារទ្រង់។

នៅទីនេះ ព្រះបាទដាវីឌតំណាងទាហានរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ប្រឆាំងនឹងព្រះបាទដាវីឌនិងទាហានរបស់ព្រះអង្គ ហើយបានប្រយុទ្ធនឹងពួកគេ»

ព្រះបាទដាវីឌ សម្លាប់

នៅទីនេះ ព្រះបាទដាវីឌតំណាងឲ្យទាហានរបស់ព្រះអង្គ។ «ព្រះបាទដាវីឌ
និងទាហានរបស់ទ្រង់ត្រូវបានសម្លាប់»

ប្រាំពីររយនាក់ ... បួនម៉ឺននាក់

«៧០០ ... ៤០,០០០»

លោកសូបាក់ជាមេបញ្ជាការរបស់ពួកគេក៏ស្លាប់នៅទីនោះដែរ

អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ជនជាតិអ៊ីស្រាអែលបានធ្វើឲ្យរបួសលោកសូបាក់ ជាមេបញ្ជាការកងទ័ពស៊ីរី
ហើយគាត់បានស្លាប់នៅទីនោះ»

លោកសូបាក់... ព្រះបាទហាដារេស៊ើរ

បកប្រែឈ្មោះទាំងនេះដូចនៅក្នុង ១០:១៥ ។

ឃើញថាពួកគេចាញ់កងទ័ពអ៊ីស្រាអែលដូច្នេះ

អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «បានដឹងថា
ជនជាតិអ៊ីស្រាអែលបានឈ្នះពួកគេ»

---

[1]នៅរដូវស្លឹកឈើលាស់ ជារដូវកាលដែលស្តេចទាំងឡាយទម្លាប់ធ្វើសង្គ្រាម នោះព្រះបាទដាវីឌបានចាត់លោកយ៉ូអាប់ ជាមេទ័ពរបស់ទ្រង់
និងពួកកងទ័ពរបស់អ៊ីស្រាអែលឲ្យចេញទៅ។ ពួកគេបានកម្ទេចកងទ័ពអាំម៉ូន និងបានឡោមព័ទ្ធក្រុងរ៉ាបាត។ ចំណែកឯព្រះបាទដាវីឌ ទ្រង់គង់នៅក្រុងយេរូសាឡិម។
[2]មានថ្ងៃមួយ នៅពេលរសៀល ព្រះបាទដាវីឌបានតើនពីក្រឡាបន្ទំ ហើយស្តេចបានយាងកំសាន្តតាមថែវដែលនៅជាន់ខាងលើព្រះដំណាក់។
ទ្រង់បានទតឃើញនារីម្នាក់ដែលកំពង់ងូតទឹក ស្ត្រីម្នាក់នោះមានរូបឆោមស្អាតណាស់ស្រស់[3]ស្តេចបានចាត់គេឲ្យទៅស៊ើបសួរអំពីស្ត្រីនោះ។ មានគេនិយាយថា៖
«តើនេះមិនមែនជានាងបេតសេបា ជាកូនស្រីរបស់លោក អេលាំ ជាភរិយារបស់លោកអ៊ូរី ជាជនជាតិហេតនោះទេឬ?»
[4]ព្រះបាទដាវីឌបានចាត់គេឲ្យនាំនាងមក នាងបានចូលគាល់ស្តេច ហើយស្តេចបានរួមដំណេកជាមួយនាង (គឺនាងទើបតែបានសម្អាតខ្លួនពីការមានរដូវរបស់នាង)។
បន្ទាប់មក នាងបានត្រឡប់ទៅផ្ទះរបស់នាងវិញ។[5]នាងបេតសេបាក៏ចាប់មានទម្ងន់ ហើយនាងក៏ចាត់មនុស្សឲ្យទៅទូលព្រះបាទដាវីឌ ថា៖ «ខ្ញុំម្ចាស់មានទម្ងន់ហើយ»។
[6]នោះ ព្រះបាទដាវីឌមានរាជឱង្ការបញ្ជាទៅលោកយ៉ូអាប់ថា៖ «ចូរបញ្ជូនអ៊ូរី ជាជនជាតិហេតមកជួបយើង»។ ដូច្នេះលោកយ៉ូអាប់បានចាត់លោកអ៊ូរីមកឯព្រះបាទដាវីឌ។
[7]នៅពេលដែលលោកអ៊ូរី មកដល់ ព្រះបាទដាវីឌបានសួរសុខទុក្ខរបស់លោកយ៉ូអាប់ អំពីពួកពលទាហាន ហើយនិងសភាពការណ៍សង្គ្រាម តើយ៉ាងណាទៅហើយ។
[8]ព្រះបាទដាវីឌ ក៏មានរាជឱង្ការទៅកាន់លោកអ៊ូរីថា៖ «ចូរត្រឡប់ទៅផ្ទះរបស់លោក ហើយសម្អាតជើងរបស់លោកចុះ»។ ដូច្នេះ លោកអ៊ូរីក៏ចាកចេញពីព្រះរាជវាំងទៅ
ហើយបន្ទាប់ពីលោកចាកចេញទៅ ស្តេចបានផ្ញើអំណោយទៅឲ្យលោក។
[9]ប៉ុន្តែ លោកអ៊ូរីមិនបានត្រឡប់ទៅផ្ទះរបស់លោកនោះទេ
គឺលោកបានសម្រាន្តនៅមាត់ទ្វារចូលព្រះរាជវាំងរបស់ស្តេចជាមួយនឹងអ្នកបម្រើទាំងអស់របស់ចៅហ្វាយរបស់លោក។
[10]ពេលនោះមានគេទូលរឿងនេះដល់ព្រះបាទដាវីឌថា៖ «លោកអ៊ូរីមិនបានត្រឡប់ទៅផ្ទះរបស់លោកនោះទេ»។ ព្រះបាទដាវីឌសួរលោកអ៊ូរីថា៖ «តើអ្នកបានធ្វើអ្វី?
តើហេតុអ្វីបានជាលោកមិនត្រឡប់ទៅផ្ទះរបស់លោក?»[11]នោះលោកអ៊ូរីទូលស្តេចថា៖ «ហឹបរបស់ព្រះអម្ចាស់ទាំងពលទាហានអ៊ីស្រាអែល ព្រមទាំងយូដា
ពួកគេស្នាក់នៅក្នុងត្រសាលនៅឡើយ ហើយចៅហ្វាយរបស់ទូលបង្គំលោកយ៉ូអាប់ និងអ្នកបម្រើរបស់លោកទាំងអស់ក៏សម្រាកនៅទីវាល។
តើនឹងឲ្យទូលបង្គំចូលទៅក្នុងផ្ទះ ស៊ីផឹក ហើយដេកជាមួយភរិយារបស់ទូលបង្គំយ៉ាងដូចម្តេចបាន? ទូលបង្គំសូមស្បថថា ដរាបណាព្រះករុណានៅមានព្រះជន្មគង់នៅ
ទូលបង្គំនឹងមិនធ្វើដូច្នេះជាដាច់ខាត។
[12]ព្រះបាទដាវីឌមានរាជឱង្ការមកលោកអ៊ូរីថា៖ «ថ្ងៃនេះសូមលោកស្នាក់នៅទីនេះចុះ ហើយថ្ងៃស្អែកសឹមចេញដំណើរទៅ»។ ដូច្នេះ
លោកក៏ស្នាក់នៅក្រុងយេរូសាឡិមក្នុងថ្ងៃនោះនឹងថ្ងៃបន្ទាប់។[13]នៅពេលដែលព្រះបាទដាវីឌ ត្រាស់ហៅលោកនោះ លោកបានបរិភោគ និងផឹកមុនស្តេច។
នៅរសៀលបន្ទាប់លោកអ៊ូរីបានសម្រាន្តលើគ្រែរបស់លោកជាមួយពួកអ្នកបម្រើចៅហ្វាយរបស់លោក គឺលោកមិនបានត្រឡប់ទៅផ្ទះរបស់លោកទេ។
[14]នៅពេលព្រឹកព្រះបាទដាវីឌបានសរសេរសំបុត្រផ្ញើទៅលោកយ៉ូអាប់ តាមរយៈលោកអ៊ូរី។[15]ស្តេចបានសរសេរនៅក្នុងសំបុត្រនោះថា៖
«ចូរបញ្ជូនលោកអ៊ូរីទៅកាន់សមរភូមិមុខ គឺទៅកាន់ខ្សែប្រយុទ្ធ ហើយដកអ្នកដទៃទៀតចេញពីគេមក នោះគាត់នឹងត្រូវគេវាយប្រហារហើយសម្លាប់នៅទីនោះ។
[16]លោកយ៉ូអាប់ សង្កេតមើលទីក្រុងដែលលោកឡោមព័ទ្ធ លោកក៏បានដាក់លោកអ៊ូរីនៅកន្លែងដែលលោកបានដឹងថាមានសត្រូវដែលខ្លាំងពូកែ។
[17]នៅពេលដែលកងទ័ពសត្រូវចេញមកច្បាំងតទល់នឹងកងទ័ពរបស់លោកយ៉ូអាប់ ពួកគេបានសម្លាប់កងទ័ពមួយចំនួន នៅក្នុងជួរទ័ពរបស់ស្តេចដាវីឌ ហើយលោកអ៊ូរី
ជាជនជាតិហេត ក៏ត្រូវបានគេសម្លាប់នៅទីនោះដែរ។
[18]លោកយ៉ូអាប់ បានចាត់គេឲ្យទៅរាយការណ៍ថ្វាយព្រះបាទដាវីឌ សព្វគ្រប់អំពីសភាពការណ៍ចម្បាំង[19]គឺលោកបញ្ជាអ្នកនាំសារថា៖
«នៅពេលដែលអ្នកបានទូលថ្វាយស្តេចចប់សព្វគ្រប់អំពីសភាពការណ៍ចម្បាំងហើយ[20]ប្រសិនបើ ស្តេចខ្ញាល់ ហើយទ្រង់មានរាជឱង្ការថា
«ហេតុអ្វីបានជាអ្នកចូលទៅជិតកំពែងក្រុង ក្នុងពេលប្រយុទ្ធ តើអ្នកមិនដឹងទេឬថា ខ្មាំងនឹងបាញ់ព្រួញពីលើកំពែងក្រុងមក?
[21]តើអ្នកណាជាអ្នកសម្លាប់លោកអប៊ីមាឡេក ជាកូនប្រុសរបស់លោកយេរូបាលដែលនៅថេបេស?
តើមិនមែនជាមនុស្សស្រីទេឬដែលបានទម្លាក់ថ្មត្បាល់ពីលើកំពែងមកចំលោក? ហេតុអ្វីបានជាអ្នកចូលទៅជិតកំពែងក្រុងនោះ? នោះ អ្នកត្រូវទូលស្តេចថា៖
«អ្នកបម្រើរបស់ព្រះករុណា លោកអ៊ូរី ជាជនជាតិហេតុ ក៏បានស្លាប់នៅទីនោះដែរ។
[22]ដូច្នេះ អ្នកនាំសារបានចាកចេញទៅគាល់ព្រះរាជា និងបានទូលថ្វាយទ្រង់គ្រប់សព្វ តាមដែលលោកយ៉ូអាប់បានបង្គាប់លោកឲ្យនិយាយ។[23]អ្នកនាំសារទូលស្តេចថា៖
«ពួកខ្មាំងសត្រូវមានប្រៀបជាងយើង គេចេញមកវាយយើងខ្ញុំនៅតាមវាល ប៉ុន្តែ យើងបានវាយបកទៅវិញ រហូតពួកគេទៅដល់ក្លោងទ្វារក្រុង។
[24]ពេលនោះ ពួកខ្មាំងសត្រូវបានបាញ់ព្រួញពីលើកំពែងក្រុង មកលើកងទ័ពរបស់ព្រះករុណា ធ្វើអោយពលទាហានមួយចំនួនបានស្លាប់ ហើយអ្នកបម្រើរបស់ព្រះករុណា
លោកអ៊ូរី ជាជនជាតិហេត ក៏បានស្លាប់នៅទីនោះដែរ។[25]«នោះព្រះបាទដាវីឌ មានរាជឱង្ការទៅអ្នកនាំសារថា «ចូរប្រាប់យ៉ូអាប់ថា សូមកុំពិបាកចិត្តព្រោះតែរឿងនេះឡើយ
ដ្បិត ការធ្វើសង្គ្រាមគឺតែងតែមានការស្លាប់ទាំងសងខាងដូច្នេះហើយ។ ចូរខំប្រឹងច្បាំងឲ្យកាន់តែខ្លាំង ហើយបំផ្លាញក្រុងនេះឲ្យបាន»។
[26]នៅពេលដែលភរិយារបស់លោកអ៊ូរី បានដឹងដំណឹងថាប្តីរបស់ស្លាប់ នាងបានធ្វើពិធីកាន់ទុក្ខសពប្តីរបស់នាង។[27]លុះពេលវេលានៃការកាន់ទុកបានចប់សព្វគ្រប់ហើយ
ព្រះបាទដាវីឌបានចាត់គេឲ្យទៅនាំនាងពីផ្ទះមក ចូលទៅក្នុងព្រះរាជវាំង ហើយនាងបានក្លាយជាមហេសីរបស់ស្តេច ហើយសម្រាលបានបុត្រមួយថ្វាយស្តេច។ ប៉ុន្តែ
អំពើដែលដាវីឌបានធ្វើ មិនគាប់ព្រះទ័យព្រះអម្ចាស់ឡើ ុយ។

---

2 Samuel 11:1
នៅរដូវស្លឹកឈើលាស់
វាបានកើតឡើងនៅរដូវស្លឹកឈើលាស់។ បង្ហាញព្រឹត្តិការណ៍ថ្មីនៅក្នុងដំណើររឿង
ជារដូវកាលដែល
«ជារដូវកាលនៃឆ្នាំ»
នោះព្រះបាទដាវីឌបានចាត់លោកយ៉ូអាប់ ជាមេទ័ពរបស់ទ្រង់
និងពួកកងទ័ពរបស់អ៊ីស្រាអែលឲ្យចេញទៅ
ព្រះបាទដាវីឌចាត់គេឲ្យទៅធ្វើសង្គ្រាម។ នេះអាចថ្លែងយ៉ាងច្បាស់។
ពាក្យថារបស់ទ្រង់ក៏សំដៅទៅលើព្រះបាទដាវីឌដែរ។ ការបកប្រែផ្សេងទៀត
«ព្រះបាទដាវីឌបានចាត់លោកយ៉ូអាប់និងអ្នកបម្រើរបស់ទ្រង់ព្រមទាំងកងទ័ពអ៊ីស្រាអែលទាំងមូលឲ្យទៅធ្វើសង្គ្រាម
កងទ័ពអាំម៉ូន
«កងទ័ពជនជាតិអាំម៉ូន»
ក្រុងរ៉ាបាត
នេះជាឈ្មោះនៃទីក្រុង។
2 Samuel 11:2
មានថ្ងៃមួយ
«ដូច្នេះវាបានកើតឡើង» ឬ «ដូច្នេះវាបានឆ្លង» ។
អ្នកនិពន្ធប្រើឃ្លានេះដើម្បីបង្ហាញពីព្រឹត្តិការណ៍បន្ទាប់នៅក្នុងសាច់រឿង។
នារីម្នាក់ដែលកំពង់ងូតទឹក
ស្រីនោះមិននៅលើដំបូលទេ នាងនឹងត្រូវងូតទឹកនៅខាងក្រៅទីធ្លាផ្ទះរបស់នាង។
ការបកប្រែផ្សេងទៀត «ស្ត្រីម្នាក់កំពុងងូតទឹកនៅទីធ្លាផ្ទះរបស់នាង»
ស្តេចបានចាត់
នៅទីនេះពាក្យថា «បានចាត់» មានន័យថាព្រះបាទដាវីឌបានចាត់អ្នកនាំសារម្នាក់។
ការបកប្រែផ្សេងទៀត «ដូច្នេះព្រះបាទដាវីឌបានបញ្ជូនអ្នកនាំសារម្នាក់»
ស្តេចបានចាត់គេឲ្យទៅស៊ើបសួរអំពីស្ត្រីនោះ។
ព្រះបាទដាវីឌកំពុងតែព្យាយាមស្វែងរកស្ត្រីនោះ។ ពាក្យថា «ស្តេច»
ត្រូវបានប្រើជាលើកទីមួយនៅក្នុងសៀវភៅនេះសំដៅដល់ដាវីឌ
ប៉ុន្តែជាពាក្យទាក់ទងសម្រាប់អ្នកនាំសារដែលព្រះបាទដាវីឌបានបញ្ជូន។
អ្នកនាំសារត្រូវសួរប្រជាជនអំពីព័ត៌មានរបស់នាង។ ការបកប្រែផ្សេងទៀត
«អ្នកនាំសារបានសួរមនុស្សដែលស្គាល់នាងថានាងជានរណា»
តើនេះមិនមែនជានាងបេតសេបា ... ជាភរិយារបស់លោកអ៊ូរី ជាជនជាតិហេតនោះ
សំណួរនេះផ្តល់ព័ត៌មាន ហើយអាចសរសេរជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «នេះគឺជានាងបាតសេបា ...
ហើយនាងជាភរិយារបស់អ៊ូរីជាជនជាតិហេត» ។

generated on Wed Sep 10 16:16:32 2025

2 Samuel 11:4
ឲ្យនាំនាងមក
ហើយព្រះអង្គបានយកនាង។ ត្រង់នេះមានចែងថា៖
ព្រះបាទដាវីឌបានយកស្ត្រីនោះ
តែតាមពិតអ្នកនាំសារបានចាត់អោយទៅនាំនាងមក។ ការបកប្រែផ្សេងទៀត
«ហើយពួកគេបាននាំនាងទៅទ្រង់»
នាងបានចូលគាល់ស្តេច ហើយស្តេចបានរួមដំណេកជាមួយនាង
ឃ្លាថា «នាងបានចូលមករកទ្រង់»
គឺជាការពិពណ៌នាការពាក់ព័ន្ធរបស់ព្រះបាទដាវីឌ ដែលបានរួមភេទជាមួយស្ត្រី។
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា ហើយត្រូវបានប្រើជាមួយគ្នា
ដើម្បីបញ្ជាក់ថាពួកគេបានដេកជាមួយគ្នា។ ការបកប្រែផ្សេងទៀត
«ព្រះអង្គបានដេកជាមួយនាង» ឬ «ព្រះអង្គបានរួមភេទជាមួយនាង»
សម្អាតខ្លួនពីការមានរដូវ
រយៈពេលមករដូវរបស់ស្ត្រីប្រចាំ
ហើយនាងក៏ចាត់មនុស្សឲ្យទៅទូលព្រះបាទដាវីឌ ថា៖ «ខ្ញុំម្ចាស់មានទម្ងន់ហើយ» ។
នៅទីនេះពាក្យថា «បានចាត់ឲ្យទៅ» មានន័យថានាងបានផ្ញើសារទៅ។
នាងបានចាត់គេអោយទៅទូលព្រះបាទដាវីឌថា នាងមានផ្ទៃពោះ។
ការបកប្រែផ្សេងទៀត
«នាងបានបញ្ជូនអ្នកនាំសារទៅព្រះបាទដាវីឌដើម្បីទូលទ្រង់ថានាងមានផ្ទៃពោះហើយ»
2 Samuel 11:6
ព្រះបាទដាវីឌមានរាជឱង្ការបញ្ជាទៅ
នៅទីនេះពាក្យថា «បញ្ជាទៅ» មានន័យថាព្រះបាទដាវីឌបានចាត់អ្នកនាំសារម្នាក់។
ការបកប្រែផ្សេងទៀត «បន្ទាប់មកព្រះបាទដាវីឌបានបញ្ជូនអ្នកនាំសារម្នាក់»
បានសួរសុខទុក្ខរបស់លោកយ៉ូអាប់ អំពីពួកពលទាហាន ហើយនិងសភាពការណ៍សង្គ្រាម
តើយ៉ាងណាទៅហើយ។
ព្រះបាទដាវីឌបានសួរ បើសិនលោកយ៉ូអាប់និងកងទ័ពអត់មានបញ្ហា
និងអំពីដំណើរនៃសង្គ្រាម ។ ការបកប្រែផ្សេងទៀត «បើលោកយ៉ូអាប់អត់បញ្ហា
បើទាហានផ្សេងទៀតអត់បញ្ហាដែរ
ហើយសង្គ្រាមបានកំពុងដំណើរការយ៉ាងណាដែរ»
ចូរត្រឡប់ទៅផ្ទះរបស់លោក
ឃ្លា «ចូរទៅចុះ» អាចមានន័យថា ១)
ផ្ទះរបស់លោកអ៊ូរីស្ថិតនៅទាបជាងព្រះរាជវាំងរបស់ស្តេច ២)
ផ្ទះរបស់លោកអ៊ូរីមិនសូវសំខាន់ដូចព្រះរាជវាំងរបស់ស្តេចទេ។
ការបកប្រែផ្សេងទៀត «ទៅផ្ទះរបស់អ្នក»
ហើយសម្អាតជើងរបស់លោកចុះ
ឃ្លានេះជាពាក្យសម្រាប់ត្រឡប់មកផ្ទះវិញ ដើម្បីសម្រាកពេលយប់
បន្ទាប់ពីធ្វើការពេញមួយថ្ងៃ។ ការបកប្រែផ្សេងទៀត «សម្រាកពេលយប់»
ស្តេចបានផ្ញើអំណោយទៅឲ្យលោក។
ព្រះបាទដាវីឌបានចាត់មនុស្សម្នាក់ ដើម្បីយកអំណោយទៅឲ្យលោកអ៊ូរី។
ឃ្លានេះអាចថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «ស្តេចបានបញ្ជូនមនុស្សម្នាក់
ឲ្យយកអំណោយទៅឲ្យលោកអ៊ូរី»
2 Samuel 11:9
ចៅហ្វាយរបស់លោក
ពាក្យថា «របស់លោក» សំដៅទៅលើលោកអ៊ូរីនិងពាក្យថា «ម្ចាស់»
សំដៅលើព្រះបាទដាវីឌ។
តើអ្នកបានធ្វើអ្វី? តើហេតុអ្វីបានជាលោកមិនត្រឡប់ទៅផ្ទះរបស់លោក?
សំណួរដ៏ប៉ិនប្រសប់នេះត្រូវបានប្រើ ដើម្បីបង្ហាញការភ្ញាក់ផ្អើលរបស់ព្រះបាទដាវីឌ
ដែលថាលោកអ៊ូរីមិនបានមកជួបប្រពន្ធរបស់គាត់។
អាចសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«បន្ទាប់ពីបានមកពីការធ្វើដំណើរដ៏វែងឆ្ងាយបែបនេះ
អ្នកគួរតែបានទៅផ្ទះរបស់អ្នក»។
ពលទាហានអ៊ីស្រាអែល ព្រមទាំងយូដា
សំដៅទៅលើកងទ័ពរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«កងទ័ពអ៊ីស្រាអែលនិងយូដា»
តើនឹងឲ្យទូលបង្គំចូលទៅក្នុងផ្ទះ ...មួយភរិយារបស់ទូលបង្គំយ៉ាងដូចម្តេចបាន?
សំណួរដ៏ប៉ិនប្រសប់នេះត្រូវបានប្រើដើម្បីបញ្ជាក់ពីការបដិសេធរបស់អ៊ូរីដើម្បីមកលេង
ការបកប្រែផ្សេងទៀត
«វាជារឿងមិនត្រឹមត្រូវសម្រាប់ខ្ញុំក្នុងការចូលទៅក្នុងផ្ទះរបស់ខ្ញុំ ...
ជាមួយប្រពន្ធរបស់ខ្ញុំនៅពេលដែលទាហានផ្សេងទៀតនៅក្នុងកងទ័ពរបស់ខ្ញុំ
ស្ថិតក្នុងគ្រោះថ្នាក់»។
ដរាបណាព្រះករុណានៅមានព្រះជន្មគង់នៅ ទូលបង្គំនឹងមិនធ្វើដូច្នេះជាដាច់ខាត។
លោកអ៊ូរីបានស្បថយ៉ាងមុតមាំថា លោកនឹងមិនត្រឡប់ទៅផ្ទះប្រពន្ធរបស់លោក
ដរាបណាទាហានដែលនៅសល់កំពុងធ្វើសង្គ្រាម។
លោកធ្វើការសន្យានេះដោយប្រៀបធៀបសេចក្តីពិតនៃការសន្យារបស់លោក
ទៅនឹងភាពប្រាកដប្រជា ដែលស្តេចមានព្រះជន្មរស់។ ការបកប្រែផ្សេងទៀត
«ខ្ញុំសន្យាយ៉ាងមុតមាំថា ខ្ញុំនឹងមិនធ្វើរឿងនេះទេ!»
2 Samuel 11:12
លោកបានបរិភោគ នឹងផឹកមុនស្តេច។
«លោកអ៊ូរីបានបរិភោគ និងផឹកជាមួយព្រះបាទដាវីឌ»
ត្រឡប់ទៅផ្ទះរបស់លោក
ឃ្លា «ចុះ» អាចមានន័យថា ១)
ផ្ទះរបស់លោកអ៊ូរីមានទីតាំងស្ថិតនៅទាបជាងព្រះរាជវាំងរបស់ស្តេច ឬ ២)
ផ្ទះរបស់អ៊ូរីមិនសូវសំខាន់ដូចជាព្រះរាជវាំងរបស់ស្តេច។
សូមមើលការបកប្រែឃ្លាស្រដៀងនេះ «ចុះទៅផ្ទះរបស់អ្នក» នៅក្នុង១១: ៦។
ការបកប្រែផ្សេងទៀត «ទៅផ្ទះគាត់»
2 Samuel 11:14
តាមរយៈដៃរបស់លោកអ៊ូរី
ឃ្លាថា «ដៃរបស់លោកអ៊ូរី» សំដៅទៅលើលោកអ៊ូរី។ ការបកប្រែផ្សេងទៀត
«បានបញ្ជូនអ៊ូរីទៅខ្លួនឯងដើម្បីប្រគល់ទៅឲ្យគាត់»
ទៅកាន់សមរភូមិមុខ គឺទៅកាន់ខ្សែប្រយុទ្ធ
«នៅពីមុខសមរភូមិ ដែលជាខ្សែប្រយុទ្ធគ្នាអាក្រក់បំផុត»
ហើយដកអ្នកដទៃទៀតចេញពីគេមក
«បញ្ជាឲ្យទាហានត្រឡប់មកវិញ នៅឆ្ងាយពីគាត់»
គាត់នឹងត្រូវគេវាយប្រហារហើយសម្លាប់
«គាត់ប្រហែលបានរងរបួសហើយបានស្លាប់»
2 Samuel 11:16
សង្កេតមើលទីក្រុងដែលលោកឡោមព័ទ្ធ
ពាក្យ «ឡោមព័ទ្ធ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «ព័ទ្ធជុំវិញ» និង
«វាយប្រហារ»។ ការបកប្រែផ្សេងទៀត «កងទ័ពរបស់គាត់ព័ទ្ធជុំវិញ
និងវាយប្រហារទីក្រុង»
បានសម្លាប់កងទ័ពមួយចំនួន នៅក្នុងជួរទ័ពរបស់ស្តេចដាវីឌ
ពាក្យថា «ធ្លាក់» គឺរបៀបគួរសមនិយាយសំដៅទៅលើទាហាន
ដែលត្រូវគេសម្លាប់។ ការបកប្រែផ្សេងទៀត
«ទាហានរបស់ស្តេចដាវីឌត្រូវបានគេសម្លាប់» ឬ
«ពួកគេបានសម្លាប់ទាហានរបស់ដាវីឌខ្លះ»
ហើយលោកអ៊ូរី ជាជនជាតិហេត ក៏ត្រូវបានគេសម្លាប់នៅទីនោះដែរ។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «
រាប់បញ្ចូលទាំងលោកអ៊ូរីជាជនជាតិហេត» ឬ
«ហើយបុរសក្នុងទីក្រុងក៏បានសម្លាប់លោកអ៊ូរី ដែលជាជនជាតិហេតផងដែរ»។
2 Samuel 11:18
លោកយ៉ូអាប់ បានចាត់គេឲ្យទៅរាយការណ៍ថ្វាយព្រះបាទដាវីឌ
ឃ្លា «ពាក្យដែលបានចាត់ទៅ» មានន័យថា
គាត់បានបញ្ជូនអ្នកនាំសារម្នាក់ឲ្យផ្តល់របាយការណ៍។ ការបកប្រែផ្សេងទៀត
«លោកយ៉ូអាប់បានចាត់អ្នកនាំសារម្នាក់ឲ្យ
ទៅទូលថ្វាយរបាយការណ៍ដល់ព្រះបាទដាវីឌ»
ហេតុអ្វីបានជាអ្នកចូលទៅ ... លើកំពែងក្រុងមក?
លោកយ៉ូអាប់និយាយថា
ព្រះបាទដាវីឌអាចស្តីបន្ទោសគាត់ដោយសួរសំណួរទាំងនេះ។
សំណួរទាំងនេះអាចសរសេរជាសេចក្តីថ្លែងការណ៍បាន។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរចូលទៅជិតទីក្រុងដើម្បីប្រយុទ្ធទេ។ អ្នកគួរតែដឹងថា
ពួកគេនឹងបាញ់ចេញពីកំពែង»។
បាញ់ព្រួញពីលើកំពែង
នេះសំដៅទៅលើទាហានក្នុងទីក្រុងបាញ់ព្រួញ ចុះមកឯសត្រូវរបស់ពួកគេ
ពីកំពូលកំពែងក្រុង។ ការបកប្រែផ្សេងទៀត
[illegible] សេចក្តីថ្លែងការណ៍។
2 Samuel 11:21
តើអ្នកណាជាអ្នកសម្លាប់លោកអប៊ីម៉ាឡេក ជាកូនប្រុសរបស់លោកយេរូបាលដែលនៅថេបេស?
លោកយ៉ូអាប់និយាយថា

generated on Wed Sep 10 16:16:32 2025

ព្រះបាទដាវីឌអាចស្តីបន្ទោសគាត់ដោយសួរសំណួរទាំងនេះ។
អាចសរសេរជាសេចក្តីថ្លែងការណ៍បាន។ ការបកប្រែផ្សេងទៀត
«ចូរចាំពីរបៀបដែលលោកអប៊ីម៉ាឡេក
ជាកូនប្រុសរបស់លោកយេរូបាលដែលនៅថេប៉េសត្រូវបានសម្លាប់!»
លោកអប៊ីមាឡេក ជាកូនប្រុសរបស់លោកយេរូបាលដែលនៅថេប៊េស
នេះជាឈ្មោះរបស់មនុស្សប្រុស។
ឪពុករបស់គាត់ក៏ត្រូវគេស្គាល់តាមឈ្មោះគេឌានដែរ។
តើមិនមែនជាមនុស្សស្រីទេឬដែលបានទម្លាក់ថ្មត្បាល់ពីលើកំពែងមកចំលោក?
លោកយ៉ូអាប់និយាយថា
ព្រះបាទដាវីឌអាចស្តីបន្ទោសគាត់ដោយសួរសំណួរទាំងនេះ។
អាចសរសេរជាសេចក្តីថ្លែងការណ៍បាន។ ការបកប្រែផ្សេងទៀត
«ចូរចងចាំថាគាត់បានស្លាប់នៅថេប៊េស
ពេលស្ត្រីម្នាក់បោះដុំថ្មលើគាត់ពីកំពូលកំពែងក្រុង»។
ថ្មត្បាល់
ថ្មធ្ងន់មួយ ដែលកិនវិលជុំត្រូវបានប្រើ
ដើម្បីកិនកំទេចគ្រាប់ធញ្ញជាតិសម្រាប់ធ្វើនំប៉័ង
ពីលើកំពែង
«ចេញពីកំពូលកំពែងក្រុង»
ថេប៊េស
នេះជាឈ្មោះទីក្រុង។
ហេតុអ្វីបានជាអ្នកចូលទៅជិតកំពែងក្រុងនោះ?
លោកយ៉ូអាប់និយាយថា
ព្រះបាទដាវីឌអាចស្តីបន្ទោសគាត់ដោយសួរសំណួរទាំងនេះ។
អាចសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកមិនគួរទៅជិតកំពែងក្រុងទេ!»
2 Samuel 11:22
ក្លោងទ្វារ
«ក្លោងទ្វារក្រុង»
2 Samuel 11:24
ពួកខ្មាំងសត្រូវបានបាញ់ព្រួញ
«អ្នកបាញ់របស់ពួកគេ បាញ់ព្រួញ»
ធ្វើឲ្យពលទាហានមួយចំនួនបានស្លាប់ ហើយអ្នកបម្រើរបស់ព្រះករុណា
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកអ្នកបម្រើរបស់ស្តេចមួយចំនួនត្រូវបានគេសម្លាប់»។
អ្នកបម្រើរបស់ព្រះករុណា
នៅទីនេះ «អ្នកបម្រើ» សំដៅទៅលើទាហានមិនមែនជាទាសករទេ
ពីព្រោះទាហានជាអ្នកបម្រើរបស់ស្តេច។
លោកអ៊ូរី ជាជនជាតិហេត ក៏បានស្លាប់នៅទីនោះដែរ
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេបានសម្លាប់អ្នកបម្រើរបស់ព្រះអង្គ ឈ្មោះលោកអ៊ូរីជាជនជាតិហេត»
ដ្បិត ការធ្វើសង្គ្រាមគឺតែងតែមានការស្លាប់ទាំងសងខាងដូច្នេះហើយ
នៅទីនេះ «ដាវ» សំដៅទៅលើមនុស្សណាម្នាក់ ដែលសម្លាប់គេដោយដាវ។
ដូចគ្នានេះផងដែរ ការសម្លាប់នរណាម្នាក់ដោយដាវ
ត្រូវបានគេនិយាយដូចជាដាវកំពុង «ស៊ី» ប្រជាជន។ ការបកប្រែផ្សេងទៀត
«សម្រាប់បុរសម្នាក់អាចត្រូវបានសម្លាប់ដោយដាវ ដូចគ្នានឹងបុរសម្នាក់ទៀតដែរ»
ឬ «សម្រាប់បុរសណាម្នាក់អាចស្លាប់ក្នុងសមរភូមិ»
ចូរខំប្រឹងច្បាំងឲ្យកាន់តែខ្លាំង
«ប្រយុទ្ធកាន់តែខ្លាំង»
2 Samuel 11:26
នាងបានធ្វើពិធីកាន់ទុក្ខ
នៅទីនេះអ្នកនិពន្ធនិយាយពីការសោកសៅរបស់នាងយ៉ាងខ្លាំង
ហាក់ដូចជាវាមានជ្រៅនៅក្នុងចិត្តរបស់នាង។ ការបកប្រែផ្សេងទៀត
«នាងមានទុក្ខខ្លាំងណាស់» ឬ «នាងមានទុក្ខយ៉ាងខ្លាំងដល់ម្ល៉េះ»
កាន់ទុក្ខ
អារម្មណ៍សោកសៅខ្លាំងដែលបណ្តាលមកពីការរងទុក្ខវេទនា ការខកចិត្ត ឬ
សំណាងអាក្រក់
ព្រះបាទដាវីឌបានចាត់គេឲ្យទៅនាំនាងពីផ្ទះមក
នៅទីនេះ ពាក្យថា «បានចាត់» មានន័យថា ព្រះអង្គបានបញ្ជូនអ្នកនាំសារម្នាក់ឲ្យ
មកទទួលនាងហើយនាំនាងមកជួបព្រះអង្គ។ ការបកប្រែផ្សេងទៀត
«ព្រះបាទដាវីឌបានចាត់អ្នកនាំសារម្នាក់ ឲ្យមកនាំនាងមកផ្ទះ»
មិនគាប់ព្រះទ័យ
«ភាពក្រៀមក្រំ» ឬ «មានខឹង»

---

12 [1]កាលនោះព្រះអម្ចាស់ បានចាត់លោកណាថាន់ទៅឯព្រះបាទដាវីឌ។ លោកបានមកគាល់ស្តេច ហើយនិយាយថា៖ «មានដំណាលថា
ក្នុងក្រុងមួយមានបុរសពីរនាក់។ ម្នាក់ជាអ្នកមាន និងម្នាក់ទៀតជាអ្នកក្រ។[2]បុរសអ្នកមានមានហ្វូងគោ និងហ្វូងចៀមជាច្រើន[3]ប៉ុន្តែបុរសអ្នកក្រមិនមានអ្វីទាំងអស់
ក្រៅពីកូនចៀមញីមួយប៉ុណ្ណោះ ដែលទិញមកហើយចិញ្ចឹមបីបាច់វាបានធំធាត់។ ចៀមនោះវាបាននៅជាមួយគាត់តាំងពីតូច ហើយក៏បានធំឡើងជាមួយគាត់។
ចៀមនោះវាតែងតែស៊ី នឹងផឹកពីពែងរបស់គាត់ ហើយវាតែងតែដេកនៅក្នុងដៃរបស់គាត់ គឺដូចជាកូនស្រីរបស់គាត់។
[4]ថ្ងៃមួយមានភ្ញៀវមកសួរសុខទុក្ខបុរសអ្នកមាន ប៉ុន្តែ បុរសអ្នកមានមិនចង់យកសត្វពីហ្វូងគោ ហ្វូងចៀមរបស់លោក ដើម្បីធ្វើអាហារទទួលភ្ញៀវនោះទេ។
ជំនួសវិញគាត់បានយកមេចៀមរបស់បុរសអ្នកក្រ ហើយចំអិនអាហារទទួលភ្ញៀវរបស់គាត់»។[5]ព្រះបាទដាវីឌ ព្រះពិរោធយ៉ាងខ្លាំងនឹងបុរសអ្នកមាន
ហើយទ្រង់មានរាជឱង្ការទៅព្យាការីណាថាន់ថា៖ «យើងសូមស្បថក្នុងព្រះនាមព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ មនុស្សដែលប្រព្រឹត្តដូច្នេះ ត្រូវដាក់ទោសដល់ស្លាប់។
[6]គេត្រូវសងចៀមមួយជាបួនឲ្យម្ចាស់ដើមវិញ ពីព្រោះគេបានប្រព្រឹត្តយ៉ាងដូច្នេះ ហើយបានកិច្ចការដ៏អាក្រក់ចំពោះអ្នកក្រ»។
[7]ព្យាការីណាថាន់ទូលព្រះបាទដាវីឌថា៖ «ទ្រង់គឺជាបុរសម្នាក់នោះ! ព្រះអម្ចាស់ ជាព្រះរបស់ជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលថា៖ «យើងបានចាក់ប្រេងតែងតាំងអ្នក
ឲ្យគ្រប់គ្រងលើអ៊ីស្រាអែល ហើយយើងក៏បានរំដោះអ្នកចេញពីដៃរបស់ស្តេចសូល។[8]យើងបានប្រគល់រាជសម្បត្តិ ព្រមទាំងស្រីស្នំទាំងអស់របស់ចៅហ្វាយរបស់អ្នក
មកក្នុងកណ្តាប់ដៃរបស់អ្នក។ យើងក៏បានប្រគល់ឲ្យអ្នកគ្រប់គ្រងលើជនជាតិអ៊ីស្រាអែល និងពួកយ៉ូថាដែរ។ ប្រសិនបើជានៅតែមិនគ្រប់គ្រាន់ទៀត
យើងអាចបន្ថែមលើសពីនេះទៅទៀត។
[9]ដូច្នេះ ហេតុដូចម្តេចបានជាអ្នកមើលងាយព្រះបន្ទូលព្រះអម្ចាស់! ដោយធ្វើអំពើដ៏អាក្រក់ដែលទាស់ចិត្តយើងដូច្នេះ? គឺអ្នកបានសម្លាប់លោកអ៊ូរីជាជនជាតិហេត
ដោយប្រគល់ឲ្យគេសម្លាប់ដោយមុខដាវ ហើយអ្នកបានយកប្រពន្ធរបស់គេមកធ្វើជាប្រពន្ធ។ អ្នកបានប្រគល់គេឲ្យទៅពួកសាសន៍អាំម៉ូនប្រហារជីវិតរបស់គេ។
[10]ដូច្នេះហើយបានជាក្នុងគ្រួសាររបស់អ្នកតែងតែមានមនុស្សស្លាប់ដោយមុខដាវជានិច្ច ព្រោះអ្នកបានមាក់ងាយយើង ដោយយកប្រពន្ធអ៊ូរី
ជាជនជាតិហេតមកធ្វើជាប្រពន្ធរស់ខ្លួន។
[11]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ មើល៍! យើងនឹងធ្វើឲ្យមានមហន្តរាយកើតមាននៅក្នុងគ្រួសាររបស់អ្នក។ យើងនឹងយកស្ត្រីស្នំទាំងប៉ុន្មានរបស់អ្នក
ឲ្យទៅសាច់ញាតិរបស់អ្នក ហើយគេនឹងរួមដំណេកជាមួយស្ត្រីស្នំរបស់អ្នកនៅកណ្តាលវាល នៅចំពោះមុខរបស់អ្នក។[12]អ្នកបានប្រព្រឹត្តអំពើបាបដោយស្ងាត់កំបាំង
ឯយើងវិញ យើងនឹងប្រព្រឹត្តការនេះចំពោះអ្នកនៅកណ្តាលវាល ចំពោះមុខប្រជាជនអ៊ីស្រាអែលទាំងមូល»។[13]ព្រះបាទដាវីឌមានរាជឱង្ការទៅព្យាការីណាថាន់ថា៖
«យើងបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអម្ចាស់»។ ព្យាការីតបទៅស្តេចវិញថា៖ «ព្រះអម្ចាស់លើកលែងទោសឲ្យព្រះករុណា។ ព្រះករុណានឹងមិនសោយទិវង្គតទេ។
[14]ប៉ុន្តែ ទោះជាយ៉ាងណាក្តី ដោយអ្នកបានមាក់ងាយព្រះអម្ចាស់ នោះក្មេងដែលកើតមកនោះនឹងត្រូវស្លាប់ជាប្រាកដ»។[15]បន្ទាប់មក
ព្យាការីណាថាន់បានត្រឡប់ទៅលំនៅរបស់លោកវិញ។ ព្រះអម្ចាស់បានធ្វើឲ្យកូនដែលភរិយាលោកអ៊ូរី បានធ្វើឲ្យព្រះបាទដាវីឌមានជម្ងឺជាទម្ងន់។
[16]ព្រះបាទដាវីឌបានទូលអង្វរព្រះអម្ចាស់សម្រាប់ក្មេងនោះ។ ស្តេចបានតមអាហារ ហើយកាលស្តេចយាងចូលក្រឡាបន្ទំ ស្តេចបានផ្ទំផ្ទាល់ដី។
[17]ពួកចាស់ទុំបានទទូចអង្វរសូមឲ្យស្តេចតើនឡើង ប៉ុន្តែ ព្រះបាទដាវីឌមិនព្រមក្រោកទេ ហើយទ្រង់ក៏មិនសោយអាហារជាមួយពួកគេដែរ។[18]នៅថ្ងៃទីប្រាំពីរ
កូននោះក៏បានស្លាប់។ ពួករាជបម្រើរបស់ព្រះបាទដាវីឌមិនហ៊ានទូលស្តេចពីការស្លាប់របស់កូននោះទេ ដោយពួកគេនិយាយថា៖ «មើល៍ កាលកូននៅមានជីវិតនៅឡើយ
យើងបាននិយាយជាមួយព្រះករុណា តែព្រះករុណាពុំព្រមស្តាប់យើងនោះទេ។ ចុះទម្រាំបើពេលនេះកូនស្លាប់ទៅហើយ តើទ្រង់នឹងធ្វើយ៉ាងណាចំពោះរូបកាយទ្រង់។

generated on Wed Sep 10 16:16:32 2025

[19]ប៉ុន្តែ ពេលដែលព្រះបាទដាវីឌបានឃើញពួករាជបម្រើខ្សឹបខ្សៀវគ្នា ទ្រង់ក៏យល់ថា កូនបានស្លាប់ហើយ។ ទ្រង់មានរាជឱង្ការទៅពួករាជបម្រើថា៖
«តើកូនរបស់យើងស្លាប់ហើយឬ?» ពួកគេទូលថា៖ «បពិត្រព្រះករុណា! ព្រះឱរសសុគតហើយ»។[20]នោះ ព្រះបាទដាវីឌ បានក្រោកពីដី ស្រង់ទឹក ប្រោះទឹកអប់
ព្រមទាំងផ្លាស់ព្រះភូសា។ ទ្រង់បានយាងចេញទៅទីសក្ការៈ ហើយថ្វាយបង្គំព្រះអម្ចាស់នៅទីនោះ ហើយស្តេចត្រឡប់មកព្រះដំណាក់របស់ទ្រង់វិញ។
ស្តេចបានបញ្ជាឲ្យគេរៀបចំអាហារ ពួកគេបានរៀបចំអាហារនៅចំពោះព្រះរាជា ហើយស្តេចក៏សោយ។
[21]ពួករាជបម្រើទូលសួរទ្រង់ថា៖ «ហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះ? ទ្រង់បានតមអាហារ និងយំសោកនៅពេលដែលរាជកុមារនៅមានជីវិតនៅឡើយ ប៉ុន្តែ
ពេលនេះព្រះឱរសចូលទិវង្គត ទ្រង់បែរជាក្រោកឡើង ហើយសោយព្រះស្ងោយទៅវិញ»។[22]ព្រះបាទដាវីឌតបថា៖ «កាលកូននៅរស់នៅឡើយ យើងបានតមអាហារ
និងសោកសង្រេងដោយយើងនឹកថា៖ ព្រះអម្ចាស់នឹងប្រណីសន្តោសដល់យើង ដោយទុកឲ្យកូននោះមានជីវិតបន្តទៀត។[23]ប៉ុន្តែ ពេលនេះកូនបានស្លាប់ផុតទៅហើយ
តើឲ្យយើងតមធ្វើអ្វីទៀត? តើយើងអាចនឹងអាចយកគេត្រឡប់មកវិញឬ? គឺយើងទេដែលនឹងត្រូវទៅជួបវា គឺវានឹងមិនត្រឡប់មកជួបយើងនោះទេ។
[24]ព្រះបាទដាវីឌបានសម្រាលទុក្ខនាងបេតសេបាជាមហេសីរបស់ទ្រង់ ហើយរួមរស់ជាមួយនាង។ បន្ទាប់មក នាងប្រសូត្របានបុត្រាមួយអង្គ និងប្រទាននាមថា សាឡូម៉ូន។
ព្រះអម្ចាស់សព្វព្រះទ័យនឹងបុត្រនេះណាស់[25]ព្រះអម្ចាស់បានចាត់ព្យាការីណាថាន ទៅទូលព្រះបាទដាវីឌជ្រាបថា ត្រូវដាក់នាមកូនថា យេឌីឌីយ៉ា មានន័យថា
អ្នកដែលព្រះអម្ចាស់ស្រឡាញ់។
[26]គ្រានោះ លោកយ៉ូអាប់វាយយកបានក្រុងរ៉ាបាត ជារាជធានីរបស់ជនជាតិអាំម៉ូន ហើយហើយដណ្តើមយកវាំងរបស់ស្តេច។[27]ដូច្នេះ
លោកយ៉ូអាប់បានចាត់អ្នកនាំសារទៅឯព្រះបាទដាវីឌទូលថា៖ «ទូលបង្គំបានវាយទីក្រុងរ៉ាបាត ហើយដណ្តើមបានទឹកន្លែងផ្គត់ផ្គង់ទឹក។[28]ឥឡូវនេះ
សូមព្រះករុណាប្រមូលទ័ពដែលនៅសល់ ហើយមកវាយយកក្រុងនេះដោយព្រះករុណាផ្ទាល់ចុះ ក្រែងលោពេលដែលទូលបង្គំវាយយកបានក្រុង ហើយគេនិយាយថា
ក្រុងនេះជាកម្មសិទ្ធិរបស់ទូលបង្គំ»។
[29]ព្រះបាទដាវីឌបានប្រមូលកងទ័ពទាំងអស់ ហើយចេញទៅរ៉ាបាត ទ្រង់វាយយកបានទីក្រុង។[30]ទ្រង់បានយកមកុដដែលស្ថិតនៅលើព្រះសិរសារបស់ស្តេចអាំម៉ូន
ដែលមកុដនោះធ្វើពីមាសមានទម្ងន់សាមសិបគីឡូក្រាម ហើយមានដាំត្បូងទៀតផង។ ទ្រង់បានពាក់មកុដលើព្រះសិរសារបស់ទ្រង់។ បន្ទាប់មក
ព្រះបាទដាវីឌបានរឹបអូសយកជ័យភ័ណ្ឌជាច្រើនពីក្រុងនេះ។
[31]ទ្រង់បានចាប់ប្រជាជនក្រុងនេះទៅជាឈ្លើយ ព្រមទាំងបង្ខំឲ្យពួកគេអារឈើ វាយដែកធ្វើចប ធ្វើពូថៅ ហើយទ្រង់ក៏ឲ្យគេធ្វើឥដ្ឋដែរ។
ព្រះបាទដាវីឌក៏បានធ្វើដូច្នេះចំពោះក្រុងឯទៀតៗរបស់ជនជាតិអាំម៉ូនដែរ។ បន្ទាប់មក ស្តេច និងពួកកងទ័ពរបស់ទ្រង់បានត្រឡប់ទៅក្រុងយេរូសាឡិមវិញ។

---

2 Samuel 12:1
ចៀមញី
កូនចៀមញីមួយ
គឺដូចជាកូនស្រីរបស់គាត់។
សំដៅទៅលើភាពជិតស្និទ្ធរបស់បុរសនេះ និងកូនចៀមតូចរបស់គាត់។
ការបកប្រែផ្សេងទៀត «គាត់ស្រឡាញ់វាខ្លាំងណាស់ ដូចជាកូនស្រីរបស់គាត់»
2 Samuel 12:4
កូនចៀមញី
ចៀមស្ទាវ ចៀមញី
ទទួលភ្ញៀវរបស់គាត់
សម្រាប់ភ្ញៀវរបស់គាត់បរិភោគ។ ការបកប្រែផ្សេងទៀត
«សម្រាប់ភ្ញៀវរបស់គាត់បរិភោគ»
ព្រះបាទដាវីឌ ព្រះពិរោធយ៉ាងខ្លាំងនឹង
នៅទីនេះអ្នកនិពន្ធពិពណ៌នាអំពីរបៀប ដែលព្រះដាវីឌព្រះពិរោធយ៉ាងខ្លាំង
ដូចជាព្រះកាយរបស់ទ្រង់ក្តៅដោយសារតែព្រះពិរោធរបស់ទ្រង់។
ការបកប្រែផ្សេងទៀត «ព្រះបាទដាវីឌព្រះពិរោធនឹង» ឬ
«ព្រះបាទដាវីឌព្រះពិរោធយ៉ាងខ្លាំងនឹង» (សូមមើលfigs-metaphor)
ព្រះបាទដាវីឌ ព្រះពិរោធយ៉ាងខ្លាំងនឹង
មានន័យថា ព្រះបាទដាវីឌមានបន្ទូលដោយខឹងទៅកាន់ព្យាការីណាថាន់។
យើងសូមស្បថក្នុងព្រះនាមព្រះអម្ចាស់
សបញ្ជាក់ឲ្យឃើញថា ស្តេចដាវីឌបានស្បថ។ ការបកប្រែផ្សេងទៀត
«ខ្ញុំសូមប្រកាសដូចព្រះអម្ចាស់មានព្រះជន្មរស់»
ត្រូវដាក់ទោសដល់ស្លាប់
មានន័យថា ត្រូវគេសម្លាប់។ ដូចគ្នានេះផងដែរ
អាចបញ្ជាក់នៅក្នុងទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ត្រូវបានគេសម្លាប់» ឬ «ស្លាប់»
គេត្រូវសងចៀមមួយជាបួនឲ្យម្ចាស់ដើមវិញ
ចំនួនទឹកប្រាក់ដែលបុរសអ្នកមានតម្រូវឲ្យសងទៅបុរសក្រីក្រវិញ
គឺស្មើនឹងបួនដងនៃតម្លៃកូនចៀមតូច។ «គាត់ត្រូវបង់លុយឲ្យអ្នកក្រ
ស្មើនឹងចំនួនបួនដងនៃតម្លៃកូនចៀម»
គេបានប្រព្រឹត្តយ៉ាងដូច្នេះ
មានអារម្មណ៍ក្រៀមក្រំ និងស្រលាញ់អ្នកដែលកំពុងរងទុក្ខវេទនា ឬឈឺចាប់
ឬមិនទទួលបានក្តីស្រឡាញ់
2 Samuel 12:7
បានរំដោះអ្នកចេញពីដៃរបស់ស្តេចសូល
នៅទីនេះពាក្យថា «ដៃ» សំដៅទៅលើការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ចេញពីការគ្រប់គ្រងរបស់ស្តេចសូល» ឬ «ពីការគ្រប់គ្រងរបស់ស្តេចសូល»
ព្រមទាំងស្រីស្នំទាំងអស់របស់ចៅហ្វាយរបស់អ្នក មកក្នុងកណ្តាប់ដៃរបស់អ្នក។
នៅទីនេះ ព្រះអម្ចាស់ពិពណ៌នាថា ព្រះបាទដាវីឌយកប្រពន្ធរបស់ចៅហ្វាយគាត់
មកធ្វើជាប្រពន្ធផ្ទាល់ខ្លួនរបស់គាត់ ដោយនិយាយថាពួកគេនៅក្នុង
«នៅក្នុងដៃរបស់គាត់»។ ការបកប្រែផ្សេងទៀត
«ភរិយារបស់ចៅហ្វាយអ្នកជារបស់អ្នក»
យើងក៏បានប្រគល់ឲ្យអ្នកគ្រប់គ្រងលើជនជាតិអ៊ីស្រាអែល
នៅទីនេះ ព្រះអម្ចាស់មានបន្ទូលអំពីរបៀប
ដែលទ្រង់ប្រទានអំណាចដល់ព្រះបាទដាវីឌ ជាស្តេចលើជនជាតិអ៊ីស្រាអែល
និងស្រុកយូដាដូចជាប្រគល់អំណោយដល់អ៊ីស្រាអែល
និងស្រុកយូដាជាអំណោយ។ ឃ្លាថា «ផ្ទះរបស់» មានន័យថា «ប្រជាជននៃ» ។
ការបកប្រែផ្សេងទៀត «
ខ្ញុំក៏បានប្រគល់អំណាចឲ្យអ្នកជាស្តេចលើប្រជាជនអ៊ីស្រាអែល និងយូដា»
ប្រសិនបើជានៅតែមិនគ្រប់គ្រាន់ទៀត
«បើខ្ញុំមិនបានផ្តល់ឲ្យអ្នកគ្រប់គ្រាន់»
2 Samuel 12:9
ដូច្នេះ ហេតុដូចម្តេចបានជាអ្នកមើលងាយ ... ព្រះអម្ចាស់!
ដោយធ្វើអំពើដ៏អាក្រក់ដែលទាស់ចិត្តយើងដូច្នេះ?
សំណួរដ៏ប៉ិនប្រសប់នេះត្រូវបានប្រើ ដើម្បីស្តីបន្ទោសដល់ព្រះបាទដាវីឌ។
អាចសរសេរជាសេចក្តីថ្លែងការណ៍បាន។ការបកប្រែផ្សេងទៀត
«អ្នកមិនគួរមើលងាយ ... ព្រះអម្ចាស់
ហើយមិនគួរធ្វើអ្វីដែលអាក្រក់នៅចំពោះព្រះអង្គ!»
ដោយធ្វើអំពើដ៏អាក្រក់ដែលទាស់ចិត្តយើង
«ការមើលឃើញ» របស់ព្រះអម្ចាស់សំដៅទៅលើអ្វី ដែលព្រះអង្គគិត។ នៅទីនេះ
និយាយជាពិសេសនូវអ្វីដែលព្រះអង្គចាត់ទុកថា អាក្រក់។ ការបកប្រែផ្សេងទៀត
«ដោយធ្វើអ្វីដែលព្រះអង្គចាត់ទុកថា ជាអំពើអាក្រក់»
គឺអ្នកបានសម្លាប់លោកអ៊ូរីជាជនជាតិហេត ដោយប្រគល់ឲ្យគេសម្លាប់ដោយមុខដាវ
ព្រះបាទដាវីឌមិនបានសម្លាប់លោកអ៊ូរី ដោយអង្គទ្រង់ផ្ទាល់ទេ ផ្ទុយទៅវិញ
ទ្រង់បានរៀបចំឲ្យគាត់ត្រូវគេសម្លាប់នៅក្នុងសមរភូមិ។ ឃ្លាដែលថា «នឹងដាវ»
តំណាងឲ្យរបៀប ដែលលោកអ៊ូរីត្រូវគេសម្លាប់នៅក្នុងសមរភូមិ។
ការបកប្រែផ្សេងទៀត «អ្នកបានរៀបចំឲ្យលោកអ៊ូរីជាជនជាតិហេត
ស្លាប់នៅក្នុងសមរភូមិ»
អ្នកបានប្រគល់គេឲ្យទៅពួកសាសន៍អាំម៉ូនប្រហារជីវិតរបស់គេ
ព្រះបាទដាវីឌមិនបានសម្លាប់លោកអ៊ូរី ដោយអង្គទ្រង់ផ្ទាល់ទេ ផ្ទុយទៅវិញ
ទ្រង់បានរៀបចំឲ្យគាត់ត្រូវបានគេសម្លាប់នៅក្នុងសមរភូមិ
ពេលអ៊ីស្រាអែលកំពុងប្រយុទ្ធនឹងអាំម៉ូន។ ឃ្លា «ដាវ» សំដៅទៅលើរបៀប
ដែលគាត់បានស្លាប់ក្នុងសមរភូមិ។ ការបកប្រែផ្សេងទៀត
«អ្នកបានរៀបចំឲ្យគាត់ស្លាប់នៅក្នុងសមរភូមិ ប្រឆាំងនឹងកងទ័ពអាំម៉ូន»

generated on Wed Sep 10 16:16:32 2025

ជាក្នុងគ្រួសាររបស់អ្នកតែងតែមានមនុស្សស្លាប់ដោយមុខដាវជានិច្ច
នៅទីនេះ ពាក្យថា «ដាវ» សំដៅទៅលើមនុស្ស ដែលស្លាប់ដោយសារសង្គ្រាម។
ម្យ៉ាងទៀត «គ្រួសារ» របស់ព្រះបាទដាវីឌសំដៅទៅលើកូនចៅរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «កូនចៅរបស់អ្នកខ្លះនឹងស្លាប់នៅក្នុងសមរភូមិ» (UDB)
2 Samuel 12:11
កើតមាននៅក្នុងគ្រួសាររបស់អ្នក
នៅទីនេះ «គ្រួសារ» របស់ព្រះបាទដាវីឌសំដៅលើគ្រួសាររបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «មកពីក្នុងចំណោមគ្រួសារអ្នកផ្ទាល់»
នៅចំពោះមុខរបស់អ្នក
នៅទីនេះ ព្រះបាទដាវីឌបានសំដៅទៅព្រះនេត្ររបស់ព្រះអង្គ
បញ្ជាក់ពីអ្វីដែលទ្រង់ទតឃើញ។ ការបកប្រែផ្សេងទៀត
«ខណៈពេលដែលអ្នកកំពុងមើល»
នៅកណ្តាលវាល
«ពេញមួយថ្ងៃ»។ ជាគំនិតនៃការធ្វើអ្វីមួយ «ដោយបើកចំហ» ឬ នៅក្នុងរបៀបមួយ
ដែលមនុស្សបានដឹងយ៉ាងពេញលេញអំពីអ្វី
ដែលកំពុងកើតឡើងជាជាទូទៅត្រូវបានគេនិយាយនៅ «កណ្តាលវាល» ។
ការបកប្រែផ្សេងទៀត «ដោយបើកចំហ» ឬ
«ហើយមនុស្សគ្រប់គ្នានឹងឃើញអ្វីដែលកំពុងកើតឡើង»
ប្រព្រឹត្តអំពើបាប
«បានប្រព្រឹត្តអំពើបាប»
ចំពោះមុខប្រជាជនអ៊ីស្រាអែលទាំងមូល
ឃ្លានេះនិយាយពីប្រជាជនអ៊ីស្រាអែល
ដែលដឹងអំពីអ្វីបានកើតឡើងចំពោះភរិយារបស់គាត់
ហាក់ដូចជាពួកគេបានឃើញផ្ទាល់នឹងភ្នែក។ ការបកប្រែផ្សេងទៀត
«មុខប្រជាជនអ៊ីស្រាអែលទាំងអស់» ឬ
«ហើយប្រជាជនអ៊ីស្រាអែលទាំងអស់នឹងដឹងរឿងនេះ»
លើកលែងទោស
ព្រះអម្ចាស់បានអត់ទោសបាបឲ្យព្រះបាទដាវីឌ។ គេនិយាយរឿងនៅទីនេះ
ដូចជាព្រះអម្ចាស់បានលើកលែងទោសបាប ដែលទ្រង់បានប្រព្រឹត្ត
និងទទួលភាពអាម៉ាសយ៉ាងខ្លាំង។ ការបកប្រែផ្សេងទៀត «បានអត់ទោស»
ព្រះករុណានឹងមិនសោយទិវង្គតទេ។
អាចបញ្ជាក់នៅក្នុងទម្រង់កិរិយាសកម្ម។
ពេលខ្លះមនុស្សប្រុសបានស្លាប់ដោយសារតែអំពើបាបរបស់ពួកគេ ប៉ុន្តែ
ទ្រង់មិនសុគតដោយសារតែអំពើបាបជាមួយស្ត្រីនោះទេ។ អាចបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ទ្រង់នឹងមិនសោយទិវង្គត» ឬ
«ទ្រង់នឹងមិនសោយទិវង្គតដោយសារតែអំពើបាបនេះទេ»
2 Samuel 12:14
បានមាក់ងាយ
មិនចូលចិត្តខ្លាំង ឬស្អប់នរណាម្នាក់ ឬអ្វីមួយ
ក្មេងដែលកើតមក
ឃ្លា «កើតមកចំពោះអ្នក» មានន័យថា គឺជាបុត្ររបស់ព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «កូនរបស់អ្នកដែលនឹងកើត»
ព្រះអម្ចាស់បានធ្វើឲ្យកូនដែល ... មានជំងឺជាទម្ងន់
នៅទីនេះ អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ ដែលធ្វើឲ្យទារកឈឺ
ដូចជាព្រះអម្ចាស់វាយប្រហារកូនក្មេង។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានធ្វើឲ្យក្មេងនោះឈឺ ... ហើយវាឈឺធ្ងន់» ឬ
«ព្រះអម្ចាស់បណ្តាលឲ្យទារកនោះឈឺធ្ងន់» ។
កូនដែលភរិយាលោកអ៊ូរី បានធ្វើឲ្យព្រះបាទដាវីឌ
មានន័យថា នាងសម្រាលបានកូនមួយ
ហើយដែលព្រះបាទដាវីឌជាបិតារបស់គាត់។ ការបកប្រែផ្សេងទៀត
«កូនរបស់ព្រះបាទដាវីឌ ដែលភរិយារបស់លោកអ៊ូរីបានបង្កើតមក»
2 Samuel 12:16
បានទូលអង្វរ
អង្វរ ឬអធិស្ឋានដោយមានបំណងប្រាថ្នាខ្លាំង
យាងចូលក្រឡាបន្ទំ
ព្រះបាទដាវីឌបានចូលទៅក្នុងបន្ទប់របស់ព្រះអង្គ ពេលព្រះអង្គគង់នៅម្នាក់ឯង។
ការបកប្រែផ្សេងទៀត «បានចូលទៅក្នុងបន្ទប់របស់ព្រះអង្គ»
ព្រះបាទដាវីឌមិនព្រមក្រោកទេ
«ហើយបានជំរុញឲ្យព្រះអង្គក្រោក»
នៅថ្ងៃទី
«បានកើតឡើង»
ព្រះករុណាពុំព្រមស្តាប់យើងនោះទេ
ទីនេះ អ្នកបម្រើសំដៅទៅលើសំឡេង ដែលបញ្ជាក់ថាពួកគេបានកំពុងនិយាយ។
ការបកប្រែផ្សេងទៀត «ព្រះអង្គមិនបានស្តាប់យើងទេ»
នៅថ្ងៃទីប្រាំពីរ
«ថ្ងៃទី៧»។ សំដៅទៅលើថ្ងៃទី៧ បន្ទាប់ពីទារកចាប់កំណើត។
ការបកប្រែផ្សេងទៀត «ថ្ងៃទីប្រាំពីរបន្ទាប់ពីទារកកើត»
មើល៍
នេះជាពាក្យដែលត្រូវបានប្រើ ដើម្បីទាញការចាប់អារម្មណ៍ពីមនុស្ស។
ការបកប្រែផ្សេងទៀត «សូមស្តាប់»
ចុះទម្រាំបើពេលនេះកូនស្លាប់ទៅហើយ តើទ្រង់នឹងធ្វើយ៉ាងណាចំពោះរូបកាយទ្រង់?
អ្នកបម្រើសួរសំណួរដ៏ប៉ិនប្រសប់នេះ ដើម្បីសម្តែងការភ័យខ្លាច។
អាចសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«យើងខ្លាចព្រះអង្គអាចធ្វើបាបអង្គទ្រង់ បើយើងប្រាប់ទ្រង់ថា
បុត្រនោះសុគតហើយ!»
2 Samuel 12:19
ឱ្យបខ្ញៀវ
«និយាយតិចៗបំផុត»
យល់ថា កូនបានស្លាប់
«បានយល់»
បានក្រោក
«ក្រោកឡើង»
2 Samuel 12:21
ព័ត៌មានទូទៅ៖
ខគម្ពីរទាំងនេះមានសំណួរដ៏ប៉ិនប្រសប់ ដែលបញ្ជាក់ថាព្រះបាទដាវីឌជ្រាបថា
ព្រះអម្ចាស់បានអនុញ្ញាតឲ្យរឿងនេះកើតឡើង។
ព្រះអម្ចាស់នឹងប្រណីសន្តោសដល់យើង ដោយទុកឲ្យកូននោះមានជីវិតបន្តទៀត។
ព្រះបាទដាវីឌបានសួរសំណួរដ៏ប៉ិនប្រសប់នេះ ដើម្បីបញ្ជាក់ថា
គ្មាននរណាម្នាក់ដឹងថា តើព្រះអម្ចាស់នឹងអនុញ្ញាតឲ្យព្រះឱរសរស់រានមានជីវិតទេ។
សំណួរដ៏ប៉ិនប្រសប់សនេះអាចបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់ដឹងថា
តើព្រះអម្ចាស់នឹងប្រណីសន្តោសដល់យើង ដើម្បីឲ្យព្រះឱរសរស់បានទេ» ។
ប៉ុន្តែ ពេលនេះកូនបានស្លាប់ផុតទៅហើយ តើឲ្យយើងតមធ្វើអ្វីទៀត?
ព្រះដាវីឌបានសួរសំណួរដ៏ប៉ិនប្រសប់នេះ
ដើម្បីបញ្ជាក់ថាព្រះអង្គលែងមានហេតុផលតមទៀតហើយ។
អាចសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត « ឥឡូវនេះ
កូនបានស្លាប់ទៅហើយ លែងមានប្រយោជន៍ក្នុងការតមទៀតទេ» ។
តើយើងអាចនឹងអាចយកគេត្រឡប់មកវិញឬ?
ព្រះបាទដាវីឌបានសួរសំណួរនេះ ដើម្បីបញ្ជាក់ថា
ព្រះឱរសនេះមិនអាចរស់ឡើងវិញបានទេ។ អាចសរសេរជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «យើងមិនអាចនាំឲ្យកូននេះមានជីវិតឡើងវិញទេ» ។
គឺយើងទេដែលនឹងត្រូទៅជួបវា
ព្រះបាទដាវីឌបញ្ជាក់ថា ព្រះអង្គនឹងទៅកន្លែងដែលព្រះឱរស ពេលព្រះអង្គសុគត។
ការបកប្រែផ្សេងទៀត « នៅពេលយើងសុគត យើងនឹងទៅកន្លែងដែលវានៅ»
2 Samuel 12:24
ហើយរួមរស់ជាមួយនាង
ឃ្លាថា «បានទៅរកនាង» គឺជាការពិពណ៌នា ដែលជាប់ទាក់ទងនឹងព្រះបាទដាវីឌ
ដែលបានរួមដំណេកជាមួយប្រពន្ធរបស់ព្រះអង្គ។
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាហើយត្រូវបានប្រើជាមួយគ្នា
ដើម្បីបញ្ជាក់ថាពួកគេបានរួមដំណេកជាមួយគ្នា។ ការបកប្រែផ្សេងទៀត
«រួមដំណេកជាមួយនាង»
ព្រះអម្ចាស់បានចាត់ព្យាការីណាថាន ទៅទូលព្រះបាទដាវីឌ
នៅទីនេះ «ទូល» សំដៅទៅលើសារមួយ
ដែលព្រះអម្ចាស់បានប្រាប់ព្យាការីណាថានប្រាប់ព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានបញ្ជូនព្យាការីណាថានទៅទូលទ្រង់»
យេឌីឌីយ៉ា
នេះជាឈ្មោះមួយទៀតរបស់ព្រះបាទសាឡូម៉ូន ជាបុត្ររបស់ព្រះបាទដាវីឌ
ដែលព្រះអម្ចាស់បានជ្រើសរើស។

generated on Wed Sep 10 16:16:32 2025

2 Samuel 12:26
លោកយ៉ូអាប់វាយយកបាន ... គាត់ដណ្តើមយក
នៅទីនេះ អ្នកនិពន្ធនិយាយថា «លោកយ៉ូអាប់» ប៉ុន្តែ
គាត់សំដៅទៅលើលោកយ៉ូអាប់ និងទាហានរបស់គាត់
ដែលបានប្រយុទ្ធជាមួយគាត់។ ការបកប្រែផ្សេងទៀត
«លោកយ៉ូអាប់និងទាហានរបស់គាត់បានប្រយុទ្ធ ... ពួកគេបានដណ្តើមយក»
ក្រុងរ៉ាបាត
ការប្រយុទ្ធប្រឆាំងនឹងទីក្រុងនេះន័យត្រង់ថា
ដើម្បីប្រយុទ្ធប្រឆាំងនឹងប្រជាជននៅក្រុងរ៉ាបាត។ បកប្រែឈ្មោះដូចគ្នានៅក្នុង
១១:១។ ការបកប្រែផ្សេងទៀត «ប្រជាជនរបស់ក្រុងរ៉ាបាត»
ដូច្នេះ លោកយ៉ូអាប់បានចាត់អ្នកនាំសារទៅឯព្រះបាទដាវីឌទូលថា
«ដូច្នេះ លោកយ៉ូអាប់ចាត់អ្នកនាំសារឲ្យទៅទូលប្រាប់ព្រះបាទដាវីឌ»
ហើយដណ្តើមបានទីកន្លែងផ្គត់ផ្គង់ទឹក
«ដណ្តើម» កន្លែង ឬកន្លែងសម្គាល់មានន័យថា គ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«បានគ្រប់គ្រងការផ្គត់ផ្គង់ទឹកក្នុងទីក្រុង»
ទូលបង្គំបានវាយទី ... ហើយដណ្តើមបាន ...ទូលបង្គំវាយយកបាន
នៅទីនេះ លោកយ៉ូអាប់និយាយអំពីខ្លួនគាត់ផ្ទាល់
ពេលគាត់កំពុងសំដៅទៅលើខ្លួនគាត់ផ្ទាល់ និងទាហានរបស់គាត់។
ការបកប្រែផ្សេងទៀត «ទាហានខ្ញុំនិងខ្ញុំបានប្រយុទ្ធ ... ទាហានខ្ញុំនិងខ្ញុំបានយក ...
បើទាហានហើយនិងខ្ញុំ»
វាយយក
នេះមានន័យថា ព័ទ្ធជុំវិញនិងវាយប្រហារ។ ការបកប្រែផ្សេងទៀត «ឡោមព័ទ្ធ» ឬ
«ព័ទ្ធជុំវិញ»
យកបានក្រុង ... ក្រុងនេះ
«ដណ្តើម» កន្លែង ឬកន្លែងសម្គាល់មានន័យថា គ្រប់គ្រងលើ។
ការបកប្រែផ្សេងទៀត «គ្រប់គ្រងវា ... កាន់កាប់ទីក្រុង»
ក្រុងនេះជាកម្មសិទ្ធិរបស់ទូលបង្គំ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សនឹងដាក់ឈ្មោះវា»
2 Samuel 12:29
ទ្រង់វាយយកបាន
នៅទីនេះ អ្នកនិពន្ធនិយាយអំពីព្រះបាទដាវីឌ
ពេលទ្រង់កំពុងមានបន្ទូលសំដៅដល់ព្រះបាទដាវីឌ និងទាហានរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «ព្រះបាទដាវីឌនិងទាហានរបស់ព្រះអង្គបានប្រយុទ្ធ»
ទេព្យកោសល្យ
ប្រហែលត្រូវបានសរសេរអំពីទម្ងន់នៅក្នុងសម័យទំនើប។ ការបកប្រែផ្សេងទៀត
«៣៤ គីឡូក្រាម»
មានដាំត្បូង
ត្បូងដ៏កម្រដូចជា ត្បូងពេជ្រ ត្បូងទទឹម ត្បូងកណ្តៀងត្បូងមរកត ឬ ពេជ្រ
ទ្រង់បានពាក្យមកុដលើព្រះសិរសារបស់ទ្រង់។
អាចថ្លែងជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេបានដាក់មកុដនៅលើព្រះសិររបស់ព្រះបាទដាវីឌ»
ព្រះបាទដាវីឌបានរឹបអូសយក
នៅទីនេះ អ្នកនិពន្ធនិយាយអំពីព្រះបាទដាវីឌ
ពេលទ្រង់កំពុងមានបន្ទូលសំដៅទៅទាហានរបស់ព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «ពួកគេបាននាំចេញ»
ជយភណ្ឌ
របស់ដែលមានតម្លៃ យកចេញពីខ្មាំងសត្រូវដែលចាញ់សង្គ្រាម
ជាច្រើន
«ចំនួន» ឬ «តួលេខ»
2 Samuel 12:31
ទ្រង់បានចាប់ប្រជាជន
ព្រះបាទដាវីឌមិនបាននាំប្រជាជនចេញដោយអង្គទ្រង់ទេ។
ទ្រង់បានបញ្ជាឲ្យទាហានរបស់ព្រះអង្គនាំពួកគេចេញ។ ការបកប្រែផ្សេងទៀត
«ព្រះបាទដាវីឌបានបញ្ជាទាហានរបស់ព្រះអង្គឲ្យនាំប្រជាជនចេញ»
អាឈើ វាយដែកធ្វើចប វាយដែកធ្វើចប
ទាំងនេះជាឧបករណ៍សម្រាប់កាត់ឈើ ឬបំបែកដី។
ធ្វើឥដ្ឋ
កន្លែងដែលឥដ្ឋស្ងួតហួតហែងនិងរឹង
ចំពោះក្រុងឯទៀតៗរបស់ជនជាតិអាំម៉ូនដែរ
សំដៅទៅលើប្រជាជនរស់នៅតាមទីក្រុង។ ការបកប្រែផ្សេងទៀត
«ប្រជាជនទាំងអស់នៅក្នុងទីក្រុងរបស់អាំម៉ូន»

---

13 [1]ក្រោយមកទៀត មានរឿងកើតឡើងគឺ៖ សម្តេចអាំម៉ូន ជាបុត្ររបស់ព្រះបាទដាវីឌ ដែលមានចិត្តប្រតិព័ទ្ធយ៉ាងខ្លាំងចំពោះប្អូនស្រីរួមឪពុករបស់គាត់
ដែលមានរូបឆោមស្រស់ស្អាតយ៉ាងខ្លាំង ឈ្មោះព្រះនាងតាម៉ា ដែលជាប្អូនស្រីរួមម្តាយរបស់សម្តេចអាប់សូឡុម ជាស្នំរបស់ព្រះបាទដាវីឌ។
[2]សម្តេចអាំណូនមានចិត្តស្រឡាញ់ព្រះនាងតាម៉ា យ៉ាងខ្លាំង រហូតធ្លាក់ខ្លួនឈឺ។ ព្រះនាងជាស្ត្រីព្រហ្មចារី ហើយព្រះបាទអាំណូន មិនអាចធ្វើអ្វីនាងបានទេ។
[3]សម្តេចអាំណូន មានមិត្តសម្លាញ់ម្នាក់ឈ្មោះ លោកយេហូណាដាប់ ជាកូនរបស់លោកសាំម៉ា ជាក្មួយប្រុសរបស់ព្រះបាទដាវីឌ។
លោកយេហូណាដាប់ជាមនុស្សដ៏ឈ្លាសវៃ។[4]លោកបានសួរសម្តេចអាំណូនថា៖ «ព្រះរាជបុត្រានៃព្រះមហាក្សត្រអើយ!
ហេតុអ្វីបានជាទ្រង់តប់ប្រមល់ជារៀងរាល់ព្រឹកដូច្នេះ? តើទ្រង់អាចប្រាប់ទូលបង្គំបានឬទេ?» សម្តេចអាំណូនឆ្លើយថា៖
«យើងស្រឡាញ់ព្រះនាងតាម៉ាជាប្អូនស្រីរបស់សម្តេចអាប់សូឡុមខ្លាំងណាស់»។
[5]លោកយេហូណាដាប់ផ្តល់យោបល់ទៅសម្តេចអាំណូនថា៖ «ចូរផ្ទុំនៅលើគ្រែរបស់ទ្រង់ ហើយធ្វើពុតជាឈឺ។ នៅពេលដែលបិតារបស់ទ្រង់យាងមកមើលទ្រង់
នោះត្រូវទូលសូមទ្រង់ថា៖ តើបិតាអាចអនុញ្ញាតឲ្យព្រះនាងតាម៉ារ ជាប្អូនស្រីរបស់ទូលបង្គំ យកអាហារមកឲ្យទូលបង្គំសោយ ហើយចម្អិននៅចំពោះមុខទូលបង្គំ
ដូច្នេះទូលបង្គំអាចឃើញ និងទទួលអាហារពីដៃរបស់នាង?»[6]ដូច្នេះសម្តេចអាំណូន ផ្ទុំនៅលើគ្រែ ហើយពុតជាឈឺ។ នៅពេលដែលស្តេចយាងមកសួរសុខទុក្ខគាត់
សម្តេចអាំណូនទូលទៅស្តេចថា៖ «សូមបិតាមេត្តាអនុញ្ញាតឲ្យតាម៉ារ ប្អូនស្រីរបស់ទូលបង្គំមកចម្អិនអាហារសម្រាប់ជំងឺរបស់ទូលបង្គំនៅនឹងមុខទូលបង្គំផង ដូច្នេះ
ទូលបង្គំនឹងអាចសោយពីដៃរបស់នាង»។
[7]ព្រះបាទដាវីឌចាត់គេឲ្យទៅប្រាប់ព្រះនាងតាម៉ារនៅដំណាក់របស់នាងថា៖ «ចូរទៅដំណាក់អាំណូណ ជាបងប្រុសរបស់នាង ហើយរៀបចំអាហារសម្រាប់គេ»។[8]ដូច្នេះ
ព្រះនាងតាម៉ារបានទៅដំណាក់របស់សម្តេចអាំណូណ កន្លែងដែលគាត់ផ្ទុំ។ ព្រះនាងបានយកម្សៅមកវាយធ្វើនំ ហើយដុតនៅចំពោះមុខសម្តេចអាំណូន។
[9]ព្រះនាងបានយកខ្ទះមកចៀននំ រួចយកទៅថ្វាយសម្តេចអាំណូន ប៉ុន្តែ ទ្រង់មិនព្រមសោយទេ។ សម្តេចបញ្ជាអ្នកដែលនៅទីនោះថា៖ ឲ្យពួកគេចេញពីយើងទៅ។ ដូច្នេះ
ពួកគេក៏ចេញទៅ។
[10]សម្តេចអាំណូនប្រាប់នាងតាម៉ារថា៖ «ចូរយកនំចូលមកក្នុងបន្ទប់របស់បងផង ដើម្បីបងបានសោយពីដៃនាង»។
ព្រះនាងតាមារក៏យកនំដែលបានធ្វើនោះចូលទៅក្នុងក្រឡាបន្ទំរបស់សម្តេចអាំណូន ជាបងរបស់នាង។[11]ពេលដែលនាងកំពុងលើកនំថ្វាយនោះ សម្តេច
បានចាប់នាងទាំងពោលថា៖ «ប្អូនអើយ! ចូលមក! រួមដំណេកជាមួយបង»។[12]ព្រះនាងតបវិញថា «ទេបងប្រុស! សូមកុំធ្វើបាបខ្ញុំបែបនេះ!
រឿងបែបនេះមិនត្រូវកើតមានក្នុងទឹកដីអ៊ីស្រាអែលទេ។ សូមកុំប្រព្រឹត្តរឿងថោកទាបបែបនេះអោយសោះ!
[13]តើទូលបង្គំនឹងអាចបំបាត់ភាពអាម៉ាស់ដោយការនោះដោយរបៀបណា? ហើយចំពោះម្ចាស់បងវិញ? ទ្រង់នឹងទៅជាមនុស្សដែលចោលម្សៀតនៅស្រុកអ៊ីស្រាអែលនេះ!
ដូច្នេះ សូមទ្រង់ទៅទូលព្រះបិតាទៅ ទ្រង់នឹងមិនបង្ខាំងខ្ញុំពីម្ចាស់បងទេ»។[14]តែទោះយ៉ាងណាសម្តេចអាំណូនមិនស្តាប់នាងទេ។ ស្តេចបានប្រើកម្លាំងចាប់បង្ខំព្រះនាង
ហើយរំលោភព្រះនាងតាម៉ារ។
[15]បន្ទាប់នោះ សម្តេចអាំណូនស្អប់ព្រះនាងយ៉ាងខ្លាំង។ សម្តេចបានស្អប់ខ្ពើមនាងច្រើនជាងកាលដែលសម្តេចបានស្រឡាញ់នាងទៅទៀត។
សម្តេចអាំណូនបណ្តេញនាងថា៖ «ចេញទៅ!»[16]ប៉ុន្តែ ព្រះនាងបានប្រកែកថា៖ «ទេ! កាលម្ចាស់បងបណ្តេញខ្ញុំម្ចាស់នេះ
គឺវាអាក្រក់ជាងអ្វីដែលម្ចាស់បងទើបនឹងធ្វើដាក់ខ្ញុំម្ចាស់អំបាញមិញនេះទៅទៀត»។ ប៉ុន្តែ សម្តេចអាំណូណមិនបានស្តាប់នាងទេ។
[17]ស្តេចបានហៅអ្នកបម្រើផ្ទាល់ខ្លួនព្រះអង្គមក ហើយបញ្ជាថា៖ «ចូរយកមនុស្សស្រីនេះចេញទៅ ហើយខ្ទាស់ទ្វារបន្ទាប់ពីនាងចេញទៅផង»។

generated on Wed Sep 10 16:16:32 2025

[18]នោះ អ្នកបម្រើរបស់សម្តេចអាំណូន បាននាំព្រះនាងទៅខាងក្រៅ និងខ្ទាស់ទ្វារផង។ ព្រះនាងតាម៉ារពាក់រ៉ូបយ៉ាងល្អប្រណិត
ដូចដែលពួកបុត្រីស្តេចពាក់ពេលដែលពួកនាងនៅក្រមុំព្រហ្មចារី។[19]ព្រះតាម៉ារបានយកផេះរោយលើព្រះកេសាររបស់ព្រះនាង
ព្រមទាំងហែកសំពត់រ៉ូបដ៏ប្រណិតនោះចោល។ ព្រះនាងបានទូលព្រះហស្តលើព្រះសិសាររបស់ព្រះនាង និង ចេញទៅទាំងស្រែកយំយ៉ាងឮៗផង។
[20]សម្តេចអាប់សូឡូមជាបងប្រុសរបស់ព្រះនាង សួរព្រះនាងថា៖ «តើម្ចាស់បងអាំណូន បានធ្វើយ៉ាងដូច្នេះជាមួយឯងឬ? ប៉ុន្តែ ឥឡូវនេះ ប្អូនស្រី ចូរនៅឲ្យស្ងៀមសិន! ។
គាត់ជាបងប្រុសរបស់ឯងទេ ដូច្នេះ កុំឈឺចិត្តនឹងរឿងនេះខ្លាំងពេក»។ ដូច្ នេះព្រះនាងតាម៉ារក៏រស់នៅតែម្នាក់ឯងក្នុងដំណាក់របស់ព្រះបាទអាប់សូឡូម ជាបង។
[21]នៅពេលដែលព្រះបាទដាវីឌបានជ្រាបពីរឿងនេះ ទ្រង់ព្រះពិរោធយ៉ាងខ្លាំងជាមួយសម្តេចអាំណូន។[22]សម្តេចអាប់សូឡូម
មិនបាននិយាយអ្វីទាំងអស់ទៅរកសម្តេចអាំណូន គឺសម្តេចអាប់សូឡូមស្អប់សម្តេចអាំណូនយ៉ាងខ្លាំងដែលបានចាប់រំលោភព្រះនាងតាម៉ារ។
[23]ពីរឆ្នាំក្រោយមក ពួកអ្នកកាត់រោមចៀមរបស់សម្តេចអាប់សូឡូម កាត់រោមចៀមនៅបាល ហាសោត នៅជិតភូមិអេប្រាអីម ហើយសម្តេចអាប់សូឡូម
បានអញ្ជើញបុត្រទាំងអស់របស់ដាវីឌអោយចូលរួមដែរ។[24]សម្តេចអាប់សូឡូម បានចូលគាត់ព្រះបាទដាវីឌហើយទូលថា៖ «បពិត្រព្រះបិតាពួកអ្នកបម្រើរបស់ទូលបង្គំ
នឹងកាត់រោមចៀម។ ដូច្នេះ សូមទ្រង់មេត្តាទៅចូលរួមក្នុងពិធីនោះជាមួយមន្ត្រីរបស់ព្រះបិតា»។
[25]ស្តេចមានរាជឱង្ការថា៖ «ទេ កូនប្រុស យើងមិនអាចទៅចូលរួមពិធីទាំងអស់គ្នាបានទេ ដ្បិត យើងមិនចង់ឲ្យកូនពិបាក»។ សម្តេចអាប់សាឡូមនៅតែទទូចអង្វរព្រះរាជា
ប៉ុន្តែ ទ្រង់មិនព្រមទៅចូលរួមពិធីនោះទេ គឺព្រះរាជាគ្រាន់តែប្រទានពរសម្តេចអាប់សាឡូមប៉ុណ្ណោះ។[26]បន្ទាប់មក ស្តេចអាប់សាឡូម ទូលទ្រង់ថា៖ «ប្រសិនបើ
ទ្រង់មិនបានយាងមកចូលរួមពិធីទេ សូមទ្រង់មេត្តាអនុញ្ញាតឲ្យសម្តេចអាំណូនបានមកចូលរួមជាមួយពួកយើងផង»។ នោះ ព្រះបាទដាវីឌមានរាជឱង្ការថា៖
«ហេតុអ្វីអាំណូនត្រូវទៅជាមួយឯង?»
[27]សម្តេចអាប់សាឡូមបានទទូចអង្វរព្រះបាទដាវីឌសាជាថ្មី ហើយស្តេចក៏អនុញ្ញាតឲ្យសម្តេចអាំណូន និងបុត្រឯទៀតៗទៅចូលរួមជាមួយសម្តេចអាប់សាឡូម។
[28]សម្តេចអាប់សាឡូមបញ្ជាពួកអ្នកបម្រើរបស់គាត់ថា៖ «ស្តាប់ឲ្យច្បាស់! នៅពេលដែលអាំណូនចាប់ផ្តើមស្រវឹងស្រា ហើយពេលដែលយើងនិយាយថា ចូរប្រហារអាំណូន
នោះឯងរាល់គ្នាត្រូវសម្លាប់វា។ កុំខ្លាចអ្វីឡើយ។ តើយើងមិនបានបញ្ជាពួកឯងទេឬអី? ត្រូវមានចិត្តអង់អាច និងក្លាហានឡើង»។[29]ពួកបម្រើរបស់សម្តេចអាប់សាឡូម
បានសម្លាប់សម្តេចអាំណូន តាមការបង្គាប់ចំពោះពួកគេ។ បុត្រទាំងអស់របស់ព្រះបាទដាវីឌបានក្រោកឡើង ហើយឡើងរទេះរៀងៗខ្លួន និងភាសន៍ខ្លួនចេញទៅ។
[30]នៅពេលដែលពួកគេកំពុងធ្វើដំណើរនោះ មានគេនាំដំណឹងទៅទូលព្រះបាទដាវីឌថា «សម្តេចអាប់សាឡូម បានធ្វើគត់បុត្រទាំងអស់របស់ទ្រង់ហើយ
មិនមានអ្នកណាម្នាក់នៅមានជីវិតនោះទេ»។[31]ពេលនោះស្តេចបានក្រោកឡើងរួចហែកព្រះពស្ត្ររបស់ទ្រង់ ហើយក្រាបចុះនៅលើកម្រាល
ពួករាជបម្រើរបស់ទ្រង់ទាំងអស់ក៏បានក្រាប់លើកម្រាលជាមួយនឹងសម្លៀកបំពាក់រហែករបស់ពួកគេ។
[32]លោកយេហូណាដាបកូនប្រុសរបស់លោកសាំម៉ា ជាក្មួយប្រុសរបស់ព្រះបាទដាវីឌ បានទូលស្តេចថា៖
«សូមទ្រង់កុំជឿឡើយថាពួកគេបានធ្វើគត់បុត្រាទាំងអស់របស់ទ្រង់ឡើយ គឺមានតែសម្តេចអាំណូនមួយអង្គគត់ដែលសុគត។
សម្តេចអាប់សាឡូមបានរៀបចំផែនការណ៍នេះ តាំងពីថ្ងៃដែលសម្តេចអាំណូនបានចាប់រំលោភលើព្រះនាងតាម៉ារប្អូនស្រីរបស់ទ្រង់ម្លេះ។[33]ដូច្នេះ
សូមព្រះរាជាជាម្ចាស់របស់ទូលបង្គំ កុំជឿលើដំណឹងដែលបានឮនេះឡើយ ថាព្រះរាជបុត្រទាំងអស់មិនសុគតនោះឡើយ
គឺមានតែសម្តេចអាំណូនមួយអង្គប៉ុណ្ណោះដែលសុគត។
[34]សម្តេចអាប់សាឡូមបានរត់គេចខ្លួន។ ពួកអ្នកបម្រើក្រឡេកមើលទៅឃើញមនុស្សមួយក្រុមបានចុះពីលើភ្នំមកតាមពីក្រោយគាត់។
[35]បន្ទាប់មកលោកយេហូណាដាបទូលស្តេចថា៖ «បពិតព្រះករុណា ព្រះរាជបុត្រទាំងប៉ុន្មានរបស់ទ្រង់បានមកវិញហើយ។
ដូចដែលទូលបង្គំជាអ្នកបម្រើរបស់ទ្រង់បានទូលនោះ»។[36]ពេលដែលគាត់និយាយចប់ នោះរាជបុត្រទាំងប៉ុន្មានបានមកដល់
ហើយពួកគេបាននាំគេបានស្រែកទ្រហោរយំយ៉ាងខ្លាំង។ ព្រះរាជា និងពួករាជបម្រើទាំងអស់របស់ទ្រង់ក៏បានស្រែកយំកាន់ទុក្ខដែរ។
[37]ប៉ុន្តែ សម្តេចអាប់សាឡូមបានរត់គេចខ្លួនទៅរកលោកតាល់ម៉ាយ ជាបុត្រារបស់ព្រះបាទអាំមីហ៊ូដ ជាស្តេចរបស់កេស៊ើរ។
ព្រះបាទដាវីឌបានកាន់ទុក្ខបុត្រារបស់ទ្រង់ជារាងរាល់ថ្ងៃ។[38]សម្តេចអាប់សាឡូមបានរត់ភៀសខ្លួនទៅក្រុងកេស៊ើរ ហើយបានស្នាក់នៅទីនោះរយៈពេលបីឆ្នាំ។
[39]ព្រះបាទដាវីឌឈប់ខ្វាល់នឹងសម្តេចអាប់សាឡូម ដោយទ្រង់បានកម្សាន្តចិត្តពីការសុគតរបស់សម្តេចអាំណូន។

---

2 Samuel 13:1

ក្រោយមកទៀត មានរឿងកើតឡើង

«វាបានកើតឡើងបន្ទាប់ពីនេះ»។ ឃ្លានេះត្រូវបានប្រើដើម្បីបង្ហាញព្រឹត្តិការណ៍ថ្មី
ទៅនឹងដំណើររឿង។

ប្អូនស្រីរួមឪពុក

ប្អូនស្រី អាំណូននិងតាម៉ារមានឪពុកតែមួយ ប៉ុន្តែ មិនមែនម្តាយដូចគ្នាទេ។

ប្អូនស្រីរួមម្តាយ

អាប់សាឡុម និងតាម៉ារមានឪពុកនិងម្តាយដូចគ្នា។

សម្តេចអាំណូនមានចិត្តស្រឡាញ់ព្រះនាងតាម៉ារយ៉ាងខ្លាំង រហូតធ្លាក់ខ្លួនឈឺ។

សម្តេចអាំណូនមានការខកចិត្ត

ព្រោះទ្រង់ចង់រួមដំណេកជាមួយប្អូនស្រីឈ្មោះព្រះនាងតាម៉ារ។
ការបកប្រែផ្សេងទៀត «អាំណូនមានការខកចិត្តយ៉ាងខ្លាំង
ព្រោះចង់បានប្អូនស្រីឈ្មោះតាម៉ារ ធ្វើឲ្យធ្លាក់ខ្លួនឈឺ»

2 Samuel 13:3

នៅទីនេះបុរសនេះត្រូវបានគេពិពណ៌នាថាគ្មានតម្លៃដោយត្រូវបានគេប្រៀបធៀបទៅនឹងឆ្កែងាប់
ការបកប្រែផ្សេងទៀត «បុរសគ្មានតម្លៃនេះ»
តើគួរអោយយើងធ្វើដូចម្តេចជាមួយអ្នក កូនរបស់លោកស្រីសេរ៉ូយ៉ាអើយ ?
នេះជាសំណួរដ៏ប៉ិនប្រសប់
ត្រូវបានគេសួរដើម្បីណែនាំកូនប្រុសរបស់លោកសេរូយ៉ា។
វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនចង់ដឹងពីអ្វីដែលអ្នកគិតទេ!»
ប្រហែលជាគេប្រទេចផ្តាសាយើងដោយសារ
«គាត់ប្រហែលជាកំពុងដាក់បណ្តាសាខ្ញុំព្រោះ»
តើអ្នកណាអាចនឹងសួរតេថា៖ ហេតុអ្វីបានជាអ្នកប្រទេចផ្តាសាដាវីឌដូច្នេះ?
នេះគឺត្រូវបានគេនិយាយថាជាសំណួរដ៏ប៉ិនប្រសប់ ដើម្បីបញ្ជាក់ថាចម្លើយគឺ
«គ្មាននរណាម្នាក់» ។ នេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់បន្ទាប់មកអាចសួរគាត់ថា
ហេតុអ្វីបានជាអ្នកដាក់បណ្តាសារស្តេច?»
2 Samuel 16:11
សូម្បីតែកូនប្រុសរបស់យើង ដែលយើងបានបង្កើតមក
ព្រះបាទដាវីឌពិពណ៌នាអំពីកូនប្រុសរបស់ទ្រង់តាមរបៀបនេះ
ដើម្បីបញ្ជាក់ពីចំណងមិត្តភាពជិតស្និទ្ធរវាងបិតានិងបុត្រ។ ការបកប្រែផ្សេងទៀត
«បុត្ររបស់យើងផ្ទាល់» ឬ «បុត្រដ៏ជាទីស្រឡាញ់របស់យើង»
វាចង់យកជីវិតរបស់យើង
នេះជារបៀបគួរសម ដើម្បីនិយាយសំដៅទៅលើការសម្លាប់នរណាម្នាក់។
ការបកប្រែផ្សេងទៀត «ចង់ធ្វើគុតយើង»
តើមានអ្វីទៅដែលអ្នកស្រុកប៊េនយ៉ាមីននេះបានធ្វើចំពោះការភៀសខ្លួនរបស់យើង?
ព្រះបាទដាវីឌប្រើសំណួរដ៏ប៉ិនប្រសប់នេះ ដើម្បីបង្ហាញថាព្រះអង្គមិនភ្ញាក់ផ្អើលទេ
ដែលមនុស្សចង់ធ្វើគុតទ្រង់។ នេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ជាការពិតប៊េនយ៉ាមីនមានបំណងប្រាថ្នាចង់បំផ្លាញយើង!»
ឬ «យើងមិនភ្ញាក់ផ្អើលទេបេនយ៉ាមីនមានបំណងប្រាថ្នាចង់បំផ្លាញយើងដែរ!»
ធ្វើចំពោះការភៀសខ្លួនរបស់យើង
នៅទីនេះព្រះបាទដាវីឌពិពណ៌នាអំពីបំណងប្រាថ្នារបស់មនុស្ស
ដែលចង់ធ្វើគុតទ្រង់ដូចជាព្រះបាទដាវីឌ ជាអ្វីដែលមនុស្សចង់បំផ្លាញ។
ការបកប្រែផ្សេងទៀត៖ "មានបំណងប្រាថ្នាចង់ធ្វើគុតយើង" រឺ
"មានបំណងប្រាថ្នាដើម្បីធ្វើគុតយើង"
ដូច្នេះចូរទុក្ខអោយគេជេរប្រទេចផ្តាសាយើងទៅចុះ
នៅទីនេះឃ្លា "ទុកឲ្យគាត់នៅម្នាក់ឯង"
មានន័យថាមិនបញ្ឈប់គាត់ពីអ្វីដែលគាត់កំពុងធ្វើ។ ការបកប្រែផ្សេងទៀត
«កុំបញ្ឈប់គាត់ពីការដាក់បណ្តាសាយើង»
ទតឃើញ
នៅទីនេះ «សម្លឹងមើល» មានន័យថា «ពិចារណា» ។ ការបកប្រែផ្សេងទៀត
«នឹងពិចារណា»
ទុក្ខវេទនារបស់យើង ហើយធ្វើអោយបណ្តាសា
នៅទីនេះព្រះបាទដាវីឌមានបន្ទូលអំពីទុក្ខវេទនាដូចជាសត្វសាហាវដ៏គ្រោះថ្នាក់ដែលបេនយ៉ាមីនបានបណ្
2 Samuel 16:13
លោកសាំម៉ាយក៏ដើរតាមចង្កេះភ្នំ
លោកសាំម៉ាយបានកំពុងដើរស្របគ្នានឹងព្រះបាទដាវីឌ និងពួកទាហានរបស់ទ្រង់
ទោះបីជាលោកសាំម៉ាយឡើងខ្ពស់នៅលើចង្កេះភ្នំ។
2 Samuel 16:15
លោកអហ៊ីថូផែល
ការបកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:១១ ។
លោកហ៊ូសាយ
ការបកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:៣២ ។
កាលនៅ
វាបានកើតឡើង។
ឃ្លានេះត្រូវបានប្រើដើម្បីបង្ហាញព្រឹត្តិការណ៍បន្ទាប់នៅក្នុងដំណើររឿង។
ឆ្នេះជាតិអើ
ការបកប្រែឈ្មោះនៃក្រុមមនុស្សនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:៣២។
2 Samuel 16:17
ជាភាពស្មោះត្រង់
អារម្មណ៍រឹងមាំនៃការគាំទ្រនិងស្រឡាញ់
តើនេះជាភាពស្មោះត្រង់របស់លោកចំពោះមិត្តសម្លាញ់របស់លោកឬ?
ឬក៏ជាលោកមិនទៅជាមួយទ្រង់?
សំណួរដ៏ប៉ិនប្រសប់ទាំងនេះត្រូវបានគេសួរដើម្បីរិះគន់លោកហ៊ូសាយ។
វាអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
"អ្នកបាននៅស្មោះត្រង់ចំពោះព្រះបាទដាវីឌ។ អ្នកគួរតែបានទៅជាមួយទ្រង់។
បើព្រះអម្ចាស់
លោកហ៊ូសាយកំពុងសំដៅទៅលើអាប់សាឡុម ។
អ្នកដែល ... អ្នកណាហើយនោះ ... នៅជាមួយស្តេច
នៅទីនេះលោកហ៊ូសាយបាននិយាយសំដៅទៅលើបុរសទីបី
ដែលរើសយកអាប់សាឡុមដើម្បីបញ្ជាក់ផ្តោតទៅលើគាត់
ហើយដាក់វាទៅលើព្រះអម្ចាស់និងប្រជាជនដែលបានជ្រើសរើសគាត់។
នេះអាចត្រូវបានសរសេរជាមនុស្សទីពីរ។ ការបកប្រែផ្សេងទៀត
«អ្នកជាមនុស្សម្នាក់ ... អ្នកគឺមនុស្ស ... នៅជាមួយអ្នក»
2 Samuel 16:19
តើអោយទូលបង្គំបម្រើអ្នកណា? តើមិនគួរអោយទូលបង្គំបុត្ររបស់មិត្តសម្លាញ់ទូលបង្គំទេឬអី?
លោកហ៊ូសាយសួរសំណួរដ៏ប៉ិនប្រសប់នេះ
ទាំងនេះដើម្បីបញ្ជាក់ថាលោកចង់បម្រើអាប់សាឡុម។
ពួកគេអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«ខ្ញុំគួរតែបម្រើតែបុត្ររបស់ព្រះបាទដាវីឌប៉ុណ្ណោះ
ដូច្នេះខ្ញុំនឹងបម្រើនៅចំពោះមុខទ្រង់» ឬ «ខ្ញុំគួរតែបម្រើព្រះអង្គ
ដោយសារព្រះអង្គគឺជាបុត្ររបស់ព្រះបាទដាវីឌ» ។

generated on Wed Sep 10 16:16:32 2025

2 Samuel 16:20

លោកអហ៊ីថូផែល

បកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:១១ ។

ដែលស្តេចបានទុកឲ្យនៅយាមដំណាក់

ឃ្លា «ដើម្បីរក្សា» មានន័យថាដើម្បីថែរក្សា។ ការបកប្រែផ្សេងទៀត
«ដើម្បីថែរក្សាព្រះដំណាក់»

បានតាំងខ្លួនជាសត្រូវរបស់បិតាទ្រង់

លោកអាហ៊ីថូផែលនិយាយអំពីសម្តេចអាប់សាឡុម
ដែលធ្វើបាបបិតារបស់ទ្រង់ដូចជាព្រះអង្គ នឹងក្លាយទៅជាអ្វីដែលបានខ្លាំងជាង
ព្រមទាំងជាមួយការប្រមាថដ៏អាក្រក់។ ការបកប្រែផ្សេងទៀត
«ធ្វើឲ្យបិតារបស់ទ្រង់អាម៉ាស់» ឬ « ប្រមាថបិតាយ៉ាងខ្លាំង»

នោះបក្សពួករបស់ព្រះករុណានឹងមានកម្លាំងចិត្តឡើង

នៅទីនេះមនុស្សដែលដើរតាមអាប់សាឡុមត្រូវបានបញ្ជូនដោយដៃរបស់ពួកគេ។
ដំណឹងនេះនឹងពង្រឹងភាពស្មោះត្រង់របស់ប្រជាជនចំពោះអាប់សាឡុមនិងលើកទឹកចិត្តពួកគេ
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «
ដំណឹងអំពីរឿងនេះនឹងជួយពង្រឹងភាពស្មោះត្រង់របស់អ្នកទាំងអស់គ្នាដែលតាមដានអ្នក

2 Samuel 16:22

បានតម្លើងត្រសាល

«រៀបចំ»

នៅលើដំបូលព្រះដំណាក់ ,ហើយសម្តេចអាប់សាឡុមបានរួមដំណេក ... ជាមួយស្រីស្នំរបស់បិតា

ឲ្យប្រជាជនអ៊ីស្រាអែលទាំងអស់បានឃើញ

នេះមានន័យថាប្រជាជនអាចមើលឃើញតង់
និងស្តេចអាប់សាឡុមដើរចេញនិងចូលក្នុងតង់ជាមួយស្រីស្នំ។ ឃ្លាថា
«អ៊ីស្រាអែលទាំងអស់» គឺជាការនិយាយបំភ្លើសមួយ
សម្រាប់តែមនុស្សនៅក្បែរព្រះបរមរាជវាំងប៉ុណ្ណោះដែលអាចមើលឃើញវា។
ការបកប្រែផ្សេងទៀត
«កំពូលនៃព្រះបរមរាជវាំងដែលជាកន្លែងមនុស្សគ្រប់គ្នាអាចមើលឃើញ
ហើយនិងអាប់សាឡុមបានដេក ...ជាមួយស្រីស្នំ »

នៅគ្រានោះយោបល់របស់អហ៊ីថូផែល ... គឺដូចជាពាក្យដែលគេបានឮ

នៅទីនេះអ្នកនិពន្ធប្រៀបធៀបថា
របៀបដែលមនុស្សទុកចិត្តលើយោបល់របស់លោកអហ៊ីថូផែល
និងរបៀបដែលពួកគេនឹងជឿទុកចិត្តលើយោបល់ដោយផ្ទាល់ពីព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «ឥឡូវនេះប្រជាជនជឿទុកចិត្តលើយោបល់របស់
លោកអហ៊ីថូផែលនៅថ្ងៃនោះតាមរបៀបដែលពួកគេនឹងបានជឿទុកចិត្តវាប្រសិនបើបានមកដល់»
ដែលគេបានឮចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់។

នៅទីនេះព្រះឱស្ឋរបស់ព្រះជាម្ចាស់តំណាងឲ្យអង្គទ្រង់ផ្ទាល់
ហើយផ្តោតទៅលើប្រសាសន៍របស់ទ្រង់ ការបកប្រែផ្សេងទៀត
«ដូចជាព្រះជាម្ចាស់បានមានព្រះបន្ទូលដោយព្រះឱស្ឋទ្រង់ផ្ទាល់» ឬ
«មនុស្សម្នាក់ឮព្រះបន្ទូលតាមរយៈព្រះជាម្ចាស់អង្គទ្រង់ផ្ទាល់» ។

តាមយោបល់

«បានយល់» ឬ «បានទទួលយក»

17

[1]កាលនោះលោកអហ៊ីថូផែលទូលស្តេចអាប់សាឡុមថា៖ «សូមអនុញ្ញាតឲ្យទូលបង្គំជ្រើសរើសទ័ព ចំនួនមួយម៉ឺនពីរពាន់នាក់
ហើយទូលបង្គំនឹងចេញដេញតាមព្រះបាទដាវីឌយប់នេះ។[2]ទូលបង្គំនឹងវាយប្រហារស្តេចនៅពេលដែលទ្រង់អស់កម្លាំង ហើយចុះខ្សោយ
រួចទូលបង្គំនឹងធ្វើឲ្យស្តេចភ័យតក់ស្លុត។ មនុស្សទាំងប៉ុន្មានដែលនៅជាមួយទ្រង់ នឹងរត់ចោលទ្រង់ ហើយទូលបង្គំនឹងធ្វើគុតស្តេចតែមួយអង្គគត់។
[3]ទូលបង្គំនឹងនាំមនុស្សទាំងអស់មកព្រះករុណាវិញ គឺដូចជាកូនក្រមុំវិលមករកស្វាមី
ហើយប្រជាជនទាំងអស់នឹងរស់នៅដោយសុខសាន្តក្រោមការគ្រប់គ្រងរបស់ព្រះករុណា»។[4]ស្តេចអាប់សូឡុម
និងចាស់ទុំទាំងអស់របស់អ៊ីស្រាអែលឃើញថាយោបល់នេះជាការសមរម្យ។
[5]សម្តេចអាប់សុឡុមមានរាជឱង្ការទៅលោកថា៖ «ចូរអញ្ជើញលោកហ៊ូសាយ ជាជនជាតិអើគីមក យើងចង់ឮយោបល់របស់គាត់»។[6]ពេលដែលលោកហ៊ូសាយមកដល់
សម្តេចអាប់សូឡុមបានរៀបរាប់លោកពីអ្វីដែលដែលលោកអហ៊ីថូផែលបានទូលទ្រង់ បន្ទាប់មកទ្រង់សួរលោកហ៊ូសាយថា៖
«តើយើងគួរធ្វើតាមយោបល់របស់លោកអាហ៊ូថូផែល ឬមិនធ្វើ? ប្រសិនបើ មិនត្រូវធ្វើ តើលោកមានយោបល់អ្វីផ្សេងឬទេ?»[7]ដូច្នេះលោកស៊ូហាយទូលទ្រង់ថា៖
«យោបល់ដែលលោកអាហ៊ីថូផែលទូលទ្រង់នៅពេលនេះគឺមិនល្អទេ»។
[8]លោកហ៊ូសាយទូលថា៖ «ព្រះករុណាស្គាល់ព្រះបិតាទ្រង់ស្រាប់ហើយថា បិតារបស់ទ្រង់ និងបរិវាររបស់ទ្រង់សុទ្ធតែជាពលទាហានដែលខ្លាំងពូកែ
ហើយពួកគេកំពុងតែក្រៅក្រហាយ ដូចមេខ្លាឃ្មុំដែលបាត់កូននៅទីវាល។ ម៉្យាងវិញទៀត ព្រះបិតារបស់ព្រះករុណាជាអ្នកចម្បាំង
ទ្រង់ប្រាកដជាមិនផ្ទុំនៅពេលយប់ជាមួយពលទាហានរបស់ទ្រង់ទេ។[9]ពេលនេះប្រហែលជាទ្រង់លាក់ខ្លួននៅក្នុងរូងភ្នំ ឬនៅកន្លែងណាមួយផ្សេងមិនខានឡើយ។ ប្រសិនបើ
មានទាហានណាម្នាក់ស្លាប់នៅក្នុងជួរ ចាប់តាំងពីពេលចាប់ផ្តើមប្រយុទ្ធ នោះនឹងឮមានដំណឹងថា ទ័ពរបស់ព្រះបាទអាប់សាឡុមទទួលបរាជ័យហើយ។[10]ដូច្នេះ
ទាហានដែលក្លាហាន ហើយមានចិត្តអង់អាចដូចជាសត្វសិង្ហ ក៏បាក់ទឹកចិត្តដែរ ព្រោះជនជាតិអ៊ីស្រាអែលទាំងអស់ដឹងថាព្រះបិតារបស់ទ្រង់ជាមេទ័ពដ៏ខ្លាំងពូកែ
ហើយពលទាហានដែលនៅជាមួយទ្រង់ទាំងអស់ក៏សុទ្ធតែជាមនុស្សក្លាហាន។
[11]ទូលបង្គំសូមផ្តល់យោបល់ថា៖ សូមព្រះករុណាប្រមូលកងទ័ពអ៊ីស្រាអែលទាំងអស់មក គឺចាប់ពីក្រុងដាន់ រហូតដល់បៀរសេបា
ឲ្យមានចំនួនច្រើនដូចគ្រាប់ខ្សាច់នៅមាត់សមុទ្រ ហើយព្រះករុណានឹងដឹកនាំពួកគេចេញទៅធ្វើសង្គ្រាម។
[12]យើងនឹងទៅទាន់ស្តេចដាវីឌនៅកន្លែងណាមួយដែលពួកគេស្នាក់ ហើយយើងនឹងសង្គ្រប់លើពួកគេ។
យើងនឹងប្រហារពួកគេដោយមិនទុកឲ្យអ្នកណាម្នាក់នៅមានជីវិតឡើយ គឺទាំងមនុស្សរបស់ទ្រង់ ទាំងព្រះបិតាទ្រង់។
[13]ប្រសិនបើ ពួកគេរត់ទៅជ្រកនៅក្រុងណាមួយ នោះប្រជាជនអ៊ីស្រាអែលទាំងអស់នឹងចងខ្សែពួរក្រុងនោះ ហើយទាញវាទំលាក់ទៅក្នុងទន្លេ
ឥតឲ្យសល់ដុំថ្មណាមួយឡើង»។[14]ព្រះបាទអាប់សាឡុម និងពួកចាស់ទុំនិយាយថា៖ «យោបល់លោកហ៊ូសាយ ជាជនជាតិអើគី
ល្អជាងយោបល់របស់លោកអហ៊ីថូផែល!»។ ព្រះអម្ចាស់បានធ្វើឲ្យគេបដិសេធយោបល់ដ៏ឆ្លាតវៃរបស់អហ៊ីថូផែល ដើម្បីធ្វើឲ្យសម្តេចអាប់សាឡុមវិនាស។
[15]លោកហ៊ូសាយរៀបរាប់ប្រាប់លោកបូជាចារ្យសាដុក និងបូជាចារ្យអបៀរធើរថា៖ «លោកអហ៊ីថូផែលបានផ្តល់
យោបល់ដល់សម្តេចអាប់សាឡុមចន្សដេញតាមព្រះបាទដាវីឌ ប៉ុន្តែ ខ្ញុំបានឲ្យយោបល់ផ្សេង។[16]ឥឡូវនេះ
ចូរចាត់អ្នកនាំសារទៅរាយការណ៍សេចក្តីទាំងនេះថ្វាយព្រះបាទដាវីឌ៖ យប់នេះសូមកុំឈប់នៅវាលទំនាបអារ៉ាបាឡើយ គឺត្រូវឆ្លងទៅត្រើយម្ខាង គឺដើម្បីកុំឲ្យព្រះរាជា
និងអ្នកនៅជាមួយត្រូវវិនាស»។
[17]លោកយ៉ូណាថាន់ និងលោកអហ៊ីម៉ាស់នៅចាំត្រង់ អេន រ៉ូកែន។ ស្ត្រីអ្នកនាំសារបានមកជួបលោក ហើយជម្រាបលោកទាំងពីរនូវកិច្ចការដែលលោកត្រូវដឹង
គឺពួកគេមិនត្រូវចូលទៅស្នាក់នៅក្នុងទីក្រុងនោះទេ។ បន្ទាប់ពី បានទទួលដំណឹង ពួកគេបាននាំយកទៅទូលព្រះបាទដាវីឌ។[18]ប៉ុន្តែ មានយុវជនម្នាក់បានឃើញពួកគេ
ហើយបានទូលទៅសម្តេចអាប់សាឡុម។ ដូច្នេះ លោកយ៉ូណាថាន់ និងលោកអហ៊ីម៉ាស់បានចាកចេញពីទីនោះយ៉ាងប្រញាប់ប្រញាល់
ហើយទៅផ្ទះរបស់មនុស្សម្នាក់នៅភូមិបាហ៊ូរីម ដែលផ្ទះរបស់នោះមានអណ្តូងទឹកនៅក្នុងបរិវេនផ្ទះ ដែលពួកគេអាចចូលពួនបាន។
[19]ស្ត្រីម្ចាស់ផ្ទះបានយកគម្របអណ្តូង មកគ្របពីលើមាត់អណ្តូង ហើយចាក់គ្រាប់ស្រូវរាយពីលើ ដូច្នេះ មិនមានអ្នកដឹងទេថា លោកយ៉ូណាថាន់
និងលោកអហ៊ីម៉ាស់នៅក្នុងអណ្តូងនោះទេ។[20]ទាហានរបស់សម្តេចអាប់សាឡុមបានមកដល់ផ្ទះរបស់ស្ត្រីនោះ ហើយសួរនាងថា៖ «តើលោកយ៉ូណាថាន់
និងលោកអហ៊ីម៉ាស់នៅឯណា?»។ នាងឆ្លើយថា៖ «ពួកគេបានឆ្លងទន្លេទៅហើយ»។ បន្ទាប់ពីពួកគេបានស្វែងរកមើលគ្រប់ទីកន្លែងហើយ តែរកមិនឃើញអ្នកទាំងពីរ
ពួកទាហានក៏ត្រឡប់ទៅក្រុងយេរូសាឡិមវិញ។

generated on Wed Sep 10 16:16:32 2025

[21]បន្ទាប់ពី ពួកទាហានចាកចេញទៅ នោះលោកយ៉ូណាថាន់ និងលោកអហ៊ីម៉ាស់បានឡើងពីអណ្តូងមក។ ពួកគេបាននាំយកដំណឹងទៅរាយការណ៍ថ្វាយព្រះបាទដាវីឌ
ពួកគេទូលថា៖ «សូមព្រះរាជាក្រោកឡើង ហើយឆ្លងទន្លេជាប្រញាប់ ព្រោះមានគេថ្វាយយោបល់សម្តេចអាប់សាឡុម ឲ្យដេញតាមទ្រង់ហើយ»។[22]ដូច្នេះ ព្រះបាទដាវីឌ
និងបណ្តាជនដែលនៅជាមួយទ្រង់ទាំងអស់ បានក្រោកឡើងឆ្លងទន្លេយ័រដាន។ លុះព្រលឹមស្រាងៗពួកគេបានឆ្លងទន្លេយ័រដានទាំងអស់គ្នា
មិនមាននៅសេសសល់នរណាម្នាក់ឡើយ។
[23]នៅពេលដែលលោកអហ៊ីថូផែលឃើញថាគេមិនអនុវត្តតាមយោបល់របស់លោកដូច្នេះ លោកបានចងកែបលា ហើយចាកចេញទៅ។
លោកបានត្រឡប់ទៅស្រុកកំណើតរបស់លោកវិញ គាត់បានធ្វើការផ្តែផ្តាំ ហើយបានចងកសម្លាប់ខ្លួនឯង។ គាត់ស្លាប់ដោយរបៀបនេះ
ហើយគេបញ្ចុះសព្វរបស់លោកក្នុងផ្នូរឪពុករបស់លោក។
[24]ព្រះបាទដាវីឌបានមកដល់ម៉ាហាណែម នៅពេលដែលសម្តេចអាប់សាឡុម និងអស់អ្នកដែលនៅជាមួយសម្តេចកំពុងឆ្លងទន្លេរយ័រដាន់[25]ស្តេចអាប់សាឡុម
បានតែងតាំងលោកអាម៉ាសាឲ្យធ្វើជាមេបញ្ជាការកងទ័ពជំនួសលោកយ៉ូអាប់។ លោកអាម៉ាសា ជាកូនរបស់លោកយេថើរ ជាជនជាតិអ៊ីស្មាអែល
ដែលបានយកនាងអប៊ីហ៊ែល ដែលជាកូនស្រីរបស់លោកណាហាស និងជាប្អូនស្រីរបស់អ្នកស្រីសេរូយ៉ា ដែលជាម្តាយរបស់លោកយ៉ូអាប់។[26]ពួកអ៊ីស្រាអែល
និងស្តេចអាប់សាឡុមបានបោះជំរំទ័ពនៅស្រុកកាឡាដ។
[27]កាលព្រះបាទដាវីឌបានមកដល់ក្រុងម៉ាហាណែម ស្តេចបានជួបនឹងលោកស៊ូបី ជាកូនប្រុសរបស់លោកណាហាស នៅក្រុងរ៉ាបា ជារាជធានីរបស់ជនជាតិអាំម៉ូន
និងលោកម៉ាកៀរ ជាកូនប្រុសរបស់លោកអាំមាល នៅឡូដេបា និងលោកបាស៊ីឡៃ អ្នកភូមិរ៉ូគីលីម ស្រុកកាឡាដ[28]បាននាំយកមុង ភួយ ក្តើយ ហើយនិងចាន ឆ្នាំង
ស្រូវសាលី ម៉្សៅស្រូវសាលី លាជ សណ្តែក[29]ទឹកឃ្មុំ ប័រ ចៀម និង ប្រូម៉ាស ដែលព្រះបាទដាវីឌ និងពួកដែលនៅជាមួយទ្រង់អាចបរិភោគបាន។
ដោយពួកគេបាននិយាយថា៖ «ពួកបណ្តាលជនប្រាកដជាឃ្លាន អស់កម្លាំង និងខ្សោយហើយ នៅវាលរហោស្ថាន»។

---

2 Samuel 17:1

លោកអហ៊ីថូផែល

ការបកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:១១ ។

ចំនួនមួយម៉ឺនពីរពាន់នាក់

«ទាហាន ១២,០០០»

នឹងចេញ

«ចាប់ផ្តើមទៅ»

វាយប្រហារ

«មកកាន់»

អស់កម្លាំង ហើយចុះខ្សោយ

ពាក្យទាំងនេះមានន័យជារួមដូចគ្នា
ហើយត្រូវបានប្រើជាមួយគ្នាដើម្បីបញ្ជាក់ពីភាពទន់ខ្សោយរបស់ព្រះបាទដាវីឌយ៉ាងណាមិញ
ការបកប្រែផ្សេងទៀត «ចុះខ្សោយ»

នឹងធ្វើឲ្យស្តេចភ័យតក់ស្លុត

នៅទីនេះពាក្យ «ការភ័យខ្លាច» អាចត្រូវបានបង្ហាញជាមួយគុណនាម
«ភ័យខ្លាច»។ ការបកប្រែផ្សេងទៀត
«នឹងធ្វើឱ្យគាត់ភ្ញាក់ផ្អើលនិងធ្វើឱ្យគាត់ភ័យខ្លាច»

ហើយទូលបង្គំនឹងធ្វើគុតស្តេចតែមួយអង្គគត់

វាបញ្ជាក់ថាគាត់មានបំណងសម្លាប់ស្តេច។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងសម្លាប់តែស្តេច»

ទូលបង្គំនឹងនាំមនុស្សទាំងអស់មកព្រះករុណាវិញ

នេះសំដៅទៅលើមនុស្សទាំងអស់ដែលនៅជាមួយព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «នាំយកមនុស្សទាំងអស់ដែលនៅជាមួយគាត់មកវិញ»

គឺដូចជាកូនក្រមុំវិលមករកស្វាមី

នៅទីនេះ លោកអហ៊ីថូផែល
និយាយពីសុភមង្គលរបស់ប្រជាជនដោយប្រៀបធៀបវាទៅនឹងសុភមង្គលរបស់កូនក្រមុំ។
ការបកប្រែផ្សេងទៀត «ហើយពួកគេនឹងមកយ៉ាងរីករាយ
ដូចជាកូនក្រមុំសប្បាយចិត្តនៅពេលនាងមករកប្តីរបស់នាង» ឬ
«ហើយពួកគេនឹងមកយ៉ាងរីករាយ»

នៅដោយសុខសាន្ត

នេះមានន័យថាមានសន្តិភាពឬរស់នៅដោយសុខសន្តិភាព។ ការបកប្រែផ្សេងទៀត
«រស់នៅដោយសន្តិភាព»

ក្រោមការគ្រប់គ្រងរបស់ព្រះករុណា

នេះសំដៅទៅលើការស្ថិតនៅក្រោមអំណាចរបស់ស្តេច។ ការបកប្រែផ្សេងទៀត
«ស្ថិតនៅក្រោមអំណាចរបស់ព្រះអង្គ»

2 Samuel 17:5

លោកហ៊ូសាយ ជាជនជាតិអើគី

បកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:៣២ ។

លោកអហ៊ីថូផែល

បកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:១១ ។

2 Samuel 17:8

ដូចមេខ្លាឃ្មុំដែលបាត់កូននៅទីវាល។

កំហឹងរបស់ទាហាននៅទីនេះត្រូវបានគេប្រៀបធៀបទៅនឹងខ្លាឃ្មុំមេដែលកូនខ្លាឃ្មុំត្រូវបានយកចេញពីវា។
ការបកប្រែផ្សេងទៀត
«ពួកវាខឹងដូចជាខ្លាឃ្មុំមេដែលកូនរបស់ពួកវាត្រូវបានគេយកចេញពីវា» ឬ
«ពួកវាខឹងខ្លាំងណាស់»

មេខ្លាឃ្មុំ

ជាសត្វរោមធំមួយដែលដើរដោយជើងបួននិងមានក្រញាំនិងធ្មេញមុត

ព្រះបិតារបស់ព្រះករុណាជាអ្នកចម្បាំង

នេះមានន័យថាទ្រង់បានប្រយុទ្ធនៅក្នុងសមរភូមិជាច្រើនហើយដឹងច្បាស់ពីរបៀបនៃសង្គ្រាម។
ការបកប្រែផ្សេងទៀត «បានប្រយុទ្ធនៅក្នុងសមរភូមិជាច្រើន»

មើល!

នៅទីនេះពាក្យនេះគឺត្រូវបានប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់នរណាម្នាក់
ចំពោះអ្វីដែលត្រូវនិយាយបន្ទាប់។ ការបកប្រែផ្សេងទៀត «ចូរស្តាប់»

ក្នុងរូងភ្នំ

រូងជ្រៅនៅក្នុងភ្នំ

ឬនៅកន្លែងណាមួយផ្សេង

នេះគឺជាកន្លែងមួយទៀតដែលព្រះអង្គប្រហែលជាកំពុងលាក់ខ្លួន។
ការបកប្រែផ្សេងទៀត «ឬលាក់ខ្លួននៅកន្លែងផ្សេងទៀត»

ប្រសិនបើ មានទាហានណាម្នាក់ស្លាប់នៅក្នុងជួរ

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នៅពេលទាហានរបស់ព្រះបាទដាវីឌសម្លាប់ទាហានរបស់អ្នក»

ទ័ពរបស់ព្រះបាទអាប់សាឡុមទទួលបរាជ័យហើយ។

ពាក្យ «ការសម្លាប់រង្គាល» ជានាម
មានន័យថាព្រឹត្តិការណ៍មួយដែលមនុស្សជាច្រើនត្រូវបានសម្លាប់យ៉ាងសាហាវព្រៃផ្សៃ។
នេះអាចត្រូវបានបង្ហាញជាកិរិយាស័ព្ទ។ ការបកប្រែផ្សេងទៀត
«ទាហានជាច្រើនដែលតាមព្រះបាទអាប់សាឡុមត្រូវបានគេសម្លាប់» ឬ
«ទាហានសត្រូវបានសម្លាប់ទាហានជាច្រើននាក់ដែលដើរតាមព្រះបាទអាប់សាឡុម»

ហើយមានចិត្តអង់អាចដូចជាសត្វសិង្ហ

នៅទីនេះទាហានគឺត្រូវបានសំដៅតាមរយៈ «ដួងចិត្ត» របស់ពួកគេ។
ភាពក្លាហានរបស់ពួកគេផងដែរគឺត្រូវបានប្រៀបធៀបទៅនឹងសត្វតោ។
ការបកប្រែផ្សេងទៀត «ដែលក្លាហានដូចតោ» ឬ «អ្នកដែលក្លាហានណាស់»

2 Samuel 17:11

សូមព្រះករុណាប្រមូលកងទ័ពអ៊ីស្រាអែលទាំងអស់មក

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។
ទាហានទាំងអស់នៃអ៊ីស្រាអែលនៅក្នុងអ៊ីស្រាអែល
ត្រូវបាននិយាយសំដៅនៅទីនេះថាជា «អ៊ីស្រាអែលទាំងអស់»។
ការបកប្រែផ្សេងទៀត «អ្នកគួរតែប្រមូលផ្តុំទាហានអ៊ីស្រាអែលទាំងអស់»

គឺចាប់ពីក្រុងដាន់ រហូតដល់បៀរសេបា

ឃ្លានេះមានន័យថាចាប់ពីព្រំប្រទល់ខាងជើងនៃអ៊ីស្រាអែលទៅព្រំប្រទល់ខាងត្បូង។
ការបកប្រែផ្សេងទៀត «ចេញពីប្រជាជាតិអ៊ីស្រាអែលទាំងមូល»

ឲ្យមានចំនួនច្រើនដូចគ្រាប់ខ្សាច់នៅមាត់សមុទ្រ

នេះគឺជាការនិយាយបំផ្លើសមួយ
គ្រប់គ្រាប់ខ្សាច់ទាំងអស់នៅមាត់សមុទ្រគឺត្រូវបានប្រៀបធៀបទៅនឹងចំនួនទាហានអ៊ីស្រាអែល។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «ច្រើនដែលពួកគេស្ទើរតែមិនអាចរាប់បាន»

ហើយព្រះករុណានឹងដឹកនាំពួកគេចេញទៅធ្វើសង្គ្រាម។

ឃ្លា «ដោយផ្ទាល់» មានន័យថាទៅខ្លួនឯងហើយមិនបញ្ជូនអ្នកដទៃជំនួសទេ។ ការបកប្រែផ្សេងទៀត «បន្ទាប់មកនាំពួកគេចូលទៅក្នុងសមរភូមិខ្លួនឯង»

ទៅទាន់ស្តេចដាវីឌ

នេះមានន័យថាមានគោលបំណងច្បាស់លាស់ ដើម្បីទៅកន្លែងដែលព្រះអង្គគង់នៅ ហើយបន្ទាប់មកវាយប្រហារ។

ហើយយើងនឹងសង្គ្រប់លើពួកគេ

កងទ័ពរបស់សម្តេចអាប់សាឡុមត្រូវបានពិពណ៌នាថា បានឡោមព័ទ្ធលើកងទ័ពរបស់ព្រះបាទដាវីឌដូចជាទឹកសន្សើមគ្របលើដីនៅពេលព្រឹក។ ការបកប្រែផ្សេងទៀត «យើងនឹងសង្គ្រប់លើ ហើយនិងវាយប្រហារកងទ័ពរបស់ព្រះបាទដាវីឌទាំងស្រុង»

ទឹកសន្សើម

អ័ព្ទ ឬពពកចុះអ័ព្ទ ដែលអាចធ្លាក់ទៅលើដីនៅពេលយប់ គ្របលើដីនិងទុកវាឲ្យសើមនៅពេលព្រឹក ។

យើងនឹងសង្គ្រប់លើពួកគេ។ យើងនឹងប្រហារពួកគេដោយមិនទុកឲ្យអ្នកណាម្នាក់នៅមានជីវិតឡើយ

គឺទាំងមនុស្សរបស់ទ្រង់ ... ព្រះបិតាទ្រង់

ប្រយោគបដិសេធនេះ ត្រូវបានប្រើសម្រាប់បញ្ជាក់និងអាចត្រូវបានថ្លែងជាទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀ «យើងនឹងប្រហារគ្រប់គ្នាគឺទាំងមនុស្សរបស់ទ្រង់»

គឺទាំងមនុស្សរបស់ទ្រង់

ពាក្យទាំងពីរនេះសំដៅទៅលើដាវីឌ។ ការបកប្រែផ្សេងទៀត «ព្រះបាទដាវីឌផ្ទាល់»

2 Samuel 17:13

នោះប្រជាជនអ៊ីស្រាអែលទាំងអស់

នេះសំដៅទៅលើទាហានអ៊ីស្រាអែលមិនមែនសម្រាប់ប្រជាជនអ៊ីស្រាអែលទាំងអស់ទេ។ ការបកប្រែផ្សេងទៀត: «បន្ទាប់មកទាហានរបស់យើងទាំងអស់»

នឹងចងខ្សែពួរក្រុងនោះ ហើយទាញវាទំលាក់ទៅក្នុងទន្លេ

នេះមានន័យថាទាហាននឹងទាញជញ្ជាំងទីក្រុង ហើយអូសបំណែកទាំងនោះទៅក្នុងទន្លេ។ ការបកប្រែផ្សេងទៀត «នឹងបំផ្លាញទីក្រុងហើយអូសផ្ទាំងថ្មទៅទន្លេដោយខ្សែពួរ»

ឥតឲ្យសល់ដុំថ្មណាមួយឡើង

នេះគឺជាការនិយាយបំភ្លើសមួយដើម្បីពិពណ៌នាអំពីរបៀបដែលពួកគេនឹងបំផ្លាញទីក្រុងទាំងស្រុង។ នឹងមិនមែនន័យត្រង់ថាសសម្អាតដុំថ្មតូចៗចេញពីទីក្រុងទាំងអស់។ ការបកប្រែផ្សេងទៀត «រហូតដល់ទីក្រុងត្រូវបានបំផ្លាញទាំងស្រុង»

លោកហ៊ូសាយ ជាជនជាតិអើគី

ការបកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:៣២ ។ ជាជនជាតិអើគី គឺជាឈ្មោះនៃក្រុមមនុស្ស។

លោកអហ៊ីថូផែល

បកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:១១ ។

ធ្វើឲ្យគេបដិសេធយោបល់ដ៏ឆ្លាតវៃរបស់អហ៊ីថូផែល

ពាក្យ «ការបដិសេធ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «បដិសេធ» ។ ការបកប្រែផ្សេងទៀត «ដើម្បីឲ្យប្រជាជនអ៊ីស្រាអែលបដិសេធនូវដំបូន្មានល្អៗរបស់លោកអហ៊ីថូផែល»

ដើម្បីធ្វើឲ្យសម្តេចអាប់សាឡុមវិនាស

ដើម្បី «នាំ»

មានអ្វីមួយនៅលើនរណាម្នាក់មានន័យថាបណ្តាលឲ្យវាកើតឡើងចំពោះពួកគេ។ ការបកប្រែផ្សេងទៀត «បង្ករឲ្យមានគ្រោះមហន្តរាយកើតឡើងទៅលើអាប់សាឡុម»

2 Samuel 17:15

លោកបូជាចារ្យសាដុក ... បូជាចារ្យអបៀរធើរ

ការបកប្រែឈ្មោះបុរសទាំងនេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១៥:២៤ ។

ឲ្យដេញតាម

ឃ្លានេះមានន័យថា «ដូចនេះ» សំដៅទៅលើអ្វីដែលលោកអហ៊ីថូផែលបានណែនាំសម្តេចអាប់សាឡុមនៅដើម ១៧: ១ ។

នៅវាលទំនាបអារ៉ាបា

វាលទំនាបគឺជាផ្នែកមួយមានជម្រៅរាក់នៃទឹកទន្លេដែលមនុស្សអាចដើរឆ្លងកាត់បាន។ អារ៉ាប់គឺជាទឹកដីនៅតាមសងខាងបណ្តោយទន្លេយ័រដាន់។

គឺត្រូវឆ្លងទៅ

នេះមានន័យថាត្រូវប្រាកដថាអ្នកធ្វើអ្វីមួយ។ ការបកប្រែផ្សេងទៀត

«ត្រូវប្រាកដថា» ឬ «ធ្វើឲ្យប្រាកដថាអ្នក»

គឺដើម្បីកុំឲ្យព្រះរាជាត្រូវវិនាស

នៅទីនេះស្តេចនិងប្រជាជនរបស់ទ្រង់ដែលត្រូវបានសម្លាប់ត្រូវបានពិពណ៌នាដូចជាពួកគេត្រូវបាន «លេប» ដោយសត្រូវរបស់ពួកគេ។ ការបកប្រែផ្សេងទៀត «ស្តេចនឹងត្រូវគេសម្លាប់»

2 Samuel 17:17

លោកយ៉ូណាថាន់ ...លោកអហ៊ីម៉ាស់

ការបកប្រែឈ្មោះបុរសទាំងនេះដូចគ្នានឹងអ្នកបានធ្វើនៅក្នុង ១៥:២៧។

បន្ទាប់ពី បានទទួលដំណឹង

នៅទីនេះ «សារ» ត្រូវបានគេនិយាយដូចជាពួកគេមកដល់ ពេលដែលជាក់ស្តែង គឺជាស្ត្រីដែលបានចូលមក បន្ទាប់មកនាំសារ។ ការបកប្រែផ្សេងទៀត «នៅពេលនាងនាំសារមកអោយពួកគេ»

ពេលនេះ

«មួយដង»

ដូច្នេះ លោកយ៉ូណាថាន់ និងលោកអហ៊ីម៉ាស់

វាគឺបានបញ្ជាក់ថាពួកគេបានរកឃើញថាយុវជននោះបានប្រាប់សម្តេចអាប់សាឡុមអំពីពួកគេនៅទីនោះ។ នេះអាចត្រូវបានថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «លោកយ៉ូណាថាន់ និង លោកអហ៊ីម៉ាស់បានរកឃើញនូវអ្វីដែលយុវជននោះបានធ្វើដូច្នេះពួកគេក៏បានចាកចេញទៅ»

នៅចាំត្រង់ អេន រ៉ូកែន ... ភូមិបាហ៊ូរីម

នេះជាឈ្មោះកន្លែងទាំងពីរនៅជិតក្រុងយេរូសាឡឹម។ ភូមិបាហ៊ូរីម គឺជាទីក្រុងតូចមួយ។

ពួកគេអាចចូលពួនបាន

«ពួកគេបានបន្ទាបខ្លួនហើយលាក់ខ្លួន»

2 Samuel 17:19

ម្តាយរបស់ស្ត្រីនោះ

«ប្រពន្ធរបស់បុរស»

លោកអហ៊ីម៉ាស់ ... លោកយ៉ូណាថាន់

ការបកប្រែឈ្មោះបុរសទាំងនេះដូចគ្នានឹងអ្នកបានធ្វើនៅក្នុង ១៥:២៧។

2 Samuel 17:21

បន្ទាប់ពី

«វាបានកើតឡើង» ។ ឃ្លានេះសម្គាល់ព្រឹត្តិការណ៍បន្ទាប់នៅក្នុងដំណើររឿង។

ទីសម្គាល់ដែលជាប្រញាប់

នៅទីនេះ «ទឹក» សំដៅទៅលើទន្លេយ័រដាន់។ ការបកប្រែផ្សេងទៀត «ឆ្លងទន្លេយ៉ាងលឿន»

មានគេថ្វាយយោបល់សម្តេចអាប់សាឡុម ឲ្យដេញតាមទ្រង់ហើយ

ពាក្យ «បែបនេះ» ត្រូវបានប្រើនៅក្នុងកន្លែងនៃព័ត៌មានដែលអ្នកអានដឹងរួចហើយ។ ត្រង់នេះវាសំដៅទៅលើអ្វីដែលលោកអហ៊ីថូផែលបានថ្វាយយោបល់ដល់ព្រះបាទអាប់សាឡុមនៅក្នុង ១៧: ១ ។ ព័ត៌មាននេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត «បានថ្វាយយោបល់ឲ្យថាព្រះបាទអាប់សាឡុមបញ្ជូនគាត់ជាមួយកងទ័ពដើម្បីវាយប្រហារព្រះអង្គឥឡូវនេះ

លុះព្រលឹមស្រាងៗពួកគេបានឆ្លងទន្លេយ័រដានទាំងអស់គ្នា

មិនមាននៅសេសសល់នរណាម្នាក់ឡើយ។

ប្រយោគបដិសេធនេះគឺត្រូវបានប្រើដើម្បីបញ្ជាក់ថាពួកគេទាំងអស់គ្នាបានឆ្លងទន្លេ។ វាអាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «នៅពេលព្រឹកថ្ងៃរះពួកគេម្នាក់ៗបានឆ្លងទន្លេយ័រដាន់ហើយ»

2 Samuel 17:23

ឃើញ

«បានដឹង» ឬ «បានយល់ដឹង»

គេមិនអនុវត្តតាមយោបល់របស់លោកដូច្នេះ

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ព្រះបាទអាប់សាឡុមមិនបានធ្វើតាមយោបល់របស់គាត់ទេ»

បានចងកែបលា

ដាក់ភួយឬកៅអីស្បែកតូចៗដាក់លើលាឬសេះដើម្បី ឲ្យ អ្នកជិះអង្គុយ។

បានធ្វើការផ្តែផ្តាំ

គាត់បានត្រៀមខ្លួនសម្រាប់ការស្លាប់របស់គាត់ ដោយប្រាប់ក្រុមគ្រួសាររបស់គាត់នូវអ្វីដែលត្រូវធ្វើបន្ទាប់ពីគាត់បានស្លាប់។ ការបកប្រែផ្សេងទៀត «គាត់បានត្រៀមខ្លួនសម្រាប់ការស្លាប់របស់គាត់»

ដោយរបៀបនេះ

«ហើយនេះជារបៀប»

បញ្ចុះសព

generated on Wed Sep 10 16:16:32 2025

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេបានបញ្ឆេះគាត់»
2 Samuel 17:24
ម៉ាហាណែម ... ស្រុកកាឡាដ
បកប្រែឈ្មោះទីកន្លែងទាំងនេះដូចគ្នានឹងអ្នកបានធ្វើនៅ ២: ៨ ។
លោកអាម៉ាសា ... លោកយ៉ូអាប់ ... លោកយេថើរ ... លោកអាម៉ាសា
ទាំងនេះគឺជាឈ្មោះរបស់បុរស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែលោកយ៉ូអាប់និងអ្នកស្រីសេរូយ៉ា(ម្តាយរបស់លោក**អប៊ីសាយ**និង**យ៉ូអាប់**) ក្នុង ២:១២ ។
ជាជនជាតិអ៊ីស្មាអែល
ពាក្យនេះមានន័យថាមនុស្សនោះត្រូវបានចុះមកពីអ៊ីស្មាអែល។
ការបកប្រែខ្លះនិយាយថា «អ៊ីស្រាអែល» នៅទីនេះ។ សូមមើលលេខយោង។
អ្នកប្រហែលជាចង់ជ្រើសរើសយកពាក្យ
ដែលត្រូវបានប្រើនៅក្នុងព្រះគម្ពីរភាសាភាគច្រើននៅក្នុងតំបន់របស់អ្នក ។.
នាងអប៊ីហ្គែល ... អ្នកស្រីសេរូយ៉ា
ទាំងនេះគឺជាឈ្មោះរបស់ស្ត្រី។
2 Samuel 17:27
កាល
ឃ្លានេះត្រូវបានប្រើដើម្បីបង្ហាញព្រឹត្តិការណ៍បន្ទាប់នៅក្នុងដំណើររឿង។
ក្រុងម៉ាហាណែម ... នៅក្រុងរ៉ាបា ...ឡូដេបា ... ភូមិរ៉ូគីលីម
ទាំងនេះជាឈ្មោះនៃទីក្រុងឬទីកន្លែង។
លោកស៊ូបី ...លោកណាហាស... លោកម៉ាកៀរ ... លោកអាំមាល ... លោកបាស៊ីឡៃ
ទាំងនេះជាឈ្មោះរបស់បុរស។
ជនជាតិអាំម៉ូន ... ស្រុកកាឡាដ
ទាំងនេះជាឈ្មោះនៃក្រុមមនុស្ស។
បាននាំយកមុង ភួយ ខ្នើយ
កន្ទេលគឺជាអ្វីដែលទន់សម្រាប់គេងលើគ្រែ
ហើយ**គ្រាប់**គឺជាក្រណាត់គ្របសម្រាប់ភាពកក់ក្តៅ។
ម្សៅ
ម្សៅត្រូវបានកិនគ្រាប់ធញ្ញជាតិផលិតទៅជាម្សៅហើយត្រូវបានគេប្រើដើម្បីធ្វើនំប៉័ង។
លីង
«ចម្អិន»
សណ្តែក
ប្រភេទនៃគ្រាប់ដែលត្រូវបានចម្អិននិងបរិភោគ
សណ្តែកបាយ
ពូជមួយប្រភេទដែលត្រូវបានចម្អិននិងបរិភោគ
ប្លេម៉ាស
ទឹកដោះគោដែលធ្វើឲ្យមានជាតិខ្លាញ់និងប្រៃជារឹង
ខ្សោយ
ត្រូវការទឹកឬភេសជ្ជៈផ្សេងទៀត

---

18 [1]ព្រះបាទដាវីឌបានរាប់ចំនួនពលទាហានដែលនៅជាមួយទ្រង់ និងតែងតាំងមេបញ្ជាការកងពលធំ និងមេបញ្ជាការកងពលតូច គ្រប់គ្រងលើពួកគេ។[2]បន្ទាប់មក
ស្តេចចែកពលទាហានជាបីកង មួយភាគបីនៅក្រោមការដឹកនាំរបស់លោកយ៉ូអាប់ កងទីពីរនៅក្រោកការបញ្ជារបស់លោកអប៊ីសាយ
កូនប្រុសរបស់លោកស្រីសេរ៉ូយ៉ា ប្អូនប្រុសរបស់លោកយ៉ូអាប់ និងមួយភាគបីផ្សេងទៀតស្ថិតក្រោមការដឹកនាំរបស់លោកអ៊ីតាយ ជាជនជាតិកាថ។
ព្រះរាជាមានព្រះរាជឱង្ការទៅកាន់ពលទាហានថា៖ «យើងនឹងចេញទៅច្បាំងជាមួយអ្នករាល់គ្នាដែរ»។
[3]ប៉ុន្តែ ពួកទាហានទូលទ្រង់ថា៖ «ទ្រង់មិនត្រូវចេញទៅសមរភូមិទេ ព្រោះប្រសិនបើ យើងរាល់គ្នាចាញ់សង្គ្រាម នោះពួកគេនឹងមិនចាប់អារម្មណ៍នឹងយើងរាល់គ្នានោះទេ
ឬក៏ប្រសិនបើ ពួកយើងពាក់កណ្តាលស្លាប់ក្តីក៏គ្មានអ្នកណាចាប់អារម្មណ៍ដែរ។ ប៉ុន្តែ ព្រះករុណាមានតម្លៃស្មើនឹងពួកយើងមួយម៉ឺននាក់!
ហេតុនេះគួរតែព្រះករុណាគង់នៅក្នុងទីក្រុងចាំជួយយើងរាល់គ្នាវិញ»។[4]នោះព្រះបាទដាវីឌមានរាជឱង្ការទៅពួកគេថា៖ «យើងនឹងធ្វើតាមការស្នើសុំរបស់អ្នករាល់គ្នា»។
នោះស្តេចគង់ប្រថាប់នៅត្រង់មាត់ទ្វារក្រុង ខណៈពេលដែលពួកទាហានចេញទៅ តាមក្រុម តាមកងរបស់ខ្លួន។
[5]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់លោកយ៉ូអាប់ លោកអប៊ីសាយ និងលោកអ៊ីតាយថា៖ «បើអ្នករាល់គ្នាស្រឡាញ់យើង សូមកុំធ្វើបាបសម្តេចអាប់សាឡុម
ជាបុត្ររបស់យើងឡើយ»។ ពលទាហានទាំងអស់បានឮរាជឱង្ការ ដែលព្រះបាទដាវីឌផ្តែផ្តាំមេទ័ពទាំងអស់ ស្តីអំពីសម្តេចអាប់សាឡុម។
[6]ដូច្នេះ ពួកទាហានបានចេញទៅច្បាំងនឹងកងទ័ពអ៊ីស្រាអែល ហើយសង្គ្រាមបានផ្ទុះឡើងនៅក្នុងព្រៃអេប្រាអ៊ីម។[7]ទាហានអ៊ីស្រាអែលបានចាញ់ទាហានរបស់ព្រះបាទដាវីឌ
នៅថ្ងៃនោះពួកគេត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ គឺមានទាហានចំនួនពីរម៉ឺននាក់បានស្លាប់។[8]ការប្រយុទ្ធបានរាលដាលពេញស្រុកទាំងមូល
ហើយមនុស្សដែលស្លាប់ក្នុងព្រៃមានចំនួនច្រើនជាងមនុស្សដែលស្លាប់ដោយមុខដាវ។
[9]សម្តេចអាប់សាឡុមបានជួបជាមួយទាហានរបស់ព្រះបាទដាវីឌ។ ពេលនោះសម្តេចអាប់សាឡុមកំពុងតែជិះលារបស់ទ្រង់ ហើយលានោះបានចូលទៅក្រោមឈើដ៏ធំ
ដែលមានមែកសាខា ស្រាប់តែព្រះសិរសារបស់ទ្រង់បានជាប់នឹងប្រគាបមែកឈើ។ សត្វលានៅតែដើរទៅមុខដោយទុកឲ្យស្តេចអាប់សាឡុមនៅព្យួរនឹងមែកឈើ
ជើងផុតពីដី។[10]ទាហានម្នាក់បានឃើញការនេះ ហើយប្រាប់លោកយ៉ូអាប់ថា៖ «មើល៍! ខ្ញុំបានឃើញស្តេចអាប់សាឡុម ព្យួរជាប់នឹងមែនឈើ!»។
[11]លោកយ៉ូអាប់មានប្រសាសន៍ទៅបុរសនោះថា៖ «មើល៍! អ្នកបានឃើញគាត់! ហេតុអ្វីបានជាអ្នកមិនសម្លាប់គាត់នៅនឹងកន្លែងនោះទៅ»
នោះខ្ញុំនឹងឲ្យប្រាក់ឯងដប់ស៊ីគែល និងខ្សែក្រវាត់មួយជារង្វាន់»។
[12]បុរសនោះតបទៅលោកវិញថា៖ «ទោះបីជាខ្ញុំបានទទួលរហូតដល់មួយពាន់ស៊ីគែលក្តី ក៏ខ្ញុំមិនលើកដៃរបស់ខ្ញុំទាស់នឹងបុត្ររបស់ស្តេចដែរ
ព្រោះយើងទាំងអស់គ្នាបានឮព្រះឱង្ការស្តេច បញ្ជាមកលោកអប៊ីសាយ និងលោកអ៊ីតាយថា៖ «សូមប្រណីដល់អាប់សាឡុមផង!»។[13]ប្រសិនបើ ខ្ញុំធ្វើគត់បុត្រាស្តេច
(មិនមានអ្វីមួយដែលអាចលាក់លៀមនឹងស្តេចបានឡើយ) លោកក៏មិនការពារខ្ញុំដែរ។
[14]លោកយ៉ូអាប់មានប្រសាសន៍ថា៖ «ខ្ញុំនឹងមិនចាំឯងទេ»។ ដូច្នេះ លោកយ៉ូអាប់ចាប់ជន្លួញបី ហើយចាក់ទំលុះបេះដូងស្តេចអាប់សាឡុម
ពេលដែលស្តេចនៅរស់ហើយជាប់នឹងមែកឈើនោះទៅ។[15]បន្ទាប់មក ពលទាហាបដប់នាក់ ដែលកាន់អាវុធរបស់លោកយ៉ូអាប់បានចោមរោមសម្តេចអាប់សាឡុម
ហើយវាយទ្រង់ រហូតសុគត។
[16]លោកយ៉ូអាប់បានហៅពួកទាហានឲ្យត្រឡប់ពីការដេញតាមទ័ពអ៊ីស្រាអែលវិញ ដោយឲ្យគេផ្លុំត្រែឡើង។[17]ពួកទាហានបានដាក់សពសម្តេចអាប់សាឡុមចុះ
ហើយបោះចោលក្នុងរណ្តៅដ៏ធំមួយនៅក្នុងព្រៃ ហើយបានយកថ្មយ៉ាងច្រើនមកគរពីលើផង ពេលនោះទាហានអ៊ីស្រាអែលបាក់ទ័ព ហើយរត់ទៅជំរំរបស់គេរៀងៗខ្លួន។
[18]នៅពេលមានព្រះជន្មរស់នៅឡើយ សម្តេចអាប់សាឡុមបានសាងបង្គោលថ្មធំមួយ នៅក្នុងជ្រលងភ្នំរបស់ស្តេច ដោយទ្រង់មានរាជឱង្ការថា៖
«យើងមិនមានកូនប្រុសបន្តវង្សត្រកូលទេ»។ ដូច្នេះ ទ្រង់បានដាក់ឈ្មោះរបស់ទ្រង់ផ្ទាល់នៅលើបង្គោលថ្មនោះ ហេតុនេះហើយបានជាគេហៅបង្គោលនោះថា៖
«ស្តូបអាប់សាឡុម» រហូតដល់សព្វថ្ងៃនេះ។
[19]នៅពេលនោះ លោកអហ៊ីម៉ាស់ កូនរបស់បូជាចារ្យសាដុកមានប្រសាសន៍ថា៖ «ចូលយើងនាំយកដំណឹងល្អនេះ ទៅទូលស្តេចឥឡូវនេះ
ថាព្រះអម្ចាស់បានរកយុត្តិធ៌មឲ្យព្រះករុណា ដោយរំដោះទ្រង់ពីដៃរបស់សត្រូវ»។[20]លោកយ៉ូអាប់តបទៅគាត់ថា៖ «ទេ! លោកមិនត្រូវនាំដំណឹងនៅថ្ងៃនេះនោះទេ
មិនត្រូវទូលស្តេចនៅថ្ងៃនេះទេ។ ថ្ងៃនេះ លោកមិនមែននាំដំណឹងល្អនោះទេ ព្រោះបុត្រារបស់ស្តេចសុគត»។
[21]លោកយ៉ូអាប់បង្គាប់ទៅជនជាតិអេត្យូពីម្នាក់ថា៖ «ចូរទៅទូលព្រះបាទដាវីឌនូវហេតុការណ៍ដែលលោកបានឃើញ»។ ជនជាតិអេត្យូពីនោះក្រាបថ្វាយបង្គំលោកយ៉ូអាប់
ហើយចាកចេញទៅ។[22]ពេលនោះ លោកអហ៊ីម៉ាស់ កូនរបស់បូជាចារ្យសាដុក សូមលោកយ៉ូអាប់ម្តងទៀតថា៖ «មិនថាមានអ្វីកើតឡើងទេ!
សូមអនុញ្ញាតឲ្យខ្ញុំរត់ទៅតាមសាសន៍អេត្យូពីនេះផងចុះ»។ លោកយ៉ូអាប់តបថា៖ «ហេតុអ្វីបានជាឯងចង់ទៅដូច្នេះកូនប្រុស?
ដំណឹងនេះមិនផ្តល់រង្វាន់អ្វីដល់អ្នកនោះទេ!»[23]«ទោះមានអ្វីកើតឡើងក៏ដោយខ្ញុំនឹងរត់ទៅ!» អហ៊ីម៉ាស់តប។ ដូច្នេះ លោកយ៉ូអាប់ក៏ឆ្លើយថា៖ «រត់ទៅចុះ!» នោះ
លោកអហ៊ីម៉ាស់ក៏រត់តាមពីក្រោយបុរសជនជាតិអេត្យូពីនោះទៅ។

generated on Wed Sep 10 16:16:32 2025

[24]ពេលនោះព្រះបាទដាវីឌកំពុងគង់នៅត្រង់ចន្លោះទ្វារខាងក្រៅ និងទ្វារខាងក្នុងកំពែងក្រុង។ អ្នកល្បាតបានឡើងទៅខាងលើកំពែងក្រុង ហើយសម្លឹងទៅខាងក្រៅ។
អ្នកល្បាតនោះបានឃើញមានបុរសម្នាក់រត់តម្រង់មក។[25]គេបានស្រែកទូលទៅស្តេច។ នោះ ព្រះរាជាមានរាជឱង្ការថា៖ «ប្រសិនបើ គេមកតែម្នាក់ឯង
នោះគឺគេមកដើម្បីនាំដំណឹងមកឲ្យយើង»។ អ្នករត់នោះចូលមកកាន់តែជិតទីក្រុង។
[26]បន្ទាប់មក អ្នកល្បាតនោះឃើញថាមានម្នាក់ទៀតកំពុងរត់ពីក្រោយមកដែរ រួចគាត់ក៏ស្រែកប្រាប់ទៅអ្នកយាមទ្វារថា៖ «មើល៍!
មានមនុស្សម្នាក់ទៀតកំពុងរត់ពីក្រោយមក»។ នោះ ព្រះបាទដាវីឌមានបន្ទូលថា៖ «គេក៏នាំដំណឹងមកឲ្យយើងដែរ!»[27]អ្នកល្បាតស្រែកថា៖ «អ្នកដែលរត់ខាងក្រោយនោះ
មើលទៅដូចជាលោកអហ៊ីម៉ាស់ កូនបូជាចារ្យសាដុក»។ ព្រះរាជាមានរាជឱង្ការថា៖ «គាត់ជាមនុស្សល្អហើយក៏នាំដំណឹងល្អមកដែរ»។
[28]លោកអហ៊ីម៉ាស់ស្រែកឡើង និងទូលស្តេចថា៖ «គ្រប់យ៉ាងគឺប្រសើរណាស់!»។ គាត់ឲ្យមុខចុះ និងក្រាបដល់ដីនៅចំពោះមុខព្រះរាជា ហើយទូលថា៖
«សូមព្រះអម្ចាស់ជាព្រះរបស់ព្រះករុណា ប្រទានពរព្រះករុណា! ព្រះអម្ចាស់បានបណ្តោញមនុស្សដែលបានលើកដៃទាស់នឹងព្រះរាជា ជាម្ចាស់របស់ខ្ញុំម្ចាស់»។
[29]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «តើវាបានកើតឡើងចំពោះសម្តេចអាប់សាឡុម បុត្ររបស់យើងឬ?» លោកអហ៊ីម៉ាស់ទូលថា៖
«ពេលដែលលោកយ៉ូអាប់ចាត់ទូលបង្គំនិងអ្នកបម្រើម្នាក់ទៀត មកគាល់ទ្រង់នោះ មានការជ្រួលច្របល់យ៉ាងខ្លាំង ប៉ុន្តែ ទូលបង្គំមិនដឹងថាមានអ្វីកើតឡើងនោះទេ»។
[30]នោះព្រះរាជាមានរាជឱង្ការថា៖ «ចូរទៅឈរនៅមួយចំហៀងទៅ!» លោកអហ៊ីម៉ាស់ក៏ថយខ្លួនចេញ ហើយនៅឈរស្ងៀមចាំ។
[31]ភ្លាមនោះអ្នកបម្រើជនជាតិអេត្យូពីបានមកដល់ ហើយទូលស្តេចថា៖ «បពិត្រព្រះករុណា! ទូលបង្គំនាំដំណឹងល្អមកទូលថ្វាយព្រះករុណា
ថ្ងៃនេះព្រះអម្ចាស់បានរកយុត្តិធម៌ថ្វាយព្រះករុណាពីមនុស្សដែលបះបោរនឹងព្រះរាជាហើយ»។[32]នោះព្រះរាជាមានរាជឱង្ការមកអ្នកបម្រើសាសន៍អេត្យូពីនោះថា៖
«ចុះអាប់សាឡុមសុខសប្បាយឬយ៉ាងណា?» ជនជាតិអេត្យូពីនោះទូលថា៖ «បពិត្រព្រះករុណា! សូមឲ្យពួកខ្មាំងសត្រូវ ដែលបះបោរប្រឆាំងនឹងព្រះករុណា
វិនាសដូចជាបុរសនោះចុះ!»[33]ពេលនោះព្រះបាទដាវីឌក្តុកក្តួលព្រះហឫទ័យយ៉ាងខ្លាំង ទ្រង់បានយាងឡើងទៅលើបន្ទប់នៅខាងលើក្លោងទ្វារក្រុង ហើយទ្រង់ព្រះកន្សែង។
ស្តេចយាងឡើងទៅទាំងរៀបរាប់ថា៖ «អាប់សាឡុមបុត្របិតា! ឱបុត្របិតា! អាប់សាឡុមបុត្របិតាអើយ! គួរតែឲ្យបិតាស្លាប់ជំនួសបុត្រវិញ អាប់សាឡុម បុត្របិតា
ឱបុត្របិតាអើយ!»។

---

2 Samuel 18:1

ព្រះបាទដាវីឌបានរាប់ចំនួនពលទាហានដែលនៅជាមួយទ្រង់ និងតែងតាំង

ដាវីឌមិនបានរាប់បញ្ជូលប្រជាជនទាំងអស់នោះទេ
ផ្ទុយទៅវិញបុរសផ្សេងទៀតបានរាប់បញ្ជូលពួកគេ។ ការបកប្រែផ្សេង
«ដាវីឌបានបញ្ជាឲ្យគេរាប់ចំនួនទាហានដែលនៅជាមួយគាត់
ហើយគាត់បានតែងតាំង» ឬ
«ដាវីឌបានចាត់ទាហានដែលនៅជាមួយគាត់ហើយតែងតាំង»

មេបញ្ជាការកងពលធំ

មេបញ្ជាការកងពលធំគឺជាអ្នកដែលមានសិទ្ធិអំណាចលើទាហានមួយក្រុម។

បីកង... មួយភាគបី

ទីបី ... មួយភាគបី - «មួយភាគបីនៃកងទ័ព ... មួយភាគបីនៃកងទ័ពផ្សេងទៀត» ។
«ទីបី» គឺជាផ្នែកមួយក្នុងចំណោមផ្នែកបីស្មើគ្នា។

លោកអប៊ីសាយ... លោកស្រីសេរ៊ូយ៉ា

បកប្រែឈ្មោះរបស់បុរសទាំងនេះដូចគ្នាពេលអ្នកបានធ្វើនៅក្នុង ២:១៨ ។

លោកអ៊ីតាយ

ការបកប្រែឈ្មោះរបស់បុរសនេះដូចគ្នាពេលអ្នកបានធ្វើនៅក្នុង ១៥:១៩។

ជនជាតិកាថ

នេះសំដៅទៅលើមនុស្សម្នាក់មកពីកាថដែលជាទីក្រុងភីលីស្ទីន។

យើងនឹងចេញទៅច្បាំងជាមួយអ្នករាល់គ្នាដែរ។

នេះមានន័យថាគាត់នឹងចេញទៅជាមួយពួកគេដើម្បីធ្វើសង្គ្រាម។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេង
«ខ្ញុំនឹងទៅជាមួយអ្នកដើម្បីធ្វើសង្គ្រាម» ឬ
«ខ្ញុំផ្ទាល់នឹងទៅជាមួយអ្នកដើម្បីធ្វើសង្គ្រាម»

2 Samuel 18:3

ពួកយើងពាក់កណ្តាល

ពាក្យ «ពាក់កណ្តាល» សំដៅទៅលើផ្នែកមួយនៃពីរផ្នែកស្មើគ្នា។

ព្រះករុណាមានតម្លៃស្មើនឹងពួកយើងមួយម៉ឺននាក់!

នេះមានន័យថាកងទ័ពសត្រូវពិចារណាសម្លាប់ព្រះបាទដាវីឌ
ដែលមានតម្លៃជាងការសម្លាប់ទាហាន មួយម៉ឺននាក់ផ្សេងទៀត។ ចំនួន ១០,០០០
នៅទីនេះគឺជាការនិយាយបំផ្លើស
ដែលត្រូវបានប្រើដើម្បីបញ្ជាក់ពីចំនួនប្រជាជនដ៏ច្រើន។ ការបកប្រែផ្សេង «
ពួកគេនឹងសម្លាប់អ្នកជាងសម្លាប់យើង ១ ម៉ឺននាក់» ឬ
«ការសម្លាប់ព្រះអង្គគឺមានតម្លៃចំពោះពួកគេជាជាងសម្លាប់យើងចំនួនច្រើន» ។

មួយម៉ឺននាក់!

«១០,០០០»

ព្រះករុណាគង់នៅក្នុងទីក្រុងចាំជួយយើងរាល់គ្នាវិញ

ព្រះបាទដាវីឌអាចជួយពួកគេពីទីក្រុងដោយណែនាំពួកគេនិងបញ្ជូនទាហាន
ឲ្យមកជួយពួកគេ។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេង
«ដែលអ្នកស្នាក់នៅទីនេះក្នុងទីក្រុងហើយផ្ញើជំនួយមកយើង»

2 Samuel 18:5

លោកយ៉ូអាប់

ការបកប្រែឈ្មោះរបស់បុរសនេះដូចគ្នានឹងអ្នកបានធ្វើនៅ ២:១៨ ។

លោកអ៊ីតាយ

បកប្រែឈ្មោះរបស់បុរសនេះដូចគ្នានឹងអ្នកបានធ្វើនៅក្នុង ១៥:១៩ ។

បើអ្នករាល់គ្នាស្រឡាញ់យើង សូមកុំធ្វើបាបសម្តេចអាប់សាឡុម ជាបុត្ររបស់យើងឡើយ

ដើម្បីជាប្រយោជន៍ដល់យើងសូមកុំធ្វើបាបយុវជនអាប់សាឡុមឡើយ។ ឃ្លាថា
«ចែកថ្នមៗ» មានន័យថាធ្វើល្អនឹងនរណាម្នាក់ហើយមិនធ្វើបាបគេឡើយ។

បើអ្នករាល់គ្នាស្រឡាញ់យើង

«សុខុមាលភាពរបស់យើង» ឬ «ដៃគូររបស់យើង»

2 Samuel 18:6

បានចេញទៅច្បាំងនឹងកងទ័ពអ៊ីស្រាអែល

នេះមានន័យថា បានចេញក្រៅហើយប្រយុទ្ធប្រឆាំងនឹងពួកគេនៅក្នុងសមរភូមិ។
ការបកប្រែផ្សេង "បានចេញទៅជនបទហើយបានប្រយុទ្ធនឹងអ៊ីស្រាអែល"

ច្បាំងនឹងកងទ័ពអ៊ីស្រាអែល

នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើទាហានរបស់ពួកគេ
មិនមែនជនជាតិអ៊ីស្រាអែលទាំងអស់ទេ។ ការបកប្រែផ្សេង
«ប្រឆាំងនឹងទាហានអ៊ីស្រាអែល»

ទាហានអ៊ីស្រាអែលបានចាញ់ទាហានរបស់ព្រះបាទដាវីឌ

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នៅទីនោះមានទាហានរបស់ព្រះបាទដាវីឌបានវាយឈ្នះកងទ័ពអ៊ីស្រាអែល»

បរាជ័យយ៉ាងធ្ងន់ធ្ងរ

ព្រឹត្តិការណ៍មួយដែលមនុស្សជាច្រើនត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃ។

ទាហានចំនួនពីរម៉ឺននាក់

«ទាហានចំនួន ២០.000 នាក់»

ហើយមនុស្សដែលស្លាប់ក្នុងព្រៃមានចំនួនច្រើនជាងមនុស្សដែលស្លាប់ដោយមុខដាវ។

នៅទីនេះ «ព្រៃ» ត្រូវបានពិពណ៌នាដូចជានៅរស់ហើយអាចធ្វើសកម្មភាពបាន។
«ដាវ» សំដៅទៅលើទាហានរបស់ព្រះបាទដាវីឌ ដែលបានប្រយុទ្ធដោយដាវ។
ការបកប្រែផ្សេងទៀត
«រឿងគ្រោះថ្នាក់នៅក្នុងព្រៃបានសម្លាប់មនុស្សច្រើនជាងទាហានរបស់ព្រះបាទដាវីឌដែលបានសម្លាប់ដោយ

2 Samuel 18:9

សម្តេចអាប់សាឡុមបានជួបជាមួយទាហានរបស់ព្រះបាទដាវីឌ

នេះគឺជាព្រឹត្តិការណ៍មួយដែលបានកើតឡើងក្នុងអំឡុងពេលប្រយុទ្ធ។
នេះអាចថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«កំឡុងពេលប្រយុទ្ធសម្តេចអាប់សាឡុមបានជួបនឹងទាហានរបស់ព្រះបាទដាវីឌ»

ស្រាប់តែព្រះសិរសារបស់ទ្រង់បានជាប់នឹងប្រគាបមែកឈើ។

សម្តេចអាប់សាឡុមមានសក់វែងដែលជាប់នឹងមែកឈើ។ការបកប្រែផ្សេងទៀត
«សក់របស់គាត់ត្រូវបានគេចាប់បាននៅក្នុងមែកឈើ»

នៅព្យួរ

ព្យួរឬយោលរលុង

ជើងផុតពីដី

generated on Wed Sep 10 16:16:32 2025

«នៅក្នុងអាកាស»
មើល!
នៅទីនេះ ពាក្យនេះត្រូវបានប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់មនុស្ស
ចំពោះអ្វីដែលត្រូវបាននិយាយបន្ទាប់។ ការបកប្រែផ្សេងទៀត «ចូរស្តាប់»
ហេតុអ្វីបានជាអ្នកមិនសម្លាប់គាត់នៅនឹងកន្លែងនោះទៅ?
សំណួរដ៏ប៉ិនប្រសប់នេះមានន័យថា គាត់គួរតែសម្លាប់ទ្រង់។
សំណួរនេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ពាក្យថា «ប្រហារ»
មានន័យថាសម្លាប់។ ការបកប្រែផ្សេងទៀត «អ្នកគួរតែវាយគាត់ទៅនឹងដី!» ឬ
«អ្នកគួរតែសម្លាប់គាត់ភ្លាមៗ!»
ដប់ស៊ីគែល
នេះអាចត្រូវបានសរសេរជាឯកតាទំនើប។ ការបកប្រែផ្សេងទៀត «កាក់ប្រាក់ដប់»
ឬ « ប្រាក់ ១១០ ក្រាម»
រង្វាន់
នេះគឺជាខ្សែក្រវ៉ាត់ពិសេសមួយ
ដែលបង្ហាញមនុស្សថានរណាម្នាក់ដែលជាទាហានដ៏អស្ចារ្យ
គួរតែទទួលបានកិត្តិយស។
2 Samuel 18:12
មួយពាន់ស៊ីគែល
«ប្រាក់ ១០០០ រៀល»។ នេះអាចត្រូវបានបញ្ជាក់នៅក្នុងឯកតាទំនើប។
ការបកប្រែផ្សេងទៀត «ប្រាក់ ១០០០ កាក់» ឬ «ប្រាក់ ១១ គីឡូក្រាមនៃប្រាក់»
ក៏ខ្ញុំមិនលើកដៃរបស់ខ្ញុំទាស់នឹងបុត្ររបស់ស្តេចដែរ
ឃ្លា «ដល់ដៃខ្ញុំ» មានន័យថាវាយប្រហារ។ ការបកប្រែផ្សេងទៀត
«នឹងមិនវាយប្រហារកូនប្រុសរបស់ស្តេចឡើយ»
សូមប្រណីដល់
នៅទីនេះ «ការប៉ះ» សំដៅទៅលើ «គ្រោះថ្នាក់» ។ ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់ត្រូវធ្វើបាប» ឬ «កុំធ្វើបាប»
លាក់លៀម
ពាក្យថា «លាក់លៀម» អាចត្រូវបានបង្ហាញដោយឃ្លាកិរិយាស័ព្ទផងដែរ។
នេះក៏សំដៅទៅលើការមិនគោរពតាមបញ្ជារបស់ស្តេចដែរ។
នេះអាចបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត « ធ្វើអ្វីដែលខុស» ឬ «
ដោយមិនស្តាប់បង្គាប់ស្តេច»
មិនមានអ្វីមួយដែលអាចលាក់លៀមនឹងស្តេចបានឡើយ
នៅទីនេះ បុរសនិយាយអំពីរបៀបដែលស្តេចដឹងអំពីអ្វីៗស្ទើរតែទាំងអស់
ដែលកើតឡើងដូចជាអ្វីៗទាំងអស់គឺជាវត្ថុខាងរាងកាយ
ដែលគាត់បានដឹងពីទីតាំង។ ការបកប្រែផ្សេងទៀត «គ្មានអ្វីដែលស្តេចមិនដឹងទេ»
ឬ «ស្តេចដឹងអំពីអ្វីគ្រប់យ៉ាងដែលកើតឡើង»
2 Samuel 18:14
ខ្ញុំនឹងមិនចាំឯងទេ»
លោកយ៉ូអាប់មានន័យថា គាត់មិនគួរបន្តនិយាយជាមួយបុរសនោះឡើយ។
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងមិនខ្ជះខ្ជាយពេលវេលានិយាយជាមួយអ្នក»
បេះដូងស្តេចអាប់សាឡុម
នៅទីនេះបេះដូងរបស់សម្តេចអាប់សាឡុម
សំដៅទៅលើទ្រូងឬផ្នែករាងកាយខាងលើរបស់ទ្រង់។ ការបកប្រែផ្សេងទៀត
«ទ្រូង»
អាវុធ
នេះសំដៅទៅលើគ្រឿងសឹកទាំងពីរ
ដែលគាត់នឹងពាក់ដើម្បីការពារខ្លួនគាត់និងអាវុធរបស់គាត់។ ការបកប្រែផ្សេងទៀត
« គ្រឿងសឹកនិងអាវុធ»
2 Samuel 18:16
លោកយ៉ូអាប់បានហៅពួកទាហានឲ្យត្រឡប់ពីការដេញតាមទ័ពអ៊ីស្រាអែលវិញ
ដោយឲ្យគេផ្លុំត្រែឡើង។
នេះពិពណ៌នានូវអ្វីដែលលោកយ៉ូអាប់បានបញ្ជាដោយផ្លុំត្រែ។ ការបកប្រែផ្សេងទៀត
«បន្ទាប់មកលោកយ៉ូអាប់ផ្លុំត្រែឡើងដើម្បីហៅកងទ័ពត្រឡប់មកវិញ
ហើយកងទ័ពបានវិលត្រឡប់មកពីដេញតាមអ៊ីស្រាអែល»។
ការដេញតាមទ័ពអ៊ីស្រាអែលវិញ
នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើកងទ័ពអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«បានវិលត្រឡប់មកពីការដេញតាមកងទ័ពអ៊ីស្រាអែល»
ពួកទាហានបានដាក់សពសម្តេចអាប់សាឡុមចុះ
«ពួកគេបានយកសពរបស់សម្តេចអាប់សាឡុមហើយបោះចោល»
ហើយបានយកថ្មយ៉ាងច្រើនមកគរពីលើផង
បន្ទាប់ពីដាក់សាកសពរបស់ទ្រង់នៅក្នុងរណ្តៅ
ពួកគេបានគ្របសាកសពនោះដោយគំនរថ្ម។
នេះអាចត្រូវបានបញ្ជាក់កាន់តែច្បាស់។ ការបកប្រែផ្សេងទៀត
«ពួកគេបានគ្របលើរាងកាយរបស់ទ្រង់ដោយផ្នាំងថ្មដ៏ធំមួយ»
ពេលនោះទាហានអ៊ីស្រាអែលបាក់ទ័ព
នៅទីនេះ «ជនជាតិអ៊ីស្រាអែលទាំងអស់» សំដៅទៅលើទាហានអ៊ីស្រាអែល។
ពាក្យថា «បាក់ទ័ព» មានន័យថា» រត់គេច ។ការបកប្រែផ្សេងទៀត
«ខណៈពេលដែលទាហានអ៊ីស្រាអែលទាំងអស់បានរត់គេចខ្លួន»
2 Samuel 18:18
ជ្រលងភ្នំរបស់ស្តេច
នេះជាឈ្មោះនៃទីកន្លែង។
បន្តរង្សត្រកូល
សម្តេចអាប់សាឡុមប្រើឃ្លា «ឈ្មោះយើង»
ដើម្បីយោងទៅលើអង្គទ្រង់និងក្រុមគ្រួសាររបស់ទ្រង់។ការបកប្រែផ្សេងទៀត
«ដាក់ឈ្មោះគ្រួសារយើងដែលមនុស្សនឹងចងចាំយើង»
ហេតុនេះហើយបានជាគេហៅបង្គោលនោះថា៖ «ស្តូបអាប់សាឡុម» រហូតដល់សព្វថ្ងៃនេះ។
នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដូច្នេះប្រជាជនបានហៅវាថាស្តូបសម្តេចអាប់សាឡុមចាប់ពីថ្ងៃនោះមក»
រហូតដល់សព្វថ្ងៃនេះ។
នេះសំដៅទៅលើពេលវេលាបច្ចុប្បន្ននៅពេលដែលសៀវភៅព្រះគម្ពីរនេះត្រូវបានសរសេរ។
2 Samuel 18:19
លោកអហ៊ីម៉ាស់
បកប្រែឈ្មោះរបស់បុរសនេះដូចគ្នានឹងអ្នកបានធ្វើនៅក្នុង ១៥:២៧។
នាំយកដំណឹងល្អនេះ ទៅទូលស្តេច
ត្រង់នេះអហ៊ីម៉ាស់និយាយពីការរត់ទៅហើយប្រាប់ដំណឹងល្អដល់ស្តេច
ហាក់ដូចជាដំណឹងល្អគឺជាវត្ថុដែលគាត់កំពុងកាន់។ ការបកប្រែផ្សេងទៀត
«រត់ទៅប្រាប់ស្តេចនូវដំណឹងល្អ»
ដៃរបស់សត្រូវ
នៅទីនេះ «ដៃ» សំដៅទៅលើការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ការគ្រប់គ្រងរបស់សត្រូវរបស់គាត់»
នាំដំណឹងនៅថ្ងៃនេះ
«អ្នកដែលប្រាប់ដំណឹង»
លោកមិនមែននាំដំណឹងល្អនោះទេ
នេះសំដៅទៅលើការមិនយកព័ត៌មានទៅថ្វាយស្តេច។ ការបកប្រែផ្សេងទៀត
«អ្នកនឹងមិនប្រាប់ដំណឹងដល់ស្តេចទេ»
2 Samuel 18:21
ទូលព្រះបាទដាវីឌនូវហេតុការណ៍ដែលលោកបានឃើញ
លោកយ៉ូអាប់កំពុងតែប្រាប់គាត់អោយទៅទូលស្តេចអំពីដំណឹងនៃសមរភូមិ។
2 Samuel 18:24
ពេលនោះ
ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការសម្រាកនៅក្នុងសាច់រឿងសំខាន់និងការចាប់ផ្តើមនៃផ្នែកថ្មី
ហើយសម្លឹងទៅខាងក្រៅ
នៅទីនេះ អ្នកយាមកំពុងសម្លឹងមើលអ្វីដែលត្រូវបានគេនិយាយ
ដូចជាកំពុងងើបមុខឡើង។ ការបកប្រែផ្សេងទៀត
«ហើយមើលទៅខាងក្រៅទីក្រុង»
នោះគឺគេមកដើម្បីនាំដំណឹងមកឲ្យយើង
នៅទីនេះស្តេចនិយាយពីបុរស
ដែលមានសារដូចជាដំណឹងនេះជាវត្ថុកំពុងអង្គុយនៅក្នុងមាត់របស់គាត់។
ការបកប្រែផ្សេងទៀត «គាត់មានព័ត៌មានដើម្បីប្រាប់យើង»
2 Samuel 18:26
«អ្នកដែលរត់ខាងក្រោយនោះ មើលទៅដូចជាលោកអហ៊ីម៉ាស់ កូនបូជាចារ្យសាដុក»។
អ្នកយាមប្រៀបធៀបរបៀបដែលបុរសនោះរត់ទៅ នឹងលោកអហ៊ីម៉ាស់រត់
ដើម្បីណែនាំថាប្រហែលជាគាត់។ ការបកប្រែផ្សេងទៀត
«ខ្ញុំគិតថាបុរសដែលរត់នៅខាងមុខគឺលោកអហ៊ីម៉ាស់កូនប្រុសបូជាចារ្យសាដុក
ព្រោះគាត់រត់ដូចលោកអហ៊ីម៉ាស់»
2 Samuel 18:28
គាត់ឲ្យមុខចុះ និងក្រាបដល់ដីនៅចំពោះមុខព្រះរាជា
គាត់ធ្វើដូច្នេះដើម្បីគោរពព្រះរាជា។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«គាត់បានក្រាបថ្វាយបង្គំនៅចំពោះព្រះភក្ត្រស្តេចដោយក្រាបថ្វាយបង្គំដល់ដីដើម្បីគោរព»។
សូមព្រះអម្ចាស់ជាព្រះរបស់ព្រះករុណា
«ចូរសរសើរដល់ព្រះអម្ចាស់» ។ នៅទីនេះ «ជូនពរ» មានន័យថាសរសើរ។
មនុស្សដែលបានលើកដៃទាស់នឹងព្រះរាជា ជាម្ចាស់របស់ខ្ញុំម្ចាស់
នៅទីនេះលោកអហ៊ីម៉ាស់និយាយពីបុរសដែលប្រឆាំងនឹងស្តេច
ហាក់ដូចជាកំពុងលើកដៃរបស់ពួកគេនៅចំពោះមុខគាត់។ ការបកប្រែផ្សេងទៀត
«បុរសដែលប្រឆាំងនិងបានប្រយុទ្ធប្រឆាំងនឹងព្រះរាជាជាម្ចាស់របស់ខ្ញុំម្ចាស់»
មានការជ្រួលច្របល់យ៉ាងខ្លាំង
នេះមានន័យថា មនុស្សបានប្រព្រឹត្តដូចជាអ្វីៗមិនត្រឹមត្រូវ។
ចូរទៅឈរនៅមួយចំហៀងទៅ!
«ចេញពីផ្លូវ» ឬ «ឈរដោយឡែក»

2 Samuel 19:1
មនុស្សដែលបះបោរនឹងព្រះរាជាហើយ
នេះមានន័យថាដើម្បីប្រឆាំង។ ការបកប្រែផ្សេងទៀត «ប្រឆាំង»
សូមឲ្យពួកខ្មាំងសត្រូវ ដែលបះបោរប្រឆាំងនឹងព្រះករុណា, ... វិនាសដូចជាបុរសនោះចុះ!
ជនជាតិអេត្យូប្រើការប្រៀបធៀបជាវិធីគួរសមដើម្បីប្រាប់ស្តេចថា
អាប់សាឡុមបានទទួលមរណភាពហើយ។ នេះអាចត្រូវបានបញ្ជាក់ដោយផ្ទាល់។
ការបកប្រែផ្សេងទៀត «ខ្ញុំចង់អោយសត្រូវទាំងអស់របស់អ្នក ...
ស្លាប់តាមរបៀបដែលយុវជនបានស្លាប់» (សូមមើល and
ក្តុកក្តួល
«ខូចចិត្ត»

---

19 [1]មានគេប្រាប់លោកយ៉ូអាប់ថា៖ «មើល៍! ព្រះរាជាព្រះកន្សែង ហើយស្រណោះស្រណោកសម្តេចអាប់សូឡុម»។[2]ដូច្នេះ
នោះជ័យជម្នះនៅថ្ងៃនេះបានប្រែទៅជាទុក្ខព្រួយសម្រាប់ស្តេច ដ្បិត កងទ័ពទាំងមូលបានឮថា «ព្រះរាជាសោកស្រណោះសម្តេចអាប់សាឡុមបុត្ររបស់ព្រះអង្គ»។
[3]នៅថ្ងៃនោះ ពួកទាហានវិលត្រឡប់ចូលក្រុងវិញយ៉ាងស្ងៀមស្ងាត់ គឺដូចជាកងទ័ពដែលបាត់ទ័ពរត់ពីសមរភូមិដោយក្តីអាម៉ាស់។[4]ចំណែកឯ ព្រះរាជាគ្របព្រះភក្ត្រជិត
ហើយបន្លឺព្រះសូរសៀងឮៗថា៖ «អាប់សាឡុមបុត្របិតា! អាប់សាឡុម បុត្រសម្លាញ់បិតា! បុត្របិតា!»។
[5]ពេលនោះ លោកយ៉ូអាប់បានចូលទៅព្រះដំណាក់របស់ស្តេច ហើយទូលស្តេចថា៖ «ពួកទាហានបានសង្គ្រោះជីវិតព្រះករុណា
ជីវិតបុត្រាបុត្រីរបស់ព្រះករុណាទាំងពួកស្រីស្នំ និងរាជបម្រើរបស់ព្រះករុណាផង ប៉ុន្តែ ព្រះករុណាបានធ្វើឲ្យពួកគេមានក្តីអាម៉ាសនៅថ្ងៃនេះ[6]ដ្បិត
ព្រះករុណាស្រឡាញ់អ្នកដែលស្អប់ព្រះករុណា ហើយទ្រង់បែរជាស្អប់អ្នកដែលស្រឡាញ់ទ្រង់ទៅវិញ។ ថ្ងៃនេះ ព្រះករុណាបានបង្ហាញឲ្យយើងឃើញថា មេទ័ពនិង
កងទ័ពទាំងអស់មិនមានតម្លៃអ្វីសោះសម្រាប់ទ្រង់។ ទូលបង្គំក៏ជឿថា ប្រសិនបើ ថ្ងៃនេះសម្តេចអាប់សាឡុមនៅរស់ ហើយទូលបង្គំរាល់គ្នាស្លាប់វិញនោះ
ព្រះករុណាច្បាស់ជាយល់ថានោះជារឿងធម្មតា។
[7]ឥឡូវនេះ សូមព្រះករុណាក្រោកឡើង ហើយចេញទៅមានរាជឱង្ការលើកទឹកចិត្តពួកពលទាហានផង ទូលបង្គំសូមស្បថក្នុងនាមព្រះអម្ចាស់ថា ប្រសិនបើ
ទ្រង់មិនធ្វើដូច្នេះទេ នៅយប់នេះនឹងមិនមានអ្នកណាម្នាក់នៅបម្រើព្រះករុណាឡើយ។ ព្រះករុណានឹងវេទនាលើសទុក្ខវេទនានានា
ដែលព្រះករុណាធ្លាប់ជួបតាំងពីក្មេងរហូតដល់ឥឡូវនេះ។[8]ដូច្នេះ សូមព្រះករុណាក្រោកឡើងចេញទៅមាត់ទ្វារក្រុង ហើយមនុស្សទាំងអស់នឹងប្រកាសថា៖ «មើល៍!
ព្រះរាជាគង់នៅមាត់ទ្វារវាំង» ហើយពលទាហានទាំងអស់នឹងមកចំពោះព្រះរាជា។ ដូច្នេះ ទាហានអ៊ីស្រាអែលបានបាក់ទ័ពរត់ទៅជំរំរបស់គេរៀងៗខ្លួន។
[9]មនុស្សទាំងអស់នៃកុលសម្ព័ន្ធអ៊ីស្រាអែលនីមួយៗបានគិតគ្នាថា៖ «ព្រះបាទដាវីឌធ្លាប់បានសង្គ្រោះយើងរាល់គ្នាចេញពីដៃខ្មាំងសត្រូវរបស់យើង
ហើយទ្រង់បានសង្គ្រោះយើងពីកណ្តាប់ដៃនៃពួកជនជាតិភីលីស្ទីន ប៉ុន្តែឥឡូវនេះ ទ្រង់បែរជាភៀសខ្លួនចេញពីស្រុកដោយសារតែសម្តេចអាប់សាឡុម។
[10]ព្រះបាទអាប់សាឡុម ដែលយើងបានតែងតាំងជាស្តេចគ្រងរាជ្យលើយើង ទ្រង់បានសុគតនៅក្នុងសមរភូមិហើយ។ ដូច្នេះ
ហេតុអ្វីបានជាយើងមិនយាងព្រះរាជាត្រឡប់មកវិញ?»។
[11]ព្រះបាទដាវីឌបានចាត់គេឲ្យទៅជម្រាបលោកបូជាចារ្យសាដុក និងបូជាចារ្យអបៀថើរថា៖ «ចូរសាកសួរពួកចាស់ទុំរបស់ជនជាតិយូដាថា
ហេតុអ្វីបានជាអស់លោកនៅដំអក់ មិនយាងស្តេចចូលក្នុងព្រះដំណាក់វិញដូច្នេះ? ព្រះរាជាបានជ្រាបពីគោលបំណងរបស់ជនជាតិអ៊ីស្រាអែលទាំងមូល
ក្នុងការយាងស្តេចត្រឡប់ទៅព្រះដំណាក់វិញនោះ។[12]អស់លោកជាបងប្អូន និងជាសាច់ញាតិរបស់យើង។ ហេតុអ្វីបានជានៅរង់ចាំធ្វើជានាក់ចុងក្រោយគេ
ក្នុងការយាងស្តេចចូលព្រះដំណាក់ដូច្នេះ?»
[13]បន្ទាប់មក ពួកគេប្រាប់លោកអាម៉ាសាថា តើលោកមិនមែនជាសាច់ញាតិរបស់យើងទេ? ប្រសិនបើ
យើងមិនតែងតាំងលោកជាមេទ័ពរបស់យើងជំនួសលោកយ៉ូអាប់ទេនោះ! សូមព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ ដាក់ទោសយើងទៅចុះ»។[14]ដូច្នេះ ព្រះបាទដាវីឌ
បានធ្វើឲ្យប្រជាជនអ៊ីស្រាអែលទាំងមូលទន់ចិត្តមកឯទ្រង់ដូចមនុស្សតែម្នាក់។ ពួកគេបានចាត់មនុស្សមកគាល់ស្តេចថា៖ «បពិតព្រះករុណា!
សូមយាងត្រឡប់មកព្រះដំណាក់វិញ ជាមួយនឹងរាជ្យបម្រើរបស់ទ្រង់»។[15]ពេលដែលព្រះបាទដាវីឌបានមកដល់ទន្លេយ័រដាន់ ពួកជនជាតិយូដាបានមកដល់គីលកាល់
ដើម្បីទទួលស្តេច និងជួយចម្លងស្តេចឆ្លងទន្លេយ័រដាន់។
[16]លោកស៊ីម៉ាយ កូនប្រុសរបស់លោកកេរ៉ា ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន ដែលមកពីភូមិបាហ៊ូរីម ក៏បានប្រញាប់ប្រញាល់ចុះមកជាមួយប្រជាជនយូដា
ដើម្បីគាល់ព្រះបាទដាវីឌដែរ។[17]មានមនុស្សមួយពាន់នាក់ពីកុលសម្ព័ន្ធបេនយ៉ាមីនដែលមកជាមួយលោកស៊ីម៉ាយ និងលោកស៊ីបា ជាអ្នកបម្រើរបស់ព្រះបាទសូល
រួមទាំងកូនប្រុសទាំងដប់ប្រាំនាក់ និងអ្នកបម្រើទាំងម្ភៃនាក់របស់លោក។ ពួកគេបានឆ្លងទន្លេយ័រដាន់ មកគាល់ស្តេច។[18]ពួកគេជួយចម្លងព្រះរាជវង្សឆ្លងទន្លេ
ហើយនឹងធ្វើអ្វីដែលពួកគេគួរនឹងធ្វើ។ ពេលដែលស្តេចឆ្លងដល់ត្រើយម្ខាងហើយ លោកស៊ីម៉ាយ កូនប្រុសលោកកេរ៉ា ឲ្យក្រាបថ្វាយបង្គំស្តេច។
[19]លោកស៊ីម៉ាយទូលព្រះរាជាថា៖ «បពិតព្រះករុណា ជាម្ចាស់របស់ទូលបង្គំ សូមកុំប្រកាន់ទោសទូលបង្គំ ឬសូមបំភ្លេចកំហុសដែលទូលបង្គំបានប្រព្រឹត្ត
នៅថ្ងៃដែលព្រះករុណាបានយាងចេញពីក្រុងយេរូសាឡឹមផង។ សូមកុំចងកគំនុំនឹងទូលបង្គំអី។[20]ទូលបង្គំបានដឹងថាទូលបង្គំពិតជាបានធ្វើអំពើបាបមែន។
ដូច្នេះហើយបានជាថ្ងៃនេះក្នុងអំបូររបស់លោកយូសែប ទូលបង្គំបានចុះមកមុន ដើម្បីថ្វាយបង្គំព្រះករុណាជាម្ចាស់នៃទូលបង្គំ»។
[21]ប៉ុន្តែ លោកអប៊ីសាយ កូនប្រុសលោកស្រីសេរូយ៉ាទូលស្តេចថា៖ «តើស៊ីម៉ាយគួរតែស្លាប់ឬទេ
ព្រោះគេបានដាក់បណ្តាសាអ្នកដែលព្រះអម្ចាស់បានចាក់ប្រេងអភិសេក?»[22]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «តើយើងគួរធ្វើយ៉ាងដូចម្តេចជាមួយអ្នក
កូនអ្នកស្រីសេរូយ៉ាអើយ ដែលអ្នកប្រឆាំងនឹងយើងដូច្នេះ? តើគួរមានជនជាតិអ៊ីស្រាអែលណាម្នាក់ត្រូវស្លាប់ក្នុងថ្ងៃនេះឬ? តើខ្ញុំមិនដឹងឬថា
ខ្ញុំពិតជាស្តេចលើប្រជាជនអ៊ីស្រាអែលវិញហើយ?»[23]ស្តេចមានរាជឱង្ការទៅលោកសាម៉ាយថា៖ «អ្នកនឹងមិនស្លាប់ទេ!» ស្តេចបានស្បថនឹងលោកដូច្នេះ។
[24]ពេលនៅលោកមេភីបូសែត ចៅព្រះបាទសូលបានចុះមកគាល់ព្រះបាទដាវីឌដែរ។ ចាប់តាំងពីថ្ងៃដែលស្តេចចាកចេញពីក្រុងទៅ ហើយត្រឡប់មកវិញដោយសុខសាន្ត
លោកមិនបានលាងជើងរបស់លោក ក៏មិនបានកោរពុកមាត់ ឬក៏បោកសម្លៀកបំពាក់របស់លោកដែរ។
[25]នៅពេលដែលលោកចេញពីក្រុងយេរូសាឡឹមមកជួបនឹងព្រះបាទដាវីឌ ទ្រង់មានរាជឱង្ការទៅគាត់ថា៖ «ហេតុអ្វីបានជាអ្នកមិនចាកចេញទៅជាមួយយើង?»
[26]គាត់ទូលស្តេចថា៖ «បពិតព្រះករុណាជាអម្ចាស់! អ្នកបម្រើរបស់ទូលបង្គំបានបញ្ឆោតទូលបង្គំ ដោយទូលបង្គំនិយាយថា៖ «ខ្ញុំនឹងចងកែបលា
ដូច្នេះខ្ញុំនឹងជិះវាទៅជាមួយស្តេច ព្រោះទូលបង្គំជាមនុស្សខ្វិន។[27]ស៊ីបា អ្នកបម្រើរបស់ទូលបង្គំបានមួលបង្កាច់ទូលបង្គំ ថ្វាយព្រះករុណាជាម្ចាស់។
ព្រះករុណាជាអម្ចាស់ប្រៀបបាននឹងទេវតារបស់ព្រះអម្ចាស់។ ដូច្នេះសូមព្រះករុណាសម្រេចតាមការដែលទ្រង់បានទតឃើញទៅចុះ។
[28]ទោះបីព្រះករុណាយល់ឃើញថាញាតិសន្តានរបស់ព្រះបាទសូល ជីតារបស់ទូលបង្គំដូចជាមនុស្សស្លាប់ទៅហើយនោះ
ក៏ព្រះករុណាបានប្រោសប្រទានអោយទូលបង្គំចូលរួម ក្នុងចំណោមអ្នកដែលបរិភោគជាមួយព្រះករុណា តើទូលបង្គំមានសិទ្ធិអ្វី
នឹងទូលអង្វរសូមអ្វីពីព្រះករុណាទៀតនោះ»។

generated on Wed Sep 10 16:16:32 2025

[29]ព្រះរាជាមានរាជឱង្ការថា៖ «មិនចាំបាច់បរិយាយអ្វីផ្សេងទៀតទេ! យើងបានសម្រេចអោយអ្នកនិងស៊ីបាបែងចែកដីស្រែចំការរបស់ស្តេចសូល»។
[30]លោកមេភីបូសែតទូលស្តេចថា៖ «បពិតព្រះករុណា! សូមអោយគាត់យកទាំងអស់ទៅចុះ! ព្រះករុណាជាអម្ចាស់វិលត្រឡប់មកវិញ ដោយសុខសាន្តដូច្នេះ
ទូលបង្គំស្កប់ចិត្តហើយ!»
[31]លោកបាស៊ីឡៃ អ្នកស្រុកកាឡាតបានចុះពីរ៉ូកេលីម ឆ្លងទន្លេយ័រដាន់មកគាល់ស្តេច ហើយគាត់បានជួយស្តេចឆ្លងទន្លេយ័រដាន់។[32]កាលនោះលោកបាស៊ីឡៃ
មានវ័យចាស់ហើយ គឺលោកមានអាយុប៉ែតសិបឆ្នាំហើយ។ លោកបានផ្គត់ផ្គង់អ្វីៗទាំងអស់ដែលព្រះរាជាត្រូវការ កាលដែលស្តេចគង់នៅម៉ាហានាម
ដ្បិតលោកជាអ្នកមានស្តុកស្តម្ភ។[33]ព្រះបាទដាវីឌមានព្រះរាជឱង្ការទៅកាន់គាត់ថា៖ «សូមលោកមកក្រុងយេរូសាឡឹមជាមួយយើង ហើយស្នាក់នៅចុះ
យើងនឹងផ្គត់ផ្គង់លោកគ្រប់យ៉ាង»។
[34]លោកបាស៊ីឡៃទូលស្តេចវិញថា៖ «ទូលបង្គំមានអាយុប៉ុណ្ណោះហើយ តើអាចរស់បានប៉ុន្មានថ្ងៃ ដែលគួរនឹងអោយទូលបង្គំឡើងទៅក្រុងយេរូសាឡឹមជាមួយនឹងទ្រង់នោះ?
[35]ទូលបង្គំមានអាយុប៉ែតសិបឆ្នាំហើយ។ តើទូលបង្គំអាចដឹងអ្វីស្អាត អ្វីអាក្រក់ឬ? តើទូលបង្គំអាចទទួលរស់ជាតិពីអាហារដែលទទួលទាន ឬពីអ្វីដែលផឹកនោះឬ?
តើទូលបង្គំអាចស្តាប់ឮសូរសម្លេងដ៏ពិរោះរបស់ពួកអ្នកចម្រៀងប្រុសស្រីនោះឬ? តើហេតុអ្វីបានជាទូលបង្គំត្រូវរំខានព្រះរាជាជាអម្ចាស់ដូច្នេះ?
[36]ទូលបង្គំមកគ្រាន់តែចង់ជូនដំណើរព្រះរាជាតែប៉ុណ្ណោះ។ ហេតុអ្វីបានជាព្រះរាជាតបស្នងនូវរង្វាន់ដូច្នេះមកទូលបង្គំ?
[37]សូមព្រះករុណាអនុញ្ញាតអោយទូលបង្គំត្រឡប់ទៅផ្ទះវិញផងចុះ ដូច្នេះទូលបង្គំអាចស្លាប់នៅក្នុងក្រុងរបស់ទូលបង្គំ ក្នុងផ្នូរឪពុកម្តាយរបស់ទូលបង្គំ។
ប៉ុន្តែព្រះករុណាអើយ គីមហាំ នៅទីនេះ សូមព្រះករុណាអនុញ្ញាតអោយគេឆ្លងទៅជាមួយព្រះអង្គ ហើយប្រព្រឹត្តចំពោះគេតាមតែការសព្វព្រះទ័យរបស់ទ្រង់ចុះ»។
[38]ព្រះបាទដាវីឌតបទៅលោកស៊ីបាឡៃថា៖ «លោកគីមហាំនឹងទៅជាមួយយើង ហើយយើងនឹងប្រព្រឹត្តចំពោះគេនូវការល្អដូចជាចំពោះអ្នកដែរ និងអ្វីដែលអ្នកសូមពីយើង
គឺយើងនឹងធ្វើសម្រាប់អ្នក»។[39]បន្ទាប់ពី មនុស្សទាំងអស់បានឆ្លងទន្លេយ័រដាន់ហើយ ស្តេចក៏ឆ្លងទៅដែរ ព្រះបាទដាវីឌបានថើបលាលោកស៊ីបាឡៃ ព្រមទាំងជូនពរលោក។
រួចមកលោកក៏ប្រឡប់ទៅផ្ទះរបស់លោកវិញ។
[40]ព្រះបាទដាវីឌបានឆ្លងមកដល់គីលកាល់ ដោយមានលោកគីមហាំឆ្លងមកជាមួយផង។ មានកងទ័ពយូដាទាំងអស់
និងកងទ័ពអ៊ីស្រាអែលចំនួនពាក់កណ្តាលបានដង្ហែស្តេចមក។[41]ភ្លាមនោះពួកជនជាតិអ៊ីស្រាអែលបានចូលមកគាល់ព្រះបាទដាវីឌ ហើយទូលសួរទ្រង់ថា៖
«ហេតុអ្វីបានជាបងប្អូនរបស់ទូលបង្គំ គឺពួកជនជាតិយូដា លួចយកព្រះករុណា ហើយនាំព្រះករុណានិងញាតិវង្ស ព្រមទាំងមនុស្សទាំងអស់របស់ព្រះករុណា
ឆ្លងទន្លេយ័រដាន់ដូច្នេះ?»
[42]ប្រជាជនយូដាបានឆ្លើយទៅពួកគេថា៖ «គឺដោយសារតែព្រះរាជា មានទំនាក់ទំនងជាមួយយើងជិតជាង។ ហេតុអ្វីបានជាអ្នករាល់គ្នាខឹងនឹងរឿងនេះ?
តើយើងបានហូបអ្វីដែលព្រះរាជាបានបង់ថ្លៃសម្រាប់យើងឬ? តើទ្រង់បានប្រទានរង្វាន់អ្វីដល់យើងឬ?»[43]នោះប្រជាជនអ៊ីស្រាអែលតបទៅពួកយូដាវិញថា៖
«យើងមានកុលសម្ព័ន្ធចំនួនដប់ដែលមានទំនាក់ទំនងជាមួយព្រះរាជា ដូច្នេះយើងមានសិទ្ធិច្រើនជាងចំពោះព្រះបាទដាវីឌ ជាជាងពួកអ្នក។
ហេតុអ្វីបានជាអ្នករាល់គ្នាស្អប់យើង? តើគំនិតដំបូងក្នុងការយាងព្រះរាជាត្រឡប់មកវិញ មិនមែនជាគំនិតរបស់យើងទេឬ?» ប៉ុន្តែ ពាក្យសំដីរបស់ជនជាតិយូដា
មានភាពម៉ឺងម៉ាត់ជាងជនជាតិអ៊ីស្រាអែល។

---

2 Samuel 19:1

មានគេប្រាប់លោកយ៉ូអាប់ថា

នេះអាចថ្លែងជាទម្រង់កិរិយាព្ឫសកម្ម។ ការបកប្រែផ្សេងទៀត

«មាននរណាម្នាក់ប្រាប់លោកយ៉ូអាប់»

មើល៍! ព្រះរាជាព្រះកន្សែង

ពាក្យនេះត្រូវបានប្រើនៅទីនេះ

ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់នរណាម្នាក់ចំពោះអ្វី

ដែលត្រូវនិយាយបន្ទាប់។ ការបកប្រែផ្សេងទៀត «ស្តាប់ស្តេចកំពុងព្រះកន្សែង»

ដូច្នេះ នោះជ័យជម្នះនៅថ្ងៃនេះបានប្រែទៅជាទុក្ខព្រួយកងទ័ពទាំងមូល

នេះមានន័យថា កងទ័ពទាំងមូលកាន់ទុក្ខជំនួសឲ្យការអបអរសាទរ។

ការបកប្រែផ្សេងទៀត

«ដូច្នេះជំនួសឲ្យការអបអរសាទរជ័យជម្នះនៅថ្ងៃនោះកងទ័ពទាំងមូលបានកាន់ទុក្ខ»

2 Samuel 19:3

គឺដូចជាកងទ័ពដែលបាក់ទ័ពរត់ពីសមរភូមិដោយក្តីអាម៉ាស់។

អ្នកនិពន្ធប្រៀបធៀបរបៀប

ដែលទាហានត្រូវជ្រៀតចូលក្នុងទីក្រុងទៅនឹងរបៀបដែលទាហានបានលួចទៅឆ្ងាយនៅ[illegible]

នេះបញ្ជាក់ ថាពួកគេត្រូវបានគេធ្វើឲ្យមានអារម្មណ៍អាម៉ាស។ ការបកប្រែផ្សេងទៀត

«តាមរបៀបដែលមនុស្សបានរត់ចេញពីសមរភូមិ

នឹងលួចរត់ព្រោះពួកគេមានភាពអាម៉ាស»

លួចរត់

ផ្លាស់ទីដោយមិនត្រូវបានគេមើលឃើញដោយអ្នកផ្សេង

ចំណែកឯ ព្រះរាជាគ្របព្រះភក្ត្រជិត

នេះគឺជារបៀបមួយដើម្បីបង្ហាញ ពីភាពទុក្ខព្រួយនិងការកាន់ទុក្ខ។

ការបកប្រែផ្សេងទៀត

«ស្តេចបានបង្ហាញភាពទុក្ខព្រួយរបស់ទ្រង់តាមរយៈការគ្របព្រះភក្ត្ររបស់ទ្រង់»

2 Samuel 19:5

ព្រះករុណាបានធ្វើឲ្យពួកគេមានក្តីអាម៉ាសនៅថ្ងៃនេះ

នៅទីនេះទាហានត្រូវបានសំដៅតាមរយៈមុខមាត់របស់ពួកគេ

ដើម្បីបញ្ជាក់ពីរបៀបដែលពួកគេអាចលាក់មុខដោយសារតែភាពអាម៉ាសរបស់ពួកគេ

ការបកប្រែផ្សេងទៀត «

ព្រះអង្គបានធ្វើឲ្យទាហានរបស់ទ្រង់ទាំងអស់លាក់មុខរបស់ពួកគេដោយភាពអាម៉ាស[illegible]

ឬ «ព្រះអង្គបានបណ្តាលឲ្យទាហានរបស់ព្រះទ្រង់ទាំងអស់ទៅជាអាម៉ាសថ្ងៃនេះ »

មិនមានតម្លៃអ្វីសោះសម្រាប់ទ្រង់

ឃ្លានេះគឺជាការនិយាយបំផ្លើសមួយប៉ុន្តែ

វាបង្ហាញពីតម្លៃទាបបំផុតដែលព្រះបាទដាវីឌបានបង្ហាញសម្រាប់កងទ័ព។

ការបកប្រែផ្សេងទៀត «មានតម្លៃតិចតួចណាស់សម្រាប់ព្រះអង្គ»

ប្រសិនបើ ថ្ងៃនេះសម្តេចអាប់សាឡុមនៅរស់ ហើយទូលបង្គំរាល់គ្នាស្លាប់វិញនោះ

ព្រះករុណាច្បាស់ជាយល់ថានោះជារឿងធម្មតា។

អ្នកនិយាយកំពុងផ្តល់នូវកាល:ទេស:ប៉ាន់ស្មាន។

2 Samuel 19:7

ទូលបង្គំសូមស្បថក្នុងនាមព្រះអម្ចាស់ថា

លោកយ៉ូអាប់កំពុងតែស្បថយ៉ាងខ្លាំង។ ការបកប្រែផ្សេងទៀត

«ខ្ញុំស្បថដូចព្រះអម្ចាស់មានព្រះជន្មរស់»

ប្រសិនបើ ទ្រង់មិនធ្វើដូច្នេះទេ នៅយប់នេះនឹងមិនមានអ្នកណាម្នាក់នៅបម្រើព្រះករុណាឡើយ

នេះមានន័យថា មានតែព្រះបាទដាវីឌទេដែលបានយាងទៅ

ទាហានរបស់ព្រះអង្គនឹងនៅជាមួយព្រះអង្គ។ ការបកប្រែផ្សេងទៀត

"ប្រសិនបើអ្នកទៅ

[illegible] អ្នកនឹងនៅជាមួយអ្នក"

នៅយប់នេះនឹងមិនមានអ្នកណាម្នាក់នៅបម្រើព្រះករុណាឡើយ។

នេះមានន័យថា

មានតែព្រះបាទដាវីឌប៉ុណ្ណោះដែលបានយាងទៅនឹងទាហានរបស់ទ្រង់

នឹងនៅបម្រើព្រះករុណា។ ការបកប្រែផ្សេងទៀត

«ប្រសិនបើព្រះអង្គយាងទៅទាហាននឹងនៅបម្រើព្រះករុណា»

ហើយមនុស្សទាំងអស់នឹងប្រកាសថា

នេះគឺជាការនិយាយបំភ្លើសវាមានន័យថា ភាគច្រើននៃបុរស។

នេះអាចថ្លែងជាទម្រង់កិរិយាព្ឫសកម្ម។ការបកប្រែផ្សេងទៀត

«បុរសជាច្រើនដែលនៅទីនោះបានឮអ្នកដទៃនិយាយ»

មើល៍! ព្រះរាជាគង់នៅមាត់ទ្វារវាំង

ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់នរណាម្នាក់

ចំពោះអ្វីដែលត្រូវនិយាយបន្ទាប់។ ការបកប្រែផ្សេងទៀត «ស្តាប់ស្តេចកំពុងអង្គុយ»

ហើយមនុស្សទាំងអស់

នៅទីនេះ « ប្រជាជន» សំដៅទៅលើមនុស្សដែលបានដើរតាមព្រះបាទដាវីឌ។

[illegible] ការនិយាយបំភ្លើស

វាមានន័យថាមានមនុស្សមួយចំនួនធំបានមកប្រមូលផ្តុំគ្នានៅជុំវិញទ្រង់។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «ប្រជាជនជាច្រើន»
ដូច្នេះ ទាហានអ៊ីស្រាអែលបានបាក់ទ័ពរត់ទៅជំរំរបស់គេរៀងៗខ្លួន។
នៅទីនេះ «អ៊ីស្រាអែល»
សំដៅទៅលើទាហានអ៊ីស្រាអែលដែលបានតាមសម្តេចអាប់សាឡុម។
ការបកប្រែផ្សេងទៀត
«ហើយទាហានអ៊ីស្រាអែលទាំងអស់បានភៀសខ្លួនទៅផ្ទះរបស់ខ្លួន» ឬ
«ហើយទាហានអ៊ីស្រាអែលទាំងអស់បានភៀសខ្លួនទៅផ្ទះរបស់ពួកគេ»
2 Samuel 19:9
ចេញពីដៃខ្មាំងសត្រូវរបស់យើង
នៅទីនេះ «ដៃ» មានន័យថាការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ពីក្រោមការគ្រប់គ្រងនៃពួកភីលីស្ទីន» ឬ «ពីការគ្រប់គ្រងរបស់ពួកភីលីស្ទីន»
ពីកណ្តាប់ដៃនៃពួកជនជាតិភីលីស្ទីន
នៅទីនេះ «ដៃ» មានន័យថាការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ចេញពីក្រោមការគ្រប់គ្រងនៃពួកភីលីស្ទីន» ឬ
«ពីការគ្រប់គ្រងរបស់ពួកភីលីស្ទីន»
ចេញពីស្រុកដោយសារតែសម្តេចអាប់សាឡុម។
នេះមានន័យថា គាត់បានចាកចេញពីប្រទេសរត់ភៀសខ្លួនពីសម្តេចអាប់សាឡុម។
នេះអាចថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត
«ចេញពីប្រទេសដែលផ្តាច់ខ្លួនចេញពីសម្តេចអាប់សាឡុម»
ដូច្នេះ ហេតុអ្វីបានជាយើងមិនយាងព្រះរាជាត្រឡប់មកវិញ?
នេះមានន័យថា ពួកគេគួរតែពិចារណានាំព្រះបាទដាវីឌត្រឡប់មកវិញ
នៅពេលដែលសម្តេចអាប់សាឡុមបានសុគត។
សំណួរអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«យើងគួរតែនិយាយអំពីការនាំស្តេចត្រឡប់មកវិញ» ។
ព្រះរាជា
នេះសំដៅទៅលើព្រះបាទដាវីឌ។
2 Samuel 19:11
ចាត់គេឲ្យទៅជម្រាបលោកបូជាចារ្យសាដុក និងបូជាចារ្យអបៀថើរថា
នេះមានន័យថាព្រះបាទដាវីឌបានបញ្ជូនអ្នកនាំសារម្នាក់ទៅលោកបូជាចារ្យសាដុក
និងលោកបូជាចារ្យអបៀថើរ។ ការបកប្រែផ្សេងទៀត
«បានបញ្ជូនអ្នកនាំសារទៅលោកបូជាចារ្យសាដុកនិងទៅបូជាចារ្យអបៀថើរ»
ហេតុអ្វីបានជាអស់លោកនៅដំអក់ មិនយាងស្តេច ... ចូលក្នុងព្រះដំណាក់វិញដូច្នេះ?
សំណួរដ៏ប៉ិនប្រសប់នេះត្រូវបានគេស្នើសុំឲ្យសួរដើម្បីបន្ទោសពួកអ្នកចាស់ទុំនៅស្រុកយូដា
នេះអាចសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកគួរតែជាមនុស្សទីមួយ ដែលបានគាប់ព្រះហឫទ័យស្តេច
ហើយនាំគាត់ត្រលប់មកវិមានវិញមិនមែនប្រជាជននៃអ៊ីស្រាអែលទេ»។
ក្នុងការយាងស្តេចត្រឡប់ទៅព្រះដំណាក់វិញនោះ។
នៅទីនេះការស្តារសិទ្ធអំណាចរបស់ស្តេចដើម្បីគ្រប់គ្រងគឺ ត្រូវបានគេនិយាយថា
ជាការនាំគាត់ត្រឡប់ទៅ ព្រះបរមរាជវាំងវិញ។ ការបកប្រែផ្សេងទៀត
«ប្រគល់សិទ្ធិអំណាចព្រះមហាក្សត្រជាស្តេច»
អស់លោកជាបងប្អូន និងជាសាច់ញាតិរបស់យើង។
នៅទីនេះព្រះរាជាពិពណ៌នាអំពីរបៀប
ដែលពួកគេមានទំនាក់ទំនងគ្នាដោយនិយាយថា ពួកគេមានសាច់ញាតិដូចគ្នា។
ពាក្យដែលបង្កប់ន័យ "អ្នកគឺជា" អាចត្រូវបានបន្ថែមទៅឃ្លាទីពីរ។
ការបកប្រែផ្សេងទៀត «អ្នកគឺជាបងប្អូនរបស់ខ្ញុំ សាច់ញាតិរបស់ខ្ញុំ» ឬ
«អ្នកគឺជាបងប្អូនរបស់ខ្ញុំអ្នកគឺជាសាច់និងសាច់ញាតិរបស់ខ្ញុំ»
ហេតុអ្វីបានជានៅរង់ចាំធ្វើជានាក់ចុងក្រោយគេ ក្នុងការយាងស្តេចចូលព្រះដំណាក់ដូច្នេះ?
នេះគឺជាដ៏ប៉ិនប្រសប់ទី២
នៅទីនេះហើយវាក៏ជាការស្តីបន្ទោសដល់ពួកចាស់ទុំនៃប្រទេសយូដាផងដែរ។
នេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកគួរតែជាអ្នកទីមួយមិនមែនជាអ្នកចុងក្រោយទេដែលនាំស្តេចត្រឡប់មកវិញ»។
2 Samuel 19:13
លោកអាម៉ាសា
ការបកប្រែឈ្មោះបុរសម្នាក់នេះដូចគ្នា នឹងអ្នកបានធ្វើនៅ ១៧:២៤ ។
តើលោកមិនមែនជាសាច់ញាតិរបស់យើងទេ
ព្រះបាទដាវីឌប្រើសំណួរដ៏ប៉ិនប្រសព្វនេះ
ដើម្បីបញ្ជាក់ថាពួកគេមានទំនាក់ទំនងគ្នា។
នេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែផ្សេងទៀត
«អ្នកជាសាច់ញាតិរបស់ខ្ញុំ«។
ជាសាច់ញាតិរបស់យើង
នៅទីនេះព្រះបាទដាវីឌមានបន្ទូលអំពីពួកគេ ដោយមានបន្ទូលថា
ពួកគេមានសាច់ញាតិដូចគ្នា។ សូមមើលពីរបៀបបកប្រែឃ្លាស្រដៀងគ្នានៅ
១៩:១១ ។ ការបកប្រែផ្សេងទៀត «សាច់ញាតិរបស់ខ្ញុំ»
សូមព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ ដាក់ទោសយើងទៅចុះ
នេះគឺជាពាក្យមួយដែលមានន័យថា ចំពោះព្រះជាម្ចាស់ដើម្បីសម្លាប់គាត់។
ការបកប្រែផ្សេងទៀត «សូមព្រះជាម្ចាស់សម្លាប់ខ្ញុំ»
ព្រះបាទដាវីឌ បានធ្វើឲ្យប្រជាជនអ៊ីស្រាអែលទាំងមូលទន់ចិត្ត
នៅទីនេះភាពស្មោះត្រង់របស់មនុស្សគឺសំដៅទៅលើ « ចិត្ត» របស់ពួកគេ។
ការបកប្រែផ្សេងទៀត «គាត់បានឈ្នះភាពស្មោះត្រង់»
ដូចមនុស្សតែម្នាក់
នេះគឺនិយាយពីមនុស្សដែលមានសាមគ្គីភាព ក្នុងភក្តីភាពរបស់ពួកគេចំពោះស្តេច
ដូចជាពួកគេជាមនុស្សតែមួយដែលមានគំនិតដូចគ្នា។ ការបកប្រែផ្សេងទៀត
«ហើយពួកគេបានរួបរួមជាមួយគ្នា» ឬ
«ពួកគេបានរួបរួមគ្នាដោយភាពស្មោះត្រង់ចំពោះស្តេច»
ពួកគេបានចាត់មនុស្សមកគាល់ស្តេច
នេះមានន័យថា ពួកគេបានបញ្ជូនអ្នកនាំសារទៅស្តេច។ ការបកប្រែផ្សេងទៀត
«ពួកគេបានបញ្ជូនអ្នកនាំសារទៅស្តេច»
2 Samuel 19:16
លោកកេរ៉ា ... លោកស៊ីបា
ទាំងនេះគឺជាឈ្មោះនៃមនុស្សប្រុស។ បកប្រែឈ្មោះ «លោកស៊ីបា»
ដូចគ្នានឹងអ្នកបានធ្វើក្នុង ៩: ១ ។
ភូមិបាហ៊ូរីម
ការបកប្រែឈ្មោះកន្លែងនេះដូចគ្នានឹងអ្នកបានធ្វើនៅក្នុង ៣:១៤។
មានមនុស្សមួយពាន់នាក់ ... កូនប្រុសទាំងដប់ប្រាំនាក់ ... អ្នកបម្រើទាំងម្ភៃនាក់
«មនុស្ស ១០០០ នាក់ ... កូនប្រុស ១៥ នាក់ ... អ្នកបម្រើ ២០ នាក់»
2 Samuel 22:50
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តច្រៀងចម្រៀងថ្វាយព្រះអម្ចាស់។
សរសើរតម្កើងព្រះនាមព្រះអង្គ
នៅទីនេះពាក្យប្រៀបធៀប «ព្រះនាម» សំដៅទៅលើកិត្តិសព្ទរបស់ព្រះអម្ចាស់។
ហើយព្រះអង្គសម្តែងសេចក្តីស្មោះត្រង់នៃសម្ព័ន្ធមេត្រីរបស់ទ្រង់ ចំពោះស្តេច
នៅទីនេះព្រះបាទដាវីឌប្រហែលជាចង់សំដៅទៅលើការសន្យាដែលព្រះអម្ចាស់បានធ្វើនៅក្នុង
៧: ៨

---

23 [1]នេះជាពាក្យបណ្តាំចុងក្រោយរបស់ព្រះបាទដាវីឌ ជាបុត្ររបស់លោកអេសាយ ជាមនុស្សដែលព្រះជាម្ចាស់លើកឡើងយ៉ាងខ្ពស់បំផុត
ជាម្ចាក់ដែលព្រះរបស់លោកយ៉ាកុប បានចាក់ប្រេងអភិសេក ជាស្តេចដែលប្រជាជនអ៊ីស្រាអែលតែងតែច្រៀងសរសើរ។
[2]«ព្រះវិញ្ញាណរបស់ព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈខ្ញុំ ហើយព្រះអង្គដាក់ព្រះបន្ទូលលើអណ្តាតរបស់ខ្ញុំ។
[3]ព្រះរបស់ជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលថា ព្រះដែលជាថ្មដានៃជនជាតិអ៊ីស្រាអែលមានបន្ទូលមកខ្ញុំថា៖ ស្តេចណាដែលគ្រប់គ្រងលើប្រជាជាតិដោយសុចរិត
គឺស្តេចដែលគ្រប់គ្រងប្រជាជន ដោយកោតខ្លាចព្រះអម្ចាស់។[4]ស្តេចនោះប្រៀបបាននឹងពន្លឺព្រះអាទិត្យរះឡើងនៅពេលព្រឹក ដោយមិនមានពពកបាំង
ពន្លឺនោះធ្វើឲ្យស្មៅលាស់ខៀវខ្ចីឡើងក្រោយពេលភ្លៀង។
[5]ជាការពិតណាស់ តើគ្រួសាររបស់ខ្ញុំមិនយ៉ាងដូច្នេះ ចំពោះព្រះអង្គទេឬ? តើព្រះអង្គមិនបានចងសម្ព័ន្ធមេត្រីស្ថិតស្ថេរអស់កល្ប
គឺជាសម្ព័ន្ធមេត្រីដែលមានមាត្រាត្រឹមត្រូវជាមួយខ្ញុំទេឬ? តើព្រះអង្គមិនបានប្រទានឲ្យខ្ញុំមានជ័យជម្នះ និងអ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវការទេឬ?
[6]ប៉ុន្តែ មនុស្សពាលវិញ ប្រៀបបាននឹងបន្លាដែលគេបោះចោលទៅ ដ្បិត មិនដែលមានអ្នកណានឹងយកដៃទៅពាល់វាទេ។[7]មនុស្សដែលប៉ះវា ពួកគេត្រូវតែប្រើទម្ពក់ដែក
ឬដងលំពែង។ ពួកគេត្រូវដុតនៅនឹងកន្លែងនោះ។
[8]ទាំងនេះគឺជាឈ្មោះទាហានដ៏អង់អាចរបស់ព្រះបាទដាវីឌ៖ លោកយេសបាអាល ជាជនជាតិតាកមូនី ជាមេបញ្ជាការនៃកងទាហានដែលអង់អាចក្លាហាន។
លោកបានសម្លាប់មនុស្សអស់ប្រាំរយនាក់ក្នុងសមរភូមិមួយ។
[9]បន្ទាប់មក គឺលោកអេឡាសារ ជាកូនរបស់លោកដូដូ លោកជាទាហានម្នាក់ ក្នុងចំណោមនាយទាហានដ៏អង់អាចក្លាហានទាំងបីនាក់របស់ព្រះបាទដាវីឌ។
លោកជាមេទ័ពម្នាក់ ក្នុងគ្រាដែលពួកភីលីស្ទីនប្រមូលគ្នាលើកទ័ពមកច្បាំងនឹងអ៊ីស្រាអែល ហើយជនជាតិអ៊ីស្រាអែលដកទ័ពថយ។[10]កាលនោះ មានតែលោកអេឡាសារ
ប៉ុណ្ណោះដែលនៅឈរទប់ទល់ និងវាយពួកភីលីស្ទីនជាច្រើន រហូតដល់ដៃរបស់គាត់រោយ ហើយម្រាមដៃរបស់គាត់ក្តាប់ដាវលែងជាប់។
ព្រះជាម្ចាស់ប្រទានឲ្យលោកនូវជ័យជម្នះដ៏ធំធេងនៅថ្ងៃនោះ។ ពួកទាហានបានវិលត្រឡប់មករកលោកវិញ ដោយគ្រាន់តែប្រមូលសាកសពតែប៉ុណ្ណោះ។
[11]បន្ទាប់មក គឺលោកសាំម៉ា ជាកូនរបស់លោកអកេ ពីអំបូរហារ៉ារី។ នៅគ្នានោះកងទពភីលីស្ទីនប្រមូលគ្នានៅវាលមួយ ដែលពេញទៅដោយសណ្តែក
ហើយទាហានអ៊ីស្រាអែលបានបាក់ទ័ពនៅចំពោះមុខពួកគេ។[12]ប៉ុន្តែ លោកសាំម៉ាឈរនៅកណ្តាលចម្ការហើយវាយដណ្តើមយកចំការនោះមកវិញ។
លោកបានសម្លាប់ជនជាតិភីលីស្ទីនយ៉ាងច្រើន ហើយព្រះអម្ចាស់បានប្រទានជ័យជម្នះដ៏ធំធេង។
[13]ទាហានបីនាក់ ក្នុងចំណោមទាហានសាមសិបនាក់ បានចុះទៅគាល់ព្រះបាទដាវីឌ នៅរដូវចម្រូតនៅក្នុងល្អាងភ្នំអាឌូឡាម។ ពួកទាហានភីលីស្ទីនបានបោះជំរំ
នៅជ្រលងភ្នំរេផាអ៊ីម។[14]នៅគ្រានោះ ព្រះបាទដាវីឌគង់នៅក្នុងបន្ទាយដ៏រឹងមាំរបស់ទ្រង់ ដែលនៅក្នុងជ្រលងភ្នំ។ ស្របពេលជាមួយគ្នាពួកភីលីស្ទីន
ក៏ឈរជើងនៅបេថ្លេហិមដែរ។
[15]ព្រះបាទដាវីឌស្រេកទឹក ទ្រង់ក៏មានរាជឱង្ការថា៖ «តើអ្នកណាអាចយកទឹកពីអណ្តូងដែលនៅភូមិបេថ្លេហិម មកឲ្យយើងសោយបាន
គឺអណ្តូងដែលនៅមាត់ទ្វារក្រុង!»[16]ដូច្នេះ មេទាហានទាំងបីរូបដែលក៏នាំគ្នាសម្រុកទៅក្នុងបន្ទាយរបស់ពួកភីលីស្ទីន ហើយដងទឹកពីអណ្តូងនៅភូមិបេថ្លេហិម
គឺអណ្តូងទឹកដែលនៅមាត់ទ្វារក្រុង។ ពួកគេបានយកទឹកនោះទៅថ្វាយព្រះបាទដាវីឌ ប៉ុន្តែ ទ្រង់មិនព្រមសោយទឹកនោះទេ។ ជំនួសវិញ
ទ្រង់បានច្រួចទឹកនោះថ្វាយព្រះជាម្ចាស់។[17]បន្ទាប់មក ទ្រង់មានរាជឱង្ការថា៖ «បពិត្រព្រះអម្ចាស់! សូមឲ្យការនេះឆ្ងាយពីទូលបង្គំ ថាទូលបង្គំនឹងទទួលទានទឹកនេះ។
តើទូលបង្គំ នឹងផឹកឈាមរបស់ទាហានដែលបានប្តូរជីវិតរបស់ពួកគេ ទៅដងឲ្យទូលបង្គំឬ?» ដូច្នេះ ទ្រង់មិនសោយវាទេ។ នេះហើយជាស្នាដៃ
ដែលទាហានអង់អាចទាំងបីនាក់បានប្រព្រឹត្ត។
[18]លោកអប៊ីសាយ ប្អូនប្រុសលោកយ៉ូអាប់ ជាកូនប្រុសរបស់លោកស្រីសេរូយ៉ា ជាប្រមុខនៃមេទ័ពទាំងបីរូប។ លោកបានប្រើលំពែងសម្លាប់ខ្មាំងសត្រូវអស់បីរយនាក់។
លោកមានកេរ្តិ៍ឈ្មោះក្នុងចំណោមទាហានទាំងបីរូប។[19]តើគាត់មិនល្បីល្បាញជាងអ្នកទាំងបីទេឬ? លោកត្រូវបានតែងតាំងជាមេបញ្ជាការនៃកងទ័ព។ ប៉ុន្តែ
លោកពុំអាចប្រៀបស្មើនឹងមេក្រុមបីរូបទៀតបានឡើយ។
[20]លោកបេនណាយ៉ា អ្នកស្រុកកាបសៀល ជាកូនរបស់លោកយេហូយ៉ាដា និងជាចៅរបស់ទាហានដ៏អង់អាចម្នាក់។ លោកបានសម្លាប់កូនប្រុសទាំងពីររបស់អរាល
អ្នកស្រុកម៉ូអាប់។ គាត់ក៏បានចុះទៅក្នុងអណ្តូង ហើយបានសម្លាប់សត្វសិង្ហមួយ នៅពេលដែលធ្លាក់ទឹកកក។[21]គាត់ក៏បានសម្លាប់ជនជាតិអេស៊ីបម្នាក់
ដែលមានមាឌធំសម្បើម។ ទាហានអេស៊ីបនោះ មានលំពែងនៅនឹងដៃ ប៉ុន្តែលោកបេណាយ៉ា ប្រយុទ្ធជាមួយនឹងគេដោយប្រើតែដំបងមួយប៉ុណ្ណោះ។
លោកបេណាយ៉ាបានដណ្តើមយកលំពែងពីដៃរបស់ទាហាននោះ ហើយបានសម្លាប់គេដោយលំពែងរបស់គេ។
[22]ទាំងនេះគឺជាស្នាដៃរបស់លោកបេណាយ៉ាកូនរបស់លោកយេហូយ៉ាដា ហើយគាត់មានកេរ្តិ៍ឈ្មោះក្នុងចំណោមវីរជនទាំងបី។
[23]ក្នុងចំណោមទាហានដ៏អង់អាចសាមសិបនាក់ លោកទទួលបានកិត្តិយសខ្លាំងជាងគេ ប៉ុន្តែលោកមិនអាចប្រៀបស្មើនឹងមេទ័ពទាំងបីរូបបានឡើយ។
ព្រះបាទដាវីឌបានតែងតាំងលោកជាមេបញ្ជាការកងអង្គរក្ស។

generated on Wed Sep 10 16:16:32 2025

[24]ទាហានទាំងសាមសិបនាក់នោះរួមមាន៖ លោកអសាអែល ជាប្អូនប្រុសរបស់លោកយ៉ូអាប់ លោកអែលហាណាន កូនប្រុសលោកដូដូ ជាអ្នកភូមិបេថ្លេហឹម[25]លោកសាំម៉ា
ជាអ្នកស្រុកហារ៉ូដ លោកអេលីកា ជាអ្នកស្រុកហារ៉ូដ[26]លោកហេលេស ជាអ្នកស្រុកប៉ាលធី លោកអ៊ីរ៉ា កូនប្រុសរបស់លោកអ៊ីកកែស ជាអ្នកក្រុងតេកូ[27]លោកអាប៊ីអាស៊ើរ
អ្នកស្រុកអាណាថោត លោកមេប៊ូណាយ អ្នកស្រុនហ៊ូសាយ[28]លោកសាលម៉ូន អ្នកស្រុកអហូអា លោកម៉ាហារ៉ៃ អ្នកស្រុកណេថូផាត
[29]លោកហេលែប កូនរបស់លោកបាណា អ្នកស្រុកណែថូផា លោកអ៊ីតាយ កូនរបស់លោករីបាយ អ្នកស្រុកគីបៀ ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន[30]លោកបេណាយ
ជាអ្នកស្រុកពីរ៉ាថូ លោកហ៊ីតដាយ អ្នកស្រុកនៃជ្រលងភ្នំអាកាស។[31]លោកអប៊ី អាល់បូន អ្នកស្រុកអើរ៉ាបា លោកអាស្មាវែត អ្នកស្រុកបាហូមីត[32]លោកអេលីយ៉ាបា
អ្នកស្រុកស្អាឡាប៊ីន លោកយ៉ូណាថាន់ កូនៗរបស់លោកយ៉ាសេន លោកយ៉ូណាថាន់ កូនប្រុសលោកសាំម៉ា អ្នកស្រុកហារ៉ារីត
[33]លោកអាហីយ៉ាម កូនលោកសារ៉ា អ្នកស្រុកហារ៉ារីត[34]លោកអែលលីផេឡែត កូនរបស់លោកអាហាសបាយ អ្នកស្រុកម៉ាកាត់ លោកអែលីយ៉ាម
កូនរបស់លោកអហីថូផែល អ្នកស្រុកគីឡូន[35]លោកហេសរ៉ូ ជានជាតិកាមែល លោកផាអារ៉ៃ អ្នកស្រុកអាប៊ីត[36]លោកអ៊ីកាល កូនរបស់លោកណាថាន់ ដែលមកពីភូមិស៊ូបា
លោកបានី ដែលមកពីកុលសម្ព័ន្ធកាថ
[37]លោកសេឡែក ជាជនជាតិអាំម៉ូន លោកណាហារ៉ាយ អ្នកស្រុកបៀរ៉ុត ដែលជាអ្នកកាន់គ្រឿងសាស្ត្រាវុធរបស់លោកយ៉ូអាប់ កូនប្រុសរបស់លោកស្រីសេរូយ៉ា[38]លោកអ៊ីរ៉ា
អ្នកស្រុកយេធើ លោកកេរែប អ្នកស្រុកយេធើ[39]លោកអ៊ូរី ជនជាតិហេត សរុបមកមានសាមសិបប្រាំពីរនាក់។

---

2 Samuel 23:1

នេះ

នេះគឺជាការសម្គាល់នៃការចាប់ផ្តើមផ្នែកថ្មីនៃសៀវភៅ។

ជាពាក្យបណ្តាំចុងក្រោយ

នេះសំដៅទៅលើអ្វីដែលព្រះបាទដាវីឌនឹងមានបន្ទូលនៅក្នុង ២៣:១ ។

ជាមនុស្សដែលព្រះជាម្ចាស់លើកឡើងយ៉ាងខ្ពស់បំផុត ជាម្ចាក់ដែលព្រះរបស់លោកយ៉ាកុប

បានចាក់ប្រេងអភិសេក

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«មនុស្សដែលព្រះជាម្ចាស់របស់លោកយ៉ាកុបបានគោរពនិងបានចាក់ប្រេងតាំង»

ព្រះរបស់លោកយ៉ាកុប បានចាក់ប្រេងអភិសេក

ការចាក់ប្រេងត្រូវបានធ្វើដោយចាក់ប្រេងលើក្បាលរបស់មនុស្សម្នាក់។

នេះត្រូវបានធ្វើដើម្បីជ្រើសរើសអ្នកណាដែលនឹងបម្រើព្រះជាម្ចាស់ជាស្តេចឬជាបូជាចារ្យ

ច្រៀងសរសើរ

នេះគឺជាមនុស្សដែលសរសេរទំនុកតម្កើងឬចម្រៀង។

តាមរយៈខ្ញុំ

តាមរយៈព្រះបាទដាវីឌ

ហើយព្រះអង្គដាក់ព្រះបន្ទូលលើអណ្តាតរបស់ខ្ញុំ។

នៅទីនេះ "នៅលើអណ្តាតរបស់ខ្ញុំ"

គឺជាពាក្យសំដីមួយសម្រាប់ស្តេចដាវីឌមានបន្ទូល។ ការបកប្រែផ្សេងទៀត

«ទ្រង់បានផ្តល់ឲ្យខ្ញុំនូវសារដើម្បីនិយាយ»

2 Samuel 23:3

ព័ត៌មានទូទៅ៖

នេះជាពាក្យចុងក្រោយរបស់ព្រះបាទដាវីឌ។

ព្រះរបស់ជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលថា ព្រះដែលជាថ្មដានៃជនជាតិអ៊ីស្រាអែល... ខ្ញុំ

នៅទីនេះ "ព្រះជាម្ចាស់នៃអ៊ីស្រាអែល" គឺដូចគ្នានឹង «ថ្មរបស់អ៊ីស្រាអែល» ។

ឃ្លាទាំងពីរនិយាយរឿងសំខាន់ដូចគ្នា។

ព្រះបាទដាវីឌប្រៀបធៀបព្រះជាម្ចាស់ទៅនឹងថ្មដើម្បីបញ្ជាក់ពីអំណាចរបស់ទ្រង់ក្នុងការ

ដែលគ្រប់គ្រងលើប្រជាជាតិដោយសុចរិត គឺស្តេចដែលគ្រប់គ្រងប្រជាជន

ដោយកោតខ្លាចព្រះអម្ចាស់។

ប្រយោគទាំងពីរនេះនិយាយថា

ស្តេចនឹងគោរពព្រះជាម្ចាស់និងធ្វើអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគាត់ធ្វើ។

ដោយកោតខ្លាចព្រះអម្ចាស់។

«គោរពព្រះជាម្ចាស់»

ស្តេចនោះប្រៀបបាននឹងពន្លឺព្រះអាទិត្យរះឡើងនៅពេលព្រឹក

នៅទីនេះព្រះជាម្ចាស់កំពុងប្រៀបធៀបស្តេចទៅនឹងពន្លឺពេលព្រឹក

និងពន្លឺព្រះអាទិត្យបន្ទាប់ពីភ្លៀង។ ទាំងអស់នេះជារបៀបនៃការនិយាយថា

ស្តេចនឹងជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់និងជាព្រះពរសម្រាប់ប្រជាជន។

ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា ហើយត្រូវបានប្រើសម្រាប់ការបញ្ជាក់។

ការបកប្រែផ្សេងទៀត «ព្រះអង្គនឹងរីករាយចំពោះមនុស្សទាំងអស់»

2 Samuel 23:5

ព័ត៌មានទូទៅ៖

នេះជាពាក្យចុងក្រោយរបស់ព្រះបាទដាវីឌ។

ជាការពិតណាស់ តើគ្រួសាររបស់ខ្ញុំមិនយ៉ាងដូច្នេះ ចំពោះព្រះអង្គទេឬ?

នៅទីនេះព្រះបាទដាវីឌកំពុងមានព្រះបន្ទូលថា

ទ្រង់យល់ស្របជាមួយនឹងព្រះជាម្ចាស់។

សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។

ការបកប្រែផ្សេងទៀត «គ្រួសាររបស់ខ្ញុំពិតជាបែបនេះនៅចំពោះព្រះជាម្ចាស់!»

តើព្រះអង្គមិនបានចងសម្ព័ន្ធមេត្រី ... ខ្ញុំទេឬ?

ព្រះបាទដាវីឌទទួលស្គាល់ថាព្រះជាម្ចាស់បានចងសម្ព័ន្ធមេត្រីជាមួយទ្រង់។

សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។

ការបកប្រែផ្សេងទៀត «ព្រះអង្គបានបង្កើតជាការពិតណាស់ ... វិធី» ។

ត្រឹមត្រូវជាមួយខ្ញុំទេ

នេះមានន័យថា

ការចងសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់គឺត្រូវបានរៀបចំយ៉ាងត្រឹមត្រូវហើយនឹងមិនផ្លាស់ប្តូរទេ

ដូច្នេះក្រុមគ្រួសាររបស់ព្រះបាទដាវីឌអាចជឿទុកចិត្តបាន។

តើព្រះអង្គមិនបានប្រទានឲ្យខ្ញុំមានជ័យជម្នះ ... អ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវការទេឬ?

ព្រះបាទដាវីឌជឿជាក់ថា

ព្រះជាម្ចាស់នឹងជួយគាត់ជានិច្ចហើយធ្វើឲ្យគាត់រីកចម្រើន។

សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។

ការបកប្រែផ្សេងទៀត

«ព្រះអង្គបង្កើនការសង្គ្រោះរបស់ខ្ញុំហើយប្រទានឲ្យខ្ញុំនូវរាល់បំណងប្រាថ្នា» ។

2 Samuel 23:6

ព័ត៌មានទូទៅ៖

នេះជាពាក្យចុងក្រោយរបស់ព្រះបាទដាវីឌ។

ប៉ុន្តែ មនុស្សពាលវិញ ប្រៀបបាននឹងបន្លាដែលគេបោះចោលទៅ

នៅទីនេះមនុស្សអាក្រក់ត្រូវបានគេប្រៀបធៀបទៅនឹងបន្លាដែលគ្មានប្រយោជន៍។

នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត

«តែមនុស្សអាក្រក់គ្មានតម្លៃនិងគ្រោះថ្នាក់ដូចបន្លាដែលយើងបោះចោល»

ដ្បិត មិនដែលមានអ្នកណានឹងយកដៃទៅពាល់វាទេ

"ពីព្រោះគ្មានអ្នកណាអាចលើកពួកគេដោយដៃបានទេបើគ្មានបន្លាធ្វើឲ្យគាត់ឈឺ"

ពួកគេត្រូវដុតនៅនឹងកន្លែងនោះ។

« កន្លែងដែលគេរកឃើញបន្លា នោះគឺជាកន្លែងដែលគេត្រូវដុត» ។

[illegible]

2 Samuel 23:8

លោកយេសបាអាល

នេះជាឈ្មោះនៃមនុស្ស។ នៅជំនាន់ផ្សេងទៀត យ៉ូសែប បាសេបែតឬយ៉ាសុបៀម

អែសបាល ឬអ៊ីសបូសែត ដោយព្រោះច្បាប់ចម្លងបុរាណមានការប្រែប្រួលទាំងនេះ។

អ្នកបកប្រែអាចជ្រើសរើសនិយាយនៅក្នុងលេខយោងនៃការបកប្រែរបស់ពួកគេ

ជាជនជាតិតាកមូនី

នេះគឺជាឈ្មោះនៃក្រុមមនុស្ស។ ការបកប្រែផ្សេងទៀត «កូនប្រុសរបស់តាកមូនី»

មនុស្សអស់ប្រាំរយនាក់

«៨០០»

2 Samuel 23:9

ព័ត៌មានទូទៅ៖

នេះជាពាក្យចុងក្រោយរបស់ព្រះបាទដាវីឌ។

បន្ទាប់មក គឺលោកអេឡាសារ

នេះមានន័យថា

កងទ័ពបានវិលត្រឡប់បន្ទាប់ពីលោកអេឡាសារត្រឡប់មកពីសមរភូមិវិញ។

ការបកប្រែផ្សេងទៀត

«កងទ័ពអ៊ីស្រាអែលបានវិលត្រឡប់ទៅសមរភូមិវិញបន្ទាប់ពីលោកអេឡាសារបានឈ្នះសមរភូមិរួចហើយ»

ដោយគ្រាន់តែប្រមូលសាកសពតែប៉ុណ្ណោះ។

«គ្រាន់តែយកអ្វីដែលពួកគេចង់បានពីសាកសពរបស់សត្រូវ»

generated on Wed Sep 10 16:16:32 2025

2 Samuel 23:11
ព័ត៌មានទូទៅ៖
នេះគឺនៅតែបន្តបញ្ជីឈ្មោះទាហានអស្ចារ្យបំផុតរបស់ព្រះបាទដាវីឌ
វាលមួយ ដែលពេញទៅដោយសណ្តែក
«វាលមួយដែលមានមនុស្សម្នាក់បានដាំសណ្តែក»
សណ្តែកបាយ
គ្រាប់ពូជសំប៉ែត បរិភោគដូចសណ្តែក
បានបាក់ទ័ព
«កងទ័ពអ៊ីស្រាអែលបានរត់គេចខ្លួន»
2 Samuel 23:13
ទាហានបីនាក់
ទាំងនេះមិនមែនដូចគ្នា ដែលទាហានបីនាក់បាននិយាយនៅក្នុង ២៣:៨ ទេ។
ទាហានសាមសិបនាក់
«ទាហាន ៣០ នាក់» ឬ «ទាហានអ៊ីស្រាអែលក្លាហានទាំងសាមសិបនាក់»។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់
ល្អាងភ្នំអាឌូឡាម
"ល្អាងនៅជិតទីប្រជុំជនអាឌូឡាម" ។ អាឌូឡាមនៅជិតភូមិបេថ្លេហិម។
នៅជ្រលងភ្នំរេផាអ៊ីម
នេះជាឈ្មោះនៃទឹកន្លែងមួយ។ បកប្រែដូចនៅក្នុង ៥:១៧ ។
បន្ទាយដ៏រឹងមាំរបស់ទ្រង់
"នៅក្នុងកន្លែងការពាររបស់ទ្រង់"
ពួកភីលីស្ទីន ក៏ឈរជើងនៅបេថ្លេហិមដែរ។
«ទាហានភីលីស្ទីនខ្លះបានកំពុងគ្រប់គ្រងភូមិបេថ្លេហិម»
2 Samuel 23:15
នាំគ្នាសម្រុកទៅក្នុងបន្ទាយ
"បានប្រយុទ្ធតាមផ្លូវរបស់ពួកគេឆ្លងកាត់កងទ័ពសត្រូវ"
តើទូលបង្គំ នឹងផឹកឈាមរបស់ទាហានដែលបានប្តូរជីវិតរបស់ពួកគេ ទៅដងឲ្យទូលបង្គំឬ?
ព្រះបាទដាវីឌប្រៀបធៀបទឹកទៅនឹងឈាម
ពីព្រោះទាហានបានប្រថុយជីវិតដើម្បីនាំទឹកទៅឲ្យទ្រង់។
ព្រះអង្គប្រើសំណួរដើម្បីបញ្ជាក់ពីរឿងនេះ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «ការផឹកទឹកនេះគឺដូចជាការផឹកឈាមរបស់ទាហានទាំងនោះ
ដែលបានប្រថុយជីវិតដើម្បីនាំវាមកឲ្យយើង» ។
2 Samuel 23:18
លោកអប៊ីសាយ ...លោកស្រីសេរូយ៉ា
ទាំងនេះជាឈ្មោះរបស់ទាហាន។ បកប្រែវាដូចនៅក្នុង ២:១៨ ។
ជាប្រមុខនៃមេទ័ពទាំងបីរូប
នេះមានន័យថា
អ័ប៊ីសាយជាមេដឹកនាំនៃមនុស្សបីនាក់ដែលបានទៅដងទឹកសម្រាប់ដាវីឌ។
បីរយនាក់
«ទាហាន ៣០០ នាក់»
លោកមានកេរ្តិ៍ឈ្មោះក្នុងចំណោមទាហានទាំងបីរូប
នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សតែងតែនិយាយអំពីគាត់នៅពេលពួកគេនិយាយអំពីបុរសក្លាហានបីនាក់»
តើគាត់មិនល្បីល្បាញជាងអ្នកទាំងបីទេឬ?
សំណួរនេះត្រូវបានប្រើដើម្បីបញ្ជាក់របៀប ដែលគាត់ល្បីល្បាញយ៉ាងណា។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «គាត់រឹតតែល្បីល្បាញជាងអ្នកទាំងបី» ។
មេក្រុមបីរូបទៀតបានឡើយ
នេះសំដៅទៅលើលោកយ៉ូសែប បាសេបែត លោកអេឡាសារនិងលោកសាម៉ា។
លោកអ័ប៊ីសាយមិនសូវល្បីដូចទាហានទាំងនេះទេ។
2 Samuel 23:20
ស្រុកកាបសៀល
នេះគឺឈ្មោះនៃទីក្រុង។
លោកយេហូយ៉ាដា
នេះជាឈ្មោះនៃទាហាន។ សូមមើលពីរបៀបដែលអ្នកបានបកប្រែរឿងនេះនៅ
៨:១៥ ។
អរាល
នេះជាឈ្មោះនៃមនុស្សប្រុស។
2 Samuel 23:22
គឺជាស្នាដៃ
«បានធ្វើការអស្ចារ្យទាំងនេះ»
ហើយគាត់មានកេរ្តិ៍ឈ្មោះក្នុងចំណោមវីរជនទាំងបី។
នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សសរសើរគាត់ដូចពួកគេបានសរសើរវីរជនទាំងបីនាក់»
ក្នុងចំណោមទាហានដ៏អង់អាចសាមសិបនាក់ លោកទទួលបានកិត្តិយសខ្លាំងជាងគេ
ប៉ុន្តែលោកមិនអាចប្រៀបស្មើនឹងមេទ័ពទាំងបីរូបបានឡើយ។
«គាត់មានភាពល្បីល្បាញជាងទាហាន
៣០នាក់ផ្សេងទៀតលើកលែងតែទាហានពូកែទាំងបី»
មេទ័ពទាំងបីរូប
នេះសំដៅទៅលើ លោកយ៉ូសែប បាសេបែត លោកអេឡាសារ និង លោកសាម៉ា។
លោកជាមេបញ្ជាការកងអង្គរក្ស។
ទាហានមួយក្រុមដែលទទួលបន្ទុកយាមព្រះបាទដាវីឌ។
2 Samuel 23:24
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមទាហានដែលពូកែបំផុតរបស់ព្រះបាទដាវីឌ។
សាមសិបនាក់
«ទាហាន ៣០នាក់ដែលល្បីល្បាញខ្លាំង»
2 Samuel 23:29
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមទាហានដែលពូកែបំផុតរបស់ព្រះបាទដាវីឌ។
2 Samuel 23:33
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមទាហានដែលពូកែបំផុតរបស់ព្រះបាទដាវីឌ។
2 Samuel 23:37
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមទាហានដែលពូកែបំផុតរបស់ព្រះបាទដាវីឌ។
សរុបមកមានសាមសិបប្រាំពីរនាក់។
ប្រាំពីរនាក់នៅក្នុងទាំងអស់ -«សរុបមានចំនួន ៣៧នាក់«

---

24 [1]ព្រះអម្ចាស់ព្រះពិរោធទាស់នឹងប្រជាជនអ៊ីស្រាអែលសារជាថ្មី ហើយទ្រង់បានធ្វើឲ្យព្រះបាទដាវីឌទាស់នឹងពួកគេ ដោយបន្ទូលថា៖
«ចូលទៅធ្វើជំរឿនប្រជាជនអ៊ីស្រាអែល និងប្រជាជនយូដា»។[2]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់លោកយ៉ូអាប់ជាមេទ័ព ដែលនៅជាមួយទ្រង់ថា៖
«ចូលចេញទៅគ្រប់ទាំងកុលសម្ព័ន្ធរបស់ប្រជាជនអ៊ីស្រាអែលទាំងអស់ ចាប់ពីក្រុងដាន់ រហូតដល់បៀសេបា ហើយរាប់ចំនួនមនុស្សទាំងអស់
ដូច្នេះយើងអាចដឹងពីចំនួនសរុបនៃមនុស្សប្រុសដែលពេញកម្លាំងអាចចេញច្បាំងបាន។
[3]លោកយ៉ូអាប់ទូលព្រះរាជាថា៖ «សូមព្រះជាម្ចាស់ ជាព្រះរបស់ព្រះករុណា ប្រោសប្រទានឲ្យប្រជាជនរបស់ព្រះករុណាកើនចំនួនទ្វេរឡើងមួយរយដង ច្រើនជាងនេះ
ហើយឲ្យព្រះករុណាជាអម្ចាស់ទតឃើញផ្ទាល់នឹងភ្នែក។ ប៉ុន្តែហេតុអ្វីបានជាព្រះរាជា ចង់ជំរឿនប្រជាជនដូច្នេះ?»[4]ដោយសារតែ
បទបញ្ជារបស់ព្រះរាជាជំទាស់នឹងលោកយ៉ូអាប់ ហើយជំទាស់នឹងពួកមេទ័ព។ ដូច្នេះលោកយ៉ូអាប់ និងពួកមេទ័ពឯទៀតៗបានចេញពីព្រះរាជា
ដើម្បីទៅធ្វើជំរឿនប្រជាជនអ៊ីស្រាអែល។
[5]ពួកគេបានឆ្លងទន្លេយ័រដាន់ ហើយបោះជំរំនៅខាងត្បូងក្រុងអារ៉ូអ៊ើរ ដែលស្ថិតនៅកណ្តាលជ្រលងភ្នំ។ បន្ទាប់មក ពួកគេធ្វើដំណើរឆ្លងតាមកាថ ទៅកាន់ក្រុងយ៉ាស៊ើរ។
[6]ពួកគេបានទៅដល់ស្រុកកាឡាត និងស្រុកថាសធីម ហុដស៊ី បន្ទាប់មក ទៅស្រុកដាន់យ៉ាអ៊ិន និងតំបន់ស៊ីដូន។[7]ពួកគេបានបន្តដំណើរទៅដល់បន្ទាយក្រុងទីរុស
ហើយនិងក្រុងនានារបស់ក្រុងហេវី និងជនជាតិកាណាន។ បន្ទាប់មក ពួកគេបានចេញតម្រង់ទៅណេកេវ ក្រុងបៀរសេបា ដែលនៅប៉ែកខាងត្បូងស្រុកយូដា។

generated on Wed Sep 10 16:16:32 2025

[8]ក្រោយពីពួកគេបានធ្វើដំណើរឆ្លងកាត់ស្រុកទាំងមូល អស់រយៈពេលប្រាំបួនខែម្ភៃថ្ងៃ បន្ទាប់ពួកគេបានត្រឡប់មកក្រុងយេរូសាឡិម។[9]លោកយ៉ូអាប់ចូលទៅគាល់ស្តេច
និងរាយការណ៍អំពីចំនួនមនុស្សដែលប្រយុទ្ធបានដល់ព្រះរាជា។ គឺនៅក្នុងអ៊ីស្រាអែលមានបុរសក្លាហានដែលអាចប្រដាប់អាវុធបាន ចំនួនប៉ែតសិបម៉ឺននាក់
និងមានហាសិបម៉ឺននាក់ក្នុងស្រុកយូដា។
[10]ព្រះបាទដាវីឌដឹងកំហុសដែលរបស់ទ្រង់ បន្ទាប់ពីការធ្វើជំរឿនប្រជាជន។ ដូច្នេះ ព្រះបាទដាវីឌបានទូលអង្វរព្រះអម្ចាស់ថា៖ «ទូលបង្គំបានធ្វើអំពើបាបធំណាស់
ដោយបានធ្វើការនេះ។ បពិត្រព្រះអម្ចាស់! សូមអត់ទោសឲ្យទូលបង្គំផង ដ្បិត ទូលបង្គំប្រព្រឹត្តដូចមនុស្សវង្វេងស្មារតីទាំងស្រុង!»។
[11]នៅពេលដែលព្រះបាទដាវីឌតើនឡើងនៅពេលព្រឹក ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្រះបាទដាវីឌតាមរយៈព្យាការីរបស់ទ្រង់
លោកព្យាការីកាថ[12]«ចូរទៅប្រាប់ដាវីឌថា៖ នេះជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល «យើងឲ្យជម្រើសបីដល់អ្នក។ ត្រូវជ្រើសរើសយកមួយក្នុងចំណោមបីនោះ»។
[13]ព្យាការីកាថបានចូលគាល់ព្រះបាទដាវីឌហើយទូលទ្រង់ថា៖ «តើព្រះករុណាសព្វព្រះហឫទ័យ ឲ្យមានគ្រោះទុរ្ភិក្សរយៈពេលបីឆ្នាំក្នុងស្រុក?
ឬព្រះករុណាត្រូវបាក់ទ័ពរត់នៅមុខសត្រូវរយៈពេលបីខែ? ឬចង់ឲ្យមានជម្ងឺអាសន្នរោគ ក្នុងស្រុករយៈពេលបីថ្ងៃ? ឥឡូវនេះ សូមព្រះករុណាពិចារណាចុះ
ទូលបង្គំនឹងនាំចម្លើយទៅថ្វាយព្រះអម្ចាស់ដែលបានចាត់ទូលបង្គំឲ្យមក។[14]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់ព្យាការីកាថថា៖ «យើងតប់ប្រមល់ខ្លាំងណាស់។
សូមឲ្យយើងធ្លាក់ទៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ជាជាងធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់មនុស្ស ដ្បិត ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដ៏ធំធេង»។
[15]ព្រះអម្ចាស់បានធ្វើឲ្យមានជម្ងឺអាសន្នរោគកើតឡើងក្នុងស្រុកអ៊ីស្រាអែលតាំងពីព្រឹករហូតដល់ពេលកំណត់ មានមនុស្សចំនួនប្រាំពីរម៉ឺននាក់
បានស្លាប់ចាប់ពីដាន់រហូតដល់បៀរសេបា។[16]នៅពេលដែលទេវតាលើកព្រះហស្តឡើងបម្រុងប្រហារក្រុងយេរូសាឡិម ព្រះអម្ចាស់ប្រែព្រះហឫទ័យអាណិត
មិនព្រមបំផ្លាញក្រុងនេះទេ ហើយព្រះអង្គមានព្រះបន្ទូលទៅទេវតាដែលកំពុងបំផ្លាញប្រជាជនថា៖ «គ្រប់គ្រាន់ហើយ! ឥឡូវនេះ ចូរដកដៃរបស់អ្នកចេញចុះ»។
ពេលនោះទេវតារបស់ព្រះអម្ចាស់កំពុងស្ថិតនៅក្បែរលានបោកស្រូវរបស់លោកអរ៉ោណា ជាជនជាតិយេប៊ូស។
[17]កាលព្រះបាទដាវីឌបានឃើញទេវតាប្រហារប្រជាជនដូច្នេះ ទ្រង់ទូលព្រះអម្ចាស់ថា៖ «ទូលបង្គំបានប្រព្រឹត្តអំពើរបាប ហើយទូលបង្គំទេតើដែលបានធ្វើខុស។
ប៉ុន្តែកូនចៀមទាំងនេះ តើពួកគេបានធ្វើអ្វីទៅ? សូមទ្រង់ដាក់ទោសទូលបង្គំ និង ក្រុមគ្រួសាររបស់ទូលបង្គំទៅចុះ!»
[18]នៅថ្ងៃនោះ ព្យាការីកាថបានចូលមកគាល់ និងទូលទ្រង់ថា៖ «ចូលក្រោកឡើងទៅលានបោកស្រូវរបស់លោកអារ៉ោណា ជាជនជាតិយេប៊ូស
ហើយសង់អាសនៈមួយសម្រាប់ព្រះអម្ចាស់ចុះ»។[19]ដូច្នេះព្រះបាទដាវីឌបានយាងទៅតាមពាក្យរបស់ព្យាការីកាដ ដូចព្រះអម្ចាស់បង្គាប់មក។
[20]លោកអារ៉ោណាក្រឡេកទៅឃើញថាព្រះរាជា និងរាជបម្រើរបស់ទ្រង់មកដល់។ ដូច្នេះ លោកចេញទៅហើយក្រាបចុះអោនមុខដល់ដីថ្វាយបង្គំស្តេច។
[21]លោកអារ៉ោណាទូលស្តេចសួរថា៖ «ហេតុអ្វីបានជាព្រះរាជាជាម្ចាស់យាងមករកទូលបង្គំដូច្នេះ?» ព្រះបាទដាវីឌតបថា៖ «គឺយើងមកទិញលានបោកស្រូវរបស់លោក
ដើម្បីសង់អាសនៈថ្វាយព្រះអម្ចាស់ ដើម្បីឲ្យប្រជាជនរួចផុតពីគ្រោះកាច»។[22]លោកអារ៉ោណាទូលទៅព្រះរាជាថា៖ «សូមព្រះករុណាជាអម្ចាស់
យកអ្វីៗទុកជារបស់ទ្រង់ទៅចុះ។ សូមធ្វើតាមការសព្វព្រះហឫទ័យរបស់ទ្រង់ចុះ។ ទតចុះ នៅទីនេះមានគោសម្រាប់ជាតង្វាយដុតទាំងមូល
ព្រមទាំងនឹមនឹងរនាស់សម្រាប់ជាអុសដុតតង្វាយផង។[23]ទូលបង្គំសូមថ្វាយរបស់ទាំងអស់នេះទៅព្រះរាជា»។ បន្ទាប់មក លោកទូលស្តេចថា៖ «សូមព្រះអម្ចាស់
ជាព្រះរបស់ព្រះរាជាទទួកយកតង្វាយទាំងនេះ»។
[24]ព្រះបាទដាវីឌតបទៅលោកថា៖ «ទេ! យើងចង់ទិញរបស់ទាំងនេះពីលោកដោយពេញថ្លៃ។ យើងមិនអាចយកយញ្ញបូជាដែលយើងមិនបានបង់ប្រាក់
ទៅដុតថ្វាយព្រះអម្ចាស់បានទេ»។ ដូច្នេះ ព្រះបាទដាវីឌបានទិញលានបោកស្រូវនិងគោអស់ប្រាក់សុទ្ធចំនួនហាសិបស្លឹង។
[25]ទ្រង់ក៏បានសង់អាសនៈសម្រាប់ព្រះអម្ចាស់នៅទីនោះហើយថ្វាយតង្វាយដុតទាំងមូល និងយញ្ញបូជាមេត្រីភាពថ្វាយព្រះអម្ចាស់។ ដូច្នេះ
ពួកគេបានទូលអង្វរព្រះអម្ចាស់ជំនួសស្រុក ហើយព្រះអម្ចាស់បានបញ្ឈប់សគ្រោះកាចនោះចេញពីស្រុកអ៊ីស្រាអែល។

---

2 Samuel 24:1

ព្រះអម្ចាស់ព្រះពិរោធទាស់នឹងប្រជាជនអ៊ីស្រាអែលសារជាថ្មី

ពាក្យថា «បញ្ជោះ» មានន័យថា ចាប់ផ្តើមឆេះ។

នៅទីនេះព្រះពិរោធរបស់ព្រះអម្ចាស់ប្រៀបទៅនឹងភ្លើង។ ការបកប្រែផ្សេងទៀត
«ព្រះពិរោធរបស់ព្រះអម្ចាស់បានចាប់ផ្តើមឆេះដូចជាភ្លើង» ។

ទ្រង់បានធ្វើឲ្យព្រះបាទដាវីឌទាស់នឹងពួកគេ

«ទ្រង់បានបណ្តាលឲ្យព្រះបាទដាវីឌប្រឆាំងពួកគេ»

ចូលទៅធ្វើជំរឿនប្រជាជនអ៊ីស្រាអែល និងប្រជាជនយូដា

នៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ
ព្រះជាម្ចាស់បានហាមស្តេចអ៊ីស្រាអែលមិនឲ្យធ្វើជម្រើនទាហាន។
អត្ថន័យពេញលេញនៃសេចក្តីថ្លែងការណ៍នេះអាចត្រូវបានធ្វើឲ្យច្បាស់។

ចាប់ពីក្រុងដាន់ រហូតដល់បៀសេបា

ឃ្លានេះប្រើឈ្មោះទីកន្លែងពីរគឺ ក្រុងដាន់នៅភាគខាងជើងឆ្ងាយ
និងបៀសេបានៅភាគខាងត្បូងឆ្ងាយដើម្បីតំណាងឲ្យប្រទេសទាំងមូល។

ហើយរាប់ចំនួនមនុស្សទាំងអស់ ... នៃមនុស្សប្រុសដែលពេញកម្លាំងអាចចេញច្បាំងបាន។

នេះមានន័យថា រាប់បុរសទាំងអស់លើកលែងតែបុរសដែលក្មេងពេក ចាស់ពេក
ឬរាងកាយមិនអាចប្រយុទ្ធបាន។

2 Samuel 24:3

កើនចំនួន ...មួយរយដង

នេះមានន័យថា «ផលិតបានមនុស្ស
១០០នាក់បន្ថែមទៀតសម្រាប់មនុស្សម្នាក់ដែលមាននៅពេលនេះ» ។

បទបញ្ជារបស់ព្រះរាជាជំទាស់នឹងលោកយ៉ូអាប់

លោកយ៉ូអាប់និងមេបញ្ជាការដទៃទៀតនៃកងទ័ពរបស់ស្តេចដាវីឌ
មិនអាចបញ្ចុះបញ្ចូលស្តេចដាវីឌមិនអោយធ្វើជំរឿនបានទេ។

បទបញ្ជារបស់ព្រះរាជា

ឃ្លានេះតំណាងឲ្យបទបញ្ជារបស់ស្តេចចំពោះពួកគេ។ អេធី
«អ្វីដែលស្តេចបានបទបញ្ជា»

2 Samuel 24:5

ពួកគេបានឆ្លង

«លោកយ៉ូអាប់និងមេបញ្ជាការកងទ័ពបានឆ្លងកាត់»

ក្រុងអារ៉ូអ៊ើរ

នេះជាទីក្រុងមួយនៅចុងខាងជើងនៃទន្លេអាណូន។

ក្រុងយ៉ាស៊ើរ

នេះគឺទីក្រុងកាថ។

ស្រុកថាសធីម ហុដស៊ី

នេះប្រហែលជាសំដៅទៅលើក្រុងកាដេស ក្នុងដែនដីរបស់ជនជាតិហេត។

2 Samuel 24:8

ពួកគេបានធ្វើដំណើរ

«លោកយ៉ូអាប់និងមេបញ្ជាការបានទៅ»

អស់រយៈពេលប្រាំបួនខែម្ភៃថ្ងៃ

«៩ ខែ ២០ថ្ងៃ» (សូមមើលranslate-numbers)

លោកយ៉ូអាប់ចូលទៅគាល់ស្តេច និងរាយការណ៍អំពីចំនួនមនុស្សដែលប្រយុទ្ធបានដល់ព្រះរាជា។

លោកយ៉ូអាប់បានប្រាប់ព្រះរាជាថា
មានពលទាហានទាំងអស់ដែលត្រៀមសម្រាប់ធ្វើសង្គ្រាម។

នៅក្នុងអ៊ីស្រាអែល

គាត់សំដៅទៅលើកុលសម្ព័ន្ធអ៊ីស្រាអែលខាងជើង។

៨០០.០០០ ... ៥០០.០០០

«ប្រាំបីរយពាន់ ... ប្រាំរយពាន់»"

ដែលអាចប្រដាប់អាវុធបាន

មេតាណុលនេះសំដៅទៅលើបុរសដែលត្រៀមខ្លួនប្រយុទ្ធក្នុងជួរកងទ័ព។

ក្នុងស្រុកយូដា

នេះសំដៅទៅលើកុលសម្ព័ន្ធយូដាខាងត្បូង។

2 Samuel 24:10

ព្រះបាទដាវីឌដឹងកំហុសដែលរបស់ទ្រង់

ពាក្យ«ចិត្ត»

នៅទីនេះគឺជាពាក្យប្រៀបធៀបសម្រាប់អារម្មណ៍និងមនសិការរបស់ព្រះបាទដាវីឌ។

ការបកប្រែផ្សេងទៀត:«ព្រះបាទដាវីឌមានអារម្មណ៍ថាធ្វើខុស»

បពិត្រព្រះអម្ចាស់! សូមអត់ទោសឲ្យទូលបង្គំផង

generated on Wed Sep 10 16:16:32 2025

ដាវីឌចាត់ទុកខ្លួនគាត់ជា «អ្នកបម្រើរបស់អ្នក»។
នេះជាវិធីគួរសមក្នុងការនិយាយទៅកាន់នរណាម្នាក់ដែលមានសិទ្ធិអំណាចខ្ពស់។
2 Samuel 24:11
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្រះបាទដាវីឌ
នេះគឺជាពាក្យមួយដែលមានន័យថា ព្រះអម្ចាស់មានព្រះបន្ទូល។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ៧: ៣ ។ ការបកប្រែផ្សេងទៀត
"ព្រះអម្ចាស់មានព្រះបន្ទូលមកទ្រង់"
ព្រះអម្ចាស់មានព្រះបន្ទូល
ត្រង់នេះពាក្យថាតំណាងអោយសាររបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«សាររបស់ព្រះអម្ចាស់»
ព្យាការីរបស់ទ្រង់
នេះមានន័យថា កាដជាព្យាការីផ្លូវការនៅក្នុងព្រះបរមរាជវាំង។
2 Samuel 24:13
យើងតប់ប្រមល់ខ្លាំងណាស់។
"ខ្ញុំកំពុងមានបញ្ហាគួរឲ្យខ្លាច"
សូមឲ្យយើងធ្លាក់ទៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ជាជាងធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់មនុស្ស
នៅទីនេះ «ដៃ» សំដៅទៅលើអំណាចឬការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«សូមឲ្យព្រះអម្ចាស់ដាក់ទណ្ឌកម្មមិនមែនប្រជាជនដាក់ទណ្ឌកម្មយើង»
2 Samuel 24:15
រហូតដល់ពេលកំណត់
នេះជាពេលវេលាដែលព្រះជាម្ចាស់បានសម្រេចថាព្រះអង្គនឹងបញ្ឈប់គ្រោះកាច។
មានមនុស្សចំនួនប្រាំពីរម៉ឺននាក់
«៧0,000»
ចាប់ពីដាន់រហូតដល់បៀរសេបា
ត្រង់នេះនិយាយអំពីទីក្រុងដាន់ នៅភាគខាងជើងបំផុតនិងទីក្រុងបៀរសេបា
នៅភាគខាងត្បូងបំផុតមានន័យថា ប្រជាជាតិអ៊ីស្រាអែលទាំងមូល។
នៅពេលដែលទេវតាលើកព្រះហស្តឡើងបម្រុងប្រហារក្រុងយេរូសាឡឹម
នៅទីនេះពាក្យប្រៀបធៀប « ដៃ» តំណាងឲ្យអំណាចរបស់ទេវតា។
ការបកប្រែផ្សេងទៀត «ទេវតាគឺបម្រុងបំផ្លាញប្រជាជននៅក្រុងយេរូសាឡឹម»
ព្រះអម្ចាស់ប្រែព្រះហឫទ័យអាណិត មិនព្រមបំផ្លាញក្រុងនេះទេ
នេះមានន័យថា
ព្រះអម្ចាស់បានបញ្ឈប់ការអាក្រក់ដែលព្រះអង្គបានអនុញ្ញាតអោយទេវតាធ្វើ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់មានព្រះទ័យព្រួយពីការធ្វើទុក្ខ»
ឥឡូវនេះ ចូរដកដៃរបស់អ្នកចេញចុះ
ពាក្យ «ដៃ» ឈរតំណាងអោយអំណាចរបស់ទេវតា។ ការបកប្រែផ្សេងទៀត
«កុំធ្វើបាបពួកគេទៀតទេ»
លោកអរ៉ៅណា
នេះជាឈ្មោះនៃមនុស្សប្រុស។
នៅក្បែរលានបោកស្រូវ
លានបោកស្រូវគឺជាកម្រាលរឹងរាបស្មើមួយ
ដែលជាកន្លែងអាចបំបែកគ្រាប់ស្រូវចេញពីអង្កាម។
2 Samuel 24:17
ទូលបង្គំបានប្រព្រឹត្តអំពើរបាប ហើយទូលបង្គំទេតើដែលបានធ្វើខុស។
ឃ្លាទាំងនេះមានន័យដូចគ្នាហើយត្រូវបានរួមបញ្ចូលគ្នាសម្រាប់ការបញ្ជាក់។
ការបកប្រែផ្សេងទៀត «ខ្ញុំបានធ្វើបាបយ៉ាងខ្លាំង»
ប៉ុន្តែកូនចៀមទាំងនេះ តើពួកគេបានធ្វើអ្វីទៅ?
ព្រះបាទដាវីឌប្រើសំណួរមួយ
ហើយប្រៀបធៀបប្រជាជនទៅនឹងចៀមដើម្បីបញ្ជាក់ថា
ពួកគេមិនបានធ្វើអ្វីខុសទេ។
សំណួរដ៏ប៉ិនប្រសព្វនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
ការបកប្រែផ្សេងទៀត «មនុស្សធម្មតាទាំងនេះមិនបានធ្វើអ្វីខុសទេ»។
សូមទ្រង់ដាក់ទោសទូលបង្គំ
នៅទីនេះពាក្យប្រៀបធៀប «ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«សូមដាក់ទោសទូលបង្គំ»
2 Samuel 24:18
លោកចេញទៅហើយក្រាបចុះអោនមុខដល់ដីថ្វាយបង្គំស្តេច។
គាត់បានបង្ហាញការគោរពនិងគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះរាជា។
2 Samuel 24:21
ដើម្បីឲ្យប្រជាជនរួចផុតពីគ្រោះកាច។
នេះអាចថ្លែងជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ដូច្នេះព្រះអម្ចាស់នឹងដកគ្រោះកាចចេញពីប្រជាជន»
សូមធ្វើតាមការសព្វព្រះហឫទ័យរបស់ទ្រង់ចុះ
ឃ្លាដែលថា «សព្វព្រះហឫទ័យរបស់ទ្រង់»
តំណាងឲ្យយោបល់ឬគំនិតរបស់ព្រះបាទដាវីឌ។ ការបកប្រែផ្សេងទៀត
«ចូរធ្វើវាជាមួយអ្វីដែលព្រះអង្គគិតថាល្អ»
នឹមនឹងរនាស់
ឈើធ្នង់បានប្រើដើម្បីញែកបំបែកគ្រាប់ស្រូវដែលនៅសល់សំរាប់ការសាបព្រោះ។
2 Samuel 24:24
យើងមិនអាចយកយញ្ញបូជា...ដែលយើងមិនបានបង់ប្រាក់
នេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«យើងនឹងផ្តល់ជូនតែ ... អ្វីមួយដែលយើងបានចំណាយសម្រាប់»
អស់ប្រាក់សុទ្ធចំនួនហាសិបស្លឹង
«៥0 ស្លឹង» មួយស្លឹង ១១ក្រាម។
ជំនួសស្រុក
នៅទីនេះពាក្យប្រៀបធៀប «ស្រុក» តំណាងឲ្យប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ក្នុងនាមប្រជាជនអ៊ីស្រាអែល»
បានបញ្ឈៀសគ្រោះកាចនោះចេញ
«បណ្តាលឲ្យគ្រោះកាចបញ្ឈប់»

១ ពង្សាវតាក្សត្រ

1 [1]នៅពេលដែលស្តេចដាវីឌកាន់តែចាស់ជរាទៅ គេបានដណ្តប់ភួយឲ្យទ្រង់ ប៉ុន្តែ មិនបានធ្វើឲ្យទ្រង់កក់ក្តៅទេ។[2]ដូច្នេះ អ្នកបម្រើរបស់ស្តេចបានទូលទៅកាន់ទ្រង់ថា៖ «ចូរយើងរកស្រីព្រហ្មចារីវ័យក្មេងម្នាក់ថ្វាយស្តេចជាចៅហ្វាយរបស់យើង។ ចូរឲ្យនាងបម្រើ និងមែលថែស្តេច។ ចូរឲ្យនាងដេកនៅក្នុងរង្វង់ដៃស្តេច ដូច្នេះ ស្តេចជាចៅហ្វាយរបស់យើងនឹងបានកក់ក្តៅ»។
[3]ដូច្នេះ គេបានរកស្រីវ័យក្មេងដ៏ស្រស់ស្អាតម្នាក់ដែលមាននៅក្នុងទឹកដីអ៊ីស្រាអែល។ ពួកគេរកបាននាងអប៊ីសាកជាអ្នកភូមិស៊ូណែម ហើយបាននាំនាងមកថ្វាយស្តេច។
[4]នាងមានរូបឆោមស្រស់ស្អាតណាស់។ នាងបានបម្រើ និងថែរក្សាស្តេច ប៉ុន្តែ ស្តេចមិនបានរួមរស់ជាមួយនាងទេ។
[5]នៅពេលនោះសម្តេចអដូនីយ៉ាជាកូនរបស់នាងហាគីត បានលើកខ្លួនឡើងដោយនិយាយថា៖ «ខ្ញុំនឹងក្លាយជាស្តេច»។ ដូច្នេះ គាត់ក៏បានរៀបចំរទេះសេះ និងអ្នកជិះសេះដែលមានអ្នករត់ពីមុខគាត់ហាសិបនាក់។[6]ឪពុករបស់គាត់មិនដែលបន្ទោសគាត់ដោយថា៖ «ហេតុអ្វីបានជាកូនធ្វើនេះ ឬធ្វើនោះឡើយ»? សម្តេចអដូនីយ៉ាក៏ជាបុរសសង្ហាម្នាក់ ដែលកើតបន្ទាប់ពីសម្តេចអាប់សាឡុម។
[7]សម្តេចបានពិភាក្សាជាមួយលោកយ៉ូអាប់ ជាកូនរបស់លោកសេរូយ៉ា និងជាមួយលោកបូជាចារ្យអបៀថើរ។ ពួកគេបានតាមសម្តេចអដូនីយ៉ា ហើយបានជួយគាត់។[8]ប៉ុន្តែ លោកបូជាចារ្យសាដុក លោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដា ព្យាការីណាថាន លោកស៊ីម៉ៃ លោករេអ៊ី និងពួកបុរសដ៏អង់អាចរបស់ព្រះបាទដាវីឌ មិនបានដើរតាមសម្តេចអដូនីយ៉ាទេ។
[9]សម្តេចអដូនីយ៉ាបានថ្វាយចៀម គោឈ្មោល និងកូនគោបំប៉ន នៅថ្មសូហេលែត ដែលនៅក្រោយអេនរូកែល។ សម្តេចបានយាងព្រះរាមគឺបុត្រាទាំងអស់របស់ស្តេច និងបានអញ្ជើញអ្នកបម្រើរបស់ស្តេចទាំងអស់នៅស្រុកយូដាទាំងមូលផង។[10]ប៉ុន្តែ សម្តេចមិនអញ្ជើញព្យាការីណាថាន លោកបេណាយ៉ា ពួកបុរសដ៏អង់អាច និងសម្តេចសាឡូម៉ូន ជាអនុជរបស់ស្តេចមកចូលរួមឡើយ។
[11]បន្ទាប់មក លោកណាថានបានទូលទៅព្រះនាងបេតសេបាជាមាតារបស់សម្តេចសាឡូម៉ូនថា៖ «តើព្រះនាងមិនបានឮថាសម្តេចអដូនីយ៉ាជាប្រុសរបស់ព្រះនាងហាគីតបានក្លាយជាស្តេចទាំងស្តេចដាវីឌជាចៅហ្វាយរបស់យើងមិនបានដឹងរឿងនេះទេឬអី?[12]ដូច្នេះ ទូលបង្គំសូមឲ្យយោបល់ដល់ព្រះនាង ដើម្បីឲ្យព្រះនាងអាចរក្សាជីវិតរបស់ព្រះនាង និងបុត្ររបស់ព្រះនាងសាឡូម៉ូនបាន។

generated on Wed Sep 10 16:16:32 2025

[13]ចូរចូលទៅគាល់ស្តេចដាវីឌ ហើយទូលទ្រង់ថា៖ «ស្តេចដ៏ជាចៅហ្វាយ តើព្រះអង្គមិនបានស្បថនឹងអ្នកបម្រើរបស់ព្រះអង្គទេថា៖
«សម្តេចសាឡូម៉ូនជាបុត្ររបស់ព្រះនាងនឹងឡើងសោយរាជ្យបន្តពីយើង ហើយបុត្រនេះនឹងគង់លើបល្ល័ងយើងទេឬអី? តើហេតុអ្វីបានជាស
ម្តេចអដូនីយ៉ាឡើងសោយរាជ្យទៅវិញ?[14]ក្នុងពេលដែលនាងកំពុងទូលទៅស្តេច ទូលបង្គំនឹងនៅក្រោយព្រះនាង និងទូលពាក្យនេះឡើងម្តងទៀត»។
[15]ដូច្នេះ ព្រះនាងបាតសេបាបានទៅដំណាក់របស់ស្តេច។ ស្តេចកាន់តែជរាណាស់ហើយ ហើយព្រះនាងអប៊ីសាក ជាអ្នកភូមិស៊ូណែមកំពុងបម្រើស្តេច។
[16]ព្រះនាងបាតសេបាបានក្រាប និងថ្វាយបង្គំនៅមុខស្តេច។ បន្ទាប់មក ស្តេចសួរថា៖ «តើនាងចង់បានអ្វី»?[17]ព្រះនាងក៏ទូលស្តេចថា៖ «ព្រះករុណា
ព្រះអង្គបានស្បថនឹងអ្នកបម្រើរបស់ព្រះអង្គដោយមានព្រះអម្ចាស់ជាព្រះរបស់ព្រះអង្គជាសាក្សីថា៖
«សម្តេចសាឡូម៉ូនជាបុត្ររបស់ព្រះនាងនឹងឡើងសោយរាជ្យបន្តពីយើង ហើយបុត្រនោះនឹងគង់លើបល្ល័ង្កយើង»។
[18]ឥឡូវនេះ មើលចុះ សម្តេចអដូនីយ៉ាគឺជាស្តេចហើយ ហើយព្រះអង្គដែលជាស្តេចមិនបានដឹងរឿងនេះនៅឡើយ។[19]សម្តេចអដូនីយ៉ាបានថ្វាយគោឈ្មោល កូនគោបំប៉ន
និងចៀមយ៉ាងច្រើន និងបានអញ្ជើញបុត្រទាំងអស់របស់ស្តេច លោកបូជាចារ្យអបៀថើរ និងលោកមេទ័ពយ៉ូអាប់ តែលោកពុំបានយាងសម្តេច
សាឡូម៉ូនជាអ្នកបម្រើរបស់ព្រះអង្គឲ្យចូលរួមទេ។
[20]សម្រាប់ព្រះអង្គវិញ លោកម្ចាស់ ភ្នែករបស់ប្រជាជនអ៊ីស្រាអែលគឺសម្លឹងមកលើព្រះអង្គ រង់ចាំឲ្យព្រះអង្គប្រាប់ពួកគេ ថាតើនរណានឹងត្រូវគង់លើបល្ល័ងបន្តពីព្រះអង្គ។
[21]ម៉្យាងវិញទៀងវានឹងកើតឡើង នៅពេលដែលស្តេចសោយទីវង្គតជាមួយបិតារបស់ស្តេច គេនឹងចាត់ទុកនាងខ្ញុំ និងកូនរបស់នាងខ្ញុំសាឡូម៉ូនជាឧក្រិដ្ឋជនមិនខាន។
[22]នៅពេលដែលព្រះនាងកំពុងទូលស្តេចនៅឡើយ លោកព្យាការីណាថានក៏ចូលមកដល់។[23]អ្នកបម្រើរបស់ស្តេចទូលស្តេចថា៖ «លោកព្យាការីណាថាននៅទីនេះ»។
នៅពេលដែលលោកចូលមកចំពោះស្តេច លោកបានគោរពស្តេចដោយឱនមុខដល់ដីនៅចំពោះស្តេច។
[24]លោកណាថានទូលថា៖ «ស្តេចដ៏ជាចៅហ្វាយរបស់ទូលបង្គំអើយ តើព្រះអង្គធ្លាប់មានបន្ទូលថា៖ «សម្តេចអដូនីយ៉ានឹងគ្រងរាជតពីយើង
ហើយសម្តេចអដូនីយ៉ានឹងគង់លើបល្ល័ងយើងដែរឬទេ»?[25]នៅថ្ងៃនេះ សម្តេចអដូនីយ៉ាបានចុះទៅ ហើយបានថ្វាយគោឈ្មោល កូនគោបំប៉ន និងចៀមជាច្រើន
ហើយក៏បានអញ្ជើញបុត្រាទាំងឡាយរបស់ស្តេច ពួកមេទ័ព និងលោកបូជាចារ្យអបៀថើរ ទៅចូលរួមផង។ ពួកគេទាំងអស់បានបរិភោគ
និងផឹកស្រាស្រវឹងនៅចំពោះមុខសម្តេច និងទូលថា៖ «សូមឲ្យស្តេចអដូនីយ៉ាមានព្រះជន្មយឺនយូ»!
[26]ប៉ុន្តែ សម្រាប់ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ លោកបូជាចារ្យសាដុក លោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដា និងអ្នកបម្រើរបស់ព្រះអង្គសម្តេចសាឡូម៉ូន
គឺសម្តេចមិនបានអញ្ជើញពួកយើងទេ។[27]តើព្រះករុណាបានធ្វើការនេះដោយមិនបានប្រាប់ដល់យើងជាអ្នកបម្រើរបស់ព្រះអង្គឬ តើនរណាគួរអង្គុយលើបល្ល័ង្កតពីព្រះអង្គ»?
[28]បន្ទាប់មក ព្រះបាទដាវីឌមានរាជឱង្ការថា៖ «សូមហៅព្រះនាងបាតសេបាឲ្យត្រឡប់មកជួបយើងវិញ»។ ព្រះនាងក៏បានចូលមកគាល់ស្តេច
ហើយបានឈរនៅមុខស្តេចផង។[29]ស្តេចបានស្បថដោយមានរាជឱង្ការថា៖ «ព្រះអម្ចាស់មានព្រះជន្មរស់
គឺព្រះអង្គបានរំដោះយើងចេញពីបញ្ហា[30]ដូចដែលយើងបានសន្យាជាមួយព្រះនាងដោយនូវព្រះនាមព្រះអម្ចាស់ ជាព្រះរបស់ជនជាតិអ៊ីស្រាអែលថា៖
«សាឡូម៉ូនជាបុត្ររបស់ព្រះនាងនឹងសោយរាជ្យបន្តពីយើង ហើយបុត្រនេះនឹងគង់លើបល្ល័ងរបស់យើង យើងនឹងធ្វើនៅថ្ងៃនេះ»។[31]បន្ទាប់មក
ព្រះនាងបាតសេបាក៏បានឱនមុខដល់ដីនៅចំពោះមុខស្តេចហើយទូលថា៖ «សូមឲ្យស្តេចដ៏ជាចៅហ្វាយមានព្រះជន្មគង់នៅរៀងរហូត»!
[32]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «សូមហៅលោកបូជាចារ្យសាដុក លោកព្យាការីណាថាន និងលោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដាមកជួបយើង»។
ដូច្នេះពួកគេក៏មកគាល់ស្តេច។[33]ស្តេចមានបន្ទូលទៅពួកគេថា៖ «សូមប្រមូលអ្នកបម្រើរបស់ចៅហ្វាយអ្នកទៅជាមួយអ្នករាល់គ្នា ហើយឲ្យសាឡូម៉ូនជិះលើសារបស់យើង
ហើយដង្ហែទៅប្រភពទឹកគីហូន។[34]សូមឲ្យលោកបូជាចារ្យសាដុក លោកព្យាការីណាថានចាក់ប្រេងតាំងតែសាឡូម៉ូនជាស្តេចលើសាសន៍អ៊ីស្រាអែល ហើយផ្លុំត្រែ
និងប្រកាសថា៖ «សូមឲ្យស្តេចសាឡូម៉ូនមានព្រះជន្មយឺនយូរ»!
[35]បន្ទាប់មក អ្នកត្រូវដើរតាមក្រោយបុត្រនោះ ហើយបុត្រនោះនឹងគង់លើបល្ល័ង្ករបស់យើង ហើយបុត្រនោះនឹងក្លាយជាស្តេចជំនួសយើង។
យើងបានតែងតាំងបុត្រនោះឲ្យគ្រប់គ្រងលើអ៊ីស្រាអែល និងយូដាទាំងមូល»។[36]លោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដាបានទូលទៅស្តេចវិញថា៖
«ចូរឲ្យការនេះបានសម្រេចចុះ! សូមឲ្យព្រះអម្ចាស់ ជាព្រះរបស់ស្តេចដ៏ជាចៅហ្វាយបានឲ្យការនេះកើតឡើង។[37]សូមឲ្យព្រះអម្ចាស់គង់នៅជាមួយស្តេចសាឡូម៉ូន
ដូចព្រះអង្គបានគង់ជាមួយព្រះករុណាដែរ និងធ្វើឲ្យបល្ល័ង្ករបស់សាឡូម៉ូនប្រសើរជាងបល្ល័ង្ករបស់ព្រះករុណាទៅទៀត»។
[38]ដូច្នេះ លោកបូជាចារ្យសាដុក ព្យាការីណាថាន និងលោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដា ព្រមទាំងពួកកេរេធីម និងពួកពេលេធីមចេញទៅ
ហើយឲ្យស្តេចសាឡូម៉ូនគង់លើសារបស់ស្តេចដាវីឌ ពួកគេបាននាំសម្តេចទៅប្រភពទឹកគីហូន។
[39]លោកបូជាចារ្យសាដុកបានយកស្នែងដែលមានពេញដោយប្រេងចេញពីជំរំ ហើយចាក់ប្រេងអភិសេកលើស្តេចសាឡូម៉ូន។[40]បន្ទាប់មក គេក៏បានផ្លុំត្រែ
ហើយមនុស្សទាំងអស់ស្រែកឡើងថា៖ «សូមស្តេចមានព្រះជន្មយឺនយូ»! បន្ទាប់មក មនុស្សជាច្រើនដើរតាមក្រោយស្តេច ហើយមានអ្នកផ្លុំខ្លុយ
ហើយពួកគេមានអំណរដ៏ពោរពេញ ធ្វើឲ្យផែនដីញាប់ញ័រដោយសារសម្លេងរបស់ពួកគេ។
[41]សម្តេចអដូនីយ៉ា និងភ្ញៀវដែលនៅជាមួយសម្តេចបានឮរឿងនេះក្រោយពីពួកគេបានបញ្ចប់ការជប់លៀង។ នៅពេលដែលលោកយូអាប់បានឮសម្លេងត្រែ
លោកនិយាយថា៖ «ហេតុអ្វីបានជាមានសម្លេងអឺងកងនៅក្នុងក្រុងដូច្នេះ»?[42]នៅពេលដែលលោកកំពុងនិយាយនៅឡើយ លោកយ៉ូណាថាន ជាកូនរបស់លោក
អបៀថើរបានចូលមក។ សម្តេចអដូនីយ៉ានិយាយថា៖ «សូមអញ្ជើញមក បើអ្នកជាមនុស្សអង់អាច និងនាំដំណឹងល្អមកមែន»។
[43]លោកយ៉ូណាថានបានឆ្លើយទៅសម្តេចអដូនីយ៉ាថា៖
«ស្តេចដាវីឌជាចៅហ្វាយរបស់យើងបានលើកសាឡូម៉ូនជាស្តេចហើយ[44]ហើយស្តេចបានបញ្ជូនបូជាចារ្យសាដុកទៅជាមួយលោកព្យាការីណាថាន និងលោកបេណាយ៉ាជា
កូនរបស់លោកយេហូយ៉ាដា ព្រមទាំងពួកកេរេធីម និងពេលេធីម។ ពួកគេបានឲ្យសម្តេចសាឡូម៉ូនជិះលារបស់ស្តេចដាវីឌ។[45]លោកបូជាចារ្យសាដុក និងព្យាការីណាថាន
បានចាក់ប្រេងអភិសេកសម្តេចសាឡូម៉ូនជាស្តេចនៅប្រភពទឹកស៊ីហុន ហើយបានចេញពីទីនោះមកវិញដោយអំណរ ដូច្នេះហើយ បានជាក្រុងទាំងមូលឮសម្លេងអឺងកង។
នេះជាសម្លេងដែលសម្តេចបានឮ។
[46]សម្តេចសាឡូម៉ូនក៏បានគង់លើបល្ល័ង្ករាជ្យដែរ។[47]លើសពីនេះទៅទៀត អ្នកបម្រើរបស់ស្តេចបានមកឲ្យពរដល់ស្តេចដាវីឌ ដោយនិយាយថា៖
«សូមឲ្យព្រះរបស់ស្តេចបានធ្វើឲ្យព្រះនាមរបស់សាឡូម៉ូនប្រសើរជាងនាមរបស់ព្រះអង្គ និងឲ្យបល្ល័ង្ករបស់បុត្រនេះប្រសើរជាងបល្ល័ង្ករបស់ព្រះអង្គដែរ។
បន្ទាប់មកស្តេចក៏បានថ្វាយបង្គំដល់គ្រែ។[48]ស្តេចក៏បានទូលថា៖ «សូមឲ្យព្រះអម្ចាស់បានពរ គឺព្រះរបស់ជនជាតិអ៊ីស្រាអែល
ដែលបានឲ្យមនុស្សបានគង់លើបល្ល័ង្ករបស់ទូលបង្គំនៅថ្ងៃនេះ ហើយឲ្យភ្នែករបស់ទូលបង្គំផ្ទាល់បានឃើញការនេះ»។
[49]បន្ទាប់មក ភ្ញៀវទាំងអស់របស់សម្តេចអដូនីយ៉ាក៏មានភាពភ័យខ្លាច។ ពួកគេបានក្រោកឡើង ហើយម្នាក់ៗទៅតាមផ្លូវរបស់គេរៀងៗខ្លួន។
[50]សម្តេចអដូនីយ៉ាភ័យខ្លាចសម្តេចសាឡូម៉ូន ហើយបានក្រោកឡើង រួចចេញទៅ និងបានតោងស្នែងរបស់អាសនាជាប់។[51]បន្ទាប់មក មានគេមកប្រាប់សម្តេចសាឡូម៉ូនថា៖
«ឃើញទេ សម្តេចអដូនីយ៉ាបានភ័យខ្លាចសម្តេចសាឡូម៉ូនយ៉ាងខ្លាំង គឺគាត់បានតោងស្នែងរបស់អាសនា ហើយមានរាជឱង្ការថា៖
«ចូរឲ្យស្តេចសាឡូម៉ូនស្បថនឹងទូលបង្គំសិនមកថា ព្រះអង្គនឹងមិនធ្វើគត់អ្នកបម្រើរបស់ទ្រង់នឹងដាវឡើយ»។
[52]ព្រះបាទសាឡូម៉ូនបានទូលថា៖ «បើសម្តេចបង្ហាញថា ទ្រង់ជាមនុស្សសក្តិសមនឹងគោរពមែន នោះគ្មានសក់មួយសរសៃរបស់ទ្រង់ណានឹងត្រូវជ្រុះទៅដីឡើយ ប៉ុន្តែ
បើរកឃើញថាទ្រង់បានប្រព្រឹត្តអំពើអាក្រក់វិញ នោះទ្រង់ត្រូវសុគត»។[53]ដូច្នេះ ព្រះបាទសាឡូម៉ូនបានចាត់គេទៅនាំសម្តេចអដូនីយ៉ាចុះពីអាសនាមក។ សម្តេចបានមក
ហើយថ្វាយបង្គំព្រះបាទសាឡូម៉ូន រួចស្តេចមានរាជឱង្ការទៅគាត់ថា៖ «ទៅដំណាក់របស់ទ្រង់ទៅ»។

generated on Wed Sep 10 16:16:32 2025

1 Kings 1:1
បានដណ្តប់ភួយឲ្យទ្រង់
ពួកគេដណ្តប់ភួយជាច្រើនលើស្តេចដាវីឌ ផ្តល់ភាពកក់ក្តៅដល់ព្រះអង្គ។
1 Kings 1:3
ដូច្នេះ គេបានរក
«ដូច្នេះពួកអ្នកបម្រើរបស់ស្តេចបានស្វែងរក»
នៅក្នុងទឹកដីអ៊ីស្រាអែល
នេះជាការធ្វើឲ្យមានលក្ខណៈទូទៅ។ ការបកប្រែផ្សេងទៀត
«ពាសពេញទឹកដីអ៊ីស្រាអែល»
នាងអប៊ីសាក
នេះជាឈ្មោះស្ត្រីម្នាក់។
អ្នកភូមិស៊ូណែម
មនុស្សមកពីទីក្រុងស៊ូណែម
ស្តេច
«ស្តេចដាវីឌ»
1 Kings 1:5
សម្តេចអដូនីយ៉ាជាកូនរបស់នាងហាគីត
ហាគីតជាប្រពន្ធរបស់ដាវីឌ។
បានលើកខ្លួនឡើង
«ចាប់ផ្តើមអួត»
អ្នកជិះសេះ
ទាំងនេះជាបុរសដែលបររទេះសេះ។
អ្នករត់ពីមុខគាត់ហាសិបនាក់
បុរសទាំងនេះនឹងចេញទៅមុខរទេះសេះ ដើម្បីឈូសឆាយផ្លូវសម្រាប់ពួកគេ និង ការពារពួកគេ។
មិនដែលបន្ទោសគាត់
មិនដែលសួរគាត់ ឬ ក៏មិនដែលចង់ធ្វើឲ្យគាត់ខឹងដូច្នេះគាត់ក៏មិនដែលសួរអ្វីដែរ។
«ហេតុអ្វីបានជាកូនធ្វើនេះ ឬធ្វើនោះឡើយ»?
នេះជាសំណួរវោហាសាស្ត្រដែលឪពុកនឹងសុំឲ្យដាក់វិន័យកូនប្រុសរបស់គាត់។
«អ្នកគួរតែដឹងថាអ្វីដែលអ្នកបានធ្វើគឺខុស»។
កើតបន្ទាប់ពីសម្តេចអាប់សាឡុម
ដាវីឌជាព្រះបិតារបស់អាប់សាឡុម និង អដូនីយ៉ាប៉ុន្តែ ពួកទ្រង់មានម្តាយផ្សេងគ្នា។ អាប់សាឡុមបានកើតមកមុនបន្ទាប់មកអាដូនីយ៉ា។
1 Kings 1:7
សម្តេចបានពិភាក្សាជាមួយលោកយ៉ូអាប់
«អដូនីយ៉ាពិភាក្សាអំពីផែនការរបស់គាត់ជាមួយយ៉ូអាប់»
លោកយ៉ូអាប់..លោកសេរូយ៉ា..លោកបូជាចារ្យ
អបៀថើរ..សម្តេចអដូនីយ៉ា..លោកបូជាចារ្យសាដុក..លោកបេណាយ៉ា..លោកយេហូយ៉ាដា..ព្យាការីណាថាន...លោកស៊ីម៉ៃ..លោករេអ៊ី
ទាំងនេះជាឈ្មោះមនុស្សប្រុស។
តាមសម្តេចអដូនីយ៉ា ហើយបានជួយគាត់
«បានគាំទ្រនិងជួយសម្តេចអដូនីយ៉ា» ឬ «សន្យាថានឹងគាំទ្រនិងជួយសម្តេចអដូនីយ៉ា»
1 Kings 1:9
កូនគោបំប៉ន
«កូនគោដែលត្រូវបានផ្តល់អាហារឲ្យបានច្រើន ដើម្បីឲ្យពួកវាធំធាត់» ឬ «គោវ័យក្មេងដែលត្រូវបានរៀបចំយ៉ាងពិសេសសម្រាប់ការបូជា»
នៅថ្មសូហេលែត
នេះជាតំបន់ថ្មនៅជិតក្រុងយេរូសាឡឹម។
នៅក្រោយអេនរ៉ូកែល
នេះជាឈ្មោះប្រភពទឹក ដែលមនុស្សទទួលបានទឹកពីទីនោះ។
ព្រះរាមគឺបុត្រាទាំងអស់របស់ស្តេច និងបានអញ្ជើញអ្នកបម្រើរបស់ស្តេចទាំងអស់
នេះជាការធ្វើឲ្យមានលក្ខណៈទូទៅ។
បងប្អូនរបស់គាត់ទាំងអស់គឺជាបុត្រារបស់ស្តេច
ឃ្លាទាំងពីរនេះសំដៅទៅលើមនុស្សតែមួយ។
អ្នកបម្រើរបស់ស្តេចទាំងអស់នៅស្រុកយូដាទាំងមូលផង
ឃ្លាទាំងពីរនេះសំដៅទៅលើមនុស្សតែមួយ។
1 Kings 1:11
តើព្រះនាងមិនបានឮ...រឿងនេះទេឬអី?
គោលបំណងនៃសំណួរនេះគឺដើម្បីណែនាំព័ត៌មានដែលលោកណាថានចង់ប្រាប់ព្រះនាងបាតសេបា។
«អ្នកហាក់ដូចជាមិនបានឮទេ ... ។ ឬ «តើអ្នកឮទេ?»
ថាសម្តេចអដូនីយ៉ាជាប្រុសរបស់ព្រះនាងហាគីតបានក្លាយជាស្តេច
«កូនប្រុសរបស់ព្រះនាង ហាគីតគឺសម្តេចអដូនីយ៉ាកំពុងតែព្យាយាមឡើងសោយរាជ្យ»
ព្រះនាងហាគីត
ម្តាយរបស់សម្តេចអដូនីយ៉ានិងមហេសីរបស់ស្តេចដាវីឌ។
1 Kings 1:13
ព័ត៌មានទូទៅ
ព្យាការីណាថានបន្តនិយាយទៅកាន់នាងបាតសេបា។
តើព្រះអង្គមិនបានស្បថនឹងអ្នកបម្រើរបស់ព្រះអង្គទេថា...បល្ល័ង្កយើងទេឬអី?
គោលបំណងនៃសំណួរនេះគឺ ដើម្បីរំលឹកស្តេចដាវីឌអំពីអ្វីដែលទ្រង់បានសន្យាជាមួយបាតសេបា។
«អ្នកបានស្បថនឹងបាវបម្រើរបស់អ្នក ... បល្ល័ង្ក។»
អ្នកបម្រើរបស់ព្រះអង្គ
នាងបាតសេបានិយាយជាមួយស្តេចដាវីឌ ហាក់ដូចជានាងជាមនុស្សម្នាក់ផ្សេងទៀត ដែលបង្ហាញថានាងគោរពស្តេចដាវីឌ។
«ចំពោះខ្ញុំអ្នកបម្រើរបស់អ្នក»
ហើយបុត្រនេះនឹងគង់លើបល្ល័ងយើង
ការអង្គុយនៅលើបល្ល័ង្កគឺជាពាក្យមួយមានន័យថា ធ្វើជាស្តេច។
«គាត់នឹងក្លាយជាស្តេចដូចខ្ញុំដែរ»
តើហេតុអ្វីបានជាសម្តេចអដូនីយ៉ាឡើងសោយរាជ្យទៅវិញ?
នាងបាតសេបាត្រូវប្រើសំណួរមួយដើម្បីឲ្យស្តេចដាវីឌយកចិត្តទុកដាក់។
«ដូច្នេះសម្តេចអដូនីយ៉ាមិនគួរសោយរាជ្យទេ»។
ទូលពាក្យនេះឡើងម្តងទៀត
«ប្រាប់គាត់ថាអ្វីដែលអ្នកបាននិយាយគឺជាការពិត»
1 Kings 1:15
ដំណាក់របស់ស្តេច
«បន្ទប់ដែលស្តេចផ្ទំ»
ព្រះនាងអប៊ីសាក ជាអ្នកភូមិស៊ូណែម
នេះជាស្ត្រីក្រមុំព្រហ្មចារីដែលអ្នកបម្រើរបស់ស្តេចដាវីឌបាននាំយកមកមើលថែទាំទ្រង់។ បកប្រែដូចក្នុង ១: ៣។
បានក្រាប និងថ្វាយបង្គំនៅមុខស្តេច
«អោនទៅជិតដល់ដីនៅចំពោះមុខស្តេច»
«តើនាងចង់បានអ្វី?»
«តើយើងអាចធ្វើអ្វីសម្រាប់អ្នក?»
ព្រះអង្គបានស្បថនឹង
ទម្រង់បែបបទនៃ «ព្រះអង្គ» នៅទីនេះគឺការយល់ចិត្ត។ «ព្រះអង្គខ្លួនឯងបានស្បថ»
អ្នកបម្រើរបស់ព្រះអង្គ
នាងបាតសេបានិយាយដូចជា នាងជាមនុស្សម្នាក់ផ្សេងទៀតដើម្បីបង្ហាញស្តេចដាវីឌថានាងគោរពទ្រង់។ បកប្រែដូចនៅក្នុង ១:១៣។ «ខ្ញុំជាអ្នកបម្រើរបស់ទ្រង់»
ព្រះអម្ចាស់
នេះជាព្រះនាមរបស់ព្រះជាម្ចាស់ ដែលទ្រង់បានបង្ហាញដល់ប្រជាជនរបស់ទ្រង់ នៅក្នុងគម្ពីរសញ្ញាចាស់។ សូមមើលការបកប្រែទំព័រពាក្យអំពី ព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។
បុត្រនោះនឹងគង់លើបល្ល័ង្កយើង
ការអង្គុយនៅលើបល្ល័ង្កគឺមានន័យថា ធ្វើជាស្តេច។ បកប្រែដូចនៅក្នុង ១:១៣។
«ទ្រង់នឹងក្លាយជាស្តេចដូចខ្ញុំដែរ»
1 Kings 1:18
ព័ត៌មានទូទៅ
នាងបាតសេបាបន្តទូលស្តេចដាវីឌ។
មើលចុះ
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក»
គោឈ្មោល កូនគោបំប៉ន និងចៀមយ៉ាងច្រើន
«គោ កូនគោបំប៉ន និងចៀមជាច្រើន»
1 Kings 1:20
ព័ត៌មានទូទៅ
នាងបាតសេបាបន្តទូលទៅកាន់ស្តេចដាវីឌ។

generated on Wed Sep 10 16:16:32 2025

ភ្នែករបស់ប្រជាជនអ៊ីស្រាអែលគឺសម្លឹងមកលើព្រះអង្គ
នៅទីនេះ «ភ្នែក» សំដៅទៅលើប្រជាជន។ នេះជាការធ្វើឲ្យមានលក្ខណៈទូទៅ។
«ប្រជាជនអ៊ីស្រាអែលទាំងអស់កំពុងតាមមើលទ្រង់»
នឹងត្រូវគង់លើបល្ល័ង្ក
ការអង្គុយនៅលើបល្ល័ង្កគឺមានន័យថា ការធ្វើជាស្តេច។
ពាក្យស្រដៀងគ្នាលេចឡើងក្នុង ១:១៣។ «នឹងក្លាយជាស្តេច»
នៅពេលដែលស្តេចសោយទីរង្គតជាមួយបិតារបស់ស្តេច
ការអង្គុយនៅលើបល្ល័ង្កគឺមានន័យថា ធ្វើជាស្តេច។ ពាក្យស្រដៀងគ្នាលេចឡើងក្នុង ១:១៣។ «នឹងក្លាយជាស្តេច»
សោយទីរង្គតជាមួយបិតារបស់ស្តេច
នេះជាវិធីគួរសមក្នុងការនិយាយថា «ស្លាប់»។
នាងខ្ញុំ និងកូនរបស់នាងខ្ញុំសាឡូម៉ូនជាឧក្រិដ្ឋជនមិនខាន
អាចបកប្រែជាទម្រង់កិរិយាស័ព្ទសកម្ម។
«ស្តេចថ្មីនឹងចាត់ទុកបុត្រាសាឡូម៉ូននិងខ្ញុំជាឧក្រិដ្ឋជន»
1 Kings 1:22
ព័ត៌មានទូទៅ
ណាថានជាព្យាការីទូលទៅកាន់ស្តេចដាវីឌ។
លោកបានគោរពស្តេច
«ឱនយ៉ាងទាប»
1 Kings 1:24
ព័ត៌មានទូទៅ
ព្យាការីណាថានបន្តនិយាយទៅកាន់ស្តេចដាវីឌ។
តើព្រះអង្គធ្លាប់មានបន្ទូលថា៖ «សម្តេចអដូនីយ៉ានឹងគ្រងរាជតពីយើង
ហើយសម្តេចអដូនីយ៉ានឹងគង់លើបល្ល័ង្កយើងដែរឬទេ»?
អាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោលថា។ «តើព្រះអង្គបាននិយាយថា
សម្តេចអដូនីយ៉ានឹងសោយរាជ្យបន្ទាប់ពីទ្រង់ហើយគាត់នឹងអង្គុយលើបល្ល័ង្ករបស់ទ្រង់?»
សម្តេចអដូនីយ៉ានឹងគង់លើបល្ល័ង្កយើង
ការអង្គុយនៅលើបល្ល័ង្កគឺមានន័យថា កាធ្វើជាស្តេច។ បកប្រែដូចនៅក្នុង ១:១៣។
«គាត់នឹងក្លាយជាស្តេចដូចខ្ញុំដែរ»
បរិភោគ និងផឹកស្រាស្រឹងនៅចំពោះមុខសម្តេច
សម្តេចអដូនីយ៉ាប្រហែលជាអង្គុយនៅតុ
ដែលទ្រង់អាចមើលអស់អ្នកដែលបានអញ្ជើញ ពេលពួកគេបរិភោគនិងផឹក។
គំនិតចម្បងគឺប្រជាជនដែលព្យាការីណាថានដាក់ឈ្មោះនៅជាមួយសម្តេចអដូនីយ៉ា
ហើយពួកគេកំពុងប្រារព្ធពិធីជាមួយគ្នា។ «បរិភោគនិងផឹកស្រាជាមួយគាត់» ឬ
«បរិភោគនិងផឹកស្រានៅកន្លែងដែលទ្រង់អាចមើលឃើញ»
1 Kings 1:26
ព័ត៌មានទូទៅ
ព្យាការីណាថានបន្តនិយាយទៅកាន់ស្តេចដាវីឌ។
តើព្រះករុណាបានធ្វើការនេះដោយមិនបានប្រាប់ដល់យើងជាអ្នកបម្រើរបស់ព្រះអង្គឬ
តើនរណាគួរអង្គុយលើបល្ល័ង្កតពីព្រះអង្គ»?
លោកណាថានសំដៅទៅលើស្តេចដាវីឌជាបុរសទីបី។
នេះជាវិធីបង្ហាញការគោរពចំពោះព្រះរាជា។ វាអាចត្រូវបានបញ្ជាក់នៅក្នុងបុរសទី ២
។ «តើព្រះករុណាបានធ្វើរឿងនេះដោយមិនប្រាប់ពួកខ្ញុំជាអ្នកបម្រើរបស់ទ្រង់
ដែលគួរអង្គុយលើបល្ល័ង្កបន្ទាប់ពីទ្រង់ទេ?»
តើនរណាគួរអង្គុយលើបល្ល័ង្កត
ការអង្គុយនៅលើបល្ល័ង្កគឺមានន័យថា កាធ្វើជាស្តេច។
ពាក្យស្រដៀងគ្នាលេចឡើងក្នុង ១:១៣។ «តើអ្នកណានឹងក្លាយជាស្តេចបន្តពីទ្រង់»
1 Kings 1:28
ព័ត៌មានទូទៅ
ស្តេចដាវីឌបានសន្យាជាមួយព្រះនាងបាតសេបា។
គាល់ស្តេច ហើយបានឈរនៅមុខស្តេច
«បានចូលគាល់ព្រះរាជា» ឬ «បានត្រឡប់មករកស្តេចវិញ»
បានស្បថ
«បានធ្វើការសន្យាដ៏ឧឡារិក»
បុត្រនេះនឹងគង់លើបល្ល័ង្ករបស់យើង
ការអង្គុយនៅលើបល្ល័ង្កគឺមានន័យថា ការធ្វើជាស្តេច។
ពាក្យស្រដៀងគ្នាលេចឡើងក្នុង ១:១៣។
«ទ្រង់នឹងជំនួសកន្លែងរបស់ខ្ញុំហើយធ្វើជាស្តេចដូចខ្ញុំដែរ»
សូមឲ្យស្តេចដ៏ជាចៅហ្វាយមានព្រះជន្មគង់នៅរៀងរហូត
ព្រះនាងបាតសេបាដឹងថាស្តេចដាវីឌនឹងមិនរស់ជារៀងរហូតទេ។
នេះជាវិធីនិយាយថាគាត់ជាស្តេចល្អ។
1 Kings 1:32
ព័ត៌មានទូទៅ
ស្តេចដាវីឌបានតែងតាំងស្តេចសាឡូម៉ូន។
អ្នកបម្រើរបស់ចៅហ្វាយអ្នក
ស្តេចដាវីឌនិយាយអំពីខ្លួនទ្រង់ថា ដូចជាទ្រង់កំពុងនិយាយអំពីអ្នកផ្សេងដូច្នេះ
សាដុក ណាថាន និងបេណាយ៉ា ចាំថាស្តេចដាវីឌនៅតែជាស្តេចដដែល។
«អ្នកបម្រើរបស់ខ្ញុំ»
គីហុន
នេះជាឈ្មោះប្រភពទឹក។
1 Kings 1:35
ព័ត៌មានទូទៅ
ស្តេចដាវីឌបន្តនិយាយជំនួសសាឡូម៉ូនជាអ្នកដែលនឹងឡើងសោយរាជ្យ។
បុត្រនោះនឹងគង់លើបល្ល័ង្ករបស់យើង
ពាក្យថា «អង្គុយលើបល្ល័ង្ក» ត្រូវបានប្រើជាការប្រៀបធៀបសម្រាប់ធ្វើជាស្តេចក្នុង
១:១៣, ១, ១៥ និង ១:២៨ ។ នៅទីនេះស្តេចដាវីឌនិយាយអំពីសាឡូម៉ូន
ដោយអង្គុយនៅលើបល្ល័ង្កខាងរាងកាយ។
ចូរឲ្យការនេះបានសម្រេចចុះ!
ពួកគេយល់ព្រមហើយនឹងធ្វើតាមអ្វីដែលស្តេចដាវីឌបានមានបន្ទូល។
សូមឲ្យព្រះអម្ចាស់ ជាព្រះរបស់ស្តេចដ៏ជាចៅហ្វាយបានឲ្យការនេះកើតឡើង
លោកបេណាយ៉ានិយាយទៅកាន់ស្តេចដាវីឌហាក់ដូចជាគាត់កំពុងតែនិយាយជាមួយនរណាម្នាក់ផ្សេងទៀ
ដើម្បីបង្ហាញថាគាត់គោរពស្តេចដាវីឌ។
«ម្ចាស់និងជាស្តេចរបស់ខ្ញុំសូមអោយព្រះអម្ចាស់ជាព្រះរបស់ទ្រង់បញ្ជាក់»
នៅជាមួយស្តេចសាឡូម៉ូន ដូចព្រះអង្គបានគង់ជាមួយព្រះករុណាដែរ
លោកបេណាយ៉ានិយាយទៅកាន់ស្តេចដាវីឌហាក់ដូចជាគាត់កំពុងតែនិយាយជាមួយនរណាម្នាក់ផ្សេងទៀ
«បាននៅជាមួយទ្រង់ជាម្ចាស់របស់ខ្ញុំ»
ធ្វើឲ្យបល្ល័ង្ករបស់សាឡូម៉ូនប្រសើរជាងបល្ល័ង្ករបស់ព្រះករុណាទៅទៀត
ពាក្យ «បល្ល័ង្ក» គឺជាពាក្យប្រៀបធៀប ១) អ្នកដែលអង្គុយលើបល្ល័ង្ក។ «
ធ្វើឲ្យអ្នកដែលអង្គុយនៅលើបល្ល័ង្កធំជាងស្តេចដាវីឌ» ឬ ២) «
ធ្វើឲ្យអាណាចក្ររបស់ទ្រង់ធំជាងអាណាចក្ររបស់ស្តេចដាវីឌ»
បល្ល័ង្ករបស់ព្រះករុណា
លោកបេណាយ៉ានិយាយទៅកាន់ស្តេចដាវីឌហាក់ដូចជាគាត់កំពុងនិយាយជាមួយមនុស្សម្នាក់ផ្សេងទៀត
ដើម្បីបង្ហាញថាគាត់គោរពស្តេចដាវីឌ។ «បល្ល័ង្ករបស់ព្រះករុណា
គឺព្រះបាទដាវីឌជាម្ចាស់របស់ទូលបង្គំ»
1 Kings 1:38
ព័ត៌មានទូទៅ
ប្រជាជនអ៊ីស្រាអែលបានចាក់ប្រេងអភិសេកសាឡូម៉ូនជាស្តេចស្រុកអ៊ីស្រាអែល។
កេរេធីម និងពួកពេលេធីម
ទាំងនេះជាឈ្មោះមនុស្ស
ប្រភពទឹកគីហុន
នេះគឺជាឈ្មោះប្រភពទឹក ដែលទឹកសាបចេញពីដី។
បានយកស្នែងដែលមានពេញដោយប្រេងចេញពីជំរុំ
នេះមានន័យថា បូជាចារ្យយកស្នែងសត្វពិសេសដែលមានពេញដោយប្រេងអូលីវ
ដែលដាក់នៅក្នុងត្រសាលពិសេសរបស់ព្រះអម្ចាស់។
បានយកស្នែងដែលមានពេញដោយប្រេង
អាចមានន័យថា ១) ស្នែងរបស់សត្វពោរពេញទៅដោយប្រេងអូលីវ ឬ ២)
ធុងមួយដែលបានជំនួសស្នែងដើម ប៉ុន្តែប្រជាជននៅតែហៅវាថាជាស្នែង។
«បានយកប្រេងមួយធុង»
គេ
នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅ។
1 Kings 1:41
ព័ត៌មានទូទៅ
សម្តេចអដូនីយ៉ាឮសំលេងខ្លាំងៗ ហើយរង់ចាំដំណឹងនេះ។
1 Kings 1:43
ព័ត៌មានទូទៅ
សម្តេចអាដូនីយ៉ាដឹងថាសាឡូម៉ូនជាស្តេចថ្មី។
ពួកកេរេធីម និងពេលេធីម
ទាំងនេះគឺជាឈ្មោះក្រុមមនុស្ស។

generated on Wed Sep 10 16:16:32 2025

1 Kings 1:46
ព័ត៌មានទូទៅ៖
យ៉ូណាថានបន្តនិយាយប្រាប់សម្តេចអដូនីយ៉ាអំពីសាឡូម៉ូន។
គង់លើបល្ល័ង្ករាជ្យដែរ
អាចមានន័យថា ១)
ដែលពាក្យទាំងនេះជាពាក្យប្រៀបធៀបសម្រាប់ការធ្វើជាស្តេច។
«ឥឡូវនេះជាស្តេច» ឬ ២)
ដែលព្រះបាទសាឡូម៉ូនកំពុងអង្គុយលើបល្ល័ង្កខាងរូបកាយ។
ពាក្យស្រដៀងគ្នាលេចឡើងក្នុង១:៣៥ ។
មនុស្សបានគង់លើបល្ល័ង្ករបស់ទូលបង្គំនៅថ្ងៃនេះ
អាចមានន័យថា ១)
ដែលពាក្យទាំងនេះជាពាក្យប្រៀបធៀបសម្រាប់ការធ្វើជាស្តេច។
«មនុស្សម្នាក់ដែលត្រូវឡើងសោយរាជ្យនៅថ្ងៃនេះដូចខ្ញុំដែរ» ឬ ២)
ដែលសាឡូម៉ូនអង្គុយលើបល្ល័ង្កខាងរូបកាយ។
ពាក្យស្រដៀងគ្នាលេចឡើងក្នុង១:៣៥ ។
1 Kings 1:49
ព័ត៌មានទូទៅ
សម្តេចអដូនីយ៉ាមានការភ័យខ្លាចចំពោះស្តេចសាឡូម៉ូន។
ពួកគេបានក្រោកឡើង
អាចមានន័យថា «ពួកគេបានចាប់ផ្តើមធ្វើសកម្មភាពយ៉ាងឆាប់រហ័ស»
សម្តេចអដូនី...បានតោងស្នែងរបស់អាសនាជាប់
« ស្នែងនៃអាសនៈ» ជានិមិត្តរូបនៃកម្លាំងនិងការការពាររបស់ព្រះអម្ចាស់
ប៉ុន្តែដោយសារសម្តេចអដូនីយ៉ាចូលទៅក្នុងតង់នៃរូបកាយដើម្បីចាប់ស្នែង
អ្នកគួរតែបកប្រែត្រង់នេះ។
សម្តេចអដូនី..បានក្រោកឡើង រួចចេញទៅ
អាចមានន័យថា «សម្តេចអដូនីយ៉ា...បានទៅយ៉ាងលឿន»
ភ័យខ្លាចសម្តេចសាឡូម៉ូន
ពួកអ្នកបំរើនិយាយទៅកាន់ស្តេចសាឡូម៉ូនដូចជា
ពួកគេកំពុងនិយាយពីនរណាម្នាក់ផ្សេងទៀតដើម្បីបង្ហាញថាពួកគេគោរពស្តេចសាឡូម៉ូន។
«ស្តេចសាឡូម៉ូនខ្លាចអ្នក»
ព្រះអង្គនឹងមិនធ្វើគត់អ្នកបម្រើរបស់ទ្រង់
សម្តេចអដូនីយ៉ានិយាយអំពីខ្លួនគាត់ដូចជា គាត់កំពុងនិយាយពីមនុស្សម្នាក់ទៀត
ដូច្នេះមនុស្សនឹងគិតថាគាត់គោរពស្តេចសាឡូម៉ូន។ «គាត់នឹងមិនសម្លាប់ខ្ញុំទេ»
1 Kings 1:52
ព័ត៌មានទូទៅ
សាឡូម៉ូនទុកជីវិតឲ្យសម្តេចអដូនីយ៉ា។
គ្មានសក់មួយសរសៃរបស់ទ្រង់ណានឹងត្រូវជ្រុះទៅដីឡើយ
នេះជាការនិយាយការបំផ្លើសដែលថា
សាឡូម៉ូននឹងរក្សាសម្តេចអដូនីយ៉ាឲ្យមានសុវត្ថិភាព។
«មិនមានសក់ក្បាលរបស់ទ្រង់នឹងធ្លាក់ចុះនោះឡើយ» ឬ
«យើងនឹងថែរក្សាទ្រង់ឲ្យមានសុវត្ថិភាព»
ឃើញថាទ្រង់បានប្រព្រឹត្តអំពើអាក្រក់វិញ
នាមអរូបី «អំពើអាក្រក់» អាចត្រូវបានបកប្រែជាកិរិយាស័ព្ទ។
វាត្រូវបានគេនិយាយថា វាជាវត្ថុដែលអាចត្រូវបានរកឃើញនៅក្នុងធុងមួយ។
នេះអាចបកប្រែជាទម្រង់កិរិយាស័ព្ទសកម្ម។ «ទ្រង់ធ្វើអំពើអាក្រក់»

---

2 [1]នៅថ្ងៃដែលស្តេចដាវីឌបានសោយទិវង្គតជិតមកដល់ ស្តេចបានបញ្ជាដល់ព្រះបាទសាឡូម៉ូនជាបុត្រារបស់ព្រះអង្គថា៖[2]«បិតានឹងចាកចេញពីផែនដីនេះទៅ។
ចូរមានកម្លាំង ហើយត្រូវបង្ហាញថាខ្លួនបុត្រជាមនុស្សប្រុស។[3]ត្រូវរក្សាបទបញ្ជារបស់ព្រះអម្ចាស់ជាព្រះរបស់បុត្រ ដើរតាមផ្លូវរបស់ព្រះអង្គ ហើយកាន់តាមច្បាប់ តាមបញ្ជា តាមវិន័យ និងការសម្រេចព្រះទ័យ និងសម្ពន្ធមេត្រីរបស់ព្រះអង្គ ចូរប្រុងប្រយ័ត្នក្នុងការប្រព្រឹត្តតាមអ្វីដែលមាននៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ដូច្នេះ
បុត្រនឹងចម្រុងចម្រើនក្នុងគ្រប់កិច្ចការដែលបុត្រធ្វើ និងគ្រប់ទាំងផ្លូវដែលបុត្រទៅ[4]ដូច្នេះ
ព្រះអម្ចាស់នឹងបំពេញព្រះបន្ទូលរបស់ព្រះអង្គដែលព្រះអង្គមានបន្ទូលជាមួយនឹងបិតាថា៖ «បើបុត្រអ្នកប្រុងប្រយ័ត្ននឹងផ្លូវដែលគេដើរ គឺដើរតាមយើងដោយស្មោះត្រង់
ដោយអស់ពីចិត្ត និងពីព្រលឹងរបស់ពួកគេ នោះពូជពង្សរបស់អ្នកនឹងបានសោយរាជ្យលើបល្ល័ង្កនៅស្រុកអ៊ីស្រាអែលរហូតតទៅ។
[5]បុត្រក៏បានដឹងនូវអំពើដែលលោកយ៉ូអាប់ ជាកូនរបស់លោកសេរូយ៉ា បានប្រព្រឹត្តចំពោះបិតា និងអ្វីដែលគាត់បានប្រព្រឹត្តចំពោះមេទ័ពពីរនាក់របស់អ៊ីស្រាអែលដែរ
គឺចំពោះលោកអប៊ីនើរ ជាកូនរបស់លោកនើរ និងលោកអម៉ាសា ជាកូនរបស់លោកយេធើរ គឺគាត់បានសម្លាប់អ្នកទាំងពីរ។
គាត់បានបង្ហូរឈាមនៃសង្គ្រាមនៅពេលមានសន្តិភាព ហើយបានដាក់ឈាមនៃសង្គ្រាមនៅលើខ្សែក្រវាត់ជុំវិញចង្កេះរបស់គាត់ និងដាក់លើស្បែកជើង
ដែលនៅនឹងជើងរបស់គាត់។[6]សូមប្រព្រឹត្តជាមួយលោកយ៉ូអាប់ដោយប្រាជ្ញាដែលបុត្របានរៀន តែកុំបណ្តោយឲ្យគាត់ចូលទៅក្នុងផ្នូរដោយសុខសាន្តឡើយ។
[7]ទោះជាយ៉ាងណាក៏ដោយ សូមសម្តែងសេចក្តីមេត្តាដល់កូនប្រុសៗរបស់លោកបាស៊ីឡៃ ជាអ្នកស្រុកកាឡាដ ហើយសូមឲ្យពួកគេបរិភោគរួមតុជាមួយជាមួយបុត្រផង
ព្រោះពួកគេបានមកជួយបិតានៅពេលដែលបិតារត់គេចពីអាប់សាឡុមជាព្រះរាមរបស់បុត្រ។
[8]មើល លោកស៊ីម៉ែ ជាកូនរបស់លោកកេរ៉ា ជាអ្នកភូមិបាហ៊ូរីម ក្នុងទឹកដីបេនយ៉ាមីននៅក្នុងចំណោមបុត្រ គេជាអ្នកដាក់បណ្តាសាបិតាដោយកម្រោល
គឺបានដាក់បណ្តាសាបិតានៅពេលបិតាភៀសខ្លួនទៅដល់ម៉ាហាណែម។ លោកស៊ីម៉ែបានមកជួបបិតានៅទន្លេយ័រដាន់
ហើយបិតាបានស្បថដោយនូវព្រះនាមព្រះអម្ចាស់ថា៖ «យើងនឹងសម្លាប់អ្នកដោយដាវ»។[9]ឥឡូវនេះ កុំបណ្តោយឲ្យគាត់រួចខ្លួនពីការដាក់ទោសឡើយ។
បុត្រជាមនុស្សមានប្រាជ្ញា ហើយបុត្រប្រាកដជាដឹងថាត្រូវប្រព្រឹត្តជាមួយពួកគេយ៉ាងដូចម្តេច។ បុត្រនឹងឲ្យសក់ប្រផះរបស់គាត់ធ្លាក់ចុះទៅក្នុងផ្នូរជាមួយឈាមមិនខាន»។
[10]បន្ទាប់មក ដាវីឌក៏បានផ្ទំលក់ជាមួយបុព្វបុរសរបស់ទ្រង់ ហើយសពរបស់ស្តេចគេកប់នៅក្នុងក្រុងរបស់ស្តេចដាវីឌ។
[11]ស្តេចដាវីឌគ្រងរាជលើទឹកដីអ៊ីស្រាអែលបានសែសិបឆ្នាំ។ ទ្រង់បានសោយរាជ្យនៅហេប្រូនបានប្រាំពីរឆ្នាំ និងសាបសិបបីឆ្នាំនៅក្រុងយេរូសាឡឹម។
[12]បន្ទាប់មកស្តេចសាឡូម៉ូនក៏បានគង់លើបល្ល័ង្ករបស់ដាវីឌជាបិតាទ្រង់ ហើយការគ្រប់គ្រងរបស់ទ្រង់គឺរឹងមាំខ្លាំងណាស់។
[13]បន្ទាប់មក សម្តេចអដូនីយ៉ា ជាបុត្ររបស់ព្រះនាងហាគីត បានចូលមកគាល់នាងបាតសេបា ជាមាតារបស់ព្រះបាទសាឡូម៉ូន។ ព្រះនាងនិយាយថា៖
«តើអ្នកមកដោយសន្តិភាពឬ»? សម្តេចបានទូលថា៖ «ទូលបង្គំមកដោយសន្តិភាពទេ»។[14]បន្ទាប់មក សម្តេចបានទូលថា៖ «ទូលបង្គំមានរឿងមួយចង់ទូលដល់ព្រះនាង»។
ព្រះនាងបាតសេបាក៏មានប្រាប់ថា៖ «ចូរនិយាយមកចុះ»។[15]សម្តេចអដូនីយ៉ាក៏បានទូលថា៖ «ព្រះនាងជ្រាបហើយថា រាជាណាចក្រនេះធ្លាប់ជារបស់ទូលបង្គំ
ហើយជនជាតិអ៊ីស្រាអែលទាំងអស់រំពឹងថាខ្ញុំនឹងក្លាយជាស្តេច។ ប៉ុន្តែអ្វីៗបានផ្លាស់ប្តូរ អំណាចបានប្រគល់ដល់ព្រះរាមរបស់ទូលបង្គំ ដោយសារការនេះមកពីព្រះអម្ចាស់។
[16]ឥឡូវនេះ ទូលបង្គំមានសំណើរមួយពីអ្នក ហើយសូមកុំងាកឆ្ងាយពីមុខទូលបង្គំឡើយ»។ ព្រះនាងបាតសេបាប្រាប់ទៅសម្តេចថា៖ «ចូរមានរាជឱង្ការមកចុះ»។
[17]សម្តេចបានទូលថា៖ «សូមជួយទូលព្រះបាទសាឡូម៉ូនថា សូមកុំឲ្យស្តេចងាកចេញពីព្រះភក្ត្ររបស់ព្រះនាងឡើយឡើយ ដូច្នេះ ស្តេចនឹងឲ្យព្រះនាងអប៊ីសាក ជាអ្នកភូមិ
ស៊ូណែម ឲ្យមកធ្វើជាមហេសីរបស់ទូលបង្គំ»។[18]ព្រះនាងបាតសេបាឆ្លើយថា៖ «ល្អណាស់មាតានឹងទៅទូលស្តេច»។
[19]ដូច្នេះ នាងបាតសេបាបានទៅគាល់ព្រះបាទសាឡូម៉ូន ទៅទូលស្តេចជំនួសសម្តេចអដូនីយ៉ា។ ស្តេចក៏មកជួបមាតា និងថ្វាយបង្គំមាតា។ បន្ទាប់មក ស្តេចក៏គង់លើបល្ល័ង្ក
ហើយក៏មានបល្ល័ង្កមួយទៀតសម្រាប់មាតា។ ព្រះនាងក៏គង់នៅខាងស្តាំស្តេច។[20]បន្ទាប់មក ព្រះនាងក៏ទូលស្តេចថា៖ «មាតាចង់សុំស្នើរឿងតូចមួយ សូមកុំបែរពីព្រះភក្ត្រ
ចេញពីមាតាឡើយ»។ ស្តេចក៏ឆ្លើយថា៖ «ទូលមកចុះមាតា ទូលបង្គំនឹងមិនបែរពីព្រះភក្ត្រមាតាឡើយ»។[21]ព្រះនាងទូលថា៖ «ចូរឲ្យនាងអប៊ីសាក ជាអ្នកភូមិស៊ូណែម ឲ្យ
មកធ្វើជាមហេសីរបស់សម្តេចអដូនីយ៉ាដាជាព្រះរាមរបស់បុត្រផងបានទេ»។
[22]ព្រះបាទសាឡូម៉ូនឆ្លើយ និងទូលទៅមាតាថា៖ «ហេតុអ្វីបានជាមាតាសុំឲ្យព្រះនាងអប៊ីសាក ជាអ្នកភូមិស៊ូណែម សម្រាប់សម្តេចអដូនីយ៉ាបែបនេះ?
ហេតុអ្វីបានជាមាតាមិនសុំនគរទាំងមូលឲ្យគាត់តែម្តងទៅ ដោយសារគាត់ជាព្រះរាមរបស់ទូលបង្គំស្រាប់ហើយ សម្រាប់ទ្រង់ ដ្បិត លោកបូជាចារ្យអបៀថើរ ព្រមទាំងលោក
មេទ័ពយ៉ូអាប់ ជាកូនអ្នកស្រីសេរូយ៉ាទៅ»?[23]បន្ទាប់មក ព្រះបាទសាឡូម៉ូនក៏បានស្បថដោយនូវព្រះនាមរបស់ព្រះអម្ចាស់ថា៖ «សូមឲ្យព្រះជាម្ចាស់ដាក់ទោសទូលបង្គំ
និងលើសនេះទៅទៀតចុះ ប្រសិនបើ សម្តេចអដូនីយ៉ាមិនបានប្រើពាក្យប្រឆាំងនឹងជីវិតរបស់ទ្រង់ផ្ទាល់។

generated on Wed Sep 10 16:16:32 2025

[24]ដូច្នេះ ក្នុងព្រះនាមព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ ដែលបានបង្កើតទូលបង្គំ និងបានលើកទូលបង្គំឲ្យសោយរាជ្យលើបល្ល័ង្ករបស់ស្តេចដាវីឌជាបិតារបស់ទូលបង្គំ
និងបានឲ្យទូលបង្គំសង់ដំណាក់មួយដូចដែលព្រះអង្គបានសន្យា ដូច្នេះ នៅថ្ងៃនេះ សម្តេចអដូនីយ៉ានឹងត្រូវតែស្លាប់»។[25]ដូច្នេះ ព្រះបាទសាឡូម៉ូនបានចាត់លោកបេណាយ៉ា
ជាកូនរបស់លោកយេហូយ៉ាដា ឲ្យទៅរកសម្តេចអដូនីយ៉ា ហើយបានធ្វើគត់ស្តេចទៅ។
[26]បន្ទាប់មក ស្តេចទូលទៅលោកបូជាចារ្យអបៀថើរថា៖ «ទៅអាណាថោត ជាចម្ការរបស់អ្នកវិញទៅ។ អ្នកគួរតែស្លាប់ ប៉ុន្តែ យើងមិនសម្លាប់អ្នកនៅពេលនេះទេ
ព្រោះអ្នកបានសែងហឹបរបស់ព្រះអម្ចាស់ជាព្រះនៅមុខដាវីឌជាបិតាយើង និងបានរងទុក្ខលំបាកគ្រប់យ៉ាងជាមួយបិតាយើង»។[27]ដូច្នេះ
ព្រះបាទសាឡូម៉ូនបានដកដំណែងជាបូជាចារ្យពីលោកអបៀថើរ ស្របតាមព្រះបន្ទូលដែលព្រះអម្ចាស់បានមានបន្ទូលទាក់ទងនឹងគ្រួសាររបស់លោកអេលីនៅស៊ីឡូ។
[28]បន្ទាប់មក លោកយ៉ូអាប់បានឮដំណឹងទាំងនេះ ព្រោះលោកយ៉ូអាប់ធ្លាប់គាំទ្រសម្តេចអដូនីយ៉ា ដូច្នេះ លោកមិនបានគាំទ្រសម្តេចអាប់សាឡុមទេ។ ដូច្នេះ
លោកយ៉ូអាប់បានគេចខ្លួនចូលទៅក្នុងជំរំរបស់ព្រះអម្ចាស់ ហើយបានតោងស្នែងអាសនាជាប់។
[29]គេបានមកប្រាប់ព្រះបាទសាឡូម៉ូនថាយ៉ូអាប់បានគេចខ្លួនចូលទៅក្នុងជំរំរបស់ព្រះអម្ចាស់ ហើយបានតោងស្នែងអាសនា។ បន្ទាប់មក ព្រះបាទសាឡូម៉ូនចាត់លោកលោក
បេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដា ដោយទូលថា៖ «ចូរទៅសម្លាប់គាត់ទៅ»។
[30]លោកបេណាយ៉ាបានមកជំរំរបស់ព្រះអម្ចាស់ ហើយបាននិយាយជាមួយលោកយ៉ូអាប់ថា៖ «ស្តេចបញ្ជាឲ្យអ្នកចេញមក»។ លោកយ៉ូអាប់បានឆ្លើយថា៖ «ទេ
ខ្ញុំសុខចិត្តស្លាប់នៅទីនេះ»។ ដូច្នេះលោកបេណាយ៉ាត្រឡប់ទៅកាន់ស្តេចរួចទូលថា៖ «លោកយ៉ូអាប់ប្រាប់ថាគាត់ចង់ស្លាប់នៅលើអាសនា»។[31]បន្ទាប់មក
ស្តេចប្រាប់គាត់ថា៖ «ចូរធ្វើតាមអ្វីដែលគាត់បាននិយាយចុះ។ ចូរសម្លាប់ ហើយដុតគាត់ចោលទៅ ធ្វើដូច្នេះដើម្បីដកឈាមចេញពីយើង និងពីគ្រួសារបិតាយើង
ដែលលោកយូអាប់បានធ្វើដោយបង្ហូរឈាមគេដោយគ្មានហេតុផល។
[32]សូមឲ្យព្រះអម្ចាស់ឲ្យឈាមរបស់គាត់បានទៅលើក្បាលរបស់គាត់ ដោយសារតែគាត់បានវាយប្រហារមនុស្សសុចរិតពីរនាក់ ដែលប្រសើរជាងគាត់
ហើយគាត់បានសម្លាប់ពួកគេដោយដាវ គឺសម្លាប់លោកអប៊ីនើរ ជាកូនរបស់លោកនើរ ជាមេទ័ពអ៊ីស្រាអែល និងលោកអម៉ាសា ជាកូនរបស់លោកយេធើរជាមេទ័ពយូដា
ដោយមិនឲ្យស្តេចដាវីឌជាបិតារបស់យើងដឹងរឿងនេះ។[33]ដូច្នេះ សូមឲ្យឈាមរបស់ពួកគេត្រឡប់ទៅលើក្បាលរបស់លោកយ៉ូអាប់
និងទៅលើកូនចៅរបស់គាត់ជារៀងរហូត។ ប៉ុន្តែ សូមព្រះអម្ចាស់ប្រោសប្រទានស្តេចដាវីឌ កូនចៅ និងគ្រួសារ និងរាជ្យបល្ល័ង្ករបស់ទ្រង់ បានប្រកបដោយសេចក្តីសុខសាន្ត
រហូតតទៅសម្រាប់ព្រះអម្ចាស់»។
[34]ដូច្នេះ លោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដាបានឡើងទៅ និងសម្លាប់លោកយ៉ូអាប់ទៅ។ លោកបានកប់គាត់នៅក្នុងផ្ទះរបស់គាត់ផ្ទាល់នៅឯវាលរហោស្ថាន។
[35]ស្តេចបានឲ្យលោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដាគ្រប់គ្រងលើទាហានជំនួសលោកយ៉ូអាប់ និងឲ្យលោកសាដុកធ្វើជាបូជាចារ្យជំនួសអបៀថើរ។
[36]បន្ទាប់មក ស្តេចក៏បានហៅលោកស៊ីម៉ែ ហើយបានទូលទៅគាត់ថា៖ «សូមសង់ផ្ទះមួយនៅក្រុងយេរូសាឡឹម ដើម្បីរស់នៅទីនេះ ហើយកុំទៅកន្លែងណាផ្សេងទៀតឡើយ។
[37]នៅថ្ងៃណាដែលអ្នកចេញទៅកន្លែងផ្សេង ហើយឆ្លងជ្រោះកេដ្រុន អ្នកប្រាកដជាស្លាប់មិនខាន។ ឈាមរបស់អ្នកនឹងនៅលើក្បាលរបស់អ្នកផ្ទាល់។[38]ដូច្នេះ
លោកស៊ីម៉ែក៏បានទូលស្តេចថា៖ «អ្វីដែលព្រះអង្គមានបន្ទូលល្អណាស់។ ដូចអ្វីដែលចៅហ្វាយរបស់ទូលបង្គំធ្លាប់មានបន្ទូលដែរ ដូច្នេះ អ្នកបម្រើរបស់ព្រះអង្គនឹងធ្វើតាម»។
ដូច្នេះលោកស៊ីម៉ែក៏ស្នាក់នៅក្រុងយេរូសាឡឹមអស់ជាច្រើនថ្ងៃ។
[39]ប៉ុន្តែ នៅចុងឆ្នាំទីបី អ្នកបម្រើរបស់លោកពីរនាក់បានរត់ទៅជ្រកកោណជាមួយស្តេចអគីស ជាបុត្ររបស់ស្តេចម៉ាកា នៅក្រុងកាថ។ ដូច្នេះ មានគេប្រាប់ស៊ីម៉ែថា៖
«យើងឃើញអ្នកបម្រើរបស់អ្នកនៅក្រុងកាថ»។[40]បន្ទាប់មក លោកស៊ីម៉ែក៏ឡើងជិះលើលារបស់លោក ហើយចេញដំណើរទៅគាល់ស្តេចអគីសនៅក្រុងកាថ
ដើម្បីរកអ្នកបម្រើរបស់លោក។ គាត់បានទៅ ហើយនាំអ្នកបម្រើរបស់លោកពីក្រុងកាថមកវិញ។
[41]នៅពេលដែលមានគេប្រាប់ព្រះបាទសាឡូម៉ូនថាលោកស៊ីម៉ែបានចេញពីក្រុងយេរូសាឡឹមទៅក្រុងកាថ ហើយបានត្រឡប់មកវិញ[42]ស្តេចបានឲ្យគេទៅហៅលោកស៊ីម៉ែមក
រួចប្រាប់គាត់ថា៖ «តើយើងមិនបានឲ្យអ្នកស្បថចំពោះព្រះនាមរបស់ព្រះអម្ចាស់ និងឲ្យអ្នកបញ្ជាក់ដោខ្លួនឯងទេថា៖ «ត្រូវដឹងច្បាស់ថានៅថ្ងៃណាដែលអ្នកចេញក្រៅ
ទៅកន្លែងផ្សេងទៀត អ្នកនឹងត្រូវស្លាប់មិនខានទេឬ»? បន្ទាប់មក អ្នកនិយាយនឹងយើងថា៖ «អ្វីដែលព្រះអង្គមានបន្ទូលល្អណាស់»។
[43]ហេតុអ្វីបានជាអ្នកមិនរក្សាសេចក្តីសម្បថរបស់អ្នកចំពោះព្រះអម្ចាស់ និងមិនគោរពបទបញ្ជារដែលយើងដាក់ឲ្យអ្នកដូច្នេះ»?[44]ស្តេចក៏បានទូលទៅលោកស៊ីម៉ែដែរថា៖
«អ្នកដឹងនៅក្នុងចិត្តរបស់អ្នកស្រាប់ពីការអាក្រក់ដែលអ្នកបានប្រព្រឹត្តចំពោះព្រះបាទដាវីឌជាបិតាយើង។
ដូច្នេះព្រះអម្ចាស់នឹងឲ្យការអាក្រក់នេះត្រឡប់មកលើក្បាលរបស់អ្នកវិញ។
[45]ប៉ុន្តែ ព្រះបាទសាឡូម៉ូននឹងបានទទួលពរ ហើយបល្ល័ង្ករបស់ស្តេចដាវីឌនឹងនៅស្ថិតស្ថេរចំពោះព្រះអម្ចាស់ជារៀងរហូត»។[46]បន្ទាប់មក ស្តេចក៏ចេញបញ្ជាឲ្យលោក
បេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដា។ លោកក៏ចេញក្រៅ រួចសម្លាប់លោកស៊ីម៉ែទៅ។ ដូច្នេះ ព្រះបាទសាឡូម៉ូនបានកាន់អំណាចក្នុងដៃយ៉ាងរឹងមាំ។

---

1 Kings 2:1
បិតានឹងចាកចេញពីផែនដីនេះទៅ
នេះជាវិធីគួរសមក្នុងការនិយាយថា «ខ្ញុំនឹងត្រូវស្លាប់» ។
ត្រូវបង្ហាញថាខ្លួនបុត្រជាមនុស្សប្រុស
បង្ហាញអ្នកទាំងអស់គ្នាថា អ្នកជាបុរសម្នាក់
ឬរស់ដើម្បីឲ្យមនុស្សគ្រប់គ្នាអាចមើលឃើញថា អ្នកជាមនុស្សល្អម្នាក់
ដើរតាមផ្លូវរបស់ព្រះអង្គ
ការដើរលើផ្លូវគឺ ជាពាក្យប្រៀបធៀបពីរបៀបដែលមនុស្សរស់នៅ។
«រស់នៅតាមរបៀបដែលទ្រង់បញ្ជា»
ចម្រុងចម្រើន
«ជោគជ័យ» ឬ «ធ្វើបានល្អ»
បំពេញព្រះបន្ទូលរបស់ព្រះអង្គ
«ធ្វើអ្វីគ្រប់យ៉ាងដែលទ្រង់បានសន្យាថាទ្រង់នឹងធ្វើ»
បើបុត្រអ្នក...នោះពូជពង្សរបស់អ្នកនឹងបានសោយរាជ្យ
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលជាមួយស្តេចដាវីឌដូច្នេះពាក្យថា «អ្នក» និង
«របស់អ្នក» គឺសំដៅទៅលើស្តេចដាវីឌ។
ដើរតាមយើងដោយស្មោះត្រង់
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលជាមួយស្តេចដាវីឌដូច្នេះពាក្យថា «ខ្ញុំ»
សំដៅទៅលើព្រះអម្ចាស់។
ដោយអស់ពីចិត្ត និងពីព្រលឹងរបស់ពួកគេ
«ដោយអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង «ដោយអស់ពីព្រលឹង»
មានន័យថា «ទាំងអស់ ... ជា» ។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
«ជាមួយនឹងការទាំងអស់» ឬ «ដោយថាមពលទាំងអស់របស់ពួកគេ»
នោះពូជពង្សរបស់អ្នកនឹងបានសោយរាជ្យលើបល្ល័ង្កនៅស្រុកអ៊ីស្រាអែលរហូតតទៅ
ពាក្យថាបល្ល័ង្កគឺជា ពាក្យប្រៀបធៀបសម្រាប់ស្តេចដែលអង្គុយលើបល្ល័ង្ក។
«កូនចៅរបស់អ្នកនឹងមិនដែលឈប់ធ្វើជាស្តេចអ៊ីស្រាអែលទេ» បល្ល័ង្ក
«មិនដែលឈប់មាន» អាចត្រូវបានបញ្ជាក់ជាវិជ្ជមាន។
«កូនចៅម្នាក់របស់អ្នកនឹងក្លាយជាស្តេចអ៊ីស្រាអែលជានិច្ច» ។
1 Kings 2:5
ព័ត៌មានទូទៅ
ស្តេចដាវីឌបន្តប្រាប់សាឡូម៉ូនពីរបៀបដឹកនាំអ៊ីស្រាអែល។
អំពើដែលលោកយ៉ូអាប់...បានប្រព្រឹត្តចំពោះបិតា...អ្វីដែលគាត់បានប្រព្រឹត្ត
ស្តេចដាវីឌកំពុងនិយាយអំពីរឿងដដែលនេះពីរដង។ «អ្វីដែលយ៉ូអាប់ ...
បានធ្វើចំពោះបិតា - នោះគឺជាអ្វីដែលគាត់បានធ្វើ»
គាត់បានបង្ហូរឈាមនៃសង្គ្រាម
អាចមានន័យថា ១)« បានសម្លាប់មនុស្សទាំងនោះក្នុងអំឡុងពេលសន្តិភាពដូចជា
គាត់បានសម្លាប់ពួកគេក្នុងសង្គ្រាម» ឬ ២)
«បានសងសឹកមនុស្សទាំងនោះក្នុងអំឡុងពេលសន្តិភាព
ពីព្រោះពួកគេបានសម្លាប់មនុស្សក្នុងសង្គ្រាម»
បានដាក់ឈាមនៃសង្គ្រាមនៅលើខ្សែក្រវាត់ជុំវិញចង្កេះរបស់គាត់ នឹងដាក់លើស្បែកជើង
ដែលនៅនឹងជើងរបស់គាត់
អាចមានន័យថា ១)

generated on Wed Sep 10 16:16:32 2025

យ៉ូអាប់ជិតស្និទ្ធនឹងមនុស្សទាំងនេះនៅពេលដែលគាត់សម្លាប់ពួកគេ
ឈាមរបស់ពួកគេខ្ចាត់ខ្ចាយលើខ្សែក្រវ៉ាត់និងស្បែកជើងរបស់គាត់ឬ ២) ពាក្យ
«ឈាម» គឺជាពាក្យប្រៀបធៀបសម្រាប់ពិរុទ្ធភាពនៃឃាតកម្ម
ខ្សែក្រវ៉ាត់និងស្បែកជើង។ ជាពាក្យសម្តីតំណាងអំណាចរបស់យ៉ូអាប់ជាមេបញ្ជាការ
ដូច្នេះស្តេចដាវីឌកំពុងតែនិយាយថា ដោយសារយ៉ូអាប់មានពិរុទ្ធពីបទឃាតកម្ម
គាត់មិនគួរធ្វើជាមេបញ្ជាការកងទ័ពទេ។
វិធីណាមួយវាជាការល្អបំផុតក្នុងការបកប្រែនេះតាមព្យញ្ជនៈ។
កុំបណ្តោយឲ្យគាត់ចូលទៅក្នុងផ្នូរដោយសុខសាន្តឡើយ
«ធ្វើឲ្យប្រាកដថាយ៉ូអាប់ស្លាប់ដោយអំពើហឹង្សាមុនពេលគាត់ចាស់»។
1 Kings 2:7
ព័ត៌មានទូទៅ
ស្តេចដាវីឌបន្តប្រាប់សាឡូម៉ូនពីរបៀបដឹកនាំអ៊ីស្រាអែល។
លោកបាស៊ីឡៃ
ឈ្មោះរបស់បុរសម្នាក់
សូមឲ្យពួកគេបរិភោគរួមតុជាមួយបុត្រផង
តុគឺជាពាក្យប្រៀបធៀបផ្ទះដែលមានតុនៅខាងក្នុង។ «
ស្វាគមន៍ពួកគេមកបរិភោគអាហារនៅផ្ទះរបស់អ្នក»
1 Kings 2:8
ព័ត៌មានទូទៅ
ស្តេចដាវីឌបន្តប្រាប់សាឡូម៉ូនពីរបៀបដឹកនាំអ៊ីស្រាអែល។
លោកស៊ីម៉ៃ...លោកកេរ៉ា
ឈ្មោះបុរស
ទឹកដីបេនយ៉ាមីន
កូនចៅបេនយ៉ាមីន
បាហ៊ូរីម..ម៉ាហាណែម
ឈ្មោះទីកន្លែង
កុំបណ្តោយឲ្យគាត់រួចខ្លួនពីការដាក់ទោសឡើយ
នេះអាចត្រូវបានបង្ហាញជាវិជ្ជមាន។ «ត្រូវប្រាកដថាដាក់ទណ្ឌកម្មគាត់»
ឲ្យសក់ប្រផះរបស់គាត់ធ្លាក់ចុះទៅក្នុងផ្នូរជាមួយឈាមមិនខាន
ឈាមគឺសំដៅទៅលើការស្លាប់ដោយអំពើហិង្សាហើយក្បាលគឺសំដៅទៅលើមនុស្សទាំងមូល
«ធ្វើឲ្យប្រាកដថាគាត់បានស្លាប់ដោយអំពើហិង្សា»
1 Kings 2:10
ព័ត៌មានទូទៅ
ស្តេចដាវីឌបានសុគតហើយសាឡូម៉ូនបានឡើងសួងរាជ្យជាស្តេចថ្មីរបស់អ៊ីស្រាអែល។
បានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
ស្តេចដាវីឌសុគត ត្រូវបានគេនិយាយដូចជាព្រះអង្គបានផ្ទុំលក់។ «បានស្លាប់»
ស្តេចដាវីឌ...ហើយសពរបស់ស្តេចគេកប់នៅ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «ដាវីឌ ...
ហើយពួកគេបានបញ្ចុះសពទ្រង់»
ស្តេចដាវីឌគ្រងរាជលើទឹកដីអ៊ីស្រាអែលបាន
«ពេលវេលាដែលដាវីឌសោយរាជ្យលើអ៊ីស្រាអែលគឺ» ឬ
«ដាវីឌសោយរាជ្យលើអ៊ីស្រាអែលសម្រាប់»
គង់លើបល្ល័ង្ករបស់ដាវីឌជាបិតាទ្រង់
បល្ល័ង្កតំណាងសិទ្ធិអំណាចស្តេច «ការបកប្រែផ្សេងទៀត»
«បានឡើងសោយរាជ្យដូចជាបុព្វបុរសរបស់ព្រះអង្គ»
ការគ្រប់គ្រង់របស់ទ្រង់គឺរឹងមាំខ្លាំងណាស់
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ព្រះអម្ចាស់បានបង្កើតការគ្រប់គ្រងស្តេចសាឡូម៉ូនយ៉ាងរឹងមាំ» ឬ «
ព្រះអម្ចាស់បានធ្វើអោយស្តេចសាឡូម៉ូនគ្រប់គ្រងនគរបានទាំងស្រុង»
1 Kings 2:13
ព័ត៌មានទូទៅ
សម្តេចអដូនីយ៉ាមកនិយាយជាមួយបាតសេបា
ដោយសន្តិភាព
«ដោយគ្មានបំណងបង្កឲ្យមានគ្រោះថ្នាក់»
ជនជាតិអ៊ីស្រាអែលទាំងអស់
នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅ។
អ្វីៗបានផ្លាស់ប្តូរ
«អ្វីដែលយើងរំពឹងថានឹងកើតឡើងមិនបានកើតឡើងទេ»
អំណាចបានប្រគល់ដល់ព្រះរាមរបស់ទូលបង្គំ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ព្រះអម្ចាស់បានប្រគល់នគរដល់បងប្អូនខ្ញុំ» ឬ
«ប្អូនប្រុសរបស់ខ្ញុំបានឡើងសោយរាជ្យ»
1 Kings 2:16
ព័ត៌មានទូទៅ
សម្តេចអដូនីយ៉ាចែករំលែកសំណូមពររបស់គាត់ជាមួយបាតសេបា។
សូមកុំងាកឆ្ងាយពីមុខទូលបង្គំឡើយ...សូមកុំឲ្យស្តេចងាកចេញពីព្រះភក្ត្ររបស់ព្រះនាងឡើយឡើយ
ងាកចេញពីមុខរបស់នរណាម្នាក់គឺ
សំដៅទៅលើការបដិសេធមិនឲ្យមើលនរណាម្នាក់
ដែលជាការប្រៀបធៀបចំពោះការបដិសេធមិនធ្វើអ្វីដែលមនុស្សនោះស្នើសុំឲ្យធ្វើ។
«កុំបដិសេធធ្វើអ្វីដែលខ្ញុំស្នើសុំ ...
គាត់នឹងមិនបដិសេធធ្វើអ្វីដែលអ្នកស្នើសុំនោះទេ»
ព្រះនាងអប៊ីសាក ជាអ្នកភូមិស៊ូណែម
(សូមមើល ១: ៣)
1 Kings 2:19
ព័ត៌មានទូទៅ
បាតសេបាទៅទូលព្រះបាទសាឡូម៉ូនតាមសំណូមពររបស់សម្តេចអដូនីយ៉ា។
ស្តេចក៏មកជួប
«ស្តេចបានក្រោកឈរ» ពីកន្លែងដែលទ្រង់កំពុងអង្គុយនៅលើបល្ល័ង្ករបស់ទ្រង់។
ក៏មានបល្ល័ង្កមួយទៀត
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«បានប្រាប់នរណាម្នាក់ឲ្យយកបល្ល័ង្កមួយមក»
សម្រាប់មាតា
បាតសេបា
សូមកុំបែរពីព្រះភក្ត្រ ចេញពីមាតាឡើយ...ទូលមកចុះមាតា ទូលបង្គំនឹងមិនបែរពីព្រះភក្ត្រមាតាឡើយ
ងាកចេញពីមុខរបស់នរណាម្នាក់គឺ
សំដៅទៅលើការបដិសេធមិនឲ្យមើលនរណាម្នាក់
គឺសម្រាប់បដិសេធមិនធ្វើអ្វីដែលមនុស្សនោះស្នើសុំ។
«អ្នកនឹងមិនបដិសេធនូវអ្វីដែលខ្ញុំស្នើសុំទេ ...
ខ្ញុំនឹងមិនបដិសេធនូវអ្វីដែលអ្នកស្នើសុំទេ» ពាក្យស្រដៀងគ្នានេះមាននៅក្នុង
២:១៦ ។
ចូរឲ្យនាងអប៊ីសាក ជាអ្នកភូមិស៊ូណែមឲ្យមកធ្វើជាមហេសី
របស់សម្តេចអដូនីយ៉ាដាជាព្រះរាមរបស់បុត្រផងបានទេ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ « អនុញ្ញាតឲ្យសម្តេចអដូនីយ៉ា ...
រៀបការជាមួយអប៊ីសាកជាជនជាតិស៊ូណែម» ឬ «
ប្រគល់អប៊ីសាសជាជនជាតិស៊ូណែមទៅសម្តេចអដូនីយ៉ា...ជាប្រពន្ធរបស់គាត់»
1 Kings 2:22
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនផ្តល់ចម្លើយចំពោះសំណូមពររបស់សម្តេចអដូនីយ៉ា។
ហេតុអ្វីបានជាមាតាសុំឲ្យព្រះនាង អប៊ីសាក ជាអ្នកភូមិស៊ូណែម សម្រាប់សម្តេចអដូនីយ៉ាបែបនេះ?
ហេតុអ្វីបានជាមាតាមិនសុំនគរទាំងមូលឲ្យគាត់តែម្តងទៅ
ដោយសារគាត់ជាព្រះរៀមរបស់ទូលបង្គំស្រាប់ហើយ សម្រាប់ទ្រង់ ដ្បិត លោកបូជាចារ្យអបៀថើរ
ព្រមទាំងលោកមេទ័ពយ៉ូអាប់ ជាកូនអ្នកស្រីសេរូយ៉ា
ស្តេចសាឡូម៉ូនខឹងនឹងសំណូមពររបស់ម្តាយគាត់។ «មាតាសួរខុសហើយ ...
អដូនីយ៉ា! នេះគឺដូចគ្នានឹងការស្នើសុំនគរឲ្យគាត់ដែរ ... សេរូយ៉ា!»
សូមឲ្យព្រះជាម្ចាស់ដាក់ទោសទូលបង្គំ និងលើសនេះទៅទៀតចុះ ប្រសិនបើ
សម្តេចអដូនីយ៉ាមិនបានប្រើពាក្យប្រឆាំងនឹងជីវិតរបស់ទ្រង់ផ្ទាល់
«ព្រះជាម្ចាស់មានសិទ្ធិប្រហារជីវិតទូលបង្គំនិងធ្វើអ្វីៗដែលអាក្រក់ជាងនេះទៀតចំពោះទូលបង្គំ
ប្រសិនបើទូលបង្គំមិនប្រតិបត្តិចំពោះសម្តេចអដូនីយ៉ា ព្រោះគាត់បានស្នើសុំ»
1 Kings 2:24
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនកាត់ទោសសម្តេចអដូនីយ៉ា។
បានលើកទូលបង្គំឲ្យសោយរាជ្យលើបល្ល័ង្ក
ពាក្យថាបល្ល័ង្កសំដៅទៅលើសិទ្ធិអំណាចរបស់ស្តេចសាឡូម៉ូន
ក្នុងការគ្រប់គ្រងដែលព្រះអម្ចាស់បានប្រទានឲ្យ។
បានឲ្យទូលបង្គំសង់ដំណាក់មួយ
នៅទីនេះ «ដំណាក់»
សំដៅទៅលើកូនចៅដែលព្រះអម្ចាស់បានប្រទានដល់ព្រះបាទសាឡូម៉ូន
ដែលនឹងគ្រងរាជ្យបន្តពីព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

1 Kings 2:26
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនបានបណ្តេញ លោកអបៀថើរ ចេញពីការធ្វើជាបូជាចារ្យ។
បានរងទុក្ខលំបាកគ្រប់យ៉ាងជាមួយបិតាយើង
លោកអប៊ីហារបានរងទុក្ខ ជាមួយស្តេចដាវីឌមុនពេលស្តេចដាវីឌឡើងសោយរាជ្យ។
ពីលោកអបៀថើរ ស្របតាម
ពាក្យថា« ព្រះអង្គ» សំដៅទៅលើស្តេចសាឡូម៉ូន។
ដែលព្រះអម្ចាស់បានមានបន្ទូល
ពាក្យថា «គាត់» សំដៅទៅលើព្រះអម្ចាស់។
1 Kings 2:28
ព័ត៌មានទូទៅ
ព្រះបាទសាឡូម៉ូនបញ្ជា ឲ្យលោកបេណាយ៉ាសម្លាប់លោកយ៉ូអាប់។
លោកយ៉ូអាប់បានឮដំណឹងទាំងនេះ
លោកយ៉ូអាប់ឮគេនិយាយអំពីអ្វីដែលព្រះបាទសាឡូម៉ូនបានធ្វើក្រោយពីទ្រង់បានឡើងសោយរាជ្យ
បានតោងស្នែងអាសនាជាប់
ស្នែងរបស់អាសនៈតំណាងអោយអំណាច និង ការការពាររបស់ព្រះអម្ចាស់។
គេបានមកប្រាប់ព្រះបាទសាឡូម៉ូនថាយ៉ូអាប់បានគេចខ្លួន
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«មានគេប្រាប់ស្តេចសាឡូម៉ូនថាលោកយ៉ូអាប់បានរត់គេចខ្លួន»
1 Kings 2:30
ព័ត៌មានទូទៅ
បេនណាយ៉ាទៅសម្លាប់យ៉ូអាប់។
ដុតគាត់ចោលទៅ ធ្វើដូច្នេះដើម្បីដកឈាមចេញពីយើង និងពីគ្រួសារបិតាយើង
ដែលលោកយ៉ូអាប់បានធ្វើដោយបង្ហូរឈាមគេដោយគ្មានហេតុផល
នៅទីនេះ «ផ្ទះ» តំណាងឲ្យកូនចៅរបស់ស្តេចដាវីឌខណៈពេលដែល «ឈាម»
តំណាងឲ្យកំហុស។ «កប់គាត់ហើយដូច្នេះសូមដកខ្ញុំនិងគ្រួសារខ្ញុំនូវទោសកំហុស
សម្រាប់ឃាតកម្មដែលយ៉ូអាប់បានធ្វើដោយគ្មានមូលហេតុ» ឬ «កប់គាត់។
ធ្វើដូច្នេះព្រះអម្ចាស់នឹងមិនដាក់ទោសខ្ញុំនិងផ្ទះឪពុកខ្ញុំទេព្រោះ
យ៉ូអាប់បានសម្លាប់មនុស្សដោយគ្មានហេតុផល»
1 Kings 2:32
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនពន្យល់ពីមូលហេតុដែលយ៉ូអាប់គួរស្លាប់។
សូមឲ្យព្រះអម្ចាស់ឲ្យឈាមរបស់គាត់បានទៅលើក្បាលរបស់គាត់
ពាក្យ «របស់គាត់» សំដៅទៅលើយ៉ូអាប់។ «ឈាម» គឺជាសំដៅលើឃាតកម្ម។
ហើយពាក្យ «ឈាមវិលនៅលើក្បាល»
មានន័យថាបុគ្គលនោះគួរតែត្រូវបានគេចាត់ទុកថាមានទោសចំពោះអំពើឃាតកម្ម។
«យ៉ូអាប់បានសម្លាប់មនុស្សហើយខ្ញុំចង់អោយព្រះអម្ចាស់ដាក់ទោសគាត់ចំពោះអ្វីដែលគាត់បានធ្វើ»
សុចរិតពីរនាក់ ដែលប្រសើរជាងគាត់
ពាក្យទាំងនេះមានន័យថា ជាមូលដ្ឋានដូចគ្នាហើយសង្កត់ធ្ងន់ថា
អប៊ីនើរនិងអម៉ាសាគឺជាបុរសប្រសើរជាងយ៉ូអាប់។
សូមឲ្យឈាមរបស់ពួកគេត្រឡប់ទៅលើក្បាលរបស់លោកយ៉ូអាប់
និងទៅលើកូនចៅរបស់គាត់ជារៀងរហូត
ពាក្យ «ឈាម» គឺជាពាក្យទាក់ទងទៅនឹងឃាតកម្ម។ ហើយពាក្យ
«ឈាមវិលនៅលើក្បាល»
មានន័យថាបុគ្គលនោះគួរតែគេចាត់ទុកថាមានទោសចំពោះអំពើឃាតកម្ម។
«ខ្ញុំចង់អោយព្រះអម្ចាស់ដាក់យ៉ូអាប់និងកូនចៅរបស់គាត់»
គ្រួសារ និងរាជ្យបល្ល័ង្ករបស់ទ្រង់
ពាក្យថា «ផ្ទះ» និង «បល្ល័ង្ក» គឺជាពាក្យប្រៀបធៀបសម្រាប់គ្រួសារ និង នគរ។
«ចំពោះកូនចៅរបស់ដាវីឌនិង នគររបស់ដាវីឌ»
1 Kings 2:34
ព័ត៌មានទូទៅ
បេណាយ៉ាសម្លាប់យ៉ូអាប់ហើយក្លាយជាមេបញ្ជាការកងទ័ពរបស់ស្តេចសាឡូម៉ូន។
លោកបានកប់គាត់នៅក្នុងផ្ទះរបស់គាត់ផ្ទាល់
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ពួកគេបានបញ្ចុះសពលោកយ៉ូអាប់នៅក្នុងផ្ទះរបស់គាត់»
នៅក្នុងផ្ទះរបស់គាត់ផ្ទាល់
ផ្ទះនេះសំដៅទៅដីដែលផ្ទះ។
ជនជាតិអ៊ីស្រាអែលបានបញ្ចុះសពមនុស្សនៅខាងក្រៅទ្វារនៅក្នុងផ្នូរ។
«កន្លែងដែលគ្រួសាររបស់គាត់រស់នៅ»
1 Kings 2:36
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនបានប្រាប់លោកស៊ីម៉ែឲ្យស្នាក់នៅក្រុងយេរូសាឡឹមឬលោកស៊ីមុែនឹងស្លាប់។
ឈាមរបស់អ្នកនឹងនៅលើក្បាលរបស់អ្នកផ្ទាល់
នៅទីនេះ «ឈាម»
តំណាងឲ្យទោសដែលនៅលើពិរុទ្ធភាពហើយក្បាលគឺសំដៅទៅលើមនុស្ស។
«អ្នកនឹងទទួលខុសត្រូវចំពោះការស្លាប់របស់អ្នក»
1 Kings 2:39
ព័ត៌មានទូទៅ
លោកស៊ីម៉ែចាកចេញពីក្រុងយេរូសាឡឹម។
ស្តេចអគីស..ស្តេចម៉ាកា..នៅក្រុងកាថ
ឈ្មោះបុរស
នៅក្រុងកាថ
ទីក្រុងភីលីស្ទីនមួយ
លោកស៊ីម៉ែក៏ឡើង
«ស៊ីម៉ែយ៉ាងឆាប់រហ័ស»
1 Kings 2:41
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនបានវិនិច្ឆ័យទោសស៊ីម៉ែដែលបានចាកចេញពីក្រុងយេរូសាឡឹម។
មានគេប្រាប់ព្រះបាទសាឡូម៉ូន
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «មានគេប្រាប់សាឡូម៉ូន»
តើយើងមិនបានឲ្យអ្នកស្បថចំពោះ...បញ្ជាក់ដោ..អ្នកនឹងត្រូវស្លាប់មិនខានទេឬ»?
សាឡូម៉ូនកំពុងតែរំលឹកលោកស៊ីម៉ែ អំពីអ្វីដែលលោកស៊ីម៉ែបានសន្យា។
«អ្នកដឹងច្បាស់ថាខ្ញុំបានធ្វើឲ្យអ្នកស្បថ ... ដោយនិយាយថា» ដឹង ... ស្លាប់ !
1 Kings 2:43
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនប្រកាសសាលក្រមលើស៊ីម៉ែដែលបានចាកចេញពីក្រុងយេរូសាឡឹម។
ហេតុអ្វីបានជាអ្នកមិនរក្សាសេចក្តីសម្បថរបស់អ្នក..ឲ្យអ្នកដូច្នេះ»?
គាត់មានកំហុស (មើលន័យផ្សេងទៀតថា ១) សាឡូម៉ូនកំពុងតែស្នើសុំចម្លើយឬ ២)
«អ្នកបានធ្វើខុសដោយការស្បថ ... អ្នក» ។
នឹងឲ្យការអាក្រក់នេះត្រឡប់មកលើក្បាលរបស់អ្នកវិញ
នៅទីនេះក្បាលគឺសំដៅទៅលើមនុស្សនិងអំពើអាក្រក់។
ត្រូវបានគេនិយាយដូចជាវត្ថុរាវដែលអាចដាក់លើក្បាលរបស់មនុស្ស។
នឹងទទួលខុសត្រូវលើអំពើទុច្ចរិតរបស់អ្នក
1 Kings 2:45
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនបញ្ជាឲ្យសម្លាប់លោកស៊ីម៉ែ។
បល្ល័ង្ករបស់ស្តេចដាវីឌនឹងនៅស្ថិតស្ថេចំពោះព្រះអម្ចាស់ជារៀងរហូត
នៅទីនេះ «បល្ល័ង្ករបស់ស្តេចដាវីឌ»
តំណាងសិទ្ធិអំណាចនិងការគ្រប់គ្រងរបស់ដាវីឌនិងកូនចៅទាំងអស់របស់គាត់ជារៀងរហូត។
ព្រះបាទសាឡូម៉ូនបានកាន់អំណាចក្នុងដៃយ៉ាងរឹងមាំ
ការប្រើ « ដៃ» នេះតំណាងឲ្យអំណាចនិងសិទ្ធិអំណាចរបស់ព្រះបាទសាឡូម៉ូន។
(សូមមើលfigs-metonymy)

3

[1]ព្រះបាទសាឡូម៉ូនបានចងសម្ពន្ធមិត្តដោយរៀបការជាមួយកូនស្រីស្តេចផារោនជាស្តេចស្រុកអេស៊ីប។
ទ្រង់បាននាំកូនស្រីរបស់ស្តេចផារោនមកនៅក្នុងក្រុងរបស់ស្តេចដាវីឌរហូតដល់ទ្រង់បានសាងសង់ដំណាក់របស់ព្រះអង្គ ព្រះវិហាររបស់ព្រះអម្ចាស់
និងជញ្ជាំងក្រុងយេរូសាឡឹមរួចរាល់។[2]ប្រជាជនបានថ្វាយតង្វាយនៅទីខ្ពស់ៗ
ដោយសារដំណាក់របស់ព្រះអម្ចាស់មិនទាន់សង់រួចរាល់សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់នៅឡើយ។

generated on Wed Sep 10 16:16:32 2025

[3]ព្រះបាទសាឡូម៉ូនបានបង្ហាញសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះព្រះអម្ចាស់ដោយដើរតាមដំបូន្មានរបស់ស្ដេចដាវីឌជាបិតា លើកលែងតែការថ្វាយតង្វាយដុត
និងគ្រឿងក្រអូបនៅទីខ្ពស់ៗប៉ុណ្ណោះ។
[4]ស្ដេចបានយាងទៅគីបៀន ដើម្បីថ្វាយតង្វាយនៅទីនោះ ព្រោះនៅទីនោះជាទីដ៏ខ្ពស់។ ព្រះបាទសាឡូម៉ូនបានថ្វាយតង្វាយដុតមួយពាន់នៅលើអាសនានោះ។
[5]ព្រះអម្ចាស់បានមកជួបព្រះបាទសាឡូម៉ូននៅគីបៀនក្នុងសុបិន្តនៅពេលយប់ ព្រះអង្គមានបន្ទូលថា៖ «ចូរសូមមកចុះ! តើយើងគួរឲ្យអ្វីដល់អ្នក»?
[6]ដូច្នេះ ព្រះបាទសាឡូម៉ូនទូលថា៖ «ព្រះអង្គបានបង្ហាញសម្ពន្ធមេត្រីអស្ចារ្យដ៏ស្មោះត្រង់ចំពោះអ្នកបម្រើរបស់ព្រះអង្គ គឺចំពោះស្ដេចដាវីឌជាបិតារបស់ទូលបង្គំ
ដោយសារតែទ្រង់បានដើរដោយទុកចិត្ត ដោយសេចក្ដីសុចរិត និងដោយចិត្តស្មោះត្រង់។ ព្រះអង្គបានរក្សាសម្ពន្ធមេត្រីអស្ចារ្យដ៏ស្មោះត្រង់
ហើយបានប្រទានឲ្យបុត្រារបស់ដាវីឌបានគង់លើបល្ល័ង្ករបស់ស្ដេចនៅថ្ងៃនេះដែរ។
[7]ឥឡូវនេះ ព្រះអម្ចាស់របស់ទូលបង្គំអើយ ព្រះអង្គបានឲ្យអ្នកបម្រើរបស់ព្រះអង្គឡើងសោយរាជ្យជំនួសស្ដេចដាវីឌជាបិតារបស់ទូលបង្គំ ទោះបីជាទូលបង្គំនៅក្មេងក៏ដោយ។
ទូលបង្គំមិនដឹងថាត្រូវទៅក្រៅ ឬចូលក្នុងដូចម្ដេចទេ។[8]អ្នកបម្រើរបស់ព្រះអង្គនៅក្នុងចំណោមមនុស្សដែលព្រះអង្គបានជ្រើសរើស ជាមនុស្សដ៏អស្ចារ្យ
ដែលមានចំនួនច្រើនដែលមិនអាចរាប់បាន។[9]ដូច្នេះចូរឲ្យទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គមានដួងចិត្តដែលមានប្រាជ្ញ ដើម្បីអាចវិនិច្ឆ័យប្រជារាស្ត្ររបស់ព្រះអង្គ
ដូច្នេះទូលបង្គំអាចញែកដាច់ពីគ្នារវាងការល្អ និងការអាក្រក់។ តើនរណាអាចវិនិច្ឆ័យប្រជារាស្ត្រដ៏អស្ចារ្យរបស់ព្រះអង្គបាន»?
[10]សំណើរដែលព្រះបាទសាឡូម៉ូនទូលសូមនេះធ្វើឲ្យព្រះអម្ចាស់គាប់ព្រះហឫទ័យណាស់។[11]ដូច្នេះ ព្រះជាម្ចាស់មានបន្ទូលទៅកាន់ស្ដេចថា៖
«ដោយសារតែអ្នកបានសុំការនេះពីយើង ហើយមិនបានសុំឲ្យខ្លួនអ្នកមានអាយុវែង ឬឲ្យមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬសុំជីវិតរបស់ខ្មាំងសត្រូវរបស់អ្នកឡើយ ប៉ុន្តែ
បានសុំការយល់ដឹង ដើម្បីគ្រប់គ្រងដោយយុត្តិធម៌វិញ[12]ឥឡូវនេះ យើងនឹងធ្វើតាមអ្វីដែលអ្នកបានសុំពីយើង។ យើងនឹងឲ្យអ្នកមានប្រាជ្ញា និងចិត្តដែលយល់ដឹង ដូច្នេះ
នឹងគ្មាននរណាម្នាក់ប្រៀបនឹងអ្នកបានឡើយ ទោះបីជាអ្នកមុន ឬក្រោយអ្នកក្ដី។
[13]យើងក៏នឹងប្រទានដល់អ្នកនូវអ្វីដែលអ្នកមិនបានសុំដែរ ទាំងទ្រព្យសម្បត្តិ និងកិត្តិយស ដូច្នេះនៅក្នុងថ្ងៃអាយុអ្នកនឹងគ្មានស្ដេចឯណាប្រៀបបាននឹងអ្នកឡើយ។
[14]បើអ្នកដើរនៅក្នុងផ្លូវរបស់យើង និងរក្សាច្បាប់ និងបញ្ញត្តិរបស់យើង ដូចជាបិតារបស់អ្នកបានធ្វើ នោះយើងនឹងឲ្យអ្នកបានអាយុវែង។
[15]បន្ទាប់មក ព្រះបាទសាឡូម៉ូនបានតើនឡើង ហើយបានដឹងថានោះជាយល់សុបិន។ ស្ដេចបានត្រឡប់មកក្រុងយេរូសាឡឹមវិញ
ហើយបានឈរនៅចំពោះហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។ ស្ដេចបានថ្វាយតង្វាយដុត និងតង្វាយមេត្រីភាព និងធ្វើពិធីជប់លៀងសម្រាប់អ្នកបម្រើទាំងអស់។
[16]បន្ទាប់មក មានស្ត្រីពេស្យាពីរនាក់បានមកគាល់ស្ដេច និងបានឈរនៅចំពោះមុខស្ដេច។[17]ស្ត្រីម្នាក់ទូលថា៖ «បពិតព្រះករុណា ស្ត្រីនេះ
និងទូលបង្គំបានរស់នៅក្នុងផ្ទះតែមួយ រួចទូលបង្គំ និងនាងបានសម្រាលកូនដូចគ្នានៅក្នុងផ្ទះនោះ។
[18]បីថ្ងៃក្រោយពីខ្ញុំម្ចាស់បានសម្រាលកូន នាងក៏បានសម្រាលកូនដែរ។ យើងរស់នៅជាមួយគ្នា។ ក្រៅពីយើងគ្មាននរណាម្នាក់ផ្សេងទៀតនៅក្នុងផ្ទះទេ
មានតែយើងពីរនាក់ប៉ុណ្ណោះ។[19]បន្ទាប់មក កូនរបស់ស្ត្រីនេះបានស្លាប់នៅពេលយប់ ដោយសារនាងកិនលើកូននោះ។[20]ដូច្នេះ នាងក៏ក្រោកឡើងនៅពេលយប់
ហើយបានយកកូនពីក្បែរខ្ញុំម្ចាស់ទៅ នៅពេលដែលខ្ញុំម្ចាស់ដេកលក់ ហើយដាក់កូននោះនៅក្បែរទ្រូងនាង
ហើយបានដាក់កូនដែលបានស្លាប់របស់នាងនៅក្បែរទ្រូងខ្ញុំម្ចាស់វិញ។
[21]នៅពេលដែលខ្ញុំម្ចាស់ក្រោកឡើងនៅពេលព្រឹកដើម្បីបំបៅកូន កូននោះបានស្លាប់ហើយ។ ប៉ុន្តែ នៅពេលដែលខ្ញុំម្ចាស់ពិនិត្យមើលកូននោះនៅពេលព្រឹក
កូននោះមិនមែនជាកូនរបស់ខ្ញុំម្ចាស់ទេ គឺមិនមែនជាកូនបង្កើតរបស់ខ្ញុំម្ចាស់ទេ»។[22]បន្ទាប់មក ស្ត្រីម្នាក់ទៀតទូលថា៖ «ទេ កូនដែលនៅរស់ជាកូនរបស់ខ្ញុំម្ចាស់ទេ
ហើយកូនដែលស្លាប់ជាកូនរបស់នាងទៅវិញទេ»។ ស្ត្រីដំបូងបានទូលថា៖ «ទេ កូនដែលស្លាប់ជាកូនរបស់នាងទេ ហើយកូនដែលនៅរស់ជាកូនរបស់ខ្ញុំម្ចាស់ទេ»។
នេះជាអ្វីដែលពួកគេបានជជែកគ្នានៅចំពោះស្ដេច។
[23]បន្ទាប់មក ស្ដេចទូលថា៖ «ម្នាក់ៗនិយាយថា៖ «កូនដែលនៅរស់នេះជាកូនរបស់ខ្ញុំ ហើយកូនរបស់នាងគឺស្លាប់ហើយ» ហើយម្នាក់ទៀតនិយាយថា៖ «ទេ
កូនដែលស្លាប់ជាកូនរបស់នាង ហើយកូនរបស់ខ្ញុំជាកូនដែលនៅរស់»។[24]ស្ដេចទូលថា៖ «ចូរយកដាវឲ្យយើង»។ ដូច្នេះ គេក៏បានយកដាវមកថ្វាយស្ដេច។[25]បន្ទាប់មក
ស្ដេចមានរាជឱង្ការថា៖ «ចូរកាប់កូនដែលនៅរស់ជាពីរចំណែក ហើយឲ្យពាក់កណ្ដាលដល់ស្ត្រីនេះ ហើយពាក់កណ្ដាលទៀតឲ្យស្ត្រីនោះ»។
[26]បន្ទាប់មក ស្ត្រីដែលមានកូននៅរស់បានទូលទៅស្ដេច ដោយសារនាងមានចិត្តពេញទៅដោយក្តីមេត្តាសម្រាប់កូនរបស់នាង ហើយនាងទូលថា៖ «បពិតព្រះករុណា
ចូរឲ្យកូនដែលនៅរស់ទៅនាងចុះ ហើយកុំសម្លាប់កូននេះឡើយ»។ ប៉ុន្តែ ស្ត្រីម្នាក់ទៀតទូលថា៖ «កូននេះមិនគួរជារបស់នាង ឬរបស់ខ្ញុំឡើយ។ យើងត្រូវចែកគ្នា»។
[27]បន្ទាប់មក ស្ដេចឆ្លើយ និងមានរាជឱង្ការថា៖ «ចូរឲ្យកូនដែលនៅរស់ដល់ស្ត្រីទីមួយទៅ ហើយកុំសម្លាប់កូននេះឡើយ។ នាងគឺជាម្តាយរបស់កូននេះ»។
[28]នៅពេលដែលប្រជាជនអ៊ីស្រាអែលបានឮពីការវិនិច្ឆ័យដែលស្ដេចបានធ្វើ ពួកគេកោតខ្លាចស្ដេច
ដោយសារតែពួកគេបានឃើញពីប្រាជ្ញារបស់ព្រះជាម្ចាស់នៅក្នុងស្ដេចចំពោះការវិនិច្ឆ័យនេះ។

---

1 Kings 3:1
ព័ត៌មានទូទៅ
ព្រះបាទសាឡូម៉ូនរៀបការជាមួយជនជាតិអេស៊ីបម្នាក់។
ព្រះបាទសាឡូម៉ូនបានចងសម្ពន្ធមិត្តដោយរៀបការជាមួយកូនស្រីស្តេចផារ៉ោនជាស្តេចស្រុកអេស៊ីប
ព្រះបាទសាឡូម៉ូនបានក្លាយជាកូនប្រសារបស់ព្រះចៅផារ៉ោនជាស្តេចស្រុកអេស៊ីបដើម្បី
រហូតដល់ទ្រង់បានសាងសង់ដំណាក់របស់ព្រះអង្គរួច
នាងនៅតែ នៅក្នុងទីក្រុងស្តេចដាវីឌបន្ទាប់ពីទ្រង់បានបញ្ចប់ការសាងសង់។
ព្រះវិហាររបស់ព្រះអម្ចាស់
ព្រះវិហារ
ដំណាក់របស់ព្រះអម្ចាស់មិនទាន់សង់រួចរាល់
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«គ្មាននរណាម្នាក់បានសង់ព្រះវិហារនៅឡើយទេ»
សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់នៅឡើយ
ពាក្យថា « ឈ្មោះ» គឺសំដៅទៅលើមនុស្សហើយ «សម្រាប់ឈ្មោះ»
គឺសំដៅទៅលើការគោរពបូជាមនុស្ស។ «ដែលមនុស្សនឹងថ្វាយបង្គំព្រះជាម្ចាស់»
ដើរតាមដំបូន្មានរបស់ស្តេចដាវីឌជាបិតា
របៀបដែលជីវិតរបស់មនុស្សម្នាក់ត្រូវបានគេនិយាយថាកំពុងដើរលើផ្លូវមួយ។
«គោរពតាមច្បាប់ដែលស្តេចដាវីឌជាបិតារបស់ទ្រង់បានធ្វើ»
1 Kings 3:4
ព័ត៌មានទូទៅ
ព្រះជាម្ចាស់សួរព្រះសាឡូម៉ូននូវអ្វីដែលទ្រង់អាចធ្វើសម្រាប់ព្យុះបាទសាឡូម៉ូន។
នៅទីនោះជាទីដ៏ខ្ពស់
«កន្លែងដ៏ល្បីបំផុតសម្រាប់ការធ្វើយញ្ញបូជា» ឬ «អាសនៈសំខាន់បំផុត»
ចូរសូមមកចុះ! តើយើងគួរឲ្យអ្វីដល់អ្នក»?
[illegible]
«តើអ្នកចង់បានអ្វី?» ចូរសុំយើងនឹងផ្តល់ឲ្យអ្នក» ។
1 Kings 3:6
ព័ត៌មានទូទៅ
លោកសាឡូម៉ូនឆ្លើយនឹងសំណួររបស់ព្រះជាម្ចាស់។
ព្រះអង្គបានបង្ហាញសម្ពន្ធមេត្រីអស្ចារ្យដ៏ស្មោះត្រង់
«ព្រះអង្គបានស្មោះត្រង់ចំពោះកិច្ចព្រមព្រៀងរបស់ទ្រង់»
ដោយសារតែទ្រង់បានដើរដោយទុកចិត្ត ដោយសេចក្ដីសុចរិត និងដោយចិត្តស្មោះត្រង់
ការដើរគឺជាការប្រៀបធៀបមួយអំពីរបៀបដែលមនុស្សរស់នៅ។ នាមអរូបី
«ភាពគួរឲ្យទុកចិត្ត» «សេចក្ដីសុចរិត» និង «ភាពទៀងត្រង់»
អាចបកប្រែជាគុណនាម។
«ពីព្រោះទ្រង់គួរឲ្យទុកចិត្តនិងសុចរិតហើយព្រះទ័យរបស់ទ្រង់គឺទៀងត្រង់»
និងដោយចិត្តស្មោះត្រង់
មនុស្សស្មោះត្រង់ត្រូវបានគេនិយាយថាជាមនុស្សម្នាក់ដែលមានចិត្តទៀងត្រង់។
«ហើយទ្រង់ស្មោះត្រង់» ឬ «ហើយទ្រង់មានបន្ទូលការពិតនិងធ្វើអ្វីដែលល្អ»
បានប្រទានឲ្យបុត្រារបស់ដាវីឌ

generated on Wed Sep 10 16:16:32 2025

«កូនប្រុស» គឺជាស្តេចសាឡូម៉ូន។
គង់លើបល្ល័ង្ករបស់ស្តេច
«ដើម្បីគ្រប់គ្រងជំនួសកន្លែងរបស់ទ្រង់»
នៅថ្ងៃនេះ
«ឥឡូវនេះ»
ស្តេចសាឡូម៉ូនមិននិយាយអំពីមួយថ្ងៃទេតែអំពីឆ្នាំដែលគាត់បានគ្រប់គ្រងរួចហើយ។
1 Kings 3:7
ព័ត៌មានទូទៅ
ព្រះបាទសាឡូម៉ូនសុំប្រាជ្ញា។
អ្នកបម្រើរបស់ព្រះអង្គ
ព្រះបាទសាឡូម៉ូនបានមានបន្ទូលដូចជា
គាត់ជាមនុស្សម្នាក់ទៀតដើម្បីគោរពដល់ព្រះអម្ចាស់។ «ខ្ញុំ»
ទូលបង្គំនៅក្មេង
ព្រះបាទសាឡូម៉ូនកំពុងតែមានបន្ទូលថា គាត់ដូចជាក្មេងដែលមិនសូវស្គាល់ឪពុក។
ទូលបង្គំមិនដឹងថាត្រូវទៅក្រៅ ឬចូលក្នុងដូចម្តេចទេ
នេះគឺសំដៅទៅលើការមិនដឹងអ្វីដែលទ្រង់ត្រូវធ្វើ។
«ខ្ញុំមិនដឹងផ្លូវត្រឹមត្រូវក្នុងការធ្វើអ្វីមួយ» ឬ «ខ្ញុំមិនដឹងថាត្រូវធ្វើជាស្តេចដូចម្តេចទេ»
តើនរណាអាចវិនិច្ឆ័យប្រជារាស្ត្រដ៏អស្ចារ្យរបស់ព្រះអង្គបាន»?
ព្រះបាទសាឡូម៉ូនសួរសំណួរនេះដើម្បីបញ្ជាក់ថា
គាត់ដឹងថាគ្មាននរណាម្នាក់អាចវិនិច្ឆ័យទោសបានទេ។
«គ្មាននរណាម្នាក់អាចវិនិច្ឆ័យទោសមនុស្សដ៏អស្ចារ្យរបស់ទ្រង់បានទេ» ។
1 Kings 3:10
ព័ត៌មានទូទៅ
ព្រះជាម្ចាស់ប្រទានប្រាជ្ញា និង អ្វីៗជាច្រើនទៀតដល់ព្រះបាទសាឡូម៉ូន។
ជីវិតរបស់ខ្មាំងសត្រូវរបស់អ្នក
«ជីវិត» គឺសំដៅទៅលើអំណាចដើម្បីសម្លាប់។
«អំណាចដើម្បីសម្លាប់សត្រូវរបស់អ្នក»
យើងនឹងធ្វើតាមអ្វីដែលអ្នកបានសុំពីយើង
«យើងនឹងធ្វើអ្វីដែលអ្នកបានស្នើសុំឲ្យយើងឲ្យធ្វើនៅពេលអ្នកនិយាយជាមួយយើង»
យើងនឹងឲ្យអ្នកមានប្រាជ្ញា និងចិត្តដែលយល់ដឹង
ចិត្តគឺជាពាក្យប្រៀបធៀបសម្រាប់អ្វីដែលមនុស្សគិតនិងប្រាថ្នាចង់បាន។
«យើងធ្វើអោយអ្នកមានប្រាជ្ញានិងយល់ពីរឿងរ៉ាវជាច្រើន»
1 Kings 3:13
ដើរនៅក្នុងផ្លូវរបស់យើង និងរក្សា
ការរស់នៅរបស់មនុស្សម្នាក់ត្រូវបានគេនិយាយថាកំពុងដើរលើផ្លូវមួយ។
«រស់នៅដូចដែលយើងចង់អោយអ្នករស់នៅ និង គោរពតាម»
បានអាយុវែង
«ថ្ងៃ» តំណាងឲ្យជីវិតរបស់ព្រះបាទសាឡូម៉ូន។ «ធ្វើឲ្យអ្នករស់នៅបានយូរ»
1 Kings 3:15
មើលចុះ
ពាក្យ «មើលចុះ»
ត្រង់នេះបង្ហាញថាព្រះបាទសាឡូម៉ូនបានឃើញអ្វីដែលគួរអោយចាប់អារម្មណ៍។
1 Kings 3:16
ព័ត៌មានទូទៅ
ស្រីពេស្យាពីរនាក់សុំព្រះបាទសាឡូម៉ូនធ្វើការសម្រេចព្រះទ័យ។
1 Kings 3:18
ព័ត៌មានទូទៅ
ស្រីពេស្យាទាំងពីរប្រាប់រឿងរបស់ពួកគេទៅស្តេចសាឡូម៉ូន។
កិនលើកូននោះ
វាអាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា នេះបណ្តាលឲ្យទារកនោះស្លាប់។
«រមៀលលើកូនរបស់នាងហើយធ្វើឲ្យកូននោះស្លាប់»
ខ្ញុំម្ចាស់ដេកលក់
ស្ត្រីនោះនិយាយដូចជាកំពុងនិយាយអំពីអ្នកណាម្នាក់
ដើម្បីបង្ហាញថានាងគោរពស្តេចសាឡូម៉ូន។ «ខ្ញុំម្ចាស់»
1 Kings 3:21
ព័ត៌មានទូទៅ៖
ស្រីពេស្យាពីរនាក់បន្តចែករំលែករឿងរ៉ាវរបស់ពួកគេជាមួយស្តេចសាឡូម៉ូន។
ដើម្បីបំបៅកូន
នេះមានន័យថា ចិញ្ចឹមកូនដោយទឹកដោះរបស់នាង។
នៅចំពោះស្តេច
«មុនពេលស្តេចសាឡូម៉ូន» ឬ
«ខណៈពេលដែលស្តេចសាឡូម៉ូនអាចមើលឃើញនិងស្តាប់ពួកគេ»
1 Kings 3:23
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនធ្វើការសម្រេចចិត្តសម្រាប់ស្ត្រីទាំងពីរនាក់នោះ។
1 Kings 3:26
ព័ត៌មានទូទៅ
ម្តាយពិតរបស់កូននោះសុំព្រះរាជាជួយសង្គ្រោះជីវិតកូនខ្ញុំម្ចាស់ផង។
នាងមានចិត្តពេញទៅដោយក្តីមេត្តាសម្រាប់កូនរបស់នាង
ចិត្តត្រូវបានគេនិយាយថា វាជាប្រអប់ និង ការអាណិតអាសូរដូចជាវាជាវត្ថុរឹងមួយ។
«នាងស្រឡាញ់កូនរបស់នាងខ្លាំងណាស់»
ប្រជាជនអ៊ីស្រាអែល
ជនជាតិអ៊ីស្រាអែលទាំងអស់នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅ។

---

4 [1]ព្រះបាទសាឡូម៉ូនជាស្តេចលើអ៊ីស្រាអែលទាំងមូល។[2]នេះជាមន្ត្រីទាំងអស់របស់ស្តេច៖ លោកអសារា ជាកូនរបស់លោកសាដុកដែលជាបូជាចារ្យ។[3]លោកអេលីហូរែប និងលោកអហ៊ីយ៉ា ជាកូនរបស់លោកស៊ីសា ជាលេខាធិការ។ លោកយេហូសាផាត ជាកូនរបស់លោកអហ៊ីលូដ ជាអ្នកកត់ត្រា។[4]លោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដា ជាមេទ័ព។ លោកសាដុក និងលោកអបៀថើរ ជាបូជាចារ្យ។
[5]លោកអសារា ជាកូនរបស់លោកណាថាន់ ជាប្រមុខលើពួកអ្នកដឹកនាំ។ លោកសាប៊ូដ ជាកូនរបស់លោកណាថាន ជាបូជាចារ្យ និងជាមិត្តរបស់ស្តេច។[6]លោកអហ៊ីសាជាអ្នកគ្រប់គ្រងរាជវាំង។ លោកអដូនីរ៉ាម ជាកូនរបស់លោកអាប់ដា ជាអ្នកគ្រប់គ្រងលើប្រុសៗដែលត្រូវធ្វើការធ្ងន់ៗ។
[7]ព្រះបាទសាឡូម៉ូនមានអ្នកគ្រប់គ្រងដប់ពីរនាក់លើស្រុកអ៊ីស្រាអែលទាំងមូល ដែលបានរៀបចំអាហារសម្រាប់ស្តេច និងរាជវាំងទាំងមូល។
ម្នាក់ៗត្រូវផ្គត់ផ្គង់មួយខែក្នុងរយៈពេលមួយឆ្នាំ។[8]នេះគឺជាឈ្មោះរបស់អ្នកទាំងនោះ៖ លោកបេន-ហ៊ើរជាអ្នកនៅតំបន់ភ្នំអេប្រាអ៊ីម។[9]លោកបេន-ដេកើរនៅតំបន់ម៉ាកាស ស្អាលប៊ីម បេតសេម៉េស ហេឡូន និងបេតហាណាន[10]លោកបេន-ហេសេឌនៅតំបន់អារូបូត (ស្រុកសូកូ និងស្រុកអេភើរទាំងមូលក៏ជាកម្មសិទ្ធរបស់គាត់ដែរ)
[11]លោកបេន-អប៊ីណាដាប់ នៅស្រុកដោរទាំងមូល (លោកបានយកព្រះនាងថាផាត ជាបុត្រីព្រះបាទសាឡូម៉ូនធ្វើជាប្រពន្ធ)[12]លោកបាណា ជាកូនប្រុសលោកអហ៊ីលូដ នៅតំបន់តាណាក់ និងមេគីដោ ព្រមទាំងតំបន់បេតសៀនទាំងមូល ដែលនៅខាងក្រោយតំបន់សារថាន ដែលស្ថិតនៅខាងក្រោមយេសរាល ពីបេតសៀនរហូតដល់អេបិល-មហូឡា និងរហូតទៅដល់ខាងនាយយ៉ុកមាម[13]លោកបេន-កេប៊ើរនៅរ៉ាម៉ូត កាឡាដ (លោកគ្រប់គ្រងភូមិទាំងប៉ុន្មានរបស់លោកយ៉ាអ៊ារ ជាកូនរបស់លោកម៉ាណាសេ គឺស្រុកកាឡាដ និងតំបន់អើកុប ក្នុងស្រុកបាសានក៏ជាកម្មសិទ្ធិរបស់លោកដែរ មានក្រុងធំៗចំនួនហុកសិប ជាទីក្រុងមានកំពែង និងមានគ្រោងទ្វារធ្វើពីលង្ហិន។[14]លោកអហ៊ីណាដាប់ ជាកូនរបស់លោកអ៊ីដោ នៅតំបន់ម៉ាហាណែម។
[15]លោកអហ៊ីម៉ាស់នៅទឹកដីណែបថាលី (លោកបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាងបាសម៉ាត ជាបុត្រីរបស់ព្រះបាទសាឡូម៉ូនធ្វើជាប្រពន្ធ)[16]លោកបាណា ជាកូនរបស់លោកហ៊ូសាយ នៅទឹកដីអេស៊ើរ និងអាឡុត។[17]លោកយេហូសាផាត ជាកូនរបស់លោកបារូអានៅទឹកដីអ៊ីសាខារ
[18]លោកស៊ីម៉ៃ ជាកូនរបស់លោកអេឡា នៅទឹកដីបេនយ៉ាមីន[19]លោកកេប៊ើរ ជាកូនរបស់លោកអ៊ូរី នៅស្រុកកាឡាដ ព្រមទាំងទឹកដីរបស់ស្តេចស៊ីហុន ស្តេចនៃជនជាតិអាម៉ូរី និងស្រុករបស់ស្តេចអុក ស្តេចស្រុកបាសាន ហើយគាត់ជាអ្នកគ្រប់គ្រងតែមួយគត់នៅក្នុងតំបន់នោះ។
[20]ស្រុកយូដា និងស្រុកអ៊ីស្រាអែលទាំងមូលមានមនុស្សច្រើនដូចខ្សាច់នៅមាត់សមុទ្រ។ ពួកគេបានស៊ី និងផឹក ហើយសប្បាយរីករាយ។
[21]ព្រះបាទសាឡូម៉ូនបានគ្រប់គ្រង់លើនគរទាំងឡាយចាប់ពីទន្លេ រហូតដល់ស្រុកភីលីស្ទីន និងដល់ព្រំប្រទល់ស្រុកអេស៊ីប។
ពួកគេបាននាំសួយសាអាករមកថ្វាយព្រះបាទសាឡូម៉ូននៅអស់មួយជីវិតរបស់ស្តេច។[22]ស្បៀងអាហារប្រចាំថ្ងៃសម្រាប់ផ្គត់ផ្គង់ក្នុងវាំងរបស់ព្រះបាទសាឡូម៉ូន មានម្សៅម៉ដ្ដ ប្រាំបួនតោន ម្សៅធម្មតាដប់ប្រាំបីតោន[23]គោបំប៉នដប់ក្បាល គោធម្មតាម្ភៃក្បាល ចៀមមួយរយក្បាល ប្រើស ឈ្លូស ក្តាន់ និងមាន់ទាបំប៉ន។

generated on Wed Sep 10 16:16:32 2025

[24]ស្តេចបានត្រួតត្រាលើតំបន់ទាំងមូលដែលស្ថិតនៅត្រើយខាងនាយទន្លេ ចាប់ពីធីពសារហូតដល់កាសា លើស្តេចទាំងប៉ុន្មាននៅខាងនាយទន្លេ ហើយមានសុខសន្តិភាព
គ្រប់ទិសទីនៅជុំវិញទ្រង់។[25]ស្រុកយូដា និងស្រុកអ៊ីស្រាអែលរស់នៅដោយសន្តិភាព ចាប់ពីក្រុងដាន់រហូតដល់ក្រុងបៀរសេបា មនុស្សរស់នៅដោយសុខសាន្ត ក្រោមដើម
ទំពាំងបាយជូរ និងដើមឧទុម្ពររបស់ខ្លួននៅថ្ងៃអាយុរបស់ព្រះបាទសាឡូម៉ូន។
[26]ព្រះបាទសាឡូម៉ូនមានសេះបួនម៉ឺនក្បាល សម្រាប់រទេះចម្បាំងរបស់ទ្រង់ និងពលទ័ពសេះមួយម៉ឺនពីរពាន់នាក់។[27]អ្នកគ្រប់គ្រងទាំងអស់ផ្គត់ផ្គង់ស្បៀងអាហារ សម្រាប់
ព្រះបាទសាឡូម៉ូន និងអស់អ្នកដែលបរិភោគរួមតុជាមួយស្តេច គឺម្នាក់មួយខែ។ ពួកគេមិនឲ្យខ្វះខាតអ្វីឡើយ។[28]ពួកគេក៏យកស្រូវ និងចំបើងសម្រាប់សេះ ព្រមទាំងសត្វ
ផ្សេងៗទៀតដែលជាជំនិះ នៅតាមកន្លែងត្រឹមត្រូវ ម្នាក់ៗនាំយកអ្វីៗដែលគេអាចយកមកបាន។
[29]ព្រះជាម្ចាស់បានប្រទានឲ្យព្រះបាទសាឡូម៉ូនមានប្រាជ្ញា និងការយល់ដឹងយ៉ាងខ្លាំង ដូចជាខ្សាច់នៅមាត់សមុទ្រ។
[30]ប្រាជ្ញារបស់ព្រះបាទសាឡូម៉ូនលើសជាងប្រាជ្ញារបស់ប្រជាជន ដែលរស់នៅទិសខាងកើត និងលើសជាងប្រាជ្ញារបស់អ្នកស្រុកអេស៊ីបទៅទៀត។
[31]ស្តេចមានប្រាជ្ញាលើសមនុស្សទាំងអស់ គឺលើសលោកអេថាន ពីអំបូរសេរ៉ាគីត លោកហេម៉ាន ព្រមទាំងលោកកាល់កូល និងលោកដារដា ជាកូនរបស់លោកម៉ាហូល
ភាពល្បីល្បាញរបស់ស្តេចបានឮដល់ជាតិសាសន៍នៅជុំវិញ។
[32]ស្តេចបានតែងសុភាសិតចំនួនបីពាន់ និងបទចម្រៀងមួយពាន់ប្រាំបទ។[33]ស្តេចបានរៀបរាប់ពីរុក្ខជាតិទាំងឡាយតាំងពីដើមតាត្រៅនៅស្រុកលីបង់ រហូតដល់ដើមហ៊ីសុប
ដែលដុះនៅក្រៅជញ្ជាំងក្រុងផង។ ស្តេចក៏បានពន្យល់អំពីសត្វចតុប្បាទ សត្វស្លាប សត្វលូនវារ និងត្រីផងដែរ។
[34]មនុស្សមកពីគ្រប់ជាតិសាសន៍បានមកស្តាប់ប្រាជ្ញារបស់ព្រះបាទសាឡូម៉ូន។ ពួកគេគឺជាស្តេចដែលមកពីប្រជាជាតិនៅលើផែនដី។

---

1 Kings 4:1
ព័ត៌មានទូទៅ
នេះជាការចាប់ផ្តើមនៃបញ្ជីរាយនាមមន្ត្រីរបស់ព្រះបាទសាឡូម៉ូន។
លោកអសារា...លោកសាដុក...លោកអេលីហូរែប...លោកអហ៊ីយ៉ា...លោកស៊ីសា...លោក
យេហូសាផាត..លោកអហ៊ីលូដ..លោកបេណាយ៉ា...លោកយេហូយ៉ាដា...លោកអរៀថើរ ..
ឈ្មោះរបស់មនុស្សប្រុស
1 Kings 4:5
ព័ត៌មានទូទៅ
បញ្ជីឈ្មោះមន្ត្រីរបស់ព្រះបាទសាឡូម៉ូននៅតែបន្ត។
លោកអសារា...លោកណាថាន់...លោកសាប៊ូដ...លោកអហ៊ីសា...លោកអដូនីរ៉ាម...លោកអាប់ដា
ឈ្មោះរបស់មនុស្សប្រុស
ជាអ្នកគ្រប់គ្រងលើប្រុសៗដែលត្រូវធ្វើការធ្ងន់ៗ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ក្រុមបុរសដែលព្រះបាទសាឡូម៉ូនបានបង្ខំឲ្យធ្វើការឲ្យទ្រង់»
1 Kings 4:7
ព័ត៌មានទូទៅ
ការបន្តបញ្ជីឈ្មោះមន្ត្រីរបស់ព្រះបាទសាឡូម៉ូន
លោកបេន-ហ៊ើរ..លោកបេន-ដេកើរ..លោកបេន-ហេសេឌ
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។ ចំណាំថា «បេន» មុនឈ្មោះមានន័យថា
«កូនប្រុសរបស់» ដូច្នេះ «នហ៊ើរ» មានន័យថា «កូនប្រុសហ៊ើរ» ។
នៅតំបន់ភ្នំ..តំបន់ម៉ាកាស...តំបន់អារូបូត
«ដែលជាមន្ត្រីទទួលបន្ទុកនៅលើភ្នំ ... ដែលជាមន្ត្រីទទួលបន្ទុករបស់តំបន់
ម៉ាកាស ... ដែលជាមន្ត្រីទទួលបន្ទុក តំបន់អារូបូត»
អេប្រាអ៊ីម...តំបន់ម៉ាកាស...ស្អាលប៊ីម...បេតសេម៉េស...ហេឡូន និងបេតហាណាន...តំបន់
អារូបូត...ស្រុកសូកូ...អេភើរ
ឈ្មោះទីកន្លែង
1 Kings 4:11
ឃ្លាភ្ជាប់
បញ្ជីរាយនាមមន្ត្រីរបស់ព្រះបាទសាឡូម៉ូននៅតែបន្តហើយបញ្ជីនៃតំបន់ដែលពួកគេមានតួនាទីធ្វើការងារ
លោកបេន-អប៊ីណាដាប់...លោកបេន-កេបើរ...យ៉ាអ៊ា...លោកម៉ាណាសេ...លោក
អហ៊ីណាដាប់...លោកអ៊ីដោ
ឈ្មោះរបស់មនុស្សប្រុស
នៅស្រុកដោរទាំងមូល...តំបន់តាណាក់...រ៉ាម៉ូត កាឡាដ...នៅតំបន់ម៉ាហាណែម
«អ្នកណាជាមន្ត្រីទទួលបន្ទុកស្រុកដូរ ... ដែលជាមន្ត្រីទទួលបន្ទុកតាណាក់ ...
ដែលជាមន្ត្រីទទួលបន្ទុករ៉ាម៉ូត កាឡាដ ... ដែលជាមន្ត្រីទទួលបន្ទុកម៉ាហាណែម»
ព្រះនាងថាផាត
ឈ្មោះរបស់ស្ត្រី
ដោរ...តំបន់បេតសៀន...តំបន់សារថាន...យេសរាល...បេតសៀនរហូតដល់
អេបិល...មហូឡា ...នាយយ៉ុកមាម...រ៉ាម៉ូត កាឡាដ...តំបន់អើកុប...ស្រុកបាសាន...តំបន់
ម៉ាហាណែម
ឈ្មោះទីកន្លែង
1 Kings 4:15
ព័ត៌មានទូទៅ
បញ្ជីរាយនាមមន្ត្រីរបស់ព្រះបាទសាឡូម៉ូននិងតំបន់ដែលពួកគេទទួលបន្ទុកនៅតែបន្ត។
លោកអហ៊ីម៉ាស់...លោកបាណា...លោកហ៊ូសាយ...លោកយេហូសាផាត...លោកបារូអា
ឈ្មោះរបស់មនុស្សប្រុស
នៅទឹកដីណែបថាលី...នៅទឹកដីអេស៊ើរ...នៅទឹកដីអ៊ីសាខារ
«នរណាជាមន្ត្រីទទួលបន្ទុកនៅទឹកដីណែបថាលី ...
ដែលជាមន្ត្រីទទួលបន្ទុកអែស៊ែរ ... ដែលជាមន្ត្រីទទួលបន្ទុកអ៊ីសាខារ»
ព្រះនាងបាសម៉ាត
ឈ្មោះរបស់ស្ត្រីម្នាក់
ណែបថាលី ...ដីអេស៊ើ...ទឹកដីអ៊ីសាខារ
ទឹកដីកុលសម្ព័ន្ធត្រូវបានដាក់ឈ្មោះតាមកូនចៅអ៊ីស្រាអែល
អាឡុត
ឈ្មោះនៃដីមួយកន្លែង
1 Kings 4:18
ព័ត៌មានទូទៅ
បញ្ជីរាយនាមមន្ត្រីរបស់ព្រះបាទសាឡូម៉ូននិងតំបន់ដែលពួកគេទទួលបន្ទុកនៅតែបន្ត។
លោកស៊ីម៉ៃ...លោកអេឡា...លោកកេបើរ ...លោកអ៊ូរី...ស្តេចស៊ីហុន...ស្តេចអុក
ឈ្មោះរបស់មនុស្សប្រុស
បេនយ៉ាមីន
ដីកុលសម្ព័ន្ធដែលមានឈ្មោះសម្រាប់កូនប្រុសរបស់អ៊ីស្រាអែល
ស្រុកកាឡាដ...ស្តេចស្រុកបាសាន
ឈ្មោះចំណែកទឹកដី
ព្រមទាំងទឹកដីរបស់ស្តេចស៊ីហុន
«ដីដែលកាលពីដើមជាកម្មសិទ្ធិរបស់ស៊ីហុន»
ជនជាតិអាម៉ូរី
ឈ្មោះក្រុមរបស់មនុស្ស
នៅក្នុងតំបន់នោះ
ត្រង់នេះ «ដី» សំដៅលើទឹកដីយូដា។
មន្ត្រីមុនៗបានធ្វើជាអធិបតីលើផ្នែកផ្សេងៗនៃដីរបស់អ៊ីស្រាអែល។
1 Kings 4:20
ការចាប់ផ្តើមថ្មីនៃប្រធានបទ
ប្រជាជនអ៊ីស្រាអែលទាំងមូលមានមនុស្សច្រើនដូចខ្សាច់នៅមាត់សមុទ្រ
អ្នកពោលប្រើពាក្យនេះដើម្បីនិយាយថា
មានមនុស្សច្រើនណាស់ដែលមិនអាចរាប់ពួកគេបានទាំងអស់។ ពាក្យ «យូដា» និង
«អ៊ីស្រាអែល»
គឺជាពាក្យប្រៀបធៀបសម្រាប់ប្រជាជនដែលរស់នៅក្នុងស្រុកយូដានិងអ៊ីស្រាអែល។
«មានប្រជាជនច្រើននៅស្រុកយូដានិងអ៊ីស្រាអែលដូចជាមានគ្រាប់ខ្សាច់តាមមាត់សមុទ្រ»
ឬ
«មានប្រជាជននៅស្រុកយូដានិងអ៊ីស្រាអែលច្រើនជាងមនុស្សដែលអាចរាប់បាន»
ទន្លេ
«ទន្លេអឺប្រាត»
ម្សៅម៉ដ្ឋប្រាំបួនតោន
គឺជាឯកតារង្វាស់ស្ងួត។
ប្រើស ឈ្លូស ក្តាន់
សត្វជើងបួនដែលរត់លឿន
ក្តាន់
បញ្ជីរាយនាមមន្ត្រីរបស់ព្រះបាទសាឡូម៉ូននិងតំបន់ដែលពួកគេទទួលបន្ទុកនៅតែបន្ត។មានច្រើនជាងមួយនៃសត្វទាំងនេះ

generated on Wed Sep 10 16:16:32 2025

មាន់ទាបំប៉ន
«បក្សីដែលមនុស្សចិញ្ចឹមដូច្នេះពួកវានឹងធំធាត់»
1 Kings 4:24
ធីពសារ
ឈ្មោះដីមួយកន្លែង
ស្រុកយូដា និងស្រុកអ៊ីស្រាអែល
ពាក្យ «យូដា» និង «អ៊ីស្រាអែល»
គឺជាពាក្យប្រៀបប្រដូចសម្រាប់ប្រជាជនយូដានិងអ៊ីស្រាអែល។
មនុស្សរស់នៅដោយសុខសាន្ត ក្រោមដើមទំពាំងបាយជូរ និងដើមឧទុម្ពររបស់ខ្លួន
«គ្រួសារនីមួយៗមានសួនច្បារផ្ទាល់ខ្លួនដោយមានដើមទំពាំងបាយជូរនិងដើមឧទុម្ពរ»
នេះបានបង្ហាញថាប្រជាជនរស់នៅដោយសុវត្ថិភាព
និងសន្តិភាពចាប់តាំងពីពួកគេមិនមានសង្គ្រាម
ហើយមានពេលវេលាដើម្បីដាំសួនច្បាររបស់ពួកគេ។
ចាប់ពីក្រុងដាន់រហូតដល់ក្រុងបៀរសេបា
នេះតំណាងអោយទឹកដីអ៊ីស្រាអែលទាំងមូលចាប់ពីក្រុងដាន់នៅខាងជើងរហូតដល់បេ[illegible]
1 Kings 4:26
មានសេះ
ក្រោលគឺជាកន្លែងដែលសត្វសេះត្រូវបានរក្សាទុកនិងថែរក្សា។
អស់អ្នកដែលបរិភោគរួមតុជាមួយស្តេច
«អ្នកណាបរិភោគជាមួយស្តេចសាឡូម៉ូន» ឬ
«នរណាដែលស្តេចសាឡូម៉ូនបានអញ្ជើញអោយបរិភោគជាមួយទ្រង់»
គឺម្នាក់មួយខែ
ស្តេចសាឡូម៉ូនបានចាត់តាំងមន្ត្រីទាំង ១២ នាក់ ក្នុងជំពូក ៤: ៧
ឲ្យនាំយកអាហារមកអោយទ្រង់នៅខែផ្សេងៗគ្នា។
ពួកគេមិនឲ្យខ្វះខាតអ្វីឡើយ
នេះអាចត្រូវបានបង្ហាញជាវិជ្ជមាន
«ពួកគេបានផ្គត់ផ្គង់អ្វីៗទាំងអស់ដែលស្តេចសាឡូម៉ូនត្រូវការ»
1 Kings 4:29
ព្រះជាម្ចាស់បានប្រទានឲ្យព្រះបាទសាឡូម៉ូនមានប្រាជ្ញា និងការយល់ដឹងយ៉ាងខ្លាំង
ព្រះអាចជួយស្តេចសាឡូម៉ូនឲ្យមានប្រាជ្ញាហើយយល់ដឹងអ្វីៗជាច្រើន
គេនិយាយដូចជាព្រះជាម្ចាស់បានប្រទានឲ្យរបស់របរដល់ស្តេចសាឡូម៉ូន។
នាមអរូបី «ប្រាជ្ញា» និង «ការយល់ដឹង» អាចបកប្រែជាកិរិយាស័ព្ទ។
«ព្រះជាម្ចាស់បានធ្វើឲ្យសាឡូម៉ូនមានប្រាជ្ញានិង យល់អ្វីៗជាច្រើន»
ការយល់ដឹងយ៉ាងខ្លាំង ដូចជាខ្សាច់នៅមាត់សមុទ្រ
ស្តេចសាឡូម៉ូនអាចយល់ដឹងអ្វីៗជាច្រើនអំពីប្រធានបទផ្សេងៗគ្នា។ នាមអរូបី
«យល់ដឹង» អាចត្រូវបានបកប្រែជាគុណនាម។
«ស្តេចសាឡូម៉ូនអាចយល់បានច្រើនអំពីប្រធានបទជាច្រើន» សូមមើល
ស្តេចមានប្រាជ្ញាលើសមនុស្សទាំងអស់
«ស្តេចសាឡូម៉ូនឆ្លាតលើសមនុស្សមានប្រាជ្ញាទាំងអស់»
[illegible]
នេះសំដៅទៅលើប្រជាជនមកពីបណ្តាប្រទេសនៅភាគខាងកើតនៃប្រទេសអ៊ីស្រាអែល
ដូចជាអារ៉ាប់និងមេសូប៉ូតាមៀ។
លោកអេថា...លោកហេម៉ាន...លោកកាល់កូល...លោកដារដា ...លោកម៉ាហូល
ឈ្មោះរបស់មនុស្សប្រុស
1 Kings 4:32
ដើមតាត្រៅ....ដើមហ៊ីសុប
ពាក្យទាំងនេះបង្កើតបានជាការរួមបញ្ចូលគ្នា ដែលរួមបញ្ចូលទាំងរុក្ខជាតិទាំងអស់។
«ដើមតាត្រៅ ... ដើមឈើហ៊ីសុប» ឬ «ដើមឈើធំបំផុត ...
សំខាន់បំផុតនៃគុម្ពឈើ»

5

[1]ស្តេចហ៊ីរ៉ាម ជាស្តេចក្រុងទីរ៉ុសបានបញ្ជូនអ្នកបម្រើរបស់ទ្រង់មកគាល់ព្រះបាទសាឡូម៉ូន
ដោយសារទ្រង់បានឮថាគេបានចាក់ប្រេងអភិសេកព្រះបាទសាឡូម៉ូនជាស្តេចតពីបិតារបស់ទ្រង់ ដោយសារតែស្តេចហ៊ីរ៉ាមតែងតែស្រឡាញ់ស្តេចដាវីឌ។
[2]ព្រះបាទសាឡូម៉ូនក៏បានបញ្ជូនពាក្យទៅស្តេចហ៊ីរ៉ាមថា៖
[3]«ព្រះករុណាក៏ជ្រាបដែថាដាវីឌជាបិតាខ្ញុំមិនអាចសង់ដំណាក់សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់ជាព្រះរបស់ព្រះអង្គបានទេ ដោយសារតែមានសង្គ្រាមជុំវិញទ្រង់
ក្នុងថ្ងៃនៃអាយុរបស់បិតាខ្ញុំព្រះអម្ចាស់បានឲ្យសត្រូវរបស់លោកស្ថិតនៅក្រោមបាតជើងលោក។
[4]ប៉ុន្តែឥឡូវនេះ ព្រះអម្ចាស់ជាព្រះរបស់ខ្ញុំបានឲ្យមានក្តីសុខសាន្តគ្រប់ទីកន្លែង។ គ្មានខ្មាំងសត្រូវ ហើយក៏គ្មានមហន្តរាយអ្វីដែរ។[5]ដូច្នេះ
ខ្ញុំចង់សង់ដំណាក់សម្រាប់ព្រះនាមព្រះអម្ចាស់ជាព្រះរបស់ខ្ញុំ ដូចដែលព្រះអម្ចាស់បានមានបន្ទូលមកកាន់ស្តេចដាវីឌជាបិតារបស់ខ្ញុំថា៖ «បុត្រារបស់អ្នក
គឺអ្នកដែលយើងឲ្យគង់លើបល្ល័ង្ករបស់អ្នក នឹងសង់ដំណាក់សម្រាប់នាមយើង»។
[6]ដូច្នេះ សូមបញ្ជាឲ្យគេកាប់ដើមតាត្រៅនៅភ្នំលីបង់សម្រាប់ខ្ញុំផង។ អ្នកបម្រើរបស់ខ្ញុំ និងចូលរួមជាមួយអ្នកបម្រើរបស់ព្រះករុណា
ហើយខ្ញុំនឹងបង់ថ្លៃឲ្យព្រះករុណាសម្រាប់អ្នកបម្រើរបស់ព្រះករុណា ដូច្នេះពួកគេនឹងបានទទួលប្រាក់ឈ្នួលត្រឹមត្រូវតាមអ្វីដែលព្រះករុណាយល់ព្រមធ្វើ។
ដូចដែលព្រះករុណាជ្រាបហើយថាក្នុងចំណោមយើងគ្មាននរណាម្នាក់ដឹងរបៀបកាប់ឈើដូចអ្នកស្រុកស៊ីដូនទេ។
[7]នៅពេលដែលព្រះបាទហ៊ីរ៉ាមបានឮពាក្យរបស់ព្រះបាទសាឡូម៉ូន ទ្រង់មានអំណរយ៉ាងខ្លាំងរួចទូលថា៖ «សូមឲ្យព្រះអម្ចាស់បានប្រកបដោយព្រះពរនៅថ្ងៃនេះ
ដែលបានប្រទានបុត្រាដ៏មានប្រាជ្ញាដល់ស្តេចដាវីឌ ដើម្បីដឹកនាំប្រជារាស្ត្រដ៏អស្ចារ្យនេះ»។[8]ព្រះបាទហ៊ីរ៉ាមបានផ្ញើសារទៅព្រះបាទសាឡូម៉ូនថា៖
«ទូលបង្គំបានឮសារដែលព្រះករុណាបានផ្ញើមកទូលបង្គំហើយ។ ទូលបង្គំនឹងផ្គត់ផ្គង់ឈើតាត្រៅ និងឈើកកោះតាមដែលព្រះករុណាចង់បាន។
[9]អ្នកបម្រើរបស់ទូលបង្គំនឹងប្រមូលឈើចុះពីភ្នំលីបង់ទៅក្នុងសមុទ្រ
ហើយទូលបង្គំនឹងចងឈើទាំងនោះជាក្បូនបណ្តែតតាមសមុទ្រទៅកាន់កន្លែងដែលព្រះករុណាបង្ហាញដល់ទូលបង្គំ។ ទូលបង្គំនឹងដាក់នៅកន្លែងនោះ
ហើយព្រះករុណាអាចយកឈើទាំងនោះទៅ។ អ្វីដែលទូលបង្គំចង់បាន គឺសូមព្រះករុណាជួយផ្តល់អាហារដល់អ្នកបម្រើក្នុងព្រះរាជវាំងរបស់ទូលបង្គំផង»។
[10]ដូច្នេះ ព្រះបាទហ៊ីរ៉ាមបានថ្វាយឈើកកោះទាំងប៉ុន្មាន តាមការចង់បានរបស់ព្រះបាទសាឡូម៉ូន។[11]ព្រះបាទសាឡូម៉ូនបានផ្តល់ស្រូវសាលីពីរម៉ឺនរង្វាល់ និងប្រេងសុទ្ធ
ចំនួនពីរពាន់រង្វាល់សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការក្នុងវាំងរបស់ព្រះបាទហ៊ីរ៉ាម។ ព្រះបាទសាឡូម៉ូនបានផ្តល់ដល់ព្រះបាទហ៊ីរ៉ាមពីមួយឆ្នាំទៅមួយឆ្នាំ។
[12]ព្រះអម្ចាស់បានផ្តល់ប្រាជ្ញាដល់ព្រះបាទសាឡូម៉ូន ដូចដែលព្រះអង្គបានសន្យា។ មានសន្តិភាពរវាងព្រះបាទសាឡូម៉ូន និងព្រះបាទហ៊ីរ៉ាម
ហើយស្តេចទាំងពីរក៏ចងសម្ពន្ធមេត្រីជាមួយគ្នា។
[13]ព្រះបាទសាឡូម៉ូនបានកែនកម្លាំងចេញពីប្រជាជនអ៊ីស្រាអែលទាំងអស់។ អ្នកដែលបានកែនមានប្រុសៗចំនួនបីម៉ឺននាក់។
[14]ស្តេចបានបញ្ជូនពួកគេទៅភ្នំលីបង់ម្តងមួយម៉ឺននាក់ដោយប្តូរវេនគ្នា។ មួយខែត្រូវនៅភ្នំលីបង់ហើយពីរខែត្រូវនៅផ្ទះ។ លោក
អដូនីរ៉ាមជាអ្នកមើលខុសត្រូវលើអ្នកដែលធ្វើការទាំងនោះ។
[15]ព្រះបាទសាឡូម៉ូនមានអ្នកលីសែងចំនួនប្រាំពីរម៉ឺននាក់ និងអ្នកដាប់ថ្មនៅភ្នំចំនួនប្រាំបីម៉ឺននាក់[16]ក្រៅពីមេក្រុម៣៣០០នាក់របស់ព្រះបាទសាឡូម៉ូន
ដែលមើលខុសត្រូវលើការងារ និងជាអ្នកណែនាំដល់អ្នកធ្វើការ។
[17]ដូចដែលស្តេចបានបង្គាប់ ពួកគេបានគាស់ថ្មធំៗដែលមានគុណភាពល្អសម្រាប់ធ្វើជាគ្រឹះរបស់ព្រះវិហារ។[18]ដូច្នេះអ្នកសាងសង់របស់ព្រះបាទសាឡូម៉ូន
និងអ្នកសាងសង់របស់ព្រះបាទហ៊ីរ៉ាម ព្រមទាំងជាងពីស្រុកកេបាលបានដាប់ថ្ម ហើយរៀបចំត្រៀមឈើ និងថ្មសម្រាប់សង់ព្រះវិហារ។

---

1 Kings 5:1
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូននិយាយជាមួយស្តេចហ៊ីរ៉ាមអំពីការកសាងព្រះវិហារ។
ស្តេចហ៊ីរ៉ាមតែងតែស្រឡាញ់ស្តេចដាវីឌ

generated on Wed Sep 10 16:16:32 2025

«ស្តេចហ៊ីរ៉ាមតែងតែជាមិត្តជិតស្និទ្ធរបស់ស្តេចដាវីឌ»
ព្រះអម្ចាស់បានឲ្យសត្រូវរបស់លោកស្ថិតនៅក្រោមបាតជើងលោក
ការដាក់សត្រូវនៅក្រោមជើងរបស់នរណាម្នាក់មានន័យថា យកឈ្នះពួកគេ។
«ព្រះជាម្ចាស់បានជួយស្តេចដាវីឌ ឲ្យយកឈ្នះខ្មាំងសត្រូវរបស់គាត់» ឬ «
ស្តេចដាវីឌរវល់តាំងពីព្រះអម្ចាស់បានប្រទានជ័យជម្នះដល់ខ្មាំងសត្រូវរបស់ទ្រង់»
។
សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់
ពាក្យ «នាម» គឺសំដៅទៅលើមនុស្សហើយ «សម្រាប់នាម»
សំដៅទៅលើការគោរពបូជាមនុស្សនៅក្នុងជំពូក ៣: ១ ។
«ដែលមនុស្សនឹងថ្វាយបង្គំព្រះជាម្ចាស់»
ដោយសារតែមានសង្គ្រាមជុំវិញទ្រង់
អត្ថន័យដែលអាចទៅរួចមួយទៀតគឺ
«ដោយសារតែសង្គ្រាមដែលសត្រូវរបស់ទ្រង់ព័ទ្ធជុំវិញ» ឬ
«ពីព្រោះទ្រង់កំពុងប្រយុទ្ធជាមួយសត្រូវនៅគ្រប់ទិសទី»
ព្រះអម្ចាស់បានឲ្យសត្រូវរបស់លោកស្ថិតនៅក្រោមបាតជើងលោក
បាតជើងគឺសំដៅទៅលើការគ្រប់គ្រងពេញលេញលើមនុស្សម្នាក់។
«ព្រះអម្ចាស់បានជួយអោយស្តេចដាវីឌឈ្នះខ្មាំងសត្រូវរបស់ទ្រង់ទាំងស្រុង»
1 Kings 5:4
ព័ត៌មានទូទៅ
ព្រះបាទសាឡូម៉ូនបន្តនិយាយជាមួយព្រះបាទហ៊ីរ៉ាមអំពីការកសាងព្រះវិហារ។
បានឲ្យមានក្តីសុខសាន្តគ្រប់ទីកន្លែង
មុនពេលដែលព្រះបាទសាឡូម៉ូនឡើងសោយរាជ្យស្តេចដាវីឌនិងប្រជាជនអ៊ីស្រាអែលបានធ្វើសង្គ្រាម
គ្មានខ្មាំងសត្រូវ ហើយក៏គ្មានមហន្តរាយអ្វីដែរ
ទាំងមនុស្សដែលបង្កអន្តរាយវិញក៏ធម្មជាតិដែលបង្កអន្តរាយ។
នេះអាចបញ្ជាក់ជាវិជ្ជមាន។
«យើងមានសុវត្ថិភាពពីសត្រូវរបស់យើងនិងពីគ្រោះមហន្តរាយធម្មជាតិ»
ខ្មាំងសត្រូវ
សត្រូវ
មហន្តរាយ
ការដែលធ្វើឲ្យមហន្តរាយដល់មនុស្សនិងទ្រព្យសម្បត្តិ
ដូច្នេះ
នេះបញ្ជាក់ពាក្យដែលនៅតាមក្រោយ។ សុំស្តាប់! នេះគឺជាអ្វីដែលយើងនឹងធ្វើ ឬ
ពីព្រោះអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់ខ្ញុំ នេះគឺជាអ្វីដែលខ្ញុំនឹងធ្វើ។
សម្រាប់ព្រះនាមព្រះអម្ចាស់ជាព្រះរបស់ខ្ញុំ ...សម្រាប់នាមយើង
ពាក្យ «នាម» គឺសំដៅទៅលើមនុស្ស។
«កន្លែងដែលព្រះអម្ចាស់ជាព្រះរបស់ខ្ញុំនឹងគង់នៅ...កន្លែងដែលយើងនឹងរស់នៅ»
គឺអ្នកដែលយើងឲ្យគង់លើបល្ល័ង្ករបស់អ្នក
នៅទីនេះ «បល្ល័ង្ក» សំដៅទៅលើការគ្រប់គ្រងជាស្តេច។ « ធ្វើជាស្តេចបន្ទាប់ពីអ្នក»
1 Kings 5:6
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនបន្តនិយាយជាមួយស្តេចហ៊ីរ៉ាមអំពីការកសាងព្រះវិហារ។
ក្នុងចំណោមយើងគ្មាននរណាម្នាក់ដឹងរបៀបកាប់ឈើដូចអ្នកស្រុកស៊ីដូនទេ
«កម្មកររបស់អ្នកដឹងពីរបៀបកាប់ឈើល្អជាងកម្មការរបស់ខ្ញុំ»
ស្រុកស៊ីដូន
«ប្រជាជនស៊ីដូន»
1 Kings 5:7
ព័ត៌មានទូទៅ
ស្តេចហ៊ីរ៉ាមឆ្លើយតបនឹងស្តេចសាឡូម៉ូន។
ពាក្យរបស់ព្រះបាទសាឡូម៉ូន
អ្វីដែលស្តេចសាឡូម៉ូនបាននិយាយ
ព្រះអម្ចាស់បានប្រកបដោយព្រះពរនៅថ្ងៃនេះ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «ខ្ញុំសរសើរដល់ព្រះជាម្ចាស់នៅថ្ងៃនេះ»
តាត្រៅ
តាត្រៅ
គឺជាប្រភេទឈើមានតម្លៃមួយប្រភេទទៀតដែលនឹងត្រូវប្រើសម្រាប់សាងសង់ព្រះវិហារ។
1 Kings 5:9
ព័ត៌មានទូទៅ
ស្តេចហ៊ីរ៉ាមបន្តឆ្លើយនឹងព្រះបាទសាឡូម៉ូន។
ចងឈើទាំងនោះជាក្បួនបណ្តែត
«ចងវាជាមួយគ្នាដូច្នេះពួកគេនឹងអណ្តែតជាក្រុម»
ដាក់នៅកន្លែងនោះ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ "កម្មករខ្ញុំស្រាយចំណង់ដែលចងនោះ"
អ្វីដែលទូលបង្គំចង់បាន
«អ្នកអាចធ្វើអ្វីដែលខ្ញុំចង់បាន» ឬ «អ្នកអាចបង់ប្រាក់ឲ្យខ្ញុំ»
1 Kings 5:10
កកោះ
ពាក្យថាឈើកកោះសំដៅទៅលើដើមឈើជាច្រើនប្រភេទរួមទាំងដើមជ្រៃផង។
ស្រូវសាលី
នេះគឺជារង្វាស់ស្ងួតរឹងប្រេងគឺជារង្វាស់រាវ។
គេមិនទាន់ដឹងច្បាស់ថាតើវិធានការណ៍ណាមួយដែលត្រូវបានគេគ្រោងទុក។
យូឌីប៊ីគិតថា ការស្មានដែលមានការអប់រំ។
ដោយសារតែសន្តិភាពនេះ ឥឡូវនេះស្តេចសាឡូម៉ូននិងប្រជាជនបានសម្រាកនិងមានសេចក្តីសុខសាន្ត។
«រៀងរាល់ឆ្នាំ»
1 Kings 5:13
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូនបង្ខំមនុស្សប្រុសឲ្យសាងសង់ព្រះវិហារ។
បានកែនកម្លាំងចេញពីប្រជាជនអ៊ីស្រាអែលទាំងអស់
«បង្ខំឲ្យមនុស្សប្រុសមកពីទូទាំងអ៊ីស្រាអែលធ្វើការ»
ប្តូរវេនគ្នា
នោះគឺមានបីក្រុមដែលបានប្តូរវេនចំណាយពេលមួយខែនៅភ្នំលីបង់និងពីរខែនៅផ្ទះ។
មួយខែត្រូវនៅភ្នំលីបង់ហើយពីរខែត្រូវនៅផ្ទះ
ក្រុមនីមួយៗនៃក្រុមទាំងបីបានចំណាយពេលមួយខែធ្វើការនៅភ្នំលីបង់ហើយបន្ទាប់មកពីរខែនៅផ្ទះនៅអ៊ីស
អ្នកមើលខុសត្រូវលើអ្នកដែលធ្វើការទាំងនោះ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«មនុស្សប្រុសដែលស្តេចសាឡូម៉ូនបានបង្ខំឲ្យធ្វើការឲ្យគាត់»
1 Kings 5:15
ព័ត៌មានទូទៅ
ព្រះបាទសាឡូម៉ូនបន្តបង្ខំមនុស្សប្រុសឲ្យសាងសង់ព្រះវិហារ។
អ្នកលីសែង
«របស់ធ្ងន់ៗ»
អ្នកដាប់ថ្ម
«បុរសដែលជីកថ្មចេញពីដីហើយកាត់វា»
1 Kings 5:17
ព័ត៌មានទូទៅ
ស្តេចសាឡូម៉ូននៅតែបន្តបង្ខំមនុស្សប្រុសឲ្យសាងសង់ព្រះវិហារ។
គាស់ថ្មធំៗដែលមានគុណភាពល្អ
«ជីកយកថ្មល្អៗ ពីលើភ្នំហើយកាត់វាអោយមានរាងត្រឹមត្រូវ»
ស្រុកកេបាល
មនុស្សប្រុសមកពីស្រុកកេបាល

---

6 [1]ដូច្នេះ ព្រះបាទសាឡូម៉ូនបានចាប់ផ្តើមសង់ព្រះវិហារសម្រាប់ព្រះអម្ចាស់។ ការនេះកើតឡើងនៅក្នុងឆ្នាំទី ៤៨០ ក្រោយពីជនជាតិអ៊ីស្រាអែលចេញពីទឹកដីស្រុកអេស៊ីប
នៅក្នុងឆ្នាំទីបួននៃរាជ្យរបស់ព្រះបាទសាឡូម៉ូនលើទឹកដីអ៊ីស្រាអែល នៅក្នុងខែពិសាខ ដែលត្រូវជាខែទីពីរ។[2]ព្រះវិហារដែលព្រះបាទសាឡូម៉ូនសង់ថ្វាយព្រះអម្ចាស់ មាន
បណ្តោយប្រវែងហុកសិបហត្ថ ទទឹងម្ភៃហត្ថ និងកម្ពស់សាមសិបហត្ថ ។
[3]បន្ទប់ល្វែងនៅខាងមុខបន្ទប់ធំនៃព្រះវិហារមានបណ្តោយប្រវែងម្ភៃហត្ថ ស្មើនឹងប្រវែងទទឹងព្រះវិហារ ហើយមានជម្រៅដប់ហត្ថនៅខាងមុខព្រះវិហារ។
សម្រាប់ព្រះវិហារ[4]ស្តេចបានធ្វើបង្អួចដែលមានដាក់គ្របរបស់វាដែលខាងក្រៅចង្អៀតជាងខាងក្នុង។
[5]នៅជាប់នឹងជញ្ជាំងបន្ទប់ធំ ស្តេចបានសង់បន្ទប់ជុំវិញ ទាំងបន្ទប់ខាងក្រៅ និងបន្ទប់ខាងក្នុង។ ស្តេចបានសង់បន្ទប់នៅជុំវិញទាំងសងខាង។
[6]ជាន់ក្រោមបំផុតមានបណ្តោយប្រាំហត្ថ នៅកណ្តាលមានបណ្តោយប្រាំមួយហត្ថ ហើយនៅជាន់ទីបីមានបណ្តោយប្រាំពីរហត្ថ។
ជញ្ជាំងខាងក្រៅព្រះវិហារស្តេចធ្វើជញ្ជាំងកម្រាស់ខុសគ្នានៅជុំវិញ ដូច្នេះមិនចាំបាច់ដាក់ធ្នឹមនៅក្នុងជញ្ជាំងព្រះវិហារទេ។

generated on Wed Sep 10 16:16:32 2025

[7]ព្រះវិហារសង់ពីថ្មដែលបានរៀបចំរួចជាស្រេចនៅនឹងកន្លែង។ គ្មានឮសម្លេងញញួរ ពូថៅ ឬសម្ភារធ្វើពីដែកណាមួយនៅក្នុងព្រះវិហារក្នុងពេលកំពុងសាងសង់ឡើយ។
[8]នៅផ្នែកខាងត្បូងនៃព្រះវិហារមានច្រកចូលមួយនៅជាន់ផ្ទាល់ដី បន្ទាប់មក មានជណ្តើរមួយឡើងទៅជាន់កណ្តាល និងពីជាន់កណ្តាលទៅជាន់ទីបី។
[9]ដូច្នេះ ព្រះបាទសាឡូម៉ូនបានសង់ព្រះវិហារ និងបានបញ្ចប់ការសាងសង់ ស្តេចគ្របដណ្តប់វិហារទាំងមូលដោយធ្នឹម និងពិដានពីឈើតាត្រៅ។
[10]ស្តេចសង់បន្ទប់ខាងក្រៅទល់នឹងបន្ទប់ធំរបស់ព្រះវិហារ ផ្នែកនីមួយៗមានកម្ពស់ប្រាំហត្ថ ហើយបន្ទប់ទាំងនោះបានភ្ជាប់ជាមួយព្រះវិហារដោយឈើតាត្រៅ។
[11]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ព្រះបាទសាឡូម៉ូនដោយមានបន្ទូលថា៖[12]«ទាក់ទងនឹងព្រះវិហារដែលអ្នកបានសង់នេះ បើអ្នកដើរតាមច្បាប់របស់យើង
និងប្រព្រឹត្តដោយយុត្តិធម៌ ដោយរក្សាបញ្ញត្តរបស់យើង និងដើរតាមបញ្ញត្តិនោះ នោះយើងនឹងសម្រេចពាក្យដែលយើងបានសន្យាជាមួយអ្នក
ដែលយើងបានសន្យាជាមួយបិតារបស់អ្នក។[13]យើងនឹងគង់នៅក្នុងចំណោមប្រជារាស្ត្រអ៊ីស្រាអែល និងមិនបោះបង់ពួកគេចោលឡើយ។
[14]ដូច្នេះ ព្រះបាទសាឡូម៉ូនបានសង់ព្រះវិហារ និងបានបញ្ចប់ការសាងសង់។[15]បន្ទាប់មក ស្តេចក៏បានសង់ជញ្ជាំងខាងក្នុងនៃព្រះវិហារជាមួយឈើតាត្រៅ។
ចាប់ពីក្រោមរហូតដល់ពិដានរបស់ព្រះវិហារ ស្តេចបានពាសឈើនៅខាងក្នុង និងក្រាលក្តារកកោះនៅក្នុងព្រះវិហារដែរ។
[16]ស្តេចក៏បានសង់ផ្នែកខាងក្រោយព្រះវិហារមានប្រវែងម្ភៃហត្ថជាមួយក្តារឈើតាត្រៅចាប់ពីក្រោមរហូតដល់ពិដាន។ ស្តេចបានសង់បន្ទប់នេះជាបន្ទប់ខាងក្នុង
ដែលជាទីសក្ការៈបំផុត។[17]បន្ទប់ធំជាងគេ ដែលជាទីសក្ការៈ គឺនៅខាងមុខទីសក្ការៈបំផុតមានប្រវែងសែសិបហត្ថ។[18]មានឈើតាត្រៅពាសនៅខាងក្នុងព្រះវិហារ ដែលឆ្លាក់
ជាក្បាច់រចនារូបផ្កាក្រពុំ និងរូបផ្កាវីក។ គ្រប់ទាំងអស់មានពាសឈើតាត្រៅនៅខាងក្នុង។ នៅផ្នែកខាងក្នុងមិនអាចមើលឃើញថ្មឡើយ។
[19]ព្រះបាទសាឡូម៉ូនបានរៀបចំបន្ទប់ខាងក្នុង នៅក្នុងព្រះវិហារ ដើម្បីដាក់ហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។[20]បន្ទប់ខាងក្នុងមានប្រវែងម្ភៃហត្ថ មានទទឹងម្ភៃហត្ថ
និងកម្ពស់ម្ភៃហត្ថដូចគ្នា។ ព្រះបាទសាឡូម៉ូនបានពាសជញ្ជាំងដោយមាសសុទ្ធ និងពាសអាសនាដោយឈើតាត្រៅ។
[21]ព្រះបាទសាឡូម៉ូនបានពាសផ្នែកខាងក្នុងនៃព្រះវិហារជាមួយនឹងមាសសុទ្ធ ហើយស្តេចបានដាក់ច្រវ៉ាក់មាសមកឃាំងខាងមុខបន្ទប់ខាងក្នុង
និងបានពាសខាងមុខនោះដោយមាស។[22]ស្តេចបានពាសផ្នែកខាងក្នុងទាំងអស់ជាមួយមាសទាល់តែព្រះវិហារបានរួចរាល់។ ស្តេចក៏បានពាសមាសលើអាសនាទាំងមូល
ដែលនៅបន្ទប់ខាងក្នុងដែរ។
[23]ព្រះបាទសាឡូម៉ូនបានឲ្យគេឆ្លាក់រូបចេរូប៊ីនពីរធ្វើអំពីឈើអូលីវ ចេរូប៊ីននីមួយៗមានកម្ពស់ដប់ហត្ថ សម្រាប់ដាក់នៅបន្ទប់ខាងក្នុង។[24]ស្លាបមួយនៃចេរូប៊ីន
ទីមួយមានប្រវែងប្រាំហត្ថ ហើយស្លាបមួយទៀតក៏មានប្រវែងប្រាំហត្ថដែរ។ ដូច្នេះ ពីចុងស្លាបម្ខាងទៅចុងស្លាបម្ខាងមានប្រវែងដប់ហត្ថ។
[25]ចេរូប៊ីនមួយទៀតក៏មានប្រវែងស្លាបដប់ហត្ថដែរ។ ចេរូប៊ីនទាំងពីរមានប្រវែង និងរូបរាងដូចគ្នា។[26]កម្ពស់របស់ចេរូប៊ីនទីមួយគឺដប់ហត្ថ
ហើយចេរូប៊ីនមួយទៀតក៏មានកម្ពស់ដូចគ្នា។
[27]ព្រះបាទសាឡូម៉ូនបានដាក់ចេរូប៊ីននៅក្នុងបន្ទប់ខាងក្នុងបំផុត។ ស្លាបរបស់ចេរូប៊ីនត្រាដាង ដូច្នេះ ស្លាបរបស់ចេរូប៊ីនមួយប៉ះនឹងជញ្ជាំងម្ខាង
ហើយស្លាបរបស់ចេរូប៊ីនមួយទៀតប៉ះជាមួយជញ្ជាំងម្ខាងទៀត។ ស្លាបរបស់ចេរូប៊ីនទាំងពីរប៉ះគ្នានៅចំណុចកណ្តាលនៃទីបរិសុទ្ធបំផុត។
[28]ព្រះបាទសាឡូម៉ូនបានពាសមាសលើចេរូប៊ីនទាំងពីរនោះ។
[29]ស្តេចបានឆ្លាក់តាមជញ្ជាំងព្រះដំណាក់ទាំងអស់ មានដូចជាក្បាច់ចេរូប៊ីន ដើមត្នោត និងផ្កាវីក ទាំងបន្ទប់ខាងក្នុង និងបន្ទប់ខាងក្រៅ។
[30]ព្រះបាទសាឡូម៉ូនក្រាលមាសក្នុងព្រះវិហារ ទាំងបន្ទប់ខាងក្រៅ និងបន្ទប់ខាងក្នុង។
[31]ព្រះបាទសាឡូម៉ូនបានធ្វើទ្វារពីឈើអូលីវសម្រាប់ច្រកចូលទៅកាន់បន្ទប់ខាងក្នុង។ ក្របទ្វារនោះមានកម្ពស់មួយភាគបួននៃជញ្ជាំង។[32]ដូច្នេះ
ស្តេចបានធ្វើទ្វារពីរពីឈើអូលីវ ហើយបានឆ្លាក់រូបចេរូប៊ីម ដើមត្នោត និងផ្កាវីកលើទ្វារទាំងនោះផង។ ស្តេចបានពាសទ្វារទាំងនោះដោយមាស និងពាសមាសលើចេរូប៊ីម
និងលើដើមត្នោតផងដែរ។
[33]តាមវិធីនេះដែលព្រះបាទសាឡូម៉ូនបានសង់ច្រកចូលព្រះវិហារពីឈើអូលីវមានកម្ពស់មួយភាគបួននៃជញ្ជាំង និងមានទ្វារពីរទៀតធ្វើពីឈើកកោះ។
[34]សន្លឹកទាំងពីររបស់ទ្វារនីមួយៗអាចបត់ចូលគ្នាបាន ហើយសន្លឹកពីរទៀតរបស់ទ្វារមួយទៀតក៏អាចបត់ចូលគ្នាបានដែរ។[35]ស្តេចបានឆ្លាក់រូបចេរូប៊ីម ដើមត្នោត និងផ្កាវីក
និងបានពាសមាសលើចម្លាក់ទាំងនោះ។
[36]ស្តេចឲ្យគេសង់ទីលានខាងក្នុងជាមួយថ្មបីជាន់ និងឈើតាត្រៅមួយជាន់។
[37]គេបានចាក់គ្រឹះព្រះដំណាក់របស់ព្រះអម្ចាស់នៅក្នុងឆ្នាំទីបួន នៅក្នុងខែពិសាខ។[38]នៅក្នុងឆ្នាំទីដប់មួយ នៅក្នុងខែកត្តិក
នៅក្នុងខែទីប្រាំបីព្រះវិហារបានសង់រួចរាល់គ្រប់ផ្នែកទាំងអស់តាមគម្រោង។ ព្រះបាទសាឡូម៉ូនបានចំណាយប្រាំពីរឆ្នាំក្នុងការសង់ព្រះវិហារ។

---

1 Kings 6:1

ព័ត៌មានទូទៅ

អ្នកពិពណ៌នារៀបរាប់អំពីការវាស់វែងនៃព្រះវិហារ។

ព្រះបាទសាឡូម៉ូនបានចាប់ផ្តើមសង់

វាជាការល្អបំផុតដើម្បីបកប្រែដូច្នេះអ្នកអានយល់ថា
មនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើបែបនេះ។

ឆ្នាំទី ៤៨០ ...ទីបួន

ទាំងនេះគឺជាទម្រង់បែបបទធម្មតានៃ ៤៨០ និង ៤។

នៅក្នុងខែពិសាខ ដែលត្រូវជាខែទីពីរ

«ពិសាខ» គឺជាឈ្មោះខែទី ២ នៃប្រតិទិនហេព្រើរ។
វាគឺជាអំឡុងពេលចុងក្រោយនៃខែមេសា និងផ្នែកដំបូងនៃខែឧសភា
នៅលើប្រតិទិនលោកខាងលិច។

មានបណ្តោយប្រវែងហុកសិបហត្ថ ទទឹងម្ភៃហត្ថ និងកម្ពស់សាមសិបហត្ថ

មួយហត្ថគឺ ៤៦ សង្ទីម៉ែត្រ។ «បណ្តោយ ២៧,៦ ម៉ែត្រទទឹង ៩,២ ម៉ែត្រនិងកំពស់ ១៣,៨ ម៉ែត្រ»

1 Kings 6:3

ព័ត៌មានទូទៅ

និទានកថានៅតែបន្តការវាស់វែងរបស់ព្រះវិហារ។

បន្ទប់ល្វែង

តំបន់មួយនៃអាគារធ្វើជាជួរឈរនិងដំបូលដែលនាំទៅដល់ និង
ភ្ជាប់ជាមួយទ្វារចូលនៃអាគារ។

ប្រវែងម្ភៃ...ជម្រៅដប់ហត្ថ

មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «៩,២ ម៉ែត្រ ... ៤,៦ ម៉ែត្រ»

1 Kings 6:5

ព័ត៌មានទូទៅ

និទានកថានៅតែបន្តការវាស់វែងនៃព្រះវិហារ។

ស្តេចបានសង់បន្ទប់ជុំវិញ

ស្តេចបានសាងសង់បន្ទប់នៅខាងក្រៅជញ្ជាំងខាងក្រៅជុំវិញបន្ទប់ធំ។

ជាន់ក្រោមបំផុត...នៅកណ្តាល...ទីបី

នេះសំដៅទៅលើបន្ទប់នៅក្នុងជាន់នីមួយៗនៃអាគារ។

ជ្រាំហត្ថ ..ជ្រាំមួយហត្ថ..ជ្រាំពីរហត្ថ

មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «ប្រហែល ២,៣ ម៉ែត្រ ... ប្រហែល ២,៨ ម៉ែត្រ ... ប្រហែល ៣,២ ម៉ែត្រ»

ស្តេចធ្វើជញ្ជាំងកម្រាស់ខុសគ្នានៅជុំវិញ

ពួកគេធ្វើជណ្តើរព័ទ្ធជុំវិញអគារធំៗ ដើម្បីទ្រទ្រង់ធ្នឹមនៃបន្ទប់តូចៗ។

ធ្នឹម

ធ្នឹមគឺជាបំណែកឈើធ្ងន់វែងដែលត្រូវបានប្រើសម្រាប់ទ្រទ្រង់អគារ។

1 Kings 6:7

ព្រះវិហារ

នៅទីនេះ « ផ្ទះ» សំដៅទៅលើដំណាក់របស់ព្រះគឺព្រះវិហារ។

ថ្មដែលបានរៀបចំរួចជាស្រេចនៅនឹងកន្លែង

កន្លែងយកថ្មគឺជាកន្លែងដែលមនុស្សកាត់ដុំថ្មធំៗ
ច្រកនេះប្រហែលជាត្រូវបានភ្ជាប់ទៅនឹងផ្នែកខាងមុខនៃជញ្ជាំងដែលព័ទ្ធជុំវិញព្រះវិហារពីលើភ្នំហើយធ្វើឲ្យមានរាងដើម្បីមើលទៅវារលូនស្អាត។

generated on Wed Sep 10 16:16:32 2025

បន្ទាប់ពីពួកគេបានរៀបចំដុំថ្មនៅកន្លែងយកថ្មរួចហើយពួកគេបានយកវាមកព្រះវិហារ។
ជាន់ផ្ទាល់ដី ...ជាន់កណ្តាល..ជាន់ទីបី
មានចំនួនសរុបបីជាន់។ ភាសាខ្លះហៅថា «ជាន់ក្រោម» «ជាន់ទីមួយ» និង «ជាន់ទី ២» ។
1 Kings 6:9
ព្រះបាទសាឡូម៉ូនបានសង់ព្រះវិហារ និងបានបញ្ចប់ការសាងសង់
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើបែបនេះ។
ធ្នឹម...តាត្រៅ
ធ្នឹមគឺជាបំណែកឈើធ្ងន់វែងដែលត្រូវបានប្រើសម្រាប់ទ្រទ្រង់អគារ។
បកប្រែដូចនៅក្នុងជំពូក ៦: ៥ ។
ពិដានពីឈើតាត្រៅ
បន្ទះក្តារគឺជាក្តារបន្ទះឈើដែលប្រើសម្រាប់ជាន់និងជញ្ជាំង។
ស្តេចសង់បន្ទប់ខាងក្រៅ
ទាំងនេះគឺជាបន្ទប់តែមួយ ដែលត្រូវបានគេសំដៅទៅក្នុងជំពូក ៦: ៥ ។
បន្ទប់ធំ
ឃ្លានេះគឺសំដៅទៅលើជញ្ជាំងដែលព័ទ្ធជុំវិញបន្ទប់។ «
ជញ្ជាំងផ្នែកខាងក្រៅដែលព័ទ្ធជុំវិញបន្ទប់ខាងក្នុង»
ជ្រាំហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ ការបកប្រែផ្សេងទៀត «២,៣ ម៉ែត្រ»
ឈើតាត្រៅ
ពាក្យថា «ឈើតាត្រៅ»
គឺជាពាក្យទូទៅដែលសំដៅទៅលើឈើដែលត្រូវបានប្រើសម្រាប់សាងសង់ដូចជាធ្នឹមនិងក្តារ។
1 Kings 6:11
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
នេះត្រូវបានប្រើដើម្បីណែនាំអ្វីមួយ
ដែលព្រះបានប្រាប់ព្យាការីឬប្រជាជនរបស់ទ្រង់។ «ព្រះអម្ចាស់មានព្រះបន្ទូលនេះ»
ឬ «ព្រះអម្ចាស់មានព្រះបន្ទូលទាំងនេះ»
ដើរតាមច្បាប់របស់យើង
ពាក្យថា « ដើរ» ជាពាក្យប្រៀបធៀបសម្រាប់ «រស់» ឬ «គោរពតាម» ។
«គោរពតាមលក្ខន្តិកៈរបស់ខ្ញុំជាបន្ត»
ប្រព្រឹត្តដោយយុត្តិធម៌
អាចមានន័យថា ១) «អនុវត្តច្បាប់របស់ខ្ញុំទាំងអស់» ឬ ២)
«ប្រព្រឹត្តចំពោះមនុស្សដែលអ្នកកំពុងគ្រប់គ្រងដោយយុត្តិធម៌» ។
រក្សាបញ្ញត្តរបស់យើង និងដើរតាមបញ្ញត្តនោះ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាហើយនិយាយពីសារសំខាន់នៃការគោរពតាមបញ្ញត្តិរបស់ព្រះ។
«គោរពតាមអ្វីទាំងអស់ដែលយើងប្រាប់អ្នកឲ្យធ្វើ»
នោះយើងនឹងសម្រេចពាក្យដែលយើងបានសន្យាជាមួយអ្នក
ដែលយើងបានសន្យាជាមួយបិតារបស់អ្នក
«យើងនឹងធ្វើអ្វីគ្រប់យ៉ាងដែលយើងបានសន្យាដល់ស្តេចដាវីឌជាឪពុករបស់អ្នកថាយើងនឹងធ្វើ
1 Kings 6:14
ព្រះបាទសាឡូម៉ូន... ស្តេចក៏បានសង់...ស្តេចបានពាស
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើអ្វីៗទាំងនេះ។
ជញ្ជាំងខាងក្នុង
ខាងក្នុង
តាត្រៅ
តាត្រៅគឺជាឈើមួយប្រភេទដែលត្រូវបានប្រើសម្រាប់សាងសង់ព្រះវិហារ។
1 Kings 6:16
ស្តេចក៏បានសង់ផ្នែកខាងក្រោយព្រះវិហារមានប្រវែងម្ភៃហត្ថ
«ស្តេចបានសាងសង់បន្ទប់មួយដែលមានបណ្តោយម្ភៃហត្ថ»
ម្ភៃហត្ថ...សែសិបហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «៩,២ ម៉ែត្រ ... ១៨,៤ ម៉ែត្រ»
បន្ទប់ធំជាងគេ
«បន្ទប់មេ»
ផ្កាក្រពុំ
ជាប្រភេទបន្លែមូលរឹងដែលដុះនៅលើដើមទំពាំងបាយជូរនៅលើដី
រូបផ្ការីក
«ផ្ការីក» ឬ «ផ្កាដែលបានបើក»
1 Kings 6:19
ម្ភៃហត្ថ
«៩,២ ម៉ែត្រ»
ពាសអាសនាដោយឈើតាត្រៅ
អាសនានេះនឹងត្រូវប្រើសម្រាប់ដុតធូប។
1 Kings 6:21
បានពាស
គ្របដណ្តប់
អាសនាទាំងមូល ដែលនៅបន្ទប់ខាងក្នុងដែរ
«អាសនាដុតធូបនៅច្រកចូលបន្ទប់ខាងក្នុង»
1 Kings 6:23
ឈើអូលីវ
«ឈើពីដើមអូលីវ»
ដប់ហត្ថ ...ជ្រាំហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «៤,៦ ម៉ែត្រ ... ២,៣ ម៉ែត្រ»
ប្រវែងស្លាប
ចម្ងាយពីចុងស្លាបមួយទៅចុងស្លាបមួយទៀត
ប្រវែង
«ទំហំ»
1 Kings 6:27
ព្រះបាទសាឡូម៉ូនបានដាក់...ព្រះបាទសាឡូម៉ូនបានពាស
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើបែបនេះ។
នៅក្នុងបន្ទប់ខាងក្នុងបំផុត
ឈ្មោះមួយទៀតសម្រាប់ទីបរិសុទ្ធបំផុត
បានពាស
«គ្របដណ្តប់»
1 Kings 6:29
ស្តេច...សាឡូម៉ូន
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើបែបនេះ។
ជាក្បាច់
រូបរាង
ក្រាល
គ្របដណ្តប់
1 Kings 6:31
ព្រះបាទសាឡូម៉ូនបានធ្វើ...ស្តេចបានធ្វើ...ស្តេចបានធ្វើ...ស្តេចបានពាស...ពាស
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើអ្វីៗទាំងនេះ។
ទ្វារឈើសម្រាប់អ្នក»
ធ្នឹមឆ្លងកាត់កំពូលនៃស៊ុមទ្វារ
នៃជញ្ជាំង
ស្នាមប្រហោងធ្មេញនៅលើផ្នែកនីមួយៗនៃប្រាំផ្នែក
បានពាស
«គ្របដណ្តប់»
1 Kings 6:33
តាមវិធីនេះដែលព្រះបាទសាឡូម៉ូនបានសង់ច្រកចូលព្រះវិហារពីឈើអូលីវមានកម្ពស់មួយភាគបួននៃ
ជញ្ជាំង និងមានទ្វារពីរទៀតធ្វើពីឈើកកោះ
«ស្តេចសាឡូម៉ូនក៏បានធ្វើខ្លោងទ្វារ ពីឈើអូលីវសម្រាប់ច្រកចូលព្រះវិហារ
ដោយមានផ្នែកចូលជាបួនផ្នែក និងទ្វារពីរ ពីឈើតាត្រៅតាមរបៀបដូចគ្នា»
ផ្នែកចូលបន្ទាត់
ស្នាមប្រហោងធ្មេញ
សន្លឹកទាំងពីររបស់ទ្វារនីមួយៗអាចបត់ចូលគ្នាបាន
នេះមានន័យថា
ទ្វារនីមួយៗមានពីរផ្នែកដែលភ្ជាប់គ្នាដូច្នេះពួកគេអាចបត់ជាមួយគ្នា។
1 Kings 6:36
ស្តេចឲ្យគេសង់ទីលានខាងក្នុង
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើបែបនេះ។

generated on Wed Sep 10 16:16:32 2025

ឈើតាត្រៅមួយជាន់
ធ្នឹមគឺជាបំណែកឈើធ្ងន់វែង ដែលត្រូវបានប្រើសម្រាប់ទ្រទ្រង់អគារ។
បកប្រែដូចនៅក្នុង ៦:៥។
1 Kings 6:37
ឆ្នាំទីបួន...ឆ្នាំទីដប់មួយ
ពាក្យ «ទីបួន» និង «ទីដប់មួយ» គឺជាទម្រង់ធម្មតានៃ «បួន» និង «ដប់មួយ»។
អ្នកប្រហែលជាត្រូវធ្វើឲ្យច្បាស់ពីព្រឹត្តិការណ៍ដែលអ្នកនិពន្ធរាប់ឆ្នាំ។ «ឆ្នាំទី៤
បន្ទាប់ពីស្តេចសាឡូម៉ូនបានឡើងសោយរាជ្យ ... នៅឆ្នាំទី១១
បន្ទាប់ពីស្តេចសាឡូម៉ូនបានឡើងសោយរាជ្យ»
ដំណាក់របស់ព្រះអម្ចាស់
ព្រះវិហារ
នៅក្នុងខែពិសាខ
«ខែពិសាខ» គឺជាឈ្មោះខែទី២ នៃប្រតិទិនហេព្រើរ។
វាគឺជាអំឡុងពេលចុងក្រោយនៃខែមេសា
និងផ្នែកដំបូងនៃខែឧសភានៅលើប្រតិទិនលោកខាងលិច។ បកប្រែដូចនៅក្នុងជំពូក
៦:១។
នៅក្នុងខែកត្តិក នៅក្នុងខែទីប្រាំបី
«ខែកត្តិក» គឺជាខែទីប្រាំបីនៃប្រតិទិនហេប្រឺ។
វាគឺជាកំឡុងពេលចុងក្រោយនៃខែតុលានិងផ្នែកដំបូងនៃខែវិច្ឆិកានៅលើប្រតិទិនលោកខាងលិច។
ព្រះវិហារបានសង់រួចរាល់គ្រប់ផ្នែកទាំងអស់តាមគម្រោង
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ពួកគេបានសាងសង់គ្រប់ផ្នែកនៃដំណាក់របស់ព្រះជាម្ចាស់
ហើយពួកគេបានសាងសង់តាមរបៀបដែលស្តេចសាឡូម៉ូនបានប្រាប់ពួកគេឲ្យសាងសង់»
ព្រះបាទសាឡូម៉ូនបានចំណាយ
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើបែបនេះ។

---

7 [1]ព្រះបាទសាឡូម៉ូនចំណាយពេលសាមសិបឆ្នាំក្នុងការសង់វាំងរបស់ស្តេចផ្ទាល់។[2]ស្តេចបានសង់វាំងពីឈើនៅស្រុកលីបង់។ វាំងនោះមានបណ្តោយមួយរយហត្ថ
មានទទឹងហាសិបហត្ថ និងមានកំពស់សាមសិបហត្ថ។ វាំងនេះមានសសរធ្វើពីឈើតាត្រៅបួនជួរ ដែលមានធ្នឹមនៅលើសសរទាំងនោះ។
[3]ដំណាក់នោះបានធ្វើដំបូលពីឈើតាត្រៅដែលដាក់លើធ្នឹម។ ធ្នឹមទាំងនោះទ្រដោយសសរជាច្រើន។ មានធ្នឹមសែសិបប្រាំ មានដប់ប្រាំជួរ។[4]មានធ្នឹមបីជួរ
ហើយបង្អួចនីមួយៗនៅទល់មុខបង្អួចម្ខាងទៀត ទាំងអស់មានបីគូរ។[5]ទ្វារ និងគ្របទ្វារទាំងអស់បានធ្វើជារៀងបួនជ្រុង ហើយបង្អួចគឺទល់មុខគ្នាបីគូរ។
[6]មានបន្ទប់ល្វែងមួយដែលមានប្រវែងហាសិបហត្ថ និងទទឹងសាមសិបហត្ថ ដែលមានរានទៅខាងមុខ និងសសរ ហើយនឹងដំបូល។
[7]ព្រះបាទសាឡូម៉ូនបានសង់បន្ទប់ធំមួយដែលមានបល្ល័ង្ក ជាកន្លែងសម្រាប់កាត់ក្តី ជាបន្ទប់យុត្តិធម៌។ បន្ទប់នោះ បានក្រាលដោយឈើតាត្រៅនៅខាងក្រោម។
[8]ដំណាក់របស់ព្រះបាទសាឡូម៉ូនដែលស្តេចគង់នៅ គឺស្ថិតក្នុងទីធ្លាមួយទៀតដែលជាដីរបស់រាជវាំង បានរចនាស្រដៀងគ្នា។
ស្តេចក៏បានសង់ដំណាក់ដូចគ្នានេះសម្រាប់បុត្រីរបស់ស្តេចផារោនដែលជាមហេសីរបស់ស្តេចដែរ។
[9]អគារទាំងនេះបានសង់ពីថ្មដ៏មានតម្លៃ បានវាស់វែងយ៉ាងផ្ចិតផ្ចង់ និងអារដ៏រឹមដោយរណា និងខាត់គ្រប់ជ្រុងទាំងអស់។
ថ្មទាំងនេះបានប្រើតាំងពីគ្រឹះរហូតដល់ផ្នែកខាងលើបំផុត និងរហូតដល់លានខាងក្រៅផង។[10]គ្រឹះបានសង់ឡើងដោយថ្មយ៉ាងធំ ជាថ្មមានតម្លៃ ដែលមានប្រវែងប្រាំបី
និងដប់ហត្ថ។
[11]នៅផ្នែកខាងលើគឺមានថ្មម៉ាបយ៉ាងមានតម្លៃដែលកាត់តាមទំហំ និងមានធ្នឹមពីឈើតាត្រៅ។[12]ទីធ្លាធំនៅជុំវិញវាំងមានបីជួរធ្វើពីថ្ម
និងមួយជួរធ្វើពីឈើតាត្រៅដូចទីលាននៅខាងក្នុងព្រះវិហាររបស់ព្រះអម្ចាស់ និងបន្ទប់ល្វែងរបស់ព្រះវិហារដែរ។
[13]ព្រះបាទសាឡូម៉ូនបានធ្វើសារទៅលោកហ៊ីរ៉ាម ដើម្បីអញ្ជើញលោកពីក្រុងទីរ៉ុសមក។[14]លោកហ៊ីរ៉ាមជាកូនរបស់ស្ត្រីមេម៉ាយម្នាក់ ក្នុងកុលសម្ព័ន្ធណែបថាលី ហើយឪពុក
ជាអ្នកក្រុងទីរ៉ុស លោកជាជាងលង្ហិនដ៏ចំណានម្នាក់។ លោកហ៊ីរ៉ាមមានពេញដោយប្រាជ្ញា និងការយល់ដឹង រួមជាមួយជំនាញ
ដើម្បីធ្វើការដ៏អស្ចារ្យជាមួយលង្ហិនសម្រាប់ស្តេច។
[15]លោកហ៊ីរ៉ាមបានរចនាសសរពីរពីលង្ហិន សសរនីមួយៗមានកម្ពស់ដប់ប្រាំបីហត្ថ និងបរិមាត្រដប់ពីរហត្ថ។[16]គាត់ធ្វើក្បាលសសរលង្ហិនពីរដាក់ខាងលើសសរទាំងពីរ។
ក្បាលសសរនីមួយៗមានកម្ពស់ប្រាំហត្ថ។[17]គាត់សិតលង្ហិនធ្វើជាក្បាច់ក្រឡាអួន និងច្រវាក់សម្រាប់លម្អក្បាលសសរ ក្បាលសសរនីមួយៗមានកម្រងច្រវាក់ប្រាំពីរ។
[18]ដូច្នេះ លោកហ៊ីរ៉ាមបានឆ្លាក់ផ្លែទទឹមពីរជួរជុំវិញក្បាលសសរនីមួយៗ ដើម្បីរចនាក្បាលសសរទាំងពីរនេះ។
[19]ក្បាលសសរខាងលើសសរបន្ទប់ល្វែងបានរចនាជាមួយផ្កាលីលី មានកម្ពស់បួនហត្ថ។
[20]ក្បាលសសរនៅលើសសរទាំងពីររួមទាំងក្បែរផ្នែកខាងលើមានផ្លែទទឹមពីររយជាជួរនៅជុំវិញ។[21]លោកបានលើកសសរនេះឡើងនៅឯបន្ទប់ល្វែងព្រះវិហារ។
សសរនៅខាងស្តាំមានឈ្មោះថាយ៉ាគីន ហើយសសរនៅខាងឆ្វេងមានឈ្មោះថាបូអូស។[22]នៅខាងលើបំផុតនៃសសរទាំងពីរនេះមានការរចនាដូចជាផ្កាលីលី។
ការរចនាសសរទាំងពីរបានធ្វើឡើងរបៀបនេះឯង។
[23]លោកហ៊ីរ៉ាមបានធ្វើអាងទឹកមូលមួយពីដែកចាក់ មានអង្កត់ផ្ចិតជុំវិញដប់ហត្ថ។ វាមានកម្ពស់ប្រាំហត្ថ និងមានបរិមាត្រជុំវិញសាមសិបហត្ថ។
[24]នៅមាត់ខាងលើនៃអាងទឹកនេះបានឆ្លាក់រូបផ្កាក្រពុំ ក្នុងមួយហត្ថមានផ្កាដប់ ក្បាច់ទាំងនោះបានចាក់ក្នុងពេលដែលគេចាក់អាងនោះ។
[25]អាងនេះនៅលើគោដប់ពីរក្បាល បីបែរទៅទិសខាងជើង បីបែរទៅទិសខាងលិច បីបែរទៅទិសខាងត្បូង និងបីទៀតបែរទៅទិសខាងខាងកើត។
អាងនោះបានដាក់នៅខាងលើគោទាំងអស់នោះ ហើយខ្លួនគោទាំងអស់បែរចូលក្នុង។[26]អាងនោះមានកម្រាលក្រាស់ដូចមួយទះដៃ
ហើយមាត់របស់អាងគឺបត់ដូចជាមាត់របស់ពែង ដូចជាផ្កាលីលីរីក។ អាងនោះអាចដាក់ទឹកបានពីពាន់អំម្រែក។
[27]លោកហ៊ីរ៉ាមបានធ្វើជើងបញ្ឈរដប់ពីលង្ហិន។ ជើងបញ្ឈរនីមួយៗមានប្រវែងបួនហត្ថ និងទទឹងបួនហត្ថ ហើយកម្ពស់ពីរហត្ថ។[28]ការងារធ្វើជើងបញ្ឈរនេះមានដូចតទៅ។
គេមានបន្ទះដាក់បញ្ឈរនៅចន្លោះគ្រោង[29]ហើយនៅលើបន្ទះ និងនៅលើគ្រោងនេះមានតោ គោ និងចេរ៉ូប៊ីម។ នៅខាងលើ និងនៅខាងក្រោមគោ និងតោមានក្បាច់រំយោល។
[30]នៅលើជើងបញ្ឈរនីមួយៗមានកង់លង្ហិនបួន និងភ្លៅ ហើយជ្រុងទាំងបួនរបស់វាមានប្រដាប់ទ្រ។ ទម្របានចាក់ភ្ជាប់គ្នាទៅជ្រុងទាំងបួនរបស់វា។
[31]នៅមាត់ខាងលើមានរាងមូលដូចជើងតាងមានប្រវែងមួយហត្ថកន្លះ ហើយមានម្តុដឡើងទៅលើមួយហត្ថ។ នៅមាត់ខាងលើងនោះក៏មានចម្លាក់ដែរ
ហើយបន្ទះទាំងនោះមានរាងបួនជ្រុង មិនមែនមូលទេ។
[32]កង់ទាំងបួនស្ថិតនៅក្រោមបន្ទះ ហើយតួ និងកង់របស់វា និងខ្លួនទាំងមូល គឺនៅក្នុងជើងបញ្ឈរនោះ។ កង់មានកម្ពស់មួយហត្ថកន្លះ។
[33]កង់ទាំងបួនមានរាងដូចកង់រទេះចំបាំង។ ខ្លួនទាំងមូល ខ្នង កាំ និងដុំ ចាក់ធ្វើពីដែកទាំងអស់។
[34]មានជើងទម្របួននៅតាមជ្រុងរបស់ជើងបញ្ឈរនោះ បានភ្ជាប់ជាមួយតួ។[35]នៅខាងលើជើងបញ្ឈរនេះមានរង្វង់មូលមួយមានជម្រៅមួយហត្ថ
ហើយនៅផ្នែកខាងលើជើងបញ្ឈរ ជើងទម្រ និងបន្ទះបានភ្ជាប់គ្នា។
[36]នៅផ្ទៃខាងលើជើងទ្រ និងនៅលើបន្ទះ លោកហ៊ីរ៉ាមបានឆ្លាក់រូបចេរ៉ូប៊ីម តោ និងដើមត្នោតនៅលើផ្ទៃដែលសេសសល់ ហើយមានរំយោទព័ទ្ធជុំវិញ។
[37]លោកបានធ្វើជើងបញ្ឈរដប់ដោយរបៀបនេះឯង។ ជើងបញ្ឈរទាំងអស់បានចាក់ដូចៗគ្នា ហើយមានទំហំដូចៗគ្នា និងមានទម្រង់ដូចៗគ្នា។
[38]លោកហ៊ីរ៉ាមបានធ្វើអាងលង្ហិនដប់។ អាងនីមួយៗអាចដាក់ទឹកបានសែសិបអំម្រែក។ អាងនីមួយៗមានកម្ពស់បួនហត្ថ
ហើយគេដាក់អាងមួយនៅលើជើងបញ្ឈរនីមួយៗ។[39]លោកបានដាក់ជើងបញ្ឈរប្រាំនៅខាងត្បូងទល់មុខព្រះវិហារ ហើយប្រាំទៀតដាក់ខាងជើងទល់មុខព្រះវិហារ។
លោកបានដាក់អាងធំនៅជ្រុងខាងកើត បែរមុខទៅខាងត្បូងព្រះវិហារ។
[40]លោកហ៊ីរ៉ាមធ្វើអាង ប្រដាប់ចូកផេះ និងធើងដាក់ឈាម។ បន្ទាប់មក
លោកបានបញ្ចប់កិច្ចការទាំងប៉ុន្មានដែលលោកបានធ្វើថ្វាយព្រះបាទសាឡូម៉ូននៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់[41]គឺសសរពីរ ក្បាលសសរមូលពីសម្រាប់ដាក់លើសសរ
និងក្បាច់ក្រឡាអួនពីរឈុត ដើម្បីគ្របពីលើក្បាលសសរដែលនៅខាងលើ។

generated on Wed Sep 10 16:16:32 2025

[42]លោកបានធ្វើផ្លែទទឹមបួនរយសម្រាប់លម្អក្បាច់ក្រឡាអួន៖
មានផ្លែទទឹមពីរជួរសម្រាប់ក្បាច់ក្រឡាអួននីមួយៗដើម្បីដាក់លើក្បាលសសរដែលនៅលើសសរ[43]ជើងបញ្ឈរដប់ អាងដប់ដែលនៅលើជើងបញ្ឈរនោះ។
[44]លោកបានធ្វើអាងធំ និងគោដប់ពីរនៅក្រោមអាងនោះ[45]លោកក៏ធ្វើធុងសម្រាប់ដាក់ផេះ ប្រដាប់ចូកផេះ អាង និងរបស់របរផ្សេងទៀត។
លោកហ៊ីរ៉ាមធ្វើរបស់ទាំងនោះពីលង្ហិនរលោងសម្រាប់ព្រះបាទសាឡូម៉ូន សម្រាប់ព្រះវិហាររបស់ព្រះអម្ចាស់។
[46]ស្តេចបានចាក់របស់ទាំងអស់នេះនៅវាលទំនាបទន្លេយ័រដាន់ នៅក្នុងពុម្ពដីឥតចន្លោះសិកូត និងសារថាន។[47]ព្រះបាទសាឡូម៉ូនមិនបានថ្លឹងគ្រឿងប្រដាប់ទាំងនោះទេ
ដោយសារតែមានច្រើនពេក ដោយសារតែទំងន់របស់លង្ហិនទាំងនោះធ្ងន់ពេកមិនអាចកំណត់បាន។
[48]ព្រះបាទសាឡូម៉ូនបានធ្វើរបស់ដែលត្រូវការនៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់ពីមាស៖ មានអាសនាមាស និងតុនំប៉័ងដែលដាក់តាំងនំប៉័ង។[49]ជើងចង្កៀង ប្រាំនៅខាងស្តាំ
និងប្រាំទៀតនៅខាងឆ្វេង នៅខាងមុខបន្ទប់ខាងក្នុងពីមាសសុទ្ធ និងផ្កា ចង្កៀង និងដង្កៀបសុទ្ធតែធ្វើពីមាស។
[50]ពែង ចង្កៀង អាង ស្លាបព្រា និងកន្លែងថ្វាយគ្រឿងក្រអូបសុទ្ធតែធ្វើពីមាសសុទ្ធ។ ត្រចៀកទ្វារនៅបន្ទប់ខាងក្នុងដែលជាកន្លែងសក្ការៈបំផុត
និងទ្វាររបស់បន្ទប់ធំនៃព្រះវិហារ សុទ្ធតែធ្វើពីមាស។
[51]តាមរបៀបនេះឯងដែលព្រះបាទសាឡូម៉ូនបានធ្វើសម្រាប់ដំណាក់របស់ព្រះអម្ចាស់ ហើយបានធ្វើរួចរាល់។ ដូច្នេះ
ព្រះបាទសាឡូម៉ូនបាននាំរបស់ដែលស្តេចដាវីឌជាបិតាទ្រង់បានរៀបចំទុកមានប្រាក់ មាស គ្រឿងប្រដាប់ប្រដាផ្សេងៗ
ហើយបានដាក់របស់ទាំងនោះនៅក្នុងឃ្លាំងនៃដំណាក់របស់ព្រះអម្ចាស់។

---

1 Kings 7:1
ព័ត៌មានទូទៅ
អ្នកនិពន្ធកំពុងសរសេរអំពីវាំងរបស់ព្រះបាទសាឡូម៉ូន។
ព្រះបាទសាឡូម៉ូនចំណាយពេលសាមសិបឆ្នាំក្នុងការសង់វាំងរបស់ស្តេចផ្ទាល់
ដោយសារសាឡូម៉ូនជាស្តេចអ្នកឯទៀតបានធ្វើការជំនួសគាត់។
វាំងរបស់ស្តេចផ្ទាល់
ប្រសិនបើភាសារបស់អ្នកមិនមានពាក្យសម្រាប់ «វាំង» អ្នកអាចបកប្រែពាក្យនេះថា «ផ្ទះ» ឬ «ផ្ទះធំ ។»
វាំងពីឈើនៅស្រុកលីបង់
«ផ្ទះដែលគេហៅថាផ្ទះនៃព្រៃលីបង់»
មួយរយហត្ថ ...ហាសិបហត្ថ..សាមសិបហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «៤៦ ម៉ែត្រ ... ២៣ ម៉ែត្រ ... ១៣.៨ ម៉ែត្រ»
ធ្នឹម
ធ្នឹមគឺជាបំណែកដ៏វែងនៃឈើរឹងមាំដែលត្រូវបានប្រើសម្រាប់ទ្រទ្រង់ជញ្ជាំងនិងដំបូល។
1 Kings 7:3
ព័ត៌មានទូទៅ
ព័ត៌មានលំអិតខ្លះត្រូវបានផ្តល់ឲ្យអំពីរចនាសម្ព័ន្ធនៃវាំងដែលធ្វើពីព្រៃលីបង់។
ដំណាក់នោះបានធ្វើដំបូលពីឈើតាត្រៅដែលដាក់លើធ្នឹម
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ជាងឈើបានសាងសង់ដំបូលពីក្តារតាត្រៅហើយភ្ជាប់ពួកវាទៅនឹងធ្នឹម»
ធ្នឹម
បំណែកដ៏វែងនៃឈើរឹងមាំជាធម្មតាត្រូវបានប្រើដើម្បីទ្រទ្រង់ដំបូល។
បានធ្វើជារៀងបួនជ្រុង
«មានស៊ុមចតុកោណ»
1 Kings 7:6
ព័ត៌មានទូទៅ
អ្នកនិពន្ធសរសេរអំពីរចនាសម្ពន្ធនៃសសរស្តម្ភ។
បន្ទប់ល្វែង
នៃជួរឈរដែលមានចម្ងាយដូចគ្នាទាំងអស់
ហាសិបហត្ថ ...សាមសិបហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «២៣ ម៉ែត្រ ... ១៣.៨ ម៉ែត្រ»
រាន
តំបន់មួយនៃអគារធ្វើពីជួរឈរ និង ដំបូលដែលនាំទៅដល់ និង
ភ្ជាប់ជាមួយទ្វារចូលនៃអគារ។ សូមមើលការបកប្រែនៅក្នុងជំពូក ៦:៣
1 Kings 7:7
ព័ត៌មានទូទៅ
អ្នកនិពន្ធសរសេរអំពីបន្ទប់ធំនៃបល្ល័ង្ក។
ព្រះបាទសាឡូម៉ូនបានសង់បន្ទប់ធំមួយដែលមានបល្ល័ង្ក
អាចមានន័យថា ១)
«ស្តេចសាឡូម៉ូនបានសង់ផ្ទះដែលគាត់នឹងដាក់បល្ល័ង្ករបស់គាត់» ឬ ២)
«សាឡូម៉ូនបានឲ្យកម្មកររបស់គាត់សាងសង់ផ្ទះមួយ
ដែលមានឈ្មោះថាផ្ទះស្តេច»។
បានក្រាលដោយឈើតាត្រៅ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«កម្មករបានគ្របកម្រាលឥដ្ឋជាមួយនឹងឈើតាត្រៅ»
នៅខាងក្រោម
នេះសំដៅទៅលើជាន់ទាំងមូល។ «ពីជញ្ជាំងមួយទៅជញ្ជាំងមួយទៀត»
1 Kings 7:8
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តសរសេរអំពីតំបន់នៃវាំង។
ដំណាក់របស់ព្រះបាទសាឡូម៉ូនដែលស្តេចគង់នៅ គឺស្ថិតក្នុងទីធ្លាមួយទៀតដែលជាដីរបស់រាជវាំង
បានរចនាស្រដៀងគ្នា
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ស្តេចសាឡូម៉ូនមាននរណាម្នាក់រចនាផ្ទះដែលទ្រង់ត្រូវរស់នៅក្នុងទីធ្លាមួយផ្សេងទៀតនៅក្នុងទីធ្លាវាំងតាម
។
1 Kings 7:9
ព័ត៌មានទូទៅ
អ្នកនិពន្ធកំពុងសរសេរអំពីថ្មដែលប្រើសម្រាប់អគារ។
អគារទាំងនេះបានសង់ពីថ្មដ៏មានតម្លៃ បានវាស់វែងយ៉ាងផ្ទិតផ្ទង់
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«កម្មករបានតាក់តែងអគារដោយថ្មដែលមានតម្លៃខ្ពស់»
បានវាស់វែងយ៉ាងផ្ទិតផ្ទង់ និងអារដ៏រឹមដោយរណា
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ថ្មមានតម្លៃដែលកម្មករបានវាស់វែងនិងកាត់យ៉ាងច្បាស់ជាមួយនឹងស្នាមភ្លឺនិងរលោង»
ថ្មទាំងនេះបានប្រើ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «កម្មករបានប្រើថ្មទាំងនេះ»
ពីគ្រឹះរហូតដល់ផ្នែកខាងលើបំផុត និងរហូតដល់លានខាងក្រៅផង
អ្នកនិពន្ធកំពុងសង្កត់ធ្ងន់ថា កម្មករបានប្រើថ្មថ្លៃៗ សម្រាប់គ្រឹះ និង អគារទាំងអស់។
គ្រឹះបានសង់ឡើង
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «កម្មករបានសាងសង់គ្រឹះ»
ជ្រាំបី និងដប់ហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «ប្រហែល ៣,៧ ម៉ែត្រនិង ៤,៦ ម៉ែត្រ»
1 Kings 7:11
ធ្នឹមពីឈើតាត្រៅ
ធ្នឹមគឺជាបំណែកឈើវែងដែលត្រូវបានប្រើសម្រាប់ការគាំទ្ររចនាសម្ពន្ធ។
មានបីជួរធ្វើពីថ្ម និងមួយជួរធ្វើពីឈើតាត្រៅ
បកប្រែដូចនៅក្នុងជំពូក ៦:៣៦។
1 Kings 7:13
ដើម្បីអញ្ជើញលោកពីក្រុងទីរ៉ុសមក
ហ៊ូរ៉ាមបានទទួលយកការអញ្ជើញរបស់ស្តេចសាឡូម៉ូនឲ្យមកក្រុងយេរូសាឡឹម។
កូនរបស់ស្ត្រីមេម៉ាយម្នាក់...ឪពុកជាអ្នកក្រុងទីរ៉ុស
ស្ត្រីមេម៉ាយគឺជាស្ត្រីដែលប្តីរបស់គាត់បានស្លាប់ចោលដូច្នេះយើងដឹងថាឪពុកបានស្លាប់ហើយ។
លោកហ៊ីរ៉ាមមានពេញដោយប្រាជ្ញា និងការយល់ដឹង រួមជាមួយជំនាញ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ ពាក្យ «ប្រាជ្ញានិងការយោគយល"
មានន័យថា ជាមូលដ្ឋានដូចគ្នាហើយត្រូវបានប្រើរួមគ្នាសម្រាប់ការសង្កត់ធ្ងន់។
ព្រះអម្ចាស់អោយប្រាជ្ញាដូចជាអ្វីៗដែលព្រះអម្ចាស់បានចាក់ទៅក្នុងធុងមួយហើយហ៊ីរ៉ាមត្រូវគេនិយាយថា
ដូចជាធុងនោះដែរ។
«ព្រះអម្ចាស់បានប្រទានប្រាជ្ញាការយល់ដឹងនិងជំនាញដល់ហ៊ីរ៉ាម»

generated on Wed Sep 10 16:16:32 2025

1 Kings 7:15
ជ្រាំបីហត្ថ...ដប់ពីរហត្ថ...ជ្រាំហត្ថ
មួយហត្ថគឺប្រហែល ៤៦ សង់ទីម៉ែត្រ។ «ប្រហែល ៨,៣ ម៉ែត្រ ... ៥.៥ ម៉ែត្រ ... ២,៣ ហត្ថ»
បរិមាត្រ
បរិមាត្រគឺចម្ងាយឬរង្វាស់ជុំវិញវត្ថុរាងជារង្វង់រឺតំបន់។
សសរទាំងពីរ
ការតុបតែងនៅលើសសរនីមួយៗនៃសសរទាំងពីរ។
ក្បាលសសរលង្ហិន
ពួកគេបានដុសលង្ហិនដើម្បីឲ្យវាឆ្លុះបញ្ចាំងពីពន្លឺព្រះអាទិត្យ។
គាត់សិតលង្ហិនធ្វើជាក្បាច់ក្រឡាអួន និងច្រវាក់សម្រាប់លម្អក្បាលសសរ
«បន្ទះដែកឆ្លងកាត់ជាប់គ្នានិងច្រវាក់ដែករមួលជាមួយគ្នា»
1 Kings 7:18
ផ្លែទទឹមពីរជួរ
ផ្លែទទឹមគឺជាផ្លែឈើមួយដែលមានសំបកក្រហម និង
គ្រាប់ដែលមានជាតិទឹកច្រើននៅខាងក្នុង។
ហ៊ីរ៉ាមមិនបានប្រើផ្លែទទឹមពិតប្រាកដដើម្បីតុបតែងសសរទេ។
គាត់បានឆ្លាក់ពីលង្ហិន។
ក្បាលសសរខាងលើសសរបន្ទប់ល្វែងបានរចនាជាមួយផ្កាលីលី មានកម្ពស់បួនហត្ថ
ផ្កាលីលីគឺជារុក្ខជាតិដែលមានផ្កាធំទូលាយនៅចុងម្ខាងហើយតូចចង្អៀតនៅចុងម្ខាងទៀត។
ពាក្យទាំងនេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
ហ៊ីរ៉ាមបានតុបតែងលំអរលើក្បាលសសរ ... ជាផ្កាលង្ហិនមានកំពស់បួនហត្ថ។
ខាងលើសសរបន្ទប់ល្វែង
បកប្រែ «បន្ទប់ល្វែង» ដូចក្នុងជំពូក ៧:៦។
បួនហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «ប្រហែល ១,៨ ម៉ែត្រ»
1 Kings 7:20
ផ្លែទទឹមពីររយ
«ផ្លែទទឹម ២០០ ដើម» ផ្លែទទឹមគឺជាផ្លែឈើមួយដែលមានសំបកក្រហម
និងគ្រាប់ដែលមានជាតិទឹកច្រើននៅខាងក្នុង។ បកប្រែដូចក្នុងជំពូក ៧:១៨
លោកបានលើកសសរនេះឡើង
វាជាការល្អបំផុតក្នុងការបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយហ៊ីរ៉ាមធ្វើការនេះ។
សសរនៅខាងស្តាំមានឈ្មោះថាយ៉ាគីន
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «ឈ្មោះសសរនៅផ្នែកខាងស្តាំគឺយ៉ាគីន»
សសរនៅខាងឆ្វេងមានឈ្មោះថាបូអូស
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «ឈ្មោះសសរនៅខាងឆ្វេងគឺបូអូស»
ការរចនាសសរទាំងពីរបានធ្វើឡើង
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។ «ហ៊ីរ៉ាមបានយកគំរូតាមសសរ» ឬ
«បុរសរបស់ហ៊ីរ៉ាមបានយកគំរូតាមសសរ»
1 Kings 7:23
អាងទឹកមូលមួយ
នេះសំដៅទៅលើធុងសំរិទ្ធឬអាងដែលទប់ទឹក។
ពីដែកចាក់
ហ៊ីរ៉ាមរលាយសំរិទ្ធហើយបង្កើតវាជាផ្សិត។
ដប់ហត្ថ...ជ្រាំហត្ថ ..សាមសិបហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «៤,៦ ម៉ែត្រ ... ២,៣ ម៉ែត្រ ... ១៣,៨ ម៉ែត្រ»
មានអង្គត់ផ្ចិតជុំវិញ
«ពីគែមមួយទៅគែមមួយទៀត»
បរិមាត្រ
បរិមាត្រគឺចម្ងាយឬរង្វាស់ជុំវិញវត្ថុរាងជារង្វង់រឺតំបន់។
នៃអាងទឹកនេះបានឆ្លាក់រូបផ្កាក្រពុំ
ផ្កាក្រពុំគឺជាប្រភេទបន្លែមូលរឹងមួយប្រភេទដែលដុះនៅលើដើមទំពាំងបាយជូរនៅលើដី។
ពេលដែលគេចាក់អាងនោះ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«នៅពេលដែលហ៊ីរ៉ាមបោះចោលអាងនោះដោយខ្លួនផ្ទាល់»
1 Kings 7:25
អាងនេះ
នេះសំដៅទៅលើធុងលង្ហិនឬអាងដែលនឹងទប់ទឹក។
នៅលើគោ
«គឺនៅលើកំពូលនៃ»
អាងនោះបានដាក់នៅខាងលើគោទាំងអស់នោះ
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«កម្មកររបស់ហ៊ីរ៉ាមបានដាក់អាងនៅលើកំពូលគោលង្ហិន»
បែរចូលក្នុង
នេះគឺជាត្រីមាសខាងក្រោយនៃរាងកាយរបស់សត្វដែលមានជើងបួន។
មាត់របស់អាងគឺបត់ដូចជាមាត់របស់ពែង ដូចជាផ្កាលីលីរីក
នេះអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ហ៊ីរ៉ាមបានក្លែងបន្លំសម្លឹងមើលទៅដូចជាពាងនៃពែង
ដើម្បីកោងទៅខាងក្រៅដូចជាផ្កាលីលី»
ទឹកបានពីពាន់អម្រែក
អាងងូតទឹកគឺជាឯកតានៃបរិមាណស្មើនឹងប្រហែល ២២ លីត្រ។ «ងូតទឹក ២០០០» ឬ « ៤៤.០០០ លីត្រ»
1 Kings 7:27
បួនហត្ថ...ពីរហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «ប្រហែល ១,៨ ម៉ែត្រ ... ប្រហែល ១,៤ ម៉ែត្រ»
ការងារធ្វើជើងបញ្ឈរនេះមានដូចតទៅ
នេះមានន័យថា អ្នកនិពន្ធនឹងរៀបរាប់អំពីជើងបញ្ឈរនៅក្នុងពាក្យតាមក្រោយ។
ស្រាលីបន្ទះ និងនៅលើគ្រោងនេះមានតោ គោ និងចេរ៉ូប៊ីន
មានរូបចម្លាក់តុបតែងលំអរាងដូចតោ គោ និងចេរូប៊ីនជាប់នឹងជើងបញ្ឈ។
មានក្បាច់រំយោល
នៅទីនេះពាក្យ «រំយោល» សំដៅទៅលើបំណែករាងលង្ហិន។
1 Kings 7:30
មានកង់លង្ហិនបួន និងភ្លៅ
មានភ្លៅមួយសម្រាប់កង់នីមួយៗ។ «កង់លង្ហិនបួននិងមានភ្លៅពីរ»
ជ្រុងទាំងបួន
«ជ្រុងទាំងបួននៃជើងបញ្ឈរនីមួយៗ»
វាមានប្រដាប់ទ្រ
ការគាំទ្រនីមួយៗត្រូវបានគេបោះជាបំណែកមួយជាមួយនឹងរំយោល។
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម
«ហ៊ីរ៉ាមធ្វើប្រដាប់ទ្រដោយបំណែករាងជារង់»
មួយហត្ថកន្លះ...មួយហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «ប្រហែល ៧០ សង់ទីម៉ែត្រ ... ប្រហែល ៥០ សង់ទីម៉ែត្រ»
មានម្កុដឡើងទៅលើ
នៅទីនេះពាក្យថា «មកុដ»
សំដៅទៅលើដុំរាងជារង្វង់នៅផ្នែកខាងលើនៃកន្លែងឈរជាប់អាង។
បន្ទះទាំងនោះមានរាងបួនជ្រុង
បន្ទះក្តារឈរជារាងការ៉ែ។
ឃ្លានេះត្រឡប់ទៅការពិពណ៌នានៃបន្ទះដែលបានចាប់ផ្តើមនៅ ៧:២៧ ។
1 Kings 7:32
ខ្លួនទាំងមូល
នៅទីនេះពាក្យ «របស់ពួកគេ» សំដៅទៅភ្លៅ។ ពាក្យថា «ខ្លួនទាំងមូល»
សំដៅទៅលើប្រអប់ដែលភ្លៅត្រូវបានបញ្ចូល។
មួយហត្ថកន្លះ
មួយហត្ថមាន ៤៦ សង់ទីម៉ែត្រ។ « ប្រហែល ៧០ សង់ទីម៉ែត្រ»
កង់ទាំងបួនមានរាងដូចកង់រទេះចំបាំង
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ហ៊ីរ៉ាមបានធ្វើកង់ដូចជាកង់រទេះតូច»
ខ្លួនទាំងមូល ខ្នង កាំ និងដុំ
នៅទីនេះពាក្យ «របស់ពួកគេ» សំដៅទៅលើកង់។
1 Kings 7:34
មានជើងទម្របួននៅតាមជ្រុងរបស់ជើងបញ្ឈរនោះ
«មានជើងទម្រនៅជ្រុងទាំងបួននៃជើងបញ្ឈរនីមួយៗ»
ជម្រៅមួយហត្ថ
មួយហត្ថមាន ៤៦ សង់ទីម៉ែត្រ។ «ទទឹងម្ភៃបីសង់ទីម៉ែត្រ»
នៅខាងលើជើងបញ្ឈរនេះមានរង្វង់មូលមួយមានជម្រៅមួយហត្ថ ហើយនៅផ្នែកខាងលើជើងបញ្ឈរ
ជើងទម្រ និងបន្ទះបានភ្ជាប់គ្នា

generated on Wed Sep 10 16:16:32 2025

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «ហ៊ីរ៉ាមភ្ជាប់បន្ទះ និងបន្ទះនៅខាងលើនៃជើងបញ្ឈរនីមួយៗ»

1 Kings 7:36

ព័ទ្ធជុំវិញ

នៅទីនេះពាក្យ «ពួកគេ» សំដៅទៅលើចេរូប៊ីន តោនិងដើមត្នោត។

រំយោលព័ទ្ធជុំវិញ

ពាក្យថា «រំយោល» សំដៅទៅលើបំណែករបស់លង្ហិន។

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «មានរំយោលនៅជុំវិញពួកគេ»

ដោយរបៀបនេះឯង

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។

«ហ៊ីរ៉ាមបានដាក់ជើងបញ្ឈរទាំងអស់នៅក្នុងពុម្ពតែមួយ»

មានទំហំដូចៗគ្នា និងមានទម្រង់ដូចៗគ្នា

«ជើងបញ្ឈរទាំងអស់មានទំហំនិងរាងដូចគ្នា»

1 Kings 7:38

ទឹកបានសែសិបអម្រែក

អម្រែកគឺជាឯកតានៃបរិមាណស្មើនឹងប្រហែល ២២ លីត្រ។ «ប្រហែល ៨៨ លីត្រ» ឬ «ប្រហែល ៩០ លីត្រ»

បួនហត្ថ

មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។ «ប្រហែល ១,៨ ម៉ែត្រ»

ជ្រុងខាងកើត បែរមុខទៅខាងត្បូងព្រះវិហារ

«នៅលើជ្រុងអាគ្នេយ៍នៃប្រាសាទ»

1 Kings 7:40

ក្បាលសសរមូលពីសម្រាប់ដាក់លើសសរ

ដូចអក្សរធំ។ អក្សរធំៗ មានរាងដូចចាន។

ក្បាច់ក្រឡាអួនពីរឈុត

«បន្ទះដែកកាត់ត្បាញជាមួយគ្នា»

1 Kings 7:42

ផ្លែទទឹមបួនរយ

«ផ្លែទទឹម ៤០០ ដើម»

ផ្លែទទឹមគឺជាផ្លែឈើមួយដែលមានសំបកក្រហមនិងគ្រាប់ដែលមានជាតិទឹកច្រើននៅខាងក្នុង

បកប្រែដូចនៅក្នុងជំពូក ៧:១៨។

1 Kings 7:44

លោកបានធ្វើ

នៅទីនេះពាក្យ «គាត់» សំដៅទៅលើហ៊ីរ៉ាមនិងអ្នកជួយរបស់គាត់។

របស់របរផ្សេងទៀត

«ឧបករណ៍ផ្សេងទៀតទាំងអស់»

លង្ហិនរលោង

លង្ហិនដែលត្រូវបានប៉ូលាដូច្នេះវាអាចឆ្លុះបញ្ចាំងពន្លឺថ្ងៃ

1 Kings 7:46

ស្តេចបានចាក់របស់ទាំងអស់នេះ

វាជាការល្អបំផុតក្នុងការបកប្រែដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចឲ្យធ្វើកិច្ចការនេះ។

នៅវាលទំនាបទន្លេយ័រដាន់

«ដីរាបស្មើក្បែរទន្លេយ័រដាន់»

សិកូត និងសារថាន

ឈ្មោះទីក្រុង

ព្រះបាទសាឡូម៉ូនមិនបានថ្លឹងគ្រឿងប្រដាប់ទាំងនោះទេ

ទោះជាយ៉ាងនោះក៏ដោយព្រះបាទសាឡូម៉ូនមិនបានធ្វើកិច្ចការនោះដោយខ្លួនឯងទេ។

«ស្តេចសាឡូម៉ូនមិនមានហ៊ីរ៉ាម

ហើយកម្មកររបស់ទ្រង់ថ្លឹងប្រដាប់ប្រដាទាំងអស់នោះ»

ទំងន់របស់លង្ហិនទាំងនោះធ្ងន់ពេកមិនអាចកំណត់បាន

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។

«គ្មាននរណាម្នាក់អាចថ្លឹងទម្ងន់លង្ហិនបានទេ»

1 Kings 7:48

ព្រះបាទសាឡូម៉ូនបានធ្វើ

វាជាការល្អបំផុតដើម្បីបកប្រែដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើការនេ

តុនំប៉័ងដែលដាក់តាំងនំប៉័ង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។

«ដែលពួកបូជាចារ្យត្រូវដាក់នំប៉័ងនៅមុខ»

ផ្តា ចង្កៀង

«ផ្តា» និង «ចង្កៀង» គឺជាផ្នែកមួយនៃជើងចង្កៀង។

1 Kings 7:50

ពែង ...ធ្វើពីមាសសុទ្ធ

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «កម្មករបានធ្វើពែង ... ចេញពីមាសសុទ្ធ»

ត្រចៀកទ្វារ...ធ្វើពីមាស

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «ពួកគេក៏បានធ្វើត្រចៀកទ្វារ ... ចេញពីមាស»

ត្រចៀកទ្វារ

នៅទីនេះ «ត្រចៀក» អាចសំដៅទៅលើ ១) ត្រចៀកដែលទ្វាររនាំងបិទបើកឬ ២) ទ្រនាប់ដែលទ្វាររុញ។

1 Kings 7:51

ព្រះបាទសាឡូម៉ូនបានធ្វើសម្រាប់ដំណាក់របស់ព្រះអម្ចាស់ ហើយបានធ្វើរួចរាល់

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ « កម្មករបានបញ្ចប់កិច្ចការដែលព្រះបាទសាឡូម៉ូនបានឲ្យ ពួកគេធ្វើដំណាក់របស់ព្រះអម្ចាស់»

---

8 [1]បន្ទាប់មក ព្រះបាទសាឡូម៉ូនបានអញ្ជើញពួកចាស់ទុំ ពួកអ្នកដឹកនាំកុលសម្ព័ន្ធ និងពួកមេដឹកនាំគ្រួសារទាំងអស់របស់ប្រជាជនអ៊ីស្រាអែល
នៅចំពោះស្តេចឯក្រុងយេរូសាឡឹម ដើម្បីនាំហឹបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ពីក្រុងរបស់ស្តេចដាវីឌ ដែលនៅក្រុងស៊ីយ៉ូនមក។
[2]ប្រុសៗទាំងអស់របស់អ៊ីស្រាអែលបានមកជួបព្រះបាទសាឡូម៉ូននៅក្នុងពិធីបុណ្យ នៅក្នុងខែអស្សុជ ជាខែទីប្រាំពីរ។
[3]ពួកចាស់ទុំទាំងអស់របស់អ៊ីស្រាអែលបានមក ហើយពួកបូជាចារ្យបានសែងហឹប។[4]ពួកគេបានយកហឹបរបស់ព្រះអម្ចាស់ តង់សម្រាប់ប្រជុំ
និងរបស់របរបរិសុទ្ធដែលមាននៅក្នុងជំរំចេញទៅ។ ពួកបូជាចារ្យ និងពួកលេវីបានកាន់របស់ទាំងនោះ។
[5]ព្រះបាទសាឡូម៉ូននិងប្រជាជនអ៊ីស្រាអែលបានដើរនៅខាងមុខហឹប ហើយបានថ្វាយចៀម និងគោច្រើនឥតគណនា។
[6]ពួកបូជាចារ្យបាននាំយកហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់មកដាក់នៅកន្លែងរបស់វា នៅក្នុងបន្ទប់ខាងក្នុងនៃព្រះដំណាក់ គឺកន្លែងបរិសុទ្ធបំផុត នៅក្រោមស្លាបចេរ៉ូប៊ីម។
[7]ចេរ៉ូប៊ីមបានត្រដាងស្លាបរបស់ពួកគេដល់កន្លែងដាក់ហឹប ហើយពួកគេបានគ្របហឹប និងដងសែងហឹបនៅពេលដែលពួកគេសែងមក។[8]ដងវែងណាស់
ចុងរបស់វាហាក់បីដូចជាចាប់តាំងពីទីបរិសុទ្ធមក គឺចាប់ពីបន្ទប់នៅមុខទីបរិសុទ្ធបំផុត ប៉ុន្តែ គេមិនអាចមើលពីក្រៅមកឃើញឡើយ។
ហឹបនៅកន្លែងនោះចាប់ពីពេលនោះមកដល់សព្វថ្ងៃ។
[9]គ្មានអ្វីនៅក្នុងហឹបឡើយមានតែបន្ទះថ្មពីរបន្ទះដែលលោកម៉ូសេបានដាក់នៅភ្នំហោរែប នៅពេលដែលព្រះអម្ចាស់បានចងសម្ពន្ធមេត្រីជាមួយជនជាតិអ៊ីស្រាអែល
នៅពេលដែលគេចេញពីស្រុកអេស៊ីបមក។[10]នៅពេលដែលពួកបូជាចារ្យចេញពីទីបរិសុទ្ធមកវិញ ក៏មានពពកពេញនៅក្នុងព្រះវិហារបស់ព្រះអម្ចាស់។
[11]ពួកបូជាចារ្យមិនអាចឈរបម្រើនៅទីនោះបានទេដោយសារតែពពក គឺសិរីរុងរឿងរបស់ព្រះអម្ចាស់បានបំពេញដំណាក់របស់ព្រះអង្គ។
[12]បន្ទាប់មក ព្រះបាទសាឡូម៉ូនមានបន្ទូលថា៖ «ព្រះអម្ចាស់ធ្លាប់មានបន្ទូលថាព្រះអង្គនឹងគង់នៅក្នុងភាពងងឹត[13]ប៉ុន្តែ
ទូលបង្គំបានសង់ដំណាក់ដ៏អស្ចារ្យនោះជាកន្លែងសម្រាប់ព្រះអង្គគង់នៅអស់កល្បជានិច្ច»។
[14]បន្ទាប់មក ស្តេចបានត្រឡប់មកឲ្យពរដល់ប្រជាជនអ៊ីស្រាអែលទាំងអស់ នៅពេលដែលពួកគេកំពុងឈរ។[15]ស្តេចមានរាជឱង្ការថា៖ «សូមឲ្យព្រះអម្ចាស់
ជាព្រះរបស់អ៊ីស្រាអែល បានទទួលសិរីល្អ ដែលទ្រង់បានមានបន្ទូលទៅកាន់បិតារបស់ទូលបង្គំ
ហើយបានឲ្យការនេះបានសម្រេចរូបរាងឡើងដោយសារព្រះហស្តរបស់ព្រះអង្គផ្ទាល់ ដោយមានបន្ទូលថា៖
[16]«ចាប់ពីថ្ងៃដែលយើងបាននាំប្រជាជនអ៊ីស្រាអែលចេញពីស្រុកអេស៊ីប

generated on Wed Sep 10 16:16:32 2025

យើងមិនបានជ្រើសរើសក្រុងចេញពីកុលសម្ព័ន្ធណាមួយរបស់អ៊ីស្រាអែលក្នុងការសង់ដំណាក់របស់យើង ដើម្បីឲ្យព្រះនាមរបស់យើងនៅទីនោះឡើយ។
ទោះជាយ៉ាងណាក៏ដោយយើងបានជ្រើសរើសដាវីឌ ដើម្បីគ្រប់គ្រងលើប្រជាជនអ៊ីស្រាអែលរបស់យើង»។
[17]ឥឡូវនេះ ការនេះជាបំណងរបស់ដាវីឌជាបិតាខ្ញុំក្នុងការសង់ដំណាក់សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះរបស់អ៊ីស្រាអែល។[18]ប៉ុន្តែ
ព្រះអម្ចាស់បានមានបន្ទូលមកដាវីឌជាបិតារបស់ខ្ញុំថា៖ «អ្នកមានដួងចិត្តក្នុងការសាងសង់ដំណាក់សម្រាប់នាមរបស់យើង អ្នកបានគិតក្នុងចិត្តនោះល្អហើយ។
[19]អ្នកមិនអាចសង់ដំណាក់របស់យើងបានឡើយ ផ្ទុយទៅវិញ គឺបុត្ររបស់អ្នកដែលកើតពីអ្នកនឹងសង់ដំណាក់សម្រាប់នាមយើង»។
[20]ព្រះអម្ចាស់បានធ្វើតាមអ្វីដែលព្រះអង្គបានសន្យា គឺព្រះអង្គបានឲ្យខ្ញុំសោយរាជ្យបន្តពីដាវីឌជាបិតារបស់ខ្ញុំ ហើយខ្ញុំបានគង់លើបល្ល័ង្កនៃស្រុកអ៊ីស្រាអែល
ដូចដែលព្រះអម្ចាស់បានសន្យា។ ខ្ញុំបានសង់ដំណាក់សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះរបស់អ៊ីស្រាអែល។
[21]ខ្ញុំបានសង់កន្លែងសម្រាប់ហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ ដែលព្រះអង្គបានចងជាមួយបុព្វបុរសរបស់យើង
នៅពេលដែលព្រះអង្គបាននាំពួកគេចេញពីស្រុកអេស៊ីបមក»។
[22]ព្រះបាទសាឡូម៉ូនបានឈរនៅមុខអាសនារបស់ព្រះអម្ចាស់ នៅមុខប្រជាជនអ៊ីស្រាអែលទាំងអស់ ហើយបានលើកដៃឡើងទៅស្ថានសួគ៌។[23]ស្តេចទូលថា៖
«ព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែល គ្មានព្រះឯណាដូចព្រះអង្គឡើយ ទោះបីជានៅស្ថានសួគ៌ ឬនៅផែនដីក្តី
ព្រះអង្គបានរក្សាសម្ពន្ធមេត្រីរបស់ព្រះអង្គយ៉ាងស្មោះត្រង់ជាមួយអ្នកបម្រើរបស់ព្រះអង្គ
គឺដល់អស់អ្នកដែលដើរនៅមុខព្រះអង្គដោយអស់ពីចិត្តរបស់ពួកគេ[24]ព្រះអង្គបានរក្សាសម្ពន្ធមេត្រីនេះជាមួយដាវីឌជាបិតាទូលបង្គំជាមួយអ្វីដែលព្រះអង្គបានសន្យា។
មែនហើយព្រះអង្គបានមានបន្ទូលដោយផ្ទាល់ ហើយបានសម្រេចដោយព្រះហស្តរបស់ព្រះអង្គ ដូចនៅថ្ងៃនេះស្រាប់។
[25]បន្ទាប់មក ព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែល បានសម្រេចនូវអ្វី ដែលព្រះអង្គបានសន្យាដល់អ្នកបម្រើរបស់ព្រះអង្គគឺដាវីឌជាបិតាទូលបង្គំ
នៅពេលដែលព្រះអង្គមានបន្ទូលថា៖ «ព្រះអង្គនឹងឲ្យពូជពង្សរបស់លោកអង្គុយលើបល្ល័ង្កស្រុកអ៊ីស្រាអែល
ប្រសិនបើជាកូនចៅរបស់អ្នកប្រុងប្រយ័ត្នក្នុងការដើរក្នុងមាគារបស់យើង ដូចដែលអ្នកបានធ្វើ»។[26]ឥឡូវនេះព្រះជាម្ចាស់របស់អ៊ីស្រាអែលអើយ
ទូលបង្គំសូមអធិស្ឋានឲ្យសេចក្តីសន្យាដែលព្រះអង្គបានសន្យាជាមួយដាវីឌជាបិតារបស់ទូលបង្គំ បានក្លាយជាការពិតផង។
[27]ប៉ុន្តែ តើព្រះនឹងគង់នៅផែនដីនេះឬទេ? មើល សកលលោកទាំងមូល និងស្ថានសួគ៌មិនគ្រប់គ្រាន់សម្រាប់ឲ្យព្រះអង្គគង់នៅទេ ចុះទំរាំវិហារដែលទូលបង្គំបានសង់នេះ!
[28]ប៉ុន្តែ សូមព្រះអង្គស្តាប់ពាក្យអធិស្ឋានរបស់ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ និងសំណើរបស់ទូលបង្គំផង ព្រះអម្ចាស់ជាព្រះរបស់ទូលបង្គំ សូមស្តាប់នូវសម្រែក
និងសេចក្តីអធិស្ឋានដែលអ្នកបម្រើរបស់ព្រះអង្គអធិស្ឋាននៅថ្ងៃនេះផង។
[29]សូមព្រះអង្គបើកព្រះនេត្រទតមើលព្រះវិហារនេះទាំងយប់ទាំងថ្ងៃ គឺជាកន្លែងដែលព្រះអង្គមានបន្ទូលថា៖ «នាម និងវត្តមានរបស់យើងនឹងនៅទីនេះ
ដើម្បីស្តាប់សេចក្តីអធិស្ឋាន ដែលអ្នកបម្រើរបស់ព្រះអង្គអធិស្ឋាននៅកន្លែងនេះ។[30]ដូច្នេះ សូមស្តាប់សំណើរបស់អ្នកបម្រើរបស់ព្រះអង្គ
និងរបស់ប្រជាជនអ៊ីស្រាអែលរបស់ព្រះអង្គ នៅពេលដែលយើងអធិស្ឋាននៅកន្លែងនេះផង។ ពិតមែនហើយ សូមស្តាប់ពីកន្លែងដែលព្រះអង្គគង់នៅ ពីស្ថានសួគ៌
និងអត់ទោសឲ្យយើងខ្ញុំផង។
[31]បើនរណាម្នាក់បានប្រព្រឹត្តអំពើបាបប្រឆាំងនឹងបងប្អូនរបស់ខ្លួន ហើយតម្រូវឲ្យស្បថ
ហើយបើគាត់មកស្បថនៅខាងមុខអាសនានៅក្នុងដំណាក់របស់ព្រះអង្គ[32]សូមព្រះអង្គផ្ទៀងព្រះការស្តាប់ពីស្ថានសួគ៌ និងវិនិច្ឆ័យអ្នកបម្រើរបស់ព្រះអង្គ
ទាក់ទងនឹងការអាក្រក់របស់គេ នឹងសូមឲ្យអ្វីដែលគាត់បានធ្វើធ្លាក់មកលើក្បាលគាត់វិញ និងប្រកាសឲ្យយុត្តិធម៌ដល់មនុស្សសុច្ចរិតស្របតាមសេចក្តីសុច្ចរិតរបស់គាត់។
[33]នៅពេលដែលប្រជាជនអ៊ីស្រាអែលរបស់ព្រះអង្គត្រូវបានខ្មាំងសត្រូវវាយប្រហារដោយសារតែពួកគេបានប្រព្រឹត្តអំពើបាបប្រឆាំងនឹងព្រះអង្គ
ហើយបើគេត្រឡប់មករកព្រះអង្គវិញ ដោយបានសារភាពអំពើបាបរបស់ពួកគេ ដោយអធិស្ឋាន ហើយសុំការអត់ទោសពីព្រះអង្គនៅក្នុងព្រះវិហារនេះ[34]សូមព្រះអង្គព្រះស
ណ្តាប់ពីនគរស្ថានសួគ៌ និងអត់ទោសបាបដល់ប្រជាជនអ៊ីស្រាអែលរបស់ព្រះអង្គផង
សូមនាំគេត្រឡប់មកទឹកដីដែលព្រះអង្គបានប្រទានដល់បុព្វបុរសរបស់ពួកគេវិញផង។
[35]នៅពេលដែលផ្ទៃមេឃបិទ និងគ្មានភ្លៀងដោយសារមនុស្សបានប្រព្រឹត្តអំពើបាបប្រឆាំងនឹងព្រះអង្គ បើពួកគេមកអធិស្ឋាននៅទីនេះ ប្រកាសព្រះនាមរបស់ព្រះអង្គ
ហើយចេញពីអំពើបាបរបស់ពួកគេ នៅពេលដែលព្រះអង្គបានផ្តាញ់ផ្តាលពួកគេ[36]ហើយអត់ទោសបាបដល់អ្នកបម្រើរបស់ព្រះអង្គ និងដល់ប្រជាជនអ៊ីស្រាអែល
នៅពេលដែលព្រះអង្គបង្រៀនពួកគេឲ្យដើរផ្លូវល្អ ដែលពួកគេគួរដើរ។ សូមប្រទានទឹកភ្លៀងនៅលើទឹកដីរបស់ព្រះអង្គ
ដែលព្រះអង្គបានប្រទានដល់ប្រជារាស្ត្ររបស់ព្រះអង្គជាមរតកផង។
[37]បើមានកើតអំណត់នៅលើទឹកដីនេះ ឬក៏មានគ្រោះមហន្តរាយ ជំងឺរាតត្បាត ស្រូវស្កកមានក្រា កណ្តូប និងចង្រិតស៊ីបង្ហិនស្រូវ ឬមានខ្មាំងសត្រូវមកវាយប្រហារទ្វារក្រុង
នៅក្នុងទឹកដីនេះ ឬមានគ្រោះកាច និងមានជំងឺផ្សេងៗ[38]ហើយបន្ទាប់មកមាននរណាម្នាក់ឬក៏ប្រជាជនអ៊ីស្រាអែលទាំងអស់អធិស្ឋានសុំ
ដោយម្នាក់ៗខ្លោចផ្សានៅក្នុងចិត្តនៅពេលដែលពួកគេដាក់ដៃរបស់ពួកគេតម្រង់មកព្រះវិហារនេះ។
[39]សូមព្រះអង្គស្តាប់ពីស្ថានសួគ៌មក ពីកន្លែងដែលព្រះអង្គគង់នៅ សូមអត់ទោសដល់ពួកគេ ហើយប្រទានដល់ពួកគេនូវអ្វីដែលពួកគេបានធ្វើ
ព្រះអង្គជ្រាបដួងចិត្តរបស់ពួកគេ ព្រោះមានតែព្រះអង្គមួយអង្គគត់ស្គាល់ជម្រៅចិត្តរបស់មនុស្ស។[40]សូមធ្វើបែបនេះ
ដើម្បីឲ្យពួកគេកោតខ្លាចព្រះអង្គនៅក្នុងពេលដែលពួកគេមានជីវិតរស់នៅក្នុងទឹកដីដែលព្រះអង្គបានប្រទានដល់បុព្វបុរសរបស់យើង។
[41]សរុបមកទាក់ទងនឹងជនបរទេស ដែលមិនមែនជាប្រជារាស្ត្រអ៊ីស្រាអែលរបស់ព្រះអង្គ៖
នៅពេលដែលគេមកពីប្រទេសឆ្ងាយដោយសារតែព្រះនាមព្រះអង្គ[42]ដោយសារតែពួកគេបានឮពីព្រះនាមដ៏អស្ចារ្យ ស្នាមព្រះហស្ត និងពីកិច្ចការរបស់ព្រះអង្គ
នៅពេលដែលពួកគេមក និងអធិស្ឋាននៅក្នុងព្រះវិហារនេះ[43]សូមព្រះអង្គស្តាប់ពីស្ថានសួគ៌ ពីកន្លែងដែលព្រះអង្គគង់នៅ
និងឆ្លើយតមនូវអ្វីដែលជនបរទេសនោះបានសុំពីព្រះអង្គផង។ សូមធ្វើដូច្នេះ ដើម្បីឲ្យមនុស្សទាំងអស់នៅលើផែនដីស្គាល់ព្រះនាមរបស់ព្រះអង្គ និងកោតខ្លាចព្រះអង្គ
ដូចជាប្រជាជនអ៊ីស្រាអែលដែរ។ សូមធ្វើដូច្នេះ ដើម្បីឲ្យគេដឹងថាដំណាក់ ដែលទូលបង្គំសង់នេះមានព្រះអង្គគង់នៅមែន។
[44]នៅពេលដែលប្រជារាស្ត្ររបស់ព្រះអង្គចេញទៅសមរភូមិ ដើម្បីច្បាំងនឹងសត្រូវ ទោះបីព្រះអង្គបញ្ជូនពួកគេទៅតាមផ្លូវណាក៏ដោយ
ហើយបើពួកគេអធិស្ឋានទៅរកព្រះអង្គ គឺទៅព្រះអម្ចាស់ ទៅកាន់ក្រុងដែលព្រះអង្គជ្រើសរើស និងទៅកាន់ដំណាក់ដែលទូលបង្គំបានសង់ដោយនូវព្រះនាមព្រះអង្គ។
[45]សូមព្រះអង្គស្តាប់ពីនរគស្ថានសួគ៌រាល់ការអធិស្ឋាន និងការស្នើសុំរបស់ពួកគេ ហើយសូមជួយពួកគេផង។
[46]បើពួកគេប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គ រហូតគ្រប់គ្នាប្រព្រឹត្តបាប ហើយព្រះអង្គព្រះពិរោធនឹងពួកគេ ហើយព្រះអង្គប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ
ដូច្នេះ ខ្មាំងសត្រូវនឹងនាំពួកគេទៅឆ្ងាយហើយចាប់យកទឹកដីរបស់ពួកគេ ទោះបីជាទៅជិត ឬក៏ឆ្ងាយក្តី។[47]បន្ទាប់មក
បើពួកគេដឹងខ្លួនថាពួកគេនៅក្នុងទឹកដីដែលពួកគេជាប់ជាឈ្លើយ ហើយពួកគេប្រែចិត្ត និងស្វែងរកព្រះអង្គពីទឹកដីនោះ។ បើគេនិយាយថា៖ «យើងបានប្រព្រឹត្តអំពើកំហុស
និងអំពើបាប។ យើងខ្ញុំបានប្រព្រឹត្តអំពើអាក្រក់»។
[48]បើពួកគេត្រឡប់មករកព្រះអង្គវិញដោយអស់ពីចិត្ត និងពីព្រលឹងរបស់ពួកគេ នៅក្នុងទឹកដីដែលខ្មាំងសត្រូវរបស់ពួកគេបានកៀរពួកគេទៅជាឈ្លើយ
ហើយបើពួកគេអធិស្ឋានទៅព្រះអង្គនៅទឹកដីរបស់ពួកគេ គឺទឹកដីដែលព្រះអង្គបានប្រទានដល់បុព្វបុរសរបស់ពួកគេ និងទៅកាន់ក្រុងដែលព្រះអង្គបានជ្រើសរើស
និងទៅកាន់ដំណាក់ដែលទូលបង្គំបានសង់សម្រាប់ព្រះនាមព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[49]សូមព្រះអង្គសណ្ដាប់ពីនគរស្ថានសួគ៌មក គឺពីកន្លែងដែលព្រះអង្គគង់នៅ សូមស្ដាប់ពាក្យអធិស្ឋាន និងការស្នើសុំរបស់ពួកគេ ហើយសូមព្រះអង្គរំដោះពួកគេផង។
[50]សូមអត់ទោសដល់ប្រជាជនរបស់ព្រះអង្គ ដែលបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គ និងអំពើទុច្ចរិតទាស់នឹងបញ្ញត្តរបស់ព្រះអង្គ។
សូមផ្ដល់ក្ដីមេត្តាលើពួកគេនៅចំពោះខ្មាំងសត្រូវរបស់ពួកគេដែលបានចាប់ពួកគេជាឈ្លើយ ដូច្នេះ សត្រូវរបស់ពួកគេនឹងមានក្ដីមេត្តាដល់ប្រជារាស្ត្ររបស់ព្រះអង្គដែរ។
[51]ពួកគេជារាស្ត្ររបស់ព្រះអង្គ ដែលព្រះអង្គជ្រើសរើស ជាអ្នកដែលព្រះអង្គសង្គ្រោះចេញពីអេស៊ីបដូចជាចេញពីឡរំលាយដែកដែរ។
[52]ទូលបង្គំសូមអធិស្ឋានឲ្យព្រះនេត្ររបស់ព្រះអង្គបានបើក មើលឃើញការទូលសូមរបស់អ្នកបម្រើរបស់ព្រះអង្គ និងសំណូមពររបស់ប្រជារាស្ត្រអ៊ីស្រាអែលរបស់ព្រះអង្គ
សូមស្ដាប់ពួកគេនៅពេលដែលពួកគេស្រែករកព្រះអង្គ។[53]ដោយសារតែព្រះអង្គញែកពួកគេចេញពីជាតិសាសន៍នានានៅលើផែនដី ដើម្បីធ្វើជារាស្ត្ររបស់ព្រះអង្គ
និងទទួលព្រះបន្ទូលសន្យារបស់ព្រះអង្គ ដូចដែលព្រះអង្គបានពន្យល់តាមរយៈលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គ
នៅពេលដែលព្រះអង្គនាំដូនតារបស់យើងចេញពីអេស៊ីបមក ព្រះអម្ចាស់អើយ។
[54]ដូច្នេះ នៅពេលដែលព្រះបាទសាឡូម៉ូនបានបញ្ចាប់ការអធិស្ឋានទាំងនេះ និងបានទូលសូមព្រះអម្ចាស់រួចមក ស្តេចក្រោកចេញពីអាសនារបស់ព្រះអម្ចាស់
ក្រោកពីការលុតជង្គង់ដោយដៃរបស់ស្តេចលើកឡើងទៅលើមេឃ។[55]ស្តេចក្រោកឡើង ហើយឲ្យពរដល់ប្រជាជនអ៊ីស្រាអែលទាំងអស់ឮៗថា៖
[56]«សូមឲ្យព្រះអម្ចាស់ប្រកបដោយព្រះពរ ដែលបានឲ្យបានជាជនអ៊ីិស្រាអែលបានសម្រាក ព្រះអង្គបានរក្សាសេចក្ដីសន្យាទាំងអស់។
គ្មានពាក្យសន្យាណាមួយដែលព្រះអង្គសន្យាជាមួយម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គមិនបានសម្រេចនោះឡើយ ។
[57]សូមឲ្យព្រះអម្ចាស់ជាព្រះរបស់យើងគង់នៅជាមួយយើង ដូចដែលព្រះអង្គគង់នៅជាមួយបុព្វបុរសរបស់យើងដែរ។ សូមកុំឲ្យព្រះអង្គបោះបង់ចោលយើង
ឬបំភ្លេចពួកយើងចោលឡើយ[58]ដូច្នេះព្រះអង្គអាចទាញចិត្តយើងទៅរកព្រះអង្គ ដើម្បីឲ្យយើងរស់ស្របតាមមាគាៈផ្លូវរបស់ព្រះអង្គ និងរក្សាបញ្ញត្ត ច្បាប់
និងបទបញ្ជារបស់ព្រះអង្គ ដែលព្រះអង្គបានបង្គាប់ដល់ដូនតារបស់យើង។
[59]សូមឲ្យពាក្យទាំងអស់ដែលទូលបង្គំបាននិយាយ ដែលទូលបង្គំទូលសូមនៅមុខព្រះអម្ចាស់ បានឮដល់ព្រះអង្គជាព្រះរបស់ពួកយើងរាល់ថ្ងៃ និងរាល់យប់ ដូច្នេះ
ព្រះអង្គអាចជួយអ្នកបម្រើរបស់ព្រះអង្គ និងជួយប្រជារាស្ត្រអ៊ីស្រាអែលរបស់ព្រះអង្គ
នៅរាល់ថ្ងៃដែលត្រូវការ[60]នោះមនុស្សទាំងអស់នៅលើផែនដីនឹងដឹងថាព្រះអម្ចាស់ជាព្រះ ហើយគ្មានព្រះឯណាទៀតឡើយ![61]ដូច្នេះ
សូមឲ្យចិត្តរបស់អ្នករាល់គ្នាស្មោះត្រង់ចំពោះព្រះអម្ចាស់ជាព្រះរបស់យើង ដើរតាមច្បាប់ របស់ព្រះអង្គ និងរក្សាបទបញ្ញត្តរបស់ទ្រង់ ដូចជានៅថ្ងៃនេះ។
[62]ដូច្នេះ ស្តេច និងប្រជាជនអ៊ីស្រាអែល ដែលនៅជាមួយស្តេចបានថ្វាយយញ្ញបូជាទៅព្រះអម្ចាស់។[63]ព្រះបាទសាឡូម៉ូនបានថ្វាយតង្វាយទៅព្រះអម្ចាស់ដូចតទៅ៖ ថ្វាយគោ
ចំនួនពីរម៉ឺនពីរពាន់ក្បាល ចៀមមួយសែនពីរម៉ឺនក្បាល។ ច្នេះស្តេច និងប្រជាជនអ៊ីស្រាអែល ដែលនៅជាមួយស្តេចបានឧទ្ទិសថ្វាយព្រះដំណាក់នោះទៅព្រះអម្ចាស់។
[64]នៅថ្ងៃដដែលនោះ ស្តេចបានញែកទីធ្លារកណ្តាលនៅខាងមុខព្រះវិហារថ្វាយព្រះអម្ចាស់សម្រាប់ថ្វាយតង្វាយដុតទាំងមូល តង្វាយម្សៅ និងខ្លាញ់របស់សត្វដែលជា
យញ្ញបូជាមេត្រីភាព ព្រោះអាសនាលង្ហិន ដែលនៅចំពោះព្រះអម្ចាស់តូចពេក ពុំអាចដាក់តង្វាយដុតទាំងមូល តង្វាយម្សៅ និងខ្លាញ់របស់សត្វដែលជាយញ្ញបូជា
មេត្រីភាពបានទេ។
[65]ដូច្នេះ ព្រះបាទសាឡូម៉ូនបានប្រកាសពិធីបុណ្យនៅពេលនោះ ហើយជនជាតិអ៊ីស្រាអែលដែលនៅជាមួយទ្រង់មានចំនួនដ៏ច្រើន គេមកពីក្រុងហាម៉ាត់ រហូតដល់ទឹកធ្លាក់
នៅស្រុកអេស៊ីប នៅមុខព្រះអម្ចាស់ជាព្រះរបស់យើងអស់រយៈពេលប្រាំពីរថ្ងៃ ហើយថែមប្រាំពីរថ្ងៃទៀត ទាំងអស់ដប់បួនថ្ងៃ។
[66]នៅថ្ងៃទីប្រាំបីស្តេចបានឲ្យបណ្តាជនចេញទៅ ហើយពួកគេបានឲ្យពរស្តេច និងត្រឡប់ទៅផ្ទះរបស់ពួកគេវិញដោយអំណរ
និងមានដួងចិត្តសប្បាយដោយសារការល្អដែលព្រះអម្ចាស់បានប្រទានដល់ដាវីឌជាអ្នកបម្រើព្រះអង្គ និងដល់ប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់ផង។

---

1 Kings 8:1
ពួកចាស់ទុំ ពួកអ្នកដឹកនាំ
«កោះហៅមេដឹកនាំអ៊ីស្រាអែលទាំងអស់គ្នា»
ប្រុសៗទាំងអស់របស់អ៊ីស្រាអែល
នេះអាចយោងទៅលើលេខ ១)
ចំពោះប្រជាជនដែលស្តេចសាឡូម៉ូនបានហៅទៅក្រុងយេរូសាឡឹមនិងដែលត្រូវបានចុះបញ្ជីនៅក្នុង
៨:១ ឬ ២) ជាទូទៅចំពោះអ្នកដែលធ្វើដំណើរទៅក្រុងយេរូសាឡឹម
សម្រាប់ពិធីបុណ្យនេះមិនចាំបាច់ចំពោះមនុស្សប្រុសទាំងអស់ដែលរស់នៅអ៊ីស្រាអែលទេ
នៅក្នុងពិធីបុណ្យ
នេះសំដៅទៅលើបុណ្យនៃស៊ូភូតដែលត្រូវបានគេស្គាល់ផងដែរថា
ជាបុណ្យនៃរោងឧបោសថឬបុណ្យនៃជម្រក ។
នៅក្នុងខែអស្សុជ ជាខែទីប្រាំពីរ
«អស្សុជ» គឺជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងក្រោយនៃខែកញ្ញា
និងផ្នែកដំបូងនៃខែតុលាតាមប្រតិទិនលោកខាងលិច។
1 Kings 8:3
ពួកចាស់ទុំទាំងអស់របស់អ៊ីស្រាអែល
នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅ។
ចៀម និងគោច្រើនឥតគណនា
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ចៀមនិងគោច្រើនដែលមិនអាចរាប់បាន»
1 Kings 8:6
នៅក្នុងបន្ទប់ខាងក្នុងនៃព្រះដំណាក់ គឺកន្លែងបរិសុទ្ធបំផុត នៅក្រោម
«ចូលទៅបន្ទប់ខាងក្នុងនៃព្រះដំណាក់គឺកន្លែងបរិសុទ្ធបំផុត - ខាងក្រោម»
ដងសែងហឹប
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «ដងសែងដែលពួកសង្ឃកាន់»។
គេមិនអាចមើលពីក្រៅមកឃើញឡើយ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«គ្មាននរណាម្នាក់អាចមើលឃើញពួកគេបានទេ»
ដល់សព្វថ្ងៃ។
នេះមានន័យថា ថ្ងៃដែលអ្នកនិពន្ធសរសេរ។
1 Kings 8:9
នៅពេលដែល
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់បកប្រែការនេះអ្នកអាចពិចារណាប្រើវានៅទីនេះបាន។
1 Kings 8:12
ព្រះអម្ចាស់ធ្លាប់មានបន្ទូលថា...ភាពងងឹត
ស្តេចសាឡូម៉ូនមានបន្ទូល
ទៅកាន់ព្រះអម្ចាស់ដូចជាគាត់កំពុងតែនិយាយជាមួយនរណាម្នាក់ផ្សេងទៀត
ដើម្បីបង្ហាញថាគាត់គោរពព្រះជាម្ចាស់។
ដំណាក់ដ៏អស្ចារ្យ
អគារដ៏ស្រស់ស្អាតដែលមាន មនុស្សសំខាន់រស់នៅទីនោះ។
1 Kings 8:14
ប្រជាជនអ៊ីស្រាអែលទាំងអស់
នេះជាការធ្វើឲ្យមានលក្ខណៈទូទៅ។
សូមឲ្យព្រះអម្ចាស់ ជាព្រះរបស់អ៊ីស្រាអែល បានទទួលសិរីល្អ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«សរសើរតម្កើងព្រះជាម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែល»។ .
ដោយសារព្រះហស្តរបស់ព្រះអង្គផ្ទាល់
ដៃគឺសំដៅទៅលើអំណាចនៅក្នុងដៃ។ «ដោយអំណាចផ្ទាល់ខ្លួនរបស់ព្រះអង្គ»
ដើម្បីឲ្យព្រះនាមរបស់យើងនៅទីនោះ
ពាក្យថា «នាម» គឺសំដៅទៅលើមនុស្សហើយ «សម្រាប់...នាម»
សំដៅទៅលើការគោរពបូជាមនុស្ស។ ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក
៣:១។ «ដើម្បីឲ្យមនុស្សគោរពបូជាទ្រង់»
1 Kings 8:17
ការនេះជាបំណងរបស់ស្តេចដាវីឌជាបិតាខ្ញុំ...មានដួងចិត្ត...អ្នកបានគិតក្នុងចិត្តនោះល្អហើយ
អ្វីដែលស្តេចដាវីឌចង់បានត្រូវបានគេនិយាយថា ជារបស់របរមួយនៅក្នុងធុង
និងបេះដូងគឺដូចជាធុង។ «ស្តេចដាវីឌដែលជាបិតាខ្ញុំចង់បាន ... អ្នកចង់ ...
ចង់ធ្វើវា»

generated on Wed Sep 10 16:16:32 2025

សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់...សម្រាប់នាមយើង
ពាក្យថា «នាម» គឺសំដៅទៅលើមនុស្សហើយ «សម្រាប់...មាន»
សំដៅទៅលើការគោរពបូជាមនុស្ស។ ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក
៣:១។ «ដែលមនុស្សនឹងថ្វាយបង្គំព្រះជាម្ចាស់ ដែលមនុស្សនឹងថ្វាយបង្គំយើង»
អ្នកមានដួងចិត្ត
«ពីព្រោះអ្នកចង់ធ្វើ»
អ្នកបានគិតក្នុងចិត្តនោះល្អហើយ
«ដោយចង់ធ្វើវា»
បុត្ររបស់អ្នកដែលកើតពីអ្នក
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«អ្នកដែលនឹងក្លាយជាកូនចៅរបស់អ្នក» ឬ «អ្នកដែលអ្នកនឹងធ្វើជាឪពុកគេ»
1 Kings 8:20
បានធ្វើតាមអ្វីដែលព្រះអង្គបានសន្យា
នេះគឺពាក្យក្រៀមភាសារ។ «បានធ្វើអ្វីដែលគាត់បាននិយាយថាគាត់នឹងធ្វើ»
ព្រះអង្គបានឲ្យខ្ញុំសោយរាជ្យបន្តពីដាវីឌជាបិតារបស់ខ្ញុំ
កម្ពស់គឺជាពាក្យប្រៀបធៀបសម្រាប់អំណាច។
«ខ្ញុំបានទទួលអំណាចដែលស្តេចដាវីឌជាឪពុកខ្ញុំមាន»
ខ្ញុំបានគង់លើបល្ល័ង្កនៃស្រុកអ៊ីស្រាអែល
បល្ល័ង្កគឺជាពាក្យសំដៅទៅលើសកម្មភាពរបស់អ្នកដែលអង្គុយលើបល្ល័ង្ក។
«ខ្ញុំគ្រប់គ្រងលើអ៊ីស្រាអែល»
សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់
ពាក្យថា « នាម» គឺសំដៅទៅលើមនុស្សហើយ «សម្រាប់...នាម»
សំដៅទៅលើការគោរពបូជាមនុស្ស។ បកប្រែដូចនៅក្នុងជំពូក ៣:១។
«ដែលមនុស្សនឹងថ្វាយបង្គំព្រះជាម្ចាស់»
សម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
បន្ទះថ្មដែលព្រះអម្ចាស់បានសរសេរនូវលក្ខខណ្ឌនៃសម្ពន្ធមេត្រីត្រូវបាននិយាយថាជាសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
«គឺជាបន្ទះថ្មដែលព្រះអម្ចាស់បានសរសេរលក្ខខណ្ឌនៃសម្ពន្ធមេត្រី»
1 Kings 8:22
នៅមុខប្រជាជនអ៊ីស្រាអែលទាំងអស់
នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅ។
ដើរនៅមុខព្រះអង្គដោយអស់ពីចិត្តរបស់ពួកគេ
របៀបដែលមនុស្សរស់នៅ
ត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងដើរលើផ្លូវមួយ។ «
រស់នៅតាមរបៀបដែលអ្នកចង់អោយពួកគេរស់នៅ»
បានសម្រេចដោយព្រះហស្តរបស់ព្រះអង្គ
ដៃគឺសំដៅទៅលើអំណាចនៃដៃ។
«ដោយអំណាចរបស់អ្នកបានបំពេញនូវអ្វីដែលអ្នកបាននិយាយ»
1 Kings 8:25
អង្គុយលើបល្ល័ង្កស្រុកអ៊ីស្រាអែល
បល្ល័ង្កគឺសំដៅទៅលើសកម្មភាពរបស់អ្នកដែលអង្គុយលើបល្ល័ង្ក។
«ដើម្បីគ្រប់គ្រងលើអ៊ីស្រាអែល»
ការដើរក្នុងមាគារបស់យើង...ដូចដែលអ្នកបានធ្វើ
របៀបដែលមនុស្សរស់នៅ
ត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងដើរលើផ្លូវមួយ។
«រស់នៅដូចដែលខ្ញុំចង់អោយអ្នករស់នៅ...បានរស់នៅដូចដែលខ្ញុំចង់អោយអ្នកធ្វើ»
1 Kings 8:27
ប៉ុន្តែ តើព្រះនឹងគង់នៅផែនដីនេះឬទេ?
អត្ថន័យដែលអាចទៅរួចនៃសំណួរនេះគឺ ១)
សាឡូម៉ូនកំពុងតែសួរសំណួរពិតហើយរំពឹងថា នឹងមានចម្លើយឬ ២)
សំណួរគឺជាវោហាសាស្ត្រ ហើយស្តេចសាឡូម៉ូនកំពុងតែបញ្ជាក់ថា
ព្រះធំពេកហើយខ្លាំងពូកែក្នុងការរស់នៅលើផែនដី។
តែវាមិនអាចទៅរួចទេដែលថាព្រះជាម្ចាស់នឹងរស់នៅលើផែនដីនេះ!»
ប៉ុន្តែ តើព្រះនឹង
នៅទីនេះស្តេចសាឡូម៉ូននិយាយអំពីព្រះនៅក្នុងមនុស្សទីបី។
វាអាចត្រូវបានបញ្ជាក់នៅក្នុងបុរសទីពីរ។ «ប៉ុន្តែអ្នកនឹង»
មើល
«អ្វីដែលខ្ញុំកំពុងនិយាយគឺសំខាន់» ឬ «ការពិតគឺថា»
ព្រះអង្គ ចុះទំរាំវិហារដែលទូលបង្គំបានសង់នេះ
«ព្រះអង្គ, ដូច្នេះព្រះវិហារដែលខ្ញុំបានសាងសង់ពិតជាមិនអាច»
សូមព្រះអង្គស្តាប់ពាក្យអធិស្ឋានរបស់ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ
ពាក្យ «ការអធិស្ឋាន» និង «ការស្នើសុំ» មានន័យថា ជាមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់ថាទ្រង់មានព្រះទ័យស្មោះត្រង់នៅពេលទ្រង់ស្តើសុំ។
ស្តេចសាឡូម៉ូនចាត់ទុកខ្លួនគាត់ជា «អ្នកបំរើរបស់ព្រះជាម្ចាស់»
ដើម្បីបង្ហាញថាគាត់គោរពព្រះអម្ចាស់។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងបុរសទីមួយ។
«គោរពទូលបង្គំជាអ្នកបំរើរបស់ព្រះអង្គដូចដែលទូលបង្គំបានស្តើសុំនេះ»
សូមស្តាប់នូវសម្រែក និងសេចក្តីអធិស្ឋានដែលអ្នកបម្រើរបស់ព្រះអង្គអធិស្ឋាននៅថ្ងៃនេះផង
ពាក្យ «សម្រែក» និង «ការអធិស្ឋាន» មានន័យថា
ជារឿងដូចគ្នាហើយសង្កត់ធ្ងន់លើ
ស្តេចមានព្រះទ័យស្មោះត្រង់នៅពេលទ្រង់សុំឲ្យព្រះអម្ចាស់ជួយគាត់។
ស្តេចសាឡូម៉ូនចាត់ទុកខ្លួនគាត់ជា «អ្នកបំរើរបស់ព្រះ»
ដើម្បីបង្ហាញថាគាត់គោរពព្រះអម្ចាស់។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងបុរសទីមួយ។
«ស្តាប់ទូលបង្គំអ្នកបម្រើរបស់ព្រះអង្គដូចដែលទូលបង្គំបានអំពាវនាវនៅថ្ងៃនេះ
ដើម្បីឲ្យទ្រង់ជួយទូលបង្គំ»
1 Kings 8:29
សូមព្រះអង្គបើកព្រះនេត្រទតមើល
ភ្នែកគឺជាពាក្យប្រៀបធៀបសម្រាប់អ្វីដែលភ្នែកធ្វើ។ «សូមឲ្យទ្រង់ឃ្លាំមើល»
ទាំងយប់ទាំងថ្ងៃ
នេះគឺជាការរួមបញ្ចូលគ្នា។ «គ្រប់ពេលវេលា» ឬ «បន្ត»
នាម និងវត្តមានរបស់យើង
ពាក្យទាំងពីរនេះរួមគ្នាបញ្ជាក់ថាព្រះអម្ចាស់នឹងគង់នៅក្នុងព្រះវិហារ។
ដែលអ្នកបម្រើរបស់ព្រះអង្គអធិស្ឋាន
ស្តេចសាឡូម៉ូនមានបន្ទូលអំពីខ្លួនគាត់ថាជា «អ្នកបម្រើរបស់ព្រះជាម្ចាស់»
ដើម្បីបង្ហាញថាគាត់គោរពដល់ព្រះអម្ចាស់។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីមួយ។
«ខ្ញុំដែលជាអ្នកបម្រើរបស់ព្រះជាម្ចាស់នឹងអធិស្ឋាន»
សូមស្តាប់សំណើរបស់អ្នកបម្រើរបស់ព្រះអង្គ និងរបស់ប្រជាជនអ៊ីស្រាអែលរបស់ព្រះអង្គ
ស្តេចសាឡូម៉ូនមានបន្ទូលអំពីខ្លួនគាត់ថាជា «អ្នកបម្រើរបស់ព្រះជាម្ចាស់»
ដើម្បីបង្ហាញថាគាត់គោរពដល់ព្រះអម្ចាស់។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងបុរសទីមួយ។
«ស្តាប់សំណើរបស់ទូលបង្គំនិងសំណូមពររបស់អ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ»
1 Kings 8:31
តម្រូវឲ្យស្បថ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «មាននរណាម្នាក់តម្រូវឲ្យគាត់ស្បថ»
បានធ្វើឆ្លាក់មកលើក្បាលគាត់វិញ
នៅទីនេះ «ក្បាល» សំដៅទៅលើមនុស្សទាំងមូល។ «លើគាត់»
ប្រកាសឲ្យយុត្តិធម៌ដល់មនុស្សសុច្ចរិតស្របតាមសេចក្តីសុច្ចរិតរបស់គាត់
«ដើម្បីផ្តល់ឲ្យគាត់នូវអ្វីដែលគាត់សមនឹងទទួលពីព្រោះគាត់គ្មានកំហុស»
1 Kings 8:33
ប្រជាជនអ៊ីស្រាអែលរបស់ព្រះអង្គត្រូវបានខ្មាំងសត្រូវវាយប្រហារ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ខ្មាំងសត្រូវនឹងកម្ចាត់អ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ»
ដោយបានសារភាពអំពើបាបរបស់ពួកគេ
អាចមានន័យថា ១)« សារភាពថាពួកគេបានធ្វើបាបអ្នក» ឬ ២)« សរសើរអ្នក» ឬ
៣)« និយាយថាពួកគេនឹងគោរពព្រះអង្គចាប់ពីពេលនេះតទៅ។»
សុំការអត់ទោសពីព្រះអង្គ
នាមអរូបី «ការអភ័យទោស» អាចត្រូវបានបកប្រែជាកិរិយាស័ព្ទ។
«សុំឲ្យព្រះអង្គអត់ទោសឲ្យពួកគេ»
1 Kings 8:35
ផ្ទៃមេឃបិទ និងគ្មានភ្លៀង
មេឃត្រូវបានគេនិយាយថា ជាអាគារដែលព្រះផ្ទុកទឹកភ្លៀង។
«ទ្រង់មិនអនុញ្ញាតឲ្យភ្លៀងធ្លាក់»
ប្រកាសព្រះនាមរបស់ព្រះអង្គ
អាចមានន័យថា ១) «សារភាពថាពួកគេបានធ្វើបាបអ្នក« ឬ ២) «សរសើរព្រះ» ឬ
៣) «និយាយថាពួកគេនឹងគោរពព្រះចាប់ពីពេលនេះតទៅ» ។
បកប្រែដូចនៅក្នុងជំពូក ៨:៣៣ ។
ដែលពួកគេគួរដើរ

generated on Wed Sep 10 16:16:32 2025

របៀបដែលមនុស្សរស់នៅត្រូវបានគេនិយាយ
ដូចជាមនុស្សនោះកំពុងដើរលើផ្លូវមួយ។ «ពួកគេគួរតែរស់នៅ»
1 Kings 8:37
ស្រូវស្កកមានក្រា
ទាំងនេះគឺជាពាក្យកសិកម្មដែលសំដៅទៅលើដំណាំដែលងាប់ដោយមានភ្លៀងតិចឬច្រើនពេក
កណ្ដូប និងចង្រិត
«កណ្ដូប» គឺជាប្រភេទសត្វដែលបង្កការបំផ្លាញដោយការស៊ីដំណាំ។ ពាក្យ «ដង្កូវ» សំដៅទៅលើដំណាក់កាលលូតលាស់ដំបូងរបស់សត្វកណ្ដូប។
មាននរណាម្នាក់ឬក៏ប្រជាជនអ៊ីស្រាអែលទាំងអស់អធិស្ឋានសុំ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«មនុស្សម្នាក់ឬអ៊ីស្រាអែលរបស់អ្នកទាំងអស់អធិស្ឋាននិងទូលសុំ»
អធិស្ឋានសុំ
ពាក្យ «ការអធិស្ឋាន» និង «ការស្នើសុំ» មានន័យថាជារួមដូចគ្នា ហើយបញ្ជាក់ថា មនុស្សនោះមានចិត្តស្មោះត្រង់នៅពេលគាត់ស្នើសុំ។
ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក ៨:២៧ ។ «សុំ»
ខ្លោចផ្សានៅក្នុងចិត្ត
អាចមានន័យថា១) «ដឹងពីបាបក្នុងចិត្តរបស់គាត់» ឬ ២) «ដឹងក្នុងចិត្តគាត់ការអាក្រក់ជាលទ្ធផលនៃអំពើបាបរបស់គាត់»។
1 Kings 8:41
ស្នាមព្រះហស្ត និងពីកិច្ចការរបស់ព្រះអង្គ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា
ជារួមហើយសំដៅទៅលើអំណាចរបស់ព្រះជាម្ចាស់។
ដំណាក់ ដែលទូលបង្គំសង់នេះមានព្រះអង្គគង់នៅមែន
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ឃ្លា «ដោយព្រះនាមរបស់ទ្រង់» បង្ហាញថាបុគ្គលនោះជាម្ចាស់លើដំណាក់។
«ទ្រង់ជាម្ចាស់ដំណាក់ដែលខ្ញុំបានសាងសង់»
1 Kings 8:44
នៅពេលដែលប្រជារាស្ត្ររបស់ព្រះអង្គ...បើពួកគេអធិស្ឋាន
នៅពេលស្តេចសាឡូម៉ូនកំពុងនិយាយពីស្ថានភាពទាំងនេះមិនបានកើតឡើងទេ ប៉ុន្តែស្តេចសាឡូម៉ូនដឹងថាពួកគេអាចនឹងកើតឡើងនាពេលអនាគត។
ប្រើទម្រង់ជាភាសារបស់អ្នកសម្រាប់និយាយអំពីព្រឹត្តិការណ៍ដែលមិនបានកើតឡើង ប៉ុន្តែអាចនឹងកើតឡើងនាពេលអនាគត។
នូវព្រះនាមព្រះអង្គ
ពាក្យថា «នាម» គឺជាសំដៅទៅលើមនុស្សហើយ « សម្រាប់...នាម» សំដៅទៅលើការគោរពបូជាមនុស្ស។ ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក ៣:១។ ការបកប្រែបន្ថែម «ដែលមនុស្សនឹងថ្វាយបង្គំអ្នក»
ការអធិស្ឋាន និងការស្នើសុំរបស់ពួកគេ
ពាក្យ «ការអធិស្ឋាន» និង «ការស្នើសុំ» មានន័យជាមូលដ្ឋានដូចគ្នា ហើយសង្កត់ធ្ងន់ថាប្រជាជនមានភាពស្មោះត្រង់នៅពេលពួកគេស្នើសុំ។
ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក ៨:២៧ ។
ការបកប្រែផ្សេងទៀត«ការស្នើសុំរបស់ពួកគេ»
1 Kings 8:46
បើពួកគេប្រព្រឹត្តអំពើបាប...នឹងពួកគេ...បន្ទាប់មក
បើពួកគេដឹងខ្លួន...ពួកគេប្រែចិត្ត ...គេនិយាយថា
នៅពេលស្តេចសាឡូម៉ូនកំពុងនិយាយស្ថានភាពទាំងនេះមិនបានកើតឡើងទេ ប៉ុន្តែស្តេចសាឡូម៉ូនដឹងថាពួកគេអាចនឹងកើតឡើងនាពេលអនាគត។
ប្រើទម្រង់ជាភាសារបស់អ្នកសម្រាប់និយាយអំពីព្រឹត្តិការណ៍ដែលមិនបានកើតឡើង ប៉ុន្តែអាចនឹងកើតឡើងនាពេលអនាគត។
ទឹកដីដែលពួកគេជាប់ជាឈ្លើយ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ជាកន្លែងដែលខ្មាំងសត្រូវរបស់ពួកគេបានយកពួកគេជាជននិរទេសខ្លួន»
អ្នកចាប់
មនុស្សដែលទុកអ្នកដទៃជាអ្នកទោស
«យើងបានប្រព្រឹត្តអំពើកំហុស និងអំពើបាប។ យើងខ្ញុំបានប្រព្រឹត្តអំពើអាក្រក់»
ប្រយោគទាំងពីរនេះមានន័យដូចគ្នា។ ពួកគេរួមគ្នាសង្កត់ធ្ងន់ថា តើសកម្មភាពរបស់ប្រជាជនអាក្រក់យ៉ាងណា។
ប្រព្រឹត្តអំពើកំហុស និងអំពើបាប
ពាក្យនេះមានន័យដូចគ្នាទៅនឹងអ្វីដែលដូចគ្នា និងសង្កត់ធ្ងន់ថា តើប្រជាជនបានធ្វើបាបយ៉ាងណា?
1 Kings 8:48
អស់ពីចិត្ត និងពីព្រលឹងរបស់ពួកគេ
«ដោយអស់ពីចិត្ត» មានន័យថា «ទាំងស្រុង» និង «ដោយអស់ពីព្រលឹង» មានន័យថា «ជាមួយទាំងអស់ ... ជា» ។ ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ការប្រែដូចក្នុងជំពូក ២:១។ ការបកប្រែផ្សេងទៀត «ជាមួយនឹងការទាំងអស់» ឬ «ដោយថាមពលទាំងអស់របស់ពួកគេ»
នៅក្នុងទឹកដី
«ខណៈពេលដែលពួកគេកំពុងរស់នៅក្នុងដី»
នៅទឹកដីរបស់ពួកគេ
«ឆ្ពោះទៅដីដែលជាកម្មសិទ្ធិរបស់ពួកគេ» នេះសំដៅទៅលើអ៊ីស្រាអែល។
សម្រាប់ព្រះនាមព្រះអង្គ
ពាក្យថា «នាម» គឺសំដៅទៅលើមនុស្សហើយ «សម្រាប់...នាម» សំដៅទៅលើការគោរពបូជាមនុស្ស។ ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក ៣:១។ ការបកប្រែផ្សេងទៀត «ដែលមនុស្សនឹងថ្វាយបង្គំអ្នក»
1 Kings 8:49
ពាក្យអធិស្ឋាន និងការស្នើសុំរបស់ពួកគេ
ពាក្យពីរគឺ «ការអធិស្ឋាន» និង «ការស្នើសុំ» មានន័យថាជាមូលដ្ឋានដូចគ្នា។ ពួកគេរួមគ្នាបញ្ជាក់ថាប្រជាជនមានចិត្តស្មោះត្រង់នៅពេលពួកគេបានស្នើសុំដល់ព្រះអម្ចាស់។ ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក ៨:២៧ ។
សូមអត់ទោសដល់ប្រជាជនរបស់ព្រះអង្គ ដែលបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គ និងអំពើទុច្ចរិត
ទាស់នឹងបញ្ញត្តរបស់ព្រះអង្គ
ស្តេចសាឡូម៉ូនសុំព្រះអម្ចាស់អភ័យទោសដល់ប្រជាជនពីរដង។ នេះសង្កត់ធ្ងន់លើភាពស្មោះត្រង់នៃសំណូមពររបស់គាត់។
1 Kings 8:51
ដូចជាចេញពីឡរំលាយដែកដែរ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ឡដំដែក»
ឲ្យព្រះនេត្ររបស់ព្រះអង្គបានបើក
ភ្នែកគឺសំដៅទៅមនុស្ស។ ការបកប្រែផ្សេងទៀត «អ្នកនឹងយកចិត្តទុកដាក់»
1 Kings 8:54
អធិស្ឋានទាំងនេះ
ពាក្យ «ការអធិស្ឋាន» និង «ការស្នើសុំ» មានន័យថា ជាមូលដ្ឋានដូចគ្នាហើយបញ្ជាក់ថា គាត់មានចិត្តស្មោះត្រង់នៅពេលគាត់ស្នើសុំ។ ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក ៨:២៧ ។ ការបកប្រែផ្សេងទៀត «ការស្នើសុំ»
សូមឲ្យព្រះអម្ចាស់ប្រកបដោយព្រះពរ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «សរសើរតម្កើងព្រះអម្ចាស់»
គ្មានពាក្យសន្យាណាមួយដែលព្រះអង្គសន្យាជាមួយម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គមិនបានសម្រេចនោះឡើយ
នេះអាចត្រូវបានបញ្ជាក់ជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានសំរេចគ្រប់ពាក្យនៃសេចក្តីសន្យាដ៏ល្អរបស់ទ្រង់»
1 Kings 8:57
បោះបង់ចោលយើង ឬបំភ្លេចពួកយើងចោលឡើយ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ជាមូលដ្ឋានហើយបញ្ជាក់ពីបំណងប្រាថ្នារបស់ស្តេចសាឡូម៉ូន ដែលចង់ឲ្យព្រះអម្ចាស់មានវត្តមានជាមួយប្រជាជន។
ទាញចិត្តយើងទៅរកព្រះអង្គ
ការចងផ្គាប់ចិត្តនរណាម្នាក់ត្រូវបានគេនិយាយថា ជាការធ្វើឲ្យមានចិត្តចំពោះមនុស្សនោះ។ ការបកប្រែផ្សេងទៀត «ធ្វើឲ្យយើងចងផ្គាប់ចិត្តជាមួយទ្រង់»
រស់ស្របតាមមាគាៈផ្លូវរបស់ព្រះអង្គ
ត្រង់នេះ «តាមមាគ៌ារបស់ព្រះអង្គ» គឺសំដៅទៅលើផ្លូវដែលទ្រង់ចង់អោយមនុស្សរស់នៅ។ ការបកប្រែផ្សេងទៀត «រស់នៅដូចដែលទ្រង់តម្រូវឲ្យយើងរស់នៅ»
1 Kings 8:59
រាល់ថ្ងៃ និងរាល់យប់
ការរួមបញ្ចូលគ្នានេះសំដៅទៅលើ «គ្រប់ពេលវេលា» ឬ «ជាប់ជានិច្ច» ។
សូមឲ្យចិត្តរបស់អ្នករាល់គ្នាស្មោះត្រង់
«ត្រូវបានលះបង់ទាំងស្រុង»
ដើរតាមច្បាប់ របស់ព្រះអង្

generated on Wed Sep 10 16:16:32 2025

របៀបដែលមនុស្សរស់នៅត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងដើរលើផ្លូវមួយ។ ជនជាតិអ៊ីស្រាអែលដែលនៅជាមួយទ្រង់
ការបកប្រែផ្សេងទៀត «គោរពតាមលក្ខន្តិក:របស់ទ្រង់» ការធ្វើឲ្យមានលក្ខណៈទូទៅ នេះអាចយោងទៅលើ ១)
1 Kings 8:62 ចំពោះប្រជាជនដែលស្តេចសាឡូម៉ូនបានហៅទៅក្រុងយេរូសាឡឹម
ប្រជាជនអ៊ីស្រាអែល ដែលនៅជាមួយស្តេច និងអ្នកដែលមានឈ្មោះក្នុងជំពូក ៨:១ ឬ ២)
ទាំងនេះអាចសំដៅទៅលើលេខ ១) ចំពោះអ្នកដែលធ្វើដំណើរទៅក្រុងយេរូសាឡឹមសម្រាប់ពិធីបុណ្យនេះមិនចាំបាច់ចំពោះមនុស្សគ្រប់គ្នាដែល
ចំពោះប្រជាជនដែលស្តេចសាឡូម៉ូនបានហៅទៅក្រុងយេរូសាឡឹម ពាក្យស្រដៀងគ្នានេះលេចឡើងនៅជំពូក ៨:៦២ ។
និងអ្នកដែលមានឈ្មោះក្នុងជំពូក ៨:១ ឬ ២) ប្រាំពីរថ្ងៃ...ប្រាំពីរថ្ងៃ...ដប់បួនថ្ងៃ
ចំពោះអ្នកដែលបានធ្វើដំណើរទៅក្រុងយេរូសាឡឹម «៧ ថ្ងៃ ... ៧ ថ្ងៃ ... ១៤ ថ្ងៃ»
សម្រាប់ពិធីបុណ្យនេះមិនចាំបាច់ចំពោះមនុស្សគ្រប់គ្នា ដែលរស់នៅអ៊ីស្រាអែលទេ។ ថ្ងៃទីប្រាំបី
1 Kings 8:64 ពាក្យ «ទីប្រាំបី» គឺជាទម្រង់ធម្មតានៃ «លេខ៨» ។
អាសនាលង្ហិន ដែលនៅចំពោះព្រះអម្ចាស់ អំណរ និងមានដួងចិត្តសប្បាយ
«អាសនាលង្ហិនដែលស្ថិតនៅចំពោះព្រះអម្ចាស់»។ ពាក្យទាំងពីរនេះមានន័យថា
ដោយហេតុថាព្រះវិហារនេះជាដំណាក់របស់ព្រះជាម្ចាស់ក្នុងចំណោមប្រជាជនរបស់ទ្រង់ [illegible]
1 Kings 8:65

---

9 [1]ក្រោយពីព្រះបាទសាឡូម៉ូនបានបញ្ចប់ការសង់ដំណាក់របស់ព្រះអម្ចាស់ និងវាំងរបស់ស្តេច
ហើយក្រោយពីស្តេចសម្រេចបាននូវអ្វីដែលស្តេចចង់ធ្វើរួចមកហើយ[2]ព្រះអម្ចាស់បានយាងមកជួបព្រះបាទសាឡូម៉ូនជាលើកទីពីរ
ដូចដែលព្រះអង្គបានមកជួបស្តេចនៅគីបៀនដែរ។
[3]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកកាន់ស្តេចថា៖ «យើងបានឮសេចក្តីអធិស្ឋាន និងការទូលអង្វរបស់អ្នកដែលអ្នកបានសុំពីយើងហើយ។ យើងបានញែកដំណាក់នេះ
គឺដំណាក់ដែលអ្នកបានសង់សម្រាប់យើង ដើម្បីឲ្យនាមយើងនៅទីនេះជារៀងរហូត។ ភ្នែក និងដួងចិត្តរបស់យើងនឹងនៅទីនោះគ្រប់ពេល។
[4]សម្រាប់អ្នក បើអ្នកដើរនៅចំពោះយើងដូចជាដាវីឌជាបិតារបស់អ្នកបានដើរដោយចិត្តស្មោះត្រង់ និងដោយសុចរិត
ដោយស្តាប់បង្គាប់គ្រប់ទាំងបទបញ្ញត្តដែលយើងបានបង្គាប់អ្នក និងរក្សាច្បាប់ និងវិន័យរបស់យើង[5]នោះយើងនឹងឲ្យរាជ្យរបស់អ្នកនៅលើអ៊ីស្រាអែលនៅគង់វង្សរហូតទៅ
ដូចជាយើងបានសន្យាជាមួយដាវីឌជាបិតារបស់អ្នកថា៖ «កូនចៅរបស់អ្នកនឹងសោយរាជ្យលើអ៊ីស្រាអែលរៀងរហូតតទៅ»។
[6]ប៉ុន្តែ បើអ្នកបែរឆ្ងាយពីយើង ទោះបីជាអ្នក ឬកូនរបស់អ្នកក្តី ហើយមិនរក្សាបញ្ញត្ត និងច្បាប់របស់យើងដែលយើងបានប្រគល់ដល់អ្នក ហើយបើអ្នកទៅថ្វាយបង្គំព្រះផ្សេង
និងឱនក្បាលនៅចំពោះព្រះទាំងនោះ[7]នោះយើងនឹងដកអ៊ីស្រាអែលចេញពីទឹកដីដែលយើងបានប្រគល់ដល់ពួកគេ
ហើយដំណាក់ដែលយើងបានញែកសម្រាប់នាមយើងនេះមិនខាន យើងនឹងរំលាយចោលពីមុខយើង ហើយអ៊ីស្រាអែលនឹងត្រូវគេមើលងាយ
និងចំអកឲ្យក្នុងចំណោមមនុស្សទាំងឡាយ។
[8]វិហារនេះនឹងត្រូវខ្ទេចខ្ទីអស់ ហើយអស់អ្នកដែលបានដើរឆ្លងកាត់ទីនេះនឹងរន្ធត់ និងហួសចិត្ត។ ពួកគេនឹងសួរគ្នាថា៖
«តើហេតុអ្វីបានជាព្រះអម្ចាស់ធ្វើបែបនេះជាមួយនឹងទឹកដី និងដំណាក់មួយនេះ»?[9]អ្នកផ្សេងទៀតនឹងឆ្លើយថា៖
«ដោយសារពួកគេបោះបង់ព្រះអម្ចាស់ជាព្រះរបស់ពួកគេចោល ជាព្រះដែលនាំបុព្វបុរសរបស់ពួកគេចេញពីទឹកដីអេស៊ីប ហើយពួកគេទៅគោរពព្រះដទៃ
និងឱនក្បាលចំពោះព្រះទាំងនោះ និងថ្វាយបង្គំផង។ ហេតុនេះហើយបានជាព្រះអម្ចាស់បាននាំមហន្តរាយទាំងអស់នេះមកលើពួកគេ»។
[10]នៅចុងឆ្នាំទីម្ភៃ ដែលព្រះបាទសាឡូម៉ូនបានបញ្ចប់ការសង់អគារទាំងពីរនោះ គឺព្រះវិហាររបស់ព្រះអម្ចាស់ និងវាំងរបស់ស្តេច។[11]ឥឡូវនេះ
ព្រះបាទហ៊ីរ៉ាមជាស្តេចក្រុងទីរ៉ុសបានថ្វាយឈើតាត្រៅ ឈើកកោះ និងមាសដល់ព្រះបាទសាឡូម៉ូន តាមដែលស្តេចត្រូវការ ដូច្នេះ
ព្រះបាទសាឡូម៉ូនបានប្រទានក្រុងម្ភៃនៅក្នុងទឹកដីកាលីឡេដល់ស្តេចហ៊ីរ៉ាម។
[12]ព្រះបាទហ៊ីរ៉ាមយាងពីក្រុងទីរ៉ុស ដើម្បីទតមើលក្រុងដែលព្រះបាទសាឡូម៉ូនបានថ្វាយដល់ទ្រង់ ប៉ុន្តែស្តេចមិនពេញចិត្តទេ។[13]ដូច្នេះព្រះបាទហ៊ីរ៉ាមទូលថា៖
«តើក្រុងទាំងនេះឬដែលព្រះអង្គប្រទានដល់ទូលបង្គំ»? ព្រះបាទហ៊ីរ៉ាមហៅក្រុងទាំងនោះថា «កាបួល» ដែលគេហៅរហូតមកដល់សព្វថ្ងៃនេះ។
[14]ព្រះបាទហ៊ីរ៉ាមបានបញ្ជូនមាស១២០ហាបមកថ្វាយព្រះបាទសាឡូម៉ូន។
[15]ខាងក្រោមនេះជាមូលហេតុដែលព្រះបាទសាឡូម៉ូនបានកែនមនុស្សមកធ្វើការ៖ ដើម្បីសង់ព្រះវិហាររបស់ព្រះអម្ចាស់ និងវាំងរបស់ព្រះអង្គ សង់នៅមីឡូ
និងសង់ជញ្ជាំងក្រុងយេរូសាឡឹម ក្រុងហាសោរ ក្រុងមេគីដោ និងក្រុងកេស៊ើរ។[16]ផារោនជាស្តេចស្រុកអេស៊ីបបានវាយដណ្តើមយកក្រុងកេស៊ើរ។ ស្តេចបានដុតក្រុងនោះ
និងសម្លាប់ជនជាតិកាណានៅក្នុងក្រុងនោះ។ បន្ទាប់មក ព្រះចៅផារោនបានឲ្យក្រុងនោះទៅបុត្រីរបស់ទ្រង់ ដែលជាមហេសីរបស់ព្រះបាទសាឡូម៉ូន
ជាអំណោយថ្ងៃមង្គលការ។
[17]ដូច្នេះ ព្រះបាទសាឡូម៉ូនបានសង់ក្រុងកេស៊ើរ ក្រុងបេតហូរ៉ូន ផ្នែកខាងក្រោមឡើងវិញ[18]ក្រុងបាឡាត ក្រុងថាត់ម៉ោរ ដែលនៅតំបន់វាលរហោស្ថាន
ក្នុងទឹកដីស្រុកយូដា[19]និងក្រុងដែលជាឃ្លាំងដែលជាកម្មសិទ្ធិរបស់ទ្រង់ និងក្រុងសម្រាប់ដាក់រទេះចំបាំង និងក្រុងសម្រាប់ទ័ពសេះ
និងអ្វីៗដែលស្តេចសព្វព្រះទ័យសង់នៅក្នុងក្រុងយេរូសាឡឹម នៅស្រុកលីបង់ និងនៅក្នុងទឹកដីដែលទ្រង់គ្រប់គ្រង។
[20]ដោយសារមនុស្សទាំងអស់ដែលនៅសេសសល់ពីជនជាតិអាម៉ូរី ជនជាតិហេត ជនជាតិពេរេស៊ីត ជនជាតិហេវី និងជនជាតិយេប៊ូស ដែលមិនមែនជាប្រជាជន
អ៊ីស្រាអែល[21]កូនចៅរបស់ពួកគេដែលបានបន្តរស់នៅក្នុងទឹកដីនេះ គឺអស់អ្នកដែលជនជាតិអ៊ីស្រាអែលមិនអាចបំផ្លាញបានទាំងស្រុង
ព្រះបាទសាឡូម៉ូនបានឲ្យពួកគេធ្វើការយ៉ាងធ្ងន់ ដែលពួកគេនៅមានរហូតដល់សព្វថ្ងៃ។
[22]ទោះជាយ៉ាងណាក៏ដោយ ព្រះបាទសាឡូម៉ូនមិនបានបង្ខំឲ្យជនជាតិអ៊ីស្រាអែលធ្វើការធ្ងន់ឡើយ។ ផ្ទុយទៅវិញពួកគេបានក្លាយជាទាហានរបស់ស្តេច ជាអ្នកគ្រប់គ្រង
ជាអ្នកមើលខុសត្រូវ ជាមេបញ្ជាការរទេះចំបាំង និងអ្នកជិះសេះរបស់ស្តេច។
[23]អ្នកទាំងនេះក៏ជាមេបញ្ជាការ ដែលបានគ្រប់គ្រងលើអ្នកមើលខុសត្រូវលើអ្នកធ្វើការថ្វាយព្រះបាទសាឡូម៉ូនមាន ៥៥០នាក់
សុទ្ធតែជាអ្នកដែលមើលខុសត្រូវលើអ្នកធ្វើការ។
[24]បុត្រីរបស់ព្រះចៅផារោនផ្លាស់ពីក្រុងរបស់ព្រះបាទដាវីឌទៅឯដំណាក់ដែលព្រះបាទសាឡូម៉ូនបានសង់ថ្វាយព្រះនាង។ ក្រោយមក ព្រះបាទសាឡូម៉ូនបានសង់នៅមីឡូ។
[25]ព្រះបាទសាឡូម៉ូនបានថ្វាយតង្វាយមួយឆ្នាំបីដង មានតង្វាយដុត តង្វាយមេត្រីភាពនៅលើអាសនាដែលបានសង់ថ្វាយព្រះអម្ចាស់
បានដុតគ្រឿងក្រអូបនៅលើអាសនាដែលនៅចំពោះព្រះអម្ចាស់។ ដូច្នេះ ព្រះអង្គបានបញ្ចប់ការសង់ព្រះវិហារ ហើយឥឡូវនេះ បានដាក់ឲ្យប្រើប្រាស់។
[26]ព្រះបាទសាឡូម៉ូនបានធ្វើសំពៅនៅអេស៊ាន-គេប៊ើរ ជិតក្រុងអេឡាត ដែលនៅមាត់សមុទ្រក់ក្នុងទឹកដីអេដុម។
[27]ព្រះបាទហ៊ីរ៉ាមបានបញ្ជូនអ្នកបម្រើរបស់ស្តេចទៅជួបកងទ័ពជើងទឹករបស់ព្រះបាទសាឡូម៉ូន ជាអ្នកដែលស្ទាត់ជំនាញខាងសមុទ្រ
ជាមួយអ្នកបម្រើផ្ទាល់របស់ព្រះបាទសាឡូម៉ូន។[28]ពួកគេបានទៅដល់ស្រុកអូភារជាមួយអ្នកបម្រើរបស់ព្រះបាទសាឡូម៉ូន។ ពីទីនោះពួកគេបាននាំយកមាស
៤២០ហាបថ្វាយព្រះបាទសាឡូម៉ូន។

generated on Wed Sep 10 16:16:32 2025

1 Kings 9:3

សេចក្ដីអធិស្ឋាន និងការទូលអង្វរបស់អ្នក

ពាក្យថា «ការអធិស្ឋាន» និង «ទូលអង្វរ» មានន័យដូចគ្នាជាមូលដ្ឋាន
ហើយបញ្ជាក់ថា
ព្រះអម្ចាស់ទទួលស្គាល់ថាសំណូមពររបស់ស្តេចសាឡូម៉ូនគឺស្មោះត្រង់។
ពាក្យស្រដៀងគ្នានេះលេចឡើងក្នុងជំពូក ៨:២៧ ។ ការបកប្រែផ្សេងទៀត
«ការស្នើសុំរបស់អ្នក»

ដើម្បីឲ្យនាមយើងនៅទីនេះជារៀងរហូត

ឈ្មោះនេះគឺសំដៅទៅលើមនុស្ស។ ការបកប្រែផ្សេងទៀត
«ដើម្បីរស់នៅទីនោះនិងទាមទារកម្មសិទ្ធិកាន់កាប់វាជារៀងរហូត»

ភ្នែក និងដួងចិត្តរបស់យើងនឹងនៅទីនោះ

ភ្នែកនិងចិត្តគឺស៊ីគ្នាសម្រាប់មនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«ខ្ញុំនឹងការពារនិងថែរក្សាវា»

1 Kings 9:4

បើអ្នកដើរនៅចំពោះយើងដូចជាដាវីឌជាបិតារបស់អ្នកបានដើរ

របៀបដែលមនុស្សរស់នៅ
ត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងដើរលើផ្លូវមួយ។ ការបកប្រែផ្សេងទៀត
«ប្រសិនបើអ្នករស់នៅតាមរបៀបដែលយើងចង់អោយអ្នករស់នៅ
ដូចស្តេចដាវីឌដែលជាឪពុករបស់អ្នកដែរ»

ដោយចិត្តស្មោះត្រង់ និងដោយសុច្ចរិត

ឃ្លាទាំងពីរនេះមានអត្ថន័យដូចៗគ្នា ហើយបញ្ជាក់ថាស្តេចដាវីឌសុចរិតយ៉ាងណា។

រាជ្យរបស់អ្នក

ត្រង់នេះ «បល្ល័ង្ក» សំដៅលើរជ្ជកាលរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត
«រាជវង្សរបស់អ្នក» ឬ «រជ្ជកាលរបស់អ្នក»

សោយរាជ្យលើអ៊ីស្រាអែលរៀងរហូតតទៅ

សកម្មភាពនៃការគ្រប់គ្រងប្រទេសមួយត្រូវបានគេនិយាយថា
ដូចជាមនុស្សអង្គុយលើបល្ល័ង្ក។ នេះអាចត្រូវបានបង្ហាញជាវិជ្ជមាន។
ការបកប្រែផ្សេងទៀត «នឹងគ្រប់គ្រងលើអ៊ីស្រាអែលជានិច្ច»

1 Kings 9:6

បញ្ញត្ត និងច្បាប់របស់យើង

នៅទីនេះពាក្យ «បទបញ្ញត្តិ» និង «លក្ខន្តិកៈ» មានន័យជាមូលដ្ឋានដូចគ្នា
ហើយសង្កត់ធ្ងន់លើអ្វីទាំងអស់ដែលព្រះអម្ចាស់បានបញ្ជា។

ថ្វាយបង្គំព្រះផ្សេង និងឱនក្បាលនៅចំពោះព្រះទាំងនោះ

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។

ញែកសម្រាប់នាមយើង

នៅទីនេះពាក្យ «នាម» គឺជាពាក្យទាក់ទងសម្រាប់អ្នកដែលមានអ្វីទាំងអស់។
ការបកប្រែផ្សេងទៀត «ញែកខ្លួនខ្ញុំចេញ»

យើងនឹងរំលាយចោលពីមុខយើង

នាមអរូបី «ការមើលឃើញ» នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម «មើល»។
ការក្រឡេកមើលអ្វីមួយគឺជាឧទាហរណ៍មួយសម្រាប់ការពារវា។
ការបកប្រែផ្សេងទៀត «យើងនឹងដាក់វានៅកន្លែងដែលយើងលែងត្រូវមើលវា» ឬ
«យើងនឹងកម្ចាត់វាចោលដូច្នេះយើងមិនចាំបាច់ការពារវាទៀតទេ»

1 Kings 9:8

វិហារនេះនឹងត្រូវខ្ទេចខ្ទីអស់

«វិហារនេះនឹងត្រូវបានបំផ្លាញហើយអ្វីដែលនៅសល់គឺជាខ្ពង់រាបខ្ពស់ប៉ុណ្ណោះ»

ទីនេះនឹងរន្ធត់ និងហួសចិត្ត

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នឹងសម្តែងការងឿងឆ្ងល់និងបង្កើតឲ្យមានសម្លេងនៃការមិនគោរព»

ឱនក្បាលចំពោះព្រះទាំងនោះ និងថ្វាយបង្គំផង

ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ឃ្លាថា «ឱនគោរពដល់ពួកគេ»
ពិពណ៌នាអំពីឥរិយាបថដែលមនុស្សប្រើក្នុងការថ្វាយបង្គំ។

1 Kings 9:10

វាបានកើតឡើង

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីបកប្រែផ្សេងអ្នកអាចពិចារណាប្រើវានៅទីនេះបាន។

នៅចុងឆ្នាំទីម្ភៃ

»បន្ទាប់ពី ២០ឆ្នាំ»

ព្រះបាទសាឡូម៉ូនបានបញ្ចប់ការសង់

វាជាការល្អបំផុតដើម្បីបកប្រែដូច្នេះអ្នកអានយល់ថា
មនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើការនេះ។

1 Kings 9:12

តើក្រុងទាំងនេះឬដែលព្រះអង្គប្រទានដល់ទូលបង្គំ»?

លោកហ៊ីរ៉ាមកំពុងស្តីបន្ទោសស្តេចសាឡូម៉ូន។ ការបកប្រែផ្សេងទៀត
«ទីក្រុងទាំងនេះដែលអ្នកបានផ្តល់ឲ្យខ្ញុំគឺគ្មានប្រយោជន៍អ្វីឡើយ»។

ដែលគេហៅរហូតមកដល់សព្វថ្ងៃនេះ

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយប្រជាជននៅតែហៅរហូតដល់សព្វថ្ងៃនេះ»

មាស១២០ហាបមក

ទេពកោសល្យគឺជាឯកតាទម្ងន់ស្មើនឹងប្រហែល ៣៤ គីឡូក្រាម។
ការបកប្រែផ្សេងទៀត «មាសប្រហែល ៤.០០០ គីឡូក្រាម»។

1 Kings 9:15

ជាមូលហេតុដែលព្រះបាទសាឡូម៉ូនបានកែនមនុស្សមកធ្វើការ

មូលហេតុដែលស្តេចសាឡូម៉ូនតម្រូវឲ្យមនុស្សធ្វើការ

សង់នៅមីឡូ

អាចមានន័យថា១) «សាងសង់ប្រព័ន្ធរាបស្មើរ» ឬ ២) «
ដើម្បីសាងសង់កន្លែងចាក់សម្រាម»

ផារ៉ោនជាស្តេចស្រុកអេស៊ីបបានវាយដណ្តើមយក

មនុស្សសំដៅទៅលើកងទ័ពដែលស្តេចបញ្ជា។ ការបកប្រែផ្សេងទៀត
«កងទ័ពរបស់ព្រះចៅផារ៉ោនជាស្តេចស្រុកអេស៊ីបបានឡើងទៅ»

1 Kings 9:17

ព្រះបាទសាឡូម៉ូនបានសង់ក្រុងកេស៊ើរ

វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើការនេះ។

1 Kings 9:22

ព្រះបាទសាឡូម៉ូនមិនបានបង្ខំឲ្យជនជាតិអ៊ីស្រាអែលធ្វើការធ្ងន់ឡើយ

«ស្តេចសាឡូម៉ូនមិនបានបង្ខំប្រជាជនអ៊ីស្រាអែលឲ្យធ្វើការទេ»។

1 Kings 9:23

៥៥០នាក់

«ប្រាំរយហាសិបក្នុងចំណោមពួកគេ»

1 Kings 9:24

សង់នៅមីឡូ

អាចមានន័យថា ១) «សាងសង់ប្រព័ន្ធរាបស្មើរ» ឬ ២)«
បានសាងសង់កន្លែងចាក់សម្រាម»។ សូមមើលពីរបៀបដែលអ្នកបកប្រែ «មីឡូ»
ក្នុងជំពូក ៩:១៥ ។

1 Kings 9:25

អាសនាដែលបានសង់ថ្វាយព្រះអម្ចាស់

បកប្រែឃ្លានេះដូចនៅក្នុងជំពូក ៨:៦៤ ។

ដូច្នេះ ព្រះអង្គបានបញ្ចប់ការសង់ព្រះវិហារ

ស្តេចសាឡូម៉ូនគឺសំដៅទៅលើកម្មករ ដែលស្តេចបានជួលឲ្យធ្វើការ។
ការបកប្រែផ្សេងទៀត «ដូច្នេះកម្មកររបស់គាត់បានបញ្ចប់ការសាងសង់ព្រះវិហារ»

1 Kings 9:26

ព្រះបាទសាឡូម៉ូនបានធ្វើ

វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើការនេះ។
(សូមមើល igs-metonymy)

សំពៅ

«ក្រុមមួយក្រុមធំនៃសំពៅ»

មាស ៤២០ហាប

ហាបគឺជាឯកតាទម្ងន់ស្មើនឹងប្រហែល ៣៤ គីឡូក្រាម។ «មាសប្រហែល ១៤,០០០
គីឡូក្រាម»

[1]នៅពេលដែលព្រះនាងសេបា បានឮពីភាពល្បីល្បាញរបស់ព្រះបាទសាឡូម៉ូនទាក់ទងនឹងព្រះនាមរបស់ព្រះអម្ចាស់
ព្រះនាងបានមកសាកល្បងជាមួយនឹងសំណួរដ៏ពិបាកៗ។[2]ព្រះនាងមកក្រុងយេរូសាឡឹមជាមួយក្បួនដង្ហែយ៉ាងវែង ជាមួយអូដ្ឋដែលមានដឹកគ្រឿងក្រអូប
មានមាសជាច្រើន និងថ្មមានតម្លៃជាច្រើនដែរ។ នៅពេលដែលព្រះនាងមកដល់ ព្រះនាងបានទូលព្រះបាទសាឡូម៉ូននូវអ្វីដែលមាននៅក្នុងចិត្តព្រះនាង។
[3]ព្រះបាទសាឡូម៉ូនបានឆ្លើយគ្រប់សំណួរដែលព្រះនាងបានសួរ។ គ្មានសំណួរអ្វីមួយដែលព្រះនាងសួរហើយព្រះបាទសាឡូម៉ូនឆ្លើយមិនបាននោះទេ។
[4]នៅពេលដែលព្រះនាងសេបាបានឃើញពីប្រាជ្ញារបស់ព្រះបាទសាឡូម៉ូន ឃើញវាំងដែលស្តេចបានសង់[5]អាហារនៅលើតុរបស់ស្តេច ការអង្គុយរបស់អ្នកបម្រើស្តេច
ការងាររបស់អ្នកបម្រើស្តេច និងសំលៀកបំពាក់របស់ពួកគេ និងពួកមហាតលិក និងរបៀបក្នុងការថ្វាយតង្វាយដុតនៅក្នុងដំណាក់របស់ព្រះអម្ចាស់
នោះព្រះនាងក៏ភ្លេចដកដង្ហើម។
[6]ព្រះនាងទូលទៅស្តេចថា៖ «អ្វីដែលខ្ញុំម្ចាស់បានឮពីពាក្យសំដី និងពីប្រាជ្ញារបស់ព្រះអង្គនៅក្នុងទឹកដីរបស់ខ្ញុំម្ចាស់ជាការពិតមែន។
[7]ខ្ញុំម្ចាស់មិនជឿលើអ្វីដែលខ្ញុំម្ចាស់បានឮទេ រហូតដល់ខ្ញុំម្ចាស់បានមកដល់ទីនេះ ហើយឥឡូវនេះ ភ្នែករបស់ខ្ញុំម្ចាស់បានឃើញហើយ។ អ្វីដែលគេបាននិយាយពីប្រាជ្ញា
និងទ្រព្យសម្បត្តិរបស់ព្រះអង្គមិនដល់ពាក់កណ្តាលផង! ព្រះអង្គពិតជាល្បីដូចដែលខ្ញុំម្ចាស់បានឮពីព្រះអង្គមែន។
[8]មហេសីទាំងអស់របស់ទ្រង់ពិតជាមានពរមែន អ្នកបម្រើរបស់ព្រះអង្គពិតជាមានពរដែលអាចនៅតែឈចំពោះព្រះអង្គ ព្រោះគេបានឮពីប្រាជ្ញារបស់ព្រះអង្គ។
[9]សូមសរសើរតម្កើងព្រះអម្ចាស់ជាព្រះរបស់ព្រះអង្គ ដែលបានដាក់អំណរនៅក្នុងព្រះអង្គ ដែលបានដាក់ព្រះអង្គនៅលើបល្ល័ង្កស្រុកអ៊ីស្រាអែល។
ដោយសារព្រះអម្ចាស់ស្រឡាញ់អ៊ីស្រាអែលរហូតទៅ ព្រះអង្គបានឲ្យទ្រង់ក្លាយជាស្តេច ដើម្បីឲ្យទ្រង់បានគ្រងរាជ្យដោយយុត្តិធម៌ និងដោយសេចក្តីសុចរិត។
[10]ព្រះនាងបានថ្វាយមាស ១២០ហាប រួមជាមួយគ្រឿងក្រអូប និងត្បូងយ៉ាងច្រើនផង។
មិនដែលមានអ្នកណាបានថ្វាយគ្រឿងក្រអូបដ៏ច្រើនដូចដែលព្រះនាងសេបាបានថ្វាយទៅព្រះបាទសាឡូម៉ូននោះឡើយ។
[11]ទាហានជើងទឹករបស់ព្រះបាទហ៊ីរ៉ាម ដែលបាននាំមាសពីស្រុកអូភារ ក៏បានដឹកឈើខ្លឹមចន្ទន៍ និងត្បូងយ៉ាងច្រើនមកដែរ។
[12]ស្តេចបានយកឈើខ្លឹមចន្ទន៍មកធ្វើជាសសររបស់ព្រះវិហាររបស់ព្រះអម្ចាស់ និងវាំងរបស់ស្តេច និងធ្វើជាពិណ និងឃឹមសម្រាប់អ្នកចម្រៀងដែរ។
មិនដែលមានឈើខ្លឹមចន្ទន៍ណាល្អដូចឈើនេះ ដែលបានឃើញ ឬបាននាំមកស្រុកអ៊ីស្រាអែលទៀតឡើយ។
[13]ព្រះបាទសាឡូម៉ូនបានប្រទានអ្វីៗគ្រប់យ៉ាងដល់ព្រះនាងសេបា គឺគ្រប់អ្វីដែលព្រះនាងចង់បាន
អ្វីក៏ដោយឲ្យតែព្រះនាងសុំពីលើអ្វីដែលព្រះបាទសាឡូម៉ូនបានប្រទានដល់ព្រះនាងនៅក្នុងវាំង។ ដូច្នេះ
ព្រះនាងក៏បានត្រឡប់ទៅទឹកដីរបស់ព្រះនាងជាមួយអ្នកបម្រើរបស់ព្រះនាងវិញ។
[14]ឥឡូវនេះ មាសដែលគេបានថ្វាយដល់ព្រះបាទសាឡូម៉ូនក្នុងមួយឆ្នាំ គឺ៦៦៦ហាប[15]ក្រៅពីមាសដែលអ្នកជំនួញ និងឈ្មួញបានថ្វាយស្តេច។ ស្តេចទាំងអស់នៃស្រុកអារ៉ាប់
និងពួកអ្នកដឹកនាំនៅក្នុងប្រទេសក៏បានយកមាស និងប្រាក់មកថ្វាយព្រះបាទសាឡូម៉ូនដែរ។
[16]ព្រះបាទសាឡូម៉ូនឲ្យគេធ្វើខែលធំៗពីមាសចំនួនពីររយ។ ខែលនីមួយៗមានទម្ងន់ប្រាំមួយរយតម្លឹង។[17]ស្តេចក៏ធ្វើខែលតូចៗបីរយពីមាសដែរ។
ខែលនិមួយៗមានទម្ងន់ប្រាំមួយនាលិ ស្តេចបានដាក់របស់ទាំងនោះនៅក្នុងវាំងស្រុកលីបង់។
[18]បន្ទាប់មក ស្តេចបានធ្វើបល្ល័ង្កមួយយ៉ាងធំពីភ្លុក និងស្រោបដោយមាសសុទ្ធ។[19]មានជណ្តើរប្រាំមួយកាំឡើងទៅលើបល្ល័ង្ក ហើយនៅខាងក្រោយបល្ល័ង្កនោះមានរាងមូល។
មានកំណល់ដៃនៅសងខាង ហើយមានតោពីរនៅខាងមុខកំណល់ដៃនោះ។[20]មានតោដប់ពីរនៅលើជណ្តើរ មានម្ខាងប្រាំមួយ។
គ្មានបល្ល័ង្កណាមួយក្នុងនគរផ្សេងដូចបល្ល័ង្កនេះឡើយ។
[21]ពែងដែលព្រះបាទសាឡូម៉ូនប្រើសុទ្ធតែធ្វើពីមាស ហើយពែងនៅក្នុងវាំងឯព្រៃស្រុកលីបង់សុទ្ធតែធ្វើពីមាសសុទ្ធ។ គ្មានអ្វីមួយធ្វើពីប្រាក់ទេ
ព្រោះប្រាក់ក្នុងរាជ្យព្រះបាទសាឡូម៉ូនគេមិនរាប់ថាជារបស់មានតម្លៃទេ។[22]ស្តេចមានកងទ័ពជើងទឹកដែលចេញសំពៅទៅសមុទ្រ
ជាមួយនឹងកងទ័ពជើងទឹករបស់ព្រះបាទហ៊ីរ៉ាម។ រៀងរាល់បីឆ្នាំម្តងកងទ័ពជើងទឹកបាននាំមាស ប្រាក់ និង ភ្លុក ក្ងោក និងស្វាផងដែរ។
[23]ព្រះបាទសាឡូម៉ូនមានទ្រព្យសម្បត្តិ និងប្រាជ្ញាលើស្តេចណាៗទាំងអស់។[24]មនុស្សនៅផែនដីទាំងមូលចង់ជួបព្រះបាទសាឡូម៉ូន ដើម្បីឮពីប្រាជ្ញារបស់ស្តេច
ដែលព្រះជាម្ចាស់បានដាក់ក្នុងចិត្តរបស់ស្តេច។[25]អ្នកដែលបានមកជួបស្តេចបាននាំសួយសារអាករ ភាជន៍ធ្វើពីប្រាក់ និងមាស សំលៀកបំពាក់ គ្រឿងសស្ត្រាវុធ គ្រឿង
ក្រអូប សេះ និងលា ពីមួយឆ្នាំទៅមួយឆ្នាំ។
[26]ព្រះបាទសាឡូម៉ូនបានប្រមូលរទេះចម្បាំង និងទ័ពសេះ។ ស្តេចមានរទេះចម្បាំង១៤០០ និងទ័ពសេះមួយម៉ឺនពីរពាន់នាក់
ដែលស្តេចបានឲ្យពួកគេនៅក្រុងដែលដាក់រទេះចម្បាំង និងនៅជាមួយព្រះអង្គផ្ទាល់នៅក្រុងយេរូសាឡឹម។[27]ស្តេចមានប្រាក់នៅក្នុងក្រុងយេរូសាឡឹមច្រើនដូចថ្មនៅតាមផ្លូវ។
ព្រះអង្គមានឈើតាត្រៅសម្បូរដូចដើមឧទុម្ពរ ដែលដុះនៅតាមវាលទំនាប។
[28]ព្រះបាទសាឡូម៉ូនមានសេះ ដែលទិញពីអេស៊ីប និងពីគីលីគាមក។ ឈ្មួញរបស់ស្តេចបានទិញសេះទាំងនោះទាំងហ្វូង តាមតម្លៃក្នុងមួយហ្វូងៗ។
[29]រទេះសម្បូរបានទិញមកពីស្រុកអេស៊ីប មួយថ្លៃ ៦០០ស្លឹងជាប្រាក់ ហើយសេះមួយថ្លៃ១៥០ស្លឹង។ សេះ និងរទេះទាំងនេះ គឺលក់ទៅឲ្យស្តេចទាំងប៉ុន្មាននៃជនជាតិហេត
និងស្តេចនៃជនជាតិអារ៉ាមដែរ។

---

1 Kings 10:1
ព្រះបាទសាឡូម៉ូនទាក់ទងនឹងព្រះនាមរបស់ព្រះអម្ចាស់
អាចមានន័យថា ១)
«កិត្តិនាមរបស់ស្តេចសាឡូម៉ូនដែលលើកតម្កើងសិរីរុងរឿងរបស់ព្រះអម្ចាស់» ឬ ២)
«កិត្តិនាមរបស់ព្រះបាទសាឡូម៉ូនដែលព្រះអម្ចាស់បានប្រទានមកគាត់»។
អ្វីដែលមាននៅក្នុងចិត្តព្រះនាង
នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅ។ «អ្វីគ្រប់យ៉ាងដែលនាងចង់ដឹង»
1 Kings 10:3
ការអង្គុយរបស់អ្នកបម្រើស្តេច
អាចមានន័យថា ១)« របៀបដែលអ្នកបម្រើរបស់ទ្រង់អង្គុយនៅជុំវិញតុ» ឬ
២)«កន្លែងដែលអ្នកបម្រើរបស់ទ្រង់រស់នៅ»។
ព្រះនាងក៏ភ្លេចដកដង្ហើម
ការបកប្រែផ្សេងទៀត «នាងភ្ញាក់ផ្អើលយ៉ាងខ្លាំង»
1 Kings 10:6
អ្វីដែលខ្ញុំម្ចាស់បានឮនៅក្នុងទឹកដីរបស់ខ្ញុំម្ចាស់
«ខ្ញុំបានឮខណៈពេលដែលខ្ញុំម្ចាស់នៅក្នុងទឹកដីរបស់ខ្ញុំម្ចាស់»
ពីពាក្យសំដី និងពីប្រាជ្ញារបស់ព្រះអង្គ
ត្រង់នេះពាក្យថា «ប្រាជ្ញា» អាចពិពណ៌នាពាក្យ «ពាក្យ» ។ ការបកប្រែផ្សេងទៀត
«សំដីដ៏ឈ្លាសវៃរបស់អ្នក» ។ .
ភ្នែករបស់ខ្ញុំម្ចាស់បានឃើញហើយ
ភ្នែកគឺសំដៅទៅលើមនុស្ស។ «ខ្ញុំម្ចាស់បានឃើញហើយ»
អ្វីដែលគេបាននិយាយពីប្រាជ្ញា និងទ្រព្យសម្បត្តិរបស់ព្រះអង្គមិនដល់ពាក់កណ្តាលផង
នេះអាចត្រូវបានបង្ហាញជាវិជ្ជមាន និងត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត «មនុស្សបានប្រាប់ខ្ញុំម្ចាស់តិចតួចណាស់»
1 Kings 10:8
មានពរដែលអាចនៅតែឈចំពោះព្រះអង្គ
នេះគឺពាក្យក្រៀមភាសារ។ ការបកប្រែផ្សេងទៀត
«ដែលតែងតែនៅមុខទ្រង់រង់ចាំបម្រើទ្រង់»
សូមសរសើរតម្កើងព្រះអម្ចាស់ជាព្រះរបស់ព្រះអង្គ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនអាចសរសើរតម្កើងព្រះអម្ចាស់ជាព្រះរបស់ព្រះអង្គ»
ព្រះអង្គ ដែលបានដាក់ព្រះអង្គនៅលើបល្ល័ង្កស្រុកអ៊ីស្រាអែល
បល្ល័ង្កគឺជានិមិត្តរូបសម្រាប់ស្តេចដែលអង្គុយលើ។ ការបកប្រែផ្សេងទៀត
«អ្នកដែលតែងតាំងព្រះអង្គអោយធ្វើជាស្តេចអ៊ីស្រាអែល»

generated on Wed Sep 10 16:16:32 2025

1 Kings 10:10
មាស ១២០ហាប
ហាបគឺជាឯកតាទម្ងន់ស្មើនឹងប្រហែល ៣៤ គីឡូក្រាម។ បកប្រែផ្សេងទៀត «មាសប្រហែល ៤.០០០ គីឡូក្រាម»
មិនដែលមានអ្នកណាបានថ្វាយគ្រឿងក្រអូបដ៏ច្រើនដូចដែលព្រះនាងសេបាបានថ្វាយទៅព្រះបាទសាឡូម៉ូន
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«គ្មានអ្នកណាផ្តល់គ្រឿងក្រអូបដល់ព្រះមហាក្សត្រស្តេចសាឡូម៉ូនម្តងទៀតជាងព្រះមហាក្សត្រស្តេចសាឡូម៉ូនបានថ្វាយ
1 Kings 10:11
ស្តេចបានយក
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើការនេះ។ បកប្រែផ្សេងទៀត «ស្តេចបានប្រាប់ប្រជាជនរបស់ទ្រង់ឲ្យធ្វើ»
ឈើខ្លឹមចន្ទន៍
ប្រភេទឈើមួយប្រភេទអាចមានក្លិនក្រអូប
ដែលបានឃើញ ឬបាននាំមកស្រុកអ៊ីស្រាអែលទៀតឡើយ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ហើយក៏មិនមានអ្នកណាម្នាក់បានឃើញបរិមាណដ៏អស្ចារ្យបែបនេះទៀតដែរ»
មកដល់ថ្ងៃនេះ
នេះមានន័យថា ដល់ថ្ងៃដែលអ្នកនិពន្ធកំពុងសរសេររឿងនេះ។
1 Kings 10:13
អ្វីៗគ្រប់យ៉ាងដល់ព្រះនាងសេបា គឺគ្រប់អ្វីដែលព្រះនាងចង់បាន អ្វីក៏ដោយឲ្យតែព្រះនាងសុំ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា
ជាមូលដ្ឋានហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។
នៅក្នុងវាំង
«ពីព្រោះជាស្តេចមានអ្វីៗច្រើនណាស់»
1 Kings 10:14
ក្នុងមួយឆ្នាំ
«រៀងរាល់ឆ្នាំ» (យូឌីប៊ី)។
នេះសំដៅទៅលើរៀងរាល់ឆ្នាំនៃរជ្ជកាលរបស់ព្រះបាទសាឡូម៉ូន
ហើយមិនមែនត្រឹមតែមួយលើកទេ។
មាស៦៦៦ហាប
ហាបគឺជាឯកតាទម្ងន់ស្មើនឹងប្រហែល ៣៤ គីឡូក្រាម។ បកប្រែផ្សេងទៀត «មាសជិត ២៣.០០០ គីឡូក្រាម»
1 Kings 10:16
ព្រះបាទសាឡូម៉ូនឲ្យគេធ្វើ
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើការនេះ។ ការបកប្រែផ្សេងទៀត « មនុស្សរបស់ព្រះបាទសាឡូម៉ូនបានបង្កើតឡើង»
ខែលធំៗពីមាសចំនួនពីររយ
«ខែលធំ ២០០ »
មានទម្ងន់ប្រាំមួយរយតម្លឹង
មួយជុំគឺជាឯកតាទំងន់ស្មើនឹងប្រហែល ១១ក្រាម។ ការបកប្រែផ្សេងទៀត «មាសប្រហែល ៦,៦ គីឡូក្រាម»
ទម្ងន់ប្រាំមួយនាលិ
ដោយសារតែពាក្យថា «និល» មិនមានបង្ហាញនៅក្នុងអត្ថបទហេព្រើរទេ
ជំនាន់ថ្មីមួយចំនួនសន្មតជំនួសឯកតាបីកាដែលស្មើនឹងចំនួនត្រឹមតែកន្លះតម្លឹង។
កំណែរណាមួយដែលបង្កើតការសន្មត់នេះនឹងជាសញ្ញាស្មើនឹងប្រមាណបីគីឡូក្រាម។
ស្តេចក៏ធ្វើ
វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចសាឡូម៉ូនឲ្យធ្វើការនេះ។ ការបកប្រែផ្សេងទៀត «មនុស្សរបស់ស្តេចក៏បានធ្វើផងដែរ»
ខែលតូចៗបីរយ
ខែល ៣០០
មាស ៣ មាស
មីណាគឺជាឯកតានៃទំងន់ស្មើនឹងប្រហែល ៦០០ ក្រាម។ ការបកប្រែផ្សេងទៀត «មាសប្រហែល ១,៨ គីឡូក្រាម»
វាំងស្រុកលីបង់
«ផ្ទះហៅថាផ្ទះនៃព្រៃលីបង់»។ បកប្រែដូចនៅក្នុងជំពូក ៧:១ ។
1 Kings 10:18
ស្តេចបានធ្វើ
វាជាការល្អបំផុតក្នុងការបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយស្តេចឲ្យធ្វើកិច្ចការនេះ។
[illegible]
បល្ល័ង្កមួយយ៉ាងធំពីភ្លុក
[illegible]
1 Kings 10:21
វាំងឯព្រៃស្រុកលីបង់
«ផ្ទះហៅថាផ្ទះនៃព្រៃលីបង់»។ បកប្រែដូចនៅក្នុងជំពូក ៧:១ ។
ភ្លុក
ភ្លុកគឺជាសារធាតុរឹងនិងពណ៌សពីទឹកឬធ្មេញរបស់សត្វធំ ៗ។ បកប្រែដូចក្នុងជំពូក ១០:១៨ ។
ក្ងោក និងស្វា
សត្វទាំងនេះរស់នៅព្រៃនៅទ្វីបអាហ្វ្រិក។
នៅចុងអវយវៈទាំងបួនរបស់ពួកគេគឺជាអ្វីដែលមើលទៅដូចជាដៃនិងជើងរបស់មនុស្សហើយពួកគេមានក
មនុស្សខ្លះចាត់ទុកជាស្វាមួយប្រភេទ។
1 Kings 10:23
នៅផែនដីទាំងមូល
នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅ។ ការបកប្រែផ្សេងទៀត «មនុស្សមកពីគ្រប់ទិសទី» ឬ «ប្រជាជនមកពីកន្លែងផ្សេងៗគ្នាជាច្រើន»
ចង់ជួបព្រះបាទសាឡូម៉ូន
វត្តមានរបស់បុគ្គលនោះសំដៅទៅលើការដែលអាចនិយាយនិងស្តាប់បាន។
ការបកប្រែផ្សេងទៀត «ចង់ជួបជាមួយព្រះបាទសាឡូម៉ូន» ឬ «ចង់ទៅលេងស្តេចសាឡូម៉ូន»
ដើម្បីឮពីប្រាជ្ញារបស់ស្តេច ដែលព្រះជាម្ចាស់បានដាក់ក្នុងចិត្តរបស់ស្តេច
ចិត្តសំដៅទៅលើអ្វីដែលមនុស្សម្នាក់គិត ហើយត្រូវបានគេនិយាយដូចជាធុង។
នាមអរូបី «ប្រាជ្ញា» ត្រូវបានគេនិយាយដូចជាវត្ថុដែលអាចដាក់ក្នុងធុង
ហើយអាចត្រូវបានបកប្រែជាគុណនាម។
វាអាចជាឈ្មោះហៅក្រៅសម្រាប់ទាំងមនុស្សឬពាក្យដែលមនុស្សនិយាយ។
ការបកប្រែផ្សេងទៀត
«ស្តាប់នូវប្រាជ្ញារបស់ស្តេចដែលព្រះជាម្ចាស់បានប្រទានដល់គាត់ ឬ
អំពីរបៀបដែលព្រះជាម្ចាស់បានជួយគាត់អោយមានប្រាជ្ញា
ឬអាចស្តាប់គាត់និយាយពាក្យប្រកបដោយប្រាជ្ញា
ដែលព្រះជាម្ចាស់បានជួយគាត់អោយនិយាយ។
1 Kings 10:26
រទេះចម្បាំង១៤០០ និងទ័ពសេះមួយម៉ឺនពីរពាន់នាក់
រទេះចំនួន ១៤០០ និង រទេះសេះ ១២.០០០ នាក់
ស្តេចមានប្រាក់នៅក្នុងក្រុងយេរូសាឡឹមច្រើនដូចថ្មនៅតាមផ្លូវ
អ្នកពណ៌នាប្រើពាក្យប្រៀបធៀប
ដើម្បីបញ្ជាក់ពីចំនួនទឹកប្រាក់ដ៏ច្រើនដែលមាននៅក្រុងយេរូសាឡឹម។
ការបកប្រែផ្សេងទៀត
«ស្តេចមានប្រាក់ច្រើនណាស់នៅក្រុងយេរូសាឡឹមដូចដុំថ្មនៅលើដី»
1 Kings 10:28
ដែលទិញពីអេស៊ីប
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ឈ្មួញរបស់ទ្រង់បានទិញពីប្រជាជននៅអេស៊ីប»
រទេះសម្បុរបានទិញ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «ឈ្មួញរបស់ទ្រង់បានទិញរទេះសេះ»
៦០០ស្លឹងជាប្រាក់...១៥០ស្លឹង
ស្លឹងគឺជាឯកតាទម្ងន់ស្មើនឹងប្រហែល ១១ ក្រាម។ ការបកប្រែផ្សេងទៀត «ប្រាក់ប្រហែល ៦,៦ គីឡូក្រាម ... ប្រហែល ១,៧ គីឡូក្រាម»
៦០០ស្លឹងជាប្រាក់
«ប្រាក់ ៦០០ ស្លឹង»
សេះ និងរទេះទាំងនេះ គឺលក់ទៅឲ្យ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «ក្រោយមកឈ្មួញរបស់ទ្រង់បានលក់របស់ទាំងនេះជាច្រើនឲ្យ»

generated on Wed Sep 10 16:16:32 2025

11 [1]ព្រះបាទសាឡូម៉ូនបានស្រឡាញ់ស្ត្រីជនជាតិបរទេសជាច្រើននាក់៖ មានបុត្រីរបស់ស្តេចផារោន ស្ត្រីជនជាតិម៉ូអាប់ ជនជាតិអាំម៉ូន ជនជាតិអេដុម ជនជាតិស៊ីដូន
និងជនជាតិហេត[2]ជាជាតិដែលព្រះអម្ចាស់បានមានបន្ទូលហាមជនជាតិអ៊ីស្រាអែលថា៖ «កុំឲ្យរៀបការជាមួយពួកគេ
ហើយកុំឲ្យពួកគេរៀបការជាមួយកូនស្រីៗរបស់អ្នករាល់គ្នា ដោយសារពួកគេនឹងទាក់ទាញចិត្តអ្នករាល់គ្នាទៅព្រះរបស់ពួកគេ»។ ប៉ុន្តែ
ព្រះបាទសាឡូម៉ូនស្រឡាញ់ស្ត្រីទាំងនេះ។
[3]ព្រះបាទសាឡូម៉ូនមានមហេសី៧០០នាក់ និងស្រីស្នំ៣០០នាក់។ មហេសីទាំងឡាយរបស់ស្តេចបានឲ្យចិត្តរបស់ស្តេចងាកឆ្ងាយពីព្រះអម្ចាស់។
[4]នៅពេលដែលព្រះបាទសាឡូម៉ូនចាស់ទៅ មហេសីរបស់ស្តេចបានបង្វែរចិត្តរបស់ស្តេចទៅព្រះរបស់ពួកគេ
ដួងចិត្តរបស់ស្តេចមិនបានចុះចូលជាមួយព្រះជាម្ចាស់ជាព្រះទាំងស្រុងទេ គឺមិនដូចព្រះបាទដាវីឌជាបិតារបស់ស្តេចឡើយ។
[5]ព្រះបាទសាឡូម៉ូនបានដើរតាមព្រះអាសថារ៉ូត ជាព្រះរបស់ជនជាតិស៊ីដូន និងព្រះមីលកូម ជារូបព្រះគួរស្អប់ខ្ពើមរបស់ជនជាតិអាំម៉ូន។
[6]ព្រះបាទសាឡូម៉ូនបានធ្វើអំពើអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ ស្តេចមិនបានដើរតាមព្រះអម្ចាស់ទាំងស្រុងឡើយ មិនដូចព្រះបាទដាវីឌជាបិតារបស់ស្តេចឡើយ។
[7]បន្ទាប់មក ព្រះបាទសាឡូម៉ូនបានសង់ទីខ្ពស់មួយនៅលើភ្នំ សម្រាប់ព្រះកេម៉ូសនៅទល់មុខក្រុងយេរូសាឡឹម ជាព្រះគួរស្អប់ខ្ពើមរបស់ជនជាតិម៉ូអាប់ និងព្រះម៉ូឡុក ជាព្រះ
គួរស្អប់ខ្ពើមរបស់ជនជាតិអាំម៉ូន។[8]ស្តេចក៏បានសង់ទីខ្ពស់សម្រាប់មហេសីបរទេសរបស់ស្តេចដែរ ដែលជាកន្លែងថ្វាយគ្រឿងក្រអូប
និងយញ្ញបូជាទៅព្រះរបស់ពួកគេនៅកន្លែងនោះ។
[9]ព្រះអម្ចាស់បានពិរោធនឹងព្រះបាទសាឡូម៉ូនយ៉ាងខ្លាំង ដោយសារស្តេចបានបែរព្រះទ័យចេញពីព្រះអង្គ ជាព្រះរបស់អ៊ីស្រាអែល
ទោះបីជាស្តេចបានជួបជាមួយព្រះអង្គពីរដង[10]ហើយព្រះអង្គបានបង្គាប់ស្តេចអំពីរឿងទាំងនេះ ដែលថាស្តេចមិនអាចដើរតាមព្រះដ៏ទៃជាដាច់ខាត។ ប៉ុន្តែ
ព្រះបាទសាឡូម៉ូនមិនបានធ្វើតាមការបង្គាប់របស់ព្រះអម្ចាស់ឡើយ។
[11]ដូច្នេះហើយ បានជាព្រះអម្ចាស់មានបន្ទូលមកកាន់សាឡូម៉ូនថា៖ «ដោយសារអ្នកធ្វើការទាំងនេះ ហើយមិនបានរក្សាសម្ពន្ធមេត្រី និងច្បាប់របស់យើង
ដែលយើងបានបង្គាប់ដល់អ្នក យើងនឹងហែករាជ្យរបស់អ្នក និងឲ្យដល់អ្នកបម្រើរបស់អ្នក។[12]ទោះជាយ៉ាងណាក៏ដោយ ដោយយល់ដល់ព្រះបាទដាវីឌជាបិតារបស់អ្នក
យើងនឹងមិនធ្វើការនេះកើតឡើងក្នុងថ្ងៃអាយុរបស់អ្នកទេ ប៉ុន្តែ យើងនឹងហែកនៅក្នុងដៃបុត្ររបស់អ្នក។[13]យើងនឹងមិនហែកអាណាចក្រទាំងអស់ឡើយ
យើងនឹងឲ្យកុលសម្ព័ន្ធមួយទៅកូនរបស់អ្នក ដោយយល់ដល់ព្រះបាទដាវីឌជាអ្នកបម្រើរបស់យើង និងយល់ដល់ក្រុងយេរូសាឡឹម ដែលយើងបានជ្រើសរើស។
[14]បន្ទាប់មក ព្រះអម្ចាស់បណ្តាលឲ្យមានគូវិវាទរបស់ព្រះបាទសាឡូម៉ូនងើបឡើង គឺលោកហាដាឌ ជាអ្នកស្រុកអេដុម។[15]លោកជារាជវង្សរបស់ស្តេចស្រុកអេដុម។
នៅពេលដែលព្រះបាទដាវីឌគង់នៅអេដុំ លោកយ៉ូអាប់ជាមេទ័ពបានឡើងទៅដុតសាកសពបុរសទាំងអស់ដែលបានលោកសម្លាប់រួចហើយនៅស្រុកអេដុម។
[16]និងទាហានអ៊ីស្រាអែលនៅទីនោះប្រាំមួយខែរហូតបានសម្លាប់បុរសៗទាំងអស់នៅស្រុកអេដុម។[17]ប៉ុន្តែ
លោកហាដាឌអ្នកបម្រើរបស់ឪពុកលោកបាននាំលោកជាមួយអ្នកស្រុកអេដុមផ្សេងទៀតទៅស្រុកអេស៊ីបតាំងពីលោកនៅក្មេងនៅឡើយ។
[18]ពួកគេចាកចេញពីស្រុកម៉ាឌានទៅដល់ស្រុកប៉ារ៉ាន ពួកគេនាំប្រុសៗជាមួយពួកគេ ទៅស្រុកអេស៊ីប ទៅជួបព្រះចៅផារោនជាស្តេចស្រុកអេស៊ីប។ ស្តេចបានឲ្យផ្ទះសំបែង
និងអាហារ ព្រមទាំងដីធ្លីឲ្យលោកទៀតផង។[19]ស្តេចផារោនពេញចិត្តនឹងលោកហាដាឌយ៉ាងខ្លាំង ដូច្នេះ ស្តេចក៏លើបួនថ្លៃរបស់ស្តេចឲ្យធ្វើជាភរិយាលោក
ជាបួនស្រីរបស់ព្រះមហាក្សត្រិយានីថាផ្ទេស។
[20]បួនស្រីរបស់ព្រះមហាក្សត្រិយានីថាផ្ទេសបានបង្កើតកូនប្រុសមួយឲ្យលោកាហាដាឌ។ ពួកគេបានដាក់ឈ្មោះថាកេនូបាត។ ព្រះមហាក្សត្រិយានី
ថាផ្ទេសបានចិញ្ចឹមកូននោះនៅក្នុងវាំងរបស់ព្រះចៅផារោន។ ដូច្នេះ កេនូបាតរស់នៅក្នុងវាំងស្តេចផារោន។[21]នៅពេលដែលលោកនៅស្រុកអេស៊ីបនៅឡើយ
លោកហាដាឌបានឮថាស្តេចដាវីឌបានសុគតហើយ ហើយលោកមេទ័ពយ៉ូអាប់បានស្លាប់ហើយដែរ នោះលោកក៏បានទូលទៅស្តេចផារោនថា៖
«ចូរឲ្យទូលបង្គំចេញទៅស្រុករបស់ទូលបង្គំវិញផង»។[22]បន្ទាប់មក ស្តេចផារោនមានរាជឱង្ការទៅគាត់ថា៖ «តើអ្នកនៅជាមួយយើងមានខ្វះខាតអ្វីទៀត
ដែលធ្វើឲ្យអ្នកចង់ទៅស្រុករបស់អ្នកវិញ»? លោកហាដាឌទូលថា៖ «មិនមានអ្វីខ្វះខាតអ្វីទេព្រះអង្គ តែសូមអនុញ្ញាតិឲ្យទូលបង្គំទៅផង»។
[23]ព្រះជាម្ចាស់ក៏ឲ្យមានម្នាក់ទៀតងើបឡើងប្រឆាំងនឹងព្រះបាទសាឡូម៉ូនដែរ គឺលោករេសោន ជាកូនរបស់លោកអេលីយ៉ាដា ដែលបានរត់ពីព្រះបាទហាដា-រេស៊ើរ ជាស្តេច
ស្រុកសូបាជាចៅហ្វាយរបស់ខ្លួន។[24]លោករេសោនបានប្រមូលមនុស្សប្រុសជាច្រើនមកជាមួយលោក ហើយលោកក្លាយជាមេក្រុមលើក្រុមតូចនោះ
នៅពេលដែលស្តេចដាវីឌបានវាយប្រហារក្រុមរបស់លោករេសោនជាអ្នកស្រុកស្រុកសូបា។ អ្នកស្រុកសូបាទាំងនោះបានរត់ទៅក្រុងដាម៉ាស ហើយរស់នៅទីនោះ
ហើយលោករេសោនបានគ្រប់គ្រងក្រុងដាម៉ាស។[25]លោកជាសត្រូវរបស់អ៊ីស្រាអែលក្នុងរាជ្យរបស់ព្រះបាទសាឡូម៉ូន គឺលោកតែងតែធ្វើទុក្ខបុកម្នេញអ៊ីស្រាអែល។
លោករេសោន តែងតែស្អប់ជនជាតិអ៊ីស្រាអែល ហើយបានឡើងសោយរាជ្យលើស្រុកអារ៉ាម។
[26]លោកយេរ៉ូបោមជាកូនរបស់លោកនេបាតមកពីកុលសម្ព័ន្ធអេប្រាអ៊ីម នៅស្រុកសេរេដា ជាអ្នកគ្រប់គ្រង់របស់ព្រះបាទសាឡូម៉ូន ម្តាយរបស់លោកឈ្មោះសេរូអា ជាស្ត្រី
មេម៉ាយក៏បានបះបោរប្រឆាំងនឹងស្តេចដែរ។[27]មូលហេតុដែលធ្វើឲ្យលោកប្រឆាំងនឹងស្តេច ព្រោះព្រះបាទសាឡូម៉ូនបានសង់កន្លែងមួយនៅមីឡូ និងជួសជុលកំពែងបាក់
បែកនៅក្រុងព្រះបាទដាវីឌជាបិតារបស់ទ្រង់។
[28]លោកយេរ៉ូបោមជាមនុស្សដ៏អង់អាច។ ព្រះបាទសាឡូម៉ូនបានឃើញថាលោកជាបុរសវ័យក្មេងដែលក្លៀវក្លា ដូច្នេះហើយ
ស្តេចបានឲ្យលោកគ្រប់គ្រងលើអ្នកធ្វើការក្នុងគ្រួសាររបស់លោកយ៉ូសែប។[29]នៅក្នុងពេលនោះ នៅពេលដែលលោកយេរ៉ូបោមចេញពីក្រុងយេរូសាឡឹមលោកព្យាការី
អហ៊ីយ៉ា ជាអ្នកភូមិស៊ីឡូ បានជួបលោកនៅតាមផ្លូវ។ លោកអហ៊ីយ៉ាបានស្លៀកសំលៀកបំពាក់ថ្មី ហើយលោកទាំងពីរបានដើរជាមួយគ្នានៅវាលស្រែ។[30]បន្ទាប់មក
លោកអហ៊ីយ៉ាបានដោះអាវនោះមកហែកជាដប់ពីរចំណែក។
[31]លោកមានប្រសាសន៍ទៅកាន់លោកយេរ៉ូបោមថា៖ «សូមយកដប់ចំណែក ព្រោះព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលមានបន្ទូលថា៖ «មើល
យើងនឹងហែកអាណាចក្រចេញពីដៃរបស់ព្រះបាទសាឡូម៉ូន ហើយយើងនឹងប្រគល់កុលសម្ព័ន្ធដប់ដល់អ្នក[32](ប៉ុន្តែ ព្រះបាទសាឡូម៉ូននឹងនៅសល់មួយកុលសម្ព័ន្ធ
ដោយយល់ដល់ព្រះបាទដាវីឌជាអ្នកបម្រើរបស់យើង គឺក្រុងដែលយើងបានជ្រើសរើសចេញពីកុលសម្ព័ន្ធអ៊ីស្រាអែល)[33]ដោយសារតែគេបានបោះបង់ចោលយើង ទៅ
ថ្វាយបង្គំអាសថារ៉ូតជាព្រះនៃជនជាតិស៊ីដូន កេម៉ូសជាព្រះនៃជនជាតិម៉ូអាប់ និងមីលកូមជាព្រះរបស់ជនជាតិអាំម៉ូន។ ពួកគេមិនបានដើរនៅក្នុងផ្លូវរបស់យើង
មិនបានធ្វើអ្វីដែលត្រឹមត្រូវនៅក្នុងភ្នែករបស់យើង មិនរក្សាច្បាប់ និងបញ្ញត្តរបស់យើង ដូចព្រះបាទដាវីឌជាបិតារបស់គេឡើយ។
[34]ទោះជាយ៉ាងណាក៏ដោយ យើងមិនដករាជ្យទាំងមូលចេញពីដៃរបស់សាឡូម៉ូនឡើយ។ ផ្ទុយទៅវិញ យើងនឹងឲ្យសាឡូម៉ូនគ្រងរាជ្យអស់មួយជីវិត
ដោយសារយល់ដល់ព្រះបាទដាវីឌជាអ្នកបម្រើដែលយើងបានជ្រើសរើស ជាអ្នកដែលរក្សាបញ្ញត្ត និងច្បាប់របស់យើង។[35]ប៉ុន្តែ
យើងនឹងដករាជ្យពីបុត្ររបស់ព្រះបាទសាឡូម៉ូន ហើយយើងនឹងប្រគល់ឲ្យអ្នក ដប់កុលសម្ព័ន្ធ។[36]យើងនឹងឲ្យកុលសម្ព័ន្ធមួយដល់បុត្ររបស់ព្រះបាទសាឡូម៉ូន ដូច្នេះ
ព្រះបាទដាវីឌជាអ្នកបម្រើរបស់យើងនឹងនៅមានចង្កៀងចំពោះយើងនៅក្រុងយេរូសាឡឹម ជាក្រុងដែលយើងបានជ្រើសរើស ដើម្បីដាក់នាមរបស់យើង។
[37]យើងនឹងប្រគល់ដល់អ្នក ហើយអ្នកនឹងគ្រប់គ្រង ដើម្បីសម្រេចតាមអ្វីដែលយើងចង់បាន ហើយអ្នកនឹងក្លាយជាស្តេចលើជនជាតិអ៊ីស្រាអែល។
[38]បើអ្នកស្តាប់តាមអ្វីដែលយើងបង្គាប់អ្នក ហើយបើអ្នកដើរតាមមាគារបស់យើង ហើយធ្វើរឿងត្រឹមត្រូវនៅក្នុងភ្នែករបស់យើង ដោយរក្សាច្បាប់ និងបញ្ញត្តរបស់យើង
ដូចដែលព្រះបាទដាវីឌជាអ្នកបម្រើរបស់យើងបានធ្វើ នោះយើងនឹងនៅជាមួយអ្នក និងកសាងគ្រួសាររបស់អ្នក ដូចយើងបានធ្វើសម្រាប់ព្រះបាទដាវីឌ
ហើយយើងនឹងប្រគល់អ៊ីស្រាអែលឲ្យអ្នក។[39]យើងនឹងដាក់ទោសកូនចៅរបស់ព្រះបាទដាវីឌ តែមិនរហូតនោះទេ»។
[40]ដូច្នេះ ព្រះបាទសាឡូម៉ូនព្យាយាមសម្លាប់លោកយេរ៉ូបោម។ ប៉ុន្តែ លោកយេរ៉ូបោមបានភាសខ្លួនទៅស្រុកអេស៊ីប ទៅជួបព្រះបាទស៊ីសាក់ ជាស្តេចស្រុកអេស៊ីប
ហើយលោកនៅស្រុកអេស៊ីបរហូតដល់ព្រះបាទសាឡូម៉ូនសោយទិវង្គត។

generated on Wed Sep 10 16:16:32 2025

[41]និយាយពីរឿងទាក់ទងនឹងព្រះបាទសាឡូម៉ូន អ្វីដែលស្តេចបានធ្វើ និងប្រាជ្ញារបស់ស្តេច តើមិនបានសរសេរទុកនៅក្នុងសៀវភៅប្រវត្តិរបស់ទ្រង់ទេឬអី?
[42]ព្រះបាទសាឡូម៉ូនបានគ្រងរាជ្យលើទឹកដីអ៊ីស្រាអែលអស់សែសិបឆ្នាំ។[43]ស្តេចបានសុគតរួមជាមួយពួកបុព្វបុរសរបស់ស្តេច
ហើយគេបានបញ្ចុះសពទ្រង់នៅក្នុងក្រុងស្តេចដាវីឌជាបិតាទ្រង់។ ព្រះបាទរេហូបោមជាបុត្រឡើងស្នងរាជ្យបន្ត។

---

1 Kings 11:1
ជនជាតិម៉ូអាប់ ជនជាតិអាំម៉ូន ជនជាតិអេដុម ជនជាតិស៊ីដូន និងជនជាតិហេត
ទាំងនេះជាឈ្មោះក្រុមមនុស្ស។
ព្រះបាទសាឡូម៉ូន
ពាក្យថា «ឥឡូវ»
ត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងដំណើររឿងសំខាន់ដែលអ្នកនិពន្ធបានផ្តល់ជូនអ្នកអានអំពីជីវិតរបស់ស្តេចសាឡូម៉ូន។
ទាក់ទាញចិត្តអ្នករាល់គ្នាទៅព្រះរបស់ពួកគេ
ដើម្បី «បង្វែរចិត្តអ្នកណាម្នាក់»
គឺដើម្បីបញ្ចុះបញ្ចូលមនុស្សនោះឲ្យផ្លាស់ប្តូរការស្រលាញ់។ កាបកប្រែផ្សេងទៀត
«បញ្ចុះបញ្ចូលអ្នកឲ្យគោរពបូជាព្រះដែលពួកគេគោរពបូជា»
1 Kings 11:3
មហេសី៧០០នាក់ និងស្រីស្នំ៣០០នាក់
« មហេសី ៧០០ នាក់ និង ស្រីស្នំ ៣០០ នាក់»
បានឲ្យចិត្តរបស់ស្តេចងាកឆ្ងាយពី
ដើម្បី «បង្វែរចិត្តអ្នកណាម្នាក់»
គឺដើម្បីបញ្ចុះបញ្ចូលមនុស្សនោះឲ្យផ្លាស់ប្តូរការស្រលាញ់។ ការបកប្រែផ្សេងទៀត
«បង្វែរចិត្តគាត់ចេញពីព្រះអម្ចាស់» ឬ
«បញ្ចុះបញ្ចូលស្តេចអោយឈប់ថ្វាយបង្គំព្រះជាម្ចាស់»
ដួងចិត្តរបស់ស្តេចមិនបានចុះចូលជាមួយព្រះជាម្ចាស់ជាព្រះទាំងស្រុងទេ
គឺមិនដូចព្រះបាទដាវីឌជាបិតារបស់ស្តេចឡើយ
ដើម្បី «ចុះចាញ់»
ដួងចិត្តរបស់អ្នកសំដៅទៅលើការផ្តល់ភាពស្មោះត្រង់និងការស្រឡាញ់រាប់អាន។
ការបកប្រែផ្សេងទៀត «គាត់មិនមានភក្តីភាពពេញលេញទេ ... ដូចស្តេចដាវីឌដែរ»
1 Kings 11:5
ព្រះអាសថារ៉ូត...ព្រះមីលកូម
ទាំងនេះជាឈ្មោះរបស់ព្រះមិនពិត។
ជនជាតិស៊ីដូន
នេះជាឈ្មោះក្រុមមនុស្ស។
អំពើអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
ឃ្លា «នៅចំពោះមុខ» សំដៅទៅលើគំនិតរបស់នរណាម្នាក់។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»
គាត់ដើរតាមព្រះមីលកូម
« ព្រះមីលកូម» ប្រហែលជាឈ្មោះមួយផ្សេងទៀតសម្រាប់រូបព្រះម៉ូឡិច»។
1 Kings 11:7
ព្រះកេម៉ូស...ព្រះម៉ូឡុក
ទាំងនេះជាឈ្មោះរបស់ព្រះមិនពិត។
យញ្ញបូជាទៅព្រះរបស់ពួកគេនៅកន្លែងនោះ
នៅទីនេះពាក្យ«នៅពួកគេ»
សំដៅទៅលើទីសក្ការៈដែលព្រះបាទសាឡូម៉ូនបានសាងសង់។
1 Kings 11:9
ដោយសារស្តេចបានបែរព្រះទ័យចេញពីព្រះអង្គ
ពាក្យថា ដួងចិត្តរបស់គាត់បានប្រែទៅជា
សំដៅទៅលើការផ្លាស់ប្តូរភក្តីភាពនិងការស្រឡាញ់រាប់អានរបស់គាត់។
ការបកប្រែផ្សេងទៀត «ស្តេចសាឡូម៉ូនបានឈប់ថ្វាយបង្គំព្រះជាម្ចាស់»
ស្តេចបានជួបជាមួយព្រះអង្គពីរដង
«ព្រះអម្ចាស់បានសំដែងអោយព្រះបាទសាឡូម៉ូនឃើញពីរដង»។
1 Kings 11:11
ហែករាជ្យរបស់អ្នក
ដើម្បី «ហែកចេញ» គឺត្រូវដកចេញដោយបង្ខំ។
នេះគឺដូចជាមនុស្សម្នាក់ហែកបំណែកមួយនៃក្រណាត់។ ការបកប្រែផ្សេងទៀត
«ដណ្តើមយកនគរពីអ្នកដោយបង្ខំ»
នៅក្នុងដៃបុត្ររបស់អ្នក
ពាក្យថា «ដៃ» សំដៅទៅលើការគ្រប់គ្រងសិទ្ធិអំណាចនិងអំណាច។
«ការគ្រប់គ្រងកូនប្រុសរបស់អ្នក»

1 Kings 11:14
លោកហាដាឌ
នេះជាឈ្មោះមនុស្សប្រុសម្នាក់។
នៅពេលដែលព្រះបាទដាវីឌគង់នៅអេដុំ
នេះគឺជាសម្ភារៈផ្នែកខាងក្រោយដែលបានកើតឡើងជាយូរមកហើយ។
ពាក្យបង្ហាញពីការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ពាក្យថា «អ៊ីស្រាអែលទាំងអស់» សំដៅទៅលើកងទ័ពអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត « យ៉ូអាប់និងកងទ័ពអ៊ីស្រាអែលទាំងអស់»
ប៉ុន្តែលោកហាដាឌ អ្នកបម្រើរបស់ឪពុកលោកបាននាំលោកជាមួយអ្នកស្រុកអេដុមផ្សេងទៀត
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ប៉ុន្តែពួកអ្នកបម្រើរបស់ឪពុកលោកហាដាឌបានយកគាត់ទៅជាមួយជនជាតិអេដុមផ្សេងទៀត»
1 Kings 11:18
ព័ត៌មានទូទៅ
ផ្នែកនេះបន្តព័ត៌មានសំខាន់ដែលបានចាប់ផ្តើមនៅជំពូក ១១:១៤ ។
ពួកគេចាកចេញពីស្រុកម៉ាឌាន
នៅទីនេះពាក្យថា «ពួកគេ» សំដៅទៅលើលោកហាដាឌ និង
ជនជាតិអេដុមផ្សេងទៀត ដែលបានរៀបរាប់នៅជំពូក ១១:១៤ ។
ស្រុកម៉ាឌាន...ស្រុកប៉ារ៉ាន...ស្រុកអេស៊ីប
ទាំងនេះជាឈ្មោះទីកន្លែង។
ថាផ្នេស
នេះជាឈ្មោះរបស់ស្ត្រីម្នាក់។
1 Kings 11:20
ព្រះមហាក្សត្រិយានីថាផ្នេស
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
កេនូបាត...ហាដាឌ
ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។
ស្តេចដាវីឌបានសុគតហើយ
នេះជាវិធីគួរសមមួយក្នុងការនិយាយថា ស្តេចដាវីឌបានស្លាប់ហើយ។
ការបកប្រែផ្សេងទៀត ស្តេចដាវីឌបានទទួលមរណភាព
1 Kings 11:23
លោករេសោន ...លោកអេលីយ៉ាដា...ព្រះបាទហាដា-រេស៊ើរ
ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។
ស្រុកសូបា...ក្រុងដាម៉ាស...ស្រុកអារ៉ាម
ទាំងនេះជាឈ្មោះនៃទីតាំង។
នៅពេលដែលស្តេចដាវីឌបានវាយប្រហារ
«ស្តេចដាវីឌ» សំដៅទៅលើកម្លាំងទាំងអស់របស់ស្តេចដាវីឌ។
ការបកប្រែផ្សេងទៀត«នៅពេលដែលកងទ័ពរបស់ស្តេចដាវីឌបានយកឈ្នះ»
ក្នុងរាជ្យរបស់ព្រះបាទសាឡូម៉ូន
នៅទីនេះពាក្យ «ថ្ងៃ» សំដៅទៅលើរយៈពេលមួយហើយ «ស្តេចសាឡូម៉ូន»
សំដៅទៅលើអ្វីគ្រប់យ៉ាងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់។
ការបកប្រែផ្សេងទៀត «គ្រប់ពេលដែលស្តេចសាឡូម៉ូនគ្រប់គ្រងបាន»
លោករេសោន តែងតែស្អប់ជនជាតិអ៊ីស្រាអែល
«លោករេសោនស្អប់អ៊ីស្រាអែលខ្លាំងណាស់»
1 Kings 11:26
លោកយេរ៉ូបោម...លោកនេបាត
ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។
ស្រុកសេរេដា...មីឡូ
ទាំងនេះជាឈ្មោះនៃទីតាំង។
សេរូអា
នេះជាឈ្មោះរបស់ស្ត្រីម្នាក់
បានបះបោរប្រឆាំងនឹងស្តេច
ពាក្យថា «ដៃ» សំដៅទៅលើសិទ្ធិអំណាចនិងការគ្រប់គ្រង។ ឃ្លា«បះបោរ»
សំដៅទៅលើការប្រឆាំងនឹងនរណាម្នាក់ដោយប្រើសិទ្ធិអំណាចនិងការគ្រប់គ្រង។
នេះគឺជាការប្រៀបធៀប ដែលត្រូវបានប្រើជាសំនួនវោហារស័ព្ទទូទៅ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត«បះបោរប្រឆាំងនឹងព្រះរាជា»

ព្រះបាទសាឡូម៉ូនបានសង់កន្លែងមួយនៅមីឡូ

បកប្រែ «មីឡូ» ដូចក្នុងជំពូក ៩:១៥។

1 Kings 11:28

ជាមនុស្សដ៏អង់អាច

អាចមានន័យថា ១) «អ្នកចម្បាំងដ៏អស្ចារ្យ» ឬ ២)
«បុរសដែលមានសមត្ថភាពខ្ពស់» ឬ ៣)
«បុរសមានទ្រព្យស្តុកស្តម្ភនិងមានឥទ្ធិពល។»

ស្តេចបានឲ្យលោក

«ស្តេចបានតែងតាំងគាត់ជាមេបញ្ជាការ»

អ្នកធ្វើការ

ពាក្យថា«ពលកម្ម»សំដៅទៅលើការងារដែលស្តេចសាឡូម៉ូនបានបញ្ជាឲ្យប្រជាជនធ្វើ
សម្រាប់រដ្ឋាភិបាលរបស់ស្តេច។ នេះគឺពាក្យប្រៀបធៀប។

ក្នុងគ្រួសាររបស់លោកយ៉ូសែប

នេះសំដៅទៅលើកូនចៅរបស់យ៉ូសែបដែលជាក្រុមប្រជាជនអេប្រាអ៊ីមនិងម៉ាណាសេ។
នេះជាពាក្យប្រៀបធៀប។

លោកអហ៊ីយ៉ា

នេះជាឈ្មោះបុរសម្នាក់។

អ្នកភូមិស៊ីឡូ

ជនជាតិស៊ីឡូគឺជាក្រុមប្រជាជន។

1 Kings 11:31

លោកមានប្រសាសន៍

ត្រង់នេះពាក្យ«គាត់»សំដៅទៅលើអ័ហ៊ីយ៉ា។

ហែកអាណាចក្រចេញ

នៅទីនេះ «បង្ហូរទឹកភ្នែក ...
ចេញ»គឺជាពាក្យប្រៀបធៀបដែលសំដៅទៅលើសកម្មភាពនៃការដកចេញដោយបង្ខំ។
នេះគឺដូចជាមនុស្សម្នាក់ហែកបំណែកមួយនៃក្រណាត់។ ការបកប្រែផ្សេងទៀត
«ដកនគរចេញដោយបង្ខំ»សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លានេះនៅជំពូក
១១:១១ ។

ដៃរបស់ព្រះបាទសាឡូម៉ូន

នៅទីនេះ «ដៃ»គឺសំដៅទៅលើសិទ្ធិអំណាចការគ្រប់គ្រង និង
អំណាចរបស់មនុស្សម្នាក់។ ការបកប្រែផ្សេងទៀត «ការគ្រប់គ្រងរបស់សាឡូម៉ូន»

ព្រះបាទសាឡូម៉ូននឹងនៅសល់

ឈ្មោះ «សាឡូម៉ូន» នៅទីនេះគឺជាពាក្យសំដីទាក់ទងនឹងកូនចៅរបស់គាត់។
ការបកប្រែផ្សេងទៀត «កូនប្រុសរបស់សាឡូម៉ូននឹងមាន» ឬ
«កូនចៅរបស់សាឡូម៉ូននឹងមាន»

អ្វីដែលត្រឹមត្រូវនៅក្នុងភ្នែករបស់យើង

«ភ្នែក» នៅទីនេះគឺសម្រាប់មតិឬគំនិតរបស់នរណាម្នាក់។
នេះគឺត្រូវបានប្រើជាទូទៅ។ ការបកប្រែផ្សេងទៀត «អ្វីដែលខ្ញុំគិតថាត្រឹមត្រូវ»

អាសចារ៉ូត... កេម៉ូស...មីលកូម

ទាំងនេះជាឈ្មោះរបស់ព្រះមិនពិត។

1 Kings 11:34

ព័ត៌មានទូទៅ

អ័ហ៊ីយ៉ាបន្តប្រាប់យេរ៉ូបោមនូវអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល។

យើងមិនដក

ត្រង់នេះពាក្យ «យើង» សំដៅទៅលើព្រះអម្ចាស់។

ចេញពីដៃរបសសាឡូម៉ូនឡើយ

ត្រង់នេះពាក្យថា «ដៃ» គឺសំដៅទៅលើសិទ្ធិអំណាចការគ្រប់គ្រង និង
អំណាចរបស់បុគ្គលម្នាក់។ «ចេញពីការគ្រប់គ្រងរបស់ស្តេចសាឡូម៉ូន»

យើងនឹងប្រគល់ឲ្យអ្នក

នៅទីនេះពាក្យ «យើង» សំដៅទៅលើយេរ៉ូបោម។

នៅមានចង្កៀងចំពោះយើង

ពាក្យថា «ចង្កៀង» គឺសំដៅទៅលើឥទ្ធិពល និង ការណែនាំរបស់មនុស្សម្នាក់។
ការបកប្រែផ្សេងទៀត « នឹងមានកូនចៅដើម្បីគ្រប់គ្រងជាឥទ្ធិពលនិងជាមគ្គុទេស
ក៍សម្រាប់ការគោរពតាមសេចក្តីសញ្ញារបស់ខ្ញុំជាមួយគ្រួសារស្តេចដាវីឌ»
1 Kings 11:37

ព័ត៌មានទូទៅ

អហ៊ីយ៉ាបន្តប្រាប់យេរ៉ូបោមនូវអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល។

យើងនឹងប្រគល់ដល់អ្នក

នៅទីនេះពាក្យ «យើង» សំដៅលើព្រះអម្ចាស់និងពាក្យថា «អ្នក»
សំដៅទៅលើយេរ៉ូបោម។

រឿងត្រឹមត្រូវនៅក្នុងភ្នែករបស់យើង

ពាក្យ «ភ្នែក»
នៅទីនេះគឺជាពាក្យប្រៀបធៀបសម្រាប់មតិឬគំនិតរបស់នរណាម្នាក់។
នេះជាការសម្គាល់ដែលត្រូវបានប្រើជាទូទៅ។
សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លានេះនៅជំពូក ១១:៣១។

កសាងគ្រួសាររបស់អ្នក

ឃ្លា «សាងសង់ផ្ទះ»
គឺជាពាក្យប្រៀបធៀបសម្រាប់បង្កើតកូនចៅតាំងពីពេលនោះមក។
ការបកប្រែផ្សេងទៀត បង្កើតនគរមួយដ៏ស្ថិតស្ថេរសម្រាប់អ្នក
1 Kings 11:40

ព្រះបាទស៊ីសាក់

នេះជាឈ្មោះបុរសម្នាក់។

1 Kings 11:41

តើមិនបានសរសេរទុកនៅក្នុងសៀវភៅប្រវត្តិរបស់ទ្រង់ទេឬអី?

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ហើយសន្មតថាចម្លើយគឺវិជ្ជមាន។
សំណួរគឺការប្រៀបធៀបហើយត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
ការបកប្រែផ្សេងទៀត «អ្នកអាចរកឃើញវានៅក្នុងសៀវភៅប្រវត្តិ
ស្តេចសាឡូម៉ូន»។

សៀវភៅប្រវត្តិរបស់ទ្រង់

សៀវភៅនេះមិនមានទៀតទេ។

ស្តេចបានសុគតរួមជាមួយពួកបុព្វបុរសរបស់ស្តេច ហើយគេបានបញ្ចុះសពទ្រង់

ឃ្លា «ផ្ទុំជាមួយបុព្វបុរសរបស់ស្តេច» គឺជាពាក្យប្រៀបធៀបដែលបង្ហាញថា
ជាការស្លាប់របស់មនុស្សម្នាក់ដោយពាក្យគួរសម។ ការបកប្រែផ្សេងទៀត
«បានសុគតហើយស្តេចត្រូវបានគេបញ្ចុះជាមួយបុព្វបុរសរបស់ស្តេច»

បញ្ចុះសពទ្រង់

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សបានបញ្ចុះសពស្តេច»

---

12 [1]លោករេហូបោមបានទៅស៊ីគែម ដោយសារប្រជាជនអ៊ីស្រាអែលទាំងអស់បានមកទីនោះ ដើម្បីអភិសេកលោកជាស្តេច។[2]នៅពេលដែលលោកយេរ៉ូបោម ជាកូនរបស់
លោកនេបាត ឮដំណឹងនេះ (កាលនោះលោកនៅស្រុកអេស៊ីបនៅឡើយ គឺនៅកន្លែងដែលលោកភាសខ្លួនពីស្តេចសាឡូម៉ូន) គាត់បានស្នាក់នៅស្រុកអេស៊ីប។
[3]ដូច្នេះ គេក៏បានបញ្ជូនមនុស្សទៅហៅលោក បន្ទាប់មក លោកយេរ៉ូបោម និងប្រជាជនអ៊ីស្រាអែលបានទូលទៅព្រះបាទរេហូបោមថា៖
[4]«បិតារបស់ព្រះករុណាបានដាក់នឹមយ៉ាងធ្ងន់លើយើងរាល់គ្នា។ ឥឡូវនេះ ចូរសម្រាលការងារដ៏លំបាក ដែលបិតារបស់ព្រះករុណាបានដាក់លើយើង
នោះយើងនឹងបម្រើព្រះអង្គ»។[3]ព្រះបាទរេហូបោមមានរាជឱង្ការទៅពួកគេថា៖ «សូមទៅបីថ្ងៃសិនទៅ បន្ទាប់មក ចាំត្រឡប់មករកយើងវិញ»។ ដូច្នេះ ពួកគេក៏ចេញទៅ។
[6]ព្រះបាទរេហូបោមបានពិភាក្សាជាមួយពួកចាស់ទុំដែលធ្លាប់បានបម្រើព្រះបាទសាឡូម៉ូនជាបិតាទ្រង់កាលនៅមានព្រះជន្ម ហើយនិយាយថា៖
«តើអ្នកចង់ឲ្យយើងនិយាយជាមួយប្រជាជននេះយ៉ាងដូចម្តេច»?[7]ពួកគេបានទូលទៅស្តេចថា៖ «បើព្រះករុណាបម្រើប្រជាជននៅថ្ងៃនេះ គឺបម្រើអ្នកទាំងនេះ
ហើយឆ្លើយពាក្យល្អៗទៅពួកគេ នោះពួកគេនឹងបម្រើព្រះករុណាជារៀងរហូត»។
[8]ប៉ុន្តែ ព្រះបាទរេហូបោមបានព្រងើយកន្តើយជាមួយយោបល់របស់ពួកចាស់ទុំ ដែលបានទូលដល់ស្តេច
ហើយស្តេចបានពិភាក្សាជាមួយប្រុសៗដែលបានធំធាត់ឡើងជាមួយស្តេច និងឈរនៅចំពោះមុខស្តេច។[9]ស្តេចបានរាជឱង្ការទៅពួកគេថា៖
«តើអ្នកទាំងអស់គ្នាមានយោបល់ដូចម្តេច ដើម្បីឲ្យយើងអាចឆ្លើយទៅប្រជាជន ដែលបានទូលយើងថា៖
«សូមសម្រាលបន្ទុកដែលបិតារបស់ព្រះករុណាដាក់មកលើយើង?»
[10]ប្រុសៗដែលបានធំធាត់ឡើងជាមួយព្រះបាទរេហូបោមបានទូលទៅស្តេចថា៖ «សូមព្រះករុណាមានរាជឱង្ការទៅប្រជាជនទាំងនេះដែលបានប្រាប់ព្រះករុណាថា
ព្រះបាទសាឡូម៉ូនជាបិតារបស់ព្រះករុណាបានដាក់បន្ទុកធ្ងន់លើពួកគេ ប៉ុន្តែ សូមព្រះករុណាសម្រាលបន្ទុកនេះ។ ព្រះករុណាគួរទូលទៅពួកគេថា៖

generated on Wed Sep 10 16:16:32 2025

«កូនដៃរបស់យើងក្រាស់ជាងចង្កេះរបស់បិតាយើង។[11]ដូច្នេះឥឡូវនេះ ទោះបីជាបិតារបស់យើងបានដាក់បន្ទុកធ្ងន់លើអ្នករាល់គ្នា
នោះយើងនឹងបន្ថែមបន្ទុកលើអ្នករាល់គ្នាថែមទៀត។ បិតារបស់យើងបានពិន័យអ្នករាល់គ្នាជាមួយនឹងរំពាត់ ប៉ុន្តែ យើងនឹងពិន័យអ្នករាល់គ្នាជាមួយនឹងខ្យាដំរី»។
[12]ដូច្នេះ ព្រះបាទរេហូបោម និងប្រជាជនទាំងអស់បានមកជួបរេហូបោមនៅថ្ងៃទីបី ដូចដែលស្តេចបានប្រាប់ពួកគេថា៖ «ចូរមកជួបយើងនៅថ្ងៃទីបី»។
[13]ស្តេចបានឆ្លើយទៅពួកគេយ៉ាងឈ្លើយ និងបានបដិសេធយោបល់របស់ពួកចាស់ទុំដែលបានថ្វាយយោបល់ស្តេច។
[14]ស្តេចបានប្រាប់ប្រជាជននូវពាក្យដែលប្រុសៗបានទូលស្តេចថា៖ «បិតារបស់យើងបានដាក់បន្ទុកធ្ងន់លើអ្នករាល់គ្នា នោះយើងនឹងបន្ថែមបន្ទុកលើអ្នករាល់គ្នាថែមទៀត។
បិតារបស់យើងបានពិន័យអ្នករាល់គ្នាជាមួយនឹងរំពាត់ ប៉ុន្តែ យើងនឹងពិន័យអ្នករាល់គ្នាជាមួយនឹងខ្យាដំរីវិញ»។
[15]ដូច្នេះ ស្តេចមិនបានស្តាប់ប្រជាជនឡើយ ដ្បិត ព្រះអម្ចាស់បណ្តាលឲ្យមានការណ៍ប្រែប្រួល ស្របតាមព្រះបន្ទូលតាមរយៈព្យាការីអហ៊ីយ៉ា ដែលព្រះអង្គបានថ្លែងមកកាន់
លោកយេរ៉ូបោម ជាកូនរបស់លោកនេបាតនៅស៊ីឡូ។
[16]នៅពេលដែលជនជាតិអ៊ីស្រាអែលឃើញថាស្តេចមិនស្តាប់ពួកគេដូច្នេះ ប្រជាជនបានទូលទៅស្តេចវិញថា៖ «តើយើងមានចំណែកអ្វីជាមួយព្រះបាទដាវីឌ? ពួកយើងក៏
គ្មានចំណែកមរតកអ្វីរួមជាមួយកូនរបស់លោកអ៊ីសាយដែរ! ទៅជំរំរបស់អ្នកវិញទៅអ៊ីស្រាអែលអើយ។ ឥឡូវនេះ ចូរមើលគ្រួសាររបស់អ្នកចុះ»។ ដូច្នេះ
ជនជាតិអ៊ីស្រាអែលបានទៅជំរំរបស់ពួកគេវិញ។[17]ប៉ុន្តែ សម្រាប់ជនជាតិអ៊ីស្រាអែលដែលនៅក្នុងក្រុងទាំងឡាយរបស់យូដា លោករេហូបោមក្លាយជាស្តេចលើពួកគេ។
[18]ព្រះបាទរេហូបោមចាត់បញ្ជូនលោកអដូរ៉ាមទៅធ្វើជាអ្នកគ្រប់គ្រងលើអ្នកធ្វើការ តែជនជាតិអ៊ីស្រាអែលយកដុំថ្មគប់សម្លាប់លោក។ ព្រះបាទរេហូបោមក៏ប្រញាប់ប្រញាល់
ឡើងរទេះចំបាំងរបស់ខ្លួនចូលក្រុងយេរូសាឡិម។[19]ដូច្នេះ អ៊ីស្រាអែលបះបោរប្រឆាំងនឹងពូជពង្សព្រះបាទដាវីឌ រហូតដល់សព្វថ្ងៃ។
[20]នៅពេលដែលប្រជាជនអ៊ីស្រាអែលបានឮថាព្រះបាទយេរ៉ូបោមបានត្រឡប់មកវិញ ពួកគេក៏បានចាត់គេឲ្យទៅហៅទ្រង់មកក្នុងចំណោមពួកគេ
ហើយលើកទ្រង់ជាស្តេចលើអ៊ីស្រាអែល។ គ្មាននរណាម្នាក់បានដើរតាមគ្រួសាររបស់ព្រះបាទដាវីឌទេ លើកលែងតែកុលសម្ព័ន្ធយូដា។
[21]នៅពេលដែលព្រះបាទរេហូបោមមកដល់ក្រុងយេរូសាឡឹម ទ្រង់បានកោះហៅកុលសម្ព័ន្ធយូដា និងកុលសម្ព័ន្ធបេនយ៉ាមីន គេជ្រើសរើសបានមនុស្សប្រុស
១៨០០០០ដែលជាទាហាន ដើម្បីប្រយុទ្ធជាមួយអ៊ីស្រាអែល ដើម្បីស្តារព្រះរាជ្យរបស់ព្រះបាទរេហូបោមជាបុត្ររបស់ព្រះបាទសាឡូម៉ូនឡើងវិញ។
[22]ប៉ុន្តែ ព្រះជាម្ចាស់មានបន្ទូលតាមរយៈលោកសេម៉ាយ៉ា ជាអ្នកជំនិតរបស់ព្រះអង្គថា៖[23]«ចូរទូលព្រះបាទរេហូបោមជាបុត្ររបស់ព្រះបាទសាឡូម៉ូន ជាស្តេចស្រុកយូដា
និងទៅកាន់កុលសម្ព័ន្ធយូដា និងកុលសម្ព័ន្ធបេនយ៉ាមីន និប្រជាជនទាំងអស់ថា[24]ព្រះអម្ចាស់មានបន្ទូលថា៖ «អ្នកមិនត្រូវប្រយុទ្ធ
ឬវាយប្រហារអ៊ីស្រាអែលជាបងប្អូនរបស់អ្នកឡើយ។ ម្នាក់ៗត្រូវត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ព្រោះរឿងនេះយើងជាអ្នកធ្វើឲ្យកើតឡើង»។ ដូច្នេះ
ពួកគេបានស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយត្រឡប់ទៅវិញ ហើយពួកគេបានស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអង្គ។
[25]បន្ទាប់ មកព្រះបាទយេរ៉ូបោមបានសង់ក្រុងស៊ីគែម នៅលើភ្នំអេប្រាអ៊ីម ហើយគង់នៅទីនោះ។ ស្តេចបានចេញពីស៊ីគែមទៅសង់ក្រុងពេនួល។
[26]ព្រះបាទយេរ៉ូបោមបានគិតនៅក្នុងចិត្តថា៖ «ឥឡូវនេះរាជ្យនេះនឹងត្រឡប់ទៅរាជវង្សរបស់ស្តេចដាវីឌវិញ។
[27]បើប្រជាជនទាំងអស់នេះឡើងទៅថ្វាយតង្វាយនៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់នៅក្រុងយេរូសាឡឹម នោះដួងចិត្តរបស់ប្រជាជននឹងត្រឡប់ទៅចៅហ្វាយរបស់ពួកគេ
គឺទៅស្តេចរេហូបោមជាស្តេចស្រុកយូដាវិញមិនខាន»។
[28]ដូច្នេះ ព្រះបាទយេរ៉ូបោមបានរិះគិតរកមធ្យោបាយមួយ គឺឲ្យគេធ្វើរូបគោមាសពីរ ហើយស្តេចនិយាយទៅប្រជាជនថា៖
«បើអ្នកទៅក្រុងយេរូសាឡឹមនោះឆ្ងាយពេកសម្រាប់អ្នករាល់គ្នា។ មើល៍! អ៊ីស្រាអែលអើយ ទាំងនេះជាព្រះរបស់អ្នក ដែលបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីបមក»។
[29]ស្តេចបានដាក់គោមួយនៅបេតអែល និងមួយទៀតនៅដាន់។[30]ដូច្នេះ អំពើនេះក្លាយជាអំពើបាប។ មនុស្សបានទៅឯរូបគោមួយនេះ ឬមួយនោះរហូតដល់ដាន់។
[31]ព្រះបាទយេរ៉ូបោមបានសង់ផ្ទះជាច្រើននៅតាមទីខ្ពស់ៗ ហើយបានរើសបូជាចារ្យពីចំណោមមនុស្សទាំងអស់ ដែលមិនមែនជាកូនចៅរបស់លេវី។
[32]ព្រះបាទយេរ៉ូបោមបានរៀបចំពិធីបុណ្យនៅក្នុងខែទីប្រាំបី នៅក្នុងថ្ងៃទីដប់ប្រាំក្នុងខែនោះ ដូចជាថ្ងៃបុណ្យនៅស្រុកយូដាដែរ រួចស្តេចក៏ឡើងទៅលើអាសនា។
ស្តេចបានធ្វើបែបនេះនៅបេតអែល គឺបានថ្វាយយញ្ញបូជាដល់រូបគោ ដែលស្តេចបានធ្វើ ហើយស្តេចបានដាក់បូជាចារ្យ ដែលទ្រង់បានរើសនៅបេតអែលដែរ។
[33]ព្រះបាទយេរ៉ូបោមបានឡើងទៅអាសនា ដែលស្តេចបានធ្វើនៅបេតអែលនៅក្នុងថ្ងៃទីដប់ប្រាំក្នុងខែទីប្រាំបី គឺនៅក្នុងខែដែលស្តេចបានរៀបចំទុកដោយខ្លួនឯង
ស្តេចបានប្រារព្ធពិធីបុណ្យសម្រាប់ប្រជាជនអ៊ីស្រាអែល ហើយស្តេចបានឡើងទៅលើអាសនានោះ ដើម្បីដុតគ្រឿងក្រអូប។

---

1 Kings 12:1
ប្រជាជនអ៊ីស្រាអែលទាំងអស់បានមកទីនោះ
នៅទីនេះ «អ៊ីស្រាអែល» គឺជាពាក្យកាត់
សម្រាប់មនុស្សរបស់ប្រុសអ៊ីស្រាអែលទាំងអស់ដែលមានសមត្ថភាពប្រយុទ្ធ។
«អ៊ីស្រាអែលទាំងអស់» គឺមានន័យថា ស្ទើរតែទាំងអស់នៃជនជាតិអ៊ីស្រាអែល»។
ការបកប្រែផ្សេងទៀត «បុរសអ៊ីស្រាអែលទាំងអស់កំពុងតែមក»
នៅពេល
ឃ្លានេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់កន្លែងដែលសកម្មភាពចាប់ផ្តើម។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់បកប្រែពាក្យ
ដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះបាន។
លោកយេរ៉ូបោម...នេបាត
ទាំងនេះជាឈ្មោះរបស់បុរស។
1 Kings 12:3
ហៅលោក
នៅទីនេះពាក្យ «គាត់»សំដៅទៅលើលោកយេរ៉ូបោម។
ដាក់នឹមយ៉ាងធ្ងន់លើយើងរាល់គ្នា
នឹមធ្ងន់គឺជាការប្រៀបធៀបមួយសម្រាប់កម្លាំងពលកម្មដែលពិបាកនិងតម្រូវការ។
ការបកប្រែផ្សេងទៀត « ធ្វើបាបយើងដោយឃោរឃៅ» ឬ
«បង្ខំយើងអោយធ្វើការយ៉ាងខ្លាំង»
1 Kings 12:6
ពួកចាស់ទុំដែលធ្លាប់បានបម្រើព្រះបាទសាឡូម៉ូន
ដើម្បី «ឈរនៅមុខ»
គឺសំដៅទៅលើការបម្រើព្រះមហាក្សត្រនៅចំពោះមុខព្រះអង្គ។
ការបកប្រែផ្សេងទៀត «ចាស់ទុំដែលប្រឹក្សាយោបល់ពីស្តេចសាឡូម៉ូន» ឬ
«ចាស់ទុំដែលបានចូលរួមជាមួយស្តេចសាឡូម៉ូន»
1 Kings 12:8
សូមសម្រាលបន្ទុកដែលបិតារបស់ព្រះករុណាដាក់មកលើយើង
ដើម្បី «សម្រាលបន្ទុក» គឺជាពាក្យប្រៀបធៀបដើម្បីតំណាងឲ្យការលើកបន្ទុក។
ការបកប្រែផ្សេងទៀត «កុំធ្វើបាបយើងយ៉ាងឃោរឃៅដូចឪពុកអ្នកបានធ្វើ» ឬ
«កុំបង្ខំយើងឲ្យធ្វើការធ្ងន់ដូចឪពុករបស់អ្នកអី»
1 Kings 12:10
កូនដៃរបស់យើងក្រាស់ជាងចង្កេះរបស់បិតាយើង
ពាក្យប្រៀបធៀបនេះមានន័យថា
រេហូបោមឃោរឃៅនិងគួរឲ្យខ្លាចជាងឪពុករបស់គាត់។ ការបកប្រែផ្សេងទៀត
«អ្វីដែលខ្ញុំនឹងធ្វើដើម្បីឲ្យបន្ទុករបស់អ្នកធ្ងន់ជាងអ្វីដែលឪពុកខ្ញុំដាក់លើអ្នកទៅទៀត»
បិតារបស់យើងបានពិន័យអ្នករាល់គ្នាជាមួយនឹងរំពាត់ ប៉ុន្តែ
យើងនឹងពិន័យអ្នករាល់គ្នាជាមួយនឹងខ្យាដំរី
ការប្រៀបធៀបនេះមានន័យថា
ការដាក់ទោសដែលលោករេហូបោមនឹងធ្វើគឺអាក្រក់ជាងអ្វីដែលឪពុករបស់គាត់បានធ្វើទៅទៀត។
ការបកប្រែផ្សេងទៀត
«ឪពុកខ្ញុំបានប្រើរំពាត់ដើម្បីបង្ខំអ្នកឲ្យធ្វើការប៉ុន្តែខ្ញុំនឹងប្រើការដាក់ទណ្ឌកម្មដ៏ឃោរឃៅជាងនេះទៀត»
ពិន័យអ្នករាល់គ្នាជាមួយនឹងខ្យាដំរី
ពាក្យថា «ខ្យាដំរី» អាចសំដៅទៅលើ ១) រំពាត់ដែលមានដែកមុតស្រួចនៅចុងឬ ២)
សត្វដែលមានរាងដូចសត្វពីងពាងដែលមានស្នាមប្រឡាក់ពុល។
1 Kings 12:12
បានពិន័យអ្នករាល់គ្នាជាមួយនឹងរំពាត់
នឹមធ្ងន់គឺជាការប្រៀបធៀបមួយសម្រាប់កម្លាំងពលកម្មដែលពិបាកនិងតម្រូវការឲ្យធ្វើ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១២:៣។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «ធ្វើបាបអ្នកយ៉ាងឃោរឃៅ» ឬ
«បង្ខំអ្នកឲ្យធ្វើការយ៉ាងខ្លាំង»
បិតារបស់យើងបានពិន័យអ្នករាល់គ្នាជាមួយនឹងរំពាត់ ប៉ុន្តែ
យើងនឹងពិន័យអ្នករាល់គ្នាជាមួយនឹងខ្យាដំរីវិញ
ការប្រៀបធៀបនេះមានន័យថាការដាក់ទោសដែលលោករេហូបោមនឹងធ្វើគឺអាក្រក់ជាងអ្វីដែលព្រះបាទសាឡូម៉ូនបានធ្វើ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែរឿងនេះនៅជំពូក ១២:១០។
ការបកប្រែផ្សេងទៀត «ឪពុកខ្ញុំបានប្រើរំពាត់ដើម្បីបង្ខំអ្នកឲ្យធ្វើការ
ប៉ុន្តែខ្ញុំនឹងប្រើការដាក់ទណ្ឌកម្មដ៏ឃោរឃៅជាងនេះទៀត»
1 Kings 12:15
ដ្បិត ព្រះអម្ចាស់បណ្តាលឲ្យមានការណ៍ប្រែប្រួល
នេះគឺការបង្រៀបធៀបហើយអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានធ្វើអោយមានរឿងកើតឡើងយ៉ាងនេះ»
ព្យាការីអហ៊ីយ៉ា...លោកយេរ៉ូបោម...លោកនេបាត
ទាំងនេះជាឈ្មោះរបស់បុរស។
នៅស៊ីឡូ
នេះជាឈ្មោះក្រុមមនុស្សមកពីទីប្រជុំជនស៊ីឡូ។
1 Kings 12:16
ជនជាតិអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែល» គឺជាពាក្យកាត់
សម្រាប់បុរសអ៊ីស្រាអែលទាំងអស់ដែលមានសមត្ថភាពប្រយុទ្ធ។
«អ៊ីស្រាអែលទាំងអស់» គឺមានន័យថាស្ទើរតែទាំងអស់នៃជនជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «បុរសអ៊ីស្រាអែលទាំងអស់»
តើយើងមានចំណែកអ្វីជាមួយព្រះបាទដាវីឌ?
«ចំណែក» គឺមានន័យថា វាជាផ្នែកមួយនៃការចូលរួមឬចំណាប់អារម្មណ៍។
សំណួរនេះអាចត្រូវបានបកប្រែជាឃ្លាសាមញ្ញ។ ការបកប្រែផ្សេងទៀត
«យើងនឹងមិនមានចំណែកនៅក្នុងគ្រួសាររបស់ស្តេចដាវីឌទេ» ។
ពួកយើងក៏គ្មានចំណែកមរតកអ្វីរួមជាមួយកូនរបស់លោកអ៊ីសាយដែរ
«កូនប្រុសរបស់អ៊ីសាយ»
គឺសំដៅទៅលើស្តេចដាវីឌដែលជាកូនប្រុសរបស់អ៊ីសាយ។ «មរតក»
គឺសំដៅទៅលើផ្នែកដែលបន្សល់ទុកសម្រាប់មនុស្សទាំងនេះពីភាពជោគជ័យរបស់ស្តេចដាវីឌ។
ការបកប្រែផ្សេងទៀត
«យើងនឹងមិនមានអ្វីដែលត្រូវធ្វើជាមួយកូនចៅរបស់អ៊ីសាយទេ»
ទៅជំរំរបស់អ្នកវិញទៅអ៊ីស្រាអែលអើយ
«តង់» គឺតំណាងឲ្យកន្លែងស្នាក់នៅរបស់មនុស្សម្នាក់។ ការបកប្រែផ្សេងទៀត
«ចូរទៅផ្ទះរបស់អ្នក ប្រជាជនអ៊ីស្រាអែលអើយ»
ឥឡូវនេះ ចូរមើលគ្រួសាររបស់អ្នកចុះ
«ផ្ទះ» គឺសំដៅទៅលើខ្សែស្រឡាយនៃអំណាចនិងកិត្យានុភាពរបស់ស្តេចដាវីឌ។
ការបកប្រែផ្សេងទៀត «ថែរក្សានគរផ្ទាល់ខ្លួនរបស់អ្នក
កូនចៅរបស់ស្តេចដាវីឌអើយ»
1 Kings 12:18
លោកអដូរ៉ាម
នេះជាឈ្មោះបុរសម្នាក់។
ជនជាតិអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែល» គឺប្រជាជនអ៊ីស្រាអែល។ «អ៊ីស្រាអែលទាំងអស់»
គឺមានន័យថា ប្រជាជនអ៊ីស្រាអែលស្ទើរតែទាំងអស់។ ការបកប្រែផ្សេងទៀត
«ប្រជាជនអ៊ីស្រាអែលទាំងអស់ដែលនៅទីនោះ»
ពូជពង្សព្រះបាទដាវីឌ
នៅទីនេះ «ផ្ទះ» គឺតំណាងឲ្យក្រុមគ្រួសារឬកូនចៅ។ ការបកប្រែផ្សេងទៀត
«ស្តេចទាំងអស់មកពីស្តេចដាវីឌ»
រហូតដល់សព្វថ្ងៃ
«ថ្ងៃ» គឺសំដៅទៅលើរយៈពេលមួយ។
ត្រង់នេះវាសំដៅទៅលើពេលវេលាដែលអ្នកនិពន្ធពិតជាបានសរសេរអំពីរឿងនេះ។
ការបកប្រែផ្សេងទៀត «ពីពេលវេលារបស់អ្នកនិពន្ធ»
1 Kings 12:20
វាបានកើតឡើង
ឃ្លានេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់បកប្រែពាក្យនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
នៅពេលដែលប្រជាជនអ៊ីស្រាអែលបានឮ
«អ៊ីស្រាអែលទាំងអស់» គឺមានន័យថា
បុរសមានសមត្ថភាពរបស់អ៊ីស្រាអែលដែលតំណាងអោយប្រជាជនដទៃទៀតដោយប្រើពាក្យប្រៀបធៀប។
ការបកប្រែផ្សេងទៀត «នៅពេលមេដឹកនាំអ៊ីស្រាអែលទាំងអស់បានឮ»
គ្រួសាររបស់ព្រះបាទដាវីឌ
«កូនចៅរបស់ស្តេចដាវីឌ»
[illegible] ដែលគាត់បានធ្វើ។
កុលសម្ព័ន្ធយូដា និងកុលសម្ព័ន្ធបេនយ៉ាមីន
នៅទីនេះ «ផ្ទះ» គឺតំណាងឲ្យកុលសម្ព័ន្ធឬកូនចៅ។ ហើយនៅទីនេះ «កុលសម្ព័ន្ធ»
សំដៅទៅលើទាហានមកពីកុលសម្ព័ន្ធទាំងនោះ។ ការបកប្រែផ្សេងទៀត
«ទាហានទាំងអស់មកពីកុលសម្ព័ន្ធយូដានិងបេនយ៉ាមីន»
អ៊ីស្រាអែល
នៅទីនេះ «ផ្ទះ» តំណាងឲ្យអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត «នគរអ៊ីស្រាអែល»
ឬ «ប្រជាជននៃកុលសម្ព័ន្ធខាងជើងនៃអ៊ីស្រាអែល»
1 Kings 12:22
ព្រះជាម្ចាស់មានបន្ទូលតាមរយៈ...
នេះប្រើដើម្បីណែនាំអ្វីមួយ ដែលព្រះជាម្ចាស់បានប្រាប់ព្យាការី ឬ
ប្រជាជនរបស់ទ្រង់។ ការបកប្រែផ្សេងទៀត «ព្រះមានបន្ទូល...
ហើយទ្រង់មានព្រះបន្ទូលថា» ឬ « ព្រះមានបន្ទូលពាក្យទាំងនេះ ...
ហើយទ្រង់មានបន្ទូល»
លោកសេម៉ាយ៉ា
នេះជាឈ្មោះបុរសម្នាក់
អ្នកជំនិតរបស់ព្រះអង្គ
ឃ្លាថា «អ្នកជំនិតរបស់ព្រះ»
គឺរបៀបមួយគួរឲ្យគោរពសំដៅទៅលើព្យាការីរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត "អ្នកដែលជាកម្មសិទ្ធិរបស់ព្រះ" ឬ "ព្យាការីរបស់ព្រះ"
កុលសម្ព័ន្ធយូដា និងកុលសម្ព័ន្ធបេនយ៉ាមីន
នៅទីនេះ «ផ្ទះ» គឺតំណាងឲ្យកុលសម្ព័ន្ធឬកូនចៅ។ ការបកប្រែផ្សេងទៀត
"ប្រជាជនទាំងអស់មកពីកុលសម្ព័ន្ធយូដានិងបេនយ៉ាមីន"
ប្រហារអ៊ីស្រាអែលជាបងប្អូនរបស់អ្នក
ពាក្យថាបងប្អូននិងប្រជាជនអ៊ីស្រាអែលគឺ
សំដៅទៅលើមនុស្សនៃកុលសម្ព័ន្ធភាគខាងជើងទាំងដប់ហើយសង្កត់ធ្ងន់លើទំនាក់ទំនងគ្រួសាររវាងពួកគេ
ព្រោះរឿងនេះយើងជាអ្នកធ្វើឲ្យកើតឡើ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ពីព្រោះយើងបានធ្វើឲ្យរឿងនេះកើតឡើង»
1 Kings 12:25
បានគិតនៅក្នុងចិត្តថា
«ចិត្ត» គឺជាពាក្យពិពណ៌នា សម្រាប់មនសិការគំនិតខាងក្នុង
ការលើកទឹកចិត្តឬអារម្មណ៍របស់មនុស្សម្នាក់។ ការបកប្រែផ្សេងទៀត
«គិតខ្លួនឯង»
រាជវង្សរបស់ស្តេចដាវីឌ
នៅទីនេះ «ផ្ទះ» គឺតំណាងឲ្យគ្រួសារឬកូនចៅ។ ការបកប្រែផ្សេងទៀត
«ស្តេចទាំងអស់បានមកពីស្តេចដាវីឌ»
បើប្រជាជនទាំងអស់នេះឡើងទៅ
ពាក្យថា «ប្រជាជនទាំងនេះ»
សំដៅទៅលើប្រជាជននៃកុលសម្ព័ន្ធអ៊ីស្រាអែលទាំងដប់នៅខាងជើង។
ដួងចិត្តរបស់ប្រជាជន
«ដួងចិត្ត» គឺសំដៅទៅលើភាពស្មោះត្រង់និងសេចក្តីស្រឡាញ់របស់ប្រជាជន។
ការបកប្រែផ្សេងទៀត «ភាពស្មោះត្រង់របស់ប្រជាជនទាំងនេះ»
ត្រឡប់ទៅចៅហ្វាយរបស់ពួកគេ គឺទៅស្តេចរេហូបោមជាស្តេចស្រុកយូដាវិញមិនខាន
ឃ្លាទាំងនេះមានន័យជាមូលដ្ឋានដូចគ្នា
ហើយត្រូវបានបញ្ចូលគ្នាដើម្បីបញ្ជាក់ពីការភ័យខ្លាចរបស់លោកយេរ៉ូបោមដែលប្រជាជននឹងវិលត្រឡប់មក
1 Kings 12:28
បាននាំអ្នករាល់គ្នាចេញពី
«អ្នក» នៅទីនេះគឺសំដៅទៅលើបុព្វបុរសរបស់ប្រជាជន។ ការបកប្រែផ្សេងទៀត
«នាំដូនតាអ្នកឡើង»
1 Kings 12:31
ព្រះបាទយេរ៉ូបោមបានសង់ផ្ទះជាច្រើននៅតាមទីខ្ពស់ៗ
ការបកប្រែផ្សេងទៀត «កម្មកររបស់លោកយេរ៉ូបោមបានធ្វើការនេះតាមបញ្ជារបស់លោកយេរ៉ូបោមតំណាងឲ្យយេរ៉ូបោមផ្ទាល់។
ការបកប្រែផ្សេងទៀត «កម្មកររបស់លោកយេរ៉ូបោមបានសង់ផ្ទះនៅកន្លែងខ្ពស់ ៗ»
ផ្ទះជាច្រើននៅតាមទីខ្ពស់ៗ

generated on Wed Sep 10 16:16:32 2025

ព័ត៌មានបង្កប់ន័យថា ទាំងនេះជាកន្លែងគោរពបូជា។
អត្ថន័យពេញលេញនៃឃ្លាភ្ជាប់នេះអាចត្រូវបានធ្វើឲ្យកាន់តែច្បាស់។
ការបកប្រែផ្សេងទៀត «ផ្ទះសម្រាប់គោរពបូជានៅកន្លែងខ្ពស់ៗ»
បានរើសបូជាចារ្យ
«តែងតាំងមនុស្សឲ្យធ្វើជាសង្ឃ»
នៅក្នុងខែទីប្រាំបី នៅក្នុងថ្ងៃទីដប់ប្រាំក្នុងខែនោះ
នេះជាខែទី ៨ នៃប្រតិទិនហេប្រឺ។
ថ្ងៃទីដប់ប្រាំគឺជិតដល់ដើមខែវិច្ឆិកានៅលើប្រតិទិនលោកខាងលិច។
ការបកប្រែផ្សេងទៀត «នៅថ្ងៃទី ១៥ នៃខែ៨»
ឡើងទៅលើអាសនា
«បានឡើងទៅ»
គឺសំដៅទៅលើកន្លែងសក្ការៈបូជាចាប់តាំងពីអាសនៈទាំងនេះស្ថិតនៅលើទីខ្ពស់។
ការបកប្រែផ្សេងទៀត «ថ្វាយយញ្ញបូជានៅលើអាសនៈ»
1 Kings 12:33
បានឡើងទៅអាសនា
«បានឡើងទៅ»
គឺជាការទៅកន្លែងសក្ការៈបូជាចាប់តាំងពីអាសនៈទាំងនេះស្ថិតនៅលើទីខ្ពស់។
ការបកប្រែផ្សេងទៀត «ថ្វាយយញ្ញបូជានៅលើអាសនៈ»
នៅក្នុងខែដែលស្តេចបានរៀបចំទុកដោយខ្លួនឯង
«នៅក្នុងខែដែលគាត់បានកំណត់»

13

[1]មានអ្នកបម្រើរបស់ព្រះអម្ចាស់មកពីយូដានាំព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅបេតអែល។ ព្រះបាទយេរ៉ូបោមកំពុងគង់នៅក្បែរអាសនា ដើម្បីដុតគ្រឿងក្រអូប។
[2]លោកបានប្រកាសប្រឆាំងនឹងសាសនាដោយព្រះបន្ទូលរបស់ព្រះអម្ចាស់ថា៖ «អាសនាអើយ អាសនាអើយ! នេះជាអ្វីដែលព្រះអម្ចាស់បានមានបន្ទូល៖
«មើលកូនប្រុសមួយនាមថាស្តេចយ៉ូសៀសនឹងកើតក្នុងគ្រួសាររបស់ស្តេចដាវីឌ នៅលើអាសនានេះយើងនឹងយកពួកបូជាចារ្យនៅតាមទីខ្ពស់ៗមកថ្វាយយញ្ញបូជា គឺពួក
បូជាចារ្យដែលធ្លាប់ដុតគ្រឿងក្រអូបនៅលើអាសនានេះ។ គេក៏យកឆ្អឹងរបស់មនុស្សមកដុតនៅលើអាសនានេះដែរ»។[3]បន្ទាប់មក
អ្នកបម្រើរបស់ព្រះអម្ចាស់បានឲ្យទីសម្គាល់មួយនៅថ្ងៃនោះដែរ ថា៖ «នេះជាទីសម្គាល់ដែលព្រះអម្ចាស់មានបន្ទូល៖ «មើល៍! អាសនានេះនឹងខ្ទេចខ្ទីអស់
ហើយផេះនៅលើអាសនានេះនឹងត្រូវខ្ចាត់ខ្ចាយអស់ដែរ»។
[4]នៅពេលដែលស្តេចបានឮពីអ្វីដែលអ្នកបម្រើរបស់ព្រះអម្ចាស់បានប្រកាសប្រឆាំងនឹងអាសនានៅបេតអែល ព្រះបាទយេរ៉ូបោមបានលើកដៃពីអាសនាមកនិយាយថា៖
«ចូរចាប់ជននេះភ្លាម»។ ដូច្នេះ ដៃដែលបានចង្អុលប្រឆាំងនឹងអ្នកបម្រើរបស់ព្រះអម្ចាស់បានស្ងួត ដូច្នេះ ស្តេចមិនអាចដកដៃនេះមកវិញបានឡើយ។
[5](អាសនាក៏បានបាក់បែក ហើយផេះនៅលើអាសនានោះក៏ខ្ចាត់ខ្ចាយពីអាសនាដែរ
ស្របតាមអ្វីដែលអ្នកបម្រើរបស់ព្រះអម្ចាស់បានរៀបរាប់ពីព្រះបន្ទូលរបស់ព្រះអម្ចាស់មែន)។
[6]ព្រះបាទយេរ៉ូបោមបាននិយាយទៅកាន់អ្នកបម្រើរបស់ព្រះអម្ចាស់ថា៖ «សូមលោកជួយទូលសុំការប្រណីសណ្តោសពីព្រះអម្ចាស់ជាព្រះរបស់លោក និងសូមអធិស្ឋានឲ្យខ្ញុំ
ផង ដើម្បីឲ្យដៃរបស់ខ្ញុំត្រឡប់ដូចធម្មតាវិញ»។ ដូច្នេះ អ្នកបម្រើរបស់ព្រះអម្ចាស់បានអធិស្ឋានទៅព្រះអម្ចាស់ ហើយដៃរបស់ស្តេចបានត្រឡប់ដូចធម្មតាវិញ
គឺបានដូចពីមុន។[7]ស្តេចទូលទៅអ្នកបម្រើរបស់ព្រះអម្ចាស់ថា៖ «សូមអញ្ជើញមកក្នុងដំណាក់របស់យើង ដើម្បីសម្រាក យើងនឹងផ្តល់រង្វាន់ជូនលោក។
[8]អ្នកបម្រើរបស់ព្រះជាម្ចាស់ បានទូលទៅស្តេចថា៖ «ទោះបីជាព្រះអង្គប្រគល់ទ្រព្យរបស់ព្រះអង្គពាក់កណ្តាលមកទូលបង្គំ ក៏ទូលបង្គំមិនទៅជាមួយព្រះអង្គដែរ
ទូលបង្គំមិនបរិភោគ ឬផឹកទឹកនៅកន្លែងនេះដាច់ខាត[9]ព្រោះព្រះអម្ចាស់បានបញ្ជាដោយព្រះបន្ទូលរបស់ព្រះអង្គថា៖ «អ្នកមិនត្រូវបរិភោគនំប៉័ង ឬផឹកទឹក
ហើយកុំឲ្យត្រឡប់មកតាមផ្លូវដដែលឡើយ»។[10]ដូច្នេះ អ្នកបម្រើរបស់ព្រះអម្ចាស់ក៏ទៅតាមផ្លូវមួយផ្សេងទៀត ហើយមិនបានទៅផ្ទះរបស់លោកវិញទេ
គឺតាមផ្លូវដែលលោកបានមកបេតអែលឡើយ។
[11]មានព្យាការីចាស់ម្នាក់រស់នៅបេតអែល ហើយកូនប្រុសៗរបស់លោកបានមកប្រាប់លោកពីរឿងគ្រប់យ៉ាងដែលអ្នកបម្រើរបស់ព្រះអម្ចាស់បានធ្វើនៅបេតអែល។
កូនប្រុសៗរបស់លោកក៏បានប្រាប់លោកពីអ្វីៗដែលអ្នកបម្រើរបស់ព្រះអម្ចាស់បានទូលស្តេចដែរ។[12]គាត់ក៏បានប្រាប់ពួកគេវិញថា៖ «តើគាត់ទៅតាមផ្លូវណា»?
កូនប្រុសៗរបស់គាត់បានដឹងពីផ្លូវរបស់អ្នកបម្រើរបស់ព្រះអម្ចាស់បានទៅស្រុកយូដាវិញ។[13]ដូច្នេះ លោកក៏បានប្រាប់កូនប្រុសៗរបស់លោកថា៖
«សូមចងកែបលាឲ្យពុក»។ ដូច្នេះ ពួកគេក៏បានចងកែបលាឲ្យលោក ហើយលោកបានជិះលានោះចេញទៅ។
[14]លោកព្យាការីចាស់នោះបានទៅតាមក្រោយអ្នកបម្រើរបស់ព្រះអម្ចាស់ ហើយបានជួបលោកកំពុងអង្គុយក្រោមដើមជ្រៃ ហើយលោកបាននិយាយទៅគាត់ថា៖
«តើអ្នកជាអ្នកបម្រើរបស់ព្រះអម្ចាស់ដែលមកពីស្រុកយូដានោះមែនទេ? គាត់បានឆ្លើយថា៖ «ខ្ញុំហ្នឹងហើយ»។[15]បន្ទាប់មក លោកព្យាការីចាស់នោះមានប្រសាសន៍ថា៖
«សូមមកផ្ទះ ហើយហូបជាមួយខ្ញុំសិន»។[16]នោះ អ្នកបម្រើរបស់ព្រះអម្ចាស់បានឆ្លើយថា៖ «ខ្ញុំនឹងមិនត្រឡប់ទៅជាមួយអ្នកឡើយ
ហើយខ្ញុំក៏មិនបរិភោគជាមួយអ្នកនៅកន្លែងនេះដែរ[17]ព្រោះព្រះអម្ចាស់បានហាមខ្ញុំដោយមានបន្ទូលថា៖ «អ្នកមិនត្រូវបរិភោគ ឬផឹកទឹកនៅទៅនោះឡើង
ហើយក៏មិនត្រូវត្រឡប់ទៅតាមផ្លូវដដែលដែរ។
[18]ដូច្នេះ ព្យាការីចាស់នោះបាននិយាយទៅគាត់ថា៖ «ខ្ញុំក៏ជាព្យាការីដូចលោកដែរ ហើយមានទេវតាមួយរូបបាននាំព្រះបន្ទូលរបស់ព្រះអម្ចាស់មកប្រាប់ខ្ញុំថា៖
«សូមនាំគាត់ត្រឡប់មកផ្ទះរបស់អ្នក នោះគាត់នឹងអាចបរិភោគ និងផឹកទឹកផង»។ ប៉ុន្តែ លោកបានកុហកអ្នកបម្រើរបស់ព្រះអម្ចាស់។[19]ដូច្នេះ
អ្នកបម្រើរបស់ព្រះអម្ចាស់បានត្រឡប់ទៅជាមួយព្យាការីចាស់នោះវិញ ហើយបានបរិភោគនៅក្នុងផ្ទះលោក និងបានផឹកទឹកផងដែរ។
[20]នៅពេលដែលពួកគេកំពុងអង្គុយនៅតុ
ព្រះជាម្ចាស់មានបន្ទូលតាមរយៈព្យាការីដែលនាំលោកមកវិញ[21]ហើយគាត់បានយំដាក់អ្នកបម្រើរបស់ព្រះអម្ចាស់មកពីស្រុកយូដាថា៖ «ព្រះអម្ចាស់មានបន្ទូលថា៖
«ដោយសារតែអ្នកមិនស្តាប់បង្គាប់ពាក្យរបស់ព្រះអម្ចាស់ និងមិនបានរក្សាបញ្ញត្តដែលព្រះអម្ចាស់ជាព្រះរបស់អ្នកផ្តល់មកអ្នក[22]ប៉ុន្តែ អ្នកបានត្រឡប់មកវិញ
ហើយបានបរិភោគអាហារ និងផឹកទឹកនៅកន្លែងនេះ គឺកន្លែងដែលព្រះអម្ចាស់បានហាមអ្នកមិនឲ្យបរិភោគ ឬផឹកទឹកឡើយ ដូច្នេះ
សពរបស់អ្នកនឹងត្រូវបញ្ចុះនៅក្នុងផ្នូររបស់ឪពុករបស់អ្នក»។
[23]ក្រោយពេលដែលលោកបរិភោគអាហារ និងបានផឹកទឹករួចមក លោកព្យាការីបានចងកែបលារបស់អ្នកបម្រើរបស់ព្រះអម្ចាស់ គឺបុរសដែលបានមកជាមួយលោក។
[24]នៅពេលដែលអ្នកបម្រើរបស់ព្រះអម្ចាស់ចេញបាត់ទៅ មានតោមួយបានមកជួបលោកនៅតាមផ្លូវ ហើយបានសម្លាប់លោកទៅ សពរបស់លោកបាននៅតាមផ្លូវនោះ។
បន្ទាប់មក លានោះបានឈរនៅក្បែរសាកសព ហើយតោនោះក៏បានឈរនៅក្បែរនោះដែរ។[25]នៅពេលដែលមនុស្សម្នាឆ្លងកាត់ហើយឃើញសាកសពនៅលើផ្លូវ
ហើយមានតោនៅឈរក្បែរនោះផង ពួកគេក៏បានមកប្រាប់ដល់អ្នកក្រុងដែលលោកព្យាការីចាស់នោះរស់នៅ។
[26]នៅពេលដែលលោកព្យាការី ដែលបាននាំអ្នកនោះត្រឡប់មកវិញបានឮពីរឿងនេះ លោកបាននិយាយថា៖ «នោះគឺជាសពរបស់អ្នកបម្រើរបស់ព្រះអម្ចាស់
ដែលមិនបានស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។ ដូច្នេះហើយ បានជាព្រះជាម្ចាស់ឲ្យតោសម្លាប់គាត់ តោបានហែក និងសម្លាប់គាត់
ដូចដែលព្រះបន្ទូលរបស់ព្រះអម្ចាស់បានព្រមានគាត់មែន»។[27]ដូច្នេះ លោកព្យាការីចាស់នោះបានប្រាប់ទៅកូនប្រុសៗរបស់គាត់ថា៖ «ចូរចងកែបលាឲ្យពុក»
ហើយពួកគេបានចងឲ្យគាត់។[28]គាត់បានចេញទៅហើយឃើញសពនៅក្បែរផ្លូវ ហើយលា និងតោឈរនៅក្បែរនោះ។ តោមិនបានស៊ីសពនោះទេ ក៏មិនបានខាំលាដែរ។
[29]លោកព្យាការីបានលើកសពរបស់អ្នកបម្រើរបស់ព្រះអម្ចាស់ដាក់នៅលើលា ហើយនាំត្រឡប់មកវិញ។ លោកបានមកក្រុងរបស់លោកវិញ ដើម្បីកាន់ទុក្ខ
និងកប់សព្វបុរសនោះ។[30]លោកបានកប់សព្វនោះនៅក្នុងផ្នូររបស់លោកផ្ទាល់ ហើយពួកគេក៏កាន់ទុក្ខដោយនិយាយថា៖ «ប្អូនអើយ ម្តេចក៏វេទនាម្ល៉េះ!»។
[31]បន្ទាប់មក ក្រោយពីលោកបានកប់គាត់រួចហើយ លោកព្យាការីចាស់នោះបានមានប្រសាសន៍ទៅកូនប្រុសៗរបស់គាត់ថា៖
«នៅពេលដែលពុកស្លាប់ទៅសូមកប់ពុកនៅក្នុងផ្នូរដែលបានកប់អ្នកបម្រើរបស់ព្រះអម្ចាស់នេះ។ សូមដាក់ឆ្អឹងពុកនៅក្បែរឆ្អឹងរបស់គាត់។

generated on Wed Sep 10 16:16:32 2025

[32]ព្រោះព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលលោកប្រកាស ប្រឆាំងនឹងអាសនានៅបេអែល និងប្រឆាំងនឹងកន្លែងទាំងឡាយនៅទីខ្ពស់នៅក្នុងក្រុងសាសន៍សាម៉ារី
នឹងកើតឡើងដូច្នោះមែន»។
[33]ក្រោយមកទៀតព្រះបាទយេរ៉ូបោមមិនបានបែរពីអំពើអាក្រក់ដែលស្តេចបានធ្វើឡើយ ប៉ុន្តែ
នៅតែបន្តតែងតាំងឲ្យមានបូជាចារ្យនៅតាមទីខ្ពស់ៗពីក្នុងចំណោមជនជាតិអ៊ីស្រាអែល។ បើអ្នកណាចង់បម្រើនោះស្តេចក៏តែងតាំងជាបូជាចារ្យភ្លាម។
[34]ការនេះក្លាយជាអំពើបាបនៅក្នុងគ្រួសារព្រះបាទយេរ៉ូបោម ហើយធ្វើឲ្យគ្រួសាររបស់លោកត្រូវវិនាស ហើយត្រូវបំបាត់ចោលពីផែនដី។

---

1 Kings 13:1

មានអ្នកបម្រើរបស់ព្រះអម្ចាស់មកពីយូដានាំព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅបេតអែល

ព័ត៌មានដែលបញ្ជាក់គឺថា ព្រះអម្ចាស់បានចាត់មនុស្សរបស់ព្រះឲ្យទៅបេតអែល។
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្មថា។ ការបកប្រែផ្សេងទៀត «
ព្រះអម្ចាស់បានចាត់អ្នកជំនិតម្នាក់របស់ព្រះពីស្រុកយូដាមកបេតអែល»

មានអ្នកបម្រើរបស់ព្រះអម្ចាស់

នេះគឺជាងារមួយទៀតសម្រាប់ព្យាការី។ ការបកប្រែផ្សេងទៀត «ហោរា»

មកពីយូដា

«មកពីស្រុកយូដា»

ព្រះបន្ទូលរបស់ព្រះអម្ចាស់

ត្រង់នេះពាក្យថា តំណាងឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រះបន្ទូលរបស់ព្រះអម្ចាស់»

លោកបានប្រកាសប្រឆាំងនឹងសាសនា

ត្រង់នេះ «គាត់» សំដៅទៅលើអ្នកជំនិតរបស់ព្រះ។

បានប្រកាសប្រឆាំងនឹងសាសនា

នេះមានន័យថា គាត់បានថ្លែងទំនាយទៅរកអាសនៈដោយសំឡេងខ្លាំងៗ
និងថ្កោលទោស។ ការបកប្រែផ្សេងទៀង
«បានថ្លែងទំនាយដោយសម្លេងលឺៗទៅកាន់អាសនា»

អាសនាអើយ អាសនាអើយ!

ព្យាការីបាននិយាយទៅកាន់អាសនៈដូចជាមនុស្សដែលអាចស្តាប់បាន។
គាត់បាននិយាយពីរដងសម្រាប់ការសង្កត់ធ្ងន់។

កូនប្រុសមួយនាមថាស្តេចយ៉ូសៀសនឹងកើតក្នុងគ្រួសាររបស់ស្តេចដាវីឌ

នៅទីនេះ «គ្រួសារស្តេចដាវីឌ» សំដៅទៅលើកូនចៅរបស់ស្តេចដាវីឌ។
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«កូនចៅរបស់ស្តេចដាវីឌនឹងមានកូនប្រុសម្នាក់ឈ្មោះយ៉ូសៀស

មនុស្សមកដុត

នៅទីនេះ «ពួកគេ» សំដៅទៅលើយ៉ូសៀសនិងប្រជាជនដែលនៅជាមួយគាត់។

អាសនានេះនឹងខ្ទេចខ្ទីអស់ ហើយផេះនៅលើអាសនានេះនឹងត្រូវខ្ចាត់ខ្ចាយអស់ដែរ

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ព្រះអម្ចាស់នឹងបំបែកអាសនៈដាច់ពីគ្នាហើយផេះនៅលើអាសនៈនោះនឹងរលំទៅលើដី»។

1 Kings 13:4

ដៃដែលបានចង្អុលប្រឆាំងនឹងអ្នកបម្រើរបស់ព្រះអម្ចាស់បានស្ងួត

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានធ្វើឲ្យដៃដែលគាត់បានទាស់នឹងបុរសនោះស្ងួត»

ស្ងួត

«ក្រៀមស្វិត» ឬ «ក្លាយជាខ្វិន»

អាសនាក៏បានបាក់បែក

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ក៏បំបែកអាសនៈដាច់ដោយឡែកពីគ្នាដែរ»

ស្របតាមអ្វីដែលអ្នកបម្រើរបស់ព្រះអម្ចាស់បានរៀបរាប់ពីព្រះបន្ទូលរបស់ព្រះអម្ចាស់មែន

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ដូចជាអ្នកជំនិតរបស់ព្រះបានពិពណ៌នាតាមរយៈព្រះបន្ទូលរបស់ព្រះអម្ចាស់ថាជាទីសម្គាល់មួយ»។

ព្រះបន្ទូលរបស់ព្រះអម្ចាស់

ត្រង់នេះពាក្យ តំណាងឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«សាររបស់ព្រះអម្ចាស់»

1 Kings 13:6

សូមលោកជួយទូលសុំការប្រណីសណ្តោសពីព្រះអម្ចាស់ជាព្រះរបស់លោក

នាមអរូបី «ប្រណីសណ្តោស» នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
ការបកប្រែផ្សេងទៀត
«សូមអង្វរព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យប្រណីសណ្តោសដល់ខ្ញុំផង»

ដើម្បីឲ្យដៃរបស់ខ្ញុំត្រឡប់ដូចធម្មតាវិញ

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ «ព្រះអម្ចាស់នឹងស្តារដៃខ្ញុំឡើងវិញ»

ដៃរបស់ស្តេចបានត្រឡប់ដូចធម្មតាវិញ គឺបានដូចពីមុន

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។
«ព្រះអម្ចាស់បានធ្វើឲ្យព្រះហស្តស្តេចជាឡើងវិញ ហើយធ្វើឲ្យដូចដើមវិញ»

សូមអញ្ជើញមកក្នុងដំណាក់របស់យើង ដើម្បីសម្រាក

ពាក្យថា «ខ្លួនអ្នក» គឺជាសព្វនាមឆ្លុះបញ្ចាំង។

«ត្រលប់មកផ្ទះជាមួយខ្ញុំហើយញ៉ាំអាហារ»

1 Kings 13:8

ទ្រព្យរបស់ព្រះអង្គពាក់កណ្តាល

«ពាក់កណ្តាលនៃផ្ទះរបស់អ្នក»

អ្នកមិនត្រូវបរិភោគនំប៉័ង ឬផឹកទឹក ហើយកុំឲ្យត្រឡប់មកតាមផ្លូវដដែលឡើយ

«កុំបរិភោគនំប៉័ងផឹកទឹកឬកុំត្រឡប់មកតាមផ្លូវដែលអ្នកមក»

ទៅតាមផ្លូវមួយផ្សេងទៀត

«ទៅផ្លូវផ្សេង»

1 Kings 13:11

កូនប្រុសៗរបស់គាត់បានដឹងពីផ្លូវ

ព័ត៌មានបង្កប់ន័យថា
កូនប្រុសទាំងពីរនាក់បានប្រាប់ឪពុករបស់ពួកគេថាតើអ្នកជំនិតរបស់ព្រះជាម្ចាស់បានទៅទីណា។

សូមចង

នេះមានន័យថា ដាក់កៅអីនៅខាងក្រោយសត្វដូច្នេះមនុស្សម្នាក់អាចជិះលើវាបាន។

1 Kings 13:14

លោកព្យាការីចាស់

នេះសំដៅទៅលើព្យាការីដែលរស់នៅបេតអែល។

លោកបាននិយាយទៅគាត់ថា

«ព្យាការីចាស់បាននិយាយទៅកាន់អ្នកជំនិតរបស់ព្រះជាម្ចាស់»

គាត់បានឆ្លើយថា

«អ្នកជំនិតរបស់ព្រះជាម្ចាស់បានឆ្លើយ»

ទៅជាមួយអ្នក

«ចូលទៅក្នុងផ្ទះរបស់អ្នក»

នៅកន្លែងនេះ

«នៅបេតអែល»

ព្រះអម្ចាស់បានហាមខ្ញុំដោយមានបន្ទូលថា

នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានបញ្ជាខ្ញុំតាមព្រះបន្ទូលរបស់ព្រះអង្គ» ។

ដោយមានបន្ទូលថា

នេះគឺមានន័យថា ព្រះអម្ចាស់មានព្រះបន្ទូល។ ត្រង់នេះពាក្យថា
តំណាងឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់។ សូមមើលការបកប្រែនៅក្នុងជំពូក ៦:១១។
ការបកប្រែផ្សេងទៀត «តាមសាររបស់ព្រះអម្ចាស់»

1 Kings 13:18

ទេវតាមួយរូបបាននាំព្រះបន្ទូលរបស់ព្រះអម្ចាស់មកប្រាប់ខ្ញុំថា

«មានទេវតាមួយនាំសារពីព្រះអង្គម្ចាស់មកកាន់ខ្ញុំ»។

ព្រះបន្ទូលរបស់ព្រះអម្ចាស់

នេះគឺមានន័យថា ព្រះអម្ចាស់មានព្រះបន្ទូល។ ត្រង់នេះពាក្យថា
តំណាងឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់។ បកប្រែឃ្លានេះដូចនៅក្នុងជំពូក ១៣:១៤ ។
ការបកប្រែផ្សេងទៀត «តាមសាររបស់ព្រះអម្ចាស់»

1 Kings 13:20

នៅពេលដែលពួកគេកំពុងអង្គុយនៅតុ

ព័ត៌មានបង្កប់ន័យថា ពួកគេនៅតែបរិភោគនៅតុ។ ការបកប្រែផ្សេងទៀត
«នៅពេលដែលពួកគេកំពុងញ៉ាំនិងផឹកស៊ីនៅតុ»

ព្រះជាម្ចាស់មានបន្ទូល

នេះគឺមានន័យថា ព្រះអម្ចាស់មានព្រះបន្ទូល។ ត្រង់នេះពាក្យថា
តំណាងឲ្យបន្ទូលរបស់ព្រះអម្ចាស់។ បកប្រែឃ្លានេះដូចនៅក្នុងជំពូក ១៣:១៤ ។
ការបកប្រែផ្សេងទៀត «បន្ទូលរបស់ព្រះអម្ចាស់បានមកដល់» ឬ

generated on Wed Sep 10 16:16:32 2025

«ព្រះអម្ចាស់បានមានបន្ទូល»
នាំលោកមកវិញ
ត្រង់នេះពាក្យ «គាត់» សំដៅលើអ្នកជំនិតរបស់ព្រះជាម្ចាស់។
គាត់បានយំដាក់អ្នកបម្រើរបស់ព្រះអម្ចាស់
«គាត់បាននិយាយលឺៗ ដល់អ្នកជំនិតរបស់ព្រះ»
ដោយសារតែអ្នកមិនស្តាប់បង្គាប់ពាក្យរបស់ព្រះអម្ចាស់
«ពីព្រោះអ្នកមិនបានស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់»
1 Kings 13:23
លោកព្យាការីបានចងកែបលា
នេះមានន័យថា
គាត់ដាក់កៅអីនៅលើខ្នងសត្វលាដូច្នេះអ្នកជំនិតរបស់ព្រះជាម្ចាស់អាចជិះលើវាបាន។
សូមមើលការបកប្រែនៅក្នុងជំពូក ១៣:១១។
សពរបស់លោកបាននៅតាមផ្លូវនោះ
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ហើយទុកសាកសពរបស់គាត់នៅលើផ្លូវ»
សព
«សាកសព»
ពួកគេក៏បានមកប្រាប់
នៅទីនេះ «វា» សំដៅទៅលើអ្វីដែលពួកគេបានឃើញនៅតាមផ្លូវ។
ការបកប្រែផ្សេងទៀត «ពួកគេបានមកហើយប្រាប់អំពីអ្វីដែលពួកគេបានឃើញ»
1 Kings 13:26
សព
«សាកសព»
នៅក្បែរផ្លូវ
«ដេកនៅលើផ្លូវ»
1 Kings 13:29
បានលើក
«លើក»
សព
សាកសព
ពួកគេក៏កាន់ទុក្ខ
ត្រង់នេះពាក្យថា «ពួកគេ» សំដៅទៅលើព្យាការីនិងកូនប្រុសរបស់គាត់។
បួនអើយ ម្តេចក៏វេទនាម្ល៉េះ!
ពាក្យថា «វរ» នៅទីនេះគឺជាការបង្ហាញពីភាពសោកសៅយ៉ាងខ្លាំង។
1 Kings 13:31
លោកបានកប់គាត់រួចហើយ
នៅទីនេះពាក្យ «គាត់» សំដៅទៅលើព្យាការីចាស់ហើយពាក្យថា «គាត់»
សំដៅទៅលើអ្នកជំនិតរបស់ព្រះជាម្ចាស់។
សូមដាក់ឆ្អឹងពុកនៅក្បែរឆ្អឹងរបស់គាត់
នៅទីនេះ «ឆ្អឹងរបស់ខ្ញុំ» តំណាឲ្យរាងកាយទាំងមូលរបស់គាត់។
ការបកប្រែផ្សេងទៀត «ដាក់សាកសពខ្ញុំនៅក្បែរឆ្អឹងរបស់គាត់»
កន្លែងទាំងឡាយនៅទីខ្ពស់
ព័ត៌មានបង្កប់ន័យថា ទាំងនេះជាកន្លែងគោរពបូជា។ ការបកប្រែផ្សេងទៀត
«ផ្ទះគោរពបូជានៅលើទីខ្ពស់»
1 Kings 13:33
ការនេះក្លាយជាអំពើបាបនៅក្នុងគ្រួសារព្រះបាទយេរ៉ូបោម
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«គ្រួសាររបស់ស្តេចយេរ៉ូបោមបានធ្វើបាបដោយការធ្វើរឿងនេះ»
ការនេះ
ឃ្លានេះសំដៅទៅលើការរៀបចំទីសក្ការៈបូជារបស់ស្តេចយេរ៉ូបោមនិងការតែងតាំងព្យាការី។
ធ្វើឲ្យគ្រួសាររបស់លោកត្រូវវិនាស ហើយត្រូវបំបាត់ចោល
នេះអាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដោយសារព្រះជាម្ចាស់បានបំផ្លាញ និង បំផ្លាញក្រុមគ្រួសាររបស់ស្តេចយេរ៉ូបោម»
ត្រូវវិនាស ហើយត្រូវបំបាត់ចោល
នេះមានន័យស្ទើរតែដូចគ្នា។ ការបកប្រែផ្សេងទៀត «នឹងត្រូវបំផ្លាញទាំងស្រុង»

---

14 [1]នៅពេលនោះព្រះបាទអប៊ីយ៉ាជាបុត្ររបស់ព្រះបាទយេរ៉ូបោមឈឺធ្ងន់។[2]ព្រះបាទយេរ៉ូបោមមានរាជឱង្ការទៅមហេសីថា៖ «ចូរក្រោកឡើង ហើយក្លែងខ្លួន ដូច្នេះ
គ្មាននរណាម្នាក់ចំណាំអូនជាមហេសីបងបានទេ ហើយចូរទៅស៊ីឡូ ព្រោះលោកបូជាចារ្យអហ៊ីយ៉ានៅទីនោះ គាត់ជាម្នាក់ដែលធ្លាប់និយាយពីបង
ធ្លាប់និយាយថាបងនឹងក្លាយជាស្តេចលើប្រជាជនទាំងនេះ។[3]ចូរយកនំប៉័ងដប់ដុំ និងនំខ្ទះ ព្រមទាំងទឹកឃ្មុំមួយដបទៅជាមួយផង ហើយត្រូវទៅជួបលោក លោកអហ៊ីយ៉ា។
លោកមុខជាប្រាប់ឲ្យអូនបានដឹងថានឹងមានអ្វីកើតឡើងចំពោះកូននេះ»។
[4]មហេសីរបស់ព្រះបាទយេរ៉ូបោមបានធ្វើតាម នាងបានធ្វើដំណើរទៅស៊ីឡូ ហើយបានទៅផ្ទះរបស់លោកអហ៊ីយ៉ា។ ឥឡូវនេះ លោកអហ៊ីយ៉ាមិនអាចមើលឃើញទេ
លោកមិនអាចមើលឃើញដោយសារលោកមានវ័យចាស់ហើយ។[5]ព្រះអម្ចាស់មានបន្ទូលមកកាន់លោកអហ៊ីយ៉ាថា៖ «មើល
មហេសីរបស់ស្តេចយេរ៉ូបោមបានមកសុំយោបល់ពីអ្នកទាក់ទងនឹងកូនរបស់នាង ព្រោះកូននោះឈឺ។ សូមប្រាប់នាងនូវអ្វីដែលយើងប្រាប់អ្នក ព្រោះនៅពេលដែលនាងមក
នាងនឹងធ្វើដូចជានាងជាស្ត្រីម្នាក់ធម្មតា»។
[6]នៅពេលដែលលោកអហ៊ីយ៉ាបានឮសម្លេងជើងរបស់នាងនៅពេលដែលនាងចូលមកដល់ទ្វារ លោកនិយាយថា៖ «សូមអញ្ជើញចូល
មហេសីរបស់ព្រះបាទយេរ៉ូបោមអើយ។ ហេតុអ្វីបានជានាងបន្លំខ្លួនធ្វើជាអ្នកផ្សេងដូច្នេះ? ខ្ញុំនឹងនាំដំណឹងអាក្រក់មកដល់នាង។
[7]សូមទៅប្រាប់ព្រះបាទយេរ៉ូបោមថាព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលមានបន្ទូលថា៖ «យើងបានលើកអ្នកពីក្នុងចំណោមមនុស្ស
ដើម្បីឲ្យអ្នកធ្វើជាអ្នកគ្រប់គ្រងលើប្រជារាស្ត្រអ៊ីស្រាអែលរបស់យើង។[8]យើងបានហែករាជ្យពីគ្រួសាររបស់ស្តេចដាវីឌ ហើយបានប្រគល់ឲ្យអ្នក
តែអ្នកមិនដូចស្តេចដាវីឌជាអ្នកបម្រើរបស់យើងទេ ស្តេចដាវីឌបានរក្សាបញ្ញត្តរបស់យើង និងដើរតាមយើងអស់ពីចិត្ត ទៅធ្វើអ្វីដែលត្រឹមត្រូវក្នុងភ្នែកយើង។
[9]ផ្ទុយទៅវិញ អ្នកបានប្រព្រឹត្តអាក្រក់ គឺអាក្រក់ជាងអស់អ្នកដែលនៅមុនអ្នកទៅទៀត។ អ្នកបានសូនធ្វើព្រះដទៃ ហើយអ្នកបានសូនរូបពីលោហៈ ដើម្បីឲ្យយើងមានកំហឹង
ហើយបានបែរខ្នងដាក់យើង។[10]ដូច្នេះ មើល យើងនឹងនាំគ្រោះមហន្តរាយមកលើគ្រួសាររបស់អ្នក យើងនិងកាត់អ្នកចេញពីប្រុសៗកូនចៅអ៊ីស្រាអែល ទោះពីជាអ្នកជា
ឬអ្នកងារក្តី ហើយអ្នកនឹងត្រូវដាច់ចេញពីគ្រួសាររបស់អ្នក ប្រៀបដូចនរណាម្នាក់ដុតសំរាមរហូតទាល់តែឆេះខ្ទេចអស់ដែរ។
[11]អស់អ្នកនៅក្នុងគ្រួសាររបស់អ្នក ដែលស្លាប់នៅទីក្រុងនឹងត្រូវឆ្កែស៊ី ហើយអស់អ្នកដែលស្លាប់នៅវាលស្រែនឹងត្រូវសត្វស្លាបចឹកស៊ី យើងជាព្រះអម្ចាស់ជាអ្នកនិយាយ»។
[12]ដូច្នេះ មហេសីស្តេចយេរ៉ូបោមអើយ ត្រឡប់ទៅផ្ទះរបស់អ្នកវិញចុះ នៅពេលដែលជើងរបស់នាងជាន់ក្រុងភ្លាម កូននាងអប៊ីយ៉ានឹងត្រូវស្លាប់។
[13]គ្រប់ជនជាតិអ៊ីស្រាអែលនឹងកាន់ទុក្ខសម្រាប់កូននោះ ហើយគេនឹងបញ្ចុះសពកូននោះ។ កូននោះជាមនុស្សតែម្នាក់គត់ពីគ្រួសាររបស់ព្រះបាទយេរ៉ូបោម
ដែលត្រូវបានកប់ក្នុងផ្នូរ ព្រោះមានតែនៅក្នុងកូននោះប៉ុណ្ណោះពីចំណោមគ្រួសាររបស់យេរ៉ូបោម ដែលព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលរកឃើញការល្អខ្លះ។
[14]ព្រះអម្ចាស់នឹងលើកស្តេចមួយអង្គទៀតនៅក្នុងស្រុកអ៊ីស្រាអែលដែលនឹងបំផ្លាញគ្រួសាររបស់យេរ៉ូបោមនៅថ្ងៃនោះ។ ថ្ងៃនោះគឺឥឡូវនេះ។[15]ព្រះអម្ចាស់នឹងវាយ
ប្រហារជនជាតិអ៊ីស្រាអែល ពេលនោះ ពួកគេប្រៀបដូចជាដើមត្រែងដែលញ័រនៅក្នុងទឹក ហើយព្រះអង្គនឹងដកអ៊ីស្រាអែលចេញពីទឹកដីដ៏ល្អ
ដែលព្រះអង្គបានប្រទានដល់ដូនតារបស់ពួកគេ។ ព្រះអង្គនឹងកម្ចាត់កម្ចាយពួកគេឲ្យទៅនៅខាងនាយទន្លេអឺប្រាត ព្រោះពួកគេធ្វើបង្គោលព្រះអាសេរ៉ា ដែលបណ្តាលឲ្យ
ព្រះអម្ចាស់ទ្រង់ព្រះពិរោធ។[16]ព្រះអង្គនឹងបោះបង់អ៊ីស្រាអែលចោល ដោយសារអំពើបាបរបស់ព្រះបាទយេរ៉ូបោម គឺអំពើបាបដែលស្តេចបានប្រព្រឹត្ត
និងតាមរយៈការដឹកនាំរបស់ស្តេច ដែលនាំឲ្យអ៊ីស្រាអែលប្រព្រឹត្តអំពើបាប»។
[17]ដូច្នេះ មហេសីរបស់ព្រះបាទយេរ៉ូបោមបានចេញទៅ ហើយបានមកដល់ក្រុងធើសា។ នៅពេលដែលនាងបានមកដល់មាត់ទ្វារក្រុង កូនរបស់នាងក៏បានស្លាប់។
[18]ប្រជាជនអ៊ីស្រាអែលទាំងអស់បានកប់កូននោះ និងកាន់ទុក្ខកូននោះ ស្របតាមអ្វីដែលព្រះអម្ចាស់មានបន្ទូលតាមរយៈលោកហោរាអហ៊ីយ៉ាជាអ្នកបម្រើរបស់ព្រះអង្គ។
[19]មានរឿងមួយទៀតទាក់ទឹងនឹងស្តេចយេរ៉ូបោម គឺរបៀបដែលស្តេចធ្វើសង្គ្រាម និងរបៀបដែលស្តេចសោយរាជ្យ
រឿងទាំងនោះបានសរសេរនៅក្នុងសៀវភៅព្រឹត្តិការណ៍ស្តេចអ៊ីស្រាអែល។[20]ព្រះបាទយេរ៉ូបោមបានសោយរាជ្យអស់ម្ភៃពីរឆ្នាំ ហើយបន្ទាប់មក
ស្តេចបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ស្តេច ហើយបុត្ររបស់ស្តេច គឺព្រះបាទណាដាប់បានសោយរាជ្យបន្តពីព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[21]ឥឡូវនេះ ព្រះបាទរេហូបោមជាបុត្ររបស់ព្រះបាទសាឡូម៉ូនបានសោយរាជ្យនៅស្រុកយូដា។ ព្រះបាទរេហូបោមមានព្រះជន្មសែសិបវស្សានៅពេលស្តេចឡើងសោយរាជ្យ
ហើយស្តេចសោយរាជ្យបានដប់ប្រាំពីរឆ្នាំនៅក្រុងយេរូសាឡឹម ជាក្រុងដែលព្រះអម្ចាស់បានជ្រើសរើសចេញពីកុលសម្ព័ន្ធនៃជនជាតិអ៊ីស្រាអែល
ដើម្បីដាក់ព្រះនាមព្រះអង្គ។ មាតារបស់ស្តេចគឺនាងណាអាម៉ា ជាជនជាតិអាំម៉ូន។[22]អ្នកក្រុងយូដាបានប្រព្រឹត្តអំពើអាក្រក់នៅក្នុងព្រះនេត្រព្រះអម្ចាស់
ពួកគេបានធ្វើឲ្យព្រះអង្គប្រច័ណ្ឌជាមួយអំពើបាបដែលពួកគេបានប្រព្រឹត្ត លើសជាងអ្វីៗដែលដូនតារបស់ពួកគេបានប្រព្រឹត្តទៅទៀត។
[23]ពួកគេក៏បានសង់កន្លែងខ្ពស់ៗសម្រាប់ខ្លួនពួកគេ មានទាំងស្តូប និងបង្គោលព្រះអាសេរ៉ា នៅតាមភ្នំខ្ពស់ៗ និងនៅក្រោមដើមឈើពណ៌បៃតង។
[24]នៅលើទឹកដីអ៊ីស្រាអែលក៏មានអំពើពេស្យាចារបែបសាសនាដែរ។
ពួកគេបានប្រព្រឹត្តអំពើគួរឲ្យស្អប់ខ្ពើមដូចជាតិសាសន៍នានាដែលព្រះអម្ចាស់បានបណ្តេញចេញពីមុខប្រជាជនអ៊ីស្រាអែលដែរ។
[25]វាកើតឡើងនៅក្នុងឆ្នាំទីប្រាំក្នុងរាជ្យរបស់ព្រះបាទរេហូបោម នៅពេលដែលព្រះចៅស៊ីសាក់ជាស្តេចស្រុកអេស៊ីបវាយក្រុងយេរូសាឡឹម។
[26]ស្តេចបានយកទ្រព្យនៅក្នុងដំណាក់របស់ព្រះអម្ចាស់ និងទ្រព្យរបស់ស្តេចទៅទាំងអស់។ ស្តេចបានយកអ្វីៗទៅទាំងអស់
ស្តេចក៏បានយកខែលមាសដែលព្រះបាទសាឡូម៉ូនបានធ្វើទៅដែរ។
ហើយបានយកនាងទៅបន្ទប់ខាងលើដែលលោកស្នាក់នៅ ហើយលោកបានដាក់កូននោះនៅលើគ្រែរបស់លោក។[20]លោកបានស្រែករកព្រះអម្ចាស់ដោយទូលថា៖
«ព្រះអម្ចាស់ជាព្រះរបស់ទូលបង្គំអើយ តើព្រះអង្គនាំមហន្តរាយមកលើស្ត្រីដែលទូលបង្គំស្នាក់នៅជាមួយនេះដោយសម្លាប់កូនរបស់នាងបែបនេះឬ»?
[21]បន្ទាប់មកលោកក៏ទ្រោមពីលើកូននោះបីដង លោកបានស្រែករកព្រះអម្ចាស់ថា៖ «ព្រះអម្ចាស់ជាព្រះរបស់ទូលបង្គំអើយ ទូលបង្គំសូមអង្វរព្រះអង្គ
សូមឲ្យជីវិតរបស់ក្មេងនេះត្រឡប់មកគាត់វិញផង»។
[22]ព្រះអម្ចាស់បានស្តាប់ឮសម្លេងរបស់លោកអេលីយ៉ា ជីវិតរបស់ក្មេងនោះបានត្រឡប់មកក្មេងនោះវិញ ហើយគាត់ក៏រស់ឡើងវិញ។
[23]លោកអេលីយ៉ាបានយកក្មេងនោះចេញពីបន្ទប់របស់គាត់មកក្រោមផ្ទះ លោកបានប្រគល់ក្មេងនោះឲ្យម្តាយរបស់ក្មេងនោះវិញ ដោយមានប្រសាសន៍ថា៖ «ឃើញទេ
កូនរបស់អ្នកនៅរស់ទេ»។[24]ស្ត្រីនោះបាននិយាយជាមួយលោកអេលីយ៉ាថា៖ «ឥឡូវនេះ ខ្ញុំដឹងហើយថា លោកជាអ្នកជំនិតរបស់ព្រះអម្ចាស់
ហើយដឹងថាព្រះបន្ទូលនៅក្នុងមាត់របស់លោកពិតជាត្រឹមត្រូវមែន»។

---

1 Kings 17:1
ភូមិធេសប៊ី
នេះជាឈ្មោះក្រុមមនុស្សមកពីភូមិធេសប៊ី។
ធេសប៊ី
នេះជាឈ្មោះទីក្រុងមួយក្នុងតំបន់កាឡាត។
ដោយសារព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលមានព្រះជន្មគង់នៅ
ឃ្លានេះគឺជាសម្បថមួយបញ្ជាក់ថា អ្វីៗដែលគាត់នឹងនិយាយជាការពិត។
ជាព្រះដែលទូលបង្គំបម្រើ
មានន័យថា «បម្រើ»។ ការបកប្រែផ្សេងទៀត «អ្នកដែលខ្ញុំបម្រើ»
សន្សើម
ដំណក់ទឹកដែលបង្កើតនៅលើរុក្ខជាតិនាពេលយប់។
1 Kings 17:2
ព្រះបន្ទូលរបស់ព្រះអម្ចាស់មកដល់
មានន័យថា ព្រះជាម្ចាស់មានបន្ទូល។ សូមមើលការបកប្រែនៅក្នុងជំពូក ៦:១១ ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់មានព្រះបន្ទូលមកគាត់។»
កេរីត
នេះជាឈ្មោះចន្លោះទឹកដ៏តូចមួយ។
វានឹងកើតឡើង
ឃ្លានេះត្រូវបានប្រើដើម្បីណែនាំពីរបៀប ដែលព្រះអម្ចាស់នឹងថែរក្សាអេលីយ៉ា
ពេលមានគ្រោះរាំងស្ងួត។ ការបកប្រែផ្សេងទៀត «នៅទីនោះ»
ក្អែក
បក្សីខ្មៅធំមួយ
1 Kings 17:5
តាមព្រះបន្ទូលរបស់ព្រះអម្ចាស់បានបង្គាប់
ត្រង់នេះ «ព្រះបន្ទូល» តំណាងឲ្យព្រះអម្ចាស់ផ្ទាល់។ ការបកប្រែផ្សេងទៀត
«ដូចដែលព្រះអម្ចាស់បានបញ្ជា»
ជ្រោះកេរីត
នេះជាឈ្មោះចន្លោះទឹកតូចមួយ។ បកប្រែដូចនៅក្នុង ១៧:២។
នៅក្នុងតំបន់នោះ
«នៅក្នុងតំបន់នោះ» ឬ «នៅក្នុងប្រទេសនោះ»

generated on Wed Sep 10 16:16:32 2025

1 Kings 17:8
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក
មានន័យថា ព្រះជាម្ចាស់មានបន្ទូល។ សូមមើលការបកប្រែនៅក្នុង ៦:១១។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់មានព្រះបន្ទូលមកគាត់»
មកដល់លោក
ត្រង់នេះពាក្យ «លោក» សំដៅទៅលើលោកអេលីយ៉ា។
សារិបតា
នេះជាទីក្រុង។
មើល
ពាក្យ «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
1 Kings 17:11
ក្នុងព្រះនាមព្រះអម្ចាស់ដែលមានព្រះជន្មរស់
ឃ្លានេះជាសម្បថដើម្បីបញ្ជាក់ថា អ្វីៗដែលនាងនឹងនិយាយជាការពិត។
មានតែអាហារបន្តិច
«មានតែអាហារបន្តិចបន្តួចប៉ុណ្ណោះ»
អាហារ
«ម្សៅ»។ នេះជាអ្វីដែលត្រូវបានប្រើធ្វើនំប៉័ង។
ឃើញទេ
ពាក្យ «ឃើញ» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
អុស
អាចសំដៅទៅលើអុសពីរ ឬ មានតែអុសពីរបីប៉ុណ្ណោះ។
ហើយយើងនឹងបរិភោគរួចយើងនឹងស្លាប់
បញ្ជាក់ថា ពួកគេនឹងស្លាប់ព្រោះពួកគេមិនមានអាហារទៀត។ ការបកប្រែផ្សេងទៀត
«ធ្វើឲ្យយើងបានបរិភោគ។ បន្ទាប់មកយើងនឹងឃ្លានរហូតដល់ស្លាប់»
បន្ទាប់មក សឹមធ្វើសម្រាប់ខ្លួននាង និងកូនរបស់នាងចុះ
ច្បាស់ណាស់ថា នឹងមានម្សៅនិងប្រេងគ្រប់គ្រាន់ធ្វើនំប៉័ងបន្ថែមទៀត។
1 Kings 17:14
ព្រះអម្ចាស់ប្រទានទឹកភ្លៀង
ជាពាក្យមានន័យថា ព្រះអម្ចាស់ធ្វើឲ្យមានទឹកភ្លៀង។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់ធ្វើឲ្យទឹកភ្លៀងធ្លាក់ចុះមក»
នាង និងលោកអេលីយ៉ា ព្រមទាំងអ្នកដែលនៅក្នុងផ្ទះនាងបានបរិភោគបានយ៉ាងច្រើនថ្ងៃ
នៅក្នុងភាសាដើមនិយាយថា
«ហើយនាងនិងគាត់និងគ្រួសាររបស់នាងបានបរិភោគអស់រយៈពេលជាច្រើនថ្ងៃ" ។
គេមិនទាន់ដឹងច្បាស់ថា «គាត់» ជានរណាទេ។ អាចមានន័យថា ១)
លោកអេលីយ៉ា
ស្ត្រីមេម៉ាយនិងកូនប្រុសរបស់នាងបានបរិភោគអស់រយៈពេលជាច្រើនថ្ងៃ ឬ ២)
ស្ត្រីមេម៉ាយ កូនប្រុសរបស់នាង និងមនុស្សគ្រប់គ្នាដែលរស់នៅក្នុងផ្ទះរបស់នាង
បានបរិភោគអស់រយៈពេលជាច្រើនថ្ងៃ ឬ៣) លោកអេលីយ៉ា ស្ត្រីមេម៉ាយ និង
អ្នករាល់គ្នាដែលរស់នៅក្នុងផ្ទះរបស់នាង។ បរិភោគអស់រយៈពេលជាច្រើនថ្ងៃ។
ព្រមទាំងអ្នកដែលនៅក្នុងផ្ទះនាង
ពាក្យ «នៅក្នុងផ្ទះ» អាចមានន័យថា ១) សំដៅទៅលើកូនប្រុសរបស់ស្ត្រីមេម៉ាយ ឬ
២) សំដៅទៅលើមនុស្សផ្សេងទៀត ដែលរស់នៅក្នុងផ្ទះ
តែមិនមានឈ្មោះក្នុងសាច់រឿងទេ ឬ ៣) សំដៅទៅលើកូនប្រុសរបស់នាង
និងអ្នកផ្សេងទៀតដែលរស់នៅក្នុងផ្ទះនាង។ ។
ដូចព្រះបន្ទូលដែលព្រះអម្ចាស់បានមានបន្ទូល
ត្រង់នេះពាក្យ «ព្រះបន្ទូល» តំណាងឲ្យព្រះអម្ចាស់ផ្ទាល់។ ការបកប្រែផ្សេងទៀត
«ដូចអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល»
1 Kings 17:17
កូនរបស់ស្ត្រីនោះ..ស្ត្រីដែលជាម្ចាស់ផ្ទះ
«កូនប្រុសរបស់ស្ត្រីដែលជាម្ចាស់ផ្ទះ»
ធ្វើឲ្យកូននោះផុតដង្ហើម
នេះជាវិធីគួរសមក្នុងការនិយាយថា ក្មេងប្រុសនោះបានស្លាប់។
ការបកប្រែផ្សេងទៀត៖ «គាត់ឈប់ដកដង្ហើម» ឬ «គាត់បានស្លាប់»
អ្នកជំនិតរបស់ព្រះជាម្ចាស់អើយ?
ឃ្លាថា «អ្នកជំនិតរបស់ព្រះជាម្ចាស់» ជាងារមួយទៀតសម្រាប់ព្យាការី។
អំពើបាបរបស់នាងខ្ញុំ
មានន័យថា អំពើបាបជាទូទៅមិនមែនជាអំពើបាបជាក់លាក់ទេ។
ការបកប្រែផ្សេងទៀត «បាបរបស់ខ្ញុំ»
1 Kings 17:19
ដែលលោកស្នាក់នៅ
ត្រង់នេះ «លោក» សំដៅទៅលោកលើអេលីយ៉ា។
នៅលើគ្រែរបស់លោក
នៅទីនេះ «របស់លោក» សំដៅទៅលើលោកអេលីយ៉ា។
តើព្រះអង្គនាំមហន្តរាយមកលើស្ត្រីដែលទូលបង្គំស្នាក់នៅជាមួយនេះដោយសម្លាប់កូនរបស់នាងបែបនេះឬ?
អាចមានន័យថា ១) លោកអេលីយ៉ាពិតជាកំពុងសួរសំណួរមួយ។
ការបកប្រែផ្សេងទៀត « ហេតុអ្វីបានជាទ្រង់ធ្វើឲ្យស្ត្រីមេម៉ាយ
ដែលខ្ញុំកំពុងស្នាក់នៅជាមួយរងទុក្ខវេទនារឹតតែខ្លាំង
ដោយការសម្លាប់កូនប្រុសរបស់នាង» ឬ ២)
លោកអេលីយ៉ាប្រើសំណួរមួយដើម្បីបង្ហាញពីភាពសោកសៅរបស់លោក។
ការបកប្រែផ្សេងទៀត «ប្រាកដណាស់ទ្រង់នឹងមិនធ្វើឲ្យស្ត្រីមេម៉ាយ
ដែលខ្ញុំកំពុងស្នាក់នៅរងទុក្ខវេទនាថែមទៀត
ដោយសម្លាប់កូនប្រុសរបស់នាងនោះទេ»
តើព្រះអង្គនាំមហន្តរាយមកលើស្ត្រី
ការធ្វើឲ្យស្ត្រីមេម៉ាយរងទុក្ខវេទនា ត្រូវបានគេនិយាយដូចជា «គ្រោះមហន្តរាយ»
ជាវត្ថុដែលដាក់លើស្ត្រីមេម៉ាយ។
នាំមហន្តរាយមក
នៅទីនេះ «ផងដែរ» មានន័យថា
បន្ថែមលើគ្រោះមហន្តរាយដែលគ្រោះរាំងស្ងួតបានបង្កឡើង។
លោកក៏ទ្រោមពីលើ
«ដាក់នៅលើកូននោះ»
1 Kings 17:22
ព្រះអម្ចាស់បានស្តាប់ឮសម្លេងរបស់លោកអេលីយ៉ា
នៅទីនេះ «សំឡេង» តំណាងឲ្យអ្វីៗ ដែលលោកអេលីយ៉ាបានអធិស្ឋាន។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់លោកអេលីយ៉ា»
ជីវិតរបស់ក្មេងនោះបានត្រឡប់មកក្មេងនោះវិញ ហើយគាត់ក៏រស់ឡើងវិញ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ ការបកប្រែផ្សេងទៀត «ក្មេងបានរស់ឡើងវិញ»
ឬ «ក្មេងបានរស់ឡើងវិញ»
បន្ទប់របស់គាត់
នៅទីនេះ «របស់គាត់» សំដៅទៅលើលោកអេលីយ៉ា។
ឃើញទេ កូនរបស់អ្នកនៅរស់ទេ
ពាក្យ «ឃើញ» នៅទីនេះព្រមានយើងឲ្យយកចិត្តទុកដាក់លើ
ព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើង។
ព្រះបន្ទូលនៅក្នុងមាត់របស់លោកពិតជាត្រឹមត្រូវមែន
នៅទីនេះ «ព្រះបន្ទូល» តំណាងឲ្យសារមួយ។ ដូចគ្នានេះផងដែរ «មាត់»
តំណាងឲ្យអ្វី ដែលលោកអេលីយ៉ាបាននិយាយ។ ការបកប្រែផ្សេងទៀត
«សារដែលអ្នកបាននិយាយពីព្រះអម្ចាស់ជាសេចក្តីពិត»

---

18 [1]ដូច្នេះ ច្រើនថ្ងៃក្រោយមកទៀត ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកអេលីយ៉ា នៅក្នុងឆ្នាំទីបីនៃគ្រោះរាំងស្ងួតថា៖
«ទៅបង្ហាញខ្លួនឲ្យស្តេចអហាប់បានឃើញ ហើយយើងនឹងបញ្ជូនទឹកភ្លៀងមកលើផែនដី»។[2]លោកអេលីយ៉ាក៏ទៅបង្ហាញខ្លួនឲ្យស្តេចអហាប់ឃើញ ពេលនោះ មានកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្រុងសាម៉ារី។
[3]ព្រះបាទអហាប់បានហៅលោកអូបាឌា ដែលជាអ្នកមើលខុសត្រូវក្នុងវាំង។ លោកអូបាឌាគោរពព្រះអម្ចាស់ណាស់[4]ព្រោះនៅពេលដែលម្ចាស់ក្សត្រីយេសិបិល
សម្លាប់ព្យាការីរបស់ព្រះអម្ចាស់ លោកអូបាឌាបានយកព្យាការីមួយរយនាក់ទៅលាក់ក្នុងរូងភ្នំ មួយកន្លែងសាសិបនាក់ ហើយបានចិញ្ចឹមពួកគេដោយនំប៉័ង និងទឹក។
[5]ស្តេចអហាប់មានរាជឱង្ការទៅកាន់លោកអូបាឌាថា៖ «ចូរចេញទៅទឹកដីទាំងមូល ទៅកន្លែងដែលមានប្រភពទឹក និងជ្រោះ។ ប្រហែលជាយើងអាចរកស្មៅបាន
ហើយសង្គ្រោះសេះ និងលាឲ្យនៅមានជីវិត ដូច្នេះ យើងនឹងមិនបាត់បង់សត្វទាំងអស់ឡើយ»។[6]ដូច្នេះ ពួកគេបានចែកតំបន់គ្នាដើរមើល ហើយស្វែងរកទឹក។
ស្តេចអហាប់បានទៅផ្លូវមួយ ហើយលោកអូបាឌាទៅផ្លូវមួយទៀត។

generated on Wed Sep 10 16:16:32 2025

[7]នៅពេលដែលលោកអូបាឌានៅតាមផ្លូវ លោកអេលីយ៉ាបានជួបលោកដោយចៃដន្យ។ លោកអូបាឌាចំណាំលោកបាន ហើយបានក្រាបមុខដល់ដី។
លោកមានប្រសាសន៍ថា៖ «តើលោកអេលីយ៉ា ដែលជាម្ចាស់របស់ខ្ញុំមែនទេ?»[8]លោកអេលីយ៉ាក៏បានឆ្លើយទៅលោកថា៖ «គឺខ្ញុំមែន។
សូមទៅប្រាប់ចៅហ្វាយរបស់លោកថា៖ «មើល លោកអេលីយ៉ានៅទីនេះ»។
[9]លោកអូបាឌាក៏ឆ្លើយថា៖ «តើខ្ញុំបានប្រព្រឹត្តបាបអ្វី បានជាលោកចង់ប្រគល់អ្នកបម្រើរបស់លោកទៅក្នុងដៃរបស់ស្តេចអហាប់ ឲ្យស្តេចសម្លាប់ខ្ញុំដូច្នេះ?
[10]ដោយសារព្រះអម្ចាស់មានព្រះជន្មគង់នៅ ខ្ញុំសូមប្រាប់លោកថាគ្មានជាតិសាសន៍ណាមួយ
ឬអាណាចក្រណាដែលចៅហ្វាយរបស់ខ្ញុំមិនបានបញ្ជូនមនុស្សទៅស្វែងរកលោកនោះទេ។ នៅពេលដែលជាតិសាសន៍ ឬអាណាចក្រណាមួយនិយាយថា៖
«លោកអេលីយ៉ាមិននៅទីនេះទេ» នោះ ស្តេចអហាប់បានឲ្យគេស្បថថាពួកគេមិនអាចរកលោកឃើញទេ។[11]តែឥឡូវនេះ លោកបែរជានិយាយថា៖
«សូមទៅប្រាប់ចៅហ្វាយរបស់អ្នកថា លោកអេលីយ៉ានៅទីនេះទៅវិញ»។
[12]នៅពេលដែលខ្ញុំចេញទៅ តែព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានយកលោកនៅកន្លែងដែលខ្ញុំមិនដឹង។ បន្ទាប់មក ខ្ញុំទៅទូលស្តេចអហាប់ ហើយស្តេចរកអ្នកមិនឃើញ
នោះស្តេចមុខជាសម្លាប់ខ្ញុំមិនខាន។ ខ្ញុំជាអ្នកបម្រើលោក បានថ្វាយបង្គំព្រះអម្ចាស់តាំងពីខ្ញុំនៅក្មេងម្ល៉ះ។[13]តើគ្មាននរណាបានប្រាប់លោកទេ លោកម្ចាស់អើយ
ថាខ្ញុំបានធ្វើអ្វីនៅពេលដែលនាងយេសិបិលបានសំលាប់ព្យាការីទាំងឡាយរបស់ព្រះអម្ចាស់ គឺពីរបៀបដែលខ្ញុំបានលាក់ព្យាការីរបស់ព្រះអម្ចាស់មួយរយនាក់នៅក្នុងរូងភ្នំ
ក្នុងមួយកន្លែងហាសិបនាក់ និងបានចិញ្ចឹមពួកគេដោយនំបុ័ង និងទឹកទេឬ?
[14]ឥឡូវនេះ លោកបាននិយាយមកខ្ញុំថា៖ «ចូរទៅប្រាប់ចៅហ្វាយរបស់អ្នកថាលោកអេលីយ៉ានៅទីនេះ ដូច្នេះ លោកនឹងសម្លាប់ខ្ញុំមិនខាន»។
[15]បន្ទាប់មកលោកអេលីយ៉ាឆ្លើយតបថា៖ «ដោយសារព្រះអម្ចាស់មានព្រះជន្មគង់នៅ ដែលខ្ញុំឈរនៅមុខព្រះអង្គ ខ្ញុំសូមប្រាប់អ្នកថា
នៅថ្ងៃនោះខ្ញុំនឹងបង្ហាញខ្លួនឲ្យស្តេចអហាប់ឃើញ»។
[16]ដូច្នេះ លោកអូបាឌាបានទៅជួបស្តេចអហាប់ ហើយបានទូលស្តេចនូវអ្វីដែលលោកអេលីយ៉ាបាននិយាយ។ បន្ទាប់មក ស្តេចបានទៅជួបលោកអេលីយ៉ា។[17]បន្ទាប់មក
ស្តេចអហាប់បានជួបលោកអេលីយ៉ា ដោយទូលទៅលោកថា៖ «តើពិតជាលោកមែនឬ? តើលោកជាម្នាក់ដែលនាំបញ្ហាដល់អ៊ីស្រាអែលនោះមែនទេ!»។
[18]លោកអេលីយ៉ាឆ្លើយថា៖ «ទូលបង្គំមិនបាននាំបញ្ហាដល់អ៊ីស្រាអែលទេ ប៉ុន្តែគឺព្រះអង្គ
និងក្រុមគ្រួសាររបស់ព្រះអង្គវិញទេដែលនាំឲ្យមានបញ្ហាដោយសារតែបានបោះបង់ចោលបទបញ្ជារបស់ព្រះអម្ចាស់ និងដោយការដើរតាមព្រះបាល។[19]ឥឡូវនេះ ចូរនាំពាក្យ
ដើម្បីប្រមូលប្រជាជនទាំងអស់មកជួបជុំគ្នានៅលើភ្នំកើមែល មានព្យាការីរបស់ព្រះបាលទាំងបួនរយហាសិបនាក់ និងព្យាការីរបស់ព្រះអាសេរ៉ាទាំងបួនរយនាក់ ដែល
បរិភោគរួមតុជាមួយម្ចាស់ក្សត្រីយេសិបិល»។
[20]ដូច្នេះ ស្តេចអហាប់បានបញ្ជូនពាក្យទៅប្រជាជនអ៊ីស្រាអែល ហើយបានប្រមូលព្យាការីទាំងអស់មកជួបជុំគ្នានៅលើភ្នំកើមែល។
[21]លោកអេលីយ៉ាមកជិតប្រជាជនអ៊ីស្រាអែល និងនិយាយថា៖ «តើអ្នកត្រូវការពេលប៉ុន្មាន ដើម្បីផ្លាស់ប្តូរគំនិតរបស់អ្នក? បើព្រះអម្ចាស់ជាព្រះ ចូរដើរតាមទ្រង់ចុះ។ ប៉ុន្តែ
បើព្រះបាលជាព្រះវិញ ចូរដើរតាមព្រះបាលចុះ»។ ប៉ុន្តែ ប្រជាជនមិនបានឆ្លើយតបទៅលោកទេ។
[22]បន្ទាប់មក លោកអេលីយ៉ាបាននិយាយទៅប្រជាជនថា៖ «ចំណែកខ្ញុំ ខ្ញុំមានតែម្នាក់ឯង ដែលជាព្យាការីរបស់ព្រះអម្ចាស់ ប៉ុន្តែ ព្យាការីរបស់ព្រះបាលមាន ៤៥០នាក់។
[23]ដូច្នេះ ចូរយកគោបាពីរមក។ សូមឲ្យពួកគេជ្រើសរើសយកគោបាមួយសម្រាប់ខ្លួនពួកគេ ហើយចូរកាប់ជាចំរៀកៗ ហើយដាក់នៅលើឈើ ប៉ុន្តែ
មិនត្រូវដាក់ភ្លើងនៅខាងក្រោមទេ។ បន្ទាប់មក ខ្ញុំនឹងរៀបចំគោបាមួយទៀត និងដាក់លើឈើ និងមិនដាក់ភ្លើងនៅខាងក្រោមទេ។[24]បន្ទាប់មក
ចូរអ្នកប្រកាសហៅឈ្មោះព្រះរបស់អ្នកចុះ ហើយខ្ញុំនឹងអំពាវនាវរកព្រះនាមរបស់ព្រះអម្ចាស់ ហើយបើព្រះណាឆ្លើយតបដោយភ្លើង នោះព្រះអង្គជាព្រះមែន»។ ដូច្នេះ
មនុស្សទាំងអស់ឆ្លើយថា៖ «ល្អណាស់»។
[25]ដូច្នេះ លោកអេលីយ៉ានិយាយទៅព្យាការីរបស់ព្រះបាលថា៖ «ចូរជ្រើសរើសយកគោបាមួយសម្រាប់ខ្លួនអ្នក ហើយរៀបចំវាមុនចុះ ដោយសារអ្នកមានគ្នាច្រើន។ បន្ទាប់មក
ចូរប្រកាសហៅនាមព្រះរបស់អ្នក ប៉ុន្តែ មិនត្រូវដាក់ភ្លើងខាងក្រោមឡើយ»។[26]ពួកគេបានយកគោបាដែលលោកបានឲ្យពួកគេ ហើយរៀបចំគោនោះ
ហើយពួកគេបានស្រែករកនាមរបស់ព្រះបាលតាំងពីព្រលឹម ដល់ថ្ងៃត្រង់ ដោយនិយាយថា៖ «ព្រះបាលអើយ ចូរស្តាប់យើងផង»។ ប៉ុន្តែ
គ្មានសម្លេងក៏គ្មាននរណាម្នាក់ឆ្លើយដែរ។ ពួកគេបានរាំជុំវិញអាសនាដែលពួកគេបានធ្វើ។
[27]នៅថ្ងៃត្រង់លោកអេលីយ៉ាបានចំអកដាក់ពួកគេ ហើយនិយាយថា៖ «សូមស្រែកឲ្យឮៗទៅ! គាត់គឺជាព្រះ! ប្រហែលជាទ្រង់កំពុងគិត ឬកំពុងរំដោះខ្លួន
ឬទ្រង់កំពុងតែធ្វើដំណើរ ឬប្រហែលជាទ្រង់កំពុងតែដេកលក់ ហើយកំពុងក្រោកឡើង»។[28]ដូច្នេះ ពួកគេស្រែកកាន់តែឮឡើងៗ
ហើយពួកគេបានកាត់សាច់ខ្លួនឯងជាមួយដាវ និងលំពែង ដូចដែលពួកគេធ្លាប់ធ្វើ រហូតដល់ឈាមប្រលាក់ខ្លួនជោគ។[29]កន្លងអស់កន្លះថ្ងៃហើយ
ពួកគេនៅតែទាយរហូតដល់ម៉ោងថ្វាយយញ្ញបូជាពេលល្ងាច ប៉ុន្តែនៅតែគ្មានសម្លេងឬនរណាម្នាក់ឆ្លើយតបឡើយ
គ្មាននរណាម្នាក់ចាប់អារម្មណ៍នឹងការប្រកួកប្រកាសរបស់ពួកគេឡើយ។
[30]បន្ទាប់មក លោកអេលីយ៉ានិយាយទៅប្រជាជនទាំងអស់ថា៖ «ចូរមកជិតខ្ញុំ» ហើយពួកគេក៏ចូលមកជិតលោក។ បន្ទាប់មក
លោកក៏រៀបចំអាសនារបស់ព្រះអម្ចាស់ដែលបានខ្ទេចខ្ទីអស់ឡើងវិញ។[31]លោកអេលីយ៉ាបានយកថ្មដប់ពីរដុំ
ថ្មនីមួយៗតំណាងឲ្យកុលសម្ព័ន្ធមួយនៃកូនៗរបស់លោកយ៉ាកុប ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកយ៉ាកុបថា៖ «អ៊ីស្រាអែលនឹងជាឈ្មោះរបស់អ្នក»។
[32]ជាមួយថ្មដែលលោកបានសង់អាសនានៅក្នុងព្រះនាមរបស់ព្រះអម្ចាស់ ហើយលោកបានជីកស្នាមភ្លោះជុំវិញអាសនានោះធំល្មមដាក់គ្រាប់ស្រូវពីររង្វាល់។
[33]លោកក៏បានរៀបចំឈើសម្រាប់ដុត ក៏បានកាប់គោជាដុំៗ ហើយលោកបានដាក់ចំណែកគោទាំងនោះនៅលើឈើ។ លោកបានមានប្រសាសន៍ថា៖
«សូមយកទឹកបួនពាងមកចាក់លើតង្វាយដុត និងលើឈើ»។[34]បន្ទាប់មក លោកបានមានប្រសាសន៍ថា៖ «ចូរធ្វើបែបនោះម្តងទៀត» ហើយពួកគេបានចាក់ទឹកម្តងទៀត។
លោកបានមានប្រសាសន៍ម្តងទៀតថា៖ «សូមធ្វើចាក់ទឹកលើទីបី» ហើយពួកគេបានចាក់ទឹកជាលើកទីបី។[35]ទឹកបានហៀរជុំវិញអាសនា ហើយបានពេញរណ្តៅផង។
[36]ការនេះកើតឡើងនៅពេលដែលត្រូវថ្វាយយញ្ញបូជាពេលល្ងាច ដែលលោកព្យាការីអេលីយ៉ាបានមកជិត ហើយនិយាយថា៖ «ព្រះអម្ចាស់ជាព្រះរបស់លោកអាប្រាហាំ
លោកអ៊ីសាក និងលោកអ៊ីស្រាអែល សូមឲ្យគ្រប់គ្នាដឹងនៅថ្ងៃនេះថា ព្រះអង្គជាព្រះនៅក្នុងស្រុកអ៊ីស្រាអែល ហើយគេដឹងថាទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ
ហើយឲ្យពួកគេដឹងថាទូលបង្គំបានធ្វើរឿងទាំងនេះតាមព្រះបន្ទូលរបស់ព្រះអង្គ។[37]សូមស្តាប់ទូលបង្គំ ព្រះអម្ចាស់អើយ សូមស្តាប់ទូលបង្គំ
ដើម្បីឲ្យប្រជាជនទាំងនេះដឹងថាព្រះអង្គជាព្រះអម្ចាស់ ជាព្រះ ហើយឲ្យគេដឹងថាព្រះអង្គនឹងបែរត្រឡប់ចិត្តរបស់ពួកគេម្តងទៀតទៅព្រះអង្គវិញ»។
[38]បន្ទាប់ មកភ្លើងរបស់ព្រះអម្ចាស់បានមកដុតបព្លោះទាំងតង្វាយ ទាំងឈើ ទាំងថ្ម និងដី ហើយធ្វើឲ្យទឹកនៅក្នុងរណ្តៅនោះរីងអស់។
[39]នៅពេលដែលប្រជាជនទាំងអស់បានឃើញការនេះ ពួកគេបានក្រាបមុខដល់ដី ហើយនិយាយថា៖ «ព្រះអម្ចាស់ ជាព្រះ! ព្រះអម្ចាស់ជាព្រះ»![40]ដូច្នេះ
លោកអេលីយ៉ាមានប្រសាសន៍ទៅកាន់ពួកគេថា៖ «ចូរនាំព្យាការីរបស់ព្រះបាលមកទីនេះ។ កុំឲ្យពួកគេណាម្នាក់រត់រួចឡើយ»។ ដូច្នេះពួកគេបាននាំអ្នកទាំងនោះមក
រួចលោកអេលីយ៉ាបាននាំពួកគេទៅកាន់ជ្រោះគីសូន រួចលោកក៏សម្លាប់ពួកគេទាំងអស់នៅទីនោះទៅ។
[41]លោកអេលីយ៉ាទូលទៅព្រះបាទអហាប់ថា៖ «ចូរព្រះករុណាក្រោកឡើង រួចសោយអាហារ និងទឹកចុះ ព្រោះមានសម្លាប់ភ្លៀងយ៉ាងខ្លាំង»។[42]ដូច្នេះ
ព្រះបាទអហាប់បានក្រោឡើង សោយអាហារ និងទឹក។ បន្ទាប់មក លោកអេលីយ៉ាបានឡើងទៅលើកំពូលភ្នំកើមែល លោកបានក្រាបមុខដល់ដី
ហើយបានឱនក្បាលនៅចន្លោះជង្គង់ទាំងពីររបស់លោក។
[43]លោកបាននិយាយទៅអ្នកបម្រើរបស់លោកថា៖ «ចូរឡើងទៅមើសមុទ្រឥឡូវនេះមើល»។ អ្នកបម្រើរបស់លោកក៏ឡើងទៅមើល ហើយបាននិយាយថា៖
«គ្មានអ្វីទាំងអស់»។ ដូច្នេះ លោកអេលីយ៉ាមានប្រសាសន៍ថា៖ «សូមទៅប្រាំពីរដងទៀត»។[44]នៅលើកទីប្រាំពីរអ្នកបម្រើរបស់លោកនិយាយថា៖

generated on Wed Sep 10 16:16:32 2025

«មើលមានពពកមួយដុំឡើងពីសមុទ្រមក គឺតូចប៉ុនបាតដៃ»។ លោកអេលីយ៉ាក៏មានប្រសាសន៍ថា៖ «សូមទៅប្រាប់ព្រះបាទអហាប់ថា៖ «សូមឡើងរាជរថរបស់ព្រះអង្គ
និងចេញដំណើរទៅមុនភ្លៀងនឹងបញ្ឈប់ព្រះអង្គ»។
[45]បន្តិចក្រោយមក ផ្ទៃមេឃប្រែជាខ្មៅជាមួយពពក និងខ្យល់ ហើយក៏មានភ្លៀងយ៉ាងខ្លាំង។ ព្រះបាទអហាប់បានជិះ និងចេញទៅយេសរាល[46]ប៉ុន្តែ
ព្រះហស្តរបស់ព្រះអម្ចាស់បាននៅលើលោកអេលីយ៉ា។ លោកបានក្រវាត់អាវរបស់លោកនៅនឹងចង្កេះ ហើយបានរត់នៅមុខព្រះបាទអហាប់ទៅច្រកក្រុងយេសរាល។

---

1 Kings 18:1
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក
«ពាក្យ» សំដៅទៅលើអ្វីដែលមនុស្សម្នាក់និយាយ។ សូមមើលការបកប្រែនៅក្នុង
៦:១១។ ការបកប្រែផ្សេងទៀត « ព្រះជាម្ចាស់មានព្រះបន្ទូលរបស់ព្រះអង្គ»
បញ្ជូនទឹកភ្លៀងមកលើផែនដី
«ធ្វើឲ្យភ្លៀងធ្លាក់នៅលើផែនដី»
ពេលនោះ មានកើតទុរ្ភិក្សយ៉ាងខ្លាំង
ពាក្យ «ពេលនោះ» ត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងដំណើររឿងសំខាន់។
នៅទីនេះអ្នកនិពន្ធបានប្រាប់ព័ត៌មានសំខាន់អំពីរបៀប
ដែលទុរ្ភិក្សបានប៉ះពាល់ដល់ស្រុកសាម៉ារី។
1 Kings 18:3
លោកអូបាឌាគោរពព្រះអម្ចាស់
ពាក្យ «ឥឡូវ» ត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងដំណើររឿងសំខាន់។
នៅទីនេះអ្នកនិពន្ធប្រាប់អំពីមនុស្សថ្មីនៅក្នុងសាច់រឿង។
កញ្ជាការីមួយរយនាក់ទៅលាក់ក្នុងរូងភ្នំ មួយកន្លែងសាសិបនាក់
«ព្យាការី ១០០នាក់ហើយលាក់ពួកគេជាក្រុមចំនួន៥០»
1 Kings 18:5
សង្គ្រោះសេះ និងលាឲ្យនៅមានជីវិត ដូច្នេះ យើងនឹងមិនបាត់បង់សត្វទាំងអស់ឡើយ»
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ន័យ។ ការបកប្រែផ្សេងទៀត
«រារាំងសេះនិងលាមិនឲ្យងាប់»
ស្តេចអហាប់បានទៅផ្លូវមួយ ហើយលោកអូបាឌាទៅផ្លូវមួយទៀត
ឃ្លា «ដោយខ្លួនឯង» បញ្ជាក់ថាស្តេចអហាប់
និងលោកអូបាឌាបានទៅទិសដៅដាច់ដោយឡែកពីគ្នា មិនចាំបាច់ថា
គ្មាននរណាម្នាក់នៅជាមួយស្តេចអហាប់ឡើយ។ ការបកប្រែផ្សេងទៀត «
ស្តេចអហាប់ដឹកនាំក្រុមមួយក្នុងទិសដៅមួយ
ហើយលោកអូបាឌាដឹកនាំក្រុមមួយក្នុងទិសដៅផ្សេងទៀត»
1 Kings 18:7
លោកអេលីយ៉ា ដែលជាម្ចាស់
នៅទីនេះពាក្យ «ម្ចាស់» ត្រូវបានប្រើជាពាក្យគោរព។
សូមទៅប្រាប់ចៅហ្វាយរបស់លោកថា៖ «មើល លោកអេលីយ៉ានៅទីនេះ»
ត្រង់នេះពាក្យថា «ម្ចាស់« សំដៅលើស្តេចអហាប់។
មើល
ពាក្យ «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
1 Kings 18:9
តើខ្ញុំបានប្រព្រឹត្តបាបអ្វី...ឲ្យស្តេចសម្លាប់ខ្ញុំដូច្នេះ?
អូបាឌាសួរសំណួរនេះដើម្បីបញ្ជាក់ពីគ្រោះថ្នាក់ដល់ខ្លួនគាត់
ដោយសារស្តេចអហាប់ខឹងនឹងលោកអេលីយ៉ា។ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនបានធ្វើបាបអ្នកទេ ... ឲ្យគាត់សម្លាប់ខ្ញុំ។»
ប្រគល់អ្នកបម្រើរបស់លោកទៅក្នុងដៃរបស់ស្តេចអហាាប់
«ដៃ» សំដៅទៅលើអំណាចនិងការគ្រប់គ្រង។ ការបកប្រែផ្សេងទៀត
«ប្រគល់អ្នកបម្រើរបស់អ្នកទៅស្តេចអហាប់»
អ្នកបម្រើរបស់លោក
លោកអូបាឌសំដៅលើខ្លួនគាត់ជាអ្នកបម្រើរបស់លោកអេលីយ៉ា
ដើម្បីគោរពដល់លោកអេលីយ៉ា។
ដោយសារព្រះអម្ចាស់មានព្រះជន្មគង់នៅ
នេះជាការសច្ចាប្រើសម្រាប់បញ្ជាក់ថា អ្វីដែលគាត់កំពុងនិយាយគឺជាការពិត។
គ្មានជាតិសាសន៍ណាមួយ....ដែលចៅហ្វាយរបស់ខ្ញុំមិនបានបញ្ជូនមនុស្សទៅ
អាចបង្ហាញជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ម្ចាស់របស់ខ្ញុំបានបញ្ជូនមនុស្សទៅគ្រប់ទីកន្លែង»
តែឥឡូវនេះ
ឃ្លានេះត្រូវបានប្រើដើម្បីបញ្ជាក់ពីគ្រោះថ្នាក់នៅក្នុងអ្វី
ដែលលោកអេលីយ៉ាកំពុងប្រាប់លោកអូបាឌាឲ្យធ្វើ។
1 Kings 18:12
តើគ្មាននរណាបានប្រាប់លោកទេ...ដោយនំប៉័ង និងទឹកទេឬ?
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«ប្រាកដណាស់អ្នកត្រូវបានគេប្រាប់អំពីអ្វី ដែលខ្ញុំបានធ្វើ ... ជាមួយនំប៉័ងនិងទឹក!»
លោកម្ចាស់អើយ
ត្រង់នេះពាក្យថា «ម្ចាស់» ជាពាក្យគោរព ដែលគេប្រើដើម្បីសំដៅទៅលើអេលីយ៉ា។
ព្យាការីរបស់ព្រះអម្ចាស់មួយរយនាក់នៅក្នុងរូងភ្នំ ក្នុងមួយកន្លែងហាសិបនាក់
«ព្យាការី ១០០នាក់របស់ព្រះអម្ចាស់នៅក្នុងមួយក្រុមមាន ៥០»
1 Kings 18:14
ចូរទៅប្រាប់ចៅហ្វាយរបស់អ្នកថាលោកអេលីយ៉ានៅទីនេះ
បកប្រែដូចនៅក្នុង ១៨:៩។
ចៅហ្វាយរបស់អ្នក
ពាក្យ «ចៅហ្វាយ» ត្រង់នេះសំដៅលើស្តេចអហាប់។
ដោយសារព្រះអម្ចាស់មានព្រះជន្មគង់នៅ
នេះជាសម្បថបញ្ជាក់ថា អ្វីដែលគាត់នឹងនិយាយគឺជាការពិត។
ដែលខ្ញុំឈរនៅមុខព្រះអង្គ
«ឈរនៅមុខ» បង្ហាញថា
នៅក្នុងវត្តមានរបស់នរណាម្នាក់ហើយត្រៀមខ្លួនដើម្បីបម្រើគាត់។
ការបកប្រែផ្សេងទៀត «អ្នកដែលខ្ញុំបម្រើ»
1 Kings 18:16
ទូលស្តេចនូវអ្វីដែលលោកអេលីយ៉ាបាននិយាយ
«លោកអូបាឌាបានប្រាប់ស្តេចអហាប់នូវអ្វី
ដែលលោកអេលីយ៉ាបានប្រាប់គាត់ឲ្យនិយាយ»
«តើពិតជាលោកមែនឬ? តើលោកជាម្នាក់ដែលនាំបញ្ហាដល់អ៊ីស្រាអែលនោះមែនទេ!»
ស្តេចអហាប់សួរសំណួរដើម្បីបញ្ជាក់ឲ្យច្បាស់
អំពីអត្តសញ្ញាណរបស់លោកអេលីយ៉ា។ ការបកប្រែផ្សេងទៀត
«អញ្ចឹងអ្នកនៅទីនេះហើយ អ្នកគឺជាអ្នកបង្កបញ្ហាដល់អ៊ីស្រាអែល!»
1 Kings 18:18
ប្រជាជនទាំងអស់
ជាការសន្និដ្ឋានទូទៅមួយ សំដៅទៅលើអ្នកដឹកនាំ
និងប្រជាជនដែលតំណាងឲ្យកុលសម្ព័ន្ធទាំងដប់នៃរាជាណាចក្រខាងជើង។
ព្យាការីរបស់ព្រះបាលទាំងបួនរយហាសិបនាក់
«ព្យាការីបួនរយហាសិបនាក់»
ព្យាការីរបស់ព្រះអាសេរ៉ាទាំងបួនរយនាក់
«ព្យាការី៤០០នាក់»
1 Kings 18:20
បញ្ជូនពាក្យ
«ពាក្យ» សម្រាប់អ្វីដែលមនុស្សម្នាក់និយាយ។ នេះជាឃ្លាភ្ជាប់រួម
ដែលប្រើជាមួយអត្ថន័យដែលបានយល់។ ការបកប្រែផ្សេងទៀត «បានផ្ញើសារ»
តើអ្នកត្រូវការពេលប៉ុន្មាន ដើម្បីផ្លាស់ប្តូរគំនិតរបស់អ្នក?
លោកអេលីយ៉ាសួរសំណួរនេះ ដើម្បីជំរុញប្រជាជនឲ្យធ្វើការសម្រេចចិត្ត។
ការបកប្រែផ្សេងទៀត «អ្នកមានភាពមិនច្បាស់លាស់យូរមកហើយ។»
មិនបានឆ្លើយតបទៅលោកទេ
«មិនបាននិយាយអ្វីទាំងអស់» ឬ «នៅស្ងាត់ស្ងៀម»
1 Kings 18:22
ចំណែកខ្ញុំ ខ្ញុំមានតែម្នាក់ឯង
ពាក្យ «ខ្ញុំ» ត្រូវបានប្រើម្តងទៀតសម្រាប់ការសង្កត់ធ្ងន់។
ចូរអ្នកប្រកាសហៅឈ្មោះព្រះរបស់អ្នកចុះ ហើយខ្ញុំនឹងអំពាវនាវរកព្រះនាមរបស់ព្រះអម្ចាស់
«ឈ្មោះ» សំដៅទៅលើកេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់នរណាម្នាក់ ហើយ
«អំពាវនាវ» តំណាងឲ្យពាក្យបណ្តឹង។ ការបកប្រែផ្សេងទៀត
«អំពាវនាវដល់ព្រះជាម្ចាស់របស់អ្នក...អំពាវនាវដល់ព្រះអម្ចាស់»

generated on Wed Sep 10 16:16:32 2025

មនុស្សទាំងអស់ឆ្លើយថា៖ «ល្អណាស់»
ប្រជាជនទាំងអស់និយាយថា នេះជារឿងល្អដែលត្រូវធ្វើ។
1 Kings 18:25
រៀបចំវា
«រៀបចំខ្លួនថ្វាយយញ្ញបូជា»
អ្នកមានគ្នាច្រើន
នៅទីនេះពាក្យ «អ្នក» គឺពហុវចន:។
ពួកគេបានយកគោបា
«ព្យាការីរបស់ព្រះបាលបានយកគោបានោះមក»
គោបាដែលលោកបានឲ្យពួកគេ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«គោបាដែលមាននរណាម្នាក់ឲ្យពួកគេ»
ប៉ុន្តែ គ្មានសម្លេងក៏គ្មាននរណាម្នាក់ឆ្លើយដែរ
ឃ្លាទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា ហើយសង្កត់ធ្ងន់ថា
គ្មាននរណាម្នាក់ឆ្លើយតបនឹងការអធិស្ឋានរបស់ព្យាការីក្លែងក្លាយឡើយ។
ការបកប្រែផ្សេងទៀត «ប៉ុន្តែ ព្រះបាលមិនបាននិយាយ ឬ ធ្វើអ្វីទាំងអស់»
1 Kings 18:27
ប្រហែលជា
«ប្រហែលជា» ឬ «អាចថា»
កំពុងរំដោះខ្លួន
ការត្រាប់តាមនេះជាវិធីរីករាយមួយ ដើម្បីបង្ហាញពីឃ្លាភ្ជាប់ដ៏ឃោរឃៅ។
លោកអេលីយ៉ានិយាយប្រមាថដល់ព្រះបាលដោយការសើចចំអក។
ការបកប្រែផ្សេងទៀត «នៅក្នុងបន្ទប់ទឹក»
កំពុងក្រោកឡើង
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែដាស់គាត់» ឬ «អ្នកត្រូវតែដាស់គាត់ឲ្យភ្ញាក់ឡើង»
ពួកគេនៅតែទាយ
ពួកគេបន្តអាកប្បកិរិយាព្រៃផ្សៃ។ ពួកព្យាការីជារឿយៗធ្វើសកម្មភាពតាមរបៀប
ដែលមើលទៅមិនធម្មតា ឬដូចឆ្កួត។ ក្នុងករណីនេះ
ពួកគេបានអំពាវនាវដល់ព្រះបាលនៅពេលកំពុងរាំ ស្រែកខ្លាំងៗ
ហើយយកកាំបិតមកកាត់ខ្លួនឯង។
យញ្ញបូជាពេលល្ងាច
ថ្វាយយញ្ញបូជាពេលល្ងាច
ប៉ុន្តែនៅតែគ្មានសម្លេងឬនរណាម្នាក់ឆ្លើយតបឡើយ
គ្មាននរណាម្នាក់ចាប់អារម្មណ៍នឹងការប្រកូកប្រកាសរបស់ពួកគេឡើយ
ឃ្លាទាំងនេះមានន័យស្រដៀងគ្នា ហើយសង្កត់ធ្ងន់ថា
គ្មាននរណាម្នាក់ឆ្លើយតបនឹងការអធិស្ឋានរបស់ពួកព្យាការីក្លែងក្លាយឡើយ។
ការបកប្រែផ្សេងទៀត «ប៉ុន្តែ ព្រះបាលមិនបាននិយាយ ឬធ្វើអ្វីទាំងអស់
សូម្បីតែយកចិត្តទុកដាក់»
គ្មានសម្លេងឬនរណាម្នាក់ឆ្លើយតប
បកប្រែដូចនៅក្នុង ១៨:២៥ ។
1 Kings 18:30
ថ្មដប់ពីរដុំ
«ថ្ម ១២ដុំ»
ក្នុងព្រះនាមរបស់ព្រះអម្ចាស់
«ឈ្មោះ» សម្គាល់កិត្តិយស និងកេរ្តិ៍ឈ្មោះ។ អាចមានន័យថា
១)«ដើម្បីគោរពដល់ព្រះជាម្ចាស់» ឬ ២)«ដោយអំណាចរបស់ព្រះអម្ចាស់» ។
ស្នាមភ្លោះ
ផ្លូវទឹកតូចមួយសម្រាប់ទប់ទឹក
គ្រាប់ស្រូវពីរង្វាល់
រង្វាល់ស៊ីហៃជាឯកតាបរិមាណស្មើនឹងប្រហែល ៧,៧ លីត្រ។
ការបកប្រែផ្សេងទៀត៖ «គ្រាប់ពូជប្រហែល ១៥ លីត្រ»
1 Kings 18:33
លោកក៏បានរៀបចំឈើសម្រាប់ដុត
«នៅលើអាសន:» ដែលគាត់បានដាក់ឈើត្រូវបានគេសន្មតនៅក្នុងប្រយោគនេះ។
ការបកប្រែផ្សេងទៀត៖ « គាត់ដាក់អុសសម្រាប់ដាក់លើអាសន:»
បួនពាង
៤ពាង
៣ពាង
ពាងជាធុងសម្រាប់ដឹកទឹក។
រណ្តៅ
បកប្រែដូចនៅក្នុង ៨:៣០ ។
1 Kings 18:36
ការនេះកើតឡើង
ឃ្លានេះត្រូវបានប្រើនៅទីនេះ ដើម្បីយោងពេលវេលាសំខាន់
និងអត្ថន័យនៃថ្ងៃនៅក្នុងរឿងនេះ។
បើភាសារបស់អ្នកមានរបៀបក្នុងការបកប្រែឃ្លានេះ
អ្នកអាចពិចារណាប្រើវានៅទីនេះបាន។
ព្រះអម្ចាស់ជាព្រះរបស់លោកអាប្រាហាំ លោកអ៊ីសាក និងលោកអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើលោកយ៉ាកុប។
ព្រះជាម្ចាស់បានប្តូរឈ្មោះរបស់លោកយ៉ាកុបទៅជាអ៊ីស្រាអែល (លោកុប្បត្តិ
៣២:២៨) ហើយព្រះជាម្ចាស់បានដាក់ឈ្មោះប្រជាជាតិនៃកូនចៅរបស់យ៉ាកុបថា
«អ៊ីស្រាអែល» ។
សូមឲ្យគ្រប់គ្នាដឹងនៅថ្ងៃនេះថា
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
ការបកប្រែផ្សេងទៀត«ធ្វើឲ្យមនុស្សទាំងនេះដឹងនៅថ្ងៃនេះថា»
សូមស្តាប់ទូលបង្គំ ...សូមស្តាប់ទូលបង្គំ
ឃ្លានេះត្រូវបាននិយាយម្តងទៀត ដើម្បីបញ្ជាក់ពីការអំពាវនាវរបស់លោកអេលីយ៉ា
ចំពោះព្រះអម្ចាស់។
បែរត្រឡប់ចិត្តរបស់ពួកគេម្តងទៀតទៅព្រះអង្គវិញ
« បង្វែរចិត្តរបស់ពួកគេ» សំដៅទៅលើការស្រឡាញ់
និងភាពស្មោះត្រង់របស់ប្រជាជន។ ការបកប្រែផ្សេងទៀត «
ធ្វើឲ្យពួកគេមានភាពស្មោះត្រង់ ចំពោះអ្នកម្តងទៀត»
1 Kings 18:38
ភ្លើងរបស់ព្រះអម្ចាស់បានមក
«ភ្លើងរបស់ព្រះជាម្ចាស់បានចុះមក»
រីង
ភ្លើងត្រូវបានប្រៀបធៀបទៅនឹងមនុស្សស្រេកទឹក។
«ព្រះអម្ចាស់ ជាព្រះ! ព្រះអម្ចាស់ជាព្រះ»!
ឃ្លានេះត្រូវប្រើម្តងទៀតសម្រាប់ការសង្កត់ធ្ងន់។
ជ្រោះគីសូន
«ទឹកជ្រោះ» ជាលំហូរតូច ឬ ប្រភពទឹក។
1 Kings 18:41
មានសម្លាប់ភ្លៀងយ៉ាងខ្លាំង
«ស្តាប់មើលទៅដូចជាមានភ្លៀងធ្លាក់ខ្លាំង»
បានក្រាបមុខដល់ដី ហើយបានឱនក្បាលនៅចន្លោះជង្គង់ទាំងពីររបស់លោក
ពិពណ៌នាអំពីជំហរ ដែលត្រូវបានប្រើសម្រាប់អធិស្ឋាន។
1 Kings 18:43
ប្រាំពីរដង
ពាក្យ «ប្រាំពីរ« អាចត្រូវបានបកប្រែជាលេខ «៧» ។ ការបកប្រែផ្សេងទៀត
«៧ដង»
តូចប៉ុនបាតដៃ
មើលពីចម្ងាយ ពពកអាចគ្របដណ្តប់ពីការមើលឃើញដោយដៃរបស់មនុស្ស។
1 Kings 18:45
វាបានកើតឡើង
ឃ្លានេះត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់កន្លែងបោះជំហានថ្មីក្នុងការចាប់ផ្តើមសកម្មភាព។
បើភាសារបស់អ្នកមានរបៀបបកប្រែឃ្លានេះ អ្នកអាចពិចារណាប្រើវានៅទីនេះ។
ព្រះហស្តរបស់ព្រះអម្ចាស់បាននៅលើលោកអេលីយ៉ា
នៅទីនេះពាក្យថា «ដៃ» សំដៅទៅលើកម្លាំង។ ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានប្រទានអំណាចដល់លោកអេលីយ៉ា»
បានក្រវាត់អាវរបស់លោកនៅនឹងចង្កេះ
លោកអេលីយ៉ាបានរុំអាវវែងរបស់គាត់ នៅជុំវិញចង្កេះដើម្បីឲ្យជើងរបស់គាត់
អាចរត់បាន។

generated on Wed Sep 10 16:16:32 2025

19 [1]ព្រះបាទអហាប់បានប្រាប់នាងយេសិបិលពីអ្វីៗទាំងអស់ដែលលោកអេលីយ៉ាបានធ្វើ និងពីរបៀបដែលលោកបានសម្លាប់ពួកព្យាការីទាំងនោះដោយដាវ។[2]បន្ទាប់មក
ព្រះនាងយេសិបិលបានឲ្យគេទៅប្រាប់លោកអេលីយ៉ាថា៖ «សូមឲ្យព្រះជាម្ចាស់បានប្រព្រឹត្តជាមួយខ្ញុំលើសជាងនេះទៅទៀត
បើខ្ញុំមិនបានធ្វើឲ្យជីវិតរបស់លោកដូចជាជីវិតរបស់អស់អ្នកដែលបានស្លាប់នៅថ្ងៃស្អែកពេលថ្មើរនេះ»។[3]នៅពេលដែលលោកអេលីយ៉ាបានឮបែបនេះ
លោកក៏ក្រោកឡើងហើយរត់យកជីវិត ហើយមកដល់បៀរ-សេបា ក្នុងស្រុកយូដា លោកទុកអ្នកបម្រើរបស់លោកនៅទីនោះ។
[4]ប៉ុន្តែ លោកបានទៅវាលរហោស្ថានចម្ងាយដើរមួយថ្ងៃ ហើយបានមកអង្គុយនៅក្រោមដើមឈើ។ លោកសុំឲ្យលោកបានស្លាប់ ហើយលោកនិយាយថា៖
«វាគ្រប់គ្រាន់ហើយព្រះអម្ចាស់អើយ សូមដកយកជីវិតទូលបង្គំទៅ ព្រោះទូលបង្គំមិនប្រសើរជាងបុព្វបុរសរបស់ទូលបង្គំដែលបានស្លាប់នោះទេ»។[5]ដូច្នេះ
លោកក៏បានផ្តេកខ្លួននៅក្រោមដើមឈើដែលមានផ្ការីកនោះទៅ។ រំពេចនោះ មានទេវតាមកប៉ះលោក ហើយនិយាយនឹងលោកថា៖ «សូមក្រោកឡើង ហើយបរិភោគចុះ»។
[6]លោកអេលីយ៉ាបានមើល ហើយនៅជិតក្បាលរបស់លោកមាននំប៉័ងដែលបានដុតក្តៅៗ និងមានទឹកមួយបំពង់។ ដូច្នេះ លោកក៏បានបរិភោគ និងផឹក
រួចក៏ផ្តេកខ្លួនម្តងទៀត។
[7]ទេវតារបស់ព្រះអម្ចាស់បានមកជាលើកទីពីរ ហើយបានប៉ះលោកដោយនិយាយថា៖ «សូមក្រោកឡើងហើយបរិភោគ ព្រោះការធ្វើដំណើរនឹងច្រើនជ្រុលសម្រាប់អ្នក»។
[8]ដូច្នេះ លោកក៏ក្រោកឡើង ហើយបានបរិភោគ និងផឹកទឹក ហើយលោកបានធ្វើដំណើរដោយមានកំលាំងពីអាហារនោះអស់រយៈពេលសែសិបយប់ សែសិបថ្ងៃទៅភ្នំ
ហោរែប ជាភ្នំរបស់ព្រះជាម្ចាស់។
[9]លោកបានទៅរូងភ្នំទីនោះ និងស្នាក់នៅក្នុងរូងនោះ។ បន្ទាប់មកព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកថា៖ «អេលីយ៉ាអើយ តើអ្នកកំពុងធ្វើអ្វីនៅទីនេះ»?
[10]លោកអេលីយ៉ាឆ្លើយថា៖ «ទូលបង្គំប្រឹងខ្នះខ្នែងសម្រាប់ព្រះអម្ចាស់ខ្លាំងណាស់ ព្រះអង្គជាព្រះនៃពិភពទាំងមូល
ដោយសារជនជាតិអ៊ីស្រាអែលបានផ្តាច់សម្ពន្ធមេត្រីរបស់ព្រះអង្គ ពួកគេបានបំផ្លាញអាសនារបស់ព្រះអង្គ ហើយបានសំលាប់ព្យាការីរបស់ព្រះអង្គដោយដាវ។
ឥឡូវនេះមានតែទូលបង្គំម្នាក់គត់នៅមានជីវិត ហើយគេក៏ព្យាយាមយកជីវិតទូលបង្គំទៀត»។
[11]ព្រះអម្ចាស់តមថា៖ «ចូរចេញទៅក្រៅ ហើយឈរនៅលើភ្នំនៅមុខយើង»។ បន្ទាប់មក ព្រះអម្ចាស់យាងឆ្លងកាត់តាមនោះ ហើយមានខ្យល់យ៉ាងខ្លាំងបក់ប៉ះភ្នំ
ហើយបានបំបែកថ្ម្ជាបំណែកនៅមុខព្រះអម្ចាស់ ប៉ុន្តែ ព្រះអម្ចាស់មិនបាននៅក្នុងខ្យល់នោះទេ។ បន្ទាប់មក ក្រោយពីមានខ្យល់ រញ្ជួយដីក៏មកដល់
ប៉ុន្តែព្រះអម្ចាស់មិននៅក្នុងរញ្ជួយដីនោះទេ។[12]បន្ទាប់មក ក្រោយពីមានរញ្ជួយដី ក៏មានភ្លើងមកដែរ ប៉ុន្តែ ព្រះអម្ចាស់មិនគង់នៅក្នុងភ្លើងនោះទេ។ បន្ទាប់ពី មានភ្លើង
ក៏មានសម្លេងតូចមួយបានមក។
[13]នៅពេលដែលលោកអេលីយ៉ាបានឮសម្លេងលោកបានយកអាវធំរបស់លោកគ្របមុខ ដើរចេញក្រៅ ហើយបានឈរនៅមាត់រូង។ បន្ទាប់មក
សម្លេងនោះមកឯលោកដោយនិយាយថា៖ «អេលីយ៉ាអើយតើអ្នកកំពុងធ្វើអ្វីនៅទីនេះ»?[14]លោកអេលីយ៉ាឆ្លើយថា៖ «ទូលបង្គំប្រឹងខ្នះខ្នែងសម្រាប់ព្រះអម្ចាស់ខ្លាំងណាស់
ព្រះអង្គជាព្រះនៃពិភពទាំងមូល ដោយសារជនជាតិអ៊ីស្រាអែលបានផ្តាច់សម្ពន្ធមេត្រីរបស់ព្រះអង្គ ពួកគេបានបំផ្លាញអាសនារបស់ព្រះអង្គ
ហើយបានសម្លាប់ពួកព្យាការីរបស់ព្រះអង្គដោយដាវ។ ឥឡូវនេះ មានតែទូលបង្គំម្នាក់គត់នៅមានជីវិត ហើយគេក៏ព្យាយាមយកជីវិតទូលបង្គំទៀត»។
[15]បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលមកកាន់គាត់ថា៖ «ចេញទៅតាមផ្លូវរបស់អ្នកទៅវាលរហោស្ថានដាម៉ាស ហើយនៅពេលដែលអ្នកមកដល់ អ្នកត្រូវតែតែងតាំងហាសែល
ឲ្យធ្វើជាស្តេចលើស្រុកអើរ៉ាម[16]ហើយអ្នកនឹងតែងតាំងយេហ៊ូវ ជាកូនរបស់នីមស៊ី ឲ្យធ្វើជាស្តេចលើស្រុកអ៊ីស្រាអែល រួចចាក់ប្រេងតែងតាំងលោកអេលីសេ ជាកូន
របស់លោកសាផាត នៅអេបិល-មហូឡា ឲ្យធ្វើជាព្យាការីជំនួសកន្លែងអ្នក។
[17]វានឹងកើតឡើងដូច្នេះថា លោកយេហូវនឹងសម្លាប់អ្នកដែលរត់គេចពីហាសែល ហើយលោកអេលីសេនឹងសម្លាប់អ្នកដែលរត់គេចពីយេហូវ។[18]ប៉ុន្តែ
យើងនឹងទុកប្រជាជនរបស់យើងប្រាំពីរពាន់នាក់នៅក្នុងស្រុកអ៊ីស្រាអែល គឺអស់អ្នកដែលមិនបានលុតជង្គង់ ដើម្បីថ្វាយបង្គំព្រះបាលឡើយ
ហើយមាត់របស់អ្នកទាំងនោះក៏មិនបានថើបព្រះនោះដែរ»។
[19]ដូច្នេះ លោកអេលីយ៉ាបានចេញពីទីនោះ ហើយជួបលោកអេលីសេជាកូនរបស់លោកសាផាត កំពុងតែភ្ជួរស្រែជាមួយនឹងគោដប់ពីរនឹមនៅមុខលោក
ហើយគាត់ផ្ទាល់កំពុងភ្ជួរគោដប់ពីរនឹម។ លោកអេលីយ៉ាបានដើរទៅជួបលោកអេលីសេហើយបានទម្លាក់អាវធំរបស់លោកលើគាត់។[20]បន្ទាប់មក
លោកអេលីសេបានទុកគោចោល ហើយបានរត់តាមលោកអេលីយ៉ាទៅ ហើយនិយាយថា៖ «សូមឲ្យខ្ញុំថើបឪពុកម្តាយរបស់ខ្ញុំសិន ហើយបន្ទាប់មក
ខ្ញុំនឹងដើរតាមលោក»។ បន្ទាប់មក លោកអេលីយ៉ាក៏បានមានប្រសាសន៍ទៅគាត់វិញថា៖ «ចូរត្រឡប់ទៅវិញចុះ តែសូមគិតអំពីអ្វីដែលខ្ញុំបានធ្វើដល់អ្នក»។
[21]ដូច្នេះ លោកអេលីសេបានត្រឡប់ពីលោកអេលីយ៉ាមកវិញ ហើយបានយកនង្គ័ល និងសម្លាប់គោ ហើយបានចម្អិនសាច់នោះដោយប្រើនង្គ័លជាអុសដុត។ បន្ទាប់មក
លោកបានឲ្យសាច់នោះទៅប្រជាជន ហើយពួកគេក៏បានបរិភោគទៅ។ បន្ទាប់មក លោកក៏ក្រោកឡើង ទៅតាមលោកអេលីយ៉ា ហើយក៏បម្រើលោក។

---

1 Kings 19:1

សូមឲ្យព្រះជាម្ចាស់បានប្រព្រឹត្តជាមួយខ្ញុំលើសជាងនេះទៅទៀត
នេះគឺជាការប្រៀបធៀបដែលត្រូវបានប្រើជាសម្បថ។
«សូមឲ្យព្រះសម្លាប់ខ្ញុំហើយធ្វើអំពើអាក្រក់ថែមទៀត»
បើខ្ញុំមិនបានធ្វើឲ្យជីវិតរបស់លោកដូចជាជីវិតរបស់អស់អ្នកដែលបានស្លាប់នៅថ្ងៃស្អែកពេលថ្មើរនេះ
«ប្រសិនបើខ្ញុំមិនសម្លាប់អ្នកដូចអ្នកបានសម្លាប់ព្យាការីទាំងនោះទេ»
លោកក៏ក្រោកឡើង
«គាត់បានក្រោកឈរ»
1 Kings 19:4

លោកបានទៅវាលរហោស្ថានចម្ងាយដើរមួយថ្ងៃ
ពាក្យ «ខ្លួនឯង» ត្រូវបានប្រើដើម្បីបញ្ជាក់ថាគាត់នៅម្នាក់ឯង។
ការបកប្រែផ្សេងទៀត «គាត់បានដើរដោយខ្លួនឯងរយៈពេលមួយថ្ងៃ»
ដើមឈើ
«ដើមឈើមួយ» គឺជារុក្ខជាតិដែលដុះនៅវាលខ្សាច់។
លោកសុំឲ្យលោកបានស្លាប់
"គាត់បានអធិស្ឋានថាគាត់នឹងស្លាប់"
វាគ្រប់គ្រាន់ហើយព្រះអម្ចាស់អើយ
«បញ្ហាទាំងនេះគឺច្រើនពេកសម្រាប់ខ្ញុំព្រះអម្ចាស់អើយ»
នំប៉័ងដែលបានដុតក្តៅៗ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«នំប៉័ងដែលនរណាម្នាក់បានចម្អិននៅលើថ្មក្តៅ»
ទឹកមួយបំពង់
«ធុងសម្រាប់ដាក់ទឹក»
1 Kings 19:7

ច្រើនជ្រុលសម្រាប់អ្នក
«នឹងពិបាកពេកសម្រាប់អ្នក»។
លោកបានធ្វើដំណើរដោយមានកំលាំងពីអាហារនោះអស់រយៈពេលសែសិបយប់ សែសិបថ្ងៃ
« អាហារនោះបានផ្តល់ថាមពលដល់គាត់ក្នុងការធ្វើដំណើរ ៤០ ថ្ងៃ ៤០ យប់»
1 Kings 19:9

ទៅរូងភ្នំទីនោះ
ត្រង់នេះពាក្យថា «ទីនោះ» សំដៅទៅលើភ្នំហូរែប។
ល្អាងគឺនៅលើភ្នំដែលនាំទៅរកកន្លែងធម្មជាតិឬបន្ទប់នៅក្រោមដី។
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកថា
នេះមានន័យថាព្រះជាម្ចាស់មានបន្ទូលហើយ «ពាក្យ»
ជាពាក្យដែលតំណាងឲ្យសារ។ «ព្រះអម្ចាស់មានព្រះបន្ទូលមកលោកថា»។
សូមមើលការបកប្រែនៅក្នុងជំពូក ៦:១។
«អេលីយ៉ាអើយ តើអ្នកកំពុងធ្វើអ្វីនៅទីនេះ»?
ព្រះអម្ចាស់សួរសំណួរនេះដើម្បីស្តីបន្ទោសអេលីយ៉ានិងរំលឹកគាត់អំពីកាតព្វកិច្ចរបស់គាត់។
ការបកប្រែផ្សេងទៀត «នេះមិនមែនជាកន្លែងដែលអ្នកគួរតែនៅទេអេលីយ៉ា» ។
ទូលបង្គំម្នាក់គត់នៅមានជីវិត
នៅទីនេះពាក្យ «ខ្ញុំ» ត្រូវបានធ្វើម្តងទៀតសម្រាប់ការសង្កត់ធ្ងន់។
1 Kings 19:11

generated on Wed Sep 10 16:16:32 2025

នៅលើភ្នំនៅមុខយើង
«មុនយើង» គឺជាពាក្យសំដៅទៅលើការឈរនៅមុខមនុស្សម្នាក់។
ការបកប្រែផ្សេងទៀត «នៅលើភ្នំក្នុងវត្តមានរបស់ខ្ញុំ»
1 Kings 19:13
លោកបានយកអាវធំរបស់លោកគ្របមុខ
«គាត់បានគ្របមុខរបស់គាត់ដោយសម្លៀកបំពាក់របស់គាត់»
សម្លៀកបំពាក់គឺជាអាវវែង ដែលជាសម្លៀកបំពាក់មួយគ្របលើរាងកាយទាំងមូល។
បន្ទាប់មក សម្លេងនោះមកឯលោក
«បន្ទាប់មកគាត់បានលឺសម្លេងមួយ»
តើអ្នកកំពុងធ្វើអ្វីនៅទីនេះ...ហើយគេក៏ព្យាយាមយកជីវិតទូលបង្គំទៀត
បកប្រែអត្ថបទនេះដូចនៅក្នុងជំពូក ១៩: ៩ ។
មានតែទូលបង្គំម្នាក់គត់នៅមានជីវិត
នៅទីនេះពាក្យ «ខ្ញុំ» ត្រូវបានប្រើម្តងទៀតសម្រាប់ការសង្កត់ធ្ងន់។
1 Kings 19:15
ព្យាការីជំនួសកន្លែងអ្នក
«ព្យាការីជំនួសអ្នក»
1 Kings 19:17
វានឹងកើតឡើង
ឃ្លានេះត្រូវបានប្រើដើម្បីណែនាំ
អ្វីដែលនឹងកើតឡើងនៅពេលអេលីយ៉ាធ្វើតាមអ្វីដែលព្រះអម្ចាស់បានប្រាប់គាត់
ឲ្យធ្វើ។ «តើនឹងមានអ្វីកើតឡើង»
អ្នកដែលរត់គេចពីហាសែល
«ដាវ» គឺសម្រាប់ការសម្លាប់ដូចនៅក្នុងសមរភូមិ។ ការបកប្រែផ្សេងទៀត
«អ្នកណាដែលហាសែលមិនសម្លាប់ដោយដាវ»
យើងនឹងទុក
ត្រង់នេះពាក្យ «ខ្ញុំ» និង «ខ្លួនខ្ញុំ» សំដៅទៅលើព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត
«ខ្ញុំនឹងរួចផុតពីសេចក្តីស្លាប់»
ប្រជាជនរបស់យើងប្រាំពីរពាន់នាក់
«៧,០០០ នាក់»
អស់អ្នកដែលមិនបានលុតជង្គង់ ដើម្បីថ្វាយបង្គំព្រះបាលឡើយ
ហើយមាត់របស់អ្នកទាំងនោះក៏មិនបានថើបព្រះនោះដែរ
«ពត់ខ្លួន» និង «ការថើប»
គឺប្រើសម្រាប់សកម្មភាពដែលមនុស្សបានធ្វើដើម្បីគោរពបូជារូបព្រះ។
នេះត្រូវបានធ្វើសម្រាប់ការសង្កត់ធ្ងន់។ ការបកប្រែផ្សេងទៀត «
អ្នកដែលមិនបានឱនក្បាលនិងថើបព្រះបាល» ឬ
«អ្នកដែលមិនបានថ្វាយបង្គំព្រះបាល»
1 Kings 19:19
លោកសាផាត
នេះជាឈ្មោះបុរសម្នាក់
គោដប់ពីរនឹម
គោដប់ពីរនឹម
គាត់ផ្ទាល់កំពុងភ្ជួរគោដប់ពីរនឹម
ពាក្យថា «ខ្លួនគាត់»
បង្ហាញថាអេលីសេកំពុងភ្ជួររាស់ជាមួយនឹមចុងក្រោយរឹងបុរសផ្សេងទៀតកំពុងភ្ជួរជាមួយនឹមដប់មួយទៀត
និយាយថា៖ «សូមឲ្យ»
ពាក្យថា «គាត់» សំដៅទៅលើអេលីសេ។
1 Kings 19:21
លោកបានឲ្យសាច់នោះទៅប្រជាជន
អេលីសេបានឲ្យសាច់ដែលឆ្អិនទៅប្រជាជននៅទីក្រុងរបស់គាត់។

---

20 [1]ព្រះបាទបេនហាដាដ ជាស្តេចស្រុកអារ៉ាមបានប្រមូលកងទ័ពទាំងអស់មក។ ព្រះអង្គមានស្តេចសម្ពន្ធមិត្តចំនួនសាមសិបពីរអង្គទៀតជាមួយនឹងព្រះអង្គ
ហើយមានសេះ និងរទេះចម្បាំងជាច្រើន។ ស្តេចឡើងទៅឡោមព័ទ្ធក្រុងសាមារី ហើយវាយក្រុងនោះ។[2]ស្តេចបានចាត់អ្នកនាំសារទៅកាន់ទីក្រុង
គឺទៅកាន់ព្រះបាទអហាប់ជាស្តេចស្រុកអ៊ីស្រាអែល ហើយទូលថា៖ «ព្រះបាទបេនហាដាដទូលថា៖[3]«ប្រាក់ និងមាសរបស់ព្រះករុណាជារបស់ទូលបង្គំ។ ហើយមហេសី
និងបុត្រទាំងអស់ឥឡូវនេះក៏ជារបស់ទូលបង្គំដែរ»។
[4]ស្តេចស្រុកអ៊ីស្រាអែលឆ្លើយថា៖ «ចូរឲ្យបានដូចព្រះករុណាមានរាជឱង្ការចុះ ស្តេចដ៏ជាចៅហ្វាយ។ ទូលបង្គំ និងអ្វីៗដែលទូលបង្គំមានជារបស់ព្រះករុណា»។
[5]អ្នកនាំសារមកម្តងទៀតហើយនិយាយថា៖ «ព្រះបាទបេនហាដាដមានរាជឱង្ការថា៖ «យើងចាត់ឲ្យគេទូលព្រះករុណាថា អ្នកត្រូវតែប្រគល់មាស ប្រាក់ មហេសី
និងបុត្ររបស់ព្រះករុណាដល់យើង។[6]ប៉ុន្តែ យើងនឹងបញ្ជូនអ្នកបម្រើរបស់យើងទៅជួបព្រះករុណានៅថ្ងៃស្អែកថ្មើរនេះ
ហើយពួកគេនឹងចូលទៅត្រួតពិនិត្យដំណាក់របស់ព្រះករុណា និងផ្ទះរបស់អ្នកបម្រើព្រះករុណា។ ពួកគេនឹងប្រមូលដោយដៃគេផ្ទាល់នូវអ្វីដែលគេពេញចិត្ត»។
[7]បន្ទាប់មក ស្តេចស្រុកអ៊ីស្រាអែលបានកោះហៅចាស់ទុំទាំងអស់ ហើយនិយាយទៅពួកគេថា៖ «សូមកត់ត្រាទុក ហើយដឹងថាអ្នកនេះកំពុងរកបញ្ហាដាក់ខ្លួនហើយ។
គេបាននាំសារមកយើង ដើម្បីយកមហេសីយើង បុត្រយើង ប្រាក់ និងមាស ហើយនិងមិនបានបដិសេធនឹងគេទេ»។[8]ពួកចាស់ទុំទាំងអស់
និងប្រជាជនទាំងអស់ទូលទៅព្រះបាទអហាប់ថា៖ «កុំឲ្យស្តាប់គេ ឬយល់ព្រមជាមួយសំណើនោះឡើយ»។
[9]ដូច្នេះ ព្រះបាទអហាប់បានទូលទៅអ្នកនាំសាររបស់ព្រះបាទបេនហាដាដថា៖ «ចូរប្រាប់ទៅស្តេចដ៏ជាចៅហ្វាយរបស់យើងថា៖
«យើងយល់ព្រមគ្រប់យ៉ាងដែលព្រះអង្គនឹងបញ្ជូនអ្នកបម្រើរបស់ព្រះអង្គមកលើកទីមួយ ប៉ុន្តែ យើងមិនអាចទទួលយកសំណើទីពីរបានដាច់ខាត»។ ដូច្នេះ
អ្នកនាំពាក្យបានចេញទៅហើយនាំពាក្យទាំងនេះទៅព្រះបាទបេនហាដាដវិញ។[10]បន្ទាប់មក ព្រះបាទបេនហាដាដបាននាំសារត្រឡប់មកព្រះបាទអហាប់វិញថា៖
«សូមឲ្យព្រះទាំងឡាយបានប្រព្រឹត្តជាមួយយើង ហើយក៏លើសទៅទៀត
បើផេះនៅស្រុកសាមារីនឹងគ្រប់គ្រាន់សម្រាប់ប្រជាជនដែលដើរតាមយើងមានមួយក្តាប់ម្នាក់នោះ»។
[11]ស្តេចស្រុកអ៊ីស្រាអែលបានឆ្លើយថា៖ «សូមប្រាប់ព្រះបាទបេនហាដាដថា៖ «គ្មាននរណាម្នាក់ដែលទើបតែចេញទៅច្បាំង នឹងអួតអាងដូចអ្នកច្បាំងឈ្នះនោះឡើយ»។
[12]នៅពេលដែលព្រះបាទបេនហាដាដបានឮសារនេះនៅពេលដែលស្តេចកំពុងផឹកស្រា គឺស្តេច និងស្តេចជាច្រើនទៀតដែលនៅក្រោមស្តេចដែលនៅក្រោមតង់។
ព្រះបាទបេនហាដាដបានបញ្ជាជាទៅអ្នកបម្រើរបស់ទ្រង់ថា៖ «សូមតម្រង់ជួរតាមតួនាទីដើម្បីធ្វើសង្គ្រាម»។ ដូច្នេះ ពួកគេបានរៀបចំខ្លួនតាមតួនាទី
ហើយវាយប្រហារក្រុង។
[13]បន្ទាប់មក មានព្យាការីម្នាក់បានចូលមកគាល់ព្រះបាទអហាប់ជាស្តេចស្រុកអ៊ីស្រាអែល ហើយទូលថា៖ «ព្រះអម្ចាស់មានបន្ទូលថា៖
«តើអ្នកមានឃើញទាហានដ៏អង់អាចទាំងនេះទេ? មើល យើងនឹងប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នកនៅថ្ងៃនេះ ហើយអ្នកនឹងដឹងថាយើងជាព្រះអម្ចាស់»។
[14]ព្រះបាទអហាប់ទូលថា៖ «តើតាមរយៈអ្នកណា»។ ព្រះអម្ចាស់ទូលថា៖ «តាមរយៈអ្នកដឹកនាំវ័យក្មេងម្នាក់ដែលជាអ្នកគ្រប់គ្រងស្រុក»។ បន្ទាប់មក
ព្រះបាទអហាប់ទូលថា៖ «តើនរណាជាអ្នកចាប់ផ្តើមក្នុងសង្គ្រាមនោះ»? ព្រះអម្ចាស់ឆ្លើយថា៖ «គឺអ្នក»។[15]បន្ទាប់មក ព្រះបាទអហាប់រាប់អ្នកគ្រប់គ្រងស្រុកឃើញថាមាន
២៣២នាក់។ បន្ទាប់ពីនាក់នោះ ស្តេចក៏ឲ្យគេរាប់ទាហានទាំងអស់ ទាហានអ៊ីស្រាអែលទាំងអស់មានប្រាំពីរពាន់អ្នក។
[16]ពួកគេបានចេញដំណើរនៅថ្ងៃត្រង់។ ព្រះបាទបេនហាដាដបានផឹកស្រាស្រវឹងនៅក្នុងតង់ ទាំងស្តេច និងស្តេចទាំងសាមសិបពីរអង្គទៀត ដែលគាំទ្រស្តេច។
[17]អ្នកដឹកនាំវ័យក្មេងដែលជាអ្នកគ្រប់គ្រងស្រុកបានចេញទៅមុន។ បន្ទាប់មក ពួកអ្នកស៊ើបការណ៍ដែលស្តេចបានចាត់ទៅបានមកប្រាប់ស្តេចថា៖
«មានមនុស្សជាច្រើនចេញពីស្រុកសាម៉ារីមកហើយ»។
[18]ព្រះបាទបេនហាដាដទូលថា៖ «មិនថាគេមកដោយសន្តិភាពឬដោយចង់បង្កសង្គ្រាមទេ ចូរទុកជីវិតឲ្យគេ»។[19]ដូច្នេះ
អ្នកដឹកនាំវ័យក្មេងដែលជាអ្នកគ្រប់គ្រងស្រុកទាំងនោះបានចេញមក ហើយពួកទាហានតាមពួកគេ។
[20]ពួកគេបានសម្លាប់សត្រូវ ហើយពួកអារ៉ាមបានគេចខ្លួន។ ពួកអ៊ីស្រាអែលបានដេញតាមពួកគេ។ ព្រះបាទបេនហាដាដជាស្តេចស្រុកអារ៉ាមបានគេចខ្លួនដោយជិះសេះ
ជាមួយមេទ័ពសេះផ្សេងទៀត។[21]បន្ទាប់មក ស្តេចរបស់អ៊ីស្រាអែលចេញមក ហើយវាយប្រហារទ័ពសេះ និងរទេះសេះ និងបានសម្លាប់ពួកអារ៉ាមឲ្យបរាជ័យយ៉ាងធ្ងន់ធ្ងរ។

generated on Wed Sep 10 16:16:32 2025

[22]ដូច្នេះ លោកព្យាការីបានមកជួបស្តេចអ៊ីស្រាអែល ហើយបានទូលស្តេចថា៖ «ចូរចេញទៅ ពង្រឹងកម្លាំងរបស់ទ្រង់ ហើយត្រូវដឹងថាត្រូវរៀបចំផែនការយ៉ាងណា
ព្រោះនៅឆ្នាំក្រោស្តេចស្រុកអារ៉ាមនឹងឡើងមកវាយអ្នកម្តងទៀត»។[23]អ្នកបម្រើរបស់ស្តេចអារ៉ាមបានទូលទៅស្តេចថា៖ «ព្រះរបស់ពួកគេជាព្រះនៃភ្នំទាំងឡាយ។
ដោយហេតុនេះហើយបានជាពួកគេខ្លាំងជាងយើង។ ប៉ុន្តែឥឡូវនេះ ចូរយើងរៀបផែនការវាយពួកគេម្តងទៀត ហើយច្បាស់ណាស់ថាយើងនឹងខ្លាំងជាងពួកគេ។
[24]ដូច្នេះ ស្តេចត្រូវធ្វើបែបនេះ៖ ចូរដកតំណែងស្តេចទាំងអស់ ហើយឲ្យមេទ័ពជំនួសកន្លែងពួកគេ។[25]សូមបង្កើតកងទ័ពដូចជាកងទ័ពដែលស្តេចបានបាត់បង់ សេះ
និងរទេះចំបាំងស្មើមុន ដូច្នេះយើងនឹងអាចរៀបផែនការវាយពួកគេបាន។ នោះយើងនឹងមានប្រៀបជាងគេមិនខាន»។ ដូច្នេះ
ព្រះបាទបេនហាដាដស្តាប់តាមយោបល់របស់ពួកគេហើយបានធ្វើតាមពួកគេ។
[26]នៅដើមឆ្នាំថ្មី ព្រះបាទបេនហាដាដប្រមូលជនជាតិអារ៉ាម ហើយឡើងទៅក្រុងអាផែក ដើម្បីវាយជនជាតិអ៊ីស្រាអែល។[27]ប្រជាជនអ៊ីស្រាអែលបានប្រមូលគ្នា
ហើយបានវាយប្រឆាំងពួកគេវិញ។ ប្រជាជនអ៊ីស្រាអែលបានបោះជំរំនៅមុខពួកគេដូច ជាពពែពីរហ្វូងតូចៗ ប៉ុន្តែជនជាតិអារ៉ាមបាននៅពេញនៅក្នុងតំបន់នោះ។
[28]បន្ទាប់មក អ្នកជំនិតរបស់ព្រះអម្ចាស់បានមកជិត ហើយបានទូលទៅស្តេចស្រុកអ៊ីស្រាអែលថា៖ «ព្រះអម្ចាស់មានបន្ទូលថា៖
«ដោយសារតែជនជាតិអារ៉ាមបាននិយាយថាព្រះអម្ចាស់ជាព្រះនៃភ្នំទាំងឡាយ ប៉ុន្តែ ទ្រង់មិនមែនជាព្រះនៃជ្រលងទាំងឡាយឡើយ
ហើយអ្នកនឹងដឹងថាយើងជាព្រះអម្ចាស់»។
[29]ដូច្នេះ ជនជាតិអារ៉ាមបានបោះជំរំទល់មុខគ្នាអស់រយៈពេលប្រាំពីរថ្ងៃ។ បន្ទាប់មក នៅថ្ងៃទីប្រាំពីរការប្រយុទ្ធចាប់ផ្តើម។
ប្រជាជនអ៊ីស្រាអែលបានសម្លាប់ទ័ពថ្មើរជើងជនជាតិអារ៉ាមអស់ ១០០, ០០០នាក់ក្នុងរយៈពេលមួយថ្ងៃ។[30]អ្នកផ្សេងទៀតគេចខ្លួនទៅអាផែក ទៅក្នុងក្រុង
ហើយជញ្ជាំងក្រុងបានបាក់រលំនៅលើមនុស្ស ២៧, ០០០នាក់ដែលនៅសល់។ ព្រះបាទបេនហាដាដបានគេចខ្លួនទៅក្នុងក្រុង ចូលទៅក្នុងបន្ទប់ខាងក្នុង។
[31]អ្នកបម្រើរបស់ព្រះបាទបេនហាដាដបានទូលទៅស្តេចថា៖ «ចូរមើលឥឡូវនេះ យើងបានឮថាស្តេចស្រុកអ៊ីស្រាអែលជាស្តេចដែលមានព្រះទ័យមេត្តា។ ដូច្នេះ ទូលបង្គំ
ទាំងអស់គ្នានឹងយកបាវមកស្លៀក ហើយយកខ្សែពួរមកពាក់ក្បាលរបស់យើង រួចនាំគ្នាចេញទៅបង្ហាញខ្លួនចំពោះស្តេចអ៊ីស្រាអែល។ ប្រហែលជាស្តេចនឹងទុកជីវិត
ព្រះករុណា»។[32]ដូច្នេះ ពួកគេបានយកបាវមកស្លៀក ហើយយកខ្សែពួរមកពាក់ក្បាល រួចនាំគ្នាចេញទៅបង្ហាញខ្លួនចំពោះស្តេចអ៊ីស្រាអែល ហើយទូលថា៖
«ព្រះបាទបេនហាដាដជាអ្នកបម្រើរបស់ព្រះករុណាទូលថា៖ សូមទុកជីវិតឲ្យទូលបង្គំផង»។ ព្រះបាទអហាប់បានទូលថា៖ «តើស្តេចនៅទីនោះនៅរស់ទៀតឬ?
ស្តេចជាបងប្អូនរបស់យើង»។
[33]ឥឡូវនេះ អ្នកទាំងនោះបានទទួលសញ្ញាពីព្រះបាទអហាប់ ដូច្នេះ ពួកគេបានឆ្លើយទូលវិញភ្លាមៗថា៖ «ក្រាបទូល បងប្អូនរបស់ព្រះករុណានៅរស់នៅឡើយ»។ បន្ទាប់មក
ព្រះបាទអហាប់ទូលថា៖ «ចូរទៅនាំស្តេចមក»។ បន្ទាប់មក ព្រះបាទបេនហាដាដបានមកជួបស្តេច ហើយព្រះបាទអហាប់បានឲ្យបេនហាដាដជិះក្នុងរាជរថជាមួយទ្រង់។
[34]ព្រះបាទបេនហាដាដបានទូលទៅព្រះបាទអហាប់ថា៖ «ទូលបង្គំនឹងប្រគល់ក្រុងទាំងឡាយដែលបិតាទូលបង្គំបានយកពីបិតាព្រះករុណា
ហើយព្រះអង្គអាចបង្កើតផ្សារសម្រាប់ព្រះអង្គផ្ទាល់នៅក្រុងដាម៉ាស ដូចដែលបិតាទ្រង់បានធ្វើនៅក្រុងសាម៉ារីដែរ»។ ដូច្នេះ ព្រះបាទអហាប់បានចងសម្ពន្ធមេត្រីជាមួយទ្រង់
ហើយអនុញ្ញាតិឲ្យស្តេចត្រឡប់ទៅវិញ។
[35]មានបុរសម្នាក់ជាកូនរបស់ព្យាការីម្នាក់ បាននិយាយជាមួយព្យាការីម្នាក់ទៀតដោយព្រះបន្ទូលរបស់ព្រះអម្ចាស់ថា៖ «សូមវាយខ្ញុំមក»។ ប៉ុន្តែ
បុរសនោះបដិសេធមិនវាយលោកទេ។[36]បន្ទាប់មក លោកព្យាការីបាននិយាយជាមួយព្យាការីម្នាក់ទៀតថា៖ «ដោយសារអ្នកមិនស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់
នៅពេលដែលអ្នកចេញពីខ្ញុំទៅ នោះសត្វតោនឹងសម្លាប់អ្នកមិនខាន»។ នៅពេលដែលបុរសនោះចេញទៅភ្លាម មានតោមួយមកសម្លាប់គាត់។
[37]បន្ទាប់មក លោកព្យាការីនោះបានជួបបុរសម្នាក់ទៀតហើយនិយាយថា៖ «សូមវាយខ្ញុំមក»។ ដូច្នេះ បុរសនោះក៏វាយលោកធ្វើឲ្យលោកមានរបួស។[38]បន្ទាប់មក
លោកព្យាការីនោះបានចេញទៅ ហើយរង់ចាំស្តេចនៅតាមផ្លូវ គាត់បានក្លែងខ្លួន ដោយរំមុខរបស់គាត់ជិត។
[39]នៅពេលដែលស្តេចយាងមកតាមនោះ ព្យាការីនោះបានស្រែកឡើងថា៖ «អ្នកបម្រើរបស់ព្រះអង្គបានចេញទៅសមរភូមិ ហើយមានទាហានម្នាក់បានឈប់
ហើយបាននាំសត្រូវម្នាក់មកឲ្យទូលបង្គំហើយនិយាយថា៖ «ចូរមើលបុរសនេះផង។ ប៉ុន្តែ ក្រោយមកគាត់ក៏រត់បាត់ ដូច្នេះ ជីវិតរបស់អ្នកនឹងត្រូវសងសម្រាប់ជីវិតអ្នកនោះ
ឬក៏អ្នកត្រូវបង់ប្រាក់មួយដួង»។[40]ដោយសារអ្នកបម្រើរបស់ព្រះករុណាជាប់រវល់ទៅនេះទៅនោះ ទាហានរបស់សត្រូវក៏បានគេចខ្លួនបាត់»។ បន្ទាប់មក
ស្តេចអ៊ីស្រាអែលបាននិយាយថា៖ «នេះជាទោសដែលអ្នកត្រូវទទួល គឺអ្នកត្រូវសម្រេចចិត្តខ្លួនឯង»។
[41]បន្ទាប់ មកលោកព្យាការីបានដោះក្រណាត់បាំងមុខលោកចេញ ហើយស្តេចស្រុកអ៊ីស្រាអែលបានស្គាល់ថាលោកជាព្យាការីម្នាក់។[42]លោកព្យាការីបានទូលស្តេចថា៖
«ព្រះអម្ចាស់បានមានបន្ទូលថា៖ «ដោយសារតែអ្នកបានដោះលែងមនុស្សដែលយើងត្រូវសម្លាប់ពីក្នុងដៃអ្នក នោះជីវិតរបស់អ្នកត្រូវសងសម្រាប់ជីវិតរបស់អ្នកនោះ
ហើយប្រជាជនរបស់អ្នក សម្រាប់ប្រជាជនរបស់គេ»។[43]ដូច្នេះ ស្តេចស្រុកអ៊ីស្រាអែលបានវិលទៅដំណាក់របស់ស្តេចវិញទាំងមួម៉ៅ និងខឹង
ហើយស្តេចក៏មកដល់ស្រុកសាម៉ារី។

---

1 Kings 20:1
ព្រះបាទបេនហាដាដ
នេះជាឈ្មោះបុរសម្នាក់។
ស្តេចសម្ពន្ធមិត្តចំនួនសាមសិបពីរអង្គទៀត
ស្តេចសម្ពន្ធពីរអង្គ «ស្តេចសម្ពន្ធ ៣២អង្គ
ស្តេចសម្ពន្ធមិត្ត
«ស្តេចគ្រប់គ្រងក្រុមមនុស្សផ្សេងទៀត»
1 Kings 20:4
រឲ្យបានដូចព្រះករុណាមានរាជឱង្ការចុះ
នេះគឺជាការបង្ហាញអំពីការព្រមព្រៀងគ្នា។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំយល់ស្របនឹងអ្នក»
នៅថ្ងៃស្អែកថ្មើរនេះ
«ថ្ងៃស្អែកនៅពេលតែមួយនឹងពេលឥឡូវនេះ»
អ្វីដែលគេពេញចិត្ត
«ផ្តាប់ភ្នែករបស់ពួកគេ» គឺសម្រាប់ការសម្លឹងមើលអ្វីមួយហើយចង់បានវា។
ការបកប្រែផ្សេងទៀត «អ្វីដែលគាប់ចិត្តដល់ពួកគេ»
1 Kings 20:7
នៃដី
« ដី» គឺជាការយកចិត្តទុកដាក់សម្រាប់ប្រជាជនទាំងអស់ដែលរស់នៅទីនោះ។
ការបកប្រែផ្សេងទៀត «នៃប្រជាជនអ៊ីស្រាអែល»
សូមកត់ត្រាទុក ហើយដឹងថា
« កត់ចំណាំ» គឺជាសំនួនវោហារស័ព្ទដើម្បីសង្កេតមើលដោយយកចិត្តទុកដាក់។
ការបកប្រែផ្សេងទៀត «យកចិត្តទុកដាក់ទៅលើ»
មិនបានបដិសេធនឹងគេទេ
នេះអាចបង្ហាញជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ខ្ញុំបានយល់ស្របនឹងការទាមទាររបស់គាត់»
1 Kings 20:9
សូមឲ្យព្រះទាំងឡាយបានប្រព្រឹត្តជាមួយយើង ហើយក៏លើសទៅទៀត
នេះជាការសច្ចាដោយសង្កត់ធ្ងន់យ៉ាងខ្លាំង។ សូមមើលការបកប្រែនៅក្នុងជំពូក
១៩:១។
បើផេះនៅស្រុកសាមារីនឹងគ្រប់គ្រាន់សម្រាប់ប្រជាជនដែលដើរតាមយើងមានមួយក្តាប់ម្នាក់នោះ
បេនហាដាដគំរាមថាកងទ័ពរបស់ទ្រង់នឹងបំផ្លាញអ្វីៗទាំងអស់នៅក្រុងសាម៉ារី។
1 Kings 20:11
សូមប្រាប់ព្រះបាទបេនហាដាដថា៖ «គ្មាននរណាម្នាក់ដែលទើបតែចេញទៅច្បាំង នឹងអួតអាងដូច
អ្នកច្បាំងឈ្នះនោះឡើយ
នេះគឺជាការបញ្ចេញមតិដើម្បីផ្តល់ដំបូន្មាន។ «ការពាក់អាវពាសដែក»
គឺជាការត្រៀមខ្លួនសម្រាប់ការប្រយុទ្ធ។
ប្រាប់ព្រះបាទបេនហាដាដថាកុំអួតខ្លួនដូចជាអ្នកបានឈ្នះការប្រយុទ្ធដែលអ្នកមិនទាន់បានធ្វើសង្គ្រាមនៅ
1 Kings 20:13
បន្ទាប់មក

generated on Wed Sep 10 16:16:32 2025

ពាក្យថា «មើល» ដាស់តឿនយើង
ឲ្យឃើញពីការលេចចេញជារូបរាងរបស់មនុស្សថ្មីនៅក្នុងរឿង។
ភាសារបស់អ្នកអាចមានរបៀបបកប្រែឃ្លានេះ។
តើអ្នកមានឃើញទាហានដ៏អង់អាចទាំងនេះទេ?
ព្រះអម្ចាស់សួរសំណួរនេះដើម្បីបញ្ជាក់ពីទំហំនិងកម្លាំងរបស់កងទ័ពស្តេចបេនហាដាដ។
ការបកប្រែផ្សេងទៀត «មើលកងទ័ពដ៏អស្ចារ្យនេះ» ។
មើល យើងនឹងប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នកនៅថ្ងៃនេះ
ពាក្យ «មើល»
នៅទីនេះប្រាប់យើងឲ្យយកចិត្តទុកដាក់លើព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលនឹងកើតឡើង។
ប្រគល់ពួកគេមកក្នុងកណ្តាប់ដៃអ្នក
ត្រង់នេះពាក្យថា «ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«ឲ្យអ្នកនូវជ័យជម្នះលើកងទ័ពនោះ»
តាមរយៈអ្នក
ស្តេចអហាប់លែងមានបន្ទូលពាក្យថា តើអ្នកនឹងធ្វើបែបនេះតាមរយៈអ្នកណា?
ព្រះបាទអហាប់រាប់អ្នកគ្រប់គ្រងស្រុក
«ស្តេចអហាប់ប្រមូលផ្តុំពួកនាយទាហានវ័យក្មេង»
២៣២នាក់
«ពីររយសាមសិបពីរនាក់»
ទាហានទាំងអស់ ទាហានអ៊ីស្រាអែលទាំង
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។
ប្រាំពីរពាន់អ្នក
៧០០០នាក់
1 Kings 20:16
ពួកគេបានចេញដំណើរ
ត្រង់នេះពាក្យថា «ពួកគេ» សំដៅទៅលើកងទ័ពអ៊ីស្រាអែល។
ស្តេចទាំងសាមសិបពីអង្គទៀត ដែលគាំទ្រស្តេច
ស្តេចពីរជាស្តេចគាំទ្រ បកប្រែដូចដែលអ្នកបានធ្វើនៅជំពូក ២០:១ ។
ពួកអ្នកស៊ើបការណ៍ដែលស្តេចបានចាត់ទៅបានមកប្រាប់ស្តេចថា
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកស៊ើបការណ៍ដែលស្តេចបេនហាដាដបានបញ្ជូនឲ្យទៅប្រាប់ស្តេចថា»
អ្នកស៊ើបការណ៍
អ្នកស៊ើបការណ៍គឺជាទាហានដែលត្រូវបានបញ្ជូនទៅប្រមូលព័ត៌មានពីសត្រូវ។
1 Kings 20:18
ព្រះបាទបេនហាដាដទូលថា
គេយល់ថាស្តេចបេនហាដាដកំពុងមានបន្ទូលជាមួយទាហានរបស់ទ្រង់។
ការបកប្រែផ្សេងទៀត «ស្តេចបេនហាដាដបាននិយាយទៅកាន់ទាហានរបស់ទ្រង់»
មិនថាគេមក...ទុកជីវិត
ត្រង់នេះ «ពួកគេ» និង «ពួកគេ» សំដៅទៅលើកងទ័ពអ៊ីស្រាអែល។
ដូច្នេះ អ្នកដឹកនាំវ័យក្មេង
«នាយទាហានអ៊ីស្រាអែលវ័យក្មេង ... កងទ័ពអ៊ីស្រាអែលបានដើរតាម»
1 Kings 20:20
ពួកអ៊ីស្រាអែលបានដេញតាមពួកគេ
«អ៊ីស្រាអែល» គឺជាថ្នាំសម្រាប់ទាហានទាំងអស់នៃប្រជាជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ពួកទាហានអ៊ីស្រាអែលបានដេញតាមពួកគេ» ។
ស្តេចរបស់អ៊ីស្រាអែលចេញមក ហើយវាយប្រហារ
« ស្តេច» គឺផ្តោតលើស្តេចនិងទាហានទាំងអស់ដែលកំពុងបម្រើនៅក្រោមស្តេច។
ការបកប្រែផ្សេងទៀត
«ស្តេចអ៊ីស្រាអែលនិងទាហានរបស់ទ្រង់បានចេញមកវាយប្រហារ»
1 Kings 20:22
ពង្រឹងកម្លាំងរបស់ទ្រង់
«ខ្លួនអ្នក» តំណាងដោយកងទ័ពរបស់ស្តេច។ ការបកប្រែផ្សេងទៀត
«ពង្រឹងកម្លាំងរបស់អ្នក»
ត្រូវដឹងថាត្រូវរៀបចំផែនការ
ពាក្យទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា និងត្រូវបានផ្សំសម្រាប់ការសង្កត់ធ្ងន់។
ការបកប្រែផ្សេងទៀត «កំណត់»
នៅឆ្នាំក្រោស្តេចស្រុកអារ៉ាមនឹងឡើងមកវាយអ្នកម្តងទៀត
អាចមានន័យថា១) «នៅនិទាឃរដូវឆ្នាំក្រោយ» ឬ ២) «នៅពេលនេះ
នៅឆ្នាំក្រោយ»។
ចូរយើងរៀបផែនការវាយពួកគេម្តងទៀត ហើយច្បាស់ណាស់ថាយើងនឹងខ្លាំងជាង
ពាក្យថា «យើង» និង «យើង» គឺសំដៅទៅលើអ្នកបម្រើស្តេចនិងកងទ័ពទាំងអស់។
1 Kings 20:24
ចូរដកតំណែងស្តេចទាំងអស់ ហើយឲ្យមេទ័ពជំនួសកន្លែងពួកគេ
«អ្នកត្រូវដកស្តេចសាមសិបពីរអង្គដែលកំពុងដឹកនាំកងទ័ពរបស់អ្នក»
1 Kings 20:26
អាផែក
នេះជាឈ្មោះនៃទីក្រុងមួយ។
ដើម្បីវាយជនជាតិអ៊ីស្រាអែល
«អ៊ីស្រាអែល» តំណាងឲ្យកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន។ ការបកប្រែផ្សេងទៀត
«ដើម្បីប្រយុទ្ធនឹងកងទ័ពអ៊ីស្រាអែល»
ប្រជាជនអ៊ីស្រាអែលបានប្រមូលគ្នា ហើយបានវាយប្រឆាំងពួកគេវិញ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«កងទ័ពអ៊ីស្រាអែលក៏បានប្រមូលផ្តុំគ្នាដែរ
ហើយពួកមេបញ្ជាការបានប្រគល់អាវុធដែលពួកគេត្រូវការសម្រាប់ការប្រយុទ្ធ»
ដូច ជាពពែពីរហ្វូងតូចៗ
ឧទាហរណ៍នេះប្រៀបធៀបកងទ័ពអ៊ីស្រាអែលទៅនឹងពពែតូចៗពីរហ្វូង។
ការបកប្រែផ្សេងទៀត
«កងទ័ពអ៊ីស្រាអែលមើលទៅដូចជាតូចនិងខ្សោយដូចជាពពែពីរហ្វូង» ។
1 Kings 20:28
អ្នកជំនិតរបស់ព្រះអម្ចាស់
នេះគឺជាងារមួយទៀតសំរាប់ព្យាការី។
ដាក់កងទ័ពដ៏អស្ចារ្យនេះទៅក្នុងដៃរបស់អ្នក
ត្រង់នេះពាក្យថា «ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«ឲ្យអ្នកនូវជ័យជម្នះលើកងទ័ពដ៏អស្ចារ្យនេះ»
1 Kings 20:29
ប្រាំពីរថ្ងៃ
«៧ថ្ងៃ»
១០០,០០០នាក់
«មួយរយពាន់»
ទ័ពថ្មើរជើង
ទាហានជើងគោកគឺជាទាហានដែលដើរដោយថ្មើរជើង។
អ្នកផ្សេងទៀតគេចខ្លួនទៅអាផែក
ការបញ្ចេញមតិ «នៅសល់» សន្មត់ថាពាក្យរបស់ទាហានអារ៉ាម។
ការបកប្រែផ្សេងទៀត «ទាហានអារ៉ាមនៅសេសសល់»
អាផែក
នេះជាឈ្មោះទីក្រុងមួយ។
២៧,០០០នាក់
ប្រាំពីរពាន់ «២៧,០០០»
1 Kings 20:31
ចូរមើលឥឡូវនេះ
នេះសង្កត់ធ្ងន់ទៅលើអ្វីដែលពួកគេនឹងនិយាយ។ ការបកប្រែផ្សេងទៀត «ស្តាប់» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក»
បានយកបាវមកស្លៀក ហើយយកខ្សែពួរមកពាក់ក្បាល
នេះគឺជាសញ្ញានៃការចុះចាញ់។
តើស្តេចនៅទីនោះនៅរស់ទៀតឬ?
ស្តេចអហាប់សួរសំណួរនេះដើម្បីបង្ហាញការភ្ញាក់ផ្អើល។ ការបកប្រែផ្សេងទៀត
«ខ្ញុំភ្ញាក់ផ្អើលដែលគាត់នៅរស់!»
ស្តេចជាបងប្អូនរបស់យើង
«បងប្អូនរបស់ខ្ញុំ» គឺជាពាក្យប្រៀបធៀបសម្រាប់នរណាម្នាក់ដែលជាមិត្តល្អ។
ការបកប្រែផ្សេងទៀត «គាត់ដូចជាបងប្អូនប្រុសរបស់ខ្ញុំ» ឬ «គាត់ដូចជាគ្រួសារ»
1 Kings 20:33
ឥឡូវនេះ អ្នកទាំងនោះ
ពាក្យ «ឥឡូវនេះ» មិនមានន័យថា «នៅពេលនេះទេ»
ប៉ុន្តែត្រូវបានប្រើដើម្បីទាក់ទាញការយកចិត្តទុកដាក់លើចំណុចសំខាន់ដែលមាននៅខាងក្រោម។
ទទួលសញ្ញាពីព្រះបាទអហាប់
«សញ្ញា» គឺជាសកម្មភាពដែលផ្តល់អត្ថន័យ។ ការបកប្រែផ្សេងទៀត
«ចំពោះសកម្មភាពណាមួយពីស្តេចអហាប់ដែលនឹងបង្ហាញពួកគេថាស្តេចអហាប់ចង់មានក្តីមេត្តាករុណា»
1 Kings 20:35

generated on Wed Sep 10 16:16:32 2025

មានបុរសម្នាក់ជាកូនរបស់ព្យាការីម្នាក់
«សមាជិកម្នាក់នៃក្រុមព្យាការី»
ដោយព្រះបន្ទូលរបស់ព្រះអម្ចាស់
«ពាក្យ» គឺសម្រាប់សារ។ ការបកប្រែផ្សេងទៀត
«ដូចដែលព្រះអម្ចាស់បានប្រាប់គាត់ឲ្យធ្វើ»
អ្នកមិនស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់
«សំលេង» គឺជាពាក្យសម្រាប់អ្វីដែលព្រះអម្ចាស់បានបញ្ជា។ ការបកប្រែផ្សេងទៀត
«អ្នកមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ទេ»
1 Kings 20:39
អ្នកបម្រើរបស់ព្រះអង្គបានចេញទៅ
ហោរាបានចាត់ទុកខ្លួនគាត់ជាមនុស្សទី៣ថាជាសញ្ញានៃការគោរពដល់ស្តេច។
ទៅសមរភូមិ
«កំដៅនៃសមរភូមិ»
គឺជាសំនួនរោហារស័ព្ទដើម្បីបង្ហាញពីការប្រយុទ្ធខ្លាំងក្លាបំផុត។
ការបកប្រែផ្សេងទៀត «ទៅកន្លែងដែលមានការប្រយុទ្ធខ្លាំងបំផុត»
ដូច្នេះ ជីវិតរបស់អ្នកនឹងត្រូវសងសម្រាប់ជីវិតអ្នកនោះ
«បន្ទាប់មកអ្នកនឹងស្លាប់នៅកន្លែងរបស់អ្នកនោះ»
ប្រាក់មួយដួង
ប្រាក់មួយដួងគឺជាឯកតាទម្ងន់ស្មើនឹងប្រហែល ៣៤ គីឡូក្រាម។
ការបកប្រែផ្សេងទៀត «ប្រាក់ ៣៤ គីឡូក្រាម»
ទៅនេះទៅនោះ
នេះគឺតំណាងឲ្យភាពមមាញឹកនិងការយកចិត្តទុកដាក់ខ្ពស់។ ការបកប្រែផ្សេងទៀត
«ធ្វើអ្វីផ្សេងទៀត» ឬ «ធ្វើរឿងនេះនិងដូច្នេះ»
1 Kings 20:41
បានដោះលែងមនុស្សដែលយើងត្រូវសម្លាប់ពីក្នុងដៃអ្នក
នៅទីនេះពាក្យថា «ដៃ» គឺដំណាងឲ្យអំណាច។ ការបកប្រែផ្សេងទៀត
«ត្រូវបានដោះលែង» រឺ «ទុកជីវិត»
នោះជីវិតរបស់អ្នកត្រូវសងសម្រាប់ជីវិតរបស់អ្នកនោះ ហើយប្រជាជនរបស់អ្នក
សម្រាប់ប្រជាជនរបស់គេ
«អ្នកនឹងស្លាប់ជំនួសកន្លែងរបស់គាត់ហើយប្រជាជនរបស់អ្នកនឹងត្រូវស្លាប់ជំនួសប្រជាជនរបស់គាត់»

---

21 [1]មួួយរយៈកន្លងទៅ លោកណាបោតជាអ្នកក្រុងយេសរាលមានចម្ការទំពាំងបាយជូរមួយ នៅជិតរាជវាំងព្រះបាទអហាប់ ជាស្តេចនៅក្រុងសាម៉ារី។
[2]ព្រះបាទអហាប់បាននិយាយទៅលោកណាបោតថា៖ «ចូរឲ្យចម្ការទំពាំងបាយជូរនេះមកឲ្យយើង ដូច្នេះ យើងអាចយកវាទៅធ្វើជាច្បារបន្លែ
ព្រោះដីនេះនៅជិតវាំងរបស់យើង។ ជាការផ្លាស់ប្តូរ យើងនឹងឲ្យចម្ការទំពាំងបាយជូរល្អជាងនេះដល់អ្នក ឬក៏យើងអាចចេញលុយឲ្យអ្នកតាមតម្លៃរបស់វា បើអ្នកចង់បាន។
[3]លោកណាបោតទូលព្រះបាទអហាប់ថា៖ «ព្រះអម្ចាស់បានហាមមិនឲ្យទូលបង្គំលក់ដីដែលជាមរតករបស់បុព្វបុរសទូលបង្គំនេះដល់ព្រះករុណាឡើយ»។[4]ដូច្នេះ
ព្រះបាទអហាប់ចេញទៅវាំងវិញដោយមួម៉ៅ និងខឹងសម្បារដោយសារតែចម្លើយរបស់លោកណាបោតជាអ្នកស្រុកយេសរាលបានទូលស្តេចថា៖
«ព្រះអម្ចាស់បានហាមមិនឲ្យទូលបង្គំលក់ដីដែលជាមរតករបស់បុព្វបុរសទូលបង្គំនេះដល់ព្រះករុណាឡើយ»។ ស្តេចក៏បានទម្រេតនៅលើក្រឡាបន្ទំរបស់ទ្រង់ បែរមុខចេញ
ហើយមិនសោយអ្វីទាំងអស់។
[5]ព្រះនាងយេសិបិលជាមហេសីស្តេចបានមកជួបស្តេច ហើយទូលទៅស្តេចថា៖ «ហេតុអ្វីបានជាព្រះករុណាក្រៀមក្រំម្លេ៉ះ ហើយព្រះអង្គមិនសោយអ្វីទាំងអស់ដូច្នេះ»?
[6]ស្តេចតបទៅនាងថា៖ «យើងបាននិយាយជាមួយណាបោតជាអ្នកស្រុកយេសរាល ហើយបាននិយាយទៅគាត់ថា៖ «ចូរលក់ចម្ការទំពាំងបាយជូរឲ្យយើង
ឬក៏អ្នកអាចដូរជាមួយចម្ការទំពាំងបាយជូររបស់យើងក៏បាន»។ បន្ទាប់មក គាត់ទូលយើងថា៖ «ទូលបង្គំមិនឲ្យចម្ការទំពាំងបាយជូររបស់ទូលបង្គំដល់ព្រះអង្គឡើយ»។
[7]ដូច្នេះ នាងយេសិបិលជាព្រះមហេសីស្តេចបានទូលទៅស្តេចថា៖ «តើព្រះករុណាមិននៅតែគ្រប់គ្រងលើស្រុកអ៊ីស្រាអែលទេឬ»? ចូរតើនឡើងហើយសោយព្រះស្ងោយចុះ
ចូរស្តេចមានចិត្តសប្បាយឡើង។ ខ្ញុំម្ចាស់នឹងយកចម្ការទំពាំងបាយជូររបស់ណាបោតជាអ្នកស្រុកយេសរាលមកថ្វាយព្រះអង្គ»។
[8]ដូច្នេះ ព្រះនាងយេសិបិលបានសរសេរសំបុត្រនៅក្នុងនាមព្រះបាទអហាប់ បានបោះត្រារបស់ស្តេច បានផ្ញើសំបុត្រនោះទៅពួកចាស់ទុំ
និងទៅពួកអ្នកមានដែលបានអង្គុយជាមួយស្តេចក្នុងអង្គប្រជុំ និងអ្នកដែលរស់នៅជិតលោកណាបោត។[9]ព្រះនាងសរសេរសំបុត្រថា៖ «សូមប្រកាសធ្វើពិធីបុណ្យ
ហើយឲ្យលោកណាបោតអង្គុយនៅកន្លែងពិសេសជាងគេ។[10]ហើយចូរដាក់មនុស្សមិនស្មោះត្រង់ពីរនាក់ជាមួយលោកដែរ ហើយឲ្យពួកគេចោទប្រកាន់គាត់ថា៖
«អ្នកបានដាក់បណ្តាសារព្រះអម្ចាស់ និងដាក់បណ្តាសារស្តេច»។ បន្ទាប់មក ចូរយកគាត់ចេញក្រៅ ហើយសម្លាប់គាត់នឹងដុំថ្មទៅ។
[11]ដូច្នេះ បុរសនៅក្រុងរបស់គាត់ ពួកចាស់ទុំ និងពួកអ្នកមានដែលនៅជិតក្រុងរបស់ណាបោត បានធ្វើដូចជានាងយេសិបិលបានរៀបរាប់ប្រាប់ពួកគេ
ដូចដែលបានសរសេរនៅក្នុងសំបុត្រដែលនាងបានធ្វើទៅពួកគេ។[12]ពួកគេបានប្រកាសពិធីបុណ្យ ហើយឲ្យលោកណាបោតអង្គុយនៅកន្លែងកិត្តិយស។
[13]អ្នកមិនស្មោះត្រង់ពីរនាក់បានមកអង្គុយមុខលោកណាបោត ពួកគេបានចោទប្រកាន់លោកនៅមុខមនុស្សគ្រប់គ្នាថា៖
«លោកណាបោតបានដាក់បណ្តាសារទាំងព្រះអម្ចាស់ ទាំងមនុស្ស»។ បន្ទាប់មក គេយកលោកចេញក្រៅក្រុងហើយបានគប់សម្លាប់លោកដោយដុំថ្ម។[14]បន្ទាប់មក
ពួកចាស់ទុំបានផ្ញើពាក្យទៅព្រះនាងយេសិបិលថា៖ «លោកណាបោតបានត្រូវគេគប់នឹងថ្ម ហើយលោកបានស្លាប់ហើយ»។
[15]ដូច្នេះ នៅពេលដែលនាងយេសិបិលបានឮថាលោកណាបោតបានត្រូវគេគប់សម្លាប់នឹងថ្មរួចមក ព្រះនាងបានទូលទៅព្រះបាទអហាប់ថា៖ «ចូរក្រោកឡើង
ហើយយកមរតករបស់ណាបោតជាអ្នកស្រុកយេសរាលទៅ ដែលលោកធ្លាប់បដិសេធមិនព្រមលក់ឲ្យព្រះអង្គ ដោយសារលោកមិននៅរស់ទៀតទេ
លោកបានស្លាប់ហើយ»។[16]នៅពេលដែលស្តេចអហាប់បានឮថាលោកណាបោតបានស្លាប់ហើយ ស្តេចក៏ក្រោកឡើង
ហើយចុះទៅចម្ការទំពាំងបាយជូររបស់លោកណាបោតជាអ្នកស្រុកយេសរាល ហើយយកជាកម្មសិទ្ធិរបស់ទ្រង់ផ្ទាល់។
[17]នៅពេលដែលព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកអេលីយ៉ាជាអ្នកភូមិធេសប៊ីថា៖[18]«ចូរក្រោកឡើង និងចេញទៅជួបអហាប់ជាស្តេចស្រុកអ៊ីស្រាអែល
ដែលគង់នៅស្រុកសាម៉ារី។ ស្តេចគង់នៅចម្ការរបស់លោកណាបោត ជាកន្លែងដែលស្តេចបានយកជារបស់ខ្លួន។
[19]អ្នកត្រូវនិយាយជាមួយស្តេច ហើយទូលថា ព្រះអម្ចាស់មានបន្ទូលថា៖ «តើអ្នកបានសម្លាប់ហើយរឹបអូសយកមរតករបស់គេដូច្នេះឬ»? បន្ទាប់មក
អ្នកត្រូវប្រាប់គាត់ថាព្រះអម្ចាស់មានបន្ទូលថា៖ «នៅកន្លែងដែលឆ្កែបានលិតឈាមរបស់ណាបោត នៅកន្លែងនោះឆ្កែនឹងលិតឈាមរបស់អ្នកដែរ
មែនហើយគឺឈាមរបស់អ្នក»។[20]ព្រះបាទអហាប់បានមានរាជឱង្ការទៅលោកអេលីយ៉ាថា៖ «តើអ្នកបានមកយើងទៀតហើយឬ សត្រូវរបស់យើងអើយ»?
លោកអេលីយ៉ាឆ្លើយថា៖ «ទូលបង្គំមកជួបព្រះករុណា ព្រោះព្រះករុណាបានលក់ខ្លួនរបស់ទ្រង់ទៅធ្វើការអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់។
[21]ព្រះអម្ចាស់មានបន្ទូលនេះមកព្រះករុណា៖ «មើល យើងនឹងនាំគ្រោះមហន្តរាយមកលើអ្នក យើងនឹងលុបបំបាត់ពូជពង្សរបស់អ្នក យើងកាត់អ្នកចេញពីប្រុសៗក្នុងក្រុម
គ្រួសាររបស់អ្នក ទាំងអ្នកងារ ទាំងអ្នកជានៅស្រុកអ៊ីស្រាអែល។[22]យើងនឹងធ្វើឲ្យគ្រួសាររបស់អ្នកដូចជាគ្រួសាររបស់ស្តេចយេរ៉ូបោម កូននេបាត និងដូចគ្រួសាររបស់បាសា
ជាកូនរបស់អហ៊ីយ៉ាដែរ ព្រោះអ្នកធ្វើឲ្យយើងខឹង ព្រមទាំងនាំប្រជាជនអ៊ីស្រាអែលប្រព្រឹត្តអំពើបាប»។
[23]ព្រះអម្ចាស់ក៏បានមានបន្ទូលទាក់ទងនឹងព្រះនាងយេសិបិលថា៖ «ឆ្កែនិងស៊ីព្រះនាងយេសិបិលនៅខាងក្រោយកំពែងក្រុងយេសរាល»។
[24]គ្រប់គ្នាដែលនៅក្នុងគ្រួសាររបស់ស្តេចអហាប់ ហើយបានស្លាប់នៅក្នុងក្រុង ឆ្កែនឹងស៊ីអ្នកនោះ ហើយបក្សីនឹងស៊ីអ្នកដែលបានស្លាប់នៅទីវាល»។
[25]គ្មាននរណាម្នាក់ដូចអហាប់ឡើយ ដែលបានលក់ខ្លួនទៅធ្វើអំពើអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ ដែលមានព្រះនាងយេសិបិលជាមហេសីជាអ្នក
ញុះញង់ក្នុងការប្រព្រឹត្តបាប។[26]ព្រះបាទអហាប់បានធ្វើរឿងគួរឲ្យស្អប់ខ្ពើមដោយថ្វាយបង្គំរូបព្រះ ដូចដែលពួកអាម៉ូរីបានធ្វើ
គឺអស់អ្នកដែលព្រះអម្ចាស់បានបណ្តេញពួកគេចេញពីមុខប្រជាជនអ៊ីស្រាអែល។
[27]នៅពេលដែលព្រះបាទអហាប់បានឮពាក្យទាំងនេះ ស្តេចបានហែកសំលៀកបំពាក់ ហើយបានស្លៀកបាវ និងតមអាហារ ហើយស្តេចស្លៀកបាវ
ហើយក្រៀមក្រំយ៉ាងខ្លាំង។[28]បន្ទាប់មក ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់អេលីយ៉ា ជាអ្នកភូមិធេសប៊ីថា៖
[29]«តើអ្នកឃើញទេថាព្រះបាទអហាប់បានបន្ទាបខ្លួននៅមុខយើង? ដោយសារស្តេចបានបន្ទាបខ្លួននៅមុខយើង យើងនឹងមិននាំមហន្តរាយមកក្នុងរាជ្យរបស់ស្តេចទេ ប៉ុន្តែ
យើងនឹងធ្វើឲ្យគ្រោះកាចកើតមានចំពោះពូជពង្សរបស់គេ នៅជំនាន់ក្រោយវិញ»។

generated on Wed Sep 10 16:16:32 2025

1 Kings 21:1
មួយរយៈកន្លងទៅ
ឃ្លានេះសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង ហើយបង្ហាញថា
ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងនៅពេលក្រោយ មិនមែនលោក
ណាបោតជាម្ចាស់ចម្ការនៅពេលក្រោយទេ។
ប្រសិនបើភាសារបស់អ្នកមានរបៀបសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿងនេះអ្នកអាចពិចារណាប្រើវានៅទីនេះ
ការបកប្រែផ្សេងទៀត «ឥឡូវ នេះគឺជាអ្វីដែលបានកើតឡើងនៅពេលក្រោយ»
លោកណាបោតជាអ្នកក្រុងយេសរាល
នេះជាឈ្មោះរបស់បុរសម្នាក់មកពីក្រុងយេសរាល។
ស្តេចនៅក្រុងសាម៉ារី
« សាម៉ារី»
គឺជាទីក្រុងសំខាន់នៃអាណាចក្រអ៊ីស្រាអែលហើយទីនេះតំណាងឲ្យប្រជាជាតិទាំងមូល។
ការបកប្រែផ្សេងទៀត «ស្តេចនៃអ៊ីស្រាអែល»
1 Kings 21:3
ព្រះអម្ចាស់បានហាមមិនឲ្យទូលបង្គំលក់ដី
ឃ្លានេះគឺជាពាក្យសម្បថមួយដែលសង្កត់ធ្ងន់ថា
អ្វីដែលនៅខាងក្រោមនឹងមិនកើតឡើងទេ។ ការបកប្រែផ្សេងទៀត
«ដោយសារតែព្រះអម្ចាស់ហាមឃាត់ ខ្ញុំនឹងមិនដែលផ្តល់ឲ្យទេ»
លក់ដីដែលជាមរតករបស់បុព្វបុរសទូលបង្គំនេះដល់ព្រះករុណាឡើយ
ដីដែលបុព្វបុរសរបស់គាត់បានទទួលជាកម្មសិទ្ធិអចិន្ត្រៃយ៍ត្រូវបានគេនិយាយថាជាមរតក
ការបកប្រែផ្សេងទៀត « ប្រគល់ទឹកដីដែលដូនតាខ្ញុំបានទទួលជាមត៌ក»
1 Kings 21:5
ហេតុអ្វីបានជាព្រះករុណាក្រៀមក្រំម្លេះ
នៅទីនេះ «ចិត្ត» សំដៅទៅលើមនុស្សទាំងមូលនិងអារម្មណ៍របស់ទ្រង់។
ការបកប្រែផ្សេងទៀត «ហេតុអ្វីបានជាអ្នកក្រៀមក្រំ»
តើព្រះករុណាមិននៅតែគ្រប់គ្រងលើស្រុកអ៊ីស្រាអែលទេឬ»?
ព្រះនាងយេសេបិលប្រើសំណួរវោហាសាស្ត្រអវិជ្ជមាននេះដើម្បីស្តីបន្ទោសស្តេចអហាប់។
វាអាចត្រូវបានបកប្រែជាឃ្លាភ្ជាប់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«អ្នកនៅតែគ្រប់គ្រងអាណាចក្រអ៊ីស្រាអែល!»
ចូរស្តេចមានចិត្តសប្បាយឡើង
នៅទីនេះ «ចិត្ត» សំដៅទៅលើមនុស្សទាំងមូលនិងអារម្មណ៍របស់ទ្រង់។
ការបកប្រែផ្សេងទៀត «សប្បាយចិត្ត» ឬ «រីករាយឡើយ»
1 Kings 21:8
សរសេរសំបុត្រនៅក្នុងនាមព្រះបាទអហាប់
អាចមានន័យថា ១) នាងបានសរសេរឈ្មោះស្តេចអហាប់លើអក្សរ។
ការបកប្រែផ្សេងទៀត
«សរសេរសំបុត្រហើយចុះហត្ថលេខាដោយប្រើឈ្មោះស្តេចអហាប់» ឬ ២) ពាក្យ
«ឈ្មោះ» គឺជាពាក្យទាក់ទងទៅលើសិទ្ធអំណាច។ ការបកប្រែផ្សេងទៀត
«សរសេរអក្សរជំនួសស្តេចអហាប់»
ពួកអ្នកមានដែលបានអង្គុយជាមួយស្តេច
ពាក្យថាអ្នកមានទ្រព្យគឺសំដៅទៅលើអ្នកមាន។ ការបកប្រែផ្សេងទៀត
«អ្នកមានដែលអង្គុយជាមួយលោកណាបោត»
លោកណាបោតអង្គុយនៅកន្លែងពិសេសជាងគេ
ពេលលោកណាបោតអង្គុយនៅកន្លែងកិត្តិយសត្រូវបានគេនិយាយថា
បានឲ្យគាត់អង្គុយនៅពីលើមនុស្សដែលមានវត្តមាននៅទីនេះ។
ការបកប្រែផ្សេងទៀត
«ឲ្យលោកណាបោតអង្គុយនៅកន្លែងកិត្តិយសក្នុងចំណោមប្រជាជន»
ឲ្យពួកគេចោទប្រកាន់គាត់ថា
«ឲ្យពួកគេចោទប្រកាន់គាត់»
1 Kings 21:11
ពួកអ្នកមានដែលនៅជិតក្រុងរបស់ណាបោត
ពាក្យថាអ្នកមានទ្រព្យគឺសំដៅទៅលើអ្នកមាន។ ការបកប្រែផ្សេងទៀត
«អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភដែលរស់នៅក្នុងក្រុងណាបោត»
ដូចដែលបានសរសេរនៅក្នុងសំបុត្រ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ដូចដែលនាងបានសរសេរនៅក្នុងសំបុត្រ»
ឲ្យលោកណាបោតអង្គុយនៅកន្លែងកិត្តិយស
ពេលលោកណាបោតអង្គុយនៅកន្លែងកិត្តិយសត្រូវបានគេនិយាយថា
គាត់អង្គុយនៅពីលើមនុស្សដែលមានវត្តមាននៅទីនោះ។
សូមមើលការបកប្រែគំនិតនេះនៅក្នុងជំពូក ២១: ៨។ ការបកប្រែផ្សេងទៀត
«ឲ្យលោកណាបោតអង្គុយនៅកន្លែងកិត្តិយសក្នុងចំណោមប្រជាជន»
អង្គុយមុខលោកណាបោត
«ចាត់ឲ្យគេទៅនាំលោកណាបោត»
គេយកលោកចេញក្រៅ
ត្រង់នេះពាក្យ «ពួកគេ» សំដៅទៅលើប្រជាជននៃទីក្រុងនោះ។
«លោកណាបោតបានត្រូវគេគប់នឹងថ្ម ហើយលោកបានស្លាប់ហើយ»
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«យើងបានគប់ដុំថ្មដាក់លោកណាបោតហើយគាត់បានស្លាប់ហើយ»
1 Kings 21:15
លោកណាបោតបានត្រូវគេគប់សម្លាប់នឹងថ្មរួចមក
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត «
ប្រជាជនបានគប់ដុំថ្មសម្លាប់លោកណាបោតហើយគាត់បានស្លាប់ហើយ»
ដោយសារលោកមិននៅរស់ទៀតទេ លោកបានស្លាប់ហើយ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយសង្កត់ធ្ងន់ទៅលើសេចក្តីថ្លែងការណ៍របស់ព្រះនាងយេសេបិល។
ការបកប្រែផ្សេងទៀត «លោកណាបោតបានស្លាប់ហើយ!»
1 Kings 21:17
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក
នេះមានន័យថា ព្រះអម្ចាស់មានបន្ទូលឬបានផ្ញើសារមក។
សូមមើលការបកប្រែនៅក្នុងជំពូក ៦:១១។ ការបកប្រែផ្សេងទៀត «
ព្រះអម្ចាស់មានព្រះបន្ទូលនេះ» ឬ «ព្រះអម្ចាស់មានព្រះបន្ទូល»
1 Kings 21:19
តើអ្នកបានសម្លាប់ហើយរឹបអូសយកមរតករបស់គេដូច្នេះឬ»?
ព្រះអម្ចាស់សួរសំណួរនេះ ដើម្បីស្តីបន្ទោសស្តេចអហាប់។ ការបកប្រែផ្សេងទៀត
«អ្នកបានសម្លាប់លោកណាបោតហើយលួចចម្ការគាត់ឬ!»
ឈាមរបស់អ្នកដែរ មែនហើយគឺឈាមរបស់អ្នក
ប្រើម្តងទៀតដើម្បីសង្កត់ន័យ។
«តើអ្នកបានមកយើងទៀតហើយឬ សត្រូវរបស់យើងអើយ»?
ស្តេចអហាប់ប្រើសំណួរនេះ ដើម្បីបង្ហាញពីកំហឹងចំពោះលោកអេលីយ៉ា។
លោកអេលីយ៉ាបានរកឃើញថា ស្តេចអហាប់ទំនងជាសំដៅទៅលើលោកអេលីយ៉ា
ដែលបានរកឃើញសកម្មភាពរបស់ស្តេចអហាប់
មិនមែនលើរាងកាយរបស់គាត់ទេ។ ការបកប្រែផ្សេងទៀត
«តើអ្នកបានមកយើងទៀតហើយ ឬសត្រូវរបស់យើងអើយ!» ឬ
«អ្នកបានរកឃើញអ្វី ដែលខ្ញុំបានធ្វើ សត្រូវរបស់ខ្ញុំ!»
ព្រះករុណាបានលក់ខ្លួនរបស់ទ្រង់ទៅធ្វើការអាក្រក់
មនុស្សម្នាក់ប្តេជ្ញាធ្វើអំពើអាក្រក់
ដូចជាមនុស្សនោះបានលក់ខ្លួនទៅឲ្យអំពើអាក្រក់។ ការបកប្រែផ្សេងទៀត
«អ្នកបានលះបង់ខ្លួនអ្នកធ្វើអំពើអាក្រក់»
ការអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
ឃ្លា «នៅចំពោះមុខ» សំដៅទៅលើគំនិតរបស់នរណាម្នាក់។
សូមមើលការបកប្រែនៅក្នុង ១១:៥។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»
1 Kings 21:21
មើល
«ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វី ដែលខ្ញុំរៀបនឹងប្រាប់អ្នក»
លុបបំបាត់ពូជពង្សរបស់អ្នក យើងកាត់អ្នកចេញពីប្រុសៗក្នុងក្រុមគ្រួសាររបស់អ្នក ទាំងអ្នកងារ ទាំង
អ្នកជានៅស្រុកអ៊ីស្រាអែល
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការបំផ្លាញក្រុមគ្រួសាររបស់ស្តេចអហាប់
និងរារាំងស្តេចមិនឲ្យទទួលមរណភាពដូចជាស្តេចកំពុងតែប្រើប្រជាជនទាំងនេះ
ដូចភ្លើងឆេះបំផ្លាញពួកគេ ហើយកាប់គេចោលដូចគេកាប់មែកឈើ។
ការបកប្រែផ្សេងទៀត « បំផ្លាញកូនប្រុសៗទាំងអស់របស់អ្នករាល់គ្នានៅអ៊ីស្រាអែល
ទោះបីខ្ញុំបម្រើ ឬជាទាសករក៏ដោយ»
យើងនឹងធ្វើឲ្យគ្រួសាររបស់អ្នកដូចជាគ្រួសាររបស់ស្តេចយេរ៉ូបោម កូននេបាត និងដូចគ្រួសាររបស់
បាសា

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់នឹងបំផ្លាញក្រុមគ្រួសាររបស់ស្តេចអហាប់
ដូចស្តេចបំផ្លាញក្រុងយេរ៉ូបោមនិងបាសាដែរ។
1 Kings 21:23
គ្រប់គ្នាដែលនៅក្នុងគ្រួសាររបស់ស្តេចអហាប់
«អ្នកណាដែលជាកម្មសិទ្ធិរបស់ក្រុមគ្រួសារស្តេចអហាប់»
1 Kings 21:25
ដែលបានលក់ខ្លួនទៅធ្វើអំពើអាក្រក់
មនុស្សម្នាក់ប្តេជ្ញាធ្វើអំពើអាក្រក់
ដូចជាមនុស្សនោះបានលក់ខ្លួនទៅនឹងអំពើអាក្រក់។ សូមមើលការបកប្រែនៅក្នុង ២១:១៩។ ការបកប្រែផ្សេងទៀត «ដែលបានលះបង់ខ្លួនឯង ប្រព្រឹត្តអំពើអាក្រក់»
អំពើអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
ឃ្លា «នៅចំពោះមុខ» សំដៅទៅលើគំនិតរបស់នរណាម្នាក់។
សូមមើលការបកប្រែនៅក្នុង ១១:៥ ។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»
បានបណ្តេញពួកគេចេញពីមុខប្រជាជនអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើកុលសម្ព័ន្ធទាំងដប់ពីររបស់អ៊ីស្រាអែល ហើយមិនមែនសំដៅទៅលើអាណាចក្រខាងជើងទេ។ ការបកប្រែផ្សេងទៀត
«ត្រូវបានដកចេញពីវត្តមានរបស់ប្រជាជនអ៊ីស្រាអែល» ឬ «
បានបណ្តេញចេញពីទឹកដី នៅចំពោះមុខប្រជាជនអ៊ីស្រាអែល»
1 Kings 21:27
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក
មានន័យថា ព្រះអម្ចាស់មានបន្ទូល ឬបានធ្វើសារមក។ សូមមើលការបកប្រែនៅក្នុង ៦:១១។ ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់មានព្រះបន្ទូលនេះ» ឬ
»ព្រះជាម្ចាស់មានព្រះបន្ទូល»
តើអ្នកឃើញទេថាព្រះបាទអហាប់បានបន្ទាបខ្លួននៅមុខយើង?
ព្រះជាម្ចាស់ប្រើសំណួរនេះ ដើម្បីបង្ហាញលោកអេលីយ៉ាថា
ទុក្ខព្រួយរបស់ស្តេចអហាប់គឺពិតប្រាកដ។ ការបកប្រែផ្សេងទៀត
«យើងបានឃើញរបៀប ដែលស្តេចអហាប់បន្ទាបខ្លួននៅចំពោះមុខយើង។»
ឬមើលរបៀប ដែលស្តេចអហាប់បន្ទាបខ្លួនចំពោះយើង។
រាជ្យរបស់ស្តេច...មានចំពោះពូជពង្សរបស់គេ
នៅទីនេះពាក្យ «ថ្ងៃ» តំណាងឲ្យអាយុកាលទាំងមូលរបស់មនុស្សម្នាក់។
ការបកប្រែផ្សេងទៀត «ក្នុងអំឡុងពេលនៃជីវិតរបស់ស្តេច ...
ក្នុងមួយជីវិតបុត្រារបស់ស្តេច»

---

22 [1]បីឆ្នាំបានកន្លងផុតទៅដោយគ្មានសង្គ្រាមរវាងស្រុកអារ៉ាម និងស្រុកអ៊ីស្រាអែល។[2]បន្ទាប់មក នៅក្នុងឆ្នាំទីបីព្រះបាទយ៉ូសាផាត ជាស្តេចស្រុកយូដា បានទៅជួបស្តេចស្រុកអ៊ីស្រាអែល។
[3]ឥឡូវនេះ ស្តេចស្រុកអ៊ីស្រាអែលបានរាជឱង្ការទៅអ្នកបម្រើរបស់ស្តេចថា៖ «តើអ្នកដឹងទេថាក្រុងរ៉ាម៉ូត កាឡាដ ជារបស់យើង ប៉ុន្តែ
យើងមិនធ្វើអ្វីសោះដើម្បីយកទឹកដីនោះពីកណ្តាប់ដៃរបស់ស្តេចស្រុកអារ៉ាម»?[4]ដូច្នេះ ស្តេចបានទូលព្រះបាទយ៉ូសាផាតថា៖
«តើព្រះករុណានឹងទៅជាមួយទូលបង្គំទៅធ្វើសង្គ្រាមនៅក្រុងរ៉ាម៉ូត កាឡាដឬទេ»? ព្រះបាទយ៉ូសាផាតឆ្លើយតបទៅស្តេចស្រុកអ៊ីស្រាអែលថា៖
«ទូលបង្គំក៏ដូចព្រះករុណាដែរ ប្រជាជនរបស់ទូលបង្គំ ក៏ដូចជាប្រជាជនរបស់ទូលបង្គំដែរ ហើយសេះរបស់ទូលបង្គំ ក៏ដូចជាសេះរបស់ព្រះករុណាដែរ»។
[5]ព្រះបាទយ៉ូសាផាតទូលទៅស្តេចស្រុកអ៊ីស្រាអែលថា៖ «សូមស្វែងរកការនែនាំពីព្រះបន្ទូលរបស់ព្រះអម្ចាស់សម្រាប់អ្វីដែលព្រះករុណាគួរធ្វើជាមុនសិនទៅ»។[6]បន្ទាប់មក
ស្តេចស្រុកអ៊ីស្រាអែលបានប្រមូលពួកព្យាការីមក មានបួនរយនាក់ ហើយបាននិយាយជាមួយពួកគេថា៖ «តើយើងគួរចេញទៅក្រុងរ៉ាម៉ូត កាឡាដ ឬមិនត្រូវទៅ»?
ពួកគេទូលថា៖ «ត្រូវតែប្រយុទ្ធ ព្រោះព្រះអម្ចាស់បានប្រគល់ទឹកដីនេះមកក្នុងព្រះហស្តរបស់ព្រះករុណាហើយ»។
[7]ប៉ុន្តែ ព្រះបាទយ៉ូសាផាតទូលថា៖ «តើនៅទីនេះមិនមានព្យាការីរបស់ព្រះអម្ចាស់ផ្សេងទៀតដែលយើងអាចសុំយោបល់ឬទេ»?
[8]ស្តេចស្រុកអ៊ីស្រាអែលបានទូលទៅយ៉ូសាផាតថា៖ «មានបុរសម្នាក់ទៀតដែលយើងអាចសុំយោបល់ពីព្រះអម្ចាស់ គឺលោកមីកាយ៉ា ជាកូនរបស់លោកយីមឡា ប៉ុន្តែ
យើងស្អប់អ្នកនោះដោយសារតែគាត់មិនដែលទាយអ្វីល្អអំពីយើងទេ ផ្ទុយទៅវិញគឺមានតែការលំបាក»។ ប៉ុន្តែ ព្រះបាទយ៉ូសាផាតទូលថា៖
«សូមព្រះករុណាកុំមានបន្ទូលបែបនេះ»។[9]បន្ទាប់មក ស្តេចស្រុកអ៊ីស្រាអែលបានហៅអ្នកត្រប់គ្រង ហើយចេញបញ្ជាថា៖ «ចូរទៅនាំមីកាយ៉ា ជាកូនរបស់លោក
យីមឡាមកឥឡូវនេះ»។
[10]ឥឡូវនេះ ព្រះបាទអហាប់ជាស្តេចស្រុកអ៊ីស្រាអែល និងព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដាបានគង់លើបល្ល័ង្កម្នាក់មួយ បានគ្រង់សំលៀកបំពាក់រុងរឿង
នៅទីវាលនៅច្រកទ្វារក្រុងសាម៉ារី ហើយពួកព្យាការីបានថ្លែងទំនាយនៅមុខស្តេច។[11]លោកសេដេគា ជាកូនរបស់លោកក្នាណា បានធ្វើស្នែងពីដែក ហើយពោលថា៖
«ព្រះអម្ចាស់មានបន្ទូលថា៖ «ដោយសារស្នែងនេះ អ្នកនឹងដេញពួកអារ៉ាមរហូតដល់ពួកគេវិនាសអស់»។[12]បន្ទាប់មក ព្យាការីទាំងអស់បាននិយាយដូចគ្នា៖ «ចូររាយក្រុង
រ៉ាម៉ូត កាឡាដចុះ យើងនឹងឈ្នះ ដោយសារព្រះអម្ចាស់នឹងប្រទានទឹកដីនេះមកក្នុងព្រះហស្តរបស់ព្រះករុណាមិនខាន»។
[13]អ្នកនាំពាក្យដែលទៅហៅលោកមីកាបាននិយាយជាមួយលោកថា៖ «ឥឡូវនេះចូលមើល ពាក្យរបស់ព្យាការីទាំងអស់បានប្រកាសរឿងល្អទៅស្តេចដោយសម្លេងតែមួយ។
សូមឲ្យពាក្យរបស់លោកដូចពាក្យរបស់អ្នកទាំងនោះផង ហើយសូមប្រាប់រឿងល្អផង»។[14]លោកមីកាឆ្លើយថា៖ «ព្រះអម្ចាស់មានព្រះជន្មគង់នៅ
នេះជាអ្វីដែលព្រះអម្ចាស់មានបន្ទូលមកខ្ញុំ ខ្ញុំនឹងនិយាយបែបនោះ»។[15]នៅពេលដែលលោកបានមកជួបស្តេច ស្តេចបានមានរាជឱង្ការទៅលោកថា៖ «មីកាអើយ
តើយើងគួរទៅក្រុងរ៉ាម៉ូត កាឡាដដើម្បីធ្វើសង្គ្រាម ឬអត់»? លោកមីកាទូលឆ្លើយថា៖ «ទៅវាយចុះ នោះនឹងឈ្នះមិនខាន។
ព្រះអម្ចាស់នឹងប្រទានមកក្នុងព្រះហស្តរបស់ព្រះករុណា»។
[16]បន្ទាប់មក ស្តេចបានមានរាជឱង្ការទៅលោកថា៖ «តើយើងត្រូវឲ្យអ្នកស្បថប៉ុន្មានដង ដើម្បីឲ្យអ្នកប្រាប់ការពិតនៅក្នុងព្រះនាមរបស់ព្រះអម្ចាស់»?
[17]ដូច្នេះលោកមីកាទូលថា៖ «ទូលបង្គំឃើញអ៊ីស្រាអែលបាក់ទ័ពនៅលើភ្នំ ដូចជាចៀមគ្មានអ្នកគង្វាល ហើយព្រះអម្ចាស់មានបន្ទូលថា៖
«ចៀមទាំងនេះគ្មានអ្នកគង្វាលឡើយ។ ចូរឲ្យអ្នកទាំងនេះត្រឡប់ទៅផ្ទះវិញដោយសន្តិភាពចុះ»។
[18]ដូច្នេះ ស្តេចស្រុកយូដា បានមានព្រះបន្ទូលទៅព្រះបាទយ៉ូសាផាតថា៖ «តើទូលបង្គំមិនបានទូលព្រះករុណាទេឬអីថាអ្នកនេះមិនដែលទាយល្អទាក់ទងនឹងទូលបង្គំទេ
ប៉ុន្តែ ទាយតែពីមហន្តរាយ»?[19]បន្ទាប់មក លោកមីកាទូលថា៖ «ដូច្នេះ សូមស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់៖ ទូលបង្គំឃើញព្រះអម្ចាស់គង់លើបល្ល័ង្ក
ហើយអ្នកបម្រើទាំងអស់នៅនគរស្ថានសួគ៌ឈរនៅជិតព្រះអង្គ នៅខាងស្តាំ និងនៅខាងឆ្វេងព្រះអង្គ។[20]ព្រះអម្ចាស់មានបន្ទូលថា៖ «តើនរណាចង់ល្បួងព្រះបាទអហាប់
ដើម្បីឲ្យស្តេចឡើងទៅ ហើយបរាជ័យនៅក្រុងរ៉ាម៉ូត កាឡាដ? មានម្នាក់និយាយបែបនេះ ហើយម្នាក់ទៀតនិយាយបែបនោះ។
[21]បន្ទាប់មក មានវិញ្ញាណមួយបានមកឈរនៅមុខព្រះអម្ចាស់ ហើយនិយាយថា៖ «ទូលបង្គំនឹងល្បួងស្តេច»។ ព្រះអម្ចាស់មានបន្ទូលមកអ្នកនោះថា៖
«តើដោយរបៀបណា»?[22]វិញ្ញាណនោះឆ្លើយតបថា៖ «ទូលបង្គំនឹងចេញទៅ ហើយក្លាយជាវិញ្ញាណកុហកនៅក្នុងមាត់របស់ពួកព្យាការីទាំងនេះ»។
ព្រះអម្ចាស់មានបន្ទូលថា៖ «ចូរទៅល្បួងស្តេចចុះ ហើយអ្នកនឹងបានជោគជ័យ។ ចូរទៅឥឡូវនេះ ហើយធ្វើបែបនោះចុះ»។[23]ឥឡូវនេះ
ព្រះអម្ចាស់បានដាក់វិញ្ញាណកុហកនៅក្នុងមាត់របស់ពួកព្យាការីទាំងអស់របស់ព្រះករុណា ហើយព្រះអម្ចាស់បានសម្រេចឲ្យមានមហន្តរាយនេះដល់ព្រះករុណា»។
[24]បន្ទាប់មក លោកសេដេគា ជាកូនរបស់លោកក្នាណា ឡើងមកទះកំផ្លៀងលោកមីកា ហើយនិយាយថា៖
«តើអ្នកដឹងដោយរបៀបណាថាព្រះវិញ្ញាណរបស់ព្រះអម្ចាស់ចេញពីយើងទៅនិយាយជាមួយអ្នក»?[25]លោកមីកាមានប្រសាសន៍ថា៖ «មើល
អ្នកនឹងដឹងនៅថ្ងៃដែលអ្នករត់ចូលទៅបន្ទប់ខាងក្នុងដើម្បីលាក់ខ្លួន»។
[26]ស្តេចស្រុកអ៊ីស្រាអែលបានទូលទៅអ្នកបម្រើរបស់ព្រះអង្គថា៖ «ចូរចាប់លោកមីកាយ៉ានាំយកទៅឲ្យលោកអាំម៉ូន ជាអ្នកគ្រប់គ្រងក្រុង និងទៅព្រះបាទយ៉ូអាស ជាបុត្រ
របស់យើងទៅ។[27]ចូរប្រាប់ទៅពួកគេថា៖ «ស្តេចទូលថា៖ «ចូរដាក់បុរសនេះក្នុងគុក ហើយឲ្យនំបុ័ងគាត់តែបន្តិច និងទឹកបន្តិចបានហើយ
រហូតយើងបានត្រឡប់មកវិញដោយសុខសាន្ត»។[28]បន្ទាប់មក លោកមីកាទូលថា៖

generated on Wed Sep 10 16:16:32 2025

«បើព្រះករុណាបានត្រឡប់មកវិញដោយសុខសាន្តមែននោះព្រះអម្ចាស់មិនបានមានបន្ទូលមកទូលបង្គំទេ»។ បន្ទាប់មក លោកបន្ថែមថា៖
«ចូរស្តាប់ពាក្យទាំងអស់នេះចុះប្រជាជនទាំងអស់អើយ»។
[29]ដូច្នេះ ស្តេចអហាប់ជាស្តេចស្រុកអ៊ីស្រាអែល និងព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដាបានឡើងទៅក្រុងរ៉ាម៉ូត កាឡាដ។
[30]ស្តេចស្រុកអ៊ីស្រាអែលបានទូលទៅព្រះបាទយ៉ូសាផាតថា៖ «ទូលបង្គំនឹងក្លែងខ្លួនធ្វើជាទាហាន ហើយចេញទៅសមរភូមិ ប៉ុន្តែ
សូមព្រះករុណាគ្រងសំលៀកបំពាក់រាជវាំងចុះ»។ ដូច្នេះ ស្តេចស្រុកអ៊ីស្រាអែលក្លែងខ្លួនធ្វើជាទាហាន ហើយចេញទៅសមរភូមិ។
[31]ឥឡូវនេះ ស្តេចអារ៉ាមបានបញ្ជាមេបញ្ជាការទាំងសាបសិបពីរនៃទ័ពរទេះចម្បាំងរបស់ស្តេចថា៖ ចូរកុំឲ្យវាយប្រហារពួកគេទាហានធម្មតាឡើយ។ ផ្ទុយទៅវិញ
ចូររាយប្រហារតែស្តេចស្រុកអ៊ីស្រាអែលបានហើយ»។[32]នៅពេលដែលពួកមេបញ្ជាការឃើញព្រះបាទយ៉ូសាផាតពួកគេនិយាយថា៖
«នេះហើយជាស្តេចស្រុកអ៊ីស្រាអែល»។ ពួកគេបានត្រឡប់ទៅវាយប្រហារស្តេច ដូច្នេះព្រះបាទយូសាផាតក៏ស្រែកឡើង។
[33]នៅពេលដែលពួកមេបញ្ជាការបានឃើញថាលោកមិនមែនជាស្តេចស្រុកអ៊ីស្រាអែល ពួកគេក៏ឈប់ដេញតាមទ្រង់ទៅ។
[34]ប៉ុន្តែ មានបុរសម្នាក់បានបាញ់ធ្នូព្រាវទៅ ហើយចំលើស្តេចអ៊ីស្រាអែលត្រង់ចន្លោះអាវក្រោះ។ បន្ទាប់មក ព្រះបាទអហាប់បាននិយាយទៅអ្នកបើករាជរថថា៖
«ចូរត្រឡប់ក្រោយ ហើយនាំយើងចេញពីសមរភូមិ ព្រោះយើងមានរបួសជាទម្ងន់»។
[35]សមរភូមិនោះកាន់តែអាក្រក់ទៅៗនៅថ្ងៃនោះ ហើយស្តេចនៅលើរាជរថប្រឈមមុខនឹងពួកអារ៉ាម។ ស្តេចសុគតនៅពេលល្ងាច។
ឈាមរបស់ទ្រង់ចេញពីរបួសរបស់ស្តេចមករហូតដល់ក្រោមរាជរថ។[36]បន្ទាប់មក នៅពេលថ្ងៃជិតលិច មានម្នាក់ស្រែកប្រកាសដល់ពួកទាហានទាំងអស់ថា៖
«គ្រប់គ្នាគួរត្រឡប់ទៅផ្ទះវិញ ហើយគ្រប់គ្នាគួរតែទៅកន្លែងរបស់ខ្លួនវិញ!»។
[37]ដូច្នេះ ស្តេចអហាប់បានសុគត ហើយគេនាំសពទ្រង់ទៅស្រុកសាម៉ារី ហើយគេបានបញ្ចុះសពទ្រង់នៅទីនោះ។[38]ពួកគេបានលាងសម្អាតរាជរថដោយទឹកអាងនៅសាម៉ារី
ហើយឆ្កែក៏បានលិតឈាមរបស់ទ្រង់ (នេះជាកន្លែងដែលស្ត្រីពេស្យាងូតទឹក) គឺស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់បានប្រកាស។
[39]រឿងរ៉ាវទាក់ទងនឹងស្តេចអហាប់ អ្វីដែលស្តេចបានធ្វើ ដំណាក់ធ្វើពីភ្លុកដែលស្តេចបានសង់ និងក្រុងទាំងប៉ុន្មានដែលស្តេចបានសង់
តើមិនមានកត់ត្រាទុកក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬអី?[40]ដូច្នេះ ព្រះបាទអហាប់បានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់ ហើយព្រះបាទ
អហាស៊ីយ៉ា ជាបុត្របានឡើងស្នងរាជ្យបន្ត។
[41]បន្ទាប់មក ព្រះបាទយ៉ូសាផាតកូនរបស់ព្រះបាទអាសាចាប់ផ្តើមគ្រងរាជលើស្រុកយូដានៅក្នុងឆ្នាំទីបួននៃរាជ្យរបស់ព្រះបាទអហាប់ជាស្តេចស្រុកអ៊ីស្រាអែល។
[42]ព្រះបាទយ៉ូសាផាតមានព្រះជន្មសាមសិបប្រាំឆ្នាំនៅពេលដែលព្រះអង្គចាប់ផ្តើមសោយរាជ្យ ហើយស្តេចសោយរាជ្យនៅក្រុងយេរូសាឡឹមអស់ម្ភៃប្រាំឆ្នាំ។ មាតារបស់ស្តេច
មាននាមថា អស៊ូបា ជាកូនរបស់លោកស៊ីលហ៊ី។
[43]ស្តេចដើរតាមមាគ៌ារបស់ព្រះបាទអាសាជាបិតាទ្រង់ ស្តេចមិនបានបែរឆ្ងាយពីមាគ៌ានោះទេ ស្តេចធ្វើអ្វីៗដែលត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់។ ប៉ុន្តែ
នៅតាមទីខ្ពស់ស្តេចមិនបានបំផ្លាញចោលឡើយ។ ប្រជាជននៅតែបន្តថ្វាយយញ្ញបូជា និងដុតគ្រឿងក្រអូបនៅតាមទីខ្ពស់ៗដដែល។
[44]ព្រះបាទយ៉ូសាផាតបានរក្សាសន្តិភាពជាមួយស្តេចស្រុកអ៊ីស្រាអែល។
[45]រឿងរ៉ាវផ្សេងទៀតដែលទាក់ទងនឹងព្រះបាទយ៉ូសាផាត និងភាពល្អីល្អាញដែលស្តេចបានបង្ហាញ និងរបៀបដែលស្តេចចេញទៅសមរភូមិ
តើមិនមានកត់ត្រាទុកក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដាទេឬអី?[46]ស្តេចបានបំផ្លាញចោលពួកពេស្យាចារបែបសាសនាចេញពីទឹកដីនោះ
គឺអ្នកដែលនៅសេសសល់ពីភ្នែករបស់បិតាទ្រង់គឺព្រះបាទអាសា។[47]នៅស្រុកអេដុំគ្មានស្តេចទេ ប៉ុន្តែ មានតែអ្នកគ្រប់គ្រងម្នាក់នៅទីនេះ។
[48]ព្រះបាទយ៉ូសាផាតបានសង់នាវាសមុទ្រ ពួកគេចេញទូកទៅអូភារដើម្បីរកមាស ប៉ុន្តែ ពួកគេមិនបានចេញទៅទេ ព្រោះសំពៅបានលិចនៅឯក្រុងអេស៊ាន-គេប៊ើរ។
[49]បន្ទាប់មក ព្រះបាទអហាស៊ីយ៉ា ជាបុត្ររបស់ព្រះបាទអហាប់ទូលទៅព្រះបាទយ៉ូសាផាតថា៖ «ចូរឲ្យអ្នកបម្រើរបស់ទូលបង្គំចេញទូកជាមួយអ្នកបម្រើរបស់ព្រះករុណា»។
ប៉ុន្តែ ព្រះបាទយ៉ូសាផាតមិនអនុញ្ញាត្តិឡើយ។[50]ព្រះបាទយ៉ូសាផាតបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
ហើយគេបានបញ្ចុះសពទ្រង់នៅក្នុងក្រុងរបស់ព្រះបាទដាវីឌដែលជាបុព្វបុរសរបស់ស្តេច ព្រះបាទយ៉ូរ៉ាម ជាបុត្រ បានឡើងស្នងរាជ្យបន្ត។
[51]ព្រះបាទអហាស៊ីយ៉ា ជាបុត្ររបស់ព្រះបាទ
អហាប់ចាប់ផ្តើមគ្រងរាជលើស្រុកអ៊ីស្រាអែលនៅស្រុកសាម៉ារីនៅក្នុងឆ្នាំទីដប់ប្រាំពីរនៃរាជ្យរបស់ព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដា
ហើយស្តេចសោយរាជ្យបានពីរឆ្នាំលើស្រុកអ៊ីស្រាអែល។[52]ស្តេចបានប្រព្រឹត្តអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ ហើយបានដើរតាមមាគ៌ារបស់បិតា និងមាតាទ្រង់
និងដើរតាមមាគ៌ារបស់ព្រះបាទយេរ៉ូបោមជាកូននេបាត ដែលនាំឲ្យអ៊ីស្រាអែលប្រព្រឹត្តអំពើបាប។[53]ស្តេចបានបម្រើព្រះបាល និងថ្វាយបង្គំព្រះនោះ
ធ្វើឲ្យព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលព្រះពិរោធ ដូចដែលបិតារបស់ស្តេចបានធ្វើដែរ។

---

1 Kings 22:1
បីឆ្នាំ
«៣ឆ្នាំ
បន្ទាប់មក
ឃ្លានេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ការចាប់ផ្តើមផ្នែកថ្មីនៃរឿង។
បើភាសារបស់អ្នកមានរបៀបកបកប្រែប្រយោគនេះ
អ្នកអាចពិចារណាប្រើវានៅទីនេះបាន។
1 Kings 22:3
«តើអ្នកដឹងទេថាក្រុងរ៉ាម៉ូត កាឡាដ ជារបស់យើង ប៉ុន្តែ
យើងមិនធ្វើអ្វីសោះដើម្បីយកទឹកដីនោះពីកណ្តាប់ដៃរបស់ស្តេចស្រុកអារ៉ាម»?
ស្តេចអហាប់សួរសំណួរនេះដើម្បីបញ្ជាក់ថា
ពួកគេគួរតែដណ្តើមបានក្រុងរ៉ាម៉ាតកាឡាតមកវិញ។ ការបកប្រែផ្សេងទៀត
«ក្រុងរ៉ាម៉ាតកាឡាតជារបស់យើង ប៉ុន្តែយើងមិនបានធ្វើអ្វី
ដើម្បីយកវាពីកណ្តាប់ដៃរបស់ស្តេចស្រុកស៊ីរីទេ។»
យកទឹកដីនោះពីកណ្តាប់ដៃរបស់ស្តេចស្រុកអារ៉ាម
ត្រង់នេះពាក្យថា «ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«ដើម្បីយកវាពីការគ្រប់គ្រងរបស់ស្តេចអារ៉ាម»
ទូលបង្គំក៏ដូចព្រះករុណាដែរ ប្រជាជនរបស់ទូលបង្គំ ក៏ដូចជាប្រជាជនរបស់ទូលបង្គំដែរ
ហើយសេះរបស់ទូលបង្គំ ក៏ដូចជាសេះរបស់ព្រះករុណាដែរ»
ស្តេចយ៉ូសាផាតប្រាប់ស្តេចអហាប់ថា ព្រះករុណា និងប្រជារាស្ត្រ
និងសេះរបស់ព្រះករុណា ជារបស់ស្តេចអ័ហាប់មានន័យថា
ស្តេចអហាប់អាចបញ្ជាពួកគេតាម ដែលគាត់ចង់។ ការបកប្រែផ្សេងទៀត «ខ្ញុំ
និងទាហានរបស់ខ្ញុំនិងសេះរបស់ខ្ញុំ
ជារបស់ព្រះករុណាប្រើតាមមធ្យោបាយណាមួយ ដែលព្រះករុណាចង់បាន»
1 Kings 22:5
បួនរយនាក់
«បុរស ៤០០ នាក់»
ព្រោះព្រះអម្ចាស់បានប្រគល់ទឹកដីនេះមកក្នុងព្រះហស្តរបស់ព្រះករុណាហើយ
ត្រង់នេះពាក្យថា «ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«ដ្បិតព្រះអម្ចាស់នឹងអនុញ្ញាតឲ្យស្តេចចាប់យកក្រុងរ៉ាម៉ូត កាឡាដ»
1 Kings 22:7
«សូមព្រះករុណាកុំមានបន្ទូលបែបនេះ»
ព្រះបាទយ៉ូសាផាតសំដៅទៅលើស្តេចអហាប់ក្នុងមនុស្សទីបីដើម្បីបង្ហាញការគោរពដល់ទ្រង់។
ការបកប្រែផ្សេងទៀត «អ្នកមិនគួរនិយាយថា»
1 Kings 22:10
បានធ្វើស្នែងពីដែក
«ធ្វើស្នែងដែកសម្រាប់ខ្លួនគាត់»
«ដោយសារស្នែងនេះ អ្នកនឹងដេញពួកអារ៉ាមរហូតដល់ពួកគេវិនាសអស់»
សកម្មភាពរបស់ព្យាការីគឺជានិមិត្តរូបដែលបង្ហាញពីរបៀបដែលស្តេចអហាប់នឹងកម្ចាត់ពួកស៊ីរី។
កងទ័ពរបស់ស្តេចអហាប់នឹងឈ្នះដោយមានកម្លាំងខ្លាំងដូចគោរាយប្រហារទៅលើសត្វមួយទៀត។
រហូតដល់ពួកគេវិនាសអស់
ការបំផ្លាញកងទ័ពសត្រូវបានគេនិយាយដូចជាកំពុងធ្វើឲ្យពួកគេវិនាស។

generated on Wed Sep 10 16:16:32 2025

អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត
«រហូតដល់អ្នកបំផ្លាញពួកវា» ឬ «រហូតដល់អ្នកបំផ្លាញពួកគេ»
ប្រទានទឹកដីនេះមកក្នុងព្រះហស្តរបស់ព្រះករុណាមិនខាន
ត្រង់នេះពាក្យថា «ព្រះហស្ត» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«អនុញ្ញាតឲ្យស្តេចចាប់យកវា»
1 Kings 22:13
ឥឡូវនេះចូលមើល
«ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក»
ពាក្យរបស់ព្យាការីទាំងអស់បានប្រកាសរឿងល្អទៅស្តេចដោយសម្លេងតែមួយ
ពួកព្យាការីទាំងអស់និយាយដូចគ្នាគឺដូចជាពួកគេនិយាយដូចគ្នា។ ឃ្លា
«ពាក្យរបស់ពួកព្យាការី» តំណាងឲ្យសារដែលពួកព្យាការីប្រកាស។
ការបកប្រែផ្សេងទៀត « ពួកព្យាការីទាំងអស់សុទ្ធតែប្រកាសការល្អៗ
ដល់ស្តេចដូចគ្នា»
សូមឲ្យពាក្យរបស់លោកដូចពាក្យរបស់អ្នកទាំងនោះផង
ត្រង់នេះពាក្យ «ពួកគេ» សំដៅទៅលើ «ពាក្យរបស់ពួកព្យាការី»។
ការបកប្រែផ្សេងទៀត
«អនុញ្ញាតឲ្យអ្វីដែលអ្នកនិយាយយល់ស្របនឹងអ្វីដែលពួកគេបាននិយាយ»
តើយើងគួរទៅ
ពាក្យថា «យើង» សំដៅទៅលើស្តេចអហាប់
ស្តេចយ៉ូសាផាតនិងកងទ័ពរបស់ពួកទ្រង់ ប៉ុន្តែមិនមែនសំដៅទៅលើមីកាទេ។
នឹងប្រទានមកក្នុងព្រះហស្តរបស់ព្រះករុណា
ត្រង់នេះពាក្យថា «ព្រះហស្ត» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«នឹងអនុញ្ញាតឲ្យស្តេចចាប់យកវា»
1 Kings 22:16
តើយើងត្រូវឲ្យអ្នកស្បថប៉ុន្មានដង ដើម្បីឲ្យអ្នកប្រាប់ការពិតនៅក្នុងព្រះនាមរបស់ព្រះអម្ចាស់?
ស្តេចអហាប់សួរសំណួរនេះដោយការមិនសប្បាយចិត្តដើម្បីស្តីបន្ទោសលោកមីកា។
ការបកប្រែផ្សេងទៀត «ខ្ញុំបានទាមទារ ... ជាច្រើនដងក្នុងនាមព្រះអម្ចាស់»។
ក្នុងព្រះនាមរបស់ព្រះអម្ចាស់
នៅទីនេះពាក្យ «នាម» សំដៅទៅលើសិទ្ធិអំណាច។ ការបកប្រែផ្សេងទៀត
«ក្នុងនាមជាអ្នកតំណាងរបស់ព្រះអម្ចាស់»
ទូលបង្គំឃើញអ៊ីស្រាអែល
នៅទីនេះ «អ៊ីស្រាអែលទាំងអស់» សំដៅទៅលើកងទ័ពអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ខ្ញុំបានឃើញកងទ័ពអ៊ីស្រាអែលទាំងមូល»
ដូចជាចៀមគ្មានអ្នកគង្វាល
ប្រជាជននៃកងទ័ពត្រូវបានគេប្រៀបធៀបទៅនឹងចៀមដែលគ្មាននរណាម្នាក់ដឹកនាំពួកគេ
ពីព្រោះអ្នកគង្វាលរបស់ពួកគេគឺជាស្តេចបានស្លាប់ហើយ។
ចៀមទាំងនេះគ្មានអ្នកគង្វាលឡើយ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីស្តេចដូចជាទ្រង់ជាអ្នកគង្វាល។
ដូចជាអ្នកគង្វាលម្នាក់ត្រូវទទួលខុសត្រូវថែរក្សានិងការពារចៀមរបស់ទ្រង់
ស្តេចមានភារកិច្ចដឹកនាំនិងការពារប្រជាជនរបស់ទ្រង់។ ការបកប្រែផ្សេងទៀត៖
«មនុស្សទាំងនេះលែងមានមេដឹកនាំ»
1 Kings 22:18
តើទូលបង្គំមិនបានទូលព្រះករុណាទេឬអីថា...ប៉ុន្តែ ទាយតែពីមហន្តរាយ»?
ស្តេចអហាប់សួរសំណួរនេះដើម្បីបញ្ជាក់ថាទ្រង់បានមានបន្ទូលការពិតអំពីលោកមីកា។
ការបកប្រែផ្សេងទៀត «ខ្ញុំបានប្រាប់អ្នក ... ប៉ុន្តែមានតែគ្រោះមហន្តរាយទេ!»
បរាជ័យនៅក្រុងរ៉ាម៉ូត កាឡាដ
ស្តេចអហាប់ស្លាប់ក្នុងសមរភូមិត្រូវបានគេនិយាយដូចជាទ្រង់នឹងដួល។
ការបកប្រែផ្សេងទៀត «ស្លាប់នៅក្រុងរ៉ាម៉ាត កាឡាដ»
មានម្នាក់និយាយបែបនេះ ហើយម្នាក់ទៀតនិយាយបែបនោះ
«មួយ ... និងមួយទៀត»
គឺសំដៅទៅលើទេវតាពីរឺច្រើននាក់នៅស្ថានសួគ៌ដែលបានឆ្លើយតបនឹងសំណួររបស់ព្រះអម្ចាស់
1 Kings 22:21
ក្លាយជាវិញ្ញាណកុហកនៅក្នុងមាត់របស់ពួកព្យាការីទាំងនេះ
ត្រង់នេះពាក្យ «វិញ្ញាណ» សំដៅទៅលើឥរិយាបថរបស់ពួកហោរានិងពាក្យ «មាត់»
តំណាងឲ្យអ្វីដែលពួកគេនឹងនិយាយ។ ការបកប្រែផ្សេងទៀត
«បណ្តាលឲ្យហោរាទាំងអស់និយាយកុហក»
ឥឡូវនេះ
«ជាការពិត» ពាក្យ «មើល»
នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
បានដាក់វិញ្ញាណកុហកនៅក្នុងមាត់របស់ពួកព្យាការីទាំងអស់របស់ព្រះករុណា
នៅទីនេះពាក្យ «វិញ្ញាណ» សំដៅទៅលើឥរិយាបថរបស់ពួកព្យាការីនិងពាក្យ
«មាត់» តំណាងឲ្យអ្វីដែលពួកគេនឹងនិយាយ។ ការបកប្រែផ្សេងទៀត
«បានធ្វើឲ្យព្យាការីរបស់អ្នកទាំងអស់និយាយកុហក»
1 Kings 22:24
តើអ្នកដឹងដោយរបៀបណាថាព្រះវិញ្ញាណរបស់ព្រះអម្ចាស់ចេញពីយើងទៅនិយាយជាមួយអ្នក»?
លោកសេដេគាសួរសំណួរដ៏អាក់រអួលនេះដើម្បីជេរប្រមាថនិងស្តីបន្ទោសលោកមីកា។
ការបកប្រែផ្សេងទៀត
«កុំគិតថាព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានចាកចេញពីខ្ញុំដើម្បីមានបន្ទូលជាមួយអ្នក!»
មើល
«ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក»
អ្នកនឹងដឹង
«អ្នកនឹងដឹងចម្លើយចំពោះសំណួររបស់អ្នក» ។
ប្រសិនបើសំណួរវោហារសាស្ត្ររបស់លោកសេដេគាត្រូវបានបកប្រែជាឃ្លាភ្ជាប់
នេះអាចត្រូវបានបកប្រែដើម្បីផ្តល់ព័ត៌មានជាក់ស្តែង។ ការបកប្រែផ្សេងទៀត
«អ្នកនឹងដឹងថាព្រះវិញ្ញាណនៃព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ»
1 Kings 22:26
បើព្រះករុណាបានត្រឡប់មកវិញដោយសុខសាន្តមែននោះ
នេះពិតណាអ្វីមួយដែលនឹងមិនកើតឡើងទេ។
ព្រះអម្ចាស់បានមានបន្ទូលប្រាប់មីការួចហើយថា
ស្តេចនឹងមិនវិលត្រឡប់មកវិញដោយសុវត្ថិភាពឡើយ។
1 Kings 22:31
បញ្ជាមេបញ្ជាការទាំងសាបសិបពីរ
មេបញ្ជាការពីររូប «មេបញ្ជាការ ៣២ រូប»
ចូរកុំឲ្យវាយប្រហារពួកគេទាហានធម្មតាឡើយ
ដោយលើកឡើងទាំង «ទាហានមិនសំខាន់» និង «ទាហានសំខាន់»
ព្រះរាជាមានន័យថាទាហានទាំងអស់។ ការបកប្រែផ្សេងទៀត
«កុំវាយប្រហារទាហានណាមួយ»
នៅពេលដែល
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។
ប្រសិនបើភាសារបស់អ្នកមានរបៀបបកប្រែធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះបាន។
1 Kings 22:34
បានបាញ់ធ្នូព្រាវទៅ
អាចមានន័យថា ១) គាត់មានគោលបំណងបាញ់ទាហានម្នាក់ដោយមិនដឹងថាស្តេចអហាប់ ឬ ២)
គាត់បានឱនធ្នូរបស់គាត់ដើម្បីបាញ់ដោយគ្មានគោលដៅជាក់លាក់ណាមួយនៅក្នុងចិត្ត។
1 Kings 22:35
ស្តេចនៅលើរាជរថ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មានមនុស្សម្នាក់បានលើកស្តេចឡើងលើរទេះរបស់គាត់»
មានម្នាក់ស្រែកប្រកាសដល់
នៅទីនេះ «ស្រែក» តំណាងឲ្យទាហានដែលកំពុងស្រែក។ ការបកប្រែផ្សេងទៀត
«ទាហានបានចាប់ផ្តើមស្រែក»
«គ្រប់គ្នាគួរត្រឡប់ទៅផ្ទះវិញ ហើយគ្រប់គ្នាគួរតែទៅកន្លែងរបស់ខ្លួនវិញ!»
ឃ្លាទាំងពីរនេះមានន័យដូចគ្នាជាមូលដ្ឋានហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។
1 Kings 22:37
គេនាំសពទ្រង់ទៅស្រុកសាម៉ារី
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ទាហានរបស់ទ្រង់បាននាំយកសាកសពរបស់ទ្រង់ទៅស្រុកសាម៉ារី»
គេបានបញ្ចុះសពទ្រង់
«អម្ចាស់ [illegible]»
គឺស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់បានប្រកាស
ត្រង់នេះ «ព្រះបន្ទូលរបស់ព្រះអម្ចាស់» តំណាងឲ្យព្រះអម្ចាស់ផ្ទាល់។
ការបកប្រែផ្សេង «ដូចអ្វីដែលព្រះអម្ចាស់បានប្រកាស»
1 Kings 22:39
តើមិនមានកត់ត្រាទុកក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬអី?
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្មហើយសន្មតថាចម្លើយគឺវិជ្ជមាន។
សំណួរវោហារសាស្ត្រហើយត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
សូមមើលការបកប្រែនៅក្នុងជំពូក ១៥:៣១។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«ពួកគេត្រូវបានសរសេរនៅក្នុងសៀវភៅព្រឹត្តិការណ៍នៃស្តេចអ៊ីស្រាអែល» ។ ឬ
«អ្នកអាចអានវានៅក្នុងសៀវភៅព្រឹត្តិការណ៍នៃស្តេចនៃអ៊ីស្រាអែល»។
ផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
ស្តេចអហាប់ស្លាប់ត្រូវបានគេនិយាយដូចជាទ្រង់បានដេកលក់។
សូមមើលការបកប្រែនៅ ជំពូក ២:១០។ ការបកប្រែផ្សេងទៀត «បានស្លាប់»
1 Kings 22:41
សាមសិបប្រាំឆ្នាំ
អាយុប្រាំឆ្នាំ «អាយុ ៣៥ ឆ្នាំ»
ម្ភៃប្រាំឆ្នាំ
ប្រាំឆ្នាំ «២៥ ឆ្នាំ»
1 Kings 22:43
ស្តេចដើរតាមមាគ៌ារបស់ព្រះបាទអេសាជាបិតាទ្រង់
អាកប្បកិរិយារបស់មនុស្សម្នាក់ត្រូវបានគេនិយាយដូចជាមនុស្សនោះដើរតាមផ្លូវ។
ការបកប្រែផ្សេងទៀត
«ទ្រង់បានធ្វើដូចស្តេចអេសាដែលជាបិតារបស់ទ្រង់បានធ្វើដែរ»
អ្វីៗដែលត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
នៅទីនេះ «ភ្នែក»
តំណាងឲ្យការមើលឃើញហើយគំនិតរបស់ព្រះអម្ចាស់ត្រូវបាននិយាយដូចជាទ្រង់អាចមើលឃើញអ្វីមួយ។
ការបកប្រែផ្សេងទៀត «អ្វីដែលព្រះអម្ចាស់បានគិតថាត្រឹមត្រូវ»
នៅតាមទីខ្ពស់ស្តេចមិនបានបំផ្លាញចោលឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«ទ្រង់មិនបានដកយកកន្លែងខ្ពស់ៗទេ»
1 Kings 22:45
តើមិនមានកត់ត្រាទុកក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដាទេឬអី?
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្មហើយសន្មតថាចម្លើយគឺវិជ្ជមាន។
សំណួរវោហារសាស្ត្រហើយត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
សូមមើលការបកប្រែនៅក្នុងជំពូក ១៤:២៩។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវបានសរសេរនៅក្នុងសៀវភៅព្រឹត្តិការណ៍នៃស្តេចយូដា»។ ឬ
«អ្នកអាចអានវានៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដា»។
1 Kings 22:48
សំពៅបានលិច
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«កប៉ាល់ទាំងនោះបានខូច»
បានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
ស្តេចយ៉ូសាផាតដែលស្លាប់ត្រូវបានគេនិយាយដូចជាទ្រង់បានផ្ទុំលក់។
សូមមើលការបកប្រែនៅជំពូក ២:១០។ ការបកប្រែផ្សេងទៀត «បានស្លាប់»
គេបានបញ្ចុះសពទ្រង់នៅក្នុងក្រុងរបស់ព្រះបាទដាវីឌដែលជាបុព្វបុរសរបស់ស្តេច
អាចបញ្ជាក់ជាទម្រង់កិរិយាស័ព្ទសកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សបានបញ្ចុះសពទ្រង់»
1 Kings 22:51
ស្តេចសោយរាជ្យបានពីរឆ្នាំ
«ទ្រង់សោយរាជ្យបាន ២ឆ្នាំ»
ប្រព្រឹត្តអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
គំនិតរបស់ព្រះអម្ចាស់ទាក់ទងនឹងអ្វីមួយត្រូវបាននិយាយថា
ដូចជាព្រះអម្ចាស់បានឃើញរឿងនោះដែរ។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអម្ចាស់បានចាត់ទុកថាអាក្រក់»
ដើរតាមមើលឃើញអ្វីមួយ។ ការបកប្រែផ្សេងទៀត
ដើរតាមមាតា និងមាតាទ្រង់ និងដើរតាមមាគ៌ារបស់ព្រះបាទយេរ៉ូបោមជាកូននេបាត
អាកប្បកិរិយារបស់មនុស្សម្នាក់ត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងដើរតាមផ្លូវមួយ។
ការបកប្រែផ្សេងទៀត «បានធ្វើដូចមាតា
បិតាទ្រង់និងស្តេចយេរ៉ូបោមជាកូនរបស់នេបាតបានធ្វើ»
ដែលនាំឲ្យអ៊ីស្រាអែលប្រព្រឹត្តអំពើបាប
ត្រង់នេះពាក្យ «អ៊ីស្រាអែល» សំដៅទៅលើកុលសម្ព័ន្ធភាគខាងជើងទាំង ១០
ដែលបានបង្កើតនគរអ៊ីស្រាអែល។
ស្តេចបានបម្រើព្រះបាល និងថ្វាយបង្គំព្រះនោះ
ពាក្យថា «បម្រើ» និង «គោរពបូជា» មានន័យជាមូលដ្ឋានដូចគ្នា។
ព្រះរបស់អ៊ីស្រាអែល
ត្រង់នេះពាក្យ «អ៊ីស្រាអែល»
សំដៅទៅលើកុលសម្ព័ន្ធទាំងដប់ពីរដែលចុះមកពីលោកយ៉ាកុប។

២ ពង្សាវតារក្សត្រ

1 [1]ក្រោយពេលដែលព្រះបាទអហាប់បានសោយទិវង្គតទៅ ជនជាតិម៉ូអាប់បានបះបោរប្រឆាំងនឹងជនជាតិអ៊ីស្រាអែល។[2]បន្ទាប់មក ព្រះបាទ
អហាស៊ីយ៉ាបានធ្លាក់ពីលើរានហាលខាងលើនៅស្រុកសាម៉ារី ហើយមានរបួសជាទំងន់។ ដូច្នេះ ស្តេចបានបញ្ជូនអ្នកនាំសារ ហើយនិយាយទៅកាន់ពួកគេថា៖
«សូមទៅសួរបាល-សេប៊ូប ជាព្រះរបស់ក្រុងអេក្រូនមើល ថាតើយើងនឹងបានជាពីបួសនេះឬទេ»។
[3]ប៉ុន្តែ មានទេវតារបស់ព្រះអម្ចាស់មួយរូបបានមានប្រសាសន៍មកលោកអេលីយ៉ាជាអ្នកស្រុកធេសប៊ីថា៖ «ចូរក្រោកឡើង
ចូរឡើងទៅដើម្បីជួបជាមួយអ្នកនាំសាររបស់ស្តេចស្រុកសាម៉ារី ហើយសួរពួកគេថា៖ «តើគ្មានព្រះនៅស្រុកអ៊ីស្រាអែលទេឬ បានជាអ្នករាល់គ្នាទៅសុំយោបល់ពីព្រះបាល-
សេប៊ូបជាព្រះរបស់ក្រុងអេក្រូនដូច្នេះ?[4]ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «អ្នកនឹងមិនអាចក្រោកពីគ្រែដែលអ្នកដេកនោះបានទេ អ្នកនឹងស្លាប់មិនខាន»។ បន្ទាប់មក
លោកអេលីយ៉ាក៏ចេញទៅ។
[5]នៅពេលដែលអ្នកនាំសារបានត្រឡប់ទៅជួបព្រះបាទអហាស៊ីយ៉ាវិញ ស្តេចបានរាជឱង្ការសួរថា៖ «ហេតុអ្វីបានជាអ្នកត្រឡប់មកវិញដូច្នេះ»?[6]ពួកគេបានទូលស្តេចថា៖
«មានបុរសម្នាក់បានមកជួបពួកយើង លោកបាននិយាយជាមួយយើងថា៖ «ចូរត្រឡប់ទៅស្តេចដែលបានបញ្ជូនអ្នកវិញទៅ ហើយទូលទ្រង់ថា៖ «ព្រះអម្ចាស់ទូលថា៖
«តើគ្មានព្រះនៅស្រុកអ៊ីស្រាអែលទេឬ បានជាអ្នកទៅសុំយោបល់ពីព្រះបាល-សេប៊ូបជាព្រះរបស់ក្រុងអេក្រូនដូច្នេះ? ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖
«អ្នកនឹងមិនអាចក្រោកពីគ្រែដែលអ្នកដេកនោះបានទេ អ្នកនឹងស្លាប់មិនខាន»។
[7]ព្រះបាទអស៊ីយ៉ាបានទូលទៅអ្នកនាំសារថា៖ «តើបុរសដែលបានឡើងមកជួបអ្នករាល់គ្នា ហើយបាននិយាយពាក្យទាំងនេះជាមួយអ្នកទាំងអស់គ្នា
តើគាត់ជាមនុស្សប្រភេទណា»?[8]ពួកគេបានទូលស្តេចវិញថា៖ «លោកបានពាក់អាវរោមសត្វ ហើយមានខ្សែក្រវ៉ាត់ស្បែកនៅនឹងចង្កេះរបស់លោក»។ ដូច្នេះ
ស្តេចមានរាជឱង្ការតបវិញថា៖ «នោះគឺលោកអេលីយ៉ា ជាអ្នកស្រុកធេសប៊ី»!
[9]បន្ទាប់មក ស្តេចបានបញ្ជូនមេទ័ពជាមួយទាហានហាសិបនាក់ទៅជួបលោកអេលីយ៉ា។ លោកមេទ័ពបានឡើងទៅជួបលោកអេលីយ៉ា
នៅកន្លែងដែលលោកបានអង្គុយគឺនៅលើកំពូលភ្នំ។ លោកមេទ័ពបាននិយាយទៅលោកថា៖ «លោកជាអ្នកបម្រើរបស់ព្រះជាម្ចាស់អើយ ស្តេចមានរាជឱង្ការថា៖
«សូមអញ្ជើញចុះមក»។[10]លោកអេលីយ៉ាឆ្លើយតបទៅលោកមេទ័ពថា៖ «បើខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់មែន សូមឲ្យមានភ្លើងធ្លាក់ពីលើមេឃមក ឆេះបំផ្លាញលោក
និងទាហានហាសិបនាក់នេះចុះ»។ បន្ទាប់មក ក៏មានភ្លើងធ្លាក់ចុះពីលើមេឃមក ឆេះបំផ្លាញមេទ័ព និងទាហានហាសិបនាក់នោះមែន។
[11]បន្ទាប់មក ព្រះបាទអហ៊ីយ៉ាបានចាត់មេទ័ពម្នាក់ទៀតទៅជួបលោកអេលីយ៉ា និងទាហានហាសិបនាក់ទៅជាមួយ។
លោកមេទ័ពនោះក៏បាននិយាយទៅកាន់លោកអេលីយ៉ាដែរថា៖ «លោកជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ស្តេចមានរាជឱង្ការថា៖ «សូមចុះមកជាប្រញាប់»។
[12]លោកអេលីយ៉ាបានឆ្លើយជាមួយពួកគេថា៖ «បើខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់មែន សូមឲ្យមានភ្លើងធ្លាក់ពីលើមេឃមក ឆេះបំផ្លាញលោក
និងទាហានហាសិបនាក់នេះចុះ»។ បន្ទាប់មក ក៏មានភ្លើងធ្លាក់ចុះពីលើមេឃមក ឆេះបំផ្លាញមេទ័ព និងទាហានហាសិបនាក់នោះម្តងទៀត។
[13]បន្ទាប់មក ស្តេចបានបញ្ជូនក្រុមទីបីដែលមានទាហានហាសិបនាក់ទៅទៀត។ លោកមេទ័ពនេះបានឡើងទៅ គាត់បានលុតជង្គង់នៅចំពោះលោកអេលីយ៉ា
ហើយអង្វរលោក ហើយបាននិយាយថា៖ «លោកដែលជាអ្នកបម្រើរបស់ព្រះអម្ចាស់អើយ សូមឲ្យជីវិតរបស់ខ្ញុំ
និងជីវិតរបស់អ្នកបម្រើហាសិបនាក់របស់លោកមានតម្លៃចំពោះភ្នែកលោកផង។
[14]ពេលមុនមានភ្លើងធ្លាក់ពីលើមេឃមកហើយបានឆេះបំផ្លាញលោកមេទ័ពទាំងពីរដែលមកមុនខ្ញុំ តែឥឡូវនេះសូមឲ្យជីវិតរបស់ខ្ញុំមានតម្លៃចំពោះមុខលោកផង»។

[15]ទេវតារបស់ព្រះអម្ចាស់បាននិយាយទៅលោកអេលីយ៉ាថា៖ «សូមចុះទៅជាមួយគាត់ទៅ។ កុំឲ្យខ្លាចគាត់ឡើយ»។ ដូច្នេះ លោកអេលីយ៉ាបានក្រោកឡើង
ហើយបានចុះទៅជាមួយគាត់ទៅជួបស្តេច។[16]ក្រោយមកលោកអេលីយ៉ាបានទូលទៅព្រះបាទអហ៊ីយ៉ាថា៖ «នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់៖
«ព្រះករុណាបានបញ្ជូនអ្នកនាំសារទៅសុំយោបល់ពីបាល-សេប៊ូល ជាព្រះរបស់ក្រុងអេក្រុន។
តើនៅស្រុកអ៊ីស្រាអែលមិនមានព្រះដែលព្រះករុណាអាចសុំពត៌មានបានទេឬ? ដូច្នេះ ឥឡូវនេះ ព្រះករុណានឹងមិនអាចចុះពីលើគ្រែរបស់អ្នក
ដែលព្រះករុណាបានឡើងទៅនោះបានទេ ព្រះករុណាមុខជាសោយទិវង្គតមិនខាន»។
[17]ដូច្នេះ ស្តេចអហាស៊ីយ៉ាបានសុគតស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលលោកអេលីយ៉ាបានថ្លែងមែន។ ព្រះបាទយ៉ូរ៉ាមបានឡើងសោយរាជ្យបន្តពីស្តេច
នៅក្នុងឆ្នាំទីពីរនៃរាជ្យរបស់ព្រះបាទយ៉ូសាផាត ស្តេចស្រុកយូដា។ ព្រោះព្រះបាទអហាស៊ីយ៉ាគ្មានបុត្រទេ។[18]រឿងរ៉ាវផ្សេងទៀតទាក់ទងនឹងព្រះបាទអហាស៊ីយ៉ា
តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចអ៊ីស្រាអែលទេឬ?

---

2 Kings 1:1

ម៉ូអាប់

«ប្រទេសម៉ូអាប់»

រានហាលខាងលើ

បន្ទប់ខាងលើត្រូវបានសាងសង់នៅលើដំបូលវិមាន។

រានហាលត្រូវបានធ្វើពីក្តារស្តើង ៗ

តុបតែងលម្អឆ្លងកាត់គ្នាដើម្បីបង្កើតជាយ៉ូឬបង្អួច។ ការបកប្រែផ្សេងទៀត៖ «
ក្តារឈើព័ទ្ធជុំវិញដំបូលរាបស្មើនៃវិមានរបស់គាត់»

បាល-សេប៊ូប

2 Kings 1:3

ព្រះអម្ចាស់

នេះគឺជាឈ្មោះរបស់ព្រះដែលគាត់បានបង្ហាញដល់ប្រជាជនរបស់ទ្រង់នៅក្នុងគម្ពីរសញ្ញាចាស់។
សូមមើលទៅការបកប្រែទំព័រនៃពាក្យអំពីព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។

ធេសប៊ី

នេះសំដៅទៅលើមនុស្សម្នាក់មកពី ទីក្រុងធេសប៊ី។

តើគ្មានព្រះនៅស្រុកអ៊ីស្រាអែលទេ ឬ បានជាអ្នករាល់គ្នាទៅសុំយោបល់ពីព្រះបាល-សេប៊ូបជាព្រះ
របស់ក្រុងអេក្រូនដូច្នេះ?

សំណួរវោហារស័ព្ទនេះត្រូវបានគេសួរថាជាការស្តីបន្ទោសសម្រាប់ការប្រឹក្សា បាល-
សេប៊ូប។ នេះអាចត្រូវបានសរសេរជាឃ្លាភ្ជាប់។

នេះជារឿងគួរឱ្យអស់សំណើចពីព្រោះពួកគេច្បាស់ជាស្គាល់ព្រះនៃអ៊ីស្រាអែល។

ការបកប្រែផ្សេងទៀត៖ «មនុស្សល្ងីល្ងើ!
អ្នកដឹងថាមានព្រះមួយនៅស្រុកអ៊ីស្រាអែលប៉ុន្តែអ្នកបានធ្វើហាក់ដូចជាអ្នកមិនដឹងនៅពេលដែលអ្នកចាត់មនុស្សឲ្យទៅពិគ្រោះជាមួយ
បាល-សេប៊ូបជាព្រះរបស់អេក្រូន!»

សុំយោបល់ពីព្រះបាល-សេប៊ូប

ពាក្យ«ពិគ្រោះយោបល់»
មានន័យថាទទួលបានយោបល់ពីនរណាម្នាក់អំពីសំណួរមួយ។

ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា

នេះជាសាររបស់ព្រះអម្ចាស់ចំពោះព្រះបាទអហាស៊ីយ៉ា។ ការបកប្រែផ្សេងទៀត៖
«ដូច្នេះព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ស្តេចអហាស៊ីយ៉ា»

អ្នកនឹងមិនអាចក្រោកពីគ្រែដែលអ្នកដេកនោះបានទេ

នៅពេលដែលស្តេចអហាស៊ីយ៉ារងរបួស ទ្រង់ត្រូវបានគេដាក់នៅលើគ្រែ។
ព្រះអម្ចាស់បានមានបន្ទូលថាគាត់នឹងមិនជាទេ
ហើយមិនអាចក្រោកពីគ្រែបានឡើយ។ ការបកប្រែផ្សេងទៀត៖
«អ្នកនឹងមិនជាសះស្បើយទេ
ហើយអ្នកនឹងមិនក្រោកពីគ្រែដែលអ្នកកំពុងដេកនោះឡើយ»

2 Kings 1:5

នៅពេលដែលអ្នកនាំសារបានត្រឡប់ទៅជួបព្រះបាទអហាស៊ីយ៉ាវិញ

បន្ទាប់ពីបានជួបជាមួយអេលីយ៉ាអ្នកនាំសារបានត្រឡប់ទៅគាល់ស្តេចជាជាងទៅអេក្រូន។

តើគ្មានព្រះជាម្ចាស់នៅស្រុកអ៊ីស្រាអែលទេ ឬ បានជាអ្នកទៅសុំយោបល់ពីព្រះបាល-សេប៊ូបជាព្រះ
របស់ក្រុងអេក្រូនដូច្នេះ?

សំណួរវោហារស័ព្ទនេះត្រូវបានគេសួរថាជាការស្តីបន្ទោសសម្រាប់ការប្រឹក្សាជាមួយព្រះ
បាល-សេប៊ូប។ នេះអាចត្រូវបានសរសេរជាឃ្លាភ្ជាប់។
នេះជារឿងគួរឱ្យអស់សំណើចពីព្រោះ ពួកគេច្បាស់ជាស្គាល់ព្រះនៃអ៊ីស្រាអែល។
សូមមើលពីរបៀបដែលបានបកប្រែសំណួរស្រដៀងគ្នានេះនៅក្នុងជំពូក ១: ៣ ។
ការបកប្រែផ្សេងទៀត៖ «មនុស្សល្ងីល្ងើ!
អ្នកដឹងថាមានព្រះមួយនៅស្រុកអ៊ីស្រាអែល
ប៉ុន្តែអ្នកបានធ្វើហាក់ដូចជាអ្នកមិនដឹងនៅពេលដែលអ្នកចាត់មនុស្សឲ្យទៅពិគ្រោះជាមួយ
អ្នកនឹងមិនអាចក្រោកពីគ្រែដែលអ្នកដេកនោះបានទេ

នៅពេលដែលស្តេចអហាស៊ីយ៉ារងរបួសគាត់ត្រូវបានគេដាក់នៅលើគ្រែ។
ព្រះអម្ចាស់បានមានបន្ទូលថាគាត់នឹងមិនដែលបានជាទេ
ហើយអាចក្រោកពីគ្រែបាន។
ការបកប្រែសេចក្តីថ្លែងការណ៍នេះដូចគ្នានឹងអ្នកបានធ្វើក្នុង ១: ៣ ។
ការបកប្រែផ្សេងទៀត៖ «អ្នកនឹងមិនអាចជាសះស្បើយទេ
ហើយអ្នកនឹងមិនអាចក្រោកពីគ្រែដែលអ្នកកំពុងដេក»

2 Kings 1:7

ពួកគេបានទូលស្តេចវិញថា៖ «លោកបានពាក់អាវរោមសត្វ

អាចមានន័យថាគឺ ១)
នេះជាពាក្យប្រៀបធៀបដែលនិយាយអំពីគាត់មានរោមខ្លាំងដូចជាសក់របស់គាត់ជាសម្លៀកបំពាក់។
ការបកប្រែផ្សេងទៀត៖ «គាត់មានរោមណាស់» ឬ ២)
«សម្លៀកបំពាក់របស់គាត់ត្រូវបានធ្វើពីរោមសត្វ»

2 Kings 1:9

បន្ទាប់មក ស្តេចបានបញ្ជូនមេទ័ពជាមួយទាហានហាសិបនាក់ទៅជួបលោកអេលីយ៉ា
ស្តេចចាត់មេបញ្ជាការឲ្យទៅជាមួយពលទាហានហាសិបនាក់ដើម្បីនាំលោកអេលីយ៉ាមកជួបស្តេច។
ការបកប្រែផ្សេងទៀត៖
«បន្ទាប់មកស្តេចបានចាត់មេទ័ពម្នាក់ដែលមានទាហានហាសិបនាក់ដើម្បីចាប់អេលីយ៉ា»

ទាហានហាសិបនាក់

«ទាហាន ៥០ នាក់»

បើខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់មែន សូមឲ្យមានភ្លើងធ្លាក់ពីលើមេឃមក
នាយទាហានបានហៅលោកអេលីយ៉ាថាជាអ្នកជំនិតរបស់ព្រះជាម្ចាស់
តែមេទ័ពនិងស្តេចមិនបានបង្ហាញការគោរពត្រឹមត្រូវដល់លោកអេលីយ៉ាទេ។
[illegible]
ការបកប្រែផ្សេងទៀត៖
«ដោយសារខ្ញុំជាមនុស្សរបស់ព្រះសូមឱ្យភ្លើងចុះពីលើមេឃ» ឬ
«ប្រសិនបើខ្ញុំជាមនុស្សរបស់ព្រះដូចដែលអ្នកបាននិយាយសូមឱ្យមានភ្លើងធ្លាក់ពីលើមេឃមក»
។

លើមេឃ

«មេឃ»

2 Kings 1:11

ទាហានហាសិបនាក់

«ទាហាន ៥០ នាក់»

បើខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់មែន សូមឲ្យមានភ្លើងធ្លាក់ពីលើមេឃមក
នាយទាហានបានហៅអេលីយ៉ាថាជាអ្នកជំនិតរបស់ព្រះជាម្ចាស់
តែមេទ័ពនិងស្តេចមិនបានបង្ហាញការគោរពត្រឹមត្រូវដល់អេលីយ៉ាទេ។
លោកអេលីយ៉ាបាននិយាយដូច្នេះថាភ្លើងនឹងធ្លាក់ចុះពីលើមេឃហើយនេះបង្ហាញថាអេលីយ៉ាពិតជាមនុស្ស
បកប្រែឃ្លានេះដូចគ្នានឹងអ្នកបានធ្វើក្នុងជំពូក ១: ៩ ។ ការបកប្រែផ្សេងទៀត៖
«ដោយសារខ្ញុំជាមនុស្សរបស់ព្រះសូមឱ្យភ្លើងចុះពីលើមេឃ» ឬ
«ប្រសិនបើខ្ញុំជាមនុស្សរបស់ព្រះដូចដែលអ្នកបាននិយាយសូមឱ្យមានភ្លើងធ្លាក់ពីលើមេឃមក»
។

ភ្លើងធ្លាក់ចុះ

នេះមានន័យថាភ្លើងបានមកពីព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត៖
«ភ្លើងមកពីព្រះជាម្ចាស់»

2 Kings 1:13

ទាហានហាសិបនាក់

« អ្នកចម្បាំង ៥០ នាក់» ឬ « ទាហាន ៥០ នាក់»

អង្វរលោក

[illegible]

អ្នកបម្រើហាសិបនាក់របស់លោក

មេបញ្ជាការនិយាយថាអ្នកបម្រើរបស់គាត់ គឺជាអ្នកបម្រើរបស់អេលីយ៉ា

generated on Wed Sep 10 16:16:32 2025

ដើម្បីបង្ហាញការគោរពដល់គាត់។ នៅ «ទាហានហាសិបនាក់របស់ខ្ញុំ»
សូមឲ្យជីវិតរបស់ខ្ញុំមានតម្លៃចំពោះមុខលោកផង
ឃ្លាថា « ការមើលឃើញរបស់អ្នក» សំដៅទៅលើអ្វីដែលអេលីយ៉ាគិត។
មេបញ្ជាការកំពុងអង្វរអេលីយ៉ាដើម្បីឱ្យពួកគេមានជីវិត។ ការបកប្រែផ្សេងទៀត៖
«សូមពិចារណាជីវិតរបស់ខ្ញុំ ... ដែលមានតម្លៃសម្រាប់អ្នក» ឬ
«ពិចារណាជីវិតរបស់ខ្ញុំ ... ឱ្យតម្លៃចំពោះអ្នកហើយកុំសម្លាប់យើង»
សូមឲ្យជីវិតរបស់ខ្ញុំមានតម្លៃចំពោះមុខលោកផង
នៅទីនេះមេបញ្ជាការកំពុងធ្វើម្តងទៀតនូវការស្នើសុំរបស់គាត់សម្រាប់អេលីយ៉ាដើម្បីបង្ហាញ
ការបកប្រែផ្សេងទៀត៖ «សូមមេត្តាចំពោះខ្ញុំ!» ឬ «សូមទុកឱ្យខ្ញុំរស់ផង»
2 Kings 1:15
តើនៅស្រុកអ៊ីស្រាអែលមិនមានព្រះដែលព្រះករុណាអាចសុំពត៌មានបានទេឬ?
សំណួរវោហារស័ព្ទនេះត្រូវបានគេសួរថាជាការស្តីបន្ទោសសម្រាប់ការប្រឹក្សាជាមួយបាល
សេប៊ូល។ នេះអាចត្រូវបានសរសេរជាឃ្លាភ្ជាប់។
នេះជារឿងគួរឱ្យអស់សំណើចពីព្រោះស្តេចពិតជាស្គាល់ព្រះជាម្ចាស់នៃអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត៖
«អ្នកគិតថាគ្មានព្រះជាម្ចាស់នៅក្នុងប្រទេសអ៊ីស្រាអែលដែលអ្នកអាចស្នើសុំព័ត៌មានបាន
ឬ «មនុស្សល្ងីល្ងើ!
អ្នកដឹងថាមានព្រះជាម្ចាស់ដែលនឹងពិគ្រោះជាមួយអ៊ីស្រាអែលតែអ្នកធ្វើដូចអ្នកមិនដឹង។

»
ព្រះករុណានឹងមិនអាចចុះពីលើគ្រែរបស់អ្នក ដែលព្រះករុណាបានឡើងទៅនោះបានទេ
នៅពេលដែលស្តេចអហាស៊ីយ៉ារងរបួសគាត់ត្រូវបានគេដាក់នៅលើគ្រែ។
ព្រះអម្ចាស់បានមានបន្ទូលថាគាត់នឹងមិនជាទេហើយមិនអាចក្រោកពីគ្រែបានទេ។
បកប្រែឃ្លានេះដូចគ្នានៅក្នុងជំពូក ១: ៣ ។ ការបកប្រែផ្សេងទៀត៖
«អ្នកនឹងមិនជាសះស្បើយទេហើយអ្នកនឹងមិនក្រោកពីគ្រែដែលអ្នកកំពុងដេកទេ»
2 Kings 1:17
ដែលមានន័យថាគាត់នឹងស្លាប់ហើយមិនមានកូនប្រុសដើម្បីឡើងសោយរាជ្យជំនួសគាត់ទេ។
«អ្វីដែលព្រះអម្ចាស់មានបន្ទូលប្រាប់លោកអេលីយ៉ាដែលថាអេលីយ៉ាបាននិយាយ»
ឆ្នាំទីពីរ
«ឆ្នាំទី ២»
នៅក្នុងឆ្នាំទីពីរនៃរាជ្យរបស់ព្រះបាទយ៉ូសាផាត ស្តេចស្រុកយូដា
នេះពិតណ៌នាអំពីពេលវេលាដែលយ៉ូរ៉ាមបានឡើងសោយរាជ្យដោយបញ្ជាក់ថាតើស្តេចស្រុកយូដាបច្ចុប្បន្ន
ការបកប្រែផ្សេងទៀត៖ «នៅឆ្នាំទី ២
ដែលយ៉ូរ៉ាមជាបុត្ររបស់យ៉ូសាផាតធ្វើជាស្តេចស្រុកយូដា»
ទីនេះមានកត់ត្រាទុកនៅក្នុង...អ៊ីស្រាអែលទេឬ?
សំណួរវោហារស័ព្ទនេះអាចត្រូវបានសរសេរជាឃ្លាបញ្ជាក់។ ការបកប្រែផ្សេងទៀត៖
ពួកគេត្រូវបានសរសេរ ... អ៊ីស្រាអែល» ។

---

2 [1]ដូច្នេះ នៅពេលដែលព្រះអម្ចាស់នឹងលើកលោកអេលីយ៉ាទៅស្ថានសួគ៌ដោយខ្យល់កួច គឺលោកអេលីយ៉ាបានចេញទៅក្រៅជាមួយលោកអេលីសេពីគីលកាល។
[2]លោកអេលីយ៉ាបានប្រសាសន៍ទៅលោកអេលីសេថា៖ «សូមនៅទីនេះសិនចុះ ព្រោះព្រះអម្ចាស់បានឲ្យខ្ញុំទៅបេតអែល»។ លោកអេលីសេឆ្លើយថា៖
«ព្រះអម្ចាស់មានព្រះជន្មរស់ ហើយលោកក៏មានជីវិតនៅរស់ដែរ ខ្ញុំសូមប្រាប់លោកថាខ្ញុំនឹងមិនចាកចេញពីលោកឡើយ»។ ដូច្នេះ ពួកគេបានចុះទៅបេតអែលជាមួយគ្នា។
[3]កូនរបស់ព្យាការីម្នាក់ដែលនៅបេតអែលបានមកជួបលោកអេលីសេ ហើយនិយាយថា៖ «តើអ្នកដឹងទេថាព្រះអម្ចាស់នឹងដកយកលោកគ្រូរបស់អ្នកនៅថ្ងៃនេះ»?
លោកអេលីសេឆ្លើយថា៖ «បាទខ្ញុំដឹងហើយ ប៉ុន្តែ កុំនិយាយរឿងនេះអី»។[4]លោកអេលីយ៉ានិយាយទៅគាត់ថា៖ «អេលីសេអើយ ចូរចាំនៅទីនេះសិន
ព្រោះព្រះអម្ចាស់នឹងចាត់ខ្ញុំឲ្យទៅយេរីខូ»។ បន្ទាប់មក លោកអេលីសេឆ្លើយថា៖ «ព្រះអម្ចាស់មានព្រះជន្មគង់នៅ ហើយលោកគ្រូក៏មានជីវិតនៅរស់ ខ្ញុំសូមប្រាប់លោកថា
ខ្ញុំនឹងមិនចាកចេញពីលោកឡើយ»។ ដូច្នេះ ពួកគេបានចេញទៅក្រុងយេរីខូជាមួយគ្នា។
[5]បន្ទាប់មក កូនរបស់ព្យាការីដែលនៅក្រុងយេរីខូបានមកជួបលោកអេលីសេ ហើយនិយាយទៅគាត់ថា៖
«តើអ្នកដឹងទេថាព្រះអម្ចាស់នឹងដកលោកគ្រូរបស់លោកទៅនៅថ្ងៃនេះ»? លោកអេលីសេតបថា៖ «បាទ ខ្ញុំដឹងហើយ ប៉ុន្តែកុំនិយាយពីវាធ្វើអ្វី»។[6]បន្ទាប់មក
លោកអេលីយ៉ាមានប្រសាសន៍ទៅលោកថា៖ «សូមនៅទីនេះសិន ព្រោះព្រះអម្ចាស់ចាត់ខ្ញុំទៅឯទន្លេយ័រដាន់»។ លោកអេលីសេឆ្លើយថា៖ «ព្រះអម្ចាស់មានព្រះជន្មគង់នៅ
ហើយលោកគ្រូក៏មានជីវិតនៅរស់ ខ្ញុំសូមប្រាប់លោកថា ខ្ញុំនឹងមិនចាកចេញពីលោកឡើយ»។ ដូច្នេះ ពួកគេបានចេញទៅដំណើរទៅមុខទៀត។
[7]ក្រោយមក មានកូនប្រុសៗហាសិបនាក់របស់ព្យាការីជាច្រើនបានឈរពីចម្ងាយនៅទល់មុខពួកគេ នៅពេលដែលពួកគេបានឈរនៅក្បែរទន្លេយ័រដាន់។
[8]លោកអេលីយ៉ាបានយកកន្សែងរបស់លោក លោកមូរកន្សែងនោះ ហើយបានយកកន្លែងនោះវាយទឹក។ ទឹកទន្លេក៏ញែកជាពីរ ដូច្នេះ
លោកទាំងពីរបានដើរឆ្លងកាត់តាមដីស្ងួត។
[9]នៅពេលដែលពួកគេបានឆ្លងកាត់រួចហើយ លោកអេលីយ៉ាបានមានប្រសាសន៍ទៅលោកអេលីសេថា៖ «តើចង់ឲ្យខ្ញុំធ្វើអ្វីសម្រាប់អ្នក
មុនពេលដែលខ្ញុំចាកចេញពីអ្នកទៅ»។ លោកអេលីសេឆ្លើយថា៖ «សូមឲ្យវិញ្ញាណរបស់លោកមកសណ្ឋិតលើខ្ញុំទ្វេដង»។[10]លោកអេលីយ៉ាឆ្លើយថា៖
«អ្នកបានសុំពីខ្ញុំនូវរឿងដ៏លំបាក។ តែបើអ្នកឃើញខ្ញុំ នៅពេលដែលខ្ញុំត្រូវបានលើកឡើងចេញពីអ្នក នោះការនេះនឹងសម្រេចដូចដែលអ្នកបានសុំ តែបើមិនដូច្នេះទេ
វានឹងមិនសម្រេចឡើយ»។
[11]នៅពេលដែលពួកគេធ្វើដំណើរបន្ត ហើយនិយាយគ្នាផង ពេលនោះមានរទេះភ្លើង និងសេះភ្លើងមួយបានបង្ហាញខ្លួន ញែកបុរសទាំងពីរចេញពីគ្នា
ហើយលោកអេលីយ៉ាបានឡើងទៅលើស្ថានសួគ៌ដោយសារខ្យល់ព្យុះ។[12]លោកអេលីសេបានឃើញការនេះ ក៏ស្រែកឡើងថា៖ «លោកឪពុកអើយ លោកឪពុកអើយ
នោះគឺរទេះចម្បាំងនិងអ្នកជិះសេះរបស់អ៊ីស្រាអែល»! លោកមិនអាចឃើញលោកអេលីយ៉ាបានទៀតទេ ហើយលោកបានយកអាវរបស់លោកមកហែកជាពីរចំណែក។
[13]លោកបានរើសកន្សែងរបស់លោកអេលីយ៉ា ដែលបានធ្លាក់នៅក្បែរគាត់ឡើង ហើយបានត្រឡប់ទៅឈរនៅក្បែរមាត់ទន្លេយ័រដាន់។
[14]លោកបានយកកន្សែងរបស់លោកអេលីយ៉ាមកវាយទឹក ទឹកក៏ញែកជាពីរ ហើយលោកអេលីសេក៏ដើរឆ្លងកាត់។
[15]នៅពេលដែលកូនប្រុសៗរបស់ពួកព្យាការីដែលមកពីក្រុងយេរីខូបានឃើញគាត់ពីចម្ងាយពួកគេនិយាយថា៖
«វិញ្ញាណរបស់លោកអេលីយ៉ាបានមកសណ្ឋិតនៅលើលោកអេលីសេហើយ!» ដូច្នេះ ពួកគេបានមកជួបលោក ហើយបានក្រាបនៅមុខលោកដល់ដី។
[16]ពួកគេបាននិយាយទៅលោកថា៖ «ឃើញទេឥឡូវនេះ នៅក្នុងចំណោមអ្នកបម្រើរបស់លោកមានមនុស្សខ្លាំងពូកែរហាសិបនាក់។ យើងសូមឲ្យពួកគេចេញទៅ
ហើយរកលោកគ្រូរបស់លោក ក្នុងករណីដែលព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានលើកគាត់ឡើង ហើយបោះលោកទៅលើភ្នំណាមួយ ឬទៅក្នុងជ្រោះណាមួយ»។
លោកអេលីសេឆ្លើយថា៖ «ទេ កុំឲ្យពួកគេទៅធ្វើអ្វី»។
[17]ប៉ុន្តែ នៅពេលដែលអ្នកទាំងនោះទទូចលោកអេលីសេរហូតដល់លោកមានការអៀនខ្មាស លោកបាននិយាយថា៖ «ចូរឲ្យពួកគេទៅចុះ»។ ដូច្នេះ
ពួកគេបានបញ្ជូនបុរសទាំងហាសិបអ្នកនោះទៅ ហើយពួកគេបានទៅរកអស់បីថ្ងៃ ប៉ុន្តែ រកមិនឃើញលោកទេ។[18]ពួកគេបានត្រឡប់មកជួបលោកអេលីសេវិញ
នៅពេលដែលលោកស្នាក់នៅក្រុងយេរីខូ ហើយបាននិយាយជាមួយលោកថា៖ «តើខ្ញុំមិនបាននិយាទៅអ្នករាល់គ្នាទេថា៖ «កុំឲ្យទៅ?»
[19]ពួកប្រុសៗក្នុងក្រុងបាននិយាយទៅលោកអលីសេថា៖ «ឃើញទេ យើងបានសុំលោក ស្ថានភាពនៅក្នុងក្រុងនេះល្អណាស់ ដូចដែលលោកអាចឃើញស្រាប់ ប៉ុន្តែ
ទឹកមិនល្អទេ ហើយដីក៏មិនបង្កើតផលដែរ»។[20]លោកអេលីសេឆ្លើយថា៖ «សូមយកចានគោមថ្មីមួយមកឲ្យខ្ញុំ ហើយសុំដាក់អំបិលនៅក្នុងនោះផង» ដូច្នេះ
ពួកគេបានយកមកជូនលោក។
[21]លោកអេលីសេបានចេញទៅប្រភពទឹកហើយបាចអំបិលក្នុងទឹកនោះ បន្ទាប់មក លោកនិយាយថា៖ «ព្រះអម្ចាស់មានបន្ទូលថា៖ «យើងបានប្រោសទឹកនេះ។
ចាប់ពីពេលនេះតទៅ នឹងគ្មានអ្វីស្លាប់ និងមិនមានដីដែលមិនបង្កើតផងទៀតទេ»។[22]ដូច្នេះ ទឹកនោះបានល្អឡើងវិញរហូតដល់ថ្ងៃនេះ
ដោយសារតែពាក្យដែលលោកអេលីសេបាននិយាយ។
[23]បន្ទាប់មក លោកអេលីសេបានឡើងពីទីនោះទៅបេតអែល។ នៅពេលដែលលោកឡើងទៅតាមផ្លូវ មានក្មេងប្រុសៗចេញពីក្រុងមក ហើយបានចំអកដាក់លោក
ហើយបាននិយាយទៅលោកថា៖ «ឡើងទៅ លោកក្បាលទំពែក ឡើងទៅ លោកក្បាលទំពែក»។[24]លោកអេលីសេបានក្រឡេកមើលក្រោយ ហើយបានឃើញពួកគេ

generated on Wed Sep 10 16:16:32 2025

លោកបានប្រកាសហៅព្រះអម្ចាស់ ដើម្បីឲ្យព្រះអង្គដាក់បណ្តាសារពួកគេ។ មានមេខ្លាឃ្មុំពីរចេញពីព្រៃមក ហើយធ្វើឲ្យក្មេងសែសិបពីរនាក់មានរបួស។[25]បន្ទាប់មក លោកអេលីសេបានចេញពីទីនោះទៅភ្នំកើមែល រួចត្រឡប់ទៅក្រុងសាម៉ារីវិញ។

---

2 Kings 2:1
ដូច្នេះ
ដូច្នេះវាបានកើតឡើង។
ឃ្លានេះត្រូវបានប្រើដើម្បីណែនាំព្រឹត្តិការណ៍បន្ទាប់នៅក្នុងដំណើររឿង។
ខ្យល់កួច
ជាខ្យល់បក់ខ្លាំងដែលវិលជុំវិញ
ព្រះអម្ចាស់មានព្រះជន្មរស់ ហើយលោកក៏មានជីវិតនៅរស់ដែរ
«ព្រះអម្ចាស់ពិតជាមានព្រះជន្មរស់និងដូចអ្នករស់នៅ»។
នៅទីនេះលោកអេលីសេប្រៀបធៀបភាពប្រាកដប្រជាដែលថាព្រះអម្ចាស់និងអេលីយ៉ា
នេះគឺជាវិធីនៃការសន្យាដ៏ឧឡារិក។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំសន្យាជាមួយអ្នកយ៉ាងម៉ឺងម៉ាត់ថា»
2 Kings 2:3
កូនរបស់ព្យាការី
នេះមិនមានន័យថាពួកគេជាកូនចៅរបស់ព្យាការីទេផ្ទុយទៅវិញពួកគេគឺជាក្រុមព្យាការី។
ការបកប្រែផ្សេងទៀត៖ « ក្រុមមនុស្សប្រុសដែលជាព្យាការី»
«ព្រះអម្ចាស់មានព្រះជន្មគង់នៅ ហើយលោកគ្រូក៏មានជីវិតនៅរស់ ខ្ញុំសូមប្រាប់លោកថា
ខ្ញុំនឹងមិនចាកចេញពីលោកឡើយ»
«ដូចព្រះអម្ចាស់មានព្រះជន្មរស់នៅ
និងដូចអ្នករស់នៅខ្ញុំនឹងមិនឃ្លាតឆ្ងាយពីអ្នកឡើយ» ។ នៅទីនេះលោកអេលីសេ
ប្រៀបធៀបភាពប្រាកដប្រជាដែលថាព្រះអម្ចាស់ និងលោកអេលីយ៉ា
នៅរស់រានមានជីវិតនឹងភាពប្រាកដប្រជានៃអ្វីដែលគាត់កំពុងនិយាយ។
នេះគឺជាវិធីនៃការសន្យាដ៏ឧឡារិក។
សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លានេះនៅជំពូក ២: ១ ។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំសន្យានឹងអ្នកថាខ្ញុំនឹងមិនចាកចេញពីអ្នកទេ»
2 Kings 2:5
បន្ទាប់មក កូនរបស់ព្យាការីដែលនៅក្រុងយេរីខូបានមកជួបលោកអេលីសេ
ហើយនិយាយទៅគាត់ថា
ពេលអេលីយ៉ានិងអេលីសេចូលមកជិតក្រុងយេរីខូ កូនៗ
របស់ពួកព្យាការីដែលនៅទីនោះ បាននិយាយទៅកាន់អេលីសេថា។
កូនរបស់ព្យាការី
នេះមិនមានន័យថាពួកគេជាកូនចៅរបស់ព្យាការីទេផ្ទុយទៅវិញពួកគេគឺជាក្រុមព្យាការី។
សូមមើលបកប្រែឃ្លានេះក្នុងជំពូក ២: ៣ ។ ការបកប្រែផ្សេងទៀត៖ «
ក្រុមមនុស្សប្រុស ដែលជាព្យាការី»
«ព្រះអម្ចាស់មានព្រះជន្មគង់នៅ ហើយលោកគ្រូក៏មានជីវិតនៅរស់ ខ្ញុំសូមប្រាប់លោកថា
ខ្ញុំនឹងមិនចាកចេញពីលោកឡើយ»
«ដូចព្រះអម្ចាស់មានព្រះជន្មគង់នៅនិងដូចអ្នករស់នៅ
ខ្ញុំនឹងមិនឃ្លាតឆ្ងាយពីអ្នកឡើយ» ។ នៅទីនេះ
អេលីសេប្រៀបធៀបភាពប្រាកដប្រជាដែលថា ព្រះអម្ចាស់និងអេលីយ៉ានៅរស់
នឹងភាពប្រាកដប្រជានៃអ្វីដែលគាត់កំពុងនិយាយ។
នេះគឺជាវិធីនៃការសន្យាដ៏ឧឡារិក។ សូមមើលបកប្រែឃ្លានេះក្នុងជំពូក ២: ១ ។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំសន្យានឹងអ្នកថាខ្ញុំនឹងមិនចាកចេញពីអ្នកទេ»
2 Kings 2:7
កូនប្រុសៗហាសិបនាក់
«កូនប្រុស ៥០ នាក់»
កូនប្រុសៗរបស់ព្យាការី
នេះមិនមានន័យថាពួកគេជាកូនចៅរបស់ព្យាការីទេផ្ទុយទៅវិញពួកគេគឺជាក្រុមព្យាការី។
សូមមើលបកប្រែឃ្លានេះក្នុងជំពូក ២: ៣ ។ ការបកប្រែផ្សេងទៀត៖ «
ក្រុមបុរសដែលជាហោរា»
បានឈរពីចម្ងាយនៅទល់មុខពួកគេ
នេះមានន័យថាពួកគេកំពុងឈរបែរមុខទៅពួកគេ។ ការបកប្រែផ្សេងទៀត៖
«ឈរបែរមុខ» ឬ« ឈរមើលពួកគេ»
កន្សែង
សម្លៀកបំពាក់ខាងក្រៅប្រើសម្រាប់គ្រប់បាំង
ទឹកទន្លេក៏ញែកជាពីរ ដូច្នេះ លោកទាំងពីរបានដើរឆ្លងកាត់តាមដីស្ងួត
« ទឹកទន្លេយ័រដាន់បានបើកឡើង
ដូច្នេះមានផ្លូវស្ងួតសម្រាប់អេលីយ៉ានិងអេលីសេឆ្លងទៅត្រើយម្ខាង»
ជាពីរ
«ទៅខាងស្តាំនិងខាងឆ្វេង» ។
នេះសំដៅទៅលើផ្នែកខាងស្តាំនិងខាងឆ្វេងកន្លែងដែលលោកអេលីយ៉ាវាយទឹក។
2 Kings 2:9
នៅពេល
«វាបានកើតឡើង»
បានឆ្លងកាត់
[illegible]
«បានឆ្លងកាត់ទន្លេយ័រដាន់»
មុនពេលដែលខ្ញុំចាកចេញពីអ្នកទៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«មុនពេលព្រះអម្ចាស់ដកខ្ញុំចេញពីអ្នក»
សូមឲ្យវិញ្ញាណរបស់លោកមកសណ្ឋិតលើខ្ញុំទ្វេដង
នៅទីនេះវិញ្ញាណរបស់អេលីយ៉ាសំដៅទៅលើអំណាចខាងវិញ្ញាណរបស់គាត់។
ការបកប្រែផ្សេងទៀត៖ «អំណាចខាងវិញ្ញាណរបស់អ្នកទ្វេដង»
2 Kings 2:11
មើលចុះ
ពាក្យថា« មើល»
នៅទីនេះដាស់តឿនយើងឱ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើលដែលកើតឡើងក្រោយ។
រទេះភ្លើង និងសេះភ្លើងមួយ
នៅទីនេះឃ្លា «ភ្លើង» មានន័យថាវត្ថុទាំងនេះព័ទ្ធជុំវិញដោយភ្លើង។
ការបកប្រែផ្សេងទៀត៖ «រទេះសេះព័ទ្ធជុំវិញដោយភ្លើង
ទាញដោយសេះព័ទ្ធជុំវិញដោយភ្លើង»
បានឡើងទៅលើស្ថានសួគ៌ដោយសារខ្យល់ព្យុះ
"ត្រូវបានគេយកទៅលើមេឃដោយខ្យល់កួច។ « បកប្រែពាក្យ » ខ្យល់កួច «
ដូចគ្នានឹងនៅក្នុងជំពូក ២: ១ »។
លោកឪពុកអើយ លោកឪពុកអើយ
អេលីសេកំពុងហៅអេលីយ៉ាជាមេដឹកនាំដែលគួរឱ្យគោរព។
ហែកជាពីរចំណែក
ជារឿយៗមនុស្សយើងហែកសម្លៀកបំពាក់របស់ពួកគេជាសញ្ញានៃភាពសោកសៅឬទុក្ខព្រួយយ៉ាងខ្លាំង។
ការបកប្រែផ្សេងទៀត៖
«ហែកពួកវាជាពីរបំណែកដើម្បីបង្ហាញពីភាពសោកសៅយ៉ាងខ្លាំងរបស់គាត់»
2 Kings 2:13
កន្សែង
កន្សែងនោះគឺជាសម្លៀកបំពាក់របស់ព្យាការី។ វាគឺជាសញ្ញានៃការងាររបស់គាត់។
នៅពេលដែលអេលីសេបានកន្សែងបំពាក់របស់អេលីយ៉ាគាត់បាននិយាយថាគាត់បានយកតួនាទីរបស់អេ
តើព្រះអម្ចាស់ជាព្រះរបស់អេលីយ៉ានៅឯណា?
អេលីសេកំពុងសួរថាតើព្រះអម្ចាស់នៅជាមួយគាត់ដូចគាត់នៅជាមួយអេលីយ៉ាដែរឬទេ?
ការបកប្រែផ្សេងទៀត៖
«ព្រះអម្ចាស់ជាព្រះរបស់លោកអេលីយ៉ាគង់នៅទីនេះជាមួយខ្ញុំទេ?»
ទឹកក៏ញែកជាពីរ ហើយលោកអេលីសេក៏ដើរឆ្លងកាត់
ទឹកទន្លេបានញែកចេញហើយលោកអេលីសេបានដើរទៅត្រើយម្ខាងលើដីហួតហែងតាមរបៀបដដែលដែ
ជាពីរ
«ទៅខាងស្តាំនិងខាងឆ្វេង» ។
នេះសំដៅទៅលើផ្នែកខាងស្តាំនិងខាងឆ្វេងកន្លែងដែលលោកអេលីយ៉ាវាយទឹក។
2 Kings 2:15
កូនប្រុសៗរបស់ពួកព្យាការី
នេះមិនមានន័យថាពួកគេជាកូនចៅរបស់ព្យាការីទេផ្ទុយទៅវិញពួកគេគឺជាក្រុមព្យាការី។
សូមមើលបកប្រែឃ្លានេះនៅជំពូក ២: ៣ ។ ការបកប្រែផ្សេងទៀត៖ «ក្រុមព្យាការី»
បានក្រាបនៅមុខលោកដល់ដី
ពួកគេកំពុងបង្ហាញការគោរពដល់គាត់និងទទួលស្គាល់គាត់ជាមេដឹកនាំថ្មីរបស់ពួកគេ។
វិញ្ញាណរបស់លោកអេលីយ៉ាបានមកសណ្ឋិតនៅលើលោកអេលីសេ
នៅទីនេះ«វិញ្ញាណ» របស់អេលីយ៉ាសំដៅទៅលើអំណាចខាងវិញ្ញាណរបស់គាត់។
នេះនិយាយអំពីអេលីសេដែលមានអំណាចខាងវិញ្ញាណនេះហាក់ដូចជាវាជាអ្វីមួយដែលពឹងផ្អែកលើរូបគា

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត៖
អេលីសេពិតជាមានអំណាចខាងវិញ្ញាណដូចគ្នានឹងអេលីយ៉ាដែរឬ«
អំណាចខាងវិញ្ញាណដែលអេលីយ៉ាមាននៅជាមួយអេលីសេ»
ឃើញទេឥឡូវនេះ នៅក្នុងចំណោមអ្នកបម្រើរបស់លោកមានមនុស្សខ្លាំងពូកែរហាសិបនាក់។
យើងសូមឲ្យពួកគេចេញទៅ
បុរសទាំងនេះកំពុងសំដៅលើខ្លួនពួកគេនៅពេលពួកគេនិយាយថា
«បុរសខ្លាំងហាសិបនាក់» ។ ការបកប្រែផ្សេងទៀត៖
«មើលឥឡូវនេះយើងជាបុរសខ្លាំងហាសិបនាក់ហើយឥឡូវនេះយើងគឺជាអ្នកបម្រើរបស់អ្នក
ចូរយើងទៅ»
មនុស្សខ្លាំងពូកែរហាសិបនាក់
«បុរសខ្លាំង ៥០ នាក់»
2 Kings 2:17
ប៉ុន្តែ អ្នកទាំងនោះទទូចលោកអេលីសេរហូតដល់លោកមានការអៀនខ្មាស
កូនប្រុសរបស់ព្យាការីបន្តសួរអេលីសេ
រហូតដល់គាត់មានអារម្មណ៍មិនល្អក្នុងការនិយាយថា «ទេ» ។
ការបកប្រែផ្សេងទៀត៖
«ពួកគេនៅតែបន្តសួរអេលីសេរហូតដល់គាត់មានអារម្មណ៍មិនល្អចំពោះការបដិសេធ
«តើខ្ញុំមិនបាននិយាយទៅអ្នករាល់គ្នាទេថា៖ «កុំឲ្យទៅ?»
អេលីសេប្រើសំណួរវោហារនេះដើម្បីបញ្ជាក់ថាគាត់ធ្លាប់បានប្រាប់ពួកគេពីអ្វីដែលនឹងកើតឡើង
នេះអាចត្រូវបានសរសេរជាឃ្លាភ្ជាប់។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំបានប្រាប់អ្នកថាអ្នកមិនគួរទៅទេព្រោះអ្នកនឹងមិនឃើញគាត់ទេ!»
2 Kings 2:19
ពួកប្រុសៗក្នុងក្រុង
«មេដឹកនាំទីក្រុង»
ស្ថានភាពនៅក្នុងក្រុងនេះល្អណាស់
នេះមានន័យថាទីក្រុងមានទីតាំងល្អ។ ការបកប្រែផ្សេងទៀត៖
«ទីក្រុងនេះស្ថិតក្នុងទីតាំងល្អ» ឬ «ទីក្រុងនេះស្ថិតក្នុងទីតាំងល្អណាស់»
ដូចដែលលោកអាចឃើញស្រាប់
បុរសទាំងនោះសំដៅទៅលើអេលីសេនៅទីនេះជា «ម្ចាស់របស់ខ្ញុំ»
ដើម្បីគោរពគាត់។
បង្កើតផល
«បង្កើតផលដំណាំល្អ»
2 Kings 2:21
ប្រោសទឹកនេះ
នេះនិយាយអំពីព្រះអម្ចាស់ធ្វើឲ្យទឹកមិនល្អទៅជាបរិសុទ្ធដូចទ្រង់បានព្យាបាល។
ការបកប្រែផ្សេងទៀត៖ «ធ្វើឱ្យទឹកបរិសុទ្ធ»
នឹងគ្មានអ្វីស្លាប់ និងមិនមានដីដែលមិនបង្កើតផងទៀតទេ
សំដៅទៅលើអ្វីដែលបណ្តាលមកពីទឹកមិនល្អ។
នេះក៏អាចត្រូវបានសរសេរជាទម្រង់វិជ្ជមានផងដែរ។ ការបកប្រែផ្សេងទៀត៖
«នឹងគ្មានការស្លាប់ឬបញ្ហាដែលបណ្តាលមកពីដំណាំដែលបណ្តាលមកពីទឹកនេះទេ»
ឬ « ចាប់ពីពេលនេះតទៅទឹកនេះនឹងនាំមកនូវជីវិតនិងជួយឱ្យដីមានផ្លែផ្កា»
ទឹកនោះបានល្អឡើងវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ទឹកនៅតែបរិសុទ្ធ»
ថ្ងៃនេះ...បាននិយាយ
នេះមានន័យថាអ្វីមួយនៅតែស្ថិតក្នុងស្ថានភាពជាក់លាក់មួយរហូតដល់បច្ចុប្បន្ន។
ការបកប្រែផ្សេងទៀត៖
«ដោយពាក្យដែលអេលីសេបាននិយាយហើយតែងតែរក្សាភាពបរិសុទ្ធតាំងពីពេលនោះមក»
2 Kings 2:23
បានឡើងពីទីនោះទៅបេតអែល
ឃ្លាដែលថា «ឡើងទៅ»
ត្រូវបានប្រើសម្រាប់នាងព្រោះបេតអែលខ្ពស់ជាងក្រុងយេរីខូ។
ឡើងទៅ
ក្មេងប្រុសចង់ឲ្យអេលីសេចេញឆ្ងាយពីពួកគេហើយសម្តែងការនេះដោយនិយាយថា
«ឡើងទៅ» ។ ការបកប្រែផ្សេងទៀត៖ «ទៅឆ្ងាយ»
ក្បាលទំពែក
មនុស្សទំពែកមិនមានសក់នៅលើក្បាលទេ។
ក្មេងប្រុសៗទាំងនោះកំពុងសើចចំអកអោយអេលីសេដែលមានក្បាលទំពែក។
ក្មេងសែសិបពីរនាក់
ក្មេងប្រុសពីរនាក់ - «ក្មេងប្រុស ៤២ នាក់»

---

3 [1]ឥឡូវនេះ នៅក្នុងឆ្នាំទីដប់ប្រាំបីនៃរាជ្យរបស់ព្រះបាទយ៉ូសាផាត ជាស្តេចស្រុកយូដា ព្រះបាទយ៉ូរ៉ាមជាបុត្ររបស់ព្រះបាទអហាប់ ចាប់ផ្តើមសោយរាជ្យលើស្រុក
អ៊ីស្រាអែល នៅក្រុងសាម៉ារី បានដប់ពីរឆ្នាំ។[2]ស្តេចបានប្រព្រឹត្តអំពើអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ ប៉ុន្តែ មិនដូចមាតា បិតារបស់ស្តេចឡើយ
ព្រោះស្តេចបានរំលំសសរថ្មរបស់ព្រះបាល ដែលបិតាទ្រង់បានសង់ឡើង។[3]ប៉ុន្តែ ស្តេចបានដើរតាមអំពើបាបរបស់ព្រះបាទយេរ៉ូបោមជាកូននេបាត
ដែលនាំឲ្យអ៊ីស្រាអែលមានបាប ព្រះអង្គមិនបានដើរចេញពីអំពើបាបទាំងនោះទេ។
[4]ឥឡូវនេះ ព្រះបាទមេសា ជាស្តេចម៉ូអាប់ មានចៀមជាច្រើន។ ស្តេចធ្លាប់ឲ្យចៀម ១០០, ០០០ក្បាល និងចៀមឈ្មោល១០០, ០០០ក្បាល ដល់ស្តេចស្រុកអ៊ីស្រាអែល។
[5]ក្រោយពេល ព្រះបាទអហាប់សោយទិវង្គត ស្តេចស្រុកម៉ូអាប់បានបះបោរប្រឆាំងនឹងស្តេចស្រុកអ៊ីស្រាអែល។[6]ដូច្នេះ ព្រះបាទយ៉ូរ៉ាមយាងចេញពីក្រុងសាម៉ារី នៅពេលនោះ
ដើម្បីគៀងគរប្រជាជនអ៊ីស្រាអែលទាំងអស់ទៅធ្វើសង្គ្រាម។
[7]ស្តេចបានផ្ញើសារប្រាប់ព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដាថា៖ «ស្តេចស្រុកម៉ូអាប់បានបះបោរប្រឆាំងនឹងយើងហើយ។
តើព្រះករុណានឹងទៅជាមួយយើងដើម្បីវាយប្រឆាំងនឹងសាសន៍ម៉ូអាប់នៅក្នុងសមរភូមិឬទេ»? ព្រះបាទយ៉ូសាផាតឆ្លើយតបថា៖ «ទូលបង្គំនឹងទៅ។
ទូលបង្គំក៏ដូចជាព្រះករុណា ព្រះជាជនរបស់ទូលបង្គំក៏ដូចជាប្រជាជនរបស់ព្រះករុណា ហើយសេះទូលបង្គំក៏ដូចសេះរបស់ព្រះករុណាដែរ»។[8]បន្ទាប់មកស្តេចទូលថា៖
«តើយើងគួរតែប្រយុទ្ធតាមផ្លូវណា»? ព្រះបាទយ៉ូសាផាតតបថា៖ «ទៅតាមផ្លូវនៅវាលរហោស្ថានអេដុម»។
[9]ដូច្នេះ ស្តេចស្រុកអ៊ីស្រាអែល ស្តេចស្រុកយូដា ស្តេចស្រុកអេដុមបានទៅទល់មុខគ្នាអស់រយៈពេលប្រាំពីរថ្ងៃ។ ពួកទាហានរបស់ពួកគេខ្វះទឹក ទោះបីជាសម្រាប់សេះ
និងសត្វរបស់ពួកគេក៏ខ្វះទឹកដែរ។ ដូច្នេះ ស្តេចស្រុកអ៊ីស្រាអែលទូលថា៖ «តើនេះជាអ្វីទៅ?[10]តើព្រះអម្ចាស់បានហៅស្តេចទាំងបីនេះមក
ដើម្បីប្រគល់ទៅក្នុងកណ្តាប់ដៃស្តេចស្រុកម៉ូអាប់ឬ?»
[11]ប៉ុន្តែ ព្រះបាទយ៉ូសាផាតទូលថា៖ «តើនៅទីនេះមិនមានព្យាការីរបស់ព្រះអម្ចាស់ ដែលយើងអាចសុំយោបល់ពីព្រះអង្គបានទេឬ?
អ្នកបម្រើម្នាក់របស់ស្តេចស្រុកអ៊ីស្រាអែលបានទូលថា៖ «លោកអេលីសេជាកូនរបស់លោកសាផាតនៅទីនេះ ដែលជាសិស្សរបស់លោកអេលីយ៉ា»។
[12]ព្រះបាទយ៉ូសាផាតទូលថា៖ «ព្រះបន្ទូលរបស់ព្រះអម្ចាស់គង់នៅជាមួយគាត់»។ ដូច្នេះ ស្តេចស្រុកអ៊ីស្រាអែល ព្រះបាទយ៉ូសាផាត
និងស្តេចស្រុកអេដុមបានទៅជួបលោក។
[13]លោកអេលីសេបានទូលទៅស្តេចស្រុកអ៊ីស្រាអែលថា៖ «តើព្រះករុណាមករកទូលបង្គំធ្វើអ្វី? ចូរទៅរកព្យាការីរបស់មាតាបិតារបស់ព្រះអង្គទៅ»។ ដូច្នេះ
ស្តេចស្រុកអ៊ីស្រាអែលបាននិយាយទៅលោកថា៖ «ទេ ដោយសារព្រះអម្ចាស់បានហៅស្តេចទាំងបីនេះមក ដើម្បីប្រគល់ដល់ស្តេចស្រុកម៉ូអាប់»។[14]លោកអេលីសេឆ្លើយថា៖
«នៅក្នុងព្រះនាមព្រះអម្ចាស់មានព្រះជន្មគង់នៅ ជាព្រះដែលទូលបង្គំបម្រើ ទូលបង្គំសូមប្រាប់ថា
បើទូលបង្គំមិនយល់ដល់វត្តមានរបស់ព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដាទេនោះ ទូលបង្គំនឹងមិនអើពើជាមួយព្រះករុណា ឬមើលព្រះភក្ត្រព្រះករុណាឡើយ។
[15]ប៉ុន្តែ ឥឡូវនេះសូមនាំអ្នកតន្ត្រីមកជួបទូលបង្គំ»។ នៅពេលដែលអ្នកលេងពិណបានចាប់ផ្តើមលេង នោះព្រះហស្តរបស់ព្រះអម្ចាស់បានមកលើលោកអេលីសេ។
[16]លោកទូលថា៖ «ព្រះអម្ចាស់បានបន្ទូលថា៖ «សូមជីកប្រឡាយនៅក្នុងជ្រោះទាំងនេះឲ្យបានច្រើន»។[17]ព្រោះព្រះអម្ចាស់មានបន្ទូលថា៖ «អ្នកនឹងមិនបានឃើញខ្យល់ទេ
ហើយអ្នកក៏មិនឃើញឃើញទឹកភ្លៀងដែរ ប៉ុន្តែ ប្រឡាយទាំងឡាយនៅក្នុងជ្រោះនេះនឹងមានទឹកពេញ ហើយអ្នកអាចផឹកបាន គឺអ្នក និងហ្វូងសត្វរបស់អ្នក
និងសត្វគ្រប់យ៉ាងផង»។
[18]ការនេះជាការងាយណាស់ក្នុងព្រះនេត្ររបស់ព្រះអម្ចាស់។ ព្រះអង្គនឹងឲ្យព្រះករុណាមានជ័យជម្នះលើជនជាតិម៉ូអាប់។[19]ព្រះករុណានឹងវាយរាល់ក្រុងដែលមានកំពែង
និងក្រុងល្អៗ ព្រមទាំងកាប់រលំដើមឈើល្អៗ បញ្ឈប់ប្រភពទឹក និងបំផ្លាញដីល្អៗដោយថ្ម»។

generated on Wed Sep 10 16:16:32 2025

[20]ដូច្នេះ នៅពេលព្រឹកគឺប្រហែលជាម៉ោងដែលត្រូវថ្វាយតង្វាយ មានទឹកមកពីស្រុកអេដុម រួចតំបន់នោះក៏មានទឹកពេញ។
[21]នៅពេលដែលស្តេចម៉ូអាប់ឮថាស្តេចទាំងនេះបានមកវាយប្រឆាំងនឹងស្តេច ពួកគេប្រមូលផ្តុំអស់អ្នកដែលមានវ័យអាចបម្រើទ័ពបាន ហើយពួកគេបានឈរនៅតាមព្រំដែន។[22]ពួកគេបានភ្ញាក់តាំងពីព្រលឹម ហើយព្រះអាទិត្យក៏បានចាំងលើផ្ទៃទឹក។ នៅពេលដែលជនជាតិម៉ូអាប់បានឃើញទឹកនៅទល់មុខពួកគេ
ទឹកនោះមានពណ៌ក្រហមដូចជាឈាម។[23]ពួកគេស្រែកឡើងថា៖ «នេះគឺឈាម! ស្តេចទាំងអស់នេះបានវិនាសអស់ហើយ ហើយពួកគេបានសម្លាប់គ្នាទៅវិញទៅមក!
ដូច្នេះឥឡូវនេះ បងប្អូនម៉ូអាប់អើយ ចូរយើងទៅរឹបអូសជ័យភណ្ឌពីពួកគេ!»
[24]នៅពេលដែលពួកគេមកដល់ជំរំអ៊ីស្រាអែល ប្រជារាស្ត្រអ៊ីស្រាអែលបានធ្វើឲ្យពួកគេភ្ញាក់ផ្អើល ហើយបានវាយប្រហារពួកម៉ូអាប់ ដែលបានរត់នៅមុខពួកគេ។
ពួកទាហានអ៊ីស្រាអែលបានដេញពួកម៉ូអាប់ឆ្លងកាត់ស្រុកនោះ ហើយបានសម្លាប់ពួកគេ។[25]ពួកគេបានកម្ទេចក្រុងទាំងឡាយ
ហើយពួកប្រុសៗបានបោះដុំថ្មនៅលើដីដែលល្អរហូតទាល់តែពេញ។ ពួកគេបានបិតប្រភពទឹកទាំងអស់ ហើយបានកាប់បំផ្លាញដើមឈើល្អៗរបស់ពួកគេ។ មានតែក្រុង
គារ-ហារ៉ាសែតនៅស្ថិតស្ថេរដែលថ្មនៅនឹងកន្លែងរបស់វា។ ប៉ុន្តែ ពួកទាហានដែលមានដង្ហក់បានព័ទ្ធ ហើយវាយប្រហារក្រុងនោះ។
[26]នៅពេលដែលព្រះបាទមេសាជាស្តេចស្រុកម៉ូអាប់បានឃើញថាចាញ់សង្គ្រាមហើយ ស្តេចបាននាំទ័ពដែលកាន់ដាវចំនួនប្រាំពីររយនាក់ សម្រុកទៅលើស្តេចអេដុម ប៉ុន្តែ
ពួកគេបរាជ័យ។[27]បន្ទាប់មក ស្តេចបានយកបុត្រច្បងរបស់ទ្រង់ដែលត្រូវសោយរាជ្យបន្តពីព្រះអង្គ ហើយបានដុតបុត្រនោះជាដង្វាយដុតនៅលើជញ្ជាំងក្រុង។ ដូច្នេះ
មានកំហឹងខ្លាំងក្លាណាស់ប្រឆាំងនឹងអ៊ីស្រាអែល បន្ទាប់មកប្រជាជនអ៊ីស្រាអែលបានចាកចេញពីស្តេចមេសា ហើយត្រឡប់ទៅទឹកដីរបស់ពួកគេវិញ។

---

2 Kings 3:1
នៅក្នុងឆ្នាំទីដប់ប្រាំបីនៃរាជ្យរបស់ព្រះបាទយ៉ូសាផាត ជាស្តេចស្រុកយូដា
នេះពិតណ៎ានាអំពីពេលវេលាដែលយ៉ូរ៉ាមបានឡើងសោយរាជ្យដោយបញ្ជាក់ថាតើស្តេចយ៉ូរ៉ាមបានសោយរាជ្យ
អត្ថន័យនៃឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
«នៅឆ្នាំទីដប់ប្រាំបីនៃរជ្ជកាលព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដា»
ឆ្នាំទីដប់ប្រាំបី
«ឆ្នាំទី ១៨»
ព្រះបាទយ៉ូរ៉ាមជាបុត្ររបស់ព្រះបាទអហាប់
ពេលខ្លះបុរសនេះគឺសំដៅទៅ« យេហូរ៉ាម» ។
នេះមិនមែនជាមនុស្សដូចបុរសដែលបានរៀបរាប់នៅក្នុងជំពូក ១:១៧
ដែលមានឈ្មោះថាយេហូរ៉ាមនោះទេ។
ស្តេចបានប្រព្រឹត្តអំពើអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
គុណនាមនាម «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លាដែលទាក់ទង។ នេះជាការ
«មើលឃើញ» របស់ព្រះជាម្ចាស់សំដៅទៅលើអ្វីដែលគាត់គិត។
ការបកប្រែផ្សេងទៀត៖ « គាត់បានធ្វើអ្វីដែលព្រះអម្ចាស់បាននិយាយថាអាក្រក់»
ឬ« គាត់បានធ្វើនូវអ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»
ប៉ុន្តែ មិនដូចមាតា បិតារបស់ស្តេចឡើយ
នេះប្រៀបធៀបថាតើគាត់បានធ្វើអាក្រក់ប៉ុណ្ណា តិចជាងចំនួនឪពុកម្តាយគាត់។
ការបកប្រែផ្សេងទៀត៖ «ប៉ុន្តែគាត់មិនបានធ្វើអំពើអាក្រក់
ដូចឪពុកនិងម្តាយរបស់គាត់បានធ្វើទេ»
សសរថ្មរបស់ព្រះបាល
សសរនេះត្រូវបានប្រើក្នុងការថ្វាយបង្គំព្រះបាលទោះបីគេមិនដឹងថាសសរនោះមើលទៅដូចអ្វីក៏ដោយ។
ការបកប្រែផ្សេងទៀត៖ « សសរថ្មដ៏សក្ការៈបូជាសម្រាប់ការថ្វាយបង្គំព្រះបាល»
ស្តេចបានដើរតាមអំពើបាប
នៅទីនេះ« ដើរតាម» ទៅនឹងអ្វីមួយមានន័យថាបន្តធ្វើវា។ ការបកប្រែផ្សេងទៀត៖
«គាត់បានបន្តប្រព្រឹត្តអំពើបាប»
នេបាត
នេះជាឈ្មោះបុរសម្នាក់។
ព្រះអង្គមិនបានដើរចេញពីអំពើបាបទាំងនោះទេ
«ងាកចេញ» ពីអ្វីមួយគឺមានន័យថាឈប់ធ្វើវា។ ការបកប្រែផ្សេងទៀត៖ «
គាត់មិនបានឈប់ប្រព្រឹត្តអំពើបាបទាំងនោះទេ» ឬ «
គាត់បានបន្តប្រព្រឹត្តអំពើបាបទាំងនោះ»
2 Kings 3:4
ស្តេចធ្លាប់ឲ្យចៀម ១០០,០០០ក្បាល និងចៀមឈ្មោល១០០,០០០ក្បាល ដល់ស្តេចស្រុកអ៊ីស្រាអែល
មេសាត្រូវប្រគល់របស់ទាំងនេះដល់ស្តេចអ៊ីស្រាអែលពីព្រោះនគររបស់គាត់ត្រូវបានគ្រប់គ្រងដោយស្តេចអ៊ីស្រាអែល។
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត៖
«ជារៀងរាល់ឆ្នាំគាត់ត្រូវបានគេបង្ខំឱ្យថ្វាយកូនចៀម ១០០,០០០
ក្បាលនិងរោមចៀមពីចៀមឈ្មោល ១០០.០០០
ក្បាលដល់ស្តេចអ៊ីស្រាអែលពីព្រោះនគររបស់គាត់ត្រូវបានគ្រប់គ្រងដោយស្តេចអ៊ីស្រាអែល»
ដើម្បីគៀងគរប្រជាជនអ៊ីស្រាអែលទាំងអស់ទៅធ្វើសង្គ្រាម
«ដើម្បីរៀបចំប្រជាជនអ៊ីស្រាអែលសម្រាប់សង្គ្រាម» ។ នៅទីនេះ
«អ៊ីស្រាអែលទាំងអស់» សំដៅទៅលើទាហានអ៊ីស្រាអែលទាំងអស់។
តែយេហ៊ូវវិញនឹងបម្រើព្រះបាលច្រើនជាងនេះទៅទៀត។[19]ដូច្នេះឥឡូវ នេះចូរហៅព្យាការីរបស់ព្រះបាល អ្នកថ្វាយបង្គំទ្រង់ទាំងអស់
និងបូជាចារ្យរបស់ព្រះបាលទាំងអស់មក។ ចូរកុំឲ្យនរណាម្នាក់នៅសល់ឡើយ ព្រោះខ្ញុំមានយញ្ញបូជាដ៏ច្រើនដើម្បីថ្វាយព្រះបាល។ អ្នកណាដែលមិនមកនឹងត្រូវស្លាប់»។
ប៉ុន្តែ លោកយេហ៊ូវប្រើឧបាយកលដូច្នេះ គឺប៉ុនប៉ងសម្លាប់អ្នកថ្វាយបង្គំព្រះបាល។[20]លោកយេហ៊ូវមានប្រសាសន៍ថា៖ «សូមកំណត់ពេលដើម្បីប្រជុំគ្នាសម្រាប់ព្រះបាល»។
ដូច្នេះ ពួកគេក៏ប្រកាសរឿងនេះ។
[21]បន្ទាប់មក លោកយេហ៊ូវបានបញ្ជូនពាក្យទៅស្រុកអ៊ីស្រាអែលទាំងមូល ហើយអ្នកដែលថ្វាយបង្គំព្រះបាលទាំងប៉ុន្មានក៏មកជួបជុំគ្នា ដូច្នេះ
គ្មាននរណាម្នាក់អវត្តមានឡើយ។ ពួកគេបានចូលមកក្នុងព្រះវិហាររបស់ព្រះបាល ហើយព្រះវិហារនោះក៏ពេញពីជ្រុងម្ខាងដល់ជ្រុងម្ខាងទៀត។
[22]លោកយេហ៊ូវក៏បានមានប្រសាសន៍ទៅបុរសម្នាក់ដែលរក្សាសំលៀកបំពាក់របស់បូជាចារ្យថា៖ «សូមយកសំលៀកបំពាក់សម្រាប់អ្នកថ្វាយបង្គំព្រះបាលទាំងអស់»។
ដូច្នេះ បុរសនោះក៏បានយកសំលៀកបំពាក់សម្រាប់ពួកគេ។
[23]លោកយេហ៊ូវអញ្ជើញមកដល់វិហាររបស់ព្រះបាលជាមួយនឹងលោកយ៉ូណាដាប់ ជាកូនរបស់លោករេកាប
ហើយលោកបាននិយាយជាមួយអ្នកថ្វាយបង្គំព្រះបាលទាំងអស់ថា៖ «សូមរកមើលឲ្យប្រាកដថានៅទីនេះក្នុងចំណោមអ្នករាល់គ្នាគ្មានអ្នកបម្រើរបស់ព្រះអម្ចាស់មែន
គឺតែអ្នកថ្វាយបង្គំព្រះបាលប៉ុណ្ណោះ»។[24]បន្ទាប់មក ពួកគេចូលទៅក្នុងដើម្បីថ្វាយតង្វាយម្សៅ និងតង្វាយដុត។ ពេលនោះ

generated on Wed Sep 10 16:16:32 2025

លោកយេហ៊ូវបានជ្រើសរើសមនុស្សប្រាំបីនាក់ដែលឈរនៅខាងក្រៅ ហើយលោកបានប្រាប់ពួកគេថា៖
«បើមាននរណាម្នាក់ដែលខ្ញុំបាននាំមកក្នុងកណ្តាប់ដៃរបស់អ្នករត់រួច បើមាននរណាម្នាក់ឲ្យអ្នកទាំងនោះរត់រួច អ្នកនោះត្រូវសងជីវិតជំនួសអ្នករត់រួចនោះមិនខាន»។
[25]ក្រោយមក ពេលដែលលោកយេហ៊ូវបានបញ្ចប់ការថ្វាយយញ្ញបូជា លោកបាននិយាយទៅអ្នកយាមទ្វារ និងមេបញ្ជាការថា៖ «ចូរចូលទៅក្នុង ហើយសម្លាប់ពួកគេទៅ។
សូមកុំឲ្យនរណាម្នាក់ចេញមកក្រៅឡើយ»។ ដូច្នេះ ពួកគេបានសម្លាប់អ្នកទាំងនោះដោយដាវ ហើយពួកអ្នកយាម និងមេបញ្ជាការបានគ្រវែងអ្នកទាំងនោះចេញក្រៅ
ហើយបានចូលទៅក្នុងបន្ទប់ក្នុងបំផុតនៃវិហារបស់ព្រះបាល។[26]ពួកគេបានអូសសសរថ្ម ដែលធ្លាប់មាននៅក្នុងវិហារបស់ព្រះបាលចេញក្រៅ
ហើយបានដុតសសរទាំងនោះ។[27]បន្ទាប់មក ពួកគេបានបំផ្លាញសសររបស់ព្រះបាល ហើយបានបំផ្លាញវិហាររបស់ព្រះបាល
ហើយធ្វើជាកន្លែងបន្ទោរបង់រហូតដល់សព្វថ្ងៃ។[28]នេះជារបៀបដែលលោកយេហ៊ូវបំផ្លាញអ្នកថ្វាយបង្គំព្រះបាលចេញពីទឹកដីអ៊ីស្រាអែល។
[29]ប៉ុន្តែ លោកយេហ៊ូវមិនបានចាកចេញពីអំពើបាបរបស់ព្រះបាទយេរ៉ូបោមជាកូនរបស់នេបាតឡើយ ដែលធ្វើឲ្យអ៊ីស្រាអែលធ្លាក់ក្នុងអំពើបាប
គឺការថ្វាយបង្គំរូបគោមាសនៅបេតអែល និងដាន់។[30]ដូច្នេះ ព្រះអម្ចាស់មានបន្ទូលមកលោកយេហ៊ូវថា៖ «ដោយសារអ្នកបានធ្វើអ្វីដែលត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់យើង
ហើយបានប្រព្រឹត្តចំពោះគ្រួសាររបស់អហាប់តាមអ្វីដែលមាននៅក្នុងចិត្តយើង នោះកូនចៅរបស់អ្នកនឹងអង្គុយលើបល្ល័ង្កស្រុកអ៊ីស្រាអែលរហូតដល់បួនតំណរ»។[31]ប៉ុន្តែ
ព្រះបាទយេហ៊ូវមិនខ្វល់ខ្វាយជាមួយនឹងបញ្ញត្តិរបស់ព្រះអម្ចាស់ ជាព្រះរបស់អ៊ីស្រាអែលអស់ពីចិត្តឡើយ។
ស្តេចមិនបានចាកចេញពីអំពើបាបរបស់ព្រះបាទយេរ៉ូបោមឡើយ ដែលនាំអ៊ីស្រាអែលឲ្យប្រព្រឹត្តអំពើបាប។
[32]នៅថ្ងៃនោះព្រះអម្ចាស់ចាប់ផ្តើមកាត់តំបន់មួយចំនួនចេញពីអ៊ីស្រាអែល ហើយព្រះបាទហាសែល វាយតាមព្រំប្រទល់ទាំងប៉ុន្មានដែលជាប់នឹងស្រុកអ៊ីស្រាអែល[33]គឺចាប់
តាំងពីត្រើយខាងកើតទន្លេយ័រដាន់ ទឹកដីស្រុកកាឡាដ ស្រុកកាដ រូបេន និងម៉ាណាសេ ហើយចាប់តាំងពីអារ៉ូអ៊ើរដែលនៅក្បែរជ្រោះអើណូន ព្រមទាំងស្រុកកាឡាដ
រហូតដល់បាសាន។
[34]រឿងរ៉ាវផ្សេងទៀតទាក់ទងនឹងព្រះបាទយេហ៊ូវ និងអ្វីដែលស្តេចបានធ្វើ និងអំណាចរបស់ទ្រង់ តើមិនបានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍បស់ស្តេចទេឬ?
[35]ព្រះបាទយេហ៊ូវបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ស្តេច ហើយគេបានបញ្ចុះទ្រង់នៅស្រុកសាម៉ារី ហើយព្រះបាទយ៉ូអាហាស ជាបុត្រ ឡើងស្នងរាជ្យបន្ត។[36]ព្រះបាទយេហ៊ូវ
សោយរាជ្យនៅក្រុងសាម៉ារីបានម្ភៃប្រាំបីឆ្នាំ។

---

2 Kings 10:1
កូនចៅចិតសិបនាក់
«កូនចៅ ៧០ នាក់»
លោកយេហ៊ូវបានសរសេរសំបុត្រ ហើយបានផ្ញើទៅស្រុកសាម៉ារី
នេះមានន័យថាយេហ៊ូវបានបញ្ជូនអ្នកនាំសារម្នាក់ដើម្បីប្រគល់សំបុត្រ។ ការបកប្រែផ្សេងទៀត «
យេហ៊ូវបានសរសេរសំបុត្រហើយបានបញ្ជូនអ្នកនាំសារម្នាក់អោយផ្ញើទៅស្រុកសាម៉ារី»ដើម្បី «នៅខាងនរណាម្នាក់» មានន័យថាស្មោះត្រង់នឹងពួកគេនិងគាំទ្រពួកគេ។
កូនចៅរបស់ចៅហ្វាយអ្នក
«អក្សរទាំងនោះនិយាយថា ចៅហ្វាយរបស់អ្នក»
ឲ្យគាត់ឡើងសោយរាជ្យជំនួសបិតារបស់ពួកគេ
ត្រង់នេះការអង្គុយលើបល្ល័ង្ករបស់ព្រះរាជាមានន័យថាត្រូវតែងតាំងជាស្តេច។ ការបកប្រែផ្សេងទៀត «តែងតាំងគាត់ឱ្យឡើងសោយរាជ្យជំនួសបិតារបស់ទ្រង់»
ដើម្បីខ្សែរាជវង្សរបស់ចៅហ្វាយអ្នកចុះ
« កូនចៅចៅហ្វាយរបស់អ្នក» នៅទីនេះបុរសដែលពួកគេបានជ្រើសរើសជាស្តេចត្រូវបានគេហៅថាជាកូនចៅរបស់ស្តេចអហាប់។ ការបកប្រែផ្សេងទៀត
«ដើម្បីការពារកូនចៅរបស់ចៅហ្វាយអ្នក» ឬ «ដើម្បីការពារគាត់»
2 Kings 10:4
ប៉ុន្តែ ពួកគេភ័យខ្លាច
«ពេលនោះពួកគេភ័យខ្លាចខ្លាំងណាស់»
ស្តេចពីរអង្គ
«ស្តេចពីរអង្គ គឺយ៉ូរ៉ាម និងអហាស៊ីយ៉ា»
មិនអាចទប់ទល់នឹងលោកយេហ៊ូវបានឡើយ
ត្រង់នេះ « ឈរ» មានន័យថាអាចទ្រាំទ្របានក្រោមបញ្ហា។ ការបកប្រែផ្សេងទៀត
«មិនអាចស៊ូទ្រាំនឹងយេហ៊ូវបានឡើយ» ឬ
«មិនអាចទប់ទល់នឹងយេហ៊ូវបានឡើយ»
ដូច្នេះ តើយើងអាចទប់ទល់ដូចម្តេចបាន?
កូនចៅប្រើសំណួរវោហារស័ព្ទ ដើម្បីបញ្ជាក់ថាពួកគេមិនអាចឈរប្រឆាំងនឹងយេហ៊ូវបានទេ។ ការបកប្រែផ្សេងទៀត
«យើងមិនអាចឈរប្រឆាំងនឹងគាត់បានទេ!» ឬ
«យើងក៏មិនអាចទប់ទល់នឹងគាត់បានដែរ!»
អ្នកដឹកនាំក្រុង
«អភិបាលក្រុង» នៅទីនេះដើម្បី «លើ» អ្វីមួយមានន័យថាមានសិទ្ធិអំណាចនិងការទទួលខុសត្រូវលើវា។ ការបកប្រែផ្សេងទៀត
«បុរសដែលទទួលបន្ទុកក្នុងទីក្រុង»
ពួកអ្នកដែលចិញ្ចឹមក្មេង
នេះសំដៅទៅលើមនុស្សដែលចិញ្ចឹមក្មេងរបស់ស្តេច។ ការបកប្រែផ្សេងទៀត « អ្នកដែលចិញ្ចឹមកូនចៅស្តេច»
សូមលោកធ្វើតាមការយល់ឃើញថាល្អចុះ
នេះជា «ភ្នែក» របស់យេហ៊ូវសំដៅទៅលើការ «មើលឃើញ» របស់គាត់។ ការមើលឃើញរបស់គាត់សំដៅទៅលើអ្វីដែលគាត់គិត។ ការបកប្រែផ្សេងទៀត
«ធ្វើអ្វីដែលល្អនៅចំពោះមុខអ្នក» ឬ «ធ្វើអ្វីដែលអ្នកគិតថាល្អបំផុត»
2 Kings 10:6
ទីពីរ
«លើកទី ២»
នៅខាងខ្ញុំ
ដើម្បី «នៅខាងនរណាម្នាក់» មានន័យថាស្មោះត្រង់នឹងពួកគេនិងគាំទ្រពួកគេ។ ការបកប្រែផ្សេងទៀត «ស្មោះត្រង់នឹងខ្ញុំ»
ស្តាប់
ដើម្បីស្តាប់និងគោរពតាម
ពាក្យខ្ញុំ
នេះគឺជា « ពាក្យ» របស់យេហ៊ូវសំដៅទៅលើអ្វីដែលគាត់និយាយ។ ការបកប្រែផ្សេងទៀត «ចំពោះអ្វីដែលខ្ញុំនិយាយ»
អ្នកត្រូវតែកាត់ក្បាល...រួចហើយមកជួបខ្ញុំ
វាបញ្ជាក់ថាពួកគេត្រូវនាំក្បាលរបស់កូនចៅអហាប់ហើយនាំពួកគេទៅឯយេហ៊ូវ។ ការបកប្រែផ្សេងទៀត «អ្នកត្រូវតែយកក្បាល ... ហើយនាំវាមកឱ្យខ្ញុំ»
អ្នកត្រូវតែកាត់ក្បាលប្រុសៗជាកូនចៅរបស់ចៅហ្វាយអ្នក
នេះសំដៅទៅលើការសម្លាប់ពួកគេនិងកាត់ក្បាលចេញ។ ការបកប្រែផ្សេងទៀត
«សម្លាប់កូនចៅចៅហ្វាយរបស់អ្នក ហើយកាត់ក្បាលរបស់ពួកគេចោល»
ចិតសិប...ចិតសិបនាក់
«ចំនួន ៧០ នាក់ ... ចំនួន ៧០ នាក់»
ដែលជាអ្នកនាំអ្នកទាំងនោះមក
នេះមានន័យថាពួកគេកំពុងត្រួតពិនិត្យពួកគេ ហើយបង្រៀនពួកគេ។ ការបកប្រែផ្សេងទៀត «អ្នកណាចិញ្ចឹមពួកគេ» ឬ
«អ្នកណាជាអ្នកមើលការខុសត្រូវពួកគេ»
ធ្វើឲ្យលោកយេហ៊ូវ
នេះមានន័យថាពួកគេបានបញ្ជូនមនុស្សឱ្យយកកន្ត្រកទៅជូហ៊ូ។ ការបកប្រែផ្សេងទៀត «ហើយបានបញ្ជូនមនុស្សឱ្យយកពួកគេទៅជូហ៊ូ»
2 Kings 10:8
បុត្ររបស់ស្តេច
«នៃកូនចៅអហាប់»
លោកយេហ៊ូវបានចេញក្រៅ ហើយបានឈរ
«យេហ៊ូវបានទៅខ្លោងទ្វារទីក្រុងហើយឈរនៅមុខប្រជាជន»
អ្នកគ្មានទោសឡើយ
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់នូវអ្វីដែលពួកគេគ្មានកំហុស។ អត្ថន័យគឺ ១) «អ្នកគ្មានកំហុសអ្វីដែលបានកើតឡើងចំពោះយ៉ូរ៉ាម» ឬទី ២) នេះមានន័យថាពួកគេមិនទទួលខុសត្រូវចំពោះការស្លាប់របស់ក្រុមគ្រួសារយ៉ូរ៉ាមទេ។ ការបកប្រែផ្សេងទៀត
«អ្នកគ្មានកំហុសអ្វីដែលបានកើតឡើងចំពោះយ៉ូរ៉ាមនិងគ្រួសាររបស់គាត់» ឬ

generated on Wed Sep 10 16:16:32 2025

«អ្នកគ្មានទោសពីបញ្ហានេះទេ»
មើល
យេហ៊ូវប្រើពាក្យនេះនៅទីនេះដើម្បីទាក់ទាញចំណាប់អារម្មណ៍
របស់ប្រជាជនចំពោះអ្វីដែលគាត់និយាយបន្ទាប់។ ការបកប្រែផ្សេងទៀត «ស្តាប់»
ឬ «ស្តាប់ពាក្យរបស់ខ្ញុំ»
តើអ្នកណាសម្លាប់អ្នកទាំងនេះ?
យេហ៊ូវប្រើសំណួរវោហារស័ព្ទដើម្បីបណ្តាលឱ្យប្រជាជនគិត
យ៉ាងជ្រាលជ្រៅអំពីស្ថានភាព។ នេះអាចត្រូវបានសរសេរជាឃ្លា។ អត្ថន័យគឺ ១)
ការបកប្រែផ្សេងទៀត «
ប៉ុន្តែពួកបុរសនៅស្រុកសាម៉ារីទទួលខុសត្រូវចំពោះការសម្លាប់កូនចៅ ៧០
នាក់របស់អហាប់» ឬ
២)ប៉ុន្តែវាជាព្រះហឫទ័យរបស់ព្រះយេហូវ៉ាដែលចង់អោយបុរសទាំងនេះស្លាប់។
2 Kings 10:10
ដឹងឲ្យបានច្បាស់ថា
«យល់» ឬ «ត្រូវដឹងអំពីការពិតដែលថា»
គ្មានផ្នែកណាមួយនៃព្រះបន្ទូលរបស់ព្រះអម្ចាស់...សម្រេចជារូបរាង
នេះនិយាយអំពីអ្វីៗដែលកើតឡើង ដែលព្រះអម្ចាស់មានព្រះបន្ទូលថា
នឹងកើតមានដូចជាអ្វីៗដែលមិនស្លាប់និងដួលដល់ដី។ ការបកប្រែផ្សេងទៀត
«គ្មានផ្នែកណាមួយនៃព្រះបន្ទូលរបស់ព្រះអម្ចាស់ ... នឹងបរាជ័យឡើយ» ឬ
«ផ្នែកទាំងអស់នៃព្រះបន្ទូលរបស់ព្រះអម្ចាស់ ... នឹងកើតឡើង»
ព្រះអម្ចាស់បានសម្រេច
នេះនិយាយអំពីព្រះអម្ចាស់ដែលធ្វើអោយកូនចៅរបស់អហាប់ត្រូវបានគេសម្លាប់ដូចជាគាត់បានសម្រេចរួចហើយ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានធ្វើអោយកើតមាន»
ដូច្នេះ លោកយេហ៊ូវបានសម្លាប់...ព្យាការីរបស់ស្តេច
លោកយេហ៊ូវមិនបានសម្លាប់មនុស្សទាំងអស់នេះដោយផ្ទាល់ទេ
តែគាត់បានបញ្ជាឱ្យគេសម្លាប់ពួកគេ។ ការបកប្រែផ្សេងទៀត
«ដូច្នេះយេហ៊ូវបានបញ្ជាឱ្យមនុស្សទាំងអស់ ... ត្រូវគេសម្លាប់» ឬ
«ដូច្នេះយេហ៊ូវបញ្ជាឱ្យមនុស្សទាំងអស់ ... ត្រូវស្លាប់»
ដែលនៅសេសសល់
«អស់អ្នកដែលនៅរស់» ឬ «អ្នកដែលនៅសល់»
រហូតដល់គ្មាននរណាម្នាក់នៅសល់ឡើយ
នេះមានន័យថាពួកគេទាំងអស់ត្រូវបានសម្លាប់។ ការបកប្រែផ្សេងទៀត
«ទាល់តែពួកគេទាំងអស់ត្រូវបានសម្លាប់» ឬ
«រហូតដល់ពួកគេទាំងអស់បានស្លាប់»
2 Kings 10:12
ប៉ែត អេកេដ ជាកន្លែងនៃអ្នកគង្វាលចៀម
នេះគឺជាឈ្មោះកន្លែងដែលចៀមត្រូវបានគេកាត់។
ចុះទៅសួរសុខទុក្ខ
«នឹងទៅសួរសុខទុក្ខ»
បុត្ររបស់ស្តេច
«កូនចៅរបស់ស្តេចយ៉ូរ៉ាម»
«ចូរចាប់ពួកគេទាំងរស់»
នេះមានន័យថាចាប់ពួកគេប៉ុន្តែមិនមែនដើម្បីសម្លាប់ពួកគេទេ។
ការបកប្រែផ្សេងទៀត «ចាប់ពួកគេ!» ឬ «ចាប់ពួកគេ!»
ដូច្នេះ ពួកគេក៏ចាប់អ្នកទាំងនោះទាំងរស់
«ដូច្នេះពួកគេបានចាប់ពួកគេ»
សរុបទាំងអស់សែសិបពីរនាក់
បុរសពីរនាក់ - «បុរស ៤២ នាក់»
លោកមិនទុកឲ្យនរណាម្នាក់នៅរស់ឡើយ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«គាត់បានសម្លាប់ពួកគេទាំងអស់»
2 Kings 10:15
លោកយ៉ូណាដាប់ ជាកូនរបស់លោករេកាប
នេះជាឈ្មោះបុរសម្នាក់
តើចិត្តរបស់លោកនៅជាមួយខ្ញុំឬទេ ព្រោះចិត្តរបស់ខ្ញុំនៅជាមួយលោក»? ... «បាទលោក»។
នៅទីនេះ «ចិត្ត» របស់មនុស្សម្នាក់សំដៅទៅលើភាពស្មោះត្រង់របស់ពួកគេ។
ប្រសិនបើភាពស្មោះត្រង់របស់មនុស្សម្នាក់គឺ « ជាមួយនរណាម្នាក់»
វាមានន័យថាពួកគេស្មោះត្រង់នឹងមនុស្សនោះ។ ការបកប្រែផ្សេងទៀត
«តើអ្នកនឹងស្មោះត្រង់ចំពោះខ្ញុំដូចខ្ញុំនឹងស្មោះត្រង់នឹងអ្នកដែរឬទេ? ... » ខ្ញុំនឹងទៅ។
«បើដូច្នេះមែន ចូរហុចដៃមក»
«បើដូច្នោះសូមដាក់ដៃអ្នកទៅក្នុងដៃរបស់ខ្ញុំ» ឬ «បើដូច្នោះមែនចូរយើងចាប់ដៃគ្នា»
នៅក្នុងវប្បធម៌ជាច្រើននៅពេលមនុស្សពីរនាក់ចាប់ដៃគ្នា
វាបញ្ជាក់ពីកិច្ចព្រមព្រៀងរបស់ពួកគេ។
ហើយមើលឃើញការខ្នះខ្នែងរបស់ខ្ញុំ
ពាក្យថា «ខ្នះខ្នែង» អាចត្រូវបានបង្ហាញជាគុណនាម។ ការបកប្រែផ្សេងទៀត
«និងមើលថាតើខ្ញុំខ្នះខ្នែងប៉ុណ្ណា»
ខ្សែរាជវង្ស
«រាជវង្សទាំងមូល»
ស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលព្រះអង្គមានបន្ទូលតាមរយៈលោកអេលីយ៉ា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដើម្បីបំពេញតាមទំនាយដែលអេលីយ៉ា
បាននិយាយដែលព្រះអម្ចាស់បានប្រទានដល់គាត់» (សូមមើល igs-activepassive)
2 Kings 10:18
ប្រមូល
«បានហៅ»
មនុស្សទាំងអស់
«ប្រជាជនសាម៉ារីទាំងអស់»
បម្រើព្រះបាលច្រើនជាងនេះទៅទៀត
«បម្រើគាត់ច្រើនជាងអាហាប់»
គាត់បានធ្វើការបម្រើព្រះបាលតិចជាងអាហាប់ទៅទៀត
«កុំទុកនរណាម្នាក់អោយនៅខាងក្រៅ»
អ្នកណាដែលមិនមកនឹងត្រូវស្លាប់
នេះមានន័យថាប្រសិនបើពួកគេមិនមកពួកគេនឹងត្រូវគេប្រហារជីវិត។
ការបកប្រែផ្សេងទៀត «យើងនឹងប្រហារជីវិតអ្នកណាដែលមិនមក»
កំណត់ពេល
នេះមានន័យថាដើម្បីកំណត់និងរៀបចំ រយៈពេលនៃអ្វីមួយ។
ក្នុងករណីនេះពួកគេត្រូវរៀបចំសម្រាប់ការប្រជុំសម្រាប់ព្រះបាល។
ការបកប្រែផ្សេងទៀត «រៀបចំ»
2 Kings 10:21
បន្ទាប់មក លោកយេហ៊ូវបានបញ្ជូន
នេះមានន័យថាគាត់បានបញ្ជូនអ្នកនាំសារអោយយកសារនេះពាសពេញប្រទេស។
ការបកប្រែផ្សេងទៀត «បន្ទាប់មក យេហ៊ូវបានបញ្ជូនអ្នកនាំសារ» ឬ «បន្ទាប់មក
យេហ៊ូវបានផ្ញើសារ»
ដូច្នេះ គ្មាននរណាម្នាក់អវត្តមានឡើយ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«ដូច្នេះរាល់អ្នកគោរពបូជាព្រះបាលនៅទីនោះ» ឬ «ដូច្នេះមនុស្សគ្រប់រូបបានមក»
ព្រះវិហារនោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេបានបំពេញវា»
បុរសម្នាក់ដែលរក្សាសំលៀកបំពាក់របស់បូជាចារ្យ
នៅទីនេះ «ដើម្បីរក្សា» អ្វីមួយមានន័យថាថែរក្សាវានិងត្រួតពិនិត្យវា។
ការបកប្រែផ្សេងទៀត «អ្នកទទួលខុសត្រូវលើសំលៀកបំពាក់របស់បូជាចារ្យ» ឬ
«អ្នកថែរក្សាសម្លៀកបំពាក់របស់បូជាចារ្យ»
2 Kings 10:23
លោកបាននិយាយជាមួយអ្នកថ្វាយបង្គំព្រះបាលទាំងអស់ថា
«ហើយយេហ៊ូវបាននិយាយទៅកាន់ប្រជាជន
ដែលនៅក្នុងព្រះវិហារអោយគោរពបូជាព្រះបាល»
អ្នកថ្វាយបង្គំព្រះបាលប៉ុណ្ណោះ
«ប៉ុន្តែមានតែអ្នកគោរពបូជាព្រះបាលនៅទីនេះប៉ុណ្ណោះ»
បើមាននរណាម្នាក់ដែលខ្ញុំបាននាំមកក្នុងកណ្តាប់ដៃរបស់អ្នករត់រួច
នៅទីនេះ « ដៃ» របស់បុរសគឺសំដៅទៅលើ « ការគ្រប់គ្រង» របស់ពួកគេ។
ដោយឈរជើងជុំវិញប្រាសាទ
ពួកគេគ្រប់គ្រងស្ថានការណ៍ហើយវាអាស្រ័យលើពួកគេថា
តើមនុស្សអាចរត់គេចបានឬអត់។ ការបកប្រែផ្សេងទៀត
«ប្រសិនបើបុរសណាមួយក្នុងចំណោមបុរសទាំងនេះ
ដែលខ្ញុំបាននាំអោយចូលទៅក្នុងការគ្រប់គ្រងរបស់អ្នក រត់គេចខ្លួន» ឬ
«ប្រសិនបើបុរសណាមួយនៅខាងក្នុងរត់គេចខ្លួន»

generated on Wed Sep 10 16:16:32 2025

បើមាននរណាម្នាក់ឲ្យអ្នកទាំងនោះរត់រួច អ្នកនោះត្រូវសងជីវិតជំនួសអ្នករត់រួចនោះមិនខាន
»យើងនឹងសម្លាប់បុរស ដែលឱ្យគេរត់គេចខ្លួន»
អ្នកនោះត្រូវសងជីវិតជំនួស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ នេះជាវិធីគួរសមដើម្បីយោងទៅលើ
មនុស្សដែលត្រូវគេសម្លាប់។ ការបកប្រែផ្សេងទៀត «យើងនឹងយកជីវិតរបស់គាត់»
ឬ «យើងនឹងសំលាប់គាត់»
សងជីវិតជំនួសអ្នករត់រួច
«នៅក្នុងការផ្លាស់ប្តូរសម្រាប់ជីវិត" នៅទីនេះបុរសនេះត្រូវបានសំដៅដោយ «ជីវិត»
របស់គាត់ដើម្បីបញ្ជាក់ថាគាត់មិនបានស្លាប់ទេ។ ការបកប្រែផ្សេងទៀត
«សម្រាប់បុរស»
2 Kings 10:25
លោកបាននិយាយទៅអ្នកយាមទ្វារ និង មេបញ្ជាការថា
អ្នកប្រហែលជាត្រូវបញ្ជាក់ថាយេហ៊ូវបានចេញពីព្រះវិហារ
មុនពេលគាត់និយាយជាមួយអ្នកយាម។ ការបកប្រែផ្សេងទៀត
«គាត់បានត្រឡប់ទៅខាងក្រៅវិហារ
នៃព្រះបាលហើយបាននិយាយទៅកាន់អ្នកយាម និងពួកមេបញ្ជាការ»
ដោយដាវ
បុរសទាំងនោះបានប្រើដាវ សម្លាប់អ្នកគោរពបូជាព្រះបាល។
ឃ្លានេះសំដៅទៅលើដាវរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«ជាមួយដាវរបស់ពួកគេ»
បានគ្រវែងអ្នកទាំងនោះចេញក្រៅ
នេះមានន័យថាបានបោះសាកសពមនុស្សចេញពីព្រះវិហារ។ ការបកប្រែផ្សេងទៀត
« បានទម្លាក់សាកសពរបស់ពួកគេចេញពីព្រះវិហារ»
ធ្វើជាកន្លែងបន្ទោរបង់
«ធ្វើវាជាបង្គន់សាធារណៈ» បង្គន់គឺជាបន្ទប់ទឹក ឬកន្លែងបង្គន់ជាធម្មតាសម្រាប់ជំរុំ
ឬអាគារដែលប្រើសម្រាប់ផ្ទះរបស់ទាហាន។
ហូតដល់សព្វថ្ងៃ
នេះមានន័យថាអ្វីមួយ នៅតែស្ថិតក្នុងស្ថានភាពជាក់លាក់មួយ
រហូតមកដល់បច្ចុប្បន្ននេះ។ ការបកប្រែផ្សេងទៀត
«ហើយចាប់តាំងពីពេលនោះមកវាតែងតែមានរបៀបនោះឯង»
2 Kings 10:29
មិនបានចាកចេញពីអំពើបាបរបស់ព្រះបាទយេរ៉ូបោម ជាកូនរបស់នេបាតឡើយ
នេះនិយាយអំពីលោកយេហ៊ូវបានប្រព្រឹត្តអំពើបាបដូចគ្នា
ដែលព្រះបាទយេរ៉ូបោមបានប្រព្រឹត្តដូចជាអំពើបាបរបស់ព្រះបាទយេរ៉ូបោម
គឺជាកន្លែងដែលលោកយេហ៊ូវមិនចាកចេញទេ។ ការបកប្រែផ្សេងទៀត «
មិនបានបញ្ឈប់ការប្រព្រឹត្តអំពើបាប
ដែលព្រះបាទយេរ៉ូបោមជាកូនរបស់នេបាតបានប្រព្រឹត្តនោះទេ»
នេបាត
បកប្រែឈ្មោះបុរសនេះដូចគ្នានឹងអ្វីដែលអ្នកបានធ្វើនៅក្នុងជំពូក ៣: ១ ។
អ៊ីស្រាអែលធ្លាក់ក្នុងអំពើបាប
នៅទីនេះ «អ៊ីស្រាអែល» សំដៅទៅលើប្រជាជនដែលរស់នៅទីនោះ។
ការបកប្រែផ្សេងទៀត «ប្រជាជនអ៊ីស្រាអែលធ្វើបាប»
ធ្វើអ្វីដែលត្រឹមត្រូវ
«នៅក្នុងការអនុវត្ត» ឬ «នៅក្នុងការសម្រេចបាននូវ»
អ្វីដែលត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់យើង
ភ្នែកតំណាងឱ្យការមើលឃើញ ហើយការមើលឃើញតំណាង ឱ្យគំនិត
ឬការវិនិច្ឆ័យ។ ការបកប្រែផ្សេងទៀត «អ្វីដែលខ្ញុំគិតថាត្រឹមត្រូវ» ឬ
«អ្វីដែលខ្ញុំគិតថាត្រឹមត្រូវ»
គ្រួសាររបស់អហាប់
នៅទីនេះ «ផ្ទះ» របស់អហាប់សំដៅទៅលើ «គ្រួសារ» របស់គាត់។
ការបកប្រែផ្សេងទៀត «គ្រួសារអ័ហាប់»
មាននៅក្នុងចិត្តយើង
នៅទីនេះ «ចិត្ត» តំណាងឱ្យ «បំណងប្រាថ្នា» ។ ការបកប្រែផ្សេងទៀត
«អ្វីៗដែលខ្ញុំចង់អោយអ្នកធ្វើ» ឬ « អ្វីៗទាំងអស់ដែលខ្ញុំចង់អោយអ្នកធ្វើ»
អង្គុយលើបល្ល័ង
«ធ្វើជាស្តេច»
រហូតដល់បួនតំណរ
«ដល់ជំនាន់ទី ៤» ឬ «សំរាប់ ៤ ជំនាន់ទៀត» ។
នេះសំដៅទៅលើកូនប្រុសរបស់គាត់ ចៅប្រុស ចៅប្រុសនិងចៅទួត។
ព្រះបាទយេហ៊ូវមិនខ្វល់ខ្វាយជាមួយនឹងបញ្ញត្តិរបស់ព្រះអម្ចាស់
នៅទីនេះ «ការដើរ» សំដៅទៅលើ «ការរស់នៅ» ។ ការបកប្រែផ្សេងទៀត «
យេហ៊ូវមិនប្រុងប្រយ័ត្នក្នុងការរស់នៅ
ស្របតាមក្រិត្យវិន័យរបស់ព្រះជាម្ចាស់ទេ» (សូមមើល ផ្ទfigs-idiom)
អស់ពីចិត្ត
នៅទីនេះ «ចិត្ត» សំដៅទៅលើឆន្ទៈ និងបំណងប្រាថ្នារបស់មនុស្សម្នាក់។
ការបកប្រែផ្សេងទៀត «នៅក្នុងអ្វីគ្រប់យ៉ាងដែលគាត់បានធ្វើ» ឬ
«នឹងឆន្ទៈទាំងអស់របស់គាត់»
ស្តេចមិនបានចាកចេញពី អំពើបាបរបស់ព្រះបាទយេរ៉ូបោមឡើយ
ដើម្បី «ងាកចេញ» ពីអ្វីមួយមានន័យថាឈប់ធ្វើវា។ ការបកប្រែផ្សេងទៀត
«យេហ៊ូវ មិនបានឈប់ធ្វើបាបដូចព្រះបាទយេរ៉ូបោមទេ»
2 Kings 10:32
ចាប់ផ្តើមកាត់តំបន់មួយចំនួនចេញពីអ៊ីស្រាអែល
«បានចាប់ផ្តើមធ្វើឱ្យទឹកដី ដែលគ្រប់គ្រងដោយអ៊ីស្រាអែលកាន់តែតូចជាងមុន»
តំបន់
«តំបន់នៃដែនដី»
ព្រះបាទហាសែល វាយ
នៅទីនេះ «ហាសែល» សំដៅទៅលើខ្លួនគាត់និងកងទ័ពរបស់គាត់។
ការបកប្រែផ្សេងទៀត «ហាសែលនិងកងទ័ពរបស់គាត់» ឬ
«កងទ័ពអារ៉ាម៉ានរបស់ស្តេចហាសែល»
ព្រះបាទហាសែល
បកប្រែឈ្មោះស្តេចនេះដូចគ្នានឹងអ្វីដែលអ្នកបានធ្វើនៅជំពូក ៨: ៧ ។
គឺចាប់តាំងពីត្រើយខាងកើតទន្លេយ័រដាន់
«ពីទឹកដីខាងកើតទន្លេយ័រដាន់»
អារ៉ូអ៊ើរ...បាសាន
ទាំងនេះគឺជាឈ្មោះទីកន្លែងទាំងអស់។
អើណូន
«ទន្លេអើណូន» នេះជាឈ្មោះទឹកទន្លេ។
2 Kings 10:34
តើមិនបានកត់ត្រាទុកនៅក្នុងសៀវភៅ ព្រឹត្តិការណ៍បស់ស្តេចទេឬ?
សំណួរវោហាស័ព្ទនេះអាចត្រូវបានសរសេរជាឃ្លា។ សូមមើលនៅក្នុងជំពូក ១:១៧
។ កាបកប្រែផ្សេងទៀត
«ពួកគេត្រូវបានសរសេរនៅក្នុងសៀវភៅព្រឹត្តិការណ៍នៃស្តេចអ៊ីស្រាអែល» ។
ព្រះបាទយេហ៊ូវបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ស្តេច ហើយគេបានបញ្ចុះទ្រង់នៅស្រុកសាម៉ារី
នេះមានន័យថាព្រះបាទយេហ៊ូវបានស្លាប់។ នេះនិយាយអំពីគាត់ត្រូវបាន
គេកប់នៅកន្លែងដែលបុព្វបុរសរបស់គាត់
ត្រូវបានគេបញ្ចុះដូចជាគាត់កំពុងដេកជាមួយពួកគេដែរ។ ការបកប្រែផ្សេងទៀត
«ព្រះបាទយេហ៊ូវបានសុគត ហើយពួកគេបានបញ្ចុះគាត់នៅសាម៉ារីជាកន្លែង
ដែលពួកគេបានបញ្ចុះបុព្វបុរសរបស់គាត់ផងដែរ» ។ ។
យ៉ូអាហាស
នេះជាឈ្មោះបុរសម្នាក់។
ព្រះបាទយេហ៊ូវសោយរាជ្យនៅក្រុងសាម៉ារី បានម្ភៃប្រាំបីឆ្នាំ
៨ ឆ្នាំ - «យេហ៊ូវសោយរាជ្យលើអ៊ីស្រាអែលនៅសាម៉ារីអស់រយៈពេល ២៨ ឆ្នាំ»
ម្ភៃប្រាំបីឆ្នាំ
ប្រាំបីឆ្នាំ - «២៨ ឆ្នាំ»

11 [1]កាលព្រះនាងអថាលា ជាមាតារបស់ព្រះបាទអហាស៊ីយ៉ា ជ្រាបថា បុត្ររបស់នាងស្លាប់ហើយ នាងក៏ក្រោកឡើង ហើយសម្លាប់ក្មេងៗរាជវង្សទាំងអស់។
[2]ប៉ុន្តែព្រះនាងយ៉ូសេបា ជាបុត្រីរបស់ស្តេចយ៉ូរ៉ាម និងជាប្អូនស្រីរបស់ព្រះបាទអហាស៊ីយ៉ា បានយកយ៉ូអាស ជាបុត្រារបស់ព្រះបាទអហាស៊ីយ៉ា ពីក្នុងចំណោមបុត្រា
របស់ស្តេចដែលត្រូវគេសម្លាប់នោះទៅជាមួយអ្នកមើលថែរបស់បុត្រនោះ នាងបានទុកពួកគេនៅក្នុងបន្ទប់របស់នាង។ ពួកគេបានលាក់បុត្រនោះពីព្រះនាងអថាលា ដូច្នេះ
បុត្រនោះមិនត្រូវបានគេសម្លាប់ឡើយ។[3]បុត្រនោះនៅជាមួយព្រះនាងយ៉ូសេបា គេបានលាក់បុត្រនោះនៅក្នុងដំណាក់របស់ព្រះអម្ចាស់អស់ប្រាំមួយឆ្នាំ
នៅពេលដែលព្រះនាងអថាលាសោយរាជ្យលើទឹកដីនោះ។

generated on Wed Sep 10 16:16:32 2025

[4]នៅក្នុងឆ្នាំទីប្រាំពីរលោកយេហូយ៉ាដាបានធ្វើពាក្យ ដើម្បីនាំមេកងរយជនជាតិការី និងអ្នកយាមល្បាត ហើយបាននាំពួកគេមកជួបគាត់ នៅក្នុងដំណាក់របស់ព្រះអម្ចាស់។
លោកបានចងសម្ពន្ធមេត្រីជាមួយពួកគេ ហើយលោកឲ្យពួកគេស្បថនៅក្នុងដំណាក់របស់ព្រះអម្ចាស់។ បន្ទាប់មកលោកក៏បានបង្ហាញបុត្រារបស់ស្តេចដល់ពួកគេ។
[5]លោកបានបញ្ជាពួកគេថា៖ «នេះជាអ្វីដែលអ្នកត្រូវធ្វើ។
មួយភាគបីក្នុងចំណោមអ្នករាល់គ្នាដែលមកនៅថ្ងៃសប្ប័ទនឹងយាមដំណាក់ស្តេច[6]ហើយមួយភាគបីទៀតត្រូវនៅឯត្រង់មាត់ទ្វារស៊ើរ និងមួយភាគបីទៀតត្រូវយាមនៅទ្វារ
ខាងក្រោយកន្លែងយាម»។
[7]ក្រុមពីរផ្សេងទៀតដែលមិនបម្រើនៅថ្ងៃសប្ប័ទ អ្នកត្រូវតែយាមដំណាក់របស់ព្រះអម្ចាស់ដើម្បីការពារស្តេច។[8]អ្នកត្រូវតែនៅជុំវិញស្តេច គ្រប់គ្នាត្រូវមានអាវុធក្នុងដៃ។
អ្នកណាដែលចូលមកក្នុងជួររបស់អ្នកត្រូវសម្លាប់ចោល។ អ្នកត្រូវនៅជាមួយស្តេចនៅពេលដែលស្តេចយាងចេញក្រៅ ហើយនៅពេលដែលទ្រង់យាងចូលក្នុងផង។
[9]ដូច្នេះ មេកងរយនាក់បានស្តាប់តាមអ្វីៗដែលលោកបូជាចារ្យយ៉ូហូយ៉ាដាបានបង្គាប់។ គ្រប់គ្នាបាននាំមនុស្សរបស់ខ្លួន គឺអស់អ្នកដែលត្រូវមកបម្រើនៅថ្ងៃសប្ប័ទ
ហើយនឹងអ្នកដែលត្រូវឈប់បម្រើនៅថ្ងៃសប្ប័ទ ហើយពួកគេបានមកជួបលោកបូជាចារ្យយ៉ូហូយ៉ាដា។[10]បន្ទាប់មកលោកបូជាចារ្យយ៉ូហូយ៉ាដាបានឲ្យលំពែង ព្រមទាំង
ខែលដែលជារបស់ព្រះបាទដាវីឌ ដែលមាននៅក្នុងដំណាក់របស់ព្រះអម្ចាស់ដល់មេកងរយនាក់នោះ។
[11]ដូច្នេះ អ្នកយាមបានឈរ គឺគ្រប់គ្នាមានអាវុធនៅក្នុងដៃ ចាប់ពីខាងឆ្វេងព្រះវិហារដល់ខាងស្តាំ នៅជិតអាសនា និងព្រះវិហារនៅជុំវិញស្តេច។
[12]បន្ទាប់មកលោកយ៉េហូយ៉ាដាបាននាំយូអាសជាបុត្រារបស់ស្តេចចេញមក បានដាក់ម្កុដលើក្បាលគាត់ ហើយថ្វាយឯកសារនៃសម្ពន្ធមេត្រីផង។ បន្ទាប់មក
ពួកគេបានប្រកាសថាទ្រង់គឺជាស្តេច ហើយបានចាក់ប្រេងតាំងលើទ្រង់។ ពួកគេបានទះដៃរបស់ពួកគេ ហើយនិយាយថា៖ «សូមស្តេចមានអាយុយឺនយូរ»!
[13]នៅពេលដែលព្រះនាងអថាលាបានឮសម្លេងរបស់អ្នកយាម និងសម្លេងរបស់ប្រជាជន នាងបានមកជួបប្រជាជននៅក្នុងដំណាក់របស់ព្រះអម្ចាស់។
នាងបានមើល[14]ហើយបានឃើញស្តេចគង់នៅក្បែរសសរ តាមទំនៀមទំលាប់ ហើយពួកមេកង និងអ្នកផ្លុំត្រែនៅក្បែរស្តេច។ ប្រជាជនទាំងអស់មានអំណរយ៉ាងខ្លាំង
ហើយបានផ្លុំត្រែ។ បន្ទាប់មក ព្រះនាងអថាលា បានហែកសំលៀកបំពាក់ ហើយស្រែកថា៖ «នេះជាអំពើក្បត់! នេះជាអំពើក្បត់!»
[15]បន្ទាប់មក លោកបូជាចារ្យយ៉េហូយ៉ាដាបានបញ្ជាឲ្យលោកមេកងរយនាក់ ដែលជាមេទាហានថា៖ «ចូរនាំនាងចេញក្រៅទៅ។ អ្នកណាទៅតាមនាង
សូមសម្លាប់ដោយដាវទៅ»។ លោកបូជាចារ្យនិយាយថា៖ «កុំឲ្យសម្លាប់នាងនៅក្នុងដំណាក់របស់ព្រះអម្ចាស់ឡើយ»។[16]ដូច្នេះ
ពួកគេក៏អូសនាងរហូតដល់ច្រកដែលសេះចូលមកក្នុងវាំង ហើយពួកគេបានសម្លាប់នាងនៅទីនោះទៅ។
[17]បន្ទាប់មក លោកយ៉េហូយ៉ាដាបានចងសម្ពន្ធមេត្រីរវាងព្រះអម្ចាស់ ស្តេច និងប្រជាជន ដែលពួកគេនឹងធ្វើជាប្រជាជនរបស់ព្រះអម្ចាស់ ហើយក៏រវាងស្តេច
និងប្រជាជនដែរ។[18]ដូច្នេះ ប្រជាជនបានទៅដំណាក់របស់ព្រះបាល ហើយបានកម្ទេចចោល។ ពួកគេកម្ទេចអាសនារបស់ព្រះបាល និងរូបព្រះទៅជាបំណែក
ហើយពួកគេបានសម្លាប់លោកម៉ាត់ថានជាបូជាចារ្យរបស់ព្រះបាលនៅមុខអាសនា។ បន្ទាប់មក
លោកបូជាចារ្យយ៉េហូយ៉ាដាបានចាត់អ្នកយាមឲ្យមើលថែព្រះវិហាររបស់ព្រះអម្ចាស់។
[19]លោកយេហូយ៉ាដាបាននាំលោកមេបញ្ជាការកងរយនាក់ជាជនជាតិការី ពួកអ្នកយាម និងប្រជាជនទាំងអស់ ហើយពួកគេបាននាំស្តេចពីដំណាក់របស់ព្រះអម្ចាស់
ហើយបានចេញដំណើរទៅក្នុងដំណាក់របស់ស្តេច ចូលតាមទ្វារអ្នកយាម។ ព្រះបាទយ៉ូអាសឡើងគង់លើរាជ្យបល្ល័ង្ក។[20]ដូច្នេះ ប្រជាជនទាំងអស់ពេញដោយអំណរ
ហើយក្រុងទាំងមូលស្ងប់ស្ងាត់ក្រោយពីព្រះនាងអថាលាត្រូវបានគេសម្លាប់ដោយដាវនៅក្នុងដំណាក់ស្តេចរួចមក។
[21]ព្រះបាទយ៉ូអាសអាយុប្រាំពីរឆ្នាំនៅពេលទ្រង់ឡើងគ្រងរាជ្យ។

---

2 Kings 11:1

ព្រះបាទអហាស៊ីយ៉ា...យ៉ូសេបា...យ៉ូអាស

ជ្រាបថា បុត្ររបស់នាងស្លាប់ហើយ

«បានដឹងថាកូនប្រុសរបស់នាង បានស្លាប់ហើយ»

នាងក៏ក្រោកឡើង ហើយសម្លាប់ក្មេងៗរាជវង្សទាំងអស់

ព្រះនាងអថាលា មិនបានសម្លាប់ក្មេងដោយផ្ទាល់ទេ។ ការបកប្រែផ្សេងទៀត «
នាងបានបញ្ជាឱ្យអ្នកបម្រើរបស់នាង
សម្លាប់សមាជិកទាំងអស់នៃគ្រួសាររបស់អហាស៊ីយ៉ា ដែលអាចនឹងក្លាយជាស្តេច»

បានយកយ៉ូអាស ជាបុត្ររបស់ព្រះបាទអហាស៊ីយ៉ា ពីក្នុងចំណោមបុត្ររបស់ស្តេចដែលត្រូវគេ
សម្លាប់នោះទៅជាមួយអ្នកមើលថែរបស់បុត្រនោះ នាងបានទុកពួកគេនៅក្នុងបន្ទប់របស់នាង។

ពួកគេបានលាក់បុត្រនោះពីព្រះនាងអថាលា ដូច្នេះ បុត្រនោះមិនត្រូវបានគេសម្លាប់ឡើយ

«បានយកកូនប្រុសយ៉ូអ័ហាស៊ីយ៉ា ដែលនៅក្មេងហើយបានលាក់គាត់
និងអ្នកមើលថែក្មេងនៅក្នុងបន្ទប់គេងមួយ
នៅក្នុងព្រះវិហារដូច្នេះគាត់មិនត្រូវបានសម្លាប់ទេ» ។

បុត្រនោះនៅជាមួយព្រះនាងយ៉ូសេបា

គេបានលាក់បុត្រនោះនៅក្នុងដំណាក់របស់ព្រះអម្ចាស់អស់ប្រាំមួយឆ្នាំ នៅពេលដែលព្រះនាង
អថាលាសោយរាជ្យលើទឹកដីនោះ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
យ៉ូអាសនិងព្រះនាងយ៉ូសេបា បានលាក់ខ្លួនអស់រយៈពេល ៦
ឆ្នាំនៅក្នុងដំណាក់ព្រះជាម្ចាស់ នៅពេលដែលអថាលាបានគ្រប់គ្រងស្រុក»

ទឹកដីនោះ

«នគរ»

2 Kings 11:4

ឃ្លាភ្ជាប់៖

នេះបន្តរឿងរ៉ាវដែលកើតឡើងបន្ទាប់ពីយ៉ូអាស ជាកូនប្រុសរបស់ស្តេចអសារា
ត្រូវបានគេលាក់នៅក្នុងព្រះវិហារ
បន្ទាប់ពីកូនចៅដទៃទៀតរបស់ស្តេចអសារាត្រូវបានសម្លាប់។

នៅក្នុងឆ្នាំទីប្រាំពីរ

«នៅឆ្នាំទីប្រាំពីរនៃរជ្ជកាលព្រះបាទអថាលា» ឬ «នៅឆ្នាំទី ៧
នៃរជ្ជកាលព្រះបាទអថាលា»

យេហូយ៉ាដា

មហាបូជាចារ្យ

ការី

នេះគឺជាឈ្មោះក្រុមពិសេសនៃឆ្មាំរាជវង្ស។

នាំពួកគេមកជួបគាត់

លោកយេហូយ៉ាដាជាសម្តេចសង្ឃបាន ឲ្យ ពួកទាហានទាំងនេះរាយការណ៍ទៅគាត់
នៅឯព្រះវិហារ។ ការបកប្រែផ្សេងទៀត «អោយគេមកជួបគាត់នៅព្រះវិហារ»

បន្ទាប់មកលោកក៏បានបង្ហាញបុត្ររបស់ស្តេចដល់ពួកគេ

លោកយេហូយ៉ាដាបានប្រាប់ពួកគេ ថាlokយ៉ូអាសជាបុត្ររបស់ស្តេចអសារា
នៅរស់នៅឡើយទេ។

2 Kings 11:7

ព័ត៌មានទូទៅ

លោកយេហូយ៉ាដាបន្តណែនាំ ដល់ទាហានដែលនឹងការពារស្តេចយ៉ូអាស។

ដើម្បីការពារស្តេច

ពួកគេត្រូវឃ្លាំមើលដើម្បីការពារស្តេចពីគ្រោះថ្នាក់។ ការបកប្រែផ្សេងទៀត
«ដើម្បីការពារស្តេចយ៉ូអាស»

អ្នកណាដែលចូលមកក្នុងជួររបស់អ្នក

ឋានៈសំដៅទៅលើខ្សែទាហាន។ ការបកប្រែផ្សេងទៀត «អ្នកដែលព្យាយាមឆ្លងកាត់
អ្នកពេលអ្នកកំពុងការពារស្តេចយ៉ូអាស»

ត្រូវសម្លាប់ចោល

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្នកត្រូវតែសម្លាប់គាត់»

អ្នកត្រូវនៅជាមួយស្តេចនៅពេលដែលស្តេចយាងចេញក្រៅ
ហើយនៅពេលដែលទ្រង់យាងចូលក្នុងផង

រឿងផ្ទុយគ្នាទាំងពីរនេះគឺជាការរួមបញ្ចូលគ្នា ដែលសំដៅទៅលើអ្វីៗដែលស្តេចធ្វើ។
ការបកប្រែផ្សេងទៀត «អ្នកត្រូវតែនៅជិតព្រះរាជាគ្រប់ពេលវេលា»

2 Kings 11:9

មេកងរយនាក់

នេះសំដៅទៅលើនាយទាហានដែលត្រួតត្រាអង្គរក្សនិងឆ្មាំវាំង។
សូមមើលនៅក្នុងជំពូក ១១: ៤ ។

generated on Wed Sep 10 16:16:32 2025

គ្រប់គ្នា
«មេបញ្ជាការនីមួយៗ»
នៅក្នុងដំណាក់របស់ព្រះអម្ចាស់
«ត្រូវបានរក្សាទុកនៅក្នុងព្រះវិហារ»
2 Kings 11:11
ចាប់ពីខាងឆ្វេងព្រះវិហារដល់ខាងស្តាំ នៅជិតអាសនា និងព្រះវិហារ
វាមិនច្បាស់ទេថាតើពាក្យ « ផ្ទះ» នៅទីនេះសំដៅទៅលើព្រះវិហារ ឬក៏វាំងទេ។
ការបកប្រែខ្លះបកប្រែការកើតឡើងពីរលើកដំបូងនៃ «ព្រះវិហារ» ដូចជា «វាំង» ។
សំណៅទាំងនេះនិយាយថា « ពីខាងស្តាំព្រះបរមរាជវាំង
ទៅខាងឆ្វេងនៃព្រះបរមរាជវាំងក្បែរអាសនៈ និងព្រះវិហារ» ។
បាននាំស្តេចយូអាសជាបុត្ររបស់ស្តេចចេញមក
លោកយេហូយ៉ាដាជាសម្តេចសង្ឃ
បាននាំកូនប្រុសរបស់ស្តេចអ័ហាស៊ីយ៉ាឈ្មោះយ៉ូអាស
ចេញពីព្រះវិហារដែលជាកន្លែងដែលគាត់ ត្រូវគេចិញ្ចឹមក្នុងទីលាក់ខ្លួននោះ។
ថ្វាយឯកសារនៃសម្ពន្ធមេត្រីផង
«បានបង្ហាញគាត់នូវសៀវភៅច្បាប់»
បានចាក់ប្រេងតាំងលើទ្រង់
បូជាចារ្យចាក់ប្រេងអូលីវលើក្បាលយ៉ូអាស ជានិមិត្តរូបដែលឥឡូវនេះគាត់ជាស្តេច។
ការបកប្រែផ្សេងទៀត «ចាក់ប្រេងអូលីវមួយចំនួនលើក្បាលរបស់យ៉ូអាស»
ពួកគេបានទះដៃរបស់ពួកគេ
ការទះដៃរបស់ពួកគេគឺជាសញ្ញា នៃសុភមង្គលរបស់ប្រជាជន
នៅពេលចាក់ប្រេងតាំងស្តេចថ្មី។
2 Kings 11:13
សម្លេងរបស់អ្នកយាម
នេះសំដៅទៅលើសម្លេងទាហានទាំងអស់។
នាងបានមកជួបប្រជាជននៅក្នុងដំណាក់របស់ព្រះអម្ចាស់
«នាងបានមកដល់កន្លែង ដែលប្រជាជនបានប្រមូលផ្តុំនៅព្រះវិហារ»
នាងបានមើល ហើយបានឃើញស្តេចគង់នៅ
នៅទីនេះ «មើល» សង្កត់ធ្ងន់ថានាងមានការភ្ញាក់ផ្អើល ដែលបានឃើញយ៉ូអាស។
ការបកប្រែផ្សេងទៀត
«នៅពេលនាងមកដល់នាងមានការភ្ញាក់ផ្អើលដែលបានឃើញស្តេចយ៉ូអាសឈរ»
នៅក្បែរសសរ
«ដោយសសរមួយនៃសសរព្រះវិហារ»
តាមទំនៀមទំលាប់
«ដែលជាកន្លែងធម្មតាសម្រាប់ស្តេចឈរ»
អ្នកផ្លុំត្រែ
ប្រជាជនដែលបានផ្លុំត្រែ
ព្រះនាងអថាលា បានហែកសំលៀកបំពាក់
នាងហែកសម្លៀកបំពាក់ដើម្បីបង្ហាញ ថានាងតូចចិត្ត និងខឹងយ៉ាងខ្លាំង។
«នេះជាអំពើក្បត់! នេះជាអំពើក្បត់!»
«អ្នកជាជនក្បត់! អ្នកបានក្បត់ខ្ញុំហើយ!»
2 Kings 11:15
មេកងរយនាក់
នេះសំដៅទៅលើនាយទាហាន ដែលត្រួតត្រាអង្គរក្ស និងឆ្មាំវាំង។
សូមមើលនៅក្នុងជំពូក ១១: ៤ ។
ចូរនាំនាងចេញក្រៅទៅ
ជួរគឺជាជួរ ឬជួរទាហាន។ អត្ថន័យដែលអាចទៅរួចគឺ
«យកនាងទៅឆ្ងាយពីឆ្មាំពីរជួរ» ឬ
«នាំនាងទៅឆ្ងាយមួយជួរពីទាហាននៅសងខាងនាង»
អ្នកណាទៅតាមនាង
វាបញ្ជាក់ថាមនុស្សម្នាក់ដែលដើរតាមនាង នឹងព្យាយាមជួយនាង។
ការបកប្រែផ្សេងទៀត «អ្នកដែលតាមព្យាយាមជួយសង្គ្រោះនាង»
ដូច្នេះ ពួកគេក៏អូសនាងរហូតដល់ច្រកដែលសេះចូលមកក្នុងវាំង
ការបកស្រាយខ្លះបកប្រែថា «ឆ្មាំបានចាប់នាងហើយនាំនាង
ទៅទីធ្លាជាកន្លែងដែលសេះចូលវាំង» ។
2 Kings 11:17
រវាងព្រះអម្ចាស់ ស្តេច និងប្រជាជន
«ក៏បានធ្វើកិច្ចព្រមព្រៀង រវាងស្តេច និងប្រជាជន»
ប្រជាជន
នេះគឺជាការបំផ្លើសមួយ ដើម្បីបង្ហាញថាមនុស្សមួយក្រុមធំ
បានទម្លាប់ព្រះវិហាររបស់ព្រះបាល។ ការបកប្រែផ្សេងទៀត
«ប្រជាជននៅលើទឹកដីមួយភាគធំ»
ដំណាក់របស់ព្រះបាល
«ព្រះវិហាររបស់ព្រះបាល»
ម៉ាត់ថាន
នេះជាឈ្មោះបូជាចារ្យ។
2 Kings 11:19
ព័ត៌មានទូទៅ
ពួកគេយកស្តេចថ្មី យ៉ូអាសចេញពីព្រះវិហាររហូតដល់ព្រះបរមរាជវាំង។
មេបញ្ជាការកងរយនាក់
នេះសំដៅទៅលើនាយទាហានដែលត្រួតត្រាអង្គរក្សនិងឆ្មាំវាំង។
សូមមើលនៅក្នុងជំពូក ១១: ៤ ។
ការី
នេះគឺជាឈ្មោះក្រុមពិសេសនៃឆ្មាំរាជវង្ស។
បាននាំស្តេចពីដំណាក់របស់ព្រះអម្ចាស់ ហើយបានចេញដំណើរទៅក្នុងដំណាក់របស់ស្តេច
«បាននាំស្តេចចេញពីព្រះវិហារទៅកាន់រាជវាំង»
ប្រជាជនទាំងអស់ពេញដោយអំណរ
នេះគឺជាការធ្វើឱ្យមានលក្ខណៈទូទៅ។ វាអាចទៅរួចដែលអ្នកខ្លះមិនរីករាយ។
ក្រុងទាំងមូលស្ងប់ស្ងាត់
«ទីក្រុងមានភាពស្ងប់ស្ងាត់» ឬ «ទីក្រុងមានសន្តិភាព»
2 Kings 11:21
ព្រះបាទយ៉ូអាសអាយុប្រាំពីរឆ្នាំ
«ព្រះបាទយ៉ូអាសមានអាយុ ៧ ឆ្នាំហើយ»

---

12 [1]នៅក្នុងឆ្នាំទីប្រាំពីរនៃព្រះបាទយេហ៊ូវ រាជ្យរបស់ព្រះបាទយ៉ូអាសបានចាប់ផ្តើម ស្តេចសោយរាជ្យបានសែសិបឆ្នាំនៅក្រុងយេរូសាឡឹម។ មាតារបស់ទ្រង់គឺស៊ីបយ៉ា ជាអ្នកស្រុកបៀរសេបា។[2]ព្រះបាទយ៉ូអាសបានប្រព្រឹត្តត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់គ្រប់ពេល ដោយសារលោកបូជាចារ្យយេហូយ៉ាដាបានណែនាំស្តេច។
[3]ប៉ុន្តែ តាមទីទួលខ្ពស់ៗស្តេចមិនបានបំផ្លាញចោលឡើយ។ ប្រជាជននៅតែថ្វាយតង្វាយ និងដុតគ្រឿងក្រអូបនៅតាមទីខ្ពស់ទាំងនោះដដែរ។
[4]ព្រះបាទយ៉ូអាសនិយាយទៅលោកបូជាចារ្យថា៖ «ប្រាក់ទាំងអស់ដែលបាននាំមកជាដង្វាយនៅក្នុងដំណាក់របស់ព្រះអម្ចាស់ ប្រាក់ដែលម្នាក់ៗយកមកថ្វាយ
ទោះបីជាប្រាក់ដែលគេយកមកបង់ពន្ធព្រះវិហារ ឬប្រាក់ដែលទទួលបានពីបុគ្គល
ឬប្រាក់ដែលគេបាននាំមកថ្វាយដោយការជំរុញចិត្តពីព្រះអម្ចាស់ក៏ដោយ[5]ក៏ពួកបូជាចារ្យគួរតែទទួលប្រាក់ទាំងនោះទៅដាក់ក្នុងឃ្លាំង
ហើយជួសជុលអ្វីៗដែលខូចខាតនៅក្នុងព្រះវិហារ»។
[6]ប៉ុន្តែ នៅឆ្នាំទីម្ភៃបីនៃស្តេចយ៉ូអាស ពួកបូជាចារ្យមិនបានជួសជុលអ្វីនៅក្នុងព្រះវិហារឡើយ។[7]បន្ទាប់មក ព្រះបាទយ៉ូអាសបានកោះហៅលោកបូជាចារ្យយេហូយ៉ាដា
និងបូជាចារ្យផ្សេងទៀតមក ស្តេចបាននិយាយទៅពួកគេថា៖ «តើហេតុអ្វីអ្នកទាំងអស់គ្នាមិនជួសជុលអ្វីៗនៅក្នុងព្រះវិហារ? ឥឡូវនេះ
ចូរឈប់យកប្រាក់ពីអ្នកបង់ពន្ធតទៅទៀត ប៉ុន្តែ ចូរយកប្រាក់ដែលប្រមូលបានដើម្បីជួសជុលព្រះវិហារ ហើយប្រគល់ដល់អ្នកដែលអាចជួសជុលបាន»។[8]ដូច្នេះ
ពួកបូជាចារ្យក៏យល់ព្រមឈប់ប្រមូលប្រាក់ពីប្រជាជន ហើយមិនជួសជុលព្រះវិហារដោយខ្លួនឯងឡើយ។
[9]ផ្ទុយទៅវិញ លោកបូជាចារ្យយេហូយ៉ាដាមកយកហឹបមួយមក ចុះរន្ធនៅលើមាត់ហឹបនោះ ហើយដាក់វានៅខាងក្រោយអាសនា
នៅខាងស្តាំច្រកចូលព្រះដំណាក់របស់ព្រះអម្ចាស់។
ពួកបូជាចារ្យដែលយាមនៅទ្វារព្រះវិហារបានដាក់ប្រាក់ទាំងអស់ដែលគេបាននាំមកដំណាក់របស់ព្រះអម្ចាស់នៅក្នុងហឹបនោះ។
[10]នៅពេលដែលគេឃើញថាមានប្រាក់ច្រើននៅក្នុងហឹប អ្នករាប់លុយរបស់ស្តេច និងលោកមហាបូជាចារ្យនឹងមក ហើយដាក់ប្រាក់នៅក្នុងបាវ ហើយបន្ទាប់មក
ពួកគេរាប់ប្រាក់នោះ គឺប្រាក់ដែលមាននៅក្នុងដំណាក់របស់ព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

[11]ពួកគេបានប្រគល់ប្រាក់ដែលបានថ្លឹងរួចទៅអ្នកដែលមើលថែព្រះវិហាររបស់ព្រះអម្ចាស់។ ពួកគេចាំចំណាយទៅលើជាងឈើ
និងជាងសាងសង់ដែលធ្វើការនៅក្នុងវិហាររបស់ព្រះអម្ចាស់[12]និងជាងកំបោរ និងអ្នកកាត់ថ្ម សម្រាប់ទិញឈើ និងថ្មដាប់ ដើម្បីជួសជុលព្រះវិហាររបស់ព្រះអម្ចាស់
និងសម្រាប់ចំណាយលើអ្វីៗដែលត្រូវជួសជុលព្រះវិហារ។
[13]ប៉ុន្តែ ប្រាក់ដែលប្រជាជនយកមកថ្វាយក្នុងព្រះដំណាក់របស់ព្រះអម្ចាស់មិនបានចំណាយ ទៅធ្វើពានប្រាក់ កាំបិត ចូ ត្រែ ឬប្រដាប់ប្រដាអ្វីផ្សេងទៀតអំពីមាសឬ ប្រាក់
ឡើយ។[14]គេប្រគល់ប្រាក់នេះឲ្យអស់អ្នកដែលធ្វើការជួសជុលព្រះដំណាក់របស់ព្រះអម្ចាស់។
[15]លើសពីនេះទៅទៀត ពួកគេមិនចាំបាច់រាប់លុយដែលត្រូវចំណាយលើការជួសជុលឡើយ ព្រោះអ្នកដែលទទួលប្រាក់ ដើម្បីបើកឲ្យអ្នកធ្វើការសុទ្ធតែជាមនុស្សស្មោះត្រង់។
[16]ប៉ុន្តែ ប្រាក់សម្រាប់តង្វាយសុំការលើកលែងទោស និងតង្វាយលោះបាបមិនបាននាំមកក្នុងដំណាក់របស់ព្រះអម្ចាស់ឡើយ ព្រោះប្រាក់នេះជាកម្មសិទ្ធិរបស់ពួកបូជាចារ្យ។
[17]បន្ទាប់មក ព្រះបាទហាសែល ជាស្តេចស្រុកស៊ីរី ឡើងមកវាយក្រុងកាដ និងដណ្តើមយកបានក្រុងនោះ។ ព្រះបាទហាសែលក៏ត្រឡប់ទៅវាយក្រុងយេរូសាឡឹមទៀត។
[18]ព្រះបាទយ៉ូអាសស្តេចស្រុកយូដា ប្រមូលវត្ថុមានតម្លៃទាំងប៉ុន្មាន ដែលព្រះបាទយ៉ូសាផាត ព្រះបាទយ៉ូរ៉ាម និងព្រះបាទអហាស៊ីយ៉ា បានញែកទុកនិងវត្ថុដែលស្តេចផ្ទាល់
បានញែកទុក និងមាសដែលបានរកឃើញនៅក្នុងឃ្លាំងនៃព្រះដំណាក់របស់ព្រះអម្ចាស់ និងក្នុងដំណាក់របស់ស្តេច ហើយបញ្ជូនរបស់ទាំងនោះទៅថ្វាយព្រះបាទហាសែល
ជាស្តេចស្រុកស៊ីរី។ បន្ទាប់មកព្រះបាទហាសែលបានចេញពីក្រុងយេរូសាឡឹមទៅ។
[19]រឿងរ៉ាវផ្សេងទៀតទាក់ទងនឹងព្រះបាទយ៉ូអាស និងអ្វីៗដែលស្តេចបានធ្វើ តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដាទេឬ?
[20]អ្នកបម្រើទាំងឡាយរបស់ស្តេចបានងើបឡើងរួមគំនិតគ្នា ហើយពួកគេបានវាយប្រហារព្រះបាទយ៉ូអាសនៅប៉មមីឡូ តាមផ្លូវចុះទៅស៊ីឡា។[21]លោកយ៉ូសាការ ជាកូនរបស់
លោកស៊ីមាត និងលោកយ៉ូសាបាឌ ជាកូនរបស់លោកសូមើរ ជាអ្នកបម្រើរបស់ស្តេចបានវាយប្រហារទ្រង់ ហើយស្តេចក៏សុគតទៅ។ គេបានបញ្ចុះសព
ព្រះបាទយ៉ូអាសជាមួយបុព្វបុរសរបស់ទ្រង់នៅក្នុងក្រុងព្រះបាទដាវីឌ ហើយព្រះបាទអម៉ាស៊ីយ៉ា ជាបុត្ររបស់ទ្រង់ បានឡើងស្នងរាជ្យបន្ត។

---

2 Kings 12:1
នៅក្នុងឆ្នាំទីប្រាំពីរនៃព្រះបាទយេហ៊ូវ
«កំឡុងឆ្នាំ ៧ នៃរជ្ជកាលយេហ៊ូសោយរាជ្យលើអ៊ីស្រាអែល»
រាជ្យរបស់ព្រះបាទយ៉ូអាសបានចាប់ផ្តើម
«ព្រះបាទយ៉ូអាសបានឡើងសោយរាជ្យលើស្រុកយូដា»
ស៊ីបយ៉ា
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
ស៊ីបយ៉ា ជាអ្នកស្រុកបៀរសេបា
«ស៊ីបយ៉ាមកពីទីក្រុងបៀរសេបា»
បានប្រព្រឹត្តត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
ឃ្លាដែលថា «ព្រះនេត្ររបស់ព្រះអម្ចាស់» តំណាង ឲ្យ ភាពជាព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «អ្វីដែលគាប់ដល់ព្រះជាម្ចាស់»
ណែនាំស្តេច
«បង្រៀនទ្រង់»
ប៉ុន្តែ តាមទីទួលខ្ពស់ៗស្តេចមិនបានបំផ្លាញចោលឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «
ប៉ុន្តែប្រជាជនមិនបានបំផ្លាញកន្លែងខ្ពស់ ៗ ទេ»
ប្រជាជននៅតែថ្វាយតង្វាយ និងដុតគ្រឿងក្រអូបនៅតាមទីខ្ពស់ទាំងនោះដដែរ
ព្រះជាម្ចាស់ហាមប្រជាជន មិនឲ្យគោរពបូជានៅកន្លែងទាំងនេះ។
នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត «
ប្រជាជនបានបន្តទៅកន្លែងដែលព្រះអម្ចាស់
មិនគាប់ព្រះហឫទ័យធ្វើយញ្ញបូជានិងដុតគ្រឿងក្រអូប»
2 Kings 12:4
ប្រាក់ទាំងអស់ដែលបាននាំមកជាដង្វាយនៅក្នុងដំណាក់របស់ព្រះអម្ចាស់
នេះសំដៅទៅលើប្រាក់ដែលប្រជាជនបានថ្វាយដើម្បីគាំទ្រព្រះវិហារ។
ប្រាក់នេះបានមកជាបីទម្រង់ដែលត្រូវបានពិពណ៌នា
នៅក្នុងប្រយោគដែលនៅសល់។
ប្រាក់ដែលគេបាននាំមកថ្វាយដោយការជំរុញចិត្តពីព្រះអម្ចាស់ក៏ដោយ
នេះសំដៅទៅលើប្រាក់ដែលប្រជាជនបានសម្រេចចិត្តថ្វាយដល់ព្រះអម្ចាស់ដោយសេរី។
2 Kings 12:6
នៅឆ្នាំទីម្ភៃបីនៃស្តេចយ៉ូអាស
ឆ្នាំទីបីនៃស្តេចយ៉ូអាស -
«នៅពេលដែលព្រះបាទយ៉ូអាសបានសោយរាជ្យអស់រយៈពេលម្ភៃបីឆ្នាំ»
តើហេតុអ្វីអ្នកទាំងអស់គ្នាមិនជួសជុលអ្វីៗនៅក្នុងព្រះវិហារ?
ស្តេចយ៉ូអាសសួរសំណួរនេះ ដើម្បីស្តីបន្ទោសពួកសង្ឃ។ ការបកប្រែផ្សេងទៀត
«អ្នកគួរតែជួសជុលព្រះវិហារនេះហើយ!»
ប្រគល់ដល់អ្នកដែលអាចជួសជុលបាន
«បើកប្រាក់ឈ្នួលអោយកម្មករដែលនឹងធ្វើការជួសជុល»
2 Kings 12:9
ផ្ទុយទៅវិញ
«ជំនួសឱ្យបូជាចារ្យប្រមូលប្រាក់»
នៅខាងស្តាំច្រកចូលព្រះដំណាក់របស់ព្រះអម្ចាស់
«នៅខាងស្តាំច្រកចូលព្រះវិហារ»
មកដំណាក់
«ដាក់ចូលហឹប» ឬ «ដាក់ក្នុងប្រអប់»
ប្រាក់ទាំងអស់ដែលគេបាននាំមកដំណាក់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រាក់ដែលមនុស្សបាននាំមក»
ដាក់ប្រាក់នៅក្នុងបាវ ហើយបន្ទាប់មក ពួកគេរាប់ប្រាក់នោះ
កំណែរជាច្រើនដាក់វាតាមលំដាប់ដូចជា «រាប់លុយហើយដាក់វាក្នុងកាបូប» ។
ដាក់ប្រាក់នៅក្នុងបាវ
អត្ថន័យគឺ ១) « ដាក់លុយក្នុងបាវ» ឬ ២) « ចងលុយដាក់ក្នុងបាវ» (យូ ឌី ប៊ី) ។
ប្រាក់ដែលមាននៅ
ប្រាក់ដែលពួកគេរកឃើញនៅក្នុងហឹប
2 Kings 12:11
ថ្លឹងរួច
«បានរាប់»
ទៅអ្នកដែលមើលថែ
នៅទីនេះ «ដៃ» សំដៅទៅលើបុរស។ ការបកប្រែផ្សេងទៀត «ចំពោះបុរស»
អ្នកដែលមើលថែព្រះវិហារ
«អ្នកដែលជួសជុលព្រះវិហារ»
ជាងឈើ
មនុស្សដែលសាងសង់ និងជួសជុលរបស់របរធ្វើពីឈើ
ជាងកំបោរ
មនុស្សដែលសាងសង់ដោយប្រើថ្ម
អ្នកកាត់ថ្ម
មនុស្សដែលកាត់ថ្មទៅជាទំហំនិងរូបរាងត្រឹមត្រូវ
សម្រាប់ទិញឈើ និងថ្មដាប់
«ទិញឈើនិងកាត់ថ្ម»
សម្រាប់ចំណាយលើអ្វីៗដែលត្រូវជួសជុលព្រះវិហារ
«ចំណាយសម្រាប់ការជួសជុល ដែលត្រូវការទាំងអស់»
2 Kings 12:13
មិនបានចំណាយ ទៅធ្វើ
«មិនត្រូវបានចំណាយ សម្រាប់របស់ណាមួយនៃព្រះវិហារឡើយ»
ពានប្រាក់ កាំបិត ចូ ត្រែ ឬ ប្រដាប់ប្រដាអ្វីផ្សេងទៀតអំពីមាសឬ ប្រាក់ឡើយ
ទាំងនេះជារបស់របរដែលបូជាចារ្យ ប្រើសម្រាប់កិច្ចការព្រះវិហារផ្សេងៗ
ដូចជាការបូជា ឬពិធីបុណ្យផ្សេងៗ។
2 Kings 12:15
ពួកគេមិនចាំបាច់រាប់លុយដែលត្រូវចំណាយលើការជួសជុលឡើយ ព្រោះអ្នកដែលទទួលប្រាក់
ដើម្បីបើកឲ្យអ្នកធ្វើការ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេមិនតម្រូវឱ្យបុរសដែលបានទទួលប្រាក់
និងបើកប្រាក់ខែឱ្យកម្មករជួសជុលរាប់ប្រាក់ទេ"
មិនចាំបាច់រាប់លុយ

generated on Wed Sep 10 16:16:32 2025

ដើម្បីរក្សាកំណត់ត្រាអំពីចំនួនទឹកប្រាក់ ដែលត្រូវបានទទួលនិងចំណាយ
ប្រាក់សម្រាប់តង្វាយសុំការលើកលែងទោស
និងតង្វាយលោះបាបមិនបាននាំមកក្នុងដំណាក់របស់ព្រះអម្ចាស់ឡើយ
វាបញ្ជាក់ថាប្រាក់នេះ មិនត្រូវបានប្រើសម្រាប់ការជួសជុលទេ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពួកគេមិនបានប្រើប្រាក់ ដែលបានមកពីដង្វាយលោះពិរុទ្ធភាព
និងដង្វាយលោះបាប
ដើម្បីចំណាយសម្រាប់ការជួសជុលព្រះវិហារនៃព្រះអម្ចាស់ទេ»
2 Kings 12:17
ព្រះបាទហាសែល ជាស្តេចស្រុកស៊ីរី ឡើងមកវាយ...ព្រះបាទហាសែលក៏ត្រឡប់ទៅវាយ
នេះសំដៅទៅលើកងទ័ពរបស់ហាសែល ក៏ដូចជាសំដៅទៅលើហាសែលផងដែរ។
ការបកប្រែផ្សេងទៀត «ស្តេចហាសែលជាស្តេចស្រុកស៊ីរី
និងកងទ័ពរបស់ទ្រង់បានវាយប្រហារ ... បន្ទាប់មកពួកគេបានងាកទៅវាយប្រហារ»
ហាសែល
នេះជាឈ្មោះស្តេចនៃប្រទេសស៊ីរី។
ដណ្តើមយក
«ចាញ់ និងកាន់កាប់យកវា»
ព្រះបាទយ៉ូសាផាត ព្រះបាទយ៉ូរ៉ាម និងព្រះបាទអហាស៊ីយ៉ា
បុរសទាំងនេះជាស្តេចមុន ៗ នៅស្រុកយូដា។
បានញែកទុក
«ឧទ្ទិស»
មាសដែលបានរកឃើញនៅក្នុងឃ្លាំង
«មាសដែលត្រូវបានរក្សាទុកនៅក្នុងឃ្លាំង»
បន្ទាប់មកព្រះបាទហាសែល បានចេញពីក្រុងយេរូសាឡឹមទៅ
អំណោយដែលស្តេចយ៉ូអាសបានផ្តល់ ឱ្យស្តេចហាសែលបានបញ្ឆោះបញ្ចូលគាត់
មិនឱ្យវាយប្រហារក្រុងយេរូសាឡិម។ នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត
«ដូច្នេះហាសែលឈប់វាយលុកក្រុងយេរូសាឡិមហើយចាកចេញទៅ»
2 Kings 12:19
តើមិនមានកត់ត្រាទុក នៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដាទេឬ?
សំណួរនេះត្រូវបានប្រើ ដើម្បីរំលឹកអ្នកអានថាការទាំងនេះត្រូវបានកត់ត្រាទុក។
សូមមើលនៅជំពូក ៨:២២ ។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវបានសរសេរនៅក្នុងសៀវភៅប្រវត្តិសាស្ត្រនៃស្តេចយូដា» ។ (សូមមើល
ផ្figs-rquestion)
ស៊ីឡា
ទីតាំងនៃកន្លែងនេះគេមិនទាន់ដឹងនៅឡើយទេ។
លោកយ៉ូសាការ ...លោកស៊ីមាត...យ៉ូសាបាឌ...លោកសូមើរ...អម៉ាស៊ីយ៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
ជាមួយបុព្វបុរសរបស់ទ្រង់
«នៅកន្លែងដែលគេបញ្ចុះ ដូនតារបស់ទ្រង់»
បានឡើងស្នងរាជ្យបន្ត
«បានក្លាយជាស្តេច បន្ទាប់នៃស្រុកយូដា»

---

13 [1]នៅក្នុងឆ្នាំទីម្ភៃបីនៃព្រះបាទយ៉ូអាសជាបុត្ររបស់ព្រះបាទអហាស៊ីយ៉ាស្តេចស្រុកយូដា ព្រះបាទយ៉ូអាហាស ជាបុត្ររបស់ព្រះបាទយេហ៊ូវ បានឡើងសោយរាជ្យលើ
ស្រុកអ៊ីស្រាអែល នៅក្រុងសាម៉ារី ស្តេចសោយរាជ្យបានដប់ប្រាំពីរឆ្នាំ។[2]ស្តេចបានប្រព្រឹត្តអំពើអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
និងដើរតាមមាគ៌ានៃអំពើបាបរបស់ព្រះបាទយេរ៉ូបោម កូននេបាត ដែលធ្វើឲ្យអ៊ីស្រាអែលធ្លាក់ក្នុងអំពើបាប ហើយព្រះបាទ
យ៉ូអាហាសមិនបានចាកចេញពីអំពើបាបទាំងអស់នេះឡើយ។
[3]កំហឹងរបស់ព្រះអម្ចាស់បានបញ្ឆេះប្រឆាំងនឹងអ៊ីស្រាអែល ហើយព្រះអង្គប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ព្រះបាទហាសែលស្តេចស្រុកស៊ីរី
និងទីក្នុងកណ្តាប់ដៃរបស់ព្រះបាទបេនហាដាដជាបុត្ររបស់ព្រះបាទហាសែលជាបន្តបន្ទាប់។[4]ដូច្នេះ ព្រះបាទយ៉ូអាហាសក៏ទូលអង្វរទៅព្រះអម្ចាស់
ហើយព្រះអម្ចាស់បានស្តាប់ការទូលអង្វររបស់ស្តេច ដោយសារព្រះអង្គឃើញស្តេចស្រុកស៊ីរីជិះជាន់សង្កត់សង្កិនពួកគេ។[5]ដូច្នេះ
ព្រះអម្ចាស់បានប្រទានអ្នកសង្គ្រោះដល់អ៊ីស្រាអែល ហើយពួកគេក៏បានរួចខ្លួនពីពួកអារ៉ាម
ហើយប្រជាជនអ៊ីស្រាអែលចាប់ផ្តើមរស់នៅក្នុងផ្ទះរបស់ពួកគេផ្ទាល់ដូចដែលពួកគេធ្លាប់រស់នៅពីមុន។
[6]ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេមិនបានបោះបង់ចោលអំពើបាបរបស់ព្រះបាទយេរ៉ូបោម ដែលធ្វើឲ្យអ៊ីស្រាអែលធ្លាក់ក្នុងអំពើបាបដែរ
ហើយពួកគេនៅតែប្រព្រឹត្តអំពើបាបនោះ ហើយសសររបស់ព្រះអាសេរានៅតែបន្តមាននៅស្រុកសាម៉ារី។[7]ពួកអារ៉ាមបានធ្វើឲ្យព្រះបាទយ៉ូអាសសល់តែទ័ពសេះហាសិបនាក់
រទេះចម្បាំងដប់ និងទាហានមួយម៉ឺននាក់ប៉ុណ្ណោះ ព្រោះស្តេចអារ៉ាមបានបំផ្លាញពួកគេ ហើយធ្វើឲ្យពួកគេទៅដូចជាធូលីដី។
[8]រឿងរ៉ាវផ្សេងទៀតទាក់ទងនឹងព្រះបាទយ៉ូអាហាស អ្វីដែលស្តេចបានធ្វើ និងអំណាចរបស់ស្តេច
តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬអី?[9]ដូច្នេះ ព្រះបាទយ៉ូអាហាសផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
ហើយគេបញ្ចុះសពទ្រង់នៅស្រុកសាម៉ារី។ ព្រះបាទយ៉ូអាស ជាបុត្រ ឡើងស្នងរាជ្យបន្ត។
[10]នៅក្នុងឆ្នាំទីសាបសិបប្រាំពីរនៃរាជ្យរបស់ព្រះបាទយ៉ូអាសស្តេចស្រុកយូដា ព្រះបាទយ៉ូអាស ជាបុត្ររបស់ព្រះបាទយ៉ូអាហាស បានឡើងសោយរាជ្យលើស្រុកអ៊ីស្រាអែល
នៅក្រុងសាម៉ារី ទ្រង់សោយរាជ្យបានដប់ប្រាំមួយឆ្នាំ។[11]ស្តេចបានប្រព្រឹត្តអាក្រក់ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់។
ស្តេចមិនបានងាកចេញពីអំពើបាបរបស់ព្រះបាទយេរ៉ូបោមជាកូនរបស់នេបាតឡើយ ដែលធ្វើឲ្យអ៊ីស្រាអែលធ្លាក់ក្នុងអំពើបាប ប៉ុន្តែ ស្តេចបានដើរតាមមាគ៌ានោះ។
[12]រឿងរ៉ាវផ្សេងទៀតទាក់ទឹងនឹងព្រះបាទយ៉ូអាស និងអ្វីៗដែលស្តេចបានធ្វើ និងភាពល្បីល្បាញរបស់ទ្រង់ ដែលទ្រង់បានធ្វើប្រឆាំងនឹងព្រះបាទអម៉ាស៊ីយ៉ា ជាស្តេចស្រុក
យូដា តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬអី?[13]ព្រះបាទយ៉ូអាសបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់ ហើយព្រះបាទ
យេរ៉ូបោមសោយរាជ្យបន្តពីទ្រង់។ ព្រះបាទយ៉ូអាសត្រូវបានបញ្ចុះនៅក្នុងស្រុកសាម៉ារីជាមួយស្តេចស្រុកអ៊ីស្រាអែល។
[14]ពេលនោះ លោកអេលីសេមានជំងឺជាទម្ងន់ហៀបនឹងស្លាប់ ដូច្នេះ ព្រះបាទយ៉ូអាស ជាស្តេចស្រុកអ៊ីស្រាអែល យាងមករកលោក ហើយបានយំស្រណោះលោក។
ស្តេចមានរាជឱង្ការថា៖ «លោកឪពុកអើយ លោកឪពុកអើយ រទេះចម្បាំង
និងទ័ពសេះរបស់អ៊ីស្រាអែលបានកំពុងយកលោកទៅឆ្ងាយហើយ!»[15]លោកអេលីសេទូលវិញថា៖ «សូមព្រះករុណាយកធ្នូ និងព្រួញមក» ដូច្នេះព្រះបាទយ៉ូអាសបានយក
ធ្នូ និងព្រួញមក។[16]លោកអេលីសេបានទូលទៅស្តេចស្រុកអ៊ីស្រាអែលថា៖ «សូមដាក់ដៃរបស់ព្រះករុណានៅលើធ្នូទៅ» ដូច្នេះ ស្តេចក៏ដាក់ដៃរបស់ទ្រង់នៅលើធ្នូ។
បន្ទាប់មក លោកអេលីសេបានដាក់ដៃរបស់លោកនៅលើដៃរបស់ស្តេច។
[17]លោកអេលីសេទូលថា៖ «សូមបើកបង្អួចនៅទិសខាងលិច» ដូច្នេះ ស្តេចក៏បើកបង្អួចនោះ។ បន្ទាប់មក លោកអេលីសេទូលថា៖ «សូមព្រះករុណាបាញ់ព្រួញទៅ»!
បន្ទាប់មក ស្តេចក៏បាញ់។ លោកអេលីសេទូលថា៖ «នេះជាព្រួញជ័យជម្នះរបស់ព្រះអម្ចាស់ ជាព្រួញជ័យជម្នះលើជនជាតិអារ៉ាម
ព្រោះព្រះអង្គនឹងវាយជនជាតិអារ៉ាមនៅក្រុងអាផែក រហូតដល់ពួកគេវិនាសសូន្យ»។[18]បន្ទាប់មកលោកអេលីសេទូលថា៖ «សូមព្រះករុណាយកគ្រាប់ព្រួញមក» ដូច្នេះ
ព្រះបាទយ៉ូអាសក៏បានយកព្រួយមក។ លោកបានទូលស្តេចថា៖ «ចូរយកព្រួញនោះវាយដីទៅ» ហើយស្តេចក៏វាដីបីដងរួចក៏ឈប់។[19]ប៉ុន្តែ
អ្នកបម្រើរបស់ព្រះអម្ចាស់ខឹងនឹងស្តេចយ៉ាងខ្លាំងហើយនិយាយថា៖ «ព្រះករុណាគួរវាយប្រាំ ឬប្រាំមួយដង។ នោះព្រះករុណាពិតជាច្បាំងឈ្នះជនជាតិអារ៉ាម រហូតដល់
បំផ្លាញពួកគេឲ្យវិនាសសូន្យ។ ប៉ុន្តែ ឥឡូវនេះ ព្រះករុណាវាយពួកគេត្រឹមតែបីដងប៉ុណ្ណោះ»។
[20]បន្ទាប់មក លោកអេលីសេក៏ស្លាប់ទៅ ហើយគេបានបញ្ចុះសពលោក។ ពេលនោះជនជាតិម៉ូអាប់មួយក្រុមបានចាប់ផ្តើមទន្ទ្រានទឹកដីនៅដើមឆ្នាំ។
[21]នៅពេលដែលគេបញ្ចុះសពបុរសម្នាក់ ហើយពួកគេបានឃើញពួកម៉ូអាប់មួយក្រុម ដូច្នេះ ពួកគេក៏បោះសពនោះទៅក្នុងផ្នូររបស់លោកអេលីសេ។
នៅពេលដែលសពរបស់បុរសនោះបានប៉ះជាមួយឆ្អឹងរបស់លោកអេលីសេ លោកក៏រស់ឡើងវិញ ហើយក្រោកឈរឡើង។
[22]ព្រះបាទហាសែលជាស្តេចស្រុកអារ៉ាមតែងតែជិះជាន់សង្កត់សង្កិនជនជាតិអ៊ីស្រាអែលនៅថ្ងៃអាយុរបស់ព្រះបាទយ៉ូអាហាស។[23]ប៉ុន្តែ
ព្រះអម្ចាស់បានផ្តល់ព្រះគុណដល់អ៊ីស្រាអែល ហើយផ្តល់ព្រះទ័យមេត្តាដល់ពួកគេ ហើយព្រួយបារម្ភណ៍ពីពួកគេ ដោយសារតែសម្ពន្ធមេត្រីជាមួយលោកអាប្រាហាំ

generated on Wed Sep 10 16:16:32 2025

ជាមួយលោកអ៊ីសាក់ ហើយជាមួយលោកយ៉ាកុប។ ដូច្នេះ ព្រះអម្ចាស់មិនបានបំផ្លាញពួកគេ
ហើយព្រះអង្គនៅតែមិនបណ្តេញពួកគេចេញពីព្រះវត្តមានរបស់ព្រះអង្គឡើយ។[24]ព្រះបាទហាសែលជាស្តេចស្រុកអារ៉ាមសុគត
ហើយព្រះបាទបេនហាដាដជាបុត្ររបស់ព្រះអង្គក្លាយជាស្តេចជំនួសទ្រង់។[25]ព្រះបាទយ៉ូអាស ជាបុត្ររបស់ព្រះបាទយ៉ូអាហាសបានយកក្រុងពីព្រះបាទបេនហាដាដមកវិញ
គឺក្រុងដែលគេបានយកពីព្រះបាទយ៉ូអាហាសជាបិតារបស់ទ្រង់ដោយសង្គ្រាម។ ព្រះបាទយ៉ូអាសបានវាយប្រហារបីដង
ហើយស្តេចគ្រប់គ្រងក្រុងទាំងអស់របស់អ៊ីស្រាអែល។

---

2 Kings 13:1

នៅក្នុងឆ្នាំទីម្ភៃបីនៃព្រះបាទយ៉ូអាស ជាបុត្ររបស់ព្រះបាទអហាស៊ីយ៉ាស្តេចស្រុកយូដា

ឆ្នាំទីបីនៃស្តេចយ៉ូអាសជាកូនប្រុស របស់អហាស៊ីយ៉ាជាស្តេចស្រុកយូដា -

បន្ទាប់ពីស្តេចយ៉ូអាសសោយរាជ្យស្រុកយូដា អស់រយៈពេលជិត ២៣ ឆ្នាំ។

សោយរាជ្យលើស្រុកអ៊ីស្រាអែល នៅក្រុងសាម៉ារី

«គ្រប់គ្រងលើរាជាណាចក្រអ៊ីស្រាអែល ដែលមានទីតាំងនៅសាម៉ារី»

ស្តេចសោយរាជ្យបានដប់ប្រាំពីរឆ្នាំ

«ស្តេចយ៉ូហាសជាស្តេច អស់រយៈពេល ១៧ ឆ្នាំ»

ស្តេចបានប្រព្រឹត្តអំពើអាក្រក់ នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់

ត្រង់នេះ «នៅចំពោះព្រះភ័ក្ត្រ» សំដៅទៅលើការគិតរបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «គាត់បានធ្វើអ្វីដែលអាក្រក់ចំពោះព្រះជាម្ចាស់»

ដើរតាមមាគ៌ានៃអំពើបាបរបស់ព្រះបាទយេរ៉ូបោម

«បានធ្វើបាបដូចព្រះបាទយេរ៉ូបោមដែរ»

ព្រះបាទយេហូអាហាសមិនបានចាកចេញពីអំពើបាបទាំងអស់នេះឡើយ

នៅទីនេះការបញ្ឈប់អំពើបាប របស់គាត់ត្រូវបានគេនិយាយដូចជាគាត់
បានងាកចេញពីពួកគេ។ នេះក៏អាចត្រូវបានបញ្ជាក់ នៅក្នុងទម្រង់វិជ្ជមានផងដែរ។
ការបកប្រែផ្សេងទៀត «
យេហូអាហាសមិនបានឈប់ធ្វើបាបតាមស្តេចយេរ៉ូបោមទេ» ឬ «
ស្តេចយេហូអាហាស នៅតែបន្តធ្វើបាបដូចព្រះបាទយេរ៉ូបោមដដែល»

2 Kings 13:3

កំហឹងរបស់ព្រះអម្ចាស់បានបញ្ឆេះប្រឆាំងនឹងអ៊ីស្រាអែល

ព្រះអម្ចាស់មានព្រះហឫទ័យខ្ញាល់ នឹងជនជាតិអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ពេលនោះព្រះអម្ចាស់ទ្រង់ព្រះពិរោធ នឹងជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង»

ប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ព្រះបាទហាសែលស្តេចស្រុកស៊ីរី
និងទីក្នុងកណ្តាប់ដៃរបស់ព្រះបាទបេនហាដាដជាបុត្ររបស់ព្រះបាទហាសែលជាបន្តបន្ទាប់

ត្រង់នេះ « ពួកគេ» សំដៅទៅលើអ៊ីស្រាអែលហើយ « ដៃ»
សំដៅទៅលើអំណាចគ្រប់គ្រងពួកគេ។ ការបកប្រែផ្សេងទៀត
«បានអនុញ្ញាតឱ្យហាសែលជាស្តេច នៃស្រុកស៊ីរីនិងបេនហាដាដ
ជាកូនប្រុសរបស់គាត់បានយកឈ្នះ លើជនជាតិអ៊ីស្រាអែលម្តងហើយម្តងទៀត
នៅក្នុងសមរភូមិ»

ទូលអង្វរទៅព្រះអម្ចាស់

«បានអធិស្ឋានដល់ព្រះអម្ចាស់»

ព្រះអម្ចាស់បានស្តាប់ការទូលអង្្វររបស់ស្តេច ដោយសារព្រះអង្គឃើញស្តេចស្រុកស៊ីរីជិះជាន់
សង្កត់សង្កិនពួកគេ

ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយត្រូវបានប្រើម្តងទៀត សម្រាប់ការសង្កត់ធ្ងន់។
នាមអរូបី « ការជិះជាន់» មានន័យថាដូចគ្នានឹង «
ស្តេចអារ៉ាមកំពុងតែគាបសង្កត់ពួកគេ» ។ ការបកប្រែផ្សេងទៀត «
ទ្រង់បានឃើញថាស្តេចនៃស្រុកស៊ីរីកំពុងគាបសង្កត់លើអ៊ីស្រាអែលយ៉ាងខ្លាំង»

អ្នកសង្គ្រោះ

«នរណាម្នាក់ជួយសង្គ្រោះពួកគេ»

ពួកគេក៏បានរួចខ្លួនពីពួកអារ៉ាម

ត្រង់នេះ « ដៃ» សំដៅទៅលើអំណាចគ្រប់គ្រងពួកគេ។ ការបកប្រែផ្សេងទៀត
«ទ្រង់បានអនុញ្ញាតឱ្យ ពួកគេរួចផុតពីអំណាចរបស់អារ៉ាម»

2 Kings 13:6

ពួកគេមិនបានបោះបង់ចោលអំពើបាបរបស់ព្រះបាទយេរ៉ូបោម

ឈប់ធ្វើបាបត្រូវបានគេនិយាយថា ហាក់ដូចជាពួកគេបានចាកចេញពីអំពើបាប។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «
អ៊ីស្រាអែលមិនបានឈប់ធ្វើបាប ដូចស្តេចយេរ៉ូបោមបានធ្វើទេ» ឬ «
អ៊ីស្រាអែលបានបន្តប្រព្រឹត្តអំពើបាប ដូចស្តេចយេរ៉ូបោមបានប្រព្រឹត្តដែរ»

ផ្ទះព្រះបាទយេរ៉ូបោម

«គ្រួសាររបស់ស្តេចយេរ៉ូបោម»

បានបំផ្លាញពួកគេ

«បានវាយឈ្នះកងទ័ពរបស់ស្តេចយ៉ូហាស»

ធ្វើឲ្យពួកគេទៅដូចជាធូលីដី

កងទ័ពស៊ីរីបានវាយឈ្នះកងទ័ពអ៊ីស្រាអែល។
អ្វីៗដែលនៅសល់ប្រៀបបានទៅនឹងអង្កាម។ ការបកប្រែផ្សេងទៀត «
បានកម្ទេចពួកគេ ដូចកម្ទេចអង្កាមនៅរដូវច្រូតកាត់»

2 Kings 13:8

តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬអី?

សំណួរនេះត្រូវបានប្រើដើម្បីរំលឹកអ្នកអានថាសកម្មភាពរបស់យ៉ូអាហាស
ត្រូវបានកត់ត្រានៅក្នុងសៀវភៅមួយទៀត។ សូមមើលនៅក្នុងជំពូក ១:១៧ ។
ការបកប្រែផ្សេងទៀត «ពួកគេត្រូវបានសរសេរនៅក្នុងសៀវភៅព្រឹត្តិការណ៍
នៃស្តេចអ៊ីស្រាអែល» ។ (សូមមើល ផ្figs-rquestion)

ផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់

នេះជាវិធីគួរសមក្នុងការនិយាយថា គាត់បានស្លាប់ទៅហើយ។

2 Kings 13:10

នៅក្នុងឆ្នាំទីសាបសិបប្រាំពីរនៃរាជ្យរបស់ព្រះបាទយ៉ូអាសស្តេចស្រុកយូដា

ឆ្នាំទីប្រាំពីរនៃព្រះបាទយ៉ូអាសជាស្តេចស្រុកយូដា -
បន្ទាប់ពីស្តេចយ៉ូអាសគ្រប់គ្រងស្រុកយូដាអស់រយៈពេលជិត ៣៧ ឆ្នាំ (សូមមើល
ប្translate-numbers)

ព្រះបាទយ៉ូអាហាស បានឡើងសោយរាជ្យលើស្រុកអ៊ីស្រាអែល នៅក្រុងសាម៉ារី

«ស្តេចយ៉ូអាសជាកូនរបស់
ស្តេចយ៉ូអាហាសបានចាប់ផ្តើមគ្រប់គ្រងស្រុកអ៊ីស្រាអែល នៅស្រុកសាម៉ារី»

ព្រះបាទយ៉ូអាស

នេះជាស្តេចស្រុកអ៊ីស្រាអែលដែលជាបុត្ររបស់ព្រះបាទយ៉ូអាហាស។

ស្តេចបានប្រព្រឹត្តអាក្រក់ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់

នៅទីនេះ «ការមើលឃើញ» តំណាងឱ្យគំនិតឬការវិនិច្ឆ័យរបស់ព្រះ។
ការបកប្រែផ្សេងទៀត « ស្តេចបានធ្វើអ្វីៗដែលព្រះអម្ចាស់ ចាត់ទុកថាអាក្រក់»

ស្តេចមិនបានងាកចេញពីអំពើបាបរបស់ព្រះបាទយេរ៉ូបោម

ដើម្បីបញ្ឈប់ការធ្វើបាបត្រូវបានគេនិយាយដូចជាគាត់បានទុកចោលអំពើបាបនោះ។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត «
យ៉ូអាសមិនឈប់ប្រព្រឹត្តអំពើបាបតាមស្តេចយេរ៉ូបោម» ឬ «
យ៉ូអាសបន្តប្រព្រឹត្តអំពើបាបដដែលដូចស្តេចយេរ៉ូបោមដែរ»

ដែលធ្វើឲ្យអ៊ីស្រាអែលធ្លាក់ក្នុងអំពើបាប

«ស្តេចយេរ៉ូបោមបានធ្វើ ឲ្យ អ៊ីស្រាអែលធ្វើបាប»

ប៉ុន្តែ ស្តេចបានដើរតាមមាគ៌ានោះ

អំពើបាបត្រូវបានគេនិយាយថា ដូចជាគាត់កំពុងដើរនៅលើផ្លូវបាប។
ការបកប្រែផ្សេងទៀត « ប៉ុន្តែស្តេចយ៉ូអាសបន្តធ្វើអំពើបាបដដែល»

2 Kings 13:12

និងភាពល្បីល្បាញរបស់ទ្រង់ ដែលទ្រង់បានធ្វើប្រឆាំងនឹងព្រះបាទអម៉ាស៊ីយ៉ា ជាស្តេចស្រុកយូដា

«និងអំណាចដែលកងទ័ពរបស់ទ្រង់
បានបង្ហាញនៅពេលពួកគេច្បាំងនឹងកងទ័ពអម៉ាស៊ីយ៉ា ស្តេចស្រុកយូដា»

តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬអី?

សំណួរនេះត្រូវបានប្រើដើម្បីរម្លឹក អ្នកអានថាសកម្មភាពរបស់យ៉ូហាស
ត្រូវបានកត់ត្រានៅក្នុងសៀវភៅមួយទៀត។ សូមមើលនៅក្នុងជំពូក ១:១៧ ។
ការបកប្រែផ្សេងទៀត «ពួកគេត្រូវបានសរសេរនៅក្នុងសៀវភៅព្រឹត្តិការណ៍
នៃស្តេចអ៊ីស្រាអែល» ។

ព្រះបាទយ៉ូអាសបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់

នេះជាវិធីគួរសមក្នុងការនិយាយថាយ៉ូអាសបានសុគត។

ព្រះបាទយេរ៉ូបោមសោយរាជ្យបន្តពីទ្រង់

នៅទីនេះ «អង្គុយលើបល្ល័ង្ករបស់ព្រះអង្គ» សំដៅទៅលើការគ្រប់គ្រងជាស្តេច។
ការបកប្រែផ្សេងទៀត «ស្តេចយេរ៉ូបោមបានឡើងសោយរាជ្យបន្ទាប់ពីគាត់» ឬ
«ស្តេចយេរ៉ូបោមបានចាប់ផ្តើមគ្រប់គ្រងបន្ទាប់ពីគាត់»

2 Kings 13:14

generated on Wed Sep 10 16:16:32 2025

បានយំស្រណោះលោក
«យំព្រោះលោកអេលីសេឈឺ»
លោកឪពុកអើយ លោកឪពុកអើយ
លោកអេលីសេមិនមែនជាឪពុករបស់ស្តេចទេ។
ស្តេចយ៉ូអាសបានប្រើពាក្យនេះជាសញ្ញានៃការគោរពលោក។
រទេះចម្បាំង និងទ័ពសេះរបស់អ៊ីស្រាអែលបានកំពុងយកលោកទៅឆ្ងាយហើយ
នេះគឺសំដៅទៅលោកអេលីយ៉ាដែលនឹងឡើងទៅស្ថានសួគ៌នៅជំពូក ២:១១ ។
យ៉ូអាសប្រើឃ្លានេះដើម្បីនិយាយថាលោកអេលីសេនឹងត្រូវស្លាប់។
ការបកប្រែផ្សេងទៀត « រទេះអ៊ីស្រាអែល
និងទ័ពសេះកំពុងនាំអ្នកឡើងទៅលើមេឃ»
ទ័ពសេះ
នេះសំដៅទៅលើបុរសដែលបើករទេះសេះ។ នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែផ្សេងទៀត « អ្នកបើករទេះសេះ»
2 Kings 13:17
ព័ត៌មានទូទៅ
លោកអេលីសេបន្តនិយាយ ជាមួយស្តេចយ៉ូអាសជាស្តេចស្រុកអ៊ីស្រាអែល។
សូមបើកបង្អួចនៅទិសខាងកើត
«បើកបង្អួចដែលបែរមុខ ទៅទិសខាងកើត» ឬ «បើកបង្អួចនោះ
ឆ្ពោះទៅទិសខាងកើត«
ដូច្នេះ ស្តេចក៏បើកបង្អួចនោះ
ចាប់តាំងពីរឿងនេះកើតឡើង បន្ទាប់ពីស្តេចយ៉ូអាសយកធ្នូ
និងព្រួញគាត់ប្រហែលជាមានអ្នកបម្រើម្នាក់បើកបង្អួច។ ការបកប្រែផ្សេងទៀត
«ដូច្នេះអ្នកបម្រើម្នាក់បានបើកវា»
ស្តេចក៏បាញ់
«ស្តេចយ៉ូអាសបាញ់ព្រួញ»
នេះជាព្រួញជ័យជម្នះរបស់ព្រះអម្ចាស់ ជាព្រួញជ័យជម្នះលើជនជាតិអារ៉ាម
ទំនាក់ទំនងរវាងព្រួញនិងជ័យជម្នះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត « ព្រួញនេះជាសញ្ញាសម្គាល់មួយ
ពីព្រះអម្ចាស់ថាព្រះអង្គនឹងប្រទានជ័យជម្នះ ដល់អ្នកលើអារ៉ាម» ឬ
«ព្រួញនេះជានិមិត្តរូបនៃជ័យជម្នះ
ដែលព្រះអម្ចាស់នឹងប្រទានមកអ្នកនៅលើទឹកដីស៊ីរី»
អាផែក
នេះជាទីក្រុងមួយនៅស្រុកអ៊ីស្រាអែល។
អ្នកបម្រើរបស់ព្រះអម្ចាស់ខឹងនឹងស្តេចយ៉ាងខ្លាំង
«ប៉ុន្តែលោកអេលីសេ ខឹងនឹងស្តេចយ៉ូអាស»
រហូតដល់បំផ្លាញពួកគេឲ្យវិនាសសូន្យ
«រហូតដល់អ្នកបានបំផ្លាញវាទាំងស្រុង» ឬ
«រហូតដល់ពួកគេត្រូវបានលុបចោលទាំងស្រុង»
2 Kings 13:20
ពេលនោះ
«នៅពេលនោះ»
នៅដើមឆ្នាំ
«រៀងរាល់ឆ្នាំក្នុងរដូវផ្ការីក»
នៅពេលដែលគេបញ្ចុះសពបុរសម្នាក់
«ដូចជាជនជាតិអ៊ីស្រាអែលខ្លះ បានបញ្ចុះសពបុរសម្នាក់»
ពួកគេបានឃើញពួកម៉ូអាប់មួយក្រុម
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា ពួកគេខ្លាចជនជាតិម៉ូអាប់។
ការបកប្រែផ្សេងទៀត « ពួកគេបានឃើញក្រុមអ្នកវាយឆ្មក់
របស់ជនជាតិម៉ូអាប់ចូលមកជិតពួកគេ ហើយពួកគេខ្លាច»
ផ្នូររបស់លោកអេលីសេ
«ផ្នូរដែលលោកអេលីសេត្រូវបានគេបញ្ចុះ»
នៅពេលដែលសពរបស់បុរសនោះបានប៉ះជាមួយឆ្អឹងរបស់លោកអេលីសេ
នៅទីនេះ «បុរស» សំដៅទៅលើសាកសពរបស់គាត់។
នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត «
នៅពេលដែលសាកសពរបស់បុរសដែលបានស្លាប់ប៉ះឆ្អឹងរបស់លោកអេលីសេ»
លោកក៏រស់ឡើងវិញ ហើយក្រោកឈរឡើង
«មនុស្សស្លាប់បានរស់ឡើងវិញ ហើយក្រោកឈរឡើង»
2 Kings 13:22
ប៉ុន្តែ ព្រះអម្ចាស់បានផ្តល់ព្រះគុណដល់អ៊ីស្រាអែល ហើយផ្តល់ព្រះទ័យមេត្តាដល់ពួកគេ
ហើយព្រួយបារម្ភណ៍ពីពួកគេ
វាអាចមានប្រយោជន៍ក្នុងការបែងចែកប្រយោគនេះទៅជាផ្នែកខ្លី។
ការបកប្រែផ្សេងទៀត « ប៉ុន្តែព្រះអម្ចាស់មានព្រះហឫទ័យអាណិតអាសូរ
ចំពោះជនជាតិអ៊ីស្រាអែលព្រះអង្គបានជួយពួកគេ»
ព្រះអម្ចាស់មិនបានបំផ្លាញពួកគេ
សម្ពន្ធមេត្រីរបស់ព្រះអម្ចាស់គឺជាហេតុផលដែលទ្រង់មិនបានបំផ្លាញអ៊ីស្រាអែល។
នេះអាចត្រូវបានធ្វើឱ្យច្បាស់។ ការបកប្រែផ្សេងទៀត
«នេះជាមូលហេតុដែលព្រះអម្ចាស់មិនបានបំផ្លាញពួកគេ» ឬ
«ដោយសារសម្ពន្ធមេត្រីរបស់ទ្រង់ នោះព្រះអម្ចាស់មិនបានបំផ្លាញពួកគេឡើយ»
មិនបណ្តេញពួកគេចេញពីព្រះវត្តមានរបស់ព្រះអង្គឡើយ
ការបដិសេធរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយដូចជាទ្រង់បានដេញជនជាតិអ៊ីស្រាអែល
ចេញពីកន្លែងដែលទ្រង់គង់នៅ។ ការបកប្រែផ្សេងទៀត
«មិនបានបដិសេធពួកគេទេ»

14

[1]នៅក្នុងឆ្នាំទីពីរនៃរាជ្យរបស់ព្រះបាទយ៉ូអាសបុត្រព្រះបាទយ៉ូអាហាស ជាស្តេចស្រុកអ៊ីស្រាអែល ព្រះបាទអម៉ាស៊ីយ៉ា ជាបុត្ររបស់ព្រះបាទយ៉ូអាស ឡើងសោយរាជ្យលើ
ស្រុកយូដា។[2]ស្តេចមានព្រះជន្មម្ភៃប្រាំឆ្នាំនៅពេលទ្រង់ចាប់ផ្តើមសោយរាជ្យ ស្តេចសោយរាជ្យបានម្ភៃប្រាំបួនឆ្នាំនៅក្រុងយេរូសាឡឹម។ មាតាមាននាមថា យ៉ូអាដាន ជាអ្នក
ក្រុងយេរូសាឡឹម។[3]ស្តេចបានប្រព្រឹត្តត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ ប៉ុន្តែមិនដូចព្រះបាទដាវីឌ ជាបិតារបស់ទ្រង់ឡើយ។
ស្តេចបានប្រព្រឹត្តអ្វីគ្រប់យ៉ាងដែលព្រះបាទយ៉ូអាស ជាបិតាបានធ្វើ។
[4]ប៉ុន្តែ នៅតាមទីខ្ពស់ៗស្តេចមិនបានបំផ្លាញចោលឡើយ។ ប្រជាជននៅតែថ្វាយតង្វាយ និងដុតគ្រឿងក្រអូបនៅតាមទីខ្ពស់ៗទាំងនោះ។[5]ក្រោយពីឡើងគ្រងរាជ្យ និងពង្រឹង
អំណាចហើយ ទ្រង់ប្រហារជីវិតពួកមេទ័ពដែលបានធ្វើគុតព្រះបាទយ៉ូអាសជាបិតារបស់ទ្រង់។
[6]ប៉ុន្តែ ស្តេចមិនបានសម្លាប់កូនប្រុសៗរបស់ឃាតករឡើយ ផ្ទុយទៅវិញ ស្តេចបានប្រព្រឹត្តស្របតាមអ្វីដែលមានសរសេរនៅក្នុងគម្ពីរវិន័យរបស់លោកម៉ូសេ
ដូចដែលព្រះអម្ចាស់បានបង្គាប់ថា៖ «ឪពុកមិនត្រូវស្លាប់ដោយសារកំហុសរបស់កូនពួកគេឡើយ
ហើយកូនក៏មិនត្រូវស្លាប់ដោយសារកំហុសរបស់ឪពុកម្តាយរបស់ពួកគេឡើយ។ ផ្ទុយទៅវិញ គ្រប់គ្នាត្រូវស្លាប់ដោយសារអំពើបាបរបស់ខ្លួនផ្ទាល់»។
[7]ស្តេចបានសម្លាប់ទាហានអេដុមមួយម៉ឺននាក់នៅក្នុងជ្រោះអំបិល ហើយនៅពេលច្បាំងគ្នានោះ ស្តេចដណ្តើមយកបានក្រុងសេឡា ដែលដាក់ឈ្មោះថាក្រុងយុគធាលវិញ
ហើយត្រូវបានហៅឈ្មោះនេះរហូតដល់សព្វថ្ងៃ។
[8]បន្ទាប់មក ព្រះបាទអម៉ាស៊ីយ៉ាបានផ្ញើសារទៅព្រះបាទយ៉ូអាសជាបុត្ររបស់ព្រះបាទយ៉ូអាហាស និងជាចៅរបស់ព្រះបាទយេហ៊ូវថា៖ «ចូរចេញមក យើងប្រយុទ្ធតទល់
គ្នានៅក្នុងសមរភូមិ»។[9]ប៉ុន្តែ ព្រះបាទយ៉ូអាសជាស្តេចអ៊ីស្រាអែលបាផ្ញើសារត្រឡប់មកព្រះបាទអម៉ាស៊ីយ៉ា ជាស្តេចស្រុកយូដាវិញថា៖ «គុម្ពបន្លាដែលដុះនៅភ្នំលីបង់ ចាត់
គេឲ្យទៅប្រាប់ដើមតាត្រៅនៅភ្នំលីបង់ថា៖ «ចូរលើកកូនស្រីរបស់អ្នក ឲ្យមកធ្វើជាប្រពន្ធរបស់កូនប្រុសយើង ប៉ុន្តែ មានសត្វព្រៃដើរកាត់តាមនោះ ហើយជាន់គុម្ពបន្លា
នោះទៅ។[10]អ្នកបានវាយប្រហារអេដុម ហើយចិត្តរបស់អ្នកលើកអ្នកឡើង។ សូមឲ្យមានមោទនភាពចំពោះជ័យជម្នះរបស់អ្នក ប៉ុន្តែ ចូរស្នាក់នៅផ្ទះរបស់អ្នក
តើហេតុអ្វីបានជាអ្នកធ្វើឲ្យខ្លួនឯងមានបញ្ហា ហើយបរាជ័យដូច្នេះ ទាំងអ្នក និងយូដានៅជាមួយអ្នក?»
[11]ប៉ុន្តែ ព្រះបាទអម៉ាស៊ីយ៉ាមិនព្រមស្តាប់ឡើយ។ ដូច្នេះ ព្រះបាទយ៉ូអាសជាស្តេចស្រុកអ៊ីស្រាអែលបានមកវាយប្រហារ ហើយស្តេច
និងព្រះបាទអម៉ាស៊ីយ៉ាស្តេចស្រុកយូដាតទល់គ្នានៅក្រុងបេតសេមែស ជាក្រុងរបស់យូដា។[12]អ៊ីស្រាអែលបានវាយយូដា ហើយគ្រប់គ្នារត់គេចទៅផ្ទះរាងខ្លួន។
[13]ព្រះបាទយ៉ូអាសស្តេចអ៊ីស្រាអែល ចាប់ព្រះបាទអម៉ាស៊ីយ៉ា ជាបុត្ររបស់ព្រះបាទយ៉ូអាស និងជាចៅរបស់ព្រះបាទអហាស៊ីយ៉ា ធ្វើជាឈ្លើយ នៅបេតសេមែស។
ស្តេចបានមកក្រុងយេរូសាឡឹម ហើយបានទំលាយជញ្ជាំងក្រុងយេរូសាឡឹមចាប់តាំងពីទ្វារអេប្រាអ៊ីមរហូតដល់ទ្វារនៅកាច់ជ្រុង ដែលមានប្រវែងបួនរយហត្ថ។

generated on Wed Sep 10 16:16:32 2025

[14]ស្តេចបានយកមាស និងប្រាក់ និងរបស់របរទាំងអស់ដែលមាននៅក្នុងដំណាក់របស់ព្រះអម្ចាស់ និងរបស់មានតម្លៃក្នុងវាំងស្តេច ជាមួយនឹងឈ្លើយសឹកផងដែរ
ហើយត្រឡប់ទៅក្រុងសាម៉ារីវិញ។
[15]រឿងរ៉ាវផ្សេងៗទៀតទាក់ទងនឹងព្រះបាទយ៉ូអាស អ្វីៗដែលស្តេចបានធ្វើ អំណាចរបស់ទ្រង់ និងពីការប្រយុទ្ធរបស់ទ្រង់ជាមួយព្រះបាទអម៉ាស៊ីយ៉ាជាស្តេចស្រុកយូដា
តើមិនមានកត់ត្រាទុកក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬ?[16]បន្ទាប់មក ព្រះបាទយ៉ូអាសបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
ហើយគេបញ្ចុះសព្វទ្រង់នៅក្រុងសាម៉ារីជាមួយស្តេចអ៊ីស្រាអែល ហើយព្រះបាទយេរ៉ូបោម ជាបុត្ររបស់ព្រះអង្គឡើងស្នងរាជ្យបន្ត។
[17]ព្រះបាទអម៉ាស៊ីយ៉ាជាបុត្ររបស់ព្រះបាទយ៉ូអាសស្តេចស្រុកយូដា
រស់បានដប់ប្រាំឆ្នាំទៀតក្រោយព្រះបាទយ៉ូអាសបុត្ររបស់ព្រះបាទយ៉ូអាហាសស្តេចស្រុកអ៊ីស្រាអែលសុគត។[18]រឿងរ៉ាវផ្សេងទៀតទាក់ទងនឹងព្រះបាទអម៉ាស៊ីយ៉ា
តើមិនមានកត់ត្រាទុកក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដាទេឬ?[19]មានគេឃុបឃិតគ្នាប្រឆាំងនឹងព្រះបាទអម៉ាស៊ីយ៉ានៅក្រុងយេរូសាឡឹម
ហើយទ្រង់ក៏គេចខ្លួនទៅក្រុងឡាគីស។ ស្តេចគេចខ្លួនទៅក្រុងឡាគីស ប៉ុន្តែគេក៏បញ្ជូនមនុស្សតាមទ្រង់ទៅក្រុងឡាគីស ហើយសម្លាប់ទ្រង់នៅទីនោះ។
[20]ពួកគេបាននាំទ្រង់ត្រឡប់មកវិញដោយដាក់លើសេះ ហើយគេបានបញ្ចុះសពទ្រង់នៅក្នុងក្រុងព្រះបាទដាវីឌ។[21]ប្រជាជននៅស្រុកយូដាទាំងអស់លើកព្រះបាទអសារ
ដែលមានព្រះជន្មដប់ប្រាំមួយឆ្នាំ ឲ្យឡើងគ្រងរាជ្យតពីព្រះបាទអម៉ាស៊ីយ៉ាជាបិតាទ្រង់។[22]ព្រះបាទអសារានេះឯងដែលបានសង់ក្រុងអេឡាតឡើងវិញ ហើយស្តារក្រុងយូដា
ក្រោយពីព្រះបាទអម៉ាស៊ីយ៉ាបានសុគតជាមួយបុព្វបុរសរបស់ទ្រង់។
[23]នៅក្នុងឆ្នាំទីដប់ប្រាំនៃរាជ្យរបស់ព្រះបាទអម៉ាស៊ីយ៉ាជាបុត្ររបស់ព្រះបាទយ៉ូអាសស្តេចស្រុកយូដា ព្រះបាទយេរ៉ូបោម ជាបុត្ររបស់ព្រះបាទយ៉ូអាសស្តេចស្រុកអ៊ីស្រាអែល
ឡើងសោយរាជ្យ នៅក្រុងសាម៉ារី ទ្រង់សោយរាជ្យបានសែសិបមួយឆ្នាំ។[24]ស្តេចប្រព្រឹត្តអាក្រក់នៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់។
ស្តេចមិនបានងាកចេញពីអំពើបាបរបស់ព្រះបាទយេរ៉ូបោមជាកូនរបស់នេបាតឡើយ ដែលធ្វើឲ្យអ៊ីស្រាអែលធ្លាក់ក្នុងអំពើបាប។
[25]ស្តេចបានកំណត់ព្រំប្រទល់របស់អ៊ីស្រាអែលឡើងវិញចាប់ពីលេបូហាម៉ាត់ រហូតដល់សមុទ្រអារ៉ាបា ស្របតាមការបង្គាប់របស់ព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែល
ដែលទ្រង់មានព្រះបន្ទូលតាមរយៈព្យាការីយ៉ូណាសជាកូនរបស់លោកអមីថាយ ជាអ្នកស្រុកកាថ-ហេភើរជាអ្នកបម្រើរបស់ព្រះអង្គ។
[26]ដោយសារព្រះអម្ចាស់បានឃើញពីទុក្ខវេទនារបស់អ៊ីស្រាអែល ដែលល្វីងជូរចត់សម្រាប់គ្រប់គ្នា ទាំងអ្នកងារ និងអ្នកជា
ហើយគ្មានអ្នកណាជួយសង្គ្រោះអ៊ីស្រាអែលសោះ។[27]ដូច្នេះព្រះអម្ចាស់បានមានបន្ទូលថាព្រះអង្គពុំសព្វព្រះហឫទ័យលុបឈ្មោះអ៊ីស្រាអែលឲ្យបាត់ពីស្ថានសួគ៌ទេ
ផ្ទុយទៅវិញ ព្រះអង្គនឹងសង្គ្រោះពួកគេដោយដៃរបស់ព្រះបាទយេរ៉ូបោមបុត្ររបស់ព្រះបាទយ៉ូអាស។
[28]រឿងរ៉ាវផ្សេងទៀតទាក់ទងនឹងព្រះបាទយេរ៉ូបោម អ្វីដែលស្តេចបានធ្វើ អំណាចរបស់ទ្រង់ របៀបដែលព្រះអង្គធ្វើសង្គ្រាមដណ្តើមបានក្រុងដាម៉ាស និងក្រុងហាម៉ាត់ពី
កណ្តាប់ដៃរបស់ជនជាតិយូដាសម្រាប់អ៊ីស្រាអែល តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកអ៊ីស្រាអែលទេឬ?
[29]ព្រះបាទយេរ៉ូបោមផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់ ជាមួយស្តេចស្រុកអ៊ីស្រាអែល ហើយព្រះបាទសាការី ជាបុត្រ ឡើងស្នងរាជ្យបន្ត។

---

2 Kings 14:1

នៅក្នុងឆ្នាំទីពីរនៃរាជ្យរបស់ព្រះបាទយ៉ូអាសបុត្រព្រះបាទយ៉ូអាហាស ជាស្តេចស្រុកអ៊ីស្រាអែល

«សូមឱ្យសត្រូវរបស់ពួកគេកម្ចាត់ពួកគេ និងកាន់កាប់ទឹកដីរបស់ពួកគេ»
2 Kings 21:16
លើសពីនេះទៅទៀត
«ផងដែរ» ឬ «បន្ថែម»
ព្រះបាទម៉ាណេបានបង្ហូរឈាមមនុស្សឥតទោសជាច្រើន
ពាក្យថា «បង្ហូរឈាមគ្មានទោសពៃរ៍» គឺជាការសម្លាប់មនុស្សដោយហិង្សា។
វាជាការល្អបំផុតក្នុងការបកប្រែរឿងនេះដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតបានជួយ
ការបកប្រែផ្សេងទៀត «ម៉ាណាសេបានបញ្ជាទាហានរបស់គាត់
សម្លាប់ប្រជាជនស្លូតត្រង់ជាច្រើននាក់»
រហូតធ្វើឲ្យមានសាកសពនៅពេញក្រុងយេរូសាឡឹមពីជ្រុងម្ខាង ដល់ជ្រុងម្ខាង
នេះបញ្ជាក់ពីចំនួនមនុស្សយ៉ាងច្រើនដែលម៉ាណាសេ
បានសម្លាប់នៅពាសពេញក្រុងយេរូសាឡឹម។ នាមអរូបី «ការស្លាប់»
អាចត្រូវបានគេនិយាយថាជា «មនុស្សស្លាប់» ។ ការបកប្រែផ្សេងទៀត
«មានមនុស្សស្លាប់យ៉ាងច្រើននៅពាសពេញក្រុងយេរូសាឡឹម»
អ្វីដែលអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
គុណនាមបន្ទាប់បន្សំ «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លាដែលទាក់ទង
«អ្វីដែល ... អាក្រក។» ត្រង់នេះព្រះនេត្ររបស់ព្រះអម្ចាស់
សំដៅទៅលើរបៀបដែលទ្រង់វិនិច្ឆ័យឬសម្រេចចិត្តលើតម្លៃអ្វីមួយ។
បកប្រែវាដូចដែលអ្នកបានធ្វើនៅក្នុងជំពូក ៣: ១ ។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអម្ចាស់បាននិយាយថាអាក្រក់» ឬ
«អ្វីដែលព្រះអម្ចាស់ចាត់ទុកជាអំពើអាក្រក់»
តើមិនមានកត់ត្រាទុក...ស្តេចយូដាទេឬ?
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្មហើយសន្មតថាចម្លើយគឺវិជ្ជមាន។
សំណួរគឺវោហារស័ព្ទហើយត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។ សូមមើលនៅជំពូក
៨:២២ ។ ការបកប្រែផ្សេងទៀត «ពួកគេត្រូវបានសរសេរ ... យូដា» ។ ឬ
«អ្នកអាចរកឃើញពួកគេ ... យូដា» ។
បានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
នេះជាវិធីគួរសមក្នុងការនិយាយថាសុគត «បានសុគតដូចដូនតារបស់ទ្រង់ដែរ»
សួនរបស់លោកអ៊ូសា
អត្ថន័យអាចគឺ ១) «សួនច្បារដែលធ្លាប់ជាកម្មសិទ្ធិរបស់បុរសម្នាក់ឈ្មោះអ៊ូសាឬ ២)
«សួនអ៊ូសា។
ព្រះបាទអាំម៉ូន
នេះជាឈ្មោះបុរសម្នាក់
2 Kings 21:19
ព្រះបាទអាំម៉ូន...លោកហារូស
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
មស៊ូលេម៉ែត
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
យ៉ុតបា
នេះគឺជាឈ្មោះនៃទីក្រុងមួយ។
អំពើអាក្រក់ នៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
គុណនាមបន្ទាប់បន្សំ «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លាដែលទាក់ទង
«អ្វីដែល ... អាក្រក់» ។ ត្រង់នេះព្រះនេត្ររបស់ព្រះអម្ចាស់
សំដៅទៅលើរបៀបដែលទ្រង់វិនិច្ឆ័យឬសម្រេចចិត្តលើតម្លៃអ្វីមួយ។
បកប្រែវាដូចដែលអ្នកបានធ្វើនៅក្នុងជំពូក ៣: ១ ។ ការបកប្រែផ្សេងទៀត
«អ្វីដែលព្រះអម្ចាស់បាននិយាយថាអាក្រក់» ឬ
«អ្វីដែលព្រះអម្ចាស់ចាត់ទុកជាអំពើអាក្រក់»
2 Kings 21:21
បានដើរតាមមាគា៌គ្រប់យ៉ាងដែលបិតារបស់ស្តេចធ្លាប់ធ្វើ
«បានដើរតាមគ្រប់វិធីដែលឪពុករបស់គាត់បានដើរ» ។
របៀបដែលមនុស្សរស់នៅត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងដើរលើផ្លូវមួយ។
ការបកប្រែផ្សេងទៀត «រស់នៅតាមរបៀបដែលឪពុករបស់គាត់បានរស់នៅ»
ស្តេចបានបោះបង់ចោលព្រះអម្ចាស់
«គាត់បានចាកចេញពីព្រះអម្ចាស់» ឬ
«គាត់មិនបានយកចិត្តទុកដាក់ចំពោះព្រះអម្ចាស់ទៀតទេ»
[illegible]។
«បានធ្វើផែនការ និងធ្វើការរួមគ្នាដើម្បីធ្វើបាបទ្រង់»
2 Kings 21:24
ប្រជាជននៅក្នុងទឹកដី
នេះគឺជាការធ្វើឱ្យមានលក្ខណៈទូទៅ។ ការបកប្រែផ្សេងទៀត «
ប្រជាជនមួយចំនួននៅស្រុកយូដា»
បានបះបោរប្រឆាំង
«បានធ្វើផែនការនិងធ្វើការរួមគ្នាដើម្បីធ្វើបាប»។ «ដូចនៅក្នុងជំពូក ២១:២១ ។
តើមិនមានកត់ត្រានៅក្នុង...ស្តេចស្រុកយ៉ូដាទេឬ?
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្មហើយសន្មតថាចម្លើយគឺវិជ្ជមាន។
សំណួរគឺវោហាស័ព្ទហើយត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
បកប្រែវាដូចដែលអ្នកបានធ្វើនៅជំពូក ៨:២២ ។ ការបកប្រែផ្សេងទៀត
«ពួកគេត្រូវបានសរសេរ ... យូដា» ។ ឬ «អ្នកអាចរកឃើញពួកគេ ... យូដា» ។
សួនរបស់លោកអ៊ូសា
អត្ថន័យដែលមានគឺ ១) «សួនច្បារដែលធ្លាប់ជាកម្មសិទ្ធិរបស់បុរសម្នាក់ឈ្មោះ
អ៊ូសាឬ ២) «សួនអ៊ូសា។ បកប្រែវាដូចអ្វីដែលអ្នកបានធ្វើក្នុងជំពូក ២១:១៦ ។

---

22 [1]ព្រះបាទយ៉ូសៀសមានព្រះជន្មប្រាំបីឆ្នាំនៅពេលដែលស្តេចចាប់ផ្តើមឡើងសោយរាជ្យ ស្តេចសោយរាជ្យបានសាបសិបមួយឆ្នាំនៅក្រុងយេរូសាឡឹម។ មាតារបស់ស្តេច
មាននាមថា យេឌីដា (កូនរបស់លោកអដាយ៉ា ជាអ្នកស្រុកបូសកាថ)។[2]ស្តេចបានប្រព្រឹត្តត្រឹមត្រូវនៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់។
ស្តេចបានដើរតាមមាគា៌របស់ព្រះបាទដាវីឌជាបុព្វបុរសរបស់ទ្រង់ ហើយស្តេចមិនបានងាកឆ្វេង ឬងាកស្តាំឡើយ។
[3]នៅក្នុងឆ្នាំទីដប់ប្រាំបីនៃរាជ្យរបស់ព្រះបាទយ៉ូសៀស ទ្រង់ចាត់លោកសាផាន ដែលត្រូវជាកូនរបស់លោកអសាលា និងជាចៅរបស់លោកមស៊ូឡាមជាស្មៀនហ្លួង ឲ្យទៅ
ព្រះដំណាក់របស់ព្រះអម្ចាស់ដោយទូលថា៖[4]«សូមទៅជួបលោកមហាបូជាចារ្យហ៊ីលគីយ៉ា ហើយប្រាប់លោកឲ្យរាប់ប្រាក់ដែលគេនាំមកក្នុងដំណាក់របស់ព្រះអម្ចាស់
គឺប្រាក់ដែលអ្នកយាមបានប្រមូលពីប្រជាជន។[5]សូមឲ្យប្រាក់ទាំងនោះដល់ដៃរបស់ជាងដែលមានបន្ទុកជួសជុលព្រះវិហាររបស់ព្រះអម្ចាស់ ហើយប្រគល់ឲ្យជាងទាំងនោះ
គឺអ្នកដែលនៅក្នុងដំណាក់របស់ព្រះអម្ចាស់ ដើម្បីឲ្យពួកគេជួសជុលកន្លែងខូចខាតនៅក្នុងព្រះវិហារ។
[6]សូមឲ្យគេប្រគល់ប្រាក់ដល់ជាងឈើ អ្នកសាងសង់ និងជាងកំបោរ និងត្រូវទិញឈើ និងថ្មកាត់ដើម្បីជួសជុលព្រះវិហារ»។[7]ប៉ុន្តែ
គេមិនត្រូវការអ្នករាប់សម្រាប់លុយដែលផ្តល់ទៅពួកគេទេ ព្រោះពួកគេចាត់ចែងប្រាក់ទាំងនោះដោយស្មោះត្រង់។

generated on Wed Sep 10 16:16:32 2025

[8]លោកមហាបូជាចារ្យហ៊ីលគីយ៉ាបាននិយាយទៅលោកលោកសាផាន ជាស្មៀនហ្លួងថា៖ «ខ្ញុំបានរកឃើញសៀវភៅក្រិតវិន័យនៅក្នុងដំណាក់របស់ព្រះអម្ចាស់»។ ដូច្នេះ
លោកមហាបូជាចារ្យហ៊ីលគីយ៉ាបានឲ្យសៀវភៅនោះទៅលោកសាផាន ហើយលោកបានអានវា។[9]លោកសាផានបានចេញទៅ ហើយយកសៀវភៅនោះទៅថ្វាយស្តេច
ដោយរាយការណ៍ទៅស្តេចថា៖ «អ្នកបម្រើរបស់ព្រះអង្គបានចំណាយប្រាក់ទាំងអស់ដែលមាននៅក្នុងព្រះដំណាក់
ហើយពួកគេបានប្រគល់ទៅដល់ដៃរបស់អ្នកធ្វើការដែលចាត់ចែងការមើលថែព្រះដំណាក់របស់ព្រះអម្ចាស់»។[10]បន្ទាប់មក លោកសាផានជាស្មៀនហ្លួងបានទូលស្តេចថា៖
«លោកមហាបូជាចារ្យហ៊ីលគីយ៉ាបានប្រគល់សៀវភៅនេះមកទូលបង្គំ»។ បន្ទាប់មក លោកសាផានបានអានថ្វាយស្តេច។
[11]នៅពេលដែលស្តេចបានឮព្រះបន្ទូលនៃក្រឹត្យវិន័យ ស្តេចបានហែកព្រះភូសារបស់ទ្រង់។[12]ស្តេចបានបង្គាប់ទៅលោកមហាបូជាចារ្យហ៊ីលគីយ៉ា លោកអហ៊ីកាម ជាកូន
របស់លោកសាផាន លោកអ័កបោរ ជាកូនរបស់លោកមីកាយ៉ា លោកសាផាន ជាស្មៀនហ្លួង និងលោកអសាយ៉ាជាអ្នកបម្រើរបស់ព្រះអង្គផ្ទាល់ថា៖
[13]«ចូរទៅទូលសួរព្រះអម្ចាស់សម្រាប់យើង និងសម្រាប់ប្រជាជនយូដាទាំងមូល ព្រោះយើងបានរកឃើញព្រះបន្ទូលនៅក្នុងសៀវភៅនេះ។
ព្រោះកំហឹងដ៏ខ្លាំងរបស់ព្រះអម្ចាស់បានប្រឆាំងនឹងយើង ដោយសារតែបុព្វបុរសរបស់យើងមិនបានស្តាប់បង្គាប់ព្រះបន្ទូលនៅក្នុងសៀវភៅនេះ
ដូចអ្វីដែលត្រូវតែធ្វើដែលបានសរសេរទាក់ទងនឹងយើងរាល់គ្នា»។
[14]ដូច្នេះ លោកបូជាចារ្យហ៊ីលគីយ៉ា លោកអហ៊ីកាម លោកអ័កបោរ លោកសាផាន និងលោកអសាយ៉ា នាំគ្នាទៅជួបព្យាការីនីហ៊ូលដា ជាភរិយារបស់លោកសាលូម ជាកូន
របស់លោកទីកវ៉ា ជាចៅរបស់លោកហារហាស ជាអ្នកថែរក្សាសំលៀកបំពាក់របស់បូជាចារ្យ (នាងរស់នៅក្រុងយេរូសាឡឹមនៅតំបន់ទីពីរ)
ហើយពួកគេបាននិយាយជាមួយនាង។[15]នាងបានឆ្លើយទៅពួកគេថា៖ «នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលមានបន្ទូលថា៖
«ប្រាប់អ្នកដែលបានបញ្ជូនអ្នកទាំងនេះដើម្បីមកជួបយើងថា៖[16]«នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់៖ «ឃើញទេ យើងបាននាំមហន្តរាយមកកន្លែងនេះ និងប្រជាជននេះ
ស្របតាមអ្វីដែលបានកត់ត្រាទុកនៅក្នុងសៀវភៅដែលស្តេចទើបតែបានអាន។
[17]ដោយសារពួកគេបានបោះបង់ចោលយើង ហើយបានដុតគ្រឿងក្រអូបទៅព្រះដ៏ទៃ ដូច្នេះ គេនឹងធ្វើឲ្យយើងខឹងជាមួយនឹងអំពើទាំងអស់ដែលពួកគេបានប្រព្រឹត្ត ដូច្នេះ
កំហឹងរបស់យើងនឹងមកប្រឆាំងនឹងកន្លែងនេះ ហើយយើងមិនអត់ឱនឲ្យឡើយ»។[18]ប៉ុន្តែ ស្តេចស្រុកយូដា ដែលបានបញ្ជូនអ្នកមកស្វែងរកព្រះហឫទ័យរបស់ព្រះអម្ចាស់
នេះជាអ្វីដែលអ្នកត្រូវនិយាយទៅកាន់ស្តេច៖ «ព្រះអម្ចាស់ជាព្រះរបស់អ៊ីស្រាអែលមានបន្ទូលថា៖ «អំពីព្រះបន្ទូលដែលអ្នកបានឮ[19]ដោយសារតែដួងចិត្តរបស់អ្នកបើកចំហ
ហើយដោយសារតែអ្នកបានបន្ទាបខ្លួននៅមុខព្រះអម្ចាស់ នៅពេលដែលអ្នកបានឮអ្វីដែលយើងនិយាយប្រឆាំងនឹងកន្លែងនេះ និងប្រជាជននេះ ថាពួកគេនឹងត្រូវអន្តរាយ
និងត្រូវបណ្តាសារ ហើយដោយសារតែអ្នកបានហែកសំលៀកបំពាក់របស់អ្នក និងយំនៅចំពោះយើង នោះយើងក៏ស្តាប់អ្នកដែរ នេះជាការប្រកាសរបស់ព្រះអម្ចាស់។
[20]ឃើញទេ យើងនឹងប្រមូលអ្នកឲ្យទៅជួបជុំបុព្វបុរសរបស់អ្នក ហើយអ្នក និងទៅក្នុងផ្នូរដោយសុខសាន្ត។
ភ្នែករបស់អ្នកនឹងមិនបានឃើញមហន្តរាយដែលយើងនឹងនាំមកកន្លែងនេះទេ»។ ដូច្នេះ ពួកគេក៏បាននាំសារនេះទៅទូលស្តេច។

---

2 Kings 22:1

សាបសិបមួយឆ្នាំ

មួយឆ្នាំ - «៣១ ឆ្នាំ»

យេឌីដា

នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។

លោកអដាយ៉ា

នេះជាឈ្មោះបុរសម្នាក់។

អ្នកស្រុកបូសកាថ

នេះជាឈ្មោះក្រុងមួយនៅស្រុកយូដា។

ស្តេចបានប្រព្រឹត្តត្រឹមត្រូវនៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់

ត្រង់នេះ «ព្រះនេត្រ» តំណាងគំនិតរបស់ព្រះអម្ចាស់ឬអ្វីដែលទ្រង់បានគិត។ ការបកប្រែផ្សេងទៀត «គាត់បានធ្វើអ្វីដែលព្រះអម្ចាស់ចាត់ទុកថាត្រឹមត្រូវ» ឬ «គាត់បានធ្វើអ្វីដែលត្រឹមត្រូវតាមព្រះជាម្ចាស់»

ស្តេចបានដើរតាមមាគ៌ារបស់ព្រះបាទដាវីឌជាបុព្វបុរសរបស់ទ្រង់

យ៉ូសៀសមានឥរិយាបទដូចដាវីឌបានធ្វើគឺដូចជាគាត់ដើរលើផ្លូវឬផ្លូវដូចដាវីឌដែរ។ ការបកប្រែផ្សេងទៀត «គាត់បានរស់នៅតាមរបៀបដែលដូនតារបស់គាត់បានរស់នៅ» ឬ «គាត់បានធ្វើតាមគំរូរបស់ដាវីឌដែលជាបុព្វបុរសរបស់គាត់»

ស្តេចមិនបានងាកឆ្វេង ឬងាកស្តាំឡើយ

ការស្តាប់បង្គាប់ព្រះជាម្ចាស់ត្រូវបានគេនិយាយថាដូចជាមនុស្សម្នាក់ដើរនៅលើផ្លូវត្រូវ ហើយមិនងាកចេញពីការត្រូវ។ ការបកប្រែផ្សេងទៀត «គាត់មិនបានធ្វើអ្វីដែលធ្វើឲ្យព្រះអម្ចាស់មិនគាប់ព្រះហឫទ័យឡើយ» គាត់បានគោរពតាមក្រិត្យវិន័យរបស់ព្រះជាម្ចាស់ទាំងស្រុង»

2 Kings 22:3

នៅក្នុង

ប្រសិនបើភាសារបស់អ្នកមានវិធីដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿងសូមពិចារណាធ្វើដូចនោះនៅទីនេះ។

ឆ្នាំទីដប់ប្រាំបី

«ទីដប់ប្រាំបី» គឺជាទម្រង់ធម្មតានៃឆ្នាំ ១៨ ។ ការបកប្រែផ្សេងទៀត «ឆ្នាំទី ១៨»

លោកសាផាន...លោកអសាលា...លោកមស៊ូឡាម...ហ៊ីលគីយ៉ា

ទាំងអស់នេះគឺជាឈ្មោះមនុស្សប្រុស។

ដំណាក់របស់ព្រះអម្ចាស់...នៅក្នុងព្រះវិហារ

នៅទីនេះ «ដំណាក់របស់ព្រះជាម្ចាស់»និង «ព្រះវិហារ» មានន័យដូចគ្នា។

សូមទៅជួបលោកមហាបូជាចារ្យហ៊ីលគីយ៉ា

ឃ្លាថា «ឡើងទៅ»

ត្រូវបានប្រើព្រោះព្រះវិហាររបស់ព្រះអម្ចាស់ខ្ពស់ជាងកន្លែងស្តេចយ៉ូសៀស។

ការបកប្រែផ្សេងទៀត «ជួបលោកមហាបូជាចារ្យហ៊ីលគីយ៉ា»

ប្រាប់លោកឲ្យរាប់ប្រាក់ដែលគេនាំមកក្នុងដំណាក់របស់ព្រះអម្ចាស់

គឺប្រាក់ដែលអ្នកយាមបានប្រមូលពីប្រជាជន

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «អ្នកយាមព្រះវិហារដែលប្រមូលប្រាក់ពីប្រជាជន បាននាំចូលវិហាររបស់ព្រះអម្ចាស់»

សូមឲ្យប្រាក់ទាំងនោះដល់ដៃរបស់ជាង

នៅទីនេះ «ដៃ» តំណាងឱ្យកម្មករនិយោជិតទាំងមូល។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «ប្រាប់ហ៊ីលគីយ៉ាឱ្យលុយទៅកម្មករ»

2 Kings 22:6

ព័ត៌មានទូទៅ

សារពីស្តេចយ៉ូសៀសដល់ហ៊ីលគីយ៉ាដែលជាសម្តេចសង្ឃនៅតែបន្ត។

សូមឲ្យគេប្រគល់ប្រាក់ដល់...ដែលផ្តល់ទៅពួកគេ...ព្រោះពួកគេចាត់ចែងប្រាក់ទាំងនោះ

ត្រង់នេះ «ពួកគេ» និង «គេ«

សំដៅទៅលើកម្មករដែលទទួលបន្ទុកក្នុងដំណាក់របស់ព្រះអម្ចាស់ក្នុងជំពូក ២២:៣ ។

ជាងឈើ អ្នកសាងសង់ និងជាងកំបោរ

ទាំងនេះគឺដូចគ្នានឹងអ្នកធ្វើការដែលស្ថិតនៅក្នុងដំណាក់របស់ព្រះអម្ចាស់ក្នុងជំពូក ២២:៣ ដែលមិនចាំបាច់ត្រូវបានពិពណ៌នាលម្អិតបន្ថែមទៀត។

ជាងឈើ

កម្មករដែលធ្វើការជាមួយឈើ

ជាងកំបោរ

កម្មករដែលសាងសង់ដោយថ្ម

គេមិនត្រូវការអ្នករាប់សម្រាប់លុយដែលផ្តល់ទៅពួកគេទេ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត «កម្មករដែលទទួលបន្ទុកមិនចាំបាច់រាយការណ៍អំពីរបៀបដែលពួកគេប្រើប្រាក់ដែលឆ្មាំព្រះវិហារបានផ្តល់ឱ្យពួកគេទេ»

ព្រោះពួកគេចាត់ចែងប្រាក់ទាំងនោះដោយស្មោះត្រង់

«ពីព្រោះពួកគេបានប្រើលុយ ដោយស្មោះត្រង់»

2 Kings 22:8

ហ៊ីលគីយ៉ា

នេះជាឈ្មោះបុរសម្នាក់។ សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅជំពូក ១៨:១៦ ។

សៀវភៅក្រិតវិន័យ

generated on Wed Sep 10 16:16:32 2025

ភាគច្រើនទំនងជាច្បាប់ទាំងនេះ
ត្រូវបានសរសេរនៅលើក្រាំងរមូរជាជាងនៅក្នុងសៀវភៅ។
ប្រគល់ទៅដល់ដៃរបស់អ្នកធ្វើការ
នៅទីនេះ «ដៃ» តំណាងឱ្យកម្មករនិយោជិកទាំងមូល។ ការបកប្រែផ្សេងទៀត
«ប្រគល់វាទៅឱ្យកម្មករ»
2 Kings 22:11
នៅពេលដែល
ប្រសិនបើភាសារបស់អ្នកមានវិធីដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿងសូមពិចារណាធ្វើដូច្នេះ។
បានឮព្រះបន្ទូលនៃក្រឹត្យវិន័យ
នៅទីនេះ «បន្ទូល» តំណាងឱ្យសារនៃច្បាប់។ ការបកប្រែផ្សេងទៀត
«បានឮច្បាប់ដែលត្រូវបានសរសេរនៅក្នុងសៀវភៅ» ឬ
«បានឮច្បាប់ដែលត្រូវបានសរសេរនៅក្នុងក្រាំងរមូរ»
ស្តេចបានហែកព្រះភូសារបស់ទ្រង់
នេះគឺជាសកម្មភាពនិមិត្តរូបដែលបង្ហាញពីភាពសោកសៅឬទុក្ខព្រួយយ៉ាងខ្លាំង។
លោកអហ៊ីកាម...លោកសាផាន ...លោកអ័កបោរ...លោកមីកាយ៉ា...លោកអសាយ៉ា
ទាំងអស់នេះគឺជាឈ្មោះរបស់មនុស្សប្រុស។
ទូលសួរព្រះអម្ចាស់
វាត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងជំពូក ២២:១៤
ថាបុរសទាំងនោះនឹងពិគ្រោះជាមួយព្រះអម្ចាស់ដោយទៅរកព្យាការីរបស់ព្រះអម្ចាស់
ដើម្បីសម្រេចតាមព្រះហឫទ័យរបស់ទ្រង់។
ទូលសួរ
ទៅរកនរណាម្នាក់ដើម្បីសុំយោបល់
បានរកឃើញព្រះបន្ទូលនៅក្នុងសៀវភៅនេះ
នៅទីនេះ «ព្រះបន្ទូល» តំណាងឱ្យច្បាប់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ច្បាប់នៅក្នុងសៀវភៅនេះដែលហ៊ីលគីយ៉ាបានរកឃើញ»
ព្រោះកំហឹងដ៏ខ្លាំងរបស់ព្រះអម្ចាស់បានប្រឆាំងនឹងយើង
កំហឹងរបស់ព្រះអម្ចាស់ត្រូវបានចែងដូចជាភ្លើងដែលកំពុងឆេះ។
ការបកប្រែផ្សេងទៀត «ត្បិតព្រះអម្ចាស់ទ្រង់ខ្ញាល់ នឹងយើងយ៉ាងខ្លាំង»
អ្វីដែលត្រូវតែធ្វើដែលបានសរសេរទាក់ទងនឹងយើងរាល់គ្នា
នេះសំដៅទៅលើច្បាប់ដែលត្រូវបានឱ្យទៅអ៊ីស្រាអែល។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«អ្វីទាំងអស់ដែលលោកម៉ូសេបានសរសេរ នៅក្នុងក្រឹត្យវិន័យដែលយើងគួរធ្វើ» ឬ
«ច្បាប់ទាំងអស់ដែលព្រះបានប្រទានតាមរយៈម៉ូសេ ដល់ប្រជាជនអ៊ីស្រាអែល»
2 Kings 22:14
ហ៊ូលដា
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
លោកសាលូម...លោកទីកវ៉ា...លោកហារហាស
ទាំងអស់នេះគឺជាឈ្មោះបុរសម្នាក់។
ជាអ្នកថែរក្សាសំលៀកបំពាក់របស់បូជាចារ្យ
អត្ថន័យដែលមានគឺ ១)
អ្នកដែលថែរក្សាសម្លៀកបំពាក់ដែលបូជាចារ្យស្លៀកនៅក្នុងព្រះវិហារ ២)
អ្នកដែលថែរក្សាសម្លៀកបំពាក់របស់ស្តេច។
នាងរស់នៅក្រុងយេរូសាឡឹមនៅតំបន់ទីពីរ
នៅទីនេះ «តំបន់ទីពីរ» សំដៅទៅលើផ្នែកថ្មីនៃទីក្រុង
ដែលត្រូវបានសាងសង់នៅប៉ែកខាងជើងនៃក្រុងយេរូសាឡិម។ ដូចគ្នានេះផងដែរ
«ទីពីរ» គឺជាទម្រង់ធម្មតានៃ២។ការបកប្រែផ្សេងទៀត
«នាងបានរស់នៅក្នុងក្រុងយេរូសាឡឹមនៅផ្នែកថ្មីនៃទីក្រុង» ឬ
«នាងបានរស់នៅក្នុងផ្នែកថ្មីនៃក្រុងយេរូសាឡិម»
អ្នកដែលបានបញ្ជូនអ្នកទាំងនេះដើម្បីមកជួបយើងថា
នៅទីនេះ «បុរស» សំដៅទៅលើស្តេចយ៉ូសៀស។
យើងបាននាំមហន្តរាយមកកន្លែងនេះ និងប្រជាជននេះ
ព្រះអម្ចាស់បានធ្វើអោយមានរឿងអាក្រក់កើតឡើងដូចជា «គ្រោះមហន្តរាយ»
គឺជាវត្ថុដែលទ្រង់អាចនាំយកទៅកន្លែងមួយ។ ការបកប្រែផ្សេងទៀត
«យើងនឹងធ្វើឱ្យមានរឿងគួរឱ្យភ័យខ្លាចកើតឡើងចំពោះកន្លែងនេះនិងអ្នកដែលរស់នៅទីនោះ»
កន្លែងនេះ
នេះសំដៅទៅលើទីក្រុងយេរូសាឡិមដែលតំណាងឱ្យទឹកដីយូដាទាំងមូល។
ការបកប្រែផ្សេងទៀត «ទៅក្រុងយេរូសាឡិម» ឬ «ទៅស្រុកយូដា»
2 Kings 22:15
ព័ត៌មានទូទៅ
សារដែលព្រះអម្ចាស់បានផ្ញើទៅស្តេចយ៉ូសៀសតាមរយៈហ៊ុលដា
ជាហោរានៅតែបន្ត។
កំហឹងរបស់យើងនឹងមកប្រឆាំងនឹងកន្លែងនេះ ហើយយើងមិនអត់ឱនឲ្យឡើយ
ព្រះជាម្ចាស់មានកំហឹងយ៉ាងខ្លាំងត្រូវបានគេនិយាយដូចជាកំហឹងរបស់ទ្រង់
គឺជាភ្លើងដែលត្រូវបានឆេះហើយមិនអាចពន្លត់បាន។ ការបកប្រែផ្សេងទៀត
«កំហឹងរបស់ខ្ញុំប្រឆាំងនឹងកន្លែងនេះ គឺដូចជាភ្លើងដែលមិនអាចពន្លត់បាន»
កន្លែងនេះ
ត្រង់នេះកន្លែងតំណាងអោយប្រជាជនដែលរស់នៅក្រុងយេរូសាឡិមនិងស្រុកយូដា។
ការបកប្រែផ្សេងទៀត «ប្រជាជនទាំងនេះ»
អំពីព្រះបន្ទូលដែលអ្នកបានឮ
នៅទីនេះ «ព្រះបន្ទូល» តំណាងឱ្យសារដែលហ៊ុលដាទើបតែនិយាយ។
ការបកប្រែផ្សេងទៀត «អំពីសារដែលអ្នកបានឮ»
ដោយសារតែដួងចិត្តរបស់អ្នកបើកចំហ
នៅទីនេះ «ចិត្ត» តំណាងឱ្យផ្នែកខាងក្នុងរបស់មនុស្ស។
ការសោកស្តាយត្រូវបានគេនិយាយហាក់ដូចជាចិត្តបើកចំហ។
ការបកប្រែផ្សេងទៀត «ដោយសារអ្នកអាណិត» ឬ «ដោយសារអ្នកបានប្រែចិត្ត»
ថាពួកគេនឹងត្រូវអន្តរាយ និងត្រូវបណ្តាសារ
នាមអរូបី «ការអន្តរាយ » និង «បណ្តាសា»
អាចត្រូវបានបញ្ជាក់ជាគុណនាមនិងកិរិយាសព្ទ។ ការបកប្រែផ្សេងទៀត
«ខ្ញុំនឹងដាក់បណ្តាសាពួកគេហើយធ្វើឱ្យទឹកដីក្លាយជាទីស្ងាត់ជ្រងំ»
ហែកសំលៀកបំពាក់របស់អ្នក
នេះគឺជាសកម្មភាពនិមិត្តរូប ដែលបង្ហាញពីភាពសោកសៅឬទុក្ខព្រួយយ៉ាងខ្លាំង។
នេះជាការប្រកាសរបស់ព្រះអម្ចាស់
នៅទីនេះព្រះអម្ចាស់និយាយអំពីខ្លួនទ្រង់នៅក្នុងមនុស្សទីបី។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីមួយ។ ការបកប្រែផ្សេងទៀត
«នេះគឺជាអ្វីដែលយើងប្រកាស»
2 Kings 22:20
ព័ត៌មានទូទៅ
នេះជាចុងបញ្ចប់នៃសារលិខិតរបស់ព្រះអម្ចាស់ដល់ព្រះចៅយ៉ូសៀសតាមរយៈព្យាការីហ៊ុលដា។
ឃើញទេ យើងនឹងប្រមូលអ្នកឲ្យទៅជួបជុំបុព្វបុរសរបស់អ្នក ហើយអ្នក
និងទៅក្នុងផ្នូរដោយសុខសាន្ត
សេចក្តីថ្លែងទាំងពីរមានន័យថាជាមូលដ្ឋានដូចគ្នា។
ពួកគេជាវិធីគួរសមក្នុងការនិយាយថាគាត់នឹងស្លាប់។ ការបកប្រែផ្សេងទៀត «ស្តាប់
យើងនឹងអនុញ្ញាតឱ្យអ្នកស្លាប់ដោយសន្តិវិធី»
ភ្នែករបស់អ្នកនឹងមិនបានឃើញ
នៅទីនេះ «ភ្នែក» តំណាងឱ្យមនុស្សទាំងមូល។ ហើយ «នឹងមិនឃើញ»
តំណាងឱ្យការមិនជួបប្រទះអ្វីមួយ។ ការបកប្រែផ្សេងទៀត
«ហើយអ្នកនឹងមិនជួបប្រទះ»
មហន្តរាយដែលយើងនឹងនាំមកកន្លែងនេះ
ព្រះអម្ចាស់បានធ្វើឱ្យមានរឿងអាក្រក់កើតឡើងដូចជា «គ្រោះមហន្តរាយ»
គឺជាគោលដៅដែលព្រះអម្ចាស់នឹងធ្វើ។ ការបកប្រែផ្សេងទៀត
«រឿងដ៏គួរឱ្យភ័យខ្លាច ដែលយើងនឹងបង្កឱ្យកើតឡើងនៅកន្លែងនេះ»

---

23 [1]ដូច្នេះ ស្តេចបានផ្ញើសារប្រមូលពួកចាស់ទុំរបស់សាសន៍យូដា និងយេរូសាឡឹមមកជួបទ្រង់។[2]បន្ទាប់មក ស្តេចបានឡើងទៅដំណាក់របស់ព្រះអម្ចាស់
ហើយប្រុសៗយូដាទាំងអស់ និងប្រជាជនក្រុងយេរូសាឡឹមទាំងអស់ក៏មកជាមួយទ្រង់ដែរ ទាំងពួកបូជាចារ្យ ពួកព្យាការីព្រមទាំងប្រជាជនទាំងអស់
ចាប់ពីតូចរហូតដល់ធំ។ បន្ទាប់មក ស្តេចបានអានគ្រប់ពាក្យដែលមាននៅក្នុងសៀវភៅសម្ពន្ធមេត្រីដែលបានរកឃើញនៅក្នុងដំណាក់របស់ព្រះអម្ចាស់។
[3]ស្តេចបានឈរក្បែរសសរ ហើយបានចងសម្ពន្ធមេត្រីនៅមុខព្រះអម្ចាស់ ថានឹងដើរតាមព្រះអម្ចាស់ និងរក្សាបញ្ញត្តរបស់ព្រះអង្គ បទបញ្ជារបស់ព្រះអង្គ
និងច្បាប់របស់ព្រះអង្គ ដោយអស់ពីចិត្ត ពីព្រលឹង ដើម្បីគោរពតាមព្រះបន្ទូលនៃសម្ពន្ធមេត្រីដែលមានសរសេរនៅក្នុងសៀវភៅនោះ។ ដូច្នេះ
ប្រជាជនទាំងអស់យល់ព្រមក្នុងការធ្វើតាមសម្ពន្ធមេត្រីនេះ។

generated on Wed Sep 10 16:16:32 2025

[4]ស្តេចបានបង្គាប់ដល់លោកមហាបូជាចារ្យហ៊ីលគីយ៉ា ពួកបូជាចារ្យនៅក្រោមលោក និងអ្នកយាមទ្វារទាំងអស់ឲ្យយកភាជន៍ដែលធ្វើសម្រាប់ព្រះបាល និងព្រះអាសេរ៉ា
និងសម្រាប់ផ្កាយទាំងប៉ុន្មាននៅលើមេឃចេញពីព្រះវិហារបស់ព្រះអម្ចាស់។ ស្តេចបានដុតរបស់ទាំងអស់នោះនៅវាលឯជ្រោះក្រេដុន
ហើយបានយកផេះរបស់វាទៅបេតអែល។[5]ស្តេចបានកំចាត់ពួកបូជាចារ្យរបស់ព្រះក្លែងក្លាយ
ដែលស្តេចស្រុកយូដាមុនៗបានជ្រើសរើសសម្រាប់ដុតគ្រឿងក្រអូបនៅតាមទីទួលខ្ពស់ៗនៅក្នុងក្រុងទាំងឡាយនៃស្រុកយូដា និងនៅកន្លែងជុំវិញក្រុងយេរូសាឡឹម
គឺអស់អ្នកដែលដុតគ្រឿងក្រអូបទៅព្រះបាល ទៅព្រះអាទិត្រ និងទៅព្រះច័ន្ទ ទៅភពទាំងឡាយ និងទៅកាន់ផ្កាយទាំងឡាយនៅលើមេឃ។
[6]ស្តេចបានយកបង្គោលរបស់ព្រះអាសេរ៉ាចេញពីវិហារបស់ព្រះអម្ចាស់ ចេញក្រៅយេរូសាឡឹម ទៅជ្រោះក្រេដុន ហើយដុតវានៅទីនោះ។ ស្តេចបានកម្ទេចវាក្លាយជាធូលី
ហើយបាចធូលីនោះទីក្នុងផ្នូររបស់មនុស្សធម្មតា។[7]ស្តេចបានបំផ្លាញបន្ទប់របស់ពួកពេស្យាចារ្យបែបសាសនាដែលមាននៅក្នុងព្រះវិហារបស់ព្រះអម្ចាស់
នៅកន្លែងដែលស្ត្រីៗធ្វើសំលៀកបំពាក់សម្រាប់ព្រះអាសេរ៉ា។
[8]ព្រះបាទយ៉ូសៀសបាននាំពួកបូជាចារ្យទាំងអស់ចេញពីក្រុងនៃស្រុកយូដា ហើយបានបំផ្លាញទីខ្ពស់ៗដែលជាកន្លែងដែលពួកបូជាចារ្យបានដុតគ្រឿងក្រអូប ចាប់ពីក្រុង
កេបារហូតដល់បៀរសេបា។ ស្តេចបានបំផ្លាញទីទួលនៅមាត់ទ្វារចូលទៅទ្វារលោកយ៉ូស្វេ (ជាអភិបាលក្រុង) នៅខាងឆ្វេងនៃទ្វារក្រុង។
[9]ទោះបីជាពួកបូជាចារ្យទាំងអស់នោះមិនត្រូវបានអនុញ្ញាតឲ្យបម្រើនៅអាសនារបស់ព្រះអម្ចាស់នៅក្រុងយេរូសាឡឹមក៏ដោយ
ក៏ពួកគេបរិភោគនំប៉័ងពីក្នុងចំណោមបងប្អូនរបស់ពួកគេដែរ។
[10]ព្រះបាទយ៉ូសៀសបានបំផ្លាញកន្លែងធ្វើបូជាយញ្ញនៅតូផេត ក្នុងជ្រោះបេនហ៊ិនណម ដូច្នេះ គ្មាននរណាម្នាក់អាចដុតកូនប្រុស
កូនស្រីរបស់ខ្លួនដើម្បីធ្វើយញ្ញបូជាថ្វាយព្រះម៉ូឡុកបានឡើយ។[11]ស្តេចបានយករូបសេះដែលស្តេចស្រុកយូដាបានថ្វាយទៅព្រះអាទិត្យចេញ។
សេះទាំងនោះនៅត្រង់ច្រកចូលទៅព្រះវិហារបស់ព្រះអម្ចាស់ នៅជិតបន្ទប់ របស់លោកនេថាន-មេឡេក គឺនៅក្នុងក្រឡាបន្ទំ។ ស្តេចក៏បានដុតរទេះរបស់ព្រះអាទិត្យចោល
ដែរ។
[12]ព្រះបាទយ៉ូសៀសជាស្តេចបានបំផ្លាញអាសនាដែលនៅលើដំបូលបន្ទប់ខាងលើរបស់ព្រះបាទអហាស់ ដែលស្តេចស្រុកយូដាបានធ្វើ
ហើយនឹងអាសនាដែលស្តេចម៉ាណាសេបានសង់នៅក្នុងទីលានទាំងពីរនៃព្រះវិហារបស់ព្រះអម្ចាស់។ ព្រះបាទយ៉ូសៀសបានកម្ទេចរបស់ទាំងនោះជាបំណែក
ហើយបានបោះចោលទៅក្នុងជ្រោះក្រេដុន។[13]ស្តេចបានបំផ្លាញទីខ្ពស់នៅខាងកើតក្រុងយេរូសាឡឹម
ខាងត្បូងភ្នំពុករលួយដែលស្តេចសាឡូម៉ូនជាស្តេចស្រុកអ៊ីស្រាអែលបានសង់កន្លែងសក្ការៈទាំងនោះថ្វាយព្រះអាសថារ៉ូត ជាព្រះគួរស្អប់ខ្ពើមនៃជនជាតិស៊ីដូន ព្រះកេម៉ូស
ជាព្រះគួរស្អប់ខ្ពើមនៃជនជាតិម៉ូអាប់ ព្រះមីលកូម ជាព្រះគួរស្អប់ខ្ពើមនៃជនជាតិអាំម៉ូន។[14]ស្តេចបានកម្ទេចសសរថ្មទៅជាបំណែក ហើយបានកាត់បង្គោលរបស់ព្រះអាសេរ៉ា
ហើយស្តេចបានដាក់ឆ្អឹងរបស់មនុស្សជំនួសវិញ។
[15]ព្រះបាទយ៉ូសៀសក៏បានបំផ្លាញអាសនាដែលនៅបេតអែល និងទីទួលខ្ពស់ដែលព្រះបាទយេរ៉ូបោមកូនរបស់នេបាតបានសង់ទៅជាបំណែកដែរ
(គឺម្នាក់ដែលនាំអ៊ីស្រាអែលឲ្យធ្លាក់ក្នុងអំពើបាប)។ ស្តេចក៏បានដុតកម្ទេចអាសនា និងទីទួលខ្ពស់ ហើយកំទេចវាឲ្យទៅជាធូលី។
ស្តេចក៏បានដុតបង្គោលរបស់ព្រះអាសេរ៉ាដែរ។[16]នៅពេលដែលស្តេចយ៉ូសៀសមើលទៅតំបន់នោះ ស្តេចបានកត់សម្គាល់ផ្នូរដែលនៅផ្នែកខាងភ្នំ។
ស្តេចបានបញ្ជូនគេទៅយកឆ្អឹងពីផ្នូរនោះមក បន្ទាប់មក ស្តេចបានដុតវានៅលើអាសនា។ នេះស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលអ្នកបម្រើរបស់ព្រះអង្គបានថ្លែង
គឺគេបានថ្លែងការទាំងនេះតាំងពីមុនមក។
[17]បន្ទាប់មក ស្តេចបានមានរាជឱង្ការថា៖ «តើផ្នូរដែលយើងបានឃើញនោះជាអ្វី»? អ្នកក្រុងនោះបានទូលទ្រង់ថា៖
«នេះជាផ្នូររបស់អ្នកមប្រើរបស់ព្រះអម្ចាស់ដែលមកពីស្រុកយូដា ហើយបាននិយាយពាក្យទាំងនេះ គឺដូចអ្វីដែលព្រះករុណាទើបតែធ្វើប្រឆាំងនឹងអាសនានៅបេតអែល»។
[18]ដូច្នេះ ព្រះបាទយ៉ូសៀសនិយាយថា៖ «ចូរទុកទីនោះចុះ។ កុំឲ្យនរណាម្នាក់យកឆ្អឹងរបស់គាត់ចេញឡើយ»។ ដូច្នេះ គេក៏ទុកឆ្អឹងរបស់គាត់នៅទីនោះ
ជាមួយឆ្អឹងរបស់លោកហោរាដែលមកពីស្រុកសាម៉ារី។
[19]បន្ទាប់មក ព្រះបាទយ៉ូសៀសបានបំផ្លាញផ្ទះដែលនៅទីខ្ពស់ៗនៅក្នុងក្រុងសាម៉ារី ដែលស្តេចស្រុកអ៊ីស្រាអែលបានសង់ ដែលបានធ្វើឲ្យព្រះអម្ចាស់ព្រះពិរោធ។
ព្រះអង្គបានធ្វើដូចដែលទ្រង់បានធ្វើនៅបេតអែលដែរ។[20]ស្តេចបានប្រហារបូជាចារ្យទាំងអស់នៅកន្លែងទួលខ្ពស់ៗនៅលើអាសនា
ហើយស្តេចបានដុតឆ្អឹងរបស់មនុស្សនៅទីនោះ។ បន្ទាប់មក ស្តេចត្រឡប់មកក្រុងយេរូសាឡឹមវិញ។
[21]បន្ទាប់មក ស្តេចបានបង្គាប់ដល់ប្រជាជនទាំងអស់ថា៖ «ចូររក្សាបុណ្យចម្លងរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នក ដូចដែលបានកត់ត្រាទុកនៅក្នុងសៀវភៅនៃសម្ពន្ធមេត្រី»។
[22]ដូច្នេះ ការប្រារព្ធពិធីបុណ្យចម្លងមិនដែលធ្វើធំដូច្នេះទេ ចាប់ពីថ្ងៃនៃពួកហៅហ្វាយដែលគ្រប់គ្រងលើអ៊ីស្រាអែល រហូតដល់សម័យស្តេចស្រុកយូដា និងស្រុកអ៊ីស្រាអែល។
[23]ប៉ុន្តែ នៅក្នុងឆ្នាំទីដប់ប្រាំបីនៃរាជ្យរបស់ព្រះបាទយ៉ូសៀសគេបានប្រារព្ធបុណ្យចម្លងនេះនៅក្រុងយេរូសាឡឹម។
[24]ព្រះបាទយ៉ូសៀសក៏បានលុបបំបាត់អ្នកដែលនិយាយជាមួយមនុស្សស្លាប់ ឬក៏ជាមួយវិញ្ញាណដែរ។ ស្តេចក៏បានលុបបំបាត់រូបចម្លាក់ រូបព្រះក្លែងក្លាយ
និងគ្រប់ទាំងរបស់គួរស្អប់ខ្ពើមដែលមាននៅក្នុងទឹកដីស្រុកយូដា និងក្រុងយេរូសាឡឹម
ដើម្បីឲ្យស្របតាមព្រះបន្ទូលនៃក្រឹត្យវិន័យដែលបានកត់ត្រានៅក្នុងសៀវភៅដែលលោកបូជាចារ្យហ៊ីលគីយ៉ាបានរកឃើញនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។
[25]នៅមុនព្រះបាទយ៉ូសៀសគ្មានស្តេចណាដូចទ្រង់ឡើយ ដែលត្រឡប់ទៅឯព្រះអម្ចាស់វិញដោយអស់ពីចិត្ត ពីព្រលឹង
និងអស់ពីកម្លាំងដែលបានធ្វើតាមក្រឹត្យវិន័យរបស់លោកម៉ូសេ។ ហើយនៅក្រោយទ្រង់ ក៏គ្មានស្តេចណាដូចព្រះបាទយ៉ូសៀសទេ។
[26]ទោះជាយ៉ាណាក៏ដោយ ព្រះអម្ចាស់មិនបានបោះបង់កំហឹងដ៏ខ្លាំងរបស់ព្រះអង្គប្រឆាំងនឹងអ្នកស្រុកយូដាឡើយ
គឺអំពើបាបដែលស្តេចម៉ាណាសេបានថ្វាយបង្គំព្រះរបស់សាសន៍ដទៃ ដែលធ្វើឲ្យព្រះអម្ចាស់ព្រះពិរោធ។[27]ដូច្នេះ ព្រះអម្ចាស់មានបន្ទូលថា៖
«យើងនឹងដេញយូដាចេញពីភ្នែករបស់យើង ដូចដែលយើងបានដេញអ៊ីស្រាអែលដែរ ហើយយើងនឹងបោះបង់ចោលក្រុងដែលយើងបានជ្រើសរើស គឺយេរូសាឡឹម
និងដំណាក់ដែលយើងបាននិយាយថា៖ «នាមរបស់យើងនឹងនៅទីនោះ»។
[28]រឿងរ៉ាវទាក់ទងនឹងព្រះបាទយ៉ូសៀស និងអ្វីៗដែលស្តេចបានធ្វើ តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដាទេឬអី?
នៅពេលនោះ[29]ស្តេចផារ៉ោននេកោ ជាស្តេចស្រុកអេស៊ីប បានចេញទៅវាយប្រឆាំងនឹងស្តេចស្រុកអាសស៊ើរត្រង់ទន្លេអ៊ីប្រាត។
ព្រះបាទយ៉ូសៀសបានចេញទៅជួបស្តេចនេកោនៅក្នុងសមរភូមិ ហើយស្តេចនេកោសម្លាប់ទ្រង់នៅមេគីដោ។
[30]អ្នកបម្រើរបស់ព្រះបាទយ៉ូសៀសបានដឹកសពរបស់ទ្រង់នៅលើរទេះពីមេគីដោ ទៅយេរូសាឡឹម ហើយបានបញ្ចុះសពទ្រង់នៅក្នុងផ្នូររបស់លោកផ្ទាល់។ បន្ទាប់មក
ប្រជាជននៅក្នុងទឹកដីនោះនាំព្រះបាទយ៉ូអាហាស ជាបុត្ររបស់ព្រះបាទយ៉ូសៀស ដើម្បីចាក់ប្រេងអភិសេកធ្វើជាស្តេចបន្តពីបិតាទ្រង់។
[31]ព្រះបាទយ៉ូអាហាសមានព្រះជន្មម្ភៃបីឆ្នាំនៅពេលទ្រង់ចាប់ផ្តើមសោយរាជ្យ ហើយស្តេចសោយរាជ្យបានបីខែនៅក្រុងយេរូសាឡឹម។ មាតារបស់ស្តេចមាននាមថា
ហាមូថាល ជាកូនរបស់លោកយេរេមី ជាអ្នកស្រុកលិបណា។[32]ព្រះបាទយ៉ូអាហាសបានប្រព្រឹត្តអាក្រក់ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
ដូចអ្វីដែលបុព្វបុរសរបស់ទ្រង់បានធ្វើដែរ។[33]ស្តេចផារ៉ោន នេកោបានដាក់ច្រវាក់ទ្រង់នៅឯនៅក្រុងរីបឡា ក្នុងស្រុកហាម៉ាត់ ដូច្នេះ
ស្តេចមិនអាចសោយរាជ្យនៅក្រុងយេរូសាឡឹមបានទៀតទេ។ បន្ទាប់មក ព្រះបាទនេកោបានរកឃើញប្រាក់មួយរយដួង និងមាសមួយដួងនៅស្រុកយូដា។
[34]ស្តេចផារ៉ោននេកោបានលើកព្រះបាទអេលាគីម ជាបុត្ររបស់ព្រះបាទយ៉ូសៀស ឲ្យស្នងរាជ្យរបស់បិតាទ្រង់ ហើយដូរនាមថា យេហូយ៉ាគីមវិញ។ ប៉ុន្តែ ព្រះចៅផារ៉ោននាំ
យកព្រះបាទយ៉ូអាហាស់ទៅជាឈ្លើយនៅស្រុកអេស៊ីប ហើយព្រះបាទយ៉ូអាហាស់បានសុគតនៅទីនោះ។[35]ព្រះបាទយេហូយ៉ាគីមបានថ្វាយប្រាក់
និងមាសដល់ស្តេចផារ៉ោន ដើម្បីបំពេញតម្រូវការរបស់ស្តេចផារ៉ោន ព្រះបាទយេហូយ៉ាគីមបានប្រមូលពន្ធដី ហើយបង្ខំឲ្យមនុស្សដែលរស់នៅលើទឹកដីនោះបង់ប្រាក់
និងមាសតាមទ្រព្យរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[36]ព្រះបាទយេហូយ៉ាគីមមានព្រះជន្មម្ភៃប្រាំឆ្នាំនៅពេលដែលទ្រង់ឡើងគ្រងរាជ្យ ហើយស្តេចសោយរាជ្យបានដប់មួយឆ្នាំនៅក្រុងយេរូសាឡិម។ មាតារបស់ស្តេចមាននាមថា
សេប៊ូដា ជាកូនរបស់លោកពេដាយ៉ា ជាអ្នកស្រុករូម៉ាល។[37]ព្រះបាទយេហូយ៉ាគីមប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
ដូចបុព្វបុរសរបស់ទ្រង់បានធ្វើដែរ។

---

2 Kings 23:1
ប្រុសៗយូដាទាំងអស់ និងប្រជាជនក្រុងយេរូសាឡឹមទាំងអស់
នេះគឺជាការធ្វើឱ្យមានលក្ខណៈទូទៅ។ ការបកប្រែផ្សេងទៀត
«មនុស្សជាច្រើនផ្សេងទៀត»
ចាប់ពីតូចរហូតដល់ធំ
ការរួមបញ្ចូលគ្នានេះរួមមានមនុស្សគ្រប់គ្នាដែលនៅចន្លោះពី។ ការបកប្រែផ្សេងទៀត
«ពីតូចបំផុតទៅសំខាន់បំផុត»
ស្តេចបានអានគ្រប់ពាក្យដែលមាននៅ
«បន្ទាប់មកព្រះរាជាអានឱ្យខ្លាំងៗ ដើម្បីឱ្យពួកគេអាចឮ"
បានរកឃើញ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលហ៊ីលគីយ៉ាបានរកឃើញ»
2 Kings 23:3
ដើរតាមព្រះអម្ចាស់
របៀបដែលមនុស្សរស់នៅត្រូវបានគេនិយាយដូចជាមនុស្សនោះកំពុងដើរនៅលើផ្លូវហើយ។
«ដើរតាម»
នរណាម្នាក់គឺជាពាក្យសំដីសម្រាប់ធ្វើអ្វីដែលមនុស្សម្នាក់ទៀតធ្វើឬចង់អោយអ្នកដទៃធ្វើ។
ការបកប្រែផ្សេងទៀត «រស់នៅដោយគោរពតាមព្រះអម្ចាស់» (សូមមើល and
បញ្ញត្តរបស់ព្រះអង្គ បទបញ្ជារបស់ព្រះអង្គ និងច្បាប់របស់ព្រះអង្គ
ពាក្យទាំងនេះចែករំលែកអត្ថន័យស្រដៀងគ្នា។
ពួកគេរួមគ្នានិយាយអំពីអ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបញ្ជាមកក្នុងក្រឹត្យវិន័យ។
ដោយអស់ពីចិត្ត ពីព្រលឹង
«ដោយអស់ពីដួងចិត្តរបស់គាត់» មានន័យថា «ទាំងស្រុង» និង
«ដោយអស់ពីព្រលឹងរបស់គាត់» មានន័យថា «ទាំងអស់របស់គាត់» ។
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ការបកប្រែផ្សេងទៀត
«ជាមួយរបស់គាត់ទាំងអស់» ឬ «ជាមួយថាមពលទាំងអស់របស់គាត់»
ដែលមានសសេរនៅក្នុងសៀវភៅនោះ
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលពួកគេបានសរសេរនៅក្នុងសៀវភៅនេះ» ឬ «សៀវភៅនេះមាន»
ធ្វើតាមសម្ពន្ធមេត្រីនេះ
នេះមានន័យថា «គោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង» ។
2 Kings 23:4
ពួកបូជាចារ្យនៅក្រោមលោក
«បូជាចារ្យផ្សេងទៀតដែលបានបម្រើគាត់»
អ្នកយាមទ្វារទាំងអស់
បុរសអ្នកយាមទ្វារចូលព្រះវិហារ
ព្រះបាល...សម្រាប់ផ្កាយទាំង
«ដូច្នេះមនុស្សអាចប្រើពួកគេដើម្បីគោរពបូជាព្រះបាល ...
ដូច្នេះមនុស្សអាចប្រើពួកគេដើម្បីគោរពបូជាផ្កាយទាំងអស់»
ស្តេចបានដុត... ហើយបានយក...ស្តេចបានកំចាត់
ឧទាហរណ៍ពីរនៃ «គាត់»
សំដៅទៅលើយ៉ូសៀសប៉ុន្តែវាប្រហែលជាល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាហ៊ីលគីយ៉ានិង
«បូជាចារ្យនៅក្រោមគាត់»
ជ្រោះក្រកដុន...បេតអែល
ឈ្មោះនៃទីកន្លែង
ទៅព្រះបាល ទៅព្រះអាទិត្រ និងទៅព្រះច័ន្ទ ទៅភពទាំងឡាយ និងទៅកាន់ផ្កាយទាំងឡាយ
«ជាវិធីដើម្បីគោរពបូជាព្រះបាល ព្រះអាទិត្យ ព្រះចន្ទ និងផ្កាយទាំងអស់»
2 Kings 23:6
ព័ត៌មានទូទៅ
នេះបន្តប្រាប់នូវអ្វីដែលស្តេចយ៉ូសៀសបានឆ្លើយតប នឹងសាររបស់ព្រះអម្ចាស់។
ស្តេចបានយក...ដុតវា...ស្តេចបានកម្ទេចវា...បាច...ស្តេចបានបំផ្លាញ
ឧទាហរណ៍ទាំងអស់នៃ «គាត់» សំដៅទៅលើស្តេចយ៉ូសៀស
ប៉ុន្តែវាប្រហែលជាល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាហ៊ីលគីយ៉ានិង
«បូជាចារ្យនៅក្រោមគាត់»
សំលៀកបំពាក់
«ធ្វើសម្លៀកបំពាក់»
2 Kings 23:8
ព្រះបាទយ៉ូសៀសបាននាំ...ហើយបានបំផ្លាញ...ស្តេចបានបំផ្លាញ
វាជាការល្អបំផុតក្នុងការបកប្រែដើម្បីឱ្យអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាហ៊ីលគីយ៉ានិង
«បូជាចារ្យដែលនៅក្រោមគាត់»
ក្រុងកេបារ.....បៀរសេបា
ឈ្មោះនៃទីកន្លែង
យ៉ូស្វេ (ជាអភិបាលក្រុង)
«ចៅហ្វាយក្រុងឈ្មោះយ៉ូស្វេ» ឬ «មេដឹកនាំទីក្រុងឈ្មោះយ៉ូស្វេ» ។ នេះគឺជាយ៉ូស្វេ
ខុសគ្នាពីយ៉ូស្វេនៅក្នុងគម្ពីរសញ្ញាចាស់គម្ពីរយ៉ូស្វេ។
បងប្អូនរបស់ពួកគេ
នៅទីនេះ «បងប្អូនប្រុស» សំដៅទៅលើបូជាចារ្យមិត្តរបស់ពួកគេ
ដែលបានបម្រើនៅព្រះវិហារ។
2 Kings 23:10
តូផេត...បេនហ៊ិនណម
ឈ្មោះទីកន្លែង
ដុតកូនប្រុស កូនស្រីរបស់ខ្លួនដើម្បីធ្វើយញ្ញបូជាថ្វាយព្រះម៉ូឡុក
«ដាក់កូនប្រុសកូនស្រីរបស់គាត់ទៅក្នុងភ្លើងហើយដុតទុកជាតង្វាយដល់ព្រះម៉ូឡុក»។
ស្តេចបានយក
វាជាការល្អបំផុតក្នុងការបកប្រែដើម្បីឱ្យអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាហ៊ីលគីយ៉ានិង
«បូជាចារ្យដែលនៅក្រោមគាត់»
រូបសេះ
អត្ថន័យដែលមានគឺ ១) សេះពិត ឬ ២) រូបសំណាកសេះ។
ថ្វាយទៅព្រះអាទិត្យ
ពាក្យនេះមានន័យថា «ធ្លាប់គោរពបូជាព្រះអាទិត្យ» ។
លោកនេថាន-មេឡេក
ឈ្មោះបុរសម្នាក់)
2 Kings 23:12
ព្រះបាទយ៉ូសៀសជាស្តេចបានបំផ្លាញ...បានកម្ទេច...បោះចោល...បំផ្លាញ...បានកាត់...បានដាក់
វាជាការល្អបំផុតក្នុងការបកប្រែដើម្បីឱ្យ
អ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាហ៊ីលគីយ៉ានិង
«បូជាចារ្យនៅក្រោមគាត់»
ជ្រោះក្រកដុន
ឈ្មោះរបស់កន្លែង សូមមើលនៅក្នុងជំពូក ២៣: ៤ ។
ដាក់ឆ្អឹងរបស់មនុស្សជំនួសវិញ
«គ្របដណ្តប់លើដីដោយឆ្អឹងមនុស្ស
ដូច្នេះមនុស្សមិនអាចប្រើវាជាទៅទៀតបានទេ»
2 Kings 23:15
ព្រះបាទយ៉ូសៀសក៏បានបំផ្លាញ...ស្តេចក៏បានដុត...កំទេចវា...ស្តេចក៏បានដុត
វាជាការល្អបំផុតក្នុងការបកប្រែដើម្បីឱ្យអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាហ៊ីលគីយ៉ានិង
«បូជាចារ្យដែលនៅក្រោមគាត់»
បានថ្លែងការទាំងនេះតាំងពីមុនមក
«បាននិយាយថារឿងទាំងនេះនឹងកើតឡើង»
2 Kings 23:17
ផ្នូរដែលយើង
សញ្ញាសម្គាល់ឬរូបសំណាក់ដែលគោរពមនុស្សម្នាក់។ ផ្នូរមួយ
គឺជាវិមានមួយប្រភេទ។
ដូច្នេះ គេក៏ទុកឆ្អឹងរបស់គាត់នៅទីនោះ ជាមួយឆ្អឹងរបស់
«ដូច្នេះពួកគេមិនបានប៉ះឆ្អឹងរបស់គាត់ ឬឆ្អឹងរបស់គាត់ទេ»
2 Kings 23:19
ព្រះបាទយ៉ូសៀសបានបំផ្លាញ...ព្រះអង្គបានធ្វើ...ស្តេចបានប្រហារ...ស្តេចបានដុត

generated on Wed Sep 10 16:16:32 2025

វាជាការល្អបំផុតក្នុងការបកប្រែដើម្បីឱ្យអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាប្រើវិធីយ៉ាងណា
«បូជាចារ្យដែលនៅក្រោមគាត់»
បានធ្វើនៅ
«អ្វីដែលគាត់បានធ្វើ»
ស្តេចបានដុតឆ្អឹងរបស់មនុស្សនៅទីនោះ
«គាត់បានដុតឆ្អឹងមនុស្សលើពួកគេ
ដូច្នេះគ្មាននរណាម្នាក់អាចប្រើវាម្តងទៀតបានទេ»
2 Kings 23:21
ចូររក្សាបុណ្យចម្លង
«អ្នកត្រូវតែធ្វើបុណ្យរំលង»
ដូច្នេះ ការប្រារព្ធពិធីបុណ្យចម្លងមិនដែលធ្វើធំដូច្នេះទេ ចាប់ពីថ្ងៃ
«កូនចៅអ៊ីស្រាអែលមិនបានធ្វើបុណ្យរំលង
ក្នុងរបៀបដ៏អស្ចារ្យបែបនេះទេនៅគ្រានោះ»
គ្រប់គ្រងលើអ៊ីស្រាអែល
ឈ្មោះ «អ៊ីស្រាអែល» គឺសំដៅទៅលើ «កូនចៅអ៊ីស្រាអែល» ។
សម័យស្តេចស្រុកយូដា និងស្រុកអ៊ីស្រាអែល
«ពេលវេលាដែលប្រជាជនអ៊ីស្រាអែល មានស្តេចរបស់ពួកគេ
ហើយប្រជាជនយូដាមានស្តេចរបស់ពួកគេផ្ទាល់
គេបានប្រារព្ធបុណ្យចម្លង
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ប្រជាជនយូដាបានធ្វើបុណ្យរំលងរបស់ព្រះអម្ចាស់»
2 Kings 23:24
បានលុបបំបាត់...វិញ្ញាណ
«បង្ខំឲ្យ ... វិញ្ញាណទាំងនោះចាកចេញ» ឬ «បានបង្កើតច្បាប់មួយដែល ...
វិញ្ញាណត្រូវតែចាកចេញ»
អ្នកដែលនិយាយជាមួយមនុស្សស្លាប់ ឬក៏ជាមួយវិញ្ញាណដែរ
ពាក្យស្រដៀងគ្នានេះ «អ្នកដែលបាននិយាយជាមួយមនុស្សស្លាប់និង ...
អ្នកដែលនិយាយជាមួយវិញ្ញាណ» លេចឡើងនៅក្នុង ជំពូក ២១: ៤ ។
រូបចម្លាក់
អ្វីដែលមនុស្សជឿខុសមានអំណាចពិសេស
ដែលត្រឡប់ទៅឯព្រះអម្ចាស់វិញ
«អ្នកដែលបានប្រគល់ខ្លួនជូនព្រះអម្ចាស់»
ក៏គ្មានស្តេចណាដូចព្រះបាទយ៉ូសៀសទេ
ហើយចាប់តាំងពីពេលនោះមកមិនដែលមានស្តេចណាដែលដូចស្តេចយ៉ូសៀសឡើយ។
2 Kings 23:26
ទោះជាយ៉ាណាក៏ដោយ
អ្នកនិពន្ធប្រើពាក្យនេះដើម្បីបង្ហាញថាទោះបីរឿងទាំងអស់ដែលយ៉ូសៀសធ្វើល្អក៏ដោយប្រជាជនដែលរស់នៅក្នុងស្រុកយូដា» ឬ ២)«
ក៏ព្រះអម្ចាស់នៅតែខឹងនឹងស្រុកយូដាដដែល។
ព្រះអម្ចាស់មិនបានបោះបង់កំហឹងដ៏ខ្លាំងរបស់ព្រះអង្គប្រឆាំងនឹង
ភ្លើងគឺជាពាក្យប្រៀបធៀបសម្រាប់កំហឹងហើយការចាប់ផ្តើមភ្លើង
គឺជាពាក្យប្រៀបធៀបសម្រាប់ការខឹង។ នាមអរូបី «កាចសាហាវ» និង «កំហឹង»
អាចត្រូវបានបកប្រែជាគុណនាម។ នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត «
ព្រះជាម្ចាស់មិនបានបែរចេញពីកំហឹងដ៏ខ្លាំងនៃកំហឹងដ៏ខ្លាំងរបស់ទ្រង់ដែលទ្រង់បានធ្វើ
ឬ «ព្រះជាម្ចាស់មិនបានឈប់ធ្វើកាចសាហាវឡើយពីព្រោះទ្រង់ខឹងនឹងគេ»
ធ្វើឲ្យព្រះអម្ចាស់ព្រះពិរោធ
«បានធ្វើឱ្យទ្រង់ខ្ញាល់»
ចេញពីភ្នែករបស់យើង
«ពីកន្លែងដែលយើងនៅ» ឬ «ពីការនៅក្បែរយើង»
«នាមរបស់យើងនឹងនៅទីនោះ»
ឈ្មោះនេះគឺសម្រាប់កិត្តិយសដែលមនុស្សគួរតែផ្តល់ដល់មនុស្ស។
ការបកប្រែផ្សេងទៀត «ប្រជាជនគួរតែគោរពបូជាខ្ញុំនៅទីនោះ»
2 Kings 23:28
តើអ្នកអាចរកឃើញការបកប្រែដែលមានន័យដូចគ្នាទុក...របស់ស្តេចស្រុកយូដាទេឬអី?
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្មហើយសន្មតថាចម្លើយគឺវិជ្ជមាន។
សំណួរគឺវោហាសាស្ត្រហើយត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
សូមមើលនៅក្នុងជំពូក ៨:២២ ។ ការបកប្រែផ្សេងទៀត
«អ្នកអាចរកឃើញពួកគេ ... យូដា» ។
ស្តេចផារោននេកោ ជាស្តេចស្រុកអេស៊ីប
«ក្នុងអំឡុងពេលដែលស្តេចយ៉ូសៀស ស្តេចស្រុកអេស៊ីបព្រះចៅផារ៉ោននេកូ»
នេកូ...មេគីដោ
នេកូគឺជាឈ្មោះបុរសម្នាក់។ មេគីដោគឺជាឈ្មោះនៃទីក្រុងមួយ។
2 Kings 23:31
ព្រះជន្មម្ភៃបីឆ្នាំ
អាយុបីឆ្នាំ - «អាយុ ២៣ ឆ្នាំ»
ហាមូថាល
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
ស្រុកលិបណា...ក្រុងរីបឡា...ស្រុកហាម៉ាត់
ទាំងនេះគឺជាឈ្មោះកន្លែង។
ព្រះបាទយ៉ូអាហាសបានប្រព្រឹត្តអាក្រក់ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
គុណនាមបន្ទាប់បន្សំ «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លាដែលទាក់ទង
«អ្វីដែល ... អាក្រក់» ។
ត្រង់នេះការមើលឃើញរបស់ព្រះអម្ចាស់សំដៅទៅលើរបៀបដែលទ្រង់វិនិច្ឆ័យ
ឬសម្រេចចិត្តលើតម្លៃអ្វីមួយ។ សូមមើលនៅក្នុងជំពូក ៣: ១ ។
ការបកប្រែផ្សេងទៀត «គាត់បានធ្វើអ្វីដែលព្រះអម្ចាស់បាននិយាយថាអាក្រក់» ឬ
«គាត់បានធ្វើនូវអ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»
ដាក់ច្រវាក់ទ្រង់
បន្ទាប់ពីចងគាត់ជាមួយនឹងច្រវាក់ ទ្រង់ប្រហែលជាដាក់គាត់នៅក្នុងគុក។
ការបកប្រែផ្សេងទៀត «ដាក់គាត់នៅក្នុងគុក»
នៅស្រុកយូដា
«បង្ខំប្រជាជនយូដាឱ្យថ្វាយដល់គាត់»
មួយរយដួង...មួយដួង
ដួងមានទម្ងន់ប្រហែល ៣៣ គីឡូក្រាម។ ការបកប្រែផ្សេងទៀត «៣,៣០០
គីឡូក្រាម ... ៣៣ គីឡូក្រាម»
2 Kings 23:34
ព្រះបាទយេហូយ៉ាគីមបានប្រមូលពន្ធដារ
«យេហូគីមបានប្រមូលពន្ធពីប្រជាជនដែលជាម្ចាស់ដី»
មនុស្សដែលរស់នៅលើទឹកដីនោះ
«ប្រជាជននៅស្រុកយូដា» ។ អត្ថន័យដែលមានគឺ ១)«
អ្នកមានជាងគេនិងអ្នកមានអំណាចបំផុតក្នុងចំណោមអ្នកដែលរស់នៅស្រុកយូដា»
។
2 Kings 23:36
សេប៊ូដា
ឈ្មោះរបស់ស្ត្រីម្នាក់
លោកពេដាយ៉ា
ឈ្មោះនៃបុរសម្នាក់
ស្រុករូម៉ាល
ឈ្មោះទីកន្លែង
ព្រះបាទយេហូយ៉ាគីមប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
គុណនាមបន្ទាប់បន្សំ «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លាដែលទាក់ទង
«អ្វីដែល ... អាក្រក់» ។ ត្រង់នេះការមើលឃើញរបស់ព្រះអម្ចាស់សំដៅទៅ
លើរបៀបដែលទ្រង់វិនិច្ឆ័យឬសម្រេចចិត្តលើតម្លៃអ្វីមួយ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៣: ១ ។
ការបកប្រែផ្សេងទៀត «គាត់បានធ្វើអ្វីដែលព្រះអម្ចាស់បាននិយាយថាអាក្រក់» ឬ
«គាត់បានធ្វើនូវអ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»

---

24 [1]ក្នុងរជ្ជកាលព្រះបាទយេហូយ៉ាគីម ព្រះចៅនេប៊ូក្នេសា ជាស្តេចស្រុកបាប៊ីឡូនបានវាយប្រហារស្រុកយូដា ព្រះបាទ
យេហូយ៉ាគីមបានក្លាយជាអ្នកបម្រើរបស់ស្តេចនោះអស់រយៈពេលបីឆ្នាំ។ ព្រះបាទយេហូយ៉ាគីមបានត្រឡប់មកបះបោរប្រឆាំងនឹងព្រះចៅនេប៊ូក្នេសា។
[2]ព្រះអម្ចាស់បានចាត់ពួកជាជនជាតិខាល់ដេ ជនជាតិអារ៉ាម ជនជាតិម៉ូអាប់ និងជនជាតិអាំម៉ូន ឲ្យប្រឆាំងនឹងព្រះបាទយេហូយ៉ាគីម
ព្រះអង្គបានបញ្ជូនពួកគេមកប្រឆាំងនឹងយូដា ដើម្បីបំផ្លាញស្រុកនេះ។
ការនោះកើតឡើងស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលបានថ្លែងដោយពួកព្យាការីជាអ្នកបម្រើរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[3]ការនេះកើតឡើងចំពោះយូដាស្រមតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលព្រះអង្គនឹងបណ្តេញពួកគេចេញពីព្រះភក្ត្ររបស់ព្រះអង្គ
ដោយសារតែអំពើបាបរបស់ស្តេចម៉ាណាសេ និងអ្វីដែលស្តេចបានប្រព្រឹត្ត[4]និងដោយសារតែការដែលស្តេចបង្ហូរឈាមជនស្លូតត្រង់
ព្រោះស្តេចបានធ្វើឲ្យឈាមរបស់អ្នកទាំងនោះបានហូរពេញយេរូសាឡឹម។ ព្រះអម្ចាស់នឹងមិនអត់ទោសចំពោះការនេះឡើយ។
[5]រឿងរ៉ាវទាក់ទងនឹងព្រះបាទយេហូយ៉ាគីម និងអ្វីដែលស្តេចបានធ្វើ តើមិនមានកត់ត្រាទុកនៅក្នុងសៀវភៅព្រឹត្តិការណ៍របស់ស្តេចស្រុកយូដាទេឬអី?
[6]ព្រះបាទយេហូយ៉ាគីមបានផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់ ហើយព្រះបាទយ៉ូយ៉ាគីនជាបុត្របានឡើងស្នងរាជ្យបន្ត។
[7]ស្តេចស្រុកអេស៊ីបមិនបានវាយប្រហារចេញពីទឹកដីរបស់ខ្លួនទៀតទេ ព្រោះស្តេចស្រុកបាប៊ីឡូនបានកាន់កាប់ទឹកដីទាំងអស់ដែលស្តេចស្រុកអេស៊ីបធ្លាប់គ្រប់គ្រង
ចាប់ពីជ្រោះអេស៊ីប រហូតដល់ទន្លេអឺប្រាត។
[8]កាលព្រះបាទយ៉ូយ៉ាគីនមានអាយុដប់ប្រាំបីឆ្នាំកាលពីស្តេចឡើងគ្រងរាជ្យ ស្តេចសោយរាជ្យបានបីខែនៅក្រុងយេរូសាឡឹម។ មាតារបស់ស្តេចមាននាមថា នេហ៊ូសថា ជា
កូនរបស់លោកអែលណាថាន អ្នកក្រុងយេរូសាឡឹម។[9]ស្តេចបានប្រព្រឹត្តអំពើអាក្រក់ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
ស្តេចបានប្រព្រឹត្តអ្វីគ្រប់យ៉ាងដូចបុព្វបុរសរបស់ទ្រង់ដែរ។
[10]នៅពេលនោះកងទ័ពរបស់ព្រះចៅនេប៊ូក្នេសា ជាស្តេចស្រុកបាប៊ីឡូន ឡើងមកច្បាំងនឹងក្រុងយេរូសាឡឹម ហើយឡោមព័ទ្ធក្រុងនោះ។[11]ព្រះចៅ
នេប៊ូក្នេសាស្តេចស្រុកបាប៊ីឡូនបានឡើងមកក្រុងនោះ នៅពេលដែលពួកទាហានរបស់ស្តេចបានឡោមព័ទ្ធក្រុងនោះ[12]ហើយព្រះបាទព្រះបាទ
យ៉ូយ៉ាគីនជាស្តេចស្រុកយូដាបានចេញមកជួបស្តេចស្រុកបាប៊ីឡូន ទាំងស្តេច ទាំងមាតា ទាំងពួកមន្ត្រី ពួកនាយទាហាន និងពួកមហាតលិក។
ស្តេចស្រុកបាប៊ីឡូនបានចាប់ស្តេចនៅក្នុងឆ្នាំទីប្រាំបីក្នុងរាជ្យរបស់ទ្រង់ផ្ទាល់។
[13]ព្រះចៅនេប៊ូក្នេសាបានរឹបអូសរបស់មានតម្លៃពីទីនោះ គឺពីដំណាក់របស់ព្រះអម្ចាស់ និងពីដំណាក់របស់ស្តេច។
ស្តេចបានកាត់របស់ធ្វើពីមាសដែលព្រះបាទសាឡូម៉ូនធ្វើនៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់ ដូចអ្វីដែលព្រះអម្ចាស់មានបន្ទូលថានឹងកើតឡើង។[14]ព្រះចៅនេប៊ូក្នេសាកៀរអ្នក
ក្រុងយេរូសាឡឹម ទាំងអ្នកដឹកនាំ និងពួកអ្នកប្រយុទ្ធ បានកៀរមនុស្សមួយម៉ឺននាក់ ព្រមទាំងពួកសិប្បករ និងជាងដែកផង
លើកលែងតែអ្នកក្រីក្របំផុតនៅក្នុងទឹកដីនោះប៉ុណ្ណោះ។
[15]ព្រះចៅនេប៊ូក្នេសាក៏បានកៀរព្រះបាទយ៉ូយ៉ាគីនទៅស្រុកបាប៊ីឡូន ព្រមទាំងមាតា មហេសី ស្រីស្នំ ពួកមេដឹកនាំ និងពួកមេទ័ពពីក្រុងយេរូសាឡឹមនៅក្នុងទឹកដីនោះ។
ស្តេចបានកៀរពួកគេទៅជាឈ្លើយពីក្រុងយេរូសាឡឹមទៅបាប៊ីឡូន។[16]អ្នកប្រយុទ្ធទាំងអស់មានចំនួនប្រាំពីរពាន់នាក់ ព្រមទាំងពួកសិប្បករ និងជាងដែក
អ្នកទាំងអស់នោះសុទ្ធតែពេញកម្លាំងប្រយុទ្ធ ដូច្នេះស្តេចបាប៊ីឡូនបានកៀរពួកគេទៅជាឈ្លើយនៅឯស្រុកបាប៊ីឡូន។[17]ស្តេចស្រុកបាប៊ីឡូនតែងតាំងម៉ាថានា
ជាបងប្រុសរបស់បិតាព្រះបាទយ៉ូយ៉ាគីន ឲ្យឡើងគ្រងរាជ្យជំនួស ហើយដូរនាមថា ព្រះបាទសេដេគា។
[18]ស្តេចសេដេគាមានព្រះជន្មម្ភៃមួយឆ្នាំនៅពេលទ្រង់ឡើងសោយរាជ្យ ស្តេចសោយរាជ្យបានដប់មួយឆ្នាំនៅក្រុងយេរូសាឡឹម។ មាតារបស់ស្តេចមាននាមថា ហាមូថាល់ ជា
កូនរបស់លោកយេរេមី ជាអ្នកស្រុកលីបណា។[19]ស្តេចបានប្រព្រឹត្តអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
ស្តេចបានប្រព្រឹត្តដូចដែលព្រះបាទយេហូយ៉ាគីមបានប្រព្រឹត្តដែរ។[20]តាមរយៈព្រះពិរោធរបស់ព្រះជាម្ចាស់ គ្រប់ទាំងហេតុការទាំងនេះកើតឡើងនៅក្រុងយេរូសាឡឹម
និងយូដា រហូតដល់ទ្រង់ដេញពួកគេចេញពីវត្តមានរបស់ព្រះអង្គអស់។ បន្ទាប់មក ស្តេចសេដេគាបានបះបោរប្រឆាំងនឹងស្តេចស្រុកបាប៊ីឡូន។

---

2 Kings 24:1
ក្នុងរជ្ជកាលព្រះបាទយេហូយ៉ាគីម
«ក្នុងអំឡុងពេលដែលយេហូយ៉ាគីមគ្រប់គ្រងស្រុកយូដា»
វាយប្រហារស្រុកយូដា
អ្នកប្រហែលជាត្រូវបញ្ជាក់ឱ្យច្បាស់ពីអ្វីដែលបានកើតឡើងបន្ទាប់ពីនេប៊ូក្នេសាវាយលុកយេរូសាឡិម
ការបកប្រែផ្សេងទៀត «វាយប្រហារនិងវាយយកស្រុកយូដា»
ការនោះកើតឡើងស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលបានថ្លែងដោយពួកព្យាការីជាអ្នកបម្រើរបស់ទ្រង់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«នេះយោងទៅតាមព្រះបន្ទូលរបស់ព្រះអម្ចាស់
ដែលពួកព្យាការីរបស់ទ្រង់បានទាយ» ឬ
»នេះគឺជាអ្វីដែលព្រះជាម្ចាស់បានប្រាប់ដល់ពួកព្យាការី
របស់ទ្រង់នូវទំនាយដែលបាននិយាយថានឹងកើតឡើង» ។
2 Kings 24:3
ការនេះកើតឡើងចំពោះយូដាស្រមតាមព្រះបន្ទូលរបស់ព្រះអម្ចាស់
ការបកប្រែខ្លះ »វាពិតជាដោយសារតែសេចក្តីក្រោធរបស់ព្រះអម្ចាស់»
ដែលល្អដូចការអានអត្ថបទដើម។
ប្រសិនបើអ្នកបកប្រែមានលទ្ធភាពទទួលបានកំណែជាភាសាសំខាន់ៗ
នៅក្នុងតំបន់របស់ពួកគេ ពួកគេគួរតែធ្វើតាមជម្រើសរបស់ពួកគេបាន។
ស្រមតាមព្រះបន្ទូលរបស់ព្រះអម្ចាស់
ត្រង់នេះពាក្យ «បន្ទូល» តំណាងអោយពាក្យបញ្ជារបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ដូចដែលព្រះអម្ចាស់បានបញ្ជា»
បណ្តេញពួកគេចេញពីព្រះភក្ត្ររបស់ព្រះអង្គ
«កម្ចាត់ពួកគេចេញ» ឬ «បំផ្លាញពួកគេ»
បង្ហូរឈាមជនស្លូតត្រង់
ឈាមគឺសំដៅទៅលើជីវិតគ្មានទោសពៃរ៍
ហើយការបង្ហូរឈាមគឺសម្រាប់សម្លាប់មនុស្សស្លូតត្រង់។ ការបកប្រែផ្សេងទៀត
«ប្រជាជនស្លូតត្រង់ដែលគាត់បានសម្លាប់»
ស្តេចបានធ្វើឲ្យឈាមរបស់អ្នកទាំងនោះបានហូរពេញយេរូសាឡឹម
ឈាមគឺសំដៅទៅលើជីវិតគ្មានទោសពៃរ៍
ហើយការបង្ហូរឈាមគឺជាការសម្លាប់មនុស្សស្លូតត្រង់។ ការបកប្រែផ្សេងទៀត
«គាត់បានសម្លាប់ប្រជាជនស្លូតត្រង់ជាច្រើននាក់ នៅក្រុងយេរូសាឡឹម»

2 Kings 24:5
តើមិនមានកត់ត្រាទុកនៅក្នុង...របស់ស្តេចស្រុកយូដាទេឬអី?
នេះត្រូវបានសរសេរជាសំណួរវោហារស័ព្ទ
ពីព្រោះនៅពេលនោះគេសរសេរថាប្រជាជនបានដឹងព័ត៌មាននេះរួចហើយ។
ឃ្លានេះត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។
វាអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ សូមមើលនៅក្នុងជំពូក ៨:២២ ។
ការបកប្រែផ្សេងទៀត «ពួកគេពិតជាត្រូវបានសរសេរ ... យូដា» ។ ឬ
«អ្នកអាចរកឃើញពួកគេ ... យូដា»
ផ្ទុំលក់ជាមួយបុព្វបុរសរបស់ទ្រង់
«បានសុគតហើយត្រូវបានគេបញ្ចុះនៅជាមួយបុព្វបុរសរបស់ទ្រង់»
2 Kings 24:7
ស្តេចស្រុកអេស៊ីបមិនបានវាយប្រហារចេញពីទឹកដីរបស់ខ្លួនទៀតទេ
«ស្តេចអេស៊ីបមិនបានចេញពីដែនដីរបស់ទ្រង់
ដើម្បីវាយប្រហារក្រុមមនុស្សផ្សេងទៀតទេ»
2 Kings 24:8
នេហ៊ូសថា...លោកអែលណាថាន
នេហ៊ូថាគឺជាឈ្មោះរបស់ស្ត្រី។ លោកអែលណាថាន គឺជាឈ្មោះរបស់មនុស្សប្រុស។
ស្តេចបានប្រព្រឹត្តអំពើអាក្រក់ចំពោះព្រះនេត្ររបស់ព្រះអម្ចាស់
គុណនាមបន្ទាប់បន្សំ «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លាដែលទាក់ទង
«អ្វីដែល ... អាក្រក់» ។
ត្រង់នេះការមើលឃើញរបស់ព្រះអម្ចាស់សំដៅទៅលើរបៀបដែលទ្រង់វិនិច្ឆ័យឬសម្រេចចិត្តលើតម្លៃអ្វីមួយ
សូមមើលនៅក្នុងជំពូក ៣: ១ ។ ការបកប្រែផ្សេងទៀត
«គាត់បានធ្វើអ្វីដែលព្រះអម្ចាស់បាននិយាយថាអាក្រក់» ឬ
«គាត់បានធ្វើនូវអ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»
ស្តេចបានប្រព្រឹត្តអ្វីគ្រប់យ៉ាងដូចបុព្វបុរសរបស់ទ្រង់ដែរ
នេះគឺជាការធ្វើឱ្យមានលក្ខណៈទូទៅ។ ការបកប្រែផ្សេងទៀត «
គាត់បានប្រព្រឹត្តអំពើបាបដដែលដែលឪពុករបស់គាត់បានធ្វើ»
2 Kings 24:10
ព្រះបាទព្រះបាទយ៉ូយ៉ាគីនជាស្តេចស្រុកយូដាបានចេញមកជួបស្តេចស្រុកបាប៊ីឡូន ទាំងស្តេច ទាំង
មាតា ទាំងពួកមន្ត្រី ពួកនាយទាហាន និងពួកមហាតលិក
អ្នកប្រហែលជាត្រូវបញ្ជាក់អោយច្បាស់ពីមូលហេតុដែលយេហូយ៉ាឈីនចេញទៅជួបនេប៊ូក្នេសា។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «ព្រះបាទព្រះបាទយ៉ូយ៉ាគឺនជាស្តេចស្រុកយូដា
ម្តាយនិងអ្នកបម្រើរបស់ព្រះអង្គព្រមទាំងមេទ័ពទាំងអស់
បានចេញដំណើរទៅកន្លែងដែលស្តេចស្រុកបាប៊ីឡូនបានប្រគល់អោយ»
ស្តេចស្រុកបាប៊ីឡូនបានចាប់ស្តេចនៅក្នុងឆ្នាំទីប្រាំបីក្នុងរាជ្យរបស់ទ្រង់ផ្ទាល់
«បន្ទាប់ពីស្តេចបាប៊ីឡូនបានឡើងសោយរាជ្យអស់រយៈពេលប្រាំពីរឆ្នាំមកហើយ
នោះស្តេចបានវាយយកព្រះបាទយេហូយ៉ាគីន»
2 Kings 24:13
ព្រះបាទសាឡូម៉ូនធ្វើ
អ្នកប្រហែលជាចង់បកប្រែវាដូច្នេះអ្នកអានយល់ថា
ស្តេចសាឡូម៉ូនប្រហែលជាមានអ្នកផ្សេងទៀតជួយគាត់ឱ្យធ្វើការនេះ។
ព្រះចៅនេប៊ូក្នេសាកៀរអ្នកក្រុងយេរូសាឡឹម
នេះគឺជាការនិយាយបំផ្លើសហើយពាក្យថា «យេរូសាឡិម»
គឺជាពាក្យប្រៀបធៀបសម្រាប់ប្រជាជនដែលរស់នៅទីនោះ។ ការបកប្រែផ្សេងទៀត
«នេប៊ូក្នេសាបានយកមនុស្សសំខាន់ៗទាំងអស់ចេញពីក្រុងយេរូសាឡឹម»
ពួកសិប្បករ និងជាងដែកផង
«មនុស្សដែលដឹងពីរបៀបធ្វើ និងជួសជុលវត្ថុដែលធ្វើពីដែក»
លើកលែងតែអ្នកក្រីក្របំផុតនៅក្នុងទឹកដីនោះប៉ុណ្ណោះ
នេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍វិជ្ជមាន។ ការបកប្រែផ្សេងទៀត
«មានតែប្រជាជនក្រីក្របំផុតនៅលើដីនេះប៉ុណ្ណោះដែលនៅតែរស់នៅទីនោះ»
2 Kings 24:15
ប្រាំពីរពាន់នាក់...មួយពាន់នាក់
«៧០០០ ... ១០០០»
ម៉ាថានា
នេះជាឈ្មោះបុរសម្នាក់។
2 Kings 24:18
ម្ភៃមួយ...ដប់មួយឆ្នាំ
មួយ ... ដប់មួយ - «២១ ... ១១»
ហាមូថាល់
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។ (សូមមើល
លោកយេរេមី
នេះជាឈ្មោះបុរសម្នាក់។
លីបណា។
នេះគឺជាឈ្មោះកន្លែងមួយ។
ស្តេចបានប្រព្រឹត្តអាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់
គុណនាមបន្ទាប់បន្សំ «អាក្រក់» អាចត្រូវបានបកប្រែជាឃ្លាដែលទាក់ទង
«អ្វីដែល ... អាក្រក់» ។
ត្រង់នេះការមើលឃើញរបស់ព្រះអម្ចាស់សំដៅទៅលើរបៀបដែលទ្រង់វិនិច្ឆ័យ
ឬសម្រេចចិត្តលើតម្លៃអ្វីមួយ។ សូមមើលនៅក្នុងជំពូក ៣: ១ ។
ការបកប្រែផ្សេងទៀត «គាត់បានធ្វើអ្វីដែលព្រះអម្ចាស់បាននិយាយថាអាក្រក់» ឬ
»គាត់បានធ្វើនូវអ្វីដែលព្រះអម្ចាស់ចាត់ទុកថាអាក្រក់»

---

25 [1]នៅក្នុងថ្ងៃទីដប់ ខែទីដប់ ឆ្នាំទីប្រាំបួននៃរាជ្យរបស់ស្តេចសេដេគា
នេប៊ូក្នេសាជាស្តេចស្រុកបាប៊ីឡូនបានឡើងមកជាមួយទាហានទាំងអស់របស់ទ្រង់ដើម្បីប្រឆាំងនឹងក្រុងយេរូសាឡឹម។ ស្តេចបានបោះត្រសាលនៅទល់មុខក្រុង
និងលើកទួលជុំវិញក្រុង។[2]ដូច្នេះ ក្រុងត្រូវបានឡោមព័ទ្ធរហូតដល់ឆ្នាំទីដប់មួយនៃរាជ្យរបស់ព្រះបាទសេដេគា។[3]នៅក្នុងថ្ងៃទីប្រាំបួន ខែទីបួន នៅក្នុងឆ្នាំនោះទុរ្ភិក្សកើតមាន
យ៉ាងខ្លាំងនៅក្នុងទីក្រុង ហើយប្រជាជននៅក្នុងទឹកដីទាំងមូលលែងមានអាហារបរិភោគទៀត។
[4]បន្ទាប់មក កំពែងក្រុងក៏ត្រូវទម្លាយហើយពួកអ្នកប្រយុទ្ធបានគេចខ្លួននៅពេលយប់តាទ្វារវាងជញ្ជាំងទាំងពីរ ក្បែរសួនច្បារបស់ស្តេច
ទោះបីជាពួកខាល់ដេនៅជុំវិញក្រុងក៏ដោយ។ ស្តេចបានរត់ឆ្ពោះទៅវាលរហោស្ថានអារ៉ាបា។[5]ប៉ុន្តែ ទាហានរបស់ពួកខាល់ដេបានដេញតាមស្តេចសេដេគា
ហើយតាមទាន់ស្តេចនៅវាលទំនាបចន្លេយ័រដាន់ជិតក្រុងយេរីខូ។ ទាហានទាំងអស់របស់ទ្រង់បានបែកខ្ញែកចេញឆ្ងាយពីទ្រង់ទាំងអស់។
[6]ពួកគេចាប់បានស្តេច ហើយនាំទ្រង់ទៅជួបស្តេចស្រុកបាប៊ីឡូននៅក្រុងរីបឡា ជាកន្លែងដែលពួកគេកាត់ទោសទ្រង់។
[7]ពួកគេបានសំលាប់បុត្រទាំងអស់របស់ទ្រង់នៅចំពោះព្រះភក្ត្រទ្រង់ផ្ទាល់។ បន្ទាប់មកពួកគេក៏ខ្វេះភ្នែករបស់ទ្រង់ ចងទ្រង់ជាមួយច្រវ៉ាក់លង្ហិន ហើយនាំទ្រង់ទៅបាប៊ីឡូន។
[8]នៅក្នុងខែទីប្រាំ ក្នុងថ្ងៃទីប្រាំពីរនៅក្នុងខែនោះ ដែលស្ថិតក្នុងឆ្នាំទីដប់ប្រាំបួននៃរាជ្យរបស់ស្តេចនេប៊ូក្នេសាជាស្តេចស្រុកបាប៊ីឡូន លោកនេប៊ូសារ៉ាដានជាអ្នកបម្រើស្តេច
ស្រុកបាប៊ីឡូន និងមេពួកអង្គរក្សរបស់លោក បានមកដល់ក្រុងយេរូសាឡឹម។[9]លោកបានដុតកម្ទេចដំណាក់របស់ព្រះអម្ចាស់ វាំងរបស់ស្តេច
និងផ្ទះទាំងអស់នៅក្រុងយេរូសាឡឹម ហើយលោកក៏បានដុតកម្ទេចអគារសំខាន់ៗទាំងអស់នៅក្នុងក្រុងដែរ។[10]ចំណែកឯ ជញ្ជាំងជុំវិញក្រុងយេរូសាឡឹមវិញ
ពួកទាហានបាប៊ីឡូនដែលស្ថិតនៅក្រោមបញ្ជារបស់មេអង្គរក្សជាអ្នកបំផ្លាញចោល។
[11]ចំណែក មនុស្សដែលនៅសេសសល់ក្នុងក្រុងយេរូសាឡឹម គឺអស់អ្នកដែលបានចុះចូលជាមួយស្តេចស្រុកបាប៊ីឡូន និងអ្នកដែលផ្សេងទៀត
លោកនេប៊ូសារ៉ាដានបានកៀរយកទៅជាឈ្លើយសឹក។[12]ប៉ុន្តែ លោកមេលើអង្គរក្សបានទុកអ្នកដែលក្រីក្របំផុតឲ្យនៅធ្វើការក្នុងចម្ការទំពាំងបាយជូរ និងនៅតាមវាលស្រែ។
[13]ចំណែកឯ សសរលង្ហិនដែលនៅក្នុងដំណាក់របស់ព្រះអម្ចាស់ និងជើងបញ្ឈរ ធើ្វងលង្ហិនធំដែលនៅក្នុងដំណាក់របស់ព្រះអម្ចាស់ ពួកខាល់ដេបានកម្ទេចជាបំណែក
ហើយនាំយកលង្ហិនទៅស្រុកបាប៊ីឡូន។[14]ឆ្នាំង ឆ្នូក ដង្កៀប ស្លាបព្រា និងរបស់ឯទៀតៗធ្វើពីលង្ហិន សម្រាប់ប្រើប្រាស់ក្នុងព្រះវិហារ ក៏ពួកខាល់ដេយកទៅអស់ដែរ។[15]
ភាជន៍សម្រាប់ចកផះ និងចានគោមដែលធ្វើពីមាស ពីប្រាក់ ក៏លោកមេលើពួកអ្នកយាមយកទៅជាមួយដែរ។
[16]សសរទាំងពីរ អាងធំ និងជើងបញ្ឈរដែលព្រះបាទសាឡូម៉ូនបានធ្វើសម្រាប់ដំណាក់របស់ព្រះអម្ចាស់ដែលមានលង្ហិនដ៏ច្រើនដែលមិនបានថ្លឹងបាន។
[17]កម្ពស់នៃសសរទីមួយគឺ១៨ហត្ថ ហើយមានក្បាលសសរលង្ហិននៅពីលើសសរនោះ។ ក្បាលសសរនោះមានកម្ពស់បីហត្ថ ជាមួយនឹងក្បាច់ក្រឡាអួន
និងក្បាច់ផ្លែទទឹមនៅជុំវិញក្បាលសសរនោះ អ្វីៗទាំងអស់ធ្វើពីលង្ហិន។ សសរមួយទៀត និងក្បាច់របស់វាគឺដូចសសរទីមួយដែរ។
[18]លោកមេបញ្ជាការលើពួកអង្គរក្សចាប់លោកមហាបូជាចារ្យសេរ៉ាយ៉ា និងលោកសេផានាជាបូជាចារ្យទីពីរ ព្រមទាំងចាប់អ្នកយាមទ្វារព្រះវិហារបីរូបយកទៅជាមួយផង។
[19]នៅក្នុងក្រុងលោកក៏ចាប់មេបញ្ជាការដាក់គុក លោកជាអ្នកមើលខុសត្រូវលើពួកទាហាន និងបុរសប្រាំនាក់ដែលជាទីព្រឹក្សារបស់ស្តេច ដែលស្ថិតនៅក្នុងក្រុងនោះ។
លោកក៏ដាក់គុកមេទ័ពរបស់ស្តេចដែលទទួលខុសត្រូវលើកការកែនប្រុសៗធ្វើទាហាន ជាមួយមនុស្សសំខាន់ហុកសិបនាក់ទៀតពីទឹកដីនោះ
គឺអស់អ្នកដែលរស់នៅក្នុងក្រុង។
[20]បន្ទាប់មក លោកនេប៊ូសារ៉ាដានជាមេបញ្ជាការលើសពួកអង្គរក្ស បានចាប់ពួកគេ ហើយនាំពួកគេទៅដល់ស្តេចបាប៊ីឡូននៅក្រុងរីបឡា។
[21]ស្តេចស្រុកបាប៊ីឡូនបានសម្លាប់ពួកគេនៅក្រុងរីបឡានោះនៅក្នុងទឹកដីហាម៉ាត់។ អ្នកស្រុកយូដាត្រូវកៀរយកទៅជាឈ្លើយ ដោយរបៀបនេះឯង។
[22]អ្នកដែលនៅសេសសល់នៅក្នុងស្រុកយូដា គឺអស់អ្នកដែលលោកនេប៊ីសារ៉ាដានបានទុកឲ្យនៅទីនោះ លោកបានទុកលោកកេដាលា ជាកូនរបស់លោកអហ៊ីកាម និងជា
ចៅរបស់លោកសាផាន បានមើលខុសត្រូវលើពួកគេ។[23]ពេលនោះនៅពេលដែលមេបញ្ជាការកងទ័ពទាំងអស់ ទាំងអ្នកទាំងនោះ
និងអ្នកនៅក្រោមបង្គាប់បានឮថាស្តេចស្រុកបាប៊ីឡូនបានតែងតាំងលោកកេដាលាឲ្យគ្រប់គ្រងលើស្រុក ពួកគេក៏នាំគ្នាមកជួបនឹងលោកកេដាលា នៅមីសប៉ា។ អ្នកទាំង
នោះ មានលោកអ៊ីស្មាអែល ជាកូនរបស់លោកនេថានា លោកយ៉ូហាណាន ជាកូនរបស់លោកការ៉ា លោកសេរ៉ាយ៉ា ជាកូនរបស់លោកថាន់ហ៊ូម៉ើត ជាអ្នកស្រុកនេថូផា និង
លោកយាសានា ជាកូនរបស់ពួកម៉ាកាធី ទាំងពួកគេ និងពលទាហានរបស់ពួកគេផង។[24]លោកកាដាលាបានប្រកាសដល់មេទាហាន និងពលទាហានទាំងនោះថា៖
«កុំឲ្យខ្លាចពួកខាល់ដេឡើយ។ ចូរបន្តរស់នៅលើទឹកដីនេះ ហើយបម្រើស្តេចស្រុកបាប៊ីឡូនទៅ ហើយអ្នកនឹងរស់នៅយ៉ាងសុខសប្បាយ»។
[25]នៅក្នុងខែទីប្រាំពីរ លោកអ៊ីស្មាអែល ជាកូនរបស់លោកនេថានា ជាចៅរបស់លោកអេលីសាម៉ា ដែលជាសាច់សារលោហិតរបស់ស្តេច បានមកជាមួយទាហានដប់នាក់
ហើយបានវាយប្រហារលោកកេដាលា។ លោកកេដាលាបានស្លាប់ ជាមួយជនជាតិយូដា និងជនជាតិខាល់ដេ ដែលនៅជាមួយលោកកេដាលា នៅមីសប៉ា។[26]បន្ទាប់មក
ប្រជាជនទាំងអស់ ពីអ្នកក្របំផុតដល់អ្នកធំ និងពួកមេទ័ពបានចេញដំណើរទៅអេស៊ីប ព្រោះពួកគេខ្លាចពួកបាប៊ីឡូន។
[27]នៅក្នុងឆ្នាំទីសាមសិបប្រាំពីរនៃការកៀរព្រះបាទយ៉ូយ៉ាគីន ជាស្តេចស្រុកយូដា ត្រូវគេចាប់យកទៅជាឈ្លើយសឹក នៅក្នុងខែទីដប់ពីរ គឺនៅក្នុងថ្ងៃទីម្ភៃប្រាំពី ព្រះចៅអេវីល-
មេរ៉ូដាក ជាស្តេចស្រុកបាប៊ីឡូនបានដោះលែងព្រះបាទយ៉ូយ៉ាគីនចេញពីគុក។ ការនេះកើតឡើងនៅក្នុងឆ្នាំដែលព្រះចៅអេវីល-មេរ៉ូដាកចាប់ផ្តើមឡើងសោយរាជ្យ។

generated on Wed Sep 10 16:16:32 2025

[28]ស្តេចបានមាករាជឱង្ការដោយសុភាពទៅកាន់ទ្រង់ ហើយប្រទានកន្លែងកិត្តិយសជាងស្តេចឯទៀតៗ ដែលនៅជាមួយទ្រង់នៅក្នុងស្រុកបាប៊ីឡូន។[29]ព្រះចៅអេវីល-
មេរ៉ូដាកបានដោះសម្លៀកបំពាក់ឈ្លើយសឹករបស់ព្រះបាទយ៉ូយ៉ាគីនចេញ ហើយព្រះបាទយ៉ូយ៉ាគីនសោយព្រះស្ងោររួមតុជាមួយស្តេចគ្រប់ពេល រហូតដល់ទ្រង់សុគត។
[30]ស្តេចស្រុកបាប៊ីឡូនតែងតែទំនុកបម្រុងដល់ព្រះបាទយ៉ូយ៉ាគីននូវអាហារដ៏សមរម្យជារៀងរាល់ថ្ងៃអស់មួយជីវិតរបស់ទ្រង់។

---

2 Kings 25:1

ឆ្នាំទីប្រាំបួន

នៅក្នុងថ្ងៃទីដប់ ខែទីដប់

នេះជាខែទី ១០ នៃប្រតិទិនហេព្រើរ។ ថ្ងៃទី ១០
ជិតដល់ចុងខែធ្នូលើប្រតិទិនលោកខាងលិច។
នេះគឺនៅរដូវត្រជាក់នៅពេលមានភ្លៀងនិងធ្លាក់ព្រិល។

ឡើងមកជាមួយទាហានទាំងអស់របស់ទ្រង់ដើម្បីប្រឆាំងនឹងក្រុងយេរូសាឡឹម

ឈ្មោះ «ក្រុងយេរូសាឡិម»
គឺជាពាក្យទាក់ទងសម្រាប់ប្រជាជនដែលរស់នៅក្នុងនោះ។ ការបកប្រែផ្សេងទៀត
«បានមកជាមួយកងទ័ពទាំងមូលរបស់គាត់ដើម្បីប្រយុទ្ធប្រឆាំងនឹងប្រជាជននៅក្រុងយេរូសាឡឹម»
ឬ «បានមកជាមួយកងទ័ពទាំងមូលរបស់គាត់ដើម្បីយកឈ្នះលើក្រុងយេរូសាឡិម»

នៅក្នុងថ្ងៃទីប្រាំបួន ខែទីបួន

នេះជាខែទីបួននៃប្រតិទិនហេព្រើរ។ ថ្ងៃទី ៩
ជិតដល់ចុងខែមិថុនាតាមប្រតិទិនលោកខាងលិច។
នេះគឺនៅរដូវប្រាំងនៅពេលមានភ្លៀងតិចឬច្រើន។

ប្រជាជននៅក្នុងទឹកដីទាំងមូល

ទាំងនេះជាប្រជាជននៅក្រុងយេរូសាឡឹម
រួមទាំងជនភៀសខ្លួនមកពីភូមិជុំវិញដែលបានភៀសខ្លួនទៅក្រុងយេរូសាឡឹមពេលសង្គ្រាមបានចាប់ផ្តើម។

2 Kings 25:4

បន្ទាប់មក កំពែងក្រុងក៏ត្រូវទម្លាយ

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ពេលនោះកងទ័ពបាប៊ីឡូនបានវាយលុកចូលទីក្រុង»

ពួកអ្នកប្រយុទ្ធ

«អ្នកចម្បាំងទាំងអស់»

តាមទ្វារវាងជញ្ជាំង

«ដោយប្រើច្រកទ្វារ»

ខាល់ដេ

ការបកប្រែខ្លះប្រើភាសា«ខាល់ដេ» ហើយខ្លះទៀតប្រើពាក្យ «បាប៊ីឡូន» ។
ពាក្យទាំងពីរនេះសំដៅទៅលើក្រុមមនុស្សតែមួយ។

ស្តេចបានរត់ឆ្ពោះទៅ

«ស្តេចសេដេគាក៏រត់ភៀសខ្លួន ហើយស្តេចក៏ឆ្ពោះទៅ»

ទាហានទាំងអស់របស់ទ្រង់បានបែកខ្ញែកចេញឆ្ងាយពីទ្រង់ទាំងអស់

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«កងទ័ពទាំងមូលរបស់គាត់បានរត់ចេញពីគាត់» ឬ
«ពួកខាល់ដេបានដេញកងទ័ពរបស់គាត់ទាំងមូលចេញ»

2 Kings 25:6

ក្រុងរីបឡា

នេះគឺជាឈ្មោះកន្លែងមួយ។

ពួកគេកាត់ទោសទ្រង់

«បានសម្រេចថាតើពួកគេនឹងដាក់ទណ្ឌកម្មគាត់យ៉ាងដូចម្តេច» (សូមមើល UDB)

ពួកគេបានសំលាប់បុត្រទាំងអស់របស់ទ្រង់នៅចំពោះព្រះភក្ត្រទ្រង់ផ្ទាល់

ភ្នែកគឺសំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត
«ពួកគេបានបង្ខំស្តេចសេដេគា ឲ្យមើលពួកគេសម្លាប់កូនប្រុសរបស់គាត់»

ពួកគេក៏ខ្វេះភ្នែករបស់ទ្រង់

«នេប៊ូក្នេសាខ្វះភ្នែករបស់សេដេគា»។ វាជាការល្អបំផុតដើម្បីបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាបានជួយនេប៊ូក្នេសាធ្វើបែបនេះ។

2 Kings 25:8

នៅក្នុងខែទីប្រាំ ក្នុងថ្ងៃទីប្រាំពីរនៅក្នុងខែនោះ

នេះជាខែទីប្រាំនៃប្រតិទិនហេព្រើរ។ ថ្ងៃទី ៧
ជិតដល់ចុងខែកក្កដាតាមប្រតិទិនលោកខាងលិច។

ឆ្នាំទីដប់ប្រាំបួន

នេះជាទម្រង់លេខនៃលេខ ១៩ ។

ស្តេចនេប៊ូក្នេសា

នេះជាឈ្មោះបុរសម្នាក់។

ចំណែកឯ ជញ្ជាំងជុំវិញក្រុងយេរូសាឡឹមវិញ
នេះជាអ្វីដែលបានកើតឡើងចំពោះកំផែងទាំងអស់នៅជុំវិញក្រុងយេរូសាឡិម។

ដែលស្ថិតនៅក្រោម

«អ្នកណាដែលធ្វើតាមបទបញ្ជារបស់»

2 Kings 25:11

ចំណែក មនុស្សដែលនៅសេសសល់ក្នុងក្រុង...អស់អ្នកដែល

«នេះជាអ្វីដែលបានកើតឡើងចំពោះប្រជាជន ... ទីក្រុង អ្នកទាំងនោះ»

មនុស្សដែលនៅសេសសល់ក្នុងក្រុងយេរូសាឡឹម

«ប្រជាជនដែលនៅសេសសល់ក្នុងទីក្រុង»

បានចុះចូលជាមួយស្តេច

«បានចុះចូលចំពោះស្តេចបាប៊ីឡូន ចាកចេញពីទីក្រុង ហើយទៅនៅជាមួយស្តេច»

2 Kings 25:13

ចំណែកឯ សសរលង្ហិន..ព្រះអម្ចាស់ ពួកខាល់ដេ

«នេះជាអ្វីដែលបានកើតឡើងដល់សសរលង្ហិន ... ព្រះអម្ចាស់៖ ពួកខាល់ដេ»

ជើងបញ្ឈរ

នេះសំដៅទៅលើរូបចម្លាក់ធ្វើពីលង្ហិនដែលមានចលនាធំ មានកង់ និងអ័ក្សលង្ហិន។
«លង្ហិនដែលអាចផ្លាស់ទីបាន» ឬ «លង្ហិនឈរដោយកង់»

ធើងលង្ហិនធំ

ធើងលង្ហិនធំ

ម្ទេចជាបំណែក

«កាត់វាជាចំណែកៗ» ឬ «កាត់វាជាដុំតូចៗ»

ឆ្នូក

ឆ្នូកគឺជាឧបករណ៍មួយដែលត្រូវបានប្រើដើម្បីសម្អាតអាសនៈដែលជាទូទៅត្រូវបានប្រើ
ដើម្បីរំកិលគំនរធំៗ ដីខ្សាច់ឬផេះ។

សម្រាប់ប្រើប្រាស់ក្នុងព្រះវិហារ

«ដែលពួកបូជាចារ្យបានប្រើនៅក្នុងព្រះវិហារ»

ភាជន៍សម្រាប់ចូកផេះ

អ្នកត្រូវបញ្ជាក់ឱ្យច្បាស់ថាតើផេះត្រូវបានគេនិយាយអ្វីខ្លះ។ ការបកប្រែផ្សេងទៀត
«ធើងដែលត្រូវបានប្រើសម្រាប់យកផេះចេញពីអាសនៈ»

2 Kings 25:16

អាងធំ

អាងលង្ហិនធំ។ បកប្រែដូចនៅក្នុងជំពូក ២៥:១៣ ។

ជើងបញ្ឈរ

បកប្រែដូចនៅក្នុងជំពូក ២៥:១៣ ។

១៨ហត្ថ...បីហត្ថ

មួយហត្ថមាន ៤៦សង្ទីម៉ែត្រ។ ការបកប្រែផ្សេងទៀត «ប្រហែល ៨,៣ ម៉ែត្រ ...
ប្រហែល ១,៤ ម៉ែត្រ»

ក្បាលសសរលង្ហិន

«សិល្បៈរចនាសំរិទ្ធ» ឬ «ដុំសំរិទ្ធដែលមានម៉ូត»

ក្បាចំក្រឡាអួន

នេះគឺជាការរចនាធ្វើពីបន្ទះឆ្លងកាត់ដែលមើលទៅដូចជាសំណាញ់។

អ្វីៗទាំងអស់ធ្វើពីលង្ហិន

«ធ្វើពីលង្ហិនទាំងស្រុង»

2 Kings 25:18

លោកមេបញ្ជាការលើពួកអង្គរក្ស

ពាក្យស្រដៀងគ្នានេះមាននៅក្នុងជំពូក ២៥: ៨ ។

សេរ៉ាយ៉ា

នេះជាឈ្មោះបុរសម្នាក់។

បូជាចារ្យទីពីរ

ពាក្យទាំងនេះសំដៅទៅលើសេផានា។ អត្ថន័យមួយទៀតគឺ
«បូជាចារ្យនៅក្រោមសេរ៉ាយ៉ា» ។

អ្នកយាមទ្វារ

បកប្រែដូចនៅក្នុងជំពូក ៧: ៩ ។

ដាក់គុក

«ចាប់បាននិងរក្សាទុកពីការរត់គេចខ្លួន»

មេទ័ពរបស់ស្តេចដែលទទួលខុសត្រូវលើកការកែនប្រុសៗធ្វើទាហាន

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀតអាចអានបានថា «អានុច ដែលទទួលបន្ទុកទាហាន» ។
បុរសម្នាក់នេះគឺជាម្នាក់ដែលផ្នែកនៃឯកជនត្រូវបានគេដកចេញ។
មេទ័ពរបស់ស្តេចដែលទទួលខុសត្រូវលើកការកែនប្រុសៗធ្វើទាហាន
អត្ថន័យដែលមានគឺ ១) មន្ត្រីបង្ខំឱ្យមនុស្សប្រុសក្លាយជាទាហាន ឬ ២)
មន្ត្រីនោះបានសរសេរឈ្មោះមនុស្សប្រុសដែលបានក្លាយជាទាហាន។
2 Kings 25:20
លោកនេប៊ូសារ៉ាដាន
នេះជាឈ្មោះបុរសម្នាក់។ បកប្រែដូចនៅក្នុងជំពូក ២៥: ៨ ។
ក្រុងរីបឡា
នេះគឺជាឈ្មោះកន្លែងមួយ។ បកប្រែដូចនៅក្នុងជំពូក ២៥: ៦ ។
បានសម្លាប់ពួកគេ
នេះគឺជាវិធីគួរសមក្នុងការនិយាយថា «បានសម្លាប់ពួកគេ» ។
វាជាការល្អបំផុតក្នុងការបកប្រែ
ដូច្នេះអ្នកអានយល់ថាមនុស្សផ្សេងទៀតប្រហែលជាបានជួយស្តេចឱ្យធ្វើរឿងនេះ។
អ្នកស្រុកយូដាត្រូវកៀរយកទៅជាឈ្លើយ ដោយរបៀបនេះឯង
ដូច្នេះជនជាតិយូដាត្រូវគេកៀរចេញពីទឹកដីរបស់ខ្លួន
អ្នកស្រុកយូដាត្រូវកៀរយកទៅជាឈ្លើយ
យូដា ជាឈ្មោះក្រុមប្រជាជនគឺជាឈ្មោះប្រើសម្រាប់ប្រជាជនខ្លួនឯង។
ការបកប្រែផ្សេងទៀត «ប្រជាជនយូដាបានចាកចេញពីទឹកដីរបស់ពួកគេ»
2 Kings 25:22
លោកកេដាលា...លោកអហ៊ីកាម...លោកសាផាន...អ៊ីស្មាអែល...លោកនេថានា... លោក
យ៉ូហាណាន...លោកការ៉ា ...លោកសេរ៉ាយ៉ា...លោកថាន់ហ៊ូម៉ែក...លោកយាសានា
ទាំងអស់នេះគឺជាឈ្មោះរបស់មនុស្សប្រុស។
នេថូផា
កូនចៅរបស់បុរសម្នាក់ឈ្មោះ នេថូផា
ម៉ាកាធី
ពីកន្លែងមួយដែលមានឈ្មោះថាម៉ាកា
2 Kings 25:25
ខែទីប្រាំពីរ
នេះជាខែទី ៧ នៃប្រតិទិនហេព្រើរ។ វាគឺជាអំឡុងពេលចុងក្រោយនៃខែកញ្ញា
និងផ្នែកដំបូងនៃខែតុលាតាមប្រតិទិនលោកខាងលិច។
លោកអេលីសាម៉ា
នេះជាឈ្មោះបុរសម្នាក់
ប្រជាជនទាំងអស់
នេះគឺជាការធ្វើឱ្យមានលក្ខណៈទូទៅ។ ការបកប្រែផ្សេងទៀត
«មានមនុស្សជាច្រើន»
អ្នកក្របំផុតដល់អ្នកធំ
នេះគឺជាការរួមបញ្ចូលគ្នាដែលមានន័យថា «អ្នករាល់គ្នា»
ដែលជាការធ្វើឱ្យមានលក្ខណៈទូទៅ។ ការបកប្រែផ្សេងទៀត
«ពីតូចទៅសំខាន់បំផុត» ឬ «មនុស្សគ្រប់គ្នា»
2 Kings 25:27
ឆ្នាំទីសាមសិបប្រាំពីរ
ឆ្នាំទី ៧ -
នៅក្នុងខែទីដប់ពីរ គឺនៅក្នុងថ្ងៃទីម្ភៃប្រាំពី
ថ្ងៃទីប្រាំពីរនៃខែ - នេះជាខែទីដប់ពីរនៃប្រតិទិនហេព្រើរ។
ថ្ងៃទីម្ភៃប្រាំពីរគឺជិតដល់ដើមខែមេសានៅលើប្រតិទិនលោកខាងលិច។
ព្រះចៅអេវីល-មេរ៉ូដាក
ព្រះចៅអេវីល-មេរ៉ូដាក -
ឈ្មោះរបស់បុរសនោះស្តាប់ទៅមិនមែនជាការពិពណ៌នាអំពីគាត់ទេ។
2 Kings 25:28
ប្រទានកន្លែងកិត្តិយសជាងស្តេចឯទៀតៗ
ការផ្តល់កន្លែងល្អនៅតុបរិភោគគឺជាការគោរពដល់ទ្រង់។ ការបកប្រែផ្សេងទៀត
«មានកិត្តិយសច្រើនជាងស្តេចដទៃទៀត»
បានដោះសម្លៀកបំពាក់ឈ្លើយសឹករបស់ព្រះបាទយ៉ូយ៉ាគីនចេញ
អ្នកអានគួរតែយល់ថាការដោះសម្លៀកបំពាក់ពន្ធនាគាររបស់គាត់
គឺជាភាពស៊ីចង្វាក់គ្នាសម្រាប់ធ្វើឱ្យគាត់ក្លាយជាមនុស្សដែលមានសេរីភាព។
តុជាមួយស្តេច
«ជាមួយព្រះមហាក្សត្រ និងមន្ត្រីរបស់ព្រះអង្គ»
នូវអាហារដ៏សមរម្យជារៀងរាល់ថ្ងៃអស់មួយជីវិតរបស់ទ្រង់
នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះរាជាបានធ្វើឱ្យប្រាកដថាទ្រង់មានប្រាក់ឧបត្ថម្ភមួយអាហារជាទៀងទាត់»
អាហារដ៏សមរម្យជារៀងរាល់ថ្ងៃ
«លុយដើម្បីទិញម្ហូប»

របាក្សត្រ ទី១

1 [1]លោកអដាំ លោកសេថ លោកអេណុស[2]លោកកៃណាន លោកម៉ាលេលាល លោកយេរេឌ[3]លោកហេណុក លោកមធូសាឡា លោកឡាមេក។
[4]លោកឡាមេកជាឪពុកលោកណូអេ កូនៗរបស់លោកណូអេមានលោកសិម លោកហាំ និង លោកយ៉ាផេត។
[5]កូនប្រុសៗរបស់លោកយ៉ាផេតមាន កូមើរ ម៉ាកុក ម៉ាដាយ យ៉ាវ៉ាន ទូបាល មែសេក និងទីរ៉ាស។[6]កូនប្រុសៗរបស់លោកកូមើរមាន អាសក្នាស រីផាត និងតូការម៉ា។
[7]កូនប្រុសៗរបស់លោកយ៉ាវ៉ានមាន អេលីសា តើស៊ីស គីទីម និងដូដានីម។
[8]កូនប្រុសៗរបស់លោកហាំ មានគូស មីសរ៉ែម ពូថ និងកាណាន។[9]កូនប្រុសៗរបស់លោកគូសមាន សេបា ហាវីឡា សាបតា រ៉ាម៉ា និងសាបតិកា។
កូនប្រុសៗរបស់លោករ៉ាអាម៉ា គឺ សេបានិងដេដាន់។[10]លោកគូស ជាឪពុករបស់លោកនីមរ៉ូដ លោកគឺជាវីរបុរសទីមួយនៅលើផែនដី។
[11]លោកមីសរ៉ែម ដូនតារបស់ជនជាតិលូឌីម ជនជាតិអណាមីម ជនជាតិលេហាប៊ីម ជនជាតិណាធូហ៊ីម[12]ជនជាតិប៉ាទ្រូស៊ីម និងជនជាតិកាសលូហ៊ីម
(ដែលត្រូវជាដូនតារបស់ជនជាតិភីលីស្ទីន) និងជនជាតិកាប់ថោរីម។
[13]លោកកាណាន បង្កើតស៊ីដូន ជាកូនច្បង និងហេត។[14]គាត់ក៏ក្លាយជាបុព្វបុរសរបស់ ជនជាតិយេប៊ូស ជនជាតិអាម៉ូរី ជនជាតិគើកាស៊ី[15]ជនជាតិហេវី ជនជាតិអើគី
ជនជាតិស៊ីនីត[16]ជនជាតិអើវ៉ាឌីត ជនជាតិសេម៉ារីត ជនជាតិហាម៉ាធីត។
[17]កូនប្រុសៗរបស់លោកសិមមាន អេឡាំ អាសស៊ើរ អើប៉ាកសាឌ លូឌ អើរ៉ាម អ៊ូស ហ៊ូល កេធើរ និងមែសេក។[18]លោកអើប៉ាកសាឌជាឪពុករបស់លោកសេឡា
លោកសេឡាជាឪពុករបស់លោកហេប៊ើរ។[19]លោកហេប៊ើរមានកូនប្រុសពីរនាក់ មួយឈ្មោះផាលេក ពីព្រោះនៅជំនាន់នោះមនុស្សបានបែកចែកផែនដីគ្នា
រីឯប្អូនគាត់ឈ្មោះយ៉ុកថាន។
[20]លោកយ៉ុកថានជាឪពុករបស់អាល់-ម៉ូដាដ សេលែប ហាសាម៉ាវែត យេរ៉ា[21]ហាដូរ៉ាម អ៊ូសាល ឌីកឡា[22]អ៊ូបាល អប៊ីម៉ាអែល សេបា[23]អូភៀរ ហាវីឡា និងយ៉ូបាប។
អ្នកទាំងនោះសុទ្ធតែជាកូនចៅរបស់លោកយ៉ុកថាន។
[24]លោកសិម លោកអើបាកសាឌលោកសេឡា[25]លោកហេប៊ើរ លោកផាលេក លោករេហ៊ូវ[26]លោកសេរូក លោកណាឃរ លោកថេរ៉ា[27]លោកថេរ៉ាជាឪពុកលោកអាប់រ៉ាម
គឺជាលោកអប្រាហាំ។
[28]កូនរបស់លោកអប្រាហាំមាន លោកអ៊ីសាក និងលោកអ៊ីស្មាអែល។[29]ពូជពង្សរបស់លោកអ៊ីស្មាអែលមានដូចតទៅ លោកនេបាយ៉ូតជាកូនច្បង កេដារ អបែល មីបសាម
[30]មីសម៉ា ឌូម៉ា ម៉ាស្សា ហាដាដ ថេម៉ា[31]យេធើរ ណាភីស និងកេដម៉ា។ អ្នកនោះសុទ្ធតែជាកូនប្រុសៗរបស់លោកអ៊ីស្មាអែល។
[32]រីឯកូនប្រុសៗរបស់នាងកិទូរ៉ា ជាប្រពន្ធចុងរបស់លោកអប្រាហាំមាន ស៊ីមរ៉ាន យ៉ុកសាន មីដាន មីឌាន អ៊ីសបាក់ និងស៊ូអា។ កូនប្រុសៗរបស់លោកយ៉ុកសានគឺ សាបា
និងដេដាន់។[33]កូនប្រុសៗរបស់លោកមីឌានគឺ អេផា អេភើរ ហេណុក អប៊ីដា និងអែលដាអា។ អ្នកទាំងនោះសុទ្ធតែជាកូនចៅរបស់នាងកិទូរ៉ា។
[34]លោកអប្រាហាំជាឪពុករបស់លោកអ៊ីសាក ហើយកូនរបស់លោកអ៊ីសាកគឺលោកអេសាវ និងលោកអ៊ីស្រាអែល។[35]កូនប្រុសៗរបស់លោកអេសាវមាន អេលីផាស រេហួល
យេអ៊ូស យ៉ាឡាម និងកូរ៉ា។[36]កូនប្រុសៗរបស់លោកអេលីផាសមាន ថេម៉ាន អូម៉ារ សេផូ កេថាម កេណាស ធីមណា និងអាម៉ាឡេក។[37]កូនប្រុសៗរបស់លោករេហួលមាន
ណាហាត់ សេរ៉ាស សាំម៉ា និងមីសសា។

generated on Wed Sep 10 16:16:32 2025

[38]កូនប្រុសៗរបស់លោកសៀរមាន ឡូថាន សូបាល ស៊ីបៀន អណា ឌីសសុន អេស៊ើរ និងឌីសាន។[39]កូនប្រុសៗរបស់លោកឡូថានមាន ហូរី និងហោម៉ាម។
ប្អូនស្រីរបស់លោកឡូថាន ឈ្មោះនាងធីមណា។[40]កូនប្រុសៗរបស់លោកសូបាលមាន អាល់វ៉ាន ម៉ាណាហាត់ អេបាល សេផូ និងអូណាម។ កូនប្រុសៗរបស់លោកស៊ីបៀន
មាន អៃយ៉ា និងអណា។
[41]កូនប្រុសៗរបស់លោកអណាគឺ ឌីសុន កូនប្រុសៗរបស់លោកឌីសុនមាន ហាមរ៉ាន អែសបាន់ អ៊ីតរ៉ាន និងកេរ៉ាន។[42]កូនប្រុសៗរបស់លោកអេស៊ើរមាន ប៊ីលហាន សាវ៉ាន
និងយ៉ាកាន។ កូនប្រុសៗរបស់លោកឌីសសាន គឺអ៊ូស និងអរ៉ាន។
[43]ស្តេចដែលគ្រងរាជ្យនៅស្រុកអេដុមមុនពេលដែលមានស្តេចគ្រងរាជ្យលើជនជាតិអ៊ីស្រាអែលមានដូចតទៅ ព្រះបាទបេឡា ជាបុត្រលោកបេអរ
គ្រងរាជ្យនៅក្រុងឌីនហាបា។[44]ពេលព្រះបាទបេឡាសោយទិវង្គតទៅ ព្រះបាទយ៉ូបាប់ ជាបុត្ររបស់លោកសេរ៉ា អ្នកក្រុងបូសរ៉ា ឡើងគ្រងរាជ្យជំនួស។
[45]ពេលព្រះបាទយ៉ូបាប់សោយទិវង្គត ព្រះបាទហ៊ូសាម ជាអ្នកស្រុកថេម៉ាន ឡើងគ្រងរាជ្យជំនួស។
[46]ពេលព្រះបាទហ៊ូសាមសោយទិវង្គត ព្រះបាទហាដាដ ជាបុត្ររបស់លោកបេដាដ មកពីក្រុងអាវីត ឡើងគ្រងរាជ្យជំនួស គឺស្តេចនេះហើយដែលវាយឈ្នះពួកមីឌាន
នៅស្រុកម៉ូអាប់។[47]ពេលព្រះបាទហាដាដសោយទិវង្គត ព្រះបាទសាំឡា ជាអ្នកស្រុកម៉ាសរេកា ឡើងគ្រងរាជ្យជំនួស។[48]ពេលព្រះបាទសាំឡាសោយទិវង្គត
ព្រះបាទសូលជាអ្នកស្រុករ៉េហូបូត ដែលនៅមាត់ទន្លេ ឡើងគ្រងរាជ្យជំនួស។
[49]ពេលព្រះបាទសូលសោយទិវង្គត ព្រះបាទបាល-ហាណាន់ជាបុត្ររបស់លោកអកបោរឡើងគ្រងរាជ្យជំនួស។[50]ពេលព្រះបាទបាល-ហាណាន់សោយទិវង្គត ព្រះបាទហាដា
ជាអ្នកក្រុងប៉ាវ ឡើងគ្រងរាជ្យជំនួស។ មហេសីរបស់ស្តេចមាននាមថា មហេថាបែល ជាបុត្រីរបស់លោកស្រីម៉ាតរ៉េត និងជាចៅស្រីរបស់លោកមេសាហាប់។
[51]បន្ទាប់មក ព្រះបាទហាដាសោយទិវង្គត។ រីឯមេកន្ទ្រាញរបស់ជនជាតិអេដុមមាន លោកធីមណា លោកអាល់វ៉ា លោកយេថេត[52]លោកអហូលីបាម៉ា លោកអេឡា
លោកពីណូន[53]លោកកេណាស លោកថេម៉ាន លោកមីបសារ[54]លោកម៉ាកឌាល លោកអ៊ីរ៉ាម។ លោកទាំងនោះសុទ្ធតែជាមេកន្ទ្រាញរបស់ជនជាតិអេដុម។

---

1 Chronicles 1:1
កូនៗរបស់លោកណូអេមានលោកសិម លោកហាំ និង លោកយ៉ាផេត។
ការបកប្រែមួយចំនួនរួមមាន ULB និងUDB បញ្ចូលទាំង «កូនប្រុសៗ»
ដើម្បីបញ្ជាក់ឲ្យច្បាស់ថា សិម ហាំ និងយ៉ាផេត ជាបងប្អូននឹងគ្នា
ហើយជាកូនប្រុសៗរបស់លោកណូអេ។ បើមិនដូច្នោះទេ អ្នកអាននឹងសន្មតថា
មនុស្សម្នាក់ៗតំណាងឲ្យជំនាន់មួយឆ្ងាយពីលោកណូអេ
ដែលជាបុព្វបុរសរបស់ពួកគេ។
លោកអេណុស លោកកៃណាន លោកម៉ាលេលាល លោកយេរេឌ...លោកមធូសាឡា
ឈ្មោះទាំងនេះជាបញ្ជីរាយនាមបុព្វបុរស។
បើភាសារបស់អ្នកមានរបៀបជាក់លាក់ក្នុងការសម្គាល់បញ្ជីប្រភេទនេះ
អ្នកអាចប្រើវានៅទីនេះបាន។
1 Chronicles 1:5
កូមើរ ... ដានីម
ចូរបកប្រែឈ្មោះមនុស្សទាំងនេះតាមរបៀប
ដែលអ្នកនឹងបកប្រែឈ្មោះនៅក្នុងភាសារបស់អ្នក។
ទាំងនេះជាឈ្មោះបុរសទាំងអស់។
ដានីម
ជួនកាល ឈ្មោះនេះត្រូវគេសរសេរថា «រ៉ូដានីម» ដូចនៅក្នុង UDB។
1 Chronicles 1:8
មីសរ៉ែម ... នីមរ៉ូដ
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:11
ដែលត្រូវជាដូនតារបស់ជនជាតិភីលីស្ទីន
ការបកប្រែផ្សេងទៀត «បុព្វបុរសរបស់ពួកភីលីស្ទីន»
1 Chronicles 1:13
ហេត
នេះជាឈ្មោះរបស់មនុស្សម្នាក់។
ជនជាតិអើគី ... ជនជាតិហាម៉ាធីត
ទាំងនេះជាឈ្មោះរបស់ក្រុមមនុស្ស។
1 Chronicles 1:17
អើប៉ាកសាឌ... យ៉ុកថាន
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:20
យ៉ុកថាន ... យ៉ូបាប
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:24
លោកសិម... លោកសេរូក
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:28
លោកនេបាយ៉ូត... កេដម៉ា។
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:32
នាងកិទូរ៉ា ... អែលដាអា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:34
លោកអេលីផាស... មីសសា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:38
ឡូថាន ... អណា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:41
លោកអណា...អរ៉ាន
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 1:43
ព្រះបាទបេឡា ... លោកបេអរ ... ព្រះបាទយ៉ូបាប់ ... លោកសេរ៉ា ...ព្រះបាទហ៊ូសាម
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ក្រុងឌីនហាបា ...ក្រុងបូសរ៉ា
ទាំងនេះជាឈ្មោះទីកន្លែង។
ព្រះបាទហ៊ូសាម ជាអ្នកស្រុកថេម៉ាន ឡើងគ្រងរាជ្យជំនួស។
«ព្រះបាទហ៊ូសាម ពីទឹកដីដែលជាកន្លែងកូនចៅរបស់ថេម៉ានរស់នៅ
និងបានសោយរាជ្យបន្ទាប់ពីព្រះអង្គ» ។
អ្នកស្រុកថេម៉ាន
នេះជាឈ្មោះក្រុមមនុស្សមួយក្រុម។
1 Chronicles 1:46
ព្រះបាទហ៊ូសាម ... ព្រះបាទហាដាដ ... លោកបេដាដ ... ព្រះបាទសាំឡា ... ព្រះបាទសូល
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ក្រុងអាវីត ... ស្រុកម៉ាសរេកា ...ស្រុករ៉េហូបូត
ទាំងនេះជាឈ្មោះទីកន្លែង។
1 Chronicles 1:49
ព្រះបាទសូល ... ព្រះបាទបាល-ហាណាន់ ...លោកអកបោរ... ព្រះបាទហាដា ... លោកមេសាហាប់
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ក្រុងប៉ាវ
នេះជាឈ្មោះទីកន្លែង។
1 Chronicles 1:51
លោកធីមណា ... លោកអ៊ីរ៉ាម
ទាំងនេះជាឈ្មោះរបស់មនុស្ស។

---

2 [1]កូនប្រុសៗរបស់លោកអ៊ីស្រាអែលមាន រូបេន ស៊ីម្មាន លេវី យូដា អ៊ីសាខារ សាប់យូឡូន[2]ដាន់ យ៉ូសែប បេនយ៉ាមីន ណែបថាលី កាឌ និងអេស៊ើរ។

generated on Wed Sep 10 16:16:32 2025

[3]កូនប្រុសៗរបស់លោកយូដាមាន អ៊ើរ អូណាន់ និងសេឡា។ អ្នកទាំងបីនេះ ជាកូនដែលកើតពីស្ត្រីជនជាតិកាណាន ជាកូនស្រីរបស់លោកស៊ូអា។
លោកអ៊ើរដែលត្រូវជាកូនច្បងរបស់លោកយូដា ជាមនុស្សអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់ ដូច្នេះ ព្រះអង្គក៏ដកជីវិតគាត់ទៅ។
[4]ក្រោយមកលោកយូដាបានយកនាងតាម៉ារជាកូនប្រសា ហើយនាងបង្កើតបានពេរេស និងសេរ៉ាស។ ដូច្នេះ លោកយូដាមានកូនទាំងអស់ប្រាំនាក់។
[5]កូនប្រុសៗរបស់លោកពេរេសមាន ហេស្រុន និងហាមុល។[6]កូនប្រុសៗរបស់លោកសេរ៉ាសមាន ស៊ីមរី អេថាន ហេម៉ាន កាល់កូល និងដារ៉ា គឺទាំងអស់មានប្រាំនាក់។
[7]កូនប្រុសៗរបស់លោកកើមីគឺអេកាន ជាអ្នកនាំទុក្ខទោសមកលើជនជាតិអ៊ីស្រាអែល ដោយបានលួចយកវត្ថុដែលត្រូវបំផ្លាញថ្វាយផ្តាច់ដល់ព្រះជាម្ចាស់។
[8]កូនលោកអេថាន គឺអសារ៉ា។
[9]កូនប្រុសៗរបស់លោកហេស្រុនមាន យេរ៉ាម្អែល រ៉ាម និងកាលែប។[10]លោករ៉ាមជាឪពុករបស់លោកអមីណាដាប់ លោកអមីណាដាប់ជាឪពុករបស់លោកណាសូន
ដែលជាប្រមុខលើពួកកូនចៅយូដា[11]លោកណាសូនជាឪពុករបស់លោកសាលម៉ូន លោកសាលម៉ូនជាឪពុករបស់លោកបូអូស[12]លោកបូអូសជាឪពុករបស់លោកអូបិឌ
លោកអូបិឌជាឪពុករបស់លោកអ៊ីសាយ។
[13]លោកអ៊ីសាយជាឪពុករបស់លោកអេលាប ជាកូនច្បង អប៊ីណាដាប់ជាកូនទីពីរ សាំម៉ាជាកូនទីបី[14]នេថានេលជាកូនទីបួន រ៉ាដាយជាកូនទីប្រាំ[15]អូសែមជាកូនទីប្រាំមួយ
និងដាវីឌជាកូនទីប្រាំពីរ។
[16]រីឯបងប្អូនស្រីរបស់ពួកគេគឺនាងសេរ៊ូយ៉ា និងអប៊ីកែល។ កូនប្រុសៗរបស់នាងសេរ៊ូយ៉ាមានបីនាក់គឺ អប៊ីសាយ យ៉ូអាប់ និងអេសាអែល។[17]នាងអប៊ីកែលបង្កើតអម៉ាសា
រីឯឪពុករបស់អម៉ាសាឈ្មោះយេធើរ ជាជនជាតិអ៊ីស្មាអែល។
[18]លោកកាលែបជាកូនរបស់លោកហេស្រុន ព្រមទាំងនាងអស៊ូបាជាភរិយា បង្កើតបានកូនស្រីមួយឈ្មោះ យេរីអូត និងកូនប្រុសបីនាក់គឺ យេស៊ើរ សូបាប និងអើដូន។
[19]ពេលនាងអស៊ូបាស្លាប់ទៅ លោកកាលែបមានភរិយាមួយទៀតឈ្មោះនាងអេប្រា នាងបង្កើតបានកូនប្រុសមួយជូនលោក ដែលមានឈ្មោះថាហ៊ើរ។
[20]លោកហ៊ើរជាឪពុករបស់លោកយូរី ហើយលោកយូរីជាឪពុករបស់លោកបេតសាលាល។
[21]ក្រោយមក លោកហេស្រុនបានយកកូនស្រីម្នាក់របស់លោកម៉ាគារ ដែលត្រូវជាឪពុករបស់លោកកាឡាដមកធ្វើជាភរិយា។ ពេលនោះលោកមានអាយុ៦០ឆ្នាំហើយ
នាងបង្កើតបានកូនប្រុសមួយជូនលោកដែលមានឈ្មោះថា សេគូប។[22]លោកសេគូបជាឪពុករបស់លោកយ៉ាអ៊ៀរ ដែលជាអ្នកគ្រប់គ្រងលើភូមិម្ភៃបីនៅស្រុកកាឡាដ។
[23]ជនជាតិកេសួរី និងជនជាតិអើរ៉ាម បានវាយយកភូមិទាំងប៉ុន្មានរបស់លោកយ៉ាអ៊ៀរ ព្រមទាំងក្រុងកេណាតនិងស្រុកភូមិនៅជុំវិញដែលមានចំនួនទាំងអស់៦០។
ប្រជាជនដែលរស់នៅក្នុងក្រុងនោះសុទ្ធតែជាពូជពង្សរបស់លោកម៉ាគារជាឪពុករបស់លោកកាឡាដ។[24]បន្ទាប់ពី លោកហេស្រុនស្លាប់ទៅ
លោកកាលែបបានគេងជាមួយអេប្រាតា ជាភរិយាលោកហេស្រុនជាឪពុកគាត់ ហើយនាងបង្កើតកូនប្រុសមួយជូនគាត់មានឈ្មោះថា អាសហើរ
ដែលត្រូវជាឪពុករបស់លោកតេកូអា។
[25]រីឯកូនចៅរបស់លោកយេរ៉ាមែល ជាកូនច្បងរបស់លោកហេស្រុនមាន រ៉ាម ជាកូនច្បង ប៊ូណា អូរែន អូសេម និងអហ៊ីយ៉ា។
[26]លោកយេរ៉ាមែលមានប្រពន្ធមួយទៀតឈ្មោះនាងអថារ៉ា ដែលត្រូវជាម្តាយរបស់លោកអូណាម។[27]កូនចៅរបស់លោករ៉ាមដែលជាកូនច្បងរបស់លោកយេរ៉ាមែលមាន
ម៉ាអាស យ៉ាគីន និងអេគើរ។[28]កូនរបស់លោកអូណាមគឺ សាម៉ាយ និងយ៉ាដា។ កូនប្រុសៗរបស់លោកសាម៉ាយគឺ ណាដាប់ និងអប៊ីស៊ើរ។
[29]ភរិយារបស់លោកអប៊ីស៊ើរឈ្មោះអប៊ីហាអែល នាងបង្កើតកូនប្រុសពីរនាក់ជូនលោក គឺអបាន់ និងម៉ូលីឌ។[30]កូនរបស់លោកណាដាប់គឺ សេលេដ និង អផែម។
លោកសេលេដស្លាប់ទៅ តែគ្មានកូនទេ។[31]លោកអផែមជាឪពុករបស់លោកអ៊ីស៊ី លោកអ៊ីស៊ី ជាឪពុករបស់លោកសេសាន លោកសេសាន ជាឪពុករបស់លោកអឡាយ។
[32]កូនរបស់លោកយ៉ាដា ដែលត្រូវជាប្អូនរបស់លោកសាម៉ាយ គឺយេធើរ និងយ៉ូណាថាន។ លោកយេធើរស្លាប់ទៅ តែគ្មានកូនទេ។[33]កូនរបស់លោកយ៉ូណាថានគឺ ពេលេត
និងសាសា។ អ្នកទាំងនេះសុទ្ធតែជាកូនចៅរបស់លោកយេរ៉ាមែល។
[34]លោកសេសានគ្មានកូនប្រុសទេ គឺមានតែកូនស្រី។ លោកសេសានមានខ្ញុំបម្រើម្នាក់ជាជនជាតិអេស៊ីប ឈ្មោះយ៉ារហា។
[35]លោកសេសានបានលើកកូនស្រីគាត់ទៅឲ្យយ៉ារហាដែលជាខ្ញុំបម្រើនោះ នាងបង្កើតបានកូនប្រុសឲ្យគាត់ ឈ្មោះអថាយ។
[36]លោកអថាយជាឪពុករបស់លោកណាថាន លោកណាថានជាឪពុករបស់លោកសាបាដ។[37]លោកសាបាដជាឪពុករបស់លោកអែបឡាល
លោកអែបឡាលជាឪពុករបស់លោកអូបិឌ។[38]លោកអូបិឌ ជាឪពុករបស់លោកយេហ៊ូវ លោកយេហ៊ូវជាឪពុករបស់លោកអសារ៉ា។
[39]លោកអសារ៉ាជាឪពុករបស់លោកហាលេស លោកហាលេសជាឪពុករបស់លោកអេឡាសា។[40]លោកអេឡាសាជាឪពុករបស់លោកស៊ីសម៉ាយ
លោកស៊ីសម៉ាយជាឪពុករបស់លោកសាលូម។[41]លោកសាលូមជាឪពុករបស់លោកយេកាមីយ៉ា យេកាមីយ៉ាជាឪពុករបស់លោកអេលីសាម៉ា។
[42]រីឯកូនប្រុសៗរបស់លោកកាលែប ជាប្អូនរបស់លោកយេរ៉ាមែល គឺមេសា ជាកូនច្បង ដែលត្រូវជាឪពុករបស់ស៊ីភ។ ម៉ារីសា ជាកូនទីពីរដែលជាឪពុករបស់ហេប្រុន។
[43]កូនប្រុសៗរបស់ហេប្រុនមាន កូរ៉ា តាពួរ រេគែម និងសេម៉ា។[44]សេម៉ាជាឪពុករបស់រ៉ាហាំ រ៉ាហាំជាឪពុករបស់យ៉ូរគាម។ រេគែមជាឪពុករបស់សាម៉ាយ។
[45]លោកសាម៉ាយជាឪពុករបស់ម៉ាអូន លោកម៉ាអូនជាឪពុករបស់បេតស៊ើរ។[46]រីឯនាងអេប្រា ជាប្រពន្ធចុងរបស់លោកកាលែបបង្កើតបានហារ៉ាន ម៉ូសា និងកាសេស។
លោកហារ៉ានក៏មានកូនប្រុសមួយឈ្មោះកាសេសដែរ។[47]កូនប្រុសៗរបស់លោកយ៉ាដាយ គឺរេគែម យ៉ូថាម កេសាន ពេលេត អេផា និងសាអាប់។
[48]មាកា ជាប្រពន្ធចុងរបស់លោកកាលែប បង្កើតបានសេប៊ើរ និងទីហាណា។[49]នាងក៏បង្កើតបានសាអាប់ ជាឪពុករបស់ម៉ាដម៉ាណា ព្រមទាំងស៊ីវ៉ា ជាឪពុករបស់ម៉ាកបេណា
និងគីបៀរ។ រីឯកូនស្រីរបស់លោកកាលែបឈ្មោះនាងអាក់សា។[50]កូនឯទៀតៗរបស់លោកកាលែបជាកូនហ៊ើរមានដូចតទៅ
កូនដែលនាងអេប្រាតាបង្កើតជូនលោកគឺស៊ូបាល ជាកូនច្បង ជាអ្នកដែលសង់ក្រុង គាយ៉ាត-យារីម។
[51]សាលម៉ាជាអ្នកសង់បេថ្លេហិម ហារេបជាអ្នកសង់បេត-កាឌើរ។
[52]លោកស៊ូបាលជាអ្នកសង់ក្រុងគាយ៉ាត-យារីមក៏មានកូនចៅដែរ គឺអ្នកភូមិហារ៉ូអេ និងអ្នកភូមិហាស៊ី-
ហាមេនូហូតចំនួនពាក់កណ្តាល[53]ព្រមទាំងអំបូរនានានៅក្រុងគាយ៉ាត-យារីម គឺពួកយេធើរ ពូធី សូម៉ាធី និងមីសរ៉ា។ ពូជពង្សរបស់អ្នកទាំងនោះគឺពួកសូរ៉ាត
និងអែសថោស។
[54]រីឯកូនចៅរបស់លោកសាលម៉ាគឺអ្នកភូមិបេថ្លេហិម អ្នកភូមិនេថូផា អ្នកភូមិអាត្រូត-បេត -យ៉ូអាប់ អ្នកភូមិហាស៊ី-ហាម៉ាណាធីចំនួនពាក់កណ្តាល
អ្នកភូមិសោរីត[55]ព្រមទាំងអំបូររបស់ពួកស្មៀន នៅភូមិយ៉ាបេស គឺពួកធីរ៉ាត់ ពួកស៊ីម៉ាត់ និងពួកស៊ូកាត់។ អ្នកទាំងនេះសុទ្ធតែជាពួកកែន
ដែលជាពូជពង្សរបស់លោកហាម៉ាត់ ជាបុព្វបុរសរបស់អំបូររេកាប។

---

1 Chronicles 2:1
រូបេន ... អេស៊ើរ
ទាំងនេះជាឈ្មោះរបស់មនុស្ស។
1 Chronicles 2:3
ព័ត៌មានទូទៅ៖
សូមមើល
ព្រះអម្ចាស់
នេះជាព្រះនាមរបស់ព្រះជាម្ចាស់
ដែលទ្រង់បានបង្ហាញដល់ប្រជារាស្ត្រព្រះអង្គនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់។
សូមមើលការបកប្រែទំព័រនេះអំពីព្រះអម្ចាស់ ទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។
បង្កើតបានពេរេស និងសេរ៉ាស
«បានផ្តល់កំណើតឲ្យកូនប្រុសរបស់គាត់ ពេរេស និង សេរ៉ាស»
ប្រាំនាក់
«កូនប្រុស៥នាក់»
មិនគាប់ព្រះហឫទ័យព្រះអម្ចាស់
ការបកប្រែផ្សេងទៀត៖ «យោងទៅតាមព្រះអម្ចាស់»

generated on Wed Sep 10 16:16:32 2025

ព្រះអង្គក៏ដកជីវិតគាត់ទៅ។
មានន័យថា ព្រះអម្ចាស់បានអនុញ្ញាតឲ្យគេសម្លាប់អ៊ើរ ។
នាងតាម៉ារជាកូនប្រសា
សាច់ថ្លៃ សំដៅទៅលើភរិយារបស់កូនប្រុសគាត់។
1 Chronicles 2:5
ព័ត៌មានទូទៅ៖
1 Chronicles 2:9
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 2:13
ព័ត៌មានទូទៅ៖
សូមមើល
កូនទីពីរ ... កូនទីបី
«កូនទី ២ ... កូនទីបី»
1 Chronicles 2:16
ព័ត៌មានទូទៅ៖
យេធើរ ជាជនជាតិអ៊ីស្មាអែល។
មានន័យថា យេធើរជាកូនចៅរបស់អ៊ីស្មាអែល។
1 Chronicles 2:18
ព័ត៌មានទូទៅ៖
សូមមើល
បង្កើតបានកូន
ការបកប្រែផ្សេងទៀត «ផ្តល់កំណើត»
1 Chronicles 2:21
ព័ត៌មានទូទៅ៖
បង្កើតបានកូន
«បានផ្តល់កំណើតឲ្យ»»
1 Chronicles 2:23
ព័ត៌មានទូទៅ៖
បង្កើតបានកូន
«បានផ្តល់កំណើតឲ្យ»
1 Chronicles 2:25
ព័ត៌មានទូទៅ៖
សូមមើល
នាងអថារ៉ា
នេះជាឈ្មោះរបស់ស្ត្រី។
1 Chronicles 2:29
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 2:34
ព័ត៌មានទូទៅ៖
សូមមើល
បង្កើតបានកូន
«បានផ្តល់កំណើតឲ្យ»
1 Chronicles 2:36
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 2:39
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 2:42
ព័ត៌មានទូទៅ៖
សូមមើល
កូនប្រុសៗរបស់លោកកាលែប ... ម៉ារីសា
ការបកប្រែផ្សេងគ្នាយល់ពីទំនាក់ទំនងក្នុងចំណោមមនុស្សទាំងនេះ
តាមរបៀបផ្សេងៗគ្នា។ អ្នកបកប្រែមួយចំនួនជឿថា «ឪពុករបស់ហេប្រុន ...
ឪពុករបស់រ៉ាម៉ាឪពុករបស់ហេប្រុន ... ឪពុករបស់សាមម៉ា «មានន័យថាអ្នក»
បង្កើតត្រកូលហេប្រុន។ ល។ ការបកប្រែខ្លះអាចប្រើការ។
1 Chronicles 2:45
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 2:48
ព័ត៌មានទូទៅ៖
សូមមើល
បង្កើត
«បានផ្តល់កំណើតឲ្យ»
1 Chronicles 2:52
ព័ត៌មានទូទៅ៖
សូមមើល
មេនូហូត ..ពួកយេធើ ពូធី ក្រុងគាយ៉ាត-យ៉ារីម គឺពួកយេធើរ ពូធី ស៊ូម៉ាធី និងមីសរ៉ាពួកសូរ៉ាត
និងអែសថោស
ទាំងនេះជាឈ្មោះអំបូរ។
1 Chronicles 2:54
ភូមិនេថូផា,ភូមិអាត្រូត-បេត -យ៉ូអាប់ ... ម៉ាណាធី—ភូមិសោរីត ... ពួកធីរ៉ាត់, ពួកស៊ីម៉ាត់
និងពួកស៊ូកាត់ ...ពួកកែន ... អំបូរេកាប
ទាំងនេះជាឈ្មោះអំបូរ។

---

3 [1]រាជបុត្ររបស់ព្រះបាទដាវីឌ ដែលប្រសូត្រនៅក្រុងហេប្រូន មានដូចតទៅ បុត្រច្បងព្រះនាមអាំណូន ប្រសូតពីនាងអហ៊ីណោម ជាអ្នកស្រុកយេសរាល
បុត្រទីពីរព្រះនាមដានីអែល ប្រសូតពីនាងអប៊ីកែល ជាអ្នកភូមិកើមែល[2]បុត្រទីបីព្រះនាមអាប់សាឡុម ប្រសូតពីព្រះនាងម៉ាកាដែលត្រូវជាបុត្រីរបស់ព្រះបាទតាលម៉ាយ
ស្តេចស្រុកកេស៊ូរី បុត្រទីបួនព្រះនាមអដូនីយ៉ា ប្រសូតពីនាងហាគីត[3]បុត្រទីប្រាំព្រះនាមសេផាធា ប្រសូតពីនាងអប៊ីថាល បុត្រទីប្រាំមួយព្រះនាមយីត្រាម
ប្រសូតពីនាងអេកឡា។
[4]ទាំងប្រាំមួយអង្គនេះប្រសូតនៅក្រុងហេប្រូន។ ព្រះបាទដាវីឌសោយរាជ្យនៅក្រុងហេប្រូនអស់រយៈពេលប្រាំពីរឆ្នាំកន្លះ
ហើយសោយរាជ្យនៅក្រុងយេរូសាឡិមអស់រយៈពេលសាមសិបបីឆ្នាំ។[5]រីឯបុត្រដែលកើតនៅក្រុងយេរូសាឡិមមានព្រះនាម សាំម៉ា សូបាប់ ណាថាន និងសាឡូម៉ូន
បុត្របួនអង្គនេះកើតពីនាងបាតសេបា ជាកូនរបស់លោកអាំមាល។
[6]ព្រះបាទដាវីឌមានបុត្រាប្រាំបួនអង្គទៀត គឺយីបហារ អេលីសា អេផេលេត[7]ណូកា នេផេក យ៉ាភា[8]អេលីសាម៉ា អេលីយ៉ាដា និងអេលីផាលេត។
[9]ទាំងនេះសុទ្ធតែជាបុត្ររបស់ព្រះបាទដាវីឌ ដោយឥតគិតបុត្រដែលកើតពីពួកស្រីស្នំឡើយ។ ព្រះបាទដាវីឌក៏មានបុត្រីមួយអង្គដែរ គឺព្រះនាងតាម៉ារ។
[10]បុត្ររបស់ព្រះបាទសាឡូម៉ូនគឺព្រះបាទរេហូបោម។ បុត្ររបស់ព្រះបាទរេហូបោមគឺព្រះបាទអប៊ីយ៉ា។ បុត្ររបស់ព្រះបាទអប៊ីយ៉ាគឺព្រះបាទអេសា។
បុត្ររបស់ព្រះបាទអេសាគឺព្រះបាទយ៉ូសាផាត។[11]បុត្ររបស់ព្រះបាតយ៉ូសាផាតគឺព្រះបាទយ៉ូរ៉ាម។ បុត្ររបស់ព្រះបាទយ៉ូរ៉ាមគឺព្រះបាទអហាស៊ីយ៉ា។
បុត្ររបស់ព្រះបាទអហាស៊ីយ៉ាគឺព្រះបាទយ៉ូអាស[12]បុត្ររបស់ព្រះបាទយ៉ូអាសគឺព្រះបាទអម៉ាស៊ីយ៉ា។ បុត្ររបស់ព្រះបាទអម៉ាស៊ីយ៉ាគឺព្រះបាទអសារ៉ា។
បុត្ររបស់ព្រះបាទអសារ៉ាគឺព្រះបាទយ៉ូថាម។
[13]បុត្ររបស់ព្រះបាទយ៉ូថាមគឺព្រះបាទអហាស។ បុត្ររបស់ព្រះបាទអហាសគឺព្រះបាទហេសេគា។ បុត្ររបស់ព្រះបាទហេសេគាគឺព្រះបាទម៉ាណាសេ។
បុត្ររបស់ព្រះបាទម៉ាណាសេគឺព្រះបាទអាំម៉ូន[14]បុត្ររបស់ព្រះបាទអាំម៉ូនគឺព្រះបាទយ៉ូសៀស។
[15]រីឯបុត្ររបស់ព្រះបាទយ៉ូសៀសគឺយ៉ូហាណានជាបុត្រច្បង យេហូយ៉ាគីមជាបុត្រទីពីរ សេដេគាជាបុត្រទីបី និងសាលូមជាបុត្រទីបួន។[16]រីឯបុត្ររបស់ព្រះបាទយេហូយ៉ាគីម
គឺយេកូនាសនិងសេដេគា។
[17]រីឯបុត្ររបស់ព្រះបាទយេកូនាស ជាឈ្លើយសឹកនោះ គឺសាលធាល[18]ម៉ាលគីរ៉ាម ពេដាយ៉ា សេណាសារ យេកាម៉ា ហូសាម៉ា និងនេដាបយ៉ា។

generated on Wed Sep 10 16:16:32 2025

[19]កូនរបស់លោកពេដាយ៉ាគឺសូរ៉ូបាបិល និងស៊ីម៉ាយ។ កូនប្រុសៗរបស់លោកសូរ៉ូបាបិល មេស៊ូឡាម និងហាណានា ព្រមទាំងនាងសេឡូមីត។
[20]លោកមានកូនប្រាំនាក់ទៀតឈ្មោះ ហាស៊ូបា អូហែល បេរេគា ហាសាឌា និងយ៉ូសាបហេសេដ។[21]កូនប្រុសៗរបស់លោកហាណានាគឺ ពេឡាធា និងអេសាយ
ព្រមទាំងកូនចៅរបស់លោករេផាយ៉ា កូនចៅរបស់លោកអើណាន កូនចៅរបស់លោកអូបាឌា កូនចៅរបស់លោកសេកានា។
[22]កូនរបស់លោកសេកានាគឺលោកសេម៉ាយ៉ា កូនប្រុសរបស់លោកសេម៉ាយ៉ាគឺហាធូស យីកាល បារីយ៉ា នារីយ៉ា និងសាផាត។ សរុបទាំងអស់ប្រាំមួយនាក់។
[23]កូនប្រុសៗរបស់លោកនារីយ៉ាមានអេលីយ៉ូណៃ ហេសេគា និងអាសរីកាំ គឺសរុបទាំងអស់បីនាក់។[24]កូនប្រុសរបស់លោកអេលីយ៉ូណៃ គឺហូដាវា អេលាស៊ីប ពេឡាយ៉ា
អកាប យ៉ូហាណាន ដេឡាយ៉ា និងអណានី សរុបទាំងអស់ប្រាំពីរនាក់។

---

1 Chronicles 3:1
ព្រះបាទដាវីឌ
ព្រះបាទដាវីឌជាកូនរបស់លោកអ៊ីសាយ ដែលជាកូនចៅលោកយូដា។ (សូមមើល ២:១៣)
នាងអហ៊ីណោម ... នាងអប៊ីកែល ... នាងម៉ាកា ...នាងហាគីត ... នាងអប៊ីថាល ... នាងអេកឡា
ទាំងនេះជាឈ្មោះរបស់ស្ត្រី។
ព្រះបាទតាលម៉ាយ ... ព្រះនាមសេផាធា ...ព្រះនាមយីតរាម
ទាំងនេះជាឈ្មោះបុរស។
នាមដានីអែល
បុរសនេះមានឈ្មោះដូចព្យាការីអ៊ីស្រាអែលដែរ តែគាត់ជាមនុស្សផ្សេង។
ប្រសូតពីនាងអេកឡា។
«នាងអេកឡាជាភរិយារបស់ព្រះបាទដាវីឌ»។
ព្រះបាទដាវីឌមានមហេសីលើសពីមួយ។ ការបកប្រែផ្សេងទៀត
«មហេសីរបស់ព្រះបាទដាវីឌឈ្មោះនាងអេកឡា»
1 Chronicles 3:4
ព្រះបាទដាវីឌសោយរាជ្យនៅក្រុងហេប្រូនអស់រយៈពេលប្រាំពីរឆ្នាំកន្លះ
អាចបកប្រែជាប្រយោគដាច់ដោយឡែកមួយផងដែរ៖ «
ព្រះបាទដាវីឌបានសោយរាជ្យនៅទីនោះ ប្រាំពីរឆ្នាំប្រាំមួយខែ។»
អស់រយៈពេលសាមសិបបីឆ្នាំ
បីឆ្នាំ «៣៣ ឆ្នាំ»
លោកអាំមាល ...ណាថាន ... ណាថាន ...ណាថាន
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 3:6
គឺយីបហារ ... អេលីសាម៉ា ... អេលីផាលេត ... ណូកា... នេផេក ... យ៉ាភា ... អេលីយ៉ាដា
ទាំងនេះជាឈ្មោះបុរស។
អេលីសាម៉ា ... អេផេលេត
ឈ្មោះទាំងនេះត្រូវគេដាក់ឲ្យកូនប្រុសពីរនាក់។
1 Chronicles 3:10
ព័ត៌មានទូទៅ៖
នេះជាការចាប់ផ្តើមនៃបញ្ជីកូនចៅរបស់ដាវីឌ ដែលបានឡើងសោយរាជ្យ។
បុត្រារបស់ព្រះបាទសាឡូម៉ូនគឺព្រះបាទរេហូបោម។ បុត្រារបស់ព្រះបាទរេហូបោមគឺព្រះបាទអប៊ីយ៉ា។
ព្រះបាទសាឡូម៉ូនមានកូនប្រុសច្រើនជាងមួយ។
បុរសផ្សេងទៀតនៅក្នុងបញ្ជីក៏ដូចគ្នាដែរ។ ការបកប្រែផ្សេងទៀត
«សាឡូម៉ូនជាបិតារបស់រេហូបោម។ រេហូបោមជាបិតារបស់អប៊ីយ៉ា»
ព្រះបាទអហាស៊ីយ៉ា
នេះជានាមមួយទៀតរបស់អូសៀស ដែលជានាមល្បីចំពោះស្តេចនេះ។
អ្នកបកប្រែអាចសម្រេចចិត្តប្រើ «អូសៀស» គ្រប់ទីកន្លែងសម្រាប់ស្តេចនេះ។
1 Chronicles 3:13
ព័ត៌មានទូទៅ៖
នេះជាបញ្ជីបន្តរបស់កូនចៅព្រះបាទដាវីឌ ដែលបានឡើងសោយរាជ្យ។
បង្កើតប្រយោគទាំងនេះ ដូចអ្នកបានធ្វើចាប់ផ្តើមនៅ ៣:១០។
ព្រះបាទអាំម៉ូន
នេះជាឈ្មោះបុរសម្នាក់។
1 Chronicles 3:15
ព័ត៌មានទូទៅ៖
នេះជាបញ្ជីបន្តរបស់កូនចៅព្រះបាទដាវីឌ ដែលបានឡើងសោយរាជ្យ។
បង្កើតប្រយោគទាំងនេះ ដូចអ្នកបានធ្វើចាប់ផ្តើមនៅ ៣:១០។
យ៉ូហាណាន ... សាលូម ...ព្រះបាទយេហូយ៉ាគីម
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 3:17
ព្រះបាទយេកូនាស
ការបកប្រែខ្លះ «យេកូនា» ដែលផ្សេងគ្នាពី «ព្រះបាទយេកូនាស»។
ជាឈ្លើយសឹក
នេះប្រហែលជាងារមួយ ដែលគេប្រគល់ជូនព្រះបាទយេកូនាស
ពីព្រោះទ្រង់ត្រូវបានគេចាប់យកទៅជាឈ្លើយ។ ទោះយ៉ាងណាក៏ដោយ
មានការបកប្រែខ្លះចាត់ទុកពាក្យនេះថា «អាស៊ើរ»
ដែលជាឈ្មោះបុត្រាម្នាក់របស់ព្រះអង្គ។
ព្រះបាទយេកូនាស ... គឺសាលធាល ម៉ាលគីរ៉ាម ពេដាយ៉ា សេណាសារ យេកាម៉ា ហូសាម៉ា
និងនេដាបយ៉ា។
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 3:19
លោកពេដាយ៉ា ... ស៊ីម៉ាយ... មេស៊ូឡាម ... ហាណានា ... ហាស៊ូបា ... អូហែល... បេរេគា ...
ហាសាឌា ... យ៉ូសាបហេសេដ ... ពេឡាធា ... អេសាយ ... លោករេផាយ៉ា ... លោកអើណាន ...
លោកសេកានា
ទាំងនេះជាឈ្មោះបុរស។
នាងសេឡូមីត
នេះជាឈ្មោះស្ត្រី។
លោកអូបាឌា
បុរសនេះមានឈ្មោះដូចគ្នានឹងព្យាការីអូបាឌាដែរ តែគាត់ជាមនុស្សផ្សេងគ្នា។
ព្រមទាំងកូនចៅរបស់លោករេផាយ៉ា កូនចៅរបស់លោកអើណាន កូនចៅរបស់លោកអូបាឌា
កូនចៅរបស់លោកសេកានា
ឈ្មោះផ្សេងៗពីគ្នាទាំងនេះធ្វើឲ្យពួកគេមានទំនាក់ទំនង ជាមួយគ្នា
ពីព្រោះភាសាហេប្រឺមិនបានបញ្ជាក់ច្បាស់ទេ។
1 Chronicles 3:22
លោកសេម៉ាយ៉ា ...ហាធូស ...យីកាល ... បារីយ៉ា ... នារីយ៉ា ... សាផាត ...អេលីយ៉ូណៃ ...
ហេសេគា ... អាសរីកាំ ... គឺហូដាវា ... អេលាស៊ីប ... ពេឡាយ៉ា ... អកាប ...
យ៉ូហាណាន...ដេឡាយ៉ា ...អណានី
ទាំងនេះជាឈ្មោះបុរស។

---

4 [1]កូនចៅរបស់លោកយូដាមាន ពេរេស ហេស្រុន កើរមី ហ៊ើរនិងសូបាល។[2]លោករីយ៉ាអា ជាកូនរបស់លោកសូបាល បង្កើតយ៉ាហាត់ យ៉ាហាត់បង្កើតអហ៊ូម៉ាយ
និងឡាហាដ អ្នកទាំងនេះជាអំបូរសូរ៉ាត។
[3]អស់អ្នកដែលកើតមកពីឪពុករបស់លោកអេថាមមាន យេសរាល យីមា និងយីដបា ហើយប្អូនស្រីរបស់គេឈ្មោះហាសែលេពូនី។[4]លោកពេនួលជាអ្នកសង់ភូមិកេដោរ
លោកអេស៊ើរជាអ្នកសង់ភូមិហ៊ូសា។ អ្នកទាំងនេះសុទ្ធតែជាកូនចៅរបស់លោកហ៊ើរ ជាកូនច្បងរបស់អេប្រាតា ហើយជាអ្នកសង់ភូមិបេថ្លេហិម។
[5]លោកអាស៊ើរជាអ្នកសង់ក្រុងតេកូអា មានប្រពន្ធពីរ គឺនាងហេឡា និងនាងណាអារ៉ា។[6]នាងណាអារ៉ាបង្កើតកូនប្រុសជូនគាត់ ដែលមានឈ្មោះថា អហូសាំ ហេភើរ ថេម៉ានី
អហាសថារី។ អ្នកទាំងនេះសុទ្ធតែជាកូនរបស់នាងណាអារ៉ា។[7]រីឯកូនរបស់នាងហេឡាមាន សេរ៉ែត សូហារ និងអេតណាន។[8]លោកកូសបង្កើតអនូប និងសូបេបា
ព្រមទាំងអំបូរអខាហែល ជាកូនប្រុសរបស់ហារូម។
[9]លោកយ៉ាបេស ជាមនុស្សដែលគេគោរពរាប់អានច្រើនជាងបងប្អូនរបស់គាត់។ ម្តាយរបស់គាត់បានដាក់ឈ្មោះគាត់ថា យ៉ាបេស ដោយពោលថា
«ខ្ញុំបានបង្កើតកូននេះមកដោយឈឺចាប់»។[10]លោកយ៉ាបេសបានអង្វររកព្រះរបស់ជនជាតិអ៊ីស្រាអែលថា៖ «សូមប្រទានពរទូលបង្គំ សូមពង្រីកទឹកដីរបស់ទូលបង្គំ
ហើយដាក់ព្រះហស្តលើទូលបង្គំ កុំឲ្យទូលបង្គំជួបប្រទះទុក្ខវេទនា និងការឈឺចាប់ឡើយ!» ដូច្នេះ ព្រះជាម្ចាស់ក៏ប្រោសប្រទានតាមសំណូមពររបស់គាត់។

generated on Wed Sep 10 16:16:32 2025

[11]លោកកេលូប ដែលត្រូវជាប្អូនរបស់លោកស៊ូហា បង្កើតបានមេហើរ ដែលជាឪពុករបស់អែសថូន[12]លោកអែសថូនបង្កើតបេតរ៉ាផា ផាសេហា និងថេហ៊ីណា។
លោកថេហ៊ីណាជាអ្នកសង់ភូមិណាហាស។ ពូជពង្សរបស់អ្នកទាំងនេះរស់នៅក្នុងតំបន់រេកា។
[13]កូនប្រុសៗរបស់លោកកេណាសគឺអូធ្នាល និងសេរ៉ាយ៉ា។ កូនប្រុសៗរបស់លោកអូធ្នាលគឺហាថាត និងមេអូណូថាយ[14]លោកមេអូណូថាយ ជាឪពុករបស់អូប្រា។
លោកសេរ៉ាយ៉ា ជាឪពុករបស់យ៉ូអាប់ ជាបុព្វបុរសរបស់ពួកសិប្បករដែលរស់នៅតាមតំបន់ជ្រលងភ្នំរបស់ពួកសិប្បករ។[15]លោកកាលែប ជាកូនរបស់លោកយេភូនេ
មានកូនប្រុសបីនាក់គឺ អ៊ីរូ អេឡា និងណាអាម។ កូនប្រុសរបស់អេឡា គឺ កេណាស។[16]កូនប្រុសៗរបស់លោកយេហាលែលគឺស៊ីភ ស៊ីផា ធារីយ៉ា និងអសារ៉ែល។
[17]កូនប្រុសៗរបស់អែសរ៉ាគឺយេធើរ ម៉ារេឌ អេភើរ និងយ៉ាឡូន។ លោកម៉ារេឌបានរៀបការជាមួយព្រះនាងប៊ីធា ជាបុត្រីរបស់ព្រះចៅផារ៉ោន ហើយបង្កើតបានម៉ារាម
សាម៉ាយ និងយីសបា ដែលជាអ្នកសង់ក្រុងអែសធេម៉ូរ។[18]អ្នកទាំងនេះគឺជាកូនប្រុសរបស់នាងប៊ីធា ជាអ្នកដែលលោកម៉ារេឌបានរៀបការជាមួយ។
រីឯប្រពន្ធរបស់លោកម៉ារេឌមួយទៀត ដែលជាជនជាតិយូដា បង្កើតបានយេរេឌ ជាអ្នកសង់ក្រុងកេដោរ ហេប៊ើរជាអ្នកសង់ក្រុងសូគរ និងយេគូធាល
ជាអ្នកសង់ក្រុងសាណូអា។
[19]កូនប្រុសពីរនាក់របស់ប្រពន្ធលោកហ៊ូឌា ដែលជាមួយប្អូនស្រីរបស់លោកណាហាំ ម្នាក់បានក្លាយជាឪពុករបស់ពួកកាមីត ជាអ្នកសង់ក្រុងកៃឡា។
ហើយម្នាក់ទៀតគឺលោកម៉ាកាធីជាអ្នកសង់ក្រុងអែសធេម៉ូរ។[20]កូនប្រុសៗរបស់លោកស៊ីម៉ូនគឺ អាំណូន រីនណា បេន-ហាណាន និងធីឡូន។
កូនប្រុសៗរបស់លោកអ៊ីស៊ីគឺសូហេត និងបេន-សូហេត។
[21]កូនចៅរបស់លោកសេឡា ដែលត្រូវជាកូនរបស់លោកយូដាគឺអ៊ើរ ជាអ្នកសង់ក្រុងលេកា លោកឡាអាដា ជាអ្នកសង់ក្រុងម៉ារីសា
ពូជអំបូររបស់អ្នកដែលត្បាញក្រណាត់ទេសឯកសុទ្ធ និងក្រុមគ្រួសារអាសបេអា[22]លោកយ៉ូគីម អ្នកស្រុកកូសេបា លោកយ៉ូអាស់ និងលោកសារ៉ាប់
ដែលគ្រប់គ្រងលើស្រុកម៉ូអាប់ ព្រមទាំងយ៉ាស៊ូប៊ី-លេហែម (នេះជាបញ្ជីពីចាស់បុរាណ)[23]អ្នកទាំងនេះជាជាងស្មូនរស់នៅភូមិនេតាអ៊ីម និងភូមិកេដេរ៉ា។ ពួកគេរស់នៅទីនោះ
ហើយធ្វើការថ្វាយស្តេច។
[24]រីឯកូនចៅរបស់លោកស៊ីម្មាន មាន នេមូល យ៉ាមីន យ៉ាគិន សេរ៉ាស និងសូល។[25]កូនចៅរបស់លោកសូលមានរាយនាមតាមតំណរង្សត្រកូលជាបន្តបន្ទាប់ដូចតទៅ
សាលូម មីបសាម មីសម៉ា[26]កូនចៅរបស់លោកមីសម៉ាគឺហាមូអែល កូនរបស់លោកហាមូអែល គឺសាគើរ កូនរបស់សាគើរ គឺស៊ីម៉ាយ។
[27]លោកស៊ីម៉ាយមានកូនប្រុសដប់ប្រាំមួយនាក់ និងកូនស្រីប្រាំមួយនាក់ រីឯបងប្អូនរបស់គាត់មិនសូវមានកូនច្រើនទេ។ ដូច្នេះ
ពូជពង្សរបស់លោកស៊ីម្មានមិនកើនចំនួនច្រើន ដូចពូជពង្សរបស់លោកយូដាឡើយ។[28]អ្នកទាំងនោះរស់នៅតាមក្រុងបៀសេបា ម៉ូឡាដា ហាសា-ស៊ូអាល។
[29]ពួកគេក៏រស់នៅតាមភូមិប៊ីលហា អេសែម ថូឡាឌ[30]បេធូល ហោម៉ា ស៊ីកឡាក់[31]បេត-ម៉ារកាបូត ហាសា-ស៊ូសា បេត-ប៊ីរៃ ហើយនៅស្អារ៉ែមផងដែរ។
ក្រុងទាំងនោះគឺជាទីក្រុងរបស់ពួកគេរហូតដល់រជ្ជកាលព្រះបាទដាវីឌ។
[32]ពួកគេក៏រស់នៅតាមទីក្រុងប្រាំទៀតគឺ អេថាម អាយីន រីម៉ូន ថូកែន និងអេសាន[33]ព្រមទាំងស្រុកភូមិដែលនៅជុំវិញក្រុងទាំងនោះ រហូតដល់ក្រុងបាល។
នេះជាឈ្មោះក្រុងដែលពួកគេរស់នៅ និងបញ្ជីរាយនាមពូជពង្សរបស់ពួកគេ។
[34]មេដឹកនាំអំបូររបស់ពួកគេមានរាយនាមដូចតទៅ លោកមេសូបាប់ លោកយ៉ាមលេក លោកយ៉ូសា ជាកូនរបស់លោកអ៊ាស៊ីយ៉ា[35]លោកយ៉ូអែល លោកយេហ៊ូ
ជាកូនរបស់លោកយ៉ូស៊ីមយ៉ា ជាចៅរបស់លោកសេរ៉ាយ៉ា និងជាចៅទួតរបស់លោកអស៊ីអែល[36]លោកអេលីយ៉ូណៃ លោកយ៉ាកូបា លោកយេសូហាយ៉ា លោកអសាយ៉ា
លោកអឌីអែល លោកយេស៊ីមាលលោកបេណាយ៉ា[37]លោកស៊ីសា ជាកូនរបស់លោកស៊ីភី ជាចៅរបស់លោកអឡូន ជាចៅទួតរបស់លោកយេដាយ៉ា
ជាចៅលួតរបស់លោកស៊ីមរី ជាចៅលោរបស់លោកសេម៉ាយ៉ា[38]អ្នកទាំងនោះសុទ្ធតែមេលើអំបូររបស់គេ ហើយក្រុមគ្រួសាររបស់ពួកគេបានកើនចំនួនឡើងជាច្រើន។
[39]ដូច្នេះ ពួកគេបានចូលទៅជិតក្រុងកេដោរ ដែលនៅខាងកើតជ្រលងភ្នំ ដើម្បីស្វែងរកវាលស្មៅសម្រាប់ចិញ្ចឹមហ្វូងសត្វរបស់ពួកគេ។[40]ពួកគេរកបានវាលស្មៅដ៏បរិបូរ។
រីឯស្រុកនោះក៏ទូលាយ ស្ងប់ស្ងាត់ ហើយសុខស្រួលផង។ ពីដើម ពូជពង្សរបស់លោកហាំរស់នៅក្នុងស្រុកនោះ។[41]នៅរជ្ជកាលព្រះបាទហេសេគាជាស្តេចស្រុកយូដា
អស់អ្នកដែលមានឈ្មោះខាងលើ បានមកដល់ស្រុកនោះ ពួកគេបំផ្លាញទីលំនៅ និងជម្រកទាំងប៉ុន្មាននៅក្នុងស្រុកនោះ។ ពួកគេបានបំផ្លាញអ្វីៗ
និងប្រជាជនឲ្យវិនាសទាំងស្រុង ដោយសារពួកគេបានរកឃើញទីនោះមានវាលស្មៅសម្រាប់ហ្វូងចៀមរបស់ពួកគេ។
[42]មានកូនចៅរបស់លោកស៊ីម្មានប្រមាណប្រាំរយនាក់ទៀត បាននាំគ្នាទៅតំបន់ភ្នំសៀរ ដោយមានលោកពេឡាធា លោកនារីយ៉ា លោករេផាយ៉ា និងលោកអ៊ូស៊ាល
ជាកូនលោកអ៊ីស៊ី ធ្វើជាមេដឹកនាំ។[43]ពួកគេប្រហារជនជាតិអាម៉ាឡេកដែលនៅសេសសល់ រួចក៏តាំងទីលំនៅក្នុងស្រុកនោះ រហូតដល់សព្វថ្ងៃ។

---

1 Chronicles 4:1

ពេរេស ... ហេស្រុន ... កើរមី ... ហ៊ើរ ... សូបាល។ ... លោករីយ៉ាអា ...

យ៉ាហាត់...អហ៊ូម៉ាយ...ឡាហាដ...អំបូរសូរ៉ាត

ទាំងនេះជាឈ្មោះបុរស។

អំបូរសូរ៉ាត

ក្រុមប្រជាជននេះត្រូវបានគេដាក់ឈ្មោះ
តាមក្រុងសូរ៉ាជាកន្លែងដែលពួកគេរស់នៅ។

1 Chronicles 4:3

អស់អ្នកដែលកើតមកពីឪពុក

សំដៅទៅលើបញ្ជីឈ្មោះនៅក្នុងខគម្ពីរមុន។ ទោះយ៉ាងណាក៏ដោយ
មានការបកប្រែខ្លះចាត់ទុកឈ្មោះទាំងនេះថា
មានទំនាក់ទំនងរវាងឪពុកនិងកូនប្រុស។ នៅក្នុងរបៀបដូចគ្នានេះដែរ
ការបកប្រែខ្លះចាត់ទុកលោកពេនួលជាឪពុករបស់កេដោរ
ជំនួសឲ្យអំបូរដើមកេដោរ។

លោកអេថាម ... ភូមិកេដោរ ... ភូមិហ៊ូសា

ទាំងនេះជាឈ្មោះទីក្រុង។

យីមា ...យីដបា... លោកពេនួល ... លោកអេស៊ើរ ... អេប្រាតា

ទាំងនេះជាឈ្មោះបុរស។

ហាសែលេលពូនី

នេះជាឈ្មោះស្ត្រី។

អ្នកទាំងនេះសុទ្ធតែជាកូនចៅរបស់លោកហ៊ើរ

លោកពេនួលនិងអេស៊ើរជាកូនចៅរបស់លោកហ៊ើរ។
ចង្អុលបង្ហាញបញ្ជីដែលនឹងមកតាមក្រោយ។

1 Chronicles 4:5

លោកអាស៊ើរ ... ក្រុងតួអា ... អហូសាំ... ហេភើរ ... សេរ៉ែត ...សូហារ ... អេតណាន ...

លោកកូស... អនូប ... សូបេបា ... អខាហែល ... ហារូម

ទាំងនេះជាឈ្មោះបុរស។

ថេម៉ានី ... អហាសថារី

គេយល់ថា ទាំងនេះជាឈ្មោះបុរស។ ទោះយ៉ាងណាក៏ដោយ
មានការបកប្រែខ្លះយល់ថា
ឈ្មោះអំបូរដែលត្រូវបានចាប់ផ្តើមដោយកូនប្រុសរបស់លោកអាស៊ើរ។

នាងហេឡា ... នាងណាអារ៉ា

ទាំងនេះជាឈ្មោះស្ត្រី។

បង្កើតកូនប្រុសជូនគាត់

ការបកប្រែផ្សេងទៀត «បានបង្កើតកូនប្រុសជូនគាត់»
ព្រមទាំងអំបូរអខាហែល ជាកូនប្រុសរបស់ហារូម។
មានប្រយោគថ្មីអាចចាប់ផ្តើមនៅទីនេះ។ ការបកប្រែផ្សេងទៀត
«លោកកូសក៏បានក្លាយជាបុព្វបុរសរបស់ហារូម
និងអំបូរដែលបានចុះមកពីអខាហែលជាកូនប្រុសរបស់ហារូម»

1 Chronicles 4:9

លោកយ៉ាបេស

នេះជាឈ្មោះបុរសម្នាក់។

សូមពង្រីកទឹកដីរបស់ទូលបង្គំ

ការបកប្រែផ្សេងទៀត «សូមប្រទានទឹកដីឲ្យខ្ញុំបន្ថែមទៀត»

ហើយដាក់ព្រះហស្តលើទូលបង្គំ

អាចមានន័យថា ព្រះហស្តរបស់ព្រះជាម្ចាស់តំណាងឲ្យ ១) ការដឹកនាំរបស់ព្រះអង្គ

generated on Wed Sep 10 16:16:32 2025

២) អំណាចរបស់ព្រះអង្គ ឬ ៣) ការការពាររបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត «សូមដឹកនាំទូលបង្គំ» ឬ «សូមធ្វើឲ្យទូលបង្គំចម្រុងចម្រើន» ឬ «ការពារទូលបង្គំ»។ អាចបកប្រែថែមទៀតថា «នៅជាមួយទូលបង្គំ» ។
ក៏ប្រោសប្រទានតាមសំណូមពររបស់គាត់
«បានធ្វើទៅតាមការអធិស្ឋានរបស់គាត់»
1 Chronicles 4:11
លោកកេលូប ... លោកស៊ូហា... មេហើរ ...លោកអែសថូន ...បេតរ៉ាផា... ផាសេហា ... ថេហ៊ីណា
ទាំងនេះជាឈ្មោះបុរស។
លោកថេហ៊ីណាជាអ្នកសង់ភូមិណាហាស។
« លោកថេហ៊ីណាជាអ្នកបង្កើតភូមិណាហាស»
ភូមិណាហាស
នេះជាឈ្មោះទីក្រុងមួយ។
តំបន់រេកា
នេះជាឈ្មោះកន្លែងមួយ។
1 Chronicles 4:13
ព័ត៌មានទូទៅ:
គឺប្រហែលមានប្រយោជន៍ក្នុងការបង្កើតស្ពានពីខមួយហើយនិងដាក់ទៅខ ១៥ ជាមួយគ្នានឹងខ ១៣ ចាប់តាំងពីលោកកេណាសជាកូនចៅរបស់លោកយេភូនេ និងកាលែប។
ជាបុព្វបុរសរបស់ពួកសិប្បករដែលរស់នៅតាមតំបន់ជ្រលងភ្នំរបស់ពួកសិប្បករ។
ពួកសិប្បករ មានន័យថា "ជ្រលងភ្នំនៃសិប្បករ" ។
អត្ថន័យនៃឈ្មោះអាចត្រូវបានបកប្រែឬវាអាចត្រូវបានធ្វើឱ្យច្បាស់ជាមួយការពន្យល់ថា «ពួកសិប្បករដែលមានន័យថា» ជ្រលងភ្នំរបស់សិប្បករ។
វាត្រូវបានគេហៅថាដូចនេះដោយសារតែប្រជាជនរបស់ខ្លួនគឺជាសិប្បករ។
លោកកេណាស... លោកអូធ្នាល ... សេរ៉ាយ៉ា ... ហាថាត ... លោកមេអូណូថាយ ... អូប្រា ... យ៉ូអាប់ ... លោកយេភូនេ ... អ៊ីរូ ... អេឡា... ណាអាម... លោកយេហាលែល ... គីស៊ីភ... ស៊ីផា ... ធារីយ៉ា ... អសារ៉ែល
ទាំងនេះគឺជាឈ្មោះរបស់បុរស។
ពួកសិប្បករ
មនុស្សមានជំនាញខាងការបង្កើតឬ ការកែច្នៃរបស់របរ
1 Chronicles 4:17
ព័ត៌មានទូទៅ៖
ព័ត៌មាននៅក្នុង ៤:១៧ ត្រូវបានរៀបចំជាថ្មីឡើងវិញ ដូច្នេះគេងាយយល់ន័យជាង។
អែសរ៉ា ... យេធើរ ... ម៉ារេឌ ... អេភើរ ... យ៉ាឡូន ... ម៉ារាម... សាម៉ាយ ... យីសបា ...អែសធេម៉ូរ ... យេរេឌ ... កេដោរ ... ហោប៊ើរ ... សូគរ ... យេគូធាល ... សាណូអា
ទាំងនេះជាឈ្មោះបុរស។
អ្នកទាំងនេះគឺជាកូនប្រុសរបស់នាងប៊ីធា
ពាក្យថា «ទាំងនេះ» សំដៅលើមីរាម សាមម៉ាយនិងអ៊ីសបា។ ពួកគេជាកូនប្រុសដែលប៊ីធាបង្កើតឲ្យប្តីរបស់នាងឈ្មោះមេដ។
នាងប៊ីធា
នេះជាឈ្មោះស្ត្រី។
ប្រពន្ធរបស់លោកម៉ារេឌមួយទៀត ដែលជាជនជាតិយូដា
ភាសាហេប្រឺសរសេរថា «ភរិយារបស់គាត់ជាជនជាតិយូដា» ប៉ុន្តែភាសាភាគច្រើនយល់ថា «របស់គាត់» សំដៅទៅលើលោកម៉ារេឌ។ សំដៅទៅលើប្រពន្ធផ្សេងរបស់លោកម៉ារេឌ បន្ថែមលើនាងប៊ីធា។
1 Chronicles 4:19
លោកហ៊ូឌា ... លោកណាហាំ ... កៃឡា ... អែសធេម៉ូរ ... លោកស៊ីម៉ូន ... លោកស៊ីម៉ូន... អាំណូន ... រីនណា បេន-ហាណាន ... ធីឡូន ... លោកអ៊ីស៊ី ... សូហេត ... បេន-សូហេត។
ទាំងនេះជាឈ្មោះបុរស។
ពួកកាមីត
ម្នាក់មកពីក្រុមប្រជាជនកា
លោកម៉ាកាធី
ម្នាក់មកពីតំបន់ម៉ាកា ដែលត្រូវបានគេហៅថា ម៉ាកាធផងដែរ
1 Chronicles 4:21
លោកសេឡា ... អ៊ើរ ...លេកា ... លោកឡាអាដា... ម៉ារីសា ... លោកយ៉ូគីម ... លោកយ៉ូអាស់ ... លោកសារ៉ាប់
ទាំងនេះជាឈ្មោះបុរស។
ក្រណាត់ទេសឯកសុទ្ធ
ក្រណាត់មួយប្រភេទ
ជាងសូន
មនុស្សដែលធ្វើក្អម ឬ ថូចេញពីដីឥដ្ឋ
អាសបេអា ... ស្រុកកូសេបា ... ភូមិនេតាអ៊ីម ... ភូមិកេដេរ៉ា
ទាំងនេះជាឈ្មោះទីក្រុង។
1 Chronicles 4:24
នេមូល ... យ៉ាមីន ... យ៉ាគិន ... សេរ៉ាស ... សូល ... សាលូម ... មីបសាម... មីសម៉ា ... ហាមូអែល ... សាគើរ ... ស៊ីម៉ាយ
ទាំងនេះជាឈ្មោះបុរស។
កូន
កូនប្រុសរបស់មនុស្សម្នាក់។
កូនរបស់
ចៅប្រុស គឺជាកូនប្រុសរបស់មនុស្ស ដែលចៅប្រុស ឬចៅស្រីរបស់មនុស្ស។
1 Chronicles 4:27
មានកូនប្រុសដប់ប្រាំមួយនាក់ និងកូនស្រីប្រាំមួយនាក់
«កូនប្រុស១៦នាក់ និងកូនស្រី៦នាក់»
ម៉ូឡាដា ... ហាសា-ស៊ូអាល។
ទាំងនេះជាឈ្មោះក្រុង។
1 Chronicles 4:29
ព័ត៌មានទូទៅ៖
តារាងឈ្មោះទីក្រុងទាំងឡាយ ដែលកូនចៅរបស់ស៊ីម្មានបន្តរស់នៅ។
បីលហា ...អេសែម... ថូឡាឌ ... បេធូល ...ហោម៉ា ...ស៊ីកឡាក់ ... បេត-ម៉ារកាបូត ... ហាសា-ស៊ូសា ... បេត-ប៊ីរ៉ៃ ... ស្ហារ៉ែម
ទាំងនេះជាឈ្មោះទីក្រុង។
1 Chronicles 4:32
ព័ត៌មានទូទៅ៖
តារាងឈ្មោះទីកន្លែង ដែលកូនចៅរបស់ស៊ីម្មានបន្តរស់នៅ។
អេថាម ... អាយីន... រីម៉ូន ... ថូកែន... អេសាន
ទាំងនេះជាឈ្មោះភូមិ។
ស្រុកភូមិ
ឆ្ងាយពីកន្លែងមានប្រជាជនច្រើន
ក្រុងបាល
នេះជាឈ្មោះទីក្រុងមួយ។ គេក៏ហៅថាទីក្រុងនោះថា បាឡាតដែរ។
1 Chronicles 4:34
លោកមេសូបាប់... លោកយ៉ាមលេ... លោកយ៉ូសា ... លោកអម៉ាស៊ីយ៉ា ... លោកយ៉ូអែល ... លោកយេហ៊ូ ជា ... លោកយ៉ូស៊ីមយ៉ា ... លោកសេរ៉ាយ៉ា ... លោកអស៊ីអែល ... លោកអេលីយ៉ូណៃ លោកយ៉ាកូបា ... លោកយេសូហាយ៉ា លោកអសាយ៉ា ... លោកអឌីអែល ... លោកយេស៊ីមាល...លោកបេណាយ៉ា ... លោកស៊ីសា ... លោកស៊ីភី ... លោកអឡូន ... លោកយេដាយ៉ា ... លោកស៊ីមរី ... លោកសេម៉ាយ៉ា
ទាំងនេះជាឈ្មោះបុរស។
អ្នកទាំងនោះសុទ្ធតែមេលើអំបូររបស់គេ
«បុរសទាំងនេះជាមេដឹកនាំ»
ហើយក្រុមគ្រួសាររបស់ពួកគេបានកើនចំនួនឡើងជាច្រើន។
«ចំនួនប្រជាជននៅក្នុងអំបូររបស់ពួកគេបានកើនឡើងយ៉ាងខ្លាំង»
1 Chronicles 4:39
កេដោរ
នេះជាឈ្មោះក្រុងមួយ។
វាលស្មៅ
ជាទឹកដី ដែលមានស្មៅឲ្យសត្វស៊ី។
ដ៏បរិបូរ
ចំនួនច្រើន
លោកហាំ
កូនចៅរបស់លោកហាំ
មេនីត
នេះជាឈ្មោះរបស់ក្រុមមនុស្ស។ ការបកប្រែផ្សេងទៀត «កូនចៅរបស់មេនូ»
1 Chronicles 4:42
ប្រមាណប្រាំរយនាក់
«បុរស៥០០នាក់»
លោកពេឡាធា ... លោកនារីយ៉ា... លោករេផាយ៉ា លោកអ៊ូស៊ាល ... ជាកូនលោកអ៊ីស៊ី

generated on Wed Sep 10 16:16:32 2025

ទាំងនេះជាឈ្មោះមនុស្ស។
ដែលនៅសេសសល់ រួចក៏តាំងទីលំនៅក្នុងស្រុកនោះ
ជនភៀសខ្លួនអាម៉ាឡេក ដែលនៅសេសសល់
ជនភៀសខ្លួន
មនុស្សដែលត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសកំណើតរបស់ខ្លួន
រហូតដល់សព្វថ្ងៃ
«ចាប់ពីពេលនោះរហូតដល់ឥឡូវនេះ»

---

5 [1]នេះជាកូនចៅរបស់លោករូបេន ដែលជាកូនច្បងរបស់លោកអ៊ីស្រាអែល លោករូបេននេះជាកូនច្បងមែន
តែដោយគាត់បានលួចរួមដំណេកជាមួយប្រពន្ធចុងរបស់ឪពុក សិទ្ធិជាកូនច្បងត្រូវបានផ្ទេរទៅឲ្យកូនៗរបស់លោកយ៉ូសែប ជាកូនរបស់លោកអ៊ីស្រាអែល។ ដូច្នេះ
គេមិនអាចរាប់លោករូបេនជាកូនច្បងបានទេ។[2]រីឯលោកយូដាវិញ គាត់មានអំណាចជាងបងប្អូនទាំងប៉ុន្មានរបស់គាត់មែន ដ្បិត
ស្តេចដែលគ្រប់គ្រងអ៊ីស្រាអែលកើតចេញពីគាត់ តែសិទ្ធិជាកូនច្បង នៅតែបានទៅលើលោកយ៉ូសែបដដែល។[3]កូនប្រុសៗរបស់លោករូបេន
ដែលត្រូវជាកូនច្បងរបស់លោកអ៊ីស្រាអែលមាន ហេណុក ប៉ាលូ ហេស្រុន និងកើមី។
[4]រីឯកូនចៅរបស់លោកយ៉ូអែលមានរាយនាមដូចតទៅនេះកូនប្រុសរបស់លោកយ៉ូអែលគឺសេម៉ាយ៉ា។ លោកសេម៉ាយ៉ាជាឪពុករបស់កុក។
លោកកុកជាឪពុករបស់ស៊ីម៉ាយ។[5]កូនប្រុសរបស់លោកស៊ីម៉ាយ គឺមីកា កូនរបស់លោកមីកា គឺរីអាយ៉ា កូនរបស់លោករីអាយ៉ា គឺបាល[6]លោកបាលមានកូនប្រុសឈ្មោះ
បេរ៉ា ដែលត្រូវព្រះចៅទីកឡាត-ពីលីស៊ើរ ជាស្តេចស្រុកអាស្ស៊ីរីនាំទៅជាឈ្លើយ។ លោកបេរ៉ាជាមេដឹកនាំកុលសម្ព័ន្ធរូបេន។
[7]បងប្អូនរបស់បេរ៉ាមានឈ្មោះក្នុងបញ្ជីរាយនាម តាមវង្សត្រកូលដូចតទៅ អ្នកទីមួយគឺលោកយីអែល បន្ទាប់មក លោកសាការី[8]លោកបេឡាជាកូនរបស់លោកអសាស
លោកអសាសជាកូនរបស់លោកសេម៉ា លោកសេម៉ាជាកូនរបស់លោកយ៉ូអែល។ កុលសម្ព័ន្ធរូបេនរស់នៅក្នុងតំបន់ចាប់ពីក្រុងអារ៉ូអ៊ើរ រហូតដល់ក្រុងនេបូ និងបាល-
មេយ៉ូន។[9]នៅទិសខាងកើត ពួកគេលាតសន្ធឹងចាប់តាំងពីទន្លេអ៊ើប្រាត រហូតដល់វាលរហោស្ថាន ដ្បិត គេមានហ្វូងសត្វជាច្រើននៅស្រុកកាឡាដ។
[10]នៅក្នុងរជ្ជកាលរបស់ព្រះបាទសូល កូនចៅរូបេនបានច្បាំងជាមួយនឹងជនជាតិហាការេន ហើយគ្រប់គ្រងលើជនជាតិនោះ ព្រមទាំងរស់នៅក្នុងជំរំរបស់ពួកគេ
ក្នុងតំបន់ប៉ែកខាងកើតស្រុកកាឡាដទាំងមូលផង។
[11]ពូជពង្សរបស់លោកកាដរស់នៅក្បែរពូជពង្សរបស់រូបេន ក្នុងស្រុកបាសាន និងរហូតដល់សាលេកា។[12]លោកយូអែលជាមេដឹកនាំរបស់ពួកគេ អ្នកបន្ទាប់គឺលោកសាផាម
រួចហើយមានលោកយ៉ាណាយ និងលោកសាផាត់នៅស្រុកបាសាន។[13]បងប្អូនពួកគេប្រាំពីរនាក់ទៀតមានឈ្មោះតាមក្រុមគ្រួសារដូចតទៅ គឺ មីកែល មស៊ូឡាម សេបា
យ៉ូរ៉ាយ យ៉ាកាន ស៊ីអា និងហេប៊ើរ។
[14]អ្នកទាំងនោះសុទ្ធតែជាកូនចៅរបស់លោកអប៊ីហែល។ លោកអប៊ីហែលជាកូនរបស់ហ៊ូរី។ លោកហ៊ូរីជាកូនរបស់លោកយ៉ារ៉ូអា។ លោកយ៉ារ៉ូអាជាកូនរបស់លោកកាឡាដ។
លោកកាឡាដជាកូនរបស់លោកមីកែល។ លោកមីកែលជាកូនរបស់លោកយេស៊ីសាយ។ លោកយេស៊ីសាយជាកូនរបស់លោកយ៉ាដោ។
លោកយ៉ាដោជាកូនរបស់លោកប៊ូស។[15]លោកអហ៊ីជាកូនរបស់លោកអាបឌាល និងជាចៅរបស់លោកគូនី ជាមេដឹកនាំលើក្រុមគ្រួសាររបស់គេ។
[16]អ្នកទាំងនោះរស់នៅក្នុងស្រុកកាឡាដ ស្រុកបាសាន ព្រមទាំងស្រុកភូមិទាំងប៉ុន្មាន ដែលនៅជុំវិញតំបន់នោះ និងវាលស្មៅដែលនៅជុំវិញក្រុងសារុន
រហូតដល់ព្រំប្រទល់ស្រុករបស់គេ។[17]អ្នកទាំងនោះមានឈ្មោះនៅក្នុងបញ្ជីជំរឿនប្រជាជននៅរជ្ជកាលព្រះបាទយ៉ូថាម ជាស្តេចស្រុកយូដា និងរជ្ជកាលព្រះបាទយេរ៉ូបោម
ជាស្តេចស្រុកអ៊ីស្រាអែល។
[18]កុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលមានទាហានចំនួន៤៤, ០០០នាក់ដែលអាចចេញទៅធ្វើសឹកសង្គ្រាមបាន
ហើយសុទ្ធតែជាមនុស្សអង់អាចក្លាហាន ពូកែប្រើខែល ប្រើដាវ បាញ់ធ្នូ និងថ្នឹកខាងចម្បាំង។[19]ពួកគេលើកគ្នាទៅច្បាំងនឹងជនជាតិហាការេន យេធើរ ណាភីស
និងណូដាប់។
[20]នៅពេលច្បាំង ពួកគេបានទូលអង្វរសូមព្រះជាម្ចាស់ជួយ ហើយដោយពួកគេទុកចិត្តលើព្រះអង្គ នោះព្រះអង្គក៏ជួយពួកគេមានជ័យជម្នះលើកងទ័ពហាការេន
និងបក្សពួក។[21]ពួកគេរឹបអូសយកបានហ្វូងសត្វរបស់ខ្មាំង គឺមានអូដ្ឋ ៥០០០០ក្បាល ចៀម ២៥០០០០ក្បាល និងលា២០០០ក្បាល
ព្រមទាំងចាប់មនុស្សបានមួយសែននាក់។[22]ពួកគេសម្លាប់ខ្មាំងសត្រូវជាច្រើននាក់ដែរ ដ្បិតចម្បាំងនោះកើតពីព្រះជាម្ចាស់។ ពួកគេតាំងទីលំនៅលើទឹកដីរបស់ខ្មាំង
រហូតដល់គ្រាដែលពួកគេជាប់ជាឈ្លើយសឹក។
[23]កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលតាំងទីលំនៅលើទឹកដីនោះ ចាប់តាំងពីស្រុកបាសានរហូតដល់ស្រុកបាល-ហ៊ើរម៉ូន ភ្នំស៊ីនៀរ (ភ្នំហ៊ើរម៉ូន)
ហើយពួកគេកើនចំនួនឡើងជាច្រើន។[24]រីឯមេដឹកនាំលើគ្រួសាររបស់ពួកគេមានលោកអេភើរ លោកអ៊ីស៊ី លោកអេលាល លោកអាសារាល លោកយេរេមី លោកហូដាវា
និងលោកយ៉ាឌាល។ អ្នកទាំងនោះសុទ្ធតែជាមនុស្សខ្លាំងពូកែ និងមានឈ្មោះល្បី ព្រមទាំងជាមេដឹកនាំលើក្រុមគ្រួសាររបស់គេផង។
[25]ប៉ុន្តែ ពួកគេមិនបានស្មោះត្រង់នឹងព្រះជាម្ចាស់នៃដូនតារបស់ពួកគេទេ ពួកគេបែរទៅគោរពបម្រើព្រះរបស់ជនជាតិទាំងឡាយនៅក្នុងស្រុកនោះ
គឺជនជាតិដែលព្រះជាម្ចាស់បានបំផ្លាញចេញពីមុខពួកគេ។[26]ហេតុនេះ ព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលបានបណ្តាលចិត្តព្រះបាទពូល (ព្រះបាទទីកឡាត-ពីលីស៊ើរ
ជាស្តេចស្រុកអាស្ស៊ីរី) ឲ្យវាយលុកទឹកដីរបស់ពួកគេ។ ព្រះបាទទីកឡាត-ពីលីស៊ើរក៏បានកៀរកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល
ទៅជាឈ្លើយសឹក នៅតំបន់ហាឡា ហាបោរ និងហារ៉ា ដែលនៅក្បែរទន្លេនៃស្រុកកូសាន ហើយពួកគេរស់នៅទីនោះរហូតដល់សព្វថ្ងៃ។

---

1 Chronicles 5:1
លោករូបេននេះ
ពាក្យ «នេះ» ប្រើនៅទីនេះដើម្បីសម្គាល់ការផ្លាស់ប្តូរពីបញ្ជីឈ្មោះកូនចៅ
ទៅជាព័ត៌មានសង្ខេបអំពីលោករូបេន។
សិទ្ធិជាកូនច្បងត្រូវបានផ្ទេរទៅឲ្យកូនៗរបស់លោកយ៉ូសែប ជាកូនរបស់លោកអ៊ីស្រាអែល។
«ប៉ុន្តែ អ៊ីស្រាអែលបានផ្តល់សិទ្ធិជាកូនច្បងរបស់រូបេនដល់កូនៗ របស់យ៉ូសែប
ដែលជាកូនប្រុសម្នាក់ផ្សេងទៀតរបស់ជនជាតិអ៊ីស្រាអែល»
លោករូបេននេះជាកូនច្បងមែន តែដោយគាត់បានលួចរួមដំណេកជាមួយប្រពន្ធចុងរបស់ឪពុក
នេះជារបៀបគួរសមក្នុងការនិយាយអំពីលោករូបេនបានរួមដំណេកជាមួយប្រពន្ធទីពីររបស់ឪពុកគាត់
សាឡុងជាកន្លែងដែលបុរស និងប្រពន្ធបានរួមរស់ជាមួយគ្នា។
ដូច្នេះ គេមិនអាចរាប់លោករូបេនជាកូនច្បងបានទេ។
«ដូច្នេះ ប្រវត្តិគ្រួសារមិនបានចុះបញ្ជីលោករូបេនជាកូនប្រុសច្បងទេ» សូមមើល
ហេណុក ... ប៉ាលូ ... ហេស្រុន ... កើមី។
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 5:4
លោកយ៉ូអែល ... សេម៉ាយ៉ា ... កុក ... ស៊ីម៉ាយ ... មីកា ... រីអាយ៉ា ... បាល ...បេរ៉ា ... ទីកឡាត-
ពីលីស៊ើរ ... លោកបេរ៉ា
ទាំងនេះជាឈ្មោះបុរស។
ទីកឡាត-ពីលីស៊ើរ
ឈ្មោះនេះក៏ត្រូវបានសរសេរថា ទីកឡាត-ពីលីស៊ើរ នៅផ្នែកផ្សេងទៀតនៃព្រះគម្ពីរ។
1 Chronicles 5:7
ក្នុងបញ្ជីរាយនាម តាមវង្សត្រកូលដូចតទៅ
នេះជាការចាប់ផ្តើមប្រយោគថ្មី
«កំណត់ត្រាតាមវង្សត្រកូលក្នុងបញ្ជីរាយនាមពួកគេ»
[illegible]ដូចតទៅ
កំណត់ត្រាបង្ហាញពីរបៀប ដែលមនុស្សនៅក្នុងគ្រួសារមានទំនាក់ទំនងនឹងគ្នា
លោកយីអែល ...លោកសាការី ...លោកបេឡា ... លោកអសាស ... លោកសេម៉ា
ទាំងនេះជាឈ្មោះបុរស។
ក្រុងអារ៉ូអ៊ើរ ... ក្រុងនេបូ ... បាល-មេយ៉ូន។
ទាំងនេះជាឈ្មោះទីក្រុងទាំងឡាយ។
1 Chronicles 5:10
ជនជាតិហាការេន

generated on Wed Sep 10 16:16:32 2025

នេះជាឈ្មោះក្រុមមនុស្ស។
1 Chronicles 5:11
សាលេកា
នេះជាឈ្មោះទីក្រុងមួយ។
លោកយូអែល ... លោកសាផាម ... លោកយ៉ាណាយ ... លោកសាផាត់ ...មីកែល មស៊ូឡាម ... សេបា ... យ៉ូរ៉ាយ ... យ៉ាកាន ... ស៊ីអា ... ហេបើ
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 5:14
លោកអប៊ីហែល ... ហ៊ូរី ... លោកយ៉ារ៉ូអា ... លោកកាឡាដ ..លោកមីកែល ... លោកយេស៊ីសាយ ... លោកយ៉ាដោ ... លោកបូស ... លោកអហ៊ី ... លោកអាបខាល ... លោកគូនី
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 5:16
អ្នកទាំងនោះរស់នៅ
ការបកប្រែផ្សេងទៀត «កុលសម្ព័ន្ធកាដបានរស់នៅ»
វាលស្មៅដែលនៅជុំវិញ
ទឹកដីដែលផ្តល់ស្មៅដល់សត្វស៊ី
អ្នកទាំងនោះមានឈ្មោះនៅក្នុងបញ្ជីជំរឿនប្រជាជន
ការបកប្រែផ្សេងទៀត «ប្រវត្តិពង្សាវតារបានរាយឈ្មោះពួកគេទាំងអស់គ្នា» ឬ «កំណត់ត្រាវង្សត្រកូលគ្រួសាររបស់ពួកគេបានចុះបញ្ជីពួកគេទាំងអស់គ្នា»
អ្នកទាំងនោះ
មិនដឹងច្បាស់សំដៅទៅលើមនុស្សចំនួនប៉ុន្មាននាក់ទេ
1 Chronicles 5:18
កុលសម្ព័ន្ធរូបេន
សំដៅទៅមនុស្សមកពីកុលសម្ព័ន្ធរូបេន។
កុលសម្ព័ន្ធកាដ
សំដៅទៅលើមនុស្សមកពីកុលសម្ព័ន្ធកាដ។
ចំនួន៤៤,០០០នាក់
ទាហានបួនពាន់នាក់ «ទាហាន ៤៤.០០០នាក់»
ពូកែប្រើខែល ប្រើដាវ បាញ់ធ្នូ និងថ្នឹកខាងចម្បាំង។
គេពិពណ៌នាទាហានថា
អ្នកមានជំនាញខាងធ្វើសង្គ្រាមដោយមានអាវុធកាន់នឹងដៃ។ ការបកប្រែផ្សេងទៀត «ពួកគេទទួលការបណ្តុះបណ្តាល ដើម្បីប្រយុទ្ធទទួលជ័យជម្នះក្នុងសមរភូមិ»។
(សូមមើល)
ហាការេន ... យេធើរ ... ណាភីស ... ណូដាប់។
ទាំងនេះជាឈ្មោះក្រុមមនុស្ស។
1 Chronicles 5:20
ពួកគេបានទូលអង្វរសូមព្រះជាម្ចាស់ជួយ
ការបកប្រែផ្សេងទៀត
«ជនជាតិអ៊ីស្រាអែលបានអធិស្ឋានអស់ពីចិត្តសុំជំនួយពីព្រះជាម្ចាស់»
ពួកគេរឹបអូសយក
ការបកប្រែផ្សេងទៀត «ជនជាតិអ៊ីស្រាអែលចាប់បានជនជាតិហាការេន» ។
មានអូដ្ឋ ៥០០០០ក្បាល
«អូដ្ឋ៥ម៉ឺនក្បាល»
មានលា២០០០ក្បាល
«សត្វលា២០០០ក្បាល»
ដ្បិត ចម្បាំងនោះកើតពីព្រះជាម្ចាស់។
ជំនួយរបស់ព្រះជាម្ចាស់ក្នុងសមរភូមិ
ប្រៀបបាននឹងទាហានម្នាក់ដែលប្រយុទ្ធនៅក្នុងសមរភូមិ។ ការបកប្រែផ្សេងទៀត «ពីព្រោះព្រះជាម្ចាស់បានជួយពួកគេ» (សូមមើល)
1 Chronicles 5:23
ស្រុកបាល-ហ៊ើរម៉ូន ... ភ្នំស៊ីនៀរ
ទាំងនេះជាឈ្មោះភ្នំ។
លោកអេភើរ ... លោកអ៊ីស៊ី... លោកអេលាល លោកអាសរាល... លោកយេរេមី ... លោកហូដាវា ... លោកយ៉ាឌាល។
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 5:25
ព្រះបាទពូល... ព្រះបាទទីកឡាត-ពីលីស៊ើរ
ទាំងនេះជាឈ្មោះបុរស។
កុលសម្ព័ន្ធរូបេន ... កុលសម្ព័ន្ធកាដ
ទាំងនេះជាឈ្មោះក្រុមមនុស្ស។
ហាឡា ... ហាបោរ ...ហារ៉ា
ទាំងនេះជាឈ្មោះក្រុង។
កូសាន
នេះជាឈ្មោះទន្លេមួយ។

---

6 [1]កូនប្រុសៗរបស់លោកលេវីមាន គើរសុន កេហាត់ និងម៉្រារី។[2]កូនប្រុសៗរបស់លោកកេហាត់មាន អាំរ៉ាម អ៊ីសារ ហេប្រូន និងអ៊ូស៊ាល។[3]កូនៗរបស់លោកអាំរ៉ាមមាន
អើរ៉ុន ម៉ូសេ និងម៉ារាម។ កូនប្រុសៗរបស់លោកអើរ៉ុនមាន ណាដាប អប៊ីហ៊ូ អេឡាសារ និងអ៊ីថាម៉ារ។
[4]លោកអេឡាសារជាឪពុករបស់លោកភីនេហាស ភីនេហាសជាឪពុករបស់លោកអប៊ីសួរ[5]លោកអប៊ីសួរជាឪពុករបស់លោកប៊ូកគី
លោកប៊ូកគីជាឪពុករបស់លោកអ៊ូស៊ី[6]លោកអ៊ូស៊ីជាឪពុករបស់លោកសេរ៉ាហ៊ា លោកសេរ៉ាហ៊ាជាឪពុករបស់លោកមេរ៉ាយ៉ូត។
[7]លោកមេរ៉ាយ៉ូតជាឪពុករបស់លោកអម៉ារា លោកអម៉ារាជាឪពុករបស់លោកអហ៊ីទូប[8]លោកអហ៊ីទូបជាឪពុករបស់លោកសាដុក
លោកសាដុកជាឪពុករបស់លោកអហ៊ីម៉ាស[9]លោកអហ៊ីម៉ាសជាឪពុករបស់លោកអសារា លោកអសារាជាឪពុករបស់យ៉ូហាណាន។
[10]លោកយ៉ូហាណានជាឪពុករបស់លោកអសារា ជាបូជាចារ្យបំពេញមុខងារក្នុងព្រះវិហារ ដែលព្រះបាទសាឡូម៉ូនបានសាងសង់ នៅក្រុងយេរូសាឡឹម។
[11]លោកអសារាជាឪពុករបស់លោកអម៉ារា លោកអម៉ារាជាឪពុករបស់លោកអហ៊ីទូប[12]លោកអហ៊ីទូបជាឪពុករបស់លោកសាដុក
លោកសាដុកជាឪពុករបស់លោកសាលូម។
[13]លោកសាលូមជាឪពុករបស់លោកហ៊ីលគីយ៉ា លោកហ៊ីលគីយ៉ាជាឪពុករបស់លោកអសារា[14]លោកអសារាជាឪពុករបស់សេរ៉ាយ៉ា
លោកសេរ៉ាយ៉ាជាឪពុករបស់លោកយេហូយ៉ាដាក[15]នៅគ្រាដែលព្រះជាម្ចាស់ឲ្យព្រះបាទនេប៊ូក្នេសាកៀរអ្នកស្រុកយូដា និងអ្នកក្រុងយេរូសាឡឹមទៅជាឈ្លើយនោះ
លោកយេហូយ៉ាដាកក៏ត្រូវគេនាំយកទៅដែរ។
[16]កូនប្រុសៗរបស់លោកលេវីមាន គើរសុន កេហាត់ និងម៉្រារី។[17]កូនប្រុសៗរបស់លោកគើរសុនមាន លីបនី និងស៊ីម៉ាយ។[18]កូនប្រុសៗរបស់លោកកេហាត់មាន អាំរ៉ាម
យីសារ ហេប្រូន និងអ៊ូស៊ាល។
[19]កូនប្រុសៗរបស់លោកម៉្រារីមាន ម៉ាស់លី និងមូស៊ី។ អំបូរទាំងប៉ុន្មាននៃកូនចៅលេវីមានឈ្មោះតាមបុព្វបុរសរបស់ពួកគេ[20]កូនចៅរបស់លោកគើរសុនមានដូចតទៅ
លោកគើសុនជាឪពុករបស់លោកលីបនី លោកលីបនីជាឪពុកលោកយ៉ាហាត់ លោកយ៉ាហាត់ជាឪពុកលោកស៊ីមម៉ា[21]លោកស៊ីមម៉ាជាឪពុកយ៉ូអា យ៉ូអាជាឪពុកអ៊ីដោ
អ៊ីដោជាឪពុកសេរ៉ាស សេរ៉ាសជាឪពុកយាតរ៉ាយ។
[22]កូនចៅរបស់លោកកេហាត់មានរាយនាមតាមដំណរវង្សត្រកូលដូចតទៅ អមីណាដាប់។ លោកអមីណាដាប់ជាឪពុកកូរ៉ា កូរ៉ាជាឪពុកអាសសៀរ។
[23]លោកអាសសៀរជាឪពុកអែលកាណា។ លោកអែលកាណាជាឪពុកអេបៀសាប់ អេបៀសាប់ជាឪពុកអាស់ស៊ារ។[24]លោកអាស់ស៊ារជាឪពុកថាហាត់
ថាហាត់ជាឪពុកអ៊ូរាល។ លោកអ៊ូរាលជាឪពុកអ៊ូស៊ីយ៉ា។ លោកអ៊ូស៊ីយ៉ាជាឪពុក សូល។
[25]កូនរបស់លោកអែលកាណាគឺ អម៉ាសាយ អហ៊ីម៉ូត និងអែលកាណា[26]កូនរបស់អែលកាណាទី២នេះមាន សូផាយ
កូនរបស់សូផាយគឺណាហាត់[27]កូនរបស់ណាហាត់គឺអេលាប កូនរបស់អេលាបគឺយេរូហាំ កូនរបស់យេរូហាំគឺអែលកាណា។
[28]រីឯកូនរបស់លោកសាំយូអែលគឺ យ៉ូអែល ជាកូនច្បង និងអប៊ីយ៉ា។[29]កូនចៅរបស់លោកម៉្រារីគឺលោកម៉ាសលី កូនរបស់លោកម៉ាសលីគឺលោកលីបនី។
កូនរបស់លោកលីបនីគឺលោកស៊ីម៉ាយ កូនរបស់លោកស៊ីម៉ាយគឺលោកអ៊ូសា។[30]កូនរបស់លោកអ៊ូសាគឺលោកស៊ីមា។ កូនរបស់លោកស៊ីមាគឺលោកហាគីយ៉ា។
កូនរបស់លោកហាគីយ៉ាគឺលោកអសាយ៉ា។

generated on Wed Sep 10 16:16:32 2025

[31]កាលហិបនៃសម្ពន្ធមេត្រីមានកន្លែងសម្រាកហើយ ព្រះបាទដាវីឌបានតែងតាំងឲ្យមានអ្នកទទួលបន្ទុកផ្នែកខាងចម្រៀង នៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
[32]មុនពេលព្រះបាទសាឡូម៉ូនសង់ព្រះដំណាក់របស់ព្រះអម្ចាស់ នៅក្រុងយេរូសាឡឹម អ្នកទាំងនោះតែងតែបំពេញមុខងារផ្នែកខាងចម្រៀងនេះ នៅមុខព្រះពន្លា
គឺនៅមុខពន្លាជួបព្រះអម្ចាស់ តាមក្បួនច្បាប់ដែលមានចែងទុក។
[33]អស់អ្នកដែលបំពេញការងារនេះជាមួយកូនចៅរបស់ខ្លួន។ ក្នុងចំណោមកូនចៅរបស់លោកកេហាត់មាន លោកហេម៉ានជាអ្នកចម្រៀង។
គាត់ត្រូវជាកូនរបស់លោកយ៉ូអែល។ លោកយ៉ូអែលជាកូនរបស់សាំយ៉ូអែល។[34]លោកសាំយូអែលជាកូនរបស់លោកអែលកាណា។
លោកអែលកាណាជាកូនរបស់លោកយេរ៉ូហាំ។ លោកយេរ៉ូហាំជាកូនរបស់លោកអេលាល។ លោកអេលាបជាកូនរបស់លោកតូអា[35]លោកតូអាជាកូនរបស់លោកស៊ូភ។
លោកស៊ូភជាកូនរបស់លោកអែលកាណា។ លោកអែលកាណាជាកូនរបស់លោកម៉ាហាត់។ លោកម៉ាហាត់ជាកូនរបស់លោកអម៉ាសាយ។
លោកអម៉ាសាយជាកូនរបស់លោកអែលកាណា។
[36]លោកអែលកាណាជាកូនរបស់លោកយ៉ូអែល លោកយ៉ូអែលជាកូនរបស់អសារ។ លោកអសារជាកូនរបស់លោកសេផានា។
[37]លោកសេផានាជាកូនរបស់លោកថាហាត់។ លោកថាហាត់ជាកូនរបស់លោកអាស់ស៊ា។ លោកអាស់ស៊ាជាកូនរបស់លោកអេបៀសាប់។
លោកអេបៀសាប់ជាកូនរបស់លោកកូរ៉ា។[38]លោកកូរ៉ាជាកូនរបស់លោកយីតសារ។ លោកយីតសារជាកូនរបស់លោកកេហាត់។ លោកកេហាត់ជាកូនរបស់លោកលេវី។
លោកលេវីជាកូនរបស់លោកអ៊ីស្រាអែល។
[39]នៅខាងស្តាំដៃលោកហេម៉ានមានលោកអេសាភ ជាសហការីរបស់គាត់។លោកអេសាភត្រូវជាកូនរបស់លោកបេរេគា។ លោកបេរេគាជាកូនរបស់លោកស៊ីមា។
[40]លោកស៊ីមាជាកូនរបស់លោកមីកែល។ លោកមីកែលជាកូនរបស់លោកបាសេយ៉ា។ លោកបាសេយ៉ាជាកូនរបស់លោកម៉ាល់គីយ៉ា។
[41]លោកម៉ាល់គីយ៉ាជាកូនរបស់លោកអែតនី លោកអែតនីជាកូនរបស់លោកសេរ៉ា។ លោកសេរ៉ាជាកូនរបស់លោកអដាយ៉ា[42]លោកអដាយ៉ាជាកូនរបស់លោកអេថាន។
លោកអេថានជាកូនរបស់លោកស៊ីម៉ា។ លោកស៊ីម៉ាជាកូនរបស់លោកស៊ីម៉ាយ។[43]លោកស៊ីម៉ាយជាកូនរបស់លោកយ៉ាហាត់។ លោកយ៉ាហាត់ជាកូនរបស់លោកគើសុន។
លោកគើសុនជាកូនរបស់លោកលេវី។
[44]នៅខាងឆ្វេងមានកូនចៅរបស់លោកម៉្រារី ដែលជាក្រុមចម្រៀង ដឹកនាំដោយលោកអេថានជាកូនរបស់លោកគីស៊ី។លោកគីស៊ីជាកូនរបស់លោកអាប់ឌី
លោកអាប់ឌីជាកូនរបស់លោកម៉ាលូក។[45]លោកម៉ាលូកជាកូនរបស់លោកសាបយ៉ា។ លោកសាបយ៉ាជាកូនរបស់លោកអម៉ាស៊ា។ លោកអម៉ាស៊ាជាកូនរបស់លោកហ៊ីគីយ៉ា។
[46]លោកហ៊ីលគីយ៉ាជាកូនរបស់លោកអាំស៊ី។ លោកអាំស៊ីជាកូនរបស់លោកបានី។លោកបានីជាកូនរបស់លោកសេមើរ។[47]លោកសេមើរជាកូនរបស់លោកម៉ាសលី។
លោកម៉ាសលីជាកូនរបស់លោកមូស៊ី។ លោកមូស៊ីជាកូនរបស់លោកម៉្រារី។ លោកម៉្រារីជាកូនរបស់លោកលេវី។
[48]កូនចៅលេវីឯទៀតៗ ដែលជាបងប្អូនរបស់ពួកគេទទួលភារកិច្ចបំពេញការងារទាំងប៉ុន្មាននៅក្នុងព្រះពន្លាជាព្រះដំណាក់របស់ព្រះជាម្ចាស់។
[49]លោកអើរ៉ុន និងកូនចៅរបស់លោកមាននាទីថ្វាយយញ្ញបូជានៅលើអាសនៈសម្រាប់ថ្វាយតង្វាយដុត
ព្រមទាំងដុតគ្រឿងក្រអូបនៅលើអាសនៈសម្រាប់ដុតគ្រឿងក្រអូបដែរ។ ពួកលោកបំពេញការងារទាំងប៉ុន្មាននៅក្នុងទីសក្ការៈបំផុត
ហើយធ្វើពិធីរំដោះបាបឲ្យប្រជាជនអ៊ីស្រាអែល ស្របតាមសេចក្តីទាំងប៉ុន្មានដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះជាម្ចាស់បានបង្គាប់ទុក។
[50]កូនចៅរបស់លោកអើរ៉ុន មានរាយនាមដូចតទៅ លោកអើរ៉ុនជាឪពុកលោកអេឡាសារ លោកអេឡាសារជាឪពុកលោកភីនេហាស។
លោកភីនេហាសជាឪពុកលោកអប៊ីសួ។[51]លោកអប៊ីសួជាឪពុកលោកប៊ូកគី។ លោកប៊ូកគីជាឪពុកលោកអ៊ូស៊ី។ លោកអ៊ូស៊ីជាឪពុកលោកសេរ៉ាហ៊ា។
[52]លោកសេរ៉ាហ៊ាជាឪពុកលោកមេរ៉ាយ៉ូត។ លោកមេរ៉ាយ៉ូតជាឪពុកលោកអម៉ារា។ លោកអម៉ារាជាឪពុកលោកអហ៊ីទូប។[53]លោកអហ៊ីទូបជាឪពុកលោកសាដុក។
លោកសាដុកជាឪពុកលោកអហ៊ីម៉ាស។
[54]រីឯទីកន្លែងនិងទឹកដីដែលកូនចៅលេវីដែលត្រូវជាពូជពង្សរបស់លោកអើរ៉ុនរស់នៅមានដូចតទៅ អំបូរកេហាត់ ជាកូនចៅរបស់លោកអើរ៉ុន (ទទួលចំណែកមុនគេ
ដោយការចាប់ឆ្នោត)[55]ពួកគេទទួលបានក្រុងហេប្រូន នៅស្រុកយូដា ព្រមទាំងវាលស្មៅដែលនៅជុំវិញ។[56]រីឯស្រែចម្ការ និងភូមិនានាដែលនៅជាប់នឹងក្រុងនោះវិញ
គេបានប្រគល់ជូនលោកកាលែប ជាកូនរបស់លោកយេភូនេ។
[57]គេក៏បានចែកក្រុងជម្រកទាំងប៉ុន្មានឲ្យកូនចៅរបស់លោកអើរ៉ុនដែរ គឺក្រុងហេប្រូន ក្រុងលីបណា និងវាលស្មៅនីជុំវិញ ក្រុងយ៉ាទៀរ ក្រុងអែសថេម៉ូរ
និងវាលស្មៅនៅជុំវិញ[58]ក្រុងហ៊ីឡេន និងវាលស្មៅនៅជុំវិញ ក្រុងដេបៀរនិងវាលស្មៅនៅជុំវិញ។
[59]ក្រុងបេតសេមែស និងវាលស្មៅនៅជុំវិញត្រូវបានប្រគល់ដល់លោកអាសាន ដែលជាពូជពង្សរបស់លកអើរ៉ុន[60]ក្នុងទឹកដីនៃកុលសម្ព័ន្ធបេនយ៉ាមីន
ពួកគេទទួលបានក្រុងកេបា និងវាលស្មៅនៅជុំវិញ ក្រុងអាលេមែត និងវាលស្មៅនៅជុំវិញ ក្រុងអាណាថោត និងវាលស្មៅនៅជុំវិញ ។សរុបទាំងអស់
អំបូរកេហាត់ទទួលបានដប់បីក្រុង។
[61]កូនចៅកេហាត់ឯទៀតៗទទួលបានក្រុងដប់នៅក្នុងទឹកដីរបស់កុលសម្ព័ន្ធអេប្រាអ៊ីម កុលសម្ព័ន្ធដាន់ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល ដោយការចាប់ឆ្នោត។
[62]អំបូរនានានៃកូនចៅគើសុនទទួលបានក្រុងដប់បីពីកុលសម្ព័ន្ធអេស៊ើរ កុលសម្ព័ន្ធណែបថាលី និងកុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាលនៅស្រុកបាសាន។
[63]អំបូរនានានៃកូនចៅម៉្រារីទទួលបានក្រុងដប់ពីរ ដោយការចាប់ឆ្នោតពីកុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធសាប់យូឡូន។
[64]កូនចៅអ៊ីស្រាអែលបានប្រគល់ក្រុងទាំងនោះ ព្រមទាំងវាលស្មៅនៅជុំវិញទៅឲ្យកុលសម្ព័ន្ធលេវី។[65]ពួកគេបានចែកទីក្រុងនានាដែលមានឈ្មោះកត់ត្រាទុកនេះដល់គេ
ដោយចាប់ឆ្នោត គឺទីក្រុងដែលស្ថិតនៅក្នុងទឹកដីរបស់ កុលសម្ព័ន្ធយូដា កុលសម្ព័ន្ធស៊ីម្មាន និងកុលសម្ព័ន្ធបេនយ៉ាមីន។
[66]អំបូរខ្លះទៀតនៃកូនចៅរបស់លោកកេហាត់ បានទទួលក្រុងនានាក្នុងទឹកដីរបស់កុលសម្ព័ន្ធអេប្រាអ៊ីម។[67]ពួកគេបានប្រគល់ក្រុងជម្រកឲ្យអ្នកទាំងនោះ គឺក្រុងស៊ីគែម
ដែលស្ថិតនៅក្នុងតំបន់ភ្នំអេប្រាអ៊ីម និងវាលស្មៅនៅជុំវិញ ក្រុងកេសើរនិងវាលស្មៅនៅជុំវិញ[68]ក្រុងយ៉ុកម៉ាម និងវាលស្មៅនៅជុំវិញ ក្រុងបេតហូរ៉ូន
និងវាលស្មៅនៅជុំវិញ[69]ក្រុងអាយ៉ាឡូន និងវាលស្មៅនៅជុំវិញ ក្រុងកាថ-រីម៉ូន និងវាលស្មៅនៅជុំវិញ។
[70]ក្នុងទឹកដីរបស់កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល កូនចៅកេហាត់ដែលនៅសល់ទទួលបានក្រុងអាន់នើរ និងវាលស្មៅនៅជុំវិញ ក្រុងប៊ីលាម
និងវាលស្មៅនៅជុំវិញ។
[71]គេបានប្រគល់ក្រុងនានាក្នុងទឹកដីរបស់អំបូរម៉ាណាសេចំនួនពាក់កណ្តាល ឲ្យកូនចៅគើសុន គឺក្រុងកូឡាន នៅស្រុកបាសាន និងវាលស្មៅនៅជុំវិញ ក្រុងអាសថារ៉ូត
និងវាលស្មៅនៅជុំវិញ។[72]ក្នុងទឹកដីរបស់កុលសម្ព័ន្ធអ៊ីសាខារ ពួកគេទទួលបានក្រុងកាដេស និងវាលស្មៅនៅជុំវិញ ក្រុងដាប្រាត និងវាលស្មៅនៅជុំវិញ[73]ក្រុងរ៉ាម៉ូត
និងវាលស្មៅនៅជុំវិញ ក្រុងអានេម និងវាលស្មៅនៅជុំវិញ។
[74]ក្នុងទឹកដីរបស់កុលសម្ព័ន្ធអេស៊ើរ ពួកគេទទួលបានក្រុងម៉ាសាល់ និងវាលស្មៅនៅជុំវិញ ក្រុងអាប់ដូន និងវាលស្មៅនៅជុំវិញ[75]ក្រុងហ៊ូកូក និងវាលស្មៅនៅជុំវិញ
ក្រុងរេហុប និងវាលស្មៅនៅជុំវិញ[76]ក្នុងទឹកដីរបស់កុលសម្ព័ន្ធណែបថាលី ពួកគេទទួលបានក្រុងកេដេស នៅស្រុកកាលីឡេ និងវាលស្មៅនៅជុំវិញ ក្រុងហាំម៉ូន
និងវាលស្មៅនៅជុំវិញ ក្រុងគារយ៉ាថែម និងវាលស្មៅនៅជុំវិញ។
[77]ពួកលេវីឯទៀតៗគឺកូនចៅលោកម៉្រារី បានទទួលក្រុងនានាក្នុងទឹកដីររបស់កុលសម្ព័ន្ធសាប់យូឡូនដូចតទៅ គឺក្រុងរីម៉ូន និងវាលស្មៅនៅជុំវិញ ក្រុងតាបោរ
និងវាលស្មៅនៅជុំវិញ[78]នៅត្រើយខាងកើតទន្លេយ័រដាន់ គឺនៅទល់មុខនិងក្រុងយេរីខូ ក្នុងទឹកដីកុលសម្ព័ន្ធរូបេន ពួកគេទទួលបានក្រុងបេស៊ើរ
ដែលស្ថិតនៅតំបន់វាលរហោស្ថាន និងវាលស្មៅនៅជុំវិញ ក្រុងយ៉ាហស និងវាលស្មៅនៅជុំវិញ[79]ក្រុងកេដេម៉ូត និងវាលស្មៅនៅជុំវិញ ក្រុងមេផាត និងវាលស្មៅនៅជុំវិញ។
[80]ក្នុងទឹកដីរបស់កុលសម្ព័ន្ធកាដ ពួកគេទទួលបានក្រុងរ៉ាម៉ូតនៅស្រុកកាឡាដ និងវាលស្មៅនៅជុំវិញ ក្រុងម៉ាហាណែម និងវាលស្មៅនៅជុំវិញ[81]ក្រុងហេសបូន
និងវាលស្មៅនៅជុំវិញ ក្រុងយ៉ាស៊ើរ និងវាលស្មៅនៅជុំវិញ។

generated on Wed Sep 10 16:16:32 2025

1 Chronicles 6:1
គើរសុន ... កេហាត់ ... លោកកេហាត់ ... អាំរ៉ាម ... អ៊ីសារ ... អ៊ូស៊ាល ... ម៉ារាម។ ... ណាដាប ...
អប៊ីហ៊ូ ... អេឡាសារ ... អ៊ីថាម៉ារ។
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 6:4
លោកអេឡាសារ ...លោកអប៊ីសួរ ...លោកប៊ូកគី ... លោកសេរ៉ាហ៊ា លោកសេរ៉ាហ៊ា ...
លោកមេរ៉ាយ៉ូត។
នេះជាឈ្មោះមនុស្សប្រុស។
1 Chronicles 6:7
លោកមេរ៉ាយ៉ូត... លោកអម៉ារា... លោកអហ៊ីទូប... លោកសាដុក លោកសាដុក...
លោកអហ៊ីម៉ាស... យ៉ូហាណាន។
នេះជាឈ្មោះរបស់មនុស្សប្រុស។
1 Chronicles 6:10
លោកអម៉ារា ... លោកអហ៊ីទូប ... លោកសាដុក ... លោកសាលូម
នេះជាឈ្មោះរបស់មនុស្សប្រុស។
1 Chronicles 6:13
លោកហ៊ីលគីយ៉ា ... សេរ៉ាយ៉ា ... លោកយេហូយ៉ាដាក
នេះជាឈ្មោះរបស់មនុស្សប្រុស។
កស្រុកយូដា និងអ្នកក្រុងយេរូសាឡឹមទៅជាឈ្លើយនោះ លោកយេហូយ៉ាដាកក៏ត្រូវគេនាំយកទៅដែរ
អំណាចដែលនេប៊ូក្នេសាមានតាមរយៈកងទ័ពរបស់ព្រះអង្គ
ត្រូវបានពិពណ៌នាថាជាផ្នែកនៃរាងកាយរបស់ព្រះអង្គ
1 Chronicles 6:16
គើរសុន ... កេហាត់ ... ម៉្រារី
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ៦:១។
លីបនី ... ស៊ីម៉ាយ។
នេះជាឈ្មោះរបស់មនុស្សប្រុស។
អាំរ៉ាម ... យីសារ ... ហេប្រុន ... អ៊ូស៊ាល។
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ៦:១។
1 Chronicles 6:19
លោកម៉្រារី ...ម៉ាស់លី ...មូស៊ី ... លោកយ៉ាហាត់ ... លោកស៊ីមម៉ា ... យ៉ូអា ... អ៊ីដោ ... សេរ៉ាស ...
យាតរ៉ាយ។
នេះជាឈ្មោះរបស់មនុស្សប្រុស។
1 Chronicles 6:22
អមីណាដាប់... កូរ៉ា...អាសសៀរ ... លោកអែលកាលណា... អេបៀសាប់... ថាហាត់...
លោកអ៊ូរាល... អ៊ូស៊ីយ៉ា.... សូល
នេះជាឈ្មោះរបស់មនុស្សប្រុស។
1 Chronicles 6:25
លោកអែលកាណា ... អម៉ាសាយ ... អហ៊ីម៉ូត ... សូផាយ ... ណាហាត់ ... អេលាប ... យេរូហាំ
នេះជាឈ្មោះរបស់មនុស្សប្រុស។
1 Chronicles 6:28
យ៉ូអែល ... លោកម៉្រារី ... លោកម៉ាសលី ...
លោកលីបនី ...លោកស៊ីម៉ាយ ...លោកអ៊ូសា ...លោកស៊ីមា ...លោកហាគីយ៉ា ...លោកអសាយ៉ា
នេះជាឈ្មោះរបស់មនុស្សប្រុស។
កូនទី២
«កូនប្រុសកើតបន្ទាប់»
1 Chronicles 6:31
នៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
«ប្រជាជនរបស់អ៊ីស្រាអែលបានដាក់ហឹបនៅទីនោះ»
នៅមុខព្រះពន្លា គឺនៅមុខពន្លាជួបព្រះអម្ចាស់
អាចមានន័យថា ១) «ព្រះពន្លានៃការជួបព្រះអម្ចាស់»
បញ្ជាក់ពីឈ្មោះផ្សេងទៀតសម្រាប់ «រោងឧបោសថ» ឬ ២)«
ទីបរិសុទ្ធបំផុតនៃព្រះពន្លាជួបព្រះអម្ចាស់» ។
អ្នកទាំងនោះតែងតែបំពេញមុខងារផ្នែកខាងចម្រៀងនេះ នៅមុខព្រះពន្លា
គឺនៅមុខពន្លាជួបព្រះអម្ចាស់ តាមក្បួនច្បាប់ដែលមានចែងទុក។
ការបកប្រែផ្សេងទៀត «អ្នកចម្រៀងបានធ្វើតាមការណែនាំរបស់ស្តេចដាវីឌ»
1 Chronicles 6:33
អស់អ្នកដែលបំពេញការងារនេះ
«ទាំងនេះជាតន្ត្រីករ»
លោកកេហាត់
នេះជាឈ្មោះរបស់ក្រុមមនុស្ស។
ក្នុងចំណោមកូនចៅ
មានន័យថា បញ្ជីមានលំដាប់លំដោយតាំងពីពេលថ្មីៗនេះរហូតដល់ចាស់ជាងគេ។
លោកហេម៉ាន ... លោកយេរ៊ូហាំ ...លោកអេលាល ... លោកតូអា ... លោកស៊ូភ ...លោកម៉ាហាត់
ទាំងនេះជាឈ្មោះបុរស។
លោកអែលកាណា ...លោកអម៉ាសាយ
សូមមើលការបកប្រែឈ្មោះបុរសទាំងនេះក្នុង ៦:២៥។
1 Chronicles 6:36
លោកថាហាត់ ... លោកអាស់ស៊ា ... លោកអេបៀសាប់ ... លោកយីតសារ ... លោកកេហាត់។
ទាំងនេះជាឈ្មោះរបស់ក្រុមមនុស្ស។
1 Chronicles 6:39
.លោកបេរេគា ... លោកស៊ីមា ... លោកមីកែល ... លោកបាសេយ៉ា ...
លោកម៉ាល់គីយ៉ា...លោកអែតនី ...
លោកសេរ៉ា...លោកអដាយ៉ា...លោកអេថាន...លោកស៊ីម៉ា...លោកស៊ីម៉ាយ...លោកយ៉ាហាត់...លោកគើសុន
ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។
នៅខាងស្តាំដៃ
«អ្នករួមការងារ»
ជាសហការីរបស់គាត់
សិទ្ធិអំណាចរបស់មនុស្សម្នាក់ ប្រៀបបាននឹងទីកន្លែងដែលពួកគេឈរជើង។
ផ្នែកខាងស្តាំរបស់មនុស្សជាកន្លែងមនុស្ស សដែលមានសិទ្ធិអំណាចខ្ពស់បំផុត។
1 Chronicles 6:44
ព័ត៌មានទូទៅ៖
សូមមើល
នៅខាងឆ្វេងមានកូនចៅរបស់លោកហេម៉ាន
ការបកប្រែផ្សេងទៀត «ឈរនៅផ្នែកខាងឆ្វេងរបស់លោកហេម៉ាន»
ដែលជាក្រុម
«អ្នករួមការងារ»
1 Chronicles 6:48
កូនចៅលេវីឯទៀតៗ ដែលជាបងប្អូនរបស់ពួកគេទទួលភារកិច្ចបំពេញការងារទាំងប៉ុន្មាន
ការបកប្រែផ្សេងទៀត «ជាកាតព្វកិច្ចរបស់អ្នកធ្វើការជាមួយគ្នា
គឺពួកលេវីដែលត្រូវធ្វើ»
1 Chronicles 6:49
ហើយធ្វើពិធីរំដោះបាបឲ្យប្រជាជនអ៊ីស្រាអែល
ការបកប្រែផ្សេងទៀត
«តង្វាយទាំងនេះសម្រាប់ធ្វើពិធីរំដោះបាបប្រជាជនអ៊ីស្រាអែល »។
1 Chronicles 6:50
ព័ត៌មានទូទៅ៖
សូមមើល
កូនចៅរបស់លោកអើរ៉ុន មានរាយនាមដូចតទៅ
ការបកប្រែផ្សេងទៀត «ទាំងនេះជាកូនចៅរបស់លោកអើរ៉ុន»។
1 Chronicles 6:54
ព័ត៌មានទូទៅ៖
សូមមើល
ឯទីកន្លែងនិងទឹកដីដែលកូនចៅលេវីដែលត្រូវជាពូជពង្សរបស់លោកអើរ៉ុនរស់នៅមានដូចតទៅ
អំបូរកេហាត់ ជាកូនចៅរបស់លោកអើរ៉ុន (ទទួលចំណែកមុនគេ ដោយការចាប់ឆ្នោត) ។
ការបកប្រែផ្សេងទៀត «ទាំងនេះជាកន្លែងកូនចៅរបស់លោកអើរ៉ុន
ដែលជាអំបូររបស់លោកកេហាត់បានរស់នៅ
(ដោយការបោះឆ្នោតកំណត់កន្លែងដែលពួកគេនឹងរស់នៅ)»
អំបូរកេហាត់
សូមមើលការបកប្រែនៅក្នុង ៦:៣៣។
ពួកគេទទួលបានក្រុងហេប្រុន
ការបកប្រែផ្សេងទៀត «ពួកគេបានប្រគល់ហេប្រុនដល់ពួកគេ»
រីឯស្រែចម្ការ និងភូមិនានាដែលនៅជាប់នឹងក្រុងនោះវិញ គេបានប្រគល់ជូនលោកកាលែប
ជាកូនរបស់លោកយេភូនេ។
ការបកប្រែផ្សេងទៀត
«កាលែបនិងក្រុមគ្រួសាររបស់គាត់បានទៅរស់នៅវាលហេប្រុន
ព្រមទាំងមានភូមិព័ទ្ធជុំវិញ»
វាលស្មៅដែលនៅជុំវិញ
នេះជាដីមានស្មៅ ដែលសត្វស៊ីជាអាហារ។

generated on Wed Sep 10 16:16:32 2025

1 Chronicles 6:57
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 6:59
ព័ត៌មានទូទៅ៖
សូមមើល
សរុបទាំងអស់ អំបូរកេហាត់ទទួលបានដប់បីក្រុង។
ការបកប្រែផ្សេងទៀត «ពួកគេមានទីក្រុងសរុបចំនួន ១៣»
1 Chronicles 6:61
អំបូរនានានៃកូនចៅគើសុនទទួលបានក្រុងដប់បី
«អំបូររបស់កូនចៅគើសុនទទួលបានទីក្រុងចំនួន១៣» (សូមមើល
កេហាត់ ... គើសុន
សូមមើលការបកប្រែនៅក្នុង ៦:១។
1 Chronicles 6:63
ចៅម៉្រារី
សូមមើលការបកប្រែនៅក្នុង ៦:១។
គឺទីក្រុងដែលស្ថិតនៅក្នុងទឹកដីរបស់
ការបកប្រែផ្សេងទៀត «ទីក្រុងទាំងនោះមកពី»
1 Chronicles 6:66
ព័ត៌មានទូទៅ៖
សូមមើល
លោកកេហាត់
សូមមើលការបកប្រែនៅក្នុង ៦:១។
1 Chronicles 6:70
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 6:71
ព័ត៌មានទូទៅ៖
សូមមើល
គើសុន
សូមមើលការបកប្រែនៅក្នុង ៦:១។
1 Chronicles 6:74
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 6:77
ព័ត៌មានទូទៅ៖
សូមមើល
លោកម៉្រារី
សូមមើលការប្រែនៅក្នុង ៦:១។
គឺកូនចៅលោកម៉្រារី ... វាលស្មៅនៅជុំវិញ
«កុលសម្ព័ន្ធសាប់យូឡូនបានផ្តល់កូនចៅរបស់ម៉្រារី
ជាកូនចៅរបស់រីម៉ូននៅវាលស្មៅ និងតាបូរនៅវាលស្មៅ»
ពួកគេទទួលបាន ... ទឹកដីកុលសម្ព័ន្ធរូបេន
ព័ត៌មាននៅក្នុង ៦:៧៧ បានរៀបចំឡើងវិញ ដូច្នេះ វាងាយយល់ជាង។
ពួកគេទទួលបាន
«ពួកគេក៏ទទួលបានផងដែរ»
1 Chronicles 6:80
ព័ត៌មានទូទៅ៖
សូមមើលការបកប្រែនៅក្នុង ៦:១។

---

7 [1]លោកអ៊ីសាខារមានកូនប្រុសៗបួននាក់ គឺថូឡា ពូអា យ៉ាស៊ូប និងស៊ីមរ៉ូន។[2]កូនប្រុសៗរបស់លោកថូឡាមាន អ៊ូស៊ី រេផាយ៉ា យេរីអែល យីបសាម និងសាំយូអែល។
អ្នកទាំងនេះសុទ្ធតែជាមេដឹកនាំលើអំបូរថូឡា និងជាមនុស្សពូកែអង់អាចក្នុងក្រុមគ្រួសាររបស់ខ្លួន។ នៅជំនាន់ព្រះបាទដាវីឌ ពួកគេមានចំនួនទាំងអស់ ២២,
៦០០នាក់។[3]កូនរបស់លោកអ៊ូស៊ីគឺ យីសរ៉ាហ៊ា កូនប្រុសៗរបស់លោកយីសរ៉ាហ៊ាមាន មីកែល អូបាឌា យ៉ូអែល និងយីសយ៉ា គឺមានមេដឹកនាំទាំងអស់ប្រាំនាក់។
[4]នៅជាមួយពួកគេ មានពួកទាហានប្រដាប់អាវុធ ដែលអាចធ្វើសឹកបាន ចំនួន៣៦, ០០០នាក់ ដោយគិតតាមវង្សត្រកូល និងតាមក្រុមគ្រួសាររបស់ពួកគេ
ព្រោះពួកគេមានប្រពន្ធច្រើន ហើយកូនក៏ច្រើនដែរ។[5]នៅក្នុងអំបូរទាំងប៉ុន្មាននៃកុលសម្ព័ន្ធអ៊ីសាខារ ពួកគេជំរឿនបានទាំងអស់៨៧, ០០០នាក់
ដែលសុទ្ធតែជាមនុស្សពូកែអង់អាច។
[6]លោកបេនយ៉ាមីនមានកូនប្រុសៗបីនាក់គឺ បេឡា បេគើរនិងយេឌីអែល។[7]កូនរបស់លោកបេឡាប្រាំនាក់មានអេសបូន អ៊ូស៊ី អ៊ូស៊ាល យេរីម៉ូត និងអ៊ីរី។
ពួកគេសុទ្ធជាមេដឹកនាំលើក្រុមគ្រួសាររបស់ខ្លួន និងជាមនុស្សខ្លាំងពូកែអង់អាច។ ចំនួនក្រុមគ្រួសាររបស់ពួកគេជំរឿនបានទាំងអស់ ២២, ០៣៤នាក់។
[8]កូនប្រុសៗរបស់លោកបេគើរមានសេមីរ៉ា យ៉ូអាស អេលាស៊ើរ អេលីយ៉ូណៃ អុមរី យេរេម៉ូត អប៊ីយ៉ា អណាថោត និងអឡាមេត។
អ្នកទាំងនេះសុទ្ធតែជាកូនរបស់លោកបេគើរ[9]ដែលជាមេលើក្រុមគ្រួសាររបស់ខ្លួន និងជាមនុស្សខ្លាំងពូកែអង់អាច។
ចំនួនក្រុមគ្រួសាររបស់ពួកគេដែលជំរឿនតាមវង្សត្រកូលមានទាំងអស់២០, ២០០នាក់។[10]កូនរបស់លោកយេឌីអែលគឺបីលហាន កូនរបស់បីលហានមាន យេអ៊ូស
បេនយ៉ាមីន អេហ៊ូដ កេនអាណា សេថាន តើស៊ីស និងអហ៊ីសាហារ។
[11]អ្នកទាំងនេះសុទ្ធតែជាកូនរបស់លោកយេឌីអែល ដែលជាមេលើក្រុមគ្រួសាររបស់ខ្លួន និងជាមនុស្សពូកែអង់អាច។ ចំនួនក្រុមគ្រួសាររបស់ពួកគេមានទាំងអស់១៧,
២០០នាក់ ហើយជាមនុស្សដែលអាចចេញទៅច្បាំងបាន។[12](រីឯកូនរបស់លោកអ៊ៀរគឺ ស៊ូភីម និងហ៊ូភីម ហើយកូនរបស់លោកអហ៊ើរគឺហ៊ូស៊ីម)។
[13]កូនប្រុសៗរបស់លោកណែបថាលី ដែលជាកូនរបស់នាងប៊ីលហា មានយ៉ាស៊ាល គូនី យេស៊ើរ និងស៊ីលីម។
[14]កូនរបស់លោកម៉ាណាសេ គឺ អាសរាល និងម៉ាគារ ជាកូនដែលប្រពន្ធចុង ជាស្ត្រីសាសន៍អើរ៉ាម បានបង្កើតជូនលោក លោកម៉ាគារជាឪពុករបស់លោកកាឡាដ។[15]លោក
ម៉ាគារបានយកប្រពន្ធពីកូនចៅហ៊ូភីម និងស៊ូភីម។ ប្អូនស្រីរបស់គាត់ឈ្មោះនាងម៉ាកា។ កូនទីពីររបស់ម៉ាណាសេឈ្មោះស្លូផិហាត លោកស្លូផិហាតមានសុទ្ធតែកូនស្រី។
[16]នាងម៉ាកា ជាភរិយារបស់លោកម៉ាគារ បង្កើតបានកូនប្រុសមួយ ហើយដាក់ឈ្មោះថាពេរេស។ ប្អូនរបស់គាត់ឈ្មោះ សេរេស ដែលត្រូវជាឪពុករបស់អ៊ូឡាម និងរ៉ាគែម។
[17]កូនរបស់លោកអ៊ូឡាម គឺបេដាន។ អ្នកទាំងនេះសុទ្ធតែជាកូនចៅរបស់លោកកាឡាដ ដែលជាកូនរបស់លោកម៉ាគារ និងជាចៅរបស់លោកម៉ាណាសេ។
[18]រីឯនាងហាម៉ូលេកេត ជាប្អូនស្រីរបស់គាត់បង្កើតបាន អ៊ីសហូដ អបៀស៊ើរ និងម៉ាឡា។[19]កូនប្រុសៗរបស់លោកសេមីដា គឺអហ៊ីយ៉ាន ស៊ីគែម លីកហ៊ី និងអនីយ៉ាម។
[20]ពូជពង្សអេប្រាអ៊ីមមានដូចតទៅ កូនរបស់លោកអេប្រាអ៊ីម គឺស៊ូថេឡា។ លោកស៊ូថេឡាជាឪពុករបស់លោកបេរេដ។ លោកបេរេដជាឪពុករបស់លោកថាហាត់។ លោក
ថាហាត់ជាឪពុករបស់លោកអេឡេដា។ លោកអេឡេដាជាឪពុករបស់លោកតាហាត់។ លោកតាហាត់ជាឪពុករបស់លោកសាបាដ។[21]លោកសាបាដជាឪពុករបស់លោក
ស៊ូថេឡា។ លោកអេប្រាអ៊ីមមានកូនពីរទៀត គឺអេស៊ើរ និងអេលាដ ប៉ុន្តែ អ្នកស្រុកកាថបានសម្លាប់អ្នកទាំងពីរ នៅពេលដែលអ្នកទាំងពីរទៅដណ្តើមយកហ្វូងសត្វរបស់ពួក
គេ។[22]លោកអេប្រាអ៊ីម ជាឪពុកបានកាន់ទុក្ខជាយូរថ្ងៃ ហើយញាតិសន្តានក៏នាំគ្នាមកជួយសម្រាលទុក្ខលោកដែរ។
[23]បន្ទាប់មក លោកបានរួមរស់ជាមួយភរិយា ហើយនាងក៏មានផ្ទៃពោះបង្កើតបានកូនប្រុសមួយ ដែលលោកដាក់ឈ្មោះថា «បេរា» ដ្បិត
មានទុក្ខលំបាកកើតឡើងនៅក្នុងគ្រួសាររបស់លោក។[24]កូនស្រីរបស់លោកឈ្មោះនាងសេអេរ៉ា ជាអ្នកសង់ក្រុងបេតហូរ៉ូនខាងក្រោម និងបេតហូរ៉ូនខាងលើ
ព្រមទាំងក្រុងអ៊ូសេន-សេអេរ៉ា។
[25]លោកបេរាជាឪពុករបស់លោករេផា។ លោករេផាជាឪពុករបស់លោករេសែប។ លោករេសែបជាឪពុករបស់លោកថេឡា។ លោកថេឡាជាឪពុករបស់លោកថាហាន។
លោកថាហានជាឪពុករបស់លោកឡាអាដាន។[26]លោកឡាដានជាឪពុករបស់លោកអាំមីហ៊ូដ។ លោកអាំមីហ៊ូដជាឪពុករបស់លោកអេលីសាម៉ា។[27]លោកអេលីសាម៉ាជា
ឪពុករបស់លោកនូន។ លោកនូនជាឪពុករបស់លោកយ៉ូស្វេ។
[28]រីឯទឹកដីដែលពួកគេបានទទួលជាកម្មសិទ្ធិ សម្រាប់តាំងទីលំនៅ នោះមានក្រុងបេតអែល និងស្រុកភូមិនៅជុំវិញ។ នៅប៉ែកខាងកើតមានក្រុងណាអារ៉ាន និងស្រុកភូមិនៅ
ជុំវិញ ខាងលិចមានក្រុងកេស៊ើរ និងស្រុកភូមិនៅជុំវិញ ក្រុងស៊ីគែម និងស្រុកភូមិនៅជុំវិញ ហើយទៅរហូតដល់ក្រុងកាសា និងស្រុកភូមិនៅជុំវិញ។[29]ទីក្រុងជាប់ព្រំដែនកូន

generated on Wed Sep 10 16:16:32 2025

ចៅម៉ាណាសេមានក្រុងបេតសាន និងស្រុកភូមិនៅជុំវិញ ក្រុងតាណាក់ និងស្រុកភូមិនៅជុំវិញ ក្រុងមេគីដោ និងស្រុកភូមិនៅជុំវិញ ក្រុងដោរ និងស្រុកភូមិនៅជុំវិញ។
ទីក្រុងទាំង នេះហើយ ជាក្រុងដែលពូជពង្សលោកយ៉ូសែប ជាកូនរបស់លោកអ៊ីស្រាអែល តាំងទីលំនៅ។
[30]កូនប្រុសៗរបស់លោកអេស៊ើរ មាន យីមណា យីសវ៉ា យីសវី និងបេរា ហើយកូនស្រីរបស់លោកឈ្មោះនាងសេរ៉ា។[31]កូនប្រុសៗរបស់លោកបេរាមាន ហេប៊ើរ
និងម៉ាលគាល។ លោកម៉ាលគាលជាឪពុករបស់លោកប៊ីរសាអ៊ីត។[32]កូនប្រុសៗរបស់លោកហេប៊ើរមាន យ៉ាផ្លេត សូមើរ ហូថាម
ហើយកូនស្រីរបស់លោកឈ្មោះនាងស៊ូអា។
[33]កូនប្រុសៗរបស់លោកយ៉ាផ្លេតមាន ផាសាក់ ប៊ីមហាល និងអាសវ៉ាត។ អ្នកទាំងនេះជាកូនរបស់លោកយ៉ាផ្លេត។[34]កូនប្រុសៗរបស់លោកសូមើរជាប្អូនរបស់យ៉ផ្លេតមាន
រ៉ូកា ហ៊ូបបា និងអើរ៉ាម។[35]កូនប្រុសៗរបស់លោកហេលេមជាប្អូនលោកសូមើរ មានសូផា យីមណា សេលេស និងអាំម៉ាល។
[36]កូនប្រុសៗរបស់លោកសូផាមាន ស៊ូអា ហានេភើរ ស៊ូអាល បេរី យីមរ៉ា[37]បេស៊ើរ ហូដ សាំម៉ា ស៊ីលសា យីតរ៉ាន និងបេរ៉ា។[38]កូនប្រុសៗរបស់លោកយេធើរ មាន យេភូនេ
ពីសផា និងអើរ៉ា។
[39]កូនប្រុសៗរបស់លោកអ៊ូឡា មាន អើរ៉ា ហាននៀល និងរីសយ៉ា។[40]អ្នកទាំងនេះសុទ្ធតែជាកូនចៅរបស់លោកអេស៊ើរ ហើយជាមេដឹកនាំលើក្រុមគ្រួសាររបស់គេ គឺជាមេដឹក
នាំដ៏ចំណាន និងមានចិត្តអង់អាច។ ចំនួនក្រុមគ្រួសាររបស់គេជំរឿនបានទាំងអស់ ២៦, ០០០នាក់ ដែលសុទ្ធតែជាអ្នកដែលអាចធ្វើចម្បាំង។

---

1 Chronicles 7:1
ព័ត៌មានទូទៅ៖
សូមមើល and
ពួកគេមានចំនួនទាំងអស់ ២២,៦០០នាក់។
«មានបុរសម្ភៃពីរពាន់ប្រាំមួយរយនាក់»
នៅជំនាន់ព្រះបាទដាវីឌ
ការបកប្រែផ្សេងទៀត «កំឡុងពេលព្រះបាទដាវីឌមានព្រះជន្ម»
1 Chronicles 7:4
នៅជាមួយពួកគេ មាន
ការបកប្រែផ្សេងទៀត «ក្នុងចំណោមពួកគេ»
ដែលអាចធ្វើសឹកបាន ចំនួន៣៦,០០០នាក់
កងទ័ពចំនួនប្រាំមួយពាន់នាក់ចូលសមរភូមិ «ទាហានចំនួន ៣៦,០០០នាក់
ដែលបានត្រៀមខ្លួនចូលសមរភូមិរួចរាល់ហើយ»
1 Chronicles 7:6
ព័ត៌មានទូទៅ៖
សូមមើល and
ជាមនុស្សខ្លាំងពូកែអង់អាច
«ឪពុក» ឬ «បុព្វបុរស»
1 Chronicles 7:8
ព័ត៌មានទូទៅ៖
សូមមើល and
1 Chronicles 7:11
លោកយេឌីអែល ... លោកអៀរគី ... លោកអហ៊ើរ
ទាំងនេះជាឈ្មោះបុរស។
ចំនួនក្រុមគ្រួសាររបស់ពួកគេមានទាំងអស់១៧,២០០នាក់
«បញ្ជីអំបូរកត់ត្រាចំនួនដប់ប្រាំពីរពាន់ពីររយ»
ហ៊ូស៊ីម ...ស៊ូភីម ... ហ៊ូភីម
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 7:13
យ៉ាសាល គូនី យេស៊ើរ និងស៊ីលីម
ទាំងនេះជាឈ្មោះបុរស។
ដែលជាកូនរបស់នាងប៊ីលហា
ការបកប្រែផ្សេងទៀត «កូនប្រុសរបស់លោកប៊ីលហា»
1 Chronicles 7:14
ព័ត៌មានទូទៅ៖
សូមមើល
អើរ៉ាម
សំដៅទៅលើមនុស្សម្នាក់មកពីអើរ៉ាម ដែលជាតំបន់មួយនៃប្រទេសស៊ីរី។
កូនដែលប្រពន្ធចុង ជាស្ត្រីសាសន៍អើរ៉ាម បានបង្កើត
ការបកប្រែផ្សេងទៀត «ប្រពន្ធចុងអើរ៉ាមបានផ្តល់កំណើត»
1 Chronicles 7:17
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 7:20
ព័ត៌មានទូទៅ៖
សូមមើល
គឺអេស៊ើរ និងអេលាដ ប៉ុន្តែ អ្នកស្រុកកាថបានសម្លាប់អ្នកទាំងពីរ
ការបកប្រែផ្សេងទៀត «បុរសស្រុកកាថដែលជាជនជាតិដើមនៅលើដី
បានសម្លាប់អេស៊ើរនិងអេលាដ»
ទៅដណ្តើមយកហ្វូងសត្វរបស់ពួកគេ
ការបកប្រែផ្សេងទៀត «បងប្អូនបានទៅលួចហ្វូងពីប្រជាជនស្រុកកាថ»
1 Chronicles 7:23
នាងក៏មានផ្ទៃពោះបង្កើតបានកូនប្រុសមួយ
«នាងមានផ្ទៃពោះ ហើយសម្រាលបានកូនប្រុសមួយ»
ដាក់ឈ្មោះថា
«បានដាក់ឈ្មោះឲ្យគាត់»
បេរា ... សេអេរ៉ា
ទាំងនេះជាឈ្មោះមនុស្ស។
ជាអ្នកសង់ក្រុងបេតហ៊ូរ៉ុនខាងក្រោម និងបេតហ៊ូរ៉ុនខាងលើ
ទាំងនេះជាឈ្មោះទីកន្លែង។
1 Chronicles 7:25
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 7:28
ព័ត៌មានទូទៅ៖
សូមមើល
តាំងទីលំនៅ
ការបកប្រែផ្សេងទៀត «ផ្ទះនៅក្នុង»
ទីក្រុងទាំងនេះហើយ ជាក្រុងដែលពូជពង្សលោកយ៉ូសែប ជាកូនរបស់លោកអ៊ីស្រាអែល តាំងទី
លំនៅ។
ការបកប្រែផ្សេងទៀត «កូនចៅរបស់លោកយ៉ូសែប
ជាកូនអ៊ីស្រាអែលបានរស់នៅក្នុងក្រុងទាំងនេះ»
1 Chronicles 7:30
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 7:33
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 7:36
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 7:39
ព័ត៌មានទូទៅ៖
សូមមើល
គឺជាមេដឹកនាំដ៏ចំណាន
«បុរសសំខាន់»
ចំនួនក្រុមគ្រួសាររបស់គេជំរឿនបានទាំងអស់ ២៦,០០០នាក់
ដែលសុទ្ធតែជាអ្នកដែលអាចធ្វើចម្បាំង។
មានបុរស ៦.០០០ នាក់ត្រូវបានចុះបញ្ជី ដែលអាចបម្រើយោធាបាន
បើយោងតាមបញ្ជីរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«យោងទៅតាមកំណត់ការកត់ត្រាអំបូរដែលមានបុរស ២៦.០០០ នាក់
មានសមត្ថភាពបអាចបម្រើក្នុងជួរយោធា»

generated on Wed Sep 10 16:16:32 2025

8 [1]កូនប្រុសទាំងប្រាំរបស់លោកបេនយ៉ាមីនមានលោកបេឡា ជាកូនច្បងរបស់គាត់ បន្ទាប់មក លោកអាសបែល លោកអហ៊ីរ៉ាម[2]លោកណូហា និងលោករ៉ាផា។[3]កូនប្រុសៗរបស់លោកបេឡាមានលោកអតដើរ លោកកេរ៉ា លោកអប៊ីហ៊ូដ[4]លោកអប៊ីសួ លោកណាម៉ាន លោកអហ៊ូអា[5]លោកកេរ៉ា លោកសេភូផាន និងលោកហ៊ូរ៉ាម។
[6]រីឯកូនចៅរបស់អេហូដ ជាមេដឹកនាំលើក្រុមគ្រួសាររបស់ពួកគេ ក្នុងចំណោមអ្នកស្រុកកេបា ដែលប្តូរទីលំនៅទៅក្រុងម៉ាណាហាត់[7]ណាម៉ាន អហ៊ីយ៉ា និងកេរ៉ា លោកកេរ៉ានេះហើយដែលនាំពួកគេឲ្យប្តូរទីលំនៅ។ គាត់ជាឪពុករបស់លោកអ៊ូសា និងលោកអប៊ីហ៊ូដ។
[8]លោកសាហារ៉ែមបានក្លាយជាឪពុករបស់កូនចៅនៅក្នុងទឹកដីម៉ូអាប់ បន្ទាប់ពីគាត់បានលែងលះជាមួយភរិយារបស់គាត់ គឺនាងហ៊ូស៊ីម និងនាងបារ៉ា។[9]ជាមួយនាងហូដេស ជាភរិយាមួយទៀត លោកសាហារ៉ែមបានក្លាយជាឪពុករបស់លោកយ៉ូបាប់ ស៊ីបយ៉ា មេសា ម៉ាលកាម[10]យេអ៊ូស សុកយ៉ា និងមៀរម៉ា។ អ្នកទាំងនោះជាកូនរបស់គាត់ ហើយជាមេដឹកនាំលើក្រុមគ្រួសាររបស់គេ។[11]លោកសាហារ៉ែមបង្កើតបានកូនប្រុសពីរនាក់ ជាមួយនាងហ៊ូស៊ីមដែរ គឺអប៊ីធូប និងអែលផ្អាល។
[12]កូនប្រុសៗរបស់លោកអែលផ្អាលមាន ហេបើរ មីសាម និងសេមើរ (ជាអ្នកដែលសង់ក្រុងអូណូ និងក្រុងឡូដ ព្រមទាំងស្រុកភូមិនៅជុំវិញ)។[13]លោកបេរា និងសេម៉ា ជាមេដឹកនាំលើគ្រួសាររបស់គេ ក្នុងចំណោមអ្នកស្រុកអាយ៉ាឡូន ជាអ្នកដែលបានវាយអ្នកក្រុងកាថឲ្យបាក់ទ័ព។
[14]កូនប្រុសៗរបស់លោកបេរ៉ាមាន អហ៊ីយ៉ូរ សាសាក់ យេរេម៉ូត[15]សេបាឌា អើរ៉ាត អេឌើរ[16]មីកែល យីសប៉ា និងយ៉ូហា។[17]កូនប្រុសៗរបស់លោកអែលផាអាលមាន សេបាឌា មស៊ូឡាម ហ៊ីសគី ហេបើរ។[18]កូនប្រុសៗរបស់លោកយីសមេរ៉ាយ យីសលា និងយ៉ូបាប់។
[19]កូនប្រុសៗរបស់លោកស៊ីម៉ៃមាន យ៉ាគីម ស៊ីគ្រី សាប់ឌី[20]អេលីយេណាយ ស៊ីលថាយ អេលាល[21]អដាយ៉ា បេរ៉ាយ៉ា និងស៊ីមរ៉ាត។
[22]កូនប្រុសៗរបស់លោកសាសាក់មាន យីសផាន ហេបើរអាលាល[23]អាបដូន ស៊ីកគ្រី ហាណាន[24]ហាណានា អាឡាំ អាន់ថូធីយ៉ា[25]យីបដេយ៉ា និងពេនួល។
[26]កូនប្រុសៗរបស់លោកយេរ៉ូហាំមាន សាំសេរ៉ាយ សេហារា អថាលា[27]យ៉ារេសយ៉ា អេលីយ៉ា និងស៊ីកគ្រី។[28]អ្នកទាំងនេះសុទ្ធតែជាមេដឹកនាំលើក្រុមគ្រួសារ តាមតំណវង្សត្រកូលរបស់គេរៀងៗខ្លួន។ ពួកគេរស់នៅក្រុងយេរូសាឡឹម។
[29]លោកយេអែលជាអ្នកសង់ក្រុងគីបៀន និងប្រពន្ធរបស់គាត់ឈ្មោះម៉ាកា រស់នៅក្នុងក្រុងនោះ[30]កូនប្រុសច្បងរបស់គាត់មានអាប់ដូន បន្ទាប់មក ស៊ើរ គីស បាល ណាដាប[31]កេដោរ អហ៊ីយ៉ូ សេកើរ។
[32]កូនប្រុសៗរបស់យ៉ាអែលម្នាក់ទៀតគឺលោកមីកឡូតដែលជាឪពុករបស់សាំម៉ា។ ពួកគេក៏រស់នៅក្រុងយេរូសាឡឹមជាមួយបងប្អូនរបស់គេដែរ។[33]លោកនើរជាឪពុករបស់លោកគីស។ លោកគីសជាឪពុករបស់ព្រះបាទសូល។ ព្រះបាទសូលជាបិតារបស់សម្តេចយ៉ូណាថាន ម៉ាលគីស៊ូអា អប៊ីណាដាប់ និងអែសបាល។[34]កូនរបស់សម្តេចយ៉ូណាថានគឺមេរីបបាល។ លោកមេរីបបាលជាឪពុករបស់លោកមីកា។
[35]កូនប្រុសៗរបស់លោកមីកាមាន ពីថូន មេឡេក ថាក់រា និងអហាស។[36]លោកអហាសជាឪពុករបស់លោកយេហូអាដា។ លោកយេហូអាដាជាឪពុករបស់លោកអលេមេត។ លោកអលេមេតជាឪពុករបស់លោកអាសម៉ាវែត និងលោកស៊ីមរី។ លោកស៊ីមរីជាឪពុករបស់លោកម៉ូសា។[37]លោកម៉ូសាជាឪពុករបស់លោកប៊ីនា។ លោកប៊ីនាជាឪពុករបស់លោករេផាយ៉ា។ លោករេផាយ៉ាជាឪពុករបស់លោកអេលាសា។ លោកអេលាសាជាឪពុករបស់លោកអេសែល។
[38]លោកអេសែលមានកូនប្រុសប្រាំមួយនាក់ឈ្មោះ អាសរីកាំ បូកេរូ អ៊ីស្មាអែល ស្អារា អូបាឌា និងហាណាន។ អ្នកទាំងនេះសុទ្ធតែជាកូនរបស់លោកអេសែល។[39]កូនរបស់លោកអេសែកជាប្អូនគាត់ មានអ៊ូឡាម ជាកូនច្បង យេអ៊ូសជាកូនទីពីរ អេលីផាលេតជាកូនទីបី។[40]កូនប្រុសៗរបស់លោកអ៊ូឡាម សុទ្ធតែជាមនុស្សមានចិត្តអង់អាច ជំនាញខាងបាញ់ធ្នូ ហើយពួកគេមានកូនចៅជាច្រើន គឺរួមទាំងអស់១៥០នាក់។ អ្នកទាំងនេះសុទ្ធតែជាកូនចៅរបស់លោកបេនយ៉ាមីន។

---

1 Chronicles 8:1
ព័ត៌មានទូទៅ៖
សូមមើល and
1 Chronicles 8:6
ព័ត៌មានទូទៅ៖
សូមមើល
ដែលប្តូរទីលំនៅ
«ចាំបាច់ត្រូវផ្លាស់ទី» ឬ «បានត្រូវផ្លាស់ទី»
1 Chronicles 8:8
លោកសាហារ៉ែម ... លោកយ៉ូបាប់.. ស៊ីបយ៉ា... មេសា ... ម៉ាលកាម ... យេអ៊ូស ... សុកយ៉ា ... មៀរម៉ា ... អប៊ីធូប...អែលផ្អាល
ទាំងនេះជាឈ្មោះបុរស។
នាងហ៊ូស៊ីម ...នាងបារ៉ា ... នាងហូដេស
ទាំងនេះជាឈ្មោះស្ត្រី។
ជាមួយនាងហូដេស ជាភរិយាមួយទៀត លោកសាហារ៉ែមបានក្លាយជាឪពុករបស់
ការបកប្រែផ្សេងទៀត «លោកសាហារ៉ែម និងភរិយាឈ្មោះនាងហូដេស
មានកូនប្រុសដូចខាងក្រោម»
1 Chronicles 8:12
លោកអែលផ្អាល ... ហេបើរ ... មីសាម ... មីសាម ... លោកបេរា ... សេមើរ
ទាំងនេះជាឈ្មោះបុរស។
ក្រុងអូណូ ... ក្រុងឡូដ ...ស្រុកអាយ៉ាឡូន
ទាំងនេះជាឈ្មោះទីកន្លែង។
1 Chronicles 8:14
ព័ត៌មានទូទៅ៖
សូមមើល
លោកអែលផាអាល ... និងយ៉ូបាប់
ព័ត៌មាននៅក្នុង ៨:១៤ ត្រូវបានរៀបចំជាថ្មី ដើម្បីធ្វើឲ្យងាយយល់។
1 Chronicles 8:19
ព័ត៌មានទូទៅ៖
ព័ត៌មាននៅក្នុង ៨:១៤ត្រូវបានរៀបចំជាថ្មី ដើម្បីធ្វើឲ្យងាយយល់។
1 Chronicles 8:22
ព័ត៌មានទូទៅ៖
ព័ត៌មានក្នុង ៨:២២ ត្រូវបានរៀបចំជាថ្មី ដើម្បីធ្វើឲ្យងាយយល់។
1 Chronicles 8:26
ព័ត៌មានទូទៅ៖
សូមមើល
អ្នកទាំងនេះសុទ្ធតែជាមេដឹកនាំលើក្រុមគ្រួសារ
ពាក្យថា «មេអំបូរ» និង «មេដឹកនាំ» មានន័យដូចគ្នា។
1 Chronicles 8:29
ព័ត៌មានទូទៅ៖
សូមមើល
លោកយេអែលជាអ្នកសង់ក្រុងគីបៀន និងប្រពន្ធរបស់គាត់ឈ្មោះម៉ាកា រស់នៅក្នុងក្រុងនោះ
នៅទីនេះ «ឪពុករបស់» សំដៅទៅលើតួនាទីរបស់ លោកយេអែល
ក្នុងនាមជាមនុស្សដែលដឹកនាំនៅក្នុងទីក្រុងគីបៀន។ ការបកប្រែផ្សេងទៀត
«លោកយេអែលមេដឹកនាំរបស់គីបៀនរស់នៅក្នុងគីបៀន។
ប្រពន្ធរបស់គាត់ឈ្មោះម៉ាកា»
កូនប្រុសច្បងរបស់គាត់
«លោកយេអែលជាកូនប្រុសច្បងរបស់គាត់»
1 Chronicles 8:32
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 8:35
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 8:38
ព័ត៌មានទូទៅ៖
សូមមើល and
យេអ៊ូសជាកូនទីពីរ អេលីផាលេតជាកូនទីបី។
ការបកប្រែផ្សេងទៀត «យេអ៊ូសកូនប្រុសទី២ និងអេលីផាលេតជាកូនទី៣»
ហើយពួកគេមានកូនចៅជាច្រើន គឺរួមទាំងអស់១៥០នាក់។
ការបកប្រែផ្សេងទៀត
«ពួកគេមានកូនប្រុសនិងចៅសរុបចំនួនមួយរយហាសិបនាក់»

generated on Wed Sep 10 16:16:32 2025

9 [1]គេបានធ្វើជំរឿនប្រជាជនអ៊ីស្រាអែលទាំងមូល តាមក្រុមគ្រួសាររបស់គេ ហើយបានកត់ត្រាទុកក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ស្តេចស្រុកអ៊ីស្រាអែល។ ប្រជាជនយូដាត្រូវខ្មាំងកៀរទៅជាឈ្លើយ នៅស្រុកបាប៊ីឡូន ពីព្រោះតែពួកគេមិនស្មោះត្រង់នឹងព្រះជាម្ចាស់។[2]អស់អ្នកដែលបានវិលត្រឡប់មកវិញមុនគេបង្អស់ ហើយកាន់កាប់ទឹកដីជាកម្មសិទ្ធិរបស់ខ្លួននៅតាមក្រុងនានា នោះគឺប្រជាជនអ៊ីស្រាអែលធម្មតា ពួកបូជាចារ្យ ពួកលេវី និងពួកអ្នកបម្រើនៅព្រះវិហារ។[3]កូនចៅយូដា កូនចៅបេនយ៉ាមីន កូនចៅអេប្រាអ៊ីម និងម៉ាណាសេខ្លះ នាំគ្នាតាំងទីលំនៅនៅក្រុងយេរូសាឡឹម។
[4]នៅក្នុងកុលសម្ព័ន្ធយូដាមានលោកអ៊ូថាយ ជាកូនរបស់លោកអាំមីហ៊ូដ ដែលជាកូនរបស់លោកអុមរី ដែលជាកូនរបស់លោកអ៊ីមរី លោកអ៊ីមរីជាកូនរបស់លោកបានី ក្នុងអំបូរពេរេស ដែលជាកូនរបស់លោកយូដា។[5]ក្នុងអំបូរស៊ីឡូរមានលោកអសាយ៉ា ជាកូនច្បងគេ និងកូនចៅរបស់គាត់។[6]ក្នុងអំបូរសេរ៉ាមានលោកយេអួល និងបងប្អូនរបស់គាត់។ សរុបទាំងអស់មាន ៦៩០នាក់។
[7]ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន មានលោកសាលូ ជាកូនរបស់លោកមេស៊ូឡាម លោកមេស៊ូឡាមជាកូនរបស់លោកហូដាវា លោកហូដាវាជាកូនរបស់លោកហាសេនួ។[8]លោកយីបនេយ៉ាជាកូនរបស់លោកយេរ៉ូហាំ។ លោកអេឡាជាកូនរបស់លោកអ៊ូស៊ី ហើយលោកអ៊ូស៊ីត្រូវជាកូនរបស់លោកមីករី លោកមីករីជាកូនរបស់លោកមេស៊ូឡាម មេស៊ូឡាមជាកូនរបស់លោកសេផាធា លោកសេផាធាជាកូនរបស់លោករេហួល លោករេហួលជាកូនរបស់លោកយីបនីយ៉ា។[9]បងប្អូនរបស់ពួកគេរាប់តាមតំណវង្សត្រកូលរបស់ពួកគេមានចំនួន ៩៥៦នាក់។ អ្នកទាំងនេះសុទ្ធតែជាមេដឹកនាំលើក្រុមគ្រួសាររបស់គេរៀងៗខ្លួន។
[10]ក្រុមបូជាចារ្យមានលោកយេដាយ៉ា លោកយេហូយ៉ារីប លោកយ៉ាគីន។[11]លោកអសារា ជាកូនរបស់លោកហ៊ីលគីយ៉ា។ លោកហ៊ីលគីយ៉ាជាកូនរបស់លោកមេស៊ូឡាម។ លោកមេស៊ូឡាមជាកូនរបស់លោកសាដុក។ លោកសាដុកជាកូនរបស់លោកមេរ៉ាយ៉ូត។ លោកមេរ៉ាយ៉ូតជាកូនរបស់លោកអហ៊ីទូប ជាអ្នកគ្រប់គ្រងលើព្រះដំណាក់របស់ព្រះជាម្ចាស់។
[12]លោកអដាយ៉ាជាកូនរបស់លោកយេរ៉ូហាំ លោកយេរ៉ូហាំជាកូនរបស់លោកផាសហ៊ើរ លោកផាសហ៊ើរជាកូនរបស់លោកម៉ាល់គា។ លោកម៉ាសាយ ជាកូនរបស់លោកអឌីអែល ជាកូនរបស់លោកយ៉ាសេរ៉ាំៗជាកូនរបស់លោកមេស៊ូឡាមៗជាកូនរបស់មេស៊ីលេមីតៗជាកូនរបស់លោកអ៊ីមមើរ[13]ព្រមទាំងបងប្អូនរបស់ពួកគេ ដែលសុទ្ធតែជាមេដឹកនាំលើក្រុមគ្រួសាររបស់ខ្លួន មានចំនួនទាំងអស់១, ៧៦០នាក់។ អ្នកទាំងនោះជាមនុស្សប៉ិនប្រសប់បំពេញការងារនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
[14]ក្រុមលេវីមានសេម៉ាយ៉ា ជាកូនលោកហាស៊ូប លោកហាស៊ូបជាកូនរបស់លោកអាសរីកាំ លោកអាសរីកាំជាកូនរបស់លោកហាសាបយ៉ាក្នុងអំបូរម៉្រារី។[15]លោកបាកបាការ លោកហេរេស លោកកាឡាល លោកម៉ាថានា ជាកូនរបស់លោកមីកា លោកមីកាជាកូនរបស់លោកស៊ីកគ្រី លោកស៊ីកគ្រីជាកូនរបស់លោកអេសាភ។[16]ក៏មានលោកអូបាឌាជាកូនរបស់លោកសេម៉ាយ៉ាផងដែរ លោកសេម៉ាយ៉ាជាកូនរបស់លោកកាឡាល លោកកាឡាលជាកូនរបស់លោកយេឌូថិន។ លោកបេរេគា ជាកូនរបស់លោកអេសា លោកអេសាជាកូនរបស់លោកអែលកាណា ដែលរស់នៅតាមភូមិរបស់ពួកនេថូផា។
[17]ក្រុមឆ្មាំទ្វារ មានលោកសាលូម លោកអាកគូប លោកថាលម៉ូន លោកអហ៊ីម៉ាន និងបងប្អូនរបស់គេ។ លោកសាលូមជាមេដឹកនាំ។[18]ពីដើមមក ពួកគេតែងតែយាមនៅខ្លោងទ្វារហ្លួងនៅប៉ែកខាងកើតជាទ្វារនៃជំរំកូនចៅលេវី។[19]លោកសាលូមជាកូនរបស់លោកកូរេ លោកកូរេជាកូនរបស់លោកអេបៀយ៉ាសាប់ លោកអេបៀយ៉ាសាប់ជាកូនរបស់លោកកូរ៉ា ព្រមទាំងបងប្អូនរួមត្រកូលរបស់គាត់ គឺពូជពង្សកូរ៉ា មានភារកិច្ចជាអ្នកយាមទ្វារពន្លាជួបព្រះអម្ចាស់។ បុព្វបុរសរបស់ពួកគេក៏ធ្លាប់ធ្វើជាអ្នកយាមនៅច្រកចូលពន្លារបស់ព្រះអម្ចាស់ដែរ។
[20]លោកភីនេហាស ជាកូនរបស់លោកអេឡាសារធ្វើជាអ្នកដឹកនាំហើយព្រះអម្ចាស់បានគង់នៅជាមួយលោក។[21]លោកសាការីជាកូនរបស់លោកមេសេលេមា ជាឆ្មាំទ្វារពន្លាជួបព្រះអម្ចាស់។
[22]អស់អ្នកដែលត្រូវគេជ្រើសរើសឲ្យធ្វើជាឆ្មាំទ្វារ ហើយបានជំរឿនតាមភូមិរបស់គេមានចំនួនទាំងអស់២១២នាក់។
ឈ្មោះរបស់ពួកគេត្រូវបានកត់ត្រាទុកដោយប្រជាជននៅក្នុងភូមិរបស់ពួកគេ។ ព្រះបាទដាវីឌ និងលោកសាំយូអែលជាព្យាការីបានតែងតាំងពួកគេឲ្យបំពេញមុខងារនេះ។[23]ដូច្នេះ ពួកគេនិងកូនចៅរបស់ពួកគេក៏បំពេញមុខងារជាឆ្មាំទ្វារព្រះដំណាក់ព្រះអម្ចាស់គឺមាត់ទ្វារពន្លាជួបព្រះជាម្ចាស់។[24]មានពួកឆ្មាំទ្វារនៅគ្រប់ទិសទាំងបួន ខាងកើត ខាងលិច ខាងជើង និងខាងត្បូង។
[25]រីឯបងប្អូនរបស់ពួកគេដែលរស់នៅតាមភូមិនានា ត្រូវចូលមកប្តូរវេនជួយការងាររបស់ពួកគេក្នុងអំឡុងពេលប្រាំពីរថ្ងៃ។[26]តែពួកលេវីទាំងបួននាក់ ដែលជាមេលើពួកឆ្មាំទ្វារនៅបំពេញការងាររបស់ខ្លួនជាប់រហូត។ លើសពីនោះ ពួកគេក៏មើលខុសត្រូវលើបន្ទប់ផ្សេងៗ និងទ្រព្យនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ដែរ។[27]ពេលយប់ ពួកគេស្នាក់នៅជុំវិញព្រះដំណាក់របស់ព្រះជាម្ចាស់ ដ្បិតពួកគេមានភារកិច្ចយាមព្រះដំណាក់និងបើកទ្វាររៀងរាល់ព្រឹក។
[28]ពួកលេវីខ្លះមានភារកិច្ចថែរក្សាគ្រឿងបរិក្ខារ សម្រាប់ប្រើប្រាស់ក្នុងព្រះដំណាក់ គឺពួកគេត្រូវរាប់នៅពេលយកចេញមកប្រើ ហើយពេលយកទៅទុកវិញក៏ត្រូវរាប់ដែរ។[29]អ្នកខ្លះទទួលភារកិច្ចថែរក្សាគ្រឿងបរិក្ខារឯទៀតៗ និងគ្រឿងសម្ភារនៅក្នុងទីសក្ការៈ ព្រមទាំងម្សៅម៉ដ្ត ស្រាទំពាំងបាយជូរ ប្រេង គ្រឿងក្រអូប និងប្រេងក្រអូបផ្សេងៗផង។
[30]ពួកបូជាចារ្យខ្លះទទួលបន្ទុកផ្នែកខាងផ្សំប្រេងក្រអូប។[31]លោកម៉ាធិធាជាពួកលេវី ហើយជាកូនច្បងរបស់លោកសាលូម ក្នុងពូជពង្សរបស់លោកកូរ៉ា មានភារកិច្ចធ្វើនំដែលសម្រាប់ថ្វាយជាតង្វាយ។[32]រីឯបងប្អូនរបស់ពួកគេពីអំបូរកេហាត់ មានភារកិច្ចចាត់ចែងមើលនំប៉័ងនៃព្រះវត្តមានព្រះអម្ចាស់ ដែលត្រូវរៀបថ្វាយព្រះអម្ចាស់ រៀងរាល់ថ្ងៃឈប់សំរាក។
[33]ពួកអ្នកចម្រៀង ដែលសុទ្ធតែជាមេដឹកនាំក្រុមគ្រួសារលេវី អាស្រ័យនៅតាមបន្ទប់នានា ក្នុងព្រះដំណាក់។ ពួកគេមិនធ្វើការអ្វីផ្សេងទៀតឡើយ ដ្បិត ពួកគេត្រូវបំពេញមុខងាររបស់ខ្លួនទាំងថ្ងៃ ទាំងយប់។[34]នេះហើយជាមេដឹកនាំរបស់ក្រុមគ្រួសារនៃកុលសម្ព័ន្ធលេវី តាមតំណវង្សត្រកូលរបស់ពួកគេ។ អ្នកទាំងនោះរស់នៅក្នុងក្រុងយេរូសាឡឹម។
[35]លោកយេហ៊ីអែល និងប្រពន្ធរបស់គាត់ឈ្មោះម៉ាកា ជាអ្នកសង់ក្រុងគីបៀន រស់នៅក្នុងក្រុងគីបៀននោះ។[36]កូនរបស់គាត់មានអាប់ដូន ជាកូនច្បង បន្ទាប់មក ស៊ើរ គីស បាល នើរ ណាដាប[37]កេដោរ អហ៊ីយ៉ូ សាការី និងមីកឡូត។
[38]លោកមីកឡូតជាឪពុករបស់លោកសាំម៉ា។ អ្នកទាំងនោះក៏រស់នៅក្រុងយេរូសាឡឹមជាមួយបងប្អូនរបស់គេដែរ។[39]លោកនើរជាឪពុករបស់លោកគីស លោកគីសជាឪពុករបស់ព្រះបាទសូល ព្រះបាទសូលជាបិតារបស់សម្តេចយ៉ូណាថាន ម៉ាលគីស៊ូអា អប៊ីណាដាប់ និងអែសបាល។[40]កូនរបស់សម្តេចយ៉ូណាថានគឺមេរីបបាល ហើយលោកមេរីបបាលជាឪពុករបស់លោកមីកា។
[41]កូនរបស់លោកមីកាមាន ពីថូន មេឡេក និងថារា និងអហាស។[42]លោកអហាសជាឪពុករបស់លោកយ៉ារ៉ា។ លោកយ៉ារ៉ាជាឪពុករបស់លោកអលេមេត។ លោកអលេមេតលោកអាសម៉ាវែត និងលោកស៊ីមរី។ លោកស៊ីមរី ជាឪពុករបស់លោកម៉ូសា។[43]លោកម៉ូសាជាឪពុករបស់លោកបីនា លោកបីនាជាឪពុករបស់លោករេផាយ៉ា។ លោករេផាយ៉ាជាឪពុករបស់លោកអេលាសា។[44]លោកអេលេសាជាឪពុករបស់លោកអសេល។ លោកអសេលមានកូនប្រុសប្រាំមួយនាក់ ឈ្មោះ អាសរីកាំ បូកេរូ អ៊ីស្មាអែល ស្អារ៉ា អូបាឌា និងហាណាន។ អ្នកទាំងនេះសុទ្ធតែជាកូនរបស់លោកអសេល។

---

1 Chronicles 9:1
គេបានធ្វើជំរឿនប្រជាជនអ៊ីស្រាអែលទាំងមូល
ពង្សាវតានេះសំដៅទៅលើកំណត់ត្រាកូនចៅគ្រួសារ ឬបុព្វបុរស។
ហើយបានកត់ត្រាទុកក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់ស្តេចស្រុកអ៊ីស្រាអែល។
សំដៅទៅលើសៀវភៅប្រវត្តិសាស្ត្រ ដែលលែងមានទៀតហើយ។
1 Chronicles 9:4

ព័ត៌មានទូទៅ៖
សូមមើល and
អំបូរស៊ីឡូរ
នេះជាឈ្មោះរបស់ក្រុមមនុស្ស ដែលចុះមកពីសេឡា។ តែសរសេរឈ្មោះថាសេឡានីតវិញ។
1 Chronicles 9:7

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ៖

សូមមើល

1 Chronicles 9:10

ព័ត៌មានទូទៅ៖

សូមមើល

1 Chronicles 9:12

ព័ត៌មានទូទៅ៖

សូមមើល and

អ្នកទាំងនោះជាមនុស្សប៉ិនប្រសប់បំពេញការងារនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។

ការបកប្រែផ្សេងទៀត «បុរសដែលមានសមត្ថភាពទាំងនេះ ធ្វើការនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់»

1 Chronicles 9:14

លោកសេម៉ាយ៉ា ... លោកអែលកាណា

ទាំងនេះជាឈ្មោះបុរស។

ជាកូនរបស់លោក

"ម្នាក់ក្នុងចំណោមកូនចៅ"

ពួកនេថូផា

នេះជាឈ្មោះរបស់ក្រុមមនុស្ស។

1 Chronicles 9:17

ព័ត៌មានទូទៅ៖

សូមមើល

ក្រុមឆ្មាំទ្វារ

«អង្គរក្ស» ឬ «អ្នកយាមទ្វារ»

ពួកគេតែងតែយាមនៅខ្លោងទ្វារហួងនៅប៉ែកខាងកើតជាទ្វារនៃជំរំកូនចៅលេវី។

កូនចៅរបស់លោកលេវីយាមនៅមាត់ទ្វារស្តេច នៅប៉ែកខាងកើតជំរំរបស់ពួកគេ "

ជាអ្នកយាមទ្វារពន្លា ...នៅច្រកចូល

ឃ្លាទាំងពីរនេះសំដៅទៅលើច្រកចូលព្រះពន្លារបស់ព្រះអម្ចាស់ ឬរោងឧបោសថ។

1 Chronicles 9:20

ធ្វើជាអ្នកដឹកនាំ

ការបកប្រែផ្សេងទៀត «ទទួលខុសត្រូវលើអ្នកយាមទ្វារ»

1 Chronicles 9:22

ព័ត៌មានទូទៅ៖

សូមមើល

ឈ្មោះរបស់ពួកគេត្រូវបានកត់ត្រាទុកដោយប្រជាជននៅក្នុងភូមិរបស់ពួកគេ។

ការបកប្រែផ្សេងទៀត

«កំណត់ត្រានៅក្នុងភូមិរបស់ប្រជាជនរួមមានឈ្មោះបុរសទាំងនេះ»

កូនចៅរបស់ពួកគេ

«កូនចៅរបស់ពួកគេ»

មានពួកឆ្មាំទ្វារនៅគ្រប់ទិស

ការបកប្រែផ្សេងទៀត «ទាហានចូល»

គ្រប់ទិសទាំងបួន ខាងកើត ខាងលិច ខាងជើង និងខាងត្បូង។

ការបកប្រែផ្សេងទៀត «នៅជុំវិញទាំងអស់»

1 Chronicles 9:25

បងប្អូនរបស់ពួកគេ

«បងប្អូនរបស់ឆ្មាំទ្វារ»

ត្រូវចូលមកប្តូរវេនជួយការងាររបស់ពួកគេក្នុងអំឡុងពេលប្រាំពីរថ្ងៃ។

ប្តូរវេនវិលជុំ។ ការបកប្រែផ្សេងទៀត «នឹងមកជួយរយៈពេល៧ថ្ងៃ គឺប្តូរវេន»

ដែលជាមេលើពួកឆ្មាំទ្វារ នៅបំពេញការងាររបស់ខ្លួន

ការបកប្រែផ្សេងទៀត «ឆ្មាំយាមបន្ទប់»

1 Chronicles 9:28

ពួកលេវីខ្លះមាន

«ឆ្មាំយាមទ្វារមួយចំនួន»

គឺពួកគេត្រូវរាប់នៅពេលយកចេញមកប្រើ ហើយពេលយកទៅទុកវិញក៏ត្រូវរាប់ដែរ។

ការបកប្រែផ្សេងទៀត «ពួកគេបានរាប់អត្ថបទ ដែលមនុស្សបានយកមកប្រើ ហើយពួកគេបានរាប់អត្ថបទនៅពេលមនុស្សនាំពួកគេមកវិញ»

ទទួលភារកិច្ចថែរក្សា

ការបកប្រែផ្សេងទៀត «ថែរក្សា» ឬ «យកចិត្តទុកដាក់»

1 Chronicles 9:30

លោកម៉ាធិធា ... លោកសាលូម

ទាំងនេះជាឈ្មោះបុរស។

លោកកូរ៉ា ... អំបូរកេហាត់

ទាំងនេះជាឈ្មោះរបស់ក្រុមមនុស្ស។

នំប៉ុងនៃព្រះវត្តមានព្រះអម្ចាស់

សូមមើលទំព័របកប្រែពាក្យអំពី «នំប៉ុង» ដើម្បីកំណត់និយមន័យជាក់លាក់ អំពី «នំប៉ុងនៃព្រះវត្តមានរបស់ព្រះអម្ចាស់ » ។

1 Chronicles 9:33

ពួកគេមិនធ្វើការអ្វីផ្សេងទៀតឡើយ

ការបកប្រែផ្សេងទៀត «ពួកគេមិនចាំបាច់ធ្វើការងារផ្សេងទៀតទេ»

ដ្បិត ពួកគេត្រូវបំពេញមុខងាររបស់ខ្លួនទាំងថ្ងៃ ទាំងយប់។

ការបកប្រែផ្សេងទៀត «ត្រូវបំពេញភារកិច្ចដែលបានកំណត់»

ខ្លួនទាំងថ្ងៃ ទាំងយប់

មានន័យថា «គ្រប់ពេលវេលា» ហើយអាចបកប្រែដោយប្រើឃ្លា ឬពាក្យពីភាសា ឬវប្បធម៌របស់អ្នកដែលផ្តល់អត្ថន័យដូចគ្នា។

នេះហើយជាមេដឹកនាំរបស់ក្រុមគ្រួសារនៃកុលសម្ព័ន្ធលេវី តាមតំណរង្សត្រកូលរបស់ពួកគេ។

ការបកប្រែផ្សេងទៀត «បញ្ជីប្រវត្តិរួមមានឈ្មោះអ្នកដឹកនាំគ្រួសារលេវីទាំងនេះ»

1 Chronicles 9:35

ព័ត៌មានទូទៅ៖

សូមមើល

ក្រុងគីបៀន

ឯកសារយោងទីមួយទៅគីបៀន គឺសំដៅទៅលើមនុស្ស តែសេចក្តីយោងទីពីរចំពោះគីបៀនវិញ គឺទីក្រុង។

1 Chronicles 9:38

ព័ត៌មានទូទៅ៖

សូមមើល

1 Chronicles 9:41

ព័ត៌មានទូទៅ៖

សូមមើល and

---

10 [1]ពួកកងទ័ពភីលីស្ទីនបានវាយប្រហារកងទ័ពអ៊ីស្រាអែល។ ពលទាហានអ៊ីស្រាអែលបាក់ទ័ពនៅមុខពួកភីលីស្ទីនហើយទាហានអ៊ីស្រាអែលជាច្រើនបានស្លាប់នៅលើ
ភ្នំគីលបោ។[2]ពួកភីលីស្ទីនបានដេញតាមព្រះបាទសូល និងបុត្រៗរបស់ស្តេចយ៉ាងប្រកិត។ ពួកគេសម្លាប់សម្តេចយ៉ូណាថាន សម្តេចអប៊ីណាដាប់ និងសម្តេច
ម៉ាល់គីស៊ូអា ជាបុត្ររបស់ព្រះបាទសូល។[3]បន្ទាប់មក គេសម្រុកទៅលើព្រះបាទសូល។ ទ័ពបាញ់ព្រួញបានដេញតាមទាន់ព្រះបាទសូល ធ្វើឲ្យទ្រង់តក់ស្លុតយ៉ាងខ្លាំង។
[4]ស្តេចមានរាជឱង្ការទៅសេនាដែលកាន់គ្រឿងសស្ត្រាវុធរបស់ស្តេចថា៖ «ចូរឯងហូតដាវរបស់ឯងចាក់យើងមក ព្រោះយើងមិនចង់ឲ្យសាសន៍ដទៃសម្លាប់យើង ហើយ
ប្រមាថមើលងាយយើងទេ»។ សេនានោះមិនហ៊ានសម្លាប់ស្តេចឡើយ ព្រោះគាត់ភ័យខ្លាចយ៉ាងខ្លាំង។ ដូច្នេះ ព្រះបាទសូលក៏ហូតដាវ ហើយផ្តួលខ្លួនលើមុខដាវនោះទៅ។
[5]កាលសេនាដែលកាន់គ្រឿងសស្ត្រាវុធរបស់ស្តេចឃើញស្តេចសោយទិវង្គតដូច្នេះ គាត់ក៏ហូតដាវ រួចផ្តួលខ្លួនលើមុខដាវដែរ។[6]ដូច្នេះ ព្រះបាទសូល និងបុត្រាទាំងបីអង្គ
ព្រមទាំងញាតិវង្សទាំងអស់ បាត់បង់ជីវិតក្នុងពេលជាមួយគ្នា។
[7]កាលជនជាតិអ៊ីស្រាអែលទាំងអស់ ដែលស្ថិតនៅក្នុងជ្រលងភ្នំ ឃើញថាអ៊ីស្រាអែលបាក់ទ័ព ហើយព្រះបាទសូល ព្រមទាំងបុត្រាសុគតអស់ ពួកគេក៏បោះបង់ទីក្រុងចោល
ហើយរត់ភៀសខ្លួនអស់ទៅ។ កងទ័ពភីលីស្ទីនក៏ចូលមកកាន់កាប់ក្រុងទាំងនោះ។[8]ស្អែកឡើង ពួកភីលីស្ទីននាំគ្នាមកប្រមូលរបស់របរដែលនៅជាប់នឹងសាកសព ហើយ
ឃើញសពរបស់ព្រះបាទសូល និងបុត្រាទាំងបីអង្គ នៅលើភ្នំគីលបោ។
[9]ពួកគេក៏ដោះយកអ្វីៗទាំងអស់ពីសពរបស់ទ្រង់ ព្រមទាំងកាត់ក និងយកគ្រឿងសស្ត្រាវុធទៅជាមួយ រួចធ្វើដំណឹងនេះទៅគ្រប់ទីកន្លែង ក្នុងស្រុកភីលីស្ទីនទាំងមូល
ឲ្យប្រកាសនៅតាមវិហារនៃព្រះរបស់គេ និងប្រកាសប្រាប់ដល់ប្រជាជន។[10]ពួកគេបានយកគ្រឿងសស្ត្រាវុធរបស់ព្រះបាទសូលទៅតម្កល់ទុកក្នុងវិហារនៃព្រះរបស់គេ
ហើយយកព្រះសិរសារបស់ស្តេចទៅព្យួរនៅក្នុងវិហារព្រះដាកុន។

generated on Wed Sep 10 16:16:32 2025

[11]កាលអ្នកក្រុងយ៉ាបេសកាឡាដ ដឹងអំពីហេតុការណ៍ទាំងប៉ុន្មាន ដែលពួកភីលីស្ទីនបានប្រព្រឹត្តចំពោះសពរបស់ព្រះបាទសូល[12]ទាហានដ៏ចំណានទាំងប៉ុន្មាននៅក្រុងនោះ បាននាំគ្នាចេញដំណើរទៅយកសពរបស់ព្រះបាទសូល និងបុត្រា នាំមកក្រុងយ៉ាបេសវិញ។ ពួកគេរើសធាតុយកទៅបញ្ចុះក្រោមដើមជ្រៃមួយនៅក្រុងយ៉ាបេស ហើយនាំគ្នាតមអាហារចំនួនប្រាំពីរថ្ងៃ។
[13]ព្រះបាទសូលសោយទិវង្គត ព្រោះតែស្តេចបានប្រព្រឹត្តខុស ដោយក្បត់នឹងព្រះអម្ចាស់។ ស្តេចពុំកាន់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ឡើយ ផ្ទុយទៅវិញស្តេចបានទៅរកគ្រូអន្ទងខ្មោចទស្សន៍ទាយ។[14]ស្តេចពុំបានទូលសួរព្រះអម្ចាស់ទេ ហេតុនេះ ព្រះអង្គធ្វើឲ្យស្តេចសោយទិវង្គត ហើយផ្ទេររាជសម្បត្តិទៅឲ្យព្រះបាទដាវីឌ ជាបុត្ររបស់លោកអ៊ីសាយវិញ។

---

1 Chronicles 10:1

ព័ត៌មានទូទៅ៖

សូមមើល

ពលទាហានអ៊ីស្រាអែលបាក់ទ័ពនៅមុខ

ការបកប្រែផ្សេងទៀត «កងទ័ពអ៊ីស្រាអែលបានរត់គេចពី»

បានដួលចុះស្លាប់

ការបកប្រែផ្សេងទៀត «បានស្លាប់»

1 Chronicles 10:4

ចូរឯងហូតដាវរបស់ឯងចាក់យើងមក

ការបកប្រែផ្សេងទៀត «សម្លាប់ខ្ញុំជាមួយវា»

ព្រោះយើងមិនចង់ឲ្យសាសន៍ដទៃសម្លាប់យើង

ឯកសារយោងទាក់ទងនឹង «ការកាត់ស្បែក» នៅទីនេះគឺជាការប្រមាថមួយ ដែលបង្ហាញថាមនុស្សទាំងនេះជាជនបរទេស ហើយគ្មានទំនាក់ទំនងជាមួយព្រះជាម្ចាស់ទេ។

ហើយផ្តួលខ្លួនលើមុខដាវនោះទៅ។

ការបកប្រែផ្សេងទៀត «បានសម្លាប់ខ្លួនឯងជាមួយវា»

1 Chronicles 10:5

និងបុត្រាទាំងបីអង្គ

ការបកប្រែផ្សេងទៀត «និងបុត្រាទាំងបីអង្គ»

1 Chronicles 10:7

កាលជនជាតិអ៊ីស្រាអែលទាំងអស់

ការបកប្រែផ្សេងទៀត «នៅពេលដែលជនជាតិអ៊ីស្រាអែល«

ចូលមកកាន់កាប់ក្រុងទាំងនោះ

«បានរស់នៅក្នុងទីក្រុងអ៊ីស្រាអែល»

ស្អែកឡើង

ឃ្លាប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។ បើភាសារបស់អ្នកមានរបៀបធ្វើដូចនេះ អ្នកអាចពិចារណាប្រើវានៅទីនេះ។

របស់របរដែលនៅជាប់នឹងសាកសព

ការបកប្រែផ្សេងទៀត «ដើម្បីយកអ្វីៗដែលមានតម្លៃចេញពីសាកសព»

ហើយឃើញសពរបស់ព្រះបាទសូល និងបុត្រា

«ស្តេចសូលនិងបុត្រាបានសុគត»

1 Chronicles 10:9

ពួកគេក៏ដោះយកអ្វីៗទាំងអស់ពីសពរបស់ទ្រង់

ការបកប្រែផ្សេងទៀត

«ពួកភីលីស្ទីនបានដករបស់ចេញពីស្តេចសូលចេញទាំងអស់»

ពួកគេបានយកគ្រឿងសស្ត្រាវុធរបស់ព្រះបាទទៅ

«ពួកភីលីស្ទីនបានបំពាក់គ្រឿងសឹករបស់ព្រះបាទសូល»

ដាកុន

នេះជាឈ្មោះរបស់ព្រះក្លែងក្លាយ។

1 Chronicles 10:11

ព័ត៌មានទូទៅ៖

សូមមើល and

កាលអ្នកក្រុងយ៉ាបេសកាឡាដ ដឹងអំពីហេតុការណ៍ទាំងប៉ុន្មាន ដែលពួកភីលីស្ទីន

ការបកប្រែផ្សេងទៀត «នៅពេលប្រជាជននៅយ៉ាបេសកាឡាតបានឮនូវអ្វីៗដែលពួកទាហានភីលីស្ទីន» (សូមមើល and)

ពួកគេរើសធាតុ

ការបកប្រែផ្សេងទៀត «សាកសពរបស់ពួកគេ» ឬ «សាកសពរបស់ពួកគេ»

1 Chronicles 10:13

បានទៅរក

នេះជាយោបល់ ឬសំណូមពរដែលមនុស្សគួរធ្វើ។

ធ្វើឲ្យស្តេចសោយទិវង្គត

ការបកប្រែផ្សេងទៀត «បានអះអាងថា នឹងនិយាយជាមួយពួកអ្នកដែលបានស្លាប់»

បានទូលសួរ

នេះជាជំនួយ ឬដំបូន្មានអំពីអ្វីដែលគាត់គួរធ្វើ។

ហើយផ្ទេររាជសម្បត្តិទៅ

ការបកប្រែផ្សេងទៀត «បានប្រគល់ការគ្រប់គ្រងលើប្រជាជនអ៊ីស្រាអែលទៅឲ្យ»

---

11 [1]ប្រជាជនអ៊ីស្រាអែលទាំងអស់បានប្រមូលគ្នាមកគាល់ព្រះបាទដាវីឌ នៅក្រុងហេប្រូន ទូលថា៖ «យើងខ្ញុំទាំងអស់គ្នាជាសាច់ញាតិរបស់ព្រះករុណាដែរ។[2]កាលពីមុន នៅពេលព្រះបាទសូលគ្រងរាជ្យលើយើងខ្ញុំ ព្រះករុណាធ្លាប់ដឹកនាំកងទ័ពអ៊ីស្រាអែលចេញទៅធ្វើសឹក។ព្រះអម្ចាស់ជាព្រះរបស់ព្រះករុណា មានព្រះបន្ទូលមកកាន់ព្រះករុណាថា អ្នកនឹងគ្រប់គ្រងលើជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើង អ្នកនឹងដឹកនាំពួកគេ»។[3]ដូច្នេះ ព្រឹទ្ធាចារ្យទាំងអស់របស់ជនជាតិអ៊ីស្រាអែលចូលមកគាល់ព្រះរាជា នៅក្រុងហេប្រូន ហើយព្រះបាទដាវីឌបានចងសម្ពន្ធមេត្រីជាមួយព្រឹទ្ធាចារ្យទាំងនោះ នៅក្រុងហេប្រូននៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ រួចហើយពួកគេបានចាក់ប្រេងអភិសេកព្រះបាទដាវីឌ ជាស្តេចរបស់ប្រជារាស្ត្រអ៊ីស្រាអែល ស្របតាមព្រះបន្ទូលដែលព្រះអម្ចាស់បានថ្លែងទុកតាមរយៈព្យាការីសាំយូអែល។
[4]ព្រះបាទដាវីឌ និងកងទ័ពអ៊ីស្រាអែលទាំងមូល នាំគ្នាចេញទៅវាយយកក្រុងយេរូសាឡឹម (គឺក្រុងយេប៊ូស)។ ពីមុនជនជាតិយេប៊ូសជាម្ចាស់ស្រុករស់នៅក្រុងនោះ។[5]អ្នកក្រុងយេប៊ូសពោលមកកាន់ព្រះបាទដាវីឌថា៖ «អ្នកឯងចូលក្នុងក្រុងរបស់យើងមិនបានទេ»។ ប៉ុន្តែ ព្រះបាទដាវីឌវាយយកបានបន្ទាយនៅភ្នំស៊ីយ៉ូន ដែលក្រោយមកហៅថា «ក្រុងព្រះបាទដាវីឌ»។[6]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «ប្រសិនបើ អ្នកណាម្នាក់ហ៊ានចេញទៅវាយពួកយេប៊ូសមុនគេ អ្នកនោះនឹងបានធ្វើជាមេទ័ព»។ លោកយ៉ូអាប់ជាកូនរបស់អ្នកស្រីសេរូយ៉ា ចេញទៅវាយមុនគេ ហើយបានទទួលតំណែងជាមេទ័ពមែន។
[7]ព្រះបាទដាវីឌគង់នៅបន្ទាយនោះ ហេតុនោះគេក៏ហៅទីនោះថា «ក្រុងព្រះបាទដាវីឌ»។[8]ព្រះករុណាពង្រីកទីក្រុងចាប់តាំងពីមីឡូរហូតដល់ជាយក្រុង។ លោកយ៉ូអាប់បានជួសជុលកន្លែងផ្សេងទៀតនៃទីក្រុង។[9]ព្រះបាទដាវីឌមានអំណាចកាន់តែខ្លាំងឡើងៗ ដ្បិត ព្រះអម្ចាស់នៃពិភពទាំងមូលគង់នៅជាមួយ។
[10]នេះជាបញ្ជីរាយនាមនាយទាហានដ៏អង់អាចរបស់ព្រះបាទដាវីឌ គឺអស់អ្នកដែលបានជួយជ្រោមជ្រែងឲ្យស្តេចទទួលរាជសម្បត្តិលើស្រុកអ៊ីស្រាអែលទាំងមូល ហើយឲ្យស្តេចបានសោយរាជ្យ ស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ស្តីអំពីជនជាតិអ៊ីស្រាអែល។[11]ពួកទាហានដ៏អង់អាចរបស់ព្រះបាទដាវីឌ មានរាយនាមដូចតទៅ លោកយ៉ាសុបៀមជាកូនរបស់លោកហាក់មុនី លោកជាប្រមុខលើមេបញ្ជាការសាមសិបនាក់។ គឺលោកហើយដែលបានប្រើលំពែង សម្លាប់ខ្មាំងអស់បីរយនាក់ ក្នុងពេលតែមួយ។
[12]បន្ទាប់មក គឺលោកអេឡាសារ ជាកូនរបស់លោកដូដូរ ជាអ្នកស្រុកអហូ លោកជាម្នាក់ក្នុងចំណោមនាយទាហានដ៏អង់អាចទាំង៣នាក់។
[13]លោកបាននៅជាមួយព្រះបាទដាវីឌ នៅផាស់ដាំមីម ក្នុងគ្រាដែលពួកជនជាតិភីលីស្ទីនលើកទ័ពមកច្បាំង នៅទីនោះមានវាលស្រែពេញដោយស្រូវ ហើយកងទ័ពអ៊ីស្រាអែលបានបាក់ទ័ពរត់នៅមុខពួកភីលីស្ទីន។[14]ពេលនោះលោកអេឡាសារនិងទាហានរបស់លោកបានឈរនៅទីនោះហើយវាយប្រហារជនជាតិភីលីស្ទីន ហើយព្រះអម្ចាស់បានប្រោសប្រទានជ័យជម្នះដ៏ធំធេង។
[15]នាយទាហានបីរូបក្នុងចំណោមនាយទាហានទាំងសាមសិបនាក់ បាននាំគ្នាចូលគាល់ព្រះបាទដាវីឌ ក្នុងល្អាងភ្នំអាឌូឡាម។ នៅពេលនោះពួកទាហានភីលីស្ទីនបោះទ័ពនៅជ្រលងភ្នំរេផែម។[16]ពេលនោះ ព្រះបាទដាវីឌគង់នៅក្នុងជម្រកដ៏រឹងមាំមួយ ស្របពេលដែលពួកកងទ័ពភីលីស្ទីនមួយក្រុមឈរជើងនៅភូមិបេថ្លេហិមដែរ។
[17]ព្រះបាទដាវីឌស្រេកទឹក ក៏មានព្រះរាជឱង្ការថា៖ «តើអ្នកណាអាចដងទឹកពីអណ្តូងនៅមាត់ទ្វារភូមិបេថ្លេហិមយកមកឲ្យយើងបាន?»។

generated on Wed Sep 10 16:16:32 2025

[18]នាយទាហានទាំងបីនាក់នាំគ្នាសម្រុកចូលទៅក្នុងទីតាំងទ័ពពួកភីលីស្ទីន ហើយដងទឹកពីអណ្តូងនៅមាត់ទ្វារភូមិបេថ្លេហិមយកមកថ្វាយព្រះបាទដាវីឌ ប៉ុន្តែ
ព្រះបាទដាវីឌមិនព្រមសោយទេ ព្រះករុណាបានយកទឹកនោះច្រួចលើដីថ្វាយព្រះអម្ចាស់វិញ។[19]រួចព្រះករុណាមានព្រះរាជឱង្ការថា៖ «ព្រះអម្ចាស់អើយ!
ទូលបង្គំគ្មានសិទ្ធិទទួលទានទឹកនេះទេ ពីព្រោះទឹកនេះដូចជាឈាមរបស់ទាហានដែលបានប្រថុយជីវិតទៅដងយកមកដែរ!»។ ដូច្នេះ ស្តេចមិនព្រមសោយទឹកនោះទេ
ព្រោះពួកទាហានបានប្រថុយជីវិតទៅដងយកមក។ នេះហើយជាស្នាដៃដែលទាហានដ៏ខ្លាំងពូកែទាំងបីនាក់បានធ្វើ។
[20]លោកអប៊ីសាយជាប្អូនរបស់លោកយ៉ូអាប់ គឺជាប្រមុខលើមេទ័ពទាំងបី។ លោកបានប្រើលំពែងរបស់លោកសម្លាប់ខ្មាំងសត្រូវអស់បីរយនាក់។
លោកមានឈ្មោះល្បីដាងគេ ក្នុងចំណោមមេទ័ពទាំងបីនាក់។[21]លោកបានទទួលកិត្តិយសច្រើនជាងគេ ក្នុងចំណោមមេទ័ពទាំងបីនាក់
ហើយលោកគឺជាប្រមុខលើមេទ័ពទាំងបី ប៉ុន្តែ លោកមិនអាចប្រៀបនឹងអ្នកទាំងបីបានទេ។
[22]លោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដាលោកបានបញ្ចេញស្នាដៃយ៉ាងច្រើន។ លោកបានវាយពួកអរាលពីរនាក់នៅស្រុកម៉ូអាប់ ព្រមទាំងចុះទៅក្នុងរណ្តៅ ដើម្បី
សម្លាប់សត្វសិង្ហមួយ នៅថ្ងៃដែលមានទឹកកកធ្លាក់។[23]លោកក៏បានសម្លាប់ជនជាតិអេស៊ីបម្នាក់ ដែលមានកម្ពស់ប្រាំហត្ថ និងប្រដាប់ដោយលំពែងមួយយ៉ាងធំ ដូចជាឈើ
កីតម្បាញ លោកទៅប្រយុទ្ធនឹងគេដោយមានតែដំបងមួយប៉ុណ្ណោះ។ លោកដណ្តើមយកលំពែងពីដៃអ្នកនោះបាន ហើយចាក់សម្លាប់នឹងលំពែងនោះទៅ។
[24]នេះហើយជាស្នាដៃរបស់លោកបេណាយ៉ា ជាកូនរបស់លោកយេហូយ៉ាដា ដែលធ្វើឲ្យលោកមានឈ្មោះល្បីជាមួយនិងមេទ័ពទាំងបី។
[25]ក្នុងចំណោមមេបញ្ជាការទាំងសាមសិបនាក់ លោកទទួលបានកិត្តិយសជាងគេ ប៉ុន្តែ លោកពុំអាចប្រៀបស្មើនឹងពួកមេទ័ពទាំងបីនាក់បានទេ។
តែព្រះបាទដាវីឌបានតែងតាំងលោកជាមេបញ្ជាការលើកងអង្គរក្សរបស់ស្តេច។
[26]វីរបុរសដ៏អង់អាចឯទៀតៗមាន លោកអេសាអែលជាប្អូនរបស់លោកយ៉ូអាប់ លោកអែលហាណានជាកូនរបស់លោកដូដូរ អ្នកភូមិបេថ្លេហិម[27]លោកសាំម៉ូតអ្នកស្រុកហារ៉ូ
លោកហេលេស អ្នកស្រុកពេឡូន[28]លោកអ៊ីរ៉ាជាកូនរបស់លោកអ៊ីកកែស អ្នកក្រុងតូអា លោកអបៀស៊ើរអ្នកស្រុកអានាថោត[29]លោកស៊ីបាកាយ អ្នកស្រុកហ៊ូសាយ លោក
អ៊ីឡាយ អ្នកស្រុកអហូ។
[30]លោកម៉ាហារាយ អ្នកស្រុកនេថូផា លោកហេលែបជាកូនរបស់លោកបាណា អ្នកស្រុកនេថូផា[31]លោកអ៊ីតាយជាកូនរបស់លោករីបាយ អ្នកក្រុងគីបៀន ក្នុងកុលសម្ព័ន្ធ
បេនយ៉ាមីន លោកបេណាយ៉ា អ្នកស្រុកពីរ៉ាថូន[32]លោកហ៊ូរ៉ាយ អ្នកស្រុកកាអាស លោកអបៀល អ្នកស្រុកអើរ៉ាបា[33]លោកអាសម៉ាវែត អ្នកស្រុកបាហ៊ូរីម លោកអេលីយ៉ាបា
អ្នកស្រុកសាអាលបូន។
[34]លោកហាសេមអ្នកស្រុកគីសូន លោកយ៉ូណាថានជាកូនរបស់លោកសាកេ អ្នកស្រុកហារ៉ារី[35]លោកអហ៊ីយ៉ាមជាកូនរបស់លោកសាកើរ អ្នកស្រុកហារ៉ារី លោកអេលីផាល
ជាកូនរបស់លោកអ៊ើរ[36]លោកហេភើរ អ្នកស្រុកមេកេរ៉ា លោកអហ៊ីយ៉ា អ្នកស្រុកពេឡូន[37]លោកហែស្រូ អ្នកស្រុកកើមែល លោកណារ៉ាយជាកូនរបស់លោកអែសបាយ
[38]លោកយ៉ូអែលជាប្អូនរបស់លោកណាថាន លោកមីបហាជាកូនរបស់លោកហាគ្រី[39]លោកសេលេកជាជនជាតិអាំម៉ូន លោកណាហារ៉ាយ អ្នកក្រុងបេរ៉ូត (ជាអ្នកកាន់គ្រឿង
សស្ត្រាវុធរបស់លោកយ៉ូអាប់ ជាកូនរបស់អ្នកស្រីសេរូយ៉ា)[40]លោកអ៊ីរ៉ា អ្នកស្រុកយេធើរ លោកការេប អ្នកស្រុកយេធើរ[41]លោកអ៊ូរីជាជនជាតិហេត លោកសាបាដជាកូន
របស់លោកអឡាយ
[42]លោកអឌីណាជាកូនរបស់លោកស៊ីសា ពីកុលសម្ព័ន្ធរូបេន (គាត់ជាមេដឹកនាំនៃកុលសម្ព័ន្ធរូបេន)
គាត់មានទាហានសាមសិបនាក់នៅជាមួយ[43]លោកហាណានជាកូនរបស់លោកម៉ាកា លោកយូសាផា អ្នកស្រុកមីតនី[44]៤៤ លោកអ៊ូស៊ីយ៉ា ជាអ្នកស្រុកអាសថារ៉ូត
លោកសាម៉ានិងលោកយេហ៊ីអែល ជាកូនរបស់លោកហូថាម ជាអ្នកស្រុកអារ៉ូអើរ។
[45]លោកយេឌីអែល ជាកូនលោកស៊ីមរី ព្រមទាំងលោកយ៉ូហា(ជាប្អូនរបស់លោកជាអ្នកស្រុកធីសា)[46]លោកអេលាល អ្នកស្រុកម៉ាហាវី លោកយេរីបាយ និងលោកយ៉ូសាវា
ជាកូនរបស់លោកអែលណាម លោកយីតម៉ាជាជនជាតិម៉ូអាប់[47]លោកអេលាល លោកអូបេដ និងលោកយ៉ាសៀល អ្នកស្រុកមេសូបៃ។

---

1 Chronicles 11:1

យើងខ្ញុំទាំងអស់គ្នាជាសាច់ញាតិរបស់ព្រះករុណាដែរ។

ការបកប្រែផ្សេងទៀត «យើងជាសាច់ញាតិរបស់ព្រះអង្គ» ឬ
«យើងមានបុព្វបុរសដូចព្រះអង្គដែរ»

ព្រះបន្ទូលដែលព្រះអម្ចាស់
ព្រះរាជសាររបស់ព្រះអម្ចាស់

1 Chronicles 11:4

ព័ត៌មានទូទៅ៖

សូមមើល

ក្រុងយេប៊ូស

នេះជាឈ្មោះបណ្តោះអាសន្នរបស់ក្រុងយេរូសាឡឹម
បន្ទាប់ពីយេប៊ូសបានដណ្តើមយកទីក្រុង
មុនជនជាតិអ៊ីស្រាអែលដណ្តើមយកបានទីក្រុងមកវិញ។

ប៉ុន្តែ ព្រះបាទដាវីឌវាយយកបាន

ការបកប្រែផ្សេងទៀត «ប៉ុន្តែ កងទ័ពរបស់ព្រះបាទដាវីឌទទួលបានជ័យជម្នះ»

ក្រុងព្រះបាទដាវីឌ

ការបកប្រែផ្សេងទៀត «ហើយគេបានហៅថា ក្រុងព្រះបាទដាវីឌ»

ចេញទៅវាយមុនគេ ហើយបានទទួលតំណែងជាមេទ័ពមែន។

ការបកប្រែផ្សេងទៀត «ដូច្នេះ
ព្រះបាទដាវីឌតែងតាំងលោកយ៉ូអាប់ជាមេបញ្ជាការ»។

1 Chronicles 11:7

ព្រះករុណាពង្រីកទីក្រុង

ការបកប្រែផ្សេងទៀត

«ជនជាតិអ៊ីស្រាអែលបានធ្វើកំពែងព័ទ្ធជុំវិញទីក្រុងឲ្យកាន់តែរឹងមាំ»

មីឡូ

សំដៅទៅលើបន្ទាយមួយនៅក្រុងយេរូសាឡឹម
ប្រហែលជាត្រូវបានសាងសង់ដោយជនជាតិយេប៊ូស។

ព្រះអម្ចាស់នៃពិភពទាំងមូលគង់នៅជាមួយ។

ការបកប្រែផ្សេងទៀត «បានជួយគាត់»

1 Chronicles 11:10

ព័ត៌មានទូទៅ៖

សូមមើល and

ទាហានដ៏អង់អាចរបស់ព្រះបាទដាវីឌ

ការបកប្រែផ្សេងទៀត «មេដឹកនាំនៅក្រោមបង្គាប់ព្រះបាទដាវីឌ»

ដែលបានជួយជ្រោមជ្រែងឲ្យស្តេចទទួលរាជសម្បត្តិលើស្រុកអ៊ីស្រាអែលទាំងមូល

ការបកប្រែផ្សេងទៀត «អ្នកណាដែលជួយរាជាណាចក្រព្រះបាទដាវីឌឲ្យនៅរឹងមាំ»

សាមសិបនាក់

ការបកប្រែផ្សេងទៀត «ទាហានខ្លាំងទាំង៣០ នាក់»

ក្នុងពេលតែមួយ។

ការបកប្រែផ្សេងទៀត «នៅពេលមួយ»

1 Chronicles 11:12

ព័ត៌មានទូទៅ៖

សូមមើល and

ហើយវាយប្រហារជនជាតិភីលីស្ទីន

ហើយបានសម្លាប់ពួកភីលីស្ទីនជាច្រើននាក់។

1 Chronicles 11:15

ព័ត៌មានទូទៅ៖

សូមមើល

នាយទាហានបីរូបក្នុងចំណោមនាយទាហានទាំងសាមសិបនាក់

«៣នាក់ក្នុងចំណោម៣០នាក់»

ពេលនោះ ព្រះបាទដាវីឌគង់នៅក្នុងជម្រកដ៏រឹងមាំមួយ

ស្របពេលដែលពួកកងទ័ពភីលីស្ទីនមួយក្រុមឈរជើងនៅភូមិបេថ្លេហិមដែរ។

ការបកប្រែផ្សេងទៀត «ព្រះបាទដាវីឌនៅក្នុងកន្លែងសុវត្ថិភាពគឺនៅក្នុងរូងភ្នំ

ខណៈពេលកងទ័ពពួកភីលីស្ទីនបានកំពុងយាមនៅភូមិបេថ្លេហិម»

ពួកកងទ័ពភីលីស្ទីនមួយក្រុមឈរជើងនៅភូមិបេថ្លេហិមដែរ។

«ពួកភីលីស្ទីនបានដាក់កងទ័ពនៅក្នុងភូមិបេថ្លេហិម»

generated on Wed Sep 10 16:16:32 2025

1 Chronicles 11:18
នាយទាហានទាំងបីនាក់
«ទាហានខ្លាំងបីនាក់»
ហើយដងទឹកពីអណ្តូងនៅមាត់ទ្វារភូមិបេថ្លេហិម
ឃ្លាទាំងពីរនេះសំដៅលើអណ្តូងដូចគ្នា។ ទីពីរបញ្ជាក់ពីអណ្តូងមួយនៅបេថ្លេហិម។
ទូលបង្គំគ្មានសិទ្ធិទទួលទានទឹកនេះទេ
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់អើយ សូមកុំអនុញ្ញាតឲ្យខ្ញុំផឹកទឹក
ដែលជាការលះបង់ដល់អាយុជីវិតទាហានទូលបង្គំ!»
ពីព្រោះទឹកនេះដូចជាឈាមរបស់ទាហានដែលបានប្រថុយជីវិតទៅដងយកមកដែរ
ព្រះបាទដាវីឌកំពុងមានបន្ទូលឆ្លើយតបសំណួរនេះថា
ទឹកមានតម្លៃណាស់ព្រោះជាការលះបង់ តាមរយៈអស់អ្នកដែលបានទទួលវា។
ការបកប្រែផ្សេងទៀត
«យើងនឹងមិនផឹកឈាមរបស់ទាហានដែលសុខចិត្តស្លាប់ដើម្បីយើង» ឬ
«យើងនឹងមិនផឹកទឹកដែលទាហានបានប្រថុយជីវិតដើម្បីទៅដងវា»
1 Chronicles 11:20
ព័ត៌មានទូទៅ៖
សូមមើល
ទាំងបីនាក់
«អ្នកចម្បាំងដ៏ពូកែទាំងបី»
គឺជាប្រមុខលើមេទ័ពទាំងបី
ការបកប្រែផ្សេងទៀត «លោកអប៊ីសាយជាមេដឹកនាំនៃអ្នកចម្បាំងដ៏ខ្លាំងទាំងបី»
លោកបានទទួលកិត្តិយសច្រើនជាងគេ ក្នុងចំណោមមេទ័ពទាំងបីនាក់
ហើយលោកគឺជាប្រមុខលើមេទ័ពទាំងបី
ការបកប្រែផ្សេងទៀត «កងទ័ពគោរពយ៉ាងខ្លាំងចំពោះលោកអប៊ីសាយ
ហើយពួកគេបានតែងតាំងគាត់ជាមេដឹកនាំ ទោះបីជាពួកគេមិនរាប់បញ្ចូលគាត់ថា
ជាកងទ័ពម្នាក់ក្នុងចំណោមកងទ័ពបីនាក់ក៏ដោយ»
1 Chronicles 11:22
ព័ត៌មានទូទៅ៖
សូមមើល
បញ្ចេញស្មាដៃ
ទាំងនេះជាសកម្មភាព ដែលបង្ហាញភាពក្លាហាន កម្លាំង ឬជំនាញ។
នៅថ្ងៃដែលមានទឹកកកធ្លាក់
ការបកប្រែផ្សេងទៀត «ក្នុងអំឡុងពេលព្យុះព្រិល»
កម្ពស់ប្រាំហត្ថ
លោកទៅប្រយុទ្ធនឹងគេដោយមានតែដំបងមួយប៉ុណ្ណោះ។
ការបកប្រែផ្សេងទៀត «លោកបេណាយ៉ាបានជួបជនជាតិអេស៊ីប»
ប្រដាប់ដោយលំពែងមួយយ៉ាងធំ
ការបកប្រែផ្សេងទៀត «លំពែងធំណាស់»
1 Chronicles 11:24
ព័ត៌មានទូទៅ៖
សូមមើល
ដែលធ្វើឲ្យលោកមានឈ្មោះល្បីជាមួយនិងមេទ័ពទាំងបី។
«គាត់មានភាពល្បីល្បាញដូចមេទ័ពខ្លាំងទាំង ៣នាក់»
ក្នុងចំណោមមេបញ្ជាការទាំងសាមសិបនាក់ លោកទទួលបានកិត្តិយសជាងគេ ប៉ុន្តែ
លោកពុំអាចប្រៀបស្មើនឹងពួកមេទ័ពទាំងបីនាក់បានទេ។
ការបកប្រែផ្សេងទៀត «ប្រជាជនគោរពគាត់ជាងកងទ័ព ៣០នាក់ ប៉ុន្តែ
មិនច្រើនដូចមេទ័ពបីនាក់ ដែលមានជំនាញខ្ពស់បំផុតទេ»
អង្គរក្សរបស់ស្តេច
នេះជាមនុស្សម្នាក់
ឬក្រុមមនុស្សដែលទទួលខុសត្រូវក្នុងការការពារបុគ្គលសំខាន់ម្នាក់។
1 Chronicles 11:26
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 11:30
ព័ត៌មានទូទៅ
សូមមើល
1 Chronicles 11:34
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 11:38
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 11:42
ព័ត៌មានទូទៅ៖
សូមមើល
ទាហានសាមសិបនាក់នៅជាមួយ
៣០នាក់មកជាមួយគាត់
1 Chronicles 11:45
ព័ត៌មានទូទៅ៖
សូមមើល

12 [1]អ្នកទាំងនេះបានមកគាល់ព្រះបាទដាវីឌ នៅគ្រាដែលព្រះបាទដាវីឌភៀសខ្លួនទៅស៊ីគឡាក់ ដើម្បីរត់គេចពីព្រះបាទសូល ជាបុត្ររបស់លោកគីស។ អ្នកទាំងនោះសុទ្ធ
តែជាទាហានអង់អាច ហើយត្រៀមខ្លួនចេញប្រយុទ្ធរួមជាមួយព្រះបាទដាវីឌជានិច្ច។[2]ពួកគេប្រដាប់ខ្លួនដោយធ្នូ ហើយស្ទាត់ជំនាញខាងបាញ់ព្រួញ ឬបាញ់ដង្ហក់
ដោយអាចប្រើបានទាំងដៃឆ្វេង និងដៃស្តាំ។ អ្នកទាំងនោះសុទ្ធតែជាសាច់ញាតិរបស់ព្រះបាទសូល ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន។
[3]លោកមេទ័ពអហ៊ីអេស៊ើរ និងលោកយ៉ូអាស់ ជាកូនរបស់លោកសេម៉ាអា អ្នកស្រុកគីបៀន។ លោកយេស៊ាល និងលោកពេលេត ជាកូនរបស់លោកអាសម៉ាវែត។លោក
បេរ៉ាកា លោកយេហ៊ូជាអ្នកស្រុកអាណាថោត[4]លោកយីសម៉ាយ៉ា អ្នកស្រុកគីបៀន ជានាយទាហានដ៏អង់អាចក្នុងចំណោមក្រុមទាំងសាមសិប (និងជាមេលើពួកគេ) លោក
យេរេមី លោកយ៉ាហាសៀល លោកយ៉ូហាណាន លោកយ៉ូសាបាដជាអ្នកក្រុងកេដេរ៉ា។
[5]លោកអេលូសាយ លោកយេរីម៉ូត លោកបាលា លោកសេម៉ារីយ៉ា លោកសេផាធា ជាអ្នកក្រុងហារូប[6]ពួកកូនចៅកូរ៉ាមានលោកអែលកាណា លោកអ៊ីសសាយ៉ា
លោកអសារាល លោកយ៉ូអេស៊ើរ លោកយ៉ាសុបៀម[7]លោកយ៉ូអេឡា និងលោកសេបាឌា ជាកូនរបស់លោកយេរ៉ូហាំ ជាអ្នកស្រុកកេដោរ។
[8]មានអ្នកខ្លះពីកុលសម្ព័ន្ធកាដ បានចាកចេញពីស្រុកទៅរស់នៅជាមួយព្រះបាទដាវីឌនៅទីរហោស្ថាន។ ពួកគេជាយុទ្ធជនស្ទាត់ជំនាញក្នុងសឹកសង្គ្រាម
ជាអ្នកដែលអាចប្រើប្រាស់ ខែល និងលំពែង។ ពួកគេមានទឹកមុខគួរឲ្យស្ញែងខ្លាចដូចជាសត្វសឹង្ហ ហើយរហ័សដូចជាសត្វប្រើសនៅលើភ្នំ។
[9]អ្នកទាំងនោះមានលោកអេស៊ើរ ជាមេលើពួកគេ លោកអូបាឌាជាមេទីពីរ លោកអេលាបជាមេទីបី[10]លោកមីសម៉ាណាជាមេទីបួន លោកយេរេមីជាមេទីប្រាំ[11]លោកអថាយជា
មេទីប្រាំមួយ លោកអេលាលជាមេទីប្រាំពីរ[12]លោកយ៉ូហាណានជាមេទីប្រាំបី លោកអែលសាបាដជាមេទីប្រាំបួន[13]លោកយេរេមីជាមេទីដប់ និងលោកម៉ាបាណាយជាមេទី
ដប់មួយ។
[14]ពួកគេមកពីកុលសម្ព័ន្ធកាដ ហើយសុទ្ធតែជានាយទាហាន។ អ្នកតូចបំផុតជាមេលើមួយរយនាក់ ហើយអ្នកធំបំផុតជាមេលើមួយពាន់អ្នក។
[15]ពួកគេបានឆ្លងទន្លេយ័រដាន់នៅខែទីមួយ គឺរដូវដែលទឹកទន្លេឡើងលិចច្រាំងអស់
ហើយវាយពួកអ្នកដែលរស់នៅតាមជ្រលងភ្នំទាំងខាងកើតនិងខាងលិចឲ្យបាក់ទ័ពអស់។
[16]មានអ្នកខ្លះពីកុលសម្ព័ន្ធបេនយ៉ាមីន និងកុលសម្ព័ន្ធយូដាបានមកឯព្រះបាទដាវីឌដល់ជម្រកនោះដែរ។[17]ព្រះបាទដាវីឌក៏ចេញទៅទទួលពួកគេ
ហើយមានព្រះរាជឱង្កាថា៖ «ប្រសិនបើ អស់លោកមកឯខ្ញុំដោយសន្តិភាព ដើម្បីជួយខ្ញុំ ខ្ញុំសូមទទួលដោយស្មោះពីចិត្ត។ ប៉ុន្តែប្រសិនបើ អស់លោកមកបន្លំខ្លួន
ហើយធ្វើការឲ្យសត្រូវរបស់ខ្ញុំ នោះសូមឲ្យព្រះនៃបុព្វបុរសរបស់យើងបានធ្វើជាសាក្សី ហើយដាក់ទោសអស់លោកចុះ ពីព្រោះខ្ញុំមិនបានធ្វើអ្វីខុសទេ»។
[18]ពេលនោះព្រះវិញ្ញាណក៏មកសណ្ឋិតលើលោកអម៉ាសាយ ដែលជាមេលើក្រុមទាំងសាមសិបនាក់ លោកពោលថា៖ «បពិត្រ ព្រះបាទដាវីឌ ជាបុត្ររបស់លោក
អ៊ីសាយអើយ! យើងខ្ញុំទាំងអស់គ្នាស៊ូប្តូរផ្តាច់នៅជាមួយ ព្រះករុណាហើយ។ សូមឲ្យសេចក្តីសុខសាន្តកើតមានដល់ព្រះករុណា និងអស់អ្នកដែលនៅជាមួយព្រះករុណា!។
ដ្បិត ព្រះរបស់ព្រះករុណាបានជួយព្រះករុណាហើយ!»។ ព្រះបាទដាវីឌក៏ទទួលពួកគេ ហើយតែងតាំងពួកគេ ឲ្យធ្វើជានាយទាហានក្នុងកងទ័ពរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[19]មានទាហានពីកុលសម្ព័ន្ធម៉ាណាសេ បានមកសុំចុះចូលខាងព្រះបាទដាវីឌ ក្នុងពេលដែលស្តេចលើកទ័ពចេញទៅជាមួយពួកភីលីស្ទីន ដើម្បី ច្បាំងនឹងព្រះបាទសូល។
ប៉ុន្តែ ទ័ពរបស់ព្រះបាទដាវីឌពុំបានចូលរួមច្បាំងទេ ព្រោះពួកមេលើជនជាតិភីលីស្ទីនបានពិគ្រោះគ្នា រួចបញ្ជូនទ័ពរបស់ព្រះបាទដាវីឌឲ្យវិលត្រឡប់ទៅវិញ ដោយគិតថា៖
«បើដាវីឌចូលដៃជាមួយស្តេចសូល ជាម្ចាស់របស់គេ នោះពួកគេមុខជាបំផ្លាញយើងទាំងអស់គ្នាមិនខាន»។[20]ពេលព្រះបាទដាវីឌ ត្រឡប់មកស៊ីគឡាក់ មានពួកនាយ
ទាហានពីកុលសម្ព័ន្ធម៉ាណាសេ បានមកសុំចុះចូលខាងព្រះបាទដាវីឌ មានលោកអ័ឌណា លោកយ៉ូសាបាដ លោកយេឌីអែល លោកមីកែល លោកយ៉ូសាបាដ លោក
អេលីហ៊ូវ និងលោកស៊ីលតាយ។ អ្នកទាំងនោះសុទ្ធតែជាមេលើកងពលធំ ក្នុងកុលសម្ព័ន្ធម៉ាណាសេ។
[21]ពួកគេដឹកនាំកងទ័ពជួយព្រះបាទដាវីឌច្បាំងជាមួយពួកចោរ ពីព្រោះពួកគេសុទ្ធតែជាទាហានអង់អាច។
ក្រោយមកគេបានក្លាយជាមេបញ្ជាការលើកងទ័ពរបស់ព្រះបាទដាវីឌ។[22]ជារៀងរាល់ថ្ងៃតែងតែមានអ្នកមកចុះចូលជាមួយព្រះបាទដាវីឌ
រហូតដល់កងទ័ពព្រះបាទដាវីឌក្លាយជាកងទ័ពយ៉ាងធំ ដូចជាកងទ័ពរបស់ព្រះជាម្ចាស់ដែរ។
[23]អ្នកដែលបានមករួបរួមជាមួយព្រះបាទដាវីឌ នៅក្រុងហេប្រូន ដើម្បីផ្ទេររាជសម្បត្តិរបស់ព្រះបាទសូលថ្វាយព្រះបាទដាវីឌ ស្របតាមបញ្ជារបស់ព្រះអម្ចាស់។
[24]ពីកុលសម្ព័ន្ធយូដា ទាហានដែលអាចកាន់ខែល និងកាន់លំពែង ហើយប្រុងប្រៀបខ្លួនចេញទៅច្បាំងបាន មាន ៦, ៨០០នាក់។[25]ពីកុលសម្ព័ន្ធស៊ីម្មាន មាន ៧, ១០០នាក់
ដែលសុទ្ធតែជាវីរជនដ៏ពូកែអង់អាច។
[26]ពីកុលស្ព័ន្ធលេវី មាន៤, ៦០០នាក់សុទ្ធតែជាអ្នកចម្បាំង។[27]លោកយេហូយ៉ាដា ជាមេដឹកនាំនៃអំបូរអើរ៉ុន មានទាហាន៣, ៧០០នាក់ជាមួយគាត់។[28]លោកសាដុក ជា
យុវជនពូកែអង់អាច និងមេបញ្ជាការម្ភៃពីររូបទៀត ក្នុងក្រុមគ្រួសាររបស់លោក។
[29]ពីកុលសម្ព័ន្ធបេនយ៉ាមីន ជាកុលសម្ព័ន្ធរបស់ព្រះបាទសូល មានទាហាន ៣, ០០០នាក់។ ពួកគេមួយចំនួនធំនៅស្មោះត្រង់នឹងរាជវង្សរបស់ព្រះបាទសូល។[30]ពីកុលសម្ព័ន្ធ
អេប្រាអ៊ីម មាន ២០, ៨០០នាក់សុទ្ធតែជាវីរជនដ៏ពូកែអង់អាច ហើយមានឈ្មោះល្បីក្នុងក្រុមគ្រួសាររបស់ពួកគេផង។[31]ពីកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល មាន
ទាហាន ១៨, ០០០នាក់ ជាអ្នកមកប្រកាសអភិសេកព្រះបាទដាវីឌ ជាព្រះមហាក្សត្រ។
[32]ពីកុលសម្ព័ន្ធអ៊ីសាខារ មានមេបញ្ជាការ ២០០នាក់ អ្នកទាំងនោះសុទ្ធតែចេះសម្គាល់មើលពេលវេលា ហើយដឹងថាតើជនជាតិអ៊ីស្រាអែលត្រូវធ្វើដូចម្តេចខ្លះ។
ព្រមទាំងពលទាហានដែលនៅក្រោមបង្គាប់របស់ពួកគេ។[33]ពីកុលសម្ព័ន្ធសាប់យូឡូន មាន ៥០, ០០០នាក់ ជាទាហានដែលបានហ្វឹកហាត់ សម្រាប់ចេញទៅច្បាំង។ ពួកគេ
ប្រដាប់ដោយសាស្ត្រាវុធគ្រប់ប្រភេទ ហើយមានចិត្តមោះមុតត្រៀមខ្លួនជាស្រេច ដើម្បីធ្វើសឹកសង្គ្រាម។
[34]ពីកុលសម្ព័ន្ធណែបថាលី មានមេដឹកនាំ១, ០០០នាក់ ព្រមទាំងមានពលទាហាន ៣៧, ០០០នាក់ ប្រដាប់ដោយខែលនិងលំពែង។[35]ពីកុលសម្ព័ន្ធដាន់ មាន២៨,
៦០០នាក់សុទ្ធតែអ្នកត្រៀមខ្លួនច្បាំង។
[36]ពីកុលសម្ព័ន្ធអេស៊ើរ មាន៤០, ០០០នាក់ សុទ្ធតែអ្នកត្រៀមខ្លួនសំរាប់ធ្វើសឹកសង្គ្រាម។[37]នៅខាងកើតទន្លេយ័រដាន់ កុលសម្ព័ន្ធរូបេន កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធ
ម៉ាណាសេចំនួនពាក់កណ្តាលទៀត មានទាហានទាំងអស់ ១២០, ០០០នាក់ ប្រដាប់ដោយសាស្ត្រាវុធគ្រប់ប្រភេទ។
[38]អ្នកទាំងនោះសុទ្ធសឹងជាទាហានដែលថ្នឹកខាងចម្បាំង។ ពួកគេធ្វើដំណើរមកដល់ក្រុងហេប្រូន ដោយចិត្តស្មោះសរ ដើម្បីអភិសេកព្រះបាទដាវីឌ ជាព្រះមហាក្សត្រលើ
ជនជាតិអ៊ីស្រាអែលទាំងមូល។ ជនជាតិអ៊ីស្រាអែលឯទៀតៗក៏ព្រមព្រៀងគ្នា ដើម្បីអភិសេកព្រះបាទដាវីឌជាព្រះមហាក្សត្រដែរ។[39]ពួកគេស្នាក់នៅក្រុងហេប្រូន ជាមួយ
ព្រះបាទដាវីឌចំនួនបីថ្ងៃ ហើយបងប្អូនរបស់ពួកគេបានរៀបចំជប់លៀងទទួល។[40]អស់អ្នកដែលស្ថិតនៅតំបន់ជិតខាងនោះ រហូតដល់ទឹកដីអ៊ីសាខារ សាប់យូឡូន និង
ណែបថាលី បានដឹកស្បៀងអាហារមក ដោយផ្ទុកលើខ្នងលា អូដ្ឋ លាកាត់ និងគោ គឺមានម្សៅ ដំណាប់ឧទុម្ពរ ទំពាំងបាយជូរក្រៀម ស្រាទំពាំងបាយជូរ ប្រេង និងសាច់គោ
សាច់ចៀម យ៉ាងច្រើនបរិបូរណ៍ ដ្បិតប្រជាជនអ៊ីស្រាអែលទាំងមូលមានការជប់លៀងយ៉ាងធំក្រៃ។

---

1 Chronicles 12:1
ព័ត៌មានទូទៅ
សូមមើល
នៅគ្រាដែលព្រះបាទដាវីឌភៀសខ្លួនដើម្បីរត់គេចពី
ការបកប្រែផ្សេងទៀត «អំឡុងពេល ទ្រង់បង្ហាញវត្តមានចំពោះ»
ពួកគេប្រដាប់ខ្លួនដោយធ្នូ ហើយស្ទាត់ជំនាញខាងបាញ់ព្រួញ ឬបាញ់ដង្ហក់
ដោយអាចប្រើបានទាំងដៃឆ្វេង និងដៃស្តាំ។
ការបកប្រែផ្សេងទៀត «គ្រឿងសាស្ត្រាវុធរបស់ពួកគេ រួមមានធ្នូ
ហើយពួកគេអាចប្រើធ្នូដោយដៃស្តាំ ឬដៃឆ្វេង»
បាញ់ដង្ហក់
ខ្សែដង្ហក់ជាបន្ទះស្បែក ដែលអាចឲ្យមនុស្សម្នាក់គ្រវែងដុំថ្មបានឆ្ងាយ។
ដុំថ្មមួយត្រូវបានគេដាក់នៅចំកណ្តាល
ខណៈពេលមនុស្សនោះកាន់ចុងហើយបង្វិលវាជារង្វង់។
នៅពេលចុងម្ខាងត្រូវបានប្រលែង ថ្មបានហោះឆ្ពោះទៅគោលដៅ។
1 Chronicles 12:3
ព័ត៌មានទូទៅ៖
សូមមើល
ទាំងសាមសិប
ការបកប្រែផ្សេងទៀត «ទាហាន៣០នាក់»
1 Chronicles 12:5
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 12:8
ព័ត៌មានទូទៅ៖
សូមមើល
ពួកគេមានទឹកមុខគួរឲ្យស្ញែងខ្លាចដូចជាសត្វសឹង្ហ
ការបកប្រែផ្សេងទៀត «ដែលកាចសាហាវណាស់»
ហើយរហ័សដូចជាសត្វប្រើសនៅលើភ្នំ។
ការបកប្រែផ្សេងទៀត «ពួកគេរត់លឿនណាស់»
សត្វប្រើស
ទាំងនេះជាសត្វតូចៗ ដែលមានរាងសង្ហា និងរហ័សស្រដៀងនឹងសត្វក្តាន់ដែរ។
1 Chronicles 12:9
ព័ត៌មានទូទៅ៖
សូមមើល
មេទីពី ... មេទីដប់មួយ
នេះជាបញ្ជីឈ្មោះបុរសទាំងនេះតាមលំដាប់នៃភាពជាអ្នកដឹកនាំ «ទី២ ... ទី៣...
ទី៤... ទី៥... ទី៥... ទី៦... ទី៧ ... ទី៨ ... ទី៩ ... ទី១០ ... ទី១១»
1 Chronicles 12:14
អ្នកតូចបំផុតជាមេលើមួយរយនាក់
មានន័យថា ក្រុមទាហានតូចបំផុត ដែលមានមេដឹកនាំលើទាហាន១០០នាក់។
ហើយអ្នកធំបំផុតជាមេលើមួយពាន់អ្នក។
មានន័យថា ក្រុមទាហានដែលធំជាងគេ
ដែលមានមេដឹកនាំលើទាហាន១០០០នាក់។
នៅខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែមីនា
និងដើមខែមេសាតាមប្រតិទិនលោកខាងលិច។ ខែនេះ នៅដើមរដូវផ្ការីក
ក្រោយរដូវភ្លៀងចុងរដូវធ្លាក់មក។
1 Chronicles 12:16
ពីកុលសម្ព័ន្ធបេនយ៉ាមីន និងកុលសម្ព័ន្ធយូដា
ការបកប្រែផ្សេងទៀត «បុរសមកពីកុលសម្ព័ន្ធបេនយ៉ាមីននិងកុលសម្ព័ន្ធយូដា»
1 Chronicles 12:18
ព័ត៌មានទូទៅ៖
សូមមើល
ព្រះវិញ្ញាណក៏មកសណ្ឋិតលើ
ការបកប្រែផ្សេងទៀត «ព្រះវិញ្ញាណបានប្រទានឫទ្ធានុភាពដល់គាត់»
សាមសិបនាក់
ការបកប្រែផ្សេងទៀត «ទាហាន៣០នាក់»
បពិត្រ ព្រះបាទដាវីឌ ជាបុត្ររបស់លោកអ៊ីសាយអើយ!

generated on Wed Sep 10 16:16:32 2025

ឃ្លាទាំងនេះមានស្រដៀងគ្នា និងបញ្ជាក់ការប្តេជ្ញាចិត្តដើរតាមព្រះបាទដាវីឌ។
1 Chronicles 12:19
ព័ត៌មានទូទៅ៖
សូមមើល
បានមកសុំចុះចូល
ការបកប្រែផ្សេងទៀត «ទុកឲ្យមេដឹកនាំរបស់ពួកគេចូលរួម»
ជាមេលើកងពលធំ
«លើកងទ័ពជាង១.០០០នាក់»
1 Chronicles 12:21
ជាមួយពួកចោរ
ការបកប្រែផ្សេងទៀត «ក្រុមបុរសដែលប្លន់មនុស្សពេញផ្ទៃប្រទេស»
ជារៀងរាល់ថ្ងៃតែងតែមាន
ការបកប្រែផ្សេងទៀត «ថ្ងៃនីមួយៗ»
ដូចជាកងទ័ពរបស់ព្រះជាម្ចាស់ដែរ។
នេះជាការប្រៀបធៀបទំហំកងទ័ពរបស់ព្រះបាទដាវីឌ
ទៅនឹងពួកទេវតារបស់ព្រះជាម្ចាស់។
1 Chronicles 12:23
ព័ត៌មានទូទៅ៖
សូមមើល
ដើម្បីផ្ទេររាជសម្បត្តិរបស់ព្រះបាទសូលថ្វាយព្រះបាទដាវីឌ
ការបកប្រែផ្សេងទៀត «ដើម្បីគ្រប់គ្រងរាជាណាចក្ររបស់ព្រះបាទសូលទៅដាវីឌ»
ស្របតាមបញ្ជារបស់ព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត «ធ្វើឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់ក្លាយជាការពិត» ឬ
«សម្រេចព្រះបន្ទូលរបស់ព្រះអម្ចាស់»
ពីកុលសម្ព័ន្ធយូដា
ការបកប្រែផ្សេងទៀត «ពីកុលសម្ព័ន្ធយូដា»
1 Chronicles 12:26
ព័ត៌មានទូទៅ៖
សូមមើល and
1 Chronicles 12:29
ព័ត៌មានទូទៅ៖
សូមមើល និងសូមមើល
ពីកុលសម្ព័ន្ធបេនយ៉ាមីន ជាកុលសម្ព័ន្ធរបស់ព្រះបាទសូល
ការបកប្រែផ្សេងទៀត «ពីកុលសម្ព័ន្ធសូល ដល់កុលសម្ព័ន្ធបេនយ៉ាមីន»
ពីកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាល
សូមមើលរបៀបបកប្រែនៅក្នុង 1CH 5:18
1 Chronicles 12:32
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 12:34
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 12:36
ព័ត៌មានទូទៅ៖
សូមមើល and
ប្រដាប់ដោយសាស្ត្រាវុធគ្រប់ប្រភេទ។
ការបកប្រែផ្សេងទៀត «ការដឹកគ្រឿងសាស្ត្រាវុធគ្រប់ប្រភេទ»
1 Chronicles 12:38
ចិត្តស្មោះសរ
ការបកប្រែផ្សេងទៀត «គម្រោង»
ដែលថ្នឹកខាងចម្បាំង
ការបកប្រែផ្សេងទៀត «ត្រៀមអាវុធចូលសមរភូមិ»
ចំនួនបីថ្ងៃ
«៣ថ្ងៃ»
ទំពាំងបាយជូរ
ទាំងនេះជាផ្លែទំពាំងបាយជូរស្ងួត ដែលជាផ្លែតូចមួយធំឡើងលើដើមទំពាំងបាយជូរ

13 [1]ព្រះបាទដាវីឌបានប្រជុំពិភាក្សាជាមួយនឹងមេបញ្ជាការតូច ធំ ព្រមទាំងអ្នកដឹកនាំទាំងអស់។[2]ព្រះបាទដាវីឌមានព្រះរាជឱង្ការទៅកាន់អង្គប្រជុំអ៊ីស្រាអែលទាំងមូលថា៖ «ប្រសិនបើ អ្នករាល់គ្នាយល់ឃើញថាល្អ ហើយការនោះមកពីព្រះជាម្ចាស់ ជាព្រះអម្ចាស់នៃយើងមែន ចូរផ្ញើសារទៅជូនបងប្អូនយើងនៅគ្រប់ទីកន្លែង ក្នុងស្រុកអ៊ីស្រាអែលទាំងមូល និងជូនពួកបូជាចារ្យ ពួកលេវី ដែលរស់នៅតាមក្រុងនានារបស់ពួកគេ ដើម្បីអញ្ជើញពួកគេមកជួបជុំជាមួយយើងទាំងអស់គ្នា។[3]បន្ទាប់មក យើងនាំគ្នាដង្ហែហិបរបស់ព្រះនៃយើងមកវិញ ដ្បិត នៅរជ្ជកាលរបស់ព្រះបាទសូល យើងពុំបាននឹកដល់ហិបនេះទេ»។[4]អង្គប្រជុំទាំងមូលក៏យល់ស្រប ព្រោះប្រជាជនទាំងមូលពេញចិត្តនឹងសំណើនេះ។
[5]ព្រះបាទដាវីឌបានប្រមូលជនជាតិអ៊ីស្រាអែលទាំងអស់ ចាប់តាំងពីជ្រោះស៊ីហូរស្រុកអេស៊ីបរហូតដល់ច្រកចូលក្រុងហាម៉ាត់ ដើម្បីដង្ហែហិបរបស់ព្រះជាម្ចាស់ពីគារយ៉ាត់-យារីម។[6]ព្រះបាទដាវីឌយាងទៅក្រុងបាឡា គឺគារយ៉ាត់-យារីម ដែលស្ថិតនៅស្រុកយូដាជាមួយជនជាតិអ៊ីស្រាអែលទាំងមូល ដើម្បីដង្ហែហិបព្រះជាម្ចាស់ គឺព្រះអម្ចាស់ដែលគង់នៅកណ្តាលពួកចេរូប៊ីន ហើយហិបនោះជាកម្មសិទ្ធិរបស់ព្រះអង្គផ្ទាល់។
[7]គេដាក់ហិបនៃព្រះជាម្ចាស់នៅលើរទេះថ្មីមួយ។ គេបាននាំយកហិបនោះចេញពីផ្ទះរបស់លោកអប៊ីណាដាប់។ លោកអ៊ូសា និងលោកអហ៊ីយ៉ូជាអ្នកបររទេះនោះ។
[8]ព្រះបាទដាវីឌ និងប្រជាជនអ៊ីស្រាអែលទាំងនាំគ្នាអបអរ សប្បាយរីករាយនៅចំពោះព្រះជាម្ចាស់ ពួកគេនាំគ្នារាំតាមចង្វាក់ពិណ ឃឹម ស្គរ ឈឹង ព្រមទាំងផ្លុំត្រែយ៉ាងរំពងនិងស្រែកច្រៀងផង។
[9]កាលបានមកដល់លានស្រូវរបស់លោកគីដុន នោះលោកអ៊ូសាបានលោកដៃរបស់គាត់ទៅទប់អិបនៃព្រះជាម្ចាស់ ពីព្រោះគោធ្វើឲ្យហិបនោះផ្អៀងចង់ធ្លាក់។
[10]នៅពេលនោះសេចក្តីក្រោធរបស់ព្រះជាម្ចាស់ក៏បានទាស់ឮនឹងលោក ហើយបានប្រហារជីវិតលោក ដោយព្រោះលោកបានយកដៃទៅពាល់ហិប
ពេលនោះគាត់ក៏បាត់បង់ជីវិតនៅចំពោះព្រះជាម្ចាស់។[11]ព្រះបាទដាវីឌរំជួលព្រះហឫទ័យយ៉ាងខ្លាំង ដោយឃើញព្រះអម្ចាស់ប្រហារជីវិតលោកអ៊ូសា។ ហេតុនេះហើយ បានជាគេហៅកន្លែងនោះថា «ពេរេស-អ៊ូសា» រហូតដល់សព្វថ្ងៃ។
[12]នៅថ្ងៃនោះព្រះបាទដាវីឌមានសេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់។ ព្រះអង្គមានព្រះរាជឱង្ការថា៖
«តើធ្វើដូចម្តេចឲ្យយើងនាំហិបនៃព្រះជាម្ចាស់មកឯយើងបាន?»[13]ព្រះបាទដាវីឌមិនបាននាំហិបរបស់ព្រះអម្ចាស់ ទៅដំណាក់នៅក្រុងព្រះបាទដាវីឌបានទេ
តែទ្រង់បានឲ្យគេនាំយកទៅទុកនៅក្នុងផ្ទះរបស់លោកអូបិឌ-អេដុំម ជាអ្នកស្រុកកាថ។[14]ហិបរបស់ព្រះអម្ចាស់ស្ថិតនៅផ្ទះរបស់លោកអូបេឌ-អេដុម គឺនៅជាមួយគ្រួសាររបស់គាត់ចំនួនបីខែ។ ព្រះអម្ចាស់បានប្រទានពរដល់ក្រុមគ្រួសាររបស់គាត់ និងអ្វីៗទាំងអស់ដែលគាត់មាន។

1 Chronicles 13:1
តូចធំ ព្រមទាំងអ្នកដឹកនាំទាំងអស់
កងទ័ពមានមេបញ្ជាការ ដែលដឹកនាំក្រុមទាហានដែលមានចំនួនខុសៗគ្នា។
ការបកប្រែផ្សេងទៀត «ទាហានជាង១.០០០ នាក់ និងទាហានជាង ១០០ នាក់»
ព្រោះប្រជាជនទាំងមូលពេញចិត្តនឹងសំណើនេះ។
នៅទីនេះ «ភ្នែក» តំណាងឲ្យគំនិត និងយោបល់របស់ប្រជាជន។
ការបកប្រែផ្សេងទៀត «ប្រជាជនទាំងអស់គិតថា
ទាំងនេះជារឿងត្រឹមត្រូវដែលត្រូវធ្វើ»
1 Chronicles 13:5
ព័ត៌មានទូទៅ៖
សូមមើល
ក្រុងបាឡា
នេះជាឈ្មោះមួយទៀតរបស់គារយ៉ាត់-យារីម ។
គឺព្រះអម្ចាស់ដែលគង់នៅកណ្តាលពួកចេរូប៊ីន
ការបកប្រែផ្សេងទៀត
«អ្នកដែលគ្រប់គ្រងរវាងសត្វស្លាបដែលនៅលើហិបសម្ព័ន្ធមេត្រី»
1 Chronicles 13:7
ព័ត៌មានទូទៅ៖

generated on Wed Sep 10 16:16:32 2025

សូមមើល
រទេះថ្មមួយ
នេះជាយានដែលមានកង់ អូសទាញដោយសត្វពុំធ្លាប់ត្រូវគេប្រើពីមុនមក។
ឃឹម
ឧបករណ៍ភ្លេងមានក្បាលដូចជាស្គរ ដែលអាចវាយ និងមានបំណែកដែកព័ទ្ធជុំវិញ
ដែលបន្លឺសម្លេងនៅពេលឧបករណ៍ញ័រ
ឈិង
ចានស្ពើងមូលមានលោហៈធាតុព័ទ្ធជុំវិញ
ដែលទង្គិចជាមួយគ្នាបង្កើតបានជាសំឡេងឮៗ
1 Chronicles 13:9
ព័ត៌មានទូទៅ៖
សូមមើល
សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ក៏បានទាស់ឮនឹងលោក ហើយបានប្រហារជីវិតលោក
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ព្រះពិរោធនឹងអ៊ូសា»។
នៅចំពោះព្រះជាម្ចាស់
ការបកប្រែផ្សេងទៀត «នៅចំពោះវត្តមានរបស់ព្រះជាម្ចាស់»
ព្រះបាទដាវីឌរំជួលព្រះហឫទ័យយ៉ាងខ្លាំង
ព្រះបាទដាវីឌខឹងនឹងព្រះអម្ចាស់។
រហូតដល់សព្វថ្ងៃ
សូមមើលការបកប្រែនៅក្នុង ៤:៤២។
1 Chronicles 13:12
ព័ត៌មានទូទៅ៖
សូមមើល
តើធ្វើដូចម្តេចឲ្យយើងនាំហិបនៃព្រះជាម្ចាស់មកឯយើងបាន?
ព្រះបាទដាវីឌកំពុងតែបង្ហាញព្រះពិរោធរបស់ទ្រង់ចំពោះមរណភាពរបស់អ៊ូសានៅពេលគាត់ព្យាយាមយក
ការបកប្រែផ្សេងទៀត
«យើងមិនអាចយកហឹបរបស់ព្រះជាម្ចាស់ត្រឡប់មកទីក្រុងយើងវិញទេ» ឬ
«ប្រាប់យើងពីក្រឹត្យវិន័យអ្វីខ្លះ អំពីរបៀបយកហិបចេញទៅយើងមិនដឹងថា
ត្រូវធ្វើយ៉ាងម៉េចទេ»
បីខែ
«៣ខែ»

---

14 [1]ព្រះបាទហ៊ីរ៉ាមជាស្តេចក្រុងទីរ៉ុស បានចាត់អ្នកនាំសារឲ្យមកគាល់ព្រះបាទដាវីឌ ដោយនាំយកឈើតាត្រៅ ជាងឈើ ជាងដាប់ថ្ម ជាងសំណង់។
ពួកគេបានសង់ដំណាក់មួយថ្វាយព្រះបាទដាវីឌ។[2]ព្រះបាទដាវីឌបានឈ្វេងយល់ថាព្រះជាម្ចាស់តែងតាំងទ្រង់ជាស្តេចលើស្រុកអ៊ីស្រាអែល
ហើយរាជសម្បត្តិរបស់ទ្រង់កាន់តែចម្រុងចម្រើនឡើង ដោយសារប្រជាជនអ៊ីស្រាអែល។
[3]នៅក្រុងយេរូសាឡឹម ព្រះបាទដាវីឌបានយកមហេសីជាច្រើនទៀត ហើយបង្កើតបានបុត្រាបុត្រីជាច្រើន។[4]បុត្ររបស់ស្តេចដែលប្រសូតនៅក្រុងយេរូសាឡឹម មាននាមដូចត
ទៅ សាំមួរ សូបាប់ ណាថាន សាឡូម៉ូន[5]យីបហារ អេលីសាម៉ា អែលផាលេត[6]ណូកា នេផេក យ៉ាភា[7]អេលីសាម៉ា បេលីយ៉ាដា និងអេលីផាលេត។
[8]នៅពេលពួកជនជាតិភីលីស្ទីនបានឮថាព្រះបាទដាវីឌបានទទួលការចាក់ប្រេងអភិសេកជាស្តេចលើស្រុកអ៊ីស្រាអែល នោះពួកគេបានលើកគ្នាមកទាស់និងព្រះអង្គ។
តែព្រះបាទដាវីឌបានជ្រាបពីការនោះ ហើយក៏បានលើកទ័ពទៅតទល់ជាមួយនឹងពួកគេ។[9]ពួកជនជាតិភីលីស្ទីនបានមកបោះទ័ពនៅជ្រលងភ្នំរេផែម។
[10]ព្រះបាទដាវីឌបានទូលសួរដល់ព្រះជាម្ចាស់ថា៖ «តើទូលបង្គំគួរចេញទៅច្បាំងជាមួយពួកភីលីស្ទីនឬទេ? តើព្រះអង្គនឹងប្រគល់ពួកគេមកក្នុងដៃទូលបង្គំដែរឬទេ?»
ព្រះអម្ចាស់មានបន្ទូលថា៖ «ចូរទៅចុះ យើងនឹងប្រគល់គេមកក្នុងកណ្តាប់ដៃរបស់អ្នក»។[11]ពួកភីលីស្ទីនបានមកដល់បាលពេរស៊ីម ហើយព្រះបាទដាវីឌក៏វាយប្រហារពួក
គេនៅទីនោះ។ បន្ទាប់មក ស្តេចមានរាជឱង្ការថា៖ «ព្រះជាម្ចាស់បានធ្វើឲ្យខ្មាំងសត្រូវបាក់ទ័ព ដោយថ្វីដៃខ្ញុំ ដូចជាទឹកបាក់ទំនប់ដែរ»។ ហេតុនេះហើយបានជាគេដាក់
ឈ្មោះកន្លែងនោះថា «បាលពេរ៉ាស៊ីម»។[12]កងទ័ពភីលីស្ទីនបោះបង់ចោលព្រះរបស់ពួកគេនៅទីនោះ ហើយព្រះបាទដាវីឌចេញបញ្ជាឲ្យគេដុតរូបព្រះទាំងនោះចោល។
[13]ពួកភីលីស្ទីនបានមកទន្ទ្រាន នៅជ្រលងភ្នំរាផែមសាជាថ្មី។[14]ព្រះបាទដាវីឌទូលសួរព្រះជាម្ចាស់ម្តងទៀត ព្រះអង្គមានព្រះបន្ទូលមកស្តេចវិញថា៖ «កុំឡើង
ទៅទល់មុខនឹងគេឡើយ ចូររវាងទៅព័ទ្ធពីក្រោយ ហើយវាយពួកគេពីម្ខុំដើមមននោះវិញ។
[15]កាលណាអ្នកឮសន្ធឹកជើងនៅលើចុងមន ចូរចេញទៅច្បាំងចុះ ដ្បិត ព្រះជាម្ចាស់នាំមុខអ្នក វាយលុកទីតាំងទ័ពភីលីស្ទីនហើយ»។[16]ព្រះបាទដាវីឌធ្វើតាមបញ្ជារបស់
ព្រះជាម្ចាស់។ ស្តេចវាយឈ្នះកងទ័ពភីលីស្ទីន ហើយដេញតាមពួកគេតាំងពីក្រុងគីបៀន រហូតដល់ក្រុងកេស៊ើរ។[17]កិត្តិនាមរបស់ព្រះបាទដាវីឌ ក៏ល្បីខ្ចរខ្ចាយគ្រប់ស្រុក
ហើយព្រះអម្ចាស់បានធ្វើឲ្យប្រជាជាតិទាំងអស់ស្ញែងខ្លាចព្រះបាទដាវីឌ។

---

1 Chronicles 14:1
ព្រះបាទហ៊ីរ៉ាម
នេះជានាមរបស់ស្តេច។
ជាងឈើ
ទាំងនេះជាមនុស្សដែលធ្វើការងារផ្នែកឈើ។
ជាងដាប់ថ្ម
ទាំងនេះជាមនុស្សដែលធ្វើការងារផ្នែកថ្ម ឬឥដ្ឋ។
តែងតាំងទ្រង់ជា
ការបកប្រែផ្សេងទៀត «ឲ្យទ្រង់ធ្វើជា»
ហើយរាជសម្បត្តិរបស់ទ្រង់កាន់តែចម្រុងចម្រើនឡើង ដោយសារប្រជាជនអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានប្រទានកិត្តិយសដល់រាជាណាចក្រព្រះបាទដាវីឌ
ដើម្បីជួយប្រជាជនអ៊ីស្រាអែល»
1 Chronicles 14:3
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 14:8
ព្រះបាទដាវីឌបានទទួលការចាក់ប្រេងអភិសេកជាស្តេចលើស្រុកអ៊ីស្រាអែល
ការបកប្រែផ្សេងទៀត «ប្រជាជនអ៊ីស្រាអែលបានចាក់ប្រេងអភិសេកដាវីឌជាស្តេច»
នៅជ្រលងភ្នំរេផែម
នេះជាឈ្មោះកន្លែងមួយ។
1 Chronicles 14:10
ប្រគល់គេមកក្នុងកណ្តាប់ដៃរបស់អ្នក
ការបកប្រែផ្សេងទៀត «ផ្តល់ឲ្យអ្នកនូវជ័យជម្នះលើពួកគេ»
បាលពេរស៊ីម
នេះជាឈ្មោះកន្លែងមួយ។
ដោយថ្វីដៃខ្ញុំ
សំដៅទៅលើធនធានរបស់ព្រះបាទដាវីឌ។ ការបកប្រែផ្សេងទៀត
«ប្រើកងទ័ពរបស់ខ្ញុំ»
ដូចជាទឹកបាក់ទំនប់
អំណាចនិងជ័យជម្នះរបស់កងទ័ពព្រះបាទដាវីឌត្រូវបានប្រៀបធៀបទៅនឹងទឹកបាក់
ទំនប់។ ការបកប្រែផ្សេងទៀត «យ៉ាងងាយ»
ចេញបញ្ជាឲ្យគេដុតរូបព្រះទាំងនោះចោល។
ការបកប្រែផ្សេងទៀត «ដើម្បីដុតព្រះក្លែងក្លាយរបស់ពួកគេ»
1 Chronicles 14:13
នៅជ្រលង
«នៅជ្រលងភ្នំរាផែម»
ទល់មុខនឹងគេ
ការបកប្រែផ្សេងទៀត «វាយប្រហារពីខាងមុខ»
ចូររវាងទៅព័ទ្ធពីក្រោយ ហើយវាយពួកគេពីម្ខុំដើមមននោះវិញ។
ការបកប្រែផ្សេងទៀត «ឆ្លងកាត់ព្រៃមានដើមមន
ហើយវាយប្រហារពួកគេពីខាងក្រោយ»
ដើមមន
នេះជាប្រភេទដើមឈើមួយប្រភេទ។
1 Chronicles 14:15
ព័ត៌មានទូទៅ៖
ព្រះជាម្ចាស់បន្តឆ្លើយសំណួររបស់ព្រះបាទដាវីឌ។
នាំមុខអ្នក

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «បានចេញទៅមុនអ្នក ដើម្បីត្រៀមប្រយុទ្ធ»
ក្រុងកេស៊ើរ
នេះជាឈ្មោះទីក្រុង។

កិត្តិនាមរបស់ព្រះបាទដាវីឌ ក៏ល្បីខ្ចរខ្ចាយគ្រប់ស្រុក
ការបកប្រែផ្សេងទៀត «ប្រជាជននៅឆ្ងាយបានឮអំពីជ័យជម្នះរបស់ព្រះបាទដាវីឌ
លើពួកភីលីស្ទីន»

15 [1]ព្រះបាទដាវីឌ បានសង់ដំណាក់សម្រាប់ខ្លួនឯងជាច្រើននៅក្នុងក្រុងព្រះបាទដាវីឌ។ ព្រះអង្គបានរៀបចំកន្លែងមួយសម្រាប់ហិបនៃព្រះជាម្ចាស់
ព្រមទាំងបានដំឡើងព្រះពន្លាសម្រាប់ហិបនោះផង។[2]ពេលនោះព្រះអង្គមានរាជឱង្ការថា៖ «មានតែពួកលេវីទេដែលមានសិទ្ធសែងហិបរបស់ព្រះជាម្ចាស់
ពីព្រោះពួកគេត្រូវបានព្រះជាម្ចាស់ជ្រើសរើសសម្រាប់ សែងហិបរបស់ព្រះអង្គនិងបម្រើព្រះអង្គរហូតតទៅ»។[3]ពេលនោះ ព្រះបាទដាវីឌបានប្រមូលពួកអ៊ីស្រាអែលទាំងមូល
នៅក្រុងយេរូសាឡឹម ដើម្បីដង្ហែហិបរបស់ព្រះជាម្ចាស់មកតម្កល់នៅកន្លែងដែលព្រះអង្គបានរៀបចំទុក។
[4]ព្រះបាទដាវីឌបានប្រមូលពួកកូនចៅលោកអើរ៉ុន ព្រមទាំងពួកកូនចៅលេវី។[5]គឺពីកូនចៅលោកកេហាត់ មានលោកអ៊ូរាលជាអ្នកដឹកនាំ និងបងប្អូនរបស់គាត់
ទាំងអស់មាន១២០នាក់។[6]ពីពួកកូនចៅលោកម៉្រារីមាន អសាយ៉ាជាអ្នកដឹកនាំ និងបងប្អូនរបស់គាត់ទាំងអស់មាន២២០នាក់។
[7]ពីពួកកូនចៅលោកគើសុនមានលោកយ៉ូអែលជាអ្នកដឹកនាំព្រមទាំងពួកបងប្អូនរបស់គាត់ទាំង១៣០នាក់។[8]ពីពួកកូនចៅរបស់លោកអេលីសាផាន
មានលោកសេម៉ាយ៉ាជាអ្នកដឹកនាំ ព្រមទាំងបងប្អូនរបស់គាត់ទាំង២០០នាក់។[9]ពីពួកកូនចៅរបស់លោកហេប្រូន
មានលោកអ៊ីលាលជាអ្នកដឹកនាំព្រមទាំងបងប្អូនរបស់គាត់ទាំង៨០នាក់។[10]ពីពួកកូនចៅរបស់លោកអ៊ូស៊ាល មានអមីណាដាប់ជាអ្នកដឹកនាំ
ព្រមទាំងបងប្អូនរបស់គាត់ទាំង១១២នាក់។
[11]ព្រះបាទដាវីឌបានកោះហៅលោកបូជាចារ្យ សាដុក និងលោកបូជាចារ្យអប៊ីថើរ ព្រមទាំងក្រុមលេវី គឺលោកអ៊ូរាល លោកអសាយ៉ា លោកយ៉ូអែល លោកសេម៉ាយ៉ា លោក
អេលាល និងលោកអមីណាដាប់។[12]ព្រះអង្គមានព្រះរាជឱង្ការទៅពួកគេថា៖ «អស់លោកជាអ្នកដឹកនាំលើក្រុមគ្រួសារលេវី។ ដូច្នេះ ចូរអស់លោកញែកខ្លួនឲ្យបានវិសុទ្ធ
ដើម្បីទៅដង្ហែហិបរបស់ព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល មកតម្កល់នៅកន្លែងដែលយើងបានរៀបចំទុក។
[13]កាលពីលើកមុនអស់លោកមិនបានទៅដង្ហែជាមួយយើងទេ។ ហេតុនោះបានជាព្រះអម្ចាស់ទ្រង់ប្រហារពួកយើង ដ្បិត ពួកយើងមិនបានស្វែងរកព្រះអង្គ
និងមិនបានដង្ហែមកតាមក្បួនតម្រារបស់ទ្រង់ទេ»។[14]ដូច្នេះ ពួកបូជាចារ្យ និងពួកលេវីនាំគ្នាញែកខ្លួនជាបរិសុទ្ធ
ដើម្បីអាចដង្ហែហិបរបស់ព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល។[15]ពួកកូនចៅលេវីបានយកឈើស្នែងមកស៊ក ហើយសែងហិបរបស់ព្រះអម្ចាស់នៅលើស្មា
ដូចជាលោកម៉ូសេបានបង្គាប់ ស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់។
[16]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់មេដឹកនាំរបស់ក្រុមលេវី ឲ្យចាត់បងប្អូនរបស់ពួកគេដែលជាអ្នកចម្រៀង ឲ្យយកឧបករណ៍ភ្លេងមាន ឃឹម ពិណ និងឈិង មក
ប្រគំព្រមទាំងច្រៀងយ៉ាងពីរោះផង។[17]ក្រុមលេវីបានចាត់គ្នាឲ្យបំពេញមុខងាររបស់ខ្លួន គឺលោកហេម៉ានជាកូនរបស់លោកយ៉ូអែល និងបងប្អូនរបស់គាត់ម្នាក់ លោក
អេសាភជាកូនរបស់លោកបេរេគា។ពួកគេបានតែងតាំងកូនចៅរបស់លោកម៉្រារី ព្រមទាំងលោកអេថានជាកូនរបស់លោកគូសាយ៉ា។[18]បន្ទាប់មកទៀត មានក្រុមលេវីដែល
នៅក្រោមបង្គាប់លោកទាំងនោះ គឺលោកសាការី លោកយ៉ាស៊ាល លោកសេមីរ៉ាម៉ូត លោកយេហ៊ីអែល លោកអ៊ូនី លោកអេលាប លោកបេណាយ៉ា លោកម៉ាសេយ៉ា លោក
ម៉ាធិធា លោកអេលីផាលេហ៊ូ លោកមីកនេយ៉ា លោកអូបេឌអេដុម និងលោកយីអែល ដែលសុទ្ធតែជាឆ្មាំទ្វារ។
[19]ក្រុមអ្នកចម្រៀងមានលោកហេម៉ាន លោកអេសាភ និងលោកអេថាន ដែលកាន់ឈិងធ្វើពីលង្ហិន។[20]រីឯលោកសាការី លោកយ៉ាស៊ាល លោកសេមីរ៉ាម៉ូត លោកយីអែល
លោកអ៊ូនី លោកអេលាប លោកម៉ាសេយ៉ា និងលោកបេណាយ៉ា ជាអ្នកកាន់ពិណដែលមានសំឡេងខ្ពស់។[21]លោកម៉ាធិធា លោកអេលីផាលេ លោកមីកនេយ៉ា លោក
អូបេដអេដុម លោកយេអែល លោកអសាស៊ា ជាអ្នកកាន់ពិណដែលមានខ្សែប្រាំបីសម្រាប់នាំមុខចម្រៀង។
[22]លោកកេណានា ជាអ្នកដឹកនាំលើពួកលេវី លោកគឺជាប្រធានលើក្រុមចម្រៀងពីព្រោះលោកជាគ្រូបង្រៀនចម្រៀង។[23]លោកបេរេគា និងលោកអែលកាណា ជាឆ្មាំឈរនៅ
ជិតហិប។[24]លោកបូជាចារ្យសេបានា យ៉ូហូសាផាត នេថានេល អម៉ាសាយ សាការី បេណាយ៉ា និងអេលាស៊ើរ ជាអ្នកផ្លុំត្រែ នៅខាងមុខហិបរបស់ព្រះជាម្ចាស់។ លោក
អូបេដអេដុម និងលោកយេហ៊ីយ៉ា ក៏ជាឆ្មាំដែលឈរនៅជិតហិបដែរ។
[25]ព្រះបាទដាវីឌ ព្រមទាំងពួកព្រឹទ្ធាចារ្យនៃជនជាតិអ៊ីស្រាអែល ពួកមេទ័ព
បាននាំគេចេញទៅដង្ហែហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ពីផ្ទះរបស់លោកអូបិឌអេដុមយ៉ាងសប្បាយរីករាយ។[26]ព្រះជាម្ចាស់បានជួយការពារក្រុមលេវី ដែលសែងហិបនៃ
សម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ ហើយគេបានយកគោបាប្រាំពីរក្បាល និងចៀមឈ្មោលប្រាំពីរក្បាល ថ្វាយជាយញ្ញបូជា។
[27]ព្រះបាទដាវីឌពាក់អាវធំធ្វើពីក្រណាត់ព្រៃ ហើយក្រុមលេវីដែលសែងហិប ក្រុមចម្រៀង និងលោកកេណានាជាមេដឹកនាំក្រុមសែង ក៏ស្លៀកពាក់ដូច្នោះដែរ។ ព្រះបាទ
ដាវីឌពាក់អាវអេផូដធ្វើពីក្រណាត់ទេសឯក។[28]ប្រជាជនអ៊ីស្រាអែលទាំងមូលដង្ហែហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ ដោយសម្រែកជ័យឃោសសម្លេងប៊ុ ត្រែ និងឈិង
ព្រមទាំងប្រគំឃឹម និងពិណយ៉ាងរំពងផង។
[29]ប៉ុន្តែ កាលហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ហែចូលមកដល់ក្រុងព្រះបាទដាវីឌ ព្រះនាងមិកាលជាបុត្រីរបស់ស្តេចសូល បានអើតតាមបង្អួច។ ព្រះនាងឃើញព្រះបាទ
ដាវីឌអបអរលោតកញ្ឆេង ព្រះនាងក៏មានចិត្តមើលងាយព្រះបាទដាវីឌ។

1 Chronicles 15:1
ព្រះបាទដាវីឌ បានសង់ដំណាក់សម្រាប់ខ្លួនឯង
ការបកប្រែផ្សេងទៀត «ប្រជាជនបានសង់ព្រះដំណាក់ថ្វាយព្រះបាទដាវីឌ»
បានរៀបចំកន្លែងមួយ
ការបកប្រែផ្សេងទៀត «បានបញ្ជាឲ្យបង្កើតកន្លែងពិសេស»
បានប្រមូលពួកអ៊ីស្រាអែលទាំងមូល
ការបកប្រែផ្សេងទៀត «បានបញ្ជាថា ប្រជាជនអ៊ីស្រាអែលទាំងអស់គួរតែមករួមគ្នា»
ដើម្បីដង្ហែហិប
ការបកប្រែផ្សេងទៀត «ដើម្បីអបអរពេលពួកលេវីសែងហិប»
1 Chronicles 15:4
ព័ត៌មានទូទៅ៖
សូមមើល and
បងប្អូន
មនុស្សជាផ្នែកមួយនៃក្រុមគ្រួសារ ឬកុលសម្ព័ន្ធដូចគ្នា
1 Chronicles 15:7
ព័ត៌មានទូទៅ៖
សូមមើល and

1 Chronicles 15:11
ព័ត៌មានទូទៅ៖
សូមមើល
ដែលយើងបានរៀបចំទុក។
ការបកប្រែផ្សេងទៀត «ខ្ញុំបានបញ្ជាពួកលេវីឲ្យរៀបចំ»
1 Chronicles 15:13
កាលពីលើកមុន អស់លោកមិនបានទៅដង្ហែជាមួយយើងទេ។
«អ្នកមិនបានសែងហិបទៅមុនទេ»
ពួកយើងមិនបានស្វែងរកព្រះអង្គ
ការបកប្រែផ្សេងទៀត «យើងមិនបានស្នើសុំឲ្យទ្រង់ណែនាំ»
ប្រហារពួកយើង
ការបកប្រែផ្សេងទៀត «បានដាក់ទណ្ឌកម្មយើង»
ពួកលេវីនាំគ្នាញែកខ្លួនជាបរិសុទ្ធ ដើម្បីអាចដង្ហែហិបរបស់ព្រះអម្ចាស់ជា
ការបកប្រែផ្សេងទៀត «ពួកលេវីធ្វើពិធីសម្អាតខ្លួន មុនពេលសែង»
1 Chronicles 15:16
ព័ត៌មានទូទៅ៖
សូមមើល

generated on Wed Sep 10 16:16:32 2025

ឈិង
សូមមើលការបកប្រែនៅក្នុង ១៣:៧។
មកប្រគំព្រមទាំងច្រៀងយ៉ាងពីរោះផង។
ការបកប្រែផ្សេងទៀត «ការច្រៀង»
នៅក្រោមបង្គាប់
ការបកប្រែផ្សេងទៀត «ទីតាំងទាបនៃអំណាច» ឬ «លំដាប់ទី២»
ជាឆ្មាំទ្វារ
អ្នកយាមទ្វារ
1 Chronicles 15:19
ព័ត៌មានទូទៅ៖
សូមមើល
ឈិង
សូមមើលការបកប្រែនៅក្នុង ១៣:៧។
លោកបេណាយ៉ា ... លោកអសាសា
អត្ថន័យនៃពាក្យទាំងនេះមិនបានបញ្ជាក់ច្បាស់ទេ
ប៉ុន្តែអាចសំដៅទៅលើបែបបទតន្ត្រី។
សម្រាប់នាំមុខចម្រៀង
«ដឹកនាំអ្នកលេងភ្លេងផ្សេងទៀត» ឬ «ដឹកនាំអ្នកសម្តែង»
1 Chronicles 15:22
ព័ត៌មានទូទៅ៖
សូមមើល
1 Chronicles 15:25
បាននាំគេចេញទៅ
ការបកប្រែផ្សេងទៀត «នៃបុរសច្រើនជាង ១.០០០ នាក់»
លោកអូបិឌអេដុម
នេះជាឈ្មោះបុរស។
1 Chronicles 15:27
ព្រះបាទដាវីឌពាក់អាវធំធ្វើពីក្រណាត់ព្រៃ ហើយក្រុមលេវីដែលសែងហិប ក្រុមចម្រៀង និងលោក
កេណានាជាមេដឹកនាំក្រុមសែង
ការបកប្រែផ្សេងទៀត «ព្រះបាទដាវីឌ ពួកលេវី និងអ្នកចម្រៀងសុទ្ធតែបានពាក់រូប
ធ្វើពីក្រណាត់ទេសឯកល្អៗ»
ក្រណាត់ទេសឯក
នេះជាប្រភេទក្រណាត់រលោង និងរឹងមាំ។
លោកកេណានា
នេះជាឈ្មោះបុរស។
ប្រជាជនអ៊ីស្រាអែលទាំងមូលដង្ហែហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
ការបកប្រែផ្សេងទៀត
«ជនជាតិអ៊ីស្រាអែលច្រើនកុះករបានយកហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ពីផ្ទះរបស់អូបេដអេដុមទៅ
ឈិង
សូមមើលការបកប្រែនៅក្នុង ១៣:៧។
1 Chronicles 15:29
កាលហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ហែចូលមកដល់ក្រុងព្រះបាទដាវីឌ
ការបកប្រែផ្សេងទៀត
«ប្រជាជនបាននាំហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់មកបុរីព្រះបាទដាវីឌ។
ព្រះនាងមិកាល
នេះជាឈ្មោះមហេសីរបស់ព្រះបាទដាវីឌ។
ព្រះនាងក៏មានចិត្តមើលងាយព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «មិនគោរពទ្រង់ ពេលព្រះនាងគិត»

16 [1]គេបានដង្ហែហិបរបស់ព្រះជាម្ចាស់មក ហើយបានដាក់តម្កល់នៅកណ្ដាលព្រះពន្លា ដែលព្រះបាទដាវីឌបានរៀបចំទុក។ រួចគេថ្វាយតង្វាយដុត
និងតង្វាយមេត្រីភាពនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់។[2]កាលព្រះបាទដាវីឌថ្វាយតង្វាយដុត និងតង្វាយមេត្រីភាពចប់សព្វគ្រប់ហើយ
ព្រះអង្គក៏ប្រទានពរដល់ប្រជាជនទាំងអស់ក្នុងព្រះនាមព្រះជាម្ចាស់។[3]ព្រះអង្គក៏ប្រទានម្ហូបអាហារដល់ប្រជាជនទាំងអស់ ទាំងប្រុស ទាំងស្រី ម្នាក់ៗទទួលបាននំប៉័ងមួយដុំ
សាច់មួយដុំ និងនំទំពាំងបាយជូរក្រៀមមួយដុំ។
[4]ព្រះបាទដាវីឌក៏ចាក់ប្រេងតែងតាំងពួកលេវីខ្លះឲ្យបម្រើនៅចំពោះហិបនៃព្រះអម្ចាស់ ដើម្បីធ្វើពិធីរំឭក អរព្រះគុណ ច្រៀងសរសើរ
និងលើកតម្កើងព្រះអម្ចាស់ជាព្រះនៃប្រជាជនអ៊ីស្រាអែល។[5]ពួកលេវីទាំងនេះ មានលោកអេសាភជាអ្នកដឹកនាំ បន្ទាប់ពី លោកមានលោកសាការី លោកយីអែល លោក
សេមីរ៉ាម៉ូត លោកយេហ៊ីអែល លោកម៉ាធិធា លោកអេលាប លោកបេណាយ៉ា លោកអូបេដអេដុម និងលោកយេអែល ដែលសុទ្ធតែជាអ្នកលេងភ្លេង គឺមានឃឹម និងពិណ។
លោកអេសាភជាអ្នកវាយឈិងឲ្យឮរំពង។[6]លោកបូជាចារ្យបេណាយ៉ា និងលោកយ៉ាហាសៀល ផ្លុំត្រែ នៅមុខហិបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ជានិច្ច។
[7]នៅថ្ងៃនោះ ព្រះបាទដាវីឌបានចាក់ប្រេងតែងតាំង លោកអេសាភ និងបងប្អូនគាត់ឲ្យប្រារព្ធពិធីច្រៀងចម្រៀងលើកតម្កើងព្រះជាម្ចាស់។[8]ចូរអរព្រះគុណដល់ព្រះអម្ចាស់!
ចូរប្រកាសពីព្រះនាមព្រះអង្គ! ចូរថ្លែងពីស្នាព្រះហស្តព្រះអង្គ ប្រាប់ដល់ជាតិសាសន៍នានា។[9]ចូរច្រៀងចម្រៀង ចូរច្រៀងសរសើរព្រះអង្គ
ចូររៀបរាប់ពីការអស្ចារ្យដែលព្រះអង្គបានធ្វើ!។
[10]ចូរអួតពីព្រះនាមបរិសុទ្ធរបស់ព្រះអង្គ! ចូរឲ្យចិត្តនៃអ្នកដែលស្វែងរកព្រះអង្គបានអរសប្បាយឡើង!។[11]ចូរស្វែងរកព្រះអម្ចាស់ដែលប្រកបដោយព្រះចេស្តា!
ចូរស្វែងរកព្រះអង្គជានិច្ចឥតឈប់ឈរឡើយ។
[12]ចូរនឹកចាំពីការអស្ចារ្យទាំងប៉ុន្មានដែលព្រះអង្គបានធ្វើ ចូរនឹកពីការអស្ចារ្យ និងឫទ្ធិបាដិហារិយ៍ទាំងប៉ុន្មានដែលចេញពីព្រះឱស្ឋទ្រង់មក។
[13]អ្នករាល់គ្នាជាពូជពង្សរបស់លោកអ៊ីស្រាអែលជាអ្នកបម្រើរបស់ព្រះអង្គ អ្នករាល់គ្នាជាកូនចៅរបស់យ៉ាកុប ដែលព្រះអង្គបានជ្រើសរើស។[14]ព្រះអង្គជាព្រះអម្ចាស់
ជាព្រះជាម្ចាស់របស់យើង។ បញ្ញត្តិទាំងប៉ុន្មានរបស់ព្រះអង្គនៅពេញលើផែនដីទាំងមូល។
[15]ចូរនឹកដល់សម្ពន្ធមេត្រីរបស់ព្រះអង្គជានិច្ច គឺជាព្រះបន្ទូលរបស់ព្រះអង្គដែលស្ថិតស្ថេរនៅរហូតដល់មួយពាន់តំណ។
[16]គឺជាសម្ពន្ធមេត្រីដែលព្រះអង្គបានចងជាមួយលោកអប្រាហាំ និងព្រះបន្ទូលសន្យាដែលទ្រង់បានសន្យាជាមួយលោកអ៊ីសាក។
[17]នេះគឺជាសម្ពន្ធមេត្រីដែលព្រះអង្គបានបញ្ជាក់ជាមួយលោកយ៉ាកុបទុកជាក្រឹត្យក្រម ហើយជាមួយអ៊ីស្រាអែលទុកជាសម្ពន្ធមេត្រីអស់កល្បជានិច្ច។
[18]ព្រះអង្គមានព្រះបន្ទូលថា៖ «យើងនឹងប្រគល់ស្រុកកាណានឲ្យអ្នកទុកជាចំណែកមរតក»។
[19]ព្រះអង្គបានសន្យាតាំងពីអ្នករាល់គ្នានៅមានគ្នាតិច គឺជាក្រុមមនុស្សដ៏តូច ហើយជាជនដទៃដែលចូលមករស់នៅស្រុកកាណាន។
[20]អ្នករាល់គ្នាបានធ្វើដំណើរពីស្រុកមួយទៅស្រុកមួយ ហើយពីនគរមួយទៅនគរមួយទៀត។[21]ព្រះជាម្ចាស់មិនបានអនុញ្ញាតឲ្យអ្នកណាម្នាក់សង្កត់សង្កិនអ្នករាល់គ្នាទេ
ព្រះអង្គបានដាក់ទោសស្តេចនានាដែលធ្វើទុក្ខគេ។[22]ព្រះអង្គមានបន្ទូលថា៖ «កុំឲ្យប៉ះពាល់អ្នកដែលយើងចាក់ប្រេងអភិសេកឡើយ
ក៏កុំឲ្យធ្វើបាបពួកព្យាការីរបស់យើងឲ្យសោះ»។
[23]មនុស្សនៅលើផែនដីអើយ ចូរច្រៀងថ្វាយព្រះអម្ចាស់! ចូរប្រកាសជារៀងរាល់ថ្ងៃពីសេចក្ដីសង្គ្រោះរបស់ព្រះអង្គ។
[24]ចូរប្រកាសពីសិរីរុងរឿងរបស់ព្រះអង្គនៅកណ្ដាលជាតិសាសន៍នានា ហើយប្រកាសពីការយ៉ាងអស្ចារ្យដែលព្រះអង្គបានធ្វើដល់គ្រប់សាសន៍ទាំងអស់។
[25]ដ្បិត ព្រះអម្ចាស់ជាព្រះដ៏ប្រសើរឧត្តមដែលយើងត្រូវតែសរសើរតម្កើងអស់ពីចិត្ត ព្រះអង្គគួរជាទីស្ញែងខ្លាចលើសជាងព្រះទាំងឡាយ។[26]ដ្បិត ព្រះទាំងប៉ុន្មានរបស់សាសន៍
នានាសុទ្ធតែជារូបសំណាក់ ប៉ុន្តែ ព្រះអម្ចាស់វិញ ព្រះអង្គបានបង្កើតផ្ទៃមេឃ។[27]ឥទ្ធានុភាពនិង ព្រះតេជៈ នៅក្នុងវត្តមានរបស់ព្រះអង្គ។ កម្លាំង
និងអំណរនៅក្នុងដំណាក់របស់ព្រះអង្គ។
[28]ចូរលើកតម្កើងដល់ព្រះអម្ចាស់! ឱប្រជាជាតិទាំងឡាយអើយ ចូរនាំគ្នាលើកតម្កើងសិរីរុងរឿងព្រះអម្ចាស់ និងឫទ្ធានុភាពរបស់ព្រះអង្គ។[29]ចូរលើកតម្កើងសិរីរុងរឿងនៃ
ព្រះនាមរបស់ព្រះអម្ចាស់! ចូរយកតង្វាយចូលមកចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ! ចូរក្រាបថ្វាយបង្គំព្រះអម្ចាស់ នៅពេលព្រះអង្គសម្តែងភាពវិសុទ្ធរបស់ព្រះអង្គ!
[30]ឱមនុស្សនៅផែនដីអើយ ចូរញាប់ញ័រចំពោះព្រះភក្ត្រព្រះអង្គចុះ ពិភពលោកបានកើតមានហើយមិនរង្គើឡើយ។[31]ចូរឲ្យស្ថានសួគ៌រីករាយ
ហើយផែនដីបានអរសប្បាយឡើង! ចូរប្រកាសនៅកណ្ដាលប្រជាជាតិនានាថា «ព្រះអម្ចាស់សោយរាជ្យ»។

generated on Wed Sep 10 16:16:32 2025

[32]ចូរឲ្យសមុទ្រ និងអ្វីៗទាំងអស់នៅក្នុងសមុទ្របានបន្លឺសម្លេងដោយអំណរ។ ចូរឲ្យស្រែចម្ការ និងដំណាំទាំងអស់បានត្រេកអរសប្បាយ។[33]ចូរឲ្យព្រៃព្រឹក្សាស្រែក
ហ៊ោដោយអំណរនៅចំពោះព្រះភក្ត្រព្រះអម្ចាស់! ដ្បិត ព្រះអង្គយាងជំនុំជម្រះផែនដី។
[34]ចូរអរព្រះគុណព្រះអម្ចាស់ ដ្បិត ព្រះអង្គល្អ ហើយព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ។[35]ចូរទូលព្រះអង្គថា៖ «ឱព្រះសង្គ្រោះរបស់យើងខ្ញុំអើយ
សូមជួយសង្គ្រោះយើងខ្ញុំផង សូមប្រមូលផ្តុំយើងខ្ញុំ ហើយសង្គ្រោះយើងខ្ញុំពីប្រជាជាតិនានា ដើម្បីឲ្យយើងខ្ញុំអរព្រះគុណ និងលើកតម្កើងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គ»។
[36]សូមលើកតម្កើងព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលតាំងពីដើមរៀងមកហើយអស់កល្បតរៀងទៅ!»។ប្រជាជនទាំងមូលឆ្លើយថា «អាម៉ែន» «សូមសរសើរតម្កើង
ព្រះជាម្ចាស់!»។
[37]ព្រះបាទដាវីឌបានចាត់លោកអេសាភ
និងបងប្អូនលោកឲ្យបំពេញមុខងារនៅចំពោះហិបនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃតាមដែលបានកំណត់ឥតដែលអាកខានឡើយ។[38]លោកអូបិឌអេដុម
ព្រមទាំងបងប្អូនគាត់ទាំង៦៨នាក់ក៏ត្រូវបានរួមបញ្ចូលក្នុងកាងារនោះដែរ។ លោកអូបេឌអេដុមជាកូនរបស់លោកយេឌូថិន និងលោកហូសាគឺជាឆ្មាំទ្វារ។[39]លោកបូជាចារ្យ
សាដុក និងបូជាចារ្យឯទៀតៗ ជាបងប្អូនរបស់គាត់ បំពេញមុខងារនៅមុខព្រះពន្លារបស់ព្រះអម្ចាស់ ដែលស្ថិតលើទួលខ្ពស់ នៅគីបៀន។
[40]ពួកគេត្រូវថ្វាយតង្វាយដុតជាអចិន្ត្រៃយ៍ចំពោះព្រះអម្ចាស់ នៅលើអាសនៈសម្រាប់ថ្វាយតង្វាយដុត ទាំងព្រឹក ទាំងល្ងាច ស្របតាមសេចក្តីទាំងប៉ុន្មានដែលមានចែងទុក
ក្នុងក្រឹត្យវិន័យ ដែលព្រះអម្ចាស់បានបង្គាប់ដល់ប្រជាជនអ៊ីស្រាអែល។[41]លោកហេម៉ាន និងលោកយេឌូថិន ព្រមទាំងអ្នកឯទៀតៗ ដែលគេបានជ្រើសរើសតាមឈ្មោះក៏មក
ចូលរួមជាមួយបូជាចារ្យទាំងនោះដែរ ដើម្បីលើកតម្កើងព្រះអម្ចាស់ ដ្បិត ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ នៅស្ថិតស្ថេររហូតតទៅ!។
[42]លោកហេម៉ាន និងលោកយេឌូថិន ក៏ទទួលខុសត្រូវលើត្រែ និងឈិងរបស់ពួកតន្ត្រីករ ព្រមទាំងឧបករណ៍ឯទៀតៗ សម្រាប់ប្រគំបទចម្រៀងថ្វាយព្រះជាម្ចាស់។ កូនចៅ
របស់លោកយេឌូថិនក៏មានមុខងារជាឆ្មាំនៅមាត់ទ្វារដែរ។[43]បន្ទាប់មក ប្រជាជនទាំងអស់នាំគ្នាវិលត្រឡប់ទៅផ្ទះរៀងៗខ្លួន ហើយព្រះបាទដាវីឌក៏វិលទៅដំណាក់វិញ ដើម្បី
ប្រទានពរដល់រាជវង្សព្រះអង្គ។

---

1 Chronicles 16:1
គេបានដង្ហែហិបរបស់ព្រះជាម្ចាស់មក
ការបកប្រែផ្សេងទៀត «ជនជាតិអ៊ីស្រាអែលបានយកហិបមក»
នំប៉័ងមួយដុំ
នំប៉័ងមានដាក់មេមួយដុំ
នំទំពាំងបាយជូរក្រៀម
ទាំងនេះជាផ្លែទំពាំងបាយជូរស្ងួត
ដែលជាផ្លែឈើតូចមួយដុះនៅលើដើមទំពាំងបាយជូរ។
1 Chronicles 16:4
ព័ត៌មានទូទៅ៖
សូមមើល
ឈិង
សូមមើលការបកប្រែនៅក្នុង ១៣:៧។
1 Chronicles 16:7
នៅថ្ងៃនោះ
នេះសំដៅទៅលើថ្ងៃ
ដែលគេយកហិបនៃសម្ពន្ធមេត្រីនេះចេញពីផ្ទះរបស់អូបេដអេដុមទៅក្រុងយេរូសាឡឹម។ឃ្លាទាំងនេះមានអត្ថន័យរួមប្រហាក់ប្រហែលគ្នា និងបញ្ជាក់ថា
ចូរអរព្រះគុណដល់ព្រះអម្ចាស់!
ការបកប្រែផ្សេងទៀត «បទចម្រៀងអរព្រះគុណ»
ចូរប្រកាសពីព្រះនាមព្រះអង្គ!
ការបកប្រែផ្សេងទៀត «អធិស្ឋានដល់ព្រះអម្ចាស់»
1 Chronicles 16:10
ព្រះនាមបរិសុទ្ធរបស់ព្រះអង្គ!
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់ជានរណា»
ចូរឲ្យចិត្តនៃអ្នកដែលស្វែងរកព្រះអង្គ
ការបកប្រែផ្សេងទៀត «សូមឲ្យអស់អ្នកចង់ស្គាល់ព្រះអម្ចាស់កាន់តែច្បាស់ឡើង»
ចូរស្វែងរកព្រះអម្ចាស់ដែលប្រកបដោយព្រះចេស្តា! ចូរស្វែងរកព្រះអង្គជានិច្ចឥតឈប់ឈរឡើយ។
ឃ្លាទាំងនេះចែករំលែកអត្ថន័យស្រដៀងគ្នា ហើយត្រូវបានប្រើសម្រាប់ការបញ្ជាក់។
ការបកប្រែផ្សេងទៀត «ចូរស្វែងរកព្រះអម្ចាស់ និងឫទ្ធានុភាពព្រះអង្គ
ចូរនៅជិតព្រះអង្គជានិច្ច»
1 Chronicles 16:12
ចូរនឹកចាំពីការអស្ចារ្យ
ការបកប្រែផ្សេងទៀត «ចូរចងចាំរឿងដ៏អស្ចារ្យ»
ដែលចេញពីព្រះឱស្ឋទ្រង់មក។
ការបកប្រែផ្សេងទៀត «ដែលព្រះអង្គមានបន្ទូល»
អ្នករាល់គ្នាជាពូជពង្សរបស់លោកអ៊ីស្រាអែលជាអ្នកបម្រើរបស់ព្រះអង្គ
អ្នករាល់គ្នាជាកូនចៅរបស់យ៉ាកុប ដែលព្រះអង្គបានជ្រើសរើស។
ឃ្លាទាំងនេះមានអត្ថន័យរួមស្រដៀងគ្នា ហើយត្រូវបានប្រើសម្រាប់ការបញ្ជាក់។
របស់ព្រះអង្គនៅពេញលើផែនដីទាំងមូល។
ការបកប្រែផ្សេងទៀត «ក្រឹត្យវិន័យរបស់ព្រះអង្គ
សម្រាប់ប្រជាជនទាំងអស់នៅលើផែនដី»
1 Chronicles 16:15
ចូរនឹកដល់សម្ពន្ធមេត្រីរបស់ព្រះអង្គជានិច្ច
ការបកប្រែផ្សេងទៀត «ចងចាំសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់»
នៅរហូតដល់មួយពាន់តំណ
«១.000 ជំនាន់»
គឺជាសម្ពន្ធមេត្រីដែលព្រះអង្គបានចងជាមួយ
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ចងចាំ»
ឲ្យអ្នកទុកជាចំណែក
«ជាចំណែករបស់អ្នក»
1 Chronicles 16:19
ព្រះអង្គបានសន្យាតាំងពីអ្នករាល់គ្នានៅមានគ្នាតិច គឺជាក្រុមមនុស្សដ៏តូច
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះនៅពេលជនជាតិអ៊ីស្រាអែលជាក្រុមតូចមួយ»
ហើយជាជនដទៃដែលចូលមករស់នៅស្រុកកាណា។
«ជនបរទេសនៅក្នុងទឹកដី»
ពីស្រុកមួយទៅស្រុកមួយ ហើយពីនគរមួយទៅនគរមួយទៀត។
ប្រជាជនអ៊ីស្រាអែលបានវង្វេងឆ្ងាយប៉ុនណា។
ព្រះជាម្ចាស់មិនបានអនុញ្ញាតឲ្យ
«ព្រះអម្ចាស់មិនបានអនុញ្ញាតទេ»
សម្រាប់ជាប្រយោជន៍របស់ពួកគេ
«សម្រាប់ពួកគេ»
1 Chronicles 16:23
ព័ត៌មានទូទៅ៖
សូមមើល
មនុស្សនៅលើផែនដីអើយ
អ្វីៗទាំងអស់នៅលើផែនដីថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។
ចូរប្រកាសជារៀងរាល់ថ្ងៃ
ការបកប្រែផ្សេងទៀត «ជារៀងរាល់ថ្ងៃ»
1 Chronicles 16:25
ឥទ្ធានុភាពនិង ព្រះតេជៈ នៅក្នុងវត្តមានរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «ភាពរុងរឿង និងតេជានុភាពនៅជុំវិញព្រះអង្គ»។
កម្លាំង និងអំណរនៅក្នុងដំណាក់របស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បង្ហាញយ៉ាងច្បាស់នូវឫទ្ធានុភាពនិងអំណាររបស់ព្រះអង្គ។»
1 Chronicles 16:28
ចូរលើកតម្កើងដល់ព្រះអម្ចាស់!
«ចូរថ្វាយការសរសើរដល់ព្រះអម្ចាស់ចំពោះ»
ព្រះនាមរបស់ព្រះអម្ចាស់!
«ព្រះអង្គសក្តិសម ឬព្រះអង្គសក្តិសមនឹងទទួល»
1 Chronicles 16:30

generated on Wed Sep 10 16:16:32 2025

ចូរញាប់ញ័រចំពោះព្រះភក្ត្រ
ការបកប្រែផ្សេងទៀត «បង្ហាញការភ័យខ្លាចដោយគោរពតាមគំនិតរបស់ព្រះអង្គ»
ចូរឲ្យស្ថានសួគ៌រីករាយ ហើយផែនដីបានអរសប្បាយឡើង!
ការបកប្រែផ្សេងទៀត «សូមឲ្យអ្នករាល់គ្នានៅគ្រប់ទីកន្លែង ចូររីករាយឡើង។»
1 Chronicles 16:32
សមុទ្របានបន្លឺសំឡេង
ការបកប្រែផ្សេងទៀត «សមុទ្រនឹងស្រែកខ្លាំងៗ» ។
និងអ្វីៗទាំងអស់នៅក្នុ
ការបកប្រែផ្សេងទៀត «សត្វសមុទ្រទាំងឡាយ»
ចូរឲ្យព្រៃព្រឹក្សាស្រែកហ៊ោដោយអំណរ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់!
សំដៅទៅលើដើមឈើ ប្រៀបបីដូចជា ពួកគេជាមនុស្សអាចស្រែកដោយអំណរ។
1 Chronicles 16:36
ពីដើមរៀងមកហើយអស់កល្បតរៀងទៅ!
ការបកប្រែផ្សេងទៀត «អស់កល្បតរៀងទៅ»
ប្រជាជនទាំងមូលឆ្លើយថា
ការបកប្រែផ្សេងទៀត «ប្រជាជន» ឬ «មនុស្សគ្រប់គ្នាដែលនៅទីនោះ»
1 Chronicles 16:37
ព័ត៌មានទូទៅ៖
សូមមើល
ជារៀងរាល់ថ្ងៃតាមដែលបានកំណត់ឥតដែលអាកខានឡើយ។
ការបកប្រែផ្សេងទៀត
«ដូចដែលបានតម្រូវជារៀងរាល់ថ្ងៃនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ»
បំពេញមុខងារនៅមុខព្រះពន្លា
ការបកប្រែផ្សេងទៀត «បម្រើនៅក្នុង ឬជិតព្រះពន្លា»
1 Chronicles 16:40
ព័ត៌មានទូទៅ៖
សូមមើល
ពួកគេ
«បូជាចារ្យ»
1 Chronicles 16:42
ព័ត៌មានទូទៅ៖
សូមមើល
ឈិង
សូមមើលការបកប្រែនៅក្នុង១ពង្ស:៧។

17 [1]នៅគ្រានោះ ព្រះបាទដាវីឌគង់នៅក្នុងព្រះរាជវាំងរបស់ព្រះអង្គ ហើយមានព្រះរាជឱង្ការទៅកាន់ព្យាការីណាថានថា៖ «មើល៍ ខ្ញុំរស់នៅក្នុងដំណាក់ធ្វើពីឈើតាត្រៅ
ប៉ុន្តែ ហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ ស្ថិតនៅក្នុងពន្លាដែលធ្វើពីក្រណាត់ទៅវិញ»។[2]ព្យាការីណាថានទូលព្រះបាទដាវីឌថា៖
«សូមព្រះករុណាធ្វើអ្វីដែលព្រះករុណាសព្វព្រះទ័យនឹងធ្វើចុះ ដ្បិតព្រះជាម្ចាស់គង់នៅជាមួយព្រះករុណាហើយ!»។
[3]ប៉ុន្តែ នៅវេលាយប់នោះព្រះអម្ចាស់បានមានបន្ទូលមកព្យាការីណាថានថា៖[4]«ចូរទៅប្រាប់ដាវីឌជាអ្នកបម្រើយើងថា ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅមិនមែនអ្នកទេ
ដែលនឹងសង់ដំណាក់ឲ្យយើងនៅ។[5]តាំងពីថ្ងៃដែលយើងបាននាំជនជាតិអ៊ីស្រាអែលចាកចេញពីស្រុកអេស៊ីប រហូតមកដល់ថ្ងៃនេះ យើងមិនដែលនៅក្នុងដំណាក់ទេ គឺ
យើងនៅតែក្នុងជំរំ និងព្រះពន្លា ពីកន្លែងមួយទៅកន្លែងមួយ។[6]គ្រប់ទីកន្លែងដែលយើងធ្វើដំណើរជាមួយជនជាតិអ៊ីស្រាអែល យើងបានតែងតាំងឲ្យមានពួកចៅហ្វាយ
គ្រប់គ្រងលើប្រជារាស្ត្ររបស់យើង តែយើងមិនបានបង្គាប់ពួកចៅហ្វាយណាម្នាក់ថា៖ «ហេតុអ្វីបានជាអ្នកមិនសង់ដំណាក់ពីឈើតាត្រៅសម្រាប់យើង?»។
[7]ឥឡូវនេះ ចូរប្រាប់ដល់ដាវីឌជាអ្នកបម្រើរបស់យើងថា៖ «ព្រះអម្ចាស់នៃពិភពទាំងមូល ព្រះអង្គមានបន្ទូលដូចតទៅ យើងបានជ្រើសរើសអ្នកចេញពីជីវិតជាអ្នកគង្វាល
ដើម្បីតាំងឲ្យធ្វើជាអ្នកដឹកនាំលើប្រជារាស្ត្ររបស់យើង។[8]យើងបាននៅជាមួយអ្នកនៅគ្រប់ទីកន្លែងដែលអ្នកទៅ
ហើយបានកម្ចាត់អស់ទាំងខ្មាំងសត្រូវរបស់អ្នកពីមុខអ្នកចេញ ហើយយើងនឹងធ្វើឲ្យកេរ្តិ៍ឈ្មោះអ្នកល្បីល្បាញ ដូចរីរជនដែលល្បីនៅលើផែនដីដែរ។
[9]យើងបានប្រគល់ស្រុកមួយឲ្យអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើង យើងឲ្យគេតាំងទីលំនៅជាប់លាប់រហូត ឥតមាននរណាមកយាយីពួកគេទៀតឡើយ។ គ្មានជាតិ
សាសន៍ដ៏ទុច្ចរិតណាមកសង្កត់សង្កិនលើពួកគេ ដូចមុនទៀតឡើយ[10]គឺដូចកាលពីមុន នៅគ្រាដែលយើងតែងតាំងពួកចៅហ្វាយឲ្យគ្រប់គ្រងលើអ៊ីស្រាអែល ជាប្រជារាស្ត្រ
របស់យើង។ យើងនឹងបង្ក្រាបខ្មាំងសត្រូវទាំងប៉ុន្មាន ឲ្យស្ថិតនៅក្រោមអំណាចរបស់អ្នក។ យើងប្រកាសឲ្យអ្នកដឹងថា យើងនឹងប្រទានឲ្យអ្នកមានសន្តតិវង្សមួយផង។
[11]នឹងមានពេលមកដល់ គឺនៅពេលណាអ្នកលាចាកលោកនេះទៅជួបជុំជាមួយពួកបុព្វបុរសរបស់អ្នក នោះយើងនឹងឲ្យពូជពង្សរបស់អ្នកស្នងរាជ្យបន្ត
ហើយយើងនឹងធ្វើឲ្យរាជ្យរបស់គេរឹងមាំ។[12]គឺបុត្រនោះហើយដែលនឹងសង់ដំណាក់ឲ្យយើង ហើយយើងនឹងធ្វើឲ្យរាជ្យសម្បត្តិរបស់គេស្ថិតស្ថេរហូតទៅ។
[13]យើងនឹងធ្វើជាឪពុករបស់គេ ហើយគេនឹងបានជាកូនរបស់យើង។ យើងនឹងមិនដកសម្ពន្ធមេត្រីនេះចេញពីគេ ដូចដែលយើងបានដកចេញសូល
ជាស្តេចដែលគ្រងរាជមុនអ្នកនោះឡើយ។[14]យើងនឹងតាំងគេឲ្យគ្រប់គ្រងលើដំណាក់របស់យើង និងនៅនគររបស់យើងរហូតទៅ
ហើយរាជសម្បត្តិរបស់គេនឹងស្ថិតស្ថេរនៅរហូតទៅ»។[15]លោកណាថានក៏ទូលដល់ព្រះបាទដាវីឌគ្រប់សេចក្តីទាំងនោះ
ដែលព្រះអម្ចាស់បានប្រាប់ដល់លោកក្នុងសុបិននិមិត្តនោះ។
[16]ព្រះបាទដាវីឌក៏យាងចូលទៅគាល់ព្រះអម្ចាស់ ហើយទូលថា៖ «ឱព្រះអម្ចាស់អើយ!
តើទូលបង្គំនឹងគ្រួសារទូលបង្គំជាអ្វីបានជាព្រះអង្គប្រោសប្រទានដល់ទូលបង្គំបែបនេះ?[17]ឱព្រះអម្ចាស់អើយ នៅចំពោះព្រះអង្គ នេះគ្រាន់តែជាការតូចមួយប៉ុណ្ណោះ។
ព្រះអង្គអើយ ព្រះអង្គបានមានបន្ទូលសន្យាដល់កូនចៅជំនាន់ក្រោយៗរបស់ទូលបង្គំដែរ ព្រះអង្គបានយកព្រះទ័យទុកដាក់នឹងទូលបង្គំ។
[18]តើទូលបង្គំអាចថ្វាយអ្វីដល់ព្រះអង្គ? ដ្បិត ព្រះអង្គបានយកព្រះទ័យទុកដាក់ចំពោះអ្នកបម្រើរបស់ព្រះអង្គ
ហើយបានផ្តល់កិត្តិយសយ៉ាងធំធេងដល់ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ។
[19]ឱព្រះអម្ចាស់អើយ ដោយយល់ដល់អ្នកបម្រើរបស់ព្រះអង្គ ហើយសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គ
ព្រះអង្គបានសម្តែងការអស្ចារ្យនេះជាស្នាព្រះហស្តដ៏អស្ចារ្យដែលព្រះអង្គបានធ្វើ។[20]ឱព្រះអម្ចាស់អើយ គ្មានព្រះណាដូចព្រះអង្គទេ
ហើយគ្មានព្រះឯណាទៀតដូចដែលយើងធ្លាប់បានឮនោះទេ។
[21]តើប្រជាជាតិមួយណានៅលើផែនដីដូចប្រជាជាតិអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គដែលព្រះអង្គជាព្រះបានរំដោះពីស្រុកអេស៊ីបឲ្យធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ដើម្បីសំដែងកេរ្តិ៍ឈ្មោ
និងគួរឲ្យស្ញែងខ្លាច? ព្រះអង្គបានបណ្តេញប្រជាជាតិនានាចេញពីមុខប្រជារាស្ត្ររបស់ព្រះអង្គដែលព្រះអង្គបានរំដោះពីស្រុកអេស៊ីបមក។
[22]ព្រះអង្គបានធ្វើឲ្យអ៊ីស្រាអែលក្លាយជាប្រជារាស្ត្ររបស់ព្រះអង្គរហូតតទៅហើយព្រះអង្គក៏បានជាព្រះរបស់គេដែរ។[23]បពិត្រព្រះអម្ចាស់ឥឡូវនេះ
សូមសម្រេចតាមព្រះបន្ទូលដែលព្រះអង្គបានសន្យាជាមួយទូលបង្គំ និងក្រុមគ្រួសាររបស់ទូលបង្គំជាអ្នកបម្រើព្រះអង្គរហូតតទៅ។
សូមសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គចុះ។[24]សូមឲ្យព្រះនាមរបស់ព្រះអង្គបានស្ថិតស្ថេររហូតតទៅ សូមឲ្យប្រជាជនបាននិយាយថា៖
«ព្រះអម្ចាស់នៃពិភពទាំងមូលជាព្រះនៃជនជាតិអ៊ីស្រាអែល»។ សូមប្រោសប្រទានឲ្យគ្រួសារដាវីឌជាអ្នកបម្រើរបស់ព្រះអង្គបានស្ថិតស្ថេរចំពោះព្រះអង្គជារៀងរហូតទៅ!។
[25]ដ្បិត ព្រះអង្គជាព្រះរបស់ទូលបង្គំព្រះអង្គបានបង្ហាញឲ្យទូលបង្គំដឹងថាព្រះអង្គនឹងចម្រើនពូជពង្សទូលបង្គំ។
ហេតុនេះហើយបានជាទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គមានចិត្តក្លាហានអធិស្ឋានដល់ព្រះអង្គ។[26]បពិត្រព្រះអម្ចាស់!
ឥឡូវនេះព្រះអង្គជាព្រះដែលបានសន្យាយ៉ាងល្អប្រពៃជាមួយអ្នកបម្រើរបស់ព្រះអង្គ។[27]ឥឡូវនេះ
ព្រះអង្គសព្វព្រះហឫទ័យប្រទានពរដល់ក្រុមគ្រួសាររបស់ទូលបង្គំឲ្យនៅស្ថិតស្ថេររហូតតទៅ។ ឱព្រះអម្ចាស់អើយ
ព្រះអង្គបានប្រទានពរហើយព្រះអង្គនឹងប្រទានពររហូតតទៅ»។

generated on Wed Sep 10 16:16:32 2025

1 Chronicles 17:1
គង់នៅ
ប្រកបដោយផាសុកភាព និងភាពរីករាយ ដោយគ្មានបំណងដកចេញ ឬផ្លាស់ប្តូរ។
ក្នុងដំណាក់ធ្វើពីឈើតាត្រៅ
គេចាត់ទុកដើមឈើតាត្រៅថា ជាដើមឈើល្អបំផុតសម្រាប់សាងសង់។
សូមព្រះករុណាធ្វើអ្វីដែលព្រះករុណាសព្វព្រះទ័យនឹងធ្វើចុះ
ព្រះបាទដាវីឌសំដៅទៅលើផ្នែកនៃរាងកាយ ដែលទាក់ទងជាមួយសតិអារម្មណ៍។ ការបកប្រែផ្សេងទៀត «ធ្វើអ្វីដែលអ្នកចង់ធ្វើ»។
ព្រះជាម្ចាស់គង់នៅជាមួយព្រះករុណាហើយ!
យល់ស្របជាមួយព្រះជាម្ចាស់ គឺប្រៀបដូចជាធ្វើការជាមួយព្រះអង្គដែរ ពីព្រោះព្រះជាម្ចាស់នឹងជួយអ្នកឲ្យទទួលជោគជ័យ។ ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់យល់ស្របនឹងអ្វីដែលអ្នកចង់ធ្វើ»
1 Chronicles 17:3
ព្រះអម្ចាស់បានមានបន្ទូលមក
«ព្រះអម្ចាស់មានបន្ទូល»
យើងបាននាំជនជាតិអ៊ីស្រាអែល
ការបកប្រែផ្សេងទៀត «យើងបាននាំជនជាតិអ៊ីស្រាអែលទៅទឹកដីសន្យា ចេញពីស្រុកអេស៊ីប»
ក្នុងជំរំ និងព្រះពន្លា
ទាំងពាក្យ «ជំរុំ» និង«ព្រះពន្លា» ពិពណ៌នាដូចគ្នានិងបញ្ជាក់ថា ព្រះអង្គធ្លាប់រស់នៅកន្លែង ដែលមិនមែនជាអគារជារៀងរហូត។
ហេតុអ្វីបានជាអ្នកមិនសង់ដំណាក់ពីឈើតាត្រៅសម្រាប់យើង?
ការបកប្រែផ្សេងទៀត «អ្នកគួរតែសង់ព្រះដំណាក់ឲ្យយើងពីឈើថ្លៃៗ។»
1 Chronicles 17:7
យើងបានជ្រើសរើសអ្នកចេញពីជីវិតជាអ្នកគង្វាល
ការងាររបស់ដាវីឌក្នុងនាមជាគង្វាលម្នាក់សំដៅទៅលើកន្លែង ដែលលោកមើលថែហ្វូងចៀម។ ការបកប្រែផ្សេងទៀត «យើងបានយកអ្នកចេញពីការងាររបស់អ្នកជាគង្វាល»
វាលស្មៅ
សូមមើលការបកប្រែពាក្យនេះនៅក្នុង ៤:៣៩។
1 Chronicles 17:9
ព័ត៌មានទូទៅ៖
ព្រះជាម្ចាស់បន្តមានព្រះបន្ទូល ដែលលោកណាថានមានបំណងផ្តល់ឲ្យព្រះបាទដាវីឌ។
ឲ្យគេតាំងទីលំនៅជាប់លាប់រហូត
ព្រះជាម្ចាស់សំដៅទៅលើការដាក់ជនជាតិអ៊ីស្រាអែល នៅលើទឹកដីសន្យា ដូចជារុក្ខជាតិដែលព្រះអង្គបានដាំនៅក្នុងដី។ ការបកប្រែផ្សេងទៀត «យើងនឹងតាំងទីលំនៅពួកគេនៅទីនោះ»
នៅគ្រាដែលយើងតែងតាំង
រយៈពេលមួយ ដែលសំដៅទៅលើជំនាន់ជាច្រើននៅគ្រានោះ។ ការបកប្រែផ្សេងទៀត «នៅពេលយើងតែតាំង» ឬ «ពីជំនាន់ដែលយើងបានតែងតាំង»
ឲ្យគ្រប់គ្រងលើអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើង។
ធ្វើជាអ្នកមានសិទ្ធិអំណាច គឺសំដៅលើការគ្រប់គ្រងលើនរណាម្នាក់។ ការបកប្រែផ្សេងទៀត «បញ្ជាប្រជាជនអ៊ីស្រាអែលរបស់យើង»
បង្ក្រាបខ្មាំងសត្រូវទាំងប៉ុន្មាន...យើងប្រកាសឲ្យអ្នកដឹងថា
ពាក្យ «របស់អ្នក» និង «អ្នក» សំដៅទៅលើព្រះបាទដាវីឌ។
បង្ក្រាប
ធ្វើឲ្យមនុស្ស ឬសត្វមិនអាចវាយប្រហារបាន។
នឹងប្រទានឲ្យអ្នកមានសន្ដតិវង្សមួយផង។
ព្រះអម្ចាស់ប្រទានឲ្យព្រះបាទដាវីឌមានកូនចៅជាច្រើនដំណាក ដើម្បីគ្រប់គ្រងលើអ៊ីស្រាអែល ដូចជាកសាងព្រះដំណាក់មួយ។
1 Chronicles 17:11
គឺនៅពេលណាអ្នកលាចាកលោកនេះ
ជីវិតសំដៅទៅលើចំនួនថ្ងៃជាក់លាក់។ ការបកប្រែផ្សេងទៀត «នៅពេលអ្នកស្លាប់» (សូមមើល
ព័ត៌មានទូទៅ៖
ទៅជួបជុំជាមួយពួកបុព្វបុរស
ឃ្លានេះសំដៅទៅលើសេចក្ដីស្លាប់ ជាកន្លែងដែលបុព្វបុរសរបស់ព្រះបាទដាវីឌបានសុគត ព្រោះពួកគេបានស្លាប់ទៅហើយ។
យើងនឹងឲ្យពូជពង្សរបស់អ្នកស្នងរាជ្យបន្ត
ដើម្បីដាក់នរណាម្នាក់ឲ្យធ្វើជាអ្នកដឹកនាំ ត្រូវគេហៅថា ជាការលើកពួកគេឲ្យខ្ពស់ជាងមុន។
យើងនឹងធ្វើឲ្យរាជ្យសម្បត្តិរបស់គេ
សិទ្ធិគ្រប់គ្រងជាស្តេចត្រូវបានពិពណ៌នា នៅកន្លែងព្រះរាជាគង់នៅ។
1 Chronicles 17:13
ហើយរាជសម្បត្តិរបស់គេ
សិទ្ធិគ្រប់គ្រងរបស់ព្រះរាជា សំដៅទៅលើកន្លែងដែលព្រះរាជាគង់នៅ។ ការបកប្រែផ្សេងទៀត «និងសិទ្ធិគ្រប់គ្រងរបស់លោក»
ក៏ទូលដល់ព្រះបាទដាវីឌ
«បានទូលព្រះបាទដាវីឌ»
1 Chronicles 17:16
ព្រះបាទដាវីឌក៏យាងចូលទៅគាល់
«ព្រះបាទដាវីឌមានបន្ទូល»
ឱព្រះអម្ចាស់អើយ!
តើទូលបង្គំនឹងគ្រួសារទូលបង្គំជាអ្វីបានជាព្រះអង្គប្រោសប្រទានដល់ទូលបង្គំបែបនេះ?
ព្រះបាទដាវីឌសួរសំណួរនេះ ដើម្បីបង្ហាញការដឹងគុណដែលព្រះជាម្ចាស់បានជ្រើសរើស និងប្រទានពរដល់ទ្រង់ទោះបីព្រះអង្គមិនសក្តិសមនឹងទទួលក៏ដោយ។
នេះគ្រាន់តែជាការតូចមួយប៉ុណ្ណោះ
អ្វីដែលមិនសំខាន់ត្រូវបានពិពណ៌នាថាតូច។
នៅចំពោះព្រះអង្គ
ការមើលឃើញរបស់ព្រះអម្ចាស់ត្រូវបានប្រើ ដើម្បីសំដៅទៅលើការយល់ដឹងរបស់ព្រះអង្គ។ ការបកប្រែផ្សេងទៀត «ទៅកាន់អ្នក»
តើទូលបង្គំអាចថ្វាយអ្វីដល់ព្រះអង្គ?
ព្រះបាទដាវីឌប្រើសំណួរនេះដើម្បីបង្ហាញថា ព្រះបាទដាវីឌមិនអាចបង្ហាញការដឹងគុណចំពោះព្រះជាម្ចាស់បានទេ។ ការបកប្រែផ្សេងទៀត «បើខ្ញុំអាចនិយាយបានច្រើនជាងនេះ ដើម្បីបង្ហាញការដឹងគុណរបស់ខ្ញុំ ពេលនោះខ្ញុំនឹង ប៉ុន្តែខ្ញុំមិនដឹងថា ត្រូវនិយាយអ្វីទៀតទេ»។
អ្នកបម្រើរបស់ព្រះអង្គ
ព្រះបាទដាវីឌបានសំដៅទៅអង្គទ្រង់ផ្ទាល់ថា ជាអ្នកបម្រើរបស់ព្រះអម្ចាស់។
ដ្បិត ព្រះអង្គបានយកព្រះទ័យទុកដាក់ចំពោះអ្នកបម្រើរបស់ព្រះអង្គ ហើយបានផ្តល់កិត្តិយសយ៉ាងធំធេងដល់ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ។
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ បើភាសារបស់អ្នកមានវិធីតែមួយគត់ដើម្បីបង្ហាញពី «កិត្តិយស» និង «ការទទួលស្គាល់» នោះអាចបកប្រែជាឃ្លាតែមួយ។
1 Chronicles 17:19
ដោយយល់ដល់អ្នកបម្រើរបស់ព្រះអង្គ
ការបកប្រែផ្សេងទៀត «ផលប្រយោជន៍របស់ទូលបង្គំ»
ព្រះអង្គបានរំដោះពីស្រុកអេស៊ីបមក
ការបកប្រែផ្សេងទៀត «បានរួចផុតពីទាសភាពនៅប្រទេសអេស៊ីប។»
ការដ៏អស្ចារ្យ និងគួរឲ្យស្ញែង
ពាក្យថា «អស្ចារ្យ» និង «គួរឲ្យស្ញែង» មានន័យថា ជារួមដូចគ្នា និងបញ្ជាក់ពីភាពអស្ចារ្យ។ ការបកប្រែផ្សេងទៀត «សកម្មភាពគួរឲ្យអស្ចារ្យណាស់»។
1 Chronicles 17:22
បានស្ថិតស្ថេររហូតតទៅ
ការបកប្រែផ្សេងទៀត «បន្តជារៀងរហូត»
1 Chronicles 17:25
នឹងចម្រើនពូជពង្សទូលបង្គំ
មានកូននិងអភិវឌ្ឍជាគ្រួសារធំមួយ ត្រូវបានគេពិពណ៌នាថា ការកសាងផ្ទះមួយ។
មានចិត្តក្លាហាន
ការបកប្រែផ្សេងទៀត «មានចិត្តក្លាហានល្មមគ្រប់គ្រាន់»
បានប្រទានពរហើយព្រះអង្គនឹងប្រទានពររហូតតទៅ
មានន័យដូចគ្នា ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់។

generated on Wed Sep 10 16:16:32 2025

18 [1]ក្រោយមក ព្រះបាទដាវីឌវាយប្រហារជនជាតិភីលីស្ទីនហើយឈ្នះពួកគេ។ ព្រះអង្គបានដណ្តើមយកក្រុងកាថ និងភូមិនានាពីតំបន់ត្រួតត្រារបស់ពួកភីលីស្ទីន។
[2]ព្រះបាទដាវីឌវាយឈ្នះជនជាតិម៉ូអាប់ហើយជនជាតិម៉ូអាប់ក៏ធ្វើជាចំណុះព្រមទាំងថ្វាយសួយអាករដល់ព្រះបាទដាវីឌដែរ។
[3]ព្រះបាទដាវីឌបានវាយឈ្នះព្រះបាទហាដាដេស៊ើរជាស្តេចស្រុកសូបា នៅតំបន់ហាម៉ាត់ នៅពេលដែលព្រះបាហាដាដេស៊ើរកំពុងទៅកាន់កាប់តំបន់ទន្លេអ៊ើប្រាត។
[4]ព្រះបាទដាវីឌចាប់បានរទេះចម្បាំងចំនួនមួយពាន់គ្រឿងទ័ពសេះប្រាំពីរពាន់នាក់និងទ័ពថ្មើរជើងចំនួនពីរម៉ឺននាក់។
ព្រះបាទដាវីឌក៏បំផ្លាញរទេះចម្បាំងព្រមសេះទាំងអស់ចោល ដោយទុកតែរទេះចម្បាំង និងសេះមួយរយក្បាលប៉ុណ្ណោះ។
[5]ពេលនោះកងទ័ពស៊ីរីនៅក្រុងដាម៉ាសក៏ចូលមកជួយព្រះបាទហាដាដេស៊ើរជាស្តេចស្រុកសូបា ព្រះបាទដាវីឌក៏ច្បាំងឈ្នះហើយបានសម្លាប់ជនជាតិស៊ីរីអស់ចំនួន ២២,
000 នាក់។[6]ព្រះបាទដាវីឌដាក់ពលទាហាននៅស្រុកស៊ីរីនៅក្រុងដាម៉ាស។ កងទ័ពស៊ីរីបានធ្វើជាចំណុះព្រះបាទដាវីឌ ព្រមទាំងថ្វាយសួយអាករដល់ព្រះបាទដាវីឌដែរ។
ព្រះអម្ចាស់ប្រទានឲ្យព្រះបាទដាវីឌមានជ័យជម្នះនៅគ្រប់កន្លែងដែលស្តេចទៅ។
[7]ព្រះបាទដាវីឌយកខែលមាសពីពួកអ្នកបម្រើរបស់ព្រះបាទហាដាដេស៊ើរហើយនាំយកមកក្រុងយេរូសាឡិម។[8]ពីក្រុងទីហាតនិងក្រុងគូន ជាទីក្រុងរបស់ព្រះហាដាដេស៊ើរ
ព្រះបាទដាវីឌបានយកលង្ហិនយ៉ាងច្រើន។ ក្រោយមកព្រះបាទសាឡូម៉ូបានយកលង្ហិននេះសិតធ្វើសមុទ្រលង្ហិន សសរសង្ហិន
ព្រមទាំងសម្ភារលង្ហិនផ្សេងៗទៀតក្នុងព្រះវិហារ។
[9]ពេលព្រះបាទតូយជាស្តេចស្រុកហាម៉ាត់បានឮដំណឹងថា ព្រះបាទដាវីឌបានវាយឈ្នះកងទ័ពទាំងប៉ុន្មានរបស់ព្រះបាទហាដាដេស៊ើរជាស្តេចស្រុកសូបា។
[10]ព្រះបាទតូយបានចាត់ព្រះរាជបុត្រព្រះនាមហាដូរ៉ាមទៅគាល់ព្រះដាវីឌ និងថ្វាយសួយអាករ ពីព្រោះព្រះបាទដាវីឌបានធ្វើសង្គ្រាមឈ្នះព្រះបាទហាដាដេស៊ើរ
ពីព្រោះព្រះបាទហាដាដេស៊ើរតែងតែធ្វើសង្គ្រាមប្រឆាំងនឹងព្រះបាទតូយ។ ហាដូរ៉ាមបាននាំយកមាសប្រាក់និងលង្ហិនមកជាមួយ ដើម្បីថ្វាយស្តេចដាវីឌ។
[11]ស្តេចដាវីឌញែកវត្ថុទាំងនេះទុកជាចំណែកថ្វាយព្រះអម្ចាស់រួមជាមួយមាសប្រាក់ដែលស្តេចបានរឹបអូសយកពីប្រជាជាតិទាំងអស់គឺអេដុម ម៉ូអាប់ ប្រជាជនអាំម៉ូន
ជនជាតិភីលីស្ទីននិងជនជាតិអាម៉ាលេក។
[12]លោកអប៊ីសាយជាកូនរបស់សេរូយ៉ាបានសម្លាប់ជនជាតិអេដុមចំនួន១៨, ០០០ នាក់នៅជ្រលងភ្នំអំបិល។[13]គាត់បានចាត់ឲ្យមានពលទាហាននៅត្រួតលើស្រុកអេដុម
ហើយជនជាតិអេដុមទាំងអស់សុទ្ធតែចុះចូលបម្រើព្រះបាទដាវីឌ។ ព្រះអម្ចាស់ប្រទានឲ្យដាវីឌមានជ័យជម្នះនៅគ្រប់កន្លែងដែលស្តេចទៅ។
[14]ព្រះបាទដាវីឌសោយរាជ្យលើជនជាតិអ៊ីស្រាអែលទាំងមូលហើយស្តេចគ្រប់គ្រងដោយសុចរិត និងយុត្តិធម៌ដល់ប្រជាជនទាំងអស់។
[15]លោកយ៉ូអាប់ជាកូនរបស់សេរូយ៉ាជាមេបញ្ជាការកងទ័ពហើយលោកសាផាតជាកូនរបស់លោកអហ៊ីឡូដជាអ្នកកត់ត្រា។
[16]លោកសាដុកជាកូនរបស់លោកអហ៊ីទូបនិងលោកអហ៊ីម៉ាឡេកជាកូនរបស់លោកអបៀថើរសុទ្ធតែជាបូជាចារ្យហើយលោកសាវសាជាស្មៀន។
[17]លោកបេណាយ៉ាជាកូនរបស់លោកយេហូយ៉ាដាបានគ្រប់គ្រងលើជនជាតិកេរេធីតនិងពេលេត រីឯបុត្រារបស់ព្រះបាទដាវីឌជាទីប្រឹក្សារបស់ស្តេច។

---

1 Chronicles 18:1
ក្រោយមក
«បន្ទាប់ពីការសន្យារបស់ព្រះជាម្ចាស់ ដែលថានឹងប្រទានពរដល់ព្រះបាទដាវីឌ»
1 Chronicles 18:3
ព្រះបាទហាដាដេស៊ើរ
នេះជាឈ្មោះបុរស។
សូបា
នេះជាឈ្មោះប្រទេសមួយ។
រទេះចម្បាំង
រទេះ ១000 គ្រឿង
ទ័ពសេះប្រាំពីរពាន់នាក់
ទាំងនេះជាទាហានដែលជិះសេះ។ «អ្នកជិះសេះ ៧.000 នាក់»
ទ័ពថ្មើរជើងចំនួនពីរម៉ឺននាក់
ទាំងនេះជាទាហានដែលបានដើរ។ «ទាហានថ្មើរជើង ២០.000នាក់»
បំផ្លាញ
ធ្វើឲ្យមនុស្ស ឬសត្វពិការដោយកាត់សាច់ដុំសរសៃពួរនៅផ្នែកខាងក្រោយភ្លៅ។
ដោយទុក
ដើម្បីរក្សាទុកសម្រាប់ការប្រើប្រាស់ពិសេស
រទេះចម្បាំង
«រទេះ ១00»
1 Chronicles 18:5
បានសម្លាប់ជនជាតិស៊ីរីអស់ចំនួន ២២,000 នាក់។
ពីរពាន់ «សម្លាប់ ២២.000 នាក់»។
ដាក់ពលទាហាន
ក្រុមទាហានដែលបានចាត់ឲ្យទៅតំបន់ជាក់លាក់មួយ។
1 Chronicles 18:7
ព្រះបាទហាដាដេស៊ើរ
សូមមើលការបកប្រែឈ្មោះនៅក្នុង ១៨:៣។
ក្រុងទីហាត ... ក្រុងគូន
ទាំងនេះជាឈ្មោះរបស់ទីក្រុង។
សមុទ្រលង្ហិន
នេះជាចានសំរឹទ្ធធំមួយ ដែលមានមុខកាត់ប្រហែល៥ម៉ែត្រ
ដែលត្រូវបានរក្សាទុកនៅក្នុងព្រះវិហារសម្រាប់ធ្វើពិធីលាងជម្រះ។
1 Chronicles 18:9
ព្រះបាទតូយ... ព្រះនាមហាដូរ៉ាម
ទាំងនេះជាឈ្មោះបុរស។
ធ្វើសង្គ្រាមប្រឆាំង
«បានធ្វើសង្គ្រាមជាមួយ»
1 Chronicles 18:12
លោកអប៊ីសាយ ..សេរូយ៉ា
ទាំងនេះជាឈ្មោះបុរស។ (សូមមើល
ជនជាតិអេដុមចំនួន១៨,000 នាក់
«អេដុម១៨.000នាក់»
នៅជ្រលងភ្នំអំបិល
នេះជាឈ្មោះជ្រលងភ្នំរវាងអេដុម និងស្រុកយូដាដែលធ្លាប់ជាសមរភូមិប្រយុទ្ធ។
ពលទាហាន
ក្រុមទាហានដែលបានចាត់ឲ្យទៅតំបន់ពិសេសមួយ។
ជនជាតិអេដុមទាំងអស់សុទ្ធតែចុះចូលបម្រើព្រះបាទដាវីឌ។
ប្រជាជនអេដុមត្រូវបានបង្ខំឲ្យទទួលយកព្រះបាទដាវីឌធ្វើជាស្តេចរបស់ពួកគេ
និងបង់សួយសារអាករថ្វាយព្រះបាទដាវីឌជារៀងរាល់ឆ្នាំ។
1 Chronicles 18:14
សេរូយ៉ា ... លោកអហ៊ីទូប ... លោកអហ៊ីទូប ... លោកអបៀថើរ ... លោកសាវសា ...
លោកបេណាយ៉ា ... លោកយេហូយ៉ាដា
ទាំងនេះជាឈ្មោះបុរស។
អ្នកកត់ត្រា
មនុស្សដែលសរសេរព័ត៌មានលម្អិតនៃព្រឹត្តិការណ៍ពិសេស។
លោកអហ៊ីម៉ាឡេក
ការប្រកបអក្សរនេះតំណាងឲ្យការកែអក្ខរាវិរុទ្ធ «អប៊ីម៉ាឡេក»
ការបកប្រែខ្លះធ្វើតាម។ អក្ខរាវិរុទ្ធដែលបានកែតម្រូវធ្វើឲ្យខគម្ពីរនេះស្របនឹង
៨:១៥។
លោកសាដុកជាកូនរបស់លោកអហ៊ីទូបនិងលោកអហ៊ីម៉ាឡេកជាកូនរបស់លោកអបៀថើរសុទ្ធតែជាបូជាចារ្យ
ការបកប្រែខ្លះកែរឿងនេះ ដើម្បីនិយាយថា
លោកអហ៊ីទូបនិងអ័ហ៊ីម៉ាឡេកជាបូជាចារ្យជាន់ខ្ពស់។
ជនជាតិកេរេធីត ... ពេលេត
ទាំងនេះជាឈ្មោះក្រុមមនុស្ស។

19

generated on Wed Sep 10 16:16:32 2025

[1]ក្រោយមកព្រះបាទណាហាសជាស្តេចរបស់ប្រជាជនអាំម៉ូនបានសោយទិវង្គតហើយព្រះរាជបុត្របានឡើងស្នងរាជ្យ។[2]ព្រះបាទដាវីឌមានរាជឱង្ការថា៖
«ខ្ញុំនឹងបង្ហាញចិត្តសប្បុរសចំពោះព្រះបាទហាណូនជាបុត្រណាហាស ព្រោះបិតារបស់ព្រះអង្គបានសម្តែងសេចក្តីសប្បុរសចំពោះខ្ញុំ»។
ព្រះបាទដាវីឌចាត់អ្នកនាំសារឲ្យទៅលួងលោម និងសម្រាលទុក្ខព្រះបាទហាណូន។
ពួកមន្ត្រីរបស់ស្តេចដាវីឌចូលទៅក្នុងទឹកដីរបស់ជនជាតិអាំម៉ូនហើយបានទៅគាល់ព្រះបាទហាណូន ដើម្បីសម្រាលទុក្ខព្រះអង្គ។[3]ប៉ុន្តែ
ពួកមេដឹកនាំជនជាតិអាំម៉ូនមានប្រសាសន៍ទៅកាន់ហាណូនថា៖ «តើព្រះអង្គគិតថាស្តេចដាវីឌបញ្ជូនអ្នកនាំសារមកដោយព្រោះគោរពដល់បិតារបស់ព្រះអង្គឬអី?
តើពួកអ្នកបម្រើរបស់ដាវីឌមិនមែនមកសង្កេតការណ៍ និងពិនិត្យមើលស្រុកក្នុងបំណងវាយដណ្តើមយកទេឬអី?»
[4]ព្រះបាទហាណូនចាប់ពួករាជបម្រើរបស់ព្រះបាទដាវីឌកោរសក់ និងកាត់សម្លៀកបំពាក់ចេញត្រឹមគូថរួចបញ្ជូនឲ្យពួកគេចេញទៅ។
[5]កាលពួកគេរៀបរាប់អំពីហេតុការណ៍ទាំងនោះទូលដល់ព្រះបាទដាវីឌ ព្រះអង្គក៏ចាត់មនុស្សឲ្យ ទៅជួបពួកគេ ដ្បិត ពួកគេមានការអាម៉ាស់យ៉ាងខ្លាំង។
ព្រះរាជាមានរាជឱង្ការថា៖ «ចូរស្នាក់នៅក្រុងយេរីខូររហូតទាល់តែពុកមាត់របស់អ្នកដុះមកវិញ បន្ទាប់មកចាំអ្នកវិលត្រឡប់មកវិញ»។
[6]ពេលជនជាតិអាំម៉ូនឃើញថាពួកគេបានធ្វើឲ្យព្រះបាទដាវីឌក្រេវក្រោធ ពេលនោះព្រះបាទហាណូន និងជនជាតិអាំម៉ូនបានយកប្រាក់មួយពាន់ហាបទៅជួលរទេះចំបាំង
និងទ័ពសេះរបស់កងទ័ពស៊ីរីពីស្រុកណាហារ៉ាម ស្រុកម៉ាកា និងស្រុកសូបា។[7]ពួកគេបានជួលរទេះចំបាំងចំនួន៣២, ០០០គ្រឿង ព្រមទាំងស្តេចស្រុកម៉ាកា
និងពលទ័ពរបស់ព្រះអង្គបានមកបោះទ័ពនៅទល់មុខមេឌីបា។ ជនជាតិអាំម៉ូនក៏បានប្រមូលផ្តុំគ្នាពីក្រុងរបស់ពួកគេហើយចេញមកច្បាំង និងពួកអ៊ីស្រាអែល។
[8]កាលព្រះបាទដាវីឌជ្រាបដំណឹងនេះ ព្រះអង្គក៏ចាត់លោកយ៉ូអាប់ និងកងទ័ពទាំងមូលឲ្យទៅច្បាំងជាមួយពួកគេ។[9]ប្រជាជនអាំម៉ូនចេញមកតម្រង់ជួរនៅមាត់ទ្វារក្រុង
រីឯស្តេចបានចេញមកនៅឯវាលតែម្នាក់ឯង។
[10]កាលលោកយ៉ូអាប់បានឃើញសមរភូមិនៅព័ទ្ធជុំវិញលោកទាំងនៅខាងមុខ និងខាងក្រោយ
លោកបានជ្រើសរើសអ្នកប្រយុទ្ធដ៏ពូកែៗរបស់ជនជាតិអ៊ីស្រាអែលហើយរៀបចំពួកគេឲ្យទៅច្បាំងនឹងជនជាតិស៊ីរី។
[11]រីឯកងទ័ពដែលនៅសល់លោកប្រគល់ទៅក្រោមការបញ្ជារបស់លោកអប៊ីសាយជាប្អូន លោកក៏ដាក់ពួកគេចូលទៅក្នុងជួរទ័ព ដើម្បីប្រយុទ្ធនឹងកងទ័ពអាំម៉ូន។
[12]លោកយ៉ូអាប់មានប្រសាសន៍ទៅលោកអប៊ីសាយជាប្អូនថា៖ «បើពួកស៊ីរីខ្លាំងជាងយើង ដូច្នេះអប៊ីសាយឯងត្រូវតែជួយសង្គ្រោះយើងផង។ ប៉ុន្តែ
បើកងទ័ពអាំម៉ូនខ្លាំងជាងឯងនោះ យើងនឹងមកជួយឯងវិញ។[13]ចូរមានកម្លាំងដើម្បីប្រជាជនរបស់យើង និងក្រុងនានានៃព្រះរបស់យើង ដ្បិត
ព្រះអម្ចាស់នឹងធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះអង្គ»។
[14]ដូច្នេះ លោកយ៉ូអាប់ និងពលទាហានរបស់គាត់បានលើកទ័ពទៅច្បាំងនឹងកងទ័ពស៊ីរី ហើយទ័ពស៊ីរីត្រូវបាក់ទ័ពរត់នៅចំពោះមុខកងទ័ពអ៊ីស្រាអែល។
[15]ពេលកងទ័ពអាំម៉ូនឃើញថាជនជាតិស៊ីរីបានបាក់ទ័ពនៅមុខយ៉ូអាប់ ហើយរត់ភៀសខ្លួន
នោះពួកគេក៏ភៀសខ្លួនចេញពីអប៊ីសាយជាប្អូនរបស់យ៉ូអាប់ហើយវិលត្រឡប់ទៅទីក្រុងរបស់គេវិញ។ ពេលនោះលោកយ៉ូអាប់ក៏វិលពីអាំម៉ូនត្រឡប់ទៅក្រុងយេរូសាឡឹមវិញ។
[16]នៅពេលដែលពួកស៊ីរីបានឃើញថាពួកគេកំពុងចាញ់អ៊ីស្រាអែល
ពួកគេបានសុំទ័ពពីខាងនាយទន្លេអើប្រាតដោយមានស្តេចសូផាកជាមេទ័ពរបស់ព្រះបាទហាដាដេស៊ើរ។
[17]មានគេនាំដំណឹងនេះទៅទូលព្រះបាទដាវីឌស្តេចក៏ប្រមូលកងទ័ពអ៊ីស្រាអែលទាំងមូលឆ្លងទន្លេយ័រដាន់ចូលមករកពួកគេ។
ស្តេចបានរៀបចំកងទ័ពឲ្យច្បាំងនឹងកងទ័ពស៊ីរី។
[18]កងទ័ពស៊ីរីបានបាក់ទ័ពរត់គេចពីអ៊ីស្រាអែល ហើយព្រះបាទដាវីឌបានសម្លាប់ពលទ័ពរទេះចម្បាំងរបស់កងទ័ពស៊ីរីចំនួនជ្រាំពីរពាន់នាក់
និងពលទាហានថ្មើរជើងចំនួនបួនម៉ឺននាក់។ ព្រះអង្គក៏បានសម្លាប់លោកសូផាក់ដែលជាមេបញ្ជាការកងទ័ពផងដែរ។
[19]ពេលស្តេចទាំងប៉ុន្មានដែលធ្វើជាចំណុះរបស់ព្រះបាទហាដាដេស៊ើរឃើញថា ព្រះអង្គបានចាញ់ស្តេចអ៊ីស្រាអែល នោះពួកគេក៏មកចងសន្តិភាព និងចំណុះព្រះបាទដាវីឌ។
ដូច្នេះប្រជាជនស្រុកស៊ីរីលែងចង់ជួយជនជាតិអាំម៉ូនទៀតហើយ។

---

1 Chronicles 19:1

ណាហាស ... ព្រះបាទហាណូន

ទាំងនេះជាឈ្មោះបុរស។

ខ្ញុំនឹងបង្ហាញចិត្តសប្បុរស ... ចិត្តសប្បុរសចំពោះ

ការបកប្រែផ្សេងទៀត «ខ្ញុំមានចិត្តល្អ ... គឺចិត្តល្អ»

សម្រាលទុក្ខ

«កម្សាន្តចិត្ត»

តើព្រះអង្គគិតថាស្តេចដាវីឌបញ្ជូនអ្នកនាំសារមកដោយព្រោះគោរពដល់បិតារបស់ព្រះអង្គឬអី?

ការបកប្រែផ្សេងទៀត «អ្នកមិនគួរគិតថាព្រះបាទដាវីឌគោរពឪពុករបស់អ្នកទេ
ព្រោះលោកបានចាត់មនុស្សឲ្យមកសម្រាលទុក្ខអ្នក»។

តើពួកអ្នកបម្រើរបស់ដាវីឌមិនមែនមកសង្កេតការណ៍
និងពិនិត្យមើលស្រុកក្នុងបំណងវាយដណ្តើមយកទេឬអី?

ការបកប្រែផ្សេងទៀត «ប្រាកដណាស់អ្នកបម្រើរបស់ព្រះអង្គមករកអ្នក
ដើម្បីសង្កេតមើលស្រុកដើម្បីដណ្តើមយក។

1 Chronicles 19:4

សម្លៀកបំពាក់

«សម្លៀកបំពាក់»

ព្រះអង្គក៏ចាត់មនុស្សឲ្យ ទៅជួបពួកគេ

«ទ្រង់បានបញ្ជូនអ្នកនាំសារមួយចំនួន ដើម្បីលើកទឹកចិត្តពួកគេ»

អាម៉ាស់យ៉ាងខ្លាំង

ការអាម៉ាសត្រូវបានពិពណ៌នាថា បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ពួកគេ។

ការបកប្រែផ្សេងទៀត «អាម៉ាសខ្លាំងណាស់»

1 Chronicles 19:6

បានធ្វើឲ្យព្រះបាទដាវីឌក្រេវក្រោធ

ពាក្យថា «ក្លិនស្អុយ» សំដៅលើក្លិនមិនល្អ។ ត្រូវគេពិពណ៌នាដូចជាជនជាតិអាំម៉ូន
ប្រៀបបាននឹងអ្វីមួយដែលមិនរីករាយ និងមិនចង់បាន។

ប្រាក់មួយពាន់ហាប

«ប្រាក់ ១០០០ហាប»

ហាប

ណាហារ៉ាម ...ម៉ាកា ... សូបា... មេឌីបា

ទាំងនេះជាឈ្មោះទីក្រុង។

1 Chronicles 19:8

ជ្រាបដំណឹងនេះ

«បានឮថា ពួកអាំម៉ូនចេញមកធ្វើសង្គ្រាម»

ច្បាំងជាមួយពួកគេ

«ដើម្បីប្រយុទ្ធប្រឆាំងនឹងពួកគេ»

1 Chronicles 19:10

លោកអប៊ីសាយ

នេះជាឈ្មោះបងប្រុសរបស់លោកយ៉ូអាប់។

1 Chronicles 19:12

ចូរមានកម្លាំង

«ចូរក្លាហានឡើង»

ដើម្បីប្រជាជនរបស់យើង

ការបកប្រែផ្សេងទៀត «ចូរយើងប្រព្រឹត្តដោយក្លាហាន»។

1 Chronicles 19:14

បានលើកទ័ពទៅច្បាំង

ការបកប្រែផ្សេងទៀត «បានផ្លាស់ទីឆ្ពោះទៅសមរភូមិ» ឬ
«បានចូលទៅជិតទាហានសត្រូវនៅក្នុងសមរភូមិ»

1 Chronicles 19:16

ពួកស៊ីរីបានឃើញ

«ពួកស៊ីរីយល់»

បានសុំទ័ព

generated on Wed Sep 10 16:16:32 2025

«ទាហានច្រើនទៀត»
ស្តេចសូផាក ... ព្រះបាទហាដាដេស៊ើរ
ទាំងនេះជាឈ្មោះបុរស។
មានគេនាំដំណឹងនេះទៅទូលព្រះបាទដាវីឌ
ការបកប្រែផ្សេងទៀត
«នៅពេលអ្នកនាំសាររបស់គាត់បានប្រាប់ស្តេចដាវីឌអំពីរឿងនេះ
បានរៀបចំកងទ័ព
«បានរៀបចំ»
ឲ្យច្បាំង
«ពួកស៊ីរីបានប្រយុទ្ធនឹងព្រះបាទដាវីឌ និងទាហានព្រះអង្គ»។
1 Chronicles 19:18
បានសម្លាប់កងទ័ពចម្បាំងចំនួនប្រាំពីរពាន់នាក់
«សម្លាប់ ៧០០០នាក់»
ពលទាហានថ្មើរជើងចំនួនបួនម៉ឺននាក់
«ទាហានថ្មើរជើង ៤ម៉ឺននាក់»
លោកសូផាក់ ... ព្រះបាទហាដាដេស៊ើរ
ទាំងនេះជាឈ្មោះបុរស។

---

20 [1]នៅរដូវផ្ការីកនៅពេលដែលស្តេចត្រូវចេញទៅធ្វើសង្គ្រាមជាធម្មតា លោកយ៉ូអាប់បានដឹកនាំកងទ័ពចូលប្រយុទ្ធ និងវាយលុកស្រុកអាំម៉ូន។
គាត់បានទៅឡោមព័ទ្ធក្រុងរ៉ាបាត។ ព្រះបាទដាវីឌស្នាក់នៅក្នុងក្រុងយេរូសាឡិម។ លោកយ៉ូអាប់វាយក្រុងរ៉ាបាត ហើយវាយយកបានក្រុងនោះ។
[2]ព្រះបាទដាវីឌយកមកុដដែលស្ថិតនៅលើសិរសេ្តចរបស់ជនជាតិអាំម៉ូន មកុដនោះធ្វើអំពីមាស ទម្ងន់សាមសិបគីឡូក្រាម ហើយមានដាំត្បូងពេជ្រទៀតផង។ គេយកមកុដ
នោះមកបំពាក់លើព្រះសិរសារបស់ព្រះបាទដាវីឌ។ ព្រះបាទដាវីឌក៏បានរឹបអូសយកជយភណ្ឌយ៉ាងច្រើនពីក្រុងនោះ។[3]រីឯប្រជាជននៅក្នុងក្រុងនោះវិញ ព្រះបាទដាវីឌបាន
ជន្លៀសយកមកជាឈ្លើយ ហើយបង្ខំឲ្យអារឈើ ដាប់ថ្ម កាប់អុស។ ព្រះបាទដាវីឌប្រព្រឹត្តដូច្នេះចំពោះក្រុងឯទៀតៗរបស់ជនជាតិអាំម៉ូនដែរ។ បន្ទាប់មក ស្តេចវិលត្រឡប់
មកក្រុងយេរូសាឡឹមវិញជាមួយកងទ័ពទាំងមូល។
[4]ក្រោយមកទៀតមានសង្គ្រាមនៅហ្គេស៊ើរជាមួយពួកភីលីស្ទីន។
លោកស៊ីបេខៃជាអ្នកស្រុកហូសាហ៊ីតបានសម្លាប់ស៊ីផាយដែលជាកូនចៅម្នាក់របស់រេផែមហើយពួកភីលីស្ទីនក៏ត្រូវបានបង្ក្រាប។
[5]ពេលមានសង្គ្រាមជាមួយពួកភីលីស្ទីននៅកូបលោកអេថាហាណានជាកូនរបស់លោកយ៉ារី
មកពីភូមិបេថ្លេហិមបានសម្លាប់ឡាហាមីជាប្អូនរបស់កូលីយ៉ាតជាអ្នកស្រុកកាថ។
[6]នៅក្នុងសមរភូមិមួយទៀតនៅក្រុងកាថមានបុរសម្នាក់ដែលមានកម្ពស់ខ្ពស់ ហើយមានម្រាមដៃជ្រាំមួយទាំងសងខាង និងម្រាមជើងជ្រាំមួយនៅលើជើងនីមួយៗ។
គាត់ក៏ជាពូជពង្សរេផែមដែរ។[7]ពេលវាសើចចម្អកដល់កងទ័ពអ៊ីស្រាអែលនោះ
លោកយ៉ូណាដាប់ជាកូនរបស់លោកស៊ីម៉ាយដែលជាបងរបស់ព្រះបាទដាវីឌក៏បានសម្លាប់វាទៅ។
[8]អ្នកទាំងនោះជាកូនចៅរបស់រេផែមនៅក្រុងកាថហើយពួកគេត្រូវបានសម្លាប់ដោយព្រះបាទដាវីឌ និងកងទ័ពរបស់ព្រះអង្គ។

---

1 Chronicles 20:1
វាយលុកស្រុក
«បានបំផ្លាញស្រុក» សំដៅទៅលើពេលកងទ័ពនឹងបំផ្លាញទឹកដី
ដែលជាកន្លែងសត្រូវរបស់ពួកគេជាំដំណាំ។
1 Chronicles 20:2
ទម្ងន់សាមសិបគីឡូក្រាម
គេយកមកុដនោះមកបំពាក់លើព្រះសិរសារបស់ព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «ព្រះបាទដាវីឌបានបំពាក់មកុដលើព្រះសិរសារព្រះអង្គ»
ជយភណ្ឌ
របស់មានតម្លៃដែលគេយកបាននៅក្នុងសង្គ្រាម។
ព្រះបាទដាវីឌប្រព្រឹត្តដូច្នេះចំពោះក្រុងឯទៀតៗ
ប្រជាជនត្រូវបានបញ្ជូនទៅកាន់ទីក្រុងរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«ស្តេចដាវីឌបានទាមទារឲ្យប្រជាជនទាំងអស់ក្នុងទីក្រុង»
1 Chronicles 20:4
ហ្គេស៊ើរ ... កូប
ទាំងនេះជាឈ្មោះទីក្រុង។
លោកស៊ីបេ ... ស៊ីផាយ ...លោកអេថាហាណាន... លោកយ៉ារី... ឡាហាមី
ទាំងនេះជាឈ្មោះបុរស។ (សូមមើល
អ្នកស្រុកហូសាហ៊ីត...រេផែម...មកពីភូមិបេថ្លេហិម...អ្នកស្រុកកាថ
នេះជាឈ្មោះរបស់ក្រុមមនុស្ស។
បានបង្ក្រាប
ដើម្បីគ្រប់គ្រងនរណាម្នាក់ ឬអ្វីមួយតាមរយៈការប្រើប្រាស់កម្លាំង។
ដំបង
ឈើវែងនិងស្រាល។
ទំពក់របស់តម្បាញ
ឈើមួយដុំត្រូវបានគេប្រើ
ដើម្បីលាតខ្សែដូចជាខ្សែអំបោះត្រូវបានត្បាញជាមួយគ្នានៅជុំវិញពួកគេ។
1 Chronicles 20:6
រេផែម
នេះជាឈ្មោះដែលគេដាក់ឲ្យក្រុមមនុស្សមានកម្ពស់ខ្ពស់និងរឹងមាំ។
លោកយ៉ូណាដាប់ ... លោកស៊ីម៉ាយ
ទាំងនេះជាឈ្មោះបុរស។
ពួកគេត្រូវបានសម្លាប់ដោយព្រះបាទដាវីឌ និងកងទ័ពរបស់ព្រះអង្គ។
ព្រះបាទដាវីឌ និងកងទ័ពព្រះអង្គ
សំដៅទៅលើចំណែកនៃរាងកាយរបស់ពួកគេដែលកាន់ដាវ។ ការបកប្រែផ្សេងទៀត
«ព្រះបាទដាវីឌនិងកងទ័ពរបស់ទ្រង់បានសម្លាប់កូនចៅរបស់លោករេផែម»

---

21 [1]មារសាតាំងបានក្រោកឡើងប្រឆាំងនឹងអ៊ីស្រាអែល ហើយបណ្តាលឲ្យព្រះបាទដាវីឌធ្វើជំរឿនជនជាតិអ៊ីស្រាអែល។[2]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់លោកយ៉ូអាប់
និងមេបញ្ជាការកងទ័ពថា៖ «ចូរទៅជំរឿនជនជាតិអ៊ីស្រាអែលចាប់ពីបៀរសេបារហូតដល់ដាន់ ហើយរាយការណ៍មកយើង ដើម្បីឲ្យយើងដឹងចំនួនពួកគេ»។
[3]លោកយ៉ូអាប់មានប្រសាសន៍ថា៖ «សូមព្រះអម្ចាស់ធ្វើឲ្យកងទ័ពរបស់ព្រះអង្គធំជាងនេះមួយរយដងទៅទៀត។ ប៉ុន្តែ ព្រះអម្ចាស់របស់ខ្ញុំជាស្តេចអើយ!
តើពួកគេទាំងអស់គ្នាមិនមប្រើម្ចាស់ខ្ញុំទេឬអី? ហេតុអ្វីបានជាម្ចាស់របស់ខ្ញុំចង់បានដូច្នេះ? ហេតុអ្វីបានជានាំឲ្យមានកំហុសនេះលើអ៊ីស្រាអែល?
[4]ប៉ុន្តែ ពាក្យរបស់ព្រះរាជាគឺប្រឆាំងនឹងលោកយ៉ូអាប់។ លោកយ៉ូអាប់ចាកចេញទៅពាសពេញស្រុកអ៊ីស្រាអែលទាំងមូល។ បន្ទាប់មក
គាត់បានត្រឡប់មកក្រុងយេរូសាឡិមវិញ។[5]លោកយ៉ូអាប់បានរាយការណ៍អំពីចំនួនសរុបនៃចំនួនអ្នកប្រយុទ្ធជូនព្រះបាទដាវីឌ។ នៅអ៊ីស្រាអែលមានបុរស ១, ១០០, ០០០
នាក់ដែលមានដាវអាចច្បាំងបាន។ នៅស្រុកយូដាមានកងទ័ព ៤៧០, ០០០ នាក់។
[6]ប៉ុន្តែ ពួកលេវី និងពួកបេនយ៉ាមីនមិនត្រូវបានរាប់បញ្ចូលក្នុងចំណោមពួកគេទេ ព្រោះលោកយ៉ូអាប់មិនពេញចិត្ត និងបញ្ជារបស់ស្តេចទេ។
[7]ព្រះជាម្ចាស់មិនសព្វព្រះទ័យនឹងអំពើនេះទេ ដូច្នេះ ព្រះអង្គក៏វាយប្រហារជនជាតិអ៊ីស្រាអែល។[8]ព្រះបាទដាវីឌទូលព្រះជាម្ចាស់ថា៖ «ទូលបង្គំបានប្រព្រឹត្តអំពើបាប
ដោយព្រោះការនេះ។ឥឡូវនេះ សូមដកទោសទូលបង្គំដែលជាអ្នកបម្រើរបស់ព្រះអង្គផងព្រោះទូលបង្គំបានប្រព្រឹត្តល្ងីល្ងើបំផុតហើយ»។
[9]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកកាដ ជាព្យាការីរបស់ព្រះបាទដាវីឌថា៖[10]«ចូរទៅប្រាប់ដាវីឌដូចតទៅ ព្រះអម្ចាស់មានព្រះបន្ទូលថា យើងមានទណ្ឌកម្មបីយ៉ាង
សម្រាប់អ្នក ចូរជ្រើសរើសយកមួយចុះ!»។
[11]លោកកាដចូលទៅគាល់ព្រះបាទដាវីឌហើយទូលថា៖ «ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ
សូមជ្រើសរើសមួយក្នុងចំណោមហេតុការណ៍ទាំងនេះចុះ[12]គ្រោះអត់ឃ្លានរយៈពេលបីឆ្នាំ ឬត្រូវបាក់ទ័ពនៅចំពោះមុខខ្មាំងសត្រូវរយៈពេលបីខែ ឬដាវរបស់ព្រះអម្ចាស់

generated on Wed Sep 10 16:16:32 2025

គឺជាគ្រោះកាចមួយនៅក្នុងស្រុកដែលទេវតារបស់ព្រះអម្ចាស់បំផ្លាញទូទាំងស្រុកអ៊ីស្រាអែលរយៈពេលបីថ្ងៃ។ ឥឡូវនេះ សូមព្រះករុណាសម្រេចថាត្រូវយកមួយណា
ដើម្បីទូលបង្គំ ទូលចំពោះព្រះជាម្ចាស់ដែលចាត់ទូលបង្គំអោយមក»។
[13]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់លោកកាដថា៖ «ខ្ញុំកំពុងរងទុក្ខវេទនាខ្លាំងណាស់។ សូមឲ្យខ្ញុំធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ព្រះអម្ចាស់ជាជាងដៃរបស់មនុស្ស ដ្បិត
ការប្រព្រឹត្តដ៏សប្បុរសរបស់ព្រះអង្គធំធេងណាស់»។[14]ព្រះអម្ចាស់បានធ្វើឲ្យគ្រោះកាចមកលើជនជាតិអ៊ីស្រាអែលហើយមានមនុស្សប្រាំពីរម៉ឺននាក់បានស្លាប់។
[15]ព្រះជាម្ចាស់បានចាត់ទេវតាមួយរូបឲ្យទៅបំផ្លាញក្រុងយេរូសាឡឹម។
នៅពេលដែលទេវតាហៀបនឹងបំផ្លាញវាព្រះអម្ចាស់បានឃ្លាំមើលហើយព្រះអង្គបានផ្លាស់ប្តូរព្រះទ័យអំពីការបំផ្លាញនេះ។
ព្រះអង្គមានបន្ទូលទៅកាន់ទេវតាដែលកំពុងតែបំផ្លាញថា៖ «ល្មមហើយ! ឥឡូវសូមដកដៃអ្នកមកវិញទៅ»។
គ្រានោះទេវតារបស់ព្រះអម្ចាស់ឈរនៅលានបោកបែនស្រូវរបស់លោកអណានជាជនជាតិយេប៊ូស។
[16]ព្រះបាទដាវីឌក្រឡេកមើលទៅឃើញទេវតារបស់ព្រះអម្ចាស់ឈរនៅចន្លោះផែនដី និងលើមេឃមានកាន់ដាវនៅដៃលើកមកលើក្រុងយេរូសាឡឹម។
ព្រះបាទដាវីឌនិងពួកព្រឹទ្ធាចារ្យដែលស្លៀកបាវកាន់ទុក្ខបានក្រាបចុះអោនមុខដល់ដី។[17]ព្រះបាទដាវីឌទូលព្រះជាម្ចាស់ថា៖
«តើមិនមែនទូលបង្គំដែលបញ្ជាអោយរាប់ចំនួនកងទ័ពទេឬអី? ទូលបង្គំបានធ្វើអំពើអាក្រក់នេះ តែចៀមទាំងនេះ តើពួកគេបានធ្វើអ្វីខ្លះ? ព្រះជាម្ចាស់អើយ
សូមឲ្យគ្រោះកាចនេះបានធ្លាក់មកលើទូលបង្គំ និងគ្រួសារទូលបង្គំវិញ ប៉ុន្តែ សូមកុំឲ្យកើតមានលើប្រជាជនរបស់ព្រះអង្គឡើយ»។
[18]ទេវតារបស់ព្រះអម្ចាស់បញ្ជាឲ្យលោកកាដទូលព្រះបាទដាវីឌថា៖
«ដាវីឌត្រូវឡើងទៅសង់អាសនៈមួយសម្រាប់ព្រះអម្ចាស់នៅលានបោកស្រូវរបស់អណានជាអ្នកស្រុកយេប៊ូស។
[19]ព្រះបាទដាវីឌក៏ឡើងទៅតាមការដាស់តឿនរបស់លោកកាដតាមព្រះបន្ទូលរបស់ព្រះអម្ចាស់។[20]ពេលលោកអណានកំពុងច្រូតស្រូវសាលី គាត់បែរទៅឃើញទេវតា។ គាត់
និងកូនប្រុសបួននាក់ដែលនៅជាមួយគាត់ក៏បានពួនខ្លួន។
[21]នៅពេលដែលព្រះបាទដាវីឌទៅជិត លោកអណានបានមើល និងឃើញព្រះបាទដាវីឌ។ លោកចាកចេញពីលានបោកស្រូវហើយក្រាបថ្វាយបង្គំព្រះបាទដាវីឌដល់ដី។
[22]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់លោកអណានថា៖ «សូមលក់លានបោកស្រូវនេះឲ្យខ្ញុំផងខ្ញុំនឹងសង់អាសនៈមួយថ្វាយព្រះអម្ចាស់។
[23]លោកអណានមានប្រសាសន៍ទៅកាន់ព្រះបាទដាវីឌថា៖ «សូមព្រះករុណាយកវាចុះ! សូមធ្វើតាមអ្វីដែលគួរឲ្យគាប់ព្រះហឫទ័យរបស់ព្រះអង្គចុះ។
ទូលបង្គំនឹងប្រគល់របស់ទាំងអស់នេះដល់ព្រះអង្គ» ។[24]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់លោកអណានថា៖ «ទេខ្ញុំសូមទិញអ្វីៗទាំងអស់ដោយពេញថ្លៃ
ខ្ញុំនឹងមិនយករបស់អ្នកមកធ្វើជាតង្វាយដុតថ្វាយព្រះអម្ចាស់ទេ ប្រសិនបើ ខ្ញុំមិនបានចំណាយអ្វីសោះ»។
[25]ដូច្នេះ ព្រះបាទដាវីឌបានចំណាយមាសប្រាំមួយរយតម្លឹងសម្រាប់កន្លែងនោះ។
[26]ព្រះបាទដាវីឌសង់អាសនៈមួយថ្វាយព្រះអម្ចាស់នៅទីនោះហើយក៏ថ្វាយតង្វាយដុតទាំងមូល និងតង្វាយមេត្រីនៅទីនោះ។ ព្រះបាទដាវីឌបានអង្វររកព្រះអម្ចាស់
ហើយព្រះអង្គបានឆ្លើយតបដោយភ្លើងពីលើមេឃមកលើអាសនៈថ្វាយតង្វាយដុតទាំងមូល។[27]ក្រោយមកព្រះអម្ចាស់បានបញ្ជាឲ្យទេវតាដាក់ដាវចូលទៅក្នុងស្រោមវិញ។
[28]ពេលព្រះបាទដាវីឌឃើញថាព្រះអម្ចាស់បានឆ្លើយតប និងពាក្យទូលអង្វររបស់ព្រះអង្គនៅលានបោកស្រូវរបស់លោកអណានជាអ្នកស្រុកយេប៊ូស
ព្រះករុណាក៏ធ្វើពិធីថ្វាយដង្វាយនៅទីនោះ។[29]នៅគ្រានោះ ព្រះពន្លារបស់ព្រះអម្ចាស់ដែលលោកម៉ូសេបានធ្វើនៅវាលរហោស្ថាន
និងអាសនៈសម្រាប់ថ្វាយតង្វាយដុតស្ថិតនៅលើទីសក្ការៈនៅគីបៀន។[30]ទោះយ៉ាងណាព្រះបាទដាវីឌមិនអាចទៅទីនោះ ដើម្បីសុំការណែនាំពីព្រះជាម្ចាស់ទេ
ដោយព្រោះខ្លាចដាវរបស់ទេវតារនៃព្រះអម្ចាស់។

---

1 Chronicles 21:1

មារសាតាំងបានក្រោកឡើងប្រឆាំងនឹងអ៊ីស្រាអែល

ដើម្បីឲ្យការពិពណ៌នាត្រឡប់ទៅជាមានអំណាចជាងមុន។ ការបកប្រែផ្សេងទៀត
«ខ្មាំងសត្រូវរបស់អ៊ីស្រាអែលកាន់តែមានអំណាច»

បណ្តាល

បណ្តាលឲ្យនរណាម្នាក់ធ្វើសកម្មភាព។

ចាប់ពីបៀរសេបារហូតដល់ដាន់

ជនជាតិអ៊ីស្រាអែលចាត់ទុកទីក្រុងទាំងពីរនេះ ជាទីក្រុងភាគខាងត្បូង
និងភាគខាងជើងបំផុត។
ព្រះបាទដាវីឌប្រើទីក្រុងទាំងនេះសំដៅទៅលើអ៊ីស្រាអែលទាំងអស់។

ធំជាងនេះមួយរយដងទៅទៀត

លោកយ៉ូអាប់បង្ហាញពីបំណងប្រាថ្នារបស់កងទ័ព ដែលមាន១០០នាក់
ដើម្បីបរិយាយអំពីព្រះអង្គដូចជាកងទ័ពមានច្រើន
និងមានពេញដោយអំណាចថែមទៀត។

ប៉ុន្តែ ព្រះអម្ចាស់របស់ខ្ញុំជាស្តេចអើយ! តើពួកគេទាំងអស់គ្នាមិនមប្រើម្ចាស់ខ្ញុំទេឬអី?

ហេតុអ្វីបានជាម្ចាស់របស់ខ្ញុំចង់បានដូច្នេះ? ហេតុអ្វីបានជានាំឲ្យមានកំហុសនេះលើអ៊ីស្រាអែល?

ការបកប្រែផ្សេងទៀត «ប៉ុន្តែ ព្រះអម្ចាស់របស់ខ្ញុំជាស្តេចអើយ!
ពួកគេទាំងអស់បានបម្រើព្រះអង្គរួចហើយ។ លោកម្ចាស់ខ្ញុំមិនគួរស្នើសុំរឿងនេះទេ។
ទ្រង់នឹងនាំកំហុសមកលើប្រជាជនអ៊ីស្រាអែល
ព្រោះទ្រង់ចង់បានអំណាចយោធា»។

ហេតុអ្វីបានជាម្ចាស់របស់ខ្ញុំចង់បានដូច្នេះ?

ពាក្យថា «នេះ»

សំដៅទៅលើផែនការរបស់ព្រះបាទដាវីឌដើម្បីរាប់ទាហានអ៊ីស្រាអែលទាំងអស់។

1 Chronicles 21:4

ពាក្យរបស់ព្រះរាជាគឺប្រឆាំងនឹង

ឃ្លានេះសំដៅទៅលើបទបញ្ជារបស់ស្តេចដាវីឌជាចុងក្រោយ
ពីព្រោះទ្រង់នឹងមិនផ្លាស់ប្តូរបទបញ្ជាទេ បន្ទាប់ពីគេផ្តល់ឲ្យ។
ហេតុអ្វីបានជាម្ចាស់របស់ខ្ញុំចង់បានដូច្នេះ?
«បទបញ្ជារបស់ស្តេចនឹងមិនផ្លាស់ប្តូរទេ»

មានដាវអាចច្បាំងបាន

ទាហាននៅអ៊ីស្រាអែលត្រូវបានពិពណ៌នា
តាមរយៈសកម្មភាពដកដាវចេញមកច្បាំង។

1 Chronicles 21:6

ប៉ុន្តែ ពួកលេវី និងពួកបេនយ៉ាមីនមិនត្រូវបានរាប់បញ្ចូលក្នុងចំណោមពួកគេទេ

ការបកប្រែផ្សេងទៀត «ប៉ុន្តែ លោកយ៉ូអាប់មិនបានរាប់ទាហានពីកុលសម្ព័ន្ធលេវី
និងបេនយ៉ាមីនទេ»

អំពើនេះទេ

«សកម្មភាពនេះ» សំដៅទៅលើផែនការរបស់ព្រះបាទដាវីឌ
ដើម្បីរាប់ទាហានអ៊ីស្រាអែលទាំងអស់ ដែលអាចប្រយុទ្ធបាន។

សូមដកទោសទូលបង្គំដែលជាអ្នកបម្រើរបស់ព្រះអង្គផងព្រោះទូលបង្គំ

ការអភ័យទោសត្រូវបានពិពណ៌នាថា មានទោសកំហុស។ ការបកប្រែផ្សេងទៀត
«អត់ទោសឲ្យខ្ញុំ» (សូមមើល gs-idiom)

ទោសទូលបង្គំដែលជាអ្នកបម្រើរបស់ព្រះអង្គ

ព្រះបាទដាវីឌចាត់ទុកព្រះអង្គផ្ទាល់ ជាអ្នកបម្រើរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «កំហុសរបស់ខ្ញុំ»

1 Chronicles 21:11

ត្រូវបាក់ទ័ពនៅចំពោះមុខខ្មាំងសត្រូវ

ឃ្លានេះជាវិធីសាមញ្ញមួយពិពណ៌នាអំពីការសម្លាប់ ដោយសត្រូវ។

ដាវរបស់ព្រះអម្ចាស់

ឃ្លានេះពិពណ៌នាអំពីវិធីសាស្ត្រសម្លាប់របស់ព្រះអម្ចាស់
ដោយឧបករណ៍ដែលកងទ័ពប្រើដើម្បីសម្លាប់។

បំផ្លាញ

ការបកប្រែផ្សេងទៀត «ការសម្លាប់»

1 Chronicles 21:13

ខ្ញុំកំពុងរងទុក្ខវេទនាខ្លាំងណាស់

ការបកប្រែផ្សេងទៀត «ខ្ញុំមានបញ្ហាច្រើនណាស់»

សូមឲ្យខ្ញុំធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ព្រះអម្ចាស់ជាជាងដៃរបស់មនុស្ស ដ្បិត
ការប្រព្រឹត្តដ៏សប្បុរសរបស់ព្រះអង្គធំធេងណាស់

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «សូមឲ្យខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់
ជាជាងការគ្រប់គ្រងរបស់មនុស្ស ព្រោះព្រះអម្ចាស់ពេញដោយក្តីមេត្តា។
មនុស្សប្រាំពីរម៉ឺននាក់បានស្លាប់
«និងមនុស្ស៧ម៉ឺននាក់បានស្លាប់»
ព្រះអង្គបានផ្លាស់ប្តូរព្រះទ័យ
ដើម្បីផ្លាស់ប្តូរការសម្រេចចិត្ត។
ឥឡូវសូមដកដៃអ្នកមកវិញទៅ
ព្រះអម្ចាស់ប្រាប់ទេវតាដែលត្រូវបំផ្លាញឲ្យឈប់សម្លាប់ប្រជាជន។
ទេវតារបស់ព្រះអម្ចាស់ឈរ
ទេវតារបស់ព្រះអម្ចាស់ប្រៀបបាននឹង អ្វីមួយដែលនឹងឈរដូចមនុស្សម្នាក់។
លោកអណាន
នេះជាឈ្មោះបុរស។
1 Chronicles 21:16
មានកាន់ដាវនៅដៃ
ការបកប្រែផ្សេងទៀត «ត្រៀមវាយប្រហារ»
តើមិនមែនទូលបង្គំដែលបញ្ជាអោយរាប់ចំនួនកងទ័ពទេឬអី?
ការបកប្រែផ្សេងទៀត «ទូលបង្គំជាអ្នកដែលបញ្ជាឲ្យគេរាប់ចំនួនកងទ័ព»។
តែចៀមទាំងនេះ
ព្រះបាទដាវីឌពិពណ៌នាអំពីប្រជាជនអ៊ីស្រាអែលថា
ជាសត្វមួយប្រភេទដែលចេះទុកចិត្ត ហើយដើរតាមមេដឹកនាំ។
តើពួកគេបានធ្វើអ្វីខ្លះ?
ការបកប្រែផ្សេងទៀត «ពួកគេពិតជាមិនបានធ្វើអ្វី
ដែលសមនឹងទទួលទណ្ឌកម្មទេ»។
1 Chronicles 21:18
លោកអណាន
សូមមើលការបកប្រែឈ្មោះរបស់គាត់នៅក្នុង ២១:១៣។
តាមការដាស់តឿនរបស់លោកកាដតាមព្រះបន្ទូលរបស់
ការបកប្រែផ្សេងទៀត «ដូចលោកកាដនិយាយអំពីសិទ្ធិអំណាចរបស់ព្រះអម្ចាស់
បានប្រាប់ព្រះបាទដាវីឌឲ្យធ្វើ»។
1 Chronicles 21:21
ហើយក្រាបថ្វាយបង្គំព្រះបាទដាវីឌដល់ដី
ឃ្លានេះពិពណ៌នាថា លោកអណានឱនទៅមុខកាន់តែទាប។
ការឱនមុខចំពោះនរណាម្នាក់ គឺជាវិធីបង្ហាញការបន្ទាបខ្លួន និងការគោរព។
ការឱនកាន់តែទាបបង្ហាញពីការបន្ទាបខ្លួន និងការគោរពកាន់តែខ្លាំង។
ពេញថ្លៃ
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងបងពេញថ្លៃ លានបោកស្រូវនេះមានតម្លៃណាស់»
1 Chronicles 21:23
សូមព្រះករុណាយកវាចុះ!
ការបកប្រែផ្សេងទៀត «ចូរទទួលយកជាអំណោយ»
អ្វីដែលគួរឲ្យគាប់ព្រះហឫទ័យរបស់ព្រះអង្គចុះ។
ការយល់ដឹងរបស់ស្តេចដាវីឌត្រូវគេពិពណ៌នាថា ជាការមើលឃើញ។
ការបកប្រែផ្សេងទៀត «អ្វីៗហាក់បីដូចជាល្អចំពោះអ្នក»
ប្រគល់របស់ទាំងអស់នេះ(រនាស់)
រនាស់មួយមានថ្ម ឬដែកដាក់នៅពីក្រោម
ដែលត្រូវបានប្រើដើម្បីញែកបំបែកគ្រាប់សូវចេញពីសំបក
ដោយទាញរនាស់ដាក់អួសលើស្រូវសាលីនៅលានបោកស្រូវ។
1 Chronicles 21:25
មាសប្រាំមួយរយតម្លឹង
«មាស៦០០តម្លឹង»
តម្លឹង
ព្រះបាទដាវីឌបានអង្វររកព្រះអម្ចាស់
ព្រះបាទដាវីឌបានអធិស្ឋានទៅកាន់ព្រះអម្ចាស់សុំជំនួយ
ឲ្យទេវតាដាក់ដាវចូលទៅក្នុងស្រោមវិញ
ការបកប្រែផ្សេងទៀត «ទេវតាឈប់សម្លាប់មនុស្ស។»
ស្រោម
ស្រោមដាវ ឬកាំបិត។
1 Chronicles 21:28
លោកអណាន
សូមមើលការបកប្រែឈ្មោះរបស់គាត់នៅ ២១:១៣។
ដើម្បីសុំការណែនាំពីព្រះជាម្ចាស់ទេ
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់ប្រាប់ព្រះបាទដាវីឌពីអ្វីដែលទ្រង់គួរធ្វើ»
ព្រោះខ្លាចដាវរបស់ទេវតារនៃព្រះអម្ចាស់។
ការបកប្រែផ្សេងទៀត
«ខ្លាចព្រះបាទដាវីឌនឹងត្រូវសម្លាប់ដោយសារទេវតារបស់ព្រះអម្ចាស់»

---

22 [1]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «ទីនេះជាព្រះដំណាក់របស់ព្រះជាម្ចាស់នឹងអាសនៈសំរាប់ថ្វាយតង្វាយដុតទាំងមូលរបស់ជនជាតិអ៊ីស្រាអែល»។
[2]ព្រះបាទដាវីឌក៏បញ្ជាឲ្យអ្នកបម្រើរបស់លោកប្រមូលជនបរទេសដែលរស់នៅក្នុងស្រុកអ៊ីស្រាអែលឲ្យមកជួបជុំគ្នា។
ព្រះករុណាបានចាត់តាំងពួកគេឱ្យធ្វើជាជាងចម្លាក់ថ្មកាត់ដុំថ្មដើម្បីសង់ព្រះដំណាក់របស់ព្រះជាម្ចាស់។
[3]ព្រះបាទដាវីឌបានត្រៀមដែកយ៉ាងច្រើនទុកធ្វើដែកគោលសម្រាប់សន្លឹកទ្វារ និងធ្វើតម្អក់។
ព្រះអង្គក៏បានត្រៀមលង្ហិនយ៉ាងច្រើនសន្ធឹកដែលមិនអាចថ្លឹងបានដែរ[4]ហើយមានឈើតាត្រៅយ៉ាងច្រើនសន្ធឹកដែលគេមិនអាចរាប់បាន។(ដ្បិតអ្នកក្រុងស៊ីដូន
និងក្រុងទីរ៉ុសបាននាំយកឈើតាត្រៅយ៉ាងសន្ធឹកមកថ្វាយព្រះបាទដាវីឌ)។[5]ព្រះបាទដាវីឌមានរាជឱង្ការថា៖ «សាឡូម៉ូន បុត្រាយើង នៅក្មេងហើយគ្មានបទពិសោធន៍
រឹងដំណាក់ដែលត្រូវសង់ថ្វាយព្រះអម្ចាស់ត្រូវតែមានភាពថ្កុំថ្កើងរុងរឿងនិងល្បីល្បាញជាងគេនៅក្នុងស្រុកនានា។
ដូច្នេះយើងនឹងត្រៀមសំភារៈសំរាប់ការសាងសង់អាគារនេះ»។ ដូច្នេះព្រះបាទដាវីឌបានត្រៀមសំភារៈសាងសង់ជាច្រើនមុនពេលព្រះអង្គសោយទិវង្គត។
[6]ព្រះបាទដាវីឌត្រាស់ហៅសម្តេចសាឡូម៉ូន ជាបុត្រមកផ្តែផ្តាំឲ្យសង់ព្រះដំណាក់ថ្វាយព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល។[7]ព្រះអង្គមានរាជឱង្ការទៅកាន់សម្តេច
សាឡូម៉ូនថា៖ «បុត្រអើយ! បិតាមានបំណងសង់ព្រះដំណាក់សម្រាប់លើកតម្កើងព្រះនាមព្រះអម្ចាស់ ជាព្រះរបស់បិតា។[8]ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់បិតាថា៖
ឯងបានបង្ហូរឈាមច្រើនណាស់ ហើយឯងក៏បានធ្វើសង្គ្រាមជាច្រើនផង។ ដូច្នេះ ឯងមិនត្រូវសង់ដំណាក់សម្រាប់នាមរបស់យើងទេ ដ្បិតឯងបានបង្ហូរឈាមយ៉ាងច្រើនលើ
ផែនដី នៅចំពោះមុខយើង។
[9]ទោះជាយ៉ាងណា ឯងនឹងមានកូនប្រុសម្នាក់ដែលនឹងក្លាយជាបុរសដែលមានសន្តិភាព។ យើងនឹងអោយគាត់សំរាកពីខ្មាំងសត្រូវទាំងអស់ដែលនៅជុំវិញ។
ដ្បិតឈ្មោះរបស់គេត្រូវហៅថាសាឡូម៉ូនហើយយើងនឹងអោយអ៊ីស្រាអែលមានសុខសាន្តត្រាណនៅក្នុងរាជរបស់គេ។[10]បុត្រនោះនឹងសង់ដំណាក់សំរាប់នាមយើង។
គេនឹងក្លាយជាកូនរបស់យើងហើយយើងនឹងធ្វើជាឪពុករបស់គេ។ យើងនឹងតាំងបល្ល័ង្កនៃរាជាណាចក្ររបស់ព្រះអង្គគ្រប់គ្រងលើជនជាតិអ៊ីស្រាអែលរហូតតទៅ។
[11]ឥឡូវនេះបុត្រអើយសូមអោយព្រះអម្ចាស់គង់ជាមួយបុត្រនិងជួយអោយបុត្រទទួលជោគជ័យ។
សូមឲ្យបុត្រអាចសង់ព្រះដំណាក់របស់ព្រះអម្ចាស់ជាព្រះរបស់បុត្រដូចព្រះអង្គបានមានព្រះបន្ទូលទុកស្រាប់។
[12]មានតែព្រះអម្ចាស់ទេដែលអាចផ្តល់យោបល់និងប្រាជ្ញាដល់បុត្រដើម្បីអោយបុត្រប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ជាព្រះរបស់បុត្រនៅពេលដែលព្រះអង្គតែងតាំងបុត្រអោយគ្រប់គ្រងជ
[13]ប្រសិនបើបុត្រប្រតិបត្តិតាមក្រឹត្យវិន័យដែលព្រះអម្ចាស់ប្រទានមកលោកម៉ូសេស្តីអំពីជនជាតិអ៊ីស្រាអែលនោះបុត្រមុខជាទទួលជោគជ័យមិនខាន។ ចូររឹងមាំនិងក្លាហាន។
កុំខ្លាចឬបាក់ទឹកចិត្តឡើយ។
[14]ឥឡូវនេះ មើល៍បិតាបានត្រៀមរៀបចំទុកសំរាប់ព្រះដំណាក់របស់ព្រះអម្ចាស់ គឺមាសចំនួន១០ម៉ឺនតោន ប្រាក់មួយលានតោនហើយលង្ហិននិងដែកយ៉ាងច្រើនសន្ធឹក។
បិតាក៏បានត្រៀមឈើនិងថ្មផងដែរ។បុត្រត្រូវតែបន្ថែមលើអ្វីៗទាំងអស់នេះបន្ថែមទៀត។
[15]បុត្រមានកម្មករច្រើននាក់នៅជាមួយបុត្រ៖ គឺមានជាងចម្លាក់ថ្ម ជាងចម្លាក់ឈើ ជាងឈើនិងជាងសិប្បកម្មជំនាញគ្រប់ប្រភេទ។
[16]សុទ្ធតែជាអ្នកអាចធ្វើការជាមួយមាសប្រាក់លង្ហិននិងដែក។ ដូច្នេះចូរចាប់ផ្តើមធ្វើការហើយសូមព្រះអម្ចាស់គង់ជាមួយបុត្រ» ។
[17]ព្រះបាទដាវីឌក៏បញ្ជាអោយមេដឹកនាំអ៊ីស្រាអែលទាំងអស់ជួយព្រះបាទសាឡូម៉ូនជាបុត្រដោយពោលថា៖
[18]«ព្រះអម្ចាស់ជាព្រះរបស់អ្នកគង់នៅជាមួយអ្នកហើយប្រទានអោយអ្នកមានសន្តិភាពនៅគ្រប់ទិសទី។

generated on Wed Sep 10 16:16:32 2025

ព្រះអង្គបានប្រគល់ប្រជាជននៅតាមតំបន់នេះមកក្នុងកណ្តាប់ដៃរបស់យើងហើយស្រុកនេះស្ថិតនៅក្រោមអំណាចរបស់ព្រះអម្ចាស់ និងប្រជារាស្ត្ររបស់ព្រះអង្គដែរ។។
[19]ឥឡូវនេះចូរស្វែងរកព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិតរបស់អ្នក។ ចូរក្រោកឡើងហើយសង់ទីសក្ការៈរបស់ព្រះ អម្ចាស់ជាព្រះរបស់អ្នក ដើម្បីដង្ហែហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ និងគ្រឿងបរិក្ខារដ៏សក្ការៈរបស់ព្រះជាម្ចាស់ ទៅតម្កល់ទុកក្នុងព្រះដំណាក់ដែលនឹងសង់ឡើងសម្រាប់ព្រះនាមរបស់ព្រះអម្ចាស់»។

---

1 Chronicles 22:1
ជាងចម្លាក់ថ្មកាត់ដុំថ្ម
ទាំងនេះជាមនុស្សដែលប្រមូលថ្មធំៗ ហើយកាត់វាឲ្យមានទំហំត្រឹមត្រូវតាមខ្នាត
ដូច្នេះ អ្នកសាងសង់អាចប្រើថ្មរៀបជញ្ជាំង និងអគារ។
1 Chronicles 22:3
តម្លក់
«អង្គំ» ឬ «ត្រចៀកទ្វារ» នេះជាវត្ថុដែលភ្ជាប់របស់ពីរជាមួយគ្នា ។
ដែលមិនអាចថ្លឹងបានដែរ
ការបកប្រែផ្សេងទៀត «ជាងអ្នកណាអាចថ្លឹងទម្ងន់»
យ៉ាងច្រើនសន្ធឹកដែលគេមិនអាចរាប់បាន។
ការបកប្រែផ្សេងទៀត «គ្មានអ្នកណាអាចរាប់បាន»
ដំណាក់ដែលត្រូវសង់ថ្វាយព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «ដំណាក់របស់ព្រះអម្ចាស់» ឬ
«ដំណាក់ដែលព្រះអង្គនឹងសង់ថ្វាយព្រះអម្ចាស់»
1 Chronicles 22:6
ត្រាស់ហៅ
«ព្រះបាទដាវីឌបានហៅ»
ផ្តែផ្តាំឲ្យសង់ព្រះដំណាក់ ...បិតាមានបំណងសង់ព្រះដំណាក់
«បញ្ជាឲ្យកម្មករសាងសង់...ផែនការរបស់ខ្ញុំគឺជួលកម្មករឲ្យសាងសង់»
លើកតម្កើងព្រះនាមព្រះអម្ចាស់ ជាព្រះរបស់បិតា។
«ដើម្បីគោរពដល់ព្រះអម្ចាស់ជាព្រះរបស់ខ្ញុំ»
ឯងបានបង្ហូរឈាមច្រើនណាស់
«អ្នកបានសម្លាប់មនុស្សជាច្រើន»
ឯងមិនត្រូវសង់ដំណាក់សម្រាប់នាមរបស់យើងទេ
«អ្នកនឹងមិនសាងសង់ប្រាសាទដើម្បីគោរពខ្ញុំ»
ដ្បិតឯងបានបង្ហូរឈាមយ៉ាងច្រើនលើផែនដី នៅចំពោះមុខយើង។
«ពីព្រោះ ខ្ញុំដឹងថា អ្នកបានសម្លាប់មនុស្សជាច្រើន»
1 Chronicles 22:9
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌទូលស្តេចសាឡូម៉ូននូវព្រះបន្ទូល
ដែលព្រះអម្ចាស់មានព្រះបន្ទូលប្រាប់។
ទាំងអស់ដែលនៅជុំវិញ
មានន័យថា នៅគ្រប់ទីកន្លែងជុំវិញអ៊ីស្រាអែល។
ក្នុងរាជ្យរបស់គេ
«ពេលព្រះអង្គគ្រប់គ្រងលើអ៊ីស្រាអែល» ។
ដំណាក់សម្រាប់នាមយើង
ការបកប្រែផ្សេងទៀត «ព្រះវិហារដើម្បីផ្តល់កិត្តិយសឲ្យយើង»
បុត្រនោះនឹងសង់ដំណាក់សម្រាប់នាមយើង។
ព្រះជាម្ចាស់នឹងប្រព្រឹត្តចំពោះស្តេចសាឡូម៉ូន
ដូចជាព្រះបាទសាឡូម៉ូនជាបុត្រារបស់ព្រះជាម្ចាស់ដែរ
យើងនឹងតាំងបល្ល័ង្កនៃរាជាណាចក្ររបស់ព្រះអង្គគ្រប់គ្រងលើជនជាតិអ៊ីស្រាអែលរហូតតទៅ។
នៅទីនេះ «បល្ល័ង្ក» សំដៅទៅលើសិទ្ធិអំណាចគ្រប់គ្រងជាស្តេច។
ការបកប្រែផ្សេងទៀត «យើងនឹងឲ្យកូនចៅរបស់ព្រះអង្គ
គ្រប់គ្រងលើអ៊ីស្រាអែលជារៀងរហូត»
1 Chronicles 22:11
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តមានព្រះបន្ទូលទៅព្រះបាទសាឡូម៉ូន។
ឥឡូវនេះ
ព្រះបាទដាវីឌប្រើពាក្យនេះ ដើម្បីណែនាំនូវអ្វីដែលព្រះអង្គមានបន្ទូល។
សូមឲ្យបុត្រអាចសង់ព្រះដំណាក់
ការបកប្រែផ្សេងទៀត
«សូមឲ្យអ្នកទទួលបានជោគជ័យក្នុងការសាងសង់ព្រះដំណាក់»
ពេលដែលព្រះអង្គតែងតាំងបុត្រអោយគ្រប់គ្រងលើជនជាតិអ៊ីស្រាអែល។
«នៅពេលទ្រង់ធ្វើឲ្យអ្នកក្លាយជាស្តេចអ៊ីស្រាអែល»
1 Chronicles 22:14
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តមានព្រះបន្ទូលទៅព្រះបាទសាឡូម៉ូន។
ឥឡូវនេះ
នេះជាការណែនាំនូវអ្វីសំខាន់ ដែលព្រះបាទដាវីឌមានបន្ទូល។
ហាប
ហាបជាឯកតាទម្ងន់។ វាស្មើនឹង៣៣គីឡូក្រាម។
មួយលានតោន
«១.000.000»
1 Chronicles 22:15
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តមានព្រះបន្ទូលទៅព្រះបាទសាឡូម៉ូន។
ជាងចម្លាក់ថ្ម ជាងចម្លាក់ឈើ
ទាំងនេះជាអ្នកធ្វើការទាំងពីរនាក់
ដែលកាត់ថ្មហើយរៀបចំវាឲ្យអ្នកសាងសង់ប្រើប្រាស់ជញ្ជាំង និងអាគារ។
ជាងឈើ
ទាំងនេះជាមនុស្សដែលធ្វើការជាមួយឈើ។
1 Chronicles 22:17
របស់អ្នក ... អ្នក
សព្វនាមទាំងនេះជាពហុវចនៈក្នុង ២២:១៨-១៩។
ប្រទានអោយអ្នកមានសន្តិភាពនៅគ្រប់ទិសទី។
«បានផ្តល់ឲ្យអ្នកនូវសន្តិភាព រួចពីសង្គ្រាមនៅគ្រប់ទីកន្លែងជុំវិញអ៊ីស្រាអែល»
ព្រះអង្គបានប្រគល់ប្រជាជននៅតាមតំបន់នេះមកក្នុងកណ្តាប់ដៃរបស់យើង
«ព្រះអម្ចាស់និងប្រជាជនរបស់ព្រះអង្គគ្រប់គ្រងទឹកដីរបស់ពួកគេ»
ឥឡូវនេះ
នេះជាការណែនាំនូវអ្វីសំខាន់ ដែលព្រះបាទដាវីឌមានបន្ទូល។
ចូរស្វែងរកព្រះអម្ចាស់ជាព្រះរបស់អ្នក
ការបកប្រែផ្សេងទៀត
«ចូរព្យាយាមធ្វើឲ្យព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នកយកចិត្តទុកដាក់ចំពោះអ្នក»
របស់អ្នកឲ្យអស់ពីចិត្តគំនិតរបស់អ្នក។
«ដោយស្មោះអស់ពីចិត្ត» ឬ «ទាំងអស់ពីចិត្តទាំងស្រុង»
ចូរស្វែងរកព្រះអម្ចាស់ជាព្រះរបស់អ្នក
ការបកប្រែផ្សេងទៀត
«ព្យាយាមរកព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យយកចិត្តទុកដាក់ចំពោះអ្នក»
ចូរក្រោកឡើងហើយសង់ទីសក្ការៈរបស់ព្រះ
ការបកប្រែផ្សេងទៀត
«ក្រោកឡើងហើយដឹកនាំកម្មករនៅពេលពួកគេសាងសង់ទីកន្លែងវិសុទ្ធ»
សង់ឡើងសម្រាប់ព្រះនាមរបស់ព្រះអម្ចាស់
«ព្រះវិហារដែលអ្នកនឹងសង់ដើម្បីគោរពដល់ព្រះអម្ចាស់»

---

23 [1]ពេលព្រះបាទដាវីឌមានអាយុចាស់ណាស់ហើយ ព្រះអង្គបានតែងតាំងព្រះបាទសាឡូម៉ូនជាបុត្រឲ្យធ្វើជាស្តេចស្រុកអ៊ីស្រាអែល។
[2]ស្តេចបានប្រមូលមេដឹកនាំអ៊ីស្រាអែលទាំងអស់ និងក្រុមបូជាចារ្យ ព្រមទាំងក្រុមលេវីឲ្យមកជួបជុំគ្នា។[3]គេរាប់ចំនួនក្រុមលេវីដែលមានអាយុសាមសិបឆ្នាំឡើងទៅ។ ពួកគេទាំងអស់មានចំនួន៣៨, ០០០នាក់។
[4]ព្រះបាទដាវីឌមានរាជឱង្ការថា៖
«ក្នុងចំណោមមនុស្សទាំងនេះមានពីរម៉ឺនបួនពាន់នាក់ត្រូវមើលការខុសត្រូវលើកិច្ចការរបស់ព្រះដំណាក់របស់ព្រះអម្ចាស់ហើយប្រាំមួយពាន់នាក់ជាមន្ត្រី និងជាចៅក្រម។

generated on Wed Sep 10 16:16:32 2025

[5]បួនពាន់នាក់ទៀតជាអ្នកយាមទ្វារព្រះដំណាក់ បួនពាន់នាក់ ជាអ្នកចម្រៀងលើកតម្កើងព្រះអម្ចាស់ និងកាន់ឧបករណ៍ភ្លេងដែលយើងបានធ្វើសម្រាប់ប្រគំកំដរ។[6]ព្រះបាទដាវីឌបានបែងចែកកូនចៅលេវីជាក្រុម តាមអំបូររបស់ពួកគេ គឺអំបូរគើរសុន អំបូរកេហាត់ និងអំបូរម៉្រារី។
[7]មកពីអំបូរកូនចៅរបស់លោកគើរសុនមាន ឡាដាន និងស៊ីម៉ែ។[8]កូនរបស់លោកឡាដានមានបីនាក់គឺ យេហ៊ីអែលជាមេដឹកនាំ សេថាម និងយ៉ូអែល។[9]កូនរបស់លោកស៊ីម៉ែមានបីនាក់គឺ សេឡូម៉ូត ហាស៊ាល និងហារ៉ាន។ អ្នកទាំងនេះសុទ្ធតែជាមេលើក្រុមគ្រួសារឡាដាន។
[10]លោកស៊ីម៉ែមានកូនបួននាក់ទៀតគឺ យ៉ាហាត់ ស៊ីស្សា យេអ៊ូស និងបេរា។[11]លោកយ៉ាហាត់ជាមេដឹកនាំ ហើយលោកស៊ីស្សាជាមេដឹកនាំទីពីរ។ លោកយេអ៊ូសនិងលោកបេរា គ្មានកូនប្រុសច្រើនទេ ដូច្នេះ ពួកគេក៏បញ្ចូលគ្នាជាក្រុមគ្រួសារតែមួយ ទទួលខុសត្រូវលើការងារតែមួយ។
[12]លោកកេហាត់មានកូនប្រុសបួននាក់គឺអាំរ៉ាម អ៊ីសារ, ហេប្រូននិងអ៊ូសៀល។[13]កូនប្រុសៗរបស់លោកអាំរ៉ាមគឺលោកអើរ៉ុន និងលោកម៉ូសេ។
លោកអើរ៉ុនត្រូវបានជ្រើសរើសឲ្យញែកអ្វីៗដែលសក្ការបំផុតដែលគាត់ និងកូនចៅរបស់គាត់ត្រូវថ្វាយគ្រឿងក្រអូបនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ដើម្បីគោរពបម្រើព្រះអង្គ និងប្រទានពរក្នុងនាមព្រះអង្គជារៀងរហូត។[14]ប៉ុន្តែ លោកម៉ូសេជាអ្នកជំនិតរបស់ព្រះជាម្ចាស់កូនៗ របស់លោកត្រូវបានគេចាត់ទុកថា ជាពួកលេវី។
[15]កូនប្រុសៗរបស់ម៉ូសេគឺគើរសុម និងអេលាស៊ើរ។[16]កូនចៅរបស់លោកគើរសុមគឺសេប៊ូអែលជាកូនច្បង។ កូនចៅរបស់អេលីស៊ើរគឺរេហាបយ៉ា។
[17]អេលាស៊ើរមិនមានកូនប្រុសទៀតទេ ប៉ុន្តែ លោករេហាបយ៉ាមានកូនចៅជាច្រើន។[18]កូនប្រុសរបស់អ៊ីសហាគឺស៊ីឡូមជាមេដឹកនាំ។
[19]កូនចៅរបស់លោកហេប្រូនមានលោកយេរីយ៉ា ជាកូនច្បង លោកអ័ម៉ារីយ៉ាជាកូនទីពីរ លោកយ៉ាហាសៀលជាកូនទីបី និងលោកយេកាមាមជាកូនទីបួន។[20]កូនប្រុសៗរបស់លោកអ៊ូស៊ាលគឺ លោកមីកា ជាកូនទីមួយ និងលោកយីសយ៉ា ជាកូនទីពីរ។
[21]កូនចៅរបស់លោកម៉្រារីមាន លោកម៉ាលី។ កូនប្រុសៗរបស់លោកម៉ាលីមានអេលាសា និងគីស។[22]អេលាសាបានស្លាប់ដោយមិនមានកូនទេ
គាត់មានតែកូនស្រីៗប៉ុណ្ណោះ។ កូនៗរបស់លោកគីស បានរៀបការជាមួយពួកគេ។[23]កូនទាំងបីរបស់លោកមូស៊ី គឺម៉ាលី អេដើ និងយេរេម៉ូត។
[24]ទាំងនេះជាកូនចៅលេវីទៅតាមពូជអំបូររបស់ពួកគេ។
ពួកគេជាមេដឹកនាំដែលត្រូវបានគេរាប់បញ្ចូលក្នុងត្រកូលនៃអំបូរដែលត្រូវធ្វើកិច្ចការក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ។[25]ព្រះបាទដាវីឌទូលថា៖ «បពិត្រព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែល ព្រះអង្គបានប្រទានឲ្យប្រជាជនរបស់ព្រះអង្គសម្រាក។
ព្រះអង្គបានសង់ព្រះដំណាក់របស់ព្រះអង្គនៅក្រុងយេរូសាឡឹមរហូតតទៅ។[26]ដូច្នេះ ពួកលេវីមិនចាំបាច់សែងព្រះពន្លា និងគ្រឿងបរិក្ខារទាំងប៉ុន្មាន ដែលសម្រាប់ប្រើប្រាស់ក្នុងព្រះពន្លាទៀតឡើយ»។
[27]គេបានរាប់ចំនួនកូនចៅលេវីចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ ស្របតាមបណ្តាំចុងក្រោយរបស់ព្រះបាទដាវីឌ។
[28]ពួកគេមានភារកិច្ចជួយកូនចៅរបស់លោកអើរ៉ុនក្នុងការបំពេញកិច្ចការក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។ ពួកគេត្រូវថែរក្សាទីធ្លា បន្ទប់នានា
ពិធីជម្រះវត្ថុផ្សេងៗដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់ឲ្យបានបរិសុទ្ធនិងបំពេញកិច្ចការផ្សេងៗទៀតក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។[29]ពួកគេត្រូវតម្កល់នំប៉័ងថ្វាយព្រះអម្ចាស់ រៀបចំម្សៅម៉ដ្ដសម្រាប់តង្វាយម្សៅ ព្រមទាំងរៀបចំនំក្រៀបធ្វើពីម្សៅឥតដាក់មេ នំចម្អិនដោយប្រើពុម្ព ឬនំផ្សេងៗទៀតដែលលាយជាមួយប្រេង។ ពួកគេក៏ទទួលខុសត្រូវពិនិត្យមើលរង្វាស់និងទំហំនៃរង្វាល់ទាំងប៉ុន្មានដែរ។
[30]ពួកគេត្រូវស្ថិតនៅក្នុងព្រះដំណាក់រៀងរាល់ព្រឹក និងរៀងរាល់ល្ងាច ដើម្បីលើកតម្កើង និងអរព្រះគុណព្រះអម្ចាស់[31]ហើយត្រូវថ្វាយតង្វាយដុតទាំងមូលចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ នៅថ្ងៃសប្ប័ទ ថ្ងៃបុណ្យចូលខែថ្មី ឬថ្ងៃបុណ្យសំខាន់ៗផ្សេងទៀត តាមចំនួនដែលបានកំណត់ទុកក្នុងក្បួនតម្រា ដែលគេត្រូវអនុវត្តតាមជានិច្ច
នៅចំពោះព្រះជាម្ចាស់។
[32]ពួកគេទទួលបន្ទុកក្នុងការមើលថែពន្លាជួបព្រះអម្ចាស់ ទីសក្ការបូជា និងជួយកូនចៅអើរ៉ុនក្នុងការបំពេញមុខងារក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។

---

1 Chronicles 23:1
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌតែងតាំងព្រះបាទសាឡូម៉ូនជាអ្នកស្នងតំណែង
ហើយចាត់តាំងបូជាចារ្យនិងពួកលេវីឲ្យបំពេញមុខងារនៅក្នុងព្រះវិហារ។
គេរាប់ចំនួនក្រុមលេវីដែលមានអាយុសាមសិបឆ្នាំឡើងទៅ។
ការបកប្រែផ្សេងទៀត
«មនុស្សមួយចំនួនរបស់ព្រះបាទដាវីឌរាប់ពួកលេវីដែលមានអាយុ៣០ឆ្នាំឡើងទៅ»
ពួកគេទាំងអស់មានចំនួន៣៨,០០០នាក់។
ប្រាំបីពាន់។ ការបកប្រែផ្សេងទៀត «មានចំនួន ៣៨,០០០»
1 Chronicles 23:4
«ក្នុងចំណោមមនុស្សទាំងនេះមានពីរម៉ឺនបួនពាន់នាក់
បួនពាន់។ ការបកប្រែផ្សេងទៀត «ក្នុងចំណោមពួកលេវីទាំង២៤,០០០នាក់»
ប្រាំមួយពាន់នាក់
«ពួកលេវី ៦.០០០ នាក់»
ជាមន្ត្រី និងជាចៅក្រម
ពួកលេវីទាំងនេះស្តាប់ការជជែកវែកញែកស្របច្បាប់
និងគ្រប់គ្រងយុត្តិធម៌ស្របតាមក្រឹត្យវិន័យរបស់លោកម៉ូសេ។
បួនពាន់នាក់
«ពួកលេវី ៤០០០នាក់»
អ្នកយាមទ្វារព្រះដំណាក់
ពួកលេវីទាំងនេះបានយាមទ្វារចូលព្រះវិហារ ដូច្នេះ
គ្មានអ្នកណាដែលមិនស្អាតចូលទេ។
កូនចៅ
«ផ្នែកលើ» ឬ «យោងទៅតាមកូនចៅរបស់»
អំបូរកេហាត់ អំបូរកេហាត់ និងអំបូរម៉្រារី។
ទាំងនេះជាឈ្មោះកូនប្រុសរបស់លោកលេវី។
1 Chronicles 23:7
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមក្រុមលេវីតាមអំបូររបស់ពួកគេ។
1 Chronicles 23:10
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមក្រុមលេវីតាមអំបូររបស់ពួកគេ។
ដូច្នេះ ពួកគេក៏បញ្ចូលគ្នាជាក្រុមគ្រួសារតែមួយ
ការបកប្រែផ្សេងទៀត «ដូច្នេះ ព្រះបាទដាវីឌបានចាត់ទុកពួកគេជាត្រកូលតែមួយ»
1 Chronicles 23:12
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមក្រុមលេវីតាមអំបូររបស់ពួកគេ។
លោកកេហាត់មានកូនប្រុសបួននាក់
ការបកប្រែផ្សេងទៀត «លោកកេហាត់មានកូនប្រុស៤ នាក់»
លោកអើរ៉ុនត្រូវបានជ្រើសរើសឲ្យញែកអ្វីៗដែលសក្ការបំផុតដែលគាត់
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានជ្រើសរើសលោកអើរ៉ុន
ដើម្បីថ្វាយតង្វាយវិសុទ្ធបំផុត»
ប្រទានពរក្នុងនាមព្រះអង្គជារៀងរហូត
ការបកប្រែផ្សេងទៀត
«ដើម្បីប្រទានពរដល់ប្រជាជនក្នុងនាមជាតំណាងរបស់ព្រះជាម្ចាស់ជារៀងរហូត»
របស់លោកត្រូវបានគេចាត់ទុកថា ជាពួកលេវី។
ការបកប្រែផ្សេងទៀត «កូនប្រុសរបស់គាត់ជាសមាជិកនៃត្រកូលលេវី» ។
កូនរបស់លោកម៉ូសេជាក្រុមលេវី។
1 Chronicles 23:15
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមក្រុមលេវីតាមអំបូររបស់ពួកគេ។
1 Chronicles 23:19
ព័ត៌មានទូទៅ៖
នេះជាបញ្ជីរាយនាមក្រុមលេវីតាមអំបូររបស់ពួកគេ។
1 Chronicles 23:21
ព័ត៌មានទូទៅ:

generated on Wed Sep 10 16:16:32 2025

នេះគឺជាបញ្ជីរាយនាមក្រុមលេវីតាមអំបូររបស់ពួកគេ។
1 Chronicles 23:24
ទាំងនេះជាកូនចៅលេវីទៅតាមពូជអំបូររបស់ពួកគេ។
ពួកគេជាមេដឹកនាំដែលត្រូវបានគេរាប់បញ្ចូលក្នុងត្រកូលនៃអំបូរ
ការបកប្រែផ្សេងទៀត «ទាំងនេះជាឈ្មោះរបស់កូនចៅលេវី
និងក្រុមគ្រួសាររបស់ពួកគេដែលមនុស្សរបស់ព្រះបាទដាវីឌបានរាប់និងចុះបញ្ជី។
ពួកគេជាមេដឹកនាំនៃអំបូរ។
ចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ
ការបកប្រែផ្សេងទៀត «ចាប់ពីអាយុ២០ឆ្នាំឡើងទៅ»
ដែលសម្រាប់ប្រើប្រាស់ក្នុងព្រះពន្លាទៀតឡើយ
ការបកប្រែផ្សេងទៀត
«និងឧបករណ៍ទាំងអស់ដែលពួកគេបានប្រើក្នុងការបម្រើរបស់ខ្លួន»
1 Chronicles 23:27
ស្របតាមបណ្តាំចុងក្រោយរបស់ព្រះបាទដាវីឌ។
ការបកប្រែផ្សេងទៀត «សម្រាប់បណ្តាំចុងក្រោយរបស់ព្រះបាទដាវីឌ
គឺឲ្យពួកមនុស្សរបស់ព្រះអង្គរាប់ពួកលេវី។»
គេបានរាប់ចំនួនកូនចៅលេវីចាប់ពីអាយុម្ភៃឆ្នាំឡើងទៅ
ការបកប្រែផ្សេងទៀត «ដែលមានអាយុ២០ឆ្នាំឡើងទៅ»
នំប៉ុងថ្វាយព្រះអម្ចាស់
សូមមើលការបកប្រែវានៅក្នុង ៩:៣០។
ម្សៅម៉ដ្ត
ម្សៅដែលមនុស្សម្នាក់ផលិតដោយកិនគ្រាប់ធញ្ញជាតិ
នំផ្សេងៗទៀតដែលលាយជាមួយប្រេង
ការបកប្រែផ្សេងទៀត «តង្វាយដែលអ្នកណាម្នាក់បានលាយជាមួយប្រេង»
1 Chronicles 23:30
ពួកគេត្រូវស្ថិតនៅក្នុង
«ពួកលេវីក៏ឈរដែរ»
ហើយត្រូវថ្វាយតង្វាយដុតទាំងមូលចំពោះព្រះភ័ក្ត្រព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «ពេលណាបូជាចារ្យថ្វាយតង្វាយដុតដល់ព្រះអម្ចាស់
ថ្ងៃបុណ្យចូលខែថ្មី
ថ្ងៃឈប់សម្រាកទាំងនេះសម្គាល់ការចាប់ផ្តើមនៃខែថ្មីនីមួយៗ។
តាមចំនួនដែលបានកំណត់ទុកក្នុងក្បួនតម្រា ដែលគេត្រូវអនុវត្តតាមជានិច្ច នៅចំពោះព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «វាជាកាតព្វកិច្ចរបស់ក្រុមលេវីមួយចំនួន
ដែលត្រូវបង្ហាញវត្តមានជានិច្ចក្នុងការថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់។

---

24 [1]ក្រុមការងារជាបូជាចារ្យត្រូវបានបែងចែកតាមកូនចៅរបស់លោកអើរ៉ុនមានដូចជា៖ លោកណាដាប់ លោកអប៊ីហ៊ូវ លោកអេឡាសារ និងលោកអ៊ីថាម៉ា។
[2]លោកណាដាប និងលោកអ័ប៊ីហ៊ូវបានស្លាប់មុនឪពុកពួកគេ។ ពួកគេគ្មានកូនទេ ដូច្នេះ លោកអេឡាសារ និងលោកអ៊ីថាម៉ាបានបំពេញមុខងារជាបូជាចារ្យ។
[3]ព្រះបាទដាវីឌ រួមជាមួយ
លោកសាដុកដែលជាកូនចៅរបស់លោកអេឡាសារនិងលោកអហ៊ីម៉ាឡេកដែលជាកូនចៅរបស់លោកអ៊ីថាម៉ាបានបែងចែកពួកគេជាក្រុមសម្រាប់ការងាររបស់ពួកគេជាបូជាចារ្យ។
[4]មានមេដឹកនាំក្នុងចំណោមកូនចៅរបស់លោកអេឡាសារច្រើនជាងក្នុងចំណោមកូនចៅរបស់លោកអ៊ីថាម៉ា ដូច្នេះគេបែងចែកកូនចៅរបស់លោកអេឡាសារជាដប់ប្រាំមួយ
ក្រុមគ្រួសារ ហើយកូនចៅលោកអ៊ីថាម៉ារជាប្រាំបីក្រុមគ្រួសារ ព្រមទាំងមានមេដឹកនាំតាមក្រុមគ្រួសារនីមួយៗផង។[5]ការបែងចែកនេះធ្វើឡើងដោយចាប់ឆ្នោត ហើយមាន
ចំនួនស្មើៗគ្នា ដ្បិតអ្នកគ្រប់គ្រងការងារនៅក្នុងទីសក្ការៈ និងអ្នកគ្រប់គ្រងការងាររបស់ព្រះជាម្ចាស់ សុទ្ធតែមកពីចំណោមកូនចៅរបស់លោកអេឡាសារ និងកូនចៅរបស់
លោកអ៊ីថាម៉ារ។
[6]លោកសេម៉ាយ៉ាជាកូនរបស់លោកនេថានេលជាស្មៀនពីកុលសម្ព័ន្ធលេវីបានសរសេរឈ្មោះរបស់ពួកគេនៅចំពោះមុខព្រះរាជា មន្ត្រី
និងលោកបូជាចារ្យសាដុកលោកអហ៊ីម៉ាឡេកជាកូនរបស់លោកអប៊ៀថើរ និងមេដឹកនាំក្រុមបូជាចារ្យ ព្រមទាំងក្រុមលេវី។ គេចាប់ឆ្នោតឆ្លាស់គ្នារវាងក្រុមគ្រួសាររបស់លោក
អេឡាសារ និងក្រុមគ្រួសាររបស់លោកអ៊ីថាម៉ារ ។
[7]ឆ្នោតទី១ ត្រូវលើលោកយេហូយ៉ារីប ឆ្នោតទី២ ត្រូវលើលោកយេដាយ៉ា[8]ឆ្នោតទី៣ ត្រូវលើលោកហារីម ឆ្នោតទី៤ ត្រូវលើលោកសេអូរីម[9]ឆ្នោតទី៥ ត្រូវលើលោកម៉ាល់គីយ៉ា
ឆ្នោតទី៦ ត្រូវលើលោកមីយ៉ាមីន[10]ឆ្នោតទី៧ ត្រូវលើលោកហាក់កូស ឆ្នោតទី៨ ត្រូវលើលោកអប៊ីយ៉ា
[11]ឆ្នោតទី៩ ត្រូវលើលោកយេសួ ឆ្នោតទី១០ ត្រូវលើលោកសេកានា[12]ឆ្នោតទី១១ ត្រូវលើលោកអេលីយ៉ាស៊ីប ឆ្នោតទី១២ ត្រូវលើលោកយ៉ាគីម[13]ឆ្នោតទី១៣
ត្រូវលើលោកហ៊ូផា ឆ្នោតទី១៤ ត្រូវលើលោកយេសេបៀប[14]ឆ្នោតទី១៥ ត្រូវលើលោកប៊ីលកា ឆ្នោតទី១៦ ត្រូវលើលោកអ៊ីមេម៉ើរ
[15]ឆ្នោតទី១៧ ត្រូវលើលោកហេសើរ ឆ្នោតទី១៨ ត្រូវលើលោកហាភីសេស[16]ឆ្នោតទី១៩ ត្រូវលើលោកពេថាហ៊ីយ៉ា ឆ្នោតទី២០ ត្រូវលើលោកហេសិគាល[17]ឆ្នោតទី២១ ត្រូវ
លើលោកយ៉ាគីន ឆ្នោតទី២២ ត្រូវលើលោកកាមូល[18]ឆ្នោតទី២៣ ត្រូវលើលោកដេឡាយ៉ា ឆ្នោតទី២៤ ត្រូវលើលោកមាស៊ា។
[19]អ្នកទាំងនេះទទួលភារកិច្ចតាមមុខងាររបស់ខ្លួន ដើម្បីចូលទៅបម្រើការងារក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ ស្របតាមក្បួនច្បាប់ដែលលោកអើរ៉ុន ជាបុព្វបុរសរបស់ពួកគេ
បានចែងទុក ដូចព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល បានបង្គាប់មកលោក។
[20]ពួកកូនចៅលេវីផ្សេងទៀតមានដូចជា: ក្នុងចំណោមកូនចៅរបស់លោកអាំរ៉ាមគឺមានសេបួល ក្នុងអំបូរសេបាអែលគឺមានលោកយេឌីយ៉ា។
[21]កូនរបស់លោករេហាបយ៉ាមានលោកយីស៊ីយ៉ាជាមេដឹកនាំ។[22]កូនចៅរបស់លោកអ៊ីសាវីតមាន លោកសេឡូម៉ូត ក្នុងចំណោមកូនចៅរបស់លោកសេឡូម៉ូតមាន លោក
យ៉ាហាត់។
[23]កូនរបស់ហេប្រុន៖ មានលោកយេរីយ៉ាជាមេដឹកនាំ លោកអម៉ារីយ៉ាជាមេទីពីរ លោកយ៉ាហាសៀលទីបី និងយេកាមៀមជាមេទីបួន។[24]កូនរបស់អ៊ូស៊ាលមានលោកមីកា។
កូនចៅរបស់លោកមីកាមានលោកសាមៀរ។[25]ប្អូនប្រុសរបស់លោកមីកាគឺលោកយីស៊ីយ៉ា។ កូនរបស់លោកយីស៊ីយ៉ាមានលោកសាការី។
[26]កូនចៅរបស់លោកម៉្រារីមាន លោកម៉ាលី និងលោកមូស៊ី។ កូនរបស់លោកយ៉ាស៊ាមានលោកបេណូ។[27]កូនចៅរបស់លោកម៉្រារីមានលោកយ៉ាស៊ា លោកបេណូ លោក
សូហាំ លោកសាគើរ និងលោកអ៊ីបរី។[28]លោកអេឡាសារ ជាកូនរបស់លោកម៉ាលី គ្មានកូនប្រុសទេ។
[29]កូនប្រុសៗរបស់លោកគីសជាកូនរបស់គីសមាន យេរ៉ាមែល[30]កូនប្រុសៗរបស់មូស៊ី គឺម៉ាលី អេឌើរ និងយេរីម៉ូត។
នេះជាក្រុមលេវីដែលត្រូវបានរាយឈ្មោះក្នុងគ្រួសាររបស់គេ។[31]បុរសទាំងនោះជាមេគ្រួសារ និងជាបងប្អូនរបស់គេរៀងៗខ្លួន
គេបានបោះឆ្នោតនៅចំពោះព្រះភ័ក្ត្រព្រះបាទដាវីឌ លោកសាដុក និងលោកអហ៊ីម៉ាឡេកព្រមទាំងមេដឹកនាំក្រុមបូជាចារ្យ និងក្រុមលេវី។
ពួកគេត្រូវបានបោះឆ្នោតដូចជាកូនចៅរបស់លោកអើរ៉ុនបានធ្វើដែរ។

---

1 Chronicles 24:1
លោកណាដាប់ លោកអប៊ីហ៊ូវ លោកអេឡាសារ លោកអ៊ីថាម៉ា
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ៦:១។
លោកអហ៊ីម៉ាឡេក
នេះជាឈ្មោះបុរស។
បានបែងចែកពួកគេជាក្រុម
«បានបែងចែកកូនចៅរបស់លោកអេឡាសារ និងអ៊ីថាម៉ាជាក្រុម»
1 Chronicles 24:4
គេបែងចែក
«ព្រះបាទដាវីឌ លោកសាដុក និងលោកអហ៊ីម៉ាឡេកបានបែកគ្នា»
ជាដប់ប្រាំមួយក្រុមគ្រួសារ
«១៦ក្រុម»
ជាប្រាំបីក្រុមគ្រួសារ ព្រមទាំងមានមេដឹកនាំតាមក្រុមគ្រួសារនីមួយៗផង។
មានការបែងចែកចំនួន៨ ដោយផ្អែកលើអំបូរនៃកូនចៅអ៊ីថាម៉ារ។
1 Chronicles 24:6
លោកសេម៉ាយ៉ា
នេះជាឈ្មោះបុរស។
លោកនេថានេល

generated on Wed Sep 10 16:16:32 2025

សូមមើលការបកប្រែនៅក្នុង ១៥:២២។
លោកអហ៊ីម៉ាឡេក
សូមមើលការបកប្រែនៅក្នុង ១៨:១៤។
គេចាប់ឆ្នោតឆ្លាស់គ្នារវាងក្រុមគ្រួសាររបស់លោកអេឡាសារ និងក្រុមគ្រួសាររបស់លោកអ៊ីថាម៉ារ ។
ការបកប្រែផ្សេងទៀត
«ពួកគេបានជ្រើសរើសតាមរយៈការចាប់ឆ្នោតពីកូនចៅរបស់លោកអេឡាសារ
បន្ទាប់មកពួកគេនឹងជ្រើសរើសតាមរយៈការចាប់ឆ្នោតពីកូនចៅរបស់លោក
អ៊ីថាម៉ារ»
1 Chronicles 24:7
ព័ត៌មានទូទៅ៖
នេះជាលំដាប់នៃការបម្រើ ដែលព្រះបាទដាវីឌ លោកសាដុក
និងលោកអហ៊ីម៉ាឡេកបានជ្រើសរើសយ៉ាងច្រើនសម្រាប់កូនចៅលោកអេឡាសារ
និងលោកអ៊ីថាម៉ារ។
1 Chronicles 24:11
ព័ត៌មានទូទៅ៖
នេះជាលំដាប់នៃការបម្រើ ដែលព្រះបាទដាវីឌ លោកសាដុក
និងលោកអហ៊ីម៉ាឡេកបានជ្រើសរើសយ៉ាងច្រើនសម្រាប់កូនចៅលោកអេឡាសារ
និងលោកអ៊ីថាម៉ារ។
1 Chronicles 24:15
ព័ត៌មានទូទៅ៖
នេះជាលំដាប់នៃការបម្រើ ដែលព្រះបាទដាវីឌ លោកសាដុក
និងលោកអហ៊ីម៉ាឡេកបានជ្រើសរើសយ៉ាងច្រើនសម្រាប់កូនចៅលោកអេឡាសារ
និងលោកអ៊ីថាម៉ារ។
1 Chronicles 24:19
ស្របតាមក្បួនច្បាប់ដែលលោកអើរ៉ុន ជាបុព្វបុរសរបស់ពួកគេបានចែងទុក ដូចព្រះអម្ចាស់ជាព្រះ
របស់ជនជាតិអ៊ីស្រាអែល បានបង្គាប់មកលោក។
ការបកប្រែផ្សេងទៀត
«ធ្វើតាមច្បាប់ដែលបុព្វបុរសរបស់ពួកគេបានប្រគល់ឲ្យលោកអើរ៉ុន»
1 Chronicles 24:20
ព័ត៌មានទូទៅ៖
នេះការចាប់ផ្តើមនៃបញ្ជីឈ្មោះកូនប្រុសផ្សេងទៀតរបស់លោកលេវី។
បញ្ជីនេះនឹងបញ្ចប់នៅក្នុង ២៤:២៩។
លោកអាំរ៉ាម
សូមមើលការបកប្រែនៅក្នុង ៦:១។
សេប៊ូអែល
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ២៣:១៥ ។
1 Chronicles 24:23
ហេប្រុន ... លោកយេរីយ៉ាh ... លោកអម៉ារីយ៉ា.. លោកយ៉ាហាសៀល ... យេកាមៀម
សូមមើលការបកប្រែឈ្មោះបុរសទាំងនេះនៅក្នុង ២៣:១៩ ។
អ៊ូសាល ... លោកមីកា ... លោកយីស៊ីយ៉ា
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ២៣:១៩។
លោកសាមៀរ ... លោកសាការី
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 24:26
លោកម៉្រារីមាន ... លោកម៉ាលី ... លោកមូស៊ី ... លោកអេឡាសារ
សូមមើលការបកប្រែឈ្មោះរបស់បុរសទាំងនេះនៅក្នុង ២៣:២១។
លោកម៉្រារី ... លោកយ៉ាស៊ា ... លោកបេណូ ... លោកសូហាំ ... លោកសាគើរ ... លោកអ៊ីបរី
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 24:29
លោកគីស ... មូស៊ី
សូមមើលការបកប្រែឈ្មោះរបស់បុរសទាំងនេះនៅក្នុង ២៣:២១។
យេរ៉ាមែល ... គីម៉ាលី ... អេឌើរ ... យេរីម៉ូត
ទាំងនេះជាឈ្មោះបុរស។
លោកអហ៊ីម៉ាឡេក
សូមមើលការបកប្រែឈ្មោះរបស់គាត់នៅក្នុង ១៨:១៤ ។

---

25 [1]ព្រះបាទដាវីឌ និងពួកមេដឹកនាំនៃព្រះពន្លាបានជ្រើសរើសកូនចៅរបស់អេសាភ កូនចៅលោកហេម៉ាន និងកូនចៅលោកយេឌូថុន
អ្នកទាំងនេះត្រូវបានញែកចេញសម្រាប់ច្រៀងថ្លែងព្រះបន្ទូលដោយលេងពិណ ឃឹម និងស្គរកំដរផង។ នេះជាបញ្ជីរាយនាមអ្នកដែលបំពេញមុខងារនេះ។
[2]កូនចៅរបស់លោកអេសាភមាន លោកសាកូស លោកយ៉ូសែប លោកនេថានា
និងលោកអេសាលាជាកូនប្រុសរបស់លោកអេសាភក្រោមការដឹកនាំរបស់លោកអេសាភដែលបានទាយក្រោមការដឹកនាំរបស់ស្តេច។
[3]កូនចៅរបស់លោកយេឌូថុនគឺលោកកេដាលាយ៉ា លោកហ្សេរី លោកយេសាយ៉ា លោកស៊ីម៉ៃ លោកហាសាបយ៉ា និងលោកម៉ាត់ធានា
ទាំងអស់មានចំនួនប្រាំមួយនាក់នៅក្រោមការដឹកនាំរបស់លោកយេឌូថុនជាឪពុក ហើយជាអ្នកលេងពិណសរសើរ និងលើកតម្កើងព្រះអម្ចាស់។
[4]កូនចៅរបស់លោកហេម៉ានមាន៖ លោកប៊ូគីគា លោកម៉ាត់ថានា លោកអូសៀល លោកសេប៊ូល លោកយេរីម៉ូត លោកហាណានា លោកហាណានី អេលីតា
លោកគីដាលធី លោករ៉ូម៉ាមធី លោកអេស៊ើរ លោកយ៉ូសបេកាសា លោកម៉ាលឡូធី លោកហូធី និងម៉ាហាស៊ីយ៉ូត។
[5]អ្នកទាំងនោះសុទ្ធតែជាកូនរបស់លោកហេម៉ានដែលជាព្យាការីរបស់ស្តេច។ ព្រះជាម្ចាស់បានប្រទានឲ្យលោកហេម៉ានកូនប្រុស ១៤នាក់ និងកូនស្រី ៣នាក់
ដើម្បីគោរពគាត់។
[6]ទាំងអស់នេះស្ថិតនៅក្រោមការដឹកនាំរបស់ឪពុករបស់ពួកគេ។ ពួកគេជាអ្នកលេងភ្លេងនៅក្នុងដំណាក់របស់ព្រះអម្ចាស់ដែលមានប្រដាប់ប្រដាភ្លេង
និងឧបករណ៍តន្ត្រីផ្សេងៗនៅពេលពួកគេបម្រើក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។ លោកអេសាភ លោកយេឌូថុន
និងលោកហេម៉ានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជា។[7]ពួកគេ និងបងប្អូនប្រុសៗរបស់ពួកគេដែលមានជំនាញ ហើយបានបង្ហាត់បង្រៀនឲ្យមានជំនាញខាងចម្រៀង
តម្កើងព្រះអម្ចាស់ ទាំងអស់មានចំនួន ២៨៨ នាក់។[8]ពួកគេចាប់ឆ្នោត ដើម្បីកំណត់មុខងាររៀងៗខ្លួន គឺទាំងអ្នកតូច ទាំងអ្នកធំ ទាំងគ្រូ ទាំងសិស្ស។
[9]កូនរបស់លោកអេសាភ ឆ្នោតទីមួយត្រូវលើលោកយ៉ូសែប និងគ្រួសាររបស់គាត់ ឆ្នោតទីពីរត្រូវលើលោកកេដាលា ព្រមទាំងកូន និងបងប្អូនរបស់គាត់ដែលមានចំនួន
ដប់ពីរនាក់។[10]ឆ្នោតទីបីត្រូវលើលោកសាគើរ ព្រមទាំងកូន និងបងប្អូនរបស់គាត់ ដែលមានចំនួនដប់ពីរនាក់។[11]ឆ្នោតទីបួនត្រូវលើលោកយីសរី ព្រមទាំងកូន និងបងប្អូន
របស់គាត់ ដែលមានចំនួនដប់ពីរនាក់។[12]ឆ្នោតទីប្រាំត្រូវលើលោកនេថានា ព្រមទាំងកូន និងបងប្អូនរបស់គាត់ ដែលមានចំនួនដប់ពីរនាក់។
[13]ឆ្នោតទីប្រាំមួយត្រូវលើលោកប៊ូគីគាព្រមទាំងកូន និងបងប្អូនរបស់គាត់ ដែលមានចំនួនដប់ពីរនាក់។[14]ឆ្នោតទីប្រាំពីរត្រូវលើលោកយេសារេឡា ព្រមទាំងកូន និងបងប្អូន
របស់គាត់ ដែលមានចំនួនដប់ពីរនាក់។[15]ឆ្នោតទីប្រាំបីត្រូវលើលោកយេសាយ៉ា ព្រមទាំងកូន និងបងប្អូនរបស់គាត់ ដែលមានចំនួនដប់ពីរនាក់។[16]ឆ្នោតទីប្រាំបួនត្រូវលើ
លោកម៉ាត់ថានាព្រមទាំងកូន និងបងប្អូនរបស់គាត់ ដែលមានចំនួនដប់ពីរនាក់។
[17]ឆ្នោតទីដប់ធ្លាក់ទៅលើលោកស៊ីម៉ៃព្រមទាំងកូនប្រុស និងបងប្អូនរបស់គាត់ដែលមានចំនួនដប់ពីរនាក់។[18]ឆ្នោតទីដប់មួយបានធ្លាក់ទៅលើលោកអសារេល
ព្រមទាំងកូនប្រុស និងបងប្អូនរបស់គាត់ដែលមានចំនួនដប់ពីរនាក់។[19]ឆ្នោតទីដប់ពីរបានធ្លាក់លើលោកហាសាបយ៉ាព្រមទាំងកូនៗ
និងបងប្អូនរបស់គាត់ដែលមានចំនួនដប់ពីរនាក់។[20]ឆ្នោតទីដប់បីបានធ្លាក់ទៅលើស៊ូបាអែលព្រមទាំងកូនប្រុស និងបងប្អូនរបស់គាត់ដែលមានចំនួនដប់ពីរនាក់។
[21]ឆ្នោតទីដប់បួនបានធ្លាក់ទៅលើលោកម៉ាធីធាព្រមទាំងកូន និងបងប្អូនញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។
[22]ឆ្នោតទីដប់ប្រាំបានធ្លាក់ទៅលើលោកយេរេម៉ូតព្រមទាំងកូនប្រុសនិងបងប្អូនញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។
[23]ឆ្នោតទីដប់ប្រាំមួយបានធ្លាក់ទៅលើលោកហាណានាព្រមទាំងកូន និងបងប្អូនញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។
[24]ឆ្នោតទីដប់ប្រាំពីរបានធ្លាក់ទៅលើលោកយ៉ូស្បេ ព្រមទាំងកូន និងបងប្អូនញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។
[25]ឆ្នោតទីដប់ប្រាំបីបានធ្លាក់ទៅលើលោកហាណានី ព្រមទាំងកូនប្រុសនិងបងប្អូនញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។
[26]ឆ្នោតទីដប់ប្រាំបួនបានធ្លាក់ទៅលើលោកម៉ាលឡូធី ព្រមទាំងកូនប្រុស និងបងប្អូនរបស់គាត់ដែលមានចំនួនដប់ពីរនាក់។[27]ឆ្នោតទីម្ភៃបានធ្លាក់លើលោកអេលីថា

generated on Wed Sep 10 16:16:32 2025

ព្រមទាំងកូននិងញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។[28]ឆ្នោតទីម្ភៃមួយត្រូវលើលោកហូធី ព្រមទាំងកូន
និងញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។
[29]ឆ្នោតទីម្ភៃពីរបានធ្លាក់ទៅលើលោកគីដាលធី ព្រមទាំងកូនប្រុស និងញាតិសន្តានរបស់គាត់ដែលមានចំនួនដប់ពីរនាក់។[30]ឆ្នោតទីម្ភៃបីបានធ្លាក់ទៅលើលោកម៉ាហាស៊ីយ៉ូត
ព្រមកូនប្រុស និងសាច់ញាតិរបស់គាត់ដែលមានចំនួនដប់ពីរនាក់។[31]ឆ្នោតទីម្ភៃបួនបានធ្លាក់ទៅលើលោករ៉ូម៉ាមធី-អេស៊ើរ ព្រមទាំងកូន
និងបងប្អូនសាច់ញាតិរបស់គាត់ដែលមានចំនួនដប់ពីរនាក់។

---

1 Chronicles 25:1

ឈិង

សូមមើលការបកប្រែនៅក្នុង ១៣:៧។

លោកហេម៉ាន ... លោកយេឌូថុន

សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ១៦:៤០។

លោកសាកូស ... លោកម៉ាត់ធានា

ទាំងនេះជាឈ្មោះបុរស។

មានចំនួនប្រាំមួយនាក់

«ទាំងអស់៦នាក់»

1 Chronicles 25:4

ព័ត៌មានទូទៅ៖

បញ្ជីឈ្មោះបន្តរបស់អ្នកដឹកនាំនៃការបម្រើព្រះពន្លាបានចាប់ផ្តើមនៅក្នុង ២៥:១។

លោកប៊ូគីគា ...ម៉ាហាស៊ីយ៉ូត

ទាំងនេះជាឈ្មោះបុរស។

លោកហេម៉ាន

សូមមើលការបកប្នេះនៅក្នុង ១៦:៤០។

កូនប្រុស ១៤នាក់ និងកូនស្រី ៣នាក់

«កូនប្រុស១៤នាក់ និងកូនស្រី៣នាក់»

1 Chronicles 25:6

ឈិង

សូមមើលការបកប្រែនៅក្នុង ១៣:៧។

លោកយេឌូថុន ... លោកហេម៉ាន

សូមមើលការបកប្រែទាំងនេះនៅក្នុង ១៦:៤០។

ទាំងអស់មានចំនួន ២៨៨

«មានបុរសពីររយប៉ែតសិបប្រាំបីនាក់«

គឺទាំងអ្នកតូច ទាំងអ្នកធំ ទាំងគ្រូ ទាំងសិស្ស។

នេះជាការពិពណ៌នាអំពីភាពលើសលប់។ ការបកប្រែផ្សេងទៀត «ពួកគេទាំងអស់»

1 Chronicles 25:9

ព័ត៌មានទូទៅ៖

ចាប់ផ្តើមដោយបញ្ជីឈ្មោះ២៤ ដែលត្រូវចាប់ឆ្នោត
ដើម្បីជ្រើសថាតើក្រុមគ្រួសារណាត្រូវបម្រើ។ បញ្ជីនេះបញ្ចប់នៅក្នុង ២៥:២៩។

ឆ្នោតទីមួយ ...ទីប្រាំ

បង្ហាញពីលំដាប់លំដោយនៃក្រុមគ្រួសារ ដែលត្រូវបានជ្រើសរើស។
ការបកប្រែផ្សេងទៀត «លេខ ១ ... លេខ ២ ... លេខ ៣ ... លេខ ៤ ... លេខ ៥»
ឬប្រើ «ដំបូង» សម្រាប់ «ទីមួយ» និង
«បន្ទាប់»សម្រាប់លេខទាំងអស់ខាងក្រោម។

ឆ្នោតទីមួយត្រូវលើលោកយ៉ូសែប និងគ្រួសាររបស់គាត់

សម្រាប់មនុស្សទាំងអស់ផ្សេងទៀតនៅក្នុងបញ្ជី អត្ថបទបញ្ជាក់ថាមាន
«មនុស្សដប់ពីរនាក់»។ ចាប់តាំងពីបានបញ្ជាក់ថា
អ្នកប្រហែលជាចង់បន្ថែមសេចក្តីថ្លែងការណ៍នេះ
ស្តីអំពីលោកយ៉ូសែបដូចនៅក្នុងUDBដែរ។
«ការចាប់ឆ្នោតទីមួយធ្លាក់ទៅលើក្រុមគ្រួសាររបស់លោកយ៉ូសែប
ដែលមានចំនួនដប់ពីរនាក់»

លោកយ៉ូសែប ... លោកសាគើរ ...លោកនេថានា

សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ២៥:១។

លោកកេដាលា

សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ២៥:១។

មានចំនួនដប់ពីរនាក់

«១២នាក់»

1 Chronicles 25:13

ព័ត៌មានទូទៅ៖

បញ្ជីនេះបន្តចាប់ផ្តើមនៅក្នុង ២៥:៩។

ទីប្រាំមួយ ...ទីប្រាំបួន

បង្ហាញពីលំដាប់លំដោយ ដែលក្រុមគ្រួសារត្រូវបានជ្រើសរើស។
ការបកប្រែផ្សេងទៀត «លេខ ៦ ... លេខ ៧ ... លេខ ៨ ... លេខ ៩»

លោកប៊ូគីគា

សូមមើលការបកប្រែនៅក្នុង ២៥:៤។

មានចំនួនដប់ពីរនាក់

«១២នាក់»

លោកយេសារេឡា

នេះជាការសរសេរឈ្មោះមួយផ្សេងទៀតរបស់ «លោកយេសារេឡា» នៅក្នុង
២៥:១។

លោកយេសាយ៉ា

សូមមើលការបកប្រែនៅក្នុង ២៥:១។

លោកម៉ាត់ថានា

សូមមើលការបកប្រែនៅក្នុង ២៥:៤។

1 Chronicles 25:17

ព័ត៌មានទូទៅ៖

នេះជាបន្តបញ្ជីដែលបានចាប់ផ្តើមនៅក្នុង ២៥:៩។

ទីដប់ ... ទីដប់បី

នេះបង្ហាញពីលំដាប់លំដោយ ដែលក្រុមគ្រួសារត្រូវបានជ្រើសរើស។
ការបកប្រែផ្សេងទៀត «លេខ ១០ ... លេខ ១១ ... លេខ ១២ ... លេខ ១៣»

លោកស៊ីម៉ៃ

សូមមើលការបកប្រែនៅក្នុង ២៥:១។

មានចំនួនដប់ពីរនាក់

«១២ នាក់»

លោកអសារេល

នេះជាការសរសេរឈ្មោះមួយផ្សេងទៀតរបស់ «លោកអសារេល» នៅក្នុង ២៥:៤។

លោកហាសាបយ៉ា

សូមមើលការបកប្រែនៅក្នុង ២៥:១។

ស៊ូបាអែល

សូមមើលការបកប្រែនៅក្នុង ២៥:៤។

1 Chronicles 25:21

ព័ត៌មានទូទៅ៖

នេះជាបញ្ជីបន្តដែលបានចាប់ផ្តើមនៅក្នុង ២៥:៩ ។

ទីដប់ ...ទីដប់ប្រាំពីរ

នេះបង្ហាញពីលំដាប់លំដោយ ដែលក្រុមគ្រួសារត្រូវបានជ្រើសរើស។
ការបកប្រែផ្សេងទៀត «លេខ ១៤ ... លេខ ១៥ ... លេខ ១៦ ... លេខ ១៧»

លោកម៉ាធីធា

សូមមើលការបកប្រែនៅក្នុង ២៥:១។

មានចំនួនដប់ពីរនាក់

«១២ នាក់»

លោកយេរេម៉ូត

នេះជាការសរសេរឈ្មោះមួយផ្សេងទៀតរបស់ «លោកយេរេម៉ូត»។

លោកហាណានា

សូមមើលការបកប្រែនៅក្នុង ២៥:៤។

លោកយ៉ូស្បេ

សូមមើលការបកប្រែនៅក្នុង ២៥:៤។

1 Chronicles 25:25

ព័ត៌មានទូទៅ៖

នេះជាបញ្ជីបន្តដែលបានចាប់ផ្តើមនៅក្នុង ២៥:៩។

ទីដប់ប្រាំបី ...ទីម្ភៃមួយ

ដំបូង បង្ហាញពីលំដាប់លំដោយក្រុមគ្រួសារ ដែលត្រូវបានជ្រើសរើស។ «លេខ
១៨ ... លេខ ១៩ ... លេខ ២០ ... លេខ ២១»

generated on Wed Sep 10 16:16:32 2025

លោកហាណានី
សូមមើលការបកប្រែនៅក្នុង ២៥:៤។
មានចំនួនដប់ពីរនាក់
«១២ នាក់»
លោកម៉ាលឡូធី
សូមមើលការបកប្រែនៅក្នុង ២៥:៤។
លោកអេលី
សូមមើលការបកប្រែនៅក្នុង ២៥:៤។
លោកហូធី
សូមមើលការបកប្រែនៅក្នុង ២៥:៤។
1 Chronicles 25:29
ព័ត៌មានទូទៅ:
នេះជាបញ្ជីបន្តដែលបានចាប់ផ្តើមនៅក្នុង ២៥:៩។
ទីម្ភៃពីរ ... ទីម្ភៃបួន
ទីពីរ ... ម្ភៃបួន បង្ហាញពីលំដាប់លំដោយក្រុមគ្រួសារ ដែលត្រូវបានជ្រើសរើស។
«លេខ ២២ ... លេខ ២៣ ... លេខ ២៤»
លោកគីដាលធី
សូមមើលការបកប្រែនៅក្នុង ២៥:៤។
មានចំនួនដប់ពីរនាក់។
«១២ នាក់»
លោកម៉ាហាស៊ីយ៉ូត
សូមមើលការបកប្រែនៅក្នុង ២៥:៤។
លោករ៉ូម៉ាមធី-អេស៊ើរ
សូមមើលការបកប្រែនៅក្នុង ២៥:៤។

---

26 [1]នេះជាការបែងចែករបស់អ្នកយាមទ្វារ ពីកុលសម្ព័ន្ធកូរ៉ា មានលោកមេសេលេមីយ៉ាជាកូនរបស់លោកកូរ៉េ ជាពូជពង្សរបស់អេសាភ។
[2]កូនប្រុសរបស់លោកមេសេលេមីយ៉ាមាន៖ លោកសាការី ជាកូនច្បង លោកយ៉ាឌែលជាកូនទីពីរ លោកសេបាឌាជាកូនទីបី
លោកយ៉ាណាលជាកូនទីបួន[3]លោកអេឡាមជាកូនទីប្រាំ លោកយេហូហាណានជាកូនទីប្រាំមួយ លោកអេលាហូណៃជាកូនទីប្រាំពីរ។
[4]កូនប្រុសរបស់លោកអូបិឌ-អេឌុមមាន៖ លោកសេម៉ាយ៉ាជាកូនច្បង លោកយេហូសាបាតជាកូនទីពីរ លោកយ៉ូអាជាកូនទីបី សាខារជាកូនទីបួន
លោកណាថាណែលជាកូនទីប្រាំ[5]អលោកមាលាជាកូនទីប្រាំមួយ លោកអ៊ីសាកជាកូនទីប្រាំពីរ លោកពេលូថាយជាកូនទីប្រាំបី ដ្បិត
ព្រះជាម្ចាស់បានប្រទានពរដល់លោកអូបេដអេដុម។[6]លោកសេម៉ាយ៉ា ជាកូនរបស់លោកអូបេដអេដុម បង្កើតបានកូនប្រុសៗ ដែលមានសិទ្ធិគ្រប់គ្រងលើក្រុមគ្រួសាររបស់
ពួកគេ ដ្បិត ពួកគេជាវីរបុរសដ៏អង់អាច។
[7]កូនៗរបស់សេម៉ាយ៉ា មានលោកអូតនី លោករេផាអែល លោកអូបិឌ និងលោកអែលសាបាត។ ញាតិសន្តានរបស់គាត់គឺលោកអេលីហ៊ូ
និងលោកសេម៉ាស៊ីយ៉ាក៏ជាបុរសដែលមានសមត្ថភាពច្រើនដែរ។[8]អ្នកទាំងនោះសុទ្ធតែជាកូនចៅរបស់លោកអូបិឌ-អេដុម។ ពួកគេ
និងកូនប្រុសព្រមទាំងសាច់ញាតិរបស់ពួកគេគឺជាបុរសដែលមានសមត្ថភាពបំពេញភារកិច្ចរបស់ពួកគេក្នុងការងារបម្រើព្រះជាម្ចាស់នៅក្នុងព្រះពន្លា។
ពួកគេមានគ្នា៦២នាក់ដែលត្រូវជាសាច់ញាតិរបស់លោកអូបិឌ-អេដុម។[9]លោកមេសេលេមីយ៉ាមានកូនប្រុស
និងសាច់ញាតិចំនួនដប់ប្រាំបីនាក់ដែលសុទ្ធតែមានសមត្ថភាព។
[10]កូនប្រុសរបស់លោកហូសាដែលជាកូនចៅរបស់ម៉្រារីមាន លោកស៊ីមរីជាមេដឹកនាំ
(ទោះបីគាត់មិនមែនជាកូនច្បងក៏ដោយឪពុកគាត់បានតែងតាំងគាត់ឲ្យធ្វើជាមេដឹកនាំ)[11]លោកហ៊ីលគីយ៉ាទីពីរ លោកថេបាលាជាកូនទីបី លោកសាការី ជាកូនទីបួន ។
កូនប្រុស និងញាតិសន្តានរបស់លោកហូសាទាំងអស់មានចំនួនដប់បីនាក់។
[12]ពួកឆ្មាំទ្វារបែងចែកជាក្រុមៗ ហើយទាំងមេដឹកនាំ ទាំងឆ្មាំទ្វារឯទៀតៗជាបងប្អូនរបស់គេ មានមុខងារយាមព្រះដំណាក់របស់ព្រះអម្ចាស់។[13]ពួកគេចាប់ឆ្នោតដើម្បីចែកគ្នា
យាមទ្វារ តាមក្រុមគ្រួសាររបស់ខ្លួន ទាំងក្មេង ទាំងចាស់។[14]ការចាប់ឆ្នោតត្រូវលើលោកសេលេមា ជាអ្នកយាមទ្វារប៉ែកខាងកើត។ បន្ទាប់មក គេចាប់ឆ្នោតត្រូវលើលោក
សាការី ជាកូនរបស់គាត់ ដែលជាទីប្រឹក្សាមួយរូបដ៏ចំណាន។ លោកសាការីត្រូវយាមទ្វារប៉ែកខាងជើង។
[15]លោកអូបិឌ-អេដុមត្រូវបានតែងតាំងឲ្យយាមទ្វារខាងត្បូង ចំណែកកូនៗរបស់គាត់ត្រូវយាមឃ្លាំង។[16]លោកស៊ូភីម និងលោកហូសាត្រូវយាមទ្វារខាងលិច
និងទ្វារសាលេគែត ដែលស្ថិតនៅផ្លូវខាងលើ។ គ្រប់ក្រុមគ្រួសារត្រូវចែកវេនគ្នាយាម។
[17]នៅទិសខាងកើតមានពួកលេវី ៦នាក់ ខាងជើងបួននាក់ក្នុងមួយថ្ងៃ នៅខាងត្បូងមានបួននាក់ក្នុងមួយថ្ងៃហើយនៅឃ្លាំងមានពីរគូ។
[18]នៅទីលានខាងលិចមានបន្ទប់អមបួន ហើយមានបួននាក់យាមនៅតាមផ្លូវ និងពីរនាក់យាមតាមមាត់ទ្វារបន្ទប់អមនោះ។[19]អ្នកទាំងនេះជាក្រុមអ្នកយាមទ្វារ។
ពួកគេត្រូវបានជ្រើសរើសពីកូនចៅរបស់លោកកូរ៉ា និងកូនចៅលោកម៉្រារី។
[20]ក្នុងចំណោមពួកលេវីលោកអហ៊ីយ៉ាទទួលខុសត្រូវលើទ្រព្យសម្បត្តិក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ និងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់។
[21]កូនចៅរបស់លោកឡាដានជាកូនចៅរបស់លោកគើរសុន អ្នកដែលជាមេដឹកនាំលើក្រុមគ្រួសាររបស់ឡាដានពីអំបូរគើរសុនមាន លោកយេហ៊ីលី
និងកូនៗរបស់គាត់[22]គឺលោកសេថាមនិងយ៉ូអែលជាបងប្អូនរបស់គាត់ដែលមើលខុសត្រូវលើឃ្លាំងនៃព្រះដំណាក់របស់ព្រះអម្ចាស់។
[23]ក្នុងនោះក៏មានឆ្មាំទ្វារ ដែលចាប់ឆ្នោតពីត្រកូលរបស់លោកអាំរ៉ាម លោកអ៊ីសា លោកហេប្រុន និងលោកអ៊ូសៀល។
[24]លោកសេបួលជាកូនរបស់លោកគើរសុមដែលជាកូនរបស់លោកម៉ូសេជាអ្នកមើលខុសត្រូវលើឃ្លាំង។[25]សាច់ញាតិរបស់គាត់មកពីអំបូរអេលាស៊ើរមានរេហាប៊ីយ៉ា
លោករេហាប៊ីយ៉ាជាឪពុកលោកយេសាយ៉ា លោកយេសាយ៉ាជាឪពុកលោកយ៉ូរ៉ាម លោកយ៉ូរ៉ាមជាឪពុករបស់លោកស៊ីគ្រី
លោកស៊ីគ្រីជាឪពុកជាឪពុករបស់លោកសេឡូម៉ូត។
[26]លោកសេឡូម៉ូត និងបងប្អូនរបស់គាត់ មានភារកិច្ចមើលខុសត្រូវលើវត្ថុសក្ការទាំងប៉ុន្មានដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ ដែលព្រះបាទដាវីឌ ព្រមទាំងមេក្រុមគ្រួសារ
មេកង មេក្រុម និងមេទ័ពយកមកថ្វាយព្រះជាម្ចាស់។[27]វត្ថុទាំងនោះសុទ្ធសឹងជាជ័យភណ្ឌ ហើយគេញែកថ្វាយព្រះអម្ចាស់ សម្រាប់ជួសជុលព្រះដំណាក់របស់ព្រះអង្គ។
[28]ពួកគេគ្រប់គ្រងលើវត្ថុទាំងប៉ុន្មានដែលលោកសាំយូអែលជាព្យាការី ព្រះបាទសូលជាបុត្ររបស់លោកគីស លោកអប៊ីនើរ ជាកូនរបស់លោកនើរ លោកយ៉ូអាប់ ជាកូនរបស់
អ្នកស្រីសេរូយ៉ា បានថ្វាយព្រះអម្ចាស់។ គ្រប់របស់ទាំងអស់សុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកសេឡូម៉ូត និងបងប្អូនរបស់គាត់។
[29]ក្នុងចំណោមកូនចៅរបស់លោកអ៊ីសាមានលោកកេណាយ៉ា និងកូនប្រុសរបស់លោកទទួលបន្ទុកកិច្ចការស៊ីវិលនៃប្រជាជនអ៊ីស្រាអែល។ ពួកគេជាមន្ត្រី និងជាចៅក្រម។
[30]ក្នុងចំណោមកូនចៅរបស់លោកហេប្រុនមានហាសាប៊ីយ៉ា និងបងប្អូនរបស់គាត់ដែលមានចំនួន ១, ៧០០ នាក់ជាអ្នកទទួលខុសត្រូវលើកិច្ចការរបស់ព្រះអម្ចាស់
និងកិច្ចការរបស់ស្តេច។ ពួកគេស្ថិតនៅភាគខាងលិចទន្លេយ័រដាន់។
[31]ពីចំណោមកូនចៅលោកហេប្រុន មានលោកយេរីយ៉ាជាមេដឹកនាំ ហើយបានរាប់បញ្ចូលក្នុងបញ្ជីគ្រួសាររបស់ពួកគេ។
នៅឆ្នាំទីសែសិបនៃរជ្ជកាលព្រះបាទដាវីឌពួកគេបានពិនិត្យមើលកំណត់ត្រានានាហើយបានរកឃើញក្នុងចំណោមពួកគេដែលជាមនុស្សពូកែនៅយ៉ាសើរនៅស្រុកកាឡាត។
[32]លោកយេរីយ៉ាមានសាច់ញាតិចំនួន ២, ៧០០ នាក់ដែលជាមេដឹកនាំគ្រួសារដែលមានសមត្ថភាព។ ព្រះបាទដាវីឌតែងតាំងអ្នកគ្រប់គ្រងលើកុលសម្ព័ន្ធរូបេន
កុលសម្ព័ន្ធកាដ និងកុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលសម្រាប់កិច្ចការទាំងអស់ដែលទាក់ទងនឹងព្រះ និងសម្រាប់ស្តេច។

---

1 Chronicles 26:1
ព័ត៌មានទូទៅ៖
នេះជាការចាប់ផ្តើមបញ្ជីឈ្មោះអ្នកយាមទ្វារ។
លោកកូរ៉េ
សូមមើលការបកប្រែនៅក្នុង ៩:១៧។
លោកមេសេលេមីយ៉ា

generated on Wed Sep 10 16:16:32 2025

សូមមើលការបកប្រែនៅក្នុង ៩:២០។
លោកកូរ៉េ
សូមមើលការបកប្រែនៅក្នុង ៩:១៧។
អេសាភ
នេះជាការសរសេរឈ្មោះមួយផ្សេងទៀតរបស់ «លោកអេប៊ីសាភ» នៅក្នុង ៩:១៧។
លោកសាការី
សូមមើលការបកប្រែនៅក្នុង ៩:២០។
លោកយ៉ាឌែល ... លោកសេបាឌា... លោកយ៉ាឌែល ... លោកអេឡាម... លោកយេហូហាណាន ...
លោកអេលាហ្សៃ
ទាំងនេះជាឈ្មោះបុរស។
ទីពីរ ...ទីបី ... ទីបួន ... ទីប្រាំពីរ
នេះបង្ហាញពីលំដាប់លំដោយកូនប្រុសកើតមក។ ការបកប្រែផ្សេងទៀត «លេខ ២ ... លេខ ៣ ... លេខ ៤ ... លេខ ៧» ឬ «បន្ទាប់»សម្រាប់លេខនីមួយៗ។
1 Chronicles 26:4
ព័ត៌មានទូទៅ៖
នេះជាបញ្ជីឈ្មោះបន្តរបស់អ្នកយាមទ្វារ ដែលបានចាប់ផ្តើមនៅក្នុង 1CH 26:1។
លោកអូបេដអេដុម
សូមមើលការបកប្រែនៅក្នុង ១៦:៣៧។
លោកសេម៉ាយ៉ា ... លោកយេហូសាបាត ...លោកយ៉ូអា ... សាខារ...
លោកណាថាណែល ...អលោកមាលា... លោកអ៊ីសាក ...លោកពេលូថាយ
ទាំងនេះជាឈ្មោះបុរស។
ទីពីរ ... ទីប្រាំបី
នេះបង្ហាញពីលំដាប់លំដោយ ដែលកូនប្រុសកើតមក។ ការបកប្រែផ្សេងទៀត «លេខ ២ ... លេខ ៣ ... លេខ ៤ ... លេខ ៥ ... លេខ ៦ ... លេខ ៧ ... លេខ ៨» ឬ «បន្ទាប់» សម្រាប់លេខនីមួយៗ។
1 Chronicles 26:7
ព័ត៌មានទូទៅ៖
នេះជាបញ្ជីឈ្មោះបន្តរបស់អ្នកយាមទ្វារ ដែលបានចាប់ផ្តើមនៅក្នុង 1CH 26:1។
សេម៉ាយ៉ា ... លោកអូបេដអេដុម
សូមមើលការបកប្រែពាក្យទាំងនេះនៅក្នុង ២៦:៤។
ញាតិសន្តានរបស់គាត់
«សាច់ញាតិរបស់លោកសេម៉ាយ៉ា» ឬ «សមាជិកគ្រួសាររបស់លោកសេម៉ាយ៉ា»
លោកអូតនី... លោកយេផាអែល ... លោកអូបិឌ ...
លោកអែលសាបាត...លោកអេលីហ៊ូ ...លោកសេម៉ាស៊ីយ៉ា ... លោកមេសេលេមីយ៉ា
ទាំងនេះជាឈ្មោះបុរស។
ពួកគេមានគ្នា៦២នាក់
ពីរនាក់ក្នុងចំណោមពួកគេ «បុរស៦២ នាក់»
ចំនួនដប់ប្រាំបីនាក់ដែលសុទ្ធតែមានសមត្ថភាព
«សរុប ១៨នាក់»
1 Chronicles 26:10
ព័ត៌មានទូទៅ:
នេះគឺនៅតែបន្តបញ្ជីនៃអ្នកយាមទ្វារដែលបានចាប់ផ្តើមនៅក្នុង 1CH 26:1.
លោកហូសា ... ម៉ារី ... លោកស៊ីមរី ... លោកហ៊ីលគីយ៉ា ... លោកថេបាលា ... លោកសាការី
ទាំងនេះគឺជាឈ្មោះរបស់បុរស។
ទីបីរ ... ទីបី ... ទីបួន
នេះបង្ហាញពីលំដាប់ដែលកូនប្រុសកើតមក។ការបកប្រែផ្សេងទៀត:«លេខ ២ ... លេខ ៣ ... លេខ ៤»ឬ«បន្ទាប់» សម្រាប់លេខនីមួយៗ។
កូនប្រុស និងញាតិសន្តានរបស់លោកហូសាទាំងអស់មានចំនួនដប់បីនាក់។
ការបកប្រែផ្សេងទៀត «មានកូនប្រុស និងញាតិសន្តានរបស់លោកហូសាចំនួន ១៣ នាក់។»
1 Chronicles 26:12
ទាំងក្មេង ទាំងចាស់
ការបកប្រែផ្សេងទៀត «មនុស្សគ្រប់រូប» ឬ «បុរសគ្រប់វ័យ»
លោកសេលេមា
នេះជាសរសេរឈ្មោះមួយផ្សេងទៀតរបស់ «លោកមីសេលេម៉ា» នៅក្នុង ២៦:១។
លោកសាការី
សូមមើលការបកប្រែនៅក្នុង ២៦:១។
ការចាប់ឆ្នោតត្រូវលើ
ការបកប្រែផ្សេងទៀត «ពេលពួកគេបោះត្រូវលើ»
ដែលជាទីប្រឹក្សាមួយរូបដ៏ចំណាន
នេះជាមនុស្សដែលបង្ហាញពីសុភវិនិច្ឆ័យក្នុងការសម្រេចចិត្ត។
1 Chronicles 26:15
លោកអូបេដអេដុមត្រូវបានតែងតាំងឲ្យយាមទ្វារខាងត្បូង ចំណែកកូនៗរបស់គាត់ត្រូវយាមឃ្លាំង។
«លោកអូបេដអេដុម ទទួលខុសត្រូវយាមទ្វារខាងត្បូង
ហើយកូនប្រុសរបស់គាត់យាមឃ្លាំង» ។
លោកអូបេដអេដុម
សូមមើលការបកប្រែនៅក្នុង ២៦:៤។
លោកស៊ូភីម
នេះជាឈ្មោះបុរស។
លោកហូសា
សូមមើលការបកប្រែនៅក្នុង ២៦:១០។
ទ្វារសាលេគែត
នេះជាឈ្មោះច្រកទ្វារ។
គ្រប់ក្រុមត្រួសារត្រូវចែកវេនគ្នាយាម។
ការបកប្រែផ្សេងទៀត «គ្រួសារនីមួយៗទទួលខុសត្រូវក្នុងការការពារអ្វីមួយ។»
1 Chronicles 26:17
ពួកលេវី ៦នាក់
«លេវី ៦នាក់»
បួននាក់ក្នុងមួយថ្ងៃ
«បុរស ៤នាក់ក្នុងមួយថ្ងៃ»
មានពីរគូ
«បុរស ២គូ» ឬ «បុរស ២នាក់ក្នុងពេលតែមួយ»
នៅទីលានខាងលិចមានបន្ទប់អមបួន
ការបកប្រែផ្សេងទៀត «បុរស ៤នាក់បានយាមទីលាននៅខាងលិច»
ហើយមានបួននាក់យាមនៅតាមផ្លូវ និងពីរនាក់យាមតាមមាត់ទ្វារបន្ទប់អមនោះ។
«បុរស ៤នាក់យាមផ្លូវ ហើយបុរសពីរនាក់យាមនៅទីលាន»
ពួកគេត្រូវបានជ្រើសរើសពី
ការបកប្រែផ្សេងទៀត «ពួកគេ»
លោកម៉ូរី
សូមមើលការបកប្រែនៅក្នុង ២៦:១០។
1 Chronicles 26:20
កូនចៅរបស់លោកឡាដានជាកូនចៅរបស់លោកគើរសុន
អ្នកដែលជាមេដឹកនាំលើក្រុមគ្រួសាររបស់ឡាដានពីអំបូរគើរសុនមាន លោកយេហ៊ីលី
និងកូនៗរបស់គាត់
«លោកយេហ៊ីអែល និងកូនប្រុសរបស់គាត់ គឺជាកូនចៅរបស់ឡាដាន
ដែលជាកូនចៅរបស់លោកគើរសុន ដែលជាកម្មសិទ្ធិរបស់លោកឡាដាន ។
លោកយេហ៊ីលី និងកូនប្រុសរបស់គាត់
គឺជាអ្នកដឹកនាំក្រុមគ្រួសាររបស់ឡាដានកូនចៅលោកគើរសុន។
គឺជាកូនប្រុសលោកយេហ៊ីលី»
លោកឡាដាន...លោកគើរសុន
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ២៣:៧។
អំបូរគើរសុន
កូនចៅរបស់លោកគើរសុន។
លោកយេហ៊ីលី ... លោកសេថាម... យ៉ូអែល
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ២៣:៧។
ដែលមើលខុសត្រូវ
«អ្នកណាជាអ្នកត្រួតពិនិត្យ»
1 Chronicles 26:23
ក្នុងនោះក៏មានឆ្មាំទ្វារ ដែលចាប់ឆ្នោតពីត្រកូល
«មេដឹកនាំក៏បានជ្រើសរើសឆ្មាំការពារពីអំបូរ»
លោកអាំរ៉ាម លោកអ៊ីសា លោកហេប្រុន ... លោកអ៊ូស៊ៀល
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ២៣:១២។
លោកសេបួល ... លោកគើរសុម... អំបូរអេលាស៊ើរ ... រេហាប៊ីយ៉ា
សូមមើលការបកប្រែឈ្មោះទាំងនេះនៅក្នុង ២៣:១៥។
លោកយេសាយ៉ា ... លោកយ៉ូរ៉ាម ...លោកស៊ីគ្រី... លោកសេឡូម៉ូត
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 26:26
ព្រមទាំងមេក្រុមគ្រួសារ មេកង មេក្រុម

generated on Wed Sep 10 16:16:32 2025

«បុរសជាង ១.០០០នាក់ និងបុរសច្រើនជាង ១០០ នាក់»
ជាជយភណ្ឌ
អ្វីដែលកងទ័ពមួយយកពីសត្រូវរបស់ខ្លួន បន្ទាប់ពីទទួលបានជ័យជម្នះ
លោកគីស ... លោកអប៊ីនើរ... អ្នកស្រីសេរូយ៉ា
ទាំងនេះជាឈ្មោះបុរស។
គ្រប់របស់ទាំងអស់សុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រង
«អ្វីគ្រប់យ៉ាងដែលមេដឹកនាំបានញែកចេញ«
1 Chronicles 26:29
លោកអ៊ីសា ... លោកហេប្រុន
សូមមើលការបកប្រែនៅក្នុង ២៣:១២។
ទទួលបន្ទុកកិច្ចការស៊ីវិលនៃប្រជាជនអ៊ីស្រាអែល។
សំដៅទៅលើការធ្វើជំនួញជាប្រចាំរបស់ប្រជាជនអ៊ីស្រាអែល
មិនជាប់ទាក់ទងនឹងយោធា ឬព្រះវិហារទេ។ ការបកប្រែផ្សេងទៀត
«ជំនួញប្រចាំថ្ងៃរបស់ប្រជាជនអ៊ីស្រាអែល» ។
លោកកេណាយ៉ា ...ហាសាប៊ីយ៉ា
ទាំងនេះជាឈ្មោះបុរស។
ចំនួន ១,៧០០ នាក់ជាអ្នកទទួលខុសត្រូវ

«បុរសមានសមត្ថភាពមួយពាន់ប្រាំពីររយនាក់»
ព្រះអម្ចាស់ និងកិច្ចការរបស់ស្តេច
ការបកប្រែផ្សេងទៀត «ការងារដែលបានធ្វើថ្វាយព្រះអម្ចាស់ និងស្តេច»។
1 Chronicles 26:31
លោកហេប្រូន
សូមមើលការបកប្រែនៅក្នុង ២៣:១២។
លោកយេរីយ៉ា
នេះជារបៀបមួយផ្សេងទៀតក្នុងការសរសេរឈ្មោះរបស់ «លោកយេរីយ៉ា»។
សូមមើលការបកប្រែនៅក្នុង ២៣:១៩។
ហើយបានរាប់បញ្ចូលក្នុងបញ្ជី
ការបកប្រែផ្សេងទៀត «ឈ្មោះរបស់ពួកគេមាននៅក្នុងបញ្ជី»
នៅឆ្នាំទីសែសិបនៃរជ្ជកាលព្រះបាទដាវីឌ
«នៅពេលព្រះបាទដាវីឌបានសោយរាជ្យអស់រយៈពេល ៤០ ឆ្នាំ»
យ៉ាសើរ
នេះជាឈ្មោះបុរស។
មានសាច់ញាតិចំនួន ២,៧០០នាក់
«សមាជិកគ្រួសារពីរពាន់ប្រាំពីររយនាក់»

---

27 [1]នេះជាបញ្ជីរាយនាមមេដឹកនាំគ្រួសារអ៊ីស្រាអែល មេបញ្ជាការលើមួយពាន់នាក់ លើមួយរយនាក់ព្រមទាំងនាយទាហានដែលបានបម្រើស្តេចតាមរបៀបផ្សេងៗ។
កងពលយោធានីមួយៗបានបម្រើការងារជារៀងរាល់ខែពេញមួយឆ្នាំ។ កងពលនីមួយៗមានទាហាន២៤, ០០០នាក់។
[2]ក្នុងខែទីមួយគឺលោកយ៉ាសូបៀមជាកូនរបស់លោកសាបដេល។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។[3]គាត់ជាកូនចៅនៃពូជពង្សរបស់លោកពេរេស
និងទទួលមុខងារជាមេទ័ពគ្រប់គ្រងលើមេទ័ពទាំងអស់ក្នុងរយៈពេលមួយខែដំបូង។
[4]កងពលទីពីរ ដែលចេញប្រតិបត្តិការក្នុងខែទីពីរ គឺដឹកនាំដោយលោកឌូដាយ មកពីត្រកូលអហូអា។ លោកមីកឡូតជាមេបញ្ជាការរង។
នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។[5]មេបញ្ជាការនៅខែទីបីគឺលោកបេណាយ៉ាជាកូនរបស់លោកយេហូយ៉ាដា ជាបូជាចារ្យនិងជាមេដឹកនាំ។
នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។[6]លោកបេនយ៉ាជាម្នាក់ក្នុងចំណោមវីរបុរសទាំងសាមសិបនាក់ ហើយជាមេដឹកនាំលើសាមសិបនាក់ផង។
លោកអាំមីសាបាដកូនប្រុសរបស់គាត់ក៏នៅក្នុងកងពលនេះដែរ។
[7]មេបញ្ជាការនៅខែទីបួនគឺលោកអេសាអែលជាប្អូនរបស់លោកយ៉ូអាប់។ លោកសេបាឌាជាកូនប្រុសរបស់គាត់បានក្លាយជាមេបញ្ជាការបន្ទាប់ពីគាត់។
នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។[8]មេបញ្ជាការនៅខែទីប្រាំគឺលោកសែមហួតដែលជាកូនចៅរបស់អ៊ីសរ៉ា។ នៅក្នុងកងពលរបស់គាត់មានទាហាន
២៤, ០០០នាក់។[9]មេបញ្ជាការនៅខែទីប្រាំមួយគឺលោកអ៊ីរ៉ាជាកូនប្រុសរបស់លោកអ៊ីកគីសមកពីក្រុងតកូអា។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។
[10]មេបញ្ជាការសំរាប់ខែទីប្រាំពីរគឺលោកហេលេស ជាអ្នកស្រុកពេឡូនី មកពីកុលសម្ព័ន្ធអេប្រាអ៊ីម។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។
[11]មេបញ្ជាការសម្រាប់ខែទីប្រាំបីគឺលោកស៊ីបេគាជាអ្នកស្រុកហ៊ូសាតមកពីអំបូរសេរ៉ា។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។
[12]មេបញ្ជាការនៅខែទីប្រាំបួនគឺលោកអប៊ីអេស៊ើរ ជាអ្នកស្រុកអាណាថោតពីកុល សម្ព័ន្ធបេនយ៉ាមីន។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។
[13]មេបញ្ជាការសំរាប់ខែទីដប់គឺលោកម៉ាហារ៉ៃ មកពីក្រុងនេតូផាពីត្រកូលសេរ៉ា។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។
[14]មេបញ្ជាការនៅខែទីដប់មួយគឺលោកបេណាយ៉ាពីក្រុងភីរ៉ាថុនពីកុលសម្ព័ន្ធអេប្រាអ៊ីម។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។
[15]មេបញ្ជាការសម្រាប់ខែទីដប់ពីរគឺលោកហេឡៃមកពីក្រុងនេតូផា ពីអំបូរអូធ្នៀល។ នៅក្នុងកងពលរបស់គាត់មានទាហាន ២៤, ០០០នាក់។
[16]អ្នកទាំងនេះជាមេដឹកនាំនៃកុលសម្ព័ន្ធអ៊ីស្រាអែល៖ សម្រាប់កុលសម្ព័ន្ធរូបេនមានលោកអេលាស៊ើរជាកូនរបស់លោកស៊ីរីគីជាមេដឹកនាំ។
សម្រាប់កុលសម្ព័ន្ធស៊ីម្មានមានលោកសេផាធីយ៉ាជាកូនរបស់លោកម៉ាកាជាមេដឹកនាំ។[17]កុលសម្ព័ន្ធលេវីមានលោកហាសាបយ៉ាជាកូនរបស់លោកកេមួលជាមេដឹកនាំ
ហើយលោកសាដុកជាមេដឹកនាំលើកូនចៅរបស់លោកអើរ៉ុន។[18]លោកអេលីហ៊ូជាបងរបស់ព្រះបាទដាវីឌត្រូវជាមេដឹកនាំរបស់កុលសម្ព័ន្ធយូដា។
សម្រាប់កុលសម្ព័ន្ធអ៊ីសាការមានលោកអំរីជាកូនប្រុសរបស់លោកមីកែលជាអ្នកដឹកនាំ។
[19]កុលសម្ព័ន្ធសាប់យូឡូនគឺលោកអ៊ីសម៉ាយ៉ាជាកូនរបស់លោកអូបាឌាជាមេដឹកនាំ។ សម្រាប់កុលសម្ព័ន្ធណែបថាលីមានលោកយេរេម៉ូតជាកូនរបស់លោកអាសរ៉ៀល
គឺជាមេដឹកនាំ។[20]កុលសម្ព័ន្ធអេប្រាអ៊ីមមានលោកហូសេជាកូនរបស់លោកអសារាជាមេដឹកនាំ។
សម្រាប់កុលសម្ព័ន្ធម៉ាណាសេពាក់កណ្តាលមានលោកយ៉ូអែលជាកូនរបស់លោកពេដាយ៉ាជាអ្នកដឹកនាំ។
[21]កុលសម្ព័ន្ធម៉ាណាសេចំនួនពាក់កណ្តាលនៅស្រុកកាឡាដមានលោកអ៊ីដូជាកូនរបស់លោកសាការីជាមេដឹកនាំ។
សម្រាប់កុលសម្ព័ន្ធបេនយ៉ាមីនមានលោកយ៉ាសៀលជាកូនរបស់លោកអប៊ីនើរជាមេដឹកនាំ។[22]កុលសម្ព័ន្ធដាន់មានលោកអសារេលជាកូនរបស់លោកយេរ៉ូហាំជាមេដឹកនាំ។
អ្នកទាំងនេះគឺជាមេដឹកនាំលើកុលសម្ព័ន្ធអ៊ីស្រាអែល។
[23]ព្រះបាទដាវីឌមិនបានរាប់អ្នកមានអាយុម្ភៃឆ្នាំឬតិចជាងនោះទេ ព្រោះព្រះអម្ចាស់បានសន្យាថានឹងបង្កើនជនជាតិអ៊ីស្រាអែលដូចផ្កាយនៅលើមេឃ។
[24]លោកយ៉ូអាប់ជាកូនរបស់អ្នកស្រីសេរូយ៉ាបានរាប់ចំនួនបុរសទាំងនោះតែពុំបានបញ្ចប់ទេ
ដោយព្រោះសេចក្តីក្រោធរបស់ព្រះជាម្ចាស់បានធ្លាក់ទៅលើជនជាតិអ៊ីស្រាអែលដោយព្រោះការនេះ។
ចំនួនទាំងនេះមិនត្រូវបានកត់ទុកក្នុងសៀវភៅរាជប្រវត្តិរបស់ស្តេចដាវីឌទេ។
[25]លោកអាសម៉ាវេតជាកូនរបស់លោកអឌាលជាអ្នកទទួលខុសត្រូវលើរតនាគាររបស់ស្តេច។
លោកយ៉ូណាថានជាកូនរបស់លោកអូសៀសបានត្រួតត្រាលើឃ្លាំងនៅតាមទីប្រជុំជន ទីក្រុង និងតាមប៉មដែលមានកំពែងរឹងមាំ។
[26]លោកអែសរីជាកូនរបស់លោកសេលូបបានត្រួតត្រាលើកសិករដែលភ្ជួររាស់ដី។[27]លោកស៊ីម៉ែមកពីរ៉ាម៉ាជាអ្នកត្រួតត្រាលើចំការទំពាំងបាយជូរ
ហើយលោកសាបឌីមកពីស្រុកសេផាមជាអ្នកត្រួតត្រាលើស្រាទំពាំងបាយជូរនិងរោងផលិតស្រា។
[28]លោកបាលហាណាន់ ជាអ្នកក្រុងកេឌើរ មើលខុសត្រូវលើចម្ការអូលីវ និងចម្ការឧទុម្ពរនៅតំបន់វាលទំនាប។ លោកយ៉ូអាសជាអ្នកមើលខុសត្រូវលើឃ្លាំងដាក់ប្រេង។
[29]លោកស៊ីតរ្រាយជាអ្នកស្រុកសារ៉ុន មើលខុសត្រូវលើហ្វូងគោនៅស្រុកសារ៉ុន។ លោកសាផាតជាកូនរបស់លោកអឌីឡាយ ជាអ្នកមើលខុសត្រូវលើហ្វូងគោ នៅតាម
ជ្រលងភ្នំ។
[30]លោកអូប៊ីលជាជនជាតិអ៊ីស្មាអែលជាអ្នកត្រួតត្រាលើសត្វអូដ្ឋ ហើយលោកយេដេយ៉ាមកពីក្រុងមេរ៉ូណោតជាអ្នកត្រួតត្រាលើសត្វលាញី។
លោកយ៉ាស៊ីសជាអ្នកស្រុកហាគ្រី ជាអ្នកត្រួតត្រាលើហ្វូងចៀម។[31]អ្នកទាំងនោះសុទ្ធតែជាអ្នកមើលខុសត្រូវលើទ្រព្យសម្បត្តិរបស់ព្រះបាទដាវីឌ។

generated on Wed Sep 10 16:16:32 2025

[32]លោកយ៉ូណាថានដែលជាឪពុកមារបស់ព្រះបាទដាវីឌជាទីប្រឹក្សារបស់ស្តេច ពីព្រោះលោកជាមនុស្សមានប្រាជ្ញា និងជាអ្នកចេះដឹងជ្រៅជ្រះ។
លោកយេហ៊ីអែលជាកូនរបស់លោកហាក់ម៉ូនីជាគ្រូបាធ្យាយដល់បុត្រារបស់ស្តេច។[33]លោកអហ៊ីថូផែលជាទីប្រឹក្សារបស់ស្តេចលោកហ៊ូសាយ ជាជនជាតិអើគី
គឺជាទីប្រឹក្សាផ្ទាល់របស់ស្តេច។[34]លោកយេហូយ៉ាដាជាកូនរបស់លោកបេណាយ៉ា និងលោកអបៀថើរបានចូលកាន់តំណែងជំនួសលោកអហ៊ីថូផែល។
លោកយ៉ូអាប់គឺជាមេបញ្ជាការកងទ័ពរបស់ស្តេច។

---

1 Chronicles 27:1
នេះជាបញ្ជីរាយនាម
ការបកប្រែផ្សេងទៀត «ទាំងនេះជាឈ្មោះ»
តាមរបៀបផ្សេងៗ។
«នៅក្នុងរបៀបផ្សេងគ្នា» ឬ «នៅក្នុងរបៀបជាច្រើន»
កងពលយោធានីមួយៗបានបម្រើការងារ
«ក្រុមនីមួយៗ»
កងពលនីមួយៗមានទាហាន២៤,០០០នាក់។
បុរសបួនពាន់នាក់ «បុរស ២៤.០០០នាក់»
ពេញមួយឆ្នាំ
ការបកប្រែផ្សេងទៀត «ពេញមួយឆ្នាំ។»
ក្នុងខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែមីនា
និងដើមខែមេសាតាមប្រតិទិនលោកខាងលិច។
គឺលោកយ៉ាសូបៀមជាកូនរបស់លោកសាបដេល។
ទាំងនេះជាឈ្មោះបុរស។
ទទួលមុខងារ
«អ្នកដឹកនាំ»
1 Chronicles 27:4
ខែទីពីរ
នេះជាខែទី២នៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែមេសា
និងដើមខែឧសភានៅលើប្រតិទិនលោកខាងលិច។
លោកឌូដាយ ... លោកអាំមីសាបាដ
ទាំងនេះជាឈ្មោះបុរស។
នៅក្នុងកងពលរបស់គាត់
«នៅក្នុងក្រុមយោធារបស់គាត់» ឬ «នៅក្នុងក្រុមទាហានរបស់គាត់»
មានទាហាន ២៤,០០០នាក់។
បុរសបួនពាន់នាក់ «បុរស ២៤.០០០នាក់»
នៅខែទីបី
នេះជាខែទីបីនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែឧសភា
និងដើមខែមិថុនាតាមប្រតិទិនលោកខាងលិច។
ទីបី
សូមមើលការបកប្រែនៅក្នុង ១១:១០។
1 Chronicles 27:7
មេបញ្ជាការនៅខែទីបួនគឺលោកអេសាអែលជាប្អូនរបស់លោកយ៉ូអាប់។
«លោកអេសាអែលជាបងរបស់លោកយ៉ូអាប់ជាមេបញ្ជាការសម្រាប់ខែទីបួន» ។
នៅខែទីបួន
នេះជាខែទីបួននៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែមិថុនា
និងដើមខែកក្កដាតាមប្រតិទិនលោកខាងលិច។
លោកអេសាអែល ... លោកអ៊ីកគីស
ទាំងនេះជាឈ្មោះបុរស។
កងពលរបស់គាត់
«ក្រុមយោធារបស់គាត់»
មានទាហាន ២៤,០០០នាក់
បុរសបួនពាន់នាក់ «បុរស ២៤.០០០នាក់»
ខែទីប្រាំ
នេះជាខែទីប្រាំនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែកក្កដា
និងដើមខែសីហានៅលើប្រតិទិនលោកខាងលិច។
ខែទីប្រាំមួយ
នេះជាខែទីប្រាំមួយនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែសីហា
និងដើមខែកញ្ញាតាមប្រតិទិនលោកខាងលិច។
ក្រុងតូអា
នេះជាឈ្មោះទីកន្លែងមួយ។
1 Chronicles 27:10
មេបញ្ជាការសំរាប់ខែទីប្រាំពីរគឺលោកហេលេស ជាអ្នកស្រុកពេឡូនី មកពីកុលសម្ព័ន្ធអេប្រាអ៊ីម។
«លោកហេលេស ជាអ្នកស្រុកពេឡូនី
ពីកុលសម្ព័ន្ធអេប្រាអ៊ីមជាមេបញ្ជាការសម្រាប់ខែទីប្រាំពីរ»។
នៅខែទីពីរ
នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។ អំឡុងពេលចុងខែកញ្ញា
និងដើមខែតុលាតាមប្រតិទិនលោកខាងលិច។
លោកហេលេស ... លោកស៊ីបេគា ...អំបូរសេរ៉ា ... លោកអប៊ីអេស៊ើរ
ទាំងនេះជាឈ្មោះបុរស។
ស្រុកពេឡូនី ... ស្រុកហ៊ូសាត ... ស្រុកអាណាថោត
ទាំងនេះជាឈ្មោះកុលសម្ព័ន្ធ ឬអំបូរ។
មានទាហាន ២៤,០០០នាក់
បុរសបួនពាន់នាក់ «បុរស ២៤.០០០នាក់»
នៅខែទីប្រាំបី
នេះជាខែទីប្រាំបីនៃប្រតិទិនហេប្រឺ។ អំឡុងពេលចុងខែតុលា
និងដើមខែវិច្ឆិកានៅលើប្រតិទិនលោកខាងលិច។
នៅខែទីប្រាំបួន
នេះជាខែទីប្រាំបួននៃប្រតិទិនហេប្រឺ។ អំឡុងពេលចុងខែវិច្ឆិកា
និងដើមខែធ្នូតាមប្រតិទិនលោកខាងលិច។
1 Chronicles 27:13
នៅខែទីដប់
នេះជាខែទីដប់នៃប្រតិទិនហេប្រឺ។
លោកម៉ាហារ៉ៃ ... ត្រកូលសេរ៉ា ... លោកហេឡៃ ... អំបូរអូធ្នៀល
ទាំងនេះជាឈ្មោះបុរស។
ក្រុងនេតូផា ... ក្រុងភីរ៉ាថុន
ទាំងនេះជាឈ្មោះទីកន្លែង។ នៅក្នុងចុងខែធ្នូ
និងដើមខែមករានៅលើប្រតិទិនលោកខាងលិច។
មានទាហាន ២៤,០០០នាក់។
បុរសបួនពាន់នាក់ «បុរស ២៤.០០០នាក់»
នៅខែទីដប់មួយ
នេះជាខែទីដប់មួយនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែមករា
និងដើមខែកុម្ភៈនៅលើប្រតិទិនលោកខាងលិច។
នៅខែទីដប់ពីរ
នេះជាថ្ងៃទីដប់ពីរ និងខែចុងក្រោយនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែកុម្ភៈ
និងដើមខែមីនានៅលើប្រតិទិនលោកខាងលិច។
1 Chronicles 27:16
លោកអេលាស៊ើរ ... លោកមីកែល
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 27:19
លោកអ៊ីសម៉ាយ៉ា ... លោកយេរ៉ូហាំ
ទាំងនេះជាឈ្មោះបុរស។
1 Chronicles 27:23
អ្នកមានអាយុម្ភៃឆ្នាំឬតិចជាងនោះ
«មនុស្សមានអាយុ ២០ឆ្នាំ ឬក្មេងជាងនេះ»
បង្កើនជនជាតិអ៊ីស្រាអែល
«បង្កើនចំនួនប្រជាជនអ៊ីស្រាអែល»
ដូចផ្កាយនៅលើមេឃ
ចំនួនប្រជាជនអ៊ីស្រាអែលត្រូវបានគេប្រៀបធៀបទៅនឹងចំនួនផ្កាយ
ដែលមានចំនួនច្រើនណាស់។
សេចក្តីក្រោធរបស់ព្រះជាម្ចាស់បានធ្លាក់ទៅលើជនជាតិអ៊ីស្រាអែល
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានដាក់ទណ្ឌកម្មប្រជាជនអ៊ីស្រាអែល»
ចំនួនទាំងនេះមិនត្រូវបានកត់ទុក
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់បានសរសេរចំនួននេះទេ»

generated on Wed Sep 10 16:16:32 2025

1 Chronicles 27:25
លោកអាសម៉ាវេត ... លោកសាបឌី
ទាំងនេះជាឈ្មោះបុរស។
អ្នកទទួលខុសត្រូវលើ
«ទទួលខុសត្រូវចំពោះការការពារ»
ប៉មដែលមានកំពែងរឹងមាំ
«ប៉មរឹងមាំ។»
ភ្ជួររាស់ដី
មានន័យថា ជីកដី ឬបំបែកដីមុនពេលដាំណាំ។
ស្រុកសេផាម
នេះជាឈ្មោះទីកន្លែងមួយ។
ផលិតស្រា
ទាំងនេះជាផ្នែកនៃអគារ ដែលស្ថិតនៅក្រោមដី ហើយត្រូវបានប្រើជាឃ្លាំងទុកស្រា។
1 Chronicles 27:28
ចម្ការឧទុម្ពរ
នេះជាប្រភេទដើមឈើ។
លោកបាលហាណាន់ ... លោកស៊ីតរ្មាយ... លោកអឌីឡាយ
ទាំងនេះជាឈ្មោះបុរស។
កេឌើ ... លោកសាផាត
ទាំងនេះជាឈ្មោះទីកន្លែង។
មើលខុសត្រូវលើហ្វូងគោ
«ដែលស៊ីស្មៅនៅតាមវាល»
1 Chronicles 27:30
លោកអូប៊ីល ... លោកយេដេយ៉ា ... លោកយ៉ាស៊ីស
ទាំងនេះជាឈ្មោះបុរស។
លោកយេដេយ៉ា ... ស្រុកហាគ្រី
ទាំងនេះជាឈ្មោះកុលសម្ព័ន្ធ ឬអំបូរ។
ក្រុងមេរ៉ូណោត
នេះជាឈ្មោះទីកន្លែងមួយ។
អ្នកទាំងនោះ
«បុរសទាំងនេះ»
1 Chronicles 27:32
លោកយ៉ូណាថា ... លោកយេហូយ៉ាដា
ទាំងនេះជាឈ្មោះបុរស។
ជាជនជាតិអើគី
នេះជាឈ្មោះកុលសម្ព័ន្ធ។

---

28 [1]ព្រះបាទដាវីឌបានកោះហៅពួកមន្ត្រីទាំងអស់នៃជនជាតិអ៊ីស្រាអែលនៅក្រុងយេរូសាឡឹម ពួកមេដឹកនាំនៃកុលសម្ព័ន្ធ
មេបញ្ជាកងពលនានាដែលបានបម្រើព្រះរាជាតាមមុខងារដែលពួកគេបានគ្រោងទុក មេបញ្ជាការ មេកង មេក្រុម និងអ្នកត្រួតត្រាលើទ្រព្យសម្បត្តិ
និងហ្វូងសត្វទាំងអស់របស់ស្តេច ព្រមទាំងពួករាជបុត្រ ពួកមន្ត្រីនិងទាហានប្រយុទ្ធដែលមានជំនាញទាំងអស់។
[2]ព្រះបាទដាវីឌក្រោកឈរឡើងហើយមានរាជឱង្ការថា៖ «បងប្អូន និងប្រជាជនរបស់ខ្ញុំអើយសូមស្តាប់ខ្ញុំ!
ខ្ញុំមានបំណងសង់ព្រះដំណាក់សម្រាប់ហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។ យើងបានរៀបចំកន្លែងសម្រាប់សង់ព្រះដំណាក់ឡើង។[3]ប៉ុន្តែ
ព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំថា អ្នកនឹងមិនសង់ព្រះដំណាក់សម្រាប់នាមយើងទេ ព្រោះអ្នកជាអ្នកធ្វើសង្គ្រាម និងបានបង្ហូរឈាមជាច្រើន»។
[4]ប៉ុន្តែ ព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលបានជ្រើសរើសខ្ញុំចេញពីក្រុមគ្រួសាររបស់ឪពុកខ្ញុំឲ្យគ្រងរាជ្យលើជនជាតិអ៊ីស្រាអែលរហូតតទៅ។
ព្រះអង្គបានជ្រើសរើសកុលសម្ព័ន្ធយូដាធ្វើជាមេដឹកនាំ។ ក្នុងកុលសម្ព័ន្ធយូដា
និងក្នុងអំបូរឪពុកខ្ញុំព្រះជាម្ចាស់បានជ្រើសរើសខ្ញុំឲ្យធ្វើជាស្តេចលើជនជាតិអ៊ីស្រាអែលទាំងមូល។[5]ក្នុងចំណោមបុត្រយើងជាច្រើន
ព្រះជាម្ចាស់ជ្រើសរើសសាឡូម៉ូនឲ្យអង្គុយនៅលើបល្ល័ង្កនៃព្រះរាជ្យរបស់ព្រះអម្ចាស់ ហើយលើជនជាតិអ៊ីស្រាអែល។
[6]ព្រះអង្គមានបន្ទូលមកខ្ញុំថា៖ «សាឡូម៉ូនជាបុត្ររបស់អ្នកនឹងសង់ដំណាក់ និងទីលានរបស់យើង ពីព្រោះយើងបានជ្រើសរើសគេឲ្យធ្វើជាកូនរបស់យើង
ហើយយើងនឹងធ្វើជាឪពុករបស់គេ។[7]ប្រសិនបើ គេគោរពប្រតិបត្តិតាមបទបញ្ជា និងវិន័យរបស់យើងយ៉ាងខ្ជាប់ខ្ជួនដូចសព្វថ្ងៃនេះ
នោះយើងនឹងតាំងឲ្យរាជ្យរបស់ព្រះអង្គនៅស្ថិតស្ថេររហូត»។
[8]ឥឡូវនេះ នៅចំពោះមុខជនជាតិអ៊ីស្រាអែលទាំងមូលជាក្រុមជំនុំនៃព្រះអម្ចាស់ និងនៅចំពោះព្រះភ័ក្ត្រព្រះរបស់យើង អ្នករាល់គ្នាត្រូវកាន់
និងប្រតិបត្តិតាមបទបញ្ជារបស់ព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា ធ្វើដូច្នេះអ្នករាល់គ្នានឹងទទួលដីល្អនេះទុកជាកេរមរតកដល់កូនចៅជំនាន់ក្រោយរបស់អ្នករហូតតទៅ។
[9]«រីឯបុត្រវិញ សាឡូម៉ូនអើយ! ចូរស្តាប់បង្គាប់ព្រះនៃបិតា ហើយគោរពបម្រើព្រះអង្គអោយអស់ពីចិត្ត និងដោយស្ម័គ្រពីចិត្ត។ ដ្បិត ព្រះអម្ចាស់ឈ្វេងយល់ចិត្តគំនិត និង
បំណងទាំងប៉ុន្មានរបស់មនុស្ស។ ប្រសិនបើ បុត្រស្វែងរកព្រះអង្គ នោះព្រះអង្គនឹងឲ្យរកទ្រង់ឃើញ ប៉ុន្តែ ប្រសិនបើ បុត្របោះបង់ចោលព្រះអង្គ
នោះព្រះអង្គនឹងបោះបង់បុត្រជារៀងរហូត។[10]ចូរពិចារណាចុះ! ព្រះអម្ចាស់បានជ្រើសរើសបុត្រឲ្យសង់ព្រះដំណាក់នេះធ្វើជាទីសក្ការរបស់ព្រះអង្គ។ ចូររឹងមាំហើយធ្វើវាចុះ»។
[11]បន្ទាប់មក ព្រះបាទដាវីឌប្រគល់គម្រោងការផ្សេងៗសម្រាប់ព្រះដំណាក់ព្រះ ព្រះវិហារ បន្ទប់ឃ្លាំង បន្ទប់ជាន់ខាងលើ បន្ទប់ខាងក្នុង
និងបន្ទប់ដែលមានគម្របធ្វើពិធីជម្រះកាយ ដល់ព្រះបាទសាឡូម៉ូន។[12]ព្រះបាទដាវីឌប្រគល់គម្រោងនៃអ្វីៗទាំងប៉ុន្មាន ដែលស្តេចបានគិតគូរនឹងធ្វើ សម្រាប់ទីលាននៃ
ព្រះដំណាក់របស់ព្រះអម្ចាស់ និងបន្ទប់ទាំងអស់ដែលនៅជុំវិញ សម្រាប់ដាក់ទ្រព្យនៃព្រះដំណាក់ និងរបស់របរដ៏សក្ការៈ។
[13]ស្តេចប្រគល់បញ្ជីពួកបូជាចារ្យ និងពួកលេវី ដែលបែងចែកជាក្រុមៗ ព្រមទាំងកិច្ចការផ្សេងៗ ដែលត្រូវបំពេញក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ និងគ្រឿងបរិក្ខារទាំង
ប៉ុន្មានសម្រាប់ប្រើប្រាស់ក្នុងព្រះដំណាក់[14]ស្តេចក៏បានប្រាប់អំពីទម្ងន់ដែលត្រូវការ ដើម្បីធ្វើគ្រឿងបរិក្ខារទាំងអស់ពីមាស និងប្រាក់ សម្រាប់ការប្រើប្រាស់គ្រប់បែប
យ៉ាង[15]ព្រមទាំងទម្ងន់របស់ជើងចង្កៀងមាស និងចង្កៀងមាស ទម្ងន់របស់ជើងចង្កៀងនិងទម្ងន់របស់ចង្កៀង ទម្ងន់របស់ជើងចង្កៀងប្រាក់ និងចង្កៀងប្រាក់ ស្របតាមការ
ប្រើប្រាស់របស់ចង្កៀងនីមួយៗ។
[16]ស្តេចឲ្យ ទម្ងន់មាសសម្រាប់តុនីមួយៗសម្រាប់ដាក់នំប៉័ងថ្វាយព្រះជាម្ចាស់ ព្រមទាំងទម្ងន់សម្រាប់តុនីមួយៗដែលធ្វើពីប្រាក់។
[17]ស្តេចឲ្យគេយកមាសសុទ្ធថ្លឹងសម្រាប់ធ្វើសម ធើងសម្រាប់ប្រោះឈាម និងពែង។ ស្តេចឲ្យទម្ងន់សម្រាប់ចានមាសនីមួយៗនិងទម្ងន់របស់ចានប្រាក់នីមួយៗ។
[18]ស្តេចឲ្យទម្ងន់របស់អាសនៈធ្វើពីមាសសុទ្ធសម្រាប់ថ្វាយគ្រឿងក្រអូប និងគំរូ រូបចេរូប៊ីនធ្វើពីមាសដែលត្រដាងស្លាបលើហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។[19]ព្រះបាទ
ដាវីឌមានរាជឱង្ការថា៖ «បិតាបានកត់ត្រា នូវកំណត់ត្រាទាំងនេះទុកក្នុងឯកសារ ដែលបិតាបានទទួលពីព្រះអម្ចាស់ នៅក្នុងឯកសារនេះ មានពន្យល់យ៉ាងលម្អិតអំពីរបៀប
ធ្វើ តាមគំរូ»។
[20]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់ព្រះបាទសាឡូម៉ូនជាបុត្រថា៖ «ចូរមានកម្លាំង និងចិត្តក្លាហានឡើង! ចូរនាំគ្នាធ្វើកិច្ចការកុំភ័យខ្លាចឬតប់ប្រមល់ឡើយ! ដ្បិត
ព្រះអម្ចាស់ជាព្រះរបស់បិតានឹងគង់ជាមួយបុត្ររហូតដល់កិច្ចការសាងសង់ព្រះដំណាក់របស់ព្រះអម្ចាស់ត្រូវចប់សព្វគ្រប់។[21]ពួកបូជាចារ្យ និងពួកលេវី ត្រូវបានបែងចែកជា
ក្រុមៗ សម្រាប់បម្រើការងារទាំងប៉ុន្មាន ក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ ហើយក៏មានមនុស្សស្ម័គ្រចិត្ត និងមានថ្វីដៃនៅជាមួយបុត្រ ដើម្បីជួយសម្រេចការងារនេះ។ រីង
ពួកមេដឹកនាំ និងប្រជាជនទាំងមូល ក៏ស្ថិតនៅក្រោមបញ្ជារបស់បុត្រដែរ»។

---

1 Chronicles 28:1
មន្ត្រី
សូមមើលការបកប្រែនៅក្នុង ២៤:៤។
តាមមុខងារ
ការងារដែលត្រូវការធ្វើម្តងទៀត ឧទាហរណ៍រាល់ថ្ងៃ ឬរៀងរាល់ខែ។
បញ្ជាការ មេកង មេក្រុម
«១000 និង១00»
អ្នកត្រួតត្រាលើទ្រព្យសម្បត្តិ

generated on Wed Sep 10 16:16:32 2025

ពាក្យទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្ នាហើយយោងទៅលើរបស់របរ
និងទឹកដីទាំងអស់ដែលព្រះរាជាមាន។
1 Chronicles 28:2
ក្រោកឈរឡើង
ការបកប្រែផ្សេងទៀត «បានក្រោកឈរឡើង»
បងប្អូន និងប្រជាជនរបស់ខ្ញុំ
ឃ្លាទាំងពីរនេះមានន័យរួមគ្នា ហើយបញ្ជាក់ថា
ព្រះបាទដាវីឌនិងប្រជាជនអ៊ីស្រាអែល គឺជាគ្រួសារ។
ហិបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់។ ជាកន្លែងសម្រាប់ទ្រព្រះបាទាព្រះជាម្ចាស់របស់យើង។
ឃ្លាទីពីរកំណត់ន័យឃ្លាទីមួយ។ ព្រះអម្ចាស់ច្រើនមានបន្ទូលសំដៅទៅលើ
«ហិបនៃសម្ពន្ធមេត្រី» ថាជា «កំណល់ព្រះបាទា»។
សង់ព្រះដំណាក់សម្រាប់នាមយើង
ការបកប្រែផ្សេងទៀត «ព្រះវិហារសម្រាប់យើង»
អ្នកធ្វើសង្គ្រាម និងបានបង្ហូរឈាមជាច្រើន។
ការពិពណ៌នាទាំងពីរសង្កត់ធ្ងន់លើចំណុចដូចគ្នា
គឺព្រះបាទដាវីឌបានសម្លាប់មនុស្ស។
បានបង្ហូរឈាមជាច្រើន
ការបកប្រែផ្សេងទៀត «បានសម្លាប់មនុស្ស»
1 Chronicles 28:4
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តមានបន្ទូលទៅកាន់ជនជាតិអ៊ីស្រាអែល។
គ្រងរាជ្យលើជនជាតិអ៊ីស្រាអែលរហូតតទៅ
អាចមានន័យថា ១)
ព្រះបាទដាវីឌនិងកូនចៅរបស់ព្រះអង្គនឹងគ្រប់គ្រងអ៊ីស្រាអែលជារៀងរហូត ឬ ២)
ព្រះបាទដាវីឌនឹងបន្តធ្វើជាស្តេចអ៊ីស្រាអែល បន្ទាប់ពីទ្រង់រស់ឡើងវិញ។
ជនជាតិអ៊ីស្រាអែលទាំងមូល
ការបកប្រែផ្សេងទៀត «ស្រុកអ៊ីស្រាអែលទាំងមូល» ឬ «
ជនជាតិអ៊ីស្រាអែលទាំងអស់»
អង្គុយនៅលើបល្ល័ង្ក
ការបកប្រែផ្សេងទៀត «ដើម្បីគ្រប់គ្រង» ឬ «ក្លាយជាស្តេច»
ព្រះរាជ្យរបស់ព្រះអម្ចាស់ ហើយលើជនជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «អ៊ីស្រាអែលពិតជារាជ្យរបស់ព្រះអម្ចាស់»
1 Chronicles 28:6
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តមានបន្ទូលទៅកាន់ជនជាតិអ៊ីស្រាអែល។
ព្រះអង្គមានបន្ទូល
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានមានបន្ទូលមកទូលបង្គំ»
សង់ដំណាក់
ពាក្យថា ព្រះដំណាក់គឺសំដៅទៅលើព្រះវិហាររបស់ព្រះអម្ចាស់។
យើងបានជ្រើសរើសគេឲ្យធ្វើជាកូនរបស់យើង ហើយយើងនឹងធ្វើជាឪពុករបស់គេ។
ពុំមែនមានន័យថា
ព្រះបាទសាឡូម៉ូនក្លាយជាបុត្រាពិតប្រាកដរបស់ព្រះជាម្ចាស់នោះទេ ប៉ុន្តែ
ជាការពិពណ៌នាអំពីទំនាក់ទំនងផ្ទាល់ខ្លួន ដែលទ្រង់និងព្រះជាម្ចាស់មាន។
ការបកប្រែផ្សេងទៀត «យើងបានជ្រើសរើស
និងប្រព្រឹត្តចំពោះព្រះអង្គប្រៀបបីដូចជាបុត្រា
ហើយយើងនឹងក្លាយជាព្រះបិតារបស់ព្រះអង្គ»
តាមបទបញ្ជា និងវិន័យ
ពាក្យទាំងពីរនេះមានន័យជារួមដូចគ្នា ហើយសំដៅទៅលើអ្វីៗទាំងអស់
ដែលព្រះអម្ចាស់បានចេញបទបញ្ជា។
ព្រះអង្គនៅស្ថិតស្ថេររហូត
ពាក្យថា «អ្នក» នៅទីនេះសំដៅទៅលើព្រះបាទដាវីឌ។ ការបកប្រែផ្សេងទៀត
«ដូចដែលអ្នកបានប្តេជ្ញាចិត្តនៅថ្ងៃនេះ»
1 Chronicles 28:8
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តមានបន្ទូលទៅកាន់ជនជាតិអ៊ីស្រាអែល។
ឥឡូវនេះ
បង្ហាញថា ព្រះបាទដាវីឌចាប់ផ្តើមដំណាក់កាលថ្មី
នៅក្នុងការថ្លែងព្រះរាជសាររបស់ព្រះអង្គ។
ត្រូវកាន់ និងប្រតិបត្តិតាម
ឃ្លា «ដើម្បីអនុវត្ត» មានន័យថា ជាមូលដ្ឋានដូចគ្នានឹង «រក្សា» ។
ពាក្យទាំងនេះរួមបញ្ចូលគ្នានូវសារៈសំខាន់នៃការធ្វើអ្វីដែលព្រះជាម្ចាស់បានបញ្ជា។
កូនចៅជំនាន់ក្រោយរបស់អ្នក
ការបកប្រែផ្សេងទៀត «កូនៗរបស់អ្នកដែលនឹងជំនួសអ្នកបន្ទាប់ពីអ្នកស្លាប់ទៅ»
1 Chronicles 28:9
ចូរស្គាប់បង្គាប់ព្រះនៃបិតា
ព្រះបាទដាវីឌហៅខ្លួនឯងថា« ឪពុកអ្នក» ពីព្រោះនេះជាឱកាសផ្លូវការហើយ។
ការបកប្រែផ្សេងទៀត «ព្រះរបស់ខ្ញុំ»
អស់ពីចិត្ត
ការបកប្រែផ្សេងទៀត «ទាំងស្រុង»
ស្ម័គ្រពីចិត្ត
ការបកប្រែផ្សេងទៀត «ស្ម័គ្រចិត្ត»
ឈ្វេងយល់ចិត្តគំនិត និងបំណងទាំងប៉ុន្មានរបស់មនុស្ស
ឃ្លាទាំងពីរនេះមានអត្ថន័យរួមដូចគ្នា ហើយបញ្ជាក់ថា ព្រះអម្ចាស់ជ្រាបពីគំនិត
និងអារម្មណ៍របស់មនុស្សទាំងអស់។
ប្រសិនបើ បុត្រស្វែងរកព្រះអង្គ នោះព្រះអង្គនឹងឲ្យរកទ្រង់ឃើញ
ការបកប្រែផ្សេងទៀត «បើអ្នកព្យាយាមឲ្យព្រះអម្ចាស់យកចិត្តទុកដាក់ចំពោះអ្នក
គឺព្រះអង្គនឹងធ្វើដូច្នេះ»
ចូរពិចារណាចុះ!
«មើលឥឡូវនេះ» ការបកប្រែផ្សេងទៀត «ចូរចងចាំ» ឬ «ចូរដឹង»
ចូររឹងមាំហើយធ្វើវាចុះ
ពាក្យថា «ខ្លាំង» នៅទីនេះសំដៅទៅលើអំណាចឆន្ទៈ និងកម្លាំងនៃចរិតលក្ខណៈ។
1 Chronicles 28:11
ព្រះដំណាក់
«រានហាលព្រះវិហារ» ឬ «ច្រកចូលព្រះវិហារ»។ សំដៅទៅលើសរសរ
ដែលទ្រដំបូលច្រកចូលប្រាសាទ។
ទ្រព្យ
បន្ទប់សម្រាប់ដាក់របស់មានតម្លៃ
1 Chronicles 28:13
បញ្ជី
ទាំងនេះជាច្បាប់ជាក់លាក់អំពីរបៀប ដែលពួកបូជាចារ្យ និង
ពួកលេវីគួរតែធ្វើការនៅក្នុងព្រះវិហារ។
បែងចែក
សំដៅទៅលើក្រុមដែលក្រុមបូជាចារ្យ និងបម្រើព្រះវិហារផ្សេងទៀត
ត្រូវបានរៀបចំឡើង ដើម្បីបំពេញភារកិច្ចរបស់ពួកគេ។
សូមមើលការបកប្រែពាក្យនៅក្នុង ២៤:១។
1 Chronicles 28:18
ធ្វើពីមាសសុទ្ធ
ការបកប្រែផ្សេងទៀត «មាសសុទ្ធ» ឬ «មាសមានតម្លៃបន្ថែម»
បិតាបានកត់ត្រា នូវកំណត់ត្រាទាំងនេះទុកក្នុងឯកសារ
ការបកប្រែផ្សេងទៀត «ខ្ញុំបានសរសេរទាំងអស់នេះ»
មានពន្យល់យ៉ាងលម្អិតអំពីរបៀបធ្វើ តាមគំរូ
ការបកប្រែផ្សេងទៀត «បានជួយខ្ញុំឲ្យយល់ពីព័ត៌មានលម្អិត»
1 Chronicles 28:20
ចូរមានកម្លាំង និងចិត្តក្លាហានឡើង!
ពាក្យទាំងពីរនេះជាទូទៅ មានន័យដូចគ្នា
ហើយបញ្ជាក់ថាព្រះបាទសាឡូម៉ូនត្រូវតែមានភាពក្លាហាន។
ចូរនាំគ្នាធ្វើកិច្ចការកុំភ័យខ្លាច
ពាក្យទាំងពីរនេះជាទូទៅមានន័យដូចគ្នាហើយបញ្ជាក់ថាព្រះបាទសាឡូម៉ូនមិនត្រូវបោះបង់ចោលឡើយ។
ការបកប្រែផ្សេងទៀត «ចូរក្លាហាន» ឬ «មានទំនុកចិត្ត»។
គង់ជាមួយបុត្រ
ការបកប្រែផ្សេងទៀត «នឹងជួយអ្នក»
នឹងគង់ជាមួយបុត្ររហូត
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយបញ្ជាក់ថាព្រះអម្ចាស់គង់នៅជាមួយព្រះបាទសាឡូម៉ូនជានិច្ច។
ការបកប្រែផ្សេងទៀត «ព្រះអង្គគង់នៅជាមួយអ្នកជានិច្ច»
ពួកបូជាចារ្យ និងពួកលេវី ត្រូវបានបែងចែកជាក្រុមៗ
សូមមើលការបកប្រែនៅក្នុង ២៨:១៣។

generated on Wed Sep 10 16:16:32 2025

29 [1]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់អង្គប្រជុំទាំងមូលថា៖ «ព្រះជាម្ចាស់បានជ្រើសរើសសាឡូម៉ូនជាបុត្ររបស់យើង តែបុត្រយើងនៅក្មេងនិងគ្មានបទពិសោធន៍
ហើយកិច្ចការនេះធំធេងណាស់។ ព្រះវិហារនេះមិនមែនសម្រាប់ប្រជាជនទេគឺសម្រាប់ព្រះអម្ចាស់ជាព្រះនៃយើង។[2]ខ្ញុំបានខំប្រឹងប្រែងអស់ពីកម្លាំងកាយ ដើម្បីត្រៀម
សម្ភារសង់ព្រះដំណាក់នៃព្រះរបស់ខ្ញុំ គឺខ្ញុំបានប្រមូលមាសសម្រាប់ធ្វើគ្រឿងប្រដាប់អំពីមាស ប្រាក់សម្រាប់ធ្វើគ្រឿងប្រដាប់អំពីប្រាក់ លង្ហិនសម្រាប់ធ្វើគ្រឿងប្រដាប់អំពី
លង្ហិន ដែកសម្រាប់ធ្វើគ្រឿងប្រដាប់អំពីដែក ឈើសម្រាប់ធ្វើគ្រឿងប្រដាប់អំពីឈើ ព្រមទាំងត្បូងមណីជោតិ ត្បូងសម្រាប់ដាំលំអ ត្បូងចម្រុះពណ៌ ពេជ្រគ្រប់ប្រភេទ និងថ្ម
កែវដ៏ច្រើនឥតគណនា។
[3]ឥឡូវនេះ ដោយសារខ្ញុំរីករាយនឹងព្រះដំណាក់នៃព្រះរបស់ខ្ញុំ ដូច្នេះខ្ញុំបានប្រគល់មាស និងប្រាក់ផ្ទាល់ខ្លួនសម្រាប់កិច្ចការនេះ។
ខ្ញុំកំពុងធ្វើកិច្ចការនេះបន្ថែមលើអ្វីៗទាំងអស់ដែលខ្ញុំបានរៀបចំសម្រាប់ព្រះដំណាក់បរិសុទ្ធនេះ[4]គឺខ្ញុំប្រគល់មាសសុទ្ធពីស្រុកអូភារ ចំនួនបីពាន់ហាប និងប្រាក់សុទ្ធចំនួន
ប្រាំពីរពាន់ហាប សម្រាប់ពាសជញ្ជាំងអាគារទាំងប៉ុន្មាន។[5]ខ្ញុំបានថ្វាយមាស និងប្រាក់ ដើម្បីឲ្យពួកជាងទងយកទៅសិតធ្វើគ្រឿងប្រដាប់ទាំងប៉ុន្មាន អំពីមាស អំពីប្រាក់។
តើនរណាខ្លះស្ម័គ្រចិត្តថ្វាយមាស ប្រាក់ ដល់ព្រះអម្ចាស់?»។
[6]ពេលនោះ តង្វាយស្ម័គ្រចិត្តត្រូវបានធ្វើឡើងដោយមេដឹកនាំក្រុមគ្រួសារ មេដឹកនាំកុលសម្ព័ន្ធនានានៃជនជាតិអ៊ីស្រាអែល មេកង មេក្រុម ព្រមទាំងអ្នកដឹកនាំការងាររបស់
ស្តេច[7]ពួកគេស្ម័គ្រចិត្តថ្វាយតង្វាយសម្រាប់ការងារនៃព្រះដំណាក់របស់ព្រះជាម្ចាស់ គឺមានមាសប្រាំពាន់ហាប កាក់មាសចំនួនមួយម៉ឺនកាក់ ប្រាក់សុទ្ធមួយម៉ឺនហាប លង្ហិន
មួយម៉ឺនប្រាំបីពាន់ហាប និងដែកមួយសែនហាប។
[8]អស់អ្នកណាដែលមានត្បូងពេជ្រ អោយគេទុកក្នុងឃ្លាំងព្រះដំណាក់របស់ព្រះអម្ចាស់ក្រោមការគ្រប់គ្រងរបស់យេហ៊ីអែលជាកូនចៅរបស់លោកគើរសុន។
[9]ប្រជាជននាំគ្នាអរសប្បាយព្រោះតែតង្វាយស្ម័គ្រចិត្តទាំងនេះ ដ្បិត ពួកគេបានថ្វាយព្រះអម្ចាស់យ៉ាងស្មោះអស់ពីចិត្ត។ ព្រះបាទដាវីឌក៏ត្រេកអរយ៉ាងខ្លាំងដែរ។
[10]ព្រះបាទដាវីឌលើកតម្កើងព្រះអម្ចាស់នៅចំពោះមុខអង្គប្រជុំទាំងមូល។ ព្រះអង្គមានព្រះបន្ទូលថា៖
«បពិត្រព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលជាបុព្វបុរសរបស់យើងអស់កល្បជាអង្វែងតរៀងទៅ។[11]ព្រះអម្ចាស់អើយ ព្រះអង្គជាព្រះដ៏ឧត្តុង្គឧត្តម ប្រកបដោយ
ឫទ្ធានុភាព ព្រះបារមី តេជានុភាព និងសិរីរុងរឿង។ ដ្បិត អ្វីៗទាំងអស់នៅលើមេឃ និងនៅលើផែនដីគឺជាកម្មសិទ្ធិរបស់ព្រះអង្គព្រះអង្គ។ ព្រះអម្ចាស់អើយ ព្រះអង្គជា
ព្រះមហាក្សត្រគ្រងរាជ្យលើអ្វីៗទាំងអស់ដែរ។
[12]ព្រះអង្គជាប្រភពនៃទ្រព្យសម្បត្តិ និងកិត្តិយសហើយព្រះអង្គគ្រប់គ្រងលើមនុស្សទាំងអស់។ ព្រះចេស្តា និងឫទ្ធានុភាព ស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអង្គ។ ហើយ
ដោយសារព្រះបារមីរបស់ព្រះអង្គ ព្រះអង្គអាចធ្វើឲ្យមនុស្សអស្ចារ្យ និងផ្តល់កម្លាំងដល់នរណាម្នាក់ស្រេចលើព្រះអង្គ។[13]ឥឡូវនេះ ឱព្រះនៃយើងខ្ញុំអើយ!
យើងខ្ញុំសូមអរព្រះគុណ និងកោតសរសើរព្រះនាមដ៏ថ្កុំថ្កើងរបស់ព្រះអង្គ។
[14]ប៉ុន្តែ តើទូលបង្គំជាអ្វី និងជាប្រជារាស្ត្ររបស់ទូលបង្គំជាអ្វីដែលយើងអាចថ្វាយតង្វាយទាំងនេះដោយស្ម័គ្រចិត្តដល់ព្រះអង្គ? អ្វីៗទាំងអស់គឺមកពីព្រះអង្គ
ហើយអ្វីៗទាំងអស់ដែលយើងខ្ញុំថ្វាយដល់ព្រះអង្គគឺសុទ្ធតែជាកម្មសិទ្ធិរបស់ព្រះអង្គ។[15]នៅចំពោះព្រះភ័ក្ត្រព្រះអង្គ យើងខ្ញុំជាជនបរទេស និងជាអ្នកស្នាក់អាស្រ័យនៅ
ដូចដូនតារបស់យើងដែរ។ អាយុជីវិតរបស់យើងនៅលើផែនដីនេះប្រៀបដូចជាស្រមោលហើយគ្មានសង្ឃឹមរស់លើផែនដីទៀតឡើយ។
[16]ឱព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំអើយ! ទ្រព្យសម្បត្តិទាំងអស់ដែលយើងខ្ញុំប្រមូលបានក្នុងគោលបំណងសង់ព្រះដំណាក់ថ្វាយព្រះកិត្តិនាមរបស់ព្រះអង្គ
សុទ្ធតែជាអំណោយមកពីព្រះអង្គហើយជាកម្មសិទ្ធិរបស់ព្រះអង្គ។[17]ឱព្រះនៃទូលបង្គំអើយ! ទូលបង្គំដឹងថាព្រះអង្គពិនិត្យមើលចិត្ត ហើយរីករាយនឹងសេចក្តីទៀងត្រង់។
ចំណែកទូលបង្គំវិញ ទូលបង្គំបានថ្វាយរបស់ទាំងអស់នេះដោយចិត្តស្មោះត្រង់ហើយ ឥឡូវនេះ
ទូលបង្គំរីករាយដោយឃើញប្រជាជនរបស់ព្រះអង្គដែលមានវត្តមាននៅទីនេះ បានថ្វាយទៅកាន់ព្រះអង្គដោយស្ម័គ្រពីចិត្ត។
[18]ឱព្រះអម្ចាស់ជាព្រះរបស់លោកអប្រាហាំ លោកអ៊ីសាក និងលោកអ៊ីស្រាអែលជាបុព្វបុរសរបស់យើងខ្ញុំអើយ!
សូមប្រោសប្រទានឲ្យប្រជារាស្ត្ររបស់ព្រះអង្គប្រកាន់ខ្ជាប់នូវចិត្តស្មោះត្រង់ចំពោះព្រះអង្គរហូតតទៅផង។
[19]សូមប្រោសប្រទានឲ្យសាឡូម៉ូនជាបុត្ររបស់ទូលបង្គំឲ្យមានចិត្តស្មោះត្រង់កាន់តាមបទបញ្ជា
និងសម្ពន្ធមេត្រីរបស់ព្រះអង្គហើយប្រតិបត្តិតាមគំរោងការទាំងប៉ុន្មាននេះឥតងាករេឡើយ ដើម្បីឲ្យគេអាចសង់ព្រះដំណាក់ដែលទូលបង្គំបានត្រៀមទុក»។
[20]ព្រះបាទដាវីឌមានរាជឱង្ការទៅកាន់អង្គប្រជុំទាំងមូលថា៖ «សូមលើកតម្កើងព្រះអម្ចាស់ជាព្រះរបស់អ្នក!»។
អង្គប្រជុំទាំងមូលនាំគ្នាលើកតម្កើងព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេ។ ពួកគេនាំគ្នាក្រាបថ្វាយបង្គំព្រះអម្ចាស់ហើយក្រាបថ្វាយបង្គំស្តេច។
[21]ស្អែកឡើងពួកគេនាំគ្នាយកយញ្ញបូជាថ្វាយព្រះអម្ចាស់ហើយថ្វាយតង្វាយដុតទាំងមូលចំពោះព្រះអង្គ។
ពួកគេបានថ្វាយគោឈ្មោលមួយពាន់ក្បាលចៀមឈ្មោលមួយពាន់ក្បាល និងកូនចៀមមួយពាន់ក្បាលដោយមានស្រា
ព្រមទាំងយញ្ញបូជាជាច្រើនសម្រាប់ជនជាតិអ៊ីស្រាអែលទាំងមូល។
[22]នៅថ្ងៃនោះពួកគេបរិភោគនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ដោយអរសប្បាយយ៉ាងខ្លាំង។ គេបានតែងតាំងព្រះបាទសាឡូម៉ូនជាបុត្ររបស់ព្រះបាទដាវីឌជាស្តេចជាលើកទីពីរ
ហើយចាក់ប្រេងអភិសេកស្តេចឲ្យគ្រងរាជ្យលើគេ។ ពួកគេក៏បានចាក់ប្រេងតាំងលោកសាដុក ដើម្បីធ្វើជាបូជាចារ្យ។
[23]ព្រះបាទសាឡូម៉ូនបានឡើងគង់លើបល្ល័ង្ករាជ្យរបស់ព្រះជាម្ចាស់ ដើម្បីស្នងរាជ្យជំនួសព្រះបាទដាវីឌជាបិតា។ រាជ្យព្រះអង្គថ្កុំថ្កើង
ហើយប្រជាជនអ៊ីស្រាអែលទាំងមូលក៏នាំគ្នាស្តាប់បង្គាប់ព្រះបាទសាឡូម៉ូន។
[24]មេដឹកនាំទាំងអស់ ព្រមទាំងពលទាហាន និងបុត្រទាំងអស់របស់ព្រះបាទដាវីឌបានស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះបាទសាឡូម៉ូន។
[25]ព្រះអម្ចាស់បានលើកតម្កើងព្រះបាទសាឡូម៉ូននៅចំពោះមុខប្រជាជនអ៊ីស្រាអែលទាំងមូល
និងប្រទានឲ្យស្តេចមានឫទ្ធានុភាពខ្លាំងក្លាជាងស្តេចនានាដែលព្រះអង្គបានតែងតាំងឲ្យធ្វើជាស្តេចនៅអ៊ីស្រាអែល។
[26]ព្រះបាទដាវីឌជាបុត្ររបស់លោកអ៊ីសាយបានសោយរាជ្យលើស្រុកអ៊ីស្រាអែលទាំងមូល។[27]ព្រះបាទដាវីឌគ្រងរាជ្យជាស្តេចស្រុកអ៊ីស្រាអែលអស់រយៈពេលសែសិបឆ្នាំ។
ស្តេចសោយរាជ្យបានប្រាំពីរឆ្នាំនៅក្រុងហេប្រូន និងសាមសិបបីឆ្នាំនៅក្រុងយេរូសាឡឹម។[28]ព្រះអង្គបានសោយទិវង្គតដោយជរា បន្ទាប់ពី មានអាយុយឺនយូរ
ហើយទ្រព្យសម្បត្តិស្តុកស្តម្ភ និងប្រកបដោយភាពថ្កុំថ្កើងរុងរឿង។ ព្រះបាទសាឡូម៉ូនជាបុត្របានឡើងស្នងរាជ្យបន្តពីព្រះបិតា។
[29]សមិទ្ធិផលនៃរាជកិច្ចទាំងឡាយរបស់ស្តេចដាវីឌត្រូវបានសរសេរនៅក្នុងប្រវត្តិសាស្ត្ររបស់ព្យាការីសាំយូអែល ព្យាការីណាថាន់
និងនៅក្នុងប្រវត្តិសាស្ត្ររបស់ព្យាការីកាដ។[30]គេក៏រៀបរាប់អំពីរាជសម្បត្តិ និងវីរភាពដ៏អង់អាចរបស់ស្តេច ព្រមទាំងហេតុការណ៍ផ្សេងៗ ដែលកើតមាននៅរជ្ជកាលរបស់
ស្តេច ក្នុងស្រុកអ៊ីស្រាអែល និងក្នុងអាណាចក្រដទៃទៀត។

---

1 Chronicles 29:1

ត្បូងមណីជោតិ

ទាំងនេះជាត្បូងដែលមានពណ៌ខ្មៅ និងត្រូវបានប្រើដើម្បីធ្វើគ្រឿងអលង្ការ។

សម្រាប់ដាំលំអ

សំដៅទៅលើការរចនាម៉ូដ

ឬលំនាំស្រស់ស្អាតនិងតុបតែងដែលបង្កើតឡើងដោយត្បូង។

1 Chronicles 29:3

ព័ត៌មានទូទៅ៖

ព្រះបាទដាវីឌបានបន្តមានបន្ទូលទៅកាន់ប្រជាជន
អំពីការផ្គត់ផ្គង់ចំពោះការកសាងព្រះវិហារ។

ចំនួនប្រាំពីរពាន់ហាប

«៣០០០ ហាប»

មាសសុទ្ធពីស្រុកអូភារ

មាសដែលមានគុណភាពល្អបំផុត និងមានតម្លៃបំផុត

1 Chronicles 29:6

ព័ត៌មានទូទៅ៖

generated on Wed Sep 10 16:16:32 2025

កាក់ ... ហាប
1 Chronicles 29:8
ឃ្លាំង
ជាទីកន្លែងសម្រាប់ទុកប្រាក់ និងវត្ថុមានតម្លៃ។
យេហ៊ីអែល
នេះជាឈ្មោះបុរស។
លោកគើរសុន
នេះជាកូនច្បងរបស់លោកលេវី។ (សូមមើលការបកប្រែនៅក្នុង 1CH 23:7)
យ៉ាងស្មោះអស់ពីចិត្ត
ដោយស្ម័គ្រចិត្ត និងដោយគ្មានការសង្ស័យ ឬការស្ទាក់ស្ទើរ
1 Chronicles 29:10
បពិត្រព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលជាបុព្វបុរសរបស់យើងអស់កល្បជាអង្វែងតរៀងទៅ។
ការបកប្រែផ្សេងទៀត «បពិត្រព្រះអម្ចាស់ជាព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែល ជាឪពុករសរបស់យើងអស់កល្បជានិច្ចតរៀងទៅ។»
1 Chronicles 29:12
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តអធិស្ឋាននៃការសរសើរតម្កើងថ្វាយព្រះអម្ចាស់។
ព្រះចេស្តា និងឫទ្ធានុភាព
ពាក្យថា «អំណាច» និង «ឫទ្ធានុភាព»
មានន័យដូចគ្នាហើយបញ្ជាក់លើភាពអស្ចារ្យនៃឫទ្ធានុភាពរបស់ព្រះអម្ចាស់។
1 Chronicles 29:14
ព័ត៌មានទូទៅ៖
ព្រះបាទដាវីឌបន្តអធិស្ឋាននៃសរសើរតម្កើងថ្វាយព្រះអម្ចាស់។
ប៉ុន្តែ តើទូលបង្គំជាអ្វី
និងជាប្រជារាស្ត្ររបស់ទូលបង្គំជាអ្វីដែលយើងអាចថ្វាយតង្វាយទាំងនេះដោយស្ម័គ្រចិត្តដល់ព្រះអង្គ?
ព្រះបាទដាវីឌមានន័យថា
ព្រះអង្គនិងប្រជារាស្ត្ររបស់ទ្រង់មិនសក្តិសមទទួលបានការសរសើរ
ចំពោះការថ្វាយអ្វីដល់ព្រះជាម្ចាស់ឡើយ។
នៅចំពោះព្រះភ័ក្ត្រព្រះអង្គ យើងខ្ញុំជាជនបរទេស និងជាអ្នកស្នាក់អាស្រ័យនៅ
ការបកប្រែផ្សេងទៀត «ព្រះអង្គដឹងថា យើងមិនសំខាន់»
អាយុជីវិតរបស់យើងនៅលើផែនដីនេះប្រៀបដូចជាស្រមោល
ស្រមោលលេចឡើង ហើយបាត់ទៅវិញយ៉ាងឆាប់រហ័ស។
1 Chronicles 29:16
ទូលបង្គំបានថ្វាយរបស់ទាំងអស់នេះដោយចិត្តស្មោះត្រង់ហើយ
«ពីព្រោះទូលបង្គំចង់បានភាពស្មោះត្រង់ និងកិត្តិយសនៅក្នុងអ្វីគ្រប់យ៉ាង
ដែលទូលបង្គំធ្វើថ្វាយព្រះអង្គ»
1 Chronicles 29:18
សូមប្រោសប្រទានឲ្យប្រជារាស្ត្ររបស់ព្រះអង្គប្រកាន់ខ្ជាប់នូវចិត្តស្មោះត្រង់ចំពោះព្រះអង្គរហូតតទៅផង។
ការបកប្រែផ្សេងទៀត
«ចូររក្សាទុកគំនិតនេះនៅក្នុងចិត្តនៃប្រជាជនរបស់អ្នកជារៀងរហូតតទៅ»
1 Chronicles 29:20
ព័ត៌មានទូទៅ៖
សូមមើល
ក្រាបថ្វាយបង្គំព្រះអម្ចាស់
ក្រាបចុះដល់ដីជារបៀបនៃការបង្ហាញការគោរពដ៏ជ្រាលជ្រៅ
1 Chronicles 29:22
នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់
ដើម្បីគោរពដល់ព្រះអម្ចាស់។
ទីពីរ
លើកដំបូងត្រូវបានពិពណ៌នានៅក្នុង ២៣: ១។
ហើយចាក់ប្រេងអភិសេកស្តេចឲ្យគ្រងរាជ្យលើគេ។
ការបកប្រែផ្សេងទៀត «តែងតាំងទ្រង់ឲ្យគ្រប់គ្រងលើអ៊ីស្រាអែលជំនួសព្រះអម្ចាស់»
1 Chronicles 29:24
ស្ថិតក្រោមការគ្រប់គ្រង
ការបកប្រែផ្សេងទៀត «ភាពស្មោះត្រង់របស់ពួកគេ»
ព្រះអម្ចាស់បានលើកតម្កើងព្រះបាទសាឡូម៉ូននៅចំពោះមុខប្រជាជនអ៊ីស្រាអែលទាំងមូល
និងប្រទានឲ្យស្តេចមានឫទ្ធានុភាពខ្លាំង
ឃ្លាទាំងពីរនេះបញ្ជាក់ថា
ព្រះបាទសាឡូម៉ូនបានទទួលការពេញចិត្តពិសេសពីព្រះអម្ចាស់
ដែលបានធ្វើឲ្យទ្រង់ក្លាយជាស្តេចដ៏អស្ចារ្យ និងខ្លាំងក្លាបំផុតរបស់អ៊ីស្រាអែល។
1 Chronicles 29:29
បានសរសេរនៅក្នុងប្រវត្តិសាស្ត្ររបស់ព្យាការីសាំយូអែល ព្យាការីណាថាន
និងនៅក្នុងប្រវត្តិសាស្ត្ររបស់ព្យាការីកាដ។
ការងារនេះលែងមានទៀតទេ។
គេក៏រៀបរាប់អំពីរាជសម្បត្តិ
ការបកប្រែផ្សេងទៀត «មានគេសរសេរនៅទីនោះ»
អំពីរាជសម្បត្តិ និងវិរភាពដ៏អង់អាចរបស់ស្តេច
«រឿងដែលបានកើតឡើងកាលដាវីឌនៅជាស្តេច»
ព្រមទាំងហេតុការណ៍ផ្សេងៗ ដែលកើតមាននៅរជ្ជកាលរបស់ស្តេច
ការបកប្រែផ្សេងទៀត «ព្រឹត្តិការណ៍នៅប្រទេសដទៃដែលប៉ះពាល់ដល់អ៊ីស្រាអែល»

របាក្សត្រទី ២

1 [1]ព្រះបាទសាឡូម៉ូន ជាបុត្រព្រះបាទដាវីឌកាន់តែមានកម្លាំងរឹងមាំឡើងក្នុងរាជ្យរបស់ទ្រង់ ហើយព្រះអម្ចាស់បានចម្រើនឲ្យព្រះករុណាកាន់តែមានអំណាចខ្លាំងឡើង។
[2]ព្រះបាទសាឡូម៉ូនមានរាជឱង្ការទៅប្រជាជនអ៊ីស្រាអែលទាំងមូលចំពោះមេបញ្ជាការលើពាន់នាក់ មេកងលើរយនាក់ចៅហ្វាយចៅក្រម
និងមេដឹកនាំទាំងអស់នៃជនជាតិអ៊ីស្រាអែលដែលជាប្រមុខនៃក្រុមគ្រួសារឪពុកគេ។
[3]ព្រះបាទសាឡូម៉ូននិងក្រុមជំនុំទាំងមូលនាំគ្នាទៅកាន់កន្លែងសក្ការៈតាមទួលខ្ពស់នៅគីបៀន
ដ្បិតមានត្រសាលប្រជុំរបស់ព្រះជាម្ចាស់ដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គបានធ្វើនៅទីរហោស្ថាន នៅទីនោះ។
[4]ប៉ុន្តែព្រះបាទដាវីឌបាននាំយកហឹបរបស់ព្រះជាម្ចាស់ពីគារយ៉ាត់-យារីមដល់កន្លែងដែលទ្រង់បានត្រៀមទុក ព្រោះទ្រង់បានបោះត្រសាលនៅក្រុងយេរូសាឡិម។
[5]អាសនៈលង្ហិនធ្វើដោយលោកបេតសាលាល ជាកូនរបស់លោកយូរី និងជាចៅរបស់លោកហើរស្ថិតនៅទីព្រះពន្លារបស់ព្រះអម្ចាស់។ ព្រះបាទសាឡូម៉ូន
និងក្រុមជំនុំទាំងមូលបានទៅដល់ទីនោះ។
[6]ព្រះបាទសាឡូម៉ូនឡើងទៅលើអាសនៈលង្ហិន នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ដែលនៅត្រង់ត្រសាលប្រជុំ ហើយបានថ្វាយដង្វាយដុតទាំងមូលមួយពាន់នៅលើនោះ។
[7]ព្រះជាម្ចាស់បានយាងមកជួបព្រះបាទសាឡូម៉ូននៅយប់នោះ ហើយមានបន្ទូលទៅទ្រង់ថា៖ «ចូរសុំចុះ! តើទ្រង់ចង់ឲ្យយើងប្រទានអ្វីឲ្យទ្រង់?»។
[8]ព្រះបាទសាឡូម៉ូនបានទូលទៅព្រះជាម្ចាស់ថា៖ «ព្រះអង្គបានសម្តែងព្រះហឫទ័យស្មោះត្រង់នឹងសម្ពន្ធមេត្រីរបស់ព្រះអង្គចំពោះព្រះបាទដាវីឌ ជាបិតារបស់ទូលបង្គំ
ហើយព្រះអង្គបានប្រទានឲ្យទូលបង្គំឡើងគ្រងរាជ្យជំនួសស្តេចផង។[9]បពិត្រព្រះអម្ចាស់ដ៏ជាព្រះជាអម្ចាស់ ឥឡូវនេះ
សូមសម្រេចតាមព្រះបន្ទូលដែលព្រះអង្គបានសន្យាចំពោះព្រះបាទដាវីឌ ជាបិតារបស់ទូលបង្គំចុះ ដ្បិត
ព្រះអង្គបានតែងតាំងទូលបង្គំឲ្យគ្រងរាជ្យលើប្រជាជនជាច្រើនដូចធូលីដី។[10]សូមប្រទានប្រាជ្ញា និងចំណេះដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គំដឹកនាំប្រជាជននេះ ដ្បិត
តើនរណាអាចវិនិច្ឆ័យប្រជាជនរបស់ទ្រង់បាន? តើអ្នកណាអាចរាប់ក្រុមមនុស្សដែលមានចំនួនយ៉ាងច្រើននេះបាន?»។
[11]ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ព្រះបាទសាឡូម៉ូនថា៖ «ការនេះស្ថិតនៅក្នុងដួងចិត្តរបស់ទ្រង់ ហើយទ្រង់មិនបានស្នើសុំទ្រព្យសម្បត្តិទ្រព្យ ឬកិត្តិយស
ឬជីវិតអ្នកដែលស្អប់ទ្រង់ និងជីវិតដ៏វែងសម្រាប់ខ្លួនទ្រង់ទេ តែទ្រង់បានសុំប្រាជ្ញា និងចំណេះដឹងដល់ខ្លួនទ្រង់ផ្ទាល់
ដើម្បីឲ្យទ្រង់អាចគ្រប់គ្រងលើប្រជារាស្ត្ររបស់យើងដែលយើងបានតែងតាំងទ្រង់ឲ្យធ្វើជាស្តេចលើគេ។ ដូច្នេះ យើងនឹងប្រទានឲ្យទ្រង់!។

generated on Wed Sep 10 16:16:32 2025

[12]ឥឡូវនេះ យើងនឹងផ្តល់ឲ្យអ្នកនូវប្រាជ្ញា និងចំណេះដឹង យើងក៏ប្រទានឲ្យទ្រង់មានទ្រព្យសម្បត្តិយ៉ាងច្រើន ព្រមទាំងកិត្តិយស ដែលទោះបើមុនទ្រង់
និងក្រោយទ្រង់មិនដែលមានស្តេចណាដូចជាទ្រង់ឡើយ។[13]ស្តេចសាឡូម៉ូនយាងពីកន្លែងសក្ការៈតាមទួលខ្ពស់នៅគីបៀនគឺពីមុខត្រសាលប្រជុំ
ត្រឡប់មកក្រុងយេរូសាឡិមវិញ ហើយស្តេចសោយរាជ្យលើស្រុកអ៊ីស្រាអែលទាំងមូល។
[14]ព្រះបាទសាឡូម៉ូនប្រមូលរទេះចម្បាំង និងពលទ័ពសេះមកមានរទេះសេះចំនួន ១, ៤០០ គ្រឿង
និងពលសេះចំនួនមួយម៉ឺនពីរពាន់នាក់ដែលស្តេចដាក់នៅក្នុងទីក្រុងជាមួយរទេះចម្បាំង និងនៅជាមួយស្តេចនៅក្រុងយេរូសាឡិម។
[15]ស្តេចបានធ្វើឲ្យមានមាសប្រាក់នៅក្រុងយេរូសាឡិមសម្បូរដូចដុំថ្ម ហើយធ្វើឲ្យឈើតាត្រៅសម្បូរដូចដើមកកោះដែលមាននៅតាមតំបន់ទំនាប។
[16]ពួកឈ្មួញរបស់ស្តេចបានទិញសេះពីស្រុកអេស៊ីប និងស្រុកគូសសម្រាប់ព្រះបាទសាឡូម៉ូន។
[17]ពួកគេនាំរទេះចម្បាំងមកពីស្រុកអេស៊ីបមានតម្លៃជាប្រាក់សុទ្ធប្រាំមួយរយស្លឹង និងសេះមួយតម្លៃ ១៥០ ស្លឹង។
ពួកគេក៏បានលក់ចេញទៅឲ្យស្តេចនៃជនជាតិហេតនិងជនជាតិស៊ីរី។

---

2 Chronicles 1:1
កាន់តែមានកម្លាំងរឹងមាំឡើងក្នុងរាជ្យរបស់ទ្រង់
ការបកប្រែផ្សេងទៀត
«ព្រះបាទសាឡូម៉ូនបានប្រើអំណាចដ៏អស្ចារ្យលើអ៊ីស្រាអែល»
ព្រះអម្ចាស់
នេះជាព្រះនាមរបស់ព្រះជាម្ចាស់
ដែលព្រះអង្គបានបង្ហាញឲ្យប្រជារាស្ត្ររបស់ព្រះអង្គស្គាល់
នៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់។ សូមមើលទំព័របកប្រែស្តីអំពីព្រះអម្ចាស់
ទាក់ទងនឹងការបកប្រែនេះ។
ព្រះអម្ចាស់បានចម្រើនឲ្យព្រះករុណា
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានគាំទ្រព្រះអង្គ» ឬ
«ព្រះជាម្ចាស់បានជួយព្រះអង្គ»
2 Chronicles 1:2
គារយ៉ាត់-យារីម
ទីក្រុងតូចមួយដែលមានចម្ងាយប្រហែល៩ម៉ាយ ភាគខាងលិចក្រុងយេរូសាឡឹម។
បានបោះត្រសាល
ការបកប្រែផ្សេងទៀត «រៀបចំព្រះពន្លា»
លោកបេតសាលាល ជាកូនរបស់លោកយូរី និងជាចៅរបស់លោកហើរ
2 Chronicles 1:6
ឡើងទៅលើអាសនៈលង្ហិន
ព្រះបាទសាឡូម៉ូនបានយាងទៅគីបៀនជាកន្លែង
ដែលអាសនៈស្ថិតនៅព្រះពន្លាជួបព្រះអម្ចាស់។
2 Chronicles 1:8
សម្រេចតាម
ការបកប្រែផ្សេងទៀត «ធ្វើហើយ» ឬ «នាំយកទៅបញ្ចប់»
ប្រជាជនជាច្រើនដូចធូលីដី។
ការបកប្រែផ្សេងទៀត «ប្រជាជនរាប់មិនអស់»
តើនរណាអាចវិនិច្ឆ័យប្រជាជនរបស់ទ្រង់បាន?,
តើអ្នកណាអាចរាប់ក្រុមមនុស្សដែលមានចំនួនយ៉ាងច្រើននេះបាន?»
ការបកប្រែផ្សេងទៀត
«គ្មាននរណាម្នាក់អាចវិនិច្ឆ័យមនុស្សទាំងអស់របស់ទ្រង់បានទេ
ហើយក៏រាប់មិនអស់របស់ដែរ»
2 Chronicles 1:12
ពីមុខត្រសាលប្រជុំ
ការបកប្រែផ្សេងទៀត «នៅពីមុខព្រះពន្លា»។
2 Chronicles 1:14
នៅក្នុងទីក្រុងជាមួយរទេះចម្បាំង
នេះជាអះអាងសម្រាប់ទីក្រុងនានា ដែលទុករទេះសេះរបស់ទ្រង់។
មានមាសប្រាក់នៅក្រុងយេរូសាឡិមសម្បូរដូចដុំថ្ម
ការបកប្រែផ្សេងទៀត «លោហធាតុដ៏កម្រ និងមានតម្លៃមានច្រើនសន្ធឹក»
ធ្វើឲ្យឈើតាត្រៅសម្បូរដូចដើមកកោះដែលមាននៅតាមតំបន់ទំនាប។
«ឈើនាំចូលដ៏កម្រ និងមានតម្លៃមានដ៏ច្រើនបរិបូរណ៍»

2

[1]ព្រះបាទសាឡូម៉ូនបញ្ជាឲ្យគេសង់ព្រះដំណាក់សម្រាប់ព្រះនាមរបស់ព្រះអម្ចាស់ និងកសាងរាជវាំងមួយសម្រាប់នគររបស់ព្រះអង្គ។
[2]ព្រះបាទសាឡូម៉ូនតែងតាំងមនុស្សប្រាំពីរម៉ឺននាក់ឲ្យលីសែង មនុស្សប្រាំបីម៉ឺននាក់ឲ្យធ្វើជាអ្នកកាប់ឈើនៅលើភ្នំ
និងមានបុរសចំនួនបីពាន់ប្រាំមួយរយនាក់ឲ្យមើលការខុសត្រូវ។[3]ព្រះបាទសាឡូម៉ូនធ្វើសារទៅព្រះបាទហ៊ីរ៉ាម ជាស្តេចនៅក្រុងទីរ៉ុសថា៖
«ព្រះករុណាបានបញ្ជូនឈើតាត្រៅឲ្យព្រះបាទដាវីឌជាបិតារបស់ទូលបង្គំដើម្បីសង់ព្រះដំណាក់ ដូច្នេះ សូមធ្វើការនេះជាមួយទូលបង្គំផង។
[4]មើល៍ ទូលបង្គំរៀបនឹងសង់ព្រះដំណាក់សម្រាប់ព្រះនាមព្រះអម្ចាស់ជាព្រះរបស់ទូលបង្គំ សម្រាប់ញែកថ្វាយដល់ព្រះនាមព្រះអង្គ
សម្រាប់ដុតគ្រឿងក្រអូបនៅចំពោះព្រះភក្ត្រព្រះអង្គ សម្រាប់តម្កល់នំប៉័ងនៅចំពោះព្រះវត្តមានព្រះអង្គ និងសម្រាប់ថ្វាយតង្វាយដុតទាំងព្រឹក និងល្ងាច នៅថ្ងៃសប្ប័ទ
និងថ្ងៃចូលខែថ្មី ព្រមទាំងពិធីបុណ្យសំខាន់ផ្សេងៗសម្រាប់ព្រះអម្ចាស់ជាព្រះរបស់យើង។ កូនចៅអ៊ីស្រាអែល និងធ្វើការនេះជារៀងរហូតទៅ។
[5]ព្រះដំណាក់ដែលទូលបង្គំនឹងសង់នោះមានទំហំធំណាស់ ដ្បិត ព្រះជាម្ចាស់របស់យើងព្រះអង្គធំឆេង និងខ្ពង់ខ្ពស់ជាងព្រះឯទៀតៗ។
[6]ប៉ុន្តែ តើអ្នកណាអាចនឹងសង់ព្រះដំណាក់ថ្វាយព្រះអង្គបាន? ដ្បិត សូម្បីសកលលោកទាំងមូល និងផ្ទៃមេឃដ៏ធំឆេងក៏មិនល្មមនឹងឲ្យព្រះអង្គគង់នៅផង?
តើទូលបង្គំជាអ្វីដែលអាចសង់ព្រះដំណាក់ថ្វាយព្រះអង្គបាន? គឺលើកលែងតែទុកសម្រាប់ថ្វាយតង្វាយនៅចំពោះព្រះភក្ត្រព្រះអង្គ[7]ដូច្នេះ
សូមចាត់មនុស្សដែលប៉ិនប្រសប់ខាងធ្វើមាស ប្រាក់ លង្ហិនដែក ចេះជ្រលក់ក្រណាត់ពណ៌ស្វាយ ពណ៌ក្រហម និងពណ៌ខៀវ ជាអ្នកដែលចេះឆ្លាក់ឈើគ្រប់ប្រភេទ។
គាត់នឹងនៅធ្វើជាមួយនឹងជាងជំនាញរបស់ទូលបង្គំនៅស្រុកយូដា និងក្រុងយេរូសាឡិមគឺជាអ្នកដែលព្រះបាទដាវីឌ ជាបិតារបស់ទូលបង្គំបានជ្រើសរើស ។
[8]សូមចាត់បញ្ជូនឈើតាត្រៅ ឈើកកោះ និងខ្លឹមចន្ទន៍ពីស្រុកលីបង់មកឲ្យទូលបង្គំផង ព្រោះទូលបង្គំដឹងថាពួកអ្នកបម្រើរបស់ព្រះករុណា
ប្រសប់កាប់ឈើនៅស្រុកលីបង់ណាស់។
មើលអ្នកបម្រើរបស់ទូលបង្គំនឹងនៅធ្វើការជាមួយអ្នកបម្រើរបស់ព្រះករុណាដែរ[9]ដើម្បីកាប់ឈើឲ្យបានច្រើនសន្ធឹកសន្ធាប់សម្រាប់ទូលបង្គំ ដ្បិត
ព្រះដំណាក់ដែលទូលបង្គំបម្រុងនឹងសង់នោះពិតជាធំស្តឹមស្តែណាស់។[10]ទូលបង្គំនឹងផ្តល់ឲ្យដល់អ្នកបម្រើរបស់ព្រះករុណាដែលកាប់ឈើនេះនូវស្បៀងជាស្រូវឱកប្រាំពាន់
តោន ស្រូវសាឡីប្រាំពាន់តោន ស្រាទំពាំងបាយជូរប្រាំបីម៉ឺនលីត្រ និងប្រេងប្រាំបីម៉ឺនលីត្រ»។
[11]ព្រះបាទហ៊ីរ៉ាម ជាស្តេចក្រុងទីរ៉ុសបានសរសេរធ្វើទៅព្រះបាទសាឡូម៉ូនថា៖ «ព្រះអម្ចាស់ពិតស្រឡាញ់ប្រជាជនរបស់ព្រះអង្គ
ទើបព្រះអង្គតែងតាំងព្រះករុណាឲ្យធ្វើជាស្តេចលើពួកគេ»។[12]លើសពីនេះទៀត ព្រះបាទហ៊ីរ៉ាមមានរាជឱង្ការថា៖
«សូមលើកតម្កើងព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលដែលបានបង្កើតផ្ទៃមេឃ និងផែនដីដែលបានប្រទានឲ្យព្រះបាទដាវីឌមានបុត្រាដែលប្រកបដោយប្រាជ្ញាវាងវៃ
និងគំនិតយោបល់ដែលនឹងសង់ព្រះដំណាក់ថ្វាយព្រះអម្ចាស់ ព្រមទាំងរាជវាំងសម្រាប់នគ។
[13]ឥឡូវនេះ ទូលបង្គំបានបញ្ជូនបុរសដែលមានជំនាញ និងមានទេពកោសល្យជាមួយនឹងការយល់ដឹងគឺលោកហ៊ីរ៉ាម ជាអ្នកជំនាញរបស់ទូលបង្គំ។
[14]លោកជាកូនរបស់ស្ត្រីរបស់ដាន់។ ឪពុករបស់លោកជាបុរសមកពីក្រុងទីរ៉ុស។ លោកមានជំនាញខាងមាសប្រាក់លង្ហិនដែកថ្ម និងឈើ និងពណ៌ស្វាយ ពណ៌ខៀវ
និងរោមចៀមពណ៌ក្រហម ព្រមទាំងក្រណាត់ធ្វើពីក្រណាត់សូត្រ។ លោកក៏មានជំនាញក្នុងការធ្វើចម្លាក់ និងឆ្លាក់រូបគ្រប់ប្រភេទ តាមគម្រោង។
សូមឲ្យគេទុកកន្លែងមួយឲ្យគាត់ក្នុងចំណោមអ្នកដែលមានជំនាញជាមនុស្សដែលព្រះបាទដាវីឌជាម្ចាស់របស់ទូលបង្គំ ហើយជាបិតារបស់ព្រះករុណាបានជ្រើសរើសចុះ។

generated on Wed Sep 10 16:16:32 2025

[15]ឥឡូវនេះ ស្រូវសាលីស្រូវឱកប្រេង និងស្រាទំពាំងបាយជូរដែលព្រះករុណាជាម្ចាស់របស់ទូលបង្គំបានមានបន្ទូល
សូមព្រះករុណាចាត់បញ្ជូនរបស់ទាំងនេះមកឲ្យពួកអ្នកបម្រើរបស់ព្រះករុណាចុះ។[16]យើងខ្ញុំនឹងកាប់ឈើពីស្រុកលីបង់តាមចំនួនដែលព្រះករុណាត្រូវការ។
យើងខ្ញុំនឹងបញ្ជូនតាមក្បូនតាមសមុទ្រឆ្ពោះទៅក្រុងយ៉ុបប៉េ ហើយព្រះករុណាអាចដឹកវាទៅដល់ក្រុងយេរូសាឡិម»។
[17]ព្រះបាទសាឡូម៉ូនបានជំរឿនជនបរទេសទាំងអស់ដែលរស់នៅក្នុងស្រុកអ៊ីស្រាអែលតាមវិធីដែលព្រះបាទដាវីឌ ជាបិតារបស់ព្រះអង្គបានធ្វើ ហើយជំរឿនពួកគេ។
ពួកគេបានធ្វើជំរឿនឃើញមានចំនួន ១៥៣, ៦០០ នាក់។[18]ស្តេចបានតែងតាំងប្រាំពីរម៉ឺននាក់ឲ្យធ្វើជាអ្នកលីសែង ប្រាំបីម៉ឺននាក់ធ្វើជាអ្នកកាប់ឈើនៅលើភ្នំនិង ៣៦០០
ឲ្យធ្វើជាអ្នកមើលការខុសត្រូវឲ្យគេធ្វើការ។

---

2 Chronicles 2:1
ព្រះបាទហ៊ីរ៉ាម
2 Chronicles 2:4
នំប៉័ងនៅចំពោះព្រះវត្តមានព្រះអង្គ
សំដៅទៅលើនំប៉័ង១២ដុំ ដែលដាក់នៅមុខអាសនៈ។
ថ្ងៃចូលខែថ្មី
នេះជាពេលវេលានៃពិធីបុណ្យមួយ ដែលស្របគ្នានឹងចលនានៃព្រះចន្ទ។
ព្រះជាម្ចាស់របស់យើងព្រះអង្គធំធេង
នេះជាឯកសារយោងមួយទៅព្រះជាម្ចាស់ ដែលសំខាន់ជាង
តែមិនធំជាងព្រះដទៃទៀត។
2 Chronicles 2:6
តើអ្នកណាអាចនឹងសង់ព្រះដំណាក់ថ្វាយព្រះអង្គបាន? ដ្បិត សូម្បីសកលលោកទាំងមូល
និងផ្ទៃមេឃដ៏ធំធេងក៏មិនល្មមនឹងឲ្យព្រះអង្គគង់នៅផង?
តើទូលបង្គំជាអ្វីដែលអាចសង់ព្រះដំណាក់ថ្វាយព្រះអង្គបាន?
គឺលើកលែងតែទុកសម្រាប់ថ្វាយតង្វាយនៅចំពោះព្រះភក្ត្រព្រះអង្គ?
ការបកប្រែផ្សេងទៀត «គ្មាននរណាអាចសង់ព្រះ
ដំណាក់ថ្វាយព្រះជាម្ចាស់បានឡើយ ព្រោះគ្មានអ្វីអាចឲ្យព្រះអង្គគង់នៅបានទេ។
ខ្ញុំមិនអាចទេ! មានតែមនុស្សម្នាក់គត់ ដែលអាចថ្វាយយញ្ញបូជាដល់ព្រះអង្គ។»
2 Chronicles 2:8
ខ្លឹមចន្ទន៍
នេះជាប្រភេទដើមឈើ ទំនងជាប្រើសម្រាប់ផលិតឧបករណ៍ភ្លេង ឬចម្លាក់។
តោន
ស្រូវសាឡី
គឺម្សៅស្រូវសាលី។
លីត្រ
2 Chronicles 2:11
គំនិតយោបល់ដែល
ការបកប្រែផ្សេងទៀត «បានផ្តល់អំណោយទាននៃការប្រុងប្រយ័ត្ន»
ទាំងរាជវាំងសម្រាប់នគ។
ការបកប្រែផ្សេងទៀត «ព្រះបរមរាជវាំងមួយថ្វាយអង្គទ្រង់ផ្ទាល់» (សូមមើល)
2 Chronicles 2:13
លោកហ៊ីរ៉ាម

3

[1]ព្រះបាទសាឡូម៉ូនបានចាប់ផ្តើមសង់ព្រះដំណាក់សម្រាប់ព្រះជាម្ចាស់នៅក្រុងយេរូសាឡិម នៅលើភ្នំម៉ូរីយ៉ា ជាកន្លែងដែលព្រះជាម្ចាស់បានលេចឲ្យព្រះបាទដាវីឌឃើញ។
ព្រះអង្គបានរៀបចំកន្លែងដែលព្រះបាទដាវីឌបានត្រៀមទុកគឺទីលានបោកស្រូវរបស់លោកអូរ៉ាណា ជាជនជាតិយេប៊ូស។
[2]ទ្រង់បានចាប់ផ្តើមសាងសង់ព្រះដំណាក់នៃព្រះអម្ចាស់នៅថ្ងៃទីពីរក្នុងខែទីពីរនៃឆ្នាំទីបួននៃរាជរបស់ព្រះអង្គ។[3]ឥឡូវនេះ
នេះជាវិមាត្រនៃគ្រឹះដែលព្រះបាទសាឡូម៉ូនបានដាក់សម្រាប់ព្រះដំណាក់របស់ព្រះជាម្ចាស់។ ដោយប្រើរង្វាស់បុរាណមានបណ្តោយប្រវែងហុកសិបហត្ថ និងទទឹងម្ភៃហត្ថ។
[4]បន្ទប់ល្វែងខាងមុខព្រះដំណាក់ព្រះអម្ចាស់មានប្រវែងម្ភៃហត្ថស្របតាមទទឹងអាគារ។ កម្ពស់របស់វាមានកម្ពស់ម្ភៃហត្ថ
ហើយព្រះបាទសាឡូម៉ូនបានយកមាសសុទ្ធមកស្រោបបន្ទប់ខាងក្នុង។[5]ស្តេចបានធ្វើពិដានពីឈើតាត្រៅនៅតាមជញ្ជាំងបន្ទប់ធំ ហើយស្រោបមាសមានគុណភាពល្អ
ព្រមទាំងឲ្យគេឆ្លាក់ក្បាច់ដើមចាក និងច្រវាក់ផង។
[6]ស្តេចបានតុបតែងព្រះដំណាក់នៃព្រះអម្ចាស់ដោយត្បូងដ៏មានតម្លៃ និងមាសគឺជាមាសពីស្រុកផារ៉ែម។[7]ស្តេចឲ្យគេស្រោប មាសសុទ្ធនៅលើធ្នឹម ជញ្ជាំង ក្របទ្វារ
និងសន្លឹកទ្វារ ព្រមទាំងឲ្យគេឆ្លាក់ចេរូប៊ីននៅលើជញ្ជាំងផង។
[8]ស្តេចបានសង់ទីបរិសុទ្ធបំផុត។ បណ្តោយរបស់វាត្រូវនឹងទទឹងនៃព្រះដំណាក់មានប្រវែងម្ភៃហត្ថ និងទទឹងម្ភៃហត្ថស្មើគ្នា។
ស្តេចឲ្យគេស្រោបមាសសុទ្ធចំនួនពីម៉ឺនប្រាំរយម្ភៃតម្លឹង។[9]ទំងន់មាសសម្រាប់ធ្វើដែកគោលមានទម្ងន់ហាសិបតម្លឹង។ ស្តេចក៏ស្រោបផ្ទៃខាងលើរបស់វាដោយមាសដែរ។
[10]ស្តេចបានឆ្លាក់រូបចេរូប៊ីនពីរសម្រាប់បន្ទប់នៃទីបរិសុទ្ធបំផុត។ ពួកជាងបានស្រោបចេរូប៊ីនទាំងនោះដោយមាសសុទ្ធ។[11]ស្លាបរបស់ចេរូប៊ីនទាំងពីរមានប្រវែងម្ភៃហត្ថ។
ស្លាបរបស់ចេរូប៊ីនមួយមានបណ្តោយប្រាំហត្ថទៅដល់ជញ្ជាំងបន្ទប់ ហើយស្លាបម្ខាងទៀតរបស់ចេរូប៊ីនមានប្រវែងប្រាំហត្ថទៅទល់នឹងស្លាបរបស់ចេរូប៊ីនទីពីរ។
[12]ស្លាបរបស់ចេរូប៊ីនមួយទៀតមានប្រវែងប្រាំហត្ថទៅទល់នឹងជញ្ជាំងបន្ទប់ ហើយស្លាបម្ខាងទៀតរបស់ចេរូប៊ីនមានប្រវែងប្រាំហត្ថទៅទល់នឹងស្លាបរបស់ចេរូប៊ីនទីមួយ។
[13]ស្លាបរបស់ចេរូប៊ីនទាំងពីរនេះលាតសន្ធឹងមានប្រវែងម្ភៃហត្ថ។ ចេរូប៊ីនឈរ និងជើងហើយបែរមុខទៅសាលធំ។[14]ស្តេចធ្វើវាំងននពីក្រណាត់ពណ៌ខៀវពណ៌ស្វាយ
ពណ៌ក្រហម និងក្រណាត់ទេសឯកហើយមានប៉ាក់ចេរូប៊ីននៅលើក្រណាត់នោះផង។
[15]ព្រះបាទសាឡូម៉ូនក៏បានធ្វើសសរពីរដែលមានកម្ពស់សាមសិបប្រាំហត្ថសម្រាប់ដាក់នៅខាងមុខព្រះដំណាក់ដែរ។
ក្បាលសសរនៅលើចុងសសរទាំងពីរមានកម្ពស់ប្រាំហត្ថ។[16]ស្តេចបានឲ្យគេធ្វើក្បាច់ច្រវ៉ាក់នៅលើក្បាលសសរទាំងពីរ។
ស្តេចក៏ឲ្យគេធ្វើក្បាច់ផ្លែទទឹមចំនួនមួយរយភ្ជាប់នឹងក្បាច់ច្រវាក់។[17]ស្តេចបានបញ្ឈរសសរទាំងពីរឡើងនៅខាងមុខព្រះវិហារគឺមួយនៅខាងស្តាំ និងមួយទៀតនៅខាងឆ្វេង។
ស្តេចដាក់ឈ្មោះសសរនៅខាងស្តាំថាយ៉ាគីន និងសសរនៅខាងឆ្វេងថា បូអូស។

---

2 Chronicles 3:1
លើភ្នំម៉ូរីយ៉ា
នេះជាកន្លែងដែលលោកអប្រាហាំបានថ្វាយអ៊ីសាកជាកូនប្រុសរបស់គាត់ថ្វាយព្រះជាម្ចាស់
លោកអូរ៉ាណា ជាជនជាតិយេប៊ូស។
នៅថ្ងៃទីពីរក្នុងខែទីពីរ
នេះជាខែទីពីរនៃប្រតិទិនហេប្រឺ។ ថ្ងៃទីពីរ
គឺជិតពាក់កណ្តាលខែមេសាតាមប្រតិទិនលោកខាងលិច។
ឆ្នាំទីបួន
ហុកសិប ... ម្ភៃ
«៦០ ... ២០»
ហត្ថ
មួយហត្ថស្មើ៤៦ សង់ទីម៉ែត្រ។
2 Chronicles 3:4
ខាងមុខ
ការបកប្រែផ្សេងទៀត «យ៉ា»
ហត្ថ
ស្តេចបានធ្វើពិដាន
ការបកប្រែផ្សេងទៀត «ស្តេចបានបង្កើត»
នៅតាមជញ្ជាំងបន្ទប់ធំ
នេះជាការអះអាងទៅលើបន្ទប់ធំ មិនមែនផ្លូវដើរទេ។
2 Chronicles 3:6
ត្បូងដ៏មានតម្លៃ

generated on Wed Sep 10 16:16:32 2025

ថ្មដែលស្រស់ស្អាតមានតម្លៃខ្ពស់ និងត្រូវបានប្រើសម្រាប់ការតុបតែង។
ស្រុកផារ៉ែម
ពាក្យទូទៅសម្រាប់ខាងកើត។
2 Chronicles 3:8
ហត្ថ
តម្លឹង
តម្លឹង
2 Chronicles 3:10
បានឆ្លាក់រូបចេរូប៊ីនពីរ
អ្នកខ្លះបកស្រាយអត្ថបទនេះមានន័យថា មានរូបរាងជាចេរូប៊ីន
ដែលត្រូវបានគេសិតធ្វើពីលោហៈ។
2 Chronicles 3:13
ក្រណាត់ទេសឯ
ការបកប្រែផ្សេងទៀត «ក្រណាត់មានគុណភាពខ្ពស់« ឬ «ក្រណាត់»

4

[1]ស្តេចបានធ្វើអាសនៈលង្ហិនមួយ មានបណ្តោយម្ភៃហត្ថទទឹងម្ភៃហត្ថ និងកម្ពស់ដប់ហត្ថ។
[2]ស្តេចបានធ្វើសមុទ្រមូលពីលង្ហិនដែលមានអង្កត់ផ្ចិតពីមាត់ម្ខាងទៅមាត់ម្ខាងប្រវែងដប់ហត្ថ។ សមុទ្រមានកម្ពស់ប្រាំហត្ថ
ហើយសមុទ្រមានទំហំសាមសិបហត្ថជារង្វង់មូល។[3]នៅខាងក្រោមគែមសមុទ្រមានរូបគោឈ្មោលគឺមួយហត្ថមានរូបគោដប់
ពាក់កណ្តាលខ្លួនជាប់ក្នុងសមុទ្រនៅពេលដែលសមុទ្ររលកចេញក្រៅ។
[4]សមុទ្រឈរលើគោចំនួនដប់ពីរ គោបីបែរទៅទិសខាងជើងបីបែរទៅទិសខាងលិចបីទៀតបែរមុខទៅទិសខាងត្បូង និងបីក្រឡេកមើលទៅទិសខាងកើត។
សមុទ្របានដាក់នៅខាងលើរូបគោទាំងនោះហើយគូទរបស់រូបគោទាំងនោះបែរចូលទៅខាងក្នុង។[5]សមុទ្រមានកម្រាស់មួយទះដៃហើយមាត់របស់វាដូចមាត់ពែង
ហើយមានរាងដូចជាផ្កាឈូករីក។ សមុទ្រនោះអាចផ្ទុកទឹកបានចំនួនបីពាន់អំម្រែក។[6]ស្តេចបានធ្វើអាងចំនួនដប់សម្រាប់លាងសម្អាត។ ស្តេចដាក់ប្រាំនៅខាងស្តាំ
និងប្រាំនៅខាងឆ្វេង ហើយសម្ភារដែលត្រូវប្រើក្នុងការថ្វាយតង្វាយដុតត្រូវលាងសម្អាតនៅក្នុងអាងនោះ។ សមុទ្រគឺសម្រាប់ពួកបូជាចារ្យលាងសម្អាតខ្លួន។
[7]ស្តេចបានធ្វើជើងចង្កៀងដប់ អំពីមាស ទៅតាមក្បួនតម្រាអំពីជើងចង្កៀង ហើយយកទៅដាក់នៅក្នុងព្រះវិហារ ប្រាំនៅខាងស្តាំដៃ និងប្រាំទៀតនៅខាងឆ្វេងដៃ។
[8]ស្តេចបានធ្វើតុចំនួនដប់ ហើយបានយកទៅដាក់នៅក្នុងព្រះវិហារ ដោយដាក់ប្រាំនៅខាងស្តាំ និងប្រាំទៀតនៅខាងឆ្វេង។ ស្តេចក៏បានធ្វើផើងមាសចំនួនមួយរយដែរ។
[9]លើសពីនេះ ស្តេចបានបង្កើតទីធ្លាសម្រាប់ពួកបូជាចារ្យ និងទីធ្លាដ៏ធំមួយព្រមទាំងធ្វើទ្វារសម្រាប់ទីធ្លាទាំងនោះផង។ ស្តេចបានឲ្យគេស្រោបទ្វារទាំងនោះដោយលង្ហិន។
[10]ស្តេចដាក់សមុទ្រនៅខាងស្តាំព្រះដំណាក់នៅទិសខាងកើត ហើយបែរមុខទៅទិសខាងត្បូង។
[11]លោកហ៊ីរ៉ាមបានធ្វើផើងប៉ែល និងចានសម្រាប់ប្រោះឈាម។
លោកហ៊ីរ៉ាមបានបង្ហើយកិច្ចការដែលព្រះបាទសាឡូម៉ូនបានឲ្យធ្វើនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់[12]គឺមានសសរទាំងពីរ
និងក្បាលសសររាងពងក្រពើដែលស្ថិតនៅលើសសរទាំងពីរព្រមទាំងក្បាប់តុបតែងលម្អទាំងពីឈុតសម្រាប់គ្របលើក្បាលសសរដែលមានរាងដូចចានគោម
ដែលនៅលើសរទាំងពីរ។[13]លោកបានធ្វើរូបផ្លែទទឹមចំនួនបួនរយសម្រាប់ការតុបតែងលម្អនៅលើក្បាលសសរទាំងពីរ គឺផ្លែទទឹមចំនួនពីរជួរភ្ជាប់
និងក្បាច់ក្រឡាសំណាញ់នីមួយៗ សម្រាប់គ្របក្បាលសសរដែលមានរាងដូចចានពងក្រពើទាំងពីរដែលស្ថិតនៅលើសសរនោះ។
[14]លោកហ៊ីរ៉ាមក៏បានធ្វើជើងទម្រ និងអាងដាក់លើជើងទម្រទាំងនោះ[15]សមុទ្រមួយ និងរូបគោចំនួនដប់ពីរ នៅពីក្រោមសមុទ្រនោះ[16]ព្រមទាំងផើង ប៉ែល សមចាក់សាច់
ព្រមទាំងសម្ភារផ្សេងទៀត។ លោកហ៊ីរ៉ាមជាអ្នកជំនាញបានធ្វើសម្រាប់ព្រះបាទសាឡូម៉ូនសម្រាប់ប្រើក្នុងព្រះដំណាក់នៃព្រះអម្ចាស់ សុទ្ធតែធ្វើពីលង្ហិនយ៉ាងរលោង។
[17]ស្តេចបានឲ្យគេយករបស់ទាំងនោះទៅសិត និងដុតនៅក្នុងឡឥដ្ឋនៅវាលទំនាបទន្លេយ័ដាន់នៅត្រង់ចន្លោះស៊ូកូត និងសារ៉េថាន។[18]ដូច្នេះហើយ
ព្រះបាទសាឡូម៉ូនបានធ្វើគ្រឿងប្រដាប់ទាំងអស់យ៉ាងបរិបូរ ហើយទំងន់លង្ហិនមិនអាចដឹងបានទេ។
[19]ព្រះបាទសាឡូម៉ូនបានធ្វើគ្រឿងសង្ហរិមទាំងអស់ដែលស្ថិតនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ មានអាសនៈមាស និងតុដែលគេដាក់នំប៉័ងនៅទីនោះ។[20]ជើងចង្កៀង
និងចង្កៀងសម្រាប់ដុតនៅក្នុងបន្ទប់ខាងក្នុងត្រូវបានធ្វើឡើងពីមាសសុទ្ធ។[21]ផ្កាភ្លើងចង្កៀង និងអណ្តាតភ្លើងចង្កៀងសុទ្ធតែធ្វើពីមាសសុទ្ធ។ រីឯតួចង្កៀង
កន្លែងដាក់ប្រេងចង្កៀង ស្លាបព្រាចូកប្រឆេះចង្កៀង និងអាសនៈដុតគ្រឿងក្រអូបសុទ្ធតែធ្វើពីមាសសុទ្ធ។[22]រីឯទ្វារចូលព្រះដំណាក់ ទ្វារចូលទៅក្នុងទីបរិសុទ្ធ
ទ្វារខាងក្នុងចូលទៅទីបរិសុទ្ធបំផុត និងទ្វារព្រះដំណាក់គឺជាទ្វារនៃព្រះវិហារគឺសុទ្ធតែធ្វើពីមាសសុទ្ធទាំងអស់។

---

2 Chronicles 4:1
ហត្ថ
សមុទ្រមូលពីលង្ហិនដែលមានអង្កត់ផ្ចិត
នេះជាធុងដែកធំណាស់។
មាត់
នេះជាគែមធុងខាងលើ។
ជារង្វង់មូល
នេះជាចម្ងាយនៅខាងក្រៅរង្វង់។
មួយហត្ថមានរូបគោដប់
ការបកប្រែផ្សេងទៀត «ដប់ក្នុងមួយហត្ថ»
2 Chronicles 4:4
គូទ
នេះជាផ្នែកខាងក្រោយនៃរាងកាយរបស់សត្វ ដែលមានជើងបួន។
សូមមើលពាក្យដដែល ដែលបានប្រើ
(មានតែឯកសារយោងផ្សេងទៀតនៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ប៉ុណ្ណោះ)។
(សូមមើល ៧:២៥)
មួយទះដៃ
ហើយមាត់របស់វាដូចមាត់ពែង ហើយមានរាងដូចជាផ្កាឈូករីក។
ការបកប្រែផ្សេងទៀត «សំរិទ្ធមានគែមកោងទន់ »
អំរែក
2 Chronicles 4:7
ផើង
នេះជាចានដែលមានបាតក្រឡូម ត្រូវបានគេប្រើសម្រាប់លាងសម្អាត។
2 Chronicles 4:11
លោកហ៊ីរ៉ាម
ចានសម្រាប់ប្រោះឈាម។
ចានដែលត្រូវបានប្រើនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ សម្រាប់ប្រោះអាសនៈ
សសរដែលមានរាងដូចចានពងក្រពើ
ផ្នែកខាងលើនៃសសរមួយហៅថា ក្បាច់ក្បាលសសរ។ ការបកប្រែផ្សេងទៀត
«កំពូលមានរាងចានពងក្រពើ» ឬ «ផ្នែកខាងលើមានរាងចានពងក្រពើ»
ក្បាប់តុបតែងលម្អ
សំដៅទៅលើក្បាប់តុបតែលម្អ ឬការឆ្លាក់នៅផ្នែកខាងលើនៃសសរ។
2 Chronicles 4:14
អាងដាក់លើជើងទម្រ
ការបកប្រែផ្សេងទៀត «ចានក្រឡូម»
សមុទ្រមួយ
នេះជាការតុបតែងលម្អដបដ៏ធំមួយ។
ព្រមទាំងសម្ភារផ្សេងទៀត
ឧបករណ៍ ឬវត្ថុផ្សេងទៀតដែលប្រើសម្រាប់អាសនៈ
ធ្វើពីលង្ហិនយ៉ាងរលោង
លង្ហិនដែលជាងសិតបានដុសខាត់ឲ្យរលោងចេញពន្លឺ។
2 Chronicles 4:17
សារ៉េថាន
ព្រះបាទសាឡូម៉ូនបានធ្វើគ្រឿងប្រដាប់ទាំងអស់
ព្រះបាទសាឡូម៉ូនមិនបានបង្កើតគ្រឿងប្រដាប់ទាំងអស់ដោយអង្គទ្រង់ទេ
តែព្រះអង្គបានបង្គាប់ឲ្យគេធ្វើ។

generated on Wed Sep 10 16:16:32 2025

ទំងន់លង្ហិនមិនអាចដឹងបានទេ។
ការបកប្រែផ្សេងទៀត «ចំនួនលង្ហិនច្រើនសន្ធឹក»
2 Chronicles 4:19
ព្រះបាទសាឡូម៉ូនបានធ្វើ
កម្មកររបស់ព្រះបាទសាឡូម៉ូនបានធ្វើអ្វីៗ តាមបង្គាប់របស់ព្រះអង្គ។
គ្រឿងសង្ហារឹមទាំងអស់
ចាននិងឧបករណ៍ទាំងអស់ ដែលប្រើក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
ដាក់នំប៉ុង
សូមមើលការបកប្រែនៅក្នុង ២:៤។

5

[1]ពេលដែលកិច្ចការទាំងប៉ុន្មានដែលព្រះបាទសាឡូម៉ូនបានធ្វើសម្រាប់ព្រះដំណាក់របស់ព្រះអម្ចាស់បានចប់សព្វគ្រប់ហើយព្រះបាទសាឡូម៉ូនបានប្រមូលរបស់របរដែលព្រះបាទដាវីឌជាបិតាបានប
ប្រាក់ និងគ្រឿងសង្ហារឹមផ្សេងៗ។ ព្រះបាទសាឡូម៉ូនបានយករតនៈសម្បត្តិទាំងនោះទៅដាក់ក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
[2]ព្រះបាទសាឡូម៉ូនបានប្រមូលពួកព្រឹទ្ធាចារ្យនៃកូនចៅអ៊ីស្រាអែលទាំងអស់ដែលជាមេដឹកនាំនៃកុលសម្ព័ន្ធ
និងមេដឹកនាំគ្រួសាររបស់ជនជាតិអ៊ីស្រាអែលនៅក្រុងយេរូសាឡិមឲ្យទៅដង្ហែរហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ពីក្រុងដាវីឌគឺក្រុងស៊ីយ៉ូន។
[3]ប្រជាជនអ៊ីស្រាអែលទាំងអស់នាំគ្នាមកគាល់ព្រះរាជានៅក្នុងពិធីបុណ្យដែលត្រូវនឹងខែទីប្រាំពីរ។
[4]ពួកព្រឹទ្ធាចារ្យទាំងអស់នៃជនជាតិអ៊ីស្រាអែលនាំគ្នាមកហើយពួកលេវីក៏សែងហឹប។[5]ពួកគេបានសែងហឹប ត្រសាលប្រជុំ
និងគ្រឿងប្រដាប់ដ៏វិសុទ្ធដែលស្ថិតនៅក្នុងព្រះពន្លាមកជាមួយផង។ ពួកបូជាចារ្យដែលមកពីកុលសម្ព័ន្ធលេវីជាអ្នកដង្ហែរនាំរបស់ទាំងនេះមក។[6]ព្រះបាទសាឡូម៉ូន
និងសហគមន៍អ៊ីស្រាអែលទាំងមូលបានជួបជុំគ្នានៅមុខហឹបនៃសម្ពន្ធមេត្រី ហើយបានថ្វាយតង្វាយជាសត្វចៀម និងគោយ៉ាងច្រើនសន្ធឹកដែលមិនអាចរាប់បាន។
[7]ពួកបូជាចារ្យបាននាំហឹបនៃសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ទៅតម្កល់នៅបន្ទប់ខាងក្នុងនៃព្រះដំណាក់គឺនៅក្នុងទីបរិសុទ្ធបំផុតនៅក្រោមស្លាបរបស់ចេរូប៊ីន។
[8]ចេរូប៊ីនទាំងពីរត្រដាងស្លាបពីលើកន្លែងតម្កល់ហឹប ដើម្បីគ្របបាំងហឹប និងឈើស្នែង។
[9]ឈើស្នែងនោះវែងណាស់ដែលចុងរបស់វាត្រូវបានគេមើលឃើញពីទីបរិសុទ្ធនៅមុខបន្ទប់ខាងក្នុង ប៉ុន្តែ គេមិនអាចមើលឃើញពីខាងក្រៅបានទេ។
ហឹបនោះតម្កល់នៅទីនោះរហូតដល់សព្វថ្ងៃនេះ។[10]នៅក្នុងហឹបនោះគ្មានអ្វីទេ គឺមានតែបន្ទះថ្មពីរផ្ទាំងដែលលោកម៉ូសេបានដាក់ គឺជាបន្ទះថ្មដែលគាត់ទទួលនៅភ្នំហោរែប
នៅពេលដែលព្រះអម្ចាស់បានចងសម្ពន្ធមេត្រីជាមួយជនជាតិអ៊ីស្រាអែលនៅពេលពួកគេចាកចេញពីស្រុកអេស៊ីបមក។
[11]នៅពេលដែលពួកបូជាចារ្យចេញពីទីបរិសុទ្ធ។ បូជាចារ្យទាំងអស់ដែលមានវត្តមានបានញែកខ្លួនជាបរិសុទ្ធថ្វាយព្រះអម្ចាស់ដោយមិនគិតពីក្រុមគ្រួសារវង្សត្រកូលទេ។
[12]ពួកលេវីដែលជាអ្នកចម្រៀងទាំងអស់រួមទាំងលោកអេសាភ លោកហេម៉ាន លោកយេឌូថុនព្រមទាំងកូនចៅ
និងបងប្អូនរបស់គេសុទ្ធតែស្លៀកសម្លៀកបំពាក់ធ្វើពីក្រណាត់ទេសឯក និងលេងភ្លេងមានពិណ ស្គរ និងឃឹម ឈរនៅចុងអាសនៈខាងកើត។
នៅជាមួយពួកគេមានបូជាចារ្យ ១២០ នាក់ដែលផ្លុំត្រែ។[13]នៅពេលអ្នកផ្លុំត្រែ និងអ្នកចម្រៀងបន្លឺសម្លេងច្រៀងឡើងជាសម្លេងតែមួយជាមួយគ្នា
ដើម្បីសរសើរតម្កើងព្រះជាម្ចាស់។ ពួកគេបន្លឺសម្លេងត្រែដោយផ្លុំត្រែ និងឧបករណ៍ឯទៀតៗរួចនាំគ្នាសរសើរតម្កើងព្រះអម្ចាស់។ ពួកគេបានច្រៀងថា៖ «ដ្បិត
ព្រះអម្ចាស់ទ្រង់ល្អ ហើយភាពស្មោះត្រង់របស់ព្រះអង្គនៅស្ថិតស្ថេរជារៀងរហូត»។ ពេលនោះ មានពពកបានមកគ្របដណ្តប់ពេញលើព្រះដំណាក់នៃព្រះអម្ចាស់។
[14]ពួកបូជាចារ្យពុំអាចឈរបំពេញមុខងារបានឡើយ ដ្បិត សិរីរុងរឿងរបស់ព្រះអម្ចាស់ស្ថិតនៅពេញព្រះដំណាក់របស់ព្រះអង្គ។

2 Chronicles 5:1
រតនៈសម្បត្តិ
នេះជាកន្លែងមួយ ដែលត្រូវបានរក្សាទុក ឬកន្លែងទុកវត្ថុមានតម្លៃ។
2 Chronicles 5:2
នៅក្នុងពិធីបុណ្យដែលត្រូវនឹងខែទីប្រាំពីរ។
នេះជាពិធីបុណ្យនៃទីជម្រក ដែលត្រូវនឹងថ្ងៃទីដប់ប្រាំ ខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។
គឺជិតដល់ដើមខែតុលាតាមប្រតិទិនលោកខាងលិច។
2 Chronicles 5:4
គ្រឿងប្រដាប់
សូមមើលការបកប្រែនៅក្នុង ៤:១៩។
សត្វចៀម និងគោយ៉ាងច្រើនសន្ធឹកដែលមិនអាចរាប់បាន។
ការបកប្រែផ្សេងទៀត «ចៀមនិងគោជាច្រើន»
2 Chronicles 5:7
ទៅតម្កល់នៅបន្ទប់
ការបកប្រែផ្សេងទៀត «ទៅដាក់កន្លែងដែលបានកំណត់»
2 Chronicles 5:9
រហូតដល់សព្វថ្ងៃនេះ
សំដៅទៅលើពេលវេលា ដែលបានសរសេរកណ្ឌគម្ពីរបាក្យត្រទី២។
2 Chronicles 5:11
លោកអេសាភ លោកហេម៉ាន លោកយេឌូថុន
ដូចគ្នាមានអ្នកនាំថ្វាយបង្គំបីនាក់
នៅពេលព្រះបាទដាវីឌយកហឹបទៅក្រុងយេរូសាឡឹម។
ក្រោយមកព្រះបាទដាវីឌបានតែងតាំងពួកគេទាំងបីនាក់
ជាអ្នកលេងភ្លេងនៅព្រះវិហារ។
ព្រមទាំងកូនចៅ និងបងប្អូន
ការបកប្រែផ្សេងទៀត «សាច់ញាតិរបស់ពួកគេ» ឬ «កូនចៅរបស់ពួកគេ »
ពិណ
ចានដែកមូលមូលចំនួនពីរ ដែលត្រូវបានបុកជាមួយគ្នាដើម្បីបង្កើតជាសំឡេងឮៗ។

6 [1]ព្រះបាទសាឡូម៉ូនមានរាជឱង្ការថា៖ «ព្រះអម្ចាស់មានព្រះបន្ទូលថា ព្រះអង្គសព្វព្រះហឫទ័យនឹងគង់នៅក្នុងទីងងឹតដ៏ក្រាស់![2]ប៉ុន្តែ
ទូលបង្គំបានសង់ព្រះវិហារដ៏ថ្កុំថ្កើងនេះ ទុកជាព្រះដំណាក់សម្រាប់ទ្រង់គង់នៅជារៀងរហូតតទៅ»។[3]បន្ទាប់មក
ស្តេចក៏ងាកមកប្រទានពរដល់សហគមន៍អ៊ីស្រាអែលទាំងមូល ពេលដែលពួកគេកំពុងតែឈរនៅទីនោះទាំងអស់គ្នា។
[4]ស្តេចមានរាជឱង្ការថា៖ «សូមឲ្យព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលបានលើកតម្កើងឡើង ដ្បិត ទ្រង់បានសម្រេចតាមព្រះបន្ទូល
ដែលព្រះអង្គបានសន្យាជាមួយព្រះបាទដាវីឌ ជាបិតារបស់ខ្ញុំ ហើយព្រះអម្ចាស់មានបន្ទូលថា៖[5]«ចាប់តាំងពីថ្ងៃដែលយើងនាំប្រជារាស្ត្ររបស់យើងចេញពីស្រុកអេស៊ីបមក
យើងមិនបានជ្រើសរើសយកទីក្រុងណាចេញពីកុលសម្ព័ន្ធអ៊ីស្រាអែលទាំងប៉ុន្មានដើម្បីសង់ដំណាក់សម្រាប់នាមយើងឡើយ
ហើយយើងក៏មិនបានជ្រើសរើសនរណាម្នាក់ឲ្យធ្វើជាមេដឹកនាំលើអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងដែរ។[6]តែយើងបានជ្រើសរើសក្រុងយេរូសាឡិមសម្រាប់នាមយើង
និងបានជ្រើសរើសព្រះបាទដាវីឌឲ្យធ្វើជាអ្នកត្រួតត្រាលើអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង»។
[7]ព្រះបាទដាវីឌ ជាបិតារបស់ទូលបង្គំមានបំណងសង់ព្រះដំណាក់ថ្វាយព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល។[8]ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្រះបាទដាវីឌ
ជាបិតារបស់ទូលបង្គំថា៖ «ដែលឯងមានចិត្តចង់សង់ព្រះដំណាក់សម្រាប់នាមយើង នោះគឺជាការប្រសើរណាស់។[9]ប៉ុន្តែ ទោះយ៉ាងណាក៏ដោយ
ស្តេចមិនត្រូវសង់ដំណាក់សម្រាប់យើងឡើយ។ ផ្ទុយទៅវិញ បុត្រារបស់ទ្រង់ដែលជាសាច់ឈាមរបស់ទ្រង់នឹងត្រូវសង់ព្រះដំណាក់សម្រាប់នាមយើង»។
[10]ព្រះអម្ចាស់សម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គ ព្រោះទូលបង្គំបានឡើងសួងរាជ្យជំនួសព្រះបាទដាវីឌជាបិតារបស់ទូលបង្គំ
ហើយទូលបង្គំញុំអង្គុយលើបល្ល័ង្ករបស់អ៊ីស្រាអែល ដូចព្រះអម្ចាស់បានសន្យា។ ទូលបង្គំបានសង់ព្រះដំណាក់ថ្វាយព្រះនាមព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល។
[11]ទូលបង្គំបានតម្កល់ហឹបដែលជាសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ដែលព្រះអង្គបានធ្វើជាមួយជនជាតិអ៊ីស្រាអែល»។

generated on Wed Sep 10 16:16:32 2025

[12]ព្រះបាទសាឡូម៉ូនឈរនៅមុខអាសនៈរបស់ព្រះអម្ចាស់នៅចំពោះមុខសហគមន៍អ៊ីស្រាអែលទាំងមូលហើយលើកព្រះហស្តឡើង។
[13]ស្តេចបានធ្វើវេទិកាលង្ហិនមានបណ្តោយប្រាំហត្ថទទឹងប្រាំហត្ថនិងកំពស់បីហត្ថ។ ព្រះអង្គបានដាក់វានៅកណ្តាលទីធ្លា។
ព្រះអង្គឈរនៅលើនោះហើយលុតជង្គង់នៅចំពោះមុខសហគមន៍អ៊ីស្រាអែលទាំងមូល បន្ទាប់មក ព្រះអង្គលើកព្រះហស្តឡើងទៅលើមេឃ។
[14]ស្តេចបានទូលថា៖ «ឱព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលអើយ នៅលើមេឃ ឬនៅលើផែនដីគ្មានព្រះណាដូចព្រះអង្គទេ ព្រះអង្គរក្សាសម្ពន្ធមេត្រី
និងសម្តែងព្រះហឫទ័យស្មោះត្រង់ចំពោះអ្នកបម្រើរបស់ព្រះអង្គដែលដើរនៅមុខព្រះអង្គដោយអស់ពីចិត្ត។
[15]គឺព្រះអង្គដែលបានធ្វើសម្រេចចំពោះព្រះបាទដាវីឌអ្នកបម្រើទ្រង់ ហើយជាបិតារបស់ទូលបង្គំស្របតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ។ មែនហើយ!
ព្រះអង្គមានបន្ទូលដោយព្រះឱស្ឋទ្រង់ ហើយបានសម្រេចដោយព្រះហស្តរបស់ទ្រង់ដូចសព្វថ្ងៃនេះ។
[16]ឥឡូវនេះ ឱព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលអើយ!
សូមធ្វើតាមព្រះបន្ទូលដែលព្រះអង្គបានសន្យាជាមួយអ្នកបម្រើរបស់ព្រះអង្គគឺព្រះបាទដាវីឌជាបិតារបស់ទូលបង្គំថា ប្រសិនបើ ពូជពង្សរបស់អ្នកប្រុងប្រយ័ត្ន
និងដើរតាមមាគា៌របស់យើងដូចជាអ្នកបានដើរនៅចំពោះមុខយើង នោះពូជអ្នកនឹងមិនដែលអាកខាននឹងមានអ្នកអង្គុយនៅលើបល្ល័ង្ករបស់អ៊ីស្រាអែលឡើយ។
[17]បពិត្រព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែលអើយ! ឥឡូវនេះ
ទូលបង្គំសូមឲ្យទ្រង់សម្រេចតាមព្រះបន្ទូលដែលព្រះអង្គបានសន្យាជាមួយព្រះបាទដាវីឌជាអ្នកបម្រើរបស់ព្រះអង្គផង។
[18]ប៉ុន្តែ តើព្រះអម្ចាស់ពិតជានឹងគង់នៅជាមួយមនុស្សនៅលើផែនដីទេ? ដ្បិត សូម្បីសកលលោកទាំងមូល និងផ្ទៃមេឃទាំងមូលមិនល្មមឲ្យទ្រង់គង់ផង
ចុះទម្រាំព្រះដំណាក់ដែលទូលបង្គំសង់ថ្វាយនេះ តើរឹងរឹតតែចង្អៀតយ៉ាងណាទៅ![19]ឱព្រះអម្ចាស់ជាព្រះនៃទូលបង្គំអើយ
សូមមេត្តាស្តាប់ពាក្យទូលអង្វររបស់អ្នកបម្រើព្រះអង្គផង។ សូមស្តាប់សម្រែកយំ និងពាក្យអធិស្ឋានដែលអ្នកបម្រើរបស់ព្រះអង្គអធិស្ឋាននៅចំពោះព្រះភក្ត្រព្រះអង្គផង។
[20]សូមឲ្យព្រះនេត្រទ្រង់ទតមើលមកព្រះវិហារនេះទាំងយប់ទាំងថ្ងៃ គឺជាកន្លែងដែលព្រះអង្គបានសន្យាទុកសម្រាប់ព្រះនាមទ្រង់។
សូមទ្រង់ព្រះសណ្តាប់ពាក្យដែលអ្នកបម្រើរបស់ទ្រង់អធិស្ឋាននៅទីនេះផង។
[21]ពេលណាយើងខ្ញុំអធិស្ឋាននៅកន្លែងនេះ សូមស្តាប់ពាក្យទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ និងជនជាតិអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គផង។
សូមស្តាប់ពីស្ថានសួគ៌ជាកន្លែងដែលព្រះអង្គគង់នៅ ហើយសូមអត់ទោសឲ្យយើងខ្ញុំផង។
[22]ប្រសិនបើ មនុស្សម្នាក់ធ្វើបាបទាស់នឹងអ្នកជិតខាង ហើយគេបង្ខំឲ្យស្បថហើយប្រសិនបើ
គាត់ចូលមកស្បថនៅមុខអាសនៈក្នុងព្រះដំណាក់របស់ព្រះអង្គ[23]សូមព្រះអង្គមេត្តាស្តាប់ពីលើស្ថានសួគ៌ ហើយវិនិច្ឆ័យ
និងសម្តែងសេចក្តីយុត្តិធម៌ដល់អ្នកបម្រើរបស់ព្រះអង្គផង! សូមសងសឹកដល់មនុស្សទុច្ចរិត សូមឲ្យអំពើអាក្រក់ធ្លាក់ទៅលើក្បាលរបស់គាត់ផ្ទាល់។
សូមប្រកាសសេចក្តីសុចរិត ស្លូតត្រង់ ដើម្បីផ្តល់រង្វាន់ដល់មនុស្សសុចរិតចំពោះភាពសុចរិតរបស់គាត់ផង។
[24]នៅពេលអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គត្រូវបរាជ័យចំពោះមុខខ្មាំង ដោយព្រោះពួកគេបានធ្វើបាបប្រឆាំងនឹងព្រះអង្គ ប្រសិនបើ
ពួកគេវិលត្រឡប់មករកព្រះអង្គវិញ ហើយសរសើរព្រះនាមព្រះអង្គ ព្រមទាំងអធិស្ឋាន និងទូលអង្វរសុំការអត់ទោសពីព្រះអង្គនៅក្នុងព្រះដំណាក់នេះ។
[25]សូមព្រះអង្គមេត្តាស្តាប់ពីលើមេឃហើយអត់ទោសឲ្យប្រជាជនអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គផង!
សូមនាំពួកគេត្រឡប់ទៅស្រុកដែលព្រះអង្គបានប្រគល់ឲ្យពួកគេ និងដូនតារបស់ពួកគេផង។
[26]ពេលមេឃរាំងស្ងួតហើយគ្មានទឹកភ្លៀងព្រោះប្រជាជនបានធ្វើបាបទាស់ប្រឆាំងនឹងព្រះអង្គ ហើយព្រះអង្គបានដាក់ទោសពួកគេ ប្រសិនបើ ពួកគេទូលអង្វរឆ្ពោះមកទីនេះ
ព្រមទាំងសរសើរតម្កើងព្រះនាមព្រះអង្គ និងលះបង់អំពើបាបចេញ[27]សូមស្តាប់នៅស្ថានបរមសុខហើយអត់ទោសឲ្យពួកអ្នកបំរើរបស់ព្រះអង្គ
និងជនជាតិអ៊ីស្រាអែលដែលជាប្រជារាស្ត្ររបស់ព្រះអង្គផង ពេលព្រះអង្គណែនាំពួកគេឲ្យដើរតាមមាគ៌ាល្អដែលពួកគេគួរដើរ។
សូមបង្អុរភ្លៀងមកលើដីដែលព្រះអង្គបានប្រគល់ឲ្យប្រជាជនរបស់ព្រះអង្គទុកជាកេរមរតក។
[28]ឧបមាថាមានទុរ្ភិក្សនៅក្នុងស្រុក ឬមានជំងឺរោគរាតត្បាត ឬក្រា កណ្តូប ឬដង្កូវ ស៊ីដំណាំ ឬខ្មាំងសត្រូវចូលមកវាយយកក្រុងក្នុងទឹកដីរបស់ពួកគេ ឬមានរោគ
ឬគ្រោះអាសន្នណាមួយកើតឡើង[29]ហើយប្រសិនបើ មាននរណាម្នាក់ ឬអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គអធិស្ឋាន និងទូលអង្វរ ដោយម្នាក់ៗដឹងអំពីគ្រោះកាច
និងទុក្ខព្រួយក្នុងចិត្តរបស់ខ្លួន ហើយពេលគាត់លើកដៃមកកាន់ព្រះវិហារនេះ។[30]សូមស្តាប់ពីស្ថានបរមសុខជាកន្លែងដែលព្រះអង្គគង់នៅ អត់ទោស
និងឲ្យរង្វាន់ដល់មនុស្សម្នាក់ៗចំពោះគ្រប់ទាំងផ្លូវរបស់គាត់។ ព្រះអង្គស្គាល់ដួងចិត្តរបស់គាត់ពីព្រោះព្រះអង្គគឺមានតែព្រះអង្គដែលស្គាល់ដួងចិត្តរបស់មនុស្ស។។
[31]ដើម្បីឲ្យពួកគេគោរពកោតខ្លាចព្រះអង្គ
ហើយឲ្យពួកគេដើរតាមមាគ៌ារបស់ព្រះអង្គជារៀងរាល់ថ្ងៃដែលពួកគេរស់នៅលើទឹកដីដែលព្រះអង្គបានប្រគល់ឲ្យបុព្វបុរសរបស់យើង។
[32]ជនបរទេសដែលមិនមែនជាកម្មសិទ្ធិរបស់ជនជាតិអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ ប៉ុន្តែ ជាអ្នកដែលឮពីព្រះនាមឧត្តុង្គឧត្តម ឫទ្ធានុភាព
និងបារមីដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ហើយនាំគ្នាមកអធិស្ឋានឆ្ពោះមកកាន់ព្រះដំណាក់នេះ។[33]សូមស្តាប់ពីស្ថានបរមសុខជាកន្លែងដែលព្រះអង្គគង់នៅ
សូមធ្វើអ្វីៗទាំងអស់ដែលជនបរទេសសុំមកទ្រង់ដើម្បីឲ្យប្រជាជនទាំងអស់នៅលើផែនដីស្គាល់ព្រះនាមរបស់ព្រះអង្គ
និងគោរពកោតខ្លាចព្រះអង្គដូចជនជាតិអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គដែរ
ហើយឲ្យគេដឹងថាព្រះដំណាក់ដែលទូលបង្គំបានសង់នេះត្រូវបានគេហៅតាមព្រះនាមរបស់ព្រះអង្គ។
[34]បើកាលណាប្រជារាស្ត្ររបស់ទ្រង់ចេញទៅច្បាំងនឹងខ្មាំងសត្រូវរបស់ពួកគេ ទោះបើទ្រង់បញ្ជូនគេទៅក្នុងរបៀបណាក៏ដោយ
ហើយបើគេអធិស្ឋានទៅទ្រង់ឆ្ពោះទៅរកក្រុងដែលព្រះអង្គបានជ្រើសរើស និងចំពោះដំណាក់ដែលទូលបង្គំបានសង់សម្រាប់ព្រះនាមព្រះអង្គ។
[35]ពេលនោះសូមស្តាប់ពីលើមេឃចំពោះពាក្យអធិស្ឋាននិងពាក្យទូលអង្វររបស់ពួកគេ ហើយជួយពួកគេផង។
[36]បើកាលណាពួកគេធ្វើបាបទាស់នឹងទ្រង់ ដ្បិត គ្មាននរណាម្នាក់មិនធ្វើបាបឡើយ ហើយទ្រង់ព្រះពិរោធនឹងពួកគេហើយប្រគល់ពួកគេទៅឲ្យខ្មាំងសត្រូវ ដូច្នេះ
ខ្មាំងសត្រូវនាំពួកគេទៅជាឈ្លើយនៅទឹកដីរបស់ពួកគេទោះបីនៅឆ្ងាយ ឬជិតក៏ដោយ។[37]ប្រសិនបើ ពួកគេដឹងថាពួកគេស្ថិតនៅលើទឹកដីដែលពួកគេត្រូវនិរទេស
ហើយពួកគេបានប្រែចិត្តហើយស្វែងរកជំនួយពីទ្រង់នៅក្នុងទឹកដីដែលពួកគេត្រូវជាប់ជាឈ្លើយនោះ។ បើកាលណាពួកគេនិយាយថាយើងបានធ្វើខុសហើយបានធ្វើបាប។
យើងបានប្រព្រឹត្តអាក្រក់។[38]បើកាលណាពួកគេវិលត្រឡប់មករកទ្រង់វិញដោយអស់ពីដួងចិត្ត
និងអស់ពីព្រលឹងរបស់ពួកគេនៅក្នុងទឹកដីដែលពួកគេបានចាប់យកជាឈ្លើយ
ហើយពួកគេបានអធិស្ឋានទៅកាន់ទឹកដីរបស់ពួកគេដែលព្រះអង្គបានប្រគល់ឲ្យដូនតារបស់ពួកគេ
និងឆ្ពោះទៅទីក្រុងដែលព្រះអង្គបានជ្រើសរើសហើយឆ្ពោះទៅកាន់ព្រះដំណាក់ដែលទូលបង្គំបានសង់សម្រាប់ព្រះនាមព្រះអង្គ។
[39]សូមស្តាប់ពីលើមេឃជាកន្លែងដែលទ្រង់គង់ ចំពោះពាក្យអធិស្ឋាននិងពាក្យទូលអង្វររបស់គេ ហើយជួយពួកគេផង។
សូមអត់ទោសឲ្យប្រជាជនរបស់ទ្រង់ដែលបានធ្វើបាបទាស់នឹងព្រះអង្គផង។[40]បពិត្រព្រះនៃទូលបង្គំ ឥឡូវនេះ ទូលបង្គំសូមអង្វរព្រះអង្គ
សូមព្រះអង្គបើកព្រះនេត្រហើយផ្ទៀងព្រះកាណ៌ស្តាប់ពាក្យអធិស្ឋានដែលបានធ្វើឡើងនៅកន្លែងនេះ។[41]បពិត្រព្រះអម្ចាស់ ឥឡូវនេះ
សូមក្រោកឡើងយាងទៅជាមួយហឹបនៃឫទ្ធានុភាពរបស់ទ្រង់ ហើយសម្រាកក្នុងព្រះដំណាក់ព្រះអង្គ។ ឱព្រះអម្ចាស់អើយ!
សូមឲ្យបូជាចារ្យរបស់ព្រះអង្គនាំគ្នាស្លៀកពាក់ដោយសេចក្តីសង្គ្រោះហើយសូមឲ្យប្រជាជនដ៏វិសុទ្ធរបស់ព្រះអង្គរីករាយចំពោះភាពល្អរបស់ព្រះអង្គ។
[42]សូមកុំងាកព្រះភក្ត្រចេញពីអ្នកដែលព្រះអង្គបានចាក់ប្រេងអភិសេកឡើយ។ សូមនឹកចាំអំពីការប្រព្រឹត្តដ៏ស្មោះត្រង់របស់ព្រះអង្គចំពោះដាវីឌជាអ្នកបម្រើរបស់ព្រះអង្គ»។

generated on Wed Sep 10 16:16:32 2025

2 Chronicles 6:1
ដ៏ថ្កុំថ្កើង
ការបកប្រែផ្សេងទៀត «កន្លែងត្រូវរស់នៅដែលត្រូវបានលើកតម្កើង»
ពួកគេកំពុងតែឈរនៅទីនោះទាំងអស់គ្នា។
ការបកប្រែផ្សេងទៀត «ពេលប្រជាជនបានឈរ»
2 Chronicles 6:4
បានសម្រេចតាមព្រះបន្ទូល ដែលព្រះអង្គបានសន្យាជាមួយព្រះបាទដាវីឌ ជាបិតារបស់ខ្ញុំ
បានបណ្តាលឲ្យវាកើតឡើង ឬបានធ្វើឲ្យប្រាកដថា
ពាក្យការសន្យារបស់ព្រះអង្គបានសម្រេច
សម្រាប់នាមយើងឡើយ
ការបកប្រែផ្សេងទៀត «ដើម្បីធ្វើឲ្យខ្លួនយើងត្រូវបានគេស្គាល់នៅទីនោះទេ»។
2 Chronicles 6:7
បិតារបស់ទូលបង្គំមានបំណង
ការបកប្រែផ្សេងទៀត «បំណងប្រាថ្នារបស់ព្រះបាទដាវីឌ»។
ថ្វាយព្រះអម្ចាស់
ព្រះនាមរបស់ព្រះអម្ចាស់តំណាងឲ្យវត្តមានព្រះអង្គ។
2 Chronicles 6:10
ដែលជាសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «ផ្ទាំងថ្មនោះជាកន្លែងបង្ហាញពីសម្ពន្ធមេត្រី
ដែលព្រះអម្ចាស់បានចងជាមួយប្រជាជនអ៊ីស្រាអែល»។
2 Chronicles 6:12
នៅចំពោះមុខសហគមន៍អ៊ីស្រាអែលទាំងមូល
ការបកប្រែផ្សេងទៀត «នៅចំពោះមុខប្រជាជនអ៊ីស្រាអែល
ដែលបានប្រមូលផ្តុំគ្នានៅទីនោះ» ។
ហត្ថ
ព្រះអង្គលើកព្រះហស្តឡើងទៅលើមេឃ។
ព្រះបាទសាឡូម៉ូនលើកព្រះហស្តរបស់ទ្រង់ឡើង ហើយលើកឡើងឲ្យខ្ពស់
ពេលព្រះអង្គបានលុតជង្គង់ចុះអធិស្ឋាននៅទីធ្លា។
2 Chronicles 6:14
អ្នកបម្រើរបស់ព្រះអង្គដែលដើរនៅមុខព្រះអង្គដោយអស់ពីចិត្ត។
ការបកប្រែផ្សេងទៀត « ពួកយើងដែលស្មោះត្រង់ព្យាយាមធ្វើអ្វី
ដែលព្រះអង្គចង់ឲ្យពួកយើងធ្វើ»។
ព្រះអង្គមានបន្ទូលដោយព្រះឱស្ឋទ្រង់ ហើយបានសម្រេចដោយព្រះហស្តរបស់ទ្រង់ដូចសព្វថ្ងៃនេះ។
សំដៅទៅលើការសន្យា ដែលព្រះជាម្ចាស់បានធ្វើចំពោះព្រះបាទដាវីឌថា
បុត្ររបស់ព្រះអង្គនឹងសង់ព្រះវិហារនេះ។ ការបកប្រែផ្សេងទៀត
«ព្រះអង្គបានសម្រេចព្រះបន្ទូលសន្យា»
2 Chronicles 6:16
សូមធ្វើតាម
នេះជាការស្នើសុំ។ ការបកប្រែផ្សេងទៀត «សូមធ្វើ»
ពូជពង្សរបស់អ្នកប្រុងប្រយ័ត្ន និងដើរតាមមាគ៌ារបស់យើងដូចជាអ្នកបានដើរនៅចំពោះមុខយើង
នោះពូជអ្នកនឹងមិនដែលអាកខានដែលមានអ្នកអង្គុយនៅលើបល្ល័ង្ករបស់អ៊ីស្រាអែលឡើយ។
ការបកប្រែផ្សេងទៀត «អ្នកនឹងតែងតែមានស្តេចមួយឡើងសោយរាជ្យ
ដែលជាកូនចៅរបស់ព្រះបាទដាវីឌ»
អ្នកអង្គុយនៅលើបល្ល័ង្ករបស់អ៊ីស្រាអែលឡើយ។
ការបកប្រែផ្សេងទៀត«តាមរបៀបដែលព្រះបាទដាវីឌបានធ្វើ»
2 Chronicles 6:18
ប៉ុន្តែ តើព្រះអម្ចាស់ពិតជានឹងគង់នៅជាមួយមនុស្សនៅលើផែនដីទេ?
ការបកប្រែផ្សេងទៀត «ប៉ុន្តែ
ព្រះជាម្ចាស់ប្រាកដជាអ្នកនឹងមិនរស់នៅជាមួយមនុស្ស នៅលើផែនដីទេ»។
សូម្បីសកលលោកទាំងមូល និងផ្ទៃមេឃទាំងមូលមិនល្មមឲ្យទ្រង់គង់ផង
សូមមើលការបកប្រែនៅក្នុង ២:៦។
សូមស្តាប់សម្រែកយំ និងពាក្យអធិស្ឋាន
ពាក្យ «យំ» និង «ការអធិស្ឋាន» មានអត្ថន័យស្រដៀងគ្នា។ ជាទូទៅ
ពាក្យទាំងពីរនេះបញ្ជាក់លើភាពស្មោះត្រង់នៃការអធិស្ឋាន។ ការបកប្រែផ្សេងទៀត
«សូមឆ្លើយនឹងសំណូមពររបស់ខ្ញុំ»។
សូមឲ្យព្រះនេត្រទ្រង់ទតមើលមកព្រះវិហារនេះទាំងយប់ទាំងថ្ងៃ
«សូមជួយអស់អ្នក ដែលមករកព្រះអង្គនៅក្នុងព្រះវិហារបរិសុទ្ធគ្រប់ពេលវេល។
ទាំងពេលថ្ងៃ ឬទាំងពេលយប់ផង»
ជាកន្លែងដែលព្រះអង្គបានសន្យាទុកសម្រាប់ព្រះនាមទ្រង់។
ការបកប្រែផ្សេងទៀត «កន្លែងដែលព្រះអង្គមានបន្ទូល
នឹងធ្វើឲ្យមនុស្សស្គាល់ព្រះអង្គ»
អ្នកបម្រើរបស់ទ្រង់អធិស្ឋាននៅទីនេះផង។
អ្នកនិពន្ធអធិស្ឋានតាមការណែនាំរបស់ព្រះវិហារ។
2 Chronicles 6:21
ហើយសូមអត់ទោសឲ្យយើងខ្ញុំផង។
ការបកប្រែផ្សេងទៀត «នៅពេលអ្នកឮការអធិស្ឋាន
សូមអភ័យទោសចំពោះអំពើបាបរបស់ពួកគេផង»
2 Chronicles 6:22
សូមឲ្យអំពើអាក្រក់ធ្លាក់ទៅលើក្បាលរបស់គាត់ផ្ទាល់។
ការបកប្រែផ្សេងទៀត «ដោយដាក់ទោសគាត់ ព្រោះគាត់សក្តិសមនឹងទទួលទោស»
2 Chronicles 6:24
សូមព្រះអង្គមេត្តាស្តាប់ពីលើមេឃហើយ
ការបកប្រែផ្សេងទៀត «សូមគោរពការអធិស្ឋានរបស់ពួកគេ»
ដែលព្រះអង្គបានប្រគល់ឲ្យពួកគេ
ការបកប្រែផ្សេងទៀត «ព្រះអង្គបានសន្យាជាមួយពួកគេ»
2 Chronicles 6:26
ពេលមេឃរាំងស្ងួតហើយគ្មានទឹកភ្លៀង
ឃ្លាថា «មេឃរាំងស្ងួត» មានន័យថា មិនមានភ្លៀងធ្លាក់ពីលើមេឃទេ។
ការបកប្រែផ្សេងទៀត «នៅពេលព្រះអង្គមិនអនុញ្ញាតឲ្យមានភ្លៀងធ្លាក់ណាមួយ» ។
សរសើរតម្កើងព្រះនាមព្រះអង្គ
ដោយពាក្យសម្តី និងសកម្មភាព
ពួកគេគោរពព្រះជាម្ចាស់និងសិទ្ធិអំណាចរបស់ព្រះអង្គ។
លះបង់អំពើបាបចេញ
ការបកប្រែផ្សេងទៀត «បញ្ឈប់ផ្លូវអាក្រក់របស់ពួកគេ »
ណែនាំពួកគេឲ្យដើរតាមមាគ៌ាល្អដែលពួកគេគួរដើរ។
ការបកប្រែផ្សេងទៀត «បង្ហាញពួកគេពីរបៀបរស់នៅដោយសេចក្តីសុចរិត»
2 Chronicles 6:28
ដោយម្នាក់ៗដឹងអំពីគ្រោះកាច និងទុក្ខព្រួយក្នុងចិត្តរបស់ខ្លួន
អាចមានន័យថា «ដឹងថាមានបាបនៅក្នុងចិត្តរបស់ខ្លួន» ឬ
«ដឹងក្នុងចិត្តរបស់ខ្លួនថា គ្រោះកាចនិងទុក្ខព្រួយជាលទ្ធផលនៃអំពើបាប»។
គាត់លើកដៃមកកាន់
សូមមើលការបកប្រែនៅក្នុង ៦:១២។
គ្រប់ទាំងផ្លូវរបស់គាត់
ការបកប្រែផ្សេងទៀត «អ្វីដែលគាត់បានធ្វើ»
2 Chronicles 6:32
ព្រះនាមឧត្តុង្គឧត្តម ឫទ្ធានុភាព និងបារមីដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ
ការបកប្រែផ្សេងទៀត «ព្រះអង្គអស្ចារ្យណាស់ហើយពេញដោយអំណាចចេស្តា»
ត្រូវបានគេហៅតាមព្រះនាមរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត «ត្រូវបានស្គាល់ថា
ជាដំណាក់របស់ព្រះអម្ចាស់ជាកម្មសិទ្ធិរបស់ព្រះអង្គ»។
2 Chronicles 6:34
ទូលបង្គំបានសង់
ការបកប្រែផ្សេងទៀត «ប្រជារាស្ត្របានសង់នៅក្រោមការដឹកនាំរបស់ទូលបង្គំ»
2 Chronicles 6:36
ព័ត៌មានទូទៅ៖
សូមមើល
ខ្មាំងសត្រូវនាំពួកគេទៅជាឈ្លើយនៅទឹកដីរបស់ពួកគេ
«ខ្មាំងសត្រូវនាំពួកគេទៅជាឈ្លើយ
ហើយនាំពួកគេទៅដល់ទឹកដីសត្រូវរបស់ពួកគេ»
ធិស្ឋានទៅកាន់ទឹកដីរបស់ពួកគេ
សំដៅលើអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«ហើយអធិស្ឋានប្រឈមមុខនឹងទឹកដីនេះ ដែលអ្នកបានផ្តល់ឲ្យដូនតារបស់ពួកគេ»

[1]ពេលព្រះបាទសាឡូម៉ូនអធិស្ឋានចប់សព្វគ្រប់ហើយស្រាប់តែមានភ្លើងធ្លាក់ពីលើមេឃមកបញ្ឆេះតង្វាយដុតទាំងមូល និងយញ្ញបូជា
ហើយសិរីរុងរឿងរបស់ព្រះអម្ចាស់ស្ថិតនៅពេញក្នុងព្រះដំណាក់។[2]ពួកបូជាចារ្យមិនអាចចូលក្នុងព្រះដំណាក់របស់ព្រះអម្ចាស់បានទេ ដ្បិត
សិរីរុងរឿងរបស់ព្រះអង្គស្ថិតនៅពេញក្នុងព្រះដំណាក់របស់ព្រះអង្គ។[3]ប្រជាជនអ៊ីស្រាអែលទាំងអស់នាំគ្នាសម្លឹងមើលពេលដែលភ្លើងឆេះ
ហើយសិរីរុងរឿងរបស់ព្រះអម្ចាស់ស្ថិតនៅលើព្រះដំណាក់។ ពួកគេក្រាបចុះឱនមុខដល់ដីនៅលើឆ្នាំងថ្មថ្វាយបង្គំ និងអរព្រះគុណព្រះអម្ចាស់។ ពួកគេនិយាយថា៖
«ព្រះអង្គម្ចាស់ទ្រង់ល្អ ហើយសេចក្តីស្មោះត្រង់របស់ព្រះអង្គនៅស្ថិតស្ថេរជារៀងរហូត»។
[4]ស្តេច និងប្រជាជនទាំងមូលបានថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់។[5]ព្រះបាទសាឡូម៉ូនបានថ្វាយគោចំនួនពីរម៉ឺនពីរពាន់ក្បាលចៀមនិងពពែចំនួនមួយសែនពីរម៉ឺនក្បាល។
ដូច្នេះ ស្តេច និងប្រជាជនទាំងមូលបានធ្វើពិធីបុណ្យឆ្លងព្រះដំណាក់របស់ព្រះជាម្ចាស់។[6]ពួកបូជាចារ្យឈរនៅទីនោះរៀងៗខ្លួន។
ពួកលេវីក៏មានឧបករណ៍តន្ត្រីរបស់ព្រះអម្ចាស់ដែលព្រះបាទដាវីឌបានធ្វើដើម្បីថ្លែងអំណរគុណដល់ព្រះអម្ចាស់ដោយច្រៀងថា៖ «ព្រះអង្គម្ចាស់ល្អ
ហើយសេចក្តីស្មោះត្រង់របស់ព្រះអង្គនៅស្ថិតស្ថេរជារៀងរហូត»។ ពួកបូជាចារ្យទាំងអស់ក៏ផ្លុំត្រែនៅចំពោះមុខជនជាតិអ៊ីស្រាអែលទាំងមូល។
[7]ព្រះបាទសាឡូម៉ូនញែកកន្លែងមួយនៅកណ្តាលទីលានស្ថិតនៅខាងមុខព្រះដំណាក់របស់ព្រះអម្ចាស់។ នៅទីនោះលោកថ្វាយតង្វាយដុតទាំងមូល
និងខ្លាញ់របស់សត្វដែលថ្វាយជាយញ្ញបូជាមេត្រីភាព។ ពីព្រោះអាសនៈលង្ហិនដែលព្រះករុណាបានធ្វើពុំអាចនឹងថ្វាយតង្វាយដុត តង្វាយម្សៅ នឹងខ្លាញ់របស់សត្វបានទេ។
[8]ព្រះបាទសាឡូម៉ូនប្រារព្ធពិធីបុណ្យនេះអស់រយៈពេលប្រាំពីរថ្ងៃ ហើយជនជាតិអ៊ីស្រាអែលទាំងមូលដែលនៅជាមួយបានប្រមូលផ្តុំគ្នាយ៉ាងឱឡារិក
ចាប់ពីលើបូហាម៉ាត់រហូតដល់ទន្លេរនៅស្រុកអេស៊ីប។[9]នៅថ្ងៃទីប្រាំបីពួកគេជួបជុំគ្នាយ៉ាងឱឡារិក ដ្បិត គេបានប្រារព្ធពិធីឧទ្ទិសឆ្លងអាសនៈចំនួនប្រាំពីរថ្ងៃ
ហើយប្រារព្ធពិធីបុណ្យអស់រយៈពេលប្រាំពីរថ្ងៃ។
[10]នៅថ្ងៃទីម្ភៃបីនៃខែទីប្រាំពីរព្រះបាទសាឡូម៉ូនបានឲ្យប្រជាជនវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់ពួកគេវិញដោយចិត្តរីករាយ
និងអរសប្បាយព្រោះព្រះអម្ចាស់បានសម្តែងព្រះហឫទ័យសប្បុរសចំពោះព្រះបាទដាវីឌ ព្រះបាទសាឡូម៉ូន និងអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ។
[11]ព្រះបាទសាឡូម៉ូនបានបញ្ចប់ការសាងសង់ព្រះដំណាក់របស់ព្រះអម្ចាស់ និងរាជវាំងព្រះករុណា។ អ្វីៗទាំងអស់ដែលស្តេចចង់ធ្វើនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់
និងក្នុងដំណាក់របស់ស្តេចនោះព្រះបាទសាឡូម៉ូនទទួលជោគជ័យទាំងអស់។[12]នៅយប់នោះ ព្រះអម្ចាស់បានសម្តែងឲ្យព្រះបាទសាឡូម៉ូនឃើញហើយមានបន្ទូលថា៖
«យើងបានស្តាប់ឮសេចក្តីអធិស្ឋានរបស់អ្នកហើយ យើងបានជ្រើសរើសកន្លែងនេះទុកសម្រាប់ធ្វើជាកន្លែងថ្វាយយញ្ញបូជា។
[13]កាលណាយើងបង្ខាំងផ្ទៃមេឃមិនឲ្យមានភ្លៀង កាលណាយើងបញ្ជាឲ្យសត្វកណ្តូបលេបត្របាក់ស្រុកនេះ
ឬកាលណាយើងធ្វើឲ្យមានជំងឺរាតត្បាតប្រជាជនរបស់យើង[14]ប្រសិនបើ ប្រជារាស្ត្ររបស់យើងដែលហៅតាមនាមរបស់យើងនឹងបន្ទាបខ្លួនអធិស្ឋាន
ស្វែងរកមុខយើងហើយងាកចេញពីមាគ៌ាអាក្រក់របស់ខ្លួន នោះយើងនឹងស្តាប់ពីស្ថានសួគ៌ ហើយអត់ទោសដល់គេព្រមទាំងព្យាបាលស្រុកគេឲ្យជាផង។[15]ឥឡូវនេះ
យើងនឹងបើកភ្នែកមើលហើយផ្ទៀងត្រចៀកស្តាប់ពាក្យអធិស្ឋាននៅទីនេះ។
[16]ឥឡូវនេះ យើងជ្រើសរើស និងញែកដំណាក់នេះទុកសម្រាប់នាមយើងរហូតតទៅ។ ភ្នែកនឹងដួងចិត្តរបស់យើងនឹងនៅទីនោះជារៀងរាល់ថ្ងៃ។[17]រីឯអ្នកវិញ ប្រសិនបើ
អ្នកដើរតាមមាគ៌ាយើងដូចព្រះបាទដាវីឌជាបិតារបស់ទ្រង់ដើរតាមអ្វីៗទាំងអស់ដែលយើងបានបង្គាប់ បើព្រះករុណានឹងកាន់តាមច្បាប់
និងក្រឹត្យវិន័យរបស់យើង[18]នោះយើងនឹងពង្រឹងរាជបល្ល័ង្ករបស់ទ្រង់ដូចយើងបានសន្យាជាមួយព្រះបាទដាវីឌ ជាបិតារបស់អ្នកថា៖
«ពូជពង្សរបស់ទ្រង់នឹងតែងតែមានម្នាក់ឡើងគ្រងរាជ្យនៅស្រុកអ៊ីស្រាអែល»។
[19]ប៉ុន្តែ ប្រសិនបើ អ្នកបែរចេញហើយបោះបង់ចោលច្បាប់ និងបទបញ្ជារបស់យើង ដែលយើងបានដាក់នៅចំពោះមុខអ្នក ហើយប្រសិនបើ
អ្នកទៅគោរពបូជាព្រះដទៃព្រមទាំងក្រាបថ្វាយបង្គំ[20]នោះយើងនឹងដកពួកគេចេញពីដីដែលយើងបានប្រគល់ឲ្យពួកគេ។
ដំណាក់ដែលយើងបានញែកចេញសម្រាប់នាមយើង យើងនឹងបោះចោលឆ្ងាយពីយើង យើងនឹងធ្វើជាសុភាសិត និងកំប្លែងលេងសើចក្នុងចំណោមប្រជាជនទាំងអស់។
[21]ទោះបីព្រះដំណាក់នេះមានសភាពអ៊ូអរខ្លាំងណាស់នៅពេលនេះអ្នកណាដែលឆ្លងកាត់ទីនេះនឹងមានការភ្ញាក់ផ្អើល ហើយនឹងទទួលយកពុំខាន។
ពួកគេនឹងសួរថាហេតុអ្វីបានជាព្រះអម្ចាស់ធ្វើដូច្នេះចំពោះស្រុកនេះ និងព្រះដំណាក់នេះ?[22]នោះគេនឹងឆ្លើយថា៖
«ដោយព្រោះពួកគេបោះបង់ចោលព្រះអម្ចាស់ជាព្រះរបស់ពួកគេដែលបាននាំបុព្វបុរសរបស់ពួកគេឲ្យចាកចេញពីស្រុកអេស៊ីបមក»។ ពួកគេបែរទៅរកព្រះដទៃ
និងក្រាបថ្វាយបង្គំព្រះទាំងនោះ។ ហេតុនេះហើយ បានជាព្រះអម្ចាស់ធ្វើឲ្យពួកគេរងទុក្ខវេទនាយ៉ាងនេះ»។

---

2 Chronicles 7:1
ក្រាបចុះឱនមុខដល់ដី
នេះជាតួនាទីរបស់អ្នកអធិស្ឋាន។ ការបកប្រែផ្សេងទៀត
«ពួកគេបានក្រាបថ្វាយបង្គំខ្លួនរបស់ពួកគេ ដោយទឹកមុខប៉ះនឹងកម្រាលថ្ម» ។
សេចក្តីស្មោះត្រង់របស់ព្រះអង្គ
ការបកប្រែផ្សេងទៀត «សម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ដ៏ស្មោះត្រង់» ឬ
«ព្រះជាម្ចាស់បានសន្យាថា នឹងស្រឡាញ់ប្រជាជនអ៊ីស្រាអែលជារៀងរហូត»
2 Chronicles 7:4
ឈរនៅទីនោះរៀងៗខ្លួន។
ការបកប្រែផ្សេងទៀត «ម្នាក់ៗឈរនៅកន្លែង ដែលបានកំណត់ទុក»
2 Chronicles 7:7
ពុំអាចនឹងថ្វាយតង្វាយដុត
ការបកប្រែផ្សេងទៀត «មិនអាចថ្វាយតង្វាយដុតដែលមានចំនួនច្រើនទេ»
2 Chronicles 7:8
ហើយសូមអត់ទោសឲ្យយើងខ្ញុំផង។
ប្រជាជនមកពីទូទាំងអ៊ីស្រាអែលបានមក។
លីបូហាម៉ាត់
ជួបជុំគ្នាយ៉ាងឱឡារិក
នេះជាការប្រមូលផ្តុំគ្នាយ៉ាងពិសេសផ្នែកសាសនា។
នៅថ្ងៃទីម្ភៃបីនៃខែទីប្រាំពីរ
ថ្ងៃទីបីខែទីប្រាំពីរ។ នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។
ថ្ងៃទីម្ភៃបីគឺជិតពាក់កណ្តាលខែតុលាតាមប្រតិទិនលោកខាងលិច។
ដោយចិត្តរីករាយ និងអរសប្បាយ
ពាក្យ «រីករាយ» និង «អរសប្បាយ» មានន័យជាមូលដ្ឋានដូចគ្នា។
ពួកគេបញ្ជាក់លើកម្លាំងនៃអំណរជាមួយគ្នា។ ការបកប្រែផ្សេងទៀត
«ដោយចិត្តរីករាយ»។
2 Chronicles 7:11
ជោគជ័យទាំងអស់
«បានបញ្ចប់»
យើងបានស្តាប់ឮសេចក្តីអធិស្ឋានរបស់អ្នក
ការបកប្រែផ្សេងទៀត «យើងបានស្តាប់ការអធិស្ឋានរបស់អ្នក»
2 Chronicles 7:13
បង្ខាំងផ្ទៃមេឃមិនឲ្យមានភ្លៀង
ការបកប្រែផ្សេងទៀត «បានបញ្ឈប់ភ្លៀងកុំឲ្យធ្លាក់»
លេបត្របាក់ស្រុកនេះ
ពាក្យ «ស្រុក» ត្រូវបានប្រើដោយមានន័យថា
«រុក្ខជាតិនិងដំណាំទាំងអស់ដែលមានជីវិត»។
ស្វែងរកមុខយើង
ការបកប្រែផ្សេងទៀត «ស្វែងរកព្រះជាម្ចាស់» ឬ
«ព្យាយាមធ្វើឲ្យព្រះជាម្ចាស់យកចិត្តទុកដាក់ដល់អ្នក»
យើងនឹងបើកភ្នែកមើល ... ហើយផ្ទៀងត្រចៀកស្តាប់
ពាក្យ «ភ្នែក» និង «ត្រចៀក» សំដៅទៅលើព្រះជាម្ចាស់ដែលជ្រើសរើសមើល
និងស្តាប់សេចក្តីអធិស្ឋានរបស់ពួកគេ។ ការបកប្រែផ្សេងទៀត
«ខ្ញុំនឹងឃើញពួកគេហើយខ្ញុំនឹងស្តាប់»
2 Chronicles 7:16
ភ្នែកនឹងដួងចិត្តរបស់យើង

generated on Wed Sep 10 16:16:32 2025

«ស្នេហារបស់យើង ការឃ្លាំមើលដោយប្រុងប្រយ័ត្ន និងការការពារ»
ប្រសិនបើ អ្នកដើរតាមមាគ៌ាយើងដូចព្រះបាទដាវីឌជាបិតារបស់ទ្រង់ដើរតាម
ការបកប្រែផ្សេងទៀត
«បើអ្នកស្តាប់បង្គាប់យើងដូចដាវីឌដែលជាបិតារបស់អ្នកបានធ្វើ។»
ពង្រឹងរាជបល្ល័ង្ក
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើឲ្យប្រាកដថា
កូនចៅរបស់អ្នកនឹងក្លាយជាស្តេចជានិច្ច»

2 Chronicles 7:19
យើងនឹងដកពួកគេចេញពីដីដែលយើងបានប្រគល់ឲ្យពួកគេ។
ការបកប្រែផ្សេងទៀត «យើងនឹងដកពួកគេចេញពីទឹកដីរបស់យើង។»
ប្រៀបធៀបនឹងការដកដំណាំ តាមរយៈការដកឫសរបស់ពួកវាចេញពីដី
ជាមួយនឹងការដកប្រជាជនអ៊ីស្រាអែលរបស់ព្រះជាម្ចាស់
ចេញពីទឹកដីរបស់ព្រះអង្គ។
វានឹងបានលទ្ធផលជាការបំផ្លាញប្រទេសជាតិនិងទុក្ខព្រួយដល់ប្រជាជន។»

---

8 [1]ម្ភៃឆ្នាំបន្ទាប់ពីព្រះបាទសាឡូម៉ូនបានសង់ព្រះដំណាក់របស់ព្រះអម្ចាស់ និងរាជដំណាក់របស់ព្រះអង្គហើយ។
[2]ព្រះបាទសាឡូម៉ូនបានសង់ក្រុងនានាដែលព្រះបាទហ៊ីរ៉ាមបានប្រគល់ឲ្យស្តេច ហើយទ្រង់ក៏ឲ្យជនជាតិអ៊ីស្រាអែលរស់នៅក្នុងក្រុងនោះវិញ។
[3]ព្រះបាទសាឡូម៉ូនវាយប្រហារហាម៉ាត់សូបា ហើយវាយយកបានក្រុងនោះ។[4]ស្តេចបានសង់ក្រុងតាម៉ូនៅទីរហោស្ថាន
និងក្រុងដែលមានឃ្លាំងទាំងអស់ដែលស្តេចបានសង់នៅហាម៉ាត់។
[5]ស្តេចបានសង់ក្រុងបេតហូរ៉ូនខាងលើ និងបេតហូរ៉ូនខាងក្រោម ជាក្រុងដែលមានកំពែងមានទ្វារ និងរនុក។[6]ស្តេចបានសង់ក្រុងបាឡាត
និងក្រុងឃ្លាំងទាំងអស់ដែលស្តេចមានហើយក្រុងសម្រាប់រទេះចម្បាំងទាំងអស់ និងក្រុងនានាសម្រាប់រទេះសេះ និងអ្វីៗដែលស្តេចចង់សង់នៅក្រុងយេរូសាឡិម លីបង់
និងទឹកដីទាំងអស់ក្រោមការគ្រប់គ្រងរបស់ស្តេច។
[7]ចំណែកឯ ប្រជាជនទាំងអស់ដែលនៅសេសសល់ពីជនជាតិហេត ជនជាតិអាម៉ូរី ជនជាតិពេរីស៊ីត ជនជាតិហេវី
និងជនជាតិយេប៊ូសដែលមិនមានចំណែកជាមួយពួកកូនចៅអ៊ីស្រាអែល[8]គឺជាពួកកូនចៅរ៉ាប់គេដែលនៅសេសសល់នៅលើទឹកដីដែលប្រជាជនអ៊ីស្រាអែលពុំបានបំផ្លាញ
នោះព្រះបាទសាឡូម៉ូនបានធ្វើឲ្យពួកគេក្លាយទៅជាកម្មករ ហើយបង្ខំឲ្យពួកគេធ្វើរហូតដល់សព្វថ្ងៃ។
[9]ប៉ុន្តែ ព្រះបាទសាឡូម៉ូនមិនបានបង្ខំប្រជាជនអ៊ីស្រាអែលឲ្យធ្វើការអ្វីឡើយ។ ផ្ទុយទៅវិញ ពួកគេបានក្លាយជាទាហានរបស់ព្រះអង្គ ជាមេបញ្ជាការ មេទ័ព
និងជាមេបញ្ជាការកងទ័ពរទេះ និងទ័ពសេះរបស់ព្រះអង្គ។[10]ពួកគេជាមេបញ្ជាការមេត្រួតត្រា របស់ស្តេចសាឡូម៉ូនមានចំនួន ២៥០
នាក់ជាអ្នកមើលខុសត្រូវលើអ្នកបំពេញការងារធ្វើជំរឿនប្រជាជន។
[11]ព្រះបាទសាឡូម៉ូននាំបុត្រីរបស់ស្តេចផារ៉ោនចេញពីក្រុងព្រះបាទដាវីឌឆ្ពោះទៅព្រះដំណាក់ដែលស្តេចបានសង់ថ្វាយព្រះនាង ដ្បិត ស្តេចមានរាជឱង្ការថា៖
«មហេសីរបស់យើងមិនត្រូវរស់នៅក្នុងដំណាក់របស់ព្រះបាទដាវីឌជាស្តេចស្រុកអ៊ីស្រាអែលឡើយ ដ្បិត ហឹបរបស់ព្រះអម្ចាស់មកដល់ទីណា ទីនោះជាកន្លែងបរិសុទ្ធ»។
[12]ក្រោយមក ព្រះបាទសាឡូម៉ូនថ្វាយតង្វាយដុតទាំងមូលថ្វាយព្រះអម្ចាស់នៅលើអាសនៈដែលព្រះអង្គបានសង់នៅខាងមុខទីលាន។
[13]ព្រះអង្គបានថ្វាយយញ្ញបូជាដូចតម្រូវតាមកាលវិភាគប្រចាំថ្ងៃ។ ព្រះអង្គបានថ្វាយតាមការណែនាំដែលមាននៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ គឺនៅថ្ងៃសប្ប័ទ
ថ្ងៃបុណ្យចូលខែថ្មី និងបុណ្យសំខាន់ៗបីដងរៀងរាល់ឆ្នាំគឺពិធីបុណ្យនំបុ័ងឥតមេ ពិធីបុណ្យសប្តាហ៍ និងពិធីបុណ្យបារាំជាដើម។
[14]ដោយគោរពតាមរាជក្រឹត្យរបស់ព្រះបាទដាវីឌជាព្រះបិតា ព្រះបាទសាឡូម៉ូនបានតែងតាំងពួកបូជាចារ្យ
និងពួកលេវីឲ្យបំពេញមុខងាររបស់ខ្លួនក្នុងគោលបំណងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងបំពេញមុខងារនៅចំពោះមុខពួកបូជាចារ្យតាមការកំណត់ប្រចាំថ្ងៃ។
ស្តេចបានតែងតាំងអ្នកយាមទ្វារតាមកងពលរបស់ពួកគេតាមខ្លោងទ្វារនីមួយៗ ដ្បិត ព្រះបាទដាវីឌ ជាអ្នកជំនិតរបស់ព្រះជាម្ចាស់បានបញ្ជាឲ្យគេបំពេញមុខងារនេះ។
[15]ប្រជាជនពុំបានប្រព្រឹត្តខុសពីបទបញ្ជារបស់ស្តេច ស្តីអំពីបូជាចារ្យ និងពួកលេវី និងអំពីទ្រព្យសម្បត្តិព្រះដំណាក់ឡើយ។
[16]ព្រះបាទសាឡូម៉ូនបានបញ្ចប់កិច្ចការទាំងអស់ ចាប់តាំងពីការសង់គ្រឹះនៃព្រះដំណាក់របស់ព្រះអម្ចាស់រហូតដល់បានចប់សព្វគ្រប់។
ដំណាក់របស់ព្រះអម្ចាស់បានសង់រួចរាល់។[17]បន្ទាប់មក ព្រះបាទសាឡូម៉ូនបានយាងទៅឯអេស៊ាន-កេបើរ និងអេឡាតដែលនៅឆ្នេរសមុទ្រក្នុងស្រុកអេដុម។
[18]ព្រះបាទហ៊ីរ៉ាមបញ្ជូនសំពៅ និងនាយទាហានជើងទឹកដែលមានជំនាញខាងសមុទ្រ។
ពួកគេធ្វើដំណើរតាមទូកជាមួយពួកអ្នកបម្រើរបស់ព្រះបាទសាឡូម៉ូនទៅដល់ស្រុកអូរភា។ ពួកគេបានយកមាសពីទីនោះចំនួន ១៥តោននាំទៅថ្វាយព្រះបាទសាឡូម៉ូន។

---

2 Chronicles 8:1
ម្ភៃឆ្នាំបន្ទាប់ពី
ការបកប្រែផ្សេងទៀត «២០ឆ្នាំក្រោយមក »
ព្រះបាទហ៊ីរ៉ាម
2 Chronicles 8:3
ព្រះបាទសាឡូម៉ូនវាយប្រហារហាម៉ាត់សូបា
ព្រះបាទស្តេចសាឡូម៉ូនតំណាងឲ្យកងទ័ពប្រយុទ្ធទាំងមូលរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត
«កងទ័ពរបស់ព្រះបាទសាឡូម៉ូនបានវាយប្រហារទីក្រុងហាម៉ាត់សូលបា»
តាម៉ូ ...ហាម៉ាត់
ទីក្រុងនៅក្នុងស្រុកស៊ីរី។
2 Chronicles 8:5
ព័ត៌មានទូទៅ៖
សូមមើល
2 Chronicles 8:7
ដែលនៅសេសសល់នៅលើទឹកដី
ការបកប្រែផ្សេងទៀត «អ្នកណានៅសល់នៅលើទឹកដី»
បង្ខំឲ្យពួកគេ
ការបកប្រែផ្សេងទៀត «ទាសករ»
រហូតដល់សព្វថ្ងៃ។
សូមមើលការបកប្រែនៅក្នុង ៥:៩។
2 Chronicles 8:9
២៥០នាក់
សូមមើល
2 Chronicles 8:12
ទីលាន
នេះជារានហាលមានដំបូង ឬផ្លូវដើរដែលមានសរសរទ្រជាជួរដែលភ្ជាប់នឹងអគារ។
ដូចតម្រូវតាមកាលវិភាគប្រចាំថ្ងៃ។
ការបកប្រែផ្សេងទៀត
«យោងទៅតាមតម្រូវការប្រចាំថ្ងៃនៃក្រឹត្យវិន័យរបស់លោកម៉ូសេ»
2 Chronicles 8:14
ប្រជាជនពុំបានប្រព្រឹត្តខុសពីបទបញ្ជារបស់ស្តេច
ការបកប្រែផ្សេងទៀត «ប្រជាជនធ្វើតាមបទបញ្ជា»

---

9 [1]ពេលមហាក្សត្រីនៃស្រុកសេបាបានឮគេនិយាយអំពីកិត្តិនាមរបស់ព្រះបាទសាឡូម៉ូន ព្រះនាងក៏បានយាងមកដល់ក្រុងយេរូសាឡិម ដើម្បីល្បងប្រាជ្ញាជាមួយព្រះអង្គ។
ព្រះនាងយាងមកដោយមានពួករាជបម្រើជាច្រើនហែហមមកជាមួយ ហើយមានទាំងសត្វអូដ្ឋដឹកគ្រឿងក្រអូបមាស និងត្បូងពេជ្រមានតម្លៃជាច្រើនសន្ធឹក។
ពេលព្រះនាងចូលទៅគាល់ព្រះបាទសាឡូម៉ូន ព្រះនាងបានចោទសួរគ្រប់សំណួរទាំងអស់ដែលមានក្នុងចិត្តព្រះនាង។[2]ព្រះបាទសាឡូម៉ូន
ឆ្លើយសំណួរទាំងអស់របស់ព្រះនាងគ្មានអ្វីដែលពិបាកសម្រាប់សាឡូម៉ូនឡើយ គ្មានសំណួរណាដែលព្រះអង្គឆ្លើយមិនបាននោះទេ។

generated on Wed Sep 10 16:16:32 2025

[3]ពេលមហាក្សត្រីស្រុកសេបាបានឃើញប្រាជ្ញារបស់ព្រះបាទសាឡូម៉ូន និងរាជវាំងដែលស្តេចបានសង់[4]ព្រះស្ងោយនៅលើតុរបស់ស្តេច
កន្លែងអង្គុយរបស់អ្នកបម្រើការងាររបស់ពួកអ្នកបម្រើនិងសម្លៀកបំពាក់របស់ពួកគេ អ្នកកាន់ពែងនិងសម្លៀកបំពាក់ពួកគេ
ព្រមទាំងរបៀបដែលស្តេចថ្វាយតង្វាយដុតនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ នោះព្រះនាងកោតស្ញប់ស្ញែងយ៉ាងខ្លាំង។
[5]ព្រះនាងបានទូលព្រះរាជាថា៖ «ពិតមែនហើយរបាយការណ៍ដែលខ្ញុំម្ចាស់បានឮនៅក្នុងទឹកដីរបស់ខ្លួនខ្ញុំម្ចាស់ផ្ទាល់អំពីព្រះរាជឱង្ការ និងប្រាជ្ញារបស់ព្រះអង្គ។
[6]ខ្ញុំម្ចាស់មិនជឿអ្វីដែលខ្ញុំម្ចាស់បានឮទេ រហូតដល់ខ្ញុំម្ចាស់មកដល់ទីនេះ ហើយឥឡូវភ្នែកខ្ញុំម្ចាស់បានឃើញហើយ។ អ្វីដែលគេប្រាប់ខ្ញុំម្ចាស់មិនបានពាក់កណ្តាល
អំពីប្រាជ្ញា និងទ្រព្យសម្បត្តិរបស់ព្រះករុណាទេ! ព្រះករុណាមានកេរ្តិ៍ឈ្មោះល្បីល្បាញលើសជាងខ្ញុំម្ចាស់ឮទៅទៀត។
[7]ប្រជាជន និងអ្នកបម្រើរបស់ស្តេចពិតជាមានសុភមង្គលណាស់ពីព្រោះពួកគេបាននៅជិត និងឮពីប្រាជ្ញារបស់ស្តេច។
[8]សូមលើកតម្កើងព្រះអម្ចាស់ជាព្រះរបស់ស្តេចដែលបានគាប់ព្រះហឫទ័យនឹងស្តេចហើយឲ្យស្តេចឡើងស្នងរាជ្យ ដើម្បីគ្រងរាជ្យជំនួសព្រះអម្ចាស់ជាព្រះរបស់ស្តេច។
ដោយសារព្រះរបស់ស្តេចស្រឡាញ់ជនជាតិអ៊ីស្រាអែល ហើយចង់ឲ្យពួកគេស្ថិតស្ថេរជារៀងរហូតនោះព្រះអង្គបានតែងតាំងព្រះករុណាឲ្យឡើងគ្រងរាជ្យលើពួកគេ
ដើម្បីឲ្យព្រះករុណាបានសោយរាជ្យដោយ សុចរិត និងយុត្តិធម៌»។
[9]ព្រះនាងបានថ្វាយមាសចំនួនបួនតោនព្រមទាំងគ្រឿងក្រអូប និងត្បូងមានតម្លៃជាច្រើនដល់ព្រះរាជា។
ពុំដែលមានអ្នកណាយកគ្រឿងក្រអូបមកថ្វាយឲ្យដូចដែលព្រះមហាក្សត្រិយានីស្រុកសេបាបានថ្វាយព្រះបាទសាឡូម៉ូនទៀតឡើយ។
[10]ពួកមន្ត្រីរបស់ព្រះបាទហ៊ីរ៉ាម និងពួកមន្ត្រីរបស់ព្រះបាទសាឡូម៉ូនដែលបានដឹកមាសពីអូភាក៏នាំយកឈើខ្លឹមចន្ទន៍ និងត្បូងមានតម្លៃដែរ។
[11]ស្តេចបានយកឈើខ្លឹមចន្ទន៍សង់ធ្វើជណ្តើរឡើងព្រះដំណាក់របស់ព្រះអម្ចាស់ និងដំណាក់របស់ស្តេចព្រមទាំងពិណសម្រាប់អ្នកលេងភ្លេង។
ពីមុនមកគេពុំដែលបានឃើញឈើបែបនេះនៅស្រុកយូដាឡើយ។[12]ព្រះបាទសាឡូម៉ូនថ្វាយអ្វីៗទាំងប៉ុន្មានដែលព្រះ
នាងសព្វព្រះហឫទ័យព្រមទាំងអ្វីៗដែលព្រះព្រះមហាក្សត្រិយានីសេបាទូលសូម លើសជាងអ្វីៗដែលព្រះនាងនាំមកថ្វាយទ្រង់ទៅទៀត។ ដូច្នេះ
ព្រះនាងបានចាកចេញហើយយាងត្រឡប់ទៅស្រុករបស់ព្រះនាងវិញព្រមទាំងពួកអ្នកបម្រើរបស់ព្រះនាងផង។
[13]ព្រះបាទសាឡូម៉ូនទទួលមាសទម្ងន់ម្ភៃពីរតោនជារៀងរាល់ឆ្នាំ។[14]ក្រៅពីមាសពាណិជ្ជករ និងឈ្មួញបានយកមកថ្វាយ។ ស្តេចទាំងប៉ុន្មាននៅស្រុកអារ៉ាប់
និងអភិបាលខេត្តទាំងអស់ក៏នាំយកមាសប្រាក់ទៅព្រះបាទសាឡូម៉ូនដែរ។
[15]ព្រះបាទសាឡូម៉ូនបានធ្វើខែលធំៗចំនួនពីររយខែលដែលធ្វើពីមាស។ ខែលនីមួយៗត្រូវបានធ្វើឡើងដោយមាសចំនួនប្រាំមួយគីឡូក្រាម។
[16]ស្តេចក៏ធ្វើខែលតូចៗធ្វើអំពីមាសចំនួនបីរយខែលទៀតផងដែរ។ ខែលនីមួយៗធ្វើឡើងដោយមាសចំនួនមួយគីឡូក្រាមកន្លះ។
ស្តេចបានដាក់ខែលទាំងនោះនៅក្នុងវិមាននៃព្រៃលីបង់។
[17]ស្តេចបានធ្វើបល្ល័ង្កមួយដ៏ធំពីភ្លុកហើយស្រោបមាសសុទ្ធផង។[18]បល្ល័ង្កមានជណ្តើរប្រាំមួយថ្នាក់ហើយកំពូលនៃបល្ល័ង្កស្ថិតនៅជុំក្រោយ។ មានដៃដាក់នៅសងខាងកៅអី
ហើយមានរូបចម្លាក់តោពីរឈរនៅជាប់នឹងដៃកៅអីនោះ។
[19]មានរូបចម្លាក់តោដប់ពីរឈរនៅលើជណ្តើរ ដោយមួយនៅសងខាងនៃជណ្តើរទាំងប្រាំមួយ។ គ្មានបល្ល័ង្កដូចនេះនៅក្នុងនគរផ្សេងទៀតទេ។
[20]ពែងទាំងប៉ុន្មានរបស់ស្តេចសាឡូម៉ូនសុទ្ធតែធ្វើពីមាសហើយពែងសម្រាប់ផឹកនៅក្នុងដំណាក់ព្រៃស្រុកលីបង់ទាំងអស់សុទ្ធតែធ្វើពីមាសសុទ្ធ។
គ្មានប្រាក់ទេពីព្រោះប្រាក់មិនត្រូវបានគេចាត់ទុកថាមានតម្លៃឡើយ នៅរាជកាលព្រះបាទសាឡូម៉ូន។
[21]ព្រះរាជាមានសំពៅមួយនៅតាមឆ្នេរសមុទ្ររួមនឹងសំពៅរបស់ព្រះបាទហ៊ីរ៉ាម។ រៀងរាល់បីឆ្នាំម្តងកងនាវាបាននាំយកមាសប្រាក់ និងភ្លុកព្រមទាំងសត្វស្វាផង។
[22]ដូច្នេះ ព្រះបាទសាឡូម៉ូនមានទ្រព្យសម្បត្តិ និងប្រាជ្ញាលើសស្តេចទាំងអស់នៅលើពិភពលោក។
[23]មនុស្សទាំងអស់នៅលើផែនដីនាំគ្នាស្វែងរកវត្តមានរបស់ព្រះបាទសាឡូម៉ូន ដើម្បីស្តាប់រាជឱង្ការប្រកបដោយប្រាជ្ញាដែលព្រះជាម្ចាស់ប្រទានមកស្តេច។[24]ជារៀងរាល់ឆ្នាំ
អស់អ្នកដែលឡើងទៅសួរសុខទុក្ខស្តេច តែងនាំយកវត្ថុសួយសារអាករពីមាស ប្រាក់ សម្លៀកបំពាក់ គ្រឿងសាស្ត្រាវុធ គ្រឿងក្រអូប សេះ និងលាផង។
[25]ព្រះបាទសាឡូម៉ូនមានរទេះចម្បាំងចំនួនបួនពាន់សម្រាប់ពលទ័ពសេះ និងរទេះសេះ ហើយមានពលទ័ពសេះចំនួនមួយម៉ឺនពីរពាន់នាក់ ទ្រង់ទុកមួយចំនួនតាមក្រុងនានា
ដែលទ្រង់បម្រុងទុកសម្រាប់ទ័ពទាំងនោះ និងមួយចំនួនទៀតឲ្យនៅជាមួយព្រះអង្គក្នុងក្រុងយេរូសាឡិម។
[26]ស្តេចបានគ្រប់គ្រងលើស្តេចទាំងអស់ចាប់ពីទន្លេអឺប្រាតរហូតដល់ស្រុកភីលីស្ទីន និងរហូតដល់ព្រំប្រទល់ស្រុកអេស៊ីប។
[27]នៅក្រុងយេរូសាឡិម ស្តេចបានធ្វើឲ្យមានប្រាក់ដូចដុំថ្មនៅលើដី។ ទ្រង់បានធ្វើឲ្យមានឈើតាត្រៅច្រើនដូចដើមរាំងនៅតាមតំបន់ទំនាប។
[28]គេនាំសេះមកថ្វាយព្រះបាទសាឡូម៉ូនពីស្រុកអេស៊ីប និងពីស្រុកនានា។
[29]តើគេពុំបានសរសេរក្នុងសៀវភៅប្រវត្តិរបស់លោកណាថាន់ជាព្យាការីនៅក្នុងទំនាយរបស់អហ៊ីយ៉ាជាអ្នកស៊ីលូន
និងនៅក្នុងសៀវភៅលោកអ៊ីដដូជាអ្នកមើលឆុតទាក់ទងនឹងលោកយេរ៉ូបោមជាកូនរបស់លោកនេបាតឬអី?។
[30]ព្រះបាទសាឡូម៉ូនសោយរាជ្យលើស្រុកអ៊ីស្រាអែលទាំងមូលនៅក្រុងយេរូសាឡិមរយៈពេលសែសិបឆ្នាំ។
[31]ព្រះបាទសាឡូម៉ូនសោយទិវង្គតជាមួយបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែលហើយប្រជាជនក៏បញ្ចុះសពព្រះអង្គនៅក្រុងព្រះបាទដាវីឌជាបិតា។
ព្រះបាទរេហូបោមជាបុត្របានឡើងស្នងរាជ្យបន្ត។

---

2 Chronicles 9:3

រាជវាំងដែលស្តេចបានសង់ ព្រះស្ងោយនៅលើតុរបស់ស្តេច

កន្លែងអង្គុយរបស់អ្នកបម្រើការងាររបស់ពួកអ្នកបម្រើនិងសម្លៀកបំពាក់របស់ពួកគេអ្នកកាន់ពែងនិងសម្លៀកបំពាក់ពួកគេ

នាងសេបាបានឃើញអ្វីៗទាំងអស់របស់ព្រះបាទសាឡូម៉ូន

អ្នកកាន់ពែង

អ្នកទាំងនេះជាអ្នកបម្រើ ដែលបានភ្លក្សភេសជ្ជៈមុនពេលដែលស្តេចសោយ
ដើម្បីដឹងថាមានជាតិជាតិពុលឬអត់។

ព្រះនាងកោតស្ញប់ស្ញែងយ៉ាងខ្លាំង។

ការបកប្រែផ្សេងទៀត «នាងលែងមានមោទនភាពទៀតហើយ»

2 Chronicles 9:5

ភ្នែកខ្ញុំម្ចាស់បានឃើញហើយ។

ការបកប្រែផ្សេងទៀត «ឥឡូវខ្ញុំបានឃើញវាដោយខ្លួនឯង»

អ្វីដែលគេប្រាប់ខ្ញុំម្ចាស់មិនបានពាក់កណ្តាល អំពីប្រាជ្ញា និងទ្រព្យសម្បត្តិរបស់ព្រះករុណាទេ!

ការបកប្រែផ្សេងទៀត «ព្រះអង្គពិតជាមានប្រាជ្ញា
និងមានទ្រព្យសម្បត្តិច្រើនណាស់»

2 Chronicles 9:7

ពួកគេបាននៅជិត

ការបកប្រែផ្សេងទៀត «អស់អ្នកណាដែលរង់ចាំបទបញ្ជាស្តេច
ដែលបានគាប់ព្រះហឫទ័យនឹងស្តេចមានព្រះអង្គ»

ដែលបានគាប់ព្រះហឫទ័យនឹងស្តេច

ការបកប្រែផ្សេងទៀត «អ្នកដែលស្តេចពេញចិត្ត»

2 Chronicles 9:9

តោន

2 Chronicles 9:10

ព្រះបាទហ៊ីរ៉ាម

ស្តេចក្រុងទីរ៉ុស។

អូភា

កន្លែងដែលគេមិនសូវស្គាល់ច្រើន តែល្បីខាងមាស។

ឈើខ្លឹមចន្ទន៍

នេះជាប្រភេទឈើម្យ៉ាង។

2 Chronicles 9:13

ទម្ងន់ម្ភៃពីរតោន

generated on Wed Sep 10 16:16:32 2025

សូមមើល
2 Chronicles 9:15
ខែលនីមួយៗត្រូវបានធ្វើឡើងដោយមាសចំនួនប្រាំមួយគីឡូក្រាម។
«ធ្វើពីមាសប្រាំមួយរយតម្លឹង»។
គីឡូក្រា ... មួយគីឡូក្រាមកន្លះ
នៅក្នុងវិមាននៃព្រៃលីបង់។
ទំនងជាកន្លែងស្តុកទុកនៅជិតវិមាន ដែលធ្វើពីឈើធំៗ ជាច្រើនពីប្រទេសលីបង់។
ហើយក៏ត្រូវគេហៅថា ជាឃ្លាំងអាវុធផងដែរ។
2 Chronicles 9:17
ភ្លុក
នេះជាឈ្មោះមួយផ្សេងទៀតសម្រាប់ភ្លុក ឬស្នែងរបស់សត្វដូចជាដំរី ឬរមាស។
ហើយកំពូលនៃបល្ល័ង្កស្ថិតនៅជុំក្រោយ។
ការបកប្រែផ្សេងទៀត «កំពូលនៃបល្ល័ង្កគឺនៅជុំវិញកន្លែងដែលស្តេចគង់នៅ»
2 Chronicles 9:19
ពីព្រោះប្រាក់មិនត្រូវបានគេចាត់ទុកថាមានតម្លៃឡើយ នៅរាជកាលព្រះបាទសាឡូម៉ូន។
ប្រាក់របស់សាមញ្ញណាស់
នៅសម័យព្រះបាទសាឡូម៉ូនដែលវាមានតម្លៃតិចតួចបំផុត។
សត្វស្វាផង
សត្វមកពីឆ្ងាយណាស់ ទំនងជាមកពីអាហ្វ្រិក។
2 Chronicles 9:22
ព្រះជាម្ចាស់ប្រទានមកស្តេច។
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានប្រទានដល់ស្តេច»
ជារៀងរាល់ឆ្នាំ
ការបកប្រែផ្សេងទៀត «រាល់ឆ្នាំ»
2 Chronicles 9:25
ព័ត៌មានទូទៅ:
សូមមើល
ទ័ពសេះ
នេះជាទ្រុងតូចមួយ ជាកន្លែងសកម្រាប់រក្សាទុកសត្វសេះ។
2 Chronicles 9:27
មានប្រាក់ដូចដុំថ្មនៅលើដី។
ការបកប្រែផ្សេងទៀត «ប្រាក់ច្រើនណាស់»
ទ្រង់បានធ្វើឲ្យមានឈើតាត្រៅច្រើនដូចដើមរាំងនៅតាមតំបន់ទំនាប។
ការបកប្រែផ្សេងទៀត «សម្បូរហូរហៀណាស់»
ពីស្រុកនានា
ការបកប្រែផ្សេងទៀត «ពីគ្រប់ទីកន្លែង» ឬ «មកពីគ្រប់ទិសទីទាំងអស់»

---

10 [1]ព្រះបាទរេហូបោមបានយាងទៅស៊ីគែមព្រោះប្រជាជនអ៊ីស្រាអែលទាំងអស់នាំគ្នាមកស៊ីគែម ដើម្បីចាក់ប្រេងអភិសេកស្តេច។
[2]លោកយេរ៉ូបោមជាកូនរបស់លោកនេបាតបានឮដំណឹងនេះ (ដ្បិត គាត់នៅស្រុកអេស៊ីបជាកន្លែងដែលគាត់បានរត់គេចពីព្រះភក្ត្រស្តេចសាឡូម៉ូន
ហើយបានត្រឡប់មកវិញ)។
[3]ដូច្នេះ គេក៏ចាត់មនុស្សឲ្យទៅហៅលោកយេរ៉ូបោម និងជនជាតិអ៊ីស្រាអែលទាំងមូលមក ពួកគេទូលព្រះបាទរេហូបោមថា៖
[4]«បិតារបស់ព្រះករុណាបានធ្វើឲ្យនឹមរបស់យើងពិបាក។ ឥឡូវនេះ សូមធ្វើឲ្យការលំបាករបស់បិតារបស់ព្រះករុណាបានស្រួលវិញ
ហើយសម្រាលបន្ទុកដែលបិតារបស់ព្រះករុណាដាក់លើយើងនោះយើងនឹងបម្រើព្រះករុណា»។[5]ព្រះបាទរេហូបោមមានរាជឱង្ការថា៖
«សូមមករកខ្ញុំម្តងទៀតបន្ទាប់ពីបីថ្ងៃក្រោយ»។ ដូច្នេះ ប្រជាជនក៏ចាកចេញទៅ។
[6]ព្រះបាទរេហូបោមបានប្រឹក្សាជាមួយពួកព្រឹទ្ធាចារ្យដែលបានឈរនៅចំពោះព្រះភក្ត្រព្រះបាទសាឡូម៉ូនជាបិតាកាលទ្រង់នៅមានព្រះជន្ម។ ទ្រង់បានមានរាជឱង្ការថា៖
«តើអស់លោកអាចណែនាំយើងឲ្យនាំចម្លើយដល់ប្រជាជនទាំងនេះដោយរបៀបណា?»។[7]ពួកគេទូលស្តេចថា៖
«បើព្រះករុណាធ្វើល្អចំពោះប្រជាជននេះហើយធ្វើឲ្យពួកគេពេញចិត្តដោយបន្ទូលល្អៗពួកគេនឹងធ្វើជាអ្នកបម្រើរបស់ព្រះករុណាជានិច្ច»។
[8]ប៉ុន្តែ ព្រះបាទរេហូបោមបានបដិសេធយោបល់របស់ពួកព្រឹទ្ធាចារ្យ
ហើយបានទៅស្វែងរកយោបល់ពីពួកយុវជនដែលធំឡើងពីវ័យកុមារជាមួយទ្រង់ដែលឈរនៅចំពោះទ្រង់។[9]ស្តេចមានរាជឱង្ការទៅគេថា៖
«តើអ្នករាល់គ្នាមានយោបល់អ្វីមកយើង ដើម្បីឲ្យយើងឆ្លើយនឹងអស់អ្នកដែលនិយាយមកយើងថា៖
«សូមសម្រាលនឹមដែលព្រះបិតារបស់ព្រះករុណាដាក់លើយើងរាល់គ្នាផង?»។
[10]ពួកយុវជនដែលបានធំធាត់ជាមួយព្រះបាទរេហូបោមបានទូលទៅកាន់ព្រះករុណាថា៖
«នេះជារបៀបដែលព្រះករុណាគួរតែមានបន្ទូលទៅកាន់ប្រជាជនដែលបានទូលទ្រង់ថា ព្រះបាទសាឡូម៉ូនដែលជាបិតារបស់ព្រះករុណាបានដាក់បន្ទុកធ្ងន់លើគេ ប៉ុន្តែ
សូមឲ្យព្រះករុណាធ្វើឲ្យវាស្រាលជាងនេះ។ ចូរប្រាប់ពួកគេថា ម្រាមកូនដៃរបស់យើងធំជាងភ្លៅបិតាយើងទៅទៀត។[11]ទោះបី
បិតាយើងដាក់បន្ទុកលើអ្នកយ៉ាងធ្ងន់ក៏ដោយយើងនឹងបន្ថែមនឹមរបស់អ្នករាល់គ្នាទៀត បិតាយើងដាក់ទោសអ្នករាល់គ្នាដោយរំពាត់
តែខ្ញុំនឹងដាក់ទោសអ្នករាល់គ្នាដោយខ្យាដំរីវិញ»។
[12]ដូច្នេះ នៅថ្ងៃទីបីលោកយេរ៉ូបោម និងប្រជាជនអ៊ីស្រាអែលទាំងមូលនាំគ្នាវិលមករកព្រះបាទរេហូបោមដូចស្តេចមានរាជឱង្ការថា៖ «សូមវិលមករកយើងវិញនៅថ្ងៃទីបី»។
[13]ព្រះបាទរេហូបោមបានមានរាជឱង្ការជាមួយពួកគេយ៉ាងធ្ងន់ៗមិនអើពើនឹងឱវាទរបស់ពួកព្រឹទ្ធាចារ្យឡើយ។
[14]ព្រះអង្គមានរាជឱង្ការទៅកាន់ពួកគេតាមយោបល់របស់ពួកយុវជនជំនិតទ្រង់ថា៖ «បិតាយើងដាក់បន្ទុកយ៉ាងធ្ងន់លើអ្នករាល់គ្នា ប៉ុន្តែ
យើងនឹងបន្ថែមបន្ទុករបស់អ្នករាល់គ្នា បិតាយើងដាក់ទោសអ្នករាល់ដោយរំពាត់ តែយើងនឹងដាក់ទោសអ្នកដោយខ្យាដំរីវិញ»។
[15]ដូច្នេះ ស្តេចមិនស្តាប់ប្រជាជនទេព្រោះព្រះជាម្ចាស់បានសម្រេចតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលលោកអហ៊ីយ៉ា
ជាអ្នកស្រុកស៊ីឡូបានមានប្រសាសន៍ជាមួយលោកយេរ៉ូបោមជាកូនរបស់លោកនេបាត។
[16]ជនជាតិអ៊ីស្រាអែលទាំងមូលឃើញថាស្តេចមិនស្តាប់ពួកគេទេ ប្រជាជននាំគ្នាទូលស្តេចថា៖ «តើយើងមានចំណែកអ្វីខ្លះជាមួយព្រះបាទដាវីឌ?
យើងពុំមានកេរមតកអ្វីពីកូនរបស់លោកអ៊ីសាយទេ! អ៊ីស្រាអែលអើយ! ចូរវិលត្រឡប់ទៅផ្ទះរៀងខ្លួនវិញទៅ! ឥឡូវនេះ ពូជពង្សរបស់ព្រះបាតដាវីឌអើយ!
ចូរថែរក្សាខ្លួនឯងចុះ»។ ជនជាតិអ៊ីស្រាអែលទាំងអស់ក៏នាំគ្នាវិលត្រឡប់ទៅជំរំរបស់គេវិញ។[17]ប៉ុន្តែ ប្រជាជនអ៊ីស្រាអែលដែលរស់នៅតាមក្រុងនានាក្នុងស្រុកយូដាវិញ
ព្រះបាទរេហូបោមសោយរាជ្យលើពួកគេ។
[18]ព្រះបាទរេហូបោមបានចាត់លោកអាដូនីរ៉ាមដែលជាអ្នកមើលការខុសត្រូវលើការកំណែនប្រជាជនឲ្យទៅឯកុលសម្ព័ន្ធអ៊ីស្រាអែល ប៉ុន្តែ
ជនជាតិអ៊ីស្រាអែលបានយកដុំថ្មគប់សម្លាប់លោក។ ព្រះបាទរេហូបោមបានឡើងរទេះភៀសខ្លួនយ៉ាងលឿនទៅក្រុងយេរូសាឡិមវិញ។
[19]ជនជាតិអ៊ីស្រាអែលបះបោរប្រឆាំងនឹងពូជពង្សដាវីឌរហូតមកដល់សព្វថ្ងៃ។

---

2 Chronicles 10:1
អ៊ីស្រាអែលទាំងអស់
«ប្រជាជនអ៊ីស្រាអែលទាំងអស់»។
កូនរបស់លោកនេបាត
2 Chronicles 10:8
ព្រះបាទរេហូបោមបានបដិសេធយោបល់
ការបកប្រែផ្សេងទៀត «ព្រះបាទរេហូបោមមិនបានធ្វើតាមដំបូន្មានទេ»
ពួកយុវជន
«ពួកយុវជន» សំដៅទៅលើការខ្វះប្រាជ្ញា
និងបទពិសោធន៍នៅក្នុងការប្រៀបធៀបនឹងបុរសចំណាស់
ដែលបានធ្វើតាមដំបូន្មានព្រះបាទសាឡូម៉ូន។
ព្រះបាទរេហូបោមបានបដិសេធយោបល់

generated on Wed Sep 10 16:16:32 2025

«ដែលជាមិត្តភក្តិយូររបស់គាត់ បានណែនាំគាត់ »
2 Chronicles 10:10
ម្រាមកូនដៃរបស់យើងធំជាងភ្លៅបិតាយើងទៅទៀត។
ចំណុចរបស់ព្រះបាទរេហូបោម
គឺថាព្រះអង្គឃោរឃៅនិងទាមទារច្រើនជាងបិតារបស់ទ្រង់
ខ្ញុំនឹងដាក់ទោសអ្នករាល់គ្នាដោយខ្សាដំរីវិញ។
ការបកប្រែផ្សេងទៀត «តែខ្ញុំនឹងវាយអ្នកដោយរំពាត់ ដែលមានដែកនៅក្នុងនោះ។»
2 Chronicles 10:12
ប្រជាជនអ៊ីស្រាអែលទាំងមូល
ការបកប្រែផ្សេងទៀត «មេដឹកនាំទាំងអស់»
ថ្ងៃទីបី
2 Chronicles 10:15
លោកអហ៊ីយ៉ា ជាអ្នកស្រុកស៊ីឡូ ... លោកយេរ៉ូបោមជាកូនរបស់លោកនេបាត
2 Chronicles 10:16
តើយើងមានចំណែកអ្វីខ្លះជាមួយព្រះបាទដាវីឌ?
«យើងមិនចង់ធ្វើអ្វីទាំងអស់ ធ្វើជាមួយកូនចៅរបស់ស្តេចដាវីឌ!»

---

11 [1]នៅពេលព្រះបាទរេហូបោមមកដល់ក្រុងយេរូសាឡិមព្រះអង្គបានប្រមូលទាហានពីកុលសម្ពន្ធយូដា និងបេនយ៉ាមីនបានចំនួន ១៨០, ០០០
នាក់សុទ្ធសឹងជាទាហានដែលថ្នឹកច្បាំង ដែលបានជ្រើសរើស ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងអ៊ីស្រាអែលដើម្បីដណ្តើមរាជាណាចក្រមកវិញ។
[2]ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកសេម៉ាយ៉ា ជាអ្នកជំនិតរបស់ព្រះជាម្ចាស់ថា៖ [3]«ចូរប្រាប់ព្រះបាទ រេហូបោម
ជាបុត្ររបស់ព្រះបាទសាឡូម៉ូនជាស្តេចស្រុកយូដា ព្រមទាំងជនជាតិអ៊ីស្រាអែលទាំងអស់នៅស្រុកយូដានិងបេនយ៉ាមីនថា៖ [4]ព្រះអម្ចាស់មានបន្ទូលថា៖
«មិនត្រូវឲ្យអ្នករាល់គ្នា ចេញធ្វើសង្គ្រាមប្រឆាំងនឹងបងប្អូនរបស់អ្នករាល់គ្នាឡើយ។ អ្នករាល់គ្នាត្រូវវិលត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ ដ្បិត
យើងជាអ្នកធ្វើឲ្យហេតុការណ៍នេះបានកើតឡើង»។ ពួកគេក៏ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយនាំគ្នាត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ
មិនបានច្បាំងជាមួយលោកយេរ៉ូបោមទេ។
[5]ព្រះបាទរេហូបោមបានគង់នៅក្រុងយេរូសាឡិម ហើយបានសង់ក្រុងដែលមានកំពែងការពារជាច្រើននៅស្រុកយូដា។ [6]ស្តេចបានសង់ក្រុងបេថ្លេហិម អេថាម តេកូអា [7]បេតស៊ើរ
សូកូ អាឌុឡាម [8]កាថ ម៉ារេសា ហ្សីប [9]អដូរ៉ាម ឡាគីស អាសេកា [10]សូរ៉ា អាយ៉ាឡូន និងហេប្រុន។ នេះជាក្រុងដែលមានកំពែងរឹងមាំក្នុងស្រុកយូដា និងបេនយ៉ាមីន។
[11]ស្តេចបានពង្រឹងបន្ទាយ និងដាក់មេបញ្ជាការត្រួតត្រាលើទីនោះ ព្រមទាំងមានស្តុកម្ហូប ប្រេងនិងស្រា។ [12]ស្តេចដាក់ខែល និងលំពែងនៅគ្រប់ក្រុងទាំងប៉ុន្មាន
ហើយធ្វើឲ្យក្រុងទាំងនោះកាន់តែរឹងមាំ។ ដូច្នេះ ស្រុកយូដា និងស្រុកបេនយ៉ាមីនជាកម្មសិទ្ធិ និងស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះអង្គ។
[13]ពួកបូជាចារ្យ និងពួកលេវីដែលនៅស្រុកអ៊ីស្រាអែលទាំងមូលនាំគ្នាទៅឯព្រះបាទរេហូបោមពីទឹកដីរបស់គេរៀងខ្លួន។ [14]កុលសម្ព័ន្ធលេវីចាកចេញពីទឹកដី វាលស្មៅ
និងទ្រព្យសម្បត្តិរបស់ពួកគេ ដើម្បីទៅស្រុកយូដា និងក្រុងយេរូសាឡិម ដ្បិត លោកយេរ៉ូបោម និងកូនៗ របស់គាត់បានបណ្តេញពួកគេចេញ ដូច្នេះ
ពួកគេមិនអាចបំពេញមុខងារជាបូជាចារ្យថ្វាយព្រះអម្ចាស់បានទៀតឡើយ។ [15]លោកយេរ៉ូបោមបានតែងតាំងបូជាចារ្យដោយខ្លួនឯងសម្រាប់កន្លែងសក្ការៈតាមទួលខ្ពស់ៗ
និងបានសិតរូបពពែឈ្មោល និងរូបកូនគោផងដែរ។
[16]ប្រជាជនមកពីគ្រប់កុលសម្ព័ន្ធអ៊ីស្រាអែលនាំគ្នាមកថ្វាយបង្គំរូបទាំងនោះ ចំណែក អស់អ្នកដែលមានចិត្តចង់ស្វែងរកព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល
ពួកគេមកក្រុងយេរូសាឡិម ដើម្បីថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ជាព្រះនៃដូនតារបស់គេ។ [17]ពួកគេបានពង្រឹងរាជាណាចក្រយូដា
និងធ្វើឲ្យរាជ្យព្រះបាទរេហូបោមជាបុត្ររបស់ព្រះបាទសាឡូម៉ូនរឹងមាំអស់រយៈពេលបីឆ្នាំ ដ្បិត ក្នុងរយៈពេលបីឆ្នាំនោះ
ពួកគេបានប្រព្រឹត្តតាមផ្លូវដ៏ត្រឹមត្រូវរបស់ព្រះបាទដាវីឌ និងព្រះបាទសាឡូម៉ូន។
[18]ព្រះបាទរេហូបោមបានរៀបអភិសេកជាមួយព្រះនាងម៉ាហាលៀត ជាបុត្រីរបស់អង្គម្ចាស់យេរីម៉ូត ត្រូវជាបុត្រាព្រះបាទដាវីឌ ព្រមទាំងព្រះនាងអប៊ីហែល
ជាកូនស្រីលោកអេលៀប ដែលជាកូនប្រុសរបស់លោកអ៊ីសាយ។ [19]ព្រះនាងប្រសូតបានបុត្រាបីអង្គ គឺយេអ៊ូស សេម៉ារីយ៉ា និង សាហាំ។
[20]បន្ទាប់ពី ព្រះនាងម៉ាហាឡាត ព្រះបាទរេហូបោមបានរៀបអភិសេកជាមួយព្រះនាងម៉ាកាជាបុត្រីរបស់សម្តេចអាប់សាឡុម។ ព្រះនាងប្រសូតបានអាប៊ីយ៉ា អាតតៃ ស៊ីសា
និងសេឡូមីត។ [21]ព្រះបាទរេហូបោមស្រឡាញ់ព្រះនាងម៉ាកាជាបុត្រីរបស់សម្តេចអាប់សាឡុមលើសជាងមហេសីឯទៀតៗ និងស្រីស្នំរបស់ព្រះអង្គទាំងអស់ (ដ្បិត
ព្រះបាទរេហូបោមមានមហេសីដប់ប្រាំបីអង្គ និងស្រីស្នំហុកសិបនាក់ ហើយមានបុត្រាម្ភៃប្រាំបីអង្គ និងបុត្រីហុកសិបអង្គ)។
[22]ព្រះបាទរេហូបោមបានតែងតាំងសម្តេចអប៊ីយ៉ាជាបុត្ររបស់ព្រះនាងម៉ាកាឲ្យធ្វើជាមេដឹកនាំក្នុងចំណោមបងប្អូនរបស់គាត់។ ដ្បិត
ស្តេចមានគំនិតចង់ឲ្យគាត់ស្នងរាជ្យបន្ត។ [23]ព្រះបាទរេហូបោមបានគ្រប់គ្រងដោយប្រាជ្ញា។ ព្រះករុណាបានចាត់បុត្រាឯទៀតៗទាំងអស់ទៅនៅទូទាំងស្រុកយូដា
និងបេនយ៉ាមីនក្នុងក្រុងដែលមានកំពែងរឹងមាំ។ ស្តេចក៏បានផ្តល់អាហារដល់ពួកគេយ៉ាងបរិបូរហើយរកប្រពន្ធជាច្រើនសម្រាប់ពួកគេ។

---

2 Chronicles 11:1
ជាទាហានដែលថ្នឹកច្បាំង ដែលបានជ្រើសរើស
ការបកប្រែផ្សេងទៀត «ទាហានដ៏ល្អបំផុតរបស់ព្រះអង្គ»
2 Chronicles 11:2
ព្រះអម្ចាស់មានព្រះបន្ទូលមក
«ព្រះអម្ចាស់មានព្រះបន្ទូល»
លោកសេម៉ាយ៉ា
2 Chronicles 11:5
ព័ត៌មានទូទៅ៖
សូមមើល
2 Chronicles 11:11
ស្រុកយូដា និងស្រុកបេនយ៉ាមីនជាកម្មសិទ្ធិ និងស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះអង្គ។
ព្រះបាទរេហូបោមបានគ្រប់គ្រងទឹកដីស្រុកយូដានិងបេនយ៉ាមីន។
2 Chronicles 11:13
ពួកបូជាចារ្យ និងពួកលេវីដែលនៅស្រុកអ៊ីស្រាអែលទាំងមូលនាំគ្នាទៅឯព្រះបាទរេហូបោម
ការបកប្រែផ្សេងទៀត «ពួកបូជាចារ្យនិងពួកលេវីបានរត់ភៀសខ្លួនពីអ៊ីស្រាអែល
ដែលជាអាណាចក្រខាងជើងទៅស្រុកយូដា» ។
វាលស្មៅ
ដីវាលដែលប្រើសម្រាប់សត្វ។
2 Chronicles 11:16
ប្រជាជនមកពីគ្រប់កុលសម្ព័ន្ធអ៊ីស្រាអែលនាំគ្នាមក
ប្រជាជនដែលមកពីកុលសម្ព័ន្ធខាងជើង
ដែលគោរពបម្រើព្រះជាអម្ចាស់បានរត់ភៀសខ្លួនទៅស្រុកយូដា។
ចំណែក អស់អ្នកដែលមានចិត្តចង់ស្វែងរកព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «អ្នកណាដែលចង់ថ្វាយបង្គំព្រះអម្ចាស់»
ពួកគេបានប្រព្រឹត្តតាមផ្លូវដ៏ត្រឹមត្រូវរបស់ព្រះបាទដាវីឌ និងព្រះបាទសាឡូម៉ូន។
ការបកប្រែផ្សេងទៀត «ពួកគេបានធ្វើតាមគំរូរបស់ព្រះបាទដាវីឌ
និងព្រះបាទសាឡូម៉ូនអស់រយៈពេលបីឆ្នាំ»
2 Chronicles 11:18
ព័ត៌មានទូទៅ៖
សូមមើល
2 Chronicles 11:20
ព័ត៌មានទូទៅ៖
សូមមើល
2 Chronicles 11:22
ព័ត៌មានទូទៅ៖
សូមមើល

---

generated on Wed Sep 10 16:16:32 2025

12 [1]ពេលរាជព្រះបាទរេហូបោមបានរឹងមាំហើយស្តេចមានកម្លាំងខ្លាំងក្លា
នោះស្តេចក៏បោះបង់ចោលក្រឹត្យវិន័យរបស់ព្រះអម្ចាស់ហើយជនជាតិអ៊ីស្រាអែលទាំងមូលក៏ប្រព្រឹត្តតាមស្តេចដែរ។
[2]នៅឆ្នាំទីប្រាំនៃរជ្ជកាលព្រះបាទរេហូបោម ស្តេចស៊ីសាកជាស្តេចស្រុកអេស៊ីបបានលើកទ័ពមកឡោមព័ទ្ធក្រុងយេរូសាឡិមព្រោះប្រជាជនបានក្បត់នឹងព្រះអម្ចាស់។
[3]ស្តេចយាងមកជាមួយរទេះចម្បាំងចំនួនមួយពាន់ពីររយពលសេះប្រាំមួយម៉ឺននាក់ និងពលទាហានយ៉ាងច្រើនសន្ធឹកបានមកជាមួយព្រះអង្គគឺពីប្រទេសអេស៊ីប ស្រុកលីប៊ី
ស្រុកស៊ូកគីនិងស្រុកអេត្សូពី។[4]ស្តេចបានយកក្រុងដែលមានកំពែងរឹងមាំក្នុងស្រុកយូដាហើយបានមកដល់ក្រុងយេរូសាឡិម។
[5]ពេលនោះ ព្យាការីសេម៉ាយ៉ាបានមកជួបព្រះបាទរេហូបោម និងមេដឹកនាំស្រុកយូដាដែលបានប្រមូលផ្តុំគ្នានៅក្រុងយេរូសាឡិម ព្រោះតែព្រះបាទស៊ីសាកឡោមព័ទ្ធ។
លោកសេម៉ាយ៉ាមានប្រសាសន៍ថា៖ «ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ៖ «អ្នករាល់គ្នាបានបោះបង់ចោលយើង ដូច្នេះ
យើងក៏ប្រគល់អ្នកទៅក្នុងកណ្តាប់ដៃរបស់លោកស៊ីសាកដែរ»។[6]ពួកមេដឹកនាំនៃជនជាតិអ៊ីស្រាអែល និងស្តេចបានបន្ទាបខ្លួនហើយទូលថា៖ «ព្រះអម្ចាស់ពិតជាសុចរិត»។
[7]ពេលព្រះអម្ចាស់ឃើញថា ពួកគេបន្ទាបខ្លួនរបស់គេនៅចំពោះទ្រង់ នោះព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការីសេម៉ាយ៉ាថា៖ «ពួកគេបានបន្ទាបខ្លួន ដូច្នេះ
យើងនឹងមិនបំផ្លាញពួកគេទេ យើងនឹងសង្គ្រោះពួកគេចេញពីដៃស៊ីសាក់ហើយកំហឹងរបស់យើងក៏នឹងមិនហូរមកលើក្រុងយេរូសាឡិមដែរ។
[8]ទោះយ៉ាងណាពួកគេនឹងត្រូវចំណុះហើយធ្វើជាអ្នកបម្រើស៊ីសាក់ ដើម្បីឲ្យពួកគេយល់ថាការបម្រើយើងនិងបម្រើស្តេចប្រទេសដទៃខុសគ្នាយ៉ាងណា»។
[9]ដូច្នេះ ព្រះបាទស៊ីសាក់ជាស្តេចស្រុកអេស៊ីបបានលើកទ័ពមកឡោមព័ទ្ធក្រុងយេរូសាឡិម
ហើយរឹបអូសយកទ្រព្យសម្បត្តិនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់និងទ្រព្យសម្បត្តិនៅក្នុងព្រះដំណាក់របស់ស្តេច។ ស្តេចបានយកអ្វីគ្រប់យ៉ាងទៅ
ព្រមខែលមាសដែលព្រះបាទសាឡូម៉ូនបានធ្វើដែរ។[10]ព្រះបាទរេហូបោមបានធ្វើខែលលង្ហិនជំនួសវិញ
ហើយប្រគល់វាទៅក្នុងកណ្តាប់ដៃរបស់មេទ័ពដែលយាមទ្វារចូលព្រះដំណាក់។
[11]គ្រប់ពេលដែលស្តេចយាងចូលព្រះដំណាក់របស់ព្រះអម្ចាស់ ពួកទាហាននាំគ្នាកាន់ខែលទាំងនោះអមដំណើរទៅ បន្ទាប់មក ពួកគេប្រមូលយកទៅទុកនៅក្នុងបន្ទប់របស់
ពួកអ្នកយាមវិញ។[12]ពេលព្រះបាទរេហូបោមបន្ទាបខ្លួននោះ ព្រះពិរោធរបស់ព្រះអម្ចាស់ងាកចេញពីព្រះអង្គដើម្បីមិនបំផ្លាញគេទាំងស្រុង។
ក្រៅពីនេះនៅមានការល្អខ្លះទៀតដែលត្រូវបានរកឃើញនៅស្រុកយូដា។
[13]ដូច្នេះ ព្រះបាទរេហូបោមបានពង្រឹងអំណាចនៅក្រុងយេរូសាឡិម ហើយស្តេចឡើងសោយរាជ្យ។
ព្រះបាទរេហូបោមមានអាយុសែសិបមួយឆ្នាំនៅពេលដែលទ្រង់ឡើងសោយរាជ្យ ហើយសោយរាជ្យអស់ដប់ប្រាំពីរឆ្នាំនៅក្រុងយេរូសាឡិម
ជាទីក្រុងដែលព្រះអម្ចាស់បានជ្រើសរើសពីកុលសម្ព័ន្ធអ៊ីស្រាអែលទាំងអស់ ដើម្បីព្រះនាមព្រះអង្គនៅទីនោះ។ ព្រះមាតារបស់ស្តេចព្រះនាមណាអាម៉ា
ជាជនជាតិអាំម៉ូន[14]ស្តេចបានប្រព្រឹត្តអំពើអាក្រក់ ព្រោះទ្រង់គ្មានចិត្តចង់ស្វែងរកព្រះអម្ចាស់ទេ។[15]ចំពោះរាជកិច្ច
និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងព្រះបាទរេហូបោមគឺតាំងពីមុន និងចុងក្រោយ តើគេមិនបានសរសេរក្នុងសំណេររបស់ព្យាការីសេម៉ាយ៉ា
និងអ៊ីដដូជាអ្នកមើលដែលមានកំណត់ហេតុអំពីពង្សប្រវត្តិ និងសង្គ្រាមរវាងព្រះបាទរេហូបោម និងលោកយេរ៉ូបោមទេឬអី?[16]ព្រះបាទរេហូបោមសោយទិវង្គត
គេបានយកសពទៅបញ្ចុះក្នុងក្រុងព្រះបាទដាវីឌ។ ព្រះបាទអប៊ីយ៉ាជាបុត្រឡើងស្នងរាជ្យ។

---

2 Chronicles 12:1
ពេល
«វាបានកើតឡើង» បង្ហាញពីចំណុចសំខាន់ពិសេសមួយនៅក្នុងរឿង។ នៅពេល «នៅពេលដែល»
ហើយជនជាតិអ៊ីស្រាអែលទាំងមូលក៏ប្រព្រឹត្តតាមស្តេចដែរ។
ការបកប្រែផ្សេងទៀត «ទាំងអ៊ីស្រាអែលនិងយូដាបានដើរតាមស្តេច
ប្រព្រឹត្តអំពើបាប។ អ៊ីស្រាអែលក៏រាប់បញ្ចូលទាំងយូដានៅទីនេះដែរ។» (សូមមើល)
2 Chronicles 12:2
ព័ត៌មានទូទៅ៖
សូមមើល
បានលើកទ័ពមកឡោមព័ទ្ធ
ការបកប្រែផ្សេងទៀត «មកដើម្បីវាយប្រហារ»
ពលទាហានយ៉ាងច្រើនសន្ធឹក
ការបកប្រែផ្សេងទៀត «ទាហានជាច្រើន»
2 Chronicles 12:5
ព័ត៌មានទូទៅ៖
សូមមើល
យើងក៏ប្រគល់អ្នកទៅក្នុងកណ្តាប់ដៃរបស់លោកស៊ីសាកដែរ។
ការបកប្រែផ្សេងទៀត «ដូច្នេះ យើងបានផ្តល់ឲ្យអ្នកនូវស៊ីសាក
ដែលជាឈ្លើយសឹក» (សូមមើល
2 Chronicles 12:7
ពួកគេបន្ទាបខ្លួនរបស់គេ
ការបកប្រែផ្សេងទៀត «ស្តេចនិងមេដឹកនាំអ៊ីស្រាអែលដទៃទៀតបានបន្ទាបខ្លួន»
ស្តេចនិងមេដឹកនាំដទៃទៀតជានិមិត្តរូបនៃប្រជាជនអ៊ីស្រាអែលទាំងអស់។
នោះព្រះអម្ចាស់មានព្រះបន្ទូលមកកាន់
«ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ។» សូមមើលការបកប្រែនៅក្នុង ១១:២។
យើងនឹងសង្គ្រោះពួកគេចេញពីដៃ
ការបកប្រែផ្សេងទៀត «យើងនឹងជួយសង្គ្រោះពួកគេពីការបំផ្លាញទាំងស្រុង»
ហើយកំហឹងរបស់យើងក៏នឹងមិនហូរមកលើក្រុងយេរូសាឡឹមដែរ។
ការបកប្រែផ្សេងទៀត «យើងនឹងមិនបញ្ចេញកំហឹងទាំងស្រុងរបស់យើង
ប្រឆាំងនឹងក្រុងយេរូសាឡឹមឡើយ»
2 Chronicles 12:9
ហើយប្រគល់វាទៅក្នុងកណ្តាប់ដៃរបស់មេទ័ព
ការបកប្រែផ្សេងទៀត «ប្រគល់ពួកគេឲ្យមេបញ្ជាការ»
2 Chronicles 12:11
គ្រប់ពេលដែល
កំណត់ចំណាំពេលវេលា សំខាន់ពិសេសនៅក្នុងរឿង។
ភាសាជាច្រើនមានវិធីដើម្បីកំណត់ចំណាំឃ្លា ពេលវេលាដ៏សំខាន់នេះ។
ព្រះពិរោធរបស់ព្រះអម្ចាស់ងាកចេញពីព្រះអង្គដើម្បីមិនបំផ្លាញគេទាំងស្រុង។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់លែងព្រះពិរោធនឹងព្រះអង្គទៀតហើយ ដូច្នេះ
ទ្រង់មិនបានបំផ្លាញព្រះអង្គចោលទាំងស្រុងទេ»
ក្រៅពីនេះ
«លើសពីនេះទៀត»
2 Chronicles 12:13
ដើម្បីព្រះនាមព្រះអង្គនៅទីនោះ។
ការបកប្រែផ្សេងទៀត «ដូច្នេះ ទ្រង់នឹងទទួលបានកិត្តិយសនៅទីនោះជានិច្ច។»
ទ្រង់គ្មានចិត្តចង់ស្វែងរកព្រះអម្ចាស់ទេ។
ការបកប្រែផ្សេងទៀត «ទ្រង់មិនមានបំណងប្រាថ្នានិងកម្លាំង
ស្តាប់បង្គាប់ព្រះជាម្ចាស់ទេ»

13

[1]នៅឆ្នាំទីដប់ប្រាំបីនៃរជ្ជកាលព្រះបាទយេរ៉ូបោម ព្រះបាទអប៊ីយ៉ាបានឡើងសោយរាជ្យលើស្រុកយូដា ។[2]ស្តេចសោយរាជ្យអស់រយៈពេលបីឆ្នាំនៅក្រុងយេរូសាឡិម។
ព្រះមាតារបស់ស្តេចមានព្រះនាមថាម៉ាកា ជាកូនស្រីរបស់លោកយូរីនៅគីបៀរ។ មានសង្គ្រាមរវាងព្រះបាទអប៊ីយ៉ា និងព្រះបាទយេរ៉ូបោម។
[3]ព្រះបាទអប៊ីយ៉ាបានចេញទៅច្បាំងជាមួយកងទ័ពដ៏ខ្លាំងពូកែ និងទាហានដ៏អង់អាចចំនួនបួនសែននាក់។
ព្រះបាទយេរ៉ូបោមបានដាក់ជួរទ័ពប្រយុទ្ធជាមួយនឹងកងទ័ពដែលបានជ្រើសរើស ប្រាំបីសែននាក់សុទ្ធតែជាទាហានខ្លាំង និងក្លាហាន។

generated on Wed Sep 10 16:16:32 2025

[4]លោកអប៊ីយ៉ាបានឈរនៅលើភ្នំសៀរសារ៉ាមដែលស្ថិតនៅលើភ្នំអេប្រាអ៊ីមមានប្រសាសន៍ថា៖ «លោកយេរ៉ូបោម និងជនជាតិអ៊ីស្រាអែលទាំងមូលសូមស្តាប់ខ្ញុំ!
[5]តើអ្នករាល់គ្នាមិនដឹងថាព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលបានប្រគល់ការគ្រប់គ្រងលើទឹកដីអ៊ីស្រាអែលឲ្យព្រះបាទដាវីឌ
និងរាជវង្សតាមសម្ពន្ធមេត្រីរហូតតទៅទេឬអី?
[6]ប៉ុន្តែ លោកយេរ៉ូបោមជាកូនរបស់លោកនេបាត ជាអ្នកបម្រើរបស់ព្រះបាទសាឡូម៉ូនជាបុត្ររបស់ព្រះបាទដាវីឌបានក្រោកឡើងបះបោរប្រឆាំងនឹងម្ចាស់របស់ខ្លួន។
[7]មនុស្សពាល មនុស្សគ្មានប្រយោជន៍បានប្រមូលគ្នាមកឯគាត់។
ពួកគេបានមកតទល់នឹងព្រះបាទរេហូបោមជាបុត្ររបស់ព្រះបាទសាឡូម៉ូននៅពេលដែលស្តេចរេហូបោមនៅក្មេង ហើយគ្មានបទពិសោធន៍
ហើយមិនអាចទប់ទល់នឹងពួកគេបាន។
[8]ឥឡូវនេះ អ្នកនិយាយថាអ្នកអាចតតាំងនឹងអំណាចរបស់ព្រះអម្ចាស់ ដែលស្ថិតក្រោមការគ្រប់គ្រងបស់កូនចៅដាវីឌ។
អ្នកមានកងទ័ពដ៏ធំព្រមទាំងរូបកូនគោមាសដែលលោកយេរ៉ូបោមបានធ្វើដូចជាព្រះសម្រាប់អ្នករាល់គ្នា នៅជាមួយអ្នករាល់គ្នាទៀត។
[9]តើអ្នកមិនបានបណ្តេញពួកបូជាចារ្យរបស់ព្រះអម្ចាស់ជាកូនចៅរបស់លោកអើរ៉ុន និងពួកលេវីទេឬ?
តើអ្នកមិនបានតែងតាំងបូជាចារ្យឲ្យខ្លួនអ្នកផ្ទាល់ដូចជនជាតិដទៃទេឬអី? អ្នកណាមកថ្វាយបង្គំដោយយកគោឈ្មោល
និងចៀមឈ្មោលប្រាំពីរមកនោះក៏អាចធ្វើជាបូជាចារ្យនៃរូបទាំងនោះដែលមិនមែនជាព្រះទេ។
[10]រីឯយើងវិញ ព្រះអម្ចាស់គឺជាព្រះរបស់យើង ហើយយើងមិនបោះបង់ចោលព្រះអង្គឡើយ។ យើងមានបូជាចារ្យជាកូនចៅរបស់លោកអើរ៉ុននៅបម្រើព្រះអម្ចាស់
និងលេវីដែលបំពេញការងាររបស់ពួកគេ។[11]ពួកគេថ្វាយតង្វាយដុតទាំងមូល និងគ្រឿងក្រអូបចំពោះព្រះអម្ចាស់ទាំងព្រឹកទាំងល្ងាច។
ពួកគេក៏រៀបចំនំបុ័ងវត្តមាននៅលើតុសុទ្ធផងដែរ។ ពួកគេមានទំនោរនឹងជើងចង្កៀងមាស និងចង្កៀងរបស់ពួកគេ ដើម្បីឲ្យពួកគេដុតរៀងរាល់ល្ងាច។
យើងកាន់តាមបទបញ្ជារបស់ព្រះអម្ចាស់ជាព្រះនៃយើង ប៉ុន្តែ អ្នករាល់បានបោះបង់ចោលព្រះអង្គវិញ។
[12]មើល៍! ព្រះជាម្ចាស់គង់នៅជាមួយយើងនឹងដឹកនាំយើង ហើយពួកបូជាចារ្យរបស់ព្រះអង្គនៅទីនេះនាំគ្នាផ្លុំត្រែឡើងដើម្បីប្រកាសអាសន្នប្រឆាំងនឹងអ្នករាល់គ្នា។
ជនជាតិអ៊ីស្រាអែលអើយ! កុំធ្វើសង្គ្រាមប្រឆាំងនឹងព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់អ្នកឡើយ! ដ្បិត អ្នករាល់គ្នានឹងមិនអាចឈ្នះព្រះអង្គឡើយ!។
[13]ប៉ុន្តែ លោកយេរ៉ូបោមបានរៀបទ័ពពួនស្ទាក់នៅពីក្រោយពួកគេ។ កងទ័ពនៅខាងមុខហើយទ័ពពួនស្ទាក់នៅខាងក្រោយកងទ័ពយូដា។
[14]ពេលជនជាតិយូដាក្រឡេកមើលទៅក្រោយគេឃើញមានការប្រយុទ្ធនៅខាងមុខ និងនៅខាងក្រោយពួកគេ។
ពួកគេស្រែកអង្វរកព្រះអម្ចាស់ហើយពួកបូជាចារ្យផ្លុំត្រែឡើង។[15]ពេលនោះ ប្រជាជននៅស្រុកយូដាស្រែកជយឃោស ពេលពួកគេស្រែកថា៖
ព្រះជាម្ចាស់បានវាយព្រះបាទយេរ៉ូបោម និងជនជាតិអ៊ីស្រាអែលទាំងមូលនៅចំពោះមុខព្រះបាទអប៊ីយ៉ា និងប្រជាជនយូដា។
[16]ប្រជាជនអ៊ីស្រាអែលរត់ភៀសខ្លួនពីមុខកងទ័ពយូដា ហើយព្រះជាម្ចាស់បានប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ពួកកងទ័ពយូដា។[17]ព្រះបាទអប៊ីយ៉ា
និងកងទ័ពបានសម្លាប់ពួកគេដោយមុខដាវ ហើយមានកងទ័ពអ៊ីស្រាអែលដែលបានជ្រើសរើសចំនួនប្រាំសែននាក់បានស្លាប់។
[18]នៅគ្រានោះជនជាតិអ៊ីស្រាអែលត្រូវគេបំបាក់មុខ។ ប្រជាជនយូដាទទួលជ័យជម្នះដោយសារពួកគេពឹងផ្អែកលើព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេ។
[19]ព្រះបាទអប៊ីយ៉ាដេញតាមលោកយេរ៉ូបោម ហើយបានដណ្តើមយកក្រុងបេតអែលជាមួយភូមិជុំវិញ ក្រុងសេសាណា និងភូមិជុំវិញ និងក្រុងអេប្រូននិងភូមិជុំវិញ។
[20]នៅជំនាន់ព្រះបាទអប៊ីយ៉ា លោកយេរ៉ូបោមមិនអាចពង្រឹងអំណាចឡើងវិញឡើយ ហើយព្រះអម្ចាស់បានប្រហារស្តេចឲ្យសោយទិវង្គតទៅ។[21]ប៉ុន្តែ ព្រះបាទ
អប៊ីយ៉ាវិញបានពង្រឹងអំណាចយ៉ាងរឹងមាំ។ ស្តេចមានមហេសីដប់បួនអង្គ មានបុត្រាម្ភៃពីរអង្គ និងបុត្រីដប់ប្រាំមួយអង្គ។[22]រាជកិច្ចឯទៀតៗរបស់ព្រះបាទអប៊ីយា
និងរាជឱង្ការរបស់ស្តេចសុទ្ធតែមានកត់ត្រាទុកក្នុងអត្ថាធិប្បាយរបស់ព្យាការីអ៊ីដោ។

---

2 Chronicles 13:1
ម៉ាកា ជាកូនស្រីរបស់លោកយូរីនៅគីបៀរ។
2 Chronicles 13:4
នៅលើភ្នំសៀរសារ៉ាម
តើអ្នករាល់គ្នាមិនដឹងថា ... តាមសម្ពន្ធមេត្រី?
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នាដឹងយ៉ាងច្បាស់ណាស់ ... តាមសម្ពន្ធមេត្រី។»
2 Chronicles 13:6
កូនរបស់លោកនេបាត
មនុស្សគ្មានប្រយោជន៍
ការបកប្រែផ្សេងទៀត «មនុស្សអាក្រក់ មនុស្សគ្មានសីលធម៌»
បានប្រមូលគ្នាមកឯគាត់។
ការបកប្រែផ្សេងទៀត «ចូលរួមជាមួយស្តេចយេរ៉ូបោម»
2 Chronicles 13:8
រូបកូនគោមាសដែលលោកយេរ៉ូបោមបានធ្វើដូចជាព្រះ
នេះជាឯកសារយោងទាក់ទងនឹងរូបព្រះ។
តើអ្នកមិនបានបណ្តេញ ... ពួកលេវីទេឬ?
ការបកប្រែផ្សេងទៀត «អ្នកបានដេញ... ពួកលេវី» ។
តើអ្នកមិនបានតែងតាំង ... ជនជាតិដទៃទេឬអី?
ការបកប្រែផ្សេងទៀត «អ្នកបានតែងតាំង ... អ្នកស្រុកដទៃ។»
អ្នកណាមកថ្វាយបង្គំដោយយកគោឈ្មោល
និងចៀមឈ្មោលប្រាំពីរមកនោះក៏អាចធ្វើជាបូជាចារ្យនៃរូបទាំងនោះដែលមិនមែនជាព្រះទេ។
ការបកប្រែផ្សេងទៀត «អ្នកណាដែលថ្វាយគោឈ្មោលមួយ
និងចៀមឈ្មោលប្រាំពីរក្បាល អាចនឹងក្លាយជាបូជាចារ្យរបស់កូនគោមាសទាំងនេះ
ដែលមិនមែនជាព្រះទេ។»
2 Chronicles 13:10
ដែលបំពេញការងាររបស់ពួកគេ។
ការបកប្រែផ្សេងទៀត «អ្នកណាដែលកំពុងធ្វើការ»
នំបុ័ងវត្តមាន
«នំបុ័ងវត្តមាន» ជាប្រភេទនំបុ័ងពិសេសមួយ ដែលត្រូវបានបង្កើតឡើងជានិមិត្តរូប
នៃវត្តមានរបស់ព្រះជាម្ចាស់និងសម្ពន្ធភាពជាមួយប្រជាស្ត្ររបស់ទ្រង់។
ពួកគេមានទំនោរនឹងជើងចង្កៀងមាស
ការបកប្រែផ្សេងទៀត «ពួកគេក៏ថែរក្សាជើងចង្កៀងមាសផងដែរ»
2 Chronicles 13:12
កុំធ្វើសង្គ្រាមប្រឆាំងនឹងព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «កុំបះបោរនឹងព្រះអម្ចាស់»
2 Chronicles 13:13
ពួនស្ទាក់នៅពីក្រោយពួកគេ។
ការបកប្រែផ្សេងទៀត «ការវាយប្រហារដ៏គួរឲ្យភ្ញាក់ផ្អើលមួយ
នៅពីក្រោយកងទ័ពយូដា»
ពួនស្ទាក់នៅខាងក្រោយ
ការបកប្រែផ្សេងទៀត «ការវាយប្រហារដ៏គួរឲ្យភ្ញាក់ផ្អើល
នៅពីក្រោយកងទ័ពយូដា»
ស្រែកអង្វរកព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «ស្រែកអង្វរឮៗទៅកាន់ព្រះអម្ចាស់» ។
ព្រះជាម្ចាស់បានវាយ
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់វាយប្រហារ»
2 Chronicles 13:16
ចំនួនប្រាំសែននាក់
សូមមើល

---

[1]ព្រះបាទអប៊ីយ៉ាបានសោយទិវង្គតទៅជាមួយបុព្វបុរសហើយគេបញ្ចុះសពស្តេចនៅក្រុងព្រះបាទដាវីឌ។ ព្រះបាទអេសាជាបុត្របានឡើងសោយរាជ្យជំនួស។
នៅរជ្ជកាលព្រះបាទអេសាប្រទេសជាតិបានសុខសាន្តត្រាណរយៈពេលដប់ឆ្នាំ។[2]ព្រះបាទអេសាធ្វើអ្វីៗដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ជាព្រះរបស់ខ្លួន។
[3]ស្តេចបានបំផ្លាញអាសនៈសាសន៍ដទៃ និងបានសម្អាតទីខ្ពស់ព្រមទាំងបានកម្ទេចសសរថ្ម និងរំលំបង្គោលព្រះអាសេរ៉ា។
[4]ស្តេចបានបញ្ជាឲ្យប្រជាជនយូដាស្វែងរកព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ខ្លួន និងប្រតិបត្តិតាមច្បាប់ និងក្រឹត្យវិន័យ។
[5]ស្តេចដកកន្លែងសក្ការៈតាមទួលខ្ពស់ៗ និងអាសនៈសក្ការៈពីក្រុងទាំងប៉ុន្មានរបស់ស្រុកយូដាដែរ។ ប្រទេសជាតិមានសេចក្តីសុខសាន្តត្រាណ នៅក្នុងរាជ្ជកាលព្រះអង្គ។
[6]ស្តេចបានសង់ក្រុងដ៏រឹងមាំជាច្រើននៅស្រុកយូដា ដ្បិត ស្រុកទេសស្ងប់ស្ងៀម ហើយមិនមានសង្គ្រាមទេ ដ្បិត ព្រះអម្ចាស់បានប្រទានសេចក្តីសុខសាន្តដល់ព្រះអង្គ។
[7]ព្រះបាទអេសាមានរាជឱង្ការទៅកាន់កុលសម្ព័ន្ធយូដាថា៖ «ចូរយើងសង់ក្រុងទាំងនេះ ហើយធ្វើកំពែងព័ទ្ធជុំវិញ ព្រមទាំងប៉ម ទ្វារ និងរនុក។
ទឹកដីនេះនៅតែជាកម្មសិទ្ធិរបស់យើងដដែលព្រោះយើងបានស្វែងរកព្រះអម្ចាស់ជាព្រះនៃយើង ហើយព្រះម្ចាស់បានប្រទានឲ្យមានសុខសន្តិភាពនៅគ្រប់ទិសទីទាំងអស់។
ដូច្នេះ ពួកគេបានកសាងដោយជោគជ័យ។[8]ព្រះបាទអេសាមានកងទ័ពដែលកាន់ខែល និងលំពែងពីកុលសម្ពន្ធយូដាមានទាហានចំនួន ៣០០, ០០០ នាក់
និងកុលសម្ព័ន្ធបេនយ៉ាមីនចំនួន ២៨០, ០០០ នាក់ដែលកាន់ខែល និងធ្នូ។ ពួកគេទាំងអស់សុទ្ធតែជាទាហានអង់អាចក្លាហាន។
[9]ព្រះបាទសេរ៉ាសជាស្តេចស្រុកអេត្យូពីបានលើកកងទ័ពមួយលាននាក់ និងរទេះចម្បាំងចំនួនបីរយគ្រឿង មកច្បាំងនឹងពួកយូដា ហើយបានឡើងមកដល់ម៉ារេសា។
[10]ព្រះបាទអេសាក៏ចេញមកតទល់ហើយគេតម្រៀបជួរទ័ពត្រៀមច្បាំងនៅតាមជ្រលងភ្នំសេផាហានៅម៉ារេសា។[11]ព្រះបាទអេសាស្រែកអង្វរព្រះអម្ចាស់ជាព្រះរបស់ទ្រង់ថា៖
«បពិត្រព្រះអម្ចាស់ ក្រៅពីព្រះអង្គ គ្មាននរណាម្នាក់អាចជួយអ្នកទន់ខ្សោយ ឲ្យតតាំងនឹងអ្នកខ្លាំងពូកែឡើយ។ ឱព្រះអម្ចាស់ជាព្រះរបស់យើងអើយសូមជួយយើងខ្ញុំផង!
ព្រះអម្ចាស់អើយព្រះអង្គជាព្រះនៃយើងខ្ញុំ សូមកុំឲ្យមនុស្សទទួលជ័យជម្នះលើទ្រង់ឡើយ»។
[12]ព្រះអម្ចាស់វាយជនជាតិអេត្យូពីនៅចំពោះមុខព្រះបាទអេសា និងពួកយូដា។ ជនជាតិអេត្យូពីបានរត់ភៀសខ្លួន។[13]ព្រះបាទអេសា
និងពលទាហានដែលនៅជាមួយបានដេញតាមពួកគេឆ្ពោះទៅកេរ៉ា។ ជនជាតិអេត្យូពីជាច្រើនបានដួលស្លាប់ដែលមិនអាចក្រោកឡើងបាន
ព្រោះពួកគេត្រូវបានបំផ្លាញនៅចំពោះមុខព្រះអម្ចាស់ និងកងទ័ពរបស់ព្រះអង្គ។ កងទ័ពបានរឹបអូសយកទ្រព្យសម្បត្តិជាជយភណ្ឌយ៉ាងច្រើន។
[14]កងទ័ពបានបំផ្លាញភូមិទាំងអស់នៅជុំវិញកេរ៉ា ដ្បិត ព្រះអម្ចាស់បានធ្វើឲ្យប្រជាជនភ័យខ្លាច។
កងទ័ពបានរឹបអូសយកភូមិទាំងអស់ហើយមានទ្រព្យសម្បត្តិច្រើនកុះករនៅក្នុងនោះ។[15]កងទ័ពយូដាបានវាយកម្ទេចជំរំរបស់ពួកអ្នកគង្វាល
ហើយពួកគេបានរឹបអូសយកហ្វូងចៀម និងសត្វអូដ្ឋយ៉ាងបរិបូរ រួចហើយនាំគ្នាត្រឡប់ទៅក្រុងយេរូសាឡិមវិញ។

---

2 Chronicles 14:1

ព្រះបាទអប៊ីយ៉ាបានសោយទិវង្គតទៅជាមួយបុព្វបុរស

ការបកប្រែផ្សេងទៀត «ព្រះបាទអប៊ីយ៉ាបានសោយទិវង្គត»

នៅរជ្ជកាល

ការបកប្រែផ្សេងទៀត «អំឡុងពេលសោយរាជ្យរបស់ព្រះអង្គ»

ប្រទេសជាតិបានសុខសាន្តត្រាណរយៈពេលដប់ឆ្នាំ។

ការបកប្រែផ្សេងទៀត «មានសន្តិភាពនៅក្នុងទឹកដីនេះអស់រយៈពេល ១០ឆ្នាំហើយ»

ដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ជាព្រះរបស់ខ្លួន។

ការបកប្រែផ្សេងទៀត «ស្របទៅតាមព្រះអម្ចាស់»

2 Chronicles 14:5

ស្តេចដកកន្លែងសក្ការៈតាមទួលខ្ពស់ៗ និងអាសនៈសក្ការៈពីក្រុងទាំងប៉ុន្មានរបស់ស្រុកយូដាដែរ។

ការបកប្រែផ្សេងទៀត «ព្រះបាទអេសាមានទីសក្ការៈបូជា និងអាសនៈទាំងអស់ដែលត្រូវបានប្រើសម្រាប់ថ្វាយបង្គំព្រះក្លែងក្លាយនៅស្រុកយូដា ដែលត្រូវបានបំផ្លាញចោល»

2 Chronicles 14:7

ព័ត៌មានទូទៅ៖

សូមមើល

ព្រះបាទអេសាមានរាជឱង្ការទៅកាន់កុលសម្ព័ន្ធយូដាថា

ការបកប្រែផ្សេងទៀត «ព្រះបាទអេសាបានមានរាជឱង្ការទៅកាន់ប្រជាជនយូដា»

យើងបានស្វែងរកព្រះអម្ចាស់ជាព្រះនៃយើង

ការបកប្រែផ្សេងទៀត «យើងបានស្មើសុំព្រះអម្ចាស់ជាព្រះរបស់យើងឲ្យជួយយើង»

2 Chronicles 14:9

ព័ត៌មានទូទៅ៖

សូមមើល and

ម៉ារេសា

នេះជាទីក្រុងមួយនៅក្នុងស្រុកយូដា។

សូមកុំឲ្យមនុស្សទទួលជ័យជម្នះលើទ្រង់ឡើយ។

ការបកប្រែផ្សេងទៀត «កុំឲ្យអ្នកដទៃយកឈ្នះលើប្រជាជនរបស់ព្រះអង្គ»

2 Chronicles 14:12

ជនជាតិអេត្យូពីជាច្រើនបានដួលស្លាប់

ការបកប្រែផ្សេងទៀត «ជនជាតិអេត្យូពីបានស្លាប់»

---

15 [1]ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មកសណ្ឋិតលើលោកអសារ៉ាជាកូនរបស់លោកអូដេត។[2]លោកបានចេញទៅជួបជាមួយព្រះបាទអេសាហើយទូលថា៖
«ឱព្រះបាទអេសា និងប្រជាជនយូដា និងបេនយ៉ាមីនទាំងមូលអើយសូមស្តាប់ខ្ញុំ! ព្រះអម្ចាស់គង់នៅជាមួយអ្នករាល់គ្នាក្នុងពេលដែលអ្នករាល់គ្នានៅជាមួយព្រះអង្គ
ប្រសិនបើ អ្នកស្វែងរកព្រះអង្គនោះអ្នកនិងរកព្រះអង្គឃើញ ប៉ុន្តែ ប្រសិនបើ អ្នកបោះបង់ចោលព្រះអង្គនោះព្រះអង្គនឹងបោះបង់ចោលអ្នកវិញ។
[3]អស់រយៈពេលជាយូរមកហើយជនជាតិអ៊ីស្រាអែលគ្មានព្រះពិតគ្មានបូជាចារ្យបង្រៀនហើយក៏គ្មានក្រឹត្យវិន័យដែរ។[4]ពេលណាពួកគេ
មានទុក្ខវេទនាពួកគេងាកមករកព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលហើយស្វែងរកព្រះអង្គ នោះព្រះអង្គឲ្យគេរកឃើញ។
[5]នៅគ្រានោះអ្នកណាដែលធ្វើដំណើរទៅឆ្ងាយ ឬមកវិញ អ្នកនោះគ្មានសន្តិភាពសម្រាប់គេទេ។ ផ្ទុយទៅវិញ ប្រជាជននៅលើទឹកដីទាំងអស់មានបញ្ហាដ៏ធំ។
[6]ពួកគេបែកបាក់គ្នា ប្រជាជាតិមួយទាស់នឹងប្រជាជាតិមួយ ហើយក្រុងមួយទាស់នឹងទីក្រុងមួយទៀត ដ្បិត ព្រះជាម្ចាស់បានធ្វើឲ្យពួកគេរឹកវរ
ហើយរងទុក្ខវេទនាគ្រប់បែបយ៉ាង។[7]ប៉ុន្តែ ចូរមានកម្លាំងហើយកុំធ្វើឲ្យដៃអ្នកទន់ខ្សោយឡើយ ព្រោះកិច្ចការរបស់អ្នកនឹងបានរង្វាន់»។
[8]កាលព្រះបាទអេសាបានឮពាក្យទាំងនេះដែលជាពាក្យទំនាយរបស់លោកអូដេតដែលជាព្យាការីបានធ្វើឲ្យស្តេចមានចិត្តអង់អាច
ហើយបានបំផ្លាញអ្វីៗដែលគួរស្អប់ខ្ពើមចេញពីស្រុកយូដា និងបេនយ៉ាមីន ព្រមទាំងចេញពីក្រុងនានាដែលស្តេចដណ្តើមបានពីតំបន់ភ្នំអេប្រាអ៊ីម។
ស្តេចក៏សង់អាសនៈដែលស្ថិតនៅខាងមុខច្រកចូលព្រះដំណាក់របស់ព្រះអម្ចាស់ឡើងវិញ។[9]ស្តេចបានប្រមូលប្រជាជនយូដា
និងបេនយ៉ាមីនព្រមទាំងអស់អ្នកដែលស្នាក់នៅជាមួយពួកគេគឺប្រជាជនមកពីអេប្រាអ៊ីមនិងម៉ាណាសេនិងពីស៊ីម្មាន។
ជនជាតិអ៊ីស្រាអែលយ៉ាងច្រើនបានវិលត្រឡប់ពីស្រុកអ៊ីស្រាអែលមកឯទ្រង់វិញ នៅពេលដែលពួកគេឃើញព្រះអម្ចាស់គង់នៅជាមួយ និងព្រះករុណា។
[10]ពួកគេប្រមូលផ្ដុំគ្នានៅក្រុងយេរូសាឡិមក្នុងខែទីបីក្នុងឆ្នាំទីដប់ប្រាំនៃរជ្ជកាលព្រះបាទអេសា។
[11]នៅគ្រានោះពួកគេបានថ្វាយយញ្ញបូជាពីរបស់ដែលពួកគេរឹបអូសយកបានថ្វាយដល់ព្រះអម្ចាស់គឺមានគោប្រាំពីររយក្បាល ចៀមនិងពពែប្រាំពីរពាន់ក្បាល។
[12]ពួកគេបានចូលក្នុងសម្ពន្ធមេត្រី ដោយបានតាំងចិត្ត និងស្វែងរកព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់គេអស់ពីចិត្ត និងអស់ពីព្រលឹង។[13]អ្នកទាំងនោះព្រមព្រៀងគ្នាថា
បើអ្នកណាមិនព្រមស្វែងរកព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលអ្នកនោះ ត្រូវទទួលទោសដល់ស្លាប់ទោះបីមនុស្សនោះជាអ្នកតូច ឬអ្នកធំក្តី ឬទោះប្រុស ឬស្រីក្តី។
[14]ពួកគេស្បថនឹងព្រះអម្ចាស់ដោយបន្លឺសម្លេងឮៗ ព្រមទាំងមានសម្លេងត្រែ និងស្នែងផង។[15]ប្រជាជនយូដាទាំងអស់មានចិត្តរីករាយចំពោះពាក្យសម្បថនេះ
ព្រោះពួកគេបានស្បថយ៉ាងអស់ពីចិត្ត ហើយពួកគេស្វែងរកព្រះជាម្ចាស់អស់ពីចិត្តហើយព្រះអង្គក៏បានឲ្យពួកគេរកឃើញដែរ។
ព្រះអម្ចាស់ក៏ប្រទានសេចក្តីសុខសាន្តដល់ពួកគេនៅគ្រប់ទិសទី។

generated on Wed Sep 10 16:16:32 2025

[16]ព្រះបាទអេសាក៏បានដកលោកម៉ាកាដែលជាជីដូនរបស់ព្រះករុណាចេញពីដំណែងជាម្ចាស់ក្សត្រី ពីព្រោះព្រះនាងបានសង់បង្គោល និងធ្វើរូបគួរស្អប់ខ្ពើមនៃព្រះអាសេរ៉ា។
ព្រះបាទអេសាកាត់បង្គោល និងរូបដែលគួរស្អប់ខ្ពើមនោះកម្ទេចឲ្យទៅជាធូលីដី ហើយដុតវានៅជ្រោះក្រកដូន។[17]ប៉ុន្តែ
ទីសក្ការៈនៅតាមទួលខ្ពស់មិនត្រូវបានយកចេញពីស្រុកអ៊ីស្រាអែលទេ។ ទោះយ៉ាងណា ស្តេចស្រឡាញ់ព្រះអម្ចាស់ដោយស្មោះអស់មួយជីវិត។
[18]ស្តេចបាននាំយកតង្វាយទាំងប៉ុន្មានដែលព្រះបិតារបស់ស្តេច និងស្តេចផ្ទាល់បានញែកជាសក្ការៈទៅដាក់ក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់គឺប្រាក់ និងមាស។
[19]នៅក្នុងស្រុកទេសគឺគ្មានសង្គ្រាមទេ រហូតដល់ឆ្នាំទីសាមសិបប្រាំនៃរជ្ជកាលរបស់ព្រះបាទអេសា។

---

2 Chronicles 15:1

ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មកសណ្ឋិតលើលោកអសារា

ការបកប្រែផ្សេងទៀត

«ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានប្រទានដល់លោកអសារានូវសមត្ថភាពថ្លែងទំនាយ

លោកអូដេត

2 Chronicles 15:3

ជនជាតិអ៊ីស្រាអែលគ្មានព្រះពិត

អ៊ីស្រាអែលបានឈប់ស្តាប់បង្គាប់ព្រះជាម្ចាស់។

គ្មានបូជាចារ្យបង្រៀន

ការបកប្រែផ្សេងទៀត «គ្មានបូជាចារ្យណាអាចបង្រៀនពួកគេបានទេ»

នោះព្រះអង្គឲ្យគេរកឃើញ។

ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានឆ្លើយតបទៅនឹងប្រជាជនអ៊ីស្រាអែល
ស្វែងរកព្រះអង្គ។»

2 Chronicles 15:6

ពួកគេបែកបាក់គ្នា ប្រជាជាតិមួយទាស់នឹងប្រជាជាតិមួយ ហើយក្រុងមួយទាស់នឹងទីក្រុងមួយទៀត

ការបកប្រែផ្សេងទៀត «ពួកគេទទួលបរាជ័យពីសំណាក់ប្រជាជាតិ
និងទីក្រុងដទៃទៀត»

2 Chronicles 15:8

ដែលជាពាក្យទំនាយរបស់លោកអូដេតដែលជាព្យាការី

ការបកប្រែជាច្រើនជាច្រើនរួមទាំងUDB ធ្វើឲ្យអត្ថបទនេះអានថា
«ទំនាយរបស់លោកអសារាជាកូនរបស់លោកអូដេតដែលជាព្យាការី។»

ពួកគេធ្វើដូចនេះឲ្យស្របជាមួយនឹង ១៥:១។

អ្នកបកប្រែប្រហែលជាចង់ធ្វើដូចគ្នានេះដែរ។

ហើយបានបំផ្លាញអ្វីៗដែលគួរស្អប់

ការបកប្រែផ្សេងទៀត «បានដកយករូបបដិមាចេញ»

ព្រះអម្ចាស់គង់នៅជាមួយ និងព្រះករុណា។

ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់កំពុងជួយព្រះករុណា»

2 Chronicles 15:10

ពួកគេប្រមូលផ្តុំគ្នា

«ពួកគេ» នៅទីនេះសំដៅទៅលើកុលសម្ព័ន្ធយូដា
និងអ៊ីស្រាអែលដែលនៅជាមួយព្រះបាទអេសា។

នេះជាខែទីបីតាមប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែឧសភា
និងដើមខែមិថុនាតាមប្រតិទិនលោកខាងលិច។

ទីបី... ទីដប់

សូមមើល

ប្រាំពីររយក្បាល ... ប្រាំពីរពាន់ក្បាល

«៧០០ ... ៧០០០»

2 Chronicles 15:12

អស់ពីចិត្ត និងអស់ពីព្រលឹង។

ការបកប្រែផ្សេងទៀត «ដោយស្មោះត្រង់ទាំងស្រុង»

ត្រូវទទួលទោសដល់ស្លាប់

ការបកប្រែផ្សេងទៀត «ត្រូវបានសម្លាប់»

2 Chronicles 15:14

ព្រះអង្គក៏បានឲ្យពួកគេរកឃើញដែរ។

សូមមើលការបកប្រែដូចនៅក្នុង ២របាក្សត្រ ១៥:៤។

ប្រជាជនយូដាទាំងអស់មានចិត្តរីករាយ

ការបកប្រែផ្សេងទៀត «ប្រជាជនជាច្រើនដែលរស់នៅស្រុកយូដាមានចិត្តរីករាយ»

2 Chronicles 15:16

ព័ត៌មានទូទៅ៖

សូមមើល

ធ្វើរូបគួរស្អប់ខ្ពើម

ការបកប្រែផ្សេងទៀត «រូបបដិមា»

ស្តេចស្រឡាញ់ព្រះអម្ចាស់ដោយស្មោះអស់មួយជីវិត។

ការបកប្រែផ្សេងទៀត «ព្រះបាទអេសាបានស្តាប់បង្គាប់
និងធ្វើតាមព្រះអម្ចាស់អស់មួយជីវិតព្រះអង្គ»

---

16 [1]នៅឆ្នាំទីសាមសិបប្រាំមួយនៃរជ្ជកាលព្រះបាទអេសាស្តេចបាសាជាស្តេចស្រុកអ៊ីស្រាអែលបានបះបោរយ៉ាងខ្លាំងប្រឆាំងនឹងស្រុកយូដាហើយបានសង់ក្រុងរ៉ាម៉ា
ដើម្បីកុំឲ្យនរណាម្នាក់ចាកចេញ ឬចូលទៅក្នុងទឹកដីព្រះបាទអេសាដែលជាស្តេចស្រុកយូដា។
[2]ព្រះបាទអេសាបានយកមាស និងប្រាក់ចេញពីឃ្លាំងនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ និងក្នុងដំណាក់របស់ស្តេចហើយចាត់គេឲ្យទៅថ្វាយព្រះបាទបេន-ហាដាឌ
ជាស្តេចស្រុកអារ៉ាមដែលគ្រងរាជ្យនៅក្រុងដាម៉ាស។ ដោយទូលថា៖[3]«សូមឲ្យមានកិច្ចព្រមព្រៀងរវាងទូលបង្គំ និងព្រះករុណាដូចជាព្រះបិតាទូលបង្គំ
ព្រមទាំងបិតារបស់ព្រះករុណាដែរ។ ទូលបង្គំបានធ្វើប្រាក់ និងមាសមកថ្វាយព្រះករុណា។ សូមព្រះករុណាផ្តាច់សម្ពន្ធមិត្តជាមួយបាសទៅ
ដើម្បីកុំឲ្យស្តេចឡើងមកច្បាំងជាមួយទូលបង្គំឡើយ»។
[4]ព្រះបាទបេន-ហាដាឌស្តាប់តាមព្រះបាទអេសា ហើយចាត់មេបញ្ជាការកងទ័ពទាំងឡាយឲ្យទៅវាយយកក្រុងនានារបស់អ៊ីស្រាអែល។ ពួកគេបានវាយលុកក្រុងអ៊ីជុន
ក្រុងដាន់ក្រុងអេបិលមៀមព្រមទាំងឃ្លាំងស្បៀងទាំងប៉ុន្មាននៅទឹកដីណេបថាលី។
[5]នៅពេលព្រះបាទបាសាឮដំណឹងនេះទ្រង់ក៏ឈប់សាងសង់កំពែងក្រុងរ៉ាម៉ាហើយទុកការងារនោះចោល។[6]ពេលនោះ
ព្រះបាទអេសាបានយកប្រជាជនយូដាទាំងអស់ទៅជាមួយ។ ពួកគេបានយកថ្ម និងឈើនៅរ៉ាម៉ាដែលព្រះបាទបាសាបានយកមកសាងសង់ក្រុង។ បន្ទាប់មក
ស្តេចអេសាបានប្រើសម្ភារសំណង់នោះ ដើម្បីសាងសង់ក្រុងកេបា និងក្រុងមីសប៉ា។
[7]នៅគ្រានោះ លោកហាណានី ដែលជាគ្រូទាយបានចូលទៅគាល់ព្រះបាទអេសាជាស្តេចស្រុកយូដាហើយទូលថា៖
«ដោយព្រោះតែព្រះករុណាបានពឹងផ្អែកលើស្តេចស្រុកស៊ីរី និងមិនពឹងផ្អែកលើព្រះអម្ចាស់ជាព្រះរបស់ព្រះករុណា នោះកងទ័ពរបស់ស្តេចស្រុកស៊ីរីបានរួចផុត
ពីព្រះហស្តព្រះករុណាហើយ។[8]តើកាលជនជាតិអេត្យូពី និងប្រជាជនលីប៊ីលើកទ័ពមក តើគេមិនមានទ័ពដ៏ច្រើនសម្បើម មានរទេះចម្បាំង និងទ័ពសេះយ៉ាងច្រើនឬអី?
ប៉ុន្តែ ដោយពឹងលើព្រះអម្ចាស់ នោះព្រះអង្គបានធ្វើឲ្យព្រះករុណាមានជ័យជម្នះលើពួកគេ។
[9]ដ្បិត ព្រះនេត្ររបស់ព្រះអម្ចាស់ពាសពេញលើផែនដីទាំងមូល ដើម្បីឲ្យព្រះអង្គសម្តែងព្រះចេស្តាជួយអស់អ្នកដែលមានចិត្តស្មោះត្រង់ចំពោះព្រះអង្គ។ ប៉ុន្តែ ក្នុងរឿងនេះ
ព្រះករុណាបានធ្វើរឿងល្ងង់ខ្លៅហើយ។ ចាប់ពីពេលនេះទៅនឹងមានសង្គ្រាមកើតឡើងហើយ»។[10]ពេលនោះព្រះបាទអេសាខឹងនឹងគ្រូទាយ
ហើយបានមចាប់គាត់ដាក់គុកព្រោះព្រះករុណាខឹងនឹងគាត់អំពីបញ្ហានេះ។ នៅពេលជាមួយគ្នានោះ ព្រះបាទអេសាបានជិះជាន់ដល់ប្រជាជនមួយចំនួនដែរ។
[11]មើល! រាជកិច្ចរបស់ព្រះបាទអេសាតាំងពីដើមដល់ចប់មានកត់ត្រាទុកក្នុងសៀវភៅរបស់ស្តេចស្រុកយូដា និងស្តេចស្រុកអ៊ីស្រាអែល។
[12]ព្រះបាទអេសាមានជំងឺនៅក្នុងប្រអប់ជើង។ ជំងឺរបស់ព្រះករុណាធ្ងន់ធ្ងរណាស់។ ទោះបីយ៉ាងនេះក្តី
ទ្រង់មិនបានស្វែងរកជំនួយពីព្រះអម្ចាស់ទេគឺស្វែងរកតែគ្រូពេទ្យប៉ុណ្ណោះ។

generated on Wed Sep 10 16:16:32 2025

[13]ព្រះបាទអេសាសោយទិវង្គតទៅជួបជុំនឹងពួកអយ្យកោ នៅឆ្នាំទីសែសិបមួយនៃរជ្ជកាលរបស់ស្តេច។
[14]ពួកគេបានបញ្ចុះសពស្តេចនៅក្នុងផ្នូររបស់ទ្រង់ដែលស្តេចបានជីកនៅឯទីក្រុងដាវីឌ។ ពួកគេបានដាក់សព្វនៅលើគ្រែដែលពោរពេញទៅដោយក្លិនផ្អែម
និងគ្រឿងក្រអូបផ្សេងៗដែលរៀបចំដោយអ្នកជំនាញអប់។ បន្ទាប់មក ពួកគេបានបង្កាត់ភ្លើងយ៉ាងខ្លាំង ជាការថ្វាយកិត្តិយសដល់ស្តេច។

---

2 Chronicles 16:1
បានសង់ក្រុងរ៉ាម៉ា
នៅទីនេះ «បានសង់» មានន័យថា សាងសង់ជញ្ជាំងព័ទ្ធជុំវិញទីក្រុង
ដើម្បីការពារទីក្រុងពីពួកអ្នកវាយប្រហារ។
2 Chronicles 16:2
ព្រះបាទបេន-ហាដាឌ
កុំឲ្យស្តេចឡើងមកច្បាំងជាមួយទូលបង្គំឡើយ។
ការបកប្រែផ្សេងទៀត «មិនវាយប្រហារទូលបង្គំ» (សូមមើល)
2 Chronicles 16:4
ចាត់មេបញ្ជាការកងទ័ពទាំងឡាយឲ្យទៅវាយយកក្រុងនានា
«បានបញ្ជូនកងទ័ពរបស់ព្រះអង្គ ទៅវាយប្រហារទីក្រុងនានា»
ក្រុងអ៊ីជុន ក្រុងដាន់ក្រុងអេបិលម៉ៃម ... ឃ្លាំងស្បៀងទាំងប៉ុន្មាននៅទឹកដីណែបថាលី។
ទាំងនេះជាទីក្រុងក្នុងប្រទេសអ៊ីស្រាអែល។
ហើយទុកការងារនោះចោល។
«ព្រះអង្គបានបញ្ជាកងទ័ព ឲ្យបញ្ឈប់ការសាងសង់នៅរ៉ាម៉ា
និងធ្វើការងារផ្សេងទៀតនៅទីនោះ។»
ឈើ
ឈើជាបំណែកធំៗ ដែលត្រូវបានប្រើសម្រាប់សាងសង់ផ្ទះ ឬជញ្ជាំង។
2 Chronicles 16:7
លោកហាណានី
តើកាលជនជាតិអេត្សូពី និងប្រជាជនលីប៊ីលើកទ័ពមក តើគេមិនមានទ័ពដ៏ច្រើនសង្កើម
មានរទេះចម្បាំង និងទ័ពសេះយ៉ាងច្រើនឬអី?
ការបកប្រែផ្សេងទៀត «ជនជាតិអេត្សូពី និងជនជាតិលីប៊ីជាកងទ័ពដ៏ធំមួយ
មានរទេះចម្បាំងនិងទ័ពសេះជាច្រើន។»
2 Chronicles 16:9
ព្រះនេត្ររបស់ព្រះអម្ចាស់ពាសពេញលើផែនដីទាំងមូល
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ទតឃើញអ្វីៗ
ដែលកំពុងតែកើតមាននៅលើផែនដីទាំងអស់»
ដើម្បីឲ្យព្រះអង្គសម្តែងព្រះចេស្តាជួយ
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់ការពារដោយកម្លាំងរបស់ព្រះអង្គ»
អស់អ្នកដែលមានចិត្តស្មោះត្រង់ចំពោះព្រះអង្គ។
ការបកប្រែផ្សេងទៀត «អស់អ្នកដែលប្តេជ្ញាចិត្តទាំងស្រុងធ្វើតាមព្រះអង្គ»
2 Chronicles 16:11
តាំងពីដើមដល់ចប់
ការបកប្រែផ្សេងទៀត «អ្វីៗទាំងអស់ដែលស្តេចបានធ្វើ»
សៀវភៅរបស់ស្តេចស្រុកយូដា និងស្តេចស្រុកអ៊ីស្រាអែល។
សៀវភៅនេះលែងមានទៀតហើយ។
ព្រះបាទអេសាមានជំងឺនៅក្នុងប្រអប់ជើង។
ការបកប្រែផ្សេងទៀត «ព្រះបាទអេសាមានជំងឺនៅក្នុងប្រអប់ជើងរបស់ព្រះអង្គ»
2 Chronicles 16:13
ព្រះបាទអេសាសោយទិវង្គតទៅជួបជុំនឹងពួកអយ្យកោ
ការបកប្រែផ្សេងទៀត «ព្រះបាទអេសាបានសោយទិវង្គត។»
ក្លិនផ្អែម
ក្លិនផ្អែមជាតុមួយ ដែលគេដាក់សាកសពពេលរៀបចំពិធីបុណ្យសព។
គ្រឿងក្រអូបផ្សេងៗដែលរៀបចំដោយអ្នកជំនាញអប់។
ការដាក់រុក្ខជាតិដែលមានក្លិនឈ្ងុយឆ្ងាញ់ជាមួយសាកសព
ជាទម្លាប់មួយនៃការបញ្ចុះសពរបស់ប្រជាជនអ៊ីស្រាអែល។ ការបកប្រែផ្សេងទៀត
«រុក្ខជាតិមានក្លិនឈ្ងុយ
ដែលរៀបចំដោយមនុស្សមានជំនាញក្នុងប្រពៃណីទំនៀមទម្លាប់នេះ»

---

17 [1]ព្រះបាទយ៉ូសាផាតជាបុត្ររបស់ព្រះបាទអេសាបានឡើងស្នងរាជ្យជំនួសបិតា។ ព្រះបាទយ៉ូសាផាតបានពង្រឹងអំណាចខ្លួនឯងប្រឆាំងនឹងអ៊ីស្រាអែល។
[2]ស្តេចបានដាក់ទ័ពនៅតាមក្រុងទាំងប៉ុន្មានដែលមានកំពែងរឹងមាំនៅស្រុកយូដា និងឲ្យមានកងទ័ពនៅក្នុងស្រុកយូដា
និងនៅតាមក្រុងនានានៅអេប្រាអ៊ីមដែលព្រះបាទអេសាជាបិតាបានកាន់កាប់។
[3]ព្រះអម្ចាស់គង់ជាមួយព្រះបាទយ៉ូសាផាតព្រោះព្រះករុណាបានដើរតាមមាគ៌ារបស់ព្រះបាទដាវីឌ ជាបិតាហើយមិនស្វែងរកព្រះបាលឡើយ។
[4]ព្រះករុណាបានពឹងលើព្រះជាម្ចាស់ជាព្រះរបស់ពួកអយ្យកោហើយគោរពតាមបទបញ្ជារបស់ព្រះអង្គ ដោយមិនដើរតាមផ្លូវរបស់ជនជាតិអ៊ីស្រាអែលទេ។
[5]ដូច្នេះ ព្រះអម្ចាស់បានពង្រឹងរាជ្យសម្បត្តិរបស់ស្តេចឲ្យរឹងមាំហើយជនជាតិយូដាទាំងអស់នាំសួយសារអាករទៅព្រះបាទយ៉ូសាផាត។ ស្តេចមានទ្រព្យសម្បត្តិ
និងកិត្តិយសច្រើនក្រៃលែង។[6]ស្តេចមានព្រះហឫទ័យស្មោះត្រង់ចំពោះមាគ៌ារបស់ព្រះអម្ចាស់។ ស្តេចក៏បំផ្លាញកន្លែងសក្ការៈតាមទួលខ្ពស់ៗ
និងដកបង្គោលព្រះអាសេរ៉ាចេញពីស្រុកយូដាទាំងអស់។
[7]នៅឆ្នាំទីបីនៃរជ្ជកាលរបស់ព្រះអង្គ ព្រះករុណាបានចាត់មន្ត្រីមានលោកបេនហែល លោកអូបាឌា លោកសាការី លោកនេថាណែល
និងលោកមីកាយ៉ាទៅបង្រៀននៅតាមក្រុងនានាក្នុងស្រុកយូដា។[8]ដោយមានពួកលេវីទៅជាមួយគឺ លោកសេម៉ាយ៉ា លោកណាថានៀ លោកសេបាឌា លោកអេសាហែល
លោកសេមីរ៉ាម៉ូត លោកយេហូណាថាន លោកអដូនីយ៉ា លោកថូប៊ីយ៉ា និងលោកថូបាដូនីយ៉ា ហើយមានបូជាចារ្យនៅជាមួយពួកគេផងគឺបូជាចារ្យអេលីសាម៉ា
និងបូជាចារ្យយ៉ូរ៉ាម។[9]ពួកគេបង្រៀននៅស្រុកយូដាដោយមានសៀវភៅក្រឹត្យវិន័យរបស់ព្រះអម្ចាស់នៅជាមួយពួកគេ។
ពួកគេធ្វើដំណើរពាសពេញក្រុងទាំងប៉ុន្មានក្នុងស្រុកយូដាដើម្បីបង្រៀនប្រជាជន។
[10]ព្រះអម្ចាស់បានធ្វើឲ្យនគរទាំងប៉ុន្មាននៅជុំវិញស្រុកយូដាកើតមានការភ័យខ្លាច ដូច្នេះ ពួកគេពុំបានធ្វើសង្គ្រាមប្រឆាំងនឹងព្រះបាទយ៉ូសាផាតឡើយ។
[11]ជនជាតិភីលីស្ទីនខ្លះនាំយកអំណោយមកថ្វាយព្រះបាទយ៉ូសាផាត និងប្រាក់មកធ្វើជាសួយសារអាករ។ ជនជាតិអារ៉ាប់ក៏បាននាំហ្វូងសត្វចៀម ៧, ៧០០ ក្បាលនិងពពែ
៧, ៧០០ ក្បាល មកថ្វាយព្រះបាទយ៉ូសាផាតដែរ។
[12]ព្រះបាទយ៉ូសាផាតមានអំណាចខ្លាំងក្លាណាស់។ ស្តេចបានសង់បន្ទាយ និងឃ្លាំងជាច្រើននៅក្នុងក្រុងនានានៅស្រុកយូដា។
[13]ស្តេចមានទ្រព្យសម្បត្តិយ៉ាងច្រើននៅក្រុងនានាក្នុងស្រុកយូដា និងកងទ័ពដែលមានសុទ្ធតែជាមនុស្សអង់អាចក្លាហានក្នុងក្រុងយេរូសាឡិម។
[14]នេះជាបញ្ជីឈ្មោះតាមក្រុមគ្រួសាររបស់ពួកគេ ពីកុលសម្ព័ន្ធយូដា មានមេបញ្ជាការកងពល ដូចតទៅ លោកអាណាណា
ជាមេបញ្ជាការហើយនៅជាមួយគាត់មានទាហានប្រយុទ្ធ ៣០, ០០០ នាក់។[15]លោកយ៉ូហាណាន ជាមេបញ្ជាការជាមួយគាត់មានពលទាហាន ២៨០, ០០០ នាក់។
[16]លោកអ័ម៉ាស៊ីយ៉ាជាកូនរបស់លោកស៊ីគ្រីដែលស្ម័គ្រចិត្តចង់បម្រើព្រះអម្ចាស់ ហើយនៅជាមួយគាត់មានទាហានចំនួន ២០០, ០០០ នាក់។[17]ពីកូនចៅបេនយ៉ាមីនមាន៖
លោកអេលីយ៉ាដា នៅជាមួយគាត់មានឥស្សរជនក្លាហានចំនួន២០០, ០០០នាក់ ប្រដាប់អាវុធមានធ្នូនិងខែល។[18]បន្ទាប់មក មានលោកយេហូសាបាត
ហើយនៅជាមួយគាត់មានទាហានចំនួន១៨០, ០០០ នាក់សុទ្ធតែត្រៀមខ្លួនសម្រាប់ធ្វើសង្គ្រាម។[19]អ្នកទាំងនេះសុទ្ធតែនៅបម្រើស្តេច រួមទាំងអ្នកឯទៀតៗ ដែលស្តេចដាក់
ឲ្យប្រចាំការនៅតាមក្រុង ដែលមានកំពែងរឹងមាំទាំងប៉ុន្មានក្នុងស្រុកយូដា។

---

2 Chronicles 17:1
ពង្រឹងអំណាចខ្លួនឯងប្រឆាំងនឹងអ៊ីស្រាអែល។
គំនិត «ខ្លួនឯង» នៅទីនេះសម្រាប់កងទ័ពរបស់ស្តេច។ ការបកប្រែផ្សេងទៀត
«រៀបចំកងទ័ពដើម្បីច្បាំងនឹងអ៊ីស្រាអែល»

generated on Wed Sep 10 16:16:32 2025

កងទ័ព
ទាំងនេះជាមូលដ្ឋានយោធាសម្រាប់ការពារ។
2 Chronicles 17:3
បានដើរតាមមាគ៌ារបស់ព្រះបាទដាវីឌ ជាបិតា
អាកប្បកិរិយាត្រូវបានគេនិយាយដូចជាវាកំពុងដើរ។ ការបកប្រែផ្សេងទៀត
«បានរស់នៅតាមផ្លូវសុចរិតរបស់បុព្វបុរសព្រះអង្គ»
ហើយមិនស្វែងរកព្រះបាលឡើយ។
មិនបានថ្វាយបង្គំព្រះបាល ដើម្បីស្វែងរកជំនួយពីព្រះបាលទេ។
2 Chronicles 17:5
បង្គោលព្រះអាសេរ៉ា
សូមមើលការបកប្រែដូចនៅក្នុង ១៤:១។
2 Chronicles 17:7
លោកបេនហែល,លោកអូបាឌា,លោកសាការី ,លោកនេថាណែល, និងលោកមីកាយ៉ា...
លោកសេម៉ាយ៉ា,លោកណាថានឿ,លោកសេបាឌា ,លោកអេសាហែល , លោកសេមីរ៉ាម៉ូត ,
លោកយេហូណាថាន, លោកអដូនីយ៉ា , លោកថូប៊ីយ៉ានិងលោកថូបាដូនីយ៉ា... បូជាចារ្យអេលីសាម៉ា
និងបូជាចារ្យយ៉ូរ៉ាម
ទាំងនេះឈ្មោះរបស់មនុស្សប្រុស។
2 Chronicles 17:10
ព្រះអម្ចាស់បានធ្វើឲ្យនគរទាំងប៉ុន្មាននៅជុំវិញស្រុកយូដា
ការបកប្រែផ្សេងទៀត «ប្រជាជននៅគ្រប់នគរទាំងប៉ុន្មាននៅជុំវិញស្រុកយូដា
មានការភ័យខ្លាចចំពោះអ្វី ដែលព្រះអម្ចាស់នឹងធ្វើដើម្បីដាក់ទោសពួកគេ។»
2 Chronicles 17:14
លោកអាណាណា ... លោកយ៉ូហាណាន ... លោកអម៉ាស៊ីយ៉ាជាកូនរបស់លោកស៊ីគ្រី
៣០,០០០ នាក់។ ... ២០០,០០០ នាក់ ... ២០០,០០០នាក់

18

[1]ព្រះបាទយ៉ូសាផាតមានទ្រព្យសម្បត្តិយ៉ាងច្រើន និងកិត្តិយសយ៉ាងខ្លាំង។ ព្រះករុណាបានចងសម្ព័ន្ធភាពជាមួយព្រះបាទអហាប់
ដោយអភិសេកបុត្រាជាមួយបុត្រីព្រះបាទអហាប់។[2]ប៉ុន្មានឆ្នាំក្រោយមកព្រះករុណាបានយាងទៅសួរសុខទុក្ខព្រះបាទអហាប់នៅក្រុងសាម៉ារី។
ព្រះបាទអហាប់បានសម្លាប់ចៀម និងគោជាច្រើនសម្រាប់ព្រះករុណា ពួកមន្ត្រីដែលមកជាមួយទ្រង់។
ព្រះបាទអហាប់ក៏បញ្ចុះបញ្ចូលឲ្យព្រះបាទយ៉ូសាផាតវាយប្រហាររ៉ាម៉ូតកាឡាតជាមួយទ្រង់ដែរ។
[3]ព្រះបាទអហាប់ជាស្តេចស្រុកអ៊ីស្រាអែលមានរាជឱង្ការទៅព្រះបាទយ៉ូសាផាតស្តេចស្រុកយូដាថា៖
«តើព្រះករុណាសព្វព្រះហឫទ័យនឹងទៅច្បាំងជាមួយទូលបង្គំនៅរ៉ាម៉ូតកាឡាតឬទេ?» ព្រះបាទយ៉ូសាផាតឆ្លើយថា៖ «ទូលបង្គំក៏ដូចព្រះករុណាដែរ
ហើយប្រជាជនរបស់ទូលបង្គំគឺដូចប្រជាជនរបស់ព្រះករុណាដែរ ទូលបង្គំនឹងទៅច្បាំងជាមួយព្រះករុណា»។
[4]ព្រះបាទយ៉ូសាផាតទូលស្តេចស្រុកអ៊ីស្រាអែលថា៖ «សូមស្វែងរកព្រះបន្ទូលរបស់ព្រះអម្ចាស់ជាមុនសិន»។
[5]ស្តេចស្រុកអ៊ីស្រាអែលប្រមូលពួកព្យាការីដែលមានចំនួនបួនរយនាក់ហើយមានរាជឱង្ការទៅពួកគេថា៖ «តើយើងត្រូវទៅវាយក្រុងរ៉ាម៉ូតនៅស្រុកកាឡាត
ឬមិនត្រូវទៅ?»។ ពួកគេឆ្លើយថា៖ «ចូរទៅច្បាំងចុះ ដ្បិត ព្រះជាម្ចាស់នឹងប្រគល់វាទៅក្នុងកណ្តាប់ដៃរបស់ព្រះករុណាហើយ»។
[6]ព្រះបាទយ៉ូសាផាតមានរាជឱង្ការថា៖ «តើនៅទីនេះគ្មានព្យាការីរបស់ព្រះអម្ចាស់ទៀតដែលយើងអាចស្វែងរកយោបល់ទេឬ?»។
[7]ស្តេចស្រុកអ៊ីស្រាអែលមានរាជឱង្ការទៅកាន់ព្រះបាទយ៉ូសាផាតថា៖ «នៅមានបុរសម្នាក់ដែលយើងត្រូវស្វែងរកដំបូន្មានពីព្រះអម្ចាស់ គឺមីកាយ៉ាជាកូនរបស់លោកអ៊ីមឡា
ប៉ុន្តែ ទូលបង្គំស្អប់គាត់ព្រោះគាត់មិនដែលថ្លែងសេចក្តីល្អអំពីទូលបង្គំទេ តែងតែអាក្រក់ជានិច្ច»។ ប៉ុន្តែ ព្រះបាទយ៉ូសាផាតមានរាជឱង្ការថា៖
«ព្រះករុណាមិនគួរមានបន្ទូលដូច្នោះទេ»។[8]ស្តេចស្រុកអ៊ីស្រាអែលហៅនាយទាហានមកហើយមានរាជឱង្ការថា៖ «ចូរនាំមីកាយ៉ាជាកូនរបស់លោកអ៊ីមឡា
ឲ្យមកជាប្រញាប់!»។
[9]ព្រះបាទអហាប់ជាស្តេចនៃស្រុកអ៊ីស្រាអែល និងព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដា ស្លៀកពាក់រុងរឿងកំពុងគង់លើបល្ល័ង្ក នៅព្រលានត្រង់ខ្លោងទ្វារក្រុងសាម៉ារី
ហើយពួកព្យាការីទាំងអស់ក៏ទាយនៅចំពោះស្តេច។[10]លោកសេដេគា ជាកូនរបស់លោកក្នាណាធ្វើស្នែងដែកហើយមានប្រសាសន៍ថា៖
«ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ៖ ដោយស្នែងដែកនេះ អ្នកនឹងរុញច្រានជនជាតិស៊ីរីឲ្យវិនាសសូន្យទៅ។[11]ពួកព្យាការីទាំងអស់សុទ្ធតែថ្លែងព្រះបន្ទូលដូចតទៅនេះថា៖
«ចូរវាយយកក្រុងរ៉ាម៉ូតនៅស្រុកកាឡាដចុះ ដ្បិត ព្រះអម្ចាស់ប្រគល់ក្រុងនោះទៅក្នុងកណ្តាប់ដៃរបស់ព្រះករុណាហើយ»។
[12]អ្នកនាំសារដែលបានទៅហៅលោកមីកាយ៉ាបាននិយាយទៅគាត់ថា៖ «មើលចុះពាក្យរបស់ពួកព្យាការីប្រកាសសេចក្តីល្អៗដល់ព្រះរាជាដោយសម្លេងតែមួយ ដូច្នេះ
សូមឲ្យលោកជាម្នាក់នៅក្នុងចំណោមពួកគេដោយប្រកាសពីសេចក្តីល្អដល់ស្តេចចុះ»។[13]លោកមីកាយ៉ាឆ្លើយថា៖
«ព្រះអម្ចាស់មានព្រះជន្មគង់នៅដូចព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំ»។[14]ពេលគាត់ចូលគាល់ស្តេច នោះស្តេចមានរាជឱង្ការថា៖ «លោកមីកាយ៉ា
តើយើងត្រូវទៅរ៉ាម៉ូតនៅស្រុកកាឡាតឬ?»។ លោកមីកាយ៉ាឆ្លើយថា៖ «ចូរវាយយកជ័យជម្នះចុះ ដ្បិត នឹងមានជ័យជម្នះធំណាស់!»។
[15]ព្រះរាជាមានរាជឱង្ការថា៖ «តើត្រូវឲ្យយើងប្រាប់អ្នកឲ្យស្បថប៉ុន្មានដង ដើម្បីកុំនិយាយអ្វីក្រៅពីសេចក្តីពិតក្នុងនាមព្រះអម្ចាស់?»។[16]លោកមីកាយ៉ាមានប្រសាសន៍ថា៖
«ទូលបង្គំបានឃើញកងទ័ពអ៊ីស្រាអែលទាំងមូលខ្ចាត់ខ្ចាយនៅលើភ្នំដូចជាចៀមដែលគ្មានគង្វាលហើយព្រះអម្ចាស់មានព្រះបន្ទូលថា៖ «អ្នកទាំងនេះគ្មានអ្នកគង្វាលទេ
ចូរឲ្យម្នាក់ៗវិលត្រឡប់ទៅផ្ទះដោយសុខសាន្តចុះ»។
[17]ស្តេចស្រុកអ៊ីស្រាអែលមានរាជឱង្ការទៅកាន់ព្រះបាទយ៉ូសាផាតថា៖ «តើទូលបង្គំមិនបានប្រាប់ព្រះករុណាទេឬអីថា គាត់នឹងមិនថ្លែងព្រះបន្ទូលល្អអំពីទូលបង្គំទេ ប៉ុន្តែ
មានតែការអាក្រក់ប៉ុណ្ណោះ?»[18]លោកមីកាយ៉ាមានប្រសាសន៍ថា៖ «ដូច្នេះ អ្នករាល់គ្នាត្រូវស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។
ខ្ញុំបានឃើញព្រះអម្ចាស់គង់លើបល្ល័ង្ករបស់ព្រះអង្គហើយកងទ័ពនៃស្ថានបរមសុខទាំងប៉ុន្មានឈរនៅខាងស្តាំ និងខាងឆ្វេង។
[19]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «តើនរណានឹងល្បួងព្រះបាទអហាប់ជាស្តេចស្រុកអ៊ីស្រាអែល ដើម្បីឲ្យស្តេចឡើងទៅវាយ ហើយដួលស្លាប់នៅរ៉ាម៉ូតកាឡាត?
ម្នាក់ទូលបែបនេះ ហើយម្នាក់ទូលនោះ។
[20]ពេលនោះមានវិញ្ញាណមួយចេញមកឈរនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ហើយទូលថា៖ «ខ្ញុំនឹងល្បួងព្រះអង្គ»។ ព្រះអម្ចាស់មានព្រះបន្ទូលមកគាត់ថា៖
«តើធ្វើដូចម្តេច?»[21]វិញ្ញាណនោះទូលព្រះអង្គថា៖ «ទូលបង្គំនឹងចាកចេញទៅហើយទូលបង្គំនឹងក្លាយទៅជាពាក្យកុហកនៅក្នុងមាត់ព្យាការីទាំងអស់»។
ព្រះអម្ចាស់មានព្រះបន្ទូលតបថា៖ «អ្នកនឹងល្បួងវាហើយអ្នកក៏នឹងទទួលជោគជ័យដែរ។ ឥឡូវ ចូរទៅធ្វើអ៊ីចឹងចុះ»។
[22]ឥឡូវនេះ ព្រះអម្ចាស់បានដាក់វិញ្ញាណភូតកុហកនៅក្នុងមាត់ព្យាការីទាំងអស់របស់ព្រះករុណា ហើយព្រះអម្ចាស់បានដាក់ទោសមហន្តរាយដល់ព្រះករុណា។
[23]ពេលនោះសេដេគាជាកូនរបស់លោកកាណាណាបានឡើងមកទះកំផ្លៀងលោកមីកាយ៉ាទាំងពោលថា៖
«តើព្រះវិញ្ញាណរបស់ព្រះអម្ចាស់ចេញពីខ្ញុំទៅនិយាយនឹងអ្នកបែបណា?»។[24]លោកមីកាយ៉ាមានប្រសាសន៍ថា៖ «មើល! អ្នកនឹងដឹងនៅថ្ងៃនោះ
គឺពេលអ្នករត់ចូលបន្ទប់ខាងក្នុងដើម្បីលាក់ខ្លួន»។
[25]ស្តេចស្រុកអ៊ីស្រាអែលមានរាជឱង្ការទៅកាន់អ្នកបម្រើខ្លះថា៖ «ចូរអ្នករាល់គ្នាចាប់លោកមីកាយ៉ា ហើយនាំវាទៅជួបលោកអាំម៉ូនជាចៅហ្វាយក្រុង និងសម្តេច
យ៉ូអាសជាបុត្រារបស់យើង។[26]ហើយត្រូវជម្រាប់សម្តេចថា៖ «ស្តេចមានរាជឱង្ការថា៖ «ចូរចាប់បុរសនេះយកទៅដាក់ក្នុងគុក ហើយចិញ្ចឹមគាត់ដោយនំប៉័ង
និងទឹកបន្តិចបន្តួចប៉ុណ្ណោះរហូតដល់យើងត្រឡប់មកវិញដោយសុវត្ថិភាព»។[27]លោកមីកាយ៉ាតបថា៖ «ប្រសិនបើ អ្នកវិលត្រឡប់មកវិញដោយសុវត្ថិភាព
នោះព្រះអម្ចាស់មិនបានមានព្រះបន្ទូលមកខ្ញុំទេ»។ បន្ទាប់មក គាត់បន្ថែមទៀតថា៖ «ប្រជាជនទាំងអស់គ្នា ចូរស្តាប់សេចក្តីទាំងនេះចុះ»។
[28]ដូច្នេះ ព្រះបាទអហាប់ ស្តេចស្រុកអ៊ីស្រាអែល និងព្រះបាទយ៉ូសាផាត ជាស្តេចស្រុកយូដាបានឡើងទៅវាយយកក្រុងរ៉ាម៉ូត កាឡាត។
[29]ស្តេចស្រុកអ៊ីស្រាអែលមានរាជឱង្ការទៅព្រះបាទយ៉ូសាផាតថា៖ «ទូលបង្គំនឹងបន្លំខ្លួន ហើយឡើងទៅច្បាំងតែព្រះករុណាត្រូវគ្រងព្រះពស្ត្រទ្រង់ចុះ»។

generated on Wed Sep 10 16:16:32 2025

ស្តេចស្រុកអ៊ីស្រាអែលក្លែងខ្លួនធ្វើជាកងទ័ព ចូលទៅក្នុងសមរភូមិ។[30]ស្តេចស្រុកស៊ីរីបានបញ្ជាទៅមេបញ្ជាការរទេះចម្បាំងទាំងអស់ដោយមានរាជឱង្ការថា៖
«កុំវាយប្រហារពលទាហានធម្មតា ឬពលទាហានសំខាន់ឡើយ ផ្ទុយទៅវិញ ត្រូវវាយប្រហារតែស្តេចអ៊ីស្រាអែលប៉ុណ្ណោះ»។
[31]ពេលមេបញ្ជាការរទេះចម្បាំងបានឃើញព្រះបាទយ៉ូសាផាត ពួកគេក៏ពោលថា៖ «នុះ ជាស្តេចស្រុកអ៊ីស្រាអែល»។ ពួកគេក៏វិលមកវាយប្រហារព្រះករុណា
តែព្រះបាទយ៉ូសាផាតស្រែកអង្វរព្រះអម្ចាស់ នោះព្រះអម្ចាស់ក៏ជួយទ្រង់។ ព្រះអម្ចាស់បានបង្វែរពួកគេចេញពីព្រះករុណា។
[32]កាលមេបញ្ជាការរទេះចម្បាំងទាំងនោះដឹងថាទ្រង់មិនមែនជាស្តេចអ៊ីស្រាអែលទេ នោះពួកគេក៏ឈប់ដេញតាម។
[33]ប៉ុន្តែ មានទាហានម្នាក់បានយឹតធ្នូរបស់ខ្លួនដោយចៃដន្យហើយបានបាញ់ត្រូវស្តេចអ៊ីស្រាអែលនៅចន្លោះនៃគ្រឿងសឹករបស់គាត់។
ព្រះបាទអហាប់ក៏មានរាជឱង្ការទៅអ្នកបើករទេះរបស់ព្រះអង្គថា៖ «ចូរនាំយើងចេញទៅ ដ្បិត យើងត្រូវរងរបួសធ្ងន់ណាស់! ។[34]នៅថ្ងៃនោះចម្បាំងកាន់តែខ្លាំងឡើងៗ
ហើយស្តេចស្រុកអ៊ីស្រាអែលនៅលើរទេះសេះឆ្ពោះទៅទល់នឹងកងទ័ពស៊ីរីរហូតដល់ល្ងាច។ ប្រហែលពេលដែលព្រះអាទិត្យលិច នោះស្តេចក៏សុគតទៅ។

---

2 Chronicles 18:1
ព្រះករុណាបានចងសម្ព័ន្ធភាពជាមួយព្រះបាទអហាប់
ការបកប្រែផ្សេងទៀត «ព្រះករុណាបានចងសម្ពន្ធភាពជាមួយព្រះបាទអហាប់» ឬ «ព្រះករុណាបានធ្វើឲ្យខ្លួនឯងជាមិត្តរបស់ព្រះបាទអហាប់»
ទូលបង្គំក៏ដូចព្រះករុណាដែរ ហើយប្រជាជនរបស់ទូលបង្គំគឺដូចប្រជាជនរបស់ព្រះករុណាដែ
ព្រះបាទយ៉ូសាផាតកំពុងបង្ហាញភក្តីភាព ចំពោះព្រះបាទអហាប់។
ការបកប្រែផ្សេងទៀត «យើងផ្តល់ជូនខ្លួនយើង និងទាហានរបស់យើងឲ្យអ្នកប្រើតាមគ្រប់វិធីណាដែលអ្នកចង់បាន។»
2 Chronicles 18:6
តើនៅទីនេះគ្មាន... យោបល់ទេឬ?
«ខ្ញុំប្រាកដថាត្រូវតែមាននៅទីនេះ ... យោបល់។»
មីកាយ៉ាជាកូនរបស់លោកអ៊ីមឡា
គាត់ជាព្យាការីរបស់ព្រះអម្ចាស់។
2 Chronicles 18:9
ជាកូនរបស់លោកក្នាណា
ដោយស្នែងដែកនេះ
នេះជាការសំដៅទៅនឹងស្នែងគោ ប៉ុន្តែ គេធ្វើវាពីលោហៈ។
អ្នកនឹងរុញជនជាតិស៊ីរីអោយវិនាសសូន្យទៅ
ការបកប្រែផ្សេងទៀត «អ្នកនឹងយកឈ្នះពួកគេ»
ព្រះអម្ចាស់ប្រគល់ក្រុងនោះទៅក្នុងកណ្តាប់ដៃរបស់ព្រះករុណាហើយ។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងប្រទានជ័យជម្នះដល់ព្រះករុណា»
2 Chronicles 18:12
លោកមីកាយ៉ា
សូមមើលការបកប្រែនៅក្នុង ១៧:៧។
សូមឲ្យលោកជាម្នាក់
នេះជាអះអាងទៅលើសារទាំងមូលរបស់ព្យាការី។
ដោយសម្លេងតែមួយ
ការបកប្រែផ្សេងទៀត «ដោយមានមតិតែមួយ» ឬ «ហើយពួកគេទាំងអស់បានយល់ព្រម»
ព្រះអម្ចាស់មានព្រះជន្មគង់នៅ
ការបកប្រែផ្សេងទៀត «ខ្ញុំសូមធានាឲ្យអ្នក»
ឬ
«ឬយើងមិនគួរទៅ»
2 Chronicles 18:15
«តើត្រូវឲ្យយើងប្រាប់អ្នកឲ្យស្បថប៉ុន្មានដង
ដើម្បីកុំនិយាយអ្វីក្រៅពីសេចក្តីពិតក្នុងនាមព្រះអម្ចាស់?»។
ការបកប្រែផ្សេងទៀត «យើងបានប្រាប់អ្នកឲ្យនិយាយតែការពិតនៅក្នុងព្រះនាមព្រះអម្ចាស់»
ដូចជាចៀមដែលគ្មានគង្វាលហើយ
ការបកប្រែផ្សេងទៀត «ដោយគ្មានការដឹកនាំល្អ»
2 Chronicles 18:17
«តើទូលបង្គំមិនបានប្រាប់ព្រះករុណាទេឬអីថា គាត់នឹងមិនថ្លែងព្រះបន្ទូលល្អអំពីទូលបង្គំទេ ប៉ុន្តែមានតែការអាក្រក់ប៉ុណ្ណោះ?»
ការបកប្រែផ្សេងទៀត «ទូលបង្គំបានប្រាប់ព្រះករុណាថា គាត់នឹងថ្លែងព្រះបន្ទូលថា គ្រោះមហន្តរាយនឹងកើតមានចំពោះទូលបង្គំ»
2 Chronicles 18:19
ល្បួង
មានន័យថា ទាក់ទាញអ្នកណាម្នាក់ ដោយផ្តល់ជូនអ្វីមួយ។
ដួលស្លាប់
ការបកប្រែផ្សេងទៀត «ឈឺចាប់យ៉ាងខ្លាំង» ឬ «ស្លាប់»
ម្នាក់ទូលបែបនេះ ហើយម្នាក់ទូលនោះ។
បង្ហាញថា មានមតិច្រើនជាងមួយ។
2 Chronicles 18:20
ក្លាយទៅជាពាក្យកុហកនៅក្នុងមាត់ព្យាការីទាំងអស់។
ការបកប្រែផ្សេងទៀត «វិញ្ញាណដែលធ្វើឲ្យព្យាការីថ្លែងទំនាយខុស»
2 Chronicles 18:22
បានដាក់ទោសមហន្តរាយដល់ព្រះករុណា។
ការបកប្រែផ្សេងទៀត «កំណត់ថា រឿងគួរឲ្យខ្លាចនឹងកើតឡើងចំពោះព្រះករុណា»
2 Chronicles 18:23
សេដេគាជាកូនរបស់លោកកាណាណា
មិនមែនជាលោកសេដេគាដូចបានយោងខាងលើទេ
តែជាព្យាការីស្មោះត្រង់នឹងព្រះបាទអហាប់
តើព្រះវិញ្ញាណរបស់ព្រះអម្ចាស់ចេញពីខ្ញុំទៅនិយាយនឹងអ្នកបែបណា?»។
ការបកប្រែផ្សេងទៀត «វិញ្ញាណរបស់ព្រះជាម្ចាស់មិនចាកបានចេញពីខ្ញុំទៅនិយាយជាមួយអ្នកឡើយ»
គឺពេលអ្នករត់ចូលបន្ទប់ខាងក្នុងដើម្បីលាក់ខ្លួន។
ការបកប្រែផ្សេងទៀត «នៅពេលអ្នករត់លាក់ខ្លួនទាំងភ័យខ្លាច»
2 Chronicles 18:25
ស្តេចស្រុកអ៊ីស្រាអែល
នេះជាសេចក្តីបញ្ជាក់ចំពោះព្រះបាទអហាប់។
លោកអាំម៉ូន
«ប្រសិនបើ អ្នកវិលត្រឡប់មកវិញដោយសុវត្ថិភាព
នោះព្រះអម្ចាស់មិនបានមានព្រះបន្ទូលមកខ្ញុំទេ»។
លោកមីកាយ៉ាដឹងថា ព្រះអម្ចាស់មានបន្ទូលតាមរយៈគាត់។
2 Chronicles 18:28
ទៅវាយយក
ការបកប្រែផ្សេងទៀត «ប្រយុទ្ធប្រឆាំងនឹង»
ក្រុងរ៉ាម៉ូត កាឡាត
សូមមើលការបកប្រែដូចនៅក្នុង ១៨:១។
បន្លំខ្លួន
មានន័យថា ផ្លាស់ប្តូររូបរាងធម្មតាដើម្បីកុំឲ្យគេស្គាល់អត្តសញ្ញាណ។
កុំវាយប្រហារពលទាហានធម្មតា ឬពលទាហានសំខាន់ឡើយ
ការបកប្រែផ្សេងទៀត «កុំវាយប្រហារទាហានណាមួយ»
2 Chronicles 18:31
នុះ ជាស្តេចស្រុកអ៊ីស្រាអែល។
ព្រះបាទយ៉ូសាផាតត្រូវគេស្គាល់អត្តសញ្ញាណខុសថា ជាស្តេចអ៊ីស្រាអែល
ពីព្រោះព្រះបាទអហាប់បានទទួចឲ្យទ្រង់ពាក់ព្រះពស្ត្រស្តេច។
ព្រះអម្ចាស់បានបង្វែរពួកគេចេញពីព្រះករុណា។
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានបណ្តាលឲ្យពួកគេឈប់តាមព្រះករុណា»
2 Chronicles 18:33
នៅចន្លោះនៃគ្រឿងសឹករបស់គាត់។
នេះជាកន្លែងមួយ ដែលគ្រឿងសឹកពីរចំណែកជាប់គ្នា
ហើយងាយនឹងរងគ្រោះដោយព្រួញ និងដាវ។

---

[1]ព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដាបានវិលត្រឡប់ទៅព្រះដំណាក់ទ្រង់នៅក្រុងយេរូសាឡិមវិញដោយសុវត្ថិភាព។[2]ពេលនោះលោកយេហ៊ូ ជាកូនរបស់ហាណានី
ជាអ្នកមើលឆុតបានចេញទៅជួបស្តេចយ៉ូសាផាតទូលថា៖ «តើអ្នកគួរជួយមនុស្សអាក្រក់ឬ? តើអ្នកគួរស្រឡាញ់អ្នកដែលស្អប់ព្រះអម្ចាស់ឬ? ដោយព្រោះ
ព្រះករុណាប្រព្រឹត្តការនេះនោះសេចក្តីក្រោធរបស់ព្រះបានទាស់នឹងព្រះករុណាហើយ[3]ទោះយ៉ាងណាក៏ដោយមានសេចក្តីល្អនៅក្នុងព្រះករុណាខ្លះដែរ
គឺព្រះករុណាបានបំផ្លាញបង្គោលព្រះអាសេរ៉ាចេញពីទឹកដីហើយបានតាំងចិត្តដើម្បីស្វែងរកព្រះអម្ចាស់»។
[4]ព្រះបាទយ៉ូសាផាតគង់នៅក្រុងយេរូសាឡិម។ បន្ទាប់មក ស្តេចយាងចេញពីទៅសួរសុខទុក្ខប្រជាជន
ចាប់ពីបៀរសេបារហូតដល់ភ្នំអេប្រាអ៊ីមហើយនាំពួកគេឲ្យវិលត្រឡប់មករកព្រះអម្ចាស់ជាព្រះនៃដូនតារបស់គេវិញ។
[5]ស្តេចបានតែងតាំងចៅក្រមនៅក្នុងស្រុកពាសពេញក្រុងទាំងប៉ុន្មានដែលមានកំពែងរឹងមាំក្នុងស្រុកយូដា។
[6]ព្រះករុណាមានរាជឱង្ការទៅពួកចៅក្រមថា៖ «ចូរពិចារណានូវអ្វីដែលអស់លោកគួរធ្វើ ព្រោះអស់លោកមិនវិនិច្ឆ័យមនុស្សទេ តែសម្រាប់ព្រះអម្ចាស់
ព្រះអម្ចាស់នឹងនៅជាមួយអ្នកក្នុងការវិនិច្ឆ័យ។[7]ឥឡូវនេះសូមឲ្យការកោតខ្លាចព្រះអម្ចាស់មកលើអស់លោក សូមប្រយ័ត្នពេលណា
អស់លោកវិនិច្ឆ័យទោសព្រោះព្រះអម្ចាស់ជាព្រះរបស់យើងគ្មានអំពើទុច្ចរិតណាមួយឡើយហើយក៏គ្មានការអនុគ្រោះ ឬទទួលសំណូកឡើយ»។
[8]លើសពីនោះ នៅក្រុងយេរូសាឡិម ព្រះបាទយេហូសាផាត បានតែងតាំងពួកលេវី និងពួកបូជាចារ្យ ព្រមទាំងមេដឹកនាំខ្លះៗនៃវង្សត្រកូលអ៊ីស្រាអែល
ដើម្បីវិនិច្ឆ័យទោសចំពោះព្រះអម្ចាស់ និងដើម្បីដោះស្រាយជម្លោះ។ ពួកអ្នកទាំងនោះគេរស់នៅក្នុងក្រុងយេរូសាឡិម។[9]ព្រះករុណាមានរាជឱង្ការទៅពួកគេថា៖
«អ្នករាល់គ្នាត្រូវគោរពកោតខ្លាចព្រះអម្ចាស់យ៉ាងស្មោះអស់ពីចិត្ត។
[10]ពេលណាមានវិវាទណាមួយពីបងប្អូនរបស់អស់លោកដែលរស់នៅទីក្រុងរបស់គេទោះបីទាក់ទងនឹងរឿងឃាតកម្មទោះបីទាក់ទងនឹងច្បាប់បទបញ្ជា ឬក្រឹត្យវិន័យក៏ដោយ
អស់លោកត្រូវក្រើនរំឭកពួកគេ ដើម្បីកុំឲ្យពួកគេត្រូវមានទោសចំពោះព្រះអម្ចាស់ ឬសេចក្តីក្រោធរបស់ព្រះអម្ចាស់និងមកទាស់នឹងអស់លោក
ហើយនឹងបងប្អូនរបស់អស់លោក។ ដូច្នេះ អស់លោកត្រូវធ្វើបែបនេះ នោះអស់លោកនឹងមិនមានកំហុសទេ។
[11]មើល! លោកអ័ម៉ារីយ៉ា ជាមហាបូជាចារ្យដឹកនាំលើអ្នករាល់គ្នាក្នុងកិច្ចការទាំងអស់របស់ព្រះអម្ចាស់។
លោកសេបាឌាជាកូនរបស់លោកអ៊ីស្មាអែលជាមេដឹកនាំរបស់កុលសម្ព័ន្ធយូដា ជាអ្នកទទួលខុសត្រូវលើកិច្ចការទាំងអស់របស់ព្រះរាជា។
ពួកលេវីនឹងធ្វើជាអាជ្ញាធរសម្រាប់ជួយបម្រើការងាររបស់អ្នក។ ចូរតាំងចិត្តក្លាហាន និងគោរពតាមការណែនាំចុះ ហើយសូមឲ្យព្រះអម្ចាស់គង់ជាមួយមនុស្សល្អ»។

---

2 Chronicles 19:1
កូនរបស់ហាណានី
តើអ្នកគួរជួយមនុស្សអាក្រក់ឬ? តើអ្នកគួរស្រឡាញ់អ្នកដែលស្អប់ព្រះអម្ចាស់ឬ?
ការបកប្រែផ្សេងទៀត «អ្នកមិនគួរជួយមនុស្សអាក្រក់ទេ
អ្នកមិនគួរស្រឡាញ់អស់អ្នក ដែលស្អប់ព្រះអម្ចាស់ទេ!»
បង្គោលព្រះអាសេរ៉ា
សូមមើលការបកប្រែដូចនៅក្នុង ១៤:១។
បានតាំងចិត្ត
ការបកប្រែផ្សេងទៀត «សម្រេចចិត្តយ៉ាងម៉ឺងម៉ាត់»
2 Chronicles 19:4
នាំពួកគេឲ្យវិលត្រឡប់មករកព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «បានស្តារជំនឿលើព្រះអម្ចាស់ឡើងវិញ»
2 Chronicles 19:6
សូមឲ្យការកោតខ្លាចព្រះអម្ចាស់មកលើអស់លោក
ការបកប្រែផ្សេងទៀត «អ្នកគួរតែចងចាំថា អ្នកត្រូវតែគោរពកោតខ្លាចព្រះអម្ចាស់
ពេលអ្នកវិនិច្ឆ័យអ្វីមួយ»
2 Chronicles 19:8
ដើម្បីដោះស្រាយជម្លោះ
ការបកប្រែផ្សេងទៀត «គ្រួសារអ៊ីស្រាអែលពីបុរាណ»
ដើម្បីដោះស្រាយជម្លោះ។
ការបកប្រែផ្សេងទៀត «ដើម្បីជួយដោះស្រាយជម្លោះ»
យ៉ាងស្មោះអស់ពីចិត្ត
2 Chronicles 19:10
ឬសេចក្តីក្រោធរបស់ព្រះអម្ចាស់និងមកទាស់នឹងអស់លោក ហើយនឹងបងប្អូនរបស់អស់លោក។
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់ក្រោធនឹងអ្នក និងបងប្អូនរបស់អ្នក»
2 Chronicles 19:11
លោកអ័ម៉ារីយ៉ា
លោកសេបាឌាជាកូនរបស់លោកអ៊ីស្មាអែល

---

20 [1]ក្រោយមកទៀត ប្រជាជនម៉ូអាប់ និងអាំម៉ូន ព្រមទាំងជនជាតិម៉ាអូន ខ្លះបានលើកទ័ពមកច្បាំងនឹងព្រះបាទយ៉ូសាផាត។[2]មានអ្នកខ្លះមកទូលព្រះបាទយ៉ូសាផាតថា៖
«មានកងទ័ពយ៉ាងច្រើនកំពុងវាយលុកលើព្រះករុណាពីខាងនាយសមុទ្រស្លាប់គឺពីស្រុកអេដុម។ ពួកគេមកដល់ហាសាសូនតាម៉ារ គឺនៅអេនគេឌី»។
[3]ព្រះបាទយ៉ូសាផាតមានការភ័យខ្លាចហើយតាំងខ្លួនស្វែងរកព្រះអម្ចាស់។ ព្រះករុណាប្រកាសឲ្យតមអាហារនៅពាសពេញស្រុកយូដា។[4]ប្រជាជនយូដាបានជួបជុំគ្នា
ដើម្បីស្វែងរកព្រះអម្ចាស់។ ពួកគេមកពីគ្រប់ក្រុងទាំងអស់ក្នុងស្រុកយូដា ដើម្បីស្វែងរកព្រះអម្ចាស់។
[5]ព្រះបាទយ៉ូសាផាតឈរក្នុងអង្គប្រជុំនៃប្រជាជនយូដា និងប្រជាជនក្រុងយេរូសាឡិមនៅត្រង់ព្រះដំណាក់របស់ព្រះអម្ចាស់ទល់មុខទីធ្លាថ្មី។[6]ស្តេចមានរាជឱង្ការថា៖
«បពិត្រព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់យើងខ្ញុំ តើព្រះអង្គមិនមែនជាព្រះដែលគង់នៅស្ថានបរមសុខឬអី?
តើព្រះអង្គមិនមែនជាអ្នកគ្រប់គ្រងលើនគរទាំងប៉ុន្មាននៃប្រជាជាតិនានាទេឬ? ព្រះអង្គប្រកបដោយព្រះចេស្តា និងឫទ្ធានុភាព គ្មាននរណាអាចតទល់នឹងព្រះអង្គបាន
ឡើយ!។[7]ព្រះជាម្ចាស់អើយ តើព្រះអង្គមិនបានបណ្តេញប្រជាជនទាំងប៉ុន្មានចេញពីស្រុកនេះនៅចំពោះមុខអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ
ហើយព្រះអង្គបានប្រទានទឹកដីនេះឲ្យកូនចៅលោកអប្រាហាំរហូតតទៅឬអី?។
[8]ពួកគេបានរស់នៅក្នុងស្រុក ហើយបានសង់ទីសក្ការៈមួយថ្វាយព្រះនាមរបស់ព្រះអង្គ ដោយពោលថា៖[9]«ប្រសិនបើ គ្រោះមហន្តរាយកើតមានមកលើយើងខ្ញុំ ដូចជាដាវ
ការកាត់ទោស ជំងឺ ឬទុរ្ភិក្ស យើងនឹងឈរនៅមុខព្រះដំណាក់នេះ និងនៅចំពោះព្រះភក្ត្រព្រះអង្គ (ព្រោះព្រះនាមព្រះអង្គនៅក្នុងដំណាក់នេះ)
ហើយយើងខ្ញុំនឹងស្រែកអង្វរព្រះអង្គដោយទុក្ខវេទនារបស់យើងខ្ញុំ នោះព្រះអង្គនឹងស្តាប់យើងខ្ញុំហើយជួយសង្គ្រោះយើងខ្ញុំ»។
[10]មើល! ឥឡូវនេះ ប្រជាជននៅស្រុកអាំម៉ូន ស្រុកម៉ូអាប់
និងភ្នំសៀរដែលព្រះអង្គមិនអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលវាយលុកបំផ្លាញនៅពេលដែលពួកគេចាកចេញពីស្រុកអេស៊ីបមក ផ្ទុយទៅវិញ
ជនជាតិអ៊ីស្រាអែលបានងាកចេញពីពួកគេ ហើយមិនបានបំផ្លាញពួកគេឡើយ។[11]សូមទតមើលពីរបៀបដែលពួកគេសងដល់យើងខ្ញុំ
គឺពួកគេលើកគ្នាមកដើម្បីនឹងដេញពួកយើងខ្ញុំចេញពីទឹកដីដែលព្រះអង្គបានប្រគល់ឲ្យយើងខ្ញុំទុកជាមរតក។
[12]ឱព្រះនៃយើងខ្ញុំអើយ! តើព្រះអង្គមិនវិនិច្ឆ័យទោសពួកគេទេឬ? ដ្បិត យើងខ្ញុំគ្មានកម្លាំងនឹងតតាំងជាមួយកងទ័ពដ៏ធំដែលកំពុងលើកទ័ពមកច្បាំងនឹងយើងទេ។
យើងមិនដឹងថាត្រូវធ្វើយ៉ាងណាទេ ប៉ុន្តែយើងកំពុងសម្លឹងមើលទៅកាន់ព្រះអង្គ»។[13]ប្រជាជនយូដាទាំងអស់បានឈរនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាមួយប្រពន្ធ និងកូនៗ
របស់ពួកគេ។
[14]នៅពាក់កណ្តាលអង្គប្រជុំនោះព្រះវិញ្ញាណរបស់ព្រះអម្ចាស់មកសណ្ឋិតលើលោកយ៉ាហាសៀលជាកូនរបស់លោកសាការីត្រូវជាកូនរបស់លោកបេណាយ៉ាដែលជាកូនរបស់លោកយេអែលត្រូវជ
[15]លោកយ៉ាហាសៀលមានប្រសាសន៍ថា៖ «អ្នកស្រុកយូដាទាំងមូល និងអ្នកក្រុងយេរូសាឡិម ព្រមទាំងព្រះករុណាយ៉ូសាផាតអើយ! សូមស្តាប់
ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «កុំខ្លាចអ្វីឡើយ! កុំធ្លាក់ទឹកចិត្តដោយសារកងទ័ពដ៏ធំនេះ ដ្បិត ការប្រយុទ្ធមិនមែនស្រេចលើអ្នករាល់គ្នាទេ តែជារបស់ព្រះជាម្ចាស់វិញ។

generated on Wed Sep 10 16:16:32 2025

[16]អ្នករាល់ត្រូវចុះទៅច្បាំងនឹងពួកគេនៅថ្ងៃស្អែក។ មើល! ពួកគេកំពុងឡើងមកតាមផ្លូវស៊ីស។
អ្នករាល់គ្នានឹងឃើញពួកគេនៅចុងជ្រលងជ្រោះនៅទល់មុខនឹងទីរហោស្ថានយេរួល។[17]អ្នករាល់គ្នានឹងមិនចាំបាច់តយុទ្ធនៅក្នុងសង្គ្រាមនេះទេ។
ចូរឈរនៅជំហររបស់អ្នកហើយឃើញការសង្គ្រោះរបស់ព្រះអម្ចាស់នៅជាមួយអ្នក ស្រុកយូដា និងក្រុងយេរូសាឡិម។ កុំឲ្យខ្លាចកុំឲ្យធ្លាក់ទឹកចិត្ត។
ចូរចេញទៅច្បាំងនឹងពួកគេនៅថ្ងៃស្អែកទៅ ដ្បិត ព្រះអម្ចាស់គង់នៅជាមួយអ្នក»។
[18]ព្រះបាទយ៉ូសាផាតបានក្រាបចុះឱនមុខដល់ដី។ ប្រជាជនយូដា និងអ្នកក្រុងយេរូសាឡិមទាំងអស់នាំគ្នាក្រាបចុះថ្វាយបង្គំព្រះអម្ចាស់។
[19]ក្រុមលេវីដែលជាកូនចៅរបស់កេហាត់ និងលោកកូរ៉ាន់នាំគ្នាក្រោកឈរឡើងសរសើរតម្កើងព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលដោយបន្លឺសម្លេងខ្លាំងៗ ។
[20]ព្រលឹមឡើង ពួកគេក្រោកឡើងចេញទៅទីរហោស្ថានតកូអា។ ពេលពួកគេចេញទៅនោះ ព្រះបាទយ៉ូសាផាតក្រោកឈរឡើងហើយមានរាជឱង្ការថា៖ «ប្រជាជនយូដា
និងប្រជាជនក្រុងយេរូសាឡិមអើយ! ចូរស្តាប់ខ្ញុំ! ចូរទុកចិត្តលើព្រះអម្ចាស់ជាព្រះរបស់អ្នកចុះ នោះ ព្រះអម្ចាស់ និងជួយអ្នករាល់គ្នា។
ចូរអ្នករាល់គ្នាទុកចិត្តលើព្យាការីរបស់ព្រះអង្គ ហើយអ្នករាល់គ្នានឹងទទួលជ័យជម្នះ»។[21]នៅពេលដែលព្រះករុណាបានពិគ្រោះជាមួយប្រជាជនរួចហើយ
ព្រះអង្គបានតែងតាំងអស់អ្នកដែលត្រូវច្រៀងថ្វាយព្រះអម្ចាស់ និងសរសើរតម្កើងសិរីរុងរឿងរបស់ព្រះអង្គនៅពេលដែលពួកកងទ័ពចេញទៅដោយពោលថា៖
«អរព្រះគុណព្រះអម្ចាស់ព្រោះភាពស្មោះត្រង់នៃសម្ពន្ធមេត្រីរបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ»។
[22]នៅពេលដែលពួកគេបន្លឺសម្លេងច្រៀងសរសើរតម្កើង ព្រះអម្ចាស់បានធ្វើឲ្យមានអ្នកលបវាយប្រហារបង្កឲ្យកើតវឹកវរនៅក្នុងជួរទ័ពរបស់ជនជាតិអាំម៉ូន ជនជាតិម៉ូអាប់ និង
អ្នកស្រុកភ្នំសៀរ ជាអ្នកដែលឡើងមកច្បាំងនឹងជនជាតិយូដា។ ពួកគេត្រូវបរាជ័យ។[23]ជនជាតិអាំម៉ូន និងម៉ូអាប់ក្រោកឡើងព្រួតគ្នាច្បាំងនឹងប្រជាជននៅភ្នំសៀរ
ដើម្បីសម្លាប់ ហើយបំផ្លាញពួកគេ។ នៅពេលដែលពួកគេបានសម្លាប់ប្រជាជននៅភ្នំសៀររួចហើយពួកគេទាំងអស់គ្នាចាប់តាំងសម្លាប់គ្នាទៅវិញទៅមក។
[24]នៅពេលដែលកងទ័ពយូដាបានមកដល់កន្លែងពិនិត្យមើលទីរហោស្ថានពួកគេបានក្រឡេកមើលកងទ័ព។ មើលចុះ ពួកគេបានស្លាប់ហើយដួលទៅនឹងដី។
គ្មាននរណាម្នាក់បានរួចខ្លួនឡើយ។
[25]នៅពេលព្រះបាទយ៉ូសាផាត និងប្រជាជនរបស់ព្រះករុណា នាំគ្នារឹបអូសយកអ្វីៗទាំងប៉ុន្មានដែលមាននៅទីនោះ។ គេឃើញមានរបស់របរ សម្លៀកបំពាក់ ព្រមទាំងវត្ថុដ៏
មានតម្លៃជាច្រើនដែលលើសពីអ្វីដែលពួកគេអាចយករួចសម្រាប់ខ្លួនឯង។ ដោយជយភណ្ឌទាំងនោះមានច្រើនពេក ពួកគេត្រូវចំណាយពេលអស់បីថ្ងៃ
ដើម្បីប្រមូលជយភណ្ឌទាំងនោះ។[26]នៅថ្ងៃទីបួនពួកគេបានជួបជុំគ្នានៅជ្រលងភ្នំបេរ៉ាកា។ នៅទីនោះគេសរសើរតម្កើងព្រះអម្ចាស់ ហេតុនេះហើយ
បានជាគេហៅកន្លែងនោះថាជ្រលងភ្នំបេរ៉ាកា រហូតដល់សព្វថ្ងៃ។
[27]បន្ទាប់មក ប្រជាជនយូដា និងអ្នកក្រុងយេរូសាឡិមទាំងអស់ ដោយមានព្រះបាទយ៉ូសាផាតជាអ្នកយាងនាំមុខគេ វិលត្រឡប់ទៅក្រុងយេរូសាឡិមវិញដោយអំណរ
ព្រោះព្រះអម្ចាស់បានធ្វើឲ្យគេមានជ័យជម្នះលើខ្មាំងសត្រូវ។[28]ជនជាតិអ៊ីស្រាអែលនាំគ្នាមកក្រុងយេរូសាឡិម និងក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ដោយកាន់ស៊ុង
ពិណនិងត្រែ។
[29]ព្រះអម្ចាស់បានធ្វើឲ្យនគរនៃប្រជាជាតិផ្សេងៗមានការភ័យខ្លាំងជាខ្លាំង ពេលគេឮនិយាយថា ព្រះអម្ចាស់បានច្បាំងនឹងខ្មាំងសត្រូវរបស់ជនជាតិអ៊ីស្រាអែល។
[30]ដូច្នេះហើយ បានជារាជ្យរបស់ព្រះបាទយ៉ូសាផាតមានសន្តិភាព ពីព្រោះព្រះជាម្ចាស់ជាព្រះរបស់ព្រះករុណាបានប្រទានសេចក្តីសុខសាន្តដល់ព្រះករុណាគ្រប់ទិសទី។
[31]ព្រះបាទយ៉ូសាផាតឡើងសោយរាជ្យលើស្រុកយូដា៖ ស្តេចឡើងគ្រងរាជ្យក្នុងព្រះជន្មាយុសាមសិបប្រាំព្រះវស្សា
ហើយសោយរាជ្យនៅក្រុងយេរូសាឡិមអស់រយៈពេលម្ភៃប្រាំឆ្នាំ។ ព្រះមាតារបស់ ព្រះករុណាមានព្រះនាមថាអាស៊ូបា ជាកូនស្រីរបស់លោកស៊ីលហ៊ី។
[32]ស្តេចបានដើរតាមមាគ៌ារបស់ព្រះបាទអេសាជាបិតា ដោយឥតងាករេចេញឡើយ ស្តេចបានធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។[33]ទោះយ៉ាងណាកន្លែងខ្ពស់ៗ
នៅតែមានដោយមិនត្រូវបានគេបំផ្លាញចេញឡើយ។ ប្រជាជនមិនបានតម្រង់ដួងចិត្តរបស់ពួកគេចំពោះព្រះនៃដូនតារបស់ពួកគេឡើយ។
[34]រាជកិច្ចផ្សេងៗរបស់ព្រះបាទយ៉ូសាផាតតាំងពីដើមដល់ចាប់ សុទ្ធតែមានកត់ទុកក្នុងសៀវភៅរបស់លោកយេហ៊ូ
ជាកូនរបស់លោកហាណានីដែលបានកត់ទុកក្នុងសៀវភៅរបស់ស្តេចស្រុកអ៊ីស្រាអែល។
[35]បន្ទាប់មក ព្រះបាទយ៉ូសាផាតជាស្តេចស្រុកយូដាបានចងសម្ព័ន្ធភាពជាមួយព្រះបាទអហាស៊ីយ៉ាជាស្តេចស្រុកអ៊ីស្រាអែលដែលប្រព្រឹត្តអំពើអាក្រក់ជាច្រើន។
[36]ស្តេចបានចងសម្ពន្ធមិត្ត ដើម្បីសង់ទូកទៅក្រុងតើស៊ីស។ ពួកគេបានសាងសង់ទូកនៅឯអេសូនគេបើរ។[37]ពេលនោះលោកអេលាស៊ើរជាកូនរបស់លោកឌូដាវ៉ាហូ
មកពីក្រុងម៉ារេសាបានទាយទាស់នឹងព្រះបាទយ៉ូសាផាត។ លោកមានប្រសាសន៍ថា៖
«ដោយព្រះករុណាបានចងសម្ព័ន្ធភាពជាមួយព្រះបាទអហាស៊ីយ៉ាព្រះអម្ចាស់បានបំផ្លាញគម្រោងការរបស់ព្រះករុណាហើយ»។ កប៉ាល់ទាំងនោះត្រូវបានខូចខាត ដូច្នេះ
ពួកគេមិនអាចបើកបរទៅបានទេ។

---

2 Chronicles 20:1
ជនជាតិម៉ាអូន
នេះជាក្រុមមនុស្ស ដែលប្រហែលជារស់នៅជិតអេដុមខាងកើតទន្លេយ័រដាន់។
ហាសាសូនតាម៉ារ
នេះជាឈ្មោះមួយទៀតសម្រាប់អេងគេឌី។
2 Chronicles 20:3
តាំងខ្លួន
ការបកប្រែផ្សេងទៀត «បានតាំងចិត្ត»
ស្វែងរកព្រះអម្ចាស់
ការបកប្រែផ្សេងទៀត
«ព្យាយាមធ្វើឲ្យព្រះជាម្ចាស់យកព្រះទ័យទុកដាក់ដល់ពួកគេ»
2 Chronicles 20:5
តើព្រះអង្គមិនមែនជាព្រះដែលគង់នៅស្ថានបរមសុខឬអី?
តើព្រះអង្គមិនមែនជាអ្នកគ្រប់គ្រងលើនគរទាំងប៉ុន្មាននៃប្រជាជាតិនានាទេឬ?
ការបកប្រែផ្សេងទៀត «ព្រះអង្គពិតជាព្រះជាម្ចាស់គង់នៅស្ថានសួគ៌
ហើយជាអ្នកគ្រប់គ្រងលើស្តេចទាំងអស់នៅលើផែនដី។»
ប្រកបដោយព្រះចេស្តា និងឫទ្ធានុភាព
ពាក្យថា «ព្រះចេស្តា» និង «ឫទ្ធានុភាព» មានន័យជាមូលដ្ឋានដូចគ្នា
និងបញ្ជាក់ពីភាពអស្ចារ្យនៃឫទ្ធានុភាពរបស់ព្រះអម្ចាស់។ ពាក្យថា «ដៃ»
សំដៅទៅលើកម្មសិទ្ធិ។ ការបកប្រែផ្សេងទៀត «អ្នកមានឫទ្ធានុភាពដ៏អស្ចារ្យ»។
តើព្រះអង្គមិនបានបណ្តេញប្រជាជនទាំងប៉ុន្មានចេញពីស្រុកនេះនៅចំពោះមុខអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ
ហើយព្រះអង្គបានប្រទានទឹកដីនេះឲ្យកូនចៅលោកអប្រាហាំរហូតតទៅឬអី?។
ការបកប្រែផ្សេងទៀត
«គឺព្រះអង្គដែលបានបណ្តេញពួកអ្នកដែលរស់នៅលើទឹកដីនេះ
ដើម្បីជាប្រយោជន៍ដល់អ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ
ហើយបានប្រគល់ទឹកដីនោះជារៀងរហូតដល់កូនចៅរបស់លោកអប្រាហាំ។»
2 Chronicles 20:8
ព្រះនាមព្រះអង្គនៅក្នុងដំណាក់នេះ
ការបកប្រែផ្សេងទៀត «វត្តមានរបស់ព្រះអង្គនៅទីនេះ នៅក្នុងដំណាក់នេះ»
2 Chronicles 20:10
ភ្នំសៀរ
នេះជាកន្លែងដែលពួកអាំម៉ូនបានរស់នៅ
សូមទតមើលពីរបៀបដែលពួកគេសងដល់យើងខ្ញុំ
គឺពួកគេលើកគ្នាមកដើម្បីនឹងដេញពួកយើងខ្ញុំចេញពីទឹកដី
ការបកប្រែផ្សេងទៀត «នេះជារបៀបដែលពួកគេបានតបស្នងមកយើង
ចំពោះសេចក្តីមេត្តាករុណា ដែលយើងបានបង្ហាញដល់ពួកគេ
ពួកគេកំពុងដើម្បីបណ្តេញយើងចេញពីទឹកដីរបស់ព្រះអង្គ។» សូមមើល
2 Chronicles 20:12
តើព្រះអង្គមិនវិនិច្ឆ័យទោសពួកគេទេឬ?
ការបកប្រែផ្សេងទៀត «សូមវិនិច្ឆ័យពួកគេ។»
សម្លឹងមើលទៅកាន់ព្រះអង្គ
ការបកប្រែផ្សេងទៀត «យើងកំពុងស្វែងរកព្រះអង្គ សុំជំនួយ»

generated on Wed Sep 10 16:16:32 2025

2 Chronicles 20:14
ព្រះវិញ្ញាណរបស់ព្រះអម្ចាស់មកសណ្ឋិតលើ
សូមមើលការបកប្រែដូចនៅក្នុង ១៥:១
លោកយ៉ាហាសៀល ... លោកសាការី ... លោកបេណាយ៉ា ... លោកយេអែល ...
លោកម៉ាថានីយ៉ា ... លោកអេសាភ
ឈ្មោះរបស់មនុស្សប្រុស។
2 Chronicles 20:16
ចុះទៅច្បាំង
ការបកប្រែផ្សេងទៀត «ទៅ» ឬ «ទៅប្រយុទ្ធ»
មកតាមផ្លូវស៊ីស
នេះជាជ្រលងភ្នំតូចមួយនៅចន្លោះភ្នំពីរនៅភាគខាងត្បូងក្រុងយេរូសាឡឹម។
ការសង្គ្រោះរបស់ព្រះអម្ចាស់
ព្រះជាម្ចាស់នឹងប្រយុទ្ធក្នុងសមរភូមិ និងជួយសង្គ្រោះប្រជារាស្ត្រ
2 Chronicles 20:18
ប្រជាជនយូដា
ការបកប្រែផ្សេងទៀត «ប្រជាជនយូដាទាំងអស់»
កូនចៅរបស់កេហាត់ និងលោកកូរ៉ា
2 Chronicles 20:20
ទីរហោស្ថានតូអា
នេះជាក្រុងមួយនៅខាងត្បូងក្រុងយេរូសាឡឹម
និងជួយអ្នករាល់គ្នា។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងជួយអ្នក»
ចូរអ្នករាល់គ្នាទុកចិត្តលើព្យាការីរបស់ព្រះអង្គ ហើយអ្នករាល់គ្នានឹងទទួលជ័យជម្នះ។
ការបកប្រែផ្សេងទៀត «បើអ្នកទុកចិត្តលើព្យាការីរបស់ព្រះអម្ចាស់
នោះអ្នកនឹងទទួលបានជោគជ័យ»
2 Chronicles 20:22
ភ្នំសៀរ
សូមមើលការបកប្រែដូចនៅក្នុង ២០:១០
បានធ្វើឲ្យមានអ្នកលបវាយប្រហារ
ការបកប្រែផ្សេងទៀត «រៀបចំវាយប្រហារគួរឲ្យភ្ញាក់ផ្អើល»
ដើម្បីសម្លាប់ ហើយបំផ្លាញពួកគេ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ឃ្លាទីពីរធ្វើឲ្យទីមួយកាន់តែតានតឹង។
ការបកប្រែផ្សេងទៀត «បីបំផ្លាញពួកវាទាំងស្រុង។»
2 Chronicles 20:24
មើលចុះ ពួកគេបានស្លាប់ហើយ
នេះជាការភ្ញាក់ផ្អើលមួយ។ សត្រូវរបស់ពួកគេបានបំផ្លាញគ្នាទៅវិញទៅមក។
ពួកគេបានស្លាប់ហើយដួលទៅនឹងដី។
ឃ្លាថា «ដួលទៅនឹងដី» ជាវិធីមួយដែលនិយាយថា « ពួកគេបានស្លាប់ហើយ។»
ការបកប្រែផ្សេងទៀត «ពួកគេទាំងអស់បានស្លាប់នៅលើដី។»
2 Chronicles 20:25
រហូតដល់សព្វថ្ងៃ
សូមមើលការបកប្រែនេះនៅក្នុង ៥:៩
2 Chronicles 20:27
ប្រជាជនយូដា និងអ្នកក្រុងយេរូសាឡឹមទាំងអស់
នេះជាការអះអាងប្រាប់ដល់ទាហានប្រយុទ្ធគ្រប់ៗគ្នា (សូមមើល
ព្រះបាទយ៉ូសាផាតជាអ្នកយាងនាំមុខគេ
ស្តេចយ៉ូសាផាតស្ថិតនៅខាងមុខកងទ័ពទាំងមូល
នៅពេលពួកគេវិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញ។
2 Chronicles 20:29
ព្រះអម្ចាស់បានធ្វើឲ្យនគរនៃប្រជាជាតិផ្សេងៗមានការភ័យខ្លាំងជាខ្លាំង
«ស្តេចទាំងប៉ុន្មានរបស់ប្រជាជាតិនានា កោតខ្លាចព្រះជាម្ចាស់យ៉ាងខ្លាំង»
នគរ
សំដៅទៅលើរដ្ឋាភិបាល ដែលមានអ្នកគ្រប់គ្រងតែមួយ។
2 Chronicles 20:31
អាស៊ូបា ជាកូនស្រីរបស់លោកស៊ីលហ៊ី។
បានដើរតាមមាគ៌ា
ការបកប្រែផ្សេងទៀត «បានធ្វើតាមគំរូរបស់បិតាទ្រង់»
ស្តេចបានធ្វើអ្វីដែលគាប់ព្រះហឫទ័យ
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
2 Chronicles 20:34
កូនរបស់លោកហាណានី
សៀវភៅរបស់ស្តេចស្រុកអ៊ីស្រាអែល។
សូមមើលការបកប្រែដូចនៅ ១៦:១១
2 Chronicles 20:35
ទូក
ទាំងនេះជាទូកដែលមានសមត្ថភាពធ្វើដំណើរ លើទឹកជ្រៅបាន។
អេសូនគេបើរ
សូមមើលការបកប្រែដូចនៅក្នុង ៨:១៧។
ក្រុងម៉ារេសា
សូមមើលការបកប្រែដូចនៅក្នុង ១១:៥។
លោកអេលាស៊ើរ
សូមមើលការបកប្រែឈ្មោះដូចបុរសម្នាក់ទៀតនៅក្នុង ៧:៨។
លោកឌូដាវ៉ាហូ
ឈ្មោះរបស់មនុស្សប្រុស

21

[1]ព្រះបាទយ៉ូសាផាតបានផ្ទំលក់ជាមួយបុព្វបុរសរបស់ស្តេចហើយគេបញ្ចុះសពស្តេចនៅក្រុងព្រះបាទដាវីឌ ព្រះបាទយ៉ូរ៉ាមជាបុត្របានឡើងស្នងរាជ្យ។
[2]ព្រះបាទយ៉ូរ៉ាមមានព្រះអនុជ ដែលត្រូវជាបុត្រព្រះបាទយ៉ូសាផាត គឺអសារា យេហ៊ីអែល សាការី អ័សារា មីកែល និងសេផាធា។
អ្នកទាំងនេះសុទ្ធតែជាបុត្រារបស់ព្រះបាទយ៉ូសាផាតស្តេចស្រុកអ៊ីស្រាអែល។[3]ព្រះបិតារបស់ពួកគេបានប្រគល់មាសប្រាក់
និងរបស់មានតម្លៃជាច្រើនដល់ពួកគេហើយថែមទាំងក្រុងដែលមានកំពែងរឹងមាំនៅស្រុកយូដាទៀតផង។ ប៉ុន្តែ រាជបល្ល័ង្កបានប្រគល់ទៅព្រះបាទយ៉ូរ៉ាម
ព្រោះព្រះករុណាជាបុត្រច្បង។
[4]កាលព្រះបាទយ៉ូរ៉ាមឡើងស្នងរាជ្យជំនួសបិតា ហើយពង្រឹងអំណាចជាស្តេចបានហើយ
នោះស្តេចបានសម្លាប់ព្រះអនុជទាំងអស់ដោយមុខដាវនិងមេដឹកនាំអ៊ីស្រាអែលជាច្រើនរូបទៀត។[5]ព្រះបាទយ៉ូរ៉ាមមានព្រះជន្មសាមសិបពីរឆ្នាំពេលឡើងសោយរាជ្យ
ហើយសោយរាជ្យបានប្រាំបីឆ្នាំនៅក្រុងយេរូសាឡិម។
[6]ស្តេចបានដើរតាមមាគ៌ារបស់ស្តេចស្រុកអ៊ីស្រាអែលដូចជាស្តេចអហាប់ដែរ ព្រោះព្រះករុណាបានរៀបភិសេកជាមួយបុត្រីរបស់ព្រះបាទអហាប់
ហើយប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់។[7]ទោះបីយ៉ាងណាក៏ដោយក៏ព្រះអម្ចាស់មិនសព្វព្រះហឫទ័យបំផ្លាញដំណាក់របស់ព្រះបាទដាវីឌដែរ
ព្រោះតែសម្ពន្ធមេត្រីដែលព្រះអង្គបានចងជាមួយព្រះបាទដាវីឌ។ ព្រះអម្ចាស់បានសន្យាថា ទ្រង់នឹងផ្តល់ជីវិតដល់ព្រះបាទដាវីឌ និងពូជពង្សទ្រង់ជានិច្ច។
[8]ក្នុងរាជ្យកាលព្រះបាទយ៉ូរ៉ាម ពួកអេដុមបានបះបោរពីការគ្រប់គ្រងរបស់ជនជាតិយូដា ហើយពួកគេបានតែងតាំងស្តេចមួយអង្គឲ្យគ្រងរាជ្យលើគេ។
[9]ព្រះបាទយ៉ូរ៉ាមឆ្លងទន្លេជាមួយមេទ័ព និងរទេះចម្បាំងទាំងអស់។ នៅពេលយប់ទ្រង់តើនឡើងប្រយុទ្ធនឹងជនជាតិអេដុមដែលឡោមព័ទ្ធទ្រង់
និងមេបញ្ជាការកងរទេះចម្បាំងរបស់ព្រះករុណា។[10]ដូច្នេះ ជនជាតិអេដុមបានបះបោរចេញពីការគ្រប់គ្រងរបស់យូដាចាប់តាំងពីពេលនោះមកទល់សព្វថ្ងៃ។
ក្រុងលីបណាក៏បានបះបោរប្រឆាំងនឹងអំណាចរបស់ស្តេចដែរ ព្រោះព្រះបាទយ៉ូរ៉ាមបានបោះបង់ចោលព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ខ្លួន។
[11]លើសពីនេះទៅទៀតព្រះបាទយ៉ូរ៉ាមក៏បានសង់កន្លែងខ្ពស់ៗនៅលើភ្នំនៃស្រុកយូដាដែរ ស្តេចបានធ្វើឲ្យអ្នកក្រុងយេរូសាឡិមរស់នៅដូចស្ត្រីពេស្យា
ហើយនាំពួកគេឲ្យបែរចេញពីព្រះជាម្ចាស់។
[12]សំបុត្ររបស់ព្យាការីអេលីយ៉ាបានមកដល់ព្រះបាទយ៉ូរ៉ាមទូលថា៖ «នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះរបស់ព្រះបាទដាវីឌ ជាបុព្វបុរសរបស់ព្រះករុណា ដ្បិត
ព្រះករុណាមិនបានដើរតាមមាគ៌ារបស់ព្រះបាទយ៉ូសាផាត ជាបិតារបស់ព្រះករុណា ហើយក៏មិនដើរតាមមាគ៌ារបស់ព្រះបាទអេសាស្តេចស្រុកយូដាដែរ»[13]ប៉ុន្តែ

generated on Wed Sep 10 16:16:32 2025

បានដើរតាមផ្លូវស្តេចស្រុកអ៊ីស្រាអែលបានធ្វើឲ្យប្រជាជនយូដា និងអ្នកក្រុងយេរូសាឡិមធ្វើអំពើពេស្យាចារដូចព្រះបាទអហាប់ដែរ
ហើយបានសម្លាប់បងប្អូនរបស់អ្នកនៅក្នុងគ្រួសារឪពុករបស់អ្នកដោយមុខដាវគឺជាអ្នកដែលពូកែជាងខ្លួន[14]មើល! ព្រះអម្ចាស់នឹងធ្វើឲ្យប្រជាជនរបស់អ្នកកូនប្រពន្ធ
និងអ្នករាល់គ្នាមានជំងឺអាសន្នរោគយ៉ាងច្រើន។
[15]អ្នកនឹងមានជំងឺជាច្រើនដោយរោគាក្នុងពោះវៀនអ្នករហូតដល់ពោះវៀនធ្លាក់ចេញដោយសារជំងឺនេះពីមួយថ្ងៃទៅមួយថ្ងៃ។
[16]ព្រះអម្ចាស់បានទាស់នឹងព្រះបាទយ៉ូរ៉ាមដោយបានធ្វើឲ្យប្រជារាស្ត្ររបស់ស្តេចភីលីស្ទីន និងជនជាតិអារ៉ាប់ដែលនៅក្បែរ ជនជាតិអេត្យូពី។[17]ពួកគេវាយលុកស្រុកយូដា
ហើយឈ្លានស្រុកយូដាព្រមទាំងរឹបអូសយកទ្រព្យសម្បត្តិទាំងអស់ដែលមាននៅក្នុងដំណាក់ស្តេច។ ពួកគេក៏បាននាំកូនប្រុសៗ និងមហេសីរបស់ស្តេចទៅជាមួយដែរ។
គ្មានកូនប្រុសណាម្នាក់ត្រូវបានទុកឲ្យនៅឡើយលើកលែងតែសម្តេចសម្តេចអហាស៊ីយ៉ា ជាបុត្រាពៅរបស់ព្រះករុណាប៉ុណ្ណោះ។
[18]បន្ទាប់មក ព្រះជាម្ចាស់បានវាយប្រហារស្តេច ដោយសារជំងឺពោះវៀន ដែលពុំអាចមើលជានោះ[19]លុះដល់ពេលកំណត់
ពីរឆ្នាំកន្លងផុតទៅពោះវៀនរបស់ស្តេចបានធ្លាក់ចេញដោយសារជំងឺហើយស្តេចបានសុគតដោយសារជំងឺយ៉ាងធ្ងន់ធ្ងរ។
ប្រជារាស្ត្ររបស់ព្រះអង្គពុំបានបូជាព្រះភ្លើងថ្វាយកិត្តិយសដល់ព្រះអង្គដូចជាបានធ្វើចំពោះបុព្វបុរសរបស់ស្តេចឡើយ។
[20]ស្តេចបានឡើងសោយរាជ្យនៅអាយុសាមសិបពីរព្រះវស្សា។ ស្តេចសោយរាជ្យនៅក្រុងយេរូសាឡិមអស់រយៈពេលប្រាំបីព្រះវស្សា។
ពេលស្តេចសោយទិវង្គតគ្មានអ្នកណាកាន់ទុក្ខឡើយ។ គេបញ្ចុះសពស្តេចនៅក្រុងព្រះបាទដាវីឌ តែមិនបញ្ចុះក្នុងផ្នូររបស់ស្តេចទេ។

---

2 Chronicles 21:1
បានផ្ចិលក់ជាមួយបុព្វបុរសរបស់ស្តេច
ការបកប្រែផ្សេងទៀត «បានសុគត»
ក្រុងព្រះបាទដាវីឌ
នេះជាទីក្រុងយេរូសាឡឹម។
អសារ យេហ៊ីអែល សាការី អ័សារ មីកែល និងសេផាធា
ព្រះបាទយ៉ូសាផាតស្តេចស្រុកអ៊ីស្រាអែល។
គេហៅរាជាណាចក្រខាងត្បូងជាផ្លូវការថា «យូដា»
ប៉ុន្តែអ្នកនិពន្ធកណ្ឌនេះជាក់ស្តែងចង់បញ្ជាក់ថា
រាជាណាចក្រខាងត្បូងស្ថិតនៅក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់
ជាព្រះពិតរបស់អ៊ីស្រាអែល។
រាជបល្ល័ង្កបានប្រគល់ទៅ
ព្រះបាទយ៉ូសាផាតបានសម្រេចព្រះទ័យថា ព្រះបាទយ៉ូរ៉ាមគួរតែគ្រងរាជ្យជាស្តេច
ក្រោយពីព្រះអង្គបានសុគត
2 Chronicles 21:4
ឡើងស្នងរាជ្យជំនួសបិតា
ការបកប្រែផ្សេងទៀត
«បានគ្រប់គ្រងលើរាជាណាចក្ររបស់បិតាព្រះអង្គទាំងស្រុង»
2 Chronicles 21:6
បានដើរតាមមាគ៌ារបស់ស្តេច
សូមមើលការបកប្រែដូចនៅក្នុង ២០:៣១
គាប់ព្រះហឫទ័យព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «ស្របទៅតាមព្រះអម្ចាស់»
ព្រះអម្ចាស់បានសន្យាថា ទ្រង់នឹងផ្តល់ជីវិតដល់ព្រះបាទដាវីឌ និងពូជពង្សទ្រង់ជានិច្ច។
ការបកប្រែផ្សេងទៀត «ព្រះជាម្ចាស់បានសន្យាថា
កូនចៅរបស់ព្រះបាទដាវីឌនឹងមានអ្នកគ្រប់គ្រងស្រុកយូដាជានិច្ច»។
2 Chronicles 21:8
ក្នុងរាជ្ជកាលព្រះបាទយ៉ូរ៉ាម
ការបកប្រែផ្សេងទៀត «ពេលព្រះបាទយ៉ូរ៉ាមសោយរាជ្យជាស្តេច»
ការគ្រប់គ្រងរបស់ជនជាតិយូដា
«ប្រឆាំងនឹងការគ្រប់គ្រងរបស់យូដា»
ឆ្លងទន្លេ
«បានឆ្លងកាត់ព្រំដែនចូលស្រុកអេដុម»
ពេលនោះមកទល់សព្វថ្ងៃ។
សូមមើលការបកប្រែដូចនៅក្នុង ៥:៩
ក្រុងលីបណា
នេះជាក្រុងមួយនៅស្រុកយូដា។
2 Chronicles 21:12
រហូតដល់ពោះវៀនធ្លាក់ចេញដោយសារជំងឺនេះ
ការបកប្រែផ្សេងទៀត «រហូតដល់ជំងឺនេះបណ្តាលឲ្យអ្នកស្លាប់»
2 Chronicles 21:16
បានទាស់នឹងព្រះបាទយ៉ូរ៉ាមដោយបានធ្វើឲ្យប្រជារាស្ត្ររបស់ស្តេចភីលីស្ទីន និងជនជាតិអារ៉ាប់
ការបកប្រែផ្សេងទៀត «បានធ្វើឲ្យជនជាតិភីលីស្ទីន
និងជនជាតិអារ៉ាប់ត្រឡប់ជាខឹងនឹងពួកយូដាយ៉ាងខ្លាំង»
2 Chronicles 21:18
បានទាស់នឹងព្រះបាទយ៉ូរ៉ាមដោយបានធ្វើឲ្យប្រជារាស្ត្ររបស់ស្តេចភីលីស្ទីន និងជនជាតិអារ៉ាប់
ការបកប្រែផ្សេងទៀត «ធ្វើឲ្យស្តេចមានជំងឺពោះវៀន ដែលមិនអាចព្យាបាលបាន»
លុះដល់ពេលកំណត់
ការបកប្រែផ្សេងទៀត «ក្នុងពេលវេលាសមស្រប» ឬ «ពេលត្រឹមត្រូវ» សូមមើល
បានបូជាព្រះភ្លើងថ្វាយកិត្តិយសដល់ព្រះអង្គ
ការបកប្រែផ្សេងទៀត «មិនបានផ្តល់កិត្តិយសដល់ស្តេចតាមរយៈការថ្វាយភ្លើង»
គ្មានអ្នកណាកាន់ទុក្ខ
ការបកប្រែផ្សេងទៀត «ដោយគ្មានទុក្ខក្រៀមក្រំ»

22

[1]ប្រជាជននៅក្រុងយេរូសាឡិមបានតែងតាំងព្រះបាទអហាស៊ីយ៉ា ជាបុត្រាពៅរបស់ព្រះបាទយ៉ូរ៉ាមឡើងស្នងរាជ្យ
ព្រោះក្រុមមនុស្សដែលមកជាមួយជនជាតិអារ៉ាប់ចូលក្នុងជំរំបានសម្លាប់កូនប្រុសច្បងទាំងអស់របស់ស្តេច។ ដូច្នេះ ព្រះបាទអហាស៊ីយ៉ាជាបុត្ររបស់ព្រះបាទយ៉ូរ៉ាម
និងជាស្តេចស្រុកយូដាបានឡើងស្នងរាជ្យ។[2]កាលព្រះបាទអហាស៊ីយ៉ាឡើងសោយរាជ្យស្តេចមានជន្មាយុសែសិបពីរឆ្នាំព្រះវស្សា។
ស្តេចសោយរាជ្យបានមួយព្រះវស្សានៅក្រុងយេរូសាឡិម។ មាតារបស់ស្តេចមានព្រះនាមថាអថាលា។ ព្រះនាងជាបុត្រីរបស់ព្រះបាទអូមរី។
[3]ស្តេចក៏ដើរតាមមាគ៌ារបស់ស្តេចអហាប់ ដោយព្រោះមានមាតាធ្វើជាអ្នកប្រឹក្សាយោបល់ក្នុងអំពើអាក្រក់។
[4]ព្រះបាទអហាស៊ីយ៉ាប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់ដូចដំណាក់របស់ស្តេចអហាប់ដែរ ព្រោះពួកគេជាអ្នកប្រឹក្សាយោបល់របស់ស្តេច
បន្ទាប់ពីព្រះបិតារបស់ទ្រង់សោយទិវង្គតទៅ។[5]ព្រះអង្គក៏ធ្វើតាមដំបូន្មានរបស់ពួកគេដែរ
ព្រះករុណាបានយាងទៅជាមួយព្រះបាទយ៉ូរ៉ាមជាបុត្ររបស់ព្រះបាទអហាប់ជាស្តេចស្រុកអ៊ីស្រាអែលដើម្បីច្បាំងនឹងព្រះបាទហាសែលជាស្តេចស្រុកស៊ីរីនៅរ៉ាម៉ូតកាឡាដ។
ជនជាតិស៊ីរីបានធ្វើឲ្យព្រះបាទយ៉ូរ៉ាមរងរបួស។
[6]ព្រះបាទយ៉ូរ៉ាមបានត្រឡប់មកព្យាបាលរបួស នៅក្រុងយេសរាល ដ្បិត ស្តេចរងរបួសនៅក្រុងរ៉ាម៉ា
ពេលដែលស្តេចឡើងទៅច្បាំងជាមួយព្រះបាទហាសែលជាស្តេចស្រុកស៊ីរី។ ព្រះបាទអហាស៊ីយ៉ាជាបុត្រព្រះបាទយ៉ូរ៉ាម
ជាស្តេចស្រុកយូដាបានយាងមកយេសរាលដើម្បីសួរសុខទុក្ខព្រះបាទយ៉ូរ៉ាមជាបុត្រព្រះបាទអហាប់ ព្រោះស្តេចកំពុងរងរបួសជាខ្លាំង។
[7]ពេលវេលានៃការកាត់ទោសព្រះបាទអហាស៊ីយ៉ាបានមកដល់ គឺនៅពេលដែលព្រះអម្ចាស់បានបណ្តាលឲ្យព្រះបាទអហាស៊ីយ៉ាចុះទៅសួរសុខទុក្ខព្រះបាទយ៉ូរ៉ាម។
ពេលទៅដល់ហើយស្តេចបានទៅជាមួយព្រះបាទយ៉ូរ៉ាមវាយលោកយេហ៊ូជាកូនរបស់លោកនីមស៊ីដែលព្រះអម្ចាស់បានជ្រើសរើសឲ្យបំផ្លាញរាជវង្សរបស់ព្រះបាទអហាប់។
[8]ពេលដែលលោកយេហ៊ូនាំការកាត់ទោសរបស់ព្រះអម្ចាស់មកលើរាជវង្សរបស់ព្រះបាទអហាប់ គាត់បានរកឃើញពួកអ្នកដឹកនាំសាសន៍យូដា
កូនប្រុសៗរបស់ញាតិវង្សព្រះបាទអហាស៊ីយ៉ា ដែលកំពុងធ្វើការបម្រើព្រះបាទអហាស៊ីយ៉ា។ លោកយេហ៊ូបានសម្លាប់ពួកគេទាំងអស់ចោល។

generated on Wed Sep 10 16:16:32 2025

[9]លោកយេហ៊ូវស្វែងរកព្រះបាទអហាស៊ីយ៉ា ហើយពួកគេចាប់ព្រះករុណាបាននៅឯក្រុងសាម៉ារី ព្រមទាំងនាំទៅដល់លោកយេហ៊ូវហើយសម្លាប់ចោល។
គេបានបញ្ចុះសពស្តេច ដ្បិត គេពោលថា៖ «ទ្រង់ជាបុត្ររបស់ព្រះបាទយ៉ូសាផាតដែលស្វែងរកព្រះអម្ចាស់អស់ពីចិត្ត»។ ដូច្នេះ
រាជវង្សរបស់ព្រះបាទអហាស៊ីយ៉ាគ្មានអំណាចគ្រប់គ្រងនគរទៀតទេ។
[10]ពេលព្រះនាងអថាលា ជាមាតារបស់ព្រះបាទអហាស៊ីយ៉ាជ្រាបថាបុត្ររបស់នាងសោយទិវង្គត ដូច្នេះ
នាងក៏ក្រោកឡើងសម្លាប់រាជបុត្រទាំងអស់នៅក្នុងរាជវង្សយូដាចោល។[11]ប៉ុន្តែ
ព្រះនាងយេហូសាបាជាបុត្រីរបស់ស្តេចបានយកព្រះបាទយ៉ូអាសជាបុត្ររបស់ព្រះបាទអហាស៊ីយ៉ាហើយរត់ចេញពីក្នុងចំណោមបុត្ររបស់ស្តេចដែលត្រូវគេសម្លាប់។
ព្រះនាងបាននាំបុត្រនោះ ព្រមទាំងមេដោះទៅលាក់នៅបន្ទប់ដេកមួយ។ ដ្បិត ម្ចាស់ក្សត្រីយ៍យេហូសាបា ជាបុត្រីរបស់ព្រះបាទយ៉ូរ៉ាម ហើយត្រូវជាភរិយារបស់លោក
បូជាចារ្យយេហូយ៉ាដា (ព្រះនាងជាអនុជរបស់ព្រះបាទអហាស៊ីយ៉ា) បានលាក់រាជកុមារ ពីព្រះនាងអថាលា ដើម្បីកុំឲ្យព្រះនាងអថាលាសម្លាប់រាជកុមារ។
[12]ព្រះរាជកុមារបានលាក់ខ្លួននៅក្នុងព្រះដំណាក់នៃព្រះអម្ចាស់ជាមួយពួកគេអស់រយៈពេលប្រាំមួយឆ្នាំ កំឡុងពេលដែលម្ចាស់ក្សត្រីអថាលាសោយរាជ្យលើស្រុកយូដា។

---

2 Chronicles 22:1
អថាលា
ស្តេចក៏ដើរតាមមាគ៌ា
សូមមើលការបកប្រែដូចនៅក្នុង ២០:៣១
2 Chronicles 22:4
គាប់ព្រះហឫទ័យព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «តាមព្រះតម្រិះរបស់ព្រះអម្ចាស់»
ព្រះបាទអហាស៊ែល
2 Chronicles 22:7
លោកនីមស៊ី
2 Chronicles 22:10
ព្រះនាងយេហូសាបា ... លោកបូជាចារ្យយេហូយ៉ាដា
ឈ្មោះរបស់មនុស្ស

---

23 [1]នៅឆ្នាំទីប្រាំពី លោកបូជាចារ្យយេហូយ៉ាដាបានតាំងចិត្តក្លាហានហើយបានចុះកិច្ចព្រមព្រៀងជាមួយមេបញ្ជាការ គឺអ័សារាជាកូនរបស់យេរ៉ូហាំ
លោកអ៊ីស្មាអែលរបស់យេហូហាណាន លោកអសារាជាកូនប្រុសរបស់លោកអូបេឌ លោកម៉ាសេយ៉ាជាកូនរបស់លោកអាដាយ៉ា
និងលោកអេលីសាផាតជាកូនរបស់លោកស៊ីគ្រី។[2]ពួកគេធ្វើដំណើរជុំវិញស្រុកយូដា ហើយប្រមូលពួកលេវី
ពីក្រុងនានានៃស្រុកយូដាព្រមទាំងមេដឹកនាំក្រុមគ្រួសាររបស់អ៊ីស្រាអែលឲ្យមកជួបជុំគ្នានៅក្រុងយេរូសាឡិមវិញ។
[3]អង្គប្រជុំទាំងមូលបានចងសម្ពន្ធមេត្រីជាមួយព្រះរាជាក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។ លោកយេហូយ៉ាដាមានប្រសាសន៍ថា៖
«មើលបុត្ររបស់ស្តេចនឹងគ្រងរាជ្យដូចព្រះអម្ចាស់មានព្រះបន្ទូលអំពីពូជពង្សព្រះបាទដាវីឌ។
[4]នេះជាអ្វីដែលអ្នករាល់គ្នាត្រូវធ្វើ ក្នុងចំណោមអ្នករាល់គ្នាមានមួយភាគបីជាបូជាចារ្យ និងក្រុមលេវីដែលមកបំពេញមុខងារនៅថ្ងៃសប្ប័ទហើយត្រូវយាមនៅមាត់ទ្វារ។
[5]មួយភាគបីទៀតនឹងស្ថិតនៅក្នុងដំណាក់របស់ស្តេចហើយទីបីទៀតនឹងនៅមាត់ទ្វារគ្រឹះ។ ប្រជាជនទាំងអស់នឹងស្ថិតនៅក្នុងទីធ្លានៃព្រះដំណាក់របស់ព្រះអម្ចាស់។
[6]មិនត្រូវឲ្យនរណាម្នាក់ចូលក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ឡើយលើកលែងតែពួកបូជាចារ្យ និងពួកលេវីដែលបំពេញមុខងារបម្រើប៉ុណ្ណោះ។
ពួកគេអាចចូលពីព្រោះពួកគេត្រូវបានញែកចេញសម្រាប់ការនោះ។ ប៉ុន្តែ ប្រជាជនទាំងអស់ត្រូវគោរពតាមបទបញ្ជារបស់ព្រះអម្ចាស់។
[7]ពួកលេវីត្រូវឡោមព័ទ្ធព្រះរាជានៅគ្រប់តំបន់ គ្រប់ៗគ្នាមានកាន់អាវុធនៅដៃ។ អ្នកណាចូលទៅក្នុងព្រះដំណាក់ត្រូវឲ្យគេសម្លាប់ចោល។
ត្រូវនៅជាមួយស្តេចនៅពេលដែលទ្រង់យាងចូល និងពេលដែលទ្រង់យាងចេញទៅ។
[8]ដូច្នេះ ពួកលេវី និងជនជាតិយូដាទាំងអស់បំពេញមុខងារតាមរបៀបដែលបូជាចារ្យយេហូយ៉ាដាបានបញ្ជា។
ពួកគេម្នាក់ៗបានយកបុរសៗដែលជាអ្នកដែលត្រូវចូលបម្រើនៅថ្ងៃឈប់សម្រាក
និងអ្នកដែលត្រូវឈប់បម្រើនៅថ្ងៃឈប់សម្រាកព្រោះលោកយេហូយ៉ាដាដែលជាបូជាចារ្យមិនបានបណ្តេញផ្នែកណាមួយរបស់ពួកគេទេ។
[9]លោកបូជាចារ្យយេហូយ៉ាដាបាននាំយកលំពែង និងខែលតូច និងធំដែលព្រះបាទដាវីឌបានបង្កើតក្នុងរជ្ជកាលរបស់ស្តេច
ហើយដាក់នៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
[10]លោកបូជាចារ្យយេហូយ៉ាដាបានដាក់កងទាហានទាំងអស់ដែលកាន់អាវុធពីផ្នែកខាងស្តាំនៃព្រះវិហាររហូតដល់ផ្នែកខាងឆ្វេងនៃព្រះវិហារនៅក្បែរអាសនៈ
និងទីសក្ការៈព្រមទាំងព័ទ្ធជុំវិញព្រះរាជា។[11]គេបាននាំបុត្ររបស់ស្តេចមកបំពាក់មកុដរាជ្យ ហើយប្រគល់ឲ្យព្រះករុណានូវក្រឹត្យវិន័យនៃសម្ពន្ធមេត្រី។ បន្ទាប់មក
លោកបូជាចារ្យយេហូយ៉ាដា និងកូនប្រុសរបស់គាត់បានចាក់ប្រេងអភិសេកព្រះករុណាឲ្យធ្វើជាស្តេច។ បន្ទាប់មក ពួកគេនិយាយថា៖
«សូមព្រះករុណាមានព្រះជន្មាយុយឺនយូរ» ។
[12]ពេលព្រះនាងអថាលាបានឮសម្លេងប្រជាជនរត់មក និងស្រែកហោរអបអររព្រះរាជា ព្រះនាងក៏យាងមកជួបប្រជាជននៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។
[13]ហើយព្រះនាងក្រឡេកមើលទៅ ឃើញស្តេចថ្មីកំពុងឈរនៅក្បែរសសររបស់ស្តេចនៅមាត់ទ្វារ ហើយមានពួកមេបញ្ជាការ និងពួកអ្នកផ្លុំត្រែឈរនៅក្បែរស្តេច។
ប្រជាជននៅលើទឹកដីទាំងមូលនាំគ្នាអរសប្បាយ និងផ្លុំត្រែក្រុមចម្រៀងនាំគ្នាលេងឧបករណ៍តន្ត្រី និងដឹកនាំការច្រៀងសរសើរតម្កើងព្រះអម្ចាស់។ ព្រះនាងអថាលាលា
ហែកព្រះភូសារបស់ព្រះនាងហើយស្រែកថា៖ «ក្បត់! ក្បត់ជាតិ!»។
[14]លោកបូជាចារ្យយេហូយ៉ាដាបាននាំមេបញ្ជាការកងទ័ពដែលត្រួតត្រាលើកងទ័ពមកហើយពោលទៅកាន់ពួកគេថា៖ «ចូរនាំព្រះនាងចេញពីទីនេះទៅ
ហើយអ្នកដែលដើរតាមព្រះនាងត្រូវឲ្យគេសម្លាប់ដោយមុខដាវទៅ»។ លោកបូជាចារ្យបានបង្គាប់ថា៖ «កុំសម្លាប់ព្រះនាងនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ឡើយ» ។
[15]ពួកគេបានធ្វើដំណើរទៅរកព្រះនាងហើយនាំព្រះនាងចេញទៅតាមទ្វារសេះឆ្ពោះទៅឯដំណាក់ស្តេចហើយពួកគេបានធ្វើគត់ព្រះនាងទៅ។
[16]បន្ទាប់មក លោកយេហូយ៉ាដាបានចងសម្ពន្ធមេត្រីមួយរវាងខ្លួនគាត់ផ្ទាល់ ជាមួយនឹងប្រជាជនទាំងអស់ និងព្រះរាជាផង
ដើម្បីឲ្យពួកគេធ្វើជាប្រជារាស្ត្ររបស់ព្រះអម្ចាស់។[17]ប្រជាជនទាំងអស់នាំគ្នាទៅវិហាររបស់ព្រះបាល ហើយវាយកម្ទេចចោល។ ពួកគេបានកម្ទេចអាសនៈរបស់ព្រះបាល
និងរូបសំណាកជាបំណែកៗ ហើយពួកគេបានសម្លាប់លោកម៉ាថាន់ ជាបូជាចារ្យរបស់ព្រះបាលនៅមុខអាសនៈទាំងនោះ។
[18]លោកយេហូយ៉ាដាបានតែងតាំងមន្ត្រីសម្រាប់ព្រះដំណាក់របស់ព្រះអម្ចាស់ក្រោមការដឹកនាំរបស់ពួកបូជាចារ្យដែលជាពួកលេវីដែលព្រះបាទដាវីឌបានតែងតាំងសម្រាប់ព្រះដំណាក់របស់ព្រះអម្
ដើម្បីថ្វាយតង្វាយដុតទាំងមូលចំពោះព្រះអម្ចាស់ដូចមានចែងទុកក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ហើយច្រៀងដូចព្រះបាទដាវីឌបានណែនាំ។
[19]លោកបូជាចារ្យយេហូយ៉ាដាដាក់ឆ្មាំនៅមាត់ទ្វារព្រះដំណាក់របស់ព្រះអម្ចាស់ដូច្នេះ មិនត្រូវឲ្យនរណាម្នាក់ដែលមិនបរិសុទ្ធអាចចូលបានឡើយ។
[20]លោកបូជាចារ្យយេហូយ៉ាដាបាននាំយកមេបញ្ជាការ ពួកអភិជន ពួកអ្នកគ្រប់គ្រងប្រជាជន និងប្រជាជនទាំងមូលទៅជាមួយ។
លោកបានដង្ហែរស្តេចចេញពីព្រះដំណាក់របស់ព្រះអម្ចាស់។ ប្រជាជននាំគ្នាឆ្លងកាត់ទ្វារខាងលើចូលព្រះដំណាក់របស់ព្រះបាទដាវីឌ
ហើយអង្គុយនៅលើបល្ល័ង្ករបស់ព្រះរាជា។[21]ប្រជាជននៅស្រុកទាំងមូលសប្បាយចិត្តណាស់ ហើយទីក្រុងក៏ស្ងប់ស្ងាត់ដែរ។
រីឯព្រះនាងអថាលាវិញគេបានធ្វើគត់ព្រះនាងដោយមុខដាវ។

---

generated on Wed Sep 10 16:16:32 2025

2 Chronicles 23:1
លោកបូជាចារ្យយេហូយ៉ាដា
នាយកបូជាចារ្យដែលបម្រើក្នុងព្រះវិហារ ហើយស្មោះត្រង់ចំពោះព្រះជាម្ចាស់។
គាត់ជាអ្នកប្រឹក្សាយោបល់ដល់លោកយ៉ូអាស។
លោកអូបេឌ ... លោកម៉ាសេយ៉ា ...លោកអាដាយ៉ា ...លោកអេលីសាផាត ... លោកស៊ីគ្រី
2 Chronicles 23:4
ប្រជាជនទាំងអស់
ការបកប្រែផ្សេងទៀត «មនុស្សជាច្រើន»
2 Chronicles 23:6
នៅពេលដែលទ្រង់យាងចូល និងពេលដែលទ្រង់យាងចេញទៅ។
អាចមានន័យថា ១) «គ្រប់ពេលវេលា» ឬ ២) «កន្លែងណាដែលទ្រង់យាងទៅ។»
2 Chronicles 23:8
ជនជាតិយូដាទាំងអស់បំពេញមុខងារតាមរបៀបដែលបូជាចារ្យយេហូយ៉ាដាបានបញ្ជា។
ការបកប្រែផ្សេងទៀត «មនុស្សភាគច្រើនបានគោរពតាមបញ្ជារបស់មហាបូជាចារ្យ»
អ្នកដែលត្រូវឈប់បម្រើនៅថ្ងៃឈប់សម្រាក
ការបកប្រែផ្សេងទៀត «ពួកគេបានបញ្ចប់ការងារនៅថ្ងៃសប្ប័ទ»
2 Chronicles 23:10
ហើយប្រគល់ឲ្យព្រះករុណានូវក្រឹត្យវិន័យនៃសម្ពន្ធមេត្រី។
ការបកប្រែផ្សេងទៀត «រៀបរាប់ពាក្យនៃសម្ពន្ធមេត្រី។
2 Chronicles 23:12
ប្រជាជននៅលើទឹកដីទាំងមូល
ការបកប្រែផ្សេងទៀត «ប្រជាជនស្ទើរតែទាំងអស់»
2 Chronicles 23:14
លោកបូជាចារ្យយេហូយ៉ាដា
ដែលត្រួតត្រាលើកងទ័ព
ការបកប្រែផ្សេងទៀត «ជាមេដឹកនាំនៅក្នុងជួរកងទ័ព»
ចេញពីទីនេះទៅ
ការបកប្រែផ្សេងទៀត «នៅកណ្តាលចំណោមទាហាន»
2 Chronicles 23:16
ប្រជាជនទាំងអស់នាំគ្នាទៅវិហាររបស់ព្រះបាល
ការបកប្រែផ្សេងទៀត «ប្រជាជនស្ទើរតែទាំងអស់បានទៅព្រះវិហាររបស់ព្រះបាល»
លោកម៉ាថាន់
2 Chronicles 23:18
ក្រោមការដឹកនាំរបស់ពួកបូជាចារ្យ
ការបកប្រែផ្សេងទៀត «ក្រោមការដឹកនាំរបស់ពួកបូជាចារ្យ»
មិនត្រូវឲ្យនរណាម្នាក់ដែលមិនបរិសុទ្ធអាចចូលបានឡើយ។
ការបកប្រែផ្សេងទៀត «គ្មានអ្នកណាមិនស្អាតត្រូវបានអនុញ្ញាតឲ្យចូល
ដោយហេតុផលណាមួយឡើយ»
2 Chronicles 23:20
លោកបានដង្ហែរស្តេចចេញពីព្រះដំណាក់របស់ព្រះអម្ចាស់។
ព្រះវិហារនេះត្រូវបានសាងសង់នៅលើភ្នំខ្ពស់បំផុត នៅក្រុងយេរូសាឡឹម។
ការបកប្រែផ្សេង
«លោកបាននាំស្តេចចេញពីព្រះវិហារនៅលើទូលទៅកាន់ព្រះបរមរាជវាំង»

24

[1]ព្រះបាទយ៉ូអាសមានជន្មាយុប្រាំពីរព្រះវស្សានៅពេលដែលព្រះករុណាចាប់ផ្តើមសោយរាជ្យ។ ស្តេចសោយរាជ្យអស់រយៈពេលសែសិបព្រះវស្សានៅក្រុងយេរូសាឡិម។
ព្រះមាតារបស់ព្រះករុណាព្រះនាមថាព្រះនាងស៊ីប ជាអ្នកស្រុកបៀរសេបា។
[2]ព្រះបាទយ៉ូអាសបានធ្វើអ្វីៗដែលគាប់ព្រះហឫទ័យព្រះអម្ចាស់អស់មួយជីវិតរបស់បូជាចារ្យយេហូយ៉ាដា។[3]បូជាចារ្យយេហូយ៉ាដាបានអភិសេកមហេសីពីរអង្គថ្វាយព្រះបាទយ៉ូអាស ហើយស្តេចបង្កើតបានបុត្រាបុត្រីជាច្រើន។
[4]ក្រោយមក ព្រះបាទយ៉ូអាសបានសម្រេចព្រះទ័យជួសជុលព្រះដំណាក់របស់ព្រះអម្ចាស់ឡើងវិញ។[5]ព្រះករុណាបានប្រមូលពួកបូជាចារ្យ និងពួកលេវីឲ្យ
ហើយមានរាជឱង្ការទៅពួកគេថា៖ «ចូរចេញទៅតាមក្រុងនានាក្នុងស្រុកយូដាជារៀងរាល់ឆ្នាំហើយប្រមូលប្រាក់ពីអ៊ីស្រាអែលទាំងអស់
ដើម្បីជួសជុលព្រះដំណាក់នៃព្រះរបស់អ្នក»។ ដំបូងពួកលេវីមិនបានធ្វើអ្វីទាំងអស់។
[6]ព្រះរាជាត្រាស់ហៅលោកយេហូយ៉ាដាជាមហាបូជាចារ្យមកហើយមានរាជឱង្ការថា៖ «ហេតុអ្វីបានជាអ្នកមិនបង្ខំឲ្យពួកលេវីចេញទៅស្រុកយូដា
និងក្រុងយេរូសាឡិមប្រមូលពន្ធដែលដែលគេត្រូវបង់ដូចដែលលោកម៉ូសេជាអ្នកបម្រើព្រះបានបង្គាប់អំពីច្បាប់សម្រាប់ត្រសាលនៃសម្ពន្ធមេត្រី?»[7]ដ្បិត
ព្រះនាងអថាលាជាស្ត្រីទុច្ចរិតបានបង្ហូចព្រះដំណាក់របស់ព្រះជាម្ចាស់ហើយ
យករបស់ដ៏វិសុទ្ធទាំងប៉ុន្មាននៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ទប្រើប្រាស់សម្រាប់ព្រះបាល។
[8]ព្រះករុណាបានបញ្ជាឲ្យគេធ្វើហឹបមួយដាក់នៅខាងក្រៅទ្វារចូលព្រះដំណាក់របស់ព្រះអម្ចាស់។[9]ពួកគេប្រកាសប្រាប់ប្រជាជននៅស្រុកយូដា
និងក្រុងយេរូសាឡិមឲ្យប្រជាជនយកពន្ធដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះជាម្ចាស់បានបង្គាប់ជនជាតិអ៊ីស្រាអែលនៅទីរហោស្ថាន។[10]មេដឹកនាំទាំងអស់
និងប្រជាជនទាំងមូលមានអំណរសប្បាយហើយយកប្រាក់មកដាក់ក្នុងហឹបរហូតដល់ហឹបទាំងអស់ត្រូវបានបំពេញ។
[11]លុះដល់ពេលដែលពួកលេវីត្រូវនាំហឹបទៅថ្វាយព្រះរាជាត្រួតពិនិត្យមើល គឺនៅពេលដែលគេឃើញមានប្រាក់ច្រើននៅក្នុងហឹបហើយ លោកស្មៀនហ្លួង និងមន្ត្រីរបស់
មហាបូជាចារ្យក៏មកយកប្រាក់ចេញពីហឹបនាំយកទៅដោយទុកហឹបនៅកន្លែងដើមវិញ។ ពួកគេបានធ្វើបែបនេះពីមួយថ្ងៃទៅមួយថ្ងៃដោយប្រមូលប្រាក់បានយ៉ាងច្រើន។
[12]ព្រះរាជា និងលោកយេហូយ៉ាដាបានប្រគល់ប្រាក់ឲ្យពួកមេជាងដែលបំពេញការងារនៅព្រះដំណាក់របស់ព្រះអម្ចាស់។ ពួកគេបានជួលជាងថ្ម
និងជាងឈើដើម្បីជួសជុលព្រះដំណាក់របស់ព្រះអម្ចាស់ព្រមទាំងជាងដែក និងលង្ហិនផង។
[13]ដូច្នេះ កម្មករបានធ្វើការនឿយហត់ ហើយការងារជួសជុលបានឈានទៅមុខ ហើយពួកគេបានសង់ព្រះដំណាក់របស់ព្រះ ជាម្ចាស់តាមលំនាំដើម
និងពង្រឹងគុណភាពឡើងវិញ។[14]ពេលពួកគេបានបញ្ចប់ពួកគេនាំយកប្រាក់ដែលនៅសល់ទៅថ្វាយព្រះរាជា និងលោកយេហូយ៉ាដា។ ប្រាក់នេះត្រូវបានប្រើ
ដើម្បីធ្វើគ្រឿងសង្ហរិមសម្រាប់ព្រះដំណាក់របស់ព្រះអម្ចាស់ដែលជាប្រដាប់ប្រដាប្រើប្រាស់ និងសម្រាប់តង្វាយផ្សេងៗដូចជាមាស និងប្រាក់។
ពួកគេបានថ្វាយតង្វាយដុតទាំងមូលនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ជារៀងរហូតអស់មួយជីវិតរបស់បូជាចារ្យយេហូយ៉ាដា។
[15]បូជាចារ្យយេហូយ៉ាដាមានវ័យចាស់ណាស់ទៅហើយ ហើយគាត់ក៏ស្លាប់ទៅ។ ពេលគាត់ស្លាប់ គាត់មានអាយុ ១៣០ ឆ្នាំ។
[16]គេបញ្ចុះសពលោកនៅក្រុងព្រះបាទដាវីឌជាមួយស្តេច ព្រោះលោកបានធ្វើអំពើល្អនៅអ៊ីស្រាអែល ចំពោះព្រះ និងក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
[17]បន្ទាប់ពី បូជាចារ្យយេហូយ៉ាដាបានទទួលមរណៈភាពទៅ ពួកមេដឹកនាំនៃស្រុកយូដាបានចូលមកគាល់ព្រះរាជា។ ព្រះរាជាក៏ស្តាប់តាមពួកគេ។
[18]ពួកគេបានបោះបង់ចោលព្រះដំណាក់របស់ព្រះអម្ចាស់ជាព្រះនៃដូនតារបស់ពួកគេហើយនាំគ្នាក្រាបថ្វាយបង្គំរូបព្រះអាសេរ៉ា និងព្រះក្លែងក្លាយ។
ព្រះជាម្ចាស់ព្រះពិរោធនឹងជនជាតិយូដា និងអ្នកក្រុងយេរូសាឡិមព្រោះតែការប្រព្រឹត្តខុសរបស់ពួកគេ។[19]ព្រះអង្គបានចាត់ព្យាការី
ឲ្យមករកគេដើម្បីនាំគេឲ្យវិលមករកព្រះអង្គវិញ។ ពួកព្យាការីបានផ្តល់សក្ខីភាពប្រឆាំងនឹងប្រជាជនតែពួកគេមិនព្រមស្តាប់ទេ។
[20]ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងមកសណ្ឋិតលើលោកសាការី ជាកូនរបស់លោកយេហូយ៉ាដាដែលជាបូជាចារ្យ។ លោកសាការីឈរនៅពីខាងលើប្រជាជន
ហើយមានប្រសាសន៍ទៅគេថា៖ «ព្រះជាម្ចាស់មានព្រះបន្ទូលដូចតទៅ៖ ហេតុអ្វីបានជាអ្នកបំពានបទបញ្ជារបស់ព្រះអម្ចាស់? ដូច្នេះ អ្នករាល់គ្នាពុំអាចរីកចម្រើនបានឡើយ!
ដោយព្រោះអ្នករាល់គ្នាបោះបង់ចោលព្រះអម្ចាស់ នោះព្រះអង្គនឹងបោះបង់ចោលអ្នករាល់គ្នាវិញដែរ»[21]ប៉ុន្តែ ពួកគេបានឃុបឃិតគ្នាប្រឆាំងនឹងព្រះអង្គ។
គេបានយកដុំថ្មគប់សម្លាប់លោកនៅក្នុងទីធ្លាព្រះដំណាក់របស់ព្រះអម្ចាស់។
[22]ព្រះបាទយ៉ូអាសជាព្រះរាជាមិនអើពើនឹងសេចក្តីសប្បុរសដែលលោកយេហូយ៉ាដាដែលជាឪពុករបស់សាការីបានធ្វើចំពោះព្រះករុណាទេ។ ផ្ទុយទៅវិញ

generated on Wed Sep 10 16:16:32 2025

ព្រះករុណាបានសម្លាប់កូនប្រុសរបស់យេហូយ៉ាដាទៅវិញ។ ពេលសាការីជិតផុតដង្ហើមហើយ លោកមានប្រសាសន៍ថា៖
«សូមព្រះអម្ចាស់មេត្តាមើលហើយហៅលោកឲ្យទទួលខុសត្រូវ»។
[23]នៅចុងឆ្នាំនោះ កងទ័ពស៊ីរីបានលើកទ័ពមកច្បាំងនឹងព្រះបាទយ៉ូអាស។ ពួកគេបានទៅដល់ស្រុកយូដា និងក្រុងយេរូសាឡិម។
ពួកគេបានសម្លាប់មេដឹកនាំទាំងអស់របស់ប្រជាជនយូដា ហើយបានរឹបអូសយកទ្រព្យសម្បត្តិពីពួកគេទៅថ្វាយស្តេចនៅក្រុងដាម៉ាស។
[24]កងទ័ពស៊ីរីបានមកជាមួយកងទ័ពតូចមួយប៉ុណ្ណោះ ប៉ុន្តែ ព្រះអម្ចាស់បានជួយពួកគេឲ្យមានជ័យជម្នះលើកងទ័ពដ៏ខ្លាំងពូកែ ដ្បិត
ជនជាតិយូដាបានបោះបង់ចោលព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ខ្លួន។ ព្រះអម្ចាស់ប្រើពួកស៊ីរីឲ្យកាត់ទោសព្រះបាទយ៉ូអាស តាមរបៀបនេះ។
[25]នៅពេលដែលពួកស៊ីរីបានចាកចេញទៅនោះព្រះបាទយ៉ូអាសបានរងរបួសយ៉ាងធ្ងន់ធ្ងរ។ ពួកអ្នកបម្រើរបស់ព្រះអង្គបានឃុបឃិតគ្នាប្រឆាំងនឹងព្រះករុណា
ព្រោះតែការដែលព្រះករុណាបានសម្លាប់លោកសាការីជាកូនប្រុសរបស់បូជាចារ្យយេហូយ៉ាដា។ ពួកគេបានធ្វើគុតព្រះករុណានៅលើគ្រែ ហើយព្រះករុណាក៏សុគតទៅ។
គេបញ្ចុះសពទ្រង់នៅក្រុងព្រះបាទដាវីឌ តែមិនបញ្ចុះក្នុងផ្នូររបស់ស្តេចទេ។
[26]ពួកអ្នកដែលបានឃុបឃិតប្រឆាំងនឹងព្រះករុណាគឺលោកសាបាបជាកូនរបស់លោកស៊ីម៉ាតជនជាតិអាំម៉ូន
និងលោកយេហូសាបាប់ជាកូនរបស់លោកស៊ីមរិទ្ធជាជនជាតិម៉ូអាប់។
[27]ឥឡូវនេះ កំណត់ត្រាអំពីបុត្រាស្តេច បទទំនាយសំខាន់ៗដែលពួកព្យាការីបានថ្លែងពីព្រះករុណា និងការជួសជុលព្រះដំណាក់ព្រះអម្ចាស់ឡើងវិញ មើល
សុទ្ធតែត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅរបស់ស្តេច។ ព្រះបាទអម៉ាស៊ីយ៉ាជាបុត្រឡើងស្នងរាជ្យ។

---

2 Chronicles 24:1
ព្រះនាងស៊ីបបា
ធ្វើអ្វីៗដែលគាប់ព្រះហឫទ័យព្រះអម្ចាស់
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
អស់មួយជីវិតរបស់បូជាចារ្យយេហូយ៉ាដា។
ការបកប្រែផ្សេងទៀត «ដរាបណាបូជាចារ្យយេហូយ៉ាដានៅរស់»
2 Chronicles 24:4
ភ្លាមៗ
ការបកប្រែផ្សេងទៀត «ភ្លាមៗ»
2 Chronicles 24:6
ហេតុអ្វីបានជាអ្នកមិនបង្ខំឲ្យពួកលេវី ...អំពីច្បាប់សម្រាប់ត្រសាលនៃសម្ពន្ធមេត្រី?
អ្នកបានប្រព្រឹត្តអំពើអាក្រក់។ ខ្ញុំបានប្រាប់អ្នកឲ្យធ្វើតាមពួកលេវី
គោរពតាមសម្ពន្ធមេត្រី ប៉ុន្តែ អ្នកមិនបានធ្វើទេ។»
អំពីច្បាប់សម្រាប់ត្រសាលនៃសម្ពន្ធមេត្រី
ទោះបី វាសំដៅទៅលើព្រះវិហារដែលព្រះបាទសាឡូម៉ូនបានសាងសង់
ក៏ជាការរំលឹកថា «ត្រសាលរបស់ព្រះអម្ចាស់»
គឺជាទីកន្លែងទីសក្ការៈបំផុតសម្រាប់ប្រជាជនរបស់ព្រះជាម្ចាស់។
របស់ដ៏វិសុទ្ធ
សំដៅទៅលើរបស់ប្រើប្រាស់នៅក្នុងព្រះវិហារ។
2 Chronicles 24:11
ជួលជាងថ្ម និងជាងឈើ
ការបកប្រែផ្សេងទៀត «អស់អ្នកដែលបានសាងសង់ដោយប្រើថ្ម
និងអ្នកដែលសាងសង់ដោយប្រើឈើ»
ជាងដែក និងលង្ហិនផង។
ការបកប្រែផ្សេងទៀត «អស់អ្នកដែលធ្វើការជាមួយដែក»
2 Chronicles 24:13
បានឈានទៅមុខ
ការបកប្រែផ្សេងទៀត «ពួកគេបានធ្វើដោយដៃរ»
ជារៀងរហូតអស់មួយជីវិតរបស់បូជាចារ្យយេហូយ៉ាដា។
ការបកប្រែផ្សេងទៀត «រាល់ថ្ងៃ ពេលបូជាចារ្យយេហូយ៉ាដានៅមានជីវិត»
2 Chronicles 24:17
បានចូលមកគាល់ព្រះរាជា។
ការបកប្រែផ្សេងទៀត «ថ្វាយការគោរពដល់ព្រះរាជា»
ការប្រព្រឹត្តខុសរបស់ពួកគេ។
ការបកប្រែផ្សេងទៀត «អំពើបាបរបស់ពួកគេ»
2 Chronicles 24:20
មិនអើពើនឹងសេចក្តីសប្បុរសដែលលោកយេហូយ៉ាដាដែលជាឪពុករបស់សាការីបានធ្វើចំពោះព្រះករុណាទេ។
លោកយ៉ូអាសមិនបានយកចិត្តទុកដាក់
ឬចងចាំសេចក្តីសប្បុរសដ៏អស្ចារ្យរបស់លោកយេហូយ៉ាដា
ដែលជាឪពុករបស់លោកសាការី។
ហៅលោកឲ្យទទួលខុសត្រូវ។
ការបកប្រែផ្សេងទៀត «អ្នកនឹងត្រូវសងថ្លៃ កំហុសដែលអ្នកបានប្រព្រឹត្ត»
2 Chronicles 24:25
លោកសាបាបជាកូនរបស់លោកស៊ីម៉ាតជនជាតិអាំម៉ូន
និងលោកយេហូសាបាប់ជាកូនរបស់លោកស៊ីមរិទ្ធជាជនជាតិម៉ូអាប់។
2 Chronicles 24:27
បានកត់ត្រាទុកនៅក្នុងសៀវភៅរបស់ស្តេច។
សៀវភៅនេះលែងមានទៀតហើយ។

---

25 [1]ព្រះបាទអម៉ាស៊ីយ៉ា ឡើងគ្រងរាជ្យក្នុងជន្មាយុម្ភៃប្រាំឆ្នាំព្រះវស្សា។ ព្រះករុណាសោយរាជ្យម្ភៃប្រាំឆ្នាំនៅក្រុងយេរូសាឡិម។ ព្រះមាតារបស់ព្រះអង្គព្រះនាមថា
ព្រះនាងយេហូយ៉ាដានជាអ្នកក្រុងយេរូសាឡិម។[2]ស្តេចបានធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះអម្ចាស់តែមិនមែនដោយចិត្តស្មោះត្រង់នោះទេ។
[3]ក្រោយពីឡើងគ្រងរាជ្យ និងពង្រឹងអំណាចហើយ ព្រះករុណាប្រហារជីវិតពួកមេទ័ពដែលបានធ្វើគុតបិតារបស់ព្រះករុណា។[4]ប៉ុន្តែ
ព្រះករុណាមិនបានសម្លាប់កូនចៅរបស់ឃាតកឡើយ ប៉ុន្តែ បានធ្វើទៅតាមអ្វីដែលមានចែងក្នុងក្រឹត្យវិន័យក្នុងគម្ពីររបស់លោកម៉ូសេដូចព្រះអម្ចាស់បានបង្គាប់ថា៖
«ឪពុកមិនត្រូវស្លាប់ដោយព្រោះបាបកូនចៅទេ ហើយកូនចៅក៏មិនត្រូវស្លាប់ដោយព្រោះបាបឪពុកដែរ។ ផ្ទុយទៅវិញ មនុស្សគ្រប់រូបត្រូវស្លាប់ព្រោះតែអំពើបាបរបស់ខ្លួន»។
[5]លើសពីនេះទៅទៀត ព្រះបាទអម៉ាស៊ីយ៉ាបានប្រមូលផ្តុំប្រជាជនយូដាហើយបានចុះបញ្ជីពួកគេតាមផ្ទះរបស់ដូនតារបស់ពួកគេក្រោមការដឹកនាំរបស់មេទ័ព មេកង
គឺពីកុលសម្ព័ន្ធយូដានិងបេនយ៉ាមីន។ ព្រះករុណាបានជំរឿនប្រុសៗដែលមានអាយុពីម្ភៃឆ្នាំឡើងទៅ ឃើញមានទាំងអស់ ៣០០, ០០០នាក់ ជាទាហានដ៏ចំណាន
ដែលអាចចេញទៅធ្វើសង្គ្រាមបាន ជាអ្នកដែលអាចប្រើលំពែង ប្រើខែលបាន។[6]ស្តេចជួលទាហានដ៏ពូកែអង់អាចចំនួន ១០០, ០០០ នាក់ពីស្រុកអ៊ីស្រាអែល
ដោយប្រាក់សុទ្ធមួយរយណែន។
[7]អ្នកជំនិតរបស់ព្រះជាម្ចាស់ចូលមកគាល់ស្តេច ហើយទូលថា៖ «បពិត្រព្រះរាជា សូមកុំឲ្យកងទ័ពអ៊ីស្រាអែលទៅជាមួយព្រះករុណាឡើយ
ដ្បិតព្រះអម្ចាស់មិននៅជាមួយអ៊ីស្រាអែលទេព្រមទាំងប្រជាជនអេប្រាអ៊ីមផង។[8]ប៉ុន្តែ ទោះបីអ្នកទៅហើយមានភាពក្លាហាន និងរឹងមាំក្នុងសមរភូមិក៏ដោយ
តែនៅក្នុងសមរភូមិព្រះជាម្ចាស់នឹងបោះព្រះករុណាចុះ នៅចំពោះមុខខ្មាំងសត្រូវ ព្រោះព្រះជាម្ចាស់មានអំណាចជួយហើយមានអំណាចអាចទម្លាក់ចុះបាន»។
[9]ព្រះបាទអម៉ាស៊ីយ៉ាមានរាជឱង្ការទៅអ្នកជំនិតរបស់ព្រះជាម្ចាស់ថា៖ «តើយើងត្រូវធ្វើអ្វីខ្លះចំពោះប្រាក់មួយរយណែនដែលខ្ញុំបានប្រគល់ឲ្យកងទ័ពអ៊ីស្រាអែល?
អ្នកជំនិតរបស់ព្រះជាម្ចាស់ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អាចប្រទានឲ្យព្រះករុណាមានប្រាក់ច្រើនជាងនេះទៅទៀត»។
[10]ព្រះបាទអម៉ាស៊ីយ៉ាបានបំបែកទ័ពដែលមកពីអេប្រាអ៊ីម ហើយឲ្យគេត្រឡប់ទៅផ្ទះវិញ។ ដូច្នេះ ពួកគេខឹងនឹងពួកយូដាយ៉ាងខ្លាំង
ហើយពួកគេវិលត្រឡប់ទៅផ្ទះវិញដោយកំហឹងយ៉ាងខ្លាំង។
[11]ព្រះបាទអម៉ាស៊ីយ៉ាមានចិត្តក្លាហាន ហើយនាំប្រជាជនឆ្ពោះទៅជ្រលងភ្នំអំបិល។ នៅទីនោះព្រះករុណាបានវាយឈ្នះអ្នកស្រុកភ្នំសៀរចំនួនមួយម៉ឺននាក់។
[12]កងទ័ពយូដាវាយហើយចាប់ទាហានមួយម៉ឺននាក់ទៀត។ ពួកគេបានយកទាហានទាំងនោះទៅខាងលើជ្រលងភ្នំហើយទម្លាក់ពួកគេចុះពីទីនោះ
ដើម្បីឲ្យពួកគេបែកជាបំណែកៗ។

generated on Wed Sep 10 16:16:32 2025

[13]ប៉ុន្តែ ទាហានដែលព្រះបាទអម៉ាស៊ីយ៉ាបានបញ្ជូនឲ្យត្រឡប់មកវិញ ដើម្បីកុំឲ្យគេទៅចូលរួមជាមួយព្រះករុណានៅក្នុងសមរភូមិ
ពួកគេបានឈ្លានពានទីក្រុងនៅក្នុងស្រុកយូដាចាប់ពីក្រុងសាម៉ារីរហូតដល់ក្រុងបេតហូរ៉ុន។ ពួកគេបានសម្លាប់ប្រជាជនបីពាន់នាក់
និងបានរឹបអូសយកទ្រព្យសម្បត្តិជាច្រើន។
[14]ព្រះករុណាបាននាំព្រះរបស់ប្រជាជនសៀរហើយឲ្យគេតម្កល់រូបនោះធ្វើជាព្រះរបស់ព្រះករុណា។ ស្តេចក្រាបចុះនៅមុខរូបទាំងនោះហើយដុតគ្រឿងក្រអូបថ្វាយផង។
[15]ដូច្នេះ ព្រះអម្ចាស់ព្រះពិរោធចំពោះស្តេចអម៉ាស៊ីយ៉ា។ ព្រះអម្ចាស់បានចាត់ព្យាការីមួយរូបឲ្យមកទូលព្រះករុណាថា៖
«ហេតុអ្វីបានជាអ្នករាល់គ្នានាំគ្នាស្វែងរកព្រះដែលមិនមែនជាព្រះ ហើយមិនអាចជួយសង្គ្រោះប្រជារាស្ត្ររបស់គេពីព្រះហស្តរបស់ព្រះអង្គបានផង?
[16]នៅពេលដែលព្យាការីកំពុងទូលជាមួយស្តេច នោះស្តេចមានរាជឱង្ការថា៖ «តើយើងបានតែងតាំងអ្នកឲ្យធ្វើជាទីប្រឹក្សារបស់ស្តេចឬ? ចូរឈប់ចុះ ដ្បិតអ្នកមិនគួរស្លាប់ទេ»
បន្ទាប់មក ព្យាការីបានឈប់ហើយមានប្រសាសន៍ថា៖ «ទូលបង្គំដឹងថា ព្រះជាម្ចាស់បានសម្រេចព្រះទ័យបំផ្លាញព្រះករុណា ពីព្រោះព្រះករុណាបានធ្វើអំពើនេះ
ហើយមិនបានស្តាប់តាមដំបូន្មានរបស់ទូលបង្គំ»។
[17]ព្រះបាទអម៉ាស៊ីយ៉ា ជាស្តេចស្រុកយូដាបានប្រឹក្សាជាមួយអ្នកប្រឹក្សាហើយចាត់គេឲ្យទៅជួបព្រះបាទយ៉ូអាស ជាបុត្ររបស់ព្រះបាទយ៉ូអាហាស ជាបុត្ររបស់ព្រះបាទ
យេហ៊ូវ ជាស្តេចស្រុកអ៊ីស្រាអែលថា៖ «មក! ចូរយើងជួបគ្នាមុខទល់មុខនៅក្នុងសមរភូមិ»។
[18]ប៉ុន្តែ ព្រះបាទយ៉ូអាស ជាស្តេចស្រុកអ៊ីស្រាអែលបានចាត់អ្នកនាំសារឲ្យទៅទូលព្រះបាទអម៉ាស៊ីយ៉ា ជាស្តេចស្រុកយូដាថា៖
«មានបន្លាមួយនៅស្រុកលីបង់បានផ្ញើសារទៅដើមឈើតាត្រៅនៅស្រុកលីបង់ដោយពោលថា៖ «ចូលើកកូនកូនស្រីរបស់អ្នកឲ្យធ្វើជាប្រពន្ធកូនប្រុសខ្ញុំ» ប៉ុន្តែ
មានសត្វព្រៃនៅស្រុកលីបង់បានដើរកាត់ ហើយជាន់បន្លានោះខ្ទេចអស់។[19]ព្រះករុណាមានរាជឱង្ការថា៖ «មើល យើងបានច្បាំងឈ្នះពួកអេដុម
ព្រះករុណាកំពុងលើកម្តើងខ្លួនឯង។ ជ័យជម្នះបានធ្វើឲ្យព្រះករុណាមានអំនួត ប៉ុន្តែ សូមព្រះករុណាគង់នៅព្រះដំណាក់ចុះ
ហេតុអ្វីបានជាព្រះករុណាចង់បង្កបញ្ហាដល់ខ្លួនឯង ហើយធ្វើឲ្យខ្លួនព្រះករុណា ព្រមទាំងពួកយូដាដែលនៅជាមួយបរាជ័យដូច្នេះ?»។
[20]ប៉ុន្តែ ព្រះបាទអម៉ាស៊ីយ៉ាមិនស្តាប់ទេ ព្រោះព្រឹត្តិការណ៍នេះមកពីព្រះជាម្ចាស់
ដើម្បីព្រះអម្ចាស់អាចប្រគល់ប្រជាជនយូដាទៅក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវរបស់ពួកគេព្រោះពួកគេបានស្វែងរកដំបូន្មានពីព្រះនៃស្រុកអេដុម។[21]ព្រះបាទយ៉ូអាស
ជាស្តេចស្រុកអ៊ីស្រាអែលលើកទ័ពមកវាយលុក ទ្រង់ និងព្រះបាទអម៉ាស៊ីយ៉ា ជាស្តេចស្រុកយូដាបានជួបតទល់គ្នានៅក្រុងបេតសេមែស នៅក្នុងស្រុកយូដា។
[22]ជនជាតិយូដាត្រូវបរាជ័យនៅមុខជនជាតិអ៊ីស្រាអែល ហើយកងទ័ពទាំងអស់នាំគ្នារត់ត្រឡប់ទៅផ្ទះវិញ។
[23]ព្រះបាទយ៉ូអាស ជាស្តេចស្រុកអ៊ីស្រាអែលចាប់បានព្រះបាទអម៉ាស៊ីយ៉ាជាបុត្ររបស់ព្រះបាទយ៉ូអាសត្រូវជាបុត្ររបស់ព្រះបាទអហាស៊ីយ៉ា ជាស្តេចស្រុកយូដានៅក្រុង
បេតសេមែស។ ទ្រង់បាននាំស្តេចទៅក្រុងយេរូសាឡិម ហើយបានរំលំកំពែងក្រុងយេរូសាឡិមចាប់ពីទ្វារក្រុងអេប្រាអ៊ីមរហូតដល់ជ្រុងខ្លោងទ្វារ
ដែលមានចម្ងាយបួនរយហត្ថ។[24]ស្តេចបានយកមាស និងវត្ថុទាំងអស់ដែលមាននៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ទៅជាមួយលោកអូបេដ-
អេដុមព្រមទាំងរបស់របរមានតម្លៃនៅក្នុងព្រះបរមរាជវាំងជាមួយពួកចំណាប់ខ្មាំងរួចរំលត់ត្រឡប់ទៅក្រុងសាម៉ារីវិញ។
[25]ក្រោយពេលព្រះបាទយ៉ូអាស ជាបុត្ររបស់ព្រះបាទយ៉ូអាហាស ស្តេចអ៊ីស្រាអែលសោយទិវង្គត ព្រះបាទអម៉ាស៊ីយ៉ា ជាបុត្ររបស់ព្រះបាទយ៉ូអាស ស្តេចស្រុកយូដា មាន
ព្រះជន្មគង់នៅបានដប់ប្រាំវស្សាទៀត។[26]រាជកិច្ចផ្សេងៗរបស់ព្រះបាទអម៉ាស៊ីយ៉ា សុទ្ធតែមានកត់ត្រាទុកក្នុងសៀវភៅរបស់ស្តេចស្រុកយូដា និងស្តេចស្រុកអ៊ីស្រាអែល។
[27]ចាប់តាំងពីពេលដែល ព្រះបាទអម៉ាស៊ីយ៉ាបានបោះបង់ចោលព្រះអម្ចាស់ ពួកមន្ត្រីចាប់ផ្តើមឃុបឃិតគ្នាប្រឆាំងនឹងព្រះអង្គនៅក្រុងយេរូសាឡិម។
ព្រះអង្គបានភៀសព្រះកាយទៅក្រុងឡាគីស ប៉ុន្តែ ពួកគេបានបញ្ជូនមនុស្សតាមព្រះករុណានៅក្រុងឡាគីស ហើយបានធ្វើគុតទ្រង់នៅទីនោះ។
[28]ពួកគេបាននាំព្រះសពដឹកលើសេះត្រឡប់មកវិញហើយបញ្ចុះសពព្រះករុណាជាមួយពួកបុព្វបុរសរបស់ព្រះករុណានៅឯក្រុងនៃស្រុកយូដា។

---

2 Chronicles 25:1
ព្រះនាងយេហូយ៉ាដាន
នេះជាឈ្មោះស្ត្រី។
អ្វីដែលគាប់ព្រះហឫទ័យព្រះអម្ចាស់
សូមមើលការបកប្រែនេះនៅក្នុង ១៤:១
2 Chronicles 25:3
ក្នុងគម្ពីររបស់លោកម៉ូសេ
នេះជាការយោងទៅលើកកណ្ឌគម្ពីរលោកុប្បត្តិ និក្ខមនំ លេវីវិន័យ និង ទុតិយកថា។
2 Chronicles 25:5
បានចុះបញ្ជី
គាត់មានឈ្មោះចុះនៅក្នុងបញ្ជីផ្លូវការ។
៣០០,០០០នាក់ ... ១០០,០០០ នាក់
សូមមើល
ណែន
2 Chronicles 25:9
ដូច្នេះ ពួកគេខឹងនឹងពួកយូដាយ៉ាងខ្លាំង
ការបកប្រែផ្សេងទៀត «ដូច្នេះ ពួកគេចាប់ផ្តើមផ្ទុះកំហឹង
ដោយកំហឹងយ៉ាងខ្លាំង។
ការបកប្រែផ្សេងទៀត «ខឹងយ៉ាងខ្លាំង»
2 Chronicles 25:11
ជ្រលងភ្នំអំបិល
នេះជាតំបន់ក្បែរសមុទ្រមរណៈ។
ដើម្បីឲ្យពួកគេបែកជាបំណែកៗ។
ការបកប្រែផ្សេងទៀត «ដូច្នេះ ពួកគេទាំងអស់បានស្លាប់»
2 Chronicles 25:13
ក្រុងបេតហូរ៉ុន
នេះជាភូមិមួយនៅជិតក្រុងយេរូសាឡឹម ក្នុងអេប្រាអ៊ីម។
បានសម្លាប់
ការបកប្រែផ្សេងទៀត «បានសម្លាប់»
2 Chronicles 25:14
ស្តេចក្រាបចុះនៅមុខរូបទាំងនោះ
ការបកប្រែផ្សេងទៀត: «ថ្វាយបង្គំព្រះក្លែងក្លាយទាំងនេះ»
ហេតុអ្វីបានជាអ្នករាល់គ្នានាំគ្នាស្វែងរកព្រះដែលមិនមែនជាព្រះ
ហើយមិនអាចជួយសង្គ្រោះប្រជារាស្ត្ររបស់គេពីព្រះហស្តរបស់ព្រះអង្គបានផង?
ការបកប្រែផ្សេងទៀត «អ្នករាល់គ្នាបានថ្វាយបង្គំព្រះក្លែងក្លាយរបស់ប្រជាជន
ដែលមិនអាចសង្គ្រោះ សូម្បីតែប្រជារាស្ត្ររបស់ខ្លួនឯងផ្ទាល់ ពីស្តេចអម៉ាស៊ីយ៉ា។
2 Chronicles 25:16
«តើយើងបានតែងតាំងអ្នកឲ្យធ្វើជាទីប្រឹក្សារបស់ស្តេចឬ? ចូរឈប់ចុះ ដ្បិតអ្នកមិនគួរស្លាប់ទេ»
ការបកប្រែផ្សេងទៀត
«យើងពិតជាមិនបានតែងតាំងអ្នកឲ្យធ្វើជាអ្នកប្រឹក្សាយោបល់របស់យើងទេ។ ដូច្នេះ
សូមឈប់និយាយ! បើអ្នកនិយាយអ្វីទៀត
យើងនឹងប្រាប់ទាហានរបស់យើងឲ្យសម្លាប់អ្នក!»
2 Chronicles 25:17
ព្រះបាទយ៉ូអាស ... ព្រះបាទយ៉ូអាហាស
2 Chronicles 25:18
ព័ត៌មានទូទៅ៖
នេះជារឿង a
បន្លា
នេះជាព្រៃតូចមួយ។
ឈើតាត្រៅ
ដើមឈើធំមួយប្រភេទ។ តំណាងឲ្យទាហានអ៊ីស្រាអែល។
ហេតុអ្វីបានជាព្រះករុណាចង់បង្កបញ្ហាដល់ខ្លួនឯង ហើយធ្វើឲ្យខ្លួនព្រះករុណា
ព្រមទាំងពួកយូដាដែលនៅជាមួយបរាជ័យដូច្នេះ?»។
ការបកប្រែផ្សេងទៀត «អ្នកមិនគួរធ្វើឲ្យខ្លួនឯងមានបញ្ហា និងដួលរលំទាំងអ្នក
និងយូដាជាមួយអ្នកទេ»។
2 Chronicles 25:20

generated on Wed Sep 10 16:16:32 2025

ត្រូវបរាជ័យនៅមុខ
ការបកប្រែផ្សេងទៀត «បរាជ័យដោយ»
2 Chronicles 25:23
ហត្ថ
លោកអូបេដ-អេដុម
2 Chronicles 25:25
សុទ្ធតែមាន
ការបកប្រែផ្សេងទៀត «អ្វីៗទាំងអស់»
សុទ្ធតែមានកត់ត្រាទុក ... អ៊ីស្រាអែល?
ការបកប្រែផ្សេងទៀត «ពួកគេត្រូវបានសរសេរ ... អ៊ីស្រាអែល។»
2 Chronicles 25:27
ក្រុងឡាគីស
ទីក្រុងមួយនៅស្រុកយូដា។
ក្រុងនៃស្រុកយូដា
ឈ្មោះមួយផ្សេងទៀតសម្រាប់ទីក្រុងព្រះបាទដាវីឌ ឬទីក្រុងយេរូសាឡឹម។

---

26 [1]ប្រជាជនយូដាទាំងអស់បានអភិសេកព្រះបាទអូសៀសដែលមានព្រះជន្មាយុដប់ប្រាំមួយព្រះវស្សាឲ្យឡើងសោយរាជ្យជំនួសព្រះបាទអម៉ាស៊ីយ៉ា ជាបិតា។
[2]គឺស្តេចដែលបានសង់ក្រុងអេឡាតហើយយកក្រុងនោះមកស្រុកយូដាឡើងវិញ។ បន្ទាប់ពីនោះ ព្រះរាជាបានផ្ទំលក់ជាមួយបុព្វបុរសរបស់ខ្លួន។[3]ព្រះបាទ
អូសៀសមានព្រះជន្មាយុដប់ប្រាំមួយព្រះវស្សាពេលឡើងសោយរាជ្យ។ ស្តេចសោយរាជ្យអស់រយៈពេលហាសិបពីរព្រះវស្សានៅក្រុងយេរូសាឡិម។
មាតារបស់ស្តេចមានព្រះនាមថាយេជីលា។ ព្រះនាងមកពីក្រុងយេរូសាឡិម។
[4]ស្តេចបានប្រព្រឹត្តត្រឹមត្រូវគាប់ព្រះហឫទ័យព្រះអម្ចាស់ដោយយកតម្រាប់តាមព្រះបាទអម៉ាស៊ីយ៉ា ជាបិតា។[5]ស្តេចតាំងខ្លួនចង់ស្វែងរកព្រះជាម្ចាស់នៅជំនាន់លោកសាការី
ដែលបានផ្តល់ដំបូន្មាន និងការណែនាំដល់ព្រះអង្គ។ ដរាបណាព្រះករុណាស្វែងរកព្រះអម្ចាស់ នោះព្រះជាម្ចាស់ធ្វើឲ្យព្រះករុណាកាន់តែរីកចម្រើនឡើង។
[6]ព្រះបាទអូសៀសចេញទៅច្បាំងនឹងពួកភីលីស្ទីន។ ព្រះករុណាបានរំលំកំពែងក្រុងកាថ ក្រុងយ៉ាបនេ និងក្រុងអាសដូឌ។ ស្តេចបានសង់ក្រុងនានាក្នុងស្រុកអាសដូឌ
និងក្នុងស្រុកភីលីស្ទីន។[7]ព្រះជាម្ចាស់បានជួយស្តេចប្រឆាំងនឹងជនជាតិភីលីស្ទីនប្រឆាំងនឹងជនជាតិអារ៉ាប់ដែលរស់នៅតំបន់ហ្គូបាអាល និងជនជាតិម៉ូន។
[8]ជនជាតិអាំម៉ូននាំគ្នាថ្វាយសួយសារអាករមកថ្វាយព្រះបាទអូសៀស ហើយកិត្តិនាមរបស់ព្រះអង្គក៏ល្បីរហូតដល់ច្រកចូលស្រុកអេស៊ីប
ព្រោះព្រះករុណាមានអំណាចយ៉ាងខ្លាំង។
[9]លើសពីនេះ ព្រះបាទអូសៀសបានសង់ប៉មនៅក្រុងយេរូសាឡិមនៅជ្រុងខ្លោងទ្វារ ច្រកទ្វារជ្រលងភ្នំ និងនៅកែងកំពែង ព្រមទាំងពង្រឹងឲ្យរឹងមាំ។
[10]ស្តេចបានសង់កន្លែងយាមនៅទីរហោស្ថានហើយជីកអណ្តូងជាច្រើនព្រោះ ស្តេចមានគោយ៉ាងច្រើននៅតំបន់ទំនាប និងនៅវាលទំនាប។ ស្តេចមានកសិដ្ឋាន
និងអ្នកដាំទំពាំងបាយជូរនៅតាមតំបន់ភ្នំ និងនៅចម្ការដែលមានផ្លែផ្កាជាច្រើនពីព្រោះស្តេចចូលចិត្តធ្វើស្រែចម្ការ។
[11]លើសពីនេះ
ព្រះអូសៀសមានកងទ័ពប្រយុទ្ធជាច្រើនដែលចេញទៅច្បាំងជាកងពលដែលបានរៀបចំឡើងតាមចំនួនរបស់ពួកគេដែលត្រូវបានជំរឿនដោយលោកយេអែលជាស្មៀន
និងលោកម៉ាសេយ៉ាដែលជាមន្ត្រីក្រោមអំណាចរបស់លោកហាណានាជាមេទ័ពរបស់ស្តេច។[12]មេក្រុមទាំងអស់នៃក្រុមគ្រួសារតាមវង្សត្រកូលមានចំនួន ២, ៦០០ នាក់។
[13]ក្រោមអំណាចពួកគេមានទាហានមួយកងពលដែលមានចំនួន ៣០៧, ៥០០ នាក់ដែលធ្វើសង្គ្រាមដោយមានឫទ្ធានុភាពខ្លាំងក្លា ដើម្បីជួយស្តេចប្រឆាំងនឹងខ្មាំងសត្រូវ។
[14]ព្រះបាទអូសៀសបានរៀបចំសម្រាប់ពួកគេ គឺសម្រាប់កងទ័ពទាំងអស់មានខែលលំពែងមួកដែកអាវក្រោះធ្នូ និងដង្ហក់បាញ់ថ្ម។[15]នៅក្រុងយេរូសាឡិម
ព្រះបាទអូសៀសឲ្យមនុស្សជំនាញផលិតគ្រឿងយន្ត ដើម្បីដាក់នៅលើប៉ម និងនៅសមរភូមិដែលអាចបាញ់ព្រួញ និងដុំថ្មធំៗ។
កិត្តិនាមរបស់ស្តេចល្បីល្បាញដល់ស្រុកឆ្ងាយៗ ដ្បិត ព្រះអម្ចាស់បានជួយយ៉ាងខ្លាំងរហូតដល់ព្រះករុណាមានកម្លាំងយ៉ាងខ្លាំងក្លា។
[16]ប៉ុន្តែ នៅពេលព្រះបាទអូសៀសក្លាយជាអ្នកមានអំណាច ព្រះករុណាមានចិត្តអំនួតធ្វើឲ្យស្តេចប្រព្រឹត្តអំពើអាក្រក់។ ស្តេចបានក្បត់ព្រះអម្ចាស់ជាព្រះរបស់ខ្លួន ដ្បិត
ស្តេចបានចូលទៅក្នុងដំណាក់របស់ព្រះអម្ចាស់ ដើម្បីដុតគ្រឿងក្រអូបនៅលើអាសនៈសម្រាប់ដុតគ្រឿងក្រអូប។
[17]លោកបូជាចារ្យអសារាដើរចូលមកតាមក្រោយព្រះអង្គហើយមានបូជាចារ្យរបស់ព្រះអម្ចាស់ចំនួនប៉ែតសិបនាក់ដែលជាមនុស្សក្លាហានមកជាមួយលោកផង។
[18]ពួកគេបានប្រឆាំងនឹងព្រះបាទអូសៀសជាស្តេចហើយទូលថា៖ «មិនមែនតួនាទីព្រះករុណាទេ ដែលត្រូវដុតគ្រឿងក្រអូបថ្វាយព្រះអម្ចាស់ ប៉ុន្តែ
គឺជាពួកបូជាចារ្យដែលជាកូនចៅរបស់លោកអើរ៉ុនដែលត្រូវបានគេតែងតាំងឲ្យដុតគ្រឿងក្រអូប។ ចូរព្រះករុណាចេញពីទីសក្ការៈទៅ។ ដ្បិត
ព្រះករុណាមិនស្មោះត្រង់ហើយព្រះករុណានឹងមិនទទួលការសរសើរពីព្រះអម្ចាស់ទេ»។
[19]ពេលនោះព្រះបាទអូសៀសខ្ញាល់យ៉ាងខ្លាំង។ ព្រះករុណាកាន់ពានគ្រឿងក្រអូបនៅក្នុងព្រះហស្ត ដើម្បីដុតគ្រឿងក្រអូប។
ពេលស្តេចខឹងនឹងពួកបូជាចារ្យនោះមានឃ្លង់កើតលើថ្ងាសនៅមុខពួកបូជាចារ្យក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ក្បែរអាសនៈដុតគ្រឿងក្រអូប។
[20]លោកមហាបូជាចារ្យអសារា និងពួកបូជាចារ្យទាំងអស់សម្លឹងមើលទៅស្តេច ហើយ មើល មានរោគឃ្លង់នៅលើថ្ងាសរបស់ស្តេច។
ពួកគេបានដេញស្តេចចេញពីទីនោះយ៉ាងលឿន។ ស្តេចក៏ប្រញាប់ប្រញាល់ចេញទៅក្រៅ ព្រោះព្រះអម្ចាស់បានដាក់ទោសស្តេច។
[21]ព្រះបាទអូសៀស ក្លាយជាមនុស្សឃ្លង់រហូតដល់ថ្ងៃសោយទិវង្គតហើយបានគង់នៅក្នុងព្រះដំណាក់ដាច់ដោយឡែកចាប់តាំងពីស្តេចបានក្លាយជាមនុស្សឃ្លង់ ហើយមិន
អាចចូលក្នុងព្រះដំណាក់របស់ព្រះអម្ចាស់បានឡើយ។ ព្រះបាទយ៉ូថាមជាបុត្រា មានភារកិច្ចមើលខុសត្រូវកិច្ចការក្នុងរាជវាំង និងទទួលបន្ទុកគ្រប់គ្រងប្រជាជននៅក្នុង
ស្រុក។
[22]រាជកិច្ចផ្សេងទៀតដែលទាក់ទងនឹងព្រះបាទអ៊ូសៀសគឺមានរៀបរាប់នៅក្នុងសៀវភៅ ព្យាការីអេសាយជាកូនរបស់លោកអម៉ុសបានសរសេរ។
[23]ព្រះបាទអូសៀសបានផ្ទំលក់ជាមួយពួកបុព្វបុរស។ ពួកគេបានបញ្ចុះសពទ្រង់ជាមួយជីដូនជីតារបស់ស្តេចនៅក្នុងផ្នូរដែលជាកម្មសិទ្ធិរបស់ស្តេចពីព្រោះពួកគេនិយាយថា
ទ្រង់ជាមនុស្សឃ្លង់។ ព្រះបាទយ៉ូថាមជាបុត្រាស្នងរាជ្យបន្ត។

---

2 Chronicles 26:1
ដប់ប្រាំមួយ ... ហាសិបពីរព្រះវស្សា
ពីរ «១៦ ... ៥២»
ក្រុងអេឡាត
នេះជាទីក្រុងមួយនៅឈូងសមុទ្រអាកាបា។
ព្រះរាជាបានផ្ទំលក់ជាមួយបុព្វបុរសរបស់ខ្លួន។
ការបកប្រែផ្សេងទៀត «ស្តេចបានសុគត»
2 Chronicles 26:4
ស្តេចបានប្រព្រឹត្តត្រឹមត្រូវគាប់ព្រះហឫទ័យព្រះអម្ចាស់។
សូមមើលការបកប្រែនៅក្នុង ១៤:១
ដោយយកតម្រាប់តាម
ការបកប្រែផ្សេងទៀត «តាមរបៀបដូចគ្នា»
ស្តេចតាំងខ្លួនចង់ស្វែងរក
ការបកប្រែផ្សេងទៀត «ទ្រង់បានប្តេជ្ញាចិត្តថា នឹងផ្គាប់ចិត្ត»
2 Chronicles 26:6
ក្រុងយ៉ាបនេ
នេះជាទីក្រុងមួយនៅភាគខាងជើងស្រុកយូដា។
តំបន់ហ្គូបាអាល
នេះជាទីក្រុងមួយនៅប្រទេសអារ៉ាប់។
ជនជាតិម៉ូន
ទំនងជាព្រះរាជាណាចក្រនៃប្រជាជនម៉ាអូន នៅក្បែរភ្នំសៀរ។
ច្រកចូលស្រុកអេស៊ីប
ការបកប្រែផ្សេងទៀត «ព្រំដែនស្រុកអេស៊ីប»
2 Chronicles 26:9

generated on Wed Sep 10 16:16:32 2025

អណ្តូង
អណ្តូងទឹកជាអាងដៅក្រោមដីធំមួយ ដែលត្រូវបានប្រើសម្រាប់រក្សាទុកទឹកភ្លៀង។
2 Chronicles 26:11
លោកយេអែលជាស្មៀន
និងលោកម៉ាសេយ៉ាដែលជាមន្ត្រីក្រោមអំណាចរបស់លោកហាណានាជាមេទ័ពរបស់ស្តេច។
២,៦០០ នាក់ ... ៣០៧,៥០០ នាក់
2 Chronicles 26:14
មួកដែក
មួកដែកសម្រាប់ការពារក្បាល។
អាវក្រោះ
នេះជាការគ្រប់បាំងដងខ្លួន ដែលធ្វើពីលោហៈធាតុភ្ជាប់គ្នា ឬច្រវាក់។
2 Chronicles 26:16
ព្រះករុណាមានចិត្តអំនួត
ការបកប្រែផ្សេងទៀត «ទ្រង់មានអំនួត»
ជាកូនចៅរបស់លោកអើរ៉ុន
ការបកប្រែផ្សេងទៀត «កូនចៅរបស់លោកអើរ៉ុន»
2 Chronicles 26:19
ពានគ្រឿងក្រអូប
នេះជាថាស ឬចានពិសេស ដែលត្រូវគេប្រើសម្រាប់ដុតគ្រឿងក្រអូប។
ពួកគេបានដេញស្តេចចេញពីទីនោះយ៉ាងលឿន។
ការបកប្រែផ្សេងទៀត «ពួកគេបានធ្វើឲ្យគាត់ចាកចេញភ្លាមៗ»
ព្រះអម្ចាស់បានដាក់ទោសស្តេច។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានធ្វើឲ្យគាត់ឈឺ»
2 Chronicles 26:21
ហើយបានគង់នៅក្នុងព្រះដំណាក់ដាច់ដោយឡែក
ចង្អុលបង្ហាញថា ស្តេចមានព្រះជន្មរស់នៅឆ្ងាយពីព្រះដំណាក់
និងមនុស្សផ្សេងទៀត។
2 Chronicles 26:22
មានរៀបរាប់
ការបកប្រែផ្សេងទៀត «គ្រប់អ្វីទាំងអស់»
កូនរបស់លោកអម៉ុស
ព្រះបាទអូសៀសបានផ្ទំលក់ជាមួយពួកបុព្វបុរស។
ការបកប្រែផ្សេងទៀត «ដូច្នេះ ព្រះបាទអូសៀសបានសុគត»

---

27 [1]ព្រះបាទយ៉ូថាមមានព្រះជន្មាយុ ២៥ ព្រះវស្សានៅពេលដែលស្តេចចាប់ផ្តើមសោយរាជ្យ។ ស្តេចសោយរាជ្យបានដប់ប្រាំមួយព្រះវស្សានៅក្រុងយេរូសាឡិម។
មាតាទ្រង់មានព្រះនាមយេរូសា ជាកូនស្រីរបស់លោកសាដុក។[2]ស្តេចបានធ្វើអ្វីៗដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ដោយយកតម្រាប់តាមព្រះបាទអូសៀស ជាបិតា។
ស្តេចព្យាយាមមិនចូលទៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់ទេ។ ប៉ុន្តែ ប្រជាជននៅតែមានអាកប្បកិរិយាអាក្រក់។
[3]ស្តេចបានសង់ខ្លោងទ្វារខាងលើនៃព្រះដំណាក់របស់ព្រះអម្ចាស់ហើយសង់នៅលើភ្នំអូផែល។[4]លើសពីនេះ ស្តេចបានសង់ក្រុងនានានៅលើភ្នំនៃស្រុកយូដា
និងសង់ព្រះដំណាក់នឹង ប៉មនៅក្នុងព្រៃផង។
[5]ស្តេចបានច្បាំងនឹងស្តេចជនជាតិអាំម៉ូន ហើយបានវាយឈ្នះពួកគេ។ នៅឆ្នាំដដែលនោះប្រជាជនអាំម៉ូន បានថ្វាយប្រាក់បួនតោនកន្លះ នឹងស្រូវសាលីមួយម៉ឺនរង្វាល់
ម៉្យាំមួយម៉ឺនរង្វាល់។ ប្រជាជនអាំម៉ូនបានថ្វាយសួយសារអាកដល់ស្តេចនៅឆ្នាំទីពីរ និងទីបី នៅចំនួនដដែល។
[6]ព្រះបាទយ៉ូថាមកាន់តែមានអំណាចខ្លាំងឡើងៗពីព្រោះស្តេចបានដើរតាមមាគ៌ាដ៏ត្រឹមត្រូវចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់ព្រះករុណា។[7]រាជកិច្ច
និងបញ្ហាផ្សេងទៀតទាក់ទងនឹងព្រះបាទយ៉ូថាម សង្គ្រាម និងមាគ៌ារបស់ស្តេចទាំងអស់ត្រូវបានកត់ទុកក្នុងសៀវភៅរបស់ស្តេចស្រុកអ៊ីស្រាអែល និងស្រុកយូដា។
[8]ព្រះករុណាមានជន្មាយុម្ភៃប្រាំព្រះវស្សា នៅពេលដែលស្តេចបានចាប់ផ្តើមសោយរាជ្យ។ ស្តេចសោយរាជ្យបានដប់ប្រាំមួយព្រះវស្សានៅក្រុងយេរូសាឡិម។
[9]ព្រះបាទយ៉ូថាមបានផ្ទំលក់ជាមួយបុព្វបុរសរបស់ព្រះករុណាហើយគេបញ្ចុះសពស្តេចនៅក្រុងព្រះបាទដាវីឌ។ ព្រះបាទអេហាសជាបុត្របានឡើងសោយរាជ្យជំនួស។

---

2 Chronicles 27:1
យេរូសា
ស្តេចបានធ្វើអ្វីៗដែលគាប់ព្រះហឫទ័យព្រះអម្ចាស់
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
ដោយយកតម្រាប់
ការបកប្រែផ្សេងទៀត «នៅក្នុងរបៀបដូចគ្នា»
2 Chronicles 27:3
នៅលើភ្នំអូផែល
នេះជាភ្នំនៅក្រុងយេរូសាឡឹម។
2 Chronicles 27:5
តោន
រង្វាល់
នៅឆ្នាំទីពីរ និងទីបី
ការបកប្រែផ្សេងទៀត «នៅឆ្នាំទីពីរនិងទីបី បន្ទាប់ពីស្តេចបានវាយឈ្នះពួកគេ»
2 Chronicles 27:6
ស្តេចបានដើរតាមមាគ៌ាដ៏ត្រឹមត្រូវចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់ព្រះករុណា។
ការបកប្រែផ្សេងទៀត «ទ្រង់បានស្តាប់បង្គាប់ព្រះអម្ចាស់ដោយមិនងាករេ» ឬ
«ទ្រង់មានព្រះជន្មរស់នៅថ្វាយព្រះអម្ចាស់»
សៀវភៅរបស់ស្តេចស្រុកអ៊ីស្រាអែល និងស្រុកយូដា។
សៀវភៅនេះលែងមានទៀតហើយ។
2 Chronicles 27:8
ព្រះបាទយ៉ូថាមបានផ្ទំលក់ជាមួយបុព្វបុរសរបស់ព្រះករុណា
ការបកប្រែផ្សេងទៀត «ព្រះបាទយ៉ូថាមបានសុគត»

---

28 [1]ព្រះបាទអហាសមានព្រះជន្មាយុម្ភៃព្រះវស្សា ពេលស្តេចឡើងសោយរាជ្យ ហើយសោយរាជ្យបានដប់ប្រាំមួយឆ្នាំនៅក្រុងយេរូសាឡិម។
ស្តេចមិនបានធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ដូចព្រះបាទដាវីឌជាអយ្យកោរបស់ខ្លួនទេ។[2]ស្តេចបានដើរតាមមាគ៌ារបស់ស្តេចស្រុកអ៊ីស្រាអែល
ក៏បានបង្កើតរូបសំណាកដែកសម្រាប់ព្រះបាលផងដែរ។
[3]លើសពីនេះ ស្តេចបានដុតគ្រឿងក្រអូបនៅជ្រលងភ្នំបេនហ៊ីណម
ហើយបានថ្វាយបុត្រជាយញ្ញបូជានៅក្នុងភ្លើងស្របតាមអំពើគួរឲ្យស្អប់ខ្ពើមរបស់ប្រជាជនដែលព្រះអម្ចាស់បានបណ្តេញចេញពីទឹកដីរបស់ពួកគេនៅចំពោះមុខជនជាតិអ៊ីស្រាអែលផង។
[4]ស្តេចបានធ្វើយញ្ញបូជា និងដុតគ្រឿងក្រអូបនៅកន្លែងសក្ការៈតាមទួលខ្ពស់ ៗនៅតាមភ្នំ និងនៅក្រោមដើមឈើបៃតង។
[5]ហេតុនោះ ព្រះអម្ចាស់ជាព្រះរបស់ព្រះបាទអហាសបានប្រគល់ស្តេចទៅក្នុងកណ្តាប់ដៃរបស់ស្តេចស្រុកស៊ីរី។ កងទ័ពស៊ីរីបានវាយយកជ័យជម្នះលើស្តេច
ហើយនាំអ្នកទោសដ៏ច្រើនកុះករចេញទៅឯក្រុងដាម៉ាស។ ព្រះបាទអហាសក៏ត្រូវបានប្រគល់ទៅក្នុងកណ្តាប់ដៃរបស់ស្តេចអ៊ីស្រាអែលដែលបានវាយឈ្នះស្តេច។
[6]លោកពេកា ជាកូនរបស់លោករេម៉ាលាបានសម្លាប់ទាហាននៅស្រុកយូដាចំនួនមួយម៉ឺនពីរពាន់នាក់ក្នុងមួយថ្ងៃ ពួកគេសុទ្ធតែជាមនុស្សក្លាហាន
ពីព្រោះពួកគេបានបោះបង់ចោលព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេ។
[7]លោកស៊ីគ្រីជាអ្នកចម្បាំងខ្លាំងពូកែម្នាក់មកពីអេប្រាអ៊ីមបានសម្លាប់សម្តេចម៉ាសេយ៉ាជាបុត្រារបស់ស្តេច លោកអ័រីកាំជាមន្ត្រីព្រះរមរាជវាំង និងលោកអែលកាណា
ជាអ្នកជំនិតនឹងព្រះរាជា។[8]កងទ័ពអ៊ីស្រាអែលបានចាប់ចងប្រពន្ធកូនប្រុសស្រីចំនួន ២០០, ០០០ នាក់ពីយូដាជាញាតិសន្តានខ្លួន។
ពួកគេក៏បានរឹបអូសយកទ្រព្យសម្បត្តិជាច្រើនដែលពួកគេបានដឹកត្រឡប់ទៅស្រុកសាម៉ារីវិញ។
[9]ប៉ុន្តែ មានព្យាការីរបស់ព្រះអម្ចាស់នៅទីនោះឈ្មោះរបស់គាត់គឺអូដេដ។ លោកចេញទៅទទួលទ័ពដែលចូលមកស្រុកសាម៉ារី។ លោកមានប្រសាសន៍ថា៖
«ព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់អ្នកទ្រង់ព្រះពិរោធនឹងស្រុកយូដា ដូច្នេះ

generated on Wed Sep 10 16:16:32 2025

ព្រះអង្គបានប្រគល់ពួកគេមកក្នុងកណ្តាប់ដៃរបស់អ្នកតែអ្នកបានសម្លាប់ពួកគេដោយកំហឹងដែលឡើងដល់ស្ថានបរមសុខ។[10]ឥឡូវនេះ
អ្នករាល់គ្នាមានបំណងទុកមនុស្សប្រុសស្រីនៃស្រុកយូដា និងក្រុងយេរូសាឡិមឲ្យធ្វើជាខ្ញុំបម្រើរបស់អ្នករាល់គ្នា។ ប៉ុន្តែ
តើអ្នកមិនមានបាបដែលបានធ្វើបាបនឹងព្រះអម្ចាស់ជាព្រះរបស់អ្នកទេឬ?[11]ឥឡូវនេះ
ចូរស្តាប់យើងសូមបញ្ជូនពួកអ្នកដែលអ្នករាល់គ្នាបានចាប់យកទៅពីបងប្អូនរបស់អ្នករាល់គ្នាឲ្យវិលទៅវិញទៅ ដ្បិត
ព្រះអម្ចាស់មានព្រះពិរោធចំពោះអ្នករាល់គ្នាខ្លាំងណាស់»។
[12]ពេលនោះ មានមេដឹកនាំរបស់កុលសម្ព័ន្ធអេប្រាអ៊ីមគឺលោកអសារាជាកូនរបស់យ៉ូហាណាន លោកបេរេគាជាកូនរបស់លោកមីសេលេម៉ូត
លោកយេហ៊ីសគាជាកូនរបស់លោកសាលូម និងលោកអម៉ាសាជាកូនរបស់លោកហាដឡៃបានក្រោកឈរប្រឆាំងនឹងអស់អ្នកដែលវិលត្រឡប់មកពីសង្គ្រាម។
[13]ពួកលោកមានប្រសាសន៍ទៅពួកគេថា៖ «អ្នករាល់គ្នាមិនត្រូវនាំអ្នកទោសមកទីនេះទេ ដ្បិត
អ្នករាល់គ្នាមានបំណងធ្វើបាបនឹងបន្ថែមអំពើបាបលើអំពើទុច្ចរិតរបស់យើងទាស់នឹងព្រះអម្ចាស់ ដ្បិត អំពើទុច្ចរិតរបស់យើងធំណាស់
ហើយមានសេចក្តីក្រោធយ៉ាងខ្លាំងប្រឆាំងនឹងអ៊ីស្រាអែល។
[14]ដូច្នេះ ពួកទាហានបានទុកអ្នកទោស និងរបស់បរជាជយភណ្ឌនៅចំពោះមុខពួកមេដឹកនាំ និងអង្គប្រជុំទាំងមូល។
[15]មនុស្សមួយចំនួនដែលបានជ្រើសរើសតាមឈ្មោះបានក្រោកឡើងចាប់ពួកអ្នកទោសហើយស្លៀកពាក់ឲ្យ អ្នកដែលអាក្រាតក្នុងចំណោមពួកគេ។
ពួកគេបានស្លៀកពាក់ឲ្យគេហើយឲ្យស្បែកជើងដល់ពួកគេផង។ ពួកគេឲ្យអាហារបរិភោគ និងទឹកផឹក។ ពួកគេបានព្យាបាលរបួសរបស់ពួកគេ
ហើយដាក់អ្នកទន់ខ្សោយលើសត្វលា។ ពួកគេបាននាំពួកគេត្រឡប់ទៅគ្រួសាររបស់ពួកគេនៅក្រុងយេរីខូរ (ហៅថាទីក្រុងដើមលម៉ើ)។ បន្ទាប់មក
ពួកគេបានវិលត្រឡប់ទៅស្រុកសាម៉ារីវិញ។
[16]នៅគ្រានោះ ព្រះបាទអហាសចាត់អ្នកនាំសារឲ្យទៅទូលស្តេចស្រុកអាស៊ីរីដើម្បីសុំឲ្យពួកគេជួយស្តេច។[17]ព្រោះជនជាតិអេដុមចូលមកវាយយកស្រុកយូដា
ហើយចាប់ប្រជាជននាំទៅជាឈ្លើយ។[18]ជនជាតិភីលីស្ទីនក៏វាយលុកចូលក្រុងនានានៅតំបន់ទំនាប និងតំបន់ណេកិបនៃស្រុកយូដា។ ពួកគេដណ្តើមយកក្រុងបេតសេមេស
ក្រុងអៃយ៉ាឡូន ក្រុងកេឌើរ៉ូត ក្រុងសូខូជាមួយភូមិនានា ក្រុងធីមណា និងភូមិនានាព្រមទាំងគីមសូជាមួយភូមិនានា។ ពួកគេបាននាំគ្នាទៅរស់នៅកន្លែងទាំងនោះ។
[19]ព្រះអម្ចាស់ធ្វើឲ្យស្រុកយូដាទន់ខ្សោយដោយសារតែស្តេចអេហាសជាស្តេចអ៊ីស្រាអែល។
ស្តេចបានប្រព្រឹត្តអំពើអាក្រក់នៅស្រុកយូដាហើយប្រព្រឹត្តអំពើបាបយ៉ាងធ្ងន់លើព្រះអម្ចាស់។[20]ព្រះបាទទីកឡាត-ពេលេស៊ើរ
ជាស្តេចស្រុកអាសស៊ើរបានលើកទ័ពចូលមកហើយធ្វើទុក្ខទោសស្តេចជាជាងគាំទ្រពង្រឹងកម្លាំងដល់ស្តេច។[21]ព្រះបាទអហាស
បានយកទ្រព្យសម្បត្តិពីព្រះដំណាក់របស់ព្រះអម្ចាស់ និងពីដំណាក់របស់ស្តេច និងពីផ្ទះពួកមេដឹកនាំដើម្បីថ្វាយដល់ស្តេចស្រុកអាស្ស៊ីរី។ ប៉ុន្តែ
ការធ្វើបែបនេះមិនបានផ្តល់ផលប្រយោជន៍ដល់ស្តេចទេ។
[22]នៅគ្រាលំបាកស្តេចអេហាសបានធ្វើបាបនឹងព្រះអម្ចាស់កាន់តែខ្លាំងឡើងៗ។[23]ស្តេចបានថ្វាយយញ្ញបូជាដល់ព្រះរបស់ក្រុងដាម៉ាសជាព្រះដែលបានវាយឈ្នះស្តេច។
ស្តេចមានរាជឱង្ការថា៖ «ដោយសារព្រះរបស់ស្តេចស្រុកស៊ីរីបានជួយពួកគេខ្ញុំនឹងថ្វាយយញ្ញបូជាដល់ពួកគេ ក្រែងលោកពួកគេអាចជួយខ្ញុំបាន» ។ ប៉ុន្តែ
ពួកគេបានបំផ្លាញព្រះអង្គ និងអ៊ីស្រាអែលទាំងមូល។
[24]ព្រះបាទអេហាសបានប្រមូលគ្រឿងសង្ហារឹមនៃព្រះដំណាក់របស់ព្រះជាម្ចាស់មកកាត់ជាចំណែកៗ ។ ស្តេចបានបិទទ្វារព្រះដំណាក់របស់ព្រះអម្ចាស់
ហើយស្តេចក៏សង់អាសនៈសម្រាប់ខ្លួនឯងនៅគ្រប់ជ្រុងនៃក្រុងយេរូសាឡិម។[25]នៅតាមក្រុងនីមួយៗនៃស្រុកយូដាស្តេចបានសង់កន្លែងសក្ការៈតាមទួលខ្ពស់ៗ
ដើម្បីធ្វើយញ្ញបូជាដល់ព្រះដទៃ។ ស្តេចបានធ្វើឲ្យព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ព្រះអង្គទ្រង់ព្រះពិរោធ។
[26]រាជកិច្ចទៀត និងការប្រព្រឹត្តទាំងអស់របស់ទ្រង់តាំងបីដើម និងដល់ចប់ សុទ្ធត្រូវបានកត់ទុកក្នុងសៀវភៅរបស់ស្តេចស្រុកយូដា និងអ៊ីស្រាអែល។[27]
ព្រះបាទអេហាសសោយទិវង្គតគេបានបញ្ចុះសពស្តេចនៅក្រុងយេរូសាឡិមតែគេពុំបានយកទៅបញ្ចុះក្នុងផ្នូររបស់ស្តេចអ៊ីស្រាអែលទេ។
ព្រះបាទហេសេគាជាបុត្រឡើងស្នងរាជ្យ។

---

2 Chronicles 28:1
ស្តេចមិនបានធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ដូចព្រះបាទដាវីឌជាអយ្យកោរបស់ខ្លួនទេ។
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
ស្តេចបានដើរតាមមាគ៌ារបស់ស្តេចស្រុកអ៊ីស្រាអែល ។
ការបកប្រែផ្សេងទៀត
«ស្តេចបានធ្វើបាបដូចស្តេចនានារបស់អ៊ីស្រាអែលនៅចំពោះព្រះអង្គ»
2 Chronicles 28:3
នៅជ្រលងភ្នំបេនហ៊ីណម
នេះជាជ្រលងភ្នំនៅទីក្រុងយេរូសាឡឹម។
នៅក្រោមដើមឈើបៃតង
ការបកប្រែផ្សេងទៀត «គ្រប់ទីកន្លែង»
2 Chronicles 28:5
លោកពេកា ជាកូនរបស់លោករេម៉ាលា
2 Chronicles 28:7
លោកស៊ីគ្រី ...សម្តេចម៉ាសេយ៉ា ... លោកអរីកាំ... លោកអែលកាណា
2 Chronicles 28:9
អូដេដ
ព្រះអង្គបានប្រគល់ពួកគេមកក្នុងកណ្តាប់ដៃរបស់អ្នក
ការបកប្រែផ្សេងទៀត «ព្រះអង្គជួយអ្នកឲ្យកម្ចាត់ពួកគេ»
ប៉ុន្តែ តើអ្នកមិនមានបាប ... ធ្វើបាបនឹងព្រះអម្ចាស់ជាព្រះរបស់អ្នកទេឬ?
ការបកប្រែផ្សេងទៀត «ប៉ុន្តែ ចូរចាំថាអ្នកមានកំហុស ...
ប្រឆាំងនឹងព្រះអម្ចាស់ជាព្រះរបស់អ្នក»។
2 Chronicles 28:12
លោកអសារាជាកូនរបស់យ៉ូហាណាន លោកបេរេគាជាកូនរបស់លោកមីសេលេម៉ូត
លោកយេហ៊ីសគាជាកូនរបស់លោកសាលូម និងលោកអម៉ាសាជាកូនរបស់លោកហាដឡៃ
2 Chronicles 28:14
ស្បែកជើង
ជាស្បែកជើងមួយប្រភេទ។
ព្យាបាលរបួសរបស់ពួកគេ
ការបកប្រែផ្សេងទៀត «ពួកគេបានផ្តល់ការយកចិត្តទុកដាក់ខាងថ្នាំពេទ្យ»
ដាក់អ្នកទន់ខ្សោយលើសត្វលា។
ការបកប្រែផ្សេងទៀត «បានឲ្យសត្វលាទៅអស់អ្នក ដែលមិនអាចដើរបាន»
2 Chronicles 28:16
ក្រុងបេតសេមេស ក្រុងអៃយ៉ាឡូន ក្រុងកេឌើរ៉ូត ក្រុងសូខូជាមួយភូមិនានា ក្រុងធីមណា
និងភូមិនានាព្រមទាំងគីមសូជាមួយភូមិនានា។
2 Chronicles 28:19
ព្រះអម្ចាស់ធ្វើឲ្យស្រុកយូដាទន់ខ្សោយដោយសារតែស្តេចអេហាស
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់បានបន្ទាបខ្លួនស្តេចអហាស»)
ព្រះបាទទីកឡាត-ពេលេស៊ើរ
នេះជាព្រះបាទទីកឡាត-ពេលេស៊ើរទី៣ ដែលត្រូវបានគេស្គាល់ផងដែរថា ពូល។
2 Chronicles 28:22
នៅគ្រាលំបាក
ការបកប្រែផ្សេងទៀត «ពេលស្តេចរងទុក្ខ»
ខ្ញុំនឹងថ្វាយយញ្ញបូជាដល់ពួកគេ
ការបកប្រែផ្សេងទៀត «ខ្ញុំនឹងលះបង់ពួកគេ»
2 Chronicles 28:24
គ្រឿងសង្ហារឹម
«គ្រឿងសង្ហារឹមនិងវត្ថុផ្សេងទៀត»
នៅគ្រប់ជ្រុងនៃក្រុងយេរូសាឡិម។
ការបកប្រែផ្សេងទៀត «នៅក្នុងក្រុងយេរូសាឡឹមទាំងមូល»

generated on Wed Sep 10 16:16:32 2025

29

[1]ព្រះបាទហេសេគាបានឡើងគ្រងនៅពេលព្រះករុណាមានព្រះជន្មាយុម្ភៃប្រាំព្រះវស្សាហើយសោយរាជ្យបានម្ភៃប្រាំបួនព្រះវស្សានៅក្រុងយេរូសាឡិម។
ព្រះមាតារបស់ព្រះអង្គមានព្រះនាមថា អប៊ីយ៉ា ជាកូនស្រីរបស់លោកសាការី។[2]ស្តេចបានធ្វើអ្វីដែលត្រឹមត្រូវគាប់ព្រះហឫទ័យព្រះអម្ចាស់ ដូចជាព្រះបាទដាវីឌ
ជាព្រះបិតាដែរ។
[3]ក្នុងឆ្នាំទីមួយនៃរជ្ជកាលរបស់ស្តេចគឺក្នុងខែទីមួយព្រះបាទហេសេគាបានបើកទ្វារព្រះដំណាក់របស់ព្រះអម្ចាស់ហើយជួសជុលឡើងវិញ។[4]ស្តេចបាននាំពួកបូជាចារ្យ
និងពួកលេវីឲ្យមកហើយប្រមូលពួកគេចូលទីធ្លាខាងកើត។[5]ព្រះករុណាមានរាជឱង្ការថា៖ «ពួកលេវីអើយ ចូរផ្ទៀងត្រចៀកស្តាប់យើង
ចូរញែកខ្លួនឲ្យបានវិសុទ្ធហើយញែកព្រះដំណាក់របស់ព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់អ្នកហើយដកការសៅហ្មងចេញពីទីសក្ការៈនៃព្រះចេញ។
[6]ដ្បិត ដូនតារបស់យើងបានប្រព្រឹត្តខុសនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់យើង។ ពួកគេបានបោះបង់ចោលព្រះអង្គ
ហើយបានបែរមុខចេញពីកន្លែងដែលព្រះអម្ចាស់គង់នៅ។[7]ពួកគេបិទទ្វារបន្ទប់ល្វែង និងដកចង្កៀងចេញ ពួកគេមិនបានដុតគ្រឿងក្រអូប
ឬថ្វាយតង្វាយដុតនៅកន្លែងសក្ការៈដល់ព្រះនៃជនជាតិអ៊ីស្រាអែលទេ។
[8]ហេតុនេះ ព្រះអម្ចាស់ព្រះពិរោធនឹងស្រុកយូដាព្រមទាំងក្រុងយេរូសាឡិមព្រះអង្គធ្វើឲ្យស្រុកនេះក្លាយទៅជាទីគួរឲ្យស្ញែងខ្លាច
និងគួរឲ្យស្អប់ខ្ពើមដូចអ្នកបានឃើញផ្ទាល់នឹងភ្នែក។[9]ហេតុនេះហើយបានជាបុព្វបុរសរបស់យើងបានស្លាប់ដោយមុខដាវកូនប្រុសកូនស្រី
និងភរិយារបស់យើងត្រូវជាប់ជាឈ្លើយ។
[10]ឥឡូវនេះ ខ្ញុំសម្រេចចិត្តចងសម្ពន្ធមេត្រីជាមួយព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែល ដើម្បីឲ្យព្រះពិរោធរបស់ព្រះអម្ចាស់ឃ្លាតឆ្ងាយពីយើង។
[11]កូនប្រុសទាំងឡាយអើយ កុំខ្ជិលច្រអូសឡើយ ដ្បិត ព្រះអម្ចាស់បានជ្រើសរើសអ្នកឲ្យឈរនៅចំពោះព្រះភក្ត្រព្រះអង្គ ដើម្បីគោរពបម្រើព្រះអង្គ
និងធ្វើជាអ្នកបម្រើរបស់ព្រះអង្គ និងដុតគ្រឿងក្រអូបផង»។
[12]ពួកលេវីបានក្រោកឡើង៖ លោកម៉ាហាត់ ជាកូនរបស់លោកអម៉ាសាយ និងលោកយ៉ូអែល ជាកូនរបស់លោកអសារាក្នុងអំបូរកេហាត់ ក្នុងអំបូរម៉្រារីមានលោកគីស
ជាកូនរបស់លោកអាបឌី និងលោកអសារា ជាកូនរបស់លោកលោកយេហាលែល។ ក្នុងចំណោមកូនចៅគើរសុនគឺលោកយ៉ូអា ជាកូនរបស់លោកស៊ីម៉្មា
និងលោកអែដែនជាកូនរបស់លោកយ៉ូអា។[13]កូនរបស់លោកអេលីសាផានគឺលោកស៊ីមរី និងលោកយីអែល។ ក្នុងអំបូរអេសាភ មានលោកសាការី និងលោកម៉ាថានា។
[14]កូនរបស់លោកហេម៉ានលោកយេហ៊ីអែល និងលោកស៊ីម៉ៃ និងកូនប្រុសៗរបស់យេឌូថិន មានលោកសេម៉ាយ៉ា និងលោកអ៊ូស៊ាល។
[15]ពួកគេបានប្រមូលបងប្អូនរបស់ពួកគេហើយពួកគេបានញែកខ្លួនចេញហើយពួកគេបានចូលតាមបញ្ជារបស់ព្រះករុណាដើម្បីសម្អាតដំណាក់របស់ព្រះអម្ចាស់។
[16]ពួកបូជាចារ្យចូលទៅផ្នែកខាងក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ដើម្បីធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធ។
ពួកគេបានយករបស់ទាំងប៉ុន្មានដែលមាននៅក្នុងទីសក្ការៈរបស់ព្រះអម្ចាស់ចូលទៅក្នុងទីធ្លានៃព្រះដំណាក់។ ពួកលេវីបានយកវាទៅកម្ទេចនៅជ្រោះកេដ្រូន។
[17]នៅថ្ងៃទីមួយនៃខែទីមួយ ពួកគេចាប់ផ្តើមធ្វើពិធីជម្រះកាយ។ នៅថ្ងៃទីប្រាំបីនៃខែទីមួយពួកគេបានទៅដល់បន្ទប់ល្វែងរបស់ព្រះអម្ចាស់។ បន្ទាប់មក
ពួកគេបានញែកព្រះដំណាក់របស់ព្រះអម្ចាស់អស់រយៈពេលប្រាំបីថ្ងៃទៀត។ នៅថ្ងៃទីដប់ប្រាំមួយនៃខែដំបូងពួកគេបានបញ្ចប់កិច្ចការងារ។
[18]បន្ទាប់មក ពួកគេចូលទៅគាល់ព្រះបាទហេសេគានៅខាងក្នុងព្រះបរមរាជវាំងហើយទូលថា៖
«យើងខ្ញុំបានសម្អាតអាសនៈទាំងអស់របស់ព្រះអម្ចាស់គឺអាសនៈសម្រាប់ថ្វាយតង្វាយដុតទាំងមូលជាមួយគ្រឿងបរិក្ខារទាំងអស់ព្រមទាំងតុតម្កល់នំប៉័ងនៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់រួមទ
[19]ដូច្នេះ យើងបានត្រៀមទុកហើយយើងបានញែកអ្វីៗទាំងអស់ដែលស្តេចអហាសបានយកប្រើប្រាស់មិនស្មោះត្រង់ពេលស្តេចសោយរាជ្យក្នុងរជ្ជកាលស្តេច។
[20]ពេលនោះ ព្រះបាទហេសេគាក្រោកពីព្រលឹម ហើយប្រមូលអ្នកដឹកនាំទីក្រុង ព្រះករុណាឡើងទៅព្រះដំណាក់របស់ព្រះអម្ចាស់។
[21]ចៀមឈ្មោលប្រាំពីរនិងកូនពពែប្រាំពីរក្បាលមកថ្វាយជាយញ្ញបូជារំដោះបាបសម្រាប់ព្រះរាជា សម្រាប់ទីសក្ការៈ និងសម្រាប់ប្រជាជនយូដា។
ព្រះករុណាបញ្ជាដល់ពួកបូជាចារ្យដែលជាកូនចៅរបស់លោកអើរ៉ុនឲ្យថ្វាយតង្វាយទាំងនេះនៅលើអាសនៈរបស់ព្រះអម្ចាស់។
[22]ដូច្នេះ ពួកគេបានសម្លាប់គោ ហើយពួកបូជាចារ្យបានទទួលឈាមហើយប្រោះឈាមលើកន្លែងថ្វាយតង្វាយ។
ពួកគេបានសម្លាប់សត្វចៀមហើយប្រោះឈាមនៅលើកន្លែងថ្វាយតង្វាយ។ ពួកគេបានសម្លាប់កូនចៀមហើយប្រោះឈាមនៅលើកន្លែងថ្វាយតង្វាយ។
[23]គេនាំពពែឈ្មោលសម្រាប់ធ្វើយញ្ញបូជារំដោះបាបនៅចំពោះព្រះភក្ត្រស្តេច និងអង្គប្រជុំ។ ពួកគេបានដាក់ដៃលើពួកគេ។
[24]ពួកបូជាចារ្យបានសម្លាប់សត្វទាំងនោះហើយពួកគេបានថ្វាយយញ្ញបូជារំដោះបាបដោយមានឈាមរបស់សត្វនៅលើកន្លែងថ្វាយតង្វាយ
ដើម្បីធ្វើពិធីលោះបាបឲ្យប្រជាជនអ៊ីស្រាអែលទាំងមូល។ ដ្បិត ព្រះករុណាបានបញ្ជឲ្យថ្វាយតង្វាយដុតទាំងមូល និងយញ្ញបូជាលោះបាបសម្រាប់ប្រជាជនអ៊ីស្រាអែល។
[25]ព្រះបាទហេសេគាដាក់ពួកលេវីក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ដោយកាន់ស្គរនិងពិណដែលមានចែងទុកតាមបញ្ជារបស់ព្រះបាទដាវីឌ លោកកាដគ្រូទាយរបស់ស្តេច
និងលោកណាថាន់ដែលជាព្យាការី។[26]ពួកលេវីឈរជាមួយឧបករណ៍របស់ព្រះបាទដាវីឌ ហើយពួកបូជាចារ្យកាន់ត្រែ។
[27]ព្រះបាទហេសេគាបង្គាប់ឲ្យគេថ្វាយតង្វាយដុតទាំងមូលនៅលើកន្លែងថ្វាយតង្វាយ។
ពេលគេថ្វាយតង្វាយដុតចប់ហើយចម្រៀងសរសើរព្រះអម្ចាស់ចាប់ផ្តើមមានសម្លេងត្រែព្រមទាំងឧបករណ៍របស់ព្រះបាទដាវីឌជាស្តេចស្រុកអ៊ីស្រាអែល។
[28]អង្គប្រជុំទាំងមូលថ្វាយបង្គំព្រះអ្នកចម្រៀងច្រៀង និងអ្នកផ្លុំត្រែបន្លឺឡើង ហើយអ្វីៗទាំងអស់នេះបន្តរហូតដល់ដង្វាយដុតបានចប់សព្វគ្រប់។
[29]ក្រោយពីបានថ្វាយតង្វាយចប់សព្វគ្រប់ហើយ ស្តេច និងអស់អ្នកដែលនៅជាមួយស្តេចក្រាបថ្វាយបង្គំ។[30]ព្រះបាទហេសេគាជាស្តេច
និងមេដឹកនាំបានបញ្ជាឲ្យពួកលេវីច្រៀងសរសើរតម្កើងព្រះអម្ចាស់ដោយទំនុកបរបស់ព្រះបាទដាវីឌ និងលោកអេសាភ។
ពួកគេច្រៀងសរសើរដោយអំណរហើយពួកគេបានឱនក្បាលថ្វាយបង្គំ។
[31]ព្រះបាទសេគាមានរាជឱង្ការថា៖ «ឥឡូវនេះ អ្នកបានញែកខ្លួនចេញថ្វាយព្រះអម្ចាស់
ហើយបាននាំយកយញ្ញបូជានិងតង្វាយអរព្រះគុណដល់ព្រះដំណាក់របស់ព្រះអម្ចាស់»។ ក្រុមជំនុំបានថ្វាយយញ្ញបូជា
និងយញ្ញបូជាអរព្រះគុណហើយអស់អ្នកដែលមានចិត្តស្មោះត្រង់បានយកតង្វាយដុតមកថ្វាយ។
[32]ចំនួនតង្វាយដុតដែលក្រុមជំនុំនាំមកថ្វាយនោះមានគោឈ្មោលចិតសិបក្បាល ចៀមឈ្មោលមួយរយក្បាល និងកូនចៀមឈ្មោលពីររយក្បាល។
អ្វីៗទាំងអស់នេះត្រូវថ្វាយជាតង្វាយដុតដល់ព្រះអម្ចាស់។[33]តង្វាយដែលត្រូវថ្វាយសម្រាប់ការញែកជាបរិសុទ្ធមានគោឈ្មោលប្រាំមួយរយក្បាល និងចៀមបីពាន់ក្បាល។
[34]ប៉ុន្តែ ដោយពួកបូជាចារ្យមានមានគ្នាតិចពេក មិនអាចបកស្បែកដង្វាយដុតទាំងមូលបានទាំងអស់ ដូច្នេះ
ពួកលេវីពួកគេបានជួយពួកគេរហូតដល់ធ្វើការហើយរហូតដល់ពួកបូជាចារ្យអាចធ្វើពិធីជម្រះខ្លួនឲ្យបានបរិសុទ្ធ ពីព្រោះពួកលេវីមានចិត្តខ្នះខ្នែង
និងប្រុងប្រយ័ត្នក្នុងការញែកខ្លួនជាបរិសុទ្ធជាងពួកបូជាចារ្យ។

[35]លើសពីនេះ មានតង្វាយដុតជាច្រើនទៀត។ ពួកគេបានយកខ្លាញ់របស់សត្វដែលថ្វាយជាយញ្ញបូជាមេត្រីភាព និងស្រាសម្រាប់ធ្វើតង្វាយច្រួចថែមទៀតផង។ ដូច្នេះ
ការគោរពព្រះដំណាក់របស់ព្រះអម្ចាស់បានរៀបរយ។[36]ព្រះបាទហេសេគា និងប្រជាជនទាំងមូលមានចិត្តរីករាយ ដោយព្រោះព្រះជាម្ចាស់បានត្រៀមទុកសម្រាប់ប្រជាជន
ដ្បិតការងារនេះបានធ្វើយ៉ាងលឿន។

---

2 Chronicles 29:1
អប៊ីយ៉ា
នេះជាឈ្មោះស្ត្រី។
ស្តេចបានធ្វើអ្វីដែលត្រឹមត្រូវគាប់ព្រះហឫទ័យព្រះអម្ចាស់
សូមមើលការបកប្រែដូចនៅក្នុង ១៤:១។
2 Chronicles 29:3
ក្នុងខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែមីនា
និងដើមខែមេសាតាមប្រតិទិនលោកខាងលិច។
ដកការសៅហ្មងចេញ
ការបកប្រែផ្សេងទៀត «ដកភាពមិនស្អាតចេញ» ឬ «ដកភាពកខ្វក់ចេញ»
2 Chronicles 29:6
បានប្រព្រឹត្តខុសនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់យើង។
សូមមើលការបកប្រែដូចនៅក្នុង ២១:៦
កន្លែងដែលព្រះអម្ចាស់គង់នៅ។
សូមមើលការបកប្រែដូចនៅក្នុង ១៨:១២
2 Chronicles 29:8
ជាទីគួរឲ្យស្ញែងខ្លាច និងគួរឲ្យស្អប់ខ្ពើម
ដូចអ្នកបានឃើញផ្ទាល់នឹងភ្នែក។
ការបកប្រែផ្សេងទៀត «ដូចដែលអ្នកបានឃើញដោយខ្លួនឯង»
ហេតុនេះហើយបានជាបុព្វបុរសរបស់យើងបានស្លាប់ដោយមុខដាវ
ការបកប្រែផ្សេងទៀត «នេះហើយជាមូលហេតុ ដែលបុព្វបុរសរបស់យើង
ត្រូវបានគេសម្លាប់ក្នុងសង្គ្រាម។»
2 Chronicles 29:10
ព្រះពិរោធរបស់ព្រះអម្ចាស់ឃ្លាតឆ្ងាយពីយើង។
ការបកប្រែផ្សេងទៀត
«ព្រះអង្គប្រហែលជាមិនសម្តែងសកម្មភាពព្រះពិរោធរបស់ព្រះអង្គ ចំពោះយើងទេ»
2 Chronicles 29:12
ព័ត៌មានទូទៅ៖
សូមមើល
2 Chronicles 29:15
នៅជ្រោះកេដ្រូន
ជ្រោះតូចមួយ ដែលហូរនៅខាងកើតក្រុងយេរូសាឡឹម។ នៅពេលខ្លះ
គេប្រើវាជាកន្លែងចាក់សំរាម។
នៅថ្ងៃទីមួយនៃខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ថ្ងៃដំបូងជាថ្ងៃ
ដែលព្រះអម្ចាស់នាំប្រជារាស្ត្រចេញពីស្រុកអេស៊ីប។
គឺនៅជិតពាក់កណ្តាលខែមីនាតាមប្រតិទិនលោកខាងលិច។
នៅថ្ងៃទីប្រាំបីនៃខែទីមួយ
នៅជិតចុងខែមីនាតាមប្រតិទិនលោកខាងលិច។
នៅថ្ងៃទីដប់ប្រាំមួយនៃខែដំបូង
នៅជិតដើមខែមេសាតាមប្រតិទិនលោកខាងលិច។
2 Chronicles 29:18
ពេលស្តេចសោយរាជ្យក្នុងរជ្ជកាលស្តេច។
ការបកប្រែផ្សេងទៀត «អំឡុងពេលស្តេចបានសោយរាជ្យ»
2 Chronicles 29:25
ស្គរ
សូមមើលការបកប្រែនៅក្នុង ៥:១១។
2 Chronicles 29:31
តង្វាយអរព្រះគុណ
ទាំងនេះជាការថ្វាយការអរព្រះគុណ។
អ្នកដែលមានចិត្តស្មោះត្រង់
ការបកប្រែផ្សេងទៀត «អ្នកមានចិត្តចង់»
2 Chronicles 29:32
ព័ត៌មានទូទៅ៖
សូមមើល
2 Chronicles 29:34
មានចិត្តខ្ទះខ្ទែង និងប្រុងប្រយ័ត្នក្នុងការញែកខ្លួនជាបរិសុទ្ធ
ការបកប្រែផ្សេងទៀត «បានប្រុងប្រយ័ត្នបន្ថែមទៀត
ដើម្បីអនុវត្តតាមច្បាប់នៃការសម្អាតខ្លួនជាបរិសុទ្ធ»
2 Chronicles 29:35
ពួកគេបានយកខ្លាញ់របស់សត្វដែលថ្វាយជាយញ្ញបូជាមេត្រីភាព
ការបកប្រែផ្សេងទៀត «បូជាចារ្យដុតខ្លាញ់សត្វ
ដែលនៅជាមួយដើម្បីថ្វាយយញ្ញបូជាមេត្រីភាពជាមួយព្រះអម្ចាស់។»
បានរៀបរយ
ការបកប្រែផ្សេងទៀត «ត្រូវបានបង្កើតឡើងវិញតាមរយៈបូជាចារ្យយោងតាមច្បាប់»

30

[1]ព្រះបាទហេសេគាបានចាត់អ្នកនាំសារឲ្យទៅស្រុកអ៊ីស្រាអែល និងយូដាទាំងមូលហើយបានសរសេរសំបុត្រទៅលោកអេប្រាអ៊ីម និងលោកម៉ាណាសេ
ដើម្បីឲ្យពួកគេចូលមកក្នុងព្រះដំណាក់របស់ព្រះអម្ចាស់នៅក្រុងយេរូសាឡិម ដើម្បីធ្វើពិធីបុណ្យចម្លងថ្វាយព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល។[2]ព្រះរាជា
ព្រមទាំងមេដឹកនាំ និងអង្គប្រជុំទាំងមូលនៅក្រុងយេរូសាឡិមបានពិភាក្សាគ្នាដោយសម្រេចចិត្តធ្វើពិធីបុណ្យចម្លងនៅខែទីពីរ។
[3]គេពុំអាចប្រារព្ធពិធីនេះបានភ្លាមៗទេព្រោះពួកបូជាចារ្យពុំទាន់បានញែកខ្លួនឲ្យបានវិសុទ្ធគ្រប់ចំនួននៅឡើយ ហើយប្រជាជនក៏ពុំបានជួបជុំគ្នានៅក្រុងយេរូសាឡិមដែរ។
[4]សំណើនេះហាក់ដូចជាត្រឹមត្រូវចំពោះព្រះភក្ត្រព្រះមហាក្សត្រ និងអង្គប្រជុំទាំងមូល។
[5]ពួកគេបានយល់ព្រមឲ្យប្រជាជនអ៊ីស្រាអែលទាំងមូលប្រកាសចាប់តាំងពីក្រុងបៀរសេបារហូតដល់ក្រុងដាន់ថា
ប្រជាជនគួរនាំគ្នាប្រារព្ធពិធីបុណ្យចម្លងថ្វាយព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែលនៅក្រុងយេរូសាឡិម។
ពីព្រោះពួកគេមិនមានកំណត់អំពីចំនួនមនុស្សដែលចូលរួមឡើយ។
[6]ដូច្នេះ គេនាំព្រះរាជសាររបស់ព្រះរាជានិងសំបុត្រមេដឹកនាំទាំងអស់ទៅកាន់ប្រជាជនអ៊ីស្រាអែលទាំងមូលតាមបញ្ជារបស់ព្រះរាជា។ ពួកគេប្រកាសថា៖
«ជនជាតិអ៊ីស្រាអែលអើយ! ចូរនាំគ្នាវិលត្រឡប់មករកព្រះអម្ចាស់ជាព្រះរបស់លោកអប្រាហាំ លោកអ៊ីសាក និងលោកអ៊ីស្រាអែលវិញ
ដើម្បីឲ្យព្រះអង្គវិលត្រឡប់ទៅរកអ្នករាល់គ្នាដែលនៅសេសសល់ពីកណ្តាប់ដៃរបស់ស្តេចស្រុកអាស្ស៊ីរី។
[7]កុំធ្វើដូចដូនតាអ្នក ឬបងប្អូនរបស់អ្នកដែលបានធ្វើខុសចំពោះព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេឡើយ ដូច្នេះ
ព្រះអង្គបានប្រគល់ពួកគេឲ្យវិនាសដូចអ្នករាល់គ្នាឃើញស្រាប់។[8]កុំធ្វើដូចជាដូនតារបស់អ្នកឡើយ។ ផ្ទុយទៅវិញ ចូរប្រគល់ខ្លួនឲ្យព្រះអម្ចាស់ហើយ
ចូលទៅក្នុងទីសក្ការៈរបស់ព្រះអង្គដែលព្រះអង្គបានញែកជារៀងរហូតហើយថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក ដើម្បីឲ្យព្រះពិរោធរបស់ព្រះអង្គបែរចេញពីអ្នក។
[9]ប្រសិនបើ អ្នករាល់គ្នាវិលត្រឡប់ទៅរកព្រះអម្ចាស់វិញ បងប្អូន និងកូនចៅរបស់អ្នកមុខជាអាណិតអាសូរចំពោះអស់អ្នកដែលនាំពួកគេទៅជាឈ្លើយ
ហើយពួកគេនឹងវិលត្រឡប់មកស្រុកនេះវិញ។ ដ្បិត ព្រះអម្ចាស់ជាព្រះរបស់អ្នកមានព្រះហឫទ័យប្រណីសន្តោស ហើយមិនងាកមុខចេញពីអ្នកទេ
ប្រសិនបើអ្នកវិលត្រឡប់មករកព្រះអង្គវិញ»។

generated on Wed Sep 10 16:16:32 2025

[10]អ្នកនាំសារឆ្លងពីក្រុងមួយទៅក្រុងមួយនៅទូទាំងតំបន់អេប្រាអ៊ីម និងម៉ាណាសេរហូតដល់សាប់យូឡូន ប៉ុន្តែ ប្រជាជនសើចចំអក ហើយមើលងាយដល់ពួកគេ។
[11]ទោះយ៉ាងណា មានមនុស្សខ្លះនៅក្រុងអេស៊ើរ ម៉ាណាសេ និងសាប់យូឡូនបានបន្ទាបខ្លួន ហើយបានមកដល់ក្រុងយេរូសាឡិម។
[12]ព្រះហស្តរបស់ព្រះជាម្ចាស់បានមកស្ថិតលើជនជាតិយូដា ដើម្បីឲ្យគេមានចិត្តតែមួយបំពេញតាមបញ្ជារបស់ស្តេច និងមេដឹកនាំតាមព្រះបន្ទូលរបស់ព្រះអម្ចាស់។
[13]មានមនុស្សជាច្រើនដែលបានប្រមូលផ្តុំគ្នា ជាអង្គប្រជុំដ៏ធំមួយនៅក្រុងយេរូសាឡិម ដើម្បីប្រារព្ធពិធីបុណ្យនំប៉័ងឥតមេនៅខែទី ២ ។
[14]ពួកគេក្រោកឡើងដកហូតអាសនៈនានានៅក្រុងយេរូសាឡិម និងអាសនៈសម្រាប់ដុតគ្រឿងក្រអូប ពួកគេបានបោះទៅក្នុងជ្រោះកេដ្រូន។
[15]គេសម្លាប់កូនចៀមសម្រាប់បុណ្យចម្លងនៅថ្ងៃទីដប់បួននៃខែទីពីរ។ ពួកបូជាចារ្យ និងពួកលេវីមានចិត្តអៀនខ្មាស ដូច្នេះ ពួកគេបានញែកខ្លួន
រួចហើយនាំយកតង្វាយដុតទៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។
[16]ពួកគេបានឈរនៅកន្លែងរបស់ពួកគេតាមការបែងចែករបស់ពួកគេដោយធ្វើតាមការណែនាំដែលបានចែងនៅក្នុងច្បាប់របស់លោកម៉ូសេ ជាអ្នកជំនិតរបស់ព្រះជាម្ចាស់។
ពួកបូជាចារ្យប្រោះឈាមដែលពួកគេទទួលពីដៃរបស់ពួកលេវី។[17]ពីព្រោះក្នុងក្រុមជំនុំមានមនុស្សជាច្រើនដែលមិនបានធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធ។ ហេតុនេះហើយ
បានជាពួកលេវីសម្លាប់កូនចៀមធ្វើពិធីបុណ្យចម្លងសម្រាប់អ្នកគ្រប់គ្នាដែលពុំបានញែកខ្លួនជាបរិសុទ្ធហើយមិនអាចថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់បាន។
[18]ក្នុងចំណោមប្រជាជនដ៏ច្រើននេះភាគច្រើនមកពីលោកអេប្រាអ៊ីម លោកម៉ាណាសេ លោកអ៊ីសាខា
និងលោកសាប់យូឡូនដែលមិនបានធ្វើពិធីជម្រះខ្លួនឲ្យបានបរិសុទ្ធនៅឡើយទេ តែពួកគេបានបរិភោគអាហារបុណ្យចម្លង ផ្ទុយពីសេចក្តីណែនាំដែលបានសរសេរទុកមក។
ព្រះបាទហេសេគាបានអធិស្ឋានឲ្យពួកគេដោយពោលថា៖
«សូមព្រះអម្ចាស់ប្រណីសន្តោសមនុស្សទាំងអស់[19]ដែលពួកគេមានចិត្តចង់ស្វែងរកព្រះជាម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេទោះបីពួកគេមិនបានញែកខ្លួនឲ្យបានស្អាតស្អំតាមកម្រិតនៃទីសក្ការ
[20]ដូច្នេះព្រះអម្ចាស់ព្រះសណ្តាប់ពាក្យរបស់ព្រះបាទហេសេគា ហើយបានប្រោសប្រជាជនឲ្យបានជា។
[21]ប្រជាជនអ៊ីស្រាអែលដែលមានវត្តមាននៅក្រុងយេរូសាឡិមបានប្រារព្ធពិធីបុណ្យនំប៉័ងឥតមេអស់រយៈពេលប្រាំពីរថ្ងៃដោយមានអំណរយ៉ាងខ្លាំង។ រៀងរាល់ថ្ងៃពួកលេវី
និងពួកបូជាចារ្យនាំគ្នាសរសើរតម្កើងព្រះអម្ចាស់ដោយច្រៀងចម្រៀង និងលេងឧបករណ៍តន្ត្រីយ៉ាងខ្លាំងថ្វាយព្រះអម្ចាស់។
[22]ព្រះបាទហេសេគាមានរាជឱង្ការលើកទឹកចិត្តប្រជាជនលេវីទាំងអស់ដែលយល់អំពីមុខងាររបស់ព្រះអម្ចាស់។ ដូច្នេះ
ពួកគេបរិភោគជារៀងរាល់ថ្ងៃរយៈពេលប្រាំពីរថ្ងៃដោយថ្វាយយញ្ញបូជាមេត្រីភាព និងលន់តួបាបនៅចំពោះព្រះអម្ចាស់ជាព្រះរបស់ដូនតារបស់គេ។
[23]បន្ទាប់មក អង្គប្រជុំទាំងមូលបានសម្រេចចិត្តប្រារព្ធពិធី ៧ ថ្ងៃទៀតហើយពួកគេក៏ធ្វើដូច្នេះដោយអំណរ។[24]ដ្បិតព្រះបាទហេសេគា
ជាស្តេចស្រុកយូដាបានថ្វាយគោឈ្មោលមួយពាន់ក្បាល និងចៀមប្រាំពីរពាន់ក្បាល។ មេដឹកនាំបានប្រគល់គោបាមួយពាន់ក្បាលចៀម និងពពែមួយម៉ឺនក្បាលឲ្យក្រុមជំនុំ។
មានបូជាចារ្យមួយចំនួនធំបានធ្វើពិធីញែកខ្លួនឲ្យបានបរិសុទ្ធនៅចំពោះព្រះអម្ចាស់។
[25]ក្រុមជំនុំទាំងប៉ុន្មាននៅស្រុកយូដាពួកបូជាចារ្យលេវី
និងប្រជាជនទាំងអស់ដែលមកជួបជុំគ្នានៅស្រុកអ៊ីស្រាអែលព្រមទាំងជនបរទេសដែលមកពីទឹកដីអ៊ីស្រាអែលនិងប្រជាជននៅស្រុកយូដាសុទ្ធតែសប្បាយរីករាយ។
[26]នៅក្រុងយេរូសាឡិមមានអំណរសប្បាយជាខ្លាំង
ព្រោះតាំងពីជំនាន់ព្រះបាទសាឡូម៉ូនជាបុត្ររបស់ព្រះបាទដាវីឌជាស្តេចស្រុកអ៊ីស្រាអែលមិនដែលមានសេចក្តីអំណរបែបនេះនៅក្រុងយេរូសាឡិមទេ។[27]ពួកបូជាចារ្យ
ពួកលេវីក៏ក្រោកឡើងប្រទានពរដល់ប្រជាជន។ សម្លេងរបស់គេ នឹងសេចក្តីអធិស្ឋានរបស់គេបានឮដល់ស្ថានសួគ៌ គឺជាកន្លែងបរិសុទ្ធ ជាកន្លែងដែលព្រះអម្ចាស់គង់នៅ។

---

2 Chronicles 30:1

សម្រេចចិត្តធ្វើពិធីបុណ្យចម្លងនៅខែទីពីរ។

ជាធម្មតាជនជាតិអ៊ីស្រាអែលធ្វើបុណ្យចម្លងក្នុងខែដំបូងតាមប្រតិទិនហេប្រឺ។
ខែដំបូងគឺអំឡុងពេលចុងខែមីនានិង ដើមខែមេសាតាមប្រតិទិនលោកខាងលិច។

នៅខែទីពីរ

នេះជាខែទីពីរតាមប្រតិទិនហេប្រឺ។ ជាកំឡុងពេលចុងខែមេសា
និងដើមខែឧសភានៅតាមប្រតិទិនលោកខាងលិច។

2 Chronicles 30:4

ចំពោះព្រះភក្ត្រ

សូមមើលការបកប្រែដូចនៅក្នុង ១៤:១

ក្រុងបៀរសេបារហូតដល់ក្រុងដាន់

ការបកប្រែផ្សេងទៀត «ប្រជាជនអ៊ីស្រាអែលទាំងអស់»

2 Chronicles 30:6

ព្រះរាជសារ

នេះជាមនុស្សម្នាក់ ដែលបានធ្វើព្រះរាជសារ។

2 Chronicles 30:7

ព្រះអង្គបានប្រគល់ពួកគេឲ្យវិនាស

ការបកប្រែផ្សេងទៀត «ព្រះអង្គបានធ្វើឲ្យពួកគេត្រូវបានបំផ្លាញ»

ចូរប្រគល់ខ្លួនឲ្យព្រះអម្ចាស់ហើយ

ការបកប្រែផ្សេងទៀត «ស្តាប់បង្គាប់ព្រះអម្ចាស់» ឬ «ថ្វាយខ្លួនដល់ព្រះអម្ចាស់»

2 Chronicles 30:13

នៅខែទី២

នេះជាខែទីពីរតាមប្រតិទិនហេប្រឺ។ ជាអំឡុងពេលចុងខែមេសា
និងដើមខែឧសភានៅតាមប្រតិទិនលោកខាងលិច។

ជ្រោះកេដ្រូន

នេះគឺជាអូរតូចមួយនៅជ្រលងភ្នំកេដ្រូន។

នៅថ្ងៃទីដប់បួននៃខែទីពីរ។

នៅជិតដើមខែឧសភានៅតាមប្រតិទិនលោកខាងលិច។

2 Chronicles 30:16

ពួកគេបានឈរនៅកន្លែងរបស់ពួកគេតាមការបែងចែករបស់ពួកគេ

ការបកប្រែផ្សេងទៀត «ពួកគេឈរនៅកន្លែងណាត់គ្នា»

កូនចៀមធ្វើពិធីបុណ្យចម្លង

ការបកប្រែផ្សេងទៀត «បានសម្លាប់កូនចៀមតាមទម្លាប់ធ្វើបុណ្យចម្លង»

2 Chronicles 30:21

ឧបករណ៍តន្ត្រី

នេះជាការបញ្ជាក់ទៅលើឧបករណ៍ភ្លេង។

---

31 [1]ក្រោយពីការទាំងអស់នេះបានចប់សព្វគ្រប់ហើយ ប្រជាជនអ៊ីស្រាអែលទាំងអស់ដែលនៅទីនោះ បាននាំគ្នាចេញដំណើរទៅតាមក្រុងនានានៅស្រុកយូដា
ហើយបានវាយបំបែកបង្គោលថ្ម ព្រមទាំងបានរំលំបង្គោលព្រះអាសេរ៉ា ហើយពួកគេបានរំលំកន្លែងសក្ការៈបូជា
និងអាសនៈនៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងស្រុកយូដា និងស្រុកបេនយ៉ាមីន ព្រមទាំងនៅក្នុងស្រុកអេប្រាអ៊ីម និងស្រុកម៉ាណាសេ។
បន្ទាប់មកជនជាតិអ៊ីស្រាអែលទាំងអស់វិលត្រឡប់ទៅផ្ទះ និងក្រុងរៀងៗខ្លួនវិញ។
[2]ព្រះបាទហេសេគាចាត់តាំងពួកបូជាចារ្យ និងពួកលេវីឲ្យបំពេញមុខងារតាមក្រុមរបស់ខ្លួនរៀងៗខ្លួន
ហើយម្នាក់ៗត្រូវបានតែងតាំងឲ្យបំពេញមុខងាររបស់ខ្លួនទាំងពួកបូជាចារ្យ និងពួកលេវីរៀងៗខ្លួន។ ស្តេចតែងតាំងពួកគេឲ្យតង្វាយដុតទាំងមូល និងយញ្ញបូជាមេត្រីភាព
បម្រើការងារ ការអរព្រះគុណ និងសរសើរនៅមាត់ទ្វារព្រះវិហារព្រះម្ចាស់។[3]ព្រះរាជាបានយករាជទ្រព្យមួយចំណែក សម្រាប់បង់ចំណាយទៅលើតង្វាយដុតទាំងមូល ដែល
ត្រូវថ្វាយនៅពេលព្រឹក នៅពេលល្ងាច នៅថ្ងៃសប្ប័ទ នៅបុណ្យដើមខែ និងបុណ្យសំខាន់ៗផ្សេងទៀត ដូចមានចែងទុកក្នុងក្រឹត្យវិន័យរបស់ព្រះអម្ចាស់។
[4]លើសពីនេះ ស្តេចបានចេញរាជបញ្ជាឲ្យប្រជាជនដែលរស់នៅក្រុងយេរូសាឡិមត្រូវចែកចំណែករបស់ដល់បូជាចារ្យ និងពួកលេវី
ដើម្បីឲ្យពួកគេផ្គង់ស្មារតីធ្វើតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់។[5]ក្រោយពីទទួលបានបញ្ជានេះ ប្រជាជនអ៊ីស្រាអែលបានយកផលដំបូងនៃស្រូវ ស្រាទំពាំងបាយជូរថ្មី ប្រេង
ទឹកឃ្មុំ និងពីអ្វីៗដែលពួកគេបានច្រូតពីចម្ការរបស់ពួកគេទាំងអស់មកថ្វាយ។ ពួកគេបានយកមួយភាគដប់នៃអ្វីៗទាំងអស់។ ដែលជាបរិមាណដ៏អស្ចារ្យ។

generated on Wed Sep 10 16:16:32 2025

[6]ជនជាតិអ៊ីស្រាអែល និងជនជាតិយូដាដែលរស់នៅតាមក្រុងនានានៅក្នុងស្រុកយូដាបាននាំយកដង្វាយជាគោ និងចៀម
មកថ្វាយជាតង្វាយមួយភាគដប់ថ្វាយព្រះអម្ចាស់ជាព្រះរបស់ពួកគេ ហើយពួកគេដាក់តង្វាយទាំងនោះជាច្រើនគំនរ។[7]ពួកគេបានចាប់ផ្តើមប្រមូលតង្វាយមកដាក់ជាគំនរ
ចាប់ពីខែទីបី រហូតដល់ខែទីប្រាំពីរ។[8]ពេលព្រះបាទហេសេគា និងអ្នកដឹកនាំបានឃើញគំនរតង្វាយទាំងនោះ ពួកគេនាំគ្នាអរព្រះគុណដល់ព្រះអម្ចាស់ និង ដល់ប្រជារាស្ត្រ
របស់ព្រះអង្គគឺជនជាតិអ៊ីស្រាអែល។
[9]បន្ទាប់មក ព្រះបាទហេសេគាបានសាកសួរពួកបូជាចារ្យ និងពួកលេវីអំពីគំនរទាំងនេះ។[10]លោកអសារា ជានាយកបូជាចារ្យនៃក្រុមគ្រួសារលោកសាដុកឆ្លើយថា៖
«ចាប់តាំងពីប្រជាជនចាប់ផ្តើមនាំតង្វាយចូលព្រះដំណាក់របស់ព្រះអម្ចាស់យើងបានបរិភោគហើយមាននៅសល់ជាច្រើនហើយនៅសល់ជាច្រើនទៀត
ដ្បិតព្រះអម្ចាស់ប្រទានពរដល់ប្រជារាស្ត្ររបស់ព្រះអង្គ។ អ្វីដែលនៅសេសសល់គឺចំនួនដ៏ច្រើននៅទីនេះ។
[11]ព្រះបាទហេសេគាបានចេញរាជបញ្ជាឲ្យគេរៀបចំឃ្លាំងក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។[12]នោះ ពួកគេបានស្មោះត្រង់ក្នុងការនាំយកតង្វាយផ្សេងៗ មួយភាគដប់
និងអ្វីៗដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់។ លោកកូណានា ជាលេវី គឺជាអ្នកមើលខុសត្រូវលើពួកគេ ហើយលោកស៊ីម៉ែជាបងប្អូនរបស់គាត់ជាអ្នកកាន់តំណែងទីពីរ។
[13]លោកយេហ៊ីអែល លោកអសាស៊ា លោកណាហាត លោកអេសាអែល លោកយេរីម៉ុត លោកយ៉ូសាបាដ លោកអេលាល លោកយីសម៉ាគា លោកម៉ាហាត និងលោក
បេណាយ៉ា ធ្វើការនៅក្រោមបញ្ជារបស់លោកកូណានា និងលោកស៊ីម៉ែ ជាប្អូន តាមការតែងតាំងរបស់ព្រះបាទហេសេគាជាស្តេច
និងលោកអសារាជាអ្នកមើលខុសត្រូវលើព្រះដំណាក់របស់ព្រះជាម្ចាស់។
[14]លោកកូរេ ជាកូនរបស់លោកអ៊ីមណាពីពួកលេវី ដែលជាឆ្មាំខ្លោងទ្វារខាងកើត ទទួលបន្ទុកលើតង្វាយស្ម័គ្រចិត្ត ដែលប្រជាជនយកមកថ្វាយព្រះជាម្ចាស់ ហើយលោកក៏
ទទួលភារកិច្ចចែកស្បៀងអាហារ ដែលប្រជាជនញែកថ្វាយព្រះអម្ចាស់ និងតង្វាយសក្ការៈបំផុតឯទៀតៗដែរ។[15]លោកមានសហការី នៅតាមក្រុងនានារបស់បូជាចារ្យ
សហការីទាំងនោះមានលោកអេដែន លោកមីនីយ៉ាមីន លោកយេសួរ លោកសេម៉ារា លោកអម៉ារា និងលោកសេកានា ជាអ្នកជួយចែកស្បៀងអាហារយ៉ាងស្មោះត្រង់ដល់
បូជាចារ្យ ទាំងតូច ទាំងធំតាមជាន់ថ្នាក់។
[16]ពួកគេចែកស្បៀងអាហារឲ្យពួកប្រុសៗដែលមានអាយុបីឆ្នាំឡើងទៅ គឺអស់អ្នកដែលមានឈ្មោះក្នុងបញ្ជីដូនតារបស់ពួកគេ
ដែលបានចូលទៅក្នុងដំណាក់របស់ព្រះអម្ចាស់ ដូចដែលលបានតម្រូវតាមវេនប្រចាំថ្ងៃ ដើម្បីធ្វើការងារនៅក្នុងមុខងាររបស់ពួកគេ និងការបែងចែករបស់ពួកគេ។
[17]ពួកគេចែកជូនដល់ពួកបូជាចារ្យស្របតាមបញ្ជីបុព្វបុរសរបស់ខ្លួន និងចែកជូនកុលសម្ព័ន្ធលេវីដែលមានអាយុពីម្ភៃឆ្នាំឡើងទៅស្របតាមមុខងារ
និងក្រុមគ្រួសាររបស់ខ្លួន។[18]ពួកគេរាប់បញ្ចូលទាំងកូនតូចៗប្រពន្ធកូន និងកូនស្រីរបស់ពួកគេពាសពេញសហគមន៍ ព្រោះពួកគេស្មោះត្រង់ក្នុងការរក្សាខ្លួនឲ្យបានបរិសុទ្ធ។
[19]ចំណែក ពួកបូជាចារ្យដែលជាកូនចៅរបស់លោកអើរ៉ុនដែលរស់នៅតាមវាលស្រែក្នុងភូមិជាកម្មសិទ្ធិទីក្រុងរបស់ពួកគេ
ឬនៅតាមទីក្រុងនីមួយៗគេបានជ្រើសរើសបុរសមួយចំនួនតាមឈ្មោះ ដើម្បីចែកចំណែកឲ្យប្រុសៗក្នុងចំណោមពួកបូជាចារ្យ
និងអស់អ្នកដែលមានឈ្មោះកត់ទុកនៅក្នុងបញ្ជីរបស់ដូនតារបស់ពួកគេ ដូចពួកអ្នកដែលនៅក្នុងចំណោមកុលសម្ព័ន្ធលេវីដែរ។
[20]ព្រះបាទបានហេសេគាធ្វើអ្វីៗទាំងអស់ក្នុងស្រុកយូដា។ ស្តេចបានសម្រេចអ្វីៗដែលល្អត្រឹមត្រូវ និងស្មោះត្រង់នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ជាព្រះរបស់ព្រះអង្គ។
[21]នៅក្នុងគ្រប់កិច្ចការទាំងអស់ដែលស្តេចចាប់ផ្តើមធ្វើ ក្នុងការបម្រើនៅក្នុងព្រះដំណាក់ព្រះអម្ចាស់ និង ក្រឹត្យវិន័យ និងបទបញ្ញត្តិនានា
ស្តេចបានធ្វើវាយ៉ាងអស់ពីព្រះហឫទ័យ ហើយស្តេចបានទទួលជោគជ័យ។

---

2 Chronicles 31:1

ជនជាតិអ៊ីស្រាអែលទាំងអស់វិលត្រឡប់

អ្នកអាចយកវាជា។ ការបកប្រែផ្សេងទៀត «ជនជាតិអ៊ីស្រាអែលស្ទើរតែទាំងអស់»

2 Chronicles 31:2

បានយករាជទ្រព្យមួយចំណែក សម្រាប់បង់ចំណាយទៅលើតង្វាយដុតទាំងមូល

ព្រះបាទហេសេគាបានយកសាច់ និងធញ្ញជាតិដែលត្រូវប្រើសម្រាប់តង្វាយដុត
ចេញពីរាជទ្រព្យផ្ទាល់ខ្លួនរបស់ព្រះអង្គ។

នៅបុណ្យដើមខែ

នេះជាពិធីបុណ្យមួយស្របគ្នានឹងចលនាព្រះចន្ទ។

បុណ្យសំខាន់ៗផ្សេងទៀត

យោងតាមពិធីបុណ្យ ដែលប្រារព្ធឡើងតាមកាលបរិច្ឆេទជាក់លាក់។

2 Chronicles 31:4

មួយភាគដប់នៃអ្វីៗទាំងអស់។

«មួយភាគដប់នៃផលដំណាំទាំងអស់របស់ពួកគេ»

2 Chronicles 31:6

ពីខែទីបី

នេះជាខែទីបីតាមប្រតិទិនហេប្រឺ។ នៅចុងបញ្ចប់នៃរដូវច្រូតកាត់ និងដើមរដូវប្រាំង។
ជាអំឡុងពេលចុងខែឧសភា និងដើមខែមិថុនាតាមប្រតិទិនលោកខាងលិច។

ខែទីប្រាំពីរ

នេះជាខែទីប្រាំពីរតាមប្រតិទិនហេប្រឺ។ ជារដូវវស្សាដែលនឹងធ្វើឲ្យដីសាបព្រោះទន់។
ជាអំឡុងពេលចុងខែកញ្ញានិងដើមខែតុលាតាមប្រតិទិនលោកខាងលិច។

2 Chronicles 31:9

អ្វីដែលនៅសេសសល់គឺចំនួនដ៏ច្រើននៅទីនេះ។

លោកនាយកបូជាចារ្យបានចង្អុលទៅគំនរធំមួយ។

2 Chronicles 31:14

លោកកូរេ ជាកូនរបស់លោកអ៊ីមណា ... លោកអេដែន លោកមីនីយ៉ាមីន លោកយេសួរ លោក
សេម៉ារា លោកអម៉ារា និងលោកសេកានា

លោកមានសហការី

«នៅក្រោមអំណាចរបស់លោក»

ទាំងតូច ទាំងធំតាមជាន់ថ្នាក់។

«អ្នករាល់គ្នា»

2 Chronicles 31:16

មានអាយុបីឆ្នាំឡើងទៅ

ការបកប្រែផ្សេងទៀត «អាយុបីឆ្នាំឡើងទៅ»

ដូចដែលលបានតម្រូវតាមវេនប្រចាំថ្ងៃ

ការបកប្រែផ្សេងទៀត «ដូចដែលត្រូវបានតម្រូវរៀងរាល់ថ្ងៃ»

---

32 [1]ក្រោយការទាំងនេះមក បន្ទាប់ពីព្រះបាទហេសេគាបង្ហាញភក្តីភាពចំពោះព្រះជាម្ចាស់នោះមក ព្រះបាទសានហេរីប ជាស្តេចស្រុកអាស្ស៊ីរី បានមក
ហើយបានចូលមកក្នុងស្រុកយូដា។ ស្តេចបានបោះជំរំ ហើយបានវាយប្រហារសែសិបទីក្រុង ស្តេចមានគោលបំណងចង់ចាប់យកដើម្បីព្រះអង្គផ្ទាល់។
[2]កាលព្រះបាទហេសេគាបានឃើញថាព្រះបាទសានហេរីបមកដល់ហើយមានបំណងធ្វើសង្គ្រាមនឹងក្រុងយេរូសាឡិម។[3]ស្តេចបានពិគ្រោះយោបល់ជាមួយមេដឹកនាំ
និងអ្នកដែលមានអំណាចរបស់ព្រះអង្គឲ្យបញ្ឈប់ប្រភពទឹកដែលនៅខាងក្រៅទីក្រុង ពួកគេបានជួយធ្វើការនោះ។
[4]មានមនុស្សជាច្រើនបានប្រមូលផ្តុំគ្នាហើយបញ្ឈប់ប្រភពទឹក និងប្រឡាយទាំងអស់ដែលហូរកាត់តំបន់នោះ។ ពួកគេនិយាយថា៖
«ហេតុអ្វីបានជាត្រូវទុកឲ្យស្តេចស្រុកអាស្ស៊ីរីមានទឹកច្រើនប្រើ?»។
[5]ព្រះបាទហេសេគាមានចិត្តក្លាហាននិងសង់កំពែងទាំងអស់ដែលបាក់បែក។ ស្តេចបានសង់ប៉មខ្ពស់ៗ និងជញ្ជាំងមួយទៀតនៅខាងក្រៅ។
ស្តេចក៏បានពង្រឹងក្រុងមីលឡូនៅក្នុងក្រុងព្រះបាទដាវីឌដែរ ហើយស្តេចក៏ធ្វើគ្រឿងសព្វាវុធ និងខែលយ៉ាងច្រើន។
[6]ស្តេចបានតែងតាំងមេបញ្ជាការយោធាលើប្រជាជន។ ស្តេចបានប្រមូលពួកគេមកជួបនៅតាមផ្លូវធំ នៅមាត់ទ្វារក្រុងហើយមានរាជឱង្កាលើកទឹកចិត្តពួកគេ។
ស្តេចមានរាជឱង្កាថា៖[7]«ចូរមានកម្លាំងនិងចិត្តក្លាហានឡើង។ កុំភ័យខ្លាច កុំធ្លាក់ទឹកចិត្ត ព្រោះតែស្តេចស្រុកអាស្ស៊ីរី និងកងទ័ពទាំងមូលដែលនៅជាមួយទ្រង់ឡើយ ដ្បិត
មានម្នាក់ដែលនៅជាមួយយើងដែលធំជាងអ្នកដែលនៅជាមួយស្តេចទៅទៀត។[8]ស្តេចមានតែកម្លាំងមនុស្សលោកប៉ុណ្ណោះ ប៉ុន្តែ ព្រះអម្ចាស់ជាព្រះនៃយើង គង់ជាមួយយើង

generated on Wed Sep 10 16:16:32 2025

ដើម្បីជួយយើង ហើយយើងនឹងប្រយុទ្ធនៅក្នុងសមរភូមិរបស់យើង។ ជនជាតិអ៊ីស្រាអែលទទួលការកំសាន្តចិត្តដោយព្រោះពាក្យរបស់ព្រះបាទហេសេគា
ជាស្តេចស្រុកយូដា។
[9]បន្ទាប់មក ព្រះបាទសានហេរីប ជាស្តេចស្រុកអាស្ស៊ីរីបានចាត់អ្នកបម្រើរបស់ព្រះអង្គឲ្យទៅក្រុងយេរូសាឡិម (ដ្បិត ស្តេច និងពួកពលទ័ពបាននៅទីក្រុងឡាគីសហើយ)
ដើម្បីចូលគាល់ ព្រះបាទហេសេគា ជាស្តេចស្រុកយូដា និងកងទ័ពយូដាទាំងមូលដែលនៅក្រុងយេរូសាឡិម។ លោកមានប្រសាសន៍ថា៖[10]«នេះជាអ្វីដែលព្រះបាទសាន
ហេរីបជាស្តេចស្រុកអាស្ស៊ីរីមានរាជឱង្ការថា៖ «តើអ្នកពឹងផ្អែកលើអ្វី ដើម្បីទ្រាំទ្រនឹងការឡោមព័ទ្ធក្រុងយេរូសាឡិម?
[11]តើព្រះបាទហេសេគាមិនបានបញ្ឆោតអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាស្លាប់ ដោយអត់បាយ អត់ទឹក ដោយស្តេចប្រាប់ថា៖ «ព្រះអម្ចាស់ជាព្រះនៃយើងនឹងរំដោះយើងឲ្យរួច
ពីកណ្តាប់ដៃរបស់ស្តេចស្រុកអាស្ស៊ីរីមិនខាន?[12]តើមិនមែនព្រះបាទហេសេគា ដែលបានបំផ្លាញទីសក្ការៈនៅតាមទួលខ្ពស់ៗ ព្រមទាំងកម្ទេចអាសនៈរបស់ព្រះអម្ចាស់
ហើយបង្គាប់ឲ្យអ្នកស្រុកយូដា និងអ្នកក្រុងយេរូសាឡិម គោរពថ្វាយបង្គំអាសនៈតែមួយ ហើយដុតគ្រឿងក្រអូបតែលើអាសនៈមួយនោះវិញទេឬអី?
[13]តើអ្នករាល់គ្នាមិនដឹងទេឬអីថា យើង និងដូនតារបស់យើងប្រព្រឹត្តបែបណា ចំពោះជាតិសាសន៍ដទៃទៀតលើផែនដីនេះ? តើព្រះរបស់ប្រជាជាតិទាំងឡាយបានរំដោះស្រុក
របស់ខ្លួន ឲ្យរួចពីកណ្តាប់ដៃរបស់យើងឬទេ?[14]ក្នុងចំណោមព្រះរបស់ប្រជាជាតិទាំងប៉ុន្មាន ដែលដូនតារបស់យើងបំផ្លាញ តើមានព្រះណាមួយអាចរំដោះប្រជាជនរបស់ខ្លួន
ឲ្យរួចពីកណ្តាប់ដៃរបស់យើងបាន? តើព្រះរបស់អ្នករាល់គ្នាអាចរំដោះអ្នករាល់គ្នា ឲ្យរួចពីកណ្តាប់ដៃរបស់យើងបានឬអី?[15]ឥឡូវនេះ មិនត្រូវឲ្យស្តេចហេសេគាបញ្ឆោតអ្នក
រាល់គ្នា នៅពេលនេះ កុំជឿតាមសំដីរបស់ស្តេចបែបនេះឡើយ! ដ្បិតគ្មានព្រះរបស់ប្រជាជាតិណាមួយ ឬនគរណាមួយ អាចរំដោះប្រជាជនរបស់ខ្លួនឲ្យរួចពីកណ្តាប់ដៃរបស់
យើង ឬដូនតារបស់យើងបានឡើយ។ តើព្រះរបស់អ្នករាល់គ្នាអាចរំដោះអ្នករាល់គ្នាឲ្យរួចពីកណ្តាប់ដៃរបស់យើងបានដោយរបៀបណា?»។
[16]ពួករាជបម្រើរបស់ព្រះបាទសានហេរីបបាននិយាយប្រមាថព្រះអម្ចាស់ដ៏ជាព្រះ និងព្រះបាទហេសេគា ជាអ្នកបម្រើរបស់ព្រះអង្គថែមទៀត។
[17]ព្រះបាទសានហេរីបក៏បានសរសេរសំបុត្រផ្សេងៗ ដើម្បីប្រមាថមើលងាយព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល និងឲ្យគេនិយាយប្រឆាំងនឹងព្រះអង្គដែរ។
ស្តេចមានរាជឱង្ការថា៖ «ដូចជាព្រះរបស់ប្រជាជាតិនានានៅលើទឹកដីដែលមិនបានរំដោះប្រជាជនរបស់ខ្លួនឲ្យរួចពីកណ្តាប់ដៃរបស់យើង ដូច្នេះ
ព្រះនៃព្រះបាទហេសេគានឹងមិនរំដោះប្រជាជនរបស់ព្រះអង្គឲ្យរួចពីកណ្តាប់ដៃរបស់យើងឡើយ»។
[18]ពួកគេបាននាំគ្នាស្រែកប្រកាសយ៉ាងខ្លាំងៗជាភាសាយូដា ទៅកាន់ប្រជាជននៅក្នុងក្រុងយេរូសាឡិម ដែលស្ថិតនៅតាមកំពែង ដើម្បីធ្វើឲ្យភ័យខ្លាច និងតក់ស្លុត ដើម្បីឲ្យ
ពួកគេងាយចូលវាយយកទីក្រុង។[19]ពួកគេបាននិយាយអំពីព្រះនៃក្រុងយេរូសាឡិម
ដូចដែលពួកគេបាននិយាយអំពីព្រះរបស់ប្រជាជាតិនានានៅលើផែនដីដែលគ្រាន់តែជាស្នាដៃរបស់មនុស្សប៉ុណ្ណោះ។
[20]ព្រះបាទហេសេគាជាស្តេច និងព្យាការីអេសាយជាកូនរបស់លោកអម៉ុសបានអធិស្ឋានព្រោះតែរឿងនេះ ហើយគាត់បានស្រែកទៅទៅស្ថានសួគ៌។
[21]ព្រះអម្ចាស់បានចាត់ទេវតាមួយរូបដែលបានសម្លាប់ទាហានដ៏ខ្លាំងពូកែមេទ័ព និងនាយទាហាននៅក្នុងជំរំ។ ដូច្នេះ ព្រះបាទ
សានហេរីបបានវិលត្រឡប់ទៅស្រុករបស់ស្តេចវិញដោយភាពអាម៉ាស់។ ពេលដែលស្តេចចូលទៅក្នុងវិហារនៃព្រះរបស់ស្តេច
នោះបុត្រារបស់ស្តេចបានធ្វើគុតស្តេចដោយដាវ។
[22]ព្រះអម្ចាស់បានសង្គ្រោះព្រះបាទហេសេគា និងប្រជាជននៅក្រុងយេរូសាឡិមពីកណ្តាប់ដៃរបស់ព្រះបាទសានហេរីបជាស្តេចស្រុកអាស្ស៊ីរីនិងពីកណ្តាប់ដៃរបស់អ្នកដទៃ
ហើយឲ្យពួកគេមានសន្តិភាពនៅគ្រប់ទិសទី តាមរបៀបនេះឯង។[23]មានមនុស្សជាច្រើននាំតង្វាយមកថ្វាយព្រះអម្ចាស់នៅក្រុងយេរូសាឡិម
ព្រមទាំងយកអំណោយដ៏មានតម្លៃមកថ្វាយព្រះបាទហេសេគា ជាស្តេចស្រុកយូដាទៀតផង ចាប់តាំងពីពេលនោះមក
ព្រះអង្គត្រូវបានលើកតម្កើងនៅចំពោះមុខប្រជាជាតិទាំងអស់។
[24]នៅគ្រានោះ ព្រះបាទហេសេគាបានប្រឈួនជាទម្ងន់ហៀបតែនឹងសុគត។ ស្តេចបានអធិស្ឋានទូលអង្វរទៅកាន់ព្រះអម្ចាស់
ហើយព្រះអម្ចាស់មានបន្ទូលមកស្តេចព្រមទាំងប្រទានទីសម្គាល់មួយ ដើម្បីបញ្ជាក់ថាស្តេចនឹងទទួលការព្យាបាល។[25]ប៉ុន្តែ
ព្រះបាទហេសេគាមិនបានតបស្នងសងគុណព្រះអម្ចាស់ចំពោះជំនួយដែលព្រះអង្គបានជួយនោះទេ។ ដូច្នេះ ព្រះពិរោធបានធ្លាក់មកលើស្តេច និងប្រជាជននៅស្រុកយូដា
និងក្រុងយេរូសាឡិមយ៉ាងខ្លាំង។[26]ទោះយ៉ាងណា ព្រះបាទហេសេគាបានបន្ទាបខ្លួនចំពោះអំនួតនៅក្នុងចិត្តរបស់ស្តេច ទាំងស្តេច ទាំងប្រជាជននៅក្រុងយេរូសាឡិម
ហេតុដូច្នេះហើយបានជាសេចក្តីក្រោធរបស់ព្រះអម្ចាស់មិនកើតមានដល់ពួកគេក្នុងជំនាន់ស្តេចហេសេគាឡើយ។
[27]ព្រះបាទហេសេគាមានទ្រព្យសម្បត្តិនិងកិត្តិយសជាច្រើន។ ស្តេចបានសាងសង់នូវឃ្លាំងសម្រាប់ដាក់ប្រាក់ មាសត្បូងមានតម្លៃ និងគ្រឿងទេស
ខែលនិងវត្ថុមានតម្លៃគ្រប់ប្រភេទ។[28]ស្តេចក៏មានឃ្លាំងសម្រាប់ស្រូវ ស្រាទំពាំងបាយជូរថ្មីប្រេង និងក្រោលសម្រាប់សត្វគ្រប់ប្រភេទ។
ស្តេចក៏មានទាំងវាលស្មៅសម្រាប់ហ្វូងសត្វផង។[29]ព្រះករុណាបានសង់ក្រុងផ្សេងៗ ហើយស្តេចមានហ្វូងសត្វជាច្រើន គឺហ្វូងគោ និងហ្វូងចៀម ដ្បិតព្រះអម្ចាស់ប្រោស
ប្រទានឲ្យព្រះករុណាមានទ្រព្យសម្បត្តិយ៉ាងស្តុកស្តម្ភបំផុត។
[30]ព្រះបាទហេសេគាដដែលបានទប់ទឹកទន្លេគីហូននៅខាងលើ ហើយបានបង្ហូរឆ្ពោះទៅទិសខាងលិចនៃក្រុងព្រះបាទដាវីឌ។
ព្រះបាទហេសេគាទទួលជោគជ័យក្នុងគ្រប់គម្រោងរបស់ទ្រង់ទាំងអស់។[31]ទោះយ៉ាងណា
នៅពេលដែលឯកអគ្គរដ្ឋទូតដែលស្តេចនៃស្រុកបាប៊ីឡូនបានចាត់ឲ្យមកសួរព័ត៌ដល់ទ្រង់ដែលបានស្គាល់អំពីទីសម្គាល់ដ៏អស្ចារ្យដែលកើតមាននៅក្នុងស្រុក
នោះព្រះជាម្ចាស់បានទុកស្តេចឲ្យនៅតែឯង ដើម្បីល្បងលស្តេច ដើម្បីឲ្យដឹងពីអ្វីទាំងអស់នៅក្នុងចិត្តរបស់ស្តេច។
[32]ចំពោះរាជកិច្ចផ្សេងទៀតដែលទាក់ទងនឹងព្រះបាទហេសេគា រួមទាំងសកម្មភាពនៃភក្តីភាពនៃសម្ពន្ធមេត្រី
អ្នកអាចឃើញថាវាត្រូវគេសរសេរនៅក្នុងសៀវភៅនិមិត្តរបស់ព្យាការីអេសាយ ជាកូនរបស់លោកអម៉ុស និងនៅក្នុងសៀវភៅស្តេចយូដា និងអ៊ីស្រាអែល។
[33]ព្រះបាទហេសេគាសោយទិវង្គតជាមួយបុព្វបុរស ហើយគេបញ្ចុះសពស្តេចនៅលើទីខ្ពស់នៅទីបញ្ចុះសពពូជពង្សព្រះបាទដាវីឌ។ ប្រជាជនយូដា
និងអ្នកក្រុងយេរូសាឡិមទាំងមូលនាំគ្នាគោរពនឹងកាន់ទុក្ខចំពោះទទួលមរណភាពរបស់ស្តេច។ ព្រះបាទម៉ាណាសេជាបុត្របានឡើងស្នងរាជ្យបន្ត។

---

2 Chronicles 32:1

បន្ទាប់ពីព្រះបាទហេសេគាបង្ហាញភក្តីភាព

សកម្មភាពទាំងនេះបានធ្វើតាមរយៈព្រះបាទហេសេគា។

2 Chronicles 32:2

ឲ្យបញ្ឈប់ប្រភពទឹកដែលនៅខាងក្រៅទីក្រុង

ពួកគេបានបិទប្រភពទឹក ដែលនៅខាងក្រៅទីក្រុង ដូច្នេះ
ប្រជាជនមិនមានទឹកប្រើប្រាស់ទេ។

«ហេតុអ្វីបានជាត្រូវទុកឲ្យស្តេចស្រុកអាស្ស៊ីរីមានទឹកច្រើនប្រើ?»។

ស្តេចស្រុកអាស្ស៊ីរីមិនគួរមករកទឹកច្រើនទេ។ អ្នកបកប្រែប្រហែលជាចង់បកប្រែ
«ស្តេចអាស្ស៊ីរី» ប៉ុន្តែ ពួកគេគួរតែបកប្រែ «ស្តេចស្រុកអាស្ស៊ីរី» ពីព្រោះ
គ្មានការគាំទ្រសម្រាប់ការអានអត្ថបទ «ស្តេច» ទេ។

2 Chronicles 32:5

មានចិត្តក្លាហាន

សូមមើលការបកប្រែដូចនៅក្នុង ១៥:៨

ព្រះបាទហេសេគាមានចិត្តក្លាហាននិងសង់

ការបកប្រែផ្សេងទៀត «ព្រះបាទហេសេគាបានលើកទឹកចិត្តខ្លួនឯង
និងប្រជាជនឲ្យកសាងខ្លួនឡើង»

ក្រុងមីលឡូ

នេះជាផ្នែកមួយនៃជញ្ជាំងដែលផ្តល់កម្លាំងមាំមួន។

2 Chronicles 32:6

មានម្នាក់ដែលនៅជាមួយយើងដែលធំជាងអ្នកដែលនៅជាមួយស្តេចទៅទៀត។

ការបកប្រែផ្សេងទៀត «ត្បិត ព្រះជាម្ចាស់របស់យើងគង់នៅជាមួយយើង
ហើយពេញដោយអំណាចចេស្តាខ្លាំងជាងពួកគេ»

កម្លាំងមនុស្សលោកប៉ុណ្ណោះ

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «អំណាចមនុស្ស»
2 Chronicles 32:9
ទីក្រុងឡាគីស
នេះជាទីក្រុងមួយនៅស្រុកយូដា។
តើអ្នកពឹងផ្អែកលើអ្វី ដើម្បីទ្រាំទ្រនឹងការឡោមព័ទ្ធក្រុងយេរូសាឡិម?
ការបកប្រែផ្សេងទៀត
«អ្នកមិនអាចស៊ូទ្រាំនឹងការឡោមព័ទ្ធនៅក្រុងយេរូសាឡឹមបានទេ»។
2 Chronicles 32:11
តើព្រះបាទហេសេគាមិនបានបញ្ឆោតអ្នករាល់គ្នា ...ដោយស្តេចប្រាប់ថា៖ «ព្រះអម្ចាស់ជាព្រះ ...
ស្តេចស្រុកអាស្ស៊ីរី?
ការបកប្រែផ្សេងទៀត «ព្រះបាទហេសេគាកំពុងបំភាន់អ្នក...
ពេលស្តេចប្រាប់អ្នកថា៖ ឱព្រះអម្ចាស់ ... ស្តេចស្រុកអាស្ស៊ីរី»
តើមិនមែនព្រះបាទហេសេគា ដែលបានបំផ្លាញ
ការបកប្រែផ្សេងទៀត «ព្រះបាទហេសេគាដូចគ្នានេះត្រូវគេបំផ្លាញ»
2 Chronicles 32:13
តើអ្នករាល់គ្នាមិនដឹងទេឬអីថា ... លើផែនដីនេះ?
«អ្នកដឹងច្បាស់ពីអ្វីដែល ... លើផែនដីនេះ!»
តើព្រះរបស់ប្រជាជាតិទាំងឡាយបានរំដោះស្រុករបស់ខ្លួន ... ពីកណ្តាប់ដៃរបស់យើងឬទេ?
«ព្រះក្លែងក្លាយរបស់ក្រុមប្រជាជននៅទឹកដីនេះ មិនអាច ... អំណាច!»
ក្នុងចំណោមព្រះ ... តើមានព្រះណាមួយអាចរំដោះ... ពីកណ្តាប់ដៃរបស់យើងបាន?
«គ្មានព្រះក្លែងក្លាយណាក្នុងចំណោមព្រះទាំងអស់ទេ ... អស់អ្នកដែល...
ពីកណ្តាប់ដៃ!»
តើព្រះរបស់អ្នករាល់គ្នាអាចរំដោះអ្នករាល់គ្នា ... ពីកណ្តាប់ដៃរបស់យើងបានឬអី?
«គ្មានហេតុផលណា ដែលព្រះជាម្ចាស់មិនអាចជួយអ្នករាល់គ្នា ...
អំណាច!» (សូមមើល
2 Chronicles 32:18
ដើម្បីធ្វើឲ្យភ័យខ្លាច និងតក់ស្លុត
ឃ្លាទាំងពីរនេះមានន័យជារួមដូចគ្នា និងបញ្ជាក់ទៅលើកម្លាំងនៃការភ័យខ្លាច។
ការបកប្រែផ្សេងទៀត «ធ្វើឲ្យពួកគេភ័យខ្លាចយ៉ាងខ្លាំង»។
ពួកគេបាននិយាយអំពីព្រះនៃក្រុងយេរូសាឡឹម
ដូចដែលពួកគេបាននិយាយអំពីព្រះរបស់ប្រជាជាតិនានានៅលើផែនដី
ការបកប្រែផ្សេងទៀត
«ពួកគេបានចំអកមើងងាយដល់ព្រះជាម្ចាស់នៃក្រុងយេរូសាឡឹម
ដូចដែលពួកគេបានចំអកមើលងាយដល់ព្រះក្លែងក្លាយ
របស់ប្រជាជាតិដទៃទៀតនៅលើផែនដី» (សូមមើល)
2 Chronicles 32:20
បានស្រែកទៅទៅស្ថានសួគ៌
ការបកប្រែផ្សេងទៀត «បានអង្វរដល់ព្រះជាម្ចាស់»
ដោយភាពអាម៉ាស់
ប្រឈមមុខ។ ការបកប្រែផ្សេងទៀត «មានភាពខ្មាសអៀន» ឬ «ភាពអាម៉ាស»
វិហារនៃព្រះរបស់ស្តេច
ការបកប្រែផ្សេងទៀត «ព្រះវិហារនៃព្រះរបស់ស្តេច»
2 Chronicles 32:22
ហើយឲ្យពួកគេមានសន្តិភាពនៅគ្រប់ទិសទី តាមរបៀបនេះឯង។
ត្រង់នេះ ពាក្យថា «សម្រាក» មានន័យថា «សន្តិភាព»។ ការបកប្រែផ្សេងទៀត
«ផ្តល់ឲ្យពួកគេមានសន្តិភាពជាមួយប្រទេសជិតខាងទាំងអស់» (សូមមើល)
នៅចំពោះមុខប្រជាជាតិទាំងអស់។
ការបកប្រែផ្សេងទៀត «ដូច្នេះ ក្រុមមនុស្សដែលនៅជុំវិញទាំងអស់បានដឹង»
2 Chronicles 32:24
ចំពោះជំនួយដែលព្រះអង្គបានជួយនោះទេ។
ការបកប្រែផ្សេងទៀត «ស្តេចត្រឡប់ជាមានអំនួត» (សូមមើល)
2 Chronicles 32:27
វាលស្មៅ
សូមមើលការបកប្រែដូចនៅក្នុង ៩:២៥
ហ្វូងសត្វ
កន្លែងដាក់សត្វតូចៗ។
2 Chronicles 32:30
ទឹកទន្លេគីហូន
2 Chronicles 32:32
នៅក្នុងសៀវភៅនិមិត្តរបស់ព្យាការីអែសាយ ជាកូនរបស់លោកអម៉ុស ... ក្នុងសៀវភៅស្តេចយូដា
និងអ៊ីស្រាអែល។
សៀវភៅទាំងនេះលែងមានទៀតហើយ។
សោយទិវង្គតជាមួយបុព្វបុរស
សូមមើលការបកប្រែដូចនៅក្នុង ៩:២៩

---

33 [1]កាលព្រះបាទម៉ាណាសេឡើងសោយរាជ្យ ពេលទ្រង់មានព្រះជន្មដប់ពីរព្រះវស្សា។ ស្តេចសោយរាជ្យបានហាសិបប្រាំព្រះវស្សា នៅក្រុងយេរូសាឡិម។
[2]ស្តេចប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់ ដូចអំពើគួរស្អប់ខ្ពើមរបស់ប្រជាជាតិនានា ដែលព្រះអម្ចាស់បានបណ្តេញចេញពីមុខជនជាតិអ៊ីស្រាអែល។
[3]ស្តេចបានសង់កន្លែងសក្ការៈតាមទួលខ្ពស់ៗ ដែលព្រះបាទហេសេគា ជាបិតាបានរំលំចោល ស្តេចបានសង់អាសនៈទាំងនោះសម្រាប់ព្រះបាលឡើងវិញ
ស្តេចបានសង់បង្គោលព្រះអាសេរ៉ា ហើយក្រាបថ្វាយបង្គំផ្កាយទាំងអស់នៅលើមេឃក៏ក្រាបថ្វាយបង្គំរូបទាំងនោះផង។
[4]ព្រះបាទម៉ាណាសេបានសង់អាសនៈសក្ការៈនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ ទោះបីព្រះអម្ចាស់មានព្រះបន្ទូលថា៖ «យើងនឹងយកក្រុងយេរូសាឡិម
ទុកជាកន្លែងសម្រាប់នាមយើងរហូតតទៅ»។[5]ស្តេចបានសង់អាសនៈសម្រាប់ផ្កាយទាំងអស់នៅលើមេឃក្នុងទីធ្លាពីរនៃព្រះដំណាក់របស់ព្រះអម្ចាស់។[6]ស្តេចបានយកបុត្រា
ទៅធ្វើបូជាយញ្ញនៅក្នុងជ្រលងភ្នំហ៊ីនណម ស្តេចរកគ្រូមើលជោគរាសី ប្រព្រឹត្តមន្តអាគម និងអំពើអាបធ្មប់ ព្រមទាំងតែងតាំងឲ្យមានគ្រូអន្ទងខ្មោច និងគ្រូទស្សន៍ទាយ
ផង។ ស្តេចប្រព្រឹត្តអំពើអាក្រក់កាន់តែខ្លាំងឡើងៗ ដែលមិនគាប់ព្រះហឫទ័យព្រះអម្ចាស់ ធ្វើឲ្យព្រះអង្គទ្រង់ព្រះពិរោធ។
[7]ស្តេចបានយករូបចម្លាក់របស់ព្រះអាសេរ៉ា ដែលស្តេចបានធ្វើទៅដាក់នៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មានព្រះបន្ទូលមកព្រះបាទដាវីឌ
និងព្រះបាទសាឡូម៉ូន ជាបុត្រអំពីព្រះដំណាក់នេះ ដោយមានព្រះបន្ទូលថា៖ «យើងគង់នៅក្នុងដំណាក់នេះ និងនៅក្រុងយេរូសាឡិម
ជាកន្លែងដែលយើងបានជ្រើសរើសពីកុលសម្ព័ន្ធអ៊ីស្រាអែលទាំងអស់ សម្រាប់នាមយើងជារៀងរហូត។
[8]យើងនឹងមិនដកពួកគេចេញពីទឹកដីដែលយើងបានឲ្យដល់បុព្វបុរសរបស់គេឡើយ ប្រសិនបើ ពួកគេយកចិត្តទុកដាក់តែនឹងកាន់តាមអ្វីៗដែលយើងបានបង្គាប់ឲ្យពួកគេធ្វើ
ហើយកាន់តាមច្បាប់ក្រឹត្យវិន័យដែលយើងបានប្រគល់ឲ្យលោកម៉ូសេ»។[9]ព្រះបាទម៉ាណាសេបាននាំអ្នកស្រុកយូដា
និងអ្នកក្រុងយេរូសាឡិមឲ្យធ្វើបាបលើសជាងប្រជាជាតិនានាដែលព្រះអម្ចាស់បានបំផ្លាញនៅចំពោះមុខជនជាតិអ៊ីស្រាអែល។
[10]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្រះបាទម៉ាណាសេ និងប្រជាជនរបស់ព្រះអង្គតែពួកគេមិនយកចិត្តទុកដាក់ស្តាប់ទេ។
[11]ព្រះអម្ចាស់បាននាំមេបញ្ជាការកងទ័ពរបស់ស្តេចស្រុកអាស្ស៊ីរីដែលបានចាប់យកព្រះបាទម៉ាណាសេដាក់ច្រវាក់ចងដៃស្តេចហើយនាំគាត់ទៅស្រុកបាប៊ីឡូន។
[12]ពេលព្រះបាទម៉ាណាសេរងទុក្ខវេទនា ស្តេចអង្វរព្រះអម្ចាស់ជាព្រះរបស់ព្រះអង្គ ហើយបន្ទាបខ្លួនយ៉ាងខ្លាំងនៅចំពោះមុខព្រះនៃបុព្វបុរសរបស់ទ្រង់។
[13]ស្តេចបានអធិស្ឋានទៅកាន់ព្រះជាម្ចាស់
ហើយទូលអង្វរព្រះជាម្ចាស់នោះព្រះជាម្ចាស់សណ្តាប់ពាក្យអង្វររបស់ស្តេចហើយនាំស្តេចវិលត្រឡប់ទៅក្រុងយេរូសាឡិមវិញឲ្យឡើងគ្រងរាជ្យ។ ពេលនោះ
ព្រះបាទម៉ាណាសេដឹងថា ព្រះអម្ចាស់ជាព្រះជាម្ចាស់។
[14]បន្ទាប់មក ព្រះបាទម៉ាណាសេបានសង់កំពែងខាងក្រៅឆ្ពោះទៅក្រុងដាវីឌ នៅខាងលិចគីហូននៅជ្រលងភ្នំរហូតដល់ច្រកចូលទ្វារត្រី។ ស្តេចបានសង់ព័ទ្ធជុំវិញភ្នំអូភែល
ហើយលើកកំពែងឡើងដល់កម្ពស់មួយយ៉ាងខ្ពស់។ ស្តេចបានតែងតាំងមេបញ្ជាការដ៏ក្លាហាននៅក្នុងក្រុងដែលមានកំពែងរឹងមាំក្នុងស្រុកយូដា។
[15]ស្តេចបានយករូបព្រះដទៃចេញពីព្រះដំណាក់របស់ព្រះអម្ចាស់ និងអាសនៈទាំងអស់ដែលស្តេចបានសង់នៅលើភ្នំនៃព្រះដំណាក់របស់ព្រះអម្ចាស់
និងនៅក្រុងយេរូសាឡិមយកទៅបោះចោលនៅខាងក្រៅទីក្រុង។

generated on Wed Sep 10 16:16:32 2025

[16]ស្តេចបានសង់អាសនៈរបស់ព្រះអម្ចាស់ឡើងវិញ ហើយបានថ្វាយយញ្ញ បូជាមេត្រីភាព និងតង្វាយអរព្រះគុណនៅលើអាសនៈនោះ។
ស្តេចបានមានរាជបញ្ជាឲ្យប្រជាជនយូដាគោរពបម្រើព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែល។[17]ទោះជាយ៉ាងណា
ប្រជាជននៅតែបន្តធ្វើយញ្ញបូជានៅកន្លែងសក្ការៈតាមទួលខ្ពស់ៗដដែលតែថ្វាយព្រះអម្ចាស់ជាព្រះរបស់គេប៉ុណ្ណោះ។
[18]រាជកិច្ច និងបញ្ហាផ្សេងទៀតទាក់ទងនឹងព្រះបាទម៉ាណាសេ ការអធិស្ឋានទូលអង្វរដល់ព្រះរបស់ស្តេច
និងសំដីរបស់ពួកគ្រូទាយដែលបាននិយាយជាមួយស្តេចក្នុងនាមព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែល
សុទ្ធតែមានកត់ត្រាទុកនៅក្នុងសៀវភៅប្រវត្តិស្តេចស្រុកអ៊ីស្រាអែល។[19]នៅក្នុងកំណត់ត្រានោះមានពាក្យដែលស្តេចអធិស្ឋាន និងរបៀបដែលព្រះជាម្ចាស់ឆ្លើយតបមកវិញ
ព្រមទាំងអំពើបាប និងចិត្តមិនស្មោះត្រង់របស់ស្តេច កន្លែងផ្សេងៗដែលស្តេចសង់ទីសក្ការៈតាមទួលខ្ពស់ៗហើយសង់បង្គោលរបស់ព្រះអាសេរ៉ា និងរូបបដិមា មុនពេល
ដែលស្តេចសារភាពអំពើបាបនោះ សុទ្ធតែមានកត់ត្រាទុកក្នុងសៀវភៅរបស់ពួកព្យាការី។[20]ព្រះបាទម៉ាណាសេសោយបានចូលទិវង្គតជាមួយបុព្វបុរស
គេយកសពទៅបញ្ចុះនៅឯដំណាក់ស្តេចផ្ទាល់។ ព្រះបាទអាំម៉ូនជាបុត្រាបានឡើងសោយរាជ្យជំនួស។
[21]ព្រះបាទអាំម៉ូនមានជន្មាយុម្ភៃពីរព្រះវស្សា ពេលចាប់ផ្តើមសោយរាជ្យ។ ស្តេចសោយរាជ្យបានពីរឆ្នាំនៅក្រុងយេរូសាឡិម។
[22]ស្តេចបានប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់ ដូចព្រះបាទម៉ាណាសេ ជាបិតាបានធ្វើ។
ព្រះបាទអាំម៉ូនបានថ្វាយយញ្ញបូជាដល់រូបចម្លាក់ទាំងអស់ដែលព្រះបាទម៉ាណាសេ ជាបិតាបានធ្វើ។[23]ស្តេចពុំបានបន្ទាបខ្លួនចំពោះព្រះអម្ចាស់ ដូចព្រះបាទម៉ាណាសេ
ជាបិតាបានធ្វើនោះទេ។ ផ្ទុយទៅវិញ ព្រះបាទអាំម៉ូនបានប្រព្រឹត្តកាន់តែអាក្រក់ឡើងៗ ។
[24]ពួករាជបម្រើរបស់ស្តេចបានឃុបឃិតគ្នាប្រឆាំងនឹងស្តេច ហើយធ្វើគុតស្តេចនៅក្នុងព្រះរាជដំណាក់។[25]ប៉ុន្តែ
ប្រជាជននៅស្រុកនោះបានសម្លាប់អស់អ្នកដែលបានឃុបឃិតគ្នាប្រឆាំងនឹងស្តេចអាំម៉ូន ហើយតែងតាំងព្រះបាទយ៉ូសៀសជាបុត្រឲ្យឡើងស្នងរាជ្យជំនួសវិញ។

---

2 Chronicles 33:1
ស្តេចប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
ដូចអំពើគួរស្អប់ខ្ពើមរបស់ប្រជាជាតិនានា
ដែលព្រះអម្ចាស់បានបណ្តេញចេញពីមុខជនជាតិអ៊ីស្រាអែល។
ការបកប្រែផ្សេងទៀត «ដូចជាបានធ្វើឲ្យក្រុមមនុស្សផ្សេងទៀត
ដែលព្រះអម្ចាស់បានធ្វើឲ្យពួកគេបរាជ័យ តាមរយៈប្រជនជាតិអ៊ីស្រាអែល។»
2 Chronicles 33:4
ទុកជាកន្លែងសម្រាប់នាមយើង
ការបកប្រែផ្សេងទៀត «យើងនឹងធ្វើឲ្យប្រជារាស្ត្រស្គាល់យើង»
ស្តេចបានយកបុត្រាទៅធ្វើបូជាយញ្ញ
សំដៅទៅលើការអនុវត្តការដុតក្មេងទាំងរស់ ជាយញ្ញបូជាថ្វាយរូបព្រះបដិមា។
ជ្រលងភ្នំហ៊ីនណម
កន្លែងមួយនៅជិតក្រុងយេរូសាឡឹម ដែលគេស្គាល់ថា ហ្គេហេណា។
2 Chronicles 33:7
អ្នកស្រុកយូដា និងអ្នកក្រុងយេរូសាឡឹម
ការបកប្រែផ្សេងទៀត «ប្រជាជននៅស្រុកយូដា និងក្រុងយេរូសាឡឹម»
2 Chronicles 33:10
បាននាំ
ការបកប្រែផ្សេងទៀត «បាននាំការវាយប្រហារលើពួកគេ ដោយ»
បានចាប់យកព្រះបាទម៉ាណាសេដាក់ច្រវាក់ចងដៃស្តេចហើយនាំគាត់ទៅស្រុកបាប៊ីឡូន។
ការបកប្រែផ្សេងទៀត
«ចាប់យកព្រះបាទម៉ាណាសេហើយយកទ្រង់ធ្វើជាអ្នកទោសទៅស្រុកបាប៊ីឡូន។»
2 Chronicles 33:12
ស្តេចបានអធិស្ឋានទៅកាន់ព្រះជាម្ចាស់
ហើយទូលអង្វរព្រះជាម្ចាស់នោះព្រះជាម្ចាស់សណ្តាប់ពាក្យអង្វររបស់ស្តេច
ឃ្លាទីពីរធ្វើឲ្យឃ្លាទីមួយកាន់តែតានតឹង
ហើយបញ្ជាក់លើការខ្ជាប់ខ្ជួនក្នុងការអធិស្ឋានរបស់ព្រះបាទម៉ាណាសេ។
ការបកប្រែផ្សេងទៀត «ស្តេចបានអធិស្ឋានដល់ព្រះជាម្ចាស់
ហើយអង្វរដល់ព្រះជាម្ចាស់។»
ឡើងគ្រងរាជ្យ
មានន័យថា «គ្រប់គ្រងម្តងទៀតលើប្រទេសជាតិ»។
2 Chronicles 33:14
ព័ត៌មានទូទៅ៖
សូមមើល
រូបព្រះដទៃ
ការបកប្រែផ្សេងទៀត «ព្រះក្លែងក្លាយយកមកពីប្រទេសដទៃ»
2 Chronicles 33:16
ស្តេចបានមានរាជបញ្ជាឲ្យប្រជាជនយូដា
ការបកប្រែផ្សេងទៀត «ស្តេចបានបញ្ជឲ្យជាប្រជាជននៅស្រុកយូដា»
2 Chronicles 33:18
មានកត់ត្រាទុកនៅក្នុងសៀវភៅប្រវត្តិស្តេចស្រុកអ៊ីស្រាអែល។
ទាក់ទងនឹងប្រវត្តិសាស្ត្រអ៊ីស្រាអែល ដែលលែងមានទៀតហើយ។
ក្នុងសៀវភៅរបស់ពួកព្យាការី
សៀវភៅនេះលែងមានទៀតហើយ។
ព្រះបាទម៉ាណាសេសោយបានចូលទិវង្គតជាមួយបុព្វបុរស គេយកសពទៅបញ្ចុះ
ការបកប្រែផ្សេងទៀត «ដូច្នេះ ព្រះបាទម៉ាណាសេបានសុគត
ហើយរាជវង្សព្រះបានបានបញ្ចុះសព»
សៀវភៅនេះលែងមានទៀតហើយ។
2 Chronicles 33:21
ស្តេចបានប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
ព្រះបាទអាំម៉ូនបានប្រព្រឹត្តកាន់តែអាក្រក់ឡើងៗ ។
ការបកប្រែផ្សេងទៀត «ព្រះបាទអាំម៉ូនបានធ្វើបាបកាន់តែច្រើន»
2 Chronicles 33:24
បានឃុបឃិតគ្នា
ការបកប្រែផ្សេងទៀត «មានផែនការសម្ងាត់»

---

34 [1]ព្រះបាទយ៉ូសៀសមានព្រះជន្មប្រាំបីព្រះវស្សា ពេលស្តេចឡើងសោយរាជ្យ ហើយសោយរាជ្យបានសាមសិបមួយព្រះវស្សានៅក្រុងយេរូសាឡិម។
[2]ស្តេចបានប្រព្រឹត្តអំពើសុចរិត ដែលជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដោយបានប្រព្រឹត្តតំរូវព្រះបាទដាវីឌ ជាអយ្យកោ ដោយឥតបែរទៅស្តាំ ឬទៅឆ្វេងឡើយ។
[3]ឆ្នាំទីប្រាំបីនៃរជ្ជកាលរបស់ស្តេច នៅពេលដែលស្តេចនៅក្មេងនៅឡើយ ស្តេចចាប់ផ្តើមស្វែងរកព្រះរបស់ព្រះបាទដាវីឌដែលជាបុព្វបុរសរបស់ស្តេច។
នៅឆ្នាំទីដប់ពីរស្តេចចាប់ផ្តើមសម្អាតស្រុកយូដា និងក្រុងយេរូសាឡិម ពីកន្លែងខ្ពស់ៗ បង្គោលព្រះអាសេរ៉ា រូបចម្លាក់ និងរូបបដិមាករផ្សេងៗ។
[4]ប្រជាជនបានរំលំអាសនៈរបស់ព្រះបាលនៅចំពោះព្រះភក្ត្រព្រះករុណា ហើយកម្ទេចស្ពាកសម្រាប់ដុតគ្រឿងក្រអូបដែលស្ថិតនៅលើនោះផង។ ស្តេចបានបំបាក់បង្គោល
របស់ព្រះអាសេរ៉ាព្រមទាំងកម្ទេចរូបបដិមា និងរូបចម្លាក់ឯទៀតៗដែលគេសិតធ្វើឲ្យក្លាយទៅជាធូលីរួចយកទៅចាក់លើផ្នូររបស់អស់អ្នកដែលបានធ្វើយញ្ញបូជានៅមុខរូប
ទាំងនោះ។[5]ស្តេចបានដុតធាតុរបស់ពួកបូជាចារ្យនៃព្រះដទៃនៅលើអាសនៈរបស់គេ។ ស្តេចធ្វើដូច្នេះដើម្បីសម្អាតស្រុកយូដា និងក្រុងយេរូសាឡិមឲ្យស្អាត។
[6]ស្តេចក៏បានធ្វើដូចគ្នានៅក្រុងម៉ាណាសេ អេប្រាអ៊ីម និងស៊ីម្មាន និងរហូតដល់ទឹកដីណែថាលី និងនៅតាមគំនរបាក់បែកដែលព័ទ្ធជុំវិញផង។[7]ស្តេចបានកម្ទេចបង្គោលរបស់
ព្រះអាសេរ៉ា និងរូបបដិមាឲ្យទៅជាធូលីដី ហើយកម្ទេចស្ពាកសម្រាប់ដុតគ្រឿងក្រអូបនៅក្នុងស្រុកអ៊ីស្រាអែលទាំងមូល រួចស្តេចបានយាងទៅក្រុងយេរូសាឡិមវិញ។
[8]នៅឆ្នាំទីដប់ប្រាំបីនៃរជ្ជកាលរបស់ស្តេចក្រោយពេលដែលព្រះបាទយ៉ូសៀសបានសម្អាតស្រុក និងព្រះវិហាររួចហើយ
ស្តេចបានចាត់លោកសាផានជាកូនរបស់លោកអសាលា និងលោកម៉ាសេយ៉ា ជាអភិបាលក្រុង និងលោកយ៉ូអា ជាកូនរបស់លោកយ៉ូអាហាស
ជាលេខាធិការឲ្យជួសជុលព្រះដំណាក់របស់ព្រះអម្ចាស់ជាព្រះរបស់ស្តេច។

generated on Wed Sep 10 16:16:32 2025

[9]ពួកគេបានទៅជួបលោកហ៊ីលគីយ៉ាជាមហាបូជាចារ្យហើយបានប្រគល់ប្រាក់ដែលបានយកមកក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់ដែលពួកលេវីជាអ្នកយាមទ្វារបានមកប្រមូលពីម៉ាណាសេ
និងអេប្រាអ៊ីម មកពីជនជាតិអ៊ីស្រាអែលទាំងអស់ដែលនៅសេសសល់ ព្រមទាំងពីប្រជាជនយូដា បេនយ៉ាមីន និងប្រជាជននៅក្រុងយេរូសាឡិមទាំងមូល។
[10]ពួកគេបានប្រគល់ប្រាក់ទៅឲ្យពួកមេជាងត្រួតត្រាលើការជួសជុលព្រះវិហាររបស់ព្រះអម្ចាស់។ អ្នកទាំងនោះបានយកប្រាក់នោះបង់ថ្លៃឈ្នួលឲ្យកម្មករដែលជួសជុល
និងស្តារព្រះដំណាក់របស់ព្រះអម្ចាស់ឡើងវិញ។[11]ពួកគេបានបង់ថ្លៃឈ្នួលដល់ពួកជាងឈើ ជាងសំណង់ និងសម្រាប់ទិញថ្មដាប់ និងឈើសម្រាប់ប្រើជាធ្នឹម ផ្ការ ហើយ
សម្រាប់ជួសជុលអាគារផ្សេងៗ ដែលស្តេចស្រុកយូដាជំនាន់មុនៗបានបំផ្លាញ។
[12]ពួកអ្នកទាំងនោះបានធ្វើកិច្ចការនេះដោយស្មោះត្រង់។ អ្នកមើលខុសត្រូវលើកិច្ចការពួកគេគឺលោកយ៉ាហាត់និងលោកអូបាឌាជាពួកលេវី ក្នុងអំបូរម៉្រារី លោកសាការី
និងលោកមេស៊ូឡាមកពីកូនចៅរបស់លោកកេហាត់។ ពួកលេវីឯទៀតៗដែលសុទ្ធតែជាអ្នកលេងភ្លេងដ៏ពូកែបានដឹកនាំកម្មករយ៉ាងជិតស្និត។
[13]ពួកលេវីមានភារកិច្ចមើលខុសត្រូវលើអស់អ្នកដែលលីសែងគ្រឿងសំណង់ និងមនុស្សឯទៀតៗដែលធ្វើការតាមរបៀបផ្សេងៗ។
មានពួកលេវីខ្លះដែលជាលេខាធិការអ្នកគ្រប់គ្រង និងអ្នកយាមទ្វារផង។
[14]ពេលគេយកប្រាក់ ដែលប្រជាជនថ្វាយជាតង្វាយសម្រាប់ព្រះដំណាក់របស់ព្រះអម្ចាស់ចេញមក នោះលោកមហាបូជាចារ្យហ៊ីលគីយ៉ារកឃើញគម្ពីរវិន័យ ដែល
ព្រះអម្ចាស់ប្រទានមកតាមរយៈលោកម៉ូសេ។[15]បូជាចារ្យហ៊ីលគីយ៉ាមានប្រសាសន៍ទៅលោកសាផានជាស្មៀនថា៖
«ខ្ញុំបានរកឃើញសៀវភៅក្រឹត្យវិន័យនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់»។ លោកហ៊ីលគីយ៉ាបានយកសៀវភៅនោះឲ្យទៅលោកសាផាន។
[16]លោកសាផានយកសៀវភៅទៅថ្វាយព្រះរាជា ហើយទូលស្តេចថា៖ «បពិត្រព្រះករុណា! យើងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គបានធ្វើអ្វីទាំងអស់តាមព្រះរាជបញ្ជា។
[17]ពួកគេបានដកប្រាក់ដែលរកបាននៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ហើយប្រគល់ទៅក្នុងកណ្តាប់ដៃរបស់ពួកអ្នកត្រួតត្រា និងអ្នកធ្វើការរួចរាល់ហើយ។
[18]លោកសាផានជាស្មៀនបានទូលព្រះរាជាថា៖ «បូជាចារ្យហ៊ីលគីយ៉ាបានប្រគល់សៀវភៅមួយឲ្យទូលបង្គំ»។ បន្ទាប់មក
លោកសាផានបានអាននៅក្នុងនោះថ្វាយព្រះរាជា។[19]កាលព្រះរាជាបានឮសេចក្តីទាំងប៉ុន្មានដែលមានចែងនៅក្នុងក្រឹត្យវិន័យ ស្តេចក៏ហែកព្រះភូសាទ្រង់។
[20]ស្តេចបានបញ្ជាទៅលោកហ៊ីលគីយ៉ា លោកអហ៊ីកាម ជាកូនរបស់លោកសាផាន លោកអាប់ដូន ជាកូនរបស់លោកមីកាយ៉ា លោកសាផាន ជាស្មៀនហ្លួង និងលោក
អសាយ៉ា ជារាជបម្រើថា៖[21]«សូមអស់លោកអញ្ជើញទៅទូលសួរព្រះអម្ចាស់ឲ្យយើង និងប្រជាជនដែលនៅសេសសល់ ក្នុងស្រុកអ៊ីស្រាអែល និងយូដាពីសេចក្តីទាំងប៉ុន្មាន
ក្នុងគម្ពីរដែលទើបរកឃើញនេះផង។ ព្រះអម្ចាស់មុខជាព្រះពិរោធនឹងយើងខ្លាំងណាស់ ដ្បិត ពួកដូនតារបស់យើងមិនបានកាន់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ដើម្បី
ប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលមានចែងទុកក្នុងគម្ពីរនេះទេ»។
[22]ដូច្នេះ លោកហ៊ីលគីយ៉ា និងអ្នកដែលព្រះរាជាបានបញ្ជា ពួកគេបានទៅឯលោកស្រីហ៊ូលដា ជាព្យាការិនីដែលជាភរិយារបស់លោកសាលូមជាកូនរបស់លោកតូហាត់
ជាកូនរបស់លោកហាសរ៉ា គឺជាអ្នកថែរក្សាសម្លៀកបំពាក់បូជាចារ្យ (នាងរស់នៅក្រុងយេរូសាឡិមនៅសង្កាត់ទីពីរ) ហើយពួកគេបាននិយាយជាមួយនាងអំពីរឿងនេះ។
[23]នាងឆ្លើយទៅពួកគេថា៖ «នេះគឺជាអ្វីដែលព្រះអម្ចាស់ជាព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលមានព្រះបន្ទូល៖ ចូរប្រាប់បុរសដែលចាត់អ្នកឲ្យមករកខ្ញុំថា៖
[24]នេះគឺជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល៖ «យើងនឹងធ្វើឲ្យមានគ្រោះមហន្តរាយកើតឡើងនៅលើទីនេះ និងប្រជាជននេះ
ស្របតាមគ្រប់ទាំងបណ្តាសាដែលមានចែងទុកក្នុងសៀវភៅដែលគេបានអាននៅចំពោះមុខស្តេចយូដា។[25]ព្រោះពួកគេបានបោះបង់ចោលយើង
ហើយបានដុតគ្រឿងក្រអូបដល់ព្រះឯទៀតៗ ដើម្បីឲ្យយើងខឹងនឹងអំពើទាំងប៉ុន្មានដែលពួកគេបានប្រព្រឹត្ត។ ដូច្នេះ កំហឹងរបស់យើងនឹងចាក់លើកន្លែងនេះ
ហើយវានឹងមិនត្រូវរលត់ឡើយ។
[26]ប៉ុន្តែ ចំពោះស្តេចស្រុកយូដាដែលចាត់អស់លោកឲ្យមកទូលសួរព្រះអម្ចាស់ ចូរទៅប្រាប់ស្តេចស្រុកយូដាថា៖ «ព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែលមានព្រះបន្ទូល
ដូចតទៅ៖ «អ្នកបានស្តាប់ឮសេចក្តីទាំងប៉ុន្មាន ដែលមានចែងទុកក្នុងគម្ពីរនេះហើយ។[27]ព្រោះអ្នកមានចិត្តទន់ភ្លន់
ហើយអ្នកបន្ទាបខ្លួននៅចំពោះព្រះនៅពេលអ្នកឮព្រះបន្ទូលរបស់ព្រះអង្គប្រឆាំងនឹងកន្លែងនេះ និងប្រជាជននៅទីនោះ
ដោយព្រោះអ្នកបន្ទាបខ្លួននៅចំពោះមុខយើងហើយបានហែកសម្លៀកបំពាក់របស់អ្នកហើយយំនៅចំពោះមុខយើង នោះយើងក៏បានស្តាប់អ្នកដែរ
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។[28]មើល! យើងនឹងប្រមូលអ្នកទៅជួបបុព្វបុរសរបស់អ្នក។ អ្នកនឹងត្រូវប្រមូលទៅក្នុងផ្នូររបស់អ្នកដោយសុខសាន្ត
ហើយភ្នែកអ្នកនឹងមិនឃើញគ្រោះមហន្តរាយដែលយើងនឹងនាំមកលើកន្លែងនេះ និងប្រជាជននៅក្រុងនោះឡើយ»។ អ្នកទាំងនោះក៏នាំពាក្យនេះមកទូលស្តេច។
[29]ព្រះរាជាចាត់អ្នកនាំសារឲ្យទៅ ហើយនាំចាស់ទុំទាំងអស់នៅស្រុកយូដានិងក្រុងយេរូសាឡិមមកជុំគ្នា។[30]បន្ទាប់មក
ព្រះរាជាយាងឡើងទៅព្រះដំណាក់របស់ព្រះអម្ចាស់ព្រមទាំងប្រជាជននៅស្រុកយូដា និងអ្នកក្រុងយេរូសាឡិមពួកបូជាចារ្យ ពួកលេវី
និងប្រជាជនទាំងមូលចាប់ពីអ្នកធំដល់តូច។ បន្ទាប់មក
ស្តេចបានអានឲ្យគេស្តាប់គ្រប់ទាំងពាក្យទាំងអស់នៃសៀវភៅសម្ពន្ធមេត្រីដែលគេបានរកឃើញនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។
[31]ស្តេចបានឈរនៅកន្លែងរបស់ខ្លួនហើយបានចងសម្ពន្ធមេត្រីនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ដើម្បីដើរតាមព្រះអម្ចាស់និងប្រតិបត្តិតាមបទបញ្ជា ដំបូន្មាន
និងលក្ខន្តិកៈរបស់ព្រះអង្គដោយអស់ពីដួងចិត្តនិងពីព្រលឹងរបស់ព្រះអង្គ ដើម្បីនឹងស្តាប់តាមគ្រប់សេចក្តីនៅក្នុងសៀវភៅនេះ។
[32]ព្រះករុណាបានបញ្ជាឲ្យអស់អ្នកដែលរស់នៅនៅក្រុងយេរូសាឡិម និងបេនយ៉ាមីនឈរនៅជាប់នឹងសម្ពន្ធមេត្រី។ ប្រជាជននៅ
ក្រុងយេរូសាឡិមបានប្រព្រឹត្តដោយគោរពចំពោះកិច្ចព្រមព្រៀងរបស់ព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេ។
[33]ព្រះបាទយ៉ូសៀសបានបំផ្លាញរបស់ដ៏គួរស្អប់ខ្ពើមចេញពីទឹកដីដែលជាកម្មសិទ្ធិរបស់ជនជាតិអ៊ីស្រាអែល។
ស្តេចបានឲ្យប្រជាជនអ៊ីស្រាអែលទាំងអស់ថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់គេ។
អស់មួយជីវិតរបស់ពួកគេពួកគេមិនងាកចេញពីព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេឡើយ។

---

2 Chronicles 34:1
ស្តេចបានប្រព្រឹត្តអំពើសុចរិត ដែលជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
ដោយបានប្រព្រឹត្តគំរូព្រះបាទដាវីឌ ជាអយ្យកោ ដោយឥតបែរទៅស្តាំ ឬទៅឆ្វេងឡើយ។
ការបកប្រែផ្សេងទៀត
«មិនស្ទាក់ស្ទើរក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់តាមរបៀបណាក៏ដោយ» ឬ
«ស្តេចបានគោរពតាមបទបញ្ញត្តិទាំងអស់របស់ព្រះជាម្ចាស់»
2 Chronicles 34:4
ធ្វើឲ្យក្លាយទៅជាធូលី
ការបកប្រែផ្សេងទៀត «រហូតដល់បំណែកតូចៗ ដែលអាចហោះតាមខ្យល់បាន»
2 Chronicles 34:6
ម្ទេច
ការបកប្រែផ្សេងទៀត «ត្រូវបានបំផ្លាញទាំងស្រុង» (សូមមើល)
2 Chronicles 34:8
ព័ត៌មានទូទៅ៖
សូមមើល
បានប្រគល់
«បានប្រគល់ការទទួលខុសត្រូវដល់លោក ក្នុងការប្រើប្រាស់លុយ»
2 Chronicles 34:10
ជំនាន់មុនៗបានបំផ្លាញ។
ការបកប្រែផ្សេងទៀត «បានអនុញ្ញាតដើម្បីរំលាយ»
2 Chronicles 34:12
ព័ត៌មានទូទៅ៖
សូមមើល
ពួកលេវីមានភារកិច្ចមើលខុសត្រូវលើអស់អ្នកដែលលីសែងគ្រឿងសំណង់
និងមនុស្សឯទៀតៗដែលធ្វើការតាមរបៀបផ្សេងៗ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត «ពួកលេវីទាំងនេះជាអ្នកមើលការខុសត្រូវលើបុរសទាំងអស់ដែលបានធ្វើការងារសាងសង់គ្រប់ប្រភេទ។»
2 Chronicles 34:14
ព័ត៌មានទូទៅ៖
សូមមើល
ពេលគេយកប្រាក់ ដែលប្រជាជនថ្វាយជាតង្វាយសម្រាប់ព្រះដំណាក់របស់ព្រះអម្ចាស់ចេញមក
ការបកប្រែផ្សេងទៀត
«នៅពេលអ្នកមើលការខុសត្រូវបានទទួលប្រាក់នៅក្នុងព្រះវិហារ»
ធ្វើអ្វីទាំងអស់តាមព្រះរាជបញ្ជា។
ការបកប្រែផ្សេងទៀត «អ្វីៗគ្រប់យ៉ាង
ដែលព្រះអង្គបានផ្តល់ឲ្យពួកគេមើលការខុសត្រូវ។»
2 Chronicles 34:17
ពួកគេបានដកប្រាក់ដែលរកបាន
ការបកប្រែផ្សេងទៀត «ពួកគេបានប្រមូលផ្តុំគ្នា»
កាលព្រះរាជាបានឮសេចក្តីទាំងប៉ុន្មានដែលមានចែង
ឃ្លានេះជាសញ្ញាសម្គាល់មួយ។ វាបង្ហាញថាអ្វីដែលនៅខាងក្រោម
ជាព្រឹត្តិការណ៍ដ៏សំខាន់ជាពិសេសនៅក្នុងរឿងនេះ។ ការបកប្រែផ្សេងទៀត
«ឥឡូវនេះសូមកត់សម្គាល់អ្វីៗ ដែលកើតឡើងបន្ទាប់»
2 Chronicles 34:20
ព័ត៌មានទូទៅ៖
សូមមើល
ទូលសួរព្រះអម្ចាស់ឲ្យយើង
ការបកប្រែផ្សេងទៀត «ទូលសុំព្រះជាម្ចាស់នូវអ្វី ដែលទ្រង់ចង់ឲ្យខ្ញុំធ្វើ»
សេចក្តីទាំងប៉ុន្មានក្នុងគម្ពីរ
ការបកប្រែផ្សេងទៀត «ទៅតាមអ្វីដែលបានសរសេរនៅក្នុងកណ្ឌគម្ពីរ»
ព្រះអម្ចាស់មុខជាព្រះពិរោធនឹងយើងខ្លាំងណាស់
អារម្មណ៍ដូចជាកំហឹង ជារឿយៗត្រូវបានគេនិយាយនៅក្នុងបទគម្ពីរដូចជាវត្ថុរាវ។
ការបកប្រែផ្សេងទៀត «ដ្បិត សេចក្តីខ្ញាល់របស់ព្រះអម្ចាស់ចំពោះយើង
គឺធំដូចជាទឹកដែលអាចលាងយើងបាន។»
2 Chronicles 34:22
ព័ត៌មានទូទៅ៖
សូមមើល
គឺជាអ្នកថែរក្សាសម្លៀកបំពាក់បូជាចារ្យ
ការបកប្រែផ្សេងទៀត «អ្នកណាថែរក្សាអាវផាយបូជាចារ្យ»
ពួកគេបាននិយាយជាមួយនាងអំពីរឿងនេះ។
ការបកប្រែផ្សេងទៀត «ពួកគេមានការសន្ទនាដូចខាងក្រោមជាមួយនាង»
2 Chronicles 34:23
ដើម្បីឲ្យយើងខឹងនឹងអំពើទាំងប៉ុន្មានដែលពួកគេបានប្រព្រឹត្ត។
«ជាលទ្ធផល ពួកគេបានធ្វើឲ្យយើងខឹងយ៉ាងខ្លាំង
ដោយសារតែអ្វីដែលពួកគេបានធ្វើ»
ដើម្បីឲ្យយើងខឹង
«ធ្វើឲ្យយើងខឹង»
ដូច្នេះ កំហឹងរបស់យើងនឹងចាក់លើកន្លែងនេះ ហើយវានឹងមិនត្រូវរលត់ឡើយ។
មានអារម្មណ៍ដូចជាកំហឹង
ជារឿយៗត្រូវបានគេនិយាយនៅក្នុងបទគម្ពីរដូចជាវត្ថុរាវ។ ការបកប្រែផ្សេងទៀត
«ដូច្នេះ វានឹងដូចជាភ្លើង ដែលខ្ញុំបានចាក់លើពួកគេ
ហើយគ្មានអ្វីនឹងបញ្ឈប់ភ្លើងនេះទេ»
2 Chronicles 34:26
«ព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលដូចតទៅ៖ «អ្នកបានស្តាប់ឮសេចក្តីទាំងប៉ុន្មាន ដែលមានចែងទុកក្នុងគម្ពីរនេះហើយ។ ព្រោះអ្នកមានចិត្តទន់ភ្លន់
ការបកប្រែផ្សេងទៀត «ឱ ព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែល
មានព្រះបន្ទូលអំពីពាក្យដែលអ្នកបានឮ។ ពីព្រោះ ចិត្តរបស់អ្នកទន់ជ្រាយ
ឆន្ទៈផ្លាស់ប្តូរ។» (សូមមើល)
ហើយបានហែកសម្លៀកបំពាក់របស់អ្នក
នេះជាសញ្ញានៃការកាន់ទុក្ខ និងការប្រែចិត្ត។
យើងនឹងប្រមូលអ្នកទៅជួបបុព្វបុរសរបស់អ្នក។ អ្នកនឹងត្រូវប្រមូលទៅក្នុងផ្នូររបស់អ្នក
ការបកប្រែផ្សេងទៀត «អ្នកនឹងស្លាប់»
ហើយភ្នែកអ្នកនឹងមិន
ការបកប្រែផ្សេងទៀត «អ្នកនឹងមិនទទួលបានបទពិសោធន៍»
2 Chronicles 34:29
ប្រជាជនទាំងមូលចាប់ពីអ្នកធំដល់តូច។
ការបកប្រែផ្សេងទៀត «គ្រប់ៗគ្នា»
បានអានឲ្យគេស្តាប់
ការបកប្រែផ្សេងទៀត «អានប្រាប់ពួកគេ»
2 Chronicles 34:31
បានឈរនៅកន្លែងរបស់ខ្លួន
ការបកប្រែផ្សេងទៀត «ឈរនៅកន្លែង ដែលគាត់ត្រូវបានគេសន្មតថា
ឈរនៅច្រកចូលព្រះវិហារ»
ដោយអស់ពីដួងចិត្តនិងពីព្រលឹងរបស់ព្រះអង្គ
ដោយការរួមបញ្ចូលគ្នា ឃ្លាទាំងពីរនេះបង្កើតបានជាការបង្ហាញ
ដែលសំដៅទៅលើខ្លួនទាំងមូលរបស់មនុស្សម្នាក់។ ការបកប្រែផ្សេងទៀត
«ដោយអស់ពីព្រះកាយព្រះអង្គ» ឬ «យ៉ាងអស់ពីចិត្ត។»
អ្នកដែលរស់នៅនៅក្រុងយេរូសាឡឹម និងបេនយ៉ាមីន
ការបកប្រែផ្សេងទៀត «អស់អ្នកដែលបានរស់នៅក្នុងក្រុងយេរូសាឡឹម
និងបេនយ៉ាមីន។»
ឈរនៅជាប់នឹងសម្ពន្ធមេត្រី។
ការបកប្រែផ្សេងទៀត «គោរពតាមសម្ពន្ធមេត្រី»
2 Chronicles 34:33
របស់ដ៏គួរស្អប់ខ្ពើម
ទាំងនេះជារូបបដិមា ដែលគួរស្អប់ខ្ពើមនៅចំពោះព្រះជាម្ចាស់។

35 [1]ព្រះបាទយ៉ូសៀសបានធ្វើបុណ្យចម្លងថ្វាយព្រះអម្ចាស់នៅក្រុងយេរូសាឡិម ហើយពួកគេបានសម្លាប់កូនចៀមសម្រាប់បុណ្យចម្លងនៅថ្ងៃទីដប់បួននៃខែទីមួយ។
[2]ស្តេចបានតែងតាំងពួកបូជាចារ្យឲ្យបំពេញមុខងាររបស់ខ្លួន ហើយបានលើកទឹកចិត្តពួកគេនៅក្នុងការបម្រើការងារនៅក្នុងដំណាក់របស់ព្រះអម្ចាស់។
[3]ស្តេចមានរាជឱង្ការទៅកាន់ពួកលេវីជាអ្នកបង្រៀនជនជាតិអ៊ីស្រាអែលទាំងមូល និងជាអ្នកដែលបានញែកខ្លួនថ្វាយព្រះអម្ចាស់ថា៖
«សូមដាក់ហឹបដ៏សក្ការៈក្នុងព្រះដំណាក់ដែលព្រះបាទសាឡូម៉ូន ជាបុត្ររបស់ព្រះបាទដាវីឌជាស្តេចស្រុកអ៊ីស្រាអែលបានសង់។ អ្នករាល់គ្នាមិនត្រូវការសែងហឹបនេះទៀតទេ ឥឡូវនេះ ចូរថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ហើយបម្រើអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់ព្រះអង្គទៅ។[4]ចូររៀបចំខ្លួនតាមឈ្មោះវង្សត្រកូល
និងក្រុមរបស់អ្នករាល់គ្នាស្របតាមការណែនាំរបស់ព្រះបាទដាវីឌ ជាស្តេចស្រុកអ៊ីស្រាអែល និងព្រះបាទសាឡូម៉ូនជាបុត្ររបស់ទ្រង់។
[5]ចូរឈរនៅទីបរិសុទ្ធ នៅតាមកន្លែងរបស់អ្នករាល់គ្នា តាមតំណវង្សត្រកូលដូនតានិងបងប្អូនរបស់អ្នករាល់គ្នា តាមតំណកូនចៅនៃប្រជាជន
និងនៅតាមកន្លែងរបស់អ្នករាល់គ្នាជាមួយក្រុមរបស់អ្នករាល់គ្នានៅក្នុងវង្សត្រកូលរបស់ពួកលេវី។[6]ចូរសម្លាប់កូនចៀមសម្រាប់បុណ្យចម្លង ហើយញែកខ្លួនឲ្យបានវិសុទ្ធ
ចូររៀបចំកូនចៀមសម្រាប់បងប្អូនរបស់អ្នករាល់គ្នា ចូរធ្វើឲ្យស្របតាមព្រះបន្ទូលដែលព្រះអម្ចាស់ប្រទានមកតាមរយៈលោកម៉ូសេ»។
[7]ព្រះបាទយ៉ូសៀសបានប្រទានកូនចៀម និងកូនពពែចំនួនបីម៉ឺនក្បាលពីហ្វូងសត្វសម្រាប់ធ្វើយញ្ញបូជាក្នុងពិធីបុណ្យចម្លង។ ស្តេចក៏ប្រទានគោបីពាន់ក្បាល
ទាំងនេះជាសម្បត្តិរបស់ព្រះរាជាផ្ទាល់។[8]ពួកអ្នកដឹកនាំរបស់ស្តេចក៏បានថ្វាយតង្វាយស្ម័គ្រចិត្តដល់ប្រជាជន ពួកបូជាចារ្យ និងពួកលេវីដែរ។ លោកហ៊ីលគីយ៉ា
លោកសាការី និងលោកយេហ៊ីអែលដែលជាអ្នកទទួលខុសត្រូវក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់បានប្រគល់ជូនពួកបូជាចារ្យសម្រាប់ពិធីបុណ្យចម្លងនូវកូនគោចំនួន ២,
៦០០ ក្បាល និងគោឈ្មោលចំនួនបីរយក្បាល។[9]ហើយលោកកូណានា លោកសេម៉ាយ៉ា និងលោកនេថានេល ជាប្អូនរបស់លោក ព្រមទាំងលោកហាសាប៊ីយ៉ា លោក
យេហ៊ីអែល និងលោកយ៉ូសាបាដ ជាអ្នកដឹកនាំពួកលេវី ក៏យកកូនគោ ៥, ០០០ក្បាល ព្រមទាំងគោឈ្មោល ៥០០ក្បាល ប្រគល់ជូនពួកលេវី សម្រាប់ពិធីបុណ្យចម្លង។
[10]ដូច្នេះ គេរៀបចំពិធីបូជា ហើយពួកបូជាចារ្យឈរនៅកន្លែងរបស់ខ្លួនជាមួយពួកលេវីតាមមុខងាររបស់គេស្របតាមបញ្ជារបស់ស្តេច។
[11]ពួកគេបានសម្លាប់កូនចៀមនៃបុណ្យចម្លង ហើយពួកបូជាចារ្យប្រោះឈាមដែលពួកគេទទួលពីដៃរបស់ពួកលេវី ចំណែក ពួកលេវីធ្វើការពន្លះស្បែកកូនចៀម។[12]គេដាក់
សាច់ដែលត្រូវថ្វាយជាតង្វាយដុតទាំងមូលដោយឡែក សម្រាប់ចែកទៅក្រុមគ្រួសារផ្សេងៗរបស់ប្រជាជន ដើម្បីឲ្យពួកគេថ្វាយព្រះអម្ចាស់ ដូចមានចែងទុកក្នុងកណ្ឌគម្ពីរ
របស់លោកម៉ូសេ។ ពួកគេបានធ្វើដូចគ្នាជាមួយគោឈ្មោលដែរ។

generated on Wed Sep 10 16:16:32 2025

[13]ពួកគេអាំងសាច់កូនចៀមដែលថ្វាយសម្រាប់ពិធីបុណ្យចម្លងនៅលើភ្លើងស្របតាមការណែនាំ។ ចំណែក តង្វាយសក្ការៈវិញ ពួកគេចម្អិនក្នុងឆ្នាំង ថ្លាង និងខ្ទះ រួច
ប្រញាប់ប្រញាល់ចែកជូនប្រជាជនទាំងអស់។[14]បន្ទាប់មក ពួកគេរៀបចំតង្វាយសម្រាប់ខ្លួនពួកគេផ្ទាល់ និងសម្រាប់ពួកបូជាចារ្យ
ពីព្រោះពួកបូជាចារ្យដែលជាកូនចៅរបស់លោកអើរ៉ុននាំគ្នាថ្វាយតង្វាយដុត និងខ្លាញ់រហូតដល់ពេលយប់។ ដូច្នេះ ពួកលេវីបានរៀបចំតង្វាយសម្រាប់ខ្លួនឯង
និងពួកបូជាចារ្យដែលជាកូនចៅរបស់លោកអើរ៉ុន។
[15]ក្រុមចម្រៀងដែលជាកូនចៅរបស់លោកអេសាភ បាននៅកន្លែងរបស់គេ ស្របតាមការណែនាំរបស់ព្រះបាទដាវីឌលោកអេសាភ
លោកហេម៉ានព្រមទាំងលោកយេឌូថុនជាព្យាការីរបស់ព្រះរាជា។
ពួកគេមិនចាំបាច់ចាកចេញពីកន្លែងទេពីព្រោះពួកលេវីដែលជាបងប្អូនរបស់ពួកគេបានរៀបចំម្ហូបសម្រាប់ពួកគេ។
[16]នៅគ្រានោះ គេបំពេញកិច្ចការរបស់ព្រះអម្ចាស់ទាំងមូលសម្រាប់ការអបអរពិធីបុណ្យចម្លង
និងថ្វាយតង្វាយដុតទាំងមូលនៅលើអាសនៈរបស់ព្រះអម្ចាស់ស្របតាមបញ្ជារបស់ស្តេចយ៉ូសៀស។[17]ប្រជាជនអ៊ីស្រាអែលដែលបានចូលរួមបានបន្តប្រារព្ធពិធីបុណ្យចម្លង
និងពិធីបុណ្យនំប៉័ងឥតមេអស់រយៈពេលប្រាំពីរថ្ងៃ។
[18]តាំងពីជំនាន់ព្យាការីសាំយូអែលគ្មាននរណាម្នាក់ធ្វើពិធីបុណ្យចម្លងបែបនេះនៅស្រុកអ៊ីស្រាអែលឡើយ
ហើយក៏មិនដែលមានស្តេចអង្គណាធ្វើពិធីបុណ្យចម្លងដូចព្រះបាទយ៉ូសៀសរួមជាមួយពួកបូជាចារ្យ ពួកលេវី និងប្រជាជនយូដា ជនជាតិអ៊ីស្រាអែលដែលមានវត្តមាន
និងប្រជាជននៅក្រុងយេរូសាឡិមដែរ។[19]គេប្រារព្ធពិធីបុណ្យចម្លងនេះ នៅឆ្នាំទីដប់ប្រាំបីនៃរជ្ជកាលព្រះបាទយ៉ូសៀស។
[20]ក្រោយហេតុការណ៍ទាំងនេះ គឺក្រោយពេលដែលព្រះបាទយ៉ូសៀសជួសជុលព្រះវិហាររួចរាល់ហើយ ព្រះបាទផារ៉ោននេកោ
ជាស្តេចស្រុកអេស៊ីបបានលោកទន័ពទៅច្បាំងជាមួយក្រុងកើកេមីស នៅទន្លេអឺប្រាត ពេលនោះព្រះបាទយ៉ូសៀសបានឡើងទៅស្ទាក់ផ្លូវទ្រង់។[21]ប៉ុន្តែ ព្រះបាទនេកោ
បានបញ្ជូនឯកអគ្គរដ្ឋទូតឲ្យមកទូលស្តេចថា៖ «បពិត្រ ស្តេចស្រុកយូដាអើយ! តើទូលបង្គំបានធ្វើអ្វីដល់ព្រះករុណា? ថ្ងៃនេះ ទូលបង្គំមិនមកច្បាំងនឹងព្រះករុណាទេ ប៉ុន្តែ
គឺប្រឆាំងនឹងផ្ទះដែលទូលបង្គំកំពុងធ្វើសង្គ្រាមវិញ។ ព្រះជាម្ចាស់បង្គាប់ឲ្យទូលបង្គំទៅជាប្រញាប់ ដូច្នេះ សូមកុំរាំងស្ទះផ្លូវទូលបង្គំអី ដ្បិត ព្រះអម្ចាស់គង់ជាមួយទូលបង្គំ
ក្រែងលោទ្រង់ប្រហារព្រះករុណាឲ្យវិនាស»។
[22]ទោះយ៉ាងណា ព្រះបាទយ៉ូសៀសបានបដិសេធ និងមិនងាកចេញឡើយ។ ស្តេចក្លែងខ្លួន ដើម្បីប្រយុទ្ធជាមួយស្តេច។
ស្តេចមិនបានស្តាប់សំដីរបស់ព្រះបាទនេកោដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ទេ។ ដូច្នេះ ស្តេចឡើងទៅប្រយុទ្ធនៅជ្រលងភ្នំមេគីដោ។
[23]ទាហានបានបាញ់ត្រូវព្រះបាទយ៉ូសៀស ហើយស្តេចបានមានរាជឱង្ការទៅកាន់ពួករាជបម្រើថា៖ «ចូរនាំយើងចេញទៅ ដ្បិត យើងញ៉ាំត្រូវរបួសធ្ងន់ណាស់»។
[24]ពួករាជបម្រើនាំស្តេចចុះពីលើរទេះសេះ ហើយដាក់ក្នុងរទេះចម្បាំងមួយទៀតរបស់ស្តេច។ ពួកគេបាននាំស្តេចទៅក្រុងយេរូសាឡិម ជាកន្លែងដែលស្តេចសោយទិវង្គត។
ស្តេចត្រូវបានគេបញ្ចុះនៅក្នុងផ្នូរនៃបុព្វបុរសរបស់ស្តេច។ ប្រជាជននៅស្រុកយូដា និងក្រុងយេរូសាឡិមនាំគ្នាកាន់ទុក្ខព្រះបាទយ៉ូសៀស។
[25]លោកយេរេមាបានទួញសោកចំពោះព្រះបាទយ៉ូសៀស។ អ្នកចម្រៀងប្រុសស្រីទាំងអស់នាំគ្នាយំទួញអំពីព្រះបាទយ៉ូសៀសរហូតដល់សព្វថ្ងៃ។
បទចម្រៀងទាំងនេះក្លាយជាទម្លាប់នៅអ៊ីស្រាអែល មើល! គេសរសេរជាបទចម្រៀងសោកសៅផង។[26]ចំពោះកិច្ចការឯទៀតៗដែលទាក់ទងនឹងព្រះបាទយ៉ូសៀស
និងអំពើល្អដែលព្រះអង្គបានប្រព្រឹត្តដោយកាន់តាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់។
[27]កិច្ចការទាំងប៉ុន្មានដែលស្តេចបានធ្វើតាំងពីដើមដល់ចប់សុទ្ធតែមានកត់ត្រាទុកក្នុងសៀវភៅរបស់ស្តេចស្រុកយូដា និងស្តេចស្រុកអ៊ីស្រាអែល។

---

2 Chronicles 35:1
នៅថ្ងៃទីដប់បួននៃខែទីមួយ។
នេះជាខែដំបូងតាមប្រតិទិនហេប្រឺ។
ថ្ងៃទីដប់បួនគឺនៅជិតដើមខែមេសានៅតាមប្រតិទិនលោកខាងលិច។
ស្តេចបានតែងតាំងពួកបូជាចារ្យឲ្យបំពេញមុខងាររបស់ខ្លួន
ការបកប្រែផ្សេងទៀត «ស្តេចបានប្រាប់ពួកបូជាចារ្យឲ្យធ្វើការងារណា ដែលត្រូវធ្វើ»
2 Chronicles 35:3
ដែលព្រះបាទសាឡូម៉ូន ជាបុត្ររបស់ព្រះបាទដាវីឌជាស្តេចស្រុកអ៊ីស្រាអែលបានសង់។
ការបកប្រែផ្សេងទៀត
«ប្រជាជនបានសាងសង់ក្រោមការដឹកនាំរបស់ស្តេចសាឡូម៉ូន»
វង្សត្រកូល និងក្រុមរបស់អ្នករាល់គ្នា
ការបកប្រែផ្សេងទៀត «កុលសម្ព័ន្ធ និងគ្រួសាររបស់អ្នក»
2 Chronicles 35:5
ចូរឈរនៅទីបរិសុទ្ធ
នៅទីនេះ« ទីបរិសុទ្ធ» ហាក់ដូចជាសំដៅទៅលើតំបន់ទូទៅនៅព្រះវិហារ។
ការបកប្រែផ្សេងទៀត «ទទួលយកតំណែងរបស់អ្នកនៅក្នុងព្រះវិហារ»។
បងប្អូនរបស់អ្នករាល់គ្នា
សំដៅទៅលើក្រុមការងារ ដែលបានចាត់តាំងសម្រាប់ក្រុមលេវីនីមួយៗ។
តាមតំណកូនចៅ
សំដៅទៅលើអំបូរផ្សេងៗក្នុងចំណោមពួកលេវី។ ហាក់ដូចជាកុលសម្ព័ន្ធលេវី
ត្រូវបានចាត់តាំងឲ្យធ្វើការងារផ្សេងៗគ្នា នាដោយផ្អែកលើប្រភេទការងារ
ដែលបានប្រគល់ឲ្យក្រុមគ្រួសារ ឬកុលសម្ព័ន្ធនីមួយៗ។
2 Chronicles 35:7
ព័ត៌មានទូទៅ៖
សូមមើល and
កូនពពែ
នេះជាកូនពពែ។
2 Chronicles 35:10
គេរៀបចំពិធីបូជា
«ពួកគេបានរៀបចំអ្វីៗគ្រប់យ៉ាង ដើម្បីធ្វើបុណ្យចម្លង»។
ឈាមដែលពួកគេទទួលពីដៃរបស់ពួកលេវី
ឈាមដែលពួកលេវីបានឲ្យដល់ពួកគេ
2 Chronicles 35:13
ពួកគេអាំងសាច់
ការបកប្រែផ្សេងទៀត «ពួកគេបានចម្អិន»
ពួកគេចម្អិនក្នុងឆ្នាំង ថ្លាង និងខ្ទះ ។
ការបកប្រែផ្សេងទៀត «ពួកគេបានចម្អិនវានៅក្នុងទឹក មានឆ្នាំងផ្សេងៗគ្នា»
សម្រាប់ខ្លួនពួកគេផ្ទាល់
2 Chronicles 35:15
ព័ត៌មានទូទៅ៖
សូមមើល
នៅកន្លែងរបស់គេ
សូមមើលការបកប្រែដូចនៅក្នុង ៣០:១៦
2 Chronicles 35:16
គេបំពេញកិច្ចការ
អ្វីគ្រប់យ៉ាងដែលទាក់ទងនឹងការរៀបចំថ្វាយយញ្ញបូជា និងការថ្វាយបង្គំព្រះអម្ចាស់
ក្នុងអំឡុងពេលបុណ្យចម្លងអាចសំដៅការថ្វាយបង្គំថាជា «ការបម្រើ» ។
2 Chronicles 35:18
ស្រុកអ៊ីស្រាអែល
ការប្រើប្រាស់ស្រុកអ៊ីស្រាអែលដំបូងបង្អស់
សំដៅទៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល តែការប្រើប្រាស់អ៊ីស្រាអែលលើកទីពីរ
សំដៅទៅលើកុលសម្ព័ន្ធខាងជើងនៃព្រះរាជាណាចក្រអ៊ីស្រាអែល។
2 Chronicles 35:20
ព័ត៌មានទូទៅ៖
សូមមើល
ជួសជុលព្រះវិហាររួចរាល់ហើយ
ការបកប្រែផ្សេងទៀត «បានស្តារការថ្វាយបង្គំព្រះជាម្ចាស់
ឲ្យបានត្រឹមត្រូវឡើងវិញ»
បពិត្រ ស្តេចស្រុកយូដាអើយ! តើទូលបង្គំបានធ្វើអ្វីដល់ព្រះករុណា?
ការបកប្រែផ្សេងទៀត «ស្តេចស្រុកយូដាគ្មានហេតុផលអ្វី

generated on Wed Sep 10 16:16:32 2025

ដែលអាចវាយប្រហារទូលបង្គំបានទេ»។
ទូលបង្គំមិនមកច្បាំងនឹងព្រះករុណាទេ
ការបកប្រែផ្សេងទៀត «ទូលបង្គំមិនតយុទ្ធនឹងនគររបស់ព្រះអង្គទេ»
គឺប្រឆាំងនឹងផ្ទះដែលទូលបង្គំកំពុងធ្វើសង្គ្រាមវិញ។
ការបកប្រែផ្សេងទៀត «ប្រឆាំងនឹងបាប៊ីឡូនដែលទូលបង្គំកំពុងធ្វើសង្គ្រាម»
2 Chronicles 35:22
ប្រយុទ្ធជាមួយស្តេច
«ប្រយុទ្ធនឹងកងទ័ពបាប៊ីឡូន»
ដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ទេ។
«មកពីព្រះជាម្ចាស់» ឬ« ដែលព្រះជាម្ចាស់មានបន្ទូលទៅកាន់ស្តេច»
2 Chronicles 35:25
រហូតដល់សព្វថ្ងៃ
សូមមើលការបកប្រែនៅក្នុង ៥:៩

---

36 [1]ក្រោយមក ប្រជាជននៅក្នុងទឹកដីស្រុកយូដាបានអភិសេកព្រះបាទយ៉ូអាហាសជាបុត្រព្រះបាទយ៉ូសៀស ឲ្យគ្រងរាជ្យជាស្តេចនៅក្រុងយេរូសាឡិម ជំនួសបិតា។
[2]ព្រះបាទយេអ៊ាហាស មានជន្មាយុម្ភៃបីព្រះវស្សា ពេលស្តេចឡើងគ្រងរាជ្យ ហើយសោយរាជ្យបានបីខែនៅក្រុងយេរូសាឡិម។
[3]ស្តេចស្រុកអេស៊ីបទម្លាក់ស្តេចពីរាជសម្បត្តិនៅក្រុងយេរូសាឡិម ហើយ បានពិន័យប្រាក់ចំនួន៣តោនកន្លះ និងមាសកន្លះតោន។
[4]ស្តេចស្រុកអេស៊ីបបានតែងតាំងព្រះបាទអេលាគីមឲ្យគ្រប់គ្រងជាស្តេចនៅស្រុកយូដា និងក្រុងយេរូសាឡិម ហើយបានប្តូរទៅជាព្រះនាមយេហូយ៉ាគីម។ បន្ទាប់មក
ស្តេចបាននាំព្រះបាទយេហូគីម ត្រូវជាព្រះរៀមរបស់ព្រះបាទយ៉ូអាហាស ហើយនាំស្តេចទៅស្រុកអេស៊ីប។
[5]ព្រះបាទយេហូយ៉ាគីមមានព្រះជន្មម្ភៃប្រាំព្រះវស្សា ពេលឡើងសោយរាជ្យ ហើយសោយរាជ្យបានដប់មួយព្រះវស្សានៅក្រុងយេរូសាឡិម។
ស្តេចបានប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់ជាព្រះរបស់ព្រះករុណាឡើយ។[6]ព្រះបាទនេប៊ូក្នេសា
ជាស្តេចស្រុកបាប៊ីឡូនលើកទ័ពមកវាយស្តេចហើយចាប់ស្តេចដាក់ច្រវាក់ដើម្បីនាំទៅស្រុកបាប៊ីឡូន។
[7]ព្រះបាទនេប៊ូក្នេសារបានយកវត្ថុខ្លះៗនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ទៅក្រុងបាប៊ីឡូន ហើយដាក់ក្នុងវាំងរបស់ទ្រង់នៅឯស្រុកបាប៊ីឡូន។
[8]ចំពោះបញ្ហាផ្សេងទៀតដែលទាក់ទងនឹងព្រះបាទយេហូយ៉ាគីម និងអំពើគួរស្អប់ខ្ពើមដែលស្តេចបានធ្វើ
និងអ្វីដែលត្រូវបានគេប្រឆាំងនឹងស្តេចនោះមានកត់ទុកក្នុងសៀវភៅរបស់ស្តេចស្រុកយូដា និងអ៊ីស្រាអែល។ បន្ទាប់មក ព្រះបាទ
យេហូយ៉ាគីនជាបុត្របានឡើងសោយរាជ្យជំនួស។
[9]ព្រះបាទយេហូយ៉ាគីនមានព្រះជន្មប្រាំបីព្រះវស្សា នៅពេលដែលទ្រង់ចាប់ផ្តើមសោយរាជ្យ។ ស្តេចសោយរាជ្យបានបីខែដប់ថ្ងៃនៅក្រុងយេរូសាឡិម។
ស្តេចប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់។[10]នៅរដូវផ្ការីក ព្រះបាទនេប៊ូក្នេសាបានចាត់មនុស្សឲ្យទៅចាប់ទ្រង់
ព្រមទាំងទ្រព្យសម្បត្តិដ៏មានតម្លៃពីព្រះដំណាក់របស់ព្រះអម្ចាស់នាំយកទៅក្រុងបាប៊ីឡូន។ រួចហើយតែងតាំងព្រះបាទសេដេគាឲ្យគ្រងរាជ្យលើស្រុកយូដា
និងក្រុងយេរូសាឡិមជំនួសវិញ។
[11]ពេលព្រះបាទសេដេគាឡើងសោយរាជ្យទ្រង់មានជន្មាយុម្ភៃមួយព្រះវស្សា ហើយស្តេចសោយរាជ្យបានដប់មួយព្រះវស្សានៅក្រុងយេរូសាឡិម។
[12]ស្តេចបានប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់ជាព្រះរបស់ខ្លួនឡើយ។
ស្តេចពុំបានបន្ទាបខ្លួននៅចំពោះមុខព្យាការីយេរេមាដែលថ្លែងព្រះបន្ទូលរបស់ព្រះអម្ចាស់ឡើយ។
[13]ព្រះបាទសេដេគាក៏បានបះបោរប្រឆាំងនឹងព្រះបាទនេប៊ូក្នេសាដែលឲ្យស្តេចស្បថក្នុងនាមព្រះជាម្ចាស់ថានឹងរក្សាភក្តីភាពចំពោះស្តេច។ ប៉ុន្តែ ព្រះបាទសេដេគារឹងរូស
ហើយធ្វើឲ្យចិត្តរឹងចចេសមិនងាកមករកព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលទេ។[14]លើសពីនេះទៅទៀតមេដឹកនាំបូជាចារ្យ
និងប្រជាជនទាំងអស់សុទ្ធតែមិនស្មោះត្រង់ហើយពួកគេបានប្រតិបត្តិតាមការស្អប់ខ្ពើមរបស់ប្រជាជាតិនានា។
ពួកគេបានបន្ទាបបន្ថោកព្រះដំណាក់របស់ព្រះអម្ចាស់ដែលព្រះអង្គបានញែកទុកជាបរិសុទ្ធនៅក្រុងយេរូសាឡិម។
[15]ព្រះអម្ចាស់ជាព្រះនៃបុព្វបុរសរបស់ពួកគេបានចាត់អ្នកនាំសាររបស់ព្រះអង្គឲ្យមកទូលស្តេចម្តងហើយម្តងទៀត
ព្រោះព្រះអង្គមានព្រះហឫទ័យអាណិតអាសូរដល់ប្រជារាស្ត្ររបស់ព្រះអង្គ និងកន្លែងដែលព្រះអង្គគង់នៅ។[16]ប៉ុន្តែ ពួកគេចំអកមើលងាយអ្នកនាំសាររបស់ព្រះជាម្ចាស់
គេមើលងាយព្រះបន្ទូលរបស់ព្រះអង្គ
ហើយចំអកមើលងាយព្យាការីរបស់ព្រះអង្គរហូតទាល់តែព្រះអម្ចាស់ទ្រង់ព្រះពិរោធទាស់នឹងប្រជារាស្ត្ររបស់ព្រះអង្គរហូតដល់គ្មាននរណាអាចជួយបាន។
[17]ដូច្នេះ ព្រះអម្ចាស់បានចាត់ស្តេចនៃជនជាតិខាល់ដេ ឲ្យលើកទ័ពមកវាយពួកគេ។ ស្តេចនោះសម្លាប់យុវជនរបស់ពួកគេនៅក្នុងព្រះវិហារ ហើយសម្លាប់រង្គាលប្រជាជនទាំង
អស់ ឥតសំចៃនរណាម្នាក់ឡើយ គឺសម្លាប់យុវជនទាំងប្រុស ទាំងស្រី និងមនុស្សចាស់ជរាសក់ស្កូវផង។ ព្រះជាម្ចាស់បានប្រគល់ពួកគេទាំងអស់គ្នាទៅក្នុងកណ្តាប់ដៃរបស់
ស្តេចនោះ។
[18]គ្រឿងសង្ហរិមរបស់ព្រះដំណាក់របស់ព្រះជាម្ចាស់ទាំងធំទាំងតូចទាំងទ្រព្យរបស់ព្រះដំណាក់របស់ព្រះអម្ចាស់ព្រមទាំងទ្រព្យសម្បត្តិរបស់ស្តេច
និងនាម៉ឺនសព្វមុខមន្ត្រីត្រូវបាននាំយកទៅស្រុកបាប៊ីឡូន។[19]ពួកគេបានដុតបំផ្លាញព្រះដំណាក់របស់ព្រះជាម្ចាស់ហើយរំលំកំពែងក្រុងយេរូសាឡិម
និងដុតវិមាននានាព្រមទាំងបំផ្លាញរបស់របរទាំងអស់ដែលមាននៅក្នុងក្រុងនោះចោលផង។
[20]ព្រះបាទនេប៊ូក្នេសាក៏កៀរប្រជាជនដែលនៅសេសសល់ទៅស្រុកបាប៊ីឡូន។ ពួកគេបានក្លាយជាអ្នកបម្រើព្រះអង្គ
និងរាជវង្សានុវង្សព្រះអង្គរហូតដល់ថ្ងៃចក្រភពពើស៊ីមកគ្រប់គ្រង។
[21]ហេតុការណ៍នេះកើតមានស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលមានចែងទុកក្នុងគម្ពីរព្យាការីយេរេមាថា រហូតដល់ស្រុកនេះបានសម្រាកនៅថ្ងៃសប្ប័ទ។
វាបានរក្សាថ្ងៃឈប់សម្រាករបស់វាដរាបណាវាត្រូវបានគេបោះបង់ចោល ដើម្បីគ្រប់រយៈពេលចិតសិបឆ្នាំ។
[22]នៅឆ្នាំទីមួយនៃរជ្ជកាលព្រះបាទស៊ីរូស ជាស្តេចស្រុកពើស៊ី ដើម្បីឲ្យព្រះបន្ទូលប្រស់ព្រះអម្ចាស់តាមរយៈមាត់របស់ព្យាការីយេរេមាបានសម្រេច
ព្រះអម្ចាស់បានជំរុញទឹកចិត្តព្រះបាទស៊ីរូស ជាស្តេចស្រុកពើស៊ី ដូច្នេះ ស្តេចចេញព្រះរាជសារប្រកាសនៅពេញក្នុងអាណាចក្ររបស់ព្រះអង្គ។ ស្តេចមានរាជឱង្ការថា៖
[23]«នេះជាព្រះរាជសារ របស់ព្រះបាទស៊ីរូស ជាស្តេចនៃអាណាចក្រពើស៊ី ស្តេចមានរាជឱង្ការថា៖
«ព្រះអម្ចាស់ជាព្រះនៃស្ថានបរមសុខបានប្រទានឲ្យយើងនូវអាណាចក្រទាំងប៉ុន្មាននៅលើផែនដី។
ព្រះអង្គបានបញ្ជាឲ្យយើងសង់ព្រះដំណាក់មួយនៅក្រុងយេរូសាឡិមដែលស្ថិតនៅស្រុកយូដា។
ក្នុងចំណោមអ្នករាល់គ្នាអ្នកណាជាប្រជារាស្ត្ររបស់ព្រះអម្ចាស់សូមឲ្យព្រះអម្ចាស់ជាព្រះរបស់អ្នកស្ថិតនៅជាមួយអ្នក។ ចូរឲ្យអ្នកនោះក្រោកឡើងត្រឡប់ទៅស្រុកវិញចុះ»។

---

2 Chronicles 36:1
ព្រះបាទយ៉ូអាហាស
2 Chronicles 36:3
ព័ត៌មានទូទៅ៖
សូមមើល
កន្លះតោន
នាំស្តេចទៅស្រុកអេស៊ីប។
ការបកប្រែផ្សេងទៀត «នាំយកស្តេចទៅធ្វើជាអ្នកទោសនៅអេស៊ីប»
2 Chronicles 36:5
ស្តេចបានប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់
សូមមើលការបកប្រែដូចនៅក្នុង ២១:៦
មកវាយស្តេច
ការបកប្រែផ្សេងទៀត «វាយប្រហារក្រុងយេរូសាឡឹម»
ព្រះបាទនេប៊ូក្នេសារបានយកវត្ថុខ្លះៗ

generated on Wed Sep 10 16:16:32 2025

កងពលរបស់ព្រះបាទនេប៊ូក្នេសារបានដឹក។
2 Chronicles 36:8
អំពើគួរស្អប់ខ្ពើមដែលស្តេចបានធ្វើ
ជាធម្មតា សំដៅទៅលើការថ្វាយបង្គំព្រះក្លែងក្លាយ ដែលព្រះអម្ចាស់បានស្អប់។
អ្វីដែលត្រូវបានគេប្រឆាំងនឹងស្តេច
អាចជាការបញ្ជាក់ទៅលើអត្តចរិករបស់ស្តេច។
សៀវភៅរបស់ស្តេចស្រុកយូដា និងអ៊ីស្រាអែល។
សូមមើលការបកប្រែដូចនៅក្នុង ៣៥:២៦
2 Chronicles 36:9
ស្តេចប្រព្រឹត្តអំពើអាក្រក់មិនគាប់ព្រះហឫទ័យព្រះអម្ចាស់។
សូមមើលការបកប្រែដូចនៅក្នុង ១៤:១
2 Chronicles 36:11
ស្តេចពុំបានបន្ទាបខ្លួននៅចំពោះមុខព្យាការីយេរេមា
ការបកប្រែផ្សេងទៀត «ស្តេចមិនបានបន្ទាបខ្លួន និងស្តាប់បង្គាប់ព្រះជាម្ចាស់
តាមរយៈការស្តាប់លោកយេរេមា ដែលជាព្យាការីទេ»
ព្រះបន្ទូលរបស់ព្រះអម្ចាស់ឡើយ។
«ចេញពីពាក្យដែលព្រះជាម្ចាស់បានប្រទានដល់លោក»
2 Chronicles 36:13
រឹងរូស ហើយធ្វើឲ្យចិត្តរឹងចចេស
ឃ្លាទាំងពីរនេះជាវិធីបង្ហាញ សំដៅទៅលើភាពរឹងចចេសរបស់មនុស្សម្នាក់។
ពួកគេបញ្ជាក់រួមគ្នាទៅលើការបះបោរ
របស់ព្រះបាទសេដេគាប្រឆាំងនឹងព្រះជាម្ចាស់។ (សូមមើល and
បានប្រតិបត្តិតាមការស្អប់ខ្ពើម
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១៥:៨
បានបន្ទាបបន្ទោកព្រះដំណាក់របស់ព្រះអម្ចាស់
ការបកប្រែផ្សេងទៀត «ពួកគេបានធ្វើអ្វីដែលមិនបរិសុទ្ធនៅកន្លែងបរិសុទ្ធ»
2 Chronicles 36:15
ម្តងហើយម្តងទៀត
ការបកប្រែផ្សេងទៀត «ច្រើនដង»
គ្មាននរណាអាចជួយបាន។
ការបកប្រែផ្សេងទៀត «គ្មានផ្លូវចៀសវាងទេ»
2 Chronicles 36:17
ព្រះជាម្ចាស់បានប្រគល់ពួកគេទាំងអស់គ្នាទៅក្នុងកណ្តាប់ដៃរបស់ស្តេចនោះ។
ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់បានអនុញ្ញាតឲ្យកងទ័ពខាល់ដេវាយឈ្នះពួកគេ។»
2 Chronicles 36:18
បាននាំយក
ទាហានរបស់ស្តេចបានយក
ពួកគេបានដុតបំផ្លាញ
«ពួកគេ» សំដៅទៅលើទាហានបាប៊ីឡូន។
2 Chronicles 36:20
ព្រះបាទនេប៊ូក្នេសារក៏កៀរ
«ទាហានរបស់ព្រះបាទនេប៊ូក្នេសារបានយក។»
2 Chronicles 36:22
នៅឆ្នាំទីមួយ
ព្រះអង្គបានបញ្ជាឲ្យយើងសង់ព្រះដំណាក់មួយ
ការបកប្រែផ្សេងទៀត «ព្រះអង្គបានជ្រើសរើសយើងឲ្យបញ្ជាកម្មកររបស់យើង
សាងសង់ព្រះវិហារថ្វាយព្រះអង្គនៅទីក្រុងយេរូសាឡឹម។» (សូមមើល

អែសរ៉ា

1 [1]នៅក្នុងឆ្នាំទីមួយនៃរជ្ជកាលស៊ីរូសជាស្តេចនៃទឹកដីពើស៊ី
ព្រះអម្ចាស់នឹងបំពេញពាក្យរបស់ព្រះអង្គដែលចេញពីមាត់របស់លោកយេរេមាបានបំផុសស្មារតីរបស់ស្តេចស៊ីរូស។[2]សម្រែករបស់ស្តេចស៊ីរូសចេញពេញនគរទាំងមូល។
នេះជាសេចក្តីដែលបានសរសេរ និងនិយាយ «ស៊ីរូសជាស្តេចនៃស្រុកពើស៊ីបានប្រកាសថា
ព្រះអម្ចាស់ជាព្រះនៃស្ថានសួគ៌ទបានប្រទាននូវនគរទាំងអស់នៅផែនដីហើយព្រះអង្គនឹងតែងតាំងយើងឲ្យសង់ដំណាក់មួយសម្រាប់ព្រះអង្គនៅក្នុងក្រុងយេរូសាឡឹមក្នុងស្រុកយូដា។
[3]អស់អ្នកដែលជាប្រជាជនរបស់ព្រះអម្ចាស់សូមឲ្យព្រះអម្ចាស់គង់នៅជាមួយគេពេលឡើងទៅកាន់ព្រះដំណាក់របស់ព្រះអម្ចាស់នៅក្រុងយេរូសាឡឹម
ជាព្រះនៃប្រជាជនអ៊ីស្រាអែល ជាព្រះអម្ចាស់ដែលគង់នៅក្នុងក្រុងយេរូសាឡឹម។[4]ប្រជាជនដែលមកពីគ្រប់ទីកន្លែងនៃនគរដែលរស់រានមានជីវិតលើទឹកដីនោះ
គួរតែផ្គត់ផ្គង់ពួកគេដោយប្រាក់ មាស ទ្រព្យសម្បត្តិ និងសត្វយកមកថ្វាយជាដង្វាយស្ម័គ្រចិត្តនៅក្នុងដំណាក់របស់ព្រះអម្ចាស់នៅក្រុងយេរូសាឡឹម»។
[5]ដូច្នេះ មេនៃពួកបុព្វបុរសក្នុងត្រកូលនៃពួកយូដា និងពួកបេនយ៉ាមីន សម្តេចសង្ឃ ពួកលេវី
និងអស់អ្នកដែលមានវិញ្ញាណរបស់ព្រះអម្ចាស់ឲ្យទៅសាងសង់ព្រះដំណាក់របស់ព្រះអម្ចាស់ឲ្យផុសឡើង។
[6]អ្នកដែលនៅជុំវិញទីនោះក៏ត្រូវជួយគាំទ្រការងាររបស់ពួកគេដោយគ្រឿងប្រាក មាស ទ្រព្យសម្បត្តិ សត្វ និងរបស់ដែលមានតម្លៃយកថ្វាយជាដង្វាយស្ម័គ្រចិត្ត។
[7]ស្តេចទឹកដីស៊ីរូស បញ្ចេញវត្ថុទាំងអស់ជាកម្មសិទ្ធិក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ ដែលស្តេចនេប៊ូក្នេសាបាននាំយកពីក្រុងយេរូសាឡឹម
ហើយបានដាក់ថ្វាយក្នុងដំណាក់ព្រះរបស់ខ្លួន។[8]ស្តេចទឹកដីស៊ីរូសបាន
ដាក់ពួកគេក្នុងកណ្តាប់ដៃនៃពួកមីត្រាដាតដែលជាក្រុមអ្នកទារពន្ធឲ្យចាក់ចេញពីលោកសេសបាសារជាមេដឹកនាំនៃទឹកដីយូដា។
[9]នេះជាចំនួនរបស់ពួកគេ មាសចំនួនសាមសិបផើង ប្រាក់ចំនួនមួយរយផើង និងរបស់ផ្សេងទៀតម្ភៃប្រាំបួនផើង
និងចានមាសសាមសិបចាន[10]ចានប្រាក់តូចៗចំនួនបួនរយដប់ចាន និងវត្ថុផ្សេងៗបន្ថែមមួយពាន់ទៀត។[11]សរុបទាំងមាស និងប្រាក់ទាំងអស់មានចំនួនប្រាំពាន់បួនរយ។
លោកសេសបាសាបាន នាំយករបស់ទាំងអស់នៅពេលដែលគេត្រូវបាននិរទេសចេញពីក្រុងបាប៊ីឡូនទៅកាន់ក្រុងយេរូសាឡឹម។

Ezra 1:1
ឆ្នាំទីមួយ
សំដៅទៅលើការចាប់ផ្តើមនៃរជ្ជកាលរបស់ស្តេចស៊ីរូស
ព្រះអម្ចាស់
នេះគឺជាព្រះនាមរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានបង្ហាញដល់ប្រជាជនរបស់ព្រះអង្គ
សូមមើលការបកប្រែទំព័រព្រះបន្ទូលអំពីព្រះអម្ចាស់ទាក់ទងរបៀបបកប្រែអត្ថបទនេះ។
ព្រះអម្ចាស់នឹងបំពេញពាក្យរបស់ព្រះអង្គ
«ព្រះអម្ចាស់បានធ្វើអ្វីដែលព្រះអង្គបានមានព្រះបន្ទូលថាព្រះអង្គនឹងធ្វើ»
ដែលចេញពីមាត់របស់លោកយេរេមា
លោកយេរេមាបានសរសេរ ឬ និយាយអំពី។
ព្រះអម្ចាស់ ... បំផុសស្មារតីរបស់ស្តេចស៊ីរូស
ការបំផុសស្មារតីគឺជាពាក្យសម្តីសម្រាប់ធ្វើឲ្យនរណាម្នាក់ចង់ធ្វើ។ «ព្រះអម្ចាស់ ...
ធ្វើឲ្យស្តេចស៊ីរូសចង់ធ្វើ»
សម្រែករបស់ស្តេចស៊ីរូសចេញពេញនគរទាំងមូល
សម្រែកគឺជាសញ្ញាសម្រាប់សារជាសម្លេង
ហើយនគរគឺជាសញ្ញាសម្រាប់ប្រជាជនដែលមានស្តេចគ្រប់គ្រង។
របៀបផ្សេងទៀតក្នុងការបកប្រែ:
«ស្តេចស៊ីរូសបានធ្វើសារទៅមនុស្សគ្រប់គ្នាដែលទ្រង់គ្រប់គ្រង»
នៅក្នុងគ្រប់ព្រះរាជាណាចក្ររបស់ទ្រង់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
នេះជាការល្អបំផុតក្នុងការបកប្រែ ដូច្នេះអ្នកអានយល់ថា
មនុស្សផ្សេងទៀតប្រហែលជាបានជួយស្តេចស៊ីរូសឲ្យទទួលសារទៅប្រជាជនដែលទ្រង់គ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលស្តេចស៊ីរូសបានសរសេរ
និងអ្វីដែលអ្នកនាំសាររបស់ទ្រង់បានអាន ដើម្បីឲ្យមនុស្សអាចស្តាប់ពួកគេ»
នគរទាំងអស់នៅលើផែនដី
នេះគឺជាការនិយាយបំផ្លើសមួយដែលមាននគរជាច្រើនដែលស្តេចស៊ីរូសមិនបានគ្រប់គ្រង។
សម្រាប់ព្រះអង្គនៅក្នុងក្រុងយេរូសាឡឹមក្នុង ... ស្រុកយូដា
អ្នកត្រូវបញ្ជាក់ឲ្យច្បាស់ថា ដំណាក់នោះគឺសម្រាប់មនុស្សថ្វាយបង្គំព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «ដំណាក់មួយនៅ ...
ស្រុកយូដាដែលមនុស្សអាចថ្វាយបង្គំព្រះអង្គ»
Ezra 1:3
ប្រជាជនរបស់ព្រះអង្គ
ប្រជាជនដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់។
អ្នករស់រានមានជីវិតលើទឹកដីនោះ ... គួរតែផ្គត់ផ្គង់ពួកគេ
ជនជាតិអ៊ីស្រាអែលទាំងនោះដែលជ្រើសរើសស្នាក់នៅកន្លែងដែលពួកគេគួរតែជួយដល់ប្រជាជនដែលបានជ្រើសរើសទៅក្រុងយេរូសាឡឹមទាំងខាងសាច់ឈាម
និងហិរញ្ញវត្ថុ។
Ezra 1:5
ការងាររបស់ពួកគេ
នេះគឺសំដៅទៅលើការងាររបស់មនុស្សនៅក្នុងខមុនដែលលើកឡើង
ដោយព្រះជាម្ចាស់។
អស់អ្នកដែលមានវិញ្ញាណរបស់ព្រះអម្ចាស់ឲ្យទៅ
ការបំផុសស្មារតីគឺជាពាក្យសម្តីសម្រាប់ធ្វើឲ្យនរណាម្នាក់ចង់ធ្វើ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សគ្រប់គ្នាដែលព្រះជាម្ចាស់បានបង្កើតចង់ទៅ»
ពាក្យស្រដៀងគ្នានេះមាននៅក្នុងជំពូកទី ១:១។
Ezra 1:7
មីត្រាដាត ... លោកសេសបាសារ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ដាក់ពួកគេក្នុងកណ្តាប់ដៃនៃពួកមីត្រាដាតដែលជាក្រុមអ្នកទារពន្ធ
ការដាក់វត្ថុមួយទៅក្នុងដៃរបស់នរណាម្នាក់គឺជាការប្រៀបធៀបមួយដែលអនុញ្ញាតឲ្យបុគ្គលនោះធ្វើអ្វីដែល
នៅទីនេះអ្នកអានគួរតែយល់ថា ស្តេចស៊ីរូសរំពឹងថា
មីត្រាដាតនឹងធ្វើអ្វីដែលស្តេចស៊ីរូសចង់ឲ្យលោកធ្វើ។ ការបកប្រែរបៀបផ្សេងទៀត:
«ដាក់លោកមីត្រាដាតជាអ្នកទារពន្ធឲ្យពួកគេ» ឬ
«ធ្វើឲ្យលោកមីត្រាដាតក្លាយជាអ្នកទទួលខុសត្រូវលើពួកគេ»
អ្នកទារពន្ធ
ម៉ាត្រីនអ្នកបង្ខុចប្រើស
ចាកចេញពីលោកសេសបាសារ
បានធ្វើឲ្យប្រាកដថា លោកសេសបាសារ
បានដឹងច្បាស់នូវអ្វីដែលជារបស់របរទាំងអស់
Ezra 1:9
ព័ត៌មានទូទៅ:
នេះគឺជាបញ្ជីនៃធាតុដែលមានលេខរៀង។
សាមសិប ... មួយពាន់ ... ម្ភៃប្រាំបួន
ប្រាំបួន - «៣០ ... ១០០០ ... ២៩»
ធើង ... ចាន
វត្ថុដែលត្រូវបានប្រើដើម្បីដាក់ទឹកសម្រាប់លាង
៥.៤០០មាស និងប្រាក់ទាំងអស់មានចំនួនប្រាំពាន់បួនរយ
ចំនួនវត្ថុទាំងអស់បានវិលត្រឡប់មកពីក្រុងបាប៊ីឡូនវិញ
ដែលមានរាយឈ្មោះខាងលើ

---

2 [1]នេះជាប្រជាជនក្នុងខេត្តដែលជាប់ជាឈ្លើយស្តេចនេប៊ូក្នេសា ជាអ្នកដែលបាននិរទេសពួកគេទៅក្នុងបាប៊ីឡូន ប្រជាជនត្រូវបានវិលត្រឡប់ទៅកាន់ទីក្រុងយេរូសាឡឹម
និងស្រុកយូដារបស់ពួកគេវិញ។[2]ពួកគេត្រឡប់មកវិញជាមួយ សូរ៉ូបាបិល យ៉ូស្វេ នេហេមា សេរ៉ាយ៉ា រេអេឡាយ៉ា ម៉ាដេកាយ បិលសាន មីសផា ប៊ីកវ៉ាយ រេហ៊ូម
និងប្អាណា។ នេះជាកំណត់ត្រាប្រជាជននៃស្រុកអ៊ីស្រាអែល។
[3]កូនចៅរបស់លោកប៉ារ៉ូសមាន ២១៧២នាក់។[4]កូនចៅរបស់លោកសេផាធាមាន ៣៧២នាក់។[5]កូនចៅរបស់លោកអើរ៉ាសមាន ៧៧៥នាក់។[6]កូនចៅរបស់លោកប៉ាហាត់
ម៉ូអាប់ជាកូនរបស់លោក យ៉ូស្វេ និងលោកយ៉ូអាប់មាន ២៨១២នាក់។
[7]កូនចៅរបស់លោកអេឡាំមាន ១ ២៥៤នាក់។[8]កូនចៅរបស់លោកសាធូមាន ៩៤៥នាក់។[9]កូនចៅរបស់លោក សាកាយមាន ៧៦០នាក់។[10]កូនចៅរបស់លោកបានីមាន
៦៤២នាក់។
[11]កូនចៅរបស់លោកបេបាយមាន ៦២៣នាក់។[12]កូនចៅរបស់លោកអាសកាដមាន ១ ២២២នាក់។[13]កូនចៅរបស់លោកអដូនីកាំមាន ៦៦៦នាក់។
[14]កូនចៅរបស់លោកប៊ីគវ៉ាយមាន ២ ០៥៦នាក់។
[15]កូនចៅរបស់លោកអេឌីនមាន ៤៥៤នាក់។[16]កូនចៅរបស់លោកអេធើខាងលោកហេសេគាមាន កៅសិបប្រាំបីនាក់។[17]កូនចៅរបស់លោកបេសាយមាន ៣២៣នាក់។
[18]កូនចៅរបស់លោកយ៉ូរ៉ាមាន ១១២នាក់។
[19]កូនចៅរបស់លោកហាស៊ូមមាន ២២៣នាក់។[20]កូនចៅរបស់លោកគីបារមាន កៅសិបប្រាំនាក់។[21]កូនចៅក្នុងភូមិបេថ្លេហិមមាន ១២៣នាក់។[22]កូនចៅក្នុងភូមិនថូផាមាន
ហាសិបប្រាំមួយនាក់។
[23]អ្នកក្នុងភូមិអាណាថោតមាន ១២៨នាក់។[24]អ្នកក្នុងភូមិអាសម៉ាវែតមាន សែសិបពីរនាក់។[25]អ្នកក្រុងគារយ៉ាត អើរីម កេភីរ៉ានិងបៀរ៉ូតមាន ៧៤៣នាក់។
[26]អ្នកក្រុងរ៉ាម៉ានិងកេបាមាន ៦២១នាក់។
[27]អ្នកក្រុងមីកម៉ាសមាន ១២២នាក់។[28]អ្នកក្រុងបេតអែលនិងអៃមាន ២២៣នាក់។[29]អ្នកភូមិនេបូរមាន ហាសិបពីរនាក់។[30]កូនចៅរបស់លោក ម៉ាកប៊ីសមាន ១៥៦នាក់។
[31]កូនចៅរបស់លោកអេឡាំម្នាក់ទៀតមាន ១ ២៥៤នាក់។[32]កូនចៅរបស់លោកហារីមមាន ៣២០នាក់។[33]កូនរបស់លោកឡូដ ហាឌីដ និងអូណូមាន ៧២៥នាក់។
[34]អ្នកក្រុងយេរីខូរមាន ៣៤៥នាក់។[35]អ្នកក្រុងសេណាអាមាន ៣ ៦៣០។
[36]ពួកបូជាចារ្យ ជាកូនចៅរបស់យេដាយ៉ាក្នុងគ្រួសាររបស់លោកយ៉ូស្វេមាន ៩៧៣នាក់។[37]កូនចៅរបស់លោកអ៊ីមមើរមាន ១ ០៥២នាក់។
[38]កូនចៅរបស់លោកផាសហ៊ើរមាន ១ ២៤៧នាក់។[39]កូនចៅរបស់លោកហារីមមាន ១ ០១៧នាក់។
[40]ពួកលេវីជាកូនចៅរបស់យ៉ូស្វេ និងជាកូនចៅរបស់លោកកាឌមាល ហើយកូនចៅលោកហូដាវ៉ាមាន ជិតសិបបួននាក់។[41]ក្រុមចម្រៀងក្នុងព្រះវិហារ
ជាកូនចៅរបស់លោកអេសាភមាន ១២៨នាក់។[42]កូនចៅរបស់អ្នកយាមក្លោងទ្វារ ជាកូនចៅរបស់លោកសាលូម លោកអេធើរ លោកថាលម៉ូន លោកអ័កគូប
លោកហាធីថានិងកូនរបស់លោកសូបាយសរុបមានចំនួន ១៣៩នាក់។
[43]ក្រុមអ្នកដែលបានចាត់ឲ្យទៅបម្រើក្នុងព្រះវិហារជាកូនចៅរបស់លោកស៊ីហា លោកហាស៊ូផា លោកតាបាអូត[44]លោកកេរ៉ុស លោកស៊ីយ៉ាហា
លោកផាដូន[45]លោកលេបាណា លោក ហាកាបា លោកអ័កគូប[46]លោកហាកាប លោកសាលម៉ាយនិងកូនចៅលោកហាណាន។
[47]កូនចៅរបស់លោកគីដេល លោកកាហារ លោករីអាយ៉ា[48]លោករេស៊ីន លោកនេកូដា លោកកាសាម[49]លោកកអ៊ូសា លោកផាសេហា លោកបេសាយ[50]លោកអាសណា
លោកមេហ៊ូនីមនិងកូនចៅរបស់លោកនេភូស៊ីម។
[51]កូនចៅរបស់លោកបាកប៊ូក កូនចៅរបស់លោកហាគូផា លោកហាហ៊ើរ[52]លោកបាសលូត លោកមេហ៊ីដា លោកហាសា[53]លោកបារកូស លោកស៊ីសេរ៉ា
លោកថាម៉ា[54]លោកនេស៊ីសេរ៉ានិងកូនចៅរបស់លោកហាធីផា។
[55]កូនចៅរបស់ព្រះបាទសាឡូម៉ូនជាអ្នកបម្រើជាកូនចៅរបស់លោកសូថាយ លោកសូផេរេត លោកពេរូដា[56]លោកយ៉ាឡា លោកដដារកុន លោកគីដេល[57]លោកសេផាធា
លោកហាធីល លោកផូកេរេត លោកសេបែម និងកូនចៅរបស់លោកអាំម៉ូន។[58]សរុបកូនចៅទាំងអស់មានចំនួន ៣៩២នាក់
ពួកគេចាត់ឲ្យជាអ្នកបម្រើក្នុងព្រះវិហារនិងកូនចៅរបស់ព្រះបាទសាឡូម៉ូនជាអ្នកបម្រើ។
[59]អស់អ្នកដែលបានចាក់ចេញពីធេល មែឡា ធេល ហារេសា កេរូប អរដាននិងអ៊ីមមើរ
ប៉ុន្តែពួកគេមិនទទួលស្គាល់ដូនតារបស់ពួកគេដែលមកពីអ៊ីស្រាអែលទេ[60]រួមបញ្ចូលទាំងកូនចៅរបស់ដេឡា ៦៥២នាក់
កូនចៅលោកថូប៊ីយ៉ានិងកូនចៅរបស់លោកនេកូដា។
[61]ដូច្នេះក្នុងចំណោមក្រុមកូនចៅរបស់បូជាចារ្យ កូនចៅរបស់លោកហាបាយ៉ា កូនចៅលោកហាកូស និងកូនចៅរបស់លោកបាស៊ីឡាយ
ជាអ្នកដែលយកប្រពន្ធរបស់លោកពីកូនស្រីរបស់លោកបាស៊ីឡាយក្នុងស្រុកកាឡាដ ហើយត្រូវបានហៅថាជាឈ្មោះរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[62]ពួកគេត្រូវស្វែងរកកំណត់ត្រាឈ្មោះពង្សាវតា ប៉ុន្តែមិនអាចរកឃើញឈ្មោះរបស់ពួកគេ ដូច្នេះពួកគេមិនរាប់បញ្ចូលពីភាពជាបូជាចារ្យដែលមិនបរិសុទ្ធ។
[63]ដូច្នេះអភិបាលនៅទីនោះបានប្រាប់ពួកគេមិនឲ្យបរិភោគយញ្ញបូជាដែលមិនបរិសុទ្ធទាំងឡាយរហូតដល់បូជាចារ្យណាម្នាក់សួរយូរីម និងធូមីមអនុញ្ញាតិ។
[64]ក្រុមទាំងអស់មានចំនួនសរុប ៤២ ៣៦០នាក់[65]ដោយមិនបូកបញ្ចូលអ្នកបម្រើស្រីប្រុសរបស់ពួកគេទាំងអស់ (មាន ៧ ៣៣៧នាក់)
និងក្រុមអ្នកចម្រៀងបុរសស្ត្រីទាំងអស់មានដល់ (ពីររយនាក់)។
[66]សេះរបស់ពួកគេមាន ៧៣៦ក្បាល។ លាកាត់របស់ពួកគេមាន ២៤៥ក្បាល។[67]អូដ្ឋរបស់ពួកគេមាន ៤៣៥ក្បាល និងសត្វលារបស់ពួកគេមាន ៦ ៧២០ក្បាល។
[68]នៅពេលដែលពួកគេទៅកាន់ព្រះដំណាក់របស់ព្រះអម្ចាស់ក្នុងក្រុងយេរូសាឡឹម អ្នកដឹកនាំពួកអយ្យកោបាននាំដង្វាយស្ម័គ្រចិត្តមកកាន់ដំណាក់សាងសង់។
[69]ពួកគេថ្វាយទៅតាមសមត្ថភាពរបស់ខ្លួនសម្រាប់ការងារនោះគឺមាន មាសប្រាំមួយពាន់តម្លឹង ប្រាក់ប្រាំពាន់ណែន និងសម្លៀកបំពាក់បូជាចារ្យចំនួនមួយរយសម្រាប់។
[70]ដូច្នេះពួកបូជាចារ្យ និងពួកលេវី ប្រជាជន ក្រុមអ្នកចម្រៀង និងក្រុមអ្នកយាមទ្វា
ព្រមអស់អ្នកដែលបានចាត់ឲ្យទៅបម្រើក្នុងព្រះវិហារស្នាក់អាស្រ័យក្នុងទីក្រុងរបស់ពួកគេ។
ប្រជាជនទាំងអស់ក្នុងទឹកដីអ៊ីស្រាអែលនឹងត្រូវរស់នៅក្នុងក្រុងរបស់ពួកគេរៀងខ្លួន។

Ezra 2:1
ព័ត៌មានទូទៅ:
នេះចាប់ផ្តើមនូវបញ្ជីឈ្មោះរបស់មនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
បានកើនឡើង
នេះគឺជាសញ្ញាណមួយដែលសំដៅទៅលើការធ្វើដំណើរឆ្ពោះទៅក្រុងយេរូសាឡឹម។
ការបកប្រែរបៀបផ្សេងទៀត: «បានត្រឡប់មកវិញ» ឬ «ត្រឡប់មកវិញ»
សេរ៉ាយ៉ា រេអេឡាយ៉ា ម៉ាដេកាយ ប៊ិលសាន មីសផា ប៊ីកវ៉ាយ រេហ៊ូមនិងប្អាណា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Ezra 2:3
ព័ត៌មានទូទៅ:
នេះគឺបន្តបញ្ជីឈ្មោះរបស់មនុស្សដែលបានវិលត្រឡប់មកពីនិរទេសព្រមជាមួយនឹងចំនួនរបស់ពួកគេ
លោកប៉ារ៉ូស ... លោកសេផាធា ... លោកអើរ៉ាស ... លោកប៉ាហាត់ ម៉ូអាប់ ... លោកយ៉ូស្វេ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Ezra 2:7
ព័ត៌មានទូទៅ:
នេះគឺជាការបន្តបញ្ជីឈ្មោះរបស់មនុស្សដែលបានវិលត្រឡប់មកពីនិរទេសព្រមជាមួយនឹងចំនួនរបស់ពួកគេ
លោកសាធូ ... លោក សាកាយ ... លោកបានី
ទាំងនេះគឺជាឈ្មោះបុរស។
Ezra 2:11
ព័ត៌មានទូទៅ:
នេះបន្តបញ្ជីឈ្មោះរបស់មនុស្សដែលបានវិលត្រឡប់មកពីនិរទេសព្រមជាមួយនឹងចំនួនរបស់ពួកគេ
លោកបេបាយ ... លោកអាសកាដ ... លោកអដូនីកាំ
ទាំងនេះគឺជាឈ្មោះបុរស។
លោកប៊ីគវ៉ាយ
ឈ្មោះរបស់មនុស្សដែលបកប្រែដូចនៅក្នុងជំពូកទី ២: ១។
Ezra 2:15
ព័ត៌មានទូទៅ:
នេះបន្តបញ្ជីឈ្មោះរបស់មនុស្សដែលបានវិលត្រឡប់មកពីនិរទេសព្រមជាមួយនឹងចំនួនរបស់ពួកគេ
លោកអេឌីន ... លោកអេធើ ... លោកបេសាយ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
កៅសិបប្រាំបី
ប្រាំបី - «៩៨»
Ezra 2:19
ព័ត៌មានទូទៅ:
នេះគឺជាការបន្តបញ្ជីមនុស្សដែលបានវិលត្រឡប់ពីការនិរទេសរួមជាមួយនឹងចំនួននៅក្នុងក្រុងនីមួយៗ។
សូមកត់សម្គាល់ថាការសម្លឹងមើលនៅក្នុងជំពូក ២:២១ទាំងនេះគឺជាឈ្មោះទីកន្លែង
ពីកន្លែងដែលពួកគេបានមកដំបូង។
លោកហាស៊ូម ... លោកគីបារ
ទាំងនេះគឺជាឈ្មោះបុរស។
កៅសិបប្រាំ ... ហាសិបប្រាំមួយ
ប្រាំ ... ហាសិបប្រាំមួយ - «៩៥ ... ៥៦»
កូនចៅក្នុងភូមិបេថ្លេហិម
នេះចាប់ផ្តើមរាប់ចំនួនប្រជាជនដែលបុព្វបុរសរបស់ពួកគេបានរស់នៅក្នុងក្រុងនានាក្នុងស្រុកយូដា
ភូមិនថូផា
នេះជាឈ្មោះក្រុងមួយនៅស្រុកយូដា។
Ezra 2:23
ព័ត៌មានទូទៅ:
នេះបន្តបញ្ជីមនុស្សដែលបានវិលត្រឡប់មកពីការនិរទេសរួម
និងចំនួនក្រុមនីមួយៗដែលបុព្វបុរសរបស់ពួកគេមកពីកន្លែងដែលបានចុះបញ្ជី។
ភូមិអាណាថោត ... ភូមិអាសម៉ាវែត ... ក្រុងគារយ៉ាត អើរីម ... កេភីរ៉ា ... បៀរ៉ូត ... កេបា
ឈ្មោះនៃទីកន្លែង
សែសិបពីរ
ពីរ - «៤២»
Ezra 2:27
ព័ត៌មានទូទៅ:
នេះនៅតែបន្តជាមួយបញ្ជីមនុស្សដែលបានវិលត្រឡប់មកពីនិរទេសរួមជាមួយចំនួនក្រុមនីមួយៗដែលបុព្វ
ក្រុងមីកម៉ាស ... ភូមិនេបូរ ... លោក ម៉ាកប៊ីស
ហាសិបពីរ
ពីរ - «៥២»
Ezra 2:31
ព័ត៌មានទូទៅ:
លោកហារីម ... លោកឡូដ ... ហាឌីដ ... អូណូ
ឈ្មោះនៃទីកន្លែង
Ezra 2:34
ព័ត៌មានទូទៅ:
អ្នកក្រុងសេណាអា
ឈ្មោះនៃទីកន្លែងមួយ
Ezra 2:36
ព័ត៌មានទូទៅ:
លោកយេដាយ៉ា ... លោកអ៊ីមមើរ ... លោកផាសហ៊ើរ ... លោកហារីម
លោកយ៉ូស្វេ
ឈ្មោះរបស់មនុស្សម្នាក់។ សូមបកប្រែដូចក្នុងជំពូកទី ២:៣ ។
លោកហារីម
«ហារីម» ក្នុងជំពូកទី ២:៣១ គឺជាឈ្មោះនៃទីកន្លែងមួយ ប៉ុន្តែនៅទីនេះ «ហារីម»
គឺជាឈ្មោះរបស់មនុស្សម្នាក់។
Ezra 2:40
ផ្នែកនេះគឺរាយឈ្មោះពួកលេវីដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីការនិរទេសខ្លួនរួមជាមួយ
និងចំនួនក្រុមនីមួយៗ។
លោកកាឌមាល ... លោកហូដាវា ... លោកសាលូម ... លោកថាលម៉ូនលោកអ័កគូប លោកហាធីថា
លោកសូបាយ
ឈ្មោះរបស់មនុស្ស
ជិតសិបបួន
បួន - «៧៤»
អ្នកទទួលខុសត្រូវ អ្នកដែលចូលតាមក្លោងទ្វារព្រះវិហារ
លោកអេធើរ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចក្នុងជំពូកទី ២:១៥ ។
Ezra 2:43

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ:

ផ្នែកនេះបន្តចុះបញ្ជីឈ្មោះពួកលេវីដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីនិរទេស

លោកស៊ីហា លោកហាស៊ូផា លោកថាបាអូត លោកកេរ៉ូស លោកស៊ីយ៉ាហា លោកផាដូន

លោកលេបាណា លោកហាកាបា ... លោកហាកាប លោកសាលម៉ាយនិងកូនចៅលោកហាណាន

ឈ្មោះរបស់មនុស្ស

លោកអ័កគូប

បកប្រែដូចក្នុងជំពូកទី ២:៤០ ។

Ezra 2:47

ព័ត៌មានទូទៅ:

ផ្នែកនេះបន្តចុះបញ្ជីឈ្មោះពួកលេវីដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីនិរទេស

ទាំងនេះជាឈ្មោះបុរសទាំងអស់។

Ezra 2:51

ព័ត៌មានទូទៅ:

ផ្នែកនេះបន្តចុះបញ្ជីឈ្មោះពួកលេវីដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីនិរទេស

ទាំងនេះជាឈ្មោះបុរសទាំងអស់។

Ezra 2:55

ព័ត៌មានទូទៅ:

ផ្នែកនេះបន្តចុះបញ្ជីឈ្មោះពួកលេវីដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីនិរទេស

សរុបកូនចៅទាំងអស់មានចំនួន ៣៩២នាក់

នេះគឺជាចំនួនប្រជាជនទាំងអស់នៅក្នុងក្រុមនេះដែលបានវិលត្រឡប់មកពីការនិរទេស។

Ezra 2:59

ព័ត៌មានទូទៅ:

នេះជាបញ្ជីរាយនាមមនុស្សដែលបានវិលត្រឡប់មកស្រុកអ៊ីុស្រាអែលវិញពីក្រុងនានាក្នុងពេលដែលពួកគេបានទៅ

ប៉ុន្តែមិនអាចបង្ហាញពីមរតករបស់ខ្លួនបានឡើយ។

ធេល មែឡា ធេល ហារេសា កេរូប អរដាន និងអ៊ីមមើរ

ជាកន្លែងដែលមិនមានទៀតទេនៅបាប៊ីឡូន

លោកដេឡា លោកថូប៊ីយ៉ា និងលោកនេកូដា

ឈ្មោះរបស់មនុស្ស

Ezra 2:61

លោកហាបាយ៉ា ... លោកហាកូស ... លោកបាស៊ីឡាយ

ឈ្មោះរបស់មនុស្ស

កំណត់ត្រាឈ្មោះពង្សាវតា

កំណត់ត្រាដែលប្រាប់ថា បុព្វបុរសរបស់ពួកគេជានរណា

មិនអាចរកឃើញឈ្មោះរបស់ពួកគេ

«មិនអាចរកឃើញឈ្មោះរបស់ពួកគេនៅក្នុងកំណត់ត្រារបស់ពួកបូជាចារ្យ»

ពួកគេមិនរាប់បញ្ចូលពីភាពជាបូជាចារ្យដែលមិនបរិសុទ្ធ

ដែលអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ នាមអរូបី «បូជាចារ្យ»

អាចត្រូវបានបកប្រែជាកិរិយាស័ព្ទ «ធ្វើការជាសង្ឃ» ។

ការបកប្រែរបៀបផ្សេងទៀត: «បូជាចារ្យផ្សេងទៀតបានប្រព្រឹត្ត

ចំពោះពួកគេដូចជាពួកគេមិនស្អាត មិនអនុញ្ញាតឲ្យពួកគេធ្វើការជាបូជាចារ្យ»

មិនបរិសុទ្ធ

មិនសមធ្វើជាបូជាចារ្យ

យូរីម និងធូមីម

វត្ថុពីរដូចជាគ្រាប់ឡុកឡាក់ដែលពួកសង្ឃប្រើ

ដើម្បីសម្រេចនូវអ្វីដែលព្រះជាម្ចាស់ចង់ឲ្យពួកគេធ្វើ

Ezra 2:64

ក្រុមទាំងអស់

ក្រុមទាំងអស់ដែលវិលត្រឡប់ទៅកាន់ទឹកដីរបស់យូដាវិញ ចេញពីការនិរទេសខ្លួន

បម្រើស្រីប្រុសរបស់ពួកគេទាំងអស់

«អ្នកបម្រើស្រីរបស់ពួកគេ»

ពីររយនាក់

«២០០»

Ezra 2:66

ព័ត៌មានទូទៅ:

នេះគឺជាបញ្ជីសត្វពាហនៈរួមជាមួយចំនួនសត្វនីមួយៗដែលបានត្រឡប់មកវិញជាមួយប្រជាជនពីការនិរទេ

Ezra 2:68

ប្រាំមួយម៉ឺនមួយពាន់ ... ប្រាំពាន់ ... មួយរយ

ក្នុងក្រុងនានា ... ប្រាំពាន់ ... មួយរយ - «៦១,០០០ ... ៥,០០០ ... ១០០»

កាក់មាស

កាក់មាសគឺជាកាក់មាសតូចមួយដែលត្រូវបានប្រើ ដោយចក្រភពពែរ្ស។

ណែន

ណែនគឺជាឯកតានៃទំងន់។ ណែនមួយស្មើនឹង ៥៥០ ក្រាម។

ណែនត្រូវបានផ្សារភ្ជាប់ជាមួយនឹងការវាស់ប្រាក់។

សម្លៀកបំពាក់

សម្លៀកបំពាក់ពាក់ជាប់នឹងស្បែក

Ezra 2:70

ប្រជាជនទាំងអស់ក្នុងទឹកដីអ៊ីុស្រាអែលនឹងត្រូវរស់នៅក្នុងក្រុងរបស់ពួកគេរៀងខ្លួន

មនុស្សគ្រប់គ្នាបានត្រឡប់ទៅផ្ទះរៀងៗខ្លួន នៅឯស្រុកយូដា។

មិនមែនមនុស្សគ្រប់គ្នាតាំងទីលំនៅនៅក្រុងយេរូសាឡឹមទេ។

---

3 [1]លុះដល់ខែទីប្រាំពីរ កាលជនជាតិអ៊ីស្រាអែល ដែលរស់នៅតាមទីក្រុងរបស់ខ្លួន បណ្តាជនបានមកជួបជុំនៅក្រុងយេរូសាឡឹម ដោយចិត្តគំនិតតែមួយ។[2]លោកយេសួ
ជាកូនលោកយ៉ូសាដាក និងបូជាចារ្យ ដែលជាបងប្អូនរបស់លោក ព្រមទាំងលោកសូរ៉ូបាបិល ជាកូនរបស់លោកសាលធាល និងបងប្អូនរបស់លោក
ក៏នាំគ្នាសង់អាសនៈជាព្រះនៃអ៊ីស្រាអែល ដើម្បីថ្វាយដង្វាយដុត ដូចមានចែងទុកក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ជាអ្នកជំនិតរបស់ព្រះជាម្ចាស់។
[3]បន្ទាប់មកពួកគេនាំគ្នាសង់អាសនៈនៅលើគ្រឹះចាស់ ដោយព្រោះពួកគេភ័យខ្លាចចំពោះប្រជាជនដែលរស់នៅក្នុងស្រុកនោះ។ ពួកគេបានថ្វាយដង្វាយដុតចំពោះព្រះអម្ចាស់
នៅលើអាសនៈ ទាំងព្រឹក ទាំងល្ងាច។[4]បន្ទាប់មកពួកគេប្រារព្ធពិធីបុណ្យបារាំ ដូចមានចែងទុកក្នុងគម្ពីរ ហើយពួកគេត្រូវថ្វាយដង្វាយដុតជារៀងរាល់ថ្ងៃ
តាមចំនួនដូចមានចែងទុកក្នុងគម្ពីរវិន័យ ដែលបានតម្រូវតាមថ្ងៃនីមួយៗ។[5]ចាប់ពីពេលនោះមក ពួកគេនាំគ្នាថ្វាយដង្វាយដុតជាប្រចាំ
ហើយដង្វាយដុតសម្រាប់បុណ្យចូលខែថ្មី និងបុណ្យដែលបានកំណត់ទុកទាំងប៉ុន្មាន ដែលគេប្រារព្ធថ្វាយព្រះអម្ចាស់
ព្រមទាំងដង្វាយស្ម័គ្រចិត្តដែលប្រជាជនយកមកថ្វាយព្រះអម្ចាស់។
[6]ចាប់ពីថ្ងៃទីមួយនៃខែទីប្រាំពីរ ពួកគេចាប់ផ្តើមថ្វាយដង្វាយដុតចំពោះព្រះអម្ចាស់ ទោះបីគ្រឹះនៃព្រះវិហាររបស់ព្រះអម្ចាស់ មិនទាន់បានចាក់នៅឡើយ។
[7]ដូច្នេះពួកគេបានឲ្យប្រាក់ទៅជាងថ្ម និងជាងឈើ ហើយពួកគេបានឲ្យស្បៀងអាហារ ភេសជ្ជៈ និងប្រេងអូលេវ ដល់អ្នកក្រុងស៊ីដូន និងក្រុងទីរ៉ុស
ដើម្បីឲ្យពួកគេយកឈើតាត្រៅតាមសមុទ្រ ពីទឹកដីលីបង់ រហូតដល់កំពង់ផែយ៉ុបប៉េ តាមការអនុញ្ញាតរបស់ព្រះបាទ ស៊ីរូស ជាស្តេចទឹកដីពែរ្ស។
[8]នៅឆ្នាំទីពីរ នៃខែទីពីរ ក្រោយពីពួកគេបានមកដល់ព្រះដំណាក់នៃព្រះជាម្ចាស់នៅក្រុងយេរូសាឡឹមវិញ លោកសូរ៉ូបាបិល ជាកូនរបស់លោកសាលធាល និងលោកយេសួ
ជាកូនលោកយ៉ូសាដាក និងបូជាចារ្យជាបងប្អូនរបស់លោក និងពួកលេវី ហើយបងប្អូនឯទៀតៗរបស់គេ ព្រមទាំងអស់អ្នកដែលត្រូវគេកៀរទៅជាឈ្លើយ
ហើយវិលត្រឡប់មកក្រុងយេរូសាឡឹមវិញ បាននាំគ្នាចាប់ផ្តើមសង់ព្រះដំណាក់។ ពួកគេចាត់ទាំងពួកលេវី ដែលមានអាយុចាប់ពីម្ភៃឆ្នាំឡើងទៅ
ឲ្យមើលការខុសត្រូវលើការសាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់។[9]លោកយេសួ ព្រមទាំងកូន និងបងប្អូនរបស់លោក គឺលោកកាឌមាល និងកូនប្រុសរបស់លោក
ដែលមកពីពូជពង្សយូដា ដើម្បីត្រួតពិនិត្យអស់អ្នកដែលសាងសង់ព្រះដំណាក់ព្រះជាម្ចាស់។ ព្រមទាំងកូនចៅរបស់លោកហេណាដាដ
និងពួកលេវីឯទៀតៗដែលជាបងប្អូនរបស់ពួកគេ។
[10]នៅពេលដែលពួកជាងចាក់គ្រឹះព្រះវិហាររបស់ព្រះអម្ចាស់។ គេសុំឲ្យអស់លោកបូជាចារ្យដែលស្លៀកសម្លៀកបំពាក់សម្រាប់ពិធីបុណ្យ បានចេញមកទាំងកាន់ត្រែ
ហើយពួកលេវី ជាកូនចៅរបស់លោកអេសាភ កាន់ឈិង ដើម្បីសរសើរដំកើងព្រះអម្ចាស់ ដូចព្រះបាទដាវីឌ ជាស្តេចអ៊ីស្រាអែលបានបង្គាប់ទុក។
[11]ពួកគេច្រៀងឆ្លងឆ្លើយគ្នាលើកតម្កើង និងអរព្រះគុណព្រះអម្ចាស់ថា «ព្រះអម្ចាស់ល្អ ព្រះហឫទ័យសប្បុរស ស្ថិតស្ថេរអស់កល្បជានិច្ច ចំពោះជនជាតិអ៊ីស្រាអែល»។
ប្រជាជនទាំងអស់ក៏ស្រែកឡើង សរសើតម្កើង ព្រះអម្ចាស់យ៉ាងកងរំពង ព្រោះពួកគេបានចាក់គ្រឹះព្រះដំណាក់របស់ព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

[12]ប៉ុន្តែ មានពួកបូជាចារ្យជាច្រើន ព្រមទាំងពួកលេវី និងមេក្រុមគ្រួសារដែលមានវ័យចាស់ៗ ដែលធ្លាប់បានឃើញព្រះដំណាក់ពីជំនាន់មុន នាំគ្នាយំជាខ្លាំង
នៅពេលដែលឃើញគេចាក់គ្រឹះព្រះដំណាក់ថ្មីនេះ។ ប៉ុន្តែ មានមនុស្សជាច្រើនបានស្រែកហ៊ោដោយអរសប្បាយ។[13]ហេតុនេះហើយបានជាប្រជាជនមិនអាចដឹង
សំឡេងណាដែលអរសប្បាយ ហើយសំឡេងណាដែលជាសម្លេងយំសោកឡើយ ព្រោះប្រជាជនស្រែកយ៉ាងខ្លាំង ហើយសម្រែកនោះលាន់ឮទៅឆ្ងាយ។

Ezra 3:1

ខែទីប្រាំពីរ

នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។ នេះគឺនៅចុងបញ្ចប់នៃរដូវប្រាំង
និងការចាប់ផ្តើមនៃរដូវភ្លៀងដំបូង។ នេះគឺជាកំឡុងពេលចុងក្រោយនៃខែកញ្ញា
និងផ្នែកដំបូងនៃខែតុលាតាមប្រតិទិនលោកខាងលិច។

ដូចមនុស្សតែម្នាក់

មនុស្សម្នាក់នៅកន្លែងតែមួយ ហើយមានគោលបំណងតែមួយ។
ការបកប្រែរបៀបផ្សេងទៀត: «សម្រាប់គោលបំណងតែមួយ»

លោកយេសួ

នេះជាឈ្មោះមនុស្សម្នាក់។ បកប្រែដូចគ្នាក្នុងជំពូកទី ២:៣៦ ។

លោកសាលធាល

នេះជាឈ្មោះបុរស។

បានក្រោកឡើង ហើយសាងសង់

ការក្រោកឈរគឺជាពាក្យប្រៀបធៀបមួយសម្រាប់ការចាប់ផ្តើមធ្វើសកម្មភាព។
ការបកប្រែរបៀបផ្សេងទៀត: «ចាប់ផ្តើមធ្វើសកម្មភាព និងសាងសង់»

ដូចមានចែងទុកក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ អ្នកត្រូវបញ្ជាក់ឲ្យច្បាស់ថាអ្នកណា
ហើយអ្វីដែលព្រះអម្ចាស់បានបញ្ជា។ ការបកប្រែរបៀបផ្សេងទៀត:
«ដូចព្រះអម្ចាស់បានបញ្ជាពួកគេឲ្យ ធ្វើតាមក្រិត្យវិន័យរបស់លោកម៉ូសេ»

Ezra 3:3

នាំគ្នាសង់អាសនៈនៅលើគ្រឹះចាស់

«បានសង់អាសនៈនៅលើកន្លែងឈររបស់វា» ឬ
«ដាក់អាសនៈនៅលើកន្លែងឈររបស់វា ដូច្នេះវានឹងស្ថិតនៅទីនោះ»

ពួកគេភ័យខ្លាច

នេះគឺជាប្រយោគ «ពួកគេភ័យខ្លាចខ្លាំងណាស់»

ដោយព្រោះប្រជាជនដែលរស់នៅក្នុងស្រុកនោះ

អ្នកប្រហែលជាត្រូវបញ្ជាក់ឲ្យច្បាស់ពីអ្វីដែលទាក់ទងនឹងប្រជាជននៅស្រុកនោះដែលធ្វើឲ្យ[illegible]ភ័យខ្លាច។
ការបកប្រែរបៀបផ្សេងទៀត: «ពីព្រោះពួកគេគិតថា
ប្រជាជននៅស្រុកនោះចង់វាយប្រហារពួកគេ»

ពួកគេបានថ្វាយដង្វាយដុតចំពោះព្រះអម្ចាស់ នៅលើអាសនៈ ទាំងព្រឹក ទាំងល្ងាច

រឿងដំបូងដែលប្រជាជនបានធ្វើគឺចាប់ផ្តើមថ្វាយយញ្ញបូជា។
នេះគឺមុនពេលដែលព្រះវិហារត្រូវបានសាងសង់ឡើងវិញ។

ប្រារព្ធពិធីបុណ្យបារាំ

នេះគឺជាពិធីបុណ្យមួយដែលត្រូវបានគេប្រារព្ធសម្រាប់រយៈពេលប្រាំបី ថ្ងៃក្នុងខែទី
៧ នៃប្រតិទិនហេប្រឺ។ នេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងពេលវេលានៃការចាកចេញ
នៅពេលជនជាតិអ៊ីុស្រាអែលរស់នៅក្នុងត្រសាល។

Ezra 3:6

ថ្ងៃទីមួយនៃខែទីប្រាំពីរ

នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។
ថ្ងៃដំបូងគឺជិតពាក់កណ្តាលខែកញ្ញាតាមប្រតិទិនលោកខាងលិច។

គ្រឹះនៃព្រះវិហាររបស់ព្រះអម្ចាស់ មិនទាន់បានចាក់នៅឡើយ

ជនជាតិយូដាបានចាប់ផ្តើមធ្វើពិធីគោរពបូជា
មុនពេលពួកគេចាប់ផ្តើមសាងសង់ព្រះវិហារ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិនទាន់បានចាក់គ្រឹះព្រះវិហារនេះទេ»

តាមការអនុញ្ញាតរបស់ព្រះបាទ ស៊ីរូស ជាស្តេចទឹកដីពែរ្ស

សំបុត្រដែលផ្ញើដោយលោកស៊ីរូសអនុញ្ញាតឲ្យជនជាតិយូដាទិញសម្ភារៈ
និងសាងសង់ព្រះវិហារ។

Ezra 3:8

ខែទីពីរ

នេះជាខែទីពីរនៃប្រតិទិនហេប្រឺ។ នេះគឺជារដូវក្តៅ
នៅពេលដែលប្រជាជនកំពុងប្រមូលផលដំណាំ។
នេះគឺជាកំឡុងពេលចុងក្រោយនៃខែមេសា
និងផ្នែកដំបូងនៃខែឧសភានៅលើប្រតិទិនលោកខាងលិច។

ឆ្នាំទីពីរ

នេះគឺនៅក្នុងអំឡុងពេលមួយឆ្នាំ បន្ទាប់ពីពួកគេបានត្រឡប់មកវិញ។

ទៅកាន់ព្រះដំណាក់ព្រះជាម្ចាស់

អ្នកប្រហែលជាត្រូវបញ្ជាក់ឲ្យច្បាស់ថាគ្មានព្រះដំណាក់របស់ព្រះជាម្ចាស់គង់
នៅពេលពួកគេមកដល់ទេ។ ការបកប្រែរបៀបផ្សេងទៀត:
«ទៅកាន់កន្លែងដែលព្រះដំណាក់របស់ព្រះជាម្ចាស់បានគង់នៅ» ឬ
«កន្លែងដែលពួកគេនឹងសាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់»

លោកយេសួ ... លោកយ៉ូសាដាក ... លោកហេណាដាដ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

អាយុម្ភៃឆ្នាំ

«អាយុ 20ឆ្នាំ»

លោកកាឌមាល

នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។ បកប្រែដូចនៅក្នុងជំពូកទី ២:៤០

Ezra 3:10

ចាក់គ្រឹះ

«គ្រឹះ» អត្ថន័យនៅក្នុងនេះគឺលើសពីការផ្តុំដុំថ្ម ដើម្បីទ្រទ្រង់ជញ្ជាំងព្រះវិហារ។
វារួមបញ្ចូលទាំងជាន់ព្រះវិហារទាំងមូលដែលដាក់ជាថ្ម។
នេះបានអនុញ្ញាតឲ្យអ្នកថ្វាយបង្គំទាំងអស់ស្លៀកសម្លៀកបំពាក់ពិសេស
ហើយរក្សាពួកគេឲ្យស្អាត។
[illegible]ភ័យខ្លាច។

«អាវធាយពិសេសរបស់ពួកគេ»

ឈឹង

បន្ទះដែកមូលស្តើងពីរ ដែលត្រូវបានគោះជាមួយគ្នា ដើម្បីបង្កើតជាសម្លេងឮខ្លាំង

ព្រះហស្តរបស់ព្រះបាទដាវីឌ ... បានបង្គាប់ទុក

ព្រះហស្តរបស់ស្តេចគឺជាទីសម្គាល់សម្រាប់អំណាច ដើម្បីបង្គាប់បញ្ជា។
ការបកប្រែរបៀបផ្សេងទៀត: «ដូចជាព្រះបាទដាវីឌ ... បានបង្គាប់ទុក»

អរព្រះគុណ

អារម្មណ៍ និងការបង្ហាញពីរការកោតសរសើរ និងការដឹងគុណ
ចំពោះសេចក្តីសប្បុរសរបស់អ្នកដទៃ។

Ezra 3:12

ព្រះដំណាក់ដំបូង

នេះសំដៅទៅលើព្រះវិហារដំបូងបង្អស់ដែលព្រះបាទសាឡូម៉ូនបានសង់គឺ
ព្រះដំណាក់របស់ព្រះជាម្ចាស់។

នៅចំពោះមុខពួកគេ

ភ្នែកតំណាងឲ្យការមើលឃើញ។ ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងការមើលឃើញរបស់ពួកគេ» ឬ «ហើយពួកគេបានឃើញវា»

យំជាខ្លាំង

នេះសំដៅទៅលើការបង្ហាញអារម្មណ៍សោកសៅដែលទាក់ទងនឹងទឹកភ្នែក
និងសម្លេងលាន់ឮ។

---

4 [1]កាលខ្មាំងសត្រូវរបស់ពួកយូដា និងបេនយ៉ាមីន ឮថាពួកឈ្លើយត្រឡប់មកវិញ កំពុងនាំគ្នាសាងសង់ព្រះវិហាររបស់ព្រះជាម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល។
[2]នោះពួកគេក៏នាំគ្នាមកជួបលោកសូរ៉ូបាបិល និងអស់លោកជាមេក្រុមលើគ្រួសារ។ ហើយជម្រាបថា «សូមឲ្យពួកយើងសាងសង់ជាមួយអស់លោកផង
ដ្បិតពួកយើងក៏គោរពបម្រើព្រះជាម្ចាស់ ដូចជាអស់លោកដែរ ហើយយើងបានថ្វាយយញ្ញបូជាចំពោះព្រះអង្គ តាំងពីជំនាន់ព្រះចៅអេសា-ហាដោន ជាស្តេចស្រុកអាស្ស៊ីរី
បាននាំពួកយើងមកទីនេះ»។
[3]ប៉ុន្តែ លោកសូរ៉ូបាបិល និងលោកយេសួ និងអស់លោកជាមេក្រុមគ្រួសារនៃជនជាតិអ៊ីស្រាអែល ឆ្លើយទៅអ្នកទាំងនោះថា «អស់លោកមិនត្រូវចូលរួមជាមួយយើងទេ
ក្នុងការសាងសង់ព្រះដំណាក់ថ្វាយព្រះរបស់ពួកយើងទេ មានតែពួកយើងប៉ុណ្ណោះដែលធ្វើការនេះថ្វាយព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល ដូចព្រះចៅសូរ៉ូស
ជាស្តេចស្រុកពើស៊ី បានបង្គាប់ដល់យើង»។

generated on Wed Sep 10 16:16:32 2025

[4]ដូច្នេះ អ្នកស្រុកនាំគ្នាធ្វើឲ្យប្រជាជនយូដាបាក់ទឹកចិត្ត ហើយបំភ័យពួកគេមិនឲ្យសាងសង់។
[5]អ្នកស្រុកទាំងនោះបានសូកប៉ាន់ពួកទីប្រឹក្សាដើម្បីរារាំងគម្រោងការរបស់ពួកជនជាតិយូដា។ តាំងពីរជ្ជកាលព្រះចៅ និងរហូតដល់រជ្ជកាលព្រះចៅដារីយុស
ជាស្តេចស្រុកពែរ្ស។[6]នៅក្នុងរជ្ជកាលព្រះចៅអហាសូរ៉ុស កាលទ្រង់ចាប់ផ្តើមសោយរាជ្យ អ្នកស្រុកនោះបានសរសេរសំបុត្រមួយថ្វាយស្តេច
ដើម្បីចោទប្រកាន់ពួកអ្នកស្រុកយូដា និងពួកអ្នកក្រុងយេរូសាឡិម។
[7]នៅក្នុងរជ្ជកាលព្រះចៅអហាសូរ៉ុស លោកប៊ីសឡាំ លោកមីត្រាដាត លោកតាបេល និងបក្សពួករបស់គេឯទៀត ក៏បានសរសេរថ្វាយទៅព្រះចៅអហាសូរ៉ុស។
សំបុត្រនោះសរសេរជាភាសារអារ៉ាម ហើយមានបកប្រែ។[8]លោករេហ៊ូមដែលជាមេបញ្ជាការ និងលោកស៊ីមសៃ ដែលជាស្មៀន
បានសរសេរសំបុត្រថ្វាយទៅព្រះចៅអើថាស៊ីកសេសស្តីអំពីក្រុងយេរូសាឡិម។
[9]រេហ៊ូមដែលជាមេបញ្ជាការ និងស៊ីមសៃ ជាស្មៀន ព្រមទាំងសហការីឯទៀតរបស់ខ្លួន អ៊ីរិច បាប៊ីឡូន ស៊ូសាន និងអេឡាំពួកគេបានសរសេរសំបុត្រ[10]និងប្រជាជនឯទៀត
ដែលព្រះចៅអស្នាផារ ជាស្តេចដ៏ឧត្តុង្គឧត្តម បានកៀរឲ្យមករស់នៅក្នុងស្រុកសាម៉ារី និងនៅក្នុងស្រុកឯទៀតដែលនៅខាងនាយទន្លេ។
[11]សេចក្តីនៅក្នុងសំបុត្រ ដែលពួកគេបានផ្ញើថ្វាយព្រះចៅអើថាស៊ីេកសេស «សូមទូលថ្វាយព្រះចៅអើថាស៊ីេកសេស ទូលបង្គំយើងខ្ញុំ
ជាប្រជាជនដែលនៅខាងនាយទន្លេ[12]សូមទូលថ្វាយព្រះករុណាជ្រាបថា ជនជាតិយូដាដែលត្រឡប់មកពីនគររបស់ព្រះករុណា ដែលមកដល់ក្រុងយេរូសាឡឹម
ពួកគេកំពុងតែសាងសង់ទីក្រុងបះបោរ។ ពួកគេបានសង់កំផែងរួចស្រេចហើយ និងកំពុងចាក់គ្រឹះទៀតផង។
[13]ដូច្នេះ សូមព្រះករុណាជ្រាបថា ប្រសិនបើពួកគេសង់ក្រុងនេះឡើងវិញ ហើយកំផែងក៏រួចស្រេច នោះពួកគេនឹងលែងបង់ពន្ធដា សួយសារអាករ ឬពន្ធផ្លូវ
ហើយធ្វើឲ្យព្រះករុណានឹងខាតបង់រាជទ្រព្យមិនខាន។
[14]ដោយព្រោះយើងខ្ញុំជ្រកកោនក្រោមព្រះគុណព្រះករុណា យើងខ្ញុំមិនអាចព្រងើយកន្តើយ ទុកឲ្យគេបង្អាប់កិត្តិយសរបស់ព្រះករុណាឡើយ។
ហេតុនេះហើយបានជាយើងខ្ញុំផ្ញើសំបុត្រនេះមកថ្វាយព្រះករុណា[15]ដើម្បីឲ្យគេស្រាវជ្រាវរកក្នុងសៀវភៅកំណត់ត្រានៃអយ្យកោរបស់ព្រះករុណា
នោះព្រះរាជានឹងឃើញច្បាស់ថា ទីក្រុងនោះតែងតែបះបោរជានិច្ច និងបង្ករឲ្យមានវិបត្តិដល់ព្រះមហាក្សត្រនិងដល់ខេត្តនានា។ តាំងពីដើមរៀងមក
ប្រជាជននៅក្រុងនេះតែងតែបង្ករឲ្យមានចលនាបះបោរជានិច្ច។ ហេតុនេះហើយបានជាទីក្រុងនេះត្រូវគេប៉ផ្លាញខ្ទេចខ្ទីអស់។[16]យើងខ្ញុំសូមទូលព្រះករុណាឲ្យបានជ្រាបថា
ប្រសិនបើទីក្រុងនេះឡើងវិញ ហើយកំផែងរួចស្រេចហើយ នោះព្រះករុណានឹងមិនមានទឹកដីនៅខាងនាយទន្លេជាមិនខាន»។
[17]ព្រះរាជាបានផ្ញើសារតបទៅលោករេហ៊ូម និងលោកស៊ីមសៃ ព្រមទាំងសហការីឯទៀតៗនៅក្នុងស្រុកសាម៉ារី និងនៅកន្លែងផ្សេងៗទៀត នៃខេត្តខាងនាយទន្លេ
«សូមឲ្យអ្នកបានប្រកបដោយសេចក្តីសុខសាន្ត។[18]រីឯសំបុត្រដែលអស់លោកបានផ្ញើមកយើង នោះគេបានបកប្រែ ហើយអានឲ្យយើងស្តាប់សព្វគ្រប់អស់ហើយ។
[19]ដូច្នេះយើងបានបញ្ជាឲ្យគេពិនិត្យស្រាវជ្រាវ ហើយឃើញថាតាំងពីដើមរៀងមក អ្នកក្រុងយេរូសាឡឹម តែងតែបង្ករការបះបោរ និងលើកគ្នាទាស់ប្រឆាំងនឹងស្តេចជានិច្ច។
[20]ហើយក៏មានស្តេចខ្លាំងពូកែ ដែលបានសោយរាជ្យនៅក្រុងយេរូសាឡឹម ហើយគ្រប់គ្រងលើអាណាខេត្តទាំងមូលខាងនាយទន្លេ។ ព្រមទាំងបង់ពន្ធដារសួយសារអាករ
និងពន្ធផ្លូវថ្វាយស្តេចទៀតផង។[21]ឥឡូវនេះ ចូរអស់លោកចេញបញ្ជាឲ្យពួកគេឈប់ធ្វើការទាំងនេះ ហើយកុំឲ្យពួកគេសាងសង់ទីក្រុងឡើងវិញ
រហូតទាល់តែមានបញ្ជាចេញពីយើង។[22]ចូរប្រយ័ត្នកុំឲ្យធ្វេសប្រហែសនឹងកិច្ចការនេះឡើយ។ តើហេតុអ្វីបានជាត្រូវឲ្យមានការខូចខាតរីកធំឡើង
ដែលនាំឲ្យមានការខូចបង់រាជទ្រព្យដល់ស្តេច?
[23]កាលគេបានអានរាជសាររបស់ព្រះចៅអើថាស៊ីេកសេស នៅចំពោះមុខលោករេហ៊ូម និងលោកស៊ីមសៃ ព្រមទាំងសហការីឯទៀតៗស្តាប់ហើយ
អ្នកទាំងនោះក៏ប្រញាប់ប្រញាល់នាំគ្នាចេញទៅក្រុងយេរូសាឡឹម ហើយបង្ខំឲ្យជនជាតិយូដាបញ្ឈប់ការសាងសង់។[24]ដូច្នេះ
កិច្ចការដែលសាងសង់ព្រះរាជដំណាក់របស់ព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម ក៏ត្រូវបានផ្អាក រហូតដល់ឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស ជាស្តេចស្រុកពែរ្ស។

Ezra 4:1

ព័ត៌មានទូទៅ:

ប្រជាជនដែលមិនមែនជាជនជាតិយូដា ក៏បានជួយសាងសង់ព្រះវិហាររដែរ។

ពួកឈ្លើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«អ្នកដែលពួកបាប៊ីឡូនបានចាប់យកទៅជាឈ្លើយ»

លោកសូរ៉ូបាបិល

ឈ្មោះរបស់បុរស។ បកប្រែដូចក្នុងជំពូក២:១ ។

ព្រះចៅអេសា-ហាដោន ជាស្តេចស្រុកអាស្ស៊ីរី

ទ្រង់បានគ្រប់គ្រងនៅស្រុកអាស្ស៊ីរី មុនពេលព្រះចៅសូរ៉ូសគ្រប់គ្រងស្រុកពើស៊ី។

Ezra 4:3

លោកយេសួ

ឈ្មោះរបស់មនុស្សម្នាក់។ បកប្រែជាដូចក្នុងជំពូក២:៣ ។

មិនមែនជាអស់លោកទេ ប៉ុន្តែយើងទេជាអ្នកសាងសង់

អាចមានន័យថា ១) អ្នកដឹកនាំជនជាតិយូដាយល់ថា
ព្រះចៅសូរ៉ូសបានអនុញ្ញាតឲ្យពួកគេសាងសង់ប្រាព្រះវិហារ ឬ ២)
ការសាងសង់ព្រះវិហារនេះជាការងារផ្តាច់មុខរបស់ជនជាតិយូដា
ហើយអ្នកដែលមិនមែនជាជនជាតិយូដានឹងមិនត្រូវបានអនុញ្ញាតិឲ្យចូលរួមក្នុងកិច្ចការ[illegible]

Ezra 4:4

អ្នកស្រុក

«ប្រជាជនដែលកំពុងរស់នៅក្នុងស្រុក នាគ្រានោះ»

ដែលអាចរាប់បញ្ចូលទាំងមិនមែនជាជនជាតិយូដា
និងជនជាតិយូដាដែលជាក្រុមគ្រួសារបាប៊ីឡូនមិនបាននិរទេសខ្លួនទេ

បានធ្វើឲ្យប្រជាជនយូដាបាក់ទឹកចិត្ត

មិនបានលើកទឹកចិត្តជនជាតិយូដា (សូមមើល:)

ប្រជាជនយូដា

ប្រជាជនដែលបានវិលត្រឡប់មកពីស្រុកបាប៊ីឡូន មករស់នៅក្នុងស្រុកយូដាវិញ

ដើម្បីរារាំងគម្រោងការរបស់ពួកគេ

«ដើម្បីធ្វើឲ្យជនជាតិយូដាមិនអាចសាងសង់ព្រះវិហារដូចដែលពួកគេបានគ្រោងទុក»

បានសរសេរសំបុត្រមួយថ្វាយស្តេច ដើម្បីចោទប្រកាន់ពួកអ្នកស្រុកយូដា
និងពួកអ្នកក្រុងយេរូសាឡឹម

នាមអរូបី «ការចោទប្រកាន់» អាចត្រូវបានបកប្រែជាកិរិយាស័ព្ទ «ចោទប្រកាន់»
និងកិរិយាស័ព្ទ «រស់នៅក្នុង» រៀងៗខ្លួន។

អ្នកប្រហែលជាត្រូវបង្ហាញឲ្យច្បាស់នូវអ្វីដែលសត្រូវបានចោទប្រកាន់ជនជាតិយូដាថាកំពុងធ្វើ។
ការបកប្រែរបៀបផ្សេងទៀត:

«បានសរសេរលិខិតមួយដែលពួកគេបានចោទប្រកាន់អស់អ្នកដែលរស់នៅក្នុងស្រុកយូដា
និងក្រុងយេរូសាឡិមពីបទមិនគោរពស្តេច»

Ezra 4:7

លោកប៊ីសឡាំ ... លោកមីត្រាដាត ... លោកតាបេល ... លោកស៊ីមសៃ

ឈ្មោះរបស់បុរស

សំបុត្រ

នេះគឺជាលិខិតដែលបាននិយាយនៅក្នុងជំពូកទី ៤:៤ ។

ភាសារអារ៉ាម

ជាភាសាដែលត្រូវបានប្រើនៅក្នុងតំបន់នោះ សម្រាប់អាជីវកម្មផ្លូវការនាពេលនោះ

ហើយមានបកប្រែ

[illegible]

លោករេហ៊ូម

ឈ្មោះរបស់មនុស្សម្នាក់។ បកប្រែដូចនៅក្នុង EZR 2:1.

Ezra 4:9

អ៊ីរិច ... ស៊ូសាន

ឈ្មោះនៃទីក្រុង

អេឡាំ

ឈ្មោះនៃតំបន់ដ៏ធំនៃទឹកដីមួយ

ព្រះចៅអស្នាផារ

នេះគឺជាឈ្មោះរបស់បុរសម្នាក់។

នៅស្រុកឯទៀតដែលនៅខាងនាយទន្លេ

generated on Wed Sep 10 16:16:32 2025

នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចទន្លេអឺប្រាត។
វាបានឆ្លងកាត់ទន្លេមកពីស៊ូសា។
Ezra 4:11
នេះជាច្បាប់ចម្លង
អែសរ៉ារួមបញ្ចូលនូវខ្លឹមសារនៃសំបុត្រដែលធ្វើថ្វាយព្រះចៅអើថាស៊ីេកសេស ។
នៅស្រុកឯទៀតដែលនៅខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចនៃទន្លេអឺប្រាត។
វាបានឆ្លងកាត់ទន្លេមកពីស៊ូសា។ បកប្រែដូចនៅក្នុងជំពូកទី ៤:៩ ។
ទីក្រុងបះបោរ
ទីក្រុងនេះគឺជាទីសម្គាល់សម្រាប់ប្រជាជនដែលរស់នៅក្នុងនោះ។
ការបកប្រែរបៀបផ្សេងទៀត: «ទីក្រុងដែលពួកគេមានគម្រោងរស់នៅ
និងបះបោរប្រឆាំងនឹងអ្នក»
ជួសជុលគ្រឹះ
«ជួសជុលគ្រឹះ» ឬ «ផ្លាស់ប្តូរគ្រឹះ»
Ezra 4:13
ប្រសិនបើពួកគេសង់ក្រុងនេះឡើងវិញ ហើយកំផែងក៏រួចស្រេច
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើពួកគេសាងសង់ទីក្រុងនេះឡើងវិញ ហើយកំផែងក៏រួចស្រេច»
ធ្វើឲ្យព្រះករុណានឹងខាតបង់រាជសម្បត្តិមិនខាន
ពាក្យថា «ខាតបង់» សំដៅទៅលើពួកយូដាលែងផ្តល់ប្រាក់ទៅឲ្យព្រះករុណាទៀត។
Ezra 4:14
យើងខ្ញុំជ្រកកោនក្រោមព្រះគុណព្រះករុណា
អាចមានន័យថា នេះសំដៅទៅលើ ១) អ្នកនិពន្ធដែលស្មោះត្រង់នឹងព្រះរាជា
ទីក្រុងបះបោរ
ទីក្រុងនេះគឺជាទីសម្គាល់សម្រាប់ប្រជាជនដែលរស់នៅក្នុងនោះ។
ការបកប្រែរបៀបផ្សេងទៀត:
«ទីក្រុងមួយដែលមនុស្សរស់នៅបានបះបោរប្រឆាំងនឹងអយ្យកោរបស់ព្រះករុណា»
ទីក្រុងត្រូវបានបំផ្លាញខ្ទេចខ្ទី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ក្នុងករណីណាក៏ដោយអ្នកនឹងត្រូវបញ្ជាក់ឲ្យច្បាស់ថា
អ្នកណាដែលបានបំផ្លាញទីក្រុង។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកបាប៊ីឡូនបានបំផ្លាញទីក្រុង»
ប្រសិនបើទីក្រុង ហើយកំផែងត្រូវបានសាងសង់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើពួកគេសាងសង់ទីក្រុង និងកំផែង»
ពាក្យស្រដៀងគ្នាលេចឡើងនៅក្នុងជំពូកទី ៤:១៣ ។
នឹងមិនមានអ្វីនៅសល់សម្រាប់ទ្រង់ទេ
នេះគឺជាការបំផ្លើសមួយដែលធ្វើឲ្យព្រះរាជាគិតថា
ទ្រង់នឹងបាត់បង់ប្រាក់ពន្ធយ៉ាងច្រើន ប្រសិនបើពួកយូដាបះបោរ។
នៅស្រុកឯទៀតដែលនៅខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចទន្លេអឺប្រាត។
វាបានឆ្លងកាត់ទន្លេមកពីស៊ូសា។ បកប្រែដូចនៅក្នុងជំពូកទី ៤:៩។
Ezra 4:17
នៅស្រុកឯទៀតដែលនៅខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចទន្លេអឺប្រាត។
វាបានឆ្លងកាត់ទន្លេមកពីស៊ូសា។ បកប្រែដូចនៅក្នុងជំពូក ៤:៩ ។
សំបុត្រដែលអស់លោកបានផ្ញើមកយើង នោះគេបានបកប្រែ ហើយអានអស់ហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ក្នុងករណីនេះអ្នកត្រូវបញ្ជាក់ឲ្យច្បាស់ថា
អ្នកណាដែលបកប្រែ និងអានសំបុត្រនោះទៅព្រះមហាក្សត្រ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំមានអ្នកបកប្រែរបស់ខ្ញុំបកប្រែ
និងអានសំបុត្រដែលអ្នកបានផ្ញើមកខ្ញុំ»
លោករេហ៊ូម
ឈ្មោះរបស់មនុស្សម្នាក់។ បកប្រែដូចក្នុងជំពូកទី ២:១ ។
លោកស៊ីមសៃ
ឈ្មោះរបស់មនុស្សម្នាក់។ បកប្រែដូចនៅក្នុងជំពូកទី ៤:៧ ។
ទន្លេ
ទន្លេអឺប្រាត
Ezra 4:20
នៅស្រុកឯទៀតដែលនៅខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចទន្លេអឺប្រាត។
វាបានឆ្លងកាត់ទន្លេមកពីស៊ូសា។ បកប្រែដូចនៅក្នុងជំពូកទី ៤:៩ ។
ពន្ធដារសួយសារអាករ និងពន្ធផ្លូវថ្នាយស្តេចទៀតផង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជននៅក្រុងយេរូសាឡិមបានថ្វាយសួយសារអាក
និងបង់ពន្ធដល់ស្តេចទាំងនោះ» ឬ «ស្តេចទាំងនោះអាចប្រមូលសួយសារអាករ
និងពន្ធបាន»
ចេញបញ្ជា
«បង្កើតច្បាប់»
ចូរប្រយ័ត្នកុំឲ្យធ្វេសប្រហែសនឹងកិច្ចការនេះឡើយ
«ចូរប្រយ័ត្នក្នុងការធ្វើកិច្ចការនេះ»
តើហេតុអ្វីបានជាត្រូវឲ្យមានការខូចខាតរីកធំឡើង ដែលនាំឲ្យមានការខូចបង់រាជសម្បត្តិដល់ស្តេច?
ព្រះចៅអើថាស៊ីេកសេសប្រើសំនួរដើម្បីប្រាប់ពួកគេថា ទ្រង់យល់ថា
ទ្រង់នឹងបាត់បង់ពន្ធ និងកិត្តិយសប្រសិនបើទីក្រុងត្រូវបានសាងសង់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកត្រូវតែធ្វើឲ្យប្រាកដថា
ការគម្រោមកំហែងនេះមិនរីកចម្រើន
និងបណ្តាលឲ្យមានការបាត់បង់កាន់តែច្រើនសម្រាប់ផលប្រយោជន៍របស់ព្រះរាជា»
។
ការខូចខាតរីកធំឡើង
គ្រោះថ្នាក់ត្រូវបានគេនិយាយថា នេះជារុក្ខជាតិដែលអាចបង្កើនទំហំ។
ការបកប្រែរបៀបផ្សេងទៀត: «គ្រោះថ្នាក់កាន់តែអាក្រក់»
ដែលនាំឲ្យមានការខូចបង់រាជសម្បត្តិដល់ស្តេច
ពាក្យថា «ខូចបង់រាជសម្បត្តិស្តេច» គឺជាពាក្យប្រៀបធៀបសម្រាប់ស្តេចផ្ទាល់។
ការបកប្រែរបៀបផ្សេងទៀត:
«ដែលនាំឲ្យមានការអាក្រក់ជាច្រើនទៀតកើតឡើងដល់ស្តេច»
Ezra 4:23
គេបានអានរាជសាររបស់ព្រះចៅអើថាស៊ីេកសេស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ក្នុងករណីណាក៏ដោយអ្នកត្រូវបញ្ជាក់ឲ្យច្បាស់ថា
អ្នកណាដែលអានរាជសារពីព្រះមហាក្សត្រដល់មន្ត្រី។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនាំសារពីព្រះចៅអើថាស៊ីេកសេសបានអានរាជសាររបស់ទ្រង់»
លោករេហ៊ូម
បកប្រែដូចនៅក្នុង EZR 2:1.
លោកស៊ីមសៃ
បកប្រែដូចនៅក្នុង EZR 4:7.
កិច្ចការដែលសាងសង់ព្រះរាជដំណាក់របស់ព្រះជាម្ចាស់នៅក្រុងយេរូសាឡិម ក៏ត្រូវបានផ្អាក
រហូតដល់ឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយុស
ការពន្យាពេលនេះមានរយៈពេលប្រហែល ១៦ឆ្នាំ។

---

5 [1]រីឯព្យាការីហាកាយ និងព្យាការីសាការី ជាកូនរបស់លោកអ៊ីដោ បាននាំព្រះបន្ទូលរបស់ព្រះនៃជនជាតិអ៊ីស្រាអែល ថ្លែងប្រាប់ទៅ ជនជាតិយូដានៅក្រុងយេរូសាឡឹម
និងទឹកដីយូដា។[2]នៅគ្រានោះលោកសេរ៉ូបាបិល ជាកូនរបស់លោកសាលធាល និងលោកយេសួ ជាកូនរបស់លោកយូសាដាក ក៏នាំគ្នាងើបឡើង
ហើយចាប់ផ្តើមសាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ នៅក្រុងយេរូសាឡឹម ដោយមានព្យាការីរបស់ព្រះជាម្ចាស់ជួយគ្រាំទ្រពួកគេ។
[3]នៅគ្រាដដែលនោះ លោកថាថ្នាយ ជាទេសាភិបាលខេត្តខាងនាយទន្លេ និងលោកសេថារ-បូសណាយ ព្រមទាំងសហការី បាននាំគ្នាមកជួបជនជាតិយូដា ហើយសួរថា
«តើនរណាបានចេញរាជបញ្ជាឲ្យអ្នករាល់គ្នាសាងសង់ដំណាក់នេះ និងជួសជុលកំផែងនេះឡើងវិញ?»[4]អ្នកទាំងនោះក៏និយាយទៀតថា
«តើអ្នកដែលកំពុងសាងសង់ដំណាក់នេះ មានឈ្មោះអ្វីខ្លះ?» [5]ប៉ុន្តែ ព្រះនេត្ររបស់ព្រះជាម្ចាស់បានទត និងការពារអស់លោកព្រឹទ្ធាចារ្យនៃជនជាតិយូដា
ហើយពួកខ្មាំងសត្រូវទាំងនោះមិនបានបញ្ឈប់ការសាងសង់ទេ។ ពួកគេរង់ចាំទាល់តែគេបញ្ជូនសំណុំរឿងទៅថ្វាយព្រះចៅដារីយុស ហើយមានរាជសារឆ្លើយតប
មកកាត់សេចក្តី។

generated on Wed Sep 10 16:16:32 2025

[6]នេះគឺជាសំបុត្រដែលលោកថាថ្នាយ ជាទេសាភិបាលនៃខេត្តខាងនាយទន្លេ និងលោកសេថារ-បូសណាយ ព្រមទាំងពួករាជការ ជាសហការីរបស់ពួកគេ
ដែលនៅខេត្តខាងនាយទន្លេ បានផ្ញើទៅព្រះចៅដារីយូស។[7]ក្នុងសំបុត្រដែលពួកគេបានថ្វាយចំពោះព្រះចៅដារីយូស បានសរសេរដូច្នេះថា
«សូមព្រះករុណាប្រកបដោយសេចក្តីសុខចម្រើន។
[8]សូមព្រះករុណាជ្រាបថា យើងខ្ញុំបានទៅទឹកដីយូដា ហើយទៅដល់ព្រះដំណាក់របស់ព្រះដ៏ប្រសើរឧត្តម។ ពួកគេចាប់ផ្តើមយកថ្មធំៗមកសង់ព្រះដំណាក់
ហើយគេបានធ្នឹមក្នុងជញ្ជាំងរួចហើយ។ គេធ្វើកិច្ចការនេះយ៉ាងម៉ត់ចត់ ហើយរីកចម្រើនយ៉ាងឆាប់រហ័សទៀតផង។[9]យើងខ្ញុំបានសួរទៅពួកប្រឹទ្ធាចារ្យថា
តើនរណាបានចេញរាជបញ្ជាឲ្យសាងសង់រាជដំណាក់នេះ ហើយនឹងជួសជុលកំផែងឡើងវិញ?[10]យើងខ្ញុំក៏បានសួរឈ្មោះពួកគេដែរ
ដើម្បីកត់ឈ្មោះពួកមេដឹកនាំកិច្ចការនោះ យកមកថ្វាយព្រះករុណា។
[11]ពួកគេឆ្លើយមកយើងខ្ញុំថា ពួកយើងជាអ្នកបម្រើរបស់ព្រះនៃសាន្តសួគ៌ និងផែនដី ហើយពួកយើងកំពុងតែសាងសង់ព្រះដំណាក់នេះឡើងវិញ
គឺជាព្រះដំណាក់ស្តេចដ៏ធំមួយអង្គនៃជនជាតិអ៊ីស្រាអែល បានសង់រួចជាស្រេច តាំងពីយូឆ្នាំណាស់មកហើយ។
[12]ដោយព្រោះ បុព្វបុរសរបស់ពួកយើងបានធ្វើឲ្យព្រះនៃស្ថានសួគ៌មានសេចក្តីក្រោធ ហើយព្រះអង្គក៏បានប្រគល់ពួកគេនៅក្នុងកណ្តាប់ដៃរបស់ព្រះចៅនេប៊ូក្នេសា
ជាជនជាតិខាល់ដេ និងជាស្តេចទឹកដីបាប៊ីឡូន ដែលបានបំផ្លាញព្រះដំណាក់ ហើយនឹងកៀរប្រជាជនទៅទឹកដីបាប៊ីឡូន។[13]ក៏ប៉ុន្តែ នៅឆ្នាំទីមួយនៃព្រះចៅស៊ីរូស
ជាស្តេចទឹកដីបាប៊ីឡូន ព្រះចៅស៊ីរូសបានចេញរាជបញ្ជាឲ្យសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ឡើងវិញ។
[14]ក្រោយមកព្រះចៅស៊ីរូសបានយកគ្រឿងប្រដាប់មាស និងប្រាក់ ចេញពីព្រះដំណាក់របស់ព្រះជាម្ចាស់ ដែលព្រះចៅនេប៊ូក្នេសា
បានយកចេញពីព្រះវិហារនៅក្រុងយេរូសាឡឹម ទៅដាក់ក្នុងព្រះវិហារបាប៊ីឡូន។ នោះព្រះចៅស៊ីរូសបានយកប្រដាប់គ្រឿងទាំងនោះប្រគល់ឲ្យទៅលោកសេសបាសារ
ដែលស្តេចបានតែងតាំងជាទេសាភិបាល។[15]ស្តេចបានបង្គាប់លោកថា «ចូរយកគ្រឿងប្រដាប់ទាំងនេះ។ ហើយយកទៅដាក់ក្នុងព្រះវិហារដែលនៅក្រុងយេរូសាឡឹម។
ហើយសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ នៅកន្លែងដើមឡើងវិញ»។
[16]ដូច្នេះ លោកសេសបាសារបានមកក្រុងយេរូសាឡឹម ហើយក៏បានចាក់គ្រឹះព្រះដំណាក់របស់ព្រះជាម្ចាស់ ហើយចាប់តាំងពីពេលនោះមក គេនៅតែសង់ព្រះដំណាក់នោះ
ប៉ុន្តែមិនទាន់បានចប់សព្វគ្រប់នៅឡើយ។
[17]ឥឡូវនេះ ប្រសិនបើព្រះករុណាគាប់ព្រះហឫទ័យ សូមឲ្យគេស្រាវជ្រាវក្នុងឯកសារក្នុងមន្ទីហ្លួងនៅក្នុងស្រុកបាប៊ីឡូន ដើម្បីបញ្ជាក់ថា
ព្រះចៅស៊ីរូសបានចេញរាជបញ្ជាឲ្យសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ នៅក្រុងយេរូសាឡឹមមែន ឬយ៉ាងណា។
រួចសូមព្រះករុណាផ្ញើសេចក្តីសម្រេចអំពីរឿងនេះមកយើងខ្ញុំផង តាមទ្រង់សព្វព្រះហឫទ័យចុះ។

Ezra 5:1

លោកអ៊ីដោ ... លោកយេសួ ... លោកយូសាដាក

ឈ្មោះរបស់បុរស

លោកសាលធាល

ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុង EZR 3:1.

សាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់

នេះជាព្រះវិហាររបស់ព្រះជាម្ចាស់។

Ezra 5:3

លោកថាថ្នាយ ... លោកសេថារ-បូសណាយ

ឈ្មោះរបស់បុរស

ខេត្តខាងនាយទន្លេ

នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចទន្លេអឺប្រាត។

វាបានឆ្លងកាត់ទន្លេមកពីស៊ូសា។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៤:៩ ។

ព្រះនេត្ររបស់ព្រះជាម្ចាស់បានទត

ភ្នែកគឺជាទីសម្គាល់សម្រាប់មនុស្សដែលឃ្លាំមើលមនុស្សម្នាក់ទៀត។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានទតមើល»

គេបានបញ្ជូនសំណុំរឿងទៅថ្វាយព្រះចៅដារីយូស ហើយមានរាជសារឆ្លើយតប

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«មន្ត្រីម្នាក់ផ្ញើសំណុំរឿងមួយទៅព្រះមហាក្សត្រ

ដើម្បីឲ្យព្រះមហាក្សត្របញ្ជូនសំណុំរឿងមួយនោះទៅពួកគេវិញជាមួយរាជសារ»

Ezra 5:6

នេះគឺជាច្បាប់ចម្លងនៃសំបុត្រ

អែសរ៉ារួមបញ្ចូលខ្លឹមសារនៃសំបុត្រទៅព្រះចៅដារីយូសទាក់ទងនឹងកិច្ចការរបស់គេលើកលែងតែអាសយដ្ឋាន

ខេត្តខាងនាយទន្លេ

នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចទន្លេអឺប្រាត។

វាបានឆ្លងកាត់ទន្លេមកពីស៊ូសា។ បកប្រែដូចនៅក្នុងជំពូកទី ៤:៩ ។

Ezra 5:8

ព័ត៌មានទូទៅ:

លិខិតមកពីលោកថាថ្នាយផ្ញើទៅកាន់ស្តេចដែលចាប់ផ្តើមនៅក្នុងជំពូក៥:៦ បន្ត។

ធ្នឹម

ឈើសម្រាប់សាងសង់

តើនរណាបានចេញរាជបញ្ជា

«តើអ្នកណាផ្តល់ការអនុញ្ញាតឲ្យអ្នក»

Ezra 5:11

ព័ត៌មានទូទៅ:

លិខិតពីលោកថាថ្នាយផ្ញើទៅកាន់ស្តេចដែលចាប់ផ្តើមនៅក្នុងជំពូក៥:៦ បន្ត។

ពួកយើងជាអ្នកបម្រើរបស់ព្រះ

អាចមានន័យថា ១) ពួកគេបានហៅពួកយូដាជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ឬ ២)
អស់អ្នកដែលបានឆ្លើយតបគឺមកពីកុលសម្ពន្ធលេវី និងអើរ៉ុន
ដែលជាអ្នកទទួលខុសត្រូវចំពោះការថ្វាយបង្គំព្រះជាម្ចាស់ និងការថ្វាយយញ្ញបូជា។

គឺជាព្រះដំណាក់ស្តេចដ៏ធំមួយអង្គនៃជនជាតិអ៊ីុស្រាអែល បានសង់រួចជាស្រេច

តាំងពីយូឆ្នាំណាស់មកហើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ស្តេចដ៏អស្ចារ្យនៃអ៊ីុស្រាអែលបានសាងសង់
និងផ្គត់ផ្គង់ឧបករណ៍ទាំងអស់សម្រាប់»

រួចជាស្រេច

«បានផ្គត់ផ្គង់ឧបករណ៍ទាំងអស់សម្រាប់វា»

Ezra 5:12

ព័ត៌មានទូទៅ:

លិខិតមកពីលោកថាថ្នាយទៅព្រះមហាក្សត្របន្ត។

លោកថាថ្នាយបន្តប្រាប់ស្តេចនូវអ្វីដែលពួកយូដាបានប្រាប់ដល់លោកតាំងពីនៅក្នុងជំពូកទី ៥:១១។

ព្រះនៃស្ថានសួគ៌មានសេចក្តីក្រោធ

«បានធ្វើឲ្យព្រះនៃស្ថានសួគ៌មានសេចក្តីក្រោធនឹងយើងយ៉ាងខ្លាំង»

ព្រះអង្គក៏បានប្រគល់ពួកគេនៅក្នុងកណ្តាប់ដៃរបស់ព្រះចៅនេប៊ូក្នេសា ជាជនជាតិខាល់ដេ

និងជាស្តេចនៃទឹកដីបាប៊ីឡូន ដែលបានបំផ្លាញព្រះដំណាក់ ហើយនឹងកៀរប្រជាជន

ដៃគឺជាទីសម្គាល់សម្រាប់អំណាច ឬការគ្រប់គ្រង។ ដូចគ្នានេះផងដែរ

«ព្រះចៅនេប៊ូក្នេសា» តំណាងឲ្យកងទ័ពរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:

ព្រះចៅនេប៊ូក្នេសាបានអនុញ្ញាតឲ្យព្រះចៅនេប៊ូក្នេសាជាស្តេចស្រុកបាប៊ីឡូន

និងកងទ័ពរបស់ទ្រង់បំផ្លាញព្រះដំណាក់នេះ ហើយចាប់ប្រជាជនទៀតផង»

បានបំផ្លាញព្រះដំណាក់

«ហែកព្រះដំណាក់នេះចោល»

ព្រះចៅស៊ីរូសបានចេញរាជបញ្ជាឲ្យសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ឡើងវិញ

ព្រះចៅស៊ីរូសបានបញ្ជាឲ្យប្រជាជនសាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ឡើងវិញ។

Ezra 5:14

ព័ត៌មានទូទៅ:

លិខិតពីលោកថាថ្នាយផ្ញើទៅកាន់ស្តេចដែលចាប់ផ្តើមនៅក្នុងជំពូក៥:៦ បន្ត។

លោកថាថ្នាយបន្តប្រាប់ស្តេចនូវអ្វីដែលពួកយូដាបានប្រាប់លោកតាំងពីនៅក្នុងជំពូក (៥:១១) ។

លោកសេសបាសារ

បកប្រែដូចនៅក្នុង EZR 1:7.

generated on Wed Sep 10 16:16:32 2025

ទ្រង់បានប្រគល់ឲ្យពួកគេ
ព្រះចៅស៊ីរូសបានប្រគល់គ្រឿងប្រដាប់ព្រះវិហារទៅវិញ។
សាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ឡើងវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទ្រង់ចង់ឲ្យពួកយូដាសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ឡើងវិញ»។
Ezra 5:16
ព័ត៌មានទូទៅ:
លិខិតពីលោកថាថ្នាយផ្ញើទៅកាន់ស្តេចដែលចាប់ផ្តើមបន្តនៅក្នុងជំពូកទី ៥:៦។
លោកថាថ្នាយបន្តប្រាប់ស្តេចនូវអ្វីដែលពួកយូដាបានប្រាប់លោកតាំងពីក្នុងជំពូកទី (៥:១១)។
គេនៅតែសង់ព្រះដំណាក់នោះ ប៉ុន្តែមិនទាន់បានចប់សព្វគ្រប់នៅឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ឥឡូវប្រជាជនកំពុងសាងសង់
ប៉ុន្តែពួកគេមិនទាន់បានធ្វើការទាំងអស់ចប់សព្វគ្រប់ទេ»
សាងសង់
សង់
Ezra 5:17
ព័ត៌មានទូទៅ:
លិខិតពីលោកថាថ្នាយផ្ញើទៅកាន់ស្តេចដែលចាប់ផ្តើមបន្តនៅក្នុងជំពូកទី៥:៦។
លោកថាថ្នាយបានបញ្ចប់ការប្រាប់ស្តេចនូវអ្វីដែលពួកយូដាបានប្រាប់ដល់លោក
ហើយឥឡូវនេះសុំឲ្យស្តេចពិនិត្យមើល
ថាតើអ្វីដែលពួកយូដាបានប្រាប់លោកគឺជាការពិត។
សូមឲ្យគេស្រាវជ្រាវ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំចង់សូមព្រះករុណាឲ្យមាននរណាម្នាក់ស្រាវជ្រាវបញ្ហានេះ»
ប្រសិនបើព្រះចៅស៊ីរូសបានចេញរាជបញ្ជានៅទីនោះ
«ប្រសិនបើមានកំណត់ត្រានៅទីនោះថា ព្រះចៅស៊ីរូសបានចេញច្បាប់មែន»

---

6 [1]ដូច្នេះព្រះចៅដារីយូស បានចេញរាជបញ្ជារឲ្យគេស្រាវជ្រាវរកឯកសារដែលគេរក្សាទុកក្នុងមន្ទីរតម្កល់ឯកសារនៅក្រុងបាប៊ីឡូន។[2]គេរកឃើញក្រាំងមួយនៅអាក់មេថា
ជាក្រុងដែលមានកំផែងរឹងមាំនៃអាណាខេត្តមេឌី ក្នុងក្រាំងនោះមានចែងថា
[3]នៅឆ្នាំទីមួយនៃរជ្ជកាលព្រះចៅស៊ីរូស ស្តេចបានចេញរាជបញ្ជាមួយស្តីអំពីព្រះដំណាក់របស់ព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម ត្រូវសង់ព្រះដំណាក់ឡើងវិញ
ជាកន្លែងដែលថ្វាយយញ្ញបូជា ហើយត្រូវចាក់គ្រឹះនៅលើគ្រឹះចាស់ ឯព្រះដំណាក់នេះត្រូវមានកម្ពស់ហុកសិបហត្ថ និងទទឹងហុកសិបហត្ថ[4]គេត្រូវរៀបថ្មធំៗបីជួរ និង
ឈើថ្មីមួយជួរ រីឯប្រាក់ចំណាយលើការសង់ត្រូវបើកពីឃ្លាំងរាជទ្រព្យ។[5]ចំណែកគ្រឿងប្រដាប់មាស និងប្រាក់ នៃព្រះដំណាក់របស់ព្រះជាម្ចាស់
ដែលស្តេចនេប៊ូក្នេសាបានរឹបអូសយកពីព្រះវិហារក្រុងយេរូសាឡឹម មកក្រុងបាប៊ីឡូន នោះត្រូវតែប្រគល់ទៅព្រះវិហារយេរូសាឡឹមវិញ។
ហើយត្រូវដាក់នៅកន្លែងដើមក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។
[6]ឥឡូវនេះលោកថាថ្នាយ ជាទេសាភិបាលនៃអាណាខេត្តខាងនាយទន្លេ និងលោកសេថា-បូសណាយ ព្រមទាំងពួករាជការនិងសហការីរបស់ពួកគេ ដែលនៅខាងនាយទន្លេ
ត្រូវនៅឲ្យឆ្ងាយពីទីនោះទៅ![7]ទុកឲ្យជនជាតិយូដាសង់ព្រះដំណាក់របស់ព្រះជាម្ចាស់តែគ្នាគេចុះ។ ត្រូវឲ្យទេសាភិបាល និងពួកព្រឹទ្ធាចារ្យរបស់ជនជាតិយូដា
សង់ព្រះដំណាក់នៅកន្លែងដើម។
[8]យើងចេញរាជបញ្ជាឲ្យអស់លោកជួយពួកព្រឹទ្ធាចារ្យរបស់ជនជាតិយូដាដែលសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ឡើងវិញផង
រីឯការចំណាយចំពោះការសង់នេះត្រូវយកពីឃ្លាំងរាជទ្រព្យ គឺប្រាក់នៃសួយសារអាករដែលទារពីតំបន់ខាងនាយទន្លេ
ដើម្បីទុកសម្រាប់ថ្លៃចំណាយឲ្យពួកគេគ្រប់ចំនួនកុំបីអាក់ខានឡើយ។[9]ហើយអ្វីៗដែលពួកគេត្រូវការ ទោះជាគោស្ទាវ ចៀមឈ្មោល និងកូនចៀមសម្រាប់ជាដង្វាយដុត
ថ្វាយចំពោះព្រះជាម្ចាស់នៃស្ថានសួគ៌ ព្រមទាំងស្រូវ អំបិល ស្រាទំពាំងបាយជូរ និងប្រេង តាមដែលពួកបូជាចារ្យនៅក្រុងយេរូសាឡឹមត្រូវការ
នោះត្រូវបើកឲ្យពួកគេជារៀងរាល់ថ្ងៃ កុំបីអាក់ខានឡើយ។[10]ធ្វើដូច្នេះ
ដើម្បីឲ្យពួកគេបានថ្វាយដង្វាយដែលមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់នៃស្ថានសួគ៌ ហើយអធិស្ឋាន សូមឲ្យព្រះរាជា និងបុត្រារបស់ស្តេច
មានព្រះជន្មយឺនយូរ។
[11]យើងក៏ចេញបង្គាប់ថា ប្រសិនបើនរណាម្នាក់មិនគោរពតាមសេចក្តីដែលយើងបង្គាប់ ត្រូវដោះធ្នឹមពីផ្ទះរបស់អ្នកនោះ ហើយបញ្ឈរឡើងសម្រាប់ដោតគេពីលើធ្នឹមនោះ។
ហើយយកផ្ទះរបស់គេធ្វើជាកន្លែងបន្ទោបង់ ដោយព្រោះហេតុនេះឯង។[12]សូមឲ្យព្រះជាម្ចាស់ដែលតាំងព្រះនាមរបស់ព្រះអង្គនៅទីនោះ ទម្លាក់ស្តេច
ឬប្រជាជនណាដែលបំពានលើសេចក្តីសម្រេច ឬបំផ្លាញព្រះដំណាក់របស់ព្រះអង្គនៅក្រុងយេរូសាឡឹម។ យើងដារីយូសបានចេញបញ្ជានេះ។
ដូច្នេះត្រូវអនុវត្តកិច្ចការនេះឲ្យបានសម្រេចជាក់ហិត!»
[13]យើងដារីយូសបានចេញបញ្ជានេះដូច្នេះ លោកថាថ្នាយ ជាទេសាភិបាលនៅខាងនាយទន្លេ និងលោកសេថារ-បូសណាយ ព្រមទាំងពួកសហការី
ក៏បានអនុវត្តតាមបញ្ជារបស់ព្រះចៅដារីយូសយ៉ាងម៉ត់ចត់បំផុត។[14]ដូច្នោះហើយ ពួកព្រឹទ្ធាចារ្យនៃជនជាតិយូដា
ក៏សាងសង់ដោយជោគជ័យតាមទំនាយដែលព្យាការីហាកាយ និងព្យាការីសាការី បានថ្លែង។ ពួកគេបានបង្ហើយការសាងសង់ព្រះដំណាក់
ស្របតាមបញ្ជារបស់ព្រះនៃអ៊ីស្រាអែល និងដោយសារព្រះរាជក្រឹត្យរបស់ព្រះចៅស៊ីរូស ព្រះចៅដារីយូស និងព្រះចៅអើថាស៊ើកសេស ជាស្តេចពែរ្ស។
[15]ព្រះដំណាក់នេះត្រូវបានគេសង់ចប់សព្វគ្រប់នៅថ្ងៃទីបី ខែផល្គុន ក្នុងឆ្នាំទីប្រាំមួយ នៃរជ្ជកាលព្រះចៅដារីយូស។
[16]ជនជាតិអ៊ីស្រាអែល ពួកបូជាចារ្យ និងពួកលេវី ព្រមទាំងប្រជាជនដែលនៅសេសសល់ ដែលត្រូវគេកៀរទៅជាឈ្លើយ
នាំគ្នាប្រារព្ធពិធីបុណ្យឆ្លងព្រះដំណាក់របស់ព្រះជាម្ចាស់ ដោយអំណរ។[17]ពួកគេបានថ្វាយគោឈ្មោលមួយរយក្បាល ចៀមឈ្មោលមួយរយក្បាល
និងកូនចៀមបួនរយក្បាល សម្រាប់ជាតង្វាយឆ្លងព្រះដំណាក់របស់ព្រះជាម្ចាស់។ គេក៏បានថ្វាយពពែឈ្មោលដប់ពីរក្បាល តាមចំនួនកុលសម្ព័ន្ធរបស់ជនជាតិអ៊ីស្រាអែល
ជាតង្វាយលោះបានសម្រាប់ប្រជាជនអ៊ីស្រាអែលទាំងមូល។[18]គេបានតែងតាំងពួកបូជាចារ្យតាមឋានៈរបស់ពួកគេ
និងតែងតាំងពួកលេវីតាមមុខងាររបស់ពួកគេសម្រាប់ធ្វើការថ្វាយព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម ដូចមានចែងទុកក្នុងគម្ពីររបស់លោកម៉ូសេ។
[19]អស់អ្នកដែលគេកៀរទៅជាឈ្លើយ ហើយវិលត្រឡប់មកវិញនោះ បាននាំគ្នាប្រារព្ធពិធីបុណ្យរំលង នៅថ្ងៃទីដប់បួន ក្នុងខែទីមួយ។[20]ដ្បិតពួកបូជាចារ្យ និងពួកលេវី
បាននាំគ្នាធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធ ហើយពួកគេក៏បានបរិសុទ្ធទាំងអស់គ្នា ហើយគេបានសម្លាប់ចៀមនៃពិធីបុណ្យរំលង
សម្រាប់ប្រជាជនទាំងអស់ដែលជាប់ជាឈ្លើយ ហើយវិលត្រឡប់មកវិញ សម្រាប់ពួកបូជាចារ្យ ជាបងប្អូន និងសម្រាប់ខ្លួនគេផ្ទាល់។
[21]ប្រជាជនអ៊ីស្រាអែលបានបរិភោគអាហារនៃបុណ្យរំលង ដែលពួកគេបានវិលត្រឡប់ពីការជាប់ជាឈ្លើយ
ហើយញែកខ្លួនចេញពីភាពសៅហ្មងរបស់ជនជាតិដ៏ទៃដែលរស់នៅក្នុងស្រុក ដើម្បីស្វែងរកព្រះជាម្ចាស់ ជាព្រះរបស់អ៊ីស្រាអែលវិញ។[22]គេប្រារព្ធពិធីបុណ្យនំបុ័ងឥតដំបែ
អស់រយៈពេលប្រាំពីរថ្ងៃដោយអរសប្បាយ ដ្បិតព្រះអម្ចាស់ប្រទានឲ្យពួកគេពេញដោយអំណរ
ហើយព្រះអង្គបានដូរព្រះហឫទ័យរបស់ស្តេចទឹកដីអាស្ស៊ីរីឲ្យមេត្តាចំពោះពួកគេ ដើម្បីលើកទឹកចិត្តពួកគេក្នុងការសាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់
ជាព្រះនៃជនជាតិអ៊ីស្រាអែល។

Ezra 6:1
បានចេញរាជបញ្ជាឲ្យគេស្រាវជ្រាវ
នាមអរូបី «ការស្រាវជ្រាវ» អាចត្រូវបានបង្ហាញជាមួយកិរិយាស័ព្ទ «ស៊ើបអង្កេត»
ឬ «ស្វែងរក» ។ ការបកប្រែរបៀបផ្សេងទៀត: «បញ្ជាឲ្យមន្ត្រីរបស់ទ្រង់ស្រាវជ្រាវ»
ឬ «បញ្ជាឲ្យមន្ត្រីរបស់ទ្រង់ស្វែងរក»
បានចេញរាជបញ្ជាឲ្យគេស្រាវជ្រាវ

generated on Wed Sep 10 16:16:32 2025

អ្វីដែលពួកគេត្រូវស្រាវជ្រាវអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«បានចេញរាជបញ្ជាឲ្យមន្ត្រីរបស់ទ្រង់ស្រាវជ្រាវកំណត់ត្រា» ឬ
«បានចេញរាជបញ្ជាឲ្យមន្ត្រីរបស់ទ្រង់ស្វែងរក
និងរកមើលថាតើមានកំណត់ត្រារបស់ព្រះចៅស៊ីរូសប្រាប់ពួកយូដាឲ្យសាងសង់ព្រះវិហារឡើងវិញ
ឬទេ»
មន្ទីរតម្កល់ឯកសារ
នេះគឺជាអាគារដែលមន្ត្រីរបស់ស្តេចបានរក្សាទុកនូវកំណត់ត្រាសំខាន់ៗរបស់រដ្ឋាភិបាល។
អាក់មេថា
នេះជាឈ្មោះរបស់ទីក្រុងមួយ។
គេរកឃើញក្រាំងមួយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានរកឃើញក្រាំងមួយ» ឬ
«ពួកគេបានរកឃើញក្រាំងមួយដែលប្រាប់អំពីព្រះចៅដារីយូស
និងក្រុងយេរូសាឡិម»
Ezra 6:3
ព័ត៌មានទូទៅ:
នេះចាប់ផ្តើមនូវកំណត់ត្រានៃការចេញរាជបញ្ជារបស់ព្រះចៅស៊ីរូសដែលឲ្យពួកយូដាក
នៅឆ្នាំទីមួយនៃរជ្ជកាលព្រះចៅស៊ីរូស
នេះអាចបញ្ជាក់យ៉ាងច្បាស់ថា នេះជាឆ្នាំដំបូងនៃរជ្ជកាលរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងឆ្នាំទីមួយនៃរជ្ជកាលព្រះចៅស៊ីរូស»
ត្រូវសង់ព្រះដំណាក់ឡើងវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សូមឲ្យជនជាតិយូដាសង់ព្រះដំណាក់ឡើងវិញ» ឬ
«ជនជាតិយូដាត្រូវសង់ព្រះដំណាក់ឡើងវិញ»
ហុកសិបហត្ថ
«៦០ ហត្ថ» ។ អ្នកអាចបម្លែងវាទៅជាវិធានការទំនើប។ ការបកប្រែរបៀបផ្សេងទៀត:
«ម្ភៃប្រាំពីរម៉ែត្រ»
គេត្រូវរៀបថ្មធំៗបីជួរ និងឈើថ្មីមួយជួរ
អាចមានន័យថា ១) នេះពិពណ៌នាអំពីរបៀបបង្កើតគ្រឹះ។
ការបកប្រែរបៀបផ្សេងទៀត:
«សាងសង់វានៅលើថ្មធំបីស្រទាប់ដែលគ្របដណ្តប់ដោយឈើថ្មីមួយស្រទាប់» ឬទី
២) នេះពិពណ៌នាអំពីរបៀបសាងសង់កំផែង។ ការបកប្រែរបៀបផ្សេងទៀត:
«បានសង់កំផែងរបស់វាជាមួយនឹងថ្មធំបីស្រទាប់ជំនួសដោយឈើមួយស្រទាប់»
រឹងប្រាក់ចំណាយលើការសង់ត្រូវបើកពីឃ្លាំងរាជទ្រព្យ
ឃ្លាថា «ឃ្លាំងរាជទ្រព្យ»
តំណាងឲ្យទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ព្រះចៅស៊ីរូសនៅក្នុងឃ្លាំងរាជទ្រព្យ។
Ezra 6:6
ព័ត៌មានទូទៅ:
នេះបន្តកំណត់ត្រានៃការចេញរាជបញ្ជារបស់ព្រះចៅស៊ីរូសថា
ជនជាតិយូដាសាងសង់ព្រះវិហាររបស់ព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម
ដែលបានចាប់ផ្តើមនៅក្នុងជំពូក ៦:៣ ។
លោកថាថ្នាយ ... លោកសេថា-បូសណាយ
ព្រះចៅដារីយូសសរសេរដោយផ្ទាល់ទៅបុរសទាំងនេះ។
បកប្រែឈ្មោះរបស់ពួកគេដូចនៅក្នុងជំពូកទី ៥:៣។
ខេត្តខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលស្ថិតនៅខាងលិចនៃទន្លេអឺប្រាត។
វាបានឆ្លងកាត់ទន្លេពីស៊ូសា។ សូមមើលពីរបៀបបកប្រែក្នុងជំពូកទី ៤:៩។
Ezra 6:8
ព័ត៌មានទូទៅ:
នេះបន្តកំណត់ត្រានៃការចេញរាជបញ្ជារបស់ព្រះចៅស៊ីរូសថា៖
ជនជាតិយូដាសាងសង់ព្រះវិហាររបស់ព្រះជាម្ចាស់នៅក្រុងយេរូសាឡិមដែលបានចាប់ផ្តើមនៅក្នុងជំពូក
៦:៣។
រឹងការចំណាយចំពោះការសង់នេះត្រូវយកពីឃ្លាំងរាជទ្រព្យ
គឺប្រាក់នៃសួយសារអាករដែលទារពីតំបន់ខាងនាយទន្លេ
ដើម្បីទុកសម្រាប់ថ្លៃចំណាយឲ្យបុរសទាំងនេះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រើប្រាក់នៃសួយសារអាករដែលទារពីតំបន់ខាងនាយទន្លេ
ដើម្បីបង់ថ្លៃឲ្យបុរសទាំងនេះ»
ការចំណាយចំពោះការសង់នេះត្រូវយកពីឃ្លាំងរាជទ្រព្យ
គឺប្រាក់នៃសួយសារអាករដែលទារពីតំបន់ខាងនាយទន្លេ
«សួយសារអាករបស់ស្តេច» សំដៅលើពន្ធដែលប្រជាជនបង់ថ្វាយស្តេច។
ការបកប្រែរបៀបផ្សេងទៀត:
[illegible]
អ្វីៗដែលពួកគេត្រូវការ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីៗដែលពួកគេត្រូវការ»
Ezra 6:11
ព័ត៌មានទូទៅ:
នេះបន្តកំណត់ត្រានៃកាចេញរាជបញ្ជារបស់ព្រះចៅស៊ីរូសថា
ជនជាតិយូដាសាងសង់ព្រះវិហាររបស់ព្រះជាម្ចាស់នៅក្រុងយេរូសាឡឹមដែលបានចាប់ផ្តើមនៅក្នុងជំពូក
៦:៣ ។
ត្រូវដោះធ្នឹមពីផ្ទះរបស់អ្នកនោះ ហើយបញ្ឈរឡើងសម្រាប់ដោតគេពីលើធ្នឹមនោះ។
ហើយយកផ្ទះរបស់គេធ្វើជាកន្លែងបន្ទោបង់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបញ្ជាឲ្យមន្ត្រីរបស់យើងទាញធ្នឹមចេញពីផ្ទះរបស់គេ ហើយព្យួរគេលើវា។
[illegible]
ធ្នឹម
ជាបំណែកឈើវែង និងរឹងមាំដែលទ្រទ្រង់ដំបូលផ្ទះ
ព្យួរ
ទម្លុះចូល
ប្រជាជនណាដែលលើកដៃដើម្បីផ្លាស់ប្តូរ ... ឬបំផ្លាញ
ការលើកដៃតំណាងឲ្យការព្យាយាម ឬហ៊ានធ្វើអ្វីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកណាព្យាយាមផ្លាស់ប្តូរ ... ឬបំផ្លាញ» ឬ
«អ្នកណាហ៊ានផ្លាស់ប្តូរ ... ឬបំផ្លាញ»
បំពានលើសេចក្តីសម្រេច
នាមអរូបី «សេចក្តីសម្រេច» អាចត្រូវបានបង្ហាញដោយឃ្លាថា
«អ្វីដែលយើងបានសម្រេច» ។ ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីផ្លាស់ប្តូរអ្វីដែលយើងបានចេញសេចក្តីសម្រេច» ឬ «និយាយថា
យើងបានចេញសេចក្តីសម្រេចអ្វីផ្សេងទៀត»
Ezra 6:13
លោកថាថ្នាយ ... លោកសេថារ-បូសណាយ
បកប្រែឈ្មោះបុរសទាំងនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូកទី ៥:៣។
ព្រះដំណាក់នេះត្រូវបានគេសង់ចប់សព្វគ្រប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ អ្នកប្រហែលជាត្រូវបញ្ជាក់ឲ្យច្បាស់ថា ៖
តើព្រះដំណាក់មួយណាដែលពួកគេបានសង់ចប់សព្វគ្រប់។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានសាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់ចប់សព្វគ្រប់» ឬ
«ពួកគេបានបញ្ចប់ការសាងសង់ព្រះវិហារ»
នៅថ្ងៃទីបី ខែផល្គុន
«ខែផល្គុន» គឺជាឈ្មោះខែទីដបពីរ និងខែចុងក្រោយនៃប្រតិទិនហេប្រឺ។
វាគឺនៅរដូវត្រជាក់។ ថ្ងៃទីបី គឺជិតពាក់កណ្តាលខែកុម្ភៈតាមប្រតិទិនលោកខាងលិច
ឆ្នាំទីប្រាំមួយ
ព្រះចៅដារីយូសបានសោយរាជ្យអស់រយៈពេលប្រាំឆ្នាំ
ដូច្នេះទ្រង់បានឡើងសោយរាជ្យនៅឆ្នាំទីប្រាំមួយនៃរជ្ជកាលរបស់ទ្រង់។
Ezra 6:16
ប្រជាជនដែលនៅសេសសល់ ដែលត្រូវគេកៀរទៅជាឈ្លើយ
ប្រជាជនទាំងនេះត្រូវបានគេចាប់យកទៅស្រុកបាប៊ីឡូន
ប៉ុន្តែពួកគេបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនដែលនៅសេសសល់ដែលត្រូវបានចាប់ជាឈ្លើយទៅស្រុកបាប៊ីឡូន
[illegible]
ត្រឡប់ទៅក្រុងយេរូសាឡិមវិញ» ឬ
«ប្រជាជនដទៃទៀតដែលបានវិលត្រឡប់ពីការជាប់ជាឈ្លើយ»
គោឈ្មោលមួយរយក្បាល ... កូនចៀមបួនរយក្បាល
«គោឈ្មោល ១០០ក្បាល ... កូនចៀម ៤០០ក្បាល»
បានតែងតាំងពួកបូជាចារ្យតាមឋានៈរបស់ពួកគេ និងតែងតាំងពួកលេវីតាមមុខងាររបស់ពួកគេ
នាមអរូបី «តាមមុខងារ» អាចត្រូវបានបង្ហាញដោយឃ្លា «បែងចែកការងារជាក្រុម»
។ ការបកប្រែរបៀបផ្សេងទៀត: «បែងចែកការងារពួកបូជាចារ្យ
និងពួកលេវីជាក្រុមៗ»

generated on Wed Sep 10 16:16:32 2025

ការបែងចែកការងារ
«ជាក្រុមដែលធ្វើការជាមួយគ្នា»
Ezra 6:19
នៅថ្ងៃទីដប់បួន ក្នុងខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ថ្ងៃទីដប់បួនគឺនៅជិតដើមខែមេសា
នៅលើប្រតិទិនលោកខាងលិច។
ពិធីជម្រះកាយឲ្យបានបរិសុទ្ធ
«ធ្វើឲ្យខ្លួនគេបរិសុទ្ធ»
ភាពបរិសុទ្ធតំណាងឲ្យការគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យខ្លួនគេគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់»
Ezra 6:21
ញែកខ្លួនចេញពីភាពសៅហ្មងរបស់ជនជាតិដ៏ទៃដែលរស់នៅក្នុងស្រុក
ការញែកខ្លួនគេចេញពីភាពសៅហ្មង
គឺជាការបដិសេធធ្វើអ្វីដែលធ្វើឲ្យមនុស្សមិនស្អាត។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានបដិសេធមិនធ្វើអ្វីដែលប្រជាជននៅក្នុងស្រុកបានធ្វើឲ្យពួកគេមិនស្អាត»
ភាពសៅហ្មងរបស់ជនជាតិដ៏ទៃដែលរស់នៅក្នុងស្រុក
ត្រង់នេះ «ភាពសៅហ្មង» តំណាងឲ្យព្រះជាម្ចាស់មិនអាចទទួលយកបានឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលប្រជាជននៅក្នុងស្រុកបានធ្វើ
ធ្វើឲ្យព្រះជាម្ចាស់មិនអាចទទួលយកពួកគេបាន»
បានស្វែងរកព្រះជាម្ចាស់
ការស្វែងរកព្រះអម្ចាស់តំណាងឲ្យការជ្រើសរើសស្គាល់ ការថ្វាយបង្គំ
ហើយនឹងការស្តាប់បង្គាប់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត:
«សម្រេចចិត្តស្តាប់បង្គាប់ព្រះអម្ចាស់»
ដួរព្រះហឫទ័យរបស់ស្តេចទឹកដីអាស្ស៊ីរី
ការដួរព្រះហឫទ័យរបស់ស្តេចតំណាងឲ្យការធ្វើឲ្យទ្រង់គិតខុសគ្នាអំពីការងារព្រះវិហារ។
ការបកប្រែរបៀបផ្សេងទៀត: «ផ្លាស់ប្តូរអាកប្បកិរិយារបស់ស្តេចអាស្ស៊ីរី» ឬ
«ធ្វើឲ្យស្តេចអាស្ស៊ីរីមានឆន្ទៈ»
ដើម្បីលើកទឹកចិត្តពួកគេក្នុងការសាងសង់ព្រះដំណាក់របស់ព្រះជាម្ចាស់
ការលើកទឹកចិត្តបស់ពួកគេនៅក្នុងការងារតំណាងឲ្យការជួយពួកគេឲ្យធ្វើការ។
ស្តេចអាស្ស៊ីរីបានធ្វើដូច្នេះដោយប្រាប់ពួកគេឲ្យធ្វើកិច្ចការ
និងផ្តល់ប្រាក់សម្រាប់កិច្ចការនោះ។ ការបកប្រែរបៀបផ្សេងទៀត:
«ជួយពួកគេធ្វើកិច្ចការព្រះដំណាក់របស់ព្រះអង្គ» ឬ
«ធ្វើឲ្យមានលទ្ធភាពធ្វើកិច្ចការព្រះដំណាក់របស់ព្រះអង្គ»
ការងារព្រះដំណាក់របស់ព្រះអង្គ
នេះសំដៅទៅលើការសាងសង់ព្រះវិហារ។

---

7 [1]ក្រោយមក នៅក្នុងរជ្ជកាលព្រះចៅអើថាស៊ើកសេស ជាស្តេចទឹកដីពែរ្ស លោកអែសរ៉ាបានវិលមកពីទឹកដីបាប៊ីឡូន។ លោក អែសរ៉ា ជាកូនរបស់លោកសេរ៉ាយ៉ា
ដែលត្រូវជាកូនរបស់លោកអសារា ហើយអសារា ជាកូនរបស់លោកហ៊ីលគីយ៉ា[2]ហ៊ីលគីយ៉ា ជាកូនរបស់លោកសាលូម លោកសាលូមជាកូនរបស់លោកសាដុក សាដុក
ជាកូនរបស់លោក អហ៊ីទូប អហ៊ីទូបជាកូនរបស់លោកអម៉ារា[3]អម៉ារាជាកូនរបស់លោក អសារា អសារាជាកូនរបស់លោកមេរ៉ាយ៉ូត[4]មេរ៉ាយ៉ូតជាកូនរបស់លោកសេរ៉ាហ៊ា
សេរ៉ាហ៊ាជាកូនរបស់លោកអ៊ូស៊ី អ៊ូស៊ីជាកូនរបស់លោកប៊ូកគី[5]ប៊ូគីជាកូនរបស់លោកអប៊ូស អប៊ូសជាកូនរបស់លោកភីនេហាស ភីនេហាសជាកូនរបស់អេឡាសា
អេឡាសាគឺជាកូនរបស់មហាបូជាចារ្យ អើរ៉ុន។
[6]លោកអែសរ៉ាបានវិលមកពីទឹកដីបាប៊ីឡូន ហើយលោកជាបណ្ឌិតដែលស្ទាត់ជំនាញខាងក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលព្រះអម្ចាស់
ជាព្រះនៃជនជាតិអ៊ីស្រាអែលបានប្រទានឲ្យ។ ហើយដោយព្រោះ ព្រះអម្ចាស់ជាព្រះរបស់លោក បានដាក់ព្រះហស្តលើលោកហេតុនេះហើយ
ទើបស្តេចប្រទានអ្វីៗទាំងអស់តាមសំណូមពររបស់លោក។[7]នៅឆ្នាំទីប្រាំពីរនៃរជ្ជកាលព្រះចៅអើថាស៊ើកសេស ប្រជាជនអ៊ីស្រាអែលមួយចំនួន ព្រមទាំងពួកបូជាចារ្យ
ពួកលេវី ពួកចម្រៀង ពួកឆ្មាំទ្វារ និងពួកអ្នកបម្រើព្រះវិហារ ក៏នាំគ្នាវិលមកក្រុងយេរូសាឡឹមវិញ។
[8]លោកអែសរ៉ាបានវិលមកក្រុងយេរូសាឡឹមវិញ នៅខែទីប្រាំ ក្នុងឆ្នាំទីប្រាំពីរនៃរជ្ជកាលព្រះចៅអើថាស៊ើកសេស។[9]លោកបានចាកចេញពីក្រុងបាប៊ីឡូន នៅថ្ងៃទីមួយ
ក្នុងខែទីមួយ។ ហើយមកដល់ក្រុងយេរូសាឡឹមនៅថ្ងៃទីមួយ ក្នុងខែទីប្រាំ ដ្បិតព្រះដ៏សប្បុរសរបស់លោកបានដាក់ព្រះហស្តលើលោក។[10]លោកអែសរ៉ា
បានតាំងចិត្តខិតខំរៀនសូត្រ និងកាន់តាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់អស់ពីចិត្ត ព្រមទាំងបង្រៀនច្បាប់ និងវិន័យដល់ជនជាតិអ៊ីស្រាអែលទៀតផង។
[11]ព្រះចៅអើថាស៊ើកសេសបានប្រគល់រាជសារជូនលោកបូជាចារ្យ ដែលជាបណ្ឌិតខាងវិន័យ គឺជាបុរសម្នាក់ដែលប្រសប់ខាងព្រះបន្ទូលនៃបទបញ្ជា
និងបញ្ញត្តិច្បាប់របស់ព្រះអម្ចាស់ប្រទានមកដល់អ៊ីស្រាអែល។[12]«យើង អើថាស៊ើកសេស ជាស្តេចលើអស់ទាំងស្តេច ធ្វើជូនលោកបូជាចារ្យអែសរ៉ា
ជាបណ្ឌិតខាងវិន័យរបស់ព្រះនៃស្ថានសួគ៌។[13]យើងចេញបញ្ជាថា ក្នុងចំណោមជនជាតិអ៊ីស្រាអែលទាំងអស់ ឬពួកបូជាចារ្យ និងពួកលេវី
ដែលនៅក្នុងព្រះរាជាណាចក្ររបស់យើង គឺអស់អ្នកណាដែលមានបំណងចង់ត្រឡប់ទៅក្រុងយេរូសាឡឹម នោះយើងអនុញ្ញាតឲ្យទៅជាមួយលោក។
[14]ដ្បិតយើងជាស្តេច និងទីប្រឹក្សារបស់ស្តេចទាំងប្រាំពីរនាក់ បានចាត់ឲ្យលោកទៅពិនិត្យមើលស្រុកយូដា និងក្រុងយេរូសាឡឹម តាមក្រឹត្យវិន័យនៃព្រះរបស់លោក
គឺគម្ពីរដែលលោកកាន់នេះ។[15]ហើយឲ្យនាំយកមាស និងប្រាក់ ដែលយើង ជាស្តេច និងទីប្រឹក្សាទាំងប្រាំពីរនាក់ បានថ្វាយដោយស្ម័គ្រពីចិត្ត ដល់ព្រះនៃជនជាតិអ៊ីស្រាអែល
ដែលគង់នៅក្រុងយេរូសាឡឹម។[16]លោកក៏ត្រូវនាំយកមាស និងប្រាក់ទាំងប៉ុន្មាន ដែលលោករៃបាននៅក្នុងអាណាខេត្តបាប៊ីឡូនទាំងមូល ព្រមទាំងតង្វាយដែលប្រជាជន
និងពួកបូជាចារ្យបានថ្វាយដោយស្ម័គ្រពីចិត្ត សម្រាប់ព្រះដំណាក់របស់ពួកគេ នៅក្រុងយេរូសាឡឹមទៅជាមួយផង។
[17]ដូច្នេះលោកត្រូវយកប្រាក់នោះទៅទិញគោបា ចៀមឈ្មោល និងកូនចៀម ព្រមទាំងតង្វាយម្សៅ និងស្រាទំពាំងបាយជូរដែលត្រូវច្រួចជាមួយ។
ហើយលោកត្រូវថ្វាយតង្វាយទាំងនោះ នៅលើអាសនៈរបស់ព្រះដំណាក់នៃព្រះរបស់ពួកលោកនៅក្រុងយេរូសាឡឹម។[18]ឯប្រាក់ និងមាស ដែលនៅសល់ លោក
និងបងប្អូនរបស់លោកអាចយកទៅប្រើការ តាមតែលោកយល់ឃើញថាល្អ ស្រមតាមព្រះហឫទ័យនៃព្រះរបស់អស់លោក។
[19]ឯគ្រឿងបរិក្ខាទាំងប៉ុន្មាន ដែលគេបានប្រគល់ជូនលោក សម្រាប់ប្រើប្រាស់ក្នុងព្រះដំណាក់នៃព្រះរបស់លោក ចូរយកទៅដាក់នៅក្រុងយេរូសាឡឹម។
[20]ឯអ្វីៗផ្សេងទៀតដែលត្រូវការចំណាយសម្រាប់ព្រះដំណាក់នៃព្រះរបស់លោក ដែលលោកត្រូវការ ចូរបើពីឃ្លាំងរាជទ្រព្យទៅ។
[21]យើងព្រះចៅអើថាស៊ើកសេស បានចេញបញ្ជាដល់អ្នកកាន់ឃាំងរាជទ្រព្យទាំងអស់ នៅក្នុងអាណាខេត្តខាងនាយទន្លេថា អ្វីៗដែលលោកបូជាចារ្យអែសរ៉ា ស្មើសុំ
ត្រូវប្រគល់ជូនលោកកុំបីអាក់ខានឡើយ[22]ទោះជាមានចំនួនរហូតដល់ប្រាក់មួយរយហាប និងស្រូវមួយរយរង្វាស់ ស្រាទំពាំងបាយជូរមួយរយបាថ ប្រេងអូលីវមួយរយបាថ
ព្រមទាំងអំបិលតាមតម្រូវការ។[23]អ្វីៗដែលព្រះនៃស្ថានសួគ៌ព្រះអម្ចាស់បង្គាប់ ត្រូវធ្វើយ៉ាងរួសរាន់ សម្រាប់ព្រះដំណាក់របស់ព្រះ។ តើត្រូវឲ្យព្រះជាម្ចាស់ទ្រង់ព្រះពិរោធ
ទាស់នឹងនគរ ឬរាជវង្សរបស់យើងឬ?
[24]មួយវិញទៀត យើងសុំបញ្ជាក់ឲ្យអស់លោកបានដឹងថា អស់លោកមិនត្រូវទារពន្ធដារសួយសារអាករ និងពន្ធផ្លូវ ពីពួកបូជាចារ្យ ពួកលេវី ពួកអ្នកចម្រៀង ពួកឆ្មាំទ្វារ
ពួកអ្នកបម្រើព្រះវិហារ ឬអ្នកបំពេញការងារផ្សេងទៀត ក្នុងដំណាក់របស់ព្រះជាម្ចាស់ឡើយ។
[25]ចំពោះលោកអែសរ៉ា ដែលបង្ហាញអំពីប្រាជ្ញានៃព្រះរបស់លោក គឺគម្ពីរដែលលោកកាន់នោះ ត្រូវតែងតាំងឲ្យមានចៅក្រម និងអ្នកគ្រប់គ្រង
ដើម្បីកាត់ក្តីឲ្យប្រជាជនដែលនៅក្នុងអាណាខេត្តខាងនាយទន្លេ ហើយអស់អ្នកដែលស្គាល់ក្រឹត្យវិន័យនៃព្រះរបស់លោក។
ហើយលោកក៏ត្រូវបង្ហាត់បង្រៀនអស់អ្នកដែលមិនស្គាល់ក្រឹត្យវិន័យផង។[26]ចូរដាក់ទោសដល់អស់អ្នកណាដែលមិនគោរពតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់
ឬមិនគោរពតាមច្បាប់របស់ស្តេច នោះត្រូវទទួលទោសដល់ស្លាប់ ឬនិរទេស ឬត្រូវរឹបអូសយកទ្រព្យសម្បត្តិ ឬត្រូវចាប់ដាក់គុក។
[27]សូមសរសើរតម្កើងព្រះជាម្ចាស់ ជាព្រះនៃបុព្វបុរសរបស់យើង ដែលព្រះអង្គបានបណ្តាលព្រះហឫទ័យព្រះរាជា ឲ្យតាក់តែងលម្អព្រះដំណាក់របស់ព្រះអម្ចាស់
នៅក្រុងយេរូសាឡឹម[28]ព្រមទាំងប្រោសប្រទានសេចក្តីមេត្តាករុណារបស់ព្រះអង្គដល់ខ្ញុំ នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ចំពោះទីប្រឹក្សារបស់ស្តេច
នៅចំពោះមន្ត្រីដ៏មានអំណាចរបស់ព្រះរាជាទៀតផង។ ខ្ញុំបានចម្រើនកម្លាំងដោយសារព្រះហស្តរបស់ព្រះជាម្ចាស់ បានសណ្ឋិតលើខ្ញុំ
ហើយខ្ញុំបានប្រមូលអស់លោកដែលជាមេដឹកនាំរបស់អ៊ីស្រាអែលឲ្យចេញដំណើរទៅជាមួយខ្ញុំ។

generated on Wed Sep 10 16:16:32 2025

Ezra 7:1

ព័ត៌មានទូទៅ:

ពង្សាវតាររបស់លោកអែសរ៉ាត្រឡប់ទៅជាលោកអើរ៉ុនដែលជាមហាបូជាចារ្យទីមួយ។

លោកអែសរ៉ាបានវិលមកពីទឹកដីបាប៊ីឡូន

កន្លែងដែលលោកអែសរ៉ាឡើងមកអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។

ការបកប្រែរបៀបផ្សេងទៀត:

«លោកកអែសរ៉ាឡើងពីស្រុកបាប៊ីឡូនមកក្រុងយេរូសាឡិម»

លោកសេរ៉ាយ៉ា

បកប្រែឈ្មោះរបស់បុរសនេះដូចអ្នកបានធ្វើនៅក្នុងជំពូក ២:១ ។

លោកសាលូម

បកប្រែឈ្មោះរបស់បុរសនេះដូចអ្នកបានធ្វើនៅក្នុងជំពូកទី ២:៤០។

លោកអសារា លោកហ៊ីលគីយ៉ា ... លោកសាដុក លោកអហ៊ីទូប លោកអម៉ារា លោកអសារា លោកមេរ៉ាយ៉ូត លោកសេរ៉ាហ៊ា លោកអ៊ូស៊ី លោកប៊ូកគី លោកអប៊ីសួ លោកភីនេហាស លោកអេឡាសា

បញ្ជីនេះគឺជាឈ្មោះរបស់មនុស្សទាំងអស់។

Ezra 7:6

ស្តេចប្រទានអ្វីៗទាំងអស់តាមសំណូមពររបស់លោក

«ស្តេចប្រទានអ្វីៗទាំងអស់ឲ្យលោកអែសរ៉ាតាមដែលលោកបានស្នើសុំ»

ព្រះហស្តរបស់ព្រះអម្ចាស់នៅជាមួយលោក

«ព្រះហស្ត» របស់ព្រះអម្ចាស់តំណាង ឲ្យព្រះពរ ឬជំនួយពីព្រះអម្ចាស់។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះពររបស់ព្រះអម្ចាស់គឺនៅជាមួយលោកអែសរ៉ា» ឬ «ព្រះអម្ចាស់កំពុងតែប្រទានព្រះពរដល់លោកអែសរ៉ា» ។

នៅឆ្នាំទីប្រាំពីរនៃរជ្ជកាលព្រះចៅអើថាស៊ើកសេស

នេះសំដៅទៅលើឆ្នាំទីប្រាំពីរនៃរជ្ជកាលរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត: «នៅឆ្នាំទីប្រាំពីរ ដែលព្រះចៅអើថាស៊ើកសេសធ្វើជាស្តេច»

Ezra 7:8

នៅខែទីប្រាំ

នេះជាខែទីប្រាំនៃប្រតិទិនហេប្រឺ។ វាគឺជាកំឡុងពេលចុងក្រោយនៃខែកក្កដា និងផ្នែកដំបូងនៃខែសីហានៅលើប្រតិទិនលោកខាងលិច។

នៅថ្ងៃទីមួយ ក្នុងខែទីមួយ

នេះគឺនៅជិតពាក់កណ្តាលខែមីនានៅលើប្រតិទិនលោកខាងលិច។

នៅថ្ងៃទីមួយ ក្នុងខែទីប្រាំ

នេះគឺនៅពាក់កណ្តាលខែកក្កដានៅលើប្រតិទិនលោកខាងលិច។

ព្រះហស្តដ៏សប្បុរសរបស់ព្រះជាម្ចាស់

«ព្រះហស្ត» តំណាងឲ្យអំណាច ឬ

ការគ្រប់គ្រងដែលព្រះជាម្ចាស់ប្រើដើម្បីទទួលបានលទ្ធផលល្អ។

លោកអែសរ៉ា បានតាំងចិត្តខិតខំរៀនសូត្រ

ការតាំងចិត្តរបស់លោកតំណាងឲ្យការសម្រេចចិត្ត ឬ ប្តេជ្ញាចិត្តខ្លួនឯងឲ្យធ្វើអ្វីមួយ។

ការបកប្រែរបៀបផ្សេងទៀត: «លោកអែសរ៉ាប្តេជ្ញាក្នុងជីវិតរបស់លោក ដើម្បីរៀនសូត្រ»

កាន់តាម

«គោរពតាម»

ក្រឹត្យវិន័យ និងវិន័យនៃច្បាប់របស់ព្រះអម្ចាស់

ទាំងនេះជាច្បាប់ដែលព្រះជាម្ចាស់បានប្រគល់ឲ្យទៅអ៊ីស្រាអែលតាមរយៈលោកម៉ូសេ។

Ezra 7:11

នេះជាក្រឹត្យវិន័យ

អត្ថបទបន្ទាប់ឃ្លានេះគឺជាក្រឹត្យវិន័យដែលបានប្រគល់ដោយព្រះចៅអើថាស៊ើកសេស ។

យើង អើថាស៊ើកសេស ជាស្តេចលើអស់ទាំងស្តេច

«ជាស្តេចលើអស់ទាំងស្តេច» គឺជាចំណងជើង មានន័យថា ទ្រង់ជាស្តេចធំជាងគេ ជាស្តេចដែលស្តេចដទៃទៀតគោរពតាម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះមហាក្សត្រអើថាស៊ើកសេស» ឬ «អើថាស៊ើកសេស ជាស្តេចដ៏ធំបំផុត»

យើងចេញបញ្ជាថា ... អ្នកណាដែលមានបំណងចង់ត្រឡប់ទៅក្រុងយេរូសាឡិម

នៅគ្រានោះប្រជាជនត្រូវការការអនុញ្ញាតពីព្រះមហាក្សត្រ

ដើម្បីតាំងទីលំនៅឡើងវិញ

និងកសាងឡើងវិញនៅក្នុងតំបន់មួយដែលត្រូវបានបំផ្លាញដោយសាសន៍ដទៃដែលដណ្តើមយកទៅ

សូមអនុញ្ញាតឲ្យទៅជាមួយលោក

ពាក្យថា «លោក» សំដៅទៅលើលោកអែសរ៉ា។

Ezra 7:14

ខ្លឹមសារភ្ជាប់

នេះបន្តក្រឹត្យវិន័យដែលព្រះចៅអើថាស៊ើកសេសប្រគល់ជូនលោកអែសរ៉ា។

ដ្បិតយើងជាស្តេច និងទីប្រឹក្សារបស់ស្តេចទាំងប្រាំពីរនាក់

ពាក្យ «យើង» និងឃ្លា «ស្តេច» សំដៅលើមនុស្សតែមួយ។

ស្តេចកំពុងតែក្រើនរំលឹកដល់ប្រជាជនដែលបានឮសំបុត្រនេះថា ទ្រង់ជាអ្នកនិពន្ធរបស់សំបុត្រនេះ។

ទៅពិនិត្យមើលស្រុកយូដា និងក្រុងយេរូសាឡិម តាមក្រឹត្យវិន័យនៃព្រះជាម្ចាស់

អ្វីដែលពួកគេត្រូវសាកសួរអាចត្រូវបានបញ្ជាក់ឲ្យកាន់តែច្បាស់។

ការបកប្រែរបៀបផ្សេងទៀត: «ការស្រាវជ្រាវស្ថានការណ៍នៅស្រុកយូដា និងក្រុងយេរូសាឡិម ដើម្បីដឹងថាតើពួកគេកំពុងធ្វើតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ឬអត់»

ហើយឲ្យនាំយកមាស និងប្រាក់

កន្លែងដែលពួកគេត្រូវយកវាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកត្រូវនាំយកប្រាក់ និងមាសទៅក្រុងយេរូសាឡិម»

មាស និងប្រាក់ដែលពួកគេមានបានថ្វាយដោយស្ម័គ្រពីចិត្ត

«ដោយស្ម័គ្រពីចិត្ត» មានន័យថាពួកគេមិនត្រូវបានបង្ខំឲ្យថ្វាយប្រាក់ទេ។ ពួកគេបានថ្វាយវា ពីព្រោះពួកគេចង់។ ការបកប្រែរបៀបផ្សេងទៀត: «ប្រាក់ និងមាសដែលពួកគេមានបានថ្វាយដោយស្ម័គ្រចិត្ត»

តង្វាយដែលប្រជាជន និងពួកបូជាចារ្យបានថ្វាយដោយស្ម័គ្រពីចិត្ត

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលប្រជាជន និងពួកបូជាចារ្យបានថ្វាយដោយស្ម័គ្រពីចិត្ត»

Ezra 7:17

ខ្លឹមសារភ្ជាប់

នេះបន្តក្រឹត្យវិន័យដែលព្រះចៅអើថាស៊ើកសេសប្រគល់ជូនលោកអែសរ៉ា។

ដូច្នេះលោកត្រូវទៅទិញ ... តង្វាយ

ឃ្លា «ពោរពេញ» មានន័យថា ការចាំបាច់ជាច្រើន ដើម្បីបំពេញភារកិច្ច។

ពួកគេត្រូវប្រើមាស និងប្រាក់ដើម្បីទិញរបស់ទាំងអស់ដែលពួកគេត្រូវការ ដើម្បីថ្វាយបង្គំព្រះជាម្ចាស់នៅព្រះវិហារ។ ការបកប្រែរបៀបផ្សេងទៀត: «ទិញគោបា ចៀមឈ្មោល កូនចៀម តង្វាយម្សៅ និងស្រាទំពាំងបាយជូរជាច្រើនដែលត្រូវការ»។

លោក និងបងប្អូនរបស់លោក

ឃ្លាដែលថា «បងប្អូនរបស់លោក» សំដៅទៅលើមនុស្សដែលកំពុងធ្វើការនេះជាមួយលោកអែសរ៉ា។

ការបកប្រែរបៀបផ្សេងទៀត: «មិត្តរួមការងាររបស់លោក» ឬ «ដៃគូរបស់លោក»

Ezra 7:19

ខ្លឹមសារភ្ជាប់

នេះបន្តក្រឹត្យវិន័យដែលព្រះចៅអើថាស៊ើកសេសប្រគល់ជូនលោកអែសរ៉ា។

គ្រឿងបរិក្ខាទាំងប៉ុន្មាន ដែលគេបានប្រគល់ជូនលោក ដោយសេរី

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «គ្រឿងបរិក្ខាទាំងប៉ុន្មាន ដែលយើងបានប្រគល់ឲ្យលោកដោយសេរី»

ឯគ្រឿងបរិក្ខាទាំងប៉ុន្មាន ... នៅចំពោះព្រះអង្គ

ពាក្យថា «ព្រះអង្គ » សំដៅទៅលើព្រះជាម្ចាស់។

សម្រាប់ប្រើប្រាស់ក្នុងព្រះដំណាក់នៃព្រះរបស់លោក

នាមអរូបី «ប្រើប្រាស់» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «បម្រើ» ឬ «ប្រើ» «ការងារ» ឬ «ការថ្វាយបង្គំ»។ ការបកប្រែរបៀបផ្សេងទៀត: «ប្រើប្រាស់នៅក្នុងព្រះដំណាក់នៃព្រះរបស់លោក» ឬ «ដើម្បីបម្រើក្នុងព្រះដំណាក់នៃព្រះរបស់លោក»

ឃ្លាំងរាជទ្រព្យ

ជាកន្លែងមានសុវត្ថិភាពដែលទ្រព្យសម្បត្តិត្រូវបានរក្សាទុក

Ezra 7:21

ខ្លឹមសារភ្ជាប់

នេះបន្តក្រឹត្យវិន័យដែលព្រះចៅអើថាស៊ើកសេសប្រគល់ជូនលោកអែសរ៉ា។

ខេត្តខាងនាយទន្លេ

នេះជាឈ្មោះខេត្តដែលនៅខាងលិចទន្លេអឺប្រាត។ វាបានឆ្លងកាត់ទន្លេពីស៊ូសា។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ៤:៩ ។

អ្វីៗដែលលោកបូជាចារ្យអែសរ៉ា ស្នើសុំ ត្រូវប្រគល់ជូនលោកកុំបីអាក់ខានឡើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ «ប្រគល់ជូនលោកបូជាចារ្យអែសរ៉ា នូវអ្វីៗទាំងអស់តាមដែលលោកសុំពីអ្នក»។

ត្រូវប្រគល់ជូនលោកកុំបីអាក់ខានឡើយ

ឃ្លាថា «កុំបីអាក់ខាន» នៅទីនេះតំណាងឲ្យបរិមាណអ្វីដែលចាំបាច់ ដើម្បីធ្វើការ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «គួរតែត្រូវបានផ្តល់ឲ្យច្រើនតាមដែលលោកត្រូវការ»
ប្រាក់មួយរយហាប
«ប្រាក់ ១០០ ហាប។ «អ្នកអាចប្តូរវាទៅជាលក្ខណៈទំនើប។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាក់ ៣.៤០០ ហាប» ឬ «៣តោនកន្លះ»
ស្រូវមួយរយរង្វាស់
អ្នកអាចប្តូរវាទៅជាលក្ខណៈទំនើប។ ការបកប្រែរបៀបផ្សេងទៀត: « ២២,០០០ លីត្រ នៃស្រូវ» ឬ «ពីរម៉ឺន លីត្រនៃស្រូវ»
ប្រេងអូលីវមួយរយបាថ
អ្នកអាចប្តូរវាទៅជាលក្ខណៈទំនើប។ ការបកប្រែរបៀបផ្សេងទៀត: ប្រេងអូលីវ ២២០០ លីត្រ» ឬ «ប្រេងអូលីវពីរពាន់លីត្រ»
ព្រះដំណាក់របស់ព្រះ
នេះសំដៅទៅលើព្រះវិហាររបស់ព្រះជាម្ចាស់។
តើត្រូវឲ្យព្រះជាម្ចាស់ទ្រង់ព្រះពិរោធ ទាស់នឹងនគរ ឬរាជវង្សរបស់យើងឬ?
ព្រះរាជាប្រើសំនួរនេះ ដើម្បីនិយាយថា
ទ្រង់មិនចង់ឲ្យព្រះពិរោធរបស់ព្រះជាម្ចាស់មានមកលើពួកគេឡើយ។
ព័ត៌មានបញ្ជាក់ថា៖
ប្រសិនបើពួកគេមិនផ្តល់ឲ្យលោកបូជាចារ្យអែសរ៉ានូវអ្វីដែលលោកត្រូវការទេនោះ
ព្រះជាម្ចាស់នឹងដាក់ទណ្ឌកម្មលើនគរ និងរាជវង្សរបស់យើង។
ការបកប្រែរបៀបផ្សេងទៀត: «ក្បិត យើងមិនចង់ឲ្យព្រះពិរោធរបស់ព្រះមកលើនគរ និងរាជវង្សរបស់យើងឡើយ» ឬ «បើអ្នកមិនធ្វើរឿងទាំងនេះទេ
ព្រះពិរោធរបស់ព្រះនឹងមកលើនគរ និងរាជវង្សរបស់យើងហើយ»។
តើត្រូវឲ្យព្រះជាម្ចាស់ទ្រង់ព្រះពិរោធ ទាស់នឹងនគរ ឬរាជវង្សរបស់យើងឬ?
ព្រះពិរោធរបស់ព្រះជាតំណាងព្រះជាម្ចាស់ដែលដាក់ទណ្ឌកម្មពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ហេតុអ្វីព្រះជាម្ចាស់គួរដាក់ទណ្ឌកម្មនគរ និងរាជវង្សរបស់យើង» ឬ
«បើអ្នកមិនធ្វើរឿងទាំងនេះទេព្រះជាម្ចាស់នឹងដាក់ទណ្ឌកម្មលើនគរ និងរាជវង្សរបស់យើង»
Ezra 7:24
ខ្លឹមសារភ្ជាប់
នេះបន្តក្រឹត្យវិន័យដែលព្រះចៅអើថាស៊ើកសេសប្រគល់ជូនលោកអែសរ៉ា។
មួយវិញទៀត យើងសុំបញ្ជាក់ឲ្យអស់លោកបានដឹងថា អស់លោកមិនត្រូវទារពន្ធដារឬសួរសារអាករ
«យើងកំពុងប្រាប់ពួកគេមិនឲ្យទារពន្ធ ឬ ពន្ធសួយសារអាករទេ»
ពួកតន្ត្រីករ
មនុស្សដែលលេងឧបករណ៍ភ្លេង
Ezra 7:25
ខ្លឹមសារភ្ជាប់
នេះជាចុងបញ្ចប់នៃក្រឹត្យដែលស្តេចអាថាស៊ើរសេសប្រគល់ជូនលោកអែសរ៉ា។
ដែលបង្ហាញអំពីប្រាជ្ញានៃព្រះរបស់លោក គឺគម្ពីរដែលលោកកាន់នោះ ត្រូវតែងតាំងឲ្យមានចៅក្រម
និងអ្នកគ្រប់គ្រង
នាម «ប្រាជ្ញា» អរូបីអាចត្រូវបានបង្ហាញដោយពាក្យថា «ឆ្លាត» និង «ឈ្លាសវៃ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានធ្វើឲ្យលោកមានប្រាជ្ញា
ដូច្នេះលោកត្រូវតែងតាំងចៅក្រម និងមនុស្សប្រកបដោយប្រាជ្ញា»
នោះត្រូវទទួលទោសដល់ស្លាប់ ឬនិរទេស ឬត្រូវរឹបអូសយកទ្រព្យសម្បត្តិ ឬត្រូវចាប់ដាក់គុក
នាមអរូបីអាចត្រូវបានបកប្រែដោយកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«មិនថាដោយសម្លាប់ពួកគេ និរទេសពួកគេ រឹបអូសយកទ្រព្យសម្បត្តិរបស់ពួកគេ
ឬដាក់គុកពួកគេ» ឬ «លោកអាចសម្លាប់ពួកគេ បញ្ជូនពួកគេទៅឲ្យឆ្ងាយ
យករបស់របរផ្ទាល់ខ្លួន ឬដាក់ពួកគេក្នុងពន្ធនាគារ»
Ezra 7:27
ខ្លឹមសារភ្ជាប់
លោកអែសរ៉ាសរសើរព្រះជាម្ចាស់ដោយសារអ្វីដែលព្រះចៅអើថាស៊ើកសេសបានសម្រេច។
បានបណ្តាលព្រះហឫទ័យព្រះរាជា ឲ្យតាក់តែងលម្អព្រះដំណាក់របស់ព្រះអម្ចាស់
នៅក្រុងយេរូសាឡឹម
កាដាក់អ្វីៗនៅក្នុងព្រះហឫទ័យរបស់ព្រះរាជាតំណាងឲ្យទ្រង់មានគំនិត
និងបំណងប្រាថ្នាជាក់លាក់។ ការបកប្រែរបៀបផ្សេងទៀត: «បណ្តាលឲ្យព្រះរាជាចង់លើកតម្កើងព្រះដំណាក់របស់ព្រះអម្ចាស់ នៅក្រុងយេរូសាឡឹម»
ព្រះដំណាក់របស់ព្រះអម្ចាស់
នេះសំដៅទៅលើព្រះវិហាររបស់ព្រះអម្ចាស់»
ខ្ញុំបានចម្រើនកម្លាំង
ការត្រូវបានចម្រើនកម្លាំងតំណាងឲ្យការលើកទឹកចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: ខ្ញុំត្រូវបានលើកទឹកចិត្ត»
ដោយសារព្រះហស្តរបស់ព្រះជាម្ចាស់ បានសណ្ឋិតលើខ្ញុំ
នៅទីនេះព្រះហស្តរបស់ព្រះអម្ចាស់ជាតំណាងអ្វីដែលព្រះអង្គបានធ្វើ
ដើម្បីជួយលោកអែសរ៉ា។ ការបកប្រែរបៀបផ្សេងទៀត:
«ពីព្រោះព្រះអម្ចាស់បានជួយខ្ញុំ»

---

8 [1]នេះជាបញ្ជីរាយនាមលើមេក្រុមគ្រួសារ ដែលវិលត្រឡប់ពីស្រុកបាប៊ីឡូនមកជាមួយខ្ញុំ នៅក្នុងរជ្ជកាលព្រះចៅអើថាស៊ើកសេស។
[2]ក្នុងពួកកូនចៅភីនេហាសមានលោកគើសុន។ ក្នុងពួកកូនចៅអ៊ីថាម៉ារមានលោកដានីយ៉ែល។ ក្នុងពួកកូនចៅដាវីឌ
មានលោកហាធូស[3]ក្នុងពួកកូនចៅសេកានាមានលោក និងពួកកូនចៅប៉ារ៉ូស មានលោកសាការី ហើយនៅក្នុងបញ្ជីបុព្វបុរសមានប្រុស ១៥០ នាក់នៅជាមួយលោក។
[4]ក្នុងពួកកូនចៅផាហាត់ ម៉ូអាប់ មានលោកអេលីយ៉ូណៃ ជាកូនរបស់លោកសេរ៉ាហ៊ា ហើយមានមនុស្សប្រុសពីររយនាក់ នៅជាមួយលោក។
[5]ក្នុងពួកកូនចៅសាទូមានលោកសេកានា ជាកូនរបស់យ៉ាហាសៀល ហើយមានមនុស្សប្រុសបីរយនាក់នៅជាមួយលោក។[6]ក្នុងពួកកូនចៅអេឌីនមានលោកអេបេដ
ជាកូនរបស់លោកយ៉ូណាថាន ហើយមានមនុស្សប្រុសហាសិបនាក់ នៅជាមួយលោក។[7]ក្នងកូនចៅអេឡាំមានលោកយេសាយ៉ា ជាកូនរបស់លោកអថាលា
ហើយមានមនុស្សប្រុសចិតសិបនាក់ នៅជាមួយលោក។
[8]ក្នុងពួកកូនចៅសេផាធាមានលោកសេបាឌា ជាកូនរបស់លោកមីកែល ហើយមានមនុស្សប្រុស ប៉ែតសិបនាក់នៅជាមួយលោក។[9]ក្នុងពួកកូនចៅយ៉ូអាប់មានលោកអូបាឌា
ជាកូនលោកយេហ៊ីអែល ហើយមានមនុស្សប្រុស ២១៨នាក់នៅជាមួយលោក។[10]ក្នុងពួកកូនចៅបានីមានលោកសឡូមីត ជាកូនរបស់លោកយ៉ូសិភា
ហើយមានមនុស្សប្រុស ១៦០នាក់ នៅជាមួយលោក។[11]ក្នុងពួកកូនចៅបេបៃមានលោកសាការី ជាកូនរបស់លោកបេបៃ ហើយមានមនុស្សប្រុស
ម្ភៃប្រាំបីនាក់នៅជាមួយលោក។
[12]ក្នុងពួកកូនចៅអាសកាដមានលោកយ៉ូហាណាន ជាកូនរបស់លោកហាកាថាន ហើយមានមនុស្សប្រុស ១១០នាក់នៅជាមួយលោក។[13]ក្នុងពួកកូនចៅអដូនីកាំ
ដែលនៅក្រោយគេ។ នោះមានឈ្មោះ លោកអេលីផាលេត លោកយីអែល និងលោកសេម៉ាយ៉ា ហើយមានមនុស្សប្រុស ហុកសិបនាក់ នៅជាមួយ។
[14]ក្នុងពួកកូនចៅប៊ីកវ៉ាយមានលោកអ៊ូថាយ និងលោកសាប៊ូឌ ហើយមានមនុស្សប្រុស ចិតសិបនាក់នៅជាមួយលោក។
[15]ខ្ញុំបានប្រមូលបណ្តាជនទាំងនោះ នៅជិតប្រឡាយដែលហូរឆ្ពោះទៅស្រុកអាវ៉ាហា ហើយយើងបានបោះជំរំនៅទីនោះបីថ្ងៃ។ ខ្ញុំពិនិត្យមើលឃើញថា មានតែប្រជាជន
និងពួកបូជាចារ្យ គឺមិនឃើញមានពួកកូនចៅលេវីទេ។[16]ដូច្នេះ ខ្ញុំបានចាត់អស់លោកដែលជាមេដឹកនាំ គឺមានលោក អេលាសុ៊ែរ លោកអើរាល លោកសេម៉ាយ៉ា
លោកអែលណាថាន លោកយ៉ារីប និងលោកអែលណាថាន ព្រមទាំងលោកណាថាន លោកសាការី និងលោកមស៊ូឡាម ដែលជាមេដឹកនាំ ហើយនិងលោកយ៉ូយ៉ារីប
និងលោកអែលណាថាន ជាអ្នកបង្រៀនវិន័យ។
[17]រួចមកខ្ញុំចាត់អ្នកទាំងនោះឲ្យទៅជួបលោកអ៊ីដោ ដែលជាមេដឹកនាំនៅតំបន់កាសិភា។ ខ្ញុំក៏បានប្រាប់ពួកគេអំពីរបៀបនិយាយទៅលោកអ៊ីដោ និងបងប្អូនរបស់លោក
ជាពួកអ្នកបម្រើព្រះវិហារដែលរស់នៅតំបន់កាសិភា ដើម្បីឲ្យពួកគេនាំមនុស្សមកបម្រើការងារនៅក្នុងព្រះដំណាក់នៃព្រះរបស់យើង។
[18]ដោយព្រះដ៏សប្បុរសបានដាក់ព្រហស្តលើយើង គេក៏នាំលោកសេរេប៊ីយ៉ាមកជួបយើង គាត់ជាមនុស្សម្នាក់ប្រកបដោយប្រាជ្ញា។ គាត់គឺជាពូជពង្សរបស់លោកម៉ាសលី
ដែលត្រូវជាកូនរបស់លោកលេវី ដែលជាកូនអ៊ីស្រាអែល។ ព្រមទាំងនាំកូនប្រុស និងបងប្អូនរបស់គាត់មកជាមួយទាំងអស់ដប់ប្រាំបីនាក់។
[19]បន្ទាប់មកក៏មានលោកហាសាបយ៉ាមកជាលោក។ និងលោកយេសាយ៉ាពីពួកកូនចៅម៉្រារី ព្រមទាំងបងប្អូន និងកូនចៅរបស់ពួកគេ ទាំងអស់មាន ម្ភៃនាក់មកជាមួយ។
[20]បន្ទាប់មកទៀតមានពួកអ្នកបម្រើព្រះវិហារចំនួន ២២០នាក់ដែលមានឈ្មោះក្នុងបញ្ជី ដែលព្រះបាទដាវីឌ និងមេដឹកនាំរបស់ទ្រង់បានតែងតាំងឲ្យជួយការងារពួកលេវី។
[21]បន្ទាប់មក ខ្ញុំបានប្រកាសឲ្យធ្វើពិធីតមអាហារនៅក្បែរប្រឡាយអាហ៊ាវ៉ានោះ ដើម្បីដាក់ខ្លួននៅចំពោះព្រះភ័ក្ត្ររបស់ព្រះនៃយើង
សូមព្រះអង្គប្រោសប្រទានឲ្យយើងធ្វើដំណើរដោយសុខសាន្ត និងកូនចៅរបស់យើង និងទ្រព្យសម្បត្តិរបស់យើងទាំងប៉ុន្មានឲ្យបានគង់វង្សផង។

generated on Wed Sep 10 16:16:32 2025

[22]ដ្បិតខ្ញុំខ្មាសមិនហ៊ានទូលសូមព្រះរាជាប្រទានទាហាន និងកងទ័ពសេះ ដើម្បីការពារពួកយើងពីខ្មាំងសត្រូវតាមផ្លូវឡើយ ដ្បិតពួកយើងបានទូលព្រះរាជាថា
ព្រះហស្តរបស់ព្រះនៃយើង បានការពារដល់អស់អ្នកដែលបានស្វែងរកព្រះអង្គ តែព្រះចេស្តា និងសេចក្តីក្រោធរបស់ព្រះអង្គ
និងដាក់ទោសអស់អ្នកដែលបោះបង់ចោលព្រះអង្គ។[23]ដូច្នេះ យើងបានតមអាហារ និងសូមអង្វរដល់ព្រះនៃយើងអំពីដំណើរនេះ
ហើយព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យទូលអង្វររបស់យើង។
[24]បន្ទាប់មក ខ្ញុំបានញែកពួកបូជាចារ្យដប់ពីររូបពីចំណោមមេដឹកនាំ គឺមានលោកសេរេប៊ីយ៉ា និងលោកហាសាបយ៉ាព្រមទាំងបងប្អូនរបស់លោក ដប់រូបទៀត។[25]ខ្ញុំបានថ្លឹង
ប្រាក់ មាស និងគ្រឿងប្រដាប់ផ្សេងៗទៀត ជូនអ្នកទាំងនោះ គឺសម្រាប់តង្វាយព្រះដំណាក់ព្រះរបស់យើង ដែលព្រះរាជា ពួកទីប្រឹក្សា ពួកមន្ត្រីស្តេច
និងជនជាតិអ៊ីស្រាអែលដែលនៅក្នុងស្រុកនោះបានថ្វាយស្ម័គ្រពីចិត្ត។
[26]ខ្ញុំបានថ្លឹងប្រាក់ប្រគល់ជូនដល់ដៃលោកទាំងនោះចំនួន ៦៥០ ហាប វត្ថុធ្វើអំពីប្រាក់ មួយរយហាប និងមាសមួយរយហាប[27]ព្រមទាំងពែងមាសចំនួន ម្ភៃ
ដែលមានតម្លៃជាមាសមួយពាន់តម្លឹង ព្រមទាំងធើងធ្វើពីលង្ហិនយ៉ាងភ្លឺ ដែលមានតម្លៃដូចមាស។
[28]បន្ទាប់មកខ្ញុំនិយាយទៅពួកគេថា «អស់លោកគឺជាមនុស្សបរិសុទ្ធដល់ព្រះអម្ចាស់ ហើយគ្រឿងប្រដាប់ទាំងនេះក៏បរិសុទ្ធដែរ ឯប្រាក់ និងមាសនេះ ជាតង្វាយស្ម័គ្រពីចិត្ត
ដែលគេថ្វាយចំពោះព្រះអម្ចាស់ ជាព្រះរបស់បុព្វបុរសនៃអស់លោក។[29]ចូរយកចិត្តទុកដាក់ ហើយថែរក្សាវត្ថុទាំងនេះ រហូតដល់អស់លោកបានថ្លឹងវត្ថុទាំងនេះ
នៅចំពោះមុខមេដឹកនាំពួកបូជាចារ្យ ពួកលេវី និងមេដឹកនាំក្រុមគ្រួសារនៃជនជាតិអ៊ីស្រាអែល នៅក្រុងយេរូសាឡឹម ក្នុងបន្ទប់នៃព្រះដំណាក់របស់ព្រះអម្ចាស់»។
[30]ពួកបូជាចារ្យ និងពួកលេវី ក៏ទទួលយក ប្រាក់ មាស និងវត្ថុទាំងអស់ដែលគេបានថ្លឹង ដើម្បីនាំយកទៅក្រុងយេរូសាឡឹម ដាក់ក្នុងព្រះដំណាក់នៃព្រះរបស់យើង។
[31]បន្ទាប់មក ពួកយើងបានចាកចេញពីប្រឡាយអាហាវ៉ា នៅថ្ងៃទីដប់ពីរ ក្នុងខែទីមួយ ដើម្បីធ្វើដំណើរទៅក្រុងយេរូសាឡឹម។
ព្រះហស្តរបស់ព្រះនៃយើងបានការពារយើងនៅតាមផ្លូវ ហើយព្រះជាម្ចាស់បានការពារយើងឲ្យរួចពីកណ្តាប់ដៃខ្មាំងសត្រូវ ឬត្រូវចោរប្លន់ឡើយ។
[32]យើងបានមកដល់ក្រុងយេរូសាឡឹម ហើយនាំគ្នាសម្រាក់នៅទីនោះចំនួនបីថ្ងៃ។
[33]បន្ទាប់មកនៅថ្ងៃទីបួន យើងបានថ្លឹង ប្រាក់ មាស និងវត្ថុទាំងអស់ នៅក្នុងព្រះដំណាក់នៃព្រះរបស់យើង រួចប្រគល់ជូនលោកបូជាចារ្យម្រេម៉ូត ជាកូនលោកអ៊ូរីយ៉ា
នៅជាមួយលោក ហើយមានលោកអេឡាសារ ជាកូនរបស់លោកភីនេហាស ព្រមទាំងមានលោកយ៉ូសាបាដ ជាកូនរបស់លោកយេសួ និងលោកណូអាឌា
ជាកូនរបស់លោកប៊ីនុយ ដែលជាពួកលេវី។[34]គេបានរាប់ចំនួន ហើយបានថ្លឹងវត្ថុទាំងនោះ។ ព្រមទាំងកត់ត្រាទម្ងន់ទុកជាលាយលក្ខណ៍អក្សរ។
[35]ពួកអ្នកដែលគេកៀរទៅជាឈ្លើយ ហើយវិលត្រឡប់មកវិញនោះ គេនាំគ្នាថ្វាយតង្វាយដុតដល់ព្រះនៃជនជាតិអ៊ីស្រាអែល គឺគោឈ្មោល ដប់ពីរក្បាល
សម្រាប់ជនជាតិអ៊ីស្រាអែលទាំងអស់ ចៀមឈ្មោល កៅសិបប្រាំមួយក្បាល កូនចៀមចិតសិបប្រាំបីរក្បាល និងពពែឈ្មោលដប់ពីរក្បាល សម្រាប់ជាតង្វាយលោះបាប។
ពួកគេដុតសត្វទាំងនោះជាតង្វាយដុតថ្វាយដល់ព្រះអម្ចាស់។[36]បន្ទាប់មកគេបានប្រគល់រាជក្រឹត្យរបស់ស្តេច ជូនអស់លោកឧបរាជ និងទេសាភិបាលនៅខាងនាយទន្លេ
ហើយអស់លោកទាំងនោះបានជួយគាំទ្រដល់ប្រជាជនអ៊ីស្រាអែល និងព្រះដំណាក់របស់ព្រះជាម្ចាស់។

Ezra 8:1

ព័ត៌មានទូទៅ:

មានការផ្លាស់ប្តូរជាក់ស្តែងក្នុងភាពជាអ្នកនិពន្ធនៅទីនេះ។ ជំពូកទី ១-៧
ត្រូវបានសរសេរដូចជាអ្នកនិពន្ធកំពុងសរសេរអំពីលោកអែសរ៉ា។ ជំពូកទី ៨
ត្រូវបានសរសេរដូចជាអ្នកនិពន្ធគឺជាលោកអែសរ៉ា។

ព័ត៌មានទូទៅ:

ខ ២-១៤ គឺជាបញ្ជីរាយនាមអ្នកដឹកនាំ និងបុព្វបុរសរបស់ពួកគេ។
ពួកគេទាំងអស់សុទ្ធតែជាបុរស។

ក្នុងពួកកូនចៅភីនេហាសមានលោកគើសុន។

នេះគឺជាធាតុដំបូងនៅក្នុងបញ្ជី។ នេះអាចត្រូវបានសរសេរដោយកិរិយាស័ព្ទ
«បាន»។ ការបកប្រែរបៀបផ្សេងទៀត:
«មេដឹកនាំកូនចៅរបស់ភីនេហាសគឺគើសុន» ឬ
«គើសុនគឺជាមេដឹកនាំនៃកូនចៅរបស់ភីនេហាស»

ក្នុងពួកកូនចៅអ៊ីថាម៉ារមានលោកដានីយ៉ែល

នេះគឺជាធាតុទីពីរនៅក្នុងបញ្ជី។ នេះអាចត្រូវបានសរសេរដោយកិរិយាស័ព្ទ «គឺ»។
ការបកប្រែរបៀបផ្សេងទៀត: «មេដឹកនាំកូនចៅរបស់អ៊ីថាម៉ារគឺលោកដានីយ៉ែល»
ឬ «លោកដានីយ៉ែលគឺជាមេដឹកនាំនៃកូនចៅអ៊ីថាម៉ា»

ប៉ារ៉ូស

បកប្រែឈ្មោះបុរសនេះដូចអ្នកបានធ្វើនៅជំពូក ២:៣ ។

ក្នុងពួកកូនចៅដាវីឌមានលោកហាធូស ក្នុងពួក ... ប៉ារ៉ូស និងលោកសាការី

នេះគឺជាធាតុទីបីនៅក្នុងបញ្ជី។ នេះអាចត្រូវបានសរសេរដោយកិរិយាស័ព្ទ «បាន»
។ ការបកប្រែរបៀបផ្សេងទៀត:
«មេដឹកនាំរបស់កូនចៅដាវីឌគឺលោកហាធូសដែលជា ... ប៉ារ៉ូស និងសាការី» ឬ
«មេដឹកនាំនៃកូនចៅរបស់ដាវីឌគឺលោកហាធូស និងសាការី។
លោកហាធូសគឺមកពី ... ប៉ារ៉ូស»

លោកហាធូស ក្នុងពួកកូនចៅសេកានា ដែលមកពីពួកកូនចៅប៉ារ៉ូស

នេះអាចត្រូវបានសរសេរជាឃ្លាដាច់ដោយឡែកមួយ បន្ទាប់ពី «សាការី» ។
ការបកប្រែរបៀបផ្សេងទៀត:
«លោកហាធូសជាកូនចៅរបស់សេកានាដែលជាកូនចៅរបស់ប៉ារ៉ូស»

ហើយនៅក្នុងបញ្ជីបុព្វបុរសមានប្រុស ១៥០ នាក់នៅជាមួយលោក
«ជាមួយលោកសាការីមានបុរសចំនួន ១៥០នាក់
ដែលត្រូវបានចុះក្នុងបញ្ជីបុព្វបុរសរបស់លោក»

Ezra 8:4

ព័ត៌មានទូទៅ:

បញ្ជីឈ្មោះរបស់បុរសនៅតែបន្ត។

ក្នុងពួកកូនចៅផាហាត់ ម៉ូអាប់ មានលោកអេលីយ៉ូណៃ ជាកូនរបស់លោកសេរ៉ាហ៊ា

នេះគឺជាធាតុបន្ទាប់នៅក្នុងបញ្ជី។ នេះអាចត្រូវបានសរសេរដោយកិរិយាស័ព្ទ «គឺ»។
ការបកប្រែរបៀបផ្សេងទៀត: «មេដឹកនាំកូនចៅរបស់ផាហាត់
ម៉ូអាប់គឺលោកអេលីយ៉ូណៃជាកូនរបស់លោកសេរ៉ាហ៊ា» ឬ
«លោកអេលីយ៉ូណៃជាកូនប្រុសរបស់លោកសេរ៉ាហ៊ាគឺជាមេដឹកនាំនៃកូនចៅរបស់ផាហាត់
ម៉ូអាប់»

ហើយមានមនុស្សប្រុសពីររយនាក់ នៅជាមួយលោក
«ហើយនៅជាមួយលោកអេលីយ៉ូណៃមានបុរសពីររយនាក់»

លោកសេរ៉ាហ៊ា

បកប្រែឈ្មោះបុរសនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូកទី ៧:១។

លោកសេកានា

បកប្រែឈ្មោះបុរសនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូកទី ៨:១។

អេឌីន

បកប្រែឈ្មោះបុរសនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូកទី ២:១៥។

ពីររយនាក់ ... បីរយនាក់ ... ហាសិបនាក់ ... ចិតសិបនាក់
«២០០ ... ៣០០ ... ៥០ ... ៧០»

Ezra 8:8

ព័ត៌មានទូទៅ:

បញ្ជីឈ្មោះរបស់បុរសនៅតែបន្ត។

ក្នុងពួកកូនចៅសេផាធាមានលោកសេបាឌា ជាកូនរបស់លោកមីកែល

នេះគឺជាធាតុបន្ទាប់នៅក្នុងបញ្ជី។ នេះអាចត្រូវបានសរសេរដោយកិរិយាស័ព្ទ «គឺ»។
ការបកប្រែរបៀបផ្សេងទៀត:
«មេដឹកនាំកូនចៅរបស់លោកសេផាធាគឺលោកសេបាឌាជាកូនរបស់លោកមីកែល»
ឬ «លោកសេបាឌាជាកូនរបស់លោកមីកែលជាមេដឹកនាំកូនចៅរបស់សេផាធា» ។

លោកសេផាធា

បកប្រែឈ្មោះបុរសនេះដូចអ្នកបានធ្វើនៅក្នុងជំពូកទី ២:៣។

លោកមីកែល

នេះជាឈ្មោះរបស់បុរស។

ហើយមានមនុស្សប្រុស ប៉ែតសិបនាក់នៅជាមួយលោក
«ហើយនៅជាមួយលោកសេបាឌាត្រូវបានចុះបញ្ជីបុរសចំនួន ៨០ នាក់»

លោកបេបៃ

បកប្រែវាដូចដែលអ្នកបានធ្វើនៅក្នុងជំពូកទី ២:១១។

ប៉ែតសិបនាក់ ... ម្ភៃប្រាំបីនាក់

generated on Wed Sep 10 16:16:32 2025

ប្រាំបី - «៨០ ... ២៨»
Ezra 8:12
ព័ត៌មានទូទៅ:
នេះគឺជាការបញ្ចប់នៃបញ្ជីឈ្មោះរបស់មនុស្ស។
ក្នុងពួកកូនចៅអាសកាដមានលោកយ៉ូហាណាន ជាកូនរបស់លោកហាកាថាន
នេះគឺជាធាតុបន្ទាប់នៅក្នុងបញ្ជី។ នេះអាចត្រូវបានសរសេរដោយកិរិយាស័ព្ទ «គឺ»។
ការបកប្រែរបៀបផ្សេងទៀត:
«មេដឹកនាំកូនចៅអាសកាដគឺលោកយ៉ូហាណានជាកូនរបស់លោកហាកាថាន » ឬ
«លោកយ៉ូហាណានជាកូនរបស់លោកហាកាថានគឺជាមេដឹកនាំនៃកូនចៅរបស់អាសកាដ»
ហើយមានមនុស្សប្រុស ១១០នាក់នៅជាមួយលោក
«ហើយនៅជាមួយលោកយ៉ូហាណានត្រូវបានចុះបញ្ជីបុរសទាំង ១១០នាក់»
ក្នុងពួកកូនចៅអដូនីកាំ
ពាក្យថា «ពួក» សំដៅទៅលើអ្នកដឹកនាំ។ ការបកប្រែរបៀបផ្សេងទៀត:
«មេដឹកនាំកូនចៅនៃកូនចៅអដូនីកាំ»
អាសកាដ
បកប្រែឈ្មោះបុរសនេះដូចអ្នកបានធ្វើនៅក្នុងជំពូកទី ២:១១។
អដូនីកាំ
បកប្រែឈ្មោះបុរសនេះដូចអ្នកបានធ្វើនៅក្នុងជំពូកទី ២:១១។
ប៊ីកវ៉ាយ
បកប្រែឈ្មោះបុរសនេះដូចអ្នកបានធ្វើនៅក្នុងជំពូកទី ២:១។
ហុកសិប ... ចិតសិប
«៦០ ... ៧០»
Ezra 8:15
ព័ត៌មានទូទៅ:
ពាក្យ «ខ្ញុំ» ក្នុងជំពូកទី ៨ សំដៅទៅលើលោកអែសរ៉ា។ លោកគឺជាអ្នកនិពន្ធ។
ព័ត៌មានទូទៅ:
ក្នុងខ ១៦ មានបញ្ជីឈ្មោះរបស់បុរស។
ប្រឡាយដែលហូរឆ្ពោះទៅស្រុកអាវ៉ាហា
អាចមានន័យថា «ប្រឡាយ» គឺ ១) ផ្លូវទឹកដែលមនុស្សបានសាងសង់ ឬ ២)
ទន្លេធម្មតា។ នេះអាចត្រូវបានបកប្រែតាមរបៀបទូទៅជាងនេះ។
ការបកប្រែរបៀបផ្សេងទៀត: «ផ្លូវទឹកដែលហូរទៅកាន់ស្រុកអាវ៉ាហា»
ស្រុកអាវ៉ាហា
នេះគឺជាឈ្មោះនៃទីកន្លែងមួយ
លោកសេម៉ាយ៉ា
បកប្រែឈ្មោះបុរសនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូក ៨:១២ ។
លោកអែលណាថាន ... លោកអែលណាថាន ... លោកអែលណាថាន
តាមមើលទៅមានបុរសបីនាក់ដែលមានឈ្មោះដូចគ្នា។
Ezra 8:17
លោកអ៊ីដោ
នេះជាឈ្មោះរបស់បុរស។
រួចមកខ្ញុំចាត់អ្នកទាំងនោះឲ្យទៅជួបលោកអ៊ីដោ
ពាក្យថា «អ្នកទាំងនោះ» សំដៅទៅលើអ្នកដឹកនាំទាំងប្រាំបួននាក់
និងគ្រូពីរនាក់ដែលបានសរសេរនៅក្នុងជំពូក ៨:១៥ អំពី។
ការបកប្រែរបៀបផ្សេងទៀត: «បន្ទាប់ខ្ញុំបានចាត់បុរសទាំងនោះទៅលោកអ៊ីដោ»
តំបន់កាសិភា
នេះគឺជាឈ្មោះរបស់កន្លែងមួយ។
ខ្ញុំក៏បានប្រាប់ពួកគេអំពីរបៀបនិយាយទៅលោកអ៊ីដោ ... នោះគឺ
ដើម្បីឲ្យពួកគេនាំមនុស្សមកបម្រើការងារនៅក្នុងព្រះដំណាក់នៃព្រះរបស់យើង
ពាក្យថា «នោះគឺ» ណែនាំពីអ្វីដែលលោកបានប្រាប់ពួកគេឲ្យនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានប្រាប់ពួកគេឲ្យប្រាប់លោកអ៊ីដោ ...
ដើម្បីឲ្យពួកគេនាំមនុស្សមកបម្រើការងារនៅក្នុងព្រះដំណាក់នៃព្រះរបស់ព្រះជាម្ចាស់»
Ezra 8:18
លោកសេរេប៊ីយ៉ា ... លោកម៉ាសលី ... លោកហាសាបយ៉ា ... ម៉្រារី
ទាំងនេះគឺជាឈ្មោះរបស់បុរស។
ដោយព្រះដ៏សប្បុរសបានដាក់ព្រហស្តលើយើង
«ព្រហស្តដ៏សប្បុរស»
របស់ព្រះជាម្ចាស់តំណាងភាពសប្បុរសរបស់ព្រះអង្គក្នុងការផ្គត់ផ្គង់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត:
«ដោយសារព្រះជាម្ចាស់មានព្រះហឫទ័យប្រណីដល់យើង
ពួកគេបានចាត់បុរសម្នាក់ឲ្យមក»
មនុស្សម្នាក់ប្រកបដោយប្រាជ្ញា
នេះគឺជាបុរសម្នាក់ដែលមានការយល់ដឹង និងមានប្រាជ្ញា។
កូនរបស់លោកលេវី ដែលជាកូនអ៊ីុស្រាអែល
នៅទីនេះ «អ៊ីុស្រាអែល» គឺជាឈ្មោះរបស់បុរសម្នាក់។
នេះជាឈ្មោះដែលព្រះជាម្ចាស់បានប្រទានឲ្យដល់លោកយ៉ាកុប។
ដប់ប្រាំបី ... ម្ភៃ
១៨, ២០។
ហាសាបយ៉ា
បកប្រែឈ្មោះបុរសនេះដូចក្នុងជំពូក ៨:៤ ។
ពួកមេដឹកនាំ
មនុស្សដែលមានសិទ្ធិអំណាចជាក់លាក់នៅក្នុងប្រព័ន្ធរដ្ឋាភិបាល
Ezra 8:21
ប្រឡាយអាហ៊ាវ៉ា
នេះគឺជាឈ្មោះប្រឡាយដែលហូរទៅកន្លែងដែលគេហៅថា អាហ៊ាវ៉ា។
សូមមើលពីរបៀបបកប្រែក្នុងជំពូក ៨:១៥ ។
សូមព្រះអង្គប្រោសប្រទានឲ្យយើងធ្វើដំណើរដោយសុខសាន្ត និងកូនចៅរបស់យើង
និងទ្រព្យសម្បត្តិរបស់យើងទាំងប៉ុន្មានឲ្យបានគង់វង្សផង
ពាក្យថា «សូមប្រោសប្រទាន»
តំណាងឲ្យការស្នើសុំឲ្យព្រះជាម្ចាស់ធ្វើអ្វីមួយសម្រាប់ពួកគេ។ នៅទីនេះ
«ដំណើរដោយសុខសាន្ត» តំណាងឲ្យសុវត្ថិភាព នៅពេលពួកគេធ្វើដំណើរ។
ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះជាម្ចាស់ប្រទានឲ្យយើង កូនចៅរបស់យើង
និងទ្រព្យសម្បត្តិរបស់យើងទាំងប៉ុន្មានឲ្យបានគង់វង្សផង នៅពេលយើងធ្វើដំណើរ»
ឬ «សូមព្រះជាម្ចាស់ការពារយើង កូនចៅរបស់យើង
និងទ្រព្យសម្បត្តិរបស់យើងទាំងប៉ុន្មានឲ្យបានគង់វង្សផង នៅពេលយើងធ្វើដំណើរ»
ព្រះហស្តរបស់ព្រះនៃយើង បានការពារដល់អស់អ្នកដែលបានស្វែងរកព្រះអង្គ
ព្រះហស្តរបស់ព្រះជាម្ចាស់បានដាក់លើមនុស្សគឺជាទីសម្គាល់សម្រាប់ព្រះជាម្ចាស់ដែលជួយមនុស្ស។
ការស្វែងរកព្រះជាម្ចាស់គឺជាការប្រៀបធៀបមួយសម្រាប់ការបម្រើព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់ជួយអស់អ្នកដែលបម្រើព្រះអង្គ»
តែព្រះចេស្តា និងសេចក្តីក្រោធរបស់ព្រះអង្គ និងដាក់ទោសអស់អ្នកដែលបោះបង់ចោលព្រះអង្គ
ព្រះចេស្តា
និងសេចក្តីក្រោធរបស់ព្រះជាម្ចាស់ចំពោះមនុស្សគឺជាទីសម្គាល់សម្រាប់ព្រះអង្គដាក់ទណ្ឌកម្មដល់មនុស្ស។
ការបំភ្លេចព្រះជាម្ចាស់គឺតំណាងឲ្យការបដិសេធមិនបម្រើព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែព្រះអង្គដាក់ទោសអស់អ្នកដែលមិនព្រមបម្រើព្រះអង្គ»
ដូច្នេះ យើងបានតមអាហារ និងសូមអង្វរដល់ព្រះនៃយើងអំពីដំណើរនេះ
នៅទីនេះការស្វែងរកព្រះជាម្ចាស់
គឺតំណាងឲ្យការស្នើសុំឲ្យព្រះជាម្ចាស់ធ្វើអ្វីមួយសម្រាប់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះយើងបានតមអាហារ
ហើយសុំព្រះជាម្ចាស់ឲ្យជួយដល់យើង»
Ezra 8:24
លោកសេរេប៊ីយ៉ា លោកហាសាបយ៉ា
បកប្រែឈ្មោះមនុស្សទាំងនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូកទី ៨:១៨។
Ezra 8:26
ប្រាក់ចំនួន ៦៥០ហាប
«ប្រាក់ចំនួន ៦៥០ ហាប។» អ្នកអាចប្តូរវាទៅជាបែបទំនើប។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាក់ ២២.០០០ គីឡូក្រាម» ឬ
ប្រាក់ពីរម៉ឺនពីរពាន់គីឡូក្រាម»
វត្ថុធ្វើអំពីប្រាក់ មួយរយហាប
អ្នកអាចប្តូរវាទៅជាបែបទំនើប។ ការបកប្រែរបៀបផ្សេងទៀត: «វត្ថុធ្វើអំពីប្រាក់
៣.៤០០គីឡូក្រាម»
មាសមួយរយហាប
អ្នកអាចប្តូរវាទៅជាបែបទំនើប។ ការបកប្រែរបៀបផ្សេងទៀត: «មាស ៣.៤០០
គីឡូក្រាម»
មួយពាន់តម្លឹង
មួយ «តម្លឹង» គឺជាកាក់មាសតូចមួយដែលប្រជាជននៅចក្រភពពែរ្សបានប្រើ។
អ្នកអាចបកប្រែវាក្នុងលក្ខខណ្ឌជាចំនួនកាក់ ឬទម្ងន់របស់ពួកវា។
ការបកប្រែរបៀបផ្សេងទៀត: «មួយពាន់កាក់មាសពែរ្ស» ឬ
«មាស៨គីឡូក្រាមកន្លះ»

generated on Wed Sep 10 16:16:32 2025

ធើងធ្វើពីលង្ហិន
លង្ហិនគឺជាលួ្ហយនៃទង់ដែង និងលោហៈមួយទៀត។ វាខ្លាំងជាងទង់ដែងសុទ្ធ។
Ezra 8:28
បន្ទាប់មកខ្ញុំនិយាយទៅពួកគេ
«បន្ទាប់មកខ្ញុំបាននិយាយទៅកាន់មេដឹកនាំពួកបូជាចារ្យទាំងដប់ពីររូប»
រហូតដល់អស់លោកបានថ្លឹងវត្ថុទាំងនេះ នៅចំពោះមុខមេដឹកនាំពួកបូជាចារ្យ ពួកលេវី និងមេដឹកនាំ
ពេលពួកគេទៅដល់ក្រុងយេរូសាឡិមពួកគេនឹងថ្លឹងប្រាក់ មាស
និងលង្ហិនដើម្បីបង្ហាញថា ពួកគេមិនបានយករបស់ទាំងនោះសម្រាប់ខ្លួនគេទេ។
ពួកបូជាចារ្យ និងពួកលេវី
យោងទៅតាមច្បាប់របស់លោកម៉ូសេកុលសម្ពន្ធលេវីមានភារកិច្ចមើលថែរក្សាព្រះវិហារ
ទ្រព្យសម្បត្តិ និងដង្វាយនានា។
Ezra 8:31
បន្ទាប់មក ពួកយើងបានចាកចេញពីប្រឡាយអាហាវ៉ា
«យើងបានចាកចេញពីប្រឡាយអាហាវ៉ា» ឬ
«យើងបានចាប់ផ្តើមធ្វើដំណើរពីប្រឡាយអាហាវ៉ា»
ប្រឡាយអាហាវ៉ា
នេះគឺជាឈ្មោះប្រឡាយដែលហូរទៅកន្លែងដែលគេហៅថា អាហាវ៉ា។
បកប្រែដូចដែលអ្នកបានធ្វើនៅក្នុងជំពូក 8:21 ។
នៅថ្ងៃទីដប់ពីរ ក្នុងខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ថ្ងៃទីដប់ពីរ គឺជិតដល់ចុងខែមីនា
តាមប្រតិទិនលោកខាងលិច។
ព្រះហស្តរបស់ព្រះនៃយើងបានការពារយើង
ព្រះហស្តរបស់ព្រះបានដាក់លើមនុស្សគឺជាទីសម្គាល់ព្រះជាម្ចាស់ដែលជួយដល់មនុស្ស
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់កំពុងជួយដល់យើង»
ព្រះជាម្ចាស់បានការពារយើងឲ្យរួចពីកណ្តាប់ដៃខ្មាំងសត្រូវ និងអ្នកដែរ ... ផ្លូវ
កណ្តាប់ដៃតំណាងឲ្យអ្វីដែលមនុស្សទាំងនោះអាចធ្វើបាន។
ជាពិសេសវាសំដៅទៅលើពួកគេវាយប្រហារក្រុមដែលកំពុងធ្វើដំណើរ។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានការពារយើងពីការវាយប្រហាររបស់សត្រូវ
និងអ្នកដែលចង់ឡោមព័ទ្ធយើងនៅតាមផ្លូវ» ឬ
«ព្រះអង្គបានការពារសត្រូវមិនឲ្យវាយប្រហារយើង
ហើយព្រះអង្គបានរារាំងចោរពីការវាយឆ្មក់យើងនៅតាមផ្លូវ»
អ្នកដែលប្រាថ្នាចង់វាយឆ្មក់ពួកយើង
នេះសំដៅទៅលើចោរ និងចោរប្លន់ដែលចង់វាយប្រហារពួកគេ
ដើម្បីយកទ្រព្យសម្បត្តិរបស់ពួកគេ។
Ezra 8:33
បានថ្លឹង ប្រាក់ មាស និងវត្ថុទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
មេដឹកនាំពួកបូជាចារ្យទាំងដប់ពីរនាក់បានថ្លឹងប្រាក់ មាស និងវត្ថុផ្សេងៗ។
បានថ្លឹង ... ប្រគល់ទៅក្នុងកណ្តាប់ដៃរបស់លោកបូជាចារ្យម្រេម៉ូត
ត្រូវបានថ្លឹង ... ចូប្រគល់ទៅក្នុងកណ្តាប់ដៃរបស់លោកបូជាចារ្យម្រេម៉ូត
លោកបូជាចារ្យម្រេម៉ូត ... លោកអ៊ូរីយ៉ា ... លោកអេឡាសា ... លោកភីនេហាស ...
លោកយ៉ូសាបាដ ... លោកយេសួ ... លោកណូអាឌា ... លោកប៊ីនុយ
ទាំងនេះគឺជាឈ្មោះរបស់បុរស។
លោកយេសួ
បកប្រែឈ្មោះបុរសនេះដូចអ្នកបានធ្វើនៅក្នុងជំពូកទី ២:៣។
Ezra 8:35
អ្នកដែលគេកៀរទៅជាឈ្លើយ ហើយវិលត្រឡប់មកវិញនោះ ... ប្រជាជនដែលនិរទេស
ឃ្លាទាំងពីរនេះសំដៅទៅលើជនជាតិយូដាដែលបានរស់នៅជាឈ្លើយនៅក្នុងស្រុកបាប៊ីឡូន
ហើយអ្នកដែលបានចាកចេញពីស្រុកបាប៊ីឡូនរួចវិលត្រឡប់មកក្រុងយេរូសាឡិមនៅស្រុកយូដាវិញ។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលត្រឡប់មកក្រុងយេរូសាឡិមពីការជាប់ជាឈ្លើយនៅស្រុកបាប៊ីឡូន
ជាប្រជាជនដែលនិរទេស»
ដប់ពីរ ... កៅសិបប្រាំមួយ ... ចិតសិបប្រាំពីរ ... ដប់ពីរ
ដប់ពីរ ... កៅសិបប្រាំមួយ ... ចិតសិបប្រាំពីរ ... ដប់ពីរ - «១២, ៩៦ ... ៧៧ ... ១២»
ទេសាភិបាលនៅខាងនាយទន្លេ
អ្នកទាំងនោះជាមេដឹកនាំរបស់ជនជាតិបាប៊ីឡូនគ្រប់គ្រងប្រជាជននៅខាងលិចទន្លេអឺប្រាត
ដែលរួមបញ្ចូលប្រជាជនដែលរស់នៅស្រុកយូដា។
ខេត្តនៅខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលនៅខាងលិចទន្លេអឺប្រាត។ វាបានឆ្លងកាត់ទន្លេពីស៊ូសា។
នេះរួមបញ្ចូលស្រុកយូដា។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ៤:៩។
ព្រះដំណាក់របស់ព្រះជាម្ចាស់
ព្រះវិហារ

---

9 [1]កាលការទាំងនោះបានសម្រេចហើយ ពួកមេដឹកនាំបានប្រាប់ខ្ញុំថា «ប្រជាជនអ៊ីស្រាអែល ពួកបូជាចារ្យ និងពួកលេវី មិនបានញែកខ្លួនចេញពីជាតិសាសន៍នានា
ដែលនៅក្នុងស្រុកនោះទេ គឺពួកគេប្រព្រឹត្តតាមអំពើគួរឲ្យស្អប់ខ្ពើមដូចជនជាតិទាំងនោះដែរ គឺមានជនជាតិកាណាន ជនជាតិហេត ជនជាតិពេរិស៊ីត ជនជាតិយេប៊ូស
ជនជាតិអាំម៉ូន ជនជាតិម៉ូអាប់ ជនជាតិអេស៊ីប និងជនជាតិអាម៉ូរី។[2]ដ្បិតពួកគេ និងកូនប្រុសរបស់ពួកគេ
បានយកកូនស្រីរបស់ជនជាតិទាំងនោះមកធ្វើជាប្រពន្ធសម្រាប់ខ្លួនគេ ជាហេតុធ្វើឲ្យជនជាតិបរិសុទ្ធបានលាយឡំជាមួយជនជាតិនៅស្រុកនោះ ហើយពួកមេដឹកនាំ
និងពួកអ្នកគ្រប់គ្រងបាននាំគ្នាប្រព្រឹត្តអំពើក្បត់នេះមុនគេ»។
[3]កាលខ្ញុំឮពាក្យទាំងនេះ ខ្ញុំក៏ហែកសម្លៀកបំពាក់របស់ខ្ញុំ និងហែកអាវធំ ហើយបោចសក់ក្បាលរបស់ខ្ញុំ និងបោចពុកចង្កាខ្លួនឯង ហើយខ្ញុំអង្គុយទាំងស្រពិចស្រពិល។
[4]អស់អ្នកដែលភ័យខ្លាចនឹងព្រះបន្ទូលរបស់ព្រះនៃជនជាតិអ៊ីស្រាអែល ក៏នាំគ្នាមកអង្គុយជុំវិញខ្ញុំ ដោយព្រោះអំពើក្បត់របស់ពួកអ្នកដែលជាប់ជាឈ្លើយ
ហើយវិលត្រឡប់មកវិញ កាលដែលខ្ញុំអង្គុយស្រពិចស្រពិល រហូតដល់ពេលថ្វាយតង្វាយល្ងាច។
[5]លុះដល់ពេលថ្វាយតង្វាយល្ងាច ខ្ញុំក៏ក្រោកចេញពីភាពសោកសៅនោះ ទាំងស្លៀកសម្លៀកបំពាក់ និងអាវធំរហែកដដែលនោះ ហើយលុតជង្គង់ចុះ
ហើយលើកដៃទូលទៅរកព្រះអម្ចាស់ ជាព្រះរបស់ខ្ញុំ។[6]ដោយទូលអង្វរថា «ឱព្រះនៃទូលបង្គំអើយ ទូលបង្គំមានសេចក្តីអាម៉ាស់ខ្លាំងណាស់
ហើយខ្មាសមិនហ៊ានងើបមុខសម្លឹងទៅរកព្រះអង្គទេ ដោយព្រោះអំពើទុច្ចរិតរបស់ខ្ញុំកើនកាន់តែច្រើនឡើង ខ្ពស់ជាងក្បាលយើងខ្ញុំទៅទៀត
ហើយទោសកំហុសរបស់ខ្ញុំក៏កើនឡើង រហូតដល់ផ្ទៃមេឃដែរ។
[7]តាំងពីជំនាន់ដូនតារបស់ខ្ញុំ រហូតមកដល់សព្វថ្ងៃនេះ យើងខ្ញុំមានទោសកំហុសធ្ងន់ណាស់។ ដោយព្រោះអំពើទុច្ចរិតរបស់យើងខ្ញុំ បានជាព្រះអង្គប្រគល់យើងខ្ញុំ
ស្តេចរបស់យើងខ្ញុំ ហើយនិងពួកបូជាចារ្យរបស់យើងខ្ញុំទៅក្នុងកណ្តាប់ដៃស្តេចរបស់ប្រជាជាតិនានា ពួកគេសម្លាប់ដោយមុខដាវ យកទៅជាឈ្លើយ
ឲ្យគេរឹបអូសយកទ្រព្យសម្បត្តិ ហើយធ្វើឲ្យយើងខ្ញុំមានសេចក្តីអាម៉ាស់ដូចសព្វថ្ងៃ។
[8]ក៏ប៉ុន្តែ នៅវេលាមួយដ៏ខ្លី ព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ បានសម្តែងព្រះហឫទ័យមេត្តាករុណាមកលើយើងខ្ញុំ ដោយប្រោសប្រទានប្រជាជនមួយចំនួននៅសេសសល់
ហើយមករស់នៅក្នុងទឹកដីដ៏បរិសុទ្ធរបស់ព្រះអង្គ។ ដើម្បីឲ្យព្រះនៃយើងបានបំភ្លឺភ្នែកយើងខ្ញុំ និងឲ្យយើងខ្ញុំមានជីវិតធូរស្រាលឡើងវិញ
ទោះបីជាយើងធ្លាក់ខ្លួនជាទាសករក្តី។[9]ដ្បិតយើងខ្ញុំជាទាសកររមែន ប៉ុន្តែព្រះនៃយើងខ្ញុំមិនបានបោះបង់ចោលយើងខ្ញុំឡើយ
ហើយព្រះអង្គសម្តែងព្រះហឫទ័យសប្បុរសដល់យើងខ្ញុំ។ គឺព្រះអង្គប្រទានជីវិតថ្មីដល់យើងខ្ញុំ នៅចំពោះព្រះភ័ក្ត្រស្តេចនៃស្រុកពែរ្ស
ដើម្បីសង់ព្រះដំណាក់ព្រះរបស់យើងខ្ញុំឡើងវិញ ហើយជួសជុសទីកន្លែងដែលបាក់បែងឡើងវិញ។ ព្រះអង្គបានធ្វើការទាំងអស់នេះ
ហើយឲ្យយើងខ្ញុំមានទីជម្រកដ៏រឹងមាំនៅស្រុកយូដា និងក្រុងយេរូសាឡឹម។
[10]ឥឡូវនេះ ឱព្រះនៃយើងខ្ញុំអើយ ក្រោយពីមានហេតុការណ៍កើតឡើងដូច្នេះ តើត្រូវឲ្យយើងខ្ញុំនិយាយដូចម្តេច? ដ្បិតយើងខ្ញុំមិនបានគោរពបទបញ្ជារបស់ព្រះអង្គទេ
[11]គឺជាបទបញ្ជាដែលព្រះអង្គបានប្រទានដល់យើងខ្ញុំ តាមរយៈព្យាការី ជាអ្នកបម្រើរបស់ព្រះអង្គ នៅពេលដែលព្រះអង្គមានព្រះបន្ទូលមកយើងខ្ញុំថា
«ស្រុកដែលអ្នករាល់គ្នាចូលទៅចាប់យកនោះ គឺជាស្រុកដែលមិនបរិសុទ្ធ។ ដ្បិតប្រជាជនរស់នៅលើទឹកដីនោះមិនបរិសុទ្ធ
ហើយដោយព្រោះអំពើគួរស្អប់ខ្ពើមដែលគេបានប្រព្រឹត្ត។ ស្រុកនោះពេញទៅដោយសេចក្តីស្មោកគ្រោករបស់គេពាសពេញក្នុងទឹកដី។[12]ដូច្នេះ
មិនត្រូវលើកកូនស្រីរបស់អ្នករាល់គ្នា អោយទៅកូនប្រុសរបស់គេឡើយ ហើយក៏មិនត្រូវយកកូនស្រីរបស់គេ មកឲ្យកូនប្រុសរបស់អ្នករាល់គ្នាដែរ

generated on Wed Sep 10 16:16:32 2025

ហើយមិនត្រូវស្វែងរកសេចក្ដីសុខ និងភាពចម្រុងចម្រើនរបស់គេឡើយ ដ្បិតធ្វើដូច្នេះ អ្នករាល់គ្នានឹងមានកម្លាំងខ្លាំងក្លា ហើយបរិភោគផលដ៏ល្អៗនៅក្នុងស្រុកនោះ
ព្រមទាំងទុកជាកេរមរតក ឲ្យកូនចៅរបស់អ្នករាល់គ្នារៀងរហូតតទៅ»។
[13]ក្រោយពីហេតុការណ៍ទាំងប៉ុន្មានបានធ្លាក់មកលើយើងខ្ញុំ ដោយព្រោះអំពើអាក្រក់ និងកំហុសដ៏ធ្ងន់របស់យើងខ្ញុំ ប៉ុន្តែ
ព្រះអង្គមិនបានដាក់ទោសយើងខ្ញុំឲ្យសមនឹងអំពើទុច្ចរិតរបស់ខ្ញុំឡើយ
ហើយដោយបានប្រោសឲ្យយើងខ្ញុំនៅមានជីវិតរស់នៅវិញ[14]តើយើងខ្ញុំនឹងបែរទៅប្រព្រឹត្តអំពើរំលងបទបញ្ជារបស់ព្រះអង្គ
ដោយរៀបការជាមួយជនជាតិដ៏គួរស្អប់ខ្ពើមទាំងនោះឬ? តើព្រះអង្គមិនមានព្រះពិរោធនឹងយើងខ្ញុំ រហូតដល់បំផ្លាញយើងខ្ញុំឲ្យវិនាសសូន្យ កុំឲ្យមាននៅសេសសល់
ហើយមិនមានអ្នកណាម្នាក់គេចផុតទេឬ?
[15]ឱព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល ព្រះអង្គជាព្រះដ៏សុចរិត ដ្បិតយើងខ្ញុំមានជីវិតរស់នៅ ដូចមានសព្វថ្ងៃនេះ។ មើល៍! យើងខ្ញុំនៅចំពោះព្រះភ័ក្ត្រព្រះអង្គ
ទាំងមានបាប ដោយព្រោះអំពើបែបនេះ គ្មានអ្នកណាអាចឈរនៅចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គបានឡើយ។

Ezra 9:1
មិនបានញែកខ្លួនចេញ
បានរៀបការជាមួយមនុស្សមកពីស្រុកផ្សេង ហើយបានកាន់សាសនារបស់ពួកគេ
Ezra 9:3
កាលខ្ញុំឮពាក្យទាំងនេះ
នៅពេលលោកអែសរ៉ាបានឮថាជនជាតិអ៊ីស្រាអែលជាច្រើនបានរៀបការជាមួយស្ត្រីស្រុកផ្សេង
ហើយពួកគេកំពុងតែគោរពបូជាព្រះរបស់ពួកគេ
ខ្ញុំក៏ហែកសម្លៀកបំពាក់របស់ខ្ញុំ និងហែកអាវធំ ហើយបោចសក់ក្បាលរបស់ខ្ញុំ
និងបោចពុកចង្កាខ្លួនឯង
លោកអែសរ៉ាបានបង្ហាញដល់មនុស្សគ្រប់គ្នាថា
លោកមិនសប្បាយចិត្តទេដែលមនុស្សបានធ្វើអ្វីដែលធ្វើឲ្យព្រះជាម្ចាស់អាក់អន់ព្រះទ័យ
តង្វាយល្ងាច
ការថ្វាយតង្វាយដែលពួកបូជាចារ្យត្រូវធ្វើនៅពេលថ្ងៃលិច
Ezra 9:5
ភាពសោកសៅរបស់ខ្ញុំ
វិធីមួយទៀតដែលនិយាយថា លោកកំពុង «អង្គុយខ្មាស់អៀន» (៩:៣)។
«កន្លែងដែលខ្ញុំអង្គុយចុះ ដើម្បីបង្ហាញពីភាពខ្មាស់អៀនរបស់ខ្ញុំ»
លុតជង្គង់ចុះ ហើយលើកដៃរបស់ខ្ញុំ
«ជង្គង់ខ្ញុំលុត ហើយលាតដៃរបស់ខ្ញុំ ដោយដៃរបស់ខ្ញុំលើកទៅលើមេឃ»
ដោយព្រោះអំពើទុច្ចរិតរបស់ខ្ញុំកើនកាន់តែច្រើនឡើង ខ្ពស់ជាងក្បាលយើងខ្ញុំទៅទៀត
ហើយទោសកំហុសរបស់ខ្ញុំក៏កើនឡើង រហូតដល់ផ្ទៃមេឃដែរ
ពាក្យទាំងនេះគឺជាវិធីពីរយ៉ាងនៃការនិយាយអំពីអំពើទុច្ចរិត និងទោសកំហុស
ដូចជាវាជាវត្ថុដែលអាចរីកចម្រើនធំជាងមនុស្ស។ នាមអរូបី «ទុច្ចរិត» និង
«ទោសកំហុស» អាចត្រូវបានបង្ហាញជានាម និងគុណនាមរៀងៗខ្លួន។
ការបកប្រែរបៀបផ្សេងទៀត: «យើងបានប្រព្រឹត្តអំពើអាក្រក់
ហើយយើងមានកំហុសខ្លាំងណាស់»
Ezra 9:7
ថ្ងៃនៃដូនតារបស់ខ្ញុំ
«ពេលវេលាដែលដូនតារបស់ខ្ញុំនៅរស់»
កំហុសធ្ងន់ណាស់ ... ដោយព្រោះអំពើទុច្ចរិតរបស់យើងខ្ញុំ
នាមអរូបី «កំហុសធ្ងន់» និង «ទុច្ចរិត» អាចត្រូវបានបកប្រែជាគុណនាម
និងកិរិយាស័ព្ទរៀងៗខ្លួន។ ការបកប្រែរបៀបផ្សេងទៀត:
«មានកំហុសខ្លាំងណាស់ ... ដោយសារតែអំពើអាក្រក់ដែលយើងខ្ញុំបានប្រព្រឹត្ត»
យើងខ្ញុំ ... ប្រគល់ទៅក្នុងកណ្ដាប់ដៃស្ដេច
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានប្រគល់យើងខ្ញុំទៅក្នុងកណ្ដាប់ដៃរបស់ស្ដេច»
ទៅក្នុងកណ្ដាប់ដៃស្ដេចរបស់ប្រជាជាតិនានា
អ្នកនិពន្ធនិយាយអំពីព្រះជាម្ចាស់អនុញ្ញាតឲ្យស្ដេចធ្វើអ្វីៗដែលស្ដេចចង់ធ្វើដល់ពួកយូដា
ដូចជាព្រះជាម្ចាស់បានដាក់វត្ថុតូចៗចូលក្នុងកណ្ដាប់ដៃរបស់ស្ដេចនៃពិភពលោកនេះ។
ដោយមុខដាវ
ដាវគឺជាទីសម្គាល់មួយសម្រាប់មនុស្សដែលសម្លាប់មនុស្សផ្សេងទៀត។ ព្រះជា
ម្ចាស់បានអនុញ្ញាតឲ្យមនុស្សសម្លាប់ជនជាតិយូដា។
ទៅជាឈ្លើយ
នាមអរូបីនេះអាចត្រូវបានបកប្រែជាឃ្លាកិរិយាស័ព្ទ។
ព្រះជាម្ចាស់បានអនុញ្ញាតឲ្យមនុស្សចាប់ជនជាតិយូដា
ហើយយកពួកគេទៅឲ្យឆ្ងាយ។
រឹបអូសយកទ្រព្យសម្បត្តិ
នាមអរូបីនេះអាចត្រូវបានបកប្រែជាឃ្លាកិរិយាស័ព្ទ។
ព្រះជាម្ចាស់បានអនុញ្ញាតឲ្យមនុស្សរឹបអូសយកទ្រព្យសម្បត្តិរបស់ជនជាតិយូដា។
អាម៉ាស់មុខ
មុខគឺជាទីសម្គាល់មួយសម្រាប់ភាពខ្មាស់អៀនដែលមនុស្សមានអារម្មណ៍ហើយអ្នកផ្សេងទៀតនឹងដឹងពីរអ
នៅពេលដែលឃើញមុខរបស់ម្នាក់នោះ ។
Ezra 9:8
ព្រះជាម្ចាស់នៃយើងខ្ញុំ បានសម្តែងព្រះហឫទ័យមេត្តាករុណាមកលើយើងខ្ញុំ
ព្រះជាម្ចាស់ដែលមានព្រះទ័យមេត្តាករុណាត្រូវបានគេនិយាយដូចជាសេចក្ដីមេត្តាករុណាគឺជាមនុស្សម្នាក់
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ជាព្រះនៃយើងបានសម្រេចព្រះហឫទ័យមេត្តាករុណាដល់យើងហើយ»
ព្រះអង្គសម្តែងព្រះហឫទ័យសប្បុរសដល់យើងខ្ញុំ
ព្រះហឫទ័យសប្បុរសត្រូវបានគេនិយាយថា
វាជាវត្ថុមួយដែលមនុស្សម្នាក់អាចកាន់នៅក្នុងដៃរបស់គេ
ហើយទុកឲ្យមនុស្សម្នាក់ផ្សេងទៀតយក។ ការបកប្រែរបៀបផ្សេងទៀត:
«បានផ្តល់ព្រះហឫទ័យសប្បុរសដល់ពួកយើង និងរក្សាសម្ពន្ធមេត្រីរបស់ព្រះអង្គ»
នៅចំពោះព្រះភ័ក្ត្រស្តេចនៃស្រុកពែរ្ស
ព្រះរាជាមិនអាចមើលឃើញព្រះវិហារពិតទេ
ប៉ុន្តែទ្រង់ជ្រាបអំពីអ្វីដែលកំពុងកើតឡើងនៅក្រុងយេរូសាឡិម។ នៅទីនេះ
«ព្រះភ័ក្ត្រ» គឺជាទីសម្គាល់សម្រាប់អ្វីដែលមនុស្សម្នាក់ដឹង។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះស្តេចស្រុកពែរ្សជ្រាបអំពីរឿងនេះ»
ព្រះដំណាក់ព្រះជាម្ចាស់
ព្រះវិហារ
អាចផ្តល់ឲ្យយើងខ្ញុំមានទីជម្រកដ៏រឹងមាំ
កំផែងដែលការពារប្រជាជនឲ្យមានសុវត្ថិភាពគឺជាពាក្យប្រៀបធៀបមួយសម្រាប់ការដែលព្រះអម្ចាស់ការព
ការបកប្រែរបៀបផ្សេងទៀត: «អាចរក្សាឲ្យយើងមានសុវត្ថិភាព»
Ezra 9:10
រៀងរហូតតទៅ
«រហូតដល់ចុងបញ្ចប់នៃអាយុ»
Ezra 9:13
ដោយព្រោះអំពើអាក្រក់ និងកំហុសដ៏ធ្ងន់របស់យើងខ្ញុំ
នាមអរូបី « ប្រព្រឹត្ត» និង «កំហុស» អាចត្រូវបានបកប្រែជានាម
និងគុណនាមរៀងៗខ្លួន។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយសារតែអំពើអាក្រក់ដែលយើងបានប្រព្រឹត្ត
ហើយដោយសារតែយើងមានកំហុសដូច្នេះ»
ឲ្យសមនឹងអំពើទុច្ចរិតរបស់ខ្ញុំឡើយ ហើយដោយបានប្រោសឲ្យយើងខ្ញុំនៅមានជីវិតរស់នៅវិញ
«អ្នកនឹងត្រូវបានគ្រាន់តែ ប្រសិនបើអ្នកបានសម្លាប់យើងទាំងអស់
ប៉ុន្តែអ្នកមិនបានដាក់ទណ្ឌកម្មពួកយើងទេហើយទុកឲ្យពួកយើងខ្លះមានជីវិតនៅរស់»
តើយើងខ្ញុំនឹងបែរទៅប្រព្រឹត្តអំពើរំលងបទបញ្ជារបស់ព្រះអង្គ ... មនុស្ស?
នេះអាចត្រូវបានបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត:
«នេះជាការខុសឆ្គងណាស់
ដែលពួកយើងខ្លះបានបែរទៅប្រព្រឹត្តអំពើរំលងបទបញ្ជារបស់ព្រះអង្គ ... មនុស្ស»។
តើព្រះអង្គមិនមានព្រះពិរោធ ... គេចផុតទេឬ?
នេះអាចត្រូវបានបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំខ្លាចថា
ព្រះអង្គនឹងព្រះពិរោធ ... គេចផុត»។
Ezra 9:15
មើល៍
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងនិយាយ»
យើងខ្ញុំនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ទាំងមានបាប
«អ្នកអាចឃើញថា យើងទាំងអស់គ្នាមានកំហុស»

generated on Wed Sep 10 16:16:32 2025

10 [1]កាលលោកអែសរ៉ាកំពុងអធិស្ឋាន និងលន់តួបាប ទាំងសម្រក់ទឹកភ្នែក ហើយក្រាបនៅមុខព្រះដំណាក់របស់ព្រះជាម្ចាស់។ នោះមានជនជាតិអ៊ីស្រាអែលជាច្រើន
ទាំងប្រុស ទាំងស្រី និងក្មេងៗ នាំគ្នាមកជុំវិញលោក ហើយប្រជាជនក៏យំសោកយ៉ាងខ្លាំង។[2]ពេលនោះ លោកសេកានា ជាកូនរបស់លោកយេហ៊ីអែល
ជាកូនចៅរបស់លោកអេឡាំ ពោលទៅកាន់លោកអែសរ៉ាថា «យើងខ្ញុំបានប្រព្រឹត្តអំពើរំលងទាស់នឹងព្រះរបស់យើងខ្ញុំ ដោយបានរៀបការជាមួយស្ត្រីសាសន៍ដទៃ
ជាប្រជាជនរស់នៅក្នុងទឹកដីនេះ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏ប្រជាជនអ៊ីស្រាអែលនៅតែមានសង្ឃឹម។
[3]ដូច្នេះ សូមឲ្យយើងខ្ញុំចងសម្ពន្ធមេត្រីជាមួយព្រះនៃយើង យើងខ្ញុំនឹងបោះបង់ប្រពន្ធជនជាតិដ៏ទៃ និងកូនទាំងប៉ុន្មានដែលកើតពីស្ត្រីទាំងនោះ
យើងខ្ញុំសុខចិត្តធ្វើតាមចេតនារបស់លោកម្ចាស់ និងអស់អ្នកដែលគោរពកោតខ្លាច ចំពោះបទបញ្ជារបស់ព្រះនៃយើង
ហើយសូមឲ្យការនោះបានសម្រេចតាមក្រឹត្យវិន័យចុះ។[4]សូមលោកក្រោកឡើង ដ្បិតនេះជាកិច្ចការរបស់លោក ហើយយើងខ្ញុំក៏នៅជាមួយលោកដែរ។
សូមមានចិត្តក្លាហានឡើង ហើយសម្រេចកិច្ចការនេះទៅ»។
[5]ពេលនោះ លោកអែសរ៉ាក្រោកឡើង ហើយបង្គាប់ឲ្យមេដឹកនាំពួកបូជាចារ្យ ពួកលេវី ព្រមទាំងមេដឹកនាំជនជាតិអ៊ីស្រាអែលទាំងប៉ុន្មានឲ្យស្បថ
ដើម្បីឲ្យគេធ្វើតាមពាក្យស្បថនោះ។ ដូច្នេះពួកគេក៏នាំគ្នាស្បថ។[6]បន្ទាប់មក លោកអែសរ៉ាបានក្រោកឡើងនៅមុខព្រះដំណាក់របស់ព្រះ
ហើយក៏ចូលក្នុងបន្ទប់របស់លោកយ៉ូហាណាន ដែលជាកូនលោកអេលីយ៉ាស៊ីប។ នៅទីនោះលោកមិនព្រមបរិភោគអាហារ ឬផឹកទឹកឡើយ
ដ្បិតលោកមានចិត្តសោកសង្រេកដោយសារអំពើរំលងរបស់ប្រជាជន ដែលជាប់ជាឈ្លើយហើយវិលមកវិញ។
[7]ដូច្នេះ គេក៏ចេញប្រកាសពាសពេញទឹកដីយូដា និងក្រុងយេរូសាឡឹម ដល់ពួកអ្នកដែលជាប់ជាឈ្លើយ ហើយវិលមកវិញ ឲ្យគេមកជួបជុំគ្នានៅក្រុងយេរូសាឡឹម។
[8]ហើយអ្នកណាមិនព្រមមកក្នុងរយៈពេលបីថ្ងៃ តាមបង្គាប់របស់ពួកមេដឹកនាំ និងព្រឹទ្ធាចារ្យ នោះគេនឹងរឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកនោះ
ហើយអ្នកនោះនឹងត្រូវកាត់ចេញពីក្រុមជុំនំនៃពួកអ្នកដែលជាប់ជាឈ្លើយ ហើយវិលមកវិញទៀតផង។
[9]ដូច្នេះ ពួកប្រុសៗទាំងអស់ក្នុងស្រុកយូដា និងបេនយ៉ាមីន បានមកជួបជុំគ្នានៅក្រុងយេរូសាឡឹមក្នុងអំឡុងពេលបីថ្ងៃ។ នៅថ្ងៃទីម្ភៃ ក្នុងខែប្រាំបួន។
ប្រជាជនទាំងអស់នោះអង្គុយនៅក្នុងទីធ្លា ខាងមុខព្រះដំណាក់របស់ព្រះជាម្ចាស់ ទាំងញាប់ញ័រដោយព្រោះព្រឹត្តិការណ៍នេះ ហើយមានភ្លៀងយ៉ាងធំ។
[10]លោកបូជាចារ្យអែសរ៉ា ក្រោកឈរឡើង មានប្រសាសន៍ទៅគេថា «អ្នករាល់គ្នាបានប្រព្រឹត្តអំពើរំលង ដោយបានរៀបការជាមួយស្ត្រីជនជាតិដ៏ទៃ។
ហើយធ្វើឲ្យជនជាតិអ៊ីស្រាអែលមានទោសកាន់តែច្រើនឡើង។
[11]ដូច្នេះ ចូរលន់តួបាបនៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ជាព្រះនៃបុព្វបុរសរបស់អ្នករាល់គ្នា ហើយប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះអង្គវិញ។
ចូរញែកខ្លួនចេញពីជនជាតិរស់នៅក្នុងស្រុកនោះ និងចេញពីប្រពន្ធជាស្ត្រីជនជាតិដ៏ទៃទៅ»។
[12]ពេលនោះ ក្រុមជុំនំទាំងអស់ក៏ឆ្លើយតប ដោយបន្លឺសំឡេងខ្លាំងៗថា «ពិតមែនហើយ យើងខ្ញុំនឹងធ្វើតាមពាក្យរបស់លោក។[13]ប៉ុន្តែ មានមនុស្សច្រើនណាស់
ហើយនេះក៏ជារដូវភ្លៀងទៀតផង។ យើងខ្ញុំមិនអាចឈរនៅខាងក្រៅបានទេ ហើយនេះក៏មិនមែនជាកិច្ចការដែលអាចសម្រេចបានក្នុងរយៈពេលមួយថ្ងៃ ឬពីរថ្ងៃឡើយ
ដ្បិតយើងខ្ញុំបានប្រព្រឹត្តអំពើរំលងយ៉ាងខ្លាំង។
[14]ដូច្នេះ សូមឲ្យពួកមេដឹកនាំរបស់យើងខ្ញុំ ឈរតំណាងឲ្យក្រុមជុំនំទាំងមូលវិញ។ សូមឲអស់អ្នកដែលរស់នៅតាមទីក្រុងរបស់យើង
ដែលបានយកប្រពន្ធជាស្ត្រីជនជាតិដ៏ទៃ ត្រូវចូលមកបង្ហាញខ្លួនចំពោះមេដឹកនាំនៅថ្ងៃដែលព្រឹទ្ធាចារ្យ និងពួកចៅក្រមនៃក្រុងនីមួយៗបានកំណត់ទុក
យើងខ្ញុំនឹងធ្វើបែបនេះ រហូតទាល់តែព្រះពិរោធរបស់ព្រះនៃយើងខ្ញុំបានស្ងប់»។[15]មានតែលោកយ៉ូណាថាន ជាកូនរបស់លោកអេសាអែល និងលោកយ៉ាហាយ៉ា
ជាកូនរបស់លោកធឹកវ៉ាប៉ុណ្ណោះដែលជំទាស់នឹងការសម្រេចនេះ ហើយមានលោកមស៊ូឡោម និងលោកសាប់ថាយ ជាពួកលេវីបានជួយគាំទ្រអ្នកទាំងពីរ។
[16]បន្ទាប់មក ប្រជាជនដែលជាប់ជាឈ្លើយ ហើយវិលមកវិញ ក៏បានធ្វើដូច្នោះ។ លោកបូជាចារ្យអែសរ៉ាបានជ្រើសរើសបុរសៗ ពីមេក្រុមគ្រួសារក្នុងអំបូរនីមួយៗ
តាមឈ្មោះរបស់ពួកគេរៀងៗខ្លួន អ្នកទាំងនោះចូលរួមពិនិត្យមើលសំណុំរឿង នៅថ្ងៃទីមួយ ក្នុងខែទីដប់។[17]ដោយនៅថ្ងៃទីមួយ ក្នុងខែទីមួយ
គេក៏បានសម្រេចការពិនិត្យមើលសំណុំរឿងដែលបុរសទាំងអស់ ដែលបានរៀបការនឹងស្ត្រីជនជាតិដ៏ទៃនោះ។
[18]ក្នុងចំណោមកូនចៅពួកបូជាចារ្យ ដែលបានរៀបការជាមួយស្ត្រីជនជាតិដ៏ទៃ។ មានកូនចៅលោកយេសួ ជាកូនលោកយ៉ូសាដាក និងបងប្អូនរបស់លោកមាន
លោកអេលាស៊ើរ លោកយ៉ារីប និងលោកកេដាលា។[19]ហើយពួកគេសន្យាថានឹងលែងលះប្រពន្ធរបស់ខ្លួន។ ហើយដោយព្រោះពួកគេមានបាប
ហើយគេថ្វាយចៀមឈ្មោលមួយជាយញ្ញបូជារំដោះបាប។
[20]ក្នុងចំណោមពួកកូនចៅលោកអ៊ីមមើរ គឺលោកហាណានី និងលោកសេបាឌា។[21]ក្នុងចំណោមពួកកូនចៅលោកហារីម គឺលោកម៉ាសេយ៉ា លោកអេលីយ៉ា លោកសេម៉ាយ៉ា
លោកយេហ៊ីអែល និងលោកអ៊ូស៊ីយ៉ា។[22]ក្នុងចំណោមពួកកូនចៅលោកប៉ាសហ៊ើរ គឺលោកអេលីយ៉ូណៃ លោកម៉ាសេយ៉ា លោកអ៊ីស្មាអែល លោកនេថានេល
លោកយ៉ូសាបាដ និងលោកអេឡាសារ។
[23]ក្នុងចំណោមពួកលេវី មានលោកយ៉ូសាបាដ លោកស៊ីម៉ៃ លោកកេឡាយ៉ា- ហៅកេលីថា លោកពេថាហ៊ីយ៉ា យូដានិងលោកអេលាស៊ើរ។
[24]ក្នុងចំណោមពួកអ្នកចម្រៀងមានលោកអេលីយ៉ាស៊ីប។ ក្នុងចំណោមពួកអ្នកយាមទ្វា មានលោកសាលូម លោកថេលែម និងលោកអ៊ូរី។[25]ក្នុងចំណោមជនជាតិអ៊ីស្រាអែល
ក្នុងចំណោមកូនចៅលោកប៉ារ៉ូស មានលោករ៉ាម៉ា លោកយីសយ៉ា លោកម៉ាល់គា លោកមីយ៉ាមីម លោកអេឡាសារ លោកម៉ាល់គា និងលោកបេណាយ៉ា។
[26]ក្នុងចំណោមពួកកូនចៅលោកអេឡាំ មានលោកម៉ាថានា លោកសាការី លោកយេហ៊ីអែល លោកអាប់ឌី លោកយេរេម៉ុត និងលោកអេលីយ៉ា។
[27]ក្នុងចំណោមពួកកូនចៅលោកសាធូ មានលោកអេលីយ៉ូណៃ លោកអេលីយ៉ាហ៊ីប លោកម៉ាថានា លោកយេរេម៉ុត លោកសាបាដ និងលោកអស៊ីសា។
[28]ក្នុងចំណោមពួកកូនចៅលោកបេបៃ មានលោកយ៉ូហាណាន លោកហាណានា លោកសាប់បាយ និងលោកអ័តឡាយ។[29]ក្នុងចំណោមពួកកូនចៅលោកបានីមាន
លោកមស៊ូឡាំ លោកម៉ាលូក លោកអដាយ៉ា លោកយ៉ាស៊ូប លោកស្អាល និងលោករ៉ាម៉ូត។
[30]ក្នុងចំណោមពួកកូនចៅលោកប៉ាហាត់ ម៉ូអាប់ មានលោកអាដណា លោកកេឡាស លោកបេណាយ៉ា លោកម៉ាសេយ៉ា លោកម៉ាថានា លោកបេសាលាល លោកប៊ីនុយ
និងលោកម៉ាណាសេ។[31]ក្នុងចំណោមពួកកូនចៅលោកហារីម មានលោកអេលាស៊ើរ លោកយីសយ៉ា លោកម៉ាល់គា លោកសេម៉ាយ៉ា លោកស៊ីម្មាន[32]លោកបេនយ៉ាមីន
លោកម៉ាលូក និងលោកសេម៉ារីយ៉ា។
[33]ក្នុងចំណោមពួកកូនចៅលោកហាស៊ូម មានលោកម៉ាថ្នាយ លោកម៉ាត់ថាត់ថា លោកសាបាដ លោកអេលីផាលេត លោកយេរេម៉ៃ លោកម៉ាណាសេ និងលោកស៊ីម៉ៃ។
[34]ក្នុងចំណោមពួកកូនចៅលោកបានីមាន លោកម៉ាដាយ លោកអាំរ៉ាម លោកអ៊ូអែល[35]លោកបេណាយ៉ា លោកបេឌីយ៉ា លោកេលូហ៊ូវ[36]លោកវ៉ានីយ៉ា លោកម្រេម៉ុត
លោកអេលីយ៉ាស៊ីប
[37]លោកម៉ាថានា លោកម៉ាថ្នាយ និងលោកយេសាយ។[38]ក្នុងចំណោមពួកកូនចៅលោកប៊ីនុយ មានលោកស៊ីម៉ៃ[39]លោកសេលេមា លោកណាថាន
លោកអដាយ៉ា[40]លោកម៉ាកណាដបៃ លោកសាសៃ លោកសារ៉ៃ
[41]អសារាល លោកសេលេមា លោកសេម៉ារីយ៉ា[42]លោកសាលូម លោកអម៉ារា និងលោកយ៉ូសែប។[43]ក្នុងចំណោមពួកកូនចៅលោកនេបូ មានលោកយីអែល លោកម៉ាធិធា
លោកសាបាដ លោកសេប៊ីណា លោកយ៉ាដៃ លោកយ៉ូអែល និងលោកបេណាយ៉ា។[44]អ្នកទាំងអស់នេះបានរៀបការជាមួយស្ត្រីជនជាតិដ៏ទៃ
ហើយមួយចំនួនមានកូនទៀតផង។

Ezra 10:1
កាលលោកអែសរ៉ាកំពុងអធិស្ឋាន និងលន់តួបាប ... ក្រាបមុខចុះ
លោកអែសរ៉ានិយាយអំពីខ្លួនលោក ដូចជាលោកជាមនុស្សម្នាក់ផ្សេងទៀត។
ផ្តួលខ្លួនរបស់លោកចុះ
បានទម្លាក់ខ្លួនចុះពីការឈរ ទៅជាការដេកផ្កាប់មុខចុះវិញ។
នៅមុខព្រះដំណាក់របស់ព្រះជាម្ចាស់
នៅមុខព្រះវិហារ
លោកសេកានា
បកប្រែដូចនៅក្នុងជំពូកទី ៨:៤។
លោកយេហ៊ីអែល
បកប្រែដូចក្នុងជំពូក ៨:៨។
យើងខ្ញុំបានប្រព្រឹត្តអំពើរំលងទាស់នឹងព្រះរបស់យើងខ្ញុំ
នេះត្រូវបានធ្វើការសារភាពជាសាធារណៈ
មិនមែនជាការអះអាងដោយអំនួតឡើយ។
Ezra 10:3
យើងខ្ញុំក៏នៅជាមួយលោកដែរ
«យើងនឹងជួយលោក»
Ezra 10:5
លោកយ៉ូហាណាន ... លោកអេលីយ៉ាស៊ីប
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Ezra 10:7
ហើយអ្នកណាមិនព្រមមក ... រឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកនោះ
ហើយអ្នកនោះនឹងត្រូវកាត់ចេញ
«ពួកមេដឹកនាំនឹងដកហូតយកទ្រព្យសម្បត្តិទាំងអស់ពីអ្នកណាដែលមិនបានមក ...
ហើយនឹងដោះសា» ឬ «ប្រជាជននៅស្រុកយូដា
និងក្រុងយេរូសាឡិមនឹងដកហូតយកទ្រព្យសម្បត្តិទាំងអស់ពីអ្នកណាដែលមិនបានមក
ហើយនឹងដកពួកគេចេញ»
រយៈពេលបីថ្ងៃ
រយៈពេល ៣ថ្ងៃ
Ezra 10:9
ក្នុងអំឡុងពេលបីថ្ងៃ
«បីថ្ងៃក្រោយមក»
នៅថ្ងៃទីម្ភៃ ក្នុងខែប្រាំបួន
នេះជាខែទីប្រាំបួននៃប្រតិទិនហេប្រឺ។ ថ្ងៃទីម្ភៃ
គឺនៅជិតពាក់កណ្តាលខែធ្នូតាមប្រតិទិនលោកខាងលិច។
នៅក្នុងទីធ្លា
ទីធ្លាបើកចំហធំមួយនៅមុខព្រះវិហារ
ប្រព្រឹត្តអំពើរំលង
នាមអរូបី «ការក្បត់» អាចត្រូវបានបកប្រែជាកិរិយាស័ព្ទ។
ការបកប្រែរបៀបផ្សេងទៀត: «បានជួយសត្រូវរបស់ប្រជាជនរបស់អ្នករាល់គ្នា»
ធ្វើឲ្យជនជាតិអ៊ីស្រាអែលមានទោសកាន់តែច្រើនឡើង
«ឥឡូវនេះព្រះជាម្ចាស់ចាត់ទុកយើងជាមនុស្សមានទោសកាន់តែច្រើនឡើង»។
Ezra 10:11
ចូរញែកខ្លួនចេញពី
ផ្លាស់ទីឲ្យឆ្ងាយពី ខុសគ្នាពី
Ezra 10:12
នេះក៏មិនមែនជាកិច្ចការដែលអាចសម្រេចបានក្នុងរយៈពេលមួយថ្ងៃ ឬពីរថ្ងៃឡើយ
ចំណងជើងនេះអាចត្រូវបានបកប្រែជាទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងត្រូវការពេលវេលាយូរ ដើម្បីធ្វើកិច្ចការទាំងអស់នេះ»
Ezra 10:14
ត្រូវចូលមកបង្ហាញខ្លួនចំពោះមេដឹកនាំនៅថ្ងៃដែលព្រឹទ្ធាចារ្យ
និងពួកចៅក្រមនៃក្រុងនីមួយៗបានកំណត់ទុក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពេលវេលាដែលព្រឹទ្ធាចារ្យ និងចៅក្រមនៃក្រុងនីមួយៗនឹងដោះស្រាយ»
លោកយ៉ូណាថាន ... លោកអេសាអែល ... លោកយ៉ាហាយ៉ា ... លោកធឹកវ៉ា ... លោកមស៊ូឡោ ...
លោកសាប់ថាយ
ឈ្មោះរបស់បុរស
មានតែលោកយ៉ូណាថាន ជាកូនរបស់លោកអេសាអែល និងលោកយ៉ាហាយ៉ា
ជាកូនរបស់លោកធឹកវ៉ាប៉ុណ្ណោះដែលជំទាស់នឹងការសម្រេចនេះ

អាចមានន័យថា ១) បុរសទាំងនេះមិនចង់ឲ្យពួកមេដឹកនាំទីក្រុងស្រាវជ្រាវបទល្មើស
ឬ ២) ពួកគេមិនចង់ឲ្យនរណាម្នាក់ស្រាវជ្រាវអំពីការរៀបការរបស់ប្រជាជនទេ។
Ezra 10:16
ក៏បានធ្វើដូច្នោះ
ប្រជាជនបានស្រាវជ្រាវរក
ថាតើអ្នកណាបានរៀបការជាមួយប្រពន្ធដែលមិនមែនជាជនជាតិយូដា។
នៅថ្ងៃទីមួយ ក្នុងខែទីដប់
នេះជាខែទីដប់ នៃប្រតិទិនហេប្រឺ។
ថ្ងៃទីមួយគឺជិតពាក់កណ្តាលខែធ្នូតាមប្រតិទិនលោកខាងលិច។
ថ្ងៃទីមួយ ក្នុងខែទីមួយ
នេះគឺនៅជិតពាក់កណ្តាលខែមីនានៅលើប្រតិទិនលោកខាងលិច។
Ezra 10:18
លោកយេសួ
សូមបកប្រែដូចនៅក្នុងជំពូកទី ២:១។
លោកយ៉ូសាដាក
សូមបកប្រែដូចនៅក្នុងជំពូកទី ៣:១។
ម៉ាសេយ៉ា ... លោកកេដាលា
ឈ្មោះរបស់មនុស្ស
លោកអេលាស៊ើរ ... លោកយ៉ារីប
សូមបកប្រែដូចនៅក្នុងជំពូកទី ៨:១៥។
Ezra 10:20
ព័ត៌មានទូទៅ:
លោកអែសរ៉ាបន្តចុះបញ្ជីបុរសដែលរៀបការជាមួយស្ត្រីដែលមិនមែនជាជនជាតិយូដា។
លោកអ៊ីមមើរ ... លោកប៉ាសហើរ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៣៦។
លោកហារីម ... លោកអេលីយ៉ូណៃ ... លោកនេថានេល ... លោកអេឡាសារ
ឈ្មោះរបស់មនុស្ស។
លោកសេបាឌា
ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុងជំពូក ៨:៨។
លោកហារីម
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៣១។
លោកម៉ាសេយ៉ា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:១៨។
លោកសេម៉ាយ៉ា ... លោកយេហ៊ីអែល
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:១២។
លោកយ៉ូសាបាដ
ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុងជំពូក ៨:៣៣ ។
Ezra 10:23
ព័ត៌មានទូទៅ:
លោកអែសរ៉ាបន្តចុះបញ្ជីបុរសដែលរៀបការជាមួយស្ត្រីដែលមិនមែនជាជនជាតិយូដា។
លោកយ៉ូសាបាដ
ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុងជំពូក ៨:៣៣ ។
លោកអេលីយ៉ាហ៊ីប
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:៥។
លោកសាលូម
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៤០។
លោកប៉ារ៉ូស
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៣។
លោកអេឡាសារ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៧:១។
Ezra 10:26
ព័ត៌មានទូទៅ:
លោកអែសរ៉ាបន្តចុះបញ្ជីបុរសដែលរៀបការជាមួយស្ត្រីដែលមិនមែនជាជនជាតិយូដា។
លោកអេឡាំ ... លោកសាធូ ... លោកបានី
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៧។
លោកយេហ៊ីអែល
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:៨។
លោកអេលីយ៉ូណៃ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២០។

generated on Wed Sep 10 16:16:32 2025

លោកអេលីយ៉ាហ៊ីប ... លោកយ៉ូហាណាន
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:៥។
លោកបេបៃ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:១១។
លោកយ៉ូហាណាន
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:៥។
លោកមស៊ូឡាំ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:១៥។
Ezra 10:30
ព័ត៌មានទូទៅ:
លោកអែសរ៉ាបន្តចុះបញ្ជីបុរសដែលរៀបការជាមួយស្ត្រីដែលមិនមែនជាជនជាតិយូដា។
លោកប៉ាហាត់ ម៉ូអាប់
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:៤។
លោកបេណាយ៉ា ... លោកម៉ាល់គា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២៣។
លោកម៉ាសេយ៉ា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:១៨។
លោកម៉ាថានា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២៦។
លោកបីនុយ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:៣៣។
លោកហារីម
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៣១។
លោកអេលាសើរ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:១៥។
លោកម៉ាលូក
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២៦។
Ezra 10:33
ព័ត៌មានទូទៅ:
លោកអែសរ៉ានៅតែបន្តចុះបញ្ជីបុរសដែលរៀបការជាមួយស្ត្រីដែលមិនមែនជាជនជាតិយូដា។
លោកហាស៊ូម
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:១៩
លោកសាបាដ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២៦ ។
លោកអេលីផាលេត
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:១២ ។
លោកម៉ាណាសេ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:៣០ ។
លោកស៊ីម៉ៃ ... លោកបេណាយ៉ា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២៣ ។
លោកបានី
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៧ ។
លោកម្រេម៉ុត
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:៣៣។
លោកអេលីយ៉ាស៊ីប
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:៥។
Ezra 10:37
ព័ត៌មានទូទៅ:
លោកអែសរ៉ាបន្តចុះបញ្ជីបុរសដែលរៀបការជាមួយស្ត្រីដែលមិនមែនជាជនជាតិយូដា។
លោកម៉ាថានា ... លោកអដាយ៉ា
ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុងជំពូក ១០:២៦។
លោកម៉ាថ្នាយ
ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុងជំពូក ១០:៣៣។
លោកបីនុយ
ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុងជំពូក ៨:៣៣។
លោកស៊ីម៉ៃ
ឈ្មោះរបស់បុរស។ បកប្រែដូចនៅក្នុងជំពូក ១០:២៣។
Ezra 10:41
ព័ត៌មានទូទៅ:
លោកអែសរ៉ាបានបញ្ចប់បញ្ជីរាយឈ្មោះបុរសដែលរៀបការជាមួយស្ត្រីដែលមិនមែនជាជនជាតិយូដា។
លោកសេលេមា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:៣៧។
លោកសេម៉ារីយ៉ា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:៣០។
លោកសាលូម
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:៤០។
លោកអម៉ារ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៧:១។
លោកនេបូ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ២:២៧។
លោកយីអែល
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៨:១២។
លោកសាបាដ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២៦។
លោកយ៉ាដៃ
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ៥:១។
លោកបេណាយ៉ា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូកទី ១០:២៣។
អ្នកទាំងអស់នេះ
មនុស្សទាំងអស់នៅក្នុងបញ្ជី ចាប់ផ្តើមនៅក្នុងជំពូកទី ១០:២០

នេហេមា

1 [1]នេះជាពាក្យរបស់លោកនេហេមា៖ ជាកូនរបស់លោកហាកាលា នៅខែមិគ្គសិរ ក្នុងឆ្នាំទីម្ភៃ គឺពេលដែលខ្ញុំស្ថិតនៅក្នុងកំផែងក្រុងស៊ូសាន[2]នោះមានបងប្អូនខ្ញុំម្នាក់ ឈ្មោះហាណានី និងអ្នកខ្លះទៀតបានមកពីយូដា ហើយខ្ញុំសួរពួកគេពីដំណើរពួកយូដាដែលបានភៀសខ្លួន គឺពួកអ្នកដែលនៅរួចជីវិតរស់ ចេញពីការជាប់ជាឈ្លើយ និងពីក្រុងយេរូសាឡិមផងដែរ។
[3]ពួកគេបាននិយាយមកខ្ញុំថា៖ «ពួកអ្នកដែលនៅតាមខេត្តនោះ គឺពួកអ្នកដែលរួចជីវិត ពីការជាប់ទោស ដែលកំពុងរងទុក្ខវេទនា និងក្តីអាម៉ាស់ជាខ្លាំង ដោយសារកំផែងក្រុងយេរូសាឡិម ក៏ត្រូវបាក់បែក ហើយទ្វារក្រុងក៏ត្រូវបានគេដុតបំផ្លាញ»។
[4]កាលខ្ញុំបានឮពាក្យទាំងនេះ ខ្ញុំក៏អង្គុយយំ ហើយសោកសៅ អស់រយៈពេលពីរបីថ្ងៃ ទាំងតមអាហារ ហើយអធិស្ឋាននៅចំពោះព្រះនៃស្ថានសួគ៌។[5]ខ្ញុំទូលព្រះអង្គថា៖ « ព្រះអម្ចាស់ ជាព្រះនៃស្ថានសួគ៌ គឺជាព្រះដ៏ធំ ហើយគួរស្ញែងខ្លាច ដែលរក្សាសេចក្តីសញ្ញា និងសេចក្តីស្រលាញ់ ដល់អស់អ្នកដែលស្រឡាញ់ព្រះអង្គ ហើយកាន់តាមបទបញ្ជារបស់ព្រះអង្គ។
[6]សូមព្រះអង្គផ្ទៀងព្រះកាណ៌ ហើយបើកព្រះនេត្រ ដើម្បីស្តាប់ពាក្យអធិស្ឋានរបស់ទូលបង្គំ ជាអ្នកបម្រើព្រះអង្គ ដែលឥឡូវនេះ ទូលបង្គំអធិស្ឋាននៅចំពោះព្រះអង្គទាំងយប់ទាំងថ្ងៃ ពីដំណើរប្រជាជនអ៊ីស្រាអែល ជាអ្នកបម្រើព្រះអង្គ ដោយលន់តួអំពើបាបរបស់ប្រជាជនអ៊ីស្រាអែល ដែលយើងខ្ញុំបានប្រព្រឹត្តទាស់នឹងព្រះអង្គ។ ទូលបង្គំ និងក្រុមគ្រួសាររបស់ឪពុកទូលបង្គំក៏បានប្រព្រឹត្តអំពើបាបដែរ។[7]យើងខ្ញុំបានប្រព្រឹត្តនឹងព្រះអង្គយ៉ាងអាក្រក់ជាខ្លាំង ហើយយើង ឥតកាន់តាមបទបញ្ជា ច្បាប់ បញ្ញត្តិដែលព្រះអង្គ នឹងសេចក្តីបង្គាប់នៃព្រះអង្គ តាមរយៈលោកម៉ូសេ ជាអ្នកបម្រើព្រះអង្គ។
[8]សូមព្រះអង្គនឹកចាំពីព្រះបន្ទូល ដែលព្រះអង្គបានបង្គាប់មកលោកម៉ូសេ ជាអ្នកបម្រើព្រះអង្គថា បើអ្នករាល់គ្នាមិនស្មោះត្រង់ យើងនឹងកម្ចាត់កម្ចាយអ្នករាល់គ្នាឲ្យទៅនៅក្នុងចំណោមជនជាតិទាំងឡាយ តែបើអ្នករាល់គ្នាត្រឡប់មករកយើងវិញ ហើយកាន់ និងប្រព្រឹត្តតាមបទបញ្ជារបស់យើង នោះទោះបើពួកនិរទេសរបស់អ្នកបានខ្ចាត់ខ្ចាយទៅនៅដល់ជើងមេឃបំផុតក៏ដោយ ក៏យើងនឹងប្រមូលគេពីទីនោះ ហើយនាំគេមកឯកន្លែងដែលយើងបានជ្រើសរើស ដើម្បីឲ្យឈ្មោះរបស់យើងតាំងជាប់នៅទីនោះ។

generated on Wed Sep 10 16:16:32 2025

[10]ឥឡូវនេះពួកគេគឺជាអ្នកបម្រើ និងប្រជារាស្ត្រដែលព្រះអង្គបានរំដោះ ដោយព្រះចេស្តាដ៏អស្ចារ្យ និងដោយព្រះហស្តដ៏ខ្លាំងពូកែ។[11]ព្រះអម្ចាស់អើយ សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យអធិស្ឋានរបស់ទូលបង្គំ និងពាក្យអធិស្ឋានរបស់ពួកអ្នកបម្រើព្រះអង្គ ដែលពេញចិត្តនឹងកោតខ្លាចដល់ព្រះនាមរបស់ព្រះអង្គ។ សូមប្រោសប្រទានឲ្យទូលបង្គំមានជោគជ័យនៅថ្ងៃនេះ ហើយសូមប្រោសមេត្តាដល់ទូលបង្គំ នៅចំពោះមនុស្សនេះផង»។ នៅគ្រានោះ ខ្ញុំជាអ្នកថ្វាយពែងដល់ស្តេច។

Nehemiah 1:1

នេហេមា ហាកាលា ហាណានី

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

នៅខែមិគ្គសិរ

«ខែមិគ្គសិរ» គឺជាខែទី៩ នៃប្រតិទិនរបស់ជនជាតិហេប្រឺ។

នេះគឺជាកំឡុងពេលចុងក្រោយនៃខែវិច្ឆិកា

និងផ្នែកដំបូងនៃដើមខែធ្នូតាមប្រតិទិនលោកខាងលិច។

ក្នុងឆ្នាំទីម្ភៃ

លោកនេហេមាគឺសំដៅទៅលើចំនួនឆ្នាំដែលអ័ថាស៊ើកសេសសោយរាជ្យជាស្តេច។

ការបកប្រែរបៀបផ្សេងទៀត: «នៅឆ្នាំទីម្ភៃ នៃរជ្ជកាលរបស់អាថាស៊ើកសេស ស្តេចនៃពើស៊ី»

បន្ទាយទីក្រុងស៊ូសាន

នេះគឺជាទីក្រុងមួយរបស់ស្តេចនៃចក្រភពពើស៊ី

ដែលមានទីតាំងស្ថិតនៅក្នុងប្រទេសអេឡាំ។ នេះជាទីក្រុងដែលមានកំពែងរឹងមាំ និងមានកំពែងខ្ពស់ព័ទ្ធជុំវិញ។

បងប្អូនរបស់ខ្ញុំម្ចាក់ លោកហាណានី

លោកហាណានីជាបងប្អូនប្រុសបង្កើតរបស់លោកនេហេមា។

លោកហាណានីបានមកពីស្រុកយូដាជាមួយអ្នកផ្សេងទៀត

«លោកហាណានីបានមកពីស្រុកយូដាជាមួយនឹងអ្នកផ្សេងទៀត»

ពួកយូដាដែលបានភៀសខ្លួន ជនជាតិយូដាដែលនៅសេសសល់នៅទីនោះ

ឃ្លាទាំងពីរនេះគឺសំដៅទៅលើក្រុមមនុស្សតែមួយ។ វាអាចមានអត្ថន័យតែ១) ជនជាតិយូដាមួយចំនួនដែលត្រូវបានគេនិរទេសទៅបាប៊ីឡូនប៉ុន្តែបានរត់គេចខ្លួនហើយ ឬ ២) ជនជាតិយូដាមួយចំនួនដែលបានរត់គេចពីពួកអ្នកដែលប៉ុនប៉ងនាំពួកគេទៅជាឈ្លើយ ហើយដូច្នេះមានអ្នកនៅសល់នៅក្រុងយេរូសាឡិម។

ដោយសារមិនច្បាស់ពីកន្លែងដែលពួកគេបានរត់គេចខ្លួន

វាជាការល្អបំផុតដែលមិនត្រូវបញ្ជាក់នៅក្នុងការបកប្រែ។ ការបកប្រែរបៀបផ្សេងទៀត៖

«ជនជាតិយូដាដែលបានរត់គេចពីការនិរទេស

និងអ្នកដែលនៅសល់ក្នុងក្រុងយេរូសាឡិម»

Nehemiah 1:3

ពួកគេបាននិយាយមកខ្ញុំ

ពាក្យ «ពួកគេ» សំដៅទៅលើលោកហាណានី

និងអ្នកផ្សេងទៀតដែលមកពីស្រុកយូដា។

អ្នកខេត្ត

ពាក្យ «ខេត្ត» សំដៅទៅលើស្រុកយូដានៅក្រោមការគ្រប់គ្រងរបស់ចក្រភពពើស៊ី។

ការបកប្រែរបៀបផ្សេងទៀត: «ស្រុកយូដា» ឬ «យូដា»

កំពែងក្រុងយេរូសាឡិមបានបាក់បែក ហើយទ្វារក្រុងក៏ត្រូវបានគេដុតបំផ្លាញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«កងទ័ពបានបំបែកកំពែងក្រុងយេរូសាឡិមហើយបានដុតទ្វារក្រុង»

Nehemiah 1:4

ខ្ញុំទូលព្រះអង្គថា

លោកនេហេមាទូលពីអ្វីដែលលោកបានអធិស្ឋាន។ ការបកប្រែរបៀបផ្សេងទៀត:

«ហើយខ្ញុំទូលព្រះអង្គថា»

អ្នកណាដែលស្រឡាញ់ព្រះអង្គ ហើយកាន់តាមបទបញ្ជារបស់ព្រះអង្គ

ចាប់តាំងពីពេលដែលលោកនេហេមាទូលទៅកាន់ព្រះអម្ចាស់ សព្វនាម «គាត់» និង «របស់គាត់» អាចបកប្រែបានដូចជា «ព្រះអង្គ» និង «របស់ព្រះអង្គ»។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកណាដែលស្រឡាញ់ព្រះអង្គ ហើយកាន់តាមបទបញ្ជារបស់ព្រះអង្គ»

Nehemiah 1:6

សូមបើកព្រះនេត្ររបស់ព្រះអង្គ

លោកនេហេមានិយាយថា:

ប្រសិនបើព្រះជាម្ចាស់យកចិត្តទុកដាក់នឹងលោកនៅពេលលោកអធិស្ឋានហាក់ដូចជាព្រះអង្គ

ការបកប្រែរបៀបផ្សេងទៀត: «សូមមើលមកខ្ញុំ» ឬ «យកចិត្តទុកដាក់ចំពោះខ្ញុំ»

ដូច្នេះព្រះអង្គនឹងឮសេចក្តីអធិស្ឋានរបស់អ្នកបម្រើរបស់ព្រះអង្គ

ដូច្នេះសូមឲ្យព្រះអង្គបានផ្ទៀងព្រះកាណ៌ស្តាប់សេចក្តីអធិស្ឋានដែលទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គកំពុង

«ពាក្យថា» «អ្នកបម្រើ» សំដៅទៅលោកនេហេមា។

នេះជារបៀបដែលមនុស្សម្នាក់អាចនិយាយទៅកាន់ចៅហ្វាយរបស់គេដើម្បីបង្ហាញពីភាពបន្ទាបខ្លួន និងការគោរព។

ថ្ងៃ និង យប់

ដោយនិយាយដូច្នេះ លោកអធិស្ឋានទាំងពេលថ្ងៃ និងពេលយប់

លោកនេហេមាសង្កត់ធ្ងន់ទៅលើភាពញឹកញាប់នៃការអធិស្ឋានរបស់លោក។

ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ពេលវេលា»

ទូលបង្គំ និងក្រុមគ្រួសាររបស់ឪពុកទូលបង្គំ

ពាក្យថា «អ្នកផ្ទះ» សំដៅទៅលើគ្រួសារ។ ការបកប្រែរបៀបផ្សេងទៀត៖ «ទូលបង្គំ និងក្រុមគ្រួសាររបស់ឪពុកទូលបង្គំ»

Nehemiah 1:8

ខ្លឹមសារភ្ជាប់៖

លោកនេហេមាបន្តអធិស្ឋានទៅកាន់ព្រះអម្ចាស់។

សូមនឹកចាំ

ពាក្យថា «នឹកចាំ» គឺជាប្រយោគដែលមានន័យថាចងចាំ។

ការបកប្រែរបៀបផ្សេងទៀត: «សូមចងចាំ»

ព្រះអង្គបានបង្គាប់មកលោកម៉ូសេ

សព្វនាម «អ្នក» និង «របស់អ្នក» សំដៅទៅព្រះជាម្ចាស់។

ប្រសិនអ្នកប្រព្រឹត្តមិនស្មោះត្រង់... កម្ចាត់កម្ចាយអ្នក... ប្រសិនបើអ្នក... ត្រឡប់មកវិញ...

មនុស្សរបស់អ្នក

[illegible]

និងសំដៅទៅលើប្រជាជនអ៊ីស្រាអែល។

[illegible]

ព្រះអម្ចាស់មានព្រះបន្ទូលអំពីការធ្វើឲ្យជនជាតិអ៊ីស្រាអែលរស់នៅជាតិសាសន៍ឯទៀតៗដូចព្រះអង្គបានកំ

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងឲ្យអ្នករស់នៅក្នុងចំណោមប្រជាជាតិនានា»

ទោះបីប្រជាជនរបស់អ្នកត្រូវខ្ចាត់ខ្ចាយក៏ដោយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ទោះបីជាជាខ្ញុំធ្វើឲ្យមនុស្សរបស់អ្នកបានខ្ចាត់ខ្ចាយ»

នៅក្រោមមេឃឆ្ងាយបំផុត

ព្រះអម្ចាស់មានព្រះបន្ទូលអំពីកន្លែងនានានៅលើផែនដីដែលនៅឆ្ងាយ

«នៅក្រោមមេឃឆ្ងាយបំផុត» ការបកប្រែរបៀបផ្សេងទៀត: «កន្លែងដ៏សែនឆ្ងាយ»

ទៅក្រុងយេរូសាឡិមជាកន្លែងដែលខ្ញុំបានជ្រើសរើស ... នៅដដែល

ឃ្លានេះនេះគឺសំដៅទៅក្រុងយេរូសាឡិម ជាទីតាំងនៃប្រាសាទនោះ។

ការបកប្រែរបៀបផ្សេងទៀត:

«ទៅក្រុងយេរូសាឡិមជាកន្លែងដែលខ្ញុំបានជ្រើសរើស ... នៅដដែល»

កន្លែងដែលយើងបានជ្រើសរើស ដើម្បីឲ្យឈ្មោះរបស់យើងតាំងជាប់នៅទីនោះ

ពាក្យ «ឈ្មោះ» គឺសំដៅទៅលើព្រះអម្ចាស់ផ្ទាល់។ ការបកប្រែរបៀបផ្សេងទៀត:

«ន្លែងដែលយើងបានជ្រើសរើសដើម្បីរស់នៅ»

Nehemiah 1:10

ព័ត៌មានទូទៅ៖

លោកនេហេមាបន្តអធិស្ឋាន។

ឥឡូវ

ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការសំរាកនៅក្នុងការអធិស្ឋានរបស់លោកនេហេមា។

នៅទីនេះលោកចាប់ផ្តើមធ្វើសំណើររបស់លោកដោយផ្អែកលើការសន្យារបស់ព្រះអម្ចាស់។

ពួកគេគឺជាអ្នកបម្រើរបស់អ្នក

ពាក្យ «ពួកគេ» សំដៅទៅលើជនជាតិអ៊ីស្រាអែល។

ដោយព្រះចេស្តាដ៏អស្ចារ្យ និងដោយព្រះហស្តដ៏ខ្លាំងពូកែ

ពាក្យ «ព្រះហស្ត» តំណាងឲ្យកម្លាំង ឬអំណាច។

រួមគ្នាឃ្លាទាំងពីរនេះគឺចង់សង្កត់ធ្ងន់ទៅលើអំណាចរបស់ព្រះអម្ចាស់។

ការបកប្រែរបៀបផ្សេងទៀត៖ «ដោយព្រះចេស្តាដ៏អស្ចារ្យ និងដោយព្រះហស្តដ៏ខ្លាំង [illegible]

ពាក្យអធិស្ឋានរបស់អ្នកបម្រើព្រះអង្គ

ពាក្យ «អ្នកបម្រើ» សំដៅទៅលើលោកនេហេមា។

generated on Wed Sep 10 16:16:32 2025

នេះជារបៀបដែលមនុស្សម្នាក់អាចនិយាយទៅកាន់ចៅហ្វាយរបស់គេ
ដើម្បីបង្ហាញពីភាពបន្ទាបខ្លួន និងការគោរព។
សូមមើលពីរបៀបបកប្រែក្នុងជំពូក១:៦។
ពាក្យអធិស្ឋានរបស់ពួកអ្នកបម្រើព្រះអង្គ
ពាក្យថា «អ្នកបម្រើ» គឺសំដៅទៅលើជនជាតិអ៊ីស្រាអែល
ដែលបានទូលសូមទៅព្រះអម្ចាស់ឲ្យធ្វើអ្វីមួយនៅក្នុងនាមរបស់ប្រជាជនរបស់ព្រះអង្គ
និងក្នុងនាមយេសរូសាឡិម។
អ្នកដែលពេញចិត្តនឹងកោតខ្លាចដល់ព្រះនាមរបស់ព្រះអង្គ
ពាក្យ «ឈ្មោះ» គឺសំដៅទៅលើព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលពេញចិត្តនឹងកោតខ្លាចដល់ព្រះនាមរបស់ព្រះអង្គ»
សូមប្រោសមេត្តាដល់ទូលបង្គំ នៅចំពោះមនុស្សនេះផង
ពាក្យ «លោក» គឺសំដៅទៅចំពោះលោកនេហេមា
ដែលសំដៅទៅលើខ្លួនលោកនៅក្នុងសព្វនាមទីបី
ដើម្បីបង្ហាញពីការបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់ ហើយ «មនុស្សនេះ»
គឺសំដៅទៅចំពោះអើថាស៊ើកសេស ស្តេចនៃស្រុកពើស៊ី។
នៅគ្រានោះ
លោកនេហេមានិយាយអំពីអាកប្បកិរិយា
ឬឥរិយាបថរបស់ស្តេចដូចជារបៀបដែលស្តេចមានទស្សនៈ។
ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះរាជាមេត្តាប្រណីដល់ទូលបង្គំ»
ខ្ញុំជាអ្នកថ្វាយពែងដល់ស្តេច
នេះជាជីវប្រវត្តិអំពីតួនាទីរបស់នេហេមាក្នុងរាជវាំង។
ភាសារបស់អ្នកអាចមានវិធីពិសេសដើម្បីសម្គាល់ពាក្យជីវប្រវត្តិ។

---

2 [1]នៅខែចេត្រ ក្នុងឆ្នាំទីម្ភៃ ក្នុងរជ្ជកាលព្រះបាទអើថាស៊ើកសេស ក្នុងពេលដែលមានស្រាទំពាំងបាយជូរដាក់នៅចំពោះស្តេច នោះខ្ញុំបានលើកស្រាថ្វាយស្តេច។ ពីមុនមក
ខ្ញុំមិនធ្លាប់មានទឹកមុខក្រៀមក្រំនៅចំពោះស្តេចឡើយ។[2]ប៉ុន្តែ ស្តេចមានព្រះបន្ទូលសួរខ្ញុំថា៖ «ហេតុអ្វីបានជាមានទឹកមុខក្រៀមក្រំដូច្នេះ? អ្នកឥតមានឈឺអ្វីសោះ។ នេះ
គ្មានអ្វីក្រៅពីមានទុក្ខព្រួយនៅក្នុងចិត្តឡើយ»។ ពេលនោះ ខ្ញុំភ័យខ្លាចណាស់។
[3]ខ្ញុំថ្លែងទៅកាន់ស្តេចថា៖ «សូមឲ្យព្រះករុណាមានព្រះជន្មគង់នៅជាដរាបតរៀងទៅ តើមិនឲ្យទូលបង្គំមានទឹកមុខក្រៀមក្រំម្តេចបាន? បើទីក្រុងជាកន្លែងដែលមានផ្នូរ
បុព្វបុរសរបស់ទូលបង្គំ នៅតែបាក់បែក ហើយទ្វារក្រុងក៏ត្រូវបំផ្លាញដោយភ្លើងដែរ»។
[4]បន្ទាប់មកព្រះរាជាមានរាជឱង្ការមកខ្ញុំថា៖ «តើលោកចង់ឲ្យយើងធ្វើអ្វី?» ដូច្នេះ ខ្ញុំក៏អធិស្ឋានដល់ព្រះនៃស្ថានសួគ៌។[5]ខ្ញុំក៏តបនឹងស្តេចថា «ប្រសិនបើព្រះករុណាសព្វ
ព្រះហឫទ័យ ហើយបើព្រះអង្គប្រណីសន្តោសដល់ទូលបង្គំ នោះសូមព្រះករុណាចាត់ទូលបង្គំឲ្យទៅស្រុកយូដា គឺទៅទីក្រុងដែលមានផ្នូរបុព្វបុរសរបស់ទូលបង្គំ ដើម្បីឲ្យ
ទូលបង្គំសង់កំផែងនោះឡើងវិញ»។[6]ព្រះរាជាមានរាជឱង្ការមកខ្ញុំ (ទាំងមានអគ្គមហេសីគង់នៅក្បែរផង) «តើលោកត្រូវការរយៈពេលប៉ុន្មាន ហើយពេលណាទើបលោក
ត្រឡប់មកវិញ?» ដូច្នេះ កាលខ្ញុំបានកំណត់ពេលរួចហើយ ស្តេចក៏សព្វព្រះហឫទ័យចាត់ខ្ញុំឲ្យទៅ។
[7]បន្ទាប់មក ខ្ញុំបានទូលទៅស្តេចថា៖ «ប្រសិនបើព្រះករុណាសព្វព្រះហឫទ័យ សូមប្រទានរាជសារឲ្យទូលបង្គំ យកទៅជូនអស់លោកអភិបាលខេត្តនៅខាងនាយទន្លេ ដើម្បី
ឲ្យលោកទាំងនោះអនុញ្ញាតឲ្យទូលបង្គំធ្វើដំណើរឆ្លងកាត់ រហូតដល់ស្រុកយូដា។[8]នោះគឺជារាជសារមួយច្បាប់ទៀតជូនលោកអេសាភ ដែលជាមេព្រៃរបស់ព្រះករុណា ដើម្បី
ឲ្យគាត់ផ្តល់ឈើមកទូលបង្គំធ្វើធ្នឹមទ្វារបន្ទាយ ដែលនៅក្បែរព្រះវិហារ និងសម្រាប់ធ្វើកំផែងទីក្រុង ហើយសម្រាប់ធ្វើផ្ទះ ដែលទូលបង្គំត្រូវស្នាក់នៅផង»។
ដោយព្រោះតែព្រះហស្តដ៏ល្អរបស់ព្រះបានសណ្ឋិតលើខ្ញុំ ស្តេចក៏អនុញ្ញាតឲ្យ តាមសំណូមពររបស់ខ្ញុំ។
[9]ខ្ញុំបានទៅជួបអស់លោកអភិបាលខេត្តនានានៅខាងនាយទន្លេ ហើយជូនរាជសាររបស់ស្តេចដល់ពួកលោក។ គ្រានោះ ស្តេចបានចាត់ពួកមេទ័ព និងពលសេះ ឲ្យទៅជា
មួយខ្ញុំដែរ។[10]នៅពេលលោកសានបាឡាត ជាអ្នកស្រុកហូរ៉ូណែម និងថូប៊ីយ៉ា ជាមន្ត្រីសាសន៍អាំម៉ូន បានឮដំណឹងនេះ ពួកគេមិនពេញចិត្តយ៉ាងខ្លាំងដែលមានអ្នកណា
ម្នាក់មករកផលប្រយោជន៍ជួយដល់ជនជាតិអ៊ីស្រាអែល។
[11]ដូច្នេះ ខ្ញុំបានមកដល់ក្រុងយេរូសាឡិម ហើយនៅទីនោះរយៈពេលបីថ្ងៃ។[12]ខ្ញុំក្រោកឡើងនៅពេលយប់ ហើយខ្ញុំបាននាំមនុស្សមួយចំនួនទៅជាមួយខ្ញុំ។ ខ្ញុំមិនបានប្រាប់អ្នក
ណាម្នាក់ពីអ្វីដែលព្រះជាម្ចាស់របស់ខ្ញុំ បានដាក់ក្នុងចិត្តខ្ញុំឲ្យធ្វើសម្រាប់ក្រុងយេរូសាឡិមឡើយ។ គ្មានសត្វណានៅជាមួយខ្ញុំឡើយ គឺមានតែសត្វមួយដែលខ្ញុំ
កំពុងជិះតែប៉ុណ្ណោះ។
[13]ខ្ញុំបានចេញទៅទាំងយប់ តាមទ្វារជ្រលងភ្នំ ឆ្ពោះទៅអណ្តូងនាគ និងទ្វារអាចម៍សត្វ ហើយបានពិនិត្យមើលកំផែងក្រុងយេរូសាឡិមដែលបាក់បែកនិងបើកចំហរ
ហើយនិងទ្វារក្រុងដែលធ្វើពីឈើ គឺត្រូវបានបំផ្លាញដោយភ្លើងឆេះ។[14]បន្ទាប់មក ខ្ញុំបានបន្តដំណើរទៅដល់ទ្វារនៃប្រភពទឹក ហើយនិងស្រះរបស់ស្តេច។
ប៉ុន្តែកន្លែងនោះតូចចង្អៀតធ្វើឲ្យសត្វដែលខ្ញុំជិះពិបាកដើរឆ្លងកាត់។
[15]ដូច្នេះ ខ្ញុំក៏ឡើងទៅតាមជ្រោះទាំងយប់ ហើយពិនិត្យមើលកំផែង រួចខ្ញុំត្រឡប់ក្រោយ ចូលតាមទ្វារជ្រលងភ្នំ ហើយក៏វិលមកវិញ។[16]ចំណែកពួកអ្នកគ្រប់គ្រងទីក្រុងពុំបាន
ដឹងថាខ្ញុំទៅណា ឬបានធ្វើអ្វីទេ ហើយខ្ញុំមិនបានប្រាប់ពួកយូដា ពួកសង្ឃ ឬពួកអភិជន ពួកអ្នកគ្រប់គ្រង ឬពួកអ្នកឯទៀតដែលត្រូវបំពេញកិច្ចការនោះឡើយ។
[17]ខ្ញុំនិយាយទៅពួកគេថា៖ «អ្នករាល់គ្នាឃើញបញ្ហាអាក្រក់របស់ពួកយើងស្រាប់ហើយថា ក្រុងយេរូសាឡិមនៅតែបែកបាក់ ហើយទ្វារក្រុងត្រូវភ្លើងឆេះអស់ដែរ។ ចូរយើងនាំ
គ្នាមក សង់កំផែងក្រុងយេរូសាឡិមឡើងវិញ ដូច្នេះ យើងនឹងមិនមានភាពអាម៉ាស់ទៀតឡើយ»។[18]រួចខ្ញុំបានប្រាប់គេពីព្រះហស្តដ៏ល្អរបស់ព្រះជាម្ចាស់នៃខ្ញុំ ដែលសណ្ឋិត
លើខ្ញុំ និងពាក្យដែលស្តេចមានរាជឱង្ការមកកាន់ខ្ញុំ។ ពួកគេក៏ពោលឡើងថា៖ «ចូរយើងក្រោកឡើង ហើយនាំគ្នាសង់» ដូច្នេះ គេក៏ចម្រើនកម្លាំងគ្នាសម្រាប់កិច្ចការដ៏ប្រពៃ
នោះ។
[19]ប៉ុន្តែ ពេលដែលសានបាឡាត ជាអ្នកស្រុកហូរ៉ូណែម និងថូប៊ីយ៉ា ជាមន្ត្រីសាសន៍អាំម៉ូន ហើយកេសែម ជាសាសន៍អារ៉ាប់ បានឮដំណឹងនេះ ពួកគេនាំគ្នាសើចចំអក
ហើយរិះគន់យើងថា៖ «តើអ្នករាល់គ្នាកំពុងធ្វើអ្វីហ្នឹង? តើអ្នករាល់គ្នាចង់បះបោរប្រឆាំងនឹងព្រះរាជាឬ?»[20]បន្ទាប់មកខ្ញុំក៏ឆ្លើយតបទៅគេថា៖ «ព្រះនៃស្ថានសួគ៌នឹងផ្តល់ឲ្យ
ពួកយើងឲ្យនូវជ័យជម្នះ។ ពួកយើងជាអ្នកបម្រើរបស់ព្រះអង្គ ហើយយើងនឹងក្រោកឡើងនាំគ្នាសាងសង់។ ប៉ុន្តែអ្នករាល់គ្នាវិញ គ្មានចំណែក គ្មានសិទ្ធិ ឬគុណបំណាច់អ្វី
នៅក្រុងយេរូសាឡិមឡើយ»។

Nehemiah 2:1
នៅខែចេត្រ
«ខែចេត្រ» គឺជាឈ្មោះខែដំបូងនៃប្រតិទិនហេប្រឺ។
ក្នុងឆ្នាំទីម្ភៃ ក្នុងរជ្ជកាលព្រះបាទអើថាស៊ើកសេស
«ក្នុងឆ្នាំទីម្ភៃ ដែលអើថាស៊ើកសេសគឺជាស្តេច»
ក្នុងពេលនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់។
នៅទីនេះលោកនេហេមាប្រាប់ពីសាវតានៃឥរិយាបទរបស់លោកនៅចំពោះព្រះភក្ត្រស្តេច
ប៉ុន្តែ ស្តេច
«ដូច្នេះស្តេច»
ហេតុអ្វីបានជាមានទឹកមុខក្រៀមក្រំ
នៅទីនេះគឺសំដៅពីទឹកមុខរបស់លោកនេហេមា
ដោយព្រោះមុខរបស់លោកបានបង្ហាញពីអារម្មណ៍មួយ។
ការបកប្រែរបៀបផ្សេងទៀត: «ហេតុអ្វីបានជាមានទឹកមុខក្រៀមក្រំ»
គ្មានអ្វីក្រៅពីមានទុក្ខព្រួយនៅក្នុងចិត្តឡើយ
នេះនិយាយអំពីលោកនេហេមាកំពុងសោកសៅហាក់ដូចជាចិត្តរបស់លោកក្រៀមក្រំព្រោះបេះដូងត្រូវបាន
ពេលនោះ ខ្ញុំភ័យខ្លាចណាស់
នៅពេលនេះលោកហេមាត្រៀមឆ្លើយ
ហើយលោកខ្លាចព្រោះលោកមិនដឹងថាតើស្តេចនឹងឆ្លើយតបយ៉ាងដូចម្តេច។
Nehemiah 2:3
សូមឲ្យព្រះករុណាមានព្រះជន្មគង់នៅជាដរាបតរៀងទៅ
លោកនេហេមាកំពុងផ្តល់កិត្តិយសដល់ស្តេចអើថាស៊ើកសេស។ ពាក្យ
«ជារៀងរហូត» គឺជាការបំផ្លើសមួយដែលសំដៅទៅលើការអាយុវែង។
ការបកប្រែរបៀបផ្សេងទៀត៖ «ព្រះករុណាមានជន្មវែង» ឬ «សូមឲ្យព្រះករុណា
មានព្រះជន្មគង់នៅជាដរាបតរៀងទៅ!»
តើមិនឲ្យទូលបង្គំមានទឹកមុខក្រៀមក្រំម្តេចបាន?

generated on Wed Sep 10 16:16:32 2025

លោកនេហេមាប្រើសំនួរនេះដើម្បីទូលស្តេចថាលោកមានហេតុផលដ៏គួរឲ្យសោកសៅ។ នេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែរបៀបផ្សេងទៀត៖ «ខ្ញុំមានហេតុផលសាកសមដែលគួរឲ្យសោកសៅ»។
កន្លែងដែលមានផ្នូរបុព្វបុរសរបស់ទូលបង្គំ
«កន្លែងបញ្ចុះសពដូនតាខ្ញុំ»
ទ្វារក្រុងក៏ត្រូវបំផ្លាញដោយភ្លើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ទ្វារក្រុងត្រូវបានឆេះដោយភ្លើង» ឬ «សត្រូវរបស់យើហបានដុតបំផ្លាញទ្វាក្រុង»
Nehemiah 2:4
ខ្ញុំក៏បានទូលទៅព្រះរាជា
«បន្ទាប់មកខ្ញុំបានឆ្លើយតបទៅព្រះរាជាវិញ»
ទូលបង្គំ
លោកនេហេមាសំដៅលើខ្លួនលោកតាមរបៀបនេះ ដើម្បីបង្ហាញការចុះចូលរបស់លោកចំពោះព្រះរាជា។
បើព្រះករុណាសព្វព្រះហឫទ័យ
សព្វព្រះហឫទ័យគឺតំណាងឲ្យការវិនិច្ឆ័យ ឬការវាយតម្លៃ។ ការបកប្រែរបៀបផ្សេងទៀត: «ក្នុងការវិនិច្ឆ័យរបស់ព្រះករុណា»
ទីក្រុងដែលមានផ្នូរបុព្វបុរសរបស់ទូលបង្គំ
«ទីក្រុងដែលដូនតាខ្ញុំត្រូវបានគេបញ្ចុះ»
ទូលបង្គំនឹងសាងសង់ឡើងវិញ
លោកនេហេមាមិនមានគម្រោងសាងសង់កំពែងទាំងអស់ដោយខ្លួនឯងទេ តែលោកនឹងក្លាយជាអ្នកដឹកនាំនៃកិច្ចការនេះ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំ និងមនុស្សរបស់ខ្ញុំនឹងសាងសង់វា»
Nehemiah 2:7
សូមប្រទានរាជសារឲ្យទូលបង្គំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះករុណាប្រទានរាជសារឲ្យទូលបង្គំ»
ខេត្តនៅខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលនៅខាងលិចទន្លេអឺប្រាត។ វាបានឆ្លងកាត់ទន្លេពីទីក្រុងស៊ូសា។
អេសាភ
នេះគឺជាឈ្មោះរបស់មនុស្ស។
ព្រះហស្តដ៏ល្អរបស់ព្រះបានសណ្ឋិតលើខ្ញុំ
«ព្រះហស្តដ៏ល្អ» នៃព្រះជាម្ចាស់សំដៅទៅលើការ «ការសព្វព្រះទ័យ» របស់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់សព្វព្រះហឫទ័យមកលើខ្ញុំ»
Nehemiah 2:9
លោកសានបាឡាត ជាអ្នកស្រុកហូរ៉ូណែម និងថូប៊ីយ៉ា
សាន់បាឡាតគឺជាឈ្មោះរបស់បុរសម្នាក់ហើយហោហូណុសគឺជាក្រុមមនុស្ស។
ថូប៊ីយ៉ា ជាមន្ត្រីសាសន៍អាំម៉ូន
បុរសនេះទំនងជាជាទាសករដែលបានដោះលែងឥឡូវកំពុងបម្រើជាមន្ត្រីនៅអាំម៉ូន។
បានឮដំណឹងនេះ
«បានឮថាខ្ញុំបានមកដល់» (UDB)
Nehemiah 2:11
បានដាក់ក្នុងចិត្តខ្ញុំ
នេះគឺជា «ដួងចិត្ត» របស់លោកនេហេមា សំដៅទៅលើគំនិតនិងបំណងប្រាថ្នារបស់លោក។ ការបកប្រែរបៀបផ្សេងទៀត: «បានបំផុសគំនិតខ្ញុំ» ឬ «បានដឹកនាំខ្ញុំ»
គ្មានសត្វណានៅជាមួយខ្ញុំ
«គ្មានសត្វណានៅជាមួយខ្ញុំ»
Nehemiah 2:13
ព័ត៌មានទូទៅ៖
បុរសពីរបីនាក់បានអមដំណើរលោកនេហេមាក្នុងការត្រួតពិនិត្យនេះ ប៉ុន្តែលោកនិយាយនៅក្នុងមនុស្សទីមួយពីព្រោះលោកជាមនុស្សសំខាន់។ (សូមមើល៖figs-123person)
ខ្ញុំបានចេញទៅទាំងយប់ តាមទ្វារជ្រលងភ្នំ
ឆ្កែ
សត្វឆ្កែព្រៃ
ទ្វារអាចម៍សត្វ
សន្មតថាការបដិសេធត្រូវបានដកចេញពីទីក្រុងតាមរយៈច្រកទ្វារនេះ។
ដែលបាក់បែក និងបើកចំហរ ហើយនិងទ្វារក្រុងដែលធ្វើពីឈើ គឺត្រូវបានបំផាញដោយភ្លើងឆេះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ដែលបាក់បែក និងបើកចំហរ ហើយនិងទ្វារក្រុងដែលធ្វើពីឈើ គឺត្រូវបានបំផាញដោយភ្លើងឆេះ»
Nehemiah 2:15
ដូច្នេះ ខ្ញុំក៏ឡើង...រួចខ្ញុំត្រឡប់ក្រោយ
មនុស្សផ្សេងៗទៀតក៏ទៅាតាមលោកនេហេមាដែរ។ ការបកប្រែរបៀបផ្សេងទៀត «ដូច្នេះ ខ្ញុំក៏ឡើង...រួចខ្ញុំត្រឡប់ក្រោយ»
តាមទ្វារជ្រលងភ្នំ
«ឆ្លងកាត់តាមជ្រលងភ្នំ»
ពួកអ្នកឯទៀត ដែលត្រូវបំពេញកិច្ចការនោះ
នេះសំដៅទៅលើបុរសដែលក្រោយមកនឹងសង់ជញ្ជាំងឡើងវិញ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកផ្សេងទៀតដែលមកក្រោយនឹងធ្វើកិច្ចការសាងសង់កំពែងឡើងវិញ»
Nehemiah 2:17
អ្នករាល់គ្នាឃើញបញ្ហា
ពាក្យ «អ្នក» គឺពហុវចន: សំដៅទៅលើមនុស្សទាំងអស់ដែលបានរៀបរាប់នៅក្នុងជំពូកទី ២៖១៥។
ទ្វារក្រុងត្រូវភ្លើងឆេះអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «របៀបដែលសត្រូវរបស់យើងបំផ្លាញទ្វារក្រុងដោយភ្លើង»
ដូច្នោះយើងនឹងមិនមានភាពអាម៉ាស់ទៀតឡើយ
«ដូច្នោះយើងនឹងអាម៉ាស់ទៀតឡើយ»
ព្រះហស្តដ៏ល្អរបស់ព្រះនៃខ្ញុំ
«ព្រះហស្តដ៏ល្អ» នៃព្រះជាម្ចាស់សំដៅទៅលើការ «ការសព្វព្រះទ័យ»របស់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត៖ «ព្រះជាម្ចាស់សព្វព្រះហឫទ័យមកលើខ្ញុំ»
ក្រោកឡើង ហើយសង់
នេះគឺជាប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត: «ចាប់ផ្តើមសាងសង់» (សូមមើល៖figs-idiom)
ដូច្នេះ គេក៏ចម្រើនកម្លាំងគ្នាសម្រាប់កិច្ចការដ៏ប្រពៃនោះ
ឃ្លា «គេក៏ចម្រើនកម្លាំងគ្នា» គឺមានន័យថារៀបចំធ្វើអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះពួកគេបានរៀបចំធ្វើកិច្ចការដ៏ប្រពៃនេះ»
Nehemiah 2:19
សានបាឡាត... ថូប៊ីយ៉ា
នេះគឺជាឈ្មោះរបស់បុរសពីរនាក់។ បកប្រែដូចនៅក្នុងជំពូកទី២៖៩។
កេសែម
នេះគឺជាឈ្មោះរបស់បុរសម្នាក់។
តើអ្នករាល់គ្នាកំពុងធ្វើអ្វី? តើអ្នករាល់គ្នាចង់បះបោរប្រឆាំងនឹងស្តេចឬ?
សំនួរទាំងនេះត្រូវបានប្រើដើម្បីចំអកដល់លោកនេហេមា។ នេះអាចសរសេរបានជាឃ្លាច្រើន។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកកំពុងធ្វើជាល្ងង់! អ្នកមិនគួរបះបោរប្រឆាំងនឹងស្តេចទេ!» (សូមមើល:figs-rquestion)
ព្រះរាជា
នេះសំដៅទៅអើថាស៊ើកសេសដែលជាស្តេចនៃចក្រភពពែរ្ស។
នឹងក្រោកឡើង ហើយនាំគ្នាសង់
នេះគឺជាឃ្លារ។ ការបកប្រែរបៀបផ្សេងទៀត: «នឹងចាប់ផ្តើមសាងសង់»
ប៉ុន្តែអ្នករាល់គ្នាវិញ គ្មានចំណែក គ្មានសិទ្ធិ ឬគុណបំណាច់អ្វីនៅក្រុងយេរូសាឡិមឡើយ
«រីឯអ្នករាល់គ្នាវិញគ្មានចំណែក គ្មានសិទ្ធិស្របច្បាប់ ឬការទាមទារខាងសាសនាណាមួយចំពោះក្រុងយេរូសាឡិមឡើយ»

[1]ក្រោយមក អេលីយ៉ាស៊ីប ជានាយកបូជាចារ្យ និងពួកបូជាចារ្យដែលជាបងប្អូនរបស់លោកបានក្រោកឡើង ហើយពួកគេបាននាំគ្នាសង់ទ្វារចៀមឡើង។ ពួកគេបានធ្វើពិធីញែកទ្វារនោះជាបរិសុទ្ធ ហើយដាក់ទ្វារនោះឡើង។ ពួកគេបានធ្វើពិធីញែកជាបរិសុទ្ធនោះ រហូតដល់ប៉មហាមេអា និងរហូតដល់ប៉ម ហាណានាល។[2]នៅជិតលោក មានពួកអ្នកក្រុងយេរីខូរបានសង់ ហើយនៅជិតពួកគេមានសាគើរ ជាកូនប្រុសរបស់អ៊ីមរីបានសង់។
[3]កូនចៅរបស់សេណាអានាំគ្នាសង់ទ្វារមច្ឆា។ ពួកគេបានដាក់ធ្នឹមខ្លោងទ្វារ និងដាក់សន្លឹកទ្វារ និងគន្លឹះទ្វារ ព្រមទាំងរនុកទ្វារទៀតផង។
[4]លោកមេរ៉ូម៉ូតជាអ្នកដែលសាងសង់ផ្នែកបន្ទាប់។ លោកគឺជាចៅរបស់ហាកូស។ ហើយនៅជិតគាត់ មានមស៊ូឡាម បានជួសជុល។ គាត់ជាកូនរបស់បេរេគា និងជាចៅរបស់មសេសាបេល។ ហើយនៅជិតគាត់មានសាដុក បានជួសជុល។ គាត់ជាកូនរបស់ប្អាណា។[5]ហើយនៅជិតពួកគេមានពួកតូអាបានជួសជុល ប៉ុន្តែ ពួកអ្នកមានត្រកូលខ្ពស់របស់គេ មិនបានចូលរួមធ្វើការតាមពួកមេដឹកនាំរបស់ខ្លួនឡើយ។
[6]យ៉ូយ៉ាដា ជាកូនរបស់ផាសេហា និងមស៊ូឡាម ជាកូនរបស់បេសូឌា បានជួសជុលទ្វារចាស់។ គេដាក់ធ្នឹមខ្លោងទ្វារ និងសន្លឹកទ្វារ គន្លឹះទ្វារ ព្រមទាំងរនុកទ្វារផងដែរ។[7]នៅជិតនឹងពួកគេទាំងនោះ មានមេឡាទា ជាអ្នកក្រុងគីបៀន និងយ៉ាដោន ជាអ្នកក្រុងមេរ៉ុន ពួកក្រុងគីបៀន និងពួកក្រុងមីសប៉ា ជាស្រុកដែលនៅក្រោមអំណាចរបស់អភិបាលខេត្តនានា នៅខាងនាយទន្លេ បានជួសជុល។
[8]នៅជាប់នឹងពួកគេ មានលោកអ៊ូស៊ាល ជាកូនរបស់លោកហារហាយ៉ា ដែលជាពួកជាងមាស បានជួសជុល ហើយនៅជាប់នឹងគាត់ មានលោកហាណានា ជាអ្នកលាយគ្រឿងក្រអូប។ ពួកគេធ្វើឲ្យក្រុងយេរូសាឡិមបានមាំមួនឡើងវិញ រហូតដល់កំផែងធំ។[9]នៅជាប់នឹងពួកគេ មានលោករេផាយ៉ា ជាកូនរបស់លោកហ៊ើរ បានជួសជុល។ គាត់ជាអ្នកគ្រប់គ្រងមួយចំហៀងនៃក្រុងយេរូសាឡិម ។[10]នៅជាប់នឹងពួកគេមានលោកយេដាយ៉ា ជាកូនរបស់លោកហារូម៉ាប បានជួសជុលផ្នែកដែលនៅខាងមុខផ្ទះគាត់។ ហើយនៅជាប់នឹងគាត់ នោះមានលោកហាធូស ជាកូនរបស់លោកហាសាបនា បានជួសជុល។
[11]ម៉ាលគា ជាកូនរបស់លោកហារីម និងលោកហាស៊ូម ជាកូនរបស់លោកផាហាត ម៉ូអាប់ បានជួសជុលផ្នែកផ្សេងទៀត ហើយនិងប៉មឡភ្លើង។[12]នៅជិតពួកគេមានលោកសាលូម ជាកូនរបស់ហាឡូហេស ជាអ្នកគ្រប់គ្រងមួយចំហៀងនៃក្រុងយេរូសាឡិម គឺគាត់ និងពួកកូនស្រីរបស់គាត់ បានជួសជុល។
[13]លោកហានូន និងអ្នកស្រុកសាណូអា បានជួសជុលទ្វារជ្រលងភ្នំ។ ពួកគេបានសង់ទ្វារនោះឡើងវិញ ហើយដាក់សន្លឹកទ្វារ គន្លឹះទ្វារ និងរនុកទ្វារ។ពួកគេ ក៏បានជួសជុលកំពែងប្រវែងមួយពាន់ហត្ថ រហូតដល់ទ្វារអាចម៍សត្វ។
[14]លោកម៉ាលគា កូនរបស់លោករេកាប ជាអ្នកគ្រប់គ្រងលើស្រុកបេត ហាកេរែម បានជួសជុលទ្វារសំរាម។ គាត់បានសង់ទ្វារ ហើយដាក់សន្លឹកទ្វារ គន្លឹះទ្វារ និងរនុកទ្វារផងដែរ។[15]លោកសាលូនជាកូនលោកកុល ហូសេ ជាអ្នកគ្រប់គ្រងលើស្រុកមីសប៉ា បានជួសជុលទ្វារប្រភពទឹក។ គាត់បានសង់ទ្វារ ហើយប្រក់ដំបូល ដាក់សន្លឹកទ្វារ គន្លឹះទ្វារ និងរនុកទ្វារផងដែរ។ រួចគាត់សង់កំផែងស្រះស៊ីឡោម ដែលនៅក្បែរឧទ្យានស្តេច រហូតដល់ជណ្តើរដែលចុះពីទីក្រុងដាវីឌ។
[16]លោកនេហេមា ជាកូនរបស់លោកអាសប៊ូក និងជាអ្នកគ្រប់គ្រងលើសង្កាត់បេតស៊ើរមួយចំហៀង បានជួសជុលរហូតដល់ចំណុចមួយទល់មុខផ្នូរព្រះបាទដាវីឌ ហើយដល់ស្រះដែលគេបានជីក និងដល់ផ្ទះរបស់ពួកខ្លាំងពូកែ។[17]នៅពីក្រោយគាត់ មានពួកលេវីបានជួសជុល រួមទាំងលោករេហ៊ូម ជាកូនរបស់លោកបានី ហើយនៅជាប់នឹងគាត់ មានលោកហាសាបយ៉ា ជាអ្នកគ្រប់គ្រងលើសង្កាត់កៃឡាមួយចំហៀង ដែលធ្វើការដើម្បីសង្កាត់របស់គាត់។
[18]បន្ទាប់ពីគាត់ មានពួកបងប្អូនរបស់គេបានជួសជុល រួមទាំងលោកបាវ៉ាយ ជាកូនរបស់លោកហេណាដាឌ និងជាអ្នកគ្រប់គ្រងលើសង្កាត់កៃឡាមួយចំហៀង។[19]នៅជាប់នឹងគាត់ មានលោកអេស៊ើរ កូនរបស់លោកយេសួរ ជាអ្នកគ្រប់គ្រងលើស្រុកមីសប៉ា បានជួសជុលមួយផ្នែកទៀត ទល់មុខនឹងផ្លូវឡើងទៅឃ្លាំងគ្រឿងសស្ត្រាវុធ ត្រង់ជ្រុងកំផែង។
[20]បន្ទាប់ពីគាត់ មានលោកបារូក ជាកូនរបស់សាប់បាយ បានជួសជុលមួយផ្នែកទៀត ចាប់តាំងពីជ្រុងកំផែង រហូតដល់ទ្វារផ្ទះលោកអេលីយ៉ាស៊ីប ជាសម្តេចសង្ឃ។[21]បន្ទាប់ពីគាត់ មានលោកមេរ៉ូម៉ូត កូនរបស់លោកអ៊ូរីយ៉ា និងជាចៅរបស់លោកហាកូស បានជួសជុលមួយផ្នែកទៀត ចាប់តាំងពីទ្វារផ្ទះរបស់លោកអេលីយ៉ាស៊ីប រហូតដល់ចុងផ្ទះរបស់លោក។
[22]បន្ទាប់ពីគាត់ មានពួកសង្ឃ គឺពួកសង្ឃដែលនៅតំបន់ជុំវិញ បានជួសជុល។[23]បន្ទាប់ពីអ្នកទាំងនោះ មានលោកបេនយ៉ាមីន និងលោកហាស៊ូបបានជួសជុលនៅមុខផ្ទះរបស់ពួកគេ។ បន្ទាប់មកទៀត មានលោកអ័សារា ជាកូនរបស់លោកម្អាសេយ៉ា និងជាចៅរបស់លោកអ័ណានា បានជួសជុលនៅក្បែរផ្ទះរបស់ខ្លួន។[24]បន្ទាប់ពីគាត់ មានលោកប៊ីនុយ ជាកូនរបស់លោកហេណាដាឌ បានជួសជុលមួយផ្នែកទៀត គឺចាប់តាំងពីផ្ទះរបស់លោកអ័សារា រហូតដល់ជ្រុង និងរហូតដល់កាច់ជ្រុងកំផែង។
[25]លោកប៉ាឡាល ជាកូនរបស់លោកអ៊ូសាយ បានជួសជុលនៅមុខជ្រុងកំផែង និងប៉មដែលសន្ធឹងចេញពីព្រះរាជដំណាក់ស្តេចខាងលើ នៅទីធ្លារបស់ក្រុមអង្គរក្សស្តេច។ បន្ទាប់ពីគាត់ មានលោកពេដាយ៉ា ជាកូនរបស់លោកប៉ារ៉ូសបានជួសជុល[26]ពួកអ្នកបម្រើព្រះវិហារ ដែលរស់នៅលើអូផែល បានជួសជុលចំណុចមួយនៅទល់មុខនឹងទ្វារទឹកខាងកើត និងប៉មដែលសន្ធឹងចេញនោះ។[27]បន្ទាប់ពីគាត់ មានពួកអ្នកស្រុកតូអា បានជួសជុលមួយផ្នែកទៀត នៅទល់មុខនឹងប៉មធំដែលសន្ធឹងចេញរហូតដល់កំផែងអូផែល។
[28]ពួកសង្ឃបានជួសជុលនៅខាងលើទ្វារសេះ នៅខាងមុខផ្ទះរបស់គេរៀងខ្លួន។[29]បន្ទាប់ពីអ្នកទាំងនោះ មានលោកសាដុក ជាកូនរបស់លោកអ៊ីមមើរ បានជួសជុលនៅខាងមុខផ្ទះរបស់គាត់។ បន្ទាប់ពីគាត់ មានលោកសេម៉ាយ៉ា កូនរបស់លោកសេកានា ជាឆ្មាំទ្វារខាងកើត បានជួសជុល។[30]បន្ទាប់ពីគាត់ មានលោកហាណានា ជាកូនរបស់លោកសេលេមា និងលោកហានូន ជាកូនទីប្រាំមួយរបស់លោកសាឡាប បានជួសជុលមួយផ្នែកទៀត។ បន្ទាប់ពីគាត់ មានលោកមស៊ូឡាម ជាកូនរបស់លោកបេរេគា បានជួសជុលផ្នែកដែលនៅទល់មុខនឹងបន្ទប់ដេករបស់គាត់។
[31]បន្ទាប់ពីគាត់ មានលោកម៉ាលគា ជាម្ចាក់ក្នុងចំណោមពួកជាងមាស បានជួសជុល រហូតដល់ផ្ទះរបស់ពួកអ្នកបម្រើព្រះវិហារ និងផ្ទះរបស់ពួកអ្នកជំនួញ ទល់មុខនឹង ទ្វារមីបកាឌ ហើយរហូតដល់បន្ទប់ខាងលើ ត្រង់ជ្រុងកំផែង។[32]ពួកជាងមាស និងពួកអ្នកជំនួញបានជួសជុលមួយផ្នែកនៅចន្លោះបន្ទប់ខាងលើត្រង់ជ្រុងកំផែង និងទ្វារចៀម ។

Nehemiah 3:1

ក្រោយមក អេលីយ៉ាស៊ីប ជានាយកបូជាចារ្យ និងពួកបូជាចារ្យដែលជាបងប្អូនរបស់លោក

«ពេលនោះលោកមហាបូជាចារ្យអេលីយ៉ាស៊ីបបានមកជួបជាមួយបងប្អូនលោកជាបូជាចារ្យ

អេលីយ៉ាស៊ីប... សាគើរ ជាកូនប្រុសរបស់អ៊ីមរី

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

ប៉មហាមេអារ

«ប៉មមួយរយ»

ពួកអ្នកក្រុងយេរីខូរ

គឺមានន័យថាបុរសទាំងនោះមកពីក្រុងយេរីខូ។ ការបកប្រែរបៀបផ្សេងទៀត:

«បុរសដែលមកពីក្រុងយេរីខូរ»

Nehemiah 3:3

សេណាអា ម្រេម៉ូត ហាកូស មស៊ូឡាម បេរេគា មសេសាបេល សាដុក ប្អាណា

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

ដាក់ធ្នឹមខ្លោងទ្វារ

«តម្លើងទ្វាររបស់វា» ឬ «ដាក់ទ្វាររបស់វានៅនឹងកន្លែង»

សន្លឹក និងរនុកទ្វារ

«ធ្នឹម និងរនាំងរបស់វា»។ សោរសម្រាប់ចាក់ច្រកទ្វារឲ្យមានសុវត្ថិភាព។

លោកម្រេម៉ូតជាអ្នកជួសជុលផ្នែកបន្ទាប់...មស៊ូឡាម បានជួសជុល... សាដុក បានជួសជុល... តូអា បានជួសជុល

ឃ្លាទាំងនេះគឺចង់សំដៅទៅលើការជួសជុលជញ្ជាំង។ ការបកប្រៀបរៀបផ្សេងទៀត:

«លោកម្រេម៉ូតជាអ្នកជួសជុលផ្នែកបន្ទាប់នៃជញ្ជាំង....មស៊ូឡាម បានជួសជុលជញ្ជាំង... សាដុក បានជួសជុលជញ្ជាំង.... តូអាបានជួសជុលជញ្ជាំង»

ជនជាតិតូអា

មនុស្សទាំងនេះគឺមកពីទីក្រុងតូអា។

ធ្វើការតាមពួកមេដឹកនាំរបស់ពួកគេ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«មេដឹកនាំរបស់ពួកគេបានបញ្ជាពួកគេឲ្យធ្វើតាម»

generated on Wed Sep 10 16:16:32 2025

Nehemiah 3:6
យ៉ូយ៉ាដា...ផាសេហា និងមស៊ូឡាម... បេសូឌា...មេឡាទា...យ៉ាដោន
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ដាក់ធ្មឹមខ្លោងទ្វារ
«តម្លើងទ្វាររបស់វា» ឬ «ដាក់ទ្វាររបស់វានៅនឹងកន្លែង»
សន្លឹក និងរនុកទ្វារ
«សោ និងរនាំងរបស់វា»។ សោរសម្រាប់ចាក់ច្រកទ្វារឲ្យមានសុវត្ថិភាព។
គីបៀន និងមេរ៉ុន
ពួកគីបៀន និងពួកមេរ៉ុនជាមនុស្សមួយក្រុម។
គីបៀន និងមីសប៉ា
នេះគឺឈ្មោះនៃទីកន្លែង។
ខេត្តនានា នៅខាងនាយទន្លេ
នេះជាឈ្មោះខេត្តដែលនៅខាងលិចទន្លេអឺប្រាត។
វាបានឆ្លងកាត់ទន្លេពីទីក្រុងស៊ូសាន។ បកប្រែដូចនៅក្នុងជំពូកទី ២:៧។
Nehemiah 3:8
អ៊ូស៊ាល...ហារហាយ៉ា...ហាណានា... យេដាយ៉ា...ហារូម៉ាប...ហាធូស...ហាសាបនា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ជាងមាស
ជាងមាសគឺជាមនុស្សម្នាក់ដែលធ្វើគ្រឿងអលង្ការមាស និងវត្ថុមាសផ្សេងៗទៀត។
ជាងមាសបានជួសជុល...ហ៊ើរបានជួសជុល... ហារូម៉ាបបានជួសជុល...ហាសាបនាបានជួសជុល
ឃ្លាទាំងនេះគឺចង់សំដៅទៅលើការជួសជុលលើជញ្ជាំង។ ការបកប្រែរបៀបផ្សេងទៀត៖
«ជាងមាសបានជួសជុលជញ្ជាំង...ហ៊ើរបានជួសជុលជញ្ជាំង...
ហារូម៉ាបបានជួសជុលជញ្ជាំង...ហាសាបនាបានជួសជុលជញ្ជាំង»
នៅជាប់នឹងគាត់ មានលោកហាណានា ជាអ្នកលាយគ្រឿងក្រអូប
លោកហាណានាក៏បានសាងសង់ជញ្ជាំងដែរ។ ការបកប្រែរបៀបផ្សេងទៀត: «នៅ
ជាប់នឹងគាត់ មានលោកហាណានា ជាអ្នកលាយគ្រឿង
ក្រអូបក៏បានជួសជុលជញ្ជាំងដែរ»
គ្រឿងក្រអូប
សារធាតុរាវដែលមនុស្សដាក់លើខ្លួនរបស់ពួកគេក្នុងបរិមាណតិចតួចដើម្បីឱ្យមានក្លិនរីកសាយ
អ្នកគ្រប់គ្រង
«ប្រមុខដឹកនាំ» ឬ «អ្នកដឹកនាំ»
មួយចំហៀងនៃក្រុង
«ពាក់កណ្តាល» មានន័យថាជាផ្នែកមួយចេញមកពីពីរផ្នែកស្មើគ្នា។
Nehemiah 3:11
ម៉ាលគា... ហារីម...ហាស៊ូម...ផាហាត...ម៉ូអាប់...សាលូម...ហាឡូហេស
ទាំងអស់នេះគឺជាឈ្មោះរបស់មនុស្ស។
បានជួសជុលមួយផ្នែកទៀត... បានជួសជុលរួមជាមួយនឹងកូនស្រីរបស់លោក
ត្រង់ឃ្លានេះគឺចង់សំដៅទៅលើការជួសជុលជញ្ជាំង។
របៀបផ្សេងទៀតក្នុងការបកប្រែ: «បានជួសជុលមួយផ្នែកទៀត...
បានជួសជុលរួមជាមួយនឹងកូនស្រីរបស់លោក»
លោកសាលូម ជាកូនរបស់ហាឡូហេស ជាអ្នកគ្រប់គ្រង
លោកសាលូមគឺជាអ្នកគ្រប់គ្រង មិនមែនលោកហាឡូហេសទេ។
អ្នកគ្រប់គ្រង
«មេគ្រប់គ្រង» ឬ «អ្នកដឹកនាំ»
មួយចំហៀងនៃក្រុង
«មួយចំហៀង» មានន័យថាជាផ្នែកម្ខាងនៃផ្នែកម្ខាងទៀត។
Nehemiah 3:13
ហានូន
នេះគឺជាឈ្មោះរបស់មនុស្ស។
អ្នកស្រុកសាណូអា
«មនុស្សដែលមកពីស្រុកសាណូអា» (UDB)
សាណូអា
នេះគឺឈ្មោះនៃទីកន្លែង។
ទ្វារជ្រលងភ្នំ
«ច្រកនៃជ្រលងភ្នំ» ឬ «ទ្វារដែលនាំទៅជ្រលងភ្នំ»
ព្យាយាមបកប្រែឃ្លានេះជាឈ្មោះមិនមែនគ្រាន់តែជាការពិពណ៌នាទេ។
ដំឡើងទ្វារ
«ដំឡើងទ្វាររបស់វា» ឬ «ដាក់ទ្វាររបស់វាទៅតាមកន្លែងរបស់វា»
សន្លឹក និងរនុកទ្វារ
«សោ និងរនាំងរបស់វា»។ សោរសម្រាប់ចាក់ច្រកទ្វារឲ្យមានសុវត្ថិភាព។
ពួកគេបានជួសជុលកំពែងប្រវែងមួយពាន់ហត្ថ រហូតដល់ទ្វារអាចម៍សត្វ
ពួកគេជួសជុលផ្នែកខ្លះនៃជញ្ជាំងនៅចន្លោះជ្រលងភ្នំ និងខ្លោងទ្វារ។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេជួសជុលជញ្ជាំងមួយពាន់ហត្ថចាប់ពីជ្រលងភ្នំរហូតដល់ទ្វារអាចម៍សត្វ»
ពួកជួសជុលកំផែងប្រវែងមួយពាន់ហត្ថ
ពាក្យបាត់«ជញ្ជាំង» នឹងត្រូវបានដាក់បញ្ចូល។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកជួសជុលកំផែងប្រវែងមួយពាន់ហត្ថ» «ពួកគេជួស
ជុលជញ្ជាំងមួយពាន់ហត្ថទៀតតាមទ្វារជ្រលងភ្នំ»
មួយពាន់ហត្ថ
«១០០០ ហត្ថ»។ នេះអាចត្រូវបានសរសេរនៅក្នុងការវាស់វែងទំនើប។
ការបកប្រែរបៀបផ្សេងទៀត: «៤៦០ម៉ែត្រ»
ទ្វារអាចម៍សត្វ
សន្មតថាការបដិសេធត្រូវបានដកចេញពីទីក្រុងតាមរយៈច្រកទ្វារនេះ។
ព្យាយាមបកប្រែឃ្លានេះជាឈ្មោះមិនមែនគ្រាន់តែជាការពិពណ៌នាទេ។
Nehemiah 3:14
ម៉ាលគា...រេកាប ...សាលូន...កុល ហូសេ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
លោកម៉ាលគា កូនរបស់លោករេកាប ជាអ្នកគ្រប់គ្រង
លោកម៉ាលគាគឺជាអ្នកគ្រប់គ្រង មិនមែនលោករេកាបទេ។
អ្នកគ្រប់គ្រង
«មេគ្រប់គ្រង» ឬ «មេដឹកនាំ»
បេតហាកេរែម
នេះគឺជាឈ្មោះទីកន្លែង។
គាត់... ដំឡើងទ្វារ
«គាត់បានដំឡើងទ្វាររបស់លោក» ឬ
«លោកបានដាក់ទ្វាររបស់ទៅតាមកន្លែងរបស់វា»
សន្លឹក និងរនុកទ្វារ
«សោ និងរនាំងរបស់វា»។ សោរសម្រាប់ចាក់ច្រកទ្វារឲ្យមានសុវត្ថិភាព។
លោកសាលូន កូនលោកកុល ហូសេ ជាអ្នកគ្រប់គ្រង
លោកសាលូនគឺជាអ្នកគ្រប់គ្រង មិនមែនលោកហូសេទេ។
កំពែងស្រះស៊ីឡោម
នេះមានន័យថាកំពែងនៅក្បែរស្រះស៊ីឡោម។ ការបកប្រែរបៀបផ្សេងទៀត:
«កំពែងដែលព័ទ្ធជុំវិញស្រះស៊ីឡោម»
Nehemiah 3:16
លោកនេហេមា ជាកូនរបស់លោកអាសប៊ូក និងជាអ្នកគ្រប់គ្រង
លោកនេហេមាជាអ្នកគ្រប់គ្រង មិនមែនលោកអាសប៊ូកទេ។
លោកនេហេមា
នេះគឺជាបុរសម្នាក់ទៀតឈ្មោះនេហេមាពីអ្នកដែលបាននិពន្ធសៀវភៅនេះ។
អ្នកគ្រប់គ្រង
«ប្រធានគ្រប់គ្រង» ឬ «មេដឹកនាំ»
មួយចំហៀងស្រុក
«ពាក់កណ្តាល» មានន័យថាផ្នែកមួយក្នុងចំណោមពីរផ្នែកស្មើគ្នា។
នេហេមា...អាសប៊ូក...ហ៊ូម...បានី...ហាសាបយ៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
បេតស៊ើរ....កៃឡា
ទាំងនេះគឺជាឈ្មោះកន្លែង។
ជួសជុលទៅតាមកន្លែង...ពួកលេវីបានជួសជុល
ឃ្លាទាំងនេះសំដៅទៅលើការជួសជុលជញ្ជាំង។ ការបកប្រែរបៀបផ្សេងទៀត:
«ជួសជុលកំពែងរហូតដល់កន្លែង...ពួក
លេវីបានជួសជុលក៏បានជួសជុលកំពែងដែរ»
បុរសខ្លាំងពូកែ
«អ្នកចម្បាំង»
សង្កាត់របស់គាត់
«តំណាងឲ្យស្រុករបស់លោក» ឬ «ក្នុងនាមស្រុករបស់លោក»
Nehemiah 3:18
បន្ទាប់ពីគាត់
«នៅជាប់គាត់»
ពួកបងប្អូនរបស់គេបានជួសជុល...ជួសជុលផ្នែកផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

ឃ្លាទាំងនេះសំដៅទៅលើការជួសជុលជញ្ជាំង។ ការបកប្រែរបៀបផ្សេងទៀត៖
«នៅក្បែរគាត់ជនជាតិរបស់ពួកគេបានជួសជុលកំពែង ...
ជួសជុលផ្នែកមួយទៀតនៃកំពែង»
បាវ៉ាយ...ហេណាដាឌ...អេស៊ើរ...យេសួរ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
លោកបាវ៉ាយ ជាកូនរបស់លោកហេណាដាឌ ជាអ្នកគ្រប់គ្រង
លោកបាវ៉ាយគឺជាអ្នកគ្រប់គ្រង មិនមែនលោកហេណាដាឌទេ។
កៃឡា...មីសប៉ា
ទាំងនេះគឺជាឈ្មោះកន្លែង។
លោកអេស៊ើរ កូនរបស់លោកយេសួរ ជាអ្នកគ្រប់គ្រង
លោកអេស៊ើរគឺជាអ្នកគ្រប់គ្រង មិនមែនលោកយេសួរទេ។
ទល់មុខនឹងផ្លូវឡើងទៅឃ្លាំងគ្រឿងសស្ត្រាវុធ
«នៅពីមុខកាំជណ្តើរដែលឡើងទៅឃ្លាំងគ្រឿងសស្ត្រាវុធ» (UDB)
ឃ្លាំងគ្រឿងសស្ត្រាវុធ
កន្លែងរក្សាទុកអាវុធ
Nehemiah 3:20
បន្ទាប់ពីគាត់
«នៅជាប់គាត់»
បារូក...សាប់បាយ...អេលីយ៉ាស៊ីប...ម្រេម៉ូត...អ៊ូរីយ៉ា...ហាកូស
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ជួសជុលមួយផ្នែកទៀត
នេះសំដៅទៅលើការជួសជុលកំពែង។ ការបកប្រែរបៀបផ្សេងទៀត: «ជួសជុលមួយ
ផ្នែកទៀតនៃកំពែង»
Nehemiah 3:22
នៅជុំវិញក្រុងយេរូសាឡិម បានជួសជុល...លោកបេនយ៉ាមីន និងលោកហាស៊ូបបានជួសជុល...
លោកអ័សារាបានជួសជុល...លោកបឺនុយបានជួសជុល
ឃ្លានេះគឺសំដៅទៅលើការជួសជុលកំពែង។ ការបកប្រែរបៀបផ្សេងទៀត:
«នៅជុំវិញក្រុងយេរូសាឡិម បានជួសជុលកំពែង...លោកបេនយ៉ាមីន និងលោក
ហាស៊ូបបានជួសជុលកំពែង...លោកអ័សារាបានជួសជុលកំពែង...លោក
បឺនុយបានជួសជុលកំពែង»
បេនយ៉ាមីន...ហាស៊ូប...អ័សារា...ម្អាសេយ៉ា...អ័ណានា...បឺនុយ...ហេណាដាឌ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ជួសជុលនៅមុខផ្ទះ
«នៅមុខផ្ទះរបស់ពួកគេ»
បន្ទាប់ពីពួកគេ ... បន្ទាប់ពីគាត់
«នៅជាប់នឹងពួកគេ ... នៅជាប់នឹងគាត់»
Nehemiah 3:25
ប៉ាឡាល...អ៊ូសាយ...ពេដាយ៉ា...ប៉ារ៉ូស
ទាំងនេះគឺឈ្មោះរបស់មនុស្ស។
អ៊ូសាយបានជួសជុល...ប៉ារ៉ូសបានជួសជុល...ពួកអ្នកបម្រើបានជួសជុល ជួសជុលផ្នែកផ្សេងទៀត
ឃ្លានេះគឺសំដៅទៅលើការជួសជុលកំពែង។ ការបកប្រែរបៀបផ្សេងទៀត:
«អ៊ូសាយបានជួសជុលកំពែង...ប៉ារ៉ូសបានជួសជុលកំពែង...ពួកអ្នក
បម្រើបានជួសជុលកំពែង ជួសជុលផ្នែកផ្សេងទៀតនៃកំពែង»
បន្ទាប់ពីគាត់
«នៅជាប់ជាមួយគាត់»
កំពែងដែលសន្ធឹង
កំពែងដែលខ្ពស់
ដំណាក់ខាងលើរបស់ព្រះរាជា
«វិមានជាន់ខ្ពស់របស់មេដឹកនាំអ៊ីស្រាអែល»
ទីធ្លារបស់ក្រុមអង្គរក្ស
ជាកន្លែងដែលក្រុមអង្គរក្សស្នាក់នៅ។
កំពែងដែលសន្ធឹងចេញ... កំពែងធំដែលសន្ធឹងចេញ
«កំពែងដែលខ្ពស់...កំពែងដែលខ្ពស់។» ឃ្លា «កំពែងដែលសន្ធឹងចេញ»
មានន័យថាកំពែងដែលខ្ពស់ជាងជញ្ជាំង។
វាទំនងជាថាឃ្លាទាំងពីរនេះសំដៅទៅលើប៉មតែមួយ។
ពួកអ្នកស្រុកតកូអា
ជាក្រុមមនុស្សមួយក្រុមដែលមកទីក្រុងតកូអា។
បកប្រែដូចអ្វីដែលអ្នកបានប្រែនៅក្នុងជំពូកទី ៣៖៣។
Nehemiah 3:28
ពួកសង្ឃបានជួសជុល...ជួសជុលផ្នែកផ្សេងទៀត...ទ្វារខាងកើត បាន
ជួសជុល...ជួសជុលផ្នែកផ្សេងទៀត...ជួសជុលខាងមុខ
ឃ្លាទាំងនេះគឺសំដៅទៅលើការជួសជល់កំពែង។ ការបកប្រែរបៀបផ្សេងទៀត៖
«ពួកសង្ឃបានជួសជុលកំពែង...ជួសជុលផ្នែកផ្សេងទៀតនៃកំពែង...ទ្វារខាងកើត
បាន
ជួសជុល...ជួសជុលផ្នែកផ្សេងទៀតនសកំពែង...ជួសជុលកំពែងដែលនៅខាងមុខ»
នៅខាងលើទ្វារសេះ
ពាក្យថា «ខាងលើ»
ត្រូវបានប្រើនៅទីនេះពីព្រោះផ្ទះរបស់បូជាចារ្យទំនងជាស្ថិតនៅទីតាំងខ្ពស់ជាងទ្វារសេះ។
នៅខាងមុខផ្ទះរបស់គាត់
«នៅទល់មុខផ្ទះរបស់គាត់»
បន្ទាប់ពីពួកគេ ... បន្ទាប់ពីគាត់
«នៅជាប់នឹងពួកគេ ... នៅជាប់នឹងគាត់»
សាដុក...អ៊ីមមើរ...សេម៉ាយ៉ា...សេកានា...ហាណានាហានូន...សាឡាប...មស៊ូឡាម...បេរេគា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
លោកសេម៉ាយ៉ា កូនរបស់លោកសេកានា ឆ្មាំទ្វារខាងកើត
លោកសេម៉ាយ៉ាគឺជាឆ្មាំទ្វារខាងកើត មិនមែនលោកសេកានាទេ។
កូនទីប្រាំមួយ
«កូនទីប្រាំមួយ»
ទល់មុខនឹងបន្ទប់ដេករបស់គាត់
«នៅខាងមុខបន្ទប់ដែលលោកបានស្នាក់នៅ។» ពាក្យ «របស់គាត់»
សំដៅទៅលោកមស៊ូឡាម។
Nehemiah 3:31
បន្ទាប់ពីគាត់
នៅជាប់គាត់
ម៉ាលគា
នេះគឺជាឈ្មោះរបស់មនុស្ស។
ជាងមាស
ជាងមាសគឺជាមនុស្សដែលធ្វើមាស គ្រឿងអលង្ការ និងគ្រឿងមាសផ្សេងទៀត។
បានជួសជុល រហូតដល់ផ្ទះ...ផ្ទះរបស់ពួកអ្នកជំនួញ
ឃ្លាទាំងនេះគឺចង់សំដៅទៅលើការជួសជុលកំពែង។ ការបកប្រែរបៀបផ្សេងទៀត:
«ជួសជុលកំពែងរហូតដល់ផ្ទះរបស់គាត់... ពួកអ្នកជំនួញជួសជុលកំពែង»
អ្នកជំនួញ
«អ្នកលក់» ឬ «ពាណិជ្ជករ»
បន្ទប់ខាងលើ
បន្ទប់ជាន់ខ្ពស់ដែលមនុស្សស្នាក់នៅ។
ទ្វារចៀម
នេះគឺជាឈ្មោះនៅលើផ្លូវចូលក្នុងកំពែង។

---

4 [1]នៅពេលដែលលោកសានបាឡាតបានឮថា ពួកយើងកំពុងសង់កំផែងឡើងវិញដូច្នេះ គាត់បានខឹងក្រេវក្រោធជាខ្លាំង ហើយគាត់ក៏បានចំអកឲ្យពួកយូដា។[2]នៅមុខពួក
បងប្អូនរបស់គាត់ និងនៅមុខពលទ័ពស្រុកសាម៉ារី គាត់និយាយថា៖ «តើពួកយូដាដែលទន់ខ្សោយទាំងនេះកំពុងធ្វើអ្វី? តើគេសង់កំផែងនេះឡើងវិញសម្រាប់ខ្លួនគេឬ?
តើគេនឹងថ្វាយយញ្ញបូជាឬ? តើគេបង្ហើយកំផែងនេះក្នុងរយៈពេលមួយថ្ងៃឬ? តើគេយកថ្មពីគំនរសំរាម ដែលឆេះអស់ទៅហើយ មករៀបឡើងវិញកើតឬ?[3]លោក
ថូប៊ីយ៉ាសាសន៍អាំម៉ូន ដែលឈរក្បែរគាត់ហើយលោកក៏មានប្រសាសន៍ថា៖ «បើគ្រាន់តែមានកញ្ជ្រោងមួយឡើងពីលើសំណង់ដែលពួកគេកំពុងសង់នេះ កំផែងនោះមុខជា
រលំមិនខាន!»
[4]ព្រះជាម្ចាស់នៃយើងអើយ សូមស្តាប់ចុះ ដ្បិតយើងខ្ញុំត្រូវបានគេមើលងាយណាស់។ សូមបង្វែរពាក្យតិះដៀលរបស់គេទៅលើក្បាលពួកគេវិញ ហើយសូមប្រគល់គេឲ្យ
សត្រូវរឹបអូសនៅក្នុងស្រុកដែលគេជាប់ជាឈ្លើយនោះទៅ។[5]សូមកុំគ្របបាំងភាពទុច្ចរិតរបស់គេ ហើយកុំលុបអំពើបាបរបស់គេចេញពីព្រះនេត្ររបស់ព្រះអង្គឡើយ ដ្បិតគេ
បានបណ្តាលឲ្យព្រះអង្គមានសេចក្តីក្រោធ នៅចំពោះពួកអ្នកសង់កំផែងនេះឡើងវិញ។[6]ដូច្នេះ ពួកយើងនាំគ្នាសង់កំផែងឡើង ហើយកំផែងក៏បានតភ្ជាប់គ្នាជុំវិញរហូតដល់
បានកម្ពស់ពាក់កណ្តាល ដ្បិតប្រជាជនបានធ្វើការយ៉ាងស្វាហាប់។

generated on Wed Sep 10 16:16:32 2025

[7]ប៉ុន្តែ កាលលោកសានបាឡាត និងលោកថូប៊ីយ៉ា ពួកអារ៉ាប់ និងពួកអាំម៉ូនហើយ ព្រមទាំងពួកអាសដូឌបានឮថា ការជួសជុលកំផែងក្រុងយេរូសាឡិមចេះតែបានចម្រើនឡើង ហើយថា កន្លែងបាក់បែកចាប់ផ្តើមភ្ជិតឡើងវិញ នោះពួកគេខឹងជាខ្លាំង។[8]ពួកគេទាំងអស់គ្នាក៏បឃុបឃិតគ្នាដើម្បីមកវាយក្រុងយេរូសាឡិម ហើយបង្កឲ្យមានការច្របូកច្របល់។[9]ប៉ុន្តែ យើងក៏បានអធិស្ឋានដល់ព្រះជាម្ចាស់នៃយើង ហើយចាត់ចែងឲ្យមានអ្នកយាមល្បាត ដើម្បីការពារទាំងយប់ទាំង
ថ្ងៃដោយព្រោះការគំរាមកំហែងរបស់ពួកគេ។
[10]ពេលនោះ ជនជាតិយូដាបាននិយាយថា៖ «កម្លាំងរបស់អស់អ្នកដែលលីសែងចេះតែចុះខ្សោយ។ មានគំនរបែកបាក់ច្រើនពេក យើងពុំអាចសង់កំផែងឡើងវិញបានទេ»។
[11]ខ្មាំងសត្រូវរបស់យើងនិយាយថា៖ «ពួកគេនិងមិនដឹង ឬឃើញអ្វីដែលកើតឡើងទេ រហូតទាល់តែយើងចូលទៅក្នុងចំណោមពួកគេ ហើយសម្លាប់ពួកគេ ដើម្បីបញ្ឈប់កិច្ចការនោះ»។
[12]នៅគ្រានោះជនជាតិយូដាដែលរស់នៅក្បែរពួកគេនាំគ្នាធ្វើដំណើរមកពីគ្រប់ទិសទី ហើយបាននិយាយដល់ទៅដប់ដង
ដោយព្រមានយើងអំពីគំរោងការដែលពួកគេកំពុងប្រឆាំងនឹងយើង។[13]ដូច្នេះ ខ្ញុំក៏ដាក់ប្រជាជននៅកន្លែងទាបៗពីក្រោយកំផែង នៅកន្លែងដែលមើលឃើញច្បាស់។ ខ្ញុំក៏ដាក់ពួកគេតាមអំបូររបស់ពួកគេរៀងៗខ្លួនទាំងកាន់ដាវ កាន់លំពែង និងធ្នូរបស់គេ។[14]កាលខ្ញុំបានត្រួតពិនិត្យមើលរួចហើយ ខ្ញុំក៏ក្រោកឡើង ហើយនិយាយទៅកាន់ពួកអភិជន និងពួកអ្នកគ្រប់គ្រង ព្រមទាំងប្រជាជនឯទៀតៗថា៖ «កុំខ្លាចពួកគេឡើយ។ ចូរនឹកចាំពីព្រះអម្ចាស់ ដែលទ្រង់ធំ ហើយដែលគួរឲ្យស្ញប់ស្ញែង។ ហើយត្រូវប្រយុទ្ធការពារពួកបងប្អូន កូនប្រុស កូនស្រី ប្រពន្ធ និងលំនៅដ្ឋានរបស់អ្នករាល់គ្នា»។
[15]កាលខ្មាំងសត្រូវរបស់យើងបានដឹង ពីផែនការរបស់គេត្រូវបានយើងដឹង ហើយព្រះអង្គបានរំលាយផែនការរបស់គេ នោះយើងទាំងអស់គ្នាក៏វិលទៅកំផែងក្រុង តាមកិច្ចការរបស់យើងរៀងៗខ្លួនវិញ។[16]ដូច្នេះ ចាប់ពីថ្ងៃនោះមក ពួកអ្នកបម្រើរបស់ខ្ញុំពាក់កណ្តាល បានធ្វើការសង់សាងកំផែងក្រុង ហើយពាក់កណ្តាលទៀត កាន់លំពែង កាន់ខែល កាន់ធ្នូ និងពាក់អាវក្រោះ កំឡុងពេលដែលមេដឹកនាំ ក៏ឈរនៅពីក្រោយពួកយូដាទាំងអស់គ្នាដែរ។
[17]ពួកក្រុមជាងដដែលនោះ ដែលកំពុងសង់កំផែងក្រុង ហើយត្រូវលីសែង ហើយដឹកជញ្ជូនទៅដល់គោលដៅរបស់គេ។ គេធ្វើការដោយដៃម្ខាង ហើយដៃម្ខាងទៀតកាន់គ្រឿងសស្ត្រាវុធ។[18]ចំណែកពួកជាងសង់ម្នាក់ៗ សុទ្ធតែស្ពាយដាវជាប់នឹងខ្លួន ហើយនេះជារបៀបដែរពួកគេធ្វើការ។ ចំណែកឯអ្នកដែលផ្លុំត្រែ គឺឈរនៅក្បែរខ្ញុំ។
[19]ខ្ញុំពោលទៅកាន់ពួកអភិជន ពួកអ្នកគ្រប់គ្រង និងប្រជាជនឯទៀតៗថា៖ «កិច្ចការនេះធំ ហើយនៅសល់កិច្ចការជាច្រើនទៀត យើងក៏នៅដាច់ពីគ្នានៅលើកំផែងទៀត។[20]អ្នករាល់គ្នាគួរតែរុះរាន់ទៅកន្លែងដែលអ្នកឮសូរត្រែ ហើយប្រមូលគ្នានៅទីនោះ។ ព្រះជាម្ចាស់នៃយើងនឹងប្រយុទ្ធជំនួសយើង»។
[21]ដូច្នេះ យើងក៏បានខំប្រឹងធ្វើការ។ ពួកគេពាក់កណ្តាលកាន់លំពែង ចាប់តាំងពីថ្ងៃរះ រហូតដល់ផ្កាយលេចចេញមក។[22]នៅគ្រានោះ ខ្ញុំក៏ប្រាប់ប្រជាជនថា៖ «ត្រូវឲ្យគ្រប់គ្នាព្រមទាំងពួកអ្នកបម្រើរបស់ខ្លួន ដេកនៅក្រុងយេរូសាឡិម ដើម្បីឲ្យគេជួយការពារយើងនៅពេលយប់ ហើយធ្វើការនៅពេលថ្ងៃ»។[23]ដូច្នេះ ទោះជាខ្ញុំ ឬបងប្អូន ពួកអ្នកបម្រើរបស់ខ្ញុំ ឬពួកអ្នកការពារដែលមកតាមខ្ញុំក្តី គ្មានអ្នកណាបានដោះសម្លៀកបំពាក់ចេញឡើយ ហើយម្នាក់ៗនៃពួកយើងកាន់អាវុធជាប់ ទោះបីពួកគេទៅផឹកទឹកក៏ដោយ។

Nehemiah 4:1

កាលលោកសានបាឡាត

ត្រង់នេះលោកនេហេមានប្រើពាក្យថា «ឥឡូវ» ដើម្បីបង្ហាញជាផ្នែកថ្មីនៃរឿង។

សានបាឡាត និងថូប៊ីយ៉ា

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ បងប្រែដូចនៅក្នុងជំពូកទី ២:៩។

វាបានធ្វើឲ្យគាត់ក្តៅក្រហាយ ហើយខឹងក្រេវក្រោធជាខ្លាំង

ត្រង់នេះ «វា»
សំដៅទៅលើការដឹងរបស់លោកសានបាឡាតដែលថាជនជាតិយូដាកំពុងសង់កំពែងឡើងវិញ។ នេះនិយាយពីសានបាឡាតក្លាយជាខឹងយ៉ាងខ្លាំងដូចជាកំហឹងរបស់គាត់គឺជាភ្លើងដែលកំពុងឆេះ

ការបកប្រែរបៀបផ្សេងទៀត: «គាត់ខឹងក្រេវក្រោធជាខ្លាំង» ឬ
«គាត់បានខឹងយ៉ាងខ្លាំង»

តើអ្វីទៅជាភាពទន់ខ្សោយទាំងនេះ ... តើពួកគេនឹងស្តារ ... ពួកគេនឹងផ្តល់ជូន ... តើពួកគេនឹងបញ្ចប់ការងារក្នុងមួយថ្ងៃ?

លោកសានបាឡាតដាក់សំណួរទាំងនេះដើម្បីចំអកដល់ជនជាតិយូដា។

ទាំងនេះអាចត្រូវបានសរសេរជាសេចក្តីថ្លែង។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ជនជាតិយូដាដែលទន់ខ្សោយទាំងនេះមិនអាចធ្វើអ្វីបានឡើយ។
ពួកគេនឹងមិនស្តារទីក្រុងឡើងវិញដោយខ្លួនឯងឡើយ។»

ជនជាតិយូដាដែលទន់ខ្សោយ

«ជនជាតិយូដាដែលទន់ខ្សោយ»

ក្នុងរយៈពេលមួយថ្ងៃ

នេះនិយាយអំពីការមិនបញ្ចប់អ្វីមួយយ៉ាងឆាប់រហ័សដោយនិយាយថាវាមិនអាចធ្វើបានក្នុងរយៈពេលមួយថ្ងៃ

ការបកប្រៀបរបៀបផ្សេងទៀត: «ឲ្យលឿន»

តើគេយកថ្មពីគំនរសំរាម ដែលឆេះអស់ទៅហើយ មករៀបឡើងវិញកើត

លោកសាន់បាឡាតក៏ដាក់សំណួរនេះដើម្បីចំអកដល់ជនជាតិយូដា។

នេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។ ការបកប្រែរបៀបផ្សេងទៀត:
«កគេនឹងមិននាំយកថ្មពីគំនរបាក់បែកដែលត្រូវបានដុតបំផ្លាញឡើងវិញទេ។»

ពីគំនរសំរាម ដែលឆេះអស់ទៅហើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពីគំនរបាក់បែកដែលមាននរណាម្នាក់បានដុត»

បើគ្រាន់តែមានកញ្ជ្រោងមួយឡើងពីលើ កំផែងនោះមុខជារលំមិនខាន

លោកសានបាឡាតមើលងាយកំពែងហើយនិយាយបំផ្លើសថាវាខ្សោយប៉ុណ្ណាដោយនិយាយថាកញ្ជ្រោងតូចមួយអាចធ្វើឱ្យកំពែងរលំបាន។ ការបកប្រែរបៀបផ្សេងទៀត:
«កំពែងដែលពួកគេកំពុងសាងសង់គឺខ្សោយណាស់សូម្បីតែកញ្ជ្រោងតូចមួយឡើងលើ

Nehemiah 4:4

សូមស្តាប់ចុះ ព្រះជាម្ចាស់នៃយើងអើយ ដ្បិតគេបានបណ្តាលឲ្យសង់កំពែងនេះមានសេចក្តីក្រោធ

ត្រង់កន្លែងនេះគឺលោកនេហេមាបានអធិស្ឋានទៅព្រះជាម្ចាស់។

នេះអាចបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត៖ «បន្ទាប់មកខ្ញុំបានអធិស្ឋាន

សូមស្តាប់ទូលបង្គំព្រះជាម្ចាស់នៃយើងអើយ
ព្រោះពួកគេបានធ្វើអោយអ្នកសាងសង់ខឹង»

សូមស្តាប់ចុះ ព្រះជាម្ចាស់នៃយើងអើយ ដ្បិតគេមើលងាយយើងខ្ញុំហើយ

ពាក្យថា «យើង» គឺសំដៅទៅជនជាតិយូដា។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត៖
«សូមឆ្លើយតបព្រះជាម្ចាស់នៃយើងអើយ
ដ្បិតសត្រូវរបស់យើងបានមើលងាយយើងហើយ។»

ហើយសូមប្រគល់គេឲ្យសត្រូវរឹបអូស

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត៖
«ចូរឲ្យសត្រូវបានប្លន់របស់ពួកគេចុះ»

សូមបង្វែរពាក្យតិះដៀលរបស់គេ ទៅលើក្បាលគេវិញ

ឃ្លា «ពាក្យតិះដៀលរបស់គេ»
សំដៅទៅលើការប្រមាថរបស់លោកសានបាឡាតនិងលោកថូប៊ីយ៉ា។ ពាក្យ
«ក្បាល» គឺសមដៅទៅមនុស្សទាំងអស់។ ការបកប្រែរបៀបផ្សេងទៀត: «សូមបង្វែរ
ពាក្យតិះដៀលរបស់គេ ទៅលើពួកគេវិញ»

សូមកុំគ្របបាំង

នេះនិយាយអំពីការអភ័យទោសពីអំពើបាបរបស់មនុស្សម្នាក់
ដូចជាពួកគេជាវត្ថុមួយដែលអាចលាក់ខ្លួនបាន។ ការបកប្រែរបៀបផ្សេងទៀត:
«កុំអភ័យទោសឲ្យពួកគេ»

កុំលុបអំពើបាបរបស់គេចេញពីព្រះភក្ត្រព្រះអង្គឡើយ

នេះនិយាយពីការបំភ្លេចអំពើបាបរបស់មនុស្សម្នាក់ដូចជាពួកគេត្រូវបានសរសេរដែលអាចត្រូវបានលុបចោ
ការបកប្រែរបៀបផ្សេងទៀត: «កុំបំភ្លេចបាបរបស់ពួកគេឡើយ»។

ដ្បិតគេបានបណ្តាលឲ្យព្រះអង្គមានសេចក្តីក្រោធ

«ពួកគេបានធ្វើឲ្យអ្នកសាងសង់ខឹងក្រោធ»

ដូច្នេះ ពួកយើងនាំគ្នាសង់កំពែងឡើង

«ដូច្នេះ ពួកយើងនាំគ្នាសង់កំពែងឡើង»

ហើយកំពែងក៏បានតភ្ជាប់គ្នាជុំវិញ រហូតដល់បានកម្ពស់ពាក់កណ្តាល

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបានធ្វើឲ្យកំពែងតភ្ជាប់គ្នា រហូតដល់បានកម្ពស់ពាក់កណ្តាល»។

កម្ពស់ពាក់កណ្តាល

Nehemiah 4:7

generated on Wed Sep 10 16:16:32 2025

ពួកគេខឹងជាខ្លាំង
នេះនិយាយពីមនុស្សដែលមានកំហឹងយ៉ាងខ្លាំងដូចជាកំហឹងរបស់ពួកគេគឺជាអ្វីដែលបានកើតឡើងចំពោះពួកគេ។ ការបកប្រែរបៀបផ្សេងទៀត៖ «ពួកគេបានខឹងជាខ្លាំង» ឬ «ពួកគេអន់ចិត្ត»
ប្រឆាំងនឹងក្រុងយេរូសាលិម
ពាក្យ «យេរូសាឡិម» គឺសំដៅទៅលើមនុស្សដែលរស់នៅទីនោះ។ ការបកប្រែរបៀបផ្សេងទៀត៖ «ប្រឆាំងនឹងប្រជាជនយេរូសាឡិម»
ចាត់ចែងឲ្យមានអ្នកយាមល្បាត ដើម្បីការពារ
«ដាក់មនុស្សជំរិញកំពែងដើម្បីការពារទីក្រុង» (UDB)
Nehemiah 4:10
មានគំនរបែកបាក់ច្រើនពេក
គំនរបែកបាក់ «ថ្មដែលត្រូវបានឆេះ» ឬ «ថ្មដែលបាក់បែក» ឬ «ថ្មដែលប្រើការមិនកើត។»
ពួកគេនិងមិនដឹងខ្លួន ឬឃើញអ្វីដែលកើតឡើង រហូតទាល់តែយើងនឹងចូលទៅក្នុងចំណោមពួកគេ
«ពួកគេនឹងមិនឃើញយើងមករហូតដល់យើងនៅក្បែរពួកគេ»
Nehemiah 4:12
មកពីគ្រប់ទិសទី
នេះតំណាងឲ្យទិសដៅជាច្រើន។ ពាក្យ «ទាំងអស់» គឺដំណាងឲ្យ «ជាច្រើន»។ ការបកប្រែរបៀបផ្សេងទៀត៖ «មកពីកន្លែងជាច្រើន»
និយាយមកកាន់យើងដប់ដង?
ត្រង់កន្លែងលេខ១០គឺប្រើសម្រាប់សំគាល់ «ច្រើន»។ ការបកប្រែរបៀបផ្សេងទៀត: «និយាយទៅកាន់ជាច្រើនដង»
កន្លែងដែលមើលឃើញច្បាស់
«កន្លែងកិត្តិយស»
ក៏ដាក់ពួកគេតាមអំបូររបស់ពួកគេ
នេះគឺសំដៅទៅលើមនុស្សជាច្រើនដែលមកពីគ្រួសារៀងៗខ្លួន ដោយជាទូទៅគេមិនរាប់បញ្ចូលស្ត្រី និងកូនក្មេងឡើយ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានតាំងមនុស្សដែលមកគ្រួសាររបស់គេ»
ចូរនឹកចាំពីព្រះអម្ចាស់
ឃ្លាថា «ហៅអោយចាំ» មានន័យថាត្រូវចាំ។ ការបកប្រែរបៀបផ្សេងទៀត: «សូមនឹកចាំពីព្រះអម្ចាស់»
Nehemiah 4:15
វាបានកើតឡើង
«វាបានកើតឡើង»
ផែនការរបស់ពួកគេត្រូវបានដឹងដោយសារយើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «យើងបានដឹងពីផែនការរបស់ពួកគេ»
កិច្ចការរបស់អ្នកបម្រើរបស់ខ្ញុំ
កិច្ចការរបស់ខ្ញុំ
បម្រើរបស់ខ្ញុំពាក់កណ្តាល ពាក់កណ្តាលនៃពួកគេ
«ពាក់កណ្តាល» មានន័យថាផ្នែកមួយក្នុងចំណោមពីរផ្នែកស្មើគ្នា។ (សូមមើល: ranslate-fraction)
ពួកមេដឹកនាំ ក៏ឈរនៅពីក្រោយមនុស្សទាំងអស់
«ពួកមេដឹកនាំ តាំងខ្លួនៗឲ្យឈរនៅពីក្រោយមនុស្សទាំងអស់»
Nehemiah 4:17
គេធ្វើការដោយដៃម្ខាង ហើយដៃម្ខាងទៀតកាន់គ្រឿងសស្ត្រាវុធ
នេះគឺជាការបំផ្លើសមួយ។ ពួកគេមិនដែលធ្វើការដោយដៃតែម្ខាងនោះទេប៉ុន្តែពួកគេតែងតែមានអាវុធរបស់ពួកគេជាមួយពួកគេដូច្នេះ
Nehemiah 4:19
ខ្ញុំបាននិយាយ
ពាក្យថា «ខ្ញុំ» គឺសំដៅទៅលោកនេហេមា។
ពួកអភិជន.... ពួកអ្នកគ្រប់គ្រង
ទាំងនេះគឺជាពួកអ្នកដឹកនាំដោយយោងទៅតាមជំពូកទី ៤:១៥។
កិច្ចការនេះអស្ចារ្យ
ពាក្យថា «អស្ចារ្យ» មានន័យថា «មានទំហំធំ» ឬ «ធំសម្បើម»។
សូរសម្លេងត្រែ
នេះសំដៅទៅលើនរណាម្នាក់ផ្លុំត្រែ។ ការបកប្រែរបៀបផ្សេងទៀត: «មាននរណាម្នាក់កំពុងផ្លុំត្រែ»
Nehemiah 4:21
ពាក់កណ្តាលនៃពួកគេ
«ពាក់កណ្តាល» មានន័យថាផ្នែកមួយក្នុងចំណោមពីរផ្នែកស្មើគ្នា។ (សូមមើល៖ ranslate-fraction)
ចាប់តាំងពីថ្ងៃរះ រហូតដល់ផ្កាយលេចចេញមក។
នេះសំដៅទៅលើពេញមួយថ្ងៃខណៈពេលដែលវាមានពន្លឺនៅខាងក្រៅ។ ការបកប្រែរបៀបផ្សេងទៀត: «តាំងពីពន្លឺថ្ងៃដំបូងរហូតដល់ព្រលប់»
ចាប់តាំងពីថ្ងៃរះ
វាគឺជាចំណុចនៅក្នុងពេលវេលាដែលព្រះអាទិត្យរះដែលជា «ព្រឹកព្រលឹម» ។ ការបកប្រែរបៀបផ្សេងទៀតើ: «ការរះឡើងនៃព្រះអាទិត្យ» ឬ «ព្រឹកប្រលឹម»
នៅកណ្តាលក្រុងយេរូសាឡិម
«នៅក្រុងយេរូសាឡិម»
ផ្លាស់ប្តូរសម្លៀកបំពាក់របស់យើង
«ដោះសម្លៀកបំពាក់របស់យើងចេញ»

---

5 [1]នៅគ្រានោះ ពួកបរុស និងប្រពន្ធរបស់ពួកគេបានស្រែកជាខ្លាំងឡើងទាស់នឹងពួកបងប្អូនរបស់គេជាសាសន៍យូដា។[2]ដ្បិតមានអ្នកខ្លះពោលថា៖ «យើងខ្ញុំ និងកូនប្រុសកូនស្រីរបស់យើងខ្ញុំ មានគ្នាជាច្រើន។ សូមឲ្យយើងខ្ញុំមានអាហារ ដើម្បីទទួលទាន ហើយរស់នៅផង»។[3]មានអ្នកខ្លះទៀតនិយាយថា៖ «យើងខ្ញុំបានបញ្ចាំស្រែចម្ការ និងផ្ទះសំបែងរបស់យើងខ្ញុំអស់ហើយ សូមឲ្យយើងខ្ញុំមានអាហារទទួលទាន នៅគ្រាគ្រោះទុរ្ភិក្សនេះផង»។
[4]មានអ្នកខ្លះទៀតក៏បាននិយាយថា៖ «យើងខ្ញុំបានខ្ចីប្រាក់គេ ដើម្បីបង់ពន្ធថ្វាយស្តេចសម្រាប់ស្រែចម្ការរបស់យើង ។[5]ប៉ុន្តែ យើងខ្ញុំ និងពួកបងប្អូនរបស់យើងខ្ញុំ មានសាច់ឈាមដូចគ្នា កូនចៅរបស់យើងខ្ញុំ ក៏ដូចជាកូនចៅរបស់ពួកគេដែរ។ យើងខ្ញុំត្រូវបង្ខំចិត្តលក់កូនប្រុស កូនស្រីរបស់យើងខ្ញុំឲ្យទៅធ្វើជាទាសកររបស់គេ។ ហើយកូនស្រីរបស់យើងខ្ញុំ ខ្លះក៏បានជាប់ជាទាសកររបស់គេរួចទៅហើយ។ យើងខ្ញុំទាល់ច្រកហើយ ដ្បិតស្រែចម្ការរបស់យើងខ្ញុំក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកដទៃដែរ»។
[6]ខ្ញុំមានខឹងខ្លាំងណាស់ នៅពេលដែលខ្ញុំបានឮសម្រែករបស់ពួកគេ និងពាក្យទាំងអស់នេះ ។[7]ខ្ញុំក៏បានគិតក្នុងចិត្ត ហើយបន្ទោសពួកអភិជន និងពួកអ្នកគ្រប់គ្រង។ ខ្ញុំបាននិយាយទៅពួកគេថា៖ «អ្នករាល់គ្នាកំពុងតែទារយកការប្រាក់ពីពួកបងប្អូនរបស់ខ្លួន»។ ខ្ញុំក៏រៀបចំឲ្យមានការប្រជុំមួយយ៉ាងធំទាស់នឹងពួកគេ[8]ហើយខ្ញុំនិយាយទៅគេថា៖ «យើងបានលោះពួកបងប្អូនរបស់យើងជាសាសន៍យូដា ដែលត្រូវគេលក់ទៅឲ្យសាសន៍ដទៃ តាមតែអាចធ្វើទៅបាន តែឥឡូវនេះ អ្នករាល់គ្នាបែរជាលក់ពួកបងប្អូនរបស់ខ្លួន ក្នុងចំណោមពួកគេត្រូវបានលក់មកវិញ!» គេក៏នៅស្ងៀម រកពាក្យឆ្លើយមិនបានឡើយ។
[9]ដូច្នេះ ខ្ញុំបាននិយាយថា៖ «អ្វីដែលអ្នកបានធ្វើនេះមិនល្អទេ។ តើអស់លោកមិនគួរដើរ ដោយការគោរពកោតខ្លាចដល់ព្រះជាម្ចាស់នៃយើង ដើម្បីទប់ស្កាត់កុំឲ្យសាសន៍ដទៃដែលជាខ្មាំងសត្រូវរបស់យើង ត្មះតិះដៀលយើងទេឬ?[10]ខ្ញុំ និងបងប្អូនរបស់ខ្ញុំ ព្រមទាំងពួកអ្នកបម្រើរបស់ខ្ញុំ ក៏បានឲ្យប្រាក់ និងស្រូវទៅពួកគេខ្ចីដែរ។ ប៉ុន្តែយើងគួរតែឈប់យកការពីពួកគេ។[11]សូមប្រគល់ស្រែ ចម្ការទំពាំងបាយជូរ ចម្ការអូលីវ និងផ្ទះសំបែងរបស់គេ ទៅគេវិញនៅថ្ងៃនេះទៅ ព្រមទាំងកុំទារប្រាក់ ស្រូវ ទឹកទំពាំងបាយជូរ និងប្រេងដែលអស់លោកបានយកការពីគេនោះផង»។
[12]ពេលនោះ គេឆ្លើយថា៖ «យើងខ្ញុំនឹងប្រគល់អ្វីដែលយើងបានយកពីពួកគេឲ្យទៅពួកគេវិញ ហើយយើងក៏មិនទាមទារអ្វីពីពួកគេទៀតដែរ។ យើងខ្ញុំនឹងធ្វើតាមពាក្យដែលលោកមានប្រសាសន៍»។ បន្ទាប់មកខ្ញុំក៏ហៅពួកបូជាចារ្យមកហើយឲ្យអ្នកទាំងនោះស្បថថា ពួកគេនឹងធ្វើតាមពាក្យសន្យា។[13]ខ្ញុំក៏រលាស់ថ្នក់អាវរបស់ខ្ញុំ ហើយពោលថា៖ «អ្នកណាមិនធ្វើតាមពាក្យសន្យានេះ សូមឲ្យព្រះរលាស់គ្រួសារ និងទ្រព្យសម្បត្តិរបស់អ្នកណាដែលមិនធ្វើតាមសន្យា។ ដូច្នេះ សូមឲ្យគេរលាស់ចេញ ហើយនៅទទេ»។ អង្គប្រជុំទាំងមូលក៏ឆ្លើយឡើងថា "អាម៉ែន" ហើយសរសើរតម្កើងព្រះអម្ចាស់ ហើយប្រជាជនក៏ធ្វើតាមពាក្យដែលពួកគេបានសន្យា។
[14]ដូច្នេះ ចាប់តាំងពីពេលដែលខ្ញុំត្រូវបានតែងតាំងឲ្យធ្វើជាទេសាភិបាលរបស់ពួកគេនៅស្រុកយូដា គឺចាប់តាំងពីឆ្នាំទីម្ភៃ រហូតដល់ឆ្នាំទីសាមសិបពីរ ក្នុងរជ្ជកាលព្រះបាទអើថាស៊ើកសេស គឺរយៈពេលដប់ពីរឆ្នាំ នោះខ្ញុំ និងបងប្អូនរបស់ខ្ញុំ មិនបានទទួលទានរបបអាហារជាទេសាភិបាលឡើយ។[15]តែពួកទេសាភិបាលដែលកាន់ស្រុកមុនខ្ញុំ បានដាក់បន្ទុកយ៉ាងធ្ងន់លើប្រជាជន ហើយបានប្រាក់ពីប្រជាជន សែសិបសេកែលសម្រាប់អាហារ និងស្រាប្រចាំថ្ងៃរបស់ពួកគេទៀតផង។ សូម្បីតែពួកអ្នកបម្រើរបស់គេ ក៏ធ្វើខ្លួនដូចជាម្ចាស់លើប្រជាជនដែរ។ តែខ្ញុំមិនបានធ្វើដូច្នោះទេ ដោយសារតែកោតខ្លាចដល់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

[16]ខ្ញុំក៏នៅតែបន្តកិច្ចការសង់កំផែង ហើយយើងក៏មិនបានទិញដីឯណាដែរ ហើយពួកអ្នកបម្រើរបស់ខ្ញុំទាំងប៉ុន្មានសុទ្ធតែបានរួមគ្នាមកជួយធ្វើកិច្ចការនេះ។
[17]នៅតុរបស់ខ្ញុំមានពួកយូដា និងពួកមន្ត្រី១៥០នាក់ និងអ្នកដែលមកជាមួយយើងជាច្រើនទៀត ពីពួកជនជាតិដទៃនៅជុំវិញយើង។
[18]ពេលនេះអ្វីដែលត្រូវរៀបចំក្នុងមួយថ្ងៃៗ គឺគោមួយ ចៀមសម្រាំងប្រាំមួយ ព្រមទាំងសត្វស្លាបដែរ ដែលគេរៀបចំឲ្យខ្ញុំ ហើយដប់ថ្ងៃម្តង មានស្រាទំពាំងបាយជូរគ្រប់ប្រភេទជាបរិបូរទៀតផង ប៉ុន្តែ ទោះបើច្រើនដល់ម្លេះ ក៏ខ្ញុំមិនបានទាមទាររបបអាហារ ដោយអាងសិទ្ធិជាទេសាភិបាលឡើយ ព្រោះបន្ទុកដ៏ធ្ងន់ដល់ប្រជាជន។[19]ឱព្រះនៃទូលបង្គំអើយ សូមនឹកចាំពីការល្អរបស់ទូលបង្គំផង គឺការទាំងប៉ុន្មានដែលទូលបង្គំបានប្រព្រឹត្តចំពោះប្រជាជននេះ។

Nehemiah 5:1

នៅគ្រានោះ ពួកបរុស និងប្រពន្ធរបស់ពួកគេបានស្រែកជាខ្លាំងឡើងទាស់នឹងពួកបងប្អូនរបស់គេជាសាសន៍យូដា

ចាប់តាំងពីពួកគេធ្វើការនៅលើកំពែងអ្នកធ្វើការមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការងារ និងទិញ ព្រមទាំងដាំដំណាំសម្រាប់គ្រួសាររបស់ពួកគេទេ។

អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។

បុរសនិងប្រពន្ធរបស់ពួកគេ

នេះគឺចង់សំដៅទៅលើបុរសដែលធ្វើការនៅលើអាគារកំពែង។

ស្រែកជាខ្លាំងឡើង

ពាក្យថា «ស្រែក» អាចបញ្ជាក់ពីកិរិយាសព្ទបាន។ ការបកប្រែរបៀបផ្សេងទៀត: «ស្រែកយ៉ាងខ្លាំង»

យើងខ្ញុំបានបញ្ចាំស្រែចម្ការ

«យើងបានដាក់បញ្ចាំ» ឬ «យើងត្រូវឲ្យបញ្ចាំ»

Nehemiah 5:4

ប៉ុន្តែ យើងខ្ញុំ និងពួកបងប្អូនរបស់យើងខ្ញុំ មានសាច់ឈាមដូចគ្នា កូនចៅរបស់យើងខ្ញុំ ក៏ដូចជាកូនចៅរបស់ពួកគេ

នៅទីនេះជនជាតិយូដាកំពុងបញ្ជាក់ថាពួកគេមានដើមកំណើតជាជនជាតិយូដាដូចគ្នានឹងសមាជិកក្រុមគ្រួសាររបស់មនុស្សម្នាក់និងរបៀបដែលគេរស់នៅ។ ហើយថាពួកគេមានសារៈសំខាន់ដូចគ្នានឹងជនជាតិដទៃទៀតដែរ។

អត្ថន័យនៃរឿងនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែ យើងខ្ញុំ និងពួកបងប្អូនរបស់យើងខ្ញុំ ក៏មានដើមកំណើតជាជនជាតិយូដាដូចគ្នានឹងជនជាតិយូដាផ្សេងទៀត ហើយកូនចៅរបស់យើងខ្ញុំក៏មានសារៈសំខាន់ដូចកូនចៅនៃជនជាតិយូដាផ្សេងទៀតដែរ»

សាច់ឈាមរបស់យើង

នេះគឺជាប្រយោឡដើម ដែលសំដៅទៅលើសមាជិកគ្រួសាររបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «គ្រួសាររបស់យើង»

កូនប្រុសកូនស្រីរបស់យើងខ្ញុំ ទៅធ្វើជាខ្ញុំបម្រើគេ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «យើងបានលកកូនប្រុសកូនស្រីរបស់យើងឲ្យធ្វើជាទាសករ»

ដ្បិតស្រែចម្ការរបស់យើងខ្ញុំក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកដទៃដែរ

ដោយសារដីស្រែនិងចម្ការទំពាំងបាយជូរមិនមែនជារបស់ពួកគេទេពួកគេមិនអាចផលិតប្រាក់ដែលពួកគេត្រូវការដើម្បីផ្គត់ផ្គង់គ្រួសារបានទេ។

អត្ថន័យពេញលេញនេះអាចត្រូវបានបញ្ជាក់ច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែយើងមិនអាចផ្លាស់ប្តូរស្ថានភាពនេះបានទេពីព្រោះមានអ្នកផ្សេងទៀតជាម្ចាស់ដីស្រែនិងចម្ការទំពាំងបាយជូររបស់យើង ដែលយើងត្រូវការដើម្បីផ្គត់ផ្គង់ជីវិតរបស់យើង។»

Nehemiah 5:6

ខ្ញុំបានឮសម្រែករបស់ពួកគេ

ពាក្យថា «សម្រែក» អ្នកអាចបកប្រែដោយប្រើកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលខ្ញុំបានឮពួកគេស្រែកឡើង»

អ្នករាល់គ្នាកំពុងតែទារយកការប្រាក់ពីពួកបងប្អូនរបស់ខ្លួន

ជនជាតិយូដាគ្រប់រូបដឹងថាខុសនឹងច្បាប់ក្នុងការគិតការប្រាក់ដល់ជនជាតិយូដាម្នាក់ទៀតឡើយ។

អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាកំពុងតែទារយកការប្រាក់ពីពួកបងប្អូនរបស់ខ្លួន ហើយការទាំងនេះគឺវាខុសនឹងច្បាប់»

ខ្ញុំក៏រៀបចំឲ្យមានការប្រជុំមួយយ៉ាងធំទាស់នឹងពួកគេ

នេះមានន័យថាគាត់បានប្រមូលផ្តុំមនុស្សមួយក្រុមធំហើយបានចោទប្រកាន់ពួកគេ។

អត្ថន័យនៃប្រយោគនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំក៏រៀបចំឲ្យមានការប្រជុំមួយយ៉ាងធំទាស់នឹងពួកគេ» ឬ «ញុំបានជំនុំជម្រះពួកគេនៅមុខអង្គប្រជុំ»

តែឥឡូវនេះ អ្នករាល់គ្នាបែរជាលក់ពួកបងប្អូនរបស់ខ្លួន ក្នុងចំណោមពួកគេត្រូវបានលក់មកវិញ

នេះមានន័យថាពួកគេកំពុងលក់សមាជិកគ្រួសាររបស់ពួកគេជាទាសករដល់ជនជាតិយូដាដែលបានរស់នៅជុំវិញពួកគេ។

អត្ថន័យពេញលេញនៃប្រយោគនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «ឥឡូវនេះ អ្នករាល់គ្នាបែរជាលក់ពួកបងប្អូនរបស់ខ្លួនក្នុងចំណោមពួកគេត្រូវបានលក់មកវិញ»

តើអ្នកណាដែលត្រូវបានលក់ទៅកាន់ប្រជាជាតិនានា

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «តើមនុស្សរបស់អ្នកណាដែលត្រូវបានលក់ឲ្យធ្វើជាទាសកររនៅប្រជាជាតិនានា»

Nehemiah 5:9

ដូច្នេះ ខ្ញុំក៏និយាយ

សព្វនាម «ខ្ញុំ» សំដៅទៅលើលោកនេហេមា។

តើអ្នកកំពុងធ្វើអ្វី?

«អ្នក» នៅទីនេះសំដៅទៅលើពួកអភិជនយូដា។

តើអស់លោកមិនគួរដើរ ដោយការគោរពកោតខ្លាចដល់ព្រះនៃយើង ដើម្បីកុំឲ្យសាសន៍ដទៃដែលជាខ្មាំងសត្រូវរបស់យើង តុះតិះដៀលយើងទេឬ

នេះគឺជាសំដែលមិនត្រូវការចម្លើយដែលលោកនេហេមាកំពុងប្រើដើម្បីស្តីបន្ទោសពួកអភិជន។

នេះអាចបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកដោយការគោរពកោត ខ្លាចដល់ព្រះនៃយើង ដើម្បីកុំឲ្យសាសន៍ដទៃដែលជាខ្មាំងសត្រូវរបស់យើង តុះតិះដៀលយើង»

ដើរដោយការគោរពកោតខ្លាចដល់ព្រះនៃយើង

នេះគឺជាប្រយោគ។ ពាក្យ «ដើរ» សំដៅលើរបៀបរស់នៅរបស់មនុស្សម្នាក់និងរបៀបដែលគេរស់នៅ។ ការបកប្រែរបៀបផ្សេងទៀត: «រស់នៅក្នុងរបៀបដែលគោរពដល់ព្រះជាម្ចាស់»។

ការតិះដៀលរបស់ប្រជាជាតិនានាដែលជាសត្រូវរបស់យើង

ពាក្យ «តិះដៀល» មានន័យថា «និយាយអាក្រក់» ឬ «ចំអកឡកឡើយ» អ្នកអាចបកប្រែដោយប្រើកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជាតិនានាដែលជាសត្រូវរបស់យើងពីការដៀលត្មះយើង» ឬ «ប្រទេសដែលជាសត្រូវមិនអោយមើលងាយយើង»

ខ្ចី

ខ្ចីប្រាក់ ឬ ឲ្យអ្វីមួយទៅនរណាម្នាក់ដែលរំពឹងថានឹងសង

ប្រាក់កម្ចី

នេះជាប្រាក់មួយចំនួន

ស្បៀងអាហារឬទ្រព្យសម្បត្តិណាមួយដែលមនុស្សម្នាក់អាចអោយអ្នកដទៃខ្ចីដើម្បីសងបំណុល។

អ្នកខ្ចីនឹងត្រូវសងបំណុលដល់អ្នកឲ្យខ្ចី។

ប្រាក់ដែលពួកគេត្រូវការដើម្បីផ្គត់ផ្គង់គ្រួសារបានទេ។

ផ្នែកមួយនៃតម្លៃនៃប្រាក់កម្ចីដែលអ្នកខ្ចីត្រូវបានគិតការប្រាក់។

[illegible]

«អ្នកបានគិតថ្លៃពីពួកគេ» ឬ «អ្នកបានធ្វើឲ្យគេបង់ថ្លៃ»

Nehemiah 5:12

ពេលនោះគេបាននិយាយថា

ពាក្យ «ពួកគេ» គឺសំដៅទៅលើមេដឹកនាំជនជាតិយូដា។

យើងខ្ញុំនឹងប្រគល់ឲ្យពួកគេវិញ

ពួកមេដឹកនាំជនជាតិយូដាបាននិយាយថាពួកគេនឹងសងការប្រាក់ដែលពួកគេទារពីប្រជាជនក្រីក្រ។

ពួកគេស្បថ

ទីនេះពាក្យថា «ពួកគេ» គឺសំដៅទៅលើមេដឹកនាំជនជាតិយូដា។

បន្ទាប់មកខ្ញុំក៏បានហៅ

«ខ្ញុំ» គឺសំដៅទៅលោកនេហេមា។

ខ្ញុំក៏រលាស់ថ្នក់អាវរបស់ខ្ញុំ

«ខ្ញុំក៏រលាស់ថ្នក់អាវរបស់ខ្ញុំ។» ជាច្រើនដងនៅក្នុងសម្ពន្ធមេត្រីចាស់ ពាក្យសម្បថត្រូវបានបង្ហាញខាងរាងកាយជាសាក្សីចំពោះអ្វីដែលបានសន្យា។ លោកនេហេមាកំពុងបង្ហាញដល់អ្នកដឹកនាំជនជាតិយូដានូវអ្វីដែលនឹងកើតឡើងប្រសិនបើពួកគេបំពានក

សូមឲ្យព្រះរលាស់អ្នកនោះចេញពីផ្ទះ... យ៉ាងនោះ សូមឲ្យគេរលាស់ចេញ ហើយនៅខ្លួនទទេទៅ

នៅត្រង់នេះលោកនេហេមាទូលទៅកាន់ព្រះជាម្ចាស់ដកយកទ្រព្យសម្បត្តិរបស់មនុស្សចេញ [illegible] ព្រះជាម្ចាស់កំពុង រលាស់គាត់ចេញពីផ្ទះនិងទ្រព្យសម្បត្តិរបស់គាត់ដូចជាលោកជានេហេមាបានរលាស់អាវរបស់គាត់។

ការបកប្រែរបៀបផ្សេងទៀត៖

«ដូច្នេះសូមអោយព្រះជាម្ចាស់ដកហូតយកអស់អ្នកដែលមិនព្រមធ្វើតាមពាក្យសន្យាទាំងប៉ុន្មានទាំងទ្រព្យ

generated on Wed Sep 10 16:16:32 2025

និងផ្ទះរបស់គេដូចខ្ញុំដែលត្រូវបានដកយកអ្វីៗទាំងអស់ចេញពីហោពៅអាវរបស់ខ្ញុំ»

Nehemiah 5:14

ចាប់តាំងពីថ្ងៃដែលខ្ញុំត្រូវបានតែងតាំង

ពាក្យ «ខ្ញុំ» គឺសំដៅទៅលោកនេហេមា។

គឺពីឆ្នាំទីម្ភៃ រហូតដល់ឆ្នាំទីសាមសិបពីរ

ឆ្នាំទីពីរ «គឺចាប់តាំងពីឆ្នាំទីម្ភៃ រហូតដល់ឆ្នាំទីសាមសិបពីរ»

ក្នុងរជ្ជកាលព្រះបាទអើថាស៊ើកសេស

«ពេលនោះព្រះបាទអើថាស៊ើកសេសគឺជាស្តេច»

ដប់ពីរឆ្នាំ

«១២ ឆ្នាំ» ឬ «កំឡុងពេល១២ឆ្នាំ»

លោកនេហេមាកំពុងរំលឹកកឡើងវិញនូវរយៈពេលជាច្រើនឆ្នាំ

ដើម្បីបញ្ជាក់ថាគាត់បានធ្វើដូចនេះជាបន្តបន្ទាប់នៅពេលដែលលោកធ្វើជាអភិបាល។

អាហារដែលផ្តល់សម្រាប់ទេសាភិបាល

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«បរិភោគអាហារដែលប្រជាជនបានផ្តល់ឲ្យសម្រាប់ទេសាភិបាល»

ជាប្រចាំរាល់ថ្ងៃ

«ជារៀងរាល់ថ្ងៃ»

ទេសាភិបាលចាស់

«ទេសាភិបាលចាស់» ឬ «ទេសាភិបាលកាលពីមុន។»

លោកនេហេមាមិនមែនជាទេសាភិបាលទីមួយទេ។

ប្រាក់សែសិបសេកែល

«៤០ កែល» ឬ «៤០កាក់»

តែខ្ញុំមិនបានធ្វើដូច្នោះទេ ដោយសារតែកោតខ្លាចដល់ព្រះជាម្ចាស់

«ដោយព្រោះតែខ្ញុំកោតខ្លាចព្រះជាម្ចាស់ ខ្ញុំមិនបានយកអាហារទេ» ឬ «ខ្ញុំមិនបានយកអាហារទេដោយសារខ្ញុំកោតខ្លាចព្រះជាម្ចាស់»

Nehemiah 5:16

តើអ្នកណាដែលពិសាអាហារដែលនៅលើតុរបស់លោកនេហេមា?

អ្នកដែលបានពិសាអាហារដែលនៅលើតុរបស់លោកនេហេមាគឺជាពួកយូដា និងពួកមន្ត្រី១៥០នាក់ បរិភោគអាហាររួមតុជាមួយខ្ញុំ និងអ្នកដែលមកជាមួយយើងជាច្រើនទៀត ពីពួកជនជាតិដទៃនៅជុំវិញពួកគេ។

Nehemiah 5:18

ព័ត៌មានទូទៅ:

អាហារដែលត្រូវរៀបចំក្នុងមួយថ្ងៃៗ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ជារៀងរាល់ថ្ងៃខ្ញុំបានប្រាប់អ្នកបម្រើរបស់ខ្ញុំឲ្យរៀបចំ» ឬ

«រាល់ថ្ងៃខ្ញុំបានប្រាប់អ្នកបំរើរបស់ខ្ញុំអោយបំរើសាច់ពីពួកយើង»

ស្រាទំពាំងបាយជូរបរិបូរ

«ស្រាទំពាំងបាយជូរមានគ្រប់គ្រាន់សម្រាប់គ្រប់គ្នា»

ប៉ុន្តែ ទោះបីយ៉ាងនេះក្តីខ្ញុំមិនបានទាមទារប្រាក់ឧបត្ថម្ភម្ហូបអាហារពីលោកអភិបាលទេ

«ប៉ុន្តែខ្ញុំមិនដែលស្នើសុំប្រាក់ឧបត្ថម្ភម្ហូបអាហាររបស់លោកអភិបាលទេ»

សូមនឹកចាំ

នេះគឈជាប្រយោគមួយ។ សម្រាប់ស្នើសុំព្រះជាម្ចាស់ឲ្យគិតដល់លោក និងចាំពីលោក។ ការបកប្រែរបៀបផ្សេងទៀត: «សូមនឹកចាំខ្ញុំ»

ការល្អ

នេះជាសំនួរដែលមិនត្រូវការចម្លើយ

គឺជាសំណូមពរសុំឲ្យព្រះប្រទានរង្វាន់ដល់លោកនូវរបស់ល្អ ៗ ដោយសារតែអំពើល្អដែលលោកបានធ្វើសម្រាប់ប្រជាជន។

ការបកប្រែរបៀបផ្សេងទៀត: «សូមផ្តល់រង្វាន់ឲ្យខ្ញុំ» ឬ «ធ្វើឲ្យមានការល្អកើតឡើងសម្រាប់ខ្ញុំ»

---

6 [1]កាលលោកសានបាឡាត លោកថូប៊ីយ៉ា និងលោកកេសែម ជាសាសន៍អារ៉ាប់ ព្រមទាំងខ្មាំងសត្រូវរបស់យើងបានឮថា ខ្ញុំបានសង់កំផែងឡើង ហើយគ្មានកន្លែងបាក់បែកណានៅសល់ទៀត ទោះជាពេលនោះ ខ្ញុំមិនទាន់បានដាក់សន្លឹកទ្វារ តាមទ្វារនៅឡើយក៏ដោយ។[2]លោកសានបាឡាត និងលោកកេសែម ចាត់គេមកជួបខ្ញុំ និយាយថា៖ «សូមមក យើងនឹងជួបគ្នានៅភូមិណាមួយ ក្នុងជ្រលងភ្នំអូណូរ»។ ប៉ុន្តែ ពួកគេមានបំណងនឹងធ្វើបាបខ្ញុំ។
[3]ខ្ញុំក៏បានចាត់មនុស្សឲ្យទៅប្រាប់គេវិញថា៖ «ខ្ញុំកំពុងធ្វើកិច្ចការមួយយ៉ាងធំ ហើយខ្ញុំមិនអាចចុះទៅបានទេ។ ហេតុអ្វីបានជាខ្ញុំត្រូវឈប់ ដោយទុកការងារនេះចោល ហើយចុះទៅជួបលោកដូច្នេះ?»[4]ពួកគេបានចាត់មនុស្សមកប្រាប់ខ្ញុំតាមបែបដដែលនេះ ដល់ទៅបួនដង ហើយខ្ញុំក៏ឆ្លើយពាក្យដដែលទៅគេវិញ។
[5]លោកសានបាឡាតចាត់អ្នកបម្រើម្នាក់ឲ្យមកជួបខ្ញុំ តាមបែបដដែល ជាលើកទីប្រាំ មានទាំងកាន់សំបុត្រដែលបើកចំហនៅដៃផង។[6]ក្នុងសំបុត្រនោះបានសរសេរថា៖ «មានឮដំណឹងនៅគ្រប់ទាំងសាសន៍ ហើយលោកកេសែម ជាសាក្សីថា លោក និងពួកយូដាមានបំណងនឹងបះបោរ ហេតុនេះហើយបានជាលោកសង់កំផែងនេះឡើង។ តាមពាក្យដែលគេនិយាយនេះ លោកចង់ឡើងធ្វើជាស្តេចរបស់គេ។
[7]លោកក៏បានតែងតាំងពួកហោរាឲ្យប្រកាសអំពីរូបលោក នៅក្រុងយេរូសាឡិមថា មានស្តេចមួយអង្គនៅស្រុកយូដាហើយ ដំណឹងនេះនឹងឮដល់ស្តេចមិនខាន។ ដូច្នេះ សូមមក យើងនឹងនិយាយជាមួយគ្នា»។
[8]ខ្ញុំតបទៅគាត់វិញថា៖ «គ្មានការបែបនេះកើតឡើងដូចជាលោករៀបរាប់ទេ គឺលោកបានប្រឌិតរឿងទាំងនេះ ដោយគំនិតខ្លួនឯងប៉ុណ្ណោះ»។[9]ដ្បិតពួកគេមានបំណងនឹងគំរាមពួកយើង ដោយគិតថា «ពួកគេនឹងថយកម្លាំងដៃ ហើយលែងធ្វើការនោះតទៅទៀត»។ ប៉ុន្តែ ឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមចម្រើនកម្លាំងដៃទូលបង្គំផង។
[10]គ្រានោះ កាលខ្ញុំចូលទៅផ្ទះរបស់លោកសេម៉ាយ៉ា ជាកូនលោកដេឡាយ៉ា ដែលជាកូនលោកមហេថាបែល គាត់មិនអាចចេញពីផ្ទះបានទេ គាត់បានមានប្រសាសន៍ថា៖ «សូមយើងទៅជួបគ្នាក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ គឺនៅក្នុងព្រះវិហា ហើយបិទទ្វារឲ្យជិតទៅ ដ្បិតគេនឹងមកសម្លាប់លោក ។ ពួកគេនឹងមកសម្លាប់លោក នៅពេលយប់»។[11]ខ្ញុំឆ្លើយថា៖ «តើគួរឲ្យមនុស្សដូចខ្ញុំរត់គេចឬ? តើមនុស្សដូចខ្ញុំនេះ អាចចូលទៅក្នុងព្រះវិហារ ឲ្យរួចជីវិតឬ? ខ្ញុំមិនចូលទៅក្នុងព្រះវិហារទេ!»
[12]ខ្ញុំយល់ឃើញថា ព្រះអម្ចាស់មិនបានចាត់គាត់ឲ្យធ្វើដូច្នោះឡើយ ប៉ុន្តែគាត់បានថ្លែងទំនាយនេះទាស់នឹងខ្ញុំ។ ព្រោះលោកថូប៊ីយ៉ា និងលោកសានបាឡាតបានជួលគាត់។
[13]ដ្បិតគេបានជួលគាត់ឲ្យធ្វើដូច្នេះ ដើម្បីឲ្យខ្ញុំភ័យខ្លាច ឲ្យខ្ញុំធ្វើតាម ហើយប្រព្រឹត្តអំពើបាប ប្រយោជន៍ឲ្យគេបានរឿងនឹងបង្ខូចឈ្មោះខ្ញុំ ហើយត្មះតិះដៀលខ្ញុំ។[14]ព្រះអម្ចាស់នៃទូលបង្គំអើយ សូមនឹកចាំពីលោកថូប៊ីយ៉ា និងលោកសានបាឡាត តាមការទាំងនេះដែលគេបានប្រព្រឹត្ត ។ហើយសូមនឹកចាំពីនាងណូអាឌា ជាហោរា និងហោរាឯទៀតៗ ដែលចង់បំភ័យទូលបង្គំផង។
[15]ដូច្នេះ កំផែងបានសង់ចប់សព្វគ្រប់ នៅថ្ងៃទីម្ភៃប្រាំ ខែភទ្របទ គឺក្នុងរយៈពេលហាសិបពីរថ្ងៃ។[16]កាលខ្មាំងសត្រូវរបស់យើងទាំងប៉ុន្មានបានឮដំណឹងនេះ សាសន៍ដទៃទាំងប៉ុន្មានដែលនៅជុំវិញយើងក៏ភ័យខ្លាច ហើយគេទ្រាមចុះជាខ្លាំងនៅចំពោះភ្នែករបស់ខ្លួន។ ដ្បិតគេយល់ឃើញថា កិច្ចការនេះកើតឡើងដោយសារជំនួយរបស់ព្រះជាម្ចាស់នៃយើង។
[17]ក្នុងគ្រានោះ ពួកអភិជនក្នុងជនជាតិយូដា បានផ្ញើសំបុត្រជាច្រើនទៅលោកថូប៊ីយ៉ា ក៏មានសំបុត្ររបស់លោកថូប៊ីយ៉ា ផ្ញើមកពួកគេវិញដែរ។[18]ដ្បិតមានមនុស្សជាច្រើននៅស្រុកយូដា ជាប់ពាក់ព័ន្ធជាមួយគាត់ដោយសារពាក្យសម្បថ ព្រោះគាត់ជាកូនប្រសារបស់លោកសេកានា ជាកូនរបស់លោកអើរ៉ាស។ លោកយ៉ូហាណានជាកូនប្រុសរបស់គាត់ បានយកកូនស្រីរបស់លោកមស៊ូឡាម ជាកូនរបស់លោកបេរេគា ធ្វើជាប្រពន្ធ។[19]ពួកគេក៏បាននិយាយពីអំពើល្អរបស់គាត់ នៅចំពោះមុខខ្ញុំ ហើយក៏នាំយកពាក្យរបស់ខ្ញុំទៅប្រាប់គាត់ដែរ។ លោកថូប៊ីយ៉ាបានផ្ញើសំបុត្រជាច្រើនដើម្បីមកបំភ័យខ្ញុំ។

Nehemiah 6:1

សានបាឡាត ថូប៊ីយ៉ា កេសែម

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូក ២:៩។

ខ្ញុំបានសង់កំពែងឡើង... ខ្ញុំមិនទាន់បាន

លោកនេហេមាត្រួតត្រាលើការសាងសង់កំពែង។ លោកមិនបានសាងសង់ដោយខ្លួនឯងនោះទេ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកយើងបានសាងសង់កំពែងឡើងវិញ...ពួកយើងមិនទាន់បានធ្វើ»

កន្លែងផ្សេងទៀត

នេះគឺចង់សំដៅទៅលើកន្លែងផ្សេងនៃកំពែង។ ការបកប្រែរបៀបផ្សេងទៀត «គ្មានកន្លែងបាក់បែកណានៅសល់ទៀត» ឬ «មានចន្លោះនៅក្នុងកំពែង»

generated on Wed Sep 10 16:16:32 2025

បានផ្ញើមកខ្ញុំ
នេះគឺមានន័យថាពួកគេបានផ្ញើសារតាមអ្នកនាំសារ។ ការបកប្រែរបៀបផ្សេងទៀត: «បានផ្ញើសារមកខ្ញុំ»
អូណូរ
នេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 6:3
ខ្ញុំកំពុងតែធ្វើកិច្ចការដ៏អស្ចារ្យ
លោកនេហេមាបានចាត់ចែងក្នុងការសាងសង់កំពែង។ លោកមិនបានសាងសង់កំពែងដោយខ្លួនលោកទេ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំជាអ្នកចាត់ចែងកិច្ចការដ៏អស្ចារ្យ»
ហេតុអ្វីបានជាខ្ញុំត្រូវឈប់ ដោយទុកចោលការងារនេះ ហើយចុះទៅជួបលោកដូច្នេះ?
សំនួរដែលមិនត្រូវការចម្លើយនេះគឺត្រូវបានប្រើដើម្បីជំទាស់នឹងសំណើរបស់លោកសានបាឡាត និងលោកតូប៊ីយ៉ា។ នេះអាចត្រូវបានសរសេរជាប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំកំពុងធ្វើកិច្ចការមួយយ៉ាងធំ ហើយខ្ញុំមិនអាចចុះទៅបានទេ»
ចុះមករកអ្នក
ពាក្យ «ចុះមក»
ត្រូវបានប្រើនៅទីនេះពីព្រោះភ្នំអូណូដែលជាកន្លែងដែលពួកគេបានស្នើសុំលោកនេហេមាឲ្យទៅជួបនោះ ស្ថិតនៅខ្ពស់ជាងក្រុងយេរូសាឡិម។
Nehemiah 6:5
លោកសានបាឡាតចាត់អ្នកបម្រើម្នាក់ឲ្យមកជួបខ្ញុំ តាមបែបដដែល ជាលើកទីប្រាំ
«លោកសានបាឡាតចាត់អ្នកបម្រើម្នាក់ឲ្យមកជួបខ្ញុំ តាមបែបដដែល ជាលើកទីប្រាំ»
ការកំណត់អត្តសញ្ញាណនៃសារនេះដាច់ដោយឡែកមានន័យថាវាមានភាពខុសគ្នាតាមវិធីមួយចំនួនពីសារពីរដងមុនៗ។
លើកទីប្រាំ
«លើកទី៥»
សំបុត្រដែលបើកចំហ
លិខិតនេះគឺជាការប្រាស្រ័យទាក់ទងការទូតដែលមិនបានបិទជិត។ នេះគឺជាការប្រមាថដល់អ្នកទទួលមួយ ដោយសារតែអ្នកនាំសំបុត្រនេះគឺអាចអានបានយ៉ាងស្រួល ហើយអាចចែកចាយអត្ថន័យនៅក្នុងសំបុត្រនោះក្នុងចំណោមមនុស្សផ្សេងទៀតដែលនៅតាមផ្លូវ។
នៅក្នុងដៃរបស់លោក
នេះមានន័យថាគាត់មានលិខិតនោះជាកម្មសិទ្ធិរបស់លោក ប៉ុន្តែលោកមិនចាំបាច់កាន់នៅក្នុងដៃលោកគ្រប់ពេលនោះទេ។ ការបកប្រែរបៀបផ្សេងទៀត: «កម្មសិទ្ធរបស់លោក»
មានឮដំណឹងនៅគ្រប់ទាំងសាសន៍
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត៖ «ពាក្យចចាមអារាមនៅក្នុងតំបន់គឺ។»
មានបំណងនឹងបះបោរ
នេះគឺមានន័យថាពួកគេកំពុងតែមានផែនការប៉ះបោរប្រឆាំងនឹងព្រះបាទអើថាស៊ើកសេសស្តេចនៃចក្រភពពើស៊ី ដែលជាអ្នកដែលគ្រប់គ្រងលើជនជាតិយូដា។ ការបកប្រែរបៀបផ្សេងទៀត: «កំពុងមានបំណងប៉ះបោរប្រឆាំងនឹងព្រះបាទអើថាស៊ើកសេសស្តេច»
Nehemiah 6:7
ព្រះករុណានឹងបានជ្រាប
«ព្រះបាទអើថាស៊ើកសេសនឹងបានជ្រាប»
ដូច្នេះ សូមអញ្ជើញមក
«ដូច្នេះ សូមអញ្ជើញមកជួបពួកយើង»
Nehemiah 6:8
ខ្ញុំតបទៅគាត់វិញថា
ពាក្យ «ខ្ញុំ» គឺសំដៅទៅលោកនេហេមា ហើយពាក្យ «គាត់» គឺសំដៅទៅលោកសានបាឡាត់។
គ្មានការបែបនេះកើតឡើងដូចជាលោករៀបរាប់ទេ
«គ្មានអ្វីដែលអ្នកនិយាយបានកើតឡើងនោះទេ»
ប្រឌិតរឿងទាំងនេះដោយគំនិតខ្លួនឯងប៉ុណ្ណោះ
ពាក្យ «ចិត្ត» គឺសំដៅទៅលើ«ការគិត» គឺជាការសម្រេចចិត្ត និងគិតតែមួយ។ «ប្រឌិតរឿងទាំងនេះដោយគំនិតខ្លួនឯងប៉ុណ្ណោះ» ឬ «ប្រឌិតរឿងនជឡើងដោយចិត្តគំនិតរបស់ខ្លួនឯង»
ដ្បិតអ្នកទាំងនោះមានបំណងនឹងគំរាមពួកយើង
ពាក្យ «ពួកគេ» គឺសំដៅទៅលើលោកនេហេមា លោកសានបាឡាត់ លោកកេសែម និងអ្នកដែលដើរតាមលោក។ ពាក្យ «ពួកយើង» គឺសំដៅទៀលើជនជាតិយូដា។
ពួកគេនឹងថយកម្លាំងដៃ ហើយលែងធ្វើការនោះតទៅទៀត
នេះគឺជាប្រយោគដែលមានន័យថាពួកគេនឹងឈប់ក្នុងការសាងសង់កំពែង។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលកំពុងតែសាងសង់កំពែងនឹងឈប់ធ្វើការរបស់គេ»
ចម្រើនកម្លាំងដៃទូលបង្គំ
ត្រង់នេះគឺលោកនេហេមាទូលសូមទៅព្រះជាម្ចាស់ឲ្យចម្រើនកម្លាំងដល់ដៃរបស់លោក ដោយទូលសូមព្រះអង្គចម្រើនកម្លាំងដល់ «ដៃ» របស់លោក។ ការបកប្រែរបៀបផ្សេងទៀត: «ចម្រើនកម្លាំងទូលបង្គំ» ឬ «ផ្តល់ឲ្យខ្ញុំនូវភាពក្លាហាន»
Nehemiah 6:10
សេម៉ាយ៉ា...ដេឡាយ៉ា...ដេឡាយ៉ា
ឈ្មោះនេះគឺជាឈ្មោះរបស់មនុស្ស។
នរណាដែលមិនអាចចេញពីផ្ទះរបស់គាត់បាន
អ្នកនិពន្ធមិនបានផ្តល់មូលហេតុគាត់ត្រូវបានគេឃុំឃាំងទេ ដូច្នេះយកល្អគួរតែនិយាយថាគាត់នៅផ្ទះដោយប្រើពាក្យទូទៅបំផុតដែលអាចធ្វើទៅបាន។ ការបកប្រែរបៀបផ្សេងទៀត៖ «អ្នកបានកំណត់ថាខ្លួនឯងត្រូវតែនៅផ្ទះរបស់គាត់»
តើគួរឲ្យមនុស្សដូចខ្ញុំរត់គេចឬ? តើមនុស្សដូចខ្ញុំនេះ អាចចូលទៅក្នុងព្រះវិហារ ឲ្យរួចជីវិតឬ?
លោកនេហេមាប្រើសំនួរទាំងនេះដើម្បីបញ្ជាក់ថាគាត់នឹងមិនធ្វើអ្វីដែលសេម៉ាយ៉ាបានលើកឡើងទេ។ សំនួរទាំងនេះអាចត្រូវបានសរសេរជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដូចខ្ញុំមិនគួររត់គេចទេ។ ហើយមនុស្សដូចខ្ញុំក៏មិនគួររត់ចូលទៅក្នុងព្រះវិហារដើម្បីជួយជីវិតខ្លួនមុនហើយដូច្នេះគួរកត់សំគាល់។
Nehemiah 6:12
ប៉ុន្តែគាត់បានថ្លែងទំនាយ
«ដោយព្រោះតែលោកបានថ្លែងទំនាយ»
អំពើបាប
ការប្រើព្រះវិហារជាកន្លែងលាក់ខ្លួនគឺជាអំពើបាប។
វាអាចមានប្រយោជន៍ក្នុងការធ្វើឲ្យវាច្បាស់លាស់។ ការបកប្រែរបៀបផ្សេងទៀត: «ដោយសារការប្រើប្រាស់ព្រះវិហារខុស»
ឈ្មោះមិនល្អ
នេះគឺជាឃ្លាមួយ។ ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះគេអាចឲ្យខ្ញុំមានកេរ្តិ៍ឈ្មោះអាក្រក់» ឬ «ដូច្នេះគេអាចនិយាយអាក្រក់អំពីខ្ញុំ»
សូមនឹកចាំ
នេះគឺជាឃ្លាមួយ។ ការបកប្រែរបៀបផ្សេងទៀត: «សូមចាំ»
ណូអាឌា
នេះគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
Nehemiah 6:15
ដូច្នេះ កំពែងបានសង់ចប់សព្វគ្រប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «យើងបានសង់កំពែងរួចហើយ»
នៅថ្ងៃទីម្ភៃប្រាំ ខែភទ្របទ គឺក្នុងរយៈពេលហាសិបពីរថ្ងៃ
ប្រាំថ្ងៃនៃខែភទ្របទ «នៅថ្ងៃទីម្ភៃប្រាំ ខែភទ្របទ។»
«គឺជាខែទីប្រាំមួយនៃប្រតិទិនហេប្រឺ។»
ហាសិបពីរថ្ងៃ
ពីរថ្ងៃ «៥២ថ្ងៃ»
ទ្រោមចុះជាខ្លាំងនៅចំពោះភ្នែករបស់ខ្លួន
«ពួកគេលែងគិតពីខ្លួនគេ» ឬ «ពួកគេបានបាត់បង់ទំនុកចិត្តលើខ្លួនឯង»
កិច្ចការនេះបានសម្រេចដោយសារជំនួយរបស់ព្រះជាម្ចាស់នៃយើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: គឺជាព្រះជាម្ចាស់របស់យើងដែលជួយឲ្យយើងបានសម្រេចកិច្ចការមួយនេះ។
Nehemiah 6:17
បានផ្ញើសំបុត្រជាច្រើន
ពួកអភិជនបានបញ្ជូនអ្នកនាំសារឲ្យនាំយកសំបុត្រទាំងនោះទៅកាន់លោកតូប៊ីយ៉ា។ ការបកប្រែរបៀបផ្សេងទៀត៖ «ផ្ញើសំបុត្រជាច្រើនតាមអ្នកនាំសារ»
មានសំបុត្ររបស់លោកតូប៊ីយ៉ាបានផ្ញើត្រឡប់មកពួកគេវិញ
មានសំបុត្ររបស់លោកតូប៊ីយ៉ាបានផ្ញលត្រឡប់មកពួកគេវិញ នៅពេលដែលសារនោះត្រូវបាននាំមកដោយអ្នកនាំសារ។ ការបកប្រែរបៀបផ្សេងទៀត: «លោកតូប៊ីយ៉ាបានផ្ញើសំបុត្រ» ឬ «លោកតូប៊ីយ៉ាបាផ្ញើសំបុត្រជាច្រើនតាមរយៈអ្នកនាំសារ»

generated on Wed Sep 10 16:16:32 2025

ថូប៊ីយ៉ា
គឺជាឈ្មោះរបស់មនុស្សប្រុសម្នាក់។
តើនរណាជាប់ពាក់ព័ន្ធជាមួយគាត់ដោយសារពាក្យសម្បថ
នេះនិយាយអំពីមនុស្សដែលស្មោះត្រង់នឹងលោកថូប៊ីយ៉ា
ពីព្រោះពួកគេបានស្បថចំពោះគាត់
ពាក្យសម្បថរបស់ពួកគេគឺជាខ្សែពួរដែលចងភ្ជាប់ខ្លួនរបស់ពួកគេ។
ការបកប្រែរបៀបផ្សេង: «តើអ្នកណាបានស្បថចំពោះលោក» ឬ
«តើនរណាបានស្បថ និងមានភាពស្មោះត្រង់ចំពោះគាត់»
គាត់ជាកូនប្រសារបស់លោកសេកានា
កូនប្រសារបស់លោកសេកានា
គឺមានន័យថាលោកថូប៊ីយ៉ាបានរៀបការជាមួយនឹងកូនស្រីរបស់លោកសេកានា។
សូមបកប្រែឈ្មោះ «សេកានា» ឲ្យដូចអ្វីដែលអ្នកបានបកប្រែនៅក្នុងជំពូកទី
៣:២៨។

អើរ៉ាស... យ៉ូណាហាន
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
មស៊ូឡាម...បេរេគា
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។ បកប្រែដូចនៅក្នុងជំពូកទី ៣:៣។
ពួកគេក៏បាននិយាយពីអំពើល្អរបស់គាត់ នៅចំពោះមុខខ្ញុំ ហើយក៏នាំយកពាក្យរបស់ខ្ញុំទៅប្រាប់គាត់
ដែរ
«ពួកអភិជនជនជាតិយូដាបានប្រាប់ខ្ញុំអំពីលោកអំពើល្អរបស់លោកថូប៊ីយ៉ា
ហើយបន្ទាប់មកក៏បានប្រាប់អំពីតួនាទីរបស់ខ្ញុំដែរ»
សារបានផ្ញើមកខ្ញុំដែលមកពីលោកថូប៊ីយ៉ា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
លោកថូប៊ីយ៉ាបានចាត់អ្នកនាំសារឲ្យយកសំបុត្រទៅកាន់លោកនេហេមា។
ការបកប្រែរបៀបផ្សេងទៀត: «លោកថូប៊ីយ៉ាផ្ញើសំបុត្រមកខ្ញុំ»

---

7 [1]កាលកំផែងបានសង់ឡើងរួចរាល់ ហើយខ្ញុំបានដាក់សន្លឹកទ្វារ រួចបានតែងតាំងឲ្យមានពួកឆ្មាំទ្វារ ពួកចម្រៀង និងពួកលេវីស្រេចហើយ[2]ខ្ញុំបានប្រគល់អំណាចគ្រប់គ្រងលើក្រុងយេរូសាឡិម ឲ្យហាណានី ជាប្អូនប្រុសរបស់ខ្ញុំ និងហាណានា ជាមេបន្ទាយ ដ្បិតគាត់ជាមនុស្សស្មោះត្រង់ ក៏កោតខ្លាចដល់ព្រះជាម្ចាស់លើសជាងមនុស្សជាច្រើន។
[3]ខ្ញុំបានប្រាប់គេថា៖ «មិនត្រូវបើកទ្វារក្រុងយេរូសាឡិម មុនថ្ងៃបញ្ចេញកម្តៅឡើយ។ ហើយកាលគេកំពុងនៅឈរចាំយាម ត្រូវបិទទ្វារ ហើយខ្ទាស់រនុក។ ក្នុងចំណោមអ្នកក្រុងយេរូសាឡិម ត្រូវចាត់តាំងឲ្យមានពួកអ្នកយាម ខ្លះតាមប៉ុស្តិ៍យាមរបស់គេ ហើយខ្លះទៀតនៅមុខផ្ទះរបស់គេរៀងខ្លួន»។[4]ទីក្រុងនេះធំហើយទូលាយ ប៉ុន្តែប្រជាជនក្នុងក្រុងនោះ មានចំនួនតិច ហើយផ្ទះសំបែងមិនទាន់បានសង់នៅឡើយ។
[5]ព្រះជាម្ចាស់នៃខ្ញុំបានបណ្តាលចិត្តខ្ញុំឲ្យប្រមូលពួកអភិជន ពួកអ្នកគ្រប់គ្រង និងប្រជាជនមកជួបជុំគ្នា ដើម្បីចុះបញ្ជីតាមពង្សាវតារ។ ខ្ញុំបានរកឃើញបញ្ជីពង្សាវតារនៃអស់អ្នកដែលបានត្រឡប់មកមុនគេ ហើយខ្ញុំឃើញមានឈ្មោះកត់ទុកក្នុងបញ្ជីនោះដូចតទៅ។
[6]«នេះជាប្រជាជននៅក្នុងអាណាខេត្ត ដែលចេញពីសណ្ឋានជាឈ្លើយ ជាអ្នកដែលព្រះបាទនេប៊ូក្នេសា ជាស្តេចស្រុកបាប៊ីឡូនបាននាំទៅជាឈ្លើយ។ ពួកគេបានវិលត្រឡប់មកក្រុងយេរូសាឡិម និងស្រុកយូដាវិញ គឺមកកាន់ក្រុងរបស់គេរៀងខ្លួន។[7]ពួកទាំងនោះបានមកជាមួយលោកសូរ៉ូបាបិល លោកយេសួរ លោកនេហេមា លោកអ័សារា លោករ៉ាអាមា លោកណាហាម៉ានី លោកម៉ាដេកាយ លោកបីលសាន លោកមីសពេរែត លោកបីកវ៉ាយ លោកនេហ៊ូម និងលោកប្អាណា។ នេះជាចំនួនបុរសក្នុងចំណោមប្រជាជនអ៊ីុស្រាអែល ដែលមានដូចតទៅនេះ។
[8]កូនចៅរបស់លោកប៉ារ៉ូសមាន ២ ១៧២ នាក់។[9]កូនចៅរបស់លោកសេផាធាមាន ៣៧២ នាក់ ។[10]កូនចៅរបស់លោកអើរ៉ាសមាន ៦៥២ នាក់។
[11]កូនចៅរបស់លោកផាហាត-ម៉ូអាប់ ខាងកូនចៅរបស់លោកយេសួរ និងលោកយ៉ូអាប់ មាន ២៨១៨ នាក់។[12]កូនចៅរបស់លោកអេឡាំមាន ១២៥៤ នាក់។[13]កូនចៅរបស់លោកសាធូរមាន ៨៤៥ នាក់។[14]កូនចៅរបស់លោកសាកាយមាន ៧៦០ នាក់។
[15]កូនចៅរបស់លោកបីនុយមាន ៦៤៨ នាក់។[16]កូនចៅរបស់លោកបេបាយមាន ៦២៨ នាក់។[17]កូនចៅរបស់អាសកាឌមាន ២ ៣២២ នាក់។[18]កូនចៅរបស់លោកអ័ដូនីកាមមាន ៦៦៧ នាក់។
[19]កូនចៅរបស់លោកបីកវ៉ាយមាន ២០៦៧ នាក់។[20]កូនចៅរបស់លោកអេឌីនមាន ៦៥៥ នាក់។[21]ពួកកូនចៅរបស់លោកអេធើ ខាងលោកហេសេគាមាន ៩៨ នាក់។[22]កូនចៅរបស់លោកហាស៊ូមមាន ៣២៨ នាក់។
[23]កូនចៅរបស់លោកបេសាយមាន ៣២៤ នាក់។[24]កូនចៅរបស់លោកហារេបមាន ១១២ នាក់។[25]កូនចៅគីបៀនមាន ៩៥ នាក់។[26]ពួកបេថ្លេហិម និងពួកនថូផាមាន ១៨៨ នាក់។
[27]ពួកអ្នកស្រុកអាណាថោតមាន ១២៨ នាក់។[28]ពួកអ្នកស្រុកបេត-អាសម៉ាវែតមាន ៤២ នាក់។[29]ពួកអ្នកក្រុងគារយ៉ាត់-យារីម កេភីរ៉ា និងប៊្លៀរ៉ុត មាន ៧៤៣ នាក់។
[30]ពួកក្រុងរ៉ាម៉ា និងកេបាមាន ៦២១ នាក់។
[31]ពួកអ្នកក្រុងមីកម៉ាសមាន ១២២ នាក់។[32]ពួកក្រុងបេត-អែល និងអៃមាន ១២៣ នាក់។[33]ពួកអ្នកក្រុងនេបូរមួយទៀតមាន ៥២ នាក់។[34]កូនចៅរបស់លោកអេឡាំមួយទៀតមាន ១ ២៥៤ នាក់។
[35]កូនចៅរបស់លោកហារីមមាន ៣២០ នាក់។[36]កូនចៅរបស់លោកយេរីខូរមាន ៣៤៥ នាក់។[37]កូនចៅរបស់លោកឡូឌ ហាឌីឌ និងលោកអូណូរមាន ៧២១ នាក់។[38]កូនចៅរបស់លោកសេណាអាមាន ៣ ៩៣០ នាក់។
[39]ឯពួកសង្ឃគឺ កូនចៅរបស់លោកយេដាយ៉ា ខាងវង្សរបស់លោកយេសួរមាន ៩៧៣ នាក់។[40]កូនចៅរបស់លោកអ៊ីមមេរមាន ១០៥២ នាក់។[41]កូនចៅរបស់លោកផាសហ៊ើរមាន ១២៤៧ នាក់។[42]កូនចៅរបស់លោកហារីមមាន ១០១៧ នាក់។
[43]ឯពួកលេវីគឺ កូនចៅរបស់លោកយេសួរ កូនចៅរបស់លោកកាឌមាល កូនចៅរបស់លោកប៊ីនុយ និងកូនចៅរបស់លោកហូដាវ៉ាមាន ៧៤ នាក់។[44]ឯពួកចម្រៀងគឺ កូនចៅរបស់លោកអសាភមាន ១៤៨ នាក់។[45]ពួកកូនចៅរបស់ឆ្មាំទ្វារគឺ កូនចៅរបស់លោកសាលូម កូនចៅរបស់លោកអេធើ កូនចៅរបស់លោកថាលម៉ូន កូនចៅរបស់លោកអ័កគូប កូនចៅរបស់លោកហាធីថា និងកូនចៅរបស់លោកសូបាយ មាន ១៣៨ នាក់។
[46]ឯពួកអ្នកបម្រើព្រះវិហារ មានកូនចៅរបស់លោកស៊ីហា កូនចៅរបស់លោកហាស៊ូផា និងកូនចៅរបស់លោកថាបាអូត។[47]កូនចៅរបស់លោកកេរ៉ូស កូនចៅរបស់លោកស៊ីយ៉ាហា កូនចៅរបស់លោកផាដូន។[48]កូនចៅរបស់លោកលេបាណា កូនចៅរបស់លោកហាកាបា កូនចៅរបស់លោកសាលម៉ាយ។[49]កូនចៅរបស់លោកហាណាន កូនចៅរបស់លោកគីដេល កូនចៅរបស់លោកកាហារ។
[50]កូនចៅរបស់លោករីអាយ៉ា កូនចៅរបស់លោករេស៊ីន កូនចៅរបស់លោកនេកូដា។[51]កូនចៅរបស់លោកកាសាម កូនចៅរបស់លោកអ៊ូសា កូនចៅរបស់លោកផាសេហា។
[52]កូនចៅរបស់លោកបេសាយ កូនចៅរបស់លោកមេហ៊ូនីម កូនចៅរបស់លោកនេភូស៊ីម។
[53]កូនចៅរបស់លោកបាកប៊ូក កូនចៅរបស់លោកហាគូផា កូនចៅរបស់លោកហាហ៊ើរ។[54]កូនចៅរបស់លោកបាសលូត កូនចៅរបស់លោកមេហ៊ីដា កូនចៅរបស់លោកហាសា។[55]កូនចៅរបស់លោកបាកូស កូនចៅរបស់លោកស៊ីសេរ៉ា កូនចៅរបស់លោកថាម៉ា។[56]កូនចៅរបស់លោកនេស៊ីយ៉ា និងកូនចៅរបស់លោកហាធីផា។
[57]កូនចៅរបស់លោកពួកអ្នកបម្រើរបស់ព្រះបាទសាឡូម៉ូន កូនចៅរបស់លោកសូថាយ កូនចៅរបស់លោកសូផេរេត កូនចៅរបស់លោកពេរូដា។[58]កូនចៅរបស់លោកយ្អាឡា កូនចៅរបស់លោកដាកុន កូនចៅរបស់លោកគីដេល។[59]កូនចៅរបស់លោកសេផាធា កូនចៅរបស់លោកហាធីល កូនចៅរបស់លោកផូកេរេត ពីសេបែម និងកូនចៅរបស់លោកអាំម៉ូន។[60]ពួកអ្នកបម្រើព្រះវិហារ ហើយនិងកូនចៅរបស់លោក ពួកអ្នកបម្រើរបស់ព្រះបាទសាឡូម៉ូន សរុបទាំងអស់មាន ៣៩២ នាក់។
[61]ពួកអ្នកដែលចេញពីក្រុងធេល មែឡា ធេល ហារេសា កេរូប អ័ដាន និងអ៊ីមមើរ។ តែពួកគេពុំអាចនឹងបង្ហាញពីពង្សាវតារ ឬជីដូនជីតារបស់ខ្លួន ថាជាពូជអ៊ីស្រាអែល ឬមិនមែន។[62]គឺកូនចៅរបស់លោកដេឡាយ៉ា កូនចៅរបស់លោកថូប៊ីយ៉ា និងកូនចៅរបស់លោកនេកូដា ទាំងអស់មាន ៦៤២ នាក់។[63]ខាងពួកបូជាចារ្យ មានកូន

generated on Wed Sep 10 16:16:32 2025

ចៅរបស់លោកហាបាយ៉ា កូនចៅរបស់លោកហាគូស កូនចៅរបស់លោកបារស៊ីឡាយ (ដែលបានយកកូនស្រីរបស់លោកបារស៊ីឡាយ នៅស្រុកកាឡាត ធ្វើជាប្រពន្ធ ហើយក៏ត្រូវហៅតាមឈ្មោះរបស់គេ)។
[64]អ្នកទាំងនោះរកនាមត្រកូលតាមបញ្ជីពង្សាវតាររបស់ខ្លួនមិនឃើញទេ ដូច្នេះ ពួកគេត្រូវបាត់បង់វចេញពីការងារជាសង្ឃ ទុកដូចជាសង្ឃដែលមិនបរិសុទ្ធ។[65]ហើយ ក្រោយមក លោកទេសាភិបាលប្រាប់ពួកគេថា គេមិនត្រូវបរិភោគអាហារសក្ការៈបំផុតឡើយ រហូតទាល់តែបានលើកឡើងជាមួយបូជាចារ្យម្នាក់ ជាមួយយូរីម និងធូមីម ។
[66]ក្រុមជំនុំទាំងអស់គ្នាមានចំនួន ៤២ ៣៦០ នាក់[67]ដោយឥតរាប់បញ្ចូលអ្នកបម្រើប្រុសស្រីរបស់ពួកគេគឺមានចំនួន ៧៣៣៧ នាក់ទេ។ ពួកគេមានពួកចម្រៀងទាំងប្រុសទាំងស្រីចំនួន ២៤៥ នាក់។
[68]សេះរបស់គេមាន ៧៣៦ ក្បាល លាកាត់មាន ២៤៥ ក្បាល[69]អូដ្ឋមាន ៤៣៥ ក្បាល និងលាមាន ៦ ៧២០ ក្បាល។
[70]អ្នកខ្លះមកពីក្នុងចំណោមពួកអ្នកដឹកនាំមេគ្រួសារមួយចំនួន បានថ្វាយតង្វាយសម្រាប់ការងារនេះ។ លោកទេសាភិបាល បានថ្វាយដាក់ក្នុងឃ្លាំង ជាមាសចំនួនមួយពាន់តម្លឹង ពែងមាស ហាសិប សម្លៀកបំពាក់ពួកបូជាចារ្យ ប្រាំរយសាមសិបសម្រាប់។[71]មានពួកមេដឹកនាំគ្រួសារមួយចំនួន បានថ្វាយមាសចំនួន ពីរមឿនតម្លឹង និងប្រាក់ចំនួនពីរពាន់ពីររយណែន ដាក់ក្នុងឃ្លាំងសម្រាប់ការសាងសង់។[72]ប្រជាជនដែលនៅសេសសល់បានថ្វាយមាសចំនួនពីរមឿនតម្លឹង ហើយប្រាក់ចំនួនពីរពាន់ពីរណែន ព្រមទាំងសម្លៀកបំពាក់ពួកបូជាចារ្យ ហុកសិបប្រាំពីរ សម្រាប់។
[73]ដូច្នេះ ពួកបូជាចារ្យ ពួកលេវី ពួកឆ្មាំទ្វារ ពួកចម្រៀង ប្រជាជនខ្លះ ពួកអ្នកបម្រើនៅព្រះវិហារ និងអ៊ីស្រាអែលទាំងអស់រស់នៅក្នុងទីក្រុងរបស់ពួកគេ។ តាមរយៈ ខែទីប្រាំពីរ ដែលប្រជាជនអ៊ីស្រាអែលបានរៀបចំឡើងវិញនៅក្នុងទីក្រុងទាំងឡាយរបស់ពួកគេ»។

Nehemiah 7:1

កាលកំពែងបានសង់ឡើងរួចរាល់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលយើងបានសង់កំពែងរួចរាល់»

ខ្ញុំបានដាក់សន្លឹកទ្វារតាមកន្លែង

នេះបានរួចរាល់ដោយសារការជួយ។ ការបកប្រែរបៀបផ្សេងទៀត: ខ្ញុំនិងអ្នកផ្សេងបានផ្ជួរទ្វារ។

ពួកឆ្មាំទ្វារ ពួកចម្រៀង និងពួកលេវីបានតែងតាំងរួចស្រេចហើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ អាចមានន័យថា: ១)លោកនេហេមាបានតែងតាំងពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានតែងតាំងពួកឆ្មាំទ្វារ ពួកចម្រៀង និងពួកលេវីបានតែងតាំងរួចស្រេចហើយ» ឬ ២) មាននរណាម្នាក់បានតែងតាំងពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបានតែងតាំងពួកឆ្មាំទ្វារ ពួកចម្រៀង និងពួកលេវីបានតែងតាំងរួចស្រេចហើយ»

ពួកឆ្មាំទ្វារ

មនុស្សដែលបានចាត់ឲ្យទៅខ្លោងទ្វារនីមួយៗទទួលខុសត្រូវក្នុងការគ្រប់គ្រងច្រកចូលទីក្រុង ឬប្រាសាទក៏ដូចជាបើក

និងបិទទ្វារតាមពេលវេលានិងហេតុផលដែលកំណត់ដោយអ្នកគ្រប់គ្រង។

ពួកចម្រៀង

អ្នកលេងតន្ត្រីដែលដឹកនាំការថ្វាយបង្គំក្នុងពិធីដង្ហែរ និងពិធីផ្សេងៗ ផលិតបទភ្លេងនិងការស្រែកដែលសង្កត់ធ្ងន់និងបង្កើតឲ្យមានការភ្ញាក់ផ្អើល

ហាណានី...ហាណានា

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស

ខ្ញុំបានប្រគល់អំណាចគ្រប់គ្រងឲ្យទៅបងប្រុសរបស់ខ្ញុំហាណានី

«ខ្ញុំបានចេញបទបញ្ជាឲ្យបងប្រុសខ្ញុំហាណានីធ្វើជាអ្នកគ្រប់គ្រង»

តើនរណាជាមេបន្ទាយ

«តើនរណាជាអ្នកគ្រប់គ្រងបន្ទាយ»

បន្ទាយ

«បន្ទាយ»

កោតខ្លាចដល់ព្រះជាង

«កោតខ្លាចដល់ព្រះលើសជាងមនុស្សជាច្រើន។»

Nehemiah 7:3

ខ្ញុំបានប្រាប់គេ

ពាក្យ «ពួកគេ» គឺសំដៅទៅលើលោកហាណានី និងលោកហាណានា។

មិនត្រូវបើកទ្វារក្រុងយេរូសាឡិម មុនថ្ងៃបញ្ចេញកម្តៅឡើយ។ ហើយកាលគេកំពុងនៅឈរចាំយាម ត្រូវបិទទ្វារ ហើយខ្ទាស់រនុក។

អាចមានន័យថា: ១) សកម្មភាពទាំងនេះត្រូវបានធ្វើឡើងដោយហាណានីនិងហាណានា ឬ ២)សកម្មភាពទាំងនេះត្រូវបានធ្វើឡើងដោយហាណានីនិងហាណានា ដោយមានជំនួយពីអ្នកយាមទ្វារ ឬ ៣)អ្នកយាមទ្វារបានធ្វើសកម្មភាពទាំងនេះក្រោមការដឹកនាំរបស់ហាណានីនិងហាណានា។

ថ្ងៃបញ្ចេញកម្តៅ

«ព្រះអាទិត្យខ្ពស់នៅលើមេឃ»

កាលគេកំពុងនៅឈរចាំយាម ត្រូវបិទទ្វារហើយខ្ទាស់រនុក

«ត្រូវបិទទ្វារហើយខ្ទាស់រនុកពេលដែលអ្នកដែលគេកំពុងនៅឈរចាំយាម»

អ្នកយាមទ្វា

បកប្រែត្រង់នេះដូចនៅក្នុងជំពូកទី ៧:១

បិទទ្វារ ហើយខ្ទាស់រនុក

«បិតទ្វា ហើយចាក់សោរផង»

ចាត់នរណាម្នាក់ដែលរស់នៅក្រុងយេរូសាឡិមឲ្យយាម

«ជ្រើសរើសនរណាម្នាក់ដែលរស់នៅក្រុងយេរូសាឡិមឲ្យយាម»

ប៉ុស្តិ៍យាម

«ប៉ុស្តិ៍យាម» ឬ «កន្លែងដែលអ្នកយាមធ្វើការ»

Nehemiah 7:5

បណ្តាលចិត្ត

ពាក្យ «ដួងចិត្ត»របស់លោកនេហេមាគឺសំដៅទៅលើចិត្តគំនិតនិងបំណងរបស់លោក។ សូមមើលរបៀបនៃការបកប្រែនេះនៅក្នុងជំពូកទី២:១១។

ការបកប្រែរបៀបផ្សេងទៀត: «ជម្រុញខ្ញុំ» ឬ «ដឹកនាំខ្ញុំ»

ប្រមូលចុះបញ្ជី

«ដើម្បីចុះបញ្ជី និងចុះឈ្មោះពួកគេ»

បញ្ជីពង្សាវតារ

នេះជាសៀវភៅដែលលែងមានទៀតហើយ។

ហើយខ្ញុំឃើញមានឈ្មោះកត់ទុកក្នុងបញ្ជីនោះ

នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ហើយបានរកឃើញថាមាននរណាម្នាក់សរសេរដូចខាងក្រោមនៅក្នុងនោះ»

Nehemiah 7:6

នេះជាប្រជាជននៅក្នុងអាណាខេត្ត

«ទាំងនេះគឺជាកូនចៅនៃតំបន់នេះ»

ដែលចេញពី

«ត្រឡប់មកពី» ឬ «ត្រឡប់មកពី»

បានចេញ

នេះគឺជាប្រយោគដែលសំដៅទៅលើការធ្វើដំណើរឆ្ពោះទៅក្រុងយេរូសាឡិមដែលស្ថិតនៅលើទីខ្ពស់ជាងតំបន់ជុំវិញ។

តើអ្នកណាដែលព្រះបាទនេប៊ូក្នេសា ជាស្តេចស្រុកបាប៊ីឡូនបាននាំទៅជាឈ្លើយ

«អ្នកណាជានេប៊ីក្នេសា

អ្នកគ្រប់គ្រងស្រុកបាប៊ីឡូនបាននិរទេសពួកគេពីប្រទេសកំណើតរបស់ពួកគេ។» កងទ័ពបាប៊ីឡូនធ្វើដូច្នេះក្រោមបញ្ជារបស់នេប៊ូក្នេសា។

សូរ៉ូបាបិល...

យេសួរ...នេហេមា...អ័សារា...រ៉ាអាមា...ណាហាម៉ានី...ម៉ាដេកាយ...ប៊ីលសាន ...មីសពេរែត...ប៊ីកវ៉ាយ...នេហ៊ូម និងលោកប្អាណា

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

Nehemiah 7:8

ខ្លឹមសារភ្ជាប់:

លោកនេហេមាកំពុងរៀបរាប់ពីចំនួនមនុស្សដែលបានត្រឡប់មកពីនិរទេស។ ប្រជាជនត្រូវបានដាក់ជាក្រុមតាមក្រុមគ្រួសាររបស់ពួកគេ។ ចំនួននេះតំណាងឲ្យចំនួនបុរសនៅក្នុងគ្រួសារនីមួយៗ។

ប៉ារ៉ូស...សេផាធា...អើរ៉ាស

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

generated on Wed Sep 10 16:16:32 2025

Nehemiah 7:11
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
កូនចៅរបស់លោកផាហាត-ម៉ូអាប់
នោះគឺកូនចៅរបស់លោកយេសួរ និងលោកយ៉ូអាប់»
Nehemiah 7:15
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
ប៊ីនុយ...បេបាយ...អាសកាឌ...អ័ដូនីកាម
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 7:19
ខ្លឹមសារភ្ជាប់
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
ប៊ីកវ៉ាយ...អេឌីន...អេធើ...ហាស៊ូម
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ពួកកូនចៅរបស់លោកអេធើ ខាងលោកហេសេគា
អ្នកនិពន្ធបានកាត់បន្ថយប្រយោគនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«កូនចៅរបស់លោកអេធើ គឺជាកូនចៅនៃលោកហេសេគាល»
Nehemiah 7:23
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
បេសាយ...ហារេប...គីបៀន
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
បេថ្លេហិម និងពួកនថូផា
ទាំងនេះគឺជាឈ្មោះនៃទីកន្លែងនៅក្នុងស្រុកយូដា។
Nehemiah 7:27
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
អាណាថោត...បេត-អាសម៉ាវែត...ក្រុងគារយ៉ាត់-យារីម...កេភីរ៉ា...និងប៉្រៀរ៉ុត...រ៉ាម៉ា...និងកេបា
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 7:31
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
(សូមមើល:
មីកម៉ាស...បេត-អែល...និងអៃយ...នេបូរ...អេឡាំ
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 7:35
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
ហារីម...យេរីខូរ..ឡូឌ ហាឌីឌ...អូណូរ...សេណាអា
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 7:39
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
យេដាយ៉ា...យេសួរ...អ៊ីមមើរ...ផាសហ៊ើរ...ហារីម
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 7:43
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
យេសួរ...កាឌមាល...ហូដាវា...អសាភ...សាលូម....អេធើ...ថាលម៉ូន...អ័កគូប...ហាធីថា...សូបាយ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ពួកអ្នកចម្រៀង
បកប្រែពាក្យនេះដូចនៅក្នុងជំពូកទី៧:១។
ពួកឆ្មាំទ្វា
បកប្រែពាក្យនេះដូចនៅក្នុងជំពូកទី៧:១។
Nehemiah 7:46
ខ្លឹមសារភ្ជាប់:
ខគម្ពីរទាំងនេះបញ្ជាក់ពីឈ្មោះមនុស្សដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីការនិរទេស
ស៊ីហា...ហាស៊ូផា...ថាបាអូត...កេរ៉ូស ...ស៊ីយ៉ាហា...
ផាដូន...លេបាណា...ហាកាបា...សាលម៉ាយ...ហាណាន ...គីដេល...កាហារ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 7:50
ខ្លឹមសារភ្ជាប់:
ខគម្ពីរទាំងនេះបញ្ជាក់ពីឈ្មោះមនុស្សដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីការនិរទេស។
រីអាយ៉ា...រេស៊ីន...នេកូដា...កាសាម ...អ៊ូសា...ផាសេហា...បេសាយ...មេហ៊ូនីម ...នេភូស៊ីម
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 7:53
ខ្លឹមសារភ្ជាប់:
ខគម្ពីរទាំងនេះបញ្ជាក់ពីឈ្មោះមនុស្សដែលកូនចៅរបស់ពួកគេបានវិលត្រឡប់មកពីការនិរទេស។
បាកប៊ូក...ហាគូផា...ហាហ៊ើរ...បាសលូត...បាសលូត...មេហ៊ីដា ...ហាសា...បាកូស...ស៊ីសេរ៉ា...ថាម៉ា...ស៊ីយ៉ា...ហាធីផា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 7:57
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
សូថាយ...សូផេរេត...ពេរូដា...យ្អាឡា...ដាកុន...គីដេល...គីដេល...
សេផាធា...ហាធីល...ផូកេរេត...សេបែម...អាំម៉ូន
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 7:61
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
បានឡើង
នេះគឺជាប្រយោគមួយដែលសំដៅទៅការធ្វើដំណើរឆ្ពោះទៅកានក្រុងយេរូសាឡិម
ដែលស្ថិតនៅលើដីខ្ពស់ជាងតំបន់ជុំវិញ។ ការបកប្រែរបៀបផ្សេងទៀត:
«បានត្រឡប់មក» ឬ «ត្រឡប់មកវិញ»
ក្រុងធេល មែឡា...ធេល ហារេសា...កេរូប... អ័ដាន.... និងអ៊ីមមើរ
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
ដេឡាយ៉ា...ថូប៊ីយ៉ា...នេកូដា...ហាបាយ៉ា...ហាគូស...បារស៊ីឡាយ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 7:64
អ្នកទាំងនោះរកនាមត្រកូលតាមបញ្ជីពង្សាវតាររបស់ខ្លួនមិនឃើញទេ
«ពួកគេបានស្វែងរកកំណត់ត្រាពង្សាវតារបស់ពួកគេដែលបានសរសេរ» ឬ
«ពួកគេបានស្វែងរកកំណត់ត្រាពង្សាវរបស់ពួកគេ ។»
អ្នកទាំងនោះ
«អ្នកទាំងនោះ» គឺសំដៅទៅលើកូនចៅជំនាក់ក្រោយនៃលោក.ហាបាយ៉ា...
ហាគូស...បារស៊ីឡាយ។ (សូមមើល: 7ः61)
តែពួកគេរកមិនឃើញទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែពួកគេរកមិនឃើញទិន្នន័យរបស់ពួកគេនោះទេ»
ដូច្នេះ ពួកគេត្រូវបាត់បង់វចេញពីការងារជាសង្ឃ ទុកដូចជាសង្ឃដែលមិនបរិសុទ្ធ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ នាមអរូបី «សង្ឃ»
អ្នកអាចបកប្រែដោយប្រើកិរិយាស័ព្ទ «ការងារជាសង្ឃ»
ការបកប្រែរបៀបផ្សេងទៀត:
«លោកទេសាភិបាលចាត់ទុកពួកគេដូចជាមិនបរិសុទ្ធហើយមិនអនុញ្ញាតឲ្យពួកគេបំពេញមុខងារជាសង្ឃ
រហូតទាល់តែបានលើកឡើងជាមួយបូជាចារ្យម្នាក់ និងយូរីម និងធូមីម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«រហូតដល់បូជាចារ្យដែលមានយូរីម និងធូមីមបានយល់ព្រម»
យូរីម និងធូមីម
ទាំងនេះជាថ្មពិសិដ្ឋដែលសម្តេចសង្ឃកាន់លើប្រដាប់ពាក់លើទ្រូងហើយប្រើនៅពេលខ្លះដើម្បីកំណត់បំណ
Nehemiah 7:66
ខ្លឹមសារភ្ជាប់:
លោកនេហេមាកំពុងបន្តរាប់ចំនួនមនុស្សដែលបានវិលត្រឡប់មកពីនិរទេស។
ក្រុមជំនុំទាំងអស់គ្នា
«ក្រុមទាំងមូល»
មាន ៤២ ៣៦០
«មានមនុស្ស៤២ ៣៦០នាក់»
ពួកចម្រៀងទាំងប្រុសទាំងស្រី
«អ្នកចម្រៀងប្រុស និងអ្នកចម្រៀងស្រី»
Nehemiah 7:68

generated on Wed Sep 10 16:16:32 2025

ទាំងនេះគឺជាចំនួននៃសត្វដែលបាននាំត្រឡប់មកវិញ។

Nehemiah 7:70

ពួកអ្នកដឹកនាំមេគ្រួសារ

«មេបុព្វបុរស» ឬ «មេដឹកនាំនៃអំបូរ» (UDB)

បានថ្វាយដាក់ក្នុងឃ្លាំង

«ដាក់ចូលទៅក្នុងឃ្លាំង»

មួយពាន់តម្លឹង

«១០០០ តម្លឹង»

មាស

គឺជាកាក់មាសតូចមួយដែលប្រជាជននៅចក្រភពពើស៊ីបានប្រើ។

សម្លៀកបំពាក់

«គ្រឿងនៃសម្លៀកបំពាក់»

មាសចំនួនពីរម៉ឺនតម្លឹង

«២០០០០ តម្លឹង»

ប្រាក់ណែន

ណែនគឺមានទំងន់ប្រហែលកន្លះកន្លះនៃទម្ងន់។

ពីរពាន់ណែន

«២០០០ណែន»

អាវផាយហុកសិបប្រាំពីរ

ប្រាំពីរអាវផាយ «៦៧ អាវផាយ»

Nehemiah 7:73

ពួកឆ្មាំទ្វារ

បកប្រែពាក្យនេះដូចនៅក្នុងជំពូកទី ៧:១។

ពួកចម្រៀង

បកប្រែពាក្យនេះដូចនៅក្នុងជំពូកទី ៧៖១។

ប្រជាជនខ្លះ

នេះជាព័ត៌មានដែលសំដៅទៅលើមនុស្សនៅក្នុងក្រុងយេរូសាឡិម
ដែលមិនមែនជាសង្ឃ ឬអ្នកដែលធ្វើការព្រះវិហារ។

អ៊ីស្រាអែលទាំងអស់

អាចមានន័យថា: ១)
ក្រុមជនជាតិអ៊ីស្រាអែលទាំងអស់ដែលត្រូវបានកត់ត្រាក្នុងខនេះ ឬ ២)
ប្រជាជនអ៊ីស្រាអែលទាំងអស់ដែលមិនធ្វើការនៅក្នុងព្រះវិហារ។

ខែទីប្រាំពីរ

«ខែទីប្រាំពីរ។» នេះគឺជាខែទីប្រាំពីរនៃប្រតិទិនរបស់ពួកយូដា។
នេះគឺជាកំឡុងពេលចុងក្រោយនៃខែកញ្ញានិងផ្នែកដំបូងនៃខែតុលាតាមប្រតិទិនលោកខាងលិច។

នៅក្នុងទីក្រុងទាំងឡាយរបស់ពួកគេ

«រស់នៅក្នុងទីក្រុងរបស់ពួកគេ»

---

8 [1]ប្រជាជនទាំងអស់បានមកជួបជុំគ្នានៅទីធ្លាខាងមុខទ្វារទឹក ដោយមានចិត្តតែមួយ។ ហើយគេសុំឲ្យលោកបូជាចារ្យអែសរ៉ាយកគម្ពីរក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលព្រះអម្ចាស់បានបង្គាប់មកពួកអ៊ីុស្រាអែល។[2]នៅថ្ងៃទីមួយនៃខែទីប្រាំពីរ លោកបូជាចារ្យអែសរ៉ាក៏យកក្រឹត្យវិន័យមកខាងមុខក្រុមជំនុំទាំងប្រុសទាំងស្រី និងអស់អ្នកដែលអាចស្តាប់យល់បាន។[3]លោកអានក្នុងគម្ពីរនោះ នៅខាងមុខទីធ្លា ដែលស្ថិតនៅមុខទ្វារទឹក តាំងពីព្រលឹម រហូតដល់ថ្ងៃត្រង់ នៅចំពោះប្រជាជនទាំងប្រុសទាំងស្រី ព្រមទាំងអស់អ្នកដែលអាចយល់បាន ហើយគេក៏ផ្ទៀងត្រចៀកស្តាប់គម្ពីរក្រឹត្យវិន័យនោះ។
[4]បន្ទាប់មកលោកបូជាចារ្យអែសរ៉ាឈរលើវេទិកាធ្វើពីឈើ ដែលគេបានធ្វើសម្រាប់ការនោះ។ លោកម៉ាធិធា លោកសេម៉ា លោកអ័ណាយ៉ា លោកអ៊ូរីយ៉ា លោកហ៊ីលគីយ៉ា និងលោកម្អាសេយ៉ា ឈរនៅខាងស្តាំដៃរបស់លោក ហើយលោកពេដាយ៉ា លោកមីសាអែល លោកម៉ាលគា លោកហាស៊ូម លោកហាសបាដាណា លោកសាការី និងលោកមស៊ូឡាម ឈរនៅខាងឆ្វេងដៃរបស់លោក។[5]លោកបូជាចារ្យអែសរ៉ាបើកគម្ពីរ នៅចំពោះភ្នែកប្រជាជនទាំងអស់ ដ្បិតលោកនៅខ្ពស់ជាងគេ ហើយពេលលោកបើកគម្ពីរឡើង ប្រជាជនទាំងអស់ក៏ក្រោកឈរ។
[6]លោកអែសរ៉ាលើកតម្កើងព្រះអម្ចាស់ ជាព្រះដ៏អស្ចារ្យ ហើយប្រជាជនក៏ឆ្លើយថា "អាម៉ែន! អាម៉ែន!" ទាំងប្រទូលដៃឡើង រួចឱនក្បាល ហើយក្រាបចុះមុខដល់ដី ថ្វាយបង្គំព្រះអម្ចាស់។[7]ចំណែក លោកយេសួរ លោកបានី លោកសេរេប៊ីយ៉ា លោកយ៉ាមីន លោកអ័កគូប លោកសាបថាយ លោកហូឌា លោកម្អាសេយ៉ា លោកកេលីថា លោកអ័សារា លោកយ៉ូសាបាឌ លោកហាណាន លោកពេឡាយ៉ា ជាពួកលេវី ជួយពន្យល់ក្រឹត្យវិន័យដល់ប្រជាជន នៅពេលប្រជាជនកំពុងឈរតាមកន្លែងរបស់គេ។
[8]ពួកគេអានគម្ពីរ ក្នុងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ យ៉ាងច្បាស់ៗ ហើយគេបកស្រាយន័យ ដើម្បីឲ្យប្រជាជនយល់សេចក្តីដែលបានអាន។
[9]លោកនេហេមាដែលជាទេសាភិបាល និងអែសរ៉ាដែលជាបូជាចារ្យ និងពណ្ឌិតខាងច្បាប់ ព្រមទាំងពួកលេវីដែលបង្រៀនប្រជាជន ពោលទៅកាន់ប្រជាជនទាំងមូលថា៖ «ថ្ងៃនេះជាថ្ងៃបរិសុទ្ធសម្រាប់ព្រះអម្ចាស់ដែលជាព្រះរបស់អ្នកគ្រប់គ្នា។ មិនត្រូវកាន់ទុក្ខ ឬយំសោកអ្វីឡើយ»។ ដ្បិតប្រជាជនទាំងឡាយយំ ពេលគេឮពាក្យក្នុងក្រឹត្យវិន័យ។[10]បន្ទាប់មក លោកនេហេមាបន្តមានប្រសាសន៍ទៅគេថា៖ «ចូរនាំគ្នាទៅបរិភោគអាហារ ហើយរកអ្វីដែលផ្អែមៗផឹកទៅ សូមយកមួយចំណែកជូនអ្នកណាដែលគ្មានអ្វីរៀបចំផង ដ្បិតថ្ងៃនេះជាថ្ងៃបរិសុទ្ធសម្រាប់ព្រះជាម្ចាស់នៃយើង។ មិនត្រូវកើតទុក្ខឡើយ ដ្បិតអំណររបស់ព្រះអម្ចាស់ ជាកម្លាំងរបស់អ្នករាល់គ្នា»។
[11]ដូច្នេះ ពួកលេវីបានលួងលោមប្រជាជនឲ្យនៅស្ងៀម ដោយពាក្យថា៖ «ចូរអ្នករាល់គ្នាស្ងាត់ស្ងៀមទៅ ដ្បិតថ្ងៃនេះជាថ្ងៃបរិសុទ្ធ មិនត្រូវកើតទុក្ខឡើយ»។
[12]បន្ទាប់មកប្រជាជនទាំងអស់ក៏នាំគ្នាទៅបរិភោគអាហារ និងស្រា ព្រមទាំងជូនអាហារដល់គ្នា ហើយនាំគ្នាសប្បាយរីករាយជាខ្លាំង ព្រោះគេបានយល់ព្រះបន្ទូលដែលបានប្រកាសប្រាប់ពួកគេ។
[13]នៅថ្ងៃទីពីរ ពួកអ្នកដឹកនាំនៃបុព្វបុរសក្នុងចំណោមប្រជាជនទាំងអស់ ព្រមទាំងពួកបូជាចារ្យ និងពួកលេវី បាននាំគ្នាមកអែសរ៉ា ដើម្បីសិក្សាព្រះបន្ទូលនៅក្នុងក្រឹត្យវិន័យ។
[14]ពួកគេឃើញមានសេចក្តីចែងទុកក្នុងក្រឹត្យវិន័យ ជាសេចក្តីដែលព្រះអម្ចាស់បានបង្គាប់មកតាមរយៈលោកម៉ូសេថា ពួកកូនចៅអ៊ីស្រាអែលត្រូវនៅក្នុងជំរុំនៅក្នុងវេលាបុណ្យនៃខែទីប្រាំពីរ[15]ពួលគេត្រូវយកដំណឹងនេះទៅប្រកាសប្រាប់នៅគ្រប់ទាំងក្រុងរបស់គេ និងនៅក្រុងយេរូសាឡិមថា៖ «ចូរចេញទៅឯភ្នំ ហើយកាប់យកមែកអូលីវស្រុក និងអូលីវព្រៃ មែកយីថោ ធាងចាក និងមែកឈើឯទៀតៗដែលមានស្លឹកច្រើន មកធ្វើក្រសាលតាមសេចក្តីដែលបានចែងទុក»។
[16]ដូច្នេះ ប្រជាជនក៏ចេញទៅកាប់យកមែកទាំងនោះមកធ្វើក្រសាល នៅលើដំបូលផ្ទះរបស់គេរៀងៗខ្លួន នៅទីធ្លាផ្ទះរបស់គេ នៅទីលាននៃព្រះដំណាក់របស់ព្រះ នៅទីធ្លាត្រង់ទ្វារទឹក និងនៅទីធ្លាត្រង់ទ្វារអេប្រាអិម។[17]គឺអស់អ្នកដែលបានវិលត្រឡប់ពីសណ្ឋានជាឈ្លើយ បានធ្វើក្រសាលគ្រប់ៗគ្នា ហើយគេស្នាក់នៅក្នុងក្រសាលទាំងនោះ។ ដ្បិតតាំងពីគ្រាលោកយ៉ូស្វេ ជាកូនរបស់លោកនុន រហូតដល់ថ្ងៃនោះ ប្រជាជនអ៊ីុស្រាអែលមិនដែលបានធ្វើពិធីអបអរអ្វីឡើយ ដូច្នេះ ពួកគេមានសេចក្តីរីករាយជាខ្លាំង។
[18]ដូច្នេះរៀងរាល់ថ្ងៃ ចាប់ពីថ្ងៃដំបូង រហូតដល់ថ្ងៃចុងបំផុត លោកបូជាចារ្យអែសរ៉ាក៏អាននៅក្នុងគម្ពីរក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ ពួកគេប្រារព្ធពិធីបុណ្យនោះអស់រយៈពេលប្រាំពីរថ្ងៃ ហើយនៅថ្ងៃទីប្រាំបី មានការប្រជុំយ៉ាងឱឡារិក តាមបញ្ញត្តិ។

Nehemiah 8:1

ប្រជាជនទាំងអស់បានមកជួបជុំគ្នា

នេះគឺជាការធ្វើឲ្យមានលក្ខណៈទូទៅដែលបង្ហាញថាប្រជាជនទាំងមូលបានរួបរួមគ្នា។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនទាំងអស់បានមកជួបជុំគ្នា»

ទ្វារទឹក

នេះគឺជាឈ្មោះនៃទ្វារធំ ឬច្រកចូលកំពែង។

គម្ពីរក្រឹត្យវិន័យរបស់លោកម៉ូសេ

នេះអាចជាផ្នែកខ្លះឬទាំងអស់នៃកណ្ឌគម្ពីរដំបូងទាំង ៥ គម្ពីរសញ្ញាចាស់។

នៅថ្ងៃទីមួយនៃខែទីប្រាំពីរ

នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។
ថ្ងៃទីមួយនៃខែទីប្រាំពីរនៅកៀកពាក់កណ្តាលខែកញ្ញានៃប្រតិទិនរបស់លោកខាលិច។
ការបកប្រែរបៀបផ្សេងទៀត៖ «នៅថ្ងៃ ១ នៃខែទី៧»

បាននាំច្បាប់

«នាំយកសៀវភៅក្រឹត្តវិន័យ»

អស់អ្នកដែលអាចយល់បាន និងស្តាប់បាន

នេះរួមបញ្ចូលទាំងកុមារដែលមានអាយុគ្រប់គ្រាន់ ដើម្បីយល់ពីអ្វីដែលកំពុងអាន។

គាត់អានពីវា

ពាក្យ «វា» គឺសំដៅទៅលើសៀវភៅក្រឹត្តវិន័យរបស់លោកម៉ូសេ។

generated on Wed Sep 10 16:16:32 2025

Nehemiah 8:4
ម៉ាធិធា...សេម៉ា...អ័ណាយ៉ា...អ៊ូរីយ៉ា...ហ៊ីលគីយ៉ា...ម្អាសេយ៉ា...ពេដាយ៉ា ...ហាស៊ូម...ហាសបាដាណា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
បន្ទាប់មកលោកបូជាចារ្យអែសរ៉ាបានបើកគម្ពីរនៅចំពោះមុខប្រជាជន
នាមអរូបី «មើល ឃើញ» អាចត្រូវបានបង្ហាញជាកិរិយាស័ព្ទ «មើល»។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សទាំងអស់បានឃើញលោកបូជាចារ្យអែសរ៉ាបានបើកគម្ពីរ»
Nehemiah 8:6
លោកអែសរ៉ាអរព្រះគុណព្រះអម្ចាស់
នាមអរូបី «អរព្រះគុណ» អាចបកប្រែជាកិរិយាស័ព្ទបាន។
ការបកប្រែរបៀបផ្សេងទៀត: «លោកអែសរ៉ាបានអរព្រះគុណព្រះអម្ចាស់»
យេសួរ បានី សេរេប៊ីយ៉ា យ៉ាមីន អ័កគូប សាបថាយ ហូឌា ម្អាសេយ៉ា កេលីថា អ័សារ ហាណាន ពេឡាយ៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ពួកគេបានអានព្រះអម្ចីរ
ពាក្យ «ពួកគេ» គឺសំដៅទៅលើពួកលេវី។ ធ្វើឲ្យវាច្បាស់លាស
ជាមួយនឹងការបកប្រែ និងប្រាប់អំពីអត្ថន័យផង។
អ្នកអាន
«តើបានអានអ្វី?»
Nehemiah 8:9
ដ្បិតប្រជាជនទាំងឡាយយំ
នេះគឺជាការទូទៅដែលបង្ហាញថាមានការយំសោកយ៉ាងខ្លាំងក្នុងចំណោមប្រជាជន។
ការបកប្រែរបៀបផ្សេងទៀត៖ «ដ្បិតប្រជាជនទាំងឡាយយំ យ៉ាងខ្លាំង»
ចូរនាំគ្នាទៅបរិភោគអាហារ ហើយផឹកស្រាឆ្ងាញ់ៗ
ព័ត៌មានបង្កប់ន័យថាប្រជាជនត្រូវបានគេប្រាប់ឲ្យបរិភោគអាហារ
និងភេសជ្ជៈផ្អែមៗ។ ការបកប្រែរបៀបផ្សេងទៀត៖
មិនត្រូវកើតទុក្ខឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «កុំកើតទុក្ខឡើយ»
ដ្បិតអំណររបស់ព្រះអម្ចាស់ ជាកម្លាំងរបស់អ្នករាល់គ្នា
នាមអរូបី «អំណរ» និង «កម្លាំង» អាចបង្ហាញពីកិរិយាស័ព្ទ ឬ គុណកិរិយា។
ការបកប្រែរបៀបផ្សេងទៀត: «មានអំណរក្នុងព្រះអម្ចាស់នឹងការពារអញនក» ឬ «មានអំណរក្នុងព្រះអម្ចាស់ អ្នកនឹងមានជម្រកដ៏រឹងមាំ»
Nehemiah 8:11
ស្ងៀម!
«នៅឲ្យសង្ងៀម» ឬ «សូមស្ងៀមស្ងាត់»
មិនត្រូវកើតទុក្ខឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «កុំកើតទុក្ខឡើយ»
នាំគ្នាសប្បាយរីករាយជាខ្លាំង
នាមអរូបី «អំណរ» អាចបកប្រែជាពាក្យបាន។ កាបកប្រែរបៀបផ្សេងទៀត: «រីករាយជាខ្លាំង» (សូមមើល:figs-abstractnouns)
ព្រះបន្ទូលដែលបានប្រកាសប្រាប់ពួកគេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះបន្ទូលដែលលោកបានប្រកាសប្រាប់ពួកគេ»
Nehemiah 8:13
នៅថ្ងៃទីពីរ
«នៅថ្ងៃទី២» ឬ «នៅថ្ងៃបន្ទាប់»
ឃើញមានសេចក្តីចែងទុក
នាមអរូបី «ឃើញ» អាចបញ្ជាក់ជាកិរិយាស័ព្ទបាន។ ការបកប្រែរបៀបផ្សេងទៀត: «យល់»
ខែទីប្រាំពីរ
«ខែទី៧» នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។
នេះគឺជាកំឡុងពេលចុងក្រោយនៃខែកញ្ញា
និងផ្នែកដំបូងនៃខែតុលាតាមប្រតិទិនលោកខាងលិច។
គេត្រូវយកដំណឹងនេះទៅប្រកាស
«ពួកគេគួរតែប្រកាស»
មែកយីថោ
ជាប្រភេទរុក្ខជាតិតូចៗដែលមានផ្កាចំរុះពណ៌
មែកឈើឯទៀតៗ
ដើមឈើស្លឹក
ដើម្បីធ្វើជម្រកបណ្តោះអាសន្ន
«ដើម្បីធ្វើជាតង់»
តាមសេចក្តីដែលបានចែងទុក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ដូចអ្វីដែលលោកម៉ូសេបានចែងទុក»
Nehemiah 8:16
បានធ្វើតង់រៀងៗខ្លួន
«សាសង់សង់រៀងៗខ្លួន»
ទ្វារទឹក និងនៅទីធ្លាត្រង់ទ្វារអេប្រាអិម
ទាំងនេះគឺជាឈ្មោះនៃច្រកចូលធំៗ ឬទ្វារចូលក្នុងកំពែង។
និងនៅទីធ្លាត្រង់ទ្វារអេប្រាអិម
«កន្លែងច្រកចូលនៅតាមមាត់ទ្វារអេប្រាអ៊ីម»
ដ្បិតតាំងពីគ្រាលោកយ៉ូស្វេ
«ចាប់តាំងពីគ្រាលោកយ៉ូស្វេ»
Nehemiah 8:18
រៀងរាល់ថ្ងៃ
«រៀងរាល់ថ្ងៃ»
ចាប់ពីថ្ងៃដំបូង រហូតដល់ថ្ងៃចុងបំផុត
ព័ត៌មានបង្កប់ន័យគឺថា: នេះគឺក្នុងអំឡុងពេលពេញមួយសប្តាហ៍នៃពិធីបុណ្យ។
ការបកប្រែរបៀបផ្សេងទៀត: «ចាប់ពីថ្ងៃដំបូងរហូតដល់ថ្ងៃចុងក្រោយនៃសប្តាហ៍»
ពួកគេប្រារព្ធពិធីបុណ្យ
«ពួកគេធ្វើពិធីជប់លៀង» ឬ «ពួកគេប្រារព្ធពិធីបុណ្យ»
នៅថ្ងៃទី៨
«នៅថ្ងៃទី៨»
ការប្រជុំយ៉ាងឱឡារិក
នេះគឺជាការប្រជុំសាសនាពិសេសមួយ។
ដោយគោរពតាមក្រឹត្យនេះ
ព័ត៌មានដែលបង្កប់ន័យថា «ក្រឹត្យ»
នេះគឺជាបទបញ្ជារបស់ព្រះអម្ចាស់អំពីរបៀបបញ្ចប់ពិធីបុណ្យនៃជម្រក។
ការបកប្រែរបៀបផ្សេងទៀត: «ដូចដែលព្រះជាម្ចាស់បានបញ្ជា»

---

9 [1]លុះដល់ថ្ងៃម្ភៃបួនក្នុងខែដដែលនោះ ប្រជាជនអ៊ីស្រាអែលបានជួបប្រជុំគ្នា ទាំងតមអាហារ ដោយស្លៀកសំពត់ធ្វើពីចង ហើយយកដីរោយលើក្បាល។[2]អស់អ្នកដែលជាពូជពង្សអ៊ីស្រាអែល បានញែកខ្លួនចេញពីជនជាតិដទៃទាំងអស់។ ពួកគេបានឈរឡើង លន់តួអំពើបាបរបស់ខ្លួន និងអំពើទុច្ចរិតនៃបុព្វបុរសរបស់គេផងដែរ។
[3]ពួកគេឈរតាមកន្លែងរបស់ពួកគេរៀងៗខ្លួន ហើយអានក្នុងគម្ពីរក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ជាព្រះរបស់ពួកគេ។ សម្រាប់បួនភាគបួននៅថ្ងៃនោះ ពួកគេលន់តួអំពើបាប និងថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់ពួកគេ។[4]ពេលនោះ លោកយេសួរ លោកបានី លោកកាឌមាល លោកសេបានា លោកប៊ូនី លោកសេរេប៊ីយ៉ា លោកបានី និងលោកកេណានី ឈរលើថ្នាក់ជណ្តើររបស់ពួកលេវី ហើយបន្លឺសំឡេងអំពាវនាវដល់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់ពួកគេ។
[5]បន្ទាប់មក ពួកលេវី លោកយេសួរ លោកកាឌមាល លោកបានី លោកហាសាបនា លោកសេរេប៊ីយ៉ា លោកហូឌា លោកសេបានា និងលោកពេថាហ៊ីយ៉ា មានប្រសាសន៍ថា៖ «ចូរក្រោលឈរឡើង ហើយសរសើរព្រះនាមព្រះអម្ចាស់ជារៀងដរាបតទៅ»។ «សូមឲ្យពួកគេលើកតម្កើងព្រះនាមដ៏រុងរឿងរបស់ព្រះអង្គ បានប្រកបដោយព្រះពរ ជាព្រះនាមដែលថ្កើងឡើងខ្ពស់លើសជាងអស់ទាំងពរ និងការសរសើរគ្រប់ទាំងអស់»។[6]ព្រះអង្គគឺជាព្រះអម្ចាស់។ ព្រះអង្គតែមួយ។ ព្រះអង្គបានបង្កើតផ្ទៃមេឃ គឺអស់ទាំងជាន់នៃផ្ទៃមេឃ ព្រមទាំងពិភពទាំងមូល ក៏បានបង្កើតផែនដី និងអ្វីៗទាំងអស់នៅលើផែនដី ហើយសមុទ្រ និងអ្វីៗទាំងអស់នៅក្នុងសមុទ្រ។ ព្រះអង្គប្រទានជីវិតឲ្យរបស់ទាំងអស់នោះ ហើយពួកពលបរិវារនៅលើមេឃ ថ្វាយបង្គំព្រះអង្គ។
[7]ព្រះអង្គគឺជាព្រះអម្ចាស់ ជាព្រះជាម្ចាស់ដែលបានជ្រើសរើសលោកអាប់រ៉ាម ព្រមទាំងនាំលោកចេញពីក្រុងអ៊ើររបស់ពួកជនជាតិខាល់ដេ ហើយប្រទានឲ្យលោកមាននាមថា អ័ប្រាហាំ។[8]ព្រះអង្គបានឃើញថា លោកមានចិត្តស្មោះត្រង់នៅចំពោះព្រះអង្គ ហើយព្រះអង្គក៏បានតាំងសញ្ញានឹងលោក ថានឹងប្រទានស្រុករបស់ពួកជនជាតិកាណាន

generated on Wed Sep 10 16:16:32 2025

ជនជាតិហេត ជនជាតិអាម៉ូរី ជនជាតិពេរិស៊ីត ជនជាតិយេប៊ូស និងជនជាតិគើកាស៊ីពូជពង្សរបស់លោក។ ព្រះអង្គក៏បានសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គ ដ្បិតព្រះអង្គសុចរិត។
9ព្រះអង្គបានទតឃើញទុក្ខវេទនារបស់បុព្វបុរសយើងខ្ញុំនៅស្រុកអេស៊ីប ហើយបានឮសម្រែករបស់គេនៅសមុទ្រក្រហម។10ព្រះអង្គបានប្រទានទីសម្គាល់ និងការអស្ចារ្យទៅលើផារ៉ោន ហើយពួកមហាតលិក និងប្រជាជននៃស្រុកនោះទាំងអស់ ដ្បិតព្រះអង្គជ្រាបថា គេបានប្រព្រឹត្តនឹងបុព្វបុរសរបស់យើងដោយចិត្តព្រហើន។ ប៉ុន្តែព្រះអង្គបានធ្វើឲ្យព្រះនាមព្រះអង្គល្បីល្បាញ រហូតដល់សព្វថ្ងៃ។
11ព្រះអង្គបានញែកសមុទ្រចេញពីគ្នានៅចំពោះមុខពួកគេ ឲ្យពួកគេដើរឆ្លងកាត់កណ្តាលសមុទ្រ លើដីគោក ហើយព្រះអង្គបានទម្លាក់ពួកអ្នកដែលដេញតាមទៅក្នុងទីជម្រៅដូចជាបោះថ្មទៅក្នុងមហាសាគរ។
12ព្រះអង្គបាននាំពួកគេ ដោយសារបង្គោលពពកនៅពេលថ្ងៃ ហើយនៅពេលយប់ ដោយបង្គោលភ្លើងដើម្បីបំភ្លឺផ្លូវដែលពួកគេត្រូវដើរ។13ព្រះអង្គបានយាងចុះមកលើភ្នំស៊ីណាយ ហើយមានព្រះបន្ទូលមកកាន់ពួកគេពីលើមេឃ ប្រទានឲ្យពួកគេមានបញ្ញត្តិដ៏ត្រឹមត្រូវ និងក្រឹត្យវិន័យដ៏ពិត ព្រមទាំងច្បាប់ និងបទបញ្ជាផ្សេងទៀត។
14ព្រះអង្គបានធ្វើឲ្យពួកគេស្គាល់ថ្ងៃសប្ប័ទដ៏បរិសុទ្ធរបស់ព្រះអង្គ ហើយប្រទានឲ្យពួកគេមានបទបញ្ញត្តិ និងច្បាប់តាមរយៈលោកម៉ូសេ ជាអ្នកបម្រើរបស់ព្រះអង្គ។15ព្រះអង្គបានប្រទាននំប័ុងពីលើមេឃមកចម្អែតពួកគេ ហើយធ្វើឲ្យមានទឹកហូរចេញពីថ្មមកឲ្យពួកគេផឹក ក៏បានបង្គាប់ឲ្យគេចូលទៅចាប់យកទឹកដី ដែលព្រះអង្គបានស្បថថានឹងឲ្យដល់ពួកគេ។
16ប៉ុន្តែ ពួកគេ គឺដូនតារបស់យើងខ្ញុំ បានប្រព្រឹត្តដោយចិត្តព្រហើន និងរឹងរូស ហើយមិនស្តាប់តាមបញ្ញត្តិរបស់ព្រះអង្គទេ។17គេមិនព្រមស្តាប់បង្គាប់ឡើយ ក៏មិនខ្វល់ពីការអស្ចារ្យដែលព្រះអង្គបានធ្វើក្នុងចំណោមពួកគេទេ គឺពួកគេមានចិត្តរឹងរូស ហើយបះបោរ គេបានតែងតាំងមេដឹកនាំ ដើម្បីវិលទៅរកភាពជាទាសកវិញ។ ប៉ុន្តែតែព្រះអង្គជាព្រះដែលមានពេញទៅដោយការអត់ទោស ប្រណីសន្តោស ហើយមេត្តាករុណា យឺតនឹងខ្ញាល់ ហើយមានព្រះហឫទ័យសប្បុរសជាបរិបូរ។ ព្រះអង្គមិនបោះបង់ចោលពួកគេឡើយ។
18ទោះជាពេលដែលពួកគេបានសូនធ្វើរូបកូនគោមាសមួយ ហើយនិយាយថា នេះជាព្រះរបស់យើង ដែលបាននាំយើងឡើងពីទឹកដីអេស៊ីប ហើយគេបានប្រមាថព្រះអង្គយ៉ាងខ្លាំង19ដោយព្រះហឫទ័យមេត្តាករុណា ព្រះអង្គមិនបានបោះបង់ចោលពួកគេនៅទីរហោស្ថានឡើយ។ បង្គោលពពកមិនបានថយចេញ លែងនាំផ្លូវពួកគេនៅពេលថ្ងៃឡើយ ហើយបង្គោលភ្លើងក៏មិនលែងបំភ្លឺពួកគេនៅពេលយប់ ដើម្បីបង្ហាញផ្លូវដែលគេត្រូវដើរនោះដែរ។
20ព្រះអង្គបានប្រទានព្រះវិញ្ញាណដ៏ល្អរបស់ព្រះអង្គ មកបង្រៀនពួកគេ ហើយប្រទាននំម៉ាណាឲ្យពួកគេបរិភោគ ព្រមទាំងប្រទានទឹកឲ្យពួកគេផឹកមិនដែលខកខានឡើយ។
21ព្រះអង្គបានចិញ្ចឹមគេនៅទីរហោស្ថានរយៈពេលសែសិបឆ្នាំ ពួកគេមិនខ្វះខាតអ្វីឡើយ។ សម្លៀកបំពាក់របស់ពួកគេក៏មិនដែលសឹក ហើយជើងរបស់ពួកគេក៏មិនធ្លាប់ហើមដែរ។
22ព្រះអង្គបានប្រទាននគរ និងជនជាតិនានាដល់ពួកគេ ហើយចែកស្រុកទាំងអស់ដល់ពួកគេ។ ដូច្នេះ ពួកគេដណ្តើមយកបានទឹកដីរបស់ព្រះបាទស៊ីហុន ជាស្តេចក្រុងហែសបូន និងទឹកដីរបស់ព្រះបាទអុក ជាស្តេចស្រុកបាសាន។
23ព្រះអង្គបានធ្វើឲ្យកូនចៅរបស់ពួកគេកើនចំនួនច្រើនឡើងដួងដារាដែលនៅលើមេឃ ហើយព្រះអង្គបាននាំពួកគេចូលទៅក្នុងទឹកដីដែលព្រះអង្គបានមានបន្ទូលទៅកាន់បុព្វបុរសរបស់ពួកគេ ឲ្យពួកគេចូលទៅហើយគ្រប់គ្រង។24ដូច្នេះ កូនចៅរបស់ពួកគេក៏ចូលទៅកាន់កាប់ទឹកដីនោះ ហើយព្រះអង្គបានបង្ក្រាបជនជាតិកាណាន។ ព្រះអង្គបានប្រគល់ជនជាតិនោះទៅក្នុងដៃរបស់ពួកគេ ព្រមទាំងស្តេចរបស់គេ និងប្រជាជននៃទឹកដីនោះ ដើម្បីជនជាតិអ៊ីស្រាអែលធ្វើអ្វីទៅចិត្តរបស់ពួកគេចង់។
25ពួកគេចាប់យកបានទីក្រុងដែលមានកំផែងការពារ និងទឹកដីដែលមានជីជាតិ ក៏បានចាប់យកផ្ទះដែលមានពេញដោយរបស់ល្អគ្រប់មុខ និងអណ្តូងដែលជីកស្រាប់ ចម្ការទំពាំងបាយជូរ ដំណាំអូលីវ និងដើមឈើស៊ីផ្លែយ៉ាងច្រើនមុខបរិបូរ។ ដូច្នេះហើយ ពួកគេបានបរិភោគឆ្អែត ហើយត្រឡប់ជាមានសាច់ឈាម ក៏មានចិត្តរីករាយ ដោយសារព្រះហឫទ័យសប្បុរសដ៏ធំរបស់ព្រះអង្គ។
26បន្ទាប់មកពួកគេក៏មានចិត្តរឹងចចេស ហើយបះបោរនឹងព្រះអង្គ។ ពួកគេបោះបង់ចោលក្រឹត្យវិន័យរបស់ព្រះអង្គទៅក្រោយខ្នង ។ ពួកគេបានសម្លាប់ព្យាការីរបស់ព្រះអង្គ ដែលបានទូន្មានឲ្យគេវិលមករកព្រះអង្គវិញ។ ហើយពួកគេបាននាំគ្នាប្រមាថព្រះអង្គយ៉ាងខ្លាំង។27ហេតុនេះហើយបានជាព្រះអង្គប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់សត្រូវ ដែលញាំញីសង្កត់សង្កិនគេ។ តែកាលពួកគេកើតមានសេចក្តីវេទនា ពួកគេក៏ស្រែករកព្រះអង្គ ហើយព្រះអង្គស្តាប់ពួកគេពីស្ថានសួគ៌ ហើយព្រះអង្គប្រទានឲ្យពួកគេមានពួកអ្នកសង្គ្រោះ មកសង្គ្រោះពួកគេឲ្យរួចពីកណ្តាប់ដៃរបស់ពួកសត្រូវ ដោយព្រះហឫទ័យមេត្តាករុណាដ៏ធំក្រៃលែងរបស់ព្រះអង្គ។
28ប៉ុន្តែ ក្រោយពីពួកគេមានសេចក្តីស្រាកស្រាន្តហើយ ពួកគេចាប់ផ្តើមប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះអង្គទៀត ហើយព្រះអង្គក៏បោះបង់ចោលពួកគេ នៅក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ ដើម្បីឲ្យខ្មាំងសត្រូវមានអំណាចលើពួកគេ។ ប៉ុន្តែ កាលពួកគេបានងាកបែរ ហើយស្រែកអំពាវនាវរកព្រះអង្គ ព្រះអង្គស្តាប់ពួកគេពីស្ថានសួគ៌ ហើយប្រោសឲ្យពួកគេរួចជាច្រើនដង តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។29ព្រះអង្គបានទូន្មានពួកគេ ដើម្បីនាំពួកគេមករកក្រឹត្យវិន័យព្រះអង្គវិញ។ តែពួកគេបានប្រព្រឹត្តដោយចិត្តព្រហើន មិនព្រមស្តាប់តាមបទបញ្ជារបស់ព្រះអង្គទេ។ ពួកគេបានប្រព្រឹត្តអំពើបាបទាស់នឹងវិន័យរបស់ព្រះអង្គ អ្នកណាប្រព្រឹត្តតាម អ្នកនោះនឹងបានរស់នៅដោយសេចក្តីនោះឯង ។ហើយពួកគេបែរស្មាដ៏រឹងចចេស ក៏តាំងករបស់គេរឹង មិនព្រមស្តាប់បង្គាប់ឡើយ។
30ព្រះអង្គបានទ្រាំទ្រនឹងពួកគេជាច្រើនឆ្នាំ ហើយបានទូន្មានពួកគេ ប្រទានព្រះវិញ្ញាណរបស់ព្រះអង្គតាមរយៈព្យាការីរបស់ព្រះអង្គ។ ប៉ុន្តែពួកគេមិនព្រមយកត្រចៀកស្តាប់នោះទេ។ ដូច្នេះ ព្រះអង្គក៏បានប្រគល់ពួកគេ ទៅក្នុងកណ្តាប់ដៃរបស់ប្រជាជនដែលរស់នៅស្រុកទាំងនោះ។31ប៉ុន្តែ ដោយព្រោះព្រះហឫទ័យមេត្តាករុណាដ៏ក្រៃលែងរបស់ព្រះអង្គ ព្រះអង្គមិនបានធ្វើឲ្យពួកគេវិនាសសាបសូន្យ ឬបោះបង់ចោលពួកគេឡើយ ដ្បិតព្រះអង្គគឺជាព្រះជាម្ចាស់ដ៏មានព្រះហឫទ័យប្រណីសន្តោស ហើយមេត្តាករុណា។
32ដូច្នេះ ព្រះជាម្ចាស់នៃយើង ជាព្រះដ៏ធំ ហើយមានឫទ្ធានុភាព គួរឲ្យស្ញែងខ្លាច ជាព្រះដែលរក្សាសេចក្តីសញ្ញា និងសេចក្តីសប្បុរសអើយ សូមកុំឲ្យសេចក្តីទេវនាទាំងប៉ុន្មានដែលបានកើតមានដល់យើងខ្ញុំ ព្រមទាំងស្តេច ម្ចាស់ក្សត្រី ពួកសង្ឃ ពួកបូជាចារ្យ បុព្វបុរសរបស់យើងខ្ញុំ និងប្រជារាស្ត្រទាំងប៉ុន្មានរបស់ព្រះអង្គ ចាប់ពីគ្រារបស់ពួកស្តេចស្រុកអាសស៊ើរ រហូតដល់សព្វថ្ងៃនេះ ។33ប៉ុន្តែ ព្រះអង្គសុចរិតក្នុងគ្រប់ទាំងការទាំងអស់ដែលបានកើតមានដល់យើងខ្ញុំ ដ្បិតព្រះអង្គបានប្រព្រឹត្តដោយស្មោះត្រង់ តែឯយើងខ្ញុំវិញ បានប្រព្រឹត្តយ៉ាងទុច្ចរិត34ពួកស្តេចរបស់យើងខ្ញុំ ពួកមេរបស់យើងខ្ញុំ ពួកសង្ឃរបស់យើងខ្ញុំ និងបុព្វបុរសរបស់យើងខ្ញុំ មិនបានកាន់តាមក្រឹត្យវិន័យរបស់ព្រះអង្គទេ ក៏មិនបានយកចិត្តទុកដាក់នឹងបទបញ្ជា ព្រមទាំងការព្រមានដែលព្រះអង្គបានប្រទានដល់ពួកគេឡើយ។
35ទោះជាពេលដែលគេរស់នៅក្នុងនគររបស់ខ្លួន ព្រះអង្គប្រទានឲ្យគេមានអស់ទាំងសេចក្តីល្អក្រៃលែង ហើយនៅក្នុងស្រុកដ៏ធំទូលាយ មានជីជាតិ ដែលព្រះអង្គបានដាក់នៅមុខគេ ក៏គេមិនបានគោរពប្រតិបត្តិដល់ព្រះអង្គ ឬងាកបែរចេញពីអំពើទុច្ចរិតរបស់ពួកគេទេ។
36ឥឡូវនេះពួកយើងខ្ញុំបានក្លាយជាបាវបម្រើនៅក្នុងទឹកដីដែលព្រះអង្គបានប្រទានដល់បុព្វបុរសរបស់យើងខ្ញុំដើម្បីរីករាយ និងបរិភោគផលផ្លែ និងសេចក្តីល្អនៅក្នុងស្រុកនោះ។37ភោគផលដ៏សម្បូរហូរហៀររបស់ស្រុកនេះ បែរជាទុកសម្រាប់ពួកស្តេច ដែលព្រះអង្គបានតាំងឲ្យគ្រប់គ្រងលើយើងខ្ញុំ ដោយព្រោះអំពើបាបរបស់យើងខ្ញុំ។ ស្តេចទាំងនោះត្រួតត្រាលើរាងកាយយើងខ្ញុំ និងហ្វូងសត្វរបស់យើងខ្ញុំ តាមអំពើចិត្តរបស់គេ។ ហើយយើងខ្ញុំមានទុក្ខវេទនាជាខ្លាំង។
38ដោយមានហេតុការណ៍ទាំងអស់នេះ យើងខ្ញុំក៏តាំងសញ្ញាមួយយ៉ាងមាំមួនជាលាយលក្ខណ៍អក្សរ។ ហើយមានពួកម្ចាស់ក្សត្រី ពួកលេវី និងពួកបូជាចារ្យរបស់យើងខ្ញុំ ជាអ្នកបោះត្រាលើសេចក្តីសញ្ញានោះ»។

Nehemiah 9:1
ថ្ងៃម្ភៃបួនក្នុងខែដដែល

ថ្ងៃម្ភៃបួនក្នុងខែដដែល ថ្ងៃទីម្ភៃបួននៅក្នុងខែប្រាំពីរ
«នេះគឺជិតពាក់កណ្តាលខែតុលា តាមប្រតិទិនលោកខាងលិច»។

generated on Wed Sep 10 16:16:32 2025

ប្រជាជនអ៊ីស្រាអែលបានជួបប្រជុំគ្នា
«ប្រជាជនអ៊ីស្រាអែលបានជួបជុំគ្នា»
ពួកគេស្លៀកសំពត់ធ្វើពីថង់ ហើយយកដីរោយលើក្បាលរបស់ពួកគេ
ធ្វើដូច្នេះគឺដើម្បីបង្ហាញការសុំទៅពីអ្វីដែលពួកគេបានធ្វើខុសឆ្គងរបស់ពួកគេ
ព្រមទាំងបុព្វបុរសរបស់គេបានធ្វើ។
ពូជពង្សអ៊ីស្រាអែល
«ប្រជាជាតិអ៊ីស្រាអែល»
«ញែកខ្លួនចេញពីជនជាតិដទៃ
គ្មាអ្វីដែលត្រូវធ្វើជាមួយអ្នកដែលមិនមែនជាជនជាតិអ៊ីស្រាអែលទៀតទេ»
ពួកគេបានឈរឡើង លន់តួអំពើបាបរបស់ខ្លួន និងអំពើទុច្ចរិតនៃបុព្វបុរសរបស់គេផងដែរ
«ពួកគេបានលន់តួនូវអ្វីដែលពួកគេបានធ្វើ
និងអ្វីដែលដូនតារបស់ពួកគេបានធ្វើខុសផងដែរ»
Nehemiah 9:3
ពួកគេបានក្រោកឈរ
ប្រជាជាតិអ៊ីស្រាអែលបានក្រោកឈរ
ពួកគេបានលន់តួ
«ពួកគេបានទទួលនូវអ្វីដែលពួកគេបានប្រព្រឹត្តិខុស»
និងថ្វាយបង្គំនៅចំពោះ
«និងថ្វាយបង្គំ» ឬ «និងសរសើរតម្កើង»
ពួកលេវី លោកយេសួរ លោកបានី បានឈេនៅលើឆាក
ការបកប្រែខ្លះបកប្រែថា «លោកយេសួរ លោកបានី ...
ឈរនៅលើជណ្តើរដែលបានសាងសង់សម្រាប់ពួកលេវី»
យេសួរ បានី កាឌមាល សេបានា ប៊ូននី សេរេប៊ីយ៉ា កេណានី
ឈ្មោះនៃមនុស្ស
Nehemiah 9:5
បន្ទាប់មក ពួកលេវី បានមានប្រសាសន៍ថា «ក្រោកឡើង »
នៅទីនេះពួកលេវីកំពុងតែនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល។
សរសើរតម្កើងព្រះអម្ចាស់
«ថ្វាយព្រះពរដល់ព្រះអម្ចាស់»
យេសួរ ...កាឌមាល...បានី...ហាសាបនា...សេរេប៊ីយ៉ា
ឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូក ៩:៣។
ហាសាបនា... ហូឌា... ពេថាហ៊ីយ៉ា
ឈ្មោះរបស់មនុស្ស។
ចូរលើកតម្កើងព្រះនាមដ៏រុងរឿងរបស់ព្រះអង្គ
ពួកលេវីកំពុងតែទូលទៅកាន់ព្រះអម្ចាស់។
«សូមឲ្យប្រជាជននៅស្រុកយូដាប្រទានពរដល់ព្រះនាមដ៏ថ្កុំថ្កើងរបស់ព្រះអម្ចាស់»
ស្ថានសួគ៌ដ៏ខ្ពស់ ជាមួយនិងពិភពទាំងអស់ ពិភពទាំងអស់ព្រមទាំងស្ថានសួគ៌ថ្វាយបង្គំព្រះអង្គ
ពលទ័ព «ពលទ័ពនៃស្ថានសួគ៌»
និយាយជាឧទាហរណ៍នៃផ្កាយជាច្រើនដូចជាពួកគេជាកងទ័ព។
ផ្កាយនៅក្នុងវេនគឺជាឧទាហរណ៍នៃទេវតាជាច្រើន។
ដួងតារាថ្វាយបង្គំព្រះអម្ចាស់គឺជាពាក្យប្រៀបធៀបសម្រាប់ពួកទេវតាដែលថ្វាយបង្គំព្រះ
Nehemiah 9:7
ខ្លឹមសារភ្ជាប់:
ពួកលេវីនៅតែបន្តការតអធិស្ឋានរបស់ពួកគេទៅចំពោះមនុស្សទាំងអស់។
អ៊ើររបស់ពួកជនជាតិខាល់ដេ
«ក្រុងអ៊ើរជាកន្លែងរបស់ពួកជនជាតិខាល់ដេរស់នៅ»
ព្រះអង្គបានឃើញថា លោកមានចិត្តស្មោះត្រង់នៅចំពោះព្រះអង្គ
ដួងចិត្ត ភាពខាងក្នុងនៃមនុស្ស ភាពដំណាងនៃមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានឃើញថា លោកមានដួងចិត្តដ៏ស្មោះត្រង់
នៅចំពោះព្រះអង្គ»
ជនជាតិកាណាន ជមជាតិហេត ជនជាតិអាម៉ូរី ជនជាតិពេរិស៊ីត ជនជាតិយេប៊ូស និងជនជាតិ
គើកាស៊ី
ឺឈ្មោះនៃក្រុមមនុស្ស
Nehemiah 9:9
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
អ្នកបានឃើញ
ព្រះអម្ចាស់បានបានឃើញ
អ្នកបានឮសម្រែករបស់ពួកគេ
ព័ត៌មានបង្កប់ន័យថាព្រះត្រូវបានជំរុញឲ្យមានសកម្មភាពដោយសារតែសម្រែករបស់ជនជាតិអ៊ីស្រាអែលនៅ
ទីសម្គាល់ និងការអស្ចារ្យទៅលើផារ៉ោន
គ្រោះកាចទាំងនោះបានសាកល្បងព្រះហឫទ័យរបស់ស្តេចផារ៉ោន
ហើយពួកគេបានក្លាយជាសាក្សីប្រឆាំងនឹងចិត្តរឹងរូសរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «មានទីសំគាល់ និងការ
អស្ចារ្យដែលធ្វើជាសាក្សីទាស់នឹងស្តេចផារ៉ោន» ឬ «ទីសំគាល់និងការ
អស្ចារ្យដែលបង្កាប់ស្តេចផារ៉ោន»
ប្រជាជននៃស្រុកនោះទាំងអស់
«ប្រជាជនអេស៊ីបទាំងអស់»
ប្រព្រឹត្តនឹងបុព្វបុរសរបស់យើងដោយចិត្តព្រហើន។
«ក្រអឺតក្រទមចំពោះជនជាតិអ៊ីស្រាអែល» ឬ
«ធ្វើបាបមនុស្សដែលព្រះបានជ្រើសរើស»
ព្រះអង្គបានធ្វើឲ្យព្រះនាមព្រះអង្គល្បីល្បាញ
នេះគឺជាវិធីមួយផ្សេងទៀតនៃការនិយាយថា
«អ្នកបានបង្ហាញពិភពលោកនូវចរិករបស់អ្នក» ឬ «អ្នកបង្ហាញអំណាចរបស់អ្នក»។
រហូតដល់សព្វថ្ងៃ
«ដែលមនុស្សនៅតែចងចាំ»
Nehemiah 9:11
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
អ្នកបានញែកសមុទ្រចេញពីគ្នា
ព្រះជាម្ចាស់ជាអ្នកដែលញែក។
ព្រះអង្គបានទម្លាក់ពួកអ្នកដែលដេញតាមទៅក្នុងទីជម្រៅ ដូចជាបោះថ្មទៅក្នុងមហាសាគរ
ក្នុងរឿងប្រៀបធៀបមួយនេះអ្នកនិពន្ធពិពណ៌នាថា
ព្រះជាម្ចាស់បានបោះជនជាតិអេស៊ីបចូលទៅក្នុងសមុទ្រយ៉ាងងាយដូចជាមនុស្សម្នាក់បោះដុំថ្មទៅក្នុងទឹក
ហើយថ្មនឹងរលាយបាត់នៅក្រោមទឹកទាំងស្រុង។
Nehemiah 9:12
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
អ្នកបានដឹកនាំពួកគេ
ព្រះអម្ចាស់បានដឹកនាំប្រជាជាតិអ៊ីស្រាអែល។
អ្នកចុះមក
នៅពេលដែលព្រះជាម្ចាស់មានបន្ទូលជាមួយប្រជាជន
ព្រះអង្គច្រើនតែត្រូវបានពិពណ៌ពី «ចុះមក ឬ «ចុះមកពីស្ថានសួគ៌» ។
នេះគឺជាវិធីពិពណ៌នាមួយដែលបង្ហាញថាព្រះបានលេចមកជួបមនុស្សនោះ»។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានចុះមកពីស្ថានសួគ៌»
វិន័យដ៏ត្រឹមត្រូវ និងក្រឹត្យវិន័យដ៏ពិត ព្រមទាំងច្បាប់ និងបទបញ្ជាផ្សេងទៀត
ឃ្លាទាំងពីរនេះពិពណ៌នាអំពីច្បាប់តែមួយរបស់លោកម៉ូសេ។
Nehemiah 9:14
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
បទបញ្ជា.... បញ្ញត្តិ....ក្រឹត្យវិន័យ
ពាក្យនីមួយៗក្នុងចំណោមពាក្យទាំងបីនេះគឺសំដៅទៅលើច្បាប់របស់លោកម៉ូសេ។
Nehemiah 9:16
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ពួកគេ គឺដូនតារបស់យើង
ជនជាតិអ៊ីស្រាអែលនៅជំនាន់លោកម៉ូសេ
និងប្រជាជនអ៊ីស្រាអែលបន្ទាប់ពីជំនាន់លោកម៉ូសេ
គេមិនព្រមស្តាប់បង្គាប់ឡើយ...ចាប់ផ្តើមរឹងចចេស
ឃ្លាត្រង់នេះគឺ «ពួកគេរឹងចចេស» ។
ប្រសិនបើភាសារបស់អ្នកមានអត្ថន័យខុសគ្នាសម្រាប់ការរឹងចចេសអ្នកប្រហែលជាចង់ប្រើវានៅទីនេះ។
ភាពអស្ចារ្យដែលអ្នកបានធ្វើក្នុងចំណោមពួកគេ
«ការអស្ចារ្យដែលព្រះអង្គបានធ្វើក្នុងចំណោមពួកគេ»

generated on Wed Sep 10 16:16:32 2025

គេបានតែងតាំងម្នាក់ឲ្យធ្វើជាមេដឹកនាំ រំលងទៅរកភាពជាទាសករ
«គេបានតែងតាំងម្នាក់ឲ្យធ្វើជាមេដឹកនាំ ហើយដឹកនាំពួកគេវិលទៅ
រកទឹកដីដែលពួកគេធ្វើជាទាសករវិញ»
តើនរណាដែលពោរពេញទៅដោយការអត់ទោស
បំណងប្រាថ្នាដើម្បីអភ័យទោសត្រូវបានគេនិយាយថាវាប្រៀបបានជាអង្គធាតុរាវដែលរួចរឹតបែនមានជីជាតិធុង។
មានព្រះហឫទ័យសប្បុរសជាបរិបូរ
សេចក្តីស្រឡាញ់ត្រូវបានគេនិយាយដូចជាដំណាំដែលព្រះអម្ចាស់អាចចែករំលែកដល់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ស្រឡាញ់ប្រជារាស្ត្ររបស់ព្រះអង្គខ្លាំងណាស់»
Nehemiah 9:18
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
អ្នក... មិនបានបោះបង់ពួកគេទេ
ព្រះអម្ចាស់មិនបានប៉ះបង់ពួកគេប្រជាជាតិចោលទេ។
សូនធ្វើរូបកូនគោមាសមួយ
លហៈរលាយហើយសូនធ្វើរូបរាងដូចរូបកូនគោ
បង្គោលពពក...បង្គោលភ្លើង
សូមបកប្រែពាក្យនេះដូចនៅក្នុងជំពូកទី ៩:២
Nehemiah 9:20
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ព្រះវិញ្ញាណដ៏ល្អ...នំម៉ាណា...ទឹក
អ្នកនិពន្ធផ្លាស់ប្តូរលំដាប់ពាក្យធម្មតាដើម្បីសង្កត់ធ្ងន់លើរឿងល្អៗ
ដែលព្រះអម្ចាស់បានប្រទានដល់ប្រជាជនរបស់ព្រះអង្គ។
ភាសារបស់អ្នកអាចមានរបៀបផ្សេងទៀតក្នុងការសង្កត់ធ្ងន់លើពាក្យទាំងនេះ។
សេចក្តីណែនាំ
«សេចក្តីបង្រៀន»
ចេញពីមាត់របស់ពួកគេ
មាត់គឺជាតំណាងសម្រាប់មនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«សម្តីដែលចេញពីមាត់»
Nehemiah 9:22
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ព្រះអង្គបានប្រទាននគរឲ្យពួកគេ
ព្រះអម្ចាស់បានប្រទាននរគដល់ប្រជាតិអ៊ីស្រាអែល។
បានប្រទាននរគ និងប្រជាជាតិនានា
«អនុញ្ញាតឲ្យពួកគេយកឈ្នះលើនគរនិងប្រជាជន»
ចែកស្រុកទាំងអស់ដល់ពួកគេ
«អនុញ្ញាតឲ្យពួកគេមានកម្មសិទ្ធិគ្រប់ផ្នែកនៃដី»
ស៊ីហុន.....អ៊ុក
ទាំងនេះគឺជាឈ្មោះរបស់ស្តេច។
ហែសបូន.....បាសាន
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 9:23
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ព្រះអង្គបានធ្វើឲ្យកូនចៅរបស់ពួកគេ
ព្រះអម្ចាស់បានធ្វើឲ្យកូនចៅនៃប្រជាជាតិអ៊ីស្រាអែលនៅជំនាន់លោកម៉ូសេកើន
ចំនួនច្រើនឡើង។
បានប្រទានប្រជាជាតិឲ្យទៅដៃរបស់ពួកគេ
ជនជាតិកាណានត្រូវបានគេនិយាយដូចជាពួកគេជាវត្ថុតូចៗដែលមនុស្សម្នាក់អាចដាក់ចេញពីដៃរបស់មនុស្សម្នាក់ទៀត។
ការផ្តល់អ្វីមួយទៅក្នុងដៃរបស់មនុស្សគឺផ្តល់ឲ្យមនុស្សនោះនូវការគ្រប់គ្រងពេញលេញលើវត្ថុនោះ។
ការបកប្រែរបៀបផ្សេងទៀត: «អនុញ្ញាតិឲ្យជនជាតិអ៊ីស្រាអែល
គ្រប់គ្រងលើពួកគេទាំងស្រុង»
Nehemiah 9:25
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ពួកគេចាប់យក
ជនជាតិអ៊ីស្រាអែលនៅជំនាន់លោកម៉ូសេ។
ចិត្តដ៏ធំធេងរបស់ព្រះអង្គ
«ដីមានជីជាតិ»
អនុត្តរៈ
រួងក្រោមដីដែលមនុស្សទុកសម្រាប់ស្តុកទឹក
ធាត់
នេះអាចជាពាក្យប្រៀបធៀបមួយគឺ «ឈប់គិតអំពីព្រះអម្ចាស់» ឬ
«ក្លាយជាការពេញចិត្ត»។
Nehemiah 9:26
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដល់ព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ពួកគេបោះបង់ចោលក្រឹត្យវិន័យរបស់ព្រះអង្គទៅក្រោយខ្នង
ក្រឹត្យវិន័យត្រូវបានគេនិយាយថាគឺជារបស់ដែលគ្មានតម្លៃដែលមនុស្សម្នាក់អាចបោះចោល។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេចាត់ទុកក្រឹត្យវិន័យរបស់ព្រះអង្គថាឥតបានការហើយមិនយកចិត្តទុកដាក់លើច្បាប់នេះឡើយ»
ពួកគេបោះបង់ចោលក្រឹត្យវិន័យរបស់អ្នកចោល
ជនជាតិអ៊ីស្រាអែលបានបោះបង់ចោលក្រឹត្យវិន័យរបស់ព្រះអម្ចាស់។
អ្នកបានប្រគល់ពួកគេឲ្យទៅក្នុងដៃសត្រូវរបស់ពួកគេ
ត្រង់នេះពាក្យថា «ដៃ»
ព្រះអង្គប្រទានឲ្យពួកគេមានពួកអ្នកសង្គ្រោះ មកសង្គ្រោះពួកគេឲ្យរួចពីកណ្តាប់ដៃរបស់ពួកសត្រូវ
ត្រង់នេះពាក្យថា «ដៃ» (ផ្នែក) បង្ហាញពីអំណាចរបស់ «ខ្មាំងសត្រូវ!
(ជាមនុស្សទាំងមូល) ធ្វើបាប។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានចាត់មនុស្សឲ្យបញ្ឈប់សត្រូវរបស់មិនឲ្យធ្វើបាបពួកគេ»
Nehemiah 9:28
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដល់ព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ពួកគេមានសេចក្តីស្រាកស្រាន្តហើយ ពួកគេចាប់ផ្តើមប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះអង្គទៀត
នៅទីនេះ «ពួកគេ» សំដៅទៅលើជនជាតិអ៊ីស្រាអែលនិង «អ្នក»
ចំពោះព្រះអម្ចាស់។
ព្រះអង្គក៏បោះបង់ចោលពួកគេ នៅក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ
ត្រង់នេះពាក្យថា «ដៃ»
មិនព្រមស្តាប់តាមបង្គាប់របស់ព្រះអង្គ
ប្រសិនបើភាសារបស់អ្នកមានពាក្យសម្រាប់បញ្ជាល់ឲ្យពាក្យ «ស្តាប់»
ដែលមានន័យថា «គោរព» សូមប្រើវានៅទីនេះ។
ក្រឹត្យក្រមរបស់ព្រះអង្គដែលផ្តល់ជីវិតដល់អ្នកណាដែលប្រតិបត្តិតាម
ព្រះអម្ចាស់ផ្ទាល់ត្រូវបានគេនិយាយដូចជាលោកជាក្រិត្យដោយខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត:
«ទោះបីអ្នកផ្តល់ជីវិតដល់មនុស្សគ្រប់គ្នាដែលគោរពតាមក្រិត្យរបស់អ្នកក៏ដោយ»
Nehemiah 9:30
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ព្រះអង្គក៏បានប្រគល់ពួកគេ ទៅក្នុងកណ្តាប់ដៃរបស់ប្រជាជាតិជិតខាង
ត្រង់នេះពាក្យថា «ដៃ» បង្ហាញពីអំណាចរបស់ «ប្រជាជាតិជិតខាង»
អ្នកឲ្យ
ព្រះអម្ចាស់បានប្រទាន
ព្រះអង្គមិនបានធ្វើឲ្យពួកគេវិនាសសាបសូន្យទេ
«ព្រះអង្គមិនបានបំផ្លាញពួកគេទេ»
Nehemiah 9:32
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
សូមកុំឲ្យសេចក្តីទេវនាទាំងប៉ុន្មាន ដែលបានកើតមានដល់យើងខ្ញុំ... រហូតដល់ថ្ងៃនេះ
អាចបែងចែកវាជាពីរប្រយោគ។

generated on Wed Sep 10 16:16:32 2025

«កុំទុកឲ្យការលំបាកទាំងអស់នេះមើលទៅដូចជាតូចសម្រាប់អ្នក។
ភាពលំបាកបានកើតមានលើពួកយើង ... រហូតមកដល់ថ្ងៃនេះ»
សេចក្តីទេវនា... បានកើតមានលើពួកយើង....គ្រប់ទាំងអស់បានកើតមកលើពួកយើង
ឃ្លា «កើតមានលើពួកយើង»
ចង់សំដៅទៅលើការអាក្រក់ដូចជាពួកគេជាមនុស្សដែលធ្វើការដែលមានគ្រោះថ្នាក់។
ការបកប្រែរៀបផ្សេងទៀត៖ «គ្រោះថ្នាក់ ... យើងបានរងទុក្ខ ...
គ្រប់បែបយ៉ាងដែលយើងបានរងទុក្ខ »
Nehemiah 9:35
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដល់ព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
កំឡុងពេលដែលពួកគេរីករាយជាមួយនឹងសេចក្តីល្អដែលព្រះអង្គបានប្រទានឲ្យពួកគេ
«កំឡុងពេលដែលពួកគេរីករាយជាមួយនឹងសេចក្តីល្អដែលព្រះអង្គបានប្រទានឲ្យពួកគេ
ពួកគេមិនបានបម្រើព្រះអង្គទេ
«ពួកគេមិនគោរពតាមក្រឹត្យវិន័យ និងសេចក្តីបង្រៀនរបស់ព្រះអង្គទេ»
Nehemiah 9:36
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដល់ព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
អំណោយដ៏ល្អរបស់វា
«គ្រប់ទាំងរបស់ដែលល្អនៅក្នុងវា» ឬ «គ្រប់ទាំងរបស់ល្អដែលយើងអាចយកពីវា»
ភោគផលដ៏សម្បូរហូរហៀររបស់ស្រុកនេះ បែរជាទុកសម្រាប់ពួកស្តេច
«យើងសូមថ្វាយសួយសារអាករដល់ព្រះរាជាដែលបានធ្វើការលើទឹកដីរបស់យើងផ្ទាល់»
ពួកគេគ្រប់គ្រង
ស្តេចជាអ្នកដែលគ្រប់គ្រង
Nehemiah 9:38
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
ពួកលេវីបន្តអធិស្ឋានដលើព្រះអម្ចាស់ជំនួសឲ្យប្រជាជាតិអ៊ីស្រាអែល។
ដោយព្រោះមានហេតុការណ៍ទាំងអស់នេះ
ព្រោះប្រជាជនបានស្តាប់បង្គាប់ហើយព្រះអម្ចាស់បានដាក់ទោសពួកគេ
នៅលើឯកសារដែលមានត្រាគឺជាឈ្មោះ
អ្នកអានគួរយល់ថាបុរសសរសេរឈ្មោះរបស់ពួកគេនៅលើឯកសារមុនពេលបោះត្រា។

---

10 [1]នៅលើឯកសារដែលបានបោះត្រានោះ មានឈ្មោះ លោកនេហេមា ជាទេសាភិបាល ជាកូនលោកហាកាលា និងលោកសេដេគា។[2]លោកសេរ៉ាយ៉ា លោកអ័សារា
លោកយេរេមា។[3]លោកផាសហ៊ើរ លោកអ័ម៉ារា លោកម៉ាលគា។
[4]លោកហាធូស លោកសេបានា លោកម៉ាលូក[5]លោកហារីម លោកមេរ៉ូត លោកអូបាឌា[6]លោកដានីយ៉ែល លោកគីនេថោន លោកបារូក[7]លោកមស៊ូឡាម លោកអ័ប៊ីយ៉ា
លោកមីយ៉ាមីន[8]លោកម្អាស៊ា លោកប៊ីលកាយ លោកសេម៉ាយ៉ា។ អ្នកទាំងនេះសុទ្ធតែជាពួកបូជាចារ្យ។
[9]ពួកលេវីមាន លោកយេសួរ ជាកូនរបស់លោកអ័សានា និងលោកប៊ីនុយ មកពីអំបូរលោកហេណាដាឌ លោកកាឌមាល[10]និងពួកអ្នកដែលដើរតាមពួកលេវីមាន
លោកសេបានា លោកហូឌា លោកកេលីថា លោកពេឡាយ៉ា លោកហាណាន[11]លោកមីកា លោករេហុប លោកហាសាបយ៉ា។[12]លោកសាគើរ លោកសេរេប៊ីយ៉ា
លោកសេបានា[13]លោកហូឌា លោកបានី និងលោកបេនីនូ។[14]ពួកមេដឹកនាំលើប្រជាជនមាន លោកប៉ារ៉ូស លោកផាហាត ម៉ូអាប់ លោកអេឡាំ លោកសាធូរ លោកបានី
[15]លោកប៊ូននី លោកអាសកាឌ លោកបេបាយ[16]លោកអ័ដូនីយ៉ា លោកប៊ីកវ៉ាយ លោកអេឌីន[17]លោកអេធើ លោកហេសេគា លោកអ័ស៊ើរ[18]លោកហូឌា លោកហាស៊ូម
លោកបេសាយ[19]លោកហារីប លោកអ័ណាថូត លោកនេបាយ[20]លោកម៉ាកពីអាស លោកមស៊ូឡាម លោកហេស៊ីរ[21]លោកមសេសាបេល លោកសាដុក លោកយ៉ាដួរ
[22]លោកពេឡាធា លោកហាណាន លោកអ័ណាយ៉ា[23]លោកហូសេ លោកហាណានា លោកហាស៊ូប[24]លោកហាឡូហេស លោកពីឡាហា លោកសូបេក[25]លោករេហ៊ូម
លោកហាសាបណា លោកម្អាសេយ៉ា[26]លោកអ័ហ៊ីយ៉ា លោកហាណាន លោកអ័ណាន[27]លោកម៉ាលូក លោកហារីម និងលោកប្អាណា។
[28]ចំណែកប្រជាជនដែលនៅសេសសល់មាន ពួកបូជាចារ្យ ពួកលេវី ពួកឆ្មាំទ្វារ ពួកចម្រៀង ពួកអ្នកបម្រើព្រះវិហារ និងអស់អ្នកដែលបានញែកខ្លួនចេញពីប្រជាជនដែល
រស់នៅស្រុកទាំងនោះ ដើម្បីធ្វើតាមក្រឹត្យវិន័យរបស់ព្រះ ព្រមទាំងប្រពន្ធ និងកូនប្រុសកូនស្រីរបស់ពួកគេ គឺអស់អ្នកដែលមានចំណេះ និងការយល់ដឹង[29]ពួកគេបានចូលរួម
ជាមួយពួកបងប្អូនរបស់ពួកគេ ពួកអភិជនរបស់ពួកគេ ពួកគេស្បថឲ្យត្រូវបណ្តាសាដល់ខ្លួន ប្រសិនបើគេមិនបានកាន់តាមក្រឹត្យវិន័យរបស់ព្រះ ដែលបានប្រទានមក
ដោយសារលោកម៉ូសេ ជាអ្នកបម្រើរបស់ព្រះអង្គ ហើយរក្សា និងប្រព្រឹត្តតាមគ្រប់ទាំងបទបញ្ជារបស់ព្រះជាម្ចាស់ជាព្រះអម្ចាស់នៃយើង ព្រមទាំងច្បាប់ និងបញ្ញត្តិរបស់
ព្រះអង្គ។
[30]យើងបានសន្យាថាមិនឲ្យកូនស្រីរបស់យើងទៅឲ្យប្រជាជនដែលនៅក្នុងស្រុកនេះ ឬយកកូនស្រីរបស់គេមកឲ្យកូនប្រុសរបស់យើងឡើយ។[31]យើងក៏បានសន្យាថា ប្រសិន
បើជនជាតិដែលនៅក្នុងទឹកដីនោះ យកទំនិញ ឬស្រូវអង្ករមកលក់នៅថ្ងៃសប្ប័ទ យើងនឹងមិនព្រមទិញពីគេនៅថ្ងៃសប្ប័ទ ឬនៅថ្ងៃបរិសុទ្ធណាឡើយ។ ជារៀងរាល់ឆ្នាំទី
ប្រាំពីរ យើងនឹងទុកដីឲ្យនៅទំនេរ ព្រមទាំងលើកលែងបំណុលគ្រប់ទាំងអស់តាមរយៈជនជាតិយូដា។
[32]យើងក៏បានទទួលយកច្បាប់ ដើម្បីបង់មួយភាគក្នុងបី ក្នុងមួយសេកែលរាល់ឆ្នាំ សម្រាប់ការងារព្រះវិហាររបស់ព្រះជាម្ចាស់នៃយើង[33]គឺថ្វាយនំប៉័ងតាំងទុក តង្វាយម្សៅ
ដែលថ្វាយជាប្រចាំ និងតង្វាយដុតដែលនៅថ្ងៃសប្ប័ទ ថ្ងៃចូលខែ និងពិធីជប់លៀងដែលបានកំណត់ វត្ថុបរិសុទ្ធ តង្វាយលោះបាប សម្រាប់ធ្វើពិធីរំដោះបាបពួកអ៊ីស្រាអែល
និងសម្រាប់អស់ទាំងកិច្ចការក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់នៃយើង។
[34]យើងជាពួកបូជាចារ្យ ពួកលេវី និងប្រជាជន បានចាប់ឆ្នោតពីដំណើរតង្វាយជាអុស។ ដើម្បីយកមកក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់នៃយើង តាមវង្សរបស់ឪពុកយើង
តាមពេលកំណត់ គឺរៀងរាល់ឆ្នាំ សម្រាប់ដុតនៅលើអាសនារបស់ព្រះអម្ចាស់ជាព្រះនៃយើង ដូចមានសេចក្តីចែងទុកក្នុងក្រឹត្យវិន័យ។[35]យើងសន្យានឹងយកផលដំបូងពីស្រែ
ចម្ការរបស់យើង និងផលដំបូងពីផ្លែឈើគ្រប់មុខ មកឯព្រះដំណាក់នៃព្រះអម្ចាស់ ជារៀងរាល់ឆ្នាំ។[36]ដូចដែលមានសេចក្តីចែងទុកក្នុងក្រឹត្យវិន័យ យើងបានសន្យាថានឹងនាំ
កូនច្បងរបស់យើង កូនដំបូងនៃសត្វ និងកូនដំបូងនៃហ្វូងគោ ហ្វូងចៀមរបស់យើង មកឯព្រះដំណាក់របស់ព្រះជាម្ចាស់នៃយើង គឺនាំមកជូនពួកបូជាចារ្យដែលបម្រើនៅ
ក្នុងព្រះដំណាក់របស់ព្រះនៃយើង។
[37]យើងនឹងយកផលនៃម្សៅលាយដំបូង និងតង្វាយលើកចុះឡើង ផ្លែឈើគ្រប់មុខ ស្រាទំពាំងបាយជូរ និងប្រេង មកជូនពួកពូជាចារ្យ ទៅក្នុងឃ្លាំងនៃព្រះដំណាក់របស់ព្រះ
នៃយើង។ យើងក៏យកតង្វាយមួយភាគក្នុងដប់នៃផលពីដីរបស់យើង មកជូនពួកលេវី ដ្បិតនៅក្នុងទីក្រុងទាំងប៉ុន្មាន គឺពួកលេវីហើយដែលប្រមូល
តង្វាយមួយភាគដប់ពីគ្រប់កន្លែងដែលយើងធ្វើការ។[38]បូជាចារ្យមួយរូប ដែលជាពូជពង្សរបស់លោកអើរ៉ុន នឹងនៅជាមួយពួកលេវី នៅពេលពួកលេវីទទួលយកតង្វាយមួយ
ភាគក្នុងដប់នោះ។ ហើយពួកលេវីត្រូវយកមួយភាគក្នុងដប់ ពីតង្វាយមួយភាគក្នុងដប់នោះ ទៅឯព្រះដំណាក់របស់ព្រះនៃយើង ដាក់ក្នុងបន្ទប់ ជាឃ្លាំងនៃព្រះដំណាក់។
[39]ដ្បិតប្រជាជនអ៊ីស្រាអែល និងពួកកូនចៅលេវី ត្រូវយកតង្វាយលើកចុះឡើង ពីស្រូវ ស្រាទំពាំងបាយជូរថ្មី និងប្រេងមកដាក់ក្នុងឃ្លាំង ជាកន្លែងដែលរក្សាទុកគ្រឿងសក្ការៈ
ហើយពួកបូជាចារ្យដែលបម្រើការងារ ពួកឆ្មាំទ្វារ និងពួកចម្រៀងក៏ស្ថិតនៅទីនោះដែរ។ យើងនឹងមិនបោះបង់ចោលព្រះដំណាក់របស់ព្រះជាម្ចាស់នៃយើងឡើយ។

Nehemiah 10:1
នៅលើឯកសារដែលបានបោះត្រា
អ្នកត្រូវតែបំពេញពាក្យដែលខ្វះខាត។ «នៅលើឯកសារដែលបានបោះត្រានោះ
មានឈ្មោះមនុស្សដែលមាននៅក្នុងសេចក្តីណែនាំ»។
ឯកសារដែលបានបោះត្រា
ឯកសារត្រូវបានបានបោះ
ត្រាក្រោយពេលដែលឈ្មោះត្រូវបានដាក់ឈ្មោះនៅលើឯកសារនោះ។
លោកនេហេមា
មនុស្សមួយចំនួនជឿថាលោកនេហេមាជាអ្នកដែលសរសេរគម្ពីរមួយនេះ
ហាកាលា
នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែដូចនៅក្នុងជំពូកទី ១:១។
សេដេគា សេរ៉ាយ៉ា យេរេមា ផាសហ៊ើរ អ័ម៉ារា

generated on Wed Sep 10 16:16:32 2025

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

អ័សារ

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែដូចនៅក្នុងជំពូកទី ៣: ២២។

ម៉ាលគា

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែដូចនៅក្នុងជំពូកទី ៣: ១១។

Nehemiah 10:4

ព័ត៌មានទូទៅ:

នៅក្នុងខគម្ពីរនេះ

លោកនេហេមាបានកត់បញ្ជីឈ្មោះពួកសង្ឃដែលបានបោះត្រានៅលើឯសារ។ (សូមមើល: ១០:១)

ហាធូស

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៣:៨។

សេបានា....មស៊ូឡាម

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី ៩:៣។

ម៉ាលូក... អូបាឌា...ដានីយ៉ែល...គីនេថោន...អ័ប៊ីយ៉ា...មីយ៉ាមីន ប៊ីលកាយ សេម៉ាយ៉ា

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

ហារីម

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី ៣:១១។

ម្រេម៉ូត

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី ៣:៣។

បារូក

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រឲ្យដូចនៅក្នុងជំពូកទី ៣:២០។

សេម៉ាយ៉ា

នេះគឺជាឈ្មោះរបស់មនុស្ស។ បកប្រែដូចនៅក្នុងជំពូក ៣:២៨។

Nehemiah 10:9

ព័ត៌មានទូទៅ:

នៅក្នុងខគម្ពីរនេះ

លោកនេហេមានៅតែបន្តកត់ត្រាបញ្ជីឈ្មោះរបស់អ្នកដែលបានបោះត្រានៅលើឯកសារ។

ពួកលេវីមាន

នេះគឺសំដៅទៅលើអស់អ្នកដែលបានដាក់ឈ្មោះរបស់ពួកគេនៅលើឯកសារដែលបានបោះត្រា។

ការបកប្រែរបៀបផ្សេងទៀត:

«ពួកឡេវីដែលបានដាក់ឈ្មោះរបស់ពួកគេនៅលើឯកសារដែលបានបោះត្រា»

យេសួរ...ហេណាដាឌ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី ៣:១៨។

អ័សានា...រេហុប...បេនីនូ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

បេនីនូ

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៣:២២។

កាឌមាល

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី៧:៤៣។

សេបានា

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី៩:៣។

ហូឌា... លីថា... ពេឡាយ៉ា...សេរេប៊ីយ៉ា

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៨:៦។

ហាណាន

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៧:៤៦។

មីកា

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១០:៩។

ហាសាបយ៉ា... បានី

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៣:១៦។

សាគើរ

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៣:១។

ពួកមេដឹកនាំលើប្រជាជន

នេះគឺសំដៅទៅអស់អ្នកដែលដាក់ឈ្មោះរបស់ពួកគេនៅលើឯកសារដែលបានបោះត្រា។

ការបកប្រែរបៀបផ្សេងទៀត: «ពួកមេដឹកនាំលើ
ប្រជាជនដែលដាក់ឈ្មោះរបស់ពួកគេនៅលើឯកសារដែលបានបោះត្រា»

ប៉ារ៉ូស

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៣:២៥។

ផាហាត ម៉ូអាប់

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៣:១១។

អេឡាំ...សាធូរ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៧:១១។

Nehemiah 10:15

ព័ត៌មានទូទៅ:

នៅក្នុងខនេះ

លោកនេហេមានៅតែបន្តកត់ត្រាបញ្ជីឈ្មោះរបស់អ្នកដែលបានបោះត្រានៅលើឯកសារ។

ប៊ូននី

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៩:៣។

អាសកាឌ បេបាយ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៧:១៥។

អ័ដូនីយ៉ា ...អេធើ...នេបាយ...ម៉ាកពីអាស...ហេស៊ារ...យ៉ាដួរ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

ប៊ីកវ៉ាយ

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៧:៦។

អេឌីន...អេធើ...ហេសេគា...ហាស៊ូម

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៧:១៩។

ហូឌា

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៨:៦។

បេសាយ ហារីប

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៧:២៣។

អ័ណាថូត

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៧:២៧។

មស៊ូឡាម...មសេសាបេល...សាដុក

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៣:៣។

Nehemiah 10:22

ព័ត៌មានទូទៅ៖

នៅក្នុងខគម្ពីរនេះ

លោកនេហេមានៅតែបន្តកត់ត្រាបញ្ជីឈ្មោះរបស់អ្នកដែលបានបោះត្រានៅលើឯកសារ។

ពេឡាធា...ហាណាន...ពីឡាហា....សូបេក ....ហាសាបណា.....អ័ណា..អ័ណាយ៉ា...

ហារីម ...ប្អាណា

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

ហាណាន

គឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងជំពូកទី៧:៤៦។ (សូមមើល:translate-names)

អ័ណា

នេះគឺជាឈ្មោះរបស់មមុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី ៨:៤។

អ័ណាយ៉ា

នេះគឺជាឈ្មោះរបស់មមុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី៣:៨។

ហាស៊ូប...ហាឡូហេស

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ សូមបកប្រែឲ្យដូចនៅក្នុងព្រះគម្ពីរស្លាចាស៊ូ។

រេហូម

នេះគឺជាឈ្មោះរបស់មមុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី៣:៨។

ម៉ាលូក ហារីម

នេះគឺជាឈ្មោះរបស់មមុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី១០:៤។

ប្អាណា

នេះគឺជាឈ្មោះរបស់មមុស្ស។ សូមបកប្រែពាក្យនេះឲ្យដូចនៅក្នុងជំពូកទី ១០:៤។

Nehemiah 10:28

ពួកឆ្មាំទ្វារ

នេះគឺសំដៅទៅលើមនុស្សដែលត្រូវបានចាត់ឲ្យទៅច្រកទ្វារនីមួយៗទទួលខុសត្រូវក្នុងការគ្រប់គ្រងការចូលឬព្រះវិហារក៏ដូចជាបើកនិងបិទទ្វារ

និងហេតុផលដែលបានកំណត់ដោយអ្នកគ្រប់គ្រង។

សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅក្នុងជំពូកទី៧:១

ពួកចម្រៀង

«ពួកអ្នកចម្រៀងនៅក្នុងព្រះវិហារ»

អស់អ្នកដែលមានចំណេះ និងការយល់ដឹង

ឃ្លានេះអាចត្រូវបានធ្វើឲ្យច្បាស់។ ការបកប្រែរបៀបផ្សេងទៀត:

«មនុស្សគ្រប់រូបដែលមានអាយុគ្រប់គ្រាន់

generated on Wed Sep 10 16:16:32 2025

ដើម្បីយល់ពីអត្ថន័យនៃការសន្យាគោរពតាមព្រះជាម្ចាស់»
បងប្អូនរបស់ពួកគេ ពួកអភិជនរបស់ពួកគេ
«បងប្អូនរបស់ពួកគេ ពួកអភិជនរបស់ពួកគេ» ឬ «បងប្អូនរបស់ពួកគេមេដឹកនាំ។»
ឃ្លាទាំងនេះគឺសំដៅទៅលើមនុស្សដូចគ្នា។
បានភ្ជាប់ខ្លួនគេទាំងបណ្តាសានិងសម្បថ
នេះនិយាយអំពីប្រជាជនដែលបានស្បថ
និងពាក្យបណ្តាសាដូចជាប្រសិនបើពាក្យសម្បថ
និងបណ្តាសាគឺជាខ្សែពួរដែលចងភ្ជាប់ពួកគេ។ ការបកប្រែរៀបផ្សេងទៀត:
«ស្បថលើខ្លួនឯងនិងពាក្យបណ្តាសា» ឬ
«ពួកគេបានស្បថហើយអំពាវនាវឲ្យមានបណ្តាសាកើតឡើងលើពួកគេប្រសិនបើពួកគេមិនធ្វើតាម
ដើម្បីឲ្យដើរតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់
នេះគឺជាឃ្លាមួយ។ ការបកប្រែរៀបផ្សេងគ្នា:
«រស់នៅស្របតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់» ឬ
«ដើម្បីស្តាប់បង្គាប់តាមច្បាប់នៃព្រះជាម្ចាស់»
តើលោកម៉ូសេជាអ្នកបម្រើព្រះជាម្ចាស់បានប្រគល់ឲ្យ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរៀបផ្សេងទៀត:
«អ្វីដែលលោកម៉ូសេជាអ្នកបម្រើរបស់ព្រះជាម្ចាស់បានប្រគល់ឲ្យទៅប្រជាជនអ៊ីស្រាអែល»
ដើម្បីរក្សា
«ដើម្បីដើរតាម»
Nehemiah 10:30
ព័ត៌មានទូទៅ:
នៅក្នុងខនេះប្រជាជនពិពណ៌នាខ្លឹមសារនៃសម្បថដែលពួកគេបានសន្យានៅក្នុងជំពូកទី
១០:២៨
មិនឲ្យកូនស្រីរបស់យើងទៅឲ្យប្រជាជនដែលនៅក្នុងស្រុកនេះ ឬយកកូនស្រីរបស់គេមកឲ្យកូនប្រុស
របស់យើងឡើយ
នេះមានន័យថាពួកគេនឹងមិនអនុញ្ញាតឲ្យកូនប្រុសស្រីរបស់ពួកគេរៀបការជាមួយពួកគេ
ការបកប្រែផ្សេងទៀត:
«នឹងមិនផ្តល់ឲ្យកូនស្រីរបស់យើងដើម្បីរៀបការជាមួយប្រជាជននៅលើទឹកដីនេះ
ឬយកកូនស្រីរបស់ពួកគេដើម្បីរៀបការជាមួយកូនប្រុសរបស់យើង»
ប្រជាជនដែលនៅក្នុងស្រុកនេះ
នេះសំដៅទៅលើប្រជាជនដែលរស់នៅលើទឹកដីរបស់ពួកគេដែលមិនថ្វាយបង្គំព្រះអម្ចាស់
ការបកប្រែរៀបផ្សេងទៀត:
«ប្រជាជនដែលនៅក្នុងទឹកដីនេះដែលមិនស្តាប់បង្គាប់ព្រះអម្ចាស់»
យើងបានសន្យា ... យើងនឹងមិនផ្តល់ឲ្យ ... យើងនឹងមិនទិញ ... យើងនឹងអនុញ្ញាតឲ្យ ...
យើងនឹងលុបចោល
សព្វនាម «យើង» នៅទីនេះរួមមានលោកនេហេមា
និងប្រជាជនយូដាប៉ុន្តែមិនមែនអ្នកអានសៀវភៅនេះទេ។
ឆ្នាំទីប្រពីរ
«ឆ្នាំទី៧»
យើងនឹងទុកដីឲ្យនៅទំនេរ
នេះគឺជាប្រយោគមួយ។ ការបកប្រែរៀបផ្សេងទៀត:
«យើងនឹងមិនភ្ជួរស្រែរបស់យើងទេ» ឬ
«យើងនឹងមិនដាំអ្វីទាំងអស់នៅក្នុងស្រែរបស់យើង»។
យើងនឹងលើកលែងបំណុលគ្រប់ទាំងអស់ តាមរយៈជនជាតិយូដា
«យើងនឹងលើកលែងបំណុលទាំងអស់ដល់ប្រជាជនយូដាផ្សេងទៀត» ឬ
«យើងនឹងលើកលែងបំណុលទាំងអស់ដល់ប្រជាជនយូដាទាំងអស់ដែលជាកជំពាក់យើង
Nehemiah 10:32
ព័ត៌មានទូទៅ:
នៅក្នុងខគម្ពីរទាំងនេះប្រជាជនបន្តរៀបរាប់ខ្លឹមសារនៃពាក្យសម្បថដែលពួកគេបានធ្វើនៅក្នុង
NEH 10:28។
យើងក៏បានទទួលយកច្បាប់
«យើងសន្យាថានឹងគោរពតាមបទបញ្ជា»
យើងទទួល
សព្វនាម «យើង»
នៅទីនេះរួមបញ្ចូលជនជាតិអ៊ីស្រាអែលទាំងអស់រួមទាំងលោកនេហេមាលើកលែងតែបូជាចារ្យ
ហើយមិនរាប់បញ្ចូលអ្នកអានគម្ពីរនេះទេ
មួយភាគក្នុងបី
«១/៣ នៃប្រាក់» ។ «ភាគបី» មានន័យថាផ្នែកមួយក្នុងចំណោមបីផ្នែកស្មើគ្នា។
នេះអាចត្រូវបានសរសេរនៅក្នុងការរាស់វែងបែបទំនើប។
ការបកប្រែរៀបផ្សេងទៀត «ប្រាក់ ៥ក្រាម»
សម្រាប់ការងារ
«ដើម្បីចំណាយសម្រាប់ការថែទាំ»
នំប៉័ងនេះព្រះវត្តមាន
នេះសំដៅទៅលើនំប៉័ងទាំង១២ដុំដែលគ្មានដំបែដែលគេរក្សាទុកនៅក្នុងព្រះវិហារហើយប្រើសម្រាប់ជាតំណ
ថ្ងៃចូលខែ
ទាំងនេះគឺជាការប្រារព្ធធ្វើនៅពេលព្រះច័ន្ទមានតែមួយចំណិតតូចមួយនៅលើមេឃ។
Nehemiah 10:34
ព័ត៌មានទូទៅ:
នៅក្នុងខទាំងនេះប្រជាជនបន្តរៀបរាប់ខ្លឹមសារនៃពាក្យសម្បថដែលពួកគេបានធ្វើនៅក្នុងជំពូកទី១០:២៨។
សម្រាប់ដុត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរៀបផ្សេងទៀត:
«សម្រាប់ពួកលេវីដើម្បីដុត»
ដូចមានសេចក្តីចែងទុក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរៀបផ្សេងទៀត:
«ដូចដែលបានចែងមក»
ពីដីរបស់យើង
«ក្នុងដីរបស់យើង» ឬ «នៅលើដីរបស់យើង»
Nehemiah 10:37
ព័ត៌មានទូទៅ:
នៅក្នុងខទាំងនេះប្រជាជនបន្តរៀបរាប់ខ្លឹមសារនៃពាក្យសម្បថដែលពួកគេបានធ្វើនៅក្នុង
NEH 10:28.
យើងនឹងនាំយក...យើងនឹងនាំយក
សព្វនាម «យើង» នៅទីនេះរួមបញ្ចូលលោកនេហេមា
និងជនជាតិអ៊ីស្រាអែលលើកលែងតែពួកបូជាចារ្យនិងពួកលេវី
ហើយក៏មិនរាប់បញ្ចូលអ្នកអានគម្ពីរនេះដែរ
ម្សៅលាយដំបូង
ម្សៅគឺ «ម្សៅគ្រើម» ឬ «គ្រាប់ធញ្ញជាតិ»។
ទំពាំងបាយជូរ និងប្រេង
ពាក្យដែលបាត់អាចត្រូវបានបន្ថែម។ ការបកប្រែរៀបផ្សេងទៀត: « ទឹក
ទំពាំងបាយជូរដំបូងបង្អស់ និងប្រេងដំបូងបង្អស់» ឬ «ទឹកទំពាំងបាយជូរ
និងប្រេងដែលល្អឥតខ្ចោះ»
បន្ទប់ព្រះដំណាក់របស់ព្រះនៃយើង
«កន្លែងដែលមានរបស់របរទុកនៅក្នុងព្រះវិហារ»
មួយភាគក្នុងដប់នៃផលពីដីរបស់យើង
នៅទីនេះ «ដីរបស់យើង» សំដៅទៅលើអ្វីគ្រប់យ៉ាងដែលត្រូវបានដាំដុះនៅក្នុងដី។
ការបកប្រែរៀបផ្សេងទៀត «មួយភាគក្នុងដប់នៃផលពីអ្វីដែលគេបានផលពីដី»
ពួកគេទទួលយកតង្វាយមួយភាគដប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរៀបផ្សេងទៀត:
«ប្រជាជនបានឲ្យតង្វាយមួយភាគដប់ទៅពួកគេ»
តង្វាយមួយភាគដប់
នេះមានន័យថាផ្នែកមួយក្នុងចំណោមដប់ចំណែកស្មើគ្នា។
ឃ្លាំងនៃព្រះដំណាក់
ឃ្លាំងនៃព្រះដំណាក់គឺនៅក្នុងព្រះវិហារ» (UDB)
Nehemiah 10:39
ព័ត៌មានទូទៅ
នៅក្នុងខទាំងនេះប្រជាជនបន្តរៀបរាប់ខ្លឹមសារនៃពាក្យសម្បថដែលពួកគេបានធ្វើនៅក្នុង
NEH 10:28.
ឃ្លាំងនៃព្រះដំណាក់ជាកន្លែងដែលទុកគ្រឿងប្រដាប់របស់ទីបរិសុទ្ធ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរៀបផ្សេងទៀត៖
«បន្ទប់ដែលបូជាចារ្យរក្សារបស់របរប្រើប្រាស់ក្នុងព្រះវិហារ»
យើងនឹងមិនបោះបង់ចោលព្រះដំណាក់របស់ព្រះជាម្ចាស់នៃយើងឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរៀបផ្សេងទៀត:
«ពួកយើងយកចិត្តទុកដាក់នឹងព្រះវិហារ»

generated on Wed Sep 10 16:16:32 2025

11 [1]ពួកមេដឹកនាំរបស់ប្រជាជនរស់នៅក្នុងក្រុងយេរូសាឡិម ហើយប្រជាជនឯទៀត គេចាប់ឆ្នោតយកម្នាក់ ក្នុងចំណោមដប់នាក់ ឲ្យមករស់នៅក្រុងយេរូសាឡិម ជាទីក្រុងបរិសុទ្ធ ហើយប្រាំបួននាក់ទៀត ឲ្យរស់នៅតាមទីក្រុងឯទៀតៗ។[2]បន្ទាប់មកប្រជាជនបានជូនពរមនុស្សទាំងអស់ដែលលះបង់មករស់នៅក្រុងយេរូសាឡិម។
[3]នេះជាពួកមេនៅក្នុងខេត្ត ដែលរស់នៅក្រុងយេរូសាឡិម។ ទោះជានៅតាមក្រុងនានានៃយូដា គ្រប់គ្នារស់នៅលើទឹកដីជាកេរអាករ តាមក្រុងរបស់គេរៀងខ្លួន គឺទាំងពួកអ៊ីស្រាអែល ពួកបូជាចារ្យ ពួកលេវី ពួកអ្នកបម្រើព្រះវិហារ និងកូនចៅរបស់ពួកអ្នកបម្រើរបស់ព្រះបាទសាឡូម៉ូន។[4]អ្នកដែលរស់នៅក្នុងក្រុងយេរូសាឡិម មានកូនចៅយូដា និងកូនចៅបេនយ៉ាមីនខ្លះ។ កូនចៅយូដា មានលោកអ័ថាយ៉ា ជាកូនរបស់លោកអ៊ូស៊ីយ៉ា ដែលជាកូនរបស់លោកសាការី លោកសាការីជាកូនរបស់លោកអ័ម៉ារា លោកអ័ម៉ារាជាកូនរបស់លោកសេផាធា លោកសេផាធាជាកូនរបស់លោកម៉ាលេលាល ក្នុងពូជពង្សពេរេស។
[5]លោកម្អាសេយ៉ា ជាកូនរបស់លោកបារូក ដែលជាកូនរបស់លោកកុល-ហូសេ លោកកុល-ហូសេជាកូនរបស់លោកហាសាយ៉ា លោកហាសាយ៉ាជាកូនរបស់លោកអ័ដាយ៉ា លោកអ័ដាយ៉ាជាកូនរបស់លោកយ៉ូយ៉ារីប លោកយ៉ូយ៉ារីបជាកូនរបស់លោកសាការី លោកសាការីជាកូនរបស់លោកស៊ីឡូនី។[6]កូនចៅរបស់ពេរេសទាំងប៉ុន្មាន ដែលរស់នៅក្រុងយេរូសាឡិមមានចំនួន៤៦៨នាក់។ ពួកគេគឺបុរសក្លាហាន។
[7]ទាំងនេះគឺជាកូនចៅបេនយ៉ាមីន មានលោកសាលូវ ជាកូនរបស់លោកមស៊ូឡាម ដែលជាកូនរបស់លោកយ៉ូអេឌ លោកយ៉ូអេឌជាកូនរបស់លោកពេដាយ៉ា លោកពេដាយ៉ាជាកូនរបស់លោកកូឡាយ៉ា លោកកូឡាយ៉ាជាកូនរបស់លោកម្អាសេយ៉ា លោកម្អាសេយ៉ាជាកូនរបស់លោកអ៊ីធាល លោកអ៊ីធាលជាកូនរបស់លោកយេសាយ៉ា[8]ពួកគេទាំងនោះបានទៅតាមគាត់ មានលោកកាបាយ និងលោកសាឡាយ ទាំងអស់មាន ៩២៨ នាក់។[9]លោកយ៉ូអែល ជាកូនរបស់លោកស៊ីកគ្រី ជាអ្នកមើលខុសត្រូវលើពួកគេ ហើយយូដាជាកូនរបស់លោកសេនួរ ជាអ្នកមើលខុសត្រូវរងលើទីក្រុង។
[10]ក្នុងចំណោមពួកសង្ឃមាន លោកយេដាយ៉ា ជាកូនរបស់លោកយ៉ូយ៉ារីប និងលោកយ៉ាគិន។[11]លោកសេរ៉ាយ៉ា ជាកូនរបស់លោកហ៊ីលគីយ៉ា ដែលជាកូនរបស់លោកមស៊ូឡាម លោកមស៊ូឡាមជាកូនរបស់លោកសាដុក លោកសាដុកជាកូនរបស់លោកមេរ៉ាយ៉ូត លោកមេរ៉ាយ៉ូតជាកូនរបស់លោកអ័ហ៊ីទូប ដែលជាមេគ្រប់គ្រងលើព្រះដំណាក់របស់ព្រះជាម្ចាស់[12]និងជំនួយការពួកគេ ដែលធ្វើការនៅក្នុងព្រះដំណាក់ ទាំងអស់មាន ៨២២ នាក់ ហើយមានលោកអ័ដាយ៉ា ជាកូនរបស់លោកយេរ៉ូហាំ ដែលជាកូនរបស់លោកពេឡាលា លោកពេឡាលាជាកូនរបស់លោកអាំស៊ី លោកអាំស៊ីជាកូនរបស់លោកសាការី លោកសាការីជាកូនរបស់លោកផាសហ៊ើរ លោកផាសហ៊ើរជាកូនរបស់លោកម៉ាលគា។
[13]និងបងប្អូនរបស់គាត់ ដែលជាកំពូលលើពូជវង្សរបស់ឪពុក ទាំងអស់មាន ២៤២ នាក់ បន្ទាប់មក មានលោកអ័ម៉ាសាយ ជាកូនរបស់លោកអ័សារាល ដែលជាកូនរបស់លោកអ័ហាសាយ លោកអ័ហាសាយជាកូនរបស់លោកមស៊ីលេម៉ូត លោកមស៊ីលេម៉ូតជាកូនរបស់លោកអ៊ីមមើរ[14]ព្រមទាំងបងប្អូនរបស់គេ ជាអ្នកខ្លាំងពូកែមានចិត្តក្លាហាន ទាំងអស់មាន ១២៨ នាក់ ឯអ្នកដែលគ្រប់គ្រងលើគេ គឺលោកសាបឌាល ជាកូនរបស់លោកកេដូលីម។
[15]ក្នុងចំណោមពួកលេវីមាន លោកសេម៉ាយ៉ា ជាកូនរបស់លោកហាស៊ូប ដែលជាកូនរបស់លោកអាសរីកាមលោកអាសរីកាមជាកូនរបស់លោកហាសាបយ៉ា លោកហាសាបយ៉ាជាកូនរបស់លោកប៊ូនី[16]ព្រមទាំងលោកសាបថាយ និងលោកយ៉ូសាបាឌ ជាមេនៃពួកលេវី ដែលគ្រប់គ្រងលើការងារខាងក្រៅព្រះដំណាក់របស់ព្រះជាម្ចាស់។
[17]មានលោកម៉ាថានា ជាកូនរបស់លោកមីកា ដែលជាកូនរបស់លោកសាបឌី លោកសាបឌីជាកូនរបស់លោកអេសាភ ដែលជាមេដឹកនាំក្នុងការអរព្រះគុណ និងការអធិស្ឋាន និងលោកបាកប៊ូគា ជាមេដឹកនាំរងក្នុងចំណោមបងប្អូនរបស់គាត់ ហើយលោកអាប់ដា ជាកូនរបស់លោកសាំមួរ ដែលជាកូនរបស់លោកកាឡាល លោកកាឡាលជាកូនរបស់លោកយេឌូថិន។[18]ពួកលេវីទាំងប៉ុន្មាន ដែលនៅក្នុងក្រុងបរិសុទ្ធមានចំនួន ២៨៤ នាក់។
[19]ពួកឆ្មាំទ្វារមាន លោកអ័កគូប លោកថាលម៉ូន និងបងប្អូនរបស់គេ ដែលចាំយាមនៅមាត់ទ្វារផ្សេងៗ ទាំងអស់មាន ១៧២ នាក់។[20]ពួកអ៊ីស្រាអែលឯទៀតៗ ពួកសង្ឃ និងពួកលេវី រស់នៅតាមទីក្រុងទាំងប៉ុន្មានក្នុងស្រុកយូដា។ គ្រប់គ្នារស់នៅតាមទឹកដីជាមរតករបស់គេរៀងខ្លួន។[21]ពួកអ្នកបម្រើព្រះវិហារ រស់នៅលើភ្នំអូផែល ហើយលោកស៊ីហា និងលោកគីសប៉ា ជាអ្នកគ្រប់គ្រងលើពួកអ្នកបម្រើព្រះវិហារ។
[22]អ្នកដែលគ្រប់គ្រងលើពួកលេវី នៅក្រុងយេរូសាឡិម គឺលោកអ៊ូស៊ី ជាកូនរបស់លោកបានី ដែលជាកូនរបស់លោកហាសាបយ៉ា លោកហាសាបយ៉ាជាកូនរបស់លោកម៉ាថានា លោកម៉ាថានាជាកូនរបស់លោកមីកា ជាពូជពង្សលោកអេសាភ ដែលជាពួកចម្រៀង គេគ្រប់គ្រងលើកិច្ចការក្នុងព្រះដំណាក់របស់ព្រះ។[23]ដ្បិតមានរាជបញ្ជាមួយពីស្តេច ស្តីអំពីដំណើរពួកគេ ឲ្យផ្គត់ផ្គង់ស្បៀងអាហារដល់ពួកចម្រៀង តាមដែលគេត្រូវការរាល់ថ្ងៃ ស្របតាមច្បាប់ដែលបានកំណត់ទុក។[24]លោកពេថាហ៊ីយ៉ា ជាកូនរបស់លោកមេសេសាបេល ក្នុងពូជពង្សលោកសេរ៉ាស ជាកូនរបស់លោកយូដា លោកជាអ្នកជំនិតរបស់ស្តេច ក្នុងគ្រប់ទាំងកិច្ចការដែលទាក់ទងនឹងប្រជាជន។
[25]ភូមិទាំងប៉ុន្មាន និងស្រែចម្ការដែលនៅជុំវិញ មានប្រជាជនយូដាខ្លះ រស់នៅត្រង់គារយ៉ាត់-អើបា និងភូមិនានាដែលនៅជុំវិញ ហើយនៅឌីបូន និងភូមិនានាដែលនៅជុំវិញ នៅយេកាបសៀល និងភូមិនានាដែលនៅជុំវិញ។[26]នៅម៉ូឡាដា និងបេត-ផាលែត។[27]នៅហាសា ស៊ូអាល នៅបៀរ សេបា និងភូមិនានាដែលនៅជុំវិញ។
[28]មានប្រជាជនយូដាខ្លះរស់នៅស៊ីកឡាក់ នៅមេកូណា និងភូមិនានាដែលនៅជុំវិញ។[29]នៅអេន រីម៉ូន នៅសូរ៉ាស់ នៅយ៉ារមុត។[30]សាណូអា អាឌុឡាម និងភូមិនានាដែលនៅជុំវិញក្រុងទាំងនោះ ឡាគីស និងស្រែចម្ការដែលនៅជុំវិញ ហើយអាសេកា និងភូមិនានាដែលនៅជុំវិញ។ ដូច្នេះ គេបានតាំងទីលំនៅ ចាប់តាំងពីបៀរ-សេបា រហូតដល់ជ្រលងភ្នំហ៊ីនណម។[31]កូនចៅបេនយ៉ាមីនក៏បានរស់នៅ ចាប់តាំងពីកេបារៀងទៅ គឺនៅមីកម៉ាស អៃយ បេត អែល និងភូមិនានាដែលនៅជុំវិញ។[32]នៅអាណាថោត ណូប ហាណានា[33]ហាសោរ រ៉ាម៉ា គីថែម។[34]ហាឌីឌ សេបោម នេបាឡាត។[35]ឡូឌ អូណូរ និងជ្រលងភ្នំរបស់ពួកជាងរចនា។[36]ពួកលេវីខ្លះដែលរស់នៅស្រុកយូដា ត្រូវបានតម្រូវឲ្យទៅរស់នៅស្រុកបេនយ៉ាមីន។

Nehemiah 11:1
ប្រជាជនបោះឆ្នោត
ប្រជាជនបានគប់ដុំថ្ម ដើម្បីកំណត់ថានរណាជាអ្នកទទួលខុសត្រូវ
ដើម្បីជ្រើសរើសមួយក្នុងចំណោមដប់
«ដើម្បីជ្រើសរើសគ្រួសារមួយក្នុងចំណោមដប់គ្រួសារ»
Nehemiah 11:3
នៅលើដីរបស់គាត់ រួមបញ្ចូលទាំងរបស់ជនជាតិអ៊ីស្រាអែលមួយចំនួន
«នៅលើទឹកដីរបស់គាត់: ប្រជាជាតិអ៊ីស្រាអែល»
មានកូនចៅយូដា និងកូនចៅបេនយ៉ាមីន
«មនុស្សមួយចំនួននៃពួកយូដា និងមួយចំនួនទៀតនៃពួកបេនយ៉ាមីន»
មនុស្សដែលមកពីយូដារួមបញ្ចូល:
«មកពីពូជពង្សរបស់យូដា:»
បេនយ៉ាមីន...អ័ថាយ៉ា...អ៊ូស៊ីយ៉ា...សាការី ...អ័ម៉ារា ...ម៉ាលេលាល...ពេរេស
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ពូជពង្សពេរេស
«មកពីពូជពង្សរបស់ពេរេស»
Nehemiah 11:5
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
លោកនេហេមាបន្តចុះបញ្ជីមន្ត្រីខេត្តដែលរស់នៅក្នុងក្រុងយេរូសាឡិម។
ម្អាសេយ៉ា...បារូក...កុល-ហូសេ...ហាសាយ៉ា...អ័ដាយ៉ា...យ៉ូយ៉ារីប ...សាការីជា....ពេរេស
ទាំងនេះគឺជាឈ្មោះរបស់របស់មនុស្ស។ (សូមមើល:translate-names)
អ្នកក្រុងស៊ីឡូ
ជាមនុស្សម្នាក់ដែលមកពីទីក្រុងស៊ីឡូ
6កូនចៅរបស់ពេរេស
«ពូជពង្សរបស់ពេរេស»
៤៦៨។ ពួកគេគឺបុរសក្លាហាន
«រសក្លាហាន ៤៦៨នាក់» ឬ «៤៦៨នាក់នៃបុរសក្លាហាន»
Nehemiah 11:7
ខ្លឹមសារភ្ជាប់:
នៅក្នុងខគម្ពីរនេះ
លោកនេហេមាបន្តចុះបញ្ជីមន្ត្រីខេត្តដែលរស់នៅក្នុងក្រុងយេរូសាឡិម។

generated on Wed Sep 10 16:16:32 2025

ទាំងនេះគឺជាកូនចៅ
ភាសារបស់អ្នកប្រហែលជាត្រូវបញ្ជាក់ថានេះមិនមែនជាបញ្ជីនៃកូនចៅទាំងអស់ទេ។ «ទាំងនេះគឺគ្រាន់តែកូនចៅមួយចំនួនតែប៉ុណ្ណោះ»
បេនយ៉ាមីន...សាលូវ...មស៊ូឡាម...យ៉ូអេឌ...ពេដាយ៉ា...កូឡាយ៉ា...ម្អាសេយ៉ា...អ៊ីធាល...
យេសាយ៉ា...កាបាយ...សាឡាយ...យ៉ូអែល...ស៊ីកគ្រី...យូដា...សេនួរ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Nehemiah 11:10
យេដាយ៉ា...យ៉ូយ៉ារីប...យ៉ាគិន...សេរ៉ាយ៉ា... ហ៊ីលគីយ៉ា...មស៊ូឡាម...សាដុក...
មេរ៉ាយ៉ូត...អ័ហ៊ីទូប...អ័ដាយ៉ា...យេរ៉ូហាំ... ពេឡាលា....អាំស៊ី...សាការី...ផាសហ៊ើរ ...ម៉ាលគា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
អ្នកដែលធ្វើការនៅក្នុងព្រះដំណាក់
«ព្រះដំណាក់» គឺជា «ដំណាក់របស់ព្រះអម្ចាស់» (១១:១១)។
«អ្នកដែលធ្វើការនៅក្នុងព្រះវិហារ»
ជំនួយការរបស់ពួកគេ
«បងប្អូនរបស់ពួកគេ» ឬ «ញាតិសន្តានរបស់ពួកគេ»
Nehemiah 11:13
បងប្អូនរបស់គាត់
បងប្អូនរបស់អាដាយ៉ាជាកូនរបស់យេរ៉ូហាម (១១:១០)
បងប្អូនប្រុស
ពាក្យនេះគឺជាពាក្យប្រៀបធៀបមួយ ១) ដើរតាមប្រជាជាតិអ៊ីស្រាអែល ឬ ២) មនុស្សដែលធ្វើកិច្ចការដូចគ្នា។ ការបកប្រែរបៀបផ្សេងទៀត: «ជំនួយការ» ឬ «អ្នកធ្វើតាម»
បងប្អូនប្រុស
ពាក្យនេះគឺជាពាក្យប្រៀបធៀបមួយនៃ ១) ដើរតាមប្រជាជាតិអ៊ីស្រាអែល ឬ ២) មនុស្សដែលធ្វើកិច្ចការដូចគ្នា។ ការបកប្រែរបៀបផ្សេងទៀត: «ជំនួយការ» ឬ «អ្នកធ្វើតាម»
អ័ម៉ាសាយ ...អ័សារាល...អ័ហាសាយ ...មស៊ីលេម៉ូត...អ៊ីមមើរ...សាបឌាល ...កេដូលីម
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
អ្នកខ្លាំងពូកែមានចិត្តក្លាហា
«អ្នកចម្បាំងក្លាហាន» ឬ «អ្នកចម្បាំងដ៏ក្លាំងពូកែ»
Nehemiah 11:15
សេម៉ាយ៉ា...ហាស៊ូប...អាសរីកាម...ហាសាបយ៉ា ...ប៊ូននី...សាបថាយ....យ៉ូសាបាឌ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
អ្នកណាដែលមកពីមេដឹកនាំនៃពួកលេវី ហើយគ្រប់គ្រងលើការងារ
អ្នកដែលគ្រប់គ្រងលើការងារ គឺមកពីមេដឹកនាំនៃពួកលេវី។
Nehemiah 11:17
ម៉ាថានា...មីកា...សាប់ឌី...អេសាភ...បាកប៊ូគា...អាប់ដា...សាំមួរ... កាឡាល...យេឌូថិន
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
តើអ្នកណាដែលចាប់ផ្តើមក្នុងការអរព្រះគុណ និងការអធិស្ឋាន
នោះគឺជាអ្នកដែលដឹកនាំការថ្វាយបង្គំ (see UDB)។
លោកបាកប៊ូគា ជាមេដឹកនាំរងក្នុងចំណោមបងប្អូនរបស់គាត់
អត្ថន័យដែលអាចមានគឺ ១)លោកបាកប៊ូគា ជាញាតិសន្តានរបស់ម៉ាណានានិងជាអ្នកមានសិទ្ធិអំណាចទី ២ ដល់ម៉ាថានា ឬ ២) «លោកបាកប៊ូគាជាអ្នកដែលដឹកនាំក្រុមទី ២ នៃអ្នកចម្រៀង។»
បងប្អូន
អត្ថន័យដែលអាចមាននោះគឺ «ជំនួយការ» ឬ «អ្នកដែលធ្វើតាម» (សូមមើល: UDB).
ទីក្រុងដ៏វិសុទ្ធ
ការបង្ហាញមួយនេះគឺសំដៅទៅលើទីក្រុងយេរូសាឡិម។
Nehemiah 11:19
ពួកឆ្មាំទ្វារ
ប្រជាជនដែលបានចាត់ឲ្យទៅច្រកទ្វារ ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រងការចូលទៅកាន់ទីក្រុង ឬព្រះវិហារក៏ដូចជាដើម្បីបើកនិងបិទទ្វារទៅតាមហេតុផលដែលបានកំណត់ដោយអ្នកគ្រប់គ្រង។ សូមមបកប្រែឲ្យដូចនៅក្នុងជំពូកទី ៧:១
អ័កគូប ...ថាលម៉ូន...ស៊ីហា...គីសប៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
អូផែល
នេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 11:22
អ្នកគ្រប់គ្រង
«អ្នកមើលការខុសត្រូវ»
អ៊ូស៊ី...បានី...ហាសាបយ៉ា..ម៉ាថានា...មីកា.. អេសាភ...ពេថាហ៊ីយ៉ា...សេរ៉ាស ...យូដា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ (សូមមើល:translate-names)
ពួកគេនៅក្រោមការបញ្ជារបស់ស្តេច
«ស្តេចបានបញ្ជាពីអ្វីដែលពួកគេត្រូវធ្វើ»
រាជបញ្ជាយ៉ាងម៉ឺងម៉ាត់មួយបានប្រទានទៅដល់ពួកអ្នកចម្រៀង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ស្តេចបានប្រាប់ពួកគេយ៉ាងជាក់លាក់នូវអ្វីដែលត្រូវធ្វើចំពោះអ្នកចំរៀង»
អ្នកជំនិតរបស់ស្តេច ក្នុងគ្រប់ទាំងកិច្ចការដែលទាក់ទងនឹងប្រជាជន
«អ្នកជំនិតស្តេចពើស៊ី និងជាទីប្រឹក្សានៅក្នុងរឿងទាំងអស់ទាក់ទងនឹងប្រជាជនយូដា»
Nehemiah 11:25
គារយ៉ាត់-អើបា...ឌីបូន... យេកាបសៀល...ម៉ូឡាដា...បេត-ផាលែត...ហាសា ស៊ូអាល...បៀរ សេបា
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 11:28
ពួកគេបានរស់នៅ
ពាក្យ «ពួកគេ» គឺសំដៅទៅលើប្រជាជនយូដា។
ស៊ីកឡាក់...មេកូណា...សូរ៉ាស់...យ៉ារមុត...សាណូអា... អាឌូឡាម..ឡាគីស...អាសេកា...បៀរ-សេបា...ជ្រលងភ្នំហ៊ីនណម
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។

12 [1]នេះគឺជាពួកបូជាចារ្យ និងពួកលេវី ដែលឡើងមកជាមួយលោកសូរ៉ូបាបិល ជាកូនរបស់លោកសាលធាល និងលោកយេសួរមាន លោកសេរ៉ាយ៉ា លោកយេរេមា
លោកអែសរ៉ា[2]លោកអ័លោកម៉ារា លោកម៉ាលូក លោកហាធូស[3]លោកសេកានា លោករេហ៊ូម ហើយនិងលោកម្រេម៉ូត។
[4]មានលោកអ៊ីដោ លោកគីនេថោន លោកអ័ប៊ីយ៉ា[5]លោកមីយ៉ាមីន លោកម្អាឌា លោកប៊ីលកា[6]លោកសេម៉ាយ៉ា លោកយ៉ូយ៉ារីប លោកយេដាយ៉ា[7]លោកសាលូវ
លោកអ័ម៉ុក លោកហ៊ីលគីយ៉ា និងលោកយេដាយ៉ា។ លោកទាំងនេះសុទ្ធតែជាមេដឹកនាំលើពួកសង្ឃ និងលើពួកបងប្អូនរបស់គេ ក្នុងគ្រាលោកយេសួរ។
[8]ពួកលេវីមាន លោកយេសួ រលោកប៊ីនុយ លោកកាឌមាល លោកសេរេប៊ីយ៉ា លោកយូដា និងលោកម៉ាថានា ដែលរួមជាមួយបងប្អូនរបស់លោក ទទួលខុសត្រូវខាងចម្រៀងអរព្រះគុណ។[9]លោកបាកប៊ូគា និងលោកអ៊ូនី និងបងប្អូនរបស់លោក ឈរបំពេញមុខងារនៅទល់មុខនឹងលោកទាំងនោះ។
[10]លោកយេសួរ ជាឪពុករបស់លោកយ៉ូយ៉ាគីម លោកយ៉ូយ៉ាគីមជាឪពុករបស់លោកអេលីយ៉ាស៊ីប លោកអេលីយ៉ាស៊ីបជាឪពុករបស់លោកយ៉ូយ៉ាដា។[11]លោកយ៉ូយ៉ាដា ជាឪពុករបស់លោកយ៉ូណាថាន ហើយលោកយ៉ូណាថាន ជាឪពុករបស់លោកយ៉ាដួរ។
[12]នៅគ្រាលោកយ៉ូយ៉ាគីម ទាំងនេះគឺជាពួកសង្ឃដែលជាមេដឹកនាំលើពូជវង្សរបស់ពួកគេមាន: លោកមេរ៉ាយាជាមេដឹកនាំខាងលោកសេរ៉ាយ៉ា លោក
ហាណានាជាមេដឹកនាំខាងលោកយេរេមា[13]លោកមស៊ូឡាមជាមេដឹកនាំខាងលោកអែសរ៉ា លោកយ៉ូហាណានជាមេដឹកនាំខាងលោកអ័ម៉ារា[14]លោកយ៉ូណាថានជាមេដឹកនាំ
ខាងលោកមេលីគូរ ហើយលោកយ៉ូសែបជាមេដឹកនាំខាងលោកសេបានា។
[15]ខាងលោកហារីម មានលោកអ័ឌណាជាមេដឹកនាំ ខាងលោកមេរ៉ាយ៉ូត មានលោកហេលកាយជាមេដឹកនាំ។[16]ខាងលោកអ៊ីដោ មានលោកសាការីជាមេដឹកនាំ ខាងលោក
គីនេថោន មានលោកមស៊ូឡាមជាមេដឹកនាំ។[17]ខាងលោកអ័ប៊ីយ៉ា មានលោកស៊ីកគ្រីជាមេដឹកនាំនៃពូជពង្សមីនយ៉ាមីន។ ខាងលោកម៉ូអាឌា មានលោក
ពីលថាយជាមេដឹកនាំ។[18]ខាងលោកប៊ីលកា មានលោកសាំមួរជាមេដឹកនាំ ខាងលោកសេម៉ាយ៉ា មានលោកយ៉ូណាថានជាមេដឹកនាំ។[19]ខាងលោកយ៉ូយ៉ារីប មាន
លោកម៉ាថ្នាយជាមេដឹកនាំ ខាងលោកយេដាយ៉ា មានលោកអ៊ូស៊ីជាមេដឹកនាំ[20]ខាងលោកសាឡាយ មានលោកកាឡាយជាមេដឹកនាំ ខាងលោកអ័ម៉ុក មានលោក
ហេបើរជាមេដឹកនាំ។[21]ខាងលោកហ៊ីលគីយ៉ា មានលោកហាសាបយ៉ាជាមេដឹកនាំ ហើយខាងលោកយេដាយ៉ា មានលោកនេថានេលជាអ្នកដឹកនាំគ្រួសារយេដាយ៉ា។

generated on Wed Sep 10 16:16:32 2025

[22]ចំណែកពួកលេវី ក្នុងគ្រាលោកអេលីយ៉ាស៊ីប លោកយ៉ូយ៉ាដា លោកយ៉ូហាណាន និងលោកយ៉ាដួរ នោះបានកត់ឈ្មោះពួកដែលជាកំពូលលើពូជពង្សរបស់គេ ព្រមទាំងពួកបូជាចារ្យ រហូតដល់រជ្ជកាលព្រះបាទដារីយុស ជាស្តេចសាសន៍ពើស៊ី។[23]ពួកកូនចៅលេវី ដែលជាអ្នកដឹកនាំលើពូជពង្សរបស់គេ បានកត់ត្រាទុកក្នុងសៀវភៅរបាក្សត្រ រហូតដល់គ្រាលោកយ៉ូហាណាន ជាកូនរបស់លោកអេលីយ៉ាស៊ីប។
[24]ពួកមេដឹកនាំក្នុងពួកលេវីមាន លោកហាសាបយ៉ា លោកសេរេប៊ីយ៉ា និងលោកយេសួរ ជាកូនរបស់លោកកាឌមាល ទទួលបន្ទុករួមជាមួយពួកបងប្អូនរបស់គេ ដែលឈរទល់មុខនឹងពួកគេ ដើម្បីសរសើរតម្កើង និងអរព្រះគុណ ស្របតាមបង្គាប់របស់ព្រះបាទដារីឌ ជាអ្នកសំណព្វរបស់ព្រះ តាមពួក តាមវេនរបស់ខ្លួន។[25]លោកម៉ាថានា បាកប៊ូគា លោកអូបាឌា លោកមស៊ូឡាម លោកថាលម៉ូន និងលោកអ័កគូប ជាឆ្មាំទ្វារដែលចាំយាមនៅឃ្លាំង ត្រង់មាត់ទ្វារ។[26]អ្នកទាំងនេះបានបំរើក្នុងគ្រាលោកយ៉ូយ៉ាគីម ជាកូនរបស់លោកយេសួរ ដែលជាកូនរបស់លោកយ៉ូសាដាក និងក្នុងគ្រាលោកនេហេមា ជាទេសាភិបាល និងលោកអែសរ៉ា ដែលជាបូជាចារ្យ និងជាស្មៀន។
[27]នៅពេលធ្វើពិធីបុណ្យឆ្លងកំផែងក្រុងយេរូសាឡិម គេស្វែងរកពួកលេវីពីគ្រប់កន្លែងទាំងអស់ដែលពួករស់នៅ នាំមកឯក្រុងយេរូសាឡិម ដើម្បីធ្វើពិធីបុណ្យឆ្លងដោយអំណរ ព្រមទាំងមានចម្រៀងអរព្រះគុណ មានច្រៀងអមដោយឈិង ពិណ និងស៊ុង។[28]កូនចៅរបស់ពួកអ្នកចម្រៀង គេបានប្រមូលផ្តុំគ្នាពីស្រុកជុំវិញក្រុងយេរូសាឡិម និងពីភូមិនានារបស់ពួកនថូផា។
[29]ពួកគេក៏មកពីបេត-គីលកាល ពីតំបន់កេបា និងអាសម៉ាវែតដែរ ដ្បិតពួកអ្នកចម្រៀងបានសង់ភូមិរបស់ខ្លួន នៅជុំវិញក្រុងយេរូសាឡិម។[30]ពួកបូជាចារ្យ និងពួកលេវីបានធ្វើពិធីសម្អាតខ្លួនឲ្យបានបរិសុទ្ធ ហើយក៏បានធ្វើពិធីសម្អាតប្រជាជន ព្រមទាំងទ្វារ និងកំផែង ឲ្យបានបរិសុទ្ធដែរ។
[31]ពេលនោះ ខ្ញុំបាននាំពួកមេដឹកនាំរបស់សាសន៍យូដាឡើងទៅលើកំផែង ហើយតែងតាំងឲ្យមានក្រុមចម្រៀងពីរក្រុមធំៗ ដែលពោលពាក្យអរព្រះគុណ។ ក្រុមមួយដើរនៅលើកំផែងទៅខាងស្តាំ ឆ្ពោះទៅកាន់ទ្វារអាចម៍សត្វ។
[32]មានលោកហូសាយ៉ា និងពួកមេដឹកនាំយូដាពាក់កណ្តាល ដើរតាមពីក្រោយក្រុមនោះ។[33]បន្ទាប់មក មានលោកអ័សារា លោកអែសរ៉ា លោកមស៊ូឡាម។[34]លោកយូដា លោកបេនយ៉ាមីន លោកសេម៉ាយ៉ា និងលោកយេរេមា។[35]ហើយកូនចៅពួកបូជាចារ្យខ្លះដែលកាន់ត្រែ មានលោកសាការី ជាកូនរបស់លោកយ៉ូណាថាន ដែលជាកូនរបស់លោកសេម៉ាយ៉ា លោកសេម៉ាយ៉ាជាកូនរបស់លោកម៉ាថានា ម៉ាថានាជាកូនរបស់លោកមីកាយ៉ា លោកមីកាយ៉ាជាកូនរបស់លោកសាគើរ លោកសាគើរជាកូនរបស់លោកអេសាភ។
[36]មានពួកបងប្អូនរបស់លោកសាការី គឺសេម៉ាយ៉ា លោកអ័សារាល លោកមីឡាឡាយ លោកគីឡាឡាយ លោកម៉ាអាយ លោកនេថានេល លោកយូដា និងលោកហាណានី ដែលកាន់ប្រដាប់ភ្លេងរបស់ព្រះបាទដារីឌ ជាអ្នកសំណព្វរបស់ព្រះ។ ហើយមានហោរាអែសរ៉ា ជាអ្នកនាំមុខពួកគេ។[37]ពេលមកដល់ទ្វារក្បាលទឹក ដែលស្ថិតនៅពីមុខគេ គេឡើងតាមជណ្តើរក្រុងព្រះបាទដារីឌ តាមកន្លែងឡើងទៅលើកំផែង ពីលើដំណាក់របស់ព្រះបាទដារីឌ រហូតទៅដល់ទ្វារទឹកដែលនៅខាងកើត។
[38]ក្រុមចម្រៀងមួយទៀត ដែលពោលពាក្យអរព្រះគុណ ចេញទៅម្ខាងទៀត។ ហើយខ្ញុំក៏ដើរតាមក្រោយពួកគេ មានទាំងប្រជាជនពាក់កណ្តាលនៅលើកំផែង ពីលើប៉មគុកភ្លើង រហូតដល់កំផែងធំ[39]ហើយពីលើទ្វារអេប្រាអិម និងត្រង់ទ្វារចាស់ ទ្វារត្រី ប៉មហាណានាល និងប៉មហាមេអា រហូតដល់ទ្វារចៀម រួចគេឈប់នៅត្រង់ទ្វារពួកអ្នកយាម។
[40]ដូច្នេះ អស់អ្នកដែលពោលពាក្យអរព្រះគុណទាំងពីរក្រុម ឈរនៅក្នុងព្រះដំណាក់របស់ព្រះ ហើយខ្ញុំ និងពួកអ្នកគ្រប់គ្រងដែលនៅជាមួយខ្ញុំក៏ឈប់នៅទីនោះ។
[41]ហើយបន្ទាប់មកពួកបូជាចារ្យ មានលោកអេលាគីម លោកម្អាសេយ៉ា លោកមីនយ៉ាមីន លោកមីកាយ៉ា លោកអេលីយ៉ូណាយ លោកសាការី និងលោកហាណានា ដែលជាអ្នកកាន់ត្រែ។[42]ហើយក៏មានលោកម្អាសេយ៉ា លោកសេម៉ាយ៉ា លោកអេលាសារ លោកអ៊ូស៊ី លោកយ៉ូហាណាន លោកម៉ាលគា លោកអេឡាំ និងលោកអេស៊ើរដែរ។ ពួកអ្នកចម្រៀង ក៏ស្រែកច្រៀងជាមួយលោកយីសរ៉ាហ៊ា ដែលជាអ្នកនាំមុខរបស់គេ។
[43]នៅថ្ងៃនោះ គេថ្វាយយញ្ញបូជាយ៉ាងសន្ធឹក ហើយមានចិត្តសប្បាយរីករាយ ដ្បិតព្រះជាម្ចាស់ធ្វើឲ្យគេអរសប្បាយជាខ្លាំង។ ឯស្ត្រី និងក្មេងៗ ក៏សប្បាយរីករាយដែរ។ ដូច្នេះអំណរលាន់ឮចេញពីក្រុងយេរូសាឡិមទៅយ៉ាងឆ្ងាយ។
[44]នៅថ្ងៃនោះ គេបានតែងតាំងមនុស្សឲ្យគ្រប់គ្រងលើបន្ទប់ឃ្លាំង ដែលសម្រាប់ទុកតង្វាយលើកចុះឡើង តង្វាយផលដំបូង និងតង្វាយមួយភាគក្នុងដប់ ដើម្បីប្រមូលចំណែក ដែលក្រឹត្យវិន័យបានតម្រូវឲ្យទុកសម្រាប់ពួកបូជាចារ្យ និងពួកលេវី។ ពីស្រែចម្ការដែលនៅជុំវិញក្រុង មកទុកក្នុងបន្ទប់ឃ្លាំងទាំងនោះ។ ដ្បិតពួកយូដាមានអំណរចំពោះពួកបូជាចារ្យ និងពួកលេវី ដែលបំពេញមុខងាររបស់ខ្លួន។[45]ពួកគេបំពេញមុខងារបម្រើតាមបង្គាប់របស់ព្រះនៃគេ និងធ្វើពិធីសម្អាតឲ្យបានបរិសុទ្ធ ឯពួកអ្នកចម្រៀង និងពួកឆ្មាំទ្វារក៏ធ្វើដូច្នោះដែរ តាមបង្គាប់របស់ព្រះបាទដារីឌ និងព្រះបាទសាឡូម៉ូន ជាព្រះរាជបុត្រា។
[46]ដ្បិតកាលពីដើម ក្នុងគ្រាព្រះបាទដារីឌ និងលោកអេសាភ មានគ្រូដឹកនាំលើពួកអ្នកចម្រៀង មានចម្រៀងសរសើរតម្កើង និងអរព្រះគុណដល់ព្រះជាម្ចាស់។[47]នៅគ្រាលោកសូរ៉ូបាបិល និងលោកនេហេមា ពួកអ៊ីស្រាអែលទាំងអស់ ជូនចំណែកអាហារដល់ពួកអ្នកចម្រៀង និងពួកឆ្មាំទ្វារ ជារៀងរាល់ថ្ងៃ។ ហើយគេញែកមួយចំណែកជូនពួកលេវី ហើយពួកលេវីក៏ញែកមួយចំណែក ជូនកូនចៅលោកអើរ៉ុនដែរ។

Nehemiah 12:1

អ្នកណាបានឡើងមក

«អ្នកណាដែលបានមកពីទីក្រុងបាប៊ីឡូន»

ជាមួយលោកសូរ៉ូបាបិល

«នៅក្រោមការគ្រប់គ្រងរបស់លោកសូរ៉ូបាបិល»

សូរ៉ូបាបិល...សាលធាល...យេសួរ...សេរ៉ាយ៉ា...យេរេម...អែសរ៉ា...ម៉ារា...

ម៉ាលូក...ហាធូស...សេកានា....រេហ៊ូម...ម្រេម៉ូត

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

Nehemiah 12:4

ខ្លឹមសារភ្ជាប់:

បញ្ជីរាយនាមដែលចាប់ផ្តើមមាននៅក្នុងជំពូកទី១២:១ ត្រូវបានបន្ត

មាន

ពាក្យទាំងនេះត្រូវបានបន្ថែមសម្រាប់ការបកប្រែនេះ។

ប្រសិនបើអ្នកបន្តបញ្ជីដែលបានចាប់ផ្តើមនៅក្នុងជំពូកទី ១២:១

អ្នកនឹងអាចលុបពាក្យនេះចេញ។

អ៊ីដោ... គីនេថោន...អ័ប៊ីយ៉ា...មីយ៉ាមីន...ប៊ីលកា ...សេម៉ាយ៉ា...យ៉ូយ៉ារីប...យេដាយ៉ា...

សាលូរ...អ័ម៉ុក...ហ៊ីលគីយ៉ា... យេដាយ៉ា...យេសួរ

ទាំងនេះគឺឈ្មោះរបស់មនុស្ស។

គីនេថោន

លោគីនេថោនី អាចមកពីទម្រង់ផ្សេងទៀតនៃឈ្មោះ «គីនេថោន »។

Nehemiah 12:8

យេសួ...ប៊ីនុយ...កាឌមាល... សេរេប៊ីយ៉ា... យូដា...ម៉ាថានា... បាកប៊ូគា...អ៊ូនី

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

ឈរបំពេញមុខងារនៅទល់មុខនឹងលោកទាំងនោះ

អត្ថន័យអាចមានគឺ ១) នេះអាចជាពេលដែលថ្វាយបង្គំ

ហើយអាចមានក្រុមអ្នកចម្រៀងពីរក្រុម (សូមមើល UDB) ឬ

អ្នកថ្វាយបង្គំផ្សេងទៀត ឬ ២)

ក្រុមទាំងនេះគឺដឹកនាំមថ្វាយបង្គំនៅព្រះវិហារក្នុងពេលផ្សេងគ្នា ឬ

«ដាក់វេនគ្នានៅព្រះវិហារ»

Nehemiah 12:10

យេសួរ...យ៉ូយ៉ាគីម...អេលីយ៉ាស៊ីប... យ៉ូយ៉ាដា...យ៉ូណាថាន...យ៉ាដួរ

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

លោកយេសួរ ជាឪពុករបស់លោកយ៉ូយ៉ាគីម

ប្រសិនបើអ្នកអានចង់ដឹងថាលោកយេសួរនេះជាបូជាចារ្យច្រើនឆ្នាំមុនពេលនេះអ្នកប្រហែលជាអ្នកត្រូវតែ

ការបកប្រែរបៀបផ្សេងទៀត:

«លោកយេសួរធ្លាប់បានធ្វើជាបូជាចារ្យអស់រយៈពេលជាច្រើនឆ្នាំ។

លោកគឺជាឪពុករបស់លោកយ៉ូយ៉ាគីម»។ (សូមមើល:figs-explicit)

Nehemiah 12:12

យ៉ូយ៉ាគីម...មេរ៉ាយ៉ា...ហាណានា...មស៊ូឡាម... យ៉ូហាណាន...យ៉ូសែប

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។

សេរ៉ាយ៉ា...យេរេមា...អែសរ៉ា..អ័ម៉ារា...មេលីគូរ...សេបានា

ទាំងនេះគឺជាឈ្មោះគ្រួសារដែលមានឈ្មោះតាមបុព្វបុរស។

generated on Wed Sep 10 16:16:32 2025

Nehemiah 12:15
ខ្លឹមសារភ្ជាប់:
បញ្ជីដែលបានចាប់ផ្តើមនៅក្នុងជំពូកទី ១២:១២ បានបន្ត
អ័ឌណា ...ហេលកាយ...សាការី...មស៊ូឡាម...ស៊ីកគ្រី...ពីលថាយ...សាំមួរ...
យ៉ូណាថាន...ម៉ាថ្នាយ...អ៊ូស៊ី...សាឡាយ...ហេប៊ើរ...សាបយ៉ា...នេថានេល
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ហារីម...មេរ៉ាយ៉ូត...អ៊ីដោ...គីនេថោន...អ័ប៊ីយ៉ា...មីនយ៉ាមីន...ម៉ាថ្នាយ...ប៊ីលកា...
សេម៉ាយ៉ា..យ៉ូយ៉ារីប...យេដាយ៉ា...សាឡាយ...អ័ម៉ុក...ហ៊ីលគីយ៉ា...យេដាយ៉ា
ទាំងនេះគឺជាឈ្មោះគ្រួសារដែលមានឈ្មោះតាមបុព្វបុរស។
គឺជាអ្នកដឹកនាំនៃ
«គឺជាអ្នកដឹកនាំក្នុងគ្រួសារ» ឬ «គឺជាអ្នកដឹកនាំនៃពូជពង្ស»
មស៊ូឡាម គឺជាមេដឹកនាំនៃគីនេថោន
គីនេថោន អាចជាទម្រង់ឈ្មោះដែលមកពីគីនេថោនី។
នៃមីនយ៉ាមីន
អត្ថបទភាសាហេព្រើរច្រឡំយកឈ្មោះមេដឹកនាំក្រុមគ្រួសារមីនមីម៉ឺនចេញ។
កំណែទម្រង់បែបទំនើបខ្លះទុកការបញ្ចេញមតិមិនពេញលេញដូចជា ULB។
កំណែផ្សេងៗទៀតផ្តល់ការពន្យល់ខ្លី ដើម្បីបង្កើតឈ្មោះរបស់មេដឹកនាំ (សូមមើល: UDB)
ម៉ូអាឌា
ម៉ូអាឌា អាចជាទម្រង់ឈ្មោះដែលមកពីម៉ូអាឌា។
Nehemiah 12:22
អេលីយ៉ាស៊ីប...យ៉ូយ៉ាដា...យ៉ូហាណាន....អេលីយ៉ាស៊ីប
ឈ្មោះរបស់មនុស្ស។
រជ្ជកាលព្រះបាទដារីយុស
អត្ថន័យមួយផ្សេងទៀតដែលអាចមានគឺ «រហូតដល់រជ្ជកាលព្រះបាទដារីយុស»។
បានកត់ត្រានៅក្នុងសៀវភៅប្រវត្តិសាស្ត្រ
នេះអាចយោងទៅលើសៀវភៅរបាក្សត្រ។
ពួកស្ត្រែបបានសរសេរពាក្យនៅក្នុងខខាងលើនៅលើសៀវភៅដែលកត់ត្រាព្រឹត្តិការណ៍ត្រូវបានកត់ត្រា
រហូតដល់គ្រាលោកយ៉ូហាណាន ជាកូនរបស់លោកអេលីយ៉ាស៊ីប
កំណត់ត្រានៅក្នុងព្រះវិហារបានកត់ត្រាទុករហូត ដល់យ៉ូហាណាន។
Nehemiah 12:24
ពួកបងប្អូនរបស់គេ ដែលឈរទល់មុខនឹងពួកគេ ដើម្បីសរសើរតម្កើង និងអរព្រះគុណតាមពួក តាមវេនរបស់ខ្លួន
នេះសំដៅទៅលើរបៀបដែលពួកគេច្រៀងចម្រៀងខ្លះរបស់ពួកគេក្នុងការគោរពថ្វាយបង្គំ។
អ្នកដឹកនាំ ឬក្រុមមួយនឹងច្រៀងឃ្លាបន្ទាប់មកមួយឬពីរក្រុមដែល
«ឈរទល់មុខពួកគេ» នឹងច្រៀងឃ្លាជាការឆ្លើយតប។
ស្របតាមបង្គាប់របស់ព្រះបាទដាវីឌ
ព្រះបាទដាវីឌបានបញ្ជាដល់ពួកលេវីពីរបៀបរៀបចំ និងដឹកនាំការថ្វាយបង្គំ។
នៅក្នុងគ្រាលោកយ៉ូយ៉ាគីម...លោកយ៉ូសាដាក និងក្នុងគ្រាលោកនេហេមា ជាទេសាភិបាល
និងលោកអែសរ៉ា ដែលជាបូជាចារ្យ និងជាស្មៀន
កាលបរិច្ឆេទត្រូវបានកំណត់ដោយចុះបញ្ជីអ្នកដែលកំពុងដឹកនាំជនជាតិយូដានៅពេលនោះ
«នៅពេលដែលយ៉ូយ៉ាគីម ...
យ៉ូសាដាកជាសម្តេចសង្ឃហើយនៅពេលដែលនេហេមាជាអភិបាល និងអ៊ីសរ៉ា ...
ជាស្មៀន»
ហាសាបយ៉ា សេរេប៊ីយ៉ា...យេសួរ ...កាឌមាល...ដាវីឌ...ម៉ាថានា...
បាកប៊ូគា...អូបាឌា...មស៊ូឡាម ...ថាលម៉ូន....អ័កគូប...យ៉ូយ៉ាគីម...យេសួរ...យ៉ូសាដាក ...
នេហេមា...អែសរ៉ា
ទាំងនេះគឺជាឈ្មោះរបស់មននុស្ស។
Nehemiah 12:27
នៅពេលធ្វើពិធីបុណ្យឆ្លងកំផែងក្រុងយេរូសាឡិម
អត្ថន័យដែលអាចមានគឺ ១)
«នៅពេលដែលពួកគេបានឧទ្ទិសកំពែងក្រុងយេរូសាឡិម» ឬ ២)
«ដូច្នេះការលះបង់ជញ្ជាំងក្រុងយេរូសាឡិមអាចនឹងកើតឡើង»។
Nehemiah 12:29
បេត-គីលកាល...កេបា និងអាសម៉ាវែត
ទាំងនេះគឺជាឈ្មោះនៃទីកន្លែង។
Nehemiah 12:31
ពួកមេដឹកនាំរបស់សាសន៍យូដា
មេដឹកនាំរបស់ប្រជាជនដែលរស់នៅក្នុងស្រុកយូដា
Nehemiah 12:32
ហូសាយ៉ា... អ័សារា... អែសរ៉ា... មស៊ូឡាម... យូដា ... យ៉ាមីន... សេម៉ាយ៉ា...យេរេមា... មីកាយ៉ា...
សេម៉ាយ៉ា... ម៉ាថានា ... មីកាយ៉ា ... សាគើរ... អេសាភ
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ក្រោយពេលដែលគេបានមក
«ហើយពួកគេបានដើរតាមក្រោយ»
កូនចៅពួកបូជាចារ្យខ្លះដែលកាន់ត្រែ មានលោកសាការី
កំណែទម្រង់ខ្លះសរសេរថា
«ហើយក្នុងចំណោមបូជាចារ្យដែលកាន់ត្រែគឺលោកសាការី»។
សាការី ជាកូនរបស់លោកយ៉ូណាថាន ដែលជាកូនរបស់លោកសេម៉ាយ៉ា លោកសេម៉ាយ៉ាជាកូន
របស់លោកម៉ាថានា ម៉ាថានាជាកូនរបស់លោកមីកាយ៉ា លោកមីកាយ៉ាជាកូនរបស់លោកសាគើរ
លោកសាគើរជាកូនរបស់លោកអេសាភ
ឈ្មោះទាំងអស់បន្ទាប់ពីលោក «សាការី» គឺជាបុព្វបុរសរបស់លោកសាការី។
បញ្ជីនេះភ្ជាប់លោកសាការីជាមួយអ្នកចំរៀងល្បីម្នាក់ឈ្មោះអេសាភ។
«លោកសាការីជាកូនរបស់យ៉ូណាថានជាកូនរបស់លោកសេម៉ាយ៉ាដែលត្រូវជាកូនរបស់ម៉ាថានាជាកូនរប
Nehemiah 12:36
ក៏មានផងដែរ
«រួមជាមួយពួកគេគឺ»
សាការី...
សេម៉ាយ៉ា...អ័សារាល ...មីឡាឡាយ...គីឡាឡាយ ...ម៉ាអាយ...នេថានេល...យូដា ...ហាណានី...ដាវីឌ...អែសរ៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។ (សូមមើល:translate-names)
អែសរ៉ា ជាអ្នកនាំមុខពួកគេ
«ហោរាអែសរ៉ា ជាអ្នកនាំមុខពួកគេ»
ទ្វារក្បាលទឹក....ទ្វារទឹក
ទាំងនេះគឺជាឈ្មោះនៃការបើកនៅក្នុងកំពែង
Nehemiah 12:38
ក្រុមចម្រៀង
ក្រុមចម្រៀង»
ខ្ញុំបានដើរតាមក្រោយពួកគេ
លោកនេហេមាបានដើរតាមក្រោយពួកគាត់
ប៉មគុកភ្លើង...ប៉មហាណានាល... ប៉មមួយរយ
ទាំងនេះគឺជាឈ្មោះនៃប៉មខ្ពស់ ៗ ដែលមនុស្សឃ្លាំមើលបង្ការគ្រោះថ្នាក់។
កំពែងធំ
នេះគឺជាឈ្មោះកំពែងផ្សេងទៀត។
ទ្វារអេប្រាអិម ... ទ្វារចាស់.... ទ្វារត្រី...ទ្វារពួកអ្នកយាម
ទាំងនេះគឺជាឈ្មោះច្រកចូលនៃកំពែង។
Nehemiah 12:40
ខ្ញុំក៏ឈប់នៅទីនោះ
ត្រង់នេះគឺលោកនេហេមាជាអ្នកដែលមានប្រសាសន៍។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំ លោកនេហេមាបានឈប់នៅទីនោះ»
នោះគឺ...ម្ចាសេយ៉ា ...មីនយ៉ាមីន ...មីកាយ៉ា...អេលីយ៉ូណាយ ...សាការី ... ហាណានា...
ម្ចាសេយ៉ា...កសេម៉ាយ៉ា...អេលាសារ...អ៊ូស៊ី ...យ៉ូហាណាន...ម៉ាលគា លោកអេឡាំ...អេស៊ើរ
ទាំងនេះជាឈ្មោះបុរសដែលជាសង្ឃនៅគ្រានោះ។
យេស៊ីរ៉ា
នេះគឺជាឈ្មោះរបស់បុរសដែលដឹកនាំក្រុមថ្វាយបង្គំ
បានធ្វើឲ្យពួកគេបានឮ
«ច្រៀងឮៗ»
Nehemiah 12:43
rejoice with great joy
«អរសប្បាយណាស់»
អំណរលាន់ឮចេញពីក្រុងយេរូសាឡិមទៅយ៉ាងឆ្ងាយ
«ក្រុងយេរូសាឡិម» គឺជាពាក្យកាត់សម្រាប់
«សំឡេងដែលប្រជាជនក្រុងយេរូសាឡិមបានធ្វើ។»
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត៖
«ប្រជាជននៅឆ្ងាយពីក្រុងយេរូសាឡិមអាច
សំឡេងដែលប្រជាជនក្រុងយេរូសាឡិមបានធ្វើដូចដែលពួកគេបានប្រារព្ធ»
Nehemiah 12:46
មានអ្នកដឹកនាំក្នុងការប្រមូលគ្នា
ប្រយោគនេះគឺប្រាប់មនុស្សថាហេតុអ្វីបានជាធ្វើវានៅក្នុងជំពូក ១២:៤៤

generated on Wed Sep 10 16:16:32 2025

ហើយប្រាប់យើងថែមទៀតអំពីពេលវេលាដែលដាវីឌបានប្រាប់ប្រជាជនពីរបៀបថ្វាយបង្គំ
នៅគ្រាលោកសូរ៉ូបាបិល
សេរូបបាបិលជាកូនចៅរបស់ព្រះបាទដាវីឌនិងជាអភិបាលមួយរូបនៅតំបន់យូដា។
ហើយគេញែកមួយចំណែកជូនពួកលេវី
ជនជាតិអ៊ីស្រាអែលទាំងអស់បែងចែកចំណែកគ្នា
ពួកឆ្មាំទ្វារ
ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រងការចូលទៅកាន់ទីក្រុង
ឬព្រះវិហារក៏ដូចជាដើម្បីបើកនិងបិទទ្វារទៅតាមហេតុផលដែលបានកំណត់ដោយអ្នកគ្រប់គ្រង។
សូមមបកប្រែឲ្យដូចនៅក្នុងជំពូកទី ៧:១
កូនចៅលោកអើរ៉ុន
ពួកបូជាចារ្យនៅអ៊ីស្រាអែលដែលបន្ទាប់ពីអើរ៉ុនជាបងរបស់លោកម៉ូសេ

13 [1]នៅថ្ងៃនោះ គេអានគម្ពីរលោកម៉ូសេឲ្យប្រជាជនស្តាប់។ ហើយគេប្រទះឃើញសេចក្តីដែលចែងទុកមកថា ពួកជនជាតិអាំម៉ូន និងពួកជនជាតិម៉ូអាប់ មិនត្រូវចូលទៅ
ក្នុងក្រុមជំនុំនៃព្រះឡើយ។[2]ដ្បិតពួកគេមិនបានយកនំប៉័ង និងទឹកមកទទួលពួកកូនចៅអ៊ីស្រាអែលទេ ប៉ុន្តែពួកគេបានជួលលោកបាឡាម ឲ្យមកដាក់បណ្តាសាដល់
ពួកគេវិញ។ ប៉ុន្តែ ព្រះអម្ចាស់នៃយើងបានបង្វែរបណ្តាសា ឲ្យទៅជាព្រះពរវិញ។[3]កាលប្រជាជនបានឮក្រឹត្យវិន័យនេះភ្លាម គេក៏ញែកជនជាតិអ៊ីស្រាអែល ចេញពីពួក
ជនជាតិដទៃ។
[4]មុនហេតុការណ៍នេះ សង្ឃអេលីយ៉ាស៊ីប ត្រូវបានតែងតាំងឲ្យមើលខុសត្រូវលើបន្ទប់នានាក្នុងព្រះដំណាក់របស់ព្រះនៃយើង។ ហើយលោកគឺជាសាច់ញាតិនឹង
លោកថូប៊ីយ៉ា។[5]លោកអេលីយ៉ាស៊ីបបានរៀបចំបន្ទប់មួយធំសម្រាប់លោកថូប៊ីយ៉ា ជាបន្ទប់ដែលពីដើមគេដាក់តង្វាយម្សៅ កំញាន គ្រឿងប្រដាប់ទាំងប៉ុន្មាន និងតង្វាយ
មួយភាគក្នុងដប់ ពីស្រូវ ទឹកទំពាំងបាយជូរ និងប្រេង ដែលគេយកមកថ្វាយតាមបង្គាប់ សម្រាប់ពួកលេវី ពួកអ្នកចម្រៀង និងពួកឆ្មាំទ្វារ ព្រមទាំងតង្វាយលើកចុះឡើង
សម្រាប់ពួកបូជាចារ្យ។
[6]ប៉ុន្តែការនេះកើតឡើង ខ្ញុំមិនបាននៅក្រុងយេរូសាឡិមទេ។ ដ្បិតនៅឆ្នាំទីសាមសិបពីរ ក្នុងរជ្ជកាលព្រះបាទអើថាស៊ើកសេស ជាស្តេចបាប៊ីឡូន ខ្ញុំបានវិលទៅគាល់ស្តេច។
រួចក្រោយយូរបន្តិចមក ខ្ញុំក៏បានសូមរាជានុញ្ញាតដើម្បីចាកចេញពីស្តេច។[7]ហើយវិលមកក្រុងយេរូសាឡិមវិញ។ ហើយពេលនោះ ខ្ញុំឃើញអំពើអាក្រក់ដែលលោក
អេលីយ៉ាស៊ីបបានប្រព្រឹត្ត ដោយរៀបចំបន្ទប់មួយសម្រាប់លោកថូប៊ីយ៉ា នៅក្នុងទីលានព្រះដំណាក់របស់ព្រះជាម្ចាស់។
[8]ខ្ញុំបានខឹងខ្លាំងណាស់ ហើយខ្ញុំក៏យកប្រដាប់ប្រដានៅក្នុងផ្ទះទាំងប៉ុន្មាន ដែលជារបស់លោកថូប៊ីយ៉ា បោះចេញទៅខាងក្រៅបន្ទប់។[9]បន្ទាប់មក ខ្ញុំបង្គាប់ឲ្យគេសម្អាតបន្ទប់
រួចខ្ញុំយកគ្រឿងប្រដាប់នៃព្រះដំណាក់របស់ព្រះ ព្រមទាំងតង្វាយម្សៅ និងកំញាន ទៅដាក់នៅទីនោះជំនួសវិញ។
[10]ខ្ញុំក៏យល់ឃើញថា គេមិនបានចែកចំណែកឲ្យពួកលេវីទេ ដូច្នេះ ពួកលេវី និងពួកអ្នកចម្រៀង ដែលត្រូវបំពេញមុខងារបម្រើ គេក៏នាំគ្នាវិលទៅធ្វើស្រែចម្ការរបស់ខ្លួនវិញ។
[11]ដូច្នេះ ខ្ញុំបានបន្ទោសពួកមេគ្រប់គ្រងថា៖ «ហេតុអ្វីបានជាព្រះដំណាក់របស់ព្រះជាម្ចាស់ូវបានបោះបង់ចោលដូច្នេះ?» ខ្ញុំក៏ប្រមូលពួកលេវី ហើយដាក់ពួកគេឲ្យបំពេញ
តួនាទីរបស់ខ្លួនវិញ។
[12]ពេលនោះ ពួកយូដាទាំងអស់ ក៏យកស្រូវ ស្រាទំពាំងបាយជូរថ្មី និងប្រេង មកដាក់ក្នុងឃ្លាំងវិញ។[13]ខ្ញុំបានតែងតាំងលោកបូជាចារ្យសេលេមា លោកសាដុក និងពេដាយ៉ា
ជាពួកលេវីឲ្យមើលការខុសត្រូវលើឃ្លាំងទាំងនោះ។ ហើយក៏មានហាណាន ជាកូនសាគើរ ដែលជាកូនម៉ាថានា ដ្បិតអ្នកទាំងនោះគេរាប់ជាមនុស្សស្មោះត្រង់។ ហើយការងារ
របស់គេ គឺជាអ្នកចែកចំណែកពួកដល់បងប្អូនរបស់ខ្លួន។[14]ឱព្រះនៃទូលបង្គំអើយ សូមនឹកចាំពីទូលបង្គំអំពីដំណើរនេះផង ហើយសូមកុំបំភ្លេចការល្អដែលទូលបង្គំបានធ្វើ
សម្រាប់ព្រះដំណាក់របស់ព្រះអង្គនៃទូលបង្គំ និងសម្រាប់កិច្ចការរបស់ព្រះអង្គឡើយ។
[15]នៅគ្រានោះ ខ្ញុំបានឃើញមនុស្សខ្លះនៅស្រុកយូដាកំពុងជាន់ធុងផ្លែទំពាំងបាយជូរ នៅថ្ងៃសប្ប័ទ ព្រមទាំងដឹកកណ្តាប់ស្រូវចូលមកផ្ទុកលើសត្វលា ដោយស្រា
ទំពាំងបាយជូរ ផ្លែទំពាំងបាយជូរ ផ្លែល្វា និងរបស់ឯទៀតៗដែលធ្ងន់ ដែលគេដឹកមកក្នុងក្រុងយេរូសាឡិម នៅថ្ងៃសប្ប័ទនោះ។ ខ្ញុំបានធ្វើប្រឆាំងទាស់ដល់ពួកគេ នៅថ្ងៃ
ដែលគេលក់ស្បៀងអាហារនោះ។
[16]ក៏មានមនុស្សពីទីក្រុងទីរ៉ុស ដែលរស់នៅក្នុងទីក្រុងយេរូសាឡិមដែលគេតែងយកត្រី និងទំនិញគ្រប់មុខមកលក់ក្នុងថ្ងៃសប្ប័ទឲ្យពួកកូនចៅយូដានៅក្រុងយេរូសាឡិម។
[17]ដូច្នេះ ខ្ញុំបន្ទោសពួកអភិជននៃជនជាតិយូដាថា៖ «ម្តេចបានជាអ្នករាល់គ្នាប្រព្រឹត្តអំពើអាក្រក់ ដោយមើលងាយថ្ងៃសប្ប័ទដូច្នេះ?[18]តើបុព្វបុរសរបស់អ្នករាល់គ្នា មិនបាន
ប្រព្រឹត្តបែបនេះទេឬ? ហើយព្រះជាម្ចាស់នៃយើងមិនបាននាំអស់ទាំងសេចក្តីអាក្រក់នេះមកលើយើង និងមកលើទីក្រុងនេះទេឬ? ឥឡូវនេះ អ្នករាល់គ្នាមើលងាយថ្ងៃ
សប្ប័ទ ហើយនាំឲ្យមានសេចក្តីក្រោធធ្លាក់មកលើពួកអ៊ីស្រាអែលថែមទៀតផង»។
[19]កាលចាប់ផ្តើមងងឹតនៅទ្វារក្រុងយេរូសាឡិម នៅល្ងាចថ្ងៃសប្ប័ទ ខ្ញុំបង្គាប់ឲ្យគេបិទទ្វារ ហើយហាមមិនឲ្យគេបើក រហូតដល់ផុតថ្ងៃសប្ប័ទ។ ខ្ញុំដាក់អ្នកបម្រើរបស់ខ្ញុំ
ខ្លះនៅតាមទ្វារក្រុង ដើម្បីកុំឲ្យអ្នកណាយកបន្ទុកអ្វីចូលមកនៅថ្ងៃសប្ប័ទឡើយ។[20]ដូច្នេះ ពួកឈ្មួញ និងពួកអ្នកលក់ដូរទំនិញគ្រប់ប្រភេទ ក៏ដេកនៅខាងក្រៅក្រុង
យេរូសាឡិមមួយយប់ ឬពីរយប់ដែរ។
[21]ប៉ុន្តែ ខ្ញុំបានព្រមានពួកគេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាដេកនៅក្រៅកំផែងក្រុងដូច្នេះ? ប្រសិនបើអ្នករាល់គ្នានៅតែធ្វើដូច្នេះទៀត ខ្ញុំនឹងចាប់អ្នករាល់គ្នាមិនខាន» ចាប់
តាំងពីពេលនោះមកពួកគេក៏លែងមកនៅថ្ងៃសប្ប័ទទៀត។[22]បន្ទាប់មក ខ្ញុំបង្គាប់ពួកលេវី ឲ្យពួកគេធ្វើពិធីសម្អាតខ្លួនជាបរិសុទ្ធ ហើយឲ្យគេមកចាំយាមនៅតាមទ្វារក្រុង
ដើម្បីញែកថ្ងៃសប្ប័ទជាបរិសុទ្ធ។ ឱព្រះនៃទូលបង្គំអើយ សូមនឹកចាំពីទូលបង្គំក្នុងការនេះផង ហើយសូមអាណិតមេត្តាទូលបង្គំ ដោយព្រះហឫទ័យសប្បុរសដ៏ធំធេងរបស់
ព្រះអង្គចំពោះទូលបង្គំ។
[23]នៅគ្រានោះ ខ្ញុំក៏ឃើញពួកយូដាខ្លះ ដែលបានរៀបការជាមួយស្ត្រីជនជាតិអាសដូឌ អាំម៉ូន និងជនជាតិម៉ូអាប់។[24]ហើយកូនរបស់ពួកគេពាក់កណ្តាលនិយាយភាសា
អាសដូឌ។ គ្មាននរណាម្នាក់ចេះនិយាយភាសាយូដាទេ គឺពួកគេនិយាយតាមតែភាសារបស់ជនជាតិដទៃទេ។
[25]ខ្ញុំបានស្តីបន្ទោសពួកគេ ហើយខ្ញុំដាក់បណ្តាសាពួកគេ ហើយវាយពួកគេខ្លះ ក៏បោចសក់ពួកគេទៀតផង។ ខ្ញុំចាប់ឲ្យគេស្បថ ក្នុងព្រះនាមរបស់ព្រះជាម្ចាស់ ដោយនិយាយ
ថា៖ «ពួកអ្នកមិនគួរលើកកូនស្រី ទៅឲ្យកូនប្រុសរបស់គេ ឬយកកូនស្រីរបស់គេ មកឲ្យកូនប្រុសរបស់ខ្លួន ឬសម្រាប់ខ្លួនឡើយ។[26]តើព្រះបាទសាឡូម៉ូន ជាស្តេចនៃ
អ៊ីស្រាអែល មិនបានប្រព្រឹត្តអំពើបាប ដោយសារតែស្ត្រីជនជាតិដទៃទេឬ? ក្នុងចំណោមសាសន៍ជាច្រើន គ្មានស្តេចណាមួយដូចព្រះបាទសាឡូម៉ូនឡើយ ព្រះជាម្ចាស់របស់
ទ្រង់បានស្រឡាញ់ទ្រង់ ព្រះបានតាំងទ្រង់ឲ្យធ្វើជាស្តេចលើជនជាតិអ៊ីស្រាអែលទាំងមូល។ ប៉ុន្តែ ស្ត្រីជនជាតិដទៃបានអូសទាញស្តេចឲ្យប្រព្រឹត្តអំពើបាប។[27]ដូច្នេះ តើត្រូវឲ្យ
យើងស្តាប់តាមអ្នករាល់គ្នា ហើយប្រព្រឹត្តអំពើអាក្រក់យ៉ាងធ្ងន់ ហើយប្រព្រឹត្តរំលងនឹងព្រះជាម្ចាស់នៃយើង ដោយរៀបការនឹងស្ត្រីជនជាតិដទៃដូច្នេះឬ?»
[28]លោកយ៉ូយ៉ាដា ជាកូនរបស់លោកអេលីយ៉ាស៊ីប ជាសម្តេចបូជាចារ្យ មានកូនប្រុសម្នាក់ដែលត្រូវជាកូនប្រសាររបស់លោកសានបាឡាត ជាអ្នកស្រុកហូរ៉ូណែម។ ហេតុ
នេះ ខ្ញុំក៏បណ្តេញអ្នកនោះចេញឆ្ងាយពីខ្ញុំ។[29]ព្រះជាម្ចាស់នៃទូលបង្គំអើយ សូមនឹកចាំពីពួកគេ ព្រោះគេបានបង្អាប់ការងារជាបូជាចារ្យ និងសេចក្តីសញ្ញារបស់ពួកបូជាចារ្យ
និងពួកលេវី។
[30]ដូច្នេះហើយ ខ្ញុំបានញែកសម្អាតពួកគេពីគ្រប់ទាំងជនជាតិដទៃ ហើយក៏ចាត់ចែងការងារដែលពួកបូជាចារ្យ និងពួកលេវីត្រូវបំពេញឡើងវិញ តាមកិច្ចការរបស់គេរៀង
ខ្លួន។[31]ហើយខ្ញុំបានរៀបចំឲ្យមានតង្វាយអុស តាមពេលកំណត់ និងសម្រាប់ផលដំបូងដែរ។ ព្រះជាម្ចាស់នៃទូលបង្គំអើយ សូមនឹកចាំពីទូលបង្គំ សម្រាប់សេចក្តីល្អផង។

Nehemiah 13:1
នៅក្នុងការស្តាប់ឮរបស់ប្រជាជន
«ដូច្នេះប្រជាជនអាចស្តាប់ឮ»
ចូលទៅក្នុងក្រុមជំនុំនៃព្រះជារៀងរហូត
«ត្រូវតែចូលទៅក្នុងក្រុមជំនុំនៃព្រះ»
នេះគឺដោយសារ
«ពួកគេមិនត្រូវចូលទៅក្នុងក្រុមជំនុំនៃព្រះដោយសារតែ»
Nehemiah 13:4
សង្ឃអេលីយ៉ាស៊ីប ដែលត្រូវបានតែងតាំង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ពួកគេបានតែងតាំងលោកអេលីស៊ីបជាបូជាចារ្យ» ឬ
«មេដឹកនាំបានតែងតាំងលោកអេលីស៊ីជាបូជាចារ្យ»
គាត់បានភ្ជាប់សាច់ញាតិនឹងលោកថូប៊ីយ៉ា។
«លោកអេលីស៊ីប និងលោកថូប៊ីយ៉ាធ្វើការជាមួយគ្នាយ៉ាងជិតស្និត»
លោកអេលីយ៉ាស៊ីបបានរៀបចំបន្ទប់មួយធំសម្រាប់លោកថូប៊ីយ៉ា
«លោកអេលីយ៉ាស៊ីបបានរៀបចំបន្ទប់មួយធំសម្រាប់លោកថូប៊ីយ៉ាដើម្បីប្រើ »
ពួកឆ្មាំទ្វារ
ប្រជាជនដែលបានចាត់ឲ្យទៅច្រកទ្វារ
ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រងការចូលទៅកាន់កំពែង
ឬព្រះវិហារក៏ដូចជាដើម្បីបើកនិងបិទទ្វារទៅតាមហេតុផលដែលបានកំណត់ដោយអ្នកគ្រប់គ្រងការ
សូមបកប្រែឲ្យដូចនៅក្នុងជំពូក៧:១
Nehemiah 13:6
ប៉ុន្តែនៅក្នុងកំឡុងពេលនេះខ្ញុំមិននៅក្រុងយេរូសាឡិមទេ។
«ក្នុងកំឡុងពេលដែលបានកើតឡើងនេះ ខ្ញុំបានចេញពីក្រុងយេរូសាឡិមហើយ»
អាក្រក់ដែលលោកអេលីយ៉ាស៊ីបបានប្រព្រឹត្ត ដោយរៀបចំបន្ទប់មួយសម្រាប់លោកថូប៊ីយ៉ា នៅក្នុងទី
លានព្រះដំណាក់របស់ព្រះជាម្ចាស់
នេះគឺជាបន្ទប់ដែលពីមុនត្រូវបានបន្សុត ដើម្បីផ្ទុកការគ្រឿងដង្វាយ (១៣:៤)។
Nehemiah 13:10
គេមិនបានចែកចំណែកឲ្យពួកលេវីទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនពុំបាននាំយកតង្វាយមួយភាគដប់
និងតង្វាយរបស់ពួកគេមកឲ្យពួកបូជាចារ្យដែលបំពេញមុខងារក្នុងព្រះវិហារទេ»
ពួកគេបានចាកចេញទៅ ពួកគេបានត្រឡប់ទៅរកការងាររបស់ពួកគេវិញ ទាំងពួកលាវី
និងពួកអ្នកចម្រៀងដែលបានបំពេញការងារ
«ពួកលេវី និងពួកអ្នកចម្រៀងដែលធ្វើការនៅក្នុងព្រះវិហារបានចាកចេញពីព្រះវិហារ
ម្នាក់ៗបានត្រឡប់ទៅកន្លែងរបស់ពួកគេវិញ»
ហេតុអ្វីបានជាបោះបង់ចោលព្រះដំណាក់របស់ព្រះដូច្នេះ?
នេះគឺជាសំណួរវោហារសាស្ត្រចាប់តាំងពីលោកនេហេមាបានប្រើនេះ ដើម្បីជំទាស់
ឬថែមទាំងចំអកដល់មន្ត្រីដែលមិនបានបំពេញការងាររបស់ខ្លួន។
Nehemiah 13:12
ពួកយូដាទាំងអស់
ឈ្មោះនៃទឹកដីគឺជាទីសម្គាល់សម្រាប់ប្រជាជននៃទឹកដីនោះ។
នេះប្រហែលជាការធ្វើឲ្យមានលក្ខណៈទូទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សទាំងអស់ដែលរស់នៅក្នុងស្រុកយូដា»
សេលេមា... សាដុក... ពេដាយ៉ា... ហាណាន...សាគើរ....ម៉ាថានា
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
ពួកគេបានរាប់ជាមនុស្សស្មោះត្រង់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ សព្វនាម «ស្មោះត្រង់»
អាចបកប្រែជាកិរិយាស័ព្ទបាន។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំដឹងថាខ្ញុំអាចទុកចិត្តពួកគេបាន»
ឱព្រះនៃទូលបង្គំអើយ សូមនឹកចាំពីទូលបង្គំអំពីដំណើរនេះ
«ព្រះជាម្ចាស់នៃទូលបង្គំអើយ សូមនឹកចាំពីទូលបង្គំផង។»
Nehemiah 13:15
ជាន់ធុងផ្លែទំពាំងបាយជូរ
ពាក្យ «ជាន់ធុងផ្លែទំពាំងបាយជូរ»
គឺជាទីសម្គាល់សម្រាប់ទំពាំងបាយជូរដែលមាននៅក្នុងស្រាទំពាំងបាយជូរ។
ប្រជាជនបានជាន់នៅលើទំពាំងបាយជូរ
ដើម្បីយកទឹកចេញពីផ្លែវាដើម្បីយកមកធ្វើស្រា។ ការបកប្រែរបៀបផ្សេងទៀត:
«ដើរជាន់នៅលើផ្លែទំពាំងបាជូរដើម្បីធ្វើស្រា»
បញ្ជាន់
ដើរជាន់លើអ្វីមួយបំបែកវា ឬសង្កត់វា។
Nehemiah 13:16
ទីរ៉ុស
ឈ្មោះនៃទីក្រុង
តើអំពើអាក្រក់ដែលអ្នកកំពុងធ្វើនេះធ្វើឲ្យថ្ងៃសប្ប័ទបង្អាប់ដល់កំរិតណា?
លោកនេហេមាបានប្រមាថមេដឹកនាំរបស់យូដា។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកកំពុងធ្វើអំពើអាក្រក់ ដោយបបង្អាប់ថ្ងៃសប្ប័ទ»។ ឬ
«ព្រះនឹងដាក់ទណ្ឌកម្មអ្នកពីការធ្វើអំពើអាក្រក់នេះ
ព្រោះអ្នកបានបង្អាប់ថ្ងៃសប្ប័ទ»។
តើបុព្វបុរសរបស់អ្នករាល់គ្នា មិនបានប្រព្រឹត្តបែបនេះទេ?
លោកនេហេមាបានប្រមាថមេដឹកនាំរបស់យូដា។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដឹងថាបុព្វបុរសរបស់អ្នកបានប្រព្រឹត្តដូច្នេះ
នោះជាមូលហេតុដែលព្រះជាម្ចាស់ធ្វើឲ្យទុក្ខវេទនានេះកើតមានដល់យើង
និងក្រុងនេះ។»
Nehemiah 13:19
កាលចាប់ផ្តើមងងឹត...មុនថ្ងៃសប្ប័ទ
«ទ្វារបានបិទ ដែលព្រះអាទិត្យលិច.... ហើយចាជាពេលដែលថ្ងៃសប្ប័ទបានចាប់ផ្តើម»
ត្រូវបិតទ្វា ហើយពួកគេមិនត្រូវបើករហូតដល់ពេល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកឆ្មាំបានបិទទ្វារហើយមិនបើកទ្វាររហូតដល់»
គ្មានទំនិញអ្វីដែលអាចនាំចូលបានទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មាននរណាអានាំចូលផលិតផលដែលពួកគេចង់លក់នោះទេ»
អ្នកលក់ដូរទំនិញគ្រប់ប្រភេទ
«មនុស្សដែលនាំចូលផលិតផលដែលពួកគេចង់នាំយកមកលក់»
Nehemiah 13:21
ហេតុអ្វីបានជាអ្នកចេញក្រៅកំពែង
លោកនេហេមាបង្ហាញសំនួរនេះដោយមិនត្រូវការចម្លើយទេ តែស្តីបន្ទោសពួកឈ្មួញ
និងសង្កត់ធ្ងន់លើបញ្ហារបស់លោក។
«អ្នកកំពុងបោះជំរំនៅខាងក្រៅកំពែងទាស់នឹងអ្វីដែលខ្ញុំបានបញ្ជា»។
ខ្ញុំនឹងដាក់ដៃទៅលើអ្នក
ពាក្យ «ដៃ» គឺជាសកម្មភាពដែលបង្ហាញពីអំណាច។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងបញ្ជូនអ្នកចេញទៅបង្ខំ» ឬ «ខ្ញុំនឹងដកអ្នកចេញដោយបង្ខំ»
Nehemiah 13:23
ខ្លឹមសារភ្ជាប់:
ខ្លឹមសារភ្ជាប់: នៅក្នុងខនេះនឹងណែនាំអំពីសកម្មដូចតទៅ។
ពួកយូដាខ្លះ ដែលបានរៀបការជាមួយស្ត្រីជនជាតិអាសដូឌ អាំម៉ូន និងម៉ូអាប់
«ពួកយូដាខ្លះ ដែលបានរៀបការជាមួយស្ត្រីសាសន៍ដទៃ»
ព្រះជាម្ចាស់បានហាមការរៀបការ។
អាសដូឌ
ឈ្មោះនៃទីក្រុង
អាំម៉ូន...ម៉ូអាប់
ឈ្មោះនៃប្រជាជាតិ
ពាក់កណ្តាលនៃកូនរបស់ពួកគេ
«ជាលិទ្ធផល ពាក់កណ្តាលនៃកូនរបស់ពួកគេ»
Nehemiah 13:25
ខ្ញុំបានស្តីបន្ទោសពួកគេ
«ខ្ញុំនិយាយទៅកាន់ពួកគេដោយផ្ទាល់អំពីអ្វីដែលពួកគេបានធ្វើ»
ខ្ញុំបានវាយពួកគេខ្លះ
ដោយដៃរបស់គាត់
ខ្ញុំបានឲ្យពួកគេស្បថដោយព្រះជាម្ចាស់
«ខ្ញុំបានធ្វើឲ្យពួកគេស្បថ នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់»
តើព្រះបាទសាឡូម៉ូន ជាស្តេចនៃអ៊ីស្រាអែល មិនបានប្រព្រឹត្តអំពើបាប ដោយសារតែស្ត្រីជនជាតិដទៃ
ទេឬ?
លោកនេហេមាកំពុងស្តីបន្ទោសបុរសទាំងនោះ។
នេះអាចត្រូវបានបកប្រែជាប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះបាទសា
ឡូម៉ូន ជាស្តេចនៃអ៊ីស្រាអែល មិនបានប្រព្រឹត្តអំពើបាប ដោយសារតែស្ត្រីជនជាតិ
ដទៃ»។
ដូច្នេះ តើត្រូវឲ្យយើងស្តាប់តាមអ្នករាល់គ្នា ហើយប្រព្រឹត្តអំពើអាក្រក់យ៉ាងធ្ងន់ ហើយប្រព្រឹត្តរំលង
នឹងព្រះជាម្ចាស់នៃយើង ដោយរៀបការនឹងស្ត្រីជនជាតិដទៃដូច្នេះឬ?
លោកនេហេមាកំពុងស្តីបន្ទោសបុរសទាំងនោះ។
នេះអាចត្រូវបានបកប្រែជាប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត: «យើង
និងមិនស្តាប់តាមអ្នកទេ ឬ ធ្វើអំពើទុច្ចរិត
ឬអំពើក្បត់ទាស់នឹងព្រះជាម្ចាស់ដោយរៀបការជាមួយនឹងនារីសាសន៍ដទៃ»
Nehemiah 13:28
យ៉ូយ៉ាដា...អេលីយ៉ាស៊ីប...សានបាឡាត

generated on Wed Sep 10 16:16:32 2025

ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ហ្ស៊ូណែម
មនុស្សម្នាក់ដែលមកពីទីក្រុងបេតហ្ស៊ូរ៉ូន
ខ្ញុំក៏បណ្តេញអ្នកនោះចេញឆ្ងាយពីខ្ញុំ
«ខ្ញុំបានដេញគេចេញ» ឬ «ខ្ញុំបានធ្វើឲ្យគេចាកចេញពីក្រុងយេរូសាឡិម»
សូមនឹកចាំពីខ្ញុំ
«គិតពីខ្ញុំ» ឬ «សូមចងចាំពីអ្វីដែលពួកគេបានធ្វើ»
ព្រោះគេបានបង្អាប់ការងារជាបូជាចារ្យ
«ពួកគេបានធ្វើឲ្យអ្នកគិតអំពីបូជាចារ្យ
និងកិច្ចការរបស់ពួកគេដូចជាពួកអ្នកមិនស្អាត»
និងសេចក្តីសញ្ញារបស់ពួកបូជាចារ្យ និងពួកលេវី
«ពួកគេបានធ្វើឲ្យអ្នកគិតអំពីសម្ពន្ធមេត្រីដែលអ្នកបានចងជាមួយបូជាចារ្យ
និងក្រុមលេវីដូចជាមិនបរិសុទ្ធ»

Nehemiah 13:30
ដូច្នេះហើយ ខ្ញុំបានញែកសម្អាតពួកគេ
«នៅក្នុងមធ្យបាយដែលខ្ញុំបន្សុទ្ធពួកគេ»
តាំងការងារដែលពួកបូជាចារ្យ និងពួកលេវី
លោកបានប្រាប់ក្រុមបូជាចារ្យ និងក្រុមលេវីឲ្យដឹងអំពីកិច្ចការដែលត្រូវធ្វើ
ខ្ញុំបានរៀបចំឲ្យមានតង្វាយអុស
«ខ្ញុំបានរៀបចំការផ្គត់ផ្គង់ឈើសម្រាប់តង្វាយឈើ»
សម្រាប់ផលដំបូង
សម្រាប់ការផ្តល់ជូនផលដំបូងនៅពេលប្រមូលផល
ព្រះនៃទូលបង្គំអើយ សូមនឹកចាំពីទូលបង្គំ សម្រាប់សេចក្តីល្អផង
«សូមគិតអំពីអ្វីដែលទូលបានធ្វើឱព្រះជាម្ចាស់របស់ខ្ញុំអើយ
ហើយសូមប្រទានពរដល់ទូលបង្គំដោយសារការល្អដែលទូលបង្គំបានធ្វើ»

នាងអេសធើរ

1 [1]នៅគ្រានោះ (ព្រះចៅអហាស៊ូរុសបានសោយរាជ្យលើខេត្តមួយរយម្ភៃប្រាំពីរ គឺចាប់ពីស្រុកឥណ្ឌារហូតដល់ស្រុកអេត្យូពី)[2]នៅជំនាន់នោះស្តេចអហាស៊ូរុស
គង់លើបល្ល័ង្ករាជ្យនៅក្រុងស៊ូសាន។
[3]នៅឆ្នាំទីបីនៃរជ្ជកាល ស្តេចបានរៀបចំពិធីជប់លៀងដល់ពួកមន្ត្រី និងពួកមេដឹកនាំរបស់ស្តេចទាំងអស់។ ព្រមទាំងមេទ័ពពើស៊ី និងមេឌី អភិជន
និងទេសាភិបាលរបស់អាណាខេត្តទាំងអស់។[4]ស្តេចទ្រង់ចង់បង្ហាញអស់ទាំងរាជសម្បត្តិដ៏ស្តុកស្តម្ភ និងកិត្តិយសនៃសិរីរុងរឿងដ៏វិសេសរបស់ទ្រង់
អស់រយៈពេលជាច្រើនថ្ងៃ គឺអស់រយៈពេល180ថ្ងៃ។
[5]នៅពេលផុតថ្ងៃទាំងនោះហើយ ស្តេចរៀបចំពិធីជប់លៀង អស់រយៈពេលប្រាំពីរថ្ងៃ។ ការនេះសម្រាប់ប្រជាជនទាំងអស់ ដែលនៅក្រុងស៊ូសាន
នៅក្នុងទីធ្លាឧទ្យាននៃដំណាក់របស់ស្តេច។[6]នៅពីចំហៀងនៃសួនច្បារត្រូវបាន តុបតែងជាមួយសំពត់ពណ៌ស និងពណ៌ខៀវ លាយនឹងក្រណាត់ធ្វើពីអំបោះពណ៌ស
ភ្ជាប់ទៅនឹងខ្សែខ្លូតទេសពណ៌ស្វាយ ភ្ជាប់នឹងសសរថ្មកែវដោយក្រវិលប្រាក់។ ក៏មានកៅអីធ្វើពីមាស និងពីប្រាក់ ដាក់លើកម្រាលថ្មកែវពណ៌ក្រហម ថ្លើមថ្ម ខ្សែងដាំ
និងថ្មខ្មៅ។
[7]គេបម្រើដោយដាក់ស្រាក្នុងពែងមាស។ ជាពែងដែលមានក្បាច់រចនាប្លែកៗពីគ្នា ហើយស្តេចឲ្យគេយកស្រាមកចាក់ជូនភ្ញៀវយ៉ាងបរិបូណ៌។[8]តាមព្រះរាជបញ្ជារបស់ស្តេច
ភ្ញៀវអាចពិសាស្រាតាមចិត្ត ដោយមិនចាំបាច់នឹងខ្លាចខ្វះខាតអ្វីឡើយ «គ្មានការការបង្ខិតបង្ខំទេ»។ ដ្បិតស្តេចបញ្ជាឲ្យរាជបម្រើចាក់ស្រាជូន តាមដែលភ្ញៀវចង់បាន។
[9]ព្រះនាងវ៉ាសធី ជាអគ្គមហេសី ក៏រៀបចំពិធីជប់លៀងសម្រាប់ពួកស្ត្រីនៅក្នុងវាំងរបស់ព្រះចៅអហាស៊ូរុសដែរ។[10]នៅថ្ងៃទីប្រាំពីរ កាលស្តេចមានព្រះហឫទ័យសប្បាយ
ដោយសារស្រា ស្តេចបង្គាប់លោកមហ៊ូម៉ាន លោកប៊ីសថា លោកហារបូណា លោកប៊ីគថា លោកអបាគថា លោកសេថារ និងលោកកើកាស (មហាតលិកទាំងប្រាំពីររូប
ដែលនៅបម្រើស្តេច)[11]ឲ្យទៅយាងព្រះនាងវ៉ាសធី ជាអគ្គមហេសីមកគាល់ស្តេច ទាំងពាក់មកុដរាជ្យ។ ដើម្បីបង្ហាញដល់ប្រជាជន
និងមេដឹកនាំឲ្យឃើញរូបឆោមដ៏ស្រស់ស្អាតរបស់ព្រះនាង ដ្បិតព្រះនាងមានរូបឆោមស្រស់ស្អាតគួរឲ្យគយគន់។
[12]ប៉ុន្តែព្រះនាងវ៉ាសធី មិនព្រមយាងមកតាមព្រះរាជបញ្ជារបស់ស្តេច ដែលពួកមហាតលិកបានទូលថ្វាយឡើយ។ ពេលនោះ ស្តេចទ្រង់ពិរោធយ៉ាងខ្លាំង
ហើយកំហឹងនោះក៏ឆេះឆួលក្នុងព្រះហឫទ័យជាខ្លាំង។
[13]ដូច្នេះ ស្តេចក៏សួរយោបល់ទៅកាន់ពួកអ្នកប្រាជ្ញ ដែលជាអ្នកមានភារកិច្ចជួយដោះស្រាយរឿងរបស់ស្តេច
(ដ្បិតនេះជាទម្លាប់របស់ស្តេចតែងតែពិគ្រោះនឹងអ្នកចេះស្ទាត់ខាងច្បាប់ដើម្បីវិនិច្ឆ័យ)។[14]ហើយអ្នកដែលនៅជិតដិតនឹងស្តេចមានលោក កើសេនា លោកសេថារ
លោកអ័ឌម៉ាថា លោកតើស៊ីស លោកម៉េរ៉ែស លោកម៉ាសេណា លោកមមូនកាន ជាមេដឹកនាំទាំងប្រាំពីររូបរបស់ជនជាតិមេឌី និងជនជាតិពែរ្ស
ដែលជាអ្នកជំនិតរបស់ស្តេច ហើយមានមុខតំណែងខ្ពស់នៅក្នុងរាជាណាចក្រ។[15]«នៅក្នុងច្បាប់វិញ តើត្រូវធ្វើដូចម្តេចចំពោះព្រះនាងវ៉ាសធី ជាអគ្គមហេសី
ដោយព្រោះមិនធ្វើតាមបញ្ជារបស់ស្តេច ដែលពួកមហាតលិកបានទូលថ្វាយដូច្នេះ?
[16]លោកមមូនកានមានប្រសាសន៍នៅចំពោះស្តេច និងពួកមេដឹកនាំថា «ព្រះនាងវ៉ាសធី ជាអគ្គមហេសីបានធ្វើខុស មិនមែនត្រឹមតែចំពោះព្រះរាជាប៉ុណ្ណោះ
គឺបានធ្វើឲ្យប៉ះពាល់ដល់ពួកមេដឹកនាំ និងប្រជាជនទាំងអស់ ក្នុងអាណាខេត្តទាំងប៉ុន្មានរបស់ព្រះចៅអហាស៊ូរុសទៀតផង។
[17]ដ្បិតការប្រព្រឹត្តរបស់អគ្គមហេសីបានលេចឮដល់ស្ត្រីទាំងអស់។ ហើយបណ្តាលឲ្យគេមើលងាយប្តីរបស់ខ្លួន។ ពួកគេនឹងនិយាយថា ព្រះចៅអហាស៊ូរុស
ចេញបញ្ជាឲ្យគេនាំព្រះនាងវ៉ែសធី ជាអគ្គមហេសី មកគាល់ទ្រង់ តែព្រះនាងមិនព្រមធ្វើតាម។[18]នៅថ្ងៃនោះ ពួកជំទាវនៃជនជាតិពែរ្ស និងជនជាតិមេឌីទាំងប៉ុន្មាន
ដែលបានឮពីទង្វើរបស់អគ្គមហេសី ដែលមិនស្តាប់បង្គាប់ព្រះករុណា នោះពួកគេមុខជាធ្វើបែបនេះចំពោះប្តីរបស់ខ្លួន ដែលជាមេដឹកនាំរបស់ព្រះករុណាដូច្នោះដែរ។
ជាហេតុធ្វើឲ្យប្តីមានកំហឹង ព្រោះតែភរិយាមើលងាយ។
[19]ប្រសិនបើព្រះករុណាសព្វព្រះហឫទ័យ សូមទ្រង់ចេញរាជបញ្ជា ហើយឲ្យគេចែងទុកក្នុងច្បាប់នៃជនជាតិពើពែរ្ស និងជនជាតិមេឌី ដែលមិនអាចប្រែប្រួលបានឡើយ
គឺថាកុំឲ្យព្រះនាងវ៉ាសធីចូលមកជួបព្រះភក្ត្រ ព្រះករុណារហូតតទៅ។ ហើយសូមព្រះករុណាផ្ទេរតំណែងជាមហេសីរបស់ព្រះនាងឲ្យទៅព្រះមហេសីមួយអង្គទៀត
ដែលល្អប្រសើជាងព្រះនាង។[20]កាលណាសេចក្តីសម្រេចរបស់ព្រះរាជាបានប្រកាសពាសពេញនគររបស់ទ្រង់ នោះស្ត្រីទាំងអស់នឹងគោរពប្រតិបត្តិប្តីរបស់ខ្លួន តាំងពីអ្នកធំ
រហូតដល់អ្នកតូច»។
[21]ព្រះរាជាសព្វព្រះហឫទ័យនឹងយោបល់នេះណាស់ ហើយអស់ពួកមេដឹកនាំក៏ពេញចិត្តដែរ ហើយព្រះរាជាក៏ធ្វើតាមសំណើររបស់លោកមមូនកាន។
[22]ស្តេចផ្ញើរាជសារទៅគ្រប់អាណាខេត្តទាំងអស់ តាមអក្សរ និងភាសារបស់ប្រជាជនក្នុងអណាខេត្តនីមួយៗ។ ដោយប្រកាសឲ្យបុរសទាំងអស់ធ្វើជាមេលើគ្រួសាររបស់ខ្លួន។
ហើយរាជ្យសារនេះបានធ្វើទៅមនុស្សនិងគ្រប់ភាសារបស់គេរាងៗខ្លួន។

Esther 1:1
នៅគ្រានោះព្រះចៅអហាស៊ូរុសបានសោយរាជ្យ
«នៅសម័យព្រះចៅអហាស៊ូរុស» ឬ
«នៅពេលដែលព្រះចៅអហាស៊ូរុសសោយរាជ្យជាស្តេច»
ព្រះចៅអហាស៊ូរុសបានសោយរាជ្យលើខេត្តមួយរយម្ភៃប្រាំពីរ
គឺចាប់ពីស្រុកឥណ្ឌារហូតដល់ស្រុកអស្សូរ
នេះគឺជាព័ត៌មានសង្ខេប ដើម្បីជួយអ្នកអានឲ្យដឹងពីព្រះចៅអហាស៊ូរុស។
១២៧
«មួយរយម្ភៃប្រាំពីរ»
ខេត្ត
«ខេត្ត»
គឺជាតំបន់ដ៏ធំមួយដែលប្រទេសខ្លះត្រូវបានបែងចែកសម្រាប់គោលបំណងរបស់រដ្ឋាភិបាល។

generated on Wed Sep 10 16:16:32 2025

គង់លើបល្ល័ង្ករាជ្យ
ត្រង់នេះ «រាជ្យបល្ល័ង្ក» អាចសំដៅលើការគ្រប់គ្រងរបស់ព្រះអង្គលើអាណាចក្រ។ ការបកប្រែរបៀបផ្សេងទៀត: «គ្រប់គ្រងចក្រភព»
បន្ទាយ
បន្ទាយ ឬទីក្រុងដែលមានកំពែងរឹងមាំ។
ក្រុងស៊ូសាន
ទីក្រុងរាជ្យនៃស្តេចពែរ្ស ។
Esther 1:3
នៅឆ្នាំទីបីនៃរជ្ជកាលរបស់ព្រះអង្គ
«បន្ទាប់ពីព្រះអង្គបានគ្រប់គ្រងអស់រយៈពេល ២ឆ្នាំ»
មេទ័ព
នេះអាចសំដៅទៅលើមេដឹកនាំនៃកងទ័ព។ ការបកប្រែរបៀបផ្សេងទៀត: «នាយទាហាននៃកងទ័ព»
រាជសម្បត្តិដ៏ស្តុកស្តម្ភ និងកិត្តិយសនៃសិរីរុងរឿងដ៏វិសេសរបស់ទ្រង់
ពាក្យទាំងនេះមានន័យប្រហាក់ប្រហែលហើយបញ្ជាក់ថា តើនគររបស់ទ្រង់អស្ចារ្យប៉ុណ្ណា។ ការបកប្រែរបៀបផ្សេងទៀត: «រាជសម្បត្តិដ៏ស្តុកស្តម្ភ នៃនគររបស់ទ្រង់»
កិត្តិយសនៃសិរីរុងរឿងដ៏វិសេសរបស់ទ្រង់
ពាក្យទាំងនេះមានន័យប្រហាក់ប្រហែលហើយបញ្ជាក់ថា តើនគររបស់ទ្រង់អស្ចារ្យប៉ុណ្ណា។ ការបកប្រែរបៀបផ្សេងទៀត: «រាជសម្បត្តិដ៏ស្តុកស្តម្ភនៃនគររបស់ទ្រង់»
១៨០
«មួយរយប៉ែតសិប»
Esther 1:5
នៅពេលផុតថ្ងៃទាំងនោះហើយ
«នៅចុងបញ្ចប់នៃពិធីនោះ»
ពិធីជប់លៀងអស់រយៈពេលប្រាំពីរថ្ងៃ
នេះជាបុណ្យទី២ ដែលមានតែសម្រាប់មន្ត្រីនៅក្រុងស៊ូសានប៉ុណ្ណោះ។ ការបកប្រែរបៀបផ្សេងទៀត: «បុណ្យមួយទៀតដែលមានរយៈពេល ៧ ថ្ងៃ»
ប្រាំពីរ
«៧»
ដំណាក់របស់ស្តេច
បកប្រែដូចនៅក្នុងជំពូកទី ១:១។
ក្រុងស៊ូសាន
បកប្រែដូចនៅក្នុងជំពូកទី ១:១។
ម្រាលថ្មកែវ
«ថ្មកែវ» មានថ្មពណ៌ដែលត្រូវបានរៀបចំតាមលំនាំដ៏គួរឲ្យទាក់ទាញ។
ថ្មកែវពណ៌ក្រហម
នេះគឺជាប្រភេទថ្មពណ៌ក្រហម និងពណ៌ស្វាយដែលមានបំណែកនៃគ្រីស្តាល់។
Esther 1:7
គេបម្រើដោយដាក់ស្រាក្នុងពែងមាស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ភ្ញៀវបានផឹកស្រាពីពែងមាស»
ស្តេចឲ្យគេយកស្រាមកចាក់ជូនភ្ញៀវយ៉ាងបរិបូណ៌
«ព្រះរាជាពេញព្រះទ័យនឹងស្រាទំពាំងបាយជូរ»
សប្បុរសធម៌
«ឆន្ទៈខ្ពស់ក្នុងការផ្តល់ឲ្យ»
គ្មានការការបង្ខិតបង្ខំទេ
«គ្មានអ្នកណាត្រូវបង្ខំចិត្តឲ្យផឹកទេ»
ដ្បិតស្តេចបញ្ជាឲ្យរាជបម្រើចាក់ស្រាជូន តាមដែលភ្ញៀវចង់បាន
ឃ្លានេះមានន័យថា ព្រះរាជាបានបញ្ជាឲ្យអ្នកបម្រើរបស់ទ្រង់ចាក់ស្រាជូនភ្ញៀវទាំងអស់តាមដែលពួកគេចង់បាន។ ការបកប្រែរបៀបផ្សេងទៀត:
Esther 1:9
នៅថ្ងៃទីប្រាំពីរ
«បន្ទាប់ពី ៦ ថ្ងៃ»
ស្តេចមានព្រះហឫទ័យសប្បាយ ដោយសារស្រា
ត្រង់នេះ «ដួងចិត្ត» សំដៅលើព្រះរាជាហើយ «មានអារម្មណ៍រីករាយ» គឺជាសំនួនវោហារស័ព្ទដែលមានន័យថា ទ្រង់ស្រវឹងហើយ។ ការបកប្រែរបៀបផ្សេងទៀត: «ស្តេចស្រវឹងស្រា»។
លោកមហ៊ូម៉ាន លោកប៊ីសថា លោកហារបូណា លោកប៊ីគថា លោកអបាគថា លោកសេថារ និងលោកកើកាស
មហាតលិកទាំងប្រាំពីររូប ដែលនៅបម្រើស្តេច
នេះគឺជាព័ត៌មានផ្នែខាងក្រោយ ដើម្បីពន្យល់ថា បុរសទាំងនេះជានរណា។
ព្រះនាងមានរូបឆោមស្រស់ស្អាតគួរឲ្យគយគន់
«ព្រះនាងស្អាតណាស់»
Esther 1:12
របស់ស្តេច ដែលពួកមហាតលិកបានទូលថ្វាយឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «នៅពេលមន្ត្រីរបស់ស្តេចបានប្រាប់ព្រះនាងអំពីបញ្ជារបស់ទ្រង់»
តាមព្រះរាជបញ្ជា
នៅទីនេះ «ព្រះរាជបញ្ជា» សំដៅទៅលើពាក្យបញ្ជាទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត: «តាមពាក្យបញ្ជា» (សូមមើល:figs-synecdoche)
ហើយកំហឹងនោះក៏ឆេះឆួលក្នុងព្រះហឫទ័យជាខ្លាំង
កំហឹងរបស់ស្តេចត្រូវបានគេនិយាយដូចជាភ្លើងដែលឆេះនៅខាងក្នុងទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«កំហឹងរបស់ទ្រង់ខ្លាំងដូចភ្លើងឆេះនៅខាងក្នុងព្រះហឫទ័យ»
Esther 1:13
អ្នកមានភារកិច្ចជួយដោះស្រាយរឿងរបស់ស្តេច
«អ្នកមានភារកិច្ចជួយរឿងរ៉ាវដែលបានកើតឡើងក្នុងជីវិតរបស់ពួកគេ»
ដ្បិតនេះជាទម្លាប់របស់ស្តេចតែងតែពិគ្រោះនឹងអ្នកចេះស្ទាត់ខាងច្បាប់ ដើម្បីវិនិច្ឆ័យ
ព័ត៌មានផ្នែខាងក្រោយនេះពន្យល់ពីមូលហេតុដែលស្តេចហៅបុរសទាំងនេះ។
លោក កើសេនា លោកសេថារ លោកអ័ឌម៉ាថា លោកតើស៊ីស លោកម៉េរែស លោកម៉ាសេណា
លោកមូនកាន
ទាំងនេះគឺជាឈ្មោះរបស់បុរស។
ប្រាំពីរ
«៧»
នៅក្នុងច្បាប់វិញ ... ដែលពួកមហាតលិក
នេះអាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីអ្នកដែលបានសួរសំណួរនេះ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះមហាក្សត្របាននិយាយទៅកាន់ពួកគេថា»
ដោយគោរពតាមច្បាប់ ... ដោយមន្ត្រី?»
នៅក្នុងច្បាប់វិញ
«នៅក្នុងការសង្កេតការណ៍នៃច្បាប់» ឬ «នៅក្នុងការគោរពដល់ច្បាប់នេះ»
Esther 1:16
លោកមូនកាន
បកប្រែឈ្មោះរបស់លោកដូចនៅក្នុងជំពូក ១:១៣។
ពួកមេដឹកនាំ និងប្រជាជនទាំងអស់... ក្នុងអាណាខេត្តទាំងប៉ុន្មាន ... ស្ត្រីទាំងអស់
ទាំងនេះគឺជាការបំផ្លើស
ដើម្បីសង្កត់ន័យលើការខូចខាតដែលការបដិសេធរបស់ស្ត្រីដែលបានបង្កឡើង។
ខេត្តទាំងប៉ុន្មាន
បកប្រែដូចនៅក្នុងជំពូក ១:១។
ជាហេតុធ្វើឲ្យប្តីមានកំហឹង ព្រោះតែភរិយាមើលងាយ
«ពួកគេនឹងខឹងនឹងប្តីរបស់ពួកគេ ហើយចាត់ទុកពួកគេដោយការមើលងាយ»
Esther 1:19
ខ្លឹមសារភ្ជាប់
លោកមូនកាននៅតែបន្តឆ្លើយនឹងស្តេច។
ប្រសិនបើព្រះករុណាសព្វព្រះហឫទ័យ...ចេញពីទ្រង់...ចំពោះទ្រង់...សូមព្រះករុណា...ព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ...នគរ
លោកមូនកាននិយាយទៅកាន់ស្តេចនៅក្នុងមនុស្សទីបីជាទម្រង់នៃការគោរព។ ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើនេះគាប់ព្រះហឫទ័យព្រះករុណា ... ពីទ្រង់ ... នៅចំពោះទ្រង់ ... សូម ... ក្រឹត្យរបស់ទ្រង់ ... នគរដ៏ធំរបស់ទ្រង់»
ដែលមិនអាចប្រែប្រួលបានឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ដែលគ្មាននរណាម្នាក់អាចផ្លាស់ប្តូរបាន»
កាលណាសេចក្តីសម្រេចរបស់ព្រះរាជាបានប្រកាសពាសពេញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «នៅពេលពួកគេឮក្រឹត្យរបស់ស្តេច» ឬ «នៅពេលដែលពួកគេបានស្តាប់ឮនូវអ្វីដែលស្តេចបានបង្គាប់»
ធំធេង
«ធំ» ឬ «ធំសម្បើម»

generated on Wed Sep 10 16:16:32 2025

តាំងពីអ្នកធំ រហូតដល់អ្នកតូច
នេះគឺជាការរួមបញ្ចូលគ្នាមួយដែលសំដៅទៅលើទាំងជ្រុលនិយម
និងមនុស្សគ្រប់គ្នាដែលនៅចំពោះមុខ។ នេះប្រហែលជាសំដៅទៅលើប្តីប៉ុ ន្តែ
នេះអាចថា សំដៅទៅលើភរិយា។
Esther 1:21
លោកមមុនកាន
បកប្រែឈ្មោះរបស់លោកដូចនៅក្នុងជំពូក ១:១៣ ។
អាណាខេត្ត
បកប្រែដូចនៅក្នុងជំពូក ១:១។
បុរសទាំងអស់នឹងធ្វើជាមេលើគ្រួសាររបស់ខ្លួន
«មនុស្សទាំងអស់គួរតែមានសិទ្ធិអំណាចពេញលេញលើប្រពន្ធ
និងកូនរបស់ខ្លួន» (UDB)
ហើយរាជ្យសារនេះបានធ្វើទៅមនុស្ស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេសរសេររាជ្យសាររបស់ទ្រង់»

---

2 [1]ក្រោយហេតុការណ៍ទាំងនោះមក ព្រះចៅអហាស៊ូរុស ឈប់ព្រះពិរោធ នោះស្តេចក៏នឹករលឹកដល់ព្រះនាងវ៉ាសធី និងការដែលព្រះនាងបានធ្វើ។
[2]ព្រមទាំងសេចក្តីដែលបានសម្រេចចំពោះព្រះនាង។ ពួករាជបម្រើទូលស្តេចថា «សូមឲ្យគេទៅរកស្ត្រីព្រហ្មចារី ដែលមានរូបឆោមស្រស់ស្អាតមកថ្វាយព្រះករុណា។
[3]សូមព្រះករុណាតែងតាំងឲ្យពួកមន្ត្រី ដែលស្ថិតនៅតាមអាណាខេត្តទាំងអស់ក្នុងរាជាណាចក្រ ដើម្បីប្រមូលស្ត្រីព្រហ្មចារីដែលនៅក្មេង ហើយមានរូបឆោមស្រស់ស្អាត
យកមកដាក់នៅវិមានស្ត្រី ក្នុងរាជធានីស៊ូសាន។ សូមឲ្យលោកហេកាយ ដែលជាមហាតលិករបស់ព្រះករុណា ដែលជាអ្នកថែរក្សាស្ត្រីទាំងនោះ
ព្រមទាំងផ្តល់គ្រឿងសម្អាងកាយដល់ស្ត្រីទាំងនោះផង។[4]ហើយស្ត្រីក្រមុំណាដែលធ្វើឲ្យព្រះករុណាសព្វព្រះហឫទ័យ
នោះសូមតែងតាំងនាងឲ្យធ្វើជាអគ្គមហេសីជំនួសព្រះនាងវ៉ាសធី»។ ព្រះរាជាសព្វព្រះហឫទ័យ ហើយសម្រេចតាមសំណើរនេះ។
[5]នៅរាជធានីស៊ូសាន មានជនជាតិយូដាម្នាក់ឈ្មោះម៉ាដេកាយ ជាកូនរបស់លោកយ៉ាអ៊ៀរ ជាពូជពង្សរបស់លោកស៊ីម៉ាយ និងលោកគីស ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន។
[6]លោកត្រូវបានគេនាំចេញពីក្រុងយេរូសាឡឹម ជាមួយពួកឈ្លើយសឹកឯទៀត ដែលព្រះចៅនេប៊ូក្នេសា ជាស្តេចស្រុកបាប៊ីឡូន បានចាប់យកមកជាមួយព្រះបាទយេកូនាស
ជាស្តេចស្រុកយូដា។
[7]ម៉ាដេកាយ ជាអ្នកចិញ្ចឹមមើលថែនាង ហាដាសា គឺនាងអេសធើ ជាកូនស្រីរបស់ឪពុកមាលោក ដ្បិតនាងគ្មានឪពុកម្តាយទេ។
នាងជាស្ត្រីក្រមុំ ដែលមានរូបឆោមស្រស់ស្អាតហើយគួរឲ្យស្រលាញ់។ លោកម៉ាដាកាយបានយកនាងមកចិញ្ចឹមទុកដូចជាកូនរបស់លោក។
[8]នៅពេលស្តេចចេញរាជបញ្ជា និងរាជក្រឹត្យរួចហើយ គេប្រមូលបានស្ត្រីក្រមុំជាច្រើនមកទុកក្នុងរាជធានីស៊ូសាន។ ហើយទុកឲ្យលោកហេកាយជាអ្នកមើលថែ។
គេក៏បាននាំនាងអេសធើមកក្នុងដំណាក់របស់ស្តេច ហើយឲ្យលោកហេកាយជាអ្នកថែរក្សាពួកស្ត្រី។[9]លោកហេកាយពេញចិត្តនឹងនាង
ហើយក៏មានចិត្តសណ្តោសចំពោះនាង។ ពេលនោះលោកបានប្រគល់គ្រឿងសម្អាងកាយ និងអាហារឲ្យទៅនាង។ ព្រមទាំងយកស្ត្រីក្រមុំប្រាំពីរនាក់មកពីដំណាក់របស់ស្តេច
ដែលជ្រើសរើសពីចំណោមពួកស្ត្រីក្រមុំក្នុងរាជវាំង ឲ្យនៅបម្រើនាង លោកបានប្រគល់បន្ទប់ដែលល្អជាងគេក្នុងវិមានស្ត្រីឲ្យទៅនាងផងដែរ។
[10]នាងអេសធើមិនបានប្រាប់ឲ្យនរណាដឹងអំពីជាតិសាសន៍ និងដើមកំណើតរបស់នាងទេ ដ្បិតម៉ាដេកាយបានហាមនាងមិនឲ្យប្រាប់គេដឹងពីរឿងនេះឡើយ។
[11]ជារៀងរាល់ថ្ងៃ លោកម៉ាដេកាយតែងតែដើរទៅមកនៅមុខទីធ្លារវិមានស្ត្រី ដើម្បីឲ្យដឹងពីសុខទុក្ខរបស់នាងអេសធើ ហើយចង់ដឹងថា គេប្រព្រឹត្តចំពោះនាងយ៉ាងណា។
[12]តាមទំនៀមសម្រាប់ស្ត្រីក្រមុំនៅក្នុងវិមានស្ត្រី ត្រូវរៀបចំខ្លួនអស់ដប់ពីរខែ មុននឹងដល់វេនចូលគាល់ព្រះចៅអហាស៊ូរុស
ពួកនាងត្រូវសម្អាងកាយជាមួយប្រេងល្វីងទេសរយៈពេលប្រាំមួយខែ ហើយប្រាំមួយខែទៀតជាមួយប្រេងក្រអូប និងគ្រឿងសម្អាងកាយផ្សេងៗ
ព្រោះនេះជារយៈពេលដែលស្របតាមពិធីការដែលមានចែងទុក[13]ពេលដែលស្ត្រីក្រមុំត្រូវចូលទៅគាល់ស្តេច បើនាងចង់យកអ្វីជាប់ជាមួយខ្លួនពីវិមានស្ត្រីទៅរាជវាំង
គេប្រគល់ឲ្យទាំងអស់។
[14]នាងទៅគាល់ស្តេចនៅពេលល្ងាច ហើយព្រឹកឡើងនាងវិលទៅវិមានទីពីររបស់ស្ត្រី ដែលស្ថិតនៅក្រោមការថែទាំរបស់លោកសាសកាស ជាមហាតលិករបស់ស្តេច
និងជាអ្នកថែរក្សាក្រុមមហេសី។ នាងលែងបានចូលទៅគាល់ស្តេចទៀតហើយលើកលែងតែស្តេចសព្វព្រហឫទ័យនឹងនាង ហើយហៅចំឈ្មោះរបស់នាង។
[15]លុះដល់វេននាងអេសធើចូលគាល់ស្តេច (ជាកូនរបស់លោកអប៊ីហែល ដែលត្រូវជាឪពុកមារបស់លោកម៉ាដេកាយ ហើយលោកម៉ាដេកាយបានយកនាងមកចិញ្ចឹម)
នាងមិនបានសុំអ្វី ក្រៅពីរបស់ដែលលោកហេកាយជាមហាតលិករបស់ស្តេច ជាអ្នកថែរក្សាពួកស្ត្រីបានប្រគល់ឲ្យនោះឡើយ។ នាងអេសធើជាស្ត្រីម្នាក់
ដែលគេស្រលាញ់រាប់អានគ្រប់ៗគ្នា។[16]គេបាននាំនាងអេសធើយកទៅថ្វាយស្តេចអហាស៊ូរុស នៅក្នុងរាជវាំង នៅខែទីដប់ គឺខែបុស្សក្នុងឆ្នាំទីប្រាំពីរនៃរជ្ជកាលរបស់ស្តេច។
[17]ព្រះរាជាស្រលាញ់នាងអេសធើលើសជាងស្ត្រីឯទៀត ស្តេចគាប់ព្រះហឫទ័យនឹងនាង ហើយនាងទទួលបានការសណ្តោសលើសជាងស្ត្រីក្រមុំឯទៀតទាំងអស់។
ហេតុដូច្នេះបានជាស្តេចបំពាក់មកុដរាជ ហើយតាំងនាងឡើងជាអគមហេសីជំនួសព្រះនាងវ៉ាសធី។[18]ពេលនោះស្តេចបានរៀបចំពិធីជប់លៀងមួយយ៉ាងធំ
សម្រាប់ពួកមេដឹកនាំ និងពួកមន្ត្រី «ក្នុងឱកាសអភិសេកព្រះនាងអេសធើ» ស្តេចក៏ប្រកាសថ្ងៃឈប់សម្រាកនៅតាមអាណាខេត្តទាំងអស់។
ព្រមទាំងចែកអំណោយដោយព្រះហឫទ័យសទ្ធា។
[19]នៅគ្រាដែលគេប្រមូលពួកស្ត្រីក្រមុំមកជួបជុំគ្នាជាលើកទីពីរ លោកម៉ាដេកាយមានមុខងារក្នុងក្រុមអ្នកយាមរាជវាំង។
[20]ឯព្រះនាងអេសធើមិនបានប្រាប់ឲ្យនរណាដឹងពីជាតិសាសន៍ និងដើមកំណើតរបស់ព្រះនាងទេ គឺព្រះនាងធ្វើតាមពាក្យដែលលោកម៉ាដេកាយបង្គាប់។
ព្រះនាងនៅតែធ្វើតាមបង្គាប់លោកម៉ាដេកាយដូចដែលព្រះនាងស្ថិតនៅក្រោមអាណាព្យាបាលរបស់គាត់នៅឡើយ។[21]នៅគ្រានោះ
ដែលលោកម៉ាដេកាយធ្វើការក្នុងក្រុមយាមទ្វាររាជវាំង មានមហាតលិកពីរនាក់ គឺលោកប៊ីកថាន និងលោកថេរែស មានកហឹងជាខ្លាំង
ហើយប៉ុនប៉ងធ្វើគុតព្រះចៅអហាស៊ូរុស។
[22]លោកម៉ាដេកាយបានដឹងគម្រោងការរបស់ពួកគេ ហើយលោកក៏ទូលដំណឹងនេះដល់ព្រះនាងអេសធើ ហើយព្រះនាងអេសធើក៏ទូលដំណឹងនេះទៅដល់ស្តេច
ក្នុងនាមលោកម៉ាដេកាយ។[23]កាលគេបានសើបអង្កេតរឿងនេះ ឃើញថាជាការពិតមែន គេក៏ព្យួរក មហាតលិកទាំងពីរនៅលើបង្គោលមួយ។
ហេតុការណ៍ត្រូវបានគេកត់ទុកនៅក្នុងសៀវភៅរាជាក្យត្រ នៅចំពោះព្រះភ័ក្ត្រស្តេច។

Esther 2:1
ក្រោយហេតុការណ៍ទាំងនោះមក
នេះណែនាំព្រឹត្តិការណ៍ថ្មីមួយដែលបានកើតឡើងនៅពេលក្រោយ។
ព្រះចៅអហាស៊ូរុស ឈប់ព្រះពិរោធ
«ស្តេចខឹងតិចជាងមុន»
ព្រះរាជសារ
នេះសំដៅទៅលើក្រឹត្យក្នុងជំពូក ១:១៩ ។
សូមឲ្យគេទៅរក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រាប់អ្នកបម្រើរបស់ទ្រង់ឲ្យស្វែងរក»
ក្នុងនាមព្រះមហាក្សត្រ
បុរសនោះនិយាយទៅកាន់ស្តេចក្នុងអង្គទីបីជាសញ្ញានៃការគោរព។
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងនាមទ្រង់»
Esther 2:3
ខ្លឹមសារភ្ជាប់
អ្នកបម្រើវ័យក្មេងបន្ត ដើម្បីនិយាយទៅព្រះមហាក្សត្រ។
សូមព្រះករុណា ... មហាតលិករបស់ព្រះករុណា ... ធ្វើឲ្យព្រះករុណាសព្វព្រះហឫទ័យ
អ្នកបម្រើបានទូលទៅកាន់ស្តេចនៅក្នុងមនុស្សទីបីជាសញ្ញានៃការគោរព។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចគួរតែ ... មហាតលិករបស់ព្រះករុណា ...
ព្រះករុណាសព្វព្រះហឫទ័យ»

generated on Wed Sep 10 16:16:32 2025

អាណាខេត្ត
បកប្រែដូចនៅក្នុងជំពូក ១:១។
ដាក់នៅវិមាន
«ជាកន្លែងដែលអ្នកគ្រប់គ្រងត្រូវបានរក្សាទុកប្រពន្ធ» (UDB)
វិមាន
បកប្រែដូចនៅក្នុងជំពូក ១:៥ ។
រាជធានីស៊ូសាន
បកប្រែនេះដូចជានៅក្នុងជំពូក ១:១។
សូមឲ្យលោកហេកាយ ដែលជាមហាតលិករបស់ព្រះករុណា ដែលជាអ្នកថែរក្សាស្ត្រីទាំងនោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សូមឲ្យលោកហេកាយជាមហាតលិករបស់ព្រះករុណាដែលជាអ្នកថែរក្សាស្ត្រីទាំងនោះ»
លោកហេកាយ
នេះជាឈ្មោះបុរសនោះ។
គ្រឿងសម្អាងកាយដល់ស្ត្រីទាំងនោះ
«គ្រឿងសម្អាង» គឺជាសារធាតុដូចជាក្រែមលាប ឡេ ឬ
ម្សៅដែលស្ត្រីតែងតែលាបលើមុខ ឬដងខ្លួនដើម្បីកែលម្អសម្រស់។
Esther 2:5
មានជនជាតិយូដាម្នាក់
នេះណែនាំលោកម៉ាដេកាយជាតួអង្គថ្មីនៅក្នុងរឿង។
រាជធានីស៊ូសាន
បកប្រែឈ្មោះទីក្រុងនេះដូចក្នុងជំពូកទី ១:១។
កូនរបស់លោកយ៉ាអៀរ ជាពូជពង្សរបស់លោកស៊ីម៉ាយ និងលោកគីស
«លោកយ៉ាអៀរ» «លោកស៊ីម៉ាយ» និង «លោកគីស» ជាបុរសដែល
«លោកម៉ាដេកាយ» ជាកូនចៅក្នុងកុលសម្ព័ន្ធ។
កុលសម្ពន្ធបេនយ៉ាមីន
«នៃកុលសម្ពន្ធបេនយ៉ាមីន» (UDB)
លោកត្រូវបានគេនាំចេញ ... ស្តេចស្រុកបាប៊ីឡូន បានចាប់យក
ព័ត៌មានផ្ទៃខាងក្រោយនេះ
ពន្យល់ពីរបៀបដែលលោកម៉ាដេកាយបានមករស់នៅរាជធានីស៊ូសាន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះចៅនេប៊ូក្នេសា ស្តេចស្រុកបាប៊ីឡូនបាននាំលោក
និងជននិរទេសម្នាក់ទៀតទៅជាមួយនឹងព្រះបាទយេកូនាស ជាស្តេចស្រុកយូដា»
លោកត្រូវបានគេនាំចេញពីក្រុងយេរូសាឡិម
អត្ថបទភាសាហេប្រឺមិនច្បាស់ថាអ្នកណាត្រូវគេនិយាយនៅទីនេះទេ។
ប្រហែលជាលោកគីសដែលហាក់ដូចជាជីតារបស់លោកម៉ាដេកាយ។
ប្រសិនបើជាលោកម៉ាដេកាយខ្លួនលោក
នោះលោកនឹងចាស់ណាស់នៅពេលព្រឹត្តិការណ៍ទាក់ទងនឹងព្រះនាងអេសធើរ។
ជំនាន់ទំនើបជាច្រើនទុកឲ្យរឿងនេះមិនច្បាស់លាស់។ កំណែពីរបីរួមទាំង យូឌីប៊ី
ជ្រើសរើសដើម្បីសន្មត់ថានេះគឺជាលោកម៉ាដេកាយដែលត្រូវបានគេនាំយកទៅឆ្ងាយពី
ព្រះបាទយេកូនាស ជាស្តេចស្រុកយូដា
Esther 2:7
ខ្លឹមសារភ្ជាប់:
នេះបន្តព័ត៌មានសង្ខេបអំពីលោកម៉ាដេកាយ
ហើយពន្យល់ពីទំនាក់ទំនងរបស់លោកជាមួយនាងអេសធើរ។
នាងហាដាសា
នេះគឺជាឈ្មោះហេប្រឺរបស់នាងអេសធើរ។
ជាកូនស្រីរបស់ឪពុកមាលោក
«បងប្អូនជីដូនមួយរបស់លោក» (UDB)
នាងគ្មានឪពុកម្តាយទេ
«ឪពុកម្តាយរបស់នាងបានស្លាប់»
បានយកនាងមកចិញ្ចឹមទុកដូចជាកូនរបស់លោក
«ថែរក្សានាងដូចជានាងជាកូនស្រីរបស់លោក»
Esther 2:8
នៅពេលស្តេចចេញរាជបញ្ជា និងរាជក្រឹត្យរួចហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បន្ទាប់ពីព្រះរាជាបញ្ជាឲ្យពួកគេស្វែងរកស្ត្រីក្រមុំស្រស់ស្អាតជាច្រើន»
ចេញរាជបញ្ជា
«បានប្រកាស»
គេប្រមូលបានស្ត្រីក្រមុំជាច្រើនមក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបាននាំស្ត្រីក្រមុំជាច្រើនមក»
ដំណាក់
ដូចបកប្រែនៅក្នុងជំពូក ១:៥។
ហើយទុកឲ្យលោកហេកាយជាអ្នកមើលថែ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«លោកហេកាយចាប់ផ្តើមថែរក្សាពួកគេ»
នាងអេសធើរមកក្នុងដំណាក់របស់ស្តេច ហើយឲ្យលោកហេកាយជាអ្នកថែរក្សាពួកស្ត្រី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«លោកហេកាយដែលជាអ្នកមើលការខុសត្រូវស្ត្រីក៏ចាប់ផ្តើមថែរក្សានាងអេសធើរដែរ
នៅពេលពួកគេនាំនាងចូលក្នុងដំណាក់របស់ស្តេច»
លោកហេកាយពេញចិត្តនឹងនាង ហើយក៏មានចិត្តសណ្តោសចំពោះនាង
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ថា នាងពេញចិត្តលោកខ្លាំងប៉ុណ្ណា។
ការបកប្រែរបៀបផ្សេងទៀត: «ស្ត្រីក្រមុំពេញចូរចិត្តលោកណាស់ដែរ»
ស្ត្រីក្រមុំ
«នាងអេសធើរ»
Esther 2:10
ពីសុខទុក្ខរបស់នាងអេសធើរ
«ពីសុខទុក្ខរបស់នាងអេសធើរកំពុងធ្វើអ្វី» ឬ
«អំពីសុខុមាលភាពរបស់នាងអេសធើរ»
Esther 2:12
ព័ត៌មានទូទៅ:
ខគម្ពីរ ១២ ដល់១៤
គឺជាព័ត៌មានប្រវត្តិអំពីទំនៀមទម្លាប់របស់ស្ត្រីដែលបានក្លាយជាមហេសីរបស់ស្តេច។
តាមទំនៀមសម្រាប់ស្ត្រីក្រមុំ
«ធ្វើសកម្មភាពស្របតាមតម្រូវការរបស់ស្ត្រី»
នាងត្រូវសម្អាងកាយ
អ្វីដែលបានធ្វើដើម្បីឲ្យស្ត្រីក្រមុំកាន់តែស្រស់ស្អាត និងមានក្លិនក្រអូបល្អ។
គ្រឿងសម្អាងកាយ
ប្រើពាក្យ ឬឃ្លាដែលប្រើក្នុងជំពូកទី ២:៣។
បើនាងចង់យកអ្វីជាប់ជាមួយខ្លួន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នាងអាចយកអ្វីដែលនាងចង់បាន»
រាជវាំង
នេះបកប្រែដូចជានៅក្នុងជំពូក ១:៥។
Esther 2:14
ខ្លឹមសារភ្ជាប់:
នេះបន្តនូវព័ត៌មានផ្ទៃខាងក្រោយដែលបានចាប់ផ្តើមនៅក្នុងជំពូក ២:១២
ព័ត៌មានផ្ទៃខាងក្រោយនេះ
ពន្យល់ពីរបៀបដែលលោកម៉ាដេកាយបានមករស់នៅរាជធានីស៊ូសាន។
ព្រឹកឡើង
នេះបញ្ជាក់ថាគឺជាព្រឹកបន្ទាប់។ ព័ត៌មាននេះអាចបញ្ជាក់ច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «នៅព្រឹកបន្ទាប់»
វិមានទីពីរ
«វិមានផ្សេងទៀត»
នៅក្រោមការថែទាំ
«ការត្រួតពិនិត្យ» ឬ «ការការពារ» (UDB)
លោកសាសកាស
នេះគឺជាឈ្មោះបុរសម្នាក់។
Esther 2:15
លុះដល់វេនចូលគាល់
នេះជាសេចក្តីណែនាំផ្នែកថ្មីនៃរឿង។
ជាកូនរបស់លោកអប៊ីហែល ដែលត្រូវជាឪពុកមារបស់លោកម៉ាដេកាយ
ហើយលោកម៉ាដេកាយបានយកនាងមកចិញ្ចឹម
ព័ត៌មានខាងក្រោយនេះរំលឹកដល់អ្នកអានអំពីទំនាក់ទំនងរបស់នាងអេសធើរជាមួយលោកម៉ាដេកាយ។
លោកអប៊ីហែល
«លោកអប៊ីហែល» គឺជាឪពុករបស់នាងអេសធើរ
និងជាឪពុកមារបស់លោកម៉ាដេកាយ។
នាងមិនបានសុំអ្វី ក្រៅពី
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ «នាងបានសួរសម្រាប់តែអ្វីដែល»

generated on Wed Sep 10 16:16:32 2025

លោកហេកាយ
បុរសនេះបកប្រែឈ្មោះដូចក្នុងជំពូកទី ២:៣។
នាងបានទទួលការស្រឡាញ់រាប់អានពីមនុស្សគ្រប់ៗគ្នា
នេះគឺជាប្រយោគមួយ។ ការបកប្រែរបៀបផ្សេងទៀត: «រីករាយទាំងអស់»
នៅខែទីដប់ គឺខែបុស្ស
«ខែបុស្ស» គឺជាឈ្មោះខែទីដប់នៃប្រតិទិនហេប្រឺ។
នេះជាក្នុងអំឡុងពេលផ្នែកមួយកាលពីខែធ្នូ
និងជាផ្នែកដំបូងខែមករានៅលើប្រតិទិនលោកខាងលិច។
ឆ្នាំទីប្រាំពីរ
«ឆ្នាំទី៧»
Esther 2:17
ព្រះរាជាស្រឡាញ់
នេះគឺជាពាក្យមនោសញ្ចេតនានៃពាក្យថា «ស្នេហា»។
ស្តេចគាប់ព្រះហឫទ័យនឹងនាង ហើយនាងទទួលបានការសណ្តោស
សញ្ញាសំគាល់ទាំងនេះមានន័យដូចគ្នាហើយបញ្ជាក់ថា
តើនាងអេសធើរពេញចិត្តនឹងស្តេចប៉ុន្មាន។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចគាប់ព្រះហឫទ័យណាស់»
បំពាក់មកុដរាជ ហើយតាំងនាង
ព្រះរាជាបានធ្វើដូច្នេះដើម្បីបង្ហាញថា
ព្រះអង្គបានតែតាំងនាងជាមហេសីរបស់ទ្រង់។
ក្នុងឱកាសអភិសេកព្រះនាងអេសធើរ
នេះអាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា នេះជាឈ្មោះបុណ្យ។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចបានហៅថាជាបុណ្យរបស់នាងអេសធើរ» ។
ឈប់សម្រាក
«ការប្រមូលពន្ធ»
អាណាខេត្ត
នេះបកប្រែដូចនៅក្នុងជំពូកទី ១:១។
ព្រះហឫទ័យសទ្ធា
«សប្បុរសធម៌ដែលមានតែស្តេចមួយអង្គគត់ដែលអាចផ្តល់ឲ្យ» (UDB)
Esther 2:19
នៅគ្រាដែលគេប្រមូលពួកស្ត្រីក្រមុំមកជួបជុំគ្នាជាលើកទីពីរ
គេមិនទាន់ច្បាស់ទេថា តើការជួបជុំលើកទី ពីរ នេះបានកើតឡើងនៅពេលណា
ហើយហេតុអ្វី។ ដូច្នេះកំណែខ្លះបានផ្លាស់ប្តូរអត្ថបទបន្តិច។
នេះជាការល្អបំផុតដើម្បីបកប្រែដូចដែលត្រូវបានសរសេរ។
លើកទីពីរ
«មួយដងទៀត» ឬ «ពេលវេលាបន្ថែម»
លោកម៉ាដេកាយមានមុខងារក្នុងក្រុមអ្នកយាមរាជវាំង
អាចមានន័យថា ១) លោកម៉ាដេកាយបានអង្គុយនៅទីនោះ
ដូច្នេះលោកអាចស្តាប់ពីរបៀបដែលនាងអេសធើរធ្វើពីមនុស្សជាច្រើនដែលបានឆ្លងកាត់ខ្លោងទ្វារឬទី
២) «អង្គុយនៅមាត់ទ្វារស្តេច» គឺជាឥរិយាបទដែលមានន័យថា
លោកម៉ាដេកាយត្រូវបានផ្តល់ឋានៈដោយស្តេច។
អ្នកយាមរាជវាំង
«ច្រកទ្វារទៅកាន់ស្តេចជាព្រះបរមរាជវាំង»
ព្រះនាងធ្វើតាមពាក្យដែលលោកម៉ាដេកាយបង្គាប់
លោកម៉ាដេកាយបានប្រាប់នាងកុំឲ្យប្រាប់អ្នកណាអំពីក្រុមគ្រួសារនាង។
នៅគ្រានោះ
នេះសេចក្តីណែនាំព្រឹត្តិការណ៍ថ្មីនៅក្នុងរឿង។
លោកប៊ីកថាន និងលោកថេរែស
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Esther 2:22
លោកម៉ាដេកាយបានដឹងគម្រោងការរបស់ពួកគេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលលោកម៉ាដេកាយដឹងអំពីអ្វីដែលពួកគេកំពុងរៀបចំផែនការ»
ក្នុងនាមលោកម៉ាដេកាយ
នេះគឺជាការបង្ហាញមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ក្នុងនាមលោកម៉ាដេកាយ»
កាលគេបានសើបអង្កេតរឿងនេះ ឃើញថាជាការពិតមែន គេក៏ព្យួរក មហាតលិកទាំងពីរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះមហាក្សត្របានស៊ើបអង្កេត និងបញ្ជាក់របាយការណ៍
ហើយបានបញ្ជាឲ្យអ្នកបម្រើរបស់ទ្រង់ព្យួរកបុរសទាំងពីរនាក់នោះ»
លើបង្គោលមួយ
នេះគឺជារចនាសម្ពន្ធដែលត្រូវបានប្រើសម្រាប់សំលាប់មនុស្សដោយចងចុងម្ខាងនៃខ្សែពួរជុំវិញកំពូលនៃរច
និងចុងម្ខាងទៀតនៃខ្សែពួរជុំវិញករបស់ពួកគេ ហើយព្យួរពួកគេពីនោះ។
ការបកប្រែរបៀបផ្សេងទៀត: «ស៊ុមសម្រាប់ព្យួរមនុស្ស»
ហេតុការណ៍ត្រូវបានគេកត់ទុក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានកត់ត្រាហេតុការណ៍នេះ»

---

3 [1]ក្រោយហេតុការណ៍នោះមក ព្រះបាទអហាស៊ូរុស បានតែងតាំងលោកហាម៉ាន ជាកូនរបស់លោកហាំម្តាថា ដែលជាពូជពង្សរបស់ស្តេចអកាក់
ហើយតាំងឲ្យលោកធ្វើជាមហាមន្ត្រី និងជាប្រមុខលើមេដឹកនាំទាំងអស់។[2]ព្រះរាជាបានចេញបញ្ជាឲ្យពួករាជបម្រើរបស់ស្តេចទាំងប៉ុន្មាន
ដែលប្រចាំការនៅមាត់ទ្វារជវាំង ឱនគោរព និងថ្វាយបង្គំលោកហាម៉ាន។ តែលោកម៉ាដេកាយមិនឱនគោរព ឬថ្វាយបង្គំលោកហាម៉ានទេ។
[3]ដូច្នេះ ពួករាជបម្រើរបស់ស្តេចដែលប្រចាំការនៅមាត់ទ្វា ក៏ពោលថាកាន់លោកម៉ាដេកាយថា
«ហេតុអ្វីបានជាអ្នកមិនធ្វើតាមរាជបញ្ជារបស់ស្តេចដូច្នេះ?»[4]ពួកគេតែងតែសួរទៅគាត់បែបនេះជារៀងរាល់ថ្ងៃ ប៉ុន្តែគាត់មិនស្តាប់ពួកគេឡើង។ ដូច្នេះ
ពួកគេក៏ប្រាប់ទៅលោកហាម៉ាន ព្រោះចង់ដឹងថា តើលោកម៉ាដេកាយនៅតែប្រកាន់ជំហរបែបនេះ ឬយ៉ាងណា ដ្បិតគាត់បានប្រាប់គេថាគាត់ជាជនជាតិយូដា។
[5]កាលលោកហាម៉ានឃើញថា លោកម៉ាដេកាយមិនព្រមឱនគោរព ឬថ្វាយបង្គំដល់ខ្លួន នោះលោកមានចិត្ត ក្រេវក្រាធជាខ្លាំង។[6]មានគេជម្រាបលោកហាម៉ានថា
លោកម៉ាដេកាយជាជនជាតិយូដា ហេតុនេះលោកហាម៉ានក៏យល់ថា នេះជាមូលហេតុមួយ ដែលត្រូវកម្ចាត់លោកម៉ាដេកាយចោល។
លោកក៏រកឱកាសនឹងបំផ្លាញជនជាតិយូដាទាំងអស់ ជាជនរួមជាតិរបស់លោកម៉ាដេកាយ ឲ្យវិនាសសូន្យពីរាជាណាចក្ររបស់ព្រះចៅអហាស៊ូរុស។
[7]នៅខែទីមួយ គឺនៅខែចេត្រ ក្នុងឆ្នាំទីដប់ពីរនៃរជ្ជកាលព្រះចៅអហាស៊ូរុស គេវាយលេខតាមរបៀន នៅចំពោះមុខលោកហាម៉ាន ដើម្បីដេញរកថ្ងៃខែដែលល្អ។
ហើយក៏ត្រូវចំលើខែទីដប់ពីរ(ដែលត្រូវជាខែផល្គុន)។
[8]ពេលនោះលោកហាម៉ាទូលទៅព្រះចៅអហាស៊ូរុសថា «មានជាតិសាសន៍មួយដែលខ្ចាតខ្ចាយនៅចំណោមជាតិសាសន៍
និងអាណាខេត្តទាំងប៉ុន្មាននៃព្រះរាជាណាចក្ររបស់ព្រះករុណា។ ពួកគេមានទម្លៀមទម្លាប់ផ្សេងពីជាតិសាសន៍ដ៏ទៃ ហើយមិនគោរពតាមច្បាប់របស់ព្រះករុណាទេ ដូច្នេះ
ព្រះករុណាមិនគួរទុកឲ្យពួកគេរស់នៅទៀតឡើយ។[9]ប្រសិនបើព្រះករុណាសព្វព្រះហឫទ័យ សូមចេញបញ្ជាឲ្យសម្លាប់ពួកគេទៅ
ហើយទូលបង្គំនឹងថ្លឹងប្រាក់មួយម៉ឺនហាបទៅដាក់ក្នុងឃ្លាំងរាជទ្រព្យ សម្រាប់ពួកអ្នកដែលចាត់ចែងការនោះ»។
[10]ដូច្នេះ ព្រះរាជាក៏ដោះព្រះទម្រង់ពីព្រះហស្ត ហើយប្រគល់ទៅឲ្យលោកហាម៉ា ជាកូនរបស់លោកហាំម្តាថា និងជាពូជពង្សរបស់ស្តេចអកាក់
ដែលជាខ្មាំងសត្រូវរបស់ជនជាតិយូដា។[11]ស្តេចមានរាជឱង្ការទៅកាន់លោកហាម៉ានថា «យើងនឹងប្រគល់ប្រាក់ និងជាតិសាសន៍នោះឲ្យទៅលោកវិញ ។
ចូរលោកប្រព្រឹត្តចំពោះពួកគេតាមតែលោកយល់ឃើញចុះ»។
[12]នៅថ្ងៃទីដប់បី ក្នុងខែទីមួយ គេបានហៅពួកស្មៀនហ្លួងមកឲ្យសរសេរបញ្ជាទាំងប៉ុន្មាន របស់លោកហាម៉ាន ដើម្បីផ្ញើជូនពួកមេបញ្ជាការកងទ័ពរបស់ស្តេច
ពួកទេសាភិបាលអាណាខេត្ត និងពួកមេដឹងរបស់ជាតិសាសន៍នានា គឺដល់គ្រប់ខេត្តតាមអក្សរជាតិរបស់គេ ហើយដល់គ្រប់សាសន៍
និងតាមភាសារបស់ជាតិសាសន៍នីមួយៗ។ ច្បាប់នោះបានកត់ទុកដោយ នាមព្រះចៅអហាស៊ូរុស ព្រមទាំងមានប្រថាប់ត្រាព្រះរាជាទៀតផង។
[13]គេចាត់អ្នកនាំសារឲ្យយកលិខិតទាំងនោះ ទៅគ្រប់អាណាខេត្តរបស់ព្រះរាជា បញ្ជាឲ្យបំផ្លាញ សម្លាប់ ពូជសាសន៍យូដាទាំងអស់ឲ្យវិនាសសាបសូន្យ ទាំងក្មេង
ទាំងមនុស្សចាស់ជរា ទាំងស្ត្រី ទាំងទារក ក្នុងរយៈពេលតែមួយថ្ងៃ គឺនៅថ្ងៃទីដប់បី ក្នុងខែទីដប់ពីរ (ដែលត្រូវនឹងថ្ងៃផល្គុន)
ព្រមទាំងរឹបអូសយកទ្រព្យសម្បត្តិរបស់ពួកគេទៀតផង។

generated on Wed Sep 10 16:16:32 2025

[14]អាណាខេត្តនីមួយៗទទួលបានរាជក្រឹត្យមួយច្បាប់។ សម្រាប់ប្រកាសដល់អស់ជាតិសាសន៍ ដើម្បីឲ្យពួកគេបានត្រៀមខ្លួនជាស្រេចនៅថ្ងៃនោះ។
[15]ពួកអ្នកនាំសារក៏ចេញទៅយ៉ាងប្រញាប់ប្រញាល់ តាមបញ្ជារបស់ស្តេច។ ហើយគេបានប្រកាសរាជក្រឹតនោះនៅក្រុងស៊ូសាន ជារាជធានី។
ពេលនោះព្រះរាជាគង់សោយស្រាជាមួយលោកហាម៉ាន តែនៅឯទីក្រុងស៊ូសានមានសម្រែកយំសោកពាសពេញជាខ្លាំង។

Esther 3:1
ក្រោយហេតុការណ៍នោះមក
នេះជាសេចក្តីណែនាំព្រឹត្តិការណ៍ថ្មីនៅក្នុងរឿង។
លោកហាម៉ាន ជាកូនរបស់លោកហាំម្តាថា ដែលជាពូជពង្សរបស់ស្តេចអកាក់
នេះជាឈ្មោះ និងការពិពណ៌នារបស់លោកហាម៉ានជាមន្ត្រីម្នាក់របស់ព្រះរាជា។
ហើយតាំងឲ្យលោកធ្វើជាមហាមន្ត្រី និងជាប្រមុខលើមេដឹកនាំទាំងអស់
នៅទីនេះ «តែតាំងសិទ្ធិអំណាច» តំណាងឲ្យឋានៈរបស់លោកនៅក្នុងរដ្ឋាភិបាល។
ការបកប្រែរបៀបផ្សេងទៀត: «តំឡើងឋានៈលោកខ្ពស់ជាងមន្ត្រីដទៃទៀត» ឬ
«បានផ្តល់សិទ្ធិអំណាចដល់លោកជាងមន្ត្រីដទៃទៀត»
ឱនគោរព...ថ្វាយបង្គំ
សកម្មភាពទាំងនេះតំណាងឲ្យការចុះចូលចំពោះសិទ្ធិអំណាចរបស់លោកហាម៉ាន។
ឱនគោរព និងថ្វាយបង្គំលោកហាម៉ាន
«បន្ទាបខ្លួន ហើយក្រាបថ្វាយបង្គំខ្លួនទៅនឹងដីនៅមុនលោកហាម៉ាន»
Esther 3:3
ព្រោះចង់ដឹងថា តើលោកម៉ាដេកាយនៅតែប្រកាន់ជំហរបែបនេះ ឬយ៉ាងណា
«ដើម្បីរកឲ្យឃើញនូវអ្វីដែលលោកហាម៉ាននឹងធ្វើអំពីសកម្មភាពរបស់លោកម៉ាដេកាយ»
Esther 3:5
មិនព្រមឱនគោរព ឬថ្វាយបង្គំដល់ខ្លួន
លោកម៉ាដេកាយបានបង្ហាញការគោរពចំពោះឋានៈរបស់លោកហាម៉ាននៅក្នុងរដ្ឋាភិបាល
លោកមានចិត្ត ក្រេវក្រាធជាខ្លាំង
នៅទីនេះកំហឹងរបស់លោកហាម៉ានត្រូវបានគេនិយាយថាជាអ្វីមួយដែលអាចបំពេញលោក
ការបកប្រែរបៀបផ្សេងទៀត: «ហាម៉ានខឹងខ្លាំងណាស់»
ហេតុនេះលោកហាម៉ានក៏យល់ថា នេះជាមូលហេតុមួយ ដែលត្រូវកម្ចាត់លោកម៉ាដេកាយចោល
«លោកបានបដិសេធគំនិតនៃការសម្លាប់គ្រាន់តែលោកម៉ាដេកាយប៉ុណ្ណោះ»។
នេះក៏អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមានផងដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«លោកចង់សម្លាប់មនុស្សច្រើនជៀសជាងលោកម៉ាដេកាយទៅទៀត»
នឹងបំផ្លាញជនជាតិយូដាទាំងអស់
«កម្ចាត់ជនជាតិយូដាទាំងអស់» ឬ «សម្លាប់ជនជាតិយូដាទាំងអស់»
Esther 3:7
នៅខែទីមួយ
«ក្នុងខែទីមួយ»
គឺនៅខែចេត្រ
« ខែចេត្រ» គឺជាឈ្មោះខែដំបូងនៃប្រតិទិនហេប្រឺ។
នេះគឺជាកំឡុងពេលចុងក្រោយនៃខែមីនា
និងផ្នែកដំបូងនៃខែមេសាតាមប្រតិទិនលោកខាងលិច។
ក្នុងឆ្នាំទីដប់ពីរនៃរជ្ជកាលព្រះចៅអហាស៊ូរុស
«នៅឆ្នាំទី ១២ នៃស្តេចអហាស៊ូរុស» ឬ
«នៅពេលដែលស្តេចអហាស៊ូរុសសោយរាជ្យប្រហែលដប់ពីរឆ្នាំ»
គេវាយលេខតាមរបៀន នៅចំពោះមុខ
«ពួកគេបោះបង់ចោលអ្វីដែលសំខាន់បំផុត» (សូមមើល:translate-names)
ខែទីដប់ពីរ
«ខែដប់ពីរ»
ខែផល្គុន
«ផល្គុន» គឺជាឈ្មោះខែទី១២ និងខែចុងក្រោយនៃប្រតិទិនហេប្រឺ។
នេះគឺជាកំឡុងពេលចុងក្រោយនៃខែកុម្ភៈ
និងដើមខែមីនានៅលើប្រតិទិនលោកខាងលិច។
Esther 3:8
មានជាតិសាសន៍មួយ
«មនុស្សមួយក្រុម»។ នេះសំដៅទៅលើជនជាតិយូដាជាក្រុមជនជាតិភាគតិច។
ខ្ចាត់ខ្ចាយ និងចែកចាយ
«អ្នកដែលរស់នៅកន្លែងផ្សេងៗគ្នាជាច្រើន»
ខេត្តនានា
សូមបកប្រែដូចជានៅក្នុងជំពូកទី ១:១។
ព្រះករុណាមិនគួរទុកឲ្យពួកគេរស់នៅទៀតឡើយ
«ស្តេចមិនអនុញ្ញាតឲ្យពួកគេនៅសេសសល់ទេ» ។
នេះក៏អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមានផងដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចគួរតែដកពួកគេចេញ»
ស្តេច...ព្រះករុណា
លោកហាម៉ានទូលទៅកាន់ស្តេចនៅក្នុងមនុស្សទីបីជាសញ្ញានៃការគោរព។
ការបកប្រែរបៀបផ្សេងទៀត: «របស់ទ្រង់ ... ទ្រង់»
ទូលបង្គំនឹងថ្លឹង...ដាក់ក្នុងឃ្លាំងរាជទ្រព្យ
នៅទីនេះ «ដៃ» តំណាងឲ្យបុរស។ ដើម្បី «ថ្លឹងទម្ងន់»
គឺជាប្រយោគដែលមានន័យថា ត្រូវបង់ប្រាក់ឲ្យពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំនឹងបង់ប្រាក់ ... ទៅបុរស»
ប្រាក់មួយម៉ឺនហាប
«ប្រាក់ ៣៤០ តោន»
Esther 3:10
ព្រះទម្រង់
ចិញ្ចៀនពិសេសមួយដែលអាចប្រើ
ដើម្បីបោះត្រាត្រាផ្លូវការរបស់ព្រះរាជាលើការប្រកាស។
យើងនឹងប្រគល់ប្រាក់ និងជាតិសាសន៍នោះឲ្យទៅលោកវិញ
យកប្រាក់ដែលយើងបានសន្យាថានឹងបង់ឲ្យ
«យើងនឹងប្រគល់ប្រាក់ជូនលោកវិញ» ឬ ២)
យកលុយហើយប្រគល់ឲ្យបុរសដូចអ្វីដែលស្តេចបានមានបន្ទូល»។
Esther 3:12
គេបានហៅពួកស្មៀនហ្លួងមកឲ្យសរសេរបញ្ជាទាំងប៉ុន្មាន របស់លោកហាម៉ាន
ដើម្បីផ្ញើជូនពួកមេបញ្ជាការកងទ័ពរបស់ស្តេច
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះរាជាកោះហៅពួកអាចារ្យរបស់ពួកគេ...
ពួកគេបានសរសេរក្រឹត្យមួយដែលមានផ្ទុកនូវអ្វីទាំងអស់ដែលលោកហាម៉ានបានបញ្ជា»
នៅថ្ងៃទីដប់បី ក្នុងខែទីមួយ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ថ្ងៃទី១៣
គឺជិតដល់ដើមខែមេសាលើប្រតិទិនលោកខាងលិច។
ពួកទេសាភិបាលអាណាខេត្ត
«អភិបាលខេត្ត»។ បកប្រែ «ខេត្ត» ដូចជានៅក្នុងជំពូក ១:១។
ច្បាប់នោះបានកត់ទុកដោយ នាមព្រះចៅអហាស៊ូរុស ព្រមទាំងមានប្រថាប់ត្រាព្រះរាជាទៀតផង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានសរសេរក្រឹត្យវិន័យនេះក្នុងនាមព្រះបាទអហាស៊ូរុស
និងលោកហាម៉ានព្រមទាំងមានប្រថាប់ត្រាព្រះរាជាទៀតផង»
ក្នុងនាម
នៅទីនេះ «នាម» តំណាងឲ្យសិទ្ធិអំណាចរបស់ស្តេច។ ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងសិទ្ធិអំណាចរបស់»
អ្នកនាំសារ
ប្រគល់ជូនប្រយោគនេះមានន័យថា ពួកគេបានប្រគល់សំបុត្រដោយផ្ទាល់។
ការបកប្រែរបៀបផ្សេងទៀត: «ប្រគល់ជូនផ្ទាល់»
បញ្ជាឲ្យបំផ្លាញ សម្លាប់
ពាក្យទាំងនេះមានន័យដូចគ្នា ហើយបញ្ជាក់ពីភាពពេញលេញនៃការបំផ្លាញ។
ការបកប្រែរបៀបផ្សេងទៀត: «បំផ្លាញទាំងស្រុង»
នៅថ្ងៃទីដប់បី ក្នុងខែទីដប់ពីរ
«ថ្ងៃទី១៣ នៃខែ ១២។»
ដែលត្រូវនឹងថ្ងៃផល្គុន
«ផល្គុន» គឺជាឈ្មោះនៃទីដប់ពីរ និងខែចុងក្រោយនៃប្រតិទិនជាតិហេប្រឺ។
នៅថ្ងៃទីដប់បី គឺនៅជិតដើមដំបូងនៃខែមីនានៅលើប្រតិទិនលោកខាងលិច។
រឹបអូស
«យកទៅ»
Esther 3:14
អាណាខេត្តនីមួយៗទទួលបានរាជក្រឹត្យមួយច្បាប់

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មន្ត្រីនៅគ្រប់ខេត្តធ្វើច្បាប់ចម្លងលិខិតនោះក្លាយជាច្បាប់»
អាណាខេត្ត
នេះបកប្រែដូចជានៅក្នុងជំពូក ១:១។
សម្រាប់ប្រកាសដល់អស់ជាតិសាសន៍ ដើម្បីឲ្យពួកគេបានត្រៀមខ្លួនជាស្រេច
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានប្រាប់ប្រជាជនទាំងអស់នៅគ្រប់ខេត្ត»
នៅថ្ងៃនោះ
«ថ្ងៃនោះ»
គេបានប្រកាសរាជក្រឹតនោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេក៏បានប្រកាសរាជក្រឹតផងដែរ»
ក្រុងស៊ូសាន
មានសម្រែកយំសោកពាសពេញជាខ្លាំង
«គឺនៅក្នុងស្ថានភាពនៃការយល់ច្រឡំមួយយ៉ាងធំមួយ»

---

4 [1]កាលម៉ាដេកាយបានដឹងហេតុការណ៍ទាំងប៉ុន្មានកើងឡើង លោកហែកសម្លៀកបំពាក់របស់ខ្លួន ហើយស្លៀកបាវ និងរោយផេះលើក្បាល។
រួចលោកចេញទៅកណ្ដាលទីក្រុង ទាំងស្រែកយំយ៉ាងជូរចត់។[2]លោកទៅឈរទល់មុខនឹងមាត់ទ្វារាជវាំង ដ្បិតលោកមិនអាចចូលទៅក្នុងបាន
ដោយស្លៀកបាវបែបនេះបានឡើយ។[3]នៅគ្រប់អាណាខេត្តនីមួយៗ ពេលគេបានទទួលរាជក្រឹត្យ ហើយរាជបញ្ជារបស់ស្តេចហើយ
នោះជនជាតិយូដានាំគ្នាកាន់ទុក្ខយ៉ាងខ្លាំង ពួកគេតមអាហារ យំសោកសង្រេក ហើយទួញសោក។ ហើយមានគ្នាជាច្រើននាំគ្នាស្លៀកបាវ ហើយដេកនៅក្នុងផ្ទះ។
[4]កាលពួកស្ត្រីបម្រើ និងពួកមហាតលិករបស់ព្រះនាងអេសធើ បាននាំដំណឹងនេះ មកទូលថ្វាយព្រះនាង នោះព្រះនាងរន្ធត់ព្រះហឫទ័យជាខ្លាំង។
ព្រះនាងក៏ឲ្យគេយកសម្លៀកបំពាក់ទៅជូនលោកម៉ាដេកាយ ដើម្បីជំនួសបាវដែលលោកស្លៀកជាប់នឹងខ្លួន តែលោកម៉ាដេកាយមិនព្រមទទួលទេ។
[5]ពេលនោះព្រះនាងបានហៅលោកហាថាក់ ជាមហាតលិក ដែលព្រះរាជាឲ្យមកបម្រើព្រះនាង។ ព្រះនាងបានបញ្ជាឲ្យគាត់ទៅសួរលោកម៉ាដេកាយ
ដើម្បីសួរឲ្យដឹងពីមូលហេតុដែលឲ្យលោកធ្វើបែបនេះ។
[6]ដូច្នេះ លោកហាថាក់បានទៅជួបលោកម៉ាដេកាយនៅទីលានក្រុង គឺនៅទីធ្លាក្រុងខាងមុខទ្វារាជវាំង។
[7]លោកម៉ាដេកាយរៀបរាប់ប្រាប់គាត់ពីហេតុការណ៍ទាំងអស់ដែលកើតមានឡើង និងពីចំនួនប្រាក់ដែលលោកហាម៉ានបានសន្យាបញ្ជូនទៅក្នុងឃ្លាំងរាជទ្រព្យ
ប្រសិនបើស្តេចចេញបញ្ជាឲ្យគេទៅសម្លាប់ជនជាតិយូដា។[8]លោកក៏បានប្រគល់រាជក្រឹត្យមួយច្បាប់ ជាសេចក្ដីដែលបានប្រកាសប្រាប់នៅទីក្រុងស៊ូសាន
អំពីការបំផ្លាញជនជាតិយូដា។ ដើម្បីឲ្យគាត់យកទៅថ្វាយព្រះនាងអេសធើ ព្រមទាំងរៀបរាប់ហេតុការណ៍ទូលថ្វាយព្រះនាង ព្រមទាំងផ្តាំឲ្យព្រះនាងចូលទៅគាល់ព្រះរាជា
ដើម្បីសូមការសន្តោសប្រណី និងទូលអង្វរព្រះរាជា សម្រាប់ជនជាតិរបស់ព្រះនាង។
[9]លោកហាថាក់ក៏នាំពាក្យទាំងប៉ុន្មានរបស់លោកម៉ាដេកាយ ទៅទូលព្រះនាងអេសធើ។
[10]ពេលនោះព្រះនាងអេសធើប្រាប់លោកហាថាក់ឲ្យទៅជម្រាបលោកម៉ាដេកាយវិញថា។[11]«ពួករាជបម្រើ និងប្រជាជននៅក្នុងអាណាខេត្តរបស់ស្តេច សុទ្ធតែដឹងថា បុរស
ឬស្ត្រីណាដែលហ៊ានចូលទៅគាល់ស្តេច នៅសាលខាងក្នុងរាជដំណាក់ ដែលស្តេចមិនបានត្រាស់ហៅ អ្នកនោះគឺត្រូវសម្លាប់
ស្រមតាមច្បាប់ដែលមានចែងទុកសម្រាប់មនុស្សទូទៅ ប៉ុន្តែ បើព្រះរាជាហុចដំបងរាជធ្វើពីមាសឲ្យប៉ុណ្ណោះ ទើបរួចជីវិត។
ចំពោះខ្ញុំវិញព្រះរាជាមិនបានហៅខ្ញុំឲ្យចូលគាល់អស់រយៈពេលសាមសិបថ្ងៃមកហើយ»។[12]គេក៏ទៅជម្រាបម៉ាដេកាយ តាមរាជសរនីយ៍របស់ព្រះនាងអេសធើ។
[13]ពេលនោះ លោកម៉ាដេកាយឲ្យគេនាំពាក្យទៅទូលព្រះនាងវិញថា។ «បពិត្រព្រះមហាក្សត្រិយានី សូមកុំនឹកស្មានថា នៅក្នុងដំណាក់របស់ស្តេច
ព្រះនាងអាចគេចផុតពីសេចក្ដីវិនាស ដែលនឹងកើតមានចំពោះជនជាតិយូដាទាំងអស់នោះឡើយ។[14]ប្រសិនបើព្រះនាងសំងំស្ងៀមនៅពេលនេះ នោះនឹងមានជំនួយ
និងរំដោះឲ្យរួច ដល់ពួកជនជាតិយូដា តាមមធ្យោបាយមួយផ្សេងទៀត រីឯព្រះនាង និងញាតិវង្សបិតារបស់ព្រះនាងនឹងត្រូវវិនាសផុតពូជ។ តើនរណាដឹង
ព្រះនាងបានឡើងធ្វើជាព្រះមហាក្សត្រិយានីនេះ ដើម្បីសង្គ្រោះជនជាតិយូដា នៅពេលនេះហើយមើលទៅ?»
[15]ពេលនោះ ព្រះនាងអេសធើចាត់គេឲ្យទៅជម្រាបលោកម៉ាដេកាយថា[16]«សូមទៅប្រមូលពួកជនជាតិយូដាទាំងអស់នៅក្នុងក្រុងស៊ូសាន ឲ្យតមអាហារសម្រាប់ខ្ញុំ។
ក្នុងរវាងបីថ្ងៃ គឺទាំងថ្ងៃ ទាំងយប់ មិនត្រូវបរិភោគ ឬផឹកអ្វីឡើយ។ ចំណែកខ្ញុំ និងពួកស្ត្រីបម្រើរបស់ខ្ញុំ ក៏តមអាហារដែរ។ បន្ទាប់មក ខ្ញុំនឹងចូលទៅគាល់ស្តេច
ទោះបីខុសច្បាប់ក៏ដោយ បើខ្ញុំត្រូវវិនាស នោះឲ្យវិនាសទៅចុះ»។[17]លោកម៉ាដេកាយក៏ទៅ ហើយក៏ធ្វើតាមសេចក្ដីទាំងប៉ុន្មាន ដែលព្រះនាងអេសធើបង្គាប់។

Esther 4:1
បានដឹងហេតុការណ៍ទាំងប៉ុន្មានកើងឡើង
«បានឃើញរាជក្រឹតទាំងនោះ»
ហែកសម្លៀកបំពាក់របស់ខ្លួន ហើយស្លៀកបាវ និងរោយផេះលើក្បាល
អំពើទាំងនេះគឺជាសញ្ញានៃភាពទុក្ខព្រួយយ៉ាងខ្លាំង។ ការបកប្រែរបៀបផ្សេងទៀត:
«ហែកសម្លៀកបំពាក់របស់ខ្លួន ហើយស្លៀកបាវ និងរោយផេះលើក្បាល
ដើម្បីបង្ហាញពីទុក្ខព្រួយរបស់លោក»
អាណាខេត្ត
នេះបកប្រែដូចនៅក្នុងជំពូក ១:១។
នោះជនជាតិយូដានាំគ្នាកាន់ទុក្ខយ៉ាងខ្លាំង
«ជនជាតិយូដានាំគ្នាកាន់ទុក្ខយ៉ាងខ្លាំង»
ស្លៀកបាវ ហើយដេកនៅក្នុងផ្ទះ
«ស្លៀកសម្លៀកបំពាក់ និងស្លៀកបាវហើយអង្គុយក្នុងផេះ» (UDB)
Esther 4:4
ពួកស្ត្រីបម្រើ និងពួកមហាតលិករបស់ព្រះនាង
«អ្នកបម្រើស្រី និងអ្នកបម្រើរបស់បុរស»
សម្លៀកបំពាក់ទៅជូនលោកម៉ាដេកាយ
«សម្រាប់លោកម៉ាដេកាយស្លៀក»
លោកហាថាក់
ជាមហាតលិក ដែលព្រះរាជាឲ្យមកបម្រើព្រះនាង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មហាតលិកម្នាក់ដែលស្តេចបានតែងតាំងឲ្យបម្រើព្រះនាង»
Esther 4:6
លោកហាថាក់
ឈ្មោះនេះបកប្រែដូចបុរសនៅក្នុងជំពូកទី ៤: ៤។
នៅទីលានក្រុង
«ទីលានទីក្រុង»
លោកហាម៉ាន
បកប្រែឈ្មោះបុរសនេះដូចក្នុងជំពូក ៣:១។
លោកក៏បានប្រគល់
«លោកម៉ាដេកាយក៏ឲ្យលោកហាថាក់ដែរ»
ដើម្បីសូមការសន្តោសប្រណី
«សូមអង្វរការសន្តោសប្រណីពីព្រះរាជា»
Esther 4:9
បុរស ឬស្ត្រីណាដែលហ៊ានចូលទៅគាល់ស្តេច...ព្រះរាជាហុចដំបងរាជធ្វើពីមាសឲ្យប៉ុណ្ណោះ
ឃ្លាដែលមានលក្ខខណ្ឌនេះអាចត្រូវបានបង្ហាញជាឃ្លា។
នេះក៏អាចមានប្រយោជន៍ផងដែរ ក្នុងការបែងចែកជាពីរប្រយោគ។
ការបកប្រែរបៀបផ្សេងទៀត: «គ្មានបុរស
ឬស្ត្រីអនុញ្ញាតឲ្យចូលទៅក្នុងព្រះរាជានៅទីធ្លាខាងក្នុងទេ
លើកលែងតែព្រះរាជាកោះហៅ
អ្នកណាដែលល្មើសនឹងច្បាប់នេះនឹងត្រូវគេប្រហារជីវិតលើកលែងតែព្រះរាជាហុចដំបងរាជ្យមាសទៅឲ្យគេ
សាមសិបថ្ងៃ
«៣០ ថ្ងៃ»
Esther 4:13
នោះនឹងមានជំនួយ និងរំដោះឲ្យរួចដល់ពួកជនជាតិយូដា តាមមធ្យោបាយមួយផ្សេងទៀត
នៅទីនេះ «ជំនួយ» និង «រំដោះ»

generated on Wed Sep 10 16:16:32 2025

ត្រូវបានគេនិយាយដូចជាពួកគេកំពុងរស់នៅវត្ថុដែលអាចងើបឡើងបាន។
ការបកប្រែរបៀបផ្សេងទៀត:
«នរណាម្នាក់ផ្សេងទៀតនឹងក្រោកឡើងពីកន្លែងផ្សេងទៀត
ហើយជួយរំដោះជនជាតិយូដា»
តើនរណាដឹង ព្រះនាងបានឡើងធ្វើជាព្រះមហាក្សត្រិយានីនេះ ដើម្បីសង្គ្រោះជនជាតិយូដា
នៅពេលនេះហើយមើលទៅ?
គោលបំណងនៃសំណួរនេះគឺចង់ឲ្យព្រះនាងអេសធើរបានគិតយ៉ាងជ្រាលជ្រៅ
អំពីតួនាទីរបស់ព្រះនាងនៅក្នុងស្ថានភាពនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«តើនរណាដឹង
ប្រហែលជាទើបតែមួយរយៈដូចនេះដែលអ្នកត្រូវបានគេតែងតាំងជាមហាក្សត្រី»។

Esther 4:15
ក្រុងស៊ូសាន
បកប្រែដូចក្នុងជំពូក ១:១។
តមអាហារសម្រាប់ខ្ញុំ...នឹងតមអាហារ
ការតមអាហារគឺជាសកម្មភាពនិមិត្តរូបមួយដែលជនជាតិយូដាបានធ្វើនៅពេលពួកគេអធិស្ឋានយ៉ាងខ្លាំង។
នេះអាចត្រូវបានធ្វើឲ្យច្បាស់។ ការបកប្រែរបៀបផ្សេងទៀត:
«តមហើយអធិស្ឋានឲ្យខ្ញុំ ... នឹងតមហើយអធិស្ឋាន»
បីថ្ងៃ
«៣ ថ្ងៃ»

---

5 [1]លុះដល់ថ្ងៃទីបី ព្រះនាងអេសធើ ទ្រង់គ្រឿងជាព្រះមហាក្សត្រិយានី យាងទៅចូលគាល់ស្តេចនៅសាលាខាងក្នុងរាជដំណាក់ ដែលទល់មុខនឹងដំណាក់របស់ស្តេច។
ឯស្តេចគង់លើបល្ល័ង្ករាជ នៅក្នុងរាជដំណាក់ ដែលស្ថិតនៅចំពីមុខទ្វារចូល។[2]ពេលព្រះរាជាទតឃើញព្រះនាងអេសធើ ជាព្រះមហាក្សត្រិយានីឈរនៅក្នុងសាលដូច្នេះ
នោះស្តេចក៏មានព្រះហឫទ័យមេត្តាករុណាដល់ព្រះនាង។ ស្តេចហុចដំបងមាសដែលកាន់នៅព្រះហស្តថ្វាយព្រះនាង។ រួចព្រះនាងក៏ចូលទៅជិតហើយពាល់ចុងដំបងនោះ។
[3]ស្តេចមានរាជឱង្ការថា «មហាក្សត្រិយានីអេសធើអើយ តើនាងចង់បានអ្វី? តើព្រះនាងគិតចង់សូមអ្វី? យើងនឹងប្រទានឲ្យទាំងអស់
ទោះបីមានតម្លៃមួយចំហៀងនគរក៏ដោយ»។[4]ព្រះនាងអេសធើទូលស្តេចថា «ប្រសិនបើព្រះករុណាសពព្រះហឫទ័យ សូមព្រះករុណា និងលោកហាម៉ាន
ស្តេចយាងទៅចូលរួមក្នុងពិធីជប់លៀង ដែលខ្ញុំម្ចាស់បានរៀបចំថ្វាយនៅថ្ងៃនេះ»។
[5]ដូច្នេះ ស្តេចក៏បង្គាប់គេថា «ចូរទៅហៅហាម៉ានឲ្យមកជាប្រញាប់ ទៅចូលរួមក្នុងពិធីជប់លៀង តាមការអញ្ជើញរបស់ព្រះនាងអេសធើ»។ បន្ទាប់មកព្រះរាជា
និងលោកហាម៉ាន ក៏យាង និងអញ្ជើញចូលរួមពិធីជប់លៀង ដែលព្រ នាងអេសធើ បានរៀបចំ។[6]កាលកំពុងសោយសុរា ស្តេចមានរាជឱង្ការសួរទៅព្រះនាងអេសធើថា
«តើព្រះនាងចង់បានអ្វី? យើងនឹងប្រទានឲ្យទាំងអស់។ តើព្រះនាងគិតចង់សូមអ្វី? ទោះបីមានតម្លៃមួយចំហៀងនគរក៏ដោយ ក៏យើងប្រទានឲ្យដែរ»។
[7]ព្រះនាងអេសធើទូលថា «សំណូមពររបស់ខ្ញុំម្ចាស់ និងសេចក្តីដែលខ្ញុំម្ចាស់ចង់បានគឺ[8]ប្រសិនបើព្រះករុណាសព្វព្រហឫឆ្លើយតបនឹងសំណូមពររបស់ខ្ញុំម្ចាស់មែន
សូមព្រះករុណា និងលោកហាម៉ាន ស្តេចយាង និងអញ្ជើញចូលរួមក្នុងពិធីជប់លៀងដែលខ្ញុំម្ចាស់នឹងរៀបចំថ្វាយនៅថ្ងៃស្អែកនេះ ហើយទូលបង្គំនឹង ហើយពេលនោះ
ខ្ញុំម្ចាស់នឹងទូលថ្វាយព្រះករុណា អំពីសំណូមពររបស់ខ្ញុំម្ចាស់»។
[9]ថ្ងៃនោះ លោកហាម៉ានក៏ចេញទៅដោយមានចិត្តត្រេចអរ ហើយសប្បាយរីករាយ។ ប៉ុន្តែ កាលលោកហាម៉ានឃើញលោកម៉ាដេកាយនៅមាត់ទ្វារាជវាំង តែលោ
កម៉ាដេកាយពុំព្រមក្រោកឈរ ឬឱនគោរពចំពោះលោកទេ នោះលោកហាម៉ានខឹងនឹងលោកម៉ាដេកាយជាខ្លាំង។[10]ប៉ុន្តែ លោកហាម៉ានទប់ចិត្ត
ហើយវិលត្រលប់ទៅផ្ទះវិញ។ លោកបានឲ្យគេហៅមិត្តភក្តិជិតស្និទ្ធ និងលោកស្រីសេរែស ជាភរិយាមកជួប។[11]លោកហាម៉ានអួតប្រាប់ពួកគេអំពីទ្រព្យសម្បត្តិរបស់លោក
ព្រមទាំងចំនួនកូនប្រុសរបស់លោក និងកិត្តិយសទាំងប៉ុន្មានដែលស្តេចប្រទានឲ្យ ដែលស្តេចបានលើកតម្កើង ហើយពីដំណែងដែលស្តេចតាំងលោកឡើង
ខ្ពស់ជាងពួកនាម៉ឺនសព្វមុខមន្ត្រីរបស់ស្តេច។
[12]លោកហាម៉ានពោលទៀតថា «សូម្បីតែព្រះនាងអេសធើ ជាព្រះមហាក្សត្រិយានីពុំបានអញ្ជើញឲ្យអ្នកណាទៅជាមួយស្តេចក្រៅពីខ្ញុំ ដើម្បីចូលរួមពិធីជប់លៀង
ដែលព្រះនាងបានរៀបចំនោះឡើយ។ ហើយថ្ងៃស្អែក ព្រះនាងក៏បានអញ្ជើញខ្ញុំទៅជាមួយស្តេចទៀតដែរ។[13]ប៉ុន្តែ ទោះបីមានកិត្តិយសយ៉ាងនេះក្តី ក៏ខ្ញុំមិនសប្បាយចិត្តដែរ
ដរាបណាខ្ញុំនៅតែឃើញម៉ាដេកាយ ជាជនជាតិយូដា ប្រចាំការនៅមាត់ទ្វារវាំង»។
[14]ពេលនោះ លោកស្រីសេរែស ជាភរិយា និងមិត្តភក្តិជិតស្និទ្ធរបស់លោកពោលថា «ចូរឲ្យគេដំឡើងបង្គោលមួយ កម្ពស់ហាសិបហត្ថ។
ហើយព្រឹកឡើងចូលទៅទូលសូមស្តេច ដើម្បីយកម៉ាដេកាយទៅព្យួរនៅលើបង្គោលនោះទៅ។ ដូច្នេះ លោកអាចទៅចូលរួមពិធីជប់លៀងជាមួយនឹងស្តេចដោយអំណរ»។
គំនិតនេះពេញចិត្តនឹងលោកហាម៉ានណាស់ លោកក៏ឲ្យគេដំឡើងបង្គោល។

Esther 5:1
នោះស្តេចក៏មានព្រះហឫទ័យមេត្តាករុណាដល់ព្រះនាង
ពាក្យ «ភ្នែក» សំដៅទៅលើការមើលឃើញរបស់ទ្រង់
ហើយជាពាក្យប្រៀបធៀបសម្រាប់ការវាយតម្លៃរបស់ទ្រង់ចំពោះព្រះនាង។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចក៏មានព្រះហឫទ័យនឹងព្រះនាង» ឬ «ស្តេចបានយល់ព្រមពីព្រះនាង»
ស្តេចហុចដំបងមាសដែលកាន់នៅព្រះហស្តថ្វាយព្រះនាង
ស្តេចធ្វើដូច្នេះ ដើម្បីបង្ហាញថា ទ្រង់សព្វព្រះហឫទ័យនឹងព្រះនាង។
ពាល់ចុងដំបងនោះ
ព្រះនាងប្រហែលជាធ្វើបែបនេះ ដើម្បីបង្ហាញថា
ព្រះនាងគោរពសិទ្ធិអំណាចរបស់ទ្រង់
ហើយអរគុណចំពោះសេចក្តីសប្បុរសរបស់ទ្រង់ចំពោះព្រះនាង។
Esther 5:3
យើងនឹងប្រទានឲ្យទាំងអស់ ទោះបីមានតម្លៃមួយចំហៀងនគរក៏ដោយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើព្រះនាងស្នើសុំពាក់កណ្តាលនៃនគររបស់យើង
យើងនឹងប្រគល់ឲ្យព្រះនាងដែរ»
ប្រសិនបើព្រះករុណាសព្វព្រះហឫទ័យ សូមព្រះករុណា និងលោកហាម៉ាន ស្តេចយាង...រៀបចំថ្វាយ
ដើម្បីបង្ហាញការគោរពចំពោះស្តេចពេលខ្លះមនុស្សមិនបានហៅទ្រង់ថា «លោក»
ទេ។ នេះអាចត្រូវបានបកប្រែជាមួយពាក្យ «លោក»
រួមជាមួយពាក្យផ្សេងទៀតដែលបង្ហាញការគោរព។ ការបកប្រែរបៀបផ្សេងទៀត:
«ឱព្រះមហាក្សត្រ ប្រសិនបើនេះគាប់ព្រះហឫទ័យព្រះអង្គសូមនាំលោកហាម៉ាន ...
សម្រាប់ខ្ញុំម្ចាស់» ឬ «ប្រសិនបើទ្រង់ចង់ធ្វើរឿងនេះលោកម្ចាស់សូមអញ្ជើញមក
ហើយអនុញ្ញាតឲ្យលោកហាម៉ានមកជាមួយទ្រង់.. សម្រាប់ខ្ញុំម្ចាស់»
លោកហាម៉ាន
បកប្រែឈ្មោះបុរសនេះដូចដែលអ្នកបានឃើញនៅក្នុងជំពូក ៣:១។
Esther 5:5
តើព្រះនាងចង់បានអ្វី?
នាមអរូបី «ញត្តិ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «សុំ» ឬ «ចង់បាន»?
ការបកប្រែរបៀបផ្សេងទៀត: «តើព្រះនាងស្នើសុំអ្វី?» ឬ «តើព្រះនាងចង់បានអ្វី?»
យើងនឹងប្រទានឲ្យទាំងអស់
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងផ្តល់ឲ្យព្រះនាងនូវអ្វីដែលព្រះនាងស្នើសុំ» ឬ
«យើងនឹងធ្វើឲ្យព្រះនាងនូវអ្វីដែលនាងស្នើសុំ»
តើព្រះនាងគិតចង់សូមអ្វី?
នាមអរូបី «ការស្នើសុំ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «សូម» ឬ
«ចង់បាន»? ការបកប្រែរបៀបផ្សេងទៀត: «តើព្រះនាងស្នើសូមអ្វី?» ឬ
«តើព្រះនាងចង់បានអ្វី?»
ទោះបីមានតម្លៃមួយចំហៀងនគរក៏ដោយ ក៏យើងប្រទានឲ្យដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើព្រះនាងស្នើសូមពាក់កណ្តាលនៃនគររបស់យើង
យើងនឹងប្រទានឲ្យដែរ»
Esther 5:7
សំណូមពររបស់ខ្ញុំម្ចាស់ និងសេចក្តីដែលខ្ញុំម្ចាស់ចង់បាន
ពាក្យ «សំណូមពរ» និង «ការស្នើសូម» មានន័យដូចគ្នា។
ព្រះនាងប្រហែលជាប្រើពាក្យទាំងនេះជាមួយគ្នាជាវិធីនៃការនិយាយជាផ្លូវការ

generated on Wed Sep 10 16:16:32 2025

និងគោរពព្រះរាជា។
ប្រសិនបើព្រះករុណាសព្វព្រះហឫទ័យ
«សព្វព្រះហឫទ័យ» គឺជាប្រយោគដែលមានន័យថា ត្រូវបានយល់ព្រម ឬថា
ព្រះករុណាសព្វព្រះហឫទ័យនឹងព្រះនាង។ «នៅចំពោះមុខព្រះរាជា»
គឺជាពាក្យប្រៀបធៀបដែលតំណាងឲ្យការសព្វព្រះហឫទ័យរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើព្រះមហាក្សត្រសព្វព្រះហឫទ័យខ្ញុំម្ចាស់ហើយយល់ព្រម» ឬ
«ប្រសិនបើព្រះមហាក្សត្រពេញចិត្តនឹងខ្ញុំម្ចាស់»
ប្រសិនបើព្រះករុណាសព្វព្រហឫទ័យឆ្លើយតបនឹងសំណូមពររបស់ខ្ញុំម្ចាស់មែន
ដើម្បីបង្ហាញការគោរពចំពោះស្តេចពេលខ្លះមនុស្សមិនបានហៅទ្រង់ថា «ទ្រង់» ទេ។
នេះអាចត្រូវបានបកប្រែជាមួយពាក្យ «ទ្រង់»
រួមជាមួយពាក្យផ្សេងទៀតដែលបង្ហាញការគោរព។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើព្រះករុណាសព្វព្រហឫទ័យនឹងខ្ញុំម្ចាស់ ឪព្រះករុណាអើយ
ហើយប្រសិនបើទ្រង់សព្វព្រហឫទ័យខ្ញុំម្ចាស់»
សូមព្រះករុណា និងលោកហាម៉ាន ស្តេចយាង
នេះអាចត្រូវបានបកប្រែជាមួយពាក្យ «ព្រះករុណា»
រួមជាមួយពាក្យផ្សេងទៀតដែលបង្ហាញការគោរព។ ការបកប្រែរបៀបផ្សេងទៀត:
«សូមមកហើយនាំលោកហាម៉ាន » ឬ «សូមយាងមក
ហើយឲ្យលោកហាម៉ានមកជាមួយទ្រង់»
ខ្ញុំម្ចាស់នឹងទូលថ្វាយព្រះករុណា អំពីសំណូមពររបស់ខ្ញុំម្ចាស់
នេះអាចត្រូវបានបកប្រែជាមួយពាក្យ «ព្រះករុណា»
រួមជាមួយពាក្យផ្សេងទៀតដែលបង្ហាញការគោរព។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយខ្ញុំម្ចាស់នឹងឆ្លើយសំណួររបស់ទ្រង់»
Esther 5:9
លោកម៉ាដេកាយពុំព្រមក្រោកឈរ
ការកើនឡើងគឺជាសញ្ញានៃការគោរព។
លោកម៉ាដេកាយមិនបានផ្តល់ការគោរពដល់លោកហាម៉ានពិសេសទេ។
លោកហាម៉ានខឹងនឹងលោកម៉ាដេកាយជាខ្លាំង
ការ «ពោរពេញដោយកំហឹង» តំណាងឲ្យការខឹង។ ការបកប្រែរបៀបផ្សេងទៀត:
«លោកខឹងខ្លាំងណាស់»
ទោះយ៉ាងណា
នេះអាចត្រូវបានបកប្រែជាមួយឃ្លាមួយ។ «ទោះបីជាលោកខឹង»
លោកហាម៉ានទប់ចិត្ត
ការដាក់កម្រិតលើខ្លួនឯងតំណាងឲ្យការបដិសេធមិនធ្វើអ្វីដែលលោកចង់ធ្វើខ្លាំងណាស់។
លោកហាម៉ានចង់បង្ហាញលោកម៉ាដេកាយថាលោកខឹងខ្លាំងណាស់។
ការបកប្រែរបៀបផ្សេងទៀត:
«លោកហាម៉ានបដិសេធមិនបង្ហាញពីកំហឹងរបស់លោក»
លោកស្រីសេរែស
នេះគឺជាឈ្មោះរបស់ស្ត្រី។
លោកហាម៉ានអួតប្រាប់ពួកគេអំពីទ្រព្យសម្បត្តិរបស់លោក
«ភាពរុងរឿង» និង «ទ្រព្យសម្បត្តិ» គឺជានាមអរូបីទាំងពីរ។
ការបកប្រែរបៀបផ្សេងទៀត:
[7]ក្រោយមក សាតាំងចាកចេញពីព្រះវត្តមានព្រះអម្ចាស់ទៅ។ ហើយសាតាំងក៏ធ្វើឲ្យលោកយ៉ូបកើតដំបៅរីកពេញខ្លួន គឺចាប់ពីចុងជើងរហូតដល់ក្បាល។[8]លោកយ៉ូបអង្គុយ
នៅក្នុងផេះ ហើយយកអំបែងឆ្នាំងមកកោសខ្លួន។
[9]ប្រពន្ធរបស់លោកយ៉ូបពោលថា៖ «តើបងនៅតាំងខ្លួនជាមនុស្សទៀងត្រង់ទៀតឬ? សូមប្រមាថព្រះជាម្ចាស់ ហើយស្លាប់ទៅ»។[10]លោកយ៉ូបតបថា៖ «អូននិយាយដូចជា
ស្រីមិនដឹងខុសត្រូវ។ តើយើងទទួលតែការល្អពីព្រះជាម្ចាស់ ហើយមិនអាចទទួលអ្វីដែលអាក្រក់ឬ?» នៅក្នុងបញ្ហាទាំងអស់នេះ
លោកយ៉ូបមិនបានធ្វើបាបជាមួយអណ្តាតរបស់គាត់ទេ។
[11]មិត្តភក្តិបីនាក់របស់លោកយ៉ូប បានឮដំណឹងពីទុក្ខវេទនាដែលកើតមានចំពោះលោក ពួកគេចាកចេញពីទឹកដីរៀងៗខ្លួន អ្នកទាំងនោះ គឺលោកអេលីផាសជាជនជាតិ
ថេម៉ាន លោកប៊ីលដាដជាជនជាតិស៊ូអា និងលោកសូផារជាជនជាតិណាអាម៉ា។ ពួកគេរៀបចំពេលដើម្បីមក ជួយលើកទឹកចិត្តលោក។
[12]ពេលក្រឡេកពីចម្ងាយ អ្នកទាំងបីមើលលោកយ៉ូបលែងស្គាល់ទៀតហើយ។ ដូច្នេះ ពួកគេនាំគ្នាទ្រហោយំ ហែកអាវធំរបស់ខ្លួន និងយកធូលីដីបាចនៅលើក្បាល។[13]អ្នក
ទាំងបីអង្គុយផ្ទាល់នឹងដីជាមួយលោក អស់រយៈពេលប្រាំពីរថ្ងៃ ប្រាំពីរយប់។ គ្មាននិយាយអ្វីមួយម៉ាត់ទៅកាន់លោកឡើយ ព្រោះពួកគេឃើញលោកឈឺចាប់ជាខ្លាំងពេក។

Job 2:1

ពត៌មានទូទៅ

ខនេះដូចគ្នាទាំងស្រុងជាមួយ ១:៦ និងប្រហែលជាត្រូវបានបកប្រែន័យដូចគ្នា។

ក្រោយមកមានថ្ងៃមួយ

សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:៦

មានថ្ងៃមួយ ពេល

មិនបានបញ្ជាក់ថ្ងៃណាច្បាស់លាស់ទេ។ ការប្រជុំគ្នាកើតមានជារឿយៗ។

របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មក នៅពេលដែល» ឬ «ថ្ងៃមួយ
នៅពេលដែល»

ពួកកូនព្រះជាម្ចាស់

សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:៦

មកក្នុងព្រះវត្តមាន គាល់ព្រះអម្ចាស់

សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:៦

ទូលបង្គំទើបនឹងមកពីដើរជុំវិញផែនដី ទៅពេញគ្រប់កន្លែងទាំងអស់

សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:៦

Job 2:3

ពត៌មានទូទៅ

ខនេះដូចគ្នាទៅនឹង ១:៦ លើកប្រយោគបន្ថែម «យ៉ូបនៅតែស្មោះត្រង់ជានិច្ច
ទោះឯងចង់ឲ្យយើងបំផ្លាញគេ ដោយឥតហេតុផលក៏ដោយ»

តើអ្នកសង្កេតឃើញយ៉ូប ជាអ្នកបម្រើរបស់យើងឬទេ?

សំណួរបែបបញ្ជិតបញ្ជៀងតែបង្ហាញពីពាក្យជាក់ស្តែង។ ដូចការបកប្រែនៅ ១:៦។

របៀបផ្សេងទៀតនៃការបកប្រែ: «ពិចារណាថា យ៉ូបជាអ្នកបម្រើរបស់យើង»

ជាមនុស្សទៀងត្រង់ និងរកកន្លែងបន្ទោសគ្មាន

ការបកប្រែនេះស្រដៀងដូចប្រយោគនៅ ១:១។

កោតខ្លាចព្រះជាម្ចាស់ ហើយបែរចេញពីការអាក្រក់

សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:១

នៅតែស្មោះត្រង់ជានិច្ច

«នៅតែស្មោះត្រង់ជានិច្ចក្នុងប្រព្រឹត្តនូវអ្វីដែលត្រឹមត្រូវ និងសុចរិត»

ចង់ឲ្យយើងបំផ្លាញគេ

«បញ្ចុះបញ្ចូលយើងមិនឲ្យបំផ្លាញគេ»

បំផ្លាញគេ

ពាក្យ «បំផ្លាញ» សំដៅលើ «ធ្វើឲ្យក្រីក្រ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើឲ្យគាត់ទៅជាបុរសក្រីក្រ»

Job 2:4

ស្បែកទល់ស្បែក

«ស្បែក» គឺជាការប្រៀបធៀបពីជីវិតរបស់យ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សនឹងធ្វើរឿងទាំងអស់ដើម្បីឲ្យរួចជីវិតរបស់គេ
បើទោះបីជាត្រូវបាត់បង់ទ្រព្យសម្បត្តិ និងអ្នកជាទីស្រឡាញ់»

សូមលូកព្រះហស្តធ្វើឲ្យរូបកាយគាត់ឈឺចាប់ នោះគាត់មុខជាប្រមាថព្រះអង្គមិនខាន

សាតាំងមានន័យថា បើសិនជាព្រះបំផ្លាញយ៉ូប
ទ្រង់នឹងឃើញពីការដែលឆ្លើយតបរបស់យ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«តែពេលនេះ បើទ្រង់លូកព្រះហស្តរបស់ទ្រង់ ហើយពាល់ឆ្អឹង និងរូបកាយគាត់
ទ្រង់នឹងទតឃើញថាគាត់នឹងប្រមាថទ្រង់នៅចំពោះព្រះភក្ររបស់ទ្រង់»

លូកព្រះហស្ត

ពាក្យ «ព្រះហស្ត» សំដៅលើអំណាចចេស្តារបស់ព្រះ។

«តែឥឡូវនេះសូមប្រើអំណាចរបស់ទ្រង់» សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:៩។

ធ្វើឲ្យ

ពាក្យ «ធ្វើឲ្យ» បង្ហាញពីសកម្មភាពនៃសេចក្តីអត្តរាយ។

របៀបផ្សេងទៀតនៃការបកប្រែ: «បំផ្លាញ»

រូបកាយគាត់ឈឺចាប់

ការបង្ហាញនេះសំដៅលើរូបកាយរបស់យ៉ូប។

គាត់មុខជាប្រមាថព្រះអង្គមិនខាន

សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:៩

ចំពោះព្រះភក្ត្ររបស់ទ្រង់

សំដៅលើពេលដែលព្រះយកព្រះទ័យទុកដាក។ របៀបផ្សេងទៀតនៃការបកប្រែ:
«ក្នុងព្រះសណ្តាប់របស់ទ្រង់»

Job 2:7

ក្រោយមក សាតាំងចាកចេញពីព្រះវត្តមានព្រះអម្ចាស់ទៅ

សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១:៩

ធ្វើឲ្យ

«វាយប្រហារ» ឬ «រងទុក្ខជាមួយ»

ដំបៅ

ជំងឺរមាស់ធំៗ និងឈឺចុកចាប់លើស្បែក

យកអំបែងឆ្នាំងមកកោសខ្លួន

កោសរមាស់លើស្បែកដើម្បីកាត់បន្ថយការរមាស់។

អង្គុយនៅក្នុងផេះ

ប្រហែងជាសំដៅទៅលើធុងដាក់សំរាម
និងកន្លែងចោលសំរាមដែលត្រូវបានចាក់ចោល ហើយក៏ប្រហែលជាត្រូវដុតចោល។
អង្គុយនៅទីកន្លែងបែបនេះបង្ហាញពីសេចក្តីទួញសោកយ៉ាងខ្លាំង។

របៀបផ្សេងទៀតនៃការបកប្រែ: «អង្គុយនៅលើគំនរសំរាម»

Job 2:9

តើបងនៅតាំងខ្លួនជាមនុស្សទៀងត្រង់ទៀតឬ?

សំណួរបែបបញ្ជិតបញ្ជៀងតែបង្ហាញពីពាក្យជាក់ស្តែង។

របៀបផ្សេងទៀតនៃការបកប្រែ: «បងមិនគួរនៅតាំងខ្លួនជាមនុស្សទៀងត្រង់
ទៀតនោះទេ»

ប្រមាថព្រះជាម្ចាស់

«បដិសេធព្រះ»

អូននិយាយដូចជាស្រីមិនដឹងខុសត្រូវ

លោកយ៉ូបនិយាយថា៖ «នាងនិយាយដូចជាឆោតល្ងង់»។

របៀបផ្សេងទៀតនៃការបកប្រែ: «អូននិយាយដូចជាស្ត្រីឆោតល្ងង់»

តើយើងទទួលតែការល្អពីព្រះជាម្ចាស់ ហើយមិនអាចទទួលអ្វីដែលអាក្រក់ឬ?

សំណួរបែបបញ្ជិតបញ្ជៀងតែបង្ហាញពីពាក្យជាក់ស្តែង។

របៀបផ្សេងទៀតនៃការបកប្រែ: «យើងគួរតែទទួលការអាក្រក់ពីព្រះអម្ចាស់
ដូចជាយើងទទួលបានការល្អជាប្រាកដដែល»

ទទួលតែការល្អ

ទទួលបានមកពីអ្វីដែលល្អៗ

ការល្អ

ត្រង់នេះបង្ហាញពីគ្រប់ទាំងការល្អដែលព្រះអម្ចាស់ប្រទាន់មកយើង។

ទទួលអ្វីដែលអាក្រក់

«រងទុក្ខគ្រប់ទាំងការដែលអាក្រក់តែមិនមានការត្អូញត្អែរអ្វីឡើយ»

generated on Wed Sep 10 16:16:32 2025

អ្វីដែលអាក្រក់
ត្រង់នេះបង្ហាញពីគ្រប់ទាំងការអាក្រក់ដែលព្រះអម្ចាស់ប្រទានមក
ឬអនុញ្ញាត្តឲ្យយើងទទួលបទពិសោធន៍។
ធ្វើបាបជាមួយអណ្តាតរបស់គាត់ទេ
ពាក្យ «អណ្តាត» បង្ហាញពីសកម្មភាពនៃការនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រព្រឹត្តបាបដោយការនិយាយទាស់ប្រឆាំងនឹងព្រះអម្ចាស់»
Job 2:11
លោកអេលីផាសជាជនជាតិថេម៉ាន លោកប៊ីលដាដជាជនជាតិស៊ូអា និងលោកសូផារ
ជាជនជាតិណាអាម៉ា
លោកអេលីផាស លោកប៊ីលដាដ លោកសូផារជាឈ្មោះរបស់មនុស្សប្រុស។
ថេម៉ានជាទីក្រុងក្នុងស្រុកអេដុម។ ស៊ូអាដើមកំណើតចាប់ផ្តើមរបស់លោកអប្រាហាំ
និងនាងកិទូរ៉ា។
រៀបចំពេល
ព្រមព្រៀងពេល
ជួយលើកទឹកចិត្តលោក
ពាក្យ «រួមទុក្ខជាមួយ» និង «លើកទឹកចិត្ត» មានន័យស្រដៀងគ្នា។
មិត្រភក្តិលោកយ៉ូបព្យាយាមលើកទឹកចិត្តដោយការរួមរំលែកទុក្ខជាមួយលោក។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទួញសោកជាមួយលោកយ៉ូបដើម្បីជួយបន្ថយការឈឺចាប់របស់លោកយ៉ូប»
Job 2:12
ក្រឡេកពីចម្ងាយ
«ពួកគេសម្លឹងមើលដោយតាំងចិត្ត» ឬ «ពួកគេសម្លឹងមើលដោយយកចិត្តទុកដាក់»
អ្នកទាំងបីមើលលោកយ៉ូបលែងស្គាល់ទៀតហើយ
ប្រហែលជាមានន័យថា
អ្នកដែលមកលេងលោកយ៉ូបមើលលោកមិនស្គាល់នៅពេលដំបូង
ពេលដែលពួកគេឃើញលោកពីចម្ងាយ។
យ៉ូបមើលទៅខុសប្លែកយ៉ាងខ្លាំងជាងពេលធម្មតា
ដោយព្រោះតែទុក្ខសោករបស់គាត់ និងដោយសារតែដំបៅនៅលើខ្លួនរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេពិបាកចំណាំគាត់»
ពួកគេនាំគ្នាទ្រហោយំ
«ពួកគេទ្រហោយំ» ឬ «ពួកគេយំយ៉ាងលឮ»
ហែកអាវធំរបស់ខ្លួន
ជាសញ្ញានៃការទួញសោក។
យកធូលីដីបាចនៅលើក្បាល
ជាសញ្ញានៃការទួញសោក។

---

3 [1]បន្ទាប់មក លោកយ៉ូបបើកមាត់ ហើយដាក់បណ្តាសាថ្ងៃកំណើតរបស់លោក។[2]លោកបាននិយាយថា៖[3]«សូមឲ្យថ្ងៃដែលខ្ញុំបានកើតមកនោះ វិនាសទៅ ចំណែកយប់
វិញគាត់និយាយថា៖ កូនប្រុសម្នាក់ចាប់ផ្ទៃហើយនោះ ជាយប់អពមង្គល។
[4]សូមឲ្យថ្ងៃនោះប្រែទៅជាងងឹត ហើយកុំឲ្យព្រះជាម្ចាស់ ដែលគង់នៅស្ថានលើ ចងចាំពីថ្ងៃនោះ ហើយក៏កុំឲ្យមានពន្លឺថ្ងៃចាំងលើថ្ងៃនោះដែរ។[5]សូមឲ្យភាពងងឹត និងភាព
អន្ធការ គ្របបាំងថ្ងៃនោះ។ ហើយសូមឲ្យមានភាពអាប់អួរគ្របបាំង មកលើវាដែរ សូមឲ្យអ្វីដែលកើតនៅថ្ងៃនោះ ត្រឡប់ទៅជាខ្មៅ ពិតជាវេទនាទាំងអស់។
[6]ដ្បិតសម្រាប់យប់នោះវិញ ក៏សូមឲ្យភាពងងឹត គ្របបាំងវាដែរ។ សូមកុំឲ្យគេរាប់បញ្ចូលយប់នោះទៅក្នុង ខែ និងឆ្នាំឡើយ។[7]មើល! សូមឲ្យយប់នោះប្រៀបបាននឹងស្ត្រីអារ
ហើយក៏កុំឲ្យមានសម្រែកអរសប្បាយនៅយប់នោះដែរ។
[8]សូមឲ្យយប់នោះត្រូវបណ្តាសា របស់គ្រូនក្ខត្តឫក្ស និងត្រូវបណ្តាសារបស់គ្រូដាស់ស្តេចក្រពើ។[9]សូមឲ្យផ្កាយព្រឹកប្រែជាងងឹតសូន្យ យប់នោះរង់ចាំពន្លឺ តែមិនឃើញពន្លឺមក
ទេ ហើយក៏មិនឃើញអរុណរះដែរ[10]ដ្បិតយប់នោះពុំបានឃាត់ខ្ញុំមិនឲ្យកើត ហើយក៏មិនបានបញ្ឈៀសទុក្ខលំបាកនេះ យកចេញពីភ្នែករបស់ខ្ញុំដែរ។
[11]ហេតុអ្វីបានជាខ្ញុំមិនបានស្លាប់ទៅតាំងពីនៅក្នុងផ្ទៃម្តាយ? ហេតុអ្វីបានជាខ្ញុំមិនផុតដង្ហើមទៅ នៅពេលកើតចេញពីផ្ទៃម្តាយ?[12]ហេតុអ្វីបានជាមានភ្លៅម្តាយចាំទទួលខ្ញុំ?
ហេតុអ្វីដោះអ្នកម្តាយចាំបំបៅខ្ញុំដូច្នេះ?
[13]ដ្បិត បើខ្ញុំបានស្លាប់តាំងពីកាលនោះ ខ្ញុំនឹងបានដេកទៅយ៉ាងស្ងាត់។ ខ្ញុំបានសម្រាកយ៉ាងសុខស្រួលហើយ[14]ទោះបីជាស្តេច និងមន្ត្រីទាំងប៉ុន្មាននៃផែនដី ជាអ្នកដែល
បានកសាងផ្នូរ ទុកសម្រាប់ខ្លួន។
[15]ឬក៏ខ្ញុំមុខជាបានសម្រាកជាមួយពួកមេដឹកនាំ ដែលជាអ្នកមានមាសប្រាក់ពេញផ្ទះ។[16]ឬប្រសិនបើខ្ញុំគ្មានជីវិត គឺដូចកូនរលូត ឬដូចកូនក្មេងដែលមិនធ្លាប់ឃើញពន្លឺថ្ងៃ
នោះប្រសើរជាង។
[17]នៅក្នុងផ្នូរ មនុស្សអាក្រក់លែងមាន សកម្មភាពទៀតហើយ រីឯអ្នកដែលនឿយហត់ អស់កម្លាំងនឹងនាំគ្នាសម្រាក។[18]អ្នកជាប់ឃុំឃាំងបានសុខក្សេមក្សាន្ត គឺគេលែងឮ
សំឡេងរបស់ឆ្មាំគុកទៀតហើយ។[19]អ្នកតូច និងអ្នកធំ ស្ថិតនៅទីនោះជាមួយគ្នា ទាសករក៏លែងនៅក្រោមអំណាច ម្ចាស់របស់ខ្លួន។
[20]ហេតុអ្វីព្រះជាម្ចាស់ប្រទានឲ្យ មនុស្សដែលត្រូវវេទនា ស្គាល់ពន្លឺថ្ងៃ ហើយផ្តល់ជីវិតឲ្យអ្នកដែលស្គាល់តែ ទុក្ខលំបាក[21]គេទន្ទឹងរង់ចាំសេចក្តីស្លាប់ តែមិនឃើញសេចក្តី
ស្លាប់មកទេ គេប្រាថ្នាចង់បានសេចក្តីស្លាប់ ជាងទ្រព្យសម្បត្តិដែលកប់ទុក។[22]ប្រសិនបើគេរកបានផ្នូរសម្រាប់ខ្លួន នោះគេមុខជាសប្បាយរីករាយត្រូវទេ?
[23]ហេតុអ្វី បានជាពន្លឺត្រូវចាំងភ្លឺមកលើមនុស្ស ដែលផ្លូវត្រូវបាំងបិត ហើយព្រះជាម្ចាស់បានដាក់របងព័ទ្ធជុំវិញនោះ?[24]ដ្បិត ខ្ញុំបានស្រែកថ្ងូរ ជំនួសអាហារ សម្រែកឈឺចាប់
របស់ខ្ញុំ ចេះតែហូរចេញមកដូចទឹក។
[25]ដ្បិតការអ្វីដែលខ្ញុំខ្លាច ការនោះកើតមានដល់ខ្ញុំ ហើយដែលខ្ញុំបារម្ភ គឺបានមករកខ្ញុំ។[26]ខ្ញុំមិនបានស្ងប់ មិនបានសុខស្រួល ហើយក៏មិនបានសម្រាកដែរ គឺខ្ញុំឈឺចាប់
កើតឡើងលើរូបខ្ញុំជានិច្ច»។

Job 3:1
លោកយ៉ូបបើកមាត់
«ចាប់ផ្តើមនិយាយ»
សូមឲ្យថ្ងៃដែលខ្ញុំបានកើតមកនោះ វិនាសទៅ ចំណែកយប់វិញ
លោកយ៉ូបនិយាយពីពេលថ្ងៃ និងពេលយប់ប្រៀបទៅនឹងមនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំរំពឹងថាខ្ញុំមិនបានកើតមក»
ចំណែកយប់វិញ លោកនិយាយថា៖ «កូនប្រុសម្នាក់ចាប់ផ្ទៃហើយនោះ ក៏ត្រូវវិនាសដែរ»។
ជាការបញ្ជាក់ពីប្រយោគដែលថា
ការទួញសោករបស់យ៉ូបឆ្ងាយខ្លាំងជាងតាំងពីពេលមុនដំបូងនៃការចាប់កំណើតរបស់លោកទៅទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «យប់នោះនិយាយថា
«កូនប្រុសដែលបានកើតមក» នឹងវិនាស»។
ចំណែកយប់វិញ លោកនិយាយថា៖
ពាក្យយប់និយាយប្រៀបដូចជាមនុស្សដែលអាចនិយាយបាន។
អ្នកបកប្រែប្រហែលជាជ្រើសយក ការបកប្រែជាន័យប្រៀបធៀប។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅយប់មួយដែលមនុស្សនឹងនិយាយ»
កូនប្រុសម្នាក់ចាប់ផ្ទៃហើយ
នេះប្រហែលជាទម្រង់កិរិយាសកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ម្តាយរបស់គាត់បានបង្កើតកូនប្រុសមួយ»
Job 3:4
ព័ត៌មានទូទៅ
ការបង្ហាញនៅខនេះគឺជាការរំពឹងថាថ្ងៃកំណើតរបស់យ៉ូបនឹងមិនមានទៀតនោះទេ។
នេះប្រហែលជាបញ្ជាក់ពីថ្ងៃនោះ មិនថានៅក្នុងអតីតកាល តែនៅមានវត្តមាន។
អ្នកបកប្រែប្រហែលជាសម្រេចបកប្រែដូចនៅ UDB)ដែរ «ខ្ញុំរំពឹងថានៅថ្ងៃនោះ
ពេលដែលខ្ញុំចាប់កំណើតនឹងមានភាពអាប់អួរ»
ឬ «សូមឲ្យថ្ងៃនោះប្រែទៅជាងងឹត... ហើយក៏កុំឲ្យមានពន្លឺថ្ងៃចាំងលើថ្ងៃនោះដែរ
ប្រយោគទាំងពីរពណ៌នាពីភាពងងឹតនៅថ្ងៃកំណើតរបស់យ៉ូប
ដែលជាការបន្ទរពីភាពសោកស្តាយរបស់យ៉ូបដែលលោកបានកើតមក។
សូមឲ្យថ្ងៃនោះប្រែទៅជាងងឹត
នេះជាការរំពឹងថានឹងមិនមានវត្តមានថ្ងៃនោះទៀតទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមឲ្យថ្ងៃនោះរលាយបាត់ទៅ»
សូមឲ្យភាពងងឹត និងភាពអន្ធការ គ្របបាំងថ្ងៃនោះ
ត្រង់នេះ ភាពងងឹត និងភាព

generated on Wed Sep 10 16:16:32 2025

អន្ធការនៃសេចក្តីស្លាប់គឺនិយាយប្រៀបធៀបថាប្រសិនជាពួកគេជាមនុស្សដែលអាចប្រ[illegible]ពួកគេ។
ពាក្យ «វា» សំដៅលើថ្ងៃដែលយ៉ូបកើត។
ភាពអន្ធការ
ត្រង់នេះ ភាពអន្ធការសំដៅលើការស្លាប់ដោយខ្លួនឯង។
របៀបផ្សេងទៀតនៃការបកប្រែ: «ការស្លាប់ប្រៀបដូចជាភាពអន្ធការ» (សូមមើល:
ហើយសូមឲ្យមានភាពអាប់អួរគ្របបាំងមកលើវាដែរ
ពាក្យភាពអាប់អួរគ្រប
បាំងនិយាយប្រៀបទៅមនុស្សណាដែលអាចរស់នៅថ្ងៃនៃកំណើតរបស់យ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមឲ្យភាពអាប់អួរគ្រប់បាំងលើវា
ដូច្នេះមិនមានអ្នកណាម្នាក់អាចមើលឃើញវាឡើយ»
សូមឲ្យអ្វីដែលកើតនៅថ្ងៃនោះ ត្រឡប់ទៅជាខ្មៅ
សំដៅលើការអ្វីដែលបិទបាំងពន្លឺរបស់ព្រះអាទិត្យ ហើយបញ្ចេញភាពងងឹត។ ពាក្យ
«ខ្មៅ» សំដៅលើ ភាពងងឹត។
វេទនាទាំងអស់
«វេទនានៅថ្ងៃនោះ»
ថ្ងៃនិយាយប្រៀបទៅនឹងមនុស្សដែលអាចវេទនាដោយសារភាពងងឹត។
Job 3:6
សូមឲ្យភាពងងឹត គ្របបាំងវា
ជាថ្មីម្តងទៀតភាពងងឹតនៅត្រង់នេះបាននិយាយប្រៀបទៅមនុស្សដែលអាចចាប់ហើយនិងបង្ហាញពីសកម្មភាពចាប់របស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
របៀបផ្សេងទៀតនៃការបកប្រែ: «សូមឲ្យភាពងងឹតយ៉ាងក្រាស់គ្របបាំងវាទៅ»
ភាពងងឹត
«ងងឹតខ្លាំង» ឬ «ងងឹតសូន្យឈឹង»
សូមកុំឲ្យគេរាប់បញ្ចូល
ពាក្យ «វា» សំដៅលើយប់ដែលយ៉ូបកើត ឬកំណើតរបស់យ៉ូប។
នៅយប់ដែលយ៉ូបចាប់កំណើតនិយាយប្រៀបទៅនឹងមនុស្សដែលមិនមានអំណរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមឲ្យយប់នោះរលាយបាត់ចេញពីតារាពេលវេលាទៅ»។
សូមកុំឲ្យគេរាប់បញ្ចូលយប់នោះទៅក្នុង ខែ និងឆ្នាំឡើយ
យប់នោះនិយាយប្រៀបទៅមនុស្សដែលអាចដើរបាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមកុំឲ្យអ្នកណាម្នាក់រាប់បញ្ចូលថាជាចំនួនឡើយ»
សូមឲ្យយប់នោះប្រៀបបាននឹងស្ត្រីអារ
នៅយប់ដែលយ៉ូបកើតនិយាយប្រៀបទៅនឹងស្ត្រីម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមកុំឲ្យមានកូនណាមួយនឹងកើតមកនៅយប់នោះឡើយ»
ហើយក៏កុំឲ្យមានសម្រែកអរសប្បាយនៅយប់នោះដែរ
ត្រង់នេះ
នៅយប់ដែលយ៉ូបកើតនោះនិយាយប្រៀបទៅនឹងពេលវេលាដែលវានៅតែអាចឲ្យណ[illegible]
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមកុំឲ្យឮសម្រែកអរសប្បាយនៅពេលកូនប្រុសនោះកើតឡើយ»
សម្រែកអរសប្បាយ
នៅត្រង់នេះសំលេងសំដៅលើមនុស្សដែលអរសប្បាយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមកុំឲ្យអ្នកណាម្នាក់អរសប្បាយក្នុងវាម្តងទៀតនោះឡើយ»
Job 3:8
និងត្រូវបណ្តាសារបស់គ្រូដាស់ស្តេចក្រពើ
ប្រហែលជានៅទីនេះយ៉ូបសំដៅទៅលើគ្រូអាបធ្មប់
និងគ្រូមន្តអាគមដែលគាត់ជឿថានឹងអាចដាស់ឲ្យស្តេចក្រពើឲ្យឡើងបង្កភាពវឹកវរ។
ស្តេចក្រពើជាប្រភេទសត្វដែលគេស្គាល់នៅសម័យបុរាណទេវកថានៅភាគខាងកើត
ដែលគេបានគិតថាវាទទួលខុសត្រូវក្នុងការបំផ្លាញ់គ្រប់គ្រប់យ៉ាង
គ្មានសណ្តាប់ធ្នាប់ និងបង្កការច្របូកច្របល់។
សូមឲ្យផ្កាយព្រឹកប្រែជាងងឹតសូន្យ
សំដៅទៅលើភពដែលតែងតែមើលឃើញបន្ទាប់ពីងងឹតទៅ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមឲ្យផ្កាយដែលរះមកជាពន្លឺថ្ងៃមុននោះទៅជាងងឹតចុះ»
យប់នោះរង់ចាំពន្លឺ តែមិនឃើញពន្លឺមកទេ
ថ្ងៃនៃការចាប់កំណើតរបស់យ៉ូបនិយាយប្រៀបទៅមនុស្សដែលកំពុងស្វែករកអ្វីមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមឲ្យថ្ងៃនោះជាទីសង្ឃឹមនៃពន្លឺ
តែមិនមានពន្លឺនោះទេ» (សូមមើល:

ំពាក្យអរុណរះនិយាយសំដៅលើត្របកភ្នែកដូចដែលមនុស្សមាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយក៏មិនឃើញពន្លឺដំបូងដែលរះមកដែរ»
ដ្បិត យប់នោះពុំបានឃាត់ខ្ញុំមិនឲ្យកើត
ផ្ទៃរបស់ស្ត្រីនិយាយប្រៀបទៅនឹងធុងស្តុកមួយដែលមានទ្វារ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត នៅថ្ងៃនោះ មិនអាចបិទផ្ទៃម្តាយរបស់ខ្ញុំទេ»
ហើយក៏មិនបានបញ្ឈៀសទុក្ខលំបាកនេះ យកចេញពីភ្នែករបស់ខ្ញុំដែរ
ថ្ងៃកំណើតរបស់យ៉ូបនិយាយប្រៀបទៅមនុស្សដែលអាចលាក់បិទបាំងអ្វីមួយ។
ពីភ្នែករបស់ខ្ញុំដែរ
ពាក្យ «ភ្នែក» សំដៅលើមនុស្សដែលអាចមើលឃើញតាមពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីខ្ញុំ»
Job 3:11
ពត៌មានទូទៅ
ក្នុងបទគម្ពីរនេះមានផ្ទុកនូវសំណួរដែលមិនទាមទារចម្លើយបន
ដែលលោកយ៉ូបសួរដើម្បីឲ្យមានប្រយោគជាបន្តបន្ទាប់។
ហេតុអ្វីបានជាខ្ញុំមិនបានស្លាប់ទៅតាំងពីនៅក្នុងផ្ទៃម្តាយ?
ហេតុអ្វីបានជាខ្ញុំមិនបានស្លាប់ទៅតាំងពីកំណើតដំបូងមក?
លោកយ៉ូបចោទសួរដើម្បីដាក់បណ្តាសានៅថ្ងៃដែលលោកកើត
និងបង្ហាញពីសកម្មភាពចាប់របស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំរំពឹងថា ខ្ញុំបានស្លាប់តាំងពីថ្ងៃដែលខ្ញុំបានកើតមក»
ហេតុអ្វីបានជាខ្ញុំមិនផុតដង្ហើមទៅ នៅពេលកើតចេញពីផ្ទៃម្តាយ?
លោកយ៉ូបចង់មានន័យថា លោកមិនគួរបានកើតមកមានជីវិតនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំសង្ឃឹមថា
ខ្ញុំបានស្លាប់តាំងពីពេលដែលខ្ញុំចេញពីផ្ទៃម្តាយមក»
មិនផុតដង្ហើមទៅ
សំដៅលើការស្លាប់
ហេតុអ្វីបានជាមានភ្លៅម្តាយចាំទទួលខ្ញុំ?
ត្រង់នេះប្រហែលជាសំដៅលើផ្ទៃនៃម្តាយរបស់លោកយ៉ូប។
ភ្លៅនៃម្តាយរបស់លោកនិយាយប្រៀបទៅមនុស្សដែលអាចបង្កើតកូនបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំរំពឹងថានឹងពុំមានផ្ទៃដើម្បីបង្កើតខ្ញុំទេ»
ហេតុអ្វីដោះអ្នកម្តាយចាំបំបៅខ្ញុំដូច្នេះ?
ដោះអ្នកម្តាយ
របស់លោកយ៉ូបនិយាយប្រៀបទៅលើពួកមនុស្សដែលអាចផ្តល់កំណើតឲ្យទារកបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំរំពឹងថានឹងពុំមានដោះអ្នកម្តាយសំរាប់បំបៅខ្ញុំ»
Job 3:13
ដ្បិត បើខ្ញុំបានស្លាប់តាំងពីកាលនោះ ខ្ញុំនឹងបានដេកទៅយ៉ាងស្ងាត់។ ខ្ញុំបានសម្រាកយ៉ាងសុខស្រួល
ហើយ
[illegible]ការយាគពីរដើម្បីពិចារណាអំពីអ្វីដែលនឹងគួរតែមានប្រសិនបើលោកមិនបានចាប់កំ
ឬបានស្លាប់តាំងពីកំណើត។
ខ្ញុំនឹងបានដេកទៅយ៉ាងស្ងាត់
លោកយ៉ូបស្រមៃមើលពីអ្វីដែលបានកើតឡើងនៅពេលកន្លងមក ប៉ុន្តែ
មិនបានកើតឡើងទេ ដូចចំនុចចំណាំខាងលើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំគួរតែបានសម្រាកយ៉ាងស្ងប់ស្ងាត់»
ដេកទៅយ៉ាងស្ងាត់
«ដេក ឬ សម្រាកយ៉ាងសុខស្រួល» (UDB)
ខ្ញុំបានសម្រាកយ៉ាងសុខស្រួលហើយ
ពាក្យ «សម្រាក» មានន័យថាដេកយ៉ាងសុខស្រួល ប៉ុន្តែ
លោកយ៉ូបនឹងមិនមានបទពិសោធន៍ឈឺចាប់ពីអ្វីដែលគាត់ប្រព្រឹត្តឡើយ។
ទោះបីជាស្តេច និងមន្ត្រីទាំងប៉ុន្មាននៃផែនដី
ជាមួយស្តេច ហើយនិងទីប្រឹក្សារបស់ពួកគេ
Job 3:15
ពត៌មានទូទៅ
លោកយ៉ូបនៅតែបន្តគំនិតរបស់គាត់អំពីការស្លាប់មុនពេលដែលគាត់បានកើត
ឬក៏ខ្ញុំមុនជាបានសម្រាក...ដែលមិនធ្លាប់ឃើញពន្លឺថ្ងៃ
ត្រង់នេះពណ៌នាពីអ្វីមួយដែលនឹងអាចកើតឡើង ប៉ុន្តែ មិនបានកើតឡើង។
ខ្ញុំមុខជាបានសម្រាកជាមួយពួកមេដឹកនាំ
«ខ្ញុំនឹងបានសម្រាកជាមួយពួកមេដឹកនាំ»
ដែលជាអ្នកមានមាសប្រាក់ពេញផ្ទះ
លោកយ៉ូបប្រើប្រាស់ការប្រៀបធៀបដើម្បីចង្អុរបង្ហាញពីអ្វីដែលលោកនិយាយ។

generated on Wed Sep 10 16:16:32 2025

ឬប្រសិនបើខ្ញុំគ្មានជីវិត គឺដូចកូនរលូត ឬដូចកូនក្មេងដែលមិនធ្លាប់ឃើញពន្លឺថ្ងៃ នោះប្រសើរជាង
លោកយ៉ូបប្រើប្រាស់ការប្រៀបធៀបដើម្បីចង្អុរបង្ហាញពីអ្វីដែលលោកនិយាយ។
ខ្ញុំគ្មានជីវិត
«ខ្ញុំគួរតែបានស្លាប់តាំងពីក្នុងផ្ទៃម្តាយមកម្ល៉េះ»
គឺដូចកូនរលូត ឬដូចកូនក្មេងដែលមិនធ្លាប់ឃើញពន្លឺថ្ងៃ ប្រសើរជាង
«ដូចជាទារកដែលពុំបានកើតមក»
កូនក្មេង
«កូនក្មេង» ឬ «ទារកតូច»
Job 3:17
ព័ត៌មានទូទៅ
លោកយ៉ូបផ្លាស់ប្តូរការនិយាយរបស់គាត់ពីការស្លាប់ហើយមានជីវិតឡើងវិញបន្ទាប់ពីស្លាប់
នៅក្នុងផ្នូរ មនុស្សអាក្រក់លែងមាន សកម្មភាពទៀតហើយ រីឯអ្នកដែលនឿយហត់ អស់កម្លាំងនឹងនាំ
គ្នាសម្រាក
លោកយ៉ូបប្រើប្រាស់ការប្រៀបធៀបដើម្បីចង្អុរបង្ហាញពីមនុស្សទន់ទាបនឹងស្វែងរកទីសម្រាកនៅស្ថានឃុំព្រលឹង
នៅក្នុងផ្នូរ មនុស្សអាក្រក់លែងមាន សកម្មភាពទៀតហើយ
លោកយ៉ូបនិយាយពីទីកន្លែងដែលមនុស្សនឹងត្រូវទៅបន្ទាប់ពីពួកគេផុតជីវិតទៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅកន្លែងនោះ
មនុស្សអាក្រក់លែងមានសកម្មភាពទៀតហើយ»
គឺគេលែងឮសំឡេងរបស់ឆ្មាំគុកទៀតហើយ
ត្រង់នេះពាក្យ «សំឡេង» ជាពាក្យប្រៀបធៀបពីអំណាចដែលឆ្មាំ
គុកមានអំណាចលើពួកទាសភាព។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេមិននៅក្រោមការគ្រប់គ្រងនៃឆ្មាំគុកទៀតទេ»
អ្នកតូច និងអ្នកធំ
រូបភាពនេះបង្ហាញពីការនិយាយដែលមានន័យ «មនុស្សទាំងអស់ ទាំងអ្នកក្រីក្រ
និងអ្នកមាន»
ទាសករក៏លែងនៅក្រោមអំណាច ម្ចាស់របស់ខ្លួន
ពួកទាសភាពមិននៅក្រោមកាតាព្វកិច្ចបម្រើម្ចាស់ទៀតទេ។
Job 3:20
ហេតុអ្វីព្រះជាម្ចាស់ប្រទានឲ្យ មនុស្សដែលត្រូវវេទនា ស្គាល់ពន្លឺថ្ងៃ ហើយផ្តល់ជីវិតឲ្យអ្នកដែលស្គាល់
តែទុក្ខលំបាក
សំណួរពីររបស់លោកយ៉ូបមានន័យប្រហែលគ្នា។ គាត់ឆ្ងល់
ហេតុអ្វីមនុស្សជួបនឹងទុក្ខលំបាកហើយ នៅតែបន្តមានជីវិតទៀត។
ហេតុអ្វីព្រះជាម្ចាស់ប្រទានពន្លឺដល់ មនុស្សដែលមានទុក្ខវេទនាដូច្នេះ?
នៅទីនេះ លោកយ៉ូបកំពុងឆ្ងល់ ហេតុអ្វីមនុស្សមានជីវិត ហើយរងវេទនា។
របៀបបកប្រែផ្សេងទៀតថា: «ខ្ញុំមិនយល់ទេ
ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានជីវិតដល់មនុស្សម្នាក់ដែលកំពុងរងទុក្ខវេទនាដូច្នេះ»
ពន្លឺ
ពន្លឺនៅទីនេះ តំណាងឲ្យជីវិត
ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានជីវិតដល់មនុស្សម្នាក់ដែលមានព្រលឹងជូរល្វីងដូច្នេះ...តំណាប់លាក់ទុក
«ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានជីវិតដល់មនុស្សដែលរងទុក្ខវេទនាដូច្នេះ?»។
របៀបបកប្រែផ្សេងទៀតថា: «ខ្ញុំមិនយល់ទេ
ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានជីវិតដល់មនុស្សម្នាក់ដែលមានទុក្ខជាខ្លាំងដូច្នេះ...ជាប់ផ្សេងទៀតនៃការបកប្រែ
ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានពន្លឺដល់មនុស្សម្នាក់ដែលមានអំណរជាខ្លាំង
និងភាពអរសប្បាយពេលគេឃើញផ្នូរដូច្នេះ
នៅទីនេះ លោកយ៉ូបសួរសំណួរមួយដើម្បីបង្កើតជាសេចក្តីថ្លែងមួយ។
របៀបបកប្រែផ្សេងទៀត: «ខ្ញុំមិនយល់ទេ
ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យមនុស្សម្នាក់នៅរស់
នៅពេលអ្នកនោះរីករាយក្នុងការកប់ចូលទៅក្នុងដី»។
មនុស្សម្នាក់មានអំណរនិងសប្បាយជាខ្លាំង
ឃ្លាថា: «អំណរជាខ្លាំង» មានន័យសមញ្ញថា អ្វីមួយដែល «ជាអំណរ»។
ឃ្លាទាំងពីរនេះជាមួយគ្នា គឺបង្ហាញពីភាពរីករាយ។ របៀបបកប្រែផ្សេងទៀង:
«មនុស្សម្នាក់ដែលមានអំណរជាខ្លាំង»។
ពេលគាត់រកផ្នូរឃើញ
នេះគឺជាពាក្យគួរសមនៃការសំដៅទៅលើការស្លាប់។ របៀបបកប្រែផ្សេងទៀតថា:
«ពេលគាត់ស្លាប់ ហើយអាចបញ្ចុះបាន»។
ផ្នូរ
ផ្នូរនៅទីនេះ សំដៅលើសេចក្តីស្លាប់។
ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានជីវិតដល់អ្នកដែលធ្វើឲ្យពួកគេមានបន្ទុកធ្ងន់។
ហេតុអ្វីបានជាពន្លឺត្រូវចាំងភ្លឺមកលើមនុស្ស ដែលផ្នូរត្រូវបាំងបិត ហើយព្រះជាម្ចាស់បានដាក់របងព័ទ្ធ
ជុំវិញនោះ?
លោកយ៉ូបសួរសំណួរនេះដើម្បីបង្កើតជាសេចក្តីថ្លែងមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់មិនគួរប្រទានជីវិតដល់មនុស្សហើយ
ដកយកអនាគតរបស់គេ ហើយឃុំឃាំងគេនោះទេ។
ហេតុអ្វីបានជាពន្លឺត្រូវចាំងភ្លឺមកលើមនុស្ស
ពាក្យ ពន្លឺនៅទីនេះតំណាងឲ្យជីវិត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុអ្វីបានជាព្រះជាម្ចាស់ទុកឲ្យមនុស្សមានជីវិតដូច្នេះ?»
មនុស្សដែលផ្នូរត្រូវបាំងបិត
នៅទីនេះ លោកយ៉ូបមានប្រសាសន៍អំពីអនាគតរបស់គាត់ ដែលគាត់មិនដឹងមុន
ហាក់បីដូចជាព្រះជាម្ចាស់បានលាក់វាពីគាត់ដូច្នេះដែរ។
ជាមនុស្សដែលព្រះជាម្ចាស់បានដាក់របងព័ទ្ធជុំវិញ
នៅទីនេះស្ថិតក្នុងស្ថានភាពលំបាក និងគ្រោះថ្នាក់ក្នុងការនិយាយថា
វាជាការដែលស្ថិតនៅក្នុងទីឃុំឃាំងនៅកន្លែងតូចង្អៀតមានព្រំដែន។
ដ្បិត ខ្ញុំបានស្រែកថ្ងូរ ជំនួសអាហារ សម្រែកឈឺចាប់របស់ខ្ញុំ ចេះតែហូរចេញមកដូចទឹក។
លោកយ៉ូបបានបង្ហាញតម្លៃរជាពីបែប។
ខ្ញុំបានស្រែកថ្ងូរ ជំនួសអាហារ
«ខ្ញុំស្រែកថ្ងូរ ជំនួសហូបអាហារ។
សម្រែកឈឺចាប់របស់ខ្ញុំ ចេះតែហូរចេញមកដូចទឹក។
គុណសម្បត្តិខាងសីលធម៌ និងអារម្មណ៍ សម្រែកថ្ងូរហូរដូចជាទឹក។
Job 3:25
ដ្បិតការអ្វីដែលខ្ញុំខ្លាច ការនោះកើតមានដល់ខ្ញុំ ហើយដែលខ្ញុំបារម្ភ គឺបានមករកខ្ញុំ។
ឃ្លាពីរនេះ មានន័យដូចគ្នា: របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលខ្ញុំខ្លាច
ភាគច្រើនបំផុតបានកើតឡើងចំពោះខ្ញុំ» ឬ «ការដែលខ្ញុំភ័យខ្លាចបំផុត
បានកើតឡើងមែន»។
ខ្ញុំមិនបានស្ងប់ មិនបានសុខស្រួល ហើយក៏មិនបានសម្រាកដែរ
លោកយ៉ូបបានបង្ហាញពីការថប់បារម្ភរបស់គាត់ នៅក្នុងឃ្លាបីផ្សេងទៀត។
របៀបបកប្រែផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមានការភ័យបារម្ភជាខ្លាំង» ឬ «ខ្ញុំបារម្ភ
និងឈឺចាប់ខាងអារម្មណ៍ខ្ញុំ»

---

4 [1]លោកអេលីផាស ជាជនជាតិថេម៉ាន ពោលឡើងថា៖[2]ប្រសិនបើយើងជូនយោបល់តែមួយម៉ាត់ តើលោកទ្រាំនឹងស្តាប់បានទេ? ប៉ុន្តែ តើនរណាទ្រាំមិននិយាយកើត?
[3]មើល! លោកបានទូន្មានមនុស្សជាច្រើន លោកមានមនុស្សឲ្យកម្លាំង ចិត្តឡើងវិញ។
[4]ពាក្យដែលលោកមានប្រសាសន៍ បានធ្វើឲ្យអ្នកដែលដួលអាចងើបឡើងវិញ លោកក៏បានធ្វើឲ្យអ្នកដែលទន់ជង្គង់ មាំមួនឡើងវិញ។[5]ប៉ុន្តែបញ្ហាបានធ្វើឲ្យលោកបាក់ទឹកចិត្ត
វាកើតឡើងដល់លោក ហើយលោកបានជួបទុក្ខដ៏ធ្ងន់។[6]តើមិនមែនការកោតខ្លាច និងទំនុកចិត្ត ហើយក្តីស្មោះត្រង់នៃផ្លូវរបស់អ្នក ជាក្តីសង្ឃឹមរបស់អ្នកទេឬ?
[7]សូមគិតពីការនេះ តើមនុស្សណាដែលនឹងវិនាស? តើពេលណាដែលមនុស្សទៀងត្រង់បានអន្តរាយនោះ?[8]តាមតែការមើលឃើញរបស់ខ្ញុំវិញ
អ្នកដែលភ្ជួររាស់ហើយសាបព្រោះការអាក្រក់នឹងចូតកាត់ផលនោះវិញ។[9]គឺពួកគេវិនាស ដោយសារព្រះពិរោធរបស់ ព្រះជាម្ចាស់ដែលបក់បោកមកលើពួកគេ ដូចព្យុះ
សង្ឃរា។
[10]ពួកគេស្រែកដូចសិង្ហ ហើយគ្រហឹមដូចខ្លា ហើយចង្កូមរបស់ពួកសិង្ហស្ទាវបានបាក់អស់។[11]សិង្ហចាស់នឹងវិនាសទៅដោយអត់អាហារ កូនរបស់វានឹងខ្ចាត់ខ្ចាយទៅគ្រប់
ទិសទី។
[12]ពេលនេះ ខ្ញុំបានឮសេចក្តីមួយយ៉ាងស្ងាត់ៗ ហើយត្រចៀកខ្ញុំស្តាប់ឮសំឡេងមួយ យ៉ាងស្រាលៗផង។[13]ខ្ញុំឮសេចក្តីនោះក្នុងសុបិននៅពេលយប់ គឺក្នុងពេលដែលមនុស្ស
ដេកលង់លក់ឥតដឹងខ្លួន។
[14]ខ្ញុំភ័យខ្លាច និងរន្ធត់ ញាប់ញ័រសព្វគ្រប់ពេញរាងកាយ ដែលបានកើតដល់រូបខ្ញុំ ហើយឆ្អឹងរបស់ស្រៀវ។[15]គឺហាក់ដូចជាមានខ្យល់បក់មកប៉ះនឹង ផ្ទៃមុខរបស់ខ្ញុំ ធ្វើឲ្យខ្ញុំព្រឺ
សម្បុរ។

generated on Wed Sep 10 16:16:32 2025

[16]មានវិញ្ញាណឈរនៅក្បែរខ្ញុំ តែខ្ញុំមើលមិនស្គាល់ថាជានរណាទេ។ មានដូចជាស្រមោលមួយនៅចំពោះមុខខ្ញុំ ហើយក្នុងភាពស្ងប់ស្ងាត់នោះ ខ្ញុំឮសំឡេងមួយបន្លឺឡើងថា៖
[17]«តើមនុស្សដែលតែងតែស្លាប់ សុចរិតជាងព្រះជាម្ចាស់ឬ? តើមនុស្សនោះបរិសុទ្ធព្រះជាម្ចាស់ឬ?
[18]មើល! បើព្រះជាម្ចាស់មិនទុកចិត្តអ្នកបម្រើរបស់ព្រះអង្គ និងព្រះអង្គចោតប្រកាន់ទេវតារបស់ព្រះអង្គ[19]នោះចំណង់បើមនុស្សដែលមានធាតុជាដីឥដ្ឋ កើតមកពីធូលីដី ហើយដែលគេអាចជាន់កម្ទេចដូចដង្កូវនេះ តើឲ្យព្រះអង្គទុកចិត្តដូចម្តេចបាន?
[20]ក្នុងរវាងពេល និងពេលល្ងាចមនុស្សត្រូវអន្តរាយ ហើយវិនាសសូន្យទៅ ដោយគ្មាននរណាចាប់អារម្មណ៍ឡើយ។[21]តើមិនមែនខ្សែជីវិតរបស់ពួកគេត្រូវបានចប់ទេឬអី? គេស្លាប់ទៅ ទាំងមិនយល់អ្វីទាំងអស់។

Job 4:1

លោកអេលីផាស

លោកអេលីផាស គឺជាឈ្មោះរបស់បុរសម្នាក់។

ជនជាតិថេម៉ាន

ជនជាតិថេម៉ាន ជាកម្មសិទ្ធិរបស់អំបូរថេម៉ាន។

តើលោកទ្រាំនឹងស្តាប់បានទេ?

លោកអេលីផាសសួរសំណួរនេះ ដើម្បីបង្កើតសេចក្តីថ្លែងមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកប្រាកដជាទ្រាំមិនបានទេ»។

ប៉ុន្តែ តើនរណាទ្រាំមិននិយាយកើត?

លោកអេលីផាសសួរសំណួរនេះ ដើម្បីនិយាយថា
គ្មានបានម្នាក់បានឃើញមិត្រភក្តិឈឺចាប់ហើយ អាចនៅស្ងៀមនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាអាចទប់ចិត្តខ្លួនឯងបានពីការនិយាយ
(ទៅកាន់មិត្តសម្លាញ់ដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ»។ ឬ
«ខ្ញុំត្រូវតែនិយាយទៅកាន់អ្នក
(ឃើញថាអ្នកកំពុងស្ថិតនៅក្នុងស្ថានភាពឈឺចាប់)»។

មើល! លោកបានទូន្មានមនុស្សជាច្រើន លោកមានមនុស្សឲ្យកម្លាំង ចិត្តឡើងវិញ។

នៅក្នុងខនេះ មានគំនិតតែមួយនៅក្នុងផ្លូវពីរ។

លោកមានមនុស្សឲ្យកម្លាំងចិត្តឡើងវិញ។

ពាក្យ «អ្នកទន់ខ្សោយ» តំណាងឲ្យមនុស្សដែលត្រូវការជំនួយ។
របៀបផ្សេងទៀតនៃការបកប្រែ: អ្នកបានជួយអ្នកដទៃ
នៅពេលពួកគេត្រូវការជំនួយ»។

Job 4:4

ព័ត៌មានទូទៅ

អ្នកនិពន្ធប្រើពាក្យបៀបធៀបនៅក្នុងខនីមួយៗ ដើម្បីបង្កើតគំនិតមួយ
ដោយប្រើប្រយោគពីផ្សេងគ្នា ដើម្បីបង្ហាញ ១) ដើម្បីគាំទ្រថា
លោកយ៉ូបបានធ្វើអ្វីមួយដល់អ្នកដទៃកាលពីអតីត ២)
ការជួបទុក្ខលំបាកដែលគាត់បានជួបបញ្ហានៅពេលបច្ចុប្បន្ននេះ និង៣)
ជាកំណាព្យរបស់គាត់ចំពោះព្រះជាម្ចាស់។

បានធ្វើឲ្យ (បានគាំទ្រ)

នរណាម្នាក់បានទទួលការលើកទឹកចិត្ត
អ្នកនោះបាននិយាយដើម្បីឲ្យកុំអ្នកនោះធ្លាក់ចុះ។

ដួល

នៅទីនេះ គឺជាការបាក់ទឹកចិត្ត ដោយសារការនិយាយពីការធ្លាក់ចុះ។

លោកក៏បានធ្វើឲ្យអ្នកដែលទន់ជង្គង់ មាំមួនឡើងវិញ

ពាក្យ បាក់ទឹកចិត្តនៅទីនេះ និយាយពីអ្នកដែលទន់ជង្គង់
មិនអាចធ្វើឲ្យគាត់អាចឈរបាន។

ប៉ុន្តែ បញ្ហាបានធ្វើឲ្យលោកបាក់ទឹកចិត្ត វាកើតឡើងដល់លោក

បញ្ហាដែលនិយាយនៅទីនេះ គឺជាអ្វីមួយដែលកើតឡើងមកលើមនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «ឥឡូវនេះ លោកបានរងទុក្ខដោយសារ
គ្រោះមហន្តរាយ» សូមមើល:

លោកបានជួបទុក្ខដ៏ធ្ងន់

«លោកបានបាក់ទឹកចិត្ត»

ការកោតខ្លាចរបស់លោក

«តាមពិតលោកកោតខ្លាចព្រះជាម្ចាស់»។

តើមិនមែនការកោតខ្លាចនិងទំនុកចិត្ត ហើយក្តីស្មោះត្រង់នៃផ្លូវរបស់អ្នក ជាក្តីសង្ឃឹមរបស់អ្នកទេឬ?

លោកអេលីផាសសួរសំណួរទាំងនេះដើម្បីឲ្យលោកយ៉ូបនិយាយថា
បាបរបស់គាត់បានធ្វើឲ្យគាត់រងឈឺចាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់គ្នាគិតថា លោកគោរពកោតខ្លាចព្រះជាម្ចាស់
មនុស្សគ្រប់គ្នាគិតថាលោកជាមនុស្សស្មោះត្រង់។ ប៉ុន្តែ
ការទាំងនេះកើតឡើងមិនអាចជាការពិតទេ
ព្រោះលោកលែងទុកចិត្តព្រះជាម្ចាស់ទៀតហើយ»។

ការកោតខ្លាចរបស់លោក

លោកអេលីផាសចង់និយាយថា ការកោតខ្លាចរបស់ព្រះជាម្ចាស់របស់លោកយ៉ូប។
«លោកកោតខ្លាចព្រះជាម្ចាស់»

ផ្លូវរបស់អ្នក

«ផ្លូវរបស់អ្នក» នៅទីនេះ តំណាងឲ្យ «ការ ប្រព្រឹត្តរបស់អ្នក»
«របៀបនៃឥរិយាបថរបស់អ្នក»។

Job 4:7

តើមនុស្សណាដែលនឹងវិនាស នៅពេលគាត់ជាមនុស្សគ្មានកំហុស?

លោកអេលីផាសប្រើសំណួរនេះដើម្បីបំផុសគំនិតលោកយ៉ូប
ឲ្យស្វែងរកបាបនៅក្នុងជីវិតរបស់គាត់

តើពេលណាដែលមនុស្សទៀងត្រង់បានវិនាសនោះ?

សំណួរនេះក៏នៅក្នុងន័យបង្កើតសេចក្តីថ្លែងដែរ
ហើយអាចដាក់នៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានមនុស្សទៀងត្រង់ណាម្នាក់ត្រូវវិនាសនោះទេ»។

ត្រូវវិនាស

ពាក្យ ត្រូវវិនាសនៅទីនេះ សំដៅលើការត្រូវបំផ្លាញ។

អ្នកដែលភ្ជួររាស់...សាបព្រោះការអាក្រក់...នឹងចូតកាត់

នៅទីនេះ សកម្មភាពនៃការភ្ជួរ
និងសាបព្រោះសំដៅលើការធ្វើមួយដល់អ្នកផ្សេងឲ្យមានបញ្ហា។
សកម្មភាពនៃការច្រូតកាត់ សំដៅលើការទទួលរងការឈឺចាប់
កើតឡើងដោយសារអំពើដែលគាត់បានធ្វើ។

គឺពួកគេវិនាស ដោយសារព្រះពិរោធរបស់ ព្រះជាម្ចាស់ដែលបក់បោកមកលើពួកគេ ដូចព្យុះសង្ឃរា។

អ្នកនិពន្ធពន្យល់ពីគំនិតមួយ ដោយប្រើប្រយោគពីផ្សេងគ្នា។
នេះគឺជាបែបបទនៃកំណាព្យរបស់ជនជាតិហេព្រើរ ប្រើសម្រាប់បញ្ជាក់
ឬអំណះអំណាង ការបង្រៀន ឬសម្រាប់ការទាំងបីនេះ។

ខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់

ឃ្លានេះ អាចសំដៅលើសកម្មភាពដែលព្រះជាម្ចាស់មានបន្ទូលបង្គាប់ចេញមក។

ព្រះពិរោធរបស់ព្រះអង្គបក់បោកមកលើពួកគេ ដូចព្យុះសង្ឃរា។

ការបង្ហាញសំណើនៅទីនេះ ជាខ្យល់ដង្ហើមយ៉ាងខ្លាំង
ដែលពេលខ្លះមនុស្សដកចេញពីច្រមុះ ពេលគាត់ខឹងជាខ្លាំង។

ខ្យល់ដង្ហើម...សន្ទុះខ្លាំង

ឃ្លាទីពីរសង់លើឃ្លាទីមួយ។ ពួកគេបង្កើតចំណុចតែមួយ
ដោយប្រើន័យដែលធ្វើឲ្យឆាប់យល់។
«ដោយកំសួលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ ពួកគេនឹងស្លាប់
ជាខ្យល់គំហុកយ៉ាងខ្លាំងនៃសេចក្តីក្រោធរបស់ព្រះអង្គ នឹងបំផ្លាញពួកគេ»

វិនាស...ដូចព្យុះសង្ឃរា

នៅក្នុងឃ្លាទីពីរសរសេរជាន់លើឃ្លាទីមួយ។ ដោយប្រើន័យដែលធ្វើឲ្យងាយយល់។
«ដោយកំសួលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ ពួកគេនឹងស្លាប់
ជាខ្យល់គំហុកយ៉ាងខ្លាំងនៃសេចក្តីក្រោធរបស់ព្រះអង្គ នឹងបំផ្លាញពួកគេ»

ពួកគេនឹងត្រូវបំផ្លាញ

នឹងត្រូវបំផ្លាញ ឬត្រូវបាក់លេបនៅទីនេះ សំដៅលើការទទួលរងការសម្លាប់។

Job 4:10

ព័ត៌មានទូទៅ

អ្នកនិពន្ធប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរទាំងនេះ
ដើម្បីបង្ហាញពីគំនិតមួយដោយប្រើប្រយោគផ្សេងគ្នា
ក្នុងការបញ្ជាក់ពីការបំផ្លាញមនុស្សអាក្រក់របស់ព្រះជាម្ចាស់។

ពួកគេស្រែកដូចសិង្ហ ហើយគ្រហឹមដូចខ្លា ហើយចង្កូមរបស់ពួកសិង្ហស្ទាវបានបាក់អស់។
សម្រែកសត្វសិង្ហ សម្លេងរបស់វា និងឆ្មៃញរបស់សត្វសិង្ហនឹងត្រូវបាក់នៅទីនេះ
ត្រូវបានប្រើជារូបភាពនៃការបំផ្លាញមនុស្សអាក្រក់។

ពួកសិង្ហស្ទាវបានបាក់អស់

ឃ្លានេះអាចដាក់នៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«អ្វីមួយបំបាក់ពួកគេ» ។
សិង្ហចាស់នឹងវិនាសទៅដោយអត់អាហារ កូនរបស់វានឹងខ្ចាត់ខ្ចាយទៅគ្រប់ទិសទី។
លោកអេលីផាសប្រើរូបភាពនៃសិង្ហចាស់ដេកដោយស្រែកឃ្លាន
និងពីក្រុមគ្រួសាររបស់សត្វសិង្ហដែលត្រូវបានបែកបាក់
ដើម្បីប្រៀបធៀបនឹងមនុស្សអាក្រក់ដែលត្រូវបំផ្លាញ។
ត្រូវខ្ចាត់ខ្ចាយ
«អ្វីមួយដែលធ្វើឲ្យកូនសិង្ហត្រូវខ្ចាត់ខ្ចាយ»
Job 4:12
ពេលនេះ ខ្ញុំបានឮសេចក្ដីមួយយ៉ាងស្ងាត់ៗ ហើយត្រចៀកខ្ញុំស្ដាប់ឮសំឡេងមួយ យ៉ាងស្រាលៗផង។
ឃ្លាទាំងនេះ បង្ហាញពីគំនិតខុសគ្នាខ្លះ។ ពួកគេបង្ហាញពីគំនិតដែលលោក
អេលីផាសបានឮពីសារដែលគេបានឱ្យបប្រាប់គាត់។
ការនិយាយម្តងហើយម្តងទៀតគឺជាទម្រង់កំណាព្យរបស់ហេព្រើរ
ប្រើជាទូទៅក្នុងការគូសបញ្ជាក់ បង្រៀន ឬការបញ្ជាក់ឲ្យច្បាស់។
បានឮសេចក្ដីមួយយ៉ាងស្ងាត់ៗ
«អ្វីមួយដែលបាននាំបញ្ហាដល់ខ្ញុំដោយសម្ងាត់»
សុបិននៅពេលយប់
«យល់សប្តិ»
ក្នុងពេលដែលមនុស្សដេកលង់លក់ឥតដឹងខ្លួន។
«នៅពេលមនុស្សគេងលក់យ៉ាងស្កប់ស្កល់»
Job 4:14
ព័ត៌មានទូទៅ
អ្នកនិពន្ធប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរទាំងនេះ ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគផ្សេងគ្នា ដើម្បីបញ្ជាក់ពីការភ័យខ្លាចរបស់លោកអេលីផាស។
ធ្វើឲ្យខ្ញុំព្រឺសម្បុរ
ឃ្លានេះបង្ហាញពីការភ័យខ្លាចជាខ្លាំង។
ខ្ញុំភ័យខ្លាច និងរន្ធត់
ពាក្យ ភ័យខ្លាច និងរន្ធត់នៅទីនេះ និយាយពី
អ្វីមួយដែលអាចកើតឡើងមកលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានចាប់ផ្តើមខ្លាច ហើយរន្ធត់ជាខ្លាំង»។
ធ្វើឲ្យខ្ញុំព្រឺសម្បុរ
«ធ្វើឲ្យខ្ញុំបាស់រោម»
Job 4:16
ព័ត៌មានទូទៅ
អ្នកនិពន្ធប្រើពាក្យប្រៀបធៀបនៅក្នុង ខ ១៧
ដើម្បីបង្ហាញពីគំនិតដែលប្រើក្នុងប្រយោគពីរ
ដើម្បីបញ្ជាក់ពីសំណួរអំពីភាពស្អាតស្អំរបស់មនុស្សនៅចំពោះព្រះជាម្ចាស់។
មានដូចជាស្រមោលមួយនៅចំពោះមុខខ្ញុំ
«អ្វីមួយដែលនៅនឹងភ្នែករបស់ខ្ញុំ» ខ្ញុំបានឃើញអ្វីមួយ»
ខ្ញុំឮសំឡេង
នោះ ខ្ញុំបានឮសម្លេង»
«តើមនុស្សដែលតែងតែស្លាប់ សុចរិតជាងព្រះជាម្ចាស់ឬ?
លោកអេលីផាសបានសួរសំណួរនេះ ដើម្បីឲ្យលោកយ៉ូបគិត «តើខ្ញុំគិតថា
ខ្លួនឯងជាមនុស្សសុចរិត ជាងព្រះជាម្ចាស់?» ឬ
«តើខ្ញុំបានសុចរិតនៅចំពោះព្រះជាម្ចាស់ដែរឬទេ?» ឬ
«មនុស្សដែលតែងតែស្លាប់មិនអាចសុចរិតជាងព្រះជាម្ចាស់នោះទេ» ឬ
«មនុស្សដែលតែងតែសម្លាប់មិនអាចសុចរិតនៅចំពោះព្រះជាម្ចាស់បានទេ» ។
តើមនុស្សនោះបរិសុទ្ធជាអ្នកដែលបង្កើតគេមកបានទេ?
សំណួរនេះមានគោលបំណងដូចគ្នាជាមួយនឹងសំណួរពីមុន។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សមិនអាចបរិសុទ្ធជាអ្នកដែលបង្កើតគេមកទេ» ឬ
«មនុស្សមិនអាចបរិសុទ្ធនៅចំពោះអ្នកដែលបង្កើតគេមកទេ»។
អ្នកបង្កើត
«ព្រះអាទិករ»
Job 4:18
បើមនុស្សដែលមានធាតុជាដីឥដ្ឋ កើតមកពីធូលីដី ហើយដែលប្រកពរបស់គេគឺជាដី
នេះគឺជារូបភាពនៃការពណ៌នាអំពីមនុស្សលោក
ដែលបានបង្កើតមកចេញពីដីនៅលើផែនដី និងរូបកាយរបស់ពួកគេប្រៀបដូចជាផ្ទះ
ដែលសង់ពីដីឥដ្ឋ និងមានដីធ្វើជាគ្រឹះ។
គេអាចជាន់កម្ទេចដូចដង្កូវ
ពាក្យថា «យ៉ាងរហ័ស» ជាទូទៅបកប្រែថា «មុន» របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងត្រូវកម្ទេចដូចជាដង្កូវ។
អាចជាន់កម្ទេច
«មានអ្វីមួយដែលជាន់កម្ទេចពួកគេ»
អាចជាន់កម្ទេច
«ត្រូវបានសម្លាប់»
Job 4:20
ព័ត៌មានទូទៅ
ខគម្ពីរទាំងនេះ ត្រូវបានប្រើជាពាក្យប្រៀបធៀប នៅទីនេះ
បានបញ្ជាក់នៅក្នុងគំនិតផ្សេងគ្នា ដែលមនុស្សស្លាប់ដោយគ្មានចំណេះដឹង
និងគ្មានការខ្វល់ខ្វាយពីអ្នកដទៃ។
ក្នុងរវាងពេលព្រឹក និងពេលល្ងាច ពួកគេនឹងត្រូវវិនាសសូន្យទៅ
ឃ្លានេះ សំដៅលើគំនិតនៃអ្វីមួយដែលកើតឡើងយ៉ាងរហ័ស។
ពួកគេនឹងត្រូវវិនាសសូន្យទៅ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបប្រែផ្សេងទៀតនៃការបកប្រែ:
«ពួកគេស្លាប់»
តើគេមិនបានដកយកខ្សែចងត្រសាលចេញពីចំណោមពួកគេទេឬអី?
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើសត្រួររបស់ពួកគេមិនបានដកយកខ្សែចងត្រសាលចេញពីចំណោមពួកគេទេឬ?
ខ្សែចងត្រសាល
ពាក្យ ខ្សែចងត្រសាល តំណាងឲ្យត្រសាល។ ពេលខ្លះ ផ្ទះរបស់មនុស្សម្នាក់
និងគ្រួសារជារូបភាពដូចជាត្រសាលរបស់ខ្លួន
ដែលអាចតំណាងឲ្យទ្រព្យសម្បត្តិរបស់ពួកគេ។

---

5 [1]ឥឡូវនេះ សូមលោកស្រែកចុះ តើមាននរណានឹងឆ្លើយតបមកលោក? តើលោកអាចហៅទេវតាណាមួយ ឲ្យមកជួយបានទេ?[2]ដ្បិតកំហឹងរមែងសម្លាប់មនុស្សល្ងីល្ងើ
ការច្រណែនសម្លាប់អ្នកដែលផ្តេសផ្តាស។[3]ខ្ញុំធ្លាប់ឃើញមនុស្សល្ងីល្ងើបានចាក់ឫស ប៉ុន្តែ រំពេចនោះ ខ្ញុំក៏ដាក់បណ្តាសាផ្ទះរបស់គេ។
[4]កូនរបស់គាត់គឺនៅឆ្ងាយពីទីសុវត្ថិភាព ពួកគេបុកចូលមកតាមទ្វារក្រុង។ ឥតមានអ្នកណានឹងជួយពួកគេឡើយ។[5]ពួកមនុស្សអត់បាយនាំគ្នាមកស៊ី ភោគផលរបស់គេ ទោះ
បីមានបន្លាជុំវិញក៏ពួកគេស៊ីដែរ។ យកទ្រព្យសម្បត្តិធ្វើជារបស់គេ។
[6]ដ្បិតសេចក្ដីវេទនាមិនមែនដុះចេញពីធូលីដីមកទេ ហើយបញ្ហាក៏មិនមែនដុះចេញពីដីមកដែរ។[7]ផ្ទុយទៅវិញ មនុស្សកើតមក ដើម្បីរងទុក្ខវេទនា ដូចផ្កាភ្លើងដែលហើរទៅ
លើ។
[8]ប្រសិនបើខ្ញុំវិញ ខ្ញុំនឹងបែរទៅរកព្រះជាម្ចាស់ ខ្ញុំនឹងឲ្យពាក្យបណ្តាសាទៅចំពោះព្រះអង្គ[9]គឺព្រះជាម្ចាស់ដែលធ្វើការយ៉ាងធំ រកគិតមិនយល់ ជាការយ៉ាងអស្ចារ្យឥតគណនា។
[10]ព្រះអង្គបង្អុរភ្លៀងមកលើផែនដី ហើយឲ្យទឹកហូរមកក្នុងស្រែ។
[11]ព្រះជាម្ចាស់លើកមនុស្សទន់ទាបឡើង ហើយជួយសង្គ្រោះអ្នកដែលកាន់ទុក្ខ។[12]ព្រះអង្គរំលាយគម្រោងការមនុស្សមានល្បិច មិនឲ្យគេសម្រេចគម្រោងការ របស់ខ្លួនបាន
ឡើយ។[13]ព្រះអង្គធ្វើឲ្យអ្នកប្រាជ្ញ ធ្លាក់ក្នុងល្បិចកិច្ចកលរបស់ខ្លួន ហើយធ្វើឲ្យយោបល់ដ៏ប៉ិនប្រសប់ របស់ពួកគេ ប្រែជាឥតន័យ។
[14]នៅពេលថ្ងៃ ពួកគេជំពប់ជើង ដូចដើរនៅពេលយប់ងងឹត ហើយពួកគេដើរស្ទាបៗ នៅកណ្តាលថ្ងៃត្រង់ ដូចដើរនៅពេលយប់ដែរ។[15]ប៉ុន្តែ ព្រះអង្គសង្គ្រោះអ្នកក្រីក្រ ឲ្យរួច
ផុតពីមុខដាវ ពីចង្កូម និងពីកណ្តាប់ដៃដ៏ខ្លាំងពូកែរបស់ពួកគេ។[16]ដូច្នេះ សេចក្ដីសង្ឃឹម មានដល់មនុស្សទន់ខ្សោយ តែព្រះអង្គបំបិទមាត់មនុស្សទុច្ចរិត។
[17]មើល! មានពរហើយអ្នកដែលព្រះជាម្ចាស់កែតម្រូវ មិនត្រូវមាក់ងាយការស្តីបន្ទោសរបស់ព្រះជាម្ចាស់ឡើយ។[18]ដ្បិតព្រះជាម្ចាស់ធ្វើឲ្យឈឺចាប់ ធ្វើឲ្យរបួស តែព្រះអង្គនឹង
ព្យាបាលមុខរបួសនោះ ដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់។[19]ព្រះអង្គនឹងជួយលោកឲ្យរួចពីទុក្ខលំបាក ចំនួនប្រាំមួយដង នឹងទីប្រាំពីរផង គ្មានការអាក្រក់នឹង
ពាល់លោកបានឡើយ។
[20]នៅពេលកើតទុរ្ភិក្ស ព្រះអង្គរំដោះលោកពីសេចក្ដីស្លាប់ ហើយនៅពេលកើតសង្គ្រាម ព្រះអង្គរំដោះលោកពីមុខដាវ។[21]ព្រះអង្គនឹងការពារលោកពីពាក្យ បរិហាររបស់អ្នក
ដទៃ ហើយលោកក៏នឹងមិនភ័យខ្លាចមហន្តរាយ ដែលកើតឡើងដែរ។[22]លោកនឹងមិនញញើត នៅចំពោះមុខ មហន្តរាយ ការអត់ឃ្លាន សត្វសាហាវនៅផែនដីឡើយ។

generated on Wed Sep 10 16:16:32 2025

[23]ដ្បិត ស្រែចម្ការរបស់លោកនឹងគ្មានដុំថ្ម ហើយគ្មានសត្វសាហាវដែលនៅស្រែចម្ការ នឹងសុខសាន្តជាមួយលោកដែរ។[24]លោកនឹងមានសុវត្ថិភាពនៅក្នុង ទីលំនៅរបស់លោក ហើយពេលលោកមើលទៅហ្វូងសត្វ ក៏មិនឃើញមានបាត់បង់ដែរ។[25]លោកនឹងឃើញពូជពង្សរបស់លោក កើនចំនួនច្រើនឡើង កូនចៅរបស់លោកកើនចំនួន ដូចស្មៅដុះនៅតាមទីវាល។
[26]លោករស់បានអាយុវែង ស្កប់ស្កល់ ហើយលាចាកលោកនេះទៅ ដូចស្រូវទុំនៅរដូវចម្រូត។[27]មើល! យើងបានសង្កេតមើលបញ្ហានេះ ហើយឃើញថាពិតជាកើតមានដូច្នេះមែន ចូរត្រងត្រាប់ស្តាប់ ហើយយកជាមេរៀនចុះ»។

Job 5:1
តើលោកអាចហៅទេវតាណាមួយ ឲ្យមកជួយបានទេ?
លោកអេលីផាស សួរសំណួរនេះ ដើម្បីបញ្ជាក់ថា
គ្មាននរណាម្នាក់ដែលលោកយ៉ូបអាចទៅរកជំនួយបានទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «តើអ្នកទៅរកអ្នកបរិសុទ្ធណាមកជួយអ្នក? ឬ «គ្មានអ្នកបរិសុទ្ធណាមួយដែលអាចជួយអ្នកបានទេ។
អ្នកបរិសុទ្ធ
សំដៅលើប្រភេទនៃអធិធម្មជាតិ មិនថា ជាទេវតា ឬវិញ្ញាណផ្សេងៗទៀត។
អ្នកដែលផ្តេសផ្តាស...មនុស្សល្ងីល្ងើ
ឃ្លានេះសំដៅលើមនុស្សផ្តេសផ្តាស និងមនុស្សល្ងីល្ងើ។
ការច្រណែនសម្លាប់អ្នកដែលផ្តេសផ្តាស
«ការច្រណែនសម្លាប់អ្នកដែលល្ងង់ខ្លៅ និង
មនុស្សល្ងីល្ងើបានចាក់ឫស
មនុស្សម្នាក់ដែលនិយាយនៅទីនេះ គាត់ប្រៀបដូចជាដើមឈើមួយដើម
ប្រហែលជាល្ងង់កាន់តែខ្លាំងឡើងនៅពេលនោះ។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សល្ងីល្ងើបានចាក់ឫសនៅក្នុងភាពល្ងីល្ងើ»
ផ្ទះរបស់គេ
ឃ្លានេះសំដៅលើគ្រួសាររបស់អ្នកនោះ និងទ្រព្យសម្បត្តិទាំងអស់របស់គាត់។
Job 5:4
ព័ត៌មានទូទៅ
ខគម្ពីរទាំងនេះ ធ្លាប់ប្រើពីមុនជាពាក្យប្រៀបធៀប នៅត្រង់នេះ
បានបញ្ជាក់ពីវិធីគិតផ្សេងគ្នា
ដែលកូនចៅរបស់មនុស្សល្ងីល្ងើនឹងមិនមានសុវត្ថិភាពទេ។
កូនរបស់គាត់គឺនៅឆ្ងាយពីទីសុវត្ថិភាព
«របស់គាត់» នៅទីនេះ សំដៅលើមនុស្សល្ងីល្ងើ ឬមនុស្សល្ងង់នៅក្នុងជំពូក ៥:១។
របៀបផ្សេងទៀតនៃការបកប្រែ: «កូនចៅរបស់ពួកគេគ្មានសុវត្ថិភាពទេ»។
ត្រូវបានគេជាន់កម្ទេច
ត្រូវបានជាន់កម្ទេចនៅទីនេះ សំដៅលើការសង្កត់សង្កិន ត្រូវគេកេងចំណេញ
នៅកន្លែងកាត់ក្តី។ គំនិតនេះអាចដាក់ជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «មាននរណាម្នាក់ជាន់កម្ទេចពួកគេ»។
ទ្វារក្រុង
ទ្វារក្រុង មានមុខងារដូចជាកន្លែងកាត់ក្តី ជាកន្លែងដែលដោះស្រាយជម្លោះ
និងជាកន្លែងជំនុំជម្រះក្តី។
ឥតមានអ្នកណាម្នាក់ជួយពួកគេឡើយ។
«គ្មានអ្នកណាម្នាក់ជួយ
កូនចៅរបស់មនុស្សល្ងីល្ងើចេញពីទុក្ខលំបាករបស់ពួកគេឡើយ។
ពួកគេស៊ីវា ទោះបីជាមានបន្លាជុំវិញក៏ដោយ
ឃ្លានេះ ប្រហែលជាសំដៅទៅលើផ្នែកមួយនៃចម្ការ
ជាកន្លែងដែលគ្រាប់ពូជដុះមិនល្អ ដោយសារបន្លាជុំវិញ។
អ្នកស្រែកឃ្លានចង់បានទ្រព្យសម្បត្តិរបស់ពួកគេ។
ពាក្យ មនុស្សលោភនៅទីនេះ ប្រៀបដូចជាមនុស្សដែលស្រែកឃ្លាន
ហើយទ្រព្យសម្បត្តិរបស់មនុស្សដែលល្ងីល្ងើ
និយាយប្រៀបដូចជាអ្វីមួយដែលគេធឹក។
Job 5:6
ដ្បិតសេចក្តីវេទនាមិនមែនដុះចេញពីធូលីដីមកទេ ហើយបញ្ហាក៏មិនមែនដុះចេញពីដីមកដែរ។
ពាក្យទុក្ខលំបាក និងបញ្ហានៅទីនេះ ប្រៀបដូចជាដើមឈើ។
មនុស្សកើតមក ដើម្បីរងទុក្ខវេទនា ដូចផ្កាភ្លើងដែលហើរឡើងទៅលើ
មនុស្សប្រៀបដូចជាធម្មជាតិ នៅពេលពួកគេកើតមក មានបញ្ហា
គឺដូចជាផ្កាភ្លើងដែលហើរចេញពីភ្លើង។
Job 5:8
ព័ត៌មានទូទៅ
នៅក្នុងខទាំងនេះ លោកអេលីផាសបានបន្តប្រសាសន៍របស់គាត់ពីជំពូក ៤:១។
អ្នកនិពន្ធបានបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខនីមួយៗ ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីផ្សេងគ្នាដើម្បីបញ្ជាក់ថា
លោកយ៉ូបត្រូវទូលទៅព្រះជាម្ចាស់ពីបញ្ហារបស់គាត់ ដែលព្រះអង្គធ្វើការល្អអស្ចារ្យ។
ព្រះជាម្ចាស់ដែលធ្វើការយ៉ាងធំ រកគិតមិនយល់ ជាការយ៉ាងអស្ចារ្យឥតគណនា
«ការយ៉ាងធំៗដែលមិនអាចយល់បាន ការអស្ចារ្យផ្សេងៗដែលមិនអាចរាប់បាន»។
ការផ្សេងៗដែលរកយល់មិនបាន
សំដៅលើអ្វីៗដែលមនុស្សមិនអាចយល់បាន។
ការយ៉ាងធំ និងការអាថ៌កំបាំងផ្សេងៗ
នៅទីនេះ អ្នកនិពន្ធប្រើពាក្យភ្ជាប់ ដោយប្រើ «និង»
ដើម្បីបញ្ជាក់ពីភាពធំឧត្តមរបស់រាជកិច្ចរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាការដ៏ធំអស្ចារ្យណាស់»
អ្វីៗដ៏អស្ចារ្យ
«កិច្ចការដ៏អស្ចារ្យ» ឬ «ការអស្ចារ្យ»
Job 5:11
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខនីមួយៗ ដើម្បីបង្ហាញពីប្រយោគ
ដើម្បីបញ្ជាក់ពីការដែលព្រះជាម្ចាស់លើកអស់អ្នកដែលទន់ទាប
និងបន្ទាបអស់អ្នកដែលមានល្បិចកិច្ចកល។
ព្រះអង្គធ្វើបែបនេះ ដើម្បីលើកអស់អ្នកដែលទន់ទាបឲ្យខ្ពស់ឡើង
អ្នកបន្ទាបខ្លួននៅក្នុងពេលមានទុក្ខនិយាយរបៀបដូចជាពួកគេស្ថិតនៅក្នុងឋានៈទន់ទាប។
នៅពេលព្រះជាម្ចាស់សង្គ្រោះពួកគេ ពួកគេបានទទួលកិត្តិយស។
នៅពេលការនេះកើតឡើង ពួកគេនិយាយរបៀបដូចជាកំពុងតែត្រូវបានលើកឡើង
ហើយបានទៅកន្លែងដែលមានឋានៈខ្ពស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ធ្វើការនេះ ដើម្បីសង្គ្រោះ និងផ្តល់កិត្តិយសដល់អ្នកបន្ទាប់ខ្លួន
ដែលបានទទួលរងការឈឺចាប់»។
ព្រះអង្គរំលាយគម្រោងការ
ការបញ្ឆរបំផែនការរបស់មនុស្សមានល្បិចកល គឺនិយាយអំពី
អ្វីដែលអាចធ្វើឲ្យរូបកាយខូចបង់។
ព្រះអង្គធ្វើឲ្យអ្នកប្រាជ្ញ ធ្លាក់ក្នុងល្បិចកិច្ចកលរបស់ខ្លួន
នៅទីនេះ ការធ្វើឲ្យអ្នកប្រាជ្ញឈឺចាប់ ដោយព្រោះអំពើអាក្រក់របស់ពួកគេផ្ទាល់
គឺនិយាយអំពីការចាប់ពួកគេបាននៅក្នុងអន្ទាក់។ សកម្មភាពរបស់ពួកគេផ្ទាល់
គឺនិយាយអំពីការដែលពួកគេស្ថិតនៅជាប់នឹងអន្ទាក់ទាំងនោះ។
មនុស្សមានល្បិចកិច្ចកល
នៅទីនេះ ការធ្វើអាក្រក់ក្នុងបែបជាល្បិចកិច្ចកល
គឺនិយាយអំពីអ្នកដែលមានល្បិចកិច្ចកល។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលមានល្បិច» ឬ «អស់អ្នកដែលបោកប្រាសគេ» ឬ
«អស់អ្នកដែលប៉ិនប្រសប់»
Job 5:14
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរនីមួយៗ បង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីរផ្សេងគ្នា
ក្នុងការបញ្ជាក់ពីរបៀបដែលព្រះជាម្ចាស់បន្ទាបអស់អ្នកដែលមានល្បិចកិច្ចកល
ហើយសង្គ្រោះអស់អ្នកដែលក្រីក្រ។
ពួកគេជួបប្រទះភាពងងឹត នៅក្នុងពេលថ្ងៃ
មនុស្សមានល្បិចកិច្ចកល និងមនុស្សអាក្រក់ ដែលព្រះជាម្ចាស់បំភាន់ពួកគេ
គឺនិយាយអំពីការដែលពួកគេជួបនឹងភាពងងឹតនៅពេលថ្ងៃដោយមិនបានរំពឹងទុក
នៅពែលព្រះអាទិត្យកំពុងពេញកំដៅនៅលើមេឃដ៏ខ្ពស់។
ពួកគេមិនអាចធ្វើអ្វីបានតាមបំណងប្រាថ្នារបស់ពួកគេឡើយ
ដោយសារពួកគេមិនអាចមើលឃើញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលមានល្បិចកិច្ចកលគឺស្ថិតនៅក្នុងទីងងឹត
ទោះបីជានៅពេលថ្ងៃត្រង់ក្តី»
ស្ទាប

generated on Wed Sep 10 16:16:32 2025

មានអារម្មណ៍ដូចជាមនុស្សពិការភ្នែក។
ថ្ងៃត្រង់
ពេលថ្ងៃត្រង់
ប៉ុន្តែ ព្រះអង្គសង្គ្រោះអ្នកក្រីក្រឲ្យរួចផុតពីមុខដាវ នៅក្នុងចង្កូមរបស់ពួកគេ
នៅទីនេះ និយាយពីការប្រមាថ និងការគំរាមកំហែងដែលមនុស្សបាននិយាយ
ប្រៀបដូចជាដាវនៅក្នុងមាត់របស់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
ព្រះអង្គសង្គ្រោះអ្នកក្រពីការគំរាមកំហែងនៃមនុស្សមានអំណាច» ឬ «ប៉ុន្តែ
ព្រះអង្គសង្គ្រោះអ្នកក្រ នៅពេលអ្នកមានអំណាចគំរាមកំហែងឬប្រមាថពួកគេ»។
អំពើទុច្ចរិតបំបិទមាត់របស់នាងផ្ទាល់
មនុស្សដែលនិយាយមិនពិត គឺនិយាយអំពីមនុស្សដែលទុច្ចរិតដោយខ្លួនឯង។
របៀបផ្សេងទៀតនៃការបកប្រែ: «បៀបបីដូចជា
អំពើទុច្ចរិតបំបិទមាត់របស់នាងផ្ទាល់»
Job 5:17
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុង៥ ១៨ និង១៩ ដើម្បីបង្ហាញគំនិតមួយ
ដោយប្រើប្រយោគពីរ ដើម្បីបញ្ជាក់ពីការដែលព្រះជាម្ចាស់វាយផ្ចាល និងព្យាបាល។
ព្រះជាម្ចាស់កែតម្រូវ...ស្តីបន្ទោសដល់អ្នកមានអំណាច។
ព្រះជាម្ចាស់បានដាក់រូបភាពនៃឪពុកម្តាយកែតម្រង់ និងវាយផ្ចាលកូនចៅ។
មានពរ
«បានទទួលក្តីមេត្តា»
កុំមើលងាយ
«កុំបដិសេធ» ឬ «កុំគិតថាគ្មានតម្លៃ»
ការវាយផ្ចាល
«ការប្រៀនប្រដៅ» ឬ «ការកែតម្រង់» ឬ «ការទូន្មានប្រដៅ» (UDB)។
ដ្បិត ព្រះអង្គធ្វើឲ្យរបួស តែព្រះអង្គនឹងព្យាបាលមុខរបួសនោះ ព្រះអង្គធ្វើឲ្យរបួស ហើយបន្ទាប់មក
ព្រះអង្គព្យាបាលដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់។
«ដ្បិត ព្រះអង្គធ្វើឲ្យរបួស ប៉ុន្តែ ព្រះអង្គព្យាបាលរបួសនោះ ព្រះអង្គបានវាយប្រដៅ
ប៉ុន្តែ ព្រះអង្គព្យាបាលដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់។
ព្រះអង្គព្យាបាលដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់។
ពាក្យ «ព្រះអង្គព្យាបាលដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់» នៅទីនេះ
តំណាងឲ្យព្រះជាម្ចាស់។
ព្រះអង្គនឹងជួយលោកឲ្យរួចពីទុក្ខលំបាក ចំនួនប្រាំមួយដង និងទីប្រាំពីរផង គ្មានការអាក្រក់នឹង
ពាល់លោកបានឡើយ។
ការប្រើចំនួនលើស ដូចជា «ប្រាំមួយ» និង «ប្រាំពីរ» សំដៅលើច្រើនដង
ច្រើនសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គនឹងសង្គ្រោះអ្នកចេញពីបញ្ហាម្តងហើយម្តងទៀត ពិតណា
ពីមួយពេលទៅមួយពេល គ្មានការអាក្រក់ណាប៉ះអ្នកបានឡើយ។
Job 5:20
ព័ត៌មានទូទៅ
នៅប្លុកទ្រង់ពី «គាត់» ទៅ «អ្នក» ដែលចាប់ផ្តើមនៅក្នុងជំពូក ៥:១៧
បន្តរហូតដល់លោកអេលីផាសនិយាយចប់នៅក្នុង ជំពូក ៥:២៦
នៅពេលកើតទុរ្ភិក្ស ព្រះអង្គសង្គ្រោះអ្នក
«ពេលកើតទុរ្ភិក្ស ព្រះជាម្ចាស់នឹងសង្គ្រោះអ្នក»
សង្គ្រោះអ្នក
«លោះអ្នក» ឬ «ប្រោសលោះអ្នក» ឬ «សង្គ្រោះអ្នកពីគ្រោះថ្នាក់»
សេចក្តីហិនវិនាស
«គ្រោះថ្នាក់ពីខ្មាំងសត្រូវ»
អ្នកមិនខ្លាចសត្វសាហាវឡើយ
«អ្នកនឹងមិនខ្លាចសត្វសាហាវឡើយ»។
សត្វសាហាវ
សត្វដែលមិនបានផ្សាំង ឬ បង្វឹក។
Job 5:23
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបតាមខនីមួយៗ
ដើម្បីបង្ហាញពីគំនិតមួយដោយប្រើប្រយោគពីផ្សេងគ្នា
ក្នុងការបញ្ជាក់ពីសុវត្ថិភាពនៅក្នុងពិភពលោក និងលំនៅ
និងកូនចៅរបស់នរណាម្នាក់។
អ្នកនឹងមានសម្ពន្ធមេត្រីជាមួយនឹង ត្បូងនៅក្នុងចម្ការរបស់អ្នក
ប្រយោគនេះប្រើជាពាក្យប្រៀបធៀបនៅក្នុងភាសា
ដើម្បីបង្ហាញពីភាពស៊ីចង្វាក់គ្នារបស់ធម្មជាតិនៅក្នុងពិភពលោក។
របៀបផ្សេងទៀតនៃការបកប្រែ:
«សម្ពន្ធមេត្រីរបស់អ្នកគឺជាត្បូងនៅក្នុងចម្ការរបស់អ្នក»។
អ្នកនឹងមានសន្តិភាពជាមួយនឹងសត្វសាហាវ
«សត្វសាហាវនឹងមានសន្តិភាពជាមួយអ្នក»
សត្វសាហាវ
សត្វសាហាវជាសត្វដែលមិនបានផ្សាំង ឬបង្វឹក
លោកនឹងបានដឹងថា ត្រសាលរបស់លោកស្ថិតនៅកន្លែងមានសុវត្ថិភាព
«លោកនឹងដឹងថា ត្រសាលរបស់លោកមានសេចក្តីសុខ»។
ពេលលោកទៅមើលហ្វូងសត្វរបស់លោក ហើយក៏មិនឃើញមានបាត់បង់ដែរ។
«ពេលលោកទៅមើលហ្វូងសត្វ នឹងមិនមានអ្វីបាត់បង់ឡើយ»
លោកនឹងបានដឹងថាពូជពង្សរបស់លោក នឹងមានចំនួនកើនច្រើនឡើង កូនចៅរបស់លោក
នឹងបានជាដូចស្មៅដុះនៅតាមទីវាល។
នៅក្នុងការបៀបធៀបនេះ «ពូជពង្ស» គឺជារូបភាព នៃចំនួនស្លឹកស្មៅ»។
«លោកក៏នឹងបានដឹងផងដែរថា ពូជពង្សរបស់លោកនឹងមានគ្នាច្រើន
ហើយពូជពង្សរបស់លោកនឹងដូចជាស្មៅដែលដុះនៅលើផែនដី»
Job 5:26
លោករស់បានអាយុវែង ស្កប់ស្កល់ ហើយលាចាកលោកនេះទៅ
«លោកនឹងស្លាប់ទៅក្នុងអាយុដ៏វែង»
ដូចស្រូវទុំនៅនឹងកណ្តាប់ដែលបានយកទៅបញ្ជាន់នៅទីលាន។
លោកអេលីផាសប្រើពាក្យប្រៀបធៀបនេះ
ដើម្បីបង្កើតចំណុចមួយដែលលោកយ៉ូបនឹងស្លាប់
ព្រោះវាជាពេលដែលគាត់ត្រូវស្លាប់ហើយ។ របៀបបកប្រែផ្សេងទៀត:
«ដូចជាគ្រាប់ស្រូវដែលគេបានច្រូចកាត់នៅពេលកំណត់ ដូច្នេះ លោកនឹងត្រូវស្លាប់
នៅពេលកំណត់របស់វា។
មើល! យើងបានសង្កេតមើលបញ្ហានេះ ហើយឃើញថាពិតជាកើតមានដូច្នេះមែន ចូរត្រងត្រាប់ស្តាប់
ហើយយកជាមេរៀនចុះ»។
«យើង» សំដៅលើមិត្តសំឡាញ់របស់លោកយ៉ូប បូករួមទាំងលោកអេលីផាស
ដែលជាអ្នកនិយាយដែរ។ របៀបផ្សេងទៀតនៃការបកប្រែ: «មើល៍
យើងបានគិតពីបញ្ហានេះ។ សូមស្តាប់ចំពោះអ្វីដែលខ្ញុំកំពុងនិយាយ
ហើយដឹងថាវាគឺជាការពិត»។

---

6 [1]ពេលនោះលោកយ៉ូបឆ្លើយថា៖[2]«ប្រសិនបើគេថ្លឹងការឈឺចាប់របស់ខ្ញុំ ប្រសិនបើគេយកទុក្ខលំបាករបស់ខ្ញុំដាក់លើជញ្ជីង![3]ដ្បិតវាអាចធ្ងន់ជាងខ្សាច់ នៅតាមឆ្នេរសមុទ្រ
ទៅទៀត។ ហេតុនេះហើយបានជាខ្ញុំនិយាយលែងរួច។
[4]ដ្បិតព្រួញរបស់ព្រះដ៏មានឫទ្ធានុភាពជាប់ទម្លុះខ្ញុំ ពិសពុលរបស់ព្រួញទាំងនោះជ្រួតជ្រាប ពេញក្នុងសរពាង្គកាយរបស់ខ្ញុំ ព្រះជាម្ចាស់ធ្វើឲ្យខ្ញុំភ័យញាប់ញ័រ ដូចមានសត្រូវ
តម្រៀបគ្នាជាក្បួនទ័ពវាយប្រហារខ្ញុំ។[5]ពេលមានស្មៅខៀវខ្ចីស៊ី តើលាព្រៃដែលស្រែកឬទេ? ពេលមានចំបើងស៊ី តើគោចេះតែរោទ៍ដែរឬ?[6]តើគេអាចបរិភោគម្ហូបសាប ដោយ
មិនបង់អំបិលកើតឬ? តើផ្នែកសរបស់ពងមាន់មានរសជាតិដែរឬ?
[7]ខ្ញុំមិនចង់បរិភោគអាហារទាំងនោះទេ ព្រោះជាអាហារដែលខ្ញុំស្អប់ខ្ពើម។[8]សូមឲ្យសំណូមពររបស់ខ្ញុំបានសម្រេច ហើយសូមព្រះជាម្ចាស់ប្រោសប្រទាន តាមសេចក្តីសង្ឃឹម
របស់ខ្ញុំ។[9]គឺសូមព្រះជាម្ចាស់មេត្តាកិនកម្ទេចខ្ញុំ សូមព្រះអង្គលាតព្រះហស្ត បង្ហើយអាយុជីវិតរបស់ខ្ញុំទៅចុះ!
[10]ធ្វើដូច្នេះ ខ្ញុំដូចជាបានលែ ហើយទោះបីខ្ញុំឈឺចាប់ដល់កម្រិតក្តី ក៏ខ្ញុំមានអំណរសប្បាយដែរ ព្រោះខ្ញុំមិនបានបោះបង់ចោល ព្រះបន្ទូលរបស់ព្រះដ៏វិសុទ្ធឡើយ។
[11]តើកម្លាំងខ្ញុំមកពីណាដែលធ្វើឲ្យមានសង្ឃឹមនោះ? តើទីបញ្ចាប់របស់ខ្ញុំគ្រាន់តែពន្យាពេលជីវិតខ្ញុំឬ?
[12]តើខ្ញុំមានកម្លាំងខ្ញុំដូចជាដូចថ្មឬ? ហើយរូបកាយខ្ញុំដូចលង្ហិនឬ?[13]ក្នុងខ្លួនខ្ញុំ ខ្ញុំលែងមានអ្វីជាទីពឹងឬជំនួយទៀតហើយ
ហើយចំណេះដឹងរបស់ខ្ញុំបានរឹងហួតអស់ហើយឬ?

generated on Wed Sep 10 16:16:32 2025

[14]អ្នកដែលរងទុក្ខគ្រាំគ្រា គួរតែទទួល ចិត្តមេត្តាករុណាពីមិត្តភក្តិរបស់ខ្លួន បើមិនដូច្នេះទេ គេមុខជាលែងគោរព កោតខ្លាចព្រះជាម្ចាស់ ។[15]ប៉ុន្តែ បងប្អូនរបស់ខ្ញុំបានធ្វើឲ្យខ្ញុំ
ខកចិត្ត ដូចទឹកជ្រោះដែលរីង ដូចជ្រលងដងអូរដែលគ្មានទឹក។[16]នៅចុងរដូវត្រជាក់ ទឹកអូរទាំងនោះប្រែជាល្អក់កករ ព្រោះតែព្រិល និងទឹកកករលាយ។[17]នារដូវក្តៅ អូរទាំង
នោះរីងស្ងួតនៅនឹងកន្លែង ព្រោះតែកម្តៅថ្ងៃ ហើយក៏រលាយនៅតាមកន្លែងរបស់វាទៅ។
[18]ក្បួនអ្នកដំណើរតាមផ្លូវនោះ ពួកគេក៏បែរទៅម្ខាងដើម្បីទឹក ពួកគេចូលទៅវាលរហោស្ថាន ហើយវិនាសបាត់បង់អស់ទៅ។[19]ក្បួនអ្នកដំណើរពីទឹកដីថេម៉ា នាំគ្នាសម្លឹងមើល
អូរទាំងនោះ ក្បួនអ្នកដំណើរពីទឹកដីសេបានាំគ្នា សង្ឃឹមលើអូរទាំងនោះ។[20]ប៉ុន្តែ ពួកគេត្រូវខូចចិត្ត ព្រោះតែទុកចិត្តលើអូរទាំងនោះ។ ពួកគេបានទៅដល់ទីនោះ
តែពួកគេត្រូវបានគេបោកប្រាស់។
[21]ដ្បិតពេលនេះ សម្លាញ់ទាំងអស់គ្នាមិនបានជួយអ្វីដល់ខ្ញុំទេ ពួកអ្នកឃើញខ្ញុំមានអាសន្ន ហើយបែរជាភ័យខ្លាច។[22]តើខ្ញុំបាននិយាយទៅកាន់អ្នកអស់គ្នាថា យករបស់អ្វី
មួយមកឲ្យខ្ញុំ? ឬយកប្រាក់របស់អស់មកជួយខ្ញុំឡើយ?[23]ខ្ញុំមិនដែលសុំអស់លោកជួយខ្ញុំ ឲ្យរួចផុតពីកណ្តាប់ដៃរបស់បច្ចាមិត្ត ឬក៏សុំឲ្យលោះខ្ញុំពីកណ្តាប់ដៃ
នៃជំងឺរបស់ខ្ញុំឬ?
[24]សូមប្រៀនខ្ញុំផង ហើយខ្ញុំនឹងនៅស្ងៀម សូមប្រាប់ខ្ញុំផង ដើម្បីឲ្យបានយល់ពីកំហុស។[25]ពាក្យសម្តីត្រឹមត្រូវ នោះពូកែបណ្តាលយ៉ាងណា តើតែសេចក្តីបន្ទោសរបស់អ្នក
រាល់គ្នា បានបន្ទោសអ្វីខ្លះដល់ខ្ញុំ?
[26]ពាក្យដែលខ្ញុំនិយាយនេះ តើអស់លោកចង់បន្ទោសកន្លែងណា តើអស់លោកយល់ថាពាក្យសម្តីរបស់ មនុស្សអស់សង្ឃឹម ឥតបានការឬ?[27]អស់លោកហ៊ានដល់ទៅចាប់
ឆ្នោតយកក្មេងកំព្រា ហើយសូម្បីតែមិត្តសម្លាញ់ ក៏អស់លោកមិនញញើតនឹងលក់ដែរ។
[28]ឥឡូវនេះ ចូរបែរមកមើលមុខខ្ញុំឲ្យចំ ដ្បិត ពិតណាស់ខ្ញុំនិយាយបំផ្លើសត្រង់ណា។[29]ខ្ញុំសូមអង្វរទៅចុះ កុំចោទខ្ញុំជ្រុលពេក ហើយក៏កុំអយុត្តិធម៌បែបនេះដែរ កុំចោទខ្ញុំជ្រុល
ពេក ខ្ញុំគ្មានកំហុសអ្វីសោះ។[30]តើអណ្តាតខ្ញុំដែលគ្រលាស់ចេញមកនូវពាក្យទុច្ចរិត ហើយមាត់របស់ខ្ញុំស្រដីចេញមក នូវពាក្យអពមង្គលឬទេ?

Job 6:1

ប្រសិនបើគេថ្លឹងការឈឺចាប់របស់ខ្ញុំ ប្រសិនបើគេយកទុក្ខលំបាករបស់ខ្ញុំដាក់លើជញ្ជីង!

នៅទីនេះ អ្នកនិពន្ធប្រើប្រយោគពីរផ្សេងគ្នា ដើម្បីបង្ហាញពីគំនិតមួយ
គឺពីបន្ទុកនៃការឈឺចាប់របស់លោកយ៉ូប។

ដាក់លើជញ្ជីង

«នៅជញ្ជីង»

ដ្បិត វាអាចធ្ងន់ជាងខ្សាច់ នៅតាមឆ្នេរសមុទ្រទៅទៀត

លោកយ៉ូបបានប្រៀបធៀបពីបន្ទុកនៃការឈឺចាប់របស់លោកទៅនឹងទម្ងន់នៃខ្សាច់ទទឹក
។ «បន្ទុកនៃទុក្ខវេទនា និង បញ្ហារបស់ខ្ញុំធ្ងន់ជាងខ្សាច់នៅតាមឆ្នេរសមុទ្រទៅទៀត»
ទាំងពីរនេះ អាចបំផ្លាញមនុស្ស។

Job 6:4

ព័ត៌មានទូទៅ

អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀប នៅក្នុងខនីមួយៗនេះ ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីរផ្សេងគ្នា ដើម្បីបញ្ជាក់ពីការរងទុក្ខវេទនារបស់លោកយ៉ូប
ប្រៀបដូចជាកន្លែងដែលគាត់អាចតវ៉ាបាន។

ដ្បិត ព្រួញរបស់អ្នកដែលខ្លាំងពូកែបាញ់ទម្លុះខ្ញុំ

នេះគឺជាពាក្យប្រៀបធៀបសម្រាប់ការឈឺចាប់របស់លោកយ៉ូប។
លោកបានប្រៀបធៀបការឈឺចាប់ទៅនឹងព្រួញដែលចាក់ទម្លុះរូបកាយរបស់លោក។

វិញ្ញាណរបស់ខ្ញុំពេញទៅដោយជាតិពុល

ពាក្យប្រៀបធៀបនៅតែបន្ត។
ការឈឺចាប់បានជ្រៀតចូលទៅក្នុងលោកយ៉ូបដល់ចំណុចស្នូលរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមានអារម្មណ៍ឈឺចាប់ដល់ឆ្អឹងរបស់ខ្ញុំ»។

សេចក្តីស្ញែងខ្លាចរបស់ព្រះជាម្ចាស់បានប្រមូលគ្នាតម្រៀបគ្នាប្រឆាំងនឹងខ្ញុំ

របៀបផ្សេងទៀតនៃការបកប្រែ: «ការអាក្រក់ទាំងប៉ុន្មានដែលបានកើតឡើង
បានប្រឆាំងជាមួយនឹងខ្ញុំនៅពេលមួយ»។

តម្រៀបគ្នា

«ដូចជាកងវរសេនាធំ» ឬ «ដូចជាទាហានមួយកងពល»។

ពេលមានស្មៅខៀវខ្ចីស៊ី តើលាព្រៃដែលស្រែកឬទេ? ពេលមានចំបើងស៊ី តើគោចេះតែរោទ៍ដែរឬ?

លោកយ៉ូបសួរសំណួរទាំងនេះដើម្បីបញ្ជាក់ថា លោកបានហេតុយ៉ាងល្អក្នុងការតវ៉ា។
របៀបផ្សេងទៀតនៃការបកប្រែ: «តើខ្ញុំត្រូវតវ៉ាទេ បើជីវិតរបស់ខ្ញុំអត់មានបញ្ហា?» ឬ
«តើខ្ញុំតវ៉ាធ្វើអ្វី ប្រសិនបើ អ្វីៗគ្រប់យ៉ាងដំណើរការល្អ?» ឬ «ខ្ញុំមិនតវ៉ា
ដោយឥតហេតុផលទេ»។

លាស្រែក

«សម្លេងលាស្រែក»

គោរោទ៍

សម្លេងគោរោទ៍

ចំបើង

អាហាររបស់សត្វ

តើគេអាចបរិភោគម្ហូបសាប ដោយមិនបង់អំបិលកើតឬ? តើផ្នែកសរបស់ពងមាន់មានរសជាតិដែរឬ?

ទោះបីជាអាហារ ឬស្ថានភាព នៅក្នុងជីវិតរបស់លោកប៉ូលឈឺចាប់យ៉ាងណា។
លោកយ៉ូបបានប្រៀបធៀបជីវិតរបស់គាត់ទៅនឹងរដូវកាល និងរស់ជាតិ។
«ជីវិតរបស់ខ្ញុំគ្មានជាតិប្រៃទេ វាដូចជាពងមាន់ដែលគ្មានរសជាតិ»។

តើគេអាចបរិភោគម្ហូបសាប ដោយមិនបង់អំបិលកើតឬ?

សំណួរនេះ អាចបកប្រែបានជាប្រយោគសកម្ម:
«មនុស្សមិនអាចបរិភោគអាហារដែលមិនបានដាក់អំបិលនោះទេ»។

Job 6:7

ព័ត៌មានទូទៅ

អ្នកនិពន្ធបន្តប្រើសំណួរបៀបធៀបនៅក្នុងខនីមួយៗ ដើម្បីបង្ហាញគំនិតមួយ
ដោយប្រើប្រយោគពីរផ្សេងគ្នា

ក្នុងការបញ្ជាក់ពីការឈឺចាប់យ៉ាងខ្លាំងរបស់លោកយ៉ូប និងលោកប្រាថ្នាចង់ស្លាប់។

ខ្ញុំមិនចង់បរិភោគអាហារទាំងនោះទេ

ពាក្យ «អាហារ» សំដៅលើអាហារដែលគ្មានរសជាតិ។ នៅទីនេះ
លោកយ៉ូបប្រើរូបភាពនៃអាហារដែលគ្មានរសជាតិ
សម្រាប់ជីវិតរបស់លោកដែលស្ថិតនៅក្នុងស្ថានភាពអាក្រក់។

សូមឲ្យសំណូមពររបស់ខ្ញុំបានសម្រេច ហើយសូមព្រះជាម្ចាស់ប្រោសប្រទាន តាមសេចក្តីសង្ឃឹម
របស់ខ្ញុំ។

របៀបផ្សេងទៀតនៃការបកប្រែ: «ឱ
សូមព្រះជាម្ចាស់បានធ្វើអ្វីដែលទូលបង្គំបានទូលព្រះអង្គទៅចុះ»។

សូមព្រះជាម្ចាស់មេត្តាកិនកម្ទេចខ្ញុំ

របៀបផ្សេងទៀតនៃការបកប្រែ: «សូមព្រះជាម្ចាស់ធ្វើតាមព្រះហឫទ័យរបស់ព្រះចុះ
គឺកម្ទេចទូលបង្គំចុះ»។

សូមព្រះអង្គលាតព្រះហស្ត បង្ហើយអាយុជីវិតរបស់ខ្ញុំទៅចុះ!

របៀបផ្សេងទៀតនៃការបកប្រែ: «សូមព្រះអង្គធ្វើការលឿនៗ
ហើយកាត់ជីវិតរបស់ទូលបង្គំទៅ»។

សូមទ្រង់លាតព្រះហស្តរបស់ព្រះអង្គ

«លាតព្រះហស្តជាប្រញាប់»

Job 6:10

ធ្វើដូច្នេះ ខ្ញុំដូចជាបានល្ហែ

«ធ្វើដូច្នេះ ខ្ញុំដូចជាបានល្ហែ» ឬ «សូមឲ្យការនេះបានលួងលោមទូលបង្គំ»
ហើយទោះបីខ្ញុំឈឺចាប់ដល់កម្រិតក្តី ក៏ខ្ញុំមានអំណរសប្បាយដែរ

«ខ្ញុំអាចនឹងលោកដោយអំណរនៅក្នុងការឈឺចាប់ដោយមិនចេះចប់ក្តី» ឬ
«ខ្ញុំអាចស៊ូទ្រាំការឈឺចាប់ដែលមិនបានធូស្បើយក្តី»

អំណរសប្បាយ

«អរសប្បាយ»

មិនចេះចប់ក្តី

«មិនបានធូស្បើយក្តី»

ព្រោះខ្ញុំមិនអាចបដិសេធចោល ព្រះបន្ទូលរបស់ព្រះដ៏វិសុទ្ធឡើយ

«ខ្ញុំមិនបានបដិសេធព្រះជាម្ចាស់បានទេ»

តើកម្លាំងខ្ញុំមកពីណាដែលធ្វើឲ្យមានសង្ឃឹមនោះ? តើទីបញ្ចាប់របស់ខ្ញុំគ្រាន់តែពន្យាពេលជីវិតខ្ញុំឬ?

លោកយ៉ូបសួរសំណួរទាំងនេះ ដើម្បីបញ្ជាក់ថា
វាគ្មានចំណុចណាដែលគាត់ត្រូវបន្តរស់ទៀតទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ក្រៅពីនេះ តើមានអ្វីផ្សេងទៀតសម្រាប់ខ្ញុំ ក្នុងការរស់នៅបន្តទៀត
ហើយបន្តទៅមុខទៀត? ឬ «ខ្ញុំគ្មានកម្លាំងបន្តរស់ទៀតទេ
ខ្ញុំក៏គ្មានហេតុនឹងអត់ធ្មត់ទៀតទេ»។

generated on Wed Sep 10 16:16:32 2025

Job 6:12
ព័ត៌មានទូទៅ
អ្នកនិពន្ធប្រើសំណួរដែលមិនទាមទារចម្លើយ នៅក្នុងខនីមួយៗ
ដើម្បីបង្ហាញពីគំនិតមួយ ដោយប្រើប្រយោគពីរផ្សេងគ្នា
ក្នុងការបញ្ជាក់ពីការខ្វះកម្លាំងរបស់លោកយ៉ូបក្នុងការទ្រាំទ្រជាមួយនឹងការឈឺចាប់ឡើយ។
តើខ្ញុំមានកម្លាំង ខ្លាំងដូចជាថ្មឬ? ហើយរូបកាយខ្ញុំដូចលង្ហិនឬ?
លោកយ៉ូបបង្ហាញពីភាពទន់ខ្សោយនៃរូបកាយរបស់គាត់ទៅនឹងភាពលំបាក
ទៅនឹងភាពធន់នៃសម្ភារអគារ ដើម្បីបញ្ជាក់ភាពកម្សោយរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនរឹងមាំដូចជាថ្មទេ។
រូបកាយរបស់ខ្ញុំក៏មិនរឹងមាំដូចជាដែកដែរ»។
តើវាមិនមែនជាការពិតទេឬដែខ្ញុំគ្មានជំនួយសម្រាប់ខ្លួនខ្ញុំទេ...ខ្ញុំ?
របៀបផ្សេងទៀតនៃការបកប្រែ:
«វាគឺជាការពិតដែលខ្ញុំគ្មានកម្លាំងនៅសល់ឡើយ...ខ្ញុំ»
តើប្រាជ្ញារបស់ខ្ញុំបានរីងហូតអស់ហើយឬ?
«ភាពជោគជ័យរបស់ខ្ញុំបានយកចេញពីខ្ញុំ» ឬ
កម្លាំងខាងក្នុងរបស់ខ្ញុំបានរីងស្ងួតពីខ្ញុំអស់ហើយ»
នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«កម្លាំងខាងក្នុងរបស់ខ្ញុំបានរីងស្ងួតអស់ហើយ»។
Job 6:14
ចំពោះ អ្នកដែលរងទុក្ខគ្រាំគ្រា គួរតែទទួល ចិត្តមេត្តាករុណាពីមិត្តភក្តិរបស់ខ្លួន បើមិនដូច្នេះទេ គេមុខ
ជាលែងគោរព កោតខ្លាចព្រះជាម្ចាស់
«មិត្តសម្លាញ់គួរតែប្រព្រឹត្តល្អចំពោះអ្នកដែលមានអារម្មណ៍អស់សង្ឃឹម»
បើមិនដូច្នេះទេ គេមុខជាលែងគោរពកោតខ្លាចព្រះជាម្ចាស់
«ទោះបីជាគាត់ឈប់គោរពកោតខ្លាចព្រះជាម្ចាស់» អាចមានន័យថា ទី១)
មនុស្សដែលមិនកោតខ្លាចព្រះជាម្ចាស់ ឬ ២)
មិត្តសម្លាញ់របស់គាត់មិនបានកោតខ្លាចព្រះជាម្ចាស់។
ប៉ុន្តែ បងប្អូនរបស់ខ្ញុំបានធ្វើឲ្យខ្ញុំខកចិត្ត ដូចទឹកជ្រោះដែលរីង ដូចជ្រលងដងអូរដែលគ្មានទឹក
លោកយ៉ូបកំពុងពណ៌នាពីមិត្តសម្លាញ់របស់គាត់ដូចជា «បឹងរីងស្ងួត»
ដែលមានខ្សែទឹក តែអាចនឹងរីងស្ងួតភ្លាមៗ ហើយមិនអាចអាចពឹងអាស្រ័យបាន។
ដូចទឹកជ្រោះដែលរីង ដូចជ្រលងដងអូរដែលគ្មានទឹក
«ដូចជាខ្សែទឹកដែលរីងស្ងួត»
នៅចុងរដូវត្រជាក់ ទឹកអូរទាំងនោះប្រែជាល្អក់កករ ព្រោះតែព្រិល និងទឹកកករលាយ
«ដែលងងឹតដូចជាទឹកកក»
ហើយព្រោះតែព្រិល ដែលបានលាក់វានៅក្នុងពួកគេ
«ហើយព្រិលបានលាក់វា» ឬ «ព្រិលបានធ្វើឲ្យមើលវាលែងឃើញ»
នៅពេលវារលាយ វានឹងរលាយអស់
«ពេលថ្ងៃក្តៅឡើង វានឹងរលាយអស់»
ពេលកម្តៅថ្ងៃក្តៅឡើង វានឹងរលាយនៅនឹងកន្លែងរបស់វាតែម្តង»
«ពេលវាក្តៅ វានឹងរលាយ»
Job 6:18
ក្បួនអ្នកដំណើរតាមផ្លូវនោះ ពួកគេក៏បែរទៅម្ខាងដើម្បីទឹក
លោកយ៉ូបបន្តការពណ៌នារបស់គាត់ពីមិត្តសម្លាញ់របស់គាត់
ដែលមិនអាចទុកចិត្តបាន ដូចជាខ្សែទឹកដែលរីងស្ងួត។
របៀបផ្សេងទៀតនៃការបកប្រែ:
«ផ្លូវរបស់អ្នកដំណើរបានផ្លាស់ប្តូរដោយព្រោះស្វែងរកទឹក»។
ក្បួនអ្នកធ្វើដំណើរ
ឃ្លានេះអាចត្រូវបានបកប្រែថា: «ផ្លូវនៃក្បួនអ្នកដំណើរ» ឬ «ផ្លូវរបស់អ្នកដំណើរ»
ឬ «អ្នកដំណើរ»។
ពួកគេចូលទៅវាលរហោស្ថាន ហើយវិនាសបាត់បង់អស់ទៅ
«ពួកគេនឹងវង្វេង ហើយបន្ទាប់មកពួកគេនឹងស្លាប់»
ថេម៉ា
នេះគឺជាឈ្មោះរបស់ទីកន្លែង។ ប្រជាជនដែលនៅកន្លែងនោះប្រើក្បួនធ្វើដំណើរ
ដើម្បីធ្វើពានិជ្ជកម្មជាមួយប្រជាជនផ្សេងទៀតពីទឹកដីផ្សេង។
ក្នុងការដែលក្បួនអ្នកដំណើរពីទឹកដីសេបានាំគ្នា សង្ឃឹមលើវា
«ក្នុងពេលអ្នកដំណើរពីសេបាសង្ឃឹមមើលវា»
សេបា
នេះគឺជាឈ្មោះរបស់ទីកន្លែង។ ប្រជាជនដែលនៅកន្លែងនោះប្រើក្បួនធ្វើដំណើរ
ដើម្បីធ្វើពានិជ្ជកម្មជាមួយប្រជាជនផ្សេងទៀតពីទឹកដីផ្សេង។
សង្ឃឹមលើអូរទាំងនោះ
«សង្ឃឹមលើវា» ឬ «ដាក់សេចក្តីសង្ឃឹមរបស់ពួកគេលើវា»
ពួកគេបានខកចិត្ត ព្រោះតែពួកគេទុកចិត្តថានឹងបានទឹកពីអូរទាំងនោះ។
«ពួកគេរង្វេង ដោយសារពួកគេបានទុកចិត្តថា ពួកគេអាចរកទឹកបាននៅទីនោះ»។
តែពួកគេត្រូវបានគេបោកប្រាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ពួកគេបានខកចិត្ត» ឬ «ប៉ុន្តែ
ពួកគេបានមិនបានស្តប់ចិត្តទេ»
Job 6:21
ព័ត៌មានទូទៅ
នៅក្នុងខទាំងនេះ លោកយ៉ូបសួរបួនសំណួរ
ដើម្បីស្តីបន្ទោសមិត្តសម្លាញ់របស់លោក និងដើម្បីបញ្ជាក់ថា
គាត់មិនសុំជំនួយពីពួកគេណាម្នាក់ទេ។
ដ្បិត ឥឡូវនេះ
លោកយ៉ូបប្រើឃ្លានេះ ដើម្បីណែនាំផ្នែកចម្បងនូវអ្វីដែលគាត់បាននិយាយ។
សម្លាញ់ទាំងអស់គ្នាមិនបានជួយអ្វីដល់ខ្ញុំទេ
«អ្នករាល់គ្នាមិនបានប្រព្រឹត្តដូចជាមិត្តសម្លាញ់របស់ខ្ញុំទេ»
បែរជាភ័យខ្លាច
«ហើយអ្នករាល់គ្នាខ្លាចថា ព្រះជាម្ចាស់អាចនឹងប្រព្រឹត្តអ្វីៗដូចជាអ្នកដែរ» (UDB)។
នៅទីនេះគម្ពីរ (UDB)
បានលាក់ទាំងស្រុងនូវព័ត៌មានដែលមិត្តសម្លាញ់របស់គាត់ខ្លាចព្រះជាម្ចាស់ដាក់ទោសពួកគេ។
តើខ្ញុំបាននិយាយទៅកាន់អ្នកអស់គ្នាថា យករបស់អ្វីមួយមកឲ្យខ្ញុំ?
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនបានសូមអ្វីពីអ្នករាល់គ្នាទេ»។
តើអ្នករាល់គ្នាបានយកទ្រព្យសម្បត្តិរបស់អ្នករាល់គ្នាមកជួយខ្ញុំទេ?
របៀបផ្សេងទៀតនៃការបកប្រែ: «តើខ្ញុំបានសុំប្រាក់ពីអ្នករាល់គ្នាទេ?» ឬ
«ខ្ញុំមិនបានសុំអ្នករាល់គ្នាឲ្យផ្តល់ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នាមកក្នុងឃ្លាំងរបស់ខ្ញុំទេ»។
ជួយខ្ញុំ ឲ្យរួចផុតពីកណ្តាប់ដៃរបស់បច្ចាមិត្ត ?
«បច្ចាមិត្តរបស់ខ្ញុំ» គឺជាពាក្យប្រៀបធៀបដែលជំនួសឲ្យអំណាចរបស់នរណាម្នាក់
ដែលប្រឆាំងជាមួយលោកយ៉ូបយ៉ាងខ្លាំង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិនដែលសុំអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាឲ្យសង្គ្រោះខ្ញុំពីខ្មាំងសត្រូវរបស់ខ្ញុំឡើយ»
។
លោះខ្ញុំពីកណ្តាប់ដៃនៃអ្នកសង្កត់សង្កិនខ្ញុំឬទេ?
«ពីដៃនៃអ្នកសង្កត់សង្កិនរបស់ខ្ញុំ» គឺជាពាក្យប្រៀបធៀបមួយដែលតំណាង
ឲ្យអំណាចរបស់នរណាម្នាក់ដែលប្រព្រឹត្តអាក្រក់ដាក់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិនបានសុំអ្នករាល់គ្នាឲ្យសង្គ្រោះខ្ញុំពីអស់អ្នកដែលប្រព្រឹត្តអាក្រក់ដាក់ខ្ញុំ»។
លោះខ្ញុំ
«សង្គ្រោះខ្ញុំ»
Job 6:24
សូមបង្រៀនខ្ញុំផង
កិរិយាសព្ទ «បង្រៀន» គឺជាទម្រង់បុរសទីពីរពហុវចន:។
ហើយខ្ញុំនឹងនៅស្ងៀម
«ហើយខ្ញុំនឹងស្ងៀមស្ងាត់»
សូមប្រាប់ខ្ញុំឲ្យបានយល់ផង
របៀបបកប្រែផ្សេងទៀត: «សូមអ្នករាល់គ្នាជួបប្រាប់ខ្ញុំឲ្យយល់ផង»។
កិរិយាសព្ទនេះស្ថិតនៅក្នុងទម្រង់បុរសទីពីរពហុវចន:។
ពាក្យពិតឈឺចាប់ណាស់
កណ្ឌគម្ពីរ ULB និង UDB មានន័យផ្ទុយគ្នាសម្រាប់ឃ្លានេះ។
នេះដោយសារអត្ថន័យរបស់ភាសាហេព្រើរ ន័យទី ១)
ពាក្យពិតឈឺចាប់នៅពេលបានឮវា ឬទី២)
ពាក្យរបស់មនុស្សពិតត្រង់មិនឈឺចាប់ពេលឮទេ។
ប៉ុន្តែ ការប្រកែកគ្នារបស់អ្នករាល់គ្នា តើអាចបន្ទោសអ្វីលះដល់ខ្ញុំបាន?
លោកយ៉ូបប្រើសំណួរនេះ ដើម្បីស្តីបន្ទោសដល់មិត្តសម្លាញ់
ហើយបញ្ជាក់ថាអ្វីដែលពួកគេនិយាយមិនអាចអនុវត្តជាមួយនឹងលោកទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុផលអ្នករាល់គ្នាមិនអាចអនុវត្តជាមួយខ្ញុំបានទេ ទោះបីជាអ្នករាល់គ្នា
ព្យាយាមកែតម្រង់ជាមួយខ្ញុំយ៉ាងខ្លាំងក្តី»។
ការប្រកែកគ្នារបស់អ្នករាល់គ្នា
«ហេតុផលរបស់អ្នករាល់គ្នា» ឬ «ការអះអាងរបស់អ្នករាល់គ្នា»
ប្រើក្នុងទម្រង់ជាបុរសទីពីរ ពហុវចន:។
Job 6:26

generated on Wed Sep 10 16:16:32 2025

តើអ្នករាល់គ្នាមានផែនការចង់បដិសេធពាក្យខ្ញុំ
ចង់ប្រព្រឹត្តចំពោះពាក្យរបស់មនុស្សសង្ឃឹមថាជាឥតបានការឬ?
លោកយ៉ូបប្រើសំណួរនេះ ដើម្បីស្តីបន្ទោសមិត្តសម្លាញ់របស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករាល់គ្នាបានប្រងើយកន្តើយចំពោះពាក្យរបស់ខ្ញុំ
ហើយប្រព្រឹត្តជាមួយពាក្យខ្ញុំដូចជាពាក្យខ្ញុំនោះជាខ្យល់ដូច្នេះ»។
តើអ្នករាល់គ្នា
«អ្នករាល់គ្នា» គឺជាបុរសទីពីរពហុវចន:។
ប្រព្រឹត្តជាមួយពាក្យខ្ញុំដូចជាពាក្យខ្ញុំនោះជាខ្យល់ដូច្នេះ»។
លោកយ៉ូបប្រៀបធៀបពាក្យរបស់មនុស្សអស់សង្ឃឹម ដែលចង់បានជំនួយ
ដូចជាខ្យល់ទទេស្អាត ទាំងពីរនេះគឺឥតបានការ។
លោកហ៊ានដល់ទៅចាប់ឆ្មោតយកក្មេងកំព្រា
«អ្នករាល់គ្នាលែងល្បិចដើម្បីយកឈ្នះក្មេងកំព្រា»
អ្នករាល់គ្នាចាប់ឆ្មោត...ដេញថ្លៃមិនសម្លាប់របស់អ្នករាល់គ្នា
ពាក្យ «អ្នករាល់គ្នា» និង «របស់អ្នករាល់គ្នា» នៅទីនេះ គឺជាបុរសទីពីរពហុវចន។
ហើយដេញថ្លៃមិនសម្លាញ់របស់អ្នករាល់គ្នាដូចជាទំនិញ
«ហើយបានជីករណ្តៅសម្រាប់មិត្តសម្លាញ់របស់អ្នករាល់គ្នា»។
Job 6:28
ឥឡូវនេះ
លោកយ៉ូបបានប្រើពាក្យនេះ ដើម្បីណែនាំព័ត៌មានថ្មី។
សូមមើល
«មើល» ជាកិរិយាសព្ទ គឺជាទម្រង់បុរសទីពីរពហុវចន។
មុខរបស់អ្នក
«របស់អ្នក» គឺជាទម្រង់បុរសទីពីរពហុវចន។

ខ្ញុំសូមអង្វរទៅចុះ កុំចោទខ្ញុំជ្រុលពេក
«សូមមេត្តាដល់ខ្ញុំផង» ឬ «សូមត្រឡប់មកវិញមក៍»
ខ្ញុំសូមអង្វរទៅចុះ
នេះជាកិរិយាសព្ទ ទម្រង់បុរសទីពីរពហុវចន។
សូមកុំឲ្យមានអំពើអយុត្តិធម៌ជាមួយអ្នករាល់គ្នាឡើយ
«សូមប្រព្រឹត្តជាមួយខ្ញុំឲ្យស្មើភាព»
សូមមេត្តាដល់ខ្ញុំផង តាមពិតទៅ ករណីរបស់ខ្ញុំត្រឹមត្រូវទេ។
«សូមបួរពីរបៀបដែលអ្នកបានប្រព្រឹត្តជាមួយខ្ញុំសារជាថ្មី ខ្ញុំត្រឹមត្រូវទេ
នៅក្នុងការនេះ» ឬ «សូមបួររបៀបនៃការប្រព្រឹត្តជាមួយខ្ញុំ ខ្ញុំត្រឹមត្រូវនឹងការនេះ»។
ខ្ញុំសូមអង្វរទៅចុះ
នេះជាកិរិយាសព្ទ ទម្រង់បុរសទីពីរពហុវចន។
តើមានការអាក្រក់នៅក្នុងអណ្តាតខ្ញុំដែលឬទេ?
«តើខ្ញុំនិយាយការអាក្រក់មែនទេ?» លោកយ៉ូបប្រើសំណួរនេះ
ដើម្បីស្តីបន្ទោសមិត្តសម្លាញ់របស់គាត់ ហើយដើម្បីបញ្ជាក់ថា
គាត់មិនមែនមនុស្សអាក្រក់ទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិននិយាយការអាក្រក់ទេ»។
ហើយមាត់របស់ខ្ញុំស្រដីចេញមក នូវពាក្យអពមង្គលឬទេ?
លោកយ៉ូបប្រើសំណួរនេះដើម្បីស្តីបន្ទោសមិត្តសម្លាញ់របស់គាត់
ហើយដើម្បីបញ្ជាក់ថា គាត់អាចប្រាប់ពីភាពខុសគ្នារវាងខុសឆ្គង និងត្រឹមត្រូវ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំអាចប្រាប់ពីភាពខុសគ្នា រវាងការល្អ
និងការអាក្រក់»។
តើមានការអាក្រក់នៅក្នុងអណ្តាតខ្ញុំដែលឬទេ?
អណ្តាតមិនអាចមានការអាក្រក់នៅលើវាខាងសាច់ឈាមបានទេ ដូច្នេះ
ពាក្យប្រៀបធៀបនេះ ប្រើដើម្បីពណ៌នាពីសំដីអាក្រក់។

---

7 [1]តើមនុស្សមិនបានធ្វើការលំបាកនៅលើផែនដីទេ? តើមនុស្សមិនបានដូចជាថ្ងៃ របស់អ្នកស៊ីឈ្នួលទេឬអី?[2]ដូចជាទាសករប្រាថ្នាជ្រកក្រោមម្លប់ ហើយអ្នកស៊ីឈ្នួលទន្ទឹង
រង់ចាំប្រាក់ឈ្នួលយ៉ាងបែបនោះដែរ[3]ខ្ញុំក៏ទទួលការឈឺចាប់ជាច្រើនខែ ហើយរងទុក្ខសោកជាច្រើនយប់ បែបយ៉ាងនោះដែរ។
[4]ពេលខ្ញុំផ្ដេកខ្លួនលួនចុះ នោះក៏ខ្ញុំនិយាយថា៖ តើពេលណាខ្ញុំនឹងក្រោកឡើង និងពេលណាទើបយប់នឹងបានឆ្លងផុត? ហើយខ្ញុំចេះតែប្រៃខ្លួននិងងាកចុះឡើង រហូតដល់
ទៀបភ្លឺឡើង។[5]រូបកាយរបស់ខ្ញុំមានសុទ្ធតែដង្កូវ និងក្រមរ ស្បែករបស់ខ្ញុំប្រេះ ហើយរលួយស្អុយផង។
[6]អាយុជីវិតរបស់ខ្ញុំបោះពួយទៅមុខ លឿនជាងត្រល់របស់អ្នកត្បាញ ពេលណាអស់អំបោះ គ្មានអ្វីសង្ឃឹមទៀតដែរ។[7]ព្រះជាម្ចាស់នឹកចាំផងថា ជីវិតរបស់ទូលបង្គំ ប្រៀប
បាននឹងមួយដង្ហើមទេ ហើយភ្នែករបស់ទូលបង្គំ នឹងមើលអ្វីល្អមិនឃើញទេ។
[8]ព្រះអង្គទតមកទូលបង្គំ តែលែងឃើញទូលបង្គំទៀតហើយ ព្រះអង្គនឹងខំរកមើលទូលបង្គំ តែទូលបង្គំបាត់សូន្យទៅ។[9]ពពកតែងតែរសាត់បាត់ទៅ រីឯអ្នកដែលចុះទៅស្ថាន
មនុស្សស្លាប់ ក៏ពុំអាចឡើងមកវិញបានដែរ។[10]គេនឹងមិនវិលត្រឡប់មកផ្ទះវិញទេ ញាតិសន្តានក៏លែងស្គាល់គេទៀតដែរ។
[11]ហេតុនេះ ទូលបង្គំមិនអាចបិតមាត់បានឡើយ ទូលបង្គំត្រូវតែនិយាយនៅពេលពិបាកចិត្ត ទូលបង្គំនឹងតួញត្អែរក្នុងការជូរល្វីញនៅក្នុងព្រលឹងរបស់ទូលបង្គំ។[12]តើទូលបង្គំ
ជាសមុទ្រ ឬជាសត្វរស់ក្នុងសមុទ្រ ដែលព្រះអង្គបានទូតមើលទូលបង្គំត្រូវទេ?
[13]ទូលបង្គំពោលថា៖ គ្រែដែលខ្ញុំដំណេក ជួយឲ្យខ្ញុំបានល្ហែ រួចផុតពីការឈឺចាប់[14]ដ្បិត ព្រះអង្គធ្វើឲ្យទូលបង្គំភ័យតក់ស្លុត ដោយយល់សប្តិអាក្រក់ ព្រះអង្គធ្វើឲ្យទូលបង្គំញ័រ
រន្ធត់ ដោយឃើញសុបិននិមិត្តមិនល្អ។[15]ទូលបង្គំចង់អត់ដង្ហើមស្លាប់ ជាជាងរស់ក្នុងរូបកាយដែលសល់តែឆ្អឹងនេះ។
[16]ស្អប់ជីវិតរបស់ទូលបង្គំណាស់ ទូលបង្គំមិនចង់រស់រហូតទេ សូមទុកទូលបង្គំឲ្យនៅតែឯង ដ្បិតជីវិតរបស់ទូលបង្គំគ្មានន័យអ្វីសោះ។[17]តើមនុស្សលោកជាអ្វី បានជាព្រះអង្គ
យកព្រះហឫទ័យទុកដាក់នឹងគេ ព្រះអង្គនឹកគិតដល់គេបែបនេះ[18]ព្រះអង្គពិនិត្យមើលគេរៀងរាល់ព្រឹក ព្រះអង្គល្បងលគេគ្រប់ពេលវេលាពិតទេ?
[19]តើព្រះអង្គនៅតែឃ្លាំមើលទូលបង្គំ ដល់កាលណាទៀត សូមទុកឲ្យទូលបង្គំមានពេល លេបទឹកមាត់ផង?[20]ព្រះអង្គដែលជាឆ្មាំយាមមនុស្សលោកអើយ ប្រសិនបើទូលបង្គំ
បានប្រព្រឹត្តអំពើបាបមែន តើទូលបង្គំបានធ្វើអ្វីទាស់នឹងព្រះអង្គ? ហេតុអ្វីបានជាព្រះអង្គចាត់ទុកទូលបង្គំ ដូចជាផ្នាំងស៊ីប តើទូលបង្គំបានធ្វើអ្វីរំខានដល់ព្រះអង្គ?
[21]តើព្រះអង្គលើកលែងទោសឲ្យទូលបង្គំ និងលុបលាងកំហុសរបស់ទូលបង្គំបានឬទេ? ដ្បិតបន្តិចទៀត ទូលបង្គំនឹងដេកលើដី ព្រះអង្គនឹងរកទូលបង្គំ តែទូលបង្គំសូន្យបាត់
ទៅហើយ»។

Job 7:1
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរនីមួយៗ
ដើម្បីបង្ហាញគំនិតមួយដោយប្រើប្រយោគពីរផ្សេងគ្នា ក្នុងការបញ្ជាក់ថា
គាត់ឈឺចាប់របស់គាត់ គឺជាចំណែកនៃការឈឺចាប់សកល
ដែលមនុស្សគ្រប់គ្នាមានបទពិសោធ។
តើមនុស្សមិនបានធ្វើការលំបាកនៅលើផែនដីទេ?
លោកយ៉ូបសួរសំណួរ ដើម្បីបញ្ជាក់ការដឹងឮរបស់គាត់ថា
មនុស្សទាំងអស់នឹងជួបការឈឺចាប់។ របៀបផ្សេងទៀតនៃការប្រែ:
«តើមិនមែនគ្រប់គ្នាត្រូវធ្វើការទាំងនឿយហត់នៅលើផែនដីទេឬអី? ឬ
«មនុស្សគ្រប់គ្នាខំធ្វើការយ៉ាងខ្លាំងនៅលើផែនដី»
តើមនុស្សមិនបានដូចជាថ្ងៃ របស់អ្នកស៊ីឈ្នួលទេឬអី?
លោកយ៉ូបសួរសំណួរនេះ ដើម្បីបញ្ជាក់ពីការយល់ដឹងរបស់គាត់ថា
មនុស្សទាំងអស់មានបញ្ហាក្នុងជីវិត។ របៀបផ្សេងទៀតនៃការបកប្រែ:

«ហើយថ្ងៃរបស់មនុស្សរបៀបដូចជាថ្ងៃរបស់មនុស្សដែលគេជួលមកធ្វើការដែរ»។
ដូចជាទាសករ...ហើយអ្នកស៊ីឈ្នួល
លោកយ៉ូបបៀបធៀបខ្លួនរបស់គាត់ផ្ទាល់
ជ្រកក្រោមម្លប់នៅពេលល្ងាច
«ម្លប់»
អ្នកស៊ីឈ្នួល
បុរសនេះដែលធ្វើការមួយថ្ងៃម្តង ហើយបង់ថ្លៃនៅពេលល្ងាច ជារៀងរាល់ថ្ងៃ។
«ធ្វើការមួយថ្ងៃ»
ហើយខ្ញុំក៏ស្ថិតនៅក្នុងការរងទុក្ខលំបាកជាច្រើនយប់ដែរ។
ជាច្រើនយប់ «ដូច្នេះ ខ្ញុំបានស៊ូទ្រាំទុក្ខលំបាកជាច្រើនខែ
និងបញ្ហាជាច្រើនយប់ដែរ»។
ការរងទុក្ខលំបាកជាច្រើនយប់
«អន្តរាយជាច្រើនខែ» «គ្មានបានអ្វីជាច្រើនខែ»
Job 7:4

generated on Wed Sep 10 16:16:32 2025

តើេពលណាខ្ញុំនឹងក្រោកឡើង ហើយតើពេលណាទើបយប់បានកន្លងផុតទៅ?
លោកយ៉ូបសួរសំណួរនេះ ដើម្បីបញ្ជាក់បពីការឈឺចាប់ជាខ្លាំងរបស់គាត់
ក្នុងអំឡុងពេលយប់ដែលគាត់គេង។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំសង្ឃឹមថា
ខ្ញុំនឹងក្រោកឡើង ប៉ុន្តែ យប់នៅតែបន្ត»។
ហើយខ្ញុំចេះតែប្រះខ្លួននិងងាកចុះឡើង
ឃ្លានេះ បញ្ជាក់ថាលោកយ៉ូបរើចុះឡើងនៅលើគ្រែរបស់ពេញមួយយប់
គ្មានបានសម្រាប់ឡើយ។
«ខ្ញុំធុញនឹងការប្រែខ្លួនចុះឡើងដោយគ្មានបានសម្រាក់នេះណាស់»។
ក្រមរស្បែក
«ក្រមរដី»
Job 7:6
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរនីមួយៗ ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីរផ្សេងគ្នា ក្នុងការបញ្ជាក់ពីអារម្មណ៍ទុក្ខលំបាកនៃជីវិត»។
អាយុជីវិតរបស់ខ្ញុំបោះពួយទៅមុខ លឿនជាងត្រល់របស់អ្នកត្បាញ
«ជីវិតខ្ញុំកន្លងទៅលឿនខ្លាំងណាស់»។
ត្រល់
មនុស្សដែលធ្វើសំលៀកបំពាក់ដោយសារត្បាញជាមួយនឹងត្រល់ ឬ អំបោះ
ត្រល់របស់អ្នកត្បាញ
ត្រល់ជារបស់ដែលគេបោះទៅបោះមកយ៉ាងលឿននៅក្នុងម៉ាស៊ីន ឬ
ឧបករណ៍សម្រាប់ធ្វើសំលៀកបំពាក់។
ពួកគេបោះទៅមកដោយគ្មានសង្ឃឹម
«វាបានមកដល់ទីបញ្ចប់ ជាមួយនឹងភាពអស់សង្ឃឹមទាំងស្រុង»។
ព្រះជាម្ចាស់នឹកចាំផងថា ជីវិតរបស់ទូលបង្គំ
ពាក្យថា «ព្រះជាម្ចាស់» ត្រូវបានបូករួមជាមួយនឹងឃ្លានេះ ដោយមនុស្សបានឮថា
«នឹកចាំ» អាចយល់បានថា ព្រះជាម្ចាស់ជាអ្នកមានបន្ទូល។
ជីវិតរបស់ទូលបង្គំ ប្រៀបបាននឹងមួយដង្ហើមទេ
នៅក្នុងពាក្យប្រៀបធៀបនេះ
លោកយ៉ូបប្រៀបធៀបពីទុក្ខលំបាកនៅក្នុងជីវិតរបស់គាត់ ទៅនឹងការដកដង្ហើម
មួយដង្ហើម។ «ជីវិតរបស់ខ្ញុំខ្លីណាស់ ដូចជាដកដង្ហើមមួយដង្ហើមដូច្នេះដែរ»។ ។
ភ្នែករបស់ទូលបង្គំនឹងមើលអ្វីល្អមិនឃើញទេ
«ទូលបង្គំនឹងមិនមានបទពិសោធជាមួយសុភមង្គលម្តងទៀតឡើយ»។
Job 7:8
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរនីមួយៗ ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីរផ្សេងគ្នា ក្នុងការបង្ហាញពីគំនិតរបស់លោកយ៉ូបថា
បន្ទាប់ពីស្លាប់ទៅ មិនថា ព្រះជាម្ចាស់ឬមនុស្សទេ គេនឹងបានឃើញគាត់សារជាថ្មី។
ព្រះនេត្ររបស់ព្រះជាម្ចាស់ ដែលទតឃើញទូលបង្គំ នឹងលែងឃើញទូលបង្គំទៀតហើយ
ពាក្យ «ព្រះជាម្ចាស់» ត្រូវបានបូកមកជាមួយនៅក្នុងឃ្លានេះ ព្រោះបរិបទនៅទីនេះ
បង្ហាញថា លោកយ៉ូបជាអ្នកទូលទៅព្រះជាម្ចាស់។
«ព្រះនេត្រដែលទតឃើញទូលបង្គំ នឹងទតលែងឃើញទៀតហើយ» ។
ពពកតែងតែរសាត់បាត់ទៅយ៉ាងណា អ្នកដែលចុះទៅស្ថានមនុស្សស្លាប់ ក៏ពុំអាចឡើងមកវិញបាន
យ៉ាងនោះដែរ។
លោកយ៉ូបកំពុងពណ៌នាពីសេចក្តីស្លាប់ប្រៀបដូចជាពពកដែលរសាត់បាត់ទៅ។
«ដូចជាពពកដែលរសាត់បាត់ទៅ ដូច្នេះ អ្នកដែលស្លាប់ទៅក៏ដូច្នោះដែរ» ឬ
«នៅពេលអ្នកនៅក្នុងផ្នូរ អ្នកមិនអាចក្រោកឡើងបានទេ»។
ពពកតែងតែរសាត់បាត់ទៅ
«ដូចជាពពកដែលរលាយសាបសូន្យ»
Job 7:11
ទូលបង្គំត្រូវតែនិយាយនៅពេលពិបាកចិត្ត ទូលបង្គំនឹងតូញត្អែរ
ពីភាពជូរល្វីញនៅក្នុងព្រលឹងរបស់ទូលបង្គំ។
លោកយ៉ូបបង្ហាញពីគំនិតមួយ ដោយប្រើប្រយោគពីរផ្សេងគ្នា
ក្នុងការបញ្ជាក់ពីហេតុផលដែលគាត់មិនព្រមស្ងាត់។
ទូលបង្គំមិនអាចបិតមាត់បានឡើយ
«ទូលបង្គំមិនព្រមឈប់និយាយឡើយ»
ពេលពិបាកចិត្ត ទូលបង្គំនឹងតូញត្អែរ
«សេចក្តីទុក្ខវេទនានៅក្នុងវិញ្ញាណរបស់ទូលបង្គំ» ឬ «ការឈឺចាប់ជាខ្លាំង
នៅក្នុងទុក្ខវេទនារបស់ទូលបង្គំ»
ភាពជូរល្វីងនៅក្នុងព្រលឹងរបស់ទូលបង្គំ
«ការអាក់អន់ចិត្តនៅក្នុងព្រលឹងរបស់ខ្ញុំ»
តើទូលបង្គំជាសមុទ្រ ឬជាសត្វនាគឬ បានជាព្រះអង្គដាក់អ្នកយាមឲ្យមើលទូលបង្គំ?
លោកយ៉ូបសួរសំណួរនេះ ដើម្បីបង្ហាញពីកំហឹងរបស់គាត់ចំពោះព្រះជាម្ចាស់។
ដោយប្រៀបធៀបខ្លួនរបស់គាត់ទៅនឹង សមុទ្រ ឬសត្វនាគ
លោកយ៉ូបានសូមព្រះជាម្ចាស់ការពារគាត់ដូចជាសត្វដែលគួរខ្ពើម។
«ទូលបង្គំមិនមែនជាសមុទ្រ ឬ ជាសត្វនាគដែលត្រូវការអ្នកចាំយាមនោះទេ»។
Job 7:13
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខពីរដំបូង ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីរផ្សេងគ្នា ក្នុងការបញ្ជាក់ពីការឈឺចាប់យ៉ាងខ្លាំងរបស់គាត់។
គ្រែដេករបស់ទូលបង្គំនឹងជួយឲ្យខ្ញុំបានល្ហែ
ហើយគ្រែទម្រេតរបស់ទូលបង្គំនឹងជួយសម្រាលការអ្ស់ទាំរបស់ទូលបង្គំ
ពាក្យ «គ្រែ» និង «គ្រែទម្រេត» នៅទីនេះ គឺជាន័យធៀបសម្រាប់ «គេង»។
ដាក់ខ្លួនដើម្បីដេក លោកយ៉ូបសង្ឃឹមថានឹងបានល្ហែ។
ពាក្យប្រៀបធៀបគឺនិយាយពីលក្ខណៈសម្បត្តិរបស់មនុស្ស
ពួកគេមានលទ្ធភាពក្នុងការបានសម្រាក ហើយជាមនុស្សបានបានល្ហែដែរ។
ព្រះអង្គធ្វើឲ្យទូលបង្គំញ័ររន្ធត់
«ព្រះអង្គ» សំដៅលើព្រះជាម្ចាស់ ដែលលោកយ៉ូបកំពុងតែរអ៊ូជាមួយ។
ច្របាច់ក
សម្លាប់មនុស្សម្នាក់ដោយច្របាច់បំពងករបស់គាត់ ដើម្បីកុំឲ្យដកដង្ហើមរួច។
រូបកាយដែលសល់តែឆ្អឹងនេះ
នៅទីនេះ លោកយ៉ូបប្រើពាក្យ «ឆ្អឹង» ដើម្បីសំដៅលើរូបកាយរបស់គាត់។
របៀបផ្សេងទៀតក្នុងការបកប្រែ: «រូបកាយនេះជារបស់ទូលបង្គំ»
Job 7:16
ប្រយោគភ្ជាប់
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរទាំងនេះ ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីរផ្សេងគ្នា
ក្នុងការបញ្ជាក់ពីឥទ្ធិពលនៃទុក្ខលំបាករបស់លោកយ៉ូបនៅក្នុងអារម្មណ៍នៃការឲ្យតម្លៃខ្លួនឯង។
ទូលបង្គំស្អប់ជីវិតរបស់ទូលបង្គំណាស់
«ទូលបង្គំស្អប់ជីវិតរបស់ទូលបង្គំ»
ចង់រស់រហូត
«ចង់រស់រហូតអស់កល្បជានិច្ច»
ជីវិតរបស់ទូលបង្គំគ្មានន័យអ្វីសោះ
«ជីវិតខ្ញុំគ្មានប្រយោជន៍ទេ» ឬ «ជីវិតរបស់ខ្ញុំគ្មានតម្លៃទេ»
តើមនុស្សលោកជាអ្វី បានជាព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងគេ
«ដែលព្រះអង្គឃ្លាំមើលគេដូច្នេះ»
ព្រះអង្គនឹកគិតដល់គេបែបនេះ
«ដែលព្រះអង្គនាំយកការយកចិត្តទុកដាក់ដល់គេដូច្នេះ»
ព្រះអង្គពិនិត្យមើលគេ
«បានជាព្រះអង្គយកព្រះទ័យទុកដាក់ដល់គេដូច្នេះ»
Job 7:19
តើព្រះអង្គនៅតែឃ្លាំមើលទូលបង្គំ ដល់កាលណាទៀត សូមទុកឲ្យទូលបង្គំមានពេល លេបទឹកមាត់
ផង?
នៅទីនេះ លោកយ៉ូបបានបង្ហាញពីគំនិតមួយ
ដោយប្រើសំណួរជាពាក្យប្រៀបធៀបពីរ ដើម្បីបញ្ជាក់ពីគោលបំណងរបស់គាត់
សូមឲ្យព្រះអង្គឈប់មើលគាត់ទៀត។ «សូមកុំទតមកទូលបង្គំទៀត!
សូមចេញឆ្ងាយពីទូលបង្គំ សូមទុកឲ្យទូលបង្គំមានពេលលេបទឹកមាត់ផង។
(សូមមើល: សូមមើល
ប្រសិនបើទូលបង្គំបានប្រព្រឹត្តអំពើបាប តើទូលបង្គំបានធ្វើអ្វីទាស់នឹងព្រះអង្គ? ហេតុអ្វីបានជា
ព្រះអង្គចាត់ទុកទូលបង្គំ
លោកយ៉ូបសួរសំណួរនេះ ដើម្បីស្តីបន្ទោស ដល់ព្រះជាម្ចាស់។ «ប្រសិនបើ
ទូលបង្គំបានធ្វើបាបមែន ទូលបង្គំមិនអាចធ្វើអ្វីបានដែរ
ជាមួយអ្នកដែលពិនិត្យមនុស្ស»។ (សូមមើល:
ហេតុអ្វីបានជាព្រះអង្គចាត់ទុកទូលបង្គំ ដូចជាផ្ទាំងស៊ីប...ព្រះអង្គ?
«ហេតុអ្វីបានជាព្រះអង្គចាត់ទុកទូលបង្គំជាផ្ទាំងស៊ីបរបស់ព្រះអង្គដូច្នេះ?»
Job 7:21
ហេតុអ្វីបានជាព្រះអង្គលើកលែងទោសអំពើរំលង និងលុបលាងកំហុសរបស់ទូលបង្គំបានឬទេ?
នៅទីនេះ លោកយ៉ូបប្រើឃ្លាពីរ នៅក្នុងសំណួរប្រៀបធៀបមួយ
ដើម្បីបញ្ជាក់ពីបំណងចិត្តរបស់គាត់ថា ព្រះជាម្ចាស់បានអត់ ទោសបាបដល់គាត់។

generated on Wed Sep 10 16:16:32 2025

លោកបានសួរសំណួរនេះដើម្បីស្តីបន្ទោសព្រះជាម្ចាស់ដែលធ្វើឲ្យគាត់ឈឺចាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមអត់ទោសអំពើរំលង
និងលុបលាងកំហុសរបស់ទូលបង្គំផង» សូមមើល: និង
ហេតុអ្វីបានជាព្រះអង្គលើកលែងទោសអំពើរំលងរបស់ទូលបង្គំ
«ហេតុអ្វីបានជាមិនអត់ទោសអំពើរំលងរបស់ទូលបង្គំ»
លុបលាងកំហុស
«ដកយកចេញ»
ទូលបង្គំនឹងដេកលើដី
ឃ្លា «ដេកនៅលើដី» និយាយក្នុងរបៀបស្លូតបូត និងសុភាពរាបសារគឺ «ស្លាប់»
«ទូលបង្គំនឹងស្លាប់នៅពេលនេះ»

---

8 [1]លោកប៊ីលដាដ ជាជនជាតិស៊ូអា បានឆ្លើយតបថា៖[2]«តើលោកនៅតែមានប្រសាសន៍បែបនេះ ដល់កាលណាទៀត? តើលោកបញ្ចេញពាក្យសម្តី ដូចខ្យល់កំបុតត្បូង
ដល់កាលណាទៀត? តើព្រះជាម្ចាស់បង្ខូចយុត្តិធម៌ឬ?[3]តើព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត បង្ខូចសេចក្តីសុចរិតឬ?
[4]ប្រសិនបើកូនប្រុសរបស់លោកប្រព្រឹត្ត អំពើបាបទាស់នឹងព្រះហឫទ័យរបស់ព្រះអង្គ ព្រះអង្គដាក់ទោសពួកគេ តាមកំហុសដែលខ្លួនបានប្រព្រឹត្ត។[5]ប៉ុន្តែលោកវិញ គួរតែស្វែងរកព្រះអង្គ បើលោកអង្វរករព្រះដ៏មានឫទ្ធានុភាព ខ្ពង់ខ្ពស់បំផុត។
[6]បើលោកពិតជាបរិសុទ្ធ និងទៀងត្រង់មែន ព្រះអង្គមុខជាជួយលោក ហើយស្តារស្ថានភាពរបស់លោក ឲ្យបានយុត្តិធម៌ឲ្យលោកដែរ។[7]ទោះបីលោកបានចាប់ផ្តើមតូចតែនៅចុងក្រោយ ទុក្ខលំបាករបស់លោកនឹងប្រសើរឡើង។
[8]ហេតុនេះ សូមសាកសួរចាស់ទុំនៅជំនាន់មុន ហើយរំពឹងគិតអំពីបទពិសោធន៍ ដែលដូនតារបស់លោករៀនបាន។[9](ដ្បិតយើងជាមនុស្សទើបនឹងកើត យើងមិនដឹងអ្វីទាំងអស់ អាយុជីវិតរបស់យើងនៅលើផែនដីនេះ ប្រៀបដូចជាស្រមោល)។[10]តើចាស់ទុំមិនបានបង្រៀនលោកទេ? តើចាស់ទុំនឹងមិនបានប្រាប់លោកពីអ្វីដែលនៅក្នុងចិត្តគេទេ?
[11]តើដើមត្រែងអាចដុះនៅក្រៅត្រពាំង? ហើយដើមកក់អាចដុះនៅកន្លែង ដែលគ្មានទឹកបានឬ?[12]ពេលវានៅខៀវខ្ចី ទោះបីគ្មាននរណាកាត់ក៏ដោយ ក៏វាក្រៀមស្ងួត មុនតិណជាតិផ្សេងដែរ។
[13]ដូច្នេះ អស់អ្នកដែលបំភ្លេចព្រះជាម្ចាស់ ក៏ធ្លាក់ខ្លួនដូច្នោះដែរ សេចក្តីសង្ឃឹមរបស់មនុស្សអាក្រក់ នឹងវិនាស។[14]បង្អែករបស់គេត្រូវបាក់ អ្វីៗដែលគេទុកចិត្ត ប្រៀបដូចជាសំបុកពីងពាង។[15]គេផ្អែកលើផ្ទះរបស់ខ្លួន តែផ្ទះរលំ គេខំប្រឹងតោងផ្ទះ តែផ្ទះមិននៅស្ថិតស្ថេរឡើយ។
[16]រុក្ខជាតិនៅក្រោមពន្លឺថ្ងៃពណ៌បៃតង ព្រោះសម្បុរណ៌កម្តៅថ្ងៃ ហើយបែកមែកសាខាពាសពេញឧទ្យាន។[17]ឫសរបស់គេចាក់ស្រេះទៅក្នុងដីដែលមានថ្ម ហើយរុកទៅដល់ផ្ទាំងសិលា។[18]ប៉ុន្តែ ពេលណាគេត្រូវរម្លើងចេញពីកន្លែង របស់ខ្លួនហើយនោះ សូម្បីតែញាតិសន្តាន ក៏លែងរាប់រកគេទៀតដែរ។
[19]មើល! នេះគឺជា «អំណរ» ចេញពីការប្រព្រឹត្តរបស់មនុស្ស ហើយមានអ្នកផ្សេងទទួលកន្លែងជំនួសគេ។[20]ព្រះជាម្ចាស់មិនបោះបង់ចោល មនុស្សគ្មានកំហុសឡើយ ហើយព្រះអង្គក៏មិនពង្រឹងអំណាចរបស់ អស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់ដែរ។
[21]បន្តិចទៀត ព្រះអង្គនឹងប្រទានឲ្យលោក សើចសប្បាយ ហើយឲ្យលោកបន្លឺសំឡេងបានវិញ។[22]អស់អ្នកដែលស្អប់លោកនឹងត្រូវអាម៉ាស់ ហើយលំនៅរបស់មនុស្សអាក្រក់នឹង រលាយសូន្យ»។

Job 8:1
ព័ត៌មានទូទៅ
នៅក្នុងខនីមួយៗនៃការនិយាយរបស់លោកប៊ីលដាដ បង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីផ្សេងគ្នា ទីមួយក្នុងការស្តីបន្ទោសលោកយ៉ូប
និងការពារព្រះជាម្ចាស់។
លោកប៊ីលដាដ ជាជនជាតិស៊ូអា បានឆ្លើយតប
«ប៊ីលដាដ» គឺឈ្មោះរបស់បុរសម្នាក់ដែលជាសមាជិកនៃកុលសម្ព័ន្ធស៊ូអា។
តើលោកបញ្ចេញពាក្យសម្តីរ ដូចខ្យល់កំបុតត្បូងដល់កាលណាទៀត?
លោកប៊ីលដាដសួរសំណួរនេះដើម្បីស្តីបន្ទោសលោកយ៉ូបដែលរអ៊ូរទាំចំពោះព្រះម្ចាស់។
នៅក្នុងពាក្យប្រៀបធៀបនេះ ទាំងពាក្យរបស់លោកយ៉ូប និងខ្យល់គឺគ្មានអ្វីទាំងអស់
ហើយគ្មានប្រយោជន៍។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពាក្យនៅក្នុងមាត់របស់អ្នកគឺជាខ្យល់ព្យុះយ៉ាងខ្លាំង»។
តើព្រះជាម្ចាស់បង្ខូចយុត្តិធម៌ឬ? តើព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត បង្ខូចសេចក្តីសុចរិតឬ?
នៅទីនេះ អ្នកនិពន្ធប្រើសំណួរដែលមិនទាមទារចម្លើយពីរជាពាក្យប្រៀបធៀប
ដែលលោកប៊ីលដាដសួរ ដើម្បីស្តីបន្ទោសលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់មិនប្រព្រឹត្តអំពើអយុត្តិធម៌ឡើយ
ព្រះដ៏មានព្រះចេស្តាមិនដែលខាននឹងធ្វើអ្វីដែលត្រឹមត្រូវឡើយ»។
Job 8:4
ព្រះអង្គដាក់ទោសពួកគេ តាមកំហុសដែលខ្លួនបានប្រព្រឹត្ត
«ដោយសារព្រះជាម្ចាស់អនុញ្ញាតឲ្យពួកគេធ្លាក់ទៅក្នុងអំណាចអំពើបាប
ដើម្បីគ្រប់គ្រងពួកគេ»។ ឬ
«ព្រះអង្គដាក់ទោសពួកគេដោយព្រោះលទ្ធផលនៃអំពើបាបរបស់ពួកគេ»។
ប៉ុន្តែ ឧបមាថាលោកខំស្វែងរកព្រះជាម្ចាស់ បើអង្វរករព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត
ឃ្លាទាំងពីរនេះសំដៅលើលោកយ៉ូបទូលសូមព្រះជាម្ចាស់ឲ្យជួយ
ឬទូលសូមព្រះគុណពីព្រះជាម្ចាស់។
ខំស្វែងរកព្រះជាម្ចាស់
«ខំប្រឹងទូលសុំឲ្យព្រះជាម្ចាស់ជួយ»
Job 8:6
ឧបមាថាលោកពិតជាបរិសុទ្ធ និងទៀងត្រង់មែន
ប្រសិនបើ មានតែលោកទេដែលបរិសុទ្ធ ហើយសុចរិត» ឬ «ប្រសិនបើចិត្ត
និងការប្រព្រឹត្តរបស់លោកត្រឹមត្រូវ»។
ទោះបីលោកបានចាប់ផ្តើមតូច តែនៅចុងក្រោយ លោកនឹងប្រសើឡើង។
«ទោះបីជាលោកមិនសូវចម្រុងចម្រើនពីមុន ប៉ុន្តែ
នៅក្នុងអំឡុងពេលចុងក្រោយរបស់លោក លោកនឹងក្លាយជាអ្នកមានស្តុកស្តម្ភ»។
Job 8:8
ព័ត៌មានទូទៅ
អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងនីមួយៗ ដើម្បីបង្ហាញពីគំនិតពីរផ្សេងគ្នា
ក្នុងការបញ្ជាក់ពីសមត្ថភាពនៃការរៀនពីដូនតារបស់ពួកគេ
និយាយពីអាយុខ្លីរបស់មនុស្ស
ហើយដូនតារបស់គេចង់ឲ្យមេរៀននោះមានឥទ្ធិពលលើពួកគេ។
រំពឹងគិតអំពីបទពិសោធន៍ ដែលដូនតារបស់លោករៀនបាន
«ចូរសិក្សាដោយយកចិត្តទុកដាក់នូវអ្វីដែលដូនតារបស់យើងបានរកឃើញ» ឬ
ចូររិះគិតពីអ្វីដែលដូនតារបស់យើងបានរៀន»។
អាយុជីវិតរបស់យើងនៅលើផែនដីនេះ ប្រៀបដូចជាស្រមោល
នៅក្នុងពាក្យការប្រៀបធៀប ជីវិតប្រៀបបីដូចជាស្រមោល ទាំងពីរនេះ
កន្លងផុតទៅយ៉ាងរហ័ស។
តើពួកគេមិនបានបង្រៀន និងប្រាប់លោកទេឬអី? តើចាស់ទុំនឹង
មិនបានប្រាប់លោកពីអ្វីដែលនៅក្នុងចិត្តគេទេ?
លោកប៊ីលដាដសួរសំណួរទាំងនេះ ដើម្បីស្តីបន្ទោលលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងបង្រៀនលោក
ហើយគេនឹងនិយាយតាមរយៈការចេះដឹងរបស់ពួកគេ»
Job 8:11
តើដើមត្រែងអាចដុះនៅក្រៅវាលភក់ល្បប់ឬ? ហើយដើមកក់អាចដុះនៅកន្លែងដែលគ្មានទឹកបានឬ?
លោកប៊ីលដាដសួរសំណួរដែលមិនទាមទារចម្លើយ
ដើម្បីបញ្ជាក់ពីចំណុចរបស់គាត់នៅក្នុងជំពូក ៨:៨
មនុស្សត្រូវការសេចក្តីបង្រៀនពីដូនតារបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើមបបុសមិនអាចដុះដោយគ្មានវាលភក់ល្បប់។
ដើមត្រែងក៏មិនអាចដុះដោយគ្មានទឹកទេ»។ .
ក្រៀមស្ងួត
«ស្វិតក្រៀម»
Job 8:13
ព័ត៌មានទូទៅ
«លោកប៊ីលដាដនៅបន្តនិយាយនៅក្នុងខគម្ពីរទាំងនេះ។ នៅក្នុង ១៤-១៥
អ្នកនិពន្ធបានប្រើពាក្យប្រៀបធៀប ដើម្បីបញ្ជាក់ពីគំនិតមួយ
ដោយប្រើប្រយោគពីផ្សេងគ្នា
ក្នុងការបញ្ជាក់ពីមហន្តរាយនៃអស់អ្នកដែលមិនព្រមសង់ជីវិតរបស់ពួកគេនៅលើសេចក្តីបង្រៀនដូនតារប

generated on Wed Sep 10 16:16:32 2025

ផ្លូវរបស់អស់អ្នកដែលភ្លេចព្រះជាម្ចាស់ ក៏ធ្លាក់ខ្លួនដូច្នោះដែរ
«ដើរនៅក្នុងផ្លូវ» គឺជាយោគប្រៀបធៀបទូទៅដែលសំដៅលើជីវិតរបស់មនុស្ស
និងគោលដៅជីវិតរបស់គេ។ ជាទូទៅសំដៅលើថា
តើអ្នកនោះដើរតាមផ្លូវរបស់ព្រះជាម្ចាស់ ឬដើរតាមផ្លូវរបស់ខ្លួន។
ទំនុកចិត្តរបស់គេទន់ខ្សោយដូចជាសំបុកពីងពាង
នៅទីនេះ លោកប៊ីលដាដប្រៀបធៀបជីវិតដែលគ្មានព្រះទៅនឹងសំបុកពីងពាង
ដែលគ្រាន់តែប៉ះបន្តិចវានឹងដាច់ទាំងពីរ។
គេខំប្រឹងតោងវា
«គាត់ព្យាយាមគ្រាំទ្រវា»
Job 8:16
ព័ត៌មានទូទៅ
នៅក្នុងខ ១៦-១៧ អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀប
ដើម្បីបញ្ជាក់ពីគំនិតមួយដោយប្រើប្រយោគពីរផ្សេងគ្នា ជារូបភាពនៃថ្ម
ជាគ្រឹះបណ្តោះអាសន្ននៃអ្នកដែលគ្មានព្រះ។
នៅក្រោមពន្លឺថ្ងៃ គេនៅតែរីកចម្រើន ហើយបែកមែករបស់គេសាខាពាសពេញឧទ្យានរបស់គេ។
នៅទីនេះ លោកប៊ីលដាដប្រៀបធៀបអ្នកគ្មានព្រះដូចជារុក្ខជាតិដែល
រីកស្គុះស្គាយនៅពេលថ្ងៃ ទាំងពេលចាប់ផ្តើម មើលទៅរស់រវើក ស្រស់បំព្រង
និងមានសុខភាពល្អ។
ឫសរបស់គេចាក់ស្រេះទៅក្នុងដីដែលមានថ្ម
ឫសរបស់មនុស្សដែលគ្មានព្រះមិនអាចចាក់ដល់ដីមានជីជាតិទេ ប៉ុន្តែ
ចាក់ឫសនៅលើថ្មវិញ។ ដីថ្មមិនអាចជួយរុក្ខជាតិឲ្យលូតលាស់បានទេ។
ឫសរបស់អ្នកនោះនឹងងាប់ជាឆាប់។ «ឫសរបស់គាត់ចាក់ឫសនៅលើដីថ្ម»។
គេរុករកកន្លែងល្អនៅតាមផ្ទាំងសិលាផ្សេងៗ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើឫសរបស់មនុស្សដែលគ្មានព្រះ។
«ពួកគេរុករកដីដែលមានជីជាតិនៅក្នុងចំណោមថ្មដា» ឬ
«ពួកគេស្វែងរកដីល្អនៅក្នុចំណោមថ្មដា»
ប៉ុន្តែ ប្រសិនបើអ្នកនោះ ត្រូវបានបំផ្លាញចេញពីកន្លែងរបស់គេនោះ កន្លែងនោះនឹងបដិសេធគេ
ហើយនិយាយថា៖ «ខ្ញុំមិនដែលឃើញអ្នកទេ»។
មនុស្សដែលគ្មានព្រះប្រៀបដូចជារុក្ខជាតិដែរ។
នៅពេលដែលវាត្រូវបានរើចេញពីថ្មដែលជាគ្រឹះរបស់វា
នៅកន្លែងផ្សេងទៀតក៏មិនអាចដុះបានទៀតដែរ
ព្រោះវាមិនអាចរីកស្គុះស្គាយនៅក្នុងដីដែលមានជីជាតិដែរ។ «ប្រសិនបើ
គេត្រូវបានដកចេញពីកន្លែងរបស់គេ វានឹងលែងទទួលស្គាល់គេទៀតហើយ
ដោយនិយាយថា៖ «ខ្ញុំមិនដែលឃើញអ្នកទេ»។
កន្លែងនោះនឹងបដិសេធគេ ហើយនិយាយថា
សមត្ថភាពរបស់មនុស្សក្នុងការបដិសេធ និងនិយាយ ប្រៀបដូចជាដីថ្ម។
ន្លែងរបស់គេ
«ដីថ្ម»
Job 8:19
អំណរ
ជារង្វាន់ ជាផលនៃឥរិយាបថរបស់មនុស្សអាក្រក់
ដែលលោកប៊ីលដាដប្រើពាក្យមើលងាយ ថាជា «អំណរ» វិញ។
ឥរិយាបថ
«ការប្រព្រឹត្ត» ឬ «វិធីជីវិត»
ហើយរុក្ខជាតិផ្សេងៗទៀតនឹងដុះកន្លែងនោះជំនួសគេ។
នៅទីនេះ អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបនៅក្នុងជំពូក ៨:១៦។
មនុស្សដែលគ្មានព្រះប្រៀបដូចជារុក្ខជាតិដែលដុះនៅក្នុងកន្លែងអ្នកមុន
ដែលដុះនៅក្នុងចំណោមថ្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលមនុស្សអាក្រក់ម្នាក់ស្លាប់ អ្នកផ្សេងនឹងយកកន្លែងអ្នកនោះ» ឬ
«អ្នកផ្សេងនឹងដុះនៅលើរបស់អ្នកនោះ»
ដុះ
«លូតលាស់»
កន្លែងដដែលនោះ
«នៅលើដីថ្ម»
ក្នុងកន្លែងរបស់គាត់
«នៅកន្លែងរបស់មនុស្សដែលគ្មានព្រះ»។
ហើយព្រះអង្គក៏មិនដកព្រះហស្តចេញពីមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ដែរ។
«ព្រះហស្ត» តំណាងឲ្យមនុស្សម្នាក់។
«ព្រះអង្គនឹងមិនគាំទ្រមនុស្សប្រព្រឹត្តអំពើអាក្រក់ឡើយ»។
Job 8:21
ប៉ុន្តែ ព្រះអង្គនឹងបំពេញមាត់របស់លោកដោយសំណើច និងបបូរមាត់របស់លោកដោយសម្រែក។
លោកប៊ីលដាដបន្តនិយាយទៅលោកយ៉ូប។ «ពាក្យថា «ព្រះអង្គ»
សំដៅលើព្រះជាម្ចាស់ ហើយ «របស់លោក» សំដៅលើលោកយ៉ូប។
អ្នកនិពន្ធបង្ហាញពីគំនិតមួយដោយប្រើប្រយោគពីរផ្សេងគ្នា ក្នុងការបង្ហាញពីអំណរ
ដែលលោកយ៉ូបនឹងបានមានបទពិសោធន៍។
«ព្រះជាម្ចាស់នឹងធ្វើឲ្យលោករីករាយសារជាថ្មី»
និងបបូរមាត់របស់លោកដោយសម្រែក
អត្ថន័យដែលមានន័យគ្រប់គ្រាន់នៅក្នុងឃ្លានេះ
អាចយល់តាំងពីការចាប់ផ្តើមនៃប្រយោគ។
«ព្រះជាម្ចាស់នឹងបំពេញបបូរមាត់របស់លោកជាមួយនឹងសម្រែកនៃអំណរ។
អស់អ្នកដែលស្អប់លោកនឹងត្រូវពាក្យដោយភាពអាម៉ាស់ ហើយត្រសាលរបស់មនុស្សអាក្រក់
នឹងលែង មានទៀត»។
«មនុស្សដែលគ្មានព្រះនឹងបានពេញដោយភាពអាម៉ាស់
មនុស្សអាក្រក់នឹងសូន្យបាត់ ទៅ»។
នឹងលែងមានទៀត
«មិនស្ថិតស្ថេរ» ឬ «នឹងសាបសូន្យ»។

---

9 [1]លោកយ៉ូបមាននិយាយតបវិញថា៖[2]«ពិតមែនហើយ ខ្ញុំដឹងថាប្រាកដជាកើត មានដូច្នោះ។ ប៉ុន្តែធ្វើដូចម្តេចឲ្យមនុស្សបានត្រឹមត្រូវជាមួយព្រះជាម្ចាស់បាន?[3]បើគេចង់
ជជែកវែកញែកជាមួយព្រះអង្គ ក្នុងមួយពាន់សំណួរ សូម្បីតែមួយ ក៏មនុស្សពុំអាចឆ្លើយបានផង។
[4]ព្រះអង្គប្រកបទៅដោយព្រះប្រាជ្ញាញាណ និងមហិទ្ធិឫទ្ធិ តើអ្នកដែលប្រឆាំងនឹងព្រះអង្គ អាចកើតផងទេ?[5]ព្រះអង្គរើភ្នំទាំងឡាយ មិនឲ្យវាដឹងខ្លួន ព្រះអង្គ
ក៏មិនប្រាប់អ្នកណា ដោយសារតែព្រះពិរោធ របស់ព្រះអង្គ[6]ហើយព្រះអង្គធ្វើឲ្យផែនដីកក្រើកនៅលើគ្រឹះរបស់វា ហើយសសររបស់វាក៏រញ្ជួយដែរ។
[7]ព្រះអង្គមានព្រះបន្ទូលទៅកាន់ថ្ងៃ នោះថ្ងៃមិនរះទេ ព្រះអង្គក៏ឃាត់ផ្កាយមិនឲ្យចាំងពន្លឺដែរ[8]ព្រះអង្គលាតសន្ធឹងផ្ទៃមេឃ ដោយគ្មាននរណាជួយ ព្រះអង្គយាងនៅលើរលក
សមុទ្រ[9]ព្រះអង្គបានបង្កើតផ្កាយក្រពើ ផ្កាយនង្គ័ល និងផ្កាយកូនមាន់ ព្រមទាំងកញ្ចុំផ្កាយនៅទិសខាងត្បូង។
[10]ព្រះអង្គបានធ្វើការដ៏ធំអស្ចារ្យ ដែលពុំអាចយល់បាន ព្រមទាំងការដ៏ល្អវិសេសច្រើនឥតគណនា។[11]ព្រះអង្គយាងមកក្បែរខ្ញុំ ក៏ខ្ញុំមើលព្រះអង្គមិនឃើញ ព្រះអង្គយាងទៅ
បាត់ ក៏ខ្ញុំមិនអាចយល់បាន។[12]ពេលព្រះអង្គដកយកអ្វីទៅហើយ តើមាននរណាអាចឃាត់ព្រះអង្គបានទេ? ហើយក៏គ្មាននរណាអាចពោលទៅព្រះអង្គ ហេតុអ្វីបានជា
ព្រះអង្គធ្វើដូច្នេះ?
[13]ពេលព្រះអង្គព្រះពិរោធហើយ ព្រះអង្គមិនប្រែព្រះហឫទ័យទេ ព្រះអង្គបង្ក្រាបសត្វសម្បើមនៅក្នុងសមុទ្រ និងបរិវាររបស់វា។[14]ហេតុនេះ តើឲ្យខ្ញុំឆ្លើយតបទៅព្រះអង្គ ដូច
ម្តេចបាន? តើខ្ញុំមានពាក្យអ្វីទូលទៅកាន់ព្រះអង្គ?[15]ទោះបីខ្ញុំសុចរិតក្តី ក៏ខ្ញុំពុំអាចឆ្លើយនឹង ព្រះអង្គបានដែរ គឺខ្ញុំមានតែអង្វរសូមចៅក្រមរបស់ខ្ញុំ មេត្តាប្រណីសន្តោសខ្ញុំ
ប៉ុណ្ណោះ។
[16]ទោះបីព្រះអង្គឆ្លើយតបមកខ្ញុំ នៅពេលខ្ញុំស្រែកហៅព្រះអង្គក៏ដោយ ក៏ខ្ញុំមិនជឿថា ព្រះអង្គផ្ទៀងព្រះកាណ៌ ស្តាប់ពាក្យទូលអង្វររបស់ខ្ញុំដែរ។[17]ព្រះអង្គវាយប្រហារខ្ញុំ ដោយ
ខ្យល់ព្យុះ ព្រះអង្គធ្វើឲ្យខ្ញុំមានរបួសកាន់តែច្រើន ដោយឥតហេតុផល។[18]ព្រះអង្គមិនទុកឲ្យខ្ញុំមានពេលដកដង្ហើមទេ ដ្បិតព្រះអង្គធ្វើឲ្យខ្ញុំឈឺចាប់ខ្លាំងណាស់។
[19]ប្រសិនបើខ្ញុំចង់ប្រើកម្លាំងបាយ ព្រះអង្គមានឫទ្ធានុភាពជាង ប្រសិនបើខ្ញុំចង់ប្តឹងរកយុត្តិធម៌ តើនរណាហៅព្រះអង្គមកកាត់ក្តី?[20]ទោះបីខ្ញុំសុចរិតក្តី ក៏ពាក្យសម្តីរបស់ខ្ញុំដាក់
ទោសខ្ញុំ ទោះបីខ្ញុំស្លូតត្រង់ក្តី ក៏ពាក្យសម្តីរបស់ខ្ញុំឲ្យខ្ញុំខុសដែរ។
[21]ខ្ញុំពិតជាមនុស្សស្លូតត្រង់ តែខ្ញុំមិនប្រាកដថាខ្លួនខ្ញុំស្លូតត្រង់ដែរ ខ្ញុំអស់ចិត្តនឹងជីវិតរបស់ខ្ញុំ។[22]ណើយ បណ្តោយតាមដំណើរទៅចុះ ហេតុនេះហើយបានជាខ្ញុំពោលថា
ព្រះអង្គប្រហារ ទាំងមនុស្សស្លូតត្រង់ ទាំងមនុស្សអាក្រក់។[23]ពេលមានមហន្តរាយអ្វីមួយកើតឡើងបណ្តាល ឲ្យមនុស្សស្លូតត្រង់ស្លាប់ភ្លាមៗនោះ ព្រះអង្គសើចចំអកឲ្យគេ
នៅពេលដែលគេវេទនា។[24]ផែនដីធ្លាក់ទៅក្នុងកណ្តាប់ដៃមនុស្សអាក្រក់ ព្រះជាម្ចាស់បិទភ្នែកចៅក្រមទាំងឡាយ បើព្រះអង្គមិនធ្វើបែបនេះទេ តើនរណាជាអ្នកធ្វើ?

generated on Wed Sep 10 16:16:32 2025

[25]ពេលវេលារបស់ខ្ញុំខិតទៅមុខ លឿនជាងអ្នកដែលរត់ទៅទៀត គឺពេលវេលានេះចេះតែរត់ទៅមុខ ដោយខ្ញុំមិនបានឃើញសុភមង្គលឡើយ។[26]ពេលវេលារបស់ខ្ញុំអណ្តែតទៅមុខ លឿនជាងនាវា ឬបោះពួយដូចខ្លែងហោះតម្រង់ទៅចាប់រំពា។
[27]ប្រសិនបើខ្ញុំពោលថា: ខ្ញុំនឹងបំភ្លេចការសោកសង្រេង ខ្ញុំនឹងធ្វើទឹកមុខរីករាយ ហើយខំប្រឹងសើចសប្បាយឡើងវិញ[28]នោះការឈឺចាប់ទាំងប៉ុន្មានរបស់ខ្ញុំ ធ្វើឲ្យខ្ញុំតក់ស្លុត ដ្បិតខ្ញុំដឹងថា ព្រះអង្គមិនចាត់ទុកខ្ញុំជា មនុស្សគ្មានទោសឡើយ។[29]ទោះបីធ្វើយ៉ាងណា ក៏ខ្ញុំនៅតែមានទោស ដូច្នេះ តើខ្ញុំនៅតែខំប្រឹងដោះសាខ្លួនបានការអ្វី?
[30]ទោះបីទូលបង្គំយកទឹកមកលាងខ្លួន ទោះបីទូលបង្គំយកសាប៊ូមកលាងដៃ[31]ព្រះអង្គបោះទូលបង្គំទៅក្នុងភក់ជ្រាំ ហើយសូម្បីតែសម្លៀកបំពាក់របស់ទូលបង្គំ ក៏ខ្ពើមទូលបង្គំដែរ។
[32]ព្រះអង្គមិនមែនជាមនុស្សដូចខ្ញុំដែលខ្ញុំអាចតវ៉ា និងហៅឡើងទៅតុលាការបានឡើយ។[33]គ្មាននរណាអាចធ្វើជាអាជ្ញាកណ្តាល សម្រុះសម្រួលរឿងរ៉ាវរវាង ព្រះអង្គ និងខ្ញុំបានទេ។
[34]សូមព្រះអង្គមេត្តាឈប់យកដំបងវាយខ្ញុំ សូមកុំឲ្យព្រះពិរោធរបស់ព្រះអង្គ ធ្វើឲ្យខ្ញុំញ័ររន្ធត់ទៀតឡើយ។[35]ពេលនោះ ទើបខ្ញុំនិយាយស្តីបាន ដោយលែងភិតភ័យ។ ប៉ុន្តែតាមពិតពេលនេះ ខ្ញុំមិនអាចធ្វើវាបានទេ។

Job 9:1
ខ្ញុំដឹងប្រាកដថា វាដូច្នោះមែន
ខ្ញុំដឹងថា អ្វីដែលអ្នកនិយាយគឺជាសេចក្តីពិត»
វាដូច្នោះមែន
ពាក្យ «នេះ» សំដៅលើអ្វីដែលលោកបីលដាដនិយាយ។
តើធ្វើដូចម្តេចឲ្យមនុស្សបានត្រឹមត្រូវជាមួយព្រះជាម្ចាស់បាន?
«តើនរណាម្នាក់អាចជាមនុស្សត្រឹមត្រូវនៅចំពោះព្រះជាម្ចាស់?»
ជជែកតវ៉ា
«ប្រកែកគ្នា»
គេមិនអាចឆ្លើយសំណួរមួយដង ក្នុងមួយពាន់សំណួរដងដល់ព្រះអង្គបានឡើយ។
«មួយក្នុងមួយពាន់សំណួរ» គឺជាពាក្យប្រៀបធៀបដែលមានន័យថា
«ទាល់តែសល់» ទី១) អាចមានន័យថា៖
គាត់មិនអាចផ្តល់ចម្លើយណាមួយដល់ព្រះជាម្ចាស់ទេ»? ទី២)
ព្រះអង្គមិនឆ្លើយតបគាត់ទាល់តែសល់។
មួយពាន់សំណួរដង
«១០០០ដង»
Job 9:4
ព្រះហឫទ័យប្រកបដោយប្រាជ្ញា
ពាក្យ ព្រះហឫទ័យ នៅទីនេះ តំណាងឲ្យ សភាវខាងក្នុងចិត្ត ឬ គំនិត។
របៀបផ្សេងទៀតនៃការបកប្រែ:
«ឈ្លាសវៃក្នុងអ្វីដែលព្រះអង្គសម្រេចព្រះហឫទ័យ»
មានឥទ្ធិឫទ្ធិ ដោយកម្លាំង
នាមអរូប «កម្លាំង» អាចបង្ហាញជាគុណនាម «ខ្លាំង»។
របៀបផ្សេងទៀតនៃការបកប្រែ: ឥទ្ធិឫទ្ធិ នៅក្នុងភាពខ្លាំងដែលព្រះអង្គមាន» ។
តើអ្នកដែលប្រឆាំងទាស់នឹងព្រះអង្គ អាចបានជោគជ័យដែរឬទេ?
នេះគឺជាសំណួរដែលមិនទាមទារចម្លើយ ដែលរំពឹងចម្លើយថា:
«គ្មាននរណាម្នាក់ឡើយ» អាចប្រើជំនួសពាក្យដែលមានប្រយោគដូចគ្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាដែលប្រឆាំងទាស់នឹងព្រះអង្គ
ហើយអាចយកឈ្នះបានឡើយ»។
ប្រឆាំងទាស់នឹងព្រះអង្គ
ប្រឆាំងទាស់ មានន័យថា រឹងរូស។ របៀបផ្សេងទៀតនៃការបកប្រែ:
«តតាំងនឹងព្រះអង្គ» ឬ «បំពានព្រះអង្គ»
ព្រះអង្គដែលរើភ្នំទាំងឡាយ
«ព្រះជាម្ចាស់បានរើភ្នំទាំងឡាយ»
សារតែសេចក្តីក្រោធរបស់ព្រះអង្គ
ពាក្យ «កំហឹង» នាមអរូប អាចបង្ហាញជាគុណនាម «ខឹង»។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយសារព្រះអង្គក្រោធ»។
ព្រះអង្គដែលអង្រួនផែនដី
«ព្រះជាម្ចាស់អង្រួនផែនដី»
គ្រឹះដែលគាំទ្រវាក៏រញ្ជួយដែរ
«ធ្វើឲ្យគ្រឹះរបស់វារញ្ជួយ»
Job 9:7
ព្រះអង្គក៏គ្របបាំងផ្កាយផងដែរ
«ព្រះអង្គបាំងមិនឲ្យមើលឃើញផ្កាយ»
ព្រះអង្គផ្ទាល់ដែលលាតសន្ធឹងស្ថានសួគ៌
ព្រះជាម្ចាស់មានបន្ទូលអំពីការបង្កើតស្ថានសួគ៌ដោយគ្មានជំនួយ
ប្រៀបដូចជាក្រណាត់ដែលព្រះអង្គត្រដាង។
ជាន់ឈ្លីលើរលកសមុទ្រ
ព្រះជាម្ចាស់មានបន្ទូលអំពីការធ្វើឲ្យរលកសមុទ្រស្ងប់
ដោយព្រះបាទារបស់ព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានដាក់ព្រះបាទារបស់ព្រះអង្គលើរលកសមុទ្រ» ឬ
«ព្រះអង្គបានធ្វើឲ្យរលកសមុទ្រស្ងប់»។
ផ្កាយក្រពើ ផ្កាយនង្គ័ល និងផ្កាយកូនមាន់
ផ្កាយទាំងនេះ សំដៅលើកញ្ចុំផ្កាយ
ដែលជាក្រុមផ្កាយដែលមើលទៅដូចជារូបភាពអ្វីមួយដែលនៅលើមេឃ។
ផ្កាយនង្គ័ល
គឺជាអ្នកប្រម៉ាញ់ដ៏ល្អនៅក្នុងរឿងនិទានបូរាណរបស់ក្រិក។
ផ្កាយកូនមាន់
ពន្លឺរបស់ផ្កាយមួយចំនួនដែលមើលទៅផ្កាយនោះនៅជិតៗគ្នានៅលើមេឃ។
កញ្ចុំផ្កាយ
ជាក្រុមផ្កាយ ដែលមើលទៅវាផ្តុំគ្នាដូចជារូបភាពអ្វីមួយនៅលើមេឃ។
Job 9:10
ព័ត៌មានទូទៅ
អ្នកនិពន្ធប្រើពាក្យប្រៀបធៀបនៅក្នុងខគម្ពីរនីមួយៗ ដើម្បីបង្ហាញពីគំនិតមួយ
ដោយប្រើប្រយោគពីផ្សេងគ្នា ក្នុងការបញ្ជាក់ថា ព្រះជាម្ចាស់មហិមា មើលមិនឃើញ
ហើយព្រះនរបតី។
ធ្វើការដែលមិនអាចយល់បាន
«ជាការដែលគ្មាននរណាអាចយល់បាន» ឬ «ជាការដែលមិនអាចយល់បាន»
ច្រើនរាប់មិនអស់
«ដែលមិនអាចរាប់បាន»
មើល៍
«មើល៍» ឬ «យកចិត្តទុកដាក់»
ព្រះអង្គយាងកាត់មុខខ្ញុំ
«ព្រះអង្គយាងកាត់» ឬ «ព្រះអង្គបន្តយាងទៅមុខ»
ប្រសិនបើ ព្រះអង្គដកយកអ្វីមួយ តើមាននរណាអាចបញ្ឈប់ព្រះអង្គបាន? តើនរណាអាចទូលទៅ
ព្រះអង្គថា៖ «តើព្រះអង្គកំពុងធ្វើអ្វីហ្នឹង»?
ទាំងនេះគឺជាសំណួរវោហាសាស្ត្រដែលរំពឹងចម្លើយថា «គ្មាននរណាឡើយ»
ពួកគេអាចប្រើប្រយោគផ្សេងជំនួស។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
ព្រះអង្គដកយកអ្វីមួយចេញ គ្មាននរណាអាចបញ្ឈប់ព្រះអង្គបានទេ។
គ្មាននរណាអាចសួរព្រះអង្គថា៖ «តើព្រះអង្គកំពុងធ្វើអ្វី? បានទេ»។
ប្រសិនបើ ព្រះអង្គដកយកអ្វីមួយ
«ប្រសិនបើ ព្រះអង្គដកយកនរណាម្នាក់» ឬ
«ប្រសិនបើព្រះអង្គដណ្តើមយកអ្វីមួយ»
Job 9:13
អ្នកជំនួយដែលមានអំនួតនឹងលុតជង្គង់នៅចំពោះព្រះអង្គ
ឃ្លា «នឹងលុតជង្គង់នៅចំពោះព្រះអង្គ» ជានិមិត្តរូបនៃការចុះចូល ឬ ចុះចាញ់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គផ្តាញ់អ្នកជំនួយដែលមានអំនួត»។
អំនួត
ពាក្យ «អំនួត» នៅទីនេះ សំដៅលើសត្វកំណាចសមុទ្រ។
តើខ្ញុំអាចឆ្លើយតបទៅព្រះអង្គ តិចប៉ុណ្ណាបាន? តើខ្ញុំត្រូវជ្រើសរើសពាក្យណា
ដើម្បីលើកហេតុផលជាមួយព្រះអង្គ?
លោកយ៉ូបសួរសំណួរពីប្រហាក់ប្រហែលគ្នា
ដើម្បីបញ្ជាក់ពីការស្ទាក់ស្ទើរក្នុងការប្រឈមជាមួយព្រះជាម្ចាស់។
គេអាចប្រើពាក្យត្រឡប់បាននៅក្នុងប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«ដូច្នេះ ខ្ញុំប្រាកដជាមិនអាចឆ្លើយជាមួយព្រះអង្គបានទេ ឬ
មិនអាចជ្រើសរើសពាក្យណា ដើម្បីលើកហេតុផលជាមួយព្រះអង្គបានឡើយ»។
Job 9:16
ដ្បិត ព្រះអង្គបានបំបាក់ខ្ញុំ ដោយខ្យល់ព្យុះ
លោកយ៉ូបប្រៀបធៀបបញ្ហារបស់គាត់ ដែលមកពីព្រះទៅនឹងឥទ្ធិពលនៃខ្យល់ព្យុះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គធ្វើឲ្យខ្ញុំមានរបួស ដូចជាខ្យល់ព្យុះអ៊ីចឹង»។
ខ្យល់ព្យុះ
ខ្យល់ព្យុះគំហុកជាខ្លាំង ឬព្យុះសង្ឃរា។
របួសជាច្រើន
«ព្រះអង្គបានធ្វើឲ្យខ្ញុំមានរបួសជាច្រើន» ឬ «ធ្វើឲ្យខ្ញុំមានរបួសម្តងហើយម្តងទៀត»
ដោយគ្មានហេតុផល
«ទោះបីជាខ្ញុំមិនបានធ្វើអ្វីឲ្យព្រះអង្គធ្វើដូច្នេះក្តី» ឬ «សូម្បីខ្ញុំជាមនុស្សស្លូតត្រង់ក្តី»
ដកដង្ហើម
នេះគឺជាពាក្យប្រៀបធៀបដែលមានន័យថា «ដកដង្ហើម» ឬ «ដង្ហើម»
ព្រះអង្គបំពេញខ្ញុំដោយភាពជូរល្វីង
រូបភាពនៅក្នុងខគម្ពីរនេះ
ព្រះជាម្ចាស់បានបំពេញអ្វីដែលនៅក្នុងជីវិតរបស់លោកយ៉ូប
ដែលធ្វើឲ្យគាត់មានភាពជូរល្វីង។ ជានាមអរូប «ភាពជូរល្វីង»
អាចបង្ហាញជាគុណនាម «ជូរល្វីង»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានបំពេញខ្ញុំនូវអ្វីៗដែលជូរល្វីង»។
Job 9:19
ប្រសិនបើ និយាយពីកម្លាំង
«ប្រសិនបើ មានការប្រកួតកម្លាំង»
មើលចុះ!
«មើល៍» ឬ «សូមយកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំនឹងប្រាប់អ្នក»។
ព្រះអង្គខ្លាំងពូកែ
«ព្រះអង្គជាព្រះដ៏ខ្លាំងពូកែ»
តើនរណាហ៊ានកោះហៅព្រះអង្គ?
សំណួរនេះចង់បានចម្លើយថា «គ្មាននរណាឡើយ»
ដើម្បីបញ្ជាក់ថាគ្មាននរណាអាចនាំព្រះជាម្ចាស់ឡើងតុលាការបានឡើយ។
ពាក្យនេះអាចជាពាក្យនិយាយជាថ្មីដូចជាប្រយោគ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាអាចកោះហៅព្រះអង្គបានឡើយ»។
ទោះបីជា ខ្ញុំត្រឹមត្រូវក្តី
ឃ្លា «ខ្ញុំត្រឹមត្រូវ» មានន័យថា ខ្ញុំជាម្នាក់ដែលប្រព្រឹត្តត្រឹមត្រូវ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីខ្ញុំបានធ្វើការត្រឹមត្រូវក្តី» ឬ
«ទោះបីខ្ញុំគ្មានកំហុសក្តី»។
ទោះបីជា ខ្ញុំត្រឹមត្រូវក្តី មាត់របស់ខ្ញុំផ្ទាល់នឹងដាក់ទោសខ្ញុំ ហើយទោះបីខ្ញុំគ្មានទោសក្តី ក៏សំដីរបស់ខ្ញុំបង្ហាញថាខ្ញុំមានកំហុសដែរ។
ខគម្ពីរនេះ បញ្ជាក់ពីគំនិតមួយដោយបញ្ជាក់ពីដង។
មាត់របស់ខ្ញុំផ្ទាល់នឹងដាក់ទោសខ្ញុំ
ពាក្យ «មាត់» នៅទីនេះ តំណាងឲ្យពាក្យរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «សំដីរបស់ខ្ញុំផ្ទាល់ នឹងចោទប្រកាន់ខ្ញុំ» ឬ
«អ្វីដែលខ្ញុំនិយាយ នឹងថ្កោលទោសខ្ញុំ»
គ្មានទោស
«គ្មានកំហុស»
សំដីរបស់ខ្ញុំបង្ហាញថាខ្ញុំមានកំហុស
«សំដីរបស់ខ្ញុំ» នៅទីនេះ និយាយរបៀបដូចជាគេអាចធ្វើសកម្មភាព។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់អាចប្រើ
អ្វីដែលខ្ញុំនិយាយដើម្បីបង្ហាញថាខ្ញុំមានកំហុស»។
កំហុស
ពាក្យនៅទីនេះមានន័យ នាំទៅផ្លូវអាក្រក់ ឬ ដែលវៀចវេរ»។
Job 9:21
ខ្ញុំជាមនុស្សគ្មានទោស
«ខ្ញុំគ្មានកំហុស»
ពីខ្លួនខ្ញុំ
«អ្វីដែលកើតឡើងដល់ខ្ញុំ»
គ្មានអ្វីខុសប្លែកឡើយ
«វាដូចតែគ្នាទេ» ឬ «គ្មានបញ្ហាអ្វីទេ»
ព្រះអង្គបំផ្លាញមនុស្សគ្មានទោស និងមនុស្សអាក្រក់ជាមួយគ្នា។
«ព្រះអង្គបាននាំមនុស្សគ្រប់ទៅកាន់ទីបញ្ចប់ មិនពួកគេគ្មានកំហុស
ឬមនុស្សអាក្រក់ឡើយ»
ប្រសិនបើ គ្រោះកាចកើតឡើងសម្លាប់មនុស្សភ្លាមៗ
«ប្រសិនបើ គ្រោះមហន្តរាយសម្លាប់មនុស្សភ្លាមៗ»
មនុស្សទៀតត្រង់នៅពេលគេរងទុក្ខវេទនា
ជានាមអរូប «រងទុក្ខវេទនា» អាចត្រូវបានបកប្រែជាកិរិយាសព្ទថា៖ «រងទុក្ខ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលមនុស្សទៀតត្រង់ត្រូវរងទុក្ខវេទនា»។
ផែនដីបានប្រគល់ទៅ
ឃ្លានេះអាចស្ថិតក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ប្រគល់ផែនដី»
ផែនដីបានប្រគល់
ពាក្យ «ផែនដីបានប្រគល់» ត្រូវបានប្រើជាតំណាងឲ្យមនុស្សដែលនៅលើផែនដី។
របៀបផ្សេងទៀតបកប្រែ: «មនុស្សនៅក្នុងផែនដីនេះបានប្រគល់»
ទៅក្នុងកណ្តាប់ដៃ
ពាក្យ «ដៃ» នៅទីនេះ គឺជាពាក្យប្រៀបធៀបសម្រាប់ «ការគ្រប់គ្រង»។
របៀបផ្សេងទៀតនៃការបកប្រែ: «ទៅក្នុងការគ្រប់គ្រងរបស់»
ព្រះជាម្ចាស់បិទភ្នែកចៅក្រមទាំងឡាយ
ពាក្យប្រៀបធៀបនេះ
ព្រះជាម្ចាស់បានរារាំងពួកចៅក្រមនៅលើផែនដីមិនឲ្យមានសមត្ថភាពក្នុងការកាត់ក្តី
ថាខុសឬក៏ត្រូវ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានធ្វើឲ្យចៅក្រមខ្វាក់ភ្នែក» ឬ
«ព្រះអង្គរារាំងការកាត់ក្តីរបស់គេពីការកាត់ក្តីដ៏ត្រឹមត្រូវ»
ប្រសិនបើ ព្រះអង្គមិនធ្វើវាទេ តើនរណាជាអ្នកធ្វើវា?
«ប្រសិនបើ ព្រះជាម្ចាស់មិនបានធ្វើការនេះទេ ដូច្នេះ តើនរណាជាអ្នកធ្វើវា?»
Job 9:25
ថ្ងៃរបស់ខ្ញុំលឿនជាងអ្នកនាំសាររត់ទៅទៀត
លោកយ៉ូបបៀបធៀប ល្បឿននៃថ្ងៃរបស់គាត់
ដែលកន្លងផុតទៅលឿនដូចអ្នករត់ដូច្នោះដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ថ្ងៃរបស់ខ្ញុំកន្លងផុតទៅលឿនណាស់»
អ្នកនាំសាររត់
«អ្នករត់» ឬ «បុរសម្នាក់ដែលរត់»
ថ្ងៃរបស់ខ្ញុំបានរត់គេចទៅឆ្ងាយ
នេះគឺជារូបភាពនៃថ្ងៃនៅក្នុងជីវិតរបស់លោកយ៉ូប
ដែលអាចរត់គេចចេញពីគាត់ដូចជាមនុស្ស។
នៅទីណាក៏គ្មានឃើញថ្ងៃណាល្អដែរ
នេះគឺជារូបភាពនៃថ្ងៃនៅក្នុងជីវិតរបស់លោកយ៉ូប អាចមើលឃើញដូចជាមនុស្ស។
មិនល្អ
«គ្មានអ្វីល្អ»
ថ្ងៃរបស់ខ្ញុំលឿនដូចទូកដើមត្រែងដូច្នេះដែរ
លោកយ៉ូបបៀបធៀបថាថ្ងៃរបស់គាត់កន្លងផុតទៅលឿនយ៉ាងណា
ដូចជាល្បឿននសទូកលឿន។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាលឿនដូចជាទូកដើមត្រែង»។
ទូកដើមត្រែង
«ទូកដែលធ្វើពីដើមត្រែង»។ ដើមត្រែងដែលប្រហោងក្នុង
ដែលដុះនៅតាមមាត់ទន្លេ។
វាលឿនដូចជាសត្វឥន្ទ្រីដែលហើរចុះឆាបចាប់រំពាដែរ
លោកយ៉ូបប្រៀបធៀបថ្ងៃរបស់គាត់កន្លងផុតទៅលឿនដូចជាសត្វដ៏ធំមួយដែលហើរឆាបចាប់រំពាររបស់វា។
របៀបផ្សេងទៀតនៃការបកប្រែ:
«លឿនដូចជាសត្វឥន្ទ្រីដែលហើយចុះយ៉ាងលឿនដើម្បីចាប់យកអាហាររបស់វា»។
ហើរចុះឆាប
«ប្រញាប់ចុះ»
Job 9:27
ទូលបង្គំនឹងបំភ្លេចពាក្យតួញតែ្ពររបស់ទូលបង្គំ
ពាក្យ «តួញតែ្ពរ» នេះជានាមអរូប អាចត្រូវបានបកប្រែជាកិរិយាសព្ទ «តួញតែ្ពរ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ទូលបង្គំនឹងឈប់តួញតែ្ពរ» ឬ
«ទូលបង្គំនឹងឈប់តួញតែ្ពរទាស់នឹងព្រះជាម្ចាស់ទៀត»
ពាក្យតួញតែ្ពររបស់ទូលបង្គំ
បូកបន្ថែមដើម្បីបញ្ជាក់ព័ត៌មាន។
«ពាក្យតួញតែ្ពររបស់ទូលបង្គំទាស់នឹងព្រះជាម្ចាស់»។

generated on Wed Sep 10 16:16:32 2025

ទូលបង្គំនឹងប្តូរទឹកមុខពីកើតទុក្ខមករីករាយវិញ
ទឹកមុខកើតទុក្ខរបស់លោកយ៉ូបនៅ ទីនេះ
ប្រៀបដូចជាអ្វីមួយដែលអាចយកចេញបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំនឹងឈប់មើលទៅភាពមិនសប្បាយ ហើយញញឹមវិញ»។
ទូលបង្គំអាចនឹងខ្លាចទុក្ខសោករបស់ទូលបង្គំទាំងអស់
ខគម្ពីរ ២៨ និង ២៩ បង្ហាញពីលទ្ធផល ប្រសិនបើ
គាត់ធ្វើតាមអ្វីដែលគាត់បាននិយាយនៅក្នុងខ ២៧។
របៀបផ្សេងទៀតនៃការបកប្រែ: «នោះ
ទូលបង្គំនឹងភ័យខ្លាចភាពទុក្ខសោករបស់ទូលបង្គំទាំងអស់»។
ទុក្ខសោករបស់ទូលបង្គំទាំងអស់
«ទុក្ខសោក» ជានាមអរូប អាចបង្ហាញជាកិរិយាសព្ទក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលធ្វើឲ្យទូលបង្គំឈឺ»
ទូលបង្គំនឹងមានទោស
«ទូលបង្គំនឹងត្រូវទទួលរងការចោទប្រកាន់ និងដាក់ទោស»។
ឃ្លានេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងដាក់ទោសខ្ញុំ»
ដូច្នេះ តើទូលបង្គំខំប្រឹងព្យាយាមដោយឥតប្រយោជន៍ធ្វើអ្វី?
លោកយ៉ូបប្រើសំណួរនេះដើម្បីបញ្ជាក់ថា គាត់មិនបានគិត គ្មានប្រយោជន៍
នៅក្នុងការខំព្យាយាមធ្វើឲ្យព្រះអង្គចាប់អារម្មណ៍នោះទេ។
ព័ត៌មានដែលបង្ហាញអំពីអ្វីដែលលោកយ៉ូបកំពុងតែព្យាយាមនេះ
អាចធ្វើឲ្យកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «វាគ្មានប្រយោជន៍អ្វីទេ
ក្នុងការព្យាយាមឲ្យព្រះជាម្ចាស់ចាប់អារម្មណ៍នោះ»។
Job 9:30
ទោះបីទូលបង្គំយកទឹកមកលាងខ្លួន
«ប្រសិនបើ ខ្ញុំបានងូតទឹកសុទ្ធហើយ ស្អាត ហើយ»
ទោះបីទូលបង្គំយកសាប៊ូមកលាងដៃ
«ធ្វើឲ្យដៃរបស់ខ្ញុំបានស្អាតយ៉ាងណា»។
នៅក្នុងកំណែនៃការបកប្រែព្រះគម្ពីរផ្សេងទៀត មានន័យថា
«សម្អាតដៃរបស់ខ្ញុំជាមួយនឹងសាប៊ូជាច្រើនដង»។
ព្រះអង្គបោះទូលបង្គំទៅក្នុងភក់ជ្រាំ
«បោះខ្ញុំចូលទៅក្នុងរណ្តៅ»
សម្លៀកបំពាក់របស់ទូលបង្គំ ក៏ខ្ពើមទូលបង្គំដែរ
សម្លៀកបំពាក់របស់លោកយ៉ូប
គឺនិយាយពីការឆ្លើយតបបែបអវិជ្ជាមានចំពោះលោកយ៉ូប
បន្ទាប់ពីព្រះជាម្ចាស់បានបោះលោកចូលទៅក្នុងភក់ជ្រាំ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានស្មោកគ្រោកជាខ្លាំង
ដោយសារសម្លៀកបំពាក់របស់ខ្ញុំផ្ទាល់»។
Job 9:32
ឆ្លើយតប
បញ្ជាក់ពីព័ត៌មានដែលអាចបូកបន្ថែម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឆ្លើយតបនឹងពាក្យចោទប្រកាន់ទាស់នឹងខ្ញុំ» ឬ «ការពារខ្លួនរបស់ខ្ញុំ» ឬ
«តវ៉ាចំពោះភាពគ្មានកំហុសរបស់ខ្ញុំជាមួយគាត់»។
ហៅឡើងទៅតុលាការ
«ចូររួមកាត់ក្តីជាមួយគ្នា»។ ពាក្យ «តុលាការ» នៅទីនេះ
ជាកន្លែងដែលមនុស្សអាចចូលមក ហើយជំនុំជម្រះក្តី។
«មកកន្លែងកាត់ក្តីជាមួយគ្នា» គឺជាពាក្យប្រៀបធៀប
នៃការចូលមកតវ៉ាជាមួយគ្នានៅក្នុងតុលាការ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រឈមមុខគ្នានៅចំពោះចៅក្រម»។
គ្មាននរណាអាចធ្វើជាចៅក្រមរវាងយើងទាំងពីរបានទេ
ឃ្លានេះមានន័យថា
គ្មានចៅក្រមណាដែលធំជាងព្រះជាម្ចាស់ដែលអាចសម្រេចអ្វីដែលត្រឹមត្រូវរបស់ព្រះអង្គនឹងយ៉ូបនោះទេ។
ដាក់ដៃរបស់គាត់លើ
ឃ្លា «ដាក់ដៃរបស់គាត់លើ» នៅទីនេះ មានន័យថា មានអំណាច
ឬសិទ្ធិអំណាចលើ។ របៀបផ្សេងទៀតនៃការបកប្រែ: «ចាប់យក» ឬ
«មានសិទ្ធិអំណាចលើ»
Job 9:34
ប្រយោគភ្ជាប់
ខគម្ពីរទាំងនេះបន្តពីការតវ៉ាពីមុនដែលគ្មាននរណាធំជាងព្រះជាម្ចាស់ដែលមានអំណាចក្នុងការជំនុំជម្រះរ
សូមព្រះអង្គមេត្តាឈប់យកដំបងវាយខ្ញុំ
ពាក្យ «ដំបងរបស់ព្រះជាម្ចាស់» នៅទីនេះ
គឺជាពាក្យប្រៀបធៀបសម្រាប់ការដាក់ទោសរបស់ព្រះជាម្ចាស់ ឬ
ការកែតម្រង់ដល់លោកយ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមបញ្ឈប់ព្រះជាម្ចាស់ពីការដាក់ទោសខ្ញុំទៅ»
សូមកុំឲ្យព្រះពិរោធរបស់ព្រះអង្គ ធ្វើឲ្យខ្ញុំញ័ររន្ធត់ទៀតឡើយ
«ញ័ររន្ធត់» ជានាមអរូប អាចប្រែជាកិរិយាសព្ទក៏បាន «រន្ធត់»។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមកុំឲ្យព្រះអង្គធ្វើឲ្យខ្ញុំភ័យរន្ធត់
និងភ័យខ្លាចឡើយ»។
ទើបខ្ញុំនិយាយស្តីបាន
«ដូច្នេះ ទើបខ្ញុំនិយាយបាន»
ប៉ុន្តែ តាមពិតពេលនេះ
«ព្រោះនេះគឺជារបៀបដែលត្រូវធ្វើនៅពេលនេះ»។

---

10 [1]ខ្ញុំឆ្អែតចិត្តនឹងជីវិតណាស់ ខ្ញុំនឹងតភ្ជាប់ត្អែររបស់ខ្ញុំ ដោយពាក្យជូរល្វីង ដោយឈឺចាប់ក្នុងចិត្ត។[2]ខ្ញុំនឹងទូលព្រះជាម្ចាស់ថា សូមកុំដាក់ទោសទូលបង្គំឡើយ សូមប្រាប់ឲ្យ
ទូលបង្គំដឹងផងថា ព្រះអង្គមានមូលហេតុអ្វី ចោទប្រកាន់ទូលបង្គំ។[3]តើមាន ប្រយោជន៍អ្វី បានជាព្រះអង្គសង្កត់សង្កិនទូលបង្គំ ហើយបោះបង់ចោលស្នា
ព្រះហស្តរបស់ព្រះអង្គ រួចបែរជាជួយជ្រោមជ្រែងផែនការ របស់មនុស្សអាក្រក់ទៅវិញ?
[4]តើព្រះអង្គមានព្រះនេត្រ ហើយទតមើល តាមរបៀបដូចមនុស្សលោកដែរឬ?[5]តើចំនួនថ្ងៃរបស់ព្រះអង្គដូចចំនួនថ្ងៃ របស់មនុស្សលោក ហើយចំនួនឆ្នាំរបស់ព្រះអង្គ[6]ក៏ដូច
ជាចំនួនឆ្នាំ របស់មនុស្សលោកដែរឬ បានជាព្រះអង្គស្វែងរកកំហុសរបស់ទូលបង្គំ ហើយរុករកអំពើបាបរបស់ទូលបង្គំដូច្នេះ?[7]ព្រះអង្គជ្រាបស្រាប់ហើយថា ទូលបង្គំគ្មាន
កំហុសអ្វីទេ ហើយក៏គ្មាននរណារំដោះទូលបង្គំឲ្យរួចផុតបាន?
[8]ព្រះហស្តទាំងពីរព្រះអង្គបានក្របជុំវិញទូលបង្គំជានិច្ច ក៏ប៉ុន្តែ ព្រះអង្គបែរជាវាយឲ្យទូលបង្គំវិនាសវិញ។[9]ទូលបង្គំសូមអង្វរព្រះអង្គ
ដែលព្រះអង្គបានសូនឆ្អែទូលបង្គដូចដីឥត្ត តើព្រះអង្គនឹងឲ្យទូលបង្គទៅជាដីវិញឬ?
[10]តើព្រះអង្គមិនបានចាក់ទូលបង្គំចេញដូចជាទឹកដោះ ហើយឲ្យទូលបង្គំកកខន់ ដូចជាផែនទឹកដោះទេឬ?[11]ព្រះអង្គបំពាក់ស្បែក និងសាច់ ពាសពេញរូបកាយទូលបង្គំ
ព្រះអង្គបង្កើតឆ្អឹង និងសរសៃឲ្យទូលបង្គំ។
[12]ព្រះអង្គប្រទានជីវិត និងសម្តែងព្រះហឫទ័យ មេត្តាករុណាចំពោះទូលបង្គំ ព្រះអង្គថែរក្សាដង្ហើមជីវិតរបស់ទូលបង្គំ។[13]ប៉ុន្តែ ទូលបង្គំដឹងច្បាស់នូវអ្វីៗ ដែលព្រះអង្គលាក់ទុក
នៅក្នុងព្រះហឫទ័យ។[14]បើទូលបង្គំប្រព្រឹត្តអំពើបាប ព្រះនឹងចំណាំទុក ហើយព្រះអង្គមិនព្រមលើកលែងទោស ឲ្យទូលបង្គំទាល់ទេ។
[15]ប្រសិនបើទូលបង្គំមនុស្សអាក្រក់ នោះទូលបង្គំពិតជាវេទនាមិនខាន ប្រសិនបើទូលបង្គំសុចរិត នោះក៏ទូលបង្គំមិនហ៊ានងើបមុខឡើងដែរ ទូលបង្គំត្រូវអាម៉ាស់ ហើយលិច
លង់ទៅក្នុងទុក្ខវេទនា។[16]ប្រសិនបើទូលបង្គំហ៊ាននងើបមុខ ព្រះអង្គនឹងដេញតាមទូលបង្គំដូចសត្វសិង្ហ ព្រះអង្គនឹងសម្តែងការអស្ចារ្យមកលើទូលបង្គំ។
[17]ព្រះអង្គមានមូលហេតុថ្មីៗ មកចោទប្រកាន់ទូលបង្គំ ព្រះអង្គទ្រង់ព្រះពិរោធនឹងទូលបង្គំ ព្រះអង្គនឹងវាយទូលបង្គំជាពលទេវតារបស់ព្រះអង្គ។
[18]ព្រះអង្គឲ្យទូលបង្គំចេញពីផ្ទៃម្តាយមកធ្វើអ្វី? បើទូលបង្គំស្លាប់តាំងពីក្នុងផ្ទៃ នោះគ្មាននរណាបានឃើញទូលបង្គំទេ។[19]បើគេយកទូលបង្គំចេញពីផ្ទៃម្តាយទៅកប់ក្នុងផ្នូរ
នោះទូលបង្គំមិនដែលមានជីវិតទាល់តែសោះ។
[20]តើអាយុជីវិតរបស់ទូលបង្គំពិតជាខ្លីមែនឬ? សូមឈប់ទៅ នឹងសូមទុកឲ្យទូលបង្គំនៅម្នាក់ឯង ដើម្បីឲ្យទូលបង្គំមានពេលសម្រាកបន្តិច[21]មុននឹងទូលបង្គំធ្វើដំណើរទៅ
ស្ថានងងឹត ដែលស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ ឥតវិលត្រឡប់វិញឡើយ។[22]កន្លែងងឹតជាងកណ្តាលយប់ ជាកន្លែងស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ ជាកន្លែង
ដែលគ្មានរបៀបរៀបរយ ហើយសូម្បីតែពន្លឺនៅទីនោះក៏ងងឹតដែរ»។

---

generated on Wed Sep 10 16:16:32 2025

Job 10:1
ខ្ញុំឆ្អែតចិត្តនឹងជីវិតណាស់
«ខ្ញុំមានការហត់នឿយកក្នុងការរស់នៅ»
ខ្ញុំនឹងតួញត្អែររបស់ខ្ញុំ ដោយពាក្យជូរល្វីង
នាមអរូប «ការបង្ហាញ» និង «ការតួញត្អែរ» អាចបកប្រែជាទម្រង់កិរិយាសព្ទថា:
«បង្ហាញ» និង «តួញត្អែរ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងបង្ហាញដោយសេរីនូវអ្វីដែលខ្ញុំត្រូវតួញត្អែរអំពី» ឬ
«ខ្ញុំនឹងប្រកែកតវ៉ាដោយសេរី»
ដោយពាក្យជូរល្វីង ដោយឈឺចាប់ក្នុងចិត្ត
ជាការប្រៀបធៀបអារម្មណ៍របស់លោកយ៉ូបទៅនឹងរស់ជាតិជូរចត់។
នាមអរូបនៃពាក្យ «ភាពល្វីងជូរចត់»
អាចត្រូវបានបកប្រែក្នុងទម្រង់ជាកិរិយាវិសេសថា: «យ៉ាងល្វីងជូរចត់»។
របៀបផ្សេងទៀតនៃការបកប្រែ: «ផ្នែកខាងក្នុងរបស់ខ្ញុំ
នឹងនិយាយយ៉ាងល្វីងជូរចត់» ឬ «ខ្ញុំនឹងនិយាយយ៉ាងល្វីងជូរចត់ចាញ់មក»
តើមាន ប្រយោជន៍អ្វី បានជាព្រះអង្គសង្កត់សង្កិនទូលបង្គំ ហើយបោះបង់ចោលស្នាព្រះហស្តរបស់
ព្រះអង្គ រួចបែរជាជួយជ្រោមជ្រែងផែនការ របស់មនុស្សអាក្រក់ទៅវិញ?
សំណួរនេះរំពឹងទៅលើចម្លើយ «ទេ» ហើយអាចត្រូវបានផ្លាស់ប្តូរនៅក្នុងប្រយោគ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាមិនល្អនោះទេដែលទ្រង់នឹងសង្កត់សង្កិនទូលបង្គំ
ដែលទ្រង់នឹងបោះបង់ចោលស្នាព្រះហស្តរបស់ព្រះអង្គ
រួចបែរជាជួយជ្រោមជ្រែងផែនការ របស់មនុស្សអាក្រក់ទៅវិញ»។
ស្នាព្រះហស្តរបស់ព្រះអង្គ
នៅទីនេះព្រះហស្តតំណាងឲ្យអំណាចដែលប្រកបដោយប្រឌិតញ្ញាណរបស់ព្រះ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលទ្រង់បានបង្កើត»
បែរជាជួយជ្រោមជ្រែងផែនការ របស់មនុស្សអាក្រក់ទៅវិញ
នៅទីនេះពាក្យ «ជួយជ្រោមជ្រែង» តំណាងការអនុញ្ញាតរបស់ព្រះជាម្ចាស់។
«អនុញ្ញាតផែនការរបស់មនុស្សអាក្រក់»
Job 10:4
តើព្រះអង្គមានព្រះនេត្រ ហើយទតមើល តាមរបៀបដូចមនុស្សលោកដែរឬ?
សំណួរទាំងពីរនេះមានអត្ថន័យស្ទើរតែដូចគ្នាទាំងស្រុង។
សំណួរទាំងនេះរំពឹងដល់ចម្លើយអវិជ្ជមាន ដើម្បីបញ្ជាក់ថាព្រះមិនបានទតឃើញ
ឬយល់ដឹងពីកិច្ចការនានាដូចជាការមើលឃើញនិងការយល់ដឹងរបស់មនុស្សនោះទេ។
ពួកវាអាចត្រូវបានបង្ហាញដូចជាប្រយោគនានាដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គមិនមានព្រះនេត្រ ហើយព្រះអង្គក៏មិនអាច
ទតមើល តាមរបៀបដូចដែលមនុស្សលោកមើលឃើញដែរ»។
តើចំនួនថ្ងៃរបស់ព្រះអង្គដូចចំនួនថ្ងៃ របស់មនុស្សលោក ហើយចំនួនឆ្នាំរបស់ព្រះអង្គ ក៏ដូចជាចំនួន
ឆ្នាំ របស់មនុស្សលោកដែរឬ...ហើយក៏គ្មាននរណារំដោះទូលបង្គំឲ្យរួចផុតបាន?
សំណួរនេះរំពឹងដល់ចម្លើយអវិជ្ជមាន ដើម្បីបង្ហាញថាព្រះគឺអស់កល្បជានិច្ច
ហើយចំនួនថ្ងៃរបស់មនុស្សគឺត្រូវបានកំណត់។
វាអាចត្រូវបានបង្ហាញថាជាសេចក្តីថ្លែងការ។ របៀបផ្សេងទៀតនៃការបកប្រែ: «
ចំនួនថ្ងៃរបស់ព្រះអង្គមិនដូចចំនួនថ្ងៃ របស់មនុស្សលោកទេ ហើយចំនួនឆ្នាំរបស់
ព្រះអង្គ ក៏មិនដូចជាចំនួនឆ្នាំ របស់មនុស្សលោកដែរ... ហើយក៏គ្មាននរណារំដោះ
ទូលបង្គំឲ្យរួចផុតបានដែរ»។
ចំនួនថ្ងៃរបស់ព្រះអង្គដូចចំនួនថ្ងៃ របស់មនុស្សលោក ហើយចំនួនឆ្នាំរបស់ព្រះអង្គ ក៏ដូចជាចំនួនឆ្នាំ
របស់មនុស្សលោកដែរឬ
ឃ្លាទាំងពីរនេះមានអត្ថន័យស្ទើរតែដូចគ្នាទាំងស្រុង។
ចំនួនថ្ងៃរបស់ព្រះអង្គ
«ចំនួននៃថ្ងៃរបស់ព្រះអង្គ»
ចំនួនឆ្នាំរបស់ព្រះអង្គ
«ចំនួននៃឆ្នាំរបស់ព្រះអង្គ»
ស្វែងរកកំហុសរបស់ទូលបង្គំ...រុករកអំពើបាបរបស់ទូលបង្គំ
ឃ្លាទាំងពីរនេះមានអត្ថន័យស្ទើរតែដូចគ្នាទាំងស្រុង។
ស្វែងរក
«តាមស្វែងរក»
ឲ្យរួចផុតបាន
នៅទីនេះ «ព្រះហស្តរបស់ព្រះអង្គ» តំណាងអោយ អំណាចរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ឲ្យរួចពីអំណាចរបស់ព្រះអង្គ»
Job 10:8
ព្រះហស្តទាំងពីរ
នៅទីនេះពាក្យ «ព្រះហស្តទាំងពីរ» តំណាងឲ្យព្រះ
និងសកម្មភាពនៃការបង្កបង្កើតរបស់ព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គ»
ព្រះហស្តទាំងពីរព្រះអង្គបានក្របជុំវិញទូលបង្គំជានិច្ច
លោកយ៉ូបកំពុងប្រើពាក្យប្រៀបធៀបនៃជាងស្មូនដែលកំពុងសូនដីឥដ្ឋដើម្បីពណ៌នារបៀបដែលព្រះបានប
បានក្របជុំវិញទូលបង្គំជានិច្ច
«បានធ្វើឲ្យមានរូបរាង្គ និងបានបង្កើតខ្ញុំ» ពាក្យ «បានធ្វើគម្រោង» និង
«បានធ្វើតាមម៉ូត» គឺមានអត្ថន័យដូចគ្នា។
ទូលបង្គំសូមអង្វរព្រះអង្គ
«នឹកចាំ»
ឲ្យទូលបង្គំទៅជាដីវិញ
«នាំទូលបង្គំត្រឡប់ទៅក្នុងធូលីដីវិញ»
Job 10:10
ព័ត៌មានទូទៅ
ខទាំងនេះ
លោកយ៉ូបបានប្រើភាសារបស់ភរិដើម្បីពណ៌នាពីរបៀបដែលព្រះបានបង្កើតលោកនៅក្នុងផ្ទៃ។
តើព្រះអង្គមិនបានចាក់ទូលបង្គំចេញដូចជាទឹកដោះ ហើយធ្វើឲ្យទូលបង្គំកកខះ ដូចជាផែនទឹកដោះ
ទេឬ?
នេះគឺជាសំណួរដែលរំពឹងដល់ចម្លើយវិជ្ជមាន។
«ព្រះអង្គបានចាក់ទូលបង្គំចេញដូចជាទឹកដោះ
និងធ្វើឲ្យទូលបង្គំកកខះដូចជាផែនទឹកដោះ»។
ព្រះអង្គ
នៅទីនេះពាក្យ «ព្រះអង្គ» សំដៅដល់ព្រះ។
ទូលបង្គំ
នៅទីនេះពាក្យ «ទូលបង្គំ» សំដៅដល់លោកយ៉ូប។
ព្រះអង្គបំពាក់ស្បែក និងសាច់
ព្រះដាក់ស្បែកនិងសាច់លើរូបកាយរបស់លោកយ៉ូបគឺបាននិយាយដូចជាព្រះបានស្លៀកសំលៀកបំពាក់អ
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានដាក់ស្បែកនិងសាច់នៅលើខ្លួនរបស់ទូលបង្គំ»
ពាសពេញរូបកាយទូលបង្គំ
«ប្រឌិតទូលបង្គំព្រមគ្នា»។
ការនិយាយថាព្រះដាក់រូបកាយរបស់លោកយ៉ូបនៅក្នុងផ្ទៃ គឺដូចជាព្រះបានត្បាញ
ឬប្រឌិតផ្នែកនៃសំលៀកបំពាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដាក់ទូលបង្គំព្រមគ្នា»
សរសៃ
«សរសៃពួរ» ទាំងនេះគឺជាផ្នែកនៃរាង្គកាយដែលភ្ជាប់សាច់ដុំទៅនឹងឆ្អឹង
ឬផ្នែកដទៃទៀតនៃរាង្គកាយ ដែលដូចជាភាពស្វិត ខ្សែពណ៌ស ឬ ខ្សែភ្លើង។
Job 10:12
ព្រះអង្គប្រទានជីវិត និងសម្តែងព្រះហឫទ័យ មេត្តាករុណាចំពោះទូលបង្គំ
នៅទីនេះនាមអរូប «ជីវិត» មានន័យអំពីជីវិតខាងរូបកាយ និង
«សន្ធិសញ្ញាដ៏ស្មោះត្រង់»
សំដៅដល់ការស្មោះត្រង់របស់ព្រះជាម្ចាស់ចំពោះការសន្យារបស់ទ្រង់។
ពាក្យទាំងពីរនេះអាចបកប្រែក្នុងទម្រង់កិរិយាសព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានអនុញ្ញាតឲ្យទូលបង្គំរស់និងមានសេចក្តីស្មោះត្រង់ដែលបានការពារទូលបង្គំ»។
ព្រះអង្គថែរក្សា
«ការថែរក្សារបស់ព្រះអង្គ»
បានដឹកនាំព្រលឹងរបស់ខ្ញុំ
នៅទីនេះពាក្យ «ព្រលឹង» បង្ហាញពីជីវិតរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «បានដឹកនាំទូលបង្គំ» ឬ
«បានទតមើលមកទូលបង្គំដោយយកព្រះទ័យទុកដាក់» ឬ
«រក្សាទូលបង្គំឲ្យមានសុវត្ថិភាព»
អ្វីៗទាំងនេះ ព្រះអង្គលាក់ទុកនៅក្នុងព្រះហឫទ័យ
ពាក្យ «អ្វីៗទាំងនេះ» នៅទីនេះ សំដៅដល់អ្វីៗដែលបាននិយាយក្នុងខបន្ទាប់។
អ្វីៗទាំងនេះ ដែលព្រះអង្គលាក់ទុកនៅក្នុងព្រះហឫទ័យ
នៅទីនេះពាក្យ «ព្រះអង្គលាក់ទុកនៅក្នុងព្រះហឫទ័យ»
មានន័យថាព្រះបានរក្សាពួកគេជាសម្ងាត់ ឬបានលាក់បាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីៗទាំងនេះ ព្រះអង្គបានរក្សាជាសម្ងាត់»
ព្រះនឹងចំណាំទុក
«ព្រះអង្គនឹងទតមើលទូលបង្គំ»

generated on Wed Sep 10 16:16:32 2025

Job 10:15
ប្រសិនបើទូលបង្គំជាមនុស្សអាក្រក់
«ប្រសិនបើ ទូលបង្គំមានកំហុស» ឬ «ប្រសិនបើ ទូលបង្គំធ្វើកិច្ចការអាក្រក់»
ទូលបង្គំពិតជាវេទនាមិនខាន
«តើភាពភ័យខ្លាចនឹងមានដល់ទូលបង្គំយ៉ាងណាទៅ?»
ប្រសិនបើ ទូលបង្គំសុចរិត
«ទោះបីជាទូលបង្គំតែងតែបានប្រព្រឹត្តកិច្ចការដ៏ត្រឹមត្រូវក្តី»
ងើបក្បាលរបស់ទូលបង្គំឡើង
ពាក្យនេះមានន័យថាពិតប្រាកដ ឬជឿជាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ងើយក្បាលរបស់ទូលបង្គំឡើង» ឬ «មានទំនុកចិត្ត» ឬ
«មានសេចក្តីពិតអំពីខ្លួនរបស់ទូលបង្គំ»
ទូលបង្គំត្រូវអាម៉ាស់
នាមអរូប «ភាពអាម៉ាស់មុខ» អាចត្រូវបានបកប្រែជាគុណនាម «ធ្វើឲ្យខូចកិត្តិយស
ធ្វើឲ្យអាច់កេរ្តិ៍ឈ្មោះ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំពេញទៅដោយភាពអាម៉ាស់»
ភាពអាម៉ាស់
«ភាពខ្មាសអៀន»
ហើយលិចលង់ទៅក្នុងទុក្ខវេទនា
នាមអរូប «ការឈឺចាប់» អាចត្រូវបានបកប្រែជាទម្រង់កិរិយាសព្ទ «ឈឺចាប់»។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយទូលបង្គំកំពុងមើលថា
តើទូលបង្គំឈឺចាប់យ៉ាងណា»
ហើយគឺកំពុងមើល
ពាក្យដែលបាត់បង់នេះ អាចត្រូវបានផ្តល់អោយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយខ្ញុំគឺកំពុងមើល»
ប្រសិនបើទូលបង្គំហ៊ានងើបមុខ
ពាក្យនេះ មានន័យសំដៅដល់ការជឿជាក់លើខ្លួនឯងឬការមានអំនួត។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើទូលបង្គំមានអំនួត»
ព្រះអង្គនឹងតាមប្រម៉ាញ់ទូលបង្គំដូចជាសត្វសិង្ហ
មានអត្ថន័យពីប្រហាក់ប្រហែលគ្នាដែលអាចទៅបានគឺ ទី ១)
ព្រះជាម្ចាស់តាមប្រម៉ាញ់លោកយ៉ូបដូចជាសត្វសឹង្ហដែលតាមប្រម៉ាញ់រំពាររបស់វា
ឬទី ២) លោកយ៉ូបគឺដូចជាសត្វសិង្ហដែលព្រះបានតាមប្រម៉ាញ់។
ព្រះអង្គនឹងសម្តែងការអស្ចារ្យមកលើទូលបង្គំ
ឃ្លានេះបង្ហាញការចំអកក្នុងរបៀបដែល
អំណាចដ៏អស្ចារ្យរបស់ព្រះត្រូវបានបង្ហាញក្នុងរបៀបដែលទ្រង់ប្រឆាំងនឹងលោកយ៉ូប។
Job 10:17
ព្រះអង្គមានមូលហេតុថ្មីៗ មកចោទប្រកាន់ទូលបង្គំ
បញ្ហារបស់លោកយ៉ូបដែលបាននិយាយ
ហាក់ដូចជាពួកវាជាមនុស្សដែលចោទប្រកាប់ប្រឆាំងនឹងលោក។
ព្រះអង្គទ្រង់ព្រះពិរោធនឹងទូលបង្គំ
នាមអរូប «ព្រះពិរោធ» អាចបកប្រែជាគុណនាម «មានកំហឹង»។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយមានកំហឹងខ្លាំងឡើងៗជាមួយទូលបង្គំ»
ព្រះអង្គនឹងវាយទូលបង្គំជាមួយពលទាហ៊ានថ្មីរបស់ព្រះអង្គ
ឃ្លាដែលបាននិយាយថា ព្រះបានបញ្ជូនបញ្ហាមកប្រឆាំងនឹងលោកយ៉ូប
គឺហាក់ដូចជាថា ព្រះបានបញ្ជូនពលទាហ៊ានថ្មីរួចជាស្រេចមកប្រឆាំងនឹងលោក។
Job 10:18
ឲ្យទូលបង្គំចេញពីផ្ទៃម្តាយមក
នៅទីនេះការនាំចេញពីផ្ទៃមក
គឺសំដៅដល់ការចាប់ផ្តើមចាប់កំណើតនៅក្នុងពិភពលោកនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «បាននាំទូលបង្គំចេញពីផ្ទៃម្តាយរបស់ទូលបង្គំមក»
ឬ «បាននាំទូលបង្គំចូលមកកាន់ពិភពលោកនេះ»
បោះបង់ព្រលឹងរបស់ខ្ញុំ
បោះបង់ព្រលឹងរបស់នរណាម្នាក់ គឺបង្ហាញពីការស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «បានស្លាប់»
នោះគ្មាននរណាបានឃើញទូលបង្គំទេ
លោកយ៉ូបប្រើពាក្យ «ភ្នែក» នៅទីនេះសម្តៅដល់តួមនុស្សទាំងមូល។ លោករំពឹងថា
លោកអាចបានស្លាប់នៅពេលចាប់កំណើត មុនពេលនរណាម្នាក់បានឃើញលោក។
របៀបផ្សេងទៀតនៃការបកប្រែ: «មុនពេលដែលមិនមាននរណាម្នាក់បានឃើញខ្ញុំ»
ឬ «មុនពេលដែលខ្ញុំកើតមក»
បានចេញមក
«បានចាកចេញ»
គេយកទូលបង្គំ
«រូបកាយរបស់ខ្ញុំនឹងត្រូវបានយកមក»
Job 10:20
តើអាយុជីវិតរបស់ទូលបង្គំពិតជាខ្លីមែនឬ?
ពាក្យ «អាយុរបស់ខ្ញុំ» នៅទីនេះបង្ហាញពីរយៈពេលដែលលោកយ៉ូបមានជីវិត។
សំណួរនេះរំពឹងដល់ចម្លើយវិជ្ជមាន ដើម្បីបញ្ជាក់ថាលោកយ៉ូប
លោកយ៉ូបរំពឹងថាគាត់រស់នៅតែពីរ បីថ្ងៃទៀតប៉ុណ្ណោះ។
វាអាចត្រូវបានបកប្រែដូចជារបាយការ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនៅសល់ពេលរស់នៅតែពីរ បីថ្ងៃទៀតប៉ុណ្ណោះ» ឬ
«ជីវិតរបស់ខ្ញុំនឹងត្រូវបញ្ចប់ឆាប់ៗនេះ»
ស្ថាន
នៅទីនេះ ទីកន្លែងដែលព្រលឹងនៃមនុស្សស្លាប់ទៅគឺត្រូវបានហៅថា ដូចជាស្ថាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ទីកន្លែង»
នៃភាពងងឹត និងនៃស្រមោលនៃសេចក្តីស្លាប់
ឃ្លានេះ «ស្រមោលនៃសេចក្តីស្លាប់» ពង្រឹងបន្ថែមនៃគំនិត នៃ «ភាពងងឹត»។
ឃ្លាទាំងពីរគឺអធិប្បាយអំពីទីកន្លែងដែលព្រលឹងរបស់មនុស្សស្លាប់ទៅ។
ស្រមោលនៃសេចក្តីស្លាប់
បកប្រែដូចនៅក្នុង ៣:៤
ងងឹតដូចជាកណ្តាលយប់
ភាពងងឹតនៃកន្លែងដែលព្រលឹងរបស់មនុស្សស្លាប់ទៅ
គឺត្រូវបានប្រៀបធៀបនឹងភាពងងឹតនៃកណ្តាលយប់។
គ្មានរបៀបរៀបរយ
ឃ្លាអវិជ្ជមាននេះ អាចត្រូវបានបង្ហាញក្នុងទម្រង់វិជ្ជមាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេញទៅដោយភាពរញ៉េរញ៉ៃ» ឬ
«ទីកន្លែងដែលគ្រប់យ៉ាងរញ៉េរញ៉ៃ»
ដែលពន្លឺក៏ដូចជាកណ្តាលរាត្រីដែល
ពន្លឺនៃទីកន្លែងដែលព្រលឹងមនុស្សស្លាប់ទៅ
គឺត្រូវបានប្រៀបធៀបទីនឹងកណ្តាលរាត្រី។ «ដែលទីនោះមិនមានពន្លឺ»

---

11 [1]លោកសូផារ ជាជនជាតិណាអាម៉ា ឆ្លើយឡើងថា៖[2]«តើយើងគួរនៅស្ងៀម មិនតបនឹងពាក្យជាចំលើយឬ? តើសម្តីរបស់អ្នកពូកែវោហារ អាចនឹងជឿបានទេ? ពាក្យ
ព្រោកប្រាជ្ញរបស់លោក អាចធ្វើឲ្យមនុស្សម្នានៅស្ងៀមឬ?[3]ពេលលោកមើលងាយការបង្រៀនរបស់យើង តើមិនធ្វើឲ្យលោកអាម៉ាស់មុខទេឬអី?
[4]ដ្បិតលោកបានទូលទៅព្រះជាម្ចាស់ថា សេចក្តីជំនឿទូលបង្គំគឺបរិសុទ្ធ ក៏គ្មានកំហុសនៅចំពោះព្រះជាម្ចាស់ដែរ។[5]ប៉ុន្តែព្រះជាម្ចាស់បានមានបន្ទូល
ដើម្បីទាស់ជាមួយនឹងទូលបង្គំ សូមព្រះអង្គថ្លែងប្រាប់លោកពីអាថ៌កំបាំង នៃព្រះប្រាជ្ញាញាណរបស់ព្រះអង្គ ដ្បិតព្រះអង្គពេញដោយប្រាជ្ញាដ៏អស្ចារ្យ។[6]លោកនឹងដឹងថា
ព្រះជាម្ចាស់ចង់បានអ្នក ច្រើនជាងអ្នកចង់បានខ្លួនឯងទៀត។
[7]តើលោកអាចស្វែងយល់ជម្រៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ? តើលោកជ្រាបពីឫទ្ធានុភាពឥតខ្ចោះទេ?[8]បញ្ហានោះគឺធំ ហើយខ្ពស់ជាងផ្ទៃមេឃ តើខ្ញុំអាចធ្វើអ្វីបាន?
គឺវាជ្រៅជាងស្ថានឃុំព្រលឹងមនុស្សស្លាប់ទៀត តើខ្ញុំអាចដឹងអ្វី?[9]វាវែងជាងផែនដីទៅទៀត ហើយក៏ធំជាងសមុទ្រផង។
[10]បើព្រះអង្គយាងកាត់ទៅ ហើយកោះឃុំអ្នកណា ព្រមទាំងហៅប្រជុំជំនុំជម្រះ តើអ្នកណាអាចនឹងឃាត់ព្រះអង្គបាន?[11]ដ្បិតព្រះអង្គស្គាល់មនុស្សកំភូត ព្រះអង្គក៏ឃើញអំពើ
ទុច្ចរិត តើព្រះអង្គមិនចាំពីរឿងនេះទេឬ?[12]ប៉ុន្តែមនុស្សល្ងីល្ងើនឹងមិនមានយោបល់សោះ លុះត្រាតែសត្វលាព្រៃកើតមកជាមនុស្ស។
[13]ប៉ុន្តែលោកគួរ តាំងចិត្តត្រឹមត្រូវឡើង ហើយលើកដៃរបស់លោកទៅរកព្រះជាម្ចាស់[14]ព្រមទាំងបោះបង់សេចក្តីអាក្រក់ ដែលនៅដៃរបស់លោកចេញ ប៉ុន្តែក្រោយមកលោក
មិនដាក់ឲ្យមានអំពើទុច្ចរិតណា នៅក្នុងទីលំនៅរបស់លោកនោះឡើយ។
[15]ប្រាកដជាលោកនឹងងើបមុខឡើង ឥតមានប្រឡាក់ភាពអាម៉ាស់ទេ លោកនឹងបានមាំមួនឥតភ័យខ្លាចអ្វីឡើយ។[16]ដ្បិតអ្នកនឹងភ្លេចសេចក្តីវេទនារបស់អ្នកទៅ លោកនឹង
នឹកចាំពីសេចក្តីនោះ ដូចជាចាំពីទឹកដែលហូរបាត់ហើយ។[17]ជីវិតរបស់លោកនឹងបានភ្លឺថ្លាជាងពេលថ្ងៃត្រង់ ប្រសិនបើមានសេចក្តីងងឹត នោះនឹងបានដូចជាពេលព្រឹកវិញ។

generated on Wed Sep 10 16:16:32 2025

[18]លោកនឹងមិនបារម្ភអ្វីសោះឡើយ ព្រោះលោកមានសង្ឃឹម។លោកលែងអាម៉ាស់ ហើយលោកនឹងសម្រាន្តយ៉ាងសុខស្រួល។[19]ពេលលោកសម្រាក គ្មាននរណាមករំខាន
លោកឡើយមនុស្សជាច្រើននឹងកោតសរសើរលោក។
[20]ប៉ុន្តែ ភ្នែករបស់ពួកមនុស្សអាក្រក់វិញ នឹងត្រូវងងឹតទៅ គេនឹងរកទីពឹងគ្មាន ហើយសេចក្តីសង្ឃឹមរបស់គេ នឹងបានជាសេចក្តីស្លាប់នោះ»។

Job 11:1
លោកសូផារ ជាជនជាតិណាអាម៉ា
សូមបកប្រែឈ្មោះរបស់បុរសនេះឲ្យដូចនៅក្នុងជំពូក ២:១១ ។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកសូផារពីតំបន់ណាអាម៉ា»
តើយើងគួរនៅស្ងៀម មិនតបនឹងពាក្យជាច្រើនឬ?
លោកសូផារបានសួរសំណួរក្នុងទម្រង់អវិជ្ជមាន
ដើម្បីបញ្ជាក់ថាពាក្យសម្តីរបស់លោកយ៉ូបត្រូវបានប្រឆាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងត្រូវតែឆ្លើយនូវពាក្យទាំងអស់នេះ!» ឬ
«អ្នកណាម្នាក់គួរតែឆ្លើយតបនឹងពាក្យទាំងអស់នេះ»
តើសម្តីរបស់អ្នកពូកែវោហារ អាចនឹងជឿបានទេ?
លោកសូផារបានប្រើសំណួរនេះដើម្បីបញ្ជាក់ថាពួកគេមិនគួរជឿអ្វីដែលលោកយ៉ូបនិយាយ
របៀបផ្សេងទៀតនៃការបកប្រែ: «បុរសនេះពេញទៅដោយរោហាសព្ទ ប៉ុន្តែ
មនុស្សមិនគួរជឿលោកនោះទេ។
ពាក្យព្រោកប្រាជ្ញរបស់លោក អាចធ្វើឲ្យមនុស្សម្នានៅស្ងៀមឬ?
លោកសូផារបានប្រើសំណួរនេះ ដើម្បីស្តីបន្ទោសលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយព្រោះលោកបាននិយាយនូវពាក្យសម្តីជាច្រើន
នេះមិនមានន័យថាអ្នកដទៃទៀតត្រូវស្ងៀមស្ងាត់នោះទេ»។
ពេលលោកមើលងាយការបង្រៀនរបស់យើង តើមិនធ្វើឲ្យលោកអាម៉ាស់មុខទេឬអី?
លោកសូផារបានប្រើសំណួរនេះ ដើម្បីស្តីបន្ទោសលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកមើលងាយការបង្រៀនរបស់យើង។
ឥឡូវនេះ យើងនឹងធ្វើឲ្យលោកមានអារម្មណ៍អាម៉ាស់!»
Job 11:4
សេចក្តីជំនឿរបស់ទូលបង្គំគឺបរិសុទ្ធ
«ការយល់ឃើញរបស់ខ្ញុំគឺត្រឹមត្រូវ»
ទូលបង្គំគ្មានកំហុសនៅចំពោះព្រះជាម្ចាស់ទេ
ភ្នែកគឺតំណាងឲ្យការមើលឃើញ
ដែលជាការប្រៀបធៀបសម្រាប់ការវាយតម្លៃរបស់ព្រះជាម្ចាស់ចំពោះលោកយ៉ូប។
អាចមានអត្ថន័យពីរ គឺទី ១) គឺលោកយ៉ូបនិយាយថា
ព្រះវិនិច្ឆ័យលោកដូចជាគ្មានបានសោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គមានព្រះបន្ទូលថាទូលបង្គំគ្មានកំហុសទេ» ឬទី ២) គឺលោកយ៉ូបជឿថា
លោកមិនមានកំហុសទេ
ហើយថាព្រះនឹងវិនិច្ឆ័យលោកដូចជាមនុស្សដែលគ្មានកំហុស។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គនឹងទទួលស្គាល់ថា
ទូលបង្គំមិនមានកំហុសទេ»
ព្រះជាម្ចាស់នឹងមានបន្ទូល...បើកព្រះឱស្ឋរបស់ទ្រង់ទាស់ជាមួយនឹងលោក
ពាក្យថា «បើកព្រះឱស្ឋរបស់ទ្រង់»
គឺជាពាក្យប្រៀបធៀបដែលមានន័យថានិយាយ។
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា
ដែលត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់បំណងប្រាថ្នារបស់លោកសូផារថា
ព្រះជាម្ចាស់នឹងមានព្រះបន្ទូលទាស់នឹងលោកយ៉ូប។ (សូមមើល: និង)
សូមព្រះអង្គថ្លែងប្រាប់លោកពីអាថ៌កំបាំង នៃព្រះប្រាជ្ញាញាណរបស់ព្រះអង្គ
អ្វីទៅជា «អាថ៌កំបាំងនៃប្រាព្រះប្រាជ្ញា» ដែលអាចត្រូវបានពន្យល់ឲ្យបានច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដែលព្រះអង្គនឹងបង្ហាញលោកថា
លោកមានសេចក្តីទុក្ខវេទនាដោយសារអំពើបាបរបស់លោក»
ព្រះជាម្ចាស់ចង់បានអ្នក ច្រើនជាងអ្នកចង់បានខ្លួនឯងទៀត
ការត្រូវការពីលោកយ៉ូប តំណាងឲ្យការដាក់ទណ្ឌកម្មលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះកំពុងដាក់ទោសលោកជាងការពឹងទុករបស់លោក»
Job 11:7
តើលោកអាចស្វែងយល់ជម្រៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ? តើលោកជ្រាបពីឫទ្ធានុភាពឥតខ្ចោះទេ?
សំណួរទម្រង់ស្របទាំងពីរនេះ គឺសួរពីកិច្ចការដូចគ្នា។
អ្នកសសេរប្រើប្រាស់សំណួរទម្រង់នេះដើម្បីសង្កត់បន្ថែមអត្ថន័យ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកមិនអាចយល់អំពីព្រះជាម្ចាស់ដោយស្វែងរកទ្រង់បានឡើយ
ហើយអ្នកក៏នឹងមិនយល់ជាក់ច្បាស់អំពីឫទ្ធានុភាពដ៏ឥតខ្ចោះបានដែរ!»
បញ្ហា
នេះគឺសំដៅដល់ការយល់ដឹងពីព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីយល់ពីព្រះ»
គឺធំហើយខ្ពស់ជាងផ្ទៃមេឃ...ជ្រៅជាងស្ថានឃុំព្រលឹងមនុស្សស្លាប់
ភាពមិនអាចទៅរួចនៃការយល់ពីព្រះ
គឺត្រូវបាននិយាយដូចជាការដែលវាមិនអាចទៅទីកន្លែងដ៏សែនឆ្ងាយបាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«តើលោកអាចស្រាវជ្រាវដែលមិនអាចចូលទៅដល់ទីកន្លែងដែលខ្ពស់បំផុតក្នុងស្ថានសួគ៌...គឺច្រើនជាងការដែលមិនអ
តើលោកអាចធ្វើអ្វីបាន?
លោកសូផារបានប្រើសំណួរនេះសើម្បីបង្ហាញថាមនុស្សម្នាក់មិនអាចធ្វើអ្វីមួយដើម្បី
យល់ដឹងពេញលេញពីព្រះជាម្ចាស់បានទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកមិនអាចធ្វើអ្វីបានទេ» ឬ «អ្នកមិនអាបយល់ពីព្រះជាម្ចាស់បានទាំងអស់ទេ»
តើលោកអាចដឹងអ្វី?
លោកសូផារបានប្រើសំណួរនេះសើម្បីបង្ហាញថាមនុស្សម្នាក់មិនអាចធ្វើអ្វីមួយដើម្បី
ស្គាល់ព្រះជាម្ចាស់បានពេញលេញទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកមិនអាចស្គាល់ព្រះបានពេញលេញទេ» ឬ
«អ្នកមិនអាចដឹងអ្វីទាំងអស់ដែលត្រូវដឹងនោះទេ»
ប្រវែងរបស់វា
អាចមានអត្ថន័យពីរដែលសំដៅដល់គឺ ទី១) ភាពអស្ចារ្យរបស់ព្រះ ទី ២)
ភាពអស្ចារ្យនៃព្រះប្រាជ្ញាញាណរបស់ព្រះ
វែងជាងផែនដីទៅទៀត ហើយក៏ធំជាងសមុទ្រផង
ភាពអស្ចារ្យរបស់ព្រះ ឬ ព្រះប្រាជ្ញាញាណ
គឺបាននិយាយដូចជាអាចមានរង្វាស់នៅក្នុងចម្ងាយ។
Job 11:10
ប្រសិនបើទ្រង់...ចាប់ឃុំនរណាម្នាក់
«ប្រសិនបើទ្រង់...បិតអ្នកណាម្នាក់នៅក្នុងគុក»
ប្រសិនបើ ព្រះអង្គកោះហៅនរណាម្នាក់មកជំនុំជម្រះ
នាមអរូប «ការជំនុំជម្រះ» អាចត្រូវបានបកប្រែជាមួយកិរិយាសព្ទ «វិនិច្ឆ័យ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
ព្រះជាម្ចាស់ត្រាស់ហៅនរណាម្នាក់ឲ្យទៅរកព្រះអង្គ ដូច្នោះ
ព្រះជាម្ចាស់អាចវិនិច្ឆ័យគាត់»
តើអ្នកណាអាចនឹងឃាត់ព្រះអង្គបាន
សំណួរនេះបញ្ជាក់ថាមិនមាននរណាម្នាក់អាចបញ្ឈប់ព្រះជាម្ចាស់បានទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនមាននរណាម្នាក់អាចបញ្ឈប់ទ្រង់បានទេ!»
តើព្រះអង្គមិនយកព្រះទ័យទុកដាក់ទេឬ?
នេះបញ្ជាក់ថាព្រះកត់ចំណាំអំពើបាប។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គប្រាកដជាកត់ចំណាំវា!»
ប៉ុន្តែ មនុស្សល្ងីល្ងើដែលគ្មានការយល់ដឹង
នាមអរូប «ការយល់ដឹង» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «យល់ដឹង»។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ មនុស្សល្ងីល្ងើមិនយល់ដឹង»
ពួកគេនឹងយល់ នៅពេលសត្វលាព្រៃបង្កើតកូនជាមនុស្ស
តាំងពីដើមមកសត្វលាព្រៃមិនអាចបង្កើតកូនមនុស្សបានទេ
នេះមានន័យថាមនុស្សល្ងីល្ងើក៏នឹងមិនអាចទទួលការយល់ដឹងបានដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «លុះណាតែសត្វលាព្រៃអាចបង្កើតកូនមនុស្ស
ទើបមនុស្សល្ងីល្ងើរទទួលការយល់ដឹង» ឬ «វាគឺអាចទៅរួចសម្រាប់មនុស្សល្ងីល្ងើ
ដើម្បីទទួលបានការយល់ដឹង
ដូចគ្នាបើវាអាចទៅរួចសម្រាប់សត្វលាព្រៃដែលអាចបង្កើតកូនមនុស្ស»
Job 11:13
ឧបមាថា លោកបានតាំងចិត្តត្រឹមត្រូវ
បេះដូងតំណាងឲ្យគំនិត និងអាកប្បកិរិយា។
ការចាត់តាំងវាត្រឹមត្រូវតំណាងឲ្យការកែតម្រូវវា។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«បើប្រសិនជាអ្នកបានកែតម្រូវអាកប្បកិរិយារបស់អ្នក»
ហើយលើកដៃរបស់លោកទៅរកព្រះជាម្ចាស់
នេះគឺជាសញ្ញាសម្គាល់សកម្មភាពការបង្ហាញការទូលសូមព្រះសម្រាប់ជំនួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយបានធ្វើអំពាវនាវនិងអធិស្ឋានដល់ព្រះ»
ឧបមាថាលោកបានបោះបង់ចោលអំពើទុច្ចរិត
ដៃតំណាងឲ្យអ្វីដែលមនុស្សប្រព្រឹត្ត។ របៀបផ្សេងទៀតនៃការបកប្រែ:
«បើប្រសិនជាលោកបានប្រព្រឹត្តការអ្វីមួយដែលអាក្រក់ក្នុងអតីតកាល»
ដូច្នេះ លោកបានដាក់វានៅឆ្ងាយពីលោក
ការដាក់អំពើបាបពីក្រោយតំណាងការបញ្ឈប់ការធ្វើអំពើបាប។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ បន្ទាប់មកអ្នកបានឈប់ប្រព្រឹត្តអំពើអាក្រក់»
មិនអនុញ្ញាតឲ្យមានអំពើទុច្ចរិតណា នៅក្នុងទីលំនៅរបស់លោកនោះឡើយ
ការរស់នៅរបស់អំពើទុច្ចរិត តំណាងឲ្យមនុស្សកំពុងធ្វើកិច្ចការទុច្ចរិត។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយអ្នកមិនអនុញ្ញាតឲ្យសមាជិកនៃគ្រួសាររបស់អ្នកប្រព្រឹត្តកិច្ចការទុច្ចរិត»
Job 11:15
លោកប្រាកដជាងើបមុខឡើង ដោយគ្មានភាពអាម៉ាស់ណាមួយឡើយ
«ងើបមុខរបស់អ្នកឡើង» តំណាងឲ្យអកប្បកិរិយានៃមនុស្សដែលមានការជឿជាក់
និងក្លាហាន។
លោកនឹងនឹកចាំពីសេចក្តីនោះ ដូចជាទឹកដែលហូរបាត់ទៅ
លោកសូផារគឺកំពុងប្រៀបធៀបសេចក្តីវេទនាជាមួយនឹងទឹកដែលហូរចុះហើយវាបាត់ទៅ
របៀបផ្សេងទៀតនៃការបកប្រែ: «លោកនឹងចងចាំវា ប៉ុន្តែ សេចក្តីវេទនានឹងបាត់ទៅ
ដូចជាទឹកដែលហូរបាត់ទៅ»
ជីវិតរបស់លោកនឹង...ដូចជាពេលព្រឹកវិញ
លោកសូផារនិយាយឡើងវិញនូវគំនិតដដែលសម្រាប់ការបញ្ជាក់។
ជីវិតរបស់លោកនឹងបានភ្លឺថ្លាជាងពេលថ្ងៃត្រង់
ភ្លឺថ្លាតំណាងឲ្យភាពថ្កុំថ្កើងនិងភាពរីករាយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ជីវិត
របស់លោកនឹងថ្កុំថ្កើងហើយរីករាយដូចពេលថ្ងៃត្រង់។
ទោះបីជាមានសេចក្តីងងឹត
សេចក្តីងងឹត តំណាងឲ្យបញ្ហានិងភាពក្រៀមក្រំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទោះបីជាបញ្ហាងងឹតនិងភាពក្រៀមក្រំក៏ដោយ»
នោះវានឹងបានដូចជាពេលព្រឹកវិញ
ពេលព្រឹកតំណាងឲ្យពន្លឺ ដែលតំណាងឲ្យភាពថ្កុំថ្កើងនិងភាពរីករាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «នោះវានឹងបានថ្កុំថ្កើងនិងរីករាយដូចជាពេល
ព្រឹក»
Job 11:18
លោកនឹងបានសុខសាន្ត...លោកនឹងសម្រាកនៅកន្លែងដែលមានសុវត្ថិភាពនោះ
លោកសូផារនិយាយអំពីគំនិតដូចគ្នាឡើងវិញសម្រាប់បញ្ជាក់
ហើយពណ៌នាអំពីភាពដែលអាចធ្វើទៅបាន។
លោកនឹងសម្រាកនៅកន្លែងដែលមានសុវត្ថិភាពនោះ
«លោកនឹងសម្រាក» គឺជាពាក្យសម្រាប់ «សម្រាក»។ ឃ្លាថា
«ដែលមានសុវត្ថិភាព» អាចបង្ហាញជាមួយពាក្យ «ដែលសុវត្ថិភាព»។
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងសម្រាកដោយមានសុវត្ថិភាព»
ពេលលោកសម្រាក...ក្តីមេត្តាពីលោក
លោកសូផារនិយាយអំពីគំនិតដូចគ្នាឡើងវិញសម្រាប់បញ្ជាក់
ហើយពណ៌នាអំពីភាពដែលអាចធ្វើទៅបាន។
លោកនឹងសម្រាកក្នុងក្តីសុខសាន្ត
នាមអរូប «សម្រាក» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «សម្រាក»។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកនឹងដេកងើយសម្រាក»
Job 11:20
ភ្នែករបស់មនុស្សអាក្រក់វិញ នឹងត្រូវងងឹតទៅ
ភ្នែករបស់ពួកគេតំណាងឲ្យការយល់ដឹងរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ការយល់ដឹងរបស់មនុស្សអាក្រក់វិញ នឹង
ត្រូវធ្លាក់ចុះទៅ» ឬ «មនុស្សអាក្រក់ នឹងមិនអាចយល់ដឹងបានទេ»
សេចក្តីសង្ឃឹមរបស់គេ ដង្ហើមចុងក្រោយរបស់ពួកគេ
នាមអរូប «សេចក្តីសង្ឃឹម» អាចត្រូវបានបង្ហាញជាមួយលិរិយាសព្ទ «សង្ឃឹម»។
ដង្ហើមចុងក្រោយតំណាងឲ្យការស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «សេចក្តី
សង្ឃឹមរបស់គេនឹងជាដង្ហើមដែលដកចុងក្រោយរបស់ពួកគេ» ឬ
«ពួកគេមានតែសង្ឃឹមថានឹងស្លាប់»

12 [1]ពេលនោះ លោកយ៉ូបឆ្លើយឡើងថា៖[2]«គ្មានផ្លូវសង្ស័យឡើយ មានតែអ្នករាល់គ្នាទេដែលជាមនុស្ស ហើយប្រាជ្ញានឹងស្លាប់ទៅ ជាមួយអ្នករាល់គ្នាដែរ។[3]ប៉ុន្តែ ខ្ញុំក៏
យល់ដូចជាអ្នករាល់គ្នាដែរ ខ្ញុំមិនអន់ជាងអ្នករាល់គ្នាទេ។ តើនរណាមិនស្គាល់សេចក្តីនេះទៅ?
[4]ខ្ញុំជាទីសើចចំអកដល់មិត្តសម្លាញ់ខ្ញុំ ជាអ្នកដែលបានអំពាវនាវដល់ព្រះជាម្ចាស់ ហើយព្រះអង្គក៏ឆ្លើយតប គឺជាមនុស្សសុចរិតត្រឹមត្រូវ ដែលត្រូវគេសើចចំអកឲ្យ។[5]ក្នុង
គំនិតរបស់អ្នកដែលមានសេចក្តីសុខ តែងមើលងាយចំពោះអ្នកវេទនា សេចក្តីនោះប្រុងប្រៀបសម្រាប់អ្នកណា ដែលភ្លាត់ជើង។[6]ទីលំនៅរបស់ពួកចោរចេះតែចម្រើន ហើយ
ពួកអ្នកដែលធ្វើឲ្យព្រះ ថ្នាំងថ្នាក់ព្រះហឫទ័យ ក៏តែងមានសេចក្តីសុខ គឺជាពួកអ្នកដែលទទួលតែអំណាច របស់ខ្លួនទុកជាព្រះជាម្ចាស់។
[7]ប៉ុន្តែ សួរសត្វតិរច្ឆានឥឡូវចុះ វានឹងបង្រៀនអ្នក ហើយសត្វស្លាប ដែលហើរលើអាកាស វានឹងប្រាប់ឲ្យអ្នកដឹង។[8]ឬសួរទៅរុក្ខជាតិនៅលើផែនដីចុះ វានឹងបង្រៀនអ្នកដែរ
ហើយសួរត្រីនៅសមុទ្រនឹងប្រកាសប្រាប់អ្នក។
[9]ក្នុងពួកសត្វទាំងនោះ តើមានមួយណាដែលមិនដឹងថា ព្រះហស្ថនៃព្រះអម្ចាស់បានបង្កើតទាំងអស់?[10]ដែលជីវិតនៃសត្វទាំងឡាយ សុទ្ធតែនៅក្នុងព្រះហស្ថរបស់ព្រះអង្គ
ព្រមទាំងខ្យល់ដង្ហើមរបស់មនុស្សផង។
[11]ត្រចៀក តើមិនស្តាប់យល់ពាក្យសម្តី ដូចជាមាត់ភ្លក់ឲ្យដឹងរសអាហារដែរទេឬ?[12]មនុស្សចាស់ៗតែងមានប្រាជ្ញា ហើយមនុស្សមានអាយុយឺនយូ ទើបមានយោបល់។
[13]នៅជាមួយព្រះជាម្ចាស់ មានទាំងប្រាជ្ញា និងឥទ្ធិឫទ្ធិផង ព្រះអង្គក៏មានព្រះតម្រិះ និងការយល់ដឹង។[14]មើល! ព្រះអង្គរំលំ ហើយគេនឹងសង់ឡើងវិញមិនបាន ប្រសិនបើ
ព្រះអង្គឃុំអ្នកណាទុកហើយ គ្មានអ្នកណាអាចនឹងដោះបានឡើយ។[15]មើល! ប្រសិនបើព្រះអង្គទប់ទឹក នោះទាំងអស់ក៏រីងស្ងួតទៅ ប្រសិនបើព្រះអង្គបើក នោះក៏លិចលង់
ផែនដីអស់។
[16]ក្នុងព្រះអង្គមានកម្លាំងឫទ្ធិ និងប្រាជ្ញា មនុស្សដែលគេឆបោក និងមនុស្សឆបោកគេ សុទ្ធតែនៅក្រោមអំណាចរបស់ព្រះអង្គ។[17]ព្រះអង្គដឹកនាំពួកអ្នកជួយគំនិតទៅខ្លួនទទេ
ហើយប្រគល់ពួកចៅក្រមទៅក្នុងសេចក្តីល្ងីល្ងើ។[18]ព្រះអង្គរំលាយអំណាចនៃពួកស្តេច ហើយចងខ្សែក្បាប់នៅចង្កេះផង។
[19]ព្រះអង្គដឹកនាំពួកសង្ឃទៅតែខ្លួនទទេ ហើយទម្លាក់ងារពួកមានអំណាចចុះ។[20]ព្រះអង្គដកពាក្យសម្តីពីពួកអ្នក ដែលគួរទុកចិត្តបាន ហើយក៏ដកយកយោបល់ពីពួកចាស់ទុំ
ចេញ។[21]ព្រះអង្គចាក់សេចក្តីមើលងាយទៅលើពួកដែលមានទ្រព្យ ក៏បន្ធូរខ្សែក្រវាត់នៃពួកខ្លាំងពូកែ។
[22]ព្រះអង្គបើកអស់ទាំងសេចក្តីជ្រៅជ្រះ ចេញពីងងឹតមក ក៏នាំយកសេចក្តីស្លាប់ចេញមក ដាក់នៅពន្លឺដែរ។[23]ព្រះអង្គចម្រើនជនជាតិទាំងប៉ុន្មាន ហើយក៏បំផ្លាញគេវិញ
ព្រះអង្គពង្រីកឲ្យគេធំឡើង រួចក៏ដឹកនាំគេទៅជាឈ្លើយ។
[24]ព្រះអង្គដកប្រាជ្ញាចេញពីពួកអ្នកដឹកនាំ នៃប្រជាជាតិនានានៅលើផែនដីដែរ ហើយព្រះអង្គបណ្តាលឲ្យគេដើរសាត់ព្រាត់ នៅទីរហោស្ថានដែលឥតមានផ្លូវសោះ។[25]ពួកគេ
ដើរក្នុងទីងងឹតឥតមានពន្លឺសោះ ព្រះអង្គក៏ធ្វើឲ្យគេដើរទ្រេតទ្រោត ដូចជាមនុស្សស្រវឹង។

Job 12:1
មិនសង្ស័យឡើយ
«យ៉ាងប្រាកដ»
អស់លោកទេដែលជាមនុស្ស
«អស់លោកជាមនុស្សសំខាន់ដែលដឹងគ្រប់យ៉ាង»
មិនសង្ស័យឡើយ មានតែអស់លោកទេដែលជាមនុស្ស ប្រាជ្ញានឹងស្លាប់ទៅ ជាមួយអស់លោកដែរ
លោកយ៉ូបចំអកឲ្យរបៀបដែលពួកគេកំពុងធ្វើនិងបង្ហាញពីរបៀបដែលពួកគេគួរឲ្យអស់សំណើច។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាកដណាស់អស់លោកដូចជាមនុស្សសំខាន់ដែលមានប្រាជ្ញាមិនអាចរស់នៅដោយមិនមានអស់លោក
ឬ «អស់លោកធ្វើដូចជាអស់លោកជាមនុស្សដែលមានប្រាជ្ញាតែម្នាក់
ហើយពេលដែលអស់លោកស្លាប់ទៅ ប្រាជ្ញាក៏នឹងបាត់ទៅដែរ»
អស់លោក

generated on Wed Sep 10 16:16:32 2025

នេះជាចំនួនពហុវចន ហើយក៏មាននៅក្នុងប្រយោគពីរបន្ទាប់ទៀត។
ជាការពិត តើនរណាមិនស្គាល់សេចក្ដីនេះទៅ?
លោកយ៉ូបបានប្រើសំណួរនេះដើម្បីបង្ហាញការពិតដែលគួរនឹងច្បាស់សម្រាប់អ្នកស្តាប់រួចហើយ។ ឃ្លានេះអាចបង្ហាញជាប្រយោគក៏បាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ជាការពិត មិនមាននរណាម្នាក់ដែលមិនដឹងពីកិច្ចការទាំងនេះនោះទេ» ឬ «ជាការពិត គ្រប់គ្នាដឹងពីកិច្ចការទាំងនេះ»
Job 12:4
ខ្ញុំជាទីសើចចំអកដល់អ្នកជិតខាងរបស់ខ្ញុំ ខ្ញុំជាម្នាក់ដែលបានអំពាវនាវដល់ព្រះជាម្ចាស់ ហើយក៏ជាអ្នកដែលព្រះអង្គបានឆ្លើយតបដែរ!
ទំនាក់ទំនងរវាងឃ្លាទាំងនេះអាចធ្វើឲ្យច្បាស់លាស់ជាមួយនឹងពាក្យ «ទោះបីជា»។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំជាទីសើចចំអកដល់អ្នកជិតខាងរបស់ខ្ញុំ ទោះបីជា ខ្ញុំជាម្នាក់ដែលបានអំពាវនាវដល់ព្រះជាម្ចាស់ ហើយក៏ជាអ្នកដែលព្រះអង្គបានឆ្លើយតបដែរ!»
ខ្ញុំជាមនុស្សសុចរិត និង គ្មានទោសទេ ឥឡូវនេះខ្ញុំត្រូវបានគេសើចចំអកឲ្យ
ទំនាក់ទំនងរវាងឃ្លាទាំងនេះអាចធ្វើឲ្យច្បាស់លាស់ជាមួយនឹងពាក្យ «ទោះបីជា»។ របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីជា ជាមនុស្សសុចរិត និង គ្មានទោសទេ ឥឡូវនេះខ្ញុំត្រូវបានគេសើចចំអកឲ្យ»
ក្នុងគំនិតរបស់អ្នកដែលមានសេចក្ដីសុខ តែងមើលងាយចំពោះភាពអកុសល
នាមអរូប «គំនិត» «សេចក្ដីសុខ» «មើលងាយ» និង «ភាពអកុសល» អាចត្រូវបានបង្ហាញជាមួយឃ្លាដទៃទៀត។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សម្នាក់ដែលរស់នៅដោយជីវិតសុខសាន្ត ស្អប់មនុស្សដែលទទួលសេចក្ដីវិនាស»
ភាពអកុសលមក
ការនាំភាពអកុសលតំណាងពីការធ្វើឲ្យអ្វីមួយកើតឡើង។ របៀបផ្សេងទៀតនៃការបកប្រែ: «បណ្ដាលឲ្យកិច្ចការអាក្រក់ជាច្រើនកើតឡើង»
ដល់អស់អ្នកណា ដែលភ្លាត់ជើង
ការភ្លាត់ជើងតំណាងឲ្យការចាប់ផ្ដើមក្នុងគ្រោះថ្នាក់ ឬបញ្ហា។ របៀបផ្សេងទៀតនៃការបកប្រែ: «ដល់អស់អ្នកណាដែលរួចរាល់នៅក្នុងបញ្ហា»
ទីលំនៅរបស់ពួកចោរកាន់តែចម្រើនឡើយ
ទីលំនៅរបស់ពួកគេកាន់តែចម្រើនឡើង តំណាងឲ្យការរីកចម្រើនរបស់ពួកចោរក្នុងទីលំនៅរបស់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកចោររស់នៅយ៉ាងរីកចម្រើនក្នុងទីលំនៅរបស់ខ្លួន»
ដៃរបស់ពួកគេគឺជាព្រះរបស់ពួកគេ
«ដៃរបស់ពួកគេ» គឺជាពាក្យប្រៀបធៀបសម្រាប់កម្លាំង ែហើយ «ព្រះរបស់ពួកគេ» គឺជាពាក្យប្រៀបធៀបសម្រាប់មោទនភាពរបស់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេមានអំនួតហួសប្រមាណអំពីសមត្ថភាពរបស់ពួកគេ»
Job 12:7
ប៉ុន្តែ ឥឡូវនេះ ចូរសួរ...នឹងប្រាប់ឲ្យអ្នកដឹង
ស្ថានការទាំងបួននេះ បង្ហាញពីគំនិតដែលសត្វតិរច្ឆាន សត្វស្លាប ផែនដី ហើយនិងត្រីនៅសមុទ្រ យល់ដឹងពីព្រះបានប្រសើរជាងមិត្តទាំងឡាយរបស់លោកយ៉ូបយល់។
ប៉ុន្តែ ឥឡូវនេះ ចូរសួរសត្វតិរច្ឆានចុះហើយវានឹងបង្រៀនអ្នក
នៅក្នុងផ្នែកទីមួយនៃប្រយោគជាការបង្គាប់ បៀបធៀបនឹងស្ថានភាពជាក់ស្តែង។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ប្រសិនបើអ្នកសួរសត្វតិរច្ឆាននោះពួកវានឹងបង្រៀនអ្នក»
ហើយចូរសួរសត្វស្លាប ដែលហើរលើមេឃ វានឹងប្រាប់ឲ្យអ្នកដឹង
នៅក្នុងផ្នែកទីមួយនៃប្រយោគជាការបង្គាប់ បៀបធៀបនឹងស្ថានភាពជាក់ស្តែង។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នកសួរ សត្វសត្វស្លាបដែលហើរលើមេឃ នោះពួកវានឹងប្រាប់អ្នក»
ឬចូរសួរទៅលើផែនដីចុះ វានឹងបង្រៀនអ្នកដែរ
នៅក្នុងផ្នែកទីមួយនៃប្រយោគជាការបង្គាប់ បៀបធៀបនឹងស្ថានភាពជាក់ស្តែង។ របៀបផ្សេងទៀតនៃការបកប្រែ: «ឬ ប្រសិនបើអ្នកនិយាយទីកាន់ផែនដីនោះវានឹងបង្រៀនអ្នក»
ហើយចូរសួរត្រីនៅសមុទ្រ វានឹងប្រកាសប្រាប់អ្នក
ការបង្គាប់ «ចូរសួរត្រីនៅសមុទ្រ» គឺបានយល់ពីប្រយើ ែាមុនៗមក។ នៅក្នុងផ្នែកទីមួយនៃប្រយោគជាការបង្គាប់ បៀបធៀបនឹងស្ថានភាពជាក់ស្តែង។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយប្រសិនបើអ្នកសួរត្រីនៅសមុទ្រ វានឹងប្រកាសប្រាប់អ្នក»
Job 12:9
ក្នុងចំណោមសត្វទាំងអស់នោះ តើមានសត្វមួយណាដែលមិនដឹង...ទាំងអស់?
សំណួរនេះ
វាមានន័យថា: «គ្រប់សត្វទាំងអស់ដឹង...នេះ»។ (សូមមើល: |Rhetorical Question)
ព្រះហស្តនៃព្រះអម្ចាស់បានបង្កើតទាំងអស់
ព្រះហស្តរបស់ព្រះជាម្ចាស់តំណាងអោយអំណាចរបស់ទ្រង់។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់បានធ្វើកិច្ចការនេះដោយអំណាចរបស់ព្រះអង្គ» (សូមមើល: |Metonymy)
ជីវិតនៃសត្វទាំងឡាយ និងខ្យល់ដង្ហើមរបស់មនុស្សផងសុទ្ធតែនៅក្នុងព្រះហស្តរបស់ព្រះអង្គទាំងអស់
ព្រះហស្តរបស់ព្រះជាម្ចាស់តំណាងឲ្យការត្រួតត្រា ឬអំណាចរបស់ទ្រង់។ របស់គ្រប់យ៉ាងចាប់ផ្ដើមក្នុងព្រះហស្តរបស់ទ្រង់តំណាងឲ្យឫទ្ធានុភាពរបស់ព្រះអង្គដើម្បីត្រួតត្រាពួកវា។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលត្រួតត្រាលើគ្រប់អ្វីៗដែលមានជីវិតទាំងអស់ និងប្រទានខ្យល់ដង្ហើមអោយមនុស្ស» (សូមមើល: |Metonymy)
ខ្យល់ដង្ហើមរបស់មនុស្សផង
«ខ្យល់ដង្ហើម» តំណាងឲ្យជីវិត ឬសមត្ថភាពដើម្បីរស់។ (សូមមើល: |Metonymy)
Job 12:11
តើត្រចៀកមិនបានភ្លក់ពាក្យសំដី ដូចជាមាត់ភ្លក់ឲ្យដឹងរសអាហារដែរទេឬ?
លោកយ៉ូបប្រើសំណួរនេះដើម្បីសង្កត់ធ្ងន់ថា មនុស្សស្តាប់អ្វីៗដែលអ្នកដទៃនិយាយហើយវិនិច្ឆ័យថាវាគឺល្អឬអាក្រក់។ ត្រចៀកហើយនិងអណ្ដាតជាពាក្យប្រៀបធៀបសម្រាប់ការស្តាប់និងការភ្លក្ស។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងឮអ្វីដែលមនុស្សនិយាយ ហើយសាកល្បងវាដូចជាភ្លក្សរសជាតិអាហារ»
មនុស្សចាស់ៗតែងមានប្រាជ្ញា
«មនុស្សចាស់ៗតែងមានប្រាជ្ញា»។ នាមអរូប «ប្រាជ្ញា» អាចត្រូវបានបង្ហាញជាមួយ «គតិបណ្ឌិត»។ ពាក្យ «មនុស្ស» សំដៅដល់មនុស្សធម្មតា។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សចាស់គឺមានប្រាជ្ញា»
មនុស្សមានអាយុយឺនយូរ ទើបមានការយល់ដឹង
ប្រយោគ «អាយុយឺនយូរ» គឺជានិយមធៀបសម្រាប់ការរស់បានយូរ។ ការយល់ដឹងក្នុងអាយុកាលយឺនយូរ តំណាងឲ្យការរីកចម្រើនការយល់ដឹងរបស់មនុស្សនៅពេលដែលរស់នៅបានយូរ។ នាមអរូប «ការយល់ដឹង» អាចត្រូវបានបង្ហាញជាមួយឃ្លា «យល់ដឹងច្រើន»។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សរីកចម្រើនការយល់ដឹងនៅពេលដែលរស់នៅបានយូរ» ឬ «មនុស្សដែលរស់នៅយូរអង្វែងយល់ដឹងច្រើន»
Job 12:13
ព័ត៌មានទូទៅ:
ខទី ១៣ និយាយថាព្រះគឺទាំងប្រាជ្ញា និងឥទ្ធិឫទ្ធិ។ ផ្នែកនៃជំពូកនេះបង្ហាញថានេះគឺជាការពិតដោយប្រាប់អំពីព្រះប្រាជ្ញាញាណ និងឥទ្ធិឫទ្ធិ ដែលព្រះបានធ្វើ។
នៅជាមួយព្រះជាម្ចាស់ មានទាំងប្រាជ្ញា និងឥទ្ធិឫទ្ធិផង
នាមអរូប «ប្រាជ្ញា» និង «ឥទ្ធិឫទ្ធិ» អាចត្រូវបានបង្ហាញជាមួយគុណនាម «ដែលប្រកបដោយគតិបណ្ឌិត» និង «ដែលមានអនុភាព»។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះគឺប្រកបដោយគតិបណ្ឌិតនិងប្រកបដោយអនុភាព»
មើល៍
ពាក្យនេះកត់ចំណាំកន្លែងដែលលោកយ៉ូបចង់ឲ្យអ្នកស្តាប់យកចិត្តទុកដាក់ជាពិសេស។
ហើយគេនឹងសង់ឡើងវិញមិនបានទេ
ឃ្លានេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «មិនមានអ្នកណាអាចសាងសង់វាឡើងវិញបានទេ»
ព្រះអង្គឃុំអ្នកណាទុកហើយ គ្មានអ្នកណាអាចនឹងដោះបានឡើយ
នាមអរូប «ដោះលែង» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «ដោះលែង»។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គឃុំអ្នកណាទុកហើយ គ្មានអ្នកណាអាចនឹងដោះបានឡើយ»
ប្រសិនបើ ព្រះអង្គទប់ទឹក នោះទាំងអស់ក៏រីងស្ងួតទៅ

generated on Wed Sep 10 16:16:32 2025

អាចមានអត្ថន័យពីរដែលបង្ហាញអំពីទឹក ទី១) ការរារាំងទឹកកុំឲ្យធ្លាក់ចុះមក» ឬទី
២) ការរារាំងទឹកកុំឲ្យហូរមក។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
ទ្រង់បញ្ឈប់ទឹកកុំឲ្យហូរ នោះដីនឹងស្ងួតហែង»
ហើយប្រសិនបើ ព្រះអង្គបើក ទឹកនឹងលិចលង់ផែនដីអស់
អាចមានអត្ថន័យពីរដែលបង្ហាញអំពីការបើក គឺ ទី១) បណ្តាលឲ្យភ្លៀងធ្លាក់ចុះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើទ្រង់បណ្តាលឲ្យភ្លៀងជាច្រើនធ្លាក់មក
វានឹងធ្វើឲ្យមានទឹកជន់លេចដី» ឬ ទី២) ការបណ្តាលឲ្យទឹកហូរមក។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ ទ្រង់បណ្តាលឲ្យទឹកជាច្រើនហូរមក
វានឹងធ្វើឲ្យមានទឹកជន់លេចដី»

Job 12:16

ក្នុងព្រះអង្គមានកម្លាំង និងប្រាជ្ញា
នាមអរូប «កម្លាំង» និង ប្រាជ្ញា អាចត្រូវបានបង្ហាញជាមួយពាក្យ «ខ្លាំង»
និងប្រាជ្ញា។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះខ្លាំងនិងឥទ្ធិឫទ្ធិ»
មនុស្សដែលគេឆបោក និងមនុស្សបោកគេ សុទ្ធតែនៅក្រោមអំណាចរបស់ព្រះអង្គ
ការចាប់ផ្តើមអំណាចរបស់ព្រះតំណាង ការគ្រប់គ្រងរបស់ព្រះអង្គលើពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សដែលជឿសេចក្តីកុហក
និងមនុស្សដែលបោកបញ្ឆោទអ្នកដទៃ ទាំងពីរនេះនៅក្នុងអំណាចរបស់ទ្រង់» ឬ
«ព្រះជាម្ចាស់គ្រប់គ្រងទាំងមនុស្សដែលជឿលើការកុហក
ទាំងលើមនុស្សដែលឆបោកអ្នកដទៃ»
ព្រះអង្គនាំអ្នកប្រឹក្សាឲ្យវង្វេង
ការនាំពួកទីប្រឹក្សាឲ្យវង្វេង តំណាងការយកប្រាជ្ញា និងអំណាចរបស់ពួកគេចេញ។
ក្នុងសេចក្តីវេទនា
នាមអរូប «សេចក្តីវេទនា» អាចត្រូវបានបង្ហាញជាមួយនឹងពាក្យ «ក្រៀមក្រំ» ឬ
«ព្រួយចិត្ត»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកគេមានអារម្មណ៍ក្រៀមក្រំយ៉ាងខ្លាំង» ឬ «ហើយពួកគេព្រួយចិត្ត»
ព្រះអង្គប្រគល់ពួកចៅក្រមទៅក្នុងសេចក្តីល្ងីល្ងើ
ព្រះអង្គធ្វើឲ្យពួកចៅក្រមទៅជាល្ងីល្ងើ
ព្រះអង្គដកយកអំណាចចេញពីស្តេចទាំងឡាយ
អាចមានអត្ថន័យពីរ គឺ១)
នេះគឺជាន័យធៀបសម្រាប់ការធ្វើឲ្យស្តេចទាំងឡាយមិនមានអំណាចយូរអង្វែង។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គយកអំណាចចេញពីស្តេចទាំងឡាយ» ឬ
២)
នេះគឺជាន័យធៀបសម្រាប់ធ្វើឲ្យមនុស្សមានសេរីភាពពីច្រវាក់ដែលស្តេចទាំងឡាយបានដាក់លើពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គដោះចំណងដែលស្តេចទាំងឡាយដាក់លើមនុស្ស»
ព្រះអង្គចងខ្សែភ្ជាប់នៅចង្កេះរបស់ស្តេចទាំងនោះផង
សម្លៀកបំពាក់នៅត្រង់នេះ ប្រហែលជាអ្វីដែលទាសករម្នាក់ស្លៀក។
ការដាក់សម្លៀកលើស្តេចនានា
តំណាងឲ្យការធ្វើឲ្យស្តេចស្លៀកសម្លៀកបំពាក់របស់ពួកទាសករ» ឬ
«ព្រះអង្គធ្វើឲ្យពួកគេក្លាយជាទាសករ»

Job 12:19

ព្រះអង្គនាំពួកបូជាចារ្យឲ្យវង្វេងក្នុងភាពទុក្ខព្រួយ
ការនាំពួកបូជាចារ្យឲ្យវង្វេងតំណាងឲ្យការយកអំណាចរបស់ពួកគេចេញ។
ក្នុងភាពទុក្ខព្រួយ
នាមអរូប «ភាពទុក្ខព្រួយ» អាចត្រូវបានបង្ហាញពាក្យ «ក្រៀមក្រំ» ឬ «ព្រួយចិត្ត»
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយពួកគេមានអារម្មណ៍ក្រៀមក្រំយ៉ាងខ្លាំង» ឬ
«ហើយពួកគេព្រួយចិត្ត»
ផ្តួលរំលំមនុស្សមានអំណាច
«កំចាត់មនុស្សមានអំណាច»
ព្រះអង្គដកពាក្យសំដីពីពួកអ្នកដែលគួរទុកចិត្តបាន
ការដកយកសម្ដីរបស់ពួកគេ តំណាងឲ្យការធ្វើឲ្យពួកគេមិនអាចនិយាយបាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គធ្វើឲ្យអ្នកដែលគេទុកចិត្តមិនអាចនិយាយបាន» ឬ
«ព្រះអង្គធ្វើឲ្យអស់អ្នកដែលគេធ្លាប់ទុកចិត្តទៅជាស្ងៀមស្ងាត់»
ដកយកយោបល់ពីពួកចាស់ទុំចេញ
ព្រះអង្គធ្វើឲ្យអស់អ្នកដែលគេធ្លាប់ទុកចិត្តមិនអាចនិយាយបាន» ឬ
«ព្រះអង្គធ្វើឲ្យមនុស្សដែលគេធ្លាប់ទុកចិត្តទៅជាស្ងាត់»
ពួកចាស់ទុំ
អាចមានអត្ថន័យពីរ គឺ ទី១) មនុស្សចាស់ ទី២) ពួកអ្នកដឹកនាំ។
ព្រះអង្គចាក់សេចក្តីមើលងាយទៅលើពួកអ្នកធំ
ការចាក់សេចក្តីមើលងាយទៅលើពួកអ្នកធំ
គឺជាការប្រៀបធៀបមួយដែលធ្វើឲ្យមនុស្សមានអារម្មណ៍មើលងាយពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានបណ្តាលឲ្យមនុស្សមិនមានការគោរពយ៉ាងខ្លាំងចំពោះពួកអ្នកគ្រប់គ្រង»
ក៏ដោះខ្សែក្រវាត់នៃពួកខ្លាំងពូកែ
ខ្សែក្រវាត់គឺជាសញ្ញាសម្គាល់ពីកម្លាំង។ ការដោះខ្សែក្រវាត់របស់មនុស្សខ្លាំង
សំដៅដល់ការយកកម្លាំងរបស់គាត់ចេញនិងធ្វើឲ្យគាត់ទៅជាខ្សោយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើឲ្យមនុស្សខ្លាំងទៅជាខ្សោយ»

Job 12:22

ព្រះអង្គបើកសម្តែងសេចក្តីជ្រៅជ្រះ ចេញពីភាពងងឹត
ការបើកសម្តែង តំណាងឲ្យការធ្វើឲ្យពួកគេបានដឹងពីកិច្ចការដទៃទៀត។
«សេចក្តីជ្រៅជ្រះពីភាពងងឹត» បង្ហាញអាថ៌កំបាំងដែកមនុស្សមិនដឹង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គធ្វើឲ្យបានដឹងការអាថ៌កំបាំងដែលមនុស្សមិនដឹង»
ហើយក៏នាំយកភពងងឹតជាកន្លែងមនុស្សស្លាប់នៅ
ការនាំចេញទៅកាន់ពន្លឺ តំណាងឲ្យការធ្វើឲ្យពួកគេបានដឹង។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើឲ្យបានស្គាល់កន្លែងដែលមនុស្សស្លាប់នៅ»។
ព្រះអង្គពង្រីកប្រជាជាតិ
«ព្រះអង្គបានធ្វើឲ្យវិសាលភាពនៃដីរបស់ក្រុមមនុស្សបានកាន់តែធំឡើងៗ» ឬ
«ព្រះអង្គនាំឲ្យប្រជាជាតិយកដីកានតែច្រើនឡើងៗ»
ព្រះអង្គក៏នាំគេទៅដូចជាពួកអ្នកទោសដែរ
ការដឹកនាំប្រជាជាតិរបស់ព្រះជាម្ចាស់
តំណាងឲ្យការនាំប្រជាជាតិដែលជាសត្រូវដឹកនាំពួកគេ។ ពាក្យ «ពួកគេ»
តំណាងឲ្យប្រជាជាតិនានា ដែលនៅទីនេះតំណាងឲ្យមនុស្សនៃប្រជាជាតិនានា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គក៏នាំសត្រូវរបស់ពួកគេឲ្យដឹកនាំពួកគេដូចជាពួកអ្នកទោសដែរ»

Job 12:24

ព្រះអង្គដកការយល់ដឹងចេញពីពួកអ្នកដឹកនាំរបស់ប្រជាជាតិទាំងឡាយនៅលើផែនដីដែរ
ការដកយកការយល់ដឹងរបស់ពួកគេចេញ
តំណាងឲ្យហេតុដែលធ្វើឲ្យពួកគេមិនអាចយល់បាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបណ្តាលឲ្យពួកមេដឹកនាំនៃប្រជាជាតិទាំងឡាយលើផែនដីមិនអាចយល់ដឹងបាន»
ដើរវង្វេងនៅទីរហោស្ថានជាកន្លែងដែលគ្មានផ្លូវសោះ
ការដើរវង្វេងក្នុងទីរហោស្ថានជាកន្លែងដែលគ្មានផ្លូវ
តំណាងឲ្យការស្ថិតនៅក្នុងស្ថានភាពដ៏ពិបាក ហើយមិនដឹងថាត្រូវធ្វើអ្វី។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនប្រាកដថាត្រូវធ្វើអ្វី
ដូចជាមនុស្សម្នាក់កុំពុងវង្វេងក្នុងទីកន្លែងដែលមិនមានផ្លូវ»
ពួកគេដើរក្នុងទីងងឹតគ្មានពន្លឺសោះ
ការចាប់ផ្តើមក្នុងទីងងឹតដែលគ្មានពន្លឺ តំណាងអោយការខ្វះចំណេះដឹង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេតស៊ូធ្វើការសម្រេចចិត្តដោយគ្មានចំណេះដឹង
ដូចជាមនុស្សតស៊ូដើរក្នុងទីងងឹតដែលគ្មានពន្លឺ»
ព្រះអង្គក៏ធ្វើឲ្យគេដើរទ្រេតទ្រោត ដូចជាមនុស្សស្រវឹងដែរ
ការដើរទ្រេតទ្រោត ឬការដើរវង្វេងដូចមនុស្សស្រវឹង
តំណាងឲ្យការរស់នៅដោយគ្មានគោលដៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គធ្វើឲ្យពួកគេរស់ដោយគ្មានគោលដៅ
ដូចមនុស្សស្រវឹងម្នាក់ដែលទ្រេតទ្រោតនៅពេលដែលគាត់ដើរ»

---

13 [1]មើល! ភ្នែកខ្ញុំបានឃើញការទាំងនេះ ហើយត្រចៀកខ្ញុំក៏បានឮ ក៏បានយល់ដែរ។[2]អ្វីៗដែលអ្នករាល់គ្នាដឹង ខ្ញុំក៏ដឹងដែរ ខ្ញុំមិនអន់ជាងអ្នករាល់គ្នាទេ។
[3]ទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់ទូលដល់ព្រះអង្គ ដ៏មានគ្រប់ព្រះចេស្តាថា ខ្ញុំមានហេតុផងជាមួយព្រះអង្គ។[4]អ្នករាល់គ្នាសុទ្ធតែជាអ្នក បង្កើតសេចក្តីពិតកុហក អ្នក
រាល់គ្នាជាគ្រូពេទ្យឥតប្រយោជន៍ទាំងអស់។[5]ឱបើអ្នករាល់គ្នានឹងនៅស្ងៀមវិញទៅ នោះនឹងសម្តែងថា អ្នករាល់គ្នាមានប្រាជ្ញាមែន។

generated on Wed Sep 10 16:16:32 2025

[6]ដូច្នេះ ចូរស្តាប់ហេតុផលរបស់ខ្ញុំ ហើយផ្ទៀងត្រចៀកស្តាប់សេចក្តីអង្វរ របស់បបូរមាត់ខ្ញុំសិន។[7]តើអ្នករាល់គ្នានឹងនិយាយសេចក្តីទុច្ចរិត ដោយយល់ដល់ព្រះ ព្រមទាំងសេចក្តីកំភូតផងឬ?[8]តើលោកពិតជាបានបង្ហាញក្តីសបុរស្សរសព្រះអង្គ? ហើយតាំងខ្លួនជាអ្នកកាន់ក្តីជំនួសព្រះអង្គឬ?
[9]អ្នករាល់គ្នាសុខចិត្តឲ្យព្រះអង្គ ស្ទង់ចិត្តរបស់អ្នកឬទេ? តើអ្នករាល់គ្នាគិតបញ្ឆោតព្រះអង្គ ដូចជាបញ្ឆោតមនុស្សដែរ?[10]ព្រះអង្គនឹងទូទាត់ជាមួយនិងអ្នក ប្រសិនបើអ្នកធ្វើការហើយបង្ហាញថាអ្នកសម្លៀងពិត។
[11]តើមិនមែនតេជានុភាពរបស់ព្រះអង្គ ដែលបានធ្វើឲ្យ លោកស្ញែងខ្លាចទេឬអី?[12]តើមិនមែនភាពភ័យខ្លាច បានធ្លាក់លើលោកទេឬ? ការចងចាំរបស់អ្នកបានប្រាប់ថា ពាក្យសុភាសិតគ្រាន់តែជាសម្លេង និងរបងការពារក៏ធ្វើអំពីដីឥដ្ឋដែរ។
[13]សូមអស់លោកបានសុខសាន្ត និងសុមឲ្យខ្ញុំនៅម្ខាក់ឯង រួចឲ្យខ្ញុំនិយាយផង សូមឲ្យផលវិបាកទាំងនោះកើតចំពោះខ្ញុំចុះ។[14]ខ្ញុំនឹងយកសាច់ឈាម ព្រមទាំងធ្មេញរបស់ខ្ញុំផង ហើយខ្ញុំនឹងទទួលខុសត្រូវជីវិតរបស់ខ្ញុំដោយដៃខ្ញុំដែរ។[15]មើល! បើព្រះអង្គសម្លាប់ខ្ញុំ នោះខ្ញុំលែងមានសង្ឃឹមទៀតទេ ប៉ុន្តែ ខ្ញុំនឹងការពារផ្លូវរបស់ខ្ញុំនៅចំពោះព្រះអង្គ។
[16]នេះគឺជាមូលហេតុដែលខ្ញុំអាចរួចជីវិត ដែលខ្ញុំមិនបាននៅចំពោះព្រះជាម្ចាស់ដូចជាមនុស្សទមិឡ។[17]ព្រះជាម្ចាស់ស្តាប់ដោយព្រះទ័យទុកដាក់ សម្រាប់ពាក្យរបស់ទូលបង្គំ សូមឲ្យពាក្យដែលទូលបង្គំបានឮដល់ព្រះកាណ៌របស់ព្រះអង្គផង។
[18]មើល ឥឡូវនេះ! ទូលបង្គំបានរៀបសេចក្តីការពារជាលំដាប់ ទូលបង្គំដឹងហើយថាទូលបង្គំគ្មានកំហុសទេ។[19]តើមានអ្នកណានឹងហ៊ានទាស់នឹងទូលបង្គំនៅមុខចៅក្រមទៅ? ប្រសិនបើមានមែន ហើយអាចរកឃើញថាទូលបង្គំខុស នោះទូលបង្គំនឹងនៅស្ងៀម ហើយព្រមប្រគល់ជីវិតរបស់ទូលបង្គំផង។
[20]ព្រះជាម្ចាស់បានធ្វើការពីរសម្រាប់ទូលបង្គំ ហើយទូលបង្គំនឹងបិតបាំងខ្លួនទូលបង្គំពីចំពោះព្រះអង្គឡើយ:[21]សូមដកព្រះហស្តនៃទុក្ខវេទនាចេញពីទូលបង្គំ ហើយសូមកុំឲ្យអំណាចព្រះអង្គធ្វើឲ្យទូលបង្គំភ័យខ្លាចដែរ។[22]សូមមានបន្ទូលមកទូលបង្គំ ហើយទូលបង្គំនឹងឆ្លើយ ឬសូមឲ្យទូលបង្គំពោលទៅកាន់ព្រះអង្គ ហើយសូមឲ្យព្រះអង្គឆ្លើយនឹងទូលបង្គំផង។
[23]តើអំពើទុច្ចរិត និងអំពើបាប របស់ទូលបង្គំមានប៉ុន្មាន? សូមព្រះអង្គឲ្យទូលបង្គំ បានស្គាល់អស់ទាំងអំពើរំលង និងអំពើបាបរបស់ទូលបង្គំផង។[24]ហេតុអ្វីបានជាព្រះអង្គលាក់ព្រះភក្ត្រ ហើយទុកទូលបង្គំដូចជាសត្រូវរបស់ ព្រះអង្គដូច្នេះ?[25]ហេតុអ្វីព្រះអង្គវាយស្លឹកឈើដែលត្រូវខ្យល់ផាត់? ហើយដេញតាមចំបើងក្រៀមបែបនេះ?
[26]ដ្បិតព្រះអង្គបានកត់ទុក សេចក្តីជូរល្វីងទាស់នឹងទូលបង្គំ ហើយឲ្យទូលបង្គំទទួលមរតក នៃបាបដែលបានប្រព្រឹត្តកាលពីក្មេង។[27]ព្រះអង្គដាក់ជើងទូលបង្គំជាប់នៅខ្នោះ ក៏ចំណាំមើលអស់ទាំងផ្លូវច្រកនៃទូលបង្គំ ហើយព្រះអង្គគូសព្រំដែន មិនឲ្យដានជើងទូលបង្គំរំលងឡើយ។[28]ទូលបង្គំប្រៀបដូចជាឈើដែលខូតស៊ីសុស ហើយដូចជាអាវដែលកន្លាត បានកាត់ស៊ីអស់។

Job 13:1
ប្រយោគភ្ជាប់
ប្រយោគភ្ជាប់: លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
មើល៍
«យកចិត្តទុកដាក់» ឬ «ស្តាប់»។
ពាក្យនេះកត់សម្គាល់កន្លែងដែលលោកយ៉ូបចង់ឲ្យមិត្តទាំងបីរបស់លោកស្តាប់ដោយយកចិត្តទុកដាក់
ភ្នែករបស់ខ្ញុំបានឃើញការទាំងនេះ
លោកយ៉ូបចាត់ទុកខ្លួនរបស់លោកដូចជាភ្នែករបស់លោក
គឺលោកបានឃើញរបស់ទាំងនេះ ចាប់តាំងពីភ្នែករបស់លោកនៅជាមួយលោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានមើលឃើញការទាំងនេះ»
ហើយត្រចៀករបស់ខ្ញុំក៏បានឮ ក៏បានយល់ដែរ
លោកយ៉ូបចាត់ទុកខ្លួនរបស់លោកដូចជាត្រចៀករបស់លោក
គឺលោកបានឮរបស់ទាំងអស់នេះ ចាប់តាំងពីត្រចៀករបស់លោកនៅជាមួយលោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានមើលឃើញការទាំងនេះ»
អ្វីដែលអស់លោកដឹង ខ្ញុំក៏ដឹងដូចអស់លោកដែរ
«អ្វីដែលអ្នកដឹង ខ្ញុំក៏ដឹងដែរ» (UDB) ឬ «ខ្ញុំដឹងច្រើនដូចជាអ្នកដែរ»
Job 13:3
ខ្ញុំចង់វែកញែកជាមួយព្រះអង្គ
មិត្រភក្តិរបស់លោកយ៉ូបកំពុងវិនិច្ឆ័យលោក ប៉ុន្តែ ពួកគេមិននិយាយការពិតទេ។
លោកយ៉ូបនឹងជជែកតវ៉ាជាមួយព្រះជាម្ចាស់តែម្នាក់ឯងអំពីបណ្តឹងរបស់លោក
អស់លោកព្យាយាមលាក់សេចក្តីពិតដោយការកុហក
ការដាក់ទឹកលុប ឬកំបោរសទៅលើការពិត តំណាងឲ្យការបដិសេធសេចក្តីពិត។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកលាក់សេចក្តីពិតដោយការកុហក» ឬ «អ្នកកុហក ហើយបដិសេធសេចក្តីពិត»
អស់លោកជាគ្រូពេទ្យដែលគ្មានតម្លៃ
ជាគ្រូពេទ្យម្នាក់ តំណាងឲ្យធ្វើជាមនុស្សម្នាក់ដែលលួងលោមចិត្តអ្នកដទៃ។
ការធ្វើជាមនុស្សគ្មានតម្លៃមានន័យថា ពួកគេមិនចេះធ្វើអ្វីដែលពួកគេគួរតែធ្វើ។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករាល់គ្នាដូចជាគ្រូពេទ្យដែលមិនចេះព្យាបាលជំងឺ» ឬ
«អ្នករាល់គ្នាមកដើម្បីលួងលោមចិត្តរបស់ខ្ញុំ ប៉ុន្តែ អ្នករាល់គ្នាមិនចេះដូចជាគ្រូពេទ្យដែលមិនមានជំនាញ»
អស់លោកនៅស្ងៀម
ការបញ្ជាក់នេះ មានន័យថា «ត្រូវស្ងាត់ស្ងៀម» ឬ «ឈប់និយាយ»
អស់លោកជាមនុស្សមានប្រាជ្ញាមែន
ពួកគេគិតថាពួកគេកំពុងនិយាយដោយប្រាជ្ញា ប៉ុន្តែ
លោកយ៉ូបបាននិយាយថាពួកគេគួរតែឈប់និយាយ។ នាមអរូប «ប្រាជ្ញា» អាចត្រូវបានបង្ហាញជាមួយពាក្យ «ប្រាជ្ញា»។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នកបានធ្វើដូច្នេះ អ្នកនឹងមានប្រាជ្ញា» ឬ «ប្រសិនបើ អ្នកឈប់និយាយ អ្នកនឹងមើលទៅមានប្រាជ្ញា»
Job 13:6
ប្រយោគភ្ជាប់
ចាប់ផ្តើមនិយាយទីពីរទៅកាន់មិត្តៗរបស់លោក។
ស្តាប់សេចក្តីអង្វរនៃបបូរមាត់របស់ខ្ញុំសិន
នៅទីនេះ «បបូរមាត់» តំណាងឲ្យមនុស្សដែលកំពុងនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរស្តាប់នូវអ្វីដែលខ្លួនរបស់ខ្ញុំទូលអង្វរសម្រាប់»
តើអស់លោកនិយាយសេចក្តីទុច្ចរិត... សេចក្តីកំភូតដោយយល់ដល់ព្រះជាម្ចាស់ឬ?
លោកយ៉ូបប្រើសំណួរទាំងពីរនេះដើម្បីបន្ទោសមិត្រសម្លាញ់របស់លោកសម្រាប់ការនិយាយសេចក្តីទុច្ចរិត។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកគិតថាអ្នករាល់គ្នាកំពុងនិយាយដោយយល់ដល់ព្រះឬ ប៉ុន្តែ
អ្នករាល់គ្នានិយាយនូវសេចក្តីទុច្ចរិត។
អ្នករាល់គ្នាកំពុងនិយាយដោយការបោកបញ្ឆោត»
និយាយសេចក្តីកំភូត
«កុហក» ឬ «និយាយកុហក»
ហើយអស់លោកពិតជា...ជំនួសព្រះជាម្ចាស់ឬ?
ការបង្ហាញសេចក្តីល្អចំពោះព្រះជាម្ចាស់ តំណាងឲ្យការជួយព្រះ ឬ
ដោះសារជួសព្រះជាម្ចាស់ទាស់នឹងការប្តឹងរបស់លោកយ៉ូប។
លោកយ៉ូបប្រើសំណួរទាំងនេះដើម្បីបន្ទោសមិត្រភក្តិរបស់គាត់
ដែលពួកគេអាចការពារព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកគិតថាអ្នកអាចការពារព្រះបានឬ។ អ្នកគិតថាអ្នកអាចជជែកតវ៉ាបានឬ»
Job 13:9
តើវាមិនមែនជាការល្អសម្រាប់អស់លោកទេឬ នៅពេលព្រះអង្គ ស្វែងរកអស់លោក
នៅទីនេះឃ្លា «ស្វែងរកអស់លោក» គឺជាន័យធៀបមានន័យថា:
«ល្បងលអ្នករាល់គ្នា»។
លោកយ៉ូបប្រើសំណួរនេះដើម្បីដាស់តឿនមិត្រភក្តិរបស់លោកថា ប្រសិនបើ
ព្រះជាម្ចាស់បានល្បងលពួកគេ ព្រះអង្គនឹងមានព្រះបន្ទូលថា
អ្វីដែលពួកគេកំពុងធ្វើគឺខុស។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
ព្រះជាម្ចាស់បានល្បងលអ្នករាល់គ្នា តើនឹងជាការល្អឬទេសម្រាប់អ្នករាល់គ្នា»។
តើអស់លោកអាចបញ្ឆោតព្រះអង្គ ដូចជាអស់លោកបញ្ឆោតមនុស្សដែរទេ
លោកយ៉ូបប្រើសំណួរនេះដើម្បីដាស់តឿនមិត្រភក្តិរបស់លោកថា
ព្រះជាម្ចាស់ដឹងគ្រប់យ៉ាងអំពីពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករាល់គ្នាប្រហែលជាអាចបញ្ឆោតមនុស្សបាន
តែអ្នករាល់គ្នាមិនអាចបញ្ឆោតព្រះបានទេ»។

generated on Wed Sep 10 16:16:32 2025

ស្តីបន្ទោសដល់អស់លោក
«បន្ទោសអ្នករាល់គ្នា»
ប្រសិនបើ នៅក្នុងអស់លោកបានបង្ហាញពីភាពលំអៀង
ការបង្ហាញភាពលំអៀង សំដៅដល់ការនិយាយរឿងល្អតែម៉្យាងអំពីអ្នកណាម្នាក់
ដូច្នេះ ការវិនិច្ឆ័យដែលនិយាយថាមនុស្សម្នាក់នោះល្អ។
ការធ្វើដោយអាថ៌កំបាំងដូច្នេះ មានន័យថាជាការធ្វើពុតជានិយាយដោយយុត្តិធម៌
ប៉ុន្តែ តាមពិត ពេញចិត្តមនុស្សម្នាក់ជាងមនុស្សម្នាក់ទៀត»
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
អ្នកបង្ហាញពីភាពលំអៀងដល់អ្នកផ្សេងទៀត»
Job 13:11
តើមិនមែនតេជានុភាពរបស់ព្រះអង្គទេឬ ដែលបានធ្វើឲ្យអស់លោកភ័យខ្លាច?
តើមិនមែនជាសេចក្តីស្ញែងខ្លាចរបស់ព្រះអង្គទេឬដែលធ្លាក់មកលើអស់លោក?
លោកយ៉ូបប្រើសំណួរទាំងនេះដើម្បីស្តីបន្ទោសមិត្រភក្តិរបស់លោក។
វាអាចមានអត្ថន័យពីរ គឺទី១) លោកយ៉ូបគឺបាននិយាយថា
ពួកគេតែខ្លាចព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«តេជានុភាពរបស់ព្រះអង្គ គួរតែធ្វើឲ្យអ្នករាល់គ្នាភ័យខ្លាច
ហើយសេចក្តីខ្ញាល់របស់ព្រះអង្គធ្លាក់មកលើអ្នករាល់គ្នា» ទី២)
លោកយ៉ូបបាននិយាយថា ពួកគេគួរតែខ្លាចព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«តេជានុភាពរបស់ព្រះនឹងធ្វើឲ្យអ្នកភ័យខ្លាច!»
មិនមែនជាសេចក្តីស្ញែងខ្លាចរបស់ព្រះអង្គទេឬដែលធ្លាក់មកលើអស់លោក
សេចក្តីស្លាប់កំពុងធ្លាក់លើមនុស្ស
តំណាងថាពួកគេបានមកជាគួរឲ្យខ្លាចខ្លាំងណាស់។
របៀបផ្សេងទៀតនៃការបកប្រែ: តើអ្នកមិនមានការខ្លាចទេឬ» ឬ
«តើអ្នកមិនភ័យខ្លាចទេឬ»
សុភាសិតដែលអស់លោកចាំយកមកនិយាយឥតបានការទេ
ឥតបានការ តំណាំងឲ្យការដែលមិនស័ក្តិសមនិងមិនស្ថិតស្ថេរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពាក្យសម្តីដែលគួរឲ្យចងចាំរបស់អ្នក
គឺមិនមានន័យដូចជាផេះ» ឬ «ពាក្យសម្តីដែលគួរឲ្យចងចាំរបស់អ្នក
នឹងត្រូវបំភ្លេចដូចជាផេះដែលហើរបានទៅ»
ការការពារខ្លួនរបស់អស់លោកជាការការពារដែលធ្វើពីដីឥដ្ឋដែរ
លោកយ៉ូបនិយាយពីអ្វី
ដែលពួកគេនិយាយពីរបស់ព័ទ្ធជុំវិញទីក្រុងដែលត្រូវបានធ្វើឡើងអំពីដីឥដ្ឋ
វាមិនអាចការពារមនុស្សបានទេ ព្រោះដីឥដ្ឋវាងាយនឹងត្រូវបំផ្លាញ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលអស់លោកនិយាយក្នុងការការពារ
គឺវាមិនមានប្រយោជន៍ដូចជាជញ្ជាំងដែលធ្វើពីដីឥដ្ឋ»
ការការពារខ្លួនរបស់អស់លោក
វាអាចមានអត្ថន័យពីរដែលសំដៅដល់ គឺទី១)
អ្វីដែលពួកគេនិយាយដើម្បីការពារខ្លួនរបស់ពួកគេ ឬ ទី២)
អ្វីដែលពួកគេនិយាយគឺការពារព្រះ។
Job 13:13
សូមអស់លោកនៅស្ងៀម
ពាក្យនេះមានន័យថា «ត្រូវស្ងៀមស្ងាត់» ឬ «ឈប់និយាយ»។
សូមឲ្យខ្ញុំនៅម្នាក់ឯងចុះ
ពាក្យនេះមានន័យថា «បញ្ឈប់ការរំខានខ្ញុំ» ឬ «បញ្ឈប់ការរារាំងខ្ញុំ»។
សូមឲ្យអ្វីដែលនឹងកើតឡើងឲ្យកើតចំពោះខ្ញុំចុះ
អ្វីដែលត្រូវកើតលើមនុស្សម្នាក់ តំណាងឲ្យអ្វីៗដែលកំពុងកើតដល់មនុស្សម្នាក់។
ការបង្ហាញនេះកំពុងចាប់ផ្តើមជាមួយ «សូម»
មានន័យថាគាត់ខ្វល់អំពីអ្វីដែលអាចកើតមានដល់គាត់នោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមឲ្យអ្វីដែលអាចកើតឡើង កើតមានដល់ខ្ញុំចុះ»
ឬ «ខ្ញុំមិនខ្វល់ថាអ្វីអាចកើតមានចំពោះខ្ញុំនោះទេ»
ខ្ញុំនឹងយកសាច់ឈាម...របស់ខ្ញុំផង... ដោយដៃខ្ញុំដែរ
«សាច់ឈាម» គឺជាពាក្យប្រៀបធៀបសម្រាប់ជីវិត។ «ធ្មេញ» និង «ដៃ»
ជាពាក្យប្រៀបធៀបសម្រាប់ការគ្រប់គ្រងខ្លួនឯងរបស់គាត់។
ឃ្លាទាំងពីរនេះសង្កត់ធ្ងន់ថា លោកយ៉ូបនឹងប្រថុយជីវិតរបស់គាត់
ដោយជជែកតវ៉ារឿងរបស់គាត់ជាមួយព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំរួចជាស្រេចដើម្បីប្រថុយជីវិតរបស់ខ្ញុំ»
Job 13:16
នេះគឺជាមូលហេតុដែលខ្ញុំអាចរួចខ្លួន
នាមអរូប «ការឲ្យរួចខ្លួន» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «ដោះលែង»។
របៀបផ្សេងទៀតនៃការបកប្រែ: «នេះគឺជាហេតុផលដែលព្រះនឹងដោះលែងខ្ញុំ» ឬ
«នេះគឺជាហេតុផលដែលព្រះនឹងមានបន្ទូលថា ខ្ញុំមិនមានកុំហុសទេ»
ព្រះជាម្ចាស់អើយ សូមសណ្តាប់ដោយព្រះទ័យទុកដាក់
លោកយ៉ូបចាប់ផ្តើមប្រើពាក្យរបស់គាត់ដោយផ្ទាល់ទៅរកព្រះ។
សូមសណ្តាប់ដោយព្រះទ័យទុកដាក់ ចំពោះពាក្យរបស់ទូលបង្គំ
សូមឲ្យពាក្យដែលទូលបង្គំបានប្រកាសឮដល់ព្រះកាណ៌របស់ព្រះអង្គផង
ល្បះទាំងពីរនេះមានន័យជាគោលដូចគ្នា
ហើយធ្វើឲ្យការទូលសូមរបស់លោកយ៉ូបសូមឲ្យព្រះសណ្តាប់លោកកាន់តែខ្លាំងឡើង។
សូមឲ្យពាក្យដែលទូលបង្គំបានប្រកាសឮដល់ព្រះកាណ៌របស់ព្រះអង្គផង
នាមអរូប «ការប្រកាស» អាចត្រូវបានបង្ហាញជាមួយនិងកិរិយាសព្ទ «ប្រកាស»។
ព្រះការណ៌
Job 13:18
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តការនិយាយទៅកាន់ព្រះ។
មើល៍ ឥឡូវនេះ
នេះជាការសង្កត់ធ្ងន់លើពាក្យបន្ទាប់។ «ស្តាប់ ឥឡូវនេះ» ឬ
«សូមយកចិត្តទុកដាក់ជាពិសេស»
ទូលបង្គំបានរៀបចំការការពារខ្លួនរបស់ទូលបង្គំជាលំដាប់
ការរៀបចំការការពាររបស់គាត់តាមលំដាប់
តំណាងឲ្យការសម្រេចចិត្តដែលគាត់នឹងនិយាយការពារខ្លួនរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានគិតតាមរយៈរបៀបដែលខ្ញុំនឹងការពារខ្លួនរបស់ខ្ញុំ» ឬ
«ខ្ញុំបានសម្រេចចិត្តពីរបៀបដែលខ្ញុំនឹងពន្យល់ការពារខ្លួនរបស់ខ្ញុំ»
តើអ្នកណាហ៊ានទាស់នឹងទូលបង្គំនៅក្នុងតុលាការទៅ?
លោកយ៉ូបប្រើសំណួរនេះដើម្បីបង្ហាញការជឿជាក់របស់លោក
ថាលោកត្រឹមត្រូវតាំងពីដើមមក មិនមានអ្នកណាម្នាក់អាចទាស់នឹងគាត់បានទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិនជឿថាមាននរណាម្នាក់នឹងនិយាយប្រឆាំងនឹងខ្ញុំក្នុងតុលាការឡើយ»
ប្រសិនបើ ព្រះអង្គមកទាស់នឹងទូលបង្គំមែន
«ប្រសិនបើ ព្រះអង្គមកនិយាយប្រឆាំងនឹងទូលបង្គំមែន»
ប្រសិនបើព្រះអង្គ
«ព្រះអង្គ» នៅទីនេះគឺមានន័យដល់អង្គព្រះជាម្ចាស់។
ប្រសិនបើ រកឃើញថាទូលបង្គំមានកំហុសមែន
នេះអាចបានបញ្ចេញក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រសិនបើព្រះអង្គបង្ហាញថាទូលបង្គំខុសមែន»
ព្រមប្រគល់ជីវិតរបស់ទូលបង្គំ
ព្រមប្រគល់ជីវិតរបស់នរណាម្នាក់សម្រាប់ការស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្លាប់»
Job 13:20
ព័ត៌មានទូទៅ
លោកយ៉ូបបន្តការនិយាយទៅកាន់ព្រះ។
ពីព្រះភក្ត្រព្រះអង្គ
«ព្រះភក្ត្រ» តំណាងឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ: «ពីព្រះអង្គ»
សូមដកព្រះហស្តនៃការសង្កត់សង្កិន
ព្រះហស្តនៃការសង្កត់សង្កិនគឺជាពាកយប្រៀបធៀបសម្រាប់ការធ្វើអ្វីមួយសង្កត់សង្កិនអ្នកណាម្នាក់។
ដកដៃ ជាពាក្យប្រៀបធៀបសម្រាប់ការឈប់ធ្វើអំពើទាំងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់សង្កត់សង្កិនខ្ញុំ»
ហើយសូមកុំឲ្យអំណាចព្រះអង្គធ្វើឲ្យទូលបង្គំភ័យខ្លាចឡើយ
ឃ្លា «អំណាចព្រះអង្គ» សំដៅដល់អ្វីដែលបណ្តាលឲ្យមនុស្សភ័យខ្លាចចំពោះព្រះ។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំបំភ័យទូលបង្គំឡើយ»
Job 13:23
ព័ត៌មានទូទៅ
លោកយ៉ូបបន្តការនិយាយទៅកាន់ព្រះ។
ហេតុអ្វីបានជាព្រះអង្គលាក់...ដូចជាសត្រូវរបស់ព្រះអង្គដូច្នេះ?
លោកយ៉ូបសួរសំណួរនេះ ដើម្បីប្តឹងអំពីការដែលព្រះប្រព្រឹត្តចំពោះគាត់។
គាត់ប្រហែលជាសង្ឃឹមថាបានចម្លើយ។
ព្រះអង្គលាក់ព្រះភក្ត្រពីទូលបង្គំ
ការលាក់មុខពីអ្នកណាម្នាក់ តំណាងឲ្យការមិនព្រមមើលមុខនរណាគាត់
ឬការបដិសេធគាត់។ ព័ត៌មានទូទៅ: «ព្រះអង្គមិនព្រមមើលមកទូលបង្គំ» ឬ

generated on Wed Sep 10 16:16:32 2025

«ព្រះអង្គបដិសេធទូលបង្គំ»
តើព្រះអង្គនឹងធ្វើទុក្ខបុកម្នីញ...ដេញតាមចំបើងក្រៀមឬ?
លោកយ៉ូបប្រើសំណួរនេះដើម្បីទូលព្រះថា
ព្រោះលោកយ៉ូបមិនសូវសំខាន់និងខ្សោយ
វាមិនមានប្រយោជន៍ដើម្បីព្រះធ្វើទុក្ខបុកម្នីញគាត់នោះទេ។
ស្លឹកឈើដែលជ្រុះ...ចំបើងក្រៀម
«ស្លឹក» និង «ចំបើង» ជាពាក្យប្រៀបធៀបដែលពណ៌នាអំពី ភាពខ្សោយ
ភាពមិនសូវសំខាន់ និងភាពមិនរឹងមុាំរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គធ្វើទុក្ខបុកម្នីញទូលបង្គំ ប៉ុន្តែ
ទូលបង្គំខ្សោយដូចជាស្លឹកឈើដែលប៉ើងដោយសារខ្យល់
ហើយមិនសូវសំខាន់ដូចជាចម្បើងស្ងួត»
Job 13:26
ព័ត៌មានទូទៅ:
លោកយ៉ូបបានបញ្ចប់ការបរិយាយពីរឿងរបស់គាត់ទៅព្រះ។
ដ្បិត ព្រះអង្គបានកត់ទុកសេចក្ដីជូរល្វីងទាស់នឹងទូលបង្គំ
«សេចក្ដីជូរល្វីង» តំណាងឲ្យការចោទប្រកាន់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គកត់ត្រាពាក្យចោទប្រកាន់ទាស់នឹងទូលបង្គំ»
ព្រះអង្គបានធ្វើឲ្យទូលបង្គំទទួលមរតកនៃបាបដែលទូលបង្គំបានប្រព្រឹត្តកាលពីក្មេង
ការទទួលមរតកនៃបាបរបស់គាត់ដែលបានប្រព្រឹត្តកាលពី
ក្មេងគឺជាន័យប្រៀបធៀប។ វាអាចមានន័យពីរយ៉ាងដែលបង្ហាញ គឺទី១)
មានកំហុសសម្រាប់អំពើរបាបនៃយុវភាពរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គមានបន្ទូលថា
ទូលបង្គំនៅតែមានកំហុសសម្រាប់អំពើបាបដែលទូលបង្គំបានប្រព្រឹត្តតាំងពីក្មេងមក។
ឬ ទី២) បានដាក់ទោសសម្រាប់អំពើបាបនាំយុវភាពរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានដាក់ទោសទូលបង្គំសម្រាប់អំពើបាបនៃយុវភាពរបស់ទូលបង្គំ។
បាបដែលទូលបង្គំបានប្រព្រឹត្តកាលពីក្មេង
នាមអរូប «ក្មេង» អាចត្រូវបានបកប្រែជាមួយពាក្យ «ក្មេង» ។
របៀបផ្សេងទៀតនៃការបកប្រែ:
«អំពើរបាបដែលខ្ញុំបានប្រព្រឹត្តនៅពេលដែលខ្ញុំនៅក្មេង»
ព្រះអង្គដាក់ជើងទូលបង្គំជាប់នៅខ្នោះ
ការធ្វើនេះ តំណាងការដាក់ទោសលោកយ៉ូប
ហើយការបង្ខាំងលោកពីការរស់នៅដោយមានសេរីភាព
ដូចជាលោកយ៉ូបបានប្រព្រឹត្តអំពើរឧក្រិដណាមួយ ហើយលោកជាអ្នកទោស។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាហាក់ដូចជាព្រះអង្គដាក់ជើងរបស់ទូលបង្គំក្នុងខ្នោះ»
ខ្នោះ
វាអាចមានអត្ថន័យពីរ គឺ ទី១)
ជាស៊ុំដែលដាក់ជើងរបស់អ្នកទោសនៅក្នុងកន្លែងដែលគេមិនអាចផ្លាស់ទីបានទាំងអស់
ឬ ទី២)
ច្រវាក់ដែលព័ទ្ធជុំវិញជើងរបស់អ្នកទោសដែលធ្វើអោយវាពិបាកសម្រាប់គេដើរ។
ទាំងអស់នេះត្រូវបានប្រើជារបៀបនៃការដាក់ទណ្ឌកម្ម។
ព្រះអង្គយកព្រះទ័យទុកដាក់ឃ្លាំមើលអស់ទាំងផ្លូវរបស់ទូលបង្គំ
ផ្លូវ តំណាងឲ្យកិច្ចការដែលលោកយ៉ូបធ្វើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រប់យ៉ាងទូលបង្គំធ្វើ»
ព្រះអង្គបានវាស់ដីដែលជើងរបស់ទូលបង្គំបានដើរ
ស្បែកជើងរបស់គាត់ តំណាងឲ្យមនុស្សដែលដើរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានវាស់ដីដែលទូលបង្គំបានដើរ»
ព្រះអង្គបានវាស់ដីដែលជើងរបស់ទូលបង្គំបានដើរ
ការវាស់ដីនេះ តំណាងឲ្យការវាស់អ្វីៗទាំងអស់ដែលលោកយ៉ូបបានធ្វើ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាហាក់ដូចជាព្រះអង្គបានវាស់ដីដែលទូលបង្គំបានដើរ» ឬ
«ព្រះអង្គវាស់គ្រប់យ៉ាងដែលទូលបង្គំធ្វើ ដូចជាការវាស់ជំហានរបស់នរណាម្នាក់
របស់មនុស្សម្នាក់ដែលនៅលើដី»
ទូលបង្គំប្រៀបដូចជាឈើដែលរលួយខូចបង់
លោកយ៉ូបបានប្រៀបធៀបជីវិតរបស់គាត់ទៅនឹងអ្វីមួយដែលរលួយខូចបង់។
គាត់កំពុងស្លាប់យឺតៗ។
ហើយដូចជាអាវ ដែលកន្លាតបានកាត់ស៊ីអស់ក្តី។
លោកយ៉ូបបានប្រៀបធៀបខ្លួនរបស់គាត់ទៅនឹងសម្លៀកបំពាក់ដែលពេញទៅដោយប្រហោង
ព្រោះស្រមោចកន្លាតបានស៊ីផ្នែករបស់វា។

---

14 [1]មនុស្សដែលកើតពីស្ត្រីមក សុទ្ធតែមានអាយុខ្លី ហើយក៏មានសេចក្ដីទុក្ខលំបាក។[2]មនុស្សចេញមកដូចជាផ្កា រួចត្រូវកាត់ដាច់ទៅ គេរួញថយបាត់ទៅ ដូចជាស្រមោល
ឥតនៅស្ថិតស្ថេរដែរ។[3]តើព្រះអង្គបានទតឃើញការទាំងនេះទេ? តើព្រះអង្គនឹងនាំទូលទូលបង្គំចូលទៅក្នុងទីជំនុំជម្រះរបស់ព្រះអង្គឬអី?
[4]តើអ្នកណាអាចនឹងដកយករបស់ស្អាត ចេញពីរបស់ស្មោកគ្រោកបាន? គ្មានអ្នកណាធ្វើទេ។[5]ថ្ងៃអាយុរបស់មនុស្សនោះបានកំណត់ស្រេច។ ហើយចំនួនខែនៃជីវិតរបស់គេ
គឺនៅជាមួយនឹងព្រះអង្គហើយ ព្រះអង្គបានដាក់ព្រំខណ្ឌ មិនឲ្យគេឆ្លងផុតឡើយ។[6]សូមបែរព្រះភក្ត្រចេញពីគេទៅ ដើម្បីឲ្យគេបានសម្រាក ហើយគេនឹងរីករាយជាមួយថ្ងៃ
របស់ខ្លួន ដូចជាកូនឈ្នួលផង។
[7]នឹងមានសង្ឃឹមដល់ដើមឈើ ប្រសិនបើវាត្រូវរលំចុះមក ហើយវានឹងអាចពន្លកមកវិញ គឺវាមិនខ្វះពន្លកចេញពីគល់ទេ។[8]ហើយទោះបើឫសបានទៅជាចាស់នៅក្នុងដី
ហើយគល់របស់វាក៏ងាប់នៅក្នុងដីដែរ[9]ប៉ុន្តែទោះបី មានទឹកភ្លិនស្គុយក៏ដោយ វានៅតែបែកមែកដូចជាដើមថ្មីវិញ។
[10]ប៉ុន្តែមនុស្សស្លាប់វិញ គឺត្រឡប់ទៅជាខ្សោយ ហើយនិងឈប់ដកដង្ហើម ក្រោយពីនេះតើមនុស្សនឹងទៅទីណា?[11]ដូចជាទឹកបឹងដែលស្រកចុះ ហើយទឹកទន្លេក៏ហូរទៅ
ហើយរីងស្ងួតដែរ[12]ដូច្នេះមនុស្សក៏ដេក ហើយមិនក្រោកឡើងយ៉ាងនោះដែរ។ រហូតដល់ផ្ទៃមេឃសូន្យបាត់ទៅ ពួកគេនឹងមិនភ្ញាក់ឡើងពីការដេកលក់របស់ពួកគេ
ឡើយវិញ។
[13]ព្រះអង្គបានលាក់ទូលបង្គំ នៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ពីទុក្ខលំបាកផ្សេងៗ ហើយរក្សាទូលបង្គំនៅកន្លែងសម្ងាត់ រហូតដល់សេចក្ដីក្រោធរបស់ព្រះអង្គកន្លងបាត់ទៅ
ហើយតម្រូវឲ្យមានពេលកំណត់ដល់ទូលបង្គំ ហើយនឹកចាំពីទូលបង្គំផង![14]បើមនុស្សស្លាប់ទៅ តើនឹងមានជីវិត រស់ឡើងវិញម្តងទៀតទេ? បើមាន ទូលបង្គំនឹងរង់ចាំអស់
រវាង សង្គ្រាមវេទនារបស់ទូលបង្គំ ដរាបដល់កំណត់ដែលទូលបង្គំបានមកដល់។
[15]ព្រះអង្គនឹងហៅ ហើយទូលបង្គំនឹងតបឆ្លើយ។ ព្រះអង្គនឹងមានបំណងព្រះហឫទ័យ ដល់ស្នាដៃដែលព្រះអង្គបានធ្វើ។[16]ដ្បិតយ៉ាងនោះ ព្រះអង្គនឹងមិនរាប់ អស់ទាំង
ជំហានរបស់ទូលបង្គំទេ ហើយក៏មិនពិនិត្យមើលអស់ទាំងអំពើបាប របស់ទូលបង្គំដែរ។[17]អំពើរំលងរបស់ទូលបង្គំបានខ្ចប់បិទត្រាទុក ហើយព្រះអង្គបិទភ្ជាប់អំពើអាក្រក់
របស់ទូលបង្គំផង។
[18]ប៉ុន្តែ ទោះភ្នំដែលរលុះបាក់ចុះ នោះត្រូវខ្ទេចខ្ទីអស់ ហើយថ្មត្រូវខ្ចាត់ចេញពីកន្លែងទៅដែរ[19]ទឹកក៏ហូរបន្សឹកថ្ម ហើយជំនន់ក៏ហូរចម្រោះផែនដីដែរ។ គឺយ៉ាងនោះដែល
ព្រះអង្គបំផ្លាញ សេចក្ដីសង្ឃឹមរបស់មនុស្សផងដែរ។
[20]ព្រះអង្គវាយផ្តួលពួកគេជានិច្ច ហើយគេស្លាប់ទៅដែរ ព្រះអង្គបានផ្តរមុខមាត់របស់ពួកគេ ហើយកម្ចាត់គេឲ្យស្លាប់ទៅ។[21]ប្រសិនបើកូនចៅរបស់គេមានស្មោះត្រង់
ហើយមិនដឹងពីការនេះ និងត្រូវបន្ទាបខ្លួនចុះ នោះពួកគេនឹងបានឃើញវាទេ។[22]គេដឹងតែឈឺចាប់លើខ្លួនគេ ហើយមានសេចក្ដីទុក្ខព្រួយតែក្នុងចិត្តខ្លួនឯងដែរ។

Job 14:1
ព័ត៌មានទូទៅ
ជំពូកនេះបន្តសម្តីរបស់លោកយ៉ូប ដែលបានចាប់ផ្តើមក្នុង ១២:១។
លោកយ៉ូបទូលទៅព្រះ។
មនុស្សដែលកើតពីស្ត្រីមក
ឃ្លានេះសំដៅលើមនុស្សទាំងអស់ ទាំងបុរសទាំងស្ត្រី
គឺមនុស្សទាំងអស់ដែលកើតក្នុងពិភពលោកនេះ។
រស់នៅបានតែមួយរយៈខ្លី
នេះគឺជាការបំផ្លើសមួយដែលសង្កត់ធ្ងន់ថា
មនុស្សរស់នៅបានតែក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«រស់នៅត្រឹមតែពេលដ៏ខ្លីបំផុត»
មានសេចក្ដីទុក្ខលំបាកជាច្រើន

generated on Wed Sep 10 16:16:32 2025

ពាក្យ «សេចក្ដីទុក្ខលំបាកជាច្រើន»
តំណាងឲ្យការមានបទពិសោធន៍នៃបញ្ហាជាច្រើន។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបញ្ហាជាច្រើន» ឬ «មានការឈឺចាប់ច្រើន»
មនុស្សចេញមកពីដី ដូចជាផ្កា ហើយត្រូវកាត់ចេញទៅ
ដូចជាជីវិតរបស់ផ្កា ជីវិតរបស់មនុស្សម្នាក់គឺខ្លី ហើយងាយនឹងត្រូវបានសម្លាប់។
គេរត់គេច ដូចជាស្រមោល ហើយឥតនៅស្ថិតស្ថេរទេ
ជីវិតដ៏ខ្លីរបស់មនុស្ស ត្រូវបានប្រៀបធៀបទៅនឹង ស្រមោល
ដែលបាត់ទៅយ៉ាងលឿន។
តើព្រះអង្គបានទតឃើញការទាំងនេះទេ?
លោកយ៉ូបបញ្ជាក់ថា
គាត់មិនចង់អោយព្រះយកព្រះទ័យទុកដាក់ចំពោះលោកខ្លាំងពេកទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គមិនទតឃើញការទាំងនេះទេ» ឬ
«ព្រះអង្គមិនយកព្រះទ័យទុកដាក់លើការទាំងនេះពេកទេ។
សូមកុំយកព្រះទ័យទុកដាក់នឹងទូលបង្គំពេក»
ទតឃើញ
នៅទីនេះ ការមើលដើញនរណាម្នាក់ តំណាងឲ្យការយកចិត្តទុកដាក់ទៅលើគេ
ក្នុងការតម្រូវដើម្បីវិនិច្ឆ័យ។ របៀបផ្សេងទៀតនៃការបកប្រែ: «ការយកចិត្តទុកដាក់»
ឬ «មើលដើម្បីចាប់កំហុស»
តើព្រះអង្គនាំទូលបង្គំចូលទៅក្នុងទីជំនុំជម្រះរបស់ព្រះអង្គឬ?
លោកយ៉ូបប្រើសំណួរនេះ ដើម្បីបង្ហាញការភ្ញាក់ផ្អើលរបស់លោក
ដែកព្រះវិនិច្ឆ័យគាត់
ទោះបីជាលោកយ៉ូបមិនសូវមានសារសំខាន់ដូចជាផ្កាក៏ដោយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ព្រះអង្គវិនិច្ឆ័យទូលបង្គំ»
Job 14:4
ព័ត៌មានទូទៅ:
ព័ត៌មានទូទៅ: លោកយ៉ូបបន្តការនិយាយទៅកាន់ព្រះ។
តើមានអ្នកណាអាចដកយកអ្វីមួយស្អាត ចេញពីអ្វីមួយដែលមិនស្អាតបានដែរឬទេ? គ្មានអ្នកណា
ធ្វើបានទេ
លោកយ៉ូបប្រើសំណួរនេះដើម្បីបញ្ចេះបញ្ចូលព្រះ
ដើម្បីដាក់សំណើអ្វីដែលគាត់ដឹងអំពីរបស់មិនស្អាតទៅលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាអាចដកយករបស់ស្អាតចេញពីរបស់មិនស្អាតបានទេ»
ថ្ងៃរបស់មនុស្សត្រូវបានកំណត់ស្រេចហើយ
ឃ្លានេះអាចត្រូវបានបង្ហាញនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានកំណត់ចំនួនថ្ងៃរបស់មនុស្ស» ឬ
«ព្រះអង្គសម្រេចថាតើមនុស្សរស់នៅរយៈពេលប៉ុន្មាន»
ហើយចំនួនខែនៃជីវិតរបស់គេ គឺនៅជាមួយនឹងព្រះអង្គហើយ
ចំនួនខែរបស់មនុស្សចាប់ផ្តើមជាមួយព្រះ តំណាងឲ្យការសម្រេចរបស់ព្រះ
នូវចំនួនខែដែលគេនឹងរស់នៅ។ «ព្រះអង្គសម្រេចថា តើគេនឹងរស់នៅប៉ុន្មានខែ»
ព្រះអង្គបានកំណត់ព្រំដែនរបស់ព្រះ មិនឲ្យគេឆ្លងផុតឡើយ
ការឆ្លងកាត់ព្រំដែន
តំណាងឲ្យការរស់នៅអតីតកាលដែលព្រះបានកំណត់សម្រាប់ការស្លាប់របស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គបានកំណត់ពេលវេលាដែលគេនឹងស្លាប់
ហើយគេមិនអាចរស់នៅយូរជាងការកំណត់នោះទេ។
កូនឈ្នួល
មនុស្សដែលត្រូវបានជួលឲ្យធ្វើការហើយត្រឡប់ទៅផ្ទះវិញ។
Job 14:7
នឹងមានសង្ឃឹមដល់ដើមឈើ
នាមអរូប «សង្ឃឹម» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «សង្ឃឹម»។ ក្តីសង្ឃឹម
បានពន្យល់នៅក្នុង ខ ៧-៩។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងសង្ឃឹមថា
ដើមឈើនឹងរស់ឡើងវិញម្តងទៀត»
ហើយវានឹងអាចពន្លកមកវិញ
«វាអាចចាប់ផ្តើមដុះឡើងវិញបាន»
មែករបស់វាលូតចេញមិនបាត់ពីគល់ទេ
ការបាត់ តំណាងឲ្យការស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះពន្លកខ្ចីរបស់វានឹងមិនស្លាប់ទេ»
គល់ឈើ
ផ្នែកនៃដើមឈើ ដែលនៅជាប់នឹងដី បន្ទាប់ពីនរណាម្នាក់បានកាត់ដើមវា។
បើទោះបីជាមានទឹកក្លិនស្អុយក៏ដោយ
ការពណ៌នាពីគល់ឈើងាប់ ដូចជាវាអាចស្រូបយកទឹក
ដើម្បីតំណាងទឹកដែលនៅក្បែរវា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទោះបីជាមានទឹកតែបន្តិចបន្ទួចនៅក្បែរវាក៏ដោយ»
វានៅតែលាស់
«វានឹងចាប់ផ្តើមដុះវិញ»
ហើយបែកមែកដូចជារុក្ខជាតិមួយដើមដែរ
ដើម្បីបែកមែក តំណាងឲ្យមែនកំពុងដុះលើដើមឈើ។
របៀបផ្សេងទៀតនៃការបកប្រែ:
ហើយមែកនឹងចាប់ផ្តើមដុះនៅលើវាដូចជារុក្ខជាតិមួយដើម»។
Job 14:10
ក្រោយពីនេះតើគេនឹងទៅទីណា?
លោកយ៉ូបប្រើសំណួរនេះដើម្បីសង្កត់ធ្ងន់ថាពេលដែលមនុស្សស្លាប់
គេមិនអាចបង្ហាញខ្លួនទៀតទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយមិនមានអ្នកណាដឹងពីកន្លែងដែលគេនៅទេ» ឬ «ហើយគេគឺទៅហើយ»
ដូចជាទឹកដែលបាត់ពីបឹង...ហើយមិនអាចក្រោកឡើងយ៉ាងនោះដែរ
ជាការពិតថាសេចក្តីស្លាប់មិនអាចជំនួយគឺ
ត្រូវបានប្រៀបធៀបទៅនឹងទឹកដេកវឹងស្ងួត ហើយមិនអាចត្រឡប់មកវិញបាន។
ដូចជាទឹកដែលបាត់ពីបឹង ហើយដូចជាទឹកទន្លេដែលអត់ទឹក
ឃ្លាទាងពីរនេះ ពណ៌នាអំពីគំនិតដូចគ្នា ហើយបាននិយាយបញ្ជាក់ឡើងវិញ
ការពិតដែលសេចក្តីស្លាប់ជាចុងបញ្ចប់។
ដូច្នេះ មនុស្សដែលដេក
ដេក តំណាងឲ្យសេចក្តីស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
មនុស្សស្លាប់»
ហើយមិនអាចក្រោកឡើងយ៉ាងនោះដែរ
ការក្រោកឡើងវិញ តំណាងឲ្យការរស់ឡើងវិញម្តងទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយមិនអាចរស់វិញម្តងទៀតបានទេ»
ពួកគេនឹងមិនភ្ញាក់ឡើង ឬក៏មិនក្រោកពីការដេកលក់របស់ពួកគេឡើយវិញ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា ហើយត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ថា
សេចក្តីស្លាប់គឺជាចុងបញ្ចប់។ ការដេកលក់ តំណាងឲ្យការស្លាប់
ហើតការក្រោកឡើងវិញ តំណាងឲ្យការរស់ឡើងវិញម្តងទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សដែលស្លាប់នឹងមិនអាចរស់ម្តងទៀតបានទេ
ហើយក៏មិនក្រោកឡើងពីសេចក្តីស្លាប់បានដែរ»
Job 14:13
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តទូលទៅព្រះ។
ព្រះអង្គបានលាក់ទូលបង្គំ
នេះជាការបង្ហាញនូវការឧទាន អ្វីដែលលោកយ៉ូបចង់បានយ៉ាងខ្លាំង ប៉ុន្តែ
មិនរំពឹងថាវាកើតឡើងបានទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំសង្ឃឹមថា ព្រះអង្គនឹងលាក់ទូលបង្គំ»
រក្សាទូលបង្គំនៅកន្លែងសម្ងាត់
«រក្សាទូលបង្គំដោយបិតបាំង» ឬ «រក្សាទូលបង្គំដោយលាក់បាំង»
ហើយបាននឹកចាំពីទូលបង្គំ
ការនឹកចាំពីអ្នកណាម្នាក់ គឺជាពាក្យដែលមានន័យថាគិតអំពីនរណាម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយបន្ទាប់មកគិតអំពីទូលបង្គំ» ឬ
«ហើយបន្ទាប់មកនឹងចាំពីទូលបង្គំ»
បើមនុស្សស្លាប់ទៅ តើគេនឹងមានជីវិតរស់ឡើងវិញម្តងទៀតទេ?
ការបញ្ជាក់ចម្លើយគឺ «ទេ» ឬ «ប្រសិនបើមនុស្សស្លាប់ទៅ គេនឹងមិនមានជីវិតរស់
ឡើងវិញម្តងទៀតបានទេ»
បើដូច្នោះមែន
អ្វីដែលពាក្យ «ដូច្នេះ» សំដៅលើ គឺការបានយល់ពីឃ្លាពីមុន។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើគាត់នឹងរស់ឡើងវិញ»
ទូលបង្គំនឹងរង់ចាំរហូតដល់វេលានៃសេចក្តីវេទនារបស់ទូលបង្គំ
ឃ្លា «វេលានៃសេចក្តីវេទនារបស់ទូលបង្គំ»
តំណាងឲ្យពេលវេលាកំឡុងពេលដែលលោកយ៉ូបមានសេចក្តីវេទនា។
របៀបផ្សេងទៀតនៃការបកប្រែ:
«រងចាំពេលវេលារបស់ទូលបង្គំទោះបីទូលបង្គំនឹងឈឺចាប់ក៏ដោយ»
ដល់កំណត់នៃសេរីភាពទូលបង្គំបានមកដល់
នាមអរូប «សេរីភាព» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «ដោះលែង»។
របៀបផ្សេងទៀតនៃការបកប្រែ: «រហូតដល់ទូលបង្គំនឹងត្រូវបានដោះលែង»

generated on Wed Sep 10 16:16:32 2025

Job 14:15

ព័ត៌មានទូទៅ:

ព័ត៌មានទូទៅ: លោកយ៉ូបបន្តការសន្ទនាជាមួយព្រះជាម្ចាស់។

ទូលបង្គំនឹងទូលឆ្លើយ

«ទូលបង្គំនឹងទូលតប»

ព្រះអង្គចង់បានអ្វី

នាមអរូប «ចង់បាន» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «ប៉ង» ឬ «ចង់»។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គប៉ង» ឬ «ព្រះអង្គចង់បាន»

ដែលជាស្នាព្រះហស្តដែលព្រះអង្គបានធ្វើ

នៅទីនេះព្រះហស្តរបស់ព្រះ តំណាងឲ្យអ្វីៗដែលព្រះអង្គបង្កើត។

លោកយ៉ូបសំដៅលើខ្លួនរបស់លោកដែលដូចជាកិច្ចការនៃស្នាព្រះហស្តរបស់ព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត ទូលបង្គំ ដែលព្រះអង្គបានបង្កើត»

រាប់ហើយយកព្រះទ័យទុកដាក់សម្រាប់

កិរិយាសព្ទទាំងពីររួមគ្នាបង្ហាញសកម្មភាពតែមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «យកព្រះទ័យទុកដាក់ចំពោះ»

ជំហានរបស់ទូលបង្គំ

ជំហានតំណាងឲ្យជីវិតរបស់គាត់ ឬអ្វីដែលគាត់ធ្វើ។ របៀបផ្សេងទៀតនៃការបកប្រែ: «ជីវិតរបស់ខ្ញុំ» ឬ «កិច្ចការដែលខ្ញុំធ្វើ»

ព្រះអង្គក៏មិនតាមដានមើល...អំពើរំលងរបស់ទូលបង្គំ...ព្រះអង្គក៏គ្របបាំង

ខ្សែរទាំងបីនេះបង្ហាញគំនិតដូចគ្នា
ហើយត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ការជឿជាក់របស់គាត់
ថាព្រះនឹងអត់ទោសអោយគាត់។

ព្រះអង្គក៏មិនតាមដានមើលអំពើបាបរបស់ទូលបង្គំដែរ

ការតាមដានអំពើបាបរបស់លោកយ៉ូប តំណាងការគិតអំពីបាបរបស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គមិនតាមដានបាបរបស់ទូលបង្គំទេ» ឬ «ព្រះអង្គមិនគិតអំពីបាបរបស់ខ្ញុំទេ»

អំពើរំលងរបស់ទូលបង្គំបានខ្ចប់ទុកនៅក្នុងសម្ពាយ

ការខ្ចប់អំពើរំលងក្នុងកាបូប តំណាងឲ្យការលាក់វា ហើយបដិសេធការគិតពីវា។ នេះអាចត្រូវថ្លែងក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គនឹងបដិសេធដើម្បីគិតពីអំពើរំលងរបស់ទូលបង្គំ
ដូចនរណាម្នាក់ដែលបានលាក់អ្វីមួយក្នុងការបូប»

ព្រះអង្គក៏គ្របបាំងអំពើទុច្ចរិតរបស់ទូលបង្គំដែរ

ការគ្របបាំងអំពើទុច្ចរិតណាមួយ ដូច្នេះ
វាមិនអាចដូចជាតំណាងការបដិសេធដើម្បីគិតពីវានោះទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គនឹងលាក់អំពើទុច្ចរិតរបស់ខ្ញុំ» ឬ «ព្រះអង្គនឹងបដិសេធអំពើទុច្ចរិតរបស់ទូលបង្គំ»

Job 14:18

ព័ត៌មានទូទៅ:

ព័ត៌មានទូទៅ: លោកយ៉ូបបន្តទូលទៅព្រះជាម្ចាស់។

ទោះបីជាភ្នំដែលបាក់រលំ ហើយត្រូវខ្ទេចខ្ទីអស់

«ខ្ទេចខ្ទីអស់» គឺជាពាក្យប្រៀបធៀប មានន័យថា ត្រូវបានបំផ្លាញទាំងស្រុង។ ឃ្លានេះពន្យល់អំពីពាក្យ «បាក់រលំ» និងបញ្ជាក់ថា បំផ្លាញទាំងស្រុង។ របៀបផ្សេងទៀតនៃការបកប្រែ: «ភ្នំបាក់រលំ ខ្ទេចខ្ទីទាំងស្រុង»

ថ្មត្រូវរើចេញពីកន្លែងរបស់វា

ឃ្លានេះអាចត្រូវបានបង្ហាញក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ថ្មក៏រលំចុះពីកន្លែងពួកវាមក»

ព្រះអង្គបំផ្លាញសេចក្តីសង្ឃឹមរបស់មនុស្សបែបនេះឯង

ប្រសិនបើ លុបនៅក្នុងភាសារបស់អ្នក អ្នកអាចដាក់ឃ្លានេះក្នុងការចាប់ផ្តើមខទីដប់ប្រាំបី ហើយកែតម្រូវអត្ថបទនេះឲ្យបានសមស្រប។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គបំផ្លាញក្តីសង្ឃឹមរបស់មនុស្ស គឺដូចជាល្អងធូលីដី»។

បំផ្លាញសេចក្តីសង្ឃឹមរបស់មនុស្ស

ការបំផ្លាញសេចក្តីសង្ឃឹម តំណាងឲ្យការនាំឲ្យអ្វីដែលមនុស្សសង្ឃឹមមិនកើតឡើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គរារាំងក្តីសង្ឃឹមរបស់មនុស្សមិនឲ្យកើតឡើង»

សេចក្តីសង្ឃឹមរបស់មនុស្ស

នាមអរូប «សេចក្តីសង្ឃឹម» អាចត្រូវបានបង្ហាញ ជាមួយកិរិយាសព្ទ «សង្ឃឹម» របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីៗដែលមនុស្សសង្ឃឹមថាបាន»

Job 14:20

ព័ត៌មានទូទៅ:

លោកយ៉ូបបន្តទូលទៅព្រះ។

ព្រះអង្គវាយផ្តួលពួកគេជានិច្ច

ពាក្យ «ពួកគេ» សំដៅដល់មនុស្សទាំងឡាយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គតែងតែវាយផ្តួលមនុស្ស» ឬ «ព្រះអង្គតែងតែវាយផ្តួលមនុស្សម្នារ»

គេស្លាប់ទៅដែរ

លាចាកទៅ តំណាងឲ្យការស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «គាត់ស្លាប់»

ព្រះអង្គបានបូរមុខមាត់របស់ពួកគេ

វាអាចមានអត្ថន័យថា ទី១) ការឈឺចាប់ពេលស្លាប់បានធ្វើឲ្យមុខមាត់របស់គេរួម ឬទី ២) នៅពេលមនុស្សស្លាប់ព្រះធ្វើឲ្យមុខរបស់គេខុសប្លែក

ចាត់គេឲ្យស្លាប់

ឃ្លានេះតំណាងឲ្យការនាំឲ្យគាត់ស្លាប់។

បើគេបន្ទាបចុះ

ការបន្ទាបចុះ តំណាងឲ្យការបំបាក់មុខ។ របៀបផ្សេងទៀតនៃការបកប្រែ: «បើសិនជាពួកគេធ្វើឲ្យខូចកិត្តិយស» ឬ «បើសិនជាមនុស្សខ្មាសគេ»

---

15 [1]អេលីផាស ជនជាតិថេម៉ាន ឆ្លើយថា៖[2]«តើគួរឲ្យអ្នកប្រាជ្ញឆ្លើយ ដោយសេចក្តីចេះដឹងបែបឥតប្រយោជន៍ ឬបំពេញចិត្តដោយខ្យល់ពីខាងកើតឬ?[3]តើគួរនឹងជជែក ដោយសម្តីឥតតម្លៃ ឬដោយពាក្យអធិប្បាយ ដែលបង្កើតសេចក្តីល្អមិនបានឬ?
[4]អ្នកបំផ្លាញសេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់ ហើយនិងការសញ្ជឹងគិតដល់ព្រះអង្គផង[5]ដ្បិតសេចក្តីអាក្រក់របស់អ្នកបង្រៀន ឲ្យមាត់អ្នកនិយាយចេញមក ហើយអ្នកប្រើពាក្យសម្តី របស់មនុស្សអាក្រក់។[6]គឺមាត់របស់អ្នកដាក់ទោសដល់ខ្លួនឯង មិនមែនជាខ្ញុំទេ បបូរមាត់របស់អ្នក ធ្វើបន្ទាល់ទាស់នឹងខ្លួនអ្នកដែរ។
[7]តើអ្នកជាមនុស្សដំបូងដែលកើតមកឬ? តើអ្នកបានលេចមកមុនអស់ទាំងភ្នំដែរឬ?[8]តើអ្នកបានឮសេចក្តីប្រឹក្សាដ៏កំបាំងរបស់ព្រះជាម្ចាស់ឬ? តើអ្នកស្មានថា មានតែខ្លួនអ្នកមួយទេ ដែលមានប្រាជ្ញា?[9]តើអ្នកចេះអ្វីដែលពួកយើងមិនចេះ? តើអ្នកយល់អ្វីដែលពួកយើងមិនបានយល់នោះ?
[10]ចំណែក យើងមានទាំងមនុស្សក្បាលសក់ស្កូវ និងមនុស្សអាយុច្រើនដែលចាស់ជាងឪពុករបស់អ្នកទៅទៀត។[11]តើអ្នកបានចាត់ទុកការលួងចិត្តរបស់ព្រះជាម្ចាស់ថាតូចតាចពេក ឬជាពាក្យផ្អែមទន្លន់សម្រាប់អ្នកឬ?
[12]ហេតុអ្វីបានជាចិត្តរបស់អ្នក នាំយកអ្នកទៅអញ្ចឹង? ហើយមិចភ្នែកដូច្នេះ[13]ហេតុអ្វីបានជាអ្នកបំបែរចិត្តទៅទាស់នឹងព្រះជាម្ចាស់ ហើយបញ្ចេញពាក្យយ៉ាងនេះ ពីមាត់របស់អ្នកមក?[14]តើមនុស្សជាអ្វីដែលអាចបានបរិសុទ្ធ? តើមនុស្សកើតមកពីមនុស្សស្រី អាចសុចរិតម្តេចបាន?
[15]មើល! ព្រះជាម្ចាស់មិនទុកចិត្ត នឹងពួកបរិសុទ្ធរបស់ព្រះអង្គ ហើយផ្ទៃមេឃក៏មិនបរិសុទ្ធ[16]នៅព្រះនេត្ររបស់ព្រះអង្គដែរ ចំណង់បើម្នាក់ដែលគួរតែខ្ពើម ហើយស្មោកគ្រោកជាអ្នកដែលផឹកសេចក្តីអាក្រក់ដូចជាទឹក!
[17]ខ្ញុំនឹងបង្ហាញឲ្យអ្នកដឹង ចូរស្តាប់ចុះ ខ្ញុំនឹងថ្លែងប្រាប់ពីសេចក្តី ដែលខ្ញុំបានឃើញហើយ[18]គឺជាសេចក្តីដែលពួកអ្នកប្រាជ្ញបានពោលតមក តាំងតែពីបុព្វបុរសគេ ឥតលាក់ទុកឡើយ
[19]ជាពួកតែមួយដែលបានគ្រប់គ្រងទឹកដី ឥតមានជនជាតិដទៃណា ចូលមកក្នុងពួកគេឡើយ។[20]គឺថា មនុស្សអាក្រក់រមែងរងទុក្ខ ដោយឈឺចាប់គ្រប់មួយជីវិតរបស់គេ ឯអស់ចំនួនឆ្នាំគេបានលាក់ទុក សម្រាប់មនុស្សគំហកកំហែង។[21]មានសូរគួរស្ញែងខ្លាចឮដល់ត្រចៀកគេ ក្នុងពេលដែលកំពុងតែចម្រើន នោះមេបំផ្លាញនឹងមកលើគេ។
[22]គេគ្មានសង្ឃឹមនឹងត្រឡប់ពីទីងងឹតមកវិញទេ ហើយដាវនៅរង់ចាំគេដែរ។[23]គេដើរចេញទៅទីនេះផង ដើម្បីរកអាហារបរិភោគទាំងនិយាយថា «តើនៅឯណា?» គេដឹងប្រាកដថា វេលាលំបាកជិតមកដល់គេហើយ។[24]ទុក្ខលំបាក និងសេចក្តីចង្អៀតចិត្តមកបំភ័យពួកគេ ហើយយកឈ្នះគេ ដូចជាស្តេចដែលត្រៀមជាស្រេចសម្រាប់ច្បាំង។
[25]ពីព្រោះពួកគេបានលូកដៃទៅទាស់នឹងព្រះជាម្ចាស់ ហើយក៏ប្រព្រឹត្តដោយឆ្មើងឆ្មៃ នៅចំពោះព្រះជាម្ចាស់ដ៏មានគ្រប់ព្រះចេស្តាដែរ[26]ពួកមនុស្សអាក្រក់បានរត់ទៅទាស់នឹងព្រះអង្គ ហើយមានខែលបាំងយ៉ាងក្រាស់។

generated on Wed Sep 10 16:16:32 2025

[27]ជាការពិតណាស់ ទោះបីមុខរបស់ពួកគេបាំងទៅដោយសាច់ធាត់ពេញ ហើយបានឡើងសាច់ចង្កេះផង[28]ពួកគេអាស្រ័យនៅក្នុងទីក្រុងស្ងាត់ឈឹង ក្នុងផ្ទះឥតមានមនុស្ស
នៅ ដែលហៀបនឹងរលំហើយ។
[29]គេនឹងមិនអាចទៅជាអ្នកមានទេ ហើយទ្រព្យសម្បត្តិគេក៏មិនគង់នៅដែរ នឹងមិនចម្រុងចម្រើននៅលើផែនដីដែរ។[30]គេនឹងមិនអាចចេញពីទីងងឹតនោះបានទេ អណ្តាតភ្លើង
នឹងធ្វើឲ្យដើមស្វិតក្រៀម ដោយសារខ្យល់នៃព្រះជាម្ចាស់គេនឹងផាត់ទៅបាត់ដែរ។
[31]កុំឲ្យគេបញ្ឆោតខ្លួន ដោយទុកចិត្តនឹងការឥតប្រយោជន៍ឡើយ ដ្បិតសេចក្តីនោះ គឺជារង្វាន់ដល់ពួកគេវិញ។[32]ការនោះនឹងបានសម្រេច មុនពេលស្លាប់របស់ពួកគេ ហើយ
មែករបស់គេនឹងមិនខៀវស្រស់ទៀតទេ។[33]គេនឹងរលាស់ជម្រុះផ្លែខ្ចីរបស់ខ្លួនអស់ទៅ ដូចជាដើមទំពាំងបាយជូរ ហើយនឹងឲ្យផ្កាខ្លួនជ្រុះចុះ ដូចជាដើមអូលីវដែរ។
[34]ដ្បិតពួកមនុស្សទមិឡល្មើស នឹងមិនអាចកើតផលបានោះទេ ហើយភ្លើងនឹងឆេះបន្សុសទីលំនៅរបស់ពួកគេដែរ។[35]ពួកគេមានគភ៌បង្កើតជាសេចក្តីអាក្រក់ ហើយក៏
សម្រាលចេញមកជាអំពើទុច្ចរិត និងការបោកប្រាស់»។

Job 15:1

លោកអេលីផាស ជនជាតិថេម៉ាន

នេះជាឈ្មោះរបស់បុរសម្នាក់។ មនុស្សពីតំបន់ថេម៉ាន
ត្រូវបានស្គាល់ថាជាជនជាតិថេម៉ាន។ សូមបកប្រែឲ្យដូចនៅក្នុង ២:១១។

តើគួរឲ្យអ្នកប្រាជ្ញឆ្លើយ ដោយសេចក្តីចេះដឹងបែបឥតប្រយោជន៍ ឬបំពេញចិត្តខ្លួនឯងដោយខ្យល់ពីខាងកើតឬ?

លោកអេលីផាស ប្រើសំណួរដែលមិនទាមទារចម្លើយនេះ
ដើម្បីបន្ទោសលោកយ៉ូប។ ឃ្លានេះអាចសរសេរជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមានប្រាជ្ញាមិនគួរឆ្លើយតបនឹងមនុស្សដែលគ្មានការចេះដឹង
ក៏មិនបំពេញចិត្តខ្លួនឯងដោយខ្យល់ពីទិសខាងកើត»

បំពេញចិត្តខ្លួនឯងដោយខ្យល់ពីខាងកើត

ខ្យល់ តំណាងឲ្យភាពទទេស្អាត។
ឃ្លានេះនិយាយពីមនុស្សដែលនិយាយនូវពាក្យទទេស្អាត និងមិនមានអត្ថន័យអ្វី
ដែលវាហាក់ដូចជាមនុស្សនោះបំពេញយើងដោយខ្យល់។
របៀបផ្សេងទៀតនៃការបកប្រែ: «បំពេញចិត្តខ្លួឯងដោយពាក្យទទេស្អាត»

ខ្យល់ពីខាងកើត

«អាកាសធាតុក្តៅ» (UDB) ឬ «ខ្យល់ពីវាលរហោស្ថាន»

តើគេគួរជជែកដោយសំដីឥតប្រយោជន៍ ឬគេអាចនិយាយសំដីដែលគេបង្កើតសេចក្តីល្អមិនបានឬ?

លោកអេលីផាស ប្រើសំណួរដែលមិនទាមទារចម្លើយនេះ
ដើម្បីបន្ទោសលោកយ៉ូប។ ឃ្លានេះអាចសសេរជារបាយការណ៍។
របៀបផ្សេងទៀតនៃការបកប្រែ: «គេមិនគួរជជែកដោយសំដីឥតប្រយោជន៍ ឬ
គេក៏មិនអាចនិយាយសំដីដែលគេបង្កើតសេចក្តីល្អមិនបានដែរ» ឬ
«គេមិនគួជជែកតវ៉ាដោយសំដីឥតប្រយោជន៍
ឬធ្វើការនិយាយស្តីអ្វីដែលមិនអាចសម្រេចផលអ្វីបាននោះទេ»

Job 15:4

លែង «ធ្វើអ្វីមួយ»

«បំផ្លាញ» ឬ «បដិសេធ»

បង្អាក់

«លែង» ឬ «យកចេញ»

សញ្ជឹងគិត

«ស្មឹងស្មាធិ» ឬ «ខ្វល់ខ្វាយនឹង»

សេចក្តីអាក្រក់របស់លោក បង្រៀនមាត់របស់លោក

ការពិព័ណនាអំពី «កំហុស» វាហាក់ដូចជាបានបង្រៀន ហើយមាត់របស់លោកយ៉ូប
ពណ៌នាហាក់ដូចជាកំពុងរៀន។
នេះមានន័យថាពាក្យសម្តីរបស់គាត់គឺឥតខ្ចោះដោយសារតែកំហុស។
របៀបផ្សេងទៀតនៃការបកប្រែ: «កំហុសរបស់លោកដូចជាគ្រូរបស់លោក
ហើយមាត់របស់លោកគឺដូចជាសិស្សរបស់វា» ឬ «គឺដោយសារតែលោក
បាបដែលលោកនិយាយគឺជារបៀបដែលលោកធ្វើ»

មាត់របស់លោក

នេះជាពាក្យសម្តីរបស់លោកយ៉ូប ប៉ុន្តែសំដៅដល់ «មាត់» របស់លោក
ដើម្បីសង្កត់លើអ្វីមួយដែលគាត់និយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកត្រូវនិយាយ» ឬ «អ្នកនិយាយអ្វីដែលអ្នកនិយាយ»

ប្រើពាក្យសំដី របស់មនុស្សអាក្រក់

សំដៅលើរបៀបដែលមនុស្សអាក្រក់និយាយ ដូចជា «ពាក្យសម្តី» របស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ: «និយាយក្នុងរបៀបដែលមនុស្សអាក្រក់និយាយ»

មនុស្សអាក្រក់

«មនុស្សបោកបញ្ឆោត»

មាត់របស់លោកផ្ទាល់បានដាក់ទោសដល់លោកខ្លួនឯង មិនមែនជាខ្ញុំទេ
ឃ្លានេះសំដៅដល់លោកយ៉ូប និងលោកអេលីផាស ដោយ «មាត់»
របស់ពួកគេបញ្ជាក់នូវអ្វីដែលពួកគេនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានដាក់ទោសដោយអ្វីដែលលោកនិយាយ
មិនមែនដោយអ្វីដែលខ្ញុំនិយាយទេ» ឬ
«លោកបានដាក់ទោសខ្លួនលោកដោយអ្វីដែលលោកនិយាយ
វាមិនមែនខ្ញុំទេដែលដាក់ទោសលោក»

បបូរមាត់របស់លោកក៏ធ្វើបន្ទាល់

នេះនិយាយពីលោកយ៉ូប ប៉ុន្តែ សំដៅដល់ «បបូរមាត់» របស់គាត់
ដែលបញ្ជាក់ពីអ្វីដែលគាត់និយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពាក្យសម្តីរបស់លោក» ឬ «ទីបន្ទាល់របស់លោក

Job 15:7

ព័ត៌មានទូទៅ

ខនីមួយៗជាពាក្យប្រៀបធៀប ដែលមានសំណួរពីរដែលមិនទាមទារចម្លើយ ។

តើលោកជាមនុស្សដំបូងដែលកើតមកឬ?

ការបញ្ជាក់ចម្លើយនៅទីនេះគឺ «ទេ»។
សំណួរដែលមិនទាមទារចម្លើយនេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកមិនមែនជាមនុស្សទីមួយដែលបានកើតមកទេ»

តើលោកបានលេចមកមុនអស់ទាំងភ្នំដែរឬ?

ការបញ្ជាក់ចម្លើយនៅទីនេះគឺ «ទេ»។
សំណួរដែលមិនទាមទារចម្លើយនេះអាចត្រូវបានសរសេរជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកមិនបានលេចមកមុនអស់ទាំងភ្នំនោះទេ» ឬ
«ព្រះមិនបាននាំលោកមកមុនពេលដែលព្រះអង្គនាំអស់ទាំងភ្នំចេញមកនោះទេ»

តើលោកបានលេចមក

ឃ្លានេះអាចនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើព្រះបាននាំលោកមក»

តើលោកបានឮពីអាថ៌កំបាំងនៃចំណេះដឹងរបស់ព្រះជាម្ចាស់ឬ?

ការបញ្ជាក់ចម្លើយនៅទីនេះគឺ «ទេ»។
សំណួរដែលមិនទាមទារចម្លើយនេះអាចត្រូវបានសរសេរជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកមិនបានឮពីអាថ៌កំបាំងនៃចំណេះដឹងរបស់
ព្រះជាម្ចាស់ទេ»

តើលោកកំណត់ដែនប្រាជ្ញាចំពោះខ្លួនឯងឬ?

សំណួរដែលមិនទាមទារចម្លើយនេះបញ្ជាក់ថាគាត់មិនអាចកំណត់ដែនប្រាជ្ញាចំពោះខ្លួនឯង។
ឃ្លានេះអាចសសេរជាប្រយោគក៏បាន របៀបផ្សេងទៀតនៃការបកប្រែ:
«លោកមិនអាចកំណត់ដែលប្រាជ្ញារបស់លោកបានទេ» ឬ
«លោកមិនមែនជាអ្នកប្រាជ្ញតែម្នាក់នោះទេ»

តើលោកដឹងអ្វីដែលពួកយើងមិនដឹងឬ?

ការបញ្ជាក់ចម្លើយនៅទីនេះគឺ «គ្មានទេ»។
សំណួរដែលមិនទាមទារចម្លើយនេះអាចត្រូវបានសរសេរជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានអ្វីដែលលោកដឹងហើយយើងមិនដឹងនោះទេ»
ឬ «គ្រប់យ៉ាងដែលលោកដឹងយើងក៏ដឹងដែរ»

អ្វីដែលលោកដឹង តើពួកយើងមិនដឹងមែនទេ?

ការនិយាយរបស់មនុស្សនេះ គឺមានការយល់ដឹងដូចជាអ្វីមួយ «នៅខាងក្នុង»
ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីគ្រប់យ៉ាងដែលលោកយល់
យើងក៏យល់ដឹងដែរ» ឬ «យើងយើល់ដឹងអ្វីគ្រប់យ៉ាងដែលលោកយល់ដឹង»

Job 15:10

ចំណែក យើងមានទាំងពីរជាមនុស្សសក់ស្កូវ និងមនុស្សអាយុច្រើនដែលចាស់

សក់ស្កូវហើយនិងមនុស្សចាស់- លោកអេលីផាសនិយាយអំពីខ្លួនរបស់លោក
និងមនុស្សដទៃទៀតដែលមានប្រាជ្ញា

generated on Wed Sep 10 16:16:32 2025

ដែលពួកគេបានរៀនសូត្រពីមនុស្សដ៏មានវ័យចាស់
គឺវាហាក់ដូចជាពួកគេជាគ្រូដែលណែនាំពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានទទួលប្រាជ្ញាពីពួកគេទាំងពីរ គឺអ្នកដែលមានសក់ស្កូវ
និងមនុស្សអាយុច្រើនដែលចាស់»
មនុស្សសក់ស្កូវ និងមនុស្សអាយុច្រើនដែលចាស់
សក់ស្កូវហើយនិងមនុស្សចាស់-ឃ្លា «មនុស្សសក់ស្កូវ»
គឺជាការពណ៌នាអំពីរូបកាយរបស់ «មនុស្សអាយុច្រើនដែលចាស់»។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សចាស់អាយុច្រើនដែលមានសក់ស្កូវ»
ចាស់ជាងឪពុករបស់លោកទៅទៀត
នេះជាការពន្លើស។ របៀបផ្សេងទៀតនៃការបកប្រែ: «ចាស់ជាងឪពុករបស់អ្នក»
តើលោកបានចាត់ទុកការលួងចិត្ត ឬពាក្យផ្អែមទន្លន់ភ្លន់របស់ព្រះ...ចំពោះលោកឬ?
សំណួរដែលមិនទាមទារចម្លើយនេះគឺជាការចោទប្រកាន់មួយ
ជាមួយការបញ្ជាក់ចម្លើយទៅកាន់សំណួរនោះគឺ «បាន»។
សំណួរនេះអាចសសេរជាសេចក្តីថ្លែងការណ៍ក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកត្រូវតែគិតថាការលួងលោមរបស់ព្រះជាម្ចាស់គឺតូចតាចសម្រាប់អ្នក
ពាក្យសម្តីទន់ភ្លន់សម្រាប់អ្នក»
ការលួងលោម
«លើកទឹកចិត្ត» ឬ «កំសាន្តចិត្ត»
Job 15:12
ហេតុអ្វីបានជាលោកបណ្តាយឲ្យចិត្តនាំរបស់លោកដូច្នេះ?
នៅទីនេះពាក្យ «ចិត្ត» តំណាងឲ្យការលើកទឹកចិត្តរបស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុអ្វីការលើកទឹកចិត្តរបស់អ្នកនាំអ្នកទៅឆ្ងាយ?» ឬ
«ហេតុអ្វីអ្នកអនុញ្ញាតឲ្យការលើកទឹកចិត្តរបស់អ្នកដឹកនាំការសម្រេចចិត្តរបស់អ្នក!»
ហេតុអ្វីបានជាលោកមិចភ្នែកដូច្នេះ
នេះប្រហែលជាសំដៅដល់លោកយ៉ូបហាក់ដូចជាខឹង
ជាពិសេសការបង្ហាញសញ្ញានៃភ្នែករបស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុអ្វីបានជាភ្នែករបស់មើលទៅហាក់ដូចជាខឹង» ឬ «ហេតុអ្វីអ្នកខឹង»
បាននាំឲ្យចិត្ត
នៅទីនេះ «ចិត្ត» សំដៅដល់តួមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«នាំខ្លួនរបស់អ្នក»
បញ្ចេញពាក្យយ៉ាងនេះ ពីមាត់របស់អ្នកមក
នេះជាការពណ៌នាពីការនិយាយរបស់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយដូច្នេះ អ្នកនិយាយការអាក្រក់ទាស់នឹងគាត់
តើមនុស្សជាអ្វី...តើអ្នកដែលកើតមក
សំនួរទាំងពីរនេះមានមូលដ្ឋានគ្រឹះដូចគ្នា
ហើយត្រូវបានប្រើរួមគ្នាដើម្បីសង្កត់ធ្ងន់ថាមនុស្សមិនមែនឥតខ្ចោះនោះទេ។
តើមនុស្សជាអ្វីដែលអាចស្អាតបាន?
នេះជាសំនួរដែលមិនទាមទារចម្លើយ ដើម្បីបញ្ជាក់ថាមនុស្សមិនអាច «ស្អាត»
ទាំងស្រុងនោះទេ។ នេះអាចត្រូវបានសសេរជាសេចក្តីថ្លែងការណ៍។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សម្នាក់ គេមិនអាចស្អាតទាំងស្រុងទេ»។
ស្អាត
មនុស្សម្នាក់ដែលព្រះជាម្ចាស់ចាត់ទុកជាមនុស្សដែលទទួលយកបានខាងព្រលឹងវិញ្ញាណ
គឺត្រូវបាននិយាយថាជាមនុស្សដែលស្អាតស្អំខាងរូបកាយ។
តើអ្នកដែលកើតមកពីមនុស្សស្រី អាចសុចរិតបានទេ?
នេះជាសំណួរដែលមិនទាមទារចម្លើយដើម្បីសង្កត់ធ្ងន់ថា មនុស្សមិនអាច
«សុចរិត» ទាំងស្រុងបានទេ។ ឃ្លានេះអាចសសេរជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សដែលកើតមកពីមនុស្សស្រី មិនអាច
សុចរិតទាំងស្រុងបានទេ»
Job 15:15
មើល៍
ពាក្យនេះត្រូវបានប្រើដើម្បីទាញចំណាប់អារម្មណ៍របស់លោកយ៉ូបទៅអ្វីដែលនិយាយបន្ទាប់។
របៀបផ្សេងទៀតនៃការបកប្រែ:
ពួកបរិសុទ្ធរបស់ព្រះអង្គ
«ទេវតារបស់ព្រះអង្គ» (UDB)
បរិសុទ្ធ
អ្វីមួយដែលព្រះចាត់ទុកថាជារបស់ដែលអាចទទួលយកបានខាងវិញ្ញាណ
គឺត្រូវបាននិយាយហាក់ដូចជាភាពបរិសុទ្ធខាងសាច់ឈាម។
នៅព្រះនេត្ររបស់ព្រះអង្គ
ព្រះនេត្រ នៅទីនេះ តំណាងឲ្យការវិនិច្ឆ័យ ឬ ការវាយតម្លៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងការវិនិច្ឆ័យរបស់ព្រះអង្គ»
គួរឲ្យស្អប់ និងពុករលួយ
ពាក្យទាំងពីរមានន័យដូចគ្នា ហើយសង្កត់ធ្ងន់ថាមនុស្សអាក្រក់យ៉ាងណា។
មនុស្សដែលផឹកសេចក្តីអាក្រក់ដូចជាទឹក
ការពណ៌នាសេចក្តីអាក្រក់នេះ ហាក់ដូចជាទឹកដែលអាចផឹកបាន។
វាប្រៀបធៀបពីរបៀបនៃការសម្រេចចិត្តរបស់មនុស្សអាក្រក់ក្នុងការប្រព្រឹត្តអំពើបាប
ទៅនឹងការសម្រេចចិត្តរួចជាស្រេចដើម្បីផឹកទឹកត្រជាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលស្រលាញ់អំពើអាក្រក់យ៉ាងខ្លាំងដូចជា
ពួកគេស្រលាញ់ទឹកស្អាតមួយកែវ» ឬ «អ្នកដែលប្រព្រឹត្តការអាក្រក់ដ៏ជ្រៅ
ដូចជាពួកគេផឹកទឹក» (UDB)
Job 15:17
ខ្ញុំនឹងបង្ហាញលោក
នេះគឺជាពាក្យ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំនឹងពន្យល់អ្នក» ឬ
«ខ្ញុំនឹងធ្វើវាអោយច្បាស់សម្រាប់អ្នក»
ខ្ញុំនឹងប្រកាសប្រាប់
«ខ្ញុំនឹងប្រកាស»
ដូនតារបស់ពួកគេមិនបានលាក់ទុក
លោកអេលីផាសសង្កត់ធ្ងន់ថា ដូនតារបស់ពួកគេ
បានបង្រៀនពួកគេអំពីគោលបំណងនៃកិច្ចការទាំងអស់នេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូនតារបស់ពួកគេ បានបង្រៀនដោយបើកចំហ»
Job 15:19
គឺអ្នកដែលបានទទួលទឹកដី
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទៅអ្នកដែលព្រះបានប្រទានដីឲ្យ»
ហើយនៅក្នុងចំណោមពួកគេគ្មានសាសន៍ដទៃណាឆ្លងកាត់ឡើយ
នេះមានន័យថា មិនមានជនបរទេសណាបានរស់នៅក្នុងចំណោយពួកគេនោះទេ
ជាពិសេស ដូច្នេះ
ពួកគេនឹងមិនទទួលរងឥទ្ធិពលពីសាសនាមិនពិតនានានោះឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនមានអ្នកណាមកពីប្រទេសដទៃ
ហើយបាននាំពួកគេគិតមិនត្រឹមអំពីព្រះនោះទេ។
រងការឈឺចាប់ទ្វេដង
«ទុក្ខព្រួយយ៉ាងច្រើននៃការឈឺចាប់»។ នេះគឺជាការឈឺចាប់ខាងសាច់ឈាម
ឬអារម្មណ៍។
ហើយចំនួនឆ្នាំដែលបានបម្រុងទុក
នេះអាចស្ថិតក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឆ្នាំទាំងអស់ដែលព្រះបានបម្រុងទុក»
ដែលបានបម្រុងទុក
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «ដែលបានរៀបចំ» ឬ
«ដែលបានកំណត់»
សម្លេងនៃភាពភ័យខ្លាចនៅក្នុងត្រចៀករបស់គេ
«គាត់តែងតែឮសម្លេងដែលនាំឲ្យគាត់ភ័យខ្លាចឥតឈប់ឈរ»
Job 15:22
ប្រយោគភ្ជាប់
លោកអេលីផាសបន្តពណ៌នាពីមនុស្សអាក្រក់ដែលគាត់បានចាប់ផ្តើមពណ៌នាក្នុងជំពូក
១៥:១៩
ចេញពីទីងងឹតមក
នៅទីនេះ «ទីងងឹត» គឺជាពាក្យប្រៀបធៀបសម្រាប់បញ្ហា ឬ សំណាងអាក្រក់។
របៀបផ្សេងទៀតនៃការបកប្រែ: «រត់គេចខ្លួនពីសំណាងអាក្រក់»
ដាវក៏នៅរង់ចាំគេ
នៅទីនេះ «ដាវ»
ជាពាក្យប្រៀបធៀបដែលតំណាងឲ្យសត្រូវដែលកំពុងរងចាំដើម្បីសម្លាប់មនុស្សអាក្រក់។
វាអាចមានអត្ថន័យពីរ គឺទី១) គាត់បានព្រួយបារម្ភ ថាអ្នកណាម្នាក់នឹងសម្លាប់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «គាត់បារម្ភថា អ្នកណាម្នាក់ហៀបនឹងសម្លាប់គាត់»
ទី ២) វាច្បាស់ណាស់ថាអ្នកណាម្នាក់នឹងសម្លាប់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកណាម្នាក់កុំពុងរងចាំដើម្បីសម្លាប់គាត់»
ដើម្បីរកនំបុ័ង
នៅទីនេះ «នំបុ័ង» សំដៅដល់អាហារជាធម្មតា។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«ដើម្បីរកអាហារ»
ថ្ងៃនៃសេចក្ដីងងឹត
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «ថ្ងៃនៃគ្រោះមហន្តរាយ» ឬ «ពេលវេលានៃសេចក្ដីស្លាប់របស់គាត់»
មកដល់ហើយ
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «គឺមកដល់ឆាប់ៗ»
យកឈ្នះ
«គ្រប់គ្រងលើ» ឬ «វាយឲ្យចាញ់»
ដូចជាស្តេចដែលត្រៀមជាស្រេចសម្រាប់ច្បាំង
នេះជាការប្រៀបធៀបពីរបៀបដែលទុក្ខព្រួយនិងទុក្ខវេទនារបស់គាត់មានអំណាចលើគាត់ ប្រៀបនឹងស្តេចមួយអង្គដែលរួចជាស្រេចសម្រាប់សមរភូមិ នឹងឈ្នះលើនឹងគាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូចជាស្តេច ដែលត្រៀមខ្លួនរួចជាស្រេចសម្រាប់សមរភូមិ ដែលនឹងធ្វើឲ្យគាត់មានទុក្ខព្រួយ និងរងទុក្ខវេទនា»
Job 15:25
ពួកគេបានលូកដៃរបស់ពួកគេទាស់នឹងព្រះជាម្ចាស់
«គាត់បានក្តាប់ដៃរបស់គាត់ទាស់នឹងព្រះជាម្ចាស់»។ នេះគឺជាសញ្ញានៃបំពាន។
បានរត់ទៅទាស់នឹងព្រះអង្គ
នេះជាការនិយាយនៃសកម្មភាពបំពានរបស់មនុស្សអាក្រក់ទាស់នឹងព្រះ វាហាក់ដូចជាគេកំពុងរត់សំដៅទៅវាយប្រហារទ្រង់។ របៀបផ្សេងទៀតនៃការបកប្រែ: «វាយប្រហារព្រះ» ឬ «សកម្មភាពកំណាចទាស់នឹងព្រះ»
ជាមួយនឹងខែលបាំងនៅនឹងកយ៉ាងក្រាស់
«ជាមួយខែលបាំងដ៏ខ្លាំងរបស់គាត់»
Job 15:27
នេះគឺជាការពិត
«នេះ» សំដៅដល់មនុស្សអាក្រក់ដែលរត់ទៅទាស់ប្រឆាំងនឹងព្រះពីខខាងមុខ។
គេគ្របបាំងមុខរបស់ពួកគេដោយខ្លាញ់របស់គេ ហើយប្រមូលខ្លាចនោះដាក់លើចង្កេះផង
មនុស្សអាក្រក់នេះ គឺបានបរិយាយហាក់ដូចជាធាត់ហើយខ្សោយ ខណៈដែលគាត់ជឿថា គាត់ខ្លាំងល្មមដើម្បីប្រឆាំងនឹងព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ: «គាត់គឺខ្សោយដោយសារខ្លាញ់លើមុខ និងខ្លាញ់លើចង្កេះ»
ដែលគ្មានមនុស្សនៅ
«ដែលត្រូវបានបោះបង់»
រលំ
«ហិនហោច» ឬ «បោះចោល»
Job 15:29
គេនឹងមិនអាចទៅជាអ្នកមានទេ ហើយទ្រព្យសម្បត្តិគេក៏មិនគង់នៅដែរ
ប្រយោគទាំងពីរបញ្ជាក់ថា គាត់នឹងមានភាពផ្ទុយពីមាន គឺថាគាត់នឹងទៅជាក្រ។ របៀបផ្សេងទៀតនៃការបកប្រែ: «គាត់នឹងក្រ ប្រាក់ទាំងប៉ុន្មានរបស់គាត់នឹងបាត់ទៅ»
សូម្បីតែស្រមោលរបស់គេក៏គ្មាននៅលើផែនដីដែរ
នេះនិយាយពីគំនិតដដែល ដែលថា ទ្រព្យសម្បត្តិរបស់មនុស្សអាក្រក់ទាំងអស់នឹងរលាយបាត់ទៅ។ ការបកប្រែដទៃទៀតអាចអាចថា: «សូម្បីតែ ទ្រព្យសម្បត្តិរបស់គាត់ក៏មិនស្ថិតស្ថេរនៅលើផែនដីនេះដែរ»។
ចេញពីទីងងឹត
ទីងងឹតនៅទីនេះ តំណាងឲ្យសេចក្ដីស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «ចេញពីទីងងឹតនៃសេចក្ដីស្លាប់»
អណ្តាតភ្លើងនឹងធ្វើឲ្យដើមស្ងិតក្រៀម
នៅទីនេះអណ្តាតភ្លើងតំណាងឲ្យការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ហើយការក្រៀមស្ងិតនៃដើមរបស់គាត់ តំណាងមុខរបស់គេ ដែលទ្រព្យសម្បត្តិត្រូវរលាយអស់ ឬថាគាត់នឹងត្រូវស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះនឹងយកអ្វីគ្រប់យ៉ាងដែលគាត់មានចេញពីគាត់ ដូចជាភ្លើងដែលសម្ងួតមែនឈើ»
ខ្យល់នៃព្រះឱស្ឋព្រះជាម្ចាស់
នៅទីនេះ «ព្រះឱស្ឋ» របស់ព្រះ តំណាងឲ្យការវិនិច្ឆ័យរបស់ព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្យល់នៃព្រះឱស្ឋព្រះ» ឬ «ការវិនិច្ឆ័យរបស់ព្រះ»
គេនឹងធាត់ទៅបាត់ដែរ
ឃ្លានេះសំដៅទៅលើគាត់ដែលបានស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «គាត់នឹងស្លាប់»
Job 15:31
ដ្បិត អ្វីៗដែលឥតប្រយោជន៍នោះ ហើយក៏ជារង្វាន់ដល់គេវិញដែរ
ពាក្យដែលខ្វះខាតអាចត្រូវបន្ថែម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើគាត់ទុកចិត្តដល់ពួកគេ ការឥតប្រយោជន៍ នឹងក្លាយជារង្វាន់របស់គាត់»
ហើយមែករបស់គេនឹងមិនខៀវស្រងាត់ទៀតទេ
នេះនិយាយពីមនុស្សដែលមើលទៅស្លេកស្លាំងហើយបានស្លាប់ វាហាក់ដូចជាគាត់ជាដើម ឬជាមែកឈើដែលស្ងួត។ របៀបផ្សេងទៀតនៃការបកប្រែ: «គាត់នឹងមើលទៅស្លាប់ គឺដូចជាមែកនៃដែលឈើដែលងាប់ វាមិនខៀវស្រងាត់ទៀតទេ»
គេនឹងរលាស់ជម្រុះផ្លែខ្ចីរបស់ខ្លួន...គេនឹងកាត់ផ្ការបស់គេ
ប្រយោគទាំងពីរនេះផ្តល់នូវរូបភាពដូចគ្នា ដែលវាបញ្ជាក់ឡើងវិញថាការនេះពិតជានឹងកើតឡើង។
គេនឹងរលាស់ជម្រុះផ្លែខ្ចីរបស់ខ្លួនអស់ទៅ ដូចជាដើមទំពាំងបាយជូរ
នេះនិយាយអំពីការលូតលាស់ដ៏ខ្សោយនិងការស្លាប់ទៅរបស់មនុស្សអាក្រក់ ហាក់ដូចជាដើមទំពាំងបាយជូរដែលជម្រុះក្តឹបទំពាំងបាយជូរ ដូច្នេះ មនុស្សអាក្រក់កម្លាំងរបស់គេនឹងធ្លាក់ចុះ»
ហើយគេនឹងកាត់ផ្ការបស់គេចោល ដូចជាដើមអូលីវដែរ
នេះនិយាយអំពីការលូតលាស់ដ៏ខ្សោយនិងការស្លាប់ទៅរបស់មនុស្សអាក្រក់ ហាក់ដូចជាដើមអូលីវដែលកំពុងជម្រុះផ្ការបស់វា ដូច្នេះ មនុស្សអាក្រក់នឹងបាត់បង់កម្លាំងរបស់គេ»
Job 15:34
ពួកមនុស្សទុច្ចរិត
«ក្រុមនៃមនុស្សដែលគ្មានព្រះ»
ភ្លើងក៏នឹងឆេះបន្សុសត្រសាលរបស់ពួកគេដែរ
ឃ្លា «ត្រសាល»
មានន័យថាពួកមនុស្សអាក្រក់បាននាំត្រសាលទាំងនេះជាមួយប្រាក់ដែលពួកគេរកបានពីការស៊ីសំណូក។ របៀបផ្សេងទៀតនៃការបកប្រែ: «ត្រសាលដែលពួកគេនាំមកជាមួយការស៊ីសំណូករបស់ពួកគេនឹងត្រូវដុតបន្សុសដោយភ្លើង»
ពួកគេមានគភ៌បង្កើតជាសេចក្ដីអន្តរាយ ហើយក៏បង្កើតចេញមកជាអំពើទុច្ចរិត
ផ្ទៃរបស់ពួកគេមានគភ៌ជាការបោកប្រាស់
គំនិតដូចគ្នា គឺនិយាយឡើងវិញបីដង ដើម្បីបញ្ជាក់ ថាតើមនុស្សអាក្រក់បានធ្វើអ្វីខ្លះ។
នេះនិយាយពីមនុស្សដែលមានគម្រោងដើម្បីប្រព្រឹត្តការអាក្រក់និងធ្វើពួកវា វាហាក់ដូចជាមនុស្សម្នាក់ដែល មានគភ៌និងឲ្យកំណើតទារក។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេរៀបផែនការឲ្យមានអំពើអាក្រក់និងធ្វើការអាក្រក់ ពួកគេតែងតែមានផែនការឆបោកអ្នកដទៃ»
ផ្ទៃរបស់ពួកគេមានគភ៌
នីទីនេះ «ផ្ទៃ» គឺត្រូវបានប្រើសំដៅលើមនុស្សដើម្បីបញ្ជាក់ការតាំងគភ៌ វាដូចជានៅក្នុងផ្ទៃដែលគភ៌បានតាំងទីកន្លែង។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកមានគភ៌»

---

16 [1]នោះលោកយ៉ូបឆ្លើយឡើងថា៖[2]«ខ្ញុំបានឮសេចក្ដីយ៉ាងនោះជាច្រើនហើយ អ្នករាល់គ្នាសុទ្ធតែជាអ្នកកម្សាន្តចិត្ត ដែលនាំឲ្យលើយវិញ។[3]តើពេលណាពាក្យឥតប្រយោជន៍ទាំងនេះត្រឹមចប់? តើមានអ្វីសុខជាមួយអ្នករាល់គ្នា បានធ្វើឲ្យអ្នកឆ្លើយមកដូច្នេះ?
[4]ខ្ញុំក៏អាចនិយាយដូចជាអ្នករាល់គ្នាបានដែរ ប្រសិនបើអ្នករាល់គ្នា ជួបនឹងស្ថានការដូចខ្ញុំ នោះខ្ញុំនឹងរកពាក្យមកទាស់នឹងអ្នករាល់គ្នា ព្រមទាំងគ្រវីក្បាលដាក់អ្នករាល់គ្នាដែរ។[5]ប៉ុន្តែ ខ្ញុំនឹងបញ្ចេញពាក្យលើកទឹកចិត្ត ដល់អ្នករាល់គ្នាវិញ ហើយបបូរមាត់ខ្ញុំនឹងរកបន្ធូរទុក្ខ របស់អ្នករាល់គ្នា!

generated on Wed Sep 10 16:16:32 2025

[6]តែឥឡូវនេះ ទោះបើខ្ញុំនិយាយ ក៏សេចក្ដីទុក្ខព្រួយរបស់ខ្ញុំមិនថយចេញពីខ្ញុំដែរ ហើយបើនៅស្ងៀម តើវានឹងជួយអ្វីដល់ខ្ញុំ?[7]ប៉ុន្តែពេលនេះ ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំល្វើយ
ទៅ ព្រះអង្គបានធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំ វិនាសអស់ហើយ។[8]ព្រះអង្គបានធ្វើឲ្យខ្ញុំនៅសល់តែស្បែក នឹងឆ្អឹង ដែលជាទីបន្ទាល់មួយទាស់នឹងខ្ញុំ ហើយអាការៈស្គមស្គាំងរបស់
ខ្ញុំ ក៏ទាស់នឹងខ្ញុំដែរ គឺវាក្រោកឡើងធ្វើបន្ទាល់នៅមុខខ្ញុំ។
[9]ព្រះជាម្ចាស់បានហែកហួរខ្ញុំ ដោយសេចក្ដីក្រោធ របស់ព្រះអង្គ ព្រមទាំងស្អប់ខ្ញុំផង ព្រះអង្គសង្កៀតធ្មេញដាក់ខ្ញុំ ខ្មាំងសត្រូវរបស់ខ្ញុំ បានសំលៀងភ្នែកទាស់នឹងខ្ញុំ។[10]ពួកគេ
បានហាមាត់គំរាមខ្ញុំ គេបានទះកំផ្លៀងនៅលើមុខរបស់ខ្ញុំ ហើយប្រមូលគ្នាដើម្បីនឹងទាស់ជាមួយខ្ញុំ។
[11]ព្រះជាម្ចាស់បានប្រគល់ខ្ញុំទៅមនុស្សទមិឡល្មើស ហើយបានបោះបង់ចោលខ្ញុំ ទៅក្នុងកណ្ដាប់ដៃនៃពួកអាក្រក់។[12]ពីដើមខ្ញុំមានសេចក្ដីសុខ តែព្រះអង្គបានបំបាក់បំបែក
ខ្ញុំ។ ព្រះអង្គបានចាប់កញ្ឆឹងកខ្ញុំ ទាំងបោកខ្ញុំកម្ទេចផង ព្រះអង្គបានបញ្ឈរខ្ញុំឡើង ទុកជាផ្នាំងស៊ីបរបស់ព្រះអង្គ។
[13]ពួកពលធ្នូរបស់ព្រះអង្គឡោមព័ទ្ធខ្ញុំ ព្រះអង្គពុះចិត្តថ្លើមខ្ញុំជាពីរឥតត្រាប្រណីឡើយ ទាំងចាក់ទឹកប្រមាត់ខ្ញុំចុះដល់ដី។[14]ព្រះអង្គចាក់ទម្លុះខ្ញុំម្តងហើយម្តងទៀត ព្រះអង្គក៏រត់
ចូលមកលើខ្ញុំ ដូចជាមនុស្សខ្លាំងពូកែខាងសង្គ្រាម។
[15]ខ្ញុំបានដេរសំពត់ធ្មៃភ្ជាប់លើស្បែកខ្ញុំ ហើយបានដាក់កិត្តិយសខ្ញុំចុះក្នុងធូលីដី។[16]ខ្ញុំយំឡើងមុខរបស់ខ្ញុំក្រហម ហើយភ្នែកខ្ញុំត្រូវរូងខ្មៅ។[17]ទោះបីជា ខ្ញុំគ្មានសេចក្ដីអាក្រក់
នៅក្នុងដៃខ្ញុំ ហើយសេចក្ដីអធិស្ឋានរបស់ខ្ញុំគឺបរិសុទ្ធ។
[18]ផែនដីអើយ កុំគ្របបាំងឈាមខ្ញុំឡើយ ហើយកុំឲ្យសម្រែករបស់ខ្ញុំ ឈប់សម្រាកបានឡើយ។[19]ឥឡូវនេះ មើលចុះ ទីបន្ទាល់របស់ខ្ញុំនៅលើស្ថានសួគ៌ ហើយសាក្សីរបស់ខ្ញុំ
នៅលើស្ថានដ៏ខ្ពស់។
[20]ពួកមិត្តរបស់ខ្ញុំ គេឡកឡឺយដាក់ខ្ញុំ ប៉ុន្តែខ្ញុំស្រក់ទឹកភ្នែកនៅចំពោះព្រះជាម្ចាស់។[21]ខ្ញុំត្រូវការមនុស្សម្នាក់ ធ្វើជាអ្នកកណ្ដាល រវាងមនុស្ស និងព្រះ ដូចជាមនុស្សម្នាក់
ដែលសម្រុះសម្រួល រវាងមិត្តសម្លាញ់របស់ខ្លួន![22]ដ្បិតនៅមិនយូឆ្នាំទេ ពេលកំណត់នឹងមកដល់ នោះខ្ញុំនឹងទៅតាមផ្លូវ ដែលមិនត្រឡប់មកវិញឡើយ។

Job 16:1

អ្នករាល់គ្នាសុទ្ធតែជាអ្នកកម្សាន្តចិត្ត ដែលនាំឲ្យកើតទុក្ខទៅវិញទេ

«ជំនួសឲ្យការកម្សាន្តចិត្តខ្ញុំ អ្នករាល់គ្នាបែរជាធ្វើឲ្យខ្ញុំកើតទុក្ខកាន់តែច្រើនទៅវិញ»

តើពាក្យឥតប្រយោជន៍ទាំងនេះចប់ពេលណា?

លោកយ៉ូបប្រើសំណួរដែលមិនទាមទារចម្លើយនេះ
ដើម្បីបញ្ជាក់ថាលោកមានប្រាជ្ញាដែលពួកគេគួរតែបញ្ឈប់ការនិយាយដែលគ្មានខ្លឹមសារ។ ឬក៏សំណួរនេះអាចត្រូវបានសរសេរជាប្រយោគក៏បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំរំពឹងថាពាក្យដ៏ឥតបានការរបស់អ្នករាល់គ្នានឹងបញ្ចប់!»

តើមានអស់លោកចេះតែយ៉ាងម៉េច បានធ្វើឲ្យអស់លោកឆ្លើយដូច្នេះ?

លោកយ៉ូបប្រើសំណួរដែលមិនទាមទារចម្លើយនេះ ដើម្បីបន្ទោសលោកអេលីផាស។
នៅទីនេះពាក្យ «អ្នក» ជាឯកវចន
និងសំដៅលើលោកអេលីផាសដែលទើបតែបញ្ចប់ការនិយាយទៅកាន់លោកយ៉ូប។
សំណួរនេះ អាចត្រូវបានសរសេរជាប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អេលីផាសអើយ
អ្នកគួតែបញ្ឈប់ការឆ្លើយមកខ្ញុំរបៀបនេះទៀតទៅ!»

Job 16:4

នោះខ្ញុំនឹងរកពាក្យ
លោកយ៉ូបនិយាយអំពីការគិតនៃកិច្ចការដែលឥតប្រយោជន៍នានា ដើម្បីនិយាយ
វាហាក់ដូចជាពាក្យរបស់លោកគឺជាធាតុចៃដន្យដែលលោកបានប្រមូលមកនិងរួមបញ្ចូលគ្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំអាចគិតអំពីកិច្ចការនានាដើម្បីនិយាយ»

គ្រវីក្បាល

នេះគឺជាសកម្មភាពដែលបង្ហាញការមិនយល់ព្រម។

ទាំងចំអកផង

ពាក្យ «ចំអក» អាចត្រូវបានបង្ហាញដូចជាកិរិយាសព្ទ។ «ដើម្បីចំអកអ្នក»

ប៉ុន្តែ ខ្ញុំនឹងមិនបញ្ចេញពាក្យលើកទឹកចិត្ត ដល់អស់លោក ហើយបបូរមាត់ខ្ញុំនឹងមិនកម្សាន្តចិត្តដល់
អស់លោកដែរ!

នៅទីនេះលោកយ៉ូបនិយាយចំអកឡកឡឺយ
និងមានន័យផ្ទុយពីអ្វីដែលលោកនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពាក្យសម្ដីរបស់ខ្ញុំគឺប្រាកដជាមិនលើកទឹកចិត្តអ្នករាល់គ្នាទេ»
ពួកគេប្រាកដជាមិនធ្វើឲ្យអស់លោកមានសេចក្ដីឈឺចាប់ទេ» ឬ
«ដោយការនិយាយមកកាន់អ្នករាល់គ្នា
ដូចដែលអ្នករាល់គ្នាបាននិយាយមកកាន់ខ្ញុំមុននេះ ខ្ញុំនឹងមិនលើកទឹកចិត្ត
ឬកម្សាន្តចិត្តអ្នករាល់គ្នាទេ!»

ដោយមាត់របស់ខ្ញុំ

នៅទីនេះ «មាត់» របស់លោកយ៉ូប តំណាងឲ្យអ្វីដែលគាត់និយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយអ្វីដែលខ្ញុំនិយាយ»

បបូរមាត់ខ្ញុំនឹងលើកទឹកចិត្ត

នេះសំដៅដល់ពាក្យលើកទឹកចិត្តដែលលោកនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពាក្យលើកចិត្តរបស់ខ្ញុំ»

នឹងកម្សាន្តចិត្តរបស់អ្នក

នេះនិយាយពីទុក្ខព្រួយ វាហាក់ដូចជាបន្ទុកដ៏ធ្ងន់ខាងសាច់ឈាម។
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងកាត់បន្ថយទុក្ខព្រួយរស់អ្នក» ឬ
«នឹងជួយអ្នកអោយស្បើយពីទុក្ខព្រួយ»

Job 16:6

សេចក្ដីសោកសង្រេង

លោកយ៉ូបមានបានទទួលបទពិសោធន៍យ៉ាងធ្ងន់ធ្ងរនៃការបាត់បង់គ្រួសារនិងសុខភាព
ដែលវាមិនអាចពន្យល់បាន ហើយដូច្នេះវានាំឲ្យលោក
មានទុក្ខព្រួយយ៉ាងខ្លាំងនិងការឈឺចាប់ក្នុងផ្លូវអារម្មណ៍»

តើវានឹងជួយអ្វីដល់ខ្ញុំ?

លោកយ៉ូបប្រើសំណួរដែលមិនទាមទារចម្លើយនេះ
ដើម្បីបញ្ជាក់ថាការរក្សាភាពស្ងៀមស្ងាត់មិនបានធ្វើឲ្យទុក្ខព្រួយរបស់លោកថយចុះនោះទេ។
សំណួរនេះអាចត្រូវបានសរសេរជាប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាមិនបានជួយខ្ញុំអ្វីទាំងអស់»។

ប៉ុន្តែ ពេលនេះ ព្រះជាម្ចាស់

លោកយ៉ូប ពេលនេះបំបែរការគ្មួញក្អែររបស់លោកទៅឯព្រះវិញ។

បានធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំ វិនាសអស់

«បានបំផ្លាញគ្រួសាររបស់ទូលបង្គំទាំងអស់» (UDB)

ព្រះអង្គបានធ្វើឲ្យខ្ញុំក្រៀមស្វិត

នេះមានន័យថាខ្លួនប្រាណរបស់លោកយ៉ូបបានញ័រហើយទៅជាជ្រីវជ្រួញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានធ្វើឲ្យខ្លួនប្រាណរបស់ទូលបង្គំក្រៀមស្វិត»

ដែលជាទីបន្ទាល់មួយទាស់នឹងខ្ញុំ

លោកយ៉ូបពណ៌នាអំពីការក្រៀមស្វិតនៃខ្លួនប្រាណ
វាហាក់ដូចជាអ្នកចោទប្រកាន់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយមនុស្សគិតថា រឿងនោះបានបង្ហាញខ្ញុំថាខ្ញុំជាមនុស្សមានបាន»

ហើយភាពស្គមស្គាំងនៃរូបកាយរបស់ខ្ញុំ ក៏បានក្រោកឡើងទាស់នឹងខ្ញុំដែរ គឺវាធ្វើបន្ទាល់នៅមុខ
របស់ខ្ញុំ

លោកយ៉ូបពណ៌នាភាពស្គមស្គាំងនៃរូបកាយរបស់គាត់
វាហាក់ដូចជាអ្នកចោទប្រកាន់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេមើលទៅរូបកាយដ៏ស្គមស្គាំងរបស់ខ្ញុំ
ហើយពួកគេគិតថាវាបង្ហាញថាខ្ញុំមានកំហុស»

ទាស់នឹងមុខរបស់ខ្ញុំ

នៅទីនេះលោកយ៉ូបបានសំដៅលើ «មុខ» របស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទាស់នឹងខ្ញុំ»

Job 16:9

ព្រះជាម្ចាស់បានហែកខ្ញុំ ដោយព្រះពិរោធរបស់ព្រះអង្គ ហើយបានធ្វើទុក្ខបុកម្នេញដល់ខ្ញុំ
ផង...ដូចជាគេចង់ហែកខ្ញុំជាបំណែក

ឃ្លានេះនិយាយពីការដែលព្រះនាំឲ្យលោកយ៉ូបឈឺចាប់ ហាក់ដូចជាសត្វសាហាវ
ហើយលោកយ៉ូបគឺជារំពារដែលទ្រង់បានសម្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រោះព្រះ ព្រះពិរោធនឹងខ្ញុំខ្លាំងណាស់
វាដូចជាសត្វព្រៃដែលហែករូបកាយរបស់ខ្ញុំជាចំណែកៗ ជាមួយចង្កូមរបស់វា
ព្រោះទ្រង់ជាខ្មាំងសត្រូវរបស់ខ្ញុំ»

ខ្មាំងសត្រូវរបស់ខ្ញុំ

លោកយ៉ូបសំដៅដល់ព្រះ ជា «សត្រូវ» របស់គាត់

generated on Wed Sep 10 16:16:32 2025

ដែលគាត់ពណ៌នាពីរបៀបដែលទ្រង់ធ្វើឲ្យគាត់ឈឺចាប់យ៉ាងខ្លាំងដូច្នេះ។
បានសំលៀងភ្នែកទាស់នឹងខ្ញុំ
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «មើលមកខ្ញុំ»
ពួកគេបានហាមាត់ដាក់ខ្ញុំ
«ចំហមាត់»
មានន័យថាសម្លឹងមើលដោយមិនដាក់ភ្នែកក្នុងការដែលធ្វើឲ្យងឿនឆ្ងល់ជាមួយការបើក
Job 16:11
បានប្រគល់ខ្ញុំទៅមនុស្សទុច្ចរិត ហើយបានបោះខ្ញុំទៅក្នុងដៃរបស់មនុស្សអាក្រក់
ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា។
ពួកវារួមគ្នាបញ្ជាក់ពីអារម្មណ៍របស់លោកយ៉ូបដែលត្រូវបានក្បត់ដោយព្រះ។
បានប្រគល់ខ្ញុំទៅ
នេះជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដាក់ខ្ញុំទៅក្រោមការត្រួតត្រារបស់»
បានបោះខ្ញុំទៅក្នុងដៃរបស់
នៅទីនេះ «ដៃ» របស់មនុស្ស សំដៅដល់ «ការត្រួតត្រា» របស់គាត់។
តែព្រះអង្គបានបំបាក់ខ្ញុំខ្ទេចខ្ទីអស់
លោកយ៉ូបនិយាយពីការឈឺចាប់របស់គាត់ ហើយនិងការអស់សង្ឃឹម
វាហាក់ដូចជាខ្លួនរបស់លោកគឺជាអ្វីមួយដែលត្រូវបានបំបែកទៅជាបំណែកៗ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ វាមានអារម្មណ៍ថា
ទ្រង់បានបំបែកខ្ញុំជាផ្នែក»
វាយកម្ទេចខ្ញុំទៅជាបំណែកផង
លោកយ៉ូបនិយាយអំពីការដែលព្រះបានធ្វើឲ្យគាត់ឈឺចាប់និងអស់សង្ឃឹម
វាហាក់ដូចជាគាត់ជាអ្វីមួយដែលព្រះបានវាយហើយកម្ទេចទៅជាបំណែក។
របៀបផ្សេងទៀតនៃការបកប្រែ: «វាដូចជាទ្រង់បានវាយបំបាក់ករបស់ខ្ញុំ
ហើយវាយកម្ទេចខ្ញុំជាបំណែក»
ទុកដូចជាផ្នាំងស៊ីបរបស់ព្រះអង្គ
លោកយ៉ូបនិយាយពីខ្លួនរបស់លោកដែលដូចជាចំនុចវាយប្រហាររបស់ព្រះ
វាហាក់ដូចជាព្រះបានទុកលោកជាផ្នាំងស៊ីបដើម្បីបាញ់ព្រួញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាគឺដូចជាព្រះអង្គបានទុកខ្ញុំដូចជាផ្នាំងស៊ីប» (UDB)
Job 16:13
ពួកអ្នកបាញ់ព្រួញរបស់ព្រះអង្គព័ទ្ធខ្ញុំជុំវិញ
លោកយ៉ូបនិយាយពីខ្លួនរបស់លោកដែលដូចជាចំនុចវាយប្រហាររបស់ព្រះ
វាហាក់ដូចជាព្រះបានទុកលោកជាផ្នាំងស៊ីប
ហើយអ្នកបាញ់ព្រួញបានព័ទ្ធជុំវិញលោកដើម្បីវាយប្រហារលោក។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាគឺដូចជាពួកអ្នកបាញ់ព្រួញរបស់ព្រះអង្គបានព័ទ្ធជុំវិញលោក»
ព្រះជាម្ចាស់បានចាក់ទម្លុះចិត្តថ្លើមខ្ញុំឥតលើកលែងឡើយ ព្រះអង្គបានចាក់ទឹកប្រមាត់របស់ខ្ញុំ
នៅលើដល់ដី
លោកយ៉ូបនិយាយពីការឈឺចាប់ គាត់មានអារម្មណ៍ដោយប្រៀបធៀបវាទៅនឹង
ការដែលព្រះចាក់ទម្លុះរាងកាយរបស់លោកជាមួយនឹងព្រួញ។ ទីនេះ «ព្រះ»
តំណាងឲ្យព្រួញដែលទ្រង់បាញ់។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាអារម្មណ៍ដូចជាព្រួញរបស់ព្រះដែលបានចាក់ទម្លុះក្រលៀននិងថ្លើមរបស់ខ្ញុំ
ចាក់ទឹកប្រមាត់របស់ខ្ញុំទៅលើដី។ ព្រះអង្គមិនទុកជីវិតខ្ញុំទេ»
បោកខ្ញុំទៅនឹងជញ្ជាំង
លោកយ៉ូបនិយាយពីការឈឺចាប់
ដែលគាត់មានអារម្មណ៍ដោយប្រៀបធៀបខ្លួនរបស់គាត់
ទៅនឹងជញ្ជាំងដែលព្រះបានបោកចាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមានអារម្មណ៍ដូចជាជញ្ជាំងដែលព្រះបានបោកទៅលើ»
ព្រះអង្គក៏រត់ជាន់លើខ្ញុំ ដូចជាអ្នកចម្បាំងដ៏ខ្លាំងពូកែ
លោកយ៉ូបពណ៌នាពីព្រះ ដូចជាទាហានដែលវាយប្រហារគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «វាហាក់ដូចជា ទ្រង់គឺទាហានចម្បាំង
ដែលរត់មករកខ្ញុំដើម្បីវាយប្រហារខ្ញុំ»
Job 16:15
ខ្ញុំបានដេរសំពត់ធ្មៃភ្ជាប់លើស្បែករបស់ខ្ញុំ
លោកយ៉ូបនិយាយពីការស្លៀកសម្លៀកបំពាក់ដែលបានធ្វើមកពីបាវ
ហាក់ដូចជាសំលៀកបំពាក់បានវាយប្រហាររូបកាយរបស់គាត់។
មនុស្សតែងតែស្លៀកបាវដើម្បីបង្ហាញពីការកាន់ទុក្ខ ឬការមានទុក្ខព្រួយជាខ្លាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រោះខ្ញុំកំពុងកាន់ទុក្ខ ខ្ញុំបានដេរបាវចូលគ្នា
ដើម្បីពាក់ជាសម្លៀកបំពាក់របស់ខ្ញុំ» ឬ
«ខ្ញុំពាក់សម្លៀកបំពាក់ដែលខ្ញុំបានធ្វើអំពីបាវ ព្រះខ្ញុំកំពុងកាន់ទុក្ខ»
ខ្ញុំបានបោះស្នែងរបស់ខ្ញុំទៅលើដី
«ស្នែង» របស់លោកយ៉ូប តំណាងឲ្យថាមពលនិងអំណាចដែលគាត់មានពីមុន ប៉ុន្តែ
ឥឡូវគឺមិនមានទៀតទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំអង្គុយទីនេះនៅក្នុងដី
មានធ្វើឲ្យក្រៀមក្រៅខ្លាំងណាស់» (UDB)
នៅលើត្របកភ្នែកខ្ញុំគឺជាស្រមោលនៃសេចក្តីស្លាប់
នៅទីនេះ ភ្នែករបស់លោកយ៉ូប ត្រូវបានតំណាងឲ្យដោយ «ត្របកភ្នែក»
របស់គាត់។ លោកយ៉ូបនិយាយពីភ្នែករបស់គាត់មានពណ៌ខ្មៅ
ហាក់ដូចជាភ្នែកត្រូវមើលទៅដូចជាដូចជាភ្នែកមនុស្សដែលស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «មានរង្វង់ពណ៌ខ្មៅនៅជុំវិញភ្នែករបស់ខ្ញុំ» ឬ
«ភ្នែករបស់ខ្ញុំគឺខ្មៅ ដូចជាភ្នែកនៃមនុស្សស្លាប់»
គ្មានអំពើឃោឃៅនៅក្នុងដៃរបស់ខ្ញុំ
«ដៃ» តំណាងឲ្យសមត្ថភាពនិងសកម្មភាពរបស់មនុស្សម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនប្រព្រឹត្តអំពើឃោឃៅទេ»
Job 16:18
ផែនដី មិនបានគ្របបាំងឈាមខ្ញុំទេ
លោកយ៉ូបនិយាយទៅកាន់ «ផែនដី» ដោយចំពោះ
ទោះបីជាផែនដីមិនអាចស្តាប់ឮលោកក៏ដោយ
ដើម្បីបន្ថែមកម្លាំងដល់ស្ថានភាពរបស់លោក។ ផែនដីគឺជាលក្ខណៈផ្ទាល់មួយ
ដែលគោលបំណងនៃការគ្របបាំងឈាមរបស់លោកបន្ទាប់ពីលោកស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំរំពឹងថាឈាមរបស់ខ្ញុំនឹងមិនជ្រាបចូលទៅក្នុងដីនោះទេ ប៉ុន្តែ
គឺវានឹងស្ថិតនៅខាងលើដីជាភស្តុតាងពីរបៀបដែលខ្ញុំស្លាប់»
ផែនដី មិនបានគ្របបាំងឈាមខ្ញុំទេតួអង្គ
លោកយ៉ូបនិយាយពីការស្លាប់របស់លោក
ហាក់ដូចជាលោកនឹងត្រូវបានគេសម្លាប់។ នៅទីនេះ «ឈាម» គឺជាគ្រាមភាសា
សំដៅដល់សេចក្តីស្លាប់របស់លោក។ របៀបផ្សេងទៀតនៃការបកប្រែ: «ផែនដី
នៅពេលដែលខ្ញុំស្លាប់ ចូរកុំលាក់ពីរបៀបដែលខ្ញុំស្លាប់ដោយអយុត្តិធម៌ឡើយ» ឬ
«ចូរកុំលាក់ពីរបៀបដែលខ្ញុំស្លាប់ដោយអយុត្តិធម៌ឡើយ»
ចូរកុំឲ្យសម្រែករបស់របស់ខ្ញុំ បានឈប់នៅកន្លែងណាឡើយ
លោកយ៉ូបនិយាយពីការរងចាំនរណាម្នាក់ដើម្បីដឹងអ្វីដែលបានកើតឡើងដល់លោក
ដូចជា «ការស្រែក» របស់លោក
ជាមនុស្សម្នាក់ដែលមិនដែលបានឈប់ការធ្វើទីបន្ទាល់ពីអ្វីដែលបានកើតដល់លោកនិងមិនដែលសម្រាក
របៀបផ្សេងទៀតនៃការបកប្រែ: «សូមឲ្យមនុស្សគ្រប់គ្នាឮ
ពីអ្វីដែលបានកើតឡើងចំពោះខ្ញុំ»
មើល
លោកយ៉ូបប្រើពាក្យនេះ
ដើម្បីទាញចំណាប់អារម្មណ៍លើអ្វីដែលលោកនឹងនិយាយនៅពេលបន្ទាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្តាប់»
ទីបន្ទាល់របស់ខ្ញុំនៅលើស្ថានសួគ៌
លោកយ៉ូប ជឿជាក់ថានរណាម្នាក់នឹងទូលថ្វាយដល់ព្រះសម្រាប់គាត់។
ធានា
«ទីបន្ទាល់»
ស្ថានដ៏ខ្ពស់
នេះជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅស្ថានសួគ៌» ឬ
«នៅស្ថានដ៏ខ្ពស់»
Job 16:20
សើចចំអក
«មើលងាយ» ឬ «ចំអក»
ខ្ញុំសម្រកទឹកភ្នែក
លោកយ៉ូបពណ៌នាថាលោកមានអារម្មណ៍រងទុក្ខខ្លាំងយ៉ាងណា។
នៅទីនេះលោកបន្ថែម ថាតើលោកបានយំញឹកញាប់យ៉ាងណា ដោយនិយាយថា
ទឹកភ្នែកបានហូរពីភ្នែករបស់លោកមក។ របៀបផ្សេងទៀតនៃការបកប្រែ:
«ភ្នែករបស់ខ្ញុំពេញទៅដោយទឹកភ្នែក ខណៈពេលដែលខ្ញុំយំចេញមក»
សម្រាប់អ្នកនេះ
នៅទីនេះលោកយ៉ូបសំដៅដល់ខ្លួនរបស់លោកក្នុងតួអង្គបុរសទីបី។ «សម្រាប់ខ្ញុំ»
ដូចជាមនុស្សម្នាក់បានធ្វើជាមួយអ្នកជិតខាងរបស់គេដែរ
«ដូចជាមនុស្សម្នាក់បានធ្វើសម្រាប់អ្នកជិតខាងរបស់គេ»។ លោកយ៉ូបពណ៌នា

generated on Wed Sep 10 16:16:32 2025

អំពីរបៀបដែលគាត់ចង់នរណាម្នាក់នៅស្ថានសួគ៌ជជែកតវ៉ាសម្រាប់គាត់។
អ្នកនេះ
លោកយ៉ូបសំដៅលើខ្លួនរបស់គាត់

ខ្ញុំនឹងទៅកន្លែង
នៅទីនេះលោកយ៉ូបកំពុងសំដៅលើការស្លាប់នៃខ្លួនរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំនឹងស្លាប់ ហើយទៅកាន់កន្លែងមួយ»

---

17 [1]វិញ្ញាណខ្ញុំខ្ទេចខ្ទាំអស់ហើយ អាយុរបស់ខ្ញុំក៏បញ្ចាប់ដែរ ផ្នូរត្រៀមរួចសម្រាប់ខ្ញុំ។[2]នៅជុំវិញខ្ញុំមានសុទ្ធតែមនុស្សឡកឡឺយ ហើយភ្នែកខ្ញុំត្រូវមើលសេចក្ដីចាក់រុក របស់គេជានិច្ច។[3]សូមព្រះអង្គប្រោសមេត្តា ធានាឲ្យទូលបង្គំ ចំពោះព្រះអង្គផង បើពុំនោះ តើមានអ្នកណានឹងចាប់ដៃ យល់ព្រមនឹងទូលបង្គំបាន?
[4]ព្រះជាម្ចាស់ ដ្បិតព្រះអង្គបានបង្ខាំងចិត្តគេចេញពីយោបល់ ហេតុនោះ ព្រះអង្គនឹងមិនតម្កើងគេនៅចំពោះទូលបង្គំឡើយ។[5]គេលួងលោមមិត្តសម្លាញ់ខ្លួន ឲ្យតែបានទ្រព្យសម្បត្តិ ហើយភ្នែករបស់កូនគេកាន់តែងងឹត។
[6]ប៉ុន្តែ ព្រះអង្គបានធ្វើឲ្យខ្ញុំទៅជាសេចក្ដីប្រៀបធៀបដល់មនុស្ស ហើយគេស្តោះដាក់ចំមុខខ្ញុំ។[7]ភ្នែកខ្ញុំក៏ស្រវាំង ដោយសេចក្ដីទុក្ខព្រួយ ហើយអវយវៈរូបកាយខ្ញុំទាំងអស់ ទុកដូចជាស្រមោលទទេ។[8]មនុស្សទៀងត្រង់នឹងមានសេចក្ដីអស្ចារ្យ ពីដំណើរនេះហើយមនុស្សផ្ទរផង់ គេនឹងលើកគ្នា ទាស់នឹងមនុស្សទមិឡល្មើស។
[9]ចំណែកអ្នកសុចរិត គេនឹងព្យាយាមក្នុងផ្លូវគេ ហើយអ្នកណាដែលមានដៃស្អាត អ្នកនោះនឹងមានកម្លាំងកាន់តែខ្លាំងឡើង។[10]ចំណែកអ្នករាល់គ្នា សូមអញ្ជើញមកវិញ តែក្នុងពួកអ្នករាល់គ្នា ខ្ញុំមិនឃើញអ្នកណាមួយ ដែលមានប្រាជ្ញាឡើយ។
[11]អស់ទាំងថ្ងៃអាយុខ្ញុំបានកន្លងហួសទៅ គម្រោងការរបស់ខ្ញុំត្រូវរលាយ គឺអស់ទាំងបំណងរបស់ខ្ញុំបានកាត់ផ្តាច់ហើយ។[12]ពួកឡកលើយ ធ្វើឲ្យយប់ទៅជាថ្ងៃ ពន្លឺនៅក្បែរងងឹតដែរ។
[13]ចាប់តាំងពីខ្ញុំបានសម្លឹងមើល ស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយខ្ញុំបានធ្វើឲ្យគ្រែធំនៅទីងងឹត[14]គ្រាខ្ញុំពោលដល់ផ្នូរថា ឯងជាឪពុកខ្ញុំ ហើយពោលទៅដង្កូវថា ឯងជាម្តាយ ឬជាបងប្អូនស្រីរបស់ខ្ញុំ[15]តើសេចក្ដីសង្ឃឹមរបស់ខ្ញុំនៅឯណា? តើមានអ្នកណាឃើញសេចក្ដីសង្ឃឹមរបស់ខ្ញុំទេ? តើវានឹងចុះទៅឯទ្វារ នៃស្ថានឃុំព្រលឹងមនុស្សស្លាប់?[16]តើយើងនឹងចុះទៅជាមួយគ្នា ចូលក្នុងធូលីដីឬ?»

Job 17:1
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
វិញ្ញាណរបស់ខ្ញុំខ្ទេចខ្ទាំ
លោកយ៉ូបសំដៅដល់ខ្លួនរបស់លោកដោយ «វិញ្ញាណ» របស់លោក
ដើម្បីបញ្ជាក់ការលើកទឹកចិត្តផ្នែកខាងក្នុងរបស់លោក។
លោកនិយាយអំពីការមិនមានកម្លាំង នៅសេសសល់ ដែលហាក់ដូចជា
លោកជារបស់អ្វីមួយដែលត្រូវបានប្រើប្រាស់អស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំត្រូវបានប្រើអស់» ឬ «កម្លាំងរបស់ខ្ញុំត្រូវបានបាត់អស់»
ថ្ងៃរបស់ខ្ញុំក៏ចប់ហើយដែរ
លោកយ៉ូបសំដៅដល់ជីវិតរបស់គាត់ ដូចជា «ថ្ងៃ» របស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលវេលារបស់ខ្ញុំចប់ហើយ» ឬ
«ខ្ញុំនឹងស្លាប់ក្នុងពេលឆាប់ៗនេះ»
ផ្នូរបានត្រៀមជាសម្រេចសម្រាប់ខ្ញុំ
ឃ្លានេះពណ៌នា «ផ្នូរ» វាហាក់ដូចជាមនុស្សដែលនឹងទទួលលោកយ៉ូបជាភ្ញៀវ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឆាប់ៗនេះខ្ញុំនឹងស្លាប់ហើយនឹងត្រូវកប់»
ប្រាកដណាស់ ពួកមនុស្សឡកឡឺយនៅជាមួយខ្ញុំ
«អស់អ្នកដែលនៅជុំវិញខ្ញុំកំពុងឡកឡឺយឲ្យខ្ញុំ»
ប្រាកដណាស់
«ជាការពិត»
ភ្នែកខ្ញុំតែងតែមើលឃើញ
លោកយ៉ូបសំដៅដល់ខ្លួនរបស់លោក ដោយសារ «ភ្នែក» របស់លោក
ដើម្បីបញ្ជាក់ពីអ្វីដែលលោកឃើញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំតែងតែឃើញ» ឬ «ខ្ញុំតែងតែឮ»
ការរករឿងរបស់គេ
«ការមើលងាយរបស់គេ»។ ពាក្យ «ការរករឿង»
អាចត្រូវបានបង្ហាញជាកិរិយាសព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេកំពុងរករឿងទូលបង្គំ» ឬ «ពួកគេកំពុងព្យាយាមធ្វើឲ្យទូលបង្គំខឹង»
សូមសន្យា សូមធានាឲ្យទូលបង្គំចំពោះព្រះអង្គផង
លោកយ៉ូបចាប់ផ្តើមនិយាយទៅកាន់ព្រះ។
នៅទីនេះលោកនិយាយពីស្ថានភាពរបស់លោកដូចជាលោកជាអ្នកទោស។
លោកបានទូលសូមឲ្យព្រះប្រទាននូវសេចក្ដីសន្យា ដូច្នេះ
លោកអាចត្រូវបានដោះលែង។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គអើយ
សូមសន្យា ដូច្នេះ ទូលបង្គំអាចត្រូវបានដោះលែងពីគុកនេះ» ឬ
«សូមបង់សម្រាប់ការដោះលែងរបស់ទូលបង្គំពីគុកនេះផង»
តើមានអ្នកណានឹងជួយដល់ទូលបង្គំបាន?
លោកយ៉ូបប្រើសំណួរដែលមិនទាមទារចម្លើយនេះ
ដើម្បីសង្កត់ធ្ងន់ថាមិនមាននរណាម្នាក់ជួយលោកនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សំណួរនេះអាចត្រូវបានសរសេរដូចជារបាយការណ៍។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនមាននរណាម្នាក់នឹងជួយខ្ញុំទេ»
Job 17:4
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
បានបង្ខាំងចិត្តរបស់ពួកគេ
ពាក្យ «របស់ពួកគេ» សំដៅដល់មិត្តៗរបស់លោក។ ពួកគេបានសំដៅដល់ «ចិត្ត»
របស់ពួកគេ ដើម្បីបញ្ជាក់ការរំជួលចិត្តរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានបង្ខាំងពួកគេ» ឬ «បានបង្ខាំងមិត្តរបស់ខ្ញុំ»។
បានជាព្រះអង្គនឹងមិនតម្កើងគេនៅចំពោះទូលបង្គំឡើយ
«ព្រះអង្គមិនបានអនុញ្ញាតឲ្យពួកគេមានជ័យជម្នះនៅចំពោះទូលបង្គំឡើយ»
អស់អ្នក
«គ្រប់គ្នា»
ដែលផ្តន្ទាទោសមិត្តសម្លាញ់របស់ខ្លួន ដើម្បីឲ្យបានរង្វាន់
«ចោទប្រកាន់ការមិនពិតមិត្តរបស់គេដើម្បីទទួលបានផលប្រយោជន៍» ឬ
«ក្បត់មិត្តរបស់ខ្លួនដើម្បីទទួលបានរង្វាន់»
ហើយភ្នែករបស់កូនគេនឹងងងឹតទៅ
កូនរបស់មនុស្ស នៅទីនេះបានសំដៅដល់ «ភ្នែក» របស់ពួកគេ។
ឃ្លានេះពណ៌នាអំពីសេចក្ដីវេទនារបស់កូនចៅពីព្រោះតែអ្វីដែលឪពុក
ឬម្តាយរស់ពួកគេបានធ្វើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«កូនចៅរបស់ពួកគេនឹងទទួលសេចក្ដីវេទនាសម្រាប់វា»
Job 17:6
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
ព្រះអង្គបានធ្វើឲ្យខ្ញុំទៅជាពាក្យស្លោកសម្រាប់មនុស្សម្នារ
នេះមានន័យថា មនុស្សម្នារនិយាយអំពីលោកក្នុងបែបមើលងាយ
និងប្រើឈ្មោះរបស់លោកដូចជាការជេរប្រមាថ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រោះតែទ្រង់ មនុស្សម្នារបានប្រើឈ្មោះរបស់ខ្ញុំដូចជាការជេរប្រមាថ» ឬ
«ដោយសារតែពួកគេ មនុស្សម្នារបានប្រើឈ្មោះរបស់ខ្ញុំដូចជាពាក្យស្លោក»
ពួកគេបានស្តោះទឹកមាត់ដាក់មុខរបស់ខ្ញុំ
«មនុស្សម្នារបានស្តោះទឹកមាត់ដាក់មុខរបស់ខ្ញុំ»។ ក្នុងវប្បធ៌មនេះ
ការស្តោះទឹកមាត់ដាក់នរណាម្នាក់ជាការមាក់ងាយយ៉ាងខ្លាំង។
ប្រសិនបើការស្តោះទឹកមាត់មានភាពខុសគ្នា មានន័យថាក្នុងវប្បធ៌មរបស់អ្នក
អ្នកអាចសរសេរភាពខុសគ្នានេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សបានមាក់ងាយខ្ញុំយ៉ាងខ្លាំង ដោយការស្តោះទឹកមាត់ដាក់មុខរបស់ខ្ញុំ»
ភ្នែកខ្ញុំក៏ស្រអាប់ដោយសារសេចក្ដីទុក្ខព្រួយ
លោកយ៉ូបនិយាយពីចក្ខុវិស័យរបស់លោកដូចជា «ភ្នែក» របស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ចក្ខុវិស័យ» របស់ខ្ញុំបានទៅជាខ្សោយ
ព្រោះតែខ្ញុំមានសេចក្ដីទុក្ខព្រួយ» ឬ «ខ្ញុំស្ទើរតែខ្វាក់ព្រោះតែទុក្ខព្រួយរបស់ខ្ញុំ»
ហើយអវយវៈរូបកាយរបស់ខ្ញុំទាំងអស់ស្គមដូចជាស្រមោល
ស្រមោលមិនមានភាពស្គម និងក៏មិនអាចកំណត់ភាពស្តើងបានដែរ។

generated on Wed Sep 10 16:16:32 2025

នោះជាការបញ្ជាក់បន្ថែមថា តើរាង្គកាយរបស់លោកយ៉ូបស្គមដល់កម្រិតណា។
របៀបផ្សេងទៀតនៃការបកប្រែ: «អវយវៈរូបកាយរបស់ខ្ញុំទាំងអស់ស្គម»
អវយវៈរូបកាយរបស់ខ្ញុំទាំងអស់
នេះជាការសរុបដែលត្រូវបានប្រើដើម្បីបញ្ជាក់ថារូបកាយទាំងមូលរបស់លោកគឺស្គម ប៉ុន្តែ សំដៅជាពិសេសទៅលើដៃ និងជើងរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ដៃនិងជើងរបស់ខ្ញុំ»
ភ្ជាក់ផ្អើល
«ត្រូវបានធ្វើឲ្យតក់ស្លុត» ឬ «ដែលត្រូវបានធ្វើឲ្យរន្ធត់»
ពីដំណើរនេះ
«ដោយអ្វីដែលបានកើតឡើងចំពោះខ្ញុំ»
ហើយស្លូតត្រង់នឹងលើកខ្លួនគេ ទាស់នឹងមនុស្សទុច្ចរិត
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «នឹងធ្វើអោយឈឺចាប់» ឬ «នាងនាំខឹងយ៉ាងខ្លាំង»
Job 17:9
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
នឹងការពារផ្លូវរបស់ខ្លួន
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «នឹងបន្តរស់នៅក្នុងផ្លូវសុចរិត»
ហើយអស់អ្នកដែលមានដៃស្អាត
នេះនិយាយពីមនុស្សដែលមិនមានបំណងអាក្រក់ដែលមានដៃស្អាត។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សដែលធ្វើអ្វីៗគឺត្រឹមត្រូវ» ឬ «មនុស្សអ្នកដែលគ្មានបំណងអាក្រក់»
នឹងមានកម្លាំងកាន់តែខ្លាំងឡើងៗ
នេះមិនមែនសំដៅត្រឹមតែដល់កម្លាំងខាងរូបកាយប៉ុណ្ណោះទេ ប៉ុន្តែ វាសំដៅដល់ទាំងកម្លាំងនៃអារម្មណ៍ និងទឹកចិត្តផងដែរ។
អស់លោកទាំងអស់គ្នា
លោកយ៉ូបកំពុងនិយាយទៅកាន់លោកអេលីផាស លោកប៊ីលដាដ និង លោកសូផារ។
សូមអញ្ជើញមកវិញ
លោកយ៉ូបអញ្ជើញមិត្រសម្លាញ់របស់លោកដើម្បីជជែកនូវអ្វីដែលលោកបាននិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមមកឥឡូវនេះ ជជែកជាមួយនឹងខ្ញុំម្តងទៀត»។
Job 17:11
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
ថ្ងៃរបស់ខ្ញុំបានកន្លងផុតទៅ
នេះជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «ពេលវេលារបស់ខ្ញុំបានកន្លងទៅ» ឬ «ជីវិតរបស់ខ្ញុំបានផុតទៅ»
ផែនការរបស់ខ្ញុំត្រូវបានវិនាស
«ផែនការរបស់ខ្ញុំនឹងមិនដែលបានសម្រេចទេ» ឬ «ផែនការរបស់ខ្ញុំនឹងមិនកើតមានទេ»
ហើយរួមទាំងបំណងរបស់ខ្ញុំដែរ
នៅទីនេះ «ចិត្ត» របស់លោកយ៉ូប សំដៅដល់បំណងប្រាថ្នាដ៏ធំរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាសម្រាប់អ្វីៗដែលខ្ញុំមានបំណងប្រាថ្នាយ៉ាងធំ»
បំណងរបស់ខ្ញុំ
នៅទីនេះលោកយ៉ូបមិនបានបំពេញប្រយោគរបស់លោកដើម្បីបង្ហាញថា លោកមិនមានសេចក្តីសង្ឃឹមទៀតនោះទេសម្រាប់បំណងប្រាថ្នារបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ចិត្តរបស់ខ្ញុំ
មិនមានផ្ទះសម្រាប់ឲ្យពួកគេកើតឡើងនោះទេ»
អ្នកទាំងនេះ ពួកមនុស្សមើលងាយ
ឃ្លាទាំងពីរនេះសំដៅលើមនុស្សប្រភេទដូចគ្នា គឺមិត្តៗរបស់លោកយ៉ូប លោកអេលីផាស លោកប៊ីលដាដ និង លោកសូផារ។
ឃ្លាទីពីរសង្កត់ធ្ងន់លោកអាកប្បកិរិយាមិនមែនជាកល្យាមិត្តរបស់ពួកគេ។
បានប្តូរពីយប់ទៅជាថ្ងៃវិញ
ុនេះនិយាយពីការទាមទាររបស់មនុស្សថាយប់គឺជាពេលថ្ងៃ
ហាក់ដូចជាពួកគេពិតជាបានផ្លាស់ប្តូរយប់ទៅជាថ្ងៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេតវ៉ាថា វាគឺជាពេលថ្ងៃ
នៅពេលដែលមានពេលយប់» ឬ «អ្វីដែលពួកគេនិយាយគឺផ្ទុយពីអ្វីដែលជាការពិត
ដូចជាយប់ផ្ទុយជាមួយនឹងថ្ងៃ»
ពន្លឺក៏ជិតងងឹតដែរ
ពាក្យដែកបាត់គួរត្រូវបន្ថែម។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេតវ៉ាថា
ពន្លឺគឺជិតយប់ហើយ» ឬ «ពួកគេតវ៉ាថានៅពេលដែលភាពងងឹតមកដល់
នោះវាគឺទទួលពន្លឺ»
Job 17:13
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
ខ្ញុំបានសម្លឹងមើលស្ថានឃុំព្រលឹងមនុស្សស្លាប់ ដូចជាផ្ទះមនុស្សស្លាប
ពាក្យ «សម្លឹងមើល» អ្វីមួយជាវិធីជាក់លាក់មួយមានន័យសំដៅដល់ «គិត»
នៃវិធីនោះ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំគិតថាស្ថានឃុំព្រលឹងមនុស្សស្លាប់
ដូចជាផ្ទះរបស់ខ្ញុំ» ឬ «ឥឡូវខ្ញុំគិតថាស្ថានឃុំព្រលឹងមនុស្សស្លាប់ជាផ្ទះរបស់ខ្ញុំ»
បានលាតត្រែតម្រែតរបស់ខ្ញុំនៅទីងងឹត
នៅទីនេះលោកយ៉ូបនិយាយពីការត្រូវបានរៀបចំឡើងសម្រាប់សេចក្តីស្លាប់
ដូចជាការលាតត្រែរបស់គាត់នៅក្នុងភាពងងឹត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ត្រូវបានរៀបចំខ្លួនរបស់ខ្ញុំដើម្បីទៅហើយដេកក្នុងចំណោមមនុស្សស្លាប»
បានលាតត្រែតម្រែតរបស់ខ្ញុំ
«បានរៀបចំគ្រែរបស់ខ្ញុំ»
ខ្ញុំបាននិយាយទៅកាន់រណ្តៅ...ហើយនិយាយទៅដង្កូវ
ប្រយោគទាំងពីរនេះបម្រែបម្រួលគ្នាទៅវិញទៅមក ហើយ
ត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ថាតើ លោកយ៉ូបអស់សង្ឃឹមយ៉ាងណា។
កាន់រណ្តៅ
ផ្នូរខ្មាច
ឯងជាឪពុកខ្ញុំ
លោកយ៉ូបនិយាយអំពីភាពជិតស្និទ្ធដែលលោកនឹងមានជាមួយផ្នូររបស់គាត់ឆាប់
ដោយប្រៀបធៀបមនុស្សជិតស្និទ្ធម្នាក់ដែលមានជាមួយឪពុករបស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកគឺជិតស្និទ្ធនឹងខ្ញុំ ដូចជាឪពុករបស់ខ្ញុំ» ឬ
«នៅពេលដែលខ្ញុំត្រូវបានកប់ អ្នកនឹងស្និទ្ធស្នាលនឹងខ្ញុំដូចជាឪពុក»
ដង្កូវ
«ដង្កូវ»។ ពពួកដង្កូវជាសត្វលោកតូចៗដែលស៊ីសាកសព។
ឯងជាម្តាយ ឬជាបងប្អូនស្រីរបស់ខ្ញុំ
លោកយ៉ូបនិយាយអំពីភាពជិតស្និទ្ធដែលលោកនឹងមានជាមួយផ្នូររបស់គាត់ឆាប់
ដោយប្រៀបធៀបមនុស្សជិតស្និទ្ធម្នាក់ដែលមានជាមួយម្តាយនិងបងប្អូនស្រីរបស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកគឺជិតស្និទ្ធនឹងខ្ញុំ
ដូចជាម្តាយនិងបងប្អូនស្រីរបស់ខ្ញុំ» ឬ
«អ្នកនឹងស្និទ្ធស្នាលនឹងខ្ញុំដូចជាម្តាយនិងបងប្អូនស្រី»
តើសេចក្តីសង្ឃឹមរបស់ខ្ញុំនៅឯណា?
ចម្លើយជាក់ស្តែងគឺ «គ្មានទេ» ពីព្រោះលោកគ្មានជំនឿ។
សំណួរដែលមិនទាមទារចម្លើយនេះ អាចសរសេរជាប្រយោគបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំគ្មានជំនឿទេ»
ដ្បិត សេចក្តីសង្ឃឹមរបស់ខ្ញុំ តើមានអ្នកណាឃើញទេ?
សំនួរដែលមិនទាមទារចម្លើយនេះត្រូវបានប្រើដើម្បីបញ្ជាក់ថាមិនមានអ្នកណាម្នាក់រំពឹងថាគាត់មានសង្ឃឹម
សំណួរនេះ អាចត្រូវបានសរសេរជាប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានអ្នកណាអាចឃើញក្តីសង្ឃឹមរបស់ខ្ញុំនោះទេ» ឬ
«គ្មានអ្នកណារំពឹងថាខ្ញុំមានក្តីសង្ឃឹមទៀតនោះទេ»

---

18 [1]បន្ទាប់មក ប៊ីលដាឌ ជនជាតិស៊ូអា ក៏ឆ្លើយឡើងថា៖[2]«តើអ្នករាល់គ្នានឹងនៅតែ និយាយដល់កាលណាទៀត? ចូរពិចារណាចុះ រួចយើងនឹងនិយាយ។
[3]ហេតុអ្វីបានជាយើងត្រូវរាប់ទុក ដូចជាសត្វតិរច្ឆាន ហេតុអ្វីបានជាយើងទៅជាមនុស្សល្ងីល្ងើ នៅក្នុងភ្នែករបស់អ្នក?[4]អ្នកដែលហែកហួរខ្លួនដោយសេចក្តីកំហឹង តើផែនដីត្រូវចោលស្ងាត់ដោយព្រោះអ្នក ឬថ្មត្រូវរើចេញពីកន្លែងរបស់វាឬ?
[5]ពន្លឺនៃមនុស្សអាក្រក់នឹងរលត់ទៅ ហើយរងើកភ្លើងរបស់គេនឹងលែងភ្លឺ។[6]ពន្លឺនៅក្នុងទីលំនៅគេនឹងត្រូវងងឹតវិញ ហើយចង្កៀងនៅពីលើគេនឹងរលត់ទៅ។
[7]អស់ទាំងជំហាននៃកម្លាំងគេនឹងកាន់តែអន់ថយ ហើយផែនការរបស់គេនឹងផ្តួលគេផងដែរ។[8]ដ្បិតជើងខ្លួនគេនាំឲ្យគេជាប់សំណាញ់ គេដើរទៅរកអន្ទាក់ជានិច្ច។

generated on Wed Sep 10 16:16:32 2025

[9]អន្ទាក់នឹងរួតជាប់កែងជើងគេ ហើយអន្ទាក់សាងនឹងវាត់ឡើងជាប់គេ។[10]មានខ្សែរួតបង្កប់ក្នុងដីសម្រាប់ចាប់គេ ហើយមានអង្គប់រង់ចាំគេនៅផ្លូវ។[11]សេចក្តីស្ញែងខ្លាចនឹងបំភ័យគេនៅគ្រប់ទិស ហើយនឹងដេញតាមប្រកិតនៅកែងជើងគេ។
[12]ទ្រព្យរបស់គេទៅជាការអត់ឃ្លាន ហើយសេចក្តីអន្តរាយនឹងប្រុងប្រៀប ជាស្រេចនៅខាងគេ។[13]ជំងឺរោគាបានបំផ្លាញស្បែករបស់គេអស់ ហើយសេចក្តីស្លាប់ក៏លេបត្រាប់ដៃជើងរបស់គេដែរ។
[14]គេនឹងត្រូវរលើងចេញពីទីលំនៅ ដែលបានយកជាទីពឹង ហើយនឹងត្រូវនាំទៅចំពោះស្តេច នៃសេចក្តីស្ញែងខ្លាច។[15]មនុស្សក្រៅវង្សត្រកូលរបស់គេ នឹងមកនៅក្នុងទីលំនៅគេវិញ ហើយនឹងមានស្ពាន់ធ័ររោយចុះមកលើ ទីអាស្រ័យរបស់គេ។
[16]ឫសគេនឹងត្រូវក្រៀមស្ងួតទៅ ហើយខាងលើមែករបស់គេនឹងត្រូវកាច់ចេញ។[17]ទាំងសេចក្តីនឹកចាំពីគេ នឹងសូន្យបាត់ពីផែនដីទៅ ហើយនឹងលែងឮនិយាយ ពីឈ្មោះគេតាមផ្លូវតទៅ។
[18]គេនឹងត្រូវដេញចេញពីពន្លឺទៅក្នុងទីងងឹត ហើយត្រូវប្រដេញចេញពីលោកីយផង។[19]គេនឹងគ្មានកូន ឬចៅក្នុងវង្សត្រកូលរបស់គេ ឬអ្នកណានៅសល់ក្នុងកន្លែង ដែលគេអាស្រ័យនោះឡើយ។[20]ពួកជំនាន់ក្រោយនឹងមានសេចក្តីអស្ចារ្យ ពីប្រវត្តិរបស់គេ ដូចជាជំនាន់មុនបានភ័យខ្លាចដែរ។
[21]ជាការពិតណាស់ ផ្ទះរបស់មនុស្សអាក្រក់ នេះហើយជាកន្លែងរបស់អ្នក ដែលមិនស្គាល់ព្រះជាម្ចាស់»។

Job 18:1
ព័ត៌មានទូទៅ:
មើល: និង
ព័ត៌មានទូទៅ:
លោកប៊ីលដាឌ ជនជាតិស៊ូអា គឺកំពុងនិយាយទៅកាន់លោកយ៉ូប។
លោកប៊ីលដាឌ ជនជាតិស៊ូអា បានឆ្លើយហើយនិយាយ
លោកប៊ីលដាឌ គឺជាឈ្មោះរបស់បុរសម្នាក់ដែលជាសមាជិកនៃកុលសម្ព័ន្ធស៊ូអា។
សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៨:១ ។
តើពេលណាទើបអ្នកបញ្ឈប់ការនិយាយអ្នក?
សំណួរដែលមិនទាមទារចម្លើយនេះមានន័យថា
លោកយ៉ូបបាននិយាយយូរពេកហើយ។ ឃ្លានេះអាចសសេរជាប្រយោគ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់និយាយ!»
ចូរពិចារណា
«ចូរមានហេតុផល» ឬ «ចូរគិតអំពីកិច្ចការអស់ទាំងនេះ»
Job 18:3
ព័ត៌មានទូទៅ:
លោកប៊ីលដាឌបន្តនិយាយទៅកាន់លោកយ៉ូប។
ហេតុអ្វីបានជាយើងត្រូវចាត់ទុក ដូចជាសត្វតិរច្ឆាន
លោកប៊ីលដាឌ ប្រើសំណួរដែលមិនទាមទារចម្លើយនេះ ដើម្បីបញ្ជាក់ថាលោកយ៉ូបគាត់មិនគួរចាត់ទុកជាមនុស្សល្ងង់ទេ។
គាត់និយាយពីពួកគេដែលចាត់ទុកជាមនុស្សល្ងង់ដោយហៅថាជាសត្វ «តិរិច្ឆាន»។
សំណួរនេះត្រូវបានសសេរជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនគួរគិតថាយើងជាសត្វតិរច្ឆាននោះទេ» ឬ
«អ្នកមិនគួរគិតថាយើងជាមនុស្សល្ងង់ដូចជាសត្វនោះទេ»
Job 18:5
ព័ត៌មានទូទៅ:
លោកប៊ីលដាឌបន្តនិយាយទៅកាន់លោកយ៉ូប។
ជាការពិត ពន្លឺនៃមនុស្សអាក្រក់នឹងរលត់បាត់ទៅ ហើយរងើកភ្លើងរបស់ពួកគេនឹងមិនអាចភ្លឺដែរ
លោកប៊ីលដាឌនិយាយអំពីការស្លាប់មនុស្សអាក្រក់ដូចជាចង្កៀងរបស់គេដែលចាប់ផ្តើមរលត់ទៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «តើនឹងមានអ្វីកើតឡើង
គឺថាជីវិតរបស់មនុស្សអាក្រក់ដូចជាអ្នកបានបញ្ឈប់យ៉ាងលឿន
ដូចជាយើងអាចពន្លត់ភ្លើង ឬ ពន្លត់អណ្តាតភ្លើង»
នឹងរលត់បាត់ទៅ
ឃ្លានេះអាចបកប្រែក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងចេញទៅ»
ពន្លឺនឹងត្រូវងងឹតនៅក្នុងត្រសាលរបស់ពួកគេ ហើយចង្កៀងរបស់ពួកគេដែលនៅពីលើគេនឹងត្រូវរលត់ទៅដែរ
លោកប៊ីលដាឌ បន្តនិយាយអំពីការស្លាប់របស់មនុស្សអាក្រក់។
គាត់និយាយអំពីជីវិតរបស់មនុស្សអាក្រក់ដូចជាពន្លឺដែលនៅក្នុងត្រសាលរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «វានឹងដូចជាពន្លឺដែលនៅក្នុងត្រសាលរបស់ពួកគេ
ដែលនឹងត្រឡប់ទៅជាងងឹត ដូចជាចង្កៀងរបស់ពួកគេដែលរលត់ទៅ»
Job 18:7
ព័ត៌មានទូទៅ:
លោកប៊ីលដាឌបន្តពណ៌នាអំពីមនុស្សអាក្រក់។
គ្រប់ជំហានទាំងអស់នៃកម្លាំងរបស់គេនឹងធ្វើឲ្យខ្លី
នេះនិយាយពីការជួបប្រទះមហន្តរាយភ្លាមៗរបស់មនុស្សអាក្រក់
ដូចជាគាត់មិនមានកម្លាំងដើម្បីដើរទៀតនោះទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាដូចជាគាត់មិនមានកម្លាំងដើម្បីដើរទៀតនោះទេ»
ផែនការរបស់គេនឹងធ្វើឲ្យគេដួលចុះដែរ
«ដំបូន្មានរបស់គេនឹងធ្វើឲ្យគេដួលចុះដែរ»។
នេះនិយាយពីការទទួលមហន្តរាយរបស់មនុស្សអាក្រក់ ដូចជាការដួលចុះរបស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ផែនការរបស់គេនាំឲ្យគេចូលទៅក្នុងមហន្តរាយ»
ដ្បិត គេនឹងត្រូវបោះទៅក្នុងអន្ទាក់ដោយជើងគេខ្លួនឯង ហើយគេនឹងដើរទៅក្នុងរណ្តៅដែរ
«ជើងរបស់គេនឹងនាំគេទៅក្នុងអន្ទាក់»។ លោកប៊ីលដាដប្រើរូបភាពនេះដើម្បីនិយាយថាផ្លូវដែលមនុស្សអាក្រក់រស់នៅ
ជីវិតរបស់គេនឹងនាំគេទៅកាន់មហន្តរាយយ៉ាងឆាប់រហ័ស។
របៀបផ្សេងទៀតនៃការបកប្រែ:
«វានឹងដូចជាគាត់នាំខ្លួនរបស់គាត់ទៅក្នុងសំណាញ់មួយ
ដូចជាគាត់បានដើរសំដៅទឹកក្នុងរណ្តៅដែរ»។
សំណាញ់
ខ្សែ ឬខ្សែពួរដែលមនុស្សត្បាញរួមគ្នាដើម្បីធ្វើជាសំណាញ់។
មនុស្សបានប្រើសំណាញ់ដើម្បីចាប់សត្វចតុប្បាទ។
រណ្តៅ
រណ្តៅដែលមានមែកឈើ ឬស្លឹកឈើនៅពីលើវា ដូច្នេះ
សត្វចតុបាទនឹងដើរពីលើមែកឈើ ឬស្លឹកឈើនោះ ហើយធ្លាក់ចូលទៅក្នុងរណ្តៅ។
Job 18:9
ព័ត៌មានទូទៅ:
លោកប៊ីលដាដ បន្តនិយាយនិងប្រើរូបភាពស្របគ្នាបី ដើម្បីពណ៌នាថា
តើមនុស្សអាក្រក់នឹងជួបមហន្តរាយយ៉ាងឆាប់រហ័សយ៉ាងដូចម្តេច។
អង្គប់នឹងចាប់ជាប់កែងជើងគេ...អន្ទាក់នឹង... អន្ទាក់រួត...ហើយមានអង្គប់សម្រាប់គេនៅក្នុងផ្លូវ
ឃ្លាទាំងបួននេះនិយាយអំពីការជួបប្រទះមហន្តរាយរបស់មនុស្សអាក្រក់
ដូចជាគេត្រូវបានចាប់ជាប់ក្នុងអង្គប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«វានឹងដូចជាអង្គប់ដែលនឹងចាប់គេ... អន្ទាក់នឹង...ហើយអន្ទាក់រួតគឺ...
ហើយមានអង្គប់សម្រាប់គេក្នុងផ្លូវ»
អង្គប់
មនុស្សបានប្រើអង្គប់ប្រភេទនេះ ដើម្បីចាប់សត្វស្លាប។
អង្គប់បានបិតមាត់ហើយជួយចាប់ជើងរបស់សត្វ។
នឹងចាប់ជាប់កែងជើងគេ
នៅទីនេះពាក្យ «កែងជើង» សំដៅលើជើងទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងចាប់ចងជើងរបស់គេ»។
អន្ទាក់រួតមួយគឺបង្កប់សម្រាប់ចាប់គេនៅលើដី
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកណាម្នាក់បានលាក់អន្ទាក់រួតនៅក្នុងដី ដើម្បីចាប់គេ»
អន្ទាក់រួត
ជាខ្សែពួរដែលរៀបរាងជារង្វង់ដើម្បីទាក់ចងជើងសត្វ
នៅពេលដែលសត្វឈានជើងចូលទៅក្នុងកណ្តាលរង្វង់
ហើយមានអង្គប់សម្រាប់គេ
ពាក្យដែលខ្វះអាចត្រូវបានបន្ថែម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អន្ទាក់រួតដែលបានលាក់នៅតាមផ្លូវដើម្បីចាប់គេ» ឬ
«ហើយអ្នកណាម្នាក់នឹងលាក់អន្ទាក់រួតដើម្បីចាប់គេក្នុងផ្លូវ»
សេចក្តីរន្ធត់នឹងធ្វើឲ្យគេភ័យខ្លាចនៅគ្រប់ទិស
«សេចក្តីរន្ធត់នៅជុំវិញនឹងធ្វើឲ្យគេភ័យខ្លាច»

generated on Wed Sep 10 16:16:32 2025

ហើយការទាំងនោះនឹងដេញតាមកែងជើងរបស់គេ
ឃ្លានេះនិយាយនិយាយពីកិច្ចការដែលធ្វើឲ្យមនុស្សអាក្រក់ភ័យខ្លាច
ដូចជាពួកវាជាសត្រូវដែលដេញតាមគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សេចក្តីភ័យខ្លាចនឹងដេញតាមគេគ្រប់ទិស»
Job 18:12
ព័ត៌មានទូទៅ:
លោកប៊ីលដាឧបន្តពណ៌នាអំពីមនុស្សអាក្រក់។
ទ្រព្យរបស់គេនឹងត្រឡប់ទៅជាការអត់ឃ្លាន
ឃ្លានេះនិយាយពីមនុស្សអាក្រក់ដែលនឹងត្រឡប់ទៅជាក្រ និងអត់ឃ្លាន
ដូចជាគាត់បានធ្វើអ្វីមួយដែលធ្វើឲ្យទ្រព្យសម្បត្តិរបស់គាត់ត្រឡប់ទៅជាមិនមានអ្វីទាំងអស់
របៀបផ្សេងទៀតនៃការបកប្រែ: «ជំនួសឲ្យការមានសម្បត្តិ
គាត់នឹងទៅជាក្រហើយអត់ឃ្លាន»
ហើយសេចក្តីអន្តរាយនឹងត្រៀមជាស្រេចនៅខាងគេ
ឃ្លាថា «ជាស្រេចនៅខាងគេ» គឺជាគ្រាមភាសាដែលមានន័យថា
អ្វីមួយដែលបន្តមកដល់បច្ចុប្បន្ន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយគេនឹងបន្តជួបប្រទះមហន្តរាយ» ឬ
«ហើយគេនឹងជៀសពីគ្រោះមហន្តរាយមិនបានទេ»
ផ្នែកនៃរាងកាយរបស់គេនឹងត្រូវលេបត្របាក់
ឃ្លានេះនិយាយជាទម្រង់សកម្ម។
ឃ្លានេះក៏និយាយពីការបំផ្លាញរូបកាយរបស់គេនៃគ្រោះមហន្តរាយផងដែរ
ដែលដូចជាសត្វសាហាវដែលបានវាយប្រហារគេ ហើយបានស៊ីគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្រោះមហន្តរាយនឹងស៊ីស្បែករបស់គេអស់ទៅ» ឬ
«គ្រោះមហន្តរាយនឹងបំផ្លាញស្បែករបស់គេ»
កូនច្បងនៃសេចក្តីស្លាប់នឹងត្រូវលេបត្របាក់ផ្នែកនៃរាងកាយរបស់គេដរ
នៅទីនេះគ្រោះមហន្តរាយមួយដែលសម្លាប់មនុស្សជាច្រើន គឺសំដៅលើ
«កូនច្បងនៃសេចក្តីស្លាប់»។
ឃ្លានេះនិយាយពីគ្រោះមហន្តរាយដែលបំផ្លាញរូបកាយរបស់គេ
ដូចជាសត្វសាហាវដែលបានវាយប្រហារគេ និងបានស៊ីគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «សេចក្តីមហន្តរាយនៃសេចក្តីស្លាប់
នឹងបំផ្លាញផ្នែកផ្សេងៗគ្នានៃរូបកាយរបស់គាត់»
Job 18:14
ព័ត៌មានទូទៅ:
លោកប៊ីលដាឧបន្តពណ៌នាអំពីមនុស្សអាក្រក់។
គេនឹងត្រូវទាញចេញពីទីលំនៅ ដែលមានសុវត្ថិភាពរបស់គេ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រោះមហន្តរាយជ្រែកគេចេញទីលំនៅរបស់គេ ជាកន្លែងដែលមានសុវត្ថិភាព»
ហើយនឹងត្រូវនាំ
ឃ្លានេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយវានាំគាត់ទៅ» ឬ «វាបង្ខំគេឲ្យទៅ»
ស្តេចនៃសេចក្តីរន្ធត់
នេះគឺជាការសំដៅលើ «ស្តេចនៃសេចក្តីស្លាប់»
ពួកព្រះក្លែងក្លាយដែលបានជឿទៅលើសេចក្តីស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ម្នាក់ដែលគ្រប់គ្រងលើសេចក្តីស្លាប់»
មនុស្សផ្សេងដែលមិនមែនពួកគេ
«មនុស្សដែលមិនមែនជាគ្រួសាររបស់គេ»
បន្ទាប់ពីពួកគេបានឃើញស្ពាន់ធ័របានពង្រាយនៅក្នុងទីលំនៅរបស់គេ
មនុស្សបានស្ពាន់ធ័រ ដើម្បីកម្ចាត់មេរោគនានាពីសាកសព។
ឃ្លានេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពី
ពួកគេពង្រាយស្ពាន់ធ័រពេញក្នុងផ្ទះរបស់ពួកគេ»
Job 18:16
ព័ត៌មានទូទៅ:
លោកប៊ីលដាឧបន្តពណ៌នាអំពីមនុស្សអាក្រក់។
ឫសរបស់គេនឹងត្រូវក្រៀមស្ងួត...មែករបស់គេនឹងត្រូវកាច់ចោល
នេះនិយាយអំពីការស្លាប់របស់មនុស្សអាក្រក់ ហើយមិនមានជំនាន់ក្រោយ
គេដូចជាដើមបឈើដែលឫសបានក្រៀមស្វិតហើយមែកបានស្វិតទៅ
មិនបានបង្កើតផលផ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ: «គេនឹងស្លាប់
ហើយចាកចេញទៅដោយមិនមានកូនចៅជំនាន់ក្រោយ
គេនឹងដូចជាដើមឈើដែលមានឫសស្ងួត
ហើយដែលមែករបស់វាបានស្វិតអស់ទៅ»
ការចងចាំរបស់គេ នឹងវិនាសពីផែនដីទៅ ហើយគេនឹងមិនមានឈ្មោះនៅតាមផ្លូវដែរ
ឃ្លាទាំងនេះមានអត្ថន័យដូចគ្នា ហើយត្រូវបានប្រើដើម្បីបញ្ជាក់កាពិតថា
មិនមាននរណាម្នាក់នឹងចងចាំគេ បន្ទាប់ពីគេស្លាប់នោះទេ។
មែករបស់គេនឹងត្រូវកាច់ចោល
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មែករបស់គេនឹងស្វិត»
ការចងចាំរបស់គេ នឹងវិនាសពីផែនដីទៅ
ឃ្លានេះនិយាយអំពី «ការចងចាំ» របស់មនុស្សអាក្រក់
ដូចជាមនុស្សម្នាក់ដែលស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមាននរណាម្នាក់នៅលើផែនដីនឹងចងចាំពីគេនោះទេ»
គេនឹងមិនមានឈ្មោះនៅតាមផ្លូវដែរ
ឃ្លានេះជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមាននរណាម្នាក់ដែលដើរតាមផ្លូវនឹងនឹកចាំពីឈ្មោះរបស់គេទេ»
Job 18:18
ព័ត៌មានទូទៅ:
លោកប៊ីលដាឧបន្តពណ៌នាអំពីមនុស្សអាក្រក់។
អ្នកនោះនឹងត្រូវដេញចេញពីពន្លឺទៅក្នុងទីងងឹត ហើយត្រូវប្រដេញចេញពីលោកីយនេះផង
ឃ្លាទាំងនេះសង្កត់ធ្ងន់លើការពិតថា
មនុស្សអាក្រក់នឹងបញ្ជូនទៅស្ថានឃុំព្រលឹងមនុស្សស្លាប់
ជាកន្លែងសម្រាប់មនុស្សស្លាប់។
អ្នកនោះនឹងត្រូវបណ្តេញចេញពីពន្លឺទៅក្នុងទីងងឹត
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនឹងដឹកនាំមនុស្សអាក្រក់ពីពន្លឺទៅក្នុងទីងងឹត»។
ពីពន្លឺទៅក្នុងទីងងឹត
ពាក្យ «ពន្លឺ» សំដៅដល់ជីវិត ហើយពាក្យ «ទីងងឹត» សំដៅដល់សេចក្តីស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីពន្លឺនៃជីវិត ទៅកាន់ទីងងឹតនៃសេចក្តីស្លាប់»
ហើយត្រូវប្រដេញចេញពីលោកីយ៍នេះផង
នេះនិយាយពីការដែលព្រះធ្វើឲ្យគេចាកចេញពីលោកីយនេះ
ហើយទៅកន្លែងមនុស្សស្លាប់ ដូចជាទ្រង់បណ្តេញគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយព្រះនឹងធ្វើឲ្យគេចាកចេញពីលោកីយនេះ»
ឬ «ហើយព្រះនឹងបញ្ជូនគេទៅកន្លែងដែលសម្រាប់មនុស្សទៅ»
ហើយត្រូវប្រដេញចេញ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនឹងបណ្តេញគេចេញ»
អ្នកនោះនឹងគ្មានកូនប្រុស...ក៏គ្មាននៅសល់គ្រួសារនៅកន្លែងដែលអ្នកនោះអាស្រ័យនៅនោះដែរ
ឃ្លាទាំងពីរនេះបញ្ជាក់ថា គេនឹងគ្មានគ្រួសារ ឬ កូនចៅជំនាន់ក្រោយសេសសល់ទេ។
កូនចៅជាពូជពង្ស
«ចៅប្រុស» ឬ «ចៅតួត»
គ្រួសារ
«សាច់ញាតិ»
ពួកអ្នកដែលរស់នៅខាងលិច...ហើយអ្នកដែលរស់នៅខាងកើតនឹងត្រូវភ័យខ្លាចដោយការនេះដែរ
ឃ្លា «នៅខាងលិច» និង «នៅខាងកើត»
គឺរួមគ្នាសំដៅដល់មនុស្សទាំងអស់ដែលរស់នៅគ្រប់ទីកន្លែង។ នេះជាការបន្ថែម
ដែលមិនមែនគ្រប់មនុស្សទាំងអស់នៅលើលោកីយនេះនឹងឮពីអ្វីដែលបានកើតឡើងចំពោះមនុស្សអាក្រក់
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សទាំងអស់នៅលើផែនដីទាំងមូលនឹងភ័យខ្លាច និងតក់ស្លុតជាខ្លាំង
នៅពេលដែលពួកគេបានឃើញអ្វីដែលបានកើតឡើងចំពោះមនុស្សអាក្រក់» ឬ
«មនុស្សជាច្រើនដែលរស់នៅទិសខាងកើតនិងខាងលិច នឹងភ័យខ្លាច
ហើយតក់ស្លុតជាខ្លាំង
នៅពេលដែលពួកគេបានឃើញអ្វីដែលបានកើតឡើងចំពោះមនុស្សអាក្រក់
ថ្ងៃមួយ
«ថ្ងៃណាមួយ»
Job 18:21
ព័ត៌មានទូទៅ:
លោកប៊ីលដាឧបន្តពណ៌នាអំពីមនុស្សអាក្រក់។
ផ្ទះទាំងឡាយ ណារបស់មនុស្សទុច្ចរិត ហើយកន្លែងរបស់អ្នកណាដែលមិនស្គាល់ព្រះជាម្ចាស់
ឃ្លាទាំងពីនេះ មានអត្ថន័យដូចគ្នា ហើយសំដៅដល់មនុស្សដូចគ្នា។
នៅទីនេះមនុស្សទាំងនេះសំដៅដល់ដោយទីកន្លែងដែលពួកគេរស់នៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សទុច្ចរិត ដែលមិនស្គាល់ព្រះជាម្ចាស់»

generated on Wed Sep 10 16:16:32 2025

19 [1]ពេលនោះ លោកយ៉ូបឆ្លើយថា៖[2]«តើអ្នករាល់គ្នាធ្វើទុក្ខដល់ខ្ញុំ ហើយជាន់ឈ្លីខ្ញុំដោយពាក្យសម្ដី ដល់កាលណាទៀត?
[3]មានដប់ដងហើយ ដែលអ្នករាល់គ្នាបានដៀលត្មះខ្ញុំ អ្នករាល់គ្នាមិនមានសេចក្ដីខ្មាសសោះ ដែលធ្វើបាបខ្ញុំ។[4]ប្រសិនបើខ្ញុំបានធ្វើខុសមែន កំហុសនោះនៅជាប់តែខ្លួនខ្ញុំទេ។
[5]ប្រសិនបើអ្នករាល់គ្នាចង់តម្កើងខ្លួន ឲ្យខ្ពស់ពីខ្ញុំ ហើយជជែកយកខុសត្រូវ ដើម្បីនឹងទាស់នឹងខ្ញុំ[6]ត្រូវដឹងថា គឺព្រះជាម្ចាស់ដែលបានផ្តួលខ្ញុំ ហើយបានព័ទ្ធខ្ញុំជុំវិញ ដោយសំណាញ់របស់ព្រះអង្គដែរ។
[7]មើល! ពេលខ្ញុំស្រែកថា "គេធ្វើបាបខ្ញុំហើយ" គ្មានអ្នកឆ្លើយសោះ។ ខ្ញុំស្រែករកជំនួយ តែគ្មានអ្នករកយុត្តិធម៌ឲ្យខ្ញុំឡើយ។[8]ព្រះអង្គបានធ្វើរបងរាំងផ្លូវខ្ញុំ មិនឲ្យទៅណាបាន ក៏បានធ្វើឲ្យផ្លូវច្រករបស់ខ្ញុំប្រែជាងងឹត។[9]ព្រះអង្គបានដោះកេរ្តិ៍ឈ្មោះខ្ញុំចេញ ព្រមទាំងយកមកុដចេញពីក្បាលខ្ញុំផង។
[10]ព្រះអង្គបានបំផ្លាញខ្ញុំគ្រប់ទិស ហើយខ្ញុំកំពុងតែវិនាសទៅ ឯសេចក្ដីសង្ឃឹមរបស់ខ្ញុំ ព្រះអង្គបានរំលើង ដូចជាដើមឈើ។[11]ព្រះអង្គបានបង្កាត់សេចក្ដីក្រោធ របស់ព្រះអង្គទាស់នឹងខ្ញុំ ក៏រាប់ខ្ញុំ ទុកដូចជាសត្រូវនឹងព្រះអង្គ។[12]ពលទ័ពរបស់ព្រះអង្គចូលមកព្រមៗគ្នា ហើយលើកផ្លូវឡើងមកទាស់នឹងខ្ញុំ ក៏បោះទ័ពព័ទ្ធជុំវិញទីលំនៅរបស់ខ្ញុំដែរ។
[13]ព្រះអង្គបានញែកពួកបងប្អូនខ្ញុំចេញឆ្ងាយពីខ្ញុំ ហើយពួកអ្នកដែលខ្ញុំស្គាល់ ក៏ត្រឡប់ទៅជាអ្នកដទៃទាំងអស់។[14]ញាតិសន្តានខ្ញុំបានទុកខ្ញុំចោល ហើយមិត្តសម្លាញ់ដែលជិតស្និទ្ធ ក៏ភ្លេចខ្ញុំដែរ។
[15]ភ្ញៀវដែលធ្លាប់ស្នាក់ក្នុងផ្ទះខ្ញុំ ហើយនិងពួកស្រីបម្រើ បានចាត់ទុកខ្ញុំដូចជាមនុស្សចម្លែក ខ្ញុំដូចជាអ្នកដែលគេមិនធ្លាប់ស្គាល់។[16]ខ្ញុំហៅអ្នកបម្រើខ្ញុំ តែវាមិនឆ្លើយសោះ ទោះបើខ្ញុំសូមអង្វរយ៉ាងណាក៏ដោយ។
[17]ដង្ហើមរបស់ខ្ញុំបានស្អប់ដល់ប្រពន្ធខ្ញុំ ហើយរូបកាយរបស់ខ្ញុំជាទីខ្ពើមដល់បងប្អូនដែលបានកើតពីម្ដាយខ្ញុំ។[18]ទោះទាំងកូនក្មេងក៏មើលងាយដល់ខ្ញុំ បើកាលណាខ្ញុំក្រោកឡើង នោះវា និយាយបង្កាច់ខ្ញុំ។[19]ពួកមិត្តសម្លាញ់ជិតស្និទ្ធក៏ខ្ពើមឆ្អើមខ្ញុំ ហើយទាំងពួកអ្នកដែលខ្ញុំបានស្រឡាញ់ថ្នម ក៏ប្រែជាទាស់នឹងខ្ញុំវិញ។
[20]ខ្ញុំនៅតែស្បែក និងឆ្អឹង ហើយបានរស់ ដោយសារតែស្បែក និងធ្មេញប៉ុណ្ណោះ។[21]អ្នករាល់គ្នា ជាសម្លាញ់ខ្ញុំអើយ សូមអាណិតខ្ញុំ សូមអាណិតខ្ញុំផង ដ្បិតព្រះហស្តនៃព្រះជាម្ចាស់បានពាល់ខ្ញុំហើយ។[22]ហេតុអ្វីបានជាអ្នករាល់គ្នា ធ្វើទុក្ខដល់ខ្ញុំដូចជាព្រះជាម្ចាស់ដែរ? ហេតុអ្វីបានអ្នកនៅមិនទាន់ឆ្អែតនឹងសាច់ខ្ញុំទៀត?
[23]ឱប្រសិនបើពាក្យខ្ញុំបានសរសេរចុះ! ឱបើបានកត់ទុកក្នុងសៀវភៅមួយក្បាលនោះ![24]គឺបានឆ្លាក់នៅនឹងថ្មដោយដែកឆ្លាក់ ហើយនឹងសំណទុកជារៀងរាបតទៅ!
[25]ប៉ុន្តែ ខ្ញុំដឹងថា ព្រះដែលលោះខ្ញុំ ព្រះអង្គមានព្រះជន្មរស់នៅ ហើយនៅទីបំផុត ព្រះអង្គនឹងឈរនៅលើផែនដី[26]ក្រោយពីសម្បកកាយខ្ញុំរលាយទៅ នោះសាច់ឈាមខ្ញុំនឹងឃើញព្រះជាម្ចាស់។[27]ខ្ញុំនឹងបានឃើញព្រះជាម្ចាស់ដោយភ្នែកខ្ញុំ មិនមែនអ្នកផ្សេងទេ។ ចិត្តខ្ញុំបានចុះចាញ់នៅក្នុងខ្លួនខ្ញុំ ដោយរង់ចាំពេលនោះ។
[28]ដូច្នេះ បើអ្នករាល់គ្នាពោលថា ចាំមើលយើងនឹងធ្វើទុក្ខវាយ៉ាងណា ហើយឃើញថា ដើមហេតុនោះគឺមកពីខ្ញុំ[29]យ៉ាងនោះត្រូវខ្លាចចំពោះដាវហើយ ដ្បិតសេចក្ដីក្តៅក្រហាយនឹងនាំឲ្យមានទោសដោយដាវនោះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា មានសេចក្ដីយុត្តិធម៌ដែរ»។

Job 19:1

ប្រយោគភ្ជាប់

លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។

ព័ត៌មានទូទៅ:

សូមមើល: និង

តើអ្នករាល់គ្នាធ្វើខ្ញុំឈឺចាប់ដល់ពេលណាទៀត ហើយ

បំបែកខ្ញុំទៅជាចំណែកតូចៗជាមួយនឹងពាក្យសម្ដីដូច្នោះ

លោកយ៉ូបប្រើមេរោគនេះដើម្បីតួញតែ្ចរថា

តើមិត្តៗរបស់លោកវិភាគលោកយ៉ាងណា។ របៀបផ្សេងទៀតនៃការបកប្រែ:

«បញ្ឈប់ការធ្វើឲ្យខ្ញុំឈឺចាប់និងបំបែកខ្ញុំទៅជាចំណែកតូចៗជាមួយនឹងពាក្យសម្ដីដូច្នោះទៀតទៅ»

បំបែកខ្ញុំទៅជាចំណែកតូចៗជាមួយនឹងពាក្យសម្ដី

លោកយ៉ូបប្រើរូបភាពនេះ

ដោយនិយាយថាពាក្យរបស់ពួកគេធ្វើឲ្យលោកមានអារម្មណ៍ក្រៀមក្រំយ៉ាងខ្លាំង

និងអស់សង្ឃឹម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ហើយធ្វើទារុណកម្មខ្ញុំដោយពាក្យសម្ដីរបស់អ្នក»

Job 19:3

ព័ត៌មានទូទៅ:

លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។

គឺដប់ដងហើយដែលអ្នករាល់គ្នាបានប្រមាថដល់ខ្ញុំ

ឃ្លា «ដប់ដងហើយ»

សំដៅដល់របៀបដែលមិត្តៗរបស់លោកបានបន្ទោសលោកយ៉ូបទាំងស្រុង។

របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាបានប្រមាថដល់ខ្ញុំ» ឬ

«អ្នកបានប្រមាថដល់ខ្ញុំជាច្រើនដង»

ហើយអ្នករាល់គ្នាមិនមានសេចក្ដីខ្មាសសោះដែលអ្នករាល់គ្នាបានប្រព្រឹត្តនឹងខ្ញុំយ៉ាងសាហាវបែបនេះ

លោកយ៉ូបបានបន្ទោសពួកគេដោយសារការនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:

«អ្នករាល់គ្នាខ្មាស់អៀន

ដែលអ្នករាល់គ្នាបានប្រព្រឹត្តចំពោះខ្ញុំយ៉ាងសាហាវបែបនេះ»

បានប្រព្រឹត្តនឹងខ្ញុំយ៉ាងសាហាវបែបនេះ

«បានស្អប់ខ្ញុំ» ឬ «បានចំអកខ្ញុំជាសាធារណៈ»

បានមានកំហុស

«បានប្រព្រឹត្តអំពើបាបដោយចៃចន្យ» ឬ «បានប្រព្រឹត្តបាបដោយអចេតនា»

នោះកំហុស

«បាបរបស់ខ្ញុំ» ឬ «កំហុសរបស់ខ្ញុំ»

នោះកំហុសនោះនឹងនៅជាប់ជាមួយខ្ញុំទេ

លោកយ៉ូបបានថ្លែងបញ្ជិតបញ្ជៀងថា

មិត្តៗរបស់លោកមិនបានទទួលខុសត្រូវសម្រាប់ការបន្តបន្ទោសលោកនោះទេ។

របៀបផ្សេងទៀតនៃការបកប្រែ: «នោះកំហុសរបស់ខ្ញុំ ជាការទទួលខុសត្រូវរបស់ខ្ញុំ

ដូច្នេះអ្នករាល់គ្នាមិនគួរបន្តបន្ទោសខ្ញុំទៀតនោះទេ» ឬ

«កំហុសរបស់ខ្ញុំមិនបានធ្វើឲ្យអ្នករាល់គ្នាឈឺចាប់នោះទេ ដូច្នេះ

អ្នករាល់គ្នាមិនគួរបន្តបន្ទោសខ្ញុំទៀតនោះទេ»

Job 19:5

ព័ត៌មានទូទៅ:

លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។

បើការពិតអ្នករាល់គ្នាចង់តម្កើងខ្លួន ឲ្យលើសពីខ្ញុំ

ឃ្លាសន្និដ្ឋាន: លោកយ៉ូបសន្និដ្ឋានថា អ្នកគិតថា អ្នកប្រសើរជាងខ្ញុំ» ឬ «គឺអ្នកធ្វើដូចជាអ្នកប្រសើរជាងខ្ញុំ»

ហើយប្រើភាពអាម៉ាស់របស់ខ្ញុំមកទាស់នឹងខ្ញុំវិញ

របៀបដែលពួកគេធ្វើនេះ អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។

របៀបផ្សេងទៀតនៃការបកប្រែ: «ហើយប្តឹងតវ៉ាថា

ភាពអាម៉ាស់របស់ខ្ញុំគឺជាឬសគល់ទាស់នឹងខ្ញុំ» ឬ

«ហើយប្រើភាពអាម៉ាស់របស់ខ្ញុំជាភ័ស្តុតាងថាខ្ញុំមានកំហុស»

ប្រើភាពអាម៉ាស់របស់ខ្ញុំមកទាស់នឹងខ្ញុំ

នាមអរូប «ភាពអាម៉ាស់» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ អាម៉ាស់។

របៀបផ្សេងទៀតនៃការបកប្រែ: «ប្តឹងតវ៉ាថាអ្វីដែលបានកើតឡើង ធ្វើឲ្យខ្ញុំអាម៉ាស់

បង្ហាញថាខ្ញុំមានកំហុស»

បានចាប់ខ្ញុំនៅក្នុងសំណាញ់របស់ព្រះអង្គ

លោកយ៉ូបនិយាយដូចជាព្រះជាអ្នកប្រម៉ាញ់ដែលបានដាក់អន្ទាក់លោកយ៉ូបក្នុងសំណាញ់របស់ព្រះអង្គ។

នេះជាពាក្យប្រៀបធៀបបង្ហាញពីការត្រួតត្រារបស់ព្រះចំពោះលោកយ៉ូប

និងអារម្មណ៍នៃការអស់សង្ឃឹមរបស់លោកយ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:

«បានដាក់អន្ទាក់ខ្ញុំ» ឬ «បានត្រួតត្រាលើខ្ញុំ» ឬ

«បានត្រួតត្រាលើអ្វីដែលបានកើតឡើងចំពោះខ្ញុំ ដូច្នេះ ខ្ញុំគ្មានជំនួយទេ»

Job 19:7

ព័ត៌មានទូទៅ:

លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។

មើល៍

ពាក្យ «មើល៍» នៅទីនេះបន្ថែមការសង្កត់ធ្ងន់លើអ្វីដែលនឹងមកតាមក្រោយ។

របៀបផ្សេងទៀតនៃការបកប្រែ: «បន្ថែមពីលើ»

អំពើហឹង្សា

នេះគឺជាការស្រែកសម្រាប់ជំនួយ។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់។

របៀបផ្សេងទៀតនៃការបកប្រែ: «អំពើហឹង្សា! ជួយផង!» ឬ «ជួយផង!

ខ្ញុំកំពុងត្រូវបានវាយប្រហារ»

generated on Wed Sep 10 16:16:32 2025

ខ្ញុំបានស្រែក រកជំនួយ
«ខ្ញុំស្រែក រកជំនួយ» ឬ «ខ្ញុំបានស្រែកយំ រកជំនួយ»
តែគ្មានយុត្តិធម៌ទេ
បានអរូប «យុត្តិធ៌ម» អាចត្រូវបានបកប្រែជាមួយនឹងឃ្លា។
របៀបផ្សេងទៀតនៃការបកប្រែ:
«តែមិនមានអ្នកណាម្នាក់ការពារខ្ញុំពីអស់អ្នកដែលធ្វើខុសចំពោះខ្ញុំនោះទេ»
ព្រះអង្គបានធ្វើរបងរាំង...ភាពងងឹតក្នុងផ្លូវរបស់ខ្ញុំ
លោកយ៉ូបប្រើរូបភាពទាំងនេះ
ដើម្បីនិយាយព្រះបានធ្វើឲ្យលោកមានអារម្មណ៍គ្មានជំនួយ និងគ្មានសង្ឃឹម។
ព្រះអង្គបានធ្វើរបងរាំងផ្លូវខ្ញុំ ដូច្នេះខ្ញុំមិនអាចឆ្លងកាត់បាន
«ព្រះបានដាក់ជញ្ជាំងនៅលើផ្លូវដែលខ្ញុំកុំពុងដើរ» ឬ «ទ្រង់បានបិតផ្លូវ ដូច្នេះ
ខ្ញុំមិនអាចបន្តទៅមុខបានទេ»
ព្រះអង្គបានដោះ...មកុដចេញពីក្បាលខ្ញុំដែរ
លោកយ៉ូបប្រើរូបភាពទាំងនេះដើម្បីនិយាយព្រះបានយកកេរ្តិ៍ឈ្មោះល្អ ទ្រព្យសម្បត្តិ
និងភាពរុងរឿងរបស់លោកចេញចេញពីលោក។
ព្រះអង្គបានយកមកុដចេញពីក្បាលខ្ញុំដែរ
មកុដ សំដៅលើសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានយកមកុដនៃសេចក្តីថ្លៃថ្នូររបស់ខ្ញុំចេញ» ឬ
«វាគឺដូចជាព្រះអង្គបានយកមកុដចេញពីក្បាលរបស់ខ្ញុំ»
Job 19:10
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ព្រះអង្គបានបំបាក់ខ្ញុំចុះនៅគ្រប់ទីកន្លែង
លោកយ៉ូបនិយាយពីការបំផ្លាញគាត់ដោយព្រះ
ហាក់ដូចជាលោកយ៉ូបកំពុងសង់អគារឡើងហើយព្រះបានកម្ទេចវាចោល។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រង់បានបំផ្លាញទូលបង្គំគ្រប់ផ្លូវ» ឬ
«ទ្រង់បានវាយប្រហារខ្ញុំគ្រប់កន្លែង»
ហើយខ្ញុំក៏វិនាសទៅ
ការចាប់ផ្តើម «វិនាសទៅ» ជាសញ្ញាការត្រូវបានកម្ទេចទាំងស្រុង។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយខ្ញុំត្រូវបានកម្ទេចទាំងស្រុង»
ព្រះអង្គបានដកក្តីសង្ឃឹមរបស់ខ្ញុំចេញ ដូចជាដកដើមឈើ
លោកយ៉ូបបាននិយាយថា ព្រះធ្វើឲ្យលោកគ្មាសង្ឃឹម
ហាក់ដូចជាសេចក្តីសង្ឃឹមរបស់លោកយ៉ូបជាដើមឈើមួយដើម
ហើយជំនួសអោយការកាប់ចោល
ព្រះបានដើមទាំងមូលជាមួយនឹងឫសរបស់វាចេញពីក្នុងដីមក។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានដកយកក្តីសង្ឃឹមទាំងស្រុងរបស់ខ្ញុំចេញ» ឬ
«ពីព្រោះអ្វីដែលព្រះអង្គបានធ្វើ
ទូលបង្គំមិនអាចមានក្តីសង្ឃឹមសម្រាប់អ្វីដែលល្អបានទៀតទេ»
ព្រះអង្គបានឆួល សេចក្តីក្រោធឡើង ហើយទាស់នឹងខ្ញុំ
លោកយ៉ូបនិយាយពីសេចក្តីក្រោធរបស់ព្រះ ហាក់ដូចជាភ្លើង។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះបានដុតភ្លើងនៃព្រះពិរោធទាស់នឹងខ្ញុំ» ឬ
«ព្រះក៏បានព្រះពិរោធនឹងខ្ញុំជាខ្លាំង»
រួចហើយព្រះអង្គចាត់ទុកខ្ញុំ ដូចជាម្នាក់ដែរជាបច្ចាមិត្តនឹងព្រះអង្គវិញ
្«ព្រះអង្គគិតថាទូលបង្គំជាសត្រូវ»
ពលទ័ពរបស់ព្រះអង្គចូលមកជាមួយគ្នា
លោកយ៉ូបនិយាយពីការវាយប្រហាររបស់ព្រះចំពោះគាត់
ហាក់ដូចជាលោកយ៉ូបជាទីក្រុងមួយហើយព្រះបានបញ្ជូនពលទាហានមកវាយប្រហារវា
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានចាត់ពលទាហានរបស់ទ្រង់មកវាយប្រហារខ្ញុំ»
ពួកគេដេញព័ទ្ធជុំវិញពំនូកទាស់នឹងខ្ញុំ
លោកយ៉ូបនិយាយពីការវាយប្រហាររបស់ព្រះចំពោះគាត់
ហាក់ដូចជាលោកយ៉ូបជាទីក្រុងមួយហើយព្រះបានបញ្ជូនពលទាហានមកវាយប្រហារវា
របៀបផ្សេងទៀតនៃការបកប្រែ: «ពលទាហានបានពួនដីដើម្បីឡើងជញ្ជាំងរបស់ខ្ញុំ»
ហើយបោះជំរំនៅជុំវិញទីលំនៅរបស់ខ្ញុំផង
លោកយ៉ូបនិយាយពីការវាយប្រហាររបស់ព្រះចំពោះគាត់
ហាក់ដូចជាលោកយ៉ូបនៅក្នុងលំនៅរបស់គាត់
ហើយពលទាហានរបស់ព្រះបានបើជំរំនៅជុំវិញគាត់
ហើយរៀបចំដើម្បីវាយប្រហារគាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានជំរំនៅជុំវិញទីលំនៅរបស់ខ្ញុំ ហើយរៀបចំដើម្បីវាយប្រហារខ្ញុំ»
Job 19:13
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ព្រះអង្គបានញែកពួកបងប្អូនខ្ញុំចេញឆ្ងាយពីខ្ញុំ
ពាក្យ «ឆ្ងាយពី»
អ្នកណាម្នាក់តំណាងឲ្យការចាប់ផ្តើមមិនពេញចិត្តដើម្បីទាក់ទងទៅគាត់
ឬជួយគាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានធ្វើឲ្យបងប្អូនប្រុសរបស់ខ្ញុំស្ថិតនៅឆ្ងាយពីខ្ញុំ» ឬ
«ព្រះបានធ្វើឲ្យបងប្អូនប្រុសរបស់ខ្ញុំបដិសេធការជួយខ្ញុំ»
ហើយមិត្តស្និទ្ធស្នាលរបស់ខ្ញុំ ដាច់ឆ្ងាយទាំងស្រុងពីខ្ញុំ
នេះអាចបញ្ជាក់នៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិត្តស្និទ្ធស្នាលរបស់ខ្ញុំបានផ្តាច់ខ្លួនរបស់ពួកគេចេញពីខ្ញុំ» ឬ
«មិត្តសម្លាញ់របស់ខ្ញុំប្រព្រឹត្តចំពោះខ្ញុំដូចជាមនុស្សចម្លែក»
គ្រួសារញាតិសន្តានខ្ញុំបានធ្វើឲ្យខ្ញុំធ្លាក់ចុះ
«សាច់ញាតិរបស់ខ្ញុំបានទុកខ្ញុំចោលដោយមិនជួយ»
មិត្តសម្លាញ់ដែលជិតស្និទ្ធ
មិត្តស្និទ្ធស្នាលរបស់ខ្ញុំ
បានបំភ្លេចខ្ញុំដែរ
នេះមានន័យថាពួកគេបដិសេធមិនប្រព្រឹត្តចំពោះគាត់តាមរបៀបដែលគាត់ត្រូវធ្វើ
ហើយពួកគេបានមានទំនាក់ទំនងជាមួយគ្នាក្នុងកាលកន្លងមក។
វាបញ្ជាក់ថាពួកគេបោះបង់គាត់ចោល។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបោះបង់ខ្ញុំចោល» ឬ «ទុកខ្ញុំចោល»
Job 19:15
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ចាត់ទុកខ្ញុំ
«គិតថាខ្ញុំជា»
ខ្ញុំដូចជាជនដទៃនៅក្នុងភ្នែករបស់ពួកគេ
ភ្នែករបស់ពួកគេតំណាងឲ្យអាកប្បកិរិយារបស់ពួកគេចំពោះគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេគិតពីខ្ញុំដូចជាជនបរទេស»
តែគាត់មិនបានឆ្លើយទេ
ចម្លើយគឺជាការឆ្លើយតបទៅនឹងការហៅរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ គេមិនបានឆ្លើយតបមកខ្ញុំវិញទេ» ឬ «ប៉ុន្តែ
គេមិនបានមករកខ្ញុំទេ»
ទោះបីជាខ្ញុំទទួចអង្វរសុំដល់គាត់ជាមួយពាក្យរបស់ខ្ញុំយ៉ាងណាក៏ដោយ
ឃ្លា «ជាមួយពាក្យរបស់ខ្ញុំ» សំដៅដល់ការនិយាយរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទោះបីខ្ញុំនិយាយទៅកាន់គាត់ហើយសូមអង្វរគាត់ក្តី»។
ទទួចអង្វរសុំដល់គាត់
«សូមអង្វរគាត់»
Job 19:17
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ដង្ហើមរបស់ខ្ញុំបានធ្វើឲ្យអាក់អន់ដល់ប្រពន្ធខ្ញុំ
នៅទីនេះ «ដង្ហើម» តំណាងឲ្យក្លិននៃខ្យល់ដង្ហើម។ ប្រសិនបើ
អ្វីមួយធ្វើឲ្យអាក់អន់ចិត្តដល់អ្នកណាម្នាក់ វាមានន័យថាគាត់ស្អប់វា។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រពន្ធរបស់ខ្ញុំស្អប់ក្លិននៃខ្យល់ដង្ហើមរបស់ខ្ញុំ»
ដែលបានកើតពីផ្ទៃម្តាយរបស់ខ្ញុំមក
លោកយ៉ូបសំដៅដល់បងប្អូនប្រុស
និងបងប្អូនស្រីរបស់លោកក្នុងរបៀបថ្លែងបញ្ជិតចញ្ជៀងថាពួកគេជាមនុស្សដែលគួរតែស្រលាញ់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនប្រុសរបស់ខ្ញុំ» ឬ «បងប្អូនប្រុស
និងបងប្អូនស្រីរបស់ខ្ញុំ»
ស្អប់ខ្ពើមខ្ញុំ
«ស្អប់ខ្ញុំ» ឬ «ស្អប់ខ្ពើមខ្ញុំ »
ពួកគេនឹងនិយាយទាស់នឹងខ្ញុំ
«ពួកគេចំអកឡកឡឺយខ្ញុំ» ឬ
«ពួកគេបានធ្វើឲ្យខ្ញុំក្លាយជាមនុស្សដែលគួរឲ្យអស់សំណើច»

generated on Wed Sep 10 16:16:32 2025

គ្រួសារនិងពួកមិត្តសម្លាញ់ទាំងអស់
នេះសំដៅដល់មិត្តជិតស្និទ្ធរបស់លោក។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិត្តជិតស្និទ្ធរបស់ខ្ញុំទាំងអស់» ឬ
«មិត្តជិតស្និទ្ធរបស់ខ្ញុំទាំងអស់ដែលខ្ញុំបានចែករំលែករឿងសម្ងាត់របស់ខ្ញុំ»
ស្អប់ខ្ពើមខ្ញុំ
«បានខ្ពើមរអើមខ្ញុំ»
បានត្រឡប់ទៅជាទាស់នឹងខ្ញុំវិញ
«បានក្បត់នឹងខ្ញុំ»
Job 19:20
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ឆ្អឹងរបស់ខ្ញុំតោងជាប់និងស្បែករបស់ខ្ញុំនិងសាច់របស់ខ្ញុំ
លោកយ៉ូបនិយាយអំពីឆ្អឹង ស្បែក និងសាច់របស់លោក
ដើម្បីពណ៌នាអំពីរូបរាងរបស់លោក។ លោកស្គមយ៉ាងខ្លាំង
ហើយមនុស្សអាចមើលឃើញទ្រង់ទ្រាយឆ្អឹងយ៉ាងច្បាស់ដោយងាយ។
ក្នុងភាសាមួយប្រើគ្រាមភាសាសម្រាប់ការនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមានត្រឹមទេស្បែកនឹងឆ្អឹងប៉ុណ្ណោះ» ឬ «ស្បែកគ្របដណ្តប់ឆ្អឹងរបស់ខ្ញុំ»
ខ្ញុំអាចរស់បានដោយសារតែស្បែកនៃធ្មេញរបស់ខ្ញុំ
គ្រាមភាសានេះមានន័យថាលោករស់នៅស្ទើរតែមិនមានអ្វីសោះឡើយ
ថាគាត់ស្ទើរតែមិនរស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំរស់នៅដោយទទេ» ឬ
«ខ្ញុំរស់នៅពិបាកខ្លាំងណាស់»
សូមអាណិតមេត្តាដល់ខ្ញុំផង
«សូមមានការអាណិតអាសូរដល់ខ្ញុំផង»
ដ្បិត ព្រះហស្តនៃព្រះជាម្ចាស់បានពាល់ខ្ញុំហើយ
នៅទីនេះពាក្យ «បានពាល់ខ្ញុំ» ជាន័យប្រៀបធៀបសម្រាប់ «វាយខ្ញុំ»។
ពាក្យប្រៀបធៀបនេះសម្រាប់អ្វី ៗដែលធ្វើឲ្យលោកយ៉ូបរងទុក្ខ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីព្រោះព្រះបានធ្វើឲ្យខ្ញុំរងទុក្ខ»
ហេតុអ្វីបានជាអ្នករាល់គ្នា បៀតបៀនដល់ខ្ញុំ...ព្រះ?
លោកយ៉ូបប្រើសំនួរនេះដើម្បីតវាអំពី
ហេតុអ្វីមិត្តៗរបស់លោកប្រព្រឹត្តចំពោះលោកដូច្នេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំបៀតបៀនខ្ញុំ...ព្រះ!»
ហេតុអ្វីបានអ្នកនៅមិនទាន់ពេញចិត្តជាមួយហូបសាច់ខ្ញុំទៀតដូច្នោះ?
លោកយ៉ូបប្រើសំណួរនេះដើម្បីតវាអំពី
ហេតុអ្វីមិត្តៗរបស់លោកប្រព្រឹត្តចំពោះលោកដូច្នេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាបានស៊ីសាច់របស់គ្រប់គ្រាន់ហើយ!»
ឬ «ឈប់ស៊ីសាច់របស់ខ្ញុំទៀតទៅ!»
ហេតុអ្វីបានអ្នកនៅមិនទាន់ពេញចិត្តជាមួយហូបសាច់ខ្ញុំទៀតដូច្នោះ?
លោកយ៉ូបនិយាយពីពាក្យសម្តីរបស់មិត្តរបស់លោកដែលឃោឃៅយ៉ាងដូច្នេះ
ចំពោះលោក ហាក់ដូចជាសត្វសាហាវកំពុងស៊ីសត្វដទៃជាអាហារ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ឈប់និយាយបង្កាច់បង្ខូចអាក្រក់បែបនេះចំពោះខ្ញុំទៀតទៅ» ឬ
«ឈប់វាយប្រហារខ្ញុំដោយពាក្យសម្តីរបស់អ្នកទៀតទៅ»។
Job 19:23
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ឱបើពាក្យរបស់ខ្ញុំទាំងនោះបានសរសេរទុកក្នុងពេលនេះ
នេះជាការឧទានដែលប្រាប់ពីអ្វីដែលលោកយ៉ូបចង់បាន។
វាអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំសង្ឃឹមថានឹងមាននរណាម្នាក់សសេរទុកនូវពាក្យសម្តីរបស់ខ្ញុំ»
ពាក្យរបស់ខ្ញុំ
ឃ្លានេះតំណាងឲ្យអ្វីដែលលោកយ៉ូបនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលខ្ញុំកំពុងនិយាយ»
ឱបើបានចារឹកទុកនៅក្នុងសៀវភៅមួយក្បាលនោះ
នេះជាការឧទានដែលប្រាប់ពីអ្វីដែលលោកយ៉ូបចង់បាន។
វាអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំសង្ឃឹមថានឹងមាននរណាម្នាក់សសេរទុកក្នុងសៀវភៅមួយក្បាល»
ឱបើទោះជាមួយប៉ាកកាដែក ហើយបាននាំទៅចារនៅលើថ្មជារៀងរហូត!
នេះជាការឧទានដែលប្រាប់ពីអ្វីដែលលោកយ៉ូបចង់បាន។
វាអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។
«ខ្ញុំសង្ឃឹមថានឹងមាននរណាម្នាកប្រើប៉ាកកាដែក
ហើយបាននាំទៅចារនៅលើថ្មជារៀងរហូត
ប៉ាកកាដែក
នេះជាឧបករណ៍ដែកត្រូវបានប្រើសម្រាប់សសេរ។ វាត្រូវបានធ្វើពីដែល
ដូច្នេះមនុស្សអាចចារពាក្យនៅលើថ្មបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«កំណាត់ដែលមួយ»
សំណ
សំណ គឺជាលោហៈទន់។
យើងមិនបានដឹងទេថាមនុស្សបានប្រើសំណនៅពេលឆ្លាក់លើថ្មយ៉ាងដូចម្តេច។
ពួកគេប្រហែលជាបានបំពេញអក្សរសិលាចារឹកជាមួយសំណ
ដើម្បីធ្វើឲ្យសិលាចារឹកនោះមានអាយុកាលយូរអង្វែង។
Job 19:25
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ព្រះសង្គ្រោះរបស់ខ្ញុំ
នៅទីនេះ «អ្នកសង្គ្រោះ»
សំដៅដល់មនុស្សម្នាក់ដែលនឹងរំដោះលោកយ៉ូបដោយការបង្ហាញភាពគ្មានកំហុសរបស់លោក
ស្តារកិត្តិយសរបស់លោកឡើងវិញ និងប្រទានឲ្យលោកនូវយុត្តិធម៌។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកការពាររបស់ខ្ញុំ»
ហើយនៅពេលចុងក្រោយ ព្រះអង្គនឹងឈរនៅលើផែនដី
នេះសំដៅដល់ការឈរដើម្បីនិយាយក្នុងកាត់ក្តី។ អាចមានអត្ថន័យពីរ គេទី ១)
អ្នកសង្គ្រោះនឹងជាម្នាកចុងក្រោយដែលនិយាយក្នុងការកាត់ក្តី។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រង់នឹងវិនិច្ឆ័យថាខ្ញុំមានកំហុស ឬអត់» ឬ ២)
ព្រះសង្គ្រោះនឹងឈរក្នុងទីនេះនៅទីបញ្ចប់ដើម្បីការពារលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅទីបំផុតព្រះអង្គនឹងការពារខ្ញុំក្នុងទីកាត់ក្តី»
បន្ទាប់ពីស្បែករបស់ខ្ញុំ...គឺបានបំផ្លាញទៅ
អាចសំដៅដល់អត្ថន័យពីរ គឺ: ទី១)
រូបកាយរបស់គាត់ត្រូវបានបំផ្លាញដោយជំងឺនានា ឬទី ២)
រូបកាយរបស់គាត់បានពុករលួយបន្ទាប់ពីលោកបានស្លាប់។
នៅក្នុងសាច់ឈាមរបស់ខ្ញុំនឹងឃើញព្រះជាម្ចាស់
សាច់ឈាមរបស់គាត់តំណាងឲ្យរូបកាយរបស់គាត់ ហើយ
«ក្នុងសាច់ឈាមរបស់ខ្ញុំ» តំណាងឲ្យការរស់នៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលខ្ញុំរស់នៅក្នុងរូបកាយរបស់ខ្ញុំនៅឡើយ ខ្ញុំនឹងបានឃើញព្រះ»
ខ្ញុំនឹងបានឃើញព្រះអង្គជាមួយនឹងភ្នែកខ្ញុំ គឺខ្ញុំមិនមែនអ្នកផ្សេងទេ
ឃ្លា «ភ្នែកខ្ញុំ» សំដៅលើលោកយ៉ូប។ ឃ្លា «ភ្នែកខ្ញុំ» និង
«ហើយមិនមែនអ្នកណាផ្សេង» បញ្ជាក់ថាលោកយ៉ូបប្រាកដជានឹងឃើញព្រះ។
វាមិនមែនអ្នកណាម្នាក់នឹងឃើញព្រះហើយនិយាយលោកយ៉ូបអំពីព្រះអង្គ។
ខ្ញុំបានបាក់ទឹកចិត្តជាខ្លាំង
មនុស្សគិតថាក្រលៀនជាកន្លែងដែលមានអារម្មណ៍។ ដូច្នេះ
ការធ្លាក់ចុះរបស់ក្រលៀនតំណាងឲ្យការមានអារម្មណ៍យ៉ាងខ្លាំងរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំពិតជារំជួលចិត្តយ៉ាងខ្លាំងចំពោះវា» ឬ
«អារម្មណ៍របស់ខ្ញុំរំជួលយ៉ាងខ្លាំងពេលដែលខ្ញុំគិតពីរឿងនោះ។
ខ្ញុំបានបាក់ទឹកចិត្តជាខ្លាំង
អាចមានអត្ថន័យពីរ គឺ: ទី១) លោកយ៉ូបមានអារម្មណ៍ ពេញដោយក្តីសង្ឃឹម
ការអរព្រះគុណ និងក្តីអំណរ ឬ ទី២) លោកយ៉ូបមានអារម្មណ៍
ហត់នឿយក្នុងការរងចាំ ដើម្បីបានឃើញព្រះសង្គ្រោះរបស់គាត់។
Job 19:28
ព័ត៌មានទូទៅ:
លោកយ៉ូបនិយាយទៅកាន់មិត្តទាំងបីរបស់លោក។
ហេតុអ្វីបានជាយើងត្រូវបៀតបៀនលោក!
នេះគឺជាការឧទានឡើង។ វាអាចមានអត្ថន័យពីរគឺ: ទី១)
នោះគឺពួកគេពិតជាបៀតបៀនលោកយ៉ូបមែន ទី២)
នោះគឺពួកគេបានបៀតបៀនលោកយ៉ាងខ្លាំង។
ហើយឫសគល់នៃបញ្ហារបស់លោកគឺបានកប់នៅក្នុងលោកវិញទេ
ពាក្យ «ឫស» តំណាងឲ្យប្រភព។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកគឺជាប្រភពនៃបញ្ហារបស់លោកទាំងអស់» ឬ
«លោកមានបញ្ហាទាំងអស់នេះ ដោយសារតែអ្វីដែលលោកបានធ្វើ»
ដូច្នេះត្រូវខ្លាចចំពោះដាវវិញចុះ
ដាវអាចមានន័យពីរគឺ: ទី១) ព្រះវិនិច្ឆ័យទោសពួកគេ។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ ត្រូវខ្លាចដែលព្រះនឹងវិនិច្ឆ័យទោសអ្នក» ឬ ទី២) ព្រះសម្លាប់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
ចូរខ្លាចដែលព្រះនឹងសម្លាប់អ្នក»
ពីព្រោះសេចក្ដីក្រោធ នឹងនាំឲ្យមានការដាក់ទោសដោយដាវ
ទីនេះ «នាំ» ជាពាក្យប្រៀបធៀបសម្រាប់ «លទ្ធផលក្នុង» ឬ «បណ្ដាលឲ្យ»។
នាមអរូប «សេចក្ដីក្រោធ» និង «ការដាក់ទោស»
អាចត្រូវបានបង្ហាញជាមួយគុណនាម «ដោយក្រោធខឹង» និងកិរិយាសព្ទ
«ដាក់ទោស»។ អាចមានអត្ថន័យពីរ គឺ: ទី១) លទ្ធផលនៃព្រះពិរោធរបស់ព្រះ
គឺការដាក់ទោស។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រោះព្រះនឹងព្រះពិរោធនឹងអ្នក
ហើយនិងដាក់ទោសអ្នក» ឬ ទី២) កំហឹងនៃមិត្តរបស់លោកយ៉ូប
លទ្ធផលគឺការដាក់ទោស។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
អ្នកខឹងនឹងខ្ញុំដូច្នេះ ព្រះនឹងដាក់ទោសអ្នក»
មានការវិនិច្ឆ័យទោស
នាមអរូប « ការវិនិច្ឆ័យទោស» អាចត្រូវបានបង្ហាញជាមយយកិរិយាសព្ទ
«វិនិច្ឆ័យទោស»។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះការវិនិច្ឆ័យទោសមនុស្ស»

---

20 [1]ពេលនោះ សូផារ ជាជនជាតិណាអាម៉ា ឆ្លើយឡើងថា៖[2]«គឺដោយហេតុនោះបានជាគំនិតខ្ញុំ បណ្ដាលឲ្យឆ្លើយ ដោយព្រោះសេចក្ដីរួសរាន់នៅក្នុងចិត្តខ្ញុំ។[3]ខ្ញុំបានឮ
សេចក្ដីបន្ទោសនោះ ដែលជាសេចក្ដីទំនាស់ចិត្តខ្ញុំ តែវិញ្ញាណនៃសេចក្ដីចេះដឹងរបស់ខ្ញុំ បានឆ្លើយមកកាន់ខ្ញុំ។
[4]តើអ្នកមិនបានដឹងសេចក្ដីនេះទេឬ ថាតាំងពីចាស់បុរាណមក គឺពីកាលព្រះជាម្ចាស់បានដាក់មនុស្សឲ្យមាននៅផែនដី:[5]នោះជ័យជម្នះរបស់មនុស្សអាក្រក់គឺខ្លី ហើយ
សេចក្ដីរីករាយរបស់មនុស្សទមិឡល្មើស ក៏នៅតែមួយភ្លែតដែរឬ?
[6]ទោះបើគេមានកម្ពស់ដល់ផ្ទៃមេឃ ហើយក្បាលគេលូតឡើងដល់ពពកក៏ដោយ[7]គង់តែនឹងត្រូវវិនាសទៅជានិច្ច ដូចជាលាមករបស់ខ្លួនគេដែរ ឯពួកអ្នកដែលធ្លាប់ឃើញគេ
នោះនឹងសួរថា "តើគេនៅឯណា?"
[8]គេនឹងហោះហើរទៅបាត់ដូចជាយល់សប្តិន ឥតមានអ្នកណាឃើញទៀតឡើយ គេនឹងត្រូវបណ្តេញទៅដូចជា ការស្រមើស្រមៃនៅពេលយប់។[9]នោះភ្នែកដែលធ្លាប់ឃើញគេ
នឹងមិនឃើញគេទៀតទេ ហើយទីកន្លែងរបស់គេនឹងលែងឃើញគេដែរ។
[10]កូនចៅគេនឹងសូមអង្វរដល់ពួកទាល់ក្រ ដៃរបស់ខ្លួនគេនឹងត្រូវប្រគល់ ទ្រព្យសម្បត្តិទៅវិញ។[11]ឆ្អឹងគេពេញកម្លាំងដោយសណ្ឋាននៅក្មេង ប៉ុន្តែ នឹងត្រូវដេកចុះ ទៅក្នុង
ធូលីដី ជាមួយខ្លួនគេដែរ។
[12]ទោះបើសេចក្ដីអាក្រក់ មានរសផ្អែមនៅក្នុងមាត់គេ ទោះបើគេលាក់សេចក្ដីនោះនៅក្រោមអណ្ដាត[13]ទោះបើលៃលកសំចៃទុក មិនចង់លេបចុះទៅ គឺបៀមទុកនៅតែក្នុង
មាត់ក៏ដោយ[14]គង់តែអាហារនៅក្នុងពោះគេបានប្រែ ទៅជាពិសនៃពស់ហនុមាននៅក្នុងខ្លួនគេដែរ។
[15]គេបានលេបទ្រព្យសម្បត្តិចូលទៅ ហើយនឹងត្រូវក្អួតចេញមកវិញ ព្រះជាម្ចាស់នឹងកម្ចាត់របស់ទាំងនោះ ចេញពីពោះគេ។[16]គេនឹងជញ្ជក់ពិសរបស់ពស់ហនុមាន ហើយនឹង
ស្លាប់ដោយសារអណ្ដាតពស់វែក។
[17]គេនឹងលែងឃើញទឹកទន្លេ ទឹកឃ្មុំ និងទឹកដោះ ហូរដូចទឹកស្ទឹងទៀតហើយ។[18]គេប្រគល់ឲ្យផ្លែឈើទៅអ្នកជិតខាងវិញ ហើយពួកគេទំពារលេបមិនបានទេ ទ្រព្យសម្បត្តិ
នឹងមិនធ្វើឲ្យគេបានសប្បាយចិត្តឡើយ។[19]ព្រោះគេបានសង្កត់សង្កិន ឥតរាមិលដល់ពួកទាល់ក្រ ក៏បានរឹបជាន់យកផ្ទះមួយ ដែលខ្លួនមិនបានសង់ផង។
[20]គេមានចិត្តលោភលន់មិនចេះស្កប់ តែគេមិនអាចរក្សាទុកនូវអ្វីៗ ដែលគេពេញចិត្តនោះបានឡើយ។[21]គេត្របាក់លេបអ្វីៗទាំងអស់ ឥតមានសល់ តែភាពចម្រុងចម្រើន
របស់គេ នឹងមិននៅស្ថិតស្ថេររហូតទេ។[22]ក្នុងពេលកំពុងតសម្បួរសប្បាយ នោះគេបែរជាខ្វះខាតវិញ ទុក្ខវេទនាទាំងអស់នឹងគ្របសង្កត់លើគេ។
[23]នៅពេលដែលគេកំពុងតែបំពេញក្រពះ នោះព្រះជាម្ចាស់ស្រោចព្រះពិរោធដ៏ខ្លាំងក្លា របស់ព្រះអង្គទៅលើគេ ហើយព្រះអង្គធ្វើឲ្យភ្លៀងនៅពេលគេបរិភោគអាហារ។
[24]ទោះបីជាគេ រត់គេចពីអាវុធដែក នោះធ្នូរលង្ហិននឹងបាញ់ព្រួញទៅទម្លុះគេ។[25]ប្រសិនបើគេដកព្រួញចេញពីខ្លួន នោះមុខដាវដ៏មុតនឹងចាក់ទម្លុះ រហូតដល់ថ្លើមរបស់គេ ការ
ភ័យតក់ស្លុតនឹងកើតមានដល់គេ។
[26]អស់ទាំងសេចក្ដីងងឹត បានមកបង្ខូចទ្រព្យសម្បត្តិគេ នឹងមានភ្លើងដែលឥតមនុស្សផ្លុំ បានឆេះបំផ្លាញគេ ព្រមទាំងបន្សុសទាំងអស់ ដែលនៅសល់ក្នុងទីលំនៅរបស់គេ។[27]
ផ្ទៃមេឃក៏នឹងសម្តែងពីអំពើទុច្ចរិតរបស់គេ ហើយទាំងផែនដី នឹងក្រោកឡើងទាស់នឹងគេដែរ។
[28]ទ្រព្យសម្បត្តិនៅក្នុងផ្ទះរបស់គេ នឹងចាកចេញទៅ ទាំងអស់នឹងហូរបាត់ទៅ នៅថ្ងៃនៃសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។[29]នេះជាចំណែករបស់មនុស្សអាក្រក់ ត្រូវទទួលពី
ព្រះជាម្ចាស់ ជាមរតក ដែលព្រះអង្គចែកឲ្យដល់គេ»។

Job 20:1
ព័ត៌មានទូទៅ:
លោកសូផារឆ្លើយតបទៅលោកយ៉ូប។
លោកសូផារ ដែលជាជនជាតិណាអាម៉ា
បកប្រែឈ្មោះមនុស្សនេះ ដូចអ្នកបានបកប្រែក្នុង ២:១១។ តាំងពីចាប់ផ្តើមមក
នេះជាលើកទីពីរដែលលោកសូផារនិយាយ ការបកប្រែខ្លះលុបពាក្យ «ជាជនជាតិ
ណាអាម៉ា» ចោលនៅទីនេះ។
ជាគំនិតខ្ញុំបានធ្វើឲ្យខ្ញុំឆ្លើយយ៉ាងរហ័ស
ការគិតរបស់លោកសូផារ ធ្វើឲ្យលោកធ្វើអ្វីមួយ
តំណាងឲ្យការសម្រេចចិត្តដ៏ខ្លាំងរបស់លោកដើម្បីធ្វើអ្វីមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំពិតជាចង់ឆ្លើយទៅអ្នកឲ្យបានឆាប់រហ័ស»
ដោយព្រោះតែការបារម្ភដែលមាននៅក្នុងខ្ញុំ
នាមអរូប «ការបារម្ភ» អាចត្រូវបានបង្ហាញជាមួយគុណនាម
«ភាពព្រួយយបារម្ភ»។
ហេតុផលសម្រាប់ការព្រួយបារម្ភអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រោះខ្ញុំមានក្តីព្រួយបារម្ភយ៉ាងខ្លាំពីអ្នក» ឬ
«ព្រោះខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ព្រោះតែអ្វីដែលអ្នកបាននិយាយ»
ខ្ញុំឮការបន្ទោសដែលធ្វើឲ្យខូចកិត្តិយសខ្ញុំ
នាមអរូបយ «ការបន្ទោស» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «ស្តីបន្ទោស»។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំឮការស្តីបន្ទោសដល់ខ្ញុំ
ហើយអ្វីដែលលោកបាននិយាយធ្វើឲ្យខ្ញុំខូចកិត្តិយស» ឬ
«អ្នកប្រមាថខ្ញុំដោយអ្នកបានស្តីបន្ទោសខ្ញុំ»
វិញ្ញាណនៃសេចក្តីយល់ដឹងរបស់ខ្ញុំ បានឆ្លើយដល់ខ្ញុំវិញ
«ព្រលឹង» នៅទីនេះប្រហែលជាសំដៅដល់ការគិត ឬ គំនិត។
របៀបផ្សេងទៀតនៃការបកប្រែ: «ការគិតពីការយល់ដឹងរបស់ខ្ញុំឆ្លើយមកកាន់ខ្ញុំ»
ព្រលឹងនៃសេចក្តីយល់ដឹងរបស់ខ្ញុំ បានឆ្លើយដល់ខ្ញុំវិញ
«ព្រលឹង» នេះ ឬ គំនិតគឺបាននិយាយ វាហាក់ដូចជាមនុស្សម្នាក់ដែលអាចឆ្លើយ
លោកសូផារ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមានគំនិតមួយពីការយល់ដឹង
ហើយឥឡូវនេះខ្ញុំដឹងនូវអ្វីដែលខ្ញុំចង់ដឹង»
ព្រលឹងនៃសេចក្តីយល់ដឹងរបស់ខ្ញុំ បានឆ្លើយដល់ខ្ញុំវិញ
ការពិតនៃចម្លើយអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«គំនិតពីការយល់ដឹងរបស់ខ្ញុំឆ្លើយមកកាន់ខ្ញុំអំពីរបៀបដែលខ្ញុំអាចឆ្លើយតបទៅអ្នក»
ឬ «ខ្ញុំមានគមនិតពីការយល់ដឹងរបស់ខ្ញុំ
ហើយឥឡូវខ្ញុំដឹងថាខ្ញុំអាចឆ្លើយទៅអ្នកដោយរបៀបណា»
ព្រលឹងនៃសេចក្តីយល់ដឹងរបស់ខ្ញុំ បានឆ្លើយដល់ខ្ញុំវិញ
នាមអរូប «ព្រលឹង» និង «ការយល់ដឹង» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ
«គិត» និង «យល់»។ របៀបផ្សេងទៀតនៃការបកប្រែ: ពីព្រោះខ្ញុំយល់កិច្ចការនានា
ខ្ញុំមានគំនិត ហើយឥឡូវខ្ញុំដឹង ខ្ញុំអាចឆ្លើយតបទៅអ្នកដោយរបៀបណា។
Job 20:4
ព័ត៌មានទូទៅ:
លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។
តើអ្នករាល់គ្នាមិនបានដឹងការពិតពីតាំងពីចាស់បុរាណ...យូរអង្វែងដែរត្រូវទេ?
លោកសូផារប្រើសំណួរនេះ
ដើម្បីនាំលោកយ៉ូបឲ្យគិតស៊ីជម្រៅអំពីអ្វីដែលគាត់នឹងនិយាយឥឡូវនេះ។
របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«ប្រាកដណាស់អ្នកដឹងថាអ្វីជាការពិតតាំងពីបុរាណកាលមក...ក៏មិនបានយូរអង្វែងដែរ...គេនឹងត្រូវរលាយទៅដូចជាសុបិន្ត...គេនឹងត្រូវបានបំភ្លេចដូចជាចក្ខុវិស័យនៃពេលយប់»

ជ័យជម្នះរបស់មនុស្សអាក្រក់គឺខ្លីទេ

នាមអរូប «ជ័យជម្នះ» អាចត្រូវបាបបង្ហាញជាមួយកិតិយាសព្ទ «ឈ្នះ» ឬ «អបអរសាទរ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សអាក្រក់ឈ្នះត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះ» ឬ
«មនុស្សអាក្រក់ត្រូវបានសាទរត្រឹមតែមួយរយៈពេលខ្លីប៉ុណ្ណោះ»

ហើយសេចក្តីអំណររបស់មនុស្សទមិឡល្មើស ក៏មិនបានយូរអង្វែងដែរ

នាមអរូប «សេចក្តីអំណរ» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «អរសប្បាយ» ឬ គុណនាម «ភាពរីករាយ»។ ពាក្យ «មិនយូរអង្វែង»
គឺជាការបន្ថែមន័យដើម្បីបញ្ជាក់ថាពីពេលវេលាគឺខ្លីណាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ការអរសប្បាយរបស់មនុស្សទមិឡល្មើស
មិនយូរអង្វែងទេ» ឬ «មនុស្សទមិឡល្មើស គឺរីករាយតែរយៈពេលដ៏ខ្លីប៉ុណ្ណោះ។

Job 20:6

ព័ត៌មានទូទៅ:

លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។

ទោះបីកម្ពស់របស់អ្នកនោះ

«ទោះបីជាកម្ពស់របស់មនុស្សអាក្រក់ខ្ពស់»

ទោះបីកម្ពស់របស់អ្នកនោះខ្ពស់ដល់ផ្ទៃមេឃ

នាមអរូបយ «កម្ពស់» អាចត្រូវបានបង្ហាញជាមួយគុណនាម «ខ្ពស់»។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីអ្នកនោះខ្ពស់ដល់ផ្ទៃមេឃ»

ទោះបីកម្ពស់របស់អ្នកនោះខ្ពស់ដល់ផ្ទៃមេឃ

កម្ពស់របស់មនុស្សអាក្រក់ តំណាងឲ្យកេរ្តិ៍ឈ្មោះ ឬកិត្តិយសរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីជា កេរ្តិ៍ឈ្មោះ របស់គេខ្ពស់ដល់ផ្ទៃមេឃ»
ឬ «ទោះបីជា កិត្តិយស របស់គេខ្ពស់ដល់ផ្ទៃមេឃ»

ទោះបីកម្ពស់របស់អ្នកនោះខ្ពស់ដល់ផ្ទៃមេឃ

ឃ្លា «ខ្ពស់ដល់ផ្ទៃមេឃ» នៅទីនេះ តំណាងឲ្យ ភាពអស្ចារ្យយ៉ាងខ្លាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីជា កេរ្តិ៍ឈ្មោះ របស់គេ
អស្ចារ្យយ៉ាងណាក្តី» ឬ «ទោះបីជា កិត្តិយស របស់គេអស្ចារ្យយ៉ាងណាក្តី»

ទោះបីកម្ពស់របស់អ្នកនោះខ្ពស់ដល់ផ្ទៃមេឃ

នាមអរូបយ «ខ្ពស់» តំណាងឲ្យកេរ្តិ៍ឈ្មោះ ឬ កិត្តិយស។
គំនិតទាំងពីរនេះអាចត្រូវបានបង្ហាញជាមួយប្រភេទផ្សេងទៀតនៃឃ្លា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទោះបីជាមនុស្សគិតថាគេជាមនុស្សអស្ចារ្យយ៉ាងណាក្តី» ឬ
«ទោះបីគេជាមនុស្សមានអំនួតយ៉ាងណាក្តី»

ហើយក្បាលរបស់គេខ្ពស់ដល់ពពកក៏ដោយ

«ហើយក្បាលរបស់គេខ្ពស់ដល់ពពកក៏ដោយ»។
នេះក៏តំណាងឲ្យកេរ្តិ៍ឈ្មោះរបស់គេ ឬ កិត្តិយសដ៏អស្ចារ្យរបស់គេ។
នេះមានន័យដូចគ្នាទៅនឹងឃ្លាពីមុនដែរ។

នឹងត្រូវវិនាសទៅជារៀងរហូត ដូចជាលាមករបស់គេដែរ

លាមកលាយជាមួយនឹងដីហើយរលាយសូន្យទៅ។ ការបញ្ជាក់ពីលាមក
ក៏បញ្ជាក់ថាមនុស្សអាក្រក់គឺមិនមានតម្លៃទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងត្រូវវិនាសទៅជារៀងរហូត ដូចជាលាមករបស់គេ
ដែលនឹងរលាយទីក្នុងដីសូន្យទៅ»

នឹងត្រូវវិនាសទៅជារៀងរហូត ដូចជាលាមករបស់គេដែរ

ប្រសិនបើ មនុស្សទើសទាល់នឹងពាក្យលាមក
អ្នកប្រើប្រែអាចប្រើពាក្យដទៃផ្សេងទៀត ដែលរលាយសូន្យទាំងស្រុង។
របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងរលាយបាត់ទាំងស្រុងដូចជាធូលីដីដែលខ្យល់បក់ផាត់ទៅ»

Job 20:8

ព័ត៌មានទូទៅ:

លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។

មនុស្សអាក្រក់នឹង

«មនុស្សអាក្រក់នឹង»

មនុស្សអាក្រក់នឹងហោះហើរទៅបាត់ដូចជាយល់សប្តិន...ហើយការពិតអ្នកនោះនឹងត្រូវបណ្តេញទៅដូចជានិមិត្តនៅពេលយប់

«ហោះហើរទៅបាត់» នៅទីនេះ និង «នឹងត្រូវបណ្តេញទៅ»
តំណាងឲ្យការរលាយសូន្យទៅ។ ពួកគេក៏អាចត្រូវបានគេបំភ្លេច ចាប់តាំងពីសុបិន្ត
និងចក្ខុវិស័យរលាយបាត់ នៅពេលដែលមនុស្សបំភ្លេចពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:

ហើយគ្មានអ្នកអាចរកឃើញឡើយ

នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយនឹងគ្មានអ្នកណាស្វែងរកគេទេ»

ហើយភ្នែកដែលធ្លាប់ឃើញគេ

ភ្នែកតំណាងឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់គ្នាដែលធ្លាប់ឃើញគាត់» ឬ «មនុស្សម្នាដែលធ្លាប់បានឃើញគេ»

កន្លែងរបស់គេ

ឃ្លា «កន្លែងរបស់គេ» តំណាងឲ្យអស់អ្នកដែលបានរស់នៅកន្លែងរបស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សម្នាកដែលរស់នៅក្នុងកន្លែងរបស់គេ» ឬ
«គ្រួសាររបស់គេ»

Job 20:10

ព័ត៌មានទូទៅ:

លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។

កូនចៅរបស់គេ

«កូនចៅរបស់មនុស្សអាក្រក់»

ហើយដៃរបស់គេនឹងត្រូវប្រគល់ទ្រព្យសម្បត្តិត្រឡប់មកវិញ

នៅទីនេះ «ដៃ» សំដៅដល់កូនចៅរបស់មនុស្សអាក្រក់។
នៅពេលដែលគេស្លាប់បាត់
កូនចៅរបស់គេនឹងត្រូវសងត្រឡប់គ្រប់យ៉ាងដែលគេបានយកពីអ្នកដទៃ។

ឆ្អឹងរបស់គេគឺពេញកម្លាំងរបស់យុវវ័យ

«ឆ្អឹង» របស់គេ តំណាងឲ្យរូបកាយរបស់គេ។ ពាក្យ «ពេញ» នៃកម្លាំងរបស់យុវវ័យ
តំណាងឲ្យការខ្លាំងដូចជាមនុស្សវ័យក្មេង។ របៀបផ្សេងទៀតនៃការបកប្រែ:
«រូបកាយរបស់គេខ្លាំងដូចជារូបការរបស់មនុស្សវ័យក្មេង»

ប៉ុន្តែ វានឹងត្រូវដួលចុះជាមួយគេ ទៅក្នុងធូលីដីដែរ

ពាក្យ «វា» សំដៅដល់កម្លាំងនៃយុវវ័យរបស់គេ។ ពាក្យប្រៀបធៀប «ដួល
ចុះជាមួយគេ ទៅក្នុងធូលីដី» តំណាងឲ្យការស្លាប់។
ភាពខ្លាំងដែលស្លាប់គឺជាការប្រៀបធៀបឲ្យការរលាយបាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ កម្លាំនៃយុវវ័យរបស់គេនឹងស្លាប់ជាមួយគេ»
ឬ «ប៉ុន្តែ កម្លាំងនៃយុវវ័យរបស់គេនឹងស្លាប់ជាមួយគេ»

Job 20:12

ព័ត៌មានទូទៅ:

លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។

ទោះបីសេចក្តីអាក្រក់ មានរស់ជាតិផ្អែមនៅក្នុងមាត់របស់គេក្តី

នៅទីនេះ «សេចក្តីអាក្រក់មានរស់ជាតិផ្អែម»
តំណាងឲ្យមនុស្សដែលមានអំណរសប្បាយក្នុងការធ្វើការអាក្រក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីការធ្វើការអាក្រក់ជាទីគាត់ចិត្ត
ដូចជាការភ្លក់អាហារផ្អែមនៅក្នុងមាត់»

ហើយទោះបីគេបានលាក់វានោះនៅក្រោមអណ្តាតក៏ដោយ

នេះជាតំណាងឲ្យការចង់បន្តរីករាយនឹងការអាក្រក់
ដូចជាគេចង់បន្តការរីករាយនឹងរស់ជាតិអាហារដោយការរក្សាវានៅក្នុងមាត់។

នោះអាហារដែលនៅក្នុងពោះរបស់គេនឹងប្រែ ទៅជាល្វីង

នៅពេលដែលអាហារវាប្រែទៅជាល្វីងនៅក្នុងក្រពះ
វានាំឲ្យឈឺចាប់ហើយមានរស់ជាតិល្វីងជូរចត់។
នេះជាការប្រៀបធៀបសម្រាប់មនុស្សដែលជួបប្រទះការឈឺចាប់
ផលវិបាកដោយសារការប្រព្រឹត្តការអាក្រក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«កិច្ចការអាក្រក់ទាំងឡាយវាត្រឡប់មកដូចជាអាហារដែលប្រែជាល្វីងជូរចត់នៅក្នុងក្រពះ
» ឬ «ផលវិបាកនៃកិច្ចការអាក្រក់អស់ទាំងនោះ
គឺជាការឈឺចាប់ដូចជាអាហារដែលមកជាមានរស់ជាតិជូរនៅក្នុងក្រពះ»

ហើយវាក្លាយទៅជាពិសនៃពស់ហនុមាននៅក្នុងមនុស្សអាក្រក់នោះ

នេះគឺជារូបភាព ដែលវាអាក្រក់ជាងអាហារជូរនៅក្នុងក្រពះទៅទៀត។
នេះជាការប្រៀបធៀបសម្រាប់មនុស្សដែលជួបប្រទះនឹងផលវិបាកដ៏អាក្រក់
នៃការធ្វើការអាក្រក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ផលវិបាកនៃការធ្វើការអាក្រក់ទាំងនោះជាសេចក្តីឈឺចាប់ដូចជាថ្នាំពុលដែលនៅក្នុងមនុស្ស»

ពិស

«ពិសនៃសត្វពស់»

Job 20:15

ព័ត៌មានទូទៅ:

លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។

generated on Wed Sep 10 16:16:32 2025

គេបានលេបទ្រព្យសម្បត្តិចូល...ដេញវាទាំងនោះ ចេញពីពោះរបស់គេដែរ
លោកសូផារនិយាយអំពីការកើនឡើងនិងការបាត់បង់ទ្រព្យសម្បត្តិ
វាហាក់ដូចជាអាហារដែលមនុស្សបរិភោគហើតក្អួតចេញមកវិញ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សអាក្រក់ក្លាយជាអ្នកមានសម្បត្តិដ៏សម្បើម
ប៉ុន្តែ
គេបានបាត់បង់ទ្រព្យសម្បត្តិរបស់គេដូចជាមនុស្សដែលក្អួតអាហាររបស់គេចេញមកវិញ។
ព្រះធ្វើឲ្យគេបាត់បង់វាទាំងអស់។
គេបានលេបទ្រព្យសម្បត្តិចូល
ឃ្លា «គេបានលេបទ្រព្យសម្បត្តិចូល» អាចមានអត្ថន័យពីរយ៉ាងដែលតំណាងឲ្យគឺ:
ទី១) មានទ្រព្យសម្បត្តិយ៉ាងច្រើនហើយរក្សាវាទុកដោយអាត្មានិយម។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សមានទ្រព្យសម្បត្តិកើនឡើងយ៉ាងច្រើន
ហើយរក្សាវាទុកសម្រាប់តែខ្លួនឯង» ឬ ទី២)
មានទ្រព្យសម្បត្តិយ៉ាងច្រើនតាមវិធីដ៏អាក្រក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សអាក្រក់លួចទ្រព្យសម្បត្តិបានយ៉ាងច្រើន»
ព្រះជាម្ចាស់នឹងដេញវាទាំងនោះ ចេញពីពោះរបស់គេដែរ
ឃ្លា «ដេញវាទាំងនោះ ចេញពីពោះរបស់គេ» នៅទីនេះ
ជាការប្រៀបធៀបសម្រាប់ការធ្វើឲ្យមនុស្សក្អួតពួកវាចេញមក។ នេះ
ជាការប្រៀបធៀបសម្រាប់ការធ្វើឲ្យមនុស្សបាត់បង់សម្បត្តិរបស់គេ។
ដេញ
«ក្រវាត់ ឬ បោះចោល»
គេនឹងជញ្ជក់ពិសរបស់ពស់ហនុមាន
នៅទីនេះ «ជញ្ជក់ពិសរបស់ពស់ហនុមាន» តំណាងឲ្យការប្រព្រឹត្តកិច្ចការអាក្រក់។
ទាំងពីរនេះគឺគ្រោះថ្នាក់ខ្លាំងណាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការធ្វើការអាក្រក់ គឺដូចជាការជញ្ជក់ពិសពីសត្វពស់ពិស» ឬ
«គាត់នឹងធ្វើការអាក្រក់ហើយនឹងធ្វើឲ្យអន្តរាយដល់ជីវិតរបស់គាត់
ដូចមនុស្សដែលជញ្ជក់ពិសពីសត្វពស់ពិស»
ពិស
«ពិសនៃសត្វពស់»
ហើយនឹងស្លាប់អណ្តាតពស់នឹងសម្លាប់គេផងដែរ
ពស់ពិស គឺជាពស់ដែលមានពិសសាហាវ។ អណ្តាតរបស់វា
តំណាងឲ្យការចឹកពិសរបស់វា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការចឹករបស់ពស់ពិសនឹងសម្លាប់គាត់» ឬ «ពស់ពិសនឹងចឹកគាត់
ហើយគាត់នឹងស្លាប់»
ហើយនឹងស្លាប់អណ្តាតពស់នឹងសម្លាប់គេផងដែរ
ពស់ពិស តំណាងឲ្យមនុស្សអាក្រក់។របៀបផ្សេងទៀតនៃការបកប្រែ:
«សេចក្តីអាក្រក់របស់គាត់ នឹងសម្លាប់គាត់ ដូចការចឹករបស់ពស់ពិស»
Job 20:17
ព័ត៌មានទូទៅ:
លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។
ទឹកទន្លេ ហើយទឹកស្ទឹង ទឹកឃ្មុំ រួមទាំងទឹកដោះ
ទឹកទន្លេ និង ទឹកស្ទឹងជាការប្រៀបធៀប ដែលតំណាងឲ្យភាពសម្បូរសប្បាយ។
ទឹកឃ្មុំនិងទឹកដោះជាការប្រៀបធៀប ដែលតំណាងការល្អ
ដែលព្រះប្រទានឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ភាពសម្បូរសប្បាយនៃការល្អដែលព្រះប្រទានឲ្យមនុស្សរបស់ព្រះអង្គ»
ផលផ្លែនៃពលកម្មរបស់គាត់
ជាធម្មតា «ផលផ្លែនៃពលកម្មរបស់គាត់»
គឺសំដៅដល់លទ្ធផលនៃកម្លាំងពលកម្មរបស់គាត់។
ក្នុងករណីនេះវាសំដៅដល់របស់ដែលមនុស្សអាក្រក់បានលួច។
របៀបផ្សេងទៀតនៃការបកប្រែ: «របស់ដែលគាត់បានធ្វើដើម្បីទទួលបានវា» ឬ
«របស់ដែលគេបានលួច»
ហើយក៏មិនអាចបរិភោគបានដែរ
នៅទីនេះ «បរិភោគ» ផលផ្លែនៃកម្លាំងពលកម្មរបស់គាត់
តំណាងឲ្យការរីករាយនឹងរបស់ដែលគាត់បានលួចមក។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយនឹងមិនអាចរីករាយនឹងពួកវាបានទេ»
Job 20:20
គេត្របាក់លេបអ្វីៗទាំងអស់ ឥតមានសល់
នេះអាចថ្លែងឡើងវិញជាមួយភាពអវិជ្ជមានតែមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «គេត្រូវបានលេបត្របាក់គ្រប់បែបយ៉ាង
ហើយមិនមានអ្វីដែលនៅសេសសល់នោះទេ» ឬ
«គ្មានធ្វើដែលនៅសេសសល់នោះទេ ព្រោះគ្រប់យ៉ាងត្រូវបានលេបត្របាក់»
គេត្របាក់លេបអ្វីៗទាំងអស់ ឥតមានសល់
ពាក្យ «លេបត្របាក់» នៅទីនេះតំណាងអោយ
ការប្រមូលរបស់គ្រប់យ៉ាងសម្រាប់ខ្លួនគាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្វីដែលនៅសេសសល់ ដែលគេមិនបានយកវាសម្រាប់ខ្លួនគេនោះទេ» ឬ
«គេបានយករបស់គ្រប់យ៉ាងសម្រាប់ខ្លួនគេ
ហើយមិនមានអ្វីមួយនៅសេសសល់នោះទេ»
គេនឹងធ្លាក់ទៅក្នុងបញ្ហា
«គេនឹងជួបប្រទះនឹងបញ្ហាយ៉ាងឆាប់រហ័ស»
ទុក្ខវេទនាទាំងអស់នឹងគ្របសង្កត់លើគេ (ដៃនៃមនុស្សគ្រប់រូបដែលនៅក្នុងភាពក្រីក្រ
នឹងមកទាស់ជាមួយនឹងគេ)
នៅទីនេះ «ដៃ» តំណាងឲ្យអំណាច ហើយ «ដៃ...នឹងមកទាស់ជាមួយនឹងគេ»
តំណាងឲ្យមនុស្សដែលកំពុងវាយប្រហារគេ។ នាមអរូប «ភាពក្រីក្រ»
អាចត្រូវបានបង្ហាញជាមួយគុណនាម «ក្រីក្រ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់គ្នាដែលនៅក្នុងភាពក្រីក្រនឹងវាយប្រហារគាត់» ឬ
«មនុស្សគ្រប់គ្នាដែលក្រីក្រនឹងវាយប្រហារគាត់»
Job 20:23
ចម្អែតក្រពះរបស់គេ
នៅទីនេះ «ចម្អែតក្រពះរបស់គេ» គឺជាការប្រៀបធៀប មានន័យថា បរិភោគច្រើន។
ព័ត៌មានទូទៅ:
លោកសូផារបន្តការនិយាយជាមួយលោកយ៉ូប។
ព្រះជាម្ចាស់នឹងបោះកំហឹងនៃសេចក្តីក្រោធរបស់ព្រះអង្គមកលើគេ
«កំហឹងនៃសេចក្តីក្រោធ» តំណាងព្រះពិរោធនិងការដាក់ទោសរបស់ព្រះ។
ការបោះការដាក់ទោសលើគេ តំណាងការដាក់ទោសគាត់យ៉ាងធ្ងន់ធ្ងរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនឹងព្រះពិរោធហើយនិងជះការដាក់ទោសលើគេ» ឬ
«ព្រះអង្គនឹងព្រះពិរោធហើយនឹងដាក់ទោសគេយ៉ាងធ្ងន់»
ព្រះជាម្ចាស់នឹងឲ្យភ្លៀងធ្លាក់ចុះមកលើគេ
«ព្រះជាម្ចាស់នឹងឲ្យភ្លៀងធ្លាក់ចុះមកលើគេ» នៅទីនេះ «ភ្លៀងធ្លាក់ចុះមកលើគេ»
តំណាងឲ្យការដាក់ទោសយ៉ាងខ្លាំងកើតមានដល់មនុស្ស។
«ព្រះជាម្ចាស់នឹងដាក់ទោសគាត់យ៉ាងខ្លាំង»
នឹងរត់គេចពីអាវុធដែក
អាវុធដែក តំណាងឲ្យមនុស្សដែលកាន់វា។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងរត់គេចពីមនុស្សដែលកាន់អាវុធដែក»
ធ្នូរនៃលង្ហិននឹងបាញ់ទៅគេដែរ
ធ្នូរ តំណាងឲ្យអ្នកដែលបាញ់ព្រួញជាមួយវា។ របៀបផ្សេងទៀតនៃការបកប្រែ:
«នរណាម្នាក់ជាមួយនឹងធ្នូរលង្ហិន នឹងបាញ់គេ»
ថ្លើម
នេះជាផ្នែកដ៏ធំ និងសំខាន់មួយនៃរាងកាយ។ ប្រសិនបើ
នរណាម្នាក់បាញ់ទម្លុះដោយព្រួញ មនុស្សដែលត្រូវបាញ់នោះអាចនឹងស្លាប់។
ការរន្ធត់នឹងកើតឡើងមានលើគេ
នេះតំណាងឲ្យការភ័យខ្លាចដែលនឹងមកដល់គាត់ភ្លាមៗ។
របៀបផ្សេងទៀតនៃការបកប្រែ: «គាត់មានការភ័យខ្លាច»
Job 20:26
សេចក្តីងងឹតទាំងមូល គឺបានមកជំនួសទ្រព្យសម្បត្តិរបស់គេ
«សេចក្តីងងឹតទាំងមូល» ជាការប្រៀបធៀបសម្រាប់ការធ្វើឲ្យវិនាស។
របៀបផ្សេងទៀតនៃការបកប្រែ: «ការធ្វើឲ្យវិនាស
គឺត្រូវបានជំនួសឲ្យសម្បត្តិរបស់គាត់» ឬ «សម្បត្តិរបស់គេ នឹងត្រូវបំផ្លាញ»
ភ្លើងដែលមិនបានបង្កាត់នឹងបំផ្លាញគេ
នៅទីនេះ «បំផ្លាញ» ជាការប្រៀធៀប មានន័យ បំផ្លាញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ភ្លើងដែលមិនបានបង្កាត់នឹងបំផ្លាញគេ»
ភ្លើងដែលមិនបានបង្កាត់នឹងបំផ្លាញគេ
ឃ្លា «មិនបានបង្កាត់» បញ្ជាក់ថាមិនមានមនុស្សណាម្នាក់នឹងចាប់ផ្តើមភ្លើងទេ។
ដូចជាព្រះធ្វើឲ្យមានភ្លើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ភ្លើងដែលមិនមានការចាប់ផ្តើមដោយមនុស្សនឹងបំផ្លាញគេ» ឬ
«ព្រះជាម្ចាស់នឹងធ្វើឲ្យឲ្យភ្លើងបំផ្លាញគេ»
វានឹងលេបត្របាក់
នៅទីនេះពាក្យ «លេបត្របាក់» ជាពាក្យប្រៀបធៀប មានន័យថា បំផ្លាញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ភ្លើងនឹងបំផ្លាញគេ»

generated on Wed Sep 10 16:16:32 2025

ផ្ទៃមេឃ...ផែនដី
អាចមានអត្ថន័យពីរ គឺ: ទី១) អស់អ្នកដែលរស់នៅលើមេឃ និងលើផែនដី ឬ ទី២) លោកសូផារពណ៌នាពីផ្ទៃមេឃ និងផែនដី ដូចជាពួកគែជាមនុស្ស ដែលនឹងធ្វើបន្ទាល់ក្នុងការវិនិច្ឆ័យទោសទាស់នឹងមនុស្សអាក្រក់។
Job 20:28
ព័ត៌មានទូទៅ:
នេះជាការបញ្ចប់ពាក្យសម្តីរបស់លោកសូផារទៅកាន់លោកយ៉ូប។
ចាកចេញទៅ
«រលាយបាត់ទៅ» ឬ «ចេញបាត់ទៅ»
ការល្អ (ទ្រព្យសម្បត្តិ) របស់គេនឹងហូរចេញបាត់ទៅ
នៅទីនេះឃ្លា «ហូរចេញបាត់ទៅ» តំណាងឲ្យការយកចេញឆ្ងាយពីគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រព្យសម្បត្តិរបស់គេនឹងត្រូវយកចេញឆ្ងាយពីគេ ដូចជាទ្រព្យសម្បត្តិដែលហូរតាមទឹកក្នុងពេលទឹកជំនន់»
ទ្រព្យសម្បត្តិរបស់គេ
«ការកាប់កាប់របស់គេ»
ថ្ងៃនៃសេចក្តីក្រោធរបស់ព្រះជាម្ចាស់
នៅទីនេះ «សេចក្តីក្រោធ» តំណាងឲ្យការដាក់ទោស។ នាមអរូប «សេចក្តីក្រោធ» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទដាក់ទោស។ របៀបផ្សេងទៀតនៃការបកប្រែ: « ថ្ងៃនោះ នៅពេលដែលព្រះដាក់ទោសមនុស្ស»
នេះជាចំណែករបស់មនុស្សអាក្រក់ ត្រូវទទួលពីព្រះជាម្ចាស់
ឃ្លា «ទទួលពីព្រះជាម្ចាស់» នៅទីនេះ សំដៅដល់អ្វីដែលព្រះបានសម្រេចព្រះទ័យថាអ្វីដែលគួរនឹងកើតចំពោះអ្នកណាម្នាក់។ វាគឺជាការនិយាយដែលហាក់ដូចជាមានអ្វីមួយដែលព្រះចង់ប្រទានឲ្យគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «នេះជាអ្វីដែលព្រះបានសម្រេចព្រះទ័យថាគឺនឹងត្រូវកើតឡើងចំពោះមនុស្សអាក្រក់»
ជាមរតកដែលបានទុកសម្រាប់គេដោយព្រះជាម្ចាស់
នេះ សំដៅដល់អ្វីដែលព្រះបានសម្រេចព្រះទ័យថាអ្វីដែលគួរនឹងកើតចំពោះអ្នកណាម្នាក់។ វាគឺជាការនិយាយដែលហាក់ដូចជាមានអ្វីមួយដែលព្រះចង់ប្រទានឲ្យគេជាមរតក។ របៀបផ្សេងទៀតនៃការបកប្រែ: «នេះជាអ្វីដែលព្រះបានរៀបផែនការដើម្បីប្រទានឲ្យគេ» ឬ «នេះជាអ្វីដែលព្រះបានរៀបផែនការដើម្បីកើតឡើងចំពោះគេ»

21 [1]ក្រោយមកលោកយ៉ូប ឆ្លើយដោយនិយាយថា[2]«សូមស្តាប់ពាក្យខ្ញុំឲ្យបានច្បាស់ ហើយយកពាក្យនេះកម្សាន្តចិត្ត ជំនួសពាក្យអ្នកវិញ។[3]សូមតាមខ្ញុំឲ្យទាន់ នោះខ្ញុំនឹងនិយាយ បន្ទាប់ពីខ្ញុំបាននិយាយ ចាំចំអកទៀតចុះ។
[4]ដ្បិតសម្រាប់ខ្ញុំ គឺជាការមិនសុខចិត្តជាមួយមនុស្សឬ? ហេតុអ្វីបានជាខ្ញុំមិនអាចទ្រាំបាននោះ?[5]សូមសម្លឹងមកខ្ញុំដោយភ្ញាក់ផ្អើល ហើយយកដៃមកបិទមាត់អ្នកផង។
[6]ពេលខ្ញុំគិតអំពីការឈឺចាប់របស់ខ្ញុំ គឺខ្ញុំវេទនាហើយភ័យខ្លាច និងញ័ររាង្គកាយផងដែរ។
[7]តើហេតុអ្វីបានជាមនុស្សអាក្រក់បន្តរស់នៅ រហូតដល់ចាស់ ហើយរឹងមាំនៅក្នុងអំណាចឬ?[8]ពូជពង្សរបស់ក៏បានតាំងទីរឹងមាំជាមួយពួកគេដោយតាមខ្សែរដែរ ហើយកូនចៅក៏បានចំរើនឡើង នៅចំពោះភ្នែករបស់គេដែរ។[9]ផ្ទះរបស់ពួកគេបានរួចផុតពីការភ័យខ្លាច ម្យ៉ាងមួយទៀត ពួកគេរួចផុតពីរំពាត់របស់ព្រះជាម្ចាស់ដែរ។
[10]គោឈ្មោលរបស់គេជាន់មេឥតខាន គោញីក៏បង្កើតកូនឥតបានរលូតដែរ។[11]គេឲ្យកូនតូចៗរបស់គេ ចេញទៅដូចជាហ្វូងចៀម ហើយកូនធំៗក៏លោតកញ្ឆាត់កញ្ឆេងផង។
[12]ពួកគេ រាល់គ្នាច្រៀងតាមចង្វាក់គែន និងស៊ុង ហើយក៏អរសប្បាយតាមសំឡេងខ្លុយ។
[13]ពួកគេបានចំណាយមួយថ្ងៃជាមួយទ្រព្យសម្បត្តិ ហើយគេបានធ្លាក់ទៅក្នុងស្ថាននរកដោយស្ងាត់ៗ។[14]ពួកគេនិយាយទៅព្រះជាម្ចាស់ថា
សូមចេញពីយើងទៅពីព្រោះយើងមិនចង់បានចំណេះដឹងពីព្រះអង្គទេ។[15]តើព្រះចេស្តារ្យគឺជាអ្វី? ហេតុអ្វីបានជាយើងត្រូវថ្វាយបង្គំព្រះអង្គ?
តើយើងបានអ្វីមកវិញបើយើងអធិស្ឋានរកព្រះអង្គ។
[16]មើល! តើទ្រព្យទាំងនោះដែលនៅក្នុងដៃទេឬអី? ខ្ញុំគ្មានអ្វីត្រូវធ្វើជាមួយនឹងយោបល់ របស់មនុស្សអាក្រកនោះទេ។[17]តើប៉ុន្មានដងដែលចង្កៀងរបស់មនុស្សអាក្រក់បានរលត់ទៅ ឬគ្រោះមហន្តរាយរបស់ពួកគេបានធ្លាក់មកលើគេនោះ? តើប៉ុន្មានដងដែលបានកើតឡើង គឺព្រះជាម្ចាស់បាននាំភាពទុក្ខសោក
មកកាន់ពួកគេជាមួយសេចក្តីក្រោធនោះ?[18]តើប៉ុន្មានដង ដែលគេដូចជាចំបើងបណ្តោយខ្យល់ ហើយដូចជាអង្កាមដែលខ្យល់ព្យុះផាត់យកទៅនោះ?
[19]អ្នកថា ព្រះជាម្ចាស់បានប្រមូលទុកអំពើទុច្ចរិត របស់មនុស្សសម្រាប់កូនចៅរបស់គេ តែសូមព្រះដាក់ទោសដល់ពួកគេនោះវិញ ដើម្បីឲ្យគេដឹងខ្លួន។[20]ត្រូវឲ្យភ្នែករបស់អ្នកនោះ ឃើញសេចក្តីវិនាសរបស់ខ្លួន ព្រមទាំងផឹកស្រូបសេចក្តីក្រោធរបស់ព្រះ ដ៏មានគ្រប់ព្រះចេស្តាផង។[21]តើគេខ្វល់អ្វីដល់ពួកវង្សរបស់ខ្លួន ដែលនៅជំនាន់ក្រោយ បើកាលណាចំនួនខែនៃជីវិតគេ បានផុតទៅហើយនោះ?
[22]តើមានអ្នកណាបង្រៀនចំណេះដល់ព្រះជាម្ចាស់បាន ឃើញហើយថា គឺព្រះអង្គហើយ ដែលជំនុំជម្រះទាំងពួកអ្នកធំៗផង។[23]អ្នកខ្លះរស់នៅយ៉ាងស្រណុក មានសេចក្តីសុខ ក៏ស្លាប់បាត់ទៅ ក្នុងកាលដែលនៅមានកម្លាំងពេញប្រាណ។[24]រូបកាយរបស់គេពេញទៅដោយទឹកដោះគោ ជាកញ្ចាក់ នៃឆ្អឹងរបស់គាត់
ហើសម្ទើមធ្វើឲ្យធ្វើឲ្យមានសុខភាពល្អ។
[25]អ្នកខ្លះទៀតស្លាប់ទៅទាំងមានចិត្តជូរល្វីង មិនដែលស្គាល់បទពិសោធន៍នៃសេចក្តីល្អឡើយ។[26]ពួកគេដេកទៅក្នុងធូលីដី ហើយក៏មានដង្កូវចោះគេដូចគ្នា។
[27]មើល! ខ្ញុំស្គាល់គំនិតរបស់អ្នករាល់គ្នាហើយ ក៏យល់អ្វីដែលគិតធ្វើអាក្រក់ដល់ខ្ញុំដែរ។[28]ដ្បិតអ្នករាល់គ្នានិយាយថា តើផ្ទះរបស់អ្នកធំនៅឯណាពេលនេះ? តើទីលំនៅរបស់មនុស្សអាក្រក់នៅទីណាដែរ?
[29]តើអ្នករាល់គ្នាមិនបានសួរ ពួកអ្នកដំណើរទេឬអី? តើមិនបានស្គាល់គោលគំនិតរបស់គេដែលចង់ប្រាប់ទេ[30]គឺថា មនុស្សអាក្រក់ ត្រូវបម្រុងទុកដល់ថ្ងៃអន្តរាយ ហើយគេត្រូវនាំចេញទៅនៅថ្ងៃនៃសេចក្តីក្រោធនោះទេ?
[31]តើអ្នកណា នឹងដាក់ទោសដល់ផ្លូវរបស់មនុស្សអាក្រក់ នៅចំពោះមុខគេ? តើអ្នកណានឹងសងគេ តាមការដែលគេបានប្រព្រឹត្ត?[32]ប៉ុន្តែ នឹងត្រូវសែងគេនាំយកទៅឯទីបញ្ចុះសព្ទ ហើយនឹងមានមនុស្សចាំយាមផ្នូរដែរ។[33]គំនរដុំដីនៅច្រកភ្នំនឹងបានស្រួលដល់គេ ហើយមនុស្សទាំងអស់នឹងទៅតាមគេ ដូចជាមានមនុស្សឥតគណនា បានទៅមុខគេដែរ។
[34]តើអ្នករាល់គ្នាយកសេចក្តីឥតប្រយោជន៍ មកកម្សាន្តចិត្តខ្ញុំធ្វើអី ចម្លើយរបស់អ្នករាល់គ្នាសុទ្ធតែកុហក?»

Job 21:1
ប្រយោគភ្ជាប់
លោកយ៉ូបចាប់ផ្តើមឆ្លើយទៅកាន់ពាក្យចោទប្រកាន់របស់លោកសូផារ។
សូមនៅជាមួយខ្ញុំ
«សូមអនុញ្ញាតឲ្យខ្ញុំ» ឬ «សូមយកចិត្តទុកដាក់ជាមួយខ្ញុំ»
ការចំអកទៀត
«អ្នកអាចបន្តការចំអកឲ្យខ្ញុំ» លោកយ៉ូបប្រើការចំអកបញ្ឈឺចិត្ត ដើម្បីបញ្ជាក់ថា មិត្តរបស់លោកនឹងបដិសេធអ្វីដែលលោកនឹងនិយាយ ហើយបន្តការចំអកឡកឡើយគេ
Job 21:4
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
ដ្បិត សម្រាប់ខ្ញុំ គឺជាការតួញតែ្អរជាមួយមនុស្សឬ? ហេតុអ្វីបានជាខ្ញុំមិនអាចទ្រាំបានដូច្នោះ?
លោកយ៉ូបប្រើសំណួរនេះដើម្បីបញ្ជាក់ថា លោកគិតថាវាជាការខុសឆ្គងសម្រាប់លោកដែលតួញតែ្អរទៅកាន់ព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនមានការតួញតែ្អរជាមួយមនុស្សទេ។ ខ្ញុំមានសិទ្ធិនឹងមិនអត់ធ្មត់»
យកដៃរបស់អ្នកមកដាក់លើមាត់អ្នកផង
«ចូរបិតមាត់របស់អ្នកជាមួយនឹងដៃរបស់អ្នក»។ អាចមានន័យពីរ គឺ: ទី១) នេះគឺជាការឆ្លើយតបទៅនឹងការធ្វើឲ្យភ្ញាក់ផ្អើល» ឬ ទី២) នេះជាសញ្ញាដែលមនុស្សនឹងមិននិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ: «កុំនិយាយអ្វីទាំងអស់»

generated on Wed Sep 10 16:16:32 2025

ញាក់ញ្ជរ័រាង្គកាយរបស់ខ្ញុំផងដែរ
«សេចក្ដីភ័យខ្លាច នាំឲ្យរាង្គកាតរបស់ខ្ញុំញាក់ញ័រ» ឬ
«ខ្ញុំញ័រព្រោះសេចក្ដីភ័យខ្លាច»
Job 21:7
ការភ្ជាប់សេចក្ដីថ្លែងការណ៍:
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
តើហេតុអ្វីបានជាមនុស្សអាក្រក់នៅតែបន្តរស់នៅ រហូតដល់ចាស់
ហើយរឹងមាំនៅក្នុងអំណាចដូច្នោះ?
លោកយ៉ូបប្រើសំណួរនេះដើម្បីបង្ហាញថា មិត្តរបស់លោកខុស ដែលគិតថា
មនុស្សអាក្រក់តែងតែទទួលការឈឺចាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សអាក្រក់នៅតែបន្តរស់នៅ ចាស់ ហើយក្លាជាអ្នកមានសម្បត្តិកាន់តែច្រើន»។
ពូជពង្សរបស់ពួកគេក៏បានតាំងឡើងរឹងមាំជាមួយពួកគេនៅនិងមុខរបស់ពួកគេ...កូនចៅរបស់ពួកគេបានចំរើនឡើង
នៅចំពោះភ្នែករបស់គេដែរ
ល្បះទាំងពីរនេះ មានន័យដូចគ្នា ហើយបញ្ជាក់ថានេះជាការពិត។
ចំពោះមុខរបស់ពួកគេ...ចំពោះភ្នែករបស់គេ
ឃ្លាទាំងនេះមានន័យដូចគ្នា ពីព្រោះ «ភ្នែក» សំដៅលើមុខ។
មនុស្សអាក្រក់បានមើលឃើញកូនចៅរបស់ពួកគេធំធាត់ឡើងយ៉ាងរឹងមាំ
និងមានសម្បត្តិស្តុកស្តម្ភ។
ផ្ទះរបស់ពួកគេ
ពាក្យ «ផ្ទះ» នៅទីនេះ សំដៅដល់សមាជិកគ្រួសាររបស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ: «សមាជិកគ្រួសាររបស់គេ»
រំពាត់នៃព្រះជាម្ចាស់
នេះសំដៅដល់ការដាក់ទោសរបស់ព្រះជាម្ចាស់។
Job 21:10
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
មិនបានបាត់បង់កូនវា ណាមួយឡើយ
«នាងមិនដែលរលូតកូនទេ» ឬ «មេគោរបស់គេបង្កើតកូនមកមានសុខភាពល្អ
និងរឹងមាំ»
កូនតូចៗរបស់វាឲ្យចេញទៅដូចជាហ្វូងចៀម
លោកយ៉ូបប្រៀបធៀបក្មេងៗទាំងនេះទៅនឹងកូនចៀម ដើម្បីបញ្ជាក់ថា ពួកគេរត់
លេង និងសប្បាយរីករាយ។
គែន()
ជាឧបករណ៍ភ្លេងម៉្យាងដែលមានក្បាលដូចជាស្គរ ដែលអាចគោះនឹងដៃ
ហើយមានបំណែកដែលនៅជុំវិញ
ដែលធ្វើឲ្យមានសម្លេងនៅពេលគេអង្រួនឧបករណ៍ភ្លេងនេះ
Job 21:13
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
ថ្លៃរបស់គេ
«ពេលវេលានៃជីវិតរបស់ពួកគេ»
ពួកគេបានធ្លាក់យ៉ាងយឺតៗទៅក្នុងស្ថាននរក
នេះជារបៀបយ៉ាងសមគួរដែលនិយាយថា ពួកគេស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេស្លាប់ទៅដោយក្តីសុខសាន្ត»
(ដឹងពីទ្រង់) ផ្លូវរបស់ទ្រង់
នេះសំដៅដល់របៀបដែលព្រះចង់ឲ្យមនុស្សប្រព្រឹត្ត។
តើព្រះចេស្តារួគឺជាអ្វី ដែលយើងត្រូវថ្វាយបង្គំព្រះអង្គ? តើយើងនឹងទទួលបានប្រយោជន៍អ្វីមកវិញ
បើយើងអធិស្ឋានទៅព្រះអង្គ?
មនុស្សអាក្រក់ប្រើសំនួរនេះដើម្បីប្រមាថព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងមិនជឿថា នេះជាព្រះដ៏ពេញដោយចេស្តារួ
ដែលស័ក្តិសមសម្រាប់ការថ្វាយបង្គំរបស់យើងនោះទេ។
គាត់មិនអាចធ្វើអ្វីបានទាំងអស់សម្រាប់យើង»។
Job 21:16
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
មើល៍! តើទ្រព្យទាំងនោះមិនបាននៅក្នុងដៃរបស់គេទេឬអី?
នៅទីនេះ «ដៃ» សំដៅលើអំណាច ឬការត្រួតត្រារបស់ពួកគេ។
លោកយ៉ូបប្រើសំណួរនេះដើម្បីជំទាស់នឹងមិត្តរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «មើល៍ មនុស្សអាក្រក់ទាំងនេះ ជំទាស់ថា
ពួកគេបានធ្វើឲ្យខ្លួនពួកគេបានចម្រុងចម្រើនឡើង!»
តើប៉ុន្មានដង...គ្រោះមហន្តរាយធ្លាក់មកលើគេនោះ?
លោកយ៉ូបប្រើសំណួរនេះដើម្បីបញ្ជាក់ថាវាហាក់ដូចជាសម្រាប់គាត់
ព្រះមិនបានដាក់ទោសមនុស្សអាក្រក់ញឹកញាប់នោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាមិនញឹកញាប់...គ្រោះមហន្តរាយរបស់ពួកគេធ្លាក់មកលើគេនោះ»។
ចង្កៀងរបស់មនុស្សអាក្រក់ បានរលត់នោះ
លោកយ៉ូបប្រៀបធៀបការរលត់ចង្កៀងទៅនឹងមនុស្សស្លាប់។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលព្រះនាំឲ្យពួកគេស្លាប់យ៉ាងឆាប់រហ័ស»
ចង្កៀងរបស់មនុស្សអាក្រក់
លោកយ៉ូបប្រៀបធៀបជីវិតរបស់មនុស្សអាក្រក់ ទៅនឹងចង្កៀងដែលកំពុងឆេះ។
តើប៉ុន្មានដងដែលវាបានកើតឡើង...ក្នុងសេចក្ដីក្រោធរបស់ព្រះអង្គនោះ?
លោកយ៉ូបប្រើសំណួរទីពីរដើម្បីបញ្ជាក់ថា វាដូចគ្នាទៅនឹងគេ
ដែលព្រះមិនបានដាក់ទោសមនុស្សអាក្រក់ញឹកញាប់នោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាមិនញឹកញាប់ទេ...ក្នុងសេចក្ដីក្រោធរបស់ទ្រង់»។
តើប៉ុន្មានដង...ខ្យល់ព្យុះផាត់យកទៅនោះ?
លោកយ៉ូបប្រើសំណួរទីបីដើម្បីបញ្ជាក់ថា
វាដូចគ្នានឹងមនុស្សដែលព្រះមិនបានដាក់ទោសមនុស្សអាក្រក់ភ្លាម។
របៀបផ្សេងទៀតនៃការបកប្រែ: «វាមិនញឹកញាប់...ខ្យល់ព្យុះផាត់យកទៅនោះ?
ពួកគេដូចជាចំបើងនៅពីមុខខ្យល់ ឬដូចជាអង្កាមដែលខ្យល់ព្យុះផាត់យកទៅនោះ?
សេចក្ដីស្លាប់របស់មនុស្សអាក្រក់ដែលបាននិយាយ
ដូចជាពួកវាជាចម្បើងដែលគ្មានតម្លៃ ហើយដូចជាអង្កាមដែលខ្យល់ផាត់ទៅ។
នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានយកពួកគេចេញដូចជាខ្យល់ផាត់អង្កាម»
Job 21:19
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
អ្នកនិយាយថា
ពាក្យទាំងនេះត្រូវបានបន្ថែមដោយរបៀបបកស្រាយស្មើរតែទាំងស្រុងដើម្បី
ធ្វើឲ្យវាច្បាស់លាស់ថា លោកយ៉ូបដកស្រង់មិត្តរបស់លោកក្នុងផ្នែកបន្ទាប់។
ព្រះជាម្ចាស់បានដាក់ទោសដល់កូនចៅរបស់គេឲ្យសងនូវដែលកំហុសគេ
កំហុសត្រូវបាននិយាយដូចជាអ្វីមួយដែលអាចត្រូវបានស្តារឡើងសម្រាប់ប្រើនៅពេលក្រោយ។
នៅទីនេះ «សង» សំដៅលើការដាក់ទោសសម្រាប់អំពើបាប។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះបានកត់ត្រាអំពើបាបរបស់មនុស្ស
បន្ទាប់មកទ្រង់ដាក់ទោសកូនចៅរបស់ពួកគេសម្រាប់ការអាក្រក់របស់គេដែលបានប្រព្រឹត្ត»
ចូរឲ្យគេសងដោយខ្លួនឯង
លោកយ៉ូបចាប់ផ្តើមបញ្ចេញគំនិតផ្ទាល់របស់លោក។
វាអាចជួយបញ្ជាក់ភាពពិតប្រកដនេះ។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
ខ្ញុំនិយាយ «ចូរឲ្យគេសងដោយខ្លួនឯង»
ចូរឲ្យភ្នែករបស់គេបានឃើញ
នៅទីនេះ «ភ្នែក» សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរឲ្យគេឃើញ»
ចូរឲ្យផឹកសេចក្ដីក្រោធនៃព្រះចេស្តាផង
នៅទីនេះ សេចក្ដីក្រោធនៃព្រះបាននិយាយ វាហាក់ដូចជាការផឹក
ដែលមនុស្សម្នាក់អាចភ្លក់ ហើយការភ្លក់
ជាការប្រៀបធៀបសម្រាប់ការមានបទពិសោធន៍នៃការផឹក។
លោកយ៉ូបចង់ឲ្យមនុស្សអាក្រក់ជួបប្រទះការដាក់ទោសរបស់លោក។
តើហេតុអ្វីបានជាគេខ្វល់ពីគ្រួសាររបស់គេ ជំនាន់ក្រោយគេ ពេលចំនួនខែនៃជីវិតគេ
ត្រូវកាត់ខ្លីហើយនោះ?
លោកយ៉ូបប្រើសំណួរនេះដើម្បីបង្ហាញថា ការដាក់ទោសកូនចៅរបស់មនុស្សអាក្រក់
គឺមិនស័ក្តិសមទេ។ នេះអាបញ្ជាក់ក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«សម្រាប់មនុស្សអាក្រក់មិនបានយកចិត្តទុកដាក់អំពីគ្រួសាររបស់គេបន្ទាប់ពីគេស្លាប់ទៅនោះទេ!»
ពេលចំនួនខែនៃជីវិតគេ ត្រូវកាត់ខ្លីហើយនោះ
នេះជារបៀបដ៏សមរម្យនៃការនិយាយថាគេស្លាប់។
ពេលចំនួនខែនៃជីវិតគេ
ឃ្លានេះសំដៅលើរយៈពេលនៃជីវិតរបស់គេ។

generated on Wed Sep 10 16:16:32 2025

Job 21:22
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
តើមានអ្នកណាអាចបង្រៀនចំណេះដឹងរបស់ព្រះជាម្ចាស់បានទេ ព្រោះព្រះអង្គជំនុំជម្រះសូម្បីពួកអ្នកដែលនៅទីខ្ពស់?
លោកយ៉ូបប្រើសំណួរនេះដើម្បីបញ្ជាក់ថា ព្រះជាម្ចាស់ដឹងគ្រប់យ៉ាង។
របៀបផ្សេងទៀតនៃការបកប្រែ: «យ៉ាងជាក់ស្តែង
មិនមានអ្នកណាម្នាក់បង្រៀនអ្វីមួយដល់ព្រះបានទេ
ព្រោះព្រះអង្គជំនុំជម្រះសូម្បីអ្នកដែលនៅទីខ្ពស់»។
ពួកអ្នកដែលនៅទីខ្ពស់
អាចមានន័យពីរគឺ ◌: ទី១) ពួកអ្នកដែលនៅស្ថានសួគ៌ (UDB) ឬ ទី២) មនុស្សមានអំណាច
មនុស្សម្នាក់បានស្លាប់ទាំងមានកម្លាំងពេញលេញ
លោកយ៉ូបធ្វើឲ្យផ្ទុយពីបុរសម្នាក់នេះដែលស្លាប់ក្នុងសុខភាពដ៏ល្អនិងសុខសាន្ត ទៅនឹងមនុស្សដែលស្លាប់ក្នុងទុក្ខសោកនិងការឈឺចាប់ ក្នុង ២១:២៥។
អ្នកអាចធ្វើឲ្យវាជាក់លាក់។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
មានមនុស្សពីរនាក់ ម្នាក់អាចស្លាប់នៅក្នុងកម្លាំងរបស់គេ»
រូបកាយរបស់គាត់ពេញទៅដោយទឹកដោះ
ទាំងពីរនេះ មានន័យថា មនុស្សដែលមានសុខភាពល្អបំផុត។
រូបកាយរបស់គាត់ពេញទៅដោយទឹកដោះ ហើយខួរឆ្អឹងខ្នង
របស់គាត់គឺមានសម្ផើមហើយមានសុខភាពល្អ
ទាំងពីរនេះ មានន័យថា មនុស្សដែលមានសុខភាពល្អបំផុត។
រូបកាយរបស់គាត់ពេញទៅដោយទឹកដោះ
ពាក្យ «ទឹកដោះ» មានន័យថា «ធាត់»។ អត្ថន័យដទៃទៀតគឺ
គាត់ត្រូវចិញ្ចឹមបានល្អ។ របៀបផ្សេងទៀតនៃការបកប្រែ:
«រាងកាយរបស់គាត់ពេញទៅដោយខ្លាញ់»
ហើយខួរឆ្អឹងខ្នងរបស់គាត់គឺមានសម្ផើមហើយមានសុខភាពល្អ
នេះជាគ្រាមភាសាមានន័យថា រូបកាយរបស់គេនៅក្មេង ហើយមានសុខភាពល្អ។
Job 21:25
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
ម្នាក់ទៀតស្លាប់ទៅ
លោកយ៉ូបប្រៀបធៀបមនុស្សម្នាក់នេះនឹងម្នាក់ទៀតដែលស្លាប់ក្នុងក្តីសុខសាន្ត ក្នុង ២១:២២។
ទាំងមានការជូរល្វីងនៃព្រលឹង
នៅទីនេះទុក្ខព្រួយត្រូវបាននិយាយ វាដូចជារស់ជាតិជូរល្វីង ហើយ «ព្រលឹង» សំដៅដល់ខ្លួនមនុស្សទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ: «ជាមួយកំហឹង
និង ការអន់ចិត្ត» ឬ «បន្ទាប់ពីរស់នៅជីវិតដ៏ក្រៀមក្រំ»
មិនដែលបានស្គាល់បទពិសោធន៍នៃសេចក្តីល្អ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានបទពិសោធន៍តែនឹងរឿងអាក្រក់»
ពួកគេដេកចុះដូចគ្នាទៅក្នុងធូលីដី
នេះជារបៀបដ៏សមរម្យក្នុងការនិយាយថាពួកគេបានស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេទាំងពីរបានស្លាប់
ហើយមនុស្សបានបញ្ចុះពួកគេ»
ដង្កូវគ្របពីលើពួកគេទាំងពីរដែរ
ដង្កូវត្រូវបានផ្សារភ្ជាប់ជាមួយនឹងសាកសពដែលពុករលួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដង្កូវនៅក្នុងធូលីដី ស៊ីសាកសពរបស់ពួកគេ»
Job 21:27
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
មើល៍
លោកយ៉ូបប្រើឃ្លានេះ
ដើម្បីហៅចំណាប់អារម្មណ៍ទៅកាន់ផ្នែកបន្ទាប់ដែលនឹងមកដល់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពិនិត្យមើល»
តើផ្ទះរបស់អ្នកធំនៅឯណាពេលនេះ? តើទីលំនៅរបស់មនុស្សអាក្រក់ រស់នៅទីណាដែរ?
លោកយ៉ូបជឿថាមិត្តរបស់លោកនឹងសួរសំណួរនេះដើម្បីស្តីបន្ទោសលោក។
សំណួរទាំងពីរមានន័យដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ: «មើល៍!
ផ្ទះរបស់អ្នកដឹកនាំអាក្រក់ គឺរលាយសូន្យទៅ។
ត្រសាលនៃពួកមនុស្សអាក្រក់នឹងលែងឃើញមានទៀត»។
Job 21:29
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
តើអ្នករាល់គ្នាមិនបានសួរ ពួកអ្នកដំណើរទេឬអី? តើអ្នករាល់គ្នាមិនស្គាល់សក្ខីភាព
ដែលពួកគេអាចប្រាប់ទេ...ពីថ្ងៃនៃសេចក្តីក្រោធ?
លោកយ៉ូបប្រើសំណួរនេះដើម្បីស្តីបន្ទោសមិត្តភក្តិរបស់លោក
សម្រាប់ការមិនរៀនសូត្រពីមនុស្សដែលធ្វើដំណើរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកគួរតែស្តាប់អស់អ្នកដែលបានធ្វើដំណើរ ទៅកាន់នានា។
សូម្បីតែពួកគេនឹងប្រាប់អ្នក...ពីថ្ងៃនៃព្រះពិរោធ»។
មនុស្សអាក្រក់ គឺរក្សាពីថ្ងៃនៃគ្រោះមហន្តរាយ ហើយដែលគេត្រូវនាំចេញពីថ្ងៃនៃសេចក្តីក្រោធ
ប្រយោគទាំងនេះមានន័យដូចគ្នា។ នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះប្រណីសណ្តោសពួកមនុស្សអាក្រក់
នៅពេលដែលគេធ្វើបាបនៅកន្លែងណាមួយ»
Job 21:31
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយទៅកាន់មិត្តរបស់លោក។
តើនរណានឹងដាក់ទោសដល់ផ្លូវរបស់មនុស្សអាក្រក់នៅចំពោះមុខរបស់គេ?
លោកយ៉ូបប្រើសំណួរនេះ ដើម្បីប្រឆាំងនឹងជំនឿរបស់មិត្តរបស់លោក
ថាមនុស្សអាក្រក់តែងតែត្រូវទទួលការកាត់ទោស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាម្នាក់ថ្កោលទោសមនុស្សអាក្រក់នៅចំពោះមុខមនុស្សអាក្រក់ទេ»។
ចំពោះមុខរបស់គេ
នេះមានន័យថាគ្មានអ្នកណាម្នាក់នឹងទៅដោយត្រង់ដោយចំពោះមនុស្សអាក្រក់
ហើយថ្កោលទោសពួកគេដោយផ្ទាល់នោះទេ។
តើនរណានឹងសងគេវិញ ដល់អ្វីដែលគេបានប្រព្រឹត្ត?
លោកយ៉ូបប្រើសំណួរនេះ ដើម្បីប្រឆាំងនឹងជំនឿរបស់មិត្តរបស់លោក
ថាមនុស្សអាក្រក់តែងតែត្រូវទទួលការកាត់ទោស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាម្នាក់សងគេសម្រាប់ការអាក្រក់ដែលគេបានធ្វើនោះទេ»។
នរណានឹងសែង
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សម្នានឹងសែងគេ»
ហើយគំនរដីនៅតាមច្រកភ្នំនឹងទន់ស្រួលដល់គេ
លោកយ៉ូបនឹកស្រមៃថាមនុស្សស្លាប់នឹងរីករាយនឹងដីដែលដាក់នៅលើគេ។
នេះមានន័យថាមនុស្សអាក្រក់នឹងមានការស្លាប់ល្អ
នឹងបញ្ចុះយ៉ាងប្រសើរបន្ទាប់ពីជីវិតដ៏ពេញបរិបូរ។ «គំនរដី»
សំដៅលើដីដែលគ្របលើផ្នូរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គេនឹងរីករាយជាមួយនឹងគម្របដីនៃជ្រលងភ្នំ» ឬ
«គេនឹងរីករាយនឹងការបញ្ចុះទៅក្នុងដីនៃជ្រលងភ្នំ»
ហើយមនុស្សទាំងអស់នឹងទៅតាមគេដែរ ដូចជាមានមនុស្សច្រើនឥតគណនា នៅចំពោះមុខគេដែរ
លោកយ៉ូបសង្កត់ធ្ងន់ថា
នឹងមានក្រុមមនុស្សដ៏ធំចូលរួមពិធីដង្ហែរសពមនុស្សអាក្រក់ ក្នុងរូបភាពនេះ
ដើម្បីលើកកិត្តិយសគេ។
Job 21:34
ប្រយោគភ្ជាប់
លោកយ៉ូបបញ្ចប់ការនិយាយទៅកាន់មិត្តរបស់លោក។
ហេតុអ្វីបានអ្នករាល់គ្នាសម្រាលទុក្ខខ្ញុំជាមួយនឹងពាក្យគ្មានន័យ ពីព្រោះចម្លើយរបស់អ្នករាល់គ្នា
គឺគ្មានប្រយោជន៍តែជាការកុហក?
លោកយ៉ូបប្រើសំណួរនេះ ដើម្បីបន្ទោសមិត្តរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចលួងលោមខ្ញុំដោយសមហេតុផលបានទេ។
ចម្លើយរបស់អ្នកទាំងអស់សុទ្ធតែមិនត្រឹមត្រូវ»។

22 [1]លោកអេលីផាស ជនជាតិថេម៉ាន ឆ្លើយឡើងថា៖[2]«តើមនុស្សមានប្រយោជន៍អ្វីសម្រាប់ព្រះជាម្ចាស់? តើមនុស្សមានប្រាជ្ញា មានប្រយោជន៍អ្វីសម្រាប់ព្រះជាម្ចាស់?[3]
បើអ្នកជាមនុស្សសុចរិត តើមានអ្វីដែលជាសំអាងដល់ព្រះជាម្ចាស់? បើអ្នកកែផ្លូវអ្នកឲ្យត្រឹមត្រូវឡើង តើជាកម្រៃដល់ព្រះអង្គឬ?

generated on Wed Sep 10 16:16:32 2025

[4]តើដោយព្រោះតែអ្នកមានសេចក្ដី កោតខ្លាចដល់ព្រះជាម្ចាស់ បានជាព្រះអង្គបន្ទោសអ្នក ហើយយកអ្នកមកដាក់ទោសឬ?[5]តើមិនមែនអំពើអាក្រក់អ្នកធំទេឬ? ហើយអំពើទុច្ចរិតរបស់អ្នកក៏មិនចេះចប់ដែរឬ?
[6]ដ្បិតអ្នកមានតម្រូវការ និងចង់បានសំណង ពីការខ្ចីរបស់បងប្អូនអ្នកដោយឥតហេតុ ហើយបានជំរឹតទាំងដោះយកខោអាវ ពីពួកគេផង។[7]អ្នកមិនបានឲ្យទឹកដល់មនុស្ស ហេវផឹកឡើយ ក៏បានបង្អត់អាហារដល់មនុស្សឃ្លានដែរ[8]ទោះបីអ្នកជាមនុស្សខ្លាំងពូកែ បានជាម្ចាស់លើផែនដី ហើយជាមនុស្សមានស្មោះត្រង់ក្ដី សូមរស់នៅជាមួយវាទៅ។
[9]អ្នកបានបណ្តេញស្ត្រីមេម៉ាយ ឲ្យទៅដោយដៃទទេ ហើយអ្នកបានបំបាក់ដៃរបស់ក្មេងកំព្រា។[10]ហេតុនោះបានជាមានអន្ទាក់នៅព័ទ្ធជុំវិញអ្នក ហើយមានសេចក្ដីស្ញែងខ្លាចភ្លាមៗ មកបំភ័យអ្នក។[11]មានសេចក្ដីងងឹតឲ្យអ្នកមើលមិនឃើញ ឬជាទឹកជន់សាយមកគ្របលើអ្នកវិញ។
[12]តើព្រះអង្គមិនគង់នៅជាន់ខ្ពស់ នៅស្ថានសួគ៌ទេឬ? ចូរមើលផ្កាយដ៏ខ្ពស់ទាំងប៉ុន្មាន ដែលជាខ្ពស់ដល់ណាទៅ![13]អ្នកពោលថា តើព្រះជាម្ចាស់ជ្រាបអ្វីខ្លះ? តើព្រះអង្គអាចទតទម្លុះសេចក្ដីងងឹត មកជំនុំជម្រះបានដែរឬ?[14]មានពពកយ៉ាងក្រាស់នៅហ៊ុមព្រះអង្គជុំវិញ មិនឲ្យឃើញអ្វីឡើយ ហើយព្រះអង្គក៏យាងនៅតែលើផ្ទៃមេឃ។
[15]តើអ្នករក្សាទុកផ្លូវចាស់ ដែលមនុស្សអាក្រក់បានដើរហើយ[16]ជាពួកមនុស្សដែលត្រូវឆក់យកទៅមុនកំណត់ កន្លែងជ្រកកោនរបស់គេ បានហូរទៅបាត់ដូចជាទឹកជ្រោះ[17]គេបានទូលដល់ព្រះជាម្ចាស់ថា សូមយាងចេញពីយើងទៅ ហើយថា តើព្រះដ៏មានគ្រប់ព្រះចេស្តា អាចធ្វើអ្វីដល់យើងបាន?
[18]ប៉ុន្តែ គឺព្រះអង្គដែលបានបំពេញផ្ទះគេ ដោយអស់ទាំងរបស់ល្អផង តែសូមឲ្យគំនិតនៃមនុស្សអាក្រក់ នៅឆ្ងាយពីខ្ញុំទៅ។[19]ពួកមនុស្សសុចរិតក៏ឃើញ ហើយមានអំណរ ពួកមនុស្សផូរផង់នឹងសើចឡកឲ្យគេថា។[20]ពួកអ្នកដែលបានលើកគ្នាទាស់នឹងយើង គេត្រូវសាបសូន្យហើយ សំណល់របស់គេ នោះភ្លើងបានឆេះអស់ទៅ។
[21]ពេលនេះ ចូរចុះសម្រុងជាមួយព្រះជាម្ចាស់ ហើយមានសេចក្ដីមេត្រីនឹងព្រះអង្គចុះ យ៉ាងនោះនឹងបានជាប្រយោជន៍ដល់អ្នក។[22]ខ្ញុំសូមឲ្យអ្នកទទួលសេចក្ដីបង្រៀន ពីព្រះឧស្ឋរបស់ព្រះអង្គ ហើយប្រមូលទុកអស់ទាំងព្រះបន្ទូល នៃព្រះអង្គនៅក្នុងចិត្តចុះ។
[23]បើអ្នកវិលត្រឡប់មកឯព្រះ ដ៏មានគ្រប់ព្រះចេស្តាវិញ នោះនឹងបានតាំងឡើងហើយ គឺបើអ្នកកម្ចាត់អំពើទុច្ចរិតឲ្យឆ្ងាយចេញ ពីទីលំនៅរបស់អ្នក។[24]ហើយបោះបង់ចោលទ្រព្យវិសេស របស់អ្នកទៅក្នុងធូលីដី ព្រមទាំងមាសពីទឹកដីអូភារទៅក្នុងថ្ម នៅបាតជ្រោះទឹកផង[25]នោះព្រះដ៏មានគ្រប់ព្រះចេស្តា ព្រះអង្គនឹងបានជាទ្រព្យវិសេស និងជាប្រាក់មានសាច់សុទ្ធដល់អ្នកហើយ។
[26]ដ្បិតយ៉ាងនោះឯងនឹងបានពេញចិត្ត ដោយសារព្រះដ៏មានគ្រប់ព្រះចេស្តាវិញ ក៏នឹងអាចងើបមុខមើលចំទៅឯព្រះអង្គផង។[27]លោកនឹងអធិស្ឋានដល់ព្រះអង្គ ហើយព្រះអង្គនឹងទទួល យ៉ាងនោះឯងនឹងបានលាបំណន់របស់អ្នក។[28]កាលណាលោកសម្រេចធ្វើការអ្វី នោះនឹងបានសម្រេចដូចបំណង និងមានពន្លឺភ្លឺមកលើផ្លូវរបស់អ្នកដែរ។
[29]ព្រះជាម្ចាស់ទម្លាក់មនុស្សមានអំនួត តែព្រះអង្គសង្គ្រោះមនុស្សទន់ទាប។[30]សូម្បីតែមនុស្សមានទោសក៏ព្រះអង្គសង្គ្រោះដែរ ដូច្នេះ ព្រះអង្គនឹងជួយលោក តាមអំពើដ៏បរិសុទ្ធដែលលោកប្រព្រឹត្ត»។

Job 22:1
លោកអេលីផាស ជនជាតិថេម៉ាន
សូមបកប្រែឈ្មោះមនុស្សនេះ ឲ្យដូចនៅក្នុង ២:១១។
តើមនុស្សអាចប្រើជាប្រយោជន៍ដល់ព្រះជាម្ចាស់ទេ? តើមនុស្សមានប្រាជ្ញា អាចប្រើជាប្រយោជន៍ដល់ព្រះជាម្ចាស់ទេ?
លោកអេលីផាស ប្រើសំណួរនេះ ដើម្បីសង្កត់ធ្ងន់ថា សកម្មភាព ឬប្រាជ្ញារបស់មនុស្សគឺមិនមានប្រយោជន៍ចំពោះព្រះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សមិនអាចមានប្រយោជន៍ចំពោះព្រះទេ។ អ្នកប្រាជ្ញក៏មិនមានប្រយោជន៍អ្វីសម្រាប់ទ្រង់»។
បើលោកជាមនុស្សសុចរិត តើអាចសព្វព្រះហឫទ័យដល់ព្រះជាម្ចាស់ទេ? បើផ្លូវរបស់អ្នកគ្មានកន្លែងបន្ទោសបាន តើព្រះអង្គបានចំណេញអ្វីពីការនេះ?
ស្ថានភាពទាំងពីរនេះមានអត្ថន័យដូចគ្នា។ លោកអេលីផាស ប្រើសំណួរនេះដើម្បីបញ្ជាក់ថាសកម្មភាពរបស់លោកយ៉ូបមិនបានជួយអ្វីដល់ព្រះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះដ៏ពេញដោយព្រះចេស្តាមិនបានទទួលអ្វីដែលប្រសើរឡើងនោះទេ ទោះបីជាអ្នកសុចរិតក្តី។ ព្រះអង្គមិនបាចម្រើនអ្វីឡើងលើយ ទោះបីជាអ្នកធ្វើឲ្យផ្លូវរបស់អ្នកគ្មានកន្លែងបន្ទោសក្តី»។
Job 22:4
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
តើដោយព្រោះតែការគោរពរបស់អ្នកដល់ព្រះជាម្ចាស់ ដែលព្រះអង្គបានបន្ទោសអ្នក ហើយបានយកអ្នកជំនុំជម្រះ ឬ? តើមិនមែនអំពើអាក្រក់របស់អ្នកអស្ចារ្យទេឬ? តើអំពើទុច្ចរិតរបស់អ្នកមិនអាចបញ្ចប់បានទេឬ?
លោកអេលីផាសប្រើសំណួរនេះដើម្បីបន្ទោសលោកយ៉ូប និងចោទប្រកាន់លោកពីការប្រព្រឹត្តអំពើដែលគួរឲ្យភ័យខ្លាច។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាពិតជាមិនមែនដោយសារអ្នកត្រូវបានជ្រើសរើសដើម្បីទ្រង់នោះទេ ដែលព្រះបន្ទោសអ្នកនិងយកអ្នកមកកាន់ការវិនិច្ឆ័យទោស!
មិនដូចជាអ្នកដឹងនោះទេ ទ្រង់ដាក់ទោសអ្នក ពីព្រោះការអាក្រក់ដ៏អស្ចារ្យរបស់អ្នក និងការបន្តធ្វើអំពើបាបរបស់អ្នក!»
Job 22:6
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
ដ្បិត លោកតម្រូវឲ្យមានរបស់អ្វីមកបញ្ចាំ
នេះសំដៅដល់ការយកអ្វីមួយរបស់អ្នកឲ្យខ្ចី ពីអ្នកខ្ចីដើម្បីអះអាងថាអ្នកខ្ចីសងគាត់ត្រឡប់មកវិញ។
ហើយលោកបានជំរឹតទាំងដោះយកសម្លៀកបំពាក់ ពីពួកអ្នកដែលគ្មានអ្វីបិតបាំង
លោកអេលីផាសកំពុងចោទប្រកាន់លោកយ៉ូប ដែលយកសំលៀកបំពាក់ដូចជាសុវត្ថិភាព ពីជនក្រីក្រ ដែលបានខ្ចីប្រាក់ពីគាត់។
ដកហូតនំប៉័ង (អាហារ)
ទីនេះ «នំប៉័ង» ជាទូទៅគឺសំដៅដល់អាហារ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដកហូតអាហារ»
ម្ចាស់លើផែនដី ទោះ...សូមរស់នៅក្នុងការនេះចុះ
លោកអេលីផាសកំពុងបន្ទោសលោកយ៉ូបដែលយកដីពីមនុស្សក្រីក្រ និងមិនអនុញ្ញាតឲ្យពួកគេរស់នៅលើទឹកដីនោះ។ គាត់កំពុងបញ្ជាក់ចំនុចនេះដោយទ្វេរាជាពីរ។
ម្ចាស់លើផែនដី
លោកអេលីផាស កំពុងពន្លើសបន្ថែមអំពីចំនួនដីដែលលោកយ៉ូបកាន់កាប់ ដើម្បីបង្ហាញយ៉ូបថា ជាមនុស្សលោកភលន់។ របៀបផ្សេងទៀតនៃការបកប្រែ: «ម្ចាស់នៃដីដ៏ច្រើនលើសលុប»
Job 22:9
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
លោកបានបណ្តេញស្ត្រីមេម៉ាយ ឲ្យទៅដោយដោយគ្មានអ្វីទាំងអស់
«អ្នកបានធ្វើឲ្យស្ត្រីមេមា៉ាយចេញទៅដោយមិនមានអ្វីទាំងអស់»
ស្ត្រីមេម៉ាយ
មនុស្សស្រីដែលប្តីបានស្លាប់ចោល
លោកបានបំបាក់ដៃរបស់ក្មេងកំព្រាផង
នៅទីនេះ «ដៃ» សំដៅលើអំណាច។ នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «សូម្បីតែក្មេងកំព្រាក៏ត្រូវអ្នកជិះជាន់ដែរ»
អន្ទាក់នៅជុំវិញលោក...មានសេចក្ដីងងឹត...ទឹកជន់ឡើង
ការប្រៀបធៀបនៃពាក្យនីមួយៗមានបញ្ហា និងគ្រោះថ្នាក់នៅជុំវិញលោកយ៉ូបដោយសារតែអំពើបាបរបស់លោក។
ទឹកជន់ឡើង
«ទឹកជំនន់»
Job 22:12
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
តើព្រះអង្គមិនបានគង់នៅទីខ្ពស់នៃស្ថានសួគ៌ទេឬ?
លោកអេលីផាសប្រើសំណួរនេះដើម្បីណែនាំថា ព្រះជាម្ចាស់បានឃើញអំពើបាបរបស់លោកយ៉ូបហើយព្រះអង្គនឹងកាត់ទោសគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់គឺគង់នៅស្ថានសួគ៌ដ៏ខ្ពស់

generated on Wed Sep 10 16:16:32 2025

ហើយទ្រង់ទតឃើញគ្រប់យ៉ាងដែលកើតមានលើផែនដី»។
ចូរមើលផ្កាយដែលនៅទីខ្ពស់ទាំងនោះ តើខ្ពស់យ៉ាងណាទៅ!
លោកអេលីផាស បញ្ជាក់ថាព្រះគឺខ្ពស់ជាងពពួកផ្កាយ។
នេះអាចត្រូវបានធ្វើឲ្យឃើញច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ចូរមើល
តើពពួកផ្កាយនៅខ្ពស់យ៉ាងណា។ ព្រះគឺគង់នៅខ្ពស់ជាងពួកវា»
តើព្រះជាម្ចាស់ដឹងបានដូចម្តេច? តើព្រះអង្គអាចកាត់ក្តីតាមរយៈសេចក្តីងងឹតដែលក្រាស់បានទេ?
លោកអេលីផាសប្រើសំណួរនេះដើម្បីបញ្ជាក់ថា
លោកយ៉ូបបាននិយាយការនេះទាស់នឹងព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះមិនបានដឹងពីអ្វីដែលកើតឡើងផែនដីទេ។
ទ្រង់គង់នៅក្នុងពពកខ្មៅក្រាស់ ហើយក៏មិនវិនិច្ឆ័យទោសយើងដែរ»។
ព្រះអង្គយាងរំលងស្ថានសួគ៌
នៅទីនេះ «រំលង»
សំដៅលើរបាំងដែលមនុស្សពីបុរាណជឿថាបានញែកផែនដីពីស្ថានសួគ៌។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រង់គង់សែនឆ្ងាយនៅស្ថានសួគ៌
ដើម្បីទតមើលអ្វីដែលកើតឡើងនៅទីនេះ»
Job 22:15
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
តើលោកនៅតែរក្សាផ្លូវចាស់ ដែលមនុស្សអាក្រក់តែងតែដើរ
នៅទីនេះការធ្វើអំពើអាក្រក់ ដូចជាការដើរក្នុងផ្លូវអាក្រក់។
របៀបផ្សេងទៀតនៃការបកប្រែ: «តើអ្នកបន្តធ្វើអ្វីដែលមនុស្សអាក្រក់ធ្វើឬ»
ពួកមនុស្សដែលត្រូវដកយក
នៅទីនេះការស្លាប់ដែលបាននិយាយ ហាក់ដូចជាព្រះបានដកពួកគេចេញ។
នេះត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលស្លាប់» ឬ «អស់អ្នកដែលព្រះបានដកចេញ»
ជាពួកដែលគ្រិះបានហូរទៅបាត់ដូចជាទឹកទន្លេ
សេចក្តីស្លាប់របស់មនុស្សអាក្រក់ដែលបាននិយាយ ហាក់ដូចជាពួកគេបានសង់ផ្ទះ
ដែលគ្រឹះរបស់ពួកវាត្រូវបានហូរបាត់ដោយសារទឹកជំនន់។
តើព្រះដ៏មានគ្រប់ព្រះចេស្តា អាចធ្វើអ្វីឲ្យយើងបាន?
លោកអេលីផាសដកស្រង់សំនួរដែលមនុស្សអាក្រក់ប្រើដើម្បីប្រមាថព្រះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះដ៏មានគ្រប់ព្រះចេស្តា មិនអាចធ្វើអ្វី
បានទាំងអស់ឲ្យយើង!»
Job 22:18
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
ផែនការនៃមនុស្សអាក្រក់ គឺនៅឆ្ងាយពីខ្ញុំវិញ
ពាក្យ «នៅឆ្ងាយពីខ្ញុំ» មានថា លោកអេលីផាស បដិសេធពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
ខ្ញុំនឹងមិនស្តាប់ផែនការអាក្រក់របស់ពួកគេទេ»
ឃើញវាសនារបស់ពួកគេ
«ដឹងពីអ្វីដែលនឹងកើតឡើងចំពោះមនុស្សអាក្រក់»
សើចពួកគេដើម្បីចំអក
«ប្រមាថមើលងាយមនុស្សអាក្រក់»
អ្នកណាដែលទាស់នឹងយើងនឹងវិនាសទៅ
នៅទីនេះ «អស់អ្នកដែលក្រោកឡើង» សម្តៅដល់មនុស្សអាក្រក់។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានបំផ្លាញពួកមនុស្សអាក្រក់ដែលបានបង្ករទុក្ខទោសដល់យើង»
Job 22:21
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
ឥឡូវនេះ
លោកអេលីផាសប្រើពាក្យនេះ
ដើម្បីណែនាំអ្វីមួយយ៉ាងសំខាន់ដែលគាត់កំពុងនឹងនិយាយ។
សេចក្តីបង្រៀន ចេញពីព្រះឧស្ឋរបស់ព្រះអង្គ
នៅទីនេះ «ចេញពីព្រះឧស្ឋរបស់ព្រះអង្គ»
តំណាងនូវអ្វីដែលព្រះបានមានព្រះបន្ទូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«សេចក្តីបង្រៀនដែលព្រះបានមានព្រះបន្ទូល»
ប្រមូលទុកព្រះបន្ទូលរបស់ព្រះអង្គ
នៅទីនេះ ព្រះបន្ទូលរបស់ព្រះដែលមានព្រះបន្ទូល
ហាក់ដូចជាពួកគេទ្រព្យសម្បត្តិដែលលោកយ៉ូបអាចរក្សាទុកក្នុងឃ្លាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្បត្តិបទបញ្ញត្តិរបស់ព្រះអង្គ»
ចិត្តលោក
នៅទីនេះ «ចិត្ត» សំដៅលើគំនិតរបស់លោកយ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«គំនិតរបស់អ្នក» (UDB)
Job 22:23
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
លោកនឹងបានសង់ឡើង
លោកអេលីផាសប្រៀបធៀបការស្តារឡើងវិញរបស់លោកយ៉ូប
ទៅនឹងការសាងសង់ឡើងវិញនៃផ្ទះដែលបានរលំ។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទ្រង់នឹងព្យាបាលអ្នក ហើយធ្វើឲ្យអ្នកចម្រុងចម្រើនម្តងទៀង»
បើលោកដាក់អំពើទុច្ចរិតឲ្យឆ្ងាយពីទីលំនៅរបស់លោក
នៅទីនេះអំពើទុច្ចរិត
ត្រូវបានពណ៌នាដូចជាមនុស្សម្នាក់ដែលរស់នៅក្នុងលំនៅរបស់លោកយ៉ូប
ដែលត្រូវផ្លាស់ចេញ។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នក
និងគ្រប់គ្នាក្នុងផ្ទះរបស់អ្នកឈប់ធ្វើបាប»
ចូរ បោះចោលទ្រព្យរបស់លោកទៅលើធូលីដី
បោះចោលទ្រព្យសម្បត្តិទីក្នុងធូលីដី គឺធ្វើវាហាក់ដូចជាគ្មានសារសំខាន់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពិចារណាចុះ ភោគទ្រព្យរបស់អ្នក
នឹងទៅជាគ្មានសារសំខាន់ដូចជាធូលីដី»
មាសនៃអូភារនៅក្នុងចំណោមថ្ម នៃដងស្ទឹង
ដាក់មាសទៅក្នុងអូរ គឺធ្វើហាក់ដូចជាវាគ្មានតម្លៃជាងដុំថ្មនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «មាសរបស់អ្នកនឹងទៅជាគ្មានតម្លៃ
ដូចជាដុំថ្មនៅក្នុងអូរ»
អូភារ
នេះជាឈ្មោះនៃភូមិភាគមួយ ដ៏ល្បីល្បាញសម្រាប់មាសរបស់គេ។
ព្រះដ៏មានគ្រប់ព្រះចេស្តា នឹងបានជាទ្រព្យរបស់លោក និងជាប្រាក់ក៏ប្រណិតសម្រាប់អ្នកផង
នេះមានន័យថាព្រះនឹងមានតម្លៃចំពោះលោកយ៉ូបច្រើនជាងទ្រព្យសម្បត្តិនានា។
Job 22:26
ប្រយោគភ្ជាប់
លោកអេលីផាសបន្តការនិយាយទៅកាន់លោកយ៉ូប។
លោកនឹងអាចងើបមុខឡើងមើលទៅព្រះអម្ចាស់
នេះមានន័យថាលោកយ៉ូបនឹងមិនអាម៉ាស់ទៀតនោះទេ ប៉ុន្តែ
លោកនឹងទុកចិត្តលើព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកនឹងអាចចូលទៅជិតទ្រង់ដោយទំនុកចិត្ត»
ការនោះនឹងបានសម្រេចដល់លោក
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងធ្វើឲ្យលោកបានសម្រេច»
ពន្លឺនឹងភ្លឺលើផ្លូវរបស់អ្នកដែរ
ព្រះពររបស់ព្រះដែលបាននិយាយ គឺដូចជាពន្លឺនៅគ្រប់ទាំងផ្លូវរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«វានឹងបានដូចជាពន្លឺដែលបំភ្លឺលើផ្លូវនៅពីមុខអ្នក»
Job 22:29
ប្រយោគភ្ជាប់
នេះជាការបញ្ចប់ពាក្យរបស់លោកអេលីផាសទៅកាន់លោកយ៉ូប។
មនុស្សភ្នែកមើលចុះក្រោម
នៅទីនេះ «ភ្នែកមើលចុះក្រោម» សំដៅលើការបន្ទាបខ្លួន។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សបន្ទាបខ្លួន»
មនុស្សដែលមិនស្លូតត្រង់
ការបកប្រែខ្លះ អានថា «ទោះបីជាមនុស្សដែលមិនស្លូតត្រង់»។
អ្នកដែលបានសង្គ្រោះតាមរយៈដៃដ៏ត្រឹមត្រូវរបស់លោក
ការបកប្រែខ្លះអានថា:
«គាត់នឹងត្រូវបានសង្គ្រោះតាមរយៈភាពស្អាតស្អំនៃដៃរបស់គាត់»
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនឹងសង្គ្រោះអ្នក ពីព្រោះភាពស្អាតស្អំនៃដៃរបស់អ្នក»
តាមរយៈដៃដ៏ត្រឹមត្រូវរបស់លោក
នៅទីនេះ «ភាពស្អាតស្អំ» សម្តៅដល់ភាពស្លូតត្រង់ និង «ដៃ»

generated on Wed Sep 10 16:16:32 2025

សំដៅលើអ្វីដែលមនុស្សធ្វើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រោះអ្នកធ្វើអ្វីដែលត្រឹមត្រូវ»

---

23 [1]បន្តិចមកលោកយ៉ូប ក៏ឆ្លើយដោយថា៖[2]«ទោះបីថ្ងៃនេះការតួញត្អែររបស់ខ្ញុំពោពេញទៅដោយភាពជូរល្វីញ
ហើយដៃរបស់ខ្ញុំបានជាធ្ងន់ដោយព្រោះតែសំលេងថ្ងូររបស់ខ្ញុំ។
[3]ដូច្នេះ ខ្ញុំនឹងដឹងថា ខ្ញុំគួរស្វែងរកព្រះអង្គ! ដូច្នេះ ខ្ញុំនឹងចូលទៅចំពោះព្រះរាជដំណាក់របស់ព្រះអង្គដែរ![4]នោះខ្ញុំនឹងបានរៀបរាប់ពីដំណើរខ្ញុំ ដោយលំដាប់លំដោយទូលនៅចំពោះព្រះអង្គ ហើយនឹងប្រើមាត់របស់ខ្ញុំ ដើម្បីជជែកពីរឿងទាំងនោះ។[5]ខ្ញុំនឹងអាចរៀនបានពីព្រះបន្ទូល ជាមួយនិងការឆ្លើយរបស់ព្រះអង្គ
ហើយខ្ញុំនឹងបានយល់ព្រះអ្វីដែរព្រះជាម្ចាស់ មានបន្ទូលមកកាន់ខ្ញុំដែរ។
[6]តើព្រះអង្គបានប្រើអំណាចដ៏ធំមកតយុទ្ធនឹងខ្ញុំមែនឬ? មិនមែនទេ ព្រះអង្គបានប្រុងស្តាប់ខ្ញុំវិញ។[7]នៅទីនោះ មនុស្សទៀងត្រង់នឹងប្រឹក្សាជាមួយព្រះអង្គបាន យ៉ាងនោះខ្ញុំនឹងបានរួចជាដរាប ពីអំណាចចៅក្រមដែលជំនុំជម្រះខ្ញុំ។
[8]មើល! ខ្ញុំដើរទៅទិសខាងកើត តែព្រះអង្គមិនបាននៅទីនោះ ខ្ញុំក៏ទៅទិសខាងលិច ក៏មិនឃើញព្រះអង្គនៅទីនោះដែរ។[9]ខ្ញុំក៏ទៅទិសខាងជើង ជាកន្លែងដែលព្រះធ្វើការ តែខ្ញុំមិនអាចឃើញព្រះអង្គទេ ហើយនៅទិសខាងត្បូង ជាកន្លែងដែលព្រះអង្គពួនដើម្បីកុំឲ្យខ្ញុំរកព្រះអង្គឃើញ។
[10]ប៉ុន្តែ ព្រះអង្គស្គាល់ផ្លូវដើររបស់ខ្ញុំ ហើយកាលណាព្រះអង្គបានសាកលខ្ញុំស្រេចហើយ នោះខ្ញុំនឹងចេញមកដូចជាមាស។[11]ជើងខ្ញុំបានដើរជាប់តាមជំហានព្រះអង្គ ខ្ញុំបានកាន់តាមផ្លូវព្រះអង្គ ឥតងាកបែរទៅខាងណាឡើយ។[12]ខ្ញុំមិនដែលគេចចេញពីបទបញ្ជា នៃព្រះរឹមរបស់ព្រះអង្គទេ ខ្ញុំបានខំប្រមូលទុកព្រះបន្ទូល នៃព្រះឧស្ឋរបស់ព្រះអង្គ ជាជាងអាហារដែលខ្ញុំត្រូវការផង។
[13]ប៉ុន្តែ ព្រះអង្គមានគំនិតតែមួយ តើអ្នកណានឹងបំផ្លាស់បំប្រែ ព្រះហឫទ័យព្រះអង្គបាន? ការអ្វីដែលព្រះអង្គចង់ធ្វើ ព្រះអង្គក៏ធ្វើ។[14]ដ្បិតព្រះអង្គធ្វើសម្រេចសេចក្ដី ដែលបានតម្រូវទុកសម្រាប់ខ្ញុំ ហើយមានសេចក្ដីយ៉ាងនោះជាច្រើនផងដែរ។
[15]ដូច្នេះ ខ្ញុំក៏ភ័យស្លុតនៅចំពោះព្រះអង្គ ពេលខ្ញុំនឹកគិតពីព្រះអង្គ នោះខ្ញុំខ្លាចព្រះអង្គណាស់។[16]ដ្បិតព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំស្រយុតចិត្ត ព្រះដ៏មានគ្រប់ព្រះចេស្តា ព្រះអង្គបានធ្វើឲ្យខ្ញុំស្វែងខ្លាច។[17]ក៏ប៉ុន្តែ ខ្ញុំមិនបាននៅស្ងៀម ដោយព្រោះសេចក្ដីងងឹត ហើយក៏គ្របមុខដោយព្រោះភាពអន្ធការ។

Job 23:1
ទោះបីថ្ងៃនេះការតួញត្អែររបស់ខ្ញុំគឺជាភាពជូរល្វីង
នៅទីនេះពាក្យ «ទោះបីថ្ងៃនេះ» សង្កត់ធ្ងន់ថា មិត្តៗរបស់លោក ជជែកតវ៉ា
មិនត្រូវបានផ្លាស់ប្តូរស្ថានភាពរបស់លោកយ៉ូបនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្នុងសេចក្ដីក្រោធ ដោយអ្វីដែលអ្នកបាននិយាយ
ការតួញត្អែររបស់ខ្ញុំនៅតែមានភាពល្វីងជូរចត់»
ការតួញត្អែររបស់ខ្ញុំគឺជាភាពជូរល្វីញ
លោកយ៉ូបនិយាយពីការមិនបានតួញត្អែររបស់លោកទាស់នឹងព្រះ
ហាក់ដូចជារស់ជាតិជូរល្វីង នៅក្នុងមាត់របស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានចម្លើយនៃការតួញត្អែររបស់ខ្ញុំអាក្រក់ដូចជាអាហារជូរល្វីងនៅក្នុងមាត់របស់ខ្ញុំ»
ដៃរបស់ខ្ញុំ គឺបានធ្ងន់ទៅដោយព្រោះតែសំលេងថ្ងូររបស់ខ្ញុំ
អាចមានន័យពីរ គឺ: ទី១) «ខ្ញុំស្ទើរតែមិនអាចលើកដៃរបស់ខ្ញុំបាន
ដោយសារតែការឈឺចាប់របស់ខ្ញុំ» ឬទី២)
ដៃរបស់គាត់បន្តធ្វើឲ្យខ្ញុំរងទុក្ខទោះបីខ្ញុំស្រែកថ្ងូរយ៉ាងណាក៏ដោយ» កន្លែង «ដៃ»
សំដៅដល់អំណាចរបស់ព្រះជាម្ចាស់ដើម្បីដាក់ទោស។
Job 23:3
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ដូច្នេះខ្ញុំនឹងដឹងថា...ហើយខ្ញុំក៏អាចចូលទៅ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយបញ្ជាក់ការបំណងប្រាថ្នារបស់លោកយ៉ូបដើម្បីជួបជាមួយព្រះ។
ខ្ញុំគួរស្វែងរកព្រះអង្គ
«ខ្ញុំអាចស្វែងរកព្រះ»
ហើយខ្ញុំនឹងដាក់រឿងរ៉ាវរបស់ខ្ញុំ... បំពេញមាត់របស់ខ្ញុំ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយបញ្ជាក់ការបំណងប្រាថ្នារបស់លោកយ៉ូបដើម្បីពន្យល់ស្ថានភាពរបស់លោកទៅព្រះ
បំពេញមាត់របស់ខ្ញុំជាមួយជំលោះ
នៅទីនេះ «បំពេញមាត់របស់ខ្ញុំ» សំដៅលើការនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំគួរនិយាយពីជំលោះរបស់ខ្ញុំទាំងអស់»
ខ្ញុំនឹងបានរៀនពីព្រះបន្ទូល ជាមួយនិងការឆ្លើយរបស់ព្រះអង្គមកកាន់ខ្ញុំ
ឈ្លះទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់បំណងប្រាថ្នារបស់លោកយ៉ូប ដើម្បីឮចម្លើយរបស់ព្រះជាម្ចាស់។
ព្រះបន្ទូល ជាមួយនិងការឆ្លើយរបស់ព្រះអង្គមកកាន់ខ្ញុំ
«ចម្លើយដែលទ្រង់នឹងប្រទានមកខ្ញុំ»
Job 23:6
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
តើព្រះអង្គ
«តើព្រះអង្គ»
មាន
នេះសំដៅដល់កន្លែងដែលព្រះគង់នៅ។
ខ្ញុំនឹងបានលើកលែងទោស ជារៀងរហូតដោយការជំនុំជម្រះរបស់ខ្ញុំ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការវិនិច្ឆ័យរបស់ខ្ញុំនឹងលើកលែងទោសខ្ញុំជារៀងរហូត» ឬ «ព្រះ
ដែលជាចៅក្រមរបស់ខ្ញុំ នឹងមានព្រះបន្ទូលថា ខ្ញុំជាមនុស្សទៀងត្រង់ម្នាក់
និងសម្រាប់ទាំងអស់»
Job 23:8
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ទិសខាងកើត...ទិសខាងលិច...ទិសខាងជើង...ទិសខាងត្បូង
ដោយការសម្គាល់ ទាំងបួនទិសនេះ
លោកយ៉ូបបញ្ជាក់ថាគាត់បានឃើញគ្រប់ទីកន្លែងទាំងអស់។
Job 23:10
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ព្រះអង្គស្គាល់ផ្លូវដែលខ្ញុំដើរ
សកម្មភាពរបស់លោកយ៉ូប បាននិយាយហាក់ដូចជាផ្លូវដែលលោកដើរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះដឹងអ្វីដែលខ្ញុំធ្វើ»
ខ្ញុំនឹងចេញទៅដូចជាមាស
លោកយ៉ូបជឿថា ការសាកល្បងនឹងបង្ហាញថាលោកគឺបរិសុទ្ធដូចមាសសុទ្ធ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រង់នឹងឃើញថាខ្ញុំបរិសុទ្ធដូចមាស
ដែលមិនសុទ្ធត្រូវបានដុតរួច»
ជើងរបស់ខ្ញុំបានដើរជាប់តាមជំហានព្រះអង្គ
នៅទីនេះ «ជើងរបស់ខ្ញុំ» សំដៅលើលោកយ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានតាមផ្លូវដែលទ្រង់បានបង្ហាញខ្ញុំ»
ខ្ញុំបានរក្សាផ្លូវរបស់ព្រះអង្គ
ការស្តាប់ឱវាទរបស់លោកយ៉ូប
គឺបាននិយាយហាក់ដូចជាគាត់កំពុងដើរក្នុងផ្លូវដែលព្រះបានបង្ហាញគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានធ្វើអ្វីដែលទ្រង់បានប្រាប់ខ្ញុំឲ្យធ្វើ»
ក៏មិនងាកបែរទៅខាងណាដែរ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អនុវត្តតាមវាដោយជាក់លាក់»
ខ្ញុំមិនដែលត្រឡប់ក្រោយពី
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានគោរពតាមអ្វីដែលទ្រង់បានបង្គាប់មក»

generated on Wed Sep 10 16:16:32 2025

នៃព្រះឱស្ឋរបស់ព្រះអង្គ
ឃ្លានេះសំដៅដល់សារដែលព្រះបានមានព្រះបន្ទូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ដែលទ្រង់បានមានព្រះបន្ទូល»
ខ្ញុំបានប្រមូលសម្បត្តិទុកក្នុងចិត្តរបស់ខ្ញុំ
នៅទីនេះ «ចិត្តរបស់ខ្ញុំ» សំដៅដល់មនុស្សផ្នែកខាងក្នុងរបស់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានស្តារមនុស្សផ្នែកខាងក្នុងរបស់ខ្ញុំ» ឬ
«ខ្ញុំគិតជារឿយៗអំពី»
ព្រះបន្ទូល នៃព្រះឱស្ឋរបស់ព្រះអង្គ
នេះសំដៅដល់ព្រះបន្ទូលរបស់ព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលទ្រង់បានមានបន្ទូល»
Job 23:13
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ប៉ុន្តែ ព្រះអង្គសប្បុរស តើអ្នកណានឹងអាចបែរព្រះអង្គបាន?
លោកយ៉ូបប្រើសំណួរនេះដើម្បីបញ្ជាក់ថា ព្រះគឺតែមួយអង្គគត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ មិនមានអ្នកណាដូជជាទ្រង់ឡើយ
ហើយក៏មិនមានអ្នកណាម្នាក់អាចធ្វើឲ្យព្រះអង្គប្តូរព្រះទ័យរបស់ទ្រង់បានដែរ» ឬ
«ប៉ុន្តែ ព្រះអង្គតែមួយអង្គគត់ជាព្រះ
ហើយមិនមាននរណាម្នាក់អាចមានអនុភាពលើទ្រង់ឡើយ។
ការអ្វីដែលព្រះអង្គចង់បាន ព្រះអង្គនឹងធ្វើ
«ទ្រង់បំពេញនូវរាល់អ្វីៗដែលទ្រង់ចង់ធ្វើ»
ដ្បិត ព្រះអង្គបានយកបញ្ញត្តិរបស់ព្រះអង្គមកទាស់នឹងខ្ញុំ
«ទ្រង់ធ្វើចំពោះខ្ញុំនូវអ្វីដែលទ្រង់មានបន្ទូលថាទ្រង់ចង់ធ្វើ»
ហើយមានសេចក្តីជាច្រើនដូចបញ្ញត្តិទាំងនោះដែរ
«ទ្រង់មានផែនការដូចៗគ្នាជាច្រើនសម្រាប់ខ្ញុំ»
Job 23:15
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ព័ត៌មានទូទៅ:
ខនីមួយៗជាទម្រង់ស្រប ដើម្បីបញ្ជាក់ពីចំនុចសំខាន់ដែលលោកយ៉ូបធ្វើ។
ដ្បិត ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំស្រយុតចិត្ត ហើយព្រះដ៏មានគ្រប់ព្រះចេស្តា បានធ្វើឲ្យខ្ញុំភ័យខ្លាច
ល្បះទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់ថាលោកយ៉ូបគឺភ័យខ្លាចព្រះជាខ្លាំង។
ធ្វើឲ្យខ្ញុំស្រយុតចិត្ត
មនុស្សដែលមានដួងចិត្តខ្សោយជាមនុស្សដែលអៀនប្រៀន ឬ ដែលភ័យខ្លាច។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើឲ្យខ្ញុំភ័យខ្លាច»
ខ្ញុំមិនបាននាំទៅក្នុងសេចក្តីងងឹតឡើយ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ អាចមានអត្ថន័យពីរគឺ: ទី១)
របៀបផ្សេងទៀតនៃការបកប្រែ: «ភាពខ្មៅក្រាស់
នៅពីមុខខ្ញុំមិនបានធ្វើអោយខ្ញុំស្ងៀមស្ងាត់នោះទេ»
មុខរបស់ខ្ញុំ
នេះសំដៅលើលោកយ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំ»

---

24 [1]តើហេតុអ្វីបានជាពេលវេលា ដើម្បីជំនុំជម្រះមនុស្សអាក្រក់មិនបានរៀបចំទុកពីព្រះពេញដោយព្រះចេស្តារឫ? តើហេតុអ្វីបានជាអ្នកដែរស្មោះត្រង់ចំពោះព្រះជាម្ចាស់
បានឃើញថ្ងៃជំនុំជម្រះមកដល់?
[2]មានពួកមនុស្សអាក្រក់ដែលបានដកបង្គោលព្រំដែន គឺមានពួកមនុស្សអាក្រក់ដែលបានលួចយកហ្វូងចៀម ហើយនាំយកទៅឃ្វាលនៅក្នុងវាលស្មៅរបស់ពួកគេវិញ។
[3]ពួកគេពង្រត់សត្វលារបស់ពួកកូនកំព្រា គេទទួលបញ្ចាំយកគោរបស់ស្ត្រីមេម៉ាយ។[4]ពួកគេបង្ខំមនុស្សកម្សត់ឲ្យចៀសចេញពីផ្លូវរបស់គេ មនុស្សក្រីក្រនៅផែនដី ក៏គេចពួន
ចេញពីពួកទាំងនោះ។
[5]មើល! អ្នកក្រីក្រទាំងនោះនាំគ្នាទៅធ្វើការ នៅទីវាលសត្វលា ក្នុងទីរហោស្ថាន ហើយស្វែរកអាហារដោយចិត្តទុកដាក់ ប្រហែលជានឹងបានអាហារសម្រាប់ខ្លួន និងកូនចៅ
របស់គេ។[6]ពួកអ្នកក្របានចូលទៅច្រូតនៅក្នុងស្រែរបស់អ្នកដទៃ នៅពេលយប់ ក៏បេះសន្សំផលទំពាំងបាយជូរ របស់មនុស្សអាក្រក់។[7]ពួកគេ ដេកខ្លួនទទេមួយយប់ទាល់ភ្លឺ
ឥតមានសម្លៀកបំពាក់ទេ ហើយពួកគេក៏គ្មានភួយនៅពេលរងាដែរ។
[8]ពួកគេត្រូវទទឹកភ្លៀងដែលមកពីភ្នំ ហើយដេកនៅក្បែនឹងថ្មដា ដោយសាពួកគេគ្មានទីជ្រកឡើយ។[9]មានមនុស្សអាក្រក់ដែរបានឆក់យកកូនកំព្រាចេញពីដោះម្តាយទៅ
អ្វីដែលពួកមនុស្សអាក្រក់បានធ្វើ គឺយកកូនអ្នកក្រទៅបញ្ចាំផងដែរ។[10]ប៉ុន្តែ ពួកអ្នកក្រនឹងត្រូវដើរដោយស្ទើតែនៅខ្លួនទទេ ឥតមានសម្លៀកបំពាក់សោះ ហើយដោយព្រោះ
ឃ្លាន បានជាត្រូវរែកជញ្ជូនកណ្តាប់ស្រូវឲ្យអ្នកដទៃវិញ។
[11]ពួកអ្នកក្រត្រូវចម្រាញ់ធ្វើប្រេងនៅខាងក្នុងរបង របស់មនុស្សអាក្រក់ទាំងនោះ គេបម្រើស្រាទំពាំងបាយជូរដល់មនុស្សអាក្រក់ ប៉ុន្តែ ពួកគេកំពុងតែស្រែកទឹកខ្លាំង។
[12]នៅក្នុងទីក្រុងមានមនុស្សថ្ងូរ អ្នកដែលត្រូវរបួសក៏ស្រែកឡើង ប៉ុន្តែ ព្រះជាម្ចាស់មិនយកព្រះហឫទ័យទុកដាក់ នឹងពាក្យអង្វររបស់គេឡើយ។
[13]ពួកមនុស្សអាក្រក់ជាអ្នកដែលទាស់ប្រឆាំងនឹងពន្លឺ គេមិនស្គាល់ផ្លូវនោះទេ ហើយកាន់ខ្ជាប់តាមផ្លូវច្រកទាំងនោះដែរ។[14]មុនពេលព្រលឹមស្រាង ឃាតកក៏សម្លាប់អ្នកក្រីក្រ
និងមនុស្សកម្សត់ទុគ៌ត ហើយនៅពេលយប់គេធ្វើដូចជាចោរ។
[15]រួចហើយ ភ្នែករបស់មនុស្សកំផិតក៏រង់ចាំពេលព្រលប់ គេនិយាយថា "គ្មានអ្នកណាឃើញខ្ញុំទេ"។ គេក៏បិទមុខចេញទៅ។[16]នៅពេលងងឹតមនុស្សអាក្រក់ទម្លុះចូលផ្ទះ តែ
នៅពេលថ្ងៃ គេលាក់ខ្លួន គេមិនឲ្យឃើញពន្លឺឡើយ ដោយពួកគេមិនខ្វាលពីពន្លឺឡើយ។[17]ដ្បិតពួកគេគិតថា ពេលភាពទទឹតគឺដូចពេលព្រឹក
ហើយពួកគឺជាមិត្តសំឡាញ់ជាមួយនិងសេចក្តីវិនាស ក្នុងជំរៅនៃភាពងងឹត។
[18]គេអណ្តែតលើទឹកទៅបាត់យ៉ាងឆាប់ ចំណែករបស់គេនៅផែនដី មានតែបណ្តាសាទេ គេមិនដែលបែរទៅ ចូលតាមផ្លូវចម្ការទំពាំងបាយជូរឡើយ។[19]បែបដូចជាទឹកពីហិម:
រីងហួតទៅ ដោយរាំងស្ងួត និងក្តៅយ៉ាងណា នោះស្ថានឃុំព្រលឹងមនុស្សស្លាប់ លេបត្របាកមនុស្សមានបាបដែរ។
[20]ផ្ទៃម្តាយនឹងភ្លេចអ្នកនោះទៅ ហើយដង្កូវនឹងចោះគេយ៉ាងឆ្ងាញ់ គ្មានអ្នកណានឹកចាំពីគេទៀតទេ យ៉ាងនោះអំពើទុច្ចរិតនឹងត្រូវកាច់ផ្តាច់ ដូចជាដើមឈើ។[21]មនុស្សអាក្រក់
បានធ្វើបាបស្ត្រីអារដែលមិនបង្កើតកូន ហើយគេក៏ធ្វើអំពើមិនល្អដល់ស្ត្រីមេម៉ាយផងដែរ។
[22]ព្រះជាម្ចាស់ធ្វើឲ្យពួកអ្នកធំទាំងនោះមានអាយុវែង ដោយសារព្រះចេស្តារបស់ព្រះអង្គ ចំណែកពួកអ្នកដែលគ្មានសង្ឃឹមក្នុងជីវិតនេះគេបានឡើងជាធំ។[23]ព្រះអង្គប្រទានឲ្យ
គេបានសេចក្តីសុខហើយគេពឹងពាក់លើសេចក្តីនោះ តែព្រះនេត្ររបស់ព្រះអង្គទតឃើញអស់ទាំងផ្លូវរបស់គេ។
[24]ពួកមនុស្សទាំងនោះត្រូវបានលើកតម្កើងឡើង ក្នុងពេលតែមួយភ្លែតទេ គេនឹងត្រូវស្វិតក្រៀម ហើយហោះហើរ ទៅដូចជាមនុស្សដទៃទាំងអស់ គេត្រូវកាត់ចេញដូចជាគួរ
ស្រូវដែរ។[25]ប្រសិនបើមិនមែនដូច្នោះទេ នោះតើអ្នកណានឹងហ៊ានថាខ្ញុំកុហក តើអ្នកណាធ្វើឲ្យសម្តីខ្ញុំនេះ ឥតខ្លឹមសារបាន?»

Job 24:1
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
តើហេតុអ្វីបានជាពេលវេលា
ដើម្បីជំនុំជម្រះមនុស្សអាក្រក់មិនបានកំណត់ទុកដោយព្រះអង្គពេញដោយព្រះចេស្តា?
លោកយ៉ូបប្រើសំណួរនេះដើម្បីបង្ហាញការខកចិត្តរបស់លោកដែលព្រះមិនបានជំនុំជម្រះ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិនយល់ហេតុអ្វីបានជាព្រះមិនពេលវាលាដែលទ្រង់នឹងជំនុំជម្រះមនុស្សអាក្រក់»
ឬ «ព្រះចេស្តាគួរតែកំណត់ពេលវេលាដែលទ្រង់នឹងជំនុំជម្រះមនុស្សអាក្រក់»។
តើហេតុអ្វីបានជាអ្នកដែលស្មោះត្រង់ដល់ព្រះជាម្ចាស់
មិនបានឃើញថ្ងៃនៃការជំនុំជម្រះដែលមកដល់?
លោកយ៉ូបប្រើសំណួរនេះដើម្បីបង្ហាញការខកចិត្តរបស់លោកដែលមនុស្សស្មោះត្រង់មិនបានឃើញព្រះជំនុំ
របៀបផ្សេងទៀតនៃការបកប្រែ:
«វាដូចជាអស់អ្នកដែលគោរពទ្រង់នឹងមិនបានជើគទ្រង់ជំនុំជម្រះមនុស្សអាក្រក់ទេ»
«ព្រះគួរតែបង្ហាញថ្ងៃដែលទ្រង់នឹងជំនុំជម្រះមនុស្សអាក្រក់ដល់អស់អ្នកដែលស្គាល់ទ្រង់»។
Job 24:2
ប្រយោគភ្ជាប់

generated on Wed Sep 10 16:16:32 2025

លោកយ៉ូបបន្តការនិយាយ។
បង្គោលព្រំដែន
ទាំងនេះគឺជាថ្មឬវត្ថុផ្សេងទៀតស្គាល់ព្រំដែនរវាងម្ចាស់ដីដោយមនុស្សផ្សេងទៀត។
វាលស្មៅ
«វាលស្មៅ» ឬ «ដីឬទីវាលសម្រាប់សត្វស៊ីស្មៅ»
ពួកគេពង្រត់
«ពួកគេលួច»
ពួកដែលគ្មានបារ (កូនកំព្រា)
«កូនកំព្រា» ឬ «ក្មេងដែលឪពុកម្តាយបានស្លាប់ចោល»
ហើយពួកគេយកគោរបស់ស្ត្រីមេម៉ាយជាការបញ្ចាំ
«ពួកគេយកគោរបស់ស្ត្រីមេម៉ាយ
ដើម្បីធានាថាស្ត្រីមេម៉ាយនឹងសងប្រាក់ដែលពួកគេឲ្យនាងខ្ចីនោះមកវិញ» (UDB)
ស្ត្រីមេម៉ាយ
ស្ត្រីដែលប្តីបានស្លាប់ចោល
ជាការបញ្ចាំ
អ្នកឲ្យខ្ចីនឹងយករបស់អ្វីមួយពីអ្នកខ្ចីដើម្បីប្រាកដថាអ្នកខ្ចីសងប្រាក់គាត់វិញ។
ចេញពីផ្លូវរបស់គេ
«ចេញពីផ្លូវរបស់គេ» ឬ «បិតផ្លូវ»
មនុស្សក្រីក្រនៅផែនដី ក៏គេចខ្លួនចេញពីពួកគេដែរ
នេះជាការបន្ថែមដើម្បីបង្ហាញថាមនុស្សក្រីក្រជាច្រើនភ័យខ្លាចមនុស្សអាក្រក់។
Job 24:5
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
អ្នកក្រីក្រទាំងនេះចេញទៅធ្វើការរបស់គេ ដូចជាសត្វលាព្រៃ នៅក្នុងទីរហោស្ថាន
ហើយស្វែរកអាហារដោយចិត្តទុកដាក់
អ្នកក្រីក្រទាំងនេះគឺបាននិយាយ ហាក់ដូចជាពួកគេជាសត្វលាព្រៃ
ដែលមិនថាកន្លែងណាដែលពួកគេនឹងរកអាហារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សក្រីក្រទាំងនេះចេញទៅដើម្បីស៊ើបរកមើលអាហារ
ហាក់ដូចជាពួកគេជាសត្វលាព្រៃ នៅក្នុងទីរហោស្ថាន»
សត្វលាព្រៃ
«សត្វលាដែលមិនមានម្ចាស់ ឬអ្នកថែរក្សា»
ពួកអ្នកក្របានចូលទៅច្រូតនៅក្នុងស្រែរបស់អ្នកដទៃ នៅពេលយប់... ពួកគេបានប្រមូលទំពាំងបាយជូរ
ល្បះទាំងពីរនេះ ពណ៌នាការរឿងដូចគ្នា ហើយត្រូវបានប្រើរួមគ្នាដើម្បីបង្ហាញថា
មនុស្សទាំងនេះឃ្លានខ្លាំងណាស់
ដែលពួកគេបង្ខំចិត្តដើម្បីលួចអាហារនៅពេលយប់។
ពួកគេដេកខ្លួនទទេ...ពួកគេអត់មានភួយ
ល្បះទាំងពីរនេះពណ៌នាការរឿងដូចគ្នា ហើយត្រូវបានប្រើរួមគ្នាដើម្បីបង្ហាញថា
មនុស្សទាំងនេះមិនមានសំលៀកបំពាក់គ្រប់គ្រាន់ដើម្បីឲ្យបានកក់ក្តៅ។
Job 24:8
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ពួកគេត្រូវទទឹកជាមួយនឹងភ្លៀងដែលមកពីភ្នំ
«ពួកគេត្រូវទទឹកនៅពេលភ្លៀងនៅក្នុងតំបន់ភ្នំ»
កូនកំព្រាចេញពីដោះម្តាយ
នៅទីនេះ «ដោះ» សំដៅលើម្តាយ។
នេះបង្ហាញថាក្មេងកំព្រាទាំងនេះនៅតូចនៅឡើយ។ នេះអាចធ្វើឲ្យច្បាស់លាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្មេងកំព្រាតូចៗចេញពីដៃម្តាយរបស់ពួកគេ» ឬ
«ទារកដែលគ្មានឪពុកពីម្តាយរបស់ពួកគេ»
កូនកំព្រា
ពាក្យនេះជាទូទៅសំដៅលើក្មេងៗដែលគ្មានពុកម្តាយ។ យ៉ាងណាក៏ដោយ នៅទីនេះ
វាក៏ត្រូវបានប្រើសម្រាប់ក្មេងដែលមានម្តាយ ប៉ុន្តែ មិនមានឪពុក។
យកកូនក្មេងធ្វើជារបស់បញ្ចាំពីអ្នកក្រផងដែរ
«យកកូនៗរបស់អ្នកក្រដើម្បីធានាថា
អ្នកក្រនឹងសងប្រាក់ដែលពួកគេបានខ្ចីពីមនុស្សអាក្រក់»
ជារបស់បញ្ចាំ
អ្នកឲ្យខ្ចីនឹងយករបស់អ្វីមួយពីអ្នកខ្ចីដើម្បីប្រាកដថាអ្នកខ្ចីសងប្រាក់គាត់វិញ។
ការបកប្រែនេះ ដូចក្នុង ២៤:២។
ត្រូវដើរ
«ដើរទៅមក»
ដោយខ្លួនទទេ អត់មានសម្លៀកបំពាក់ទេ
ពាក្យ «អត់មានសំលៀកបំពាក់» មានន័យដូចគ្នាទៅនឹង «ខ្លួនទទេ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្លួនទទេទាំងស្រុង» ឬ
«ខ្លួនទទេព្រោះពួកគេគ្មានសំលៀកបំពាក់»
ពួកគេនៅតែជញ្ជូនកណ្តាប់ស្រូវឲ្យអ្នកដទៃដដែល
នេះមានន័យថាការងាររបស់ពួកគេនឹងផ្តល់អាហារសម្រាប់អ្នកដទៃគឺមិនមែនសម្រាប់ខ្លួនពួកគេទេ។
Job 24:11
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ពួកអ្នកក្រត្រូវចម្រាញ់ធ្វើប្រេង
ពួកគេគាបផ្លែអូលីវ ដើម្បីស្រង់យកប្រេងអូលីវពីវា។
ប្រេងនៅខាងក្នុងរបង របស់មនុស្សអាក្រក់
នៅទីនេះ «ជញ្ជាំង» សំដៅលើផ្ទះទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅក្នុងផ្ទះរបស់មនុស្សអាក្រក់ទាំងនោះ»
ពួកគេបម្រើស្រាទំពាំងបាយជូរដល់មនុស្សអាក្រក់
វាអាចជួយបញ្ជាក់ថាពួកគែធ្វើនេះដើម្បីផ្តល់ទឹកទំពាំងបាយជូរ
ដើម្បីធ្វើស្រាទំពាំងបាយជូរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេជាន់ទំពាំងបាយជូរដើម្បីធ្វើទឹកទំពាំងបាយជូរសម្រាប់ស្រា»។
ពួកគេកំពុងតែស្រែកទឹកខ្លាំង
«ពួកគេរងទុក្ខដោយការស្រែកទឹក» ឬ «ពួកគេស្រែកទឹកយ៉ាងខ្លាំង»
Job 24:13
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ទាស់ប្រឆាំនឹងពន្លឺ
អាចមានន័យពីរ «ពន្លឺ» គឺ: ទី១) ពន្លឺជាក់ស្តែង ឬ ទី២) ពន្លឺខាងវិញ្ញាណ
ដែលសំដៅដល់ព្រះ ឬ ការរស់នៅដោយសុចរិត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ស្អប់ពន្លឺថ្ងៃ» ឬ «មិនចង់ធ្វើកិច្ចការដែលបើកចំហ» ឬ
«ពួកគេទាស់ប្រឆាំងព្រះជាម្ចាស់»
ពួកគេមិនស្គាល់ផ្លូវរបស់វាទេ ហើយពួកគេក៏មិនរស់នៅក្នុងផ្លូវរបស់គេដែរ
ល្បះទាំងពីរនេះពណ៌នាពីរឿងដូចគ្នា
ហើយត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ថាពួកគេមិនចង់តាមផ្លូវនៃពន្លឺទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេមិនដឹងពីរបៀបរស់នៅក្នុងជីវិតដែលមានក្រមសីលធម៌ទេ
ពួកគេស្ថិតនៅឆ្ងាយពីការរស់ក្នុងជីវិតដែលសុចរិត»
អ្នកក្រីក្រ និងមនុស្សកម្សត់ទុគ៌ត
ពាក្យ «ក្រីក្រ» និង «កម្សត់ទុគ៌ត» សំដៅលើក្រុមមនុស្សដូចគ្នា
និងបញ្ជាក់ថាមនុស្សទាំងនោះ ជាមនុស្សដែលមិនអាចជួយខ្លួនឯងបាន។
គេដូចជាចោរម្នាក់ដែរ
ឃាតករសម្លាប់ក្នុងភាពអាថ៌កំបាំងដូចជាចោរលួចដោយមិនមានអ្នកណាម្នាក់បានឃើញអ្វីដែលគេធ្វើទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គេបានសម្លាប់មនុស្សដោយអាថ៌កំបាំង
ដូចជាចោរលួចដោយអាថ៌កំបាំង»
Job 24:15
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ភ្នែករបស់មនុស្សកំផិត
នៅទីនេះ «ភ្នែក» សំដៅលើរូបកាយមនុស្សទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សផិតក្បត់»
ពេលរាត្រី
«ពេលព្រះអាទិត្យលិច»
គ្មានភ្នែកឃើញខ្ញុំទេ
នៅទីនេះ «ភ្នែក» សំដៅដល់រូបកាយមនុស្សទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានអ្នកណាម្នាក់នឹងឃើញខ្ញុំទេ»
ពួកមនុស្សអាក្រក់ទម្លុះចូលផ្ទះ
ពួកគេទម្លុះចូលទៅក្នុងផ្ទះដើម្បីលួចពីពួកគេ។ នេះអាចបញ្ជាក់ភាពជាក់លាក់។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សអាក្រក់ជីកទម្លុះចូលទៅក្នុងផ្ទះដើម្បីលួចពីពួកគេ»
ពួកគេលាក់ខ្លួនវិញ
«ពួកគេលាក់ខ្លួននៅខាងក្នុង»

generated on Wed Sep 10 16:16:32 2025

សម្រាប់ពួកគេទាំងនោះ ភាពក្រាស់នៃងងឹតគឺដូចជាពេលព្រឹកវិញ
ភាពងងឹតដ៏ក្រាស់គឺដូចជាមានផាសុខភាពសម្រាប់មនុស្សអាក្រក់
ដូចជាពន្លឺនៃពេលព្រឹកសម្រាប់មនុស្សធម្មតា។
ការរន្ធត់នៃភាពក្រាស់របស់សេចក្តីងងឹត
«រឿងដ៏គួរឲ្យភ័យខ្លាចដែលកើតមាននៅពេលយប់»
Job 24:18
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ដូចជាពពុះដែលនៅលើផ្ទៃទឹក
ពពុះនៅបានតែរយៈពេលខ្លី។
នេះបញ្ជាក់ថាតើព្រះនឹងបណ្តាលឲ្យមនុស្សសាលសូន្យទៅរហ័សយ៉ាងដូចម្តេច។
ដីដែលជាចំណែករបស់ពួកគេគឺជាបណ្តាសា
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះដាក់បណ្តាសាដីដែលជាចំណែករបស់ពួកគេ»
ដូចជាការហួតហែងហើយក្តៅរលាយអស់ទៅ...ពួកអ្នកដែលធ្វើបាបដែរ
លោកយ៉ូបនិយាយថាអ្នកប្រព្រឹត្តបាបនឹងសាបសូន្យក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់
ដូចគ្នានឹងគ្រាប់ព្រិលនិងរលាយនៅពេលកម្តៅមកដល់។
ភាពហួតហែង និង កម្តៅ
ពាក្យទាំងពីរនេះពណ៌នាយ៉ាងសំខាន់អំពីរដូវកាលដូចគ្នា
ហើយត្រូវបានប្រើរួមគ្នាដើម្បីពណ៌នាវាឲ្យបានពេញលេញ។
Job 24:20
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ផ្ទៃពោះ
នេះសំដៅលើម្តាយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ម្តាយ»
ហើយដង្កូវដែលបានចោះរូបគេយ៉ាងឆ្ងាញ់នោះ
នេះមានន័យថា គាត់នឹងស្លាប់ហើយពពួកដង្កូវនឹងស៊ីសពរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដង្កូវនឹងរីករាយជាមួយការស៊ីសាកសពរបស់គេ»
ឬ «គាត់នឹងស្លាប់ ហើយរូបកាយរបស់គាត់នឹងត្រូវស៊ីដោយពួកដង្កូវ»
ក៏មិនអាចនឹកចាំពីគេតទៅទៀតផងដែរ
នេះអាចត្រូវបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាម្នាក់នឹងចងចាំពីគាត់ទៀតទេ»
ពួកមនុស្សអាក្រក់នឹងត្រូវបាក់បែកទៅដូចជាដើមឈើដែរ
ការបំផ្លាញមនុស្សអាក្រក់របស់ព្រះជាម្ចាស់ គឺបានពណ៌នា
ថាគាត់ហាក់ដូចជាដើមឈើដែលត្រូវបានកាត់។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងបំផ្លាញមនុស្សអាក្រក់ដូចជាគេជាដើមឈើមួយដើម»
មនុស្សអាក្រក់បានលេបត្របាក់
នេះជាការប្រៀបធៀបបញ្ជាក់ពីភាពគ្មានមេត្តារបស់មនុស្សអាក្រក់។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សអាក្រក់ប្រព្រឹត្តការអាក្រក់
គឺដូចជាសត្វសាហាវសម្លាប់រំពារបស់វា»
ពួកស្ត្រីអារដែលមិនបង្កើតកូនបាន
មនុស្សក្នុងជំនាន់នោះចាត់ទុកថាមនុស្សស្រីដែលអារ គឺត្រូវបណ្តាសាពីព្រះ។
ទោះបី គឺតំណាងគ្រោះកាចបំផុតរបស់ស្ត្រី។
ស្ត្រីមេម៉ាយ
ស្ត្រីដែលប្តីស្លាប់ចោល
Job 24:22
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ដោយព្រះចេស្តារបស់ព្រះអង្គ
«ដោយប្រើអំណាចរបស់ទ្រង់» ឬ «ព្រោះទ្រង់ពេញដោយអំណាច»
ហើយគេបានក្រោកឡើង ប៉ុន្តែពួកគេគ្មានកម្លាំងដើម្បីរស់នៅទេ
នៅទីនេះ «ពួកគេគ្មានកម្លាំងដើម្បីរស់នៅទេ»
មានន័យថាព្រះមិនរក្សាជីវិតរបស់ពួកគេទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះតើនឡើង ប៉ុន្តែ មិនប្រទានឲ្យមនុស្សអាក្រក់មានកម្លាំងដើម្បីរស់ទេ» ឬ
«ព្រះតើនឡើងហើយនាំពួកគេឲ្យស្លាប់»
ប៉ុន្តែ ភ្នែករបស់ពួកគេបានមើលផ្លូវដែលគេដើរវិញ
នៅទីនេះ «ភ្នែក» សំដៅលើព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
ទ្រង់តែងតែទតមើលអ្វីដែលពួកគេធ្វើ»
Job 24:24
ប្រយោគភ្ជាប់
លោកយ៉ូបបន្តការនិយាយ។
ពួកគេនឹងត្រូវទាបចុះវិញ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនឹងនាំពួកគេឲ្យទាបចុះ» ឬ «ព្រះនឹងបំផ្លាគពួកគេ»
ពួកគេនឹងត្រូវប្រមូលគ្នាឡើង ដូចជាមនុស្សដទៃទៀតដែរ
ការបកប្រែមួយចំនួនផ្អែកលើភាពខុសគ្នានៃអត្ថបទខាងមុខ ដែលនិយាយថា
«ពួកវាស្ងិត ហើយក្រៀមស្រពោនដូចជាស្មៅ»
ពួកគេនឹងត្រូវប្រមូលគ្នាឡើង ដូចជាមនុស្សដទៃទៀតដែរ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ អ្វី «ដទៃទៀត» សំដៅលើ
ការធ្វើឲ្យបានច្បាស់លាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនឹងប្រមូលពួកគេឡើងដូចទ្រង់ប្រមូលមនុស្សអាក្រក់ដទៃទៀត»
ពួកគេត្រូវកាត់ចេញដូចជាគួរស្រូវដែរ
មនុស្សអាក្រក់ទាំងនេះនឹងត្រូវកាត់ចេញដូចជាគួរស្រូវ ដែលកាត់ក្នុងរដូវច្រូតកាត់។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះនឹងកាត់ពួក ដូចជាកសិករកាត់គួរស្រូវ»
ប្រសិនបើមិនបានដូច្នោះទេ តើអ្នកណាហ៊ានបញ្ជាក់ថាខ្ញុំកុហក តើនរណាអាចធ្វើឲ្យសម្តីខ្ញុំ
ទៅជាគ្មានន័យបាន?
លោកយ៉ូបប្រើសំណួរនេះដើម្បីបង្ហាញភាពជាក់ស្តែងនៃជម្លោះរបស់ពួកគេ។
ចម្លើយនោះគឺ: «គ្មានអ្នកណាម្នាក់ទេ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះជាការពិត ហើយមិនមានអ្នកណាម្នាក់អាចបង្ហាញថាខ្ញុំគឺជាមនុស្សកុហក
មិនមានអ្នកណាអាចបង្ហាញថាខ្ញុំមានកំហុស»។
ធ្វើឲ្យសម្តីខ្ញុំ ទៅជាគ្មានន័យបាន
«បង្ហាញអ្វីដែលខ្ញុំនិយាយគឺខុស»

25 [1]គ្រានោះ លោកប៊ីលដាឌ ជនជាតិស៊ូអា គាត់ឆ្លើយឡើងថា៖[2]«ព្រះចេស្តា និងសេចក្តីស្ញែងខ្លាចនៅជាមួយព្រះជាម្ចាស់ ហើយព្រះអង្គក៏ធ្វើឲ្យមានសេចក្តីសុខ នៅ
ស្ថានដ៏ខ្ពស់គឺស្ថានសួគ៌។[3]តើចំនួនពលទ័ពព្រះអង្គ តើនឹងរាប់បានឬទេ? តើក្នុងចំណោមគេដែលមានពន្លឺដែលមិនចែងចាំងទេ?
[4]ដូច្នេះ ធ្វើដូចម្តេចឲ្យមនុស្ស បានសុចរិតនៅចំពោះព្រះជាម្ចាស់បាន? ហើយធ្វើដូចម្តេចឲ្យមនុស្ស ដែលកើតពីស្ត្រីមកបានបរិសុទ្ធហើយព្រះអង្គអាចទទួលយកបាន?[5]សូម្បី
តែខែក៏មិនភ្លឺដែរ ហើយផ្កាយទាំងប៉ុន្មានក៏មិនជ្រះថ្លា នៅព្រះនេត្ររបស់ព្រះអង្គផង។[6]ចុះចំណង់បើមនុស្សដែលមិនខុសពីដង្កូវ ហើយកូនមនុស្សដែលមិនខុសពីជន្លេន តើ
គេរឹតតែអន់យ៉ាងណាទៅទៀត!»

Job 25:1
លោកប៊ីលដាឌ ដែលជាជនជាតិស៊ូអា
ការបកប្រែឈ្មោះមនុស្សនេះដូចក្នុង ២:១១
ព្រះចេស្តា និងការភ័យខ្លាចគឺនៅជាមួយព្រះអង្គ
នៅទីនេះ «ព្រះអង្គ» សំដៅលើព្រះជាម្ចាស់។ «ព្រះចេស្តា» និង «ការភ័យខ្លាច»
នាមអរូប។ អាចបញ្ជាក់ជាកិរិយាសព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះចេស្តា
និង ការភ័យខ្លាចគឺនៅជាមួយព្រះ» ឬ «ព្រះគ្រប់គ្រងលើគ្រប់ទាំងអស់
ហើយមនុស្សគួរភ័យខ្លាចចំពោះតែទ្រង់មួយព្រះអង្គ»
នៅស្ថានដ៏ខ្ពស់របស់ព្រះអង្គនៃស្ថានសួគ៌
«នៃស្ថានសួគ៌» ឬ «នៅស្ថានដ៏ខ្ពស់នៃស្ថានសួគ៌»
តើដែលមានអ្នកណាអាចរាប់ពលទ័ពរបស់ព្រះអង្គបានឬទេ?
លោកប៊ីលដាដប្រើសំណួរនេះដើម្បីបង្ហាញពីភាពអស្ចារ្យរបស់ព្រះ។ ចម្លើយគឺ
«ទេ»។ ឃ្លានេះ សំដៅលើទាហានដែលជាពលទេវតារបស់ព្រះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាអាចរាប់ចំនួននៃពួកទេវតាក្នុងពលទាហានរបស់ទ្រង់បានទេ» ឬ
«ពលទាហានរបស់ទ្រង់គឺធំណាស់ ដែលមិនមានអ្នកណាអាចរាប់បានទេ»។
តើពន្លឺរបស់ទ្រង់មិនបានចែងចាំងទៅលើអ្នកណាខ្លះ?
លោកប៊ីលដាដប្រើសំណួរនេះដើម្បីបង្ហាញថាព្រះប្រទានពន្លឺដល់មនុស្សគ្រប់គ្នា។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាម្នាក់ទេដែលពន្លឺរបស់ទ្រង់មិនចែងចាំងលើគេនោះ» ឬ
«ព្រះបានធ្វើឲ្យពន្លឺរបស់ទ្រង់ចែងចាំងលើមនុស្សគ្រប់ៗគ្នា»។
Job 25:4
ប្រយោគភ្ជាប់
លោកប៊ីលដាដបន្តការនិយាយ។
តើធ្វើដូចម្តេចឲ្យមនុស្ស...ព្រះ? តើធ្វើដូចម្តេចឲ្យមនុស្ស ដែលកើត... ទ្រង់?
សំណួរទាំងពីរនេះត្រូវបានប្រើជាមួយគ្នាដើម្បីបញ្ជាក់ថា
វាអាចទៅរួចសម្រាប់មនុស្សម្នាក់ឲ្យបានល្អគ្រប់គ្រាន់សម្រាប់ព្រះ។
តើធ្វើដូចម្តេចឲ្យមនុស្សបានសុចរិតនៅចំពោះព្រះជាម្ចាស់?
ចម្លើយដ៏ពិតនោះគឺគេមិនអាចទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សម្នាក់មិនអាចបានសុចរិតនៅចំពោះព្រះបានទេ»។
តើធ្វើដូចម្តេចឲ្យមនុស្ស ដែលកើត...ព្រះអង្គអាចទទួលយកបាននោះ?
ចម្លើយដ៏ពិតនោះគឺគេមិនអាចទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សដែលកើតពីស្ត្រីមិនអាចបរិសុទ្ធ ឬ
អាចទទួលយកបានចំពោះព្រះបានទេ»។
ស្អាត់ហើយព្រះអង្គអាចទទួលយកបាន
«ស្អាត - នោះគឺ ព្រះអង្គអាចទទួលយកបាន»
មនុស្ស ដែលកើតពីស្ត្រីមក
នេះជាការប្រៀបធៀប ដែលរួមបញ្ចូលមនុស្សទាំងអស់។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សខ្លះ»
មើល៍
ពាក្យ «មើល៍» នៅទីនេះបន្ថែមការបញ្ជាក់ដើម្បីអ្វីដែលនឹងតាមមក។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយពិត»
ដួងខែក៏មិនអាចភ្លឺស្មើព្រះអង្គដែរ
«ពន្លឺរស្មី» នាមអរូប។ អាចត្រូវបានបង្ហាញជាគុណនាម។
របៀបផ្សេងទៀតនៃការបកប្រែ: «ដួងខែក៏មិនមានពន្លឺគ្រប់គ្រាន់សម្រាប់ព្រះដែរ»
ផ្កាយទាំងឡាយក៏មិនអាចឥតខ្ចោះនៅក្នុងព្រះនេត្ររបស់ព្រះអង្គដែរ
នៅទីនេះពាក្យ «បរិសុទ្ធ» មានន័យថា «ឥតខ្ចោះ»។
របៀបផ្សេងទៀតនៃការបកប្រែ: «គេគិតថាសូម្បីតែផ្កាយក៏ល្អឥតខ្ចោះដែរ»
តើមនុស្សនឹងទាបយ៉ាងណាទៅ...តើមនុស្សនឹងទាបយ៉ាងណាទៅ
ល្បះទាំងពីរនេះនិយាយពីកិច្ចការដូចគ្នា
ហើយត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ថាមនុស្សមិនមែនឥតខ្ចោះនោះទេ។
ដែលជាជន្លេន
លោកប៊ីលដាដបញ្ជាក់ថាមនុស្សមានតម្លៃតិចតួចដូចជាដង្កូវ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដែលគ្មានតម្លៃដូចជាសត្វដង្កូវ»
កូនមនុស្ស
នេះជារបៀបផ្សេងទៀតនៃការបកប្រែសំដៅលើមនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្ស»

---

26 [1]ក្រោយមក លោកយ៉ូបក៏ឆ្លើយដោយនិយាយថា៖ [2]«តើអ្នកបានជួយដល់មនុស្ស ដែលគ្មានអំណាច! ម្យ៉ាងវិញទៀត តើអ្នកអាចជួយដល់ដៃដែលគ្មានកម្លាំងបាន!
[3]គួរឲ្យទាំងទូន្មានមនុស្សដែលគ្មានប្រាជ្ញា ដោយប្រើពាក្យនៃការចេះដឹងបាន![4]តើអ្នកបានពោលពាក្យទាំងនេះដល់អ្នកណា? តើជាវិញ្ញាណរបស់អ្នកណា ដែលបណ្តាលឲ្យអ្នកនិយាយ?
[5]អស់អ្នកដែលស្លាប់ទៅហើយ នាំគ្នាញ័ររន្ធត់នៅពីក្រោមសមុទ្រ និងអ្វីៗដែលរស់នៅក្នុងសមុទ្រផង។[6]ស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏អាក្រាតទទេនៅចំពោះព្រះជាម្ចាស់ ហើយទីជង្ហុកជ្រៅគ្មានអ្វីគ្របបាំងឡើយ។
[7]ព្រះអង្គត្រដាងទិសខាងជើងពីលើទីអាកាស ហើយក៏ព្យួរផែនដីនៅលើលំហដែលគ្មានអ្វីទាំងអស់។[8]ព្រះជាម្ចាស់បានទប់ទឹកទុកនៅក្នុងពពកដ៏ក្រាស់របស់ព្រះអង្គ ទោះជាយ៉ាងណាក៏ដោយពពកមិនធ្លាយចុះក្រោមទេ។
[9]ព្រះជាម្ចាស់បានបាំងខាងមុខបល្ល័ង្កដោយព្រះច័ន្ទ ហើយត្រដាងពពករបស់ព្រះអង្គពីលើផង។[10]ព្រះជាម្ចាស់បានធ្វើរបងព័ទ្ធជុំវិញទឹក ក្នុងចន្លោះពន្លឺ ហើយនឹងភាពងងឹតផងដែរ។
[11]សសរនៃផ្ទៃមេឃញាប់ញ័រ ហើយមានសេចក្តីអស្ចារ្យ ដោយព្រះអង្គបញ្ជា។[12]ព្រះជាម្ចាស់ធ្វើឲ្យសមុទ្រកម្រើកឡើង ដោយឥទ្ធិឫទ្ធិរបស់ព្រះអង្គ និងតាមរយៈព្រះប្រាជ្ញាញាណព្រះជាម្ចាស់វាយបែកខ្ចាយ។
[13]ព្រះអង្គតុបតែងផ្ទៃមេឃ ដោយសារព្រះវិញ្ញាណព្រះអង្គ ហើយព្រះហស្តរបស់ព្រះអង្គ បានចាក់ទម្លុះពស់។[14]ការទាំងនេះគ្រាន់តែជាកិច្ចខាងក្រៅ របស់ព្រះអង្គទេ ហើយយើងឮនិយាយពីព្រះអង្គ ជាសំឡេងខ្សាវៗយ៉ាងណាទៅ សំឡេងលាន់ឮពីឥទ្ធិឫទ្ធិរបស់ព្រះអង្គ តើអ្នកណានឹងយល់បាន?»

Job 26:1
ហេតុអ្វីបានជាអ្នកជួយដល់មនុស្ស... ដៃដែលគ្មានកម្លាំងបាន!
នៅក្នុងស្ថានភាពទាំងនេះ លោកយ៉ូបកំពុងបន្ទោសលោកប៊ីលដាដ។ ពាក្យ «មនុស្ស» សំដៅលើខ្លួនរបស់គេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំគ្មានអំណាច ហើយក៏គ្មានកម្លាំងដែរ ប៉ុន្តែ អ្នកប្រព្រឹត្តដូចជាអ្នកបានជួយខ្ញុំ ប៉ុន្តែ ជាការពិត អ្នកមិនបានជួយខ្ញុំអ្វីទាំងអស់!»
ដៃដែលគ្មានកម្លាំង
លោកយ៉ូបប្រើឃ្លានេះដើម្បីពណ៌នាពីខ្លួនរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំ ដែលដូចជាដៃដែលមិនមានកម្លាំង» ឬ
«មនុស្សម្នាក់ដែលខ្សោយយ៉ាងខ្លាំង»
ហេតុអ្វីបានជាអ្នកឲ្យយោបល់ដល់មនុស្សដែលគ្មានប្រាជ្ញា
ហើយប្រកាសទៅគាត់ជាពាក្យនៃចំណេះដឹង!
លោកយ៉ូបគឺកំពុងនិយាយថាលោកប៊ីលដាដមិនបានផ្តល់យោបល់
និងចំណេះល្អណាមួយដល់លោកទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកធ្វើដូចជាខ្ញុំគ្មានប្រាជ្ញា ហើយថាអ្នកបានឲ្យយោបល់ដល់ខ្ញុំ
ថាអ្នកផ្តល់យោបល់ល្អៗដល់ខ្ញុំ!»
ប្រកាសទៅគាត់ជាពាក្យនៃចំណេះដឹង
«ផ្តល់ឲ្យគាត់នូវយោបល់ល្អៗ»
តើអ្នកណាជួយអ្នកឲ្យនិយាយពាក្យទាំងនេះបាននោះ? តើជាវិញ្ញាណរបស់អ្នកណា ដែលបានចេញទៅពីអ្នក?
នៅក្នុងសំណួរទាំងនេះលោកយ៉ូបបន្តចំអកលោកប៊ីលដាដ។
ពួកគេទាំងពីរសួរសំណួរដែលមិនទាមទារចម្លើយ និងមានន័យដូចគ្នាទាំងស្រុង។
ពួកគេត្រូវបានប្រើរួមគ្នាដើម្បីជំរុញកម្លាំងគ្នាទៅវិញទៅមក។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកត្រូវបានជួយឲ្យនិយាយពាក្យទាំងនេះ។
ប្រហែលជាមានព្រលឹងបានជួយអ្នកឲ្យនិយាយពួកវា!»
Job 26:5
មនុស្សស្លាប់
ឃ្លានេះសំដៅលើមនុស្សស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអ្នកដែលស្លាប់» ឬ «ព្រលឹងនៃមនុស្សស្លាប់»
(ញាប់ញ័រ) ការភ័យខ្លាច
ពួកគេញាប់ញ័រព្រោះពួកគេខ្លាចព្រះ។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ញាប់ញ័រនៅក្នុងភាពភ័យខ្លាច» ឬ
«ញាប់ញ័រនៅក្នុងភាពភ័យខ្លាចព្រះជាម្ចាស់»
អ្នកដែលស្លាប់នៅក្រោមទឹក
នេះប្រាប់ពីមនុស្សស្លាប់ដែលញាប់ញ័រ។
អស់អ្នកដែលបាននៅក្នុងទឹកនោះផង
នេះប្រាប់ពីមនុស្សស្លាប់ដែលញាប់ញ័រ។ ពាក្យ «ពួកគេ» សំដៅលើទឹក។
ស្ថានឃុំព្រលឹងមនុស្សស្លាប់ គឺអាក្រាតនៅចំពោះព្រះជាម្ចាស់ ហើយការបំផ្លិចបំផ្លាញ
វាខ្លួនឯងគឺគ្មានការបិតបាំង
ស្ថានឃុំព្រលឹងមនុស្សស្លាប់ ត្រូវបាននិយាយ ហាក់ដូចជាវា ជាមនុស្សម្នាក់។
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ «អាក្រាត» ឬ «មិនមានអ្វីបិតបាំង»
គឺជាការបើកឲ្យឃើញ និងមិនអាចលាក់បាំងរបស់អ្វីមួយបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «វាគឺដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់
ដែលអាក្រាតនៅចំពោះព្រះ ដែលគ្មានអ្វីទាំងអស់ក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់
កន្លែងនៃការបំផ្លិចបំផ្លាញ គឺលាក់បាំងពីព្រះ»
ការបំផ្លិចបំផ្លាញ

generated on Wed Sep 10 16:16:32 2025

នេះជាឈ្មោះមួយផ្សេងទៀតសម្រាប់ស្ថានឃុំព្រលឹងមនុស្សស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «កន្លែងនៃការបំផ្លិចបំផ្លាញ»
Job 26:7
ព្រះអង្គលាតសន្ធឹងទៅទិសខាងជើងនៃអាកាស នៅលើលំហដែលទំនេរ
ទិសខាងជើងនៃអាកាស តំណាងឲ្យស្ថានសួគ៌
កន្លែងដែលទ្រង់គង់នៅជាមួយនឹងអ្វីៗដែលទ្រង់បានបង្កើតអោយរស់នៅទីនោះ។
ហើយព្រះអង្គបានព្យួរផែនដីលើកន្លែងដែលគ្មានអ្វីទាំងអស់
ពពកគឺបាននិយាយនោះ ហាក់ដូចជាភួយដ៏ធំដែលព្រះរុំទឹកភ្លៀង។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រង់រុំទឹកឡើងក្នុងពពកដ៏ក្រាស់»
ប៉ុន្តែ ពពកមិនធ្លាយចុះក្រោមពួកគេឡើយ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ពាក្យ «ពួកគេ» សំដៅលើទឹក។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ទម្ងន់របស់ទឹកមិនបានជ្រែកពពកឡើយ»
Job 26:9
ហើយត្រដាងពពករបស់ព្រះអង្គពីលើផង
ឃ្លានេះប្រាប់ ថាតើព្រះបាំងផ្ទៃរបស់ព្រះចន្ទដោយរបៀបណា។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយការលាតសន្ធឹងពពករបស់ទ្រង់នៅពីមុខវា»
ព្រះជាម្ចាស់បានធ្វើរបងព័ទ្ធជុំវិញ
នេះនិយាយអំពីព្រំដែន ហាក់ដូចជាព្រះបានបង្កើតព្រំប្រទល់នៅលើមហាសមុទ្រ។
Job 26:11
សសរនៃផ្ទៃមេឃញាប់ញ័រ ហើយមានភ្ញាក់ផ្អើល និងសេចក្តីបន្ទោសរបស់ព្រះអង្គ
មនុស្សគិតពីស្ថានសួគ៌ ឬផ្ទៃមេឃដូចជាលាតសន្ធឹងលើជើងសសរ។
លោកយ៉ូបនិយាយ
ពីសសរហាក់មនុស្សដែលរញ្ជួយដោយការភ័យខ្លាចនៅពេលដែលព្រះពិរោធ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សសរដែលទ្រស្ថានសួគ៌រញ្ជួយដោយភាពភ័យខ្លាចនៅពេលដែលព្រះបន្ទោសពួកគេ»
ឬ
«សសរដែលទ្រមេឃរញ្ជួយដូចជាមនុស្សដែលភ័យខ្លាចនៅពេលដែលព្រះបន្ទោសពួកគេ»
បានខ្ចាត់ខ្ចាយរ៉ាហាប
ទ្រង់បានបំផ្លាញរ៉ាហាប
រ៉ាហាប
នេះជាឈ្មោះនៃសត្វធំសម្បើមដែលគួរឲ្យភ័យខ្លាច ដែលរស់នៅក្នុងសមុទ្ទ។
ចូរមើលពីរបៀបបកប្រែនេះក្នុង [JOB 9:13]
Job 26:13
ដោយព្រោះខ្យល់ដង្ហើមរបស់ព្រះអង្គបានធ្វើឲ្យ
នាមអរូប «ដង្ហើម» អាចត្រូវបានបកប្រែជាមួយកិរិយាសព្ទ «ដកដង្ហើម» ឬ «ផ្លុំ»។
រូបភាពនេះតំណាងឲ្យព្រះធ្វើឲ្យខ្យល់បក់ទៅពពក។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានសម្អាតផ្ទៃមេឃ ដោយការដកដង្ហើម» ឬ «ព្រះបានផ្លុំពពកចេញទៅ
ដូច្នេះ ផ្ទៃមេឃក៏បានស្រឡះ»។
ផ្ទៃមេឃស្រឡះ ហើយព្រះហស្តរបស់ព្រះអង្គ បានចាក់ទម្លុះពស់ដែលរត់គេច
នៅទីនេះ «ព្រះហស្តរបស់ព្រះអង្គ» តំណាងឲ្យសាស្ត្រាវុធរបស់ព្រះ និង «ទម្លុះ»
តំណាងឲ្យការសម្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជាមួយសាស្ត្រាវុធរបស់ព្រះ ទ្រង់ទម្លុះសត្វពោះដែលរត់គេច»
ពស់ដែលរត់គេច
«សត្វពស់បានព្យាយាមរត់ចេញពីព្រះអង្គ»។ នេះសំដៅលើរ៉ាហាប
សត្វដ៏ធំសម្បើមក្នុងសមុទ្រ។ (សូមមើល ២៦:១១។
មើល៍! ការទាំងនេះគ្រាន់តែជាជាចំណែកតូច នៃផ្លូវព្រះអង្គ
នៅទីនេះ «ចំណែកតូច» តំណាងឲ្យផ្នែកតូចៗ
ដែលយើងអាចឃើញអ្វីមួយដែលធំសម្បើម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មើល៍!
របស់ទាំងនេះដែលព្រះបានបង្ហាញគ្រាន់តែជាផ្នែកតូចមួយនៃអំណាចមហិមារបស់លោក»
ហើយការនិយាយខ្សិបគ្នាពីព្រះអង្គ!
នេះជាការឧទាន
ដែលបង្ហាញការធ្វើអោយឆ្ងល់របស់លោកយ៉ូបនៃកិច្ចការដ៏អស្ចារ្យទាំងអស់ដែលលោកយ៉ូបធ្វើ
ដែលយើងមិនបានដឹងអំពីវា។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងឮត្រឹមតែការខ្សឹបខ្សៀវ»
ហើយការនិយាយខ្សិបគ្នាពីព្រះអង្គ!
ការឃើញអ្វីដែលព្រះធ្វើ ត្រូវបាននិយាយដូចជាការឮព្រះសូសៀររបស់ព្រះ។
ការឮការខ្សឹបខ្សៀវអំពីទ្រង់
តំណាងឲ្យការមើលឃើញការតូចតាចនៃកិច្ចការដ៏មហិមាដែលទ្រង់បានធ្វើ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាការឮត្រឹមតែការខ្សឹបខ្សៀវនៃព្រះសូរសៀងដ៏ពេញដោយព្រះចេស្តារបស់ទ្រង់»
តើអ្នកណាអាចយល់ពីផ្គរលាន់នៃព្រះចេស្តារបស់ព្រះអង្គបាន?
«ផ្គរលាន់នៃព្រះចេស្តារបស់ព្រះអង្គ»
តំណាងភាពអស្ចារ្យទាំងអស់នៃអ្វីដែលព្រះធ្វើ។
លោកយ៉ូបប្រើសំណួរនេះដើម្បីបញ្ជាក់ថាអំណាចរបស់ព្រះគឺមហិមាដែលមិនមានអ្នកណាម្នាក់អាចយល់ដ
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាអាចយល់ពីអំណាចដ៏មហិមារបស់ទ្រង់បានទេ!»

---

27 [1]លោកយ៉ូបក៏បន្តសេចក្តីអធិប្បាយ របស់លោកទៅទៀតថា៖[2]«ការពិតណាស់ព្រះដ៏មានព្រះជន្មរស់នៅ ដែលព្រះអង្គបានដកសេចក្តីយុត្តិធម៌ពីខ្ញុំចេញ គឺជាព្រះដ៏
មានគ្រប់ព្រះចេស្តាដែលព្រះអង្គបានធ្វើឲ្យជីវិតខ្ញុំជូរចត់[3]កាលខ្ញុំនៅមានដង្ហើមចេញចូល ហើយមានខ្យល់វិញ្ញាណ នៃព្រះជាម្ចាស់នៅក្នុងរន្ធច្រមុះខ្ញុំនៅឡើយ
នេះគឺជាអ្វីដែលខ្ញុំនឹងធ្វើ។
[4]បបូរមាត់ខ្ញុំនឹងមិននិយាយការអាក្រក់ ហើយអណ្តាតខ្ញុំក៏មិនបញ្ចេញ ពាក្យភូតភរឡើយ។[5]ខ្ញុំនឹងមិនព្រមនិយាយថា អ្នកទាំងបីត្រូវនោះទេ រហូតដល់ខ្ញុំស្លាប់
នោះខ្ញុំនៅតែមិនបដិសេធ សេចក្តីត្រឹមត្រូវនិងស្មោះត្រង់ដែរ។
[6]ខ្ញុំនឹងប្រកាន់សេចក្តីសុចរិតរបស់ខ្ញុំ ហើយខ្ញុំនឹងបោះបង់វាចោលឡើយ និងគំនិតខ្ញុំក៏មិនអាចទាញខ្ញុំចេញ ដរាបណាខ្ញុំនៅមានជីវិត។[7]សូមឲ្យសត្រូវខ្ញុំបានរាប់ជាមនុស្ស
អាក្រក់ចុះ ហើយឲ្យអ្នកដែលទាស់នឹងខ្ញុំ បានរាប់ជាទុច្ចរិតផង។
[8]ដ្បិត តើអ្វីទៅដែលជាក្តីសង្ឃឹមរបស់មនុស្សទមិឡ នៅពេលព្រះជាម្ចាស់បដិសេធគេ និងពេលព្រះជាម្ចាស់ដកយកជីវិតរបស់គេនោះ?
[9]តើព្រះជាម្ចាស់នឹងស្តាប់សម្រែកពេលពួកគេជួបបញ្ហាដែលឬទេ?[10]តើនៅពេលពួកទមិឡរីករាយជាខ្លាំង តើគេដែលនឹកឃើញព្រះជាម្ចាស់គ្រប់ពេលវេលាទេ?
[11]ខ្ញុំនឹងបង្រៀនអ្នករាល់គ្នា អំពីព្រះហស្តនៃព្រះជាម្ចាស់ ដែលមាននៅនឹងព្រះដ៏មានគ្រប់ព្រះចេស្តា ខ្ញុំមិនលាក់និងរាល់គ្នាទេ។[12]មើល! អ្នករាល់គ្នាក៏បានឃើញសេចក្តីទាំង
នេះហើយ ហេតុអ្វីបានជាអ្នករាល់គ្នា នៅតែនិយាយសេចក្តីគ្មាប្រយោជន៍ទៀត?
[13]នេះហើយគឺជាវាសនា ដែលមនុស្សអាក្រក់ជាមួយព្រះជាម្ចាស់ គឺជាសេចក្តីដែលមនុស្សសង្កត់សង្កិន ត្រូវទទួលពីព្រះដ៏មានគ្រប់ព្រះចេស្តា[14]ប្រសិនបើកូនចៅគេបាន
ចម្រើនជាច្រើនឡើង នោះគឺសម្រាប់តែដាវប៉ុណ្ណោះ ហើយពូជពង្សគេមិនបានបរិភោគឆ្អែតទេ។
[15]ពួកអ្នកដែលរួចជីវិត នឹងត្រូវស្លាប់ ដោយជំងឺរាតត្បាត ប្រពន្ធរបស់គេដែលនៅមេម៉ាយ នឹងមិនយំកាន់ទុក្ខឲ្យគេឡើយ។[16]ទោះបើគេប្រមូលប្រាក់ទុកដូចជាធូលីដី ក៏ត្រៀម
ទុកសម្លៀកបំពាក់ដូចជាភក់[17]នោះគេនឹងរៀបចំបាន តែគឺពួកសុចរិតជាអ្នកស្លៀកពាក់វិញ ហើយពួកអ្នកដែលគ្មានទោស គឺពួកគេនឹងគ្នាចែកប្រាក់ក្នុងចំណោមគ្នាទៅ។
[18]ផ្ទះដែលគេសង់ ប្រៀបដូចជាសំបុកកណ្តៀរ ឬដូចខ្ទមរបស់ឆ្មាំចម្ការ។[19]ពេលចូលដំណេក គេជាអ្នកមាន ប៉ុន្តែ នេះជាលើកចុងក្រោយហើយ ដ្បិតពេលភ្ញាក់ឡើង គេបាត់
បង់ទ្រព្យសម្បត្តិអស់។
[20]ការភ័យខ្លាចធ្លាក់មកលើគេដូចទឹកជំនន់ ហើយនៅពេលយប់ ខ្យល់កួចនាំយកគេបាត់ទៅ។[21]ខ្យល់ពីទិសខាងកើតបក់មក កន្ត្រាក់គេចេញបាត់ពីលំនៅរបស់ខ្លួន។
[22]ខ្យល់នោះបក់បោកទៅលើគេឥតត្រាប្រណី ធ្វើឲ្យគេខិតខំរត់គេចចេញ។[23]អ្នកដទៃឃើញដូច្នេះ ក៏ទះដៃហ៊ោ ហើយនាំគ្នាចំអកនៅកន្លែង ដែលគេធ្លាប់រស់នៅ។

Job 27:1
ការពិតណាស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់នៅ
ឃ្លានេះបង្ហាញថាលោកយ៉ូបគឺកំពុងនិយាយការស្បថ។ លោកយ៉ូបប្រៀបធៀប
ភាពជាក់លាក់ថាព្រះមានព្រះជន្មគង់នៅយ៉ាងពិតប្រាកដ
ជាក់លាក់ពីអ្វីដែលទ្រង់មានព្រះបន្ទូល។
នេះគឺជារបៀបនៃការបង្កើតការសន្យានៃសេចក្តីសុខសាន្ត។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំស្បថដោយនូវព្រះ»
ព្រះអង្គបានដកសេចក្ដីយុត្តិធម៌ពីខ្ញុំចេញ
សេចក្ដីយុត្តិធម៌ត្រូវបាននិយាយហាក់ដូចជាវាជាគោលបំណងដែលត្រូវបានដកចេញ ឬផ្តល់ឲ្យ។ ការដកចេញ
តំណាងឲ្យការបដិសេធមិនប្រព្រឹត្តចំពោះយ៉ូបដោយយុត្តិធម៌។
របៀបផ្សេងទៀតនៃការបកប្រែ: «ត្រូវបានបដិសេធប្រព្រឹត្តដល់ខ្ញុំដោយយុត្តិធម៌»
បានធ្វើឲ្យជីវិតរបស់ខ្ញុំជូរល្វីង
«ជីវិត» របស់លោកយ៉ូប ចាប់ផ្តើមជូរល្វីង
តំណាងឲ្យលោកយ៉ូបមានអារម្មណ៍អន់ចិត្តចំពោះព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បាននាំឲ្យទូលបង្គំអន់ចិត្ត» ឬ «បានធ្វើឲ្យខ្ញុំមានអារម្មណ៍ខឹង ពីព្រោះវិធីដ៏អយុត្តិធម៌ដែលបានប្រព្រឹត្តចំពោះខ្ញុំ»
កាលខ្ញុំនៅមានដង្ហើមចេញចូល (កាលជីវិតរបស់ខ្ញុំមិនទាន់នៅក្នុងខ្ញុំនៅឡើយ)
ឃ្លានេះសំដៅដល់រយៈពេលនៃការសម្រាកនៃជីវិតរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ក្នុងកំឡុងពេលទាំងមូលដែលជីវិតរបស់ខ្ញុំនៅមិនទាន់នៅក្នុងខ្ញុំនៅឡើយ» ឬ «ជាយូរមកហើយជីវិតរបស់គេមិនទាន់នៅក្នុងខ្ញុំនៅឡើយ»
កាលខ្ញុំនៅមានដង្ហើមចេញចូល (កាលជីវិតរបស់ខ្ញុំមិនទាន់នៅក្នុងខ្ញុំនៅឡើយ)
នាមអរូប «ជីវិត» អាចត្រូវបានបង្ហាញជាមួយគុណនាម «មានជីវិត» ឬ កិរិយាសព្ទ «រស់នៅ»។ របៀបផ្សេងទៀតនៃការបកប្រែ: «ជាយូរមកហើយខ្ញុំនៅមានជីវិត» ឬ «កំឡុងពេលខ្ញុំនៅតែរស់នៅ»
ហើយដង្ហើមពីព្រះជាម្ចាស់គឺនៅក្នុងរន្ធច្រមុះខ្ញុំផង
ដង្ហើមនៅក្នុងច្រមុះ តំណាងឲ្យការទទួលដង្ហើម។ ហើយ «ដង្ហើមពីព្រះ» តំណាងឲ្យការដែលព្រះធ្វើឲ្យគាត់ដកដង្ហើមបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះធ្វើឲ្យខ្ញុំមានសមត្ថភាពដកដង្ហើមបាន»
រន្ធច្រមុះ
«ច្រមុះ»
Job 27:4
បបូររបស់មាត់ខ្ញុំនឹងមិននិយាយការអាក្រក់ទេ ហើយអណ្ដាតរបស់ខ្ញុំក៏មិននិយាយពីការបោកប្រាស់ដែរ
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា
ហើយត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ថាលោកនឹងមិននិយាយតាមរបៀបនោះទេ។
ឃ្លា «បបូរមាត់របស់ខ្ញុំ» និង «អណ្ដាតរបស់ខ្ញុំ» តំណាងឲ្យរូបលោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាកដណាស់ខ្ញុំនឹងមិននិយាយការអាក្រក់ និងការបោកប្រាស់ឡើយ»
និយាយការអាក្រក់...និយាយពីការបោកប្រាស់
នាមអរូប «ការអាក្រក់» និង «ការបោកប្រាស់» អាចត្រូវបានបង្ហាញជាមួយ «យ៉ាងឃោឃៅ» និង «ដែលបោកបញ្ឆោត»។ របៀបផ្សេងទៀតនៃការបកប្រែ: «និយាយយ៉ាងឃោឃៅ...និយាយដែលបោកបញ្ឆោត»
ខ្ញុំនឹងមិនព្រមនិយាយថា អ្នកទាំងបីបាននិយាយត្រូវនោះទេ
«ខ្ញុំនឹងមិនយល់ព្រមជាមួយអ្នក ហើយនិយាយថាអ្នកទាំងបីនិយាយត្រូវដែរ»
អ្នកទាំងបីបាននិយាយត្រូវនោះទេ
ពាក្យ «អ្នក» នៅទីនេះគឺជាពហុវចន។វាសំដៅដល់មិត្តៗរបស់លោកយ៉ូប។
ខ្ញុំនៅតែមិនបដិសេធ សេចក្ដីត្រឹមត្រូវរបស់ខ្ញុំ
«ខ្ញុំនឹងមិននិយាយថាខ្ញុំគ្មានទោសកំហុសនោះទេ» ឬ «ខ្ញុំនៅតែនិយាយថាខ្ញុំគ្មានកំហុស»
Job 27:6
ខ្ញុំនឹងតោងសេចក្ដីសុចរិតរបស់ខ្ញុំ
នៅទីនេះ «នឹងតោង»
ជាពាក្យប្រៀបធៀបដែលបង្ហាញពីការកំណត់ដើម្បីបន្តនិយាយអ្វីមួយ។ នាមអរូប «សេចក្ដីសុចរិត» អាចត្រូវបានបង្ហាញជាមួយ «សុចរិត»។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំនៅតែរឹងមាំដើម្បីបន្តនិយាយថាខ្ញុំសុចរិត»
នឹងមិនបោះបង់វាចោលឡើយ
នៅទីនេះឃ្លា «នឹងមិនបោះបង់វាចោល»
គឺជាការប្រៀបធៀបដែលបង្ហាញការឈប់និយាយអ្វីមួយ។ រឹងមាំ
«នឹងមិនបញ្ឈប់ការនិយាយថាខ្ញុំសុចរិត» ឬ «នឹងមិនបញ្ឈប់ការនិយាយដូច្នេះ»
គំនិតខ្ញុំនឹងមិនបន្ទោសខ្ញុំ
នៅទីនេះ «គំនិតខ្ញុំ» តំណាងឲ្យលោកយ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទោះបីជាក្នុងគំនិតរបស់ខ្ញុំ ខ្ញុំនឹងមិនបន្ទោសខ្លួនរបស់ខ្ញុំទេ»
ចូរឲ្យសត្រូវរបស់ខ្ញុំបានដូចជាមនុស្សអាក្រក់ចុះ ហើយចូរឲ្យពួកអ្នកដែលទាស់នឹងខ្ញុំ
ល្មះពីរដែលចាប់ផ្តើមជាមួយនឹងពាក្យដូចគ្នា។
ពួកវាត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ពីបំណងប្រាថ្នាដ៏រឹងមាំរបស់លោកយ៉ូប ដែលវានឹងកើតឡើង។
ចូរឲ្យសត្រូវរបស់ខ្ញុំបានដូចជាមនុស្សអាក្រក់ចុះ
គាត់ចង់ឲ្យត្រូវរបស់គាត់បានដូចជាមនុស្សអាក្រក់
អាចត្រូវបញ្ជាក់យ៉ាងច្បាស់លាស់។
ហើយចូរឲ្យពួកអ្នកដែលទាស់នឹងខ្ញុំ បានដូចជាមនុស្សទុច្ចរិតផងដែរ
គាត់ចង់ឲ្យសត្រូវរបស់គាត់បានដូចជាមនុស្សអាក្រក់
អាចត្រូវបានបញ្ជាក់ច្បាស់លាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមឲ្យសត្រូវរបស់ខ្ញុំត្រូវបានដាក់ទោសដូចជាមនុស្សអាក្រក់» ឬ «សូមឲ្យព្រះដាក់ទោសសត្រូវរបស់ខ្ញុំដូចព្រះអង្គដាក់ទោសមនុស្សអាក្រក់»
ពួកអ្នកដែលទាស់នឹងខ្ញុំ
នៅទីនេះ «ក្រោកឡើងទាស់នឹងខ្ញុំ» គឺជាការប្រៀបធៀប មានន័យផ្ទុយពីគាត់។
ឃ្លាទាំងមូលគឺសំដៅលើគូបដិបក្សរបស់លោកយ៉ូប»
Job 27:8
ដ្បិត តើអ្វីទៅដែលជាក្តីសង្ឃឹមរបស់មនុស្សទមិឡ
នៅពេល...ហើយពេលព្រះជាម្ចាស់បានដកយកជីវិតរបស់គេផងនោះ?
លោកយ៉ូបប្រើសំណួរនេះដើម្បីនិយាយថាដូចគ្នានឹងមនុស្សដែលគ្មានក្តីសង្ឃឹម។
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានក្តីសង្ឃឹមសម្រាប់មនុស្សទមិឡទេនៅពេលព្រះ...ដកព្រលឹងរបស់ពួកគេ!»
នៅពេលព្រះជាម្ចាស់ បានបដិសេធគេចេញ
ហើយពេលព្រះជាម្ចាស់បានដកយកជីវិតរបស់គេផងនោះ?
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលព្រះកាត់ពួកគេចេញហើយដកជីវិតរបស់ពួកគេ» ឬ «ពេលព្រះបណ្ដាលឲ្យគេស្លាប់»
បានបដិសេធគេចេញ
នេះគឺជាការប្រៀបធៀប មានន័យថា «សម្លាប់ពួកគេ» ឬ «បណ្ដាលឲ្យគេស្លាប់»
បានដកយកជីវិតរបស់គេផង
នេះគឺជាការប្រៀបធៀប មានន័យថា «សម្លាប់គាត់» ឬ «ធ្វើឲ្យគាត់បញ្ឈប់ការរស់នៅ»
តើព្រះជាម្ចាស់នឹងស្តាប់ឮសម្រែករបស់ពួកគេ នៅពេលជួបបញ្ហាបានកើតឡើងលើគេទេ?
លោកយ៉ូបប្រើសំណួរទាំងនេះដើម្បីនិយាយថាព្រះនឹងមិនជួយអ្នកនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះនឹងមិនស្តាប់សម្រែករបស់គេ
នៅពេលបញ្ហាធ្លាក់មកលើគេទេ»។ ឬ «នៅពេលបញ្ហាធ្លាក់មកលើគេ
ហើយគេស្រែករកជំនួយ ព្រះជាម្ចាស់នឹងមិនស្តាប់សម្រែករបស់គេទេ»។
តើព្រះជាម្ចាស់នឹងស្តាប់ឮសម្រែករបស់ពួកគេ
នៅទីនេះ «ឮសម្រែករបស់ពួកគេ»
តំណាងការឆ្លើយតបទៅនឹងសម្រែករបស់មនុស្សទមិឡ និងការជួយគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «តើព្រះឆ្លើយតបនឹងសម្រែករបស់គេឬ»
តើពួកទមិឡរីករាយខ្លួនគេនៅក្នុងព្រះដ៏មានគ្រប់ព្រះចេស្តា
ហើយស្រែករកព្រះជាម្ចាស់គ្រប់ពេលវេលាទេ?
លោកយ៉ូបប្រើសំណួរនេះដើម្បីនិយាយថាមនុស្សទមិឡ មិនត្រូវធ្វើការទាំងនេះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គេនឹងមិនរីករាយនឹងអ្វីដែលព្រះដ៏ពេញដោយព្រះចេស្តាធ្វើនោះទេ
ហើយគេក៏មិនអធិស្ឋានរបស់ព្រះគ្រប់ពេលនោះដែរ»។
Job 27:11
ខ្ញុំនឹងបង្រៀនអ្នករាល់គ្នា
រាល់ការជួបប្រទះនៃពាក្យ «អ្នក» នៅក្នុងឃ្លាទាំងនេះគឺជាពហុវន
និងសំដៅដល់មិត្តទាំងបីរបស់លោកយ៉ូប
អំពីព្រះហស្តនៃព្រះជាម្ចាស់
«ព្រះហស្ត» របស់ព្រះ តំណាងឲ្យអំណាចរបស់ទ្រង់។
របៀបផ្សេងទៀតនៃការបកប្រែ: «អំណាចនៃព្រះ»
ខ្ញុំនឹងមិនលាក់គំនិតនៃព្រះដ៏មានគ្រប់ព្រះចេស្តាទេ
នាមអរូប «គំនិត» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «គិត»។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំនឹងមិនលាក់ពីអ្នករាល់គ្នា
នូវអ្វីដែលព្រះដ៏ពេញដោយព្រះចេស្តាគិតនោះទេ»
ហេតុអ្វីបានជាអ្នករាល់គ្នា នៅតែនិយាយសេចក្ដីគ្មានប្រយោជន៍ទាំងនេះទៀត?
លោកយ៉ូបប្រើសំណួរនេះដើម្បីបន្ទោសមិត្តរបស់លោកសម្រាប់ការនិយាយហាក់ដូចជាល្ងីល្ងើ។
របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«អ្នករាល់គ្នានៅតែនិយាយការគ្មានបានការទាំងនេះទៀត» ឬ
«អ្នករាល់គ្នាគួរតែឈប់និយាយល្ងីល្ងើដូច្នេះទៀត!»
Job 27:13
ការនេះហើយគឺជាវាសនា របស់មនុស្សអាក្រក់ជាមួយព្រះជាម្ចាស់
វាសនារបស់មនុស្សអាក្រក់ជាមួយព្រះ
សំដៅដល់អ្វីដែលព្រះបានមានផែនការសម្រាប់គេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«នេះជាផែនការដែលព្រះបានមានផែនការសម្រាប់មនុស្សអាក្រក់»
គឺជាកេរដំណែលនៃពួកអ្នកជិះជាន់គេ ត្រូវទទួលពីព្រះដ៏មានគ្រប់ព្រះចេស្តា
នៅទីនេះ «កេរដំណែលនៃពួកអ្នកជិះជាន់»
ជាការប្រៀបធៀបដែលតំណាងឲ្យអ្វីដែលនឹងកើតឡើងចំពោះពួកជិះជាន់គេ។
អ្វីដែលព្រះនឹងធ្វើចំពោះពួកគេដែលបាននិយាយ
វាហាក់ដូចជាកេរមរតកដែលព្រះបានប្រទានឲ្យគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលព្រះដ៏មានគ្រប់ព្រះចេស្តា
នឹងធ្វើចំពោះពួកជិះជាន់គេ»
សម្រាប់ឲ្យដាវសម្លាប់ប៉ុណ្ណោះ
នៅទីនេះដាវគឺតំណាងឲ្យការស្លាប់នៅក្នុងសង្គ្រាម។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងស្លាប់នៅក្នុងសង្គ្រាម»
Job 27:15
ពួកអ្នកដែលរស់នៅបន្តពីគេ
«ពួកអ្នកដែលនៅរស់បន្ទាប់ពីគាត់ស្លាប់»។
ឃ្លានេះសំដៅដល់កូនចៅរបស់មនុស្សអាក្រក់។
នេះអាចត្រូវបានបញ្ជាក់ច្បាស់លាស់។
«ពួកអ្នកដែលនៅរស់បន្ទាប់ពីឪពុកជាមនុស្សអាក្រក់របស់ពួកគេស្លាប់ទៅ»
នឹងត្រូវស្លាប់កប់ ដោយជំងឺរាតត្បាត
នៅទីនេះ «ត្រូវកប់» តំណាងឲ្យការស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងស្លាប់ដោយជំងឺរាតត្បាត»
ស្ត្រីមេម៉ាយរបស់គេ...ពួកគេ
ពាក្យ «របស់ពួកគេ» និង «ពួកគេ» សំដៅលើ «អស់អ្នកដែលនៅរស់បន្តពីគេ»
ដែលជា កូនចៅរបស់មនុស្សអាក្រក់។
ប្រមូលប្រាក់ទុកដូចជាធូលីដី
ពាក្យ «ពូនឡើង» នៅទីនេះ ជាការប្រៀបធៀប
ដែលមានន័យថាប្រមូលមកយ៉ាងច្រើន។ លោកយ៉ូបនិយាយ
ហាក់ដូចជាប្រាក់ងាយនឹងប្រមូលដូចជាធូលីដី។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រមូលប្រាក់ជាពំនូកដ៏ធំ» ឬ «ប្រមូលប្រាក់ ងាយដូចជាគាត់អាចប្រមូលធូលីដី»
ប្រមូល (ពូនឡើង) ទុក ស្មៀកពាក់ ដូចជាដីឥដ្ឋ
ពាក្យ «ពូនឡើង» នៅទីនេះ ជាការប្រៀបធៀប
ដែលមានន័យថាប្រមូលមកយ៉ាងច្រើន។ លោកយ៉ូបនិយាយ
ហាក់ដូចជាសំលៀកបំពាក់យ៉ាងស្រួលនឹងក្លាយទៅជាដីឥដ្ឋ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រមូលសំលៀកបំពាក់ជាពំនូកដ៏ធំ» ឬ
«ប្រមូលសំលៀកបំពាក់ ងាយដូចជាគាត់អាចប្រមូលដីឥដ្ឋ»
Job 27:18
ពួកគេបានសងផ្ទះដូចជាសំបុកពីងពាង
បន្ទាប់ពី «ពីងពាង» ឃ្លា «សង់សំណាញ់របស់វា» គឺត្រូវបានយល់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូចសត្វពីងពាងសង់សំណាញ់របស់វា»
ពួកគេបានសងផ្ទះដូចជាសំបុកពីងពាង
សំណាញ់ពីងពាងគឺផុយហើយងាយបំផ្លាញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គាត់សង់ផ្ទះរបស់គាត់ផុយដូចជាពីងពាងសង់សំណាញ់របស់វា» ឬ
«គាត់សង់ផ្ទះរបស់គាត់ផុយដូចសំណាញ់ពីងពាង»
ដូចជាខ្ទម
ខ្ទមដូចជាផ្ទះបណ្តោះអាសន្នដែលមិនសូវជាធំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាខ្ទមបណ្តោះអាសន្ន»
គេបានដេកចុះនៅលើគ្រែ អ្នកមាន
«គាត់គឺសម្បូរសប្បាយពេលដែលគេដេកនៅលើគ្រែ»។
ឃ្លានេះសំដៅដល់ការដេកចុះនៅលើគ្រែពេលយប់ហើយដេកលក់។
ប៉ុន្តែ គេមិនរក្សាការអ្វីដែលគេកំពុងធ្វើនោះទេ
«ប៉ុន្តែ គេនឹងមិនរក្សាការដេកនៅលើគ្រែអ្នកមានទេ» ឬ «ប៉ុន្តែ គេនឹងមិនបន្ត
សម្បូរសប្បាយពេលដែលគេដេកនៅលើគ្រែទេ»
គេបើកភ្នែករបស់គេឡើង
ការបើកភ្នែកតំណាងឲ្យការភ្ញាក់ឡើងនៅពេលព្រឹក។
របៀបផ្សេងទៀតនៃការបកប្រែ: «គេនឹងក្រោកឡើង»
គ្រប់យ៉ាងគឺបាត់អស់ហើយ
«គ្រប់យ៉ាងរបស់អ្នកមាននឹងបាត់បង់ទៅ» ឬ «គ្រប់យ៉ាងនឹងត្រូវអន្តរាយទៅ»
Job 27:20
ការភ័យរន្ធត់បានយកឈ្នះគេ
នៅទីនេះ «ភ័យរន្ធត់» តំណាងឲ្យការកើតមានឡើងយ៉ាងលឿនលើគាត់។
វាអាចមានន័យពីរ «ភ័យរន្ធត់» គឺ: ទី១)
ជាការប្រៀបធៀបសម្រាប់អ្វីៗដែលបណ្តាលឲ្យមនុស្សខ្លាច។
របៀបផ្សេងទៀតនៃការបកប្រែ: «រឿងដែលរ
គួរឲ្យភ័យរន្ធត់ដែលកើតយ៉ាងលឿនលើគាត់» ឬ ទី ២)
«ភ្លាមៗគាត់ត្រូវបានធ្វើឲ្យភ័យខ្លាច»
ដូចទឹកជំនន់
ពាក្យ «ទឹក» សំដៅលើទឹកជំនន់។
ទឹកជំនន់អាចកើតឡើងយ៉ាងលឿននៅពេលដែលមនុស្សមិនបានរំពឹងទុកពីពួកវា
ហើយពួកវាគ្រោះថ្នាក់និងបំផ្លិចបំផ្លាញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាទឹកជំនន់» ឬ «ដូចជាទឹកដែលកើនឡើងយ៉ាងលឿន»
ហើយខ្យល់ព្យុះនឹងយកគេទៅ
«ខ្យល់យ៉ាងខ្លាំងបក់គាត់ចេញទៅ»
ហើយបោសគេចេញទៅក្រៅពីកន្លែងរបស់គេដែរ
លោកយ៉ូបនិយាយពីខ្យល់ដែលបក់មនុស្សអាក្រក់ចេញពីផ្ទះរបស់ពួកគេ
ដូចជាខ្យល់ដែលមនុស្សបោសដីចេញពីផ្ទះជាមួយអំបោស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្យល់បោសគាត់ចេញពីកន្លែងរបស់គាត់ដូចជាស្ត្រីដែលបោសសំរាមចេញពីផ្ទះរបស់នាង»
ឬ «ខ្យល់បក់គាត់យ៉ាងងាយចេញពីកន្លែងរបស់គាត់»
កន្លែងរបស់គេដែរ
«ផ្ទះរបស់គាត់»
Job 27:22
ព័ត៌មានទូទៅ:
ក្នុងខ ២២-២៣ យ៉ូបនិយាយពីខ្យល់
ដែលដូចជាមនុស្សកំពុងវាយប្រហារមនុស្សអាក្រក់។
ខ្យល់នោះបក់បោកយ៉ាងខ្លាំងមកលើ
នីទៅនេះ «បក់មកលើគាត់»
តំណាងឲ្យការបក់នៃខ្យល់យ៉ាងខ្លាំងទាស់នឹងគាត់ដូចជាអ្នកវាយប្រហារ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាបក់យ៉ាងខ្លាំងទាស់នឹងគាត់ដូចជានរណាម្នាក់កំពុងវាយប្រហារគាត់»
គេព្យាយាមរត់គេចចេញពីដៃរបស់វាផងដែរ
នៅទីនេះ «ដៃ» តំណាងឲ្យអំណាច ឬការត្រួតត្រា
ដែលខ្យល់មានទៅលើមនុស្សអាក្រក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«គេបានព្យាយាមរត់គេចពីការត្រួតត្រារបស់វា»
ហើយវាបានទះដៃដាក់គេក្នុងការចំអក
ការទះដៃគឺជារបៀបនៃការចំអកអោយអ្នកណាម្នាក់។
នៅទីនេះវាតំណាងឲ្យការធ្វើសម្លេងខ្លាំងៗនៃខ្យល់។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាធ្វើឲ្យមានសម្លេងខ្លាំងៗដូចជានរណាម្នាក់កំពុងទះដៃរបស់គេដើម្បីចំអកឲ្យគាត់»
ហើយវាហួចដាក់គេនៅកន្លែងរបស់គេដែរ
ខ្យល់ធ្វើឲ្យមានសម្លេងដូចជាផ្លុំគេចេញពីកន្លែងរបស់គេ។
វាមានសម្លេងដូចជាសម្លេងហួចដែលមនុស្សធ្វើដើម្បីចំអកអ្នកណាម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «វាធ្វើសម្លេងហួច
ដូចជានាំឲ្យគេចេញពីផ្ទះរបស់គេ» ឬ «វាផ្លុំគេចេញពីកន្លែងរបស់គេ
ហើយធ្វើសម្លេងហួចដូចជាអ្នកណាម្នាក់ដែលហួចដាក់គេដើម្បីចំអកគេ»

---

28 [1]មានអណ្តូងរ៉ែសម្រាប់ជីកយកប្រាក់ ហើយក៏មានកន្លែងបន្សុទ្ធមាសដែរ។[2]គេយកដែកចេញពីដី ហើយយកលង្ហិនចេញមកពីថ្មដែរ។
[3]មនុស្សបានជីកចុះទៅខាងក្រោមជ្រៅដល់ទីងងឹត ដើម្បីស្វែងរកថ្ម ដែលកប់នៅបាតដីក្នុងទីងងឹតអន្ធការ។[4]គេជីកអណ្តូងរ៉ែឆ្ងាយពីកន្លែងមនុស្សរស់នៅ
ជាកន្លែងដែលមនុស្សស្ទើតែភ្លេចថាគេដើរតាមនោះ។ គេសម្រួតខ្លួនចុះទៅក្នុងអណ្តូងរ៉ែ ហើយយោលចុះយោលឡើងនៅទីនោះ គឺនៅឆ្ងាយពីមនុស្ស។

generated on Wed Sep 10 16:16:32 2025

[5]ដីតែងតែផ្តល់អាហារដល់មនុស្ស តែនៅខាងក្រោម ដូចជាត្រូវភ្លើងឆេះបំផ្លាញអស់។[6]គេរកឃើញត្បូងនៅជាមួយថ្មក្នុងដី ហើយរកបានមាសក្នុងធូលីដី។
[7]សត្វត្មាតមិនស្គាល់ផ្លូវចូលទៅ ក្នុងអណ្តូងរ៉ែនោះទេ ហើយសត្វរអាតក៏មើលមិនឃើញដែរ។[8]សត្វដ៏ខ្លាំងពូកែមិនដែលចូលទៅក្នុងនោះទេ សត្វសិង្ហក៏មិនដែលដើរកាត់តាមនោះដែរ។
[9]មនុស្សបានដាក់ដៃលើថ្មដ៏រឹង ហើយរម្លើងភ្នំរហូតដល់បាតខាងក្រោមនៃភ្នំ។[10]គេចោះរូងនៅក្នុងចំណោមថ្មដា ហើយភ្នែករបស់គេបានឃើញវត្ថុធាតុទាំងប៉ុន្មានដ៏មានតម្លៃ។[11]គេទប់ប្រភពទឹកឲ្យរឹងស្ងួត ដើម្បី ពួកគេនឹងនាំយកអ្វីៗដែលលាក់កំបាំង មកដាក់នៅដែលមានពន្លឺវិញ។
[12]តើគេអាចរកប្រាជ្ញាបាននៅទីណាបាន? តើការយល់ដឹងស្ថិតនៅកន្លែងណា?[13]មនុស្សលោកមិនស្គាល់តម្លៃរបស់ប្រាជ្ញាទេ ហើយប្រាជ្ញាក៏មិនស្ថិតនៅលើផែនដីដែរ។[14]ទីជម្រៅពោលថា ប្រាជ្ញាមិននៅក្នុងខ្ញុំទេ មហាសមុទ្រពោលថា ប្រាជ្ញាក៏មិននៅជាមួយខ្ញុំដែរ។
[15]គេមិនអាចយកមាសសុទ្ធ ហើយយកប្រាក់ទៅទិញប្រាជ្ញាបានទេ។[16]គេមិនអាចយកប្រាជ្ញាទៅថ្លឹងជាមួយ កែវមរកត ពេជ្រ ឬត្បូងកណ្តៀងបានឡើយ។[17]គ្មានមាស ឬពេជ្រណាផ្ទឹមស្មើនឹងប្រាជ្ញាទេ ហើយគេក៏មិនអាចយកប្រាជ្ញាទៅដូរជាមួយ ភាជន៍ដែលធ្វើពីមាសសុទ្ធដែរ។
[18]ផ្កាថ្ម និងគុជ រឹតតែផ្ទឹមនឹងប្រាជ្ញាមិនបាន ហើយមានប្រាជ្ញាប្រសើរជាងមាន កែវមុក្តាទៅទៀត។[19]ត្បូងជម្ពូវ័ត្តពីទឹកដីអេត្យូពីក៏មិនអាចប្រដូច ទៅនឹងប្រាជ្ញា ហើយប្រាជ្ញាមិនអាចយកទៅថ្លឹង ជាមួយមាសបានទេ។
[20]ដូច្នេះ តើប្រាជ្ញាមានប្រភពនៅទីណា? តើការយល់ដឹងស្ថិតនៅកន្លែងណាដែរ?[21]មនុស្សលោកមិនអាចមើលឃើញប្រាជ្ញាទេ ហើយក៏បានលាក់បាំងពីសត្វ ដែលហើរនៅលើមេឃដែរ។[22]រណ្តៅនៃសេចក្តីវិនាស និងសេចក្តីស្លាប់ពោលថា យើងបានឮគេនិយាយពីប្រាជ្ញាដោយផ្ទាល់ត្រចៀក។
[23]មានតែព្រះជាម្ចាស់ទេដែលស្គាល់ផ្លូវ ហើយជ្រាបថា ប្រាជ្ញាស្ថិតនៅកន្លែងណា។[24]ដ្បិតព្រះអង្គមើលធ្លុះរហូតដល់ទៅ ទីដាច់ស្រយាលនៃផែនដី និងទតឃើញអ្វីៗទាំងអស់នៅក្រោមមេឃ។[25]ពេលណាព្រះអង្គកំណត់កម្លាំងរបស់ខ្យល់ និងទំហំរបស់ផ្ទៃទឹក។
[26]ព្រះជាម្ចាស់បានកំណត់ច្បាប់មួយ សម្រាប់ទឹកភ្លៀង ព្រមទាំងកំណត់ផ្លូវសម្រាប់ផ្លេកបន្ទោរ និងផ្គររួចស្រេចហើយ។[27]ព្រះអង្គក៏ទតឃើញប្រាជ្ញា ព្រះអង្គលើកតម្លៃប្រាជ្ញានោះ ព្រះអង្គតាំងប្រាជ្ញាឡើង ហើយពិនិត្យពិច័យមើលយ៉ាងល្អិតល្អន់។[28]ចំពោះមនុស្សវិញ ព្រះជាម្ចាស់មានបន្ទូលថា៖ មើល! ការកោតខ្លាចនៃព្រះអម្ចាស់ គឺជាប្រាជ្ញា ហើយញែកចេញពីការអាក្រក់ ក៏ជាប្រាជ្ញាដែរ។

Job 28:1
អណ្តូងរ៉ែ
នេះគឺជាកន្លែងដែលមនុស្សជីកថ្មចេញពីផែនដី។
ថ្មទាំងនេះមានលោហធាតុនៅក្នុងវា។
ចម្រាញ់
នេះគឺជាដំណើរការនៃការវាយរំលាយលោហធាតុដើម្បីយកភាពមិនសុទ្ធទាំងអស់ដែលមានក្នុងវាចេញ។ ការប្រើប្រាស់ពាក្យនេះសម្រាប់ផ្លាស់ប្តូរ។ របៀបផ្សេងទៀតនៃការបកប្រែ: យកដែកចេញពីផែនដី
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សយកដែកចេញពីផែនដី»
ស្ពាន់ដុតកំដៅឲ្យចេញមកពីថ្ម
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សរំលាយយកស្ពាន់ចេញថ្ម» ឬ «មនុស្សវាយថ្មដើម្បីរំលាយស្ពាន់ចេញពីវា»
ស្ពាន់
ជាលោហធាតុពណ៌ទង់ដែងដ៏សំខាន់មួយ។
ដុតកំដៅ (រំលាយ)
នេះគឺជាដំណើរការនៃការវាយថ្មដើម្បីរំលាយលោហធាតុនៅក្នុងពួកវាដើម្បីយកបានលោហធាតុដែលមានតម្លៃ។ ប្រយោគទាំងនេះបង្ហាញអត្ថន័យដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
Job 28:3
មនុស្សបានតាំងពន្លឺដល់ខាងចុងដល់ទីងងឹត
នៅទីនេះ «តាំងទីបញ្ចប់នៃភាពងងឹត» តំណាងឲ្យការបញ្ចេញពន្លឺនៅក្នុងទីងងឹត។
មនុស្សអាចនឹងប្រើអណ្តាតភ្លើង ទាំងចន្លុះ និង គប់ភ្លើង។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សកាន់ភ្លើងទៅក្នុងកន្លែងងងឹត»
ទៅកាន់តែឆ្ងាយដែលអាចធ្វើបាន
«ទៅផ្នែកដែលឆ្ងាយបំផុតនៃអណ្តូងរ៉ែ»
កន្លែងសុគ្រស្ទាញ...ទីងងឹតដ៏ក្រាស់
ឃ្លាទាំងពីរនេះត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ថាភាពងងឹតគឺ ងងឹតយ៉ាងខ្លាំង។
រូង
រូងតូចចង្អៀតដែលជីកទីក្នុងដី ឬថ្ម។ មនុស្សចូលទៅក្នុងរូងដើម្បីជីកវា។
ជាកន្លែងដែលមនុស្សស្ទើរតែភ្លេចថាគេធ្លាប់ដើរកាត់តាមនោះ
កន្លែងដែលមនុស្សមិនដើរ
ត្រូវបានិយាយហាក់ដូចជាជើងនៃនរណាម្នាក់ដែលអាចបានដើរនោះទីនោះជាយូរមកហើយ
ហើយបានភ្លេចទីកន្លែងនោះ»
គេព្យួរឲ្យឆ្ងាយពីមនុស្ស
គេអាចបញ្ជាក់ឲ្យបានច្បាស់លាស់ពីរបៀបនិងកន្លែងព្យួរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឆ្ងាយពីមនុស្សម្នារ
គេព្យួរពីខ្សែរពួរនៅក្នុងអណ្តូង»
Job 28:5
ដ្បិតសម្រាប់ផែនដី គឺតែងតែផ្តល់ចេញមកអាហារ
នៅទីនេះ «អាហារ» គឺជាន័យធៀបក្នុងន័យធម្មតាសម្រាប់អាហារ។
អាហារបានចេញមកពីដី ជាន័យធៀបសម្រាប់អាហារដុះចេញពីដី។
របៀបផ្សេងទៀតនៃការបកប្រែ: «ផែនដី ជាកន្លែងអាហារដុះ»
ហើយវាគឺបានផ្លូវពីខាងក្រោមប្រសិនបើជាត្រូវភ្លើងឆេះ
អាចមានន័យពីរគឺ: ទី១) មនុស្សបានបង្កើតភ្លើងនៅខាងក្រោមដី ដើម្បីបំបែកថ្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាត្រូវបានបំបែកនៅខាងក្រោមដោយភ្លើងរបស់អ្នករុករក» ឬ ទី២) «ត្រឡប់»
មានន័យថា ប្រៀបធៀបសម្រាប់ផ្លាស់ប្តូរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាត្រូវបានបំបែកនៅខាងក្រោមយ៉ាងខ្លាំង
ហាក់ដូចជាវាត្រូវបានបំផ្លាញដោយភ្លើង»
បានប្តូរពីខាងក្រោម...ត្បូងរបស់វា...ដីរបស់វា
ពាក្យ «វា» សំដៅលើផែនដី។
ត្បូងទទឹម
ពាក្យនេះសំដៅលើប្រភេទត្បូងពណ៌ខៀវដែលមានតម្លៃដ៏កម្រ។
Job 28:7
អត់មានសត្វត្មាតដែលបានស្គាល់ផ្លូវចូលទៅទេ ហើយភ្នែករបស់សត្វស្ទាំងក៏មើលរូងនោះមិនឃើញដែរ
ប្រយោគទាំងនេះក៏បង្ហាញនូវអត្ថន័យដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«អត់មានសត្វត្មាត ឬ សត្វស្ទាំងដឹង
ឬធ្លាប់បានឃើញផ្លូវដែលទៅកាន់អណ្តូងរ៉ែទេ»
សត្វត្មាត
បក្សីដែលស៊ីសត្វចតុបាតជាចំណី
សត្វស្ទាំង
ពាក្យនេះក៏អាចបកប្រែថា «សត្វត្មាត»។ ទាំងពីរនេះជាប្រភេទសត្វស្លាបធំៗ
ដែលស៊ីសត្វដែលតូចជាងជាចំណី។
អ្នកអាចបកប្រែឈ្មោះនេះដោយឈ្មោះសត្វស្លាបដូចគ្នាក្នុងវប្បធម៌របស់អ្នកដែលជាសត្វធំនិងស៊ីសត្វជាចំ
ហើយសត្វដែលមានកម្លាំងមិនដែលបានដើរចូលតាមផ្លូវនោះដែរ ហើយសត្វសិង្ហក៏មិនដែលដើរកាត់តាមនោះដែរ
ប្រយោគទាំងនេះក៏បង្ហាញនូវអត្ថន័យដូចគ្នា។
សត្វដែលមានកម្លាំង
នេះសំដៅដល់សត្វព្រៃដែលមានកម្លាំងខ្លាំង។
Job 28:9
បុរសម្នាក់បានដាក់ដៃរបស់គាត់លើថ្មដ៏រឹង
នេះសំដៅលើការបំបែកថ្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ជីកទៅក្នុងថ្មដ៏រឹង»
ថ្មដ៏រឹង
«ថ្មដ៏រឹង»
រម្លើងភ្នំទាំងនោះដល់ ឫសរបស់ពួកវា
«បង្វិលភ្នំឡើងមកលើដោយការរុញឫសរបស់ពួកគេចេញមកក្រៅ»
ការបរិយាយនេះសំដៅលើការជីកភ្នំឡើង ហើយនិងដីនៅក្រោមពួកគេ។
គេបានរម្លើងភ្នំទាំងនោះដល់ ឫសរបស់ពួកវា
ដីនៅក្រោមភ្នំ ត្រូវបាននិយាយដូចជា ភ្នំដែលមានដើមឈើ

generated on Wed Sep 10 16:16:32 2025

ហើយដីនៅពីក្រោមពួកគេដែលមានឫស។
ភ្នែករបស់គេបានឃើញ
នៅទីនេះ «ភ្នែករបស់គេ» តំណាងឲ្យគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គាត់ឃើញ»
គេចងទប់ប្រភពទឹក ដើម្បីរបស់មានតម្លៃទាំងនោះមិនហូរទៅតាមទឹក
នៅទីនេះ «ចងទប់ប្រភពទឹក» តំណាងឲ្យការធ្វើឲ្យខុចឬ ការបិតប្រភពទឹក។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រង់បិតប្រភពទឹក ដូច្នេះពួកគេមិនហូរបានទេ»
អ្វីៗដែលលាក់បាំងនៅទីនោះ
ឃ្លានេះសំដៅលើវត្ថុដែលមនុស្សទូទៅមិនបានឃើញព្រោះពួកវានៅក្នុងដី
ឬនៅក្រោមទឹក។
Job 28:12
ព័ត៌មានទូទៅ:
ក្នុង ២៨:១២-២៨ ប្រាជ្ញា និងការយល់ដឹង ត្រូវបាននិយាយដូចជា
ពួកគេជាវត្ថុដ៏មានតម្លៃដែលនៅក្នុងកន្លែងមួយចំនួន
ហើយមនុស្សចង់ស្វែងរកពួកគេ។ ការស្វែងប្រាជ្ញា និងការយល់ដឹង
តំណាងឲ្យការក្លាយមកជាអ្នកប្រាជ្ញ
និងការរៀនសូត្រដើម្បីយល់ដឹងកិច្ចការបានប្រសើរ។
តើនឹងអាចរកប្រាជ្ញាពីទីណាបាន? តើការយល់ដឹងស្ថិតនៅកន្លែងណា?
សំណួរនេះមានន័យដូចគ្នា និងត្រូវបានប្រើដើម្បីបង្ហាញថា
វាពិបាកខ្លាំងណាស់ក្នុងការស្វែងរកប្រាជ្ញា និងការយល់ដឹង។
របៀបផ្សេងទៀតនៃការបកប្រែ: «វាពិបាកខ្លាំងណាស់ក្នុងការស្វែងរកប្រាជ្ញា និង
ការយល់ដឹង»
តើនឹងអាចរកប្រាជ្ញាពីទីណាបាន? តើការយល់ដឹងស្ថិតនៅកន្លែងណា?
ការមកជា អ្នកមានប្រាជ្ញា និងការយល់ដឹង ត្រូវបាននិយាយពីការស្វែងរកប្រាជ្ញា
និងការយល់ដឹង។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើមនុស្សអាចមានប្រាជ្ញាយ៉ាងដូចម្តេច?
តើមនុស្សរៀនឲ្យយល់ដឹងកិច្ចការនានាឲ្យបានប្រសើរដូចម្តេច?»
មនុស្សមិនអាចស្គាល់តម្លៃរបស់ប្រាជ្ញាទេ
អាចមានន័យពី គឺ: ទី១)
ប្រាជ្ញាត្រូវបាននិយាយហាក់ដូចជារបស់អ្វីមួយដែលមនុស្សអាចទិញ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សមិនដឹងអ្វីដែលស័ក្តិសមនោះទេ» ឬ ទី២)
ពាក្យត្រូវបានបងប្រែដូច «តម្លៃ» មានន័យ «កន្លែង»។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សមិនដឹងនៅកន្លែងណាទេ»
ហើយប្រាជ្ញាក៏មិនអាចមាននៅលើទឹកដីដែលគេរស់នៅដែរ
«ហើយក៏មិនអាចរកឃើញនៅលើដីដែលរស់នៅនេះដែរ» ពាក្យ «ដីដែលរស់នៅ»
សំដៅលើពិភពលោកនេះ ដែលមនុស្សរស់នៅ។ នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយមិនមាននរណាម្នាក់អាចស្វែងរកប្រាជ្ញាក្នុងលោកនេះទេ»
ទីជម្រៅរបស់ទឹកបាននិយាយថា «ប្រាជ្ញាមិនបាននៅក្នុងខ្ញុំទេ» ហើយសមុទ្រនិយាយថា «ប្រាជ្ញាក៏
មិននៅជាមួយខ្ញុំដែរ»
ទីជម្រៅទឹកនិងសមុទ្រ បានពណ៌នាហាក់ដូចជា
ពួកគេជាមនុស្សដែលអាចនិយាយបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាជ្ញាតែមិននៅក្នុងជម្រៅទឹក ក្រោមដី ហើយក៏មិននៅក្នុងសមុទ្រដែរ»
Job 28:15
វាមិនអាចទួលបានដោយសារមានទេ
អាចបញ្ជាក់ក្នុងទម្រង់សកម្ម។ នេះបញ្ជាក់ថាប្រាជ្ញាមានតម្លៃខ្លាំងជាងមាស។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សមិនអាចបង់ថ្លៃដោយមាសសម្រាប់ប្រាជ្ញាបានឡើយ»
ប្រាក់ក៏មិនអាចមានតម្លៃស្មើនិងប្រាជ្ញាដែរ
នេះបញ្ជាក់ថាប្រាជ្ញាមានតម្លៃខ្លាំងជាប្រាក់។ វាអាចបញ្ជាក់ក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយមនុស្សមិនមានប្រាក់ល្មមដើម្បីប្តូរសម្រាប់ប្រជ្ញានោះទេ»
ប្រាជ្ញាមិនអាចឲ្យតម្លៃជាមួយមាសមកពីស្រុកអូភារហើយជាមួយកែវមរកតដ៏មានតម្លៃ ឬត្បូងទទឹម
បានដែរ
នេះបញ្ជាក់ថាប្រាជ្ញាមានតម្លៃខ្លាំងជាមាសនៃអូផារកែវមរកតដ៏មានតម្លៃ ឬត្បូង
ទទឹមទៅទៀត។
អូភារ
នេះគឺជាឈ្មោះនៃដី ទីកន្លែងដែលស្វែងរកមាស។
កែវមរកត
ត្បូងថ្មមានតម្លៃពណ៌ខ្មៅ
ត្បូងទទឹម
ត្បូងថ្មមានតម្លៃពណ៌ខៀវ
មាសហើយត្បូងចរណៃមិនអាចស្មើនឹងប្រាជ្ញាទេ
នេះអាចបញ្ជាក់ថាប្រាជ្ញាមានតម្លៃខ្លាំងជាអលង្ការនៃមាសនិងត្បូងចរណៃទៅទៀត។
ត្បូងចរណៃ
ត្បូងថ្មមានតម្លៃដែលមានពណ៌ថ្លា ឬ ពន្លឺស្រាល
ហើយគេក៏មិនអាចយកប្រាជ្ញាទៅដូរជាមួយ គ្រឿងអលង្ការដែលធ្វើពីមាសសុទ្ធដែរ
ហើយក៏មិនអាចប្តូរជាមាសសុទ្ធបានដែរ។
នេះអាចបញ្ជាក់ថាប្រាជ្ញាមានតម្លៃខ្លាំងជាគ្រឿងអសង្ការនៃមាសសុទ្ធទៅទៀត។
ដូរ
«ដូរ»
Job 28:18
ផ្កាថ្មនិងគុជ គឺមិនអាចធ្មឹមនឹងប្រាជ្ញាបានឡើយ
វាមិនស័ក្តិសមនឹងធ្វើការប្រៀបធៀបដោយផ្កាថ្មនិងគុជ»។
នេះបញ្ជាក់ថាប្រាជ្ញាគឺមានតម្លៃខ្លាំងជាងផ្កាថ្មនិងគុជ
ដែលលោកយ៉ូបមិនត្រូវការនិយាយអំពីពួកវានោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំនឹងមិនធុញទ្រាន់ដើម្បីធ្មឹម ផ្កាថ្ម និង គុជទេ» ឬ
«ផ្កាថ្ម និង គុជ មិនស័ក្តិសមនឹងត្រូវបានប្រៀបធៀបនឹងប្រាជ្ញាទេ»
ផ្កាថ្ម
នេះគឺជាភោគទ្រព្យរឹងដ៏ស្រស់ស្អាតដែលលូតលាស់ឡើងនៅបាតមហាសមុទ្រ។
គុជ...ត្បូងទទឹម...ត្បូងពណ៌លឿង
ទាំងនេះជាត្បូងថ្មដ៏មានតម្លៃ។
ត្បូងពណ៌លឿងមកពីទឹកដីអេត្យូពីក៏មិនអាចស្មើនឹងប្រាជ្ញាដែរ
នេះបញ្ជាក់ថាប្រាជ្ញាមានតម្លៃខ្លាំងជាងត្បូងពណ៌លឿងទៅទៀត។
ហើយតម្លៃនៃប្រាជ្ញាមិនអាចយកមាសសុទ្ធមកប្រដូចបានទេ
«ហើយប្រាជ្ញាមិនអាចយកតម្លៃក្នុងមាសមកប្រៀបធៀបបានទេ»។
នេះបញ្ជាក់ថាប្រាជ្ញាមានតម្លៃខ្លាំងជាមាសសុទ្ធ។
Job 28:20
តើប្រាជ្ញាបានមកពីទីណា? ហើយតើការយល់ដឹងនៅទីកន្លែងណាដែរ?
លោកយ៉ូបប្រើសំណួរទាំងនេះដើម្បីណែនាំ របៀបដែលមនុស្សទទួលបានប្រាជ្ញា
និងការយល់ដឹង។ អលង្ការ «ខ្ញុំនឹងប្រាប់អ្នក ទីកន្លែងដែលប្រាជ្ញាមក និង
កន្លែងរបស់ការយល់ដឹង» ឬ «ខ្ញុំនឹងប្រាប់អ្នក ធ្វើដូចម្តេចឲ្យមានប្រាជ្ញា
និងរបៀបរៀនឲ្យយល់ដឹងពីកិច្ចការនានា»
តើប្រាជ្ញាបានមកពីទីណា
ប្រាជ្ញា គឺត្រូវបាននិយាយហាក់ដូចជានៅក្នុងកន្លែងមួយ ហើយមកឯមនុស្ស។
ការមករបស់ប្រាជ្ញា តំណាងឲ្យមនុស្សមានប្រាជ្ញា។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សទទួលបានប្រាជ្ញានៅទីណា» ឬ «មនុស្សអាចមានប្រាជ្ញាដោយរបៀបណា»
ហើយតើការយល់ដឹងនៅទីកន្លែងណាដែរ?
ការយល់ដឹង ត្រូវបាននិយាយ ហាក់ដូចជានៅក្នុងកន្លែងមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «កន្លែងដែលមនុស្សទទួលការយល់ដឹង» ឬ
«របៀបដែលមនុស្សរៀនឲ្យយល់ដឹងកិច្ចការនានា»
ប្រាជ្ញាគឺបានលាក់បាំងពីផ្នែកទាំងឡាយនៃរបស់ដែលមានជីវិត
នេះតំណាងឲ្យអ្វីៗដែលមានជីវិត មិនអាចឃើញប្រាជ្ញាទេ។
វាអាចត្រូវបានបង្ហាញក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានសត្វមានជីវិតណាមួយអាចឃើញប្រាជ្ញាឡើយ»
ហើយបិតបាំងពីសត្វស្លាប់ដែលនៅលើមេឃដែរ
នេះតំណាងថា សត្វស្លាបគឺមិនបានឃើញ ប្រាជ្ញាទេ។
នេះអាចត្រូវបានបង្ហាញក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយទោះបីជាសត្វស្លាបដែកហើរលើអាកាសក៏មិនអាចឃើញប្រាជ្ញាដែរ»
ការបំផ្លិចបំផ្លាញ ហើយសេចក្តីស្លាប់បាននិយាយថា
នៅទីនេះ «ការបំផ្លិចបំផ្លាញ» និង «សេចក្តីស្លាប់» ជាការប្រៀបធៀប
សម្រាប់ទីកន្លែងដែលមនុស្សទៅនៅពេលដែលស្លាប់។ ពួកគេ ត្រូវបាននិយាយ
ហាក់ដូចជាពួកគេជាមួយដែលអាចនិយាយបាន។
Job 28:23
ព្រះជាម្ចាស់យល់ដឹងពីផ្លូវទៅរកប្រាជ្ញា ព្រះអង្គស្គាល់ពីកន្លែងរបស់វា
ប្រាជ្ញា ត្រូវបាននិយាយហាក់ដូចជានៅកន្លែងមួយជាក់លាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះដឹង ពីរបៀបដើម្បីស្វែងរកប្រាជ្ញា។
ទ្រង់ដឹងថាវានៅទីណា»

generated on Wed Sep 10 16:16:32 2025

ដល់ចុងបំផុតនៃផែនដី
«កន្លែងឆ្ងាយបំផុតលើផែនដី»
បានកំណត់ទំហំរបស់ផ្ទៃទឹកឲ្យស្មើគ្នាដែរ
នេះតំណាងឲ្យការសម្រេចរបស់ព្រះជាម្ចាស់
ថាតើគួរមានទឹកប៉ុន្មានក្នុងកន្លែងនីមួយៗ។ អាចមានន័យពីរ
ដែលសំដៅដល់ការសម្រេចចិត្តនេះ គឺ: ទី១)
តើគួរមានទឹកភ្លៀងប៉ុន្មានក្នុងពពកនីមួយៗ ឬ ទី២)
តើគួរមានទឹកភ្លៀងប៉ុន្មានក្នុងសមុទ្រនីមួយៗ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ត្រូវបានសម្រេចថាត្រូវមានទឹកប៉ុន្មានក្នុងកន្លែងនីមួយៗ» ឬ
«ដាក់ចំនួនទឹកដែលព្រះអង្គបានរៀបផែនការសម្រាប់កន្លែងនីមួយៗ»
Job 28:26
និងផ្លូវសម្រាប់ផ្លេកបន្ទោរ នៃផ្គរផង
អាចមានន័យពីរគឺ ១) ទ្រង់បានសម្រេចថាតើគួរមានផ្លេកបន្ទោរយ៉ាងណា ឬ ២)
ទ្រង់បានសម្រេចទឹកន្លែងដែលគួរមានផ្គរលាន់។
ការកោតខ្លាចនៃព្រះអម្ចាស់ នោះហើយគឺជាប្រាជ្ញា
នាមអរូប «ភាពភ័យខ្លាច» អាចត្រូវបានបង្ហាញជាមួយពាក្យ «ប្រាជ្ញា»។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នកខ្លាចព្រះជាម្ចាស់
អ្នកនឹងមានប្រាជ្ញា»
ហើយញែកចេញពីការអាក្រក់ គឺជាប្រាជ្ញាដែរ
នៅទីនេះ «ញែកចេញពីការអាក្រក់» តំណាងការបដិសេធការប្រព្រឹត្តការអាក្រក់។
មានអរូប «ការយល់ដឹង» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «យល់ដឹង»។
របៀបផ្សេងទៀតនៃការបកប្រែ: «បដិសេធប្រព្រឹត្តការណ៍អាក្រក់គឺការយល់ដឹង» ឬ
«ប្រសិនបើអ្នកបដិសេធប្រព្រឹត្តការអាក្រក់
អ្នកនឹងទទួលយល់ដឹងកិច្ចការនានាបានប្រសើរ»

---

29 [1]លោកយ៉ូបរៀបរាប់សាជាថ្មីដោយនិយាយថា៖[2]«ខ្ញុំប្រាថ្នាឲ្យបានដូចកាលពីមុន គឺនៅគ្រាដែលព្រះជាម្ចាស់មើលថែទាំខ្ញុំ[3]នៅគ្រាដែលចង្កៀងរបស់ព្រះអង្គបំភ្លឺខ្ញុំ
ហើយខ្ញុំដើរកាត់ភាពងងឹតដោយពន្លឺរបស់ព្រះអង្គ។
[4]ពេលដែលខ្ញុំកំពុងតែចម្រុងចម្រើននោះ ព្រះជាម្ចាស់ជាមិត្តសម្លាញ់របស់ខ្ញុំ ព្រះជាម្ចាស់បានគង់នៅក្នុងទីលំនៅរបស់ខ្ញុំ។[5]ព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត គង់នៅជា
មួយខ្ញុំ ហើយកូនចៅរបស់ខ្ញុំក៏នៅជុំវិញខ្ញុំដែរ[6]នោះហ្វូងសត្វរបស់ខ្ញុំផ្តល់ទឹកដោះឲ្យខ្ញុំ យ៉ាងបរិបូណ៌ ចម្ការអូលីវរបស់ខ្ញុំ ផ្តល់ប្រេងដ៏ច្រើនហូរហៀរមកខ្ញុំ!
[7]ពេលខ្ញុំចេញទៅមាត់ទ្វារក្រុង ហើយពេលខ្ញុំអង្គុយកាត់ក្តីក្នុងចំណោមពួកព្រឹទ្ធាចារ្យ[8]ពួកក្មេងយុវជនបានឃើញខ្ញុំ គេនាំគ្នាដកខ្លួនថយទៅទីឆ្ងាយដែរ ហើយពួកអ្នកចាស់ទុំ
នាំគ្នាក្រោកឈរឡើងនៅចំពោះខ្ញុំផងដែរ។
[9]ពួកមេដឹកនាំឈប់និយាយ យកដៃខ្ទប់មាត់ ហើយនៅស្ងៀម នៅពេលដែរខ្ញុំចូលទៅដល់ទីនោះ។[10]សម្លេងរបស់ពួកអ្នកអភិជនក៏នៅស្ងៀមស្ងាត់
ហើយមាត់របស់ពួកគេក៏បិទ មិនហ៊ាននិយាយស្តីអ្វីទៀតទេ។
[11]ដ្បិតនៅពេលត្រចៀក របស់ពួកគេបានឮខ្ញុំនិយាយ នោះពួកនឹងគេឲ្យពរខ្ញុំ ពេលភ្នែករបស់គេឃើញខ្ញុំ ពួកគេនឹងធ្វើសាក្សីហើយនឹងយល់ស្រប់តាមខ្ញុំដែរ[12]ដ្បិតពេល
មនុស្សជួបទុក្ខលំបាកស្រែកឡើង នោះខ្ញុំជួយយកអាសាគេ ហើយខ្ញុំក៏បានជួយក្មេងកំព្រា និងអ្នកដែលគ្មានទីពឹងដែរ។[13]អ្នកដែលហៀបនឹងស្លាប់ តែងឲ្យពរខ្ញុំ ហើយខ្ញុំ
បានលើកទឹកចិត្តស្ត្រីមេម៉ាយ ច្រៀងដោយអំណរសប្បាយផងដែរ។
[14]សេចក្តីសុចរិតនៅជាប់ជាមួយខ្ញុំ ប្រៀបដូចជាសម្លៀកបំពាក់របស់ខ្ញុំ ហើយយុត្តិធម៌ក៏ប្រៀបដូចជាអាវធំ។[15]ខ្ញុំធ្វើជាភ្នែករបស់មនុស្សខ្វាក់ និងជាជើងរបស់មនុស្សខ្វិន។
[16]ខ្ញុំធ្វើជាឪពុករបស់ជនក្រីក្រ ហើយខ្ញុំជួយរកខុសត្រូវឲ្យមនុស្ស ដែលខ្ញុំពុំស្គាល់ផង។
[17]ខ្ញុំបំបាក់ថ្គាមរបស់មនុស្សទុច្ចរិត ដណ្តើមយកជនរងគ្រោះពីចង្កូមរបស់គេ។[18]ពេលនោះ ខ្ញុំនិយាយថា៖ ខ្ញុំនឹងស្លាប់នៅក្នុងទីលំនៅរបស់ខ្ញុំ
ហើយជីវិតរបស់នឹងបានវែងដូចចំនួនគ្រាប់ខ្សាច់។[19]ហើយឫសរបស់ខ្ញុំនឹងចាក់ទៅរកទឹក ហើយនៅពេលយប់ មានសន្សើមធ្លាក់មកលើមែកផងដែរ។
[20]កិត្តិយសទាំងនេះតែងតែនៅជាមួយខ្ញុំជានិច្ច កម្លាំងរបស់ខ្ញុំចេះតែចម្រើនឡើងសាជាថ្មី ដូចខ្សែធ្នូដែលគេរឹតយ៉ាងតឹង។[21]មនុស្សម្នាត្រងត្រាប់ស្តាប់ពាក្យខ្ញុំ ពេលខ្ញុំផ្តល់
យោបល់ គេនៅស្ងៀមស្ងាត់។[22]បន្ទាប់ពីខ្ញុំនិយាយផុតហើយនោះ គ្មាននរណាប្រកែកតវ៉ាទេហើយពាក្យខ្ញុំធ្លាក់ទៅលើគេ ដូចជាទឹកស្រក់លើពួកគេ។
[23]ពួកគេតែងតែរង់ចាំខ្ញុំ ដូចពួកគេរង់ចាំទឹកភ្លៀងដែរ ហើយពួកគេបានបើកមាត់យ៉ាងធំ ដើម្បីផឹកយកពាក្យរបស់ខ្ញុំ គឺដូចពួកគេទន្ទឹងរង់ចាំភ្លៀងចុងរដូវ។[24]ពេលខ្ញុំញញឹម
ដាក់ពួកគេ ពួកគេមិនចង់ជឿទេ ពួកគេមិនបានបដិសេធពន្លឺដែលចេញពីមុខខ្ញុំទេ។
[25]ខ្ញុំសុខចិត្តធ្វើជាមេដឹកនាំរបស់ពួកគេ ខ្ញុំនឹងបង្ហាញផ្លូវពួកគេ ហើយខ្ញុំរស់នៅ ដូចស្តេចដែលនៅជាកងទ័ពរបស់ខ្លួន និងដូចអ្នកលើកទឹកចិត្ត អស់អ្នកដែលកើតទុក្ខ។

Job 29:1
ដូច្នេះ ខ្ញុំចង់បានដូចពេលដែលក្នុងខែកន្លងទៅ
លោកយ៉ូបប្រើការឧទាននេះដើម្បីបង្ហាញបំណងប្រាថ្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំចង់បានដូចដែលខ្ញុំពីខែកន្លងមក»
នៅពេលដែលចង្កៀងរបស់ព្រះអង្គភ្លឺលើក្បាលខ្ញុំ
ចង្កៀងរបស់ព្រះអង្គភ្លឺលើលោកយ៉ូប
តំណាងការប្រទានពររបស់ព្រះជាម្ចាស់ដល់លោកយ៉ូប។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលការប្រទានពររបស់ព្រះដូចជាចង្កៀងជះពន្លឺរបស់វាលើក្បាលរបស់ខ្ញុំ»
ពេលខ្ញុំដើរកាត់ភាពងងឹតដោយពន្លឺរបស់ព្រះអង្គ
ការដើរកាត់ភាពងងឹត តំណាងឲ្យការជួបប្រទះស្ថានភាពដ៏លំបាក។
Job 29:4
កាលពីគ្រាមុន ក្នុងពេលដែលខ្ញុំនៅក្មេងហើយមានកម្លាំង
លោកយ៉ូបនិយាយអំពី ពេលដែលលោកនៅក្មេង និងមានកម្លាំងដូចជា
ថ្ងៃរបស់លោកពេលដែលចម្រូតទុំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលដែលខ្ញុំនៅក្មេងនិងមានកម្លាំង»
ពេលមិត្តភាពនៃព្រះជាម្ចាស់បាននៅក្នុងទីលំនៅរបស់ខ្ញុំ
មានអរូប «មិត្តភាព» អាចត្រូវបានបង្ហាញជាមួយនាម «មិត្ត»។ ពាក្យ «ទីលំនៅ»
តំណាងឲ្យផ្ទះរបស់លោកយ៉ូប។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលព្រះជាមិត្តរបស់ខ្ញុំ និងបានការពារផ្ទះរបស់ខ្ញុំ»
ពេលផ្លូវរបស់ខ្ញុំបានពេញទៅដោយការ៉ែម (ទឹកដោះខាប់)
«នៅពេលដែលផ្លូវរបស់ខ្ញុំបានហូរជាមួយទឹកដោះខាប់»។
លោកយ៉ូបប្រើពាក្យបំផ្លើសទាំងនេះដើម្បីបង្ហាញថាគាត់មានគោជាច្រើនហើយពួកវាបានផ្តល់ទឹកដោះឲ្យគាត់ច្រើនលើសលប់។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលគោរបស់ខ្ញុំបានផ្តល់ទឹកដោះយ៉ាងហូរហៀរ»
ហើយថ្មបានហូរប្រេងចេញសម្រាប់ខ្ញុំជាប្រភពនៃប្រេង
«ហើយថ្មបានបង្ហូរចេញនូវប្រេងសម្រាប់ខ្ញុំ»។ លោកយ៉ូបប្រើការបំផ្លើសសម្តីនេះ
ដើម្បីបង្ហាញថាគាត់បានមានទឹកអូលីវនិងប្រេងអូលីវយ៉ាងច្រើនក្រាស់ក្រែ។
ថ្មជាកន្លែងដែលអ្នកបម្រើរបស់លោកគាបប្រេងចេញពីផ្លែអូលីវ។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលអ្នកបម្រើរបស់ខ្ញុំបានគាបចេញនូវប្រេងអូលីវជច្រើនក្រាស់ក្រែ» ឬ
«នៅពេលដែលប្រេងបានហូរដូចទឹកជ្រោះពីថ្មគាប»
Job 29:7
កណ្តាលទីក្រុង
នេះគឺជាតំបន់បើកនៅក្នុងភូមិ ឬទីក្រុង កន្លែងដែលផ្លូវពីរ ឬច្រើនជួបគ្នា។
បានក្រោកហើយឈរឡើងសម្រាប់ខ្ញុំ
នេះគឺជារូបភាពនៃការគោរព។ វាអាចត្រូវបញ្ជាក់យ៉ាងច្បាស់លាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្រោក និងឈរ ដោយការគោរពសម្រាប់ខ្ញុំ»
Job 29:9
ពួកមេដឹកនាំធ្លាប់បានឈប់និយាយ នៅពេលខ្ញុំបានមកដល់
នេះជាសញ្ញានៃការគោរព។
ហើយពួកគេបានយកដៃបិទមាត់របស់គេផង
ពួកគេបានធ្វើនេះ ដើម្បីបង្ហាញថាពួកគេមិនអាចនិយាយបាន។
នេះជាសញ្ញានៃការគោរពរបស់ពួកគេសម្រាប់លោកយ៉ូប។
សម្លេងរបស់ពួកអ្នកអភិជនក៏នៅស្ងៀមស្ងាត់
នេះអាចត្រូវបញ្ជាក់ក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
របស់ពួកអ្នកអភិជនស្ងៀមស្ងាត់ដោយសារពាក្យរបស់លោក ឬ
«ពួកអ្នកអភិជនបានឈប់និយាយ»

generated on Wed Sep 10 16:16:32 2025

ហើយអណ្តាតរបស់ពួកគេក៏ខាំជាប់ មិនមានអ្វីនិយាយចេញមកទេ
នេះតំណាងឲ្យការមានការគោរពយ៉ាងខ្លាំងរបស់ពួកគេ សម្រាប់លោកយ៉ូប
ដែលពួកគេមិនមានអ្វីនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកគេមានអារម្មណ៍មិនអាចនិយាយអ្វីបាន» ឬ
«ហើយពួកគេមិនមានអ្វីនិយាយទាំងអស់»
Job 29:11
ដ្បិត បន្ទាប់ពីត្រចៀករបស់ពួកគេបានស្តាប់ឮខ្ញុំ...បន្ទាប់មកភ្នែករបស់គេបានឃើញ
ត្រចៀក តំណាងឲ្យអស់អ្នកដែលបានឮគាត់ ហើយភ្នែក
តំណាងឲ្យអស់អ្នកដែលឃើញគាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់ពីពួកគេបានឮអ្វីដែលខ្ញុំប្រាប់ពួកគេ...បន្ទាប់ពីពួកគេបានឃើញខ្ញុំ»
ពួកគេនឹងធ្វើសាក្សីដល់ខ្ញុំហើយនឹងយល់ស្របតាមខ្ញុំដែរ
«ពួកគេធ្វើជាសាក្សីដោយយល់ស្របជាមួយខ្ញុំ»
ខ្ញុំបានសង្គ្រោះមនុស្សក្រលំបាក ពេលគេស្រែកឡើង
នៅទីនេះ «មនុស្សក្រលំបាក» សម្តៅដល់អ្នកក្រមួយចំនួន។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានសង្គ្រោះមនុស្សក្រលំបាក
ពេលគេស្រែកឡើង»
ជាពររបស់អ្នកនឹងជិតវិនាសបានមកលើខ្ញុំ
ព្រះពររបស់អ្នកណាម្នាក់មកដល់អ្នកណាម្នាក់ តំណាងថា
មនុស្សអោយពរអ្នកដទៃ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលហៀបនឹងវិនាសគួរអោយពរខ្ញុំ»
អ្នកនឹងជិតវិនាសបានមកលើខ្ញុំ
នេះតំណាងមនុស្សគ្រប់គ្នាដែលជិតស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលជិតស្លាប់»
ខ្ញុំបានធ្វើឲ្យចិត្តរបស់ស្ត្រីមេម៉ាយ ច្រៀងដោយអំណរដែរ
នៅទីនេះ «ចិត្តរបស់ស្ត្រីមេម៉ាយ» តំណាងឲ្យស្ត្រីមេម៉ាយមួយចំនួន។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានធ្វើឲ្យស្ត្រីមេម៉ាយច្រៀងដោយអំណរ»
Job 29:14
ខ្ញុំបានបំពាក់សេចក្តីសុចរិត ហើយការនេះដូចជាសម្លៀកបំពាក់របស់ខ្ញុំ
ជាញឹកញាប់មនុស្សនិយាយពី សេចក្តីសុចរិត វាដូចជាសំលៀកបំពាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានធ្វើអ្វីដែលសុចរិត
ហើយវាដូចជាសំលៀកបំពាក់លើខ្ញុំ»
ហើយសេចក្តីយុត្តិធម៌របស់ខ្ញុំក៏ប្រៀបដូចជាអាវធំហើយនិងមួក
ជាញឹកញាប់មនុស្សនិយាយពី សេចក្តីសុចរិត វាដូចជាសំលៀកបំពាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានធ្វើអ្វីដែលសុចរិត ហើយវាដូចជាអាវវែង
និងមួកលើខ្ញុំ»
មួក
ក្រណាត់វែងដែលមនុស្សប្រុសពាក់ជុំវិញក្បាលរបស់គេ និងពាក់ដូចជាមួកមួយ។
ខ្ញុំធ្វើជាភ្នែករបស់មនុស្សពិការ
នេះតំណាងឲ្យការជួយមនុស្សពិការ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានដូចជាភ្នែកសម្រាប់មនុស្សពិការ» ឬ «ខ្ញុំដឹកនាំមនុស្សពិការភ្នែក»
ខ្ញុំជាជើងរបស់មនុស្សពិការជើង
នេះតំណាងឲ្យការជួយមនុស្សពិការ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានដូចជាជើងសម្រាប់មនុស្សពិការ» ឬ «ខ្ញុំគាំទ្រមនុស្សពិការ»
ខ្ញុំធ្វើជាឪពុកដល់ជនក្រីក្រ
នៅទីនេះ «ខ្ញុំធ្វើជាឪពុក» តំណាងឲ្យការផ្តល់ឲ្យសម្រាប់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំផ្តល់ឲ្យជនក្រីក្រដូចជាឪពុកផ្តល់ឲ្យសម្រាប់កូនៗរបស់គេ»
Job 29:17
ព័ត៌មានទូទៅ:
ក្នុងខ ១៨-២០ លោកយ៉ូបប្រាប់អំពីកិច្ចការដែលលោកបានធ្វើ
ដើម្បីនិយាយមុនពេលការអាក្រក់ត្រូវបានកើតឡើងចំពោះគាត់។
ខ្ញុំបំបាក់ថ្គាម...ខ្ញុំបានដណ្តើមយកជនរង
លោកយ៉ូបនិយាយអំពីមនុស្សទុច្ចរិតដែលធ្វើទុក្ខបុកម្នេញអ្នកដទៃ
ហាក់ដូចជាពួកគេជាសត្វសាហាវ
ដែលវាយប្រហារជនរងគ្រោះដោយចាប់ពួកគេដោយសារធ្មេញរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានធ្វើឲ្យមនុស្សទុច្ចរិតឈប់ធ្វើទុក្ខបុកម្នេញមនុស្ស
ដូចនរណាម្នាក់ដែលបំបាក់ធ្មេញរបស់សត្វសាហាវនិងរំដោះជនរងគ្រោះពីធ្មេញរបស់ពួកវា»
ខ្ញុំនឹងស្លាប់នៅក្នុងទ្រនំរបស់ខ្ញុំ
នៅទីនេះ «ទ្រនំ» តំណាងឲ្យផ្ទះរបស់លោកយ៉ូបនិងគ្រួសារ។
លោកយ៉ូបបាននិយាយ
ហាក់ដូចជាលោកជាសត្វស្លាបដែលរស់នៅក្នុងសំបុកជាមួយកូនបក្សីតូចៗរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងស្លាប់ក្នុងផ្ទះរបស់ខ្ញុំជាមួយគ្រួសាររបស់ខ្ញុំ» (UDB) ឬ
«ខ្ញុំនឹងស្លាប់ក្នុងសុវត្ថិភាពនៃផ្ទះរបស់ខ្ញុំ»
ខ្ញុំនឹងធ្វើឲ្យថ្ងៃរបស់ខ្ញុំវែងដូចចំនួនគ្រាប់ខ្សាច់
លោកយ៉ូបបាននិយាយ ហាក់ដូចជាថ្ងៃនៃជីវិតរបស់លោកអាចកើនចំនួនច្រើនឡើង
ដូចជាគ្រាប់ខ្សាច់នៅលើឆ្នេរ។ នេះគឺសង្កត់ធ្ងន់
ដើម្បីបង្ហាញថាលោកអាចរស់នៅបានយូរអង្វែងទៀត» ឬ
«ខ្ញុំនឹងរស់នៅជាច្រើនឆ្នាំទៀត»
ឫសរបស់ខ្ញុំ...មែករបស់ខ្ញុំ
លោកយ៉ូបបាននិយាយពីកម្លាំងរបស់លោក
ហាក់ដូចជាលោកបានខ្លាំងដូចជាដើមឈើដែលមានទឹកហូរហៀរ។
Job 29:20
កិត្តិយសដែលនៅក្នុងខ្ញុំតែងតែស្រស់ស្រាយជានិច្ច
នាមអរូប «កិត្តិយស» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «កិត្តិយស»។
នៅទីនេះ «ស្រស់ស្រាយ» តំណាងឲ្យការផ្តល់កិត្តិយសជានិច្ចកាល។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សម្នារជានិច្ចកាលផ្តល់កិត្តិយសឲ្យខ្ញុំ» ឬ «
មនុស្សតែងតែផ្តល់កិត្តិយសដល់ខ្ញុំ»
ធ្នូរនៃកម្លាំងរបស់ខ្ញុំតែងតែថ្មីនៅក្នុងដៃរបស់ខ្ញុំដែរ
ធ្នូរថ្មីគឺខ្លាំងណាស់។ ធ្នូរនៃកម្លាំងរបស់លោកយ៉ូប
តំណាងឲ្យកម្លាំងរូបកាយរបស់លោក។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំតែងតែខ្លាំងជានិច្ចដូចជាធ្នូរថ្មី»
ពាក្យខ្ញុំធ្លាក់ ដូចជាទឹកស្រក់លើពួកគេ
នៅទីនេះ «បានធ្លាក់ដូចជាទឹកស្រក់លើពួកគេ»
តំណាងឲ្យការធ្វើឲ្យមនុស្សដែលបានឮពាក្យរបស់គាត់បានស្រស់ស្រាយ។
នាមអរូប «ពាក្យ» អាចត្រូវបានបកប្រែជាមួយកិរិយាសព្ទ «និយាយ» ឬ
«ពោល»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពាក្យរបស់ខ្ញុំបានធ្វើឲ្យដួងចិត្តរបស់គេស្រស់ស្រាយ
ដូចជាតំណក់ទឹកដែលធ្វើឲ្យរូបកាយរបស់មនុស្សបានស្រស់បស់» ឬ
«អ្វីដែលខ្ញុំនិយាយទៅកាន់ពួកគេបានធ្វើឲ្យពួកគេស្រស់បស់ ដូចជាតំណក់ទឹក»
Job 29:23
ពួកគេតែងតែរង់ចាំដល់ខ្ញុំ ដូចដែលពួកគេបានរង់ចាំទឹកភ្លៀងដែរ
មនុស្សបានរងចាំសម្រាប់លោកយ៉ូបយ៉ាងអត់ធ្មត់និងបានរំពឹងឮនូវការល្អ។
ហើយពួកគេបានបើកមាត់យ៉ាងធំ ដើម្បីក្រេបជញ្ជក់យកពាក្យរបស់ខ្ញុំ
នេះសំដៅដល់ការរងចាំយ៉ាងអន្ទះអន្ទែងសម្រាប់លោកយ៉ូបនិយាយ
ដើម្បីផលប្រយោជន៍ពីអ្វីដែលនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានរងចាំយ៉ាងអន្ទះសារសម្រាប់ពាក្យសម្តីរបស់ខ្ញុំ
ដើម្បីប្រយោជន៍ពីអ្វីដែលខ្ញុំនិយាយ»
គឺដូចពួកគេទន្ទឹងរង់ចាំភ្លៀងចុងរដូវដែរ
«កសិកររងចាំយ៉ាងអន្ទះអន្ទែងសម្រាប់ភ្លៀងចុងរដូវ»
ភ្លៀងចុងរដូវ
នេះសំដៅដល់ភ្លៀងមេយ៉ាងធំដែលធ្លាក់មុនពេលរដូវរាំងស្ងួតមកដល់។
ខ្ញុំបានញញឹមដាក់ពួកគេ
វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ថាគោលបំណងនៃការញញឹម
គឺដើម្បីលើកទឹកចិត្តពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានញញឹមដាក់ពួកគេដើម្បីលើកទឹកចិត្តពួកគេ»
ពន្លឺដែលចេញពីមុខខ្ញុំ
នេះតំណាងឲ្យសេចក្តីសប្បុរសដែលពួកគេបានឃើញលើផ្ទៃមុខរបស់លោកយ៉ូប។
Job 29:25
ខ្ញុំបានជ្រើសរើសផ្លូវរបស់គេ
នៅទីនេះ «ជ្រើសរើសផ្លូវរបស់គេ» តំណាងការសម្រេចចិត្តអ្វីដែលពួកគេគួរធ្វើ។
អង្គុយធ្វើជាអ្នកដឹកនាំរបស់ពួកគេ
នៅទីនេះ «អង្គុយ» សំដៅឲ្យការគ្រប់គ្រងឬ ការដឹកនាំ។
ពួកចៅហ្វាយបានអង្គុយចុះ នៅពេលដែលពួកគេធ្វើការសម្រេចចិត្តសំខាន់ៗ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានដឹកនាំពួកគេ ដូចជាចៅហ្វាយរបស់ពួកគេ»
អង្គុយធ្វើជាអ្នកដឹកនាំរបស់ពួកគេ
លោកបានជាចៅហ្វាយរបស់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«បានដឹកនាំពួកគេ ព្រោះខ្ញុំជាចៅហ្វាយរបស់ពួកគេ»
ខ្ញុំបានរស់ នៅដូចស្តេចមួយអង្គ នៅក្នុងជាកងទ័ពរបស់ទ្រង់
លោកយ៉ូបនិយាយ ថាតើលោកបានដឹកនាំមនុស្សយ៉ាងដូចម្តេច
ហើយថាតើពួកគេបានគោរពលោក
ដូចជាលោកជាស្តេចហើយពួកគេជាពលទាហានរបស់លោក។
ខ្ញុំដូចអ្នកលើកទឹកចិត្តដល់អ្នកដែលកាន់ទុក្ខផង
ឃ្លានេះមានន័យថា លោកយ៉ូបពិតជាអ្នកដែលលើកទឹកចិត្តមនុស្សម្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានលើកទឹកចិត្តពួកគេ
នៅពេលដែលពួកគេកាន់ទុក្ខ»

---

30 [1]ឥឡូវនេះ អស់អ្នកដែលនៅក្មេងជាងខ្ញុំ សើចចំអកឲ្យខ្ញុំ! ឪពុករបស់អ្នកទាំងនោះ សុទ្ធតែជាមនុស្សប្រើការមិនកើត សូម្បីតែប្រើឲ្យកៀងហ្វូងសត្វ ជាមួយឆ្កែរបស់ខ្ញុំ
ក៏ខ្ញុំមិនទុកចិត្តដែរ។[2]កម្លាំងដៃរបស់ឪពុកអ្នកទាំងនោះ ប្រើមិនកើតទេ តើធ្វើដូចម្តេចអាចជួយខ្ញុំបាន ហើយមនុស្សវ័យកាន់តែចាស់តើមិនវិនាសទេឬ?
[3]ពួកគេស្គមដោយដោយការក្រីក្រ និងឃ្លានខ្លាំងពេក ពួកគេរត់ទៅវាលហួតហែង ដែលជាទីស្មសាន រាំងស្ងួតតាំងពីយូរយារមកហើយ។
[4]ពួកគេបោចស្លឹកឈើនៅតាមគុម្ពោត យកមកធ្វើជាអាហារ សូម្បីតែមើមក្តួច ក៏ពួកគេបរិភោគដែរ។[5]មនុស្សម្នាដេញអ្នកទាំងនោះចេញពីទីប្រជុំជន ហើយស្រែកពីក្រោយ
ដូចស្រែកដេញចោរ។[6]ពួកគេនាំគ្នារត់ទៅស្នាក់អាស្រ័យ នៅតាមជ្រលងភ្នំដ៏ចង្អៀតគួរព្រឺខ្លាច និងនៅតាមរូងភ្នំ តាមក្រហែងថ្ម។
[7]ពួកគេស្រែកនៅក្នុងគុម្ពោតព្រៃ ដូចសត្វធាតុ ហើយប្រជ្រៀតគ្នានៅក្រោមដើមផ្អាវ។[8]ពួកគេគឺជាកូននៃមនុស្សល្ងង់ ហើយជាកូននៃមនុស្សមិនដឹងខ្យល់ ឥតពូជឥតអំបូរ
ហើយពួកគេត្រូវបានអ្នកស្រុកដេញចេញពីទឹកដីរបស់គេផង។
[9]ប៉ុន្តែ ឥឡូវនេះ ពួកកូនចៅរបស់គេបែរជានាំគ្នា ច្រៀងឡកឡឺយ និងយកខ្ញុំមកនិយាយលេងសើច។[10]ពួកគេខ្ពើមខ្ញុំ ហើយដើរវាងឆ្ងាយពីខ្ញុំ ពួកគេមិនញញើតនឹងស្តោះទឹក
មាត់ ដាក់មុខខ្ញុំផង។[11]ដ្បិត ព្រះជាម្ចាស់ធ្វើឲ្យខ្ញុំធ្លាក់ខ្លួនខ្សោយ ព្រះអង្គបន្ទាបបន្ថោកខ្ញុំ ហេតុនេះហើយបានជាពួកគេមើលងាយខ្ញុំ តាមចិត្តរបស់ពួកគេ។
[12]ជនពាលជាច្រើនប្រហារខ្ញុំពីខាងស្តាំ ពួកគេទាត់ជើងខ្ញុំ ហើយសង្រ្គប់មកលើខ្ញុំ ដើម្បីកម្ទេចខ្ញុំផងដែរ។[13]ពួកគេបានបំផ្លាញផ្លូវខ្ញុំ មិនឲ្យរត់រួច ពួកគេប្រាថ្នាធ្វើឲ្យខ្ញុំវិនាស
ដោយមិនបាច់មាននរណាឃាត់ពួកគេបានឡើយ។
[14]ពួកគេលើកគ្នាសម្រុកមកលើខ្ញុំ ដូចកងទ័ពទម្លុះកំពែង សម្រុកចូលវាយក្រុងដ៏ធំមួយ ហើយនៅកណ្តាលនៃការបំផ្លាញនោះ គេបានរមៀលខ្លួនពួកគេមកលើខ្ញុំ។[15]ការភ័យ
តក់ស្លុតក៏កើតមានដល់ខ្ញុំ កិត្តិយសដ៏រុងរឿងរបស់ខ្ញុំប៉ើងទៅតាមខ្យល់ ភាពចម្រុងចម្រើនរបស់ខ្ញុំរសាត់បាត់ ដូចពពក។
[16]ឥឡូវនេះ ជីវិតរបស់ខ្ញុំកំពុងតែរលត់ គ្មានអ្វីសម្រាលទុក្ខវេទនារបស់ខ្ញុំបានទេ។[17]នៅពេលយប់ ការឈឺចាប់ស៊ីរូងឆ្អឹងរបស់ខ្ញុំឥតមានពេលល្ហែសោះឡើយ។
[18]ព្រះជាម្ចាស់បានជំរុញការឈឺចាប់ខ្លាំងពេក រហូតដល់ធ្វើឲ្យ សម្លៀកបំពាក់របស់ខ្ញុំ ហើយរឹតរួតខ្ញុំ ដូចកអាវរឹតកខ្ញុំ។[19]ព្រះជាម្ចាស់បានបោះខ្ញុំទៅក្នុងភក់ជ្រាំ ខ្ញុំមិនខុសពី
ធូលីដី និងផេះទេ។
[20]ទូលបង្គំស្រែកអង្វរសូមព្រះអង្គជួយ តែព្រះអង្គមិនឆ្លើយមកទូលបង្គំទេ ពេលទូលបង្គំក្រោកឈរ ព្រះអង្គគ្រាន់តែសម្លឹងមកទូលបង្គំប៉ុណ្ណោះ។[21]ព្រះអង្គប្រព្រឹត្តចំពោះ
ទូលបង្គំយ៉ាងឃោរឃៅ ព្រះអង្គប្រហារទូលបង្គំ ជាមួយព្រះហស្តដ៏ខ្លាំងពូកែ មកលើទូលបង្គំ។
[22]ព្រះអង្គលើកទូលបង្គំឡើង ហើយឲ្យខ្យល់ផាត់ទូលបង្គំយកទៅ ព្រមទាំងឲ្យខ្យល់ព្យុះបក់បោក មកលើទូលបង្គំផង។[23]ដ្បិត ទូលបង្គំដឹងហើយថាព្រះអង្គនាំទូលបង្គំ ទៅ
រកសេចក្តីស្លាប់ គឺនៅកន្លែងដែលរបស់ដែលមានជីវិតរស់នៅ។
[24]ទោះជាយ៉ាងណាក៏ដោយ តើមានអ្នកណាដែលខ្លួនជិតដួលហើយមិនលូកដៃ សុំរកជំនួយទេឬ?[25]តើនៅពេលជួយបញ្ហា ហើយមិនស្រែកហៅឲ្យគេជួយទែឬ?[26]ខ្ញុំសង្ឃឹម
ថាបានសុភមង្គល តែទុក្ខវេទនាបែរជាកើតមានដល់ខ្ញុំ ខ្ញុំទន្ទឹងរង់ចាំពន្លឺ តែសេចក្តីងងឹតបែរជា កើតមានដល់ខ្ញុំទៅវិញ។
[27]ចិត្តរបស់ខ្ញុំតប់ប្រមល់ ឥតឈប់ឈរ ទុក្ខលំបាកកើតមានដល់ខ្ញុំរៀងរាល់ថ្ងៃ។[28]មុខរបស់ខ្ញុំឡើងខ្មៅ តែមិនមែនដោយសារកម្តៅថ្ងៃទេ ខ្ញុំក្រោកឈរនៅទីប្រជុំជន ស្រែក
ហៅគេឲ្យជួយ។[29]ខ្ញុំបានក្លាយមកជាបងប្អូនរបស់ឆ្កែព្រៃ និងជាមិត្តសម្លាញ់របស់ខ្លែងស្រាក។
[30]ស្បែករបស់ខ្ញុំឡើងខ្មៅ ហើយបានធ្លាក់ចុះពីខ្ញុំដែរ ឆ្អឹងរបស់ខ្ញុំបានឆេះដោយសារកំដៅថ្ងៃ។[31]សំលេងពិណរបស់ខ្ញុំលេងបានតែបទទំនួញ សំឡេងប៊ីរបស់ខ្ញុំបានត្រឹមតែ
កំដរ អស់អ្នកដែលយំកាន់ទុក្ខប៉ុណ្ណោះ។

Job 30:1
មិនមានអ្វីទាំងអស់ ប៉ុន្តែ បានសើចចំអកដល់ខ្ញុំ
នាមអរូប «ពួកអ្នកសើចចំអក» អាចត្រូវបានបង្ហាញជាមួយកិរិយាសព្ទ «ចំអក»។
របៀបផ្សេងទៀតនៃការបកប្រែ: «ត្រឹមតែចំអកឲ្យខ្ញុំ»
ឪពុកវ័យក្មេងទាំងនេះ គឺជាពួកមនុស្សដែលខ្ញុំបដិសេធមិនឲ្យធ្វើការជាមួយឆ្កែនៃហ្វូងចៀមរបស់ខ្ញុំ
នេះបង្ហាញថាតើគាត់ស្អប់ឪពុករបស់ពួកគេខ្លាំងយ៉ាងណា។
ពួកគេមិនល្អស្មើរនឹងឆ្កែរបស់គាត់ផង។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកឪពុក
ដែលខ្ញុំស្អប់ហើយមិនត្រូវបានអនុញ្ញាតឲ្យធ្វើការនៅក្បែរឆ្កែនៃហ្វូងចៀមរបស់ខ្ញុំទេ»
ឆ្កែនៃហ្វូងចៀមរបស់ខ្ញុំ
ទំនាក់ទំនងរបស់ឆ្កែទៅនឹងហ្វូងចៀម អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ឆ្កែដែលចាំយាមហ្វូងចៀមរបស់ខ្ញុំ»
ជាការពិតណាស់ កម្លាំងដៃនៃឪពុករបស់ពួកគេទាំងនោះ គឺយកប្រើការមិនកើតទេ
តើធ្វើដូចម្តេចអាចជួយដល់ខ្ញុំ...កម្លាំងក៏ខ្សោយទៅដែរ?
លោកយ៉ូបបានប្រើសំណួរនេះដើម្បីចំអកនៃភាពកម្សោយរបស់មនុស្សទាំងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«កម្លាំងនៃដៃរបស់ឪពុករបស់ពួកគេមិនអាចជួយខ្ញុំបានទេ...កម្លាំងក៏ខ្សោយ»។
ហើយមនុស្សដែលមានវ័យកាន់តែចាស់ហើយកម្លាំងក៏ខ្សោយទៅដែរ?
កម្លាំងកាន់តែខ្សោយរបស់ពួកគេ
គឺជាការប្រៀបធៀបដែលតំណាងឲ្យការមិនមានកម្លាំងទៀតទេ ប៉ុន្តែ ខ្សោយ។ ឃ្លា
«វ័យចាស់ទុំ» សំដៅដល់ពួកគេសចាប់ផ្តើមចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សដែលចាស់និងគ្មានកម្លាំង» ឬ «មនុស្សដែលចាស់និងខ្សោយ»
ពួកគេទៅជាស្គមដោយសារភាពក្រីក្រ និងការអត់ឃ្លាន
ពាក្យ «ពួកគេ» សំដៅដល់ពួកឪពុកនៃពួកចំអកវ័យក្មេង។
ពួកគេទៅជាស្គមដោយសារភាពក្រីក្រ និងការអត់ឃ្លាន
នាមអរូប «ភាពក្រីក្រ» អាចត្រូវបានបង្ហាញជាមួយពាក្យ «ក្រីក្រ»។ នាមអរូប
«អ្នកឃ្លាន» អាចត្រូវបានបង្ហាញជាមួយពាក្យ «ឃ្លាន» ឬ «អត់អាហារ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេស្គមស្គាំងយ៉ាងខ្លាំង
ព្រោះពួកគេក្រនិងអត់អាហារ»
ពួកគេក្រៀមស្វិតនៅដីដែលហួតហែង
វាអាចមានអត្ថន័យពីរគឺ: ទី១) «ដីស្ងួត»
គឺជាការប្រៀបធៀបសម្រាប់ឬសស្ងួតដែលដុះនៅក្នុងដី។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេខាំស៊ីលើឬសដែលស្ងួតដែលរកឃើញនៅក្នុងដី» ឬ ២)
កកេរនៅដីដែលស្ងួត» គឺជាការប្រៀបធៀបសម្រាប់ការសរិភោគ
ទោះបីជាពួកគេអាចរកក្នុងដីស្ងួត។
Job 30:4
ប្រយោគភ្ជាប់
លោកយ៉ូបបន្តនិយាយអំពីឪពុកនៃពួកសើចចំអក។
ស្លឹកឈើ..គុម្ពបន្លា...មើមក្តួច
រុក្ខជាតិទាំងនេះដែលមនុស្សអាចបរិភោគបាន
ប្រសិនបើពួកគេអាចរកឃើញថាគ្មានបញ្ហា។
មើមក្តួច ដែលជាអាហាររបស់ពួកគេ
អាចមានអត្ថន័យពីរគឺ: ទី១) មនុស្សបានបរិភោគមើមក្តួច ឬ ទី២)
មនុស្សកម្តៅខ្លួនរបស់គេ ដោយដុតមើមក្តួច។
ពួកគេត្រូវបណ្តេញចេញពីចំណោមមនុស្ស ជាអ្នកដែលស្រែកពីក្រោយពួកគេ ដូចជាស្រែកដេញ
ចោរដែរ
ឃ្លា «ត្រូវបណ្តេញចេញ» មានន័យថា «បានបណ្តេញពួកគេចេញ»។
ឃ្លាទាំងនេះរៀបសារឡើងវិញ ហើយនិយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សបានស្រែកពីក្រោយពួកគេដូចជា...ចោរម្នាក់

generated on Wed Sep 10 16:16:32 2025

ហើយបានបង្ខំពួកគេឲ្យចេញ»
ស្រែកពីក្រោយពួកគេ ដូចជាស្រែកដេញចោរដែរ
«បានស្រែកពីក្រោយពួកគេ ដូចជាពួកគេជាចោរ»
Job 30:7
ស្រែកដូចជាសត្វលា
របៀបផ្សេងទៀតនៃការបកប្រែ: «បានស្រែកក្នុងការស្រែកឃ្លានរបស់ពួកគេ»
ពួកគេគឺជាកូននៃមនុស្សល្ងង់ ពិតណាស់ ជាកូននៃមនុស្សមិនដឹងខ្យល់
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានប្រព្រឹត្តដូចមនុស្សដែលគ្មានសតិល្អ»។
ពួកគេត្រូវបណ្តេញចេញពីទឹកដី ជាមួយនឹងរំពាត់
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេត្រូវបណ្តេញចេញពីទឹកដី ដូចឧក្រិដ្ឋជន»
Job 30:9
ពួកគេមិនបដិសេធពីការស្តោះទឹកមាត់ដាក់មុខខ្ញុំនោះទេ
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានស្តោះទឹកមាត់ដាក់មុខរបស់ខ្ញុំ!»
ដ្បិត ព្រះជាម្ចាស់បានបន្ធូរខ្សែរបស់ទូលបង្គំ ហើយធ្វើទុកដល់ទូលបង្គំ
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះបានដកយកអំណាចរបស់ខ្ញុំ
ដើម្បីការពារខ្ញុំ»។
Job 30:12
ពួកជនពាលបានងើបប្រហារខ្ញុំពីខាងស្តាំ
ពួកជនពាលនៃមនុស្សវ័យក្មេងវាយប្រហារកម្លាំងរបស់ខ្ញុំ» ឬ
«ពួកមនុស្សឥតសណ្តាប់ធ្នាប់វាយប្រហារកិត្តិយសរបស់ខ្ញុំ»
ប្រមូលគ្នាឡើងទាស់នឹងខ្ញុំ ឡោមព័ទ្ធភ្នំរបស់គេ
លោកយ៉ូបដឹងថាសត្រូវរបស់គាត់កំពុងរៀបចំដើម្បីវាយប្រហារគាត់
ដូចគ្នានឹងពួកទាហានរៀបចំដើម្បីវាយប្រហារជញ្ជាំងការពារជុំវិញទីក្រុង។
Job 30:14
ដូចកងទ័ពទម្លុះកំពែងដ៏ធំចូលមកវាយទីក្រុង
លោកយ៉ូបប្រៀបធៀបស្ថានភាពរបស់លោកទៅនឹងទីក្រុងដែលស្ថិតក្រោមការវាយប្រ
កិត្តិយសរបស់ខ្ញុំហើរទៅតាមខ្យល់
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្យល់បានផ្លុំកិត្តិយសរបស់ខ្ញុំទៅ»
ការចម្រុងចម្រើនរបស់ខ្ញុំរសាត់បាត់ ដូចជាពពក
អ្វីៗដែលជារបស់លោកយ៉ូបបានបាត់បង់ទៅដូចជាពពកដែលលេចមកភ្លាមហើយបន្ទា
Job 30:16
ឥឡូវនេះ ជីវិតរបស់ខ្ញុំនេះកំពុងតែជិតរលត់ពីខ្លួនខ្ញុំហើយ
លោកយ៉ូបមានអារម្មណ៍ថាលោកជិតស្លាប់ហើយ។
ការឈឺចាប់យ៉ាងខ្លោចផ្សារនៅក្នុងខ្ញុំគ្មានពេលល្ហែសោះឡើយ
លោកយ៉ូបនិយាយអំពីការឈឺចាប់របស់លោក ហាក់ដូចជាវាមានជីវិត។
Job 30:18
ព្រះជាម្ចាស់បានបោះខ្ញុំទៅក្នុងភក់ជ្រាំ
លោកយ៉ូបនិយាយថាព្រះបានបំបាក់មុខរបស់លោក។
Job 30:20
ឃោរឃៅ
ពាក្យនេះមានន័យថាមិនសប្បុរស។
ជាមួយព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គ នោះព្រះអង្គបៀតបៀនទូលបង្គំ
ពាក្យ «ព្រះហស្ត» តំណាងឲ្យអំណាចរបស់ព្រះ។
Job 30:22
លើកទូលបង្គំឡើងទៅដល់ខ្យល់...ធ្វើឲ្យវាផាត់ទូលបង្គំទៅផង
ហើយព្រះអង្គយកខ្ញុំមកវិញនិងដាក់ខាងមុខក្នុងខ្យល់ព្យុះម្តង
ការសង្កត់ធ្ងន់នេះ
តំណាងឲ្យការឈឺចាប់ហួសប្រមាណដែលព្រះបានធ្វើឲ្យលោកយ៉ូបអត់ទ្រាំ។
ទីលំនៅនិងវាសនាសម្រាប់របស់ដែលមានជីវិតទាំងអស់
«ផ្ទះ» តំណាងឲ្យកន្លែងដែលមនុស្សស្លាប់នឹងទៅ។
របស់ដែលមានជីវិតទាំងអស់
នោះគឺអ្វីៗទាំងអស់ដែលរស់នៅឥឡូវនេះ ប៉ុន្តែនៅថ្ងៃមួយវានឹងស្លាប់។
Job 30:24
តើមិនមានអ្នក ណានឹងលូកដៃរបស់គេចេញមកដើម្បីអង្វរឲ្យជួយពេលគេធ្លាក់ចុះនោះទេ?
តើមិនមានអ្នកណាដែលនៅក្នុងបញ្ហាហើយស្រែករកជំនួយទេឬ?
អាចមានអត្ថន័យពីរគឺ: ទី១)
«ខ្ញុំបានជួយមនុស្សដែលបានធ្លាក់នៅពេលដែលគេអង្វរសុំជំនួយពីខ្ញុំ។
ខ្ញុំបានជួយមនុស្សនៅក្នុងបញ្ហាពេលដែលគេស្រែកសុំឲ្យខ្ញុំជួយ។» ឬ ទី២)
ខ្ញុំបានមានបញ្ហា ហើយដូច្នេះព្រះមិនគួរគិតថាខ្ញុំធ្វើការខុសឆ្គងនោះទេ
ពេលដែលខ្ញុំអង្វរសុំឲ្យទ្រង់ជួយ។ ខ្ញុំនៅក្នុងបញ្ហា
ដូច្នេះជាការពិតណាស់ខ្ញុំបានស្រែកសមជំនួយ!»
តើខ្ញុំមិនបានយំសោក...បញ្ហា? តើខ្ញុំមិនបានសោកសង្រេង...ជនក្រីក្រទេឬ?
«ទ្រង់ដឹងថាខ្ញុំយំសោក...បញ្ហា ហើយខ្ញុំសោកសង្រេង...ជនក្រីក្រ!»
ខ្ញុំរង់ចាំដើម្បីពន្លឺ...សេចក្តីងងឹតបែរជាមក
នៅទីនេះ «ពន្លឺ» តំណាងឲ្យព្រះពររបស់ព្រះនិងក្តីអនុគ្រោះ ហើយ «សេចក្តីងងឹត»
តំណាងឲ្យទុក្ខលំបាកនិងការសោកសៅ។ ការពាររបស់វា។
Job 30:27
ដួងចិត្តរបស់ខ្ញុំតប់ប្រមល់ ហើយមិនអាចឈប់សម្រាក់
លោកយ៉ូបនិយាយពីដួងចិត្តរបស់លោកហាក់ដូចជាវាជាមនុស្សម្នាក់។
ខ្ញុំមានតែបាត់បង់ពន្លឺនៅក្នុងទីងងឹត តែមិនមែនដោយសារពន្លឺថ្ងៃទេ
នៅទីនេះលោកយ៉ូបសំដៅដល់ទីងងឹតនៃភាពស្រអាប់និងអស់សង្ឃឹមរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំតែងតែនៅក្នុងភាពស្រអាប់និងក្តីអស់សង្ឃឹម»។
បងប្អូនរបស់ឆ្កែព្រៃ និងជាមិត្តសម្លាញ់របស់សត្វអូទ្រីសដែរ
លោកយ៉ូបប្រៀបធៀបការដង្ហោយហៅរបស់លោកក្នុងទុក្ខវេទនាដល់សម្រែកនៃឆ្កែព្រៃនិងអូទ្រីស។
Job 30:30
ឆ្អឹងរបស់ខ្ញុំបានឆេះដោយសារកម្តៅថ្ងៃ
នៅទីនេះ «ឆ្អឹង» សំដៅដល់រូបកាយទាំងមូលដែលរងទុក្ខពីការគ្រុន។
សោកសង្រេង
«សោកសង្រេង» គឺជាសម្លេងដែលឮ ការយំអស់រយៈពេលយូរនៃទុក្ខសោក ឬ
ការឈឺចាប់។

---

31 [1]ខ្ញុំបានតាំងសញ្ញានឹងភ្នែកខ្ញុំហើយ ដូច្នេះ ធ្វើដូចម្តេចឲ្យខ្ញុំមើលស្ត្រីក្រមុំ ដោយចាប់ចិត្តបាន?[2]ដ្បិតយ៉ាងនោះ តើនឹងមានចំណែកអ្វី ពីព្រះជាម្ចាស់ដ៏គង់នៅស្ថានលើ
តើនឹងមានមរតកអ្វីពីព្រះដ៏មានគ្រប់ព្រះចេស្តា នៅស្ថានដ៏ខ្ពស់?
[3]ខ្ញុំធ្លាប់គិតសេចក្តីអន្តរាយដល់មនុស្សទុច្ចរិត ហើយជាសេចក្តីវេទនាដល់ពួកអ្នក ដែលប្រព្រឹត្តអាក្រក់។[4]តើព្រះអង្គមិនឃើញផ្លូវខ្ញុំ ហើយរាប់អស់ទាំងជំហាននៃខ្ញុំទេឬ?
[5]បើខ្ញុំបានដើរដោយសេចក្តីភូតភរ ហើយជើងខ្ញុំបានរហ័សទៅតាមសេចក្តីល្បួង[6]សូមឲ្យព្រះថ្លឹងខ្ញុំ ដោយជញ្ជីងត្រឹមត្រូវ ដើម្បីឲ្យព្រះអង្គបានជ្រាបគំនិតទៀងត្រង់របស់ខ្ញុំ។
[7]ប្រសិនបើជើងខ្ញុំងាកចេញពីមាគ៌ាត្រឹមត្រូវ ប្រសិនបើចិត្តខ្ញុំបណ្តោយឲ្យភ្នែកអូសទាញ ប្រសិនបើមានអំពើសៅហ្មងណាមួយ នៅជាប់នឹងដៃរបស់ខ្ញុំ[8]ពេលខ្ញុំសាបព្រោះអ្វី
សូមឲ្យអ្នកផ្សេងមកទទួលយកផល ហើយសូមច្រូតកាត់ពីវាលស្រែខ្ញុំចុះ។
[9]បើចិត្តខ្ញុំបានចុះចូល នឹងសេចក្តីលួងលោមរបស់ស្ត្រីណា ហើយខ្ញុំបានលបចាំនៅមាត់ទ្វារអ្នកជិតខាងខ្ញុំ[10]សូមឲ្យប្រពន្ធខ្ញុំបានកិនស្រូវឲ្យម្នាក់ទៀត ហើយ
សូមឲ្យអ្នកផ្សេងទៀតគោរពនាង។
[11]ដ្បិតប្រព្រឹត្តដូច្នោះជាអំពើមួយដ៏អាស្រូវបំផុត ជាអំពើដែលចៅក្រមត្រូវដាក់ទោស។[12]ដ្បិត អំពើនេះប្រៀបបាននឹងភ្លើង ឆេះរាលដាល
ដូចជាគ្រប់យ៉ាងដែលនៅស្ថានឃុំព្រលឹងមនុស្សស្លាប់ និងឆេះផលដំណាំរបស់ខ្ញុំទាំងអស់។
[13]បើខ្ញុំដែលមើលងាយ រឿងរបស់បាវប្រុសបាវស្រីខ្ញុំ ក្នុងកាលដែលវាបានតវ៉ានឹងខ្ញុំ[14]យ៉ាងនោះ តើខ្ញុំនឹងធ្វើដូចម្តេច ក្នុងកាលដែលព្រះក្រោកឡើង កាលណាព្រះអង្គ
ពិចារណាសួរខ្ញុំ តើខ្ញុំនឹងឆ្លើយដល់ព្រះអង្គដូចម្តេច?[15]ព្រះដែលបានបង្កើតខ្ញុំនៅក្នុងពោះម្តាយ តើមិនបានបង្កើតបាវនោះដែរទេឬ? តើមិនមែនជាព្រះតែមួយ ដែលស្អាង
យើងទាំងពីរនៅក្នុងផ្ទៃម្តាយទេឬ?
[16]ប្រសិនបើ ខ្ញុំមិនដែលបដិសេធជួយជនក្រីក្រ ឬប្រសិនបើ ខ្ញុំបានធ្វើឲ្យស្ត្រីភ្នែក របស់ស្ត្រីមេម៉ាយហើមធំដោយការស្រែកយំ[17]ឬប្រសិនបើ ខ្ញុំមិនដែលបរិភោគអាហារតែ
ម្នាក់ឯង ដោយមិនបានចែកឲ្យក្មេងកំព្រាទេ ដែលគ្មានឪពុកនោះ[18]ពីព្រោះតែ តាំងពីខ្ញុំនៅក្មេង ខ្ញុំបានបីបាច់ថែរក្សាពួកគេ រូបខ្ញុំបីដូចជាឪពុករបស់ពួកគេ
ហើយខ្ញុំក៏បានណែនាំម្តាយគេដែរ ជាស្ត្រីមេម៉ាយ ដែលកើតពីផ្ទៃម្តាយរបស់ខ្ញុំដែរ។

generated on Wed Sep 10 16:16:32 2025

[19]ប្រសិនបើខ្ញុំបានឃើញអ្នកណាវិនាសទៅ ដោយឥតមានអ្វីស្លៀកពាក់ ឬប្រសិនបើអ្នកក្រីក្រឥតមានសំលៀកបំពាក់[20]ប្រសិនបើចិត្តរបស់ពួកគេមិនបានឲ្យពរដល់ខ្ញុំ
ពីព្រោះគេមិនបានកក់ក្តៅដោយរោមចៀមរបស់ខ្ញុំនោះទេ[21]ប្រសិនបើខ្ញុំបានលើកដៃទាស់នឹងក្មេងកំព្រា ពីព្រោះតែខ្ញុំបានឃើញសេចក្តីជំនួយរបស់ខ្ញុំ នៅឯទ្វារទីក្រុង
បើដូច្នេះខ្ញុំជាប់ទោសហើយ!
[22]ប្រសិនបើបានធ្វើការនេះ សូមឲ្យដៃរបស់ខ្ញុំដាច់ចេញពីស្មា ហើយសូមឲ្យកំភួនដៃរបស់ខ្ញុំ បានបាក់ចេញពីគ្នា។[23]ដ្បិតខ្ញុំភ័យខ្លាចព្រះជាម្ចាស់ដាក់ទោសណាស់ ខ្ញុំមិនអាច
តទល់នឹងឫទ្ធិបារមីដ៏ថ្កុំថ្កើង របស់ព្រះអង្គបានឡើយ។
[24]ប្រសិនបើ ខ្ញុំបានយកមាសមកធ្វើជាទីសង្ឃឹម ហើយបើសិនខ្ញុំបាននិយាយថា ទៅស្វែងរកមាស «គឺមាសសុទ្ធបានក្លាយជាទីពឹងលើមាសហើយ»[25]បើសិនខ្ញុំរីករាយ
ដោយព្រោះតែទ្រព្យសម្បត្តិស្តុកស្តម្ភ ដែលក្នុងដៃខ្ញុំមានទ្រព្យ នោះនឹងមកនូវការជាប់ទោសដល់ខ្ញុំវិញ!
[26]ប្រសិនបើខ្ញុំបានឃើញព្រះអាទិត្យ ពេលកំពុងចាំងរស្មី ឬព្រះចន្ទកំពុងតែដើរជាមួយពន្លឺ[27]ហើយបើបេះដូងរបស់ខ្ញុំស្ងាត់ៗក៏លង់ រហូតយកដៃមកដាក់លើមាត់ទាំងថើប
ក្នុងបង្ហាញពីការថ្វាយបង្គំ ដល់ព្រះអាទិត្យនិងព្រះចន្ទនោះ[28]ការធ្វើបែបនេះគឺខ្ញុំបានជាប់ទោស ដោយការជំនុំជម្រះ គឺខ្ញុំបានបដិសេធព្រះជាម្ចាស់ដែលធំជាងអ្វីទាំងអស់។
[29]បើខ្ញុំដែលរីករាយសប្បាយ ដោយឃើញសេចក្តីហិនវិនាស របស់អ្នកដែលស្អប់ខ្ញុំ ឬបំប៉ោងខ្លួនខ្ញុំឡើង នៅពេលទុក្ខវេទនាបានកើតឡើងជាមួយគេឡើយ
បើបែរនេះខ្ញុំនឹងជាប់ទោសហើយ![30]ប៉ុន្តែ គឺខ្ញុំមិនបានឲ្យមាត់របស់ខ្ញុំធ្វើបាប ដោយដាក់បណ្តាសា ដល់ជីវិតគេឡើយ។
[31]ប្រសិនបើពួកមនុស្សនៅទីលំនៅខ្ញុំ មិនដែលបាននិយាយថា៖ «តើមានអ្នកណាដែលមិនបានឆ្អែត ដោយអាហាររបស់លោកយ៉ូប?»[32](សូម្បីតែពួកអ្នកដំណើរបរទេស ក៏
មិនបានសម្រាកនៅឯបន្ទុបក្នុងទីក្រុងដែរ ដ្បិតខ្ញុំបានបើកទ្វារទទួលគេឲ្យស្នាក់នៅដែរ) បើខ្ញុំមិនបានធ្វើការនោះទេ គឺខ្ញុំជាប់ទោសហើយ!
[33]បើខ្ញុំបានគ្របបាំងអំពើរំលងរបស់ខ្ញុំ ដូចជាមនុស្សលោក ដោយលាក់សេចក្តីអាក្រក់ដែលនៅក្នុងខ្លួនខ្ញុំ[34](ពីព្រោះតែខ្លាចចំពោះហ្វូងមនុស្ស ហើយដោយសេចក្តីមើល
ងាយរបស់គ្រួសារផ្សេងៗ បាននាំឲ្យខ្ញុំភ័យ ដល់ម៉្លេះបានជាខ្ញុំនៅស្ងៀម មិននិយាយចេញមកក្រៅទេ) ដូចនេះខ្ញុំនឹងជាប់ទោសហើយ!
[35]ឱបើមានអ្នកណាមួយស្តាប់ខ្ញុំ មើល ខ្ញុំចុះឈ្មោះហើយ សូមឲ្យព្រះដ៏មានគ្រប់ព្រះចេស្តា ឆ្លើយមកខ្ញុំចុះ ឱបើអ្នកដែលតតាំងនឹងខ្ញុំ បានធ្វើពាក្យថ្លែងការទៅ![36]នោះប្រាកដ
ជាខ្ញុំនឹងយកទៅដោយភ្ជាប់នឹងស្មា ហើយដាក់ពាក់នៅលើក្បាលដូចជាម្កុដ។[37]ខ្ញុំនឹងទូលព្រះអង្គពីចំនួនជំហានខ្ញុំ ហើយនឹងចូលទៅជិតព្រះអង្គ ដូចអ្នកធំផ្សេងទៀតដែរ។
[38]ប្រសិនបើដីស្រែរបស់ខ្ញុំស្រែកឡើងទាស់នឹងខ្ញុំ ហើយគន្លងទាំងប៉ុន្មានយំជាមួយគ្នា[39]បើខ្ញុំបានបរិភោគផលនៃដីនោះឥតបង់ថ្លៃ ឬបានធ្វើឲ្យម្ចាស់ដើមបង់ជីវិតនោះ[40]សូម
ឲ្យមានតែបន្លាដុះឡើង ជំនួសស្រូវភោជ្ជសាលី ហើយស្រងែជំនួសស្រូវឱកវិញចុះ»។ ពាក្យរបស់លោកយ៉ូបចប់តែប៉ុណ្ណេះ។

Job 31:1
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
ខ្ញុំបានតាំងសញ្ញាជាមួយភ្នែកខ្ញុំ
របៀបផ្សេងទៀតក្នុងការបកប្រែ: «ខ្ញុំបានសន្យាជាមួយនឹងខ្លួនឯងថា
ខ្ញុំនឹងមិនមើលទៅកាន់ស្ត្រីដោយបំណងតណ្ហានោះទេ»
តើខ្ញុំគួរមើលដោយមានបំណងប្រាថ្នាទៅលើស្ត្រីព្រហ្មចារីដោយរបៀបណា?
លោកយ៉ូបប្រើសំណួរមួយដើម្បីបញ្ជាក់ថាគាត់នឹងមិនដែលក្បត់ការសន្យារបស់គាត់ឡើយ
របៀបផ្សេងទៀតក្នុងការបកប្រែ: «ដូច្នេះ
ខ្ញុំប្រាកដជាមិនមើលស្ត្រីព្រហ្មចារីដោយតណ្ហានោះទេ»
ដ្បិត តើអ្វីដែលជាចំណែកពីព្រះជាម្ចាស់ពីស្ថានលើ ហើយមរតកពីព្រះដ៏មានគ្រប់ព្រះចេស្តា នៅ
ស្ថានដ៏ខ្ពស់ទេឬ?
ទាំងពីរនេះមានន័យដូចគ្នា។
លោកយ៉ូបប្រើសំណួរមួយនេះដើម្បីបញ្ជាក់ថាព្រះជាម្ចាស់នឹងមិនផ្តល់អ្វីល្អដល់លោកឡើយ
Job 31:3
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
តើព្រះអង្គមិនឃើញផ្លូវរបស់ខ្ញុំ ហើយរាប់អស់ទាំងជំហានរបស់ខ្ញុំទេឬ?
នេះគឺជា «ផ្លូវរបស់ខ្ញុំ» និង «ជំហានរបស់ខ្ញុំ»
គឺសំដៅទៅលើចរិតលក្ខណរបស់លោកយ៉ូប។
លោកយ៉ូបប្រើសំណួរនេះដើម្បីប្រៀបធៀប។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«ពិតប្រាកដណាស់ព្រះជាម្ចាស់ទតមើលខ្ញុំហើយដឹងអ្វីៗទាំងអស់ដែលខ្ញុំធ្វើ»។
Job 31:5
ព័ត៌មានទូទៅ:
លោកយ៉ូបបន្តនិយាយ។
បើខ្ញុំបាន
នៅក្នុងជំពូកទី ៣១: ៥-៤០
លោកយ៉ូបពិពណ៌នាអំពីស្ថានភាពផ្សេងៗគ្នាដែលគាត់គួរតែទទួលទោសពីព្រះជាម្ចាស់
ប៉ុន្តែលោកដឹងថាពួកគេមិនពិតហើយគាត់គ្មានកំហុសទេ។
ដើរជាមួយសេចក្តីមិនពិត បើជើងរបស់ខ្ញុំបានរហ័សទៅតាមសេចក្តីបោកប្រាស់
របៀបផ្សេងទៀតក្នុងការបកប្រែ: «ធ្វើអ្វីមួយដែលមិនពិត
ឬបោកបញ្ឆោតនរណាម្នាក់»
សូមឲ្យខ្ញុំបានថ្លឹងជាមួយជញ្ជីងត្រឹមត្រូវ
ប្រជាជនបានប្រើជញ្ជីងថ្លឹងវត្ថុនិងកំណត់តម្លៃរបស់វា។
របៀបផ្សេងទៀតក្នុងការបកប្រែ: «សូមឲ្យព្រះជាម្ចាស់វិនិច្ឆ័យខ្ញុំដោយទៀងត្រង់»
Job 31:7
ព័ត៌មានទូទៅ
យ៉ូបបន្តរៀបរាប់ពីស្ថានភាពដែលលោកសមនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់
ប៉ុន្តែលោកដឹងថាពួកគេមិនពិតទេ។
ប្រសិនបើជំហានរបស់ខ្ញុំបានបែរចេញពីផ្លូវដ៏ត្រឹមត្រូវ
របៀបផ្សេងទៀតក្នុងការបកប្រែ: «ប្រសិនបើ ខ្ញុំឈប់ប្រព្រឹត្តអ្វីដែលត្រឹមត្រូវ»
ប្រសិនបើចិត្តរបស់ខ្ញុំបណ្តោយឲ្យភ្នែករបស់ខ្ញុំ
របៀបផ្សេងទៀតក្នុងការបកប្រែ: «ប្រសិនបើខ្ញុំបានធ្វើអំពើទុច្ចរិតណាមួយ»
បើមានកន្លែងណាមួយស្មោកគ្រោកនៅនឹងដៃរបស់ខ្ញុំ
របៀបផ្សេងទៀតក្នុងការបកប្រែ: «ប្រសិនបើខ្ញុំមានទោសទាំងអស់»
ដែលកាត់ដល់ឫសទាំងមូលចេញពីស្រែខ្ញុំចុះ
របៀបផ្សេងទៀតក្នុងការបកប្រែ:
«ចូរឲ្យផ្សេងទៀតមកយកផលដំណាំចេញពីស្រែខ្ញុំចុះ
Job 31:9
ព័ត៌មានទូទៅ
លោកយ៉ូបបន្តរៀបរាប់ពីស្ថានភាពដែលលោកសមនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់
ប៉ុន្តែលោកដឹងថាពួកគេមិនពិតហើយគ្មានការសន្យារបស់លោក។
ប្រសិនបើ ចិត្តរបស់ខ្ញុំបានទទួលសេចក្តីលួងលោមរបស់ស្ត្រី
របៀបផ្សេងទៀតក្នុងការបកប្រែ: «ប្រសិនបើខ្ញុំមានចិត្តចំពោះប្រពន្ធរបស់អ្នកដទៃ»
ហើយបើសិនខ្ញុំបានដេករង់ចាំនៅមាត់ទ្វារអ្នកជិតខាងខ្ញុំ
«ហើយខ្ញុំបានរង់ចាំឲ្យគាត់ចាកចេញពីផ្ទះរបស់គេ ដូច្នេះ ខ្ញុំអាចគេងជាមួយនាង»
រួចហើយចូរឲ្យប្រពន្ធខ្ញុំបានកិនស្រូវសម្រាប់ម្នាក់ទៀត
អត្ថន័យដែលអាចមានគឺ ១)
នេះជារបៀបនិយាយថាបុរសផ្សេងនឹងដេកជាមួយប្រពន្ធរបស់លោកយ៉ូប ឬ ២)
វាមានន័យថានាងនឹងក្លាយជាទាសកររហើយធ្វើការឲ្យបុរសម្នាក់ផ្សេងទៀត។
Job 31:11
ព័ត៌មានទូទៅ
លោកយ៉ូបបន្តរៀបរាប់ពីស្ថានភាពដែលលោកសមនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់
ប៉ុន្តែ លោកដឹងថាពួកគេមិនពិតទេ។
វាគឺជាកំហុសដែលត្រូវដាក់ទោសដោយចៅហ្វាយ
របៀបផ្សេងទៀតក្នុងការបកប្រែ:
«វាអាចជាបទឧក្រិដ្ឋដែលចៅហ្វាយត្រូវដាក់ទណ្ឌកម្មខ្ញុំ»
Job 31:13
ព័ត៌មានទូទៅ
យ៉ូបបន្តរៀបរាប់ពីស្ថានភាពដែលលោកសមនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់ ប៉ុន្តែ
លោកដឹងថាពួកគេមិនពិតទេ។
តើគួរឲ្យខ្ញុំធ្វើដូចម្តេច ក្នុងពេលដែលព្រះជាម្ចាស់ក្រោកឡើង ដើម្បីចោទដល់ខ្ញុំនោះ?
លោកយ៉ូបប្រើសំណួរមួយនេះដើម្បីប្រៀបធៀប។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«បន្ទាប់មកគ្មានអ្វីដែលខ្ញុំអាចនិយាយដើម្បីការពារខ្លួនបានឡើយនៅពេលដែលព្រះជាម្ចាស់យាងមកវិនិច្ឆ័
នៅពេលព្រះអង្គយាងមកដាក់ទោសខ្ញុំ តើខ្ញុំនឹងឆ្លើយដល់ព្រះអង្គដូចម្តេច?
បន្ទាប់មក

generated on Wed Sep 10 16:16:32 2025

គ្មានអ្វីដែលខ្ញុំអាចនិយាយដើម្បីការពារខ្លួនបានឡើយនៅពេលដែលព្រះជាម្ចាស់យាងមកវិនិច្ឆ័យខ្ញុំ។
Job 31:16
ព័ត៌មានទូទៅ
យ៉ូបបន្តរៀបរាប់ពីស្ថានភាពដែលលោកសមនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់
ប៉ុន្តែលោកដឹងថាពួកគេមិនពិតទេ។
ប្រសិនបើ ខ្ញុំបានធ្វើឲ្យភ្នែករបស់ស្ត្រីមេម៉ាយហើមធំដោយការយំស្រែក
ពាក្យ «ហើមធំ» សំដៅទៅលើស្ត្រីមេម៉ាយហើមភ្នែកធំដោយសារការយំរបស់នាង។
របៀបផ្សេងទៀតក្នុងការបកប្រែ: «ខ្ញុំបានធ្វើឲ្យស្ត្រីមេម៉ាយយំសោកយ៉ាងក្រៀមក្រំ»
អាហាររបស់ខ្ញុំ
«អាហាររបស់ខ្ញុំ»
ពីព្រោះតាំងពីខ្ញុំនៅក្មេង នោះខ្ញុំបានបីបាច់ថែរក្សាពួកក្មេងកំព្រា រួបខ្ញុំបីដូចជាឪពុករបស់ពួកគេ
ហើយខ្ញុំក៏បានណែនាំម្តាយពួកគេដែរ ជាស្ត្រីមេម៉ាយ ដែលកើតពីផ្ទៃម្តាយរបស់ខ្ញុំដែរ
លោកយ៉ូបកំពុងពណ៌នាអំពីរបៀបដែលលោកបានព្រព្រឹត្តចំពោះក្មេងកំព្រា
និងស្ត្រីមេម៉ាយដោយត្រឹមត្រូវ។ «ខ្ញុំបានមើលថែក្មេងកំព្រា
និងស្ត្រីមេម៉ាយចាប់តាំងពីពេលដែលខ្ញុំនៅក្មេងខ្ចី»
Job 31:19
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកសាកសមនឹងទទួលការដាក់ទោសរបស់ព្រះ
ប្រសិនបើចិត្តរបស់គេមិនបានឲ្យពរដល់ខ្ញុំ ពីព្រោះគេមិនបានកក់ក្តៅជាមួយរោមចៀមរបស់ខ្ញុំនោះទេ
របៀបផ្សេងទៀតក្នុងការបកប្រែ:
«យើងបានឲ្យសម្លៀកបំពាក់បែបនេះដល់ពួកគេដែលបានធ្វើឲ្យពួកគេកក់ក្តៅ ដូច្នេះ
ពួកគេបានឲ្យពរដល់ពួកគេ។ ប៉ុន្តែ ប្រសិនបើខ្ញុំមិនបានធ្វើវាទេ»
ខ្ញុំបានលើកដៃទាស់នឹង
របៀបផ្សេងទៀតក្នុងការបកប្រែ: «ខ្ញុំបានគំរាមឲ្យធ្វើបាប»
នៅឯទ្វារទីក្រុង
នេះគឺជាកន្លែងដែលមនុស្សសំខាន់ៗនៃទីក្រុងនឹងប្រមូលផ្តុំដើម្បីធ្វើការសម្រេចចិត្ត។
Job 31:22
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកសាកសមនិងទទួលការដាក់ទោសរបស់ព្រះ
ប៉ុន្តែ លោកបានដឹងថាពួកគេទាំងនោះមិនស្មោះត្រង់។
រួចហើយសូមឲ្យស្មារបស់ខ្ញុំធ្លាក់ចុះពីសន្ទះស្មា ហើយសូមឲ្យកំភួនដៃរបស់ខ្ញុំ បានបាក់ចេញពីសន្លាក់
របៀបផ្សេងទៀតក្នុងការបកប្រែ:
«បន្ទាប់មកសូមឲ្យនរណាម្នាក់ហែកស្មារបស់ខ្ញុំហើយបំបាក់ដៃរបស់ខ្ញុំ»
Job 31:24
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកស័ក្តសមនឹងទទួលការដាក់ទោសរបស់ព្រះ
ប៉ុន្តែ លោកបានដឹងថាពួកគេទាំងនោះមិនស្មោះត្រង់។
ប្រសិនបើខ្ញុំបានបង្កើតមាសជាទីសង្ឃឹមរបស់ខ្ញុំ
ជួរនេះមានន័យថាដូចគ្នានឹងជួរមុនៗដែរ។
ពួកគេរួមគ្នាសង្កត់ធ្ងន់ថាលោកយ៉ូបមិនទុកចិត្តលើទ្រព្យសម្បត្តិដើម្បីនាំឲ្យគាត់មានសុវត្ថិភាព
ដៃរបស់ខ្ញុំមានទ្រព្យច្រើន
របៀបផ្សេងទៀតក្នុងការបកប្រែ:
«ខ្ញុំបានទទួលទ្រព្យសម្បត្តិជាច្រើនដោយសមត្ថភាពផ្ទាល់ខ្លួន»
Job 31:26
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកស័ក្តិសមនិងទទួលការដាក់ទោសរបស់ព្រះ
ប៉ុន្តែលោកបានដឹងថាពួកគេទាំងនោះមិនស្មោះត្រង់។
ព្រះចន្ទកំពុងតែដើរ
របៀបផ្សេងទៀតក្នុងការបកប្រែ: «ព្រះចន្ទធ្វើដំណើរឆ្លងកាត់ផ្ទៃមេឃ»
ហើយបើបេះដូងរបស់ខ្ញុំត្រូវបានទាក់ទាញដោយស្ងាត់ៗ
របៀបផ្សេងទៀតក្នុងការបកប្រែ: «ប្រសិនបើខ្ញុំចង់គោរពបូជាជាសម្ងាត់»
មាត់របស់ខ្ញុំបានថើបដៃរបស់ខ្ញុំ

នេះគឺជាការបង្ហាញនៃសេចក្តីស្រឡាញ់និងការលះលែងគ្នា។
ដើម្បីជំនុំជម្រះចៅហ្វាយ
របៀបផ្សេងទៀតក្នុងការបកប្រែ:
«តើចៅហ្វាយណាដែលអាចនឹងដាក់ទោសខ្ញុំបាន»
Job 31:29
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកស័ក្តិសមនឹងទទួលការដាក់ទោសរបស់ព្រះ។
ប៉ុន្តែ លោកបានដឹងថាពួកគេទាំងនោះមិនស្មោះត្រង់។
ការពិតណាស់ ខ្ញុំមិនបានឲ្យមាត់របស់ខ្ញុំធ្វើបាបដោយសុំបណ្តាសាដាក់លើជីវិតគេនោះទេ
លោកយ៉ូបកំពុងរៀបរាប់អំពីរបៀបដែលលោកប្រព្រឹត្តចំពោះអ្នកដែលស្អប់លោក។
របៀបផ្សេងទៀតក្នុងការបកប្រែ: «ជាការពិត
ខ្ញុំមិនបានសូម្បីតែធ្វើឲ្យខ្លួនខ្ញុំធ្វើបាបដោយដាក់បណ្តាសាជីវិតរបស់កគេឡើយ»
Job 31:31
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកស័ក្តិសមនិងទទួលការដាក់ទោសរបស់ព្រះ។
ប៉ុន្តែ លោកបានដឹងថាពួកគេទាំងនោះមិនស្មោះត្រង់។
ប្រសិនបើមនុស្សដែលនៅទីលំនៅខ្ញុំ មិនដែលបាននិយាយថា៖ «តើមានអ្នកណាដែលមិនបានឆ្អែត
របៀបផ្សេងទៀតក្នុងការបកប្រែ: «បុរសរបស់ខ្ញុំតែងតែនិយាយថា៖
មនុស្សគ្រប់គ្នាដែលយើងស្គាល់សុទ្ធតែមានអាហារដូចលោកយ៉ូបច្រើនតាមដែលគេចង់បាន
បើការនោះមិនពិតទេ»
ពួកបរទេស ក៏មិនបានស្នាក់នៅកណ្តាលទីក្រុងដែរ ពីព្រោះខ្ញុំតែងតែបើកទ្វារទទួលគេឲ្យស្នាក់នៅ
លោកយ៉ូបកំពុងពន្យល់ពីរបៀបដែលគាត់បានប្រព្រឹត្តចំពោះជនបរទេស។
របៀបផ្សេងទៀតក្នុងការបកប្រែ: «ជនបរទេសមិនដែលបានដេកនៅតាមផ្លូវ។
ខ្ញុំតែងតែស្វាគមន៍ពួកគេចូលក្នុងផ្ទះរបស់ខ្ញុំ»
Job 31:33
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកស័ក្តសមនឹងទទួលការដាក់ទោសរបស់ព្រះ។
ប៉ុន្តែ លោកបានដឹងថាពួកគេទាំងនោះមិនស្មោះត្រង់។
ពីព្រោះខ្ញុំខ្លាចថាការនេះធំឡើង ហើយដោយសេចក្តីមើលងាយរបស់គ្រួសារជាច្រើនបានធ្វើឲ្យខ្ញុំ
ភ័យរន្ធត់
ទាំងនេះមានន័យដូចគ្នា។
ពួកគេសង្កត់ធ្ងន់ថាមនុស្សម្នាក់អាចលាក់បាំងអំពើបាបរបស់គាត់ព្រោះគាត់ខ្លាចអ្វីដែលអ្នកដទៃអាចនិយា
Job 31:35
មើល៍ នេះគឺជាហត្ថលេខារបស់ខ្ញុំ
លោកយ៉ូបកំពុងពណ៌នាអំពីការអ៊ូរទាំរបស់គាត់ទៅកាន់ព្រះជាម្ចាស់ដូចជាគាត់សរសេរវានៅក្នុងឯកសារ
គាត់នឹងសរសេរឈ្មោះរបស់គាត់នៅលើវាជាការសន្យាថាអ្វីគ្រប់យ៉ាងនៅក្នុងឯកសារគឺពិត។
ប្រសិនបើខ្ញុំបានបង្ហាញការចោទប្រកាន់ដែលសត្រូវរបស់ខ្ញុំបានសរសេរ
«ប្រសិនបើ មានតែខ្ញុំអាចអានពាក្យបណ្តឹងរបស់គូប្រជែងប្រឆាំងនឹងខ្ញុំ!»
ខ្ញុំនឹងនាំវាទៅបើកចំហនៅលើស្មារបស់ខ្ញុំ ហើយខ្ញុំនឹងពាក់វានៅលើក្បាលដូចជាមកុដ
នេះមានន័យថាប្រសិនបើព្រះជាម្ចាស់នឹងសរសេរពាក្យបណ្តឹងរបស់ព្រះអង្គចំពោះលោកយ៉ូប។
បន្ទាប់មក លោកយ៉ូបអារក្សាឯកសារនេះដើម្បីឲ្យគេបានមើលឃើញ។
សម្រាប់ជំហានរបស់ខ្ញុំ
នេះសំដៅទៅលើសកម្មភាពរបស់លោកយ៉ូប។ ជាព្រះអង្គម្ចាស់ដែលមានទំនុកចិត្ត
អ្នកដឹកនាំមានទំនុកចិត្ត
នេះមានន័យថាលោកយ៉ូបនឹងចូលទៅជិតព្រះជាម្ចាស់ ដោយគ្មានការភ័យខ្លាច។
Job 31:38
ព័ត៌មានទូទៅ:
លោកយ៉ូបបានបន្តពណ៌នាអំពីស្ថានភាពដែលលោកស័ក្តសមនឹងទទួលការដាក់ទោសរបស់ព្រះ។
ប៉ុន្តែ លោកបានដឹងថាពួកគេទាំងនោះមិនស្មោះត្រង់។
ប្រសិនបើ ដីស្រែរបស់ខ្ញុំស្រែកឡើងទាស់នឹងខ្ញុំ ហើយគន្លងរបស់ពួកវាបានយំជាមួយគ្នា
លោកយ៉ូបពណ៌នាអំពីដីនោះថាជាមនុស្សដែលស្រែកយំពីព្រោះលោកយ៉ូបបានលួចវាពីម្ចាស់ដីពិតប្រាកដ

---

32 [1]កាលមិត្តភក្តិទាំងបីរូបរបស់លោកយ៉ូប ឃើញលោកប្រកាន់ជំហរថាខ្លួនសុចរិតដូច្នេះ ពួកគេក៏លែងឆ្លើយឆ្លងទៀត។[2]ពេលនោះ លោកអេលីហ៊ូវ ជាកូនរបស់លោក
បារ៉ាគាល ក្នុងអំបូរប៊ូសនៃត្រកូលរ៉ាម ក៏ចាប់ផ្តើមខឹងជាខ្លាំង គាត់ខឹងនឹងលោកយ៉ូប ព្រោះលោកប្រកាន់ថាខ្លួនលោកសុចរិតជាងព្រះជាម្ចាស់ ។
[3]គាត់ក៏ខឹងនឹងមិត្តភក្តិទាំងបីរបស់លោកយ៉ូបដែរ ព្រោះលោកទាំងបីពុំអាចរកពាក្យឆ្លើយទៅលោកវិញបាន ធ្វើហាក់ដូចជាព្រះជាម្ចាស់មានកំហុសមែន ។[4]ពេលនេះលោក
អេលីហ៊ូវក្មេងជាងគេ គាត់រង់ចាំនិយាយជាមួយលោកយ៉ូបក្រោយគេ។[5]ប៉ុន្តែ ពេលគាត់ឃើញលោកទាំងបីគ្មានពាក្យអ្វីឆ្លើយទៅលោកយ៉ូបទៀតនោះ គាត់ក៏ខឹងជាខ្លាំង។
[6]លោកអេលីហ៊ូវ ជាកូនរបស់លោកបារ៉ាគាល ក្នុងអំបូរប៊ូស ពោលឡើងថា៖ «ខ្ញុំនៅក្មេង ហើយអស់លោកសុទ្ធតែជាចាស់ទុំ។ ហេតុនេះហើយបានជាខ្ញុំភ័យញាប់ញ័រ មិន
ហ៊ានជម្រាបអស់លោកពីចំណេះរបស់ខ្ញុំ។[7]ខ្ញុំបាននិយាយថា មនុស្ស «មានអាយុវែង រមែងប្រសប់និយាយ អ្នករស់បានច្រើនឆ្នាំគួរបង្រៀនពីប្រាជ្ញា។

generated on Wed Sep 10 16:16:32 2025

[8]ក៏ប៉ុន្តែ តាមពិត មានតែវិញ្ញាណនៅក្នុងមនុស្ស គឺខ្យល់ដង្ហើមមកពីព្រះដ៏មានឫទ្ធានុភាព ខ្ពង់ខ្ពស់បំផុតប៉ុណ្ណោះ ទើបផ្តល់ឲ្យគេយល់ដឹងបាន។
[9]គឺមិនមែនដោយសារមនុស្សដែលមានប្រាជ្ញា ហើយក៏មិនមែនសារអាយុ ដែលអាចមានចំណេះដឹងនិង ការវិនិច្ឆ័យដែរ។[10]ហេតុនេះ ខ្ញុំនឹងនិយាយទៅកាន់លោកម្តង
សូមស្តាប់ខ្ញុំ នោះខ្ញុំនឹងប្រាប់អំពីចំណេះដឹងរបស់ខ្ញុំ។
[11]មើល! ខ្ញុំបានផ្ទៀងត្រចៀកស្តាប់ពាក្យ ដែលអស់លោកថ្លែង រហូតដល់អស់លោកវែកញែកអស់សេចក្តី។[12]ខ្ញុំបានផ្ចង់ចិត្តស្តាប់អស់លោក ក៏ប៉ុន្តែ គ្មាននរណាម្នាក់ក្នុង
ចំណោមអស់លោក ជជែកឈ្នះលោកយ៉ូប ឬអាចឆ្លើយតបនឹងពាក្យរបស់គាត់វិញសោះ។
[13]ហេតុនេះ សូមកុំអះអាងថា អស់លោករកបានប្រាជ្ញានោះឡើយ! មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាច តទល់នឹងគាត់បាន គឺមិនមែនមនុស្សទេ។[14]ដ្បិតលោកយ៉ូបពុំមាន
ប្រសាសន៍មកកាន់ខ្ញុំផ្ទាល់ទេ ដូច្នេះ ខ្ញុំនឹងមិនឆ្លើយទៅគាត់វិញ តាមរបៀបដែលអស់លោកឆ្លើយនោះឡើយ។
[15]លោកយ៉ូបអើយ លោកទាំងបីនេះមិនហ៊ានឆ្លើយទៀតទេ ដ្បិតពួកគាត់រកពាក្យនិយាយពុំបាន។[16]តើគួរឲ្យខ្ញុំរង់ចាំដែរ ពីព្រោះមិនឃើញពួកគាត់និយាយទេ ដោយពួកគាត់
នៅស្ងៀម លែងឆ្លើយដូច្នេះទៀតហើយឬ?
[17]ខ្ញុំសូមឆ្លើយតបទៅលោកវិញម្តង ខ្ញុំក៏ចង់បង្ហាញចំណេះដឹងរបស់ខ្ញុំដែរ។[18]ដ្បិត ខ្ញុំមានសេចក្តីជាច្រើនដែលចង់និយាយ វិញ្ញាណដែលនៅក្នុងខ្ញុំ បានបង្ខំខ្ញុំដែរ។[19]មើល!
ទ្រូងរបស់ខ្ញុំមុខតែធ្លុះធ្លាយដូចថង់ស្បែក ដែលដាក់ស្រាទំពាំងបាយជូរថ្មី។
[20]ខ្ញុំសូមនិយាយ ដើម្បីឲ្យបានធូរទ្រូង ខ្ញុំត្រូវតែបើកមាត់ឆ្លើយទៅអស់លោកវិញ។[21]ខ្ញុំមិនរើសមុខនរណាឡើយ ហើយខ្ញុំក៏មិនបញ្ចើចបញ្ចើនរណាម្នាក់ដែរ។[22]ដ្បិត ខ្ញុំមិនចេះ
បញ្ចើចបញ្ចើទេ បើខ្ញុំធ្វើដូច្នេះ ព្រះដែលបង្កើតខ្ញុំមុខជា ដកជីវិតខ្ញុំយ៉ាងឆាប់មិនខាន។

Job 32:1
នៅក្នុងភ្នែករបស់ពួកគេ
ភ្នែកគឺតំណាងឲ្យការមើលឃើញ ហើយការមើលឃើញគឺតំណាងឲ្យការគិត ឬ
ក៏វិនិច្ឆ័យ។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«គាត់ចាត់ទុកខ្លួនថាជាមនុស្សបរិសុទ្ធ»
រួចហើយបានបង្កាត់កំហឹងរបស់លោកអេលីហ៊ូវ ជាកូនរបស់លោកបារ៉ាគាល នៃអំបូរប៊ូសនៃត្រកូល
រ៉ាម ហើយវាបានចាប់ផ្តើមទាស់នឹងលោកយ៉ូប
នេះប្រៀបធៀបកំហឹងរបស់អេលីហ៊ូវទៅនឹងនរណាម្នាក់ដែលចាប់ផ្តើមឆេះ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពេលនោះលោកអេលីហ៊ូវជាកូនរបស់លោកបារ៉ាក់
និងជាអ្នកស្រុកប៊ូសមកពីអំបូររ៉ាមខឹងនឹងលោកយ៉ូបយ៉ាងខ្លាំង»
អេលីហ៊ូវ...បារ៉ាគាល...រ៉ាម
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
អំបូរប៊ូស
នេះគឺជាឈ្មោះនៃអំបូរមនុស្ស។
លោកប្រកាន់ថាខ្លួនលោកសុចរិតជាងព្រះជាម្ចាស់នោះ
នេះមានន័យថាគាត់ចាត់ទុកខ្លួនគាត់ជាមនុស្សសុទ្ធត្រង់ហើយជឿថាព្រះជាម្ចាស់ខុសនឹងគាត់ ឬថាគាត់ល្អជាងព្រះជាម្ចាស់។ ការបកប្រែ
របៀបផ្សេងទៀតក្នុងការបកប្រែ:
«លោកបានរាប់ជាសុចរិតហើយបានអះអាងថាព្រះជាម្ចាស់បានដាក់ទោសគាត់ខុស»
Job 32:3
លោកអេលីហ៊ូវក៏បានបង្កាត់កំហឹងទាស់នឹងមិត្តភក្តិទាំងបីរបស់លោក
នេះប្រៀបធៀបកំហឹងរបស់អេលីហ៊ូវទៅនឹងនរណាម្នាក់ដែលចាប់ផ្តើមឆេះ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«លោកអេលីហ៊ូវក៏ខឹងនឹងមិត្រភក្តិបីនាក់របស់គាត់ដែរ»
ពេលនេះ
ពាក្យរបស់លោកត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់។
នេះប្រាប់ព័ត៌មានពីប្រវត្តិរបស់លោកអេលីហ៊ូវ។
ឃើញថាគ្មានពាក្យឆ្លើយនៅក្នុងមាត់អ្នកទាំងបី
នេះមានន័យថាបុរសទាំងនោះបាននិយាយទៅកាន់លោកយ៉ូប។
នេះគឺនិយាយអំពីបុរសដែលអាចមានចម្លើយ
ហើយដូចជាចម្លើយគឺជាវត្ថុដែលនឹងមាននៅក្នុងមាត់របស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ថាបុរសទាំងបីនាក់នេះគ្មានអ្វីត្រូវនិយាយទេ» ឬ
«បុរសទាំងបីនាក់នេះមិនមានចម្លើយអ្វីទៀតទេក្នុងការផ្តល់ចម្លើយមកកាន់លោកយ៉ូប»
កំហឹងរបស់លោកបានបង្កាត់ឡើង
នេះប្រៀបធៀបកំហឹងរបស់លោកអេលីហ៊ូវទៅនឹងនរណាម្នាក់ដែលចាប់ផ្តើមឆេះ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«លោកបានខឹងយ៉ាងខ្លាំង»
Job 32:6
លោកមានវ័យចាស់ណាស់ហើយ
ពាក្យ «លោក» គឺជាពហុវចនហើយសំដៅទៅលើលោកយ៉ូប
និងមិត្រភក្តិរបស់លោកទាំងបី។
រយៈពេលនៃថ្ងៃគួរតែនិយាយ ហើយការចម្រើននៃឆ្នាំគួរតែបង្រៀនពីប្រាជ្ញា
ប្រយោគទាំងពីរនេះមានន័យដូចគ្នា។
អេលីហ៊ូវសង្កត់ធ្ងន់ថាចាប់តាំងពីមនុស្សចាស់មានប្រាជ្ញាជាងមនុស្សវ័យក្មេងពួកគេគួរតែជាមនុស្សដំបូង
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលបានរស់នៅច្រើនឆ្នាំគួរនិយាយ
អ្នកដែលចាស់ជាងនេះគួរតែបង្រៀនពីប្រាជ្ញា»
Job 32:8
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូបនិងមិត្រភក្តិរបស់លោក។
ប៉ុន្តែ គឺមានវិញ្ញាណនៅក្នុងមនុស្ស ...ខ្យល់ដង្ហើមនៃព្រះដ៏មានព្រះចេស្តា
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
អេលីហ៊ូវកំពុងសង្កត់ធ្ងន់ថាប្រាជ្ញារបស់បុរសគឺមកពីព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «មានវិញ្ញាណមួយនៅក្នុងមនុស្ស
ពោលគឺដង្ហើមរបស់ព្រះដែលមានឫទ្ធានុភាពខ្លាំងក្លាបំផុត»
ខ្យល់ដង្ហើមនៃព្រះដ៏មានព្រះចេស្តា
នៅទីនេះស្មារតីត្រូវបានតំណាងដោយ «ខ្យល់ដង្ហើម»។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះវិញ្ញាណដ៏មានព្រះចេស្តា»
Job 32:11
មើល៍
ឃាត់មាត់ស្តាប់ពាក្យ
របៀបផ្សេងទៀតនៃការបកប្រែ: «សូមស្តាប់»
ខ្ញុំបានរង់ចាំស្តាប់ពាក្យរបស់លោក
ពាក្យថា «លោក» គឺសំដៅទៅលើមិត្តសម្លាញ់របស់លោកយ៉ូប។ «ពាក្យ»
របស់ពួកគេសំដៅទៅលើអ្វីដែលពួកគេនឹងនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានរង់ចាំស្តាប់នូវអ្វីដែលអ្នកនឹងនិយាយ»
នរណាអាចឆ្លើយតបនឹងពាក្យរបស់គាត់បាន
នៅទីនេះពាក្យថា «ឆ្លើយតប» មិនត្រឹមតែមានន័យថាឆ្លើយប៉ុណ្ណោះទេ ប៉ុន្តែ
ត្រូវឆ្លើយដោយការឆ្លើយតបដែលចំណេញ។
Job 32:13
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូបនិងមិត្រភក្តិរបស់លោក។
«យើងបានរកឃើញប្រាជ្ញាហើយ
«យើងបានរកឃើញអ្វីដែលមានប្រាជ្ញា» ។
នេះមានន័យថាពួកគេជឿថាពួកគេបានរកឃើញអ្វីដែលមានប្រាជ្ញា។
នឹងការពារលោកយ៉ូប
នេះគឺនិយាយអំពីព្រះជាម្ចាស់ឆ្លើយតបនឹងលោកយ៉ូប
និងប្រដៅលោកដូចជាព្រះអង្គបានការពារលោកនៅក្នុងសមរភូមិ។
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងបដិសេធលោកយ៉ូប» ឬ
«នឹងឆ្លើយតបនឹងលោកយ៉ូប»
ដោយពាក្យរបស់លោក
«ដោយនិយាយអ្វីដែលអ្នកបាននិយាយ»
Job 32:15
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយ។
ស្រឡាំងកាំង
«និយាយមិនចេញ»
តើគួរឲ្យខ្ញុំរង់ចាំ ដោយព្រោះពួកលោកមិនបាននិយាយអីទៀត ពីព្រោះពួកលោកបានឈរស្ងៀម

generated on Wed Sep 10 16:16:32 2025

ហើយមិនឆ្លើយទៀតទេ?
លោកអេលីហ៊ូវប្រើសំណួរ ដើម្បីបញ្ជាក់ថាលោកនឹងមិនរង់ចាំនិយាយទៀតទេ។
លោកអេលីហ៊ូវឆ្លើយសំណួរនេះដោយខ្លួនឯងនៅក្នុងខបន្ទាប់។
Job 32:17
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយដោយប្រើពាក្យប្រៀបធៀប។
ខ្ញុំនឹងឆ្លើយតបទៅចំណែករបស់ខ្ញុំ
«ពេលនេះខ្ញុំនឹងឆ្លើយម្តង»
ខ្ញុំមានពាក្យសម្តីជាច្រើន
លោកអេលីហ៊ូវនិយាយពីការនិយាយច្រើនដែលពេញទៅដោយពាក្យជាច្រើន។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមានពាក្យជាច្រើនដើម្បីនិយាយ»
វិញ្ញាណដែលនៅក្នុងខ្ញុំ បានបង្ខំខ្ញុំ
«វិញ្ញាណរបស់ខ្ញុំបានបង្ខំខ្ញុំឲ្យនិយាយវា» (UDB)
មើល៍! ដើមទ្រូងរបស់ខ្ញុំដូចស្ពឺអំពីស្រាទំពាំងបាយជូរ ដែលអត់មានចង់ស្បែកដែលវាជិតផ្ទុះ
ខណៈពេលដែលស្រាកំពុងបង្កើនឧស្ម័នប្រមូលនៅក្នុងធុង។ ប្រសិនបើ
ឧស្ម័នមិនត្រូវបានភាយចេញទេ នោះធុងនឹងផ្ទុះ។
លោកអេលីហ៊ូវមានន័យថាគាត់មានអ្វីដែលត្រូវនិយាយច្រើន ប្រសិនបើ
គាត់មិននិយាយគាត់មានអារម្មណ៍ថាគាត់នឹងផ្ទុះឡើង។
ឃ្លាទាំងពីរនេះគឺស្របគ្នានិងមានអត្ថន័យដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមានអារម្មណ៍ថាដើមទ្រូងរបស់ខ្ញុំផ្ទុះចេញដូចជាធុងស្រាដែលគ្មានស្រា»
ដើមទ្រូងរបស់ខ្ញុំ
ឃ្លានេះសំដៅទៅលកអេលីហ៊ូវ ជាពិសេសគឺវិញ្ញាណរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «គឺវិញ្ញាណរបស់ខ្ញុំ» ឬ «ជាខ្ញុំ»
Job 32:20
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយដោយប្រើពាក្យប្រៀបធៀប។
ខ្ញុំនឹងបានធូរចិត្ត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងមានអារម្មណ៍ល្អប្រសើរ»
បើកបបូរមាត់របស់ខ្ញុំ
ពាក្យ «បបូរមាត់» គឺសំដៅទៅលើមាត់។ «បើកមាត់របស់ខ្ញុំ»
ខ្ញុំនឹងមិនខ្លាចតួនាទីរបស់មនុស្សណាឡើយ
«ខ្ញុំក៏មិនដែលសរសើរមនុស្សណាម្នាក់ ឬលើកកិត្តិយសដល់គេដែរ»
ព្រះដែលបង្កើតខ្ញុំ
«ព្រះដែលបង្កើតខ្ញុំ» នេះគឺជាឈ្មោះដែលសំដៅព្រះជាម្ចាស់។
នឹងដកជីវិតខ្ញុំទៅ
នេះមានន័យថាគាត់នឹងបំផ្លាញគាត់ចោល។ របៀបផ្សេងទៀតនៃការបកប្រែ
«បំផ្លាញខ្ញុំ»

---

33 [1]ពេលនេះ លោកយ៉ូបអើយ! សូមស្តាប់ពាក្យខ្ញុំ នឹងសូមស្តាប់ពាក្យទាំងប៉ុន្មានរបស់ខ្ញុំ។[2]មើល! ខ្ញុំរៀបចំពាក្យសម្តី ហើយត្រៀមមាត់ជាស្រេចនឹងនិយាយ។[3]ពាក្យខ្ញុំ
របស់គឺដោយស្មោះត្រង់ ចេញពីចិត្ត មាត់របស់ខ្ញុំនិយាយចំណេះដឹងដែលបរិសុទ្ធ។
[4]ព្រះវិញ្ញាណនៃព្រះជាម្ចាស់បានសូនខ្ញុំឡើង ខ្យល់ដង្ហើមរបស់ព្រះដ៏មានឫទ្ធានុភាព ប្រទានឲ្យខ្ញុំមានជីវិត។[5]សូមឆ្លើយមកខ្ញុំចុះ បើលោកអាចឆ្លើយបាន
សូមរៀបចំពាក្យរបស់លោកមុនខ្ញុំចាប់ផ្តើម។
[6]មើល! ខ្ញុំក៏នៅខាងព្រះជាម្ចាស់ដែរ ព្រះអង្គបានសូនខ្ញុំពីដីឥដ្ឋ ដូចលោកដែរ។[7]មើល! សូមកុំញាប់ញ័រនៅចំពោះមុខខ្ញុំឡើយ ហើយក៏មិនធ្វើឲ្យលោកភ័យខ្លាច
ឬដាក់បន្ទុកលើលោកដែរ។
[8]ខ្ញុំបានឮពាក្យដែលលោកថ្លែងប្រាប់ ហើយខ្ញុំចងចាំ ឥតភ្លេចឡើយ គឺលោកពោលថា៖[9]ខ្ញុំជាមនុស្សគ្មានទោស គ្មានបាប ខ្ញុំជាមនុស្សស្អាតស្អំដែរ ឥតមានកំហុសអ្វីទេ។
[10]មើល! ព្រះជាម្ចាស់រករឿងទាស់នឹងខ្ញុំ ព្រះអង្គចាត់ទុកខ្ញុំជាខ្មាំងសត្រូវ។[11]ព្រះអង្គដាក់ខ្នោះជើងខ្ញុំ ព្រះអង្គឃ្លាំមើលគ្រប់ផ្លូវរបស់ខ្ញុំ។[12]មើល! លោកមានប្រសាសន៍ដូច្នេះ
មិនត្រូវទេ ចាំខ្ញុំពន្យល់លោក ដ្បិតព្រះជាម្ចាស់ធំជាងមនុស្សលោក។
[13]ហេតុអ្វីបានជាលោកចោទប្រកាន់ព្រះអង្គ? ព្រះអង្គមិនទទួលខុសត្រូវ សម្រាប់ការដែលព្រះអង្គបានធ្វើ។[14]ព្រះជាម្ចាស់មានព្រះបន្ទូលតាមរបៀបផ្សេងៗ តែគ្មាននរណា
ចាប់អារម្មណ៍ទេ។[15]តាមការយល់សប្តិ តាមរយៈសុបិននិមិត្តនៅពេលយប់ ក្នុងពេលដែលមនុស្សកំពុងតែដេក លង់លក់នៅលើគ្រែផង
[16]ព្រះអង្គក៏សម្តែងឲ្យគេស្គាល់ ហើយពួកគេមានការរន្ធត់ជាង ការសម្លុតទៅទៀត។[17]ធ្វើដូច្នេះ ព្រះអង្គនាំមនុស្សឲ្យងាក ចេញពីអំពើបាប ហើយការពារមនុស្សកុំឲ្យមាន
អំនួត។[18]ព្រះជាម្ចាស់រក្សាគេកុំឲ្យគេធ្លាក់ទៅក្នុងរណ្តៅ និងការពារជីវិតគេ ឲ្យរួចពីក្តីស្លាប់។
[19]មនុស្សនឹងទទួលទោស នឹងជាមួយការឈឺចាប់នៅលើគ្រែរបស់គេ នឹងមានការឈឺចាប់ក្នុងឆ្អឹងមិនឈប់[20]ដូច្នេះ គេបរិភោគអាហារលែងកើត ហើយ
ក៏លែងដឹងរស់ជាតិអាហារដែរ។
[21]រូបកាយរបស់គេកាន់តែស្គមទៅៗ នៅសល់តែស្បែកដែលមើលស្ទើតែមិនឃើញ និងឆ្អឹងរបស់គេក៏ដូចគ្នាដែរ។[22]ព្រលឹងគេកាន់តែខិតជិតរណ្តៅ ជីវិតរបស់គេ ក៏ខិតទៅ
ជិតដល់ក្តីវិនាសដែរ។
[23]ក៏ប៉ុន្តែ ប្រសិនបើមានទេវតាមួយណា ក្នុងចំណោមទេវតាមួយពាន់ មកបកស្រាយ និងបង្ហាញឲ្យអ្នកនោះ ស្គាល់ផ្លូវត្រឹមត្រូវ។[24]ព្រះជាម្ចាស់មុខជាលើកលែងទោសឲ្យគេ
ដ្បិតទេវតាអង្វរថា៖ សូមដោះលែងអ្នកនេះទៅ កុំឲ្យគេធ្លាក់ទៅក្នុងរណ្តៅឡើយ ទូលបង្គំរកបានហេតុផល ដើម្បីរំដោះគេហើយ។
[25]ពេលនោះ សាច់ឈាមរបស់គេនឹងប្រែជា ស្រស់ស្អាតដូចគ្រានៅពីក្មេង ហើយគេនឹងបានដូចគ្រានៅវ័យជំទង់។[26]ពេលគេទូលអង្វរព្រះជាម្ចាស់ ព្រះអង្គស្តាប់គេ គេចូល
ទៅគាល់ព្រះអង្គដោយអំណរ ព្រះអង្គរាប់គេជាមនុស្សសុចរិតឡើងវិញ។
[27]ពេលនោះ គេនឹងច្រៀង នៅចំពោះមុខមនុស្សម្នាថា៖ ខ្ញុំបានប្រព្រឹត្តអំពើបាប ខ្ញុំបានវង្វេងចេញពីមាគ៌ាដ៏ត្រឹមត្រូវ តែព្រះជាម្ចាស់ពុំបានដាក់ទោសខ្ញុំ ស្របតាមអំពើដែលខ្ញុំ
ប្រព្រឹត្តនោះឡើយ។[28]ព្រះជាម្ចាស់បានរំដោះខ្ញុំមិនឲ្យធ្លាក់ទៅក្នុងរណ្តៅ ខ្ញុំនៅមានជីវិត ហើយមើលឃើញពន្លឺ។
[29]មើល! ព្រះជាម្ចាស់ធ្វើការទាំងនេះចំនួនពីរ ឬបីលើក ចំពោះមនុស្ស[30]ដើម្បីនាំគេឲ្យចេញផុតពីរណ្តៅ ហើយឲ្យពន្លឺជីវិតចាំងចែងទៅលើគេផងដែរ។
[31]លោកយ៉ូបអើយ សូមត្រងត្រាប់ស្តាប់ពាក្យខ្ញុំ! សូមលោកនៅស្ងៀមទៅ នោះខ្ញុំនឹងនិយាយ។[32]ប្រសិនបើលោកចង់ឆ្លើយ សូមឆ្លើយមកចុះ សូមមានប្រសាសន៍មក ដ្បិត
ខ្ញុំចង់រកយុត្តិធម៌ជូនលោក។[33]បើគ្មានទេ សូមស្តាប់ខ្ញុំ! សូមនៅស្ងៀមទៅ ខ្ញុំនឹងបង្រៀនលោកអំពីប្រាជ្ញា»។

Job 33:1
សូមស្តាប់ពាក្យរបស់ខ្ញុំ ហើយសូមស្តាប់ដល់ពាក្យទាំងអស់របស់ខ្ញុំ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
លោកអេលីហ៊ូវកំពុងសង្កត់ធ្ងន់ថាលោកយ៉ូបត្រូវតែស្តាប់ដោយយកចិត្តទុកដាក់។
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយ។
ឥឡូវនេះ ខ្ញុំបានបើកមាត់របស់ខ្ញុំ ហើយអណ្តាតរបស់ខ្ញុំជាបាននិយាយនៅក្នុងមាត់ខ្ញុំដែរ
ទាំងនេះមានន័យដូចគ្នា។
លោកអេលីហ៊ូវកំពុងសង្កត់ធ្ងន់ថាឥឡូវនេះគាត់ត្រៀមខ្លួននិយាយហើយ។
«អណ្តាត» របស់គាត់និងការនិយាយតំណាងឲ្យខ្លួនរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានចាប់ផ្តើមបើកមាត់របស់ខ្ញុំ
ហើយខ្ញុំក៏ចាប់ផ្តើមនិយាយ»
ពាក្យរបស់ខ្ញុំបានចេញពីភាពស្មោះត្រង់ នៃដួងចិត្តខ្ញុំ
នៅទីនេះលោកអេលីហ៊ូវសំដៅលើខ្លួនគាត់ដោយ «ដួងចិត្ត»
ដូចដែលគាត់និយាយអំពីភាពត្រឹមត្រូវ។
ដូចគ្នានេះផងដែរគាត់និយាយពីខ្លួនគាត់និយាយដូចជា «ពាក្យ»
របស់គាត់បាននិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងនិយាយដោយត្រង់» ឬ «ខ្ញុំនឹងនិយាយដោយការគោរព»
ពាក្យរបស់ខ្ញុំបានចេញពីភាពស្មោះត្រង់ នៃដួងចិត្តខ្ញុំ មាត់របស់ខ្ញុំនិយាយពីចំណេះដឹងដែលបរិសុទ្ធ
ទីនេះលោកអេលីហ៊ូវចង់សំដៅទៅលើខ្លួនរបស់គាត់ «មាត់»
គឺប្រៀបធៀបទៅនឹងការនិយាយស្តី។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងនិយាយនូវអ្វីដែលខ្ញុំដឹងទៅកាន់អ្នកដោយភាពទន់ភ្លន់»

generated on Wed Sep 10 16:16:32 2025

Job 33:4
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់...បានប្រទានឲ្យខ្ញុំមានជីវិត
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
លោកអេលីហ៊ូវបាននិយាយប្រៀបធៀបពីព្រះជាម្ចាស់បានបង្កើតលោក
និងបានប្រទានសិទ្ធិអំណាចនូវអ្វីដែលលោកបាននិយាយ។
សូមត្រៀមពាក្យឲ្យរបស់លោកឲ្យបានល្អមុនពេលខ្ញុំក្រោកឈរឡើង
នេះនិយាយអំពីលោកយ៉ូបរៀបចំអ្វីដែលគាត់នឹងនិយាយ
ដូចជានៅទីនេះលោកកំពុងតែរៀបចំអ្វីដែលត្រូវនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «រៀបចំអ្វីដែលអ្នកត្រូវនិយាយ
ហើយរៀបចំឆ្លើយសំណួររបស់ខ្ញុំ»
Job 33:6
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
មើល៍
លោកអេលីហ៊ូវប្រើសម្តីនៅត្រង់នេះដើម្បីធ្វើឲ្យលោកយ៉ូបផ្តោតអារម្មណ៍ចំអ្វីដែលលោកនិយាយ
របៀបផ្សេងទៀតនៃការបកប្រែ: «សូមស្តាប់»
ខ្ញុំក៏ដូចជាលោកដែលនៅខាងព្រះជាម្ចាស់
នៅត្រង់នេះពាក្យនៅខាង គឺតំណាងឲ្យវិនិច្ឆ័យ ឬ ការវាយតម្លៃ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំក៏នៅក្នុងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ដូចជាអ្នកដែរ» ឬ
«ព្រះជាម្ចាស់វិនិច្ឆ័យអ្នកគឺដូចគ្នាជាមួយនឹងអ្វីដែលព្រះអង្គវិនិច្ឆ័យខ្ញុំដែរ»
ខ្ញុំបានរកឃើញថាខ្ញុំកើតពីដីឥដ្ឋផងដែរ
ទោះបីមនុស្សមិនត្រូវបានធ្វើពីដីឥដ្ឋក៏ដោយព្រះជាម្ចាស់បានបង្កើតមនុស្សគ្រប់រូបដូចជាយើងដែរ
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានបង្កើតយើងទាំងពីរដូចជាងស្មូនធ្វើអ្វីៗពីដីឥដ្ឋ»
ព្រះជាម្ចាស់ក៏បានបង្កើតខ្ញុំដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានបង្កើតខ្ញុំ» ឬ «ព្រះជាម្ចាស់បានបង្កើតយើងទាំងពីរនាក់»
មើល៍! ការភ័យខ្លាំងរបស់ខ្ញុំនឹងមិនធ្វើឲ្យអ្នកភ័យទេ
«អ្នកមិនត្រូវខ្លាចខ្ញុំឡើយ» (UDB)
ម៉្យាងទៀតវត្តមានរបស់ខ្ញុំ នឹងដាក់បន្ទុកលើលោកដែរ
នេះមានន័យថាលោកនឹងមិនរារាំងការងារ ឬធ្វើជាបន្ទុកលោកយ៉ូបទេ។
លោកនិយាយពីបន្ទុកនៅក្នុងអារម្មណ៍នៅទីនេះហាក់ដូចជាបន្ទុករាងកាយធ្ងន់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំដាច់ខាតមិនធ្វើជាបន្ទុកអ្នកទេ» ឬ
«ខ្ញុំនឹងមិននិយាយអ្វីដែលរំខានដល់អ្នកទេ»
Job 33:8
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
ខ្ញុំក៏បានឮ
«អ្វីដែលខ្ញុំបានឮ»
ក៏បានឮសម្លេងនៃពាក្យរបស់លោកដែលបាននិយាយ
នេះគឺជាការនិយាយរបស់លោកយ៉ូប និយាយដូចជាវាជា «ពាក្យ» របស់គាត់។
របៀបផ្សេងទៀតក្នុងការបកប្រែ: «ខ្ញុំបានឮអ្នកនិយាយ»
ស្អាត
មនុស្សដែលព្រះជាម្ចាស់ចាត់ទុកជាមនុស្សដែលអាចទទួលការសព្វព្រះទ័យពីព្រះជាម្ចាស់
ត្រូវគេចាត់ទុកដូចជាមនុស្សស្អាតស្អំខាងរូបកាយ។
មិនមានអំពើបាបនៅក្នុងខ្ញុំទេ
«ខ្ញុំគ្មានបាបទេ»
Job 33:10
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តស្រង់ពាក្យសម្តីដែលលោកយ៉ូបនិយាយ។
មើល៍
អ្នកនិយាយប្រើពាក្យនេះនៅទីនេះដើម្បីទាក់ទាញចំណាប់អារម្មណ៍ទៅនឹងអ្វីដែលគាត់
របៀបផ្សេងទៀតនៃការបកប្រែ: «សូមស្តាប់»
ព្រះអង្គយកខ្នោះមកដាក់ជើងខ្ញុំ
«ខ្នោះ»
គឺជាប្លុកឈើដែលអ្នកទោសម្នាក់ដាក់ជើងអ្នកទោសដើម្បីរឹតត្បិតចលនារបស់គាត់។
លោកយ៉ូបនិយាយពីអារម្មណ៍ដូចជាគាត់ជាអ្នកទោសដោយនិយាយថាគាត់ជាប់ខ្នោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមានអារម្មណ៍ថាព្រះអង្គបានធ្វើឲ្យខ្ញុំជាប់ឃុំឃាំង»
ផ្លូវរបស់ខ្ញុំ
ពាក្យនេះគឺសំដៅលើកន្លែងដែលលោកទៅ។
កន្លែងដែលលោកទៅគឺចង់សំដៅទៅអ្វីដែលលោកធ្វើ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីៗទាំងអស់ដែលខ្ញុំធ្វើ»
ខ្ញុំនឹងឆ្លើយទៅអ្នក
លោកអេលីហ៊ូវនិយាយទៅកាន់លោកយ៉ូប។
Job 33:13
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
ហេតុអ្វីបានជាលោកនៅតែចោទប្រកាន់ព្រះអង្គ?
លោកអេលីហ៊ូវ
ប្រើសំណួរនេះដើម្បីបញ្ជាក់ថាលោកយ៉ូបមិនគួរប្រឆាំងនឹងព្រះជាម្ចាស់ទេ។
សំណួរនេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនគួរមានបញ្ហាប្រឆាំងនឹងព្រះជាម្ចាស់ទេ»
ឬ «អ្នកមិនគួរព្យាយាមប្រឆាំងជាមួយព្រះជាម្ចាស់ទេ»
ព្រះអង្គមិនបាច់ទទួលខុសត្រូវសម្រាប់ការដែលព្រះអង្គបានធ្វើទេ
«ព្រះអង្គមិនចាំបាច់បកស្រាយអ្វីដែលព្រះអង្គធ្វើនៅទេ»
ដ្បិត ព្រះជាម្ចាស់មានព្រះបន្ទូលមួយដងជាពីរដង
នេះគឺជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់និយាយម្តងហើយម្តងទៀត»
យល់សប្តិ...នៅក្នុងសុបិននិមិត្តនៅពេលយប់
ឃ្លាទាំងពីរនេះធ្វើឡើងដើម្បីមានន័យដូចគ្នា។
និងពេលដែលមនុស្សកំពុងតែដេកលង់លក់ ក្នុងការដែលងងុយលើគ្រែផង
នេះនិយាយអំពីមនុស្សដែលកំពុងដេកលក់យ៉ាងស្កប់ស្កល់ដូចជាការដេកលក់ធ្លាក់មកលើពួកគេ
ឬយកឈ្នះពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលមនុស្សកំពុងដេកលក់យ៉ាងពេញលេញនៅលើគ្រែរបស់ពួកគេ»
Job 33:16
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
រួចហើយព្រះជាម្ចាស់ក៏បើកត្រចៀករបស់មនុស្ស
នេះនិយាយអំពីព្រះជាម្ចាស់ធ្វើឲ្យមនុស្សដឹងពីអ្វីដែលហាក់ដូចជាគាត់បើកត្រចៀកដើម្បីឲ្យពួកគេអាចស្តា
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មក
ព្រះជាម្ចាស់បើកសំដែងអ្វីៗទាំងអស់ដល់មនុស្ស»
ក្នុងគោលបំណងដើម្បីទាញមនុស្សឲ្យត្រឡប់ចេញពីអំពើ
នេះនិយាយអំពីព្រះជាម្ចាស់ជួយការពារនរណាម្នាក់ពីការធ្វើអ្វីមួយដូចជាព្រះអង្គបានទាញគេចេញពីគ្រោះ
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីទាញគេចេញពី»
ព្រះជាម្ចាស់រក្សាជីវិតមនុស្សពីការធ្លាក់ទៅក្នុងរណ្តៅ...ការពារជីវិតគេកុំឲ្យឆ្លងកាត់សេចក្តីស្លាប់
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានជួយសង្គ្រោះមនុស្សពីរណ្តៅ និងសេចក្តីស្លាប់»
ឋាននរក
ជាកន្លែងដែលមនុស្សនឹងត្រូវទៅនៅពេលដែលពួកគេស្លាប់ នោះគឺសំដៅទៅ
«ឋាននរក» របៀបផ្សេងទៀតក្នុងការបកប្រែ:
ជីវិតរបស់មនុស្សត្រឡប់មកវិញ... ជីវិតរបស់គាត់
ដើម្បីកុំឲ្យគាត់ត្រូវស្លាប់ដោយឥតប្រយោជន៍។ របៀបផ្សេងទៀតនៃការបកប្រែ: «ជួយមនុស្សពីការស្លាប់...
ព្រះអង្គរក្សាគាត់»
ឲ្យឆ្លងផុតពីសេចក្តីស្លាប់
ពាក្យ «ស្លាប់» គឺសំដៅទៅលើកន្លែងដែរមនុស្សត្រូវទៅនៅពេលដែលពួកគេស្លាប់
នោះគឺ ឋានឃុំព្រលឹង។ របៀបផ្សេងទៀតនៃការបកប្រែ:
«រួចផុតពីការទៅកាន់ឋានឃុំព្រលឹង»
Job 33:19
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
មនុស្សគឺទទួលទោស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ក៏ដាក់ទោសមនុស្សដែរ»
ជាមួយការឈឺចាប់នៅលើគ្រែរបស់គេ

generated on Wed Sep 10 16:16:32 2025

នេះមានន័យថាមនុស្សនោះនឹងមានបទពិសោធន៍នៃការឈឺចាប់ដែលត្រូវគេងនៅលើគ្រែ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ជាមួយការឈឺចាប់ដែលពួកគេត្រូវគេងនៅលើគ្រែ»។
ដូច្នេះហើយ ជីវិតពួកគេបរិភោគអាហារលែងបាន ហើយព្រលឹងគេក៏លែងដឹងរស់ជាតិឆ្ងាញ់ដែរ
ឃ្លាទាំងពីរនេះមានន័យដូចគ្នាទៅនឹងអ្វីដែលមនុស្សមានការឈឺចាប់យ៉ាងខ្លាំងរហូតដល់មិនចង់បរិភោគ
មនុស្សនេះត្រូវបានតំណាងដោយ «ជីវិត» និង «ព្រលឹង» របស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«លទ្ធផលគឺថាគាត់មិនចង់បានម្ហូបទេសូម្បីតែអាហារពិសេសក៏ដោយ»
លែងដឹងរស់ជាតិឆ្ងាញ់
«មិនចូលចិត្តសូម្បីតែអាហារដែលឆ្ងាញ់ៗ»
Job 33:21
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
សាច់ឈាមរបស់ពួកគេគឺបានលេបត្របាក់បាត់ទៅ ដូច្នេះហើយវាមិនអាចមើលឃើញទេ
ហើយឆ្អឹងរបស់គេទាំងនោះមើលស្ទើរតែមិនឃើញ ពេលនេះជាប់ចេញក្រៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ «សាច់ឈាមរបស់គេ»
សំដៅទៅលើខ្លាញ់
និងសាច់ដុំរបស់គាត់មិនមែនទៅលើស្បែកខាងក្រៅរបស់រាងកាយទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ជំងឺធ្វើឲ្យរាងកាយរបស់គាត់ខ្សោយនិងស្គម
ដូច្នេះហើយបានជាគេអាចមើលឃើញឆ្អឹងរបស់គាត់»
ព្រលឹងគេបានចូលទៅជិតរណ្តៅ
ពាក្យមនុស្សនៅត្រង់នេះគឺចង់សំដៅទៅលើ «ព្រលឹង»
របៀបផ្សេងទៀតនៃការបកប្រែ «គាត់ជិតចូលទៅក្នុងសេចក្តីស្លាប់ហើយ»
ឋាននរក
កន្លែងដែលមនុស្សទៅនៅពេលពួកគេស្លាប់ត្រូវបានគេហៅថាទីនេះគឺជា
«ឋាននរក»។ របៀបផ្សេងទៀតនៃការបកប្រែ: «កន្លែងដែលមនុស្សស្លាប់នៅ»
ជីវិតរបស់គេទាំងនោះដែលវិនាសនៅទីនោះ
នៅទីនេះមនុស្សត្រូវបានតំណាងដោយ «ជីវិត» របស់គាត់។ ឃ្លាថា
«អ្នកដែលចង់បំផ្លាញវា»
សំដៅទៅលើកន្លែងដែលមនុស្សទៅបន្ទាប់ពីពួកគេស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយគាត់ជិតនឹងទៅកន្លែងដែលមនុស្សស្លាប់ទៅហើយ» ឬ
«គាត់នឹងទៅកន្លែងស្លាប់ឆាប់ៗនេះ»
Job 33:23
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
សម្រាប់គាត់
នេះមិនសំដៅទៅលើមនុស្សជាក់លាក់ទេ។ លោកអេលីហ៊ូវ
បន្តនិយាយអំពីមនុស្សទូទៅ។
ក្នុងចំណោមទេវតារាប់ពាន់
នៅក្នុងភាសាខ្លះវាជារឿងធម្មតាទេដែលយោងទៅលើ «ចំនួនដ៏ច្រើន» ជំនួសឲ្យ
«រាប់ពាន់នាក់» ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មកពីទេវតាដែលមានចំនួនច្រើនលើសលប់»
ឋាននរក
កន្លែងដែលមនុស្សទៅនៅពេលពួកគេស្លាប់ត្រូវបានគេហៅថាទីនេះគឺជា
«ឋាននរក»។ របៀបផ្សេងទៀតនៃការបកប្រែ: «កន្លែងដែលមនុស្សស្លាប់នៅ»
ទូលបង្គំបានឃើញការលោះបាបសម្រាប់គេហើយ
នេះមានន័យថាទេវតាបានរកវិធីសងថ្លៃលោះបាបរបស់បុរសនោះដើម្បីកុំឲ្យគាត់ស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត
ខ្ញុំរកឃើញវិធីដែលអាចឲ្យអ្នករក្សាជីវិតរបស់គេហើយ»
Job 33:25
ព័ត៌មានទូទៅ:
លោកអេលីហ៊ូវបន្តនិយាយទៅកាន់លោកយ៉ូប។
រួចហើយ
ពាក្យថា «រួចហើយ» ត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់អ្វីដែលនឹងកើតឡើង
ប្រសិនបើព្រះជាម្ចាស់យល់ព្រមតាមសំណើរបស់ទេវតា។
«ដោយនិយាយអ្វីៗ ដែលអ្នកមិនបានដឹងដូច្នេះ»
ពាក្យមិនមានការយល់ដឹង
«យល់ដឹង» អាចបកប្រែជាគុណនាមក៏បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពាក្យដែលមិនស្គាល់» ឬ «ពាក្យល្ងីល្ងើ»
ចូរក្រវាត់ចង្កេះរបស់អ្នកដូចមនុស្សអង់អាច
«ចង់អាវរបស់អ្នកនៅជុំវិញចង្កេះរបស់អ្នកដូចជាមនុស្សម្នាក់»
មនុស្សចង់អាវរបស់គេនៅជុំវិញចង្កេះរបស់គេ ធ្វើឲ្យគេអាចធ្វើចលនាស្រួល។
«ក្រវាត់ចង្កេះរបស់អ្នកដូចជាមនុស្សអង់អាច» គឺជាគ្រាមភាសា
មានន័យថារួចរាល់ក្នុងការធ្វើអ្វីមួយទាក់ទងនឹងសកម្មភាពដូចជា
ធ្វើការប្រគួតប្រជែង ឬ ការធ្វើសង្គ្រាម
ហើយលោកយ៉ូបខំប្រឹងរបៀបចំចម្លើយដើម្បីឆ្លើយជាមួយនឹងព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូររៀបចំខ្លួនជាស្រេច សម្រាប់ការងារលំបាក»
Job 38:4

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ
ព្រះអម្ចាស់ចាប់ផ្តើមសួរសំណួរលោកយ៉ូបជាច្រើន។
តើអ្នកនៅទីណា នៅពេលយើងបានចាក់គ្រឹះរបស់ផែនដី? ចូរប្រាប់យើង ប្រសិនបើ
អ្នកមានពេញដោយចំណេះដឹង
ឃ្លានេះ អាចបកប្រែជាប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:«ប្រាប់យើងមក
តើអ្នកនៅទីណា ពេលយើងចាក់គ្រឹះផែនដី ចូរប្រាប់យើងផងប្រសិនបើ បើអ្នកដឹង»
តើនរណាជាអ្នកកំណត់ទំហំរបស់ផែនដី? ចូរប្រាប់យើងប្រសិនបើអ្នកបានដឹង។
ពាក្យ «យល់ដឹង» ជានាមអរូប អាចប្រែជាកិរិយាសព្ទ «យល់ដឹង»
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ អ្នកយល់ខ្លាំងមែន»
តើអ្នកលាតសន្ធឹងហើយវាស់ប្រវែងនៅលើផែនដីបាន?
ឃ្លានេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាប់យើងមក ប្រសិនបើអ្នកដឹង តើនរណាលាសន្ធឹងហើយវាស់ប្រវែងផែនដី»
វាស់ប្រវែង
«រង្វាស់»
តើអ្នកណាលាតសន្ធឹងហើយវាស់ប្រវែងនៅលើផែនដីបាន?
ឃ្លានេះ អាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាប់យើងមើល៍ តើអ្នកណាលាតសន្ធឹង វាស់លើវា»
វាស់ប្រវែង
ខ្សែ ឬ ចំណងដែលមនុស្សប្រើ ដើម្បីវាស់ពីទំហំ និងទម្រង់។
Job 38:6
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ប្រយោគភ្ជាប់
ពាក្យ «វា» សំដៅលើផែនដី។
តើផែនដីចាក់គ្រឹះនៅលើអ្វី?
ឃ្លានេះ អាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាប់យើងមក តើផែនដីចាក់គ្រឹះនៅលើអ្វី?»
តើនរណាបានបញ្ចុះថ្មដ៏សំខាន់... ពពួកទេវតានៃព្រះជាម្ចាស់បន្លឺសំឡេងឡើងដោយអំណរ?
ឃ្លានេះ អាចបកប្រែជាប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាប់ខ្ញុំមក
តើនរណាបានបញ្ចុះថ្មដ៏សំខាន់ ពេល...ពពួកទេវតានៃព្រះជាម្ចាស់បន្លឺ
សំឡេងឡើងដោយអំណរ»
នៅពេលព្រឹកមានផ្កាយស្រែកច្រៀងជាមួយគ្នា ហើយពពួកទេវតានៃព្រះជាម្ចាស់បន្លឺ
សំឡេងឡើងដោយអំណរ?
មានពីរបន្ទាត់ដែលមានន័យប្រហាក់ប្រហែលគ្នា។
នៅពេលព្រឹកមានផ្កាយស្រែកច្រៀងជាមួយគ្នា
ផ្កាយព្រឹកច្រៀងដូចជាមនុស្សច្រៀង។ អាចមានន័យពីរ។ ទី១) «ផ្កាយព្រឹក»
ដូចគ្នាជាមួយនឹងកូនរបស់ព្រះជាម្ចាស់» នៅក្នុងបន្ទាត់បន្ទាប់ ទី២) «ផ្កាយព្រឹក»
សំដៅលើផ្កាយនៅលើមេឃ។
ផ្កាយព្រឹក
«ជាផ្កាយដែលមានពន្លឺ ជះនៅពេលព្រឹក»
បន្លឺសំឡេងឡើងដោយអំណរ
«អំណរ» អាចបកប្រែជាកិរិយាវិសេស «ពេញដោយអំណរ»
របៀបផ្សេងទៀតនៃការបកប្រែ: «បានស្រែកច្រៀងដោយអំណរ»
ដោយអំណរ
«ព្រោះពួកគេពេញដោយអំណរ»
Job 38:8
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើអ្នកណាអាចបិតសមុទ្រជាប់ដោយទ្វារបាន...ហើយយកភាពងងឹតក៏ក្រាស់ជាក្រណាត់រុំវាផងដែរ
ឃ្លានេះអាចបកប្រែជាប្រយោគបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាប់យើងមើល៍ តើនរណាបិទទ្វារសមុទ្រ...ហើយយកភាពងងឹតក៏ក្រាស់
ជាក្រណាត់រុំវាផងដែរ»
នរណាបិទទ្វារសមុទ្រ
ព្រះអម្ចាស់បានរៀបចំផ្លូវដែលព្រះអង្គការពារមិនឲ្យទឹកសមុទ្រហូរចូលដោយបិទទ្វាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានការពារទឹកពីការលេចលង់ផែនដី»
វាក៏ដូចជាការសម្រាលកូនចេញពីក្នុងផ្ទៃដែរ
ព្រះអម្ចាស់បានប្រៀបការបង្កើតសមុទ្រទៅនឹងការបង្កើតកូនដែរ។
ដូចជាសម្លៀកបំពាក់
«ដូចជាសម្លៀកបំពាក់សម្រាប់ទឹកសមុទ្រ»
ក្រណាត់រុំ
ក្រណាវែងដែលមនុស្សប្រើ ដើម្បីរុំកូនងែតដែលទើបនឹងកើត។
Job 38:10
យើងបានកំណត់ចេញព្រំដែនឲ្យសមុទ្ររបស់យើង
«យើងបានកំណត់ព្រំដែនសមុទ្រ»
ព្រំដែន
ព្រះអម្ចាស់បានកំណត់ព្រំដែនសមុទ្រមិនឲ្យទៅហួស។
យើងបានដាក់របារហើយទ្វារឲ្យសមុទ្រ
ព្រះអម្ចាស់របៀបធៀបពីវិធីដែលព្រះអង្គបានដាក់របារ និងទ្វារនៅសមុទ្រ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានដាក់របារហើយទ្វារ»
របារ
ជាឈើមួយដុំវែង ឬដែកដែលប្រើដើម្បីទប់ទ្វារបិទ។
ហើយនៅពេលយើងបាននិយាយទៅកាន់សមុទ្រថា
«ហើយនៅពេលយើងបាននិយាយទៅកាន់សមុទ្រ»
ព្រះអម្ចាស់មានបន្ទូលទៅកាន់សមុទ្រ ប្រៀបដូចជាមនុស្ស។
ចូរឯងមកត្រឹមនេះបានហើយ ប៉ុន្តែ កុំទៅហួសជាងនេះ
ពាក្យ «ត្រឹមនេះ»
មានន័យថាសមុទ្រអាចទៅដល់តែព្រំប្រទល់ដែលព្រះអម្ចាស់បានកំណត់ទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឯងអាចទៅត្រឹមព្រំប្រទល់នេះ ប៉ុន្តែ
មិនអាចទៅលើពីនេះបានទេ»
ដាក់ព្រំដែនដល់រលកក៏ខ្ពស់របស់ឯង
«ទៅកាន់អំណាចនៃរលករបស់ឯង»។
រលកនិយាយរបៀបដូចជាពួកគេមានអំនួត។ «អំនួត» ជានាមអរូប។
អាចបកប្រែជាគុណនាម «អំនួត»។ របៀបផ្សេងទៀតនៃការបកប្រែ:
«រលក់មានអំនួត» ឬ «ចំពោះអំណាចនៃរលករបស់ឯង»
Job 38:12
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើអ្នកធ្លាប់ទេ...នឹងត្រូវរង្គោះរង្គើចេញពីផែនដីមែនទេ?
សំណួរនេះរំពឹងចម្លើយអវិជ្ជមាន។ ឃ្លានេះ អាចបកប្រែជាប្រយោគបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកនឹងមិនត្រូវរង្គោះរង្គើចេញពីផែនដី»
តាំងពីថ្ងៃដែលអ្នកបានកើតមក ហើយបានរៀបចំឲ្យមានពេលព្រឹកបានចាប់ផ្តើម
«តាំងពីថ្ងៃដែលអ្នកបានកើតមក» ឬ «នៅថ្ងៃផ្សេងទៀតដែលអ្នករស់នៅ»
ហើយកំណត់ពេលវេលាពេលព្រឹកមានថ្ងៃរះឡើង ដើម្បីឲ្យដឹងពីកន្លែងរបស់វា
នៅក្នុងគ្រោងការណ៍នៃអ្វីមួយ
ឃ្លាពីរនេះមានន័យប្រហាក់ប្រហែលគ្នា។
តាំងពីថ្ងៃដែលអ្នកបានកើតមក ហើយបានរៀបចំឲ្យមានពេលព្រឹកបានចាប់ផ្តើម
ព្រះអម្ចាស់ពណ៌នាពេលព្រឹកប្រៀបដូចជាបានទទួលសេចក្តីបង្គាប់
ហើដឹងអ្វីៗដូចជាមនុស្សដែរ។
ដើម្បីឲ្យដឹងពីកន្លែងរបស់វា នៅក្នុងគ្រោងការណ៍នៃអ្វីមួយ
«ធ្វើឲ្យព្រឹកព្រលឹមស្គាល់ពីកម្មសិទ្ធិរបស់វា»
ព្រលឹម
ថ្ងៃដែលបានរះឡើងនៅពេលព្រឹក នៅលើមេឃមុនថ្ងៃរះពេញកម្តៅ។
ត្រូវតែកាន់ឲ្យជាប់ជាមួយនឹងម្ខាងនៃផែនដី
ពន្លឺរះឡើង និយាយពីចេញពីជើងមេឃ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ត្រូវតែកាន់ឲ្យជាប់ចុងបំផុតនៃផែនដី»
ដូច្នេះហើយ
ពាក្យ «វា» សំដៅលើព្រឹកព្រលឹម។
ត្រូវតែកាន់ឲ្យជាប់ជាមួយនឹងម្ខាងនៃផែនដី
ពន្លឺរះឡើង និយាយពីចេញពីជើងមេឃ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ត្រូវតែកាន់ឲ្យជាប់ចុងបំផុតនៃផែនដី»
ដូច្នេះ ពួកមនុស្សអាក្រក់នឹងត្រូវរង្គោះរង្គើចេញពីផែនដីមែនទេ?
ពន្លឺថ្ងៃគឺជារូបភាពដែលធ្វើឲ្យមនុស្សចាកចេញដូចជាអង្រួនអ្វីមួយ
ដើម្បីយកចេញអ្វីដែលមិនចង់បាន។ ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «អង្រួនមនុស្សអាក្រក់ចេញពីផែនដី»
Job 38:14
ផែនដីគឺត្រូវផ្លាស់ប្តូររូបរាង ដូចជាដីឥដ្ឋបានផ្លាស់ប្តូរនៅក្រោមត្រាដែរ
នៅពេលយប់ មនុស្សមិនអាចមើលឃើញច្បាស់ ប៉ុន្តែ
ពន្លឺពេលព្រឹកបានបើកសម្តែងពីភាពខុសគ្នានៃអ្វីៗទាំងអស់

generated on Wed Sep 10 16:16:32 2025

ប្រៀបដូចជាត្រាធ្វើខុសពីដីឥដ្ឋ។
ហើយគ្រប់យ៉ាងនៅលើផែនដីបានបង្ហាញយ៉ាងច្បាស់ដូចជាចំណែកតូចនៃសម្លៀកបំពាក់ដែរ
ពាក្យ «វា» សំដៅលើលផែនដី។
ឃ្លានេះមានន័យប្រហាក់ប្រហែលឃ្លានៅក្នុងខដំបូង។
មនុស្សអាក្រក់ «ពន្លឺ» របស់ពួកគេគឺត្រូវយកចេញ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលព្រឹកបានដក «ពន្លឺ» ចេញមនុស្សអាក្រក់»
«ពន្លឺ» របស់ពួកគេ
មនុស្សអាក្រក់គិងថា សេចក្តីងងឹតគឺជាពន្លឺរបស់ពួកគេ
ព្រោះអំពើអាក្រក់របស់ពួកគេនៅក្នុងសេចក្តីងងឹត
ហើយពួកគេចូលចិត្តសេចក្តីងងឹត។
ដៃពួកគេដែលលើកឡើងបានត្រូវបាក់វិញ
បានលើកដៃរបស់មនុស្សអាក្រក់ឡើង តំណាងឲ្យអំណាច
និងបំណងចិត្តនៃការធ្វើការអាក្រក់ នៅពេលពន្លឺពេលព្រឹករះឡើង។
Job 38:16
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ព័ត៌មានទូទៅ
ខ ១៦ និង ១៧ ឃ្លាពីរដែលមានន័យប្រហែលគ្នា។
តើអ្នកបានទៅដល់...នៅបាតនៃសមុទ្រទេ?
សំណួរនេះ រំពឹងចម្លើយអវិជ្ជមាន។ ពួកគេអាចបង្ហាញជាប្រយោគ។
របៀបផ្សេងទៀតនៃការបកប្រែ:«អ្នកមិនអាចទៅដល់ប្រភពរបស់ទឹកសមុទ្រ
ឬដើរទៅក្នុងបាតសមុទ្របានទេ។ ទ្វារនៃសេចក្តីស្លាប់
មិនបានបើកសម្តែងដល់អ្នកទេ
ហើយអ្នកមិនអាចឃើញទ្វារនៃសេចក្តីស្លាប់បានឡើយ។
អ្នកមិនអាចយល់ពីទំហំរបស់ផែនដីបានទេ»
ដល់ទីជម្រៅនៃទឹក
«ប្រភពទឹក»
ជម្រៅ
សំដៅលើសមុទ្រ ឬមហាសមុទ្រ ដែលមានទឹកជ្រៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «ជម្រៅសមុទ្រ» ឬ «ជម្រៅមហាសមុទ្រ» ឬ
«ជម្រៅទឹក»
ទ្វារនៃស្ថានឃុំមនុស្សស្លាប់បានបង្ហាញដល់អ្នក
សេចក្តីស្លាប់និយាយប្រៀបដូចជាទ្វារក្រុង ដែលមនុស្សអាចចូលទៅក្នុងនោះបាន។
ឃ្លានេះ អាចនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើមាននរណាបានបង្ហាញទ្វារនៃសេចក្តីស្លាប់ដល់អ្នកដែរឬទេ?»
ម្លប់សេចក្តីស្លាប់
សូមបកប្រែពាក្យនេះ ឲ្យដូចនៅក្នុងជំពូក ៣:៤។
ទំហំនៃផែនដី
«ជាកន្លែងដ៏ធំលូលាយនៃផែនដី»
សូមប្រាប់យើង ប្រសិនបើអ្នកដឹងការទាំងអស់
ប្រសិនបើអ្នកដឹងការទាំងអស់»
Job 38:19
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ព័ត៌មានទូទៅ
ខនីមួយៗរបស់ឃ្លាពីរនេះជាពាក្យប្រៀបធៀប។
តើផ្លូវឆ្ពោះទៅកន្លែងសម្រាក់នៃពន្លឺនៅទីណា ហើយតើសេចក្តីងងឹតនៅកន្លែងទីណាទៅ?
សំណួរនេះ អាចបង្ហាញពីប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនបានដឹងវិធីសម្រាកនៅកន្លែងនៃពន្លឺ ឬកន្លែងនៃសេចក្តីងងឹត»
ពន្លឺ
«ពេលថ្ងៃ» ឬ «ពន្លឺព្រះអាទិត្យ»
តើអ្នកអាចដឹកនាំពន្លឺហើយនិងភាពងងឹត ទៅកាន់កន្លែងរបស់ពួកវា ដើម្បីឲ្យធ្វើការបានទេ?
តើអ្នកអាចស្គាល់ផ្លូវត្រឡប់ទៅផ្ទះរបស់វាសម្រាប់ពួកវាបានទេ?
សំណួរនេះ រំពឹងចម្លើយអវិជ្ជមាន។ ពួកគេអាចបញ្ជាក់ជាប្រយោគបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនអាចនាំពន្លឺ
ហើយភាពងងឹតទៅកន្លែងធ្វើការ ឬ ស្វែងរកវិធីត្រឡប់ទៅផ្ទះ សម្រាប់ពួកគេ»។
ទៅកាន់កន្លែងធ្វើការរបស់ពួកគេ
«ទឹកដីរបស់ពួកគេ»។ ពន្លឺ និងសេចក្តីងងឹត និយាយដូចជានាំទៅសេចក្តីងងឹត
និងត្រឡប់ទៅថ្ងៃដើម្បីសម្រេចតាមព្រះហឫទ័យរបស់ព្រះអម្ចាស់។
មិនត្រូវឆ្ងល់ទេអ្នកគួរដឹង
ព្រះអម្ចាស់ប្រើការចំអក ដើម្បីបញ្ជាក់ថាលោកយ៉ូបមិនយល់ពីពន្លឺ និងងងឹត។
របៀបផ្សេងទៀតនៃការបកប្រែ: «វាប្រាកដណាស់ថា អ្នកមិនដឹង
ដោយសារអ្នកមិនបានកើតមក នៅពេលយើងបង្កើតពួកគេទេ
ហើយអ្នកក៏មិនមានអាយុច្រើនដែរ»
ដ្បិត អ្នកបានកើតមក
«ដ្បិត អ្នកបានកើតមកហើយ»។ ពាក្យ «បន្ទាប់មក» សំដៅលើពេលវេលា
ដែលពន្លឺត្រូវបានបង្កើតមក ញែកចេញពីងងឹត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដ្បិត អ្នកបានកើតមករួចហើយ ពេលយើងបង្កើតពួកវា»។
ថ្ងៃនៃអាយុរបស់អ្នកក៏វែងដែរ
«អ្នកក៏រស់នៅបានយូរឆ្នាំដែរ»
Job 38:22
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើអ្នកធ្លាប់បានចូលទៅក្នុងឃ្លាំងដែលដាក់ព្រិលទេ
ឬតើអ្នកធ្លាប់បានឃើញឃ្លាំងនៃព្រិលគ្រាប់ទេ...ហើយសម្រាប់ថ្ងៃនៃចម្បាំងហើយសង្គ្រាម?
សំណួរនេះ រំពឹងចម្លើយអវិជ្ជមាន។ ពួកគេអាចបញ្ជាក់ជាប្រយោគបាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចចូលទៅក្នុងឃ្លាំងដែលដាក់ព្រិលនោះទេ ឬ
ឃើញឃ្លាំងសម្រាប់ដុំទឹកកក...និងសង្គ្រាមឡើយ។
ព្រិល ទឹកកក
ទឹកកកដុំៗ (ជាទូទៅតូចៗ) ដែលពេលខ្លះវាធ្លាក់ចុះមកពីលើមេឃពេលភ្លៀង។
តើអ្វីទៅដែលជាផ្លូវទៅកន្លែងផ្លេកបន្ទោរបូល ហើយចូលរួម ឬទៅតាមខ្យល់ដែលបក់ពីទិសខាង
កើតទៅទិសខាងជើងឬ?
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើអ្វីទៅជាផ្លូវទៅកាន់កន្លែងដែលយើងនឹងចែកចាយផ្លេកបន្ទោលទៅ ឬ
ចែកចាយខ្យល់ពីកើតទៅនៅលើផែនដី?»
ខ្យល់ដែលបក់
«ខ្យល់បក់»
Job 38:25
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ព័ត៌មានទូទៅ
ព្រះអម្ចាស់បានសួរសំណួរលោកយ៉ូប ដើម្បីបញ្ជាក់ថា ព្រះអង្គធំជាងលោកយ៉ូប
ព្រះអម្ចាស់បានធ្វើឲ្យមានភ្លៀង និងផ្គរ ហើយលោកយ៉ូបមិនអាចទេ។
តើអ្នកណាបានបង្កើតផ្លូវទឹក សម្រាប់ពេលមានទឹកភ្លៀងជន់ឡើង...និងធ្វើឲ្យមានតិណជាតិដុះ
ឡើងវិញ?
ឃ្លានេះ និយាជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «មានតែយើងទេ
ដែលបង្កើតប្រឡាយសម្រាប់ទឹកហូរ ហើយមានតែយើងទេ ដែលបង្កើត...ឲ្យមាន
តិណជាតិដុះឡើង»។
ទឹកភ្លៀងជន់
«ទឹកភ្លៀងហូរ»
ផ្លូវនិងទឹកន្លែងដែលផ្ទុះនៃផ្គរលាន់
«ផ្លូវសម្រាប់ផ្គរដែលមានផ្លេកបន្ទោល»។ អាចមានន័យ ទី១)
ព្រះអម្ចាស់បានសម្រេចពីការដែលផ្លេកបន្ទោលត្រូវបាញ់ ឬទី២)
ព្រះអង្គបានសម្រេច សម្លេងផ្គរលាន់គួរទៅណា។
មកលើផែនដី ដែលជាកន្លែងគ្មានមនុស្សរស់នៅ ហើយនៅលើវាលរហោស្ថាន
ដែលអត់មានមនុស្សសូម្បីមួយនាក់
ឃ្លាពីរនេះ មានន័យស្ទើរតែដូចគ្នា។
ដែលជាកន្លែងគ្មានមនុស្សរស់នៅ
«ដែលជាកន្លែងគ្មានមនុស្ស»
រឹងសួតនិង បែកក្រហែង
«ដីចោលទទេ ហើយហួតហែង»។ ពាក្យពីរនេះ មានន័យស្ទើរតែដូចគ្នា
ដើម្បីបញ្ជាក់ពីដីចោលទទេ ហើយហួតហែង នៅក្នុងតំបន់នោះ។
មានតិណជាតិដុះ
«មានស្មៅថ្មីដុះឡើង» ឬ «ស្មៅស្រស់»
ដុះឡើង
«ចាប់ផ្តើមដុះឡើង»

generated on Wed Sep 10 16:16:32 2025

Job 38:28
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើនរណាបានផ្តល់កំណើតឲ្យដំណក់ទឹកសន្សើម?
ព្រះអម្ចាស់ប្រើសំណួរទាំងនេះ ដើម្បីបញ្ជាក់ថា
លោកយ៉ូបមិនបានយល់ពីការដែលព្រះអម្ចាស់បង្កើតទឹកភ្លៀង ទឹកសន្សើម ទឹកកក
និងផ្កាព្រិល។
តើនរណាបានផ្តល់កំណើតឲ្យដំណក់ទឹកសន្សើម?
ព្រះអម្ចាស់ពណ៌នាពីភ្លៀង ប្រៀបដូចជាមនុស្សម្នាក់។
បានផ្តល់កំណើតឲ្យ
តួរនាទីដែលឪពុកមាន គឺធ្វើឲ្យកូនបានកើតឡើង។
ដំណក់ទឹកសន្សើម
ដំណក់ទឹកសន្សើម បានកើតមកពីការបង្រួបបង្រួមរបស់រុក្ខជាតិ
និងរបស់ផ្សេងទៀត។
តើនរណាជាម្តាយរបស់ទឹកកកនោះ?
«តើនរណាផ្តល់កំណើតទឹកកក»
ផ្ទៃទឹកទាំងឡាយបានលាក់បាំងពួកវា
នៅអំឡុងរដូវរងារទឹកនៅក្រោមទឹកកក។
ទឹកជ្រៅ
សំដៅលើទឹកជ្រៅ ដូចជាបឹង ទន្លេ និងមហាសមុទ្រជាដើម។
Job 38:31
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើអ្នកអាចយកច្រវាក់ចង...គ្រប់គ្រងផែនដីបានឬទេ?
ព្រះអម្ចាស់ប្រើសំណួរទាំងនេះ ដើម្បីបញ្ជាក់ថា
លោកយ៉ូបមិនដឹងពីរបៀបគ្រប់គ្រងផ្កាយផ្សេងៗទេ។
យកច្រវាក់ចង
«ចងច្រវាក់» ឬ «ចងចំណង»
ផ្កាយបណ្តើរកូន...ផ្កាយនង្គ័ល...ក្រុមផ្កាយ
ទាំងនេះគឺជាឈ្មោះរបស់ផ្កាយ។ សូមមើលក្នុងជំពូក ៩:៧។
អាចស្រាយខ្សែផ្កាយនង្គ័លបានដែរឬ?
«ផ្តាច់ខ្សែដែលចង់ផ្កាយនង្គ័លបាន»
កញ្ចុំផ្កាយ
ឃ្លានេះ សំដៅលើ កញ្ចុំផ្កាយដប់ពីរដែលលេចមកក្រោយពីថ្ងៃលិច។ មាន
កញ្ចុំផ្កាយផ្សេងៗដែលលេចមកនៅក្រោយថ្ងៃរះរាល់ខែ។
ដែលលេចចេញមកតាមពេលកំណត់របស់វា
«នៅពេលពួកគេលេចមកនៅពេលកំណត់»
កូនៗរបស់វា
«កូនៗរបស់ផ្កាយនោះ»
Job 38:34
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើអ្នកអាច...យើងនៅទីនេះ
ព្រះអម្ចាស់ប្រើសំណួរទាំងនេះ ដើម្បីបញ្ជាក់ថា
លោកយ៉ូបមិនដឹងពីរបៀបគ្រប់គ្រងផ្កាយផ្សេងៗទេ។
ដូច្នេះហើយមេឃនឹងធ្លាក់ភ្លៀងយ៉ាងច្រើនមកដណ្តប់លើអ្នក?
«មានទឹកភ្លៀងយ៉ាងច្រើនមកដណ្តប់លើអ្នក»
តើអ្នកអាចបញ្ជាផ្លេកបន្ទោរឲ្យបញ្ចេញពន្លឺរស្មី ហើយផ្លេកបន្ទោរធ្វើតាម
«តើអ្នកអាចបង្គាប់ផ្លេកបន្ទោរ ឲ្យទៅណាបានដូចអ្នកចង់ឲ្យវាទៅ
ហើយពួកវាទៅតាមឬអត់»
នឹងនិយាយទៅអ្នកថា
«ពួកគេនឹងនិយាយទៅអ្នក»
យើងនៅទីនេះ
ឃ្លានេះ មានន័យថា «យើងនៅទីនេះ ដើម្បីអ្នកអាចប្រាប់យើងថា
តើអ្នកចង់ឲ្យយើងធ្វើអ្វី»។
Job 38:36
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើនរណាបានដាក់ប្រាជ្ញា...ចងយ៉ាងតឹងរឹងជាមួយគ្នាឬ?
ព្រះអម្ចាស់ប្រើសំណួរទាំងនេះ ដើម្បីបញ្ជាក់ថា
លោកយ៉ូបមិនដឹងពីរបៀបគ្រប់គ្រងផ្កាយផ្សេងៗទេ។
បានដាក់ប្រាជ្ញានៅលើពពក
«បានប្រគល់ប្រាជ្ញាទៅលើពពក» ព្រះអម្ចាស់ពណ៌នាពីពពក ប្រៀបដូចជាមនុស្ស
ហើយប្រគល់ប្រាជ្ញាដល់ពួកគេ ដើម្បីពួកគេដឹងថាត្រូវធ្វើអ្វី។
តើនរណាអាចមានជំនាញការរាប់ដុំពពកបានទេ?
ឃ្លានេះ មានន័យថា «តើអ្នកណាមានប្រាជ្ញាអាចរាប់ពពកនៅលើមេឃបាន»។
ទឹកចង់ស្បែក
ស្បែកដែលមនុស្សដេរ ដើម្បីពួកគេអាចយកទៅដាក់ទឹកបាន។
ព្រះអម្ចាស់សំដៅលើពពកយ៉ាងក្រាស់ ដូចជា «ចង់ស្បែក»
ដោយសារវាបានផ្ទុកទឹកជាច្រើនដូចស្បែកដាក់ទឹកដែរ។
នៅពេលដីបានរត់ទៅក្នុងការលំបាក
«នៅពេលដីធុំគ្នាទៅជាដីមួយដុំ»។ ភ្លៀងធ្វើបានច្រោះដីដែលធុំគ្នា ដូចជាដីមួយដុំ។
ហើយពពកនៃផែនដីបានចងយ៉ាងតឹងរឹងជាមួយគ្នា
«កំណាត់របស់ដីស្អិតជាប់គ្នា»
Job 38:39
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើអ្នកអាចបរបាញ់សត្វ...ដើម្បីក្រាបក្នុងការរង់ចាំ
ព្រះអម្ចាស់ប្រើសំណួរនេះ ដើម្បីបញ្ជាក់ថា ព្រះអង្គអាចចម្អែតសត្វតោ ប៉ុន្តែ
លោកយ៉ូបមិនដឹងទេ។
ជាអាហារ
«បរបាញ់សត្វ»។ នេះគឺជាសត្វដែលសត្វតោត្រូវស៊ី។
កូនសិង្ហ
«ជាសត្វតោ»
ឬផ្គត់ផ្គង់អាហារគ្រប់គ្រាន់ដល់កូនសិង្ហឲ្យបានឆ្អែត
«ឬផ្គត់ផ្គង់អាហារគ្រប់គ្រាន់ដល់កូនសិង្ហឲ្យបានឆ្អែត ដើម្បីឲ្យវារស់បាន»
ដល់កូនសិង្ហឲ្យបានឆ្អែត
«ដល់កូនតោ»។ គឺជាកូនតោដែលធំល្មមអាចរកចាប់រំពារដោយខ្លួនឯង។
នៅក្នុងរូងរបស់វា
«នៅកន្លែងដែលពួកវារស់នៅ» ឬ «នៅក្នុងដែលវារស់នៅ»
ហើយសំងំក្នុងការលាក់ខ្លួន
«កន្លែងដែលមានរុក្ខជាតិដុំយ៉ាងត្រុបត្រុល»។
ក្រាបក្នុងការរង់ចាំ
«ជាកន្លែងដែលពួកវាលាក់ខ្លួន» ឬ
«ជាកន្លែងដែលពួកវាអាចចាប់សត្វផ្សេងទៀតបាន»។
សត្វតោលាក់ខ្លួននៅក្នុងព្រៃត្រុបត្រុល ហើយរង់ចាំចាប់សត្វដែលឆ្លងកាត់ទីនោះ
ហើយវានឹងលោតចេញពីកន្លែងនោះ ហើយចាប់សត្វទាំងនោះ។
Job 38:41
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើនរណាជាអ្នកផ្តល់ចំណីឲ្យ
ព្រះអម្ចាស់ប្រើសំណួរនេះ ដើម្បីបញ្ជាក់ថា ព្រះអង្គបានផ្តល់អាហារឲ្យសត្វក្អែក
ប៉ុន្តែ លោកយ៉ូបអត់ទេ។
ស្រែកហៅព្រះជាម្ចាស់
«ស្រែករកព្រះជាម្ចាស់ឲ្យជួយ» ឬ «ស្រែករកព្រះឲ្យសង្គ្រោះពួកគេ»
ហើរចុះហើរឡើង
«ហើរវិលទៅវិលមក»
ព្រោះអត់អាហារ?
«ដោយសារ ពួកវាអត់អាហារ» ឬ «ដោយសារពួកគេគ្មាន

---

39 [1]តើអ្នកដឹងទេថាវេលាណាដែលពពែព្រៃ នៅភ្នំថ្មសម្រាលកូន? តើអ្នកចំណាំបានពេលដែលក្តាន់ញីទម្លាក់កូនឬទេ?[2]តើអ្នកអាចកំណត់ដឹងថាវាត្រូវមានទម្ងន់ប៉ុន្មាន
ខែបានទេ? តើអ្នកអាចដឹង ពេលដែលសត្វទាំងនោះនឹងកើតកូនមកឬទេ?

generated on Wed Sep 10 16:16:32 2025

[3]ពួកវាបានក្រាបចុះ រួចហើយបង្កើតកូនចេញមក ហើយក្រោយមក ក៏បញ្ចាប់ការឈឺចាប់។[4]កូនរបស់វាក៏មានកម្លាំងមាំមួន ហើយចម្រើនធំឡើងនៅតាមទីវាល ហើយពួកវាចាកចេញពីមេវាទៅ ឥតវិលត្រឡប់មកវិញឡើយ។
[5]តើនរណាផ្តល់សេរីភាពឲ្យដល់សត្វលាព្រៃ? តើអ្នកណាបានស្រាយចំណងរឲ្យវា[6]យើងបានឲ្យវារស់នៅតាមព្រៃល្បោះ ហើយជម្រករបស់ពួកវាគឺកន្លែងដីដែលមានជាតិប្រៃ?
[7]វាមិនដែលស្គាល់ទីក្រុងដ៏អ៊ូអរ ហើយក៏មិនដែលឮសំឡេងម្ចាស់ណា ស្រែកដាក់វាដែរ។[8]ពយកវារកចំណីនៅតាមដងភ្នំជាវាលរបស់វា នៅទីនោះវាស្វែងរកស្លឹកឈើខៀវខ្ចីមកធ្វើជាចំណី។
[9]តើគោព្រៃចូលចិត្តធ្វើការបម្រើអ្នក ហើយចង់ដេកនៅក្នុងក្រោលគោរបស់អ្នកឬទេ?[10]ជាមួយនិងរំពាត់ តើអ្នកអាចយកខ្សែមកចងគោព្រៃ បង្ខំវាឲ្យភ្ជួរស្រែបានឬទេ? តើវាសុខចិត្តអូសរនាស់ឲ្យអ្នកនៅតាមជ្រលងភ្នំឬទេ?
[11]តើអ្នកអាចទុកចិត្តវា ព្រោះតែវាមានកម្លាំងដ៏ខ្លាំងក្លាឬ? តើអ្នកនឹងទុការអាររបស់អ្នកឲ្យពួកវាធ្វើបានទេ?[12]តើអ្នកអាចទុកចិត្តវាឲ្យដឹកស្រូវ យកទៅលានបោកបែន ហើយនាំភោគផលទៅដាក់ជង្រុកបានឬទេ?
[13]សត្វអូទ្រីស ទទេះស្លាបយ៉ាងមានអំនួត ក៏ប៉ុន្តែ ពួកវាទាំងពីរក៏បានហើរទៅរកគូរស្នេហ៍របស់វា?[14]ដ្បិតវាពងចោលនៅលើដី ហើយបង្កប់ពងនោះឲ្យក្តៅនៅក្នុងដី[15]ដោយពួកវាមិននឹកស្មានថា គេអាចដើរពីលើ ឬមានសត្វព្រៃមកជាន់កម្ទេចឡើយ។
[16]វាតឹងតែងជាមួយកូនរបស់វា ធ្វើហាក់បីដូចជាមិនមែនកូនទាំងនោះមិនមែនរបស់វា។ វាខំប្រឹងពង ទោះបីមិនបានការ ក៏វាមិនខ្វល់ខ្វាយអ្វីដែរ[17]ដ្បិតព្រះជាម្ចាស់បានធ្វើឲ្យវាខ្វះប្រាជ្ញា ហើយគ្មានក៏គ្មានប្រាជ្ញាដែរ។[18]ប៉ុន្តែ ពេលវាក្រោកឡើង រត់បោះពួយទៅមុខ វាសើចមើលងាយសត្វសេះ និងអ្នកជិះសេះនោះផង។
[19]តើអ្នកឬដែលផ្តល់កម្លាំងឲ្យដល់សេះ? តើអ្នកឬដែលធ្វើឲ្យមានក្រណាត់ដែលដាក់នៅនឹងក ហើយសរសេរឈ្មោះរបស់វាដែរនោះ?[20]តើអ្នកឬដែលធ្វើឲ្យវាចេះលោតដូចកណ្តូប? សម្រែករបស់វាគឺដូចញាប់ញ័រណាស់។
[21]វាបោលនៅតាមជ្រលងភ្នំ ហើយបញ្ចេញកម្លាំង សម្រុកទៅរកសមរភូមិ។[22]វាមិនចេះភ័យខ្លាច ឬតក់ស្លុតហើយមិនរាថយនៅចំពោះមុខដាវនោះដែរ។[23]សំឡេងបំពង់ព្រួញ សន្ធឹកលំពែង ហើយនិងស្នួ បានលាន់ឮនៅលើខ្លួនវាដែរ។
[24]វាលោត វាកញ្ជ្រោល វាបោះពួយទៅមុខ ហើយពេលឮគេផ្លុំស្នែងវាពុំអាចនៅស្ងៀមមួយកន្លែងបានទេ។[25]កាលណាឮគេផ្លុំស្នែង វាស្រែកឡើងដោយសប្បាយរីករាយ វាស្រង់ក្លិនចម្បាំងពីចម្ងាយ ហើយក៏ស្គាល់សំឡេងរបស់មេទ័ព និងសម្រែកប្រកាសពីការធ្វើសឹកដែរ។
[26]តើសត្វប្រមង់សំកាំងស្លាប តម្រង់ទៅទិសខាងត្បូង ដើម្បីឲ្យរោមស្លាបដុះឡើងសាជាថ្មី ដោយសារគំនិតយោបល់របស់អ្នកឬ?
[27]តើសត្វឥន្ទ្រីហើរឡើងទៅលើ ហើយដាក់កូនរបស់វានៅតាមទីខ្ពស់ៗ តាមបញ្ជារបស់អ្នកឬ?[28]វាស្នាក់នៅតាមថ្ម វាយកក្រហែងថ្មនៅតាមកំពូលភ្នំដ៏ខ្ពស់ៗ ធ្វើជាកំពែងការពារខ្លួន។
[29]ពីទីដ៏ខ្ពស់នោះ វាសម្លឹងចាំចាប់រំពាធ្វើជាអាហារ វាអាចមើលឃើញពីចម្ងាយ។[30]កូនរបស់វាជញ្ជក់ឈាម ទីណាមានសាកសព វាស្ថិតនៅទីនោះ»។

Job 39:1
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រើបួនសំណួរដើម្បីបញ្ជាក់ថា ព្រះអង្គធំជាងលោកយ៉ូប ព្រោះព្រះអម្ចាស់យកព្រះទ័យទុកដាក់នឹងព្រៃភ្នំ ពពែ និងសត្វក្តាន់ ប៉ុន្តែលោកយ៉ូបអត់ទេ។
តើអ្នកបានដឹងនៅវេលាណាដែលពពែព្រៃ...បានបង្កើតកូននោះ?
ឃ្លានេះអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាកដណា អ្នកមិនដឹងថា ពេលណា...បានបង្កើតកូននោះ!»
តើអ្នកអាចនៅចាំមើលពេលដែលសត្វក្តាន់បានបង្កើតកូនរបស់វាឬទេ?
ឃ្លានេះអាចបកប្រែជាប្រយោគមួយបាន។
របៀបផ្សេងទៀតនៃការបកប្រែ:«អ្នកមិនអាចមើលថែ ដើម្បីឲ្យប្រាកដថាគ្រប់យ៉ាងដំណើរការល្អ នៅពេលសត្វក្តាន់បង្កើតកូនរបស់ពួកវា!»
បានបង្កើតកូនរបស់វា
«បានបង្កើតកូនរបស់វា»
តើអ្នកអាចកំណត់ដឹងថាវាត្រូវមានទម្ងន់ប៉ុន្មានខែបានទេ?
ឃ្លានេះអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនអាចរាប់ខែដែលពួកវាមានកូនទេ»។
តើអ្នកអាចដឹងថា ពេលណាដែលសត្វទាំងនោះនឹងកើតកូនមកដែរឬទេ?
ឃ្លានេះអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ពិតណាស់ អ្នកមិនដឹងថា ពេលណាពួកវាបង្កើតកូនរបស់វាឡើយ»
ថាវាត្រូវមានទម្ងន់
«ដល់ពេលកើតនោះទេ»
ពួកវា
ពាក្យ «ពួកវា» សំដៅលើ សត្វពពែ និងក្តាន់។
មានទម្ងន់
«ផើម»
តើអ្នកអាចដឹងថា ពេលណាដែលសត្វទាំងនោះនឹងកើតកូនមកដែរឬទេ?
ឃ្លានេះអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ពិតណាស់ អ្នកមិនដឹងថា ពេលណាពួកវាបង្កើតកូនរបស់វាឡើយ»
Job 39:3
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ពួកវាបានក្រាបចុះ
ពាក្យ «ពួកវា» សំដៅលើ សត្វពពែ និងក្តាន់។
បង្កើតកូនរបស់វាចេញមក
«បង្កើតកូនចៅរបស់ពួកវា»
ក្រោយមកពួកវាបានបញ្ចាប់ការបង្កើតដ៏ឈឺចាប់
អាចមានន័យពីរ។ ទី១) ការឈឺចាប់នៃការបង្កើតកូនរបស់ពួកវាត្រូវបានបញ្ចប់បន្ទាប់ពីបង្កើតកូនហើយ ឬទី២) «បង្កើតកូនដោយការឈឺចាប់»
គឺជាពាក្យប្រៀបធៀប ដែលសំដៅលើកូនចៅរបស់ពពែ និងក្តាន់ដោយសារពួកវាបានកើតមកដោយសារតែមេវាបង្កើតពួកវាមកដោយឈឺចាប់។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានបង្កើតកូនរបស់ពួកវាចេញពីពោះរបស់ពួកវា»
នៅតាមទីវាល
«នៅតាមជនបទ» ឬ «នៅតាមព្រៃ»
មិនវិលត្រឡប់មកវិញឡើយ
«មិនវិលត្រឡប់មករកពួកគេវិញទេ» ឬ «ត្រឡប់មករកម្តាយរបស់ពួកគេវិញ»
Job 39:5
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើនរណាបាន...កន្លែងដីដែលមានជាតិប្រៃ
ព្រះអម្ចាស់ប្រើបួនសំណួរដើម្បីបញ្ជាក់ថា ព្រះអង្គធំជាងលោកយ៉ូប ព្រោះព្រះអម្ចាស់យកព្រះទ័យទុកដាក់នឹងព្រៃភ្នំ ពែ និងសត្វក្តាន់ ប៉ុន្តែលោកយ៉ូបអត់ទេ។
តើនរណាបានដោះឲ្យមានសេរីភាពដល់សត្វលាព្រៃ?
ឃ្លានេះអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងគឺជាអ្នកដែលអនុញ្ញាតឲ្យលាព្រៃមានសេរីភាព»។
សត្វលាព្រៃ...សត្វលា
ឈ្មោះខុសគ្នាសម្រាប់ប្រភេទលាតែមួយ។
តើនរណាបានចងចំណងដល់សត្វលាក៏លឿននោះ
ឃ្លានេះអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងជាអ្នកស្រាយចំណង...កន្លែងដីដែលមានជាតិប្រៃ»។
ចំណង
ខ្សែ ច្រវាក់ ឬអន្ទាក់ដែលចងសត្វ និងការពារវាកុំវារត់បាត់។
តើផ្ទះអ្នកណាដែលយើងបានសាងនៅក្នុងអារ៉ាប់
ព្រះអម្ចាស់ពណ៌នាពីសត្វលា ប្រៀបដូចជាមនុស្សដែលអាចមានផ្ទះ។

generated on Wed Sep 10 16:16:32 2025

«យើងបានឲ្យអារ៉ាបដល់វា ទុកជាកន្លែងសម្រាប់រស់នៅ»
កន្លែងដីដែលមានជាតិប្រៃ
ជាទឹកដីនៅជុំវិញសមុទ្រស្លាប់ ដែលមានអំបិលជាច្រើននៅក្នុងនោះ។
Job 39:7
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
វា
ពាក្យ «វា» សំដៅលើលាព្រៃ។
សើចជាមួយនឹងការមើលងាយ
ព្រះអម្ចាស់ពណ៌នាពីសត្វលា ប្រៀបដូចជាវាជាមនុស្ស។ សត្វលាសើច
ដោយសារអ្នកនៅក្នុងទីក្រុងនោះបានឮសម្លេងយ៉ាងខ្លាំង ប៉ុន្តែ
វារស់នៅកន្លែងដែលស្ងៀមស្ងាត់។
អ្នកបរ
មនុស្សម្នាក់ដែលបង្ខំសត្វនោះឲ្យធ្វើការ
វាលស្មៅ
កន្លែងដែលសត្វនោះអាចស៊ីស្មៅដែលដុះនៅតាមវាល។
Job 39:9
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ព័ត៌មានទូទៅ
នៅទីនេះ ព្រះអម្ចាស់ប្រើសំណួរបួន ដើម្បីបញ្ជាក់ថា
លោកយ៉ូបមិនចូលចិត្តព្រះអម្ចាស់
ដោយសារលោកយ៉ូបមិនអាចគ្រប់គ្រងគោព្រៃបាន។
តើគោព្រៃចូលចិត្តធ្វើការបម្រើអ្នកដែលឬទេ?
សំណួរនេះ អាចបកប្រែជាប្រយោគមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គោព្រៃមិនសប្បាយចិត្តនឹងបម្រើអ្នកទេ»។
គោព្រៃ
អាចមានន័យពីរ។ ទី១) ជាគោមួយប្រភេទដែលរស់នៅក្នុងព្រៃ។ ឬទី២)
ជាក្របីដែលមើលទៅដូចជាគោឈ្មោល។
ចូលចិត្ត
«ព្រម»
តើវាយល់ព្រមនៅក្នុងការគ្រប់គ្រងរបស់អ្នកដែរឬទេ?
សំណួរនេះ អាចបកប្រែជាប្រយោគមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាមិនព្រមនៅក្រោមការគ្រប់គ្រងរបស់អ្នកទេ»
យល់ព្រមនៅក្នុងការគ្រប់គ្រងរបស់អ្នក
«ព្រមនៅក្រោមការគ្រប់គ្រងរបស់អ្នកពេញមួយថ្ងៃ»
ទ្រុងស្មៅ
ជាវត្ថុមួយសម្រាប់ដាក់ស្មៅ ដើម្បីឲ្យសត្វអាចស៊ីបាន។
ជាមួយនិងរំពាត់ តើអ្នកអាចយកខ្សែមកចងគោព្រៃ បង្ខំវាឲ្យភ្ជួរស្រែបានឬទេ?
សំណួរនេះ អាចបកប្រែជាប្រយោគមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចគ្រប់គ្រងគោរព្រៃ ជាមួយខ្សែ ដើម្បីចងគោព្រៃ បង្ខំវាឲ្យភ្ជួរនៅក្នុងស្រែ
របស់អ្នកបាន»។
យកខ្សែ
យកខ្សែមួយមកចង ក្បាល ឬកសត្វនោះ ដើម្បីដឹកវា
គន្លង
ជាផ្លូវមួយដ៏វែងនៅក្នុងដីដែលកំពុងភ្ជួរ។ សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៣១:៣៨
តើវាសុខចិត្តអូសរនាស់សម្រាប់អ្នកនៅជួរភ្នំដែរឬទេ?
នេះជាសំណួរអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «
វានឹងមិនព្រមអូសរនាស់សម្រាប់អ្នកនៅជួរភ្នំទេ»
រនាស់
ធ្វើឲ្យដីតូច និងបំបែកដីឲ្យល្អិត។
Job 39:11
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ព័ត៌មានទូទៅ
នៅត្រង់នេះ ព្រះអម្ចាស់ប្រើសំណួរបី ដើម្បីឈ្លោះជាមួយលោកយ៉ូប ថា
លោកយ៉ូបមិនចូលចិត្តព្រះអម្ចាស់
ព្រោះលោកយ៉ូបមិនអាចគ្រប់គ្រងគោព្រៃបានទេ។
តើអ្នកអាចទុកចិត្តវា ដោយព្រោះតែវាមានកម្លាំងអស្ចារ្យឬ?
នេះជាសំណួរអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចទុកចិត្តវា ដោយសារវាមានកម្លាំងខ្លាំងក្លាឡើយ»។
ទុកចិត្តវា
ពាក្យ «វា» សំដៅលើ «គោព្រៃ»
តើអ្នកនឹងទុកការងាររបស់អ្នកឲ្យពួកវាធ្វើបានទេ?
នេះជាសំនួរអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចធ្វើឲ្យវាធ្វើការងារឲ្យអ្នកបានទេ»
ទុកការងាររបស់អ្នកឲ្យពួកវាធ្វើបាន
«ឲ្យវាធ្វការយ៉ាងធ្ងន់សម្រាប់អ្នក»
តើអ្នកអាចទុកចិត្តវា...នាំស្រូវរបស់អ្នកទៅដាក់ជង្រុកបានឬទេ?
ឃ្លាពីរនេះ មានន័យដូចគ្នា។ នេះជាសំណួរអាចបកប្រែជាប្រយោគមួយបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនអាចទុកចិត្តលើវាបានទេ...នាំ
ស្រូវរបស់អ្នកទៅដាក់ជង្រុកបាន»
Job 39:13
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ស្លាបរបស់សត្វអូទ្រីស...ស្លាបដ៏វែងហើយពណ៌វាស្អាតគួឲ្យស្នេហ៍?
ព្រះអម្ចាស់ប្រើសំណួរនេះ ដើម្បីបញ្ជាក់ថា
លោកយ៉ូបមិនអាចពន្យល់ពីសត្វអូទ្រីសមានឥរិយាថយ៉ាងដូចម្តេច។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនដឹងទេ ថាស្លាបដ៏វែង និងមានពណ៌សត្វ
អូទ្រីស តំណាងឲ្យសេចក្តីស្រឡាញ់
ពេលស្លាបរបស់ពួកវាហើរឡើងដោយមោទនភាព» (សូមមើល: |Rhetorical
Question)
សត្វអូទ្រីស
ជាសត្វដែលមានស្លាបវែងដេលអាចរត់បានយ៉ាងលឿន ប៉ុន្តែ មិនអាចហើរបានទេ។
ពណ៌វាស្អាតគួឲ្យស្នេហ៍
«ហើរដោយអំណរ»
ស្លាប
មានរោមវែងៗនៅលើស្លាបរបស់សត្វនោះ
ស្លាប
មានរោមខ្លីជារោមដែលគ្របលើរូបកាយរបស់សត្វនោះ
ស្អាតគួឲ្យស្នេហ៍
ភាសាហេព្រើរប្រើពាក្យមិនច្បាស់នៅត្រង់នេះ។ អាចមានន័យពីរ។ ទី១)
«ពីភាពស្មោះត្រង់» ទី២) «ពីក្រសា»។ ឈ្មោះរបស់សត្វក្រសាមានន័យថា
«ជាអ្នកស្មោះត្រង់» ឬ «ជាមនុស្សគួរឲ្យស្រឡាញ់» ព្រោះមនុស្សដឹងថា
សត្វក្រសាយកចិត្តទុកដាក់ជាមួយកូនរបស់វាខ្លាំងណាស់។
នៅក្នុងដី
«នៅលើដី»
ជាន់កម្ទេចពួកវា
ពាក្យ «ពួកវា» សំដៅលើ ពងសត្វទាំងនោះ។
ជាន់បំបែក
«ជាន់លើពួកវា»
Job 39:16
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
វាតឹងតែង
ពាក្យ «វា» សំដៅលើ សត្វអូទ្រីសញី។
ខំប្រឹងធ្វើការ
ការងារដែលវាធ្វើ ពេលវាញាស់ពង
អាចនឹងទៅជាឥតបានការ
ប្រសិនបើកូនវាងាប់អស់ ការងារដែលវាខំនោះបែរជាឥតប្រយោជន៍។
របៀបផ្សេងទៀតនៃការបកប្រែ: «អាចប្រែជាឥតប្រយោជន៍
ប្រសិនបើកូនរបស់វាស្លាប់»
បានដកយកប្រាជ្ញារបស់វាចេញ
«ធ្វើឲ្យវាភ្លេចពីប្រាជ្ញា» ឬ «មិនផ្តល់ប្រាជ្ញាដល់វាឡើយ»
ចំណេះដឹង
សូមបកប្រែឲ្យដូចនៅក្នុងជំពូក ១១:៤
នៅពេលវារត់
ខនេះ ផ្ទុយពីភាពកម្សោយរបស់វា នៃការមើលថែកូនរបស់វា។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ពេលវារត់»
វាសើចចំអកដាក់...អ្នកជិះ
ឃ្លានេះ បញ្ជាក់ថា វាសើច ដោយសារវារត់លឿនជាងសេះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«វាសើចដាក់...អ្នកជិះសេះព្រោះវាអាចរត់លឿនជាងសេះ» ។
Job 39:19
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ព័ត៌មានទូទៅ
ព្រះអម្ចាស់ប្រើបីសំណួរដើម្បីបញ្ជាក់ថា
លោកយ៉ូបមិនងាចគ្រប់គ្រង់សេះព្រៃបានទេ។
តើអ្នកបានផ្តល់កម្លាំងឲ្យទៅសេះឬ?
នេះជាសំណួរអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចផ្តល់កម្លាំងដល់សេះបានទេ»
តើឯងឬ ដែលបានតុបតែងឲ្យសេះមានសក់ដែលរលាស់តាមខ្យល់?
នេះជាសំណួរអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចតុបតែងឲ្យសេះមានសក់ដែលរលាស់តាមខ្យល់បានទេ»
តុបតែងឲ្យសេះមានសក់ដែលរលាស់តាមខ្យល់
«សក់សេះ» និយាយប្រៀបដូចជាសម្លៀកបំពាក់សម្រាប់ករបស់សេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើឲ្យសក់របស់វាលាស់
ដើម្បីគ្របបាំករបស់វាដូជជាសម្លៀកបំពាក់»។
រលាស់តាមខ្យល់
សក់វែងនៅលើករបស់សេះ
តើអ្នកឬដែលធ្វើឲ្យវាចេះលោតដូចជាសត្វកណ្តូប?
នេះជាសំណួរអាចបកប្រែជាប្រយោគមួយបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចធ្វើឲ្យវាលោកត ដូចជាកណ្តូបបានទេ»
កណ្តូប
សត្វកណ្តូបដែលអាចលោតបានឆ្ងាយ ហើយលឿនថែមទៀតផង។
ស្រមុំក
ជាសម្លេងយ៉ាងខ្លាំងដែលសត្វសេះបញ្ចេញពីច្រមុះរបស់វា។
Job 39:21
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
ក្រញាំវាកាយដី
ពាក្យ «វា» សំដៅលើសេះ។ សេះកាយដី ដោយវាភ្ជាក់ផ្អើលជាមួយនឹងការប្រយុទ្ធ។
របៀបផ្សេងទៀតនៃការបកប្រែ: «វាផាយដីដោយភាពភ្ញាក់ផ្អើល»
ក្រញាំ
«កាយដីជាមួយនឹងក្រចងរបស់វា»
ទៅពាក់គ្រឿងសស្ត្រាវុធ
ពាក្យ «គ្រឿងសស្ត្រាវុធ» តំណាងឲ្យការធ្វើសង្គ្រាម ដែលពួកគេត្រូវការប្រើវា។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីចូលរួមធ្វើសង្គ្រាម»
វាមើលងាយសេចក្តីភិតភ័យ
«វាមិនចេះភ័យខ្លាចទាល់តែសោះ»
មើលងាយ
«សើចដាក់»
តក់ស្លុត
«បាក់ទឹកចិត្ត»
មិនរាថយ
«មិនរត់ចោលឡើយ»
បំពង់ព្រួញ
ប្រអប់មួយសម្រាប់ដាក់ព្រួញ។
ឮក្រុកក្រាក់
«អង្រួន ហើយធ្វើឲ្យមានសម្លេង»។
ចំហៀង
នៃផ្នែកម្ខាងរបស់សេះ
ដែកពួយ
ឈើវែងមានមុខមុតស្រួចចុង មនុស្សគប់វាដាក់ខ្មាំងសត្រូវ។
Job 39:24
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
វា
ពាក្យ «វា» សំដៅលើសេះ។
កញ្ជ្រោលនៅលើដី
សេះរត់នៅលើដី យ៉ាងលឿនដែលហុយដីដូចជាមនុស្សទឹកដែលមនុស្សធឹក។
របៀបផ្សេងទៀតនៃការបកប្រែ: «រត់យ៉ាងលឿននៅលើដី»
វាលោត វាកញ្ជ្រោល
សេះភ្ញាក់ផ្អើល ដូច្នេះ វារត់យ៉ាងលឿន ហើយដោយកម្លាំង។
នៅពេលឮសម្លេងត្រែ
ឃ្លានេះ អាចនិយាយបានថា មនុស្សម្នាក់បានផ្លុំត្រែ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលមនុស្សផ្លុំត្រែ
ដើម្បីប្រកាសថាសង្គ្រាមចាប់ផ្តើមហើយ»
វាមិនអាចឈរនៅកន្លែងតែមួយបានទេ។
«វារំភើបខ្លាំងពេក មិនអាចឈរនៅកន្លែងតែមួយបាន»។
វាស្រែកឡើងថា «ហាហា»
ពាក្យ «ហាហា» ជាសម្លេងមនុស្សធ្វើ នៅពេលពួកគេរកឃើញអ្វីមួយ។
សេះធ្វើសម្លេងមួយនេះ ដោយសារវាស្ថិតនៅក្នុងសង្គ្រាម។
ស្រង់ក្លិនចម្បាំង
ឃ្លានេះ បញ្ជាក់ថា សេះបានឮសម្លេងទាំងនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាបានឮសម្លេងនៃការបកប្រកាសសង្គ្រាម។
សម្រែកប្រកាសពីការធ្វើសឹក
«សម្រែកប្រកាសពីការធ្វើសឹក»។ មនុស្សស្រែកជាពិសេស
ពួកគេប្រើការនេះក្នុងសង្គ្រាម ដើម្បីបង្ហាញពីកម្លាំង និងសេចក្តីក្លាហាន
ព្រមទាំងបំភ័យដល់សត្រូវផងដែរ។
Job 39:26
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើដោយប្រាជ្ញារបស់អ្នកឬ...ទៅទិសខាងត្បូង?
ព្រះអម្ចាស់ប្រើសំណួរនេះ ដើម្បីបង្ហាញថា លោកយ៉ូបមិនធំជាងព្រះអម្ចាស់ទេ។
ចម្លើយច្បាស់ចំពោះសំណួរនេះគឺ «ទេ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមែនដោយសារប្រាជ្ញារបស់អ្នកទេ...ទៅទិសខាងត្បូង»។
ដែលសត្វស្ទាំងហើរសំកាំងស្លាប ហើយត្រដាងស្លាបវាទៅទិសខាងត្បូង
ត្រដាងស្លាបរបស់វានៅទីនេះ សំដៅលើហើរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើរទៅទិសខាងត្បូង»
ទៅទិសខាងត្បូង
នៅក្នុងភូមិសាស្ត្រព្រះគម្ពីរ សត្វហើរទៅទិសខាងត្បូងនៅអំឡុងពេលរដូវរងា
ដើម្បីទៅរកតំបន់ដែលមានអាកាសធាតុក្តៅ។
Job 39:27
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
តើអ្នកបានបង្គាប់...ធ្វើសំបុកឲ្យកូនរបស់វានៅតាមទីខ្ពស់ៗឬ?
ព្រះអម្ចាស់ប្រើសំណួរនេះ
ដើម្បីបង្ហាញថាលោកយ៉ូបគ្មានអំណាចគ្រប់គ្រាន់នឹងបង្គាប់សត្វឥន្ទ្រីឡើយ។
ចម្លើយច្បាស់ចំពោះសំណួរនេះគឺ «ទេ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចបង្គាប់សត្វឥន្ទ្រីឲ្យហើរទៅលើភ្នំ
ហើយធ្វើសំបុករបស់វានៅទីខ្ពស់បានទេ»។
ធ្វើជាទីមាំមួនរបស់ខ្លួន
ច្រាំងថ្មចោទខ្ពស់គឺជាទីមាំមួនសម្រាប់សត្វឥន្ទ្រី
ព្រោះសត្វដែលចង់ស៊ីវាមិនអាចដល់បានទេ។
Job 39:29
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តសួរសំណួរលោកយ៉ូប។
វាអាចមើលឃើញពីចម្ងាយ
ពាក្យ «វា» នៅទីនេះ សំដៅលើសត្វឥន្ទ្រី។
រំពា
«ជាសត្វដែលវាអាចសម្លាប់ ហើយចាប់ស៊ី»
ភ្នែករបស់វាអាចមើលឃើញពីចម្ងាយ
ពាក្យ «ភ្នែករបស់វា» សំដៅលើសត្វឥន្ទ្រី។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាមើលឃើញពួកវា»

generated on Wed Sep 10 16:16:32 2025

កូនរបស់វា
«កូនរបស់ឥន្ទ្រី» អាចជួយឲ្យងាយយល់អាចនិយាយថា
សត្វឥន្ទ្រីសម្លាប់សត្វផ្សេងៗហើយ យកមកឲ្យកូនវា។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពីសត្វឥន្ទ្រីសម្លាប់សត្វផ្សេងៗហើយ
កូនឥន្ទ្រី»
ជញ្ជក់ឈាម
«ផឹកឈាមរបស់សត្វដែលវាបានសម្លាប់»
ទីកន្លែងណាមានសាកសពនោះ
«កន្លែងដែលមានមនុស្សស្លាប់» ឃ្លានេះស
ំដៅលើសាកសពដែលបានដេកស្លាប់នៅទីវាល
មិនមែនជាសាកសពដែលកប់នៅក្នុងដីទេ។
វាក៏នៅទីនោះ
ឃ្លានេះអាចធ្វើឲ្យកាន់តែច្បាស់គឺថា វាបានទៅស៊ីសាកសពរបស់មនុស្សស្លាប់។
របៀបផ្សេងទៀតនាំការបកប្រែ: «វានៅទីនោះដើម្បីស៊ីសាកសពនោះ»

40 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ លោកយ៉ូបទៀតថា៖[2]«តើអ្នកដែលមានប្រាជ្ញា នឹងពូកែទាស់ទែង អាចកែតម្រូវ ព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុតបានទេ? អ្នក
ដែលទាស់នឹងព្រះជាម្ចាស់ សូមឲ្យគាត់ឆ្លើយចុះ»។
[3]លោកយ៉ូបទូលព្រះអម្ចាស់ថា៖[4]«មើល៍! ទូលបង្គំជាមនុស្សទន់ទាបណាស់ តើឲ្យទូលបង្គំឆ្លើយទៅព្រះអង្គវិញ ដូចម្តេចបាន?[5]ទូលបង្គំនឹងយកដៃខ្ទប់មាត់។ ទូលបង្គំបាន
និយាយម្តងរួចមកហើយ ទូលបង្គំមិននិយាយទៀតទេ ហើយទូលបង្គំក៏បាននិយាយជាលើកទីពីរដែរ ទូលបង្គំនឹងគ្មានអ្វីនិយាយទៀតទេ»។
[6]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយ៉ូបពី ក្នុងខ្យល់ព្យុះថា៖[7]«ចូររៀបចំខ្លួនឲ្យបានដូចមនុស្សអង់អាច យើងនឹងសួរអ្នកហើយអ្នកត្រូវតែឆ្លើយទៅនឹងសំនួរយើងដែរ។
[8]តើអ្នកពិតជាបាននិយាយថា យើងមិនយុត្តិធម៌មែនទេ? តើអ្នកចង់ថ្កោលទោសយើង ដើម្បីបង្ហាញថាអ្នកជាមនុស្សសុចរិតឬ?[9]តើដៃរបស់អ្នកមានចេស្តាដូច
ព្រះជាម្ចាស់ទេ? តើអ្នកមានសំឡេងដូចផ្គរលាន់ដូចព្រះអង្គទេ?
[10]អ្នកមានភាពថ្កុំថ្កើង និងភាពឧត្តុង្គឧត្តម ហើយពោរពេញទៅពន្លឺរស្មីដ៏រុងរឿងដ៏អស្ចារ្យ។[11]ចូរក្រឡេកមើលមនុស្សមានអំនួត ហើយជះកំហឹងដ៏ខ្លាំងក្លារបស់អ្នកលើពួក
គេនឹងបង្ក្រាបគេចុះ។
[12]ចូរក្រឡេកមើលមនុស្សដែលមានអំនួត ហើយបំបាក់ពួកគេដែរ ចូរជាន់ឈ្លីមនុស្សអាក្រក់នៅនឹងកន្លែងគេទៅ។[13]ចូរយកពួកគេទៅកប់នៅក្នុងធូលីដីជាមួយគ្នា ចូរឃុំពួក
គេទុកក្នុងរណ្តៅងងឹត។[14]ពេលនោះ យើងនឹងទទួលស្គាល់ថាអ្នកពិតជាខ្លាំងមែន ដោយដៃស្តាំរបស់អ្នកនោះនឹងអាចសង្គ្រោះខ្លួនបានហើយ។
[15]ចូរមើលទៅសត្វដំរីទឹក ដែលយើងបានបង្កើតមកដូចជាអ្នកដែរ វាស៊ីស្មៅដូចសត្វគោ។[16]មើល៍! កម្លាំងរបស់វាស្ថិតនៅត្រង់ចង្កេះ អំណាចដ៏ខ្លាំងក្លារបស់វាស្ថិតនៅត្រង់
សាច់ដុំពោះ។
[17]កន្ទុយរបស់វារឹងដូចដើមតាត្រៅ សរសៃភ្លៅរបស់វាឡើងដូចពួរពាក់ព័ន្ធគ្នា។[18]ឆ្អឹងរបស់វាប្រៀបបាននឹងបំពង់លង្ហិន ហើយឆ្អឹងជំនីររបស់វាដូចចម្រឹងដែក។
[19]វាជាស្នាព្រះហស្តដ៏វិសេសរបស់ព្រះជាម្ចាស់។[20]មានតែព្រះជាម្ចាស់ដែលបង្កើតវា ដែលអាចបង្ក្រាបវាបាន។ ដ្បិត វាស៊ីស្មៅនៅតាមភ្នំ ជាកន្លែងដែល សត្វព្រៃទាំងប៉ុន្មាន
ប្រឡែងគ្នា។[21]វាដេកនៅក្រោមស្លឹកឈូក ហើយសំងំនៅតាមដើមត្រែង ក្នុងត្រពាំង។
[22]ម្លប់ស្លឹកឈូកបាំងលើវា ដើមចាកនៅតាមដងស្ទឹងព័ទ្ធជុំវិញវា។[23]ទោះបីទឹកហូរយ៉ាងខ្លាំងក្តី ក៏វាមិនបារម្ភ ទោះបីទឹកទន្លេយ័រដាន់ជន់ឡើងលិចមាត់ច្រាំង ក៏វាមិនព្រួយ
ដែរ។[24]តើមាននរណាអាចចាប់វាបានដោយប្រើសន្ទូចទេ ឬទម្លុះច្រមុះ របស់វាតាមរយៈអន្ទាកបានទេ?

Job 40:1
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តស្តីបន្ទោសលោកយ៉ូប ដោយសួរសំណួរទាំងនេះ។
តើអ្នកដែលមានប្រាជ្ញា នឹងពូកែទាស់ទែអាចនឹងកែតម្រូវ ព្រះដ៏មានគ្រប់ព្រះចេស្តាបានទេ?
ព្រះអម្ចាស់ស្តីបន្ទោសលោកយ៉ូប។ ឃ្លានេះអាចបកប្រែជាប្រយោគបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាអាចរិះគន់យើង
ឬញុះញង់ឲ្យយើងបានទេ ដ្បិត យើងគឺជាព្រះដ៏មានគ្រប់ព្រះចេស្តា» ឬ
«អ្នក ជាមនុស្ស ចង់រិះគន់យើង ជាព្រះដ៏មានគ្រប់ព្រះចេស្តា ប៉ុន្តែ
អ្នកមិនត្រូវកែតម្រង់យើងទេ»
ឯងដែលបន្ទោសដល់ព្រះជាម្ចាស់ដូច្នេះ ចូរឆ្លើយមកចុះ
ព្រះអម្ចាស់មានបន្ទូលពីលោកយ៉ូប និងអង្គទ្រង់ ប្រៀបដូចជា
ពួកគេជាមនុស្សពីរនាក់ផ្សេងទៀតដែលរំលឹកលោកយ៉ូបថា
គ្មាននរណានៅទីណាអាចបន្ទោសព្រះជាម្ចាស់បានទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកចង់ឈ្លោះជាមួយយើង ដូច្នេះ
ឆ្លើយយើងសិនមក»។
Job 40:3
មើល៍
«ប្រាកដណាស់» ពាក្យ «មើល៍» នៅទីនេះ
បន្ថែមដើម្បីបញ្ជាក់ពីអ្វីដែលលោកនឹងមានបន្ទូលបន្ទាប់។
ទូលបង្គំមិនមែនមនុស្សសំខាន់ទេ
«ទូលបង្គំមិនមែនមនុស្សសំខាន់ទេ»
តើឲ្យទូលបង្គំឆ្លើយទៅព្រះអង្គវិញដូចម្តេចបាន?
លោកយ៉ូបប្រើសំណួរនេះ ដើម្បីសុំទោសចំពោះសំណួររបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទូលបង្គំមិនអាចឆ្លើយព្រះអង្គបានទេ»
Job 40:6
ចូរក្រវាត់ចង្កេះអ្នកឲ្យបានដូចមនុស្ស
មនុស្សលើកអាវវែងរបស់ខ្លួនឡើងដល់ចង្កេះរបស់ខ្លួន ឬ
ក្រវាត់ចង្កេះគឺរៀបចំសម្រាប់ការងារធ្ងន់ ហើយ
លោកយ៉ូបរៀបចំខ្លួនដើម្បីឆ្លើយនឹងសំណួរដ៏ពិបាករបស់ព្រះជាម្ចាស់។
សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៣៨:១
Job 40:8
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តស្តីបន្ទោសលោកយ៉ូបដោយសួរសំណួរលោកជាច្រើនទៀត។
តើអ្នកពិតជាបាននិយាយថា យើងមិនយុត្តិធម៌មែនទេ?
ពាក្យ «ការពិតជាក់ស្តែង» បង្ហាញថា ព្រះអម្ចាស់ភ្ញាក់ផ្អើល
លោកយ៉ូបអាចនិយាយថា ព្រះជាម្ចាស់មិនយុត្តិធម៌
ហើយថាលោកយ៉ូបអាចប្រាកដថា ព្រះអង្គពិតជាចង់មានបន្ទូលដូច្នោះ។
ឃ្លានេះអាចបកប្រែជាប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងភ្ញាក់ផ្អើលដែលអ្នកនិយាយថា យើងមិនយុត្តិធម៌» ឬ «អ្នកអាចប្រាកដថា
អ្នកចង់និយាយថា យើងមិនយុត្តិធម៌ ដោយសារអ្វីដែលអ្នកបាននិយាយ»។
តើអ្នកចង់ថ្កោលទោសយើង ដើម្បីបង្ហាញថាអ្នកជាមនុស្សសុចរិតឬ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកកំពុងតែថ្កោលទោសយើង ដើម្បីប្រកាសថាអ្នកជាមនុស្សសុចរិត»។
មានចេស្តាដូចព្រះជាម្ចាស់
មានដៃគឺជាពាក្យប្រៀបធៀបសម្រាប់កម្លាំងនៅក្នុងដៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «មានកម្លាំងដូចកម្លាំងរបស់ព្រះជាម្ចាស់»។
តើអ្នកអាចធ្វើសំឡេងផ្គរលាន់ដូចជាព្រះអង្គទេ?
ឃ្លានេះអាចបកប្រែជាប្រយោគក៏បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«តាមពិតទៅអ្នកអាចធ្វើឲ្យមានសំឡេងផ្គរលាន់ដូចជាព្រះជាម្ចាស់បានធ្វើទេ»
អ្នកអាចធ្វើសំឡេង
«អ្នកអាចធ្វើសំឡេង ដូចព្រះអង្គបានធ្វើ» ការបកប្រែភាគច្រើនអានថា
«សម្លេងដូចសម្លេងព្រះអង្គ» (សូមមើល: UDB)
Job 40:10
ចូរបំពាក់ខ្លួនអ្នកក្នុងសិរីរុងរឿង និងភាពឧត្តុង្គឧត្តម ហើយអ្នកត្រូវស្លៀកពាក់ក្នុងសិរីរុង
រឿងហើយដោយតេជានុភាព
«សិរីល្អ» «ភាពឧត្តុង្គឧត្តម» «កិតិយស» «តេជានុភាព» គឺជានាមអរូប។
និយាយប្រៀបដូចជាសម្លៀកបំពាក់ដែលមនុស្សស្លៀកពាក់។ ពាក្យទាំងនេះ
អាចបកប្រែជាគុណនាម ឬជាកិរិយាសព្ទក៏បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើឲ្យខ្លួនអ្នកក្នុងសិរីរុងរឿង ធ្វើអ្វីមួយអស្ចារ្យ ដើម្បីឲ្យមនុស្សគោរពដល់អ្នក
ហើយផ្តល់កិតិយសដល់អ្នក ធ្វើឲ្យមនុស្សគិតថាអ្នកគឺជាស្តេចដ៏អស្ចារ្យ»។
កម្លាយសេចក្តីកំហឹងរបស់អ្នកទៅជុំវិញទៅ
«កំហឹង» ជានាមអរូប និយាយប្រៀបដូចជាអ្វីមួយដែលលើពីប្រអប់មួយ

generated on Wed Sep 10 16:16:32 2025

ដែលអាចផ្ទុកបាន ដើម្បីមនុស្សអាចរីករាយដាល់។
នេះគឺជាពាក្យប្រៀបធៀបអំពីសក្ដភាពរបស់មនុស្ស នៅពេលពួកគេខឹង។
អ្នកចាំបាច់ត្រូវបញ្ជាក់ឲ្យច្បាស់ ហេតុអ្វីបានជាមនុស្សខឹង។
របៀបផ្សេងទៀតនៃការបកប្រែ: «មានកំហឹងដោយសារមនុស្សអួត
និងដាក់ទោសពួកគេ»។
ផ្តួលពួកគេចុះ
«ដក់យកអ្វីមួយចេញ ដោយសារពួកគេអួត»
Job 40:12
មុខរបស់ពួកគេ
មុខគឺជាផ្នែកមួយនៃរូបកាយមនុស្សទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេ»
នៅក្នុងកន្លែងងងឹត
ពាក្យមានសុជីវធម៌សម្រាប់កន្លែងដែលវិញ្ញាណរបស់មនុស្សទៅនៅពេលពួកគេស្លាប់ទៅ
Job 40:15
សត្វដំរីទឹក
ជាសត្វនៅក្នុងទឹក អាចជាដំរីទឹក (សូមមើល: UDB)
វាស៊ី
សត្វដំរីទឹកស៊ី
ស៊ីស្មៅដូចសត្វគោ
ទាំងសត្វដំរីទឹក និងគោស៊ីស្មៅ។
ត្រង់ចង្កេះ...សាច់ដុំពោះ
ឃ្លាពីនេះសំដៅលើផ្នែកតែមួយនៃរូបកាយ។
Job 40:17
ដើមតាត្រៅ
ដើមតាត្រៅ ជាឈើដ៏រឹងមាំ ហើយកន្ទុយរបស់វារឹងតែរឹង។
ឆ្អឹងរបស់វាប្រៀបបាននឹងបំពង់លង្ហិន
ពាក្យ ឆ្អឹងរបស់វា នៅទីនេះ ប្រៀបដូចជាបំពង់ធ្វើពីលង្ហិន
ដើម្បីបង្ហាញពីសត្វនេះខ្លាំងប៉ុណ្ណា។
ដូចចម្រឹងដែក
នេះគឺជាការប្រៀបធៀបចុងក្រោយ
ពណ៌នាពីកម្លាំងរបស់ខ្លាំងក្លាយរបស់សត្វនោះ។
Job 40:19
ប្រធាននៅលើរបស់ដែលព្រះជាម្ចាស់បានបង្កើត
«សំខាន់បំផុតលើរបស់ទាំងអស់ដែលព្រះអង្គបង្កើត» ឬ «ខ្លាំងបំផុតលើសត្តនិករ»
មានតែព្រះជាម្ចាស់តែមួយដែលបានបង្កើតវា
ព្រះអម្ចាស់មានបន្ទូល ប្រៀបដូចព្រះអង្គជាមនុស្សម្នាក់ទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីអ្វីៗដែលយើងបានបង្កើត»
ជ្រលោងភ្នំបានផ្តល់ឲ្យវានូវចំណី
អ្នកនិពន្ធនិយាយអំពីភ្នំ ប៉ៀបដូចជាភ្នំទាំងនោះជាមនុស្ស
ដែលអាចផ្តល់អាហារដល់វា។ របៀបផ្សេងទៀតនៃការបកប្រែ:
«អាហារដុះនៅលើភ្នំនោះសម្រាប់ពួកវា»
ផ្កាឈូក
ជាជាតិមានផ្កា ដែលដុះនៅលើទឹក នៅក្នុងតំបន់ដែលមានភក់។
ដើមត្រែង
ជាប្រភេទស្មៅខ្ពស់ៗ ដុះនៅតាមភក់ ឬវាលភក់ល្បប់។
Job 40:22
ផ្កាឈូក
រុក្ខជាតិមានផ្កា ដែលដុះនៅលើទឹក នៅក្នុងតំបន់ដែលមានភក់។
សូមបកប្រែឲ្យដូចនៅក្នុងជំពូក ៤០:១៩
ដើមចាកនៅតាមដងស្ទឹង
ដើមចាកគឺជាដើមដ៏ធំមួយដែលដុះនៅក្នុងដីសើម។ ប្រសិនបើ
អ្នកមិនស្គាល់ដើមឈើនេះ នៅក្នុងវប្បធម៌របស់អ្នកទេ
អ្នកអាចប្រើដើមឈើទូទៅដែលដុះនៅក្បែរទឹក។
មាត់ច្រាំង
នៅក្បែរទន្លេ
ទោះបើទន្លេដូចយ៉ាងទន្លេយ័រដាន់ ឡើងលិចមាត់ច្រាំងក៏ដោយ គង់តែវាមានចិត្តរឹងត្អឹងដែរ
«ទោះបីជាទឹកជំនន់ឡើងដល់ច្រមុះវាក៏ដោយ»
តើមាននរណាអាចចាប់វាបានដោយប្រើសន្ទូចទេ...អន្ទាក់បានទេ?
ឃ្លានេះអាចបកប្រែជាសេចក្ដីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងថា
គ្មាននរណាអាចចាប់វាដោយសន្ទូច ឬ ចាក់ច្រមុះរបស់វាដោយអន្ទាក់នោះឡើយ»

---

41 [1]តើអ្នកអាចយកសន្ទូចទៅស្ទូចស្តេចក្រពើបានទេ? ហើយយកខ្សែទៅចងអណ្តាត របស់វាបានឬ?[2]តើអ្នកអាចយកកន្លុះទៅដាក់ច្រមុះវា ហើយយកដែកសន្ទូច ចោះ
ថ្គាមរបស់វាបានទេ?[3]តើវានឹងអង្វរដល់អ្នកឬ? តើវានឹងនិយាយមកអ្នកដោយទន់ភ្លន់ឬ?
[4]តើវាចេះចុះខសន្យាជាមួយអ្នកដោយសន្តិភាព ហើយអ្នកអាចប្រើប្រាស់វាបានជារៀងរហូតឬទេ?[5]តើអ្នកអាចលេងជាមួយវា ដូចលេងសត្វចាបបានទេ?[6]តើអ្នកអាចចងវា
ទុកឲ្យកូនអ្នកបម្រើស្រីរបស់អ្នកបានទេ? តើពួកអ្នកនេសាទអាចចាប់វាបានទេ? ហើយអ្នកលក់អាចយកវាដាក់ដេញថ្លៃបានទែ?
[7]តើអ្នកអាចយកជន្លួញមកចាក់ទម្លុះស្បែកវា ហើយយកស្នូចាក់ត្រីមកចាក់ក្បាលវាបានឬ?[8]ចូរលូកដៃពាល់វាមើល៍ ពេលអ្នកគិតដល់ការប្រយុទ្ធជាមួយនឹងវា នោះអ្នកមុខ
ជាលែងហ៊ានពាល់វាជាប់ទៀតមិនខាន។[9]មើល៍! អ្នកណាប្រាថ្នាចង់ចាប់វា អ្នកនោះកុហកហើយ តើធ្លាប់មានអ្នកណាអាចចាប់វាឲ្យនៅស្ងៀមនៅដីបានទេ?
[10]បើគ្មាននរណាម្នាក់ហ៊ានតទល់នឹងវាដូច្នេះ តើនរណាអាចប្រឈមមុខនឹងយើងបាន?[11]គ្មាននរណាឲ្យរបស់មកយើងខ្ចី ហើយយើងត្រូវសងទៅគេវិញនោះឡើយ ដ្បិតអ្វីៗ
ទាំងអស់នៅលើផែនដីនេះ សុទ្ធតែជាកម្មសិទ្ធិរបស់យើង។[12]មកដល់ត្រឹមពេលនេះ យើងមិនទាន់បានថ្លែង អំពីអវយវៈ កម្លាំង និងសរីរាង្គដ៏ល្អ របស់ក្រពើនៅឡើយទេ។
[13]តើនរណាអាចពន្លាត់ស្បែកវាបាន? តើនរណាហ៊ានប៉ះពាល់ចង្កូមរបស់វា?[14]តើនរណាហ៊ានបើកមាត់របស់វា? ដ្បិតវាមានធ្មេញគួរឲ្យស្ញែងខ្លាចណាស់មែនទេ?[15]ស្រកាដ៏
សង្ហា ហើយមាំរបស់វា តភ្ជាប់គ្នា ទៅវិញទៅមកយ៉ាងស្អិតល្អត។
[16]ស្រការបស់វានៅភ្ជាប់គ្នាយ៉ាងជិត សូម្បីតែខ្យល់ក៏ពុំអាចឆ្លងកាត់បានផង។[17]ស្រកានីមួយៗតភ្ជាប់គ្នាយ៉ាងមាំ ដែលពុំអាចបំបែកចេញពីគ្នាបានឡើយ។[18]កាលណាវាព្រួស
ទឹកចេញមក នោះមានបែកជាពន្លឺ ភ្នែករបស់វាភ្លឺដូចជាពេលថ្ងៃរះ។
[19]មានភ្លើងចេញពីមាត់របស់វា ហើយផ្កាភ្លើងក៏ហើរចេញមកដែរ។[20]មានផ្សែងហុយចេញតាមច្រមុះរបស់វា ដូចផ្សែងហុយចេញពីថ្លាងដែលកំពុងពុះ។[21]ខ្យល់ដង្ហើមរបស់វា
អាចបង្កាត់ភ្លើងបាន ហើយក៏មានអណ្តាតភ្លើងផុសចេញពី ក្នុងមាត់របស់វាដែរ។
[22]ករបស់វាមានកម្លាំងណាស់ ធ្វើឲ្យអស់អ្នកដែលឃើញវា ចូលមកជិត ភ័យខ្លាចជាខ្លាំង។[23]សាច់ស្រទាប់របស់វានៅជាប់គ្នាយ៉ាងរឹងមាំ ដែលមិនអាចផ្តាច់ចេញពីគ្នាបាន
ទេ។[24]បេះដូងរបស់វារឹងដូចដុំថ្ម គឺរឹងដូចត្បាល់ថ្មផងដែរ។
[25]ពេលណាវាក្រោកឡើង សូម្បីតែអ្នកខ្លាំងពូកែក៏ភ័យតក់ស្លុតដែរ ហើយរត់ចេញទៅ ទាំងបាក់ស្បាត។[26]ប្រសិនបើគេយកដាវ លំពែង ស្ន និងព្រួញ ឬអាវុធផ្សេងទៀត មក
ចាក់ទម្លុះវា ក៏មិនមុតហើយធ្វើអ្វីមិនបានដែរ។[27]ដ្បិតពួកវាបានគិតថា ដែកដូចជាចំបើង ហើយលង្ហិនដូចជាឈើពុក។
[28]ព្រួញមិនដែលធ្វើឲ្យវាដកខ្លួនថយទេ រីឯថ្មដែលគេបាញ់ពីខ្សែដង្ហក់ ក៏ប្រៀបដូចជាចំបើងសម្រាប់វាដែរ។[29]វាមើលមកព្រនង់ដូចជាចំបើង ហើយមិនញញើតនឹងសន្ធឹកស្ន
ឡើយ។[30]ចំណែកក៏តូចរបស់វាមុតដូចអំបែងឆ្នាំង ធ្វើឲ្យមានដានៅលើភក់ដូចដានរនាស់។
[31]វាធ្វើឲ្យទឹកនៅក្នុងមហាសាគរ ពុះកញ្ជ្រោលដូចទឹកពុះនៅក្នុងថ្លាង ហើយធ្វើឲ្យសមុទ្រប្រៀបដូចជា ឆ្នាំងរម្ងាស់ទឹកអប់។[32]វាធ្វើឲ្យមានដានរលោងនៅពីក្រោយវា គឺប្រៀបបី
ដូចជាសក់របស់ចាស់ព្រឹទ្ធាចារ្យ។
[33]នៅលើផែនដីនេះ គ្មានសត្វណាដូចវាឡើយ យើងបង្កើតវាមក មិនខ្លាចអ្វីទាំងអស់។[34]វាមិនញញើតនឹងមើលទៅសត្វដ៏សម្បើមៗ ដ្បិតវាជាស្តេចលើសត្វសាហាវទាំង
អស់»។

Job 41:1
ព័ត៌មានទូទៅ
ព្រះជាម្ចាស់បន្តមានបន្ទូល។ ព្រះអង្គប្រើសំណួរដែលមិនទាមទាចម្លើយជាច្រើន
ដើម្បីសួរលោកយ៉ូណាស។

generated on Wed Sep 10 16:16:32 2025

តើអ្នកអាចយកសន្ទូចទៅស្ទូចនាគបានទេ?
ឃ្លានេះ អាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងទេ ថាអ្នកមិនអាចស្ទូចសត្វនាគជាមួយនឹងដងសន្ទូចបានទេ»។
យកសន្ទូចទៅ
ទាញចេញពីទឹក
របស់វា...វា
ពាក្យ «របស់វា» និង «វា» សំដៅលើសត្វនាគ។
ចងថ្គាមរបស់វាជាមួយនិងខ្សែបានឬទេ?
ប្រយោគនេះមិនពេញទេ ប៉ុន្តែ អត្ថន័យរបស់វាអាចយល់បានពីបរិបទដូចជា «អ្នកអាចចង់ផ្គាមរបស់វាជាមួយខ្សែបានទេ?»
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា អ្នកមិនអាចចងផ្គាមនាគជាមួយនឹងខ្សែបានទេ»។
តើអ្នកអាចយកខ្សែពួរទៅដាក់ច្រមុះវា ...ជាមួយសន្ទូចបានទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា
អ្នកមិនអាចយកខ្សែទៅចងច្រមុះរបស់វា...ជាមួយនឹងសន្ទូចបានទេ។
តើវានឹងធ្វើការអង្វរដល់អ្នកឬទេ
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា វាមិនស្តាប់ពាក្យអង្វរបស់អ្នកទេ»។
តើវានឹងនិយាយមកអ្នកដោយទន់ភ្លន់ឬទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា អ្នកមិនអាចនិយាយពាក្យទន់ភ្លន់ទៅកាន់វាបានទេ»។
Job 41:4
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តស្តីបន្ទោលលោកយ៉ូបដោយសួរគាត់នូវសំណួរជាច្រើន។
តើវានឹងតាំងសេចក្តីសញ្ញាជាមួយអ្នក ហើយអ្នកអាចយកវាមកធ្វើជាអ្នកបម្រើបានជារៀងរហូតឬទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា វាមិនអាចចងសម្ពន្ធមេត្រីជាមួយអ្នកទេ ព្រោះអ្នក
អាចយកវាមកធ្វើជាអ្នកបម្រើបានជារៀងរហូត»
តើអ្នកអាចលេងជាមួយវា ដូចជាលេងជាមួយសត្វចាបបានទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា អ្នកមិនអាចលេងជាមួយវា ដូចអ្នកលេងជាមួយចាបទេ»។
តើអ្នកអាចចងវាទុកឲ្យអ្នកបម្រើស្រីរបស់អ្នកបានទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា អ្នកមិនអាចចងវា ដូចជាចង់អ្នកបម្រើស្រីរបស់អ្នកទេ»។
តើពួកអ្នកនេសាទអាចចាប់វាបានទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា ក្រុមអ្នកនេសាទនឹងមិនតថ្លៃជាមួយវាទេ»
តើពួកគេពុះវាជាចំណែក ហើយដាក់លក់ក្នុងចំណោមអ្នកដេញថ្លៃបានទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹងហើយថា ពួកគេនឹងពុះវាជាចំណែក
ដើម្បីដាក់លក់ក្នុងចំណោមអ្នកដេញថ្លៃ»។
ពួកគេនឹងពុះ
«ក្រុមអ្នកនេសាទនឹងពុះចែកគ្នា»
Job 41:7
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តស្តីបន្ទោលលោកយ៉ូបដោយសួរគាត់នូវសំណួរជាច្រើន។
តើអ្នកអាចយកជន្លួញមកចាក់ទម្លុះស្បែករបស់វា ឬយកស្នូចាក់ត្រីមកចាក់ក្បាលវាបានឬទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែងបាន។ របៀបផ្សេងទៀតនៃការបកប្រែ: អ្នកមិនអាចយកចាក់ទម្លុះស្បែករបស់វាដោយអាវុធរបស់អ្នកបានទេ ឬ
អ្នកមិនអាចចាក់ទម្លុះក្បាលរបស់វាដោយស្នូចាក់ត្រីរបស់អ្នកដែរ»។
ផ្លែឈូក
ជាលំពែងធំៗ ដែលមានបន្លាលួសដែលមនុស្សប្រើដើម្បីប្រមាញ់សត្វសមុទ្រធំៗ។
មើល៍
«សូមយកចិត្តទុកដាក់ចំពោះចំណុចសំខាន់ដែលខ្ញុំកំពុងតែនិយាយ»
អ្នកណាប្រាថ្នាចង់ចាប់វា អ្នកនោះកុហកហើយ
តើធ្លាប់មានអ្នកណាអាចចាប់វាឲ្យនៅស្ងៀមនៅនិងដីបានទេ?
ឃ្លានេះ អាចបកប្រែជាទូទៅ ដូចជាប្រយោគសកម្មដែរ។ ពាក្យ «នៅចំពោះមុខវា» ហេតុផលដែលមនុស្សខ្លាច ហើយបោះវាចោលទៅនឹងដី។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សគ្រប់គ្នាដែលមើលវា នឹងខ្លាច
ហើយនឹងបោះវាចោលទៅនឹងដី»
Job 41:10
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តស្តីបន្ទោលលោកយ៉ូបដោយសួរគាត់នូវសំណួរជាច្រើន។
បើគ្មាននរណាម្នាក់ហ៊ានតទល់នឹងនាគនោះបានទេ ដូច្នេះហើយតើនរណាដែលអាចឈរនៅចំពោះមុខយើងបាន?
ការដាស់នាគឲ្យភ្ញាក់គឺជាការងាយស្រួល ជាងឈរនៅចំពោះព្រះអម្ចាស់។
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកបានដឹងរួចហើយថា គ្មាននរណាហ៊ានដាស់នាគឲ្យភ្ញាក់ទេ
អ្នកអាចដឹងហើយថា គ្មាននរណាអាចឈរនៅចំពោះយើងទេ» Status: Idle
តើមានអ្នកណាឲ្យរបស់មកយើងខ្ចី ហើយដើម្បីឲ្យយើងត្រូវសងទៅអ្នកនោះវិញដែលឬទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
អ្នកដឹងហើយថា គ្មាននរណាឲ្យអ្វីមកយើងមុនទេ ដូច្នេះ
ក៏គ្មាននរណាដែលយើងចាំបាច់ត្រូវសងវិញដែរ»
យើងនឹងមិននៅស្ងៀម
ឃ្លានេះអាចបកប្រែជាទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងនិយាយជាប្រាកដ»
ពីជើង និងកម្លាំងវា ឬពីរាងដ៏សមសួនរបស់វាផង
អ្នកចាំបាច់ត្រូវបន្ថែមពាក្យដែលលុបចោលនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ជើង យើងនឹងនិយាយអំពីបញ្ហានៃកម្លាំងរបស់វា»
អំពីបញ្ហាកម្លាំងរបស់វា និងសរីរាង្គដ៏ល្អ របស់សត្វនាគនោះ
អ្នកមិនចាំបាច់បន្ថែមពាក្យដែលលុបចោលឡើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«កម្លាំង យើងនឹងនិយាយអំពីសរីរាង្គដ៏ល្អរបស់វា។
Job 41:13
ប្រយោគភ្ជាប់
ព្រះអម្ចាស់បន្តស្តីបន្ទោលលោកយ៉ូបដោយសួរគាត់នូវសំណួរជាច្រើន។
តើនរណាអាចពន្លាត់ស្បែកវាបាន?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាអាចពន្លាត់ស្បែករបស់វាចេញក្រៅស្បែករបស់វាបានទេ»
តើនរណាហ៊ានលូកដៃទៅកាច់ធ្មោងក្រោយខ្នងរបស់វាបានទេ?
ពាក្យ «ធ្មុងក្រោយខ្នង» គឺជាពាក្យប្រៀបធៀប សម្រាប់ស្រកាដ៏រឹង ឬ
ស្រកាដែលលាក់នៅខាងក្រោយខ្នងរបស់វា។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាអាចវះកាត់ធ្មុងក្រោយរបស់វាទេ»
តើនរណាអាចហ៊ានបើកមាត់កាច់ថ្គាមពីមុខរបស់វា...គួរឲ្យស្ញែងខ្លាចណាស់មែនទេ?
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាហ៊ានកាច់ថ្គាមរបស់វាទេ... វាគួរឲ្យខ្លាចណាស់»
ខែល
ទាំងខែង ទាំងធ្មុងដែលនៅខាងក្រោយនាគ បានការពារពីព្រួញ
និងអាវុធផ្សេងទៀតបានយ៉ាងល្អ។
ចងភ្ជាប់ជាមួយគ្នាជាមួយនឹងបិទត្រាផង
ឃ្លានេះមានន័យថា «ខែល» នៅជិតគ្នានឹងគ្នា
ហើយគ្មានអ្វីអាចចូលទៅក្នុងចន្លោះនោះបានទេ។
Job 41:16
ស្រការបស់វានៅភ្ជាប់គ្នាយ៉ាងជិត
ខែលមួយជួរៗ ជំពូក ៤១:១៣ នៅជិតគ្នាខ្លាំងណាស់។
របស់ពួកវា...ពួកវា
ពាក្យ «របស់ពួកវា» «ពួកវា» សំដៅលើជួររបស់ខែលនោះ។ (៤១:១៣)។
វាមិនអាចបែកចេញពីគ្នាបានទេ
ឃ្លានេះអាចបកប្រែជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាអាចទាញវាចេញពីគ្នាបានទេ»
វាបានព្រួស
«ពេលវាព្រួស»។ ព្រួសគឺជាសម្លេងដូចជាស្រម៉ុកខ្លីៗដែរ។ ន័យមួយផ្សេងទៀតគឺ
«ចេញពីសម្លេងស្រម៉ុករបស់វា» ឬ «ពេលវាកណ្តាស់»
ភ្នែករបស់វាភ្លឺដូចជាពេលថ្ងៃរះ
ភ្នែករបស់វាក្រហម គឺក្រហមដូចជាពេលថ្ងៃរះ។
Job 41:19
ភ្លើងបានចេញពីមាត់របស់វា ហើយទៅឆេះចន្លុះ និងផ្កាភ្លើងហើរចេញមកដែរ
«ភ្លើងបានចេញពីមាត់របស់វា ហើយទៅឆេះចន្លុះ និងផ្កាភ្លើងហើរចេញមកដែរ»

generated on Wed Sep 10 16:16:32 2025

ព្រះជាម្ចាស់បង្ហាញពីគំនិតដូចជាទៅនឹងវិធីពីរផ្សេងទៀតនៃការបង្ហាញពីរូបភាពដែលគួរឲ្យខ្លាច
មានផ្សែងហុយចេញតាមច្រមុះរបស់វា ដូចបានដុតថ្លាង
ទាំងផ្សែង និងថ្លាងដុតទឹកពុះក្តៅជាខ្លាំង។
តាមច្រមុះ
តាមរន្ធច្រមុះ
អាចបង្កាត់ភ្លើងបាន
«ធ្វើបង្កាត់ភ្លើង ឲ្យឆេះបាន»
Job 41:22
របស់វា...វា
នាគ
សេចក្តីភ័យខ្លាចបានរាំនៅពីមុខវា
«ភ័យខ្លាច» ជានាមអរូប អាចបកប្រែជាកិរិយាសព្ទ «ខ្លាច»
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលមនុស្សឃើញវាមក ពួកគេភ័យខ្លាចជាខ្លាំង»
ពួកវាមិនអាចផ្តាច់ចេញពីគ្នាបានទេ
ឃ្លានេះអាចបកប្រែជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាអាចផ្តាចវាចេញពីគ្នាឡើយ»
បេះដូងរបស់វារឹងដូចដុំថ្ម
ថ្មមិនអាចផ្លាស់ប្តូរបានទេ ហើយមិនអាចទន់បានដែរ។ អត្ថន័យទី១)
ទ្រូងខាងរូបកាយរបស់នាគ និងគ្រឿងក្នុងរបស់វារឹង ឬទី២)
នាគគ្មានខ្លាចអ្វីទាំងអស់ ឬទី៣)
នាគនិយាយពីមនុស្សដែលសម្លាប់គេដោយគ្មានអអារឡើយ។
រឹងទាបជាងត្បាល់ថ្ម
ជាថ្មពីដុំធំហើយរឹង ប្រើប្រើដើម្បីកិនគ្រាប់ស្រូវ។
វាជាថ្មដែលរឹងខ្លាំងណាស់ដែលមនុស្សអាចរកបាន។ «ថ្មដ៏រឹងបំផុត»
Job 41:25
ព្រះផ្សេងៗ
អត្ថន័យផ្សេងទៀត អាចសំដៅលើ «មនុស្សខ្លាំងពូកែ» ឬ
«មនុស្សដែលមានកម្លាំងខ្លាំង» (សូមមើល: UDB)
វាបានគិតថា ដែកគឺដូចជាចំបើង
«វាបានគិតពីគ្រឿងសាស្ត្រាវុធ ថា ដែកគឺដូចជាចំបើង»
ចំបើងមិនអាចចាក់ចូលស្បែករបស់វាបានទេ
ហើយអាវុធដែកក៏មិនអាចចាក់ចូលស្បែករបស់វាបានដែរ»
ហើយលង្ហិនគឺដូចជាឈើពុកដែរ
ឲ្យគិតថាវាមានតម្លៃតិចតួច ដូចជាឈើ ឬលង្ហិន ប្រៀបដូចជាអាវុធដែលធ្វើពីឈើពុក»
ឈើពុកមិនអាចចាក់ចូលស្បែករបស់វាបានទេ។
ហើយអាវុធលង្ហិនក៏មិនអាចចាក់ចូលស្បែករបស់វាបានដែរ។
Job 41:28
សម្រាប់វាគឺថ្មខ្សែដង្ហក់ប្រៀបបីដូចជាអង្កាម
អង្កាមមិនអាចធ្វើទុក្ខដល់សត្វនាគបានទេ
ហើយខ្សែដង្ហក់ក៏មិនអាចធ្វើទុក្ខវាបានដែរ។
ដំបងវិញវាចាត់ទុកដូចជាចំបើងដែរ
ឃ្លានេះអាចបកប្រែជាទម្រង់សកម្ម។ ដំបងធ្វើពីចំបើង មិនអាចធ្វើទុក្ខដល់វាបានទេ
ហើយដំបងឈើក៏មិនអាចធ្វើទុក្ខវាបានដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាគិតថា ដំបូង ប្រៀបដូចជាចំបើង»
ធ្វើឲ្យមានដានៅលើភក់ដូចដានរនាស់។
ដានរនាស់នៅលើគ្រាប់ស្រូវ រាស់នៅលើដី ហើយត្រឡប់វាទៅក្នុងដីភ្លូរ
ហើយកន្ទុយរបស់វាសន្សល់ទុកនូវដាននៅលើភក់ ប្រៀបដូចដានវាតំចុះវាត់ឡើង
ដូចជាមនុស្សដើរ។
Job 41:31
វាធ្វើឲ្យទឹកជ្រៅមានពពុះឡើងមក ដូចជាឆ្នាំងទឹកកំពុងតែពុះ
«នៅពេលវាហែលទឹក វាបន្សល់ទុកដានពពុះនៅខាងក្រោយវា
ដូចជាពពុះទឹកដាំពុះនៅក្នុងឆ្នាំដូច្នោះដែរ»។
វាធ្វើឲ្យសមុទ្រប្រៀបដូចជាឆ្នាំងក្រមួនដែរ។
ប្រេងនៅក្នុងឆ្នាំនឹងបែកពពុះប្រសិនបើនរណាម្នាក់អង្រួនវា ហើយសមុទ្រនឹងល្អក់
នៅពេលសត្វនាគហែលក្នុងវា។
អ្នកគិតជ្រៅគឺមានសក់ពណ៌ប្រផេះ
ដោយសារពពុះនៅពីក្រោយវានោះពណ៌ស។
Job 41:33
គ្មានអ្វីស្មើវាទេ
«គ្មានសត្វណាបានស្មើនឹងសត្វនាគទេ»
វាមើលគ្រប់របស់ទាំងអស់ដោយអំនួត
«វាពិតជាមានអំនួតណាស់»
វាគឺជាស្តេចលើពួកកូនចៅនៃដែលមានអំនួត
សត្វនាគនោះត្រូវបានគេនិយាយថាវាប្រៀបបានដូចជាមនុស្សដែលអំនួត
និងអាចសោយរាជ្យជាស្តេច។ របៀបផ្សេងទៀតនៃការបកប្រែ:
«សត្វនាគគឺជាសត្វដែលសាកសមនិងការកោតសរសើរជាងសត្វដទៃទៀតនៅលើផែនដី»

---

42 [1]លោកយ៉ូបទូលព្រះអម្ចាស់ថា៖[2]«ទូលបង្គំដឹងថា ព្រះអង្គអាចធ្វើគ្រប់កិច្ចការទាំងអស់បាន ហើយគ្មានការអ្វីធ្វើឲ្យព្រះអង្គ ឈប់បានឡើយ។[3]ព្រះអង្គមានព្រះបន្ទូលមកទូលបង្គំថា ម្តេចក៏អ្នកសង្ស័យលើគម្រោងការរបស់យើង ដោយពោលពាក្យឥតខ្លឹមសារដូច្នេះ? ដ្បិត ទូលបង្គំបានថ្លែងនូវសេចក្តី ដោយពុំដឹងខ្លួន គឺជាអ្វីដែលលើសពីការយល់ដឹង ដែលទូលបង្គំមិនបានដឹងពីមុន។
[4]ព្រះអង្គមានព្រះបន្ទូលទៀតថា ចូរស្តាប់សេចក្តីដែលយើងថ្លែង យើងនឹងសួរអ្នក ហើយអ្នកត្រូវតែឆ្លើយ។[5]កាលពីមុន ទូលបង្គំគ្រាន់តែបានឮគេនិយាយ អំពីព្រះអង្គ ឥឡូវនេះ ទូលបង្គំឃើញព្រះអង្គ ផ្ទាល់នឹងភ្នែកតែម្តង។[6]ហេតុនេះ ទូលបង្គំសូមសារភាពកំហុស ហើយដាក់ខ្លួន ដោយក្រាបនៅក្នុងធូលីដី និងផេះ»។
[7]ក្រោយពេលព្រះអម្ចាស់មានព្រះបន្ទូលទាំងនេះមកកាន់លោកយ៉ូបហើយ ព្រះអង្គមានព្រះបន្ទូលទៅកាន់លោកអេលីផាសជាជនជាតិថេម៉ានថា៖ «យើងខឹងនឹងអ្នក ព្រមទាំងមិត្តភក្តិទាំងពីររបស់អ្នកខ្លាំងណាស់ ដ្បិតអ្នកពុំបានថ្លែងអំពីយើង ដោយត្រឹមត្រូវដូចយ៉ូប ជាអ្នកបម្រើរបស់យើងឡើយ។[8]ដូច្នេះ ចូរយកគោបាប្រាំពីរ និងចៀមឈ្មោលប្រាំពីរ ទៅជួបយ៉ូប ជាអ្នកបម្រើរបស់យើង ហើយថ្វាយជាតង្វាយដុតទាំងមូល សម្រាប់អ្នកចុះ។ យ៉ូប ជាអ្នកបម្រើរបស់យើង យើងនឹងទទួលពាក្យអធិស្ឋានគាត់ ហើយយើងមិនសងតាមអ្វីដែលាបនប្រព្រឹត្តឡើយ អ្នកមិនបាននិយាយអ្វីដែលត្រឹមត្រូវ ដូចយ៉ូបអ្នកបម្រើយើងបាននិយាយ»។[9]លោកអេលីផាសជាជនជាតិថេម៉ាន លោកប៊ីលដាដជាជនជាតិស៊ូអា និងលោកសូផារជាជនជាតិណាអាម៉ានាំគ្នាចាកចេញទៅ ហើយធ្វើតាមសេចក្តីដែលព្រះអម្ចាស់បានបង្គាប់ ហើយព្រះអម្ចាស់ក៏ទទួលលោកយ៉ូប។
[10]ពេលលោកយ៉ូបទូលអង្វរឲ្យមិត្តរបស់លោក ព្រះអម្ចាស់ប្រោសប្រណីលោកឲ្យបានចម្រុងចម្រើនឡើងវិញ។ ព្រះអម្ចាស់ប្រទានទ្រព្យឲ្យលោកពីរដងច្រើនលើសមុន។
[11]បងប្អូនប្រុសស្រីទាំងប៉ុន្មានរបស់លោក និងញាតិមិត្តទាំងអស់ដែលលោកធ្លាប់ស្គាល់ នាំគ្នាមកសួរសុខទុក្ខលោក ហើយបរិភោគអាហាររួមជាមួយលោក នៅក្នុងផ្ទះរបស់លោក។ ពួកគេសម្តែងការអាណិតអាសូរ និងសម្រាលទុក្ខលោក ព្រោះតែទុក្ខវេទនាទាំងប៉ុន្មានដែលព្រះអម្ចាស់បានបណ្តាលឲ្យកើតមានដល់លោក។ ពួកគេយកប្រាក់មួយណែនម្នាក់ ព្រមទាំងកងមាសម្នាក់មួយ មកជូនលោក។
[12]ព្រះអម្ចាស់ ប្រទានពរដល់លោកយ៉ូបលើកនេះ ច្រើនជាងមុនទៅទៀត គឺលោកមានចៀមមួយម៉ឺនបួនពាន់ក្បាល អូដ្ឋប្រាំមួយពាន់ក្បាល គោមួយពាន់នឹម និងលាញីមួយពាន់ក្បាល។[13]លោកមានកូនប្រុសប្រាំពីរនាក់ និងកូនស្រីបីនាក់។[14]លោកដាក់ឈ្មោះកូនស្រីទីមួយថា យេមីម៉ា កូនស្រីទីពីរ កេស៊ីយ៉ា និងកូនស្រីទីបី កេរេន ហាពូក។
[15]នៅក្នុងទឹកដីនោះទាំងមូល គ្មាននារីណាមានរូបឆោមល្អស្អាត ដូចកូនស្រីរបស់លោកយ៉ូបទេ។ លោកយ៉ូប ជាឪពុក ក៏បានចែកមត៌កឲ្យនាងទាំងបី ដូចបងប្អូនប្រុសៗទាំងប្រាំពីរនាក់ដែរ។[16]ក្រោយមក លោកយ៉ូបរស់បាន ១៤០ឆ្នាំទៀត លោកបានឃើញកូនចៅរបស់លោករហូតដល់បួនតំណ។[17]បន្ទាប់ពីមានអាយុយឺនយូរសម្បូរសប្បាយមក លោកយ៉ូប ក៏លាចាកលោកទៅ។

Job 42:1
ទូលបង្គំដឹងថាព្រះអង្គអាចធ្វើគ្រប់ការទាំងអស់បាន
គឺគ្មានមូលហេតុអ្វីដែលអាចបញ្ឈប់ព្រះអង្គនោះដែរ។
អ្នកចាំបាច់ត្រូវប្រើពាក្យ «ទូលបង្គំដឹង» ម្តងហើយម្តងទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ទូលបង្គំដឹងថា ព្រះអង្គអាចធ្វើគ្រប់ការទាំងអស់។
ទូលបង្គំដឹងថាគ្មាននរណាអាចបញ្ឈប់ព្រះអង្គបានទេ»
ឃាត់ព្រះតម្រិះព្រះអង្គណាមួយ អាចបញ្ជាប់បានទេ
ឃ្លានេះអាចបកប្រែជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«គ្មាននរណាអាចបញ្ឈប់ផែនការរបស់ព្រះអង្គបានទេ»។
តើអ្នកនេះជាអ្នកណា ដែលគ្មានចំណេះដឹងលាក់បាំងគម្រោងការដូច្នេះ?
នៅក្នុងកំណែទំនើបយល់ស្រប់ថា
លោកយ៉ូបបានយកការដកស្រង់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ទាល់ចេញពីជំពូក ៣៨:១។ អ្នកបកប្រែ អាចសម្រេច ប្រើដូចនៅក្នុង UDB ដើម្បីបញ្ជាក់ថា
ព្រះជាម្ចាស់បានសួរលោកយ៉ូប
ហើយឥឡូវនេះលោកយ៉ូបបានយកវាមកវិញដើម្បីរំលឹកវា។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គមានបន្ទូលមកទូលបង្គំថា
តើនរណាជាមនុស្សដែលគ្មានចំណេះដឹង
តើនរណាហ៊ានលាក់គម្រោងការរបស់យើងពីមនុស្ស?» ឬ
«ព្រះអង្គមានបន្ទូលមកទូលបង្គំថា «អ្នកគ្មានចំណេះដឹងទេ
អ្នកមិនត្រូវកុហកពីផែនការរបស់យើងទេ»។
លាក់បាំងគម្រោងការ
លាក់បាំង ឬ ប្រាប់ ឬប្រឹក្សាពីគម្រោងការរបស់ព្រះជាម្ចាស់មិនត្រឹមត្រូវ (សូមមើល:figs-explicit)
Job 42:4
តែពេលនេះភ្នែកទូលបង្គំបានឃើញព្រះអង្គវិញ
អ្នកអានមិនអាចយល់ពីការនេះ ថាលោកយ៉ូបឃើញព្រះអម្ចាស់នោះទេ។
ការមើលឃើញនឹងភ្នែកគ្រាន់តែជាពាក្យប្រៀបធៀបដើម្បីងាយយល់ប៉ុណ្ណោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ឥឡូវនេះ ទូលបង្គំយល់ពីព្រះអង្គហើយ»
ទូលបង្គំស្អប់ខ្លួនឯង
លោកយ៉ូបខ្លួនឯង គឺជាពាក្យប្រៀបធៀបសម្រាប់អ្វីដែលលោកបាននិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទូលបង្គំស្អប់អ្វីៗដែលទូលបង្គំបាននិយាយ»
ទូលបង្គំប្រែចិត្តដោយក្រាបនៅក្នុងធូលីដី និងផេះ
មិនច្បាស់ថាលោកយ៉ូបពិតជាអង្គុយក្នុង ឬគ្របខ្លួនលោកដោយដី ឬផេះនោះទេ។
ឃ្លានេះ អាចជាពាក្យប្រៀបធៀបសម្រាប់ការសោកស្តាយចំពោះបាបរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ទូលបង្គំសុំទោសសម្រាប់បាបរបស់ទូលបង្គំ
ដែលទូលបង្គំគួរអង្គុយនៅលើដី និងផេះ។
Job 42:7
ក្រោយពេល
ឃ្លានេះ ប្រើនៅទីនេះដើម្បីសម្គាល់ពីព្រឹត្តការណ៍សំខាន់នៅក្នុងសាច់រឿង។
ប្រសិនបើ នៅក្នុងភាសារបស់អ្នកមានរបៀបធ្វើការនេះ អ្នកអាចប្រើវានៅទីនេះ។
លោកអេលីផាសជាជនជាតិថេម៉ាន
សូមបកប្រែឈ្មោះគាត់ឲ្យដូចនៅក្នុងជំពូក ២:១១
កំហឹងរបស់យើង បានទាស់នឹងអ្នក
ភ្លើងគឺជាពាក្យប្រៀបធៀបសម្រាប់កំហឹង និងចាប់ផ្តើមដូចជាភ្លើង នៅពេលខឹង។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមានកំហឹងជាខ្លាំងជាមួយអ្នក»
គោបាប្រាំពីរ
«គោបា៧»
យើងមិនសងតាមអ្វីដែលអ្នកបានប្រព្រឹត្តឡើយ
«ល្ងីល្ងើ» ជានាមអរូប អាចបកប្រែជាគុណនាមក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបី អ្នកធ្លាប់ជាមនុស្សល្ងង់
និងសមឲ្យយើងដាក់ទោសឯងដល់ខ្លាំង យើងនឹងមិនធ្វើដូច្នោះទេ»។
លោកបីលដាដជាជាជនជាតិស៊ូអា
សូមបកប្រែឈ្មោះមនុស្សនេះដូចនៅក្នុងជំពូក ២:១១
ព្រះអម្ចាស់ក៏ទទួលលោកយ៉ូប
មនុស្សជាពាក្យប្រៀបធៀបសម្រាប់សេចក្តីអធិស្ឋាន ដែលគាត់បានអធិស្ឋាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានទទួលសេចក្តីអធិស្ឋានរបស់លោក
សម្រាប់មិត្តភក្តិទាំងបីរបស់គាត់»
Job 42:12
រហូតដល់ចុងក្រោយ
អ្នកប្រហែលជាត្រូវបន្ថែមពាក្យដែលបានលុបចោល។
របៀបផ្សេងទៀតនៃការបកប្រែ: «រហូតដល់ជីវិតចុងក្រោយ»
ចៀមមួយម៉ឺនបួនពាន់ក្បាល
១៤,០០០ ចៀម
អូដ្ឋប្រាំមួយពាន់ក្បាល
៦,០០០អូដ្ឋ
គោមួយពាន់នឹម ហើយលាញីមួយពាន់ក្បាល។
១,០០០ គោ និងលាញី
កូនប្រុសប្រាំពីរនាក់
កូនប្រុស ៧នាក់ និង កូនស្រី ៣នាក់
យេមីម៉ា...កេស៊ីយ៉ា...កេរេនហាពូក
ឈ្មោះរបស់មនុស្សស្រី
Job 42:15
គ្មាននារីណាមានរូបឆោមល្អស្អាត ដូចកូនស្រីរបស់លោកយ៉ូបទេ
«កូនស្រីរបស់លោកយ៉ូបមានសម្រស់ស្រស់ស្អាតជាងស្រីដទៃទៀត»
ដល់វ័យចំណាស់ ហើយយឺនយូរ
ពាក្យ «យឺនយូរ» គឺមានអត្ថន័យដូចជាពាក្យ «វ័យចំណាស់»
ឃ្លាទាំងពីរគឺជាប្រយោគដែលគេប្រើទូទៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បុរសវ័យចំណាស់»។

ទំនុកតម្កើង

1 [1]មានពរហើយអ្នកដែលមិនដើរតាមដំបូន្មានរបស់មនុស្សពាល ឬឈរតាមផ្លូវជាមួយមនុស្សមានបាប ឬអង្គុយជាមួយមនុស្សដែលចំអកឡកឡាយ។
[2]ប៉ុន្តែរីករាយជាមួយក្រឹត្យវិន័យនៃព្រះអម្ចាស់ ហើយសញ្ជឹងគិតអំពីក្រឹត្យវិន័យ ទាំងយប់ទាំងថ្ងៃ។
[3]អ្នកនោះប្រៀបបាននឹងដើមឈើ ដែលដុះនៅក្បែរផ្លូវទឹក ដែលផ្តល់ផលផ្លែតាមរដូវកាល ដែលមានស្លឹកមិនចេះស្រោកស្រពោន ការអ្វីដែលគាត់ធ្វើនឹងចម្រុងចម្រើនឡើង។
[4]ការរបស់មនុស្សពាលវិញ គឺមិនដូច្នោះឡើយ តែពួកគេប្រៀបបាននឹងអង្កាម ដែលត្រូវខ្យល់ផាត់បាត់ទៅ។[5]មនុស្សពាលនឹងមិនអាចឈរក្នុងថ្ងៃជំនុំជម្រះបានឡើយ ហើយ
មនុស្សបាបក៏ពុំអាចស្ថិតនៅក្នុងចំណោម មនុស្សសុចរិតបានដែរ។
[6]ដ្បិតព្រះជាម្ចាស់ស្គាល់ផ្លូវរបស់មនុស្សសុចរិត ប៉ុន្តែរបស់មនុស្សពាលនឹងវិនាសអន្តរាយ។

Psalms 1:1
ព័ត៌មានទូទៅ
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។ (សូមមើល: writing-poetry និង
អ្នកដែលមិនដើរតាមដំបូន្មានរបស់មនុស្សពាល
ឃ្លានេះ «ដំបូន្មានរបស់មនុស្សពាល» ត្រូវបានគេនិយាយដូចជាផ្លូវត្រូវដើរតាម។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលមិនធ្វើតាមដំបូន្មានរបស់មនុស្សអាក្រក់»
ឈរតាមផ្លូវជាមួយមនុស្សមានបាប
ឃ្លាថា «តាមផ្លូវ» តំណាងឲ្យរបៀបរស់នៅរបស់ប្រជាជន។ ពាក្យ «ឈរ»
គឺស្របជាមួយ «ដើរ»។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើត្រាប់តាមឥរិយាបទរបស់មនុស្សមានបាប»
ឬ អង្គុយជាមួយមនុស្សដែលចំអកឡកឡឺយ
អង្គុយជាមួយមនុស្សដែលសើចចំអកឡកឡឺយដល់ព្រះជាម្ចាស់តំណាងឲ្យមនុស្សដែលសើចចំអកឡកឡឺ
ការបកប្រែរបៀបផ្សេងទៀត: «ឬ ចូលរួមជាមួយអ្នកដែលមើលងាយព្រះជាម្ចាស់»
ឬ
«ឬចំអកឡកឡឺយឲ្យព្រះជាម្ចាស់ជាមួយអ្នកដែលចំអកឡកឡឺយមើលងាយព្រះអង្គ»
ត្រេកអរ
«ស្កប់ស្កល់» ឬ «អំណរ»
ព្រះអម្ចាស់
នេះគឺជាឈ្មោះរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានបង្ហាញដល់ប្រជាជនរបស់ព្រះអង្គ
នៅក្នុងគម្ពីរសញ្ញាចាស់។
សូមមើលទំព័រពាក្យបកប្រែអំពីព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែនេះ។
Psalms 1:3
ព័ត៌មានទូទៅ:

generated on Wed Sep 10 16:16:32 2025

អត្ថបទនេះបង្ហាញអំពីរូបភាពដ៏ឧឡារិកដែលមនុស្សសុចរិតត្រូវបានគេគិតអំពីដើមឈើ
អ្នកនោះប្រៀបបាននឹងដើមឈើ....ផ្តល់ផលផ្លែតាមរដូវកាល
នៅក្នុងព្រះគម្ពីរ គេច្រើនតែនិយាយអំពីដើមឈើ។
មនុស្សដែលត្រេកអរនឹងក្រឹត្យវិន័យរបស់ព្រះអម្ចាស់អាចធ្វើអ្វីដែលព្រះអង្គសព្វព្រះហឫទ័យ
ផ្លូវទឹកបង្កើតបានផលល្អ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងមានភាពរុងរឿងដូចដើមឈើ...ផ្តល់ផលផ្លែតាមរដូវកាល»
ដែលដុះនៅក្បែរផ្លូវទឹក
ដើមឈើដែលត្រូវបានដាំនៅក្បែរផ្លូវទឹកអាចទទួលបានទឹកគ្រប់គ្រាន់
ដើម្បីឲ្យមានការលូតលាស់បានល្អ។
បង្កើតផលតាមរដូវកាល
ដើមឈើដែលមានការលូតលាស់បានល្អនិងផ្តល់ផ្លែល្អនៅតាមពេលវេលាត្រឹមត្រូវ។
ស្លឹកមិនចេះស្ងោកស្រពោន
ប្រសិនបើដើមឈើទទួលបានទឹកគ្រប់គ្រាន់ស្លឹករបស់វាមិនស្ងួត ហើយនិងងាប់។
ការអ្វីដែលគាត់ធ្វើនឹងចម្រុងចម្រើនឡើង
«លោកនឹងទទួលជោគជ័យ ទោះបីជាលោកធ្វើអ្វីក៏ដោយ»
Psalms 1:4
ការរបស់មនុស្សពាលវិញ
របៀបដែលពួកគេមិនដូចនោះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
«មនុស្សអាក្រក់មិនរីកចម្រើនទេ» ឬ
«មនុស្សអាក្រក់មិនចម្រើនឡើងទេ» (សូមមើល:figs-explicit)
ផុយទៅវិញពួកគេប្រៀបដូចជាអង្កាម
របៀបដែលពួកគេដូចជាអង្កាមអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ផុយទៅវិញពួកគេគ្មានតម្លៃដូចអង្កាម»
នឹងមិនអាចឈរក្នុងថ្ងៃជំនុំជម្រះបានឡើយ
រស់រានមានជីវិតនៅពេលព្រះជាម្ចាស់វិនិច្ឆ័យថាជា «ឈរ»

«នឹងមិនអាចរស់បានទេនៅពេលដែលព្រះជាម្ចាស់វិនិច្ឆ័យពួកគេ» ឬ
«ព្រះជាម្ចាស់នឹងដាក់ទោសពួកគេនៅពេលព្រះជាម្ចាស់វិនិច្ឆ័យទោសពួកគេ»
អ្នកបកប្រែអាចបន្ថែមកិរិយាស័ព្ទ «ឈរ» ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបាបក៏ពុំអាចឈរនៅក្នុងអង្គប្រជុំនេះបានដែរ» (សូមមើល:figs-ellipsis)
ហើយមនុស្សបាបក៏ពុំអាចស្ថិតនៅក្នុងចំណោម មនុស្សសុចរិតបានដែរ
ការទទួលយកពីព្រះជាម្ចាស់ជាមនុស្សសុចរិតត្រូវបានគេនិយាយថាកំពុងឈរជាមួយក្រុមមនុស្សសុចរិត។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងមិនទទួលមនុស្សបាបរួមជាមួយមនុស្សសុចរិតទេ» (សូមមើល:figs-metonymy)
Psalms 1:6
ដ្បិតព្រះជាម្ចាស់ស្គាល់ផ្លូវរបស់មនុស្សសុចរិត ប៉ុន្តែរបស់មនុស្សពាលនឹងវិនាសអន្តរាយ
ឃ្លាទាំងពីរនេះខុសគ្នាពីអ្វីដែលកើតឡើងចំពោះមនុស្សសុចរិត
និងអ្វីដែលកើតឡើងចំពោះមនុស្សអាក្រក់។ (សូមមើល:figs-parallelism)
ផ្លូវរបស់មនុស្សសុចរិត
របៀបដែលមនុស្សរស់នៅត្រូវបានគេនិយាយដូចជា «មធ្យោបាយ» ឬ «ផ្លូវ»
ដែលពួកគេកំពុងដើរ។ ការបកប្រែរបៀបផ្សេងទៀត:«
របៀបដែលមនុស្សសុចរិតរស់នៅ» (សុមើល:figs-metaphor)
ផ្លូវរបស់មនុស្សពាលនឹងត្រូវវិនាសអន្តរាយ
នេះ «មធ្យោបាយ» តំណាងមនុស្សអាក្រក់ដែលកំពុងដើរតាមផ្លូវ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សអាក្រក់នឹងត្រូវវិនាស ដោយសារផ្លូវរបស់គេ»
ឬ «មនុស្សអាក្រក់នឹងត្រូវស្លាប់ព្រោះតែរបៀបរស់នៅរបស់ពួកគេ»

---

2 [1]តើហេតុអ្វីបានជាប្រជាជាតិទាំងឡាយនៅក្នុងភាពវឹកវរ ហើយហេតុអ្វីបានជាប្រជាជនរៀបផែនការដែលនឹង បរាជ័យនោះ?
[2]ពួកស្តេចនៅលើផែនដីបានរួមគ្នាជាមួយនឹងពួកអ្នកដែលមានអំណាច បះបោរហើយប្រឆាំងនឹងព្រះអម្ចាស់ ព្រមទាំងទាស់ទៅនឹងព្រះមេស្ស៊ី ដោយពោលថា៖[3]«ចូរ
យើងនាំគ្នាបំបាក់នឹមរបស់ព្រះអង្គ ហើយគ្រវែងច្រវាក់របស់ព្រះអង្គចេញទៅ»។
[4]ព្រះអម្ចាស់ដែលគ្រងរាជ្យនៅស្ថានបរមសុខ ព្រះជាម្ចាស់អស់សំណើច និងចំអកឲ្យពួកគេ។[5]ក្រោយមកព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេដោយព្រះពិរោធ ហើយធ្វើឲ្យ
ពួកគេ ភ័យតក់ស្លុត ដោយសារព្រះពិរោធដ៏ខ្លាំងរបស់ព្រះអង្គ ដោយព្រះបន្ទូលថា៖
[6]«គឺយើងនេះហើយ ដែលបានអភិសេកស្តេចរបស់យើងឲ្យឡើងគ្រងរាជ្យនៅលើភ្នំស៊ីយ៉ូន ជាភ្នំដ៏វិសុទ្ធរបស់យើង»។[7]ខ្ញុំនឹងប្រកាសច្បាប់មួយរបស់ព្រះអម្ចាស់។ ព្រះអង្គ
មានព្រះ បន្ទូលមកកាន់ខ្ញុំថា៖ «អ្នកគឺជាបុត្ររបស់យើង! ថ្ងៃនេះយើងបានត្រឡប់ជាឪពុករបស់អ្នក។
[8]ចូលសូម នោះយើងនឹងប្រគល់ប្រជាជាតិនានា ឲ្យអ្នកទុកជាមត៌ក យើងក៏នឹងប្រគល់ផែនដីទាំងមូល ឲ្យអ្នកទុកជាកម្មសិទ្ធិដែរ។[9]ព្រះអង្គនឹងបង្ក្រាបពួកគេដោយដំបង
ដែកហើយព្រះអង្គកម្ទេចគេ ដូចជាងស្មូនកម្ទេចភាជន៍»។
[10]ដ្បិតពេលនេះ ស្តេចទាំងឡាយអើយ ត្រូវដឹងនិងកែតម្រូវឡើង រួមទាំងអ្នកមានអំណាចទាំងឡាយផងដែលនៅលើផែនដីនេះផង។
[11]ចូលថ្វាយបង្គំដល់ព្រះអម្ចាស់ដោយកោតខ្លាច ហើយមានអំណរដោយញាប់ញ័រផង។
[12]ចូលថើបព្រះបុត្រឬព្រះជាម្ចាស់នឹងទ្រង់ព្រះពិរោធ នោះអ្នករាល់គ្នានឹងស្លាប់ក្នុងរបៀបដែលព្រះពិរោធបានឆេះឆួលឡើងក្នុងគ្រានោះ។
មានពរហើយអស់អ្នកដែលជ្រកកោនក្រោមម្លប់បារមីរបស់ព្រះជាម្ចាស់។

Psalms 2:1
ព័ត៌មានទូទៅ៖
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
តើហេតុអ្វីបានជាប្រជាជាតិទាំងឡាយ នាំគ្នាបង្កើតចលាចល ហើយប្រជារាស្ត្រនានារអ៊ូរទាំ ដោយ
ឥតខ្លឹមសារយ៉ាងនេះ?
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នាហើយ «ប្រជាជាតិ» និង «ប្រជារាស្ត្រ»
សំដៅទៅលើក្រុមមនុស្សតែមួយ។ ពាក្យថា «ប្រជាជាតិ» និង «ប្រជារាស្ត្រ»
អាចតំណាងឲ្យអ្នកគ្រប់គ្រងរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ហេតុអ្វីបានជាមេដឹកនាំនៃប្រជាជាតិនានាកំពុងមានភាពច្របូកច្របល់
និងធ្វើផែនការដែលនឹងបរាជ័យ?» (សូមមើល: និងfigs-metonymy)
តើហេតុអ្វីបានជាប្រជាជាតិទាំងឡាយ នាំគ្នាបង្កើតចលាចល ហើយប្រជារាស្ត្រនានារអ៊ូរទាំ ដោយ
ឥតខ្លឹមសារយ៉ាងនេះ?
សំណួរទាំងនេះត្រូវបានប្រើ
ដើម្បីបង្ហាញការភ្ញាក់ផ្អើលដែលមនុស្សកំពុងធ្វើអ្វីដែលខុស និងល្ងីល្ងើ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជាតិនានាកំពុងស្ថិតក្នុងភាពច្របូកច្របល់
ហើយប្រជាជនកំពុងរៀបចំផែនការដែលនឹងបរាជ័យ»។
គឺជាប្រជាជាតិដែលកំពុងមានចលាចល
នេះប្រហែលជាមានន័យថា ប្រជាជាតិនានាកំពុងធ្វើឲ្យមានសម្លេងរំខាន
និងខឹងស្ថានភាពចលាចល។
ផែនការនឹងបរាជ័យ
ទាំងនេះប្រហែលជាផែនការប្រឆាំងនឹងព្រះជាម្ចាស់ និងប្រជាជនរបស់ព្រះអង្គ។
ស្តេចនៅលើផែនដីឈររួមគ្នា...មេដឹកនាំឃុបឃិតគ្នា
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ឈរនៅជាមួយគ្នា
«ប្រមូលផ្តុំដើម្បីប្រយុទ្ធ» ឬ «រួបរួមនិងរៀបចំដើម្បីបះបោរ»
សូមឲ្យយើងហែកច្រវាក់...បោះច្រវាក់របស់ពួកគេ
ប្រជាជននៃប្រជាជាតិនានានិយាយអំពីព្រះអម្ចាស់
និងការគ្រប់គ្រងរបស់ព្រះមេស្ស៊ីដែលគ្រប់គ្រងលើពួកគេដូចជាជាប់ច្រវាក់
និងច្រវាក់។ ការបកប្រែរបៀបផ្សេងទៀត:
«យើងគួរតែដោះលែងខ្លួនយើងពីការគ្រប់គ្រងរបស់ពួកគេ។
យើងមិនគួរអនុញ្ញាតឲ្យពួកគេគ្រប់គ្រងលើយើងទៀតទេ!»
Psalms 2:4
ព្រះអង្គ...គឺជាព្រះជាម្ចាស់
ឃ្លាទាំងនេះសំដៅទៅលើព្រះអម្ចាស់។ ជារឿយៗព្រះអម្ចាស់ត្រូវបានគេហៅថា
«ព្រះជាម្ចាស់» ប៉ុន្តែពាក្យសម្រាប់ «ព្រះអម្ចាស់» និង «ព្រះជាម្ចាស់» គឺខុសគ្នា។
គ្រងរាជ្យនៅស្ថានបរមសុខ

generated on Wed Sep 10 16:16:32 2025

នៅទីនេះការគ្រងរាជ្យតំណាងឲ្យការគ្រប់គ្រង។ អ្វីដែលព្រះអង្គគ្រងរាជ្ជាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «គ្រងរាជ្យនៅស្ថានបរមសុខ» ឬ «គ្រងរាជ្យលើបល្ល័ង្ករបស់ព្រះអង្គនៅស្ថានបរមសុខ»

ព្រះអម្ចាស់អស់សំណើច និងចំអកឲ្យពួកគេ

«ព្រះអម្ចាស់ចំអកឲ្យប្រជាជនទាំងនោះ»។ ហេតុអ្វីបានជាព្រះអង្គចំអកឲ្យពួកគេអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់ចំអកឲ្យពួកគេចំពោះផែនការដ៏ល្ងង់ខ្លៅរបស់ពួកគេ»

ហើយធ្វើឲ្យពួកគេ ភ័យតក់ស្លុត

«ព្រះពិរោធ» អាចសំដៅទៅលើការខឹង ឬខឹងខ្លាំង។

ភ័យខ្លាច

«ការបំភិតបំភ័យ»

Psalms 2:6

គឺយើងនេះហើយ

ព្រះអម្ចាស់កំពុងសង្កត់ធ្ងន់ថា៖ ព្រះអង្គមិនមែនជាអ្នកផ្សេងទេដែលបានចាក់ប្រេងតាំងស្តេចរបស់ព្រះអង្គ។

បានអភិសេកស្តេចរបស់យើង

«តែងតាំងស្តេចរបស់យើងឲ្យគ្រប់រាជ្យ»

ខ្ញុំនឹងប្រកាសច្បាប់មួយរបស់ព្រះអម្ចាស់

អ្នកដែលនិយាយថា នេះគឺជាស្តេច។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះរាជាមានរាជឱង្ការថា៖ «ខ្ញុំនឹងប្រកាសក្រឹត្យរបស់ព្រះអម្ចាស់»

ព្រះអង្គមានព្រះបន្ទូលមកកាន់ខ្ញុំ

«ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ»

អ្នកគឺជាបុត្ររបស់យើង! ថ្ងៃនេះយើងបានត្រឡប់ជាឪពុករបស់អ្នក

ក្នុងចំណោមប្រជាជនជាច្រើននៅតំបន់នោះនៃពិភពលោកបន្ទាប់មកបុរសអាចសម្រេចចិត្តធ្វើបុត្រ នៅទីនេះព្រះអម្ចាស់ជ្រើសរើសបុរសម្នាក់ហើយតែងតាំងលោកឲ្យធ្វើជាស្តេចអ៊ីុស្រាអែល។

ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំធ្វើឲ្យអ្នកជាកូនប្រុសរបស់ខ្ញុំ។ ថ្ងៃនេះខ្ញុំបានក្លាយជាឪពុករបស់អ្នកហើយ» ឬ «ឥឡូវអ្នកគឺជាកូនប្រុសរបស់ខ្ញុំ ហើយយើងជាឪពុករបស់អ្នក»

Psalms 2:8

ប្រយោគភ្ជាប់:

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ស្តេចថ្មីនៃអ៊ីុស្រាអែល។

ប្រជាជាតិនានាឲ្យអ្នកទុកជាមត៌ក... យើងក៏នឹងប្រគល់ផែនដីទាំងមូលឲ្យអ្នកទុកជាកម្មសិទ្ធិដែរ

ឃ្លាទាំងនេះបង្ហាញពីគំនិតស្រដៀងគ្នាខ្លាំងណាស់។

ផែនដីទាំងមូល

«ទឹកដីដែលនៅឆ្ងាយ»

ព្រះអង្គនឹងបង្ក្រាបពួកគេដោយដំបងដែកហើយព្រះអង្គកម្ទេចគេ ដូចជាងស្ងួនកម្ទេចភាជន៍

ឃ្លាទាំងនេះបង្ហាញពីគំនិតស្រដៀងគ្នាខ្លាំងណាស់។

ព្រះអង្គនឹងបង្ក្រាបពួកគេ

ការវាយឈ្នះប្រជាជាតិនានាត្រូវបានគេនិយាយថា៖ កំពុងតែបំបែកពួកគេ ហើយអំណាចរបស់ព្រះអង្គត្រូវបានគេនិយាយដូចជាដំបងដែក។

ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអង្គនឹងកម្ចាត់ពួកគេទាំងស្រុងដោយអំណាចរបស់ព្រះអង្គ»

ព្រះអង្គកម្ទេចគេ ដូចជាងស្ងួនកម្ទេចភាជន៍

ការបំផ្លាញប្រជាជាតិនានាត្រូវបានគេនិយាយ ដូចជាពួកគេអាចត្រូវគេវាយបំបែកដូចជាងស្ងួនកម្ទេចភាជន៍។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គនឹងកម្ទេចពួកគេដូចជាងស្ងួនកម្ទេចភាជន៍»

ជាងស្ងួនកម្ទេចភាជន៍

ជាងស្ងួនគឺជាមនុស្សម្នាក់ដែលធ្វើផើងដីឥដ្ឋ និងពាង។ ទាំងនេះមានភាពផុយស្រួយ ហើយអាចបែកបានយ៉ាងងាយស្រួល។

ការបកប្រែរបៀបផ្សេងទៀត: «ពាងដីឥដ្ឋ» ឬ «ឆ្នាំងដីឥដ្ឋ»

Psalms 2:10

ដ្បិតពេលនេះ ស្តេចទាំងឡាយអើយ ត្រូវដឹងនិងកែតម្រូវឡើង

រួមទាំងអ្នកមានអំណាចទាំងឡាយផងដែលនៅលើផែនដីនេះផង

ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ការបកប្រែរបៀបផ្សេងទៀត: «ឥឡូវនេះស្តេចនិងអ្នកគ្រប់គ្រងលើផែនដីអើយចូរព្រមាន និងកែតម្រូវឡើង»

ការព្រមាន

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ស្តាប់ការព្រមាននេះ» ឬ «មានប្រាជ្ញា»

ត្រូវបានកែតម្រង់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ស្តាប់ការកែនេះ» ឬ «ទទួលយកការកែតម្រូវនេះ»

Psalms 2:12

ចិត្តមិនស្មោះត្រង់ កូនដោយស្របច្បាប់ដែលនឹងក្លាយជាអ្នកស្នងមរតករបស់ពួកគេ។ មនុស្សនឹងបង្ហាញស្តេចរបស់ពួកគេថាពួកគេស្មោះត្រង់នឹងទ្រង់ដោយថើបទ្រង់ប្រហែលជានៅលើជើង។

ការបកប្រែរបៀបផ្សេងទៀត: បង្ហាញព្រះបុត្រថាអ្នកពិតជាស្មោះត្រង់នឹងព្រះអង្គ» ឬ «ក្រាបគោរព ដល់ព្រះបុត្ររបស់ព្រះអង្គ»

អ្នករាល់គ្នានឹងស្លាប់ក្នុងរបៀបនេះ

នេះអាចសំដៅទៅលើការស្លាប់នៅទីនោះមុនពេលមនុស្សមានឱកាសបាត់ខ្លួន។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងស្លាប់ភ្លាមៗ»

នៅពេលដែលព្រះពិរោធបានឆេះឆួលឡើងក្នុងគ្រានោះ

ព្រះពិរោធរបស់ស្តេចត្រូវបានគេនិយាយដូចជាភ្លើងដែលអាចឆេះបាន។

ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលភ្លាមៗនោះព្រះអង្គព្រះពិរោធ»

ជ្រកកោនក្រោមម្លប់បារមីរបស់ព្រះជាម្ចាស់

ការស្នើសុំការការពារព្រះមហាក្សត្រត្រូវបានគេនិយាយថា៖ ជាការស្វែងរកការជ្រកកោននៅក្នុងខ្លួន។ ការបកប្រែរបៀបផ្សេងទៀត: «ស្នើឲ្យព្រះមហាក្សត្រការពារពួកគេ»

---

3 ទំនុកតម្កើង របស់ស្តេចដាវីឌ ក្នុងគ្រាដែលទ្រង់រត់ភៀសចេញពីសម្តេចអាប់សាឡុម ជាព្រះរាជបុត្រ។[1]ព្រះអម្ចាស់ ខ្មាំងសត្រូវរបស់ទូលបង្គំមានគ្នាច្រើនណាស់! ហើយអ្នកដែលលើកគ្នាប្រឆាំងនឹងទូលបង្គំ ក៏មានគ្នាច្រើនដែរ។[2]មានមនុស្សជាច្រើននិយាយថា «គ្មានជំនួយណាមកពីព្រះជាម្ចាស់សម្រាប់គាត់ឡើយ»។ សម្រាក
[3]ប៉ុន្តែព្រះអម្ចាស់អើយ ព្រះអង្គគឺជាខែលការពារទូលបង្គំ ក៏ជាសិរីរុងរឿងរបស់ទូលបង្គំ ហើយព្រះអង្គគឺជាអ្នកលើកមុខទូលបង្គំឡើង។[4]ខ្ញុំស្រែកដង្ហោយហៅរកព្រះអម្ចាស់យ៉ាងអស់ពីដួងចិត្ត ហើយព្រះអង្គឆ្លើយតបមកខ្ញុំវិញ ពីភ្នំដ៏វិសុទ្ធរបស់ព្រះអង្គ។ សម្រាក
[5]ខ្ញុំទម្រេត នឹងដេកយ៉ាងស្កប់ស្កល់ ហើយខ្ញុំក៏បានភ្ញាក់ឡើងវិញ ដ្បិតព្រះអម្ចាស់បានការពារខ្ញុំ។[6]ទោះបីមានមនុស្សម្នាដ៏ច្រើនអនេកអនន្ត លើកគ្នាពីគ្រប់ទីកន្លែង មកប្រឆាំងនឹងខ្ញុំយ៉ាងណាក្តីក៏ខ្ញុំមិនភ័យខ្លាចដែរ។
[7]តើនឡើង ព្រះអម្ចាស់អើយ! សូមសង្គ្រោះទូលបង្គំផង ព្រះអម្ចាស់នៃទូលបង្គំអើយ! ដ្បិតព្រះអង្គនឹងវាយពួកខ្មាំងរបស់ទូលបង្គំ ព្រះអង្គនឹងបំបាក់ធ្មេញរបស់មនុស្សពាលដែរ។[8]សេចក្តីសង្គ្រោះគឺបានមកពីព្រះអម្ចាស់។ សូមឲ្យព្រះពររបស់ព្រះអង្គបានដល់ប្រជារាស្ត្ររបស់ព្រះអង្គផង។ សម្រាក

Psalms 3:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។ (សូមមើល: និងfigs-parallelism)

ទំនុកតម្កើង របស់ព្រះបាទដាវីឌ

អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ ២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣) បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។

ឱព្រះអម្ចាស់អើយ តើខ្មាំងសត្រូវរបស់ទូលបង្គំមានប៉ុន្មាននាក់!

ការប្រកាសនេះបង្ហាញថា ព្រះបាទដាវីឌខ្លាចសត្រូវរបស់ទ្រង់។

ការបកប្រែរបៀបផ្សេងទៀត: «ឱព្រះអម្ចាស់អើយ ខ្មាំងសត្រូវច្រើនណាស់!»

បានក្រោកឡើងប្រឆាំងនឹងទូលបង្គំ

ការប្រយុទ្ធប្រឆាំងនឹងនរណាម្នាក់ត្រូវបានគេនិយាយថា៖ កំពុងកើនឡើងប្រឆាំងនឹងទ្រង់។ ការបកប្រែរបៀបផ្សេងទៀត: «មកប្រឆាំងនឹងទូលបង្គំ»

សម្រាក

នេះប្រហែលជាពាក្យតន្ត្រីដែលប្រាប់មនុស្សពីរបៀបច្រៀង ឬលេងឧបករណ៍របស់ពួកគេនៅទីនេះ។ ការបកប្រែខ្លះសរសេរពាក្យភាសាហេប្រឺ

generated on Wed Sep 10 16:16:32 2025

ហើយការបកប្រែខ្លះមិនរួមបញ្ចូលវាទេ។
Psalms 3:3
ឱព្រះអម្ចាស់អើយ ព្រះអង្គជាខែលការពារទូលបង្គំ
ខែលការពារទាហាន។
ព្រះបាទដាវីឌមានបន្ទូលហាក់ដូចជាព្រះជាម្ចាស់ជាខែលការពាររបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ឱព្រះអម្ចាស់អើយសូមការពារទូលបង្គំដូចខែល»
ក៏ជាសិរីរុងរឿងរបស់ទូលបង្គំ
«ព្រះអង្គគឺជាសិរីរុងរឿងរបស់ទូលបង្គំ»។
ដោយហៅព្រះជាម្ចាស់ថាជាសិរីរុងរឿងរបស់ទ្រង់ ព្រះបាទដាវីឌមានរាជឱង្ការថា៖
ព្រះជាម្ចាស់គឺជាអ្នកដែលលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។
ដោយសារព្រះបាទដាវីឌទើបតែមានបន្ទូលអំពីខ្មាំងសត្រូវរបស់ទ្រង់
ហើយព្រះជាម្ចាស់ជាអ្នកការពារទ្រង់ ទ្រង់ប្រហែលជាចង់មានន័យថា
ព្រះជាម្ចាស់ប្រទានសិរីរុងរឿងដល់ទ្រង់
ដោយផ្តល់ជ័យជម្នះដល់ទ្រង់លើខ្មាំងសត្រូវរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គគឺជាអ្នកដែលផ្តល់ឲ្យទូលបង្គំនូវសិរីរុងរឿង»
ឬ «ព្រះអង្គគឺជាអ្នកដែលផ្តល់ឲ្យទូលបង្គំនូវជ័យជំនះ» (សូមមើល:figs-metonymy)
ព្រះអង្គគឺជាអ្នកលើកមុខទូលបង្គំឡើង
«ព្រះអង្គគឺជាអ្នកលើកមុខទូលបង្គំឡើង»
ផ្តល់ឲ្យនរណាម្នាក់នូវភាពក្លាហានត្រូវបានគេនិយាយថា៖
ជាការលើកមុខរបស់លោកឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គគឺជាអ្នកលើកទឹកចិត្តទូលបង្គំ»
ទូលបង្គំស្រែកដង្ហោយហៅ
ការប្រើសំឡេងរបស់មនុស្សម្នាក់ ដើម្បីបន្លឺសំឡេងត្រូវបាននិយាយ
ដូចជាការលើកសំឡេងរបស់លោក។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំស្រែកយំ»
សម្រាក
នេះប្រហែលជាពាក្យតន្ត្រីដែលប្រាប់មនុស្សពីរបៀបច្រៀង
ឬលេងឧបករណ៍របស់ពួកគេនៅទីនេះ។ ការបកប្រែខ្លះសរសេរពាក្យភាសាហេប្រឺ
ហើយការបកប្រែខ្លះមិនរួមបញ្ចូលវាទេ។
Psalms 3:5
បានប្រឆាំងនឹងខ្ញុំពីគ្រប់ទីកន្លែង
«បានឡោមព័ទ្ធខ្ញុំ ដើម្បីបំផ្លាញខ្ញុំ»
Psalms 3:7
តើនឡើង
ព្រះបាទដាវីឌរាជឱង្ការពីការចាប់ផ្តើមធ្វើអ្វីមួយដូចជាតើនឡើង។
ការបកប្រែរបៀបផ្សេងទៀត: «ចាត់វិធានការ» ឬ «ធ្វើអ្វីមួយ»
វាយពួកខ្មាំងរបស់ទូលបង្គំ...បំបាក់ធ្មេញរបស់មនុស្សពាល
ឃ្លាទាំងនេះនិយាយស្រដៀងគ្នា។ ឃ្លាថា «ខ្មាំងរបស់ទូលបង្គំ» និង «មនុស្សពាល»
សំដៅ ទៅក្រុមមនុស្សដដែល។
ដ្បិតព្រះអង្គនឹងវាយពួកខ្មាំងរបស់ទូលបង្គំលើថ្គាម
នេះជាវិធីប្រមាថមនុស្ស។
ព្រះបាទដាវីឌមានបន្ទូលដូចជាព្រះអម្ចាស់នឹងមកវាយបំផ្លាញខ្មាំងសត្រូវរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គនឹងជេរប្រមាថខ្មាំងសត្រូវរបស់ទូលបង្គំដូចជាអ្នកណាម្នាក់វាយពួកគេនៅលើថ្គាម»
ព្រះអង្គនឹងបំបាក់ធ្មេញរបស់មនុស្សពាល
សត្វវាយប្រហារដោយធ្មេញរបស់ពួកគេ។ បំបែកធ្មេញដកអំណាច
ដើម្បីវាយប្រហារ។
ព្រះបាទដាវីឌមានបន្ទូលដូចជាព្រះអម្ចាស់នឹងមកប្រយុទ្ធនឹងមនុស្សពាល។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គនឹងធ្វើឲ្យមនុស្សពាលពុំអាចធ្វើបាបទូលបង្គំដូចជាអ្នកដែលបំបាក់ធ្មេញសត្វសាហាវ»
សេចក្តីសង្គ្រោះគឺបានមកពីព្រះអម្ចាស់
នេះជានាម «ការសង្គ្រោះ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «ជួយ។»
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់សង្គ្រោះប្រជាជនរបស់ព្រះអង្គ»

---

4 ទំនុកពីសៀវភៅរបស់គ្រូចម្រៀង កំដរដោយក្រុមតន្ត្រីមានខ្សែ។ ទំនុករបស់ស្តេចដាវីឌ។[1]ព្រះជាម្ចាស់នៃសេចក្តីសុចរិតរបស់ទូលបង្គំអើយ!
ពេលទូលបង្គំដង្ហោយរកព្រះអង្គនោះសូមព្រះអង្គតបនឹងទូលបង្គំផង ពេលទូលបង្គំមានទុក្ខធុរៈព្រះអង្គបានធ្វើឲ្យទូលបង្គំធូរស្បើយ។ សូមអាណិតមេត្តាទូលបង្គំ ហើយ
ព្រះសណ្តាប់ពាក្យអធិស្ឋានរបស់ទូលបង្គំផង។
[2]មនុស្សទាំងឡាយអើយតើអ្នករាល់គ្នាជាន់ឈ្លីកិត្តិយសខ្ញុំដល់កាលណាទៀត? តើអ្នករាល់គ្នាចូលចិត្តចោទប្រកាន់ដោយឥតបានការនិងនិយាយកុហកមួលបង្កាច់ដល់
កាលណាទៀត? សម្រាក[3]ប៉ុន្តែ ត្រូវដឹងថា ព្រះអម្ចាស់តែងតែប្រោសប្រណីមនុស្សស្មោះត្រង់ពេលណាខ្ញុំស្រែកអង្វររកព្រះអម្ចាស់ទ្រង់ព្រះសណ្តាប់ខ្ញុំជានិច្ច។
[4]បើអ្នកញាប់ញ័ររក្នុងការភ័យក្លាច សូមកុំធ្វើបាប! តែត្រូវដេកគិតពិចារណា នៅក្នុងចិត្តរបស់អ្នកដោយស្ងៀមស្ងាត់ចុះ។ សម្រាក[5]ចូរថ្វាយយញ្ញបូជាដ៏សុចរិត ហើយពឹងផ្អែក
លើព្រះអម្ចាស់ចុះ។
[6]មានមនុស្សជាច្រើននិយាយថា៖ «តើអ្នកណានឹងបង្ហាញយើងអំពីការល្អទៅ?» ព្រះអម្ចាស់អើយ សូមពន្លឺនៃព្រះភ័ក្ត្ររបស់ព្រះអង្គដល់យើងផង។[7]ព្រះអង្គបានដាក់អំណរ
នៅក្នុងចិត្តទូលបង្គំ ច្រើនជាងអំណរដែលគេមាននៅពេលច្រូតស្រូវ និងបេះផ្លែទំពាំងបាយជូរដ៏បរិបូណ៌ទៅទៀត។[8]ពេលទូលបង្គំចូលដំណេកនោះទូលបង្គំនឹងដេកលក់
ដោយសុខសាន្ត ដ្បិត ឱព្រះអម្ចាស់អើយ មានតែព្រះអង្គទេដែលធ្វើឲ្យទូលបង្គំរស់នៅ ដោយសុខដុមរមនា។

Psalms 4:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ទំនុកពីសៀវភៅរបស់គ្រូចម្រៀង
«នេះគឺសម្រាប់អ្នកដឹកនាំតន្ត្រី ដើម្បីប្រើប្រាស់ក្នុងការថ្វាយបង្គំ»
កំដរដោយក្រុមតន្ត្រីមានខ្សែ
«ប្រជាជនគួរតែលេងឧបករណ៍ដែលមានខ្សែរជាមួយនឹងបទចំរៀងនេះ»
ទំនុករបស់ព្រះបាទដាវីឌ
អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ
២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
ពេលទូលបង្គំដង្ហោយរកតបនឹងទូលបង្គំផង
«ឆ្លើយតបមកទូលបង្គំពេលទូលបង្គំដង្ហោយរក» ឬ
«ជួយទូលបង្គំពេលទូលបង្គំដង្ហោយរក»
ព្រះជាម្ចាស់នៃសេចក្តីសុចរិតរបស់ទូលបង្គំអើយ!
«ព្រះជាម្ចាស់ ដែលបង្ហាញថាទូលបង្គំជាមនុស្សសុចរិត»
ពេលទូលបង្គំមានទុក្ខធុរៈព្រះអង្គបានធ្វើឲ្យទូលបង្គំធូរស្បើយ
កំពុងស្ថិតក្នុងគ្រោះថ្នាក់ត្រូវបានគេនិយាយថា៖ ស្ថិតនៅក្នុងចន្លោះតូចចង្អៀត។
ការបកប្រែរបៀបផ្សេងទៀត:
«សូមជួយសង្គ្រោះទូលបង្គំពេលទូលបង្គំស្ថិតនៅក្នុងគ្រោះថ្នាក់» (សូមមើល:figs-metaphor)
Psalms 4:2
ព័ត៌មានទូទៅ:
ព្រះបាទដាវីឌច្រៀងផ្នែកនេះ
ដូចជាទ្រង់កំពុងតែនិយាយជាមួយខ្មាំងសត្រូវរបស់ទ្រង់។
មនុស្សទាំងឡាយអើយ តើអ្នករាល់គ្នាជាន់ឈ្លីកិត្តិយសខ្ញុំដល់កាលណាទៀត?
ព្រះបាទដាវីឌប្រើសំណួរនេះ ដើម្បីស្តីបន្ទោសសត្រូវរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកបន្តធ្វើឲ្យកិត្តិយសរបស់ខ្ញុំអាម៉ាស់មុខឥតឈប់ឈរ!»
ធ្វើឲ្យកិត្តិយសរបស់ខ្ញុំក្លាយជាការអាម៉ាស់
ការនិយាយចំអកទ្រង់ជំនួសឲ្យការផ្តល់កិត្តិយសដល់ទ្រង់ត្រូវបានគេនិយាយថា៖
ធ្វើឲ្យកិត្តិយសរបស់ទ្រង់ក្លាយជាការអាម៉ាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្មាស់ខ្ញុំជំនួសឲ្យការផ្តល់កិត្តិយសដល់ខ្ញុំ» ឬ «នាំឲ្យខ្ញុំខ្មាស់អៀន
នៅពេលដែលអ្នកគួរតែផ្តល់កិត្តិយសដល់ខ្ញុំ»
តើអ្នករាល់គ្នាចូលចិត្តចោទប្រកាន់ដោយឥតបានការ និងនិយាយកុហកមួលបង្កាច់ដល់កាលណា
ទៀត?
ព្រះបាទដាវីឌប្រើសំណួរនេះ ដើម្បីស្តីបន្ទោសសត្រូវរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនៅតែបន្តចូលចិត្តចោទ

generated on Wed Sep 10 16:16:32 2025

ប្រកាន់របស់ដែលគ្មានតម្លៃ ហើយស្វែងរកការភូតកុហក។»
ចូលចិត្តអ្វីដែលឥតប្រយោជន៍ ... ស្វែងរកការភូតភរ
ឃ្លាទាំងពីរនេះគឺស្រដៀងនឹងអត្ថន័យ។ ការកុហកគឺគ្មានតម្លៃទេ។
ការបកប្រែរបៀបផ្សេងទៀត: «ចូលចិត្តអ្វីការកុហកដែលគ្មានតម្លៃ»
ព្រះអម្ចាស់តែងតែប្រោសប្រណីមនុស្សស្មោះត្រង់ពេលណាខ្ញុំស្រែកអង្វរ
«ព្រះអម្ចាស់រើសយកមនុស្សដែលកោតខ្លាចដល់ព្រះអង្គ»
Psalms 4:4
បើអ្នកញាប់ញ័រក្នុងការភ័យក្លាច
ទំនាក់ទំនងរវាង «ញាប់ញ័រ» និង «ការភ័យខ្លាច»
និងអ្នកណាដែលមនុស្សគួរភ័យខ្លាចអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ចូរកោតខ្លាចដល់ព្រះអម្ចាស់រហូតដល់កោតខ្លាចញាប់ញ័រ» ឬ
«ចូរកោតខ្លាចដល់ព្រះអម្ចាស់»
ញាប់ញ័រ
«អង្រន់»
រំពឹងគិតនៅក្នុងចិត្តរបស់អ្នក
បេះដូងតំណាងឲ្យគំនិតរបស់មនុស្ស។
ការគិតដោយយកចិត្តទុកដាក់ត្រូវបានគេនិយាយថា៖
ជាការសញ្ជឹងគិតនៅក្នុងចិត្តរបស់មនុស្សម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«គិតដោយប្រុងប្រយ័ត្ន»
ថ្វាយយញ្ញបូជាដ៏សុចរិត
«ថ្វាយយញ្ញបូជាត្រឹមត្រូវ»
ចូរទុកចិត្តលើព្រះអម្ចាស់
ការជឿទុកចិត្តត្រូវបានគេនិយាយដូចជាវត្ថុដែលអាចដាក់នៅកន្លែងណាមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ទុកចិត្តលើព្រះអម្ចាស់» ឬ «ទុកចិត្តលើព្រះអម្ចាស់»
Psalms 4:6
តើអ្នកណានឹងបង្ហាញយើងអំពីការល្អទៅ?
សំណួរនេះត្រូវបានប្រើ ដើម្បីស្នើសុំអ្វីមួយ
ឬដើម្បីបង្ហាញពីបំណងប្រាថ្នាអំពីអ្វីមួយដែលមិនបានកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត: «សូមបង្ហាញអ្វីដែលល្អដល់យើង» ឬ
«យើងសង្ឃឹមថាអ្នកណាម្នាក់នឹងបង្ហាញយើងនូវអ្វីដែលល្អ»
តើអ្នកណានឹងបង្ហាញយើងអំពីការល្អទៅ?
ការបង្ហាញអ្វីមួយដែលល្អតំណាងឲ្យការនាំមកនូវរបស់ល្អ វិនិយាយថា៖
របស់ល្អបានកើតឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«តើអ្នកណានឹងនាំរបស់ល្អមកយើង?» ឬ «តើអ្នកណានឹងនិយាយថា៖
មានអ្វីដែលបានកើតឡើង?»
សូមពន្លឺនៃព្រះភ័ក្ត្ររបស់ព្រះអង្គដល់យើងផង
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ធ្វើល្អចំពោះពួកគេដូចជាព្រះភ័ក្ត្ររបស់ព្រះអម្ចាស់បានបញ្ចាំងពន្លឺមកលើ
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើល្អចំពោះយើង»
ព្រះអង្គបានដាក់អំណរនៅក្នុងចិត្តទូលបង្គំ
បេះដូងតំណាងឲ្យមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានដាក់អំណរ
នៅក្នុងចិត្តទូលបង្គំ»
ព្រះអង្គបានដាក់អំណរនៅក្នុងចិត្តទូលបង្គំ ច្រើនជាងអំណរដែលគេមាន
ភាពអំណត្រូវបានគេនិយាយដូចជាវត្ថុដែលអាចផ្តល់ឲ្យ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គធ្វើឲ្យទូលបង្គំមានអំណរច្រើនជាងអ្នកដទៃ»
នៅពេលច្រូតស្រូវ និងបេះផ្លែទំពាំងបាយជូរដ៏បរិបូណ៌ទៅទៀត
«ស្រាថ្មី» អាចតំណាងឲ្យទំពាំងបាយជូរ។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលពួកគេច្រូតកាត់យ៉ាងបរិបូណ៌»
ពេលទូលបង្គំចូលដំណេកនោះទូលបង្គំនឹងដេកលក់ដោយសុខសាន្ត
សន្តិភាពត្រូវបានគេនិយាយដូចជាកន្លែងនោះ។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំចូលដំណេកនោះទូលបង្គំនឹងដេកលក់ដោយសុខសាន្ត» ឬ «ទូលបង្គំ
នឹងមិនភ័យខ្លាចគ្រោះថ្នាក់នៅពេលទូលបង្គំនឹងដេកលក់»
ធ្វើឲ្យទូលបង្គំរស់នៅ ដោយសុខដុមរមនា
ពាក្យថា «សុវត្ថភាព» និង «សន្តិសុខ» មានន័យថា ជាមូលដ្ឋានដូចគ្នា
និងបញ្ជាក់ពីសុវត្ថិភាពពេញលេញ។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឲ្យខ្ញុំមានសុវត្ថិភាពទាំងស្រុង»

---

5 ទំនុកពីសៀវភៅរបស់គ្រូចម្រៀង។ កំដរដោយខ្លុយ។ ទំនុករបស់ស្តេចដាវីឌ។[1]ព្រះអម្ចាស់អើយ! សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យរបស់ទូលបង្គំ! សូមទ្រង់ព្រះសណ្តាប់
សម្រែកឈឺចាប់ របស់ទូលបង្គំផង។[2]ព្រះជាម្ចាស់ ជាព្រះមហាក្សត្រនៃទូលបង្គំអើយ សូមយកព្រះហឫទ័យទុកដាក់នឹងសូរសម្រែករបស់ទូលបង្គំផងដ្បិតទូលបង្គំ
អធិស្ឋានរកព្រះអង្គ។[3]ព្រះអម្ចាស់អើយ! នៅពេលព្រឹក ព្រះអង្គព្រះសណ្តាប់សំឡេងរបស់ទូលបង្គំ ទូលបង្គំចូលមកគាល់ ហើយនៅរង់ចាំព្រះអង្គ តាំងពីព្រលឹម។
[4]ការពិតណាស់ ព្រះអង្គមិនមែនជាព្រះដែលសព្វព្រះហឫទ័យនឹងអំពើទុច្ចរិតនោះទេ មនុស្សអាក្រក់ពុំអាចនៅក្បែរព្រះអង្គបានឡើយ។
[5]ពួកអ្នកដែលមានអំនួតនឹងមិនអាចឈរក្នុងព្រះវត្តមានព្រះអង្គឡើយ ព្រះអង្គមិនសព្វព្រះហឫទ័យអស់អ្នកប្រព្រឹត្តអំពើទុច្ចរិតដែរ។[6]ព្រះអង្គនឹងធ្វើឲ្យពួកកុហកវិនាស
សាបសូន្យ។ ព្រះអម្ចាស់ស្អប់ខ្ពើមអ្នកបង្ហូរឈាម និងអ្នកមានល្បិចកល។
[7]ប៉ុន្តែ ទូលបង្គំវិញ ដោយសារតែសេចក្តីមេត្រីនិងភាពស្មោះត្រង់ដ៏អស្ចារ្យ ទូលបង្គំចូលមកក្នុងព្រះដំណាក់របស់ព្រះអង្គបាន ទូលបង្គំសូមក្រាបថ្វាយបង្គំព្រះអង្គ ដោយបែរ
មុខតម្រង់ទៅរកព្រះវិហារដ៏វិសុទ្ធ របស់ព្រះអង្គ។[8]ព្រះអម្ចាស់អើយ! មានមនុស្សជាច្រើនប្រឆាំងនឹងទូលបង្គំ! សូមដឹកនាំទូលបង្គំឲ្យធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ សូម
ពង្រាបផ្លូវរបស់ព្រះអង្គនៅមុខទូលបង្គំផង។
[9]ដ្បិត អ្នកទាំងនោះគ្មានពាក្យពិតក្នុងម៉ាត់របស់គេទេ ពួកគេគិតតែចង់បំផ្លិចបំផ្លាញអណ្តាតរបស់គេគ្រលាស់ចេញនូវពាក្យបញ្ឆើចបញ្ឆាលតែមានបង្អប់ទៅដោយពិសពុល
សម្រាប់ប្រហារជីវិត។[10]ព្រះជាម្ចាស់អើយ សូមដាក់ទោសគេទៅ! សូមឲ្យគេវិនាសអន្តរាយ ដោយសារគម្រោងការរបស់ខ្លួន គេបានប្រព្រឹត្តអំពើអាក្រក់ច្រើនរាប់មិនអស់
ព្រោះគេបះបោរប្រឆាំងនឹងព្រះអង្គ ដូច្នេះ សូមកាត់កាល់គេចោលទៅ។
[11]ប៉ុន្តែ អស់អ្នកដែលជ្រកកោនក្រោមម្លប់បារមីព្រះអង្គ គេនឹងមានអំណរ គេនឹងសប្បាយរីករាយរហូតតទៅ ហើយព្រះអង្គនឹងរក្សាការពារគេ អស់អ្នកដែលស្រឡាញ់
ព្រះនាមរបស់ព្រះអង្គ។[12]ដ្បិត ព្រះអម្ចាស់អើយ ព្រះអង្គប្រទានពរឲ្យមនុស្សសុចរិត ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ប្រៀបបាននឹងខែលការពារគេ។

Psalms 5:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។ (សូមមើល: និងfigs-parallelism)
កំដរដោយក្រុមតន្ត្រីមានខ្សែ
«ប្រជាជនគួរតែលេងឧបករណ៍ដែលមានខ្សែរជាមួយនឹងបទចំរៀងនេះ»
កំដរដោយខ្លុយ
«បទចម្រៀងនេះគួរតែត្រូវបានអមដោយមនុស្សដែលលេងឧបករណ៍ភ្លេងខ្យល់» ។
ទំនុករបស់ព្រះបាទដាវីឌ
អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ
២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យរបស់ទូលបង្គំ!
នេះគឺជាការអំពាវនាវរកជំនួយ។ ការបកប្រែរបៀបផ្សេងទៀត: «សូមស្តាប់ពាក្យ
របស់ទូលបង្គំដែលអំពាវនាវរកជំនួយ»
សម្រែកឈឺចាប់
សំឡេងតិចៗដែលមនុស្សបង្កើតជាមួយសំលេងនៅពេលពួកគេកំពុងរងទុក្ខ។
ពេលព្រឹកព្រះអង្គឮសម្រែករបស់ទូលបង្គំ...នៅពេលព្រឹកទូលបង្គំ
នឹងយកការទូលអង្វររបស់ទូលបង្គំមកថ្វាយព្រះអង្គ
ឃ្លាទាំងពីរនេះគឺស្រដៀងនឹងអត្ថន័យ។
ទូលបង្គំយកពាក្យទូលអង្វររបស់ទូលបង្គំមកថ្វាយព្រះអង្គ
«ទូលបង្គំនឹងធ្វើសំណើរបស់ខ្ញុំ» ឬ «ទូលបង្គំនឹងស្នើសុំព្រះអង្គនូវអ្វីដែលខ្ញុំត្រូវការ»
សង្ឃឹម
«សង្ឃឹមថា»
Psalms 5:4
ព្រះអម្ចាស់ស្អប់ខ្ពើមអ្នកបង្ហូរឈាម និងអ្នកមានល្បិចកល
ចាប់តាំងពីព្រះបាទដាវីឌកំពុងតែទូលទៅកាន់ព្រះអង្គនៅក្នុងទំនុកនេះការកាត់ទោសនេះអាចត្រូវបានបញ្ជ
«អ្នក» ការបកប្រែរបៀបផ្សេងទៀត: «ឱព្រះអម្ចាស់អើយ ព្រះអង្គស្អប់ខ្ពើមអ្នកបង្ហូរ

generated on Wed Sep 10 16:16:32 2025

ឈាម និងអ្នកមានល្បិចកល» ឬ «ព្រះអម្ចាស់អើយ
ព្រះអង្គស្អប់មនុស្សដែលប្រព្រឹត្តអំពើឃោរឃៅ ហើយបញ្ឆោតអ្នកដទៃ»
Psalms 5:7
ព្រះដំណាក់របស់ព្រះអង្គ
នេះសំដៅទៅលើព្រះវិហាររបស់ព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះវិហាររបស់ព្រះជាម្ចាស់»
សូមដឹកនាំទូលបង្គំឲ្យធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ
ព្រះបាទដាវីឌមានបន្ទូលអំពីសេចក្ដីសុចរិតដូចជាផ្លូវ និងការបង្រៀនដែលនាំមុខ។
ឃ្លាថា «សេចក្ដីសុចរិតរបស់អ្នក» មានន័យថា ព្រះជាម្ចាស់សុចរិត
ការបកប្រែរបៀបផ្សេងទៀត:
«បង្រៀនទូលបង្គំធ្វើអ្វីដែលសុចរិតដូចដែលអ្រែអង្គបានធ្វើ»
សូមពង្រាបផ្លូវរបស់ព្រះអង្គនៅមុខទូលបង្គំផង
ព្រះបាទដាវីឌនិយាយអំពីសេចក្ដីសុចរិតហាក់ដូចជាផ្លូវនោះ។
ផ្លូវត្រង់ងាយមើលឃើញឬដើរ។ ការបកប្រែរបៀបផ្សេងទៀត:
«បង្ហាញទូលបង្គំយ៉ាងច្បាស់ពីរបៀបរស់នៅត្រឹមត្រូវ»
Psalms 5:9
ព័ត៌មានទូទៅ:
ព្រះបាទដាវីឌនិយាយអំពីសត្រូវរបស់ទ្រង់។
ដ្បិត អ្នកទាំងនោះគ្មានពាក្យពិតក្នុងមាត់របស់គេទេ
សេចក្ដីពិតនៅក្នុងមាត់តំណាងឲ្យការនិយាយដោយស្មោះត្រង់។
ការបកប្រែរបៀបផ្សេងទៀត:
«សម្រាប់ពួកគេមិនដែលនិយាយអ្វីដែលជាការពិតទេ»
ពួកគេគិតតែចង់បំផ្លិចបំផ្លាញ
ផ្នែកខាងក្នុងបង្ហាញពីគំនិត និងបំណងប្រាថ្នារបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:
«គំនិតនិងសេចក្ដីប៉ងប្រាថ្នារបស់ពួកគេសុទ្ធតែអាក្រក់»
បំពង់ករបស់ពួកគេ
បំពង់កតំណាងឲ្យការនិយាយរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ការនិយាយរបស់ពួកគេ» ឬ «អ្វីដែលពួកគេនិយាយ»
បំពង់ករបស់ពួកគេគឺជាផ្នូរបើកចំហ
បំពង់ករបស់ពួកគេត្រូវបានគេនិយាយថា៖
ដូចជាផ្នូរបើកចំហរដែលត្រៀមដាក់សាកសព។ អាចមានន័យថា ១)
«ពួកគេនិយាយថា៖ ពួកគេនឹងសម្លាប់មនុស្ស» ឬ ២) «អ្វីដែលពួកគេ
និយាយសម្លាប់មនុស្ស»
ពួកគេនិយាយអណ្ដាត
«ពួកគេនិយាយរឿងល្អៗ អំពីមនុស្ស ដោយគ្មានអត្ថន័យពិត»
អណ្ដាតរបស់ពួកគេ
អណ្ដាតតំណាងឲ្យអ្វីដែលមនុស្សនិយាយ។
សូមឲ្យគេវិនាសអន្តរាយ ដោយសារគម្រោងការរបស់ខ្លួន
«គ្រោងការណ៍របស់ពួកគេអាចបណ្ដាលឲ្យពួកគេជួបប្រទះគ្រោះមហន្តរាយ» ឬ
«អាចឲ្យពួកគេក្លាយជាមិនសូវសំខាន់ដោយសារតែគ្រោងការណ៍របស់ពួកគេ»
គម្រោង
ផែនការធ្វើបាបប្រជាជន
ការធ្លាក់ចុះ
នេះគឺជាអ្វីដែលបណ្ដាលឲ្យមនុស្សម្នាក់ជួបប្រទះគ្រោះមហន្តរាយ
ឬបាត់បង់អំណាច។ ជួបគ្រោះមហន្តរាយ
ឬក្លាយជាមនុស្សមិនសូវសំខាន់ត្រូវបានគេនិយាយថា៖ ធ្លាក់ចុះ។
Psalms 5:11
អស់អ្នកដែលជ្រកកោនក្រោមម្លប់បារមីព្រះអង្គគេនឹងមានអំណរ
ព្រះជាម្ចាស់ត្រូវបានគេនិយាយដូចជាព្រះអង្គជាជម្រកដែលជាកន្លែងដែលមនុស្សអាចត្រូវបានការពារ។
ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យអស់អ្នកដែលទៅរកព្រះអង្គការពាររីករាយ»
អស់អ្នកដែលពឹងផ្អែកលើព្រះអង្គអរសប្បាយ ... ស្រែកដោយអំណរ ព្រោះព្រះងង្គការពារពួកគេ
ឃ្លាទាំងពីរនេះបង្ហាញពីគំនិតស្រដៀងគ្នា។
ជ្រកកោនក្រោមម្លប់បារមីព្រះអង្គ
ការចូលទៅរកព្រះអម្ចាស់ ដើម្បីការពារ ត្រូវបានគេនិយាយថា៖
ជាទីពឹងជ្រករបស់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត:
«ទៅរកព្រះអង្គដើម្បីទទួលបានការពារ»
អស់អ្នកដែលស្រឡាញ់ព្រះនាមរបស់ព្រះអង្គ
ព្រះនាមរបស់ព្រះអង្គតំណាងឲ្យទូលបង្គំ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលស្រឡាញ់ព្រះអង្គ»
ព្រះអង្គនឹងឡោមព័ទ្ធពួកគេដូចនឹងខែលការពារ
ការសព្វព្រះហឫទ័យរបស់ព្រះអង្គ ត្រូវបានគេនិយាយដូចជាខែល។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គនឹងសព្វព្រះហឫទ័យពួកគេ
និងការពារពួកគេដូចជាទាហានការពារខ្លួនលោកជាមួយនឹងខែលរបស់លោក» ឬ
«ពីព្រោះព្រះអង្គមានព្រះទ័យសប្បុរស ចំពោះពួកគេ ព្រះអង្គនឹងការពារពួកគេ»

---

6 ទំនុកពីសៀវភៅរបស់គ្រូចម្រៀង កំដរដោយក្រុមតន្ត្រីមានខ្សែ និងពិណប្រាំបីខ្សែ។ ទំនុករបស់ស្តេចដាវីឌ។[1]ឱព្រះអម្ចាស់អើយ! សូមកុំដេញទូលបង្គំដោយ
ព្រះពិរោធសូមកុំដាក់ទោសទូលបង្គំ ដោយការខ្ញាល់របស់ព្រះអង្គឡើយ។[2]ព្រះអម្ចាស់អើយ សូមសេចក្តីមេត្តារបស់ព្រះអង្គបានមកលើទូលបង្គំ ដ្បិត
ទូលបង្គំខ្សោយណាស់ សូមប្រោសទូលបង្គំឲ្យជាផង ព្រះអម្ចាស់អើយ ដ្បិតរូបកាយទូលបង្គំទាំងមូលញ័ររញាក់។
[3]ព្រលឹងរបស់ទូលបង្គំតប់ប្រមល់ជាខ្លាំង។ ប៉ុន្តែ ព្រះអម្ចាស់អើយ តើទុកឲ្យទូលបង្គំនៅក្នុងការនេះដល់កាលណាទៀត?[4]ព្រះអម្ចាស់អើយ សូមទ្រង់យាងមកវិញ ហើយ
សង្គ្រោះទូលបង្គំផង។ សូមរំដោះទូលបង្គំ ដោយព្រះហឫទ័យស្មោះត្រង់និងសម្ព័ន្ធមេត្រីនេះផង![5]ដ្បិតពេលស្លាប់ផុតទៅហើយ គ្មាននរណាអាចនឹកដល់ព្រះអង្គបានទៀត
ទេ។ ពុំដែលមាននរណាសរសើរតម្កើងព្រះអង្គ នឹងអរព្រះគុណដែរ។
[6]ទូលបង្គំស្រែកថ្ងូរ ហើយកាន់តែល្វើយទៅៗ។ រៀងរាល់យប់ ទូលបង្គំយំសោកនៅលើគ្រែ ហើយបង្ហូរទឹកភ្នែកជោកខ្នើយ។[7]ភ្នែកទូលបង្គំក៏ប្រែទៅជាស្រវាំង ព្រោះតែ
បច្ចាមិត្តរបស់ទូលបង្គំ។ ទុក្ខកង្វល់បានធ្វើឲ្យទូលបង្គំស្លក់មុខ។
[8]សូមដកការនេះចេញពីទូលបង្គំទៅ អស់អ្នកដែលប្រព្រឹត្តអំពើទុច្ចរិតអើយ ដ្បិតព្រះអម្ចាស់បានឮសម្រែកនៃការយំសោករបស់ខ្ញុំ។[9]ព្រះអម្ចាស់ទ្រង់ព្រះសណ្តាប់ឮពាក្យ
ទទូចអង្វររបស់ខ្ញុំ ព្រះអម្ចាស់ទទួលពាក្យអធិស្ឋានរបស់ខ្ញុំហើយ។[10]សូមឲ្យខ្មាំងសត្រូវទាំងប៉ុន្មានរបស់ខ្ញុំ ត្រូវអាម៉ាស់ និងញ័ររន្ធត់ ហើយឲ្យគេដកខ្លួនថយទៅវិញ ទាំង
អៀនខ្មាសយ៉ាងខ្លាំង។

Psalms 6:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។ (សូមមើល: និងfigs-parallelism)
ទំនុកពីសៀវភៅរបស់គ្រូចម្រៀង
«នេះគឺសម្រាប់អ្នកដឹកនាំតន្ត្រី ដើម្បីប្រើប្រាស់ក្នុងការថ្វាយបង្គំ»
នៅលើឧបករណ៍មានខ្សែ
«មនុស្សគួរតែលេងឧបករណ៍ដែលមានខ្សែរជាមួយបទចម្រៀងនេះ»
ពិណប្រាំបីខ្សែ
នេះអាចសំដៅទៅលើរចនាប័ទ្មរបស់តន្ត្រី។
ទំនុករបស់ព្រះបាទដាវីឌ
អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ
២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុតម្តើងគឺមានលក្ខណៈដូចនឹងទំនុករបស់ស្តេចដាវីឌ។
រូបកាយទូលបង្គំទាំងមូលញ័ររញាក់
ឆ្អឹងតំណាងឲ្យរាងកាយទាំងមូល។
រាងកាយរបស់ទ្រង់ប្រហែលជារញ្ជួយព្រោះទ្រង់ឈឺ ឬហត់ខ្លាំង។
ការបកប្រែរបៀបផ្សេងទៀត: «រាងកាយរបស់ទូលបង្គំទាំងមូលញ័រ»
Psalms 6:3
តប់ប្រមល់ជាខ្លាំង
«ភ័យរន្ធត់» ឬ «ព្រួយបារម្ភ»
តើទុកឲ្យទូលបង្គំនៅក្នុងការនេះដល់កាលណាទៀត?
ព្រះបាទដាវីឌប្រើសំណួរនេះ ដើម្បីបង្ហាញថា
ទ្រង់មិនចង់បន្តមានអារម្មណ៍ទន់ខ្សោយ និងបញ្ហាទៀតទេ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «សូមមេត្តាកុំទុករឿងនេះតទៅទៀត!»
ព្រះអម្ចាស់អើយ សូមទ្រង់យាងមកវិញ
ព្រះបាទដាវីឌមានបន្ទូលអំពីព្រះជាម្ចាស់ដែលមានព្រះហឫទ័យសប្បុរសចំពោះទ្រង់
នៅពេលដែលព្រះជាម្ចាស់វិលត្រឡប់មកទ្រង់វិញ។ ការបកប្រែរបៀបផ្សេងទៀត:
«ឱព្រះអម្ចាស់អើយ សូមយាងមករកទូលបង្គំវិញ» ឬ «ឱព្រះអម្ចាស់អើយ
សូមអាណិតមេត្តាទូលបង្គំផង»
ដ្បិត ពេលស្លាប់ផុតទៅហើយ គ្មាននរណាអាចនឹកដល់ព្រះអង្គបានទៀតទេ។ ពុំដែលមាននរណា
សរសើរតម្កើងព្រះអង្គ នឹងអរព្រះគុណដែរ?
ប្រយោគទាំងពីរនេះបង្ហាញពីអត្ថន័យស្រដៀងគ្នា។
ដ្បិតពេលស្លាប់ផុតទៅហើយ គ្មាននរណាអាចនឹកដល់ព្រះអង្គបានទៀតទេ
ការចងចាំតំណាងឲ្យការសរសើរតម្កើង។ ការបកប្រែរបៀបផ្សេងទៀត: «ដ្បិត
ពេលមនុស្សស្លាប់ គេនិងលែងសរសើរអ្នកទៀតហើយ»
ពុំដែលមាននរណាសរសើរតម្កើងព្រះអង្គ នៅក្នុងស្ថានមនុស្សស្លាប់ឡើយ?
ព្រះបាទដាវីឌប្រើសំណួរនេះ ដើម្បីបញ្ជាក់ថា គ្មាននរណាម្នាក់នៅក្នុងស្ថានមនុស្ស
ស្លាប់អរគុណព្រះអង្គទេ។ ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្នកណាម្នាក់នៅក្នុង
ស្ថានមនុស្សស្លាប់នឹងអរគុណព្រះអង្គទេ!» ឬ
«មនុស្សស្លាប់មិនអាចសរសើរព្រះអង្គបានទេ!»
Psalms 6:6
ទូលបង្គំនឿយហត់នឹងការថ្ងូររបស់ទូលបង្គំ
ការថ្ងូររបស់ទ្រង់តំណាងឲ្យការឈឺចាប់ ឬទុក្ខព្រួយដែលទ្រង់មាន។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំនឿយហត់
ដោយព្រោះការឈឺចាប់របស់ទូលបង្គំ»
ទូលបង្គំយំសោកនៅលើគ្រែ ហើយបង្ហូរទឹកភ្នែកជោកខ្នើយ
ប្រយោគទាំងពីរនេះមានអត្ថន័យដូចគ្នា។
ទូលបង្គំយំសោកនៅលើគ្រែ
«ទូលបង្គំធ្វើឲ្យគ្រែរបស់ទូលបង្គំសើម ដោយទឹកភ្នែករបស់ទូលបង្គំ» ឬ
«គ្រែរបស់ទូលបង្គំសើមណាស់ ដោយសារតែទឹកភ្នែករបស់ទូលបង្គំ»
ទូលបង្គំបង្ហូរទឹកភ្នែកជោកខ្នើយរបស់ទូលបង្គំ
«ទូលបង្គំធ្វើឲ្យទឹកភ្នែកបង្ហូរជោកខ្នើយរបស់ទូលបង្គំ»
ភ្នែកទូលបង្គំក៏ប្រែទៅជាស្រវាំង
សមត្ថភាពក្នុងការមើលឃើញត្រូវបានគេនិយាយលក្ខណៈនឹងភ្នែក។
ការបកប្រែរបៀបផ្សេងទៀត: «ចក្ខុរបស់ខ្ញុំគឺព្រិលៗ» ឬ
«ខ្ញុំមិនអាចមើលឃើញច្បាស់ទេ»
ទុក្ខកង្វល់
ទុក្ខកង្វល់នៅទីនេះតំណាងឲ្យការយំ។ ការបកប្រែរបៀបផ្សេងទៀត: «មកពីយំ» ឬ
«ព្រោះខ្ញុំយំខ្លាំង»
Psalms 6:8
ព្រះអម្ចាស់ទ្រង់ព្រះសណ្ដាប់ឮពាក្យ ទទូចអង្វររបស់ខ្ញុំ... ព្រះអម្ចាស់ទទួលពាក្យអធិស្ឋានរបស់ខ្ញុំ
ហើយ
ខ្សែទាំងពីរនេះមានអត្ថន័យស្រដៀងគ្នាខ្លាំងណាស់។
ព្រះអម្ចាស់ទទួលពាក្យអធិស្ឋានរបស់ខ្ញុំហើយ
ការសុខចិត្តធ្វើតាមអ្វីដែលស្តេចដាវីឌបានអធិដ្ឋានគឺបានទទួលយកពេលដែលទ្រង់ព្រមទទួលយកសេចក្តី
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់នឹងឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ខ្ញុំ»

---

7 [1]ទំនួញរបស់ស្តេចដាវីឌ ព្រះអង្គសូត្រថ្វាយព្រះជាម្ចាស់ នៅពេលមានរឿងជាមួយមនុស្សម្នាក់ឈ្មោះគូស ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន។ ព្រះអម្ចាស់ជាព្រះនៃទូលបង្គំ
អើយ! ទូលបង្គំសូមយកព្រះអង្គធ្វើជាទីពឹងជ្រក សូមសង្គ្រោះទូលបង្គំ សូមរំដោះទូលបង្គំ ឲ្យរួចផុតពីអស់អ្នក ដែលបៀតបៀនទូលបង្គំផង។[2]ទោះបី មានគេហែក
ទូលបង្គំ ដូចសត្វសិង្ហខាំរំពានាំយកទៅ ហើយគ្មានអ្នកណានឹងនាំទូលបង្គំទៅកន្លែងសុវត្ថិភាពឡើយ។
[3]ព្រះអម្ចាស់ជាព្រះនៃទូលបង្គំអើយ! ទូលបង្គំមិនដែលបានធ្វើតាមពាក្យរបស់សត្រូវរបស់ទូលបង្គំឡើយ ហើយក៏មិនដែលធ្វើអំពើទុច្ចរិតដោយដៃទូលបង្គំដែរ។
[4]ទូលបង្គំមិនដែលធ្វើអ្វីដែលខុសដល់អ្នកណា ដែលកំពុងនៅក្នុងសេចក្តីសុខសានជាមួយទូលបង្គំឡើយ
ឬក៏ធ្វើឲ្យអ្នកណាម្នាក់ខ្មាស់ទោះបីជាអ្នកនោះជំទាស់និងទូលបង្គំ។
[5]បើសិនទូលបង្គំទូលមិនពិតទេ សូមឲ្យខ្មាំងសត្រូវដេញទាន់ និងប្រហារទូលបង្គំទៅចុះ ឲ្យគេជាន់ឈ្លីជីវិតទូលបង្គំនៅនឹងដី និងឲ្យគេយកកិត្តិយសរបស់ទូលបង្គំ ទៅ
ទម្លាក់ក្នុងភក់ជ្រាំចុះ។ សម្រាក
[6]តើនឡើង ព្រះអម្ចាស់អើយ សូមតើនឡើង សូមទ្រង់ព្រះពិរោធតបនឹងអំពើឃោរឃៅ របស់បច្ចាមិត្តទូលបង្គំ សូមជួយការពារទូលបង្គំផង ដ្បិតព្រះអង្គហ្នឹងហើយ ដែល
បានតែងតាំងច្បាប់ឡើង។[7]សូមឲ្យប្រទេសនានា នាំគ្នាមកជុំវិញព្រះអង្គ សូមព្រះអង្គគ្រប់គ្រងលើពួកគេទាំងអស់គ្នា។
[8]ព្រះអម្ចាស់ជាចៅក្រមវិនិច្ឆ័យប្រជារាស្ត្រទាំងអស់ ព្រះអម្ចាស់អើយ សូមរកយុត្តិធម៌ឲ្យទូលបង្គំផង ដ្បិតទូលបង្គំសុចរិត ហើយក៏ទៀងត្រង់ដែរ។
[9]សូមឲ្យការអាក្រក់នៃអំពើទុច្ចរិតឈានដល់ទីបញ្ចប់ ប៉ុន្តែ សូមជួយមនុស្សសុចរិត ឲ្យមានចិត្តរឹងប៉ឹងឡើង ព្រះដ៏សុចរិតអើយ ព្រះអង្គឈ្វេងយល់ចិត្តថ្លើមរបស់មនុស្ស។
[10]ព្រះជាម្ចាស់ជាខែលរបស់ទូលបង្គំ ព្រះអង្គសង្គ្រោះអស់អ្នក ដែលមានចិត្តទៀងត្រង់។[11]ព្រះជាម្ចាស់ គឺជាព្រះដ៏សុចរិតហើយយុត្តិធម៌
ព្រះជាម្ចាស់ដែលប្រឆាំងនឹងអំពើអាក្រក់រាល់ថ្ងៃផងដែរ។
[12]ប្រសិនបើ មនុស្សមិនប្រែចិត្ត ព្រះជាម្ចាស់នឹងសំលៀងមុខដាវ ហើយត្រៀមសម្រាប់ការប្រយុទ្ធ។[13]ព្រះជាម្ចាស់ នឹងរៀបចំអាវុធដើម្បីប្រហារអ្នកនោះ ព្រមទាំងត្រៀមព្រួញ
ភ្លើងចាំជាស្រេចផង។
[14]សូមគិតតែពីប្រព្រឹត្តអំពើទុច្ចរិត ហើយរិះគិតពីអំពើឧក្រិដ្ឋ អ្នកនោះនឹងបង្កើតបានការបោកបញ្ឆោត។[15]អ្នកនោះនឹងជីករណ្តៅកាន់តែជ្រៅទៅៗ អ្នកនោះនឹងធ្លាក់ទៅក្នុង
រណ្តៅ ដែលខ្លួនជីកនោះជាមិនខាន។[16]អំពើទុច្ចរិតដែលគេប្រព្រឹត្ត នឹងធ្លាក់មកលើក្បាលគេវិញ អំពើឃោរឃៅរបស់គេ ក៏នឹងធ្លាក់មកលើលលាដ៍ក្បាលគេវិញដែរ។
[17]ខ្ញុំនឹងសរសើរតម្កើងព្រះអម្ចាស់ ដ្បិតព្រះអង្គយុត្តិធម៌ ខ្ញុំនឹងច្រៀងលើកតម្កើងព្រះនាមព្រះអម្ចាស់ ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត។

Psalms 7:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ទំនួញរបស់ព្រះបាទដាវីឌ
«នេះជាចម្រៀងដែលព្រះបាទដាវីឌបាននិពន្ធ»
នៅពេលមានរឿងជាមួយមនុស្សម្នាក់ឈ្មោះគូស ក្នុងកុលសម្ព័ន្ធបេនយ៉ាមីន
ឃ្លាថា «ពាក្យ» តំណាងឲ្យអ្វីដែលទ្រង់បាននិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«អំពីអ្វីដែលមានជាមួយជាបុរសម្នាក់មកពីកុលសម្ព័ន្ធបេនយ៉ាមីន បាននិយាយ»
ទូលបង្គំសូមយកព្រះអង្គធ្វើជាទីពឹងជ្រក
ការចូលទៅរកព្រះអម្ចាស់ ដើម្បីទទួលបានការពារ ត្រូវបានគេនិយាយថា៖
ជាទីពឹងជ្រករបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«ទៅរកព្រះអង្គដើម្បីការពារ!»
ពួកគេនឹងហែកទូលបង្គំ ដូចសត្វសិង្ហខាំរំពានាំយកទៅ
ព្រះបាទដាវីឌបាននិយាយអំពីខ្មាំងសត្រូវរបស់ទ្រង់វាយប្រហារទ្រង់ដូចជាពួកគេនឹងទារ**ជ្រីវជំរាយ**ហែកសត្វ
ហើយហែកវាជាបំណែកៗ ដូចជាសត្វសិង្ហ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងសម្លាប់ទូលបង្គំយ៉ាងសាហាវដូចជាសត្វ
សិង្ហដែលហែកខ្លួនរបស់ជនរងគ្រោះហើយហែកវាជាបំណែកៗ» ឬ
«ពួកគេនឹងសម្លាប់ទូលបង្គំ ដោយហិង្សា»។
ហើយគ្មានអ្នកណានឹងនាំទូលបង្គំទៅកន្លែងសុវត្ថិភាពឡើយ
«ហើយគ្មាននរណាម្នាក់អាចជួយទូលបង្គំបានទេ»
Psalms 7:3
ហើយក៏មិនដែលធ្វើអំពើទុច្ចរិតដោយដៃទូលបង្គំដែរ
ដៃតំណាងឲ្យអ្វីដែលមនុស្សម្នាក់ធ្វើ។
មានភាពអយុត្តិធម៌មកលើពួកគេតំណាងឲ្យការធ្វើអ្វីមួយដែលមិនត្រឹមតែ។
ការបកប្រែរបៀបផ្សេងទៀត: «គ្មានភាពអយុត្តិធម៌នៅអ្វីដែលទូលបង្គំបានធ្វើ» ឬ
«ខ្ញុំមិនបានធ្វើអ្វីដែលអយុត្តិធម៌ចំពោះនរណាម្នាក់ឡើយ»
Psalms 7:5
ជីវិតរបស់ទូលបង្គំ
ជ្រីវជំរាយឈ្លានពានសត្វ**ជ្រីវ**ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំ»
ដេញទាន់

generated on Wed Sep 10 16:16:32 2025

«ចាប់យកវា» ឬ «ឈានដល់វា។» នេះតំណាងឲ្យការចាប់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ចាប់ទូលបង្គំ»
ឲ្យគេជាន់ឈ្លីជីវិតទូលបង្គំនៅនឹងដី
នេះ «រាងកាយរស់របស់ទូលបង្គំ» តំណាងឲ្យអ្នកនិពន្ធ។
ការបកប្រែរបៀបផ្សេងទៀត: «អនុញ្ញាតឲ្យសត្រូវរបស់ខ្ញុំបំផ្លាញទូលបង្គំ»
ទៅទម្លាក់ក្នុងភក់ជ្រាំចុះ
នេះមានន័យថា៖ ដេកស្លាប់ហើយ ដោយមិនញញើតនឹងភាពអាម៉ាស់។
Psalms 7:6
តើនឡើង ព្រះអម្ចាស់អើយ ដោយព្រះពិរោធរបស់ព្រះអង្គ
ការក្រោកឈរតំណាងឲ្យធ្វើអ្វីមួយ ឬធ្វើសកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើអ្វីមួយដោយព្រះពិរោធរបស់ព្រះអង្គ» ឬ
«ខឹងនឹងសត្រូវរបស់ខ្ញុំហើយចាត់វិធានការ»
សូមតើនឡើង សូមទ្រង់ព្រះពិរោធតបនឹងអំពើឃោរឃៅ របស់បច្ចាមិត្តទូលបង្គំ
ការប្រយុទ្ធប្រឆាំងនឹងប្រជាជន ត្រូវបានគេនិយាយថា៖
កំពុងឈរប្រឆាំងនឹងពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រយុទ្ធប្រឆាំងនឹងកំហឹងរបស់ខ្មាំងសត្រូវរបស់ខ្ញុំ» ឬ
«វាយប្រហារសត្រូវរបស់ខ្ញុំដែលខឹងនឹងខ្ញុំ»
អំពើឃោរឃៅ របស់បច្ចាមិត្តទូលបង្គំ
កំហឹងរបស់ពួកគេតំណាងឲ្យការវាយប្រហាររបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ការវាយប្រហាររបស់សត្រូវរបស់ខ្ញុំ» ឬ
«សត្រូវរបស់ខ្ញុំដែលវាយប្រហារខ្ញុំ»
សូមតើនឡើង
ការភ្ញាក់ពីដំណាងតំណាងឲ្យចាប់ផ្តើមធ្វើអ្វីមួយ ឬចាត់វិធានការធ្វើអ្វីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ចាត់វិធានការធ្វើអ្វីមួយ» ឬ «ធ្វើអ្វីមួយ»
សម្រាប់ជាប្រយោជន៍របស់ទូលបង្គំ
«សម្រាប់ទូលបង្គំ» ឬ «ដើម្បីជួយទូលបង្គំ»
សូមឲ្យប្រទេសនានា នាំគ្នាមកជុំវិញ
ឃ្លាថា «ប្រទេសនានា»
តំណាងឲ្យកងទ័ពទាំងអស់ដែលបានប្រមូលផ្តុំដើម្បីវាយប្រហារ។
សូមព្រះអង្គគ្រប់គ្រងលើពួកគេទាំងអស់គ្នា
មនុស្សដែលគ្រប់គ្រងត្រូវបានគេនិយាយថា៖ ជាអ្នកត្រួតត្រាលើពួកគេ។
កន្លែងដ៏ត្រឹមត្រូវរបស់ព្រះអម្ចាស់សំដៅទៅលើឋានសួគ៌ ឬការគ្រប់គ្រងទូទៅ។
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់គ្រងពួកគេពីឋានសួគ៌» ឬ
«គ្រប់គ្រងលើពួកគេ»
Psalms 7:8
សូមរកយុត្តិធម៌ឲ្យទូលបង្គំ
«បង្ហាញពួកគេថា ទូលបង្គំមិនមានកំហុសទេ»
សូមជួយមនុស្សសុចរិត ឲ្យមានចិត្តរឹងប៉ឹងឡើង
«ធ្វើឲ្យមនុស្សសុចរិតរឹងមាំ» ឬ «ធ្វើឲ្យមនុស្សសុចរិតរុងរឿង»
ព្រះអង្គឈ្វេងយល់ចិត្តថ្លើមរបស់មនុស្ស
ដួងចិត្ត និងគំនិតតំណាងឲ្យបំណងប្រាថ្នា និងគំនិតរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គដែលដឹងពីគំនិតខាងក្នុងរបស់យើង»
Psalms 7:10
ព្រះជាម្ចាស់ជាខែលរបស់ទូលបង្គំ
ពាក្យថា «ខែល» តំណាងឲ្យការការពាររបស់ព្រះជាម្ចាស់។
ព្រះជាម្ចាស់ដែលប្រឆាំងនឹងអំពើអាក្រក់រាល់ថ្ងៃផងដែរ
តើអ្នកណាដែលធ្វើឲ្យព្រះជាម្ចាស់ទ្រង់ក្រោធនឹងគេ
អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ដែលទ្រង់ក្រោធនឹងមនុស្សអាក្រក់រាល់ថ្ងៃ»
Psalms 7:12
ព្រះជាម្ចាស់នឹងសំលៀងមុខដាវ ហើយត្រៀមសម្រាប់ការប្រយុទ្ធ
នៅក្នុងខ ១២ និង ១៣
ស្តេចដាវីឌនិយាយអំពីព្រះជាម្ចាស់ដែលសំរេចដាក់ទណ្ឌកម្មមនុស្សទុច្ចរិតហាក់
ដូចជាព្រះជាម្ចាស់ជាអ្នកចំបាំងដែលត្រៀមប្រយុទ្ធនឹងពួកគេដោយអាវុធ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់នឹងចាត់វិធានការប្រឆាំងនឹងគេ
ដូចជាអ្នកចំបាំងម្នាក់ដែលដាវរបស់ព្រះអង្គ
ហើយរៀបចំធ្នូរបស់ព្រះអង្គសម្រាប់ការប្រយុទ្ធ»
Psalms 7:14
អ្នកមានផ្ទៃពោះដែលមានអំពើអាក្រក់ ... មានផ្ទៃពោះគំរោងបំផ្លិចបំផ្លាញ ... ផ្តល់
កំណើតដល់ការកុហកដែលបង្កអន្តរាយ
ព្រះបាទដាវីឌនិយាយអំពីអ្វីដែលមនុស្សអាក្រក់ធ្វើដូចជាមនុស្សមានផ្ទៃពោះ
ហើយអំពើអាក្រក់គឺមកជាទារក។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សអាក្រក់។
គេមានផែនការបំផ្លាញមនុស្ស និងការបង្កគ្រោះថ្នាក់»
អំពើទុច្ចរិតដែលគេប្រព្រឹត្ត នឹងធ្លាក់មកលើក្បាលគេវិញ អំពើឃោរឃៅរបស់គេ ក៏នឹងធ្លាក់មកលើ
លលាដ៍ក្បាលគេវិញដែរ
ការបំផ្លាញដោយអំពើហឹង្សា ត្រូវបានគេនិយាយថា៖
ដូចជាពួកគេវាយក្បាលរបស់មនុស្សម្នាក់ ឬដួលលើវា។
ការបកប្រែរបៀបផ្សេងទៀត: «ផែនការបំផ្លាញខ្លួនឯងបំផ្លាញគេ
ព្រោះអំពើឃោរឃៅរបស់គេវាយប្រហារគេវិញ» ឬ
«នៅពេលដែលគេមានផែនការបំផ្លាញអ្នកដទៃ អ្នកដទៃបំផ្លាញគេវិញ
នៅពេលគេវាយប្រហារអ្នកដទៃ អ្នកដទៃវាយប្រហារវិញ»

---

8 ទំនុកពីសៀវភៅរបស់គ្រូចម្រៀង សម្រាប់ពិណពីក្រុងកាថ។ ទំនុករបស់ស្តេចដាវីឌ។[1]ព្រះអម្ចាស់ ជាអម្ចាស់របស់យើង! ព្រះនាមរបស់ព្រះអង្គថ្កុំថ្កើងរុងរឿង ពាសពេញ
លើផែនដីទាំងមូល! ព្រះអង្គថ្កុំថ្កើងរុងរឿងលើសផ្ទៃមេឃទៅទៀត។[2]ចេញពីពាក្យសរសើរតម្កើងរបស់ក្មេងៗ និងទារក ធ្វើជាកម្លាំងប្រយុទ្ធនឹងបច្ចាមិត្តរបស់ព្រះអង្គ
ដើម្បីបង្ក្រាបខ្មាំងសត្រូវដ៏កាចសាហាវ ឲ្យវិនាសសាបសូន្យទៅ។
[3]ពេលទូលបង្គំសម្លឹងមើលផ្ទៃមេឃ ដែលជាស្នាព្រះហស្តរបស់ព្រះអង្គ ហើយសម្លឹងមើលដួងច័ន្ទ និងហ្វូងតារាដែលព្រះអង្គដាក់នៅលើមេឃ
នោះ[4]អ្វីដែលសំខាន់នោះគឺមនុស្សមានឋានៈអ្វីបានជាព្រះអង្គនឹកគិតដល់គេដូច្នេះ តើបុត្រមនុស្សជាអ្វីបានជាព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងគេយ៉ាងនេះ?[5]ប៉ុន្តែ
ព្រះអង្គបានធ្វើឲ្យគេមានឋានៈទាបជាងទេវតាតែបន្តិចប៉ុណ្ណោះ ព្រះអង្គប្រទានសិរីរុងរឿងនិងកិត្តិយសដល់គេ។
[6]ព្រះអង្គបានតាំងគេឲ្យគ្រប់គ្រង លើស្នាព្រះហស្តរបស់ព្រះអង្គ ព្រះអង្គបានដាក់អ្វីៗទាំងអស់ ឲ្យនៅក្រោមជើងរបស់គេដែរ[7]អស់ទាំងចៀម ទាំងគោ និងសត្វព្រៃ[8]សត្វហើរ
លើអាកាស និងត្រីនៅក្នុងសមុទ្រ គឺសត្វផងទាំងពួងដែលហែលនៅបាតសមុទ្រ។
[9]ឱព្រះអម្ចាស់ ជាម្ចាស់របស់យើងខ្ញុំអើយ ព្រះនាមរបស់ព្រះអង្គថ្កុំថ្កើងរុងរឿងពាសពេញលើផែនដីទាំងមូល!

Psalms 8:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។ (សូមមើល: និងfigs-parallelism)
ទំនុកពីសៀវភៅរបស់គ្រូចម្រៀង
«នេះគឺសម្រាប់អ្នកដឹកនាំតន្ត្រី ដើម្បីប្រើប្រាស់ក្នុងការថ្វាយបង្គំ»
សម្រាប់ពិណពីក្រុងកាថ
នេះអាចសំដៅទៅលើរចនាប័ទ្មនៃតន្ត្រី។
ទំនុករបស់ស្តេចដាវីឌ
អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ
២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
នៅលើផែនដីទាំងមូលព្រះនាមរបស់ព្រះអង្គអស្ចារ្យណាស់!
«ព្រះនាម» របស់ព្រះជាម្ចាស់ តំណាងឲ្យការទាំងមូលរបស់ព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៅទូទាំងពិភពលោកដឹងថា
ព្រះអង្គពូកែខ្លាំងណាស់»
ចេញពីពាក្យសរសើរតម្កើងរបស់ក្មេងៗ និងទារក
ការធ្វើឲ្យទារកសរសើរព្រះជាម្ចាស់ ត្រូវបានគេនិយាយថា៖
ការសរសើរគឺជាវត្ថុដែលព្រះជាម្ចាស់បានបង្កើតនៅក្នុងមាត់ទារក
ហើយបង្កើតចេញមក។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានផ្តល់ឲ្យទារក
និងក្មេងៗនូវសមត្ថភាពក្នុងការសរសើរព្រះអង្គ»
Psalms 8:3

generated on Wed Sep 10 16:16:32 2025

ផ្ទៃមេឃដែលជាស្នាព្រះហស្តរបស់ព្រះអង្គ
ស្នាព្រះហស្តរបស់ព្រះជាម្ចាស់តំណាងឲ្យព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត:
«ផ្ទៃមេឃដែលព្រះអង្គបានបង្កើត»
អ្វីដែលសំខាន់នោះគឺមនុស្សមានឋានៈអ្វីបានជាព្រះអង្គនឹកគិតដល់គេដូច្នេះ តើបុត្រមនុស្សជាអ្វីបានជាព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងគេយ៉ាងនេះ?
ការកត់សម្គាល់ទាំងនេះត្រូវបានបង្ហាញជាទម្រង់សំណួរ
ដើម្បីបន្ថែមការសង្កត់ធ្ងន់។ ការបកប្រែរបៀបផ្សេងទៀត:
«នេះពិតជាអស្ចារ្យដែលព្រះអង្គគិតអំពីមនុស្ស
ហើយមានការព្រួយបារម្ភអំពីពួកគេ!»
ពូជមនុស្ស ... មនុស្សលោក
ឃ្លាទាំងពីរនេះសំដៅទៅលើមនុស្សទូទៅ។
ព្រះអង្គបានគ្រងរាជ្យលើពួកគេដោយសិរីរុងរឿងនិងកិត្តិយស
សិរីរុងរឿង និងកិត្តិយសត្រូវបានគេនិយាយថា៖ ដូចជាមកុដ។ ពាក្យថា
«សិរីរុងរឿង» និង «កិត្តិយស» គឺស្រដៀងនឹងអត្ថន័យដែរ។
ការបកប្រែរបៀបផ្សេងទៀត: «បានផ្តល់ឲ្យពួកគេនូវភាពរុងរឿង និងកិត្តិយស» ឬ
«បានធ្វើឲ្យពួកគេក្លាយជាស្តេច»
Psalms 8:6
ព្រះអង្គបានតាំងគេឲ្យគ្រប់គ្រង លើស្នាព្រះហស្តរបស់ព្រះអង្គ...ព្រះអង្គបានដាក់អ្វីៗទាំងអស់ ឲ្យនៅក្រោមជើងរបស់គេដែរ
ឃ្លាទាំងពីរនេះបង្ហាញពីអត្ថន័យស្រដៀងគ្នា។
ព្រះអង្គធ្វើឲ្យទ្រង់... នៅក្រោមជើងរបស់ទ្រង់
«ព្រះអង្គធ្វើឲ្យពួកគេ...នៅក្រោមជើងរបស់ពួកគេ»។ ពាក្យ «លោក» និង
«របស់លោក» នៅទីនេះសំដៅទៅលើមនុស្ស។
លើស្នាព្រះហស្តរបស់ព្រះអង្គ
លើស្នាព្រះហស្តតំណាងអ្វីដែលព្រះជាម្ចាស់បានធ្វើ។
ព្រះអង្គបានដាក់អ្វីៗទាំងអស់នៅក្រោមជើងរបស់ទ្រង់
មានសិទ្ធិអំណាច ដើម្បីគ្រប់គ្រងអ្នកដទៃ ឬគ្រប់គ្រងអ្វីៗ ត្រូវបានគេនិយាយថា៖
មានរបស់ទាំងនោះនៅក្រោមបាតជើងរបស់មនុស្សម្នាក់។ នេះមានន័យថា៖
ព្រះជាម្ចាស់បានផ្តល់សិទ្ធិអំណាចដល់មនុស្សលើការបង្កើតទាំងអស់។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានប្រទានឲ្យគេមានអំណាចលើអ្វីៗទាំងអស់»
Psalms 8:9
នៅលើផែនដីទាំងមូលព្រះនាមរបស់ព្រះអង្គអស្ចារ្យណាស់
ជាមួយនឹងការលាន់មាត់នេះព្រះបាទដាវីឌបង្ហាញពីអំណរ និងការភ័យខ្លាច
តើព្រះជាម្ចាស់ពិតជាអស្ចារ្យយ៉ាងណា។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះនាមរបស់ព្រះអង្គគឺអស្ចារ្យនៅលើផែនដីទាំងមូល» ឬ
«មនុស្សនៅលើផែនដីដឹងថា ព្រះអង្គអស្ចារ្យប៉ុណ្ណា»
ព្រះនាមរបស់ព្រះអង្គ
«ព្រះនាម» របស់ព្រះជាម្ចាស់តំណាងព្រះអង្គ ឬកេរ្តិ៍នាមរបស់ព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «កេរ្តិ៍នាមរបស់ព្រះអង្គ»
អស្ចារ្យ
«ល្អបំផុត» ឬ «ដ៏មហិមាយ»

9 ទំនុកពីសៀវភៅរបស់គ្រូចម្រៀង តាមលំនាំបទកូនប្រុសស្លាប់។ ទំនុករបស់ស្តេចដាវីឌ។[1]ខ្ញុំនឹងអរព្រះគុណដល់ព្រះអម្ចាស់ អស់ពីដួងចិត្តរបស់ទូលបង្គំ ទូលបង្គំនឹងនិទានពីគ្រប់ការអស្ចារ្យដែលព្រះអង្គបានធ្វើ។[2]ខ្ញុំនឹងអរសប្បាយ ហើយនិងរីករាយនៅក្នុងព្រះជាម្ចាស់
ហើយទូលបង្គំនឹងសរសើរតម្កើនដល់ព្រះនាមរបស់ព្រះអង្គដ៏ខ្ពស់បំផុត!
[3]កាល ពួកខ្មាំងសត្រូវរបស់ទូលបង្គំថយទៅ គេជំពប់ដួល ហើយវិនាសនៅចំពោះព្រះអង្គ។[4]ដ្បិតព្រះអង្គបានរក្សារឿងក្តីដ៏ទៀងត្រង់ របស់ទូលបង្គំ ព្រះអង្គគង់នៅលើបល្ល័ង្កដោយយុត្តិធម៌!
[5]ព្រះអង្គបានបន្ទោសជនជាតិផ្សេងៗ ព្រះអង្គបានបំបាត់មនុស្សអាក្រក់ឲ្យវិនាស ព្រះអង្គបានលុបឈ្មោះគេឲ្យបាត់ ជារៀងរហូត តទៅ។[6]សត្រូវបានវិនាសអន្តរាយអស់កល្បជានិច្ច ព្រះអង្គបានដករំលើងទីក្រុងនានារបស់គេ សេចក្តីនឹកចាំពីពួកគេក៏បាត់វិនាសទៅដែរ។
[7]ប៉ុន្តែ ព្រះអម្ចាស់នឹងគង់នៅអស់កល្បជានិច្ច ព្រះជាម្ចាស់ នឹងតាំងព្រះរាជ្យរបស់ព្រះអង្គសម្រាប់សេចក្តីយុត្តិធម៌។
[8]ព្រះជាម្ចាស់នឹងជំរុំជម្រះពិភពលោកនេះដោយសេចក្តីសុចរិត ហើយព្រះអង្គនឹងជំរុំជម្រះប្រជាជនទាំងឡាយដោយយុត្តិធម៌ដែរ។
[9]សូមព្រះអម្ចាស់ធ្វើជាបន្ទាយដ៏រឹងមាំការពារ អស់អ្នកដែលត្រូវគេជិះជាន់ គឺជាបន្ទាយការពារនៅពេលមានអាសន្ន។[10]អស់អ្នកដែលស្គាល់ព្រះនាមព្រះអង្គ គេទុកចិត្តដល់ព្រះអង្គ ដ្បិត ព្រះអម្ចាស់អើយ ព្រះអង្គមិនបានបោះបង់អស់អ្នក ដែលស្វែងរកព្រះអង្គឡើយ។
[11]សូមលើកតម្កើនដល់ព្រះអម្ចាស់ ដែលគង់លើក្រុងស៊ីយ៉ូន ចូរថ្លែងប្រាប់ប្រជាជនទាំងឡាយ ពីស្នាព្រះហស្តរបស់ព្រះអង្គ។[12]ដ្បិតព្រះអង្គនឹងដាក់ទោសអ្នកសម្លាប់គេ ព្រះអង្គនឹកចាំពីអ្នកទាំងនោះ ព្រះអង្គមិនភ្លេចសម្រែក របស់មនុស្សរងទុក្ខឡើយ។
[13]ព្រះអម្ចាស់អើយ សូមផ្តល់ក្តីមេត្តាដល់ទូលបង្គំផង សូមទតមើលទុក្ខលំបាករបស់ទូលបង្គំ ដោយសារអស់អ្នកដែលស្អប់ទូលបង្គំផង ព្រះអង្គនេះហើយដែលលើកទូលបង្គំឡើង ឲ្យរួចពីទ្វារនៃសេចក្តីស្លាប់។[14]អូរ! ដើម្បីឲ្យទូលបង្គំបានថ្លែងពី អស់ទាំងសេចក្តីសរសើររបស់ព្រះអង្គ នៅមាត់ទ្វារទាំងប៉ុន្មាននៃកូនស្រីស៊ីយ៉ូន ហើយត្រេកអរក្នុងការសង្គ្រោះរបស់ព្រះអង្គ!
[15]ប្រជាជាតិនានាបានផុង ទៅក្នុងរណ្តៅដែលគេបានជីក ជើងរបស់ពួកគេក៏ជាប់អន្ទាក់ ដែលខ្លួនគេបានបង្កប់ទុក។[16]ព្រះអម្ចាស់បានបើកសម្តែងព្រះអង្គឲ្យស្គាល់ ព្រះអង្គបានសម្រេចដោយយុត្តិធម៌ មនុស្សអាក្រក់បានជាប់អន្ទាក់ ដោយការដែលដៃរបស់គេធ្វើ។ ប្រគំភ្លេង សម្រាក
[17]មនុស្សអាក្រក់នឹងត្រូវវិលទៅរក ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ គឺគ្រប់ទាំងប្រជាជាតិដែលបានភ្លេចព្រះជាម្ចាស់។[18]ដ្បិតមនុស្សលំបាកមិនត្រូវគេភ្លេចទេ ហើយសេចក្តីសង្ឃឹមរបស់មនុស្សទ័លក្រ ក៏មិនត្រូវវិនាសបាត់ជានិច្ចដែរ។
[19]សូមតើនឡើង ព្រះអម្ចាស់អើយ សូមកុំឲ្យអ្នកដែលទាស់និងព្រះអង្គបានឈ្នះឡើយ សូមឲ្យប្រជាជាតិនានាទទួលការជំរុំជម្រះជាមួយព្រះអង្គ។[20]ឱព្រះអម្ចាស់អើយ សូមឲ្យពួកគេភិតភ័យ សូមឲ្យប្រជាជាតិទាំងឡាយដឹងខ្លួនថា គេគ្រាន់តែជា មនុស្សប៉ុណ្ណោះ។ សម្រាក

Psalms 9:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ទំនុកពីសៀវភៅរបស់គ្រូចម្រៀង
«នេះគឺសម្រាប់អ្នកដឹកនាំតន្ត្រី ដើម្បីប្រើប្រាស់ក្នុងការថ្វាយបង្គំ»
តាមលំនាំបទកូនប្រុសស្លាប់
នេះអាចសំដៅទៅលើទំនុកនៃតន្ត្រី។
ទំនុករបស់ស្តេចដាវីឌ
អត្ថន័យដែលអាចមានគឺ១) ស្តេចដាវីឌបានសរសេរទំនុកនេះ ឬ
២)ទំនុកនេះគឺអំពីស្តេចដាវីឌ ឬ ៣)
បទទំនុកដំកើងគឺមានលក្ខណៈដូចនឹងទំនុករបស់ស្តេចដាវីឌ។
ខ្ញុំនឹងអរព្រះគុណដល់ព្រះអម្ចាស់ អស់ពីដួងចិត្តរបស់ទូលបង្គំ
ចាប់តាំងពីបទចំរៀងនេះត្រូវបានធ្វើទៅព្រះអម្ចាស់
ព្រះអម្ចាស់អាចត្រូវបានគេហៅថា «ព្រះអង្គ»។ ការបកប្រែរបៀបផ្សេងទៀត:
«ឱព្រះអម្ចាស់អើយ ទូលបង្គំនឹងអរព្រះគុណព្រះអង្គអស់ពីចិត្ត»
និទានពីគ្រប់ការអស្ចារ្យដែលព្រះអង្គបានធ្វើ
នាមនេះ «ការប្រព្រឹត្ត» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «ធ្វើ»។
ការបកប្រែរបៀបផ្សេងទៀត: «អព្ភូតហេតុទាំងអស់ដែលព្រះអង្គបានធ្វើ» ឬ
«ការអស្ចារ្យទាំងអស់ដែលព្រះអង្គបានធ្វើ»
ទូលបង្គំនឹងសរសើរតម្កើនដល់ព្រះនាមរបស់ព្រះអង្គ
នៅទីនេះព្រះនាមរបស់ព្រះអង្គតំណាងឲ្យព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំនឹងច្រៀងសរសើរព្រះអង្គ»
Psalms 9:3
ថយទៅ
«ដកថយ» ឬ «ភៀសខ្លួន ដោយភ័យខ្លាច»
ព្រះអង្គគង់នៅលើបល្ល័ង្កដោយយុត្តិធម៌!

generated on Wed Sep 10 16:16:32 2025

ស្តេចមានសិទ្ធិអំណាចវិនិច្ឆ័យមនុស្ស
ហើយស្តេចទាំងអស់នឹងអង្គុយលើបល្ល័ង្ករបស់ពួកទ្រង់នៅពេលពួកទ្រង់វិនិច្ឆ័យ។
ព្រះអម្ចាស់ដាវីឌនិយាយដូចជាព្រះជាម្ចាស់ជាស្តេចនៅលើផែនដី។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គវិនិច្ឆ័យ
ដូចជាស្តេចដែលអង្គុយលើបល្ល័ង្ករបស់ព្រះអង្គ ហើយព្រះអង្គគឺសុចរិត»
Psalms 9:5
ព្រះអង្គបានលុបឈ្មោះគេឲ្យបាត់ ជារៀងរហូត តទៅ
បណ្តាលឲ្យមនុស្សត្រូវបានគេបំភ្លេចចោល
ត្រូវបានគេនិយាយថាជាការលុបឈ្មោះរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានធ្វើឲ្យពួកគេត្រូវបានគេបំភ្លេចចោលដូចជាឈ្មោះរបស់ពួកគេត្រូវបានលុបចេញ»
ឬ «គ្មាននរណាម្នាក់នឹងចងចាំពួកគេម្តងទៀត»
បានលុបចោល
«បានលុប»
សត្រូវបាននិរាសអន្តរាយអស់កល្បជានិច្ច
សត្រូវត្រូវបានគេនិយាយដូចជារាជាទីក្រុងមួយដែលពោរពេញទៅដោយអាគារដែលបានរលំ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្មាំងសត្រូវរបស់យើងត្រូវបានបំផ្លាញ»
ព្រះអង្គបានដករំលើងទីក្រុងនានារបស់គេ
«នៅពេលព្រះអង្គបំផ្លាញទីក្រុងរបស់ពួកគេ»
សេចក្តីនឹកចាំពីពួកគេក៏បាត់វិនាសទៅដែរ
ការចងចាំត្រូវបានគេនិយាយថា៖ ហាក់ដូចជាការរស់នៅដែលអាចស្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «រាល់ការចងចាំរបស់ពួកគេបានបញ្ឈប់» ឬ
«មិនមានការចងចាំពីពួកគេទៀតទេ»
សេចក្តីនឹកចាំពីពួកគេក៏បាត់វិនាសទៅដែរ
ការចងចាំអាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ «ចងចាំ»។
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់ចងចាំពួកគេទាល់តែសោះ»
Psalms 9:7
ព្រះអម្ចាស់នឹងគង់នៅអស់កល្បជានិច្ច
«នៅតែ» ប្រហែលជាតំណាងឲ្យអង្គុយលើបល្ល័ង្កជាស្តេច។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់គង់នៅលើបល្ល័ង្ករបស់ព្រះអង្គជារៀងរហូត» ឬ «
ព្រះអម្ចាស់គ្រងរាជ្យអស់កល្បជានិច្ច»។
ព្រះជាម្ចាស់ នឹងតាំងព្រះរាជ្យរបស់ព្រះអង្គសម្រាប់សេចក្តីយុត្តិធម៌
ឃ្លា «បល្ល័ង្ករបស់ព្រះអង្គ» តំណាងការគ្រប់គ្រងរបស់ព្រះអង្គ។
អត្ថន័យដែលអាចមានគឺ ១) «ព្រះអង្គគ្រប់គ្រងដើម្បីវិនិច្ឆ័យប្រជាជន» ឬ
«ព្រះអង្គគ្រប់គ្រងលើមនុស្សដោយយុត្តិធម៌»
ព្រះជាម្ចាស់នឹងជំរុំជម្រះពិភពលោកនេះដោយសេចក្តីសុចរិត...ព្រះអង្គនឹងជំរុំជម្រះប្រជាជនទាំងឡាយដោយយុត្តិធម៌ដែរ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។
ព្រះជាម្ចាស់នឹងជំរុំជម្រះពិភពលោកនេះដោយសេចក្តីសុចរិត
នៅទីនេះ«ពិភពលោក» សំដៅទៅលើប្រជាជនទាំងអស់នៅលើពិភពលោក។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គនឹងវិនិច្ឆ័យប្រជាជនទាំងអស់នៅលើពិភពលោកដោយយុត្តិធម៌»
Psalms 9:9
សូមព្រះអម្ចាស់ធ្វើជាបន្ទាយដ៏រឹងមាំការពារ អស់អ្នកដែលត្រូវគេជិះជាន់
ព្រះជាម្ចាស់គឺត្រូវបានគេនិយាយដូចជាព្រះអង្គជាកន្លែងដែលមនុស្សអាចទៅរកសុវត្ថិភាព។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់ក៏នឹងការពារអ្នកដែលត្រូវគេជិះជាន់» ឬ
«ព្រះអម្ចាស់ក៏នឹងផ្តល់សុវត្ថិភាពដល់អ្នកដែលត្រូវគេជិះជាន់ដែរ»
បន្ទាយដ៏រឹងមាំ
«ជ្រកកោន» ឬ «ទីជម្រក»
អស់អ្នកដែលស្គាល់ព្រះនាមព្រះអង្គ
នៅទីនេះពាក្យ «ព្រះនាមរបស់ព្រះអង្គ» តំណាងឲ្យព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលស្គាល់ព្រះអង្គ»
មិនបានបោះបង់
«កុំបោះបង់ចោល» ឬ «កុំចាកចេញ»
Psalms 9:11
អ្នកដែលគ្រប់គ្រងនៅក្រុងស៊ីយ៉ូន
«អ្នកដែលរស់នៅក្នុងក្រុងយេរូសាឡិម»
ចូរថ្លែងប្រាប់ប្រជាជនទាំងឡាយ
នៅទីនេះ «ប្រជាជាតិនានា» តំណាងឲ្យប្រជាជនទាំងអស់។
ដ្បិតព្រះអង្គនឹងដាក់ទោសអ្នកសម្លាប់គេ ព្រះអង្គនឹកចាំពីអ្នកទាំងនោះ
អ្វីដែលព្រះអង្គចងចាំអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិត
ព្រះជាម្ចាស់ដែលសងសឹកការបង្ហូរឈាមចងចាំអ្នកដែលត្រូវបានសម្លាប់» ឬ «ដ្បិត
ព្រះជាម្ចាស់ចងចាំអ្នកដែលត្រូវបានគេសម្លាប់
ហើយព្រះអង្គដាក់ទោសអ្នកសម្លាប់»
ព្រះអង្គមិនភ្លេចសម្រែក
«ព្រះអង្គមិនព្រងើយកន្តើយនឹងសម្រែកទេ»
Psalms 9:13
សេចក្តីមេត្តាករុណាមើលទុក្ខលំបាករបស់ទូលបង្គំ ដោយសារអស់អ្នកដែលស្អប់ទូលបង្គំផង
នេះអាចត្រូវបានបង្ហាញជាទម្រង់អសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មើលពីរបៀបដែលអ្នកដែលស្អប់ទូលបង្គំគាបសង្កត់ខ្ញុំ» ឬ
«មើលថាតើសត្រូវរបស់ទូលបង្គំ ធ្វើបាបខ្ញុំយ៉ាងដូចម្តេច»
ព្រះអង្គនេះហើយដែលលើកទូលបង្គំឡើង ឲ្យរួចពីទ្វារនៃសេចក្តីស្លាប់
សេចក្តីស្លាប់ ត្រូវបានគេនិយាយថា៖
ដូចជាទីក្រុងដែលមានទ្វារដែលមនុស្សចូលទៅក្នុងនោះ។
ប្រសិនបើមាននរណាម្នាក់នៅជិតទ្វារនៃសេចក្តីស្លាប់
វាមានន័យថាគាត់នឹងស្លាប់ឆាប់។ ការការពាររណាម្នាក់ពីការស្លាប់
ត្រូវបានគេនិយាយថា៖ ជាការយកគាត់ចេញពីច្រកទ្វារនៃទីក្រុងនោះ។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គដែលអាចជួយទូលបង្គំឲ្យរួចផុតពីសេចក្តីស្លាប់» ឬ
«ព្រះអង្គដែលអាចជួយទូលបង្គំឲ្យរួចផុតពីសេចក្តីស្លាប់»
Psalms 9:15
ប្រជាជាតិនានាបានផុង ទៅក្នុងរណ្តៅដែលគេបានជីក
មនុស្សជីករណ្តៅដើម្បីចាប់សត្វដែលធ្លាក់ចូលទៅក្នុងពួកគេ។
នៅទីនេះការជីករណ្តៅតំណាងឲ្យការធ្វើផែនការបំផ្លាញមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជាតិនានាដូចជាមនុស្សដែលជីករណ្តៅសម្រាប់អ្នកដទៃហើយបន្ទាប់មកធ្លាក់ចូលទៅ»
ជើងរបស់ពួកគេក៏ជាប់អន្ទាក់ ដែលខ្លួនគេបានបង្កប់ទុក
មនុស្សលាក់អួន ដើម្បីចាប់សត្វដែលចាប់បាន។
នៅទីនេះការលាក់សំណាញ់តំណាងឲ្យការធ្វើផែនការបំផ្លាញមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេដូចជាមនុស្សដែលលាក់សំណាញ់
ហើយជាប់នៅក្នុងសំណាញ់ទៅ»
អន្ទាក់
«ជាប់» ឬ «ចាប់បាន»។ នេះតំណាងឲ្យការបំផ្លាញ។ ការបកប្រែរបៀបផ្សេងទៀត:
«បំផ្លាញចោល»
Psalms 9:17
វិលទៅរក
«បដិសេធ»
គឺគ្រប់ទាំងប្រជាជាតិដែលបានភ្លេចព្រះជាម្ចាស់
«ជាកន្លែងដែលប្រជាជាតិទាំងអស់ដែលភ្លេចព្រះអង្គនឹងនៅ»
ដ្បិតមនុស្សលំបាកមិនត្រូវគេភ្លេចទេ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងមិនភ្លេចអ្នកខ្វះខាត» ឬ «ព្រះជាម្ចាស់នឹងចងចាំអ្នកខ្វះខាត»
ការសង្ឃឹមរបស់មនុស្សទ័លក្រ ក៏មិនត្រូវវិនាសបាត់ជានិច្ចដែរ
ក្តីសង្ឃឹម ត្រូវបានគេនិយាយដូចជាពួកគេជាវត្ថុដែលអាចខូច ឬបំផ្លាញ។
ក្តីសង្ឃឹមកំពុងត្រូវបានបំផ្លាញតំណាងឲ្យអ្វីដែលមនុស្សសង្ឃឹមថា
និងមិនដែលកើតឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយអ្នកដែលត្រូវគេជិះជាន់គេនឹងមិនសង្ឃឹមជារៀងរហូតទេបើគ្មានលទ្ធផល»
ឬ «ហើយនៅថ្ងៃណាមួយអ្វីដែលសេចក្តីសង្ឃឹមត្រូវបានគេជិះជាន់នឹងកើតឡើង»
Psalms 9:19
សូមតើនឡើង
ក្រោកឡើងតំណាងឲ្យចាប់ផ្តើមធ្វើអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើអ្វីមួយ» ឬ «ចាត់វិធានការ»
បុរស
«ប្រជាជន»
ទទួលការជំរុំជម្រះ
នៅទីនេះការជំរុំជម្រះតំណាងឲ្យការដាក់ទណ្ឌកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ត្រូវបានដាក់ទណ្ឌកម្ម»

generated on Wed Sep 10 16:16:32 2025

ចំពោះព្រះភ័ក្ត្រព្រះអង្គ
នៅទីនេះ ការមើលឃើញតំណាងឲ្យវត្តមាន។ ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងវត្តមានរបស់ព្រះអង្គ»
សូមធ្វើឲ្យប្រជាជនទាំងឡាយដឹងថា ពួកគេគ្រាន់តែជាមនុស្សប៉ុណ្ណោះ!
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់អសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ការជំរុំជម្រះប្រជាជាតិនានា នៅចំពោះព្រះភ័ក្ត្រព្រះអង្គ» ឬ
«នាំប្រជាជាតិនានាទៅក្នុងព្រះវត្តមានរបស់ព្រះអង្គ និងដាក់ទណ្ឌកម្មពួកគេ»

10 [1]ឱព្រះអម្ចាស់អើយ ហេតុអ្វីបានជាព្រះអង្គគង់នៅឆ្ងាយយ៉ាងនេះ? តើហេតុអ្វីបានជាព្រះអង្គពួន នៅគ្រាដែលមានទុក្ខលំបាកដូច្នេះ?[2]ដោយព្រោះ មនុស្សពាលនាំគ្នាតាមធ្វើបាបមនុស្សទុគ៌ត ទាំងឥតអៀនខ្មាស ពួកគេប្រើកលល្បិចធ្វើឲ្យ មនុស្សទុគ៌តវិនាស។[3]ដ្បិត មនុស្សដែលអាក្រក់និងចំអក ឡកឡាយ
នៅក្នុងបំណងបោកប្រាស់របស់ពួកគេ ហើយគេនឹងឲ្យពរដល់អ្នកលោភលន់ ហើយនិងអ្នកដែលប្រមាថព្រះអម្ចាស់។
[4]មនុស្សអាក្រក់និយាយទាំងវាយឫកខ្ពស់ថា គេមិនដែលស្វែងរកព្រះជាម្ចាស់ទេ។ ហើយគេក៏មិនដែលគិតអំពីព្រះអង្គដែរ ដោយសារគេមិនដែរខ្វល់ពីព្រះជាម្ចាស់ទេ។[5]គេមានសុវត្ថិភាពគ្រប់ពេលជានិច្ច ប៉ុន្តែក្តីសុចរិតរបស់ព្រះអង្គនៅខ្ពស់ ហួសពីភ្នែករបស់គេ ហើយគេបូញមាត់ឡកឡាយដាក់បច្ចាមិត្តរបស់គេ។
[6]គេនិយាយក្នុងចិត្តថា «អញនឹងមិនត្រូវរង្គើឡើយ អញមិនជួបទុក្ខលំបាក ជារៀងរហូតគ្រប់ជំនាន់តទៅ»។[7]មាត់របស់គេពេញទៅដោយបណ្តាសារ
ការបោកប្រាស់ហើយនិងពាក្យជេរប្រមាថ អណ្តាតគេមានតែពាក្យអពមង្គលនិងការបំផ្លាញ់។
[8]គេអង្គុយពួនស្ទាក់នៅតាមភូមិ នៅកន្លែងស្ងាត់កំបាំង គេសម្លាប់មនុស្សស្លូតត្រង់ ភ្នែកគេតាមឃ្លាំមើលមនុស្សដែលគ្មានទីពឹងអាង។[9]គេពួនចាំនៅទីសម្ងាត់ ដូចសិង្ហសម្ងំនៅក្នុងរូង គេលបចាំចាប់មនុស្សក្រីក្រ។ គេចាប់មនុស្សក្រីក្រ ដោយទាញគេមកក្នុងអន្ទាក់របស់ខ្លួន។[10]គេបំពានដោយអាក្រក់ហើយវាយដំឲ្យដេកចុះ រួចដួលទៅក្នុងអំណាចរបស់គេ។
[11]គេនិយាយក្នុងចិត្តថា «ព្រះជាម្ចាស់បានបំភ្លេច ដោយបិតព្រះភក្ត្រ ព្រះអង្គក៏នឹងមិនទូតលើគេដែរ»។[12]ព្រះអម្ចាស់ អើយ សូមតើនឡើង! សូមលើកព្រះហស្តឡើង ព្រះជាម្ចាស់ អើយ! សូមកុំបំភ្លេចពួកអ្នកក្រក្រីឡើយ។
ដើម្បីពិពណ៌នាអំពីមនុស្សពេញលេញ។
Psalms 31:10
ជីវិតជីវិតទូលបង្គំនឹងផុតទៅដោយទុក្ខព្រួយ
នៅទីនេះ «ជីវិតរបស់ខ្ញុំ» សំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំខ្សោយហើយ»
ដោយទុក្ខព្រួយ ... ដោយថ្ងូរ
«ដោយសារតែទុក្ខព្រួយរបស់ទូលបង្គំ...ដោយសារតែការថ្ងូររបស់ទូលបង្គំ»
ឆ្នាំនៃអាយុទូលបង្គំថយទៅដោយស្រែកថ្ងូរ
ឃ្លាថា «នឿយហត់» គឺបាត់ប៉ុន្តែត្រូវបានបង្កប់ន័យ។ ការបកប្រែរបៀបផ្សេងទៀត:
«ឆ្នាំរបស់ទូលបង្គំនឿយហត់ នឹងការថ្ងូរ»
កម្លាំងទូលបង្គំចុះខ្សោយ
នៅទីនេះ «កម្លាំងរបស់ខ្ញុំ» សំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំបានចុះខ្សោយ»
ឆ្អឹងទូលបង្គំក៏ខ្សោះទៅដែរ
នៅទីនេះ «ឆ្អឹងរបស់ខ្ញុំ» សំដៅទៅលើសុខភាពរាងកាយរបស់អ្នកនិពន្ធ។
ការបកប្រែរបៀបផ្សេងទៀត: «សុខភាពរបស់ទូលបង្គំកំពុងខ្សោយ»
មនុស្សមើលងាយទូលបង្គំ
«មនុស្សប្រមាថទូលបង្គំ»
ត្រឡប់ជាទីត្មះតិះដៀល
«មានការភ្ញាក់ផ្អើលចំពោះស្ថានភាពរបស់ទូលបង្គំ»
Psalms 31:12
ប្រៀបដូចជាមនុស្សស្លាប់ ទូលបង្គំបានត្រឡប់ដូចជាឆ្នាំងបាក់បែក
អ្នកនិពន្ធនិយាយថា៖ មនុស្សបានភ្លេចទ្រង់ណាស់
ហើយនេះដូចជាទ្រង់បានស្លាប់ទៅហើយ។
ដូចជាឆ្នាំងបាក់បែក
អ្នកនិពន្ធនិយាយអំពីខ្លួនឯងដូចជាទ្រង់គ្មានប្រយោជន៍ទាំងស្រុង។
«គ្មានប្រយោជន៍ដូចជាឆ្នាំងដែលបែក»
ពាក្យមិនល្អរបស់មនុស្សជាច្រើន
នេះបញ្ជាក់ថា «ជាច្រើន» សំដៅទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សជាច្រើននិយាយពីទូលបង្គំ»
ការភ័យខ្លាចមកពីគ្រប់ជ្រុង
«ដំណឹងគួរឲ្យខ្លាចពីប្រភពជាច្រើន»
ដកជីវិតទូលបង្គំ
ឃ្លានេះមានន័យថា សម្លាប់នរណាម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«សម្លាប់ទូលបង្គំ»
Psalms 31:14
វាសនារបស់ទូលបង្គំ ស្ថិតនៅក្នុងព្រះហស្តព្រះអង្គ
ត្រង់នេះ «ព្រះហស្តរបស់ព្រះអង្គ» សំដៅទៅលើឫទ្ធានុភាពរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គមានអំណាចសំរេចអនាគតរបស់ទូលបង្គំ»
ពីអស់អ្នកដែលបៀតបៀនទូលបង្គំផង
«ពីមនុស្សដែលព្យាយាមចាប់ទូលបង្គំ»
សូមឲ្យព្រះភ័ក្ត្រព្រះអង្គ ភ្លឺមកលើអ្នកបម្រើព្រះអង្គ
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ធ្វើល្អចំពោះទ្រង់ដូចជាព្រះភ័ក្ត្ររបស់ព្រះអម្ចាស់បានបំភ្លឺមកលើគាត់។ ការបកប្រែរបៀបផ្សេងទៀត: «ធ្វើល្អចំពោះអ្នកបម្រើរបស់ព្រះអង្គ»
Psalms 31:17
សូមកុំឲ្យទូលបង្គំត្រូវខ្មាសឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«កុំឲ្យអ្នកដទៃធ្វើឲ្យទូលបង្គំខ្មាស់អៀន»
សូមឲ្យពួកមនុស្សអាក្រក់ត្រូវខ្មាស
«ទូលបង្គំសង្ឃឹមថា ព្រះជាម្ចាស់នឹងធ្វើឲ្យអាម៉ាស់មុខមនុស្សអាក្រក់!»
មនុស្សអាក្រក់
នេះសំដៅទៅលើ «មនុស្សអាក្រក់»។
សូមឲ្យគេដេកស្ងៀមនៅស្ថាន ឃុំព្រលឹងមនុស្សស្លាប់ទៅ។ សូមឲ្យបបូរមាត់ភូតភរ
មិនអាចនិយាយបាន
គំនិតនេះត្រូវបានធ្វើម្តងទៀត ដើម្បីបញ្ជាក់ពីបំណងប្រាថ្នារបស់អ្នកនិពន្ធថា
សម្លេងរបស់មនុស្សអាក្រក់មិនត្រូវបានគេឮទេ។
សូមឲ្យគេដេកស្ងៀមនៅស្ថាន ឃុំព្រលឹងមនុស្សស្លាប់ទៅ
នៅទីនេះ «នៅស្ថានឃុំព្រលឹង» តំណាងឲ្យការស្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ទុកឲ្យពួកគេស្លាប់ ដូច្នេះពួកគេមិនអាចនិយាយបាន»
បបូរមាត់ភូតភរ
ទាំងនេះតំណាងឲ្យមនុស្សកុហក។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សកុហក»
អាចនិយាយបាន ជាបបូរមាត់ដែលពោលទាស់នឹងមនុស្សសុចរិត
ត្រង់នេះ «សុចរិត» សំដៅលើមនុស្សសុចរិត។ ការបកប្រែរបៀបផ្សេងទៀត:
«និយាយអ្វីដែលគួរឲ្យខ្លាចអំពីមនុស្សសុចរិត»
ដោយព្រហើន និងប្រមាថមើលងាយ
ពាក្យទាំងនេះមានអត្ថន័យស្រដៀងគ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយខ្វះការគោរពទាំងស្រុង»
Psalms 31:19
គឺភាពល្អរបស់ព្រះអង្គ
នេះអាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«គឺជារបស់ល្អដែលព្រះអង្គធ្វើ»
ព្រះអង្គបានបម្រុងទុកសម្រាប់
ភាពល្អរបស់ព្រះអម្ចាស់ត្រូវបានគេនិយាយដូចជាអ្វីដែលអាចត្រូវបានរក្សាទុកដូចជាការប្រមូលផល។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គកំពុងត្រៀមរួចរាល់ក្នុងការប្រើប្រាស់»
អស់អ្នកដែល កោតខ្លាចព្រះអង្គ
«អ្នកដែលគោរពព្រះអង្គខ្លាំង»
ដែលពឹងជ្រកក្នុងព្រះអង្គ
ការចូលទៅរកព្រះអម្ចាស់
ដើម្បីទទួលបានការពារត្រូវបាននិយាយថាជាទីពឹងជ្រករបស់ទ្រង់។
សូមមើលពីរបៀបបកប្រែក្នុងជំពូក ៣១: ១។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលទៅរកព្រះអង្គដើម្បីការពារ»
ព្រះអង្គលាក់គេក្នុងទីកំបាំង នៃព្រះវត្តមានព្រះអង្គ...ព្រះអង្គថែរក្សាគេនៅក្នុងព្រះពន្លារបស់ព្រះអង្គ
ឃ្លាទាំងពីរនេះមានន័យថា ព្រះជាម្ចាស់ការពារពួកគេ។
នៅក្នុងព្រះពន្លា
ព្រះវត្តមានរបស់ព្រះអម្ចាស់ត្រូវបានគេនិយាយដូចជាអាគារដែលរឹងមាំដែលអ្នកនិពន្ធនឹងមានសុវត្ថិភាព។
(សូមមើល:figs-metaphor)
ព្រះអង្គថែរក្សាគេនៅក្នុងព្រះពន្លា
នៅទីនេះ «ជំរក» តំណាងឲ្យកន្លែងមានសុវត្ថិភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គផ្តល់កន្លែងសុវត្ថិភាពដល់ពួកគេ»
ឲ្យរួចពីអណ្តាតមិនល្អ
នៅទីនេះ «អណ្តាត»
សំដៅទៅលើមនុស្សដែលកំពុងនិយាយពាក្យប្រឆាំងនឹងអ្នកនិពន្ធ។
ការបកប្រែរបៀបផ្សេងទៀត:
«ជាកន្លែងដែលសត្រូវរបស់ពួកគេមិនអាចនិយាយអាក្រក់ដាក់ពួកគេ»
Psalms 31:21
ទូលបង្គំត្រូវកាត់ចេញពីព្រះនេត្ររបស់ព្រះអង្គ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានយកទូលបង្គំចេញពីព្រះវត្តមានរបស់ព្រះអង្គ»
ព្រះនេត្ររបស់ព្រះអង្គ
ត្រង់នេះ «ភ្នែក» សំដៅទៅលើព្រះវត្តមានរបស់ព្រះអម្ចាស់។
ភ្លឺមកលើអ្នក ការបកប្រែរបៀបផ្សេងទៀត: «ព្រះវត្តមានរបស់ព្រះអង្គ»
ព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យទូលអង្វររបស់ទូលបង្គំ
នៅទីនេះ «អង្វរ» អាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គទូលបង្គំអង្វររកជំនួយ»
Psalms 31:23
ស្មោះត្រង់
នេះសំដៅទៅលើមនុស្សស្មោះត្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនដ៏ស្មោះត្រង់»
ព្រះអង្គសងដល់មនុស្សព្រហើនជាបរិបូរណ៌
នៅទីនេះ «សងត្រលប់មកវិញ» គឺជាឃ្លាដែលសំដៅទៅលើការដាក់ទណ្ឌកម្ម។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គផ្តល់ឲ្យមនុស្សដែលមានមោទនភាពនូវរាល់ការដាក់ទណ្ឌកម្មដែលពួកគេសមនឹងទទួលបាន»

generated on Wed Sep 10 16:16:32 2025

32 ទំនុករបស់ស្តេចដាវីឌ។ ពាក្យកាព្យ។[1]មានពរហើយ អ្នកដែលទទួលការអត់ទោស គឺជាអ្នកដែលបានគ្របបាំងអំពើបាបរបស់ខ្លួន។[2]មានពរហើយ អ្នកដែលព្រះអម្ចាស់ មិនរាប់ថាមានទោស ជាអ្នកដែលគ្មានកលឧបាយក្នុងចិត្ត។
[3]ពេលទូលបង្គំចេះតែនៅស្ងៀម ឆ្អឹងទូលបង្គំបានខ្សោះទៅ ដោយសារទូលបង្គំស្រែកថ្ងូរជារៀងរាល់ថ្ងៃ។[4]ដ្បិតព្រះហស្តព្រះអង្គបានសង្កត់ លើទូលបង្គំយ៉ាងធ្ងន់ ទាំងយប់ទាំងថ្ងៃ កម្លាំងទូលបង្គំខ្សោះល្វើយ ដូចទឹករីងស្ងួត ដោយកម្តៅនៅរដូវប្រាំង។ សម្រាក
[5]ទូលបង្គំបានសារភាពអំពើបាប របស់ទូលបង្គំ នៅចំពោះព្រះអង្គ ឥតលាក់លៀមអំពើទុច្ចរិតរបស់ទូលបង្គំឡើយ។ ទូលបង្គំពោលថា«ទូលបង្គំនឹងលន់តួអំពើរំលងរបស់ទូលបង្គំចំពោះព្រះយេហូវ៉ា»ហើយព្រះអង្គក៏បានអត់ទោសអំពើបាបឲ្យទូលបង្គំ។ សម្រាក[6]ដូច្នេះ ត្រូវឲ្យអស់អ្នកដែលកោតខ្លាចដល់ព្រះបានអធិស្ឋានដល់ព្រះអង្គ នៅពេលដែលអាចរកព្រះអង្គឃើញយ៉ាងនោះ កាលណាមានទឹកជំនន់ធំជន់ឡើង ប្រាកដជានឹងមិនលិចលង់ដល់អ្នកនោះឡើយ។
[7]ព្រះអង្គជាទីពួនជ្រករបស់ទូលបង្គំ ព្រះអង្គការពារទូលបង្គំ ឲ្យរួចពីទុក្ខលំបាក។ ព្រះអង្គហ៊ុមព័ទ្ធទូលបង្គំ ដោយចម្រៀងនៃជ័យជម្នះ។ សម្រាក[8]យើងនឹងបង្ហាត់បង្រៀនអ្នកឲ្យស្គាល់ផ្លូវដែលអ្នកត្រូវដើរ។ យើងនឹងទូន្មានអ្នកទាំងភ្នែកយើងមើលអ្នកជានិច្ច។
[9]កុំឲ្យអ្នកធ្វើដូចជាសេះ ឬលាកាត់ ដែលគ្មានការយល់ដឹង ដែលគេត្រូវដាក់បង្ហាំ ហើយនិងបង្ហៀរ ដើម្បីទប់វា ក្រែងវាមិនព្រមមករកអ្នកនោះឡើយ។[10]មនុស្សអាក្រក់គេនឹងមានទុក្ខព្រួយជាច្រើន តែអ្នកណាដែលទុកចិត្តនឹងព្រះអម្ចាស់ នោះនឹងមានសេចក្តីសប្បុរសនៅព័ទ្ធជុំវិញខ្លួន។
[11]ឱមនុស្សសុចរិតរាល់គ្នាអើយ ចូរមានចិត្តសប្បាយ ហើយរីករាយឡើង ក្នុងព្រះអម្ចាស់ចុះ អស់អ្នកដែលមានចិត្តទៀតត្រង់អើយចូរនាំគ្នាស្រែកឡើងដោយអំណរចុះ។

Psalms 32:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។ (សូមមើល: និងfigs-parallelism)
ទំនុករបស់ព្រះបាទដាវីឌ
អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ ២) ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣) បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
ពាក្យកាព្យ
នេះអាចសំដៅទៅលើទំនុកតន្ត្រី។
អ្នកដែលទទួលការអត់ទោស គឺជាអ្នកដែលបានគ្របបាំងអំពើបាបរបស់ខ្លួន
ឃ្លាទាំងនេះមានអត្ថន័យស្រដៀងគ្នា។ ពួកគេអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់អភ័យទោស ចំពោះការរំលងរបស់ទ្រង់ ហើយគ្របបាំងអំពើបាបរបស់ទ្រង់»
គ្របបាំងអំពើបាបរបស់ខ្លួន
នៅទីនេះអំពើបាបដែលត្រូវបានអត់ទោសត្រូវបានគេនិយាយដូចជាត្រូវបានគ្របដណ្តប់ដើម្បីឲ្យវាមិនអាចមើលឃើញ។ ការបកប្រែរបៀបផ្សេងទៀត: «បាបរបស់គេត្រូវបានគេមិនអើពើ» ឬ «អំពើបាបរបស់គេត្រូវបានគេបំភ្លេចចោលដោយចេតនា»
អ្នកដែលព្រះអម្ចាស់ មិនរាប់ថាមានទោស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់មើលឃើញថា គ្មានទោស:» ឬ «មិនមានកំហុសយោងទៅតាមព្រះអម្ចាស់»
ជាអ្នកដែលគ្មានកលឧបាយក្នុងចិត្ត
នៅទីនេះ «ស្មារតី» សំដៅទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងការដែលមិនមានការបោកបញ្ឆោត» ឬ «ដែលមានភាពស្មោះត្រង់ទាំងស្រុង»
Psalms 32:3
ឆ្អឹងទូលបង្គំបានខ្សោះទៅ
នៅទីនេះ «ឆ្អឹងរបស់ខ្ញុំ» សំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំខ្ជះខ្ជាយទៅឆ្ងាយ» ឬ «ខ្ញុំកាន់តែចុះខ្សោយ»
ជារៀងរាល់ថ្ងៃ
ឃ្លានេះមានន័យថា «បន្ត»។ ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ពេលវេលា»
ទាំងយប់ទាំងថ្ងៃ
ចំណុចខ្លាំងទាំងនេះរួមបញ្ចូលអ្វីៗទាំងអស់នៅចន្លោះ។ ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ពេលវេលា»
ព្រះហស្តព្រះអង្គបានសង្កត់ លើទូលបង្គំយ៉ាងធ្ងន់
ត្រង់នេះ «ព្រះហស្ត» សំដៅទៅលើព្រះអម្ចាស់។ ឃ្លាទាំងមូលគឺជាសំនួនវោហារដែលមានន័យថា «ព្រះអង្គធ្វើបាបខ្ញុំ»។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គធ្វើទូលបង្គំឈឺចាប់យ៉ាងខ្លាំង»
កម្លាំងទូលបង្គំខ្សោះល្វើយ ដូចទឹករីងស្ងួត ដោយកម្តៅនៅរដូវប្រាំង
ភាពរឹងមាំរបស់ព្រះបាទដាវីឌត្រូវបានគេប្រៀបធៀបទៅនឹងរុក្ខជាតិបៃតងតូចមួយដែលប្រែទៅជាពណ៌ត្នោតនិងដួលរលំនៅរដូវប្រាំង។
សម្រាក
នេះប្រហែលជាពាក្យតន្ត្រីដែលប្រាប់មនុស្សពីរបៀបច្រៀងឬលេងឧបករណ៍របស់ពួកគេនៅទីនេះ។ ការបកប្រែខ្លះសរសេរពាក្យភាសាហេប្រឺហើយការបកប្រែខ្លះមិនរួមបញ្ចូលវាទេ។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ៣:១ ។
Psalms 32:5
សម្រាក
នេះប្រហែលជាពាក្យតន្ត្រីដែលប្រាប់មនុស្សពីរបៀបច្រៀងឬលេងឧបករណ៍របស់ពួកគេនៅទីនេះ។ ការបកប្រែខ្លះសរសេរពាក្យភាសាហេប្រឺហើយការបកប្រែខ្លះមិនរួមបញ្ចូលវាទេ។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ៣:១ ។
នៅពេលដែលអាចរកព្រះអង្គឃើញយ៉ាងនោះ
«នៅពេលដែលពួកគេមានបញ្ហាយ៉ាងខ្លាំង»។
កាលណាមានទឹកជំនន់ធំជន់ឡើង ប្រាកដជានឹងមិនលិចលង់ដល់អ្នកនោះឡើយ
ការលំបាកត្រូវបានគេនិយាយដូចជាពួកគេត្រូវទឹកជំនន់។ ការបកប្រែរបៀបផ្សេងទៀត: «បន្ទាប់មកនៅពេលមានការលំបាកកើតឡើងដូចជាទឹកជំនន់ប្រជាជនទាំងនោះនឹងមានសុវត្ថិភាព»
Psalms 32:7
ព្រះអង្គជាទីពួនជ្រករបស់ទូលបង្គំ
ព្រះអម្ចាស់គឺត្រូវបានគេនិយាយថា៖ ជាកន្លែងដែលមានសុវត្ថិភាពពីការវាយប្រហាររបស់ខ្មាំងសត្រូវរបស់អ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គគឺដូចជាកន្លែងដែលទូលបង្គំអាចលាក់ខ្លួនទូលបង្គំពីសត្រូវរបស់ទូលបង្គំ»
ព្រះអង្គហ៊ុមព័ទ្ធទូលបង្គំ ដោយចម្រៀងនៃជ័យជម្នះ
ពាក្យប្រៀបធៀបនេះមានន័យថា ការការពាររបស់ព្រះអម្ចាស់ដល់អ្នកនិពន្ធគឺជាបុព្វហេតុនៃចម្រៀងជ័យជម្នះ។ ការបកប្រែរបៀបផ្សេងទៀត: «ដោយសារតែព្រះអង្គ ទូលបង្គំនឹងចម្រៀងនៃជ័យជំនះ»
សម្រាក
នេះប្រហែលជាពាក្យតន្ត្រីដែលប្រាប់មនុស្សពីរបៀបច្រៀងឬលេងឧបករណ៍របស់ពួកគេនៅទីនេះ។ ការបកប្រែខ្លះសរសេរពាក្យភាសាហេប្រឺហើយការបកប្រែខ្លះមិនរួមបញ្ចូលវាទេ។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ៣:១ ។
យើងនឹងបង្ហាត់បង្រៀនអ្នកឲ្យស្គាល់ផ្លូវដែលអ្នកត្រូវដើរ
ពាក្យ «ត្រាស់បង្រៀន» និង «បង្រៀន» មានន័យថា ជាមូលដ្ឋានដូចគ្នា ហើយសង្កត់ន័យលើការណែនាំយ៉ាងប្រុងប្រយ័ត្ន។ ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបង្រៀនអ្នកពីផ្លូវទាំងអស់»
យើងនឹងបង្ហាត់បង្រៀន
នៅទីនេះ «យើង» គឺប្រហែលជាព្រះអម្ចាស់ដែលមានព្រះបន្ទូលផ្ទាល់ជាមួយព្រះបាទដាវីឌ។
អ្នកឲ្យស្គាល់ផ្លូវដែលអ្នកត្រូវដើរ
ការរស់នៅតាមរបៀបត្រឹមត្រូវ គឺត្រូវបានគេនិយាយដូចជាវាជាផ្លូវដែលអ្នកនិពន្ធគួរដើរ។ ការបកប្រែរបៀបផ្សេងទៀត: «របៀបដែលទ្រង់គួររស់នៅក្នុងជីវិតរបស់ព្រះអង្គ»
ទាំងភ្នែកយើងមើលអ្នកជានិច្ច
ត្រង់នេះ «ភ្នែកខ្ញុំ» សំដៅលើការយកចិត្តទុកដាក់របស់ព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «ហើយ
ដឹកនាំការយកចិត្តទុកដាក់របស់ទូលបង្គំទៅព្រះអង្គ» ឬ «និង មើលព្រះអង្គ»
Psalms 32:9
កុំឲ្យអ្នកធ្វើដូចជាសេះ...គ្មានការយល់ដឹង
អ្នកនិពន្ធប្រៀបធៀបមនុស្សដែលគ្មានការយល់ដឹងទៅនឹងសេះ និងលា។
អត្ថន័យដែលអាចធ្វើបានគឺ ១)
អ្នកនិពន្ធកំពុងនិយាយពាក្យរបស់ព្រះអម្ចាស់ទៅកាន់អ្នកអានរបស់ទ្រង់ថា
«អ្នកទាំងអស់គ្នាមិនត្រូវធ្វើដូចសេះទេ...គ្មានការយោគយល់ទេ» ឬ ២)
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់អ្នកនិពន្ធដូចជាមនុស្សមួយក្រុម។
ដាក់ដែកបង្ខាំ និងចងបង្ខៀរ
ឧបករណ៍ពីរដែលត្រូវបានប្រើដោយមនុស្ស ដើម្បីណែនាំសេះ
និងស្លៃទៅកន្លែងដែលអ្នកជិះចង់ឲ្យពួកគេទៅ។
កន្លែងណាដែលអ្នកចង់ពួកវាទៅ
«កន្លែងណាដែលអ្នកណាចង់ឲ្យគេទៅ»។ «អ្នក» នៅទីនេះគឺឯកវចន:
ហើយសំដៅលើនរណាម្នាក់ជាពិសេស។
ព័ទ្ធជុំវិញ
ភាពស្មោះត្រង់របស់ព្រះអម្ចាស់ដែលនឹង «ព័ទ្ធជុំវិញ»
ព្រះអង្គបណ្តាលឲ្យមានការការពារ និងការណែនាំ។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងណែនាំ» ឬ «នឹងការពារ»។
Psalms 32:11
ចូរមានចិត្តសប្បាយ ហើយរីករាយឡើង ក្នុងព្រះអម្ចាស់ចុះ
ត្រង់នេះ «នៅក្នុងព្រះអម្ចាស់»
សំដៅទៅលើអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់ពួកគេ។ «ចូរអរសប្បាយ
ដោយព្រោះអ្វីដែលព្រះអម្ចាស់បានធ្វើ»
ឱមនុស្សសុចរិតរាល់គ្នាអើយ
នេះសំដៅទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកជាមនុស្សសុចរិត»
ស្រែកឡើងដោយអំណរចុះ
«ស្រែកដោយអំណរ» ឬ «ស្រែកដោយសារអំណរ»
អ្នកដែលមានចិត្តទៀតត្រង់អើយ
នៅទីនេះ «ដួងចិត្ត» សំដៅទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សទៀងត្រង់»

---

33 [1]ឱមនុស្សសុចរិតអើយ! ចូររីករាយក្នុងព្រះអម្ចាស់ចុះ សូមសរសើរតម្កើងព្រះជាម្ចាស់ ដ៏សមគួរហើយក្នុងផ្លូវត្រឹមត្រូវ។[2]ចូរអរព្រះគុណដល់ព្រះអម្ចាស់ដោយចាប់ស៊ុង
ហើយលើកទំនុកថ្វាយព្រះអង្គ ដោយដេញពិណខ្សែដប់។[3]ចូរច្រៀងបទថ្មីថ្វាយព្រះអង្គ ហើយប្រគំភ្លេងយ៉ាងពិរោះឲ្យឮរងំទាំងស្រែកដោយអំណរ។
[4]ដ្បិតព្រះបន្ទូលរបស់ព្រះអម្ចាស់ទៀងត្រង់ ហើយអស់ទាំងកិច្ចការរបស់ព្រះអង្គ ព្រះអង្គបានធ្វើដោយស្មោះត្រង់។[5]ព្រះអង្គស្រឡាញ់សេចក្តីសុចរិត និងយុត្តិធម៌ ផែនដីមាន
ពេញដោយព្រះហឫទ័យសប្បុរស របស់ព្រះអម្ចាស់។[6]ផ្ទៃមេឃកើតឡើងដោយសារព្រះបន្ទូល របស់ព្រះអម្ចាស់ ហើយអ្វីៗទាំងអស់នៅលើមេឃ ក៏កើតឡើងដោយសារ
ខ្យល់ដង្ហើមចេញពីព្រះឧស្ឋរបស់ព្រះអង្គដែរ។
[7]ព្រះអង្គធ្វើឲ្យទឹកសមុទ្រផ្ទុំគ្នាឡើងជាគំនរ ព្រះអង្គយកទីជម្រៅដាក់ក្នុងឃ្លាំង។[8]ចូរឲ្យផែនដីទាំងមូលកោតខ្លាចព្រះអម្ចាស់ ចូរឲ្យមនុស្សទាំងអស់នៅលើពិភពលោក កោត
ស្ញប់ស្ញែងព្រះអង្គ។[9]ដ្បិតព្រះអង្គមានព្រះបន្ទូល នោះអ្វីៗក៏កើតមាន ព្រះអង្គបានបង្គាប់ នោះអ្វីៗក៏មាននៅ។
[10]ព្រះអម្ចាស់ធ្វើឲ្យការប្រឹក្សា របស់ជាតិសាសន៍នានា ទៅជាអសារឥតការ ព្រះអង្គធ្វើឲ្យគំនិតរបស់ប្រជាជនទាំងឡាយ អសារបង់។[11]ផែនការរបស់ព្រះអម្ចាស់ នៅស្ថិតស្ថេរ
ជារៀងរហូត ហើយគម្រោងការក្នុងព្រះហឫទ័យព្រះអង្គ សម្រាប់ គ្រប់ជំនាន់។[12]មានពរហើយ ជាតិសាសន៍ណា ដែលយកព្រះអម្ចាស់ទុកជាព្រះរបស់ខ្លួន ជាប្រជាជន
ដែលព្រះអង្គបានជ្រើសរើស ទុកជាមរតករបស់ព្រះអង្គ!
[13]ព្រះអម្ចាស់ទតមកពីលើស្ថានសួគ៌ ព្រះអង្គឃើញមនុស្សលោកទាំងអស់។[14]ពីព្រះដំណាក់ជាកន្លែងគង់នៅរបស់ព្រះអង្គ ព្រះអង្គទតឃើញមនុស្សទាំងអស់ ដែលរស់នៅ
លើផែនដី។[15]គឺព្រះអង្គហើយដែលបង្កើតចិត្ត របស់គេទាំងអស់គ្នា ក៏ពិចារណាមើលអស់ទាំងការដែលគេប្រព្រឹត្តដែរ។
[16]គ្មានស្តេចណាបានសង្គ្រោះ ដោយសារមានទ័ពច្រើននោះឡើយ ហើយមនុស្សខ្លាំងពូកែ ក៏មិនបានរួច ដោយសារកម្លាំងខ្លួនដែរ។[17]សេះចម្បាំង មិនមែនជាទីសង្ឃឹម ឲ្យ
មានជ័យជម្នះឡើយ ក៏មិនអាចសង្គ្រោះដោយសារកម្លាំងដ៏ខ្លាំងរបស់វាបានដែរ។
[18]មើល៍ ព្រះនេត្ររបស់ព្រះអម្ចាស់ ទតមកលើអស់អ្នក ដែលកោតខ្លាចព្រះអង្គ គឺមកលើអស់អ្នកដែលសង្ឃឹម ដល់ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ[19]ដើម្បីឲ្យព្រះអង្គ
បានរំដោះព្រលឹងគេ ឲ្យរួចពីសេចក្តីស្លាប់ ហើយការពារគេ ឲ្យបានរស់នៅក្នុងគ្រាអំណត់។
[20]យើងរង់ចាំចំពោះព្រះអម្ចាស់ ព្រះអង្គជាជំនួយ និងជាខែលរបស់យើងខ្ញុំ។[21]ដ្បិតចិត្តរបស់យើងខ្ញុំ រីករាយក្នុងព្រះអង្គ ព្រោះយើងខ្ញុំទុកចិត្តដល់ព្រះនាមបរិសុទ្ធ របស់
ព្រះអង្គ។
[22]ឱព្រះអម្ចាស់អើយ សូមឲ្យសេចក្តីសប្បុរសរបស់ព្រះអង្គ នៅជាមួយយើង ដូចដែលយើងដាក់សង្ឃឹមក្នុងព្រះអង្គ។

Psalms 33:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។ (សូមមើល: និងfigs-parallelism)
ចូររីករាយក្នុងព្រះអម្ចាស់ចុះ
ត្រង់នេះ «នៅក្នុងព្រះអម្ចាស់»
សំដៅទៅលើអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់ពួកគេ។
«អរសប្បាយដោយសារអ្វីដែលព្រះអម្ចាស់បានធ្វើ»
សូមសរសើរតម្កើងព្រះជាម្ចាស់ ដ៏សមគួរ ហើយក្នុងផ្លូវត្រឹមត្រូវ
«សរសើរព្រះអម្ចាស់គឺសមរម្យ សម្រាប់មនុស្សទៀងត្រង់»។
Psalms 33:4
ព័ត៌មានទូទៅ:
នៅក្នុង ខ នីមួយៗមានពីរបន្ទាត់ដែលមានអត្ថន័យប្រហាក់ប្រហែល។
ព្រះបន្ទូលរបស់ព្រះអម្ចាស់ទៀងត្រង់
ត្រង់នេះ«ទៀងត្រង់»
ត្រូវបានប្រើជាពាក្យប្រៀបធៀបសម្រាប់អ្វីមួយដែលជាការពិត។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់តែងតែធ្វើអ្វីដែលព្រះអង្គមានបន្ទូលថាទ្រង់នឹងធ្វើ»
ព្រះអង្គស្រឡាញ់សេចក្តីសុចរិត និងយុត្តិធម៌
នាមអរូបីទាំងនេះអាចត្រូវបានថ្លែងជាសកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គចូលចិត្តធ្វើអ្វីដែលត្រឹមត្រូវ និងយុត្តិធម៌» ឬ
«ព្រះអង្គស្រឡាញ់អ្នកដែលធ្វើអ្វីដែលត្រឹមត្រូវ និងយុត្តិធម៌»
ផែនដីមានពេញដោយព្រះហឫទ័យសប្បុរស របស់ព្រះអម្ចាស់
នៅទីនេះ «ផែនដីពេញហើយ» គឺជាសញ្ញាសម្គាល់ដែលមានន័យថា
ភាពស្មោះត្រង់នៃសេចក្តីសញ្ញារបស់ព្រះអង្គអាចមើលឃើញនៅទូទាំងផែនដី។
ការបកប្រែរបៀបផ្សេងទៀត:
«ភាពស្មោះត្រង់នៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់អាចមាននៅពាសពេញពិភពលោក»
ផ្ទៃមេឃកើតឡើងដោយសារព្រះបន្ទូល របស់ព្រះអម្ចាស់ ហើយអ្វីៗទាំងអស់នៅលើមេឃ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«តាមរយៈព្រះបន្ទូលរបស់ព្រះអង្គ ព្រះអម្ចាស់បានបង្កើតផ្ទៃមេឃ»
ដោយសារខ្យល់ដង្ហើមចេញពីព្រះឧស្ឋរបស់ព្រះអង្គដែរ
នេះសំដៅទៅលើព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយព្រះបន្ទូលរបស់ព្រះអង្គ»
Psalms 33:7
ព័ត៌មានទូទៅ:
នៅក្នុង ខ នីមួយៗមានពីរបន្ទាត់ដែលមានអត្ថន័យប្រហាក់ប្រហែល។
ឡើងជាគំនរ
«ដូចជានៅពីក្រោយទំនប់ទឹក»។
អ្នកនិពន្ធពិពណ៌នាអំពីការបង្កើតសមុទ្រដូចជាព្រះអង្គប្រមូលទឹកទាំងអស់រួមមកគ្នា។
ព្រះអង្គយកទីជម្រៅដាក់ក្នុងឃ្លាំង
អ្នកនិពន្ធពិពណ៌នាអំពីការបង្កើតមហាសមុទ្រដូចជាព្រះជាម្ចាស់បានដាក់វានៅក្នុងឃ្លាំងមួយ។
ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ព្រះអង្គដាក់មហាសមុទ្រនៅកន្លែងរបស់វាដូចជាបុរសម្នាក់ដាក់ស្រូវនៅក្នុងឃ្លាំង»
ចូរឲ្យផែនដីទាំងមូល
នេះសំដៅទៅលើប្រជាជននៅលើផែនដី។ ការបកប្រែរបៀបផ្សេងទៀត:
«សូមឲ្យអ្នករាល់គ្នានៅលើផែនដី»
កោតស្ញប់ស្ញែងព្រះអង្គ
ត្រង់នេះ «ឈរស្ញើចសរសើរ» គឺជាសំនួនវោហារដែលមានន័យថា៖
«គួរឲ្យស្ញប់ស្ញែង»។ ការបកប្រែរបៀបផ្សេងទៀត: «គោរពព្រះអង្គ»
នោះអ្វីៗក៏មាននៅ
នៅទីនេះ «ឈរនៅនឹងកន្លែង» គឺជាឃ្លាដែលមានន័យថា៖
«ត្រូវបានបង្កើតឡើង»។ ការបកប្រែរបៀបផ្សេងទៀត: «ចាប់ផ្តើមមាន»
Psalms 33:10
ព័ត៌មានទូទៅ:
នៅក្នុង ខ នីមួយៗមានពីរបន្ទាត់ដែលមានអត្ថន័យប្រហាក់ប្រហែល។
ព្រះអម្ចាស់ធ្វើឲ្យការប្រឹក្សា
«ព្រះអម្ចាស់បំផ្លាញ» ឬ «ព្រះអម្ចាស់បំបែក»
ការប្រឹក្សា របស់ជាតិសាសន៍នានា
នៅទីនេះ «ប្រជាជាតិ» សំដៅទៅលើប្រជាជននៃប្រជាជាតិទាំងនេះ។
ការបកប្រែរបៀបផ្សេងទៀត: «សម្ព័ន្ធភាពរបស់ប្រជាជននៃប្រជាជាតិផ្សេងៗគ្នា»
សម្ព័ន្ធភាព
សម្ព័ន្ធភាពគឺជាកិច្ចព្រមព្រៀងរវាងប្រជាជាតិពីរ
ឬច្រើនដើម្បីគាំទ្រគ្នានៅក្នុងសង្គ្រាមប្រឆាំងនឹងសត្រូវរួម។
គំនិតរបស់ប្រជាជនទាំងឡាយ អសារបង់
«ចេតនារបស់ប្រជាជន» ការបកប្រែរបៀបផ្សេងទៀត:
«ផែនការអាក្រក់របស់ប្រជាជន»
នៅស្ថិតស្ថេរជារៀងរហូត
នៅទីនេះ «ឈរ» គឺជាឃ្លាដែលមានន័យថា «ស៊ូទ្រាំ»។
គម្រោងការក្នុងព្រះហឫទ័យព្រះអង្គ សម្រាប់ គ្រប់ជំនាន់
ពាក្យ «ឈរ» ដែលបាត់ត្រូវបានបញ្ជាក់។ ការបកប្រែរបៀបផ្សេងទៀត:
«ផែនការនៃដួងចិត្តរបស់គាព្រះអង្គឈរសម្រាប់មនុស្សគ្រប់ជំនាន់»
គម្រោងការក្នុងព្រះហឫទ័យព្រះអង្គ
ត្រង់នេះ «ព្រះហឫទ័យរបស់ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ផែនការរបស់ព្រះអង្គ»
សម្រាប់ គ្រប់ជំនាន់
«សម្រាប់មនុស្សជំនាន់ក្រោយទាំងអស់» នេះគឺជាឃ្លាដែលមានន័យថា៖
«ជារៀងរហូត»។
មានពរហើយ ជាតិសាសន៍ណា
ត្រង់នេះ «ប្រជាជាតិ» សំដៅទៅលើប្រជាជនរបស់មនិស្សជាតិ។
ការបកប្រែរបៀបផ្សេងទៀត: «មានពរគឺជាប្រជាជននៃប្រជាជាតិ»
ព្រះអម្ចាស់ទុកជាព្រះរបស់ខ្លួន
«អ្នកដែលថ្វាយបង្គំព្រះអង្គម្ចាស់ដូចព្រះជាម្ចាស់»
ទុកជាមរតករបស់ព្រះអង្គ!
ប្រជាជនដែលព្រះអម្ចាស់បានជ្រើសរើសយកមកថ្វាយបង្គំព្រះអង្គត្រូវបានពិពណ៌នាថាជាមរតក
គឺដូចជាមរតកដែលព្រះអង្គបានទទួល។
Psalms 33:13
ព្រះអង្គទតឃើញមនុស្សទាំងអស់
កន្លែងដែលព្រះអម្ចាស់មានព្រះជន្មគង់នៅ គឺខ្ពស់ជាងផែនដីដែលមនុស្សរស់នៅ។
បង្កើតចិត្ត របស់គេទាំងអស់គ្នា
ត្រង់នេះ «ដួងចិត្ត» សំដៅទៅលើការគិតរបស់មនុស្សទាំងនេះ។
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ដឹកនាំការគិតរបស់ប្រជាជនដូចជាព្រះអង្គជាជាងស្មូនម្នាក់ដែលកំពុងធ្វើ
ការបកប្រែរបៀបផ្សេងទៀត: «ដឹកនាំការគិតរបស់ពួកគេដូចជាជាងស្មូនធ្វើចាន»
Psalms 33:16
គ្មានស្តេចណាបានសង្គ្រោះ ដោយសារមានទ័ពច្រើននោះឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពដ៏ធំមួយមិនមែនជាអ្វីដែលជួយស្តេចទេ»
សេះចម្បាំង មិនមែនជាទីសង្ឃឹម
នៅទីនេះ «សេះ» តំណាងឲ្យផ្នែកខ្លាំងបំផុតនៃកងទ័ព។
ការបកប្រែរបៀបផ្សេងទៀត: «មានកងទ័ពដែលមានសេះខ្លាំងមិនផ្តល់សន្តិសុខ»
Psalms 33:18
មើល៍
ពាក្យនេះបង្ហាញថា ប្រធានបទថ្មីមួយចាប់ផ្តើមនៅក្នុងទំនុកតម្កើងនេះ។
ការបកប្រែរបៀបផ្សេងទៀត: «មើល៍» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់
ចំពោះអ្វីដែលទូលបង្គំរៀបនឹងប្រាប់ព្រះអង្គ»
ព្រះនេត្ររបស់ព្រះអម្ចាស់
ត្រង់នេះ «ព្រះនេត្រ» សំដៅទៅលើការយកចិត្តទុកដាក់របស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ការយកចិត្តទុកដាក់របស់ព្រះអម្ចាស់»
អ្នកដែលសង្ឃឹម
«អ្នកណាដែលរង់ចាំ» ឬ «អ្នកណាដែលសង្ឃឹម»
ដើម្បីឲ្យព្រះអង្គបានរំដោះព្រលឹងគេ ឲ្យរួចពីសេចក្តីស្លាប់
នៅទីនេះ «ជីវិតរបស់ពួកគេ» សំដៅទៅលើប្រជាជន។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីកុំឲ្យពួកគេស្លាប់»
Psalms 33:20
យើងរង់ចាំចំពោះព្រះអម្ចាស់
នៅទីនេះ «រង់ចាំ» គឺជាឃ្លាដែលសំដៅទៅលើការទុកចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «យើងទុកចិត្តលើព្រះអម្ចាស់»
ព្រះអង្គជាជំនួយ និងជាខែលរបស់យើងខ្ញុំ
ត្រង់នេះព្រះអម្ចាស់មានព្រះបន្ទូលដូចព្រះអង្គជាខែលការពារទាហាននៅសមរភូមិ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គជាជំនួយរបស់យើង
ហើយការពារយើងដូចជាខែល»
ចិត្តរបស់យើងខ្ញុំ
ត្រង់នេះ «ដួងចិត្ត» សំដៅទៅលើប្រជាជន។ ការបកប្រែរបៀបផ្សេងទៀត:
«យើងរីករាយ»
ដល់ព្រះនាមបរិសុទ្ធ របស់ព្រះអង្គ
ត្រង់នេះ «ព្រះនាមបរិសុទ្ធ» សំដៅទៅលើចរិតដ៏វិសុទ្ធរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងចរិតបរិសុទ្ធរបស់ព្រះអង្គ» ឬ
«នៅក្នុងព្រះអង្គព្រោះព្រះអង្គបរិសុទ្ធ»
Psalms 33:22
នៅជាមួយយើង
ឃ្លានេះមានន័យថា «ជួយយើង»។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើការដើម្បីភាពល្អរបស់យើង» ឬ «ជួយយើង» ឬ «ការពារយើង»
ដូចដែលយើងដាក់សង្ឃឹមក្នុងព្រះអង្គ
«ដូចដែលយើងសង្ឃឹមថា ជំនួយរបស់ព្រះអង្គ»។

---

34 ទំនុករបស់ស្តេចដាវីឌ នៅគ្រាដែលទ្រង់ក្លែងធ្វើជាឆ្កួត នៅចំពោះអ័ប៊ីម៉ាឡិច ហើយអ័ប៊ីម៉ាឡិចក៏បណ្តេញទ្រង់ចេញទៅ។[1]ទូលបង្គំនឹងសរសើរតម្កើងព្រះអម្ចាស់ គ្រប់
ពេលវេលា ការសរសើរព្រះអង្គ នៅក្នុងមាត់ទូលបង្គំជានិច្ច។
[2]ចូរឲ្យមនុស្សរាបសារស្តាប់ ហើយមានចិត្តត្រេកអរឡើង។[3]ឱ សូមតម្កើងព្រះអម្ចាស់ជាមួយខ្ញុំ ចូរយើងនាំគ្នាលើកតម្កើងព្រះនាមព្រះអង្គជាមួយគ្នា។
[4]ខ្ញុំបានស្វែងរកព្រះអម្ចាស់ ហើយព្រះអង្គក៏ឆ្លើយតបមកខ្ញុំ ក៏ជួយខ្ញុំយកឈ្នះការភ័យខ្លាចរបស់ខ្ញុំ។[5]អ្នកណាសម្លឹងឆ្ពោះទៅព្រះអង្គ អ្នកនោះនឹងបានពោរពេញទៅដោយ
អំណរ ហើយនឹងមិនខកចិត្តសោះឡើយ។[6]មនុស្សក្រលំបាកបានស្រែកឡើង ហើយព្រះអម្ចាស់សណ្តាប់ នឹងសង្គ្រោះគេឲ្យរួច ពីទុក្ខលំបាកទាំងប៉ុន្មានរបស់គេ។
[7]ទេវតានៃព្រះអម្ចាស់ ចោមរោមជុំវិញអស់អ្នកដែល កោតខ្លាចព្រះអង្គ ហើយរំដោះគេឲ្យរួច។[8]ឱសូមភ្លក់មើលឲ្យដឹងថា ព្រះអម្ចាស់ល្អចុះ។ មានពរហើយ មនុស្សណាដែល
ពឹងជ្រកក្នុងព្រះអង្គ។[9]ឱពួកបរិសុទ្ធរបស់ព្រះអង្គអើយ ចូរកោតខ្លាចព្រះអម្ចាស់។ ដ្បិតអស់អ្នកដែលកោតខ្លាចព្រះអង្គ មិនខ្វះអ្វីឡើយ។
[10]ពួកសិង្ហស្ទាវ អាចជួបនឹងការខ្វះអាហារ ហើយអត់ឃ្លាន តែអស់អ្នកដែលស្វែងរកព្រះអម្ចាស់ នឹងមិនខ្វះគ្រប់ការល្អឡើយ។[11]ឱ កូនទាំងឡាយអើយ ចូរនាំគ្នាមក ហើយ
ស្តាប់ខ្ញុំនឹងបង្រៀនអ្នករាល់គ្នា ពីការកោតខ្លាចព្រះអម្ចាស់។
[12]តើមានអ្នកណាដែលចង់បានជីវិត ហើយស្រឡាញ់អាយុយឺនយូរដើម្បីឲ្យខ្លួនបានឃើញសេចក្តីល្អឬទេ?[13]សូមរក្សាអណ្តាតរបស់អ្នកពីសេចក្តីអាក្រក់ និងបបូរមាត់ កុំ
ពោលពាក្យបោកបញ្ឆោត។[14]ចូរចៀសចេញពីអំពើអាក្រក់ ហើយប្រព្រឹត្តអំពើល្អវិញ។ ចូរស្វែងរកសេចក្តីសុខ ហើយដេញតាមចុះ។

generated on Wed Sep 10 16:16:32 2025

[15]ព្រះនេត្រព្រះអម្ចាស់ ទតឆ្ពោះទៅរកមនុស្សសុចរិតហើយព្រះកាណ៌ព្រះអង្គ ផ្ទៀងស្តាប់សម្រែករបស់គេ។[16]ព្រះភ័ក្ត្រព្រះអម្ចាស់ទាស់ទទឹងនឹងពួកអ្នក ដែលប្រព្រឹត្ត
អាក្រក់ដើម្បីកុំឲ្យមនុស្សនៅលើផែនដី នឹកចាំពីពួកគេតទៅទៀត។[17]ពេលមនុស្សសុចរិតស្រែកឡើង ព្រះអម្ចាស់ព្រះសណ្តាប់ ហើយព្រះអង្គក៏រំដោះគេឲ្យរួច ពីគ្រប់ទុក្ខ
លំបាករបស់គេ។
[18]ព្រះអម្ចាស់គង់នៅជិត អ្នកដែលមានចិត្តខ្ទេចខ្ទាំ ហើយសង្គ្រោះអស់អ្នក ដែលមានវិញ្ញាណសោកសង្រេង។[19]មនុស្សសុចរិតរងទុក្ខលំបាកជាច្រើន តែព្រះអម្ចាស់នាំចេញ
ឲ្យរួចពីទុក្ខលំបាកទាំងឡាយ។[20]ព្រះអង្គរក្សាអស់ទាំងឆ្អឹងរបស់អ្នកនោះ មិនឲ្យឆ្អឹងណាមួយត្រូវបាក់ឡើយ។
[21]អំពើអាក្រក់នឹងសម្លាប់មនុស្សពាល។ អស់អ្នកដែលស្អប់មនុស្សសុចរិតនឹងត្រូវទទួលទោស។[22]ព្រះអម្ចាស់សង្គ្រោះជីវិតពួកអ្នកបម្រើរបស់ព្រះអង្គ។ ក្នុងចំណោមអស់អ្នក
ដែលពឹងជ្រកក្នុងព្រះអង្គ គ្មានអ្នកណាម្នាក់នឹងត្រូវទោសឡើយ។

Psalms 34:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។

ទំនុកររបស់ស្តេចដាវីឌ

អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ
២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុកររបស់ព្រះបាទដាវីឌ។

ក្លែងធ្វើជាឆ្កួត

«ធ្វើដូចជាមនុស្សឆ្កួត»

នៅចំពោះអ័ប៊ីម៉ាឡិច

នេះសំដៅទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាក់លាក់មួយដែលប្រជាជនហេព្រើរ
បានស្គាល់ច្បាស់។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលទ្រង់នៅក្នុងផ្ទះរបស់លោកអ័ប៊ីម៉ាឡិច» ឬ
«នៅពេលទ្រង់នៅជាប់អ្នកទោសរបស់លោកអ័ប៊ីម៉ាឡិច»

ក៏បណ្តេញទ្រង់ចេញទៅ

«បញ្ជូនទ្រង់ទៅដោយបង្ខំ»

ការសរសើរព្រះអង្គ នៅក្នុងមាត់ទូលបង្គំជានិច្ច

ត្រង់នេះ «នៅក្នុងមាត់ខ្ញុំ» គឺសំដៅទៅលើព្រះបាទ
ដាវីឌដែលនិយាយអំពីព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំនឹងសរសើរព្រះអង្គជានិច្ច»

Psalms 34:2

មនុស្សទន់ទាប

នេះសំដៅទៅលើមនុស្សដែលត្រូវគេជិះជាន់។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនដែលត្រូវបានគេជិះជាន់»

ឱ សូមតម្កើងព្រះអម្ចាស់ជាមួយខ្ញុំ

កិរិយាស័ព្ទ «ការសរសើរ» គឺជាពាក្យបញ្ជាដល់ក្រុមមួយ។
ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សគ្រប់គ្នាគួរតែសរសើរដល់ព្រះអម្ចាស់ជាមួយខ្ញុំ»

លើកតម្កើងព្រះនាមព្រះអង្គ

ត្រង់នេះ «លើកដៃឡើង»
គឺជាសំនួនវោហារដែលសំដៅទៅលើការលើកតម្កើងព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាប់មនុស្សថាព្រះអង្គអស្ចារ្យប៉ុណ្ណា»

ព្រះនាមព្រះអង្គ

ត្រង់នេះ «ព្រះនាមរបស់ព្រះអង្គ» សំដៅទៅលើចរិតលក្ខណៈរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ចរិតលក្ខណៈរបស់ព្រះអង្គ»

Psalms 34:4

ខ្ញុំបានស្វែងរកព្រះអម្ចាស់

ត្រង់នេះ «ស្វែងរកព្រះអម្ចាស់» មានន័យថា ព្រះបាទ
ដាវីឌកំពុងតែសុំជំនួយពីព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំបានអធិស្ឋានដល់ព្រះអម្ចាស់»

អ្នកណាសម្លឹងឆ្ពោះទៅព្រះអង្គ

នៅទីនេះ «មើលទៅ» តំណាងឲ្យការស្វែងរកជំនួយពីព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលមើលព្រះអង្គឲ្យជួយ» ឬ
«អ្នកដែលរំពឹងថានឹងជួយតែពីព្រះអង្គ»

បានពោរពេញទៅដោយអំណរ

សំនួនវោហារស័ព្ទនេះសំដៅទៅលើរូបរាងរបស់ពួកគេដូចជារីករាយ។
ការបកប្រែរបៀបផ្សេងទៀត: «រីករាយ»

ហើយនឹងមិនខកចិត្តសោះឡើយ

នៅទីនេះ «មុខរបស់ពួកគេ» សំដៅទៅលើមនុស្សដែលមើលទៅព្រះអម្ចាស់។
នេះក៏អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមានផងដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនខ្មាស់អៀន» ឬ «ពួកគេមានមោទនភាព»

មនុស្សក្រលំបាកបានស្រែកឡើង

ព្រះបាទដាវីឌពណ៌នាខ្លួនទ្រង់ជាមនុស្សដែលត្រូវគេជិះជាន់។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំត្រូវបានគេជិះជាន់ហើយ»

ព្រះអម្ចាស់សណ្តាប់ទ្រង់

ត្រង់នេះ «បានឮ» មានន័យថាព្រះអម្ចាស់បានជួយទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានឮទូលបង្គំ» ឬ
«ព្រះអម្ចាស់បានជួយទ្រង់»

Psalms 34:7

ចោមរោមជុំវិញ

ទេវតារបស់ព្រះអម្ចាស់ត្រូវបានគេនិយាយដូចជាទ្រង់ជាកងទ័ពដែលឡោមព័ទ្ធជុំវិញនរណាម្នាក់
ដើម្បីការពារពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «ឆ្មាំ»

ឱសូមភ្លក់មើលឲ្យដឹងថា ព្រះអម្ចាស់ល្អចុះ

ភាពល្អរបស់ព្រះអម្ចាស់ត្រូវបានគេនិយាយថា៖
ជាអ្វីដែលអាចភ្លក់បាននិងមើលឃើញ។ ការបកប្រែរបៀបផ្សេងទៀត:
«សាកល្បងនិងពិសោធថាព្រះអម្ចាស់ល្អ»

ដែលពឹងជ្រក

ព្រះអម្ចាស់ត្រូវបានគេនិយាយថា៖
ជាកន្លែងដែលមនុស្សអាចលាក់ការពារពីសត្រូវរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ទុកចិត្តព្រះអង្គដើម្បីការពារពួកគេ»

ដ្បិតអស់អ្នកដែលកោតខ្លាចព្រះអង្គ មិនខ្វះអ្វីឡើយ

នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលកោតខ្លាចព្រះអង្គនឹងតែងតែមានអ្វីដែលពួកគេត្រូវការ»

Psalms 34:10

នឹងមិនខ្វះគ្រប់ការល្អឡើយ

នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងតែងតែមានរបស់ល្អដែលពួកគេត្រូវការ»

កូនទាំងឡាយអើយ

នេះមិនមែនសំដៅទៅលើកូនប្រុសរបស់អ្នកនិពន្ធទេ
តែសំដៅទៅលើប្រជាជនដែលព្រះអង្គកំពុងបង្រៀន អំពីព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «សិស្សរបស់យើង» (UDB)

Psalms 34:12

តើមានអ្នកណាដែលចង់បានជីវិត ហើយស្រឡាញ់អាយុយឺនយូរ ដើម្បីឲ្យខ្លួនបានឃើញសេចក្តីល្អ
ឬទេ?

ចម្លើយជាក់ស្តែង ចំពោះសំណួរនេះគឺ «មនុស្សគ្រប់រូប»។
សំណួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សគ្រប់រូបប្រាថ្នាចង់បានជីវិត និងបំណងប្រាថ្នាចង់រស់នៅច្រើនថ្ងៃ
និងមានជីវិតដ៏ល្អ»

សូមរក្សាអណ្តាតរបស់អ្នកពីសេចក្តីអាក្រក់...សូមរក្សាបបូរមាត់របស់អ្នក កុំពោលពាក្យបោកបញ្ឆោត

ឃ្លាទាំងពីរនេះសំដៅទៅលើរឿងតែមួយ
ហើយនេះត្រូវបានគេនិយាយតាមរបៀបផ្សេងៗគ្នា
ដើម្បីបញ្ជាក់ពីសារៈសំខាន់របស់វា។

សូមរក្សាអណ្តាតរបស់អ្នកពីសេចក្តីអាក្រក់

នៅទីនេះ «អណ្តាត» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះកុំនិយាយអាក្រក់»

សូមរក្សាបបូរមាត់របស់អ្នក កុំពោលពាក្យបោកបញ្ឆោត

នៅទីនេះ «បបូរមាត់» សំដៅទៅលើអ្នកនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«កុំនិយាយកុហក»

ចូរចៀសចេញពីអំពើអាក្រក់

នៅទីនេះ «ងាកទៅឆ្ងាយ»

generated on Wed Sep 10 16:16:32 2025

គឺជាពាក្យប្រៀបធៀបសម្រាប់ការជៀសវាងអំពើអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត: «បដិសេធមិនធ្វើអំពើអាក្រក់»
ចូរស្វែងរកសេចក្ដីសុខ
ត្រង់នេះ «ស្វែងរក» មានន័យថា មានការព្រួយបារម្ភអំពីសន្តិភាព។
ការបកប្រែរបៀបផ្សេងទៀត:
«ព្យាយាមរស់នៅដោយសន្តិភាពជាមួយមនុស្សផ្សេងទៀត»
Psalms 34:15
ព្រះនេត្រព្រះអម្ចាស់ ទតឆ្ពោះទៅរកមនុស្សសុចរិត
ត្រង់នេះ «ព្រះនេត្ររបស់ព្រះអម្ចាស់»
សំដៅទៅលើការឃ្លាំមើលដ៏ប្រុងប្រយ័ត្នរបស់ព្រះអង្គ។ «មនុស្សសុចរិត»
គឺជាឯកសារយោងសំដៅទៅលើមនុស្សសុចរិត។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ទតមើលដោយប្រុងប្រយ័ត្នចំពោះមនុស្សសុចរិត»
ព្រះកាណ៌ព្រះអង្គ ផ្ទៀងស្តាប់សម្រែករបស់គេ
ត្រង់នេះ «ព្រះកាណ៌ព្រះអង្គ»
សំដៅទៅលើបំណងប្រាថ្នារបស់ព្រះអម្ចាស់ក្នុងការឆ្លើយតបចំពោះពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គយកចិត្តទុកដាក់នឹងសម្រែករបស់ពួកគេ» ឬ
«ព្រះអង្គឆ្លើយតបនឹងសម្រែករបស់ពួកគេ»
ដើម្បីកុំឲ្យមនុស្សនៅលើផែនដី នឹកចាំពីពួកគេតទៅទៀត
ព្រះអម្ចាស់នឹងធ្វើឲ្យប្រជាជនបំភ្លេចពួកគេទាំងស្រុង នៅពេលពួកគេស្លាប់
គឺដូចជាព្រះអង្គយកកាំបិតមកកាត់ផ្តាច់ការចងចាំរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះ នៅពេលពួកគេស្លាប់
មនុស្សនឹងភ្លេចពួកគេទាំងស្រុង»
ព្រះអម្ចាស់ព្រះសណ្ដាប់
ត្រង់នេះ «ព្រះសណ្ដាប់» មានន័យថាព្រះអម្ចាស់ចង់ឆ្លើយតបនឹងពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់យកចិត្តទុកដាក់ចំពោះពួកគេ»
Psalms 34:18
ព្រះអម្ចាស់គង់នៅជិត
នៅទីនេះ «ជិត» មានន័យថា «ត្រៀមខ្លួនដើម្បីជួយ»។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់តែងតែជួយ»
អ្នកដែលមានចិត្តខ្ទេចខ្ទាំ
ភាពសោកសៅយ៉ាងជ្រាលជ្រៅត្រូវបានគេនិយាយដូចជាបេះដូងរបស់មនុស្សនោះត្រូវបានបំផ្លិចបំផ្លាញ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលមានទុកក្រៀមក្រំ»
អ្នកដែលមានវិញ្ញាណសោកសង្រេង
មនុស្សដែលធ្លាក់ទឹកចិត្តយ៉ាងខ្លាំង
ត្រូវបានគេនិយាយដូចជាវិញ្ញាណរបស់ពួកគេត្រូវបានកំទេច។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលបាក់ទឹកចិត្ត»
មនុស្សសុចរិត
នេះសំដៅទៅលើមនុស្សសុចរិត។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សសុចរិត»
ព្រះអង្គរក្សាអស់ទាំងឆ្អឹងរបស់អ្នកនោះ មិនឲ្យឆ្អឹងណាមួយត្រូវបាក់ឡើយ
នៅទីនេះ «ឆ្អឹងរបស់លោកទាំងអស់»
គឺព្យញ្ជនៈប៉ុន្តែវាក៏បញ្ជាក់ផងដែរថាព្រះអម្ចាស់ថែរក្សាមនុស្សទាំងមូល។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គផ្តល់ការការពារពេញលេញសម្រាប់ទ្រង់នឹងមិនបង្កគ្រោះថ្នាក់អ្វីទេ»
Psalms 34:21
អំពើអាក្រក់នឹងសម្លាប់មនុស្សពាល
អំពើអាក្រក់ត្រូវបានពិពណ៌នាថា ជាបុរសដែលអាចសម្លាប់មនុស្សបាន។
ការបកប្រែរបៀបផ្សេងទៀត: «អំពើអាក្រក់របស់មនុស្សពាលនឹងសំលាប់ពួកគេ»
មនុស្សពាល
នេះសំដៅទៅលើមនុស្សអាក្រក់។
អស់អ្នកដែលស្អប់មនុស្សសុចរិតនឹងត្រូវទទួលទោស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់នឹងថ្កោលទោសអ្នកដែលស្អប់មនុស្សសុចរិត»
មនុស្សសុចរិត
នេះសំដៅទៅលើមនុស្សសុចរិត។
ក្នុងចំណោមអស់អ្នក ដែលពឹងជ្រកក្នុងព្រះអង្គ គ្មានអ្នកណាម្នាក់នឹងត្រូវទោសឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
នេះក៏អាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមានផងដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់នឹងអត់ទោសឲ្យអស់អ្នកដែលពឹងផ្អែកលើព្រះអង្គ»
ពឹងជ្រកក្នុងព្រះអង្គ
ការចូលទៅរកព្រះអម្ចាស់ ដើម្បីទទួលបានការពារ ត្រូវបាននិយាយថា
ជាទីពឹងជ្រករបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត: «ទៅរកព្រះអង្គ
ដើម្បីការពារ»

---

35 [1]ទំនុករបស់ស្តេចដាវីឌ។ ឱព្រះអម្ចាស់អើយ! សូមតតាំងនឹងអស់អ្នកដែលតតាំងនឹងទូលបង្គំ សូមតយុទ្ធនឹងអស់អ្នក ដែលតយុទ្ធនឹងទូលបង្គំផង។[2]សូមយកខែល
ទាំងតូចទាំងធំ ហើយក្រោកឡើង ជួយទូលបង្គំផង។[3]សូមប្រើលំពែង និងដែកពួយ ប្រហារពួកអ្នកដែលដេញតាមទូលបង្គំទៅ សូមមានព្រះបន្ទូលមកព្រលឹង
ទូលបង្គំថា យើងជាព្រះសង្គ្រោះអ្នក»។
[4]សូមឲ្យអ្នកដែលប៉ុនប៉ងដល់ជីវិតទូលបង្គំ ត្រូវខ្មាស ហើយបាក់មុខ សូមឲ្យអ្នកដែលប៉ុនប៉ងធ្វើបាបទូលបង្គំ ត្រូវដកខ្លួនថយ ហើយអៀនខ្មាស។[5]សូមឲ្យគេបានដូចជា
ចំបើងដែលត្រូវខ្យល់ផាត់ ហើយឲ្យទេវតារបស់ព្រះអម្ចាស់បណ្តេញគេចេញ។[6]សូមឲ្យផ្លូវរបស់គេងងឹតសូន្យសុង ហើយរអិល ដូចឲ្យទេវតារបស់ព្រះអម្ចាស់ ដេញតាមគេ
ផង។
[7]ដ្បិតគេបានបង្កប់អន្ទាក់ ដើម្បីចាប់ទូលបង្គំ ដោយឥតហេតុ គេបានជីករណ្តៅ ដើម្បីចាប់ជីវិតទូលបង្គំដោយឥតហេតុដែរ។[8]សូមឲ្យគេជួបនឹងការហិនវិនាស ដោយមិនដឹង
ខ្លួន។ សូមឲ្យគេជាប់អន្ទាក់ដែលខ្លួនគេបានបង្កប់ទុក សូមឲ្យគេធ្លាក់ចូលអន្ទាក់នោះ ហើយវិនាសអន្តរាយទៅ។
[9]ពេលនោះ ព្រលឹងទូលបង្គំ នឹងអរសប្បាយក្នុងព្រះអម្ចាស់ ហើយត្រេកអរក្នុងការសង្គ្រោះរបស់ព្រះអង្គ។[10]អស់ទាំងឆ្អឹងរបស់ទូលបង្គំនឹងពោលថា «ឱព្រះអម្ចាស់អើយ តើ
មានអ្នកណាដូចព្រះអង្គ ព្រះអង្គរំដោះមនុស្សក្រីក្រ ឲ្យរួចពីអ្នកដែលខ្លាំងជាងខ្លួន ទាំងជនក្រីក្រ និងកម្សត់ទុគ៌តឲ្យរួចពីអ្នកលួចប្លន់ពួកគេ?»។
[11]មានសាក្សីក្លែងក្លាយលើកគ្នាឡើង គេចោទសួរពីរឿងហេតុដែលទូលបង្គំមិនដឹង។[12]ពួកគេយកការអាក្រក់ មកតបស្នងនឹងការល្អរបស់ទូលបង្គំ។ ទូលបង្គំ
ឈឺចាប់ណាស់។
[13]កាលគេបានឈឺ នោះទូលបង្គំបានស្លៀកពាក់សំពត់ធ្មៃ ទូលបង្គំបានតមអាហារ និងទូលបង្គំឱនក្បាលអធិស្ឋានយ៉ាងអស់ពីចិត្ត។[14]ទូលបង្គំបានប្រព្រឹត្ត ដូចប្រព្រឹត្ត
ចំពោះបងប្អូនខ្លួនរបស់ទូលបង្គំ ទូលបង្គំបានកាន់ទុក្ខ ដូចនៅពេលម្តាយរបស់ទូលបង្គំស្លាប់។
[15]ប៉ុន្តែ ពេលទូលបង្គំមានទុក្ខលំបាក ពួកគេអរសប្បាយ និងប្រមូលផ្តុំគ្នា ហើយគេប្រមូលផ្តុំគ្នាទាស់នឹងទូលបង្គំ ហើយទូលបង្គំមិនយល់ពីពួកគេឡើយ។ ពួកគេបានហែក
ហួរទូលបង្គំឥតឈប់ឈរ។[16]គេប្រមាថមើលងាយទូលបង្គំឥតស្រាកស្រាន្ត ហើយសង្កៀតធ្មេញដាក់ទូលបង្គំ។
[17]ឱព្រះអម្ចាស់អើយ! តើព្រះអង្គធ្វើព្រងើយដល់កាលណាទៀត? សូមរំដោះព្រលឹងទូលបង្គំ ឲ្យរួចពីការរាយប្រហាររបស់ពួកគេ ហើយសង្គ្រោះជីវិតទូលបង្គំ ឲ្យរួចពីពួកសិង្ហ
ផង។[18]ទូលបង្គំនឹងអរព្រះគុណព្រះអង្គ នៅក្នុងក្រុមជំនុំធំ ទូលបង្គំនឹងសរសើរតម្កើងព្រះអង្គ ក្នុងចំណោមមនុស្សជាច្រើន។
[19]សូមកុំឲ្យពួកខ្មាំងសត្រូវរបស់ទូលបង្គំ អរសប្បាយដោយឈ្នះទូលបង្គំឡើយ ក៏កុំឲ្យអស់អ្នកដែលស្អប់ទូលបង្គំ បានចំអកដាក់ទូលបង្គំដែរ។[20]ដ្បិតគេមិននិយាយដោយ
មេត្រីទេ គឺគេតែងតែបង្កើតពាក្យមួលបង្កាច់ ទាស់នឹងអស់អ្នកដែលស្ងប់ស្ងៀមនៅក្នុងស្រុក។
[21]គេហាមាត់យ៉ាងធំទាស់នឹងទូលបង្គំ ដោយពាក្យថា «អេ អេ! ភ្នែកយើងបានឃើញច្បាស់ហើយ»។[22]ឱព្រះអម្ចាស់អើយ ព្រះអង្គទតឃើញស្រាប់ហើយ សូមកុំនៅស្ងៀម ឱ
ព្រះអម្ចាស់អើយ សូមកុំគង់ឆ្ងាយពីទូលបង្គំឡើយ។[23]សូមតើនឡើង! សូមក្រោកឡើង ហើយការពារក្តីឲ្យទូលបង្គំផង ឱព្រះជាព្រះអម្ចាស់នៃទូលបង្គំអើយ! សូមរកយុត្តិធម៌
ឲ្យទូលបង្គំផង។
[24]ឱព្រះអម្ចាស់ ជាព្រះនៃទូលបង្គំអើយ! សូមការពារទូលបង្គំ តាមសេចក្តីសុចរិតរបស់ព្រះអង្គ សូមកុំឲ្យគេអរសប្បាយ ដោយឈ្នះទូលបង្គំឡើយ។[25]សូមកុំឲ្យគេគិតក្នុងចិត្ត
ថា «អេ យើងបានអ្វីដែលយើងចង់បានហើយ»។ សូមកុំឲ្យគេពោលថា «យើងបានលេបវាបាត់ហើយ»។[26]អស់អ្នកដែលលើកគ្នាទាស់នឹងទូលបង្គំ សូមឲ្យគេហ៊ុម
ព័ទ្ធដោយភាពអាម៉ាស់ហើយបាក់មុខទៅ។ អស់អ្នកដែលអរសប្បាយនឹងទុក្ខលំបាករបស់ទូលបង្គំសូមឲ្យគេត្រូវខ្មាសហើយខូចឈ្មោះចុះ។

generated on Wed Sep 10 16:16:32 2025

[27]តែអស់អ្នកដែលកាន់ខាងសេចក្ដីសុចរិត របស់ទូលបង្គំ សូមឲ្យគេបានស្រែកហ៊ោឡើងដោយអំណរ ហើយសប្បាយរីករាយវិញ សូមឲ្យគេបន្តពោលថា «ព្រះអម្ចាស់គួរតម្កើងឡើងព្រះអង្គសព្វព្រះហឫទ័យ ឲ្យអ្នកបម្រើព្រះអង្គបានចម្រុងចម្រើន»។[28]ពេលនោះ អណ្ដាតទូលបង្គំនឹងថ្លែងអំពីសេចក្ដីសុចរិតរបស់ព្រះអង្គ ហើយសរសើរតម្កើងព្រះអង្គដរាបរាល់ថ្ងៃ។

Psalms 35:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។

ទំនុកបរបស់ស្តេចដាវីឌ

អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ ២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣) បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុកបរបស់ព្រះបាទដាវីឌ។

សូមយកខែលទាំងតូចទាំងធំ...សូមប្រើលំពែង និងដែកពួយ

ឃ្លាទាំងនេះពិពណ៌នាអំពីព្រះជាម្ចាស់ជាអ្នកចម្បាំងដែលកំពុងរៀបចំខ្លួនសម្រាប់ការប្រយុទ្ធ

ខែលទាំងតូចទាំងធំ

ទាំងនេះគឺជាអាវុធការពារ

លំពែង និងដែកពួយ

ទាំងនេះគឺជាអាវុធវាយលុក

ពួកអ្នកដែលដេញតាមទូលបង្គំ

អត្ថន័យដែលអាចមានគឺ ១) សត្រូវទាំងនេះកំពុងដេញតាមអ្នកនិពន្ធ ឬ ២) នេះគឺជាការប្រៀបធៀបសម្រាប់មនុស្សដែលជាសត្រូវរបស់អ្នកនិពន្ធ។

សូមមានព្រះបន្ទូលមកព្រលឹងទូលបង្គំ

នេះសំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «មានព្រះបន្ទូលមកទូលបង្គំ»

យើងជាព្រះសង្គ្រោះអ្នក

នេះអាចត្រូវបានបញ្ជាក់ ដោយគ្មាននាមអរូបី។ ការបកប្រែរបៀបផ្សេងទៀត: «យើងជាព្រះសង្គ្រោះរបស់អ្នក» ឬ «យើងនឹងជួយសង្គ្រោះអ្នក»

Psalms 35:4

សូមឲ្យអ្នកដែលប៉ុនប៉ងដល់ជីវិតទូលបង្គំ ត្រូវខ្មាស ហើយបាក់មុខ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះអម្ចាស់អៀនខ្មាស និងអាម៉ាស់មុខដល់អស់អ្នកដែលស្វែងរកជីវិតទូលបង្គំ»

សូមឲ្យ

«ទូលបង្គំប្រាថ្នាថា»

អ្នកដែលប៉ុនប៉ងដល់ជីវិតទូលបង្គំ

នៅទីនេះ «ប៉ុនប៉ងជីវិតរបស់ទូលបង្គំ» មានន័យថាពួកគេចង់សម្លាប់អ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលកំពុងរកសម្លាប់ទូលបង្គំ»

សូមឲ្យអ្នកដែលប៉ុនប៉ងធ្វើបាបទូលបង្គំ ត្រូវដកខ្លួនថយ ហើយអៀនខ្មាស

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះអម្ចាស់វិលត្រឡប់ទៅវិញ ហើយធ្វើឲ្យអ្នកដែលមានគំរោងធ្វើបាបទូលបង្គំ»

ត្រូវដកខ្លួនថយ

«ងាកក្រោយ»

គឺជាពាក្យប្រៀបធៀបមួយសម្រាប់ការមិនអាចសម្រេចគោលដៅរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «មិនជោគជ័យ»

មានការភ័ន្តច្រឡំ

«ច្រឡំ» ឬ «ច្របូកច្របល់»

ដូចជាចំបើងដែលត្រូវខ្យល់ផាត់

សត្រូវរបស់អ្នកនិពន្ធ ត្រូវបានគេនិយាយដូចជាពួកគេដែលត្រូវបានគេដេញដោយងាយដែលត្រូវបានផ្លុំចេញ។ ការបកប្រែរបៀបផ្សេងទៀត: «បក់បោកដោយខ្យល់ដូចអង្កាម»

ផ្លូវរបស់ពួកគេ

នៅទីនេះ «ផ្លូវរបស់ពួកគេ» សំដៅទៅលើជីវិតរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «ជីវិតរបស់ពួកគេ»

ងងឹតសូន្យសុង ហើយរអិល

នេះសំដៅទៅលើវិធីដែលលាក់ និងមានគ្រោះថ្នាក់។ ការបកប្រែរបៀបផ្សេងទៀត: «លាក់និ ងពោរពេញដោយគ្រោះថ្នាក់»

ដេញតាមពួកគេ

នេះសំដៅទៅលើទេវតារបស់ព្រះអកម្ចាស់ដែលកំពុងប្រឆាំងនឹងសត្រូវរបស់អ្នកនិពន្ធ។នេះគឺជាការប្រៀបធៀបដែលមានន័យថា ការបកប្រែរបៀបផ្សេងទៀត: «ធ្វើការប្រឆាំងនឹងពួកគេ» ឬ «ប្រឆាំងនឹងពួកគេ»

Psalms 35:7

ពួកគេបានបង្កប់អន្ទាក់ ដើម្បីចាប់ទូលបង្គំ

គ្រោងការណ៍របស់មនុស្សអាក្រក់

ត្រូវបានគេនិយាយដូចជាពួកគេជាសំណាញ់ដែលពួកគេកំណត់ដើម្បីចាប់អ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេចង់ចាប់ទូលបង្គំនៅក្នុងសំណាញ់ដូចជាសត្វតូច»

គេបានជីករណ្តៅ ដើម្បីចាប់ជីវិតទូលបង្គំ

គ្រោងការណ៍របស់មនុស្សអាក្រក់ ត្រូវបានគេនិយាយថា៖ ដូចជារណ្តៅដែលពួកគេជីក ដើម្បីចាប់អ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេចង់ចាប់ទូលបង្គំនៅក្នុងរណ្តៅដូចជាសត្វធំ»

ជីវិតទូលបង្គំ

នេះសំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំ»

សូមឲ្យគេជួបនឹងការហិនវិនាស ដោយមិនដឹងខ្លួន

ការបំផ្លាញ

ត្រូវបានគេនិយាយដូចជាវាជាសត្វដ៏គ្រោះថ្នាក់ដែលនឹងវាយប្រហារពួកគេភ្លាមៗ។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យពួកគេត្រូវបានបំផ្លាញភ្លាមៗ» ឬ «សូមឲ្យពួកគេភ្ញាក់ផ្អើលព្រោះព្រះអង្គបំផ្លាញពួកគេភ្លាមៗ»

អន្ទាក់ដែលខ្លួនគេបានបង្កប់ទុក

គ្រោងការណ៍របស់មនុស្សអាក្រក់

ត្រូវបានគេនិយាយដូចជាពួកគេជាសំណាញ់ដែលពួកគេដាក់ដើម្បីចាប់អ្នកសរសេរ។ ការបកប្រែរបៀបផ្សេងទៀត: «សំណាញ់ដែលពួកគេបានដាក់ដើម្បីចាប់ទូលបង្គំដូចជាសត្វ ហើយធ្វើបាបទូលបង្គំ»

សូមឲ្យគេធ្លាក់ចូលអន្ទាក់នោះ

នេះជាពាក្យប្រៀបធៀបដូចគ្នានឹង ខ ៧។

សំណាញ់មានគោលបំណងចាប់អ្នកសរសេរ។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យពួកគេធ្លាក់ចូលទៅក្នុងរណ្តៅដែលពួកគេបានជីកសម្រាប់ទូលបង្គំ»

ធ្លាក់ចូល

អត្ថន័យដែលអាចមានគឺ ១) ធ្លាក់ទៅក្នុងរណ្តៅនៃ ខ ៧ ឬ ២) ធ្លាក់ចូលទៅក្នុងការបំផ្លាញ។

ហើយ ពួកគេវិនាសអន្តរាយទៅ

នាមអរូបី «ការបំផ្លាញចោល» អាចត្រូវបានចែងក្នុងទម្រង់ផ្សេងទៀត។ ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះពួកគេនឹងត្រូវបានបំផ្លាញ» ឬ «នោះគឺជារបៀបដែលព្រះអង្គគួរតែបំផ្លាញពួកគេ»

Psalms 35:9

ក្នុងការសង្គ្រោះរបស់ព្រះអង្គ

នាមអរូបី «សេចក្ដីសង្គ្រោះ» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត: «ពីព្រោះព្រះអង្គជួយសង្គ្រោះទូលបង្គំ»

អស់ទាំងឆ្អឹងរបស់ទូលបង្គំ

នៅទីនេះ «ឆ្អឹង» សំដៅទៅលើផ្នែកខាងក្នុងជ្រៅបំផុតរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «ផ្នែកខាងក្នុងរបស់ទូលបង្គំទាំងមូល»

ឱព្រះអម្ចាស់អើយ តើមានអ្នកណាដូចព្រះអង្គ...អ្នកដែលព្យាយាមប្លន់ពួកគេ?

ចម្លើយចំឡែកចំពោះសំណួរនេះ គឺគ្មាននរណាម្នាក់ដូចព្រះអម្ចាស់ឡើយ។ ការបកប្រែរបៀបផ្សេងទៀត: «ឱព្រះអម្ចាស់អើយ គ្មាននរណាដូចព្រះអង្គទេ...អ្នកដែលព្យាយាមប្លន់ពួកគេ»។

ទាំងជនក្រីក្រ និងកម្សត់ទុគ៌ត

ពាក្យថា «អ្នកក្រ» និង «អ្នកខ្វះខាត» មានន័យដូចៗគ្នាហើយសង្កត់ន័យថាព្រះអម្ចាស់សង្គ្រោះមនុស្សជាច្រើនដែលត្រូវការជំនួយរបស់ព្រះអង្គ។

Psalms 35:11

លើកគ្នាឡើង

នេះមានន័យថា ពួកគេផ្តល់សក្ខីកម្មនៅក្នុងការសាកល្បង។ ការបកប្រែរបៀបផ្សេងទៀត: «ស្ម័គ្រចិត្តផ្តល់សក្ខីកម្ម»

ពួកគេប្រព្រឹត្តអំពើអាក្រក់ តបស្នងនឹងអំពើល្អរបស់ទូលបង្គំ

generated on Wed Sep 10 16:16:32 2025

ពួកគេបានផ្តល់នូវអំពើអាក្រក់តបវិញជាថ្នូរនឹងអ្វីដែលពួកគេបានទទួល។
ការបកប្រែរបៀបផ្សេងទៀត:
«ជាថ្នូរនឹងការដែលទូលបង្គំធ្វើអំពើល្អចំពោះពួកគេពួកគេបានធ្វើអំពើអាក្រក់ដាក់ទូលបង្គំ»
អំពើអាក្រក់...អំពើល្អ
នាមអរូបីទាំងនេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់ផ្សេងទៀត។
ការបកប្រែរបៀបផ្សេងទៀត: «រឿងអាក្រក់...រឿងល្អ»
ទូលបង្គំឈឺចាប់ណាស់
«ទូលបង្គំក្រៀមក្រំណាស់»
Psalms 35:13
ពេលពួកគេបានឈឺ
ពាក្យថា «ពួកគេ» សំដៅទៅលើ «សាក្សីទុច្ចរិត» (ជំពូក ៣៥:១១)។
នោះទូលបង្គំបានស្លៀកពាក់សំពត់ធ្មៃ
«ទូលបង្គំបានបង្ហាញថា ទូលបង្គំសោកសៅ» (UDB)
ទូលបង្គំឱនក្បាលអធិស្ឋានយ៉ាងអស់ពីចិត្ត
នេះគឺជានិមិត្តរូបនៃការអធិស្ឋាន។ «ឱនក្បាលចុះអធិស្ឋាន»
ទុក្ខព្រួយដូចបងប្អូនទូលបង្គំដែរ
អ្នកនិពន្ធសោកសៅដូចជាបងប្រុសរបស់ទ្រង់បានស្លាប់ទៅ។
ការបកប្រែរបៀបផ្សេងទៀត: «សោកសៅហាក់ដូចជាបងប្រុសទូលបង្គំឈឺ»
ទូលបង្គំបានកាន់ទុក្ខ ដូចនៅពេលម្តាយរបស់ទូលបង្គំស្លាប់
អ្នកនិពន្ធបានកាន់ទុក្ខដូចជាម្តាយរបស់ទ្រង់បានស្លាប់ទៅ។
ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំកាន់ទុក្ខដូចជាម្តាយរបស់ទូលបង្គំបានស្លាប់»
ខ្ញុំបានឱនចុះ
នេះគឺជានិមិត្តរូបនៃការឈឺចាប់ និងការរងទុក្ខ។
Psalms 35:15
ប្រមូលផ្តុំគ្នា
«បានប្រមូលផ្តុំគ្នា» ឬ «បានមកជាមួយគ្នា»
ទាស់នឹងទូលបង្គំ
នេះមានន័យថា ពួកគេបានជួបជុំគ្នាក្នុងគោលបំណងវាយប្រហារអ្នកនិពន្ធ។
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើផែនការប្រឆាំងនឹងទូលបង្គំ» ឬ
«រៀបចំផែនការបំផ្លាញទូលបង្គំ»
ពួកគេបានហែកហួរទូលបង្គំ
នៅទីនេះពួកគេបានចាត់ទុកអ្នកនិពន្ធដូចជាទ្រង់ដូចជាក្រណាត់ដែលពួកគេអាចហែកបាន
។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបានវាយប្រហារទូលបង្គំ»
គេប្រមាថមើលងាយទូលបង្គំ
«ជាមួយមនុស្សដែលគ្មានតំលៃពួកគេបានសើចចំអកឲ្យទូលបង្គំ» ឬ ២)
«ដោយគ្មានការគោរពពួកគេបានសើចចំអកឲ្យទូលបង្គំ»
ហើយពួកគេសង្កៀតធ្មេញដាក់ទូលបង្គំ
នេះគឺជាសញ្ញានៃការខឹងនិងស្អប់។ «ពួកគេបានបង្កើតសំឡេងរំខាន
ដោយធ្មេញរបស់ពួកគេនៅឯទូលបង្គំ»
Psalms 35:17
តើព្រះអង្គធ្វើព្រងើយដល់កាលណាទៀត?
សំណួរវោហារស័ព្ទនេះបង្ហាញថា អ្នកនិពន្ធចង់ឲ្យព្រះជាម្ចាស់ឈប់សម្លឹងមើល
ហើយចាប់ផ្តើមជួយទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«តើព្រះអង្គនឹងមើលពួកគេធ្វើបែបនេះយូរប៉ុណ្ណា?»
សូមរំដោះព្រលឹងទូលបង្គំ
នៅទីនេះ «ព្រលឹង» សំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត:
«សង្គ្រោះទូលបង្គំ»
សង្គ្រោះជីវិតទូលបង្គំ ឲ្យរួចពីពួកសិង្ហផង
ពាក្យ «រក្សាទុក» ត្រូវបានបង្កប់ន័យ។ ការបកប្រែរបៀបផ្សេងទៀត:
«សង្គ្រោះជីវិតខ្ញុំពីគោ»
ជីវិតទូលបង្គំ
នេះសំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំ»
ពីពួកសិង្ហ
នៅទីនេះអ្នកនិពន្ធនិយាយអំពីសត្រូវរបស់ទ្រង់ ដូចជាពួកគេជាពួកសិង្ហដ៏សាហាវ។
ការបកប្រែរបៀបផ្សេងទៀត:
«ពីសត្រូវរបស់ទូលបង្គំដែលវាយប្រហារទូលបង្គំដូចជាសត្វព្រៃ»
Psalms 35:19
សូមកុំឲ្យពួកខ្មាំងសត្រូវរបស់ទូលបង្គំ
«សូមកុំឲ្យសត្រូវរបស់ទូលបង្គំដែលនិយាយកុហកអំពីទូលបង្គំ»។
គ្រោងការណ៍អាក្រក់របស់ពួកគេ
គេមិននិយាយដោយមេត្រីទេ
នាមអរូបី «សន្តិភាព» អាចត្រូវបានចែងក្នុងទម្រង់ផ្សេងទៀត។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិននិយាយដោយសន្តិភាពទៅកាន់មនុស្សទេ»
គឺគេតែងតែបង្កើតពាក្យមួលបង្កាច់
«ស្វែងរកមធ្យោបាយ ដើម្បីនិយាយកុហក» (UDB)
អស់អ្នកដែលស្ងប់ស្ងៀមនៅក្នុងស្រុក
«អ្នកដែលរស់នៅដោយសុខសាន្តនៅលើទឹកដីរបស់យើង»
រស់នៅដោយសន្តិភាព
នាមអរូបី «សន្តិភាព» អាចត្រូវបានចែងក្នុងទម្រង់ផ្សេងទៀត។
ការបកប្រែរបៀបផ្សេងទៀត: «កុំធ្វើបាបនរណាម្នាក់»
Psalms 35:21
គេហាមាត់យ៉ាងធំទាស់នឹងទូលបង្គំ
មូលហេតុដែលពួកគេបើកមាត់គឺដើម្បីចោទប្រកាន់អ្នកនិពន្ធ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេស្រែកដាក់ទូលបង្គំ
ដើម្បីចោទប្រកាន់ទូលបង្គំ»
អេ អេ!
នេះគឺជាការលាន់មាត់ដែលត្រូវបានប្រើនៅពេលដែលអ្វីមួយត្រូវបានគេមើលឃើញភ្លាមៗ
ឬយល់។ នេះសង្កត់ន័យលើឃ្លាដែលមាននៅខាងក្រោម។
ភ្នែកយើងបានឃើញច្បាស់ហើយ
នៅទីនេះ «ភ្នែករបស់យើង» សំដៅទៅលើភ្នែករបស់សត្រូវ។
នេះបញ្ជាក់ថាពួកគេកំពុងនិយាយថា៖ ពួកគេបានឃើញអ្នកនិពន្ធធ្វើអ្វីខុស។
ការបកប្រែរបៀបផ្សេងទៀត: «យើងបានឃើញវា» ឬ
«យើងបានឃើញអ្វីដែលទ្រង់បានធ្វើខុស»
ព្រះអង្គទតឃើញស្រាប់ហើយ
ត្រង់នេះ «វា» សំដៅទៅលើការចោទប្រកាន់មិនពិតរបស់សត្រូវរបស់អ្នកនិពន្ធ។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានឃើញពីរបៀបដែលពួកគេចោទប្រកាន់ទូលបង្គំមិនពិត»
សូមកុំនៅស្ងៀម
«សូមកុំធ្វើព្រងើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត:
«វិនិច្ឆ័យពួកគេដោយសារតែអ្វីដែលពួកគេបានធ្វើ»
សូមកុំគង់ឆ្ងាយពីទូលបង្គំឡើយ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត:
«ជិតស្និទ្ធនឹងទូលបង្គំ»
សូមតើនឡើង! សូមក្រោកឡើង
នេះមិនមានន័យថា ព្រះជាម្ចាស់ពិតជាផ្ទុំលក់ទេ។
អ្នកនិពន្ធចង់ឲ្យព្រះជាម្ចាស់ធ្វើអន្តរាគមន៍។ ពាក្យទាំងពីរមានន័យថា
ជាមូលដ្ឋានដូចគ្នា ហើយបញ្ជាក់ពីភាពបន្ទាន់នៃសំណើនេះ។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំមានអារម្មណ៍ថាព្រះអង្គកំពុងផ្ទុំលក់! សូម
តើនឡើង!»
ហើយការពារក្តីឲ្យទូលបង្គំផង
នេះនាមអរូបីអាចត្រូវជាឃ្លានៅក្នុងទម្រង់ផ្សេងទៀត។ ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីការពារទូលបង្គំ»
រកយុត្តិធម៌ឲ្យទូលបង្គំផង
នេះសំដៅទៅលើអ្នកនិពន្ធ។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំ»
Psalms 35:24
សូមកុំឲ្យគេអរសប្បាយ ដោយឈ្នះទូលបង្គំឡើយ
«កុំឲ្យគេអរសប្បាយ ដោយព្រោះទូលបង្គំរងទុក្ខ»
និយាយនៅក្នុងចិត្តរបស់ពួកគេ
នេះគឺជាសំនួនវោហារស័ព្ទដែលមានន័យថា និយាយទៅកាន់ខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត: «និយាយទៅកាន់ខ្លួនឯង»
អេ
នេះគឺជាការលាន់មាត់ដែលត្រូវបានប្រើនៅពេលដែលអ្វីមួយត្រូវបានគេមើលឃើញភ្លាមៗ
ឬយល់។ នេះសង្កត់ន័យទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «បាទ/ចាស»

generated on Wed Sep 10 16:16:32 2025

យើងបានអ្វីដែលយើងចង់បានហើយ
នេះបញ្ជាក់ថា សត្រូវរបស់អ្នកនិពន្ធចង់ឲ្យទ្រង់ត្រូវបានប្រកាសថា មានកំហុស។ ការបកប្រែរបៀបផ្សេងទៀត:
«ទ្រង់ត្រូវបានគេប្រកាសថាមានកំហុសដូចដែលយើងចង់បាន!»
យើងបានលេបវាបាត់ហើយ
សត្រូវរបស់អ្នកនិពន្ធនិយាយអំពីការបំផ្លាញរបស់ទ្រង់ ដូចជាពួកគេជាសត្វព្រៃដែលបានស៊ីទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបានលេបទ្រង់ហើយ« យើងបានបំផ្លាញទ្រង់»
បាក់មុខ
«ធ្វើឲ្យអាម៉ាស់មុខ» ឬ «វង្វេងស្មារតី»
អស់អ្នកដែលអរសប្បាយនឹងទុក្ខលំបាករបស់ទូលបង្គំសូមឲ្យគេត្រូវខ្មាសហើយខូចឈ្មោះចុះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សូមឲ្យព្រះអង្គគ្របដណ្តប់ដោយភាពអាម៉ាស់ និងធ្វើឲ្យអាម៉ាស់ដល់អ្នកដែលតិះដៀលទូលបង្គំ»
តិះដៀល
ជេរប្រមាថនរណាម្នាក់ធ្វើឲ្យពួកគេខឹង
គ្របដណ្តប់ដោយភាពអាម៉ាស់និងភាពអាម៉ាស់
នៅទីនេះភាពអាម៉ាស់ និងភាពមិនស្មោះត្រង់ ត្រូវបានគេនិយាយដូចជាពួកគេជាសម្លៀកបំពាក់គួរឲ្យអាម៉ាស់ដែលអ្នកនិពន្ធអាចស្លៀក។ នាមអរូបីទាំងនេះអាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្មាស់អៀននិងអាម៉ាស់មុខ»
ខ្មាស់អៀននិងអាម៉ាស់មុខ
ពាក្យទាំងនេះមានន័យថានិយាយអំពីរឿងដូចគ្នា ហើយត្រូវបានប្រើដើម្បីបញ្ជាក់ថា តើនេះនឹងទៅជាអន់ថយកម្រិតណា។
Psalms 35:27
ការកែតម្រូវរបស់ទូលបង្គំ
ត្រង់នេះ «ភាពត្រឹមត្រូវ» សំដៅទៅលើព្រះអម្ចាស់ដែលប្រកាស ឬកាត់ទោសអ្នកតែងទំនុកតម្កើងដែលគ្មានទោស។
សូមឲ្យគេបន្តពោលថា
«ប្រហែលជាពួកគេតែងតែនិយាយ»
ព្រះអម្ចាស់គួរតម្កើងឡើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ចូរយើងសរសើរតម្កើងព្រះអម្ចាស់»
ព្រះអង្គសព្វព្រះហឫទ័យ
«អ្នកដែលសប្បាយចិត្តជាមួយ» ឬ «អ្នកដែលរីករាយសម្រាប់»
ចម្រុងចម្រើន
សុខុមាលភាពសុភមង្គល
ថ្លែងអំពីសេចក្តីសុចរិតរបស់ព្រះអង្គ
នាមអរូបី «យុត្តិធម៌» អាចត្រូវបានបញ្ជាក់ដោយកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត: «ប្រកាសថា ព្រះអង្គធ្វើតាមរបៀបត្រឹមត្រូវ»

36 ទំនុកពីសៀវភៅរបស់គ្រូចម្រៀង។ ទំនុករបស់ស្តេចដាវីឌ ជាអ្នកបម្រើព្រះអម្ចាស់។[1]ការរំលងច្បាប់របស់មនុស្សអាក្រក់ សម្តែងក្នុងចិត្តខ្ញុំថា នៅចំពោះភ្នែកគេគ្មានការកោតខ្លាចដល់ព្រះជាម្ចាស់ទេ។[2]ដ្បិតនៅក្នុងភ្នែកគេ គេបញ្ឆោរខ្លួនឯងថា អំពើទុច្ចរិតរបស់គេ មិនអាចមានអ្នកណា ឃើញ ឬស្អប់ឡើយ។
[3]ពាក្យដែលចេញពីមាត់គេ ពេញអំពើបាប និងពាក្យបោកបញ្ឆោត គេមិនចង់បានប្រាជ្ញា និងប្រព្រឹត្តល្អទៀតហើយ។[4]គេគិតដើម្បីធ្វើបាប តាំងកំពុងនៅក្នុងដំណេកនៅឡើយ គេមិនព្រមបោះបង់អំពើអាក្រក់ឡើយ ដោយទទួលយកផង។
[5]ឱព្រះអម្ចាស់អើយ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ខ្ពស់ដល់ផ្ទៃមេឃ ព្រះហឫទ័យស្មោះត្រង់របស់ព្រះអង្គ ខ្ពស់ដល់ពពក។[6]សេចក្តីសុចរិតរបស់ព្រះអង្គ ប្រៀបដូចជាភ្នំនៃព្រះ ជំនុំជម្រះរបស់ព្រះអង្គ ប្រៀបដូចមហាសមុទ្រដ៏ជ្រៅ ឱព្រះអម្ចាស់អើយ ព្រះអង្គសង្គ្រោះ ទាំងមនុស្សលោក ទាំងសត្វផង។
[7]ឱព្រះជាម្ចាស់អើយ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ថ្លៃវិសេសយ៉ាងណាទៅ! មនុស្សលោកនឹង ជ្រកក្រោមម្លប់នៃស្លាបរបស់ព្រះអង្គហើយ។[8]គេនឹងបានឆ្អែត ដោយរបស់ដ៏បរិបូរក្នុងដំណាក់ព្រះអង្គ ហើយព្រះអង្គនឹងឲ្យគេផឹកពីទន្លេ នៃព្រះហឫទ័យសប្បុរសរបស់ព្រះអង្គដែរ។[9]ដ្បិតប្រភពទឹកនៃជីវិតស្ថិតនៅជាមួយព្រះអង្គ យើងខ្ញុំមើលឃើញពន្លឺ ដោយសារពន្លឺរបស់ព្រះអង្គដែរ។
[10]ឱសូមសម្តែងព្រះហឫទ័យសប្បុរស ដល់អស់អ្នកដែលស្គាល់ព្រះអង្គផង ហើយសម្តែងសេចក្តីសុចរិតរបស់ព្រះអង្គ ដល់អ្នកដែលមានចិត្តទៀងត្រង់ផងចុះ។[11]សូមកុំឲ្យជើងរបស់មនុស្សពាល ជាន់ឈ្លីទូលបង្គំឡើយ ក៏កុំឲ្យដៃគេ នាំយកទូលបង្គំចេញដែរ។[12]ពួកអ្នកដែលប្រព្រឹត្តអាក្រក់ ត្រូវដួលចុះនៅទីនោះ គេត្រូវទម្លាក់ចុះ មិនអាចងើបឡើងវិញបានឡើយ។

Psalms 36:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ទំនុកពីសៀវភៅរបស់គ្រូចម្រៀង
«នេះគឺសម្រាប់អ្នកដឹកនាំតន្ត្រី ដើម្បីប្រើប្រាស់ក្នុងការថ្វាយបង្គំ»។
ទំនុករបស់ព្រះបាទដាវីឌ ជាអ្នកបម្រើព្រះអម្ចាស់
អត្ថន័យដែលអាចមានគឺ១) ស្តេចដាវីឌបានសរសេរទំនុកនេះ ឬ ២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣) បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
បាបនិយាយដូចជាពាក្យសម្តី
អំពើបាបត្រូវបានពិពណ៌នាថា ជាព្យាការីក្លែងក្លាយ។ ការបកប្រែរបៀបផ្សេងទៀត:
«បាបគឺដូចជាព្យាការីក្លែងក្លាយដែលនិយាយ»
នៅក្នុងដួងចិត្តរបស់មនុស្សអាក្រក់
ត្រង់នេះ «ដួងចិត្ត» សំដៅទៅលើផ្នែកខាងក្នុងរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «ដល់ផ្នែកខាងក្នុងរបស់មនុស្សអាក្រក់»
មនុស្សអាក្រក់
នេះមិនសំដៅទៅលើបុរសជាក់លាក់ទេតែសំដៅទៅលើមនុស្សអាក្រក់ជាទូទៅ។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សអាក្រក់»
នៅក្នុងភ្នែកគេ
នៅទីនេះ «ភ្នែក» សំដៅទៅលើមនុស្សអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងគេ»
គេបញ្ជើចបញ្ជើលើកតម្កើងខ្លួនឯងខ្លាំងពេក
«គេចូលចិត្តជឿ» ឬ «គេចង់គិត»
អំពើទុច្ចរិតរបស់គេ មិនអាចមានអ្នកណា ឃើញ ឬស្អប់ឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងមិនស្វែងរក និងស្អប់អំពើបាបរបស់គេ»
Psalms 36:3
ពាក្យដែលចេញពីមាត់គេ
នេះសំដៅទៅលើឃ្លារបស់គេ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលគេនិយាយគឺ»
ប្រព្រឹត្តល្អ
«ល្អ» អាចត្រូវបានថ្លែងនៅក្នុងទម្រង់ផ្សេងទៀត។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើអ្វីដែលល្អ»
គេមិនព្រមបោះបង់អំពើអាក្រក់ឡើយ ដោយទទួលយកផង
អំពើបាបរបស់បុរសនេះត្រូវបានគេនិយាយដូចជាកំពុងដើរលើផ្លូវអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត: «គេចាប់ផ្តើមធ្វើអ្វីដែលអាក្រក់»
គេមិនបដិសេធអំពើអាក្រក់ទេ
«អាក្រក់» អាចត្រូវបានថ្លែងនៅក្នុងទម្រង់ផ្សេងទៀត។ ការបកប្រែរបៀបផ្សេងទៀត: «គេមិនបដិសេធអាកប្បកិរិយាអាក្រក់ទេ»។
Psalms 36:5
ខ្ពស់ដល់ផ្ទៃមេឃ
ភាពអស្ចារ្យនៃភាពស្មោះត្រង់នៃសេចក្តីសញ្ញារបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយហាក់ដូចជាខ្ពស់ណាស់ ការបកប្រែរបៀបផ្សេងទៀត: «ខ្ពស់ដូចផ្ទៃមេឃ» ឬ «គឺអស្ចារ្យណាស់»
ខ្ពស់ដល់ពពក
ភាពអស្ចារ្យនៃភាពស្មោះត្រង់របស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា៖ ខ្ពស់ណាស់។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ពស់ដូចពពក» ឬ «គឺអស្ចារ្យណាស់»
ប្រៀបដូចជាភ្នំនៃព្រះ...ប្រៀបដូចមហាសមុទ្រដ៏ជ្រៅ
ឃ្លាទាំងនេះពិពណ៌នាអំពីភាពអស្ចារ្យនៃសេចក្តីសុចរិត

generated on Wed Sep 10 16:16:32 2025

និងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ដូចជាពួកគេខ្ពស់ និងជ្រៅ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ពស់ដូចភ្នំខ្ពស់បំផុត...ជ្រៅដូចសមុទ្រជ្រៅ»
ព្រះអង្គសង្គ្រោះ
«ព្រះអង្គជួយ» ឬ «ព្រះអង្គរក្សាទុក»
Psalms 36:7
ឱព្រះជាម្ចាស់អើយ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ថ្លៃវិសេសយ៉ាងណាទៅ!
ភាពស្មោះត្រង់នៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា៖
ជាគ្រឿងអលង្ការដ៏កម្រ និងថ្លៃណាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ភាពស្មោះត្រង់នៃកិច្ចព្រមព្រៀងរបស់ព្រះអង្គមានតម្លៃដូចគ្រឿងអលង្ការដ៏កម្រ»
មនុស្សលោកនឹង ជ្រក
«មនុស្សនឹងស្វែងរកការការពារ»
មនុស្សលោកនឹង ជ្រកក្រោមម្លប់នៃស្លាបរបស់ព្រះអង្គហើយ
ព្រះជាម្ចាស់ពិតជាមិនមានស្លាបទេ។
នេះគឺជាពាក្យប្រៀបធៀបសម្រាប់ការការពាររបស់ព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សជាតិភៀសខ្លួនជាមួយព្រះអង្គ
ដូចជាសត្វស្លាបវ័យក្មេងស្វែងរកការការពារនៅក្រោមស្លាបម្តាយ»
គេនឹងបានឆ្អែត ដោយរបស់ដ៏បរិបូរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គនឹងបំពេញចិត្តពួកគេយ៉ាងបរិបូរណ៌»
ក្នុងដំណាក់ព្រះអង្គ ហើយព្រះអង្គនឹងឲ្យគេផឹក
នេះមិនមានន័យថា៖ ព្រះជាម្ចាស់មានផ្ទះមួយដែលមានអាហារទេ។
នេះគឺជាពាក្យប្រៀបធៀបសម្រាប់ការផ្គត់ផ្គង់ច្រើនក្រៃលែង។
ការបកប្រែរបៀបផ្សេងទៀត:
«ដូចជាពួកគេកំពុងញ៉ាំអាហារសម្បូរបែបពីផ្ទះរបស់ព្រះអង្គ» ឬ
«ជាមួយព្រះពរដ៏សំបូរបែបរបស់ព្រះអង្គ»
ហើយព្រះអង្គនឹងឲ្យគេផឹកពីទន្លេ នៃព្រះហឫទ័យសប្បុរសរបស់ព្រះអង្គដែរ
មានពាក្យប្រៀបធៀបពីរនៅទីនេះ។ ព្រះពរជាច្រើនរបស់ព្រះជាម្ចាស់
ត្រូវបានគេនិយាយថា៖ ដូចជាទឹក នៅក្នុងទន្លេដែលហូរ។
ដូចគ្នានេះផងដែលអ្នកដែលទទួលបានព្រះពរទាំងនោះ
ត្រូវបានគេនិយាយដូចជាកំពុងផឹករបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះពរដ៏មានតម្លៃរបស់ព្រះអង្គ ប្រៀបដូចជាទន្លេដែលព្រះអង្គនឹងឲ្យពួកគេផឹក»
ប្រភពទឹកនៃជីវិត
«ប្រភពនៃជីវិត»
ស្ថិតនៅជាមួយព្រះអង្គ យើងខ្ញុំមើលឃើញពន្លឺ ដោយសារពន្លឺរបស់ព្រះអង្គដែរ
នៅទីនេះ «ពន្លឺ» គឺជាពាក្យប្រៀបធៀបសម្រាប់ចំណេះដឹងពិត។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលព្រះអង្គបំភ្លឺយើង យើងនឹងដឹងការពិត» ឬ
«ពន្លឺរបស់ព្រះអង្គគឺជាអ្វីដែលអាចឲ្យយើងដឹងការពិតអំពីព្រះអង្គ» (UDB)
Psalms 36:10
ឱសូមសម្តែងព្រះហឫទ័យសប្បុរស
«បន្តភាពស្មោះត្រង់នៃសេចក្តីសញ្ញារបស់ព្រះអង្គ»
ដល់អ្នកដែលមានចិត្តទៀងត្រង់ផងចុះ
នាមអរូបី «ការការពារ» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។ «បន្ត»
ត្រូវបានបង្កប់ន័យពីឃ្លាមុន។ ការបកប្រែរបៀបផ្សេងទៀត:
«បន្តការពារភាពទៀងត្រង់នៃដួងចិត្ត»
ចិត្តទៀងត្រង់ផងចុះ
ត្រង់នេះ «ដួងចិត្ត» សំដៅទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សទៀងត្រង់» ឬ «មនុស្សដែលប្រព្រឹត្តដោយសុចរិត»
ជើងរបស់មនុស្សពាល ជាន់ឈ្លី...ដៃរបស់មនុស្សអាក្រក់
ត្រង់នេះ «ជើង» និង «ដៃ» សំដៅទៅលើមនុស្សអាក្រក់។
ទាំងនេះមិនមែនជាបុរសជាក់លាក់ទេ។ នេះសំដៅទៅលើមនុស្សអាក្រក់ជាទូទៅ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សក្រអឺតក្រទម...មនុស្សអាក្រក់»
នាំយកទូលបង្គំចេញដែរ
«បញ្ជូនទូលបង្គំទៅឆ្ងាយ» ឬ «ធ្វើឲ្យទូលបង្គំចាកចេញពីកន្លែងរបស់ទូលបង្គំ»
ពួកអ្នកដែលប្រព្រឹត្តអាក្រក់ ត្រូវដួលចុះនៅទីនោះ គេត្រូវទម្លាក់ចុះ មិនអាចងើបឡើងវិញបានឡើយ
ឃ្លាទាំងបីនេះពណ៌នាអំពីមនុស្សអាក្រក់ថា និងចាញ់។
គេត្រូវទម្លាក់ចុះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានផ្តួលរំលំពួកគេ» ឬ «ព្រះអង្គបានបំផ្លាញពួកគេ»
មិនអាចងើបឡើងវិញបានឡើយ
«មិនអាចក្រោក»

---

37 ទំនុករបស់ស្តេចដាវីឌ។[1]កុំក្តៅចិត្ត ដោយព្រោះមនុស្ស ដែលប្រព្រឹត្តអាក្រក់ឡើយ ក៏កុំច្រណែននឹងពួកអ្នកដែលប្រព្រឹត្តអំពើទុច្ចរិតដែរ;[2]ដ្បិតពួកគេនឹងត្រូវស្រពោនដូចជាស្មៅ ហើយក៏ក្រៀមស្វិត ដូចតិណជាតិខៀវខ្ចីដែរ។
[3]ចូរទុកចិត្តដល់ព្រះអម្ចាស់ ហើយប្រព្រឹត្តអំពើល្អ នោះអ្នកនឹងបាននៅក្នុងស្រុក ហើយរស់នៅយ៉ាងសុខក្សេមក្សាន្ត។[4]ចូរយកព្រះអម្ចាស់ជាអំណររបស់អ្នកចុះ នោះព្រះអង្គនឹងប្រទានអ្វីៗ ដែលចិត្តអ្នកប្រាថ្នាចង់បាន។
[5]ចូរទុកដាក់ផ្លូវរបស់អ្នកដល់ព្រះអម្ចាស់ ចូរទុកចិត្តដល់ព្រះអង្គនោះព្រះអង្គនឹងប្រោសឲ្យបានសម្រេច។[6]ព្រះអង្គនឹងឲ្យសេចក្តីសុចរិត របស់អ្នកផ្សាយចេញដូចពន្លឺ ហើយអំពើយុត្តិធម៌របស់អ្នក ដូចពន្លឺនៅពេលថ្ងៃរសៀល។
[7]សូមស្ងប់ស្ងៀមនៅចំពោះព្រះអម្ចាស់ ហើយរង់ចាំព្រះអង្គដោយអំណត់ កុំរហ័សខឹងឡើយ ដែលចម្រុងចម្រើនក្នុងផ្លូវរបស់គេ ហើយនឹងមនុស្សដែលសម្រេចបាន តាមផ្លូវអាក្រក់របស់ខ្លួននោះឡើយ។
[8]សូមកុំរហ័សកំខឹង ហើយមានចិត្តក្តៅក្រហាយ។ សូមកុំខ្វាល់ចិត្តពេក។ ការទាំងនោះគ្រានតែនាំយើងឲ្យមានបញ្ហាទេ។[9]ព្រោះពួកអ្នកដែលប្រព្រឹត្តអាក្រក់ នឹងត្រូវកាត់ចេញ តែអស់អ្នកដែលរង់ចាំព្រះអម្ចាស់ នឹងបានទទួលទឹកដីជាមរតក។[10]នៅតែបន្តិចទៀត មនុស្សអាក្រក់ នឹងលែងមានទៀតហើយ អ្នកនឹងខំរកមើលកន្លែងគេ តែគេមិននៅទីនោះទៀតដែរ។
[11]ប៉ុន្តែ មនុស្សទន់ទាប គេនឹងបានទទួលទឹកដីជាមរតក ហើយមានចិត្តរីករាយ ដោយសេចក្តីសុខក្សេមក្សាន្តជាបរិបូរ។[12]មនុស្សអាក្រក់គេបង្កើតគម្រោងការអាក្រក់ទាស់នឹងមនុស្សសុចរិត ហើយសម្តែងធ្មេញដាក់មនុស្សសុចរិត។[13]ព្រះអម្ចាស់សើចចំអក ដាក់មនុស្សអាក្រក់វិញ ដ្បិតព្រះអង្គជ្រាបថាថ្ងៃអន្សារបស់គេជិតមកដល់ហើយ។
[14]ពួកមនុស្សអាក្រក់បានហូតដាវជាស្រេច ហើយយឹតធ្នូរដើម្បីទម្លាក់មនុស្សទ័លក្រ និងមនុស្សកម្សត់ទុគ៌ត ព្រមទាំងសម្លាប់អស់អ្នកដែលកាន់តាមផ្លូវទៀងត្រង់។[15]តែដាវរបស់គេនឹងចាក់ចូល ទៅក្នុងបេះដូងខ្លួនគេវិញ ហើយធ្នូររបស់គេនឹងត្រូវបែកបាក់។
[16]ទ្រព្យបន្តិចបន្តួចដែលមនុស្សសុចរិតមាន នោះប្រសើជាងទ្រព្យដ៏ច្រើន របស់មនុស្សអាក្រក់ជាច្រើននាក់។[17]ដ្បិតដៃរបស់មនុស្សអាក្រក់នឹងត្រូវបាក់ តែព្រះអម្ចាស់ជួយមនុស្សសុចរិតវិញ។
[18]ព្រះអម្ចាស់បានជ្រាបអស់ទាំងថ្ងៃ របស់មនុស្សទៀងត្រង់ ហើយមរតករបស់គេនៅជាប់ជាដរាប។[19]ពួកគេនឹងមិនត្រូវខ្មាសក្នុងគ្រាលំបាកឡើយ។ ហើយនៅវេលាអំណត់មកដល់ ពួកគេនឹងមានជាបរិបូរ។
[20]ប៉ុន្តែ មនុស្សអាក្រក់នឹងត្រូវវិនាស ហើយខ្មាំងសត្រូវរបស់ព្រះអម្ចាស់ ដូចជាវាលស្មៅខៀវខ្ចី ដែលនឹងសាបសូន្យទៅ គឺនឹងរលាយសូន្យទៅដូចជាផ្សែង។[21]មនុស្សអាក្រក់ខ្ចីគេ តែមិនសងវិញឡើយ ឯមនុស្សសុចរិតវិញ មានចិត្តសទ្ធា ហើយចេះឲ្យទៅអ្នកដទៃ។
[3]ព្រះជាម្ចាស់បានអត់ទោសបាបទាំងអស់ ដល់ទូលបង្គំ ហើយព្រះជាម្ចាស់បានប្រោសជំងឺគ្រប់យ៉ាងរបស់អ្នក។[4]ព្រះជាម្ចាស់បានរំដោះអ្នកពីសេចក្តីវិនាស
នឹងប្រទានមុដហើយនិងសម្ព័ន្ធមេត្រីដ៏ស្មោះត្រង់ជាមួយសេចក្តីមេត្តាផងដែរ។[5]ព្រះជាម្ចាស់សម្អាតជីវិតរបស់អ្នកជាមួយការល្អគ្រប់យ៉ាង ដូច្នេះយុវជនរបស់អ្នក
នឹងបានលើកតម្កើងឡើងដូចជាសត្វឥន្ទ្រី។
[6]ព្រះអម្ចាស់ បានធ្វើអ្វីដែលត្រឹមត្រូវហើយនិងសេចក្តីយុត្តិធម៌ សម្រាប់ពួកអ្នកដែលក្រីក្រ។[7]ព្រះជាម្ចាស់បានបើកឲ្យមូសេបានស្គាល់ពីផ្លូវរបស់ព្រះអង្គ
ហើយសម្រាប់មនុស្សជំនាន់របស់ជនជាតិ អ៊ីស្រាអែលផងដែរ។[8]ព្រះអម្ចាស់ពេញដោយក្តីមេត្តា និងព្រះគុណ ព្រះអង្គអត់ធ្មត់
ព្រះជាម្ចាស់មានក្តីសប្បុរសនិងភាពស្មោះត្រង់ដ៏អស្ចារ្យ។
[9]ព្រះជាម្ចាស់នឹងមិនវាយដំ ហើយនឹងតែងតែក្រោធនោះទេ។[10]ព្រះជាម្ចាស់ មិនបានធ្វើនិងយើងតាមអ្វីដែល ជាអំពើបាបដែលយើងសមនឹងទទួលនោះទេ
ឬសងមកយើងវិញនូវអ្វីតាមតម្រូវការនៃបាបរបស់យើងឡើយ។
[11]ដ្បិត ដូចជាផ្ទៃមេឃដែលខ្ពស់នៅលើផែនដីយ៉ាងណា ដូច្នេះសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ក៏អស្ចារ្យសម្រាប់ដល់អស់អ្នក ដែលលើកតម្កើងព្រះអង្គដែរ។[12]ក៏ដូចជា
ទិសខាងលិចឆ្ងាយពីទិសខាងកើតយ៉ាងណា នោះព្រះជាម្ចាស់ក៏នឹងលើកលែងទោសនៃអំពើបាបពីយើងបែបនោះដែរ។[13]ដូចជាឪពុកមានក្តីមេត្តា ដល់កូនៗយ៉ាងណា
ដូច្នោះ ព្រះអម្ចាស់ក៏មានក្តីមេត្តាដល់អស់អ្នកដែលលើកតម្កើងព្រះអង្គយ៉ាងនោះដែរ។
[14]ដ្បិត ព្រះជាម្ចាស់ ស្គាល់ពីការចាប់កំណើតរបស់យើង ព្រះអង្គដឹងថាយើងគឺជាដី។[15]សម្រាប់មនុស្សពេលវេលារបស់គេដូចជាស្មៅ ព្រះជាម្ចាស់បានដាំឲ្យវាលូតលាស់ល្អ
ដូចជាផ្កានៅតាមទីវាល។[16]ពេលខ្យល់បកមកលើពួកវា នោះវាក៏បាត់អស់ទៅ ហើយក៏នឹងមិនមាននរណាអាចប្រាប់បានថា វាបានដុះនៅទីណាដែរ។
[17]ប៉ុន្តែ ភាពស្មោះត្រង់ដ៏សប្បុរសនៃព្រះអម្ចាស់ គឺមិនដែលបញ្ចប់បានឡើយដល់អ្នកណាដែលលើកតម្កើងព្រះអង្គ។
សេចក្តីសុចរិតរបស់ព្រះអង្គបានពន្លាតដល់ប្រជារាស្ត្ររបស់ព្រះអង្គ។[18]ពួកគេបានរក្សាសេចក្តីសប្បុរសហើយនិងនឹកចាំពីសេចក្តីបង្រៀនក៏ធ្វើតាមផងដែរ។
[19]ព្រះអម្ចាស់បានសាងព្រះរាជ្យរបស់ព្រះអង្គនៅស្ថានសួគ៌ ហើយព្រះរាជ្យនៃនរគរបស់ព្រះអង្គគ្រប់គ្រង់លើមនុស្សទាំងអស់។
[20]ចូរថ្វាយព្រះពរព្រះអម្ចាស់ ពួកទេវតារបស់ព្រះអង្គអើយ! អស់លោកជាអ្នកខ្លាំងពូកែ ដែលប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គ ក៏ស្តាប់តាមព្រះសូរសៀង នៃព្រះបន្ទូល
របស់ព្រះអង្គជានិច្ច។[21]អស់ទាំងពួកពលបរិវាររបស់ព្រះអង្គ ពួកអ្នកបម្រើរបស់ព្រះអង្គ អ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គអើយ ចូរថ្វាយព្រះពរព្រះអម្ចាស់។[22]អស់
ទាំងស្នាព្រះហស្តរបស់ព្រះអង្គ នៅគ្រប់ទីកន្លែងដែលព្រះអង្គគ្រប់គ្រងអើយ ចូរថ្វាយព្រះពរព្រះអម្ចាស់ ព្រលឹងខ្ញុំអើយ ចូរថ្វាយព្រះពរព្រះអម្ចាស់។

Psalms 103:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ទំនុកតម្កើងនៃព្រះបាទដាវីឌ
អត្ថន័យដែលអាចមានគឺ១) ព្រះបាទដាវីឌបានសរសេរទំនុកនេះ ឬ
២)ទំនុកនេះគឺអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
ទូលបង្គំលើកសរសើរ ដល់ព្រះអម្ចាស់ពេញមួយជីវិតរបស់ទូលបង្គំ
ហើយនឹងអ្វីទាំងអស់ដែលទូលបង្គំមាននៅក្នុងទូលបង្គំ
ទូលបង្គំលើកតម្កើងដល់ព្រះនាមដ៏បរិសុទ្ធនៃព្រះអង្គ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា ហើយបញ្ជាក់ថា
តើទ្រង់នឹងសរសើរដល់ព្រះអម្ចាស់ដល់កម្រិតណា។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំនឹងសរសើរដល់ព្រះអម្ចាស់ជាមួយនឹងអ្វីដែលទូលបង្គំមាន»
លើកតម្កើងដល់ព្រះនាមដ៏បរិសុទ្ធនៃព្រះអង្គ
នេះសំដៅទៅលើការសរសើរព្រះនាមរបស់ព្រះអម្ចាស់ជាព្រះអម្ចាស់។
អ្វីទាំងអស់ដែលទូលបង្គំមាននៅក្នុងទូលបង្គំ
«អ្វីទាំងអស់នៃទូលបង្គំ» ឬ «អ្វីទាំងអស់ដែលទូលបង្គំមាន»។
ព្រះបាទដាវីឌប្រើឃ្លានេះ ដើម្បីសំដៅទៅលើអង្គទ្រង់ផ្ទាល់
និងដើម្បីបញ្ជាក់ពីភក្តីភាពរបស់ទ្រង់ ចំពោះព្រះអម្ចាស់។
Psalms 103:3
របស់អ្នក...អ្នក
ការបកប្រែជាច្រើនសម្តែងរឿងនេះជាមួយ «របស់ខ្ញុំ ខ្ញុំ យើង» ដូចជា UDB ដែរ។
ព្រះជាម្ចាស់បានរំដោះអ្នកពីសេចក្តីវិនាស
នេះមានន័យថា ព្រះអម្ចាស់ជួយឲ្យទ្រង់មានជីវិត។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គជួយសង្គ្រោះទូលបង្គំពីសេចក្តីស្លាប់»
ព្រះអង្គប្រទានមុដដល់អ្នក
នៅទីនេះ «ពរជ័យ» ត្រូវបានពិពណ៌នាដូចជាវាត្រូវបានគេ «មុដ»។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គឲ្យពរអ្នក»
ព្រះជាម្ចាស់សម្អាតជីវិតរបស់អ្នកជាមួយការល្អគ្រប់យ៉ាង
ឃ្លា «ជីវិតរបស់អ្នក» សំដៅទៅលើ «អ្នក» ប៉ុន្តែវាសង្កត់ន័យថា
ព្រះអម្ចាស់ប្រទានពរពេញមួយជីវិត។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គគាប់ចិត្តអ្នកជាមួយការល្អគ្រប់យ៉ាង តាមរយៈជីវិតរបស់អ្នក»
យុវជនរបស់អ្នក នឹងបានលើកតម្កើងឡើងដូចជាសត្វឥន្ទ្រី
ការមានរបស់អ្នក «យុវវ័យជាថ្មី» របស់អ្នកមានន័យថា អ្នកមានអារម្មណ៍ថា
ក្មេងម្តងទៀត។
នៅទីនេះព្រះបាទដាវីឌប្រៀបធៀបអារម្មណ៍យុវវ័យនេះទៅនឹងភាពរហ័ស
និងកម្លាំងរបស់ឥន្ទ្រី។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកមានអារម្មណ៍ថាក្មេង
ហើយខ្លាំងដូចឥន្ទ្រី»
យុវជនរបស់អ្នក
«យុវជន» គឺសំដៅទៅលើភាពខ្លាំងដែលមាននៅពេលពេញវ័យ។
Psalms 103:6
ធ្វើឲ្យយុត្តិធម៌ សម្រាប់
«ធ្វើឲ្យមានយុត្តិធម៌កើតឡើង»
ពួកអ្នកដែលក្រីក្រ
តើអ្នកណាកំពុងធ្វើការគាបសង្កត់អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលត្រូវគេជិះជាន់ដោយមនុស្ស»
ការប្រព្រឹត្តរបស់ព្រះអង្គចំពោះកូនចៅ
ពាក្យដែលបាត់អាចត្រូវបានបន្ថែម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានបង្ហាញការប្រព្រឹត្តរបស់ព្រះអង្គដល់កូនចៅ»
ព្រះអង្គមានក្តីសប្បុរស និងភាពស្មោះត្រង់ដ៏អស្ចារ្យ។
«ពោរពេញទៅដោយសេចក្តីមេត្តា និងសេចក្តីស្រឡាញ់»
Psalms 103:9
ព្រះជាម្ចាស់នឹងមិនវាយដំ ហើយនឹងតែងតែក្រោធនោះទេ
ប្រយោគទាំងពីរមានន័យស្រដៀងគ្នា។
ពាក្យទីពីរបានជួយធ្វើឲ្យក្នុងការគិតរបស់ពាក្យទីមួយរឹតតែច្បាស់។
ព្រះជាម្ចាស់ មិនបានធ្វើនិងយើង...ឬសងមកយើងវិញ
ឃ្លាទាំងពីរនេះគឺស្របគ្នា ហើយសង្កត់ន័យថា
ព្រះជាម្ចាស់មិនដាក់ទណ្ឌកម្មយើងដូចដែលយើងសមនឹងទទួលនោះទេ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គមិនតបស្នងសងយើងវិញទេ
ជាមួយនឹងការដាក់ទណ្ឌកម្មដែលយើងសមនឹងទទួលបានសម្រាប់អំពើបាបរបស់យើង»
ធ្វើនិងយើង
«ដាក់ទណ្ឌកម្មយើង»
Psalms 103:11
ដ្បិត ដូចជាផ្ទៃមេឃដែលខ្ពស់...សម្រាប់ដល់អស់អ្នក ដែលលើកតម្កើងព្រះអង្គ
ឧទាហរណ៍នេះប្រៀបធៀបចម្ងាយដ៏ឆ្ងាយរវាងស្ថានសួគ៌
និងផែនដីទៅនឹងភាពអស្ចារ្យនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់
ចំពោះប្រជារាស្ត្ររបស់ព្រះអង្គ។
ក៏ដូចជា ទិសខាងកើតឆ្ងាយ...លើកលែងទោសនៃអំពើបាបពីយើងបែបនោះ
ចម្ងាយរវាងទិសខាងកើត និងទិសខាងលិចគឺឆ្ងាយរហូតដែលមិនអាចវាស់បាន។
ក្នុងរូបភាពប្រៀបធៀបនេះចម្ងាយនោះត្រូវបានប្រៀបធៀបទៅនឹងចម្ងាយដែលព្រះជាម្ចាស់ដកទោសចេញ

generated on Wed Sep 10 16:16:32 2025

ដូចជាឪពុកមានក្តីមេត្តា...ដល់អស់អ្នកដែលលើកតម្កើងព្រះអង្គយ៉ាងនោះដែរ
ទីនេះអ្នកនិពន្ធបានប្រៀបធៀបការអាណិតអាសូររបស់ឪពុក ចំពោះកូនៗ
របស់គេទៅនឹងសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់
ចំពោះអស់អ្នកដែលគោរពព្រះអង្គ។
Psalms 103:14
ការចាប់កំណើតរបស់យើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«តើរាងកាយរបស់យើងដូចជាអ្វី» ឬ
«ពីរបៀបដែលព្រះអង្គបានបង្កើតរាងកាយរបស់យើង»
ព្រះអង្គដឹងថាយើងគឺជាដី
នៅពេលដែលព្រះអម្ចាស់បានបង្កើតអ័ដាមជាបុរសដំបូង
ព្រះអង្គបានបង្កើតលោកពីធូលីដី។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គចងចាំថាព្រះអង្គបានបង្កើតយើងពីធូលីដី»
សម្រាប់មនុស្សពេលវេលារបស់គេដូចជាស្មៅ
នៅក្នុងរឿងប្រៀបប្រដូចនេះ
រយៈពេលនៃជីវិតរបស់មនុស្សត្រូវបានប្រៀបធៀបទៅនឹងរយៈពេលខ្លីដែលស្មៅដុះមុនពេលវាងាប់។
ការបកប្រែរបៀបផ្សេងទៀត: «អាយុជីវិតរបស់មនុស្សគឺខ្លីដូចជាស្មៅ»
ព្រះជាម្ចាស់បានដាំឲ្យវាលូតលាស់ល្អ ដូចជាផ្កានៅតាមទីវាល
នៅក្នុងឧទាហរណ៍ស្រដៀងនេះ
តើមនុស្សលូតលាស់តាមពេលវេលាត្រូវបានប្រៀបធៀបទៅនឹងរបៀបដែលផ្កាដុះ។
លូតលាស់
ដើម្បី «រីកចម្រើន» គឺលូតលាស់ល្អ ឬ មានសុខភាពល្អ។
ពេលខ្យល់បក់មកលើពួកវា នោះវាក៏បាត់អស់ទៅ...រាបានដុះនៅទីណា
ឃ្លាទាំងនេះបន្តនិយាយអំពីផ្កា និងស្មៅ។ ពួកគេប្រៀបធៀបរបៀបដែលផ្កា
និងស្មៅស្លាប់ទៅនឹងរបៀបដែលមនុស្សស្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្យល់បក់បោកលើផ្កា និងស្មៅហើយវារលាយបាត់ទៅ
ហើយគ្មាននរណាម្នាក់អាចប្រាប់ពីកន្លែងដែលពួកវាធ្លាប់លូតលាស់នោះទេ -
នេះជាវិធីដូចគ្នាជាមួយមនុស្ស»
Psalms 103:17
គឺមិនដែលបញ្ចប់បានឡើយ
នេះមានន័យថា សេចក្តីស្រឡាញ់របស់ព្រះអម្ចាស់នៅស្ថិតស្ថេរជារៀងរហូត។
ការបកប្រែរបៀបផ្សេងទៀត: «នឹងបន្តជារៀងរហូត»
ប្រជារាស្ត្ររបស់ព្រះអង្គ
«កូនចៅរបស់អ្នកដែលគោរពព្រះអង្គ»
ពួកគេបានរក្សាសេចក្តីសប្បុរសហើយនិងនឹកចាំពីសេចក្តីបង្រៀនក៏ធ្វើតាមផងដែរ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ព្រះអម្ចាស់បានសាងព្រះរាជ្យរបស់ព្រះអង្គនៅស្ថានសួគ៌
នេះជាការសោយរាជ្យរបស់ព្រះអម្ចាស់ដែលត្រូវបានគេហៅថា «រាជបល្ល័ង្ក»
របស់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានឡើងគ្រងរាជ្យនៅស្ថានសួគ៌ជាកន្លែងដែលព្រះអង្គគ្រប់គ្រងជាស្តេច»
សាង
«បានបង្កើត»
នគររបស់ព្រះអង្គគ្រប់គ្រង់
នៅទីនេះព្រះអម្ចាស់ត្រូវបានយោងដោយ «នគររបស់ព្រះអង្គ»
ដើម្បីសង្កត់ន័យលើសិទ្ធិអំណាចរបស់ព្រះអង្គជាស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គគ្រប់គ្រង»
Psalms 103:20
ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ
នេះគឺជាអត្ថន័យពិសេសមួយ ដើម្បី «ធ្វើតាមឆន្ទៈរបស់ព្រះអង្គ»។
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើតាមឆន្ទៈរបស់ព្រះអង្គ»។
នៅគ្រប់ទីកន្លែងដែលព្រះអង្គគ្រប់គ្រង
«សរសើរព្រះអង្គនៅគ្រប់ទីកន្លែងដែលព្រះអង្គគ្រប់គ្រង»
ពេញមួយជីវិតរបស់ខ្ញុំ
«ជាមួយខ្ញុំទាំងអស់» ឬ «ដោយអស់ពីព្រលឹងរបស់ខ្ញុំ»។ ឃ្លានេះមានន័យថា
គេនឹងសរសើរដល់ព្រះអម្ចាស់អស់ពីដួងចិត្ត ហើយត្រូវបានប្រើ
ដើម្បីបញ្ជាក់ពីភក្តីភាពចំពោះព្រះអង្គ។

---

104 [1]សូមសរសើរតម្កើងព្រះអម្ចាស់ ឱព្រះអម្ចាស់ជាព្រះនៃទូលបង្គំអើយ ព្រះអង្គជាព្រះដ៏ឧត្តុង្គឧត្តមបំផុត នៅជុំវិញព្រះអង្គមានពេញទៅដោយពន្លឺរស្មី ដ៏រុងរឿង
ចិញ្ចែងចិញ្ចាច។[2]ព្រះអង្គយកពន្លឺមកគ្របដណ្តប់ជុំវិញព្រះអង្គ ព្រះអង្គលាតផ្ទៃមេឃធ្វើជាព្រះពន្លា។[3]ព្រះអង្គបានសង់ព្រះដំណាក់ខ្ពស់ លើសផ្ទៃមេឃទៅទៀត
ព្រះអង្គយកពពកធ្វើជាព្រះរាជរថ ព្រះអង្គប្រើខ្យល់ធ្វើជាជំនិះ។
[4]ព្រះអង្គយកខ្យល់ធ្វើជាអ្នកនាំសាររបស់ព្រះអង្គ ហើយយកអណ្តាតភ្លើង ធ្វើជាអ្នកបម្រើរបស់ព្រះអង្គ។[5]ព្រះអង្គបានដាក់ផែនដីនៅលើគ្រឹះរបស់វា មិនឲ្យផែនដីរង្គើសោះ
ឡើយ។
[6]ព្រះអង្គបានគ្របផែនដីដោយទឹកជ្រៅ ដូចគ្របដោយអាវ មហាសាគរក៏ឡើងខ្ពស់ជាងភ្នំផង។[7]ពេលព្រះអង្គបន្ទោស ទឹកទាំងនោះក៏រត់ចេញ ពេលមានសូរផ្គររបស់ព្រះអង្គ
វាក៏រត់ទៅបាត់។
[8]ភ្នំទាំងឡាយងើបឡើង ហើយជ្រលងភ្នំទាំងប៉ុន្មានក៏ស្រុតចុះ ទៅរកកន្លែងដែលព្រះអង្គបានកំណត់ឲ្យវា។[9]ព្រះអង្គបានដាក់ព្រំប្រទល់ កុំឲ្យទឹកហូររំលង ដើម្បីកុំឲ្យឡើង
លិចផែនដីទៀត។
[10]ព្រះអង្គធ្វើឲ្យមានប្រភពទឹក ផុសឡើងនៅក្នុងជ្រោះ ទឹកទាំងនោះក៏ហូរតាមជ្រលងភ្នំ។[11]សត្វទាំងឡាយនៅទីវាលផឹកទឹកនោះ ចំណែកលាព្រៃក៏បំបាត់សម្រេករបស់វា
ដែរ។[12]ប៉ុន្តែបក្សាបក្សីហើរលើអាកាសធ្វើសម្បុក នៅក្បែរផ្លូវទឹកទាំងនោះ ហើយនាំគ្នាស្រែកខ្ទៀវខ្ទារនៅលើមែកព្រឹក្សា។
[13]ព្រះអង្គស្រោចស្រពភ្នំទាំងឡាយពីស្ថានដ៏ខ្ពស់ ហើយផែនដីស្កប់ស្កល់ដោយផល នៃស្នាព្រះហស្តព្រះអង្គ។[14]ព្រះអង្គធ្វើឲ្យស្មៅដុះឡើងសម្រាប់សត្វ ហើយរុក្ខជាតិ
សម្រាប់មនុស្សដាំដុះ ដើម្បីឲ្យគេមានអាហារចេញពីផែនដី។[15]ព្រះអង្គបង្កើតស្រាទំពាំងបាយជូរ ធ្វើឲ្យចិត្តមនុស្សបានរីករាយ មានប្រេងសម្រាប់ឲ្យមុខគេបានភ្លឺ និង
អាហារសម្រាប់ផ្គត់ផ្គង់ជីវិតរបស់គេផងដែរ។
[16]ដើមឈើទាំងប៉ុន្មានរបស់ព្រះអម្ចាស់ មានភ្លៀងជាបរិបូរណ៌ គឺដើមតាត្រៅនៅភ្នំល្បាណូន ជាដើមដែលព្រះអង្គបានដាំ។[17]បក្សាបក្សីនាំគ្នាធ្វើសម្បុក។ សត្វកុកមានលំនៅ
របស់វា នៅលើដើមកកោះ។[18]ភ្នំខ្ពស់ៗជាកន្លែងសម្រាប់ពពែព្រៃ ហើយថ្មដានានាជាទីពឹងជ្រកនៃសត្វទន្សាយថ្ម។
[19]ព្រះអង្គបានតម្រូវព្រះច័ន្ទ ទុកសម្រាប់ជាទីកំណត់រដូវ ចំណែកព្រះអាទិត្យ ក៏ដឹងពេលដែលត្រូវលិចដែរ។[20]ព្រះអង្គធ្វើឲ្យងងឹត ហើយនោះជារាត្រីកាល ជាពេលដែលសត្វ
នៅព្រៃទាំងប៉ុន្មាន សសៀរចេញមក។
[21]សិង្ហស្ទាវគ្រហឹមរកចាប់រំពា វាស្វែងរកអាហាររបស់វាពីព្រះជាម្ចាស់។[22]កាលព្រះអាទិត្យរះឡើង វាក៏ដកខ្លួនថយ ចូលទៅដេកក្នុងរូងរបស់វាវិញ។
[23]ចំណែកមនុស្សចេញទៅធ្វើការរបស់ខ្លួន ហើយគេធ្វើការរហូតដល់ល្ងាច។[24]ព្រះអម្ចាស់អើយ ស្នាព្រះហស្តរបស់ព្រះអង្គ មានច្រើនប្រការណាស់ ព្រះអង្គបានធ្វើការអស់
នោះ ដោយព្រះប្រាជ្ញាញាណ ផែនដីមានពេញដោយអ្វីៗសព្វសារពើ ដែលព្រះអង្គបានបង្កើតមក។
[25]សមុទ្រដ៏ធំ ហើយទូលាយ នៅទីនោះមានមច្ឆាជាតិរស់រវើក ច្រើនឥតគណនា ជាសត្វមានជីវិត ទាំងតូច ទាំងធំ។[26]មាននាវាបើកទៅមក ហើយមានសត្វធំសម្បើមដែល
ព្រះអង្គ បានបង្កើតមកឲ្យលេងនៅក្នុងសមុទ្រ។
[27]គ្រប់សត្វទាំងអស់នោះសង្ឃឹមលើព្រះអង្គ គឺឲ្យព្រះអង្គប្រទានចំណីដល់វាតាមពេលកំណត់។[28]ពេលព្រះអង្គប្រទានចំណីឲ្យ វាក៏ទទួលយក ពេលព្រះអង្គលាព្រះហស្ត
ពួកវាក៏បានឆ្អែត។
[29]ពេលព្រះអង្គលាក់ព្រះភ័ក្ត្រ វាក៏ថប់ព្រួយ កាលព្រះអង្គដកយកដង្ហើមរបស់វាចេញ វាក៏ស្លាប់ ហើយត្រឡប់ទៅជាធូលីដី។[30]ពេលព្រះអង្គចាត់ព្រះវិញ្ញាណរបស់ព្រះអង្គទៅ
ពួកវាក៏កើតឡើង ហើយព្រះអង្គធ្វើឲ្យផែនដី ស្រស់បស់ឡើងវិញ។
[31]សូមឲ្យសិរីល្អរបស់ព្រះអម្ចាស់ ស្ថិតស្ថេរអស់កល្បជានិច្ច សូមឲ្យព្រះអម្ចាស់រីករាយ នឹងស្នាព្រះហស្តរបស់ព្រះអង្គ។[32]ព្រះអង្គទតមកផែនដី នោះផែនដីក៏ញាប់ញ័រ ហើយ
ព្រះ អង្គពាល់ភ្នំ នោះភ្នំក៏ហុយផ្សែងឡើង។

generated on Wed Sep 10 16:16:32 2025

[33]ខ្ញុំនឹងច្រៀងថ្វាយព្រះអម្ចាស់ជាដរាប ពេញមួយជីវិតរបស់ខ្ញុំ ខ្ញុំនឹងច្រៀងសរសើរដល់ព្រះរបស់ខ្ញុំ កាលខ្ញុំនៅមានជីវិត។[34]សូមឲ្យការសញ្ជឹងគិតរបស់ខ្ញុំ បានគាប់
ព្រះហឫទ័យដល់ព្រះអង្គ ដ្បិតខ្ញុំរីករាយក្នុងព្រះអម្ចាស់។
[35]សូមឲ្យមនុស្សបាបវិនាសបាត់ពីផែនដី ហើយកុំឲ្យមានមនុស្សអាក្រក់ទៀតឡើយ។ ខ្ញុំនឹងសរសើរតម្កើងដល់ ព្រះពរព្រះអម្ចាស់ ពេញមួយជីវិតរបស់ខ្ញុំ។
សូមសរសើរព្រះអម្ចាស់។

Psalms 104:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។

ព័ត៌មានទូទៅ:

ទំនុកនេះគឺជាចម្រៀងនៃការសរសើរតម្កើង។

ពេញមួយជីវិតរបស់ទូលបង្គំ

«ជាមួយទូលបង្គំទាំងអស់» ឬ «ដោយអស់ពីព្រលឹងរបស់ទូលបង្គំ»។

ឃ្លានេះមានន័យថា ទ្រង់នឹងសរសើរដល់ព្រះអម្ចាស់អស់ពីដួងចិត្ត
ហើយត្រូវបានប្រើដើម្បីបញ្ជាក់ពីភក្តីភាពចំពោះព្រះអង្គ។

នៅជុំវិញព្រះអង្គមានពេញទៅដោយពន្លឺរស្មី ដ៏រុងរឿងចិញ្ចែងចិញ្ចាច

ពាក្យថា «ភាពរុងរឿង» និង «ឫទ្ធានុភាព»
មានអត្ថន័យប្រហាក់ប្រហែលគ្នានឹងបញ្ជាក់ពីភាពអស្ចារ្យនៃសិរីរុងរឿងរបស់ព្រះអម្ចាស់ដូចជា
សម្លៀកបំពាក់ទាំងនោះត្រូវបានពិពណ៌នាថា
ជាសម្លៀកបំពាក់របស់ព្រះអម្ចាស់ដូចសម្លៀកបំពាក់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមានភាពរុងរឿង និងភាពរុងរឿងនៅជុំវិញអ្នក»

ព្រះអង្គយកពន្លឺមកគ្របដណ្តប់ជុំវិញព្រះអង្គ

ព្រះអម្ចាស់ត្រូវបានពិពណ៌នាថា
ជាពន្លឺដែលគ្របដណ្តប់ដូចជាពន្លឺដែលជាសម្លៀកបំពាក់នៅព័ទ្ធជុំវិញព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គត្រូវបានគ្របដណ្តប់ដោយពន្លឺ»

ព្រះអង្គលាតផ្ទៃមេឃធ្វើជាព្រះពន្លា

នៅទីនេះព្រះជាម្ចាស់ត្រូវបានពិពណ៌នាថា
កំពុងលាតផ្ទៃមេឃដូចជានរណាម្នាក់លាតព្រះពន្លានៅពេលដំឡើងវា។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គលាតសន្ធឹងផ្ទៃមេឃដូចនរណាម្នាក់រៀបចំព្រះពន្លា»

ព្រះអង្គបានសង់ព្រះដំណាក់ខ្ពស់ លើសផ្ទៃមេឃទៅទៀត

«ព្រះអង្គសាងសង់ព្រះដំណាក់របស់អ្នកនៅលើផ្ទៃមេឃ»។
នេះសំដៅទៅលើផ្ទះរបស់ព្រះអង្គខ្ពស់ណាស់ដែលជាន់ខាងលើលាតសន្ធឹងពពក។

ព្រះអង្គយកពពកធ្វើជាព្រះរាជរថ

នៅទីនេះត្រូវបានពិពណ៌នាពីពពកដែលបានដឹកព្រះអម្ចាស់ដូចជារាជរថ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គធ្វើឲ្យពពកដឹកព្រះអង្គដូចជារាជរថ»

ព្រះអង្គប្រើខ្យល់ធ្វើជាជំនិះ

នៅទីនេះត្រូវបានពិពណ៌នាពីការផ្លុំខ្យល់ជាស្លាបដែលព្រះអម្ចាស់ធ្វើជាជំនិះ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គយាងលើខ្យល់»

Psalms 104:4

ព្រះអង្គយកខ្យល់ធ្វើជាអ្នកនាំសាររបស់ព្រះអង្គ

អត្ថន័យដែលអាចមានគឺ១)
ព្រះអង្គធ្វើឲ្យខ្យល់មានលទ្ធភាពអនុវត្តសារដូចជាអ្នកនាំសារ
«ព្រះអង្គធ្វើឲ្យមានខ្យល់បក់ដូចជាអ្នកនាំសាររបស់ព្រះអង្គ» ឬ ២)
«ព្រះអង្គធ្វើឲ្យអ្នកនាំសាររបស់ព្រះអង្គលឿនដូចខ្យល់»

យកអណ្តាតភ្លើង ធ្វើជាអ្នកបម្រើរបស់ព្រះអង្គ

អត្ថន័យដែលអាចមានគឺ១)
«ព្រះអង្គធ្វើឲ្យមានអណ្តាតភ្លើងដូចជាអ្នកបម្រើរបស់ព្រះអង្គ»។
ព្រះអង្គបណ្តាលឲ្យភ្លើងបម្រើព្រះអង្គដូចជាអ្នកបម្រើនឹងឬ 2)
«ព្រះអង្គធ្វើឲ្យអ្នកបម្រើរបស់ព្រះអង្គដូចជាអណ្តាតភ្លើង» និង

យកអណ្តាតភ្លើង ធ្វើជាអ្នកបម្រើរបស់ព្រះអង្គ

នេះអាចត្រូវបានបញ្ជាក់ដោយព័ត៌មានបង្កប់ពីខ្សែមុន។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គធ្វើឲ្យអណ្តាតភ្លើងឆេះអ្នកបម្រើរបស់ព្រះអង្គ»

ព្រះអង្គបានដាក់ផែនដីនៅលើគ្រឹះរបស់វា

នៅទីនេះឃ្លា «ចាក់គ្រឹះ» មានន័យថា «បង្កើត»។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានបង្កើតផែនដីទាំងមូល»

Psalms 104:6

ព្រះអង្គបានគ្របផែនដីដោយទឹកជ្រៅ ដូចគ្របដោយអាវ
នៅទីនេះទឹកដែលគ្របលើផែនដីកំពុងប្រៀបធៀបទៅនឹងរបៀបដែលអាវដ៏ធំមួយអាចគ្របលើអ្វីមួយបាន។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានគ្របដណ្តប់លើផែនដីដោយទឹកទាំងស្រុង»

ពេលព្រះអង្គបន្ទោស ទឹកទាំងនោះក៏រត់ចេញ...រាក៏រត់ទៅបាត់

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន ហើយត្រូវបានប្រើជាមួយគ្នា
ដើម្បីបញ្ជាក់ពីរបៀបដែលព្រះជាម្ចាស់បានមានព្រះបន្ទូល
ហើយទឹកបានរសាត់ទៅ។

ស្រក

«ដកថយ» ឬ «ថយក្រោយ»

រាក៏រត់ទៅបាត់

នៅទីនេះអ្នកតែងទំនុកតម្កើងនិយាយអំពីទឹកដែលស្រកចុះ ដូចជាពួកគេបានរត់
ដូចជាសត្វបន្ទាប់ពីឮសម្លេងរបស់ព្រះអម្ចាស់។ ពាក្យថា «រត់គេច» មានន័យថា
រត់ទៅយ៉ាងលឿន។ ការបកប្រែរបៀបផ្សេងទៀត: «ប្រញាប់ទៅឆ្ងាយ»

Psalms 104:8

ភ្នំទាំងឡាយងើបឡើង ហើយជ្រលងភ្នំទាំងប៉ុន្មានក៏ស្រុតចុះ

នៅទីនេះអ្នកតែងទំនុកតម្កើងនិយាយអំពីព្រះជាម្ចាស់ដែលបណ្តាលឲ្យភ្នំ
និងជ្រលងភ្នំផ្លាស់ប្តូរ ដូចជាពួកគេសម្រេចចិត្តផ្លាស់ប្តូរខ្លួនឯង។
ពួកគេត្រូវបានពិពណ៌នាតាមវិធីនេះ ដើម្បីបញ្ជាក់ពីអំណាចរបស់ព្រះជាម្ចាស់។

ដាក់ព្រំប្រទល់ កុំឲ្យទឹកហូររំលង

នៅទីនេះអ្នកតែងទំនុកតម្កើងនិយាយអំពីព្រះជាម្ចាស់បណ្តាលឲ្យទឹកមិនឲ្យឆ្លងកាត់ព្រំដែនដែលព្រះអង្គប
សម្រាប់ពួកគេដូចជាទឹកបានជ្រើសរើសមិនឲ្យឆ្លងកាត់វា។
ពួកគេត្រូវបានពិពណ៌នាតាមវិធីនេះ
ដើម្បីបញ្ជាក់ពីសិទ្ធិអំណាចរបស់ព្រះជាម្ចាស់លើពួកគេ។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រំដែនសម្រាប់ពួកគេដែលពួកគេមិនអាចឆ្លងកាត់បាន»

ព្រំប្រទល់

«បន្ទាត់» ឬ «ព្រំដែន»

សម្រាប់ពួកគេ

ពាក្យថា «ពួកគេ» សំដៅទៅលើទឹក។

Psalms 104:10

អូរ

ទន្លេតូច

ចំណែកលាព្រៃក៏បំបាត់សម្រេករបស់វា

វាអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា
ពួកគេបំបាត់ការស្រេកឃ្លានរបស់ពួកគេដោយផឹកទឹក។
ការបកប្រែរបៀបផ្សេងទៀត:
«សត្វលាព្រៃផឹកទឹកដើម្បីបំបាត់ការស្រេកឃ្លានរបស់ពួកគេ»

ផ្លូវទឹក

ដីនៅតែមទឹកទន្លេ

នាំគ្នាស្រែកខ្ទៀវខ្ទារនៅលើមែកព្រឹក្សា

នៅទីនេះព្រះបាទដាវីឌពិពណ៌នាអំពីសត្វបក្សីដែលស្រែកដូចជាពួកគេកំពុងច្រៀង។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេស្រែកច្រៀងក្នុងចំណោមមែកឈើ»

Psalms 104:13

ព្រះអង្គស្រោចស្រពភ្នំទាំងឡាយពីស្ថានដ៏ខ្ពស់

នេះមានន័យថា ព្រះជាម្ចាស់ធ្វើឲ្យមានភ្លៀង។ ទឹកត្រូវបានពិពណ៌នាថា
មាននៅក្នុងបន្ទប់នានានៅស្ថានដ៏ខ្ពស់។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គដាក់ទឹកលើភ្នំដោយបណ្តាលឲ្យភ្លៀងធ្លាក់ពីស្ថានដ៏ខ្ពស់»

ផលនៃស្នាព្រះហស្តព្រះអង្គ

«របស់ល្អៗជាច្រើនដែលព្រះអង្គបង្កើត» (UDB)

ហើយរុក្ខជាតិសម្រាប់មនុស្សដាំដុះ

ពាក្យដែលបាត់អាចត្រូវបានបន្ថែម។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយនឹងធ្វើឲ្យរុក្ខជាតិដុះលូតលាស់សម្រាប់ដើម្បីដាំដុះ»

Psalms 104:16

generated on Wed Sep 10 16:16:32 2025

ដើមឈើទាំងប៉ុន្មានរបស់ព្រះអម្ចាស់ មានភ្លៀងជាបរិបូរណ៏
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ផ្តល់ទឹកភ្លៀងជាបរិបូរណ៏ដល់ដើមឈើរបស់ព្រះអង្គ»
បក្សាបក្សីនាំគ្នាធ្វើសម្បុក
ពួកវាធ្វើសម្បុកនៅលើដើមតាត្រៅ។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «បក្សាបក្សីធ្វើសម្បុកនៅក្នុងដើមតាត្រៅ»
សត្វកុក
នេះគឺជាប្រភេទបក្សី។ ការបកប្រែរបៀបផ្សេងទៀត: «បក្សី»
សត្វទន្សាយថ្ម
ខ្ញុំទន្សាយថ្មគឺជាសត្វតូចមួយដែលមើលទៅដូចជាសត្វកកេរធំ។
ការបកប្រែរបៀបផ្សេងទៀត: «សត្វទន្សាយថ្ម»
Psalms 104:19
រដូវ
ពាក្យនេះសំដៅទៅលើការប្រែប្រួលអាកាសធាតុផ្សេងៗគ្នាពេញមួយឆ្នាំ។
កន្លែងខ្លះមានរដូវវស្សា និងរដូវប្រាំងរីឯកន្លែងខ្លះទៀតមាននិទាឃរដូវ រដូវក្តៅ
រដូវស្លឹកឈើជ្រុះ និងរដូវរងា។
ព្រះអាទិត្យក៏ដឹងពេល
នៅទីនេះព្រះបាទដាវីឌពិពណ៌នាអំពីព្រះអាទិត្យហាក់ដូចជាវាដឹងថា
ពេលវេលានៃថ្ងៃណា។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានបង្កើតព្រះអាទិត្យ ដើម្បីកំណត់ពេលវេលាហើយ»
ព្រះអង្គធ្វើឲ្យ
«ឱព្រះអង្គអើយ!»
នៅទីនេះអ្នកនិពន្ធផ្លាស់ប្តូរពីការនិយាយអំពីព្រះអម្ចាស់ទៅនិយាយជាមួយព្រះអង្គ។
Psalms 104:21
ចាប់រំពា
នេះគឺជាសត្វដែលជាអាហារសម្រាប់សត្វផ្សេងទៀត។
រាស្មែងរកអាហាររបស់វាពីព្រះជាម្ចាស់
«ប៉ុន្តែពួកវាពឹងផ្អែកលើព្រះជាម្ចាស់ ដើម្បីផ្តល់អាហារឲ្យពួកវា»
ដកថយ
«ថយក្រោយ» ឬ «ផ្លាស់ទីទៅឆ្ងាយ»
រូង
ផ្ទះរបស់ថនិកសត្វ និងសត្វតូចៗមួយចំនួន
Psalms 104:23
ពេញដោយអ្វីៗសព្វសារពើ ដែលព្រះអង្គបានបង្កើតមក
នៅទីនេះព្រះបាទដាវីឌរៀបរាប់ពីចំនួនវត្ថុដែលព្រះអម្ចាស់បានបង្កើតដូចជាវត្ថុរាវដែលមានច្រើនសន្ធឹកសន្ធាប់
ការបកប្រែរបៀបផ្សេងទៀត: «ត្រូវបានបំពេញដោយការងាររបស់ព្រះអង្គ!»
Psalms 104:25
ធំ ហើយទូលាយ
វាជ្រៅណាស់ ហើយធំទូលាយណាស់។ ជម្រៅ និងទទឹងនៃសមុទ្រសង្កត់ន័យថា
តើវាធំប៉ុនណា។
ពោរពេញ
«ហូរហៀរ»
ច្រើនឥតគណនា
«រាប់មិនអស់»
ទាំងតូច ទាំងធំ
នេះមានន័យថា សត្វគ្រប់ទំហំ។
មាននាវាបើកទៅមក
«នាវាធ្វើដំណើរលើសមុទ្រ»។
Psalms 104:27
ទាំងអស់នោះ
«សត្វទាំងអស់នោះ»
ប្រទានចំណីដល់វាតាមពេលកំណត់
«ប្រទានអាហារដល់ពួកវានៅពេលពួកវាត្រូវការ»
ពេលព្រះអង្គប្រទានចំណីឲ្យវាក៏ទទួលយក
នេះអាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា នេះជាអាហារដែលត្រូវបានផ្តល់ឲ្យ។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលព្រះអង្គប្រទានអាហារដល់ពួកវា ពួកវាក៏
ទទួលយក»
ទទួលយក
«ប្រមូល»
ពេលព្រះអង្គលាព្រះហស្ត
នេះពណ៌នាអំពីព្រះអម្ចាស់ដូចជាកំពុងលាព្រះហស្តប្រទានអាហារដល់សត្វ។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលព្រះអង្គលាព្រះហស្តរបស់ព្រះអង្គ
ដើម្បីចិញ្ចឹមពួកវា»
Psalms 104:29
លាក់ព្រះភ័ក្ត្រ
នេះមានន័យថា ព្រះអម្ចាស់មិនមើលពួកវា ឬយកចិត្តទុកដាក់ចំពោះពួកវាទេ។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលព្រះអង្គមិនមើលពួកវា» ឬ
«នៅពេលព្រះអង្គមិនអើពើនឹងពួកវា»
ត្រឡប់ទៅជាធូលីដី
នេះមានន័យថា រាងកាយរបស់ពួកវារលួយ ហើយប្រែក្លាយជាដីម្តងទៀត។
ការបកប្រែរបៀបផ្សេងទៀត: «សាកសពរបស់ពួកវារលួយ ហើយត្រឡប់ទៅដីវិញ»
ពេលព្រះអង្គចាត់ព្រះវិញ្ញាណរបស់ព្រះអង្គទៅ
នេះសំដៅទៅលើព្រះវិញ្ញាណរបស់ព្រះអង្គដែលត្រូវបានចាត់មក
ដើម្បីផ្តល់ជីវិតសត្វ។ (សូមមើល:figs-idiom)
ពួកវាក៏កើតឡើង
នេះជាព្រះវិញ្ញាណរបស់ព្រះអម្ចាស់ដែលបានបង្កើតពួកវាមក។
ព្រះអង្គធ្វើឲ្យផែនដី ស្រស់បស់ឡើងវិញ
«ព្រះអង្គបណ្តាលឲ្យដីពោរពេញទៅដោយជីវិតថ្មី»
Psalms 104:33
ការសញ្ជឹងគិតរបស់ខ្ញុំ បានគាប់ព្រះហឫទ័យ
ទ្រង់កំពុងប្រៀបធៀបគំនិតរបស់ទ្រង់ទៅនឹងអ្វីមួយដែលមានរសជាតិផ្អែម។
ការបកប្រែរបៀបផ្សេងទៀត: «គំនិតរបស់ខ្ញុំគាប់ចិត្ត»
Psalms 104:35
វិនាស
«បាត់»
កុំឲ្យមានមនុស្សអាក្រក់ទៀតឡើយ
ឃ្លាថា «មនុស្សអាក្រក់» សំដៅទៅលើមនុស្សអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សអាក្រក់អាចនឹងបាត់»

---

105 [1]ចូរអរព្រះគុណដល់ព្រះអម្ចាស់ ចូរអំពាវនាវរកព្រះនាមព្រះអង្គ ចូរថ្លែងប្រាប់ពីស្នាព្រះហស្តរបស់ព្រះអង្គ នៅកណ្តាល ជនជាតិទាំងប៉ុន្មានចុះ។[2]ចូរច្រៀងថ្វាយ
ព្រះអង្គ ចូរច្រៀង សរសើរតម្កើងព្រះអង្គ ចូររៀបរាប់ពីការអស្ចារ្យទាំងប៉ុន្មានរបស់ព្រះអង្គ។[3]ចូរខ្ពស់មុខនឹងព្រះនាមដ៏បរិសុទ្ធរបស់ព្រះអង្គចុះ ចូរឲ្យចិត្តនៃអស់អ្នក
ដែលស្វែងរកព្រះអម្ចាស់រីករាយឡើង។
[4]ចូរស្វែងរកព្រះអម្ចាស់ និងឫទ្ធានុភាពរបស់ព្រះអង្គ ចូរស្វែងរកព្រះវត្តមានរបស់ព្រះអង្គ ឥតឈប់ឈរ។[5]ចូរនឹកចាំពីស្នាព្រះហស្តដ៏អស្ចារ្យ ដែលព្រះអង្គបានធ្វើ ពីការ
អស្ចារ្យ និងការជំនុំជម្រះ ដែលព្រះអង្គបានសម្រេច[6]ឱពូជពង្សរបស់លោកអ័ប្រាហាំ ជាអ្នកបម្រើរបស់ព្រះអង្គ គឺកូនចៅរបស់លោកយ៉ាកុប ជាអ្នកដែលព្រះអង្គជ្រើសរើស។
[7]ព្រះអង្គជាព្រះជាម្ចាស់នៃយើង ព្រះនាមជាព្រះអម្ចាស់ ការជំនុំជម្រះរបស់ព្រះអង្គ ស្ថិតនៅលើផែនដីទាំងមូល។[8]ព្រះអង្គនឹកចាំពីសេចក្តីសញ្ញា របស់ព្រះអង្គជានិច្ច គឺជា
ព្រះបន្ទូលដែលព្រះអង្គបានបង្គាប់ ដល់មនុស្សមួយពាន់តំណ។
[9]ព្រះអង្គនឹកដល់សម្ព័ន្ធមេត្រី ដែលព្រះអង្គបានចងជាមួយលោកអប្រាហាំ ព្រមទាំងព្រះបន្ទូលដែលព្រះអង្គបានសន្យាជាមួយលោកអ៊ីសាក។[10]ហើយព្រះអង្គក៏បានបញ្ជាក់
ជាមួយលោកយ៉ាកុបទុកជាច្បាប់ គឺជាមួយលោកអ៊ីស្រាអែល ទុកជាសេចក្តីសញ្ញាអស់កល្បជានិច្ច។[11]ព្រះអម្ចាស់មានបន្ទូលថា៖ «យើងនឹងប្រគល់ស្រុកកាណានឲ្យអ្នក
ទុកជាចំណែកមរតករបស់អ្នក»។
[12]ព្រះជាម្ចាស់បែបនេះ គឺកាលគេមានចំនួនតិច ហើយក៏គ្រាន់តែជាអ្នក ស្នាក់អាស្រ័យក្នុងស្រុកនោះ។[13]ពួកគេធ្វើដំណើរចុះឡើង ពីស្រុកមួយទៅស្រុកមួយ ហើយពីនគរ
មួយទៅនគរមួយទៀត
[14]ព្រះអង្គមិនបណ្តោយឲ្យអ្នកណា សង្កត់សង្កិនគេឡើយ ដោយយល់ដល់ពួកគេ ព្រះអង្គបានបន្ទោសពួកស្តេច។[15]ដោយព្រះបន្ទូលថា «កុំប៉ះពាល់ពួកអ្នកដែលយើង បាន
ចាក់ប្រេងតាំងឡើយ កុំធ្វើបាបពួកហោរារបស់យើងឲ្យសោះ»។

generated on Wed Sep 10 16:16:32 2025

[16]កាលព្រះអង្គបានបង្គាប់ ឲ្យមានអំណត់កើតឡើងក្នុងទឹកដី ហើយផ្តាច់អស់ទាំងអាហារ។[17]ព្រះអង្គបានចាត់មនុស្សម្នាក់ឲ្យទៅមុនពួកគេ គឺលោកយ៉ូសែបដែលគេ បានលក់ទៅធ្វើជាបាវបម្រើ។
[18]ជើងរបស់លោកត្រូវរឹតរួតដោយចំណង ហើយមានច្រវាក់ដែកជាប់នៅក[19]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានល្បងលលោករហូតទាល់តែសេចក្តី ដែលលោកថ្លែងទុកបានសម្រេច។
[20]ស្តេចបានចាត់គេឲ្យទៅដោះលែងលោក គឺអ្នកគ្រប់គ្រងលើប្រជាជននានា បានដោះលោកឲ្យរួច។[21]ស្តេចបានតាំងលោកឲ្យធ្វើជាម្ចាស់លើព្រះដំណាក់ ហើយជាអ្នកគ្រប់គ្រងលើព្រះរាជទ្រព្យ ទាំងអស់របស់ទ្រង់[22]ឲ្យមានអំណាចនឹងចាប់ចងពួកមន្ត្រីរបស់ស្តេចបានតាមចិត្ត ហើយនឹងបង្ហាត់បង្រៀនឲ្យពួកចាស់ទុំរបស់ស្តេចមានប្រាជ្ញា។
[23]ពេលនោះ អ៊ីស្រាអែលក៏ចូលមកក្នុងស្រុកអេស៊ីប គឺយ៉ាកុបបានស្នាក់នៅក្នុងទឹកដីរបស់ហាំ។
[24]ព្រះអម្ចាស់បានឲ្យប្រជារាស្ត្រព្រះអង្គចម្រើនឡើង មានកូនចៅជាច្រើន ហើយឲ្យគេមានកម្លាំងជាងបច្ចាមិត្ត របស់គេ។[25]ព្រះអង្គបានបង្វែរចិត្តគេ ឲ្យស្អប់ប្រជារាស្ត្រព្រះអង្គ ឲ្យគេប្រព្រឹត្តដោយកិច្ចកល មកកាន់អ្នកបម្រើព្រះអង្គ។[26]ព្រះអង្គបានចាត់លោកម៉ូសេ ជាអ្នកបម្រើព្រះអង្គ និងលោកអើរ៉ុន ដែលព្រះអង្គបានជ្រើសរើស។[27]លោកទាំងពីរ បានសម្តែងទីសម្គាល់ របស់ព្រះអង្គនៅកណ្តាលពួកគេ និងការអស្ចារ្យនៅក្នុងទឹកដីរបស់ហាំ។
[28]ព្រះអង្គចាត់សេចក្តីងងឹតមក ហើយធ្វើឲ្យស្រុកងងឹត ពួកលោកមិនបានទាស់ទទឹង នឹងព្រះបន្ទូលរបស់ព្រះអង្គទេ។[29]ព្រះអង្គបានធ្វើឲ្យទឹកនៅស្រុកគេ ត្រឡប់ទៅជាឈាម ហើយធ្វើឲ្យត្រីនៅ ស្រុកគេទាំងប៉ុន្មានស្លាប់អស់។[30]ស្រុកគេមានសត្វកង្កែបពេញដេរដាស សូម្បីតែនៅក្នុងក្រឡាបន្ទំរបស់ស្តេចក៏មានដែរ។
[31]ព្រះអង្គមានព្រះបន្ទូល នោះក៏មានរុយទាំងហ្វូងៗហើរមក ហើយក៏មានចៃនៅពាសពេញក្នុងស្រុករបស់គេ។[32]ព្រះអង្គប្រទានព្រឹលឲ្យគេជំនួសភ្លៀង ហើយរន្ទះក៏បាញ់ឆេះពេញក្នុងទឹកដីរបស់គេ។[33]ព្រះអង្គបានបំផ្លាញដើមទំពាំងបាយជូរ និងដើមល្វារបស់គេ ក៏បំបាក់ដើមឈើទាំងប៉ុន្មាន នៅក្នុងទឹកដីរបស់គេ។
[34]ព្រះអង្គមានព្រះបន្ទូល នោះក៏មានកណ្តូបហើរមក ហើយក៏មានចង្រិតច្រើនឥតគណនា។[35]សត្វទាំងនោះស៊ីបំផ្លាញ អស់ទាំងដំណាំនៅក្នុងទឹកដីរបស់គេ ហើយស៊ីភោគផលដែលដុះចេញពីដីរបស់គេ។[36]ព្រះអង្គបានប្រហារអស់ទាំងកូនច្បង នៅក្នុងទឹកដីគេ គឺជាផលដំបូងនៃកម្លាំងទាំងប៉ុន្មានរបស់គេ។
[37]ព្រះអង្គបាននាំអ៊ីស្រាអែលចេញ ទាំងនាំយកប្រាក់ និងមាសទៅជាមួយ ក្នុងចំណោមកុលសម្ព័ន្ធរបស់គេ គ្មានអ្នកណាម្នាក់ជំពប់ដួលឡើយ។[38]កាលគេបានចាកចេញទៅ ជនជាតិអេស៊ីបក៏អរសប្បាយ ដ្បិតគេភ័យខ្លាចពួកអ៊ីស្រាអែលជាខ្លាំង។[39]ព្រះអង្គបានលាតពពកជាម្លប់គ្របបាំងគេ ហើយប្រទានភ្លើងជាពន្លឺបំភ្លឺនៅពេលយប់។
[40]ពួកគេបានសុំ ហើយព្រះអង្គក៏នាំសត្វក្រួចមក ហើយប្រទានឲ្យគេមាននំប៉័ង ជាបរិបូរពីស្ថានសួគ៌។[41]ព្រះអង្គបានបំបែកថ្មឲ្យទឹកផុលចេញមក ហើយទឹកក៏ហូរកាត់ទីហួតហែង ដូចទន្លេ។[42]ដ្បិតព្រះអង្គនឹកចាំពីព្រះបន្ទូល ដ៏បរិសុទ្ធរបស់ព្រះអង្គ និងពីលោកអ័ប្រាហាំ ជាអ្នកបម្រើរបស់ព្រះអង្គ។
[43]ព្រះអង្គបាននាំប្រជារាស្ត្ររបស់ព្រះអង្គ ចេញមកដោយអំណរ ព្រះអង្គបាននាំពួកអ្នកដែលព្រះអង្គ បានជ្រើសរើសចេញមក ដោយច្រៀងចម្រៀង។[44]ព្រះអង្គបានប្រគល់ទឹកដី របស់ជនជាតិនានាដល់គេ ហើយគេចាប់យកភោគផល ដែលប្រជាជនទាំងនោះបានទឿយហត់[45]ដើម្បីឲ្យគេបានប្រតិបត្តិ តាមច្បាប់របស់ព្រះអង្គ ហើយប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ព្រះអង្គ។ សរសើរព្រះអម្ចាស់។

Psalms 105:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។

ចូរអំពាវនាវរកព្រះនាមព្រះអង្គ...ចូរខ្ពស់មុខនឹងព្រះនាមដ៏បរិសុទ្ធរបស់ព្រះអង្គចុះ

នៅទីនេះ «ព្រះនាម» តំណាងឲ្យព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:

«អំពាវនាវដល់ព្រះអង្គ...ខ្ពស់មុខក្នុងព្រះអម្ចាស់»

ជនជាតិទាំងប៉ុន្មាន

នេះសំដៅទៅលើប្រជាជនដែលនៅក្នុងប្រជាជាតិនានា។

ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៃប្រជាជាតិនានា»

ចូរឲ្យចិត្តនៃអស់អ្នកដែលស្វែងរកព្រះអម្ចាស់រីករាយឡើង

ត្រង់នេះ «ចិត្ត» តំណាងអ្នកដែលស្វែងរកព្រះអម្ចាស់។

ការបកប្រែរបៀបផ្សេងទៀត:

«ចូរឲ្យប្រជាជនដែលស្វែងរកព្រះអម្ចាស់រីករាយឡើង»

Psalms 105:4

ចូរស្វែងរកព្រះអម្ចាស់ និងឫទ្ធានុភាពរបស់ព្រះអង្គ

ដើម្បី «ស្វែងរកកម្លាំងរបស់ព្រះអម្ចាស់» មានន័យថា ស្នើសុំឲ្យ
ព្រះអង្គចម្រើនកម្លាំងអ្នក។ ការបកប្រែរបៀបផ្សេងទៀត: «

ចូរនឹកចាំ

«ចងចាំ»

ព្រះអង្គបានធ្វើការអស្ចារ្យ និង

វាអាចមានប្រយោជន៍ក្នុងការបន្ថែមពាក្យដែលបាត់។ ការបកប្រែរបៀបផ្សេងទៀត:

«ចងចាំការអស្ចារ្យរបស់ព្រះអង្គនិង»

ការជំនុំជម្រះ ដែលព្រះអង្គបានសម្រេច

ត្រង់នេះ «មាត់» សំដៅទៅលើអ្វីដែលព្រះអង្គបានមានព្រះបន្ទូល។

ការបកប្រែរបៀបផ្សេងទៀត: «បញ្ញត្តិដែលព្រះអង្គបានមានព្រះបន្ទូល»

ឱពូជពង្សរបស់លោកអ័ប្រាហាំ...កូនចៅរបស់លោកយ៉ាកុប

អ្នកនិពន្ធកំពុងនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល ដោយហៅឈ្មោះពួកគេ។

អ្នកបម្រើរបស់ព្រះអង្គ

«អប្រាហាំ ជាអ្នកបម្រើរបស់ព្រះអម្ចាស់»។

Psalms 105:7

ព្រះអង្គនឹកចាំជានិច្ច...ព្រះបន្ទូលដែលព្រះអង្គបានបង្គាប់

ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា
ហើយត្រូវបានប្រើរួមគ្នាសម្រាប់ការសង្កត់ន័យ។ ពាក្យថា «ព្រះបន្ទូល»
សំដៅទៅលើសេចក្តីសញ្ញា។ ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអង្គចងចាំជានិច្ចនូវសេចក្តី
សញ្ញារបស់ព្រះអង្គជាការសន្យាដែលព្រះអង្គបានធ្វើ»

នឹកចាំជានិច្ច

នេះមានន័យថា ត្រូវចងចាំ និងគិតអំពីអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត:

«ចងចាំ»

មនុស្សមួយពាន់តំណ

«១០០០ តំណ»

Psalms 105:9

ព្រះអង្គនឹកចងជានិច្ច

ឃ្លាថា «នឹកចងជានិច្ច» មានន័យថាចាំអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអង្គចងចាំ»

សម្ពន្ធមេត្រី ដែលព្រះអង្គបានចងជាមួយលោកអប្រាហាំ...ព្រះអង្គបានសន្យាជាមួយលោកអ៊ីសាក

ឃ្លាទាំងពីរនេះគឺ «សម្ពន្ធមេត្រី» និង «សម្បថ»
សំដៅទៅលើការសន្យាដូចគ្នាដែលព្រះអម្ចាស់បានធ្វើ
ចំពោះប្រជាជនរបស់ព្រះអង្គ។

ព្រះអង្គបានសន្យាជាមួយលោកអ៊ីសាក

នេះអាចមានប្រយោជន៍ក្នុងការបន្ថែមពាក្យដែលបាត់។
ការបកប្រែរបៀបផ្សេងទៀត: «សម្បថដែលព្រះអង្គបានប្រទានឲ្យអ៊ីសាក»

Psalms 105:12

ប្រយោគភ្ជាប់:

អ្នកតែងទំនុកតម្កើងកំពុងតែសរសេរអំពីអ៊ីុស្រាអែល។

កាលគេមានចំនួនតិច

ពាក្យថា «ពួកគេ» សំដៅទៅលើជនជាតិអ៊ីុស្រាអែល។

ហើយក៏គ្រាន់តែជាអ្នក ស្នាក់អាស្រ័យក្នុងស្រុកនោះ

នេះបញ្ជាក់ថា «ស្រុក» សំដៅទៅលើកាណាន។ ការបកប្រែរបៀបផ្សេងទៀត:

«ហើយជាបរទេសនៅស្រុកកាណាន»

ពួកគេធ្វើដំណើរចុះឡើង

«ពួកគេបានបន្តវង្វេង»

ពីស្រុកមួយទៅស្រុកមួយ ហើយពីនគរមួយទៅនគរមួយទៀត

ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា
ហើយត្រូវបានប្រើរួមគ្នាសម្រាប់ការសង្កត់ន័យ។

Psalms 105:14

ប្រយោគភ្ជាប់

អ្នកតែងទំនុកតម្កើងកំពុងតែសរសេរអំពីអ៊ីុស្រាអែល។

generated on Wed Sep 10 16:16:32 2025

ដោយយល់ដល់ពួកគេ
«ដើម្បីសុខុមាលភាពផ្ទាល់ខ្លួន»។ នេះគឺសំដៅទៅលើអ៊ីុស្រាអែល។
កុំប៉ះពាល់ពួកអ្នកដែលយើងបានចាក់ប្រេងតាំងឡើយ
ត្រង់នេះ «ប៉ះពាល់» មានន័យថា
បង្កអន្តរាយវាគឺជាការនិយាយបំផ្លើសដែលព្រះអម្ចាស់បានប្រើ
ដើម្បីពង្រឹងការព្រមានរបស់ព្រះអង្គ កុំឲ្យធ្វើបាបប្រជាជនរបស់ព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «កុំធ្វើបាបប្រជាជនដែលខ្ញុំបានចាក់ប្រេងតាំង»
Psalms 105:16
កាលព្រះអង្គបានបង្គាប់
«ព្រះអង្គបានចាត់»។ នេះមានន័យថា
បណ្តាលឲ្យមានអំណត់កើតឡើងនៅក្នុងទឹកដី។
អស់ទាំងអាហារ
នៅទីនេះ «នំបុ័ង» សំដៅទៅលើអាហារជាទូទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«ការផ្គត់ផ្គង់អាហារទាំងមូល»
ព្រះអង្គបានចាត់មនុស្សម្នាក់ឲ្យទៅមុនពួកគេ លោកយ៉ូសែប
នេះអាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា
ព្រះអង្គបានចាត់លោកទៅមុនពួកគេទៅកាន់ប្រទេសអេស៊ីប។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានចាត់មនុស្សម្នាក់ឲ្យទៅមុនពួកគេទៅស្រុកអេស៊ីប
ព្រះអង្គបានចាត់លោកយ៉ូសែបដែល»
លោកយ៉ូសែបដែលគេបានលក់ទៅធ្វើជាបាវបម្រើ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនរបស់លោកយ៉ូសែបបានលក់លោកឲ្យទៅធ្វើជាទាសករ»
Psalms 105:18
ចំណង
ការរឹតបន្តឹងដែកប្រើ ដើម្បីភ្ជាប់កដៃ ឬកជើងរបស់អ្នកទោសជាមួយគ្នា
ជើងរបស់លោកត្រូវរឹតួតដោយចំណង ហើយមានច្រវាក់ដែកជាប់នៅក
ឃ្លាទាំងនេះអាចត្រូវបានកំណត់ឡើងវិញថា ជាសកម្ម។
ការបកប្រែរបៀបផ្សេងទៀត:
«ជនជាតិអេស៊ីបបានចងជើងរបស់លោកជាប់នឹងច្រវាក់ពួកគេបានដាក់ដែកនៅករបស់លោក»
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានល្បងលលោក
ត្រង់នេះ «ព្រះបន្ទូល» សំដៅទៅលើសាររបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «សាររបស់ព្រះអម្ចាស់បានសាកល្បងលោក»
Psalms 105:20
ស្តេចបានចាត់គេឲ្យទៅដោះលែងលោក គឺអ្នកគ្រប់គ្រងលើប្រជាជននានាបានដោះលោកឲ្យរួច
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាហើយត្រូវបានប្រើជាមួយគ្នា ដើម្បីបញ្ជាក់ថា
ស្តេចបានដោះលែងលោកយ៉ូសែបឲ្យមានសេរីភាព។
ពេលនោះ អ៊ីស្រាអែលក៏ចូលមកក្នុងស្រុកអេស៊ីប
នៅទីនេះ «អ៊ីុស្រាអែល» សំដៅទៅលើលោកយ៉ាកុប។
លោកយ៉ាកុបក៏បាននាំគ្រួសាររបស់លោកទៅជាមួយលោកដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«ពេលនោះអ៊ីុស្រាអែលនិងគ្រួសាររបស់គេបានចូលមកស្រុកអេស៊ីប»
Psalms 105:24
ព្រះអម្ចាស់បានឲ្យប្រជារាស្ត្រព្រះអង្គចម្រើនឡើង
អ្នកនិពន្ធនិយាយអំពីការកើនឡើងនៃជនជាតិអ៊ីុស្រាអែលហាក់ដូចជាពួកគេជារុក្ខជាតិដែលកំពុងលូតលាស់
«ព្រះជាម្ចាស់បានបង្កើនចំនួនប្រជាជនរបស់ព្រះអង្គយ៉ាងច្រើន»
ឲ្យស្អប់ប្រជារាស្ត្រព្រះអង្គឲ្យគេប្រព្រឹត្តដោយកិច្ចកលមកកាន់អ្នកបម្រើព្រះអង្គ
«ស្អប់ប្រជាជនរបស់ព្រះអង្គ និងធ្វើបាបអ្នកបម្រើរបស់ព្រះអង្គ»
លោកទាំងពីរបានសម្តែងទីសម្គាល់...ការអស្ចារ្យរបស់ព្រះអង្គនៅក្នុងទឹកដីរបស់ហាំ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានប្រើជាមួយគ្នាសម្រាប់ការសង្កត់ន័យ។ ការបកប្រែរបៀបផ្សេងទៀត:
«ម៉ូសេ និងអើរ៉ុនបានធ្វើការ
អស្ចារ្យរបស់ព្រះជាម្ចាស់នៅស្រុកអេស៊ីបក្នុងចំណោមកូនចៅរបស់ហាំ»
ការអស្ចារ្យរបស់ព្រះអង្គ
ពាក្យដែលបាត់អាចត្រូវបានបន្ថែម។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយពួកគេបានសម្តែងការអស្ចារ្យរបស់ព្រះអង្គ»
Psalms 105:28
ធ្វើឲ្យស្រុកងងឹត
«ធ្វើឲ្យមេឃងងឹត»
សត្វកង្កែប
សត្វល្មូនតូចមួយលោត
សូម្បីតែនៅក្នុងក្រឡាបន្ទំរបស់ស្តេចក៏មានដែរ
«ពួកគេនៅក្នុងបន្ទប់របស់មេដឹកនាំពួកគេ»
Psalms 105:31
ប្រយោគភ្ជាប់
អ្នកតែងទំនុកតម្កើងបន្តរៀបរាប់អំពីការជំនុំជម្រះរបស់ព្រះអម្ចាស់លើស្រុកអេស៊ីប។
សត្វរុយ
ហោះក្រុមធំ
សត្វចៃ
សត្វល្អិតហោះតូចៗដូចជាសត្វរុយប៉ុន្តែតូចជាង
ព្រិល
ទឹកកកដែលធ្លាក់ពីលើមេឃដូចភ្លៀង
ព្រះអង្គបានបំផ្លាញ...ព្រះអង្គបានបំបាក់
ព្រះជាម្ចាស់បានធ្វើឲ្យព្រិល ភ្លៀង និងផ្លេកបន្ទោរបំផ្លាញដើមទំពាំងបាយជូរ
និងដើមឈើ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបណ្តាលឲ្យវាបំផ្លាញ...ហើយបំបែក»
Psalms 105:34
មានកណ្តូបជាច្រើន
«មានកណ្តូបច្រើនណាស់»
សត្វទាំងនោះស៊ីបំផ្លាញ អស់ទាំងដំណាំ...ពួកវាស៊ីភោគផលដែលដុះចេញពីដី
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា និងត្រូវបានប្រើរួមគ្នាសម្រាប់ការសង្កត់ន័យ។
ការបកប្រែរបៀបផ្សេងទៀត: «សត្វល្អិតបានស៊ីរុក្ខជាតិ
និងដំណាំទាំងអស់នៅលើដី»
ព្រះអង្គបានប្រហារអស់ទាំងកូនច្បង នៅក្នុងទឹកដីគេ គឺជាផលដំបូងនៃកម្លាំងទាំងប៉ុន្មានរបស់គេ
នៅទីនេះឃ្លាទីពីរអំពី «ផលដំបូង» ត្រូវបានប្រើ ដើម្បីពិពណ៌នាអំពី «កូនច្បង»
នៅក្នុងឃ្លាទីមួយ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានប្រហារ
កូនច្បងទាំងអស់នៅក្នុងទឹកដីរបស់ពួកគេដែលជាផលដំបូងនៃកម្លាំងទាំងអស់របស់ពួកគេ»
ឬ
«បន្ទាប់មកព្រះអម្ចាស់បានប្រហារកូនប្រុសច្បងនៅគ្រប់ផ្ទះរបស់ប្រជាជនអេស៊ីប»។
Psalms 105:37
ព្រះអង្គបាននាំអ៊ីស្រាអែលចេញ ទាំងនាំយកប្រាក់ និងមាសទៅជាមួយ
នៅពេលដែលជនជាតិអ៊ីុស្រាអែលចាកចេញពីស្រុកអេស៊ីបពួកគេបានយកប្រាក់
និងមាសទៅជាមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបាននាំជនជាតិអ៊ីុស្រាអែលចេញពីស្រុកអេស៊ីបជាមួយប្រាក់
និងមាសជាកម្មសិទ្ធិរបស់ពួកគេ»
ក្នុងចំណោមកុលសម្ព័ន្ធរបស់គេ គ្មានអ្នកណាម្នាក់ជំពប់ដួលឡើយ
គ្មាននរណាម្នាក់ត្រូវបានទុកចោលទេ។ នេះអាចត្រូវបានបញ្ជាក់ជាវិជ្ជមាន
ការបកប្រែរបៀបផ្សេងទៀត:
«កុលសម្ព័ន្ធទាំងអស់របស់ព្រះអង្គអាចធ្វើដំណើរបាន»
អេស៊ីបក៏អរសប្បាយ
នៅទីនេះ «អេស៊ីប» សំដៅទៅលើប្រជាជនដែលរស់នៅក្នុងប្រទេសអេស៊ីប។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអេស៊ីបអរសប្បាយ»
ព្រះអង្គបានលាតពពកជាម្លប់គ្របបាំងគេ
ដើម្បីការពារពួកគេពីពន្លឺភ្លើងនៅពេលយប់
ដូចជាព្រះអង្គកំពុងតែលាតអាវ។ ពពកគឺជា «គ្របបាំង»
ដើម្បីការពារពួកគេពីព្រះអាទិត្យ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានដាក់ពពកនៅលើមេឃ ដើម្បីការពារពួកគេពីព្រះអាទិត្យ និងកំដៅ»
ប្រទានភ្លើងជាពន្លឺបំភ្លឺនៅពេលយប់
ព្រះអម្ចាស់ដាក់បង្គោលភ្លើងនៅលើមេឃ ដើម្បីបំភ្លឺនៅពេលយប់។
ការបកប្រែរបៀបផ្សេងទៀត: «ដាក់ភ្លើងជាមេឃ ដើម្បីបំភ្លឺពេលយប់»
Psalms 105:40
ហើយព្រះអង្គក៏នាំសត្វក្រួចមក
នេះអាចមានប្រយោជន៍ក្នុងការបញ្ជាក់ឲ្យច្បាស់ថា
សត្វក្រួចគឺជាសត្វបក្សីតូចៗដែលព្រះអម្ចាស់បានប្រទានឲ្យពួកគេសម្រាប់បរិភោគ។
ការបកប្រែរបៀបផ្សេងទៀត:
«ហើយព្រះអម្ចាស់បានប្រទានឲ្យសត្វបក្សីតូចៗមកស៊ី»
ជាមួយនំបុ័ងជាបរិបូរពីស្ថានសួគ៌
ព្រះអម្ចាស់បាននាំនំម៉ាណាមក ជានំបុ័ងមួយប្រភេទ ធ្លាក់ចុះពីលើមេឃ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «ជាមួយនំប៉័ងដែលធ្លាក់ពីលើមេឃ»
ពួកគេបានហូរ
«ទឹកបានហូរ»
នឹកចាំ
នេះមានន័យថា ត្រូវចងចាំ។ ការបកប្រែរបៀបផ្សេងទៀត: «ចងចាំ»
Psalms 105:43
ព្រះអង្គបាននាំប្រជារាស្ត្ររបស់ព្រះអង្គចេញ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាហើយត្រូវបានប្រើជាមួយគ្នា ដើម្បីបញ្ជាក់ថា
ប្រជាជនរបស់ព្រះជាម្ចាស់មានសេចក្ដីអំណរ
នៅពេលដែលព្រះអង្គបាននាំពួកគេចេញពីស្រុកអេស៊ីប។
បានស្រែកយ៉ាងសប្បាយរីករាយ។ ការបកប្រែរបៀបផ្សេងទៀត:
និងជ័យជម្នះ»
ការជ្រើសរើសរបស់ព្រះអង្គ
ត្រង់នេះ «ការជ្រើសរើស»
គឺសំដៅទៅលើប្រជាជនដែលត្រូវបានជ្រើសរើសរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនដែលព្រះអង្គបានជ្រើសរើស»
ជ័យជម្នះ
«អបអរសាទរ» ឬ «សេចក្ដីអំណរ»
ប្រតិបត្តិតាមច្បាប់របស់ព្រះអង្គ ហើយប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ព្រះអង្គ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានប្រើជាមួយគ្នាសម្រាប់ការសង្កត់ន័យ។ «ដើម្បីរក្សា»
ច្បាប់របស់ព្រះអង្គមានន័យថា ត្រូវគោរពតាម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានដឹកនាំប្រជាជនដែលព្រះអង្គបានជ្រើសរើសជាមួយការស្រែកដោយអំណរ»គោរពច្បាប់ និងក្រឹត្យវិន័យរបស់ព្រះអង្គ»

---

106 [1]សរសើរតម្កើងព្រះអម្ចាស់ ចូរអរព្រះគុណដល់ព្រះអម្ចាស់ ដ្បិតព្រះអង្គល្អ ព្រះហឫទ័យសប្បុរស របស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។[2]តើអ្នកណាអាចរៀបរាប់អំពីស្នាព្រះហស្ត ដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ឬប្រកាសអំពីការទាំងប៉ុន្មាន ដើម្បីសរសើរតម្កើងព្រះអង្គបាន?
[3]មានពរហើយ អស់អ្នកដែលរក្សាសេចក្ដីយុត្តិធម៌ ជាអ្នកដែលប្រព្រឹត្តតាមសេចក្ដីសុចរិត គ្រប់ពេលវេលា។[4]ព្រះអម្ចាស់អើយ ពេលព្រះអង្គសម្តែងព្រះហឫទ័យ ប្រោសប្រណីដល់ប្រជារាស្ត្រព្រះអង្គ សូមនឹកចាំពីទូលបង្គំផង! ពេលព្រះអង្គសង្គ្រោះគេ សូមជួយទូលបង្គំផង។[5]ទូលបង្គំបានឃើញភាពចម្រុងចម្រើន របស់ពួកអ្នកដែលព្រះអង្គបានជ្រើសរើស ហើយឲ្យទូលបង្គំបានសប្បាយរីករាយ រួមជាមួយជនជាតិរបស់ព្រះអង្គ ដើម្បីឲ្យទូលបង្គំបានខ្ពស់មុខ រួមជាមួយមរតករបស់ព្រះអង្គ។
[6]ទាំងយើងខ្ញុំ និងបុព្វបុរសរបស់យើងខ្ញុំ បានប្រព្រឹត្តអំពើបាប យើងខ្ញុំបានប្រព្រឹត្តអំពើទុច្ចរិត គឺយើងបានប្រព្រឹត្តអំពើអាក្រក់។[7]កាលនៅទឹកដីអេស៊ីប បុព្វបុរសរបស់យើងខ្ញុំ មិនបានពិចារណាអំពីការដ៏អស្ចារ្យ របស់ព្រះអង្គទេ ក៏មិនបាននឹកចាំពីព្រះហឫទ័យសប្បុរស ដ៏បរិបូរណ៌របស់ព្រះអង្គដែរ គឺគេបានបះបោរនៅមាត់សមុទ្រ គឺនៅសមុទ្រក្រហម។
[8]ក៏ប៉ុន្តែ ព្រះអង្គបានសង្គ្រោះគេ ដោយយល់ដល់ព្រះនាមព្រះអង្គដើម្បីឲ្យគេស្គាល់ព្រះចេស្តា ដ៏ខ្លាំងពូកែរបស់ព្រះអង្គ។[9]ព្រះអង្គបានបន្ទោសសមុទ្រក្រហម សមុទ្រនោះក៏រីងទៅ ហើយព្រះអង្គបាននាំគេដើរកាត់ទីជម្រៅ ដូចដើរកាត់វាលខ្សាច់។
[10]ព្រះអង្គបានសង្គ្រោះគេ ពីកណ្តាប់ដៃរបស់ខ្មាំងសត្រូវ ក៏រំដោះគេឲ្យរួចពីអំណាចរបស់ខ្មាំងសត្រូវ។[11]ទឹកសមុទ្របានហូរគ្របលើបច្ចាមិត្តរបស់គេ គ្មានសល់អ្នកណាម្នាក់ឡើយ។[12]ពេលនោះ គេក៏ជឿព្រះបន្ទូលរបស់ព្រះអង្គ ហើយនាំគ្នាច្រៀងសរសើរតម្កើងព្រះអង្គ។
[13]ប៉ុន្តែ មិនយូរប៉ុន្មាន គេក៏ភ្លេចពីកិច្ចការរបស់ព្រះអង្គ ហើយមិនបានរង់ចាំស្តាប់ដំបូន្មាន របស់ព្រះអង្គឡើយ។[14]ពួកគេមានចិត្តខ្ទួលខ្ទាញ់នៅទីរហោស្ថាន ហើយល្បងលព្រះនៅទីហួតហែង។[15]ព្រះអង្គក៏បានប្រទានតាមសំណូមរបស់គេ តែក៏ចាត់ឲ្យមានជំងឺផ្សេងៗ នៅក្នុងរូបកាយរបស់គេវិញ។
[16]កាលមនុស្សក្នុងជំរំច្រណែននឹងលោកម៉ូសេ ហើយនឹងលោកអើរ៉ុន ជាអ្នកបរិសុទ្ធរបស់ព្រះអម្ចាស់។[17]ផែនដីក៏ប្រេះហា ហើយស្រូបយកដាថាន រួចគ្របលើបក្សពួករបស់អ័ប៊ីរ៉ាមទៀតផង។[18]ភ្លើងឆេះឡើងក្នុងបក្សពួករបស់គេ អណ្តាតភ្លើងក៏ឆាបឆេះ មនុស្សអាក្រក់ទាំងនោះទៅ។
[19]ពួកគេបានធ្វើរូបកូនគោនៅភ្នំហោរែប ហើយនាំគ្នាក្រាបថ្វាយបង្គំរូប ដែលធ្វើពីលោហធាតុ។[20]គេបានប្តូរយករូបដូចគោដែលស៊ីស្មៅ ជំនួសព្រះជាម្ចាស់ដែលប្រកបដោយសិរីល្អវិញ។[21]គេបានភ្លេចព្រះជាម្ចាស់ដែលសង្គ្រោះគេ ជាព្រះដែលបានធ្វើការយ៉ាងដ៏ធំ នៅក្នុងទឹកដីអេស៊ីប។
[22]ព្រះអង្គបានធ្វើការយ៉ាងអស្ចារ្យនៅទឹកដីហាំ និងការគួរស្ញែងខ្លាចនៅសមុទ្រក្រហម។[23]ដូច្នេះ ព្រះអង្គមានព្រះបន្ទូលថានឹងបំផ្លាញគេ ប៉ុន្តែ លោកម៉ូសេជាអ្នក ដែលព្រះអង្គបានជ្រើសរើស លោកបានឈរក្នុងទីបែកបាក់ នៅចំពោះព្រះអង្គ ដើម្បីបង្វែរសេចក្ដីក្រោធរបស់ព្រះអង្គចេញ ពីការបំផ្លាញដល់គេ។
[24]បន្ទាប់មក ពួកគេបានមើលងាយ ទឹកដីដ៏សប្បាយនោះ គេមិនបានជឿព្រះបន្ទូលសន្យាទេ[25]ពួកគេនាំគ្នារទូរទាំនៅក្នុងជំរំរៀងៗខ្លួន ហើយមិនស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់ដែរ។
[26]ដូច្នេះ ព្រះអង្គក៏លើកព្រះហស្តឡើង ស្បថនឹងគេថា ព្រះអង្គនឹងធ្វើឲ្យគេដួលស្លាប់ នៅក្នុងទីរហោស្ថាន[27]ហើយឲ្យពូជពង្សរបស់គេដួលស្លាប់ នៅកណ្តាលជនជាតិផ្សេង ព្រមទាំងកម្ចាត់កម្ចាយគេ ឲ្យទៅនៅពាសពេញស្រុករបស់ជនជាតិដទៃ។
[28]ពួកគេទៅភ្ជាប់ខ្លួន នឹងព្រះបាល-ពេអរ ហើយបានបរិភោគសំណែន ដែលបានថ្វាយទៅព្រះដែលគ្មានជីវិត។[29]គេបានធ្វើឲ្យព្រះអម្ចាស់ខ្ញាល់ ដោយសារអំពើរបស់គេ ហើយគ្រោះកាចក៏កើតឡើង ក្នុងចំណោមពួកគេ។
[30]ក្រោយមក ភីនេហាសក៏ឈរឡើង ហើយធ្វើអន្តរាគមន៍ រួចគ្រោះកាចនោះក៏ស្ងប់ទៅវិញ។[31]ការនោះបានរាប់ជាសុចរិតដល់ភីនេហាស ជារៀងរហូត ដល់មនុស្សគ្រប់ជំនាន់តមក។
[32]ពួកគេបានធ្វើឲ្យព្រះអង្គខ្ញាល់ នៅត្រង់ទឹកមេរីបាទៀត ហើយការនោះជាហេតុនាំឲ្យលោកម៉ូសេ មានទោសដោយសារតែពួកគេ។[33]ពួកគេធ្វើឲ្យចិត្តលោកជូរល្វីង ហើយបបូរមាត់លោកក៏និយាយចេញមក ដោយមិនបានគិត។[34]ពួកគេមិនបានបំផ្លាញប្រជាជនទាំងប៉ុន្មាន ដូចព្រះជាម្ចាស់បានបង្គាប់ទេ[35]តែគេបែរជាប្រព្រឹត្តច្របូកច្របល់ ជាមួយជនជាតិដទៃ ហើយរៀនប្រព្រឹត្តដូចពួកទាំងនោះទៅវិញ។[36]ហើយគោរពប្រតិបត្តិរូបព្រះ របស់ជនជាតិដទៃទាំងនោះ ជាការដែលត្រឡប់ជាអន្ទាក់ដល់គេ។
[37]ពួកគេបានយកកូនប្រុសកូនស្រីរបស់គេ ទៅធ្វើយញ្ញបូជាឲ្យអារក្ស។[38]គេបានបង្ហូរឈាមមនុស្សដែលគ្មានទោស គឺជាឈាមកូនប្រុសកូនស្រីរបស់ខ្លួន ដែលគេយកទៅធ្វើយញ្ញបូជា ឲ្យរូបព្រះនៅទឹកដីកាណាន ហើយទេកដីនោះក៏ត្រឡប់ជាស្មោកគ្រោក ដោយសារឈាម។[39]ដូច្នេះ គេបានធ្វើឲ្យខ្លួនមានសៅហ្មង ដោយសារអំពើដែលប្រព្រឹត្ត ហើយបានក្បត់ព្រះដោយសារអំពើរបស់គេ។
[40]សេចក្ដីក្រោធរបស់ព្រះអម្ចាស់ បានឆួលឡើងទាស់នឹងប្រជារាស្ត្ររបស់ព្រះអង្គ ហើយព្រះអង្គក៏ស្អប់ខ្ពើមមរតករបស់ព្រះអង្គ។[41]ព្រះអង្គបានប្រគល់គេទៅក្នុងកណ្តាប់ដៃជនជាតិដទៃ ដើម្បីឲ្យអស់អ្នកដែលស្អប់គេ បានគ្រប់គ្រងលើគេ។
[42]ខ្មាំងសត្រូវរបស់គេបានសង្កត់សង្កិនគេ ហើយបង្ក្រាបគេ ឲ្យនៅក្រោមអំណាចរបស់ខ្លួន។[43]ព្រះអង្គបានរំដោះគេជាច្រើនលើកច្រើនគ្រា ប៉ុន្តែ គេនៅតែតាំងចិត្តបះបោរ ហើយគេបានធ្វើឲ្យខ្លួនឯងទាបថោក ដោយសារអំពើទុច្ចរិតរបស់ខ្លួន។
[44]ទោះជាដូច្នេះក្តី ក៏ព្រះអង្គនៅតែយោគយល់ ពីទុក្ខព្រួយរបស់គេ នៅពេលព្រះអង្គឮសម្រែករបស់គេ។[45]ដោយយល់ដល់ពួកគេ ព្រះអង្គនឹកចាំពីសេចក្ដីសញ្ញារបស់ព្រះអង្គ ហើយសម្តែងព្រះហឫទ័យអាណិតអាសូរ ដោយព្រោះព្រះហឫទ័យសប្បុរស ដ៏បរិបូររបស់ព្រះអង្គ។[46]ព្រះអង្គធ្វើឲ្យពួកអ្នកដែលចាប់ពួកគេយកទៅ ជាឈ្លើយ មានចិត្តអាណិតអាសូរដល់គេ។
[47]ឱព្រះអម្ចាស់ជាព្រះជាម្ចាស់នៃយើងខ្ញុំអើយ សូមសង្គ្រោះយើងខ្ញុំផង សូមប្រមូលយើងខ្ញុំពីកណ្តាល ជាតិសាសន៍ដទៃមកវិញ ដើម្បីឲ្យយើងខ្ញុំបានអរព្រះគុណ ដល់ព្រះនាមដ៏បរិសុទ្ធរបស់ព្រះអង្គ ហើយបានខ្ពស់មុខ ដោយសរសើរតម្កើងព្រះអង្គ។[48]សូមលើកតម្កើងព្រះអម្ចាស់ ជាព្រះជាម្ចាស់នៃអ៊ីស្រាអែល ចាប់តាំងពីអស់កល្ប រហូតដល់អស់កល្បជានិច្ច។ ត្រូវឲ្យមនុស្សទាំងអស់ពោលថា «អាម៉ែន» សរសើរតម្កើងព្រះអម្ចាស់។

---

generated on Wed Sep 10 16:16:32 2025

Psalms 106:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
តើអ្នកណាអាចរៀបរាប់អំពីស្នាព្រះហស្ត ដ៏អស្ចារ្យរបស់ព្រះអម្ចាស់...សរសើរតម្កើង?
អ្នកនិពន្ធសួរសំណួរនេះ ដើម្បីសរសើរព្រះជាម្ចាស់ ហើយមិនរំពឹងថា
និងមានចម្លើយទេ។ ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់អាចរៀប
រាប់ពីការអស្ចារ្យរបស់ព្រះអម្ចាស់...សរសើរតម្កើង»។
ការទាំងប៉ុន្មាន ដើម្បីសរសើរតម្កើង
«អំពើដែលសក្តិសមនឹងការសរសើរ»
Psalms 106:3
សូមនឹកចាំពីទូលបង្គំផង
ឃ្លាថា «នឹកចាំ» មានន័យថា ចាំអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ចងចាំទូលបង្គំ»
ព្រះអង្គបានជ្រើសរើស
ពាក្យថា «បានជ្រើសរើស»
គឺសំដៅទៅលើមនុស្សដែលបានជ្រើសរើសរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «នៃមនុស្សដែលព្រះអង្គបានជ្រើសរើស»
សប្បាយរីករាយ...និងសិរីរុងរឿង
ទាំងនេះជាអ្វីដែលព្រះបាទដាវីឌបានមានបន្ទូលថា៖ ទ្រង់នឹងធ្វើរួមជាមួយ
«ការមើលឃើញភាពរុងរឿងរបស់អ្នកដែលព្រះអង្គបានជ្រើសរើស»។
ពាក្យដែលបាត់អាចត្រូវបានបន្ថែម។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំនឹងរីករាយនៅក្នុងភាពរីករាយ...ហើយទូលបង្គំនឹងលើកតម្កើង»
សប្បាយរីករាយ
«អំណរ» ឬ «រីករាយ»
បានខ្ពស់មុខ រួមជាមួយមរតករបស់ព្រះអង្គ
ត្រង់នេះឃ្លាដែលថា «មរតករបស់ព្រះអង្គ»
សំដៅទៅលើពួកអ៊ីុស្រាអែលដែលជាប្រជាជនដែលព្រះអម្ចាស់បានជ្រើសរើស។
ត្រង់នេះ «បានខ្ពស់មុខ» មានន័យថា «អួតអំពី» អ្វីមួយ។
ក្នុងករណីនេះពួកគេអួតអំពីព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«អួតពីការអស្ចារ្យរបស់ព្រះអង្គជាមួយប្រជាជនរបស់ព្រះអង្គ»
Psalms 106:6
មិនបានពិចារណាអំពីការដ៏អស្ចារ្យ របស់ព្រះអង្គទេ
«មិនមានអំណរគុណចំពោះទង្វើដ៏អស្ចារ្យដែលព្រះអង្គបានធ្វើ»
នៅមាត់សមុទ្រ...គឺនៅសមុទ្រក្រហម
ឃ្លាទាំងពីរនេះ សំដៅលើសមុទ្រតែមួយ។ ទីពីរគឺឈ្មោះរបស់សមុទ្រ។
Psalms 106:8
ក៏ប៉ុន្តែ
«នៅមិនទាន់» ឬ «សូម្បីតែអញ្ចឹង»
ដោយយល់ដល់ព្រះនាមព្រះអង្គ
ត្រង់នេះ «ព្រះនាមរបស់ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីជាប្រយោជន៍ដល់ព្រះនាមរបស់ព្រះអង្គ»
ដើរកាត់ទីជម្រៅ ដូចដើរកាត់វាលខ្សាច់
នៅទីនេះព្រះបាទដាវីឌប្រៀបធៀបវិធីដែលព្រះអម្ចាស់បានដឹកនាំពួកអ៊ីុស្រាអែលឆ្លង
«ជម្រៅទឹក» សំដៅទៅលើបាតទន្លេដែលលេចចេញ
បន្ទាប់ពីព្រះអម្ចាស់បានញែកទឹកចេញ។ ការបកប្រែរបៀបផ្សេងទៀត:
«ឆ្លងកាត់សមុទ្រក្រហមនៅលើដីស្ងួត»
Psalms 106:10
ព្រះអង្គបានសង្គ្រោះគេ ពីកណ្តាប់ដៃ...ក៏រំដោះគេឲ្យរួចពីកណ្តាប់ដៃ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានប្រើជាមួយគ្នាដើម្បីបញ្ជាក់ថា
ព្រះអម្ចាស់បានសង្គ្រោះពួកគេពីខ្មាំងសត្រូវរបស់ពួកគេ។
ពីកណ្តាប់ដៃរបស់ខ្មាំងសត្រូវដែលស្អប់ពួកគេ
ត្រង់នេះ «កណ្តាប់ដៃ» សំដៅទៅលើអំណាច ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «អំណាចរបស់ខ្មាំងសត្រូវដែលស្អប់ពួកគេ» ឬ
«ការគ្រប់គ្រងរបស់ខ្មាំងសត្រូវដែលស្អប់ពួកគេ»
គ្របលើបច្ចាមិត្តរបស់គេ
នេះជាវិធីគួរសម ដើម្បីនិយាយពីពួកគេលង់ទឹក។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្មាំងសត្រូវរបស់ពួកគេលង់ទឹក»
ពេលនោះ ពួកគេក៏ជឿព្រះបន្ទូលរបស់ព្រះអង្គ
ត្រង់នេះពាក្យថា «ពួកគេ» សំដៅទៅលើ «បុព្វបុរសរបស់ពួកគេ» ហើយពាក្យ
«របស់ព្រះអង្គ» សំដៅទៅលើ «ព្រះម្ចាស់»។
Psalms 106:13
ពួកគេមិនបានរង់ចាំស្តាប់ដំបូន្មាន របស់ព្រះអង្គឡើយ
នេះបញ្ជាក់ថា ពួកគេបានធ្វើអ្វីដោយមិនរង់ចាំ ដើម្បីដឹងថា
តើព្រះអម្ចាស់ចង់ឲ្យពួកគេទៅណា។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានធ្វើអ្វីដោយមិនបានរង់ចាំការណែនាំពីព្រះអម្ចាស់ជាមុនសិន»
ចិត្តខ្ជួលខ្ចាញ់
«សេចក្តីប៉ងប្រាថ្នាដែលមិនអាចពេញចិត្ត»
ពួកគេល្បងលព្រះជាម្ចាស់
«ពួកគេបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់»
ប្រើប្រាស់
«វ៉ាដាច់» ឬ «បានកាន់កាប់»
តែក៏ចាត់ឲ្យមានជម្ងឺផ្សេងៗ
នៅទីនេះព្រះបាទដាវីឌមានបន្ទូលអំពីព្រះអម្ចាស់ដែលធ្វើឲ្យប្រជាជនរងទុក្ខវេទនា
ដោយជម្ងឺមួយដូចជាព្រះអម្ចាស់បានឲ្យជម្ងឺដល់ពួកគេតាមរបៀបដែលអ្នកណាម្នាក់ចាត់មនុស្ស
ឬអ្នកនាំសារ។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែព្រះអង្គបណ្តាលឲ្យមានជម្ងឺមួយដែលបំផ្លាញរាងកាយរបស់ពួកគេ»
Psalms 106:16
ក្នុងជំរំ
នេះសំដៅទៅលើជំរំរបស់ជនជាតិអ៊ីុស្រាអែលនៅទីរហោស្ថាន។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងជំរំនៅទីរហោស្ថាន»
ផែនដីបានបើក ហើយស្រូបយក
នេះជារបៀបដែលដីបើក
ហើយកប់ប្រជាជនកំពុងប្រៀបធៀបទៅនឹងរបៀបដែលសត្វមួយបានលេបអ្វីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ផែនដីបានបើក និងកប់»
ដាថាន
នេះជាមន្ត្រីដែលបានបះបោរប្រឆាំងនឹងលោកម៉ូសេ។
រួចគ្របលើបក្សពួករបស់អ័ប៊ីរ៉ាមទៀតផង
អ្នកដើរតាមអ័ប៊ីរ៉ាមក៏ត្រូវបានគេបញ្ចុះផងដែរ
នៅពេលដែលផែនដីបើកនិងកប់ដាថាន។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយវាក៏គ្របដណ្តប់អ្នកដើរតាមអ័ប៊ីរ៉ាម» ឬ
«ហើយវាក៏កប់អ្នកដើរតាមអ័ប៊ីរ៉ាម»
អ័ប៊ីរ៉ាម
នេះជាមន្ត្រីដែលបានបះបោរប្រឆាំងនឹងលោកម៉ូសេ។
ភ្លើងឆេះឡើងក្នុងបក្សពួករបស់គេ អណ្តាតភ្លើងក៏ឆាបឆេះ មនុស្សអាក្រក់ទាំងនោះទៅ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយត្រូវបានសរសេរជាមួយគ្នា
ដើម្បីបញ្ជាក់ពីរបៀបដែលមនុស្សអាក្រក់ត្រូវបានសម្លាប់ ដោយភ្លើង។
Psalms 106:19
ពួកគេបានធ្វើរូបកូនគោនៅភ្នំហោរែប ហើយនាំគ្នាក្រាបថ្វាយបង្គំរូប ដែលធ្វើពីលោហធាតុ
ព័ត៌មាននេះអាចត្រូវបានដាក់ជាថ្មីដូច្នេះវាច្បាស់ណាស់ថា រូបកូន
គោគឺជាលោហធាតុ។ ការបកប្រែរបៀបផ្សេងទៀត: «នៅភ្នំ
[illegible] នៃវាលរហោស្ថាន។
ពួកគេបានជំនួសសិរីល្អរបស់ព្រះជាម្ចាស់ដោយរូបគោ
នេះមានន័យថា ជំនួសឲ្យការថ្វាយបង្គំព្រះជាម្ចាស់ ពួកគេគោរពបូជារូបគោ។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានប្តូរការថ្វាយបង្គំសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដើម្បីគោរពបូជារូបគោ»
សិរីល្អនៃព្រះជាម្ចាស់
ត្រង់នេះព្រះជាម្ចាស់ សំដៅទៅលើសិរីរុងរឿងរបស់ព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់ដ៏រុងរឿងរបស់ពួកគេ» ឬ
«ព្រះជាម្ចាស់ដែលរុងរឿង»
Psalms 106:22
ទឹកដីហាំ
នេះសំដៅទៅលើទឹកដីដែលកូនចៅរបស់ហាំរស់នៅ។ ការបកប្រែរបៀបផ្សេងទៀត:
«ទឹកដីដែលកូនចៅរបស់ហាំរស់នៅ»
ការគួរស្ញែងខ្លាច
«អ្វីៗដែលអស្ចារ្យ»
ដើម្បីបង្វែរ...ពីការបំផ្លាញដល់គេ
នៅទីនេះព្រះបាទដាវីឌមានបន្ទូលអំពីលោកម៉ូសេបញ្ចុះបញ្ចូលព្រះអម្ចាស់កុំឲ្យបំផ្លាញជនជាតិអ៊ីុស្រាអែ

generated on Wed Sep 10 16:16:32 2025

ដោយបង្វែរព្រះអង្គក្នុងការបំពាន។ ការបកប្រែរបៀបផ្សេងទៀត:
«បានឈរនៅចំពោះមុខព្រះអម្ចាស់ និងពួកអ៊ីុស្រាអែល
ហើយបានអង្វរដល់ព្រះអម្ចាស់កុំឲ្យបំផ្លាញពួកគេ»
Psalms 106:24
រអ៊ូរទាំ
«បានតូញតែ្ឋរ»
ព្រះបន្ទូលសន្យារបស់ព្រះអង្គ
នេះសំដៅទៅលើសេចក្ដីសន្យារបស់ព្រះអម្ចាស់ដែលថា៖
ព្រះអង្គនឹងអនុញ្ញាតឲ្យពួកគេកាន់កាប់ទឹកដីកាណានជាកម្មសិទ្ធិរបស់ពួកគេ។
Psalms 106:26
លើកព្រះហស្តរបស់ព្រះអង្គឡើង
ពាក្យ «របស់ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។ ដូចគ្នានេះផងដែរ
វាជាទម្លាប់ក្នុងការលើកដៃនៅពេលស្បថ។
កម្ចាត់កម្ចាយពូជពង្សរបស់គេ...នៅពាសពេញស្រុករបស់ជនជាតិដទៃ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយត្រូវបានប្រើជាមួយគ្នាសម្រាប់ការសង្កត់ន័យ។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយព្រះអង្គនឹងធ្វើឲ្យពូជពង្សរបស់ពួកគេរស់នៅក្នុងស្រុករបស់ជនជាតិដទៃ»
កម្ចាត់កម្ចាយ
នេះមានន័យថា ខ្ចាតខ្ចាយ ឬរាលដាលអ្វីមួយ។
Psalms 106:28
ថ្វាយទៅព្រះដែលគ្មានជីវិត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ការលះបង់ដែលពួកគេបានផ្តល់ដល់មនុស្សស្លាប់»
គ្រោះកាចក៏កើតឡើង
«គ្រោះកាចរាលដាល»
ធ្វើឲ្យព្រះអម្ចាស់ខ្ញាល់
«ព្រះអង្គខ្ញាល់»
Psalms 106:30
ក្រោយមក ភីនេហាសក៏ឈរឡើង ហើយធ្វើអន្តរាគមន៍
ភីនេហាសបានធ្វើអន្តរាគមន៍ក្នុងចំណោមប្រជាជន
ដោយដាក់ទណ្ឌកម្មពួកគេចំពោះអំពើបាបរបស់ពួកគេ។ នេះអាចបញ្ជាក់ច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«បន្ទាប់មកភីនេហាសបានក្រោកឡើងធ្វើអន្តរាគមន៍ក្នុងចំណោមប្រជាជន
ដោយសារតែអំពើបាបរបស់ពួកគេ»
ការនោះបានរាប់ជាសុចរិត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបានចាត់ទុកវាថា ជាអំពើសុចរិតមួយ»
Psalms 106:32
មេរីបា
នេះគឺជាកន្លែងមួយ។
មានទោសដោយសារតែពួកគេ
លោកម៉ូសេបានរងទុក្ខ ដោយសារអំពើបាបរបស់ប្រជាជន។ នៅទីនេះពាក្យថា
«ពួកគេ» គឺជាសព្វនាមសម្រាប់ប្រជាជន
និងជាសញ្ញាសម្គាល់ដែលសំដៅទៅលើអំពើបាបរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «រងទុក្ខដោយសារអំពើរបស់ពួកគេ»
តែគេបែរជាប្រព្រឹត្តច្របូកច្របល់ ជាមួយជនជាតិដទៃ
ហេព្រះបាទដាវីឌនិយាយអំពីមនុស្សដែលកំពុងរៀបការជាមួយស្ត្រីដែលមកពីជនជាតិ
ដទៃទៀតថា ជាការនិយាយលេងជាមួយពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែពួកគេលាយបញ្ចូលគ្នាក្នុងអាពាហ៍ពិពាហ៍ជាមួយប្រជាជាតិផ្សេងទៀត»
ជាការដែលត្រឡប់ជាអន្ទាក់ដល់គេ
រូបព្រះបានក្លាយជាអន្ទាក់របស់ពួកគេ។
Psalms 106:37
គេបានបង្ហូរឈាមមនុស្សដែលគ្មានទោស គឺជាឈាមកូនប្រុសកូនស្រីរបស់ពួកគេ
ឃ្លាដែលថា «បង្ហូរឈាម» គឺជាការពិពណ៌នាដែលប្រើសម្រាប់ «ការសម្លាប់»។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបានបង្ហូរឈាមមនុស្សដែលគ្មានទោស
នៅពេលពួកគេបានសម្លាប់កូនប្រុស និងស្រីរបស់ពួកគេ»
ដូច្នេះ គេបានធ្វើឲ្យខ្លួនមានសៅហ្មង ដោយសារអំពើដែលពួកគេប្រព្រឹត្ត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អំពើដែលពួកគេបានប្រព្រឹត្តធ្វើឲ្យគេស្មោកគ្រោក»
ក្នុងសកម្មភាពរបស់ពួកគេ ពួកគេដូចជាស្រីពេស្យា
នៅទីនេះព្រះបាទដាវីឌប្រៀបធៀបភាពមិនស្មោះត្រង់របស់ពួកគេទៅនឹងព្រះអម្ចាស់
ចំពោះភាពមិនស្មោះត្រង់របស់ស្រីពេស្យា។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិនស្មោះត្រង់នឹងព្រះអម្ចាស់ដូចស្រីពេស្យាទេ»
Psalms 106:40
សេចក្ដីក្រោធរបស់ព្រះអម្ចាស់ បានឆួលឡើងទាស់នឹងប្រជារាស្ត្ររបស់ព្រះអង្គ...ព្រះអង្គក៏ស្អប់ខ្ពើម
មរតករបស់ព្រះអង្គ
«ដូច្នេះព្រះអម្ចាស់ទ្រង់ព្រះពិរោធនឹងប្រជារាស្ត្ររបស់ព្រះអង្គ ហើយស្អប់
ខ្ពើមពួកគេ»
ព្រះអង្គបានប្រគល់គេទៅក្នុងកណ្តាប់ដៃជនជាតិដទៃ
ត្រង់នេះ «ដៃ» សំដៅទៅលើអំណាច ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានអនុញ្ញាតឲ្យជនជាតិ
ដទៃត្រួតត្រាពួកគេ»
អស់អ្នកដែលស្អប់ពួកគេ
«មនុស្សដែលស្អប់ពួកគេ»
Psalms 106:42
ហើយបង្ក្រាបគេ ឲ្យនៅក្រោមអំណាចរបស់ខ្លួន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សត្រូវរបស់ពួកគេបានបង្ខំពួកគេអោនចុះចូលនឹងអំណាចរបស់ពួកគេ»
គេបានធ្វើឲ្យខ្លួនឯងទាបថោក ដោយសារអំពើទុច្ចរិតរបស់ខ្លួន
នៅទីនេះឃ្លាដែលថា «ទាបថោក» មានន័យថា ត្រូវបំផ្លាញចោល។
ដូចគ្នានេះផងដែរ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «បាបរបស់ពួកគេបានបំផ្លាញពួកគេ»
Psalms 106:44
ទោះជាដូច្នេះក្តី
«នៅឡើយទេ» ឬ «សូម្បីតែអញ្ចឹង»។ សូមមើលពីរបៀបបកប្រែក្នុងជំពូក
១០៦:៨។
ទុក្ខព្រួយរបស់គេ
«ទុក្ខវេទនារបស់ពួកគេ» ឬ «ការរងទុក្ខរបស់ពួកគេ»
នឹកចាំ
ឃ្លាថា «នឹកចាំ» មានន័យថា ចាំអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត: «ចងចាំ»
ហើយសម្តែងព្រះហឫទ័យអាណិតអាសូរ
«ហើយព្រះអង្គមានការអាណិតអាសូរចំពោះពួកគេ»
ជ័យជម្នះរបស់ពួកគេ
«អ្នកចាប់ពួកគេ»។
នេះសំដៅទៅលើសត្រូវរបស់អ៊ីុស្រាអែលដែលបានចាប់ពួកគេជាឈ្លើយ។
អាណិតអាសូរដល់គេ
«ចេះអាណិតអាសូរពួកគេ»
Psalms 106:47
ព័ត៌មានទូទៅ:
នៅទីនេះជំពូក ១០៦:៤៨ គឺច្រើនជាងចុងបញ្ចប់នៃទំនុកនេះ។
នេះគឺជាសេចក្តីថ្លែងចុងក្រោយនៃសៀវភៅទី ៤
នៃទំនុកតម្កើងដែលចាប់ផ្តើមពីទំនុកតម្កើងជំពូក ៩០
និងបញ្ចប់ដោយទំនុកតម្កើងជំពូក ១០៦។
សូមលើកតម្កើងព្រះអម្ចាស់ ជាព្រះជាម្ចាស់នៃអ៊ីស្រាអែល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
សូមឲ្យប្រជាជនសរសើរតម្កើងព្រះអម្ចាស់ជាព្រះជាម្ចាស់នៃអ៊ីស្រាអែល»
ដល់ព្រះនាមដ៏បរិសុទ្ធរបស់ព្រះអង្គ
នៅទីនេះព្រះអម្ចាស់ត្រូវបានសំដៅដល់ដោយ «ព្រះនាមដ៏បរិសុទ្ធ» របស់ព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ទៅកាន់អ្នក»
ចាប់តាំងពីអស់កល្ប រហូតដល់អស់កល្បជានិច្ច
នេះសំដៅទៅលើភាពជ្រាលជ្រៅ និងមធ្យោបាយពីរសម្រាប់គ្រប់ពេលវេលា។
សូមមើលពីរបៀបបកប្រែក្នុងជំពូក ៤១:១៣។ ការបកប្រែរបៀបផ្សេងទៀត:
«ជារៀងរហូត»

generated on Wed Sep 10 16:16:32 2025

107 [1]ឱចូរអរព្រះគុណដល់ព្រះអម្ចាស់ ដ្បិតព្រះអង្គល្អ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។[2]ត្រូវឲ្យអស់អ្នកដែលព្រះអម្ចាស់ បានប្រោសលោះ ពោលដូច្នេះ គឺអស់អ្នកដែលព្រះអង្គបានប្រោសលោះ ឲ្យរួចពីកណ្តាប់ដៃរបស់បច្ចាមិត្ត។[3]ហើយបានប្រមូលមកពីទឹកដីទាំងប៉ុន្មាន គឺពីទិសខាងកើត ពីទិសខាងលិច ពីទិសខាងជើង និងពីទិសខាងត្បូង។
[4]ពួកគេបានដើរសាត់អណ្តែតនៅក្នុង ទីរហោស្ថានដ៏ហួតហែង រកទីក្រុងណានឹងស្នាក់អាស្រ័យ នៅមិនបានឡើយ។[5]ព្រលឹងគេក៏ហេវទៅ ដោយស្រេកឃ្លាន។[6]គ្រានោះ គេស្រែករកព្រះអម្ចាស់ ដោយសេចក្តីវេទនារបស់គេ ហើយព្រះអង្គក៏រំដោះគេឲ្យរួចពីទុក្ខលំបាក។[7]ព្រះអង្គបាននាំគេតាមផ្លូវត្រង់ រហូតទាល់តែគេចូលដល់ទីក្រុង ដែលអាស្រ័យនៅបាន។
[8]ត្រូវឲ្យគេអរព្រះគុណដល់ព្រះអម្ចាស់ ដោយព្រោះព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ និងដោយព្រោះការដ៏អស្ចារ្យ របស់ព្រះអង្គដល់មនុស្សជាតិ។[9]ដ្បិតព្រះអង្គប្រោសព្រលឹង ដែលស្រេកឲ្យបានស្កប់ ហើយព្រះអង្គចម្អែតព្រលឹងដែលឃ្លាន ដោយសេចក្តីល្អ។[10]អ្នកខ្លះអង្គុយនៅក្នុងទីងងឹត និងនៅក្នុងម្លប់នៃសេចក្តីស្លាប់ ជាអ្នកទោសដែលជាប់ក្នុងសេចក្តីវេទនា និងជាប់ច្រវាក់
[11]ដ្បិតគេបានបះបោរប្រឆាំង នឹងព្រះបន្ទូលរបស់ព្រះ ហើយបានមើលងាយដំបូន្មាន របស់ព្រះដ៏ខ្ពស់បំផុត។[12]ហេតុនេះ ព្រះអង្គក៏បន្ទាបចិត្តគេ ដោយការនឿយហត់ គេដួលចុះ ហើយគ្មានអ្នកណាជួយបានឡើយ។[13]ក្រោយមកពួកគេស្រែករកព្រះអម្ចាស់ ដោយសេចក្តីវេទនារបស់គេ ហើយព្រះអង្គក៏រំដោះគេឲ្យរួចពីទុក្ខលំបាក។
[14]ព្រះអង្គបាននាំគេចេញពីទីងងឹត និងម្លប់នៃសេចក្តីស្លាប់ ព្រមទាំងផ្តាច់ចំណងរបស់គេចេញ។[15]ត្រូវឲ្យគេអរព្រះគុណដល់ព្រះអម្ចាស់ ដោយព្រោះព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ និងដោយព្រោះការដ៏អស្ចារ្យរបស់ព្រះអង្គ ដល់មនុស្សជាតិ។[16]ដ្បិតព្រះអង្គបានទម្លាយទ្វារលង្ហិន ហើយបំបាក់រនុកដែក។
[17]ពួកគេខ្លះល្ងីល្ងើ ព្រោះតែអំពើបាប ដែលគេបានប្រព្រឹត្ត ហើយដោយព្រោះអំពើទុច្ចរិតរបស់គេ បណ្តាលឲ្យគេរងទុក្ខវេទនា។[18]ពួកគេស្អប់ខ្ពើមអាហារគ្រប់មុខ ហើយគេចូលទៅជិតទ្វារនៃសេចក្តីស្លាប់។[19]គ្រានោះ គេស្រែករកព្រះអម្ចាស់ ដោយសេចក្តីវេទនារបស់គេ ហើយព្រះអង្គក៏រំដោះគេឲ្យរួចពីទុក្ខលំបាក។
[20]ព្រះអង្គបានចាត់ព្រះបន្ទូលទៅប្រោសគេឲ្យជា ក៏រំដោះឲ្យគេរួចពីសេចក្តីវិនាស។[21]ត្រូវឲ្យគេអរព្រះគុណដល់ព្រះអម្ចាស់ ដោយព្រោះព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ និងដោយព្រោះការដ៏អស្ចារ្យរបស់ព្រះអង្គ ដល់មនុស្សជាតិ។[22]ត្រូវឲ្យគេថ្វាយយញ្ញបូជានៃការអរព្រះគុណ ហើយប្រកាសពីស្នាព្រះហស្តរបស់ព្រះអង្គ ដោយបទចម្រៀងយ៉ាងអរសប្បាយ។
[23]អ្នកខ្លះចុះនាវាដើរផ្លូវសមុទ្រ ប្រកបមុខរបរតាមមហាសាគរ។[24]ពួកគេឃើញកិច្ចការរបស់ព្រះអម្ចាស់ គឺការដ៏អស្ចារ្យរបស់ព្រះអង្គនៅក្នុងសមុទ្រ។
[25]ដ្បិតព្រះអង្គបានបញ្ជា នោះក៏កើតមានខ្យល់ព្យុះ ដែលបណ្តាលឲ្យរលកសមុទ្រកម្រើកឡើង។[26]រលកទាំងនោះផាត់ឡើងដល់ផ្ទៃមេឃ ក៏ធ្លាក់ចុះទៅវិញដល់ទីជម្រៅ សេចក្តីក្លាហានរបស់គេក៏រលាយ នៅក្នុងស្ថានភាពអាក្រក់។[27]ពួកគេ ឃ្លេងឃ្លោងចុះឡើង ដើរទទេរតទទោត ដូចមនុស្សស្រវឹង ហើយគេក៏ទាល់ប្រាជ្ញា។
[28]ក្រោយមក ពួកគេស្រែករកព្រះអម្ចាស់ ដោយសេចក្តីវេទនារបស់គេ ហើយព្រះអង្គក៏រំដោះគេឲ្យរួចពីទុក្ខលំបាក។[29]ព្រះអង្គធ្វើឲ្យព្យុះសង្ឃរានៅស្ងៀម ហើយធ្វើឲ្យរលកសមុទ្រស្ងប់។[30]ពេលនោះ គេមានចិត្តរីករាយ ដោយព្រោះរលកស្ងប់ ហើយព្រះអង្គក៏នាំគេទៅដល់ជម្រក ដែលគេប្រាថ្នាចង់ទៅ។
[31]ត្រូវឲ្យគេអរព្រះគុណដល់ព្រះអម្ចាស់ ដោយព្រោះព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ និងដោយព្រោះការដ៏អស្ចារ្យរបស់ព្រះអង្គដល់មនុស្សជាតិ។[32]ចូលឲ្យគេលើកតម្កើងព្រះអង្គ នៅក្នុងក្រុមជំនុំនៃប្រជាជន ហើយសរសើរតម្កើងព្រះអង្គ នៅក្នុងអង្គប្រជុំរបស់ពួកចាស់ទុំ។
[33]ព្រះអង្គធ្វើឲ្យទន្លេត្រឡប់ទៅជាទីរហោស្ថាន ឲ្យក្បាលទឹកប្រែទៅជាដីខ្សាច់[34]ឲ្យទឹកដីដែលមានផលផ្លែទៅជាដីប្រៃ ព្រោះតែអំពើអាក្រក់របស់អ្នកទីនោះ។[35]ព្រះអង្គធ្វើឲ្យទីរហោស្ថានទៅជាអាងទឹក ហើយដីស្ងួតហួតហែងទៅជាប្រភពទឹក។
[36]ព្រះអង្គឲ្យមនុស្សអត់ឃ្លានទៅរស់នៅទីនោះ ហើយគេសង់ទីក្រុងសម្រាប់អាស្រ័យនៅ។[37]គេធ្វើស្រែ និងធ្វើចម្ការទំពាំងបាយជូរ ហើយមានផលផ្លែចម្រើនឡើង។[38]ព្រះអង្គប្រទានពរឲ្យគេចម្រើនឡើងជាច្រើន ហើយព្រះអង្គមិនឲ្យហ្វូងសត្វ របស់គេថយចុះឡើយ។
[39]ពួកគេត្រូវថយចុះវិញ ហើយត្រូវអាប់ឱន ដោយមានគេសង្កត់សង្កិន ធ្វើទុក្ខបុកម្នេញ ហើយឲ្យមានទុក្ខព្រួយ។[40]ព្រះអង្គចាក់សេចក្តីមើលងាយទៅលើពួកអ្នកធំ ហើយធ្វើឲ្យគេដើរសាត់ព្រាត់ នៅក្នុងទីស្ងាត់ឈឹង ដែលឥតមានផ្លូវ
[41]ប៉ុន្តែ ព្រះអង្គលើកមនុស្សកម្សត់ទុគ៌តឡើង ឲ្យរួចពីសេចក្តីវេទនា ហើយធ្វើឲ្យគ្រួសាររបស់គេ មានគ្នាច្រើនដូចហ្វូងសត្វ។[42]មនុស្សទៀងត្រង់ឃើញដូច្នេះ គេមានចិត្តត្រេកអរ ហើយគ្រប់ទាំងមនុស្សទុច្ចរិតនឹងត្រូវបិទមាត់។[43]អ្នកណាដែលមានប្រាជ្ញា ត្រូវឲ្យអ្នកនោះយកចិត្តទុកដាក់ចំពោះ សេចក្តីទាំងនេះ ត្រូវឲ្យគេពិចារណាពីព្រះហឫទ័យសប្បុរសរបស់ព្រះអម្ចាស់។

Psalms 107:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច
«សេចក្តីស្រឡាញ់ស្មោះត្រង់របស់ព្រះអង្គចំពោះខ្ញុំនឹងមិនចេះចប់»
ព្រះអម្ចាស់ដែលបានប្រោសលោះ
«អ្នកដែលបានលោះ» គឺសំដៅទៅលើប្រជាជនដែលព្រះអម្ចាស់បានសង្គ្រោះ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលព្រះអម្ចាស់បានសង្គ្រោះ»
ពោលដូច្នេះ
«ប្រជាជននៃប្រជាជាតិនានាមិនគួរនិយាយថា តើព្រះរបស់ពួកគេនៅឯណា?»
តើព្រះរបស់ពួកគេនៅឯណា?
ប្រជាជននៃប្រជាជាតិដទៃទៀតប្រើសំនួរនេះ ដើម្បីចំអកប្រជាជនអ៊ីុស្រាអែល
និងបង្ហាញថា ពួកគេមិនបានឃើញព្រះអម្ចាស់ជួយពួកគេទេ។
សំណួរនេះអាចបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះរបស់អ្នកមិននៅទីនេះ ដើម្បីជួយអ្នកទេ»។
Psalms 115:3
ស្នាដៃដែលមនុស្សធ្វើ
ត្រង់នេះពាក្យថា «ដៃ» តំណាងឲ្យមនុស្សដែលធ្វើរូបព្រះ។
ការបកប្រែរបៀបផ្សេងទៀត: «របស់ដែលមនុស្សបានបង្កើត»
Psalms 115:5
រូបទាំងនោះមានមាត់
រូបព្រះមិនមានមាត់ ភ្នែក ត្រចៀក ឬច្រមុះពិតទេ។
ផ្ទុយទៅវិញមនុស្សធ្វើឲ្យពួកគេមានរាង ដូចមាត់ ភ្នែក ត្រចៀក និងច្រមុះ។
អ្នកនិពន្ធកំពុងសង្កត់ន័យថា រូបព្រះទាំងនេះពិតជាមិនមានជីវិតទេ។
អ្នកអាចធ្វើឲ្យច្បាស់នូវព័ត៌មានដែលបង្កប់ន័យ។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបានផ្តល់មាត់ដល់រូបព្រះទាំងនោះ» (សូមមើល:figs-explicit)
Psalms 115:7
រូបទាំងនោះមានដៃ
រូបព្រះមិនមានដៃ ជើង ឬមាត់ពិតទេ។
ផ្ទុយទៅវិញមនុស្សធ្វើឲ្យពួកគេមានរាងដូចដៃ ជើង និងមាត់។
អ្នកនិពន្ធកំពុងសង្កត់ន័យថា រូបព្រះទាំងនេះពិតជាមិនមានជីវិតទេ។
អ្នកអាចធ្វើឲ្យព័ត៌មានខាងក្នុងនេះច្បាស់លាស់។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបានផ្តល់ដៃដល់រូបព្រះទាំងនោះ»
ប៉ុន្តែមិនមានអារម្មណ៍
«ប៉ុន្តែដៃទាំងនោះមិនមានអារម្មណ៍ទេ»
ពួកអ្នកដែលធ្វើ អស់អ្នកដែលទុកចិត្ត នឹងរូបទាំងនោះ នឹងបានដូចជារូបទាំងនោះដែរ
អ្នកដែលធ្វើ និងគោរពបូជារូបព្រះក្លាយទៅជាគ្មានជីវិត
និងគ្មានអំណាចដូចរូបព្រះទាំងនោះ។
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលធ្វើឲ្យពួកគេក្លាយជាមនុស្សគ្មានជីវិត
ដូចពួកគេគ្រប់គ្នាដែលទុកចិត្តលើពួកគេ»
Psalms 115:9
អ៊ីស្រាអែលអើយ ចូរទុកចិត្តដល់ព្រះអម្ចាស់
ពាក្យថា «អ៊ីុស្រាអែល» តំណាងឲ្យប្រជាជនអ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអ៊ីុស្រាអែលអើយ
ចូរទុកចិត្តលើព្រះអម្ចាស់»
ជំនួយ និងជាខែលរបស់អ្នក
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ដូចជាព្រះអង្គជាខែល
ព្រោះព្រះអង្គការពារប្រជាជនរបស់ព្រះអង្គដូចជាខែលការពារពួកគេពីគ្រោះថ្នាក់។
ការបកប្រែរបៀបផ្សេងទៀត: «ម្នាក់ដែលជួយអ្នក និងការពារអ្នក»
ពួកវង្សអើរ៉ុន
នៅទីនេះពាក្យ «ពួកវង្ស» តំណាងឲ្យគ្រួសារ ឬកូនចៅ។

generated on Wed Sep 10 16:16:32 2025

ឃ្លានេះសំដៅទៅលើពួកសង្ឃដែលជាកូនចៅរបស់អើរ៉ុន។
ការបកប្រែរបៀបផ្សេងទៀត: «ពួកវង្សរបស់លោកអើរ៉ុន» ឬ «ពួកសង្ឃ»

Psalms 115:12

បាននឹកចាំពីយើង
«បានយកចិត្តទុកដាក់ដល់ពួកយើង»
ពួកវង្សអ៊ីស្រាអែល
នេះសំដៅទៅលើប្រជាជនអីុស្រាអែលដែលជាកូនចៅរបស់យ៉ាកុបដែលត្រូវបានគេហៅថា
អីុស្រាអែលផងដែរ។ ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអីុស្រាអែល»
ពួកវង្សអើរ៉ុន
នេះសំដៅទៅលើពួកសង្ឃដែលជាកូនចៅរបស់អើរ៉ុន។
ការបកប្រែរបៀបផ្សេងទៀត: «ពួកវង្សរបស់អើរ៉ុន» ឬ «ពួកសង្ឃ»
ទាំងអ្នកតូច ទាំងអ្នកធំ
ទាំងតូច ទាំងធំ។ អាចមានន័យថា នេះសំដៅទៅលើ ១) ទៅនឹងស្ថានភាពសង្គម ឬ
២) ទៅតាមអាយុ។
ក្នុងករណីណាក៏ដោយចុងបំផុតទាំងពីរតំណាងឲ្យមនុស្សគ្រប់គ្នា
ដោយមិនគិតពីអាយុ ឬស្ថានភាពសង្គម។
សូមព្រះអម្ចាស់ប្រទានពរ ឲ្យអ្នករាល់គ្នាបានចម្រើនឡើង
អ្នកនិពន្ធកំពុងនិយាយអំពីចំនួនកុមារដែលប្រជាជនអីុស្រាអែលនឹងមាន។
ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះអម្ចាស់ប្រទានពរ ឲ្យអ្នករាល់គ្នាបានចម្រើន
ឡើង»
ទាំងអ្នករាល់គ្នា ទាំងកូនចៅរបស់អ្នករាល់គ្នា
ទាំងកូនៗ និងកូនចៅរបស់កូនចៅអ្នក។ អ្នកនិពន្ធបានបញ្ជាក់ថា ការស្នើសុំរបស់គេ
សម្រាប់កុមារបន្ថែមទៀត មិនត្រឹមតែសម្រាប់មនុស្សជំនាន់បច្ចុប្បន្នប៉ុណ្ណោះទេ
ប៉ុន្តែសម្រាប់កូនចៅរបស់ពួកគេផងដែរ។

Psalms 115:15

សូមឲ្យអ្នកបានពរពីព្រះអម្ចាស់ ជាព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សូមព្រះអម្ចាស់ដែលបានបង្កើតផ្ទៃមេឃ និងផែនដីប្រទានពរដល់អ្នក»
ផែនដី ព្រះអង្គបានប្រទានដល់មនុស្សជាតិ
នេះមិនមានន័យថា ផែនដីមិនមែនជាកម្មសិទ្ធិរបស់ព្រះអម្ចាស់ទេ
ប៉ុន្តែព្រះអង្គបានប្រគល់ផែនដីដល់មនុស្សជាតិជាទីជម្រកវិញ។

Psalms 115:17

មនុស្សស្លាប់
គុណនាម «ស្លាប់» អាចត្រូវបានបកប្រែជាមួយឃ្លានាម។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សស្លាប់»
ហើយអ្នកណាដែលចុះទៅស្ថានស្ងាត់ឈឹង ក៏មិនចេះសរសើរតម្កើងព្រះអង្គដែរ
ឃ្លាស្របគ្នានេះមានអត្ថន័យស្រដៀងនឹងឃ្លាមុនវា។
កិរិយាស័ព្ទអាចត្រូវបានផ្គត់ផ្គង់ពីឃ្លាមុននោះ ដើម្បីធ្វើឲ្យអត្ថន័យច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ហើយកុំឲ្យអ្នកណាដែលនៅស្ងៀមសរសើរតម្កើងព្រះអម្ចាស់»
ហើយអ្នកណាដែលចុះទៅស្ថានស្ងាត់ឈឹង ក៏មិនចេះសរសើរតម្កើងព្រះអង្គដែរ
អ្នកនិពន្ធនិយាយពីផ្នូរ
ឬកន្លែងនៃការស្លាប់ជាកន្លែងស្ងាត់ដែលគ្មាននរណាអាចនិយាយបាន។
នេះគឺជាការលួងលោមសម្រាប់ការស្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយក៏មិនត្រូវឲ្យអ្នកណាម្នាក់ទៅកន្លែងស្លាប់ដែរ»
ប៉ុន្តែ យើង
ពាក្យថា «យើង» សំដៅទៅលើប្រជាជនអីុស្រាអែលដែលនៅរស់នៅឡើយ។

---

116 [1]ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ព្រោះព្រះអង្គទ្រង់ព្រះសណ្ដាប់សំឡេងខ្ញុំ និងពាក្យដែលខ្ញុំទូលអង្វរ។[2]ដោយព្រោះព្រះអង្គបានផ្អៀងព្រះកាណ៌ស្ដាប់ខ្ញុំ ដូច្នេះ ខ្ញុំនឹង
អំពាវនាវរកព្រះអង្គអស់មួយជីវិត។
[3]អន្ទាក់នៃសេចក្ដីស្លាប់បាននៅជុំវិញខ្ញុំ ការឈឺចាប់នៃស្ថានឃុំព្រលឹងមនុស្សស្លាប់ បានរឹតរួតខ្ញុំ ខ្ញុំរងទុក្ខវេទនា ហើយថប់បារម្ភ។[4]ខ្ញុំបានអំពាវនាវ ដល់ព្រះនាមព្រះអម្ចាស់
ថា៖ «ឱព្រះអម្ចាស់អើយ ទូលបង្គំសូមអង្វរ សូមរំដោះព្រលឹងទូលបង្គំផង»។
[5]ព្រះអម្ចាស់ ប្រកបដោយព្រះហឫទ័យ ប្រណីសន្ដោស ហើយសុចរិត ព្រះនៃយើងប្រកបដោយ ព្រះហឫទ័យមេត្តា ករុណា។[6]ព្រះអម្ចាស់ជួយការពារមនុស្សឆោតល្ងង់
កាលខ្ញុំត្រូវគេបន្ទាបបន្ថោក ព្រះអង្គបានសង្គ្រោះខ្ញុំ។
[7]ឱព្រលឹងខ្ញុំអើយ! ចូរបែរមករក ទីសម្រាករបស់ខ្លួនវិញទៅ ដ្បិតព្រះអម្ចាស់បានប្រព្រឹត្តនឹងអ្នក ដោយព្រះគុណហើយ។[8]ដ្បិតព្រះអង្គបានរំដោះព្រលឹងខ្ញុំឲ្យរួចពីស្លាប់ ជូត
ទឹកភ្នែកឲ្យខ្ញុំហើយការពារជើងខ្ញុំមិនឲ្យជំពប់ដួល។
[9]ខ្ញុំនឹងដើរនៅចំពោះព្រះអម្ចាស់ នៅក្នុងទឹកដីរបស់មនុស្សរស់។[10]ខ្ញុំបានជឿ ទោះជាពេលដែលខ្ញុំពោលថា៖«ខ្ញុំមាន ទុក្ខព្រួយខ្លាំងណាស់»។[11]ខ្ញុំបានពោលទាំងប្រញាប់
ប្រញាល់ថា «មនុស្សទាំងអស់សុទ្ធតែភូតកុហក»។
[12]តើខ្ញុំនឹងតបស្នងអ្វីដល់ព្រះអម្ចាស់ ចំពោះអស់ទាំងព្រះគុណ ដែលទ្រង់បានផ្ដល់មកខ្ញុំ?[13]ខ្ញុំនឹងលើកពែងនៃការសង្គ្រោះឡើង ហើយអំពាវនាវរកព្រះនាមព្រះអម្ចាស់។[14]ខ្ញុំ
នឹងលាបំណន់របស់ខ្ញុំចំពោះព្រះអម្ចាស់ នៅចំពោះមុខប្រជាជនទាំងប៉ុន្មាន របស់ព្រះអង្គ។[15]ការស្លាប់របស់ពួកអ្នកបរិសុទ្ធនៃព្រះអម្ចាស់មានតម្លៃវិសេសណាស់ នៅចំពោះ
ព្រះនេត្ររបស់ព្រះអង្គ។
[16]ព្រះអម្ចាស់អើយ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ កូនរបស់ស្ត្រីជាអ្នកបម្រើរបស់ព្រះអង្គ ព្រះអង្គបានស្រាយចំណងរបស់ទូលបង្គំ
ហើយ។[17]ទូលបង្គំនឹងថ្វាយយញ្ញបូជា នៃការអរព្រះគុណដល់ព្រះអង្គ ហើយអំពាវនាវរកព្រះនាមព្រះអម្ចាស់។
[18]ខ្ញុំនឹងលាបំណន់របស់ខ្ញុំចំពោះព្រះអម្ចាស់ នៅចំពោះមុខប្រជាជនទាំងប៉ុន្មានរបស់ព្រះអង្គ[19]នៅក្នុងព្រះលាននៃព្រះដំណាក់ របស់ព្រះអម្ចាស់ នៅកណ្ដាលអ្នក ក្រុង
យេរូសាឡិមអើយ។ សរសើរព្រះអម្ចាស់។

Psalms 116:1

ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ព្រះអង្គទ្រង់ព្រះសណ្ដាប់សម្លេងខ្ញុំ និងពាក្យដែលខ្ញុំទូលអង្វរ
នៅទីនេះពាក្យ «សម្លេង» តំណាងឲ្យមនុស្សដែលកំពុងនិយាយ។ ឃ្លា
«ការអង្វររបស់ខ្ញុំសុំសេចក្ដីមេត្តាករុណា» ពន្យល់ពីអ្វីដែលគេកំពុងនិយាយ
ហើយអាចត្រូវបានបកប្រែដោយឃ្លា។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គ
ព្រះសណ្ដាប់សម្លេងខ្ញុំ ពេលខ្ញុំទូលអង្វរព្រះអង្គសុំសេចក្ដីមេត្តាករុណា»

Psalms 116:3

ព័ត៌មានទូទៅ:
អ្នកដែលតែងទំនុកនេះបន្តនិយាយ។
អន្ទាក់នៃសេចក្ដីស្លាប់បាននៅជុំវិញខ្ញុំ
អ្នកនិពន្ធនិយាយពីសេចក្ដីស្លាប់ហាក់ដូចជាមនុស្សដែលអាចចាប់គាត់ហើយចងគាត់ដោយខ្សែបាន។
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១៨:៤។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំមានអារម្មណ៍ថា ខ្ញុំជិតស្លាប់»
ការឈឺចាប់នៃស្ថានឃុំព្រលឹងមនុស្សស្លាប់បានរឹតរួតខ្ញុំ
អ្នកនិពន្ធនិយាយអំពី «ស្ថានឃុំព្រលឹង» កន្លែងនៃមនុស្សស្លាប់
ហាក់ដូចជាមនុស្សដែលអាចជាប់អន្ទាក់របស់គេ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំត្រៀមចូលផ្នូរ»
បានអំពាវនាវ ដល់ព្រះនាមព្រះអម្ចាស់
ត្រង់នេះពាក្យ «ព្រះនាម» តំណាងឲ្យព្រះអម្ចាស់ផ្ទាល់។
ការបកប្រែរបៀបផ្សេងទៀត: «បានអំពាវនាវព្រះអម្ចាស់»
សូមរំដោះព្រលឹងទូលបង្គំផង
នៅទីនេះពាក្យ «ជីវិត» តំណាងឲ្យមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ជួយសង្គ្រោះទូលបង្គំ» ឬ «រក្សាទូលបង្គំពីការស្លាប់»

Psalms 116:5

ព័ត៌មានទូទៅ:
អ្នកនិពន្ធបន្តសរសើរតម្កើងព្រះអម្ចាស់ក្នុងបទចម្រៀងនេះនៅតែបន្តនិយាយ។
មនុស្សឆោតល្ងង់
នេះសំដៅទៅលើមនុស្សដែលគ្មានបទពិសោធន៍ ឬមិនអាចថែទាំខ្លួនឯង។

generated on Wed Sep 10 16:16:32 2025

គុណនាមអាចត្រូវបានបកប្រែជាឃ្លានាម។ ការបកប្រែរបៀបផ្សេងទៀត:
«អស់អ្នកដែលឆោតល្ងង់» ឬ «អស់អ្នកដែលអស់សង្ឃឹម»
កាលខ្ញុំត្រូវគេបន្ទាបបន្ដោក
អ្នកនិពន្ធនិយាយអំពីការបន្ទាបខ្លួនដូចជាស្ថិតនៅក្នុងឋានៈទាប។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំអស់សង្ឃឹម»
Psalms 116:7
ព័ត៌មានទូទៅ:
អ្នកដែលតែងទំនុកនេះបន្ដនិយាយ។
ឱព្រលឹងខ្ញុំអើយ! ចូរបែរមករក ទីសម្រាករបស់ខ្លួនវិញទៅ
អ្នកនិពន្ធនិយាយអំពីការមានសន្តិភាពនិងទំនុកចិត្ត
ហាក់ដូចជាវាជាកន្លែងដែលព្រលឹងរបស់គេអាចសម្រាកបាន។ ពាក្យ «ព្រលឹង»
តំណាងឲ្យមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំអាចសម្រាកដោយសន្តិភាពម្ដងទៀត»
ព្រះអង្គបានរំដោះព្រលឹងខ្ញុំឲ្យរួចពីស្លាប់
ត្រង់នេះពាក្យ «ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។ ពាក្យ «ជីវិត»
តំណាងឲ្យមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានសង្គ្រោះខ្ញុំឲ្យរួចពីសេចក្ដីស្លាប់» ឬ «ព្រះអង្គបានការពារខ្ញុំពីការស្លាប់»
តទឹកភ្នែកឲ្យខ្ញុំ
ឃ្លាពាក្យសម្ដីអាចត្រូវបានផ្គត់ផ្គង់ពីឃ្លាមុន ដើម្បីឲ្យអត្ថន័យច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានជួយសង្គ្រោះភ្នែកខ្ញុំពីទឹកភ្នែក» ឬ
«ព្រះអង្គបានការពារខ្ញុំពីការយំ»
ជើងខ្ញុំមិនឲ្យជំពប់ដួល
ឃ្លាពាក្យសម្ដីអាចត្រូវបានផ្គត់ផ្គង់ពីឃ្លាមុន ដើម្បីឲ្យអត្ថន័យច្បាស់។
ជើងនៅទីនេះតំណាងឲ្យមនុស្ស។
ការជំពប់ដួលនៅទីនេះប្រហែលជាតំណាងឲ្យការសម្លាប់ដោយសត្រូវរបស់គេ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានជួយសង្គ្រោះខ្ញុំពីការជំពប់ដួល» ឬ
«ព្រះអង្គបានការពារខ្ញុំពីការសម្លាប់ដោយសត្រូវរបស់ខ្ញុំ»
Psalms 116:9
ព័ត៌មានទូទៅ:
អ្នកដែលតែងទំនុកនេះបន្ដនិយាយ។
នៅក្នុងទឹកដីរបស់មនុស្សរស់
«នៅក្នុងពិភពលោកនេះដែលមនុស្សនៅរស់»។ នេះគឺផ្ទុយពីកន្លែងស្លាប់។
ខ្ញុំមានទុក្ខព្រួយខ្លាំងណាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំរងទុក្ខយ៉ាងខ្លាំង» ឬ «មនុស្សធ្វើបាបខ្ញុំខ្លាំងណាស់»
ខ្ញុំបានពោលទាំងប្រញាប់ប្រញាល់
«ខ្ញុំនិយាយលឿនពេក» ឬ «ខ្ញុំនិយាយដោយមិនពិចារណា»
មនុស្សទាំងអស់សុទ្ធតែភូតកុហក
«មនុស្សគ្រប់រូបគឺជាអ្នកកុហក» ឬ «មនុស្សទាំងអស់គឺជាអ្នកកុហក»។
Psalms 116:12
ព័ត៌មានទូទៅ:
អ្នកដែលបង្កើតបទចម្រៀងនេះនៅតែបន្ដនិយាយ។
តើខ្ញុំនឹងតបស្នងអ្វីដល់ព្រះអម្ចាស់...ផ្ដល់មកខ្ញុំ
អ្នកនិពន្ធសួរសំណួរឈានមុខគេនេះដើម្បីណែនាំអំពីរបៀបដែលគាត់នឹងឆ្លើយតប
ចំពោះអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់គាត់។ សំណួរនេះអាចបកប្រែជាឃ្លា។
ការបកប្រែរបៀបផ្សេងទៀត: «នេះជារបៀបដែលខ្ញុំនឹងសងដល់ព្រះអម្ចាស់...ផ្ដល់
មកខ្ញុំ»។
ខ្ញុំនឹងលើកពែងនៃការសង្គ្រោះឡើង
នេះប្រហែលជាការនិយាយអំពីការថ្វាយភេសជ្ជៈដែលជាការលះបង់ដែលទាក់ទងនឹងការចាក់ស្រានៅលើអ
ហើយអ្នកនិពន្ធនឹងផ្ដល់ជាការឆ្លើយតបចំពោះព្រះអម្ចាស់ដែលជួយសង្គ្រោះគាត់។
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានធ្វើឲ្យច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំនឹងថ្វាយតង្វាយជូនព្រះអម្ចាស់
ព្រោះព្រះអង្គបានសង្គ្រោះខ្ញុំ»
អំពាវនាវរកព្រះនាមព្រះអម្ចាស់
ត្រង់នេះពាក្យ «ព្រះនាម» តំណាងឲ្យព្រះអម្ចាស់ផ្ទាល់។
ការបកប្រែរបៀបផ្សេងទៀត: «អំពាវនាវដល់ព្រះអម្ចាស់»
ការស្លាប់របស់ពួកអ្នកបរិសុទ្ធនៃព្រះអម្ចាស់មានតម្លៃវិសេសណាស់ នៅចំពោះព្រះនេត្ររបស់ព្រះអង្គ
ពាក្យថា «វិសេស» នៅទីនេះមិនមានន័យថា
ព្រះអម្ចាស់ឲ្យតម្លៃដល់ការស្លាប់របស់ប្រជាជនបរិសុទ្ធរបស់ព្រះអង្គនោះទេ ប៉ុន្តែថា
ការស្លាប់របស់ពួកបរិសុទ្ធរបស់ព្រះអង្គមានតម្លៃណាស់ ចំពោះព្រះអង្គ
និងធ្វើឲ្យព្រះអង្គព្រួយព្រះហឫទ័យ។ ឃ្លាដែលថា «នៅចំពោះព្រះនេត្រ»
តំណាងឲ្យការប្រព្រឹត្តរបស់ព្រះអម្ចាស់ចំពោះអ្វីដែលព្រះអង្គបានឃើញ។
អត្ថន័យពេញលេញនៃឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ចាត់ទុកការស្លាប់របស់ប្រជាជនបរិសុទ្ធរបស់ព្រះអង្គថា
ជាអ្វីៗដែលមានតម្លៃវិសេសណាស់»
Psalms 116:16
ព័ត៌មានទូទៅ:
អ្នកដែលតែងទំនុកនេះបន្ដនិយាយ។
កូនរបស់ស្ត្រីជាអ្នកបម្រើរបស់ព្រះអង្គ
នេះទំនងជាសេចក្ដីយោងទៅម្ដាយរបស់អ្នកនិពន្ធ ហើយបង្ហាញថា
នាងគោរពប្រណិប័តន៍ព្រះអម្ចាស់យ៉ាងស្មោះត្រង់។
អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដូចជាម្ដាយរបស់ខ្ញុំ»
ព្រះអង្គបានស្រាយចំណងរបស់ទូលបង្គំហើយ
អ្នកនិពន្ធនិយាយអំពីគ្រោះថ្នាក់នៃការស្លាប់
ដូចជាគាត់ត្រូវបានគេដាក់ច្រវាក់នៅក្នុងពន្ធនាគារ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានសង្គ្រោះទូលបង្គំពីសេចក្ដីស្លាប់»
ការថ្វាយយញ្ញបូជា នៃការអរព្រះគុណ
«ការលះបង់ ដើម្បីបង្ហាញពីការអរព្រះគុណរបស់ទូលបង្គំ»
នឹងអំពាវនាវរកព្រះនាមព្រះអម្ចាស់
ត្រង់នេះពាក្យ «ព្រះនាម» តំណាងឲ្យព្រះអម្ចាស់ផ្ទាល់។
ការបកប្រែរបៀបផ្សេងទៀត: «នឹងអំពាវនាវរកព្រះអម្ចាស់»
Psalms 116:18
ព័ត៌មានទូទៅ:
អ្នកដែលបង្កើតបទចម្រៀងនេះនៅតែបន្ដនិយាយ។
ខ្ញុំនឹងលាបំណន់...ប្រជាជនទាំងប៉ុន្មានរបស់ព្រះអង្គ
បកប្រែខនេះ តាមរបៀបដែលអ្នកបានបកប្រែ ១១៦: ១២។
នៅក្នុងព្រះលាននៃព្រះដំណាក់ របស់ព្រះអម្ចាស់
ពាក្យថា «ផ្ទះ» គឺសំដៅទៅលើព្រះដំណាក់របស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងទីធ្លានៃព្រះដំណាក់របស់ព្រះអម្ចាស់»
នៅកណ្ដាលអ្នក ក្រុងយេរូសាឡឹមអើយ
អ្នកនិពន្ធនិយាយពី ក្រុងយេរូសាឡឹម ដូចជាមនុស្សម្នាក់។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្រុងយេរូសាឡឹម»

117 [1]ជនជាតិទាំងឡាយអើយ ចូរសរសើរតម្កើងព្រះអម្ចាស់ ប្រជារាស្ត្រទាំងប៉ុន្មានអើយ ចូរលើកតម្កើងព្រះអង្គ។[2]ដ្បិតព្រះអង្គមានព្រះហឫទ័យ មេត្តាករុណាចំពោះ
យើងពន់ពេកក្រៃ ព្រះអម្ចាស់មានព្រះហឫទ័យស្មោះស្ម័គ្រ ចំពោះយើងរហូត។ សរសើរតម្កើងព្រះអម្ចាស់។

Psalms 117:1
ព័ត៌មានទូទៅ:
ព័ត៌មានទូទៅ: លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ដ្បិតព្រះអង្គ
«ពីព្រោះព្រះអង្គ»
ដ្បិតព្រះអង្គមានព្រះហឫទ័យ មេត្តាករុណាចំពោះយើង
«ដ្បិតព្រះអង្គមានព្រះហឫទ័យ មេត្តាករុណាចំពោះយើងគឺអស្ចារ្យណាស់»
រហូត
«ស្ថិតស្ថេរជារៀងរហូត»។

generated on Wed Sep 10 16:16:32 2025

118 [1]ចូរអរព្រះគុណដល់ព្រះអម្ចាស់ ដ្បិតព្រះអង្គល្អព្រះ ហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។[2]ចូរឲ្យអ៊ីស្រាអែលពោលថា៖ «ព្រះហឫទ័យ
សប្បុរសរបស់ព្រះអង្គស្ថិតស្ថេរអស់កល្បជានិច្ច»។
[3]ចូរឲ្យពូជពង្សរបស់លោកអើរ៉ុនពោលថា៖ «ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច»។[4]ចូរឲ្យអស់អ្នកដែលកោតខ្លាចព្រះអម្ចាស់ ពោលថា៖
«ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច»។
[5]ខ្ញុំបានអំពាវនាវដល់ព្រះអម្ចាស់ ក្នុងសេចក្ដីវេទនារបស់ខ្ញុំ ព្រះអម្ចាស់បានឆ្លើយតបមកខ្ញុំ ហើយបានដោះខ្ញុំឲ្យមានសេរីភាព។[6]ព្រះអម្ចាស់កាន់ខាងខ្ញុំ នោះខ្ញុំនឹងមិនខ្លាចអ្វី
ឡើយ តើមនុស្សអាចធ្វើអ្វីដល់ខ្ញុំបាន?[7]ព្រះអម្ចាស់កាន់ខាងខ្ញុំ ហើយព្រះអង្គជាជំនួយរបស់ខ្ញុំ នោះខ្ញុំនឹងឃើញជ័យជម្នះឈ្នះលើ អស់អ្នកដែលស្អប់ខ្ញុំ។
[8]ស៊ូពឹងជ្រកក្នុងព្រះអម្ចាស់ ជាជាងទុកចិត្តដល់មនុស្ស។[9]ស៊ូពឹងជ្រកក្នុងព្រះអម្ចាស់ ជាជាងទុកចិត្តដល់ពួកអ្នកធំ។
[10]ជាតិសាសន៍ទាំងប៉ុន្មានបានឡោមព័ទ្ធខ្ញុំ តែក្នុងព្រះនាមព្រះអម្ចាស់ ខ្ញុំនឹងបំផ្លាញគេចេញ។[11]គេបានឡោមព័ទ្ធខ្ញុំ បានឡោមព័ទ្ធខ្ញុំគ្រប់ទិស តែក្នុងព្រះនាមព្រះអម្ចាស់ ខ្ញុំ
នឹងបំផ្លាញគេចេញ។[12]គេបានឡោមព័ទ្ធខ្ញុំដូចឃ្មុំ តែគេត្រូវរលត់ទៅ ដូចភ្លើងដែលឆេះបន្លា ក្នុងព្រះនាមព្រះអម្ចាស់ ខ្ញុំនឹងបំផ្លាញគេចេញ។
[13]ពួកគេបានច្រានខ្ញុំយ៉ាងខ្លាំង ដើម្បីឲ្យខ្ញុំដួល តែព្រះអម្ចាស់បានជួយខ្ញុំ។[14]ព្រះអម្ចាស់ជាកម្លាំង និងជាបទចម្រៀងរបស់ខ្ញុំ ព្រះអង្គបានត្រឡប់ជាការសង្គ្រោះរបស់ខ្ញុំ។
[15]នៅក្នុងជំរំរបស់មនុស្សសុចរិត មានចម្រៀងយ៉ាងសប្បាយរីករាយ អំពីការសង្គ្រោះ គឺព្រះហស្តស្តាំនៃព្រះអម្ចាស់សម្តែងឥទ្ធិឫទ្ធិ។[16]ព្រះហស្តស្តាំនៃព្រះអម្ចាស់បានថ្កើង
ឡើង ព្រះហស្តស្តាំនៃព្រះអម្ចាស់សម្តែងឥទ្ធិឫទ្ធិ។
[17]ខ្ញុំនឹងមិនស្លាប់ទេ គឺខ្ញុំនឹងរស់នៅ ហើយរៀបរាប់អំពីស្នាព្រះហស្តនៃព្រះអម្ចាស់។[18]ព្រះអម្ចាស់បានវាយផ្ចាលខ្ញុំយ៉ាងខ្លាំង តែមិនបានបណ្តោយឲ្យខ្ញុំស្លាប់ទេ។
[19]សូមបើកទ្វារនៃសេចក្ដីសុចរិតឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំបានចូលទៅ ហើយអរព្រះគុណដល់ព្រះអម្ចាស់។[20]នេះហើយជាទ្វារនៃព្រះអម្ចាស់ មនុស្សសុចរិតនឹងចូលតាមទ្វារនេះ។
[21]ទូលបង្គំអរព្រះគុណព្រះអង្គ ដ្បិតព្រះអង្គបានឆ្លើយមកទូលបង្គំ ហើយបានត្រឡប់ជាការសង្គ្រោះរបស់ទូលបង្គំ។
[22]ថ្មដែលពួកជាងសង់ផ្ទះបានចោលចេញ នោះបានត្រឡប់ជាថ្មជ្រុងយ៉ាងឯក។[23]នេះហើយជាការដែលព្រះអម្ចាស់ធ្វើ ជាការដ៏អស្ចារ្យនៅភ្នែកនៃយើងខ្ញុំ។
[24]នេះគឺជាថ្ងៃដែលព្រះអម្ចាស់បានបង្កើត ចូរយើងមានអំណរ ហើយសប្បាយរីករាយក្នុងថ្ងៃនេះ។[25]ឱព្រះអម្ចាស់អើយ យើងខ្ញុំទូលអង្វរព្រះអង្គ សូមសង្គ្រោះយើងខ្ញុំ! ឱ
ព្រះអម្ចាស់អើយ យើងខ្ញុំទូលអង្វរព្រះអង្គ សូមប្រទានឲ្យយើងខ្ញុំមានជោគជ័យ!
[26]សូមឲ្យព្រះអង្គដែលយាងមកក្នុងព្រះនាម ព្រះអម្ចាស់ បានប្រកបដោយព្រះពរ យើងសូមឲ្យពរអ្នករាល់គ្នា ពីក្នុងដំណាក់របស់ព្រះអម្ចាស់។[27]ព្រះអម្ចាស់ជាព្រះ ព្រះអង្គ
បានប្រទានពន្លឺបំភ្លឺយើង ចូរចងយញ្ញបូជាភ្ជាប់នឹងស្នែងអាសនា ដោយខ្សែចុះ។[28]ព្រះអង្គជាព្រះនៃទូលបង្គំ ហើយទូលបង្គំនឹងអរព្រះគុណដល់ព្រះអង្គ ព្រះអង្គជាព្រះនៃ
ទូលបង្គំ ទូលបង្គំនឹងលើកតម្កើងព្រះអង្គ។
[29]ចូរអរព្រះគុណដល់ព្រះអម្ចាស់ ដ្បិតព្រះអង្គល្អ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។

Psalms 118:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។
ចូរអរព្រះគុណដល់ព្រះអម្ចាស់ ដ្បិតព្រះអង្គល្អ
«អរគុណព្រះអម្ចាស់ ដោយសារការល្អដែលព្រះអង្គធ្វើ»
ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គស្ថិតស្ថេរអស់កល្បជានិច្ច
«ព្រះអង្គស្រឡាញ់យើងដោយស្មោះត្រង់ជារៀងរហូត»
ចូរឲ្យអ៊ីស្រាអែលពោល
ពាក្យថា «អ៊ីស្រាអែល» តំណាងឲ្យប្រជាជនអ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យប្រជាជនអ៊ីស្រាអែលពោល»
Psalms 118:3
ចូរឲ្យពូជពង្សរបស់លោកអើរ៉ុនពោល
នៅទីនេះពាក្យ «ផ្ទះ» តំណាងឲ្យគ្រួសារ និងកូនចៅរបស់មនុស្សម្នាក់។
ឃ្លានេះសំដៅទៅលើពួកសង្ឃដែលជាពូជពង្សរបស់លោកអើរ៉ុន។
ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យពូជពង្សរបស់លោកអើរ៉ុនពោល» ឬ
«ចូរឲ្យសង្ឃពោល»
ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច
«ព្រះអង្គស្រឡាញ់យើងដោយស្មោះត្រង់ជារៀងរហូត»
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១១៨:១។
អស់អ្នកដែលកោតខ្លាចព្រះអម្ចាស់
«អស់អ្នកដែលគោរពកោតខ្លាចព្រះអម្ចាស់» ឬ
«អស់អ្នកដែលថ្វាយបង្គំព្រះអម្ចាស់»។
Psalms 118:5
ដោះខ្ញុំឲ្យមានសេរីភាព
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ជួយសង្គ្រោះលោកពីទុក្ខព្រួយដូចជាព្រះអម្ចាស់បាននាំអ្នកដែលជាប់ឃុំឃាំងឲ្យមានសេរីភាពដូច្នេះដែរ។
តើមនុស្សអាចធ្វើអ្វីដល់ខ្ញុំបាន?
អ្នកនិពន្ធសួរសំណួរវោហារសាស្ត្រនេះ ដើម្បីបញ្ជាក់ថា
គ្មានអ្វីដែលមនុស្សអាចធ្វើបាបលោកបានទេ ព្រោះព្រះអម្ចាស់នៅជាមួយលោក។
សំណួរនេះអាចត្រូវបានបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សមិនអាចធ្វើអ្វីដែលធ្វើបាបខ្ញុំបានទេ»។
ព្រះអម្ចាស់កាន់ខាងខ្ញុំ ហើយព្រះអង្គជាជំនួយរបស់ខ្ញុំ
ការនៅម្ខាងគឺជាការបញ្ចេញមតិបែបអសុរសដែលបង្ហាញថា មនុស្សនោះយល់ព្រម
ហើយនឹងជួយអ្នកដទៃ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងខ្ញុំហើយនឹងជួយខ្ញុំ»
នោះខ្ញុំនឹងឃើញជ័យជម្នះឈ្នះលើ អស់អ្នកដែលស្អប់ខ្ញុំ
នេះបញ្ជាក់ថា ព្រះអម្ចាស់គឺជាអ្នកដែលនឹងយកឈ្នះខ្មាំងសត្រូវរបស់អ្នកនិពន្ធ
រីឯអ្នកនិពន្ធវិញមើលទៅ។
អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងឃើញព្រះអម្ចាស់វាយឈ្នះអស់អ្នកដែលស្អប់ខ្ញុំ»
Psalms 118:8
ស៊ូពឹងជ្រកក្នុងព្រះអម្ចាស់
ព្រះជាម្ចាស់ត្រូវបានគេនិយាយ
ដូចជាព្រះអង្គជាជម្រកដែលជាកន្លែងដែលមនុស្សអាចត្រូវបានការពារ។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីស្វែងរកការការពារពីព្រះអម្ចាស់»
ស៊ូពឹងជ្រកក្នុងព្រះអម្ចាស់
ខនេះគឺស្របគ្នានឹងខមុន។ ព្រះជាម្ចាស់ត្រូវបានគេនិយាយ
ដូចជាព្រះអង្គជាជម្រកដែលជាកន្លែងដែលមនុស្សអាចត្រូវបានការពារ។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីស្វែងរកការការពារពីព្រះអម្ចាស់»
Psalms 118:10
ជាតិសាសន៍ទាំងប៉ុន្មាន
ត្រង់នេះពាក្យថា ជាតិសាសន៍ទាំងប៉ុន្មាន
តំណាងឲ្យកងទ័ពរបស់ប្រជាជាតិទាំងនោះ។ អ្នកនិពន្ធប្រើទិដ្ឋភាព ជាក់ស្តែង
ដើម្បីបញ្ជាក់ពីចំនួនកងទ័ពជាច្រើនដែលព័ទ្ធជុំវិញគាត់។
ការបកប្រែរបៀបផ្សេងទៀត: «កងទ័ពរបស់ប្រជាជាតិជាច្រើន»
ក្នុងព្រះនាមព្រះអម្ចាស់
ត្រង់នេះពាក្យ «ព្រះនាម» តំណាងឲ្យអំណាចរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដោយឫទ្ធានុភាពរបស់ព្រះអម្ចាស់»
ខ្ញុំនឹងបំផ្លាញគេចេញ
អ្នកនិពន្ធនិយាយអំពីការដែលលោកបានបំផ្លាញសត្រូវរបស់លោកតាមរយៈការជួយសង្គ្រោះរបស់ព្រះអម្ចាស់ ដែលជាការប្រៀបធៀបមួយ
ដូចជាគាត់កំពុងកាប់ពួកគេចោលដែលមនុស្សម្នាក់នឹងកាត់មែកឈើចោល។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានកម្ចាត់ពួកគេ»
គេបានឡោមព័ទ្ធខ្ញុំដូចឃ្មុំ តែគេត្រូវរលត់ទៅ
អ្នកនិពន្ធប្រៀបធៀបកងទ័ពសត្រូវទៅនឹងឃ្មុំមួយហ្វូង។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេព័ទ្ធជុំវិញខ្ញុំដូចជាឃ្មុំមួយហ្វូងកំពុងព័ទ្ធជុំវិញមនុស្ស»
ពួកគេនឹងបាត់ដូចភ្លើងដែលឆេះបន្លា
ដូចជាបន្លាស្ងួតឆេះចេញយ៉ាងឆាប់រហ័ស
ការវាយប្រហាររបស់កងទ័ពសត្រូវបានបញ្ចប់យ៉ាងលឿន។
ការបកប្រែរបៀបផ្សេងទៀត: «ការវាយប្រហាររបស់ពួកគេមានរយៈពេលតែមួយខ្លី

generated on Wed Sep 10 16:16:32 2025

ប៉ុណ្ណោះដូចជាភ្លើងដែលឆេះបន្លាបានងាប់ភ្លាមៗ»

Psalms 118:13

ដើម្បីឲ្យខ្ញុំដួល

លោកបាននិយាយអំពីកងទ័ពសត្រូវដែលកំពុងព្យាយាម

ដើម្បីកម្ចាត់លោកដូចជាពួកគេកំពុងព្យាយាមរុញលោកឲ្យដួល។

ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីកម្ចាត់ខ្ញុំ»

ព្រះអម្ចាស់ជាកម្លាំង និងជាបទចម្រៀងរបស់ខ្ញុំ

«ព្រះអម្ចាស់ប្រទានកម្លាំង និងអំណរដល់ខ្ញុំ»

Psalms 118:15

នៅក្នុងជំរំរបស់មនុស្សសុចរិត មានចម្រៀងយ៉ាងសប្បាយរីករាយ អំពីការសង្គ្រោះ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ប្រជាជនឮសម្លេងស្រែកហ៊ោកញ្ជ្រៀវនៃជ័យជម្នះនៅក្នុងត្រសាលរបស់មនុស្សសុចរិត» ឬ «មនុស្សសុចរិតស្រែកដោយអំណរ

ចំពោះជ័យជម្នះនៅក្នុងត្រសាលរបស់ពួកគេ»

គឺព្រះហស្តស្តាំនៃព្រះអម្ចាស់សម្តែងឥទ្ធិឫទ្ធិ

ត្រង់នេះពាក្យថា «ព្រះហស្ត» តំណាងឲ្យអំណាចរបស់ព្រះអម្ចាស់។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានឈ្នះ

ដោយកម្លាំងដ៏អស្ចារ្យរបស់ព្រះអង្គ»

ព្រះហស្តស្តាំនៃព្រះអម្ចាស់បានថ្កើងឡើង

នៅទីនេះ ការលើកដៃរបស់មនុស្សម្នាក់គឺជាកាយវិការនៃជ័យជម្នះ។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអម្ចាស់បានលើកព្រះហស្តស្តាំរបស់ព្រះអង្គ» ឬ

«ព្រះអម្ចាស់បានលើកព្រះហស្តស្តាំរបស់ព្រះអង្គឲ្យមានជ័យជម្នះ»

Psalms 118:17

ខ្ញុំនឹងមិនស្លាប់ទេ តែរស់

អ្នកនិពន្ធសរសេរគំនិតដូចគ្នាទាំងអវិជ្ជមាន និងវិជ្ជមាន

ដើម្បីបញ្ជាក់ថាគាត់ប្រាកដជានឹងរស់នៅ។

ព្រះអម្ចាស់បានវាយផ្ចាលខ្ញុំយ៉ាងខ្លាំង

«ព្រះអម្ចាស់បានប្រៀនប្រដៅខ្ញុំ»

ព្រះអង្គមិនបានបណ្តោយឲ្យខ្ញុំស្លាប់ទេ

អ្នកនិពន្ធនិយាយពីសេចក្តីស្លាប់ហាក់ដូចជាមនុស្សម្នាក់ដែលនៅក្រោមអំណាចរបស់ព្រះអម្ចាស់ ដែលមិនអាចសម្លាប់គាត់បានឡើយ។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គមិនបានអនុញ្ញាតឲ្យខ្ញុំស្លាប់» ឬ

«ព្រះអង្គមិនបានអនុញ្ញាតឲ្យសត្រូវរបស់ខ្ញុំសម្លាប់ខ្ញុំទេ»

Psalms 118:19

សូមបើកទ្វារនៃសេចក្តីសុចរិតឲ្យខ្ញុំ

«បើកទ្វារឲ្យខ្ញុំដែលជាកន្លែងដែលមនុស្សសុចរិតចូល»។

នេះជាឯកសារយោងទៅនឹងខ្លោងទ្វារព្រះវិហារ

ហើយអ្នកនិពន្ធកំពុងនិយាយទៅកាន់អ្នកយាមទ្វារ។

អត្ថន័យពេញលេញនៃរឿងនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។

ការបកប្រែរបៀបផ្សេងទៀត: «បើកឲ្យខ្ញុំនូវច្រកទ្វារព្រះវិហារ»

ទ្វារនៃព្រះអម្ចាស់

«ទ្វារដែលនាំទៅដល់វត្តមានរបស់ព្រះអម្ចាស់» ឬ «ទ្វាររបស់ព្រះអម្ចាស់»

ទូលបង្គំនឹងអរព្រះគុណព្រះអង្គ

នៅទីនេះអ្នកសរសេរចាប់ផ្តើមនិយាយទៅកាន់ព្រះអម្ចាស់។

ព្រះអង្គបានត្រឡប់ជាការសង្គ្រោះរបស់ទូលបង្គំ

ពាក្យថា «សេចក្តីសង្គ្រោះ» អាចត្រូវបានបកប្រែដោយពាក្យសម្តី។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានសង្គ្រោះខ្ញុំ»

Psalms 118:22

ថ្មដែលពួកជាងសង់ផ្ទះបានចោលចេញ នោះបានត្រឡប់ជាថ្មជ្រុងយ៉ាងឯក

នេះទំនងជាសុភាសិតមួយដែលអ្នកនិពន្ធបានប្រើ ដើម្បីពិពណ៌នាអំពីស្តេច

ឬប្រជាជាតិអ៊ីស្រាអែល។ អ្វីដែលអ្នកដទៃបានគិតថា

គ្មានតម្លៃនោះព្រះអម្ចាស់បានបង្កើតអ្វីដែលសំខាន់បំផុត។

ជាការដ៏អស្ចារ្យនៅភ្នែកនៃយើងខ្ញុំ

អាចមានន័យថា ១) «នេះគឺជារឿងដ៏អស្ចារ្យសម្រាប់យើងក្នុងការឃើញ» ឬ ២)

«យើងចាត់ទុកវាជារឿងដ៏អស្ចារ្យ»។

Psalms 118:24

ថ្ងៃនេះគឺជាថ្ងៃនៃជ័យជម្នះ ហើយសប្បាយរីករាយ

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន

ហើយសង្កត់ន័យយ៉ាងខ្លាំងនៃសេចក្តីអំណរ។ ការបកប្រែរបៀបផ្សេងទៀត:

«រីករាយណាស់»

Psalms 118:26

សូមឲ្យព្រះអង្គដែលយាងមកក្នុងព្រះនាម ព្រះអម្ចាស់ បានប្រកបដោយព្រះពរ

នៅទីនេះពួកសង្ឃចាប់ផ្តើមនិយាយទៅកាន់ស្តេច។

ព្រះអង្គដែលយាងមកក្នុងព្រះនាម ព្រះអម្ចាស់ បានប្រកបដោយព្រះពរ

ត្រង់នេះពាក្យ «ព្រះនាម» តំណាងឲ្យអំណាចរបស់ព្រះអម្ចាស់។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលចូលមកដោយអំណាចរបស់ព្រះអម្ចាស់»

យើងសូមឲ្យពរអ្នករាល់គ្នា ពីក្នុងដំណាក់របស់ព្រះអម្ចាស់

នៅទីនេះពួកសង្ឃនិយាយទៅកាន់ប្រជាជន។

ដំណាក់របស់ព្រះអម្ចាស់

ពាក្យថា «ដំណាក់» សំដៅទៅលើព្រះវិហារ។ ការបកប្រែរបៀបផ្សេងទៀត:

«ព្រះវិហាររបស់ព្រះអម្ចាស់»

ព្រះអង្គបានប្រទានពន្លឺបំភ្លឺយើង

អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ប្រទានពរដល់ប្រជារាស្ត្ររបស់ព្រះអង្គ

ដូចជាព្រះអម្ចាស់កំពុងតែបំភ្លឺពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអង្គបានប្រទានពរដល់យើង»

[illegible]

«ភ្ជាប់ឃញ្ចបូជាជាមួយខ្សែពួរ»

ព្រះអង្គជាព្រះនៃទូលបង្គំ

នៅទីនេះអ្នកនិពន្ធចាប់ផ្តើមនិយាយម្តងទៀត

ហើយនិយាយទៅកាន់ព្រះអម្ចាស់ដោយផ្ទាល់។

Psalms 118:29

ចូរ

នេះគឺជាការឧទានដែលគួរតែត្រូវបានបកប្រែជាមួយនឹងការឧទានសព្ទអ្វីដែលអ្នកសង្កត់ន័យនៅក្នុងភាសា

ដើម្បីឲ្យវាមានលក្ខណៈធម្មជាតិ។

អរព្រះគុណដល់ព្រះអម្ចាស់ ដ្បិតព្រះអង្គល្អ

«អរព្រះគុណដល់ព្រះអម្ចាស់ ដោយសារការល្អដែលព្រះអង្គបានធ្វើ។

សូមមើលពីរបៀបបកប្រែក្នុងជំពូក ១១៨:១

ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច

«ព្រះអង្គស្រឡាញ់យើងដោយស្មោះត្រង់ជារៀងរហូត»។

សូមមើលពីរបៀបបកប្រែក្នុងជំពូក ១១៨:១

---

119 [1]មានពរហើយ អស់អ្នកដែលផ្លូវប្រព្រឹត្ត របស់ខ្លួនបានគ្រប់លក្ខណ៍ ជាអ្នកដែលដើរតាមក្រឹត្យវិន័យ របស់ព្រះអម្ចាស់។[2]មានពរហើយ អស់អ្នកដែលកាន់តាម
សេចក្តីបន្ទាល់របស់ព្រះអង្គ ជាអ្នកដែលស្វែងរកព្រះអង្គដោយអស់ពីចិត្ត។
[3]ជាអ្នកដែលមិនប្រព្រឹត្តអំពើទុច្ចរិត គឺដើរតាមផ្លូវរបស់ព្រះអង្គវិញ។[4]ព្រះអង្គបានប្រកាសព្រះឱវាទរបស់ព្រះអង្គមក ដើម្បីឲ្យយើងខ្ញុំបានប្រតិបត្តិតាម ដោយយកចិត្ត
ទុកដាក់។
[5]ឱប្រសិនបើផ្លូវទាំងប៉ុន្មានរបស់ទូលបង្គំ បានខ្ជាប់ខ្ជួន ដោយប្រតិបត្តិតាមច្បាប់របស់ព្រះអង្គទៅ![6]នោះទូលបង្គំនឹងមិនត្រូវខ្មាសឡើយ ដោយភ្នែកទូលបង្គំបានសម្លឹងមើល
បទបញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ។
[7]កាលទូលបង្គំរៀនអស់ទាំងវិន័យ ដ៏សុចរិតរបស់ព្រះអង្គ នោះទូលបង្គំនឹងសរសើរតម្កើងព្រះអង្គ ដោយចិត្តទៀងត្រង់។[8]ទូលបង្គំនឹងកាន់តាមច្បាប់របស់ព្រះអង្គ ឱសូមកុំ
បោះបង់ចោលទូលបង្គំសោះឡើយ។
[9]តើមនុស្សកំលោះធ្វើដូចម្តេច ដើម្បីរក្សាផ្លូវដែលខ្លួនប្រព្រឹត្តឲ្យបានបរិសុទ្ធ? គឺដោយប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។[10]ទូលបង្គំបានស្វែងរកព្រះអង្គយ៉ាងអស់ពីចិត្ត
សូមកុំឲ្យទូលបង្គំវង្វេងចេញពីបទបញ្ជា របស់ព្រះអង្គឡើយ។
[11]ទូលបង្គំបានរក្សាព្រះបន្ទូលព្រះអង្គ ទុកនៅក្នុងចិត្តដើម្បីកុំឲ្យទូលបង្គំប្រព្រឹត្តអំពើបាប ទាស់នឹងព្រះអង្គ។[12]ព្រះ អម្ចាស់អើយ ព្រះអង្គមានពរ សូមបង្រៀនឲ្យ
ទូលបង្គំស្គាល់ច្បាប់របស់ព្រះអង្គផង។

generated on Wed Sep 10 16:16:32 2025

[13]បបូរមាត់ទូលបង្គំប្រកាសពីគ្រប់ទាំងវិន័យ ដែលចេញមកពីព្រះឧស្ឋរបស់ព្រះអង្គ។[14]ទូលបង្គំរីករាយនឹងផ្លូវប្រព្រឹត្ត តាមសេចក្ដីបន្ទាល់របស់ព្រះអង្គ ដូចជាទូលបង្គំរីករាយ នឹងទ្រព្យសម្បត្តិគ្រប់យ៉ាង។
[15]ទូលបង្គំនឹងសញ្ជឹងគិតពីសេចក្ដីបង្រៀនរបស់ព្រះអង្គ ហើយភ្នែកទូលបង្គំសម្លឹងមើលផ្លូវរបស់ព្រះអង្គ។[16]ទូលបង្គំមានចិត្តរីករាយនឹងច្បាប់របស់ព្រះអង្គ ទូលបង្គំមិនភ្លេចព្រះបន្ទូលរបស់ព្រះអង្គឡើយ។
[17]សូមប្រទានឲ្យអ្នកបម្រើរបស់ព្រះអង្គ បានប្រកបដោយគុណដើម្បីឲ្យទូលបង្គំបានរស់នៅ ហើយប្រតិបត្តិតាមព្រះ បន្ទូលរបស់ព្រះអង្គ។[18]សូមបំភ្លឺភ្នែកទូលបង្គំ ឲ្យបានឃើញការដ៏អស្ចារ្យនៅក្នុងក្រឹត្យវិន័យរបស់ព្រះអង្គ។
[19]ទូលបង្គំជាមនុស្សស្នាក់អាស្រ័យ បណ្តោះអាសន្ននៅលើផែនដីសូមកុំលាក់បទបញ្ជារបស់ព្រះអង្គ នឹងទូលបង្គំឡើយ។[20]ព្រលឹងទូលបង្គំសោកសង្រេង ដោយចង់បានវិន័យរបស់ព្រះអង្គគ្រប់ពេលវេលា។
[21]ព្រះអង្គបន្ទោសមនុស្សព្រហើន ជាពួកអ្នកដែលត្រូវបណ្តាសាជាពួកអ្នកដែលវង្វេងចេញពីបទបញ្ជា របស់ព្រះអង្គ។[22]សូមដកយកដំណៀល និងការមើលងាយចេញពីទូលបង្គំ ដ្បិតទូលបង្គំបានកាន់តាមសេចក្ដីបន្ទាល់ របស់ព្រះអង្គហើយ។
[23]ទោះបីពួកអ្នកធំបានអង្គុយប្រឹក្សាគ្នា ទាស់នឹងទូលបង្គំក៏ដោយក៏អ្នកបម្រើរបស់ព្រះអង្គនៅតែសញ្ជឹងគិត ពីច្បាប់របស់ព្រះអង្គជានិច្ច។[24]សេចក្ដីបន្ទាល់របស់ព្រះអង្គ ជាទីសប្បាយរីករាយរបស់ទូលបង្គំ ហើយសេចក្ដីបន្ទាល់ទាំងនោះ ជាដំបូន្មានដល់ទូលបង្គំ។
[25]ព្រលឹងទូលបង្គំជាប់ស្អិតនឹងធូលីដី សូមប្រទានឲ្យទូលបង្គំមានជីវិត តាមព្រះបន្ទូលរបស់ព្រះអង្គផង។[26]ទូលបង្គំបានទូល អំពីផ្លូវប្រព្រឹត្តរបស់ទូលបង្គំ ព្រះអង្គបានឆ្លើយតបមកទូលបង្គំ សូមបង្រៀនឲ្យទូលបង្គំស្គាល់ច្បាប់ របស់ព្រះអង្គផង។
[27]សូមឲ្យទូលបង្គំបានយល់ផ្លូវ នៃសេចក្ដីបង្រៀនរបស់ព្រះអង្គ នោះទូលបង្គំនឹងសញ្ជឹងគិត អំពីការដ៏អស្ចារ្យរបស់ព្រះអង្គ។[28]ព្រលឹងទូលបង្គំរលាយទៅ ដោយព្រោះទុក្ខព្រួយ សូមចម្រើនកម្លាំងទូលបង្គំ តាមព្រះបន្ទូលរបស់ព្រះអង្គផង។
[29]សូមដកផ្លូវភូតភរចេញឆ្ងាយពីទូលបង្គំ ហើយសូមប្រោសប្រទានក្រឹត្យវិន័យ របស់ព្រះអង្គដោយព្រះគុណផង។[30]ទូលបង្គំបានរើសយកផ្លូវស្មោះត្រង់ ទូលបង្គំបានតាំងវិន័យរបស់ព្រះអង្គ នៅមុខទូលបង្គំ។
[31]ទូលបង្គំជាប់ចិត្តនឹងសេចក្ដីបន្ទាល់របស់ព្រះអង្គ ឱព្រះ អម្ចាស់អើយ សូមកុំឲ្យទូលបង្គំត្រូវខ្មាសឡើយ។[32]ទូលបង្គំនឹងរត់តាមផ្លូវនៃបទបញ្ជារបស់ព្រះអង្គ ដ្បិតព្រះអង្គបានពង្រីកចិត្តទូលបង្គំ។
[33]ឱព្រះអម្ចាស់អើយ សូមបង្រៀនទូលបង្គំ ឲ្យស្គាល់ផ្លូវនៃច្បាប់របស់ព្រះអង្គ នោះទូលបង្គំនឹងកាន់តាមរហូតដល់ទីបំផុត។[34]សូមប្រទានឲ្យទូលបង្គំមានយោបល់ ដើម្បីឲ្យទូលបង្គំបានកាន់តាម ក្រឹត្យវិន័យរបស់ព្រះអង្គ ទូលបង្គំនឹងប្រតិបត្តិតាមយ៉ាងអស់ពីចិត្ត។
[35]សូមនាំទូលបង្គំទៅតាមផ្លូវច្រក នៃបទបញ្ជារបស់ព្រះអង្គ ដ្បិតទូលបង្គំមានចិត្តរីករាយ នឹងផ្លូវនោះណាស់។[36]សូមធ្វើឲ្យចិត្តទូលបង្គំផ្ទៀងទៅរក សេចក្ដីបន្ទាល់របស់ព្រះអង្គ កុំឲ្យផ្ទៀងទៅរកសេចក្ដីលោភឡើយ។
[37]សូមបង្វែរភ្នែកទូលបង្គំកុំឲ្យមើលអ្វីៗ ដែលឥតប្រយោជន៍ ហើយប្រទានឲ្យទូលបង្គំមានជីវិតរស់នៅ តាមផ្លូវរបស់ព្រះអង្គ។[38]សូមបញ្ជាក់ដល់អ្នកបម្រើព្រះអង្គតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ជាសេចក្ដីដែលទុកសម្រាប់អស់អ្នក កោតខ្លាចព្រះអង្គ។
[39]សូមបង្វែរពាក្យដំណៀល ដែលទូលបង្គំខ្លាចនោះចេញ ដ្បិតវិន័យរបស់ព្រះអង្គសុទ្ធតែល្អទាំងអស់។[40]មើល៍ ទូលបង្គំប្រាថ្នាចង់បាន ព្រះឱវាទរបស់ព្រះអង្គ សូមប្រទានឲ្យទូលបង្គំមានជីវិតរស់នៅ តាមសេចក្ដីសុចរិតរបស់ព្រះអង្គ។
[41]ព្រះអម្ចាស់អើយ សូមព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ផ្សាយមកដល់ទូលបង្គំ គឺការសង្គ្រោះរបស់ព្រះអង្គ តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ។[42]នោះទូលបង្គំនឹងមានពាក្យឆ្លើយតបដល់អ្នកណា ដែលត្មះតិះដៀលទូលបង្គំ ដ្បិតទូលបង្គំទុកចិត្តដល់ព្រះបន្ទូលរបស់ព្រះអង្គ។
[43]សូមកុំដកព្រះបន្ទូលនៃសេចក្ដីពិត ចេញពីមាត់ទូលបង្គំ សោះឡើយ ដ្បិតទូលបង្គំសង្ឃឹមដល់វិន័យរបស់ព្រះអង្គ។[44]ទូលបង្គំនឹងកាន់តាមក្រឹត្យវិន័យ របស់ព្រះអង្គជានិច្ច នៅអស់កល្បជានិច្ចរហូត។
[45]ទូលបង្គំនឹងដើរដោយមានសេរីភាព ដ្បិតទូលបង្គំបានស្វែងរកសេចក្ដីបង្រៀនរបស់ព្រះអង្គ។[46]ទូលបង្គំនឹងថ្លែងអំពីសេចក្ដីបន្ទាល់របស់ព្រះអង្គ នៅចំពោះពួកស្តេច ហើយនឹងមិនខ្មាសឡើយ
[47]ដ្បិតទូលបង្គំមានចិត្តរីករាយ នឹងបទបញ្ជារបស់ព្រះអង្គ ជាសេចក្ដីដែលទូលបង្គំស្រឡាញ់។[48]ទូលបង្គំនឹងលើកដៃប្រណម្យ ឆ្ពោះទៅបទបញ្ជារបស់ព្រះអង្គ ជាសេចក្ដីដែលទូលបង្គំស្រឡាញ់ ហើយទូលបង្គំនឹងសញ្ជឹងគិត អំពីច្បាប់របស់ព្រះអង្គ។
[49]សូមនឹកចាំពីសេចក្ដីដែលព្រះអង្គ មានព្រះបន្ទូលមកកាន់អ្នកបម្រើព្រះអង្គ ជាសេចក្ដីដែលនាំឲ្យទូលបង្គំមានសង្ឃឹម។[50]នេះហើយជាសេចក្ដីកម្សាន្តចិត្តដល់ទូលបង្គំ ក្នុងវេលាដែលទូលបង្គំកើតទុក្ខព្រួយ គឺព្រះបន្ទូលព្រះអង្គប្រទាន ឲ្យទូលបង្គំមានជីវិត។
[51]មនុស្សព្រហើនចំអកមើលងាយ ទូលបង្គំជាពន់ពេក ប៉ុន្តែ ទូលបង្គំមិនបានបែរចេញ ពីក្រឹត្យវិន័យរបស់ព្រះអង្គឡើយ។[52]ព្រះអម្ចាស់អើយ កាលទូលបង្គំនឹកដល់វិន័យរបស់ព្រះអង្គពីបុរាណ នោះចិត្តទូលបង្គំក៏បានធូរស្បើយ។
[53]កំហឹងបានតោងខ្ញុំដោយព្រោះមនុស្សអាក្រក់ ជាអ្នកដែលបោះបង់ចោល ក្រឹត្យវិន័យរបស់ព្រះអង្គ។[54]ច្បាប់របស់ព្រះអង្គបានក្លាយជា បទចម្រៀងរបស់ទូលបង្គំ នៅក្នុងផ្ទះដែលទូលបង្គំស្នាក់អាស្រ័យ។
[55]ព្រះអម្ចាស់អើយ ទូលបង្គំនឹកដល់ព្រះនាមព្រះអង្គនៅពេលយប់ ហើយកាន់តាមក្រឹត្យវិន័យរបស់ព្រះអង្គ។[56]ព្រះពរនេះបានធ្លាក់មកដល់ទូលបង្គំ ព្រោះទូលបង្គំបានប្រតិបត្តិតាម សេចក្ដីបង្រៀនរបស់ព្រះអង្គ។
[57]ព្រះអម្ចាស់ជាចំណែករបស់ទូលបង្គំ ទូលបង្គំសន្យានឹងប្រតិបត្តិតាម ព្រះបន្ទូលព្រះអង្គ។[58]ទូលបង្គំសូមអង្វរដល់ព្រះអង្គយ៉ាងអស់ពីចិត្ត សូមប្រណីសន្តោសទូលបង្គំតាមព្រះបន្ទូលរបស់ព្រះអង្គផង។
[59]កាលទូលបង្គំគិតអំពីផ្លូវប្រព្រឹត្តរបស់ខ្លួន នោះជើងទូលបង្គំក៏បែរទៅរក សេចក្ដីបន្ទាល់របស់ព្រះអង្គ។[60]ទូលបង្គំប្រញាប់ប្រញាល់ ហើយមិនបង្អង់នឹង ប្រតិបត្តិតាមបទបញ្ជារបស់ព្រះអង្គឡើយ។
[61]ទោះជាមនុស្សអាក្រក់ដាក់អន្ទាក់ ចាំចាប់ទូលបង្គំក៏ដោយ ក៏ទូលបង្គំមិនភ្លេចក្រឹត្យវិន័យ របស់ព្រះអង្គឡើយ។[62]នៅពាក់កណ្តាលអធ្រាត្រ ទូលបង្គំក្រោកឡើង ហើយសរសើរតម្កើងព្រះអង្គ ដោយព្រោះវិន័យដ៏សុចរិតរបស់ព្រះអង្គ។
[63]ទូលបង្គំជាមិត្តភក្តិនៃអស់អ្នក ដែលកោតខ្លាចព្រះអង្គ និងអស់អ្នកដែលកាន់តាម ការបង្រៀនរបស់ព្រះអង្គ។[64]ផែនដីមានពេញដោយ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ សូមបង្រៀនឲ្យទូលបង្គំ ស្គាល់ច្បាប់របស់ព្រះអង្គផង។
[65]ព្រះអម្ចាស់អើយ ព្រះអង្គបានប្រោសប្រណីអ្នកបម្រើព្រះអង្គតាមព្រះបន្ទូលរបស់ព្រះអង្គ។[66]សូមបង្រៀនឲ្យទូលបង្គំចេះវិនិច្ឆ័យដឹងខុសត្រូវ ដ្បិតទូលបង្គំជឿដល់បទបញ្ជារបស់ព្រះអង្គ។
[67]ពីមុនទូលបង្គំបានវង្វេង ហើយក៏មានទុក្ខព្រួយ តែឥឡូវនេះ ទូលបង្គំប្រតិបត្តិតាម ព្រះបន្ទូលព្រះអង្គ។[68]ព្រះអង្គល្អ ហើយធ្វើការល្អ សូមបង្រៀនឲ្យទូលបង្គំ ស្គាល់ច្បាប់របស់ព្រះអង្គ។
[69]មនុស្សព្រហើននាំគ្នាបង្ខូចឈ្មោះទូលបង្គំ ដោយពាក្យភូតភរ តែទូលបង្គំនឹងប្រតិបត្តិតាមព្រះឱវាទ របស់ព្រះអង្គយ៉ាងអស់ពីចិត្ត។[70]ចិត្តរបស់គេស្អឹក ដូចមនុស្សមានខ្លាញ់កក តែទូលបង្គំមានចិត្តរីករាយ នឹងក្រឹត្យវិន័យរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[71]ការដែលទូលបង្គំមានទុក្ខព្រួយ នោះជាការល្អដល់ទូលបង្គំ គឺដើម្បីឲ្យទូលបង្គំអាចរៀនច្បាប់របស់ព្រះអង្គ។[72]ក្រឹត្យវិន័យដែលចេញពីព្រះឧស្ឋរបស់ព្រះអង្គ វិសេសដល់ទូលបង្គំ ជាជាងមាសប្រាក់ទាំងពាន់។
[73]ព្រះហស្តរបស់ព្រះអង្គបានបង្កើត និងបានសូនទូលបង្គំ សូមប្រទានឲ្យទូលបង្គំមានយោបល់ ដើម្បីឲ្យទូលបង្គំបានរៀនស្គាល់ បទបញ្ជារបស់ព្រះអង្គ។[74]អស់អ្នកដែលកោតខ្លាចព្រះអង្គ នឹងឃើញទូលបង្គំ ហើយមានចិត្តត្រេកអំណរ ព្រោះទូលបង្គំបាន សង្ឃឹមដល់ព្រះបន្ទូលរបស់ព្រះអង្គ។
[75]ព្រះអម្ចាស់អើយ ទូលបង្គំដឹងថា វិន័យរបស់ព្រះអង្គសុទ្ធតែសុចរិត ហើយថា ព្រះអង្គបានធ្វើឲ្យទូលបង្គំមានទុក្ខ ដោយសេចក្តីស្មោះត្រង់របស់ព្រះអង្គទេ។[76]សូមឲ្យព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ កម្សាន្តចិត្តទូលបង្គំ តាមសេចក្តីដែលព្រះអង្គបានសន្យា ដល់អ្នកបម្រើរបស់ព្រះអង្គ។
[77]សូមសម្តែងព្រះហឫទ័យមេត្តាករុណា របស់ព្រះអង្គដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គំបានរស់នៅ ដ្បិតក្រឹត្យវិន័យរបស់ព្រះអង្គ ជាទីសប្បាយរីករាយរបស់ទូលបង្គំ។[78]សូមឲ្យមនុស្សព្រហើនត្រូវខ្មាស ព្រោះគេបានប្រព្រឹត្តមួលបង្កាច់ទូលបង្គំ រីឯទូលបង្គំវិញ ទូលបង្គំនឹងសញ្ជឹងគិត អំពីព្រះឱវាទរបស់ព្រះអង្គ។
[79]សូមឲ្យអស់អ្នកដែលកោតខ្លាចព្រះអង្គ ងាកមករកទូលបង្គំ ដើម្បីឲ្យគេបានស្គាល់ សេចក្តីបន្ទាល់របស់ព្រះអង្គ។[80]សូមឲ្យចិត្តទូលបង្គំបានឥតសៅហ្មង តាមច្បាប់របស់ព្រះអង្គ ដើម្បីកុំឲ្យទូលបង្គំត្រូវខ្មាសឡើយ។
[81]ព្រលឹងទូលបង្គំដង្ហក់ចង់បាន ការសង្គ្រោះរបស់ព្រះអង្គ ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលរបស់ព្រះអង្គ។[82]ភ្នែកទូលបង្គំស្រវាំងដោយចង់ឃើញ ព្រះបន្ទូលសន្យារបស់ព្រះអង្គ ទូលបង្គំសួរថា តើពេលណាទើបព្រះអង្គកម្សាន្តចិត្តទូលបង្គំ?
[83]ដ្បិតទូលបង្គំបានត្រឡប់ដូចជា ថង់ស្បែកដែលត្រូវផ្សែង តែទូលបង្គំមិនភ្លេចបញ្ញត្តិរបស់ព្រះអង្គឡើយ។[84]តើអ្នកបម្រើព្រះអង្គត្រូវស៊ូទ្រាំ ដល់កាលណាទៀត តើពេលណាទើបព្រះអង្គវិនិច្ឆ័យទោស អស់អ្នកដែលបៀតបៀនទូលបង្គំ?
[85]មនុស្សព្រហើនបានជីករណ្តៅ ដើម្បីចាប់ទូលបង្គំ គេមិនរស់នៅតាមក្រឹត្យវិន័យរបស់ព្រះអង្គទេ។[86]បទបញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ សុទ្ធតែពិតទាំងអស់ គេបៀតបៀនទូលបង្គំដោយឥតហេតុ សូមជួយទូលបង្គំផង។
[87]ពួកគេបានធ្វើឲ្យទូលបង្គំ ហៀបតែនឹងសូន្យបាត់ពីផែនដី ប៉ុន្តែ ទូលបង្គំមិនបានបោះបង់ចោល សេចក្តីបង្រៀនរបស់ព្រះអង្គឡើយ។[88]សូមប្រទានឲ្យទូលបង្គំមានជីវិតរស់នៅ តាមព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ដើម្បីឲ្យទូលបង្គំបានប្រតិបត្តិតាមសេចក្តីបន្ទាល់ ដែលចេញពីព្រះឧស្ឋរបស់ព្រះអង្គ។
[89]ព្រះអម្ចាស់អើយ ព្រះបន្ទូលរបស់ព្រះអង្គបានតាំងជាប់ នៅស្ថានសួគ៌រហូតអស់កល្បជានិច្ច។[90]ព្រះហឫទ័យស្មោះត្រង់របស់ព្រះអង្គ នៅស្ថិតស្ថេរដល់មនុស្សគ្រប់ជំនាន់តរៀងទៅ ព្រះអង្គបានប្រតិស្ឋានផែនដី ហើយផែនដីក៏តាំងនៅជាប់។
[91]អ្វីៗទាំងអស់ស្ថិតស្ថេរនៅរហូតដល់សព្វថ្ងៃ ដោយសារច្បាប់របស់ព្រះអង្គ ដ្បិតអ្វីៗទាំងអស់សម្រាប់បម្រើព្រះអង្គ។[92]ប្រសិនបើទូលបង្គំមិនបានរីករាយ នឹងក្រឹត្យវិន័យរបស់ព្រះអង្គនោះទូលបង្គំមុខជាវិនាស ទៅក្នុងសេចក្តីទុក្ខព្រួយ របស់ទូលបង្គំមិនខាន។
[93]ទូលបង្គំនឹងមិនដែលភ្លេចសេចក្តីបង្រៀន របស់ព្រះអង្គឡើយ ដ្បិតព្រះអង្គបានប្រោសឲ្យទូលបង្គំមានជីវិត ដោយសារសេចក្តីបង្រៀនទាំងនេះ។[94]ទូលបង្គំជារបស់ព្រះអង្គហើយ សូមសង្គ្រោះទូលបង្គំផង ដ្បិតទូលបង្គំបានស្វែងរក សេចក្តីបង្រៀនរបស់ព្រះអង្គ។
[95]មនុស្សអាក្រក់ពួនចាំសម្លាប់ទូលបង្គំ តែទូលបង្គំពិចារណាសេចក្តីបន្ទាល់ របស់ព្រះអង្គ។[96]ទូលបង្គំបានឃើញថា អ្វីៗទាំងអស់សុទ្ធតែមានដែនកំណត់ តែបទបញ្ជារបស់ព្រះអង្គធំទូលាយក្រៃលែង។
[97]ឱទូលបង្គំស្រឡាញ់ក្រឹត្យវិន័យ របស់ព្រះអង្គណាស់ហ្ន៎! ទូលបង្គំរំពឹងគិតអំពីក្រឹត្យវិន័យ នោះដរាបរាល់ថ្ងៃ។[98]បទបញ្ជារបស់ព្រះអង្គ ធ្វើឲ្យទូលបង្គំមានប្រាជ្ញា លើសជាងខ្មាំងសត្រូវរបស់ទូលបង្គំ ដ្បិតបាននៅជាប់ជាមួយទូលបង្គំជានិច្ច។
[99]ទូលបង្គំមានយោបល់ជាងគ្រូទាំងប៉ុន្មាន របស់ទូលបង្គំទៅទៀត ដ្បិតទូលបង្គំសញ្ជឹងគិតពីសេចក្តីបន្ទាល់របស់ព្រះ អង្គ។[100]ទូលបង្គំយល់ដឹងជាងមនុស្សចាស់ដ្បិតទូលបង្គំ ប្រតិបត្តិតាម សេចក្តីបង្រៀនរបស់ព្រះអង្គ។
[101]ទូលបង្គំបានបង្ខាំងជើង ឲ្យវៀរចាកពីអស់ទាំងផ្លូវអាក្រក់ ដើម្បីនឹងប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គ។[102]ទូលបង្គំមិនបានបែរចេញ ពីវិន័យរបស់ព្រះអង្គឡើយ ដ្បិតព្រះអង្គបានបង្រៀនទូលបង្គំ។
[103]ព្រះបន្ទូលរបស់ព្រះអង្គ ផ្អែមដល់អណ្តាតទូលបង្គំណាស់ហ្ន៎ គឺផ្អែមដល់មាត់ទូលបង្គំជាងទឹកឃ្មុំទៅទៀត![104]ទូលបង្គំមានយោបល់ដោយសារ ការប្រៀនរបស់ព្រះអង្គ ហេតុនេះហើយបានជាទូលបង្គំ ស្អប់ដល់អស់ទាំងផ្លូវភូតភរ។
[105]ព្រះបន្ទូលរបស់ព្រះអង្គ ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំ។[106]ទូលបង្គំបានស្បថ ហើយបានសម្រេចតាមថា ទូលបង្គំនឹងប្រតិបត្តិតាមវិន័យ ដ៏សុចរិតរបស់ព្រះអង្គ។
[107]ទូលបង្គំមានទុក្ខព្រួយខ្លាំងណាស់ ព្រះអម្ចាស់អើយ សូមប្រទានឲ្យទូលបង្គំមានជីវិត តាមព្រះបន្ទូលរបស់ព្រះអង្គផង។[108]ព្រះអម្ចាស់អើយ សូមទទួល តង្វាយស្ម័គ្រចិត្តរបស់ទូលបង្គំ ហើយសូមបង្រៀនទូលបង្គំ ឲ្យស្គាល់វិន័យរបស់ព្រះអង្គផង។
[109]ជីវិតទូលបង្គំមានអន្តរាយឥតឈប់ឈរ តែទូលបង្គំមិនភ្លេចក្រឹត្យវិន័យ របស់ព្រះអង្គឡើយ។[110]មនុស្សអាក្រក់បានដាក់អន្ទាក់ ចាំចាប់ទូលបង្គំ ប៉ុន្តែ ទូលបង្គំមិនបានវង្វេងចេញ ពីការបង្រៀនរបស់ព្រះអង្គឡើយ។
[111]សេចក្តីបន្ទាល់របស់ព្រះអង្គ ជាមរតករបស់ទូលបង្គំជាដរាបដ្បិតសេចក្តីទាំងនោះ ធ្វើឲ្យចិត្តទូលបង្គំមានអំណរ។[112]ទូលបង្គំដាក់ចិត្តដើម្បីធ្វើតាមច្បាប់ របស់ព្រះអង្គជាដរាប រហូតដល់ចុងបំផុត។
[113]ទូលបង្គំស្អប់មនុស្សដែលមានចិត្តពីរ តែទូលបង្គំស្រឡាញ់ក្រឹត្យវិន័យរបស់ព្រះអង្គ។[114]ព្រះអង្គជាទីពួនជ្រក និងជាខែលរបស់ទូលបង្គំ ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលរបស់ព្រះអង្គ។
[115]អ្នករាល់គ្នាដែលប្រព្រឹត្តអាក្រក់អើយ ចូរថយចេញពីខ្ញុំទៅ ដើម្បីឲ្យខ្ញុំបានប្រតិបត្តិតាម បទបញ្ជារបស់ព្រះនៃខ្ញុំ។[116]សូមទ្រទ្រង់ទូលបង្គំតាម ព្រះបន្ទូលរបស់ព្រះអង្គ ឲ្យទូលបង្គំបានរស់នៅ សូមកុំឲ្យទូលបង្គំត្រូវខ្មាស ដោយព្រោះសេចក្តីសង្ឃឹមរបស់ទូលបង្គំឡើយ។
[117]សូមធ្វើជាបង្អែករបស់ទូលបង្គំ ឲ្យទូលបង្គំបានសេចក្តីសុខ ហើយបានគោរពរាប់អានច្បាប់ របស់ព្រះអង្គជានិច្ច។[118]ព្រះអង្គមិនរាប់រកអស់អ្នកដែលវង្វេងចេញ ពីច្បាប់របស់ព្រះអង្គ ដ្បិតឧបាយកលរបស់គេ ជាសេចក្តីឥតប្រយោជន៍។
[119]ព្រះអង្គផាត់មនុស្សអាក្រក់បាត់ចេញពីផែនដី ដូចគេផាត់សំរាម ហេតុនេះហើយបានជាទូលបង្គំស្រឡាញ់ សេចក្តីបន្ទាល់របស់ព្រះអង្គ។[120]រូបកាយទូលបង្គំញ័រញាក់ដោយកោតខ្លាចព្រះអង្គ ហើយទូលបង្គំភ័យខ្លាចការជំនុំជម្រះ របស់ព្រះអង្គ។
[121]ទូលបង្គំបានប្រព្រឹត្តអំពើសុចរិត និងយុត្តិធម៌ សូមកុំប្រគល់ទូលបង្គំទៅឲ្យពួកអ្នក ដែលសង្កត់សង្កិនឡើយ។[122]សូមធានាឲ្យអ្នកបម្រើរបស់ព្រះអង្គ បានសេចក្តីល្អ សូមកុំឲ្យមនុស្សព្រហើនសង្កត់សង្កិន ទូលបង្គំឡើយ។
[123]ភ្នែកទូលបង្គំស្រវាំង ដោយរង់ចាំមើល ការសង្គ្រោះទូលបង្គំរបស់ព្រះអង្គ និងរង់ចាំមើលព្រះបន្ទូលសន្យាដ៏សុចរិត របស់ព្រះអង្គបានសម្រេច។[124]សូមប្រព្រឹត្តនឹងអ្នកបម្រើរបស់ព្រះអង្គ តាមព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ហើយសូមបង្រៀនឲ្យទូលបង្គំ ស្គាល់ច្បាប់របស់ព្រះអង្គ។
[125]ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ សូមប្រទានឲ្យទូលបង្គំមានយោបល់ផង ដើម្បីឲ្យទូលបង្គំបានស្គាល់ សេចក្តីបន្ទាល់របស់ព្រះអង្គ។[126]នេះជាពេលដែលព្រះអម្ចាស់ចាត់វិធានការហើយ ដ្បិតគេបានប្រព្រឹត្តល្មើស នឹងក្រឹត្យវិន័យរបស់ព្រះអង្គ។
[127]ទូលបង្គំស្រឡាញ់ បទបញ្ជារបស់ព្រះអង្គលើសជាងមាស គឺលើសជាងមាសសុទ្ធទៅទៀត។[128]ដូច្នេះ ទូលបង្គំរាប់ថា សេចក្តីបង្រៀនទាំងប៉ុន្មានរបស់ព្រះអង្គសុទ្ធតែត្រឹមត្រូវទាំងអស់ ទូលបង្គំស្អប់គ្រប់ទាំងផ្លូវភូតភរ។

generated on Wed Sep 10 16:16:32 2025

[129]សេចក្តីបន្ទាល់របស់ព្រះអង្គសុទ្ធតែអស្ចារ្យ ហេតុនេះហើយបានជាព្រលឹងទូលបង្គំ ប្រតិបត្តិតាម។[130]ការបើកសម្តែងព្រះបន្ទូលរបស់ព្រះអង្គ ប្រទានឲ្យមានពន្លឺ ក៏ធ្វើឲ្យមនុស្សឆោតល្ងង់មានយោបល់។
[131]ទូលបង្គំហាមាត់ ដកដង្ហើមធំ ព្រោះទូលបង្គំចង់បានបទបញ្ជា របស់ព្រះអង្គណាស់។[132]សូមបែរមកទូលបង្គំ ហើយប្រណីសន្តោសទូលបង្គំ ដូចព្រះអង្គធ្លាប់ធ្វើដល់អស់អ្នក ដែលស្រឡាញ់ព្រះនាមព្រះអង្គផង។
[133]សូមរក្សាជំហានទូលបង្គំ តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ហើយសូមកុំឲ្យអំពើទុច្ចរិតមានអំណាច លើទូលបង្គំឡើយ។[134]សូមលោះទូលបង្គំឲ្យរួចពី ការសង្កត់សង្កិនរបស់មនុស្សដើម្បីឲ្យទូលបង្គំបានប្រតិបត្តិតាម ការបង្រៀនរបស់ព្រះអង្គ។
[135]សូមឲ្យព្រះភ័ក្ត្រព្រះអង្គ ភ្លឺមកលើអ្នកបម្រើរបស់ព្រះអង្គ ហើយសូមបង្រៀនឲ្យទូលបង្គំ ស្គាល់ច្បាប់របស់ព្រះអង្គផង។[136]ទឹកភ្នែកទូលបង្គំហូររហាម ព្រោះគេមិនប្រតិបត្តិតាម ក្រឹត្យវិន័យរបស់ព្រះអង្គ។
[137]ព្រះអម្ចាស់អើយ ព្រះអង្គសុចរិត ហើយវិន័យរបស់ព្រះអង្គសុទ្ធតែត្រឹមត្រូវ។[138]ព្រះអង្គបានតាំងសេចក្តីបន្ទាល់របស់ព្រះអង្គ ដោយសេចក្តីសុចរិត និងដោយសេចក្តីស្មោះត្រង់ទាំងអស់។
[139]ទូលបង្គំមានចិត្តឈឺឆ្អាលជាខ្លាំង ព្រោះបច្ចាមិត្តរបស់ទូលបង្គំបំភ្លេចព្រះបន្ទូលរបស់ព្រះអង្គ។[140]ព្រះបន្ទូលសន្យារបស់ព្រះអង្គ បានសម្រិតសម្រាំងយ៉ាងល្អ ហើយអ្នកបម្រើរបស់ព្រះអង្គ ស្រឡាញ់ព្រះបន្ទូលនេះណាស់។
[141]ទូលបង្គំជាមនុស្សតូចតាច ហើយត្រូវគេមើលងាយ ប៉ុន្តែ ទូលបង្គំមិនភ្លេចសេចក្តីបង្រៀនរបស់ព្រះអង្គឡើយ។[142]សេចក្តីសុចរិតរបស់ព្រះអង្គ សុចរិតអស់កល្បជានិច្ច ហើយក្រឹត្យវិន័យរបស់ព្រះអង្គជាសេចក្តីពិត។
[143]ទុក្ខលំបាក និងភាពតានតឹង បានគ្របសង្កត់ទូលបង្គំ តែបទបញ្ជារបស់ព្រះអង្គ ជាទីរីករាយដល់ទូលបង្គំ។[144]សេចក្តីបន្ទាល់របស់ព្រះអង្គ សុចរិតអស់កល្បជានិច្ច សូមប្រទានឲ្យទូលបង្គំមានយោបល់ ដើម្បីឲ្យទូលបង្គំនឹងបានរស់នៅ។
[145]ទូលបង្គំស្រែករកព្រះអង្គយ៉ាងអស់ពីចិត្ត ព្រះអម្ចាស់អើយ សូមឆ្លើយមកទូលបង្គំផង ទូលបង្គំនឹងប្រតិបត្តិតាមច្បាប់របស់ព្រះអង្គ។[146]ទូលបង្គំអំពាវនាវរកព្រះអង្គ សូមសង្គ្រោះទូលបង្គំផង ដើម្បីឲ្យទូលបង្គំបានកាន់តាម សេចក្តីបន្ទាល់របស់ព្រះអង្គ។
[147]ទូលបង្គំក្រោកពីដំណេកមុនព្រលឹមស្រាង ហើយស្រែករកជំនួយ ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលរបស់ព្រះអង្គ។[148]ភ្នែកទូលបង្គំមិនបានលង់លក់ នៅអស់ទាំងយាមយប់ ដើម្បីឲ្យទូលបង្គំបានសញ្ជឹងគិត អំពីព្រះបន្ទូលសន្យារបស់ព្រះអង្គ។
[149]ព្រះអម្ចាស់អើយ សូមស្តាប់សំឡេងទូលបង្គំ តាមព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ សូមប្រទានឲ្យទូលបង្គំមានជីវិត តាមសេចក្តីយុត្តិធម៌របស់ព្រះអង្គ។[150]អស់អ្នកដែលបៀតបៀនទូលបង្គំ ដោយបំណងអាក្រក់ នាំគ្នាចូលមកជិត អ្នកទាំងនោះនៅឆ្ងាយពីក្រឹត្យវិន័យ របស់ព្រះអង្គ។
[151]ប៉ុន្តែ ឱព្រះអម្ចាស់អើយ ព្រះអង្គគង់នៅជិត ហើយបទបញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ សុទ្ធតែពិតត្រង់។[152]តាំងពីយូរមកហើយ ទូលបង្គំបានដឹង ដោយសារសេចក្តីបន្ទាល់របស់ព្រះអង្គថា ព្រះអង្គបានតាំងសេចក្តីទាំងនោះមក ឲ្យនៅអស់កល្បជានិច្ច។
[153]សូមទតមើលទុក្ខព្រួយរបស់ទូលបង្គំ ហើយរំដោះទូលបង្គំផង ដ្បិតទូលបង្គំមិនភ្លេចក្រឹត្យវិន័យ របស់ព្រះអង្គទេ។[154]សូមការពាររឿងក្តីរបស់ទូលបង្គំ ហើយលោះទូលបង្គំ សូមប្រទានឲ្យទូលបង្គំមានជីវិត តាមព្រះបន្ទូលសន្យារបស់ព្រះអង្គផង។
[155]ការសង្គ្រោះស្ថិតនៅឆ្ងាយពីមនុស្សអាក្រក់ ដ្បិតគេមិនស្វែងរកច្បាប់របស់ព្រះអង្គទេ។[156]ព្រះអម្ចាស់អើយ ព្រះហឫទ័យមេត្តាករុណា របស់ព្រះអង្គធំវិសេសណាស់ សូមប្រទានឲ្យទូលបង្គំមានជីវិត តាមវិន័យរបស់ព្រះអង្គ។
[157]អស់អ្នកដែលបៀតបៀន ហើយបច្ចាមិត្តរបស់ទូលបង្គំមានគ្នាច្រើន ប៉ុន្តែ ទូលបង្គំមិនបានបែរចេញ ពីសេចក្តីបន្ទាល់របស់ព្រះអង្គឡើយ។[158]ទូលបង្គំមើលទៅមនុស្សក្បត់ដោយស្អប់ខ្ពើមព្រោះគេមិនប្រតិបត្តិតាម ព្រះបន្ទូលរបស់ព្រះអង្គទេ។
[159]សូមទតមើលថា ទូលបង្គំស្រឡាញ់ ព្រះឱវាទរបស់ព្រះអង្គយ៉ាងណា ព្រះអម្ចាស់អើយ សូមប្រទានឲ្យទូលបង្គំ មានជីវិតរស់ តាមព្រះហឫទ័យសប្បុរស របស់ព្រះអង្គ។
[160]បូករួមទាំងអស់ ព្រះបន្ទូលរបស់ព្រះអង្គ ជាសេចក្តីពិត ហើយគ្រប់ទាំងវិន័យដ៏សុចរិតរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[161]ពួកអ្នកធំបានបៀតបៀន ទូលបង្គំដោយឥតហេតុ ប៉ុន្តែ ចិត្តទូលបង្គំស្ញប់ស្ញែងនឹងព្រះបន្ទូល របស់ព្រះអង្គ។[162]ទូលបង្គំរីករាយនឹងព្រះបន្ទូលរបស់ព្រះអង្គ ប្រៀបដូចជាមនុស្សដែលប្រទះនឹងរបឹបដ៏មានតម្លៃ។
[163]ទូលបង្គំស្អប់ ហើយខ្ពើមពាក្យភូតភរ តែទូលបង្គំស្រឡាញ់ក្រឹត្យវិន័យរបស់ព្រះអង្គ។[164]ទូលបង្គំសរសើរតម្កើងព្រះអង្គ មួយថ្ងៃប្រាំពីរដង ព្រោះតែវិន័យដ៏សុចរិតរបស់ព្រះអង្គ។
[165]អស់អ្នកដែលស្រឡាញ់ក្រឹត្យវិន័យ របស់ព្រះអង្គ មានសេចក្តីសុខដ៏លើសលប់ គ្មានអ្វីអាចធ្វើឲ្យគេជំពប់ដួលសោះឡើយ។[166]ព្រះអម្ចាស់អើយ ទូលបង្គំសង្ឃឹមដល់ការសង្គ្រោះរបស់ព្រះអង្គ ហើយទូលបង្គំប្រព្រឹត្តតាម បទបញ្ជារបស់ព្រះអង្គ។
[167]ព្រលឹងទូលបង្គំប្រតិបត្តិតាម សេចក្តីបន្ទាល់របស់ព្រះអង្គ ទូលបង្គំស្រឡាញ់សេចក្តីបន្ទាល់នោះ យ៉ាងក្រៃលែង។[168]ទូលបង្គំប្រតិបត្តិតាមសេចក្តីបង្រៀន និងសេចក្តីបន្ទាល់របស់ព្រះអង្គ ដ្បិតផ្លូវដែលទូលបង្គំប្រព្រឹត្ត សុទ្ធតែនៅចំពោះព្រះអង្គទាំងអស់។
[169]ព្រះអម្ចាស់អើយ សូមឲ្យសម្រែករបស់ទូលបង្គំ បានចូលទៅដល់ព្រះអង្គ សូមប្រទានឲ្យទូលបង្គំមានយោបល់ តាមព្រះបន្ទូលរបស់ព្រះអង្គផង។[170]សូមឲ្យពាក្យអង្វរបស់ទូលបង្គំ បានចូលទៅដល់ព្រះអង្គ សូមរំដោះទូលបង្គំ តាមព្រះបន្ទូលរបស់ព្រះអង្គផង។
[171]បបូរមាត់ទូលបង្គំនឹងហូរចេញជាពាក្យសរសើរ ដ្បិតព្រះអង្គបង្រៀនឲ្យទូលបង្គំ ស្គាល់ច្បាប់របស់ព្រះអង្គ។[172]អណ្តាតទូលបង្គំនឹងច្រៀង អំពីព្រះបន្ទូលរបស់ព្រះអង្គ ដ្បិតគ្រប់ទាំងបទបញ្ជារបស់ព្រះអង្គ សុទ្ធតែសុចរិតទាំងអស់។
[173]សូមឲ្យព្រះហស្តរបស់ព្រះអង្គ បានប្រុងប្រៀបនឹងជួយទូលបង្គំ ដ្បិតទូលបង្គំបានជ្រើសរើសយក សេចក្តីបង្រៀនរបស់ព្រះអង្គ។[174]ព្រះអម្ចាស់អើយ ទូលបង្គំចង់ឃើញការសង្គ្រោះរបស់ព្រះអង្គ ហើយក្រឹត្យវិន័យរបស់ព្រះអង្គ ជាទីរីករាយដល់ទូលបង្គំ។
[175]សូមឲ្យព្រលឹងទូលបង្គំរស់នៅ ហើយសរសើរតម្កើងព្រះអង្គ ហើយសូមឲ្យវិន័យរបស់ព្រះអង្គ ជួយទូលបង្គំផង។[176]ទូលបង្គំបានវង្វេងទៅ ដូចចៀមដែលបាត់បង់ សូមយាងមករកអ្នកបម្រើរបស់ព្រះអង្គផង ដ្បិតទូលបង្គំមិនភ្លេចបទបញ្ជា របស់ព្រះអង្គឡើយ។

Psalms 119:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេព្រើរ។

អេលភីអេ

នេះគឺជាឈ្មោះនៃអក្សរទីមួយនៃអក្ខរក្រមភាសាហេព្រើរ។

មានពរហើយ

«វាល្អសម្រាប់អ្នកទាំងនោះ»

អស់អ្នកដែលផ្លូវប្រព្រឹត្ត របស់ខ្លួនបានគ្រប់លក្ខណ៍

របៀបដែលមនុស្សម្នាក់មានការប្រព្រឹត្តត្រូវបានគេនិយាយថា៖ ជា «វិធី» ឬ «ផ្លូវ»។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលមានការប្រព្រឹត្តមិនចេះបន្ទោស» ឬ «អ្នកដែលគ្មាននរណាម្នាក់អាចស្តីបន្ទោស ចំពោះការធ្វើខុស»

ជាអ្នកដែលដើរតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់

របៀបដែលមនុស្សម្នាក់រស់នៅ ឬប្រព្រឹត្តត្រូវបានគេនិយាយថា៖ ជាការដើរ។ ការបកប្រែរបៀបផ្សេងទៀត: «ដែលរស់នៅស្របតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់» ឬ «អ្នកដែលគោរពច្បាប់របស់ព្រះអម្ចាស់»។ ឃ្លានេះបញ្ជាក់ពីអត្ថន័យនៃ «អ្នកដែលផ្លូវប្រព្រឹត្ត របស់ខ្លួនបានគ្រប់លក្ខណ៍»។

ជាអ្នកដែលស្វែងរកព្រះអង្គដោយអស់ពីចិត្ត

ដើម្បី «ស្វែងរក» ព្រះជាម្ចាស់មានន័យថា ចង់ស្គាល់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

ដោយអស់ពីចិត្ត
នេះគឺជាសំនួនវោហារស័ព្ទដែលមានន័យខ្លាំង ឬស្មោះត្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ជាមួយរបស់ទាំងអស់» ឬ
«ជាមួយអ្វីគ្រប់យ៉ាងនៅក្នុងពួកគេ» ឬ «ដោយស្មោះត្រង់»
Psalms 119:3
ព័ត៌មានទូទៅ:
ទំនុកតម្កើងនេះភាគច្រើនទាក់ទងនឹងព្រះជាម្ចាស់ ហើយពាក្យថា «ព្រះអង្គ» និង
«របស់ព្រះអង្គ» តែងតែសំដៅទៅលើព្រះអង្គ។
ជាអ្នកដែលមិនប្រព្រឹត្តអំពើទុច្ចរិត
ពួកគេមិនគោរពតាមព្រះអម្ចាស់ទេ។
ពួកគេដើរតាមផ្លូវរបស់ព្រះអង្គវិញ
ពួកគេដើរតាមផ្លូវរបស់ព្រះអម្ចាស់។
នៅទីនេះប្រព្រឹត្តរបស់ពួកគេត្រូវបានគេនិយាយថា៖ ជា «ការដើរ»
ហើយវិធីដែលព្រះជាម្ចាស់ចង់ឲ្យពួកគេប្រព្រឹត្តត្រូវបានគេនិយាយថា៖ ជា
«ផ្លូវរបស់ព្រះអង្គ»។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេប្រព្រឹត្តដូចព្រះអម្ចាស់ចង់ឲ្យពួកគេធ្វើ» (UDB)
ព្រះឱវាទរបស់ព្រះអង្គ
«គោរពតាមអ្វីទាំងអស់ដែលព្រះអង្គបានប្រកាសថា យើងគួរតែធ្វើ»
ដោយយកចិត្តទុកដាក់
នេះគឺត្រូវដឹង និងយល់ច្បាស់ពីបទបញ្ជារ និងគោរពអ្នកដែលបញ្ជារ។
Psalms 119:5
ទូលបង្គំនឹងបានតាំងឡើងខ្ជាប់ខ្ជួន
អ្នកនិពន្ធនិយាយអំពីការត្រូវបានបង្កើតឡើង នៅក្នុងបទបញ្ជារបស់ព្រះជាម្ចាស់
ដូចជាគ្មាននរណាម្នាក់អាចធ្វើឲ្យព្រះអង្គផ្លាស់ទីលំនៅបានទេ។
ប្រតិបត្តិតាមច្បាប់របស់ព្រះអង្គ
«ក្នុងការគោរពតាមច្បាប់របស់ព្រះអង្គ»
ទូលបង្គំនឹងមិនត្រូវខ្មាសឡើយ
អ្នកនិពន្ធមិនចង់ខ្មាស់អៀន នៅពេលគាត់នៅក្នុងវត្តមានរបស់ព្រះជាម្ចាស់។
បទបញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ
«អ្វីទាំងអស់ដែលព្រះអង្គបានបញ្ជាយើង»
Psalms 119:7
ដ៏សុចរិត
«ចិត្តស្មោះត្រង់»។ មនុស្សដែលស្មោះត្រង់នឹងធ្វើអ្វីដែលត្រឹមត្រូវ។
ចិត្តសំដៅទៅលើចំណុចកណ្តាលនៃអារម្មណ៍នៅក្នុងមនុស្សម្នាក់។
សូមមើលពីរបៀបបកប្រែ «ភាពទៀងត្រង់» ក្នុងជំពូក ២៥:២០។
ច្បាប់របស់ព្រះអង្គ
«ច្បាប់» សំដៅទៅលើច្បាប់ ឬបទបញ្ជារបស់ព្រះជាម្ចាស់។
Psalms 119:9
ប៊ែត
នេះគឺជាឈ្មោះនៃអក្សរទី ២ នៃអក្ខរក្រមហេប្រឺ។
នៅក្នុងភាសាហេប្រឺជួរនីមួយៗនៃខ ៩-១៦ ចាប់ផ្តើម ដោយអក្សរនេះ។
តើមនុស្សកំលោះធ្វើដូចម្តេច ដើម្បីរក្សាផ្លូវដែលខ្លួនប្រព្រឹត្តឲ្យបានបរិសុទ្ធ?
សំណួរនេះត្រូវបានប្រើ ដើម្បីណែនាំតម្លៃថ្មី ចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់។
សំណួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត:
«នេះជារបៀបដែលមនុស្សកំលោះធ្វើ ដើម្បីរក្សាផ្លូវដែលខ្លួនប្រព្រឹត្តឲ្យបានបរិសុទ្ធ»
ដើម្បីរក្សាផ្លូវដែលខ្លួនប្រព្រឹត្តឲ្យបានបរិសុទ្ធ
អ្នកនិពន្ធប្រៀបធៀបការរស់នៅស្របតាមច្បាប់របស់ព្រះជាម្ចាស់ជាផ្លូវមួយដែលមិនត្រូវ
ដោយអស់ពីចិត្តទូលបង្គំ
នេះគឺជាប្រយោគ។ ចិត្តសំដៅទៅលើផ្លូវចិត្ត អារម្មណ៍បំណងប្រាថ្នា និងឆន្ទៈ។
ការបកប្រែរបៀបផ្សេងទៀត: «ជាមួយទាំងអស់របស់ទូលបង្គំ» ឬ
«ជាមួយអ្វីគ្រប់យ៉ាងនៅក្នុងខ្លួនទូលបង្គំ» ឬ «ដោយស្មោះ»
សូមកុំឲ្យទូលបង្គំវង្វេងចេញពីបទបញ្ជារបស់ព្រះអង្គឡើយ
នៅទីនេះ ការមិនគោរពបទបញ្ជារបស់ព្រះជាម្ចាស់ត្រូវបានពិពណ៌នាថា
កំពុងវង្វេងផ្លូវ។ ការបកប្រែរបៀបផ្សេងទៀត:
«សូមកុំឲ្យទូលបង្គំមិនគោរពតាមបទបញ្ជារបស់ព្រះអង្គឡើយ»
Psalms 119:11
ទូលបង្គំបានរក្សាព្រះបន្ទូលព្រះអង្គទុកនៅក្នុងចិត្តរបស់ទូលបង្គំ
«ទូលបង្គំបានដាក់ព្រះបន្ទូលព្រះអង្គនៅក្នុងចិត្តរបស់ទូលបង្គំ»។
នេះគឺជាពាក្យប្រៀបធៀបដែលមានន័យថា «ទូលបង្គំបានចងចាំព្រះបន្ទូលរបស់
ព្រះអង្គ»។ ចិត្តត្រូវបានបង្ហាញជាធុងមួយដែលអាចផ្ទុកនូវអ្វីដែលមនុស្សគិត។
Psalms 119:13
រីករាយនឹងទ្រព្យសម្បត្តិគ្រប់យ៉ាង
«លើសពីទ្រព្យសម្បត្តិទាំងអស់»
Psalms 119:15
ទូលបង្គំនឹងសញ្ជឹងគិត...ហើយភ្នែកទូលបង្គំសម្លឹងមើល
ទូលបង្គំនឹងសញ្ជឹងគិត...ហើយភ្នែកទូលបង្គំសម្លឹងមើល
ទាំងនេះគឺជាគំនិតស្របគ្នាដែលមានអត្ថន័យស្រដៀងគ្នាដែលត្រូវបានធ្វើម្តងទៀតសម្រាប់ការសង្កត់ន័យ
សញ្ជឹងគិតពីសេចក្តីបង្រៀនរបស់ព្រះអង្គ
«គិតឲ្យច្បាស់អំពីអ្វីដែលព្រះអង្គបានណែនាំយើង»
យកចិត្តទុកដាក់
ប្រយោគនេះ សំដៅទៅលើការគិតឲ្យបានច្បាស់ អំពីអ្វីដែលកំពុងត្រូវបានពិភាក្សា។
ការបកប្រែរបៀបផ្សេងទៀត: «គិតឲ្យបានម៉ត់ចត់»
ទូលបង្គំមានចិត្តរីករាយ
ដើម្បីរីករាយ
Psalms 119:17
ជីមីល
នេះគឺជាឈ្មោះនៃអក្សរទីបី នៃអក្សរហេប្រឺ។ នៅក្នុងភាសាហេប្រឺជួរនីមួយៗនៃខ
១៧-២៤ ចាប់ផ្តើមដោយអក្សរនេះ។
អ្នកបម្រើរបស់ព្រះអង្គ
អ្នកនិពន្ធបានហៅខ្លួនឯងថាជា «ជាអ្នកបម្រើរបស់ព្រះអង្គ»
ដើម្បីបង្ហាញពីការបន្ទាបខ្លួនរបស់លោក។
សូមបំភ្លឺភ្នែកទូលបង្គំ ដើម្បីឲ្យទូលបង្គំបានឃើញ
អ្នកនិពន្ធនិយាយអំពីការទទួលបានការយល់ដឹង ចំណេះដឹង
និងប្រាជ្ញាដែលអាចមើលឃើញ។ ការបកប្រែរបៀបផ្សេងទៀត:
ជួយទូលបង្គំឲ្យយល់ដឹង»
ការដ៏អស្ចារ្យនៅក្នុងក្រឹត្យវិន័យរបស់ព្រះអង្គ
អ្នកនិពន្ធនិយាយពីការយល់ដឹង អំពីច្បាប់ជាអ្វីមួយដែលគួរឲ្យងឿងឆ្ងល់។
នៅក្នុងក្រឹត្យវិន័យរបស់ព្រះអង្គ
«នៅក្នុងការណែនាំរបស់ព្រះអង្គ» ឬ «នៅក្នុងបទបញ្ជារបស់ព្រះអង្គ»
Psalms 119:19
ទូលបង្គំជាមនុស្សស្នាក់អាស្រ័យ បណ្តោះអាសន្ននៅលើផែនដី
អាចមានន័យថា ១) អ្នកនិពន្ធនិយាយពីជីវិតខ្លីរបស់គាត់
នៅលើផែនដីហាក់ដូចជាគាត់ជាជនបរទេសដែលមិនស្នាក់នៅយូរ នៅលើផែនដី។
ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំដូចជាជនបរទេសដែលរស់នៅក្នុងរយៈពេលខ្លីនៅក្នុងផែនដី» ឬ ២)
ភាពល្ងង់ខ្លៅរបស់អ្នកនិពន្ធអំពីច្បាប់របស់ព្រះជាម្ចាស់
ដូចជាគាត់ជាជនបរទេសដែលមិនស្គាល់ច្បាប់នៃផែនដី។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំល្ងង់ដូចជនបរទេសនៅលើផែនដី»
ព្រលឹងទូលបង្គំសោកសង្រេង ដោយការចង់បាន
អ្នកនិពន្ធនិយាយពីបំណងប្រាថ្នារបស់គាត់ខ្លាំងណាស់ ដូចជាពួកគេឈឺចាប់។
ការបកប្រែរបៀបផ្សេងទៀត: «ផ្នែកខាងក្នុងរបស់ទូលបង្គំចង់ដឹងយ៉ាងខ្លាំង» ឬ
«អារម្មណ៍ទូលបង្គំឈឺចាប់ ព្រោះទូលបង្គំចង់ដឹងច្រើន»
Psalms 119:21
ជាពួកអ្នកដែលត្រូវបណ្តាសា
អាចមានន័យថា ១) ព្រះជាម្ចាស់នឹងដាក់បណ្តាសាដល់ពួកគេ ឬ ២)
ព្រោនាសាំងនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកណាសមនឹងទទួលទណ្ឌកម្មរបស់ព្រះអង្គ»
ជាពួកអ្នកដែលវង្វេងចេញពីបទបញ្ជា របស់ព្រះអង្គ
អ្នកនិពន្ធនិយាយពីការមិនគោរពបទបញ្ជារបស់ព្រះជាម្ចាស់
ហាក់ដូចជាពួកគេជាផ្លូវដែលអាចវង្វេងចេញពី។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកណាទៅឆ្ងាយពីផ្លូវនៃបទបញ្ជារបស់ព្រះអង្គ» ឬ
«អ្នកដែលមិនស្តាប់បង្គាប់បទបញ្ជារបស់ព្រះអង្គ»
សូមដកយកទូលបង្គំពី
«រក្សាទូលបង្គំពី» ឬ «សង្គ្រោះទូលបង្គំពី»
និងការមើលងាយ
«ហើយមានអារម្មណ៍ខ្មាស់អៀន និងល្ងីល្ងើ»
Psalms 119:23
ទោះបីពួកអ្នកធំបានអង្គុយប្រឹក្សាគ្នា ទាស់នឹងទូលបង្គំ

generated on Wed Sep 10 16:16:32 2025

«ទោះបីពួកអ្នកធំធ្វើផែនការធ្វើបាបទូលបង្គំ
ហើយនិយាយអាក្រក់ពីទូលបង្គំក៏ដោយ»
សេចក្តីបន្ទាល់របស់ព្រះអង្គជាទីសប្បាយរីករាយរបស់ទូលបង្គំ
«សេចក្តីបន្ទាល់របស់ព្រះអង្គ ធ្វើឲ្យទូលបង្គំរីករាយណាស់»។
ហើយសេចក្តីបន្ទាល់ទាំងនោះ ជាដំបូន្មានដល់ទូលបង្គំ
ច្បាប់របស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា៖ ពួកគេជាប្រជាជន។
ការបកប្រែរបៀបផ្សេងទៀត:
«ហើយពួកគេដូចជាអ្នកផ្តល់យោបល់ដ៏ឈ្លាសវៃចំពោះទូលបង្គំ» ឬ
«ហើយពួកគេផ្តល់ដំបូន្មានឲ្យទូលបង្គំ»
Psalms 119:25
ដាលីស
នេះគឺជាឈ្មោះនៃអក្សរទីបួន នៃអក្សរហេប្រឺ។ នៅក្នុងភាសាហេប្រឺជួរនីមួយៗនៃខ
២៥-៣២ ចាប់ផ្តើមដោយអក្សរនេះ។
ព្រលឹងទូលបង្គំជាប់ស្អិតនឹងធូលីដី
នេះគឺជាប្រយោគ។ អាចមានន័យថា ១) គាត់គិតថា គាត់នឹងស្លាប់ឆាប់ៗ ឬ ២)
គាត់ដេកនៅក្នុងធូលីដី ដោយសារគាត់ពិបាកចិត្តខ្លាំងណាស់ឬ ៣) គាត់ដឹងថា
គាត់ចង់បានរបស់ដែលគ្មានតម្លៃនៅលើផែនដី។
សូមប្រទានឲ្យទូលបង្គំមានជីវិត តាមព្រះបន្ទូលរបស់ព្រះអង្គផង
នេះគឺជាប្រយោគ។ នៅទីនេះ «ជីវិត» សំដៅទៅលើគោលបំណង
និងសារៈសំខាន់មិនត្រឹមតែជីវសាស្ត្រជីវិតប៉ុណ្ណោះទេ។
តាមព្រះបន្ទូលរបស់ព្រះអង្គ
«ព្រះបន្ទូល» របស់ព្រះជាម្ចាស់តំណាងឲ្យអ្វីដែលព្រះអង្គបានមានព្រះបន្ទូល។
នៅត្រង់នេះវាសំដៅទៅលើអ្វីដែលព្រះអង្គបានសន្យា។
ការបកប្រែរបៀបផ្សេងទៀត: «តាមការសន្យារបស់ព្រះអង្គ»
ផ្លូវប្រព្រឹត្តរបស់ទូលបង្គំ
អ្វីដែលមនុស្សម្នាក់ធ្វើ ឬអាកប្បកិរិយារបស់គេត្រូវបានគេនិយាយថា៖ ដូចជាផ្លូវ ឬ
វិថី។ ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលទូលបង្គំបានធ្វើ»
Psalms 119:27
ការបង្រៀនដ៏អស្ចារ្យ
«ការបង្រៀនដ៏អស្ចារ្យ»
ដោយទុក្ខព្រួយ
«ព្រោះទូលបង្គំពិបាកចិត្តណាស់»
សូមចម្រើនកម្លាំងទូលបង្គំ
«ធ្វើឲ្យទូលបង្គំរឹងមាំ»។ នេះអាចសំដៅទៅលើភាពរឹងមាំខាងរាងកាយ ឬ
កម្លាំងខាងវិញ្ញាណ។
Psalms 119:29
សូមដកផ្លូវភូតភរចេញឆ្ងាយពីទូលបង្គំ
ពាក្យថា «ផ្លូវ» នៅទីនេះសំដៅទៅលើផ្លូវនៃឥរិយាបទ។
ការបកប្រែរបៀបផ្សេងទៀត: «រក្សាទូលបង្គំពីផ្លូវបោកបញ្ឆោត» ឬ
«រារាំងទូលបង្គំពីការបោកបញ្ឆោត»
ការភូតភរ
អាចមានន័យថា ១) «និយាយកុហក» ឬ ២) «ការជឿកុហក» ឬ «
ធ្វើតាមការកុហក»។
ផ្លូវស្មោះត្រង់
របៀបដែលមនុស្សម្នាក់មានអាកប្បកិរិយា ឬ
សកម្មភាពត្រូវបានគេនិយាយដូចជាវាជាផ្លូវ ឬ វិថី។ ការបកប្រែរបៀបផ្សេងទៀត:
«ស្មោះត្រង់នឹងព្រះអង្គ»
Psalms 119:31
ទូលបង្គំជាប់ចិត្តនឹងសេចក្តីបន្ទាល់របស់ព្រះអង្គ
ការកាន់ពួកគេយ៉ាងម៉ឺងម៉ាត់គឺសំដៅទៅលើការប្តេជ្ញាចិត្តគោរពពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ចំពោះសេចក្តី
បន្ទាល់របស់ព្រះអង្គ» ឬ «ទូលបង្គំប្តេជ្ញាគោរពតាមសេចក្តីបន្ទាល់របស់ព្រះអង្គ»
ច្បាប់នៃសេចក្តីសញ្ញា
នេះសំដៅទៅលើច្បាប់របស់លោកម៉ូសេ។
ទូលបង្គំនឹងរត់តាមផ្លូវនៃបទបញ្ជារបស់ព្រះអង្គ
អ្នកនិពន្ធនិយាយអំពីការផ្តោតអារម្មណ៍ ឬ
ប្តេជ្ញាគោរពតាមបទបញ្ជារបស់ព្រះជាម្ចាស់
ដូចជាមនុស្សម្នាក់កំពុងដើរលើផ្លូវមួយ។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំ
នឹងប្តេជ្ញាគោរពតាមបទបញ្ជារបស់ព្រះអង្គ»
ព្រះអង្គបានពង្រីកចិត្តទូលបង្គំ
នេះគឺជាប្រយោគ។ អាចមានន័យថា ១)
«ព្រះអង្គជួយទូលបង្គំឲ្យយល់កាន់តែច្បាស់ អំពីបទបញ្ជារបស់ព្រះអង្គ» ឬ ២)
«ព្រះអង្គផ្តល់ឲ្យទូលបង្គំនូវបំណងប្រាថ្នាកាន់តែខ្លាំង
ដើម្បីគោរពតាមបទបញ្ជារបស់ព្រះអង្គ»
Psalms 119:33
ហ៊ី
នេះគឺជាឈ្មោះនៃអក្សរទីប្រាំ នៃអក្សរហេប្រឺ។ នៅក្នុងភាសាហេប្រឺជួរនីមួយៗនៃខ
៣៣-៤០ ចាប់ផ្តើមដោយអក្សរនេះ។
ច្បាប់របស់ព្រះអង្គ
នេះគឺជាវិធីមួយទៀតនៃការពិពណ៌នាអំពីច្បាប់របស់លោកម៉ូសេ។
ដល់ទីបំផុត
អាចមានន័យថា ១) «ទាំងស្រុង» ឬ ២) «ដល់ទីបញ្ចប់នៃជីវិតរបស់ទូលបង្គំ» ឬ
៣) «ដល់ទីបញ្ចប់»។
កាន់តាមក្រឹត្យវិន័យរបស់ព្រះអង្គ
«គោរពច្បាប់របស់ព្រះអង្គ»
ទូលបង្គំនឹងប្រតិបត្តិតាមយ៉ាងអស់ពីចិត្ត
«ទូលបង្គំប្រាកដជាគោរពច្បាប់របស់ព្រះអង្គ» ឬ
«ទូលបង្គំប្តេជ្ញាចិត្តទាំងស្រុងក្នុងការធ្វើអ្វីដែលនិយាយ»
យ៉ាងអស់ពីចិត្តទូលបង្គំ
នេះគឺជាប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត:
«ជាមួយការទាំងអស់របស់ទូលបង្គំ» ឬ «ជាមួយអ្វីគ្រប់យ៉ាងនៅក្នុងខ្លួនទូលបង្គំ»
ឬ «ដោយស្មោះត្រង់»
Psalms 119:35
សូមនាំទូលបង្គំទៅតាមផ្លូវច្រក នៃបទបញ្ជារបស់ព្រះអង្គ
«ណែនាំទូលបង្គំតាមបទបញ្ជារបស់ព្រះអង្គ» ឬ «បង្រៀនទូលបង្គំឲ្យ
គោរពតាមបទបញ្ជាររបស់ព្រះអង្គ»។
បទបញ្ជារបស់ព្រះជាម្ចាស់ត្រូវបានប្រៀបធៀបទៅនឹងផ្លូវដែលមនុស្សម្នាក់ដើរតាមការគោរពព្រះជាម្ចាស់។
សូមធ្វើឲ្យចិត្តទូលបង្គំផ្ទៀងទៅរក
នេះគឺជាប្រយោគ។ «ចិត្ត» នៅទីនេះសំដៅទៅលើឆន្ទៈ បំណងប្រាថ្នា
និងជម្រើសដែលដឹកនាំជីវិតរបស់មនុស្សម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឲ្យទូលបង្គំចង់បាន»
សេចក្តីបន្ទាល់របស់ព្រះអង្គ
«គោរពតាមសេចក្តីបន្ទាល់របស់ព្រះអង្គ»។
នេះគឺសំដៅទៅលើការគោរពច្បាប់របស់លោកម៉ូសេ។
សេចក្តីលោភលន់
«សេចក្តីបំណងប្រាថ្នាសម្រាប់ទ្រព្យសម្បត្តិ»។
នេះគឺសំដៅទៅលើទ្រព្យសម្បត្តិដែលទទួលបានដោយវិធីខុសច្បាប់ ឬ
ការធ្វើខុសចំពោះអ្នកដទៃ។
Psalms 119:37
សូមបង្វែរភ្នែកទូលបង្គំកុំឲ្យមើលអ្វីៗ ដែលឥតប្រយោជន៍
នេះគឺជាការប្រៀបធៀប
ដែលសំដៅទៅលើវត្ថុដែលចង់បានមួយដែលមិនមានតម្លៃអស់កល្បជានិច្ច។
ប្រទានឲ្យទូលបង្គំមានជីវិតរស់នៅ តាមផ្លូវរបស់ព្រះអង្គ
«ធ្វើឲ្យទូលបង្គំអាចរស់នៅដូចដែលព្រះអង្គចង់ឲ្យទូលបង្គំរស់នៅ»
ប្រទានឲ្យទូលបង្គំមានជីវិតរស់នៅវិញ
«ធ្វើឲ្យជីវិតទូលបង្គំរឹងមាំ» ឬ «ផ្តល់កម្លាំងឲ្យទូលបង្គំ»
សូមបញ្ជាក់ដល់អ្នកបម្រើព្រះអង្គតាម ព្រះបន្ទូលសន្យារបស់ព្រះអង្គ ជាសេចក្តីដែលទុកសម្រាប់អស់
អ្នក កោតខ្លាចព្រះអង្គ
«ធ្វើសម្រាប់អ្នកបម្រើរបស់ព្រះអង្គនូវអ្វីដែលព្រះអង្គបានសន្យាថា
និងធ្វើសម្រាប់អស់អ្នកដែលគោរពព្រះអង្គ»
អ្នកបម្រើព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត:«នាំពួកគេទៅឆ្ងាយដើម្បីដាក់ទណ្ឌកម្មពួកគេ»

---

126 ទំនុកច្រៀងតាមថ្នាក់។[1]កាលព្រះអម្ចាស់បានលើកមុខ ក្រុងស៊ីយ៉ូនឡើងវិញ យើងរាល់គ្នាបានដូចជាមនុស្ស ដែលយល់សប្តិ។
[2]ក្រោយមក មាត់យើងបានពេញដោយ សំណើចក្អាកក្អាយ ហើយអណ្តាតយើងក៏ពេញដោយ សម្រែកអរសប្បាយ នោះក្នុងចំណោមជាតិតសាសន៍នានា មានគេពោលថា «ព្រះអម្ចាស់បានធ្វើការ យ៉ាងធំសម្រាប់ពួកគេ»។[3]ព្រះអម្ចាស់បានធ្វើការយ៉ាងធំសម្រាប់យើងមែន ហើយយើងក៏អរសប្បាយ!
[4]ព្រះអម្ចាស់អើយ សូមលើកមុខយើងខ្ញុំឡើងវិញ ដូចជាទឹកជ្រោះនៅតំបន់ណេកិបផង។[5]អស់អ្នកដែលសាបព្រោះទាំងស្រក់ទឹកភ្នែក គេនឹងច្រូតបានវិញទាំងសម្រែកអរសប្បាយ។[6]អ្នកដែលកណ្តៀតពូជសម្រាប់សាបព្រោះ ចេញទៅទាំងយំ គេនឹងវិលត្រឡប់មកវិញ ទាំងសម្រែកអរសប្បាយ ព្រមទាំងយកកណ្តាប់មកជាមួយផង។

Psalms 126:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
ទំនុកច្រៀងតាមថ្នាក់
អាចមានន័យថា ១)
បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ
ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣)
បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក
១២០:១។
បានលើកមុខ ក្រុងស៊ីយ៉ូនឡើងវិញ
«ធ្វើឲ្យក្រុងស៊ីយ៉ូនរីកចម្រើនឡើងវិញ»
Psalms 126:2
មាត់យើងបានពេញដោយ សំណើចក្អាកក្អាយ
ការសើចត្រូវបានគេនិយាយថា៖ ដូចជាមាត់របស់ពួកគេគឺជាធុងមួយ
ហើយការសើចរបស់ពួកគេស្ថិតនៅក្នុងនោះ។
នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា
ការសើចនេះជាការឆ្លើយតបចំពោះសេចក្តីអំណររបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «យើងសើច ដោយរីករាយ»
អណ្តាតយើងក៏ពេញដោយ សម្រែកអរសប្បាយ

កិរិយាស័ព្ទ «ត្រូវបានបំពេញ» អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការច្រៀងត្រូវបានគេនិយាយថា៖ ដូចជាអណ្តាតរបស់ពួកគេគឺជាធុង
ហើយការច្រៀងគឺនៅក្នុងពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«អណ្តាតរបស់យើងបានពេញ ដោយការច្រៀង» ឬ «យើងបានច្រៀងចម្រៀង
ដោយអំណរ»
ពួកគេបានចំណោមជាតិសាសន៍នានា
«ប្រជាជននៃជាតិសាសន៍នានា និយាយគ្នា»។
សព្វនាមត្រូវបានប្រើមុននឹងណែនាំអ្វីដែលវាយោង។ នេះមិនធម្មតាទេ។
ព្រះអម្ចាស់បានធ្វើការយ៉ាងធំសម្រាប់យើងមែន ហើយយើងក៏អរសប្បាយ!
«យើងសប្បាយចិត្តណាស់
ព្រោះព្រះអម្ចាស់បានធ្វើការអស្ចារ្យទាំងនេះសម្រាប់យើង!»
Psalms 126:4
អស់អ្នកដែលសាបព្រោះទាំងស្រក់ទឹកភ្នែក...អ្នកដែលកណ្តៀតពូជសម្រាប់សាបព្រោះ ចេញទៅទាំងយំ...ព្រមទាំងយកកណ្តាប់មកជាមួយផង
ខទាំងពីរនេះស្របគ្នា។ ប្រយោគទីពីរមានអត្ថន័យដូចគ្នានឹងប្រយោគទីមួយដែរ
ប៉ុន្តែវាផ្តល់ព័ត៌មានលម្អិតបន្ថែមទៀត។
អស់អ្នកដែលសាបព្រោះទាំងស្រក់ទឹកភ្នែក
«អស់អ្នកដែលសាបព្រួស ដោយទឹកភ្នែក»

---

127 ទំនុកច្រៀងតាមថ្នាក់ ជាបទរបស់ស្តេចសាឡូម៉ូន។[1]ប្រសិនបើព្រះអម្ចាស់មិនសង់ផ្ទះទេ អស់អ្នកដែលសង់នឹងធ្វើការជាឥតប្រយោជន៍។ ប្រសិនបើព្រះអម្ចាស់មិនថែរក្សាទីក្រុងទេ អ្នកយាមល្បាតនឹងខំប្រឹងយាម ជាឥតប្រយោជន៍។[2]ការដែលអ្នករាល់គ្នាក្រោកឡើងតាំងពីព្រលឹម ហើយក្រចូលដេកនៅពេលយប់ ព្រមទាំងខំប្រឹងរកស៊ីចិញ្ចឹមជីវិតយ៉ាងពិបាក នោះជាការឥតប្រយោជន៍ ដ្បិតព្រះអង្គប្រោសប្រទានឲ្យពួកស្ងួនភ្ងារបស់ព្រះអង្គបានដេកលក់។
[3]មើល៍ កូនចៅជាមរតកមកពីព្រះអម្ចាស់ ហើយផលដែលកើតពីផ្ទៃ ជារង្វាន់ដែលព្រះអង្គប្រទាន។[4]កូនប្រុសៗដែលកើតមកកាលឪពុកនៅក្មេង នោះប្រៀបដូចជាព្រួញ នៅក្នុងដៃរបស់មនុស្សខ្លាំងពូកែ។[5]មានពរហើយអ្នកណា ដែលមានព្រួញពេញបំពង់។ អ្នកនោះនិយាយ នឹងខ្មាំងសត្រូវនៅមាត់ទ្វារក្រុង គេនឹងមិនត្រូវខ្មាសឡើយ។

Psalms 127:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
ទំនុកច្រៀងតាមថ្នាក់
អាចមានន័យថា ១)
បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ
ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣)
បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក
១២០:១។
ក្រោកឡើងតាំងពីព្រលឹម
មនុស្សដែលឧស្សាហ៍ធ្វើការច្រើនតែងតែត្រូវក្រោកពីព្រលឹម
ហើយត្រឡប់មកផ្ទះវិញពេលយប់ជ្រៅ។
រកស៊ីចិញ្ចឹមជីវិតយ៉ាងពិបាក
នេះគឺជាប្រយោគ។ នំប៉័ងច្រើន
តែងតែតំណាងឲ្យអាហារដែលមនុស្សម្នាក់ត្រូវការរាល់ថ្ងៃ ដើម្បីរស់នៅ។
ការបកប្រែរបៀបផ្សេងទៀត: «ខិតខំធ្វើការ ដើម្បីតម្រូវការប្រចាំថ្ងៃ»

Psalms 127:3
មរតក
«អំណោយ» ឬ «កម្មសិទ្ធិដែលមានតម្លៃ»។
ជាធម្មតាកូនៗទទួលបានមរតកពីឪពុកម្តាយរបស់ពួកគេ។
មរតកពីឪពុកម្តាយទៅកូនៗ។
ការអនុម័តនេះសំដៅទៅលើកូនចៅដែលជាមរតករបស់ឪពុកម្តាយ។
កូនប្រុសៗដែលកើតមកកាលឪពុកនៅក្មេង នោះប្រៀបដូចជាព្រួញ នៅក្នុងដៃរបស់មនុស្សខ្លាំងពូកែ
ព្រួញមានសារៈសំខាន់ណាស់ ចំពោះអ្នកចម្បាំង
ព្រោះពួកវាការពារគេក្នុងសមរភូមិ។ ក្មេងៗត្រូវបានគេនិយាយថា
ដូចជាពួកគេគឺជាព្រួញរបស់អ្នកចម្បាំង។ ការបកប្រែរបៀបផ្សេងទៀត:
«មានកូនច្រើននឹងជួយការពារអ្នក»
មានព្រួញពេញបំពង់
បំពង់គឺជាធុងសម្រាប់ដាក់ព្រួញ។ ការមានកូនច្រើនត្រូវបានគេនិយាយថា៖
ដូចជាកូនៗជាព្រួញនៅក្នុងបំពង់។ ការបកប្រែរបៀបផ្សេងទៀត:
«ផ្ទះដែលពោរពេញទៅដោយក្មេង» ឬ «ក្មេងជាច្រើន»

---

128 ទំនុកច្រៀងតាមថ្នាក់។[1]មានពរហើយអស់អ្នកដែលកោតខ្លាចព្រះអម្ចាស់ ជាអ្នកដែលដើរតាមផ្លូវរបស់ព្រះអង្គ។[2]អ្នកនឹងបានបរិភោគផល ចេញពីកម្លាំងដៃរបស់អ្នក អ្នកនឹងមានពរ ហើយមានសេចក្តីសុខ។
[3]ប្រពន្ធរបស់អ្នកនឹងបានដូចជា ដើមទំពាំងបាយជូរមានផ្លែ នៅក្នុងផ្ទះរបស់អ្នក កូនៗរបស់អ្នកនឹងបានដូចជា ដើមអូលីវនៅជុំវិញតុរបស់អ្នក។[4]មើល៍ មនុស្សដែលកោតខ្លាចព្រះអម្ចាស់ នឹងមានពរបែបនេះឯង។[5]សូមព្រះអម្ចាស់ប្រទានពរអ្នកពីក្រុងស៊ីយ៉ូន សូមឲ្យអ្នកបានឃើញភាពចម្រុងចម្រើន របស់ក្រុងយេរូសាឡិម អស់មួយជីវិតរបស់អ្នក។[6]សូមឲ្យអ្នកបានឃើញចៅរបស់អ្នកដែរ។ សូមឲ្យសេចក្តីសុខគ្របដណ្តប់លើអ៊ីស្រាអែល!

generated on Wed Sep 10 16:16:32 2025

Psalms 128:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
ទំនុកច្រៀងតាមថ្នាក់
អាចមានន័យថា ១) បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣) បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ១២០:១។
មានពរហើយអស់អ្នកដែលកោតខ្លាចព្រះអម្ចាស់
ឃ្លានេះកើតឡើងនៅក្នុងសម្លេងអកម្ម ដើម្បីជៀសវាងពីការក្លែងបន្លំថា ព្រះអម្ចាស់មានកាតព្វកិច្ចប្រទានពរដល់អ្នកដែលគោរពព្រះអង្គ។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់នឹងប្រទានពរដល់អស់អ្នកដែលគោរពព្រះអង្គ»
អ្នកនឹងបានបរិភោគផល ចេញពីកម្លាំងដៃរបស់អ្នក
មនុស្សម្នាក់អាចត្រូវបានសំដៅទៅលើដៃរបស់គេ ពីព្រោះនោះគឺជាផ្នែកនៃរាងកាយដែលគេធ្វើការជាមួយ។ ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលអ្នកផ្តល់ឲ្យ» ឬ «អ្វីដែលអ្នកធ្វើការសម្រាប់»
អ្នកនឹងមានពរ ហើយមានសេចក្តីសុខ
ពាក្យថា «ត្រូវបានប្រទានពរ» និង «សេចក្តីសុខ» មានអត្ថន័យស្រដៀងគ្នានិងសង្កត់ន័យលើការពេញចិត្តរបស់ព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់នឹងប្រទានពរដល់អ្នក ហើយធ្វើឲ្យអ្នកចម្រើនឡើង» ឬ «ព្រះអម្ចាស់នឹងធ្វើឲ្យអ្នកមានសុភមង្គល និងភាពរុងរឿង»។
Psalms 128:3
ដូចជាដើមទំពាំងបាយជូរមានផ្លែ នៅក្នុងផ្ទះរបស់អ្នក
ប្រពន្ធត្រូវបានគេនិយាយថា៖ ដូចជាដើមទំពាំងបាយជូរដែលបង្កើតផលបានច្រើន។ នេះបញ្ជាក់ថា កូនៗដូចជាផលផ្លែ ហើយប្រពន្ធនឹងមានកូនច្រើន។ ការបកប្រែរបៀបផ្សេងទៀត: «មានផលិតផលច្រើន ហើយផ្តល់ឲ្យអ្នកនូវកូនជាច្រើន»
កូនៗរបស់អ្នកនឹងបានដូចជា ដើមអូលីវ
កូនៗត្រូវបានគេប្រៀបធៀបទៅនឹងដើមអូលីវ ដោយវិធីដែលពួកគេលូតលាស់ដើម្បីព័ទ្ធជុំវិញអ្វីមួយ។ កូនៗនឹងព័ទ្ធជុំវិញតុ ហើយធ្វើឲ្យវាពេញ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងមានកូនជាច្រើនដែលនឹងលូតលាស់ និងរីចម្រើនឡើង»
ជុំវិញតុរបស់អ្នក
នេះសំដៅទៅលើកន្លែងដែលក្រុមគ្រួសារជួបជុំគ្នាបរិភោគ។ ជារឿយៗអស់អ្នកដែលបរិភោគតុរបស់បុរសគឺស្ថិតនៅក្រោមអំណាច ឬការគ្រប់គ្រងរបស់គាត់។
មនុស្សដែលកោតខ្លាចព្រះអម្ចាស់ នឹងមានពរបែបនេះឯង
នេះអាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទសកម្ម។ «ព្រះអម្ចាស់នឹងប្រទានពរដល់មនុស្សណាដែលគោរពព្រះអង្គ»
អស់មួយជីវិតរបស់អ្នក
«ពេញមួយជីវិតរបស់អ្នក»
សូមឲ្យសេចក្តីសុខគ្របដណ្តប់លើអ៊ីស្រាអែល
«សូមឲ្យអ៊ីស្រាអែលមានសន្តិភាព»

129 ទំនុកច្រៀងតាមថ្នាក់។[1]«តាំងពីខ្ញុំនៅក្មេង គេបានធ្វើទុក្ខខ្ញុំជាច្រើនដង» សូមឲ្យអ៊ីស្រាអែលពោលតាមឥឡូវនេះថា។[2]«តាំងពីខ្ញុំនៅក្មេង គេបានធ្វើទុក្ខខ្ញុំជាច្រើនដង តែគេមិនបានឈ្នះខ្ញុំឡើយ។[3]ពួកអ្នកភ្ជួរបានភ្ជួរលើខ្នងខ្ញុំ គេបានធ្វើគន្លងរបស់គេឲ្យវែង។
[4]ប៉ុន្តែ ព្រះអម្ចាស់សុចរិត ព្រះអង្គបានផ្តាច់ចំណង របស់មនុស្សអាក្រក់ចេញ។[5]សូមឲ្យអស់អ្នកដែលស្អប់ក្រុងស៊ីយ៉ូនត្រូវខ្មាស ហើយត្រឡប់ថយក្រោយទៅ។
[6]សូមឲ្យគេបានដូចជាស្មៅ ដែលដុះនៅលើដំបូលផ្ទះ ដែលស្វិតក្រៀមទៅ មុនពេលវាលូតលាស់ឡើង[7]ជាស្មៅដែលមិនបានពេញមួយក្តាប់ ក្នុងដៃរបស់អ្នកច្រូត ក៏មិនបានពេញដៃរបស់អ្នក ដែលចងជាកណ្តាប់ដែរ។[8]ហើយសូមកុំឲ្យអស់អ្នកដែលដើរតាមទីនោះ ពោលថា៖ «សូមឲ្យព្រះពរនៃព្រះអម្ចាស់ ស្ថិតនៅលើអ្នក! យើងឲ្យពរអ្នក ក្នុងព្រះនាមព្រះអម្ចាស់»។

Psalms 129:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
ទំនុកច្រៀងតាមថ្នាក់
អាចមានន័យថា ១) បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣) បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ១២០:១។
ពួកអ្នកភ្ជួរបានភ្ជួរលើខ្នងខ្ញុំ
ទម្រង់ការកាត់ពីការវាយត្រូវបានគេនិយាយថា អ្នកភ្ជួររាស់បានភ្ជួររាស់។ កសិករម្នាក់បានភ្ជួរយ៉ាងជ្រៅទៅក្នុងចម្ការ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្មាំងសត្រូវរបស់ខ្ញុំបានកាប់ខ្ញុំយ៉ាងខ្លាំងនៅលើខ្នង»
គេបានធ្វើគន្លងរបស់គេឲ្យវែង
នេះគឺជាការបន្តនៃការប្រៀបធៀបការភ្ជួរ។ «គន្លង» គឺជាខ្សែដែលកសិករភ្ជួរ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបានធ្វើការកាត់ឲ្យវែង»
Psalms 129:4
ព្រះអង្គបានផ្តាច់ចំណង របស់មនុស្សអាក្រក់ចេញ
អ៊ីស្រាអែលត្រូវបានគេនិយាយថា៖ ត្រូវបានចងភ្ជាប់ដោយមនុស្សអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានដោះលែងយើងពីសត្រូវរបស់យើង»
សូមឲ្យអស់អ្នកដែលត្រូវខ្មាសត្រឡប់ថយក្រោយ
ព្រះអម្ចាស់មិនត្រូវបានគេនិយាយយ៉ាងច្បាស់ថា ជាអ្នកដែលធ្វើកិច្ចការទាំងនេះទេ។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យព្រះអម្ចាស់ខ្មាស់គេ និងយកឈ្នះគេ»
Psalms 129:6
សូមឲ្យគេបានដូចជា...កណ្តាប់
អ្នកតែងទំនុកតម្កើងនិយាយពីខ្មាំងសត្រូវរបស់គាត់ដែលស្លាប់ ហើយមានចំនួនតិចណាស់។ ពួកវាត្រូវបានគេប្រៀបធៀបទៅនឹងស្មៅបន្តិចបន្តួចដែលដុះនៅលើដំបូលផ្ទះ ហើយក្រៀមស្វិតដែលមិនគ្រប់គ្រាន់សម្រាប់កាត់ ឬបាច់។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យពួកគេស្លាប់ ហើយប្រហែលជាមានមនុស្សតិចតួចណាស់ដែលពួកគេនឹងដូចជាស្មៅ...កណ្តាប់»
ព្រះពរនៃព្រះអម្ចាស់ ស្ថិតនៅលើអ្នក
«ព្រះអម្ចាស់ប្រទានពរដល់អ្នក»

130 ទំនុកច្រៀងតាមថ្នាក់។[1]ព្រះអម្ចាស់អើយ ពីក្នុងទីដ៏ជ្រៅ ទូលបង្គំស្រែករកព្រះអង្គ។[2]ឱព្រះអម្ចាស់អើយ សូមស្តាប់សំឡេងទូលបង្គំ សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យទូលអង្វរ របស់ទូលបង្គំផង។
[3]ព្រះអម្ចាស់ ប្រសិនបើព្រះអង្គកត់ចំណាំអំពើទុច្ចរិត ឱព្រះអម្ចាស់អើយ តើអ្នកណាអាចធន់នៅបាន?[4]ប៉ុន្តែ ព្រះអង្គមានព្រះហឫទ័យអត់ទោស ដើម្បីឲ្យគេបានកោតខ្លាចព្រះអង្គ។
[5]ទូលបង្គំរង់ចាំព្រះអម្ចាស់ ព្រលឹងទូលបង្គំរង់ចាំ ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលរបស់ព្រះអង្គ។[6]ព្រលឹងទូលបង្គំរង់ចាំព្រះអម្ចាស់ខ្លាំងជាងពួកអ្នកយាមរង់ចាំឲ្យបានដល់ពេលព្រឹកទៅទៀត។

generated on Wed Sep 10 16:16:32 2025

[7]អ៊ីស្រាអែលអើយ ចូរសង្ឃឹមដល់ព្រះអម្ចាស់។ ដ្បិតមានសេចក្ដីសប្បុរសនៅនឹងព្រះអម្ចាស់ ហើយមានសេចក្ដីប្រោសលោះ ជាបរិបូរនៅនឹងព្រះអង្គ។[8]ព្រះអង្គនឹងលោះអ៊ីស្រាអែលឲ្យរួចពីគ្រប់ទាំងអំពើទុច្ចរិតរបស់គេ។

Psalms 130:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។

ទំនុកច្រៀងតាមថ្នាក់

អាចមានន័យថា ១) បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣) បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ១២០:១។

ពីក្នុងទីដ៏ជ្រៅ

ភាពក្រៀមក្រំរបស់អ្នកនិពន្ធត្រូវបានគេនិយាយថា៖ ដូចជាធុង។ ភាពសោកសៅរបស់គាត់គឺចេញពីបាតធុង។ ភាពសោកសៅត្រូវបានគេនិយាយជាញឹកញាប់ថា ជាធុងដែលបំពេញពីកំពូលទៅបាត។ ការបកប្រែរបៀបផ្សេងទៀត: «ព្រោះខ្ញុំពិបាកចិត្តណាស់»

សូមផ្ទៀងព្រះកាណ៌ស្តាប់

ព្រះកាណ៌តំណាងឲ្យព្រះអម្ចាស់ ប៉ុន្តែដោយសារអ្នកនិពន្ធដឹងថា ព្រះអម្ចាស់ឮអ្វីៗទាំងអស់ ទូលបង្គំពិតជាសុំឲ្យព្រះអម្ចាស់ឆ្លើយតប។ ការបកប្រែរបៀបផ្សេងទៀត:«សូមស្តាប់» ឬ «សូមឆ្លើយតប»

ចំពោះការអង្វររបស់ទូលបង្គំសុំសេចក្ដីមេត្តាករុណា

«មេត្តាករុណា» មិនមែនជាអ្វីដែលអាចផ្តល់ឲ្យដោយរាងកាយដល់នរណាម្នាក់ឡើយ។ អ្នកនិពន្ធកំពុងសុំឲ្យព្រះអម្ចាស់មេត្តាករុណាដល់លោក។ ការបកប្រែរបៀបផ្សេងទៀត: «ចំពោះការអង្វររបស់ទូលបង្គំ ហើយសូមមេត្តាដល់ទូលបង្គំ»

Psalms 130:3

តើអ្នកណាអាចធន់នៅបាន?

អ្នកនិយាយប្រើសំណួរនេះ ដើម្បីបង្ហាញពីភាពឥតប្រយោជន៍នៃការគិតថា នរណាម្នាក់អាចឈរនៅក្នុងស្ថានភាពនេះ។ សំណួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាឃ្លា។ ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់អាចធន់បានទេ»។

តើអ្នកណាអាចធន់នៅបាន

«ឈរ» ជាញឹកញាប់តំណាងឲ្យការរត់គេចខ្លួន ឬរស់រានមានជីវិតនៅពេលនរណាម្នាក់វាយប្រហារ។ ក្នុងករណីនេះវានឹងអាចរួចផុតពីការដាក់ទណ្ឌកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់អាចរួចផុតពីទណ្ឌកម្មរបស់ព្រះអង្គ» ឬ «គ្មាននរណាម្នាក់អាចរួចជីវិតពីទណ្ឌកម្មរបស់ព្រះអង្គ»

Psalms 130:5

ព្រលឹងទូលបង្គំ

«ព្រលឹងទូលបង្គំ» តំណាងអ្នកតែងទំនុកតម្កើង។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំ»

ព្រលឹងទូលបង្គំរង់ចាំ

អ្នកតែងទំនុកតម្កើងត្រូវបានគេនិយាយថា៖ ដូចជាគាត់កំពុងរង់ចាំអ្វីមួយដោយក្តីរំពឹង។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំសង្ឃឹមថា» ឬ «ទូលបង្គំទុកចិត្ត» ឬ «ទូលបង្គំប្រាថ្នាចង់បានអ្វីមួយ»

ព្រលឹងទូលបង្គំរង់ចាំ...ជាជាងពួកអ្នកយាមរង់ចាំពេលព្រឹក

អ្នកតែងទំនុកតម្កើងនិយាយអំពីបំណងប្រាថ្នារបស់លោក ចំពោះព្រះជាម្ចាស់ដើម្បីជួយលោកដែលធំជាងការចង់បានដែលអស់អ្នកដែលធ្វើការពេញមួយយប់មានពេ (សូមមើល: [[rc://*/ta//man/translate/figs-simile]])

ពួកអ្នកយាម

ទាំងនេះគឺជាមនុស្សដែលជាអ្នកយាមទីក្រុង ឬវាលប្រឆាំងនឹងសត្រូវ ឬចោរប្លន់។ នៅទីនេះវាសំដៅទៅលើមនុស្សដែលជាអ្នកដែលត្រូវដេកនៅពេលយប់ដោយធ្វើបែបនេះ។

Psalms 130:7

អ៊ីស្រាអែលអើយ...អំពើទុច្ចរិតរបស់គេ

ប្រជាជនអ៊ីុស្រាអែលត្រូវបានគេនិយាយថា ដូចជាពួកគេជាមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអ៊ីុស្រាអែល...របស់ពួកគេ» ឬ «យើងជាប្រជាជនអ៊ីុស្រាអែល...របស់យើង»

---

131 ទំនុកច្រៀងតាមថ្នាក់ ជាបទរបស់ស្តេចដាវីឌ។[1]ព្រះអម្ចាស់ អើយ ទូលបង្គំគ្មានចិត្តអំនួតឡើយ ហើយភ្នែកទូលបង្គំក៏មិនមើលដោយឆ្មើងឆ្មៃដែរ ទូលបង្គំមិនយកចិត្តទុកដាក់នឹងការធំៗ និងអ្វីដែលអស្ចារ្យហួសល្បត់ទូលបង្គំឡើយ។
[2]ទូលបង្គំបានរម្ងាប់ចិត្ត ហើយធ្វើឲ្យព្រលឹងទូលបង្គំស្ងប់ ដូចកូនក្មេងដែលនៅជាប់នឹងទ្រូងម្តាយ គឺព្រលឹងនៅក្នុងខ្លួនទូលបង្គំ ដូចកូនក្មេងដែលបៅឆ្អែតស្កប់ស្កល់។[3]អ៊ីស្រាអែលអើយ ចូរសង្ឃឹមដល់ព្រះអម្ចាស់ ចាប់តាំងពីឥឡូវនេះ រហូតអស់កល្ប។

Psalms 131:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។

ទំនុកច្រៀងតាមថ្នាក់

អាចមានន័យថា ១) បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣) បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ១២០:១។

ទូលបង្គំគ្មានចិត្តអំនួតឡើយ ហើយភ្នែកទូលបង្គំក៏មិនមើលដោយឆ្មើងឆ្មៃដែរ

ចិត្ត និងភ្នែកតំណាងឲ្យមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំគ្មានចិត្តអំនួត ឬក្រអឺតក្រទម»

ទូលបង្គំមិនមានក្តីសង្ឃឹមដ៏អស្ចារ្យសម្រាប់ទូលបង្គំឡើយ

អាចមានន័យថា «ទូលបង្គំមិនរំពឹងថានឹងធ្វើរឿងអស្ចារ្យទេ» ឬ «ទូលបង្គំមិនគិតថាទូលបង្គំអស្ចារ្យទេ»។

ហួសល្បត់ពីទូលបង្គំ

រឿងដែលពិបាកពេកសម្រាប់មនុស្សម្នាក់ក្នុងការយល់ត្រូវបានគេនិយាយថា៖ ដូចជាពួកគេហួសពីមនុស្ស ឬឆ្ងាយពីមនុស្សដែលអាចទៅដល់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «រឿងដែលពិបាកយល់»

Psalms 131:2

ទូលបង្គំបានរម្ងាប់ចិត្ត ហើយធ្វើឲ្យព្រលឹងទូលបង្គំស្ងប់

ព្រលឹងតំណាងឲ្យមនុស្ស ឬអារម្មណ៍របស់ទូលបង្គំ។ មានភាពស្ងប់ស្ងាត់ និងសន្តិភាពត្រូវបានគេនិយាយថា៖ បានធ្វើឲ្យព្រលឹងរបស់មនុស្សម្នាក់នៅតែស្ងាត់ស្ងៀម។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំស្ងប់ស្ងាត់ និងសន្តិភាព»

ព្រលឹងនៅក្នុងខ្លួនទូលបង្គំ

ព្រលឹងតំណាងឲ្យមនុស្ស ឬអារម្មណ៍របស់ទូលបង្គំ។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំ»

កូនក្មេងដែលនៅជាប់នឹងទ្រូងម្តាយ

អ្នកតែងទំនុកតម្កើងនិយាយអំពីខ្លួនទ្រង់ស្កប់ស្កល់ ហើយសម្រាកដូចជាទ្រង់នៅក្មេងដែលលែងត្រូវការទឹកដោះពីម្តាយរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត: «មាតិកាដូចជាកូនតូចដែលលែងយំរកទឹកដោះម្តាយតែសម្រាកក្នុងដៃម្តាយ» ឬ «មាតិកា និងសម្រាក»

132

generated on Wed Sep 10 16:16:32 2025

ទំនុកច្រៀងតាមថ្នាក់។[1]ព្រះអម្ចាស់ សូមនឹកចាំពីព្រះបាទដាវីឌ និងពីគ្រប់ទាំងសេចក្ដីទុក្ខព្រួយរបស់លោក។[2]ពីដំណើរដែលលោកបានស្បថ ចំពោះព្រះអម្ចាស់ គឺបានស្បថ
ចំពោះព្រះដ៏ខ្លាំងពូកែ របស់លោកយ៉ាកុបថា។
[3]លោកបាននិយាយថា៖ «ទូលបង្គំនឹងមិនចូលទៅក្នុងផ្ទះរបស់ទូលបង្គំ ឬឡើងទៅដេកនៅលើគ្រែរបស់ទូលបង្គំដែរ[4]ទូលបង្គំនឹងមិនព្រមឲ្យភ្នែកទូលបង្គំដេក ឬឲ្យត្របក
ភ្នែកទូលបង្គំលង់លក់ឡើយ[5]ទាល់តែទូលបង្គំរកបានទីកន្លែងមួយ ថ្វាយព្រះអម្ចាស់ គឺជាព្រះពន្លាសម្រាប់ព្រះដ៏ខ្លាំងពូកែ របស់លោកយ៉ាកុប»។
[6]មើល៍ យើងខ្ញុំបានឮថា ហិបរបស់ព្រះអង្គនៅភូមិអេប្រាតា យើងក៏បានរកឃើញហិបនេះនៅវាលយ៉ាអើរ។[7]សូមឲ្យយើងខ្ញុំចូលទៅក្នុងព្រះពន្លារបស់ព្រះអង្គ សូមឲ្យយើងខ្ញុំ
ក្រាបថ្វាយបង្គំ នៅទៀបកំណល់ព្រះបាទរបស់ព្រះអង្គ។[8]ព្រះអម្ចាស់ សូមក្រោកឡើង សូមព្រះអង្គយាងចូលទៅក្នុងទីសម្រាក របស់ព្រះអង្គ ព្រមទាំងហិបនៃព្រះចេស្តា
របស់ព្រះអង្គផង។
[9]សូមឲ្យពួកសង្ឃរបស់ព្រះអង្គបានប្រដាប់កាយ ដោយសេចក្ដីសុចរិត ហើយឲ្យពួកអ្នកបរិសុទ្ធរបស់ព្រះអង្គ ស្រែក ហ៊ោដោយអំណរ។[10]ដោយយល់ព្រះបាទដាវីឌ ជាអ្នក
បម្រើរបស់ព្រះអង្គសូមកុំបោះបង់អ្នកដែលព្រះអង្គ បានចាក់ប្រេងតាំងឡើយ។
[11]ព្រះអម្ចាស់បានស្បថនឹងព្រះបាទដាវីឌ ដោយសេចក្ដីពិត ដែលព្រះអង្គនឹងមិនប្រែប្រួលឡើយថា៖ «ក្នុងចំណោមកូនប្រុសៗ ដែលកើតចេញពីខ្លួនអ្នក យើងនឹងតាំង
ម្នាក់ឲ្យអង្គុយលើបល្ល័ង្ករបស់អ្នក។[12]ប្រសិនបើកូនៗរបស់អ្នកកាន់តាម សេចក្ដីសញ្ញារបស់យើង និងសេចក្ដីបន្ទាល់ដែលយើងនឹងបង្រៀនដល់គេ នោះកូនៗរបស់គេក៏នឹង
អង្គុយលើបល្ល័ង្ក របស់អ្នកជារៀងរហូតដែរ»។
[13]ដ្បិតព្រះអម្ចាស់បានជ្រើសរើសក្រុងស៊ីយ៉ូន ព្រះអង្គសព្វព្រះហឫទ័យចង់បានក្រុងនេះ សម្រាប់ជាលំនៅរបស់ព្រះអង្គ។[14]«នេះជាទីសម្រាករបស់យើងរហូតតទៅ យើង
នឹងអាស្រ័យនៅទីនេះ ដ្បិតយើងមានចិត្តចង់បានក្រុងនេះ។
[15]យើងនឹងឲ្យពរក្រុងនេះមានអ្វីៗជាបរិបូរណ៍ យើងនឹងឲ្យអ្នកក្រនៅក្រុងនេះ មានអាហារបរិភោគឆ្អែតស្កប់ស្កល់។[16]ពួកសង្ឃរបស់ក្រុងនេះ យើងនឹងតាក់តែងដោយសេចក្ដី
សង្គ្រោះហើយពួកបរិសុទ្ធនៅក្រុងនេះ នឹងស្រែកហ៊ោដោយអំណរ។
[17]នៅទីនេះ យើងនឹងធ្វើឲ្យស្នែង របស់ដាវីឌដុះពន្លកឡើង យើងបានរៀបចំចង្កៀងមួយសម្រាប់អ្នក ដែលយើងបានចាក់ប្រេងតាំង។[18]យើងនឹងគ្របដណ្ដប់ខ្មាំងសត្រូវរបស់
គេ ដោយសេចក្ដីខ្មាស តែនៅលើក្បាលលោកវិញ នឹងមានមកុដដ៏រុងរឿង»។

Psalms 132:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។

ទំនុកច្រៀងតាមថ្នាក់

អាចមានន័យថា ១) បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣) បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ១២០:១។

សូមនឹកចាំពីព្រះបាទដាវីឌ

«ដោយសារអ្វីដែលបានកើតឡើងចំពោះព្រះបាទដាវីឌ»

សូមនឹកចាំ

«ចងចាំ» ឬ «គិតអំពី»

ព្រះដ៏ខ្លាំងពូកែ របស់លោកយ៉ាកុប

នេះសំដៅទៅលើព្រះជាម្ចាស់។

Psalms 132:3

ទ្រង់មានបន្ទូល

«ព្រះបាទដាវីឌបានមានបន្ទូល»

ទូលបង្គំនឹងមិនព្រមឲ្យភ្នែកទូលបង្គំដេក ឬឲ្យត្របកភ្នែកទូលបង្គំលង់លក់ឡើយ

ការដេក និងការសម្រាកត្រូវបានគេនិយាយថា៖ ដូចជាអ្វីដែលអាចផ្តល់ឲ្យ។ នៅទីនេះភ្នែក និងត្របកភ្នែកតំណាងឲ្យមនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំនឹងមិនអនុញ្ញាតឲ្យភ្នែករបស់ទូលបង្គំដេក ឬត្របកភ្នែករបស់ទូលបង្គំសម្រាក» ឬ «ទូលបង្គំនឹងមិនដេកលក់ ឬបិទភ្នែកហើយសម្រាក»

ទាល់តែទូលបង្គំរកបានទីកន្លែងមួយ ថ្វាយព្រះអម្ចាស់

ការកសាងកន្លែងសម្រាប់ព្រះអម្ចាស់ត្រូវបានគេនិយាយថា៖ ជាការរកកន្លែងសម្រាប់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត: «រហូតដល់ទូលបង្គំសង់កន្លែងសម្រាប់ព្រះអម្ចាស់»

ព្រះដ៏ខ្លាំងពូកែ របស់លោកយ៉ាកុប

នេះសំដៅទៅលើព្រះជាម្ចាស់។

Psalms 132:6

យើងខ្ញុំបានឮអំពីវានៅភូមិអេប្រាតា

ពាក្យថា «វា» ប្រហែលជាសំដៅទៅលើកន្លែងដែលទ្រូងដ៏ពិសិដ្ឋរបស់ព្រះជាម្ចាស់នៅ។ ឃ្លា «នៅភូមិអេប្រាតា» ប្រហែលជាសំដៅទៅលើកន្លែងដែលពួកគេស្ថិតនៅពេលដែលពួកគេបានឮអំពីវា។ នេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «យើងដែលនៅភូមិអេប្រាតាបានឮអំពីកន្លែងដែលទ្រូងដ៏ពិសិដ្ឋស្ថិតនៅ» ឬ «យើងនៅភូមិអេប្រាតាបានឮថា ហិបដ៏សក្ការៈនោះស្ថិតនៅយ៉ាអើរ»

វាលយ៉ាអើរ

យ៉ាអើរគឺប្រហែលជាឈ្មោះមួយផ្សេងទៀតសម្រាប់ទីក្រុងគីរីយ៉ាត ចារីម។ នេះប្រហែលជាសំដៅទៅលើវាលដែលនៅជុំវិញទីក្រុង។

ខ្ញុំក្រាបថ្វាយបង្គំ នៅទៀបកំណល់ព្រះបាទរបស់ព្រះអង្គ

ការថ្វាយបង្គំព្រះជាម្ចាស់នៅឯហិបនៃសម្ពន្ធមេត្រីត្រូវបានគេនិយាយថា៖ ការឱនក្បាលនៅទៀបកំណល់ព្រះបាទ ស្តេចដែលកំពុងគង់នៅលើបល្ល័ង្ករបស់ព្រះអង្គ។ នេះបង្ហាញពីទំនាក់ទំនង និងការចុះចូលចំពោះព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងចូលទៅក្នុងប្រអប់នៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ ហើយថ្វាយបង្គំព្រះអង្គជាស្តេច»

ព្រះអម្ចាស់ សូមក្រោកឡើង សូមព្រះអង្គយាងចូលទៅក្នុងទីសម្រាក របស់ព្រះអង្គ

កិរិយាស័ព្ទ «មក» អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ «ព្រះអម្ចាស់ សូមក្រោកឡើង សូមយាងមកកន្លែងសម្រាករបស់ព្រះអង្គវិញ»។

ទីសម្រាក របស់ព្រះអង្គ

កន្លែងដែលព្រះជាម្ចាស់បានជ្រើសរើសសម្រាប់មនុស្ស ដើម្បីថ្វាយបង្គំព្រះអង្គត្រូវបានគេនិយាយថា៖ ជាកន្លែងដែលព្រះអង្គសម្រាក ឬគង់នៅជារៀងរហូត។ ការបកប្រែរបៀបផ្សេងទៀត: «កន្លែងដែលព្រះអង្គសម្រាក» ឬ «ព្រះពន្លារបស់ព្រះអង្គ»

ព្រះអង្គ ព្រមទាំងហិបនៃព្រះចេស្តារបស់ព្រះអង្គផង!

អាចមានន័យថា ១) «មកឯហិបនៃព្រះចេស្តារបស់ព្រះអង្គ» ឬ ២) «មក ហើយយកហិបនៃព្រះចេស្តារបស់ព្រះអង្គមក»។

ហិបនៃព្រះចេស្តារបស់ព្រះអង្គ

«ហិបដែលបង្ហាញពីព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះអង្គ»។

Psalms 132:9

សូមឲ្យពួកសង្ឃរបស់ព្រះអង្គបានប្រដាប់កាយ ដោយសេចក្ដីសុចរិត

សេចក្ដីសុចរិតត្រូវបានគេនិយាយថា៖ ដូចជាសម្លៀកបំពាក់។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យមនុស្សទទួលស្គាល់ថា ពួកសង្ឃរបស់ព្រះអង្គមានភាពស្មោះត្រង់» ឬ «ទូលបង្គំចង់ឲ្យមនុស្សមើលឃើញពីរបៀបដែលពួកសង្ឃរបស់ព្រះអង្គតែងតែធ្វើអ្វីដែលត្រឹមត្រូវ»

ដោយយល់ព្រះបាទដាវីឌ ជាអ្នកបម្រើរបស់ព្រះអង្គ

«ដោយសារតែអ្វីដែលបានកើតឡើងចំពោះព្រះបាទដាវីឌជាអ្នកបម្រើរបស់ព្រះអង្គ»។ សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ១៣២:១។

សូមកុំបោះបង់អ្នកដែលព្រះអង្គ បានចាក់ប្រេងតាំងឡើយ

ត្រង់នេះ «ងាកចេញ» មានន័យថា បដិសេធនរណាម្នាក់។ ការបកប្រែរបៀបផ្សេងទៀត: «កុំបោះបង់ស្តេចដែលព្រះអង្គបានចាក់ប្រេងតាំងឡើយ»

Psalms 132:11

ក្នុងចំណោមកូនប្រុសៗ ដែលកើតចេញពីខ្លួនអ្នក យើងនឹងតាំងម្នាក់ឲ្យអង្គុយលើបល្ល័ង្ករបស់អ្នក

generated on Wed Sep 10 16:16:32 2025

ការនិយាយថា៖
ការធ្វើឲ្យកូនចៅរបស់ស្តេចក្លាយជាស្តេចជំនួសកន្លែងទ្រង់ត្រូវបានគេនិយាយថា៖
បានដាក់គាត់នៅលើបល្ល័ង្ករបស់ស្តេច។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើឲ្យកូនចៅរបស់អ្នកម្នាក់គ្រប់គ្រងលើអ៊ីស្រាអែលជំនួសអ្នក»
អង្គុយលើបល្ល័ង្ក របស់អ្នក
ការគ្រប់គ្រងដូចជាស្តេចត្រូវបានគេនិយាយថា កំពុងអង្គុយលើបល្ល័ង្ក។
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់គ្រងដូចជាស្តេច»
កូនៗរបស់អ្នក
នៅទីនេះ «កូនៗរបស់អ្នក»
តំណាងឲ្យកូនចៅរបស់ព្រះបាទដាវីឌដែលនឹងក្លាយជាស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «កូនចៅរបស់អ្នក»
Psalms 132:13
ព័ត៌មានទូទៅ:
«ព្រះអង្គ» «របស់យើង» និង «យើង» សំដៅទៅលើព្រះអម្ចាស់ និង «នាង»
សំដៅទៅលើក្រុងស៊ីយ៉ូន។
ក្រុងស៊ីយ៉ូន...នាង...នាង
អ្នកនិពន្ធសរសេរហាក់ដូចជា ទីក្រុងស៊ីយ៉ូនជាស្ត្រី។
ព្រះអង្គសព្វព្រះហឫទ័យចង់បានក្រុងនេះ សម្រាប់ជាលំនៅរបស់ព្រះអង្គ
ត្រង់នេះ «លំនៅ» តំណាងឲ្យ ១)
បល្ល័ង្ករបស់ព្រះអង្គជាកន្លែងដែលព្រះអង្គនឹងគ្រប់គ្រង ឬ ២)
ជាកន្លែងដែលព្រះអង្គនឹងគង់នៅ។
ព្រះអង្គសព្វព្រះហឫទ័យចង់បានក្រុងនេះ សម្រាប់ជាលំនៅរបស់ព្រះអង្គ
«ព្រះអម្ចាស់សព្វព្រះហឫទ័យចង់
បានក្រុងស៊ីយ៉ូនសម្រាប់ជាលំនៅរបស់ព្រះអម្ចាស់។»
នេះបង្ហាញអ្នកចូលរួមជាក់ស្តែង។
ទីសម្រាករបស់យើង
កន្លែងដែលព្រះជាម្ចាស់បានជ្រើសរើសសម្រាប់មនុស្ស
ដើម្បីថ្វាយបង្គំព្រះអង្គត្រូវបានគេនិយាយថា៖ ជាទីដែលព្រះអង្គសម្រាក
ឬគង់នៅជារៀងរហូត។ ការបកប្រែរបៀបផ្សេងទៀត: «កន្លែងដែលយើងគង់នៅ»
ឬ «ព្រះពន្លារបស់យើង»
Psalms 132:15
ប្រយោគភ្ជាប់:
ព្រះជាម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីទីក្រុងស៊ីយ៉ូន ដូចជាក្រុងស៊ីយ៉ូនជាស្ត្រី។
នឹងឲ្យពរក្រុងនេះមានអ្វីៗជាបរិបូរណ៍
«នឹងប្រទានពរយ៉ាងច្រើនដល់ក្រុងស៊ីយ៉ូន»
នឹងឲ្យអ្នកក្រនៅក្រុងនេះ មានទំប៉ុងបរិភោគឆ្អែតស្កប់ស្កល់
នៅទីនេះ «អ្នកក្រ» សំដៅទៅលើប្រជាជនក្រីក្រនៅក្រុងស៊ីយ៉ូន។ នៅទីនេះ
«នំប៉ុង» ប្រហែលជាតំណាងឲ្យម្ហូបជាទូទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងផ្គាប់ចិត្តប្រជាជនក្រីក្រនៅក្រុងស៊ីយ៉ូនជាមួយអាហារ»
ពួកសង្ឃរបស់ក្រុងនេះ យើងនឹងតាក់តែងដោយសេចក្តីសង្គ្រោះ
ការសង្គ្រោះត្រូវបានគេនិយាយដូចជាសម្លៀកបំពាក់។ អាចមានន័យថា ១)
«យើងនឹងធ្វើឲ្យពួក
សង្ឃមានអាកប្បកិរិយាសមនឹងអ្នកដែលយើងបានជួយសង្គ្រោះ»
Psalms 132:17
យើងនឹងធ្វើឲ្យស្នែង របស់ដាវីឌដុះពន្លកឡើង
ព្រះជាម្ចាស់មានព្រះបន្ទូលអំពីកូនចៅរបស់ព្រះបាទដាវីឌដែលមានអំណាចហាក់ដូចជាព្រះអង្គជាស្នែងដ៏
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើឲ្យកូនចៅព្រះបាទដាវីឌក្លាយជាស្តេចតាមទ្រង់» ឬ
«យើងនឹងធ្វើឲ្យព្រះបាទដាវីឌមានកូនចៅដែលនឹងក្លាយជាស្តេចដ៏មានឥទ្ធិពល»។
រៀបចំចង្កៀងមួយសម្រាប់អ្នក ដែលយើងបានចាក់ប្រេងតាំង
ព្រះជាម្ចាស់មានព្រះបន្ទូលអំពីការដែលធ្វើឲ្យកូនចៅរបស់ព្រះបាទដាវីឌបន្តគ្រប់គ្រងជាស្តេច
ដូចជាពួកគេដែលជាចង្កៀងដែលនឹងបន្តបញ្ចាំង។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើឲ្យកូនចៅម្នាក់ដែលយើងបានចាក់ប្រេងតាំងឲ្យបន្តគ្រប់គ្រងជាស្តេច»
យើងបានចាក់ប្រេងតាំង
«យើងបានជ្រើសរើសស្តេច» ឬ «ស្តេចដែលយើងបានជ្រើសរើស»
យើងនឹងគ្របដណ្តប់ខ្មាំងសត្រូវរបស់គេ ដោយសេចក្តីខ្មាស
ភាពអាម៉ាស់ត្រូវបានគេនិយាយថា៖ ដូចជាសម្លៀកបំពាក់។
ភាពអាម៉ាសជាលទ្ធិផលពីការបាត់បង់ក្នុងសង្គ្រាម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើឲ្យសត្រូវរបស់គេខ្មាស់» ឬ «យើងនឹងធ្វើឲ្យសត្រូវរបស់គេត្រូវចាញ់
និងអាម៉ាស់»
មកុដដ៏រុងរឿង
មកុដនេះតំណាងឲ្យការគ្រប់គ្រងរបស់ទ្រង់
ហើយភាពអស្ចារ្យត្រូវបានគេនិយាយថា៖ ជាពន្លឺចែងចាំង។
ការបកប្រែរបៀបផ្សេងទៀត: «ទ្រង់នឹងក្លាយជាស្តេចដ៏អស្ចារ្យ» ឬ
«ភាពអស្ចារ្យរបស់ទ្រង់នឹងភ្លឺចាំង»

---

133 ទំនុកច្រៀងតាមថ្នាក់។[1]មើល៍ ការដែលបងប្អូនរស់នៅជាមួយគ្នា ដោយចិត្តព្រមព្រៀងនោះជាការល្អ ហើយសមគួរយ៉ាងណាទៅ!
[2]គឺធៀបដូចជាប្រេងដ៏វិសេសដែលចាក់លើក្បាល ក៏ហូរចុះមកដល់ពុកចង្កា គឺជាពុកចង្ការបស់លោកអើរ៉ុន រួចស្រក់ទៅដល់ជាយអាវរបស់លោកផង។[3]ក៏ធៀបដូច
ជាទឹកសន្សើមនៅលើភ្នំហ៊ើរម៉ូន ដែលធ្លាក់មកលើភ្នំនៃក្រុងស៊ីយ៉ូន ដ្បិតនៅទីនោះ ព្រះអម្ចាស់បានបង្គាប់ឲ្យមានព្រះពរ គឺជាជីវិតដែលនៅអស់កល្បជានិច្ច។

Psalms 133:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
ទំនុកច្រៀងតាមថ្នាក់
អាចមានន័យថា ១)
បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ
ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣)
បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក
១២០:១។
មើល៍
ពាក្យនេះត្រូវបានប្រើ ដើម្បីបញ្ជាក់ពីសារៈសំខាន់នៃឃ្លាដែលមាននៅខាងក្រោម។
បងប្អូនរស់នៅជាមួយគ្នា
ទំនាក់ទំនងក្នុងចំណោមរាស្ត្ររបស់ព្រះជាម្ចាស់គឺនិយាយដូចជាពួកគេជាបងប្អូននឹងគ្នា
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីឲ្យប្រជាជនរបស់ព្រះជាម្ចាស់រស់នៅជាមួយគ្នា
ដោយសន្តិភាពដូចបងប្អូន»
Psalms 133:2
គឺធៀបដូចជាប្រេងដ៏វិសេសដែលចាក់លើក្បាល
ភាពល្អនៃសាមគ្គីភាពក្នុងចំណោមរាស្ត្ររបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា៖
ដូចជាប្រេងល្អដែលបានចាក់លើក្បាលរបស់លោកអើរ៉ុន។
ការបកប្រែរបៀបផ្សេងទៀត: «សាមគ្គីភាពនេះមានតម្លៃ
ដូចជាប្រេងដែលចាក់លើក្បាលរបស់លោកអើរ៉ុន»
ដូចជាទឹកសន្សើមនៅលើភ្នំហ៊ើរម៉ូន
ភាពល្អនៃសាមគ្គីភាពក្នុងចំណោមប្រជាជនរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា៖
នេះហាក់ដូចជាស្រស់ស្រាយដូចទឹកសន្សើម។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឲ្យស្រស់ស្រាយ ដូចជាទឹកសន្សើមនៅលើភ្នំហ៊ើរម៉ូន»
ភ្នំហ៊ើរម៉ូន
នេះជាភ្នំនៅអ៊ីស្រាអែលដែលមានព្រិលធ្លាក់ពេញមួយឆ្នាំ។

---

134 ទំនុកច្រៀងតាមថ្នាក់។[1]មក អស់អ្នកបម្រើរបស់ព្រះអម្ចាស់ ដែលឈរនៅក្នុងព្រះដំណាក់របស់ព្រះអង្គ នៅពេលយប់អើយ ចូរថ្វាយព្រះពរព្រះអម្ចាស់។[2]ចូរ
ប្រណម្យដៃទៅឯទីបរិសុទ្ធ ហើយថ្វាយព្រះពរព្រះអម្ចាស់។
[3]សូមព្រះអម្ចាស់ ដែលព្រះអង្គបង្កើតផ្ទៃមេឃ និងផែនដី ប្រទានពរអ្នករាល់គ្នាពីក្រុងស៊ីយ៉ូន។

---

generated on Wed Sep 10 16:16:32 2025

Psalms 134:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។

ទំនុកច្រៀងតាមថ្នាក់

អាចមានន័យថា ១) បទចំរៀងដែលមនុស្សបានច្រៀងពេលឡើងទៅក្រុងយេរូសាឡឹមសម្រាប់ការអបអរសាទរ ឬ ២) បទចំរៀងដែលមនុស្សច្រៀងពេលកំពុងឡើងជណ្តើរចូលព្រះវិហារ ឬ ៣) បទចំរៀងដែលពាក្យទាំងនោះដូចជាជំហាន។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ១២០:១។

អស់អ្នកបម្រើរបស់ព្រះអម្ចាស់

«អស់អ្នកដែលបម្រើព្រះអម្ចាស់»

ចូរប្រណម្យដៃ

នេះជារបៀបដែលមនុស្សបានអធិស្ឋាន ឬសរសើរព្រះជាម្ចាស់។

ទៅឯទីបរិសុទ្ធ

អាចមានន័យថា ១) «ទៅព្រះវិហារ» ឬ ២) «ទៅកន្លែងបរិសុទ្ធនៅក្នុងព្រះវិហារ»។

Psalms 134:3

ផ្ទៃមេឃ និងផែនដី

ឃ្លាថា «ផ្ទៃមេឃ និងផែនដី» នៅទីនេះតំណាងឲ្យអ្វីៗទាំងអស់។

ការបកប្រែរបៀបផ្សេងទៀត: «អ្វីៗនៅផ្ទៃមេឃនិងផែនដី»

---

135 [1]ចូរសរសើរតម្កើងព្រះអម្ចាស់។ ចូរសរសើរតម្កើងព្រះនាមព្រះអម្ចាស់ ឱពួកអ្នកបម្រើរបស់ព្រះអម្ចាស់អើយ ចូរនាំគ្នាសរសើរតម្កើង[2]អ្នករាល់គ្នាដែលឈរនៅក្នុងដំណាក់របស់ ព្រះអម្ចាស់គឺនៅក្នុងទីព្រះលាននៃព្រះដំណាក់របស់ព្រះជា ម្ចាស់នៃយើងអើយ។
[3]ចូរសរសើរតម្កើងព្រះអម្ចាស់ ដ្បិតព្រះអម្ចាស់ល្អ ចូរច្រៀងថ្វាយព្រះនាមព្រះអង្គ ដ្បិតនេះជាទីដ៏សប្បាយរីករាយ។[4]ដ្បិតព្រះអម្ចាស់ បានជ្រើសរើសយ៉ាកុប សម្រាប់ព្រះអង្គ គឺអ៊ីស្រាអែល ទុកជាកម្មសិទ្ធិរបស់ព្រះអង្គផ្ទាល់។
[5]ដ្បិតខ្ញុំដឹងថា ព្រះអម្ចាស់ធំអស្ចារ្យ ហើយថា ព្រះអម្ចាស់របស់យើង ព្រះអង្គខ្ពស់លើសអស់ទាំងព្រះ។[6]ព្រះអម្ចាស់ធ្វើការអ្វី ដែលព្រះអង្គសព្វព្រះហឫទ័យ នៅលើមេឃ និងនៅផែនដី នៅក្នុងសមុទ្រ និងអស់ទាំងទីជម្រៅ។
[7]ព្រះអង្គហើយដែលធ្វើឲ្យពពកឡើងពីចុងផែនដី ព្រះអង្គធ្វើឲ្យមានផ្លេកបន្ទោរសម្រាប់ភ្លៀង ក៏បញ្ចេញខ្យល់ពីឃ្លាំងរបស់ព្រះអង្គមកដែរ។
[8]ព្រះអង្គហើយដែលបានប្រហារ អស់ទាំងកូនច្បងរបស់សាសន៍អេស៊ីប ទាំងមនុស្ស ទាំងសត្វ។[9]អេស៊ីបអើយ ព្រះអង្គបានចាត់ទីសម្គាល់ និងការអស្ចារ្យ ឲ្យចូលទៅកណ្តាលឯង គឺឲ្យទាស់នឹងផារ៉ោន និងមហាតលិកទាំងប៉ុន្មានរបស់ទ្រង់។
[10]ព្រះអង្គបានប្រហារជាតិសាសន៍ជាច្រើន ហើយសម្លាប់ពួកស្តេចដ៏ខ្លាំងពូកែ[11]គឺស៊ីហុន ជាស្តេចសាសន៍អាម៉ូរី និងអុក ជាស្តេចនៅទឹកដីបាសាន ហើយអស់ទាំងនគរនៅស្រុកកាណាន។
[12]ព្រះអង្គបានប្រគល់ស្រុករបស់គេទុកជាមរតក គឺជាមរតកដល់អ៊ីស្រាអែល ជាប្រជារាស្ត្ររបស់ព្រះអង្គ។[13]ព្រះអម្ចាស់អើយ ព្រះនាមរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច ព្រះអម្ចាស់អើយ ព្រះកិត្តិនាមរបស់ព្រះអង្គ ក៏ស្ថិតស្ថេរជារៀងតទៅ។
[14]ដ្បិតព្រះអម្ចាស់នឹងវិនិច្ឆ័យ ឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ហើយមានព្រះហឫទ័យអាណិតអាសូរ ដល់ពួកអ្នកបម្រើរបស់ព្រះអង្គ។[15]ព្រះរបស់សាសន៍ដទៃសុទ្ធតែជារូប ធ្វើពីប្រាក់ និងមាស ដែលជាស្នាដៃរបស់មនុស្ស។[16]រូបទាំងនោះមានមាត់ តែមិនចេះនិយាយ មានភ្នែក តែមើលមិនឃើញ[17]មានត្រចៀក តែស្តាប់មិនឮ ក៏គ្មានខ្យល់ដង្ហើមនៅក្នុងមាត់ដែរ។[18]អស់អ្នកដែលធ្វើរូបទាំងនោះ នឹងត្រឡប់ដូចជារូបនោះឯង ហើយអស់អ្នកដែលទុកចិត្តនឹងរូបទាំងនោះ ក៏នឹងត្រឡប់ដូចជារូបទាំងនោះដែរ។
[19]ពូជពង្សអ៊ីស្រាអែលអើយ ចូរថ្វាយព្រះពរព្រះអម្ចាស់ ឱពូជពង្សអើរ៉ុនអើយ ចូរថ្វាយព្រះពរព្រះអម្ចាស់។[20]ឱពូជពង្សលេវីអើយ ចូរថ្វាយព្រះពរព្រះអម្ចាស់ អស់អ្នកដែលកោតខ្លាចព្រះអម្ចាស់អើយ ចូរថ្វាយព្រះពរព្រះអម្ចាស់។[21]សូមឲ្យព្រះអម្ចាស់បានប្រកបដោយព្រះពរ ពីក្រុងស៊ីយ៉ូន គឺព្រះអង្គដែលគង់នៅក្រុងយេរូសាឡិម។
សរសើរតម្កើងព្រះអម្ចាស់។

Psalms 135:1

ព័ត៌មានទូទៅ:

លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។

ចូរសរសើរតម្កើងព្រះនាមព្រះអម្ចាស់

ព្រះនាមរបស់ព្រះអម្ចាស់តំណាងឲ្យព្រះអង្គ។ «សរសើរតម្កើងដល់ព្រះអម្ចាស់» ឬ «សរសើរតម្កើងដល់ព្រះអង្គ»

ឈរនៅក្នុងដំណាក់របស់ព្រះអម្ចាស់

នេះតំណាងឲ្យការបម្រើព្រះអម្ចាស់នៅក្នុងព្រះវិហាររបស់ព្រះអង្គ។

ព្រះអម្ចាស់...ព្រះជាម្ចាស់នៃយើងអើយ

ត្រូវប្រាកដថា មនុស្សអាចយល់បានថាឃ្លា «ព្រះជាម្ចាស់នៃយើង» សំដៅទៅលើព្រះអម្ចាស់។

Psalms 135:3

ដ្បិតនេះជាទីដ៏សប្បាយរីករាយ

«ពីព្រោះយើងរីករាយនឹងការសរសើរព្រះនាមរបស់ព្រះអង្គ»

ព្រះអម្ចាស់ បានជ្រើសរើសយ៉ាកុប

«យ៉ាកុប» ត្រង់នេះសំដៅទៅលើកូនចៅរបស់លោកគឺ ប្រជាជនអ៊ីស្រាអែល។

ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអម្ចាស់បានជ្រើសរើសកូនចៅរបស់លោកយ៉ាកុប»

អ៊ីស្រាអែល ទុកជាកម្មសិទ្ធិរបស់ព្រះអង្គផ្ទាល់

ការចាប់ផ្តើមនៃប្រយោគអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។

ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអង្គបានជ្រើសរើសជនជាតិអ៊ីស្រាអែលជាកម្មសិទ្ធិរបស់ព្រះអង្គ»

Psalms 135:5

ព្រះអម្ចាស់របស់យើង ព្រះអង្គខ្ពស់លើសអស់ទាំងព្រះ

«ខ្ញុំដឹងថា ព្រះអម្ចាស់របស់យើងខ្ពស់ជាងព្រះទាំងអស់»។

ការដែលធំជាងអ្វីដែលគេនិយាយគឺខ្ពស់ជាងវា។ ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអម្ចាស់របស់យើងគឺធំជាងព្រះទាំងអស់»

Psalms 135:7

ក៏បញ្ចេញខ្យល់ពីឃ្លាំងរបស់ព្រះអង្គមកដែរ

ឃ្លាំងផ្ទុកទំនិញគឺជាកន្លែងមួយដែលរក្សាទុករបស់របរទុកសម្រាប់ប្រើប្រាស់នាពេលអនាគត។ រូបភាពនេះបង្ហាញពីអំណាចរបស់ព្រះជាម្ចាស់ក្នុងការគ្រប់គ្រងខ្យល់។

ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យខ្យល់បក់ ដោយអំណាចរបស់ព្រះអង្គ»

Psalms 135:8

ទីសម្គាល់ និងការអស្ចារ្យ

ពាក្យទាំងពីរនេះមានន័យដូចគ្នាជាមូលដ្ឋាន

ហើយវាសំដៅទៅលើការអស្ចារ្យដែលព្រះជាម្ចាស់បានបង្កនៅអេស៊ីប។

ឲ្យចូលទៅកណ្តាលឯង...អេស៊ីប

អ្នកតែងទំនុកតម្កើងនិយាយដូចជាប្រជាជនអេស៊ីបកំពុងស្តាប់ទ្រង់។

ការបកប្រែរបៀបផ្សេងទៀត: «ក្នុងចំណោមអ្នកប្រជាជនអេស៊ីប» ឬ «ក្នុងចំណោមប្រជាជនអេស៊ីប»

ទាស់នឹងផារ៉ោ

«ដើម្បីដាក់ទោសផារ៉ោ»

Psalms 135:10

ស៊ីហុន...អុក

ទាំងនេះជាឈ្មោះបុរសពីរនាក់។

Psalms 135:12

ព្រះអង្គបានប្រគល់ស្រុករបស់គេទុកជាមរតក

អំណោយរបស់ព្រះជាម្ចាស់ជាមរតករបស់អ៊ីស្រាអែល

ចំពោះជនជាតិអ៊ីស្រាអែលគឺដូចជាដីដែលជាចំណែកមរតកពីឪពុកទៅកូនប្រុស។

ការបកប្រែរបៀបផ្សេងទៀត:

«ព្រះអង្គបានប្រគល់ឲ្យយើងនូវទឹកដីរបស់ពួកគេជារៀងរហូត» រឺ

«ព្រះអង្គបានប្រគល់ឲ្យយើងនូវទឹកដីរបស់ពួកគេធ្វើជាកម្មសិទ្ធិរបស់យើងជារៀងរហូត»

ព្រះនាមរបស់ព្រះអង្គ

ព្រះនាមរបស់ព្រះអង្គ នៅទីនេះតំណាងឲ្យព្រះកិត្តិនាម ឬ

generated on Wed Sep 10 16:16:32 2025

ព្រះកេរ្តិ៍នាមរបស់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះកិត្តិនាមរបស់ព្រះអង្គ» ឬ «ព្រះកេរ្តិ៍នាមរបស់ព្រះអង្គ»
Psalms 135:19
ព្រះអង្គដែលគង់នៅក្រុងយេរូសាឡឹម

ព្រះជាម្ចាស់បានត្រូវគេនិយាយថា៖ ដូចជាព្រះអង្គគង់នៅក្រុងយេរូសាឡឹម
ពីព្រោះព្រះវិហារដែលជនជាតិអ៊ីុស្រាអែលថ្វាយបង្គំព្រះអង្គនៅទីនោះ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គដែលមានព្រះវិហារនៅក្រុងយេរូសាឡឹម»

---

136 [1]សូមអរព្រះគុណដល់ព្រះអម្ចាស់ ដ្បិតព្រះអង្គល្អ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។[2]សូមអរព្រះគុណដល់ព្រះដ៏ធំលើអស់ទាំងព្រះ
ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។[3]សូមអរព្រះគុណដល់ព្រះអម្ចាស់ ដ៏ធំលើអស់ទាំងព្រះអម្ចាស់ ដ្បិតព្រះហឫទ័យសប្បុរសរបស់
ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[4]គឺដល់ព្រះអង្គដែលធ្វើការអស្ចារ្យធំៗ តែមួយព្រះអង្គឯង ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[5]គឺដល់ព្រះអង្គដែលបានបង្កើតផ្ទៃមេឃ ដោយ
ប្រាជ្ញាញាណ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[6]គឺដល់ព្រះអង្គដែលបានក្រាលផែនដីនៅលើទឹក ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[7]គឺដល់ព្រះអង្គដែលបានបង្កើតតួពន្លឺធំៗ
ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[8]គឺព្រះអាទិត្យ ឲ្យគ្រប់គ្រងនៅពេលថ្ងៃ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[9]ព្រះច័ន្ទ និងហ្វូងផ្កាយ ឲ្យគ្រប់គ្រងនៅពេលយប់ ដ្បិត
ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[10]គឺដល់ព្រះអង្គដែលបានប្រហារ អស់ទាំងកូនច្បងរបស់ពួកអេស៊ីព្ទ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[11]ព្រះអង្គបាននាំអ៊ីស្រាអែល ចេញពី
ក្នុងចំណោមពួកគេ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[12]ដោយព្រះហស្តខ្លាំងពូកែ និងព្រះពាហុលើកសម្រេច ដ្បិតព្រះហឫទ័យសប្បុរស
របស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[13]គឺដល់ព្រះអង្គដែលបានញែក សមុទ្រក្រហមចេញជាពីរ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[14]ព្រះអង្គឲ្យសាសន៍អ៊ីស្រាអែល ដើរកាត់
កណ្តាលសមុទ្រនោះ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[15]តែព្រះអង្គបានបោះទម្លាក់ផារ៉ោន ព្រមទាំងពលទ័ពរបស់ស្តេច ទៅក្នុងសមុទ្រ
ក្រហម ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[16]គឺដល់ព្រះអង្គដែលបាននាំប្រជារាស្ត្រ របស់ព្រះអង្គដើរកាត់ទីរហោស្ថាន ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[17]គឺដល់ព្រះអង្គដែលបាន
ប្រហារស្តេចធំៗ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[18]ព្រះអង្គបានសម្លាប់ពួកស្តេចដ៏ខ្លាំងពូកែ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[19]គឺស៊ីហុន ជាស្តេចនៃសាសន៍អាម៉ូរី ដ្បិតព្រះហឫទ័យ
សប្បុរសរបស់ព្រះអង្គស្ថិតស្ថេរអស់កល្បជានិច្ច[20]និងអុក ជាស្តេចស្រុកបាសាន ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[21]ហើយប្រគល់ស្រុករបស់គេ ទុកជាមរតក ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[22]គឺជាមរតកដល់អ៊ីស្រាអែល ជាអ្នកបម្រើរបស់ព្រះអង្គ ដ្បិត
ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។[23]គឺព្រះអង្គហើយដែលបាននឹកចាំពីយើង កាលយើងនៅក្នុងសណ្ឋានទាបថោកនៅឡើយ ដ្បិតព្រះហឫទ័យ
សប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។
[24]ហើយបានសង្គ្រោះយើងឲ្យរួចពីខ្មាំងសត្រូវ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច[25]ព្រះអង្គជាព្រះដែលប្រទានអាហារ ដល់អស់ទាំងសាច់
ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។[26]សូមអរព្រះគុណដល់ព្រះនៃស្ថានសួគ៌ ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្ប
ជានិច្ច។

Psalms 136:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
សូម
នេះគឺជាការឧទានដែលគួរតែត្រូវបានបកប្រែជាមួយនឹងការឧទានសព្ទអ្វីដែលអ្នកសង្កេតឃើញនៅក្នុងភាសារបស់អ្នក
ដើម្បីឲ្យវាមានលក្ខណៈធម្មជាតិ។
ព្រះដ៏ធំលើអស់ទាំងព្រះ
ព្រះជាម្ចាស់ដែលធំជាងព្រះដែលមនុស្សឯទៀតគោរពបូជា
Psalms 136:4
ដោយប្រាជ្ញាញាណ
នោះគឺ ដោយសារតែព្រះអង្គមានប្រាជ្ញាញាណ។
Psalms 136:6
ក្រាលផែនដីនៅលើទឹក
ជនជាតិអ៊ីុស្រាអែលពីបុរាណបានគិតថា ដីស្ងួតនៅលើសមុទ្រ។
ការបកប្រែរបៀបផ្សេងទៀត: «ដាក់ផែនដីលើទឹក»
ពន្លឺធំៗ
នេះជាឯកសារយោងទៅប្រភពពន្លឺសម្រាប់ផែនដី ជាពិសេសព្រះអាទិត្យ
និងព្រះច័ន្ទ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ»
Psalms 136:8
ឲ្យគ្រប់គ្រងនៅពេលថ្ងៃ
ព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយត្រូវបានគេនិយាយថា៖ ដូចជាស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីសម្គាល់ពេលថ្ងៃ...ដើម្បីសម្គាល់ពេលយប់»
Psalms 136:10
ចេញពីក្នុងចំណោមពួកគេ
«ចេញពីក្នុងចំណោមប្រជាជននៃអេស៊ីប»
ដោយព្រះហស្តខ្លាំងពូកែ និងព្រះពាហុលើកសម្រេច
នៅទីនេះ «ព្រះហស្ត» និង «ពាហុ» តំណាងឲ្យអំណាច។

ការបកប្រែរបៀបផ្សេងទៀត: «ជាមួយអំណាចដ៏អស្ចារ្យ»
Psalms 136:13
សមុទ្រក្រហម
ទាហានរបស់ផារ៉ោនបានលង់ទឹកស្លាប់នៅសមុទ្រក្រហម។
[illegible]
នៅទីនេះការបរាជ័យត្រូវបានគេនិយាយថា៖ ដូចជាកំពុងយកនរណាម្នាក់។
ការបកប្រែរបៀបផ្សេងទៀត: «ផារ៉ោនបានបរាជ័យ» ឬ
«ស្តេចអេស៊ីបបានបរាជ័យ»
ព្រះចៅផារ៉ោន
នោះគឺជា កងទ័ពរបស់ព្រះចៅផារ៉ោន។
Psalms 136:18
ស៊ីហុន...អុក
ស្តេចទាំងនេះគ្រាន់តែជាស្តេចពីរអង្គក្នុងចំណោមស្តេចជាច្រើនដែលព្រះជាម្ចាស់បានអនុញ្ញាត
ឲ្យជនជាតិអ៊ីុស្រាអែលឲ្យយកឈ្នះ។
Psalms 136:21
បាននឹកចាំពីយើង
«គិតអំពីពួកយើង»
កាលយើងនៅក្នុងសណ្ឋានទាបថោកនៅឡើយ
ស្ថានភាពនៃការខ្ចាស់អៀនត្រូវបានគេនិយាយថា៖
ដូចជាកន្លែងដែលជនជាតិអ៊ីុស្រាអែលបានស្ថិតនៅ។
នេះជាឯកសារយោងជាច្រើនដងនៅពេលដែលខ្មាំងសត្រូវរបស់អ៊ីុស្រាអែលបានវាយឈ្នះពួកគេនៅក្នុង
និងធ្វើឲ្យពួកគេអាម៉ាស់មុខ។ ការបកប្រែរបៀបផ្សេងទៀត:
«យកចិត្តទុកដាក់នៅពេលដែលយើងត្រូវអាម៉ាស់»
Psalms 136:24
ហើយបានសង្គ្រោះយើងឲ្យរួចពីខ្មាំងសត្រូវ
បណ្តាលឲ្យមនុស្សមានជ័យជម្នះ
និងកម្ចាត់សត្រូវរបស់ពួកគេត្រូវបានគេនិយាយថា៖

generated on Wed Sep 10 16:16:32 2025

ផ្តល់ឲ្យពួកគេនូវជ័យជម្នះដូចជាជ័យជម្នះគឺជាវត្ថុដែលអាចផ្តល់ឲ្យ។
ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឲ្យយើងទទួលបានជ័យជម្នះលើសត្រូវរបស់យើង» ឬ
«បានធ្វើឲ្យយើងអាចកម្ចាត់សត្រូវរបស់យើង»

ព្រះនៃស្ថានសួគ៌
«ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌» ឬ
«ព្រះជាម្ចាស់ដែលអ្នកនៅស្ថានសួគ៌ថ្វាយបង្គំ»

---

137 [1]យើងបានអង្គុយចុះ នៅមាត់ទន្លេទឹកដីបាប៊ីឡូន យើងបានយំ ដោយនឹករឭកដល់ក្រុងស៊ីយ៉ូន។[2]នៅទីនោះ យើងបានព្យួរស៊ុងរបស់យើង នៅដើមចាក។
[3]ដ្បិតនៅទីនោះ ពួកអ្នកដែលនាំយើង ទៅជាឈ្លើយ បានសុំឲ្យយើងច្រៀង គឺពួកអ្នកដែលធ្វើទុក្ខយើង គេបានសុំឲ្យយើងលេង ឲ្យគេបានអរសប្បាយ គេពោលថា «ចូរច្រៀងបទមួយរបស់ក្រុងស៊ីយ៉ូន ឲ្យយើងស្តាប់ផង»។[4]តើឲ្យយើងច្រៀងបទរបស់ព្រះអម្ចាស់ នៅក្នុងប្រទេសដទៃដូចម្តេចកើត?
[5]ក្រុងយេរូសាឡិមអើយ ប្រសិនបើខ្ញុំភ្លេចអ្នក សូមឲ្យដៃស្តាំរបស់ខ្ញុំភ្លេចជំនាញរបស់វាទៅចុះ។[6]ប្រសិនបើខ្ញុំមិននឹកដល់អ្នកទេ ប្រសិនបើខ្ញុំមិនដាក់ក្រុងយេរូសាឡិម ឲ្យខ្ពស់លើសជាងអំណរដ៏ខ្ពស់បំផុតរបស់ខ្ញុំទេ នោះសូមឲ្យអណ្តាតខ្ញុំ ស្អិតជាប់នឹងក្រអូមមាត់ខ្ញុំទៅចុះ។
[7]ព្រះអម្ចាស់អើយ សូមនឹកចាំពីពួកអេដុម នៅថ្ងៃដែលក្រុងយេរូសាឡិមដួលរលំ គេពោលថា៖ «ចូររំលំវា ចូររំលំវាទៅ រំលំវាឲ្យដល់គ្រឹះទៅ»។
[8]កូនស្រីក្រុងបាប៊ីឡូនអើយ ឯងនឹងត្រូវវិនាសមិនខាន មានពរហើយ អ្នកណាដែលសងដល់ឯង តាមអំពើដែលឯងបានប្រព្រឹត្តចំពោះយើង។[9]មានពរហើយ អ្នកណាដែលនឹងចាប់កូនតូចរបស់ឯង ទៅបោកនឹងថ្ម។

Psalms 137:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
នៅមាត់ទន្លេទឹកដីបាប៊ីឡូន
«នៅជាប់នឹងទន្លេមួយនៅជិតក្រុងបាប៊ីឡូន»
យើងបានអង្គុយ ...បានយំ ...យើងនឹករឭក ...យើងបានព្យួរ
អ្នកនិពន្ធមិនរាប់បញ្ចូលអ្នកអានទេ។
នៅលើដើមចាក
ដើមចាកមិនលូតលាស់នៅអ៊ីស្រាអែលទេ។ «ដើមចាក»
នៅទីនេះអាចឈរសម្រាប់ដើមឈើទាំងអស់នៅបាប៊ីឡូន។
ការបកប្រែរបៀបផ្សេងទៀត: «នៅលើដើមឈើនៅបាប៊ីឡូន»
Psalms 137:3
ពួកអ្នកដែលនាំយើង ទៅជាឈ្លើយ បានសុំឲ្យយើងច្រៀង
នៅទីនេះ «ចម្រៀង» តំណាងឲ្យសកម្មភាពនៃការច្រៀង។
ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកដែលនាំយើង ទៅជាឈ្លើយ បានសុំឲ្យយើងច្រៀង»
គេបានសុំឲ្យយើងលេង ឲ្យគេបានអរសប្បាយ
«ធ្វើឲ្យពួកយើងធ្វើពុតជាសប្បាយចិត្ត»
បទច្រៀងមួយរបស់ក្រុងស៊ីយ៉ូន
នេះប្រហែលជាសំដៅទៅលើចម្រៀងដែលជនជាតិអ៊ីស្រាអែលបានប្រើក្នុងការថ្វាយបង្គំ
នៅព្រះវិហារនៅក្រុងយេរូសាឡឹម។
Psalms 137:5
ក្រុងយេរូសាឡឹមអើយ ប្រសិនបើខ្ញុំភ្លេចអ្នក
អ្នកនិពន្ធនិយាយដូចជាក្រុងយេរូសាឡឹមកំពុងស្តាប់គាត់។
ការបកប្រែរបៀបផ្សេងទៀត: «ក្រុងយេរូសាឡឹមអើយ
ប្រសិនបើខ្ញុំធ្វើដូចជាខ្ញុំមិនចាំអ្នក» ឬ «ក្រុងយេរូសាឡឹមអើយ
ប្រសិនបើខ្ញុំព្យាយាមបំភ្លេចអ្នក»
ដៃស្តាំ
ដៃដែលមនុស្សភាគច្រើនប្រើញឹកញាប់បំផុត

Psalms 137:7
សូមនឹកចាំ
«ចងចាំ» ឬ «គិតអំពី»
ព្រះអម្ចាស់អើយ សូមនឹកចាំពីអ្វីដែលពួកអេដុមបានធ្វើ
នៅទីនេះការចងចាំនូវអ្វីដែលជនជាតិអេដុមបានធ្វើតំណាងឲ្យការដាក់ទណ្ឌកម្មពួកគេចំពោះអ្វីដែលពួកគេបានធ្វើ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់អើយ ដាក់ទណ្ឌកម្មជនជាតិអេដុម ចំពោះអ្វីដែលពួកគេបានធ្វើ»
នៅថ្ងៃដែលក្រុងយេរូសាឡឹមដួលរលំ
ក្រុងយេរូសាឡឹមត្រូវបានចាប់ខ្លួន ដោយកងទ័ពសត្រូវត្រូវបានគេនិយាយថាដូចជាវាបានធ្លាក់ចុះ។
តើអ្នកណាដែលបានកាន់កាប់ក្រុងយេរូសាឡឹមអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ថ្ងៃដែលក្រុងយេរូសាឡឹមត្រូវបានគេចាប់យក» ឬ «ថ្ងៃដែលកងទ័ពបាប៊ីឡូនបានចូលក្នុងក្រុងយេរូសាឡឹម»
Psalms 137:8
ព័ត៌មានទូទៅ:
អ្នកតែងបទទំនុកតម្កើងបាននិយាយទៅកាន់ប្រជាជននៅបាប៊ីឡូន
ដូចជាពួកគេកំពុងតែស្តាប់គាត់ដែរ។
កូនស្រីក្រុងបាប៊ីឡូនអើយ
នេះតំណាងឲ្យទីក្រុងបាប៊ីឡូន និងប្រជាជននៅក្រុងនោះ។
ឱម្នុសឲ្យមនុស្សនោះបានទទួលព្រះពរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សូមព្រះប្រទានពរដល់មនុស្សនោះ»
សងដល់ឯង តាមអំពើដែលឯងបានប្រព្រឹត្តចំពោះយើង
អ្នកនិពន្ធនិយាយពីនរណាម្នាក់ដែលធ្វើចំពោះអ្នកដទៃនូវអ្វីដែលពួកគេបានធ្វើដូចជាការបង់សង។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើចំពោះអ្នកនូវអ្វីដែលអ្នកបានធ្វើ ចំពោះពួកយើង»
អ្នកណាដែលនឹងចាប់កូនតូចរបស់ឯង ទៅបោកនឹងថ្ម
«វាយក្បាលកូនរបស់អ្នកនឹងថ្ម»

---

138 ទំនុករបស់ស្តេចដាវីឌ[1]ព្រះអម្ចាស់អើយ ទូលបង្គំសូមអរព្រះគុណព្រះអង្គ យ៉ាងអស់ពីចិត្តរបស់ទូលបង្គំ ទូលបង្គំច្រៀងសរសើរព្រះអង្គ នៅចំពោះព្រះទាំងឡាយ។
[2]ទូលបង្គំក្រាបថ្វាយបង្គំ តម្រង់ទៅឯព្រះវិហារបរិសុទ្ធរបស់ព្រះអង្គ ហើយអរព្រះគុណដល់ព្រះនាមព្រះអង្គ ដោយព្រោះព្រះហឫទ័យសប្បុរស និងព្រះហឫទ័យស្មោះត្រង់របស់ព្រះអង្គ ដ្បិតព្រះអង្គបានលើកតម្កើង ព្រះបន្ទូលរបស់ព្រះអង្គ ខ្ពស់លើសជាងព្រះនាមរបស់ព្រះអង្គទៅទៀត។
[3]នៅថ្ងៃដែលទូលបង្គំបានអំពាវនាវ ព្រះអង្គបានឆ្លើយតបមកទូលបង្គំ ព្រះអង្គបានចម្រើនកម្លាំងចិត្តទូលបង្គំ។[4]ព្រះអម្ចាស់អើយ អស់ទាំងស្តេចនៅផែនដី នឹងអរព្រះគុណដល់ព្រះអង្គ ដ្បិតគេបានឮព្រះបន្ទូល ដែលចេញពីព្រះឧស្ឋរបស់ព្រះអង្គ។
[5]ហើយគេនឹងច្រៀងពីផ្លូវរបស់ព្រះអម្ចាស់ ដ្បិតសិរីល្អរបស់ព្រះអម្ចាស់ នោះធំក្រៃលែង។[6]ដ្បិតទោះបើព្រះអម្ចាស់ខ្ពស់ ក៏ព្រះអង្គនៅតែគិតដល់មនុស្សទន់ទាបជានិច្ច តែឯមនុស្សឆ្មើងឆ្មៃវិញ ព្រះអង្គស្គាល់គេពីចម្ងាយ។
[7]នៅពេលទូលបង្គំដើរនៅកណ្តាលទុក្ខវេទនា ព្រះអង្គរក្សាការពារជីវិតទូលបង្គំ ព្រះអង្គលើកព្រះហស្តឡើង ទាស់នឹងសេចក្តីក្រេវក្រោធ របស់ខ្មាំងសត្រូវទូលបង្គំ ហើយព្រះហស្តស្តាំរបស់ព្រះអង្គរំដោះទូលបង្គំ។[8]ព្រះអម្ចាស់នឹងសម្រេចគោលបំណង របស់ព្រះអង្គដល់ទូលបង្គំ ព្រះអម្ចាស់អើយ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។ សូមកុំបោះបង់ចោលស្នាព្រះហស្ត របស់ព្រះអង្គឡើយ។

Psalms 138:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
ទំនុករបស់ព្រះបាទដាវីឌ

generated on Wed Sep 10 16:16:32 2025

អាចមានន័យថា ១) ព្រះបាទដាវីឌបានសរសេរទំនុកតម្កើង ឬ ២)
បទទំនុកតម្កើងគឺនិយាយអំពីព្រះបាទដាវីឌ ឬ ៣) បទទំនុកតម្កើងគឺមានលក្ខណៈ
ដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
ទូលបង្គំសូមអរព្រះគុណព្រះអង្គ យ៉ាងអស់ពីចិត្តរបស់ទូលបង្គំ
ចិត្តនៅទីនេះតំណាងឲ្យអារម្មណ៍។ ធ្វើអ្វីមួយដោយស្មោះ
ឬទាំងស្រុងត្រូវបានគេនិយាយថា៖ ធ្វើវាដោយអស់ពីចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំនឹងអរគុណព្រះអង្គ ដោយស្មោះ»
នៅចំពោះព្រះទាំងឡាយ
អាចមានន័យថា ១) «ទោះបីមានរូបព្រះក្លែងក្លាយដែលមានស្រាប់» ឬ ២)
«នៅចំពោះមុខការប្រជុំនៅស្ថានសួគ៌» ដែលមានន័យថា
«ចំនេះដឹងដល់ពួកទេវតានៅស្ថានសួគ៌»។
ទូលបង្គំនឹងក្រាបថ្វាយបង្គំ
ការក្រាបថ្វាយបង្គំគឺជាសញ្ញាតំណាងឲ្យការគោរព និងផ្តល់កិត្តិយស។
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំនឹងថ្វាយបង្គំព្រះអង្គ»
អរព្រះគុណដល់ព្រះនាមព្រះអង្គ
«អរព្រះគុណដល់ព្រះអង្គ»
ព្រះបន្ទូលរបស់ព្រះអង្គ
នេះសំដៅទៅលើអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូល។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលព្រះអង្គបានមានព្រះបន្ទូល» ឬ
«ព្រះបន្ទូលបង្គាប់ និងការសន្យារបស់ព្រះអង្គ»
ព្រះនាមព្រះអង្គ
អាចមានន័យថា ១) «ព្រះអង្គផ្ទាល់» ឬ ២) «កិត្តិនាមរបស់ព្រះអង្គ»។
Psalms 138:3
អស់ទាំងស្តេចនៅផែនដី
«មេដឹកនាំទាំងអស់នៅលើពិភពលោក»
ព្រះឧស្ឋរបស់ព្រះអង្គ
ឃ្លានេះតំណាងឲ្យព្រះជាម្ចាស់។ «ព្រះអង្គ»
Psalms 138:5
ព្រះអម្ចាស់ខ្ពស់ ក៏ព្រះអង្គនៅតែគិតដល់មនុស្សទន់ទាបជានិច្ច
ព្រះអម្ចាស់គឺខ្ពស់ជាងការបង្កើតទាំងអស់នៅក្នុងអំណាច ឋានៈ និងសិទ្ធិអំណាច។
ប៉ុន្តែចំណាប់អារម្មណ៍របស់ព្រះអង្គគឺ
ចំពោះអស់អ្នកដែលមានចិត្តរាបទាបខាងស្មារតី អ្នកបម្រើទាំងអស់។
នេះគឺជាការផ្ទុយគ្នាសាមញ្ញ។
មនុស្សឆ្មើងឆ្មៃវិញ ព្រះអង្គស្គាល់គេពីចម្ងាយ
ការបញ្ចេញមតិនេះប្រហែលជាមានន័យថា
ព្រះជាម្ចាស់មិនស្មោះត្រង់នឹងអ្នកដែលមានអំនួតឡើយ។
Psalms 138:7
ដើរ
រស់ មាន
នៅកណ្តាលទុក្ខវេទនា
កំពុងស្ថិតក្នុងទុក្ខវេទនាត្រូវបានគេនិយាយថា
កំពុងស្ថិតក្នុងស្ថានភាពខាងរាងកាយ។
ព្រះអង្គលើកព្រះហស្តឡើង ទាស់នឹងសេចក្តីក្រេវក្រោធ របស់ខ្មាំងសត្រូវទូលបង្គំ
ព្រះជាម្ចាស់ត្រូវបានគេនិយាយថា៖ ដូចជាព្រះអង្គនឹងវាយប្រហារខ្មាំងសត្រូវ ដោយ
ព្រះហស្តរបស់ព្រះអង្គ។
សេចក្តីក្រេវក្រោធ របស់ខ្មាំងសត្រូវទូលបង្គំ
សេចក្តីក្រេវក្រោធត្រូវបានគេនិយាយថា៖ ដូចជាវាជារឿងជំនួសអារម្មណ៍។
ការបកប្រែរបៀបផ្សេងទៀត: «ខ្មាំងសត្រូវរបស់ទូលបង្គំ ដែលមានសេចក្តី
ក្រេវក្រោធ»
ស្នាព្រះហស្ត របស់ព្រះអង្គ
ព្រះជាម្ចាស់ត្រូវបានគេនិយាយថា៖ ដូចជាព្រះអង្គបានប្រើព្រះហស្ត ដើម្បីបង្កើត។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានបង្កើត»
ជាអ្នកដែលស្នាព្រះហស្ត របស់ព្រះអង្គបានបង្កើត
ឃ្លានេះប្រហែលជាសំដៅទៅលើប្រជាជាតិអ៊ីុស្រាអែល។

---

139 ទំនុករបស់ស្តេចដាវីឌ ដែលទ្រង់លើកសម្រាប់មេភ្លេង។[1]ព្រះអម្ចាស់អើយ ព្រះអង្គបានពិនិត្យមើលទូលបង្គំ ហើយបានស្គាល់ទូលបង្គំ។[2]ព្រះអង្គជ្រាបពេលដែល
ទូលបង្គំអង្គុយចុះនិងពេលដែលទូលបង្គំក្រោកឡើង ព្រះអង្គយល់គំនិតរបស់ទូលបង្គំតាំងពីចម្ងាយ។
[3]ព្រះអង្គពិនិត្យពិចារណាផ្លូវច្រករបស់ទូលបង្គំ និងទីដេកសម្រាករបស់ទូលបង្គំ ហើយស្គាល់អស់ទាំងផ្លូវប្រព្រឹត្តរបស់ទូលបង្គំ។[4]ដ្បិត ព្រះអម្ចាស់អើយ សូម្បីតែពាក្យសម្តី
មិនទាន់មាន នៅអណ្តាតទូលបង្គំនៅឡើយ នោះព្រះអង្គក៏ជ្រាបគ្រប់ជំពូកទៅហើយ។[5]ព្រះអង្គបានព័ទ្ធទូលបង្គំជិត ពីមុខពីក្រោយហើយបានដាក់ព្រះហស្តលើទូលបង្គំ។
[6]ការជ្រាបច្បាស់បែបនេះអស្ចារ្យពេកសម្រាប់ទូលបង្គំ គឺខ្ពស់ណាស់ ទូលបង្គំមិនអាចយល់បានឡើយ។
[7]តើទូលបង្គំនឹងទៅឯណា ឲ្យផុតពីព្រះវិញ្ញាណរបស់ព្រះអង្គបាន? តើទូលបង្គំនឹងរត់ទៅឯណា ឲ្យផុតពីព្រះវត្តមានរបស់ព្រះអង្គបាន?[8]ប្រសិនបើទូលបង្គំឡើងទៅស្ថានសួគ៌
ព្រះអង្គគង់នៅទីនោះ ប្រសិនបើទូលបង្គំរៀបដំណេក នៅស្ថានឃុំនៅព្រលឹងមនុស្សស្លាប់ ព្រះអង្គគង់នៅទីនោះ។
[9]ប្រសិនបើទូលបង្គំពាក់ស្លាបហោះ ទៅទិសព្រះអាទិត្យរះ ហើយទៅរស់នៅឯទីបំផុតនៃសមុទ្រ។[10]ក៏គង់តែព្រះហស្តរបស់ព្រះអង្គ នឹងនាំទូលបង្គំនៅទីនោះ ហើយព្រះហស្ត
ស្តាំរបស់ព្រះអង្គ នឹងក្តាប់ទូលបង្គំជាប់។
[11]ប្រសិនបើទូលបង្គំពោលថា៖ «ប្រាកដជាភាពងងឹតនឹងគ្របពីលើខ្ញុំ ហើយពន្លឺដែលនៅជុំវិញខ្ញុំ នឹងត្រឡប់ទៅជាយប់»[12]នោះសូម្បីតែភាពងងឹត ក៏លាក់ពីព្រះអង្គមិនបាន
ឡើយ គឺយប់ភ្លឺដូចជាថ្ងៃ ដ្បិតភាពងងឹត និងពន្លឺ ស្មើគ្នានៅចំពោះព្រះអង្គ។
[13]ដ្បិតគឺព្រះអង្គហើយដែលបានបង្កើត ចិត្តថ្លើមទូលបង្គំ ហើយបានផ្សំគ្រឿងទូលបង្គំនៅក្នុងផ្ទៃម្តាយ។[14]ទូលបង្គំសូមសរសើរតម្កើងព្រះអង្គ ដ្បិតព្រះអង្គបានបង្កើត
ទូលបង្គំមក គួរឲ្យស្ញប់ស្ញែង ហើយអស្ចារ្យ ស្នាព្រះហស្តរបស់ព្រះអង្គសុទ្ធតែអស្ចារ្យព្រលឹងទូលបង្គំដឹងច្បាស់ណាស់។
[15]កាលទូលបង្គំបានកកើតឡើងក្នុងទីកំបាំង គឺបានចាក់ស្រេះយ៉ាងស្មុគស្មាញ ក្នុងទីជ្រៅនៃផែនដី នោះគ្រោងកាយរបស់ទូលបង្គំ មិនកំបាំងនឹងព្រះអង្គឡើយ។[16]ព្រះនេត្រ
របស់ព្រះអង្គ បានឃើញធាតុនៃទូលបង្គំ តាំងពីទូលបង្គំមិនទាន់មានរូបរាងនៅឡើយ។ គ្រប់ទាំងអស់សុទ្ធតែបានកត់ទុក ក្នុងបញ្ជីរបស់ព្រះអង្គ គឺអស់ទាំងថ្ងៃអាយុដែល
បានតម្រូវ ឲ្យទូលបង្គំរស់នៅ មុននឹងមានថ្ងៃទាំងនោះមកដល់ទៅទៀត។
[17]ព្រះជាម្ចាស់ ព្រះតម្រិះរបស់ព្រះអង្គ មានតម្លៃវិសេសដល់ទូលបង្គំណាស់ គឺមានច្រើនឥតគណនា![18]ប្រសិនបើទូលបង្គំខំប្រឹងរាប់ នោះមានច្រើនជាងគ្រាប់ខ្សាច់ទៅទៀត
កាលណាទូលបង្គំភ្ញាក់ឡើង នោះទូលបង្គំនៅជាមួយព្រះអង្គដដែល។
[19]ព្រះជាម្ចាស់ សូមទ្រង់ប្រហារមនុស្សអាក្រក់ទៅមនុស្សកម្ចាយឈាមអើយ ចូរថយចេញពីខ្ញុំទៅ។[20]គេពោលពាក្យអាក្រក់ទាស់នឹងព្រះអង្គ ហើយខ្មាំងសត្រូវរបស់ព្រះអង្គ
ចេញព្រះនាម ព្រះអង្គជាអសារឥតការ។
[21]ព្រះអម្ចាស់អើយ តើទូលបង្គំមិនបានស្អប់អស់អ្នក ដែលស្អប់ព្រះអង្គទេឬ? តើទូលបង្គំមិនបានខ្ពើមអស់អ្នក ដែលលើកគ្នាទាស់នឹងព្រះអង្គទេឬ?[22]ទូលបង្គំស្អប់អ្នកទាំង
នោះពេញទីហើយ ទូលបង្គំចាត់ទុកពួកគេជាខ្មាំងសត្រូវ របស់ទូលបង្គំ។
[23]ព្រះជាម្ចាស់អើយ សូមពិនិត្យមើលទូលបង្គំ ហើយស្គាល់ចិត្តទូលបង្គំផង! សូមល្បងមើលទូលបង្គំ ដើម្បីឲ្យស្គាល់គំនិតទូលបង្គំ។[24]សូមទតមើល ប្រសិនបើមានអំពើ
អាក្រក់ណា នៅក្នុងទូលបង្គំ ហើយនាំទូលបង្គំ តាមផ្លូវដ៏នៅអស់កល្បជានិច្ចផង។

Psalms 139:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
សម្រាប់មេភ្លេង
«នេះគឺសម្រាប់អ្នកដឹកនាំតន្ត្រី ដើម្បីប្រើក្នុងការថ្វាយបង្គំ»។
ទំនុករបស់ព្រះបាទដាវីឌ
អាចមានន័យថា ១) ព្រះបាទដាវីឌបានសរសេរទំនុកតម្កើង ឬ ២)
បទទំនុកតម្កើងគឺនិយាយអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុករបស់ព្រះបាទដាវីឌ។
បានពិនិត្យ

generated on Wed Sep 10 16:16:32 2025

«សាកល្បង»
Psalms 139:3
ផ្លូវច្រករបស់ទូលបង្គំ និងទីដេកសម្រាករបស់ទូលបង្គំ
នៅទីនេះ «ផ្លូវ» តំណាងឲ្យអាកប្បកិរិយារបស់មនុស្សម្នាក់។ «ផ្លូវ និងទីដេក
សម្រាករបស់ទូលបង្គំ» រួមគ្នាតំណាងឲ្យអ្វីគ្រប់យ៉ាងអំពីអ្នកតែងទំនុកតម្កើង។
សូម្បីតែពាក្យសម្តីមិនទាន់មាន នៅអណ្តាតទូលបង្គំនៅឡើយ
នៅទីនេះ «ពាក្យនៅលើអណ្តាត» តំណាងឲ្យការនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «មុនពេលទូលបង្គំនិយាយអ្វី»
ព្រះអង្គបានព័ទ្ធទូលបង្គំជិត ពីមុខពីក្រោយ
ឃ្លានេះសំដៅទៅលើវត្តមានរបស់ព្រះជាម្ចាស់គ្រប់ទីកន្លែង។
ដាក់ព្រះហស្តលើទូលបង្គំ
ពាក្យនេះសំដៅទៅលើការដឹកនាំ និងជំនួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គដឹកនាំ និងជួយទូលបង្គំ»
អស្ចារ្យពេកសម្រាប់ទូលបង្គំ
«ច្រើនពេកសម្រាប់ទូលបង្គំ ដើម្បីយល់»
គឺខ្ពស់ណាស់ ទូលបង្គំមិនអាចយល់បានឡើយគឺខ្ពស់ណាស់ ទូលបង្គំមិនអាចយល់បានឡើយ
ខ្ពស់ និងឈានដល់កំរិតខ្ពស់គឺជាការបង្ហាញមួយ
អំពីចំណេះដឹងមួយចំនួនដែលមនុស្សមិនអាចមាន។ ការបកប្រែរបៀបផ្សេងទៀត:
«វាពិបាកយល់ណាស់»
Psalms 139:7
តើទូលបង្គំនឹងទៅឯណា ឲ្យផុតពីព្រះវិញ្ញាណរបស់ព្រះអង្គបាន? ...តើទូលបង្គំនឹងរត់ទៅឯណា ឲ្យ
ផុតពីព្រះវត្តមានរបស់ព្រះអង្គបាន?
សំណួរទាំងពីរនេះគឺស្របគ្នា។ អ្នកតែងទំនុកតម្កើងមានប្រសាសន៍ថា៖
លោកមិនអាចទៅឆ្ងាយពីព្រះវត្តមានរបស់ព្រះជាម្ចាស់បានទេ។
ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំមិនអាចគេចពីព្រះវិញ្ញាណរបស់ព្រះអង្គបានទេ»។
ប្រសិនបើទូលបង្គំរៀបដំណេក នៅស្ថានឃុំព្រលឹង
«ធ្វើគ្រែមួយ» សំដៅទៅលើការស្នាក់នៅកន្លែងណាមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ទោះបីទូលបង្គំនៅស្ថានឃុំព្រលឹងក៏ដោយ»
Psalms 139:9
ប្រសិនបើទូលបង្គំពាក់ស្លាបហោះ ទៅទិសព្រះអាទិត្យរះ ហើយទៅរស់នៅឯទីបំផុតនៃសមុទ្រ
អ្នកនិពន្ធកំពុងពន្យល់ថា គ្រប់ទីកន្លែងដែលគាត់នៅគឺ
ព្រះជាម្ចាស់ក៏នៅទីនោះដែរ។
ប្រសិនបើទូលបង្គំពាក់ស្លាបហោះ ទៅទិសព្រះអាទិត្យរះ
នៅសម័យបុរាណក្បែរទិសខាងកើតព្រះអាទិត្យត្រូវបានគេស្រមៃគិតជាញឹកញាប់ដូចជាកន្លែងដែលថ្ងៃរះ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើព្រះអាទិត្យអាចដឹកទូលបង្គំទៅលើមេឃ»
ទីបំផុតនៃសមុទ្រ
«ឆ្ងាយទៅភាគខាងលិច»
នឹងក្តាប់ទូលបង្គំជាប់
«នឹងជួយទូលបង្គំ»
Psalms 139:11
ប្រសិនបើទូលបង្គំពោលថា៖ «ប្រាកដជាភាពងងឹតនឹងគ្របពីលើខ្ញុំ
អ្នកតែងទំនុកតម្កើងនិយាយអំពីពេលយប់ហាក់ដូចជាភួយដែលអាចលាក់បាំងគាត់។
គឺយប់ភ្លឺដូចជាថ្ងៃ
រាត្រី ដែលងងឹតត្រូវបានគេនិយាយថា៖ ហាក់ដូចជាភ្លឺដោយពន្លឺ។
Psalms 139:13
ដ្បិតគឺព្រះអង្គហើយដែលបានបង្កើត ចិត្តថ្លើមទូលបង្គំ
«ចិត្តថ្លើម» សំដៅទៅលើសរីរាង្គខាងក្នុងរបស់មនុស្ស
ប៉ុន្តែនៅទីនេះការបញ្ចេញមតិប្រហែលជាតំណាងឲ្យរាងកាយទាំងមូល។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានបង្កើតរាងកាយរបស់ទូលបង្គំទាំងមូល
ព្រលឹងទូលបង្គំដឹងច្បាស់ណាស់

នៅទីនេះ «ព្រលឹង»
ប្រហែលជាសំដៅទៅលើសមត្ថភាពខាងក្នុងរបស់អ្នកតែងទំនុកតម្កើង
ដើម្បីដឹងច្បាស់អំពីសេចក្តីស្រឡាញ់ និងការណែនាំរបស់ព្រះជាម្ចាស់។
អ្នកបកប្រែអាច ចាត់ទុក «ព្រលឹង» នៅទីនេះថា ជាពាក្យមេតាណុលសម្រាប់ចិត្ត
និងចិត្តរបស់អ្នកតែងទំនុកតម្កើង។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំដឹងរឿងនេះអស់ពីចិត្ត»
Psalms 139:15
បានចាក់ស្រេះយ៉ាងសុគសាញ
«បង្កើតជាមួយភាពសុគសាញដ៏ធំ»
ក្នុងទីជ្រៅនៃផែនដី
នេះប្រហែលជាវិធីនិយាយអំពី ផ្ទៃរបស់ម្តាយ
គ្រប់ទាំងអស់សុទ្ធតែបានកត់ទុក ក្នុងបញ្ជីរបស់ព្រះអង្គ គឺអស់ទាំងថ្ងៃអាយុដែលបានតម្រូវ ឲ្យ
ទូលបង្គំរស់នៅ មុននឹងមានថ្ងៃទាំងនោះមកដល់ទៅទៀត
ឃ្លានេះបញ្ជាក់ថា ជនជាតិអ៊ីុស្រាអែលពីបុរាណស្រមៃថា ព្រះជាម្ចាស់បានកត់
ទុកផែនការរបស់ព្រះអង្គនៅក្នុងសៀវភៅមួយ។
Psalms 139:17
មានតម្លៃវិសេស
«សំខាន់» ឬ «មានតម្លៃ»
គឺមានច្រើនឥតគណនា!
«ព្រះតម្រិះរបស់ព្រះអង្គមានច្រើនណាស់»។
ពួកគេនឹងមានច្រើនជាងគ្រាប់ខ្សាច់ទៅទៀត
«ពួកគេមិនអាចរាប់អស់»
Psalms 139:19
មនុស្សកម្ចាយឈាមអើយ ចូរថយចេញពីខ្ញុំទៅ
អ្នកតែងទំនុកតម្កើងគ្រាន់តែធ្វើពុតនិយាយដោយផ្ទាល់ទៅនឹងមនុស្សឃោរឃៅដែលគាត់មាននៅក្នុងគំនិត
អ្នកបកប្រែអាចសម្រេចចិត្តបង្ហាញពាក្យបញ្ជានេះតាមការចង់បាន
គេពោលពាក្យអាក្រក់ទាស់នឹងព្រះអង្គ
«ពួកគេបះបោរទាស់នឹងអំណាចរបស់ព្រះអង្គ ព្រះជាម្ចាស់»
សត្រូវរបស់ព្រះអង្គ ចេញព្រះនាម ព្រះអង្គជាអសារឥតការ
«សត្រូវរបស់ព្រះអង្គកុហកព្រះអង្គ»
Psalms 139:21
ព្រះអម្ចាស់អើយ តើទូលបង្គំមិនបានស្អប់អស់អ្នក ដែលស្អប់ព្រះអង្គទេឬ? តើទូលបង្គំមិនបានខ្ពើម
អស់អ្នក ដែលលើកគ្នាទាស់នឹងព្រះអង្គទេឬ?
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ អ្នកទី ២
ក្តីឃ្លាំងគំនិតក្នុងគំនិតទីមួយ។ សំណួរទាំងនេះពិតជាបង្កើតឃ្លា។
លើកគ្នាទាស់នឹង
បះបោរទាស់នឹង
Psalms 139:23
សូមពិនិត្យមើលទូលបង្គំ
នេះជាការស្នើសុំឲ្យព្រះជាម្ចាស់ប្រាប់ដល់អ្នកតែងទំនុកតម្កើងអំពីគំនិតខុសឆ្គងណាមួយដែលគាត់ប្រហែ
ការបកប្រែរបៀបផ្សេងទៀត: «សូមស្វែងរកទូលបង្គំ» ឬ
«ទូលបង្គំសូមអង្វរព្រះអង្គឲ្យស្វែងរកទូលបង្គំ»
ព្រះជាម្ចាស់អើយ សូមពិនិត្យមើលទូលបង្គំ ហើយស្គាល់ចិត្តទូលបង្គំផង! សូមល្បងមើលទូលបង្គំ
ដើម្បីឲ្យស្គាល់គំនិតទូលបង្គំ
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ទី២ ពង្រឹងគំនិតក្នុងគំនិតទីមួយ។
ផ្លូវអាក្រក់ណា
នៅទីនេះ «ផ្លូវ» តំណាងឲ្យឥរិយាបថ។
តាមផ្លូវដ៏នៅអស់កល្បជានិច្ចផង
ត្រង់នេះ «ផ្លូវ» សំដៅទៅលើការទុកចិត្ត និងការគោរពប្រតិបត្តិចំពោះព្រះជាម្ចាស់។
អ្នកណាដែល «ដើរ» តាមផ្លូវនេះនឹងមានជីវិតអស់កល្បជានិច្ច។

---

140 ទំនុករបស់ស្តេចដាវីឌ សម្រាប់មេភ្លេង។[1]ព្រះអម្ចាស់អើយ សូមប្រោសទូលបង្គំ ឲ្យរួចពីមនុស្សអាក្រក់សូមការពារទូលបង្គំ ឲ្យរួចពីមនុស្សឃោរឃៅ។[2]ជាអ្នកដែល
គិតគូរបង្កើត សេចក្តីអាក្រក់នៅក្នុងចិត្ត ហើយចេះតែញុះញង់ឲ្យមានចម្បាំងជានិច្ច។[3]គេបានសំលៀងអណ្តាតរបស់គេ ឲ្យស្រួចដូចជាអណ្តាតពស់ ហើយនៅ
ក្រោមបបូរមាត់របស់គេ មានសុទ្ធតែពិសពស់ហនុមាន។ សម្រាក
[4]ព្រះអម្ចាស់អើយ សូមការពារទូលបង្គំ ឲ្យរួចពីកណ្តាប់ដៃមនុស្សអាក្រក់ សូមរក្សាទូលបង្គំឲ្យរួចពីមនុស្សឃោរឃៅ ជាអ្នកដែលគិតនឹងធ្វើឲ្យទូលបង្គំ ភ្លាត់ជើងដួល។[5]អ្នក
អួតអាងបានដាក់អន្ទាក់ចង់ចាប់ទូលបង្គំ គេបានលាតមង ទាំងមានខ្សែចាំរូត ហើយគេដាក់អង្គប់តាមផ្លូវ ចាំចាប់ទូលបង្គំ។ សម្រាក

generated on Wed Sep 10 16:16:32 2025

[6]ខ្ញុំទូលព្រះអម្ចាស់ថា៖ «ព្រះអង្គជាព្រះនៃទូលបង្គំ ឱព្រះអម្ចាស់អើយ សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យ ដែលទូលបង្គំ ទូលអង្វរផង»។[7]ព្រះអម្ចាស់ ជាព្រះអម្ចាស់នៃទូលបង្គំអើយ ព្រះអង្គជាកម្លាំងនៃការសង្គ្រោះរបស់ទូលបង្គំ ព្រះអង្គបានគ្របក្បាលទូលបង្គំ នៅថ្ងៃសឹកសង្គ្រាម។[8]ព្រះអម្ចាស់អើយ សូមកុំឲ្យចិត្តប៉ងប្រាថ្នារបស់មនុស្សអាក្រក់ បានសម្រេចឡើយ ក៏កុំឲ្យកិច្ចកលរបស់គេបានលឿនទៅមុខដែរ ក្រែងគេអួតខ្លួន។ សម្រាក
[9]អស់អ្នកដែលឡោមព័ទ្ធទូលបង្គំ សូមឲ្យអំពើអាក្រក់នៃបបូរមាត់របស់គេ បានធ្លាក់ទៅលើគេវិញទៅ។[10]សូមឲ្យមានរងើកភ្លើងឆេះធ្លាក់ទៅលើគេ ហើយឲ្យគេត្រូវបោះទៅក្នុងភ្លើង គឺទៅក្នុងរណ្តៅយ៉ាងជ្រៅ ងើបឡើងវិញមិនរួចឡើយ។[11]សូមកុំឲ្យមនុស្សដែលមួលបង្កាច់គេ តាំងនៅជាប់លើផែនដីឡើយ សូមឲ្យសេចក្តីអាក្រក់ដេញតាម មនុស្សឃោរឃៅយ៉ាងលឿនទៅ។
[12]ទូលបង្គំដឹងថា ព្រះអម្ចាស់នឹងកាន់ក្តី របស់មនុស្សមានទុក្ខវេទនា ហើយរកយុត្តិធម៌ឲ្យមនុស្សកម្សត់ទុគ៌ត។[13]ប្រាកដហើយ មនុស្សសុចរិត នឹងអរព្រះគុណដល់ព្រះនាមព្រះអង្គ ហើយមនុស្សទៀងត្រង់ នឹងរស់នៅក្នុងព្រះវត្តមានព្រះអង្គ។

Psalms 140:1
ព័ត៌មានទូទៅ:
លក្ខណៈស្របគ្នាជាទូទៅនៅក្នុងកំណាព្យហេប្រឺ។
សម្រាប់មេភ្លេង
នេះសម្រាប់អ្នកដឹកនាំតន្ត្រី ដើម្បីប្រើប្រាស់ក្នុងការថ្វាយបង្គំ»។
ទំនុកបស់ព្រះបាទដាវីឌ
អាចមានន័យថា ១) ព្រះបាទដាវីឌបានសរសេរទំនុកតម្កើង ឬ ២)
បទទំនុកតម្កើងគឺនិយាយអំពីព្រះបាទដាវីឌ ឬ ៣)
បទទំនុកតម្កើងគឺមានលក្ខណៈដូចនឹងទំនុកបរបស់ព្រះបាទដាវីឌ។
ចេះតែញុះញង់ឲ្យមានចម្បាំងជានិច្ច
នៅទីនេះ «ចម្បាំង»
ប្រហែលជាសំដៅទៅលើជម្លោះគ្រប់ប្រភេទរួមទាំងការឈ្លោះប្រកែកគ្នា។
គេបានសំលៀងអណ្តាតរបស់គេឲ្យស្រួចដូចជាអណ្តាតពស់
មនុស្សដែលបង្កជម្លោះដោយអ្វីដែលពួកគេនិយាយត្រូវបានគេនិយាយថា៖
ដូចជាពួកគេមានអណ្តាតពស់។ ជាការពិតណាស់ ពស់
មិនធ្វើឲ្យខូចខាតដល់អណ្តាតរបស់ពួកគេទេ ប៉ុន្តែជាមួយនឹងការខាំរបស់ពួកគេ
និងជាពិសេសជាមួយពិស។ មនុស្សម្នាក់ក៏មិនអាចធ្វើឲ្យអណ្តាតមុតដែរ។
ផ្ទុយទៅវិញនៅទីនេះគំនិតនៃអណ្តាតមុតស្រួចតំណាងឲ្យការនិយាយតាមរបៀបដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃ
ហើយគំនិតពស់មានអណ្តាតមុតស្រួចតំណាងឲ្យការពិតដែលថា
ពួកគេជាច្រើនមានជាតិពិស។
Psalms 140:4
កណ្តាប់ដៃមនុស្សអាក្រក់
នោះគឺជា អំណាចរបស់មនុស្សអាក្រក់
ដាក់អន្ទាក់...លាតមង...ដាក់អង្គប់
អន្ទាក់ប្រភេទពិតប្រាកដមិនសំខាន់ដូចគំនិតដែលថា «មនុស្សអាក្រក់...
ត្បូងទទឹមគឺជាឧបករណ៍ភ្លេងមួយដែលមានក្បាល ដូចជាស្គរដែលអាចវាយ
និងមានបំណែកដែកព័ទ្ធជុំវិញដែលឮសូរនៅពេលឧបករណ៍នោះរង្គើ។
ឈិង
ចានដែកមូលមូលចំនួន ២ ដែលត្រូវបានវាយបញ្ចូលគ្នា ដើម្បីបង្កើតជាសម្លេងឮៗ
Psalms 150:6
ព័ត៌មានទូទៅ:
ខគម្ពីរនេះគឺច្រើនជាងចុងបញ្ចប់នៃទំនុកនេះ។ នេះគឺជាឃ្លាចុងក្រោយនៃសៀវភៅទី
៥ នៃទំនុកតម្កើងដែលចាប់ផ្តើមពីទំនុកតម្កើង ១០៧ និងបញ្ចប់ដោយទំនុកតម្កើង
១៥០។
អ្វីៗទាំងអស់ដែលមានជីវិត
អាចមានន័យថា ១) មនុស្សទាំងអស់ដែលនៅរស់គឺសរសើរព្រះជាម្ចាស់ ឬ ២)
រាល់ការបង្កើតទាំងអស់ដែលដែលមានជីវិតគឺសរសើរព្រះជាម្ចាស់។

សុភាសិត

1 [1]សុភាសិតរបស់ព្រះបាទសាឡូម៉ូន ជាព្រះរាជបុត្រព្រះបាទដាវីឌ និងជាព្រះមហាក្សត្រស្រុកអ៊ីស្រាអែល។[2]សុភាសិតទាំងនេះផ្តល់ឲ្យមនុស្សមានប្រាជ្ញា និងការចេះដឹង
ដើម្បីយល់ពាក្យពេចន៍ប្រកបដោយអត្ថន័យជ្រៅជ្រះ[3]ព្រមទាំងបង្រៀនមនុស្សឲ្យចេះដឹង សុចរិត ត្រឹមត្រូវ និងមានចិត្តទៀងត្រង់។
[4]ដើម្បីបង្រៀនមនុស្សឆោតល្ងង់ឲ្យចេះប្រុងប្រយ័ត្ន ហើយឲ្យយុវជនស្គាល់ខុសស្គាល់ត្រូវ។[5]សូមឲ្យអ្នកប្រាជ្ញបានស្តាប់ ហើយបង្កើនចំណេះដឹងរបស់ខ្លួនថែមទៀត សូមឲ្យ
អ្នកណាដែលមានយោបល់ បានដឹងពីផ្លូវដែលត្រូវដើរ[6]ព្រមទាំងឲ្យបានយល់ពាក្យសុភាសិត និងប្រស្នា អស់ទាំងពាក្យរបស់អ្នកប្រាជ្ញ និងពាក្យអាថ៌កំបាំងទាំងប៉ុន្មានផង។
[7]ការគោរពកោតខ្លាចព្រះអម្ចាស់ជាប្រភពនៃការចេះដឹង។ មនុស្សខ្លៅតែងតែមើលងាយតម្រិះប្រាជ្ញា និងការប្រៀនប្រដៅ។[8]កូនអើយ ចូរស្តាប់ឪពុកប្រៀនប្រដៅ ហើយ
ត្រងត្រាប់ស្តាប់ម្តាយទូន្មាន[9]ដ្បិតដំបូន្មានរបស់ឪពុកម្តាយនឹងកសាងចរិយាសម្បត្តិរបស់កូន ឲ្យបានល្អដូចមកុដ និងខ្សែកមាស។
[10]កូនអើយ បើមនុស្សមានបាបបបួលនាំឯង កុំព្រមតាមគេឡើយ។[11]ប្រសិនបើពួកគេថា «ចូរមកជាមួយយើង យើងនឹងរង់ចាំឱកាសកម្ចាយឈាម យើងនឹងលបដោយ
សម្ងាត់ដើម្បីចាប់មនុស្សដែលឥតទោសដោយឥតហេតុ។
[12]យើងនឹងលេបគេទាំងរស់ ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយទាំងមូលផង ដូចជាពួកអ្នកដែលចុះទៅក្នុងរណ្តៅ។[13]យើងនឹងរឹបអូស របស់មានតម្លៃគ្រប់យ៉ាង ក៏
នឹងបំពេញលំនៅយើង។[14]ចូរឯងចូលមកក្នុងពួកយើងចុះ យើងនឹងមានថង់ប្រាក់តែមួយប៉ុណ្ណោះ»។
[15]កូនអើយ សូមកូនកុំដើររួមផ្លូវជាមួយគេឡើយ ត្រូវឃាត់ជើងកូនមិនឲ្យចូលទៅក្នុង ផ្លូវច្រករបស់គេវិញ។[16]ដ្បិតជើងគេរត់តាមតែការអាក្រក់ទេ គេក៏រហ័សនឹងកម្ចាយ
ឈាមផង។[17]ដ្បិតការដែលដាក់អន្ទាក់ នៅចំពោះសត្វស្លាបដែលវាមើលឃើញនោះ គឺឥតប្រយោជន៍ទេ។
[18]មនុស្សទាំងនេះរង់ចាំតែនឹងសម្លាប់ខ្លួនឯង ហើយក៏អែបលបដោយសម្ងាត់ ដើម្បីតែនឹងបំផ្លាញជីវិតខ្លួនគេវិញ។[19]ផ្លូវនៃអស់អ្នកដែលលោភចង់បាន កម្រៃក៏យ៉ាងនោះដែរ
សេចក្តីនោះនឹងដកយកជីវិត ចេញពីអ្នកដែលបានកម្រៃបែបនោះ។
[20]ប្រាជ្ញាតែងបន្លឺឡើងនៅក្នុងផ្លូវ ក៏បញ្ចេញសំឡេងនៅទីធ្លា[21]ប្រាជ្ញាស្រែកប្រកាស នៅទីផ្លូវប្រសព្វទ្រហឹងអឺងកង និងនៅមាត់ទ្វារក្រុង ឯនៅខាងក្នុងទីក្រុង នោះក៏បញ្ចេញ
ពាក្យថា[22]«មនុស្សឆោតល្ងង់អើយ តើនៅស្រឡាញ់សេចក្តីឆោតល្ងង់ដល់កាលណាទៀត? ពួកមនុស្សចំអក គេនឹងចូលចិត្តខាងសេចក្តីឡកឡឺយ តើមនុស្សកំឡៅនឹងចេះ
តែស្អប់ ដល់ការចេះដឹងដល់កាលណា?
[23]ចូរអ្នករាល់គ្នាស្តាប់តាមនូវសេចក្តីកែរតម្រូវរបស់យើង នោះយើងនឹងចាក់វិញ្ញាណយើងទៅលើអ្នករាល់គ្នា ហើយឲ្យអ្នករាល់គ្នាបានយល់ពាក្យរបស់យើង។[24]ពីព្រោះយើង
បានស្រែកហៅ តែអ្នករាល់គ្នាមិនព្រមស្តាប់ទេ យើងបានហុចដៃទៅ តែឥតមានអ្នកណារវល់សោះ។[25]អ្នករាល់គ្នាក៏បោះបង់ចោល អស់ទាំងដំបូន្មានរបស់យើង ហើយមិន
ព្រមទទួលពាក្យបន្ទោសរបស់យើងដែរ។
[26]យើងនឹងសើចដែរ ក្នុងថ្ងៃដែលអ្នករាល់គ្នាត្រូវអន្តរាយ យើងនឹងចំអកឲ្យ ក្នុងកាលដែលអ្នករាល់គ្នា កើតមានសេចក្តីភិតភ័យផង[27]កាលដែលសេចក្តីភិតភ័យ មកលើអ្នក
រាល់គ្នា ដូចជាព្យុះសង្ឃរា ហើយសេចក្តីអន្តរាយរបស់អ្នករាល់គ្នាមក ដូចជាខ្យល់កួច ក្នុងកាលដែលសេចក្តីលំបាក និងសេចក្តីទុក្ខព្រួយ មកគ្របសង្កត់លើអ្នករាល់គ្នា។
[28]ក្រោយមក គេនឹងអំពាវនាវដល់យើង តែយើងមិនព្រមឆ្លើយសោះ គេនឹងស្វែងរកយើងអស់ពីចិត្ត តែគេនឹងរកមិនឃើញឡើយ។[29]ព្រោះពួកគេបានស្អប់ការចេះដឹង ហើយ
មិនបានរើសយកសេចក្តីកោតខ្លាច ដល់ព្រះអង្គម្ចាស់ទេ។[30]ពួកគេមិនបានយកចិត្តទុកដាក់ នឹងដំបូន្មានរបស់យើងឡើយ ក៏បានមើលងាយសេចក្តីបន្ទោសរបស់យើងដែរ។

generated on Wed Sep 10 16:16:32 2025

[31]ពួកគេនឹងស៊ីផលនៃផ្លូវរបស់ខ្លួនគេវិញ ហើយគេនឹងបានឆ្អែតដោយកិច្ចការរបស់ខ្លួន។[32]ដ្បិតពួកឆោតល្ងង់នោះ ការថយទៅវិញរបស់គេនឹងសម្លាប់គេទៅ ហើយចំណែកមនុស្សកំឡៅ នោះសេចក្ដីសុខស្រួលរបស់គេ នឹងបំផ្លាញគេផងដែរ។[33]ប៉ុន្តែអ្នកណាដែលស្តាប់តាមយើង នោះនឹងរស់ដោយសេចក្ដីសុខ ហើយនឹងមានសេចក្ដីសម្រាក ឥតភ័យខ្លាចចំពោះការអាក្រក់ឡើយ»។

Proverbs 1:1

ព័ត៌មានទូទៅ:

ខ ២-៣៣ គឺជាកំណាព្យ។

ផ្តល់ឲ្យមនុស្សមានប្រាជ្ញា និងការចេះដឹង

នេះអាចត្រូវបានប្រើឡើងវិញ ដូច្នេះនាមអរូបី «ប្រាជ្ញា» និង «សេចក្ដីណែនាំ» អាចបញ្ជាក់ជាគុណនាម ឬ កិរិយា។ ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីបង្រៀនអ្នកពីរបៀបធ្វើជាមនុស្សឆ្លាតវៃ និង ណែនាំអ្នកពីរបៀបរស់នៅប្រកបដោយសីលធម៌»។

ដើម្បីយល់ពាក្យពេចន៍ប្រកបដោយអត្ថន័យជ្រៅជ្រះ

ពាក្យថា «ពាក្យពេចន៍» នៅទីនេះតំណាងឲ្យសារ ឬ សេចក្ដីបង្រៀន។ ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីជួយអ្នកឲ្យយល់ពីសេចក្ដីបង្រៀនដែលមានប្រាជ្ញា»

ដែលអ្នកនឹងទទួល

ពាក្យថា «អ្នក» នៅទីនេះសំដៅទៅលើអ្នកអាន។ ប្រសិនបើវាជាភាសាដើមរបស់អ្នក អ្នកអាចបញ្ជាក់វាជាការបញ្ចូលគ្នា «យើង» ការបកប្រែរបៀបផ្សេងទៀត: «យើងអាចនឹងទទួល»

អាចនឹងទទួលបានសេចក្ដីណែនាំក្នុងការរស់នៅ

ឃ្លានេះអាចត្រូវបានប្រើឡើងវិញ ដូច្នេះនាមអរូបី «សេចក្ដីណែនាំ» អាចបញ្ជាក់ជាកិរិយា។ ការបកប្រែរបៀបផ្សេងទៀត: «អាចត្រូវបានណែនាំពីការរស់នៅ»

Proverbs 1:4

ដើម្បីបង្រៀនមនុស្សឆោតល្ងង់ឲ្យចេះប្រុងប្រយ័ត្ន

ឃ្លានេះអាចត្រូវបានប្រើឡើងវិញ ដូច្នេះនាមអរូបី «ប្រាជ្ញា» អាចបញ្ជាក់ជាគុណនាម «ឆ្លាតវៃ» នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ក៏បង្រៀនអស់អ្នកដែលឆោតល្ងង់ឲ្យឆ្លាតវៃ»

មនុស្សឆោតល្ងង់

«គ្មានបទពិសោធន៍ មិនទាន់ពេញវ័យ»

ឲ្យយុវជនស្គាល់ខុសស្គាល់ត្រូវ

នាមអរូបីនេះ «ចំណេះដឹង» និង «ការដឹងខុសត្រូវ» អាចបញ្ជាក់ជាកិរិយា។ ការបកប្រែរបៀបផ្សេងទៀត: «ហើយបង្រៀនយុវជនពីអ្វីដែលគេចង់ដឹង និង ពីអ្វីដែលគេគួរដឹងរបៀបដែលត្រឹមត្រូវ»

ការដឹងខុសត្រូវ

ការដែលដឹងអ្វីគួរធ្វើនៅក្នុងស្ថានភាពជាក់លាក់ណាមួយ

សូមឲ្យអ្នកប្រាជ្ញបានស្តាប់ ហើយបង្កើនចំណេះដឹងរបស់ខ្លួនថែមទៀត

«សូមឲ្យអស់អ្នកដែលមានប្រាជ្ញាយកចិត្តទុកដាក់ ហើយរៀនបន្ថែមទៀត។

សូមឲ្យអ្នកណាដែលមានយោបល់ បានដឹងពីផ្លូវដែលត្រូវដើរ

«សូមឲ្យអស់អ្នកដែលមានការយល់ដឹងរៀនសូត្រពីសុភាសិតទាំងនេះពីរបៀបក្នុងការធ្វើការសម្រេចចិត្តត្រឹមត្រូវ»

ពាក្យអាថ៌កំបាំង

ពាក្យដែលមនុស្សម្នាក់អាចយល់បាន ក្រោយពេលដែលពួកគេគិតពិចារណា។

Proverbs 1:7

ព័ត៌មានទូទៅ:

ឪពុកបង្រៀនកូន។

ការគោរពកោតខ្លាចព្រះអម្ចាស់ជាប្រភពនៃការចេះដឹង

នាមអរូបី «ការគោរពកោតខ្លាច» «ជាប្រភព» និង «ការចេះដឹង» អាចបញ្ជាក់ជាកិរិយា។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកត្រូវតែគោរពកោតខ្លាចព្រះអម្ចាស់ដើម្បីឲ្យបានប្រាជ្ញា» ឬ «អ្នកត្រូវតែគោរពថ្វាយកិត្តិយសដល់ព្រះអម្ចាស់ដើម្បីឲ្យបានប្រាជ្ញា»

ព្រះអម្ចាស់

នេះគឺជាព្រះនាមរបស់ព្រះជាម្ចាស់ដែលព្រះអង្គបើកសម្តែងដល់ប្រជាជនរបស់ព្រះអង្គ សូមមើលទំព័រនៃការបកប្រែអំពីព្រះអម្ចាស់ទាក់ទងនឹងពីការបកប្រែនេះ។

មនុស្សខ្លៅតែងតែមើលងាយតម្រិះប្រាជ្ញា និងការប្រៀនប្រដៅ

«អស់អ្នកដែលមិនឲ្យតម្លៃប្រាជ្ញា និង ការប្រៀនប្រដៅអ្នកនោះជាមនុស្សល្ងីល្ងើ»

កុំចោល

នេះគឺជាពាក្យក្រៀមភាសាដែលមានន័យថា «មិនប្រងើយ» ឬ «មិនបដិសេធ» ដ្បិតដំបូន្មានរបស់ឪពុកម្តាយនឹងកសាងចរិយាសម្បត្តិរបស់កូន ឲ្យបានល្អដូចមកុដ និងខ្សែកមាស ច្បាប់ និង ការប្រៀនប្រដៅ ដែលឪពុកម្តាយបង្រៀនកូនចៅគឺមានតម្លៃ និង សំខាន់ដែលពួកគេនិយាយបានថាវាប្រៀបដូចជាកម្រងផ្កា ឬ បន្ទោងដែលមនុស្សម្នាក់ពាក់។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងជួយឲ្យអ្នកមានប្រាជ្ញាដូចជា ការពាក់កម្រងផ្កានៅលើក្បាល ឬ ពាក់បន្ទោងនៅនឹងកដែលធ្វើឲ្យអ្នកស្រស់ស្អាត»

កម្រងផ្កា

រង្វង់ត្បាញធ្វើពីស្លឹកឈើ ឬផ្កា

បន្ទោង

ជាគ្រឿងអលង្ការដែលពាក់នៅនឹងក

Proverbs 1:10

បបួលអ្នកឲ្យធ្វើបាប

«ព្យាយាមបញ្ចុះបញ្ចូលអ្នកឱ្យធ្វើបាបដូចដែលពួកគេបានធ្វើ»

កុំព្រមតាមគេឡើយ

«ប្រកែកជាមួយពួកគេ» ឬ «កុំស្តាប់តាមពួកគេ»

ប្រសិនបើពួកគេថា

នៅទីនេះអ្នកនិយាយឧទាហរណ៍ពីអ្វីដែលមនុស្សប្រព្រឹត្តិបាបព្យាយាមបបួលនរណាម្នាក់ឲ្យធ្វើតាមគេ។

លបដោយសម្ងាត់

«ពួន និងរងចាំឱកាសល្អ»

Proverbs 1:12

ព័ត៌មានទូទៅ:

ខ ១២-១៤

បញ្ចប់ការថ្លែងស្រមៃរបស់មនុស្សមានបាបដែលព្យាយាមចង់បបួលអ្នកដទៃប្រព្រឹត្តបាប។

យើងនឹងលេបគេទាំងរស់ ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយទាំងមូលផង

អ្នកមានបាបនិយាយពីការសម្លាប់មនុស្សស្លូតត្រង់ ដូចជាស្ថានឃុំមនុស្សស្លាប់ ហើយគេនឹងយកមនុស្សដែលនៅរស់ និង មានសុខភាពល្អចុះទៅក្រោមជាកន្លែងដែលមនុស្សស្លាប់ទៅ។

យើងនឹងលេបគេទាំងរស់...ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់

នេះនិយាយពីផ្នូរ ដូចជាមនុស្សដែលលេបត្របាក់មនុស្ស ហើយយកគេទៅក្រោមដែលជាកន្លែងមនុស្សស្លាប់។

ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់ដែលយកមនុស្សនៅរស់

មនុស្សអាក្រក់រំពឹងគិតចង់បំផ្លាញមនុស្សទន់ទាបដូចជាស្ថានឃុំមនុស្សស្លាប់ ជាកន្លែងមនុស្សស្លាប់ ដែលយកទៅទាំងរស់។

ដូចជាពួកអ្នកដែលចុះទៅក្នុងរណ្តៅ

អាចមានន័យថា ទី១) នេះសំដៅទៅលើអ្នកធ្វើដំណើរដែលធ្លាក់ទៅក្នុងរណ្តៅដែលគ្មាននរណាម្នាក់រកឃើញ ឬ ទី២) នៅទីនេះពាក្យ «រណ្តៅ» [illegible] ស្ថានឃុំព្រលឹងមនុស្សស្លាប់ ឬ កន្លែងដែលមនុស្សស្លាប់ទៅ។

ចូរឯងចូលមកក្នុងពួកយើងចុះ

នេះគឺជាពាក្យក្រៀមភាសា។ ការបកប្រែរបៀបផ្សេងទៀត: «មកចូលរួមជាមួយយើង»

យើងនឹងមានថង់ប្រាក់តែមួយប៉ុណ្ណោះ

ពាក្យថា «ថង់ប្រាក់» នៅទីនេះតំណាងឲ្យអ្វីៗដែលគេលួច។ ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងចែកអ្វីៗដែលយើងលួចបានស្មើគ្នា»

ថង់ប្រាក់

កាបូបដាក់ប្រាក់

Proverbs 1:15

សូមកូនកុំដើររួមផ្លូវជាមួយគេឡើយ ត្រូវឃាត់ជើងកូនមិនឲ្យចូលទៅក្នុង ផ្លូវច្រករបស់គេវិញ [illegible] ដែលមនុស្សមានបាបធ្វើ គឺនិយាយដូចជា កូនប្រុសមិនត្រូវដើរតាមផ្លូវ ឬ ប៉ះផ្លូវដែលមនុស្សមានបាបដើរឡើយ។ ការបកប្រែរបៀបផ្សេងទៀត: «កុំដើរជាមួយមនុស្សមានបាប ឬ ធ្វើអ្វីតាមដែលគេធ្វើ»

ជើងគេរត់តាមតែការអាក្រក់ទេ

មនុស្សមានបាបដែលចូលចិត្តតែខាងប្រព្រឹត្តអំពើអាក្រក់

generated on Wed Sep 10 16:16:32 2025

ត្រូវបានគេនិយាយថាពួកគេរត់តាមតែការអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេចូលចិត្តតែខាងធ្វើការអាក្រក់»

ជើងគេរត់

ពាក្យថា «ជើង» នៅទីនេះតំណាងឲ្យមនុស្សទាំងមូល។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេរត់»

រហ័សនឹងកម្ចាយឈាម

ពាក្យថា «ឈាម» នៅទីនេះតំណាងឲ្យជីវិតមនុស្ស។ «កម្ចាយឈាម»
មានន័យថាសម្លាប់មនុស្ស។

ដ្បិតការដែលដាក់អន្ទាក់គឺឥតប្រយោជន៍ទេ...ដែលវាមើលឃើញនោះ
នេះចាប់ផ្តើមការប្រៀបធៀបដែលបញ្ចប់នៅក្នុងជំពូក ១:១៨ ។
វាប្រៀបធៀបប្រាជ្ញារបស់សត្វស្លាបដែលគេចផុតពីអន្ទាក់
ដែលវាមើលឃើញចំពោះភាពល្ងង់ខ្លៅរបស់មនុស្សមានបាបដែលជាប់អន្ទាក់
ដែលពួកគេបានធ្វើដោយខ្លួនឯង។

Proverbs 1:18

មនុស្សទាំងនេះរង់ចាំតែនឹងសម្លាប់ខ្លួនឯង ហើយក៏អែបលបដោយសម្ងាត់ ដើម្បីតែនឹងបំផ្លាញជីវិតខ្លួនគេវិញ
ការបញ្ចប់ការប្រៀបធៀបនេះអាចចាប់ផ្តើមនៅក្នុងជំពូក ១:១៥។
មនុស្សបំផ្លាញខ្លួនឯង ដោយប្រព្រឹត្តអំពើបាប ដូចដែលគេនិយាយថា
ពួកគេដាក់អន្ទាក់ហើយសម្លាប់ខ្លួនឯង។ ការបកប្រែរបៀបផ្សេងទៀត:
«តែមនុស្សទាំងនោះសម្លាប់ខ្លួនឯង ដោយសារអន្ទាក់ខ្លួនឯង»

ផ្លូវរបស់អ្នករាល់គ្នា

វាសនា ឬ ជោគវាសនារបស់មនុស្ស ប្រៀបដូចជាផ្លូវមនុស្សដើរ។
ការបកប្រែរបៀបផ្សេងទៀត: «នេះគឺជាអ្វីដែលកើតឡើងចំពោះមនុស្សគ្រប់គ្នា»

សេចក្តីនោះនឹងដកយកជីវិត ចេញពីអ្នកដែលបានកម្រៃបែបនោះ
មនុស្សម្នាក់បំផ្លាញខ្លួនគេ
ដោយសារការព្យាយាមប្រមូលទ្រព្យសម្បត្តិតាមរយៈការប្រើអំពើហឹង្សា លួច
ការឆបោក នោះត្រូវបានចាត់ទុកថា ការទទួលបានដោយអយុត្តិធម៌នោះ
នឹងសម្លាប់អស់អ្នក ដែលទទួលបានវា។ ការបកប្រែរបៀបផ្សេងទៀត:
«វាដូចជាការដែលទទួលផលកម្រៃដោយអយុត្តិធម៌នឹងបំផ្លាញអស់អ្នកដែលបាននោះ»

Proverbs 1:20

ព័ត៌មានទូទៅ:

នៅក្នុងជំពូក ១:២០-១:៣៣ ប្រាជ្ញាត្រូវគេចាត់ទុកថា
ដូចជាស្ត្រីដែលនិយាយទៅកាន់មនុស្ស។

ប្រាជ្ញាតែងបន្លឺឡើង

ប្រសិនបើក្នុងភាសារបស់អ្នកមិនអនុញ្ញាតឲ្យចាត់ទុកប្រាជ្ញាដូចជាស្ត្រី
ដែលស្រែកទៅកាន់មនុស្សនៅក្នុងទីក្រុង អ្នកអាចសាកអ្វីមួយដូចជា
«លោកយាយដ៏ឆ្លាតវៃស្រែកបន្លឺឡើង» ឬ «បវរកញ្ញាកិត្តិយសបន្លឺសម្លេងឡើង» ឬ
«ប្រាជ្ញាប្រៀបដូចជាស្ត្រីដែលបន្លឺសម្លេងឡើង»

បញ្ចេញសំឡេង

នេះគឺជាពាក្យក្រៀមភាសា។ ការបកប្រែរបៀបផ្សេងទៀត: «និយាយឮៗ»

នៅទីធ្លា

នេះមានន័យថាកន្លែងដែលមានមនុស្សច្រើន។ ការបកប្រែរបៀបផ្សេងទៀត:
«នៅទីផ្សារ» ឬ «នៅតាមទីប្រជុំជន»

ប្រាជ្ញាស្រែកប្រកាស នៅទីផ្លូវប្រសព្វទ្រហឹងអឺងកង

អាចមានន័យថា គឺ១) «ផ្លូវប្រសព្វ» សំដៅទៅលើកន្លែងដែលប្រជុំជនប្រសព្វគ្នា ឬ
២) «ផ្លូវប្រសព្វ» សំដៅទៅលើ កំពូលជញ្ជាំង
ជាកន្លែងដែលមនុស្សនៅលើផ្លូវដែលអ៊ូអរអាចមើលឃើញ និង
ស្តាប់ឮពីប្រាជ្ញាដែលកំពុងប្រកាស។

មនុស្សឆោតល្ងង់អើយ តើនៅស្រឡាញ់សេចក្តីឆោតល្ងង់ដល់កាលណាទៀត?
ប្រាជ្ញាប្រើសំនួរនេះដើម្បីស្តីបន្ទោសអស់អ្នកដែលឆោតល្ងង់។
ការបកប្រែរបៀបផ្សេងទៀត:
«អស់អ្នកដែលឆោតល្ងង់ត្រូវតែឈប់ស្រឡាញ់ភាពឆោតល្ងង់ទៀតទៅ»

ឆោតល្ងង់

«គ្មានបទពិសោធន៍ មិនទាន់ពេញវ័យ»

ពួកមនុស្សចំអក គេនឹងចូលចិត្តខាងសេចក្តីឡកឡឺយ តើមនុស្សកំឡៅនឹងចេះតែស្អប់ ដល់ការចេះដឹងដល់កាលណា?
ប្រាជ្ញាប្រើសំនួរនេះដើម្បីស្តីបន្ទោសអស់មនុស្សចំអក និង មនុស្សល្ងីល្ងើ។
ការបកប្រែរបៀបផ្សេងទៀត:«អ្នកចំអកត្រូវឈប់រីករាយនឹងការចំអកឡកឡឺយ
ហើយអ្នកល្ងីល្ងើក៏ឈប់ស្អប់ការចេះដឹងទៀតទៅ»

Proverbs 1:23

ព័ត៌មានទូទៅ:

ប្រាជ្ញាបានបន្តនិយាយ។

យកចិត្តទុកដាក់

«ស្តាប់ដោយប្រុងប្រយ័ត្ន»

នោះយើងនឹងចាក់វិញ្ញាណយើងទៅលើអ្នករាល់គ្នា
ប្រាជ្ញាកំពុងប្រាប់មនុស្សពីអ្វីដែលគេគិតពីពួកគេ
ដែលចាត់ទុកថាការគិតរបស់គេហាក់ដូចជាសារធាតុរាវ
ដែលគេនឹងចាក់ចេញមកក្រៅ។

ឲ្យអ្នករាល់គ្នាបានយល់ពាក្យរបស់យើង
ពាក្យថា «ពាក្យ» នៅទីនេះតំណាងឲ្យគំនិត។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងប្រាប់អ្នកពីអ្វី ដែលយើងគិត»

យើងបានហុចដៃទៅ
ឃ្លានេះគឺជាក្រៀមភាសាដែលមានន័យថា ដើម្បីហៅនរណាម្នាក់ ឬ
អញ្ជើញនរណាម្នាក់ឲ្យមក។ ការបកប្រែរបៀបផ្សេងទៀត:
«យើងអញ្ជើញអ្នកឲ្យមក»

Proverbs 1:26

ព័ត៌មានទូទៅ:

ប្រាជ្ញាបន្តនិយាយ ពិពណ៌នាពីអស់អ្នកដែលមិនអើពើនឹងប្រាជ្ញា។

យើងនឹងសើច
នេះអាចត្រូវបានបញ្ជាក់ដោយពាក្យ «ដូច្នេះ» ដើម្បីបង្ហាញថា
ប្រាជ្ញានឹងសើចចំពោះអស់អ្នកណាដែលមិនអើពើនឹងខ្លួន»
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះយើងនឹងសើច»

ក្នុងថ្ងៃដែលអ្នករាល់គ្នាត្រូវអន្តរាយ
«នៅពេលដែលការអាក្រក់កើតមានលើអ្នក»

ក្នុងកាលដែលអ្នករាល់គ្នា កើតមានសេចក្តីភិតភ័យផង
នាមអរូបី «សេចក្តីភិតភ័យ» អាចបញ្ជាក់ជាគុណនាម។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលអ្នកភ័យខ្លាច»

កាលដែលសេចក្តីភិតភ័យ មកលើអ្នករាល់គ្នា ដូចជាព្យុះសង្ឃរា...ដូចជាខ្យល់កួច...មកគ្របសង្កត់លើអ្នករាល់គ្នា
សេចក្តីភិតភ័យកើតមានចំពោះមនុស្ស ដែលប្រៀបបានដូចជាព្យុះ
សង្ឃរាដែលបោកបក់គេ ហើយធ្វើឲ្យគេភ័យខ្លាច និង រងទុក្ខ។

ខ្យល់កួច
ខ្យល់ដែលបោកបក់ខ្លាំង ដែលបំផ្លាញអ្វីៗ

Proverbs 1:28

ខ្លឹមសារភ្ជាប់:

ប្រាជ្ញាបានបន្តនិយាយ។

គេនឹងអំពាវនាវដល់យើង
«ក្រោយមកអស់អ្នកដែលមិនអើពើនឹងយើង
គេនឹងស្រែកអំពាវនាវរកយើងឲ្យជួយ»

ព្រោះពួកគេបានស្អប់ការចេះដឹង
នាមអរូបី «ការចេះដឹង» អាចបញ្ជាក់ជាកិរិយាស័ព្ទ «រៀន»
ការបកប្រែរបៀបផ្សេងទៀត: «ដោយព្រោះពួកគេបដិសេធការចេះដឹង»

មិនបានរើសយកសេចក្តីកោតខ្លាច ដល់ព្រះអង្គម្ចាស់ទេ
នេះអរូបី «សេចក្តីកោតខ្លាច» អាចបញ្ជាក់ជាកិរិយាស័ព្ទ។
ការបកប្រែរបៀបផ្សេងទៀត: «មិនកោតខ្លាចព្រះអម្ចាស់» ឬ «មិនថ្វាយកិត្តិយស
និង គោរពដល់ព្រះអម្ចាស់»

មិនបានយកចិត្តទុកដាក់ នឹងដំបូន្មានរបស់យើង
«គេមិនទទួលយកដំបូន្មានរបស់យើង» ឬ «បដិសេធដំបូន្មានរបស់យើង»

Proverbs 1:31

ព័ត៌មានទូទៅ:

ខ ៣៣ បញ្ចប់ពីសេក្តីថ្លែងរបស់ប្រាជ្ញា ដែលចាប់ផ្តើមនៅក្នុងជំពូក ១:២០។

ស៊ីផលនៃផ្លូវរបស់ខ្លួនគេវិញ
នៅទីនេះជាឥរិយាបថរបស់មនុស្ស ដែលត្រូវគេចាត់ទុកថាដូចជាផ្លូវ។ ដូចគ្នាដែរ
មនុស្សទទួលផលពីអ្វីដែលគេប្រព្រឹត្តិ ដែលត្រូវបានចាត់ទុកថា
ស៊ីផលនៃការប្រព្រឹត្តិរបស់ខ្លួន»

គេនឹងបានឆ្អែតដោយកិច្ចការរបស់ខ្លួន
«គេនឹងស៊ីផលនៃគម្រោងការរបស់គេដល់ឆ្អែត»
មនុស្សម្នាក់ទទួលផលពីគម្រោងការដ៏អាក្រក់របស់គេ

generated on Wed Sep 10 16:16:32 2025

ដែលត្រូវគេចាត់ទុកថាស៊ីផលពីកិច្ចការរបស់ខ្លួន។ ការបកប្រែរបៀបផ្សេងទៀត:
ពួកគេនឹងទទួលនូវផលវិបាកនៃផែនការអាក្រក់របស់ពួកគេ។»
ឆោតល្ងង់
«គ្មានបទពិសោធន៍ មិនទាន់ពេញវ័យ»
ការចរយទៅវិញរបស់គេនឹងសម្លាប់គេទៅ
មនុស្សម្នាក់បដិសេធប្រាជ្ញា
ត្រូវបានគេចាត់ទុកថាដូចជាមនុស្សម្នាក់ដែលបែរចេញពីប្រាជ្ញា។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ស្លាប់ដោយសារពួកគេបដិសេធមិនរៀន»
មនុស្សកំឡៅ នោះសេចក្ដីសុខស្រួលរបស់គេ នឹងបំផ្លាញគេផងដែរ
នាមអរូបី «ការប្រើយកន្តើយ» អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សល្ងីល្ងើនឹងស្លាប់
ដោយសារពួកគេមិនខ្វល់ពីអ្វីដែលគេធ្វើ»
ការប្រើយកន្តើយ
ខ្វះការយកចិត្តទុកដាក់លើអ្វីមួយ។

---

2 [1]កូនអើយ បើឯងទទួលពាក្យយើង ហើយប្រមូលពាក្យបណ្តាំរបស់យើង ទុកនៅជាប់នឹងកូន[2]សូមឲ្យត្រចៀករបស់កូនស្តាប់តាមប្រាជ្ញា ហើយផ្ទង់ចិត្តឲ្យបានយល់
នឹងសេចក្ដីចេះដឹងផង។
[3]ប្រសិនបើកូនស្រែកហៅរកចំណេះដឹង ព្រមទាំងបន្លឺសំឡេងឡើង សូមឲ្យបានយោបល់[4]បើកូនខំរកដូចជារកប្រាក់ ហើយស្វែងរកដូចជារកកំណប់ទ្រព្យ[5]នោះកូននឹងបាន
យល់សេចក្ដីកោតខ្លាច ដល់ព្រះអម្ចាស់ ហើយកូននឹងអាចស្គាល់ពីប្រាជ្ញានៃព្រះជាម្ចាស់។
[6]ដ្បិតព្រះអម្ចាស់ប្រទានឲ្យមានប្រាជ្ញា នោះចេញពីព្រះឪស្ឋរបស់ព្រះអង្គមក គឺជាចំណេះដឹងហើយនិងយោបល់។[7]ព្រះអង្គបម្រុងទុកសេចក្ដីដែលមានប្រាជ្ញា សម្រាប់
មនុស្សសុចរិត ក៏ជាខែលដល់អស់អ្នក ដែលដើរក្នុងសេចក្ដីទៀងត្រង់[8]ព្រះជាម្ចាស់បានរក្សាអស់ទាំងផ្លូវច្រកនៃសេចក្ដីយុត្តិធម៌ ហើយការពារផ្លូវរបស់ពួកបរិសុទ្ធរបស់
ព្រះអង្គ។
[9]ក្រោយមក អ្នកនឹងបានយល់សេចក្ដីសុចរិត សេចក្ដីយុត្តិធម៌ និងសេចក្ដីទៀងត្រង់ គឺគ្រប់ទាំងផ្លូវល្អ។[10]ដ្បិតប្រាជ្ញានឹងចូលមកស្ថិតនៅក្នុងចិត្តកូន ហើយការចេះដឹងនឹង
គាប់ចិត្តដល់ព្រលឹងកូនផង។
[11]ការចេះគិតពិចារណានឹងការពារកូន ហើយការដឹងខុសត្រូវនឹងថែរក្សាកូន។[12]ការទាំងនោះនឹងជួយឲ្យកូនរួចពីផ្លូវអាក្រក់ ហើយពីពួកមនុស្ស ដែលតែងតែនិយាយពាក្យ
មិនពិត[13]ជាអ្នកដែលបោះបង់ចោលផ្លូវទៀងត្រង់ ដើម្បីនឹងដើរតាមផ្លូវងងឹតវិញ។
[14]ពួកគេមានចិត្តរីករាយដោយប្រព្រឹត្តការអាក្រក់ ហើយត្រេកអរដោយចិត្តមិនត្រង់ របស់មនុស្សអាក្រក់។[15]ផ្លូវពួកគេសុទ្ធតែភ្ញិចភ្ញក់ ហើយបិទបាំងការទទួលខុសត្រូវ។
[16]ប្រាជ្ញានឹងយោបល់ជួយឲ្យកូនរួចពីស្រីកំផិតក្បត់ និងសម្រស់ដោយប្រលោមដោយពាក្យផ្អែមល្ហែមរបស់នាង។[17]នាងជាអ្នកដែលលះចោលគូសម្លាញ់ ដែលបានគ្នាពីក្រមុំ
កំលោះ ក៏ភ្លេចសេចក្ដីសញ្ញានៃព្រះរបស់ខ្លួន។
[18]ដ្បិតផ្ទះរបស់ស្ត្រីនោះ ទ្រេតទៅខាងសេចក្ដីស្លាប់ ហើយផ្លូវច្រករបស់នាង នាំទៅចំពោះពួកមនុស្សស្លាប់។[19]ពួកអ្នកដែលទៅវានោះគ្មានអ្នកណាត្រឡប់មកវិញឡើយ ក៏
មិនចាប់កាន់ផ្លូវច្រកនៃជីវិតដែរ។
[20]ដូច្នេះ ចូរកូនដើរក្នុងផ្លូវរបស់មនុស្សល្អ ព្រមទាំងរក្សាផ្លូវច្រកនៃពួកសុចរិត។[21]ដ្បិតមនុស្សទៀងត្រង់នឹងអាស្រ័យនៅផែនដី ហើយមនុស្សគ្រប់លក្ខណ៍នឹងបាននៅជាប់។
[22]ប៉ុន្តែមនុស្សអាក្រក់នឹងត្រូវកាត់ចេញ ឲ្យសូន្យពីផែនដីវិញ ហើយមនុស្សប្រទូសរ៉ាយ និងត្រូវរំលើងចេញពីទីនេះ។

Proverbs 2:1
ព័ត៌មានទូទៅ៖
ឪពុកបង្រៀនកូនដោយប្រើកំណាព្យ។
បើឯងទទួលពាក្យយើង
ពាក្យថា «ពាក្យ» នៅទីនេះតំណាងឲ្យសេចក្ដីបង្រៀន។
ការបកប្រែរបៀបផ្សេងទៀត: «បើអ្នកស្តាប់នូវអ្វីដែលយើងបង្រៀន»
បើឯងទទួល
នេះជាការចាប់ផ្តើមជាភាគនៃសេចក្ដីថ្លែងតាមលក្ខខ័ណ្ឌដែលបញ្ចប់នៅក្នុងជំពូក
២:៥។ ប្រសិនបើមានលក្ខណៈបែបធម្មជាតិចំពោះភាសារបស់អ្នក
អ្នកអាចបកប្រែសេចក្ដីថ្លែងតាមលក្ខខ័ណ្ឌទាំងនេះតាមបែបបញ្ជានៅក្នុង UDB។
ប្រមូលពាក្យបណ្តាំរបស់យើង ទុកនៅជាប់នឹងកូន
ការឲ្យតម្លៃអ្វីដែលជាបញ្ជា ត្រូវបានគេចាត់ទុកថា បទបញ្ជានោះមានតម្លៃ
ហើយមនុស្សនោះមានកន្លែងសុវត្ថិភាពដើម្បីរក្សាទុករបស់មានតម្លៃនោះ។
ការបកប្រែរបៀបផ្សេងទៀត:
«សូមចាត់ទុកពាក្យបណ្តាំរបស់យើងជាទ្រព្យមានតម្លៃ»
សូមឲ្យត្រចៀករបស់កូនស្តាប់តាមប្រាជ្ញា ហើយផ្ទង់ចិត្តឲ្យបានយល់ នឹងសេចក្ដីចេះដឹងផង។
បើអ្នកបកប្រែជំពូក ២:១ ដូចជាការបញ្ជា អ្នកអាចបកប្រែជំពូក ២:២ ជាការបញ្ជា
ដូចនៅក្នុង UDB ឬ បើអ្នកបកប្រែជំពូក ២:១ ជាសេចក្ដីថ្លែងលក្ខខ័ណ្ឌដែរ។
អ្នកអាចបកប្រែជំពូក ២:២ ជាសេចក្ដីថ្លែងការណ៍ ដែលមានលក្ខខណ្ឌផងដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើអ្នកបើកត្រចៀកយកចិត្តទុកដាក់ស្តាប់ពីប្រាជ្ញា
ហើយបង្វែរចិត្តដើម្បីយល់»
សូមបើកត្រចៀកយកចិត្តទុកដាក់ស្តាប់
នេះជាក្រៀមភាសា។ ការបកប្រែរបៀបផ្សេងទៀត:
«ត្រូវបង្ខំខ្លួនឯងឲ្យយកចិត្តទុកដាក់ស្តាប់ដោយប្រុងប្រយ័ត្ន»
ប្រាជ្ញា
នាមអរូបីនេះអាចត្រូវបានបញ្ជាក់ជាគុណនាម។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តាប់ពាក្យប្រៀនប្រដៅដែលយើងកំពុងបង្រៀនអ្នក»
បង្វែរចិត្តឲ្យយល់
ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យចិត្តគំនិតរបស់មនុស្ស។ ឃ្លា «បង្វែរចិត្តគំនិត»
គឺជាក្រៀមភាសាដែលមានន័យថា ប្តេជ្ញាចិត្ត ឬ
លះបង់ចិត្តគំនិតដើម្បីធ្វើការអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រឹងប្រែងដើម្បីឲ្យយល់នូវអ្វីដែលជាការប្រៀនប្រដៅ»
Proverbs 2:3
ប្រសិនបើកូនស្រែកហៅរកចំណេះដឹង ព្រមទាំងបន្លឺសំឡេងឡើង
ប្រយោគទាំងពីរនេះមានន័យដូចគ្នា។
វាបញ្ជាក់ថាមនុស្សម្នាក់នោះកំពុងតែទទូចសុំនូវការយល់ដឹងពីព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើអ្នកទូលអង្វរព្រះអម្ចាស់ជាបន្ទាន់សុំការយល់ដឹង»
ប្រសិនបើកូនស្រែក...បើកូនខំរក
នេះបន្តជាភាគនៃសេចក្ដីថ្លែងលក្ខខ័ណ្ឌចាប់ផ្តើមនៅក្នុងជំពូក ២:១។
បើអ្នកបកប្រែប្រយោគនៅក្នុងជំពូក ១:១-២ ជាការប្រៀនប្រដៅ
អ្នកក៏អាចបកប្រែសេចក្ដីប្រៀនប្រដៅទាំងនេះនៅក្នុង UDB បានដែរ។
ព្រមទាំងបន្លឺសំឡេងឡើង
នេះគឺជាប្រយោគដែលមានន័យថានិយាយខ្លាំងៗ ឬស្រែក។
បើកូនខំរកដូចជារកប្រាក់ ហើយស្វែងរកដូចជារកកំណប់ទ្រព្យ
ប្រយោគទាំងពីរនេះមានន័យដូចគ្នា។ ការប្រៀបប្រដូចទាំងនេះសង្កត់ធ្ងន់ថា
មនុស្សម្នាក់ត្រូវតែប្រឹងប្រែងដើម្បីឲ្យបានយល់ពីប្រាជ្ញា។
ការបកប្រែរបៀបផ្សេងទៀត:
«បើអ្នកខំរកការចេះដឹងដូចដែលអ្នកខំរកទ្រព្យសម្បត្តិមានតម្លៃ»
កូនខំរក...ស្វែងរកការចេះដឹង
ព្យាយាមយ៉ាងខ្លាំងដើម្បីឲ្យបានយល់នូវអ្វីដែលជាប្រាជ្ញា គឺត្រូវបានគេចាត់ទុកថា
ការយល់ដឹងដូចជាអ្វីដែលមនុស្សត្រូវតែប្រឹងរក។
កូននឹងអាចស្គាល់ពីប្រាជ្ញានៃព្រះជាម្ចាស់
ដើម្បីឲ្យបានស្គាល់ព្រះជាម្ចាស់ គឺត្រូវបានគេចាត់ទុកថាប្រាជ្ញានៃ
ព្រះជាម្ចាស់ជាអ្វីដែលមនុស្សនឹងឃើញបន្ទាប់ពីគេបានខំស្វែងរក។
Proverbs 2:6
ចេញពីព្រះឪស្ឋរបស់ព្រះអង្គមក គឺជាចំណេះដឹងហើយនិងយោបល់
ពាក្យថា «ព្រះឪស្ឋ» នៅទីនេះតំណាងឲ្យព្រះអម្ចាស់ផ្ទាល់ ឬ
អ្វីដែលព្រះអង្គមានព្រះបន្ទូល។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ការដែលចេញពីព្រះអម្ចាស់មកនោះគឺជាចំណេះដឹង ហើយនឹងយោបល់» ឬ «ព្រះអម្ចាស់បើកសម្តែងនូវអ្វីដែលយើងចង់ដឹង និង ចង់យល់»
ព្រះអង្គបម្រុងទុកសេចក្តីដែលមានប្រាជ្ញា សម្រាប់មនុស្សសុចរិត
ព្រះអម្ចាស់បានបង្រៀនពីប្រាជ្ញាដល់មនុស្ស ដែលចាត់ទុកថាប្រាជ្ញាប្រៀបដូចជារបស់ដែលព្រះអម្ចាស់បម្រុងទុកសម្រាប់ប្រទានដល់មនុស្សសុចរិត។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបង្រៀនអ្វីដែលជាប្រាជ្ញាពិតប្រាកដដល់មនុស្សសុចរិត»
សម្លេង
«ដែលអាចពឹងផ្អែកបាន»
ព្រះអង្គជាខែលដល់អស់អ្នក
ព្រះអម្ចាស់អាចការពារមនុស្សរបស់ព្រះអង្គ ដែលប្រៀបដូចជាខែល។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់ការពារដល់អស់អ្នក»
អស់អ្នកដែលដើរក្នុងសេចក្តីទៀងត្រង់
មនុស្សដែលប្រព្រឹត្តដោយទៀងត្រង់ ប្រៀបដូចជាដើរក្នុងសេចក្តីទៀងត្រង់។ ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលប្រព្រឹត្តដោយសេចក្តីទៀងត្រង់» ឬ «អស់អ្នកដែលរស់នៅក្នុងជីវិតដែលពួកគេគួរតែរស់នៅ»
ព្រះជាម្ចាស់បានរក្សាអស់ទាំងផ្លូវច្រកនៃសេចក្តីយុត្តិធម៌
អាចមានន័យថា គឺ១) យុត្តិធម៌ប្រៀបដូចជាផ្លូវ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់ប្រោកដព្រះទ័យថាមនុស្សប្រព្រឹត្តដោយយុត្តិធម៌» គឺ២) ជីវិតមនុស្សប្រៀបដូចជា ផ្លូវ។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់ការពារអស់អ្នកដែលប្រព្រឹត្តដោយយុត្តិធម៌»
ការពារផ្លូវរបស់ពួក
ជីវិតមនុស្សត្រូវបានគេចាត់ទុកថា ជាផ្លូវ។ ការបកប្រែរបៀបផ្សេងទៀត: «ការពារអស់ពួកអ្នក»
Proverbs 2:9
សេចក្តីទៀងត្រង់
«សេចក្តីស្មោះត្រង់»
គ្រប់ទាំងផ្លូវល្អ
ឥរិយាបថដែលជាប្រាជ្ញា និង គាប់ព្រះហឫទ័យព្រះជាម្ចាស់ ត្រូវបានគេចាត់ទុកថា ជាមាគា៌ល្អ។ ការបកប្រែរបៀបផ្សេងទៀត: «របៀបរស់នៅដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់» (សូមមើលfigs-metaphor)
ប្រាជ្ញានឹងចូលមកស្ថិតនៅក្នុងចិត្តកូន
ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យភាពខាងក្នុងរបស់មនុស្ស។ មនុស្សដែលមានប្រាជ្ញា ត្រូវបានគេចាត់ទុកថា ប្រាជ្ញាចូលទៅក្នុងចិត្តគេ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកចម្រើនប្រាជ្ញាថែមទៀត» ឬ «អ្នកនឹងរៀនពីរបៀបដែលមានប្រាជ្ញាពិតប្រាកដ»
គាប់ចិត្តដល់ព្រលឹងកូនផង
ពាក្យថា «ព្រលឹង» នៅទីនេះតំណាងឲ្យមនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត: «គាប់ចិត្តខ្លួនឯង» ឬ «ពេញចិត្តខ្លួនឯង»
Proverbs 2:11
ការចេះគិតពិចារណានឹងការពារកូន ហើយការដឹងខុសត្រូវនឹងថែរក្សាកូន
នេះនិយាយអំពី «ការចេះគិតពិចារណា» និង «ការដឹងខុសត្រូវ» ប្រៀបបានដូចជាមនុស្សដែលអាចមើលការខុសត្រូវលើនរណាម្នាក់ទៀត។ ប្រយោគទាំងពីរមានន័យមូលដ្ឋានដូចគ្នា។ ការបកប្រែរបៀបផ្សេងទៀត: «ដោយសារអ្នកបានគិតដោយប្រុងប្រយ័ត្ន និង យល់ពីអ្វីដែលត្រឹមត្រូវ និង មិនត្រឹមត្រូវ នោះអ្នកនឹងមានសុវត្ថិភាព»
ការចេះគិតពិចារណា
គុណតម្លៃនៃការប្រព្រឹត្ត និង និយាយដោយប្រុងប្រយ័ត្ន។
នឹងការពារ
ការពារ ថែរក្សា មើលថែនរណាម្នាក់ ឬ អ្វីមួយ
ការទាំងនោះនឹងជួយឲ្យកូនរួចពីផ្លូវអាក្រក់
ឃ្លាថា «ការទាំងនោះ» សំដៅទៅលើការចេះគិតពិចារណា និង ការដឹងខុសត្រូវ ដែលត្រូវបានគេចាត់ទុកថាដូចជាមនុស្សដែលអាចជួយសង្គ្រោះនរណាម្នាក់ពីការអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត : «អ្នកនឹងដឹងថាត្រូវនៅអោយឆ្ងាយពីអ្វីដែលអាក្រក់»
ពីផ្លូវអាក្រក់
ការប្រព្រឹត្តិអាក្រក់ត្រូវបានគេចាត់ទុកថា ការអាក្រក់គឺជារបៀប ឬ ផ្លូវដែលមនុស្សដើរ។
ជាអ្នកដែលបោះបង់ចោលផ្លូវទៀងត្រង់ ដើម្បីនឹងដើរតាមផ្លូវងងឹតវិញ
មនុស្សម្នាក់ដែលលែងធ្វើកិច្ចការដែលត្រឹមត្រូវ ប៉ុន្តែសម្រេចចិត្តទៅធ្វើការអាក្រក់វិញ
ត្រូវបានគេចាត់ទុកថាបោះបង់ចោលផ្លូវទៀងត្រង់ ហើយជ្រើសរើសដើរផ្លូវងងឹតវិញ។
ជាអ្នកដែលបោះបង់ចោល
ពាក្យថា «អ្នក» សំដៅទៅលើមនុស្សដែលនិយាយសេចក្តីមិនពិត។
បោះបង់ចោល
ចាកចេញ និង មិនត្រឡប់មករកនរណាម្នាក់ ឬ របស់អ្វីមួយ។
Proverbs 2:14
ពួកគេមានចិត្តរីករាយ
ពាក្យថា «ពួកគេ» សំដៅទៅលើមនុស្សដូចគ្នានៅក្នុងជំពូក ២:១១។
គ្រែកអរដោយចិត្តមិនត្រង់របស់មនុស្សអាក្រក់
នេះមានន័យមូលដ្ឋានដូចគ្នានឹងផ្នែកដំបូងនៃប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត: «រីករាយនឹងអ្វីដែលគេដឹងថាជាការអាក្រក់»
ផ្លូវពួកគេសុទ្ធតែកွិចកွក់
មនុស្សដែលកុហកអ្នកដទៃ ត្រូវបានគេចាត់ទុកថា ពួកគេដើរលើផ្លូវកွិចកွក់ ឬ ផ្លូវវៀចវេរ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបោកបញ្ឆោតអ្នកដទៃ»
ហើយបិទបាំងការទទួលខុសត្រូវ
មនុស្សកុហក នោះអ្នកដទៃនឹងឃើញថាអ្វីដែលគេធ្វើ ត្រូវបានគេចាត់ទុកថាដូចជាគេបានដាក់របាំងបាំងផ្លូវ ដែលគ្មាននរណាតាមគេបាន។ ការបកប្រែរបៀបផ្សេងទៀត: «ហើយពួកគេកុហកនោះនឹងគ្មាននរណាម្នាក់នឹងដឹងថាគេធ្វើអីនោះទេ»
Proverbs 2:16
ព័ត៌មានទូទៅ:
ឪពុកបន្តបង្រៀនកូនគាត់ពីរបៀបដែលប្រាជ្ញាការពារគាត់។
ប្រាជ្ញានឹងយោបល់ជួយឲ្យកូនរួច
អ្នកនិពន្ធនិយាយអំពីប្រាជ្ញា និង យោបល់ ប្រៀបដូចជា មនុស្សដែលជួយសង្គ្រោះអស់អ្នកមានប្រាជ្ញានិង យោបល់។ ការបកប្រែរបៀបផ្សេងទៀត: «បើអ្នកមានប្រាជ្ញា និង យោបល់ នោះអ្នកនឹងអាចជួយខ្លួនឯងបាន»
លះចោលគូសម្លាញ់ ដែលបានគ្នាពីក្រមុំកំលោះ
នេះសំដៅទៅលើប្តីរបស់នាង ដែលនាងបានរៀបការជាមួយកាលនាងនៅក្រមុំ។
សេចក្តីសញ្ញានៃព្រះរបស់ខ្លួន
នេះដូចជាសំដៅទៅលើសេចក្តីសញ្ញាអាពាហ៍ពិពាហ៍ដែលនាងបានចុះជាមួយប្តីរបស់នាងនៅចំពោះព្រះជ
Proverbs 2:18
ផ្ទះរបស់ស្ត្រីនោះ ទ្រេតទៅខាងសេចក្តីស្លាប់
អាចមានន័យថា គឺ១) ចូលទៅក្នុងផ្ទះនាងនោះនឹងនាំទៅកាន់សេចក្តីស្លាប់» ឬ ២) «ផ្លូវទៅកាន់ផ្ទះនាង ជាផ្លូវទៅរកក្តីស្លាប់។»
ផ្លូវច្រករបស់នាង នាំទៅចំពោះពួកមនុស្សស្លាប់
អាចមានន័យថា គឺ១) «ផ្លូវទៅកាន់ផ្ទះរបស់នាងនឹងនាំអ្នក» នេះសំដៅទៅលើផ្លូវឬផ្លូវដែលនាំទៅដល់ផ្ទះរបស់នាង ឬ ២) នេះជាពាក្យប្រៀបធៀបដែលនិយាយពីផ្លូវជីវិតរបស់នាងដូចជាផ្លូវដែលនាងដើរ។ ការបកប្រែរបៀបផ្សេងទៀត: «របៀបរស់នៅរបស់នាងនឹងនាំអ្នក»
ទៅចំពោះពួកមនុស្សស្លាប់
នេះសំដៅទៅលើព្រលឹងមនុស្សស្លាប់ ហើយជាឈ្មោះផ្សេងនៃកន្លែងមនុស្សស្លាប់។ ការបកប្រែរបៀបផ្សេងទៀត: «ទៅកាន់ផ្លូវ»
ចូលទៅកាន់នាង
នេះមានន័យថា ចូលទៅកាន់ផ្ទះរបស់នាង ហើយដេកជាមួយនាង ដូចជាចូលទៅកាន់ស្ត្រីពេស្យា។
គេនឹងមិនចាប់កាន់ផ្លូវច្រកនៃជីវិត
អាចមានន័យថា គឺ១) «ពួកគេនឹងមិនត្រឡប់មកកាន់ផ្លូវនៃជីវិត» ឬ ២) «ពួកគេនឹងមិនអាចរស់នៅក្នុងជីវិតរីករាយម្តងទៀតឡើយ។»
Proverbs 2:20
ដូច្នេះ
អ្នកនិពន្ធប្រាប់លទ្ធផលនៃការយល់ដឹង និងការសំរេចចិត្ត។
កូនដើរក្នុងផ្លូវ...រក្សាផ្លូវច្រក
កាយវិការរបស់មនុស្សម្នាក់ ដែលត្រូវបានគេចាត់ទុកថាដូចជាដើរលើផ្លូវ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងរស់នៅតាមរបៀប...ដើរតាមគំរូ»
មនុស្សអាក្រក់នឹងត្រូវកាត់ចេញ ឲ្យសូន្យពីផែនដីវិញ
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់នឹងដកមនុស្សចេញពីផែនដី

generated on Wed Sep 10 16:16:32 2025

ប្រៀបដូចជាព្រះអង្គកាត់មនុស្សដូចជាកាត់មែកឈើចេញពីដើម។
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់នឹងដកមនុស្សអាក្រក់ចេញពីផែនដី»
មនុស្សអាក្រក់...មនុស្សប្រទូសរ៉ាយ
ទាំងនេះជាគុណនាមបន្ទាប់បន្សំ ដែលអាចបញ្ជាក់ជាគុណនាម។
ការបកប្រែរបៀបផ្សេងទៀត:
«អស់អ្នកដែលជាមនុស្សអាក្រក់...អស់មនុស្សប្រទូសរ៉ាយ» ឬ «មនុស្សអាក្រក់...
មនុស្សប្រទូសរ៉ាយ»
មនុស្សប្រទូសរ៉ាយ និងត្រូវរំលើងចេញពីទីនេះ
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់នឹងដកមនុស្សចេញពីផែនដី
ប្រៀបដូចជាព្រះអង្គកាត់មនុស្សដូចជាកាត់មែកឈើចេញពីដើម។
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គនឹងរំលើងមនុស្សប្រទូសរ៉ាយអាក្រក់ចេញ»

---

3 [1]កូនអើយ ចូរកុំភ្លេចពាក្យទូន្មានរបស់យើងឡើយ ចូរប្រតិបត្តិតាមពាក្យដែលយើងបានផ្តែផ្តាំជានិច្ច។[2]ដ្បិត ពាក្យរបស់យើងនឹងផ្តល់ឲ្យកូនមានអាយុយឺនយូរ ប្រកបដោយសេចក្តីសុខសាន្ត។
[3]ចូរកាន់ចិត្តភក្តី និងចិត្តសច្ចៈជានិច្ច គឺត្រូវចារឹកគុណសម្បត្តិនេះជាប់ក្នុងចិត្ត ដូចពាក់គ្រឿងអលង្ការជាប់នៅនឹងកដែរ។[4]ក្រោយមក កូននឹងបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ គាប់ចិត្តមនុស្សផងទាំងពួង ហើយកូននឹងមានកេរ្តិ៍ឈ្មោះល្អ។
[5]កុំពឹងលើចំណេះចេះដឹងរបស់ខ្លួនឡើយ តែត្រូវទុកចិត្តលើព្រះអម្ចាស់ទាំងស្រុងវិញ។[6]ចូរនឹកដល់ព្រះអម្ចាស់ក្នុងគ្រប់កិច្ចការដែលកូនធ្វើ នោះព្រះអង្គនឹងរៀបចំផ្លូវរបស់កូន។
[7]កុំចាត់ទុកខ្លួនកូនថាជាអ្នកមានប្រាជ្ញាឡើយ ប៉ុន្តែ ត្រូវគោរពកោតខ្លាចព្រះអម្ចាស់ ដោយងាកចេញពីការអាក្រក់។[8]ការទាំងនេះគឺជាឱសថព្យាបាលខ្លួនឲ្យបានជាសះស្បើយពីជំងឺ។
[9]ចូរយកផលដំបូងពីផលដំណាំ និងសម្បត្តិដែលកូនរកបាន មកថ្វាយព្រះអម្ចាស់ ដើម្បីសម្តែងការគោរពចំពោះព្រះអង្គ។[10]ដូច្នេះ កូននឹងមានស្រូវពេញជង្រុក ហើយមានស្រាទំពាំងបាយជូរដ៏បរិបូណ៌ហូរហៀរផង។
[11]កូនអើយ មិនត្រូវមើលងាយការប្រៀនប្រដៅរបស់ព្រះអម្ចាស់ឡើយ ហើយក៏មិនត្រូវធ្លាក់ទឹកចិត្តដែរ នៅពេលព្រះអង្គស្តីបន្ទោស[12]ដ្បិតព្រះអម្ចាស់តែងតែប្រៀនប្រដៅអស់អ្នកដែលព្រះអង្គស្រឡាញ់ ដូចឪពុកវាយប្រដៅកូនជាទីស្រឡាញ់របស់ខ្លួន។
[13]អ្នកណារកប្រាជ្ញាឃើញ និងយល់ដឹងពីយោបល់ អ្នកនោះមានសុភមង្គលហើយ។[14]ដ្បិតប្រាជ្ញាដែលកូនរកបាននេះគឺប្រសើរជាងមានប្រាក់ ហើយផ្តល់ឲ្យបានចំណេញប្រសើរជាងមានមាសផងដែរ។
[15]ប្រាជ្ញាមានតម្លៃលើសត្បូង ហើយអ្វីៗទាំងអស់ដែលអ្នកប្រាថ្នាចង់បាន ពុំអាចមានតម្លៃស្មើនឹងប្រាជ្ញានេះឡើយ។[16]ប្រាជ្ញាផ្តល់ឲ្យមានអាយុយឺនយូរ ព្រមទាំងនាំឲ្យមានសម្បត្តិ និងកិត្តិយសដ៏រុងរឿងទៀតផង។
[17]ប្រាជ្ញាដឹកនាំមនុស្សឲ្យរស់នៅដោយសុខដុមរមនា និងសុខសាន្ត។[18]ប្រាជ្ញាជាដើមឈើផ្តល់ជីវិត សម្រាប់អស់អ្នកដែលបេះផ្លែបរិភោគ អ្នកណាមានប្រាជ្ញាជាប់ក្នុងខ្លួន អ្នកនោះនឹងរីករាយ។
[19]ព្រះអម្ចាស់បានបង្កើតផែនដី ដោយសារព្រះប្រាជ្ញាញាណ ហើយព្រះអង្គបានលាតសន្ធឹងផ្ទៃមេឃ ដោយសារព្រះតម្រិះរបស់ព្រះអង្គ។[20]ដោយសារព្រះតម្រិះដ៏វាងវៃរបស់ព្រះអង្គ និងឲ្យពពកបង្អុរភ្លៀងចុះមក។
[21]កូនអើយ កុំឲ្យសេចក្តីទាំងនេះ ចេញបាត់ពីភ្នែកកូនឡើយ ចូររក្សាសេចក្តីដែលមានប្រាជ្ញា និងគំនិតវាងវៃ។[22]ដូច្នេះ សេចក្តីនោះនឹងបានជាជីវិត ដល់ព្រលឹងកូន ហើយជាគ្រឿងលម្អនៅករបស់កូនផង។
[23]នោះកូននឹងបានដើរតាមផ្លូវរបស់កូន ដោយសេចក្តីសុខ ហើយជើងកូននឹងមិនចំពប់ឡើយ។[24]ប្រសិនបើកូន អង្គុយចុះ នោះកូននឹងមិនភ័យខ្លាចអ្វីឡើយ កាលណាកូនចូលដេក នោះកូននឹងដេកលក់យ៉ាងស្កប់ស្កល់។
[25]កុំឲ្យនឹកខ្លាច ក្រែងលោមានហេតុភ័យ កើតមកឆាប់ភ្លាមនោះឡើយ ក៏កុំឲ្យខ្លាចការហិនវិនាសរបស់មនុស្សអាក្រក់ ក្នុងកាលដែលកើតមកនោះដែរ[26]ដ្បិតព្រះអម្ចាស់នឹងបានជាទីទុកចិត្តដល់កូន ព្រះអង្គនឹងរក្សាជើងកូនមិនឲ្យត្រូវជាប់ឡើយ។
[27]កាលណាកូនមានលទ្ធភាពអាចនឹងធ្វើបាន នោះមិនត្រូវបដិសេធនឹងអ្នក ដែលត្រូវការជំនួយពីកូនឡើយ។[28]បើកាលណាកូនមានរបស់អ្វីនៅជិតកូន ដែលអ្នកជិតខាងត្រូវការ នោះកុំនិយាយឡើយថា ទៅសិនចុះ ស្អែកសឹមមក នោះខ្ញុំនឹងឲ្យ។
[29]កុំបង្កើតការអាក្រក់ទាស់នឹងអ្នកជិតខាងកូន ដែលអាស្រ័យនៅជិតកូន ដោយសុខសាន្តនោះឡើយ។[30]បើមនុស្សណាមិនបានធ្វើប្រទូស្តដល់កូន នោះកុំឲ្យតតាំងនឹងគេដោយឥតហេតុឲ្យសោះ។
[31]កុំច្រណែននឹងមនុស្សច្រឡោតឡើយ ក៏កុំរើសយកផ្លូវប្រព្រឹត្តណាមួយរបស់គេដែរ។[32]ដ្បិតមនុស្សវៀចជាទីខ្ពើមឆ្អើមដល់ព្រះអម្ចាស់ តែចំណែកមនុស្សទៀងត្រង់ ព្រះអង្គជាមិត្តនឹងគេវិញ។
[33]បណ្តាសានៃព្រះអម្ចាស់ នោះនៅក្នុងផ្ទះរបស់មនុស្សអាក្រក់តែព្រះអង្គប្រទានពរដល់ទីលំនៅ របស់មនុស្ស សុចរិតវិញ។[34]ព្រះអង្គតែងមើលងាយ ដល់ពួកអ្នកដែលមើលងាយតែព្រះអង្គផ្តល់ព្រះគុណចំពោះអ្នកបន្ទាបខ្លួនវិញ។
[35]មនុស្សមានប្រាជ្ញានឹងគ្រងបានសិរីល្អទុកជាមរតក តែសេចក្តីអាម៉ាស់ខ្មាសនឹងបានជារង្វាន់ ដល់មនុស្សឆោតល្ងង់វិញ។

Proverbs 3:1
ព័ត៌មានទូទៅ:
អ្នកនិពន្ធនិយាយដូចជាឪពុកបង្រៀនកូនដោយប្រើកំណាព្យ។
ចូរកុំភ្លេចពាក្យទូន្មានរបស់យើងឡើយ
ពាក្យថា «ពាក្យទូន្មាន» អាចបកប្រែជាកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«កុំភ្លេចនូវអ្វីដែលយើងទូន្មានឯង»
ចូររក្សាសេចក្តីបង្រៀនរបស់យើងនៅក្នុងចិត្ត
ឃ្លានេះនិយាយជាពាក្យវិជ្ជមាន នៅក្នុងឃ្លាមុននិយាយជាពាក្យអវិជ្ជមាន។ ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យចិត្តគំនិត។ ពាក្យថា «សេចក្តីបង្រៀន» អាចបកប្រែជាកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«សូមចងចាំនូវអ្វីដែលយើងបានបង្រៀនដល់ឯង»
មានអាយុយឺនយូរ
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា និង សំដៅទៅលើការរស់នៅមានអាយុវែង។ ការបកប្រែរបៀបផ្សេងទៀត: «អាយុវែង»

Proverbs 3:3
ចូរកាន់ចិត្តភក្តី និងចិត្តសច្ចៈជានិច្ច
អ្នកនិពន្ធនិយាយពី «ចិត្តភក្តី» និង «ចិត្តសច្ចៈ» ដូចជាមនុស្សដែលអាចចាកចេញពីមនុស្សម្នាក់។
ពាក្យទូន្មានអវិជ្ជមាននេះអាចបញ្ជាក់ជាវិជ្ជមានបាន។ ការបកប្រែរបៀបផ្សេងទៀត:
«ត្រូវតែប្រាកដថាធ្វើអ្វីដោយមានចិត្តភក្តី និងចិត្តសច្ចៈ»
ដូចពាក់គ្រឿងអលង្ការជាប់នៅនឹងក
អ្នកនិពន្ធនិយាយពីចិត្តភក្តី និងចិត្តសច្ចៈ ប្រៀបដូចជារបស់ដែលមនុស្សពាក់នៅនឹងក ដូចជាខ្សែក។
រូបភាពនេះបង្ហាញថាទាំងនេះគឺជាអ្វីដែលមានតម្លៃនៅខាងក្រៅ។
ការបកប្រែរបៀបផ្សេងទៀត: «ត្រូវបង្ហាញឲ្យគេឃើញដូចជាពាក្យខ្សែក»
ត្រូវចារឹកគុណសម្បត្តិនេះជាប់ក្នុងចិត្ត
នៅទីនេះពាក្យថា ចិត្ត តំណាងឲ្យចិត្តគំនិតរបស់មនុស្ស។
ចិត្តគំនិតត្រូវបានគេចាត់ទុកថាដូចជាអ្វីដែលនរណាម្នាក់អាចសរសេរជាសារ ឬ

generated on Wed Sep 10 16:16:32 2025

ជាសេចក្តីទូន្មាន។ ការបកប្រែរបៀបផ្សេងទៀត: «ចងចាំគ្រប់ពេល
ដូចជាអ្នកបានចារឹកក្នុងចិត្ត»
គាប់ព្រះហឫទ័យព្រះជាម្ចាស់ គាប់ចិត្តមនុស្ស
ការយល់ឃើញនៅទីនេះតំណាងឲ្យការវិនិច្ឆ័យ ឬ ការវាយតម្លៃ។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ និង មនុស្ស»
Proverbs 3:5
អស់ពីចិត្ត
ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យភាពខាងក្នុងរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ខ្លួនទាំងមូល»
កុំពឹងលើចំណេះចេះដឹងរបស់ខ្លួនឡើយ
អ្នកនិពន្ធនិយាយពីការពឹងផ្អែកលើការចេះដឹងរបស់ខ្លួនដូចជា «ការចេះដឹង»
ជាអ្វីដែលមនុស្សម្នាក់អាចពឹងផ្អែកបាន។ ការបកប្រែរបៀបផ្សេងទៀត:
«កុំពឹងផ្អែកលើការចេះដឹងរបស់ខ្លួនឡើយ»
ក្នុងគ្រប់កិច្ចការដែលកូនធ្វើ
អ្នកនិពន្ធនិយាយអំពីទង្វើររបស់មនុស្សម្នាក់ ប្រៀបដូចជា ផ្លូវដែលមនុស្សដើរ។
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងគ្រប់កិច្ចការដែលអ្នកធ្វើ»
ព្រះអង្គនឹងរៀបចំផ្លូវរបស់កូន
អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់ដែលចម្រុងចម្រើនលើទង្វើររបស់មនុស្ស
ដែលដូចជាទង្វើរនោះជាផ្លូវដែលគេដើរ
ដែលព្រះអម្ចាស់រៀបចំផ្លូវសម្រាប់ពួកគេមិនឲ្យមានឧបសគ្គ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គនឹងជួយឲ្យគេមានជ័យជម្នះ»
Proverbs 3:7
កុំចាត់ទុកខ្លួនកូនថាជាអ្នកមានប្រាជ្ញាឡើយ
អ្នកនិពន្ធនិយាយអំពីគំនិតរបស់មនុស្សម្នាក់
ដែលមនុស្សមើលឃើញថាខ្លួនមានប្រាជ្ញា។ ការបកប្រែរបៀបផ្សេងទៀត:
«កុំគិតថាខ្លួនមានប្រាជ្ញា»
ងាកចេញពីការអាក្រក់
អ្នកនិពន្ធនិយាយការដែលមិនចុះចូលជាមួយនឹងការអាក្រក់
ដូចជាការបែរចេញពីការអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត:
«កុំចុះចូលនឹងការអាក្រក់»
ការទាំងនេះគឺជាឱសថព្យាបាលខ្លួន
ពាក្យថា «ការទាំងនេះ»
សំដៅទៅលើសេចក្តីណែនាំដែលអ្នកនិពន្ធផ្តល់ឲ្យនៅក្នុងខមុន។
អត្ថន័យពេញនេះអាចនឹងច្បាស់លាស់។ ពាក្យថា «ខ្លួន»
តំណាងឲ្យរាងកាយទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើអ្នកធ្វើបែបនេះ នោះអ្នកនឹងទទួលបានការព្យាបាល»
Proverbs 3:9
ផល
«ភោគផល»
កូននឹងមានស្រូវពេញជង្រុក
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ជង្រុករបស់អ្នកនឹងបានពេញ»
ជង្រុក
អគារ ឬ បន្ទប់ស្តុកទុកអាហារ។
ធុងរបស់របស់អ្នកនឹងផ្ទុះបែក
ធុងដែលស្តុកទុកនឹងពេញខ្លាំង ហៀបនឹងផ្ទុះបែក។
Proverbs 3:11
ព័ត៌មានទូទៅ:
អ្នកនិពន្ធសរសេរដូចជាឪពុកបង្រៀនកូន។
កូនជាទីស្រឡាញ់
«កូនប្រុសដែលគាត់ពេញចិត្ត» នេះសំដៅទៅលើ ឪពុកដែលស្រឡាញ់កូន និង
មិនមែនឲ្យឪពុកយោគយល់ចំពោះអកប្បកិរិយារបស់កូន។
ការបកប្រែរបៀបផ្សេងទៀត: «កូនដែលគាត់ស្រឡាញ់ពេញចិត្ត»
Proverbs 3:13
អ្នកណារកប្រាជ្ញាឃើញ
អ្នកនិពន្ធនិយាយពី «ប្រាជ្ញា» ដូចជារបស់ដែលគេរកឃើញ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលទទួលបានប្រាជ្ញា»
ប្រសើរជាងមានប្រាក់ចំណេញ
នេះសំដៅទៅលើប្រាក់ចំណេញដែលគេបានមកពីការធ្វើជំនួញ ឬ វិនិយោគប្រាក់។
Proverbs 3:15
ព័ត៌មានទូទៅ:
អ្នកនិពន្ធនិយាយពីប្រាជ្ញាប្រៀបដូចជាស្ត្រីម្នាក់។ (សូមមើល:figs-personification)
មានតម្លៃ
«ដែលមានតម្លៃ» ឬ «មានតម្លៃ»
ប្រាជ្ញាផ្តល់ឲ្យមានអាយុយឺនយូរ ព្រមទាំងនាំឲ្យមានសម្បត្តិ និងកិត្តិយសដ៏រុងរឿងទៀតផង
អ្នកនិពន្ធនិយាយពីប្រយោជន៍ដែលទទួលបានពីប្រាជ្ញា ដែលប្រាជ្ញាប្រៀបដូចជា
ស្ត្រីដែលកាន់គុណសម្បត្តិទាំងនោះនៅក្នុងដៃ ហើយប្រគល់ទៅឲ្យមនុស្សនានា។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញាផ្តល់ឲ្យមនុស្សមានអាយុវែង មានទ្រព្យសម្បត្តិ
និង កិត្តិយស»
អាយុយឺនយូរ
ពាក្យក្រៀមភាសានេះសំដៅទៅលើអាយុវែង។ ការបកប្រែរបៀបផ្សេងទៀត:
«អាយុយឺនយូរ»
Proverbs 3:17
ប្រាជ្ញាដឹកនាំមនុស្សឲ្យរស់នៅដោយសុខដុមរមនា និងសុខសាន្ត
អ្នកនិពន្ធនិយាយពីប្រាជ្ញាប្រៀបដូចជាស្ត្រី និង អត្ថប្រយោជន៍
ដែលប្រាជ្ញាផ្តល់ឲ្យមនុស្សម្នាក់ ដែលប្រៀបដូចជាការនាំផ្លូវមនុស្សម្នាក់ទៀត។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញានឹងនាំឲ្យអ្នកមានសន្តិភាព»
ប្រាជ្ញាជាដើមឈើផ្តល់ជីវិត សម្រាប់អស់អ្នកដែលបេះផ្លែបរិភោគ
អ្នកនិពន្ធនិយាយពីប្រាជ្ញាដែលប្រៀបដូចជាដើមឈើដែលផ្តល់ផ្លែជីវិត
ហើយអស់អ្នកណាដែលទទួលបានប្រាជ្ញា ប្រៀបដូចជាគេបរិភោគផ្លែនោះ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញាដូចជាដើមឈើ ដែលទ្រទ្រង់ជីវិតដល់អស់អ្នក
ដែលបរិភោគផ្លែឈើនោះ»
ដើមឈើផ្តល់ជីវិត
«ដើមឈើដែលផ្តល់ជីវិត» ឬ «ដើមឈើដែលទ្រទ្រង់ជីវិត»
អស់អ្នកដែលបេះផ្លែបរិភោគ
«អស់អ្នកដែលបេះផ្លែរបស់វា»
Proverbs 3:19
ព្រះអម្ចាស់បានបង្កើតផែនដី...ព្រះអង្គបានលាតសន្ធឹងផ្ទៃមេឃ
អ្នកនិពន្ធនិយាយពីការបង្កើតផែនដី និង ផ្ទៃមេឃរបស់ព្រះអម្ចាស់
ដូចជាការចាក់គ្រឹះនៃអគារមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បង្កើតផែនដី... បង្កើតផ្ទៃមេឃ»
ពពកបង្ហូរភ្លៀងចុះ
តាមគំនិតបុរាណ ទឹកមាននៅក្រោមដី។
ឃ្លានេះសំដៅទៅលើព្រះអម្ចាស់បានបង្ករឲ្យមានទឹកចេញមកពីផែនដី និង
ធ្វើឲ្យមហាសមុទ្រ និង ទឹកទន្លេកើតមានឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបណ្តាលឲ្យទឹកទន្លេហូរ» ឬ
«ព្រះអង្គធ្វើឲ្យកើតមានមហាសមុទ្រកើតមានឡើង»
ទឹកសន្សើម
ទឹកដែលមានលើដីនៅពេលយប់។
Proverbs 3:21
កុំឲ្យសេចក្តីទាំងនេះ ចេញបាត់ពីភ្នែកកូនឡើយ
អ្នកនិពន្ធនិយាយពីការដែលកុំបំភ្លេចអ្វីមួយ ដូចជាអ្វីដែលអាចមើលឃើញជានិច្ច។
ការបកប្រែរបៀបផ្សេងទៀត: «មិនត្រូវបំភ្លេចសេចក្តីទាំងនោះឡើយ»
សេចក្តីនោះនឹងបានជាជីវិត ដល់ព្រលឹងកូន
ពាក្យថា «ព្រលឹង» នៅទីនេះតំណាងឲ្យមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«សេចក្តីទាំងនោះគឺជាជីវិតដល់អ្នក»
ជាគ្រឿងលម្អនៅករបស់កូនផង
អ្នកនិពន្ធនិយាយពី «ការវិនិច្ឆ័យដ៏ត្រឹមត្រូវ» និង «ការស្តាប់ខុសត្រូវ»
ដូចជាអ្វីដែលមនុស្សម្នាក់អាចចងជាប់នឹងកដូចជាខ្សែក។
រូបភាពបង្ហាញថាទាំងនេះជារបស់មានតម្លៃ
ដែលមនុស្សបង្ហាញចេញមកខាងក្រៅ។ ការបកប្រែរបៀបផ្សេងទៀត:
«ការបង្ហាញការពេញចិត្តដូចជាមនុស្សម្នាក់បំពាក់ខ្សែកនៅលើកពួកគេ»
បំពាក់គ្រឿងលម្អ
អាចមានន័យថា គឺ១) «គ្រឿងលម្អដែលជាទីពេញចិត្ត» ឬ ២)
«គ្រឿងលម្អដែលគាប់ព្រះទ័យព្រះអម្ចាស់។»
Proverbs 3:23
នោះកូននឹងបានដើរតាមផ្លូវរបស់កូន ដោយសេចក្តីសុខ

generated on Wed Sep 10 16:16:32 2025

អ្នកនិពន្ធនិយាយពីជីវិតរស់នៅរបស់ម
នុស្សម្នាក់ដែលប្រៀបដូចជាមនុស្សនោះដើរលើផ្លូវតែមួយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងរស់នៅដោយសេចក្តីសុខសាន្ត»
ជើងកូននឹងមិនចំពប់ឡើយ
ពាក្យថា «ជើង» តំណាងឲ្យមនុស្សទាំងមូល។ អ្នកនិពន្ធនិយាយពីការប្រព្រឹត្តិខុស
ដូចជាមនុស្សជំពប់ដួលនឹងអ្វីមួយនៅលើផ្លូវរបស់គេ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងមិនធ្វើអ្វីដែលខុសឆ្គងឡើយ»
នៅពេលកូនអង្គុយចុះ
វាបញ្ជាក់ថាមនុស្សម្នាក់អង្គុយចុះដើម្បីដេក។ អត្ថន័យនេះអាចនឹងច្បាស់លាស់។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលអ្នកអង្គុយចុះដើម្បីដេក»
នោះកូននឹងដេកលក់យ៉ាងស្កប់ស្កល់
អ្នកនិពន្ធនិយាយពីការគេងដែលលង់លក់ស្រួល និង ស្រស់ស្រាយ
ដែលដូចជាមានរសជាតិផ្អែមចំពោះអ្នកដែលកំពុងគេង។ ពាក្យថា «គេង»
អាចបកប្រែជាកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកគេងលង់លក់ស្រួល» ឬ «អ្នកនឹងគេងលក់ដោយសុខសាន្ត»
Proverbs 3:25
កុំឲ្យខ្លាចការហិនវិនាសរបស់មនុស្សអាក្រក់ ក្នុងកាលដែលកើតមកនោះដែរ
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលមនុស្សអាក្រក់ធ្វើឲ្យមានសេចក្តីហិនវិនាស»
ព្រះអម្ចាស់នឹងបានជាទីទុកចិត្តដល់កូន
«ព្រះអម្ចាស់នឹងជាទីទុកចិត្តដល់កូន» មនុស្សម្នាក់ដែលនៅក្បែរមនុស្សម្នាក់ទៀត
ជាក្រៀមភាសា ដែលមានន័យថា
មនុស្សម្នាក់នោះជាអ្នកដែលចាំជួយជ្រោមជ្រែងអ្នកដទៃ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់នឹងចាំជួយគាំទ្រ និង ការពារអ្នក»
នឹងរក្សាជើងកូនមិនឲ្យត្រូវជាប់ឡើយ
អ្នកនិពន្ធនិយាយពីមនុស្សម្នាក់ដែលធ្លាប់ជួបរឿងរន្ធត់ភ័យខ្លាច «ភេរវកម្ម» និង
«សេចក្តីហិនវិនាស» ដូចជាមនុស្សម្នាក់ជាប់អន្ទាក់។ ពាក្យថា «ជើង»
តំណាងឲ្យមនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងការពារអ្នកពីមនុស្សដែលចង់ធ្វើបាបអ្នក»
Proverbs 3:27
កុំបដិសេធនឹងធ្វើការល្អ
«កុំបដិសេធចំពោះការល្អ» ឬ «មិនត្រូវរារាំងក្នុងការធ្វើការល្អ»
កាលណាកូនមានលទ្ធភាពអាចនឹងធ្វើបាន
«នៅពេលដែលអ្នកអាចជួយគេបាន»
នៅពេលដែលអ្នកមានលុយជាប់ខ្លួន
«នៅពេលដែលមានលុយនៅពេលនេះ» នៅទីនេះមានន័យថា
មនុស្សម្នាក់មានលុយអាចជួយគេថ្ងៃនេះ ប៉ុន្តែប្រាប់គេថាចាំមកថ្ងៃស្អែក។
Proverbs 3:31
កុំ...កុំរើសយកផ្លូវប្រព្រឹត្តណាមួយរបស់គេដែរ
វាបញ្ជាក់ថា គាត់មិនជ្រើសរើសប្រព្រឹត្តតាមមនុស្សអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត:
«កុំ...ជ្រើសរើសយករបៀបណាមួយរបស់គេមកប្រព្រឹត្តតាម»
មនុស្សវៀចជាទីខ្ពើមឆ្អើមដល់ព្រះអម្ចាស់
«ព្រះអម្ចាស់ស្អប់មនុស្សវៀចវេរ»
មនុស្សវៀវេរ
មនុស្សដែលមិនស្មោះត្រង់ មនុស្សបោកប្រាស់
ចំណែកមនុស្សទៀងត្រង់ ព្រះអង្គជាមិត្តនឹងគេវិញ
ព្រះអម្ចាស់នឹងចែករំលែកគំនិតរបស់ព្រះអង្គជាមួយអស់អ្នកដែលប្រព្រឹត្តត្រឹមត្រូវ
ដោយជិតស្និទ្ធបែបមិត្តភក្តិ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់នឹងធ្វើជាមិត្តជិតស្និទនឹងមនុស្សដែលប្រព្រឹត្តត្រឹមត្រូវ»
Proverbs 3:33
បណ្តាសានៃព្រះអម្ចាស់ នោះនៅក្នុងផ្ទះរបស់មនុស្សអាក្រក់
អ្នកនិពន្ធនិយាយពីបណ្តាសាររបស់ព្រះអម្ចាស់
ដែលដូចជារបស់អ្វីមួយដែលព្រះអង្គដាក់នៅលើដំបូលផ្ទះរបស់មនុស្សអាក្រក់។
ពាក្យថា «ផ្ទះ» ជាឈ្មោះក្រៅសម្រាប់គ្រួសារ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ដាក់បណ្តាសារលើគ្រួសាររបស់មនុស្សអាក្រក់» (សូមមើល: និងfigs-metonymy)
ព្រះអង្គប្រទានពរដល់ទីលំនៅ របស់មនុស្ស សុចរិតវិញ
ពាក្យថា «ទីលំនៅ» តំណាងឲ្យគ្រួសារ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គប្រទានពរដល់ក្រុមគ្រួសាររបស់មនុស្សសុចរិត»
ព្រះអង្គផ្តល់ព្រះគុណចំពោះអ្នកបន្ទាបខ្លួនវិញ
អ្នកនិពន្ធនិយាយពីព្រះគុណរបស់ព្រះអម្ចាស់ ប្រៀបដូចជា
របស់ដែលព្រះអង្គអាចប្រទានដល់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គសម្តែងព្រះគុណដល់មនុស្សដែលបន្ទាបខ្លួន» ឬ
«ព្រះអង្គជាព្រះគុណដល់មនុស្សដែលបន្ទាបខ្លួន»
Proverbs 3:35
មនុស្សមានប្រាជ្ញានឹងគ្រងបានសិរីល្អទុកជាមរតក
អ្នកនិពន្ធនិយាយពីមនុស្សមានប្រាជ្ញាមានកិត្តិយសជាមរតក
ដូចជាមរតកដែលមានគេមានជាប់រហូត។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សមានប្រាជ្ញានឹងមានកិត្តិយស» ឬ
«មនុស្សមានប្រាជ្ញានឹងបានកិត្តិយសជាមរតក»
សេចក្តីអាម៉ាស់ខ្មាសនឹងបានជារង្វាន់ ដល់មនុស្សឆោតល្ងង់វិញ
អ្នកនិពន្ធនិយាយពីព្រះអម្ចាស់នឹងធ្វើឲ្យមនុស្សឆោតល្ងង់មានភាពអាម៉ាស់
នៅចំពោះមុខមនុស្សគ្រប់គ្នា ដូចជាព្រះអម្ចាស់នឹងលើកមនុស្សឆោតល្ងង់ឡើង
ដើម្បីឲ្យមនុស្សគ្រប់គ្នាបានឃើញពួកគេ។ នេះអាចបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់នឹងធ្វើឲ្យមនុស្សគ្រប់គ្នា
បានឃើញពីភាពអាម៉ាស់របស់មនុស្សល្ងីល្ងើ»

---

4 [1]កូនអើយ ចូរស្តាប់ពាក្យទូន្មានរបស់យើង ចូរប្រុងស្មារតី ដូច្នេះកូននឹងយល់ដឹងហើយនិងចំណេះផង។[2]យើងបានបង្រៀនកូនអំពីការល្អ កុំបោះបង់ចោល
សេចក្តីបង្រៀនរបស់យើងឡើយ។
[3]ពេលមុន យើងធ្លាប់ជាកូនរបស់ឪពុកយើង ហើយក៏ជាកូនសំណព្វរបស់ម្តាយយើងដែរ។[4]ឪពុកយើងបានបង្រៀនយើងថា៖ «ចូរកូនចងចាំពាក្យរបស់ឪពុកទុកក្នុងចិត្ត ចូរ
ប្រតិបត្តិតាមដំបូន្មានរបស់ឪពុក នោះកូននឹងមានជីវិត។
[5]ចូររកប្រាជ្ញា និងចំណេះដឹងឲ្យបាន មិនត្រូវបំភ្លេច ឬងាកចេញពីពាក្យរបស់ឪពុកឡើយ[6]កុំបោះបង់ប្រាជ្ញាឲ្យសោះ នោះប្រាជ្ញានឹងការពារកូន ចូរស្រឡាញ់ប្រាជ្ញា នោះប្រាជ្ញា
នឹងថែរក្សាកូន។
[7]ប្រភពនៃប្រាជ្ញាចាប់ផ្តើមដូចតទៅ គឺត្រូវរកប្រាជ្ញាឲ្យបាន ហើយចំណាយអ្វីៗទាំងអស់ដែលកូនមាន ដើម្បីរកឲ្យបានការចេះដឹង។[8]ចូរឱបរឹតប្រាជ្ញាឲ្យជាប់ក្នុងដួងចិត្ត នោះ
ប្រាជ្ញានឹងលើកតម្កើងកូនឡើងយ៉ាងថ្លៃថ្នូរ។[9]ប្រាជ្ញានឹងផ្តល់ឲ្យកូនបានរុងរឿង គឺប្រៀបដូចជាមកុដ នឹងជាគ្រឿងអលង្ការដ៏ថ្លៃបំផុត សម្រាប់កូន»។
[10]កូនអើយ ចូរស្តាប់ ហើយធ្វើតាមពាក្យរបស់យើង នោះកូននឹងមានអាយុវែង។[11]យើងបានណែនាំកូនឲ្យស្គាល់របៀបរស់នៅប្រកបដោយប្រាជ្ញា និងបានអប់រំកូនឲ្យដើរ
តាមផ្លូវទៀងត្រង់។[12]ពេលណាកូនដើរតាមផ្លូវនេះ នឹងគ្មានឧបសគ្គអ្វីមករារាំងកូនឲ្យជំពប់ដួលឡើយ។
[13]ចូរកាន់តាមសេចក្តីបង្រៀនរបស់យើង ដោយឥតលះបង់ចោលឡើយ ចូរថែរក្សាឲ្យជាប់ ដ្បិតដំបូន្មាននេះជាជីវិតរបស់កូន។[14]មិនត្រូវចូលរួមក្នុងផ្លូវរបស់មនុស្សពាល
ឡើយ ហើយក៏មិនត្រូវយកតម្រាប់តាមមនុស្សអាក្រក់ដែរ។[15]ចូរចៀសវាងដើរតាមផ្លូវនោះ ត្រូវដើរវាងឲ្យឆ្ងាយតាមផ្លូវផ្សេងវិញ។
[16]ដ្បិត ពួកគេមិនចូលដំណេកទេ ដរាបទាល់តែបានប្រព្រឹត្តអំពើអាក្រក់ជាមុនសិន គឺប្រសិនបើគេមិនបានធ្វើទុក្ខទោសអ្នកផ្សេងទេនោះ គេដេកមិនលក់ឡើយ។[17]ដ្បិតគេ
ចិញ្ចឹមជីវិតដោយសារអំពើទុច្ចរិត ហើយគេផឹកស្រាដែលបានមកដោយសារអំពើឃោរឃៅ។
[18]ប៉ុន្តែ ផ្លូវរបស់មនុស្សសុចរិតប្រៀបបីដូចជាពន្លឺអរុណរះ បញ្ចេញរស្មីកាន់តែភ្លឺឡើងៗ រហូតដល់ព្រះអាទិត្យពេញកម្តៅ។[19]ចំណែកផ្លូវរបស់ជនពាលវិញ ដូចទៅនឹងភាព
ងងឹតអន្ធការ គឺពួកគេមិនអាចមើលឧបសគ្គដែលធ្វើឲ្យខ្លួនជំពប់ដួលនោះឃើញឡើយ។
[20]កូនអើយ ចូរផ្ទៀងត្រចៀក ចូរត្រងត្រាប់ស្តាប់ពាក្យទូន្មាន និងសេចក្តីបង្រៀនរបស់យើង។[21]កុំបំភ្លេចពាក្យយើង គឺត្រូវរក្សាទុកឲ្យជាប់នៅក្នុងដួងចិត្តរបស់កូនផង។
[22]ដ្បិតពាក្យទាំងនេះនឹងផ្តល់ជីវិត និងសុខភាពដល់រូបកាយអស់អ្នកដែលទទួលយក។[23]ចូរកូនថែរក្សាចិត្តដោយប្រុងប្រយ័ត្ន ដ្បិតចិត្តគំនិតរបស់កូនយ៉ាងណា ជីវិតរបស់
កូនក៏យ៉ាងនោះដែរ។

generated on Wed Sep 10 16:16:32 2025

[24]ចូរទប់មាត់កុំឲ្យពោលពាក្យអាស្រូវឡើយ ហើយក៏កុំគ្រលាស់អណ្តាតពោលពាក្យមួលបង្កាច់គេដែរ។[25]ចូរឲ្យភ្នែកកូនមើលចំទៅមុខ ហើយត្របកភ្នែកឯងទៅត្រង់ទៅមុខដែរ។
[26]ត្រូវកំណត់ផ្លូវដែលជើងកូនដើរ ហើយផ្លូវរបស់កូននឹងមានសុវត្ថិភាព។[27]កុំងាកបែរទៅខាងស្តាំ ឬខាងឆ្វេងឡើយ ត្រូវឲ្យជើងរបស់កូនងាកចេញពីសេចក្តីអាក្រក់វិញ។

Proverbs 4:1
ព័ត៌មានទូទៅ:
អ្នកនិពន្ធនិយាយពីឪពុកដែលកំពុងបង្រៀនកូន។
យកចិត្តទុកដាក់
«ស្តាប់ដោយប្រុងប្រយ័ត្ន»
កូននឹងយល់ដឹង ហើយនិងចំណេះផង
«អ្នកនឹងយល់ពីចំណេះដឹង» ឬ «អ្នកនឹងចម្រើនប្រាជ្ញា»
យើងបានបង្រៀនកូនអំពីការល្អ
«អ្វីដែលយើងបង្រៀនអ្នកជាសេចក្តីល្អ»
Proverbs 4:3
ពេលមុន យើងធ្លាប់ជាកូនរបស់ឪពុកយើង
នេះសំដៅទៅលើពេលដែលអ្នកនិពន្ធធ្លាប់ជាកូនដែលរស់នៅក្រោមការមើលថែរបស់ឪពុកគាត់ ដូចជាការបកប្រែរបៀបផ្សេងទៀត: «ពេលដែលយើងធ្លាប់ជាកូនដែលរៀនពីឪពុកយើង»
ជាក្មេងទន់ភ្លន់តែម្នាក់
ពាក្យថា «ទន់ភ្លន់» នៅទីនេះសំដៅទៅលើក្មេងដែលនៅខ្សោយ។ វាបង្កើតជាតំណពូជមួយនឹងពាក្យ «តែមួយ»។ ការបកប្រែរបៀបផ្សេងទៀត: «ក្មេងទន់ភ្លន់តែមួយគត់» (សូមមើល:figs-hendiadys)
ចូរកូនចងចាំពាក្យរបស់ឪពុកទុកក្នុងចិត្ត
ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យចិត្តរបស់មនុស្ស។ អ្នកនិពន្ធនិយាយពីការដែលចងចាំពាក្យ ដូចជាចិត្តដែលចង់ជាប់យ៉ាងណែន។ ការបកប្រែរបៀបផ្សេងទៀត: «ចង់ចាំជានិច្ចនូវអ្វីដែលខ្ញុំបង្រៀនដល់អ្នក»
Proverbs 4:5
ព័ត៌មានទូទៅ:
ឪពុកនៅតែបន្តបង្រៀនកូនពីអ្វីដែលឪពុករបស់គាត់បានបង្រៀន។
ចូររកប្រាជ្ញា
«ចូរប្រឹងប្រែងដើម្បីឲ្យបានចម្រើនប្រាជ្ញា» ឬ «បានប្រាជ្ញា»
មិនត្រូវបំភ្លេច
«ចងចាំ»
មិនត្រូវងាកចេញ
«ទទួលយក»
ពាក្យចេញពីមាត់ខ្ញុំ
ពាក្យថា «មាត់» នៅទីនេះតំណាងឲ្យមនុស្សដែលនិយាយ។ ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលខ្ញុំកំពុងនិយាយ»
កុំបោះបង់ប្រាជ្ញាឲ្យសោះ នោះប្រាជ្ញានឹងការពារកូន ចូរស្រឡាញ់ប្រាជ្ញា នោះប្រាជ្ញានឹងថែរក្សាកូន។
អ្នកនិពន្ធបាននិយាយពីប្រាជ្ញាដែលប្រៀបដូចជាស្ត្រីដែលការពារមនុស្សដែលស្មោះត្រង់ចំពោះនាង។
កុំបោះបង់ប្រាជ្ញា
នេះអាចបញ្ជាក់ជាទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត: «ចាប់ប្រាជ្ញាឲ្យជាប់» ឬ «ត្រូវស្មោះត្រង់ចំពោះប្រាជ្ញា»
ចូរស្រឡាញ់ប្រាជ្ញា
«ស្រឡាញ់ប្រាជ្ញា»
Proverbs 4:7
ព័ត៌មានទូទៅ:
ឪពុកបានបញ្ចប់សេចក្តីបង្រៀនកូនៗពីអ្វីដែលឪពុករបស់គាត់បានបង្រៀន។
ចំណាយអ្វីៗទាំងអស់ដែលកូនមាន ដើម្បីរកឲ្យបានការចេះដឹង
«ឲ្យតម្លៃការចេះដឹងជាងអ្វីៗដែលកូនមាន»
ចូរឱបរឹតប្រាជ្ញាឲ្យជាប់ក្នុងដួងចិត្ត នោះប្រាជ្ញានឹងលើកតម្កើងកូន
អ្នកនិពន្ធនិយាយពីប្រាជ្ញាដែលប្រៀបដូចជា ប្រាជ្ញាផ្តល់កិត្តិយសដល់មនុស្ស ដូចជាប្រាជ្ញាបានលើកមនុស្សនោះក្នុងងត់ណែងខ្ពង់ខ្ពស់។ ការបកប្រែរបៀបផ្សេងទៀត: «បើអ្នកចាប់ប្រាជ្ញាជាប់ នោះប្រាជ្ញានឹងផ្តល់កិត្តិយសដល់អ្នក»
ចិត្តស្រឡាញ់
អារម្មណ៍ ឬ ការបង្ហាញពីក្តីស្រឡាញ់ចំពោះនរណាម្នាក់ ឬ អ្វីមួយ។
ប្រាជ្ញានឹងផ្តល់កិត្តិយសដល់អ្នកពេលដែលអ្នកអោបប្រាជ្ញាជាប់
អ្នកនិពន្ធនិយាយពីប្រាជ្ញា ដែលប្រៀបដូចជាស្ត្រី និង មនុស្សដែលឲ្យតម្លៃប្រាជ្ញាដូចជាមនុស្សដែលដាក់ដៃអោបជុំវិញប្រាជ្ញា។ ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើអ្នកស្រឡាញ់ប្រាជ្ញា នោះប្រាជ្ញានឹងធ្វើឲ្យមនុស្សផ្តល់កិត្តិយសដល់អ្នក»
ប្រាជ្ញានឹងផ្តល់ឲ្យកូនបានរុងរឿង
អ្នកនិពន្ធបាននិយាយពីកិត្តិយស ដែលមនុស្សម្នាក់នឹងមានពីការចម្រើនប្រាជ្ញាដូចជាប្រាជ្ញាបំពាក់កម្រងផ្កាលើក្បាលគេ។ ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញាដូចជាកម្រងផ្កាដែលពាក់លើក្បាលរបស់អ្នកដែលបង្ហាញពីកិត្តិយសដ៏អស្ចារ្យ»
កម្រង់ផ្កា
រង្វង់កងដែលក្រងស្លឹក ឬ ផ្កា
ប្រាជ្ញានឹងផ្តល់ឲ្យកូនជាម្កុដដ៏ស្រស់ស្អាត
អ្នកនិពន្ធនិយាយពីកិត្តិយសដែលមនុស្សម្នាក់នឹងទទួលបានពីប្រាជ្ញាដូចជាប្រាជ្ញាបំពាក់ម្កុដលើក្បាលគេ។ ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញាប្រៀបបានទៅនឹងម្កុដដ៏ស្រស់ស្អាតនៅលើក្បាលរបស់អ្នក»
Proverbs 4:10
ចូរស្តាប់ពាក្យយើងដោយយកចិត្តទុកដាក់
«ចូរស្តាប់នូវអ្វីដែលយើងបង្រៀនអ្នកដោយប្រុងប្រយ័ត្ន»
នោះកូននឹងមានអាយុវែង
«កូននឹងមានអាយុវែង»
យើងបានណែនាំកូនឲ្យស្គាល់របៀបរស់នៅប្រកបដោយប្រាជ្ញា និងបានអប់រំកូនឲ្យដើរតាមផ្លូវទៀងត្រង់
អ្នកនិពន្ធនិយាយពីការបង្រៀនកូនគាត់ឲ្យរស់នៅដោយប្រាជ្ញា ដូចជាការដែលគាត់ដឹកនាំកូនគាត់ដើរលើផ្លូវដែលរកបានប្រាជ្ញា។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំកំពុងបង្រៀនអ្នកពីរបៀបដែលរស់នៅដោយប្រាជ្ញា ខ្ញុំកំពុងពន្យល់អ្នកពីរបៀបរស់នៅដោយត្រឹមត្រូវ»
ពេលណាកូនដើរតាមផ្លូវនេះ នឹងគ្មានឧបសគ្គអ្វីមករារាំងកូនឲ្យជំពប់ដួលឡើយ។
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា។ អ្នកនិពន្ធនិយាយពីការសម្រេចចិត្ត និងសកម្មភាពដែលមនុស្សម្នាក់ធ្វើដូចជាមនុស្សម្នាក់ដើរ ឬ រត់លើផ្លូវ និងមនុស្សដែលជោគជ័យប្រៀបដូចជាផ្លូវដែលគ្មានឧបសគ្គដែលធ្វើឲ្យគេជំពប់ដួលឡើយ។ ការបកប្រែរបៀបផ្សេងទៀត: «ពេលដែលអ្នកមានគម្រោងការអ្វីមួយ អ្នកនឹងទទួលបានជោគជ័យ»
Proverbs 4:13
ចូរកាន់តាមសេចក្តីបង្រៀនរបស់យើង ដោយឥតលះបង់ចោលឡើយ
អ្នកនិពន្ធបាននិយាយពីមនុស្សម្នាក់ ដែលចង់ចាំនូវអ្វីដែលគាត់បានរៀនដូចជា «សេចក្តីណែនាំ» ដែលដូចជារបស់ដែលមនុស្សចាប់ជាប់។ ការបកប្រែរបៀបផ្សេងទៀត: «បន្តគោរពស្តាប់បង្គាប់នូវអ្វី ដែលខ្ញុំបានបង្រៀនអ្នក ហើយមិនដែលភ្លេចវាឡើយ»
ដ្បិតជំបូន្មាននេះជាជីវិតរបស់កូន
អ្នកនិពន្ធបាននិយាយពីការលត់ដំដើម្បីការពារជីវិតរបស់មនុស្សម្នាក់ដូចជាជីវិតរបស់មនុស្សម្នាក់នោះ។ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតវានឹងការពារជីវិតរបស់អ្នក»
មិនត្រូវចូលរួមក្នុងផ្លូវរបស់មនុស្សពាលឡើយ ហើយក៏មិនត្រូវយកតម្រាប់តាមមនុស្សអាក្រក់ដែរ
អ្នកនិពន្ធនិយាយពីសកម្មភាពរបស់មនុស្សម្នាក់ដែលដូចជាមនុស្សនោះដើរលើផ្លូវ។ ការបកប្រែរបៀបផ្សេងទៀត: «កុំធ្វើតាមអ្វីដែលមនុស្សអាក្រក់ធ្វើ ហើយក៏កុំចូលរួមនឹងសកម្មភាពដែលមនុស្សអាក្រក់ធ្វើដែរ»
ចៀសវាងដើរតាមផ្លូវនោះ
«ជៀសវាងផ្លូវអាក្រក់»
Proverbs 4:16
ពួកគេមិនចូលដំណេកទេ ដរាបទាល់តែបានប្រព្រឹត្តអំពើអាក្រក់ជាមុនសិន
អ្នកនិពន្ធប្រើការបំផ្លើសមួយដើម្បីបញ្ជាក់ពីបំណងចិត្តរបស់មនុស្សអាក្រក់ដែលចង់តែប្រព្រឹត្តអាក្រក់។
គេដេកមិនលក់ឡើយ
អ្នកនិពន្ធនិយាយពីមនុស្សដែលមិនអាចគេងលក់ដូចជាការគេងគឺជាវត្ថុមួយដែលនរណាម្នាក់លួចពីពួកគេ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនអាចដេកលក់»

generated on Wed Sep 10 16:16:32 2025

ប្រសិនបើគេមិនបានធ្វើទុក្ខទោសអ្នកផ្សេងទេនោះ
អ្នកនិពន្ធនិយាយពីការធ្វើបាបអ្នកដទៃ ដូចជាការធ្វើឲ្យនរណាម្នាក់ជំពប់ដួល»
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើពួកគេធ្វើបាបនរណាម្នាក់»
ដ្បិតគេចិញ្ចឹមជីវិតដោយសារអំពើទុច្ចរិត ហើយគេផឹកស្រាដែលបានមកដោយសារអំពើឃោរឃៅ
អាចមានន័យថា គឺ១)
នេះជាការប្រៀបធៀបដែលអ្នកនិពន្ធនិយាយពីមនុស្សទាំងនេះដែលចូលចិត្តប្រព្រឹត្តអាក្រក់ដូចជាពួកគេបានធ្វើ
ប្រៀបបានដូចជាស៊ីផឹក ដូចជាការបរិភោគនំប៉័ង និង ស្រាដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«សេចក្តីអាក្រក់ប្រៀបបានទៅនឹងនំប៉័ងដែលគេបរិភោគ និង
អំពើឃោឃៅដូចជាស្រាដែលគេផឹក» ២)មនុស្សទាំងនេះបានអាហារ និង
ភេសជ្ជៈដោយការប្រព្រឹត្តការអាក្រក់ និង អំពើឃោឃៅ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបរិភោគនំប៉័ង
ដែលគេបានមកពីការធ្វើអាក្រក់ និង ផឹកស្រាដែលបានមកពីអំពើឃោឃៅដែរ»
Proverbs 4:18
ផ្លូវរបស់មនុស្សសុចរិត...ផ្លូវរបស់ជនពាល
អ្នកនិពន្ធនិយាយពីសកម្មភាព និង ការរស់នៅរបស់មនុស្សសុចរិត និង
មនុស្សពាល ដែលវាជា «ផ្លូវ» ឬ «ផ្លូវ» ដែលពួកគេដើរលើ។
ការបកប្រែរបៀបផ្សេងទៀត:
«របៀបរស់នៅរបស់មនុស្សសុចរិត...របៀបរស់នៅរបស់មនុស្សពាល»
ផ្លូវរបស់មនុស្សសុចរិតប្រៀបបីដូចជាពន្លឺអរុណរះ បញ្ចេញរស្មីកាន់តែភ្លឺឡើងៗ
អ្នកនិពន្ធប្រៀបធៀបផ្លូវរបស់មនុស្សសុចរិតដូចជាពន្លឺអរុណរះ
ដែលមានន័យថាពួកគេមានសុវត្ថិភាពដោយសារពួកគេមានពន្លឺដើម្បីមើលពីកន្លែង
ដែលគេកំពុងតែដើរ។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សសុចរិតដើរលើផ្លូវរបស់ពួកគេដោយសុវត្ថិភាព
ដោយសារពន្លឺអរុណរះបញ្ចេញរស្មីកាន់តែភ្លឺឡើងៗ»
ពន្លឺអរុណរះ
នេះសំដៅទៅលើពន្លឺថ្ងៃរះ
រហូតដល់ព្រះអាទិត្យពេញកម្តៅ
នេះសំដៅទៅលើពេលថ្ងៃដែលព្រះអាទិត្យជះពន្លឺខ្លាំង។
ការបកប្រែរបៀបផ្សេងទៀត: «រហូតទាល់តែព្រះអាទិត្យបញ្ចេញពន្លឺចាំងចែង» ឬ
«រហូតទាល់តែពន្លឺថ្ងៃពេញ»
ចំណែកផ្លូវរបស់ជនពាលវិញ ដូចទៅនឹងភាពងងឹតអន្ធការ
អ្នកនិពន្ធប្រៀបធៀបផ្លូវរបស់មនុស្សអាក្រក់ទៅនឹងភាពងងឹតអន្ធការ
មានន័យថាពួកគេតែងតែស្ថិតក្នុងភាពគ្រោះថ្នាក់
ដោយសារពួកគេគ្មានពន្លឺដើម្បីមើលផ្លូវដែលគេដើរ។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សអាក្រក់ដើរតាមផ្លូវរបស់គេប្រកបដោយគ្រោះថ្នាក់
ដោយសារពួកគេគ្មានពន្លឺ ដែលគេអាចមើលឃើញបាន»
ពួកគេមិនអាចមើលឧបសគ្គដែលធ្វើឲ្យខ្លួនជំពប់ដួលនោះឃើញឡើយ
អ្នកនិពន្ធនិយាយពីបទពិសោធន៍ដែលបង្កគ្រោះថ្នាក់
ដូចជាការជំពប់ដួលទៅលើអ្វីមួយតាមផ្លូវ ដែលគេដើរ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនដឹងថា
មូលហេតុអ្វីដែលពួកគេជួបគ្រោះថ្នាក់ និងសំណាងអាក្រក់»
Proverbs 4:20
យកចិត្តទុកដាក់
«ស្តាប់ដោយប្រុងប្រយ័ត្ន»
ចូរផ្ទៀងត្រចៀក ចូរត្រងត្រាប់ស្តាប់ពាក្យទូន្មាន និងសេចក្តីបង្រៀនរបស់យើង
ពាក្យថា «ត្រចៀក» នៅទីនេះតំណាងឲ្យមនុស្សដែលកំពុងស្តាប់។
អ្នកនិពន្ធនិយាយពីការស្តាប់នរណាម្នាក់ដោយយកចិត្តទុកដាក់
ដូចជាការរៀនពីអ្វីមួយដោយផ្ទៀងត្រចៀកជាប់នឹងអ្វីដែលម្នាក់នោះកំពុងនិយាយ។
ពាក្យថា «សេចក្តីបង្រៀន» អាចបកប្រែជាកិរិយាស័ព្ទ។
ការបកប្រែរបៀបផ្សេងទៀត:
«សូមស្តាប់ដោយប្រុងប្រយ័ត្នចំពោះអ្វីដែលខ្ញុំកំពុងនិយាយ» (សូមមើល: និង និង
កុំបំភ្លេចពាក្យយើង
អ្នកនិពន្ធនិយាយអំពីការគិតអំពីអ្វីមួយជានិច្ច
ដូចជាកំពុងរក្សាវានៅកន្លែងដែលមនុស្សម្នាក់អាចមើលឃើញ។
ការបកប្រែរបៀបផ្សេងទៀត: «កុំឲ្យបំភ្លេចសេចក្តីទាំងនោះ»
ត្រូវរក្សាទុកឲ្យជាប់នៅក្នុងដួងចិត្តរបស់កូន
អ្នកនិពន្ធនិយាយពីការចងចាំអ្វីមួយ ដូចជាការរក្សាអ្វីមួយទុកក្នុងចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «តែងតែចងចាំសេចក្តីទាំងនោះទុក»
Proverbs 4:22
ពាក្យទាំងនេះនឹងផ្តល់ជីវិត
អ្នកនិពន្ធនិយាយពីសំដីរបស់គាត់ថែរក្សាជីវិតរបស់មនុស្សម្នាក់
ដូចជាជីវិតរបស់មនុស្សម្នាក់នោះ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យខ្ញុំផ្តល់ជីវិត»
[illegible]
អ្នកនិពន្ធនិយាយពីការយល់ពីសម្តីរបស់គាត់ទាំងស្រុង
ដូចជាមនុស្សនោះស្វែងរកបានសេចក្តីទាំងនោះ។ ការបកប្រែរបៀបផ្សេងទៀត:
«ចំពោះអស់អ្នកដែលយល់ ហើយអនុវត្តតាម»
ផ្តល់សុខភាពដល់រូបកាយពួកគេ
ពាក្យថា «របស់ពួកគេ» សំដៅទៅលើ «អស់អ្នកដែលរកបានសេចក្តីទាំងនោះ»។
ប្រធានសម្រាប់ឃ្លានេះអាចត្រូវបានគាំទ្រពីឃ្លាមុន។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យយើងនឹងផ្តល់សុខភាពល្អដល់រាងកាយទាំងមូលចំពោះអស់អ្នក
ដែលរកបានសេចក្តីទាំងនោះ»
ចូរកូនថែរក្សាចិត្តដោយប្រុងប្រយ័ត្ន
ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យចិត្តគំនិតរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ចូររក្សាចិត្តគំនិត»
ដោយការប្រឹងប្រែងព្យាយាម
ជាមួយការខំប្រឹងប្រែងអស់ពីសមត្ថភាព
ចិត្តគំនិតរបស់កូនយ៉ាងណា ជីវិតរបស់កូនក៏យ៉ាងនោះដែរ
ពាក្យថា «វា» សំដៅទៅលើចិត្ត ដែលឈ្មោះផ្សេងទៀតសម្រាប់ពាក្យចិត្ត និង
គំនិត។ អ្នកនិពន្ធនិយាយពីជីវិតមនុស្ស ដូចជាប្រភពចេញពីចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «គំនិតរបស់អ្នកចេញជាអ្វីដែលអ្នកនិយាយ និង ធ្វើ»
ឬ «ចិត្តគំនិតរបស់អ្នកកំណត់ជីវិតរបស់អ្នក»
Proverbs 4:24
ចូរទប់មាត់កុំឲ្យពោលពាក្យអាស្រូវឡើយ ហើយក៏កុំត្រលាស់អណ្តាតពោលពាក្យមួលបង្កាច់គេដែរ
អ្នកនិពន្ធនិយាយពីការនិយាយកុហក ឬ ពាក្យបោកបញ្ឆោត
ដូចជាពាក្យវៀចវេរដែលមនុស្សម្នាក់មិនប្រើភាសាបែបនេះ
ដូចជាគេកំពុងដកពាក្យនេះចេញពីគេ។ ការបកប្រែរបៀបផ្សេងទៀត:
«កុំនិយាយកុហក ឬ ប្រព្រឹត្តការបោកបញ្ឆោតឡើយ»
ចូរឲ្យភ្នែកកូនមើលចំទៅមុខ ហើយត្របកភ្នែកឯងទៅត្រង់ទៅមុខដែរ
ពាក្យថា «ភ្នែក» នៅទីនេះតំណាងឲ្យមនុស្សម្នាក់ដែលកំពុងតែមើល។
អ្នកនិពន្ធនិយាយពីមនុស្សម្នាក់ដែលប្តេជ្ញាប្រព្រឹត្តការត្រឹមត្រូវ
ដូចដែលមនុស្សនោះនឹងមើលឆ្ពោះទៅមុខមិនងាកទៅផ្លូវផ្សេង។
ការបកប្រែរបៀបផ្សេងទៀត: «តែងតែសម្លឹងទៅមុខ និង ផ្តោតត្រង់ទៅមុខ»
Proverbs 4:26
ត្រូវកំណត់ផ្លូវដែលជើងកូនដើរ
ពាក្យថា «ជើង» នៅទីនេះតំណាងឲ្យមនុស្សដែលកំពុងដើរ។
អ្នកនិពន្ធនិយាយពីសកម្មភាពរបស់មនុស្សដែលគេកំពុងតែដើរ និង
ធ្វើផែនការដោយប្រុងប្រយ័ត្នដូចជាបង្កើតកម្រិតនៃផ្លូវនោះ។
ការបកប្រែរបៀបផ្សេងទៀត: «កំណត់ផ្លូវដែលត្រូវដើរ» ឬ
«រៀបចំឱ្យបានល្អនូវអ្វីដែលអ្នកចង់ធ្វើ»
កំណត់ផ្លូវ
«ផ្លូវរលោង» ឬ «ផ្លូវណាមួយ»
ផ្លូវរបស់កូននឹងមានសុវត្ថិភាព
អ្នកនិពន្ធនិយាយពីសកម្មភាពរបស់មនុស្សម្នាក់ ដូចជាមនុស្សកំពុងដើរលើផ្លូវ
ហើយសកម្មភាពទាំងនោះទទួលបានជោគជ័យ ដូចជាផ្លូវដែលមានសុវត្ថិភាព និង
សន្តិសុខល្អ។ ការបកប្រែរបៀបផ្សេងទៀត: «នោះអ្វីៗដែលអ្នកធ្វើនឹងត្រឹមត្រូវ»
កុំងាកបែរទៅខាងស្តាំ ឬខាងឆ្វេងឡើយ
ទិសដៅ «ស្តាំ» ឬ «ឆ្វេង» ចេញពីការរួមបញ្ចូលគ្នា
ដែលមានន័យថាមនុស្សម្នាក់មិនបែរចេញពីផ្លូវ
ដែលបានកំណត់ទៅទិសដៅណាមួយឡើយ។ ការបកប្រែរបៀបផ្សេងទៀត:
«ដើរត្រង់ទៅមុខមិនចាកចេញពីផ្លូវដែលបានកំណត់»
ត្រូវឲ្យជើងរបស់កូនងាកចេញពីសេចក្តីអាក្រក់វិញ
ពាក្យថា «ជើង» នៅទីនេះតំណាងឲ្យមនុស្សដែលដើរ។
អ្នកនិពន្ធនិយាយពីការដែលមិនចុះចូលនឹងសកម្មភាពអាក្រក់
ដូចជាមនុស្សដែលដើរចេញពីការអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត:
«បែរចេញពីការអាក្រក់» ឬ «នៅឲ្យឆ្ងាយពីការអាក្រក់»

generated on Wed Sep 10 16:16:32 2025

5 [1]កូនអើយ ចូរយកចិត្តទុកដាក់នឹងប្រាជ្ញារបស់យើង ហើយចាប់អារម្មណ៍ និងតម្រិះរបស់យើងផងដែរ[2]ដើម្បីឲ្យកូនស្គាល់ការរិះគិត និងការនិយាយស្តីដឹងខុសត្រូវ។
[3]ដ្បិត ស្ត្រីក្បត់ប្តីតែងតែនិយាយមាយាផ្អែមដូចទឹកឃ្មុំ ហើយមាត់រអិលដូចប្រេង[4]ប៉ុន្តែ តាមពិតស្ត្រីនោះប្រៀបបាននឹងផ្លែស្វែងដែលមានជាតិល្វីង ហើយមុតដូចដាវមុខពីរ។
[5]ស្ត្រីប្រភេទនេះបណ្តាលឲ្យអ្នកត្រូវស្លាប់ ដ្បិតផ្លូវរបស់គេតម្រង់ទៅរកមច្ចុរាជ។[6]ផ្លូវរបស់ស្ត្រីនេះមិននាំទៅកាន់ជីវិតទេ។ តែនាំឲ្យគេវង្វេង ដោយនាងមិនដឹងថាកំពុងតែធ្វើអ្វីនោះទេ។
[7]ឥឡូវនេះ កូនអើយ ចូរស្តាប់យើង កុំងាកចេញពីពាក្យ ដែលចេញពីមាត់របស់យើងឡើយ។[8]រក្សាផ្លូវរបស់កូនឲ្យឆ្ងាយពីស្ត្រីប្រភេទនេះ កុំទៅជិតមាត់ទ្វារផ្ទះរបស់គេឲ្យសោះ។
[9]ក្នុងផ្លូវនេះ អ្នកខ្លះអាចនឹងប្រមាថមាក់ងាយកេរ្តិ៍ឈ្មោះកូន ហើយមនុស្សគ្មានចិត្តមេត្តាបំផ្លាញជីវិតកូន[10]ក្រែងលោអ្នកដទៃមករឹបអូសយកទ្រព្យសម្បត្តិរបស់កូន ហើយអ្វីៗដែលកូនរកបានដោយកម្លាំងញើស ត្រូវធ្លាក់ក្នុងកណ្តាប់ដៃរបស់អ្នកផ្សេង។
[11]នៅទីបំផុត កូនលែងមានកម្លាំងអ្វីទៀត ហើយកូននឹងស្រែកថ្ងូរដូចសត្វ។[12]កូននឹងពោលថា «ហេតុអ្វីបានជាខ្ញុំស្អប់ដំបូន្មាន ហើយមិនយកចិត្តទុកដាក់ស្តាប់ការប្រៀនប្រដៅដូច្នេះ!
[13]ហេតុអ្វីបានជាខ្ញុំមិនស្តាប់ពាក្យសម្តីគ្រូ ហើយក៏មិនផ្ទៀងត្រចៀកស្តាប់អ្នកបង្រៀនខ្ញុំដូច្នេះ។[14]យើងស្ទើរតែនឹងចូលទៅក្នុងអស់ទាំងអំពើអាក្រក់ហើយ គឺនៅកណ្តាលចំណោមមនុស្សនិងក្រុមជំនុំផង»។
[15]ចូរផឹកទឹកពីពាងរបស់ខ្លួនកូន ព្រមទាំងទឹកដែលហូរចេញពីអណ្តូងរបស់ខ្លួនផងដែរ។[16]តើគួរឲ្យរន្ធទឹករបស់កូនហូរសាចេញទៅក្រៅ ហើយគន្លងទឹករបស់កូនហូរទៅក្នុងផ្លូវឬ?[17]ត្រូវទុកសម្រាប់ខ្លួនកូនតែមួយប៉ុណ្ណោះ មិនមែនសម្រាប់មនុស្សដទៃ ជាមួយកូនផងនោះទេ។
[18]ចូរផ្តល់សុភមង្គលឲ្យភរិយារបស់កូន ចូររួមរស់យ៉ាងសប្បាយជាមួយភរិយា ដែលកូនបានរៀបការតាំងពីកំលោះក្រមុំ។[19]ភរិយារបស់កូនមានចរិយាសមសួនគួរឲ្យស្រឡាញ់ សម្រស់របស់នាងគួរជាទីគាប់ចិត្ត។ ចូរត្រេកត្រអាលនឹងសម្ផស្សរបស់នាង ចូរស្រឡាញ់នាងយ៉ាងអស់ពីចិត្តរហូតតទៅ។
[20]កូនអើយ ហេតុអ្វីបានជាកូនមានចិត្តស្រឡាញ់ប្រពន្ធរបស់គេទៅវិញ? ហេតុអ្វីបានជាកូនចង់សប្បាយជាមួយស្រីផ្សេងដូច្នេះ?[21]អ្វីៗដែលមនុស្សលោកប្រព្រឹត្ត ព្រះអម្ចាស់ជ្រាបទាំងអស់ ព្រះអង្គទតឃើញកិរិយាមារយាទរបស់គេ។
[22]កំហុសរបស់មនុស្សអាក្រក់ជាចំណងចងខ្លួន ហើយអំពើបាបជាអន្ទាក់ដែលធ្វើឲ្យខ្លួនគេរើពុំរួច។[23]គេនឹងត្រូវស្លាប់ ព្រោះខ្វះការអប់រំ គេនឹងត្រូវវិនាស ព្រោះតែអំពើលេលាហួសល្បត់របស់ខ្លួន។

Proverbs 5:1
ព័ត៌មានទូទៅ:
អ្នកនិពន្ធនិយាយពីឪពុកម្នាក់ដែលបង្រៀនកូនរបស់គាត់
បើកត្រចៀកស្តាប់
ពាក្យថា «ត្រចៀក» នៅទីនេះតំណាងឲ្យមនុស្សដែលកំពុងស្តាប់។
អ្នកនិពន្ធនិយាយពីការស្តាប់ដោយយកចិត្តទុកដាក់ចំពោះនរណាម្នាក់
ដូចជាផ្ទៀងត្រចៀករបស់គេផ្តោតទៅលើការនិយាយរបស់នរណាម្នាក់។
សូមមើលការបកប្រែនេះនៅក្នុងជំពូក ៤:២០។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តាប់ដោយយកចិត្តទុកដាក់»
ការរិះគិត
ការរិះគិតជាការចេះប្រុងប្រយ័ត្នជាមួយការប្រព្រឹត្ត និង ការនិយាយ។
សូមមើលពីរបៀបអ្នកបកប្រែនៅក្នុងជំពូក ១:៤។
ការនិយាយស្តីដឹងខុសត្រូវ
ពាក្យថា «មាត់» នៅទីនេះតំណាងឲ្យមនុស្សដែលនិយាយ។
អ្នកនិពន្ធនិយាយពីមនុស្សម្នាក់ដែលមានការប្រុងប្រយ័ត្នក្នុងការដែលនិយាយតែអ្វីដែលត្រឹមត្រូវ
ដូចជាមាត់ដែលនិយាយស្តីដឹងខុសត្រូវ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងនិយាយតែអ្វីដែលជាការពិតប៉ុណ្ណោះ»
Proverbs 5:3
ដ្បិត ស្ត្រីក្បត់ប្តីតែងតែនិយាយមាយាផ្អែមដូចទឹកឃ្មុំ
ន័យដែលអាចមាន គឺ១) ពាក្យថា «បបូរមាត់» តំណាងឲ្យពាក្យការផិតក្បត់
ហើយអ្នកនិពន្ធនិយាយពីពាក្យសម្តីទាក់ទាញរបស់នាង
ដែលសម្តីនោះផ្អែមដូចទឹកឃ្មុំ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យសម្តីរបស់ស្ត្រីផិតក្បត់គឺផ្អែម ដូចជាទឹកឃ្មុំ» ឬ ២)
អ្នកនិពន្ធនិយាយពីភាពទាក់ទាញនៃការថើបរបស់ស្ត្រីផិតក្បត់
ដែលបបូរមាត់របស់នាងផ្អែមដូចទឹកឃ្មុំ។ ការបកប្រែរបៀបផ្សេងទៀត:
«ការថើបរបស់ស្ត្រីផិតក្បត់គឺផ្អែម ដូចជាបបូរមាត់របស់នាងផ្អែមដូចទឹកឃ្មុំ»
មាត់រអិលដូចប្រេង
ន័យដែលអាចមាន គឺ១)ពាក្យថា «មាត់» តំណាងឲ្យពាក្យសម្តីរបស់ស្ត្រីផិតក្បត់
ហើយអ្នកនិពន្ធនិយាយពី ពាក្យលួងលោមរបស់នាង
ដូចជាមាត់ដែលរអិលជាងប្រេង។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យសម្តីរបស់នាងជាពាក្យលួងលោមបញ្ចុះបញ្ចូល ហើយរអិលជាងប្រេង» ឬ
២) អ្នកនិពន្ធនិយាយពីការរីករាយនឹងការថើបរបស់ស្ត្រីផិតក្បត់
ដូចជាមាត់នោះរអិលជាងប្រេង។ ការបកប្រែរបៀបផ្សេងទៀត:
«ការថើបរបស់នាងរអិលជាងប្រេង»
ប៉ុន្តែ តាមពិតស្ត្រីនោះប្រៀបបាននឹងផ្លែស្វែងដែលមានជាតិល្វីង
អ្នកនិពន្ធនិយាយពីគ្រោះថ្នាក់
ដែលកើតមានចេញពីការដែលមានទំនាក់ទំនងជាមួយស្ត្រីផិតក្បត់
ដូចជាការដែលភ្លក់រសជាតិនៃផ្លែស្វែង។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែចុងក្រោយ នាងប្រៀបដូចជារសជាតិផ្លែស្វែង
ហើយវានឹងបង្កគ្រោះថ្នាក់ដល់អ្នក»
ដើមស្វែង
រុក្ខជាតិដែលរសជាតិល្វីង
មុតដូចដាវមុខពីរ
អ្នកនិពន្ធនិយាយពីការឈឺចាប់ដែលស្ត្រីផិតក្បត់
និងធ្វើឲ្យមនុស្សដែលមានទំនាក់ទំនងជាមួយនាង
ដូចជាដាវមុខពីរដែលកាប់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«នាងធ្វើឲ្យមនុស្សមានរបួស នាងដូចជាដាវមុតមុខពីរ»
Proverbs 5:5
ដ្បិតផ្លូវរបស់គេតម្រង់ទៅរកសេចក្តីស្លាប់
ពាក្យថា «ជើងរបស់នាង» នៅទីនេះតំណាងឲ្យស្ត្រីផិតក្បត់ដូចជានាងដើរ។
អ្នកនិពន្ធនិយាយពីការប្រព្រឹត្តរបស់នាង ដូចជានាងកំពុងដើរលើផ្លូវមួយ។
ការបកប្រែរបៀបផ្សេងទៀត: «នាងដើរលើផ្លូវតម្រង់ទៅរកសេចក្តីស្លាប់» ឬ
«ការរស់នៅរបស់នាងនាំទៅរកសេចក្តីស្លាប់»
ផ្លូវរបស់គេតម្រង់ទៅរកមច្ចុរាជ
អ្នកនិពន្ធនិយាយពីដំណើររបស់នាង ដូចជានាងកំពុងដើរលើផ្លូវ។
ការបកប្រែរបៀបផ្សេងទៀត: «នាងដើរតម្រង់ទៅរកមច្ចុរាជ» ឬ
«ដំណើររបស់នាងនាំនាងទៅរកមច្ចុរាជ»
ផ្លូវរបស់ស្ត្រីនេះមិននាំទៅកាន់ជីវិតទេ
អ្នកនិពន្ធនិយាយពីអាកប្បកិរិយាដែលផ្តល់ឲ្យមនុស្សមានអាយុវែង
ដូចជាផ្លូវដែលនាំទៅរកជីវិត។ ការបកប្រែរបៀបផ្សេងទៀត:
«នាងមិនបានគិតពីផ្លូវដែលផ្តល់ជីវិតឡើយ» ឬ
«នាងមិនខ្វល់ពីដំណើរដែលនាំនាងទៅរកជីវិតឡើយ»
នាំឲ្យគេវង្វេង
អាចមានន័យថា គឺ១) «នាងវង្វេងស្មារតី ដូចជានាងវង្វេងផ្លូវ» ឬ គឺ២)
«នាងដើរតាមផ្លូវដែលវង្វេង»
Proverbs 5:7
ឥឡូវ
នៅទីនេះគ្រូបង្រៀនផ្លាស់ប្តូរការព្រមានអំពីស្ត្រីផិតក្បត់ក្នុងការផ្តល់ដំបូន្មាន។
ចូរស្តាប់យើង...កុំងាកចេញពីពាក្យ ដែលចេញពីមាត់របស់យើងឡើយ
ឃ្លាទាំងពីរនេះបញ្ជាក់ពីគំនិតដូចគ្នា ដែលធ្វើឲ្យសិស្សយកចិត្តទុកដាក់។
កុំងាកចេញពីពាក្យ ដែលចេញពីមាត់របស់យើងឡើយ
អ្នកនិពន្ធនិយាយពីការបញ្ឈប់សកម្មភាព ដូចជាមនុស្សម្នាក់បែរចេញពីវា។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «មិនត្រូវឈប់ស្តាប់ឡើយ»

ពាក្យ ដែលចេញពីមាត់របស់យើង

ពាក្យថា «មាត់» នៅទីនេះតំណាងឲ្យមនុស្សដែលកំពុងនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ពាក្យរបស់យើង» ឬ «អ្វីដែលខ្ញុំកំពុងនិយាយ»

រក្សាផ្លូវរបស់កូនឲ្យឆ្ងាយពីស្ត្រីប្រភេទនេះ

ពាក្យថា «ផ្លូវ» នៅទីនេះតំណាងឲ្យការប្រព្រឹត្ត និង
ស្ថានភាពប្រចាំថ្ងៃរបស់មនុស្សម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«រក្សាខ្លួនអ្នកឱ្យនៅឆ្ងាយពីនាង» ឬ «នៅឲ្យឆ្ងាយពីនាង»

កុំទៅជិតមាត់ទ្វារផ្ទះរបស់គេឲ្យសោះ

ពាក្យថា «មាត់ទ្វារផ្ទះ» នៅទីនេះតំណាងឲ្យផ្ទះរបស់នាង។
ការប្រើពាក្យសមរម្យជាងដែលប្រើពាក្យ «ទៅ» ជំនួសឲ្យពាក្យ «មក»
ក្រោយមកអាចបញ្ជាក់ថាអ្នកនិយាយនៅជិតមាត់ទ្វាររបស់នាង។
ការបកប្រែរបៀបផ្សេងទៀត: «កុំទៅក្បែរទ្វារផ្ទះរបស់នាង» ឬ
«កុំទៅក្បែរផ្ទះរបស់នាង»

Proverbs 5:9

ក្នុងផ្លូវនេះ

«ប្រសិនបើធ្វើបែបនេះ» ឃ្លានេះសំដៅទៅលើអ្វីដែលទើបតែនិយាយពីខមុន។

កុំឲ្យអ្នកដទៃមាក់ងាយកេរ្តិ៍ឈ្មោះកូន

ន័យដែលអាចមានចំពោះពាក្យ «កេរ្តិ៍ឈ្មោះ» គឺ១)
វាសំដៅទៅលើកិត្តិយសរបស់នរណាម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងមិនបាត់បង់កិត្តិយសនៅចំណោមអ្នកដទៃ» ឬ ២)
វាសំដៅទៅលើទ្រព្យសម្បត្តិរបស់មនុស្សម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងមិនប្រគល់ទ្រព្យសម្បត្តិរបស់អ្នកទៅអ្នកផ្សេង» ឬ ៣)
វាសំដៅទៅលើកម្លាំង ហើយ តំណាងឲ្យឆ្នាំដំបូងនៃជីវិតរបស់នរណាម្នាក់។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងមិនលះបង់ពេលវេលាល្អបំផុតនៃជីវិតរបស់អ្នកទៅមនុស្សផ្សេងទៀតឡើយ»

មិនប្រគល់ជីវិតទៅមនុស្សគ្មានមេត្តា

អ្នកនិពន្ធនិយាយពីមនុស្សដែលស្លាប់មុនអាយុ
ដែលអាចជាការស្លាប់ដោយគេសម្លាប់
ដែលជីវិតរបស់គេដូចជារបស់ដែលគេប្រគល់ទៅឲ្យនរណាម្នាក់។
កិរិយាស័ព្ទអាចទ្រទ្រង់ពីឃ្លាមុន។ ការបកប្រែរបៀបផ្សេងទៀត:
«ឬប្រគល់ជីវិតទៅឲ្យមនុស្សឃោឃៅ» ឬ «ធ្វើឲ្យមនុស្សឃោឃៅសម្លាប់អ្នក
កាលអ្នកនៅក្មេងនៅឡើយ»

មនុស្សគ្មានចិត្តមេត្តា

នេះអាចសំដៅទៅលើប្តីរបស់ស្ត្រីផិតក្បត់
ដែលនឹងប្រព្រឹត្តយ៉ាងឃោរឃៅចំពោះអ្នកណាដែលដេកជាមួយនាង។

អ្នកដទៃនឹងមិនមករឹបអូសយកទ្រព្យសម្បត្តិរបស់កូន

អ្នកនិពន្ធនិយាយពីមនុស្សដែលរីករាយនឹងទ្រព្យសម្បត្តិរបស់អ្នកដទៃ
ដូចជារឹបអូសយកទ្រព្យសម្បត្តិគេ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដទៃនឹងមិនរឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកឡើយ»

ហើយអ្វីៗដែលកូនរកបានដោយកម្លាំងញើស ត្រូវធ្លាក់ក្នុងកណ្តាប់ដៃរបស់អ្នកផ្សេង

ពាក្យថា «ផ្ទះ» នៅទីនេះសំដៅទៅលើក្រុមគ្រួសាររបស់នរណាម្នាក់។
ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលអ្នកខំរកបាននឹងមិនធ្លាក់ទៅក្នុងក្រុមគ្រួសាររបស់អ្នកដទៃឡើយ»

Proverbs 5:11

កូនលែងមានកម្លាំងអ្វីទៀត

ពាក្យថា «សាច់ឈាម» និង «រាងកាយ» មានន័យដូចគ្នា
ហើយតំណាងឲ្យមនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«រាងកាយអស់កម្លាំងទៅ» ឬ «អ្នកអស់កម្លាំង»

លែងមានកម្លាំង

«រូបរាងខាងក្រៅធ្លាក់ចុះ» ឬ «ធ្លាក់ខ្លួនខ្សោយ ហើយ សុខភាពចុះខ្សោយ»

ខ្ញុំស្អប់ដំបូន្មាន...មិនយកចិត្តទុកដាក់ស្តាប់ការប្រៀនប្រដៅ

ឃ្លាទាំងពីរនេះបញ្ជាក់ពីគំនិតដូចគ្នា
ហើយបញ្ជាក់ថាមនុស្សស្អប់នូវអ្វីដែលគាត់បង្រៀនប៉ុណ្ណា។ (សូមមើល:figs-parallelism)

ខ្ញុំស្អប់ដំបូន្មានប៉ុណ្ណា

ពាក្យថា «ប៉ុណ្ណា» គឺជាសញ្ញាដែលសង្កត់ធ្ងន់ថាស្អប់ខ្លាំងប៉ុណ្ណា។ ពាក្យថា
«ដំបូន្មាន» អាចបកប្រែជាឃ្លាកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំស្អប់ណាស់ពេលនរណាម្នាក់ទូន្មានខ្ញុំ»

មិនយកចិត្តទុកដាក់ស្តាប់ការប្រៀនប្រដៅ

ពាក្យថា «ចិត្ត» តំណាងឲ្យមនុស្ស និង អារម្មណ៍របស់មនុស្ស។ ពាក្យថា
«ការប្រៀនប្រដៅ» អាចបកប្រែជាឃ្លាកិរិស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំតែងតែមើលងាយពេលគេកែតម្រូវខ្ញុំ»

Proverbs 5:13

បើកត្រចៀកខ្ញុំស្តាប់សេចក្តីបង្រៀនរបស់គ្រូ

ពាក្យថា «ត្រចៀក» នៅទីនេះតំណាងឲ្យមនុស្សដែលកំពុងស្តាប់។
អ្នកនិពន្ធនិយាយពីការស្តាប់ដោយយកចិត្តទុកដាក់ចំពោះនរណាម្នាក់
ដូចជាការស្តាប់នរណាម្នាក់ដោយផ្ទៀងត្រចៀកស្តាប់ក្បែរអ្នកដែលកំពុងនិយាយនោះ។
សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លានេះស្រដៀងគ្នានៅក្នុងជំពូក ៤:២០
«ស្តាប់អស់អ្នកដែលណែនាំខ្ញុំ»

នៅកណ្តាលចំណោមមនុស្សនិងក្រុមជំនុំផង

ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា ហើយសំដៅទៅលើសហគមន៍មនុស្ស
ដែលប្រមូលផ្តុំគ្នា ឬ ទី១) ថ្វាយបង្គំព្រះជាម្ចាស់ ឬ ទី២)
ដើម្បីកាត់ក្តីគាត់ចំពោះអំពើល្មើសរបស់គាត់។

Proverbs 5:15

ទឹកពីពាងរបស់ខ្លួនកូន...ទឹកដែលហូរចេញពីអណ្តូងរបស់ខ្លួន

ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។
អ្នកនិពន្ធនិយាយពីបុរសដែលគេងតែជាមួយប្រពន្ធខ្លួន
ដូចជាបុរសនោះផឹកតែទឹកដែលចេញពីអណ្តូងរបស់ខ្លួន។

ទឹកដែលហូរ

អ្នកនិពន្ធនិយាយពីស្រស់ថ្មីៗ ឬ ទឹកដែលហូរ ដូចជាទឹកដែលកំពុងហូរ។
ការបកប្រែរបៀបផ្សេងទៀត: «ទឹកថ្មីៗ» ឬ «ទឹកហូរ» (សូមមើល:figs-metaphor)

តើគួរឲ្យរន្ធទឹករបស់កូន...គន្លងទឹករបស់កូនហូរទៅក្នុងផ្លូវឬ?

អ្នកនិពន្ធសួរសំណួរនេះដើម្បីបញ្ជាក់ថាកូនរបស់គាត់មិនធ្វើរឿងទាំងនេះឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «រន្ធទឹករបស់កូនមិនត្រូវ...គន្លងទឹក
របស់កូនមិនត្រូវហូរទៅក្នុងផ្លូវសាធារណៈ។»

តើគួរឲ្យរន្ធទឹករបស់កូន...គន្លងទឹករបស់កូនហូរទៅក្នុងផ្លូវឬ?

ពាក្យថា «រន្ធទឹក» នៅទីនេះ និង ពាក្យ «គន្លងទឹក»
មានលក្ខណៈស្រោលជាងប្រើពាក្យ ទឹកកាមបុរស។
ន័យដែលអាចមានសម្រាប់ឃ្លាទាំងនេះ ទី១) ការដេកជាមួយស្រីក្រៅពីប្រពន្ធ
ដូចជាអនុញ្ញាតឲ្យរន្ធទឹករបស់ខ្លួនហូរចេញទៅផ្លូវសាធារណៈ ឬ
២)មានកូនជាមួយស្រីក្រៅ ដែលមិនមែនជាប្រពន្ធ
គឺប្រៀបដូចជាឲ្យរន្ធទឹកហូរទៅផ្លូវសាធារណៈ។

ទីសាធារណៈ

តំបន់ទីក្រុង ឬ ទីក្រុងដែលមានផ្លូវលើសពីពីរប្រសព្វគ្នា។
ជាកន្លែងដែលមនុស្សចូលចិត្តប្រមូលផ្តុំគ្នា។

សូមឲ្យ

ពាក្យថា «វា» សំដៅទៅលើ «ប្រភពទឹក» និង «ទឹកហូរ» និង អ្វីដែលពួកគេរង់ចាំ។

មិនមែនសម្រាប់មនុស្សដទៃ ជាមួយកូនផងនោះទេ

«មិនត្រូវចែករំលែកវាជាមួយមនុស្សដទៃឡើយ»

Proverbs 5:18

ចូរផ្តល់សុភមង្គលឲ្យភរិយារបស់កូន

អ្នកនិពន្ធនិយាយពីភរិយារបស់កូនគាត់ ដូចជាប្រភពទឹក។ ពាក្យថា «ព្រះពរ»
សំដៅលើអំណរដែលបុរសមានចំពោះប្រពន្ធរបស់គាត់។
ការបកប្រែរបៀបផ្សេងទៀត:
«សូមឱ្យអ្នកតែងតែមានអំណរជាមួយប្រពន្ធរបស់អ្នក»

ភរិយា ដែលកូនបានរៀបការតាំងពីកំលោះក្រមុំ

អាចមានន័យថា គឺ១) «ភរិយាដែលអ្នកបានរៀបការតាំងពីកំលោះក្រមុំ» ឬ គឺ២)
«ប្រពន្ធតាំងពីនៅក្មេង»

ភរិយារបស់កូនមានចរិយាសមសួនគួរឲ្យស្រឡាញ់

អ្នកនិពន្ធនិយាយពីភរិយារបស់កូនគាត់ដែលដូចជានាងជា « ក្តាន់ និង
លលកដែលគួរឲ្យស្រឡាញ់ »។ ពាក្យថា «ក្តាន់» និង «លលក»
នៅទីនេះមានន័យថាក្តាន់ញី។
ពួកវាតំណាងឲ្យភាពស្រស់ស្អាតទាំងលក្ខណៈខាងក្រៅ និង ការផ្លាស់ទី។
ការបកប្រែរបៀបផ្សេងទៀត: «នាងស្រស់ស្អាតដូចជាសត្វក្តាន់ និង លលក» ឬ
«នាងស្រស់ស្អាតដូចជាក្តាន់ញី»

ប្រកបដោយព្រះគុណ

generated on Wed Sep 10 16:16:32 2025

ពាក្យនេះមិនមែនមានន័យថា «ពេញដោយព្រះគុណ» តែមានន័យថា «ស្រស់ស្អាតនៅពេលដែលផ្លាស់ទី»។

ចូរត្រេកត្រអាលនឹងសម្ផស្សរបស់នាង

អាចមានន័យថា គឺ១) សុដន់របស់ប្រពន្ធធ្វើឲ្យប្តីមានចំណង់ផ្លូវភេទរំភើប និងអាចតំណាងឲ្យរូបរាងកាយរបស់ប្រពន្ធទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យសុដន់របស់នាងធ្វើឲ្យអ្នកត្រេកត្រអាល» ឬ «សូមឲ្យរាងកាយរបស់នាងជាទីពេញចិត្តដល់អ្នក» ឬ ទី២)នេះជាពាក្យប្រៀបធៀបដែលអ្នកនិពន្ធនិយាយពីសុដន់ទាំងគូររបស់ប្រពន្ធបំពេញសេចក្តីត្រូវការរបស់ប្តី ប្រៀបដូចជាកូនក្មេងដែលស្រេកទឹកដែរ។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យសុដន់របស់នាងបំពេញអ្នកដោយក្តីរីករាយដូចម្តាយដែលផ្តល់ចំណីដល់កូនដែរ»

ចូរស្រឡាញ់នាងយ៉ាងអស់ពីចិត្តរហូតតទៅ

ការរំភើបនឹងរីករាយជាមួយនឹងស្នេហារ៉ូមែនទិករបស់ប្រពន្ធត្រូវបានគេចាត់ទុកថាដូចជា ការដែលស្រវឹងនឹងសេចក្តីស្នេហា។ នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យសេចក្តីស្នេហារបស់នាងគ្រប់គ្រងលើអ្នកដូចជាស្រាដែលគ្រប់គ្រងអ្នកផឹកដែរ»

ដោយក្តីស្រឡាញ់របស់នាង

អាចមានន័យថា គឺ១) «ក្តីស្រឡាញ់របស់អ្នកចំពោះនាង» ឬ ២) «ក្តីស្រឡាញ់របស់នាងចំពោះអ្នក»

Proverbs 5:20

កូនអើយ ហេតុអ្វីបានជាកូនមានចិត្តស្រឡាញ់ប្រពន្ធរបស់គេទៅវិញ? ហេតុអ្វីបានជាកូនចង់សប្បាយជាមួយស្រីផ្សេងដូច្នេះ?

អ្នកនិពន្ធសួរសំណួរទាំងនេះបែបវោហាដើម្បីបញ្ជាក់ថាកូនមិនត្រូវធ្វើការទាំងនោះឡើយ ការបកប្រែរបៀបផ្សេងទៀត: «កូនអើយ មិនត្រូវជាប់ចិត្តជាមួយស្ត្រីផិតក្បត់ឡើយ! មិនត្រូវអោបសុដន់ស្ត្រី ដែលគ្មានសីលធម៌ឡើយ!»

ជាប់ចិត្តជាមួយស្ត្រីផិតក្បត់

ភាពរំភើបរីករាយដែលកើតចេញពីចំណង់ជាមួយស្ត្រីគឺប្រៀបដូចជាការជាប់ចិត្តនឹងស្ត្រីនោះ។ នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «អនុញ្ញាតឲ្យស្ត្រីផិតក្បត់ចាប់អ្នកជាប់» ឬ «អនុញ្ញាតឲ្យស្ត្រីផិតក្បត់ទាក់ទាញអ្នកបាន»

ហេតុអ្វីបានជាកូនចង់សប្បាយជាមួយស្រីផ្សេងដូច្នេះ

ពាក្យថា «សុដន់» នៅទីនេះតំណាងឲ្យស្ត្រីគ្មានសីលធម៌ ហើយនិងភាពទាក់ទាញនៃផ្លូវភេទរបស់នាង។ ការបកប្រែរបៀបផ្សេងទៀត: «ហេតុអ្វីបានជាអ្នកចង់អោបក្រសោបស្ត្រី ដែលគ្មានសីលធម៌យ៉ាងដូច្នេះ»

ស្ត្រីគ្មានសីលធម៌

ន័យដែលអាចមាន គឺ១) «ស្ត្រីដែលមិនជាប្រពន្ធរបស់អ្នក» ឬ ២) «ស្ត្រីដែលជាប្រពន្ធរបស់អ្នកផ្សេង»

ជ្រាបទាំងអស់...ទតឃើញកិរិយាមារយាទ

ឃ្លាទាំងពីរនេះមានន័យដូចគ្នា និង បញ្ជាក់ថាព្រះជាម្ចាស់ជ្រាបគ្រប់កិច្ចការទាំងអស់ដែលមនុស្សធ្វើ។ (សូមមើល:figs-parallelism)

អ្វីៗដែលមនុស្សលោកប្រព្រឹត្ត

អ្នកនិពន្ធនិយាយពីសកម្មភាពរបស់មនុស្ស ឬ ការរស់នៅដូចជាផ្លូវដែលមនុស្សដើរ។ ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ទីកន្លែងដែលគាត់ទៅ» ឬ «គ្រប់កិច្ចការដែលគាត់ធ្វើ»

Proverbs 5:22

កំហុសរបស់មនុស្សអាក្រក់ជាចំណងចងខ្លួន

អ្នកនិពន្ធនិយាយពីមនុស្សអាក្រក់មិនអាចគេចផុតពីផលដែលខ្លួនបានធ្វើដូចជាអំពើអាក្រក់ទាំងនោះចាប់មនុស្សអាក្រក់។ នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «អំពើអាក្រក់របស់មនុស្សអាក្រក់នឹងរឹបអូសគេ» ឬ «មនុស្សអាក្រក់នឹងមិនអាចគេចផុតពីអំពើដែលគេធ្វើទេ»

អំពើបាបជាអន្ទាក់ដែលធ្វើឲ្យខ្លួនគេរើពុំរួច

អ្នកនិពន្ធនិយាយពីមនុស្សអាក្រក់មិនអាចជៀសផុតពីអំពើបាបដែលខ្លួនបានធ្វើដូចជាអំពើបាននោះជាអំពើបាបនោះជាអន្ទាក់ដែលធ្វើពីខ្សែដែលចាប់ចង់គេ។ ការបកប្រែរបៀបផ្សេងទៀត: «ដោយសារអំពើបាបរបស់គាត់ គាត់នឹងលង់ខ្លួនដូចជាសត្វជាប់អន្ទាក់»

គេនឹងត្រូវវិនាស ព្រោះតែអំពើលេលាហួសល្បត់របស់ខ្លួន

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ភាពល្ងង់ខ្លៅរបស់គាត់នឹងនាំឲ្យគាត់វង្វេង»

អំពើលេលាហួសល្បត់របស់ខ្លួន

«ដោយសារគាត់លេលាខ្លាំង»

---

6 [1]កូនអើយ ប្រសិនបើកូន រៀបចំទ្រព្យសម្បត្តិរបស់កូន ឲ្យទៅអ្នកជិតខាងរបស់កូន ប្រសិនបើកូនបានសន្យាឲ្យអ្នកណាខ្ចីហើយមិនបានស្គាល់[2]ក្រោយមកកូន បានជាប់អន្ទាក់ ដោយសារពាក្យសន្យារបស់កូន គឺកូនបានត្រូវចាប់ហើយ ដោយពាក្យសម្តីដែលចេញពីមាត់កូនមក។
[3]នោះកូនអើយ ចូរធ្វើដូច្នេះវិញ ហើយដោះខ្លួនឲ្យរួចចុះ ដ្បិតកូនបានធ្លាក់ទៅក្នុងកណ្តាប់ដៃ នៃអ្នកជិតខាងរបស់កូនហើយ ដូច្នេះ ចូរទៅជួបអ្នកជិតខាងរបស់កូនភ្លាម ហើយអង្វរដោយការបន្ទាបខ្លួននៅចំពោះអ្នកជិតខាង។
[4]សូមកុំឲ្យភ្នែករបស់កូនដេក ហើយកុំត្របកភ្នែករបស់បិទឡើយ។[5]គឺខំប្រឹងរើបម្រះឲ្យទាល់តែរួចខ្លួន ដូចឈ្លូស និងបក្សីខំប្រឹងរំដោះខ្លួន ឲ្យរួចពីអន្ទាក់របស់ព្រានដែរ។
[6]កូនកម្ជិលអើយ ចូរទៅមើលស្រមោច ហើយពិចារណាអំពីការរស់នៅរបស់វា រួចយកឲ្យមានប្រាជ្ញា។[7]វាគ្មានអ្នកដឹកនាំ គ្មានមេកើយ ឬគ្មានអ្នកត្រួតត្រាទេ[8]ប៉ុន្តែនៅរដូវក្តៅ វាប្រមូលចំណី នៅរដូវចម្រូត វាសន្សំស្បៀងដែលវាអាចស៊ីបានទុក។
[9]កូនកម្ជិលអើយ តើកូននៅតែដេកដល់ណាទៀត? តើដល់អង្កាល់ទើបកូនភ្ញាក់ឡើង?[10]«កូនចង់ដេកថែមបន្តិច ចង់ដំអក់បន្តិច ដេកឱបដៃបន្តិច»។[11]បើបែបនេះ កូននឹងខ្វះខាត ហើយធ្លាក់ខ្លួនក្រភ្លាម ដូចមានមកលួច ហើយមានតម្រូវការហើយត្រូវការជំនួយជាដរាប។
[12]អ្នកគឺជាមនុស្សឥតប្រយោជន៍ អ្នកនោះជាមនុស្សពាល រស់នៅជាមួយនឹងការនិយាយពាក្យមិនពិត[13]គេមិចភ្នែក ធ្វើជាសញ្ញាដោយលើកដៃលើកជើង ហើយនិងចង្អុលដោយម្រាមដៃរបស់គេដែរ។
[14]គេមានចិត្តពាលហើយរិះគិតធ្វើអាក្រក់គ្រប់ពេលវេលា ហើយគេនិងបង្កជំលោះ។[15]ហេតុនេះ គេមុខជាវិនាសយ៉ាងទាន់ហន់ ព្រមទាំងត្រូវអន្តរាយមួយរំពេចរកអ្វីមកកែកុនពុំបាន។
[16]មានអំពើប្រាំមួយ ឬប្រាំពីរយ៉ាងផង ដែលព្រះអម្ចាស់មិនសព្វព្រះហឫទ័យ ដែលជាការគួរខ្ពើម ហើយព្រះជាម្ចាស់មិនអាចទ្រាំទ្របាន។
[17]ភ្នែកនៃអ្នកដែលមានឫកធំ ការពោលពាក្យកុហក ការបង្ហូរឈាមដល់មនុស្សស្លូតត្រង់[18]ដួងចិត្តដែលរិះគិតធ្វើអំពើទុច្ចរិត ជើងដែលរត់ទៅប្រព្រឹត្តអំពើអាក្រក់[19]ការធ្វើជាសាក្សីក្លែងក្លាយ ដែលពោលពាក្យមិនពិត និងការបង្កជំលោះបំបាក់បំបែកបងប្អូន។
[20]កូនរបស់យើងអើយ ចូរស្តាប់ឱវាទរបស់យើង កុំចោលសេចក្តីបង្រៀនរបស់ម្តាយកូនឡើយ។[21]ចូរចងចាំទុកក្នុងចិត្ត ចូររក្សាជាប់នឹងខ្លួនដូចគ្រឿងអលង្ការ។
[22]ពេលកូនធ្វើដំណើរទៅណាមកណាដំបូន្មានទាំងនេះនឹងនាំផ្លូវកូន ការពារកូនក្នុងពេលដេកផង ហើយនិងបង្រៀនកូនថែមទៀតនៅពេលកូនភ្ញាក់ឡើង។[23]ដ្បិតឱវាទប្រៀបបាននិងចង្កៀង សេចក្តីបង្រៀនដូចជាពន្លឺ ហើយការប្រៀនប្រដៅគឺជាផ្លូវដឹកនាំជីវិតរបស់កូន។
[24]ពាក្យដាស់តឿនទាំងនេះការពារកូន កុំឲ្យចាញ់បោកស្រីទុច្ចរិត កុំឲ្យចាញ់បញ្ឆោតពាក្យផ្អែមល្ហែមរបស់ស្ត្រីក្បត់ប្តី។[25]កុំមានចិត្តពុះកញ្ជ្រោលនិងសម្ផស្សរបស់ស្រីរបៀបនេះឡើយ ហើយក៏កុំបណ្តោយឲ្យចិត្តអ្នកឈ្លក់វង្វេងទៅតាមកែវភ្នែករបស់គេដែរ។
[26]ដេកជាមួយស្រីពេស្យា គឺនាងចង់បាននំប៉័ងតែមួយដុំប៉ុណ្ណោះ ប៉ុន្តែប្រពន្ធរបស់អ្នកផ្សេងវិញ គឺនាងនឹងត្រូវការជីវិតរបស់អ្នក។[27]តើមានមនុស្សណាអាចយកភ្លើងមកដាក់លើទ្រូង ហើយភ្លើងនោះមិនឆេះអាវរបស់អ្នកនោះទេ?
[28]តើមានមនុស្សណាដែលអាចដើរលើរងើកភ្លើង ដោយមិនរលាកជើងរបស់គាត់ទេ?[29]ដូច្នេះ អ្នកដែលបានដេកជាមួយប្រពន្ធរបស់អ្នកជិតខាង គឺអ្នកដែលបានដេកជានាង នឹងត្រូវទទួលផលវិបាកជានិច្ច។

generated on Wed Sep 10 16:16:32 2025

[30]គ្មានមនុស្សណានឹងចាប់ទោសដល់ ចោរលួចបើសិនដើម្បីគ្រាន់តែចម្អែតក្រពះដែលគាត់ឃ្លាននោះ។[31]ប៉ុន្តែបើគេចាប់បានចោរនោះ គឺត្រូវតែសងមួយជាប្រាំពីរ
នូវអ្វីដែលគាត់បានលួចទោះបើត្រូវចំណាយរបស់ដែលមានតម្លៃនៅក្នុងផ្ទះក៏ដោយ។
[32]អ្នកណាលួចប្រពន្ធគេ អ្នកនោះជាមនុស្សមិនចេះពិចារណា ដ្បិតប្រព្រឹត្តយ៉ាងនេះនាំតែវិនាសខ្លួនឯង។[33]អ្នកនោះនឹងទទួលទោសបាត់បង់កិត្តិយស ហើយត្រូវ
ខ្មាសនោះនឹងនៅជាមួយគេរហូត។
[34]ដ្បិតសេចក្តីប្រចណ្ឌរបស់ប្តីនាងគឺសាហាវណាស់ ហើយប្តីនឹងបានសងសឹកឥតត្រាប្រណីឡើយ។[35]គាត់មិនព្រមទទួលសំណង ហើយគាត់ក៏មិនអត់ទោសឲ្យដែរ ទោះបី
យកជំងឺចិត្តទៅសងច្រើនយ៉ាងណាក៏ដោយ។

Proverbs 6:1

រៀបចំទ្រព្យសម្បត្តិរបស់កូន

សេចក្តីបញ្ជាក់នៅទីនេះ គឺបញ្ជាក់ថាការសន្យារបស់អ្នក
ហើយស្ថានភាពនោះនឹងបង្ខំអ្នកឲ្យសន្សំប្រាក់។ ការបកប្រែរបៀបផ្សេងទៀត:
«ត្រូវតែរៀបចំសន្សំប្រាក់របស់អ្នក»

សន្យាឲ្យអ្នកណាខ្លី

ន័យដែលអាចមាន គឺ១) អ្នកជិតខាងនឹងមកសុំខ្ចីលុយ ឬ ២)
អ្នកជិតខាងចង់ខ្ចីលុយអ្នកផ្សេងតែអ្នកធានាអះអាងសង់ប្រាក់ជំនួសគេបើអ្នកជិតខាងនោះមិនសង

អ្នកជិតខាង

ពាក្យនេះដូចពាក្យហេព្រើអាចមានន័យថា «មិត្តភក្តិ»

កូន បានជាប់អន្ទាក់

នេះជាពាក្យប្រៀបធៀប ដែលនិយាយថាអ្នកនឹងជាប់អន្ទាក់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបានធ្វើអន្ទាក់ទុកទាក់ខ្លួនឯង»

ពាក្យសម្តីដែលចេញពីមាត់កូនមក

«អ្វីដែលអ្នកបាននិយាយ» ឬ «អ្វីដែលអ្នកសន្យាថានឹងធ្វើ»

Proverbs 6:3

ដោះខ្លួនឲ្យរួច

«ការពារខ្លួនឯង» ឬ «ជួយខ្លួនឯងឲ្យដោះរួចពីបញ្ហាទាំងអស់នោះ»

កូនបានធ្លាក់ទៅក្នុងកណ្តាប់ដៃ

នេះគឺជាពាក្យប្រៀបប្រដូចដោយប្រើពាក្យ «ដៃ» ដែលមានន័យថា «គ្រោះថ្នាក់»
ការបកប្រែរបៀបផ្សេងទៀត: «អ្នកជិតខាងអ្នកនឹងនាំគ្រោះថ្នាក់ដល់អ្នក
ប្រសិនបើគេចង់» ឬ «អ្នកជិតខាងមានអំណាចលើអ្នក»

អ្នកជិតខាង

«មិត្តភក្តិ»

Proverbs 6:4

សូមកុំឲ្យភ្នែករបស់កូនដេក ហើយកុំត្របកភ្នែករបស់បិទឡើយ

«កុំឲ្យភ្នែករបស់អ្នកដេក ក៏កុំឲ្យត្របកភ្នែករបស់អ្នកបិទ»។
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយលើកមកម្តងទៀតដើម្បីបញ្ជាក់ថាវាសំខាន់ប៉ុណ្ណា ក្នុងការដែលមិនខ្ជិល។
វាក៏អាចបញ្ជាក់ជាអវិជ្ជមានដើម្បីកាន់តែច្បាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ភ្ញាក់ឡើង ហើយធ្វើអ្វីដែលអ្នកអាចធ្វើបាន»

ភ្នែករបស់អ្នក...ត្របករបស់អ្នក

នេះជាពាក្យប្រៀបប្រដូច ដែលប្រើផ្នែកនៃមុខរបស់អ្នក
ដើម្បីសំដៅទៅលើរាងកាយទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្លួនអ្នក...ខ្លួនអ្នក» (សូមមើល:

គឺខំប្រឹងរើបម្រះឲ្យទាល់តែរួចខ្លួន ដូចឈ្លូស

«រត់គេចពីអ្នកជិតខាងរបស់អ្នក ដូចជាសត្វឈ្លូសដែលរត់ចេញពីអ្នកប្រមាញ់»

ឈ្លូស

នេះជាប្រភេទសត្វគ្មានខ្លាញ់ធំដែលស៊ីស្មៅ ហើយមនុស្សប្រមាញ់វាយកសាច់។
វាត្រូវបានគេស្គាល់ថាជាសត្វដែលរត់លឿនបំផុត។

ពីអន្ទាក់របស់ព្រាន

កណ្តាប់ដៃរបស់ព្រានសំដៅទៅលើ ការគ្រប់គ្រងរបស់ព្រាន។
ការបកប្រែរបៀបផ្សេងទៀត:«ចេញពីការគ្រប់គ្រងរបស់ព្រាន»

បក្សីខំប្រឹងរំដោះខ្លួន ឲ្យរួចពីអន្ទាក់របស់ព្រានដែរ

«ហើយដោះខ្លួនដូចជាបក្សីដែលខំដោះខ្លួនពីព្រានដែរ»

Proverbs 6:6

ចូរទៅមើល...ពិចារណា

«រៀន...គិតពី» ឬ «ពិចារណាដោយប្រុងប្រយ័ត្ន...សញ្ជឹងគិត»

ស្រមោច

ស្រមោចជាសត្វល្អិតដែលរស់នៅក្រោមដី ឬ ទួលដែលវាសង់ឡើងខ្លួនឯង។
ជាធម្មតាពួកវារស់នៅជាក្រុមដែលមានគ្នារាប់ពាន់នាក់
ហើយពួកវាអាចលើករបស់ដែលធំជាងខ្លួនវាបាន។

ពិចារណាអំពីការរស់នៅរបស់វា

នេះជាពាក្យប្រៀបធៀបដែលប្រើ «របៀបរស់នៅ»
របស់ស្រមោចសំដៅទៅលើឥរិយាបថរបស់ស្រមោច។ ការបកប្រែរបៀបផ្សេងទៀត:
«ពិចារណាពីរបៀបរស់នៅរបស់ស្រមោច»

អ្នកដឹកនាំ មេកើយ អ្នកត្រួតត្រា

ពាក្យទាំងបីនេះមានន័យដូចគ្នា ហើយត្រូវបានគេប្រើដើម្បីបញ្ជាក់ថា
ព្រះអម្ចាស់ជាអ្នកត្រួតត្រាលើពួកស្រមោចឡើយ។

នៅរដូវក្តៅវាប្រមូលចំណី នៅរដូវចម្រូត...វាសន្សំស្បៀងដែលវាអាចស៊ីបានទុក

ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា
ហើយលើកមកម្តងទៀតដើម្បីបង្ហាញពីការទទួលខុសត្រូវរបស់ស្រមោច។

រដូវចម្រូត

រដូវក្តៅជាពេលវេលានៃឆ្នាំដែលដើមឈើខ្លះបង្កបង្កើតផល។

Proverbs 6:9

តើកូននៅតែដេកដល់ណាទៀត...តើដល់អង្កាល់ទើបកូនភ្ញាក់ឡើង?

គ្រូបង្រៀនប្រើសំណួរទាំងនេះដើម្បីស្តីបន្ទោសដល់អស់មនុស្សខ្ជិលដែលចូលចិត្តដេកច្រើន។
ការបកប្រែរបៀបផ្សេងទៀត: «ក្រោកឡើង មនុស្សកម្ជិលអើយ! ងើបចេញពីគ្រែ!»

ដេកថែមបន្តិច...ដេកឱបដៃបន្តិច

ទាំងអស់នេះជាអ្វីដែលមនុស្សខ្ជិលតែងតែនិយាយ។

ដេកថែមបន្តិច ចង់ដំអក់បន្តិច

ប្រយោគទាំងពីរនេះមានន័យដូចគ្នា។
ប្រយោគនេះអាចបញ្ជាក់ជាប្រយោគពេញលេញ។ ការបកប្រែរបៀបផ្សេងទៀត:
«ញុំនឹងគេងបានយូរជាងនេះបន្តិច។ ទុកឱ្យខ្ញុំគេងតិចជាងនេះបន្តិច»

ដេកឱបដៃបន្តិច

ជាទូទៅមនុស្សចូលចិត្តអោបដៃពួកគេ
ខណៈពេលដែលអង្គុយដើម្បីសម្រាកឲ្យបានកាន់តែស្រួល។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំអោបដៃបន្តិច ហើយគេងតែបន្តិចប៉ុណ្ណោះ»

កូននឹងខ្វះខាត ហើយធ្លាក់ខ្លួនក្រភ្លាម

នេះអាចបញ្ជាក់ជាប្រយោគថ្មីដើម្បីឲ្យកាន់តែច្បាស់ថា
នេះគឺជាលទ្ធផលនៃភាពខ្ជិលច្រអូស។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើបន្តខ្ជិលច្រអូសទៀត នោះភាពក្រីក្រនឹងកើតមានដល់អ្នក» ឬ
«ពេលដែលអ្នកកំពុងតែដេកនោះភាពក្រីក្រនឹងមក»

កូននឹងខ្វះខាត ហើយធ្លាក់ខ្លួនក្រភ្លាម ដូចមានមកលួច

មិនយូរទេមនុស្សខ្ជិលនឹងធ្លាក់ខ្លួនក្រភ្លាម ដូចជាចោរមកប្លន់ភ្លាម។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងក្លាយជាអ្នកក្រភ្លាមៗ
ដូចជាចោរមកប្លន់យកទ្រព្យដែលអ្នកមាន»

ហើយមានតម្រូវការហើយត្រូវការជំនួយជាដរាប

ភ្លាមៗមនុស្សខ្ជិលនឹងមានតម្រូវការ
ដូចជាទាហានដែលដកយករបស់ពីមនុស្សម្នាក់។
នេះអាចបញ្ជាក់ជាប្រយោគពេញលេញបាន។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយតម្រូវការរបស់អ្នកនឹងរត់មករកអ្នកដូចជាទាហានប្រដាប់អាវុធ» ឬ
«ហើយអ្នកនឹងក្លាយជាមនុស្សខ្វះខាត
ដូចជាទាហានប្រដាប់អាវុធបានរឹបយករបស់របរអ្នក»

ទាហានប្រដាប់អាវុធ

«ទាហានដែលកាន់អាវុធ» ឬ «មនុស្សដែលមានអាវុធ»

Proverbs 6:12

មនុស្សឥតប្រយោជន៍—មនុស្សពាល

ពាក្យទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ពីភាពអាក្រក់របស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលគ្មានតម្លៃ —
មនុស្សអាក្រក់» (សូមមើល:figs-doublet)

រស់នៅជាមួយនឹងការនិយាយពាក្យមិនពិត

generated on Wed Sep 10 16:16:32 2025

«និយាយកុហកឥតឈប់ឈរ»
គេមិចភ្នែក ធ្វើជាសញ្ញាដោយលើកដៃលើកជើង ហើយនិងចង្អុលដោយម្រាមដៃរបស់គេដែរ
ឃ្លាទាំងបីនេះពិពណ៌នាពីរបៀបដែលមនុស្សអាក្រក់មានទំនាក់ទំនងស្ងាត់ៗ
ហើយបោកបញ្ឆោតគេ។
គេមិចភ្នែក
បើនរណាម្នាក់មិចភ្នែក គឺគេព្រិចភ្នែកមួយជាសញ្ញាសម្ងាត់ទៅកាន់នរណាម្នាក់។
នេះអាចជាសញ្ញាដែលបង្ហាញពីការទុកចិត្ត ការយល់ព្រម ឬ
ជាសញ្ញាអ្វីផ្សេងទៀត។
Proverbs 6:14
មនុស្សធ្វើអំពើឃោឃៅ
«គេគិតធ្វើអំពើអាក្រក់» ឬ «គេរៀបចំធ្វើការអាក្រក់»
គេនិងបង្កជម្លោះ
«គេតែងតែបង្កជម្លោះ» ឬ «គេគិតតែរករឿង ហើយបង្កើតជំលោះឥតឈប់ឈរ»
ដូច្នេះ
«ដោយហេតុនោះ»
គេមុខជាវិនាសយ៉ាងទាន់ហន់
នេះបញ្ជាក់ថាសេចក្ដីវិនាសនឹងដេញតាមគេ ដូចជាមនុស្ស ឬ សត្វ
ហើយដែលមិនយូរទេ វានឹងចាប់គេជាប់។ ការបកប្រែរបៀបផ្សេងទៀត:
«សេចក្ដីវិនាសនឹងចាប់គេជាប់»
វិនាសយ៉ាងទាន់ហន់
នេះសំដៅទៅលើគ្រោះដែលនឹងកើតមានដល់គេ
ប៉ុន្តែវាជាគ្រោះដែលគេបានធ្វើដោយខ្លួនឯង។
យ៉ាងទាន់ហន់ មួយរំពេច
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយឃ្លាតែមួយ ឬ ទាំងពីរអាចជំនួសឲ្យពាក្យថា
«ភ្លាមៗនោះ» ឬ «យ៉ាងលឿនជាទីបំផុត»។
Proverbs 6:16
មានអំពើប្រាំមួយ ឬប្រាំពីរយ៉ាងផង ដែលព្រះអម្ចាស់មិនសព្វព្រះហឫទ័យ
ខគម្ពីរទាំងមូលនេះស្របគ្នាដែលបញ្ជាក់ថាព្រះជាម្ចាស់ស្អប់អំពើប្រាំពីរយ៉ាង
មិនមែនតែមួយទេ។ ការបកប្រែរបៀបផ្សេងទៀត:
«មានអំពើប្រាំមួយដែលព្រះអម្ចាស់ស្អប់ ក៏មានប្រាំពីរផង»
ហើយព្រះជាម្ចាស់មិនអាចទ្រាំទ្របាន
«ដែលធ្វើឲ្យព្រះអង្គខ្ពើម» ឬ «ដែលធ្វើឲ្យអ្នកខ្ពើមដោយសារគេ»
Proverbs 6:17
ខ្ពើមសារភ្លាប់:
នេះគឺជាបញ្ជីនៃអ្វីដែលព្រះជាម្ចាស់ស្អប់ ដែលត្រូវបានណែនាំនៅក្នុងជំពូក ៦:១៦។
ភ្នែក...អណ្ដាត...ដៃ...ដួងចិត្ត...ជើង
ទាំងអស់នេះជាផ្នែកនៃរាងកាយ ដែលសំដៅទៅលើមនុស្សទាំងមូល។
អ្នកអាចបកប្រែពាក្យទាំងនេះថា «មនុស្ស»
ការបង្ហូរឈាម
«សម្លាប់» ឬ «ឃាតកម្ម»
រិះគិតធ្វើអំពើទុច្ចរិត
«គម្រោងការអាក្រក់»
ដែលពោលពាក្យមិនពិត
ពាក្យប្រៀបធៀបនេះប្រើ «ដកដង្ហើម» គឺសំដៅទៅលើ ការកុហកឥតឈប់ឈរ។
ការបកប្រែរបៀបផ្សេងទៀត: «កុហកឥតឈប់ឈរ»
មិនចុះសម្រុងគ្នា
បកប្រែពាក្យនេះដូចនៅក្នុងជំពូក ៦:១៤។
អ្នកដែលបង្កជំលោះ
ពាក្យប្រៀបធៀបនេះប្រើ «បង្ក» សំដៅទៅលើបង្ក ឬ ធ្វើឲ្យបានការបាក់បែង។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលបង្កជម្លោះបាក់បែក»
Proverbs 6:20
ចូរស្តាប់ឱវាទរបស់យើង...កុំចោលសេចក្ដីបង្រៀនរបស់ម្តាយកូនឡើយ។
ឃ្លាទាំងពីរនេះបើគិតមួយបែប គឺមានន័យដូចគ្នា។
ម៉្យាងទៀតការសង្កត់ធ្ងន់ម្តងហើយម្តងទៀតដែលបញ្ជាក់ថាទាំង «ឪពុក» និង
«ម្តាយ» គឺរួមបញ្ចូលទាំងស្ត្រីក្នុងដំណើរការបង្រៀននេះ។
កុំចោលសេចក្ដីបង្រៀនរបស់ម្តាយកូនឡើយ
ពាក្យប្រៀបធៀបនេះកំពុងប្រើន័យអវិជ្ជមាន «បោះបង់ចោល»
ដើម្បីធ្វើឲ្យវាមានន័យវិជ្ជមានថា «ស្តាប់បង្គាប់»។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តាប់បង្គាប់ចំពោះសេចក្ដីបង្រៀនរបស់ម្តាយអ្នក»
ចូរចងចាំទុកក្នុងចិត្ត ចូររក្សាជាប់នឹងខ្លួនដូចគ្រឿងអលង្ការ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។ ពួកវាពិពណ៌នាពីសេចក្ដីប្រៀនប្រដៅ និង
ការទូន្មាន ដូចជាបានសរសេរចុះដេើម្បីឲ្យគេអាចដាក់វាជាប់ខ្លួន ដើម្បីរំលឹកគេ។
ចូរចងចាំទុកក្នុងចិត្ត
«ស្រឡាញ់សេចក្ដីទាំងនោះ» ឬ «គិតពីសេចក្ដីទាំងនោះ»
Proverbs 6:22
ពេលកូនធ្វើដំណើរទៅណាមកណា...ក្នុងពេលដេក...ពេលកូនភ្ញាក់ឡើង
ឃ្លាទាំងបីនេះគឺប្រើរួមគ្នាដើម្បីបញ្ជាក់ថាដំបូន្មានគឺមានតម្លៃគ្រប់ពេល។
ដំបូន្មានទាំងនេះនឹងនាំផ្លូវកូន...ការពារកូន...និងបង្រៀនកូន
ឃ្លាដែលលើកឡើងម្តងហើយម្តងទៀតនេះ
គឺចង់បង្ហាញថាដំបូន្មានមានតម្លៃសម្រាប់គ្រប់កិច្ចការទាំងអស់។
វាក៏និយាយពីដំបូន្មានទាំងនេះដូចជា មនុស្ស។
ឱវាទ...សេចក្ដីបង្រៀន...ការប្រៀនប្រដៅគឺជាផ្លូវដឹកនាំជីវិត
ឃ្លាទាំងបីនេះមានន័យមូលដ្ឋានដូចគ្នា
ហើយរួមគ្នាបង្ហាញពីប្រភេទនៃដំបូន្មានផ្សេងៗ ដែលឪពុកនិង ម្តាយបង្រៀន។
ចង្កៀង...ពន្លឺ...ផ្លូវដឹកនាំជីវិត
ពាក្យទាំងបីនេះមានន័យមូលដ្ឋានដូចគ្នា
ហើយលើកមកដដែលៗដើម្បីបញ្ជាក់ពីការពិតនៃដំបូន្មានដែលធ្វើឲ្យជីវិតប្រើសើរឡើង
និង ងាយស្រួលជាងមុន។ ការបកប្រែរបៀបផ្សេងទៀត:
«ជាចង្កៀងដែលផ្តល់ប្រយោជន៍...ជាពន្លឺដែលជាជំនួយនៅពេលងងឹត...ជាការចាំបាច់ក្នុងការដើរតាម
ដែលជាផ្លូវជីវិត»
ផ្លូវដឹកនាំជីវិត
«ផ្លូវដែលនាំទៅរកជីវិត» ឬ «របៀបរស់នៅដែលព្រះជាម្ចាស់សព្វព្រះទ័យ»
Proverbs 6:24
ការពារកូនពី
ពាក្យថា «វា» នៅទីនេះសំដៅទៅលើដំបូន្មានដែលបង្រៀនដោយឪពុក និង
ម្តាយនៅក្នុងជំពូក ៦:២០។ ការបកប្រែរបៀបផ្សេងទៀត: «វាជួយសង្គ្រោះពី» ឬ
«វាការពារកូនពី»
ស្រីទុច្ចរិត...ស្ត្រីក្បត់ប្តី
ពាក្យទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ «ស្ត្រីផិតក្បត់» នៅក្នុងជំពូក ៥:៣។
គ្មានសីលធម៌
«អសីលធម៌»
សម្ផស្សរបស់នាង
«អ្វីដែលជាសម្រស់របស់នាង» ឬ «ជារបស់នាង»
ឈ្លក់វង្វេង
«ត្រូវគេគ្រប់គ្រងលើ»
កែវភ្នែករបស់នាង
ពាក្យថា «កែវភ្នែក» តំណាងឲ្យអ្វីដែលជាភាពស្រស់ស្អាតរបស់នាង
ពីរាងកាយរបស់នាង ដែលនាងប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីបុរស។
ការបកប្រែរបៀបផ្សេងទៀត: «កែវភ្នែកដ៏ស្រស់ស្អាតរបស់នាង»
Proverbs 6:26
នំប៉ុងតែមួយដុំ
នេះគឺជាការនិយាយអំពីថ្លៃដើមជាសម្ភារៈ មិនមែនថ្លៃខាងព្រលឹងវិញ្ញាណ ឬ
ថ្លៃខាងសីលធម៌ទេ។ ការបកប្រែរបៀបផ្សេងទៀត: «តិចតួច»
ត្រូវការជីវិតរបស់អ្នក
អាចមានន័យថា គឺ១) ប្រពន្ធរបស់អ្នកផ្សេងនឹងបំផ្លាញជីវិតរបស់អ្នក
ដោយសារតែងតែទាមទារចង់បាន ហើយចង់បានថែមទៀត ឬ ២)
ប្តីរបស់អ្នកផ្សេងនឹងប្រមាញ់ ហើយសម្លាប់អ្នក។
តើមានមនុស្សណាអាចយកភ្លើងមកដាក់លើទ្រូង ហើយភ្លើងនោះមិនឆេះអាវរបស់អ្នកនោះទេ?
សកម្មភាពនេះគឺគ្រោះថ្នាក់ណាស់ ហើយវាបង្កហានិភ័យ។ វាបង្កប់នូវចម្លើយថា
«ទេ»។ ការបកប្រែរបៀបផ្សេងទៀត: «គ្រប់បុរសដែលកាន់ភ្លើងដាក់លើទ្រូង
នឹងឆេះអាវរបស់គេ»
នោះមិនឆេះ
«មិនខូចខាត» ឬ «និងមិនបំផ្លាញ»
អាវរបស់គេ
សម្លៀកបំពាក់របស់គេគ្របបាំងរាងកាយគេទាំងមូល។
Proverbs 6:28
តើមានមនុស្សណាដែលអាចដើរលើរងើកភ្លើង ដោយមិនរលាកជើងរបស់គាត់ទេ?

generated on Wed Sep 10 16:16:32 2025

ការដើរលើរងើកភ្លើងក្តៅ នឹងរលាកជើងគេ ដូច្នេះចម្លើយបង្កប់គឺ «ទេ»។
ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់មនុស្សដែលដើរលើរងើកភ្លើងនឹងរលាកជើងហើយ»
ដើរលើរងើកភ្លើង
នេះសំដៅទៅលើការចុះចូលនឹងអំពើផិតក្បត់។
ដើរ
នេះជាការដើរយឺតៗ ចម្ងាយឆ្ងាយ ដោយគ្មានប្រើវេទមន្ត ឬ មន្តអាគម។
រលាក
រលាក
Proverbs 6:30
ចាប់ទោសដល់ ចោរលួច
«កុំមើលចោរដោយការមើលងាយ» ឬ «កុំគិតថាចោរអាក្រក់»
បើគេចាប់បានចោរ
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើនរណាម្នាក់ចាប់គាត់»
ក្នុងផ្ទះរបស់គាត់
ពាក្យប្រៀបធៀបនេះនិយាយថា អ្វីៗដែលមាននៅក្នុងផ្ទះជារបស់គាត់។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលជាកម្មសិទ្ធរបស់គាត់»
Proverbs 6:32
អ្នកណា
«មនុស្ស» ឬ «នរណាម្នាក់»
អ្នកនោះនឹងទទួល
«ការដាក់ទណ្ឌកម្មឲ្យសមនឹងអ្វីដែលគាត់បានធ្វើ»
ភាពអាម៉ាស់របស់គេ
ពាក្យប្រៀបធៀបនេះកំពុងប្រើពាក្យ «ភាពអាម៉ាស់»
ចង់សំដៅទៅលើអារម្មណ៍ដែលគាត់បានប្រព្រឹត្តដោយភាពអាម៉ាស់។
ការបកប្រែរបៀបផ្សេងទៀត: «ការចងចាំនូវទង្វើរដ៏អាម៉ាស់របស់ខ្លួន»
នឹងនៅជាមួយគេរហូត
ពាក្យប្រៀបធៀបនេះកំពុងប្រើន័យអវិជ្ជមាន «នឹងមិនរលុបចេញឡើយ»
ចង់សំដៅទៅលើថា វានឹងនៅជាប់រហូត។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងនៅសល់រហូត»
Proverbs 6:34
សាហាវណាស់
«ខឹងខ្លាំងណាស់»
ឥតត្រាប្រណីឡើយ
ពាក្យថា «គាត់»
អ្នកជិតខាងដែលប្រពន្ធគេបានប្រព្រឹត្តអំពើផិតក្បត់ជាមួយបុរសផ្សេង។
ការបកប្រែរបៀបផ្សេងទៀត: «គាត់នឹងមិនសម្រាលការឈឺចាប់ឡើយ
ដែលគាត់ធ្វើនឹងធ្វើដាក់អ្នកឡើយ» ឬ «គាត់នឹងធ្វើឲ្យអ្នកឈឺតាម
ដែលគាត់អាចធ្វើទៅបាន»
ហើយប្តីនឹងបានសងសឹក
«ក្នុងពេលណាមួយនៃការសងសឹករបស់គាត់» ឬ
«នៅពេលមួយមកដល់ដែលគាត់អាចនឹងសងសឹក»
គាត់សងសឹក
ប្រសិនបើនរណាម្នាក់សងសឹក
វាជាការដែលធ្វើឲ្យអ្នកដែលបានធ្វើឲ្យគាត់ឈឺចាប់ពីមុន បានឈឺចាប់វិញម្តង។
សំណង
«បង់ថ្លៃ»
គាត់ក៏មិនអត់ទោសឲ្យដែរ
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមិនអាចសងលុយឲ្យគ្រប់ដើម្បីឲ្យគាត់ប្តូរចិត្តនោះទេ»
បិទ ទោះបីជា
«បិទ។ នេះនឹងក្លាយជាការពិតទោះបីជា»
ផ្តល់ឲ្យ
«ឲ្យ» ឬ «សន្យា»

---

7 [1]កូនអើយ កុំភ្លេចពាក្យបណ្តាំយើង ចូរចងចាំពាក្យដែលយើងទូន្មាន។[2]ចូររក្សាពាក្យដែលយើងទូន្មាននេះ ទើបកូនមានជីវិត ចូររក្សាសេចក្តីបង្រៀនរបស់យើងទុកដូចជាកែវភ្នែក។[3]ចូរចងចាំពាក្យរបស់ឪពុកគ្រប់ពេលវេលា ហើយចារឹកទុកក្នុងដួងចិត្តជានិច្ច។
[4]ចូរនិយាយដោយប្រាជ្ញា «អ្នកគឺជាបងប្អូនស្រីរបស់ខ្ញុំ» ហើយត្រូវហៅការចេះដឹងថាជាមិត្តសម្លាញ់[5]ធ្វើដូច្នេះ កូនអាចគេចផុតពីស្ត្រីក្បត់ប្តី និងគេចផុតពីប្រពន្ធគេ ដែលប្រសប់លួងលោម។
[6]ដ្បិតយើងបានមើលតាមបង្អួចផ្ទះរបស់យើង សម្លឹងទៅផ្លូវកែង។[7]យើងឃើញមនុស្សដែលមិនសូវដឹងខុសត្រូវ យើងក៏ឃើញក្មេងកំលោះម្នាក់ គឺជាអ្នកគ្មានប្រាជ្ញាទាល់តែសោះ។
[8]ក្មេងកំលោះនោះដើរតាមផ្លូវមានផ្ទះលក់ដូរ ក្បែរកន្លែងដែលស្ត្រីក្បត់ប្តីរស់នៅ ហើយដើរតម្រង់ទៅផ្ទះនាង។[9]ពេលនោះ ជាពេលល្ងាច ថ្ងៃកំពុងលិច ហើយយប់ងងឹតក៏ជិតមកដល់។
[10]ស្ត្រីនោះចេញមកជួបអ្នកកំលោះ ទាំងស្លៀកពាក់ជារបៀបស្រីពេស្យា ដើម្បីទាក់ទាញចិត្តគេ។[11]នាងពុះកញ្ជ្រោល ស្រើបស្រាល ឥតអៀនខ្មាស ទ្រាំនៅក្នុងផ្ទះមិនបានទេ។
[12]នាងនេះដើររកប្រុសនៅតាមដងផ្លូវ នៅតាមផ្សារ និងនៅគ្រប់កៀនកោះ។
[13]ដូច្នេះ នាងចាប់អ្នកកំលោះមកឱបរឹតនិងថើប ហើយនិយាយដោយមុខខឹងថា[14]«ថ្ងៃនេះ ខ្ញុំទើបនឹងថ្វាយយញ្ញបូជាអរព្រះគុណ ដើម្បីលាបំណន់។[15]ហេតុនេះហើយបានជាខ្ញុំចេញមកជួបបង ដ្បិតខ្ញុំចង់ស្គាល់បងយូរហើយ ឥឡូវ ខ្ញុំជួបបងមែន។
[16]អូនបានរៀបចំគ្រែរួចហើយ ដែលមានភួយចម្រុះពណ៌ និងមានផាហ៊ុមល្អៗមកពីអេស៊ីប។[17]អូនបានប្រោះទឹកអប់ និងគ្រឿងក្រអូបផ្សេងៗពីលើគ្រែនោះ។[18]សូមមកចុះ ហើយផឹកស្រារួមស្នេហ៍យ៉ាងសប្បាយជាមួយគ្នា រហូតដល់ព្រឹកស្អែក។
[19]ដ្បិត ប្តីអូនមិននៅផ្ទះទេ គាត់បានចេញដំណើរទៅកន្លែងឆ្ងាយទៅហើយ។[20]គាត់យកប្រាក់មួយថង់ទៅជាមួយដល់ថ្ងៃពេញបូណ៌ ទើបគាត់វិលត្រឡប់មកផ្ទះវិញ»។[21]នាងនិយាយបញ្ចុះបញ្ចូលយ៉ាងប៉ិនប្រសប់ អូសទាញអ្នកកំលោះដោយពាក្យសម្តីផ្អែមល្ហែម។
[22]អ្នកកំលោះក៏ទៅតាមនាងភ្លាម ដូចគោដែលគេនាំទៅទីសត្តឃាត និងដូចមនុស្សឆ្កួតដែលបណ្តោយឲ្យគេចងជើងចងដៃ យកទៅធ្វើទោស។[23]អ្នកនោះប្រៀបបាននឹងសត្វស្លាប ហើរបោះពួយទៅរកអន្ទាក់ ដោយមិនដឹងថា ខ្លួនមានគ្រោះថ្នាក់ដល់ជីវិតទេ។ លុះត្រាតែមានព្រួញមកទម្លុះដល់បេះដូង។
[24]ឥឡូវនេះ កូនអើយ ចូរស្តាប់យើង ចូរត្រងត្រាប់ស្តាប់សេចក្តីដែលដែលចេញពីមាត់របស់យើង។[25]កុំបាក់ចិត្តទៅតាមស្ត្រីប្រភេទនេះឡើយ ហើយក៏កុំរង្វេងទៅសេពគប់ជាមួយផ្លូវរបស់នាងដែរ។
[26]ដ្បិត ស្ត្រីនេះបានធ្វើឲ្យមនុស្សវិនាសជាច្រើនហើយ សេចក្តីស្លាប់ដោយសារស្នាដៃនាងគឺមានច្រើនណាស់ដែរ។[27]ផ្ទះរបស់នាងជាស្ថានមច្ចុរាជ គេបានចូលទៅក្នុងបន្ទុប់ដែលងងឹត នៃសេចក្តីស្លាប់។

Proverbs 7:1
កុំភ្លេចពាក្យបណ្តាំយើង
ការរក្សានៅទីនេះតំណាងឲ្យការស្តាប់បង្គាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តាប់បង្គាប់តាមពាក្យរបស់យើង»
ចូរចងចាំពាក្យដែលយើងទូន្មាន
ពាក្យទូន្មានរបស់ព្រះជាម្ចាស់នៅទីនេះគឺ
និយាយដែលវាដូចជាអ្វីដែលមនុស្សអាចរក្សាទុកនៅក្នុងឃ្លាំងបាន។
ការបកប្រែរបៀបផ្សេងទៀត: «ចងចាំពាក្យទូន្មានរបស់យើង»
ចូររក្សាសេចក្តីបង្រៀនរបស់យើង
ការរក្សានៅទីនេះតំណាងឲ្យការដែលស្តាប់បង្គាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តាប់បង្គាប់សេចក្តីបង្រៀនរបស់យើង»
ដូចជាកែវភ្នែក

generated on Wed Sep 10 16:16:32 2025

កែវភ្នែក គឺជាកែវភ្នែកដែលនៅខាងក្នុងភ្នែក
ដែលជាធម្មតាវាការពារភ្នែកមនុស្សពីការប៉ះទង្គិចនឹងរបស់អ្វីដែលហើរមកប៉ះលើមុខ។
ពាក្យថា «កែវភ្នែក» នៅទីនេះតំណាងឲ្យអ្វីដែលមនុស្សឲ្យតម្លៃ
ហើយការពារបំផុត។ ការបកប្រែរបៀបផ្សេងទៀត:
«ជាកម្មសិទ្ធរបស់អ្នកដែលមានតម្លៃបំផុត»
ចូរចងចាំពាក្យរបស់ឪពុកគ្រប់ពេលវេលា
អាចមានន័យថា គឺ១)
ថាអ្នកនិពន្ធចង់ឲ្យកូនរបស់គាត់ឆ្លាក់ពាក្យទូន្មានពីព្រះជាម្ចាស់លើចិញ្ចៀនហើយពាក់វា
ឬ គឺ២) អ្នកនិពន្ធចង់ឲ្យកូនរបស់គាត់តែងតែចងចាំពាក្យទូន្មានរបស់ព្រះជាម្ចាស់
ដូចជាពាក់ចិញ្ចៀន។
ចារឹកទុកក្នុងដួងចិត្តជានិច្ច
ពាក្យចិត្ត នៅទីនេះតំណាងឲ្យចិត្តរបស់មនុស្ស និង ការចងចាំអ្វីមួយបានល្អ
ត្រូវបានគេចាត់ទុកថា ដូចជាមនុស្សដែលបានចារឹកនៅលើថ្ម។
សូមមើលរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៣:៣។ ការបកប្រែរបៀបផ្សេងទៀត:
«ចូរចងចាំនូវទូន្មាន ដូចជាគេចារឹកនៅលើថ្ម»
Proverbs 7:4
ចូរនិយាយដោយប្រាជ្ញា «អ្នកគឺជាបូនស្រីរបស់ខ្ញុំ»
ពាក្យប្រាជ្ញានៅទីនេះ ត្រូវបានគេចាត់ទុកថាដូចជាមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ឲ្យតម្លៃប្រាជ្ញា ដូចជាបូនស្រី»
ត្រូវហៅការចេះដឹងថាជាមិត្តសម្លាញ់
នៅទីនេះគុណតម្លៃរបស់ការចេះដឹងត្រូវបានគេចាត់ទុកដូចជាមិនសម្លាញ់ ឬ
សាច់ញាតិ។ ការបកប្រែរបៀបផ្សេងទៀត: «ចាត់ទុកការចេះដឹងដូចជាមិត្តសម្លាញ់»
សាច់ញាតិ
«សាច់ញាតិ» ឬ «សមាជិកគ្រួសារ»
ស្ត្រីក្បត់ប្តី
នេះសំដៅទៅលើស្ត្រីទាំងឡាយណានៅជាមួយបុរសដោយមិនបានរៀបការ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សស្រីដែលមិនគួរធ្វើអ្វីជាមួយនាង»
ប្រពន្ធគេ
នេះសំដៅទៅលើស្ត្រីទាំងឡាយណាដែលមិនត្រូវបានស្គាល់ដោយបុរសណា។
ដែលប្រសប់លួងលោម
ពាក្យចេតនាបញ្ឆោត ត្រូវបានគេចាត់ទុកថា ដូចជាអ្វីដែលទន់រលោង។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលនិយាយសម្តីផ្អែម
តែក្នុងគោលបំណងចង់បញ្ឆោតអ្នក»
Proverbs 7:6
បង្អួចផ្ទះ
គម្របបង្អួចដែលធ្វើពីបន្ទះឈើដែលកាត់គ្នាទៅវិញទៅមកក្នុងលំនាំរអិល
ជាទម្រង់បិទបើកជាការ
ដែលមិនសូវដឹងខុសត្រូវ
«ខ្វះបទពិសោធន៍» ឬ «នៅក្មេងខ្ចី»
Proverbs 7:8
កន្លែងដែលស្ត្រីក្បត់ប្តីរស់នៅ
ពាក្យថា «របស់នាង»
នៅទីនេះសំដៅទៅលើស្ត្រីចម្លែកណាមួយដែលយោងនៅក្នុងជំពូក ៧:៤។
នាងកំពុងឈរនៅកាច់ជ្រុង រង់ចាំបុរសណាដែលដើរកាត់។
ការបកប្រែរបៀបផ្សេងទៀត:«នៅកាច់ជ្រុង ជាកន្លែងដែលស្ត្រីចម្លែកកំពុងតែឈរ»
កន្លែងប្រសព្វគ្នា
នេះសំដៅទៅលើផ្លូវពីប្រសព្វគ្នា។
ថ្ងៃកំពុងលិច
ជាពេលដែលមេឃចាប់ផ្តើមងងឹតទៅៗ ឈានចូលពេលរាត្រី។
Proverbs 7:10
ដើម្បីទាក់ទាញចិត្តគេ
ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យចេតនា ឬ រៀបផែនការ។
ការបកប្រែរបៀបផ្សេងទៀត: «នាងរៀបគម្រោងដើម្បីបញ្ឆោតនរណាម្នាក់»
នាងពុះកញ្ជ្រោល ស្រើបស្រាល
«នាងនិយាយឮៗ ហើយធ្វើអ្វីដែលនាងចង់ធ្វើ»
ទ្រាំនៅក្នុងផ្ទះមិនបានទេ
ឃ្លាថា «ជើងរបស់នាង» តំណាងឲ្យស្ត្រី។ ការបកប្រែរបៀបផ្សេងទៀត:
«នាងមិនចេះនៅផ្ទះ»
នាងរង់ចាំឆ្មក់
នៅទីនេះស្ត្រីត្រូវបានគេចាត់ទុកថា ដូចជានាងរៀបចំអន្ទាក់ដាក់មនុស្ស និង សត្វ។
គំនិតនៃការដាក់អន្ទាក់ឆ្មក់នរណាម្នាក់ទីនេះតំណាងឲ្យការលួងលោមនរណាម្នាក់ឲ្យប្រព្រឹត្តបាប។
ការបកប្រែរបៀបផ្សេងទៀត: «នាងរង់ចាំដាក់អន្ទាក់នរណាម្នាក់» ឬ
«នាងរង់ចាំមើលក្រែងមាននរណាម្នាក់ដែលនាងអាចលួងលោមឲ្យធ្វើអំពើបាប»
Proverbs 7:13
នាង
«នាង» សំដៅទៅលើស្ត្រីដែលត្រូវបានណែនាំនៅក្នុងជំពូក ៧:១០។
ចាប់អ្នកកំលោះមកឱបរឹត
«ចាប់អោបគាត់យ៉ាងជាប់»
មុខខឹង
ពាក្យថា «ខ្លាំង» តំណាងអោយ «រឹងចចេស»។ «មុខមាំ»
មានន័យថាការបង្ហាញទឹកមុខរឹងចចេសរបស់នរណាម្នាក់។
នេះបញ្ជាក់ថាស្ត្រីកំពុងធ្វើអ្វីដោយរឹងចចេស
ដែលនាងមានចេតនាធ្វើវាទាំងដឹងអ្វីដែលនាងធ្វើខុស។
ការបកប្រែរបៀបផ្សេងទៀត: ធ្វើដោយទឹកមុខមិនខ្មាសអៀន»
ដើម្បីលាបំណន់
ពាក្យថា «សម្បថ»
នៅទីនេះតំណាងនូវអ្វីដែលមនុស្សម្នាក់សន្យាថានឹងថ្វាយដល់ព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងថ្វាយចំពោះអ្វីដែលខ្ញុំបានសន្យាចំពោះព្រះជាម្ចាស់»
ចង់ស្គាល់បង
ពាក្យ «មុខ» ទីនេះតំណាងឲ្យមនុស្សជាពិសេសវត្តមានរបស់នណាម្នាក់។
ការបកប្រែរបៀបផ្សេងទៀត: «ចង់ស្គាល់អ្នក» ឬ «រកចង់ដឹងថាអ្នកនៅទីណា»
Proverbs 7:16
បោះអ្វីដាក់លើគ្រែ
«អ្វីៗនៅរាយប៉ាយលើគ្រែ»
គ្រឿងក្រអូប
ជាប្រភេទឈើម៉្យាងចេញពីដើមដែលមានក្លិនក្រអូប។
ឈើអែម
នេះគឺជាគ្រឿងទេសម្យ៉ាងដែលធ្វើពីសំបកឈើដែលមានក្លិនឈ្ងុយ និង
រសជាតិឆ្ងាញ់។
ផឹកស្រាមួមស្នេហ៍
នៅទីនេះភាពរីករាយនៃស្នេហារ៉ូមែនទិក ត្រូវបានគេចាត់ទុកថាដូចជា
អ្វីមួយល្អសម្រាប់ផឹក។ ការបកប្រែរបៀបផ្សេងទៀត:
«សូមឲ្យយើងបង្កើតសេចក្តីស្នេហាចំពោះគ្នាតាមក្តីប្រាថ្នា»
Proverbs 7:19
មិននៅផ្ទះទេ
«មិននៅផ្ទះ»
ថ្ងៃពេញបូណ៌ា
ព្រះច័ន្ទដែលគេហៅថាពេញបូណ៌ា នៅពេលដែលវាមានរាងមូលដូចថាស ជះពន្លឺ
ហើយចាំង។
នាងនិយាយបញ្ចុះបញ្ចូល
បញ្ចុះបញ្ចូលនរណាម្នាក់ដើម្បីឲ្យធ្វើអ្វីមួយ ត្រូវបានគេចាត់ទុកថាដូចជា
ប្តូរទិសដៅដែលមនុស្សម្នាក់កំពុងតែដើរ។ ការបកប្រែរបៀបផ្សេងទៀត:
«នាងបញ្ចុះបញ្ចូលគាត់»
របស់នាង...នាង...គាត់
ស្ត្រី គឺជាស្ត្រីដែលរៀបការហើយ ដែលចង់ដេកជាមួយ «គាត់» បុរសក្មេង។
ពាក្យសម្តីផ្អែមល្ហែម
ពាក្យថា «បបូរមាត់» នៅទីនេះតំណាងឲ្យអ្វីដែលមនុស្សនិយាយ។
នៅពេលដែលនរណាម្នាក់ព្យាយាមរុញច្រានអួសទាញនរណាម្នាក់ដោយនិយាយអ្វីដែលមិនស្មោះត្រង់
ពាក្យទាំងនេះត្រូវបានគេចាត់ទុកថាជា ផ្អែមរលួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ការសសើរ ពាក្យបញ្ឆោត»
អូសទាញអ្នកកំលោះ
«នាងបញ្ចុះបញ្ចូលគាត់ឲ្យធ្វើការអាក្រក់» ការបកប្រែរបៀបផ្សេងទៀត:
«នាងលួងលោមគាត់ឲ្យធ្វើបាបជាមួយនាង»
Proverbs 7:22
អ្នកកំលោះក៏ទៅតាមនាងភ្លាម
នេះហាក់ដូចជាបញ្ជាក់ថា
បុរសក្មេងមានពេលតិចតួចដើម្បីគិតពីអ្វីដែលគាត់គួរធ្វើ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «គាត់សម្រេចចិត្តភ្លាមៗទៅតាមនាង»
ដូចគោដែលគេនាំទៅ...ទៅរកអន្ទាក់
របៀបឆោតល្ងង់ និង មិនដឹងខ្លួនរបស់បុរសក្មេងដែលធ្វើតាមស្ត្រីផិតក្បត់
ដែលប្រៀបធៀបទៅនឹងសត្វទាំងបីដែលមិនដឹងពីគ្រោះថ្នាក់ដែលគេកំពុងតែស្ថិតនៅ។
សត្តឃាត
នេះសំដៅទៅលើការសម្លាប់សត្វដើម្បីយកសាច់បរិភោគ។
សត្វក្តាន់
បកប្រែសត្វនេះនៅក្នុងជំពូក ៥:១៨។
លុះត្រាតែមានព្រួញមកទម្លុះដល់ថ្លើម
នេះបញ្ជាក់ថាព្រានបានដាក់អន្ទាក់ក្តាន់ដើម្បីបាញ់ដោយព្រួញ។
ការបកប្រែរបៀបផ្សេងទៀត: «រហូតទាល់តែព្រានបាញ់ត្រូវចំនុចសំខាន់»
ថ្លើម
សរីរាង្គនេះតំណាងឲ្យចំនុចសំខាន់បំផុតនៃរាងកាយរបស់សត្វក្តាន់។
ខ្លួនមានគ្រោះថ្នាក់ដល់ជីវិត
នេះគឺជារបៀបនៃការនិយាយពីមនុស្សដែលលទ្ធផលចុងក្រោយគេត្រូវស្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «វានឹងសម្លាប់គាត់» ឬ
«គាត់នឹងស្លាប់ឆាប់ៗ» (សូមមើល:figs-idiom)
Proverbs 7:24
ឥឡូវនេះ
នេះគឺជាការផ្តោតលើការយកចិត្តទុកដាក់នៃកូនរបស់អ្នកនិយាយក្នុងការបញ្ចប់មេរៀននេះ។
កុំបាក់ចិត្តទៅតាមស្ត្រីប្រភេទនេះឡើយ
ពាក្យថា «ផ្លូវ» នៅទីនេះមានន័យថាផ្លូវដែលមនុស្សម្នាក់ជ្រើសរើសដើរ។
វាតំណាងឲ្យឥរិយាបថរបស់មនុស្ស អ្វីដែលគាត់សម្រេចចិត្តធ្វើនៅក្នុងជីវិត។
ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យចិត្តរបស់អ្នកនៅឲ្យឆ្ងាយពីស្ត្រីផិតក្បត់» ឬ
«កុំឲ្យចិត្តរបស់អ្នកចង់ធ្វើអ្វីដែលស្ត្រីផិតក្បត់ធ្វើ»
ចិត្តរបស់អ្នក
ពាក្យថា «ចិត្ត» នៅទីនេះតំណាងឲ្យអ្វីដែលជាចំណង់ចិត្តរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «អ្នក»
កុំវង្វេងទៅសេពគប់ជាមួយផ្លូវរបស់នាងដែរ
នេះមានន័យដូចប្រយោគពីមុនដែរ។ វាពង្រឹងការព្រមានដំបូង។
ការបកប្រែរបៀបផ្សេងទៀត:
«កុំបោះបង់ផ្លូវត្រឹមត្រូវដើម្បីទៅតាមផ្លូវរបស់នាងឡើយ»
Proverbs 7:26
ស្ត្រីនេះបានធ្វើឲ្យមនុស្សវិនាសជាច្រើនហើយ
ការដែលត្រូវគេចាក់ទម្លុះដោយលំពែង ឬ ព្រួញតំណាងឲ្យការដែលត្រូវគេសម្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «នាងបានធ្វើឲ្យមនុស្សជាច្រើនធ្លាក់ក្នុងសេចក្តីស្តាប់»
ផ្ទះរបស់នាងជាស្ថានមច្ចុរាជ...គេបានចូលទៅក្នុង
ពាក្យថា «ផ្លូវ» នៅទីនេះតំណាងឲ្យប្រភេទនៃឥរិយាបថដែលមនុស្សលីលាចូលរួម។
ស្ថានមច្ចុរាជជាឈ្មោះនៃពិភពសេចក្តីស្លាប់។
ផ្លូវទៅស្ថានមច្ចុរាជ ...ចូលទៅក្នុងបន្ទប់ដែលងងឹត នៃសេចក្តីស្លាប់
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា
ដើម្បីលើកមកម្តងទៀតដើម្បីបញ្ជាក់ថាជនរងគ្រោះរបស់ស្ត្រីនោះនឹងត្រូវវិនាស។
បន្ទប់ដែលងងឹត នៃសេចក្តីស្លាប់
នេះបញ្ជាក់ពីរូបភាពសាកសពដេកនៅក្នុងបន្ទប់ខុសៗគ្នានៅក្នុងស្ថានមច្ចុរាជ។

---

8 [1]តើប្រាជ្ញានេះចេញមកពីណា? តើមិនមែនចំណេះដឹងដែលបានចេញមកតាមសម្លេងនាងទេ?[2]នៅលើទីខ្ពស់ ក្បែរមាត់ផ្លូវ និងនៅត្រង់ផ្លូវបំបែក
គឺនាងឈរពេញដោយប្រាជ្ញា។[3]ក្បែរមាត់ទ្វារក្រុង នៅតាមផ្លូវចេញចូល ហើយនាងស្រែកឡើងថា។
[4]«មនុស្សរាល់គ្នាអើយ ពាក្យទាំងនេះគឺសម្រាប់អ្នក ហើយសម្លេងរបស់យើងគឺសម្រាប់កូនមនុស្សទាំងអស់។[5]មនុស្សមិនដឹងខុសត្រូវអើយ ចូររៀនពីប្រាជ្ញា មនុស្សឥតប្រាជ្ញាអើយ អ្នកត្រូវខំឲ្យបានចំណេះដឹងដល់គំនិតផង។
[6]សូមស្តាប់ ពីព្រោះយើងនឹងនិយាយសេចក្តីសំខាន់ៗប្រាប់អ្នករាល់គ្នា ពេលមាត់យើងបើកគឺថ្លែងពីផ្លូវទៀងត្រង់។[7]ដ្បិត យើងថ្លែងប្រាប់តែសេចក្តីពិតប៉ុណ្ណោះ យើងមិនចូលចិត្តនិយាយសេចក្តីអាក្រក់ឡើយ។
[8]ពាក្យទាំងអស់ដែលចេញពីមាត់យើងសុទ្ធតែទៀងត្រង់ គឺគ្មានពាក្យវៀចវេរ ឬបោកបញ្ឆោតទេ។[9]ពាក្យទាំងនោះគឺសំដៅទៅរក អ្នកដែលនឹងយល់ដឹង
ហើយពាក្យរបស់យើងនឹងធ្វើឲ្យមានសេចក្តីត្រឹមត្រូវដល់អ្នកដែលមានប្រាជ្ញាដែរ។
[10]ចូរទទួលដំបូន្មានខ្ញុំជាជាងទទួលប្រាក់ រីឯការចេះដឹងមានតម្លៃលើសមាសទឹកដប់ទៅទៀត។[11]ដ្បិត ប្រាជ្ញាមានតម្លៃជាងត្បូងពេជ្រ គ្មានរបស់អ្វីមានតម្លៃស្មើនឹងប្រាជ្ញាឡើយ។
[12]យើង គឺជាប្រាជ្ញា រស់នៅជាមួយនិងការពិចារណា ហើយយើងមានតម្រិះរិះគិត ដោយសុភនិច្ឆ័យ។[13]អ្នកគោរពកោតខ្លាចព្រះអម្ចាស់ តែងតែស្អប់អំពើអាក្រក់។ យើងមិនចូលចិត្ត ការអួតអាងនិងការព្រហើន របៀបអាក្រក់ និងការពោលពាក្យបោកបញ្ឆោតឡើយ។ យើងមិនចូលចិត្តទេ។
[14]យើងមានយោបល់ល្អ ហើយសម្លេងនៃប្រាជ្ញាដែរ យើងជាតួនៃប្រាជ្ញា ហើយយើងជាកម្លាំងដែរ។[15]ស្តេចនានាគ្រប់គ្រងទឹកដីបាន ដោយសារយើង អ្នកដឹកនាំទាំងឡាយតែងច្បាប់ដ៏ត្រឹមត្រូវ។[16]អ្នកធំទាំងឡាយត្រួតត្រាទឹកដី ដោយសារយើងហើយអ្នកទាំងនោះធ្វើការដ៏សុចរិត។
[17]យើងស្រឡាញ់អ្នកណាដែលស្រឡាញ់យើង ហើយអ្នកណាដែលស្វែងរកយើង អ្នកនោះនឹងរកឃើញ។[18]យើងផ្តល់ទ្រព្យសម្បត្តិ និងសិរីរុងរឿង ភាពចម្រុងចម្រើន និងសេចក្តីសុចរិតផងដែរ។
[19]ផលផ្លែរបស់យើងមានតម្លៃជាងមាសទឹកដប់ អ្វីៗដែលខ្ញុំផ្តល់ឲ្យមានតម្លៃជាងប្រាក់សុទ្ធទៅទៀត។[20]យើងនឹងដើរតាមមាគ៌ាដ៏សុចរិត និងប្រព្រឹត្តតាមផ្លូវយុត្តិធម៌។[21]យើងផ្តល់ទ្រព្យសម្បត្តិយ៉ាងបរិបូណ៌ ឲ្យដល់អ្នកដែលស្រឡាញ់យើង ក៏បំពេញមិនឲ្យចេះខ្វះអ្វីឡើយ។
[22]ព្រះអម្ចាស់បានបង្កើតយើងតាំងពីដើមដំបូងបង្អស់ គឺមុនអ្វីៗដែលព្រះអង្គបង្កើតមកទៅទៀត។[23]ព្រះអង្គបានចាក់ប្រេងតែងតាំងយើង តាំងពីអស់កល្បរៀងមក គឺនៅគ្រាដំបូងបង្អស់ មុនកំណើតពិភពលោកទៅទៀត។
[24]កាលយើងកើតមក មិនទាន់មានសមុទ្រ ហើយក៏មិនទាន់មានប្រភពទឹកផងដែរ។[25]ព្រះអង្គបង្កើតខ្ញុំមក មុនព្រះអង្គបង្កើតឲ្យមានភ្នំធំភ្នំតូចនិងជ្រលោងផ្សេងៗផងដែរ។
[26]ពេលយើងកើតមក គឺមុនពេលដែលព្រះអម្ចាស់បានបង្កើតផែនដីឬទីវាល ឬទោះបីធូលីដីដំបូងគេនៅផែនដីទៅទៀត។[27]កាលព្រះអម្ចាស់លាតសន្ធឹងផ្ទៃមេឃ និងគូរវាសជើងមេឃពីលើមហាសមុទ្រ យើងក៏បាននៅទីនោះដែរ។
[28]កាលព្រះជាម្ចាស់បង្កើតពពកនៅលើទីខ្ពស់អាកាស ហើយកាលប្រភពទឹកផុសទាំងឡាយត្រូវបានបង្កើតរួច យើងក៏នៅទីនោះដែរ។[29]កាលព្រះអង្គកំណត់ព្រំដែនសមុទ្រ
ដើម្បីខណ្ឌទឹកកុំឲ្យហៀរចេញ កាលព្រះអង្គចាក់គ្រឹះផែនដីផងដែរនោះ យើងក៏បាននៅទីនោះជាមួយព្រះអង្គដែរ។
[30]នៅពេលនោះ យើងបានជាមេជាងជួយធ្វើការព្រះអង្គ ហើយយើងគឺជាអំណរព្រះអង្គ ពីមួយថ្ងៃទៅមួយថ្ងៃទៀត។ នៅចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ
យើងតែងតែមានអំណរ។[31]យើងមានអំណរនៅលើផែនដីដែលព្រះអង្គបានបង្កើត យើងមានអំណរកើតក្នុងចំណោមមនុស្សលោក។
[32]ឥឡូវនេះ កូនអើយ ចូរនាំគ្នាស្តាប់យើង អ្នកណាប្រតិបត្តិតាមមាគ៌ារបស់ឪពុក អ្នកនោះពិតជាមានសុភមង្គល។[33]ចូរស្តាប់ដំបូន្មានរបស់យើង ដោយឥតធ្វេសប្រហែសឡើយ នោះកូននឹងទៅជាអ្នកមានប្រាជ្ញា។[34]អ្នកណាស្តាប់យើង ហើយឈរយាមមាត់ទ្វារខ្ញុំជារៀងរាល់ថ្ងៃ អ្នកនោះពិតជាមានពរហើយ។
[35]អ្នកណារកយើងឃើញ អ្នកនោះមានជីវិត ហើយព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងអ្នកនោះ។[36]អ្នកណារកយើងមិនឃើញ អ្នកនោះធ្វើបាបខ្លួនឯង អ្នកណាស្អប់យើង អ្នកនោះស្រឡាញ់សេចក្តីស្លាប់»។

Proverbs 8:1
ព័ត៌មានទូទៅ:
នៅក្នុងជំពូកទី៨ ប្រាជ្ញាត្រូវបានគេចាត់ទុកថា
ដូចជាស្ត្រីដែលបង្រៀនមនុស្សឲ្យមានភាពឆ្លាតវៃ។
ព័ត៌មានទូទៅ:
ខជាច្រើននៅក្នុងជំពូក ៨ មានភាពដូចគ្នា។ (សូមមើល:figs-parallelism)

generated on Wed Sep 10 16:16:32 2025

តើប្រាជ្ញានេះចេញមកពីណា?
សំណួរនេះគឺប្រើដើម្បីរំលឹកអ្នកអានពីអ្វីដែលពួកគេគួរតែដឹងរួចមកហើយ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញាស្រែកហៅ»
តើប្រាជ្ញានេះចេញមកពីណា?
ពាក្យប្រាជ្ញានៅទីនេះមានរូបភាពជាស្ត្រី។
បើសិនភាសាមួយមិនឲ្យប្រើពាក្យប្រៀបធៀបបែបនេះ
ការបកប្រែដែលអាចមានផ្សេងទៀតគឺ ១)
«តើប្រាជ្ញាមិនដូចជាស្ត្រីដែលស្រែកហៅនោះទេ?»
តើមិនមែនចំណេះដឹងដែលបានចេញមកតាមសម្លេងនាងទេ?
ពាក្យថា «ចំណេះដឹង» នៅទីនេះមានន័យដូចគ្នានឹង «ប្រាជ្ញា»
មាត់ទ្វារក្រុង
នៅសម័យបុរាណជាធម្មតានៅទីក្រុងមានជញ្ជាំងខាងក្រៅដែលមានច្រកទ្វាចូល។
នាងស្រែកឡើង
នេះបន្តសំដៅទៅលើប្រាជ្ញាបុគ្គលិកលក្ខណៈជាស្ត្រី។
Proverbs 8:4
ព័ត៌មានទូទៅ:
ប្រាជ្ញាបាននិយាយពីមនុស្សនៅក្នុង ខ ៤-៣៦។
សម្លេងរបស់យើងគឺសម្រាប់កូនមនុស្សទាំងអស់
ពាក្យថា «សម្លេង» នៅទីនេះតំណាងឲ្យពាក្យដែលគេនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ពាក្យរបស់យើងគឺសម្រាប់កូនមនុស្សទាំងអស់»
កូនមនុស្ស
នេះជាឃ្លាតំណាងឲ្យមនុស្សទាំងអស់។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សលោកទាំងអស់»
ល្ងង់ខ្លៅ
«គ្មានបទពិសោធន៍ ក្មេងខ្ចី»
រៀនពីប្រាជ្ញា
ពាក្យអរូបី «ប្រាជ្ញា» សំដៅទៅលើអ្វីដែលមនុស្សឆ្លាតជឿជាក់លើអ្វីដែលគាត់ធ្វើ។
ការបកប្រែរបៀបផ្សេងទៀត: «រៀនពីរបៀបដែលមនុស្សឆ្លាតធ្វើ» ឬ
«រៀនពីអត្ថន័យដែលក្លាយជាមនុស្សឆ្លាត»
អ្នកត្រូវខំឲ្យបានចំណេះដឹងដល់គំនិត
ដើម្បីឲ្យបានយល់ ត្រូវបានគេចាត់ទុកដូចជា មានគំនិតដែលអាចយល់។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកត្រូវចាប់ផ្តើមយល់កិច្ចការផ្សេងៗដោយគំនិតរបស់អ្នក»
Proverbs 8:6
ពេលមាត់យើងបើក
ពាក្យថា «មាត់» នៅទីនេះតំណាងឲ្យមាត់របស់មនុស្ស ដែលគាត់និយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ពេលយើងបើកមាត់យើងនិយាយ»
ផ្លូវទៀងត្រង់
«ត្រឹមត្រូវ» ឬ «ត្រឹមត្រូវ»
យើងថ្លែងប្រាប់
ពាក្យថា «មាត់» នៅទីនេះតំណាងឲ្យមនុស្សដែលនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំ ុនិយាយ»
សេចក្តីពិត
«អ្វីដែលមនុស្សគួរជឿ»
យើងមិនចូលចិត្តនិយាយសេចក្តីអាក្រក់ឡើយ
ពាក្យថា «មាត់» តំណាងឲ្យមនុស្សដែលកំពុងនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: យើងមិនចូលចិត្តនិយាយសេចក្តីអាក្រក់ឡើយ» ឬ
«ការនិយាយសេចក្តីអាក្រក់គឺធ្វើឲ្យយើងស្អប់»
សេចក្តីអាក្រក់
នាមអរូបីនេះ «សេចក្តីអាក្រក់» តំណាងឲ្យសម្តីអាក្រក់។
Proverbs 8:8
ពាក្យទាំងអស់ដែលចេញពីមាត់យើង
ពាក្យថា «ពាក្យ» នៅទីនេះតំណាងឲ្យសារ ឬ សេចក្តីបង្រៀន។ ពាក្យថា «មាត់»
ក៏សំដៅលើមនុស្សដែលកំពុងនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលខ្ញុំបង្រៀន»
ពាក្យរៀចវេ
«មិនត្រឹមត្រូវ»
ត្រង់
«ស្មោះត្រង់ ហើយច្បាស់លាស់»
ពាក្យរបស់យើងនឹងធ្វើឲ្យមានសេចក្តីត្រឹមត្រូវដល់អ្នកដែលមានប្រាជ្ញាដែរ
នេះអាចមានន័យថាអស់អ្នកដែលមានចំណេះដឹងនឹងងាយយល់ថាសម្តីរបស់អ្នកនិយាយគឺត្រឹមត្រូវ។
ពាក្យថា «ពាក្យ» នៅទីនេះតំណាងឲ្យសារ ឬ សេចក្តីបង្រៀន។
ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលដឹងនូវអ្វីដែលត្រឹមត្រូវ និង
អ្វីដែលខុស ត្រូវពិចារណាពីអ្វីដែលខ្ញុំបង្រៀនគឺត្រឹមត្រូវ»
សេចក្តីត្រឹមត្រូវ
«ស្មោះត្រង់»
Proverbs 8:10
ចូរទទួលដំបូន្មានខ្ញុំជាជាងទទួលប្រាក់
«អ្នកត្រូវតែព្យាយាមជាងនេះដើម្បីឲ្យបានយល់ពីដំបូន្មានខ្ញុំជាជាងទទួលបានប្រាក់»
ដ្បិត ប្រាជ្ញាមានតម្លៃជាងត្បូងពេជ្រ គ្មានរបស់អ្វីមានតម្លៃស្មើនឹងប្រាជ្ញាឡើយ
ប្រាជ្ញានៅទីនេះមានលក្ខណៈដូចជាស្ត្រីដែលមិនមែនកំពុងនិយាយ។
យ៉ាងណាក៏ដោយ
វានៅតែអាចក្នុងការដែលឲ្យស្ត្រីក្លាយទៅជាអ្នកនិយាយបានដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ត្បិតប្រាជ្ញា ប្រសើរជាងគ្រឿងអលង្ការ
ដែលគ្មានតម្លៃស្មើនឹងខ្ញុំទេ»
Proverbs 8:12
យើង គឺជាប្រាជ្ញា រស់នៅជាមួយនិងការពិចារណា
ការពិចារណានៅទីនេះក៏តំណាងឲ្យមនុស្សដែរ។
ការពិចារណា
«ការចេះប្រយ័ត្ន» ឬ «ការវិនិច្ឆ័យល្អ»
យើងមានតម្រិះរិះគិត ដោយសុភនិច្ឆ័យ
គំនិតអរូបីនេះ «តម្រិះរិះគិត» និង «ដោយសុភនិច្ឆ័យ»
អាចបញ្ជាក់ក្នុងរបៀបផ្សេងទៀត។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំជាចំណេះដឹង
និង សុភនិច្ឆ័យ» ឬ «ខ្ញុំដឹងគ្រប់ការទាំងអស់ ហើយខ្ញុំចេះប្រុងប្រយ័ត្ន»
សុភនិច្ឆ័យ
មានការប្រុងប្រយ័ត្នអំពីអ្វីដែលត្រូវនិយាយ និង ធ្វើ។
ចេះប្រយ័ត្នប្រយែងមិនធ្វើឲ្យនរណាឈឺចាប់ ឬ មានគ្រោះថ្នាក់។
ពាក្យបោកបញ្ឆោត
«និយាយអាក្រក់»
ធ្វើឲ្យខូច
បង្វែរពីអ្វីដែលត្រឹមត្រូវ
Proverbs 8:14
យោបល់ល្អ
«សំណើរដែលឆ្លាតវៃ»
ដំបូន្មាន
យោបល់ដែលជួយមនុស្ស
សម្លេង
ល្អ សេចក្តីពិត
យើងជាតួនៃប្រាជ្ញា
ប្រាជ្ញានៅទីនេះត្រូវបានគេចាត់ទុកថាការយល់ដឹងទូលំទូលាយ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំជាតួនៃប្រាជ្ញា»
អ្នកធំ
អភិជន អ្នកនាំមុខនៃគ្រួសារដ៏សំខាន់នៅក្នុងប្រទេស។
Proverbs 8:17
ស្រឡាញ់
នេះសំដៅទៅលើសេចក្តីស្រឡាញ់ជាបងប្អូន ឬសេចក្តីស្រឡាញ់ចំពោះមិត្តភក្តិ
ឬសមាជិកគ្រួសារ។ នេះគឺជាស្នេហាធម្មជាតិរបស់មនុស្សរវាងមិត្តភក្តិ
ឬសាច់ញាតិ។
ឧស្សាហ៍ព្យាយាម
ដោយការខិតខំព្យាយាម និង យកចិត្តទុកដាក់
យើងផ្តល់ទ្រព្យសម្បត្តិ និងសិរីរុងរឿង
«ខ្ញុំមានទ្រព្យ និង កិត្តិយស»
ភាពចម្រុងចម្រើន និងសេចក្តីសុចរិតផងដែរ
នេះពន្យល់ពីអ្វីដែលមានន័យ «មាន និង កិត្តិយស»។
នេះអាចបញ្ជាក់ច្បាស់ជាមួយខ្លឹមសារភ្ជាប់ «ដូច្នេះ» ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះយើងនឹងផ្តល់ទ្រព្យសម្បត្តិនៅអស់កល្ប និង
សេចក្តីសុចរិតដល់អស់អ្នកដែលស្វែងរកយើង» (សូមមើល:writing-connectingwords)

generated on Wed Sep 10 16:16:32 2025

សេចក្ដីសុចរិត
«លទ្ធភាពរស់នៅក្នុងរបៀបត្រឹមត្រូវ»
Proverbs 8:19
ផលផ្លែរបស់យើង
អ្វីដែលប្រាជ្ញាបង្កើតផលផ្លែ ឬ ធ្វើឲ្យកើតមាន
ដែលខ្ញុំផ្តល់ឲ្យ
ផលប្រយោជន៍ ឬ អ្វីដែលប្រាជ្ញាធ្វើឲ្យកើតមាន
យើងនឹងដើរតាមមាគ៌ាដ៏សុចរិត
ការរស់នៅក្នុងផ្លូវដែលត្រឹមត្រូវ ត្រូវបានគេចាត់ទុកដូចជាដើរលើផ្លូវត្រឹមត្រូវ។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំរស់នៅត្រឹមត្រូវ» ឬ «ខ្ញុំធ្វើអ្វីដែលត្រឹមត្រូវ»
ប្រព្រឹត្តតាមផ្លូវយុត្តិធម៌
នេះប្រាប់បន្ថែមពីអ្វីដែលមានន័យ «ផ្លូវសុចរិត» ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំធ្វើអ្វីដែលជាយុត្តិធម៌» ឬ «ខ្ញុំធ្វើតែអ្វីដែលយុត្តិធម៌»
បំពេញមិនឲ្យចេះខ្វះ
ឃ្លាំងស្តុកទ្រព្យមានតម្លៃនៅក្នុងផ្ទះ។
ប្រាជ្ញាត្រូវបានគេចាត់ទុកថាដូចជាស្ត្រីដែលបំពេញឃ្លាំងនៅក្នុងផ្ទះរបស់អ្នកដែលដើរតាមគាត់ទុកឲ្យមានតម្លៃ។ ប្រាជ្ញាពេលនេះកំពុងនិយាយថា
Proverbs 8:22
មុនអ្វីៗដែលព្រះអង្គបង្កើតមក
«ខ្ញុំត្រូវបានបង្កើតមុនអ្វីៗដែលព្រះអង្គបង្កើតទៅទៀត»
នៅគ្រាដំបូងបង្អស់
«តាំងពីយូរលង់ណាស់មកហើយ»
អាយុកាល
ពាក្យថា «អាយុកាល» សំដៅទៅលើរយៈពេលទូទៅ ដែលមានរយៈពេលយូរ។
ខ្ញុំត្រូវបានបង្កើត
នេះអាចដាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានបង្កើតខ្ញុំមក»
មុនកំណើតពិភពលោក
គំនិតនៃការចាប់ផ្តើមអាចបកប្រែជារបៀបអរូបី។ ការបកប្រែរបៀបផ្សេងទៀត: «តាំងពីមុនពេលដែលព្រះជាម្ចាស់បង្កើតផែនដី»
Proverbs 8:24
ព័ត៌មានទូទៅ:
ប្រាជ្ញានៅតែបន្តនិយាយ។
មុនព្រះអង្គបង្កើតឲ្យមានភ្នំធំភ្នំតូច
«ពីមុនពេលដែលភ្នំនានាត្រូវបានបង្កើតឡើង» នេះអាចដាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «មុនពេលដែលព្រះជាម្ចាស់បង្កើតភ្នំនានា ហើយដាក់វាតាមកន្លែងសមគួរ»
Proverbs 8:26
ពេលយើងកើតមក...យើងក៏បាននៅទីនោះដែរ
នេះគឺប្រាជ្ញានិយាយអំពីខ្លួនឯង។ (សូមមើល:figs-personification)
កើតមក
«ខ្ញុំមានជីវិតរស់»
បង្កើត
បង្កើតអ្វីដែលអាចនៅស្ថិតស្ថេរ។ ការបកប្រែរបៀបផ្សេងទៀត: «បង្កើត» ឬ «បង្កើត»
គូរវាសជើងមេឃពីលើមហាសមុទ្រ
នេះសំដៅទៅលើការកំណត់ព្រំដែនពីចម្ងាយ ដែលនរណាម្នាក់នៅក្នុងកាប៉ាល់នៅឯសមុទ្រអាចមើលឃើញពីអ្វីដែលនៅជុំវិញខ្លួនគាត់។ ការបកប្រែរបៀបផ្សេងទៀត: «នៅពេលព្រះអង្គកំណត់សម្គាល់នៅលើផ្ទៃមហាសមុទ្រពីចម្ងាយដែលមនុស្សម្នាក់នៅលើនាវាអាចមើលឃើញ»
មហាសមុទ្រ
«មហាសមុទ្រ»
Proverbs 8:28
ព័ត៌មានទូទៅ:
ប្រាជ្ញាបន្តនិយាយ។
បង្កើត
នាំមកនូវស្ថេរភាព
ប្រភពទឹកផុសទាំងឡាយត្រូវបានបង្កើតរួច
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលព្រះជាម្ចាស់បានកំណត់ប្រភពនៅក្នុងជម្រៅទឹក»
ប្រភពទឹកផុសទាំងឡាយ
ជនជាតិហេប្រឺកាលពីសម័យបុរាណគិតថាមហាសមុទ្រមានប្រភពទឹកនៅបាតសមុទ្រ។
កាលព្រះអង្គកំណត់ព្រំដែនសមុទ្រ
«កាលព្រះជាម្ចាស់បង្កើតឆ្នេរសមុទ្រនៃមហាសមុទ្រ។ «ដែនកំណត់នៃសមុទ្រ» គឺបែងចែកមហាសមុទ្រចេញពីដីស្ងួត។
កាលព្រះអង្គចាក់គ្រឹះផែនដីផងដែរនោះ យើងក៏បាននៅទីនោះជាមួយព្រះអង្គដែរ
ពាក្យថាហេប្រឺ «ផែនដី» មានន័យថា «ដី»។
កាលព្រះអង្គចាក់គ្រឹះផែនដីផងដែរនោះ យើងក៏បាននៅទីនោះជាមួយព្រះអង្គដែរ
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «នៅពេលព្រះជាម្ចាស់កំណត់ព្រំដែនសំរាប់ការចាក់គ្រឹះផែនដី»
Proverbs 8:30
យើងនៅក្បែរព្រះអង្គ
[illegible] ប្រាជ្ញាពេលនេះកំពុងនិយាយថា
ប្រាជ្ញានៅក្បែរព្រះអម្ចាស់
ដែលបង្ហាញថាប្រាជ្ញាជាជំនួយការរបស់ព្រះអង្គក្នុងការបង្កើតពិភពលោក។
មេជាង
នេះគឺជាមនុស្សដែលឆ្លងកាត់ការហ្វឹកហាត់ច្រើនឆ្នាំក្នុងការធ្វើអ្វីដែលមានប្រយោជន៍ល្អ ដូចជាគ្រឿងសង្ហារឹម ឬ ផ្ទះ។
អំណរ
«ប្រភពនៃអំណរ» ឬ «ហេតុផលដែលនាំឲ្យមានភាពរីករាយ»
ពីមួយថ្ងៃទៅមួយថ្ងៃទៀត
នេះគឺជារបៀបដើម្បីបញ្ជាក់ពីគំនិតនៃសកម្មភាពទម្លាប់ ឬ ស្ថានភាពបន្ត។ ការបកប្រែរបៀបផ្សេងទៀត: «បន្ត» ឬ «ពេញម៉ោង»
នៅលើផែនដីដែលព្រះអង្គបានបង្កើត
«ផែនដីទាំងមូលដែលព្រះជាម្ចាស់បានបង្កើត» (UDB) ឬ «អ្វីៗដែលព្រះអង្គបានបង្កើត»
មនុស្សលោក
នេះសំដៅទៅលើមនុស្សជាលក្ខណៈទូទៅ។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលព្រះអង្គបានបង្កើតមក» (UDB)
Proverbs 8:32
ឥឡូវនេះ
នេះគឺជាការផ្តោតលើការយកចិត្តទុកដាក់របស់កូនៗក្នុងការបញ្ចប់មេរៀន។
ចូរនាំគ្នាស្តាប់យើង
នេះគឺប្រាជ្ញាកំពុងបន្តនិយាយពីខ្លួនឯង។ (សូមមើល:figs-personification)
អ្នកណាប្រតិបត្តិតាមមាគ៌ារបស់ឪពុក
ពាក្យថា «មាគ៌ារបស់ឪពុក» នៅទីនេះតំណាងឥរិយាបថរបស់ប្រាជ្ញា។ ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលធ្វើអ្វីដែលខ្ញុំបង្រៀន» ឬ «មនុស្សដែលធ្វើតាមគំរូរបស់យើង»
កុំធ្វេសប្រហែស
«កុំព្រងើយកន្តើយ» ការបកប្រែរបៀបផ្សេងទៀត: «ត្រូវតែយកចិត្តទុកដាក់» ឬ «ត្រូវតែដើរតាម»
ស្តាប់យើង ហើយឈរយាមមាត់ទ្វារខ្ញុំជារៀងរាល់ថ្ងៃ អ្នកនោះពិតជាមានពរហើយ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។ ប្រាជ្ញាពិពណ៌នាពីការដែលមានផ្ទះ [illegible] (សូមមើលន័យដែលអាចមានចំពោះពាក្យថា «មើល» ទី១) មនុស្សឆ្លាតវៃរង់ចាំនៅខាងក្រៅផ្ទះនៅពេលព្រឹកព្រលឹមដើម្បីបម្រើប្រាជ្ញា ឬ ទី២) [illegible] ដើម្បីឲ្យប្រាជ្ញាចេញមកបង្រៀនគេ។
Proverbs 8:35
រកយើងឃើញ...រកយើងឃើញ...ស្អប់យើង
នេះគឺប្រាជ្ញាបន្តនិយាយពីខ្លួនឯង។
អ្នកណារកយើងមិនឃើញ
គំនិតពេញលេញគឺ «អស់អ្នកដែលរកយើងមិនឃើញ»
ជីវិតខ្លួនឯង
ពាក្យថា «ជីវិត» នៅទីនេះតំណាងឲ្យខ្លួនឯង។

---

9 [1]ប្រាជ្ញាបានសង់ផ្ទះរបស់ខ្លួនរួចហើយគឺបានចាំងសសរទាំងប្រាំពីរស្រេចឡើងពីថ្ម។[2]ក៏បានសម្លាប់សត្វសម្រាប់ជប់លៀង ព្រមទាំងលាយស្រាទំពាំងបាយជូរ និងរៀបតុស្រេចហើយផងដែរ។

generated on Wed Sep 10 16:16:32 2025

[3]បានទាំងចាត់ពួកស្រីបម្រើក្រមុំៗឲ្យចេញទៅ ក៏ស្រែកប្រកាសនៅលើទីខ្ពស់បំផុតនៃទីក្រុង[4]«តើអ្នកណាដែលឆោតល្ងង់ខ្លះ? ចូរបែរចូលមកក្នុងទីនេះមក!» ឯចំណែកអ្នកណាដែលឥតមានយោបល់» គឺនិយាយទៅកាន់អ្នកដែលខ្វះប្រាជ្ញា។
[5]«ចូរមកបរិភោគអាហាររបស់យើង ហើយផឹកស្រាទំពាំងបាយជូរដែលយើងបានលាយហើយ។[6]ចូរលះចោលសេចក្ដីល្ងង់ខ្លៅចេញនោះនឹងបានរស់នៅ រួចដើរក្នុងផ្លូវនៃការចេះដឹងផង។
[7]អ្នកណាស្តីបន្ទោសមនុស្សវាយឫកខ្ពស់ អ្នកនោះនឹងត្រូវគេមើលងាយ អ្នកណាស្តីបន្ទោសមនុស្សពាល អ្នកនោះនឹងត្រូវការនោះវិញ។[8]កុំស្តីបន្ទោសមនុស្សវាយឫកខ្ពស់ក្រែងគេស្អប់អ្នក បើអ្នកស្តីបន្ទោសមនុស្សមានប្រាជ្ញា គេនឹងស្រឡាញ់អ្នក។[9]សេចក្ដីដែលអ្នកពោលទៅកាន់មនុស្សមានប្រាជ្ញា ធ្វើឲ្យគេកាន់តែមានប្រាជ្ញា សេចក្ដីដែលអ្នកបង្រៀនមនុស្សសុចរិត ធ្វើឲ្យគេកាន់តែចេះដឹងទៀត។
[10]ការកោតខ្លាចព្រះអម្ចាស់ជាដើមចមនៃប្រាជ្ញា ហើយការដែលស្គាល់ដល់ព្រះដ៏បរិសុទ្ធ នោះគឺជាយោបល់។[11]ដ្បិតដោយសារយើង នោះអស់ទាំងថ្ងៃរបស់កូន នឹងបានចម្រើនជាច្រើនឡើង ហើយអស់ទាំងឆ្នាំនៃអាយុកូន នឹងបានយឺនយូរទៅ។[12]បើកូនមានប្រាជ្ញា នោះគឺមានសម្រាប់តែខ្លួនកូនទេ ឬបើកូនចំអក នោះមានតែកូនម្នាក់គត់ នឹងត្រូវរងភារៈនោះ»។
[13]ចំណែកពួកស្ត្រីដែលល្ងីល្ងើ គេតែងស្រែកឡូឡា ក៏ល្ងង់ខ្លៅឥតដឹងអ្វីសោះ។[14]ពួកគេអង្គុយនៅមាត់ទ្វារផ្ទះរបស់ខ្លួនរបស់នាង ឬទីអង្គុយត្រង់ទីខ្ពស់នៃទីក្រុង។[15]ដើម្បីហៅរកអស់អ្នកដែលដើរតាមទីនោះ ជាពួកអ្នកដែលដើរតម្រង់តាមផ្លូវរបស់ខ្លួនពួកគេ។
[16]«ចូលឲ្យអ្នកណាដែលឆោតល្ងង់ បែរមកទីនេះចុះ» ប្រាជ្ញានិយាយបបួលអស់អ្នក ដែលគ្មានយោបល់ថា។[17]«ទឹកដែលលួចពីគេ នោះរមែងផ្អែម នំប៉័ងដែលលួចគេ នោះក៏ឆ្ងាញ់ណាស់ដែរ»។[18]ប៉ុន្តែ គេមិនដឹងថា ពួកមនុស្សស្លាប់មាននៅទីនោះ ឬថាភ្ញៀវរបស់ស្ត្រីនោះស្ថិតនៅក្នុង ទីជម្រៅនៃស្ថានឃុំព្រលឹងដែរនោះទេ។

Proverbs 9:1
ព័ត៌មានទូទៅ:
ខទាំងនេះចាប់ផ្តើមជាពាក្យប្រៀបធៀបដែលប្រាជ្ញាដូចជាស្ត្រីដែលផ្តល់ដំបូន្មានដល់មនុស្ស។
ប្រាជ្ញាបានសង់ផ្ទះ
អ្នកនិពន្ធនិយាយពីប្រាជ្ញាដែលដូចជាស្ត្រីដែលសង់ផ្ទះខ្លួន។
ក៏បានសម្លាប់សត្វសម្រាប់ជប់លៀង
នេះសំដៅទៅលើសត្វដែលសាច់គេបរិភោគនៅពិធីជប់លៀងដែលប្រាជ្ញានឹងរៀបចំឲ្យ។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រាជ្ញាបានសម្លាប់សត្វដើម្បីធ្វើជាអាហារសម្រាប់ជប់លៀង»
លាយស្រាទំពាំងបាយជូរ
នៅអ៊ីស្រាអែលសម័យបុរាណ ជាទូទៅគេលាយស្រាជាមួយទឹក។
ការបកប្រែរបៀបផ្សេងទៀត: «រៀបចំស្រា ដោយលាយស្រាជាមួយទឹក»
រៀបតុ
«ប្រាជ្ញារៀបចំតុ»
Proverbs 9:3
ព័ត៌មានទូទៅ:
ខទាំងនេះចាប់ផ្តើមផ្តល់សារនៃប្រាជ្ញា ដែលមានលក្ខណៈដូចជាស្ត្រី។
បានទាំងចាត់ពួកស្រីបម្រើក្រមុំៗឲ្យចេញទៅ
ពួកស្រីទាំងនេះចេញទៅអញ្ជើញមនុស្សម្នាឲ្យមកចូលរួមពិធីជប់លៀង
ដែលប្រាជ្ញាបានរៀបចំ។
ពួកស្រីបម្រើ
ស្ត្រីក្មេងៗ ឬ ក្មេងស្រីដែលបម្រើស្ត្រីដែលគួរឲ្យគោរព និង ចាស់ទុំដូចជាប្រាជ្ញា។
ស្រែកប្រកាស
«ប្រាជ្ញាប្រកាស» ឬ «កោះហៅ» ការបកប្រែរបៀបផ្សេងទៀត:
«ប្រាជ្ញាស្រែកឮៗអញ្ជើញគេមក»
ទីខ្ពស់បំផុតនៃទីក្រុង
ការស្រែកហៅអញ្ជើញពីទីខ្ពស់ដែលមនុស្សគ្រប់គ្នាអាចស្តាប់ឮបាន។
តើអ្នកណាដែលឆោតល្ងង់ខ្លះ? ចូរ...អ្នកដែលខ្វះប្រាជ្ញា
ឃ្លាទាំងពីរនេះពិពណ៌នាពីក្រុមមនុស្សដូចគ្នា
ដែលត្រូវការប្រាជ្ញាថែមទៀតនៅក្នុងជីវិតរបស់គេ។
សំណួរនៅទីនេះសំដៅទៅលើចំពោះមនុស្សប្រភេទនេះទាំងអស់។
ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលល្ងង់ខ្លៅ ចូរអស់អ្នកដែលខ្វះប្រាជ្ញា»
ល្ងង់ខ្លៅ
«គ្មានបទពិសោធន៍ ឬ ក្មេងខ្ចី»
ចូរបែរចូលមកក្នុងទីនេះ
«ចូរបែរផ្លូវ ហើយមកផ្ទះរបស់ខ្ញុំ»
Proverbs 9:5
ព័ត៌មានទូទៅ:
ខទាំងនេះបន្តផ្តល់សារនៃប្រាជ្ញា។
ចូរមក...បរិភោគ...ផឹក...លះចោល...រស់នៅ...ដើរ
បញ្ជាទាំងអស់នេះជាពហុវចន
ប្រាជ្ញាកំពុងនិយាយសំដៅទៅមនុស្សជាច្រើនក្នុងពេលតែមួយ។
ស្រាទំពាំងបាយជូរដែលយើងបានលាយហើយ
នៅអ៊ីស្រាអែលសម័យបុរាណ មនុស្សជាទូទៅលាយស្រាជាមួយទឹក។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញារៀបចំស្រាដោយលាយជាមួយទឹក»
ចូរលះចោលសេចក្ដីល្ងង់ខ្លៅចេញ
សកម្មភាពល្ងង់ខ្លៅត្រូវបានគេចាត់ទុកដូចជាកន្លែងដែលមនុស្សគួរតែដកខ្លួនចេញ។
ការបកប្រែរបៀបផ្សេងទៀត: «បញ្ឈប់ឥរិយាបថល្ងង់ខ្លៅ»
អំពើល្ងង់ខ្លៅ
«គ្មានបទពិសោធន៍ សកម្មភាពនៅក្មេងខ្ចី»
ផ្លូវនៃការចេះដឹង
ដំណើរការនៃការចេះដឹងត្រង់នេះប្រាជ្ញាត្រូវបានគេចាត់ទុកដូចជាផ្លូវដែលមនុស្សគួរតែដើរតាម។
ការបកប្រែរបៀបផ្សេងទៀត: «ឥរិយាបថនៃការរស់នៅដែលមនុស្សឆ្លាតមាន»
Proverbs 9:7
ព័ត៌មានទូទៅ:
ខទាំងនេះនៅតែផ្តល់សារនៃប្រាជ្ញា។
អ្នកណាស្តីបន្ទោស...អ្នកណាស្តីបន្ទោស
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។
មនុស្សវាយឫកខ្ពស់
អ្នកដែលតែងតែមើលងាយមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលនិយាយប្រមាថរឿងអ្នកដទៃ» (UDB) ឬ
«អ្នកដែលចូលចិត្តធ្វើឲ្យអ្នកដទៃមើលទៅអាក្រក់»
ត្រូវគេមើលងាយ
«ត្រូវគេធ្វើឲ្យអាម៉ាស់»
អ្នកណាស្តីបន្ទោស
«អ្នកដែលកែតម្រូវ»
កុំស្តីបន្ទោស
«កុំកែតម្រូវ»
សេចក្ដីដែលអ្នកពោលទៅកាន់មនុស្សមានប្រាជ្ញា ធ្វើឲ្យគេ...បង្រៀនមនុស្សសុចរិត ធ្វើឲ្យគេ
បទបញ្ជាទាំងពីរនេះតំណាងឲ្យប្រយោគលក្ខខ័ណ្ឌ។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើអ្នកឲ្យទៅមនុស្សឆ្លាត ធ្វើឲ្យគេ...ប្រសិនបើអ្នកបង្រៀនមនុស្សសុចរិត
ធ្វើឲ្យគេ»
សេចក្ដីដែលអ្នកពោលទៅកាន់មនុស្សមានប្រាជ្ញា...សេចក្ដីដែលអ្នកបង្រៀនមនុស្សសុចរិត
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។
សេចក្ដីដែលអ្នកពោលទៅកាន់មនុស្សមានប្រាជ្ញា
នេះសំដៅទៅលើការផ្តល់ដំបូន្មានដល់មនុស្សមានប្រាជ្ញា។
Proverbs 9:10
ព័ត៌មានទូទៅ:
ខទាំងនេះបានបញ្ចប់សារនៃប្រាជ្ញា។
ការកោតខ្លាចព្រះអម្ចាស់
បកប្រែឃ្លានេះនៅក្នុងជំពូក ១:៧។
ដ្បិតដោយសារយើង នោះអស់ទាំងថ្ងៃរបស់កូន នឹងបានចម្រើនជាច្រើនឡើង
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងចម្រុងចម្រើនថ្ងៃរបស់កូន» ឬ «យើងនឹងធ្វើឲ្យកូនរស់នៅមានអាយុវែង»
ដ្បិតដោយសារយើង
ប្រាជ្ញាដែលមានលក្ខណៈជាស្ត្រី បានបន្តនិយាយនៅត្រង់នេះ។

generated on Wed Sep 10 16:16:32 2025

ថ្ងៃរបស់កូន នឹងបានចម្រើនជាច្រើនឡើង ហើយអស់ទាំងឆ្នាំនៃអាយុកូន នឹងបានយឺនយូរទៅ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា
ហើយត្រូវបានយកមកប្រើដើម្បីបញ្ជាក់ពីអត្ថប្រយោជន៍ដ៏អស្ចារ្យដែលប្រាជ្ញាមាន។
ទាំងឆ្នាំនៃអាយុកូន នឹងបានយឺនយូរទៅ
ប្រាជ្ញានិយាយពីអាយុជីវិត ដូចជាវត្ថុអ្វីមួយ។ នេះអាចបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបន្ថែមអាយុដល់ឯង» ឬ
«យើងនឹងបន្ថែមថ្ងៃរបស់កូន» ឬ «យើងនឹងធ្វើឲ្យកូនមានអាយុវែង»
បើកូនមានប្រាជ្ញា...បើកូនចំអក
ប្រយោគទាំងពីរនេះហាក់ដូចជាមានន័យដូចគ្នា
ដែលមនុស្សមានប្រាជ្ញាចម្រើនប្រាជ្ញាចំពោះខ្លួនគេដោយសារប្រាជ្ញា
ហើយអ្នកដែលចំអកនឹងទទួលរងដោយសារទង្វើររបស់គេ។
កូនម្នាក់គត់ នឹងត្រូវរងភារៈនោះ
នេះនិយាយពីផលវិបាកដែលទង្វើរអាក្រក់របស់មនុស្សម្នាក់
ដូចជាបន្ទុកយ៉ាងធ្ងន់មនុស្សម្នាក់ស្ពាយនៅលើខ្នងរបស់គេ។
Proverbs 9:13
ព័ត៌មានទូទៅ:
ខទាំងនេះចាប់ផ្តើមពិពណ៌នាពីភាពល្ងង់ខ្លៅ ដែលមានលក្ខណៈដូចជាស្ត្រី។
ពួកស្ត្រីដែលល្ងីល្ងើ
វាអាចបកប្រែ «ល្ងីល្ងើ» ដូចជាការពិពណ៌នា។ ការបកប្រែរបៀបផ្សេងទៀត:
«ស្ត្រីល្ងីល្ងើ»។ ទោះជាយ៉ាងណា
ប្រសិនបើភាសាមួយអនុញ្ញាតិឲ្យប្រាជ្ញាមានលក្ខណៈដូចជានៅក្នុងជំពូកមុន
នោះវានឹងអនុញ្ញាតិឲ្យភាពល្ងង់ខ្លៅមានលក្ខណៈបញ្ជាក់ដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ស្ត្រីល្ងង់ខ្លៅ»
នាងល្ងង់ខ្លៅឥតដឹងអ្វីសោះ
ឃ្លាទាំងពីរនេះបញ្ជាក់ន័យមូលដ្ឋានដូចគ្នា
ដែលលើកមកដដែលៗដើម្បីបង្ហាញពីភាពឥតប្រយោជន៍របស់ស្ត្រីល្ងីល្ងើ។
ការបកប្រែរបៀបផ្សេងទៀត: «នាងមិនដឹងអ្វីទាំងអស់»
នាងល្ងង់ខ្លៅ
«នាងមិនដែលរៀនពីបទពិសោធន៍អ្វីទាំងអស់» ឬ «នាងនៅក្មេង ហើយល្ងង់»
ដើរតម្រង់តាមផ្លូវរបស់ខ្លួនពួកគេ
នេះហាក់ដូចជាក្រៀមភាសាចំពោះឃ្លា «គិតគូរតែពីកិច្ចការរបស់គេប៉ុណ្ណោះ» ឬ
«ខ្វល់តែពីការងារផ្ទាល់ខ្លួនរបស់គេ»
Proverbs 9:16
ល្ងង់ខ្លៅ
«គ្មានបទពិសោធន៍ ឬ ក្មេងខ្ចី»
បែរមកទីនេះ
«ចេញពីផ្លូវរបស់គេហើយបែរមកនេះ»
នាងនិយាយ
នេះគឺជាស្ត្រីល្ងង់ខ្លៅ ដែលត្រូវបានគេណែនាំនៅក្នុងជំពូក ៩:១៣។
អស់អ្នកដែលគ្មានយោបល់
«អស់អ្នកដែលគ្មានប្រាជ្ញា» ឬ «អស់អ្នកដែលមិនឆ្លាត»
ទឹកដែលលួចពីគេ នោះរមែងផ្អែម នំប៉័ងដែលលួចគេ នោះក៏ឆ្ងាញ់ណាស់ដែរ
ស្ត្រីល្ងីល្ងើនិយាយពីភាពរីករាយនៃការលួចទឹក និង នំប៉័ងស្ងាត់ៗ
ទៅកាន់បុរសដែលគេងជាមួយនាង ពួកគេនឹងមានភាពរីករាយ។
នេះអាចបញ្ជាក់យ៉ាងច្បាស់នៅក្នុងឧទាហរណ៍មួយ:
«អ្នកអាចរីករាយនឹងខ្ញុំដូចជាអ្នកចូលចិត្តទឹកដែលអ្នកបានលួច
ឬនំប៉័ងដែលជាអាថ៌កំបាំង»
ពួកមនុស្សស្លាប់មាននៅទីនោះ
«អស់ពួកបុរសដែលបានទៅរកនាងពេលនេះបានស្លាប់អស់ហើយ»
ទីជម្រៅនៃស្ថានឃុំព្រលឹង
«ស្ថានឃុំព្រលឹង» សំដៅទៅលើពិភពនៃសេចក្តីស្លាប់។ (សូមមើល: UDB)

---

10 [1]សុភាសិតរបស់ព្រះបាទសាឡូម៉ូន។ កូនដែលមានប្រាជ្ញាគឺធ្វើឲ្យឪពុកសប្បាយចិត្ត ប៉ុន្តែកូនដែលល្ងង់គឺធ្វើឲ្យម្តាយព្រួយចិត្ត។[2]ទ្រព្យដែលរកបានដោយទុច្ចរិតមិនមានតម្លៃឡើយ ប៉ុន្តែធ្វើអ្វីដែលត្រឹមត្រូវ នោះនឹងរក្សាជីវិតពីស្លាប់បាន។[3]ព្រះអម្ចាស់មិនបណ្តោយឲ្យមនុស្សសុចរិតអត់ឃ្លានឡើយ ប៉ុន្តែព្រះអង្គនឹងធ្វើឲ្យឧកចិត្តដល់មនុស្សទុច្ចរិតវិញ។
[4]មនុស្សដែលមានដៃខ្ជិលនាំឲ្យអ្នកទៅជាក្រ ប៉ុន្តែមនុស្សដែលមានដៃឧស្សាហ៍នាំឲ្យខ្លួនមានទ្រព្យ។[5]កូនដែលមានប្រាជ្ញាប្រមូលស្បៀងទុកនៅរដូវចម្រូត ប៉ុន្តែនឹងមិនមានក្តីមេត្តាដល់អ្នកដែលគិតតែដេកនៅរដូវចម្រូតនោះទេ។
[6]អំណោយទានរបស់ព្រះជាម្ចាស់គឺបើកដល់ដៃមនុស្សសុចរិត ប៉ុន្តែមនុស្សពាលតែងតែនិយាយបិទបាំងអំពើឃោរឃៅរបស់ខ្លួន។[7]មនុស្សតែងតែនឹកចាំដោយសប្បាយដល់មនុស្សសុចរិតជានិច្ច ប៉ុន្តែឈ្មោះរបស់មនុស្សទុច្ចរិត នឹងត្រូវបំភ្លេចចោលវិញ។
[8]មនុស្សមានប្រាជ្ញាតែងតែយកចិត្តទុកដាក់ស្តាប់ដំបូន្មាន ចំណែកមនុស្សនិយាយទទឹងទទែងតែងតែរត់ទៅរកភាពអន្តរាយ។[9]អ្នកដើរតាមផ្លូវទៀងត្រង់តែងតែបានសុខសាន្ត តែអ្នកដើរតាមផ្លូវវៀចវេរ នឹងត្រូវគេរកមុខឃើញ។
[10]អ្នកលាក់សេចក្តីពិតរមែងធ្វើឲ្យអ្នកដទៃអំពល់ទុក្ខ ប៉ុន្តែមនុស្សនិយាយទទឹងទទែងតែងតែរត់ទៅរកភាពអន្តរាយ។[11]ពាក្យសម្តីរបស់មនុស្សសុចរិតជាប្រភពនៃជីវិត ចំណែកមនុស្សពាលតែងតែនិយាយបិទបាំងអំពើឃោរឃៅរបស់ខ្លួន។
[12]ចិត្តស្អប់រមែងបង្កជំលោះ ប៉ុន្តែចិត្តស្រឡាញ់រមែងគ្របបាំងកំហុសទាំងអស់។[13]គេអាចសម្គាល់មនុស្សមានប្រាជ្ញា តាមរយៈពាក្យសម្តីដ៏ឆ្លាតវាងវៃ ប៉ុន្តែមនុស្សនិយាយដោយឥតគិតពិចារណា រមែងត្រូវរំពាត់។
[14]អ្នកប្រាជ្ញតែងប្រមូលចំណេះទុកជាសម្បត្តិ ប៉ុន្តែពាក្យសម្តីរបស់មនុស្សល្ងីល្ងើតែងនាំឲ្យវិនាសមួយរំពេច។[15]ទ្រព្យសម្បត្តិរបស់អ្នកមាន ប្រៀបបាននឹងក្រុងមួយដែលមានកំពែងរឹងមាំ ប៉ុន្តែភាពទុគ៌តរបស់អ្នកក្រក្សត់ រមែងនាំឲ្យគេវិនាស។
[16]កម្រៃរបស់សុចរិតគឺនឹងនាំមនុស្សឲ្យបានជីវិតតែផលរបស់មនុស្សអាក្រក់ នឹងនាំអ្នកនោះទៅធ្វើបាបវិញ។[17]អ្នកណាដែលស្តាប់តាមសេចក្តីប្រៀនប្រដៅ នោះឈ្មោះថាដើរក្នុងផ្លូវនៃជីវិតហើយ តែអ្នកណាដែលមិនព្រមទទួលសេចក្តីកែតម្រូវ នឹងនាំទៅកាន់ក្តីវិនាស។
[18]អ្នកណាដែលលាក់សេចក្តីសម្អប់ទុក គឺជាអ្នកកុហក ហើយអ្នកណាដែលនិយាយដើមគេ នោះជាមនុស្សល្ងីល្ងើ។[19]អ្នកណាដែលនិយាយច្រើន នឹងមានកំហុសច្រើន ប៉ុន្តែអ្នកណាដែលឃាត់ទប់បបូរមាត់បាន នោះជាមនុស្សប្រព្រឹត្តដោយប្រាជ្ញា។
[20]អណ្តាតរបស់មនុស្សសុចរិតប្រៀបបីដូចជាប្រាក់ដែលវិសុទ្ធ តែវាមានតម្លៃតិចណាស់ ក្នុងចិត្តរបស់មនុស្សអាក្រក់ ។[21]បបូរមាត់របស់មនុស្សសុចរិត នឹងរក្សាមនុស្សជាច្រើន តែមនុស្សល្ងីល្ងើស្លាប់បាត់ទៅ ដោយការខ្វះយោបល់វិញ។
[22]ព្រះអំណោយទាននៃព្រះអម្ចាស់ នាំឲ្យមានទ្រព្យ ហើយព្រះអង្គមិនបន្ថែមការឈឺចាប់ឡើយ។[23]មនុស្សល្ងីល្ងើប្រព្រឹត្តអាក្រក់ ដូចជាល្បែងលេងសប្បាយដល់គេ តែប្រាជ្ញានោះតែងតែរីករាយជាមួយមនុស្សដែលមានចំណេះដឹងវិញ។
[24]សេចក្តីដែលមនុស្សអាក្រក់ភ័យខ្លាច នោះនឹងកើតឡើងដល់គេជាការពិត ហើយសេចក្តីដែលមនុស្សសុចរិត ប្រាថ្នាចង់បាន នោះនឹងបានបើកឲ្យដែរ។[25]កាលណាខ្យល់គួចហួសបាត់ទៅ នោះមនុស្សអាក្រក់ឥតមានសល់ឡើយ តែមនុស្សសុចរិត មានឫសដ៏ស្ថិតស្ថេរនៅអស់កល្បវិញ។
[26]ម្ជូរធ្វើឲ្យស្រកៀរធ្មេញ ផ្សែងធ្វើឲ្យផ្សាភ្នែក រីឯកូនឈ្នួលកម្ចីលក៏ធ្វើឲ្យចៅហ្វាយមួម៉ៅដែរ។[27]សេចក្តីកោតខ្លាចដល់ព្រះអម្ចាស់ នោះចម្រើនថ្ងៃអាយុ តែអាយុរបស់មនុស្សអាក្រក់ នឹងខ្លីទៅ។
[28]ក្តីសង្ឃឹមរបស់មនុស្សសុចរិត នោះនាំឲ្យមានចិត្តរីករាយ តែសេចក្តីទុកចិត្តរបស់មនុស្សអាក្រក់ នឹងសូន្យបាត់ទៅ។[29]ផ្លូវព្រះអម្ចាស់ ជាបន្ទាយដល់មនុស្សទៀងត្រង់ តែសេចក្តីវិនាសវិញ ជារបស់អស់អ្នកណាដែលប្រព្រឹត្តអំពើអាក្រក់។[30]មនុស្សសុចរិត នឹងមិនត្រូវរង្គើឡើយ តែមនុស្សអាក្រក់ នឹងអាស្រ័យនៅផែនដីមិនបាន។
[31]មាត់របស់មនុស្សសុចរិត តែងបញ្ចេញផលផ្លែនៃប្រាជ្ញា ប៉ុន្តែអណ្តាតមិនទៀងត្រង់ នឹងត្រូវបានកាត់ចេញ។[32]បបូរមាត់របស់មនុស្សសុចរិត រមែងដឹងសេចក្តីដែលគួរគប្បី តែមាត់របស់មនុស្សអាក្រក់ ពោលតែសេចក្តីក្រវិចក្រវៀនវិញ។

generated on Wed Sep 10 16:16:32 2025

Proverbs 10:1
ព័ត៌មានទូទៅ:
ខជាច្រើននៅក្នុងជំពូក ១០ មានភាពដូចគ្នា
សុភាសិតរបស់ព្រះបាទសាឡូម៉ូន
បន្ទាប់ពីសេចក្តីណែនាំនៃជំពូក ១-៩ ជំពូក ១០ ចាប់ផ្តើមប្រមូលសុភាសិត
ពាក្យខ្លីដែលបង្រៀនពីប្រាជ្ញា។
ដែលរកបាន
ដែលរកបានពីពេលវេលា
ព្រះអម្ចាស់មិនបណ្តោយឲ្យមនុស្សសុចរិតអត់ឃ្លានឡើយ
ពាក្យថា «ព្រលឹង» នៅទីនេះសំដៅទៅលើមនុស្ស។
នេះអាចបញ្ជាក់ជាទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ធ្វើឱ្យប្រាកដថាអ្នកដែលធ្វើអ្វីដែលត្រឹមត្រូវមានអាហារបរិភោគ»
Proverbs 10:4
ដៃខ្ជិល
ពាក្យថា «ដៃ» តំណាងឲ្យកម្លាំង និងសមត្ថភាពរបស់មនុស្សម្នាក់។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សមិនចង់ធ្វើការ»
ដៃឧស្សាហ៍
ពាក្យថា «ដៃ» តំណាងឲ្យកម្លាំង និងសមត្ថភាពរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលខំប្រឹងប្រែងធ្វើការ»
Proverbs 10:6
គឺបើកដល់ដៃ
ពាក្យថា «ក្បាល» តំណាងឲ្យមនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«ផ្តល់ឲ្យ»
មាត់របស់មនុស្សអាក្រក់
ពាក្យថា «មាត់» តំណាងឲ្យមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យដែលមនុស្សអាក្រក់និយាយ»
គ្របបាំង
លាក់ការពិត
ឈ្មោះ
ពាក្យថា «ឈ្មោះ» តំណាងឲ្យកេរ្តិ៍ឈ្មោះរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ការចងចាំ» (សូមមើល:figs-metonymy)
Proverbs 10:8
ទៅរកភាពអន្តរាយ
«ត្រូវគេបំផ្លាញ» ឬ «ត្រូវគេធ្វើឲ្យឥតប្រយោជន៍»
វៀចវេរ
មិនត្រង់ ខូចទ្រង់ទ្រាយ មិនស្មោះត្រង់ បោកប្រាស់
Proverbs 10:10
អ្នកលាក់សេចក្តីពិត
ពាក្យថា «មិចភ្នែក»
តំណាងឲ្យសញ្ញាសម្ងាត់យ៉ាងឃោឃៅចំពោះនរណាម្នាក់ទៀត។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលធ្វើសញ្ញាដោយប្រើកាយវិការ»
រត់ទៅរកភាពអន្តរាយ
មនុស្សដែលត្រូវគេបំផ្លាញដូចជាត្រូវគេបោះបង់ចោល។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដទៃនឹងបំផ្លាញគេ»
ពាក្យសម្តីរបស់មនុស្សសុចរិត
«ពាក្យសម្តីរបស់មនុស្សសុចរិត»
ជាប្រភពនៃជីវិត
ពាក្យសម្តីរបស់មនុស្សនេះគឺត្រូវបានគេចាត់ទុកដូចជាការការពារសត្វ និង មនុស្ស
ដូចជាប្រភពទឹកហូរនៅក្នុងជីវិត។
មាត់របស់មនុស្សអាក្រក់
ពាក្យថា «មាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យសម្តីរបស់មនុស្សអាក្រក់»
មនុស្សពាលតែងតែនិយាយបិទបាំងអំពើឃោរឃៅរបស់ខ្លួន
នោះគឺជាមនុស្សអាក្រក់ដែលនិយាយមិនអាក្រក់
តែមានគម្រោងការឃោរឃៅប្រឆាំងទាស់នឹងអ្នកដទៃ។
Proverbs 10:12
ចិត្តស្រឡាញ់រមែងគ្របបាំង
ក្តីស្រឡាញ់ដូចជាមនុស្សដែលលាក់បញ្ហាចំពោះគ្នាជាជាងបង្កឲ្យមានរឿងឡើង។
ពាក្យសម្តីរបស់មនុស្សឆ្លាតវាងវៃ
ពាក្យថា «បបូរមាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលមនុស្សត្រឹមត្រូវនិយាយ»
រមែងត្រូវរំពាត់
ពាក្យថា «រំពាត់» តំណាងឲ្យការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ហើយពាក្យ «ខ្នង»
តំណាងឲ្យមនុស្សដែលទទួលទណ្ឌកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សនិយាយឥតគិតត្រូវទទួលទណ្ឌកម្មដោយបង្ខំ»
Proverbs 10:14
ពាក្យសម្តីរបស់មនុស្សល្ងីល្ងើ
ពាក្យថា «មាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យសម្តីដែលចេញពីមនុស្សល្ងីល្ងើ»
ក្រុងមួយដែលមានកំពែងរឹងមាំ
នេះតំណាងឲ្យទ្រព្យសម្បត្តិដែលដូចជាកន្លែងដែលមានសុវត្ថិភាព។
ការបកប្រែរបៀបផ្សេងទៀត: «កន្លែងមានសុវត្ថិភាព»
Proverbs 10:16
កម្រៃ...ផល
ពាក្យទាំងពីរនេះជាធម្មតា សំដៅទៅលើប្រាក់ដែលគេខំរកបាន។
ត្រង់នេះពាក្យពីរនេះតំណាងឲ្យលទ្ធផលនៃការធ្វើត្រឹមត្រូវ និង ការធ្វើអាក្រក់។
អ្នកណាដែលស្តាប់តាមសេចក្តីប្រៀនប្រដៅ នោះឈ្មោះថា ដើរក្នុងផ្លូវនៃជីវិតហើយ
«មនុស្សដែលស្តាប់បង្គាប់តាមដំបូន្មាននៃប្រាជ្ញានោះនឹងមានអាយុវែង និង
ប្រកបដោយសុភមង្គល»
តែអ្នកណាដែលមិនព្រមទទួលសេចក្តីកែតម្រូវ នឹងនាំទៅកាន់ក្តីវិនាស
«ប៉ុន្តែអស់អ្នកណាដែលមិនស្តាប់បង្គាប់តាមដំបូន្មានប្រាជ្ញានោះនឹងមិនបានជីវិតល្អប្រសើរឡើយ»
Proverbs 10:18
អ្នកកុហក
ពាក្យថា «បបូរមាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «និយាយកុហក»
មានកំហុសច្រើន
«មានបាបច្រើន»
Proverbs 10:20
អណ្តាតរបស់មនុស្សសុចរិត
ពាក្យថា «អណ្តាត» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត:«អ្វីដែលមនុស្សសុចរិតនិយាយ»
ដូចជាប្រាក់ដែលវិសុទ្ធ
ពាក្យថា «ប្រាក់» តំណាងឲ្យការនិយាយអ្វីដែលមានតម្លៃ។
ការបកប្រែរបៀបផ្សេងទៀត: «ដែលមានតម្លៃខ្លាំង»
បបូរមាត់របស់មនុស្សសុចរិត
ពាក្យថា «បបូរមាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ការនិយាយរបស់មនុស្សសុចរិត»
ចិញ្ចឹម
ដែលធ្វើឲ្យរីកចម្រើន ឬ លូតលាស់រឹងមាំ
Proverbs 10:22
មនុស្សល្ងីល្ងើប្រព្រឹត្តអាក្រក់ ដូចជាល្បែងលេងសប្បាយដល់គេ
ល្បែងជាសកម្មភាពដែលមនុស្សធ្វើដើម្បីកម្សាន្តសប្បាយ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សល្ងីល្ងើរីករាយនឹងអំពើអាក្រក់»
Proverbs 10:24
កើតឡើងដល់
យកឈ្នះលើនរណាម្នាក់
មនុស្សអាក្រក់ប្រៀបបានដូចជាខ្យល់គួច
ដូចជាខ្យល់គួចដែលបក់អ្វីៗទៅ ហើយមនុស្សអាក្រក់នឹងគ្មានសល់អ្វីឡើយ។
មានឫសដ៏ស្ថិតស្ថេរនៅអស់កល្ប
ពាក្យថា «គ្រឹះ» តំណាងឲ្យមូលដ្ឋាន ឬ ការចាប់ផ្តើមនៃការសាងសង់អ្វីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «គឺជាការចាប់ផ្តើមអ្វីមួយដែលស្ថិតស្ថេរជារៀងរហូត»
Proverbs 10:26
ម្ហូរធ្វើឲ្យស្រកៀរធ្មេញ ផ្សែងធ្វើឲ្យផ្សារភ្នែក រីឯកូនឈ្នួលកម្ងិលក៏ធ្វើឲ្យចៅហ្វាយមួម៉ៅដែរ
ពាក្យថា «ម្ហូរ» និង «ផ្សែង» តំណាងអ្វីដែលធ្វើឲ្យធ្មេញ និង
ភ្នែករបស់មនុស្សឈឺចាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ការបញ្ជូនឲ្យមនុស្សខ្ជិលឲ្យទៅសម្រេចកិច្ចការអ្វីមួយ គឺគួរឲ្យមួរម៉ៅ និង
មិនពេញចិត្ត»
ម្ហូរ

generated on Wed Sep 10 16:16:32 2025

ជាទឹកដែលមានរសជាតិជូរដែលប្រើដើម្បីបន្ថែមរសជាតិ ឬ រក្សាអាហារ។
អាយុរបស់មនុស្សអាក្រក់
ពាក្យថា «ឆ្នាំ» តំណាងឲ្យអាយុរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«អាយុជីវិតរបស់មនុស្សអាក្រក់»
Proverbs 10:28
អាយុរបស់មនុស្សអាក្រក់
ពាក្យ «ឆ្នាំ» តំណាងអាយុរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:«អាយុរបស់មនុស្សអាក្រក់»
នឹងមិនត្រូវរង្គើឡើយ
នេះអាចបញ្ជាក់ជាទម្រង់សកម្ម និង វិជ្ជមាន: ការបកប្រែរបៀបផ្សេងទៀត:
«មានសុវត្ថិភាព»
Proverbs 10:31
មាត់របស់មនុស្សសុចរិត
ពាក្យថា «មាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យដែលចេញពីមនុស្សសុចរិត»
អណ្តាតមិនទៀងត្រង់ នឹងត្រូវបានកាត់ចេញ
ពាក្យថា «អណ្តាត» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងបិទមាត់មនុស្សដែលនិយាយសេចក្តីខុសឆ្គង»
បបូរមាត់របស់មនុស្សសុចរិត រមែងដឹងសេចក្តីដែលគួរគប្បី
ពាក្យថា «បបូរមាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សសុចរិតដឹងពីរបៀបដែលគួរនិយាយសមរម្យ»
មាត់របស់មនុស្សអាក្រក់
ពាក្យថា «មាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យសម្តីរបស់មនុស្សអាក្រក់»

---

11 [1]ព្រះអម្ចាស់ស្អប់អ្នកបន្លំភ្នែកជញ្ជីង តែព្រះអង្គគាប់ព្រះហឫទ័យនឹងអ្នកដែលប្រើជញ្ជីងត្រឹមត្រូវ។[2]អ្នកណាដែលមានអំនួត នឹងមិនត្រូវគេឲ្យតម្លៃទេ ប៉ុន្តែអ្នកណាដែលបន្ទាបខ្លួន គឺជាអ្នកដែលពេញដោយប្រាជ្ញា។
[3]ចិត្តទៀងត្រង់តែងតែនាំផ្លូវមនុស្សត្រឹមត្រូវ ប៉ុន្តែផ្លូវអាក្រក់តែងតែនាំទៅរកសេចក្តីវិនាស។[4]នៅថ្ងៃព្រះអម្ចាស់វិនិច្ឆ័យទោស ទ្រព្យសម្បត្តិគ្មានប្រយោជន៍អ្វីទេ គឺមានតែសេចក្តីសុចរិតប៉ុណ្ណោះ ទើបអាចជួយឲ្យរួចពីស្លាប់បាន។
[5]សេចក្តីសុចរិតរបស់មនុស្សគ្មានកំហុស រមែងតម្រង់ផ្លូវរបស់ខ្លួន រីឯមនុស្សពាលវិញ តែងតែស្លាប់ដោយសារអំពើពាលរបស់ខ្លួន។[6]សេចក្តីទៀងត្រង់នៃអ្នកដែលគោរពកោតខ្លាចព្រះជាម្ចាស់ នឹងរក្សាពួកគេឲ្យបានសង្គ្រោះ ប៉ុន្តែមនុស្សវៀចវេរ តែងតែជាប់អន្ទាក់របស់ពួកគេខ្លួនឯង។
[7]នៅពេលមនុស្សពាលស្លាប់ ក្តីសង្ឃឹមរបស់គេនឹងត្រូវវិនាសដែរ ហើយក្តីសង្ឃឹមជាកម្លាំងរបស់គេក៏គ្មានន័យអ្វីដែរ។[8]ពួកអ្នកសុចរិតនឹងរក្សាគេចេញពីសេចក្តីទុក្ខលំបាក ហើយការអាក្រក់ទាំងនោះ និងត្រូវធ្លាក់មកលើមនុស្សពាលវិញ។
[9]មនុស្សមានមាត់អាក្រក់គឺបំផ្លាញអ្នកជិតខាង ប៉ុន្តែមនុស្សសុចរិតវិញ តែងតែបានសង្គ្រោះ ដោយសារចំណេះដឹង។[10]ពេលមនុស្សសុចរិតមានសុភមង្គល អ្នកក្រុងទាំងមូលនឹងសប្បាយរីករាយ ពេលមនុស្សអាក្រក់វិនាស ពួកគេបែរជានាំគ្នាស្រែកហ៊ោវិញ។[11]តាមរយៈសេចក្តីល្អរបស់អ្នកដែល កោតខ្លាចព្រះជាម្ចាស់ធ្វើឲ្យទីក្រុងរបស់ពួកគេកាន់តែរីកចំរើនឡើង ប៉ុន្តែតាមរយៈមាត់មិនល្អរបស់មនុស្សពាលវិញ នោះធ្វើឲ្យទីក្រុងធ្លាក់ចុះវិញ។
[12]អ្នកណាមើលងាយមិត្តរបស់ខ្លួន អ្នកនោះជាមនុស្សមិនចេះពិចារណាប៉ុន្តែមនុស្សមានចំណេះដឹងតែងតែនៅស្ងៀម។[13]អ្នកនិយាយដើមគេមិនអាចរក្សារឿងសម្ងាត់ជិតឡើយ តែអ្នកដែលគេទុកចិត្តតែងតែលាក់រឿងសម្ងាត់ទាំងនោះបាន។
[14]កន្លែងណាដែលគ្មានអ្នកដឹកនាំមានប្រាជ្ញា ប្រជាជនតែងតែវិនាស ប៉ុន្តែជ័យជំនះគឺដែលមានទីប្រឹក្សា និងអ្នកឲ្យយោបល់ច្រើនៗ។
[15]អ្នកណាធានារ៉ាប់រងអ្នកដទៃ អ្នកនោះតែងតែកើតទុក្ខ រីឯអ្នកដែលមិនព្រមធានា តែងតែបានសុខ។[16]ស្ត្រីរូបស្អាតតែងតែមានគេសរសើរ ប៉ុន្តែមនុស្សស្វាហាប់ តែងតែរកទ្រព្យបាន។
[17]អ្នកមានចិត្តសប្បុរសតែងតែធ្វើឲ្យខ្លួនមានសុភមង្គល ប៉ុន្តែមនុស្សឃោរឃៅរមែងធ្វើឲ្យរូបកាយរបស់ខ្លួនកាន់តែរងទុក្ខវេទនា។[18]មនុស្សពាលរកបានតែសម្បត្តិក្តៅក្រហាយ រីឯមនុស្សដែលសាបព្រោះសេចក្តីសុចរិត រមែងទទួលផលដែលមិនចេះសាបសូន្យ។
[19]សេចក្តីសុចរិតតែងតែនាំទៅកាន់ជីវិត ប៉ុន្តែអ្នកដែលដើរតាមផ្លូវអាក្រក់រមែងស្លាប់ខ្លួន។[20]ព្រះអម្ចាស់ស្អប់មនុស្សមានចិត្តវៀចវេរ ប៉ុន្តែព្រះអង្គគាប់ព្រះហឫទ័យនឹងមនុស្សទៀងត្រង់។
[21]មនុស្សទុច្ចរិតត្រូវតែទទួលទោសជៀសមិនផុត រីឯពូជពង្សរបស់មនុស្សសុចរិតនឹងរួចជីវិត។[22]ដូចជាស្ត្រីមានរូបស្អាតតែឥតគំនិត ប្រៀបដូចជាចិញ្ចៀនមាស ដែលគេយកទៅពាក់នៅច្រមុះជ្រូក។
[23]មនុស្សសុចរិតមានបំណងតែមួយគត់ គឺធ្វើអំពើល្អ ប៉ុន្តែសេចក្តីប៉ងប្រាថ្នារបស់មនុស្សអាក្រក់រមែងធ្វើឲ្យខ្លួនទទួលទោស។[24]មនុស្សមានចិត្តទូលាយរឹតតែមានទ្រព្យច្រើន រីឯមនុស្សកំណាញ់ធ្វើឲ្យខ្លួនកាន់តែក្រទៅៗ។
[25]មនុស្សមានចិត្តសទ្ធាតែងតែបានចម្រុងចម្រើន ប៉ុន្តអ្នកដាក់ទានទឹកឲ្យគេ តែងតែទទួលទឹកពីគេវិញ។[26]អ្នកដែលទុកស្រូវក្នុងឃ្លាំង ដើម្បីដំឡើងថ្លៃតែងតែត្រូវប្រជាជនដាក់បណ្តាសា រីឯអ្នកដែលសុខចិត្តលក់ស្រូវរបស់ខ្លួននឹងបានទទួលពរ។
[27]ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងអ្នកដែលព្យាយាមប្រព្រឹត្តល្អ រីឯអ្នកដែលគិតតែពីប្រព្រឹត្តអាក្រក់ តែងតែទទួលផលអាក្រក់។[28]មនុស្សដែលពឹងផ្អែកលើទ្រព្យសម្បត្តិ មុខជាត្រូវអន្តរាយ ប៉ុន្តែមនុស្សសុចរិតប្រៀបបាននឹងស្លឹកឈើលាស់ខៀវខ្ចី។
[29]អ្នកណាធ្វើឲ្យគ្រួសាររបស់ខ្លួនមានទុក្ខកង្វល់ អ្នកនោះនឹងមិនទទួលផលអ្វីទាំងអស់។ មនុស្សល្ងីល្ងើនឹងធ្លាក់ខ្លួនទៅជាខ្ញុំបម្រើរបស់មនុស្សមានប្រាជ្ញា។
[30]អំពើដែលមនុស្សសុចរិតប្រព្រឹត្ត ប្រៀបបាននឹងដើមឈើផ្តល់ជីវិត ហើយអ្នកប្រាជ្ញតែងតែទាក់ទាញចិត្តមនុស្ស។[31]មនុស្សសុចរិតតែងតែទទួលរង្វាន់ នៅលើផែនដីនេះ រីឯមនុស្សអាក្រក់ និងមនុស្សបាប តែងតែទទួលផល តាមអំពើដែលគេប្រព្រឹត្ត។

Proverbs 11:1
ព័ត៌មានទូទៅ:
ខជាច្រើននៅក្នុងជំពូក១១ មានភាពដូចគ្នា
ព្រះអម្ចាស់ស្អប់អ្នកបន្លំភ្នែកជញ្ជីង
ពាក្យថា «ជញ្ជីង» តំណាងការថ្លឹងដែលត្រឹមត្រូវ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ស្អប់ជញ្ជីងបោកប្រាស់» ឬ
«ព្រះជាម្ចាស់ស្អប់ពេលដែលមនុស្សបោកប្រាស់»
តែព្រះអង្គគាប់ព្រះហឫទ័យនឹងអ្នកដែលប្រើជញ្ជីងត្រឹមត្រូវ
ពាក្យថា «ជញ្ជីងត្រឹមត្រូវ» តំណាងឲ្យរង្វាល់ដែលត្រឹមត្រូវ។
ការបកប្រែរបៀបផ្សេងទៀត: «តែព្រះអង្គសព្វព្រះទ័យនឹងរបៀបដែលស្មោះត្រង់» ឬ «តែព្រះអង្គសព្វព្រះទ័យនឹងមនុស្សដែលស្មោះត្រង់»
Proverbs 11:3
មនុស្សក្បត់
គុណនាមបន្ទាប់បន្សំនេះអាចបញ្ជាក់ជាគុណនាម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សក្បត់» ឬ «អស់អ្នកដែលក្បត់»
នៅថ្ងៃព្រះអម្ចាស់វិនិច្ឆ័យទោស ទ្រព្យសម្បត្តិគ្មានប្រយោជន៍អ្វីទេ
ឃ្លាថា «ថ្ងៃព្រះអម្ចាស់វិនិច្ឆ័យទោស» តំណាងឲ្យព្រឹត្តិការណ៍ជាក់លាក់ដូចជា «ថ្ងៃនៃព្រះអម្ចាស់» ឬ «ថ្ងៃជំនុំជំរះ» ការបកប្រែរបៀបផ្សេងទៀត:
«ទ្រព្យរបស់មនុស្សនឹងមិនអាចធ្វើឲ្យគាត់ស្អាតស្អំទេនៅពេលដែលព្រះជាម្ចាស់ជំនុំជំរះ»
Proverbs 11:5
តម្រង់ផ្លូវរបស់ខ្លួន
«មានគោលដៅច្បាស់លាស់»
មនុស្សពាល...មនុស្សវៀចវេរ
គុណនាមបន្ទាប់បន្សំទាំងនេះអាចបញ្ជាក់ជាគុណនាមបាន។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត:
«អស់មនុស្សអាក្រក់ទាំងនេះ...អស់អ្នកដែលមនុស្សវៀចវេរ»
មនុស្សពាលវិញ តែងតែស្លាប់ដោយសារអំពើពាលរបស់ខ្លួន
«អស់អ្នកដែលធ្វើការអាក្រក់នឹងត្រូវជាប់ដោយសារចិត្តពាលខ្លួនឯង»
មនុស្សវៀចវេរ
រួចរាល់ក្នុងការក្បត់សេចក្ដីទុកចិត្ត ជនក្បត់ បោកបញ្ឆោត
Proverbs 11:7
ក្ដីសង្ឃឹមជាកម្លាំងរបស់គេ
«ទំនុកចិត្តដែលគេមាននៅក្នុងកម្លាំងរបស់គេ»
វិនាស
«បាត់បង់គ្មានសល់»
ពួកអ្នកសុចរិតនឹងរក្សាគេចេញពីសេចក្ដីទុក្ខលំបាក
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់រក្សាគេពីទុក្ខលំបាកចំពោះអស់អ្នកណាដែលប្រព្រឹត្តត្រឹមត្រូវ»
ត្រូវធ្លាក់មក
«បញ្ហាធ្លាក់មក»
Proverbs 11:9
មនុស្សមានមាត់អាក្រក់
ពាក្យថា «មាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យសម្ដីអាក្រក់»
អ្នកក្រុងទាំងមូលនឹងសប្បាយរីករាយ
ពាក្យថា «ក្រុង» តំណាងឲ្យសហគមន៍ ឬ ក្រុមមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ក្រុមមនុស្សដែលចម្រុងចម្រើន» ឬ
«សហគមន៍ដែលចម្រុងចម្រើន»
មាត់មិនល្អរបស់មនុស្សពាល
ពាក្យថា «មាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពាក្យសម្ដីរបស់មនុស្សអាក្រក់»
Proverbs 11:12
លាក់រឿងសម្ងាត់
ពាក្យថា «លាក់» តំណាងឲ្យការរក្សាអ្វីជាសំងាត់តាមដែលអាចធ្វើទៅបាន។
ការបកប្រែរបៀបផ្សេងទៀត: «មិនដើរនិយាយប្រាប់គេ» ឬ «មិននិយាយពីបញ្ហា»
Proverbs 11:14
ទីប្រឹក្សា
អស់អ្នកដែលផ្ដល់អនុសាសន៍ ដូចជាតម្រង់ទិស អ្នកប្រឹក្សាយោបល់
Proverbs 11:15
អ្នកដែលមិនព្រមឲ្យ
«អ្នកដែលបដិសេធមិនព្រមឲ្យ»
មនុស្សឥតមេត្តា
មនុស្សដែលគ្មានចិត្តអាណិតអាសូរ មេត្តា មនុស្សឃោឃៅ
រកទ្រព្យបាន
«គឺលោភលន់ចង់បានទ្រព្យ»
Proverbs 11:17
អ្នកដែល
«មនុស្សដែល»
សាបព្រួសសេចក្ដីសុចរិត
ពាក្យថា «សាបព្រួស» តំណាងឲ្យការពង្រីកពង្រាយដើម្បីបានផលច្រើន។
ការបកប្រែរបៀបផ្សេងទៀត: «ពង្រាយនូវអ្វីដែលជាសេចក្ដីសុចរិត»
ទទួលផលដែលមិនចេះសាបសូន្យ
ពាក្យថា «ប្រមូល» តំណាងឲ្យទទួលបាន ឬ ការប្រមូលផល។
ការបកប្រែរបៀបផ្សេងទៀត: «នឹងទទួលបានរង្វាន់ពិតប្រាកដ»
Proverbs 11:19
អ្នកដែល
«មនុស្សដែល»
ដើរតាមផ្លូវអាក្រក់
«រត់តាមការអាក្រក់» ឬ «ស្វែងរកធ្វើការអាក្រក់»
មនុស្សមានចិត្តវៀចវេរ
ពាក្យថា «ចិត្ត» តំណាងឲ្យអារម្មណ៍ ឥរិយាបថ និង
ការជំរុញចិត្តរបស់មនុស្សម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលមានគំនិតអាក្រក់»
Proverbs 11:21
ទទួលទោសជៀសមិនផុត
«នឹងត្រូវទទួលទោស»
ប្រៀបដូចជាចិញ្ចៀនមាស...តែឥតគំនិត
ស្ត្រីស្រស់ស្អាតតែឥតគំនិតត្រូវបានគេប្រៀបប្រដូចទៅនឹង
ចិញ្ចៀនមាសដែលគ្មានប្រយោជន៍ ហើយមិនសមនឹងយកទៅពាក់នឹងច្រមុះជ្រូក។
ឥតគំនិត
«គ្មានការគិតពិចារណា» ឬ «មនុស្សដែលល្ងីល្ងើ»
Proverbs 11:23
អ្នកដែលសាបព្រោះគ្រាប់ពូជ
ឃ្លាថា «សាបព្រោះគ្រាប់ពូជ» តំណាងឲ្យការរៀបចំអនាគត។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលរៀបចំអនាគត»
មានទ្រព្យច្រើន
«នឹងចម្រើនឡើង»
មិនសាបព្រោះ
ពាក្យថា «សាបព្រោះ» តំណាងឲ្យការរៀបចំសម្រាប់លទ្ធផល។
ការបកប្រែរបៀបផ្សេងទៀត: «មិនបានរៀបចំ»
Proverbs 11:25
បានចម្រុងចម្រើន
«នឹងចម្រុងចម្រើនឡើង»
អ្នកដែល
«សប្បុរសជនដែល» ឬ «អ្នកដែល»
អ្នកដែលមិនលក់
នេះពិពណ៌នាពីមនុស្សដែលលាក់ទ្រព្យសម្បត្តិរបស់ខ្លួនជាជាងជួយអ្នកដទៃដែលត្រូវការ។
អ្នកដែលសុខចិត្តលក់ស្រូវរបស់ខ្លួននឹងបានទទួលពរ
ពាក្យថា «មុដ» តំណាងឲ្យរង្វាន់សម្រាប់មនុស្ស ដែលនឹងលក់ស្រូវរបស់ខ្លួន។
ការបកប្រែរបៀបផ្សេងទៀត:
«រង្វាន់យ៉ាងល្អដូចជាមុដដែលជាកិត្តិយសសម្រាប់អ្នកដែលលក់វា» ឬ
«មនុស្សដែលលក់ នឹងទទួលបានកិត្តិយសជាមួយនឹងព្រះពរជាច្រើន»
Proverbs 11:27
អ្នកដែលព្យាយាម
អ្នកដែលខំស្វែងរកដោយយកចិត្តទុកដាក់ និង បន្តខំប្រឹងប្រែង
មុខជាត្រូវអន្តរាយ
នេះគឺជាក្រៀមមភាសា។ ពាក្យថា «ធ្លាក់» នៅទីនេះតំណាងឲ្យ ការបំផ្លាញ ឬ
បរាជ័យ។ ការបកប្រែរបៀបផ្សេងទៀត: «ត្រូវគេបំផ្លាញ» ឬ
«រង់ចាំអនាគតដែលអាក្រក់មកដល់»
មនុស្សសុចរិតប្រៀបបាននឹងស្លឹកឈើលាស់ខៀវខ្ចី
ពាក្យថា «ស្លឹកឈើ» តំណាងឲ្យការលូតលាស់ និង រីកចម្រើន។
ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សសុចរិតនឹងចម្រុងចម្រើនដូចជាស្លឹកឈើដែលលូតលាស់ខៀវខ្ចី»
មនុស្សសុចរិតចម្រុងចម្រើនឡើង
នេះមានន័យថាមនុស្សសុចរិតនឹងលូតលាស់ ឬ រីកចម្រើនឡើង។
Proverbs 11:29
នឹងមិនទទួលផលអ្វីទាំងអស់
ពាក្យថា «ខ្យល់» គឺជាអ្វីដែលមិនអាចចាប់វាបាន។ ការបកប្រែរបៀបផ្សេងទៀត:
«មិនទទួលបានមរតកអ្វីទាំងអស់»
Proverbs 11:30
មនុស្សសុចរិតប្រៀបបាននឹងដើមឈើផ្ដល់ជីវិត
មនុស្សដែលធ្វើអ្វីដែលត្រឹមត្រូវប្រៀបបានទៅនឹងដើមឈើ
ដែលផ្ដល់ផលផ្លែជាជីវិត។ ការបកប្រែរបៀបផ្សេងទៀត:
«អស់អ្នកដែលធ្វើការត្រឹមត្រូវនឹងនាំជីវិតដល់ខ្លួនឯង និង អ្នកដទៃ»
ដើមឈើជីវិត
បកប្រែឃ្លានេះនៅក្នុងជំពូក ៣:១៧។
តែងតែទទួលផល
«ទទួលបានថែមទៀត»

generated on Wed Sep 10 16:16:32 2025

12 [1]អ្នកណាស្រឡាញ់ការប្រៀនប្រដៅ និងស្រឡាញ់ចំណេះដឹង ប៉ុន្តែអ្នកណាស្អប់ការកែតម្រូវគឺជាមនុស្សល្ងង់។[2]ព្រះអម្ចាស់ ផ្តល់ព្រះគុណដល់មនុស្សល្អ
ប៉ុន្តែព្រះជាម្ចាស់នឹងមិនផ្តល់ក្តីមេត្តាដល់ មនុស្សដែលដើរតាមផ្លូវអាក្រក់ឡើយ។
[3]គ្មានមនុស្សណាបានតាំងមាំមួនឡើង ដោយសារអំពើអាក្រក់ទេ ប៉ុន្តែមនុស្សសុចរិត មិនត្រូវរលើងឡើយ។[4]ស្ត្រីមានចិត្តបរិសុទ្ធ នោះជាមកុដដល់ប្តី តែស្ត្រីណាដែលនាំឲ្យ
មានសេចក្តីខ្មាស និងដូចជាជំងឺដែលបានចាក់ឫស នៅក្នុងឆ្អឹងរបស់ប្តីវិញ។
[5]គ្រប់ទាំងផែនការរបស់មនុស្សសុចរិត គឺសុទ្ធតែទៀងត្រង់ តែយោបល់របស់មនុស្សអាក្រក់ គឺជាការឆបោកវិញ។[6]ពាក្យសម្តីរបស់មនុស្សអាក្រក់
គឺរកតែរឿងនឹងរង់ចាំដើម្បីសម្លាប់ តែពាក្យរបស់មនុស្សទៀងត្រង់ នឹងជួយឲ្យគេបានជីវិត។
[7]បើមនុស្សអាក្រក់រលំ គេគ្មាននៅសល់អ្វីឡើយ តែពូជពង្សរបស់មនុស្សសុចរិតនៅស្ថិតស្ថេរជានិច្ច។[8]មនុស្សដែលចេះត្រិះរិះពិចារណាតែងតែមានគេសរសើរ ប៉ុន្តែមនុស្ស
មានចិត្តមិនត្រង់តែងតែមានគេមើលងាយ។
[9]រស់នៅជាមនុស្សសាមញ្ញ ហើយមានអ្នកបម្រើតែម្នាក់ នោះប្រសើរជាងវាយឫកហ៊ឺហា តែខ្វះអាហារបរិភោគវិញ។[10]មនុស្សសុចរិតតែងតែថែទាំសត្វរបស់ខ្លួន ប៉ុន្តែមនុស្ស
អាក្រក់វិញ គ្មានចិត្តមេត្តាករុណាសោះឡើយ។
[11]អ្នកខំប្រឹងធ្វើស្រែចម្ការ គឺតែងតែមានអាហារបរិភោគឆ្អែតគ្រប់គ្រាន់ ចំណែកអ្នកចូលចិត្តនិយាយឥតប្រយោជន៍ជាមនុស្សខ្វះការពិចារណា។[12]មនុស្សពាលតែងតែលោភ
ចង់បានទ្រព្យសម្បត្តិរបស់មនុស្សអាក្រក់ ប៉ុន្តែអ្វីៗដែលមនុស្សសុចរិតបានធ្វើផងនោះគឺចេញមកពីគេខ្លួនឯង។
[13]មនុស្សអាក្រក់ជាប់អន្ទាក់ ដោយសារតែពាក្យសម្តីរបស់ខ្លួនចំណែកមនុស្សសុចរិតតែងតែរួចពីទុក្ខលំបាកវិញ។[14]ផលចេញពីពាក្យដែលអ្នកនោះប្រើ
បានបំពេញដល់គាត់នូវការល្អ គឺបានមកពីផលនៃដៃរបស់គាត់បានជារង្វាន់។
[15]ផ្លូវរបស់មនុស្សអាក្រក់គឺនៅត្រង់ចំពោះមុខ ប៉ុន្តែមនុស្សមានប្រាជ្ញា គឺស្តាប់យោបល់អ្នកដទៃ។[16]មនុស្សខ្លៅឆាប់ច្រឡោតខឹង ចំណែកមនុស្សឆ្លាតតែងតែចេះទប់ចិត្ត។
[17]មនុស្សនិយាយការពិតរមែងធ្វើឲ្យមានភាពត្រឹមត្រូវ ចំណែកសាក្សីក្លែងក្លាយតែងតែធ្វើឲ្យមានមិនត្រឹមត្រូវ។[18]អ្នកដែលនិយាយប៉ប៉ាច់ប៉ប៉ោចតែងតែធ្វើឲ្យអ្នកដទៃរបួស
ដូចចាក់មួយដាវ ចំណែកពាក្យសម្តីរបស់មនុស្សមានប្រាជ្ញាជាឱសថព្យាបាលមុខរបួស។
[19]ពាក្យពិតពីមាត់មានតម្លៃរហូត ប៉ុន្តែពាក្យភូតភរស្ថិតនៅតែមួយគ្រាខ្លីតែប៉ុណ្ណោះ។[20]អ្នកដែលប៉ុនប៉ងធ្វើអំពើអាក្រក់តែងតែលាក់ចិត្តអាក្រក់ជានិច្ច ប៉ុន្តែអ្នកកសាង
សន្តិភាពតែងតែមានក្តីសុខសាន្ត។
[21]គ្មានគ្រោះកាចណាកើតមានដល់មនុស្សសុចរិតទេ ប៉ុន្តែមនុស្សអាក្រក់វិញ តែងតែជួបប្រទះនឹងទុក្ខលំបាក។[22]ព្រះអម្ចាស់ស្អប់មនុស្សកុហក តែព្រះអង្គគាប់ព្រះហឫទ័យ
មនុស្សដែលរស់ជាមួយពាក្យស្មោះត្រង់។
[23]មនុស្សឆ្លាតមិនអួតពីចំណេះដឹងខ្លួនទេ ប៉ុន្តែមនុស្សខ្លៅចូលចិត្តអួតអាងអំពីអវិជ្ជារបស់ខ្លួន។[24]មនុស្សឧស្សាហ៍នឹងក្លាយទៅជាមេគ្រប់គ្រង ចំណែកមនុស្សខ្ជិលច្រអូស
នឹងធ្លាក់ខ្លួនជាអ្នកបម្រើវិញ។
[25]ការខ្វល់ខ្វាយតែងតែធ្វើឲ្យមនុស្សបាក់ទឹកចិត្ត ប៉ុន្តែពាក្យទន់ភ្លន់តែងតែធ្វើឲ្យមានអំណរឡើងវិញ។[26]មនុស្សសុចរិតតែងតែនាំមិត្តសម្លាញ់របស់ខ្លួនឲ្យដើរតាមផ្លូវល្អ
ចំណែកកិរិយារបស់មនុស្សអាក្រក់នាំឲ្យគេវង្វេងវិញ។
[27]ព្រានកម្ចិលគ្មានសាច់អាំងទេ ចិត្តឧស្សាហ៍ជាសម្បត្តិដ៏មានតម្លៃរបស់មនុស្ស។[28]នៅក្នុងផ្លូវសុចរិតមានជីវិត ហើយផ្លូវនេះមិននាំមនុស្សទៅរកសេចក្តីស្លាប់ឡើយ។

Proverbs 12:1

ព័ត៌មានទូទៅ:

អ្នកនិពន្ធប្រើ នៅជំពូកនេះទាំងមូល។

ព័ត៌មានទូទៅ:

ខ ១-១៥ ផ្ទុយពីប្រាជ្ញា និង ភាពល្ងង់ខ្លៅ។

អ្នកណាក៏ដោយ

«មនុស្សណាដែល»

អ្នកណាស្អប់ការកែតម្រូវ

«មនុស្សដែលមិនចូលចិត្តឲ្យគេណែនាំពីអ្វីដែលត្រូវធ្វើ»

គឺជាមនុស្សល្ងង់

«ល្ងីល្ងើ» ឬ «មិនឆ្លាត»

Proverbs 12:3

គ្មានមនុស្សណាបានតាំងមាំមួនឡើង ដោយសារអំពើអាក្រក់ទេ

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«គ្មាននរណាម្នាក់អាចមានសុវត្ថិភាព និង ក្តីសុខដោយសារការធ្វើអាក្រក់ឡើយ»

មិនត្រូវរលើងឡើយ

ពាក្យថា «រលើង» តំណាងឲ្យការដែលត្រូវការទាញរុក្ខជាតិ ឬ ដើមឈើចេញពីដី។
នេះមិនអាចកើតមានឡើងចំពោះមនុស្សសុចរិតឡើយ។

ការបកប្រែរបៀបផ្សេងទៀត: «គឺដូចជាដើមឈើដែលឈរមាំចាក់ឫសយ៉ាងជ្រៅ»

ស្ត្រីមានចិត្តបរិសុទ្ធ នោះជាមកុដដល់ប្តី

មកុដតំណាងឲ្យកិត្តិយសដ៏អស្ចារ្យដែលមនុស្សម្នាក់ទទួលបាន។

ការបកប្រែរបៀបផ្សេងទៀត:

«ប្រពន្ធល្អជាសញ្ញាបង្ហាញថាប្តីមាកិត្តិយសយ៉ាងអស្ចារ្យ»

ស្ត្រីណាដែលនាំឲ្យមានសេចក្តីខ្មាស និងដូចជាជំងឺដែលបានចាក់ឫស នៅក្នុងឆ្អឹងរបស់ប្តីវិញ

ជំងឺដែលចាក់ឫសក្នុងឆ្អឹងតំណាងឲ្យការបំផ្លាញជីវិតនរណាម្នាក់។

ការបកប្រែរបៀបផ្សេងទៀត: «ទង្វើដ៏គួរឲ្យអាម៉ាស់របស់ប្រពន្ធបំផ្លាញឥទ្ធិពល និង
សុភមង្គលរបស់ប្តី»

Proverbs 12:5

ពាក្យសម្តីរបស់មនុស្សអាក្រក់ គឺរកតែរឿងនឹងរង់ចាំដើម្បីសម្លាប់

ការបោកបញ្ឆោតដែលមនុស្សអាក្រក់និយាយគឺចង់បំផ្លាញអ្នកដទៃ
ដែលត្រូវបានគេចាត់ទុកថា ពាក្យសម្តីរបស់គេចាំតែសម្លាប់នរណាម្នាក់។

ការបកប្រែរបៀបផ្សេងទៀត:

«កិច្ចការរបស់មនុស្សអាក្រក់ដូចជាមនុស្សដែលរង់ចាំសម្លាប់មនុស្សដោយមិនដឹងខ្លួន» (សូមមើល:figs-metaphor)

ពាក្យរបស់មនុស្សទៀងត្រង់ នឹងជួយឲ្យគេបានជីវិត

«ដំបូន្មានរបស់មនុស្សទៀងត្រង់ នឹងជួយឲ្យមនុស្សរួចជីវិត»

មនុស្សទៀងត្រង់

«មនុស្សសុចរិត» ឬ «មនុស្សស្មោះត្រង់» ឬ «មនុស្សយុត្តិធម៌»

Proverbs 12:7

មនុស្សអាក្រក់រលំ

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«មនុស្សនឹងផ្តួលរំលំមនុស្សអាក្រក់» ឬ
«គេនឹងដកមនុស្សអាក្រក់ចេញពីមនុស្សដែលមានអំណាច» (សូមមើល:figs-activepassive)

ផ្ទះ

ពាក្យ «ផ្ទះ» ជាទូទៅត្រូវបានប្រើជាន័យធៀបនៅក្នុងព្រះគម្ពីរ ដើម្បីសំដៅទៅលើ
ដូនតា កូនចៅ ឬ សាច់ញាតិរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:

«គ្រួសារ» ឬ «កូនចៅ»

មនុស្សដែលចេះត្រិះរិះពិចារណាតែងតែមានគេសរសើរ

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«គេនឹងសរសើរមនុស្សដែលមានប្រាជ្ញា»

មនុស្សមានចិត្តមិនត្រង់តែងតែមានគេមើលងាយ

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«មនុស្សគេនឹងស្អប់អ្នកដែលមានគំនិតអាក្រក់» ឬ
«មនុស្សនឹងស្អប់មនុស្សដែលបង្វែរពីការល្អមកជាការអាក្រក់»

Proverbs 12:9

រស់នៅជាមនុស្សសាមញ្ញ

«វាប្រសើរជាជាងក្នុងការរស់នៅជាមនុស្សសាមញ្ញ»

ដែលឃោឃៅ

«បង្កឲ្យមានទុក្ខសោក»

Proverbs 12:11

កិច្ចការ

generated on Wed Sep 10 16:16:32 2025

«គម្រោងការ» ឬ «ការងារ»

ផលផ្លែ

នេះសំដៅទៅលើសកម្មភាព និង គំនិតរបស់មនុស្ស។
ដូចជាផលផ្លែនៅលើដើមឈើដែលបង្ហាញពីប្រភេទដើមរបស់វា
ក៏ដូចគ្នាដែរនឹងពាក្យសម្ដីរបស់មនុស្ស និង
សកម្មភាពដែលបង្ហាញអត្តចរិតរបស់គេបែបនោះដែរ។

Proverbs 12:13

មនុស្សអាក្រក់ជាប់អន្ទាក់ ដោយសារតែពាក្យសម្ដីរបស់ខ្លួន

ពាក្យថា «អន្ទាក់» តំណាងឲ្យការជាប់អន្ទាក់ ឬ ការត្រូវគេបោកបញ្ឆោត។
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«កិច្ចការអាក្រក់ដែលមនុស្សអាក្រក់និយាយនឹងធ្វើឲ្យគេជាប់អន្ទាក់»

បានមកពីផលនៃដៃរបស់គាត់បានជារង្វាន់

ឃ្លាថា «ផលនៃដៃរបស់គាត់» តំណាងឲ្យកិច្ចការដែលបានធ្វើរួចហើយ។
ការបកប្រែរបៀបផ្សេងទៀត: «ដូចជាកិច្ចការល្អដែលគេបានធ្វើ
ផ្តល់ជារង្វាន់ដល់គេ»

Proverbs 12:15

នៅក្នុងភ្នែករបស់គេផ្ទាល់

ឃ្លានេះតំណាងឲ្យគំនិតដែលចេញពី ការសង្កេត ការស្រមើស្រមៃផ្ទាល់ខ្លួន។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងគំនិតផ្ទាល់ខ្លួនរបស់គេ»

យោបល់

សំណើរឆ្លាតវៃ

ចេះទប់ចិត្ត

«ដែលឆ្លាត» ឬ «ដែលចេះគិត»

Proverbs 12:17

អ្នកដែលនិយាយប៉ប៉ាច់ប៉ប៉ោចតែងតែធ្វើឲ្យអ្នកដទៃរបួស ដូចចាក់មួយដាវ

ឃ្លាថា «ចាក់មួយដាវ» តំណាងឲ្យពាក្យឃោឃៅដែលធ្វើឲ្យអ្នកដទៃឈឺចាប់។
ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលមនុស្សម្នាក់និយាយដោយមិនចេះគិតនឹងធ្វើឲ្យមានការឈឺចាប់ដូចជាត្រូវមួយដាវ**តានតឹង**។ ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យគេកើតទុក្ខ ឬ តានតឹងក្នុងចិត្ត»

ពាក្យសម្ដីរបស់មនុស្សមានប្រាជ្ញា

ពាក្យថា «អណ្តាត» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត:«អ្វីដែលមនុស្សមានប្រាជ្ញានិយាយ»

ជាឱសថព្យាបាល

«ដែលជួយឲ្យធូរស្រាល និង ព្យាបាល»

Proverbs 12:19

ពាក្យពិតពីមាត់មានតម្លៃរហូត

ពាក្យថា «បបូរមាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សស្មោះត្រង់ម្នាក់មានការតស៊ូជារៀងរហូត»

ពាក្យភូតភរស្ថិតនៅតែមួយគ្រាខ្លីតែប៉ុណ្ណោះ

ពាក្យថា «អណ្តាត» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត:

«អ្នកដែលនិយាយកុហកនៅបានតែមួយរយៈពេលប៉ុណ្ណោះ»

អ្នកផ្តល់ដំបូន្មាន

អស់អ្នកដែលផ្តល់សេចក្តីណែនាំក្នុងការធ្វើអ្វីមួយ អ្នកប្រឹក្សាយោបល់

Proverbs 12:21

គ្មានគ្រោះកាចណាកើតមានដល់

ពាក្យអវិជ្ជមាន «គ្មាន» បដិសេធចំពោះគំនិតដែល
«គ្រោះកាច» (រឿងអាក្រក់ដែលកើតឡើង)។ ការបកប្រែរបៀបផ្សេងទៀត:
«ការល្អនឹងមកដល់» (សូមមើល:figs-litotes)

ព្រះអម្ចាស់ស្អប់មនុស្សកុហក

ពាក្យថា «បបូរមាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់ស្អប់អ្នកដែលនិយាយកុហក»

Proverbs 12:23

មិនអួតពីចំណេះដឹងខ្លួនទេ

«មិននិយាយពីអ្វីដែលខ្លួនចេះ»

ដៃរបស់មនុស្សឧស្សាហ៍

ពាក្យថា «ដៃ» តំណាងឲ្យអ្វីដែលមនុស្សធ្វើកិច្ចការរបស់គេ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សឧស្សាហ៍»

នឹងធ្លាក់ខ្លួនជាអ្នកបម្រើវិញ

ពាក្យថា «អ្នកបម្រើ» ពិពណ៌នាពីអ្វីដែលមនុស្សត្រូវតែធ្វើ
មនុស្សដែលមិនមានពេលសម្រាប់ធ្វើអ្វីដែលខ្លួនចង់ធ្វើ។
ការបកប្រែរបៀបផ្សេងទៀត: «នឹងក្លាយជាទាសករគេ»

Proverbs 12:25

ការខ្វល់ខ្វាយ

អារម្មណ៍មិនស្រួលចំពោះភាពភ័យខ្លាច ឬ ភាពភ័យខ្លាច ការព្រួយបារម្ភ

ធ្វើឲ្យមនុស្សបាក់ទឹកចិត្ត

«ធ្វើឲ្យបាក់ទឹកចិត្ត» តំណាងឲ្យគំនិតនៃការដាក់បន្ទុកលើនរណាម្នាក់
ដូច្នេះគ្មានអារម្មណ៍ធូរស្រាល។ ឃ្លានេះមានន័យថាធ្វើឲ្យមនុស្សម្នាក់ពិបាកចិត្ត ឬ
តានតឹង។ ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យគេកើតទុក្ខ ឬ តានតឹងក្នុងចិត្ត»

ប៉ុន្តែពាក្យទន់ភ្លន់តែងតែធ្វើឲ្យមានអំណរឡើងវិញ

នាមអរូបី «ពាក្យ» អាចបញ្ជាក់ជាកិរិយាស័ព្ទ «និយាយ» ។
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែពេលអ្នកដទៃនិយាយល្អដាក់គេ
នោះគេនឹងរីករាយម្តងទៀត»

Proverbs 12:27

គ្មានសាច់អាំងទេ

ពាក្យថា «សាច់»
មានន័យថាសត្វដែលគេចាប់បានហើយសម្លាប់ពេលដែលគេបាញ់បាន។ ហើយ
«អាំង» គឺជារបៀបដែលគេចំអិនអាហារ។

ទ្រព្យដែលមានតម្លៃ

«ទ្រព្យសម្បត្តិដែលមានតម្លៃ»

---

13 [1]កូនដែលឆ្លាតនឹងស្តាប់សេចក្តីបង្រៀនរបស់ឪពុកខ្លួន តែអ្នកចំអកនឹងមិនស្តាប់ក៏មិនទទួលយកដែរ។[2]ពីផលដែលចេញពីមាត់របស់អ្នកគឺមានអំណរហើយនឹងការល្អ
ប៉ុន្តែអ្នកព្រហើនមិនព្រមស្តាប់ការបន្ទោសហើយរកតែហឹង្សា។
[3]អ្នកណាដែលរវាំងមាត់របស់ខ្លួន នោះរមែងរក្សាជីវិតខ្លួន តែអ្នកណាដែលហាមាត់ធំ នោះនឹងត្រូវវិនាសទៅ។[4]ព្រលឹងនៃមនុស្សខ្ជិលច្រអូសប្រាថ្នាចង់បាន តែមិនបានអ្វីសោះ ប៉ុន្តែព្រលឹងនៃមនុស្សឧស្សាហ៍ នោះនឹងបានសម្បត្តិជាបរិបូរវិញ។
[5]មនុស្សសុចរិតរមែងស្អប់ពាក្យភូតភរ តែមនុស្សអាក្រក់គេគួរខ្ពើមហើយមានសេចក្តីខ្មាសផង។[6]សេចក្តីសុចរិតតែងតែការពារអ្នកណា ដែលប្រព្រឹត្តតាមផ្លូវទៀងត្រង់ តែអំពើអាក្រក់តែងតែនាំនឹងជំរុញឲ្យមនុស្សបែរចុះចូលជាមួយបាបវិញ។
[7]អ្នកមានតែងតែអាងលើទ្រព្យ ដើម្បីធានាជីវិតរបស់ខ្លួន ប៉ុន្តែអ្នកដែលបានឲ្យទាំងអស់ ដែលខ្លួនមាន គ្មានអ្វីជាបន្ទុកឡើយ អ្នកនេះហើយជាសម្បត្តិពិតប្រាកដវិញ។[8]ទ្រព្យសម្បត្តិរបស់អ្នកមាន នឹងទុកសម្រាប់លោះជីវិតរបស់គេ តែមនុស្សក្រ គេមិនដែលឮពាក្យគំរាមកំហែងទេ។
[9]មនុស្សសុចរិតប្រៀបដូចជាពន្លឺត្រចះត្រចង់ ប៉ុន្តែមនុស្សអាក្រក់ប្រៀបដូចជាចង្កៀងរលត់។[10]ការវាយឫកធំតែងតែបង្កឲ្យមានទំនាស់ រីឯអ្នកដែលសុខចិត្តទទួលដំបូន្មានជាមនុស្សមានប្រាជ្ញា។
[11]ទ្រព្យរកបានរហ័ស បាត់បង់ក៏រហ័សដែរ ប៉ុន្តែទ្រព្យរកបានដោយសន្សំ រមែងកើនឡើងជាដរាប។[12]ការអស់សង្ឃឹមតែងតែនាំឲ្យព្រួយចិត្ត រីឯការសម្រេចដូចបំណង ប្រៀបបាននឹងដើមឈើដែលមានជីវិត។
[13]អ្នកណាមើលងាយសេចក្តីបង្រៀន អ្នកនោះនឹងតែងតែមានការចុះចូលជាមួយកំហុស ប៉ុន្តែអ្នកដែលគោរពព្រះបន្ទូលតែងតែទទួលរង្វាន់។[14]ការប្រៀនប្រដៅរបស់មនុស្សសុចរិតជាប្រភពនៃជីវិត ហើយការពារជីវិតឲ្យរួចពីអន្ទាក់នៃសេចក្តីស្លាប់។
[15]អ្នកចេះគិតពិចារណាតែងតែមានគេគោរព ប៉ុន្តែមនុស្សដែលគេទុកចិត្តមិនបានតែងតែវិនាស។[16]មនុស្សឆ្លាតរមែងគិតមុននឹងគួរ ប៉ុន្តែមនុស្សខ្លៅតែងតែលាតត្រដាងភាពល្ងីល្ងើរបស់ខ្លួន។
[17]អ្នកនាំសារដែលជាមនុស្សអាក្រក់ តែងតែធ្លាក់ខ្លួនអន្តរាយ ប៉ុន្តែទូតដ៏ស្មោះត្រង់តែងតែនាំសេចក្តីសុខ។[18]អ្នកដែលមិនទទួលការអប់រំរមែងធ្លាក់ខ្លួនក្រ ហើយត្រូវគេមើលងាយ រីឯអ្នកដែលសុខចិត្តទទួលការកែតម្រូវ តែងតែមានកិត្តិយស។

generated on Wed Sep 10 16:16:32 2025

[19]សេចក្ដីប៉ងប្រាថ្នាដែលបានសម្រេច រមែងនាំឲ្យសប្បាយចិត្ត ប៉ុន្តែមនុស្សខ្លៅមិនចូលចិត្តលះបង់គំនិតអាក្រក់របស់ខ្លួនចោលទេ។[20]ដើរជាមួយមនុស្សមានប្រាជ្ញានាំឲ្យខ្លួនមានប្រាជ្ញា តែសេពគប់ជាមួយមនុស្សខ្លៅ នាំឲ្យខ្លួនទៅជាមនុស្សអាក្រក់។
[21]ទុក្ខវេទនាគឺដេញតាមមនុស្សមានបាប ប៉ុន្តែមនុស្សសុចរិតតែងតែទទួលសុភមង្គលទុកជារង្វាន់។[22]មនុស្សសប្បុរសតែងតែមានមរតកទុកចែកឲ្យកូនចៅ ប៉ុន្តែមនុស្សបាបតែងតែប្រមូលទ្រព្យទុកសម្រាប់មនុស្សសុចរិត។
[23]ស្រែចម្ការដែលជនក្រីក្រភ្ជួររាស់ តែងតែបង្កើតផលយ៉ាងបរិបូណ៌ ប៉ុន្តែ មានអ្នកខ្លះស្លាប់ ព្រោះតែខ្វះយុត្តិធម៌។[24]អ្នកណាមិនសូវប្រើរំពាត់ អ្នកនោះមិនស្រឡាញ់កូនទេ ប៉ុន្តែអ្នកដែលស្រឡាញ់កូនតែងតែបង្រៀនប្រដៅដល់កូនៗ។
[25]មនុស្សសុចរិតតែងតែមានអាហារបរិភោគគ្រប់គ្រាន់ជាដរាប ប៉ុន្តែមនុស្សអាក្រក់តែងតែអត់ខ្វះខាត។

Proverbs 13:1

កូនដែលឆ្លាតនឹងស្តាប់

ពាក្យថា «ស្តាប់» នៅទីនេះតំណាងឲ្យការស្តាប់ដើម្បីធ្វើតាម។
ការបកប្រែរបៀបផ្សេងទៀត: «កូនឆ្លាតចេះស្តាប់បង្គាប់»

នឹងមិនស្តាប់សេចក្ដីបង្រៀន

ពាក្យថា «ស្តាប់» នៅទីនេះតំណាងឲ្យការយកចិត្តទុកដាក់ដើម្បីធ្វើអ្វីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «នឹងមិនរៀនពីសេចក្ដីបង្រៀន» ឬ
«នឹងមិនស្តាប់បង្គាប់ ទោះបីជាមានការស្ដីបន្ទោសក៏ដោយ»

ផលដែលចេញពីមាត់របស់អ្នក

ពាក្យថា «ផល» នៅទីនេះតំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ពីពាក្យដែលចេញពីមាត់របស់គេ» ឬ
«ចេញពីអ្វីដែលគេនិយាយ»

ចូលចិត្តតែ

ចំណង់តែ ឬ ចូលចិត្តអ្វីមួយ

អ្នកព្រហើន

អស់អ្នកដែលចង់តែក្បត់ ឬ បោកបញ្ឆោតអ្នកដទៃ

Proverbs 13:3

មាត់របស់គេ

ពាក្យថា «មាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលគេនិយាយ»

ហាមាត់ធំ

ហាមាត់តំណាងឲ្យការនិយាយ និង បើកមាត់ធំតំណាងឲ្យការនិយាយច្រើន។
ការបកប្រែរបៀបផ្សេងទៀត: «និយាយច្រើន» ឬ «ជជែកច្រើន»

ព្រលឹង...ព្រលឹង

បកប្រែដូចនៅក្នុងជំពូក ១៣:១។

ប្រាថ្នាចង់បាន តែមិនបានអ្វីសោះ

«ចង់បានខ្លាំងតែមិនបានអ្វីទាំងអស់»

ព្រលឹងនៃមនុស្សឧស្សាហ៍ នោះនឹងបានសម្បត្តិជាបរិបូរវិញ

ឃ្លាថា «ប្រាថ្នាចង់បាន» តំណាងឲ្យចំណង់ប្រាថ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សឧស្សាហ៍នឹងមានជីវិតដែលមានបរិបូរណ៍» ឬ
«ការឧស្សាហ៍ព្យាយាមនឹងធ្វើឲ្យមនុស្សមានជីវិតមានបរិបូរណ៍»

មនុស្សឧស្សាហ៍

មនុស្សដែលធ្វើការដោយប្រុងប្រយ័ត្ន និង បន្តខំប្រឹងប្រែងធ្វើការ។

Proverbs 13:5

គួរខ្ពើម

ធ្វើឲ្យមានអារម្មណ៍ខ្ពើមខ្លាំង

សេចក្ដីសុចរិតតែងតែការពារអ្នកណា

ឃ្លាថា «សេចក្ដីសុចរិត» តំណាងឲ្យផ្លូវជីវិតដែលព្រះអម្ចាស់គាប់ព្រះទ័យ។
សកម្មភាពនេះដូចជាមនុស្សការពារ។ ការបកប្រែរបៀបផ្សេងទៀត:
«ផ្លូវជីវិតដែលព្រះអម្ចាស់សព្វព្រះទ័យការពារ»

អ្នកណា ដែលប្រព្រឹត្តតាមផ្លូវរបស់គេ

ពាក្យថា «ផ្លូវ» នៅទីនេះតំណាងឲ្យរបៀបដែលមនុស្សរៀបចំជីវិតរបស់គេ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលប្រព្រឹត្តតាមរបៀបរស់នៅរបស់គេ» ឬ
«អ្នកដែលរស់នៅដោយភាពស្មោះត្រង់»

អំពើអាក្រក់តែងតែនាំនឹងជំរុញឲ្យមនុស្សបែរចុះចូលជាមួយបាបវិញ

ឃ្លាថា «អំពើអាក្រក់» នៅទីនេះតំណាងឲ្យជីវិតដែលប្រព្រឹត្តអាក្រក់។
ទង្វើដែលល្អនេះដូចជាមនុស្សដែលបែរចេញពីមនុស្សដែលប្រព្រឹត្តអំពើបាប។
ការបកប្រែរបៀបផ្សេងទៀត:
«អំពើអាក្រក់ធ្វើឲ្យអ្នកមានបាបបែរចេញពីផ្លូវដែលជោគជ័យ» ឬ
«អំពើអាក្រក់បំផ្លាញជីវិតមនុស្សមានបាប»

Proverbs 13:7

អ្នកដែលធ្វើឲ្យខ្លួនមាន

«អ្នកដែលធ្វើឲ្យខ្លួនមាន»

មិនដែលឮពាក្យគំរាមកំហែងទេ

អាចមានន័យថា គឺ១) គ្មាននរណាម្នាក់គំរាម ឬ លួចអ្វីពីគេទេ
ពីព្រោះគេគ្មានអ្វីដែលគេចង់លួចឡើយ ឬ ២)
គេនឹងមិនស្តាប់ទេនៅពេលនរណាម្នាក់កែតម្រូវគេ
ព្រោះគេគ្មានអ្វីដែលត្រូវបាត់បង់ទេនៅពេលគេដាក់ពិន័យ។
ការបកប្រែរបៀបផ្សេងទៀត: «មិនស្តាប់ការទូន្មានទេ»

Proverbs 13:9

មនុស្សសុចរិតប្រៀបដូចជាពន្លឺត្រចះត្រចង់

ពន្លឺ តំណាងឲ្យឥទ្ធិពលនៃមនុស្សសុចរិត និង
ពិពណ៌នាអំពីបទពិសោធន៍នៃអារម្មណ៍រីករាយរបស់មនុស្ស។
នេះក៏អាចបញ្ជាក់ជាគំរូដូចនៅ UDB។ ការបកប្រែរបៀបផ្សេងទៀត:
«ឥទ្ធិពលនៃមនុស្សសុចរិតនឹងផ្តល់អំណរ» (សូមមើល: និង

មនុស្សអាក្រក់ប្រៀបដូចជាចង្កៀងរលត់

ចង្កៀងរបស់មនុស្សអាក្រក់ តំណាងឲ្យឥទ្ធិពលរបស់មនុស្សអាក្រក់។
ចង្កៀងរលត់មានន័យថាឥទ្ធិពលរបស់គេត្រូវចប់ដែរ។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សអាក្រក់នឹងបាត់បង់ឥទ្ធិពលរបស់គេ»

ការវាយឫកធំតែងតែបង្កឲ្យមានទំនាស់

«អំនួតតែងតែបង្កបញ្ហា»

ស្តាប់តាម

«យកចិត្តទុកដាក់» ឬ «ដើរតាម»

ដំបូន្មានល្អ

សំណើរដែលជួយ និងផ្តល់ផលប្រយោជន៍

Proverbs 13:11

ទ្រព្យបាត់បង់ក៏រហ័សដែរ

«ទ្រព្យដែលថយទៅ» ឬ «ទ្រព្យដែលអស់បន្តិចម្តងៗ»

ទ្រព្យរកបានដោយសន្សំ

ឃ្លាថា «ធ្វើការដោយដៃ» សំដៅទៅលើការងារពលកម្មប្រើកម្លាំង
ជាជាងការងារប្រើខួរក្បាល ឬ ប្រភេទការងារផ្សេងទៀត។
មនុស្សជាច្រើនមិនសូវឲ្យតម្លៃលើការងារប្រើកម្លាំងទេ»

រកប្រាក់រមែងកើនឡើងជាដរាប

លុយត្រូវបានគេប្រៀបប្រដូចទៅនឹងដើមឈើដែលដុះលូតលាស់។
ការបកប្រែរបៀបផ្សេងទៀត:«គេរកប្រាក់ចម្រើនឡើង»

ការអស់សង្ឃឹម

ពាក្យថា «សង្ឃឹម» នៅទីនេះតំណាងឲ្យអ្វីដែលមនុស្សសង្ឃឹមលើ។
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលមនុស្សម្នាក់សង្ឃឹមលើអ្វីដែលមួយ
ប៉ុន្តែពួកគេមិនបានទទួលវាជាយូរមកហើយ»

ព្រួយចិត្ត

ការខូចចិត្តរបស់មនុស្ស តំណាងឲ្យមនុស្សដែលពិបាកចិត្តខ្លាំង។
ការបកប្រែរបៀបផ្សេងទៀត: «វាធ្វើឲ្យគេកើតទុក្ខជាខ្លាំង»

ដើមឈើដែលមានជីវិត

មនុស្សដែលទទួលបានអ្វីដែលគេសង្ឃឹម ហើយវាធ្វើឲ្យមានក្តីរីករាយ
ត្រូវបានគេចាត់ទុកថា
ការសម្រេចក្តីសង្ឃឹមរបស់គេប្រៀបបានដូចជាដើមឈើដែលផ្តល់ជីវិត។
ការបកប្រែរបៀបផ្សេងទៀត: «ក្តីប្រាថ្នាដ៏វែងឆ្ងាយដូចជាដើមឈើមានជីវិត»

ដើមឈើជីវិត

«ដើមឈើដែលផ្តល់ជីវិត» ឬ «ដើមឈើដែលមានផ្លែទ្រទ្រង់ជីវិត»

generated on Wed Sep 10 16:16:32 2025

បកប្រែពាក្យនេះនៅក្នុងជំពូក ៣:១៧។

Proverbs 13:13

អ្នកដែលគោរពព្រះបន្ទូលតែងតែទទួលរង្វាន់

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គេនឹងផ្តល់រង្វាន់ដល់អ្នកដែលឲ្យតម្លៃដល់ព្រះបន្ទូល»

ប្រភពនៃជីវិត

ប្រភពគឺជាប្រភពទឹកយ៉ាងល្អ ហើយតំណាងឲ្យប្រភពនៃជីវិត។
ការបកប្រែរបៀបផ្សេងទៀត: «ប្រភពនៃជីវិតដែលបរិបូណ៌»

អន្ទាក់នៃសេចក្តីស្លាប់

ពាក្យថា «អន្ទាក់» តំណាងឲ្យគ្រោះថ្នាក់ដែលសម្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «អន្ទាក់ដែលនាំទៅរកសេចក្តីស្លាប់»

Proverbs 13:15

មនុស្សដែលគេទុកចិត្តមិនបានតែងតែវិនាស

សេចក្តីបញ្ចប់ - អាកប្បកិរិយា និង
ការប្រព្រឹត្តត្រូវបានគេចាត់ទុកដូចជាផ្លូវដែលមនុស្សដើរ។

មនុស្សដែលត្រូវបានបំផ្លាញពីទង្វើបោកប្រាស់របស់ខ្លួនឯង

ប្រៀបដូចជាដើរលើផ្លូវដែលមិនចេះចប់។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែអាកប្បកិរិយារបស់មនុស្សបោកប្រាស់នឹងធ្វើឲ្យគេវិនាសដោយខ្លួនឯង»

បោកប្រាស់

គុណនាមបន្ទាប់បន្សំនេះអាចបញ្ជាក់ជាគុណនាម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបោកប្រាស់»

មនុស្សខ្លៅតែងតែលាតត្រដាងភាពល្ងីល្ងើរបស់ខ្លួន

ពាក្យថា «លាតត្រដាង» មានន័យថាបង្ហាញចំពោះមុខមនុស្សគ្រប់គ្នា។
ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សល្ងង់ខ្លៅបង្ហាញភាពល្ងីល្ងើរបស់ខ្លួននៅចំពោះមនុស្សគ្រប់គ្នា»

Proverbs 13:17

ធ្លាក់ខ្លួនអន្តរាយ

«ដែលមិនអាចទុកចិត្តបាន» ឬ «ធ្វើកិច្ចការអាក្រក់»

ទូត

«អ្នកនាំសារ» ឬ «អ្នកការទូត»

ទទួលការកែតម្រូវ

បែបបទនៃគំនិតនេះ «ការកែតម្រូវ» អាចបញ្ជាក់ជាសកម្មភាព។
ការបកប្រែរបៀបផ្សេងទៀត: «បើកចិត្តរៀនពេលនរណាម្នាក់បង្រៀនយើង»

Proverbs 13:19

នាំឲ្យសប្បាយចិត្ត

«សេចក្តីរីករាយ» ឬ «នាំអំណរ»

សេចក្តីប៉ងប្រាថ្នា

សេចក្តីប៉ងប្រាថ្នា ឬ ចំណូលចិត្តចំពោះអ្វីមួយ

នាំឲ្យខ្លួនទៅជាមនុស្សអាក្រក់

«នឹងនាំឲ្យមានគ្រោះថ្នាក់» ឬ «នឹងត្រូវបំផ្លាញ»

Proverbs 13:21

ទុក្ខវេទនាគឺដេញតាមមនុស្សមានបាប

ឃ្លាថា «ទុក្ខវេទនា» ត្រូវបានប្រៀបទៅនឹងលក្ខណៈរបស់មនុស្សដែលដូចជាសមត្ថភាពដែលពួកគេរត់។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបាបនឹងមានបញ្ហាគ្រប់ទីកន្លែងដែលពួកគេទៅ»

មនុស្សសុចរិតតែងតែទទួលសុភមង្គលទុកជារង្វាន់

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងផ្តល់រង្វាន់យ៉ាងល្អដល់មនុស្សសុចរិត»

កូនចៅ

«កូនចៅរបស់គេ» ឬ «កូនៗរបស់គេ» ឬ «កូនចៅរបស់គេ»

មនុស្សបាបតែងតែប្រមូលទ្រព្យទុកសម្រាប់មនុស្សសុចរិត

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលប្រព្រឹត្តត្រឹមត្រូវនឹងទទួលទ្រព្យដែលមនុស្សអាក្រក់ខំសន្សំទុក»

Proverbs 13:23

ស្រែដែលមិនទាន់ភ្ជួររាស់

«ស្រែដែលមិនទាន់រួចរាល់ដើម្បីបង្កបង្កើតផល» ឬ
«ស្រែដែលមិនទាន់រួចរាល់ដើម្បីដាំដុះ»

ប៉ុន្តែ មានអ្នកខ្លះស្លាប់ ព្រោះតែខ្វះយុត្តិធម៌

ពាក្យថា «ដកចេញ» តំណាងឲ្យការដកអ្វីមួយចេញទាំងស្រុង។
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែភាពអយុត្តិធម៌ដកអាហារចេញពីគេ» ឬ
«ប៉ុន្តែមនុស្សអយុត្តិធម៌ដកអាហារចេញ»

តែងតែបង្រៀនប្រដៅដល់កូនៗ

«តែងតែអប់រំទូន្មានកូន»

Proverbs 13:25

តែងតែមានអាហារបរិភោគគ្រប់គ្រាន់

«គេបានបំពេញចិត្តខ្លួនឯង» ឬ «គេបានបំពេញសេចក្តីត្រូវការខ្លួនឯង»

មនុស្សអាក្រក់តែងតែអត់ខ្វះខាត

ពាក្យថា «ក្រពះ» នៅទីនេះតំណាងឲ្យសេចក្តីប៉ងប្រាថ្នារបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សអាក្រក់តែងតែស្រេកឃ្លាន»

---

14 [1]ស្ត្រីមានប្រាជ្ញាតែងតែកសាងគ្រួសាររបស់ខ្លួន ប៉ុន្តែស្ត្រីដែលគ្មានគំនិតតែងតែបំផ្លាញគ្រួសារ ដោយដៃរបស់នាងផ្ទាល់។[2]អ្នកដែលដើរតាមផ្លូវទៀងត្រង់ តែងតែគោរពកោតខ្លាច ព្រះអម្ចាស់ ប៉ុន្តែអ្នកដែលដើរតាមផ្លូវវៀចវេរ តែងតែមើលងាយព្រះអង្គ។
[3]មនុស្សល្ងង់ខ្លៅហាមាត់និយាយតែពាក្យអួតអាងរបស់គេ ប៉ុន្តែពាក្យសម្តីរបស់អ្នកប្រាជ្ញតែងតែការពារខ្លួន។[4]អ្នកណាគ្មានគោភ្ជួរស្រែ អ្នកនោះក៏គ្មានស្រូវដាក់ក្នុងជង្រុកដែរ តែគេទទួលបានភោគផលច្រើន ដោយសារកម្លាំងរបស់គោ។
[5]សាក្សីគួរឲ្យទុកចិត្ត មិនដែលនិយាយកុហកទេ ប៉ុន្តែសាក្សីក្លែងក្លាយតែងតែនិយាយចេញនូវពាក្យកុហកគ្រប់យ៉ាង។[6]មនុស្សព្រហើនខំស្វែងរកប្រាជ្ញា តែរកមិនបានទេ ប៉ុន្តែមនុស្សដែលមានចំណេះដឹងវិញ រកតម្រិះបានយ៉ាងងាយ។
[7]ចូរចៀសឲ្យឆ្ងាយពីមនុស្សខ្លៅ ព្រោះអ្នកនឹងមិនអាចឮពាក្យចេះដឹងចេញពីមាត់អ្នកនោះឡើយ។[8]ប្រាជ្ញារបស់មនុស្សឆ្លាត គឺការយល់ច្បាស់នូវផ្លូវដែលខ្លួនកំពុងដើរ ប៉ុន្តែភាពល្ងីល្ងើរបស់មនុស្សខ្លៅ គឺកលល្បិចរបស់គេ។
[9]មនុស្សល្ងីល្ងើតែងសើចចំអក នឹងតង្វាយលើកលែងទោសតែមនុស្សទៀងត្រង់ នោះគាប់ព្រះហឫទ័យព្រះវិញ។[10]ចិត្តដែលកើតទុក្ខរមែងឈឺចាប់តែម្នាក់ឯង ហើយពេលមានអំណរ អ្នកក្រៅពុំអាចរំលែកបានឡើយ។
[11]ផ្ទះរបស់មនុស្សអាក្រក់នឹងត្រូវរលំ ប៉ុន្តែជំរំរបស់មនុស្សទៀងត្រង់ នឹងចម្រុងចម្រើន។[12]មនុស្សខ្លះយល់ថា ផ្លូវដែលខ្លួនដើរជាផ្លូវត្រឹមត្រូវ ក៏ប៉ុន្តែ នៅទីបំផុត ផ្លូវនោះនាំទៅរកសេចក្តីស្លាប់។
[13]ការសើចសប្បាយអាចបង្កប់នូវទុក្ខលំបាកក្នុងចិត្ត ហើយនៅទីបំផុតអំណរសប្បាយ អាចក្លាយទៅជាទុក្ខព្រួយ។[14]មនុស្សគ្មានសីលធម៌តែងតែទទួលផលពីអំពើដែលខ្លួនប្រព្រឹត្ត ប៉ុន្តែមនុស្សសប្បុរសរមែងទទួលផលគាប់ប្រសើរ។
[15]មនុស្សឆោតជឿពាក្យគេទាំងអស់ ប៉ុន្តែមនុស្សឆ្លាត មិនធ្វើអ្វីដោយឥតគិតពិចារណាឡើយ។[16]មនុស្សមានប្រាជ្ញាតែងតែខ្លាច និងចៀសវាងប្រព្រឹត្តអំពើអាក្រក់ ប៉ុន្តែមនុស្សល្ងង់ខ្លៅឆាប់ប្រព្រឹត្តអំពើអាក្រក់ ព្រោះទុកចិត្តលើខ្លួន។
[17]អ្នករហ័សខឹងតែងតែប្រព្រឹត្តអំពើមិនត្រឹមត្រូវ ប៉ុន្តែអ្នកដែលមានកលល្បិច តែងតែធ្វើឲ្យគេស្អប់។[18]មនុស្សឆោតតែងតែទទួលភាពល្ងីល្ងើទុកជាមរតក ប៉ុន្តែមនុស្សឆ្លាតរមែងទទួលយកការចេះដឹងទុកជាកិត្តិយស។
[19]មនុស្សអាក្រក់មុខជាឱនកាយ គោរពមនុស្សល្អ ហើយឈរចាំនៅមាត់ទ្វារផ្ទះរបស់មនុស្សសុចរិត។[20]អ្នកក្រីក្រតែងតែមានគេស្អប់ សូម្បីតែអ្នកជិតជិតក៏មិនរាប់អានដែរ ប៉ុន្តែអ្នកមានវិញ គឺមានមិត្តច្រើនរាប់អានណាស់។
[21]អ្នកណាមើលងាយអ្នកដទៃ អ្នកនោះជាមនុស្សបាប ប៉ុន្តែអ្នកដែលមានចិត្តមេត្តាដល់ជនក្រីក្រ នឹងបានទទួលពរ។[22]តើអស់អ្នកដែលមានបំណងអាក្រក់តែងតែត្រូវវង្វេងឬ? ប៉ុន្តែអ្នកដែលមានបំណងល្អរមែងទទួលបានចិត្តសប្បុរស និងស្មោះត្រង់ជានិច្ច។

generated on Wed Sep 10 16:16:32 2025

[23]អ្នកណាធ្វើការ អ្នកនោះតែងតែទទួលប្រាក់ចិញ្ចឹមជីវិត ប៉ុន្តែអ្នកដែលពូកែព្រោកប្រាជ្ញរមែងធ្លាក់ខ្លួនក្រ។[24]សម្បត្តិស្តុកស្តម្ភជារង្វាន់របស់មនុស្សមានប្រាជ្ញា តែមនុស្សល្ងង់ខ្លៅនៅតែល្ងង់ខ្លៅ។
[25]សាក្សីដែលគេទុកចិត្តតែងតែជួយសង្គ្រោះជីវិត តែសាក្សីមិនពិតគឺដកដង្ហើមចេញមកដោយការកុហក។
[26]អ្នកណាគោរពកោតខ្លាចព្រះអម្ចាស់ អ្នកនោះមានទីបង្អែកដ៏រឹងមាំក្នុងព្រះជាម្ចាស់ ហើយការទាំងនោះគឺដូចជាធ្វើជម្រកដល់កូនចៅរបស់ពួកគេ។[27]ការគោរពកោតខ្លាចព្រះអម្ចាស់ជាប្រភពនៃជីវិត ដូច្នេះ ហើយការពារខ្លួនឲ្យរួចផុតពីអន្ទាក់របស់សេចក្តីស្លាប់។
[28]ព្រះមហាក្សត្របានរុងរឿងដោយសារមានប្រជារាស្ត្រ តែបើប្រជារាស្ត្រចុះអន់ថយ ស្តេចក៏អស់អំណាចដែរ។[29]អ្នកណាចេះអត់ធ្មត់ អ្នកនោះមានប្រាជ្ញាវាងវៃ ប៉ុន្តែអ្នកដែលរហ័សខឹង រមែងបង្ហាញនូវភាពលេលារបស់ខ្លួន។
[30]ចិត្តស្ងប់តែងតែធ្វើឲ្យមានសុខភាពល្អ ប៉ុន្តែចិត្តច្រណែននិន្ទា ប្រៀបដូចជាមហារីកនៅក្នុងឆ្អឹង។[31]អ្នកណាសង្កត់សង្កិនជនក្រីក្រ អ្នកនោះប្រមាថព្រះជាម្ចាស់ដែលបានបង្កើតពួកគេ អ្នកណាជួយជនក្រីក្រ អ្នកនោះលើកតម្កើងព្រះអង្គវិញ។
[32]មនុស្សអាក្រក់តែងតែទទួលបរាជ័យ ដោយសារអំពើអាក្រក់របស់ខ្លួន ប៉ុន្តែមនុស្សសុចរិត ទោះបីក្នុងពេលស្លាប់ក្តី ក៏នៅតែមានទីពឹងជានិច្ច។[33]ប្រាជ្ញានៅក្នុងចិត្តគឺតែងតែនាំឲ្យចេះគិតពិចារណា ប៉ុន្តែមនុស្សខ្លៅមិនដែលមានប្រាជ្ញាទេ។
[34]សេចក្តីសុចរិតតែងតែលើកតម្កើងប្រជាជាតិមួយ ប៉ុន្តែអំពើបាបរមែងធ្វើឲ្យជាតិសាសន៍ទាំងឡាយត្រូវអាម៉ាស់មុខ។[35]ព្រះមហាក្សត្រតែងតែសព្វព្រះហឫទ័យនឹងមន្ត្រីណាដែលមានសុភនិច្ឆ័យ តែស្តេចខ្ញាល់នឹងមន្ត្រីដែលបង្កភាពអាម៉ាស់។

Proverbs 14:1

កសាងគ្រួសាររបស់ខ្លួន

«សង់គ្រួសារនាងឡើង» ឬ «កសាងគ្រួសារឲ្យប្រសើរឡើង»

ផ្ទះ

អាចមានន័យថា គឺ១) នេះសំដៅទៅលើផ្ទះពិតរបស់នាង
នោះគឺជាអាគារដែលនាងរស់នៅ ឬ ២) នេះអាចសំដៅលើគ្រួសាររបស់នាង។ (UDB)

ដោយដៃរបស់នាងផ្ទាល់

ពាក្យថា «ដៃ» តំណាងឲ្យសកម្មភាពដែលនាងធ្វើ។ ការបកប្រែរបៀបផ្សេងទៀត: «ដោយខ្លួនឯង» ឬ «ដោយរបៀបដែលនាងប្រព្រឹត្ត»

អ្នកដែល...អ្នកដែល

«មនុស្សដែល...មនុស្សដែល»

ដើរតាមផ្លូវទៀងត្រង់

ពាក្យថា «ដើរ» តំណាងឲ្យការដឹកនាំជីវិត។ ការបកប្រែរបៀបផ្សេងទៀត: «ដឹកនាំជីវិតតាមរបៀបត្រឹមត្រូវ និង ស្មោះត្រង់»

មើលងាយ

«ការមិនគោរពទាំងស្រុង» ឬ «បង្ហាញថាគេស្អប់»

តែងតែមើលងាយព្រះអង្គ

ពាក្យថា «របស់គាត់» សំដៅទៅលើមនុស្សមិនគោរព និង «ព្រះអង្គ» សំដៅលើព្រះអម្ចាស់។

Proverbs 14:3

មាត់...បបូរមាត់

មាត់ និង បបូរមាត់ពាក្យទាំងពីរនេះសំដៅទៅលើអ្វីដែលមនុស្សនិយាយ។

និយាយតែពាក្យអួតអាងរបស់គេ

ពាក្យអួតអាងគឺជាអ្វីដែលដុះចេញពីអ្វីមួយទៀត។ ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលសេចក្តីអំនួតរបស់គេផ្តល់ផល»

អ្នកប្រាជ្ញ

ពាក្យនេះគឺជាពហុវចន:។ «មនុស្សមានប្រាជ្ញា» ឬ «មនុស្សឆ្លាតវៃ»

ការពារខ្លួន

«នឹងការពារពួកគេពីគ្រោះថ្នាក់» ឬ «នឹងជួយគេឲ្យមានសុវត្ថិភាព

ជង្រុក

«ជង្រុក» ជាធុងដែលទុកដាក់ចំណីសម្រាប់សត្វ។

ភោគផលច្រើន

«ភោគផលច្រើន»

ដោយសារកម្លាំងរបស់គោ

«កម្លាំង» តំណាងឲ្យការងារខ្លាំងដូចសត្វគោ។ ការបកប្រែរបៀបផ្សេងទៀត: «ដោយសារកិច្ចការដែលគោធ្វើ»

Proverbs 14:5

និយាយចេញនូវពាក្យកុហក

ការនិយាយនេះប្រើពាក្យ «ដង្ហើម» ចង់សំដៅទៅលើការនិយាយកុហកឥតឈប់ឈរ។ ការបកប្រែរបៀបផ្សេងទៀត: «កុហករហូត» ។ សូមមើលរបៀបដែលអ្នកបកប្រែឃ្លានេះនៅក្នុងជំពូក ៦:១៧។

រកមិនបានទេ

«ហើយគ្មានប្រាជ្ញានៅទីនោះទេ» ឬ «ប៉ុន្តែគេនឹងរកប្រាជ្ញាមិនឃើញទេ» (UDB)

បានយ៉ាងងាយ

«រកបានយ៉ាងស្រួល» ឬ «រកបានដោយស្រួល»

មនុស្សដែលមានចំណេះដឹង

«មនុស្សដែលមានប្រាជ្ញា» ឬ «មនុស្សដែលមានការយល់ដឹង»

Proverbs 14:7

មាត់

ពាក្យថា «បបូរមាត់» តំណាងឲ្យអ្វីដែលមនុស្សនិយាយ។
ការបកប្រែរបៀបផ្សេងទៀត: «ចេញពីមាត់របស់យើង» ឬ «ចេញពីមតិរបស់យើង»

មនុស្សឆ្លាត

មនុស្សដែលមានវិនិច្ឆ័យល្អ ឬ ការគិតល្អ

ផ្លូវដែលខ្លួនកំពុងដើរ

ពាក្យថា «ផ្លូវ» តំណាងឲ្យការរៀបចំជីវិតរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ការរៀបចំរបស់គេ» ឬ «របៀបដែលគេរស់នៅ»

ភាពល្ងីល្ងើរបស់មនុស្សខ្លៅ គឺកលល្បិចរបស់គេ

ភាពល្ងង់ខ្លៅរបស់មនុស្សល្ងីល្ងើដែលគេគិតថាគេឆ្លាត តែតាមពិតមិនមែន។

Proverbs 14:9

តង្វាយលើកលែងទោស

ឃ្លាថា «ទោស» ឬ «តង្វាយលើកលែងទោស»
អត្ថន័យនៅពីក្រោយឃ្លានេះគឺមនុស្សល្ងីល្ងើមិនចេះសុំទោសចំពោះព្រះជាម្ចាស់ ឬ មនុស្សនៅចំពោះអ្វីដែលគេបានធ្វើខុស។

តែមនុស្សទៀងត្រង់ នោះគាប់ព្រះហឫទ័យព្រះវិញ

នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែមនុស្សទៀងត្រង់រីករាយនឹងការពេញចិត្តជាមួយគ្នា» ឬ «ប៉ុន្តែព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងមនុស្សស្មោះត្រង់»

ចិត្តដែលកើតទុក្ខ

«ទុក្ខសោក» ឬ «សោកសៅ»

អ្នកក្រៅ

«អស់អ្នកដែលមិនស្គាល់គេ»

Proverbs 14:11

ជំរំ

ពាក្យថា «ជំរំ» តំណាងឲ្យអ្វីៗដែលកើតឡើងនៅក្នុងវា។
ការបកប្រែរបៀបផ្សេងទៀត: «ផ្ទះ»

ចម្រុងចម្រើន

ពាក្យថា «ចម្រុងចម្រើន» មានន័យដូចជាផ្កាដែលរីកលូតលាស់ ហើយតំណាងឲ្យអ្វីៗដែលលូតលាស់យ៉ាងរឹងមាំ។ ការបកប្រែរបៀបផ្សេងទៀត: «ដែលធ្វើបានល្អ និងបានយូរ» ឬ «ដែលមានសុខភាពល្អ» ឬ «ដែលជោគជ័យខ្លាំង»

មនុស្សខ្លះយល់ថា ផ្លូវដែលខ្លួនដើរជាផ្លូវត្រឹមត្រូវ

ពាក្យថា «ផ្លូវ» តំណាងឲ្យការរៀបចំជីវិតដើម្បីឲ្យមនុស្សដើរតាម។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សគិតថារបៀបដែលគេរស់នៅគឺត្រឹមត្រូវ»

Proverbs 14:13

ការសើចសប្បាយ

ពាក្យថា «ចិត្ត» តំណាងឲ្យអារម្មណ៍ ឥរិយាបថ និង ការជំរុញចិត្តរបស់មនុស្ស។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «អារម្មណ៍របស់មនុស្សអាចបង្ហាញតាមការសើច»
បង្កប់នូវទុក្ខសំបាក
«មានការឈឺចាប់» ឬ «ឈឺចាប់»
មនុស្ស
«មនុស្សដែល»
ទទួលផលពីអំពើដែលខ្លួនប្រព្រឹត្ត
ពាក្យថា «របៀប» តំណាងឲ្យការរបៀបចំជីវិតរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:«អ្វីដែលគេសមនឹងទទួល
វាអាស្រ័យលើរបៀបដែលរស់នៅ»
ទទួលផលតាប់ប្រសើរ
«អ្វីដែលជាកម្មសិទ្ធរបស់គេ» ឬ «អ្វីដែលគេមាន»
Proverbs 14:15
មនុស្សឆោត
«គ្មានបទពិសោធន៍ ក្មេងខ្ចី»
គិតពិចារណា
គំនិតនេះ តំណាងឲ្យឥរិយាបថរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«សកម្មភាពរបស់គេ»
ចៀសវាងប្រព្រឹត្តអំពើអាក្រក់
ការអាក្រក់នេះ ត្រូវបានគេចាត់ទុកថាជាទីកន្លែង។ ការបកប្រែរបៀបផ្សេងទៀត:
«ជៀសវាងប្រព្រឹត្តការអាក្រក់»
បោះបង់ព្រោះទុកចិត្តលើខ្លួន
«មិនអើពើយ៉ាងមោះមុត»
Proverbs 14:17
រហ័សខឹង
«ឆាប់ខឹង»
មនុស្សឆោត
«មិនមានបទពិសោធន៍ នៅក្មេងខ្ចី»
ទទួលភាពល្ងីល្ងើទុកជាមរតក
ពាក្យថា «ទទួលមរតក»
នៅទីនេះតំណាងឲ្យការកាន់កាប់របស់អ្វីមួយជារៀងរហូត។
ភាពល្ងីល្ងើ
ពាក្យថា «ភាពល្ងីល្ងើ» ជានាមអរូបីដែលតំណាងឲ្យការគិតល្ងីល្ងើ និង
សកម្មភាពល្ងីល្ងើ។
មនុស្សឆ្លាត
មនុស្សឆ្លាត
ទទួលយកការចេះដឹងទុកជាកិត្តិយស
ការចេះដឹង
ត្រង់នេះត្រូវបានគេចាត់ទុកថាជាគ្រឿងតុបតែងដ៏ស្រស់ស្អាតដែលពាក់លើក្បាល
ដូចជាខ្សែក្រវ៉ាត់ជាមួយគ្រឿងអលង្ការ។ ការបកប្រែរបៀបផ្សេងទៀត:
«ក្រវ៉ាត់ការចេះដូចជាពាក្យខ្សែក្រវ៉ាត់»
Proverbs 14:19
ឱនកាយ
នេះមានន័យថាឱនចុះដោយការបន្ទាបខ្លួនដើម្បីបង្ហាញពីការគោរព និង
ផ្តល់កិត្តិយសចំពោះនរណាម្នាក់។
សកម្មភាពនេះតំណាងឲ្យការផ្តល់អំណោយដល់មនុស្សដែលមានឥទ្ធិពល។
(សូមមើល:figs-synecdoche)
មាត់ទ្វារផ្ទះរបស់មនុស្សសុចរិត
ពាក្យថា «មាត់ទ្វារ» តំណាងឲ្យច្រកចូលដើម្បីទៅជួបនរណាម្នាក់។
នេះមានន័យថាមនុស្សអាក្រក់នឹងរង់ចាំមនុស្សសុចរិត ហើយអង្វរសុំជួបគេ។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីជួបមនុស្សសុចរិត»
អ្នកក្រីក្រតែងតែមានគេស្អប់ សូម្បីតែអ្នកជិតជិតក៏មិនរាប់អានដែរ
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់គ្នាស្អប់អ្នកក្រសូម្បីតែអ្នកជិតខាងរបស់គេ»
Proverbs 14:21
អស់អ្នក...អស់អ្នក
«មនុស្ស...មនុស្ស»
មនុស្សក្រីក្រ
«មនុស្សក្រីក្រ»
តើអស់អ្នកដែលមានបំណងអាក្រក់តែងតែត្រូវវង្វេងឬ?
ចម្លើយដែលឆ្លើយតបចំពោះសំណួរនេះ «ចាស/បាទ»។
ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលធ្វើអាក្រក់នឹងត្រូវវង្វេង»
មានបំណងអាក្រក់
«អ្នកដែលមានគម្រោងអាក្រក់» ឬ «អ្នកដែលមានផែនការធ្វើការអាក្រក់»
Proverbs 14:23
ប៉ុន្តែអ្នកដែលពូកែព្រោកប្រាជ្ញរមែងធ្លាក់ខ្លួនក្រ
«ប៉ុន្តែបើអ្នកដែលពូកែនិយាយ» ឬ «ប៉ុន្តែពេលដែលមនុស្សគិតតែពីនិយាយ»
សម្បត្តិស្តុកស្តម្ភជារង្វាន់របស់មនុស្សមានប្រាជ្ញា
ពាក្យថា «ម្កុដ» តំណាងឲ្យសមិទ្ធិផលខ្ពង់ខ្ពស់ដែលអាចមាន និង
មើលឃើញចំពោះមនុស្សគ្រប់គ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«រង្វាន់សម្រាប់មនុស្សឆ្លាត»
មនុស្សល្ងង់ខ្លៅ
បកប្រែឃ្លានេះនៅក្នុងជំពូក ១៤: ៧។
Proverbs 14:25
ដកដង្ហើមចេញមកដោយការកុហក
ចំនួននៃការលើកមកនិយាយនេះប្រើពាក្យ «ដកដង្ហើម»
សំដៅការកុហកឥតឈប់ឈរ។
សូមមើលរបៀបអ្នកដែលបកប្រែឃ្លានេះនៅក្នុងជំពូក ៦:១៧។
ការបកប្រែរបៀបផ្សេងទៀត: «កុហកឥតឈប់ឈរ»
Proverbs 14:26
ប្រភពនៃជីវិត
ពាក្យថា «ប្រភព» គឺជាប្រភពទឹក និងនៅទីនេះតំណាងឲ្យប្រភពជីវិត។
ការបកប្រែរបៀបផ្សេងទៀត: «ប្រភពនៃជីវិត»
អន្ទាក់របស់សេចក្តីស្លាប់
ពាក្យថា «អន្ទាក់» ជាប្រភេទនៃអន្ទាក់ដែលប្រើដើម្បីសម្លាប់សត្វ និង
តំណាងឲ្យអ្វីដែលមានល្បិច និង គ្រោះថ្នាក់ដែលនឹងសម្លាប់ជីវិត។
ការបកប្រែរបៀបផ្សេងទៀត: «ពីអន្ទាក់ដែលនឹងសម្លាប់ជីវិត»
Proverbs 14:28
ប្រជារាស្ត្រ
«ចំនួនមនុស្សដែលគេគ្រប់គ្រង»
ស្តេចក៏អស់អំណាច
«ស្តេចដែលគ្មានអ្វីទាំងអស់ និង រាជ្យត្រូវធ្លាក់ចុះ»
រហ័សខឹង
ឆេវឆាវ មនុស្សដែលងាយនឹងខឹង។
Proverbs 14:30
ចិត្តស្ងប់
«ផ្នត់គំនិតដែលប្រកបដោយសន្តិភាព» ឬ
«អកប្បកិរិយាដែលប្រកបដោយសន្តិភាព»
ហារីកនៅក្នុងឆ្អឹង
ពាក្យថា «ផុយរលួយ» តំណាងឲ្យភាពពុករលួយរបស់មនុស្ស ហើយពាក្យថា
«ឆ្អឹង» តំណាងឲ្យមនុស្សទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«បង្កឲ្យមនុស្សឈឺទាំងសាច់ឈាម និង ព្រលឹងវិញ្ញាណ»
អ្នកណាដែល...អ្នកណាដែល
«មនុស្សដែល...មនុស្សដែល»
បណ្តាសារ
នេះមានន័យថាបង្ហាញពីបំណងចិត្តដើម្បីឲ្យការអាក្រក់នឹងកើតឡើងចំពោះនរណាម្នាក់។
ជនក្រីក្រ...ជនក្រីក្រ
«មនុស្សក្រីក្រ...មនុស្សទ័លក្រ»
ជួយ
«ចិត្តល្អ» ឬ «ជួយគេ»
Proverbs 14:32
ទទួលបរាជ័យ ដោយសារអំពើអាក្រក់របស់ខ្លួន
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទង្វើអាក្រក់ទាញឲ្យធ្លាក់ចុះ» ឬ «ទង្វើអាក្រក់នាំឲ្យវិនាស»
ប្រាជ្ញានៅក្នុងចិត្ត
ពាក្យថា «ចិត្ត» តំណាងឲ្យអារម្មណ៍ ឥរិយាបថ និង ការជម្រុញចិត្តរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាជ្ញានៅក្នុងឥរិយាបថ»
ចេះគិតពិចារណា
«មនុស្សចេះគិតពិចារណា»

generated on Wed Sep 10 16:16:32 2025

ប្រាជ្ញាឲ្យគេស្គាល់ខ្លួន
នេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រាជ្ញាតែងតែឲ្យគេស្គាល់ខ្លួន»
នាង
ពាក្យថា «នាង» សំដៅទៅលើប្រាជ្ញា។
Proverbs 14:34
អាម៉ាស់មុខ
«ធ្វើឲ្យអាម៉ាស់មុខ»
មានសុភនិច្ឆ័យ
«ឆ្លាតវៃ»
អ្នកដែល
«មន្ត្រីដែល»

15 [1]ចម្លើយទន់ភ្លន់រមែងបន្ថយកំហឹង ប៉ុន្តែសម្តីគំរោះគំរើយតែងតែធ្វើឲ្យច្រឡោតខឹង។[2]សម្តីរបស់អ្នកមានប្រាជ្ញា រមែងធ្វើឲ្យអ្នកដទៃចង់ចេះដឹង ប៉ុន្តែមាត់របស់មនុស្សខ្លៅ សាបព្រោះតែសេចក្តីល្ងីល្ងើ។
[3]ព្រះអម្ចាស់ទតឃើញសព្វអន្លើ ព្រះអង្គសង្កេតមើលទាំងមនុស្សល្អ ទាំងមនុស្សអាក្រក់។[4]ពាក្យនៃការព្យាបាលប្រៀបដូចជាដើមឈើនៃជីវិត ប៉ុន្តែសម្តីបោកប្រាសនាំឲ្យធ្លាក់ចុះខាងវិញ្ញាណ។
[5]មនុស្សល្ងីល្ងើតែងតែមើលងាយការប្រៀនប្រដៅរបស់ឪពុក តែអ្នកដែលស្តាប់តាមពាក្យកែតម្រូវជាមនុស្សឆ្លាត។[6]ផ្ទះរបស់មនុស្សសុចរិតតែងមានសម្បត្តិច្រើន តែទ្រព្យដែលរកបានដោយអំពើអាក្រក់ រមែងនាំឲ្យកើតទុក្ខ។
ការងារ ដូចដេញចាប់ខ្យល់
អាចមានន័យថា គឺ១) «ព្យាយាមដើម្បីចាប់ខ្យល់» ឬ ២)
«ធ្វើការសម្រាប់ខ្យល់ដកដង្ហើម»
មិនតែប៉ុណ្ណោះគេរស់នៅក្នុងសេចក្ដីងងឹត
នៅទីនេះគឺជាឃ្លា «ភាពងងឹត» សំដៅលើការវេលាដែលអស់សង្ឃឹម។
អាចមានន័យថា គឺ១) «អំឡុងពេលនៃជីវិតរបស់គាត់គឺគាត់បរិភោគការកាន់ទុក្ខ»
ឬ ២) «ជីវិតរបស់គាត់ចំនាយលើការកាន់ទុក្ខ»
ហើយកើតទុក្ខលំបាកយ៉ាងខ្លាំងដោយជំងឺ និងក្តៅក្រហាយផង
ការបកប្រែរបៀបផ្សេងទៀត: «ហើយការឈឺចាប់ដ៏ខ្លាំងនៅតែបន្ត
ហើយនិងកំហឹង»
Ecclesiastes 5:18
មើល
«ប្រុងស្មារតី» ឬ «សូមស្តាប់»
អ្វីដែលខ្ញុំបានឃើញថាជាការល្អ និងប្រពៃ
នេះគឺជាឃ្លា «ល្អ» ហើយ «ប្រពៃ» ន័យមូលដ្ឋានមានន័យដូចគ្នា។
ទីពីរបង្កើនន័យឲ្យទីមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលខ្ញុំបានឃើញជាការសម្រាប់ធ្វើ»។
ក្នុងពេលដែលព្រះជាម្ចាស់បានប្រទានឲ្យមានជីវិត
ការបកប្រែរបៀបផ្សេងទៀត:
«បើសិនជាព្រះជាម្ចាស់នៅតែប្រទានជីវិតឲ្យយើងរស់»
ភារកិច្ចរបស់មនុស្ស
អាចមានន័យថា គឺ១) «រង្វាន់របស់មនុស្ស» ឬ ២) «មនុស្សមានអ្វីច្រើនក្នុងជីវិត»។
Ecclesiastes 5:19
ទ្រព្យសម្បត្តិ ធនធាន
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានគឺដូចគ្នា។ ការទាំងពីរយ៉ាងបានសំដៅទៅលើលុយ
ហើយនិងអ្វីដែលមនុស្សអាចទិញជាមួយលុយបាន។
ទទួលយកនូវអ្វីដែលព្រះបានប្រទានឲ្យ និងអរសប្បាយនៅក្នុងកិច្ចការរបស់ខ្លួន
ការនេះបានបញ្ជាក់ន័យពីលទ្ធិភាព ដើម្បីធ្វើឲ្យស្កប់ចិត្ត
ហើយរីករាយជាមួយកិច្ចការរបស់គាត់។
ដ្បិតគេនឹងមិននឹកចាំ
នៅទីនេះគឺជាឃ្លា «គាត់»
សំដៅលើមនុស្សដែលព្រះជាម្ចាស់បានប្រទានអំណោយទាន។
ការបកប្រែរបៀបផ្សេងទៀត: «គាត់មិនអាចនឹកឃើញ»
ពីអាយុជីវិតរបស់ខ្លួនទេ
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលបានកើតឡើងនៅក្នុងពេលជីវិតរបស់គាត់»
ធ្វើឲ្យគេរស់
«រស់ជានិច្ច»

---

6 [1]នេះគឺជាអំពើអាក្រក់ដែលខ្ញុំបានឃើញនៅក្រោមថ្ងៃ ហើយការនេះគឺជាការធ្ងន់ធ្ងរណាស់សម្រាប់មនុស្ស។[2]ព្រះជាម្ចាស់នឹងប្រទានទ្រព្យសម្បត្តិ ធនធាន
និងកិត្តិយសឲ្យមនុស្ស ដូច្នេះហើយគេមិនខ្វះខាតអ្វីទេ គេពេញចិត្តនឹងខ្លួនគេ ប៉ុន្តែ ព្រះជាម្ចាស់មិនប្រទានឲ្យគេមានសមត្ថភាពក្នុងការសប្បាយរីករាយនោះទេ។
គឺមានម្នាក់ទៀតទទួលជំនួសវិញ។ ការនេះគឺឥតបានការ ហើយអាក្រក់បំផុត។
[3]ប្រសិនមានឪពុកម្នាក់មានកូនមួយរយ ហើយរស់នៅបានច្រើនឆ្នាំ ទោះបីគាត់រស់នៅបានច្រើនឆ្នាំក៏ដោយ ប៉ុន្តែបើសិនចិត្តរបស់គាត់មិនចេះស្កប់ស្កល់ដោយសេចក្ដីល្អ
ហើយគាត់មិនបានធ្វើពិធីបញ្ចុះដោយកិត្តិយសផង ខ្ញុំយល់ថាកូនដែលកើតមកស្លាប់នោះគឺល្អប្រសើរជាងគាត់ទៅទៀត។[4]ទោះបីជាកូននោះដែលកើតដោយឥតប្រយោជន៍
ហើយស្លាប់បាត់ក្នុងទីងងឹត ហើយគ្មាននរណានឹកនា។
[5]ទោះបីជាកូននោះមិនបានឃើញពន្លឺថ្ងៃ ឬស្គាល់អ្វីទាំងអស់ ប៉ុន្តែវាសុខជាងអ្នកដែលមានអាយុវែងនោះទៅទៀត។[6]ទោះបីជាបុរសនោះអាចរស់បានពីរពាន់ឆ្នាំក្តី
ប៉ុន្តែគេមិនបានរៀនពីសេចក្ដីល្អនោះ គេគង់តែទៅកន្លែងដូចអ្នកដ៏ទៃទៀតដែរ។
[7]គ្រប់កិច្ចការទាំងអស់ដែលមនុស្សធ្វើគឺបានត្រឹមតែមាត់គេប៉ុណ្ណោះ ពុំទាន់អាចបំពេញសេចក្ដីស្រែកឃ្លានរបស់គេបានទេ។[8]ជាការពិតណាស់
តើមនុស្សដែលមានប្រាជ្ញាមានគុណសម្បត្តិអ្វីលើសជាងមនុស្សល្ងីល្ងើ? តើមនុស្សក្រីក្រមានគុណសម្បត្តិអ្វី ទោះបីជាគេដឹងពីការប្រព្រឹត្តនៅចំពោះមុខមនុស្សដទៃទៀត?
[9]ជាការល្អប្រសើរក្នុងការដែលភ្នែកស្កប់ស្កល់នឹងអ្វីដែលបានឃើញជាជាងចង់បានអ្វីដោយការវង្វេងស្រែកឃ្លានខ្លាំង នេះជាការឥតបានការ
និងដូចជាការដេញចាប់ខ្យល់ដែរ។[10]អ្វីៗដែលកើតមកស្រាប់ សុទ្ធតែមានឈ្មោះរបស់ខ្លួនស្រេច ហើយក៏ដឹងថាអ្វីទៅដែលហៅថាមនុស្សដែរ។ ដូច្នេះហើយ
គេពុំអាចជជែកតវ៉ានឹងអ្នកដែលខ្លាំងជាងខ្លួនបានឡើយ។[11]និយាយកាន់តែច្រើនយ៉ាងណា ការឥតប្រយោជន៍កាន់តែច្រើនយ៉ាងនោះដែរ ដូច្នេះ
តើមនុស្សបានប្រយោជន៍អ្វីខ្លះទៅ?[12]ដ្បិត តើអ្នកណាដឹងថាអ្វីទៅការល្អសម្រាប់មនុស្សនៅក្នុងជីវិតដែលគ្មានប្រយោជន៍របស់គេ
ចំនួនថ្ងៃដែលគេឆ្លងកាត់ដូចជាស្រមោលបាន? តើអ្នកណាអាចប្រាប់មនុស្សពីអ្វីដែលនឹងកើតមាននៅក្រោមថ្ងៃ ក្រោយពីគេស្លាប់ផុតទៅ?

Ecclesiastes 6:1
ការធ្ងន់ធ្ងរណាស់សម្រាប់មនុស្ស
ការបកប្រែរបៀបផ្សេងទៀត: «វាបានធ្វើឲ្យជីវិតរបស់ពិបាកខ្លាំង»
ទ្រព្យសម្បត្តិ ធនធាន
ឃ្លាទាំងពីរមានន័យមូលដ្ឋានដូចគ្នា។ ពាក្យទាំងពីរសំដៅទៅលើលុយ
ហើយនិងរបស់អ្វីដែលអាចយកលុយទៅទិញបាន។
ហើយគេមិនខ្វះខាតអ្វីទេ
ការបកប្រែរបៀបផ្សេងទៀត: «គាត់មានអ្វីទាំងអស់»
ព្រះជាម្ចាស់មិនប្រទានឲ្យគេមានសមត្ថភាពក្នុងការសប្បាយរីករាយ
ដើម្បីខំឲ្យបានមាន ឬមានសិទ្ធលើ
តែអត់អាចរីករាយជាមួយទ្រព្យទាំងនោះគឺឥតប្រយោជន៍។
ឥតបានការ ហើយអាក្រក់បំផុត
ការដែលមិនអាចរីករាយនៅលើទ្រព្យសម្បត្តិមនុស្សម្នាក់បាន គឺជាទុក្ខវេទនា
ឬការដាក់បណ្តាសា។
Ecclesiastes 6:3
ឪពុកម្នាក់មានកូនមួយរយ
ការបកប្រែរបៀបផ្សេងទៀត: «ឪពុកមានកូន១០០នាក់»
រស់នៅបានច្រើនឆ្នាំ ទោះបីគាត់រស់នៅបានច្រើនឆ្នាំ
ឃ្លាទាំងពីរមានន័យមូលដ្ឋានដូចគ្នា ហើយបានបញ្ជូលគ្នា ដើម្បីឲ្យមានការបញ្ជាក់។
ចិត្តរបស់គាត់មិនចេះស្កប់ស្កល់ដោយសេចក្ដីល្អ
ការបកប្រែរបៀបផ្សេងទៀត: «គាត់មិនចេះស្កប់ស្កល់ដោយសេចក្ដីល្អ»
គាត់មិនបានធ្វើពិធីបញ្ចុះដោយកិត្តិយស
អាចមានន័យថា គឺ១) «គ្មាននរណាបញ្ចុះគាត់ទេ» ឬ ២)
«គ្មាននរណាបញ្ចុះគាត់ឲ្យបានសមរម្យ»។
ជាកូននោះដែលកើតដោយឥតប្រយោជន៍
ការបកប្រែរបៀបផ្សេងទៀត: «ដូចជាកូនដែលកើតដោយឥតប្រយោជន៍»
ហើយស្លាប់បាត់ក្នុងទីងងឹត
នៅទីនេះគឺជាឃ្លា «ភាពងងឹត» សំដៅលើពិភពលោកនៃសេចក្ដីស្លាប់ ឬ
ទៅលើអ្វីដែលវាលំបាកដើម្បីយល់។ ការបកប្រែរបៀបផ្សេងទៀត:
«ស្លាប់ដោយមិនអាចពន្យល់បាន»
ហើយគ្មាននរណានឹកនា
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាស្គាល់ឈ្មោះរបស់វាទេ»

generated on Wed Sep 10 16:16:32 2025

Ecclesiastes 6:5

វាសុខជាងអ្នកដែលមានអាយុវែងនោះទៅទៀត

ក្មេងដែលទើបតែកើតនឹងមិនដែលមានបទពិសោធន៏ទុក្ខលំបាកទេ
ដឹងតែសម្រាកជានិច្ច។ ចំណែកមនុស្សដែលរស់នៅជាច្រើនឆ្នាំ
ប៉ុន្តែមិនដែលស្កប់ចិត្តនោះគឺខ្វះការសម្រាក។

ទោះបីជាបុរសនោះអាចរស់បានពីរពាន់ឆ្នាំក្តី

ការនិយាយបំផ្លើសនេះដើម្បីបង្ហាញថា វាមិនអីទេទោះជាគាត់រស់បានវែងយ៉ាងនោះ
ប្រសិនបើជីវិតរបស់គាត់មិនបានរីករាយជាមួយការល្អនៅក្នុងជីវិត។

ពីរពាន់ឆ្នាំ

ការបកប្រែរបៀបផ្សេងទៀត: «២០០០ឆ្នាំ»

ប៉ុន្តែគេមិនបានរៀនពីសេចក្តីល្អ

នេះគឺជាចំណុច មនុស្សត្រូវការរៀនដើម្បីរីករាយការល្អនៅក្នុងជីវិតរបស់គាត់។

Ecclesiastes 6:7

គឺបានត្រឹមតែមាត់

ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីដាក់អាហារនៅក្នុងមាត់» ឬ «ដើម្បីបរិភោគ»

ពុំទាន់អាចបំពេញសេចក្តីស្រែកឃ្លានរបស់គេបានទេ

ការបកប្រែរបៀបផ្សេងទៀត: «គាត់មិនបានបរិភោគឆ្អែតទេ»

តើមនុស្សដែលមានប្រាជ្ញាមានគុណសម្បត្តិអ្វីលើសជាងមនុស្សល្ងីល្ងើ?

ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលមានប្រាជ្ញាមិនបានប្រយោជន៍ពីអ្នកល្ងង់នោះទេ»។

តើមនុស្សក្រីក្រមានគុណសម្បត្តិអ្វី ទោះបីជាគេដឹងពីការប្រព្រឹត្តនៅចំពោះមុខមនុស្សដទៃទៀត?

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សក្រីក្រមានគុណសម្បត្តិអ្វី
ទោះបីជាគេដឹងពីការប្រព្រឹត្តនៅចំពោះមុខមនុស្សដទៃ»។

Ecclesiastes 6:9

ភ្នែកស្កប់ស្កល់នឹងអ្វីដែលបានឃើញ

មនុស្សម្នាក់អាចឃើញការនេះ ដោយសារគាត់ធ្លាប់មានហើយ។

ការបកប្រែរបៀបផ្សេងទៀត: «តើមនុស្សធ្លាប់មានអី»

ចង់បានអ្វីដោយការវង្វេងស្រែកឃ្លានខ្លាំង

ការនេះសំដៅទៅអ្វីដែលអ្នកនោះចង់បាន តែមិនដែលមានពីមុន។

ការបកប្រែរបៀបផ្សេងទៀត: «ចង់បាន តែមិនដែលមានពីមុន»

ការឥតបានការ និងដូចជាការដេញចាប់ខ្យល់

សូមមើលពីរបៀបបកប្រែពាក្យនេះនៅក្នុងជំពូក ១:១២។

អ្វីៗដែលកើតមកស្រាប់ សុទ្ធតែមានឈ្មោះរបស់ខ្លួន

របៀបផ្សេងទៀត ដើម្បីបកប្រែ:

«មនុស្សបានដាក់ឈ្មោះគ្រប់យ៉ាងដែលមានរួចហើយ»

អ្វីដែលមនុស្សចូលចិត្ត ក៏បានដឹងដែរ

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សបានដឹងថាមនុស្សជាតិនេះយ៉ាងណា»

អ្នកប្រាជ្ញមិនអាចយកចំណេះដឹងមកបំពេញបន្ថែមដើម្បីជួយឲ្យគាត់បានកំសាន្តចិត្តនោះទេ

---

7 [1]កេរ្តិ៍ឈ្មោះល្អប្រសើរជាងទឹកអប់ដែលមានតម្លៃ ហើយថ្ងៃស្លាប់នោះក៏វិសេសជាងថ្ងៃដែលកើតមកដែរ។
[2]ចូលទៅក្នុងដែលមានការកាន់ទុក្ខប្រសើរជាងចូលផ្ទះដែលគេជប់លៀង ដ្បិតការកាន់ទុក្ខមានសម្រាប់មនុស្សគ្រប់គ្នានៅចុងបញ្ចប់នៃជីវិត ដូច្នេះហើយ
មនុស្សដែលនៅរស់ត្រូវតែយកចិត្តទុកដាក់ចំពោះការនេះ។
[3]ទុក្ខព្រួយប្រសើរជាងសើចសប្បាយ ដ្បិតបន្ទាប់ពីទឹកមុខសោកសៅនឹងប្រែជាចិត្តសប្បាយវិញ។[4]ចិត្តរបស់មនុស្សមានប្រាជ្ញាគឺនៅក្នុងផ្ទះរបស់មនុស្សកាន់ទុក្ខ
ប៉ុន្តែចិត្តរបស់មនុស្សល្ងីល្ងើ គឺនៅក្នុងផ្ទះអ្នកជប់លៀងវិញ។
[5]ការដែលស្តាប់ការបន្ទោសនៃមនុស្សមានប្រាជ្ញាប្រសើរជាងស្តាប់ចម្រៀងរបស់មនុស្សល្ងីល្ងើ។[6]ដ្បិតសំណើចរបស់មនុស្សល្ងីល្ងើ
ដូចជាស្នូរគេដុតបន្លាដែលឆេះក្រោមឆ្នាំង។ ការនេះក៏ឥតបានការដែរ។
[7]ការគំរាមកំហែងច្បាស់ជាធ្វើឲ្យមនុស្សមានប្រាជ្ញាទៅជាល្ងីល្ងើ ហើយសំណូកក៏បង្ខូចចិត្តដែរ។
[8]បញ្ចប់បញ្ហាប្រសើរជាងចាប់ផ្តើម ហើយមនុស្សអត់ធ្មត់ប្រសើរជាងមនុស្សអួតបំប៉ោង។[9]កុំឆាប់មានចិត្តខឹងពេក ដ្បិតកំហឹងមាននៅតែក្នុងចិត្តរបស់មនុស្សល្ងីល្ងើទេ។
[10]កុំនិយាយថា «ហេតុអ្វីបានជាសម័យបុរាណល្អជាងសម័យនេះ?» ដ្បិតការសួរសំនួរបែរនេះគឺមិនមែនដោយប្រាជ្ញានោះទែ ។
[11]ប្រាជ្ញាល្អដូចមរតកមានតម្លៃ ដែលយើងទទួលពីដូនតារបស់ពួកយើង។ វាផ្តល់ផលប្រយោជន៍ដល់អ្នកណាដែលឃើញពន្លឺថ្ងៃផង។
[12]ដ្បិតប្រាជ្ញាផ្តល់ការការពារដូចជាលុយក៏អាចផ្តល់នូវការការពារខ្លួនដែរ ប៉ុន្តែគុណសម្បត្តិនៃការចេះដឹងគឺជាប្រាជ្ញាដែលឲ្យអ្នកនោះមានជីវិតវិញ។
[13]ចូរសង្កេតមើលកិច្ចការនៃព្រះជាម្ចាស់ តើអ្នកណាអាចកែនូវអ្វីៗដែលព្រះអង្គបានធ្វើឲ្យវៀចវិញបាន?
[14]នៅគ្រាដែលមានពេលល្អ ចូររស់នៅដោយសប្បាយចុះ ប៉ុន្តែនៅគ្រាដែលទុក្ខលំបាក ចូរពិចារណាការនេះ ព្រះជាម្ចាស់បានដាក់ការទាំងពីរនេះនោះឲ្យនៅទន្ទឹមគ្នា។
ហេតុនេះហើយ គ្មានរណាម្នាក់នឹងយល់អ្វីៗដែលកើតមកនៅពេលក្រោយទេ។
[15]ខ្ញុំបានឃើញហេតុការណ៍ជាច្រើននៅក្នុងជីវិតឥតបានការរបស់ខ្ញុំ។ មានមនុស្សសុចរិតបាត់បង់ ដោយសារតែអំពើសុចរិតរបស់ពួកគេ
ហើយមនុស្សទុច្ចរិតរស់នៅបានអាយុវែង ដោយសារអំពើទុច្ចរិតរបស់ពួកគេ។[16]កុំធ្វើជាមនុស្សសុចរិត ដោយខ្លួនឯងឡើយ ក៏កុំឲ្យធ្វើខ្លួនមានប្រាជ្ញាជ្រុសពេកដែរ។
ហេតុអ្វីអ្នកចង់បំផ្លាញខ្លួនឯងដូច្នេះ?
[17]កុំធ្វើជាមនុស្សអាក្រក់ពេក និងជាមនុស្សល្ងីល្ងើពេក។ ហេតុអ្វីអ្នកចង់ស្លាប់មុនពេលកំណត់យ៉ាងនេះ?[18]ជាការល្អដែលអ្នកចង់ចាប់យកប្រាជ្ញានេះ
ហើយកុំឲ្យចាក់ចេញពីសេចក្តីសុចរិត។ ដ្បិតអ្នកណាដែលកោតខ្លាចព្រះជាម្ចាស់នឹងចៀសចេញរួចពីសេចក្តីទាំងនេះបាន។
[19]អ្នកប្រាជ្ញាមានកម្លាំងជាងអ្នកគ្រប់គ្រងដប់នាក់នៅក្នុងក្រុងមួយ។[20]នៅលើផែនដី គ្មានមនុស្សណាម្នាក់សុចរិត ដែលធ្វើអំពើល្អ និងមិនដែលធ្វើអំពើបាបនោះទេ។
[21]កុំស្តាប់ចំពោះពាក្យសម្តីណាដែលមនុស្សនិយាយឡើយ ព្រោះអ្នកអាចឮបាវបម្រើរបស់អ្នកដាក់បណ្តាសាអ្នក។[22]ដូចគ្នាដែរ អ្នកដឹងខ្លួនឯងហើយថា
នៅក្នុងចិត្តរបស់អ្នកធ្លាប់និយាយអាក្រក់ពីអ្នកដ៏ទៃច្រើនលើកដែរ។
[23]ខ្ញុំបានបង្ហាញឲ្យឃើញការទាំងនេះដោយប្រាជ្ញា។ ខ្ញុំនិយាយថា «ខ្ញុំនឹងមានប្រាជ្ញា» ប៉ុន្តែវាច្រើនជាងអ្វីដែលខ្ញុំអាចធ្វើបាន។[24]ប្រាជ្ញាគឺនៅឆ្ងាយហើយជ្រៅណាស់។
តើអ្នកណាអាចយល់បាន?[25]ខ្ញុំបានប្តូរចិត្តរបស់ខ្ញុំទៅរៀនហើយពិចារណា និងស្វែងរកប្រាជ្ញាហើយការពន្យល់នៃការពិត
និងដើម្បីស្វែងយល់ថាអំពើអាក្រក់គឺជាការឆោតល្ងង់ និងភាពល្ងីល្ងើគឺការឆ្កួតបំផុត។
[26]ខ្ញុំស្វែងយល់ថាភាពដែលល្ងីងជូរចត់ជាងសេចក្តីស្លាប់នោះគឺស្រីៗណាមានចិត្តពេញដោយអន្ទាក់ ជាសំណាញ់ និងមានដៃជាចំណង។
អ្នកណាដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់នឹងគេចរួចពីពួកស្រីៗទាំងនោះ ប៉ុន្តែមនុស្សមានបាបនឹងត្រូវធ្លាក់ក្នុងដៃរបស់នាងវិញ។
[27]គ្រូនិយាយថា «ចូរពិចារណាអ្វីដែលខ្ញុំបានរកឃើញ» ។ «ខ្ញុំបានបន្ថែមការសង្កេតមើលហេតុការណ៍មួយទៅមួយតាមលំដាប់ដើម្បីស្វែងរកការពន្យល់នៃការពិត។
[28]នេះគឺជាអ្វីដែលខ្ញុំនៅតែស្វែងរក ប៉ុន្តែខ្ញុំមិនទាន់បានរកឃើញនៅឡើយ។ ខ្ញុំបានរកឃើញបុរសសុចរិតម្នាក់ក្នុងចំណោមមនុស្សមួយពាន់នាក់
ប៉ុន្តែក្នុងចំណោមស្រីទាំងអស់នោះ ខ្ញុំរកពុំបានសូម្បីតែម្នាក់។
[29]ខ្ញុំបានរកឃើញតែការមួយនេះ គឺព្រះជាម្ចាស់បានបង្កើតមនុស្សមកឲ្យបានទៀងត្រង់ តែមនុស្សស្វែងរកការដែលពិបាកយ៉ាងច្រើនទៅវិញ» ។

Ecclesiastes 7:1

កេរ្តិ៍ឈ្មោះល្អ

ការបកប្រែរបៀបផ្សេងទៀត: «គឺមានកេរ្តិ៍ ឈ្មោះ»

មនុស្សដែលនៅរស់ត្រូវតែយកចិត្តទុកដាក់

ពួកគេត្រូវការគិតពីឈ្មោះអ្វី ឬកេរ្តិ៍ឈ្មោះដែលពួកគេមាន
ឬទុកឈ្មោះល្អក្រោយពេលគេស្លាប់ទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលមានជីវិតត្រូវតែគិតពីការមានមែនតែន»។

Ecclesiastes 7:3

ទឹកមុខសោកសៅ

ការនេះគឺសំដៅលើការសោកសៅ។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«បទពិសោធន៏មួយដែលធ្វើឲ្យមនុស្សកើតទុក្ខ»
ចិត្តសប្បាយ
ពាក្យថា «ចិត្ត» នៅទីនេះសំដៅលើនរណាម្នាក់ដែលគិត
និងអារម្មណ៍នៃការសប្បាយចិត្ត ហើយនិងសុខសាន្ត។
ការបកប្រែរបៀបផ្សេងទៀត: «ការគិតត្រឹមត្រូវ»
ចិត្តរបស់មនុស្សមានប្រាជ្ញាគឺនៅក្នុងផ្ទះរបស់មនុស្សកាន់ទុក្ខ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកប្រាជ្ញគិតវែងឆ្ងាយអំពីសេចក្តីស្លាប់»
ប៉ុន្តែចិត្តរបស់មនុស្សល្ងីល្ងើ គឺនៅក្នុងផ្ទះអ្នកជប់លៀង
របៀបផ្សេងទៀត ដើម្បីបកប្រែ:
«ប៉ុន្តែមនុស្សល្ងីល្ងើគិតតែពីការសប្បាយសម្រាប់ខ្លួនឯង»
ផ្ទះរបស់មនុស្សកាន់ទុក្ខ ... ផ្ទះអ្នកជប់លៀង
ឃ្លាទាំងនេះសំដៅទៅលើអ្វីដែលបានកើតឡើងនៅទីនេះ។
Ecclesiastes 7:5
ការបន្ទោសនៃមនុស្សមានប្រាជ្ញា
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលអ្នកដែលមានប្រាជ្ញាបន្ទោសអ្នក»
ស្តាប់ចម្រៀងរបស់មនុស្សល្ងីល្ងើ
ការបកប្រែរបៀបផ្សេងទៀត: «ការស្តាប់មនុស្សល្ងីល្ងើច្រៀង»
ដ្បិតសំណើចរបស់មនុស្សល្ងីល្ងើ ដូចជាស្នូរគេដុតបន្លាដែលឆេះក្រោមឆ្នាំង
«កាសើចនៃមនុស្សល្ងីល្ងើ»
គឺប្រៀបធៀបទៅដូចជាស្នូរគេដុតបន្លាដែលឆេះក្រោមឆ្នាំង។
Ecclesiastes 7:7
ការគំរាមកំហែង
ការនេះសំដៅលើការផ្តោតនរណាម្នាក់ដែលបានឲ្យប្រាក់
ឬអ្វីដែលមានតម្លៃផ្សេងទៀតឲ្យទៅអ្នកផ្សេង
ដូច្នេះអ្នកផ្សេងនោះនឹងមិនប្រមាថអ្នកដែលបានឲ្យឡើយ។
ការនេះគឺមិនត្រឹមត្រូវទេ។
មនុស្សមានប្រាជ្ញទៅជាល្ងីល្ងើ
អាចមានន័យថា គឺ១) «បែរជាអ្នកប្រាជ្ញទៅជាល្ងីល្ងើ» ឬ ២)
«ធ្វើឲ្យយោបល់របស់អ្នកមានប្រាជ្ញាបង្ហាញទៅចំពោះអ្នកល្ងីល្ងើ»។
សំណូកក៏បង្ខូចចិត្ត
ពាក្យថា «ចិត្ត» នៅទីនេះសំដៅដល់គំនិត។ ការបកប្រែរបៀបផ្សេងទៀត:
«បំផ្លាញលទ្ធិភាពមនុស្សដើម្បីគិតពីវិនិច្ឆ័យដ៏ត្រឹមត្រូវ»
Ecclesiastes 7:8
ហើយមនុស្សអត់ធ្មត់ប្រសើរជាងមនុស្សអួតបំប៉ោង
ពាក្យថា «វិញ្ញាណ» នៅទីនេះសំដៅទៅលើអាកប្បកិរិយារបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សអត់ធ្មត់ប្រសើរជាងមនុស្សអួតបំប៉ោង» ឬ
«អាកប្បកិរិយាអត់ធ្មត់ប្រសើរជាងមនុស្សអួតបំប៉ោងឥរិយាបថ»
កុំឆាប់មានចិត្តខឹងពេក
ការបកប្រែរបៀបផ្សេងទៀត: «កុំឲ្យក្លាយជាអ្នករហ័សខឹង» ឬ
«កុំឲ្យកំហឹងទៅជាអាក្រក់ឡើយ»
កំហឹងមាននៅតែក្នុងចិត្តរបស់មនុស្សល្ងីល្ងើ
ការខឹងអាចបៀបធៀបទៅអ្វីដែលរស់នៅក្នុងរបស់មនុស្សល្ងីល្ងើ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សល្ងីល្ងើពេញដោយកំហឹង»
Ecclesiastes 7:10
ហេតុអ្វីបានជាសម័យបុរាណល្អជាងសម័យនេះ?
អ្នកដែលសួរសំនួរនេះក្នុងរបៀបដែលតួញតែ្អរអំពីពេលបច្ចុប្បន្ន។
ការបកប្រែរបៀបផ្សេងទៀត:
«ការនេះវាប្រសើរជាងនៅពេលកន្លងមកនូវអ្វីដែលគេបានធ្វើ»
ការសួរសំនួរបែរនេះគឺមិនមែនដោយប្រាជ្ញានោះទេ
អ្នកដែលបានចេញសេចក្តីប្រកាសមិនរួមបញ្ចូលបច្ចុប្បន្ន
ហើយនិងវែកញែកអតីតកាលទេ តែជាប្រធានបទវិញ។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើអ្នកមានប្រាជ្ញានោះអ្នកនឹងមិនសួរសំនួរនេះទេ» ឬ
«ការសួរនូវសំនួរបែបនេះបង្ហាញថាអ្នកមិនមានប្រាជ្ញាទេ»
Ecclesiastes 7:11
អ្នកណាដែលឃើញពន្លឺថ្ងៃ
ការបកប្រែរបៀបផ្សេងទៀត: «គឺជាអ្នកដែលមានជីវិតរស់នៅ»
គុណសម្បត្តិនៃការចេះដឹងគឺជាប្រាជ្ញាដែលឲ្យអ្នកនោះមានជីវិត
អាចមានន័យថា គឺ១) អ្នកនិពន្ធប្រើពាក្យ «ចំណេះដឹង» និង «ប្រាជ្ញា»
ដើម្បីមានន័យដូចគ្នា ឬ ២)
«គុណប្រយោជន៍នៃការដឹងពីចំណេះដឹងគឺជាការផ្តល់ជីវិត»។
ឲ្យអ្នកនោះមានជីវិត
«វា» សំដៅទៅលើចំណេះដឹង។ ការចេះដឹងហើយនិងប្រាជ្ញា «ផ្តល់ជីវិត»
ក្នុងផ្លូវផ្សេងទៀត ការជ្រើសរើសការរកស៊ីដែលល្អ គឺនឹងធ្វើឲ្យមានមិត្តសំឡាញ់
និងជ្រើសរើសជីវិតដែលមានសុខភាពល្អ
ការរស់នៅដោយសុខសាន្តជាមួយអ្នកដទៃជារបៀបដែលមានចំណេះដឹង
«ផ្តល់ជីវិត»។
Ecclesiastes 7:13
តើអ្នកណាអាចកែនូវអ្វីៗដែលព្រះអង្គបានធ្វើឲ្យវៀចវិញបាន?
ការបកប្រែរបៀបផ្សេងទៀត:
«គ្មានអ្នកណាអាចកែនូវអ្វីៗដែលព្រះអង្គបានធ្វើឲ្យវៀចវិញបាន»។
Ecclesiastes 7:14
នៅគ្រាដែលមានពេលល្អ ចូររស់នៅដោយសប្បាយចុះ ប៉ុន្តែនៅគ្រាដែលទុក្ខលំបាក
«នៅពេលការល្អបានកើតឡើង...នៅពេលការអាក្រក់បានកើតឡើង»
ចូររស់នៅដោយសប្បាយចុះ
«សូមសប្បាយចិត្តអំពីការល្អទាំងនោះ»
ឲ្យនៅទន្ទឹមគ្នា
«នៅពេលតែមួយ»
អ្វីៗដែលកើតមកនៅពេលក្រោយ
អាចមានន័យថា គឺ១) «អ្វីដែលនឹងកើតឡើងនៅពេលអនាគត» ឬ ២)
«អ្វីដែលនឹងកើតឡើងក្នុងពិភពលោកនេះបន្ទាប់ពីគាត់ស្លាប់» ឬ ៣)
«អ្វីដែលនឹងកើតឡើងដល់គាត់បន្ទាប់ពីគាត់បានស្លាប់»។
Ecclesiastes 7:15
ដោយសារអំពើទុច្ចរិតរបស់ពួកគេ
«ទោះបីពួកគេទុច្ចរិតក៏ដោយ»
ធ្វើជាមនុស្សសុចរិត ដោយខ្លួនឯង
សុចរិត ប្រាជ្ញានៅក្នុងភ្នែកខ្លួនឯង -
ឃ្លាទាំងពីរនេះមានមូលដ្ឋានដូចគ្នាទៅនឹងអ្វីដែលបានរួមបញ្ចូលសម្រាប់បញ្ជាក់ន័យ។
កុំធ្វើជាមនុស្សសុចរិត ដោយខ្លួនឯង
សុចរិត - «កុំឲ្យគិតថាអ្នកសុចរិតច្រើនជាងពីមុនឡើយ»
ធ្វើខ្លួនមានប្រាជ្ញាជ្រុសពេក
ការបកប្រែរបៀបផ្សេងទៀត: «សូមឲ្យមានប្រាជ្ញាក្នុងការគិតវិញ»
ហេតុអ្វីអ្នកចង់បំផ្លាញខ្លួនឯងដូច្នេះ?
អ្នកនិពន្ធប្រើសំនួរនេះដើម្បីបញ្ជាក់ថា
ការដែលតាំងខ្លួនឯងថាសុចរិតគឺជាការបំផ្លាញមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «គឺគ្មានហេតុផលដើម្បីបំផ្លាញខ្លួនអ្នកឡើយ»។
Ecclesiastes 7:17
ហេតុអ្វីអ្នកចង់ស្លាប់មុនពេលកំណត់យ៉ាងនេះ?
«វាគ្មានហេតុផលអ្វីដែលត្រូវស្លាប់មុនពេលមកដល់របស់អ្នកនោះទេ»។
ចាប់យកប្រាជ្ញានេះ
«សូមឲ្យអ្នកច្បាស់ជាមួយចំណេះដឹង»
កុំឲ្យចាក់ចេញពីសេចក្តីសុចរិត
«អ្នកមិនគួរឈប់ដើម្បីធ្វើឲ្យខ្លួនអ្នកបានសុចរិត» ឬ
«អ្នកគួរតែព្យាយាមធ្វើឲ្យខ្លួនអ្នកបានសុចរិត»
ចៀសចេញរួចពីសេចក្តីទាំងនេះ
«នឹងធ្វើអ្វីដែលព្រះជាម្ចាស់រំពឹងសម្រាប់ព្រះអង្គ»។
Ecclesiastes 7:19
អ្នកគ្រប់គ្រងដប់នាក់នៅក្នុងក្រុងមួយ
ប្រាជ្ញាបានយកទៅប្រៀបធៀបទៅនឹងអ្នកគ្រប់គ្រងទីក្រុងជាច្រើនទៀត។
ប្រាជ្ញាអាចធ្វើឲ្យក្លាយជាមនុស្សសំខាន់ជាងអ្នកដែលគ្រប់គ្រងទីក្រុងផង។
ធ្វើអំពើល្អ និងមិនដែលធ្វើអំពើបាប
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើកិច្ចការល្អ និងមិនដែលធ្វើអំពើបាប»
Ecclesiastes 7:21
ពាក្យសម្តីណាដែលមនុស្សនិយាយ
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់យ៉ាងដែលមនុស្សបាននិយាយ»
អ្នកដឹងខ្លួនឯងហើយ
«អ្នកស្គាល់ខ្លួនឯង»។ នៅទីនេះ «ខ្លួនអ្នក» គឺប្រើដើម្បីបញ្ជាក់ថា «អ្នកដឹង»។
នៅក្នុងចិត្តរបស់អ្នក

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងគំនិតរបស់អ្នក»

Ecclesiastes 7:23

ខ្ញុំបានបង្ហាញឲ្យឃើញ

«គ្រប់ការទាំងនេះខ្ញុំបានសរសេរហើយបង្ហាញឲ្យឃើញ»

វាច្រើនជាងអ្វីដែលខ្ញុំអាចធ្វើបាន

«វាលើសពីអ្វីដែលខ្ញុំអាចយល់បាន»

នៅឆ្ងាយហើយជ្រៅណាស់

ប្រាជ្ញាគឺជាអ្វីដែលពិបាកនឹងឈោងចាប់។ នៅពេលដែលមានការចេះដឹង
នៅមានកំរិត។ វាត្រូវការជិកចូលទៅជ្រៅជាងអ្វីដែលយើងយកមកជាប្រយោជន៍។

ការបកប្រែរបៀបផ្សេងទៀត: «ពិបាកក្នុងការយល់»

អ្នកណាអាចយល់បាន?

អ្នកនិពន្ធបានប្រើសំនួរនេះសម្រាប់បញ្ជាក់ពីការលំបាកក្នុងយល់ដឹងអំពីប្រាជ្ញា។

ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាអាចយល់ពីវាបានឡើយ។

ខ្ញុំបានប្តូរចិត្តរបស់ខ្ញុំ

ពាក្យថា «ចិត្ត» នៅទីនេះសំដៅលើគំនិត។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំបានប្តូរគំនិតរបស់ខ្ញុំ» ឬ «ខ្ញុំប្រាថ្នា»

Ecclesiastes 7:26

គឺស្រីៗណាមានចិត្តពេញដោយអន្ទាក់ ជាសំណាញ់ និងមានដៃជាចំណង

អ្នកនិពន្ធនិយាយថាទាក់ទាញមនុស្សដូចជាអន្ទាក់ដែលអ្នកប្រមាញ់
ប្រើសម្រាប់ចាប់សត្វ។

ចិត្តពេញដោយអន្ទាក់ ជាសំណាញ់

ពាក្យថា «ចិត្ត» នៅទីនេះសំដៅទៅលើគំនិតហើយអារម្មណ៍។
នេះគឺជាស្ត្រីដែលរកតែផលចំណេញក្នុងខ្លួនបានជាប្រយោជន៍។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកណាដែលចង់បានអន្ទាក់សម្រាប់ខ្លួនឯង»

ដោយអន្ទាក់ ជាសំណាញ់

ពាក្យទាំងពីរនេះបានសំដៅទៅលើពីរបៀប ដែលមនុស្សដាក់អន្ទាក់យកសត្វ។
ស្ត្រីនោះបន្តគិតដើម្បីដាក់អន្ទាក់យកមនុស្សប្រុសដើម្បីផ្តល់អ្វីដែលនាងមានដល់គេ។

និងមានដៃជាចំណង

ពាក្យថា «ដៃ» នៅទីនេះសំដៅទៅលើអំណាច ឬការគ្រប់គ្រង។

ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាអាចគេចចេញបានទេ»

មនុស្សមានបាបនឹងត្រូវធ្លាក់ក្នុងដៃរបស់នាង

ការបកប្រែរបៀបផ្សេងទៀត: «នាងនឹងចាប់បើមនុស្សមានបាប»

Ecclesiastes 7:27

ហេតុការណ៍មួយទៅមួយតាមលំដាប់ដើម្បីស្វែងរក

ការបកប្រែរបៀបផ្សេងទៀត: «ស្វែងរកហេតុការណ៍មួយទៅមួយតាមលំដាប់»

លំដាប់ដើម្បីស្វែងរកការពន្យល់នៃការពិត

ការបកប្រែរបៀបផ្សេងទៀត: «តាមលំដាប់ដើម្បីងាយក្នុងការពន្យល់ពីជីវិត»

បុរសសុចរិតម្នាក់ ក្នុងចំណោមមនុស្សមួយពាន់នាក់

មនុស្សតែម្នាក់ដែលសុចរិតម្នាក់ ក្នុងចំណោមមនុស្ស១០០០នាក់។

ការបកប្រែរបៀបផ្សេងទៀត: «ម្នាក់ដែលសុចរិតម្នាក់ ក្នុងចំណោម១០០០នាក់»

ស្រីទាំងអស់នោះ

ក្នុងចំណោមស្រីទាំងអស់នោះ ខ្ញុំរកពុំបានល្អក្នុងចំណោមស្ត្រី១០០០នាក់។

Ecclesiastes 7:29

មនុស្សស្វែងរកការដែលពិបាកយ៉ាងច្រើនទៅវិញ

អាចមានន័យថា គឺ១) «ពួកគេបានរៀបចំផែនការណ៍ដើម្បីធ្វើបាប» ឬ ២)
«ពួកគេស្វែងរកការដែលពិបាកឲ្យខ្លួនគេ»។

មនុស្សស្វែងរកការចាកចេញ

ពាក្យថា «ពួកគេ» នៅទីនេះសំដៅទៅលើ «មនុស្សជាតិ»។

---

8 [1]តើនរណាជាអ្នកមានប្រាជ្ញា? តើអ្នកណាដឹងថាអ្វីជាព្រឹត្តិការណ៍នៅក្នុងជីវិតមានន័យដូចម្តេច? ប្រាជ្ញានៅក្នុងមនុស្សធ្វើឲ្យមុខមាត់គេចែងចាំងឡើង
ហើយភាពរឹងនៃមុខមាត់គេក៏ផ្លាស់ប្តូរដែរ។
[2]ខ្ញុំសូមណែនាំឲ្យអ្នកប្រព្រឹត្តតាមបញ្ជារបស់ស្តេចចុះ ដោយយល់ពាក្យសច្ចារបស់ព្រះជាម្ចាស់ដើម្បីការពារស្តេចនោះ។[3]កុំប្រញាប់រត់ចេញពីវត្តមានរបស់ស្តេចឡើយ
និងកុំមានចិត្តប្រព្រឹត្តកំហុសដែរ ដ្បិតស្តេចអាចធ្វើអ្វីៗទាំងអស់តាមតែព្រះរាជបំណង។[4]ស្តេចមានរាជឱង្ការយ៉ាងណា ក៏មានអំណាច
ហេតុនេះហើយនរណានឹងហ៊ានសួរស្តេចថា «តើព្រះករុណាកំពុងធ្វើអ្វី?»
[5]អ្នកណាដែលធ្វើតាមបញ្ជារបស់ស្តេច នឹងអាចគេចផុតពីគ្រោះថ្នាក់។ ចិត្តរបស់មនុស្សមានប្រាជ្ញារមែងស្គាល់កាលៈទេសៈត្រឹមត្រូវ និងការវិនិច្ឆ័យ។
[6]ដ្បិតគ្រប់ការទាំងអស់គឺមានការឆ្លើយតបត្រឹមត្រូវ និងមានពេលដើម្បីតប ពីព្រោះបញ្ហារបស់មនុស្សគឺធំណាស់។
[7]គ្មាននរណាម្នាក់ដឹងថានឹងមានអ្វីកើតឡើងពេលបន្ទាប់ទេ។ តើអ្នកណាអាចប្រាប់គេថានឹងមានអ្វីកើតឡើង?
[8]គ្មាននរណាម្នាក់មានអំណាចឃាត់ដង្ហើមរបស់ខ្លួនបានឡើយ និងគ្មាននរណាម្នាក់មានអំណាចលើថ្ងៃនៃសេចក្តីស្លាប់របស់ខ្លួនបានដែរ។
គ្មាននរណាម្នាក់អាចគេផុតពីសត្រូវនៅពេលប្រយុទ្ធបានទេ ហើយអំពើអាក្រក់នឹងមិនសង្គ្រោះអស់អ្នកណាដែលប្រព្រឹត្តអាក្រក់បានដែរ។
[9]ខ្ញុំបានយល់គ្រប់ការទាំងអស់ហើយ ខ្ញុំបានអនុវត្តនៅក្នុងចិត្តរបស់ខ្ញុំចំពោះគ្រប់ការងារទាំងអស់ដែលបានធ្វើនៅក្រោមថ្ងៃ។
មានគ្រាដែលមនុស្សម្នាក់ជិះជាន់ម្នាក់ទៀតដើម្បី ឲ្យម្នាក់នោះឈឺចាប់។
[10]ខ្ញុំបានឃើញគេបញ្ចុះសពមនុស្សអាក្រក់នៅទីសាធារណៈ។ ពួកគេត្រូវបានដកចេញពីកន្លែងបរិសុទ្ធ ហើយបញ្ចុះ
ហើយមនុស្សដែលរស់នៅក្នុងក្រុងដែលគេបានប្រព្រឹត្តការអាក្រក់របស់ពួកគេនោះបានសរសើរគេ។ ការនេះក៏គ្មានប្រយោជន៍ដែរ។
[11]ការកាត់ទោសប្រឆាំងនឹងទោសអំពើអាក្រក់គឺមិនបានជំនុំជំរះភ្លាមៗនោះទេ ដូច្នេះហើយបានជាចិត្តរបស់មនុស្សនៅតែបន្តធ្វើអំពើអាក្រក់។
[12]ទោះបីជាមនុស្សមានបាបប្រព្រឹត្តអំពើអាក្រក់មួយដង ហើយនៅតែរស់បានយូរយ៉ាងណាក្តី តែខ្ញុំដឹងថាការនេះនឹងល្អដល់អ្នកណាដែលកោតខ្លាចព្រះជាម្ចាស់
ដល់អ្នកណាដែលគោរពព្រះវត្តមានរបស់ព្រះជាម្ចាស់។[13]ប៉ុន្តែការនេះនឹងមិនល្អទេសម្រាប់មនុស្សអាក្រក់ ជីវិតរបស់គេនឹងមិនបានវែងឡើយ។
ជីវិតរបស់គេដូចជាស្រមោលមួយប្រព្រិចភ្នែក ដោយសារគេមិនគោរពព្រះជាម្ចាស់។
[14]មានការឥតបានការផ្សេងមួយទៀតដែលបានធ្វើនៅលើផែនដី។ រឿងទាំងឡាយដែលកើតឡើងចំពោះមនុស្សសុចរិតដូចជារឿងដែលកើតឡើងចំពោះមនុស្សទុច្ចរិតដែរ
ហើយរឿងទាំងឡាយដែលកើតឡើងចំពោះមនុស្សទុច្ចរិតក៏ដូចជារឿងដែលកើតឡើងចំពោះមនុស្សសុចរិតដែរ។ ដូចដែលខ្ញុំបាននិយាយហើយថា
ការនេះក៏ឥតបានការដែរ។[15]ដូច្នេះហើយ ខ្ញុំឲ្យតម្លៃលើការសប្បាយ ព្រោះនៅក្រោមថ្ងៃគ្មានអ្វីដែលប្រសើរសម្រាប់មនុស្សជាជាងស៊ី និងផឹកដើម្បីភាពសប្បាយឡើយ។
ការសប្បាយនេះនឹងនៅជាមួយនឹងការងាររបស់គេ សម្រាប់ថ្ងៃនៃជីវិតរបស់គេដែលព្រះជាម្ចាស់បានប្រទានដល់គេនៅក្រោមថ្ងៃ។
[16]ពេលដែលខ្ញុំធ្វើតាមចិត្តរបស់ខ្ញុំដើម្បី ដឹងពីប្រាជ្ញា និងដើម្បីយល់ពីកិច្ចការដែលបានធ្វើនៅលើផែនដី
គឺកិច្ចការទាំងឡាយដែលបានបញ្ចប់ជាទូទៅធ្វើដោយមិនបានដេកលក់មិនថាពេលថ្ងៃឬពេលយប់ឡើយ[17]ពេលនោះ ខ្ញុំបានយល់ពីកិច្ចការរបស់ព្រះជាម្ចាស់ទាំងអស់
គឺមនុស្សមិនអាចស្គាល់ពីកិច្ចការដែលមាននៅក្រោមថ្ងៃបានទេ។ មិនថាមនុស្សខិតខំស្វែងរកចម្លើយយ៉ាងណាក៏ដោយ គេនឹងមិនអាចរកឃើញឡើយ។
ទោះបីជាមនុស្សមានប្រាជ្ញាដែលគេជឿថាគេស្គាល់ ក៏គេមិនអាចនឹងយល់បានដែរ។

Ecclesiastes 8:1

តើនរណាជាអ្នកមានប្រាជ្ញា? តើអ្នកណាដឹងថាអ្វីជាព្រឹត្តិការណ៍នៅក្នុងជីវិតមានន័យដូចម្តេច?

អ្នកនិពន្ធសួរសំនួរទាំងនេះដូចជាកំពុងតែនាំសំនួរដើម្បីធ្វើការឆ្លើយទៅក្នុងអ្វីដែលគាត់នឹងនិយាយនៅ Ecclesiastes 8:2

ធ្វើឲ្យមុខមាត់គេចែងចាំង

មានន័យថាមុខរបស់គាត់បង្ហាញពីប្រាជ្ញាដែលគាត់មានក្នុងគាត់។

ការបកប្រែរបៀបផ្សេងទៀត: «បង្ហាញនៅលើមុខ»

ភាពរឹងនៃមុខមាត់

ការបកប្រែរបៀបផ្សេងទៀត: «ទុក្ខលំបាកចេញមកតាមលក្ខណៈខាងក្រៅ»

Ecclesiastes 8:2

ពាក្យសច្ចារបស់ព្រះជាម្ចាស់ដើម្បីការពារស្តេច

«ពាក្យនៃអ្នកបានធ្វើនៅចំពោះព្រះជាម្ចាស់ដើម្បីការពារគាត់»

កុំប្រញាប់រត់ចេញពីវត្តមានរបស់ស្តេច

generated on Wed Sep 10 16:16:32 2025

អាចមានន័យថា គឺ១) សូមកុំរហ័សផ្អែករូបកាយចាកចេញពីវត្តមានស្តេច ឬ ២) បន្ទាបខ្លួនហើយឲ្យតម្លៃចំពោះស្តេច កុំប្រញាប់ចាកចេញពីទ្រង់ទៅរកអ្នកផ្សេង។

ស្តេចមានរាជឱង្ការយ៉ាងណា ក៏មានអំណាច

ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលស្តេចមានរាជឱង្ការគឺជាច្បាប់»

នរណានឹងហ៊ានសួរស្តេច

ការបកប្រែរបៀបផ្សេងទៀត: «អត់មាននរណាហ៊ាននិយាយទៅស្តេចទេ»

តើព្រះករុណាកំពុងធ្វើអ្វី?

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គមិនធ្វើអ្វីដែលព្រះអង្គធ្វើនោះទេ»

Ecclesiastes 8:5

ចិត្តរបស់មនុស្សមានប្រាជ្ញារមែងស្គាល់កាលៈទេសៈ

ពាក្យថា «ចិត្ត» សំដៅដល់ការគិត។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សមានប្រាជ្ញារមែងស្គាល់កាលៈទេសៈ»

តើអ្នកណាអាចប្រាប់គេថានឹងមានអ្វីកើតឡើង?

សំនួរនេះគឺបញ្ជាក់ថាមិនមានអ្នកណាដឹងអ្វីដែលនឹងកើតឡើងនៅពេលខាងមុខទេ។ ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្នកណាអាចប្រាប់គេថានឹងមានអ្វីកើត»។

Ecclesiastes 8:8

គ្មាននរណាម្នាក់មានអំណាចឃាត់ដង្ហើមរបស់ខ្លួនបានឡើយ

និងគ្មាននរណាម្នាក់មានអំណាចលើថ្ងៃនៃសេចក្តីស្លាប់របស់ខ្លួនបានដែរ

គឺមិនមានអ្នកណាអាចបញ្ឈប់ខ្លួនពីការដកដង្ហើមបានទេ

គ្មានអ្នកណាអាចបន្តរស់នៅបានទៀតទេនៅពេលដែលពេលវេលាស្លាប់បានមកដល់នោះ

អំពើអាក្រក់នឹងមិនសង្គ្រោះអស់អ្នកណាដែលប្រព្រឹត្តអាក្រក់បានទេ

អ្នកនិពន្ធនិយាយដល់មនុស្សអាក្រក់

ដែលវាគឺជាមេលើអ្នកផ្សេងទៀតដែលបម្រើវា។

ចិត្តរបស់ខ្ញុំចំពោះគ្រប់ការងារ

សូមមើលការបកប្រែនេះនៅក្នុងជំពូក ១:១៦។

គ្រប់ការងារទាំងអស់ដែលបានធ្វើ

ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ការទាំងដែលមនុស្សបានធ្វើ»

Ecclesiastes 8:10

បញ្ចុះសពមនុស្សអាក្រក់នៅទីសាធារណៈ

មនុស្សអាក្រក់ដែលស្លាប់ត្រូវបានបញ្ចុះកិត្តិយស។

បង្កប់ន័យដែលរូបកាយរបស់ពួកគេគួរតែត្រូវបានគេបោះចោលទៅទីក្រុងបដិសេធគំនរសំរាម

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សបញ្ចុះសពមនុស្សអាក្រក់នៅទីសាធារណៈ»

ពួកគេត្រូវបានដកចេញពីកន្លែងបរិសុទ្ធ ហើយបញ្ចុះ

ហើយមនុស្សដែលរស់នៅក្នុងក្រុងដែលគេបានប្រព្រឹត្តការអាក្រក់របស់ពួកគេនោះបានសរសើរគេ

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សបានយកពួកគេចេញពីកន្លែងបរិសុទ្ធ ហើយបញ្ចុះពួកគេ និងបានសរសើរគេ»

ការកាត់ទោសប្រឆាំងនឹងទោសអំពើអាក្រក់គឺមិនបានជំនុំជំរះភ្លាមៗនោះទេ

ការបកប្រែរបៀបផ្សេងទៀត: «អ្នកមានសិទ្ធអំណាចមិនព្រមធ្វើការកាត់ទោសភ្លាមៗ និងប្រឆាំងនឹងទោសអំពើអាក្រក់»

ដូច្នេះហើយបានជាចិត្តរបស់មនុស្ស

ពាក្យថា «ចិត្ត» នៅទីនេះសំដៅទៅដល់បំណងចិត្ត។ ការបកប្រែរបៀបផ្សេងទៀត: «ទាក់ទាញចិត្តរបស់មនុស្ស»

Ecclesiastes 8:12

មួយរយដង

ការបកប្រែរបៀបផ្សេងទៀត: «១០០ដង»

នឹងល្អដល់អ្នកណាដែលកោតខ្លាចព្រះជាម្ចាស់

ការបកប្រែរបៀបផ្សេងទៀត: «ជីវិតនឹងបានប្រើសម្រាប់អ្នកណាដែលកោតខ្លាចព្រះជាម្ចាស់»

អ្នកណាដែលគោរពព្រះវត្តមានរបស់ព្រះជាម្ចាស់

ពាក្យទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា ហើយទាំងពីរពាក្យបានរួមចូលគ្នាដើម្បីបញ្ជាក់។

ជីវិតរបស់គេនឹងមិនបានវែងឡើយ

ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់នឹងជីវិតរបស់គេមិនបានវែងទេ»

ថ្ងៃរបស់គេដូចជាស្រមោលមួយប្រព្រិច

អាចមានន័យថា គឺ១) អ្នកនិពន្ធប្រៀបធៀបខ្សែជីវិតរបស់មនុស្សអាក្រក់ទៅនឹងស្រមោលមួយប្រព្រិចភ្នែក ឬ ២) គុណភាព ឬការរីករាយនៃជីវិតរបស់មនុស្សអាក្រក់គឺខ្លី ហើយគ្មានអ្វីស្ថិតស្ថេរក្នុងជីវិតគេឡើយ។

Ecclesiastes 8:14

ការឥតបានការ

«គ្មានន័យខ្លឹមសារ» ឬ «គ្មានប្រយោជន៍»។ អ្វីដែលគួរកើតឡើងតែវាមិនកើតវិញ។

ការល្អបានកើតឡើងជាមួយមនុស្សអាក្រក់

តែការអាក្រក់វិញបានកើតឡើងជាមួយមនុស្សល្អ។

ការផ្សេងមួយទៀតដែលបានធ្វើនៅលើផែនដី

ការបកប្រែរបៀបផ្សេងទៀត: «អ្វីផ្សេងទៀតដែលមនុស្សបានធ្វើនៅលើផែនដី»

សម្រាប់ថ្ងៃនៃជីវិតរបស់គេដែលព្រះជាម្ចាស់បានប្រទានដល់គេ

ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានអនុញ្ញាតឲ្យគេមានជីវិតរស់នៅ»

Ecclesiastes 8:16

តាមចិត្តរបស់ខ្ញុំ

ដើម្បីអោយខ្ញុំយកចិត្តទុកដាក់គំនិតនរណាម្នាក់ ហើយធ្វើការស្វែងយល់ អំពីអ្វីមួយ។

សូមមើលពីរការបកប្រែពាក្យនេះនៅក្នុងជំពូក ១:១៦។

កិច្ចការដែលបានធ្វើនៅលើផែនដី

ការបកប្រែរបៀបផ្សេងទៀត: «កិច្ចការដែលមនុស្សធ្វើនៅលើផែនដី»

មិនបានដេកលក់

ការបកប្រែរបៀបផ្សេងទៀត: «មិនបានដេក»

កិច្ចការដែលមាននៅក្រោមថ្ងៃ

អាចមានន័យថា គឺ១) «កិច្ចការរបស់ព្រះជាម្ចាស់ធ្វើនៅក្រោមថ្ងៃ» ឬ ២) «កិច្ចការរបស់ព្រះជាម្ចាស់អនុញ្ញាតឲ្យមនុស្សទៅធ្វើនៅក្រោមថ្ងៃ»។

---

9 [1]ខ្ញុំបានគិតអំពីការទាំងអស់នេះនៅក្នុងគំនិតរបស់ខ្ញុំដើម្បី ឲ្យខ្ញុំយល់អំពីមនុស្សសុចរិត និងមនុស្សមានប្រាជ្ញា ហើយនិងកិច្ចការទាំងអស់របស់គេ។
ពួកគេគឺស្ថិតនៅក្នុងព្រះហស្តនៃព្រះជាម្ចាស់។ គ្មានអ្នកណាម្នាក់ដឹងថា តើសេចក្តីស្រឡាញ់ ឬការស្អប់នឹងមកកាន់អ្នកណាឡើយ។
[2]មនុស្សគ្រប់ៗរូបមានវាសនាដូចគ្នា។ វាសនាដូចគ្នានេះ រង់ចាំទាំងមនុស្សសុចរិត ទាំងមនុស្សទុច្ចរិត ទាំងមនុស្សល្អ ទាំងមនុស្សបរិសុទ្ធ ទាំងមនុស្សមិនបរិសុទ្ធ
ទាំងមនុស្សដែលថ្វាយយញ្ញបូជា និងទាំងមនុស្សដែលមិនបានថ្វាយយញ្ញបូជា។ ក្នុងនាមជាមនុស្សល្អនឹងស្លាប់ ដូច្នេះហើយមនុស្សមានបាបក៏នឹងស្លាប់ដែរ។
ក្នុងនាមជាមនុស្សដែលស្បថនឹងស្លាប់ ដូច្នេះហើយមនុស្សដែលភ័យខ្លាចក្នុងការបង្កើតពាក្យស្បថក៏នឹងស្លាប់ដូចគ្នាដែរ។
[3]អ្វីៗទាំងអស់ដែលកើតមាននៅក្រោមថ្ងៃគឺសុទ្ធតែជួបវាសនាអាក្រក់ គឺមនុស្សទាំងអស់មានជោគវាសនាដូចគ្នា។ ចិត្តរបស់មនុស្សមានពេញទៅដោយអំពើអាក្រក់
ហើយភាពឆ្កួតលីលាគឺនៅក្នុងចិត្តរបស់ពួកគេក្នុងកាលគេរស់នៅ។ ដូច្នេះ បន្ទាប់មកពួកគេនឹងធ្លាក់ទៅក្នុងសេចក្តីស្លាប់។
[4]ដ្បិតអ្នកណាដែលនៅរួមគ្នាជាមួយអ្នកដែលមានជីវិតរស់នៅ នោះនឹងមានសេចក្តីសង្ឃឹម ទោះបីដូចជាសត្វឆ្កែដែលរស់នៅនោះប្រសើរជាងសិង្ហងាប់ដែរ។
[5]ដ្បិតមនុស្សដែលមានជីវិតរស់នៅដឹងថា ពួកគេនឹងស្លាប់ ប៉ុន្តែសេចក្តីស្លាប់មិនបានដឹងអ្វីទាំងអស់។ ពួកគេលែងបានទទួលរង្វាន់អ្វីទៀតឡើយ
ព្រោះការចាំរបស់ពួកគេនឹងត្រូវបំភ្លេចចោល។
[6]សេចក្តីស្រឡាញ់ សេចក្តីស្អប់ខ្ពើម និងការច្រណែនរបស់ពួកគេបានវិនាសបាត់ទៅជាយូណាស់ហើយ។ ពួកគេនឹងលែងមានចំណែកណា
ក្នុងការអ្វីដែលធ្វើនៅក្រោមថ្ងៃទៀតហើយ។[7]ចូរទៅចុះ បរិភោគអាហាររបស់អ្នកដោយអំណរ និងផឹកស្រាទំពាំងបាយជូររបស់អ្នកដោយចិត្តសប្បាយ
ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងកិច្ចការដែលអ្នកធ្វើហើយ។[8]ចូរឲ្យសំលៀកបំពាក់របស់អ្នកនៅសជានិច្ច ហើយលាបប្រេងលើក្បាលរបស់អ្នកផងដែរ។
[9]ចូររស់នៅដោយសប្បាយជាមួយប្រពន្ធដែលអ្នកស្រឡាញ់ ជារៀងរាល់ថ្ងៃអស់មួយជីវិតរបស់អ្នក ក្នុងជីវិតដែលឥតបានការ ជាថ្ងៃដែលព្រះជាម្ចាស់បានប្រទានមកអ្នក
នៅក្រោមថ្ងៃ គឺជាជីវិតដែលឥតបានការរបស់អ្នក។ ដ្បិតនេះគឺជារង្វាន់ដែលអ្នកបានធ្វើនៅក្រោមថ្ងៃក្នុងជីវិតរបស់អ្នក។[10]អ្វីៗដែលដៃរបស់អ្នកស្វែងរកដើម្បីធ្វើ
ចូរធ្វើដោយអស់ពីកម្លាំងរបស់អ្នក ព្រោះគ្មានកិច្ចការ ឬការពន្យល់ ឬការចេះដឹង ឬប្រាជ្ញានៅក្នុងស្ថានឃុំព្រលឹង ជាកន្លែងដែលអ្នកនឹងទៅនោះទេ។
[11]ខ្ញុំបានឃើញរឿងដែលគួរឲ្យចាប់អារម្មណ៍មួយចំនួនដែលនៅក្រោមថ្ងៃ ការរត់ប្រណាំងមិនមែនកម្មសិទ្ធអ្នកដែលរត់លឿននោះទេ។
ចម្បាំងមិនមែនជាកម្មសិទ្ធអ្នកដែលខ្លាំងពូកែនោះទេ។ នំប៉័ងមិនមែនជាកម្មសិទ្ធអ្នកដែលមានប្រាជ្ញានោះទេ។ ទ្រព្យសម្បត្តិមិនមែនជាកម្មសិទ្ធអ្នកដែលយល់ដឹងទេ។
ការពេញចិត្តមិនមែនជាកម្មសិទ្ធអ្នកដែលមានការចេះដឹងដែរ។ ផ្ទុយទៅវិញ ពេលវេលា និងឱកាសជះឥទ្ធិពលដល់ពួកគេទាំងអស់វិញ។

generated on Wed Sep 10 16:16:32 2025

[12]ដ្បិតគ្មាននរណាម្នាក់ដឹងថាពេលណាគេស្លាប់នោះទេ ដូចជាត្រីដែលជាប់ក្នុងសំណាញ់នៃសេចក្តីស្លាប់ ឬដូចជាសត្វចាបដែលជាប់អន្ទាក់។ ដូចជាសត្វយ៉ាងណា
មនុស្សត្រូវជាប់ក្នុងពេលវេលាអាក្រក់នឹងធ្លាក់ទៅលើគេភ្លាមយ៉ាងនោះដែរ។
[13]នៅក្រោមថ្ងៃ ខ្ញុំក៏បានឃើញប្រាជ្ញា ដែលខ្ញុំយល់ថាអស្ចារ្យណាស់សម្រាប់ខ្ញុំ។[14]នៅក្នុងក្រុងតូចមួយ មានមនុស្សតែបន្តិចបន្តួចទេដែលរស់នៅ
ហើយមានស្តេចដ៏ពូកែមួយអង្គបានប្រឆាំងនឹងក្រុងនោះ និងឡោមព័ទ្ធក្រុងនោះ ទាំងបង្កើតបន្ទាយយ៉ាងធំឡាំងនឹងក្រុងនោះ។[15]នៅក្នុងក្រុងនោះ
មានមនុស្សក្រីក្រម្នាក់តែមានប្រាជ្ញា គាត់បានសង្គ្រោះទីក្រុងនោះដោយសារប្រាជ្ញារបស់លោក។ ក្រោយមក គ្មាននរណាម្នាក់នឹកនាដល់បុរសក្រីក្រនោះទៀតទេ។
[16]ដូច្នេះ ខ្ញុំយល់ថា «ប្រាជ្ញាគឺប្រសើរជាងភាពក្លាហាន ប៉ុន្តែប្រាជ្ញារបស់បុរសក្រីក្រនោះគឺ គេមើលងាយ ហើយពាក្យសម្តីរបស់គេក៏គ្មានអ្នកណាស្តាប់ដែរ»។
[17]ស្តាប់ពាក្យសម្តីរបស់មនុស្សមានប្រាជ្ញានិយាយដោយភាពស្ងាត់ៗនោះប្រសើរជាងស្តាប់សម្រែករបស់មនុស្សដែលគ្រប់គ្រងមនុស្សល្ងីល្ងើ។
[18]ប្រាជ្ញាគឺប្រសើរជាងគ្រឿងសស្ត្រាវុធ ប៉ុន្តែមនុស្សបាបតែម្នាក់អាចបំផ្លាញការល្អជាច្រើន។

Ecclesiastes 9:1
ខ្ញុំបានគិតអំពីការទាំងអស់នេះនៅក្នុងគំនិត
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់យ៉ាងខ្ញុំបានគិតដោយវែងឆ្ងាយ»
ពួកគេគឺស្ថិតនៅក្នុងព្រះហស្តនៃព្រះជាម្ចាស់
ពាក្យថា «ពួកគេ» នៅទីនេះសំដៅទៅលើ «មនុស្សសុចរិត
ហើយមនុស្សមានប្រាជ្ញា» ក៏ដូចជា «កិច្ចការរបស់គេ»។
ក្នុងព្រះហស្តនៃព្រះជាម្ចាស់
ពាក្យថា «ដៃ» នៅទីនេះសំដៅលើអំណាច ហើយនិងសិទ្ធអំណាច។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្រោមការគ្រប់គ្រងនៃព្រះជាម្ចាស់»
Ecclesiastes 9:2
មនុស្សសុចរិត ទាំងមនុស្សទុច្ចរិត
មនុស្សល្អ និងមនុស្សមិនល្អ
ទាំងមនុស្សបរិសុទ្ធ ទាំងមនុស្សមិនបរិសុទ្ធ
មនុស្សល្អ ... ដូច្នេះហើយមនុស្សមានបាបក៏នឹងស្លាប់ដែរ
មនុស្សដែលស្បថ... ដូច្នេះហើយមនុស្សដែលភ័យខ្លាចក្នុងការបង្កើតពាក្យស្បថ
Ecclesiastes 9:3
អ្វីៗទាំងអស់ដែលកើតមាន
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់យ៉ាងដែលមនុស្សធ្វើ»
វាសនាដូចគ្នា
ពាក្យថា «វាសនា» នៅទីនេះសំដៅដល់សេចក្តីស្លាប់។
ចិត្តរបស់មនុស្សមានពេញទៅដោយអំពើអាក្រក់ ហើយភាពឆ្កួតលីលាគឺនៅក្នុងចិត្តរបស់ពួកគេ
ពាក្យថា «ចិត្ត» នៅទីនេះសំដៅដល់ការគិត និងអារម្មណ៍។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សជាតិគឺពេញទៅដោយការអាក្រក់
ហើយមានតែការចំកួតនៅក្នុងគំនិតរបស់គេ»
ពួកគេនឹងធ្លាក់ទៅក្នុងសេចក្តីស្លាប់
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងទៅក្នុងកន្លែងនៃសេចក្តីស្លាប់» ឬ
«ពួកគេស្លាប់»។
Ecclesiastes 9:4
ការចាំរបស់ពួកគេនឹងត្រូវបំភ្លេចចោល
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនឹងបំភ្លេចពួកគេ»
Ecclesiastes 9:6
អ្វីដែលធ្វើនៅក្រោមថ្ងៃ
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់យ៉ាងដែលធ្វើនៅក្រោមថ្ងៃ»
បរិភោគអាហាររបស់អ្នកដោយអំណរ និងផឹកស្រាទំពាំងបាយជូររបស់អ្នកដោយចិត្តសប្បាយ
ឃ្លាទាំងពីរមានន័យស្រដៀងគ្នាហើយបានបញ្ជាក់ពីការសំខាន់នៃសេចក្តីរីករាយដែលមកពីការទទួលទានអាហារ
បរិភោគអាហាររបស់អ្នកដោយអំណរ
ការបកប្រែរបៀបផ្សេងទៀត: «រីករាយជាមួយអាហាររបស់អ្នក»
ផឹកស្រាទំពាំងបាយជូររបស់អ្នកដោយចិត្តសប្បាយ
ពាក្យថា «ចិត្ត» នៅទីនេះសំដៅដល់អារម្មណ៍។ ការបកប្រែរបៀបផ្សេងទៀត:
«ផឹកស្រាទំពាំងបាយជូររបស់អ្នកដោយអំណរ»
ចូរឲ្យសំលៀកបំពាក់របស់អ្នកនៅសជានិច្ច ហើយចូរឲ្យសំលៀកបំពាក់របស់អ្នកនៅសជានិច្ច
ហើយលាបប្រេងលើក្បាលរបស់អ្នក
ស្លៀកសំលៀកបំពាក់ ហើយលាបប្រេងលើក្បាលរបស់នរណាម្នាក់
ទាំងពីរជាសញ្ញារីករាយ និងពិធីអបអរសាទរ។
លាបប្រេងលើក្បាលរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «ចាក់ប្រេងតាំងនៅលើក្បាលអ្នកដោយប្រេង»
Ecclesiastes 9:9
រស់នៅដោយសប្បាយជាមួយប្រពន្ធ ដែលអ្នកស្រឡាញ់
អ្នកត្រូវស្រឡាញ់ប្រពន្ធរបស់ខ្លួន។ ការបកប្រែរបៀបផ្សេងទៀត:
«តាំងពីអ្នកបានប្រពន្ធដែលអ្នកបានស្រឡាញ់ សូមរស់ដោយរីករាយជាមួយនាង»
អ្វីៗដែលដៃរបស់អ្នកស្វែងរកដើម្បីធ្វើ
ការបកប្រែរបៀបផ្សេងទៀត: «អ្វីក៏ដោយដែលអ្នកអាចធ្វើបាន»
គ្មានកិច្ចការ ឬការពន្យល់ ឬការចេះដឹង ឬប្រាជ្ញា
ការបកប្រែរបៀបផ្សេងទៀត: «កិច្ចការមិនបានធ្វើ ឬការពន្យល់ ឬការចេះដឹង
ឬប្រាជ្ញា»
Ecclesiastes 9:11
ពេលវេលា និងឱកាសជះឥទ្ធិពលដល់ពួកគេទាំងអស់
«អ្វីដែលកើតឡើង
និងនៅពេលណាវាកើតឡើងនឹងជះឥទ្ធិពលដល់ពួកគេទាំងអស់»
ជះឥទ្ធិពលដល់ពួកគេទាំងអស់
ពាក្យថា «ពួកគេទាំងអស់» នៅទីនេះសំដៅដល់ការប្រណាំង តយុទ្ធ អាហារ
ទ្រព្យសម្បត្តិ ហើយព្រះគុណ។
ដូចជាត្រី... ដូចជាសត្វចាប ... ដូចជាសត្វ ហើយនិងមនុស្សជាតិ
សេចក្តីស្លាប់ចាប់មនុស្សជាតិ
ពេលពួកគេមិនរំពឹងទុកពីវាគឺដូចដែលមនុស្សចាប់សត្វនៅពេលពួកវាមិនបានប្រយ័ត្នដែរ។
ក្នុងពេលវេលាអាក្រក់នឹងធ្លាក់ទៅលើគេ
អាចមានន័យថា គឺ១)
«នៅក្នុងកាលៈទេសៈដ៏អាក្រក់ហើយវាបានកើតឡើងភ្លាមដល់ពួកគេ» ឬ ២)
«តាមរយៈសេចក្តីស្លាប់បានឆក់យកពួកគេភ្លាម»។
Ecclesiastes 9:13
ក្នុងក្រុងនោះ មានមនុស្សក្រីក្រម្នាក់តែមានប្រាជ្ញា
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងទីក្រុងគេរកឃើញអ្នកក្រដែលមានប្រាជ្ញា» ឬ
«អ្នកក្រ រស់នៅក្នុងទីក្រុង»
Ecclesiastes 9:16
ប្រាជ្ញារបស់បុរសក្រីក្រនោះគឺគេមើលងាយ
តាំងពីមនុស្សនេះក្រ មនុស្សដទៃទៀតមិនបានឲ្យតម្លៃប្រាជ្ញារបស់គាត់ទេ
ហើយមិនគោរពពីចំណេះដឹងរបស់គាត់ដែរ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនយកចិត្តទុកដាក់ចំពោះប្រាជ្ញារបស់អ្នកក្រនោះ»
ពាក្យសម្តីរបស់គេក៏គ្មានអ្នកណាស្តាប់
មនុស្សទាំងនោះឈប់ស្តាប់គាត់។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិនស្តាប់អ្វីដែលគាត់បាននិយាយទេ» ឬ
«ពួកគេក៏មិនបានទទួលយកយោបល់គាត់ដែរ»
Ecclesiastes 9:17
ប្រសើរជាងស្តាប់
ការបកប្រែរបៀបផ្សេងទៀត: «គឺយល់ប្រសើរជាង»

---

10 [1]រុយងាប់បង្ករឲ្យទឹកអប់ទៅជាស្អុយ ដូច្នេះភាពល្ងីល្ងើតូចមួយក៏អាចយកឈ្នះប្រាជ្ញា និងកិត្តិយសបានដែរ។
[2]ចិត្តរបស់មនុស្សមានប្រាជ្ញាមានទំនោរទៅលើសេចក្តីត្រឹមត្រូវ ប៉ុន្តែចិត្តរបស់មនុស្សល្ងីល្ងើមានទំនោរទៅសេចក្តីខុសឆ្គងវិញ។
[3]នៅពេលដែលមនុស្សល្ងីល្ងើដើរតាមផ្លូវ ការគិតរបស់គឺមិនគ្រប់គ្រាន់ បង្ហាញឲ្យមនុស្សគ្រប់គ្នាដឹងថាគេជាមនុស្សល្ងីល្ងើ។
[4]ប្រសិនបើអ្នកគ្រប់គ្រងមានអារម្មណ៍ខឹងនឹងអ្នក កុំបោះបង់ការងាររបស់អ្នកឡើយ។ ការរងាប់ចិត្តអាចបញ្ឈៀសកំហឹងដ៏ខ្លាំងបាន។

generated on Wed Sep 10 16:16:32 2025

[5]នេះគឺជាការអាក្រក់ដែលខ្ញុំបានឃើញនៅក្រោមថ្ងៃ គឺជាកំហុសដែលចេញពីអ្នកគ្រប់គ្រង[6]មនុស្សល្ងីល្ងើបានទទួលតំណែងជាអ្នកដឹកនាំ
ហើយអ្នកដែលទទួលការជោគជ័យបានទទួលតំណែងតូចតាចទៅវិញ។[7]ខ្ញុំបានឃើញអ្នកបម្រើជិះសេះ តែអ្នកដែលជោគជ័យបែរជាដើរនៅលើដី ដូចជាអ្នកបម្រើទៅវិញ។
[8]អ្នកណាដែលជិករណ្តៅអាចនឹងធ្លាក់ទៅក្នុងរណ្តៅនោះ ហើយពេលណា មានអ្នកណាម្នាក់វាយបំបែកជញ្ជាំង នោះអាចត្រូវពស់ចឹក។
[9]អ្នកណាដែលរើសថ្មចេញអាចនឹងត្រូវមុតថ្មនោះ និងអ្នកណាដែលកាប់ឈើក៏មានគ្រោះថ្នាក់ដោយសាឈើនោះដែរ។
[10]ប្រសិនបើកាំបិតដែកមួយរិល ហើយមនុស្សមិនបានសំលៀងកាំបិតនោះទេ គេនឹងត្រូវប្រើកម្លាំងបន្ថែម ប៉ុន្តែប្រាជ្ញាផ្តល់ឲ្យសម្រេចជោគជ័យ។
[11]ប្រសិនបើពស់ចឹកមុនពេលដែលគ្រូស្តោះផ្សុំ នោះគ្មានប្រយោជន៍អ្វីទេសម្រាប់គ្រូស្តោះផ្សុំ។
[12]ពាក្យសម្តីដែលចេញពីមាត់របស់អ្នកមានប្រាជ្ញាមានភាពទន់ សន្តោស ប៉ុន្តែបបូរមាត់របស់មនុស្សល្ងីល្ងើបំផ្លាញខ្លួនគេវិញ។
[13]ពាក្យចាប់ផ្តើមហូរចេញពីមាត់របស់មនុស្សល្ងីល្ងើ ចេញមកតែពាក្យលីលា ហើយចុងបញ្ចប់នៃមាត់របស់គេចេញមកដោយភាពឆ្កួតរបស់មនុស្សអាក្រក់។
[14]ពាក្យរបស់មនុស្សល្ងីល្ងើកាន់តែចម្រើនឡើង ប៉ុន្តែគ្មាននរណាម្នាក់ដឹងថានឹងមានអ្វីកើតឡើងនោះទេ។ តើអ្នកណាដឹងថានឹងមានអ្វីកើតឡើងបន្ទាប់បានទេ?
[15]កិច្ចការរបស់មនុស្សល្ងីល្ងើធ្វើឲ្យគេព្រួយបារម្ភណ៍ ដូច្នេះហើយពួកគេមិនបានដឹង សូម្បីតែផ្លូវទៅកាន់ក្រុងផង។
[16]វេទនាដល់អ្នកហើយ ទឹកដីណាមានក្មេងប្រុសជាស្តេច ហើយបើសិនអ្នកដឹកនាំរបស់អ្នកនាំគ្នាជប់លៀងនៅតាំងពីពេលព្រឹក![17]ប៉ុន្តែមានពរដល់អ្នកហើយ
ទឹកដីណាមានអ្នកថ្លៃថ្នូរជាស្តេច ហើយបើសិនអ្នកដឹកនាំរបស់អ្នកបរិភោគតាមពេលវេលាត្រឹមត្រូវ សម្រាកកម្លាំង និងមិនមែនសម្រាប់ផឹកស្រាស្រវឹងនោះទេ។
[18]ដំបូងផ្ទះស្រុតធ្លាក់ ដោយសារតែភាពខ្ជិលច្រអូស ហើយផ្ទះលិចធ្លាយ ដោយសារតែដៃទំនេរ។[19]មនុស្សរៀបចំអាហារសម្រាប់សំណើច
រីឯស្រានាំមកការសប្បាយរីករាយដល់ជីវិត និងលុយបំពេញនូវសេចក្តីត្រូវការទាំងអស់។
[20]កុំដាក់បណ្តាសារស្តេចឡើយ សូម្បីតែនៅក្នុងចិត្តរបស់ក៏ដោយ ហើយកុំដាក់បណ្តាសាអ្នកមាននៅក្នុងបន្ទប់របស់អ្នកដែរ។ ដ្បិតសត្វចាបដែលហើរលើមេឃ
អាចនឹងនាំពាក្យសម្តីរបស់អ្នក អ្វីៗដែលមានស្លាបអាចថ្លែងប្រាប់តាមរឿងនោះ។

Ecclesiastes 10:1

រុយងាប់បង្ករឲ្យទឹកអប់ទៅជាស្អុយ ដូច្នេះភាពល្ងីល្ងើ

ដូចជាសត្វរុយងាប់ ធ្វើឲ្យបំផ្លាញក្លិនក្រអូប

ដូច្នេះការល្ងីល្ងើអាចបំផ្លាញកេរ្តិ៍ឈ្មោះមនុស្ស សម្រាប់ប្រាជ្ញានិងការសរសើរ។

ចិត្តរបស់មនុស្សមានប្រាជ្ញា...ចិត្តរបស់មនុស្សល្ងីល្ងើ

ពាក្យថា «ចិត្ត» នៅទីនេះសំដៅលើគំនិត ឬបំណងចិត្ត។

ការបកប្រែរបៀបផ្សេងទៀត: «របៀបមនុស្សបានគិត ...
របៀបមនុស្សល្ងង់បានគិត»

មានទំនោរទៅលើសេចក្តីត្រឹមត្រូវ...មានទំនោរទៅសេចក្តីខុសឆ្គង

ពាក្យថា «ស្តាំ» ហើយនិង «ឆ្វេង» នៅទីនេះសំដៅទៅលើការត្រឹមត្រូវ
ហើយនិងខុស។ ការបកប្រែរបៀបផ្សេងទៀត:
«មានទំនោរទៅលើធ្វើការអ្វីដែលត្រឹមត្រូវ...មានទំនោរទៅលើធ្វើការអ្វីដែលខុស»

ការគិតរបស់គាត់គឺមិនគ្រប់គ្រាន់

ការបកប្រែរបៀបផ្សេងទៀត: «គាត់គឺជាមនុស្សល្ងង់»

Ecclesiastes 10:4

ប្រសិនបើអ្នកគ្រប់គ្រងមានអារម្មណ៍ខឹងនឹងអ្នក

ការបកប្រែរបៀបផ្សេងទៀត: «បើសិនអ្នកគ្រប់គ្រងខឹងនឹងអ្នក»

Ecclesiastes 10:5

មនុស្សល្ងីល្ងើបានទទួលតំណែងជាអ្នកដឹកនាំ

ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដឹកនាំបានប្រគល់កិច្ចការគ្រប់គ្រងដល់មនុស្សល្ងង់»

អ្នកដែលទទួលការជោគជ័យបានទទួលតំណែងតូចតាច

ការបកប្រែរបៀបផ្សេងទៀត: «ពួកគេប្រគល់តួនាទីទាបដល់អ្នកដែលជោគជ័យ»

Ecclesiastes 10:8

ព័ត៌មានទូទៅ:

ធ្វើការដោយគ្មានហានិភ័យ។

អ្នកណាដែលរើសថ្មចេញអាចនឹងត្រូវមុតថ្មនោះ

ការបកប្រែរបៀបផ្សេងទៀត: «ថ្មទាំងនោះនឹងធ្វើឲ្យគេឈឺ»

Ecclesiastes 10:10

ព័ត៌មានទូទៅ:

សុភាសិតខ្លះ

ប្រាជ្ញាផ្តល់ឲ្យសម្រេចជោគជ័យ

អ្នកមានប្រាជ្ញាគួរតែបានសំលៀងកាំបិតឲ្យមុត
ពេលយកទៅប្រើមិនបាច់ប្រើកម្លាំងច្រើន។

មុនពេលដែលគ្រូស្តោះផ្សុំ

ការបកប្រែរបៀបផ្សេងទៀត: «នៅចំពោះមុខសត្វពស់មានគ្រូស្តោះផ្សុំវា»

Ecclesiastes 10:12

ព័ត៌មានទូទៅ:

បន្តសុភាសិតទៀត។

ពាក្យសម្តីដែលចេញពីមាត់របស់អ្នកមានប្រាជ្ញាមានភាពទន់សន្តោស

ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលអ្នកមានប្រាជ្ញាមានភាពទន់»

បបូរមាត់របស់មនុស្សល្ងីល្ងើបំផ្លាញខ្លួនគេ

ពាក្យថា «លេប» នៅទីនេះសំដៅលើការបំផ្លាញ។ ការបកប្រែរបៀបផ្សេងទៀត:
«ជាអ្វីដែលមនុស្សល្ងង់និយាយហើយនឹងបំផ្លាញគេវិញ»។

Ecclesiastes 10:13

ពាក្យចាប់ផ្តើមហូរចេញពីមាត់របស់មនុស្សល្ងីល្ងើ

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សល្ងង់ចាប់ផ្តើមនិយាយ»

ចុងបញ្ចប់នៃមាត់របស់គេចេញមកដោយភាពឆ្កួតរបស់មនុស្សអាក្រក់

ការបកប្រែរបៀបផ្សេងទៀត: «ពេលមនុស្សល្ងង់បញ្ចាប់ការនិយាយ
ដោយពោលការអាក្រក់ និងកំហឹង»

ពាក្យរបស់មនុស្សល្ងីល្ងើកាន់តែចម្រើនឡើង

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សល្ងីល្ងើនិយាយច្រើន»

គ្មាននរណាម្នាក់ដឹងថានឹងមានអ្វីកើតឡើង

សូមមើលការបកប្រែនេះនៅក្នុងជំពូក ៨:៥។

តើអ្នកណាដឹងថានឹងមានអ្វីកើតឡើងបន្ទាប់បានទេ?

អ្នកនិពន្ធសួរសំនួរនេះដើម្បីបញ្ជាក់ថា
គ្មានអ្នកណានឹងដឹងថាមានអ្វីកើតឡើងពេលអនាគតនោះទេ។
ការបកប្រែរបៀបផ្សេងទៀត:
«គ្មានអ្នកណាដឹងថាមានអ្វីមកតាមក្រោយគាត់ឡើយ»។

Ecclesiastes 10:15

គេព្រួយបារម្ភណ៍

«ធ្វើឲ្យពួកគេមានអារម្មណ៍នឿយហត់»

ដូច្នេះហើយពួកគេមិនបានដឹង សូម្បីតែផ្លូវទៅកាន់ក្រុងផង

អាចមានន័យថា គឺ១)
ដែលមនុស្សល្ងីល្ងើទៅជាអស់កម្លាំងពីការងារដែលធ្វើលើសកម្លាំង
ហើយគាត់មិនអាចស្វែងរកផ្លូវណាផ្សេងទៀត ឬ ២)
ដែលមនុស្សល្ងីល្ងើទៅជាអស់កម្លាំងពីការងារដែលធ្វើលើសកម្លាំង
ដោយសារពួកគេមិនបានដឹងផ្លូវទៅផ្ទះវិញ។

Ecclesiastes 10:16

វេទនាដល់អ្នកហើយ ទឹកដី...មានពរដល់អ្នកហើយ ទឹកដី

នៅក្នុងខគម្ពីរនេះ អ្នកនិពន្ធគឺនិយាយទៅកាន់ប្រជាជាតិ
ដូចជាការនិយាយទៅកាន់មនុស្សដែល។

បើមានក្មេងប្រុសជាស្តេចរបស់អ្នក

មានន័យថាស្តេចមិនទាន់មានបទពិសោធន៏ ឬមិនទាន់ពេញវ័យ។
នៅក្នុងកំណែថ្មីខ្លះ ដែលជាអ្នកបកប្រែពីពាក្យហេព្រើរដូចជា «អ្នកបម្រើម្នាក់»

ជប់លៀងនៅតាំងពីពេលព្រឹក

ការបង្កប់ន័យ
ដែលអ្នកដឹកនាំបានបារម្ភពីការដែលពួកគេបានទទួលបានល្អជាងការដឹកនាំប្រជាជាតិមួយ។

អ្នកថ្លៃថ្នូរជាស្តេច

ការបង្កប់ន័យ
ដែលកូនប្រុសបានបង្ខិតបង្ខើនដោយអ្នកចាស់ទុំនៅក្នុងទំនៀមទម្លាប់
ដើម្បីក្លាយជាស្តេចល្អ។

generated on Wed Sep 10 16:16:32 2025

Ecclesiastes 10:18
ដោយសារតែភាពខ្ជិលច្រអូស ហើយផ្ទះលិចធ្លាយ
អ្នកខ្ជិលច្រអូសនឹងមិនបានមើលថែផ្ទះសម្បែងឲ្យល្អទេ។
ដោយសារតែដៃទំនេរ
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារដៃរបស់មនុស្ស»
មនុស្សរៀបចំអាហារសម្រាប់សំណើច
ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សរៀបចំអាហារដោយមានរបៀបសម្រាប់សើច»
ស្រានាំមកការសប្បាយរីករាយដល់ជីវិត
ការបកប្រែរបៀបផ្សេងទៀត: «ស្រាជួយឲ្យមនុស្សបានរីករាយក្នុងជីវិត»
លុយបំពេញនូវសេចក្តីត្រូវការទាំងអស់
អាចមានន័យថា គឺ១) «ប្រាក់ផ្តល់ឲ្យសម្រាប់គ្រប់តម្រូវការ» ឬ ២)
«ប្រាក់ផ្តល់ឲ្យសម្រាប់ទាំងពីរអាហារ និងស្រា»។

Ecclesiastes 10:20
សូម្បីតែនៅក្នុងចិត្តរបស់អ្នក
«មិនមាននៅក្នុងការគិត»
អ្នកមាននៅក្នុងបន្ទប់របស់អ្នកដែរ
«ភាពមានបានរបស់អ្នកគឺនៅក្នុងបន្ទាប់គេងរបស់អ្នក»។
មានន័យថាអ្នកមិនបានដាក់បណ្តាសារដល់អ្នកមាន
ទោះបីគាត់នៅកន្លែងដោយឡែក ហើយមិនមានអ្នកអាចឮផង។
ដ្បិតសត្វចាបដែលហើរលើមេឃ ... អាចថ្លែងប្រាប់តាមរឿងនោះ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា ហើយរួមជាមួយគ្នាសម្រាប់បញ្ជាក់ន័យ។
អ្នកនិពន្ធប្រើពាក្យប្រៀបធៀប
ពីសត្វស្លាបដើម្បីប្រាប់ដល់មនុស្សនូវអ្វីដែលអ្នកបាននិយាយ
ពីរបៀបមួយទៅកាន់របៀបមួយផ្សេងទៀត។

---

11 [1]ចូរបោះនំបុ័ងរបស់អ្នកទៅក្នុងទឹក ដ្បិតអ្នកនឹងរកនំបុ័ងវិញនៅថ្ងៃបន្ទាប់ៗទៀត។[2]ចែកនំបុ័ងនេះជាមួយមនុស្សប្រាំពីរនាក់ ឬប្រាំបីនាក់
ដ្បិតអ្នកមិនដឹងថាមានគ្រោះមហន្តរាយអ្វីកើតមាននៅលើផែនដីនោះទេ។[3]ប្រសិនបើ ពពកពោរពេញទៅដោយទឹកភ្លៀង
ពពកនោះនឹងបង្ហូរទឹកភ្លៀងមកលើផែនដីពុំខាន ហើយប្រសិនបើ ដើមឈើរលំ ទោះបីរលំទៅទិសខាងត្បូង ឬទិសខាងជើង
កន្លែងណាដែលដើមឈើនោះរលំនឹងនៅតែមាន។
[4]អ្នកណាដែលមើលខ្យល់ មិនសាបព្រោះទេ ហើយអ្នកណាដែលមើលពពក ក៏មិនច្រូតកាត់ដែរ។[5]បើអ្នកមិនដឹងអំពីផ្លូវនៃខ្យល់
ឬមិនដឹងពីរបៀបដែលឆ្អឹងទារកកកើតនៅក្នុងផ្ទៃម្តាយនោះទេ ដូច្នេះ អ្នកក៏មិនអាចយល់ពីកិច្ចការនៃព្រះជាម្ចាស់ ជាព្រះដែលបង្កើតអ្វីៗទាំងអស់មកដែរ។
[6]ចូរសាបព្រោះគ្រាប់ជូពរបស់អ្នកនៅពេលព្រឹក រហូតដល់ពេលល្ងាច ធ្វើការដោយមិនទំនេរដៃរបស់អ្នកឡើយ ដ្បិតអ្នកមិនដឹងថា កិច្ចការណាមួយនឹងបង្កើតផលឡើយ
ថាតើពេលព្រឹក ឬពេលល្ងាច ថាតើខាងនោះ ឬខាងនេះ ឬថាតើទាំងពីរនឹងបង្កើតផលល្អដូចគ្នាទេ។[7]ពន្លឺរមែងធ្វើឲ្យចិត្តទន់ភ្លន់
ហើយពន្លឺគឺជារឿងរីករាយសម្រាប់ភ្នែកដើម្បីមើលព្រះអាទិត្យ។[8]ប្រសិនបើមានម្នាក់រស់នៅបានយូរឆ្នាំ ចូរឲ្យគេរីករាយក្នុងឆ្នាំទាំងប៉ុន្មាននៃអាយុរបស់ខ្លួន
ប៉ុន្តែចូរឲ្យគេគិតអំពីថ្ងៃសេចក្តីងងឹតនឹងមកដល់ ដ្បិតថ្ងៃនោះនឹងមានច្រើនណាស់។ អ្វីៗទាំងអស់ដែលកើតមកសុទ្ធតែឥតបានការ។
[9]យុវជនអើយ ចូរសប្បាយទាន់ខ្លួនអ្នកនៅក្មេង ចូរឲ្យចិត្តរបស់អ្នកបានរីករាយក្នុងគ្រាយុវវ័យនេះ។ ចូរប្រព្រឹត្តតាមចិត្តប៉ងប្រាថ្នា និងតាមការយល់ឃើញរបស់អ្នក។
ទោះជាយ៉ាងណាត្រូវដឹងថា ព្រះជាម្ចាស់នឹងវិនិច្ឆ័យគ្រប់កិច្ចការទាំងនេះជាមិនខាន។[10]ចូរដកកំហឹងចេញពីចិត្តរបស់អ្នក ហើយធ្វើគធ្វើថ្លង់ការឈឺចាប់ក្នុងខ្លួនរបស់អ្នក
ព្រោះភាពជាយុវវ័យ និងភាពរឹងមាំនៃយុវវ័យគឺគ្មានប្រយោជន៍ទេ។

Ecclesiastes 11:1
ចូរបោះនំបុ័ងរបស់អ្នកទៅក្នុងទឹក ដ្បិតអ្នកនឹងរកនំបុ័ងវិញនៅថ្ងៃបន្ទាប់ៗទៀត
អាចមានន័យថា គឺ១) អ្នកនេះគួរជាមនុស្សដែលមានចិត្តល្អជាមួយទ្រព្យរបស់ខ្លួន
ហើយគាត់នឹងទទួលបានការល្អពីអ្នកដទៃវិញ។ ឬ ២) មនុស្សនឹងគាត់នៅក្រៅស្រុក
ហើយនឹងទទួលបានការកម្រៃពីវាវិញ។
ចែកនំបុ័ងនេះជាមួយមនុស្សប្រាំពីរនាក់ ឬប្រាំបីនាក់
អាចមានន័យថា គឺ១) ដើម្បីចែកទ្រព្យឲ្យទៅមនុស្សជាច្រើនទៀត ឬ ២)
ដើម្បីដាក់វិនិយោគទ្រព្យសម្បត្តិរបស់អ្នកនឹងគាត់នៅក្រៅស្រុកឲ្យចំរើនឡើង។
មនុស្សប្រាំពីរនាក់ ឬប្រាំបីនាក់
ការបកប្រែរបៀបផ្សេងទៀត: «៧ ឬក៏៨» ឬ «ចំនួនច្រើន»
មិនដឹងថាមានគ្រោះមហន្តរាយអ្វីកើតមាននៅលើផែនដី
ឃ្លាថា «នៅលើផែនដី» នៅទីនេះមានន័យថា «នៅក្នុងពិភពលោក» ឬ
«នៅក្នុងសង្គម» ។
ពពកនោះនឹងបង្ហូរទឹកភ្លៀងមកលើផែនដី
ឃ្លាថា «នៅលើផែនដី» នៅទីនេះមានន័យថា «នៅលើដី»។
ទៅទិសខាងត្បូង ឬទិសខាងជើង
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងទិសដៅណាមួយ»

Ecclesiastes 11:4
អ្នកណាដែលមើលខ្យល់ មិនសាបព្រោះទេ
អាចមានន័យថា គឺ១)
«អ្នកកសិករណាដែលចាំមើលទៅលើខ្យល់គឺនឹងមិនអាចដាំដំណាំបានទេដោយសារតែ[illegible]»
ឬ ២) «អ្នកកសិករណាដែលចាំមើលទៅលើខ្យល់គឺនឹងមិនអាចដាំដំណាំបានទេ»។
អ្នកណាដែលមើលពពក ក៏មិនច្រូតកាត់
អាចមានន័យថា ទី១) «អ្នកកសិករណាដែលចាំមើលទៅលើពពកនឹងបានច្រូតកាត់
ពេលវាជិតរដូវភ្លៀងមកដល់» ឬ២)
«អ្នកកសិករណាដែលចាំមើលទៅលើពពកនឹងបានច្រូតកាត់»។
របៀបដែលឆ្អឹងទារកកកើត
អាចមានន័យថា ទី១) «តើទារកលូតលាសបែបណា» ឬ២) ជាការពិត
«តើឆ្អឹងរបស់ទារកលូតលាស់បែបណា»។

Ecclesiastes 11:6
ធ្វើការដោយមិនទំនេរដៃរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «បន្តធ្វើការទៀត»
ថាតើពេលព្រឹក ឬពេលល្ងាច ថាតើខាងនោះ ឬខាងនេះ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់ថាការងារអ្នកនោះនឹងរីកចម្រើន
មិនថានៅក្នុងពេលណាដែលគាត់បានធ្វើវានោះទេ។ ការបកប្រែរបៀបផ្សេងទៀត:
«មិនថាគ្រាប់ពូជដែលអ្នកដាំចុះនៅពេលព្រឹក ឬក៏នៅពេលល្ងាចទេ»។
ពន្លឺរមែងធ្វើឲ្យចិត្តទន់ភ្លន់
ឃ្លាថា «ពន្លឺ» នៅទីនេះសំដៅទៅលើពីការដែលអាចមើលឃើញពន្លឺថ្ងៃ
ហើយបន្តនៅតែមានជីវិត។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលនៅតែឃើញពន្លឺថ្ងៃគឺទន់ភ្លន់» ឬ «នៅមានជីវិតដែលទន់ភ្លន់»
សម្រាប់ភ្នែកដើម្បីមើលព្រះអាទិត្យ
ឃ្លានេះមានន័យមូលដ្ឋានដូចគ្នាទៅនឹងឃ្លាដែលមានកន្លងមក។
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតមនុស្សឃើញពន្លឺថ្ងៃ» ឬ «ដើម្បីរស់នៅ»
រីករាយក្នុងឆ្នាំទាំងប៉ុន្មាន
ឃ្លាថា «ពួកគេ» នៅទីនេះសំដៅដល់ឆ្នាំដែលមនុស្សនោះបានរស់នៅ។
ថ្ងៃសេចក្តីងងឹតនឹងមកដល់
ឃ្លាថា «ងងឹត» នៅទីនេះសំដៅទៅលើសេចក្តីស្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«តើនៅសល់ប៉ុន្មានថ្ងៃទៀតដែលគាត់នឹងត្រូវស្លាប់»។
ដ្បិតថ្ងៃនោះនឹងមានច្រើន
ឃ្លាថា «ពេលវេលាទាំងនេះ[illegible]ត្រូវថ្ងៃនៃភាពងងឹត»។
ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតគាត់នឹងត្រូវបានស្លាប់ជាច្រើនថ្ងៃជាងដែលគាត់បានរស់នៅផង» ឬ
«ដ្បិតគាត់នឹងស្លាប់ជារៀងរហូត»។
អ្វីៗទាំងអស់ដែលកើតមក
អាចមានន័យថា គឺ១) «គ្រប់យ៉ាងដែលនឹងកើតឡើងក្រោយពីសេចក្តីស្លាប់» ឬ ២)
«អ្វីដែលនឹងកើតឡើងនៅពេលអនាគត»។

Ecclesiastes 11:9
យុវជនអើយ ចូរសប្បាយទាន់ខ្លួនអ្នកនៅក្មេង ចូរឲ្យចិត្តរបស់អ្នកបានរីករាយក្នុងគ្រាយុវវ័យនេះ
ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា ហើយរួមជាមួយសម្រាប់ការបញ្ជាក់។

generated on Wed Sep 10 16:16:32 2025

ចូរឲ្យចិត្តរបស់អ្នកបានរីករាយ
ឃ្លាថា «ចិត្ត» នៅទីនេះសំដៅទៅលើអារម្មណ៍។ ការបកប្រែរបៀបផ្សេងទៀត: «ចូររីករាយ»
ចូរប្រព្រឹត្តតាមចិត្តប៉ងប្រាថ្នារបស់អ្នក
ឃ្លាថា «ចិត្ត» នៅទីនេះសំដៅដល់គំនិត ឬ អារម្មណ៍។
ការបកប្រែរបៀបផ្សេងទៀត: «ចូរប្រព្រឹត្តតាមចិត្តប៉ងប្រាថ្នារបស់អ្នក» ឬ «ចូរឲ្យការល្អដែលអ្នកប្រាថ្នាបានកើតឡើង»
ទោះជាយ៉ាងណាត្រូវដឹងថាដូចឃើញនឹងភ្នែក
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលអ្នកឃើញគឺជាបំណងចិត្តរបស់អ្នក» ឬ «អ្វីដែលអ្នកឃើញគឺល្អបំផុត»
ព្រះជាម្ចាស់នឹងវិនិច្ឆ័យគ្រប់កិច្ចការទាំងនេះ
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់នឹងធ្វើតាមអ្វីដែលអ្នកបានប្រព្រឹត្ត»
ចូរដកកំហឹងចេញពីចិត្តរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «បដិសេធក្នុងការខឹង»

12 [1]ចូរនឹកចាំពីព្រះអាទិករបស់អ្នក នៅពេលដែលអ្នកនៅជាយុវវ័យនៅឡើយ មុនពេលដែលថ្ងៃនៃលំបាកមកដល់ ហើយមុនពេលច្រើនឆ្នាំកន្លងផុតទៅ
ពេលដែលអ្នកនិយាយថា «ខ្ញុំលែងមានភាពរីករាយក្នុងឆ្នាំទាំងនេះទៀតហើយ»។[2]ត្រូវធ្វើការនេះមុនពេលពន្លឺនៃព្រះអាទិត្យ ទាំងព្រះច័ន្ទ និងផ្កាយទៅជាងងឹត
ហើយពពកខ្មៅនឹងត្រលប់មកវិញបន្ទាប់ពីភ្លៀងរួច។
[3]ជាពេលដែលឆ្មាំយាមរាជវាំងនឹងញ័ររន្ធត់ និងមនុស្សខ្លាំងពូកែក្រាបចុះ ចំណែកស្ត្រីដែលកិនម្សៅនឹងឈប់កិន ដោយសារមានគ្នាពីបីនាក់
ហើយអស់អ្នកណាដែលមើលមកតាមបង្អួចត្រូវងងឹតទៅ។
[4]ជាពេលដែលទ្វាទាំងឡាយនៅតាមផ្លូវនឹងត្រូវបិទ និងជាពេលដែលលែងឮសំឡេងសូរត្បាល់កិន ហើយនៅពេលដែលមនុស្សភ្ញាក់ផ្អើលដោយឮសត្វចាបយំ
ព្រមទាំងសំឡេងកូនស្រីដែលច្រៀងបាត់ទៅ។
[5]ជាពេលដែលមនុស្សនឹងប្រែជាខ្លាចទីខ្ពស់ និងប្រែជាខ្លាចគ្រោះថ្នាក់ពេលធ្វើដំណើរតាមផ្លូវ ហើយនៅពេលដែលដើមចំបក់ចេញផ្កា
ហើយនៅពេលដែលកណ្តូបអូសខ្លួនឯងតាមផ្លូវ និងនៅពេលដែលបំណងប្រាថ្នាពីកំណើតត្រូវបរាជ័យ។ មនុស្សលោកឈានទៅរកផ្ទះដែលអស់កល្បជានិច្ចរបស់ពួកគេ
និងពួកអ្នកកាន់ទុក្ខដើរទៅតាមផ្លូវ។
[6]ចូរនឹកចាំពីព្រះអាទិករបស់អ្នក មុនពេលដែលខ្សែប្រាក់ដាច់ ឬចានមាសបែក ឬក្អមបែកនៅប្រភពទឹក ឬរហាត់ទឹកនៅអណ្តូងខូចបាត់ទៅ
និងមុនពេលធូលីត្រលប់ទៅជាដីវិញ[7]ហើយប្រលឹងវិញ្ញាណត្រលប់ទៅកាន់ព្រះជាម្ចាស់ជាព្រះដែលបានប្រទានមកវិញ។
[8]«ឥតបានការសោះ» គ្រូនិយាយថា «អ្វីៗទាំងអស់សុទ្ធតែឥតបានការសោះ»។[9]គ្រូជាអ្នកប្រាជ្ញ ហើយលោកបានបង្រៀនមនុស្សឲ្យចេះដឹង។ លោកបានរៀន
ហើយសញ្ជឹងគិត និងរៀបចំជាសុភាសិតជាច្រើន។
[10]គ្រូព្យាយាមស្វែងរកពាក្យល្អត្រឹមត្រូវ នៃសេចក្តីពិតដែលបានចែងទុកមកសរសេរ។[11]ពាក្យសម្តីរបស់មនុស្សមានប្រាជ្ញាប្រៀបដូចជាគ្រឿងលើកទឹកចិត្ត។
ពាក្យសម្តីរបស់អ្នកមានប្រាជ្ញាប្រៀបដូចជាដែកគោល ដែលគេបោះយ៉ាងជាប់ ជាពាក្យដែលបង្រៀនដោយអ្នកគង្វាលតែមួយគត់។
[12]កូនអើយ ត្រូវដឹងពីអ្វីៗបន្ថែមទៀត ដ្បិតការបង្កើតសៀវភៅជាច្រើន គឺគ្មានទីបញ្ចប់ទេ ហើយការរៀនសូត្រច្រើនក៏នាំមកនូវភាពធុញថប់ដល់រាងកាយដែរ។
[13]ចុងបញ្ចប់នៃអ្វីៗបញ្ហា គឺក្រោយពីបញ្ហាបានឮ នោះគឺថាអ្នកត្រូវតែគោរពកោតខ្លាចដល់ព្រះជាម្ចាស់ ហើយកាន់តាមបទបញ្ជារបស់ព្រះអង្គ
ដ្បិតនេះគឺជាកាតព្វកិច្ចទាំងមូលរបស់មនុស្សជាតិ។[14]ព្រះជាម្ចាស់នឹងប្រទានគ្រប់កិច្ចការទាំងអស់ទៅកាន់ការជំនុំជំរះ ទោះបីជាអំពើដែលគេលាក់កំបាំង មិនថាជាការល្អ
ឬការអាក្រក់។

Ecclesiastes 12:1
ចូរនឹកចាំ
ការបកប្រែរបៀបផ្សេងទៀត: «ចងចាំ»
ខ្ញុំលែងមានភាពរីករាយក្នុងឆ្នាំទាំងនេះទៀតហើយ
ឃ្លាថា «ពួកគេ» នៅទីនេះសំដៅទៅលើ «ឆ្នាំ»។
Ecclesiastes 12:3
ព័ត៌មានទូទៅ:
អ្នកនិពន្ធពិពណ៌នាអំពីផ្ទះមួយដែលសកម្មភាពជាច្រើនទៀតបានឈប់។
ការនេះហាក់កើតឡើងជាមួយរូបកាយរបស់មនុស្សនៅពេលវាចាស់។
ចំណែកស្ត្រីដែលកិនម្សៅនឹងឈប់កិន ដោយសារមានគ្នាពីរបីនាក់
«ពួកស្ត្រីដែលកិនម្សៅនឹងឈប់កិន ដោយសារមានគ្នាតែពីរបីនាក់»
Ecclesiastes 12:4
ព័ត៌មានទូទៅ:
អ្នកនិពន្ធបន្តប្រៀបប្រដូច។
ទ្វាទាំងឡាយនៅតាមផ្លូវនឹងត្រូវបិទ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សបានបិទទ្វាទាំងឡាយនៅតាមផ្លូវ»
នៅពេលដែលមនុស្សភ្ញាក់ផ្អើលដោយឮសត្វចាបយំ
ការបកប្រែរបៀបផ្សេងទៀត: «ពេលសម្លេងសត្វចាបយំភ្ញាក់ផ្អើលដល់មនុស្ស»
Ecclesiastes 12:5
ព័ត៌មានទូទៅ:
អ្នកនិពន្ធបន្តប្រៀបប្រដូច។
នៅពេលដែលបំណងប្រាថ្នាពីកំណើតត្រូវបរាជ័យ
ការបកប្រែរបៀបផ្សេងទៀត:
«ពេលមនុស្សគ្មានបំណងនូវអ្វីដែលពួកគេប្រាថ្នាពីកំណើត»
ពេលដែលដើមចំបក់ចេញផ្កា
«ដើមចំបក់» គឺជាដើមដែលចេញផ្កានៅរដូវធ្លាក់ខ្យល់ ហើយមានផ្កាពណ៌ស។
មនុស្សលោកឈានទៅរកផ្ទះដែលអស់កល្បជានិច្ចរបស់ពួកគេ
ការនេះសំដៅទៅលើការស្លាប់។
ពួកអ្នកកាន់ទុក្ខដើរទៅតាមផ្លូវ
អាចមានន័យថា គឺ១) ដែលពួកអ្នកកាន់ទុក្ខដើរទៅតាមផ្លូវដើម្បីចូលរួមបុណ្យសព ឬ ២) ដែលពួកអ្នកកាន់ទុក្ខដើរទៅតាមផ្លូវដើម្បីទៅផ្ទះនៃអ្នកដែលជិតនឹងស្លាប់។
Ecclesiastes 12:6
ចូរនឹកចាំ
«នៅចងចាំបាន»
មុនពេលដែលខ្សែប្រាក់ដាច់ ... ឬរហាត់ទឹកនៅអណ្តូងខូចបាត់
អ្នកនិពន្ធបានប្រៀបប្រដូចសេចក្តីទៅនឹងការបាក់បែកអ្វីជាច្រើនទៀត។
សេចក្តីស្លាប់គឺជាការបាក់បែកខាងរូបកាយ
ក៏ដូចជាមនុស្សដែលបានធ្វើឲ្យរបស់អ្វីមួយខូច ឬបែក
ក្នុងពេលដែលគេកំពុងតែប្រើវានោះ។
មុនពេលដែលខ្សែប្រាក់ដាច់
«អ្នកណាម្នាក់បានកាត់ខ្សែប្រាក់»
ចានមាសបែក
«អ្នកណាម្នាក់បានធ្វើឲ្យចានមាសបែក»
ក្អមបែកនៅប្រភពទឹក
«អ្នកណាម្នាក់ធ្វើឲ្យក្អមបែក»
ទឹកអណ្តូងខូចបាត់
«អ្នកណាម្នាក់បានធ្វើឲ្យទឹកអណ្តូងខូច»
ធូលីត្រលប់ទៅជាដីវិញ
ពាក្យថា «ធូលី» នៅទីនេះសំដៅទៅលើរូបកាយរបស់មនុស្សបានបំបែកធាតុ។
Ecclesiastes 12:8
អ្វីៗទាំងអស់សុទ្ធតែឥតបានការសោះ
«គ្រប់យ៉ាងមាននៅតែមួយគ្រាទេ ដូចជាទឹកដែលហូរទៅ»។
ហើយសញ្ជឹងគិត និងរៀបចំ
«ការគិតអំពីការរៀបចំ» ឬ «គិតច្រើនអំពីការសរសេរទុកសម្រាប់អ្នកក្រោយ»
Ecclesiastes 12:10
ពាក្យសម្តីរបស់មនុស្សមានប្រាជ្ញា...បង្រៀនដោយអ្នកគង្វាលតែមួយ
អ្នកនិពន្ធបានប្រៀបធៀបការបង្រៀនដោយប្រើពាក្យរបស់លោក
ដើម្បីបង្ហាញដល់មនុស្សនឹងអ្នកគង្វាលដែលបានប្រើឧបករណ៍ក្នុងការដឹកនាំចៀមរបស់ព្រះអង្គ។
ពាក្យសម្តីរបស់មនុស្សមានប្រាជ្ញាប្រៀបដូចជាគ្រឿងលើកទឹកចិត្ត
«អ្នកប្រាជ្ញ លើកទឹកចិត្តយើងឲ្យធ្វើការ

generated on Wed Sep 10 16:16:32 2025

ហើយដំបងឈើជំរុញឲ្យសត្វធ្វើដំណើរទៅមុខ»។
ដូចជាដែកគោល ដែលគេបោះយ៉ាងជាប់ ជាពាក្យដែលបង្រៀនដោយអ្នកគង្វាល
«ដូចអ្នកបានទុកចិត្តលើដែកគោល ដែលបានបោះយ៉ាងជ្រៅ
ហើយអ្នកក៏អាចទុកចិត្តលើសុភាសិតដែលបានសរសេរទុកដោយមនុស្សមានប្រាជ្ញា»។
ជាពាក្យដែលបង្រៀនដោយសុភាសិតសរសេរទុក
«ពាក្យអ្នកទាំងនោះគឺល្អឥតខ្ចោះដែលបានរៀបចំទុកជាសុភាសិត»
ដែលបង្រៀនដោយអ្នកគង្វាលតែមួយគត់
«តើអ្នកណាទៅដែលអ្នកគង្វាលបង្រៀននោះ»
Ecclesiastes 12:12
ដ្បិតការបង្កើតសៀវភៅជាច្រើន គឺគ្មានទីបញ្ចប់ទេ
«មនុស្សនឹងមិនបញ្ឈប់ធ្វើសៀវភៅជាច្រើននោះទេ»
នាំមកនូវភាពធុញថប់ដល់រាងកាយ
«ធ្វើឲ្យមនុស្សអស់កម្លាំង»
Ecclesiastes 12:13
ចុងបញ្ចប់នៃបញ្ហា
«សេចក្តីសន្និដ្ឋានចុងក្រោយលើបញ្ហានេះ»
គឺក្រោយពីបញ្ហាបានឮ
ការបកប្រែរបៀបផ្សេងទៀត: «បន្ទាប់ពីអ្នកបានឮគ្រប់យ៉ាងហើយ»

បទចម្រៀងសាឡូម៉ូន

1 [1]នេះជាចម្រៀងមួយ ក្នុងចំណោមចម្រៀងទំនុករបស់ស្តេចសាឡូម៉ូន។[2]សូមឲ្យប្តីថើបខ្ញុំដោយស្និតស្នាល ដ្បិតសេចក្តីស្រឡាញ់របស់បង វិសេសជាងស្រាទំពាំងបាយជូរទៅទៀត។[3]ប្រេងអប់របស់បងក្រអូបណាស់ ហើយឈ្មោះរបស់បង ក៏ដូចជាប្រេងក្រអូបដែលចាក់ចេញ ហេតុនោះបានជាពួកព្រហ្មចារីសុទ្ធតែស្រឡាញ់បង[4]ខ្ញុំសូមដើរតាមបង ហើយយើងនឹងរត់។ ស្តេចបាននាំខ្ញុំចូលទៅក្នុងបន្ទប់របស់ទ្រង់ យើងនឹងមានអំណរ ហើយរីករាយជាមួយព្រះអង្គ យើងនឹងចាំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ជាជាងស្រាទំពាំងបាយជូរ គេស្រឡាញ់ព្រះអង្គនោះត្រឹមត្រូវណាស់។ ស្ត្រីនិយាយទៅកាន់ស្ត្រីផ្សេងទៀត
[5]ពួកកូនស្រីក្រុងយេរូសាឡិមអើយ ខ្ញុំមានសម្បុរខ្មៅមែន តែគួរឲ្យស្រឡាញ់ ឧបមាដូចជាត្រសាលរបស់ពួកកេដារ ក៏ដូចជាវាំងននរបស់ស្តេចសាឡូម៉ូន។[6]សូមកុំមើលខ្ញុំដោយព្រោះខ្ញុំជាមនុស្សខ្មៅ ដ្បិតខ្ញុំបានហាលថ្ងៃហើយ។ ម្តាយរបស់កូនប្រុសរបស់ខ្ញុំ បានខឹងនឹងខ្ញុំ ពួកគេបានឲ្យខ្ញុំថែរក្សាចម្ការទំពាំងបាយជូរ ឯចម្ការរបស់ខ្លួនខ្ញុំវិញនោះមិនបានថែរក្សាទេ។ ស្ត្រីនិយាយទៅកាន់គូរស្នេហ៍របស់នាង
[7]អ្នកដែលចិត្តខ្ញុំម្ចាស់ស្រឡាញ់អើយ សូមប្រាប់ខ្ញុំម្ចាស់ថា ព្រះអង្គឃ្វាលហ្វូងសត្វនៅត្រង់ណាផង តើនៅកន្លែងណាដែលឲ្យសម្រាកពេលថ្ងៃត្រង់? តើមានទំនងអ្វីឲ្យខ្ញុំម្ចាស់បានដូចជាស្រី ដែលត្រូវបាំងមុខ នៅជាមួយហ្វូងសត្វឬ? គួរស្នេហ៍របស់នាងបានឆ្លើយទៅនាង
[8]នាងដែលល្អលើសជាងគេក្នុងពួកស្រីៗអើយ បើមិនដឹងទេ មានតែចេញទៅតាមដានជើង របស់ហ្វូងសត្វទៅ ហើយឃ្វាលកូនពពែរបស់ឯង ក្បែរត្រសាលរបស់ពួកគង្វាលចុះ។
[9]ឱមាសសម្លាញ់អើយ យើងបានប្រៀបឯងដូចជាសេះ ទឹមរាជរថរបស់ផារ៉ោន។[10]ថ្ពាល់ឯងស្រស់ល្អសមនឹងគ្រឿងតែងហើយកឯងផង ដែលប្រដាប់ដោយខ្សែដូច្នេះ។
[11]យើងនឹងធ្វើខ្សែកមាសដាំដោយប្រាក់ឲ្យឯង។ ស្ត្រីនិយាយមកកាន់ខ្លួននាង
[12]កំពុងដែលស្តេចគង់នៅតុ នោះប្រេងទេពិរូរបស់ខ្ញុំបានសាយភ្លិនក្រអូបទៅ។[13]ស្ងួនសម្លាញ់របស់ខ្ញុំជាកញ្ចប់កំញាន នៅដើមទ្រូងរបស់ខ្ញុំ។[14]ស្ងួនសម្លាញ់របស់ខ្ញុំប្រៀបដូចជា កញ្ចុំផ្កាក្រពេនដល់ខ្ញុំ ដែលដុះនៅក្នុងចម្ការទំពាំងបាយជូរ ទឹកដីអេន កេឌី។ គួរស្នេហ៍និយាយមកកាន់នាង
[15]មើល ឯងស្រស់បស់ល្អ មាសសម្លាញ់អើយ មើលឯងស្រស់បស់ល្អណាស់ ភ្នែកឯងដូចជាភ្នែកព្រាប។ ស្ត្រីនិយាយទៅកាន់គូរស្នេហ៍របស់នាង
[16]មើល! ព្រះអង្គក៏ល្អ ស្ងួនសម្លាញ់អើយអើ ព្រះអង្គគួរស្រឡាញ់ណាស់។[17]ដំណេករបស់យើងខៀវខ្ចី រតនៈរបស់យើងជាដើមតាត្រៅ ហើយផ្ទឹមរបស់យើងជាដើមកកោះ។

Song of Solomon 1:1
ព័ត៌មានទូទៅ៖
សូមមើល: និង
ព័ត៌មានទូទៅ៖
ផ្នែកមួយចាប់ផ្តើមនៃព្រះគម្ពីរក្នុងជំពូក ១: ២។
ជាចម្រៀងមួយ
«ជាចម្រៀងដែលល្អជាងគេ» ឬ «ចម្រៀងពិរោះបំផុត»
ទំនុករបស់ស្តេចសាឡូម៉ូន
«ដែលនិយាយអំពីសាឡូម៉ូន» ឬ «ដែលសាឡូម៉ូនតាក់តែង»
ប្រេងអប់របស់បង
«ប្រេងដែលអ្នកលាបនៅលើខ្លួនរបស់អ្នក»
ក្រអូបណាស់
«ក្លិនអស្ចារ្យ»
ឈ្មោះរបស់បង ក៏ដូចជាប្រេងក្រអូបដែលចាក់ចេញ
ស្ត្រីដឹងថាគូស្នេហ៍របស់នាងមានកេរ្តិ៍ឈ្មោះល្អ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឈ្មោះរបស់បងគឺអស្ចារ្យដូចជាក្លិនប្រេងដែលមាននរណាម្នាក់បានបង្ហូរ»។
ខ្ញុំសូមដើរតាមបង
«សូមឲ្យខ្ញុំទៅជាមួយបងផង»។ ពាក្យថា «បង» សំដៅទៅលើគូស្នេហ៍
យើងនឹងរត់
ពាក្យថា «យើង» សំដៅទៅលើស្ត្រីវ័យក្មេងរួមជាមួយគូស្នេហ៍របស់នាង។
ជាមួយព្រះអង្គ
«ដោយសារតែអ្នក»
យើងនឹងចាំពី
«សូមឲ្យខ្ញុំសរសើរ»
គេស្រឡាញ់ព្រះអង្គនោះត្រឹមត្រូវណាស់
«អស់អ្នកដែលស្រឡាញ់ព្រះអង្គគឺត្រឹមត្រូវ»
Song of Solomon 1:5
ខ្ញុំមានសម្បុរខ្មៅមែន តែគួរឲ្យស្រឡាញ់
«ស្បែករបស់ខ្ញុំគឺខ្មៅ ប៉ុន្តែខ្ញុំនៅតែស្អាត»
ខ្មៅដូចជាត្រសាលរបស់ពួកកេដារ
កុលសម្ព័ន្ធដែលលេចធ្លោនៅកេដារបានប្រើស្បែកពពែខ្មៅ
ដើម្បីសាងសង់ផ្ទះរបស់ពួកគេ។
ស្ត្រីកំពុងប្រៀបធៀបស្បែករបស់នាងទៅនឹងត្រសាលទាំងនេះ។
ក៏ដូចជាវាំងននរបស់ស្តេចសាឡូម៉ូន
នាងប្រៀបធៀបស្បែករបស់នាងទៅនឹងវាំងននដ៏ស្រស់ស្អាត
ដែលសាឡូម៉ូនបានបង្កើតសម្រាប់ព្រះរាជវាំងរបស់ព្រះអង្គផ្ទាល់
ឬសម្រាប់ព្រះវិហារ។
បានហាលថ្ងៃ
«រលាក»
ម្តាយរបស់កូនប្រុសរបស់ខ្ញុំ
«បងប្អូនប្រុសម្តាយតែមួយរបស់ខ្ញុំ» បងប្អូនប្រុសទាំងនេះប្រហែលជា
មានម្តាយតែមួយដូចស្ត្រីមាននោះ ប៉ុន្តែមានឪពុកខុសគ្នា។
ថែរក្សាចម្ការទំពាំងបាយជូរ
«អ្នកដែលថែរក្សាចម្ការទំពាំងបាយជូរ»
ឯចម្ការរបស់ខ្លួនខ្ញុំវិញ នោះមិនបានថែរក្សាទេ
ស្ត្រីប្រៀបធៀបរូបនាងផ្ទាល់ទៅនឹងចម្ការទំពាំងបាយជូរ។
[14]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «សម្បត្តិនៃអេស៊ីប និងភោគទ្រព្យរបស់អេត្សូពី ជាមួយនិងស្រុកសេបាដែលបុរសមាឌធំ នឹងនាំមកឲ្យអ្នក។
ពួកគេទាំងនោះនឹងជារបស់អ្នក។ ពួកគេនឹងដើរតាមអ្នក ទាំងជាប់ច្រវាក់។ ពួកគេនាំគ្នាក្រាបនៅចំពោះមុខអ្នក ហើយប្រកាសប្រាប់អ្នកថា៖ «ព្រះជាម្ចាស់គង់នៅជាមួយអស់លោកពិតមែន ក្រៅពីព្រះអង្គគ្មានព្រះណាទៀតទេ»។[15]ពិតណាស់ ព្រះអង្គគឺជាព្រះជាម្ចាស់ ដែលបានលាក់អង្គទ្រង់
ហើយជាព្រះជាម្ចាស់នៃអ៊ីស្រាអែលក៏ជាព្រះសង្គ្រោះដែរ។
[16]ពួកគេទាំងនោះនឹងមានការអាម៉ាស់និងបាក់មុខទាំងអស់គ្នា ពួកអ្នកដែលសូនធ្វើរូបបដិមានឹងត្រូវដើរក្នុងភាពអាម៉ាស់ដែរ ។[17]ប៉ុន្តែជនជាតិអ៊ីស្រាអែល នឹងបានទទួលការសង្គ្រោះពីព្រះអម្ចាស់ ជាមួយការសង្គ្រោះដ៏អស់កល្បជានិច្ច អ្នកមិនត្រូវអាម៉ាស់ ឬបាក់មុខសោះឡើយ។
[18]នេះជាព្រះបន្ទូលព្រះអម្ចាស់ ដែលបានបង្កើតផ្ទៃមេឃ ព្រះជាម្ចាស់ដ៏ពិតដែលបានបង្កើតផែនដីមក ហើយធ្វើឲ្យវាកើតឡើង គឺព្រះអង្គបានតាំងផែនដីឡើង។ ព្រះអង្គបង្កើតវាឡើងមិនមែនអត់ប្រយោជន៍ទេគឺឲ្យសត្វលោកស្នាក់អាស្រ័យនៅ។ «គឺយើងនេះហើយជាព្រះអម្ចាស់ ក្រៅពីយើង គ្មានព្រះណាទៀតទេ។
[19]យើងមិនបាននិយាយនៅទីស្ងាត់នោះទេ ឬក្នុងទីកន្លែងលាក់បាំងទេ។ យើងក៏មិនដែលប្រាប់ពូជពង្សរបស់យ៉ាកុប «ឲ្យស្វែងរកយើងដោយគ្មានប្រយោជន៍ដែរ!» យើងជាព្រះអម្ចាស់ យើងតែងនិយាយត្រឹមត្រូវ ហើយយើងប្រកាសសុទ្ធតែការពិតត្រង់។
[20]ចូរនាំគ្នាខិតចូលមកជិត! មកទាំងអស់គ្នា អ្នកបានសេសសល់ពីប្រជាជាតិនានាអើយ! ពួកគេគ្មានប្រាជ្ញាអ្វីសោះឡើយ ជាអ្នកដែលសែងព្រះរបស់ខ្លួនធ្វើពីឈើ ហើយបួងសួងព្រះដែលមិនអាចសង្គ្រោះខ្លួនបាន។
[21]ចូរមកជិត និងប្រកាសមកកាន់យើង ចូរយកភស្តុតាងមកមើល! ចូលឲ្យគេឃុបឃិតគ្នាទៅ។ តើអ្នកណាដែលបានបង្ហាញគេតាំងពីយូរហើយនោះ? តើអ្នកបានប្រកាស់ពីវា? តើមិនមែនយើងទេឬ ជាព្រះអម្ចាស់? គ្មានព្រះណាផ្សេងទៀតទេគឺមានតែយើង មានព្រះជាម្ចាស់តែមួយ និងព្រះសង្គ្រោះតែមួយ គ្មានព្រះណាទៀតឡើយ។

generated on Wed Sep 10 16:16:32 2025

[22]ចូរនាំគ្នាបែរមករកយើង យើងនឹងសង្គ្រោះអ្នក គឺសម្រាប់គ្រប់គ្នាពេញផែនដីទាំងមូល ដ្បិតយើងជាព្រះជាម្ចាស់ គ្មានព្រះណាទៀតទេ។[23]យើងខ្លួនឯងស្បថថា
នេះជាពាក្យយើង ហើយវានឹងមិនត្រឡប់មកវិញទេ «នៅមុខយើងមនុស្សលោកនឹងលុតជង្គង់ចុះ ហើយគ្រប់ទាំងអណ្តាតថ្លែងប្រាប់ផង។
[24]ពួកគេនឹងពោលពីយើងថា «មានតែព្រះអម្ចាស់មួយព្រះអង្គទេ ដែលនាំនូវការសង្គ្រោះ និងកម្លាំង»។ ពួកគេពេញដោយភាពអាម៉ាស់ អស់អ្នកដែលបានខឹងនិងព្រះអង្គ។
[25]ក្នុងព្រះអម្ចាស់ ពូជពង្សអ៊ីុស្រាអែលទាំងមូលនឹងបានសុចរិត ហើយខ្ពស់មុខផង។

Isaiah 45:1

យើងកាន់ដៃស្តាំរបស់អ្នក

ព្រះអម្ចាស់បានជួយដល់ស្តេចស៊ីរូស និងធ្វើឲ្យទ្រង់ទទួលបានជោគជ័យ
ត្រូវបានគេនិយាយដូចជាព្រះអង្គកាន់ដៃស្តាំរបស់ទ្រង់។

Isaiah 45:2

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស្តេចស៊ីរូស។

ភ្នំនឹងរាបស្មើ

ព្រះអម្ចាស់មានបន្ទូលអំពីការដកឧបសគ្គដែលរាំងស្ទះដល់ភាពជោគជ័យរបស់ស្តេចស៊ីរូស
វាហាក់ដូចជាភ្នំនៅពីមុខទ្រង់។

ភ្នំ

ពាក្យភាសាហេព្រើរដែលត្រូវបានប្រើនៅក្នុងអត្ថបទគឺកម្រមានណាស់
ហើយវាមិនមានអត្ថន័យច្បាស់លាស់ទេ។ ជំនាន់ទំនើបខ្លះមាន «កន្លែងរដុប» ឬ
«កន្លែងកោង»។

រនុកដែក

នេះសំដៅទៅលើរនាំងដែកនៅលើខ្លោងទ្វារសំរិទ្ធ។

ទ្រព្យសម្បត្តិ ដែលបានកប់ទុកក្នុងទីងងឹត

នៅទីនេះ «ភាពងងឹត» សំដៅទៅលើកន្លែងដែលមានការសម្ងាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រព្យសម្បត្តិ ដែលបានកប់ទុកក្នុងទីងងឹត» ឬ «
ទ្រព្យសម្បត្តិ នៅកន្លែងសម្ងាត់»

Isaiah 45:4

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស្តេចស៊ីរូស។

យ៉ាកុប...អ៊ីស្រាអែល

ទាំងពីរនេះគឺសំដៅទៅលើកូនចៅរបស់អ៊ីស្រាអែល។

យើងនឹងឲ្យអ្នកមានកម្លាំងក្នុងចំបាំង

អាចមានន័យថាទី ១) «យើងនឹងឲ្យអ្នកមានកម្លាំងក្នុងចំបាំង» ឬ ទី២)
«យើងនឹងបំពាក់ប្រដាប់គ្រឿងបរិក្ខាដល់អ្នកសម្រាប់ក្នុងចំបាំង»។

តាំងពីទិសខាងកើតដល់ទិសខាងលិច

ចាប់តាំងពីព្រះអាទិត្យរះនៅភាគខាងកើត
ឃ្លានេះបង្កើតបានជាការច្របាច់បញ្ចូលគ្នា
និងមានន័យថាគ្រប់ទីកន្លែងនៅលើផែនដី។ របៀបផ្សេងទៀតនៃការបកប្រែ:
«មកពីគ្រប់ទីកន្លែងលើផែនដី»

Isaiah 45:7

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

យើងបង្កើតពន្លឺ និងភាពងងឹត យើងធ្វើឲ្យមានសេចក្តីសុខ និងទុក្ខវេទនា

កន្សោមទាំងពីរនេះបង្កើតបានឲ្យមានសេចក្តីសុខ
ដែលបញ្ជាក់ថាព្រះអម្ចាស់ជាព្រះបង្កើតអ្វីៗទាំងអស់។

ចូរឲ្យផ្ទៃមេឃសម្រក់សេចក្តីសុចរិតចុះមកដូច ទឹកសន្សើម...សេចក្តីសុចរិត ពន្លកចេញជាមួយគ្នាដែរ

ព្រះអម្ចាស់មានព្រះបន្ទូលអំពីសេចក្តីសុចរិតរបស់ព្រះអង្គដូចជាភ្លៀងដែលធ្លាក់មកលើផែនដី
ហើយអំពីសេចក្តីសុចរិត
និងសេចក្តីសង្គ្រោះរបស់ព្រះអង្គដូចជារុក្ខជាតិដែលដុះនៅលើផែនដី។

ចូរឲ្យផ្ទៃមេឃ

ព្រះអម្ចាស់បង្វែរការយកចិត្តទុកដាក់ពីប្រជារាស្ត្ររបស់ព្រះអង្គមួយរំពេច
ហើយចាប់ផ្តើមមានបន្ទូលទៅកាន់ផ្ទៃមេឃ។

Isaiah 45:9

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

អ្នកនោះកើតពីដី មិនខុសពីអ្នកឯទៀតៗទេ

ព្រះអម្ចាស់មានព្រះបន្ទូលអំពីព្រះកាយព្រះអង្គ ដូចជាជាងស្មូន
ហើយម្នាក់ដែលប្រកែកជាមួយព្រះអង្គ ដូចជាមនុស្សនោះ
និងមនុស្សជាតិទាំងអស់សុទ្ធតែជាឆ្នាំងដីឥដ្ឋ។

ដីឥដ្ឋ

អាចមានន័យថាទី ១) «ធើងដីឥដ្ឋ» ឬ ទី២) «ធើងផ្តាដីឥដ្ឋដែលខូច»។

ដីឥដ្ឋណាពោលទៅកាន់ជាងស្មូន ដែលកំពុងតែសូនខ្លួនថា...អ្វីទេ?

ព្រះអម្ចាស់សួរសំណួរនេះដើម្បីស្តីបន្ទោសអ្នកដែលប្រកែកជាមួយព្រះអង្គអំពីអ្វីដែលព្រះអង្គបានធ្វើ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដីឥដ្ឋមិនគួរនិយាយទៅកាន់ជាងស្មូន... អ្វីទេ?»

Isaiah 45:10

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់នៅតែស្តីបន្ទោសពួកអ្នកដែលប្រកែកជាមួយព្រះអង្គអំពីអ្វីដែលព្រះបានធ្វើ។

អ្នកណានឹងនិយាយទៅកាន់ឪពុកខ្លួនថា...តើអ្នកជាឪពុកបែបណា?

ព្រះអម្ចាស់មានព្រះបន្ទូលអំពីអស់អ្នកដែលចង់ប្រកែកនឹងព្រះអង្គ
ដូចពួកគេជាកូនដែលមិនទាន់កើតដែលឈ្លោះជាមួយឪពុកម្តាយរបស់ពួកគេផ្ទាល់។

តើអ្នកជាឪពុកបែបណា?...ហេតុអ្វីបានជាផ្តល់កំណើត?

កូនដែលមិនទាន់កើតសួរសំណួរវោហារទាំងនេះ ដើម្បីប្រមាថឪពុកម្តាយរបស់គេ
ចំពោះការផ្តល់កំណើតឲ្យពួកគេ។ ទាំងនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែង។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនគួរជាឪពុកខ្ញុំទេ...អ្នកមិនគួរតែផ្តល់កំណើតឲ្យខ្ញុំ»។ ឬ
«អ្នកមិនមែនជាឪពុកខ្ញុំពិតប្រាកដទេ...អ្នកមិនផ្តល់កំណើតឲ្យខ្ញុំពិតប្រាកដទេ»។

Isaiah 45:11

ជាព្រះដ៏វិសុទ្ធរបស់ ជនជាតិអ៊ីស្រាអែល

បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១:៤។

ហេតុអ្វីអ្នករាល់គ្នាចង់សួរយើង អំពីកិច្ចការដែលយើងត្រូវធ្វើ នៅពេលអនាគត សម្រាប់កូនចៅរបស់
យើងឬ? អ្នករាល់គ្នាចង់បញ្ជាយើងអំពីកិច្ចការ ដែលយើងត្រូវធ្វើឬ?

ព្រះអម្ចាស់ប្រើសំនួរដើម្បីស្តីបន្ទោសអ្នកដែលឈ្លោះជាមួយព្រះអង្គអំពីអ្វីដែលព្រះបានធ្វើ។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំសួរយើងអំពីអ្វីដែលយើងធ្វើសម្រាប់កូនចៅ
របស់យើង។ កុំប្រាប់យើង...កិច្ចការ ដែលយើងធ្វើ»។

កូនចៅរបស់យើង

នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។

អំពីកិច្ចការ ដែលយើងត្រូវធ្វើ

ទីនេះពាក្យ «ព្រះហស្ត» តំណាងឲ្យព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«កិច្ចការទាំងនេះដែលយើងបានធ្វើ»

Isaiah 45:12

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

បានបង្កើតមនុស្សឲ្យរស់ នៅលើផែនដីនេះផង

ទីនេះពាក្យ «ព្រះហស្ត» តំណាងឲ្យព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«នោះយើងគឺជាព្រះ»

លាតសន្ធឹងផ្ទៃមេឃ

ព្រះអម្ចាស់មានព្រះបន្ទូលអំពីការបង្កើតផ្ទៃមេឃដូចជាក្រណាត់ដែលព្រះអង្គបានលាត។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៤២:៥។

Isaiah 45:13

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

យើងនេះហើយដែលលើកស្តេចស៊ីរូសឡើង ក្នុងសេចក្តីសុចរិត

ត្រង់នេះពាក្យថា «សេចក្តីសុចរិត» សំដៅទៅលើសកម្មភាពត្រឹមត្រូវ។
អាចមានន័យថាទី ១) ដែលព្រះអម្ចាស់បានលើក ឲ្យស្តេចស៊ីរូសធ្វើអ្វីៗដែលត្រូវ
ឬទី ២) ថាព្រះអម្ចាស់មានសិទ្ធិលើកស្តេចស៊ីរូសឡើង។

លើកស្តេចស៊ីរូសឡើង

ព្រះអម្ចាស់មានព្រះបន្ទូលអំពីការធ្វើឲ្យស្តេចស៊ីរូសដើរតួដូចជាជំរុញអោយទ្រង់ស្រងាកចិត្ត។

យើងនឹងរៀបចំផ្លូវ

ព្រះអម្ចាស់មានបន្ទូលអំពីការដកឧបសគ្គចេញហើយធ្វើឲ្យស្តេចស៊ីរូសទទួលបានជោគជ័យ
ដូចជាព្រះអង្គកំពុងធ្វើឲ្យផ្លូវរលូនដល់ស្តេចស៊ីរូសដើរ។

ស្តេចនោះនឹងសង់ទីក្រុងរបស់យើង

នេះសំដៅទៅលើក្រុងយេរូសាឡិម។

generated on Wed Sep 10 16:16:32 2025

ដោយមិនបាច់បង់ពិន័យ និងស៊ីសំណូកទេ
នៅទីនេះពាក្យ «បង់ពិន័យ» និង «សំណូក» ចែករំលែកអត្ថន័យស្រដៀងគ្នា។
ស្តេចស៊ីរូសនឹងមិនធ្វើរឿងទាំងនេះដើម្បីជាផលចំណេញខាងហិរញ្ញវត្ថុទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយទ្រង់នឹងមិនធ្វើរឿងទាំងនេះដើម្បីលុយទេ»
ព្រះអម្ចាស់នៃពិភពទាំងមូល
បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១:៩។
Isaiah 45:14
សម្បត្តិរបស់ស្រុកអេស៊ីប និងភោគទ្រព្យរបស់ស្រុកអេត្យូពី ប្រជាជនមានមាឌខ្ពស់ៗមកពីស្រុក
សេបា នឹងឆ្លងកាត់តាមអ្នក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនអេស៊ីប អេត្យូពី
និងប្រជាជនដែលមានមាឌខ្ពស់ពីស្រុកសេបានឹងនាំមកនូវប្រាក់ចំណូល
និងទំនិញរបស់ពួកគេដល់អ្នក»
សម្បត្តិរបស់ស្រុកអេស៊ីប
«ផលចំណេញរបស់ស្រុកអេស៊ីប»
ស្រុកសេបា
ទាំងនេះជាមនុស្សមកពីប្រជាជាតិសេបា។
របស់អ្នក
ទីនេះ «អ្នក» សំដៅទៅលើប្រជាជនក្រុងយេរូសាឡិម។
Isaiah 45:16
ពួកគេចេញទៅទាំងអៀនខ្មាសជាខ្លាំង អស់អ្នកដែលសូនធ្វើរូបបដិមា ត្រូវអាម៉ាស់ និងបាក់មុខគ្រប់ៗ
គ្នា
បន្ទាត់ទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នាជាមួយនឹងឃ្លាទី ២
បញ្ជាក់អំពីប្រធានបទទីមួយ។
ពួកគេចេញទៅទាំងអៀនខ្មាសជាខ្លាំង
ពាក្យថា «ខ្មាស់អៀន» និង «អាម៉ាស់» មានន័យថាជាមូលដ្ឋានរឿងដូចគ្នា
និងបញ្ជាក់អាំងតង់ស៊ីតេនៃការខ្មាស់អៀន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«រូបព្រះរបស់ពួកគេនឹងធ្វើអោយពួកគេខ្មាស់អៀនទាំងស្រុង»
និងបាក់មុខគ្រប់ៗគ្នា
ការរស់នៅក្នុងភាពអាម៉ាស់ឥតឈប់ឈរត្រូវបានគេនិយាយដូចជាកំពុងដើរក្នុងភាពអាម៉ាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងត្រូវអាម៉ាស់ឥតឈប់ឈរ»
ជនជាតិអ៊ីស្រាអែលវិញ គេបានទទួលការសង្គ្រោះពីព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងសង្គ្រោះប្រជាជនអ៊ីស្រាអែល»
អ្នកមិនត្រូវអាម៉ាស់ ឬបាក់មុខសោះឡើយ
ទីនេះ «អ្នក» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។ ពាក្យថា «ខ្មាស់អៀន» និង
«អាម៉ាស់» មានន័យថាជាមូលដ្ឋានរឿងដូចគ្នា។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាម្នាក់នឹងធ្វើឲ្យអ្នកបាក់មុខម្តងទៀតទេ»
Isaiah 45:18
ដើម្បីឲ្យនៅទទេឡើយ
«មិននៅទទេឡើយ»។ ពាក្យនៅត្រង់នេះ «ខ្ជះខ្ជាយ» សំដៅទៅលើទទេ
កន្លែងដែលគ្មានប្រយោជន៍។
ឲ្យសត្វលោកស្នាក់អាស្រ័យនៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែព្រះអម្ចាស់បានបង្កើតផែនដី ដូច្នេះមនុស្សអាចរស់នៅលើផែនដីបាន»
Isaiah 45:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
Isaiah 45:20
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
អស់អ្នកសេសសល់
មនុស្សដែលបានភៀសខ្លួនចេញពីផ្ទះរបស់ពួកគេ ដូច្នេះសត្រូវនឹងមិនចាប់យក
ឬសម្លាប់ពួកគេទេ
Isaiah 45:21
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅពួកជនភៀសខ្លួន។ (សូមមើល: 45:20)
បង្ហាញភស្តុតាងមកមើល
ពាក្យត្រង់នេះ «ពួកគេ» សំដៅទៅលើពួកជនភៀសខ្លួន
ដែលមកក្នុងចំណោមប្រជាជាតិដែលថ្វាយបង្គំរូបព្រះ។
តើនរណាបានប្រាប់ទុកជាមុននូវហេតុការណ៍ទាំងអម្បាលម៉ាន ដែលកើតមាននៅពេលនេះ? ដែល
បានប្រាប់ជាមុនក្រៅពីយើង? គ្មានព្រះជាម្ចាស់ណាទៀតទេ។ ជាព្រះអម្ចាស់ ?
ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ថាព្រះអង្គគឺជាព្រះដែលបានប្រាប់ពួកគេថារឿងទាំងនេះនឹងកើតឡើង។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងប្រាប់អ្នកដែលបានបង្ហាញរឿងនេះតាំងពីយូរយារណាស់មកហើយ។
យើងនឹងប្រាប់អ្នកដែលបានប្រកាសហេតុការណ៍ទាំងនេះ។
គឺយើងជាព្រះអម្ចាស់»។
Isaiah 45:22
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
ចូរនាំគ្នាបែរមករកយើង យើងនឹងសង្គ្រោះអ្នក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរនាំគ្នាបែរមករកយើង នោះយើងនឹងសង្គ្រោះអ្នក»
គឺសម្រាប់គ្រប់គ្នាពេញផែនដីទាំងមូល
កន្លែងនៅលើផែនដីដែលនៅឆ្ងាយគឺត្រូវបានគេនិយាយថាជាកន្លែងដែលផែនដីបានបញ្ចប់។
ឃ្លានេះក៏បង្កើតជាការច្របាច់បញ្ចូលគ្នា
និងសំដៅទៅលើគ្រប់ទិសទីនៅចន្លោះចុងបញ្ចប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីកន្លែងឆ្ងាយបំផុតនៃផែនដី» ឬ «ផែនដីទាំងមូល»
គឺសម្រាប់គ្រប់គ្នាពេញផែនដីទាំងមូល
ត្រង់ឃ្លានេះតំណាងឲ្យប្រជាជនដែលរស់នៅ «ចុងបំផុតនៃផែនដី» ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលរស់នៅកន្លែងឆ្ងាយបំផុតនៃផែនដី» ឬ
«អ្នកទាំងអស់គ្នាដែលរស់នៅលើផែនដីទាំងមូល»
មនុស្សលោកទាំងអស់នឹងលុតជង្គង់ ហើយគ្រប់ទាំងអណ្តាតថ្លែងប្រាប់ផង
ពាក្យ «ជង្គង់» និង «អណ្តាត» តំណាងឲ្យប្រជាជន។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សទាំងអស់នឹងលុតជង្គង់នៅចំពោះយើង
ហើយគ្រប់ទាំងអណ្តាតថ្លែងប្រាប់ផង»
Isaiah 45:24
ពោលថា
មនុស្សដែលរស់នៅលើផែនដីកំពុងតែនិយាយ។
ក្នុងព្រះអម្ចាស់ ពូជពង្សអ៊ីស្រាអែលទាំងមូលនឹងបានសុចរិត
នៅទីនេះពាក្យថា «រាប់ជាសុចរិត»
មិនមានន័យថាព្រះអម្ចាស់លើកលែងទោសអោយគេទេ
តែបង្ហាញអោយប្រជាជាតិនានាឃើញថាអ៊ីស្រាអែលគោរពសក្ការៈថ្វាយព្រះអង្គ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងបង្ហាញភាពត្រឹមត្រូវដល់កូនចៅអ៊ីស្រាអែលទាំងអស់» ឬ
«ព្រះអម្ចាស់នឹងរកយុត្តិធម៌អោយកូនចៅអ៊ីស្រាអែលទាំងអស់»

---

46 [1]ព្រះបាលបានក្រាប់ចុះ ព្រះនេបូក៏អស់ឫទ្ធិដែរ។ រូបព្រះរបស់ពួកគេលើសែងដោយសត្វពាហនៈ និងសត្វព្រៃដាក់ទំងន់លើពួកវា។ រូបព្រះទាំងនោះដែលអ្នកដឹកទៅមក
គឺមានធ្ងន់ណាស់នៅសម្រាប់សព្វទាំងនោះ។[2]ពួកគេក៏ទន់ជើងចុះ លត់ចង្កុងចុះ គេមិនអាចជួយរូបទាំងបានទេ ហើយពួកគេក៏ត្រូវដឹកទៅជាឈ្លើយសឹកដែរ។
[3]ចូរស្តាប់យើង កូនចៅយ៉ាកុបអើយ និងអ្នករួចជីវិតកូនចៅអ៊ីស្រាអែលដែរ យើងបានថែទាំអ្នករាល់គ្នា តាំងពីអ្នករាល់គ្នាមុនពេលចាប់កំណើតមក
ហើយពីក្នុងផ្ទៃម្តាយដែរ។[4]ទោះបីជាអ្នកចាស់ជរា យើងនឹងបីអ្នកដរាបដល់អ្នកមានសក់ស គឺយើងបានបង្កើតអ្នក ហើយយើងនឹងថែរក្សាអ្នក ហើយយើងនឹង
សង្គ្រោះអ្នកផងដែរ។
[5]តើអ្នកនឹងប្រៀបធៀបយើងទៅនឹងអ្នកណា? តើអ្នកគិតថាយើងស្រដៀងនឹងអ្នកណាដើម្បីឲ្យយើងអាចប្រៀបធៀបបាន?[6]មនុស្សខ្លះចាក់មាសអស់ពីថង់របស់ខ្លួនពួកគេ
ថ្លឹងប្រាក់ គេជួលជាងមាស ជាងនោះក៏ធ្វើជាព្រះឲ្យគេ រួចគេក្រាបចុះ ថ្វាយបង្គំចំពោះរូបនោះ។
[7]ពួកគេលើករូបព្រះទាំងនោះនៅលើស្មារបស់ពួកគេហើយកាន់វា ហើយរូបព្រះនោះមិនកម្រើកទៅណាឡើយ។ ពួកគេអំពាវនាវដល់រូបនោះ ប៉ុន្តែវាមិនចេះតប ឬជួយ
សង្គ្រោះឲ្យរួចពីសេចក្តីទុក្ខវេទនាបានឡើយ។

generated on Wed Sep 10 16:16:32 2025

[8]ចូរគិតពីការទាំងនេះចុះ កុំបដិសេធឡើយ អ្នករាល់គ្នាដែលជាមនុស្សបះបោរអើយ![9]គិតពីការគ្រាដំបូង គឺអ្វីដែលកន្លងទៅ ដ្បិតយើងជាព្រះជាម្ចាស់ គ្មានព្រះណាទៀតទេ
យើងគឺជាព្រះជាម្ចាស់ គ្មានអ្នកណាដូចយើងឡើយ។
[10]យើងបានប្រាប់ពីគ្រាចុងក្រោយ តាំងពីពេលដំបូង ហើយអ្វីដែលមិនទាន់កើតឡើង យើងបានថ្លែងថា «ផែនការរបស់យើងនឹងកើតឡើង
ហើយយើងនឹងធ្វើតាមបំណងចិត្តយើង»។[11]យើងបានហៅបក្សីព្រៃពីទិសខាងកើត និងមនុស្សដែលនឹងសម្រេចតាមគំនិតរបស់យើងឲ្យមកពីទីឆ្ងាយ យើងបានចេញថ្លែង
ហើយ យើងនឹងធ្វើឲ្យសម្រេចជារូបរាង អ្វីដែលយើងគិតគូរ យើងមុខជាធ្វើមិនខាន។
[12]ចូរស្តាប់យើង មនុស្សមានចិត្តរឹងរូស ដែលនៅឆ្ងាយពីការងារត្រឹមត្រូវអើយ[13]យើងនាំសេចក្តីសុចរិតរបស់យើងមកជិត គឺមិននៅឆ្ងាយឡើយ ហើយការសង្គ្រោះ
យើងក៏មិនរង់ចាំដែរ យើងនឹងសង្គ្រោះក្រុងស៊ីយ៉ូន ហើយអ៊ីស្រាអែល ដែលស្រស់ស្អាតរបស់យើង។

Isaiah 46:1

ព្រះបាលបរាជ័យហើយ ព្រះនេបូក៏អស់ឫទ្ធិដែរ។ គេផ្ទុករូបព្រះ...ព្រោះមានបន្ទុកយ៉ាងធ្ងន់នៅលើខ្នងរា

លោកអេសាយនិយាយអំពីមនុស្សដាក់រូបព្រះរបស់ព្រះបាល
និងព្រះនេបូទៅក្នុងរទេះសត្វដើម្បីដឹក
ដូចជារូបព្រះទាំងនេះត្រូវបានបង្កើតឡើងដើម្បី «អស់ឫទ្ធិ» និង «បរាជ័យ»។
ឃ្លាទាំងពីរនេះគឺជាឥរិយាបថគួរឲ្យអាម៉ាស់។

ព្រះបាល...ព្រះនេបូ

ទាំងនេះគឺជារូបព្រះដើមតំបូងដែលពួកបាប៊ីឡូនគោរពបូជា។

គេផ្ទុករូបព្រះ

រូបព្រះដែលតំណាងឲ្យព្រះបាល និងព្រះនេបូ។

ពួកគេ មិនអាចដោះបន្ទុករបស់ពួកគេបានផង

«ប្រះបាល និងព្រះនេបូមិនអាចដោះបន្ទុករបស់ពួកគេបានទេ»

ពួកគេក៏ត្រូវដឹកទៅជាឈ្លើយសឹកដែរ

លោកអេសាយនិយាយអំពីមនុស្សដែលយករូបចម្លាក់ទាំងនេះដូចជាព្រះក្លែងក្លាយដែលត្រូវតែ[illegible]
Isaiah 46:3

ចូរស្តាប់យើង

គឺនេះ «យើង» សំដៅទៅលើព្រះអម្ចាស់។

យើងបានថែទាំអ្នករាល់គ្នា តាំងពីអ្នករាល់គ្នាមុនពេលចាប់កំណើតមក ហើយពីក្នុងផ្ទៃម្តាយដែរ

ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជាតិអ៊ីស្រាអែលប្រៀបដូចជាមនុស្សម្នាក់
និងពីដើមកំណើតរបស់ប្រជាជាតិគឺដូចជាកំណើតរបស់ខ្លួនដែរ។ (សូមមើល:|
Metaphor)

យើងបានថែទាំអ្នករាល់គ្នា

ព្រះអម្ចាស់មានព្រះបន្ទូលអំពីការជួយ និងសង្គ្រោះប្រជាជនអ៊ីស្រាអែល
ដូចព្រះអង្គលើកពួកគេដែរ។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានថែទាំ» (សូមមើល:|Metaphor
និង|Active or Passive)

ទោះបីជាអ្នកចាស់ជរា យើងនឹងបីអ្នកដរាបដល់អ្នកមានសក់ស

ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជាតិអ៊ីស្រាអែលថាពួកគេមានអាយុច្រើនដូចមនុស្សចាស់ដែលមាន[illegible]
(សូមមើល:|Metaphor)
Isaiah 46:5

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជនអ៊ីស្រាអែល។

តើអ្នកនឹងប្រៀបធៀបយើងទៅនឹងអ្នកណា?

តើអ្នកគិតថាយើងស្រដៀងនឹងអ្នកណាដើម្បីឲ្យយើងអាចប្រៀបធៀបបាន?

ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ថាគ្មាននរណាម្នាក់ដូចព្រះអង្គទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាម្នាក់
ដែលអ្នករាល់គ្នាអាចប្រៀបធៀបនឹងយើងបានទេ។
យើងមិនស្រដៀងនឹងអ្នកណាទេ ដូច្នេះយើងអាចប្រៀបធៀបបាន»។ (សូមមើល:|
Rhetorical Question)

យើងអាចប្រៀបធៀបបាន

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះអ្នកអាចប្រៀបធៀបនឹងយើងបាន» (សូមមើល:|Active or Passive)
Isaiah 46:7

ពួកគេលើករូបព្រះ

«ពួកគេ» សំដៅទៅលើប្រជាជនដែលបង្កើតរូបព្រះ ហើយ «វា»
សំដៅទៅលើរូបព្រះដែលពួកគេបានបង្កើត។
Isaiah 46:8

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជន។
Isaiah 46:10

[illegible]ត្រូវបានចាប់យកទៅជាឈ្លើយ។

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជន។

យើងបានប្រាប់ពីគ្រាចុងក្រោយ តាំងពីពេលដំបូង គឺជាអ្វីដែលមិនទាន់កើតឡើង

នេះជាមូលដ្ឋានធ្វើម្តងទៀតនូវគំនិតដូចគ្នាសម្រាប់ការបញ្ជាក់។
កិរិយាស័ព្ទពីឃ្លាទីមួយអាចត្រូវបានផ្តល់ឲ្យសម្រាប់ឃ្លាទីពីរ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានប្រាប់ពីគ្រាចុងក្រោយ តាំងពីពេលដំបូង
គឺជាអ្វីដែលមិនទាន់កើតឡើង»

យើងបានហៅបក្សីព្រៃពីទិសខាងកើត

ព្រះអម្ចាស់មានបន្ទូលអំពីស្តេចស៊ីរុសដូចជាទ្រង់ជា «បក្សីនៃសត្វព្រៃ»។
ដូចសត្វស្លាបចាប់សត្វព្រៃយ៉ាងលឿនដូច្នេះស្តេចស៊ីរុសនឹងសំរេចព្រះហឫទ័យរបស់ព្រះអម្ចាស់យ៉ាងលឿ[illegible]

យើងបានចេញថ្លែងហើយ យើងនឹងធ្វើឲ្យសម្រេចជារូបរាង អ្វីដែលយើងគិតគូរ យើងមុខជាធ្វើមិន
ខាន

នេះគំនិតដូចគ្នាដើម្បីបញ្ជាក់ម្តងទៀត។
Isaiah 46:12

[illegible]ដែលមានសក់ស្កូវ។

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជនអ៊ីស្រាអែល។

ដែលនៅឆ្ងាយពីការងារត្រឹមត្រូវអើយ

ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនដែលរឹងចចេសធ្វើខុស
ដូចជាពួកគេនៅឆ្ងាយពីការងារត្រឹមត្រូវ។

ការសង្គ្រោះយើងក៏មិនរង់ចាំដែរ

ព្រះអម្ចាស់មានបន្ទូលអំពីការជួយសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គអោយបានឆាប់
ប្រសិនបើការសង្គ្រោះរបស់ព្រះអង្គជាមនុស្សដែលមិនរង់ចាំធ្វើសកម្មភាព។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងមិនរង់ចាំជួយអ្នកទេ»

---

47 [1]ចុះមកហើយអង្គុយនៅលើដី ក្រុងបាប៊ីឡូនអើយ អ្នករលំហើយ ក្រុងរបស់ជនជាតិខាល់ដេអើយ ចូរអង្គុយផ្ទាល់នឹងដីនេះទៅ អ្នកគ្មានបល្ល័ង្កទៀតទេ។ អ្នកលែងត្រូវ
ហៅថា ជាអ្នកល្វីតល្វន់ហើយទន់ភ្លន់ទៀតហើយ។[2]ចូរយកត្បាល់មកកិនម្សៅ ចូរយកស្បៃចេញពីមុខ ហើយដាក់សម្លៀកបំពាក់អ្នកចុះ ចូរលាត់សំពត់ឡើង
ហើយដើរឆ្លងទឹកទន្លេទៅ។
[3]ភាពអាក្រាតនិងកេរ្តិ៍ខ្មាស់បស់អ្នកនឹងត្រូវបានគេមើលឃើញ យើងនឹងសងសឹក ឥតប្រណីដល់អ្នកណាឡើយ។
[4]ព្រះអង្គដែលជាព្រះដ៏ប្រោសលោះរបស់យើងព្រះអង្គជាព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល។[5]សូមអង្គុយនៅស្ងៀមហើយចូលទៅក្នុងភាពងងឹតឱកូនស្រីនៃពួកខាល់ដេ
អើយ ដ្បិតគេនឹងលែងហៅអ្នកជាម្ចាស់នៃនរគផ្សេងៗទៀតហើយ។
[6]យើងបានខឹងនឹងប្រជារាស្ត្ររបស់យើង យើងបានឲ្យមរតកប្រជារាស្ត្ររបស់យើងទៅក្នុងដៃអ្នក តែអ្នកមិនបានអាណិតអាសូរពួកគេទេ។ អ្នកបានដាក់នឹមធ្ងន់ៗ
លើមនុស្សចាស់។[7]អ្នកនិយាយថា៖ «ខ្ញុំនឹងត្រួតត្រាលើអ្នកជារៀងរហូតគឺជាម្ចាស់»។ អ្នកមិនបានយកការនេះដាក់ក្នុងចិត្ត ហើយក៏មិនបានគិតដល់ចុង
បំផុតថាពួកគេនឹងងៀកចេញដែរ។
[8]ដូច្នេះឥឡូវនេះសូមស្តាប់ អ្នកដែលចូលចិត្តការសប្បាយ ហើយនៅដោយឥតកង្វល់ អ្នកនឹកក្នុងចិត្ត «គឺយើងនេះហើយ
គ្មាននរណាម្នាក់ដូចយើងទេហើយយើងនឹងមិនអង្គុយធ្វើដូចជាស្ត្រីមេម៉ាយទៀតទេហើយយើងក៏មិនដែលបាត់បង់កូនដែរ»។

generated on Wed Sep 10 16:16:32 2025

[9]ប៉ុន្តែសេក្តីទាំងពីរនេះនឹងមកដល់អ្នកក្នុងពេលតែមួយថ្ងៃតែមួយគឺការបាត់បង់កូននិងជាស្ត្រីមេម៉ាយ ទុក្ខវេទនានេះនឹងកើតមានដល់អ្នក ទោះបីអ្នកមានមន្តអាគម ឬមានគាថា ការពារខ្លួនច្រើនយ៉ាងណាក៏ដោយ។
[10]អ្នកបានទុកចិត្តនៅក្នុងអំពើអាក្រក់របស់អ្នក ហើយអ្នកបាននិយាយថា «គ្មាននរណាម្នាក់មើលឃើញទេ»
ប្រាជ្ញានិងចំណេះដឹងរបស់អ្នកបាននាំអ្នកឲ្យវង្វេងប៉ុន្តែអ្នកនិយាយក្នុងចិត្តថា «ខ្ញុំមានហើយគ្មាននរណាម្នាក់ដូចខ្ញុំទេ»។
[11]ដោយហេតុនេះគ្រោះមហន្តរាយនឹងកើតមានដល់អ្នក អ្នកនឹងមិនអាចបណ្តេញវាចេញបានទេ មហន្តរាយនឹងធ្លាក់មកលើ
អ្នកគ្រោះមហន្តរាយនឹងវាយប្រហារអ្នកភ្លាមៗមុនពេលដែលអ្នកដឹង។
[12]ចូរប្រើមន្តអាគមគាថាដ៏ច្រើនរបស់អ្នក ជាវិជ្ជាដែលអ្នកបានខំប្រព្រឹត្តតាម តាំងតែពីក្មេងមក ប្រហែលជាអ្នកនឹងទទួលបានជោគជ័យឬ ប្រហែលជាអ្នកអាចឈ្នះ
គ្រោះមហន្តរាយដែរ។[13]អ្នកអស់កម្លាំង ដោយគំនិតយោបល់គ្រូហោរជាច្រើនរបស់អ្នក អ្នកទាំងនោះបែងចែកមេឃ សង្កេតមើលផ្កាយហើយទស្សន៍ទាយរៀងរាល់ខែ អំពី
ការដែលត្រូវនឹងកើតមាន សូមអោយពួកគ្រូទាំងនោះ ក្រោកឈរហើយជួយសង្គ្រោះអ្នក។
[14]ចូរមើល៍! ពួកគេនឹងក្លាយដូចជាចំបើង។ ភ្លើងនឹងឆាបឆេះពួកគេអស់ទៅដែរ។ ពួកគេនឹងមិនសង្គ្រោះខ្លួនពួកគេពីដៃនៃអណ្តាតភ្លើងទេ។ ដ្បិតភ្លើងនោះមិនមែនជាភ្លើង
សម្រាប់ចម្អិនអាហារ ឬសម្រាប់អាំងកម្តៅខ្លួននោះឡើយ![15]របស់ទាំងប៉ុន្មានដែលអ្នកបានខំតាមនោះ នឹងបានដូច្នោះ ហើយពួកអ្នកដែលបានខំតាមជាមួយអ្នកតាំងតែពី
ក្មេងមកគេនឹងធ្វើការឆ្លុតលីលាទៅតាមផ្លូវរបស់គេរៀងខ្លួន ហើយនៅពេលដែលអ្នកស្រែករកជំនួយគ្មាននរណាម្នាក់អាចជួយសង្គ្រោះអ្នកបានទេ»។

Isaiah 47:1
ព័ត៌មានទូទៅ៖
ក្នុងជំពូកនេះព្រះអម្ចាស់មានបន្ទូលទៅកាន់បាប៊ីឡូនអំពីការធ្លាក់ចុះរបស់ទីក្រុង
ដូចជាព្រះមហាក្សត្រីដែលត្រូវអាម៉ាស់មុខ។
អង្គុយនៅលើដី ក្រុងបាប៊ីឡូនអើយ អ្នករលំហើយ...ក្រុងរបស់ជនជាតិខាល់ដេអើយ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ ការអង្គុយនៅលើ
ដីគឺជាសញ្ញានៃភាពអាម៉ាស់មួយ។ (សូមមើល: និងtranslate-symaction)
ក្រុងបាប៊ីឡូនអើយ...ក្រុងរបស់ជនជាតិខាល់ដេអើយ
ឃ្លាទាំងពីរនេះសំដៅទៅលើទីក្រុងបាប៊ីឡូនដែលត្រូវបានគេនិយាយថាដូចជាកូនស្រី។
ទីក្រុងគឺជា «កូនស្រី»
ចង្អុលបង្ហាញពីរបៀបដែលមនុស្សគិតពីទីក្រុងដោយពេញចិត្ត។
គ្មានបល្ល័ង្កទៀតទេ
ទីនេះ «បល្ល័ង្ក» សំដៅទៅលើអំណាចនៃការគ្រប់គ្រង។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានអំណាចគ្រប់គ្រងទៀតទេ»
អ្នកលែងត្រូវហៅថា ជាអ្នកលួតលង់ហើយទន់ភ្លន់ទៀតហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
មនុស្សនឹងលែងហៅអ្នកថាជាអ្នកលួតលង់ហើយទន់ភ្លន់ទៀតហើយ»
លួតលង់ហើយទន់ភ្លន់
ពាក្យទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ពួកគេពិពណ៌នាអំពីមនុស្សម្នាក់ដែលស្រស់ស្អាតហើយរស់នៅក្នុងភាពល្អប្រណីត។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្រស់ស្អាតណាស់» ឬ «ល្អប្រណីតបំផុត»
ត្បាល់
ថ្មធំមួយប្រើសម្រាប់កិនម្សៅ
Isaiah 47:3
ប្រយោគភ្ជាប់៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់បាប៊ីឡូនអំពីការធ្លាក់ចុះរបស់ទីក្រុង
ដូចជាព្រះមហាក្សត្រីដែលត្រូវអាម៉ាស់មុខ។
ភាពអាក្រាតនិងកេរ្តិ៍ខ្មាស់របស់អ្នកនឹងត្រូវបានគេមើលឃើញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនឹងអាក្រាត»
កេរ្តិ៍ខ្មាស់របស់អ្នកនឹងត្រូវបានគេមើលឃើញ
ត្រង់នេះពាក្យថា «កេរ្តិ៍ខ្មាស់» គឺជាពាក្យសម្រាប់ផ្នែកឯកជនរបស់មនុស្សម្នាក់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សនឹងឃើញភាពកេរ្តិ៍ខ្មាស់របស់អ្នក» ឬ
«មនុស្សនឹងឃើញផ្នែកឯកជនរបស់អ្នក»
ព្រះអង្គដែលជាព្រះដ៏ប្រោសលោះរបស់យើង
«របស់យើង» សំដៅទៅលើលោកអេសាយ និងប្រជាជនអ៊ីស្រាអែល។
សូមមើលរបៀបដែលអ្នកបកប្រែ «ព្រះដ៏ប្រោះលោះ» នៅក្នុងជំពូក ៤១:១៤។
ព្រះអង្គនៃពិភពទាំងមូល
បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ១:២៤។
ព្រះអង្គជាព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល
បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ៥:១៥។
កូនស្រីនៃពួកខាល់ដេអើយ
ឃ្លានេះសំដៅទៅលើទីក្រុងបាប៊ីឡូនដែលត្រូវបានគេនិយាយថាដូចជាកូនស្រី។
ថាទីក្រុងគឺជា «កូនស្រី»
ចង្អុលបង្ហាញពីរបៀបដែលជនជាតិខាល់ដេគិតគូរពីទីក្រុង។
បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ៤១:១។
ដ្បិតគេនឹងលែងហៅអ្នក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដ្បិតប្រជាជននឹងលែងហៅអ្នកទៀតហើយ»
ម្ចាស់នៃនរគ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីបាប៊ីឡូនថាជារាជធានីនៃចក្រភពបាប៊ីឡូន
ដូចជាព្រះរាជាដែលគ្រងរាជ្យលើនគរជាច្រើន។
Isaiah 47:6
ប្រយោគភ្ជាប់:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់បាប៊ីឡូនអំពីការធ្លាក់ចុះរបស់ទីក្រុង
ដូចជាមហាក្សត្រីដែលត្រូវអាម៉ាស់មុខ។
យើងបានខឹង
ទីនេះ «យើង» សំដៅទៅលើព្រះអម្ចាស់។
យើងបានឲ្យមរតក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនអ៊ីស្រាអែលថាជាកម្មសិទ្ធិរបស់ព្រះអង្គ
គឺដូចជាកម្មសិទ្ធិរបស់ពួកគេផ្ទាល់។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងធ្វើឲ្យមនុស្សរបស់យើងស្មោកគ្រោកដែលជាកម្មសិទ្ធិពិសេសរបស់យើង»
ប្រជារាស្ត្ររបស់យើងទៅក្នុងដៃអ្នក
ពាក្យត្រង់នេះ «ដៃ» តំណាងឲ្យអំណាច ឬ ការគ្រប់គ្រងរបស់ក្រុងបាប៊ីឡូន។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងធ្វើឲ្យពួកគេសិត្តនៅក្រោមអំណាចរបស់អ្នក»
អ្នកបានដាក់នឹមធ្ងន់ៗ លើមនុស្សចាស់
ព្រះអម្ចាស់មានព្រះបន្ទូលអំពីជនជាតិបាប៊ីឡូនដែលជិះជាន់សង្កត់សង្កិនលើមនុស្សចាស់
គឺដូចជាពួកគេបានធ្វើបាបមនុស្សចាស់
ដូចគោនិបានដាក់នឹមធ្ងន់ៗនៅលើកញ្ឆឹងក។
ខ្ញុំនឹងត្រួតត្រាលើអ្នកជារៀងរហូតគឺជាម្ចាស់
បាប៊ីឡូននិយាយអំពីការគ្រប់គ្រងជាអធិរាជ្យលើប្រជាជាតិជាច្រើន
ដូចជាមហាក្សត្រីដែលនឹងគ្រប់គ្រងជារៀងរហូត។
អ្នកមិនបានយកការនេះដាក់ក្នុងចិត្ត
ព្រះអម្ចាស់មានបន្ទូលអំពីការព្រះតម្រិះយ៉ាងម៉ត់ចត់អំពីអ្វីមួយ
ដូចជាកំពុងដាក់រឿងនោះនៅក្នុងចិត្តរបស់មនុស្សម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនបានពិចារណាអំពីរឿងទាំងនេះទេ»
Isaiah 47:8
ប្រយោគភ្ជាប់៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់បាប៊ីឡូនអំពីការធ្លាក់ចុះរបស់ទីក្រុង
ដូចជាមហាក្សត្រីដែលត្រូវអាម៉ាស់មុខ។
អ្នកដែលចូលចិត្តការសប្បាយ
«ល្អប្រណីត»។
នេះសំដៅទៅលើភាពប្រណីតជាច្រើនដែលបាប៊ីឡូនចូលចិត្តការសប្បាយ ។
ដោយឥតកង្វល់
នេះសំដៅទៅលើអារម្មណ៍មិនពិតរបស់បាប៊ីឡូនក្នុងការគិតថាទីក្រុងនឹងមិនបាត់បង់ឋានៈ
ទ្រព្យសម្បត្តិ និងកិត្តិយសឡើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកណាគិតថាអ្នកមានសុវត្ថិភាព»
យើងនឹងមិនអង្គុយធ្វើដូចជាស្ត្រីមេម៉ាយទៀតទេ...ដែលបាត់បង់កូន

generated on Wed Sep 10 16:16:32 2025

បាប៊ីឡូនជឿថាប្រជាជាតិផ្សេងទៀតនឹងមិនអាចយកឈ្នះទីក្រុងបានទេ
គេនិយាយថាតីក្រុងធ្វើដូចជាស្ត្រីមេម៉ាយ ឬមិនដែលមានកូនស្លាប់ឡើយ។
យើងនឹងមិនអង្គុយធ្វើដូចជាស្ត្រីមេម៉ាយទៀតទេ
«យើងនឹងមិនក្លាយជាស្ត្រីមេម៉ាយទេ»
ក្នុងពេលតែមួយថ្ងៃតែមួយ
«ភ្លាមៗក្នុងពេលតែមួយ»
Isaiah 47:10
ប្រយោគភ្ជាប់៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់បាប៊ីឡូនអំពីការធ្លាក់ចុះរបស់ទីក្រុង
ដូចជាមហាក្សត្រីដែលត្រូវអាម៉ាស់មុខ។
អ្នកនិយាយក្នុងចិត្តថា
ពាក្យត្រង់នេះ «ចិត្ត» សំដៅលើចិត្តរបស់មនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនិយាយទៅខ្លួនឯង»
ដោយហេតុនេះគ្រោះមហន្តរាយនឹងកើតមានដល់អ្នក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីគ្រោះមហន្តរាយ
ដែលហាក់ដូចជាមនុស្សដែលចាប់យកក្រុងបាប៊ីឡូន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកនឹងជួបគ្រោះមហន្តរាយ»
មហន្តរាយនឹងធ្លាក់មកលើអ្នក
ព្រះអម្ចាស់មានព្រះបន្ទូលថាក្រុងបាប៊ីឡូននឹងត្រូវវិនាសដូចជាការបំផ្លាញវត្ថុដែលធ្លាក់ចេញពីផ្ទៃមេឃ
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកនឹងជួបប្រទះនូវការបំផ្លាញ» ឬ
«អ្នកផ្សេងទៀតនឹងបំផ្លាញអ្នក»
គ្រោះមហន្តរាយនឹងវាយប្រហារអ្នក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីក្រុងបាប៊ីឡូនដែលកំពុងមានទុក្ខលំបាក
ដូចជាមានមនុស្សវាយប្រហារក្រុងបាប៊ីឡូន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនឹងជួបគ្រោះមហន្តរាយ»
Isaiah 47:12
ប្រយោគភ្ជាប់៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់បាប៊ីឡូនអំពីការធ្លាក់ចុះរបស់ទីក្រុង
ដូចជាមហាក្សត្រីដែលត្រូវអាម៉ាស់មុខ។
ចូរប្រើមន្តអាគមគាថាដ៏ច្រើនរបស់អ្នក... ប្រហែលជាអ្នកអាចឈ្នះ គ្រោះមហន្តរាយដែរ
ព្រះអម្ចាស់ចំអកក្រុងបាប៊ីឡូនដោយប្រាប់ទីក្រុងនោះ
ឲ្យបន្តធ្វើអំពើអាបធ្មប់ដើម្បីរក្សារឿងអាក្រក់
ប៉ុន្តែព្រះអង្គដឹងថាវានឹងមិនជួយដល់ទីក្រុងនោះទេ។
Isaiah 47:14
ប្រយោគភ្ជាប់៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់បាប៊ីឡូនអំពីការធ្លាក់ចុះរបស់ទីក្រុង
ដូចជាមហាក្សត្រីដែលត្រូវអាម៉ាស់មុខ។
ពួកគេនឹងក្លាយជាចំបើង។ ភ្លើងនឹងឆាបឆេះពួកគេ
ព្រះអម្ចាស់ប្រៀបធៀបគ្រូមន្តអាគម
និងអាបធ្មប់ទៅនឹងចំបើងដែលឆាបឆេះយ៉ាងឆាប់រហ័ស។
នេះមានន័យថាព្រះអម្ចាស់នឹងកំទេចពួកគេយ៉ាងងាយ ដូចភ្លើងឆេះគល់ចំបើង
ហើយដូច្នេះពួកគេគ្មានសមត្ថភាពក្នុងការជួយដល់ក្រុងបាប៊ីឡូនឡើយ។
ភ្លើងដែលឆេះ
ពាក្យត្រង់នេះ «ដៃ» តំណាងឲ្យកម្លាំង។ របៀបផ្សេងទៀតនៃការបកប្រែ:
«កម្លាំងនៃអណ្តាតភ្លើង»
ដ្បិតភ្លើងនោះមិនមែនជាភ្លើង សម្រាប់ចម្អិនអាហារ ឬសម្រាប់អាំងកម្តៅខ្លួននោះឡើយ
ព្រះអម្ចាស់បញ្ជាក់ថានេះជាភ្លើងបំផ្លាញ
ដោយបញ្ជាក់ថាវាមិនមែនជាភ្លើងដែលមនុស្សនឹងប្រើដើម្បីកម្តៅខ្លួនឡើយ។

---

48 [1]សូមស្តាប់ការនេះ កូនចៅរបស់លោកយ៉ាកុបដែលមានឈ្មោះថាអ៊ីស្រាអែលហើយមកពីពូជពង្សរបស់យូដា អ្នកដែលបានស្បថនៅចំពោះព្រះនាមព្រះអម្ចាស់
ហើយស្រែកអង្វររកព្រះនាមរបស់ជនជាតិអ៊ីស្រាអែល ប៉ុន្តអ្នករាល់គ្នាមិនបានសម្តែងនូវភាពស្មោះត្រង់និងភាពសុចរិកឡើយ។
[2]ដ្បិតគេហៅខ្លួនឯងថាជាប្រជាជននៃក្រុងដ៏វិសុទ្ធហើយទុកចិត្តលើព្រះរបស់ជនជាតិអ៊ីស្រាអែល ព្រះអម្ចាស់នៃពិភពទាំងមូលជាព្រះនាមរបស់ព្រះអង្គ។
[3]«យើងបានប្រកាសប្រាប់អ្នក តាំងពីយូរណាស់មកហើយ សេចក្តីដែលចេញពីមាត់យើង ហើយឲ្យអ្នកគេបានដឹង យើងក៏បានធ្វើឲ្យការទាំងនោះមែន ហើយក៏កើតមួយជារំពេចដែរ។[4]ដ្បិតយើងបានដឹងថា អ្នកជាមនុស្សរឹងចចេស សាច់ដុំករបស់អ្នករឹងដូចដែកហើយថ្ងាសរបស់អ្នកដូចជាលង្ហិន[5]ហេតុនេះហើយ
បានជាខ្ញុំប្រាប់អោយអ្នកបានដឹងជាមុន យើងបានឲ្យអ្នកដឹងមុនការដែលនឹងមកដល់ ដើម្បីកុំឲ្យអ្នកនិយាយថា «គឺរូបព្រះរបស់ខ្ញុំដែលបានធ្វើការនេះ» ឬ «គឺរូបព្រះដែល
ខ្ញុំបង្កើត បានធ្វើឲ្យការកើតមក»។
[6]អ្នករាល់គ្នាបានឮពីការណ៍ទាំងនេះ មើលទៅភស្តុតាងទាំងនោះ ហើយអ្នកនឹងមិនទទួលស្គាល់ អ្វីដែលយើងបានប្រាប់ថាជាការពិតទេ? តាំងពីពេលនេះទៅ យើងប្រាប់ឲ្យ
អ្នកដឹង អំពីការណ៍ថ្មីៗទៀត ដែលយើងបានគ្រោងទុក តែអ្នករាល់គ្នាមិនទាន់ដឹងនៅឡើយ។[7]ឥឡូវនេះ មិនមែនកាលពីបុរាណទេ ការណ៍ទាំងនោះនឹងកើត រហូតមកទល់
ពេលនេះ អ្នកពុំដែលឮគេនិយាយពីការណ៍នេះទេ ដូច្នេះអ្នកមិនអាចនិយាយថា «ពិតណាស់ ខ្ញុំស្គាល់ការណ៍នោះហើយ»។
[8]អ្នកមិនដែលបានឮសោះ មិនបានដឹងទេ ហើយតាំងពីដើមមក អ្នកមិនដែលយកចិត្តទុកដាក់ស្តាប់ឡើយ។ ដ្បិតយើងបានដឹងថា អ្នកនឹងប្រព្រឹត្តដោយចិត្តបោកប្រាស់
ហើយអ្នកបាន បះបោរតាំងពីចាប់កំណើតមក។
[9]ដោយយល់ដល់នាមយើងនឹងបំបាត់សេចក្តីក្រោធរបស់យើង ដោយយល់ដល់កិត្តិនាមរបស់យើង យើងបានទុកជីវិតឲ្យអ្នក យើងមិនបំផ្លាញអ្នកឡើយ។[10]មើល៍ យើង
បានបន្សុទ្ធអ្នក ប៉ុន្តែមិនដូចគេបន្សុទ្ធប្រាក់នោះទេគឺយើងលត់ដំអ្នក ដោយទុក្ខលំបាកដ៏ខ្លាំង។[11]ដ្បិតយើងនឹងធ្វើការនោះ ដោយយល់ដល់ខ្លួនយើង គឺដោយយល់ដល់ខ្លួន
យើង តើធ្វើដូចម្តេចដើម្បីឱ្យឈ្មោះខ្ញុំត្រូវអាម៉ាស់? សិរីល្អរបស់យើង យើងមិនឲ្យទៅព្រះដទៃណាផ្សេងឡើយ។
[12]ចូរស្តាប់យើងយ៉ាកុបនិងអ៊ីស្រាអែល ដែលយើងត្រាស់ហៅអើយ ចូរនាំគ្នាស្តាប់ពាក្យយើង! គឺយើងនេះហើយដែលនៅមុនគេ និងនៅក្រោយគេបំផុត។[13]ត្រូវហើយ ដៃ
យើងបានដាក់ឫសនៃផែនដី ហើយដៃស្តាំរបស់យើងបានលាតផ្ទៃមេឃ កាលណាយើងហៅ នោះទាំងពីរក៏ឈរឡើងជាមួយគ្នា។
[14]ប្រជាជនទាំងមូលអើយ ចូរមកជួបជុំគ្នា ហើយស្តាប់ចុះ! ក្នុងចំណោមអ្នករាល់គ្នាតើមាននរណាម្នាក់ដែលបានប្រកាសសេចក្តីទាំងនេះ? សម្ព័ន្ធមិត្តរបស់យើងនឹងប្រហារ
ក្រុងបាប៊ីឡូន គេ នឹងធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ប្រឆាំងនឹងជនជាតិខាល់ដេ។[15]យើង គឺយើងនេះហើយបានថ្លែង យើងបានហៅគេ យើងបាននាំគេមក ហើយគេ
នឹងសម្រេចកិច្ចការបាន។
[16]ចូរនាំគ្នាចូលមកជិត ហើយស្តាប់យើងចុះ! តាំងតែពីដើមដំបូងមក យើងមិនបាននិយាយដោយសម្ងាត់ទេ ពេលការទាំងនេះចាប់ផ្តើមកើតឡើង យើងក៏ស្ថិតនៅទីនោះ
ដែរ»។ ឥឡូវនេះ ព្រះអម្ចាស់ជាព្រះបានចាត់ខ្ញុំអោយមកនិងព្រះវិញ្ញាណរបស់ព្រះអង្គ។
[17]ព្រះអម្ចាស់ជាព្រះដ៏ប្រោសលោះនិងជាព្រះដ៏វិសុទ្ធនៃជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖
«យើងជាព្រះអម្ចាស់ជាព្រះរបស់អ្នកដែលបង្រៀនអ្នកពីរបៀបដែលអ្នកអាចទទួលជោគជ័យបាន។[18]ប្រសិនបើអ្នកបានធ្វើតាមបញ្ញត្តិរបស់ខ្ញុំ!
ពេលនោះសេចក្តីសុខសាន្តនិងភាពថ្កុំថ្កើងរបស់អ្នកនឹងហូរដូចជាទន្លេហើយសេចក្តីសង្គ្រោះរបស់អ្នកនឹងដូចជារលកសមុទ្រ។
[19]កូនចៅរបស់អ្នកនឹងកើនចំនួនច្រើនឥតគណនា ដូចខ្សាច់ ចំណែកកូនចៅដែលចេញពីផ្ទៃរបស់អ្នកកើនចំនួនច្រើនដូចគ្រាប់ខ្សាច់ផងដែរ
ឈ្មោះរបស់ពួកគេនឹងមិនត្រូវបានគេកាត់ចេញ ឬបំផ្លាញពីមុខយើងនោះឡើយ។
[20]ចូរចេញពីក្រុងបាប៊ីឡូន! ចូររត់ចេញពីក្នុងចំណោមជនជាតិខាល់ដេ! ចូរបន្លឺសំឡេងប្រកាសយ៉ាងសប្បាយ! ចូរប្រកាសរហូតដល់ទីដាច់ស្រយាលនៃផែនដី! ចូលនិយាយ
ថា «ព្រះអម្ចាស់បានរំដោះយ៉ាកុបជាអ្នកបំរើរបស់ព្រះអង្គ»។
[21]ពួកគេនៅមិនស្រែកទឹកទេនៅពេលព្រះអង្គនាំឆ្លងវាលហួតហែង ព្រះជាម្ចាស់បានធ្វើឱ្យទឹកហូរចេញពីថ្មសម្រាប់ពួកគេ ដោយអង្គបំបែកថ្មហើយទឹកក៏ហូរចេញមក។
[22]ព្រះអម្ចាស់មានព្រះបន្ទូលថា មនុស្សអាក្រក់អត់មានក្តីសុខសាន្តទេ»។

---

generated on Wed Sep 10 16:16:32 2025

Isaiah 48:1
សូមស្តាប់
«ចូរស្តាប់ពាក្យរបស់យើង» ព្រះអម្ចាស់កំពុងមានព្រះបន្ទូល។
កូនចៅរបស់លោកយ៉ាកុប
ត្រង់ពាក្យថា «កូនចៅ» សំដៅទៅលើកូនចៅរបស់លោកយ៉ាកុប។
របៀបផ្សេងទៀតនៃការបកប្រែ: «កូនចៅរបស់លោកយ៉ាកុប»
ដែលមានឈ្មោះថាអ៊ីស្រាអែល
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលហៅប្រជាជនអ៊ីស្រាអែល»
មកពីពូជពង្សរបស់យូដា
ឃ្លានេះបញ្ជាក់ថាពួកគេជាកូនចៅផ្ទាល់របស់យូដា។
របៀបផ្សេងទៀតនៃការបកប្រែ: «គឺជាកូនចៅរបស់យូដា»
ស្រែកអង្វរកព្រះនាមរបស់ជនជាតិអ៊ីស្រាអែល
«អំពាវនាវដល់ព្រះនៃជនជាតិអ៊ីស្រាអែល»
គេហៅខ្លួនឯង
ឃ្លានេះសំដៅលើប្រជាជនអ៊ីស្រាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកហៅខ្លួនឯង»
ក្រុងដ៏វិសុទ្ធ
ពាក្យនេះសំដៅទៅលើយេរូសាឡិម។
ព្រះអម្ចាស់នៃពិភពទាំងមូល
បកប្រែឃ្លានេះតាមរបៀបដែលអ្នកបានបកក្នុងជំពូក ១:៩។
Isaiah 48:3
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជនអ៊ីស្រាអែល។
សេចក្តីដែលចេញពីមាត់យើង
«មាត់» សំដៅទៅលើនរណាម្នាក់និយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបាននិយាយរឿងទាំងនេះ»
សាច់ដុំករបស់អ្នករឹងដូចដែកហើយថ្ងាសរបស់អ្នកដូចជាលង្ហិន
ព្រះអម្ចាស់ប្រៀបធៀបភាពរឹងនៃសាច់ដុំករបស់ពួកគេ
ហើយភាពរឹងនៃថ្ងាសរបស់ពួកគេទៅនឹងភាពរឹងរបស់ដែក និងលង្ហិន។
ត្រង់ពាក្យថាមានករឹង
ឬថ្ងាសរឹងគឺជាពាក្យប្រៀបធៀបដែលមានន័យថាប្រជាជនរឹងរូស។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូចជាករបស់អ្នកត្រូវបានគេធ្វើពីដែក
និងក្បាលរបស់អ្នកធ្វើពីលង្ហិន»
បានជាខ្ញុំប្រាប់អោយអ្នកបានដឹងជាមុន យើងបានឲ្យអ្នកដឹងមុនការដែលនឹងមកដល់
ឃ្លានេះកំពុងនិយាយដូចគ្នាពីរដងសម្រាប់ការបញ្ជាក់ន័យ។
Isaiah 48:6
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជនអ៊ីស្រាអែល។
អ្នកនឹងមិនទទួលស្គាល់ អ្វីដែលយើងបានប្រាប់ថាជាការពិតទេ?
ព្រះអម្ចាស់ប្រើសំនួរមួយដើម្បីធ្វើឲ្យប្រជាជនអ៊ីស្រាអែលស្តីបន្ទោសចំពោះការមិនទទួលយកអ្វីដែលយើងបានប្រាប់ថាជាការពិត
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជាមនុស្សរឹងចចេសហើយនឹងមិនទទួលយកអ្វីដែលយើងបានប្រាប់ថាជាការពិតទេ»
។
Isaiah 48:8
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជនអ៊ីស្រាអែល។
ហើយតាំងពីដើមមក អ្នកមិនដែលយកចិត្តទុកដាក់ស្តាប់ឡើយ
ព្រះអម្ចាស់មានបន្ទូលអំពីការពន្យល់អ្វីមួយដូចជាការនោះកំពុងលាតត្រដាងឡើង។
ពាក្យថា «ស្តាប់» តំណាងឲ្យមនុស្សដែលកំពុងស្តាប់។
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមិនបានពន្យល់រឿងទាំងនេះប្រាប់អ្នកជាមុនទេ»
ចាប់កំណើតមក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការចាប់ផ្តើមនៃប្រជាជាតិដូចជាកំណើតរបស់ប្រជាជាតិ។
Isaiah 48:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅប្រជាជនអ៊ីស្រាអែល។
ដោយយល់ដល់នាមយើងនឹងបំបាត់សេចក្តីក្រោធរបស់យើង
ត្រង់ពាក្យ «នាម» សំដៅទៅលើកេរ្តិ៍នាមរបស់ព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីជាប្រយោជន៍ដល់កេរ្តិ៍នាមរបស់យើង
យើងនឹងពន្យារសេចក្តីក្រោធរបស់យើង»
ដោយយល់ដល់កិត្តិនាមរបស់យើង យើងបានទុកជីវិតឲ្យអ្នក យើងមិនបំផ្លាញអ្នកឡើយ
ផ្នែកនៃប្រយោគនេះមានន័យថាមានលក្ខណៈដូចគ្នានឹងផ្នែកទីមួយដែរ។
មើល៍ យើងបានបន្សុទ្ធអ្នក ប៉ុន្តែមិនដូចគេបន្សុទ្ធប្រាក់នោះទេគឺយើងលត់ដំអ្នក ដោយទុក្ខលំបាកដ៏
ខ្លាំង
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការប្រើទុក្ខវេទនាដើម្បីជំរះប្រជារាស្ត្ររបស់ព្រះអង្គឲ្យបានបរិសុទ្ធដូចជាលោ
និងទុក្ខលំបាកដ៏ខ្លាំងដែលព្រះអង្គបានលត់ដំពួកគេ។
តើធ្វើដូចម្តេចដើម្បីឱ្យឈ្មោះខ្ញុំត្រូវអាម៉ាស់?
ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីបញ្ជាក់ថាព្រះអង្គមិនដែលអនុញ្ញាតិឲ្យព្រះនាមរបស់ព្រះអង្គត្រូវអាម៉ាស់ទេ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដ្បិតយើងនិងមិនអនុញ្ញាតិឲ្យនរណាម្នាក់ត្រូវអាម៉ាស់ដោយឈ្មោះរបស់យើងទេ»
Isaiah 48:12
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជនអ៊ីស្រាអែល។
យ៉ាកុប និងអ៊ីស្រាអែល
ពាក្យទាំងពីរនេះគឺសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
គឺយើងនេះហើយដែលនៅមុនគេ និងនៅក្រោយគេបំផុត
ឃ្លានេះសង្កត់ធ្ងន់លើធម្មជាតិដ៏អស់កល្បរបស់ព្រះអម្ចាស់។ អាចមានន័យថាទី ១)
គឺ «យើងជាព្រះដែលបានចាប់ផ្តើមអ្វីៗទាំងអស់
ហើយយើងជាអ្នកដែលបញ្ចប់អ្វីៗទាំងអស់» ឬ ទី២)
«យើងជាព្រះដែលតែងតែរស់នៅហើយយើងជាព្រះដែលនឹងរស់នៅជានិច្ច» ។
មើលរបៀបដែលអ្នកបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៤៤:៦។
ដៃយើងបានដាក់ឫសនៃផែនដី ហើយដៃស្តាំរបស់យើងបានលាតផ្ទៃមេឃ
ត្រង់ពាក្យថា «ដៃ» សំដៅទៅលើព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានដាក់ឫសនៃផែនដី ហើយដៃស្តាំរបស់យើងបានលាតផ្ទៃមេឃ»
ឫសនៃផែនដី
ពាក្យថា «គ្រឹះ»
ជាធម្មតាសំដៅទៅលើរចនាសម្ព័ន្ធថ្មមួយដែលសម្រាប់ទ្រទំង់ដល់អាគារពីក្រោម។
នៅត្រង់ពាក្យនេះពិពណ៌នាអំពីរចនាសម្ព័ន្ធស្រដៀងគ្នាដែលត្រូវបានគេគិតថាទ្រទ្រង់
និងរក្សាផែនដីឲ្យនៅនឹងកន្លែង។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុងជំពូក ២៤:១៧។
លាតផ្ទៃមេឃ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការបង្កើតផ្ទៃមេឃ
ដូចជាក្រណាត់ដែលព្រះអម្ចាស់បានលាតសន្ធឹង។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៤២:៥ ។
កាលណាយើងហៅ នោះទាំងពីរក៏ឈរឡើងជាមួយគ្នា
ការក្រោកឈរនៅពេលព្រះអម្ចាស់ត្រាស់ហៅ
គឺជាពាក្យប្រៀបធៀបមួយសម្រាប់ការត្រៀមខ្លួនដើម្បីប្រព្រឹត្តតាមព្រះអង្គ។
ព្រះអម្ចាស់មានព្រះបន្ទូលអំពីផែនដី និងផ្ទៃមេឃហាក់
[illegible]
កាលណាយើងហៅ
ឃ្លានេះអាចមានន័យថាទី ១) គឺ «នៅពេលយើងហៅផែនដី និងផ្ទៃមេឃ» ឬ ទី២)
«នៅពេលដែលយើងហៅផ្កាយនៅលើមេឃ»។
Isaiah 48:14
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជាជនអ៊ីស្រាអែល។
ចំណោមអ្នករាល់គ្នាតើមាននរណាម្នាក់ដែលបានប្រកាសសេចក្តីទាំងនេះ?
ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីបញ្ជាក់ថារូបព្រះទាំងនោះមិនបានប្រកាសសេចក្តីទាំងនេះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានរូបព្រះណារបស់ពួកគេដែលហ៊ានប្រកាសសេចក្តីទាំងនេះទេ»
សម្ព័ន្ធមិត្តរបស់យើងនឹងប្រហារក្រុងបាប៊ីឡូន គេ
នឹងធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ប្រឆាំងនឹងជនជាតិខាល់ដេ
ត្រង់ពាក្យថា «សម្ព័ន្ធមិត្ត» សំដៅទៅលើស្តេចស៊ីរូស។
ប្រយោគទាំងពីរនេះមានន័យដូចគ្នា ហើយត្រូវបានប្រើសម្រាប់ការបញ្ជាក់។
ធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់
«ព្រះហឫទ័យរបស់ព្រះអម្ចាស់»
យើង គឺយើង
ពាក្យ «យើង» ត្រូវបានធ្វើម្តងទៀតសម្រាប់ការបញ្ជាក់។

generated on Wed Sep 10 16:16:32 2025

---

49 [1]ចូរស្តាប់យើង កោះទាំងឡាយអើយ! ឥឡូវនេះសូមចំណាយពេលស្តាប់យើងដោយចិត្តទុកដាក់ អស់អ្នកដែលនៅកន្លែងឆ្ងាយ។ ព្រះអម្ចាស់ត្រាស់ហៅខ្ញុំ តាំងពីខ្ញុំនៅ
ក្នុងផ្ទៃម្តាយ ព្រះអង្គបានត្រាស់ហៅខ្ញុំតាំងពីមុនខ្ញុំកើត។[2]ព្រះអង្គបានធ្វើអោយមាត់ខ្ញុំដូចជាដាវមុតស្រួច ព្រះអង្គបានលាក់ខ្ញុំនៅក្នុងម្លប់ព្រះហស្តរបស់ព្រះអង្គ
ព្រះអង្គធ្វើឲ្យខ្ញុំក្លាយជាព្រួញមួយស្រួច ហើយលាក់ទុកក្នុងបំពង់ព្រួញរបស់ព្រះអង្គ។
[3]ព្រះអង្គមានបន្ទូលមកកាន់ខ្ញុំថា «អ៊ីស្រាអែលដែលជាអ្នកបំរើរបស់យើង ដែលយើងនឹងបានសិរីល្អដោយសារអ្នក»។[4]ប៉ុន្តែខ្ញុំបានឆ្លើយថា
«ទោះបីខ្ញុំគិតថាខ្ញុំបានធ្វើការអត់ប្រយោជន៍ ខ្ញុំក៏បានប្រើកម្លាំងរបស់ខ្ញុំដោយអត់ប្រយោជន៍ ប៉ុន្តែយុត្តិធម៌របស់ខ្ញុំ គឺនៅជាមួយព្រះអម្ចាស់ ហើយរង្វាន់របស់ខ្ញុំក៏នៅមួយ
ព្រះជាម្ចាស់ដែរ»។
[5]ឥឡូវនេះ ព្រះអម្ចាស់មានព្រះបន្ទូលថា ព្រះអង្គដែលបានបង្កើតខ្ញុំមកដើម្បីឲ្យខ្ញុំបម្រើព្រះអង្គ សម្រាប់នឹងនាំពួកយ៉ាកុបមករកព្រះអង្គវិញ ហើយឲ្យពួកអ៊ីស្រាអែលបាន
មូលមករកព្រះអង្គដែរ ដ្បិតនៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ខ្ញុំជាមនុស្សដែលមានកិត្តិយស ហើយព្រះជាម្ចាស់ជាកម្លាំងនៃខ្ញុំ[6]ព្រះអង្គមានព្រះបន្ទូលថា
«ធ្វើជាអ្នកបំរើរបស់យើងគឺជារឿងដែលតូចតាចបំផុត ក្នុងការបង្កើតកុលសម្ព័ន្ធរបស់លោកយ៉ាកុបឡើងវិញ ដើម្បីស្តារជនជាតិអ៊ីស្រាអែលដែលនៅសល់ឡើងវិញ
យើងនឹងធ្វើឱ្យអ្នកក្លាយជាពន្លឺបំភ្លឺដល់ប្រជាជាតិទាំងមូល ដើម្បីអោយអ្នកធ្វើជាក្តីសង្គ្រោះរបស់យើងដល់ចុងផែនដី»។
[7]នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ ដែលបានលោះអ៊ីស្រាអែល ហើយជាព្រះជាម្ចាស់ដ៏បរិសុទ្ធផង មកចំពោះអ្នក ដែលត្រូវគេមើលងាយ និងជាអ្នកដែលប្រជាជាតិបានស្អប់
ខ្ពើម ដែលជាខ្ញុំបម្រើនៃអ្នកដឹកនាំ «បណ្តាក្សត្រនឹងឃើញ ហើយក្រោកឈរឡើង ព្រមទាំងពួកអ្នកដឹកនាំផង អ្នកនឹងក្រាបចុះ ដោយសារព្រះអម្ចាស់ ដែលជាព្រះដ៏
ស្មោះត្រង់ គឺជាព្រះដ៏បរិសុទ្ធនៃជនជាតិអ៊ីុស្រាអែលដែលព្រះអង្គបានរើសអ្នក»។
[8]នេះជាអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល «ដល់ពេលមួយដែលយើងគាប់ព្រះហឫទ័យយើងនិងឆ្លើយតបទៅកាន់អ្នក
ហើយនៅថ្ងៃនៃការសង្គ្រោះមកដល់យើងនិងជួយដល់អ្នក យើងនិងការពារអ្នក ហើយយើងបានញែកអ្នកឲ្យនៅដាច់ឡែកពីគេដើម្បីធ្វើជាសម្ពន្ធមេត្រីសម្រាប់ប្រជាជន
ដើម្បីតាំងទឹកដីឡើង ប្រយោជន៍នឹងចែកដីដែលចោលស្ងាត់ដល់គេ ទុកជាមរតក។
[9]អ្នកនឹងនិយាយទៅកាន់អ្នកទោសថា «ចេញមក» ដើម្បីប្រាប់អ្នកដែលនៅក្នុងគុកងងឹតថា«ចូរបង្ហាញខ្លួនអ្នក» ពួកគេនឹងមានអាហារបរិភោគតាមផ្លូវ ហើយស្វែងរក
អាហារ តាមទីវាលផងដែរ។
[10]ពួកគេនឹងមិនឃ្លាន ឬ ស្រេកទឹកឡើយ ចំហាយក្តៅ ឬព្រះអាទិត្យ នឹងធ្វើអីគេមិនបានឡើយ ដ្បិតព្រះដែលមានព្រះហឫទ័យ មេត្តាករុណាចំពោះគេ ទ្រង់នាំផ្លូវគេ ព្រះអង្គ
ដឹកនាំគេឆ្ពោះទៅកាន់ប្រភពទឹក។[11]យើងនឹងធ្វើអស់ទាំងភ្នំរបស់យើងឲ្យជាផ្លូវ អស់ទាំងថ្នល់របស់យើង នឹងបានលើកឡើង»។
[12]ចូរមើល៎! ពួកគេមកពីឆ្ងាយណាស់អ្នកខ្លះមកពីខាងជើង អ្នកខ្លះមកពីខាងលិច អ្នកខ្លះទៀតមកពីស្រុកខាងត្បូង និងផ្សេងទៀតមកពីស្រុកស៊ីនីម។[13]ផ្ទៃមេឃអើយ ចូរ
ច្រៀងឡើង ឱផែនដីអើយ ចូរឲ្យអរសប្បាយចុះភ្នំទាំងឡាយអើយ ចូរស្រែកអបអរសាទរ! ដ្បិតព្រះអម្ចាស់សម្រាលទុក្ខ ប្រជារាស្ត្ររបស់ទ្រង់ ទាំងមានព្រះហឫទ័យអាណិត
អាសូរដល់ប្រជារាស្ត្រ របស់ព្រះអង្គ។
[14]ប៉ុន្តែក្រុងស៊ីយ៉ូនបានថា «ព្រះអម្ចាស់បានបោះបង់ចោលខ្ញុំហើយព្រះអម្ចាស់បានបំភ្លេចខ្ញុំហើយ»។[15]«តើម្តាយអាចបំភ្លេចកូនរបស់ខ្លួន ដែលនៅបៅបានឬ?
ដូច្នេះនាងមិនអាណិតអាសូរកូនប្រុសដែលនាងបានសម្រាលទេ? មែនហើយ ពួកគេនឹងភ្លេចបាន ប៉ុន្តែ យើងមិនដែលភ្លេចអ្នកឡើយ។

[16]ចូរមើល៍! យើងបានចារឈ្មោះអ្នក នៅលើបាតដៃរបស់យើង ហើយកំពែងរបស់អ្នក តែងនៅមុខយើងជានិច្ច។[17]កូនចៅអ្នកនឹងត្រឡប់មកវិញ ក្នុងពេលសត្រូវដែលបានកម្ទេច និងបំផ្លាញអ្នក នឹងចាកចេញឆ្ងាយពីអ្នក។[18]ចូរងើបភ្នែកឡើងមើលជុំវិញចុះ កូនចៅរបស់អ្នកមកជួបជុំគ្នាអស់ហើយ គេនាំគ្នាមករកអ្នក។ ដរាបណាយើងគង់នៅនេះជាព្រះអម្ចាស់ថ្លែងព្រះបន្ទូល អ្នកនឹងបានពាក់វាដូចគ្រឿងអលង្ការ អ្នកនឹងពាក់ដូចកូនក្រមុំតាក់តែងខ្លួន។
[19]ដ្បិតទីកន្លែងដែលគេបំផ្លាញចោលឲ្យនៅស្ងាត់ជ្រងំ ហើយមានតែគំនរបាក់បែកនេះ នឹងបានជាទីចង្អៀតណែន ដល់ពួកអ្នកដែលអាស្រ័យនៅវិញ សត្រូវដែលបានលេបទឹកដីអ្នកកាលពីមុន នឹងចាកចេញឆ្ងាយពីទីនេះ។[20]ពួកកូនចៅអ្នកដែលកើតក្នុងសេចក្ដីទុក្ខលំបាករបស់អ្នក ពួកគេនឹងនិយាយដាក់ត្រចៀកអ្នកថា
កន្លែងនេះចង្អៀតពេកសម្រាប់ពួកយើងទុកកន្លែងសម្រាប់ពួកយើងដូច្នេះយើងអាចរស់នៅទីនេះ។
[21]បន្ទាប់មកអ្នកនឹងសួរខ្លួនឯងថា«តើអ្នកណាបានយកកូនទាំងនេះមកអោយខ្ញុំ? ដ្បិតខ្ញុំបានបាត់កូនចៅអស់ហើយ ខ្ញុំនៅម្នាក់ឯង។
តើអ្នកណាបានមើលថែកូនៗទាំងនេះ? មើល៍! ខ្ញុំបាននៅម្នាក់ឯង តើកូនទាំងនេះបានមកពីទីណា?»
[22]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «មើល យើងនឹងលើកដៃហៅទៅប្រជាជាតិនានាយើងនឹងលើកទង់សញ្ញារបស់យើងដល់ប្រជាជន។ គេនឹងបីយកកូនប្រុសៗរបស់អ្នកមក ហើយដាក់កូនស្រីៗរបស់អ្នកនៅលើស្មាគេ។
[23]ស្តេចនឹងទៅជាឪពុកចិញ្ចឹមរបស់អ្នក ហើយម្ចាស់ក្សត្រីទាំងនោះនឹងធ្វើជាអ្នកមើលថែជំនួសអ្នក
ពួកគេនឹងក្រាបសំពះអ្នកនៅលើផែនដីហើយលិទ្ធធូលីដីនៅជើងរបស់អ្នក ពេលនោះអ្នករាល់គ្នានឹងទទួលស្គាល់ថាយើងពិតជាព្រះអម្ចាស់មែន។
អ្នកដែលរង់ចាំខ្ញុំនឹងមិនត្រូវអាម៉ាស់ឡើយ»។
[24]អ្វីៗដែលអ្នកចម្បាំងដ៏ជំនាញរឹបអូសយកហើយ តើនរណា អាចដណ្តើមយកមកវិញបាន? រំដោះពួកឈ្លើយពីជនកំណាចបាន?[25]ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលថា៖
«ពិតមែនហើយអស់អ្នកដែលត្រូវចាប់ជាឈ្លើយសឹកនឹងត្រូវខ្មាំងកៀរយកទៅជាឈ្លើយ។ យើងនឹងប្រឆាំងនឹងខ្មាំងសត្រូវរបស់អ្នកហើយសង្គ្រោះកូនចៅរបស់អ្នក។
[26]យើងនឹងឃ្វាលពួកសង្កត់សង្កិនរបស់អ្នកដោយ អោយគេបរិភោគសាច់ខ្លួនឯង ហើយពួកគេនឹងស្រវឹងឈាមរបស់ខ្លួនដូចជាស្រា។
ពេលនោះមនុស្សលោកទាំងអស់នឹងដឹងថាយើងជាព្រះសង្គ្រោះនិងជាព្រះប្រោសលោះរបស់អ្នកគឺព្រះរបស់យ៉ាកុបដ៏មានឫទ្ធានុភាព»។

Isaiah 49:1

ចូរស្តាប់យើង

ត្រង់ពាក្យថា «ខ្ញុំ» សំដៅទៅលើអ្នកបម្រើរបស់ព្រះអម្ចាស់។

កោះទាំងឡាយអើយ

ឃ្លានេះសំដៅទៅលើប្រជាជនដែលរស់នៅលើកោះ។

របៀបផ្សេងទៀតនៃការបកប្រែ: «អស់អ្នកដែលរស់នៅលើកោះ»

ព្រះអង្គបានធ្វើអោយមាត់ខ្ញុំដូចជាដាវមុតស្រួច

ត្រង់ពាក្យ «មាត់» តំណាងឲ្យពាក្យដែលគាត់និយាយ។

ពាក្យរបស់គាត់ត្រូវបានគេប្រៀបធៀបទៅនឹងដាវមុតដើម្បីបញ្ជាក់ថាពួកគេនឹងមានប្រសិទ្ធភាពដូចដាវមុត

សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៤២:៥។

របៀបផ្សេងទៀតនៃការបកប្រែ:

«ព្រះអង្គបានធ្វើឲ្យពាក្យរបស់ខ្ញុំមានប្រសិទ្ធភាពដូចដាវមុត»

ព្រះអង្គបានលាក់ខ្ញុំនៅក្នុងម្លប់ព្រះហស្តរបស់ព្រះអង្គ

ព្រះអម្ចាស់ការពារអ្នកបម្រើរបស់ព្រះអង្គ

និងរក្សាព្រះហឫទ័យរបស់ព្រះអង្គឲ្យបានសម្ងាត់គឺដូចជាព្រះអង្គបានលាក់ខ្ញុំនៅក្នុងម្លប់ព្រះហស្តរបស់ព្រះអង្គ

ព្រះអង្គធ្វើឲ្យខ្ញុំក្លាយជាព្រួញមួយស្រួច ហើយលាក់ទុកក្នុងបំពង់ព្រួញរបស់ព្រះអង្គ

អ្នកបម្រើរបស់ព្រះអម្ចាស់អាចបំពេញបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់បានយ៉ាងមានប្រសិទ្ធភាពដូចអ្នកបំរើនោះគឺជាបំពង់ព្រួញថ្មី។

ហើយលាក់ទុកក្នុងបំពង់ព្រួញរបស់ព្រះអង្គ

ព្រះអម្ចាស់ការពារអ្នកបម្រើរបស់ព្រះអង្គ

និងរក្សាបំណងព្រះហឫទ័យរបស់ព្រះអង្គឲ្យបានលាក់កំបាំងដូចជាព្រះអម្ចាស់បានលាក់ខ្ញុំនៅក្នុងម្លប់ព្រះហស្តរបស់ព្រះអង្គ

បំពង់ព្រួញមួយដែរ។

បំពង់ព្រួញ

ករណីប្រើសម្រាប់ដឹកព្រួញ

Isaiah 49:3

ព័ត៌មានទូទៅ៖

អ្នកបម្រើរបស់ព្រះអម្ចាស់កំពុងបន្តនិយាយ។

ព្រះអង្គមានបន្ទូល

«ព្រះអម្ចាស់មានបន្ទូល»

អ៊ីស្រាអែលដែលជាអ្នកបំរើរបស់យើង

«អ្នករាល់គ្នាជាអ្នកបម្រើរបស់យើង ដែលយើងហៅថាអ៊ីស្រាអែល»

Isaiah 49:5

ព័ត៌មានទូទៅ៖

អ្នកបម្រើរបស់ព្រះអម្ចាស់កំពុងបន្តនិយាយ។

ហើយឲ្យពួកអ៊ីស្រាអែលបានមូលមករកព្រះអង្គដែរ

ផ្នែកនៃប្រយោគនេះមានន័យដូចគ្នានឹងផ្នែកមុនដែរ។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ដើម្បីនាំប្រជាជនអ៊ីស្រាអែលមកឯព្រះអង្គវិញ»

នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ខ្ញុំជាមនុស្សដែលមានកិត្តិយស

ទីនេះ «ព្រះនេត្រ» តំណាងឲ្យព្រះតម្រិះ ឬយោបល់របស់ព្រះអម្ចាស់។

ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ព្រះអម្ចាស់បានផ្តល់កិត្តិយសដល់ខ្ញុំ»

ព្រះជាម្ចាស់ជាកម្លាំងនៃខ្ញុំ

ព្រះបានផ្តល់កម្លាំងដល់អ្នកបម្រើ ដូចដែរព្រះជាកម្លាំងរបស់គាត់។

របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះរបស់ខ្ញុំបានផ្តល់កម្លាំងដល់ខ្ញុំ» ឬ
«ព្រះរបស់ខ្ញុំជាកម្លាំងនៃខ្ញុំ»

យើងនឹងធ្វើឲ្យអ្នកក្លាយជាពន្លឺបំភ្លឺដល់ប្រជាជាតិទាំងមូល

អ្នកបម្រើនាំសាររបស់ព្រះអម្ចាស់ដល់សាសន៍ដទៃហើយជួយពួកគេឲ្យយល់

វាត្រូវបានគេនិយាយដូចជាព្រះអម្ចាស់បានធ្វើឲ្យអ្នកបំរើមានពន្លឺភ្លឺចិញ្ចាចក្នុងចំណោមប្រជាជាតិនានា។

សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៤២:៥។

ដល់ចុងផែនដី

កន្លែងនៅលើផែនដីដែលនៅឆ្ងាយគឺត្រូវបានគេនិយាយថាជាកន្លែងដល់ចុងផែនដី។

ឃ្លានេះក៏បង្កើតជាការច្របាច់បញ្ចូលគ្នា

និងសំដៅទៅលើគ្រប់ទិសទីនៅចន្លោះចុងផែនដី។ របៀបផ្សេងទៀតនៃការបកប្រែ:

«ដល់ចុងផែនដីទាំងមូល» ឬ «ដល់ផែនដីទាំងមូល»

Isaiah 49:7

ព័ត៌មានទូទៅ៖

បកប្រែពាក្យនេះតាមរបៀបដែលអ្នកបានធ្វើក្នុងជំពូក ៤១:១៤។

មកចំពោះអ្នក ដែលត្រូវគេមើលងាយ និងជាអ្នកដែលប្រជាជាតិបានស្អប់ខ្ពើម

ដែលជាខ្ញុំបម្រើនៃអ្នកដឹកនាំ

ពាក្យត្រង់នេះ «ជីវិត» តំណាងឲ្យប្រជាជន។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«មកចំពោះអ្នកដែលត្រូវគេមើលងាយ ដែលប្រជាជាតិបានស្អប់ខ្ពើម
ហើយជាអ្នកបម្រើ»

ជាព្រះដ៏បរិសុទ្ធនៃជនជាតិអ៊ីស្រាអែល

បកប្រែពាក្យនេះតាមរបៀបដែលអ្នកបានបកក្នុងជំពូក ១:៤។

Isaiah 49:8

ដល់ពេលមួយដែលយើងគាប់ចិត្តយើងនិងឆ្លើយតបទៅកាន់អ្នក

ហើយនៅថ្ងៃនៃការសង្គ្រោះមកដល់យើងនិងជួយដល់អ្នក

ឃ្លាទាំងពីរនេះមានន័យថាជាមូលដ្ឋានដូចគ្នា។

យើងនិងឆ្លើយតបទៅកាន់អ្នក

ទីនេះ «អ្នក» សំដៅទៅលើអ្នកបម្រើរបស់ព្រះអម្ចាស់។

នៅថ្ងៃនៃការសង្គ្រោះ

ពាក្យត្រង់នេះ «ថ្ងៃ» សំដៅទៅលើពេលវេលាជាក់លាក់
ហើយមិនមែនសំដៅទៅលើ ២៤ ម៉ោងក្នុងមួយថ្ងៃនោះទេ។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ខណៈដែលពេលវេលាមកដល់ នោះយើងនឹងសង្គ្រោះអ្នករាល់គ្នា»

យើងបានញែកអ្នកឲ្យនៅដាច់ឡែកពីគេដើម្បីធ្វើជាសម្ពន្ធមេត្រីសម្រាប់ប្រជាជន

នៅទីនេះពាក្យថា «សម្ពន្ធមេត្រី»

គឺជាពាក្យកាត់សម្រាប់អ្នកដែលបង្កើតឬសម្រុះសម្រួលកិច្ចព្រមព្រៀង។

សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុង ៤២:៥។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើឲ្យអ្នកក្លាយជាអ្នកសម្រុះសម្រួលនៃសម្ពន្ធមេត្រីជាមួយប្រជាជន»
ដើម្បីតាំងស្រុកទេសឡើង
ត្រង់នេះពាក្យថា «ទឹកដី»
តំណាងឲ្យទីក្រុងនានានៅលើទឹកដីដែលត្រូវបានបំផ្លាញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីតាំងស្រុកទេស
ឡើងវិញនៅកន្លែងដែលបាក់បែក»
ប្រយោជន៍នឹងចែកដីដែលចោលស្ងាត់ដល់គេ ទុកជាមរតក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីទឹកដីនោះដូចជាទឹកដីដែលជាចំណែកមត៌កដែលប្រជាជនអ៊ីស្រាអែលទទួលជាមត៌ករហូត។
មានន័យថាអ្នកបម្រើត្រូវប្រគល់ដីជូនប្រជាជនអ៊ីស្រាអែលវិញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រគល់ទឹកដីដែលស្ងាត់ជ្រងំដល់ប្រជាជនអ៊ីស្រាអែលទុកជាមត៌ករបស់ពួកគេ»
Isaiah 49:9
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅអ្នកបម្រើរបស់ព្រះអម្ចាស់។
ពួកគេនឹងមានអាហារបរិភោគតាមផ្លូវ ហើយស្វែងរកអាហារ តាមទីវាលផងដែរ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនដែលរស់នៅដោយសេរី និងរុងរឿង
ដូចជាពួកគេជាចៀមដែលមានវាលស្មៅហើយស្វែងរកអាហារ តាមទីវាលផងដែរ។
Isaiah 49:10
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
ពួកគេនឹងមិន
ទីនេះ «ពួកគេ» សំដៅទៅលើប្រជាជនរបស់ព្រះ។
ចំហាយក្តៅ ឬព្រះអាទិត្យ នឹងមិនធ្វើទុក្ខគេ
ពាក្យនៅត្រង់នេះ «ចំហាយក្តៅ» ពិព័ណ៌នាទៅលើពាក្យ «ព្រះអាទិត្យ»។
ប្រជាជនរងទុក្ខមកពីចំហាយក្តៅព្រះអាទិត្យ គឺអាចនិយាយបានថា
ចំហាយក្តៅនឹងវាយប្រហារមកលើពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងមិនរងទុក្ខដោយសារតែចំហាយក្តៅព្រះអាទិត្យនោះទេ»
ដ្បិតព្រះដែលមានព្រះហឫទ័យ មេត្តាករុណាចំពោះគេ ...ព្រះអង្គនាំផ្លូវគេ
ព្រះអម្ចាស់មានបន្ទូលអំពីព្រះកាយព្រះអង្គផ្ទាល់នៅក្នុងមនុស្សទីបី។
ព្រះអង្គមានបន្ទូលពីការការពារប្រជាជន និងថែរក្សាពួកគេ
ដូចជាព្រះអង្គជាអ្នកគង្វាលរបស់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមានព្រះហឫទ័យ មេត្តាករុណាចំពោះគេ ... យើងនឹងនាំផ្លូវពួកគេ»
យើងនឹងធ្វើអស់ទាំងភ្នំរបស់យើងឲ្យជាផ្លូវ អស់ទាំងថ្នល់របស់យើង នឹងបានលើកឡើង
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការនាំប្រជាជនរបស់ព្រះអង្គដោយសុវត្ថិភាព
និងដកឧបសគ្គចេញពីផ្លូវរបស់គេ
ដូចជាព្រះអង្គបានប្រែក្លាយភ្នំអោយទៅជាផ្លូវថ្នល់និងផ្លូវខ្ពស់ៗ។
Isaiah 49:12
ស្រុកខាងត្បូង
ទីតាំងនៃកន្លែងនេះមិនច្បាស់នោះទេ
ប៉ុន្តែវាអាចសំដៅទៅលើតំបន់មួយនៅភាគខាងត្បូងនៃប្រទេសអេស៊ីប។
ផ្ទៃមេឃអើយ ចូរច្រៀងឡើង ឱផែនដីអើយ ចូរឲ្យអរសប្បាយចុះភ្នំទាំងឡាយអើយ ចូរស្រែក
អបអរសាទរ
លោកអេសាយបង្វែរការយកចិត្តទុកដាក់ពីប្រជាជនអ៊ីស្រាអែល
ហើយនិយាយទៅកាន់ផ្ទៃមេឃ ផែនដី និងភ្នំដូចជាពួកគេ។
Isaiah 49:14
ប៉ុន្តែក្រុងស៊ីយ៉ូនបានពោលថា
ពាក្យ «ស៊ីយ៉ូន» គឺជាឈ្មោះទីក្រុងយេរូសាឡិម។ លោកអេសាយនិយាយថាទីក្រុង
ប្រៀបដូចជាស្ត្រីម្នាក់ដែលអ៊ូរអ៊ូរទ្រាំទៅចំពោះព្រះអម្ចាស់ថា
ព្រះអង្គបានបំភ្លេចនាងហើយ។
តើម្តាយអាចបំភ្លេចកូនរបស់ខ្លួន ដែលនៅបៅបានឬ?
ដូច្នេះនាងមិនអាណិតអាសូរកូនប្រុសដែលនាងបានសម្រាលទេ?
ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីជួយដល់ប្រជាជនរបស់ព្រះអង្គឲ្យយល់ថាព្រះអង្គមិនដែលភ្លេចពួកគេ
ឬ ឈប់ការពាពួកគេនោះទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ម្តាយមិនដែលបំភ្លេចកូនរបស់ខ្លួន
ឬឈប់ថែរក្សាកូនប្រុសដែលនាងបានសម្រាលទេ»។
Isaiah 49:16
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស៊ីយ៉ូន។
យើងបានចារឈ្មោះអ្នក នៅលើបាតដៃរបស់យើង
ព្រះអម្ចាស់មានព្រះបន្ទូលអំពីភក្តីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គចំពោះក្រុងស៊ីយ៉ូន
ដូចជាព្រះអង្គបានចារឈ្មោះរបស់ពួកគេនៅលើបាតដៃ។
កំពែងរបស់អ្នក តែងនៅមុខយើងជានិច្ច
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការព្រះតម្រិះអំពីក្រុងស៊ីយ៉ូនជានិច្ចកាលប្រៀបដូចកំពែងរបស់ក្រុងតែងតែ
ពាក្យថា «កំពែង» គឺជាឈ្មោះហៅក្រៅសម្រាប់ទីក្រុង។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងកំពុងព្រះតម្រិះអំពីកំពែងរបស់អ្នកជានិច្ច»
ឬ «យើងតែងតែព្រះតម្រិះអំពីអ្នក»
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនដែលវិលត្រឡប់ទៅរស់នៅក្រុងយេរូសាឡឹមវិញ
ប្រៀបដូចជាកូនចៅរបស់អ្នកត្រឡប់ទៅក្រុងដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនរបស់អ្នកកំពុងប្រញាប់ត្រឡប់មកវិញ»
ដរាបណាយើងគង់នៅ
នេះជារូបមន្តសម្បថមួយដែលព្រះអម្ចាស់ប្រើដើម្បីធានានូវអ្វីដែលព្រះអង្គកំពុងមានបន្ទូល។
នេះជាព្រះអម្ចាស់ថ្លែងព្រះបន្ទូល
នេះអាចត្រូវបានប្រើឡើងវិញដូច្នេះនាមអរូបី «ការប្រកាស»
ត្រូវបានបង្ហាញជាកិរិយាស័ព្ទ «ប្រកាស» ឬ «បាននិយាយយ៉ាងឱឡារិក»។
សូមមើលពីររបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១៤:២១។
របៀបផ្សេងទៀតនៃការបកប្រែ: «នេះគឺជាអ្វីដែលព្រះអម្ចាស់បានប្រកាស» ឬ
«នេះជាអ្វីដែលព្រះអម្ចាស់មានបន្ទូលយ៉ាងឱឡារិក»
អ្នកនឹងបានពាក់វាដូចគ្រឿងអលង្ការ អ្នកនឹងពាក់ដូចកូនក្រមុំតាក់តែងខ្លួន
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជននៅស៊ីយ៉ូនប្រៀបដូចជាគ្រឿងអលង្ការដែលទីក្រុងស្លៀក
ដើម្បីបង្ហាញភាពស្រស់ស្អាត និងភាពរីករាយរបស់ក្រុងនេះ។
អ្នកនឹងពាក់ដូចកូនក្រមុំតាក់តែងខ្លួន
ផ្នែកចុងក្រោយនៃឃ្លាអាចត្រូវបានបញ្ជាក់ច្បាស់ពីប្រយោគមុន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកនឹងពាក់វាដូចជាកូនក្រមុំពាក់គ្រឿងអលង្ការ»
Isaiah 49:19
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស៊ីយ៉ូន ដូចជាស្ត្រីម្នាក់។
ដ្បិតទឹកន្លែងដែលគេបំផ្លាញចោលឲ្យនៅស្ងាត់ជ្រងំ
ពាក្យថា «ខ្ទេះខ្ទាយ» និង «ស្ងាត់ជ្រងំ» មានន័យថាជាមូលដ្ឋានរឿងដូចគ្នា
និងបញ្ជាក់ថាសត្រូវបានបំផ្លាញស៊ីយ៉ូន ហើយទុកឲ្យវានៅទទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីជាអ្នកត្រូវបានគេបំផ្លាញទាំងស្រុង»
សត្រូវដែលបានលេបទឹកដីអ្នកកាលពីមុន
សត្រូវដែលបានបំផ្លាញស៊ីយ៉ូន គឺអាចនិយាយបានថាពួកគេបានលេបទឹកដី។
របៀបផ្សេងទៀតនៃការបកប្រែ: «សត្រូវដែលបានបំផ្លាញអ្នក»
ពួកកូនចៅអ្នកដែលកើតក្នុងសេចក្តីទុក្ខលំបាករបស់អ្នក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីគ្រាមួយដែលប្រជាជននៅក្រុងយេរូសាឡឹមត្រូវគេនិរទេសទៅនោះ
ហាក់ដូចជាពួកកូនចៅនៅទីក្រុងនោះត្រូវបានបោះបង់ចោល។
អ្នកដែលបានកើតមកនៅពេលដែលប្រជាជនកំពុងនិរទេសខ្លួនត្រូវបានគេនិយាយថាជាកូនចៅរបស់ទីក្រុ
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលនឹងរស់នៅ
អស់អ្នកដែលបានកើតនៅពេលប្រជាជនកំពុងនិរទេសខ្លួន»
កន្លែងនេះចង្អៀតពេកសម្រាប់ពួកយើង
នេះមានន័យថានឹងមានមនុស្សច្រើនណាស់ដែលរស់នៅហើយទីក្រុងនេះចង្អៀតពេកសម្រាប់ពួកគេទាំងអ
Isaiah 49:21
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស៊ីយ៉ូន ប្រៀបដូចជាស្ត្រីម្នាក់។
តើអ្នកណាបានយកកូនទាំងនេះមកអោយខ្ញុំ?
ស៊ីយ៉ូននិយាយអំពីមនុស្សដែលកំពុងវិលត្រឡប់មករស់នៅក្នុងទីក្រុងវិញ
ហាក់ដូចជាមនុស្សទាំងនោះជាកូនរបស់នាង។
សំណួររបស់ស៊ីយ៉ូនបង្ហាញពីការភ្ញាក់ផ្អើលដែលមានក្មេងៗជាច្រើនឥឡូវនេះជាកូនរបស់នាង។
ដ្បិតខ្ញុំបានបាត់កូនចៅអស់ហើយ ខ្ញុំនៅម្នាក់ឯង
ស៊ីយ៉ូនរៀបរាប់ពីនាងខ្លួននាងថាជាស្ត្រីម្នាក់ដែលមិនអាចមានកូនបានច្រើន។
នាងចង្អុលបង្ហាញហេតុផលដែលធ្វើឲ្យនាងភ្ញាក់ផ្អើលយ៉ាងខ្លាំង។
ដ្បិតខ្ញុំបានបាត់កូនចៅអស់ហើយ
«ខ្ញុំបានកាន់ទុក្ខចំពោះកូនៗ របស់ខ្ញុំដែលបានស្លាប់ហើយមិនអាចមានកូនទៀត»
ខ្ញុំនៅម្នាក់ឯង
«ខ្ញុំត្រូវបានគេបញ្ជូនទៅឆ្ងាយដោយគ្មានប្តី»
តើអ្នកណាបានមើលថែកូនៗទាំងនេះ? មើល៍! ខ្ញុំបាននៅម្នាក់ឯង តើកូនទាំងនេះបានមកពីទីណា?

generated on Wed Sep 10 16:16:32 2025

ជាថ្មីម្តងទៀតស៊ីយ៉ូនប្រើសំណួរដើម្បីបង្ហាញពីការភ្ញាក់ផ្អើលរបស់នាង។
របៀបផ្សេងទៀតនៃការបកប្រែ: « មើលទៅខ្ញុំត្រូវបានទុកឲ្យនៅម្នាក់ឯង។
ឥឡូវនេះកូនៗទាំងអស់ដែលខ្ញុំមិនបានចិញ្ចឹមបានមករកខ្ញុំហើយ»។
Isaiah 49:22
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ស៊ីយ៉ូនដូចស្ត្រីដែរ។
ព្រះអង្គពន្យល់ពីរបៀបដែលនាងអាចមានកូនបានច្រើន។
យើងនឹងលើកដៃហៅទៅប្រជាជាតិនានាយើងនឹងលើកទង់សញ្ញារបស់យើងដល់ប្រជាជន
ឃ្លាទាំងពីរនេះមានន័យថាជាមូលដ្ឋានដូចគ្នា។របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងលើកដៃនិងផ្តល់សញ្ញាដោយមានទង់ជាតិសំរាប់ប្រជាជននៃប្រជាជាតិនានា»
គេនឹងបីយកកូនប្រុសៗរបស់អ្នកមក ហើយដាក់កូនស្រីៗរបស់អ្នកនៅលើស្មាគេ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនដែលនឹងរស់នៅក្រុងយេរូសាឡឹម
ប្រៀបដូចជាកូនៗរបស់ក្រុងនោះដែរ។
ព្រះអង្គមានបន្ទូលអំពីប្រជាជននៃប្រជាជាតិដទៃទៀតដែលជួយជនជាតិអ៊ីស្រាអែលឲ្យ
ដូចជាពួកគេកំពុងដឹកនាំជនជាតិអ៊ីស្រាអែលដែរ។
Isaiah 49:23
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស៊ីយ៉ូន ដូចជាស្ត្រីម្នាក់។
ស្តេចនឹងទៅជាឪពុកចិញ្ចឹមរបស់អ្នក ហើយម្ចាស់ក្សត្រីទាំងនោះនឹងធ្វើជាអ្នកមើលថែជំនួសអ្នក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនដែលនឹងរស់នៅក្រុងស៊ីយ៉ូន
ដូចពួកគេជាកូនចៅរបស់ទីក្រុងនោះ។ ពាក្យ «ឪពុកចិញ្ចឹម» និង
«អ្នកមើលថែជំនួស» យោងទៅលើបុរស
និងស្ត្រីដែលក្លាយជាអ្នកទទួលខុសត្រូវក្នុងការមើលថែកុមារ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ស្តេចនិងព្រះមហាក្សត្រិយានីនៃប្រជាជាតិដទៃទៀតនឹងផ្តត់ផ្តង់ដល់ប្រជាជនរបស់អ្នក»
ពួកគេនឹងក្រាបសំពះអ្នកនៅលើផែនដីហើយលិទ្ធធូលីដីនៅជើងរបស់អ្នក
ឃ្លាទាំងនេះពិពណ៌នាអំពីកាយវិការដែលមនុស្សប្រើដើម្បីបង្ហាញការដាក់ស្នើពេញលេញ
លិទ្ធធូលីដីនៅជើងរបស់អ្នក
អាចមានន័យថាទី ១)
ដែលនេះគឺជាការបង្ហាញពីការដាក់ស្នើតាមព្យញ្ជនៈដែលមនុស្សនោះលិទ្ធធូលីដីចេញពី
ឬពីលើដីនៅជើងរបស់ថ្នាក់ជាន់ខ្ពស់ ឬ ទី២)
ដែលនេះជាសម្មតិកម្មដែលពិពណ៌នាអំពីមនុស្សម្នាក់ដែលលង់ខ្លួនឯងមុនថ្នាក់ខ្ពស់។
នឹងមិនត្រូវអាម៉ាស់ឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងមិនអាម៉ាស់ឡើយ» ឬ «នឹងមិនខកចិត្ត»
Isaiah 49:24
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស៊ីយ៉ូន ប្រៀបដូចជាស្ត្រីម្នាក់។

អ្វីៗដែលអ្នកចម្បាំងដ៏ជំនាញរឹបអូសយកហើយ តើនរណា អាចដណ្តើមយកមកវិញបាន?
លោកអេសាយប្រើសំនួរមួយដើម្បីបង្ហាញពីការលំបាកក្នុងការយករបស់អ្វីពីទាហានខ្លាំងពូកែ
ឬអ្នកចម្បាំងខ្លាំងម្នាក់។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សម្នាក់មិនអាចយករបស់របរពីអ្នកចម្បាំង
ឬជួយសង្គ្រោះអ្នកដែលចាប់បានពីទាហានដ៏សាហាវ»។
រឹបអូស
របស់របរមានតម្លៃដែលយកចេញពីអ្នកចាញ់ក្នុងសមរភូមិ
អស់អ្នកដែលត្រូវចាប់ជាឈ្លើយសឹកនឹងត្រូវខ្ទាំងកៀរយកទៅជាឈ្លើយ
ព្រះអម្ចាស់មានព្រះបន្ទូលថាព្រះអង្គនឹងធ្វើអ្វីដែលមនុស្សមិនអាចធ្វើបាន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងយកអ្នកដែលបានចាប់ពីអ្នកចម្បាំង
ហើយយើងនឹងជួយសង្គ្រោះអ្នកទាំងនោះ»
យើងនឹង...សង្គ្រោះកូនចៅរបស់អ្នក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនដែលនឹងរស់នៅក្រុងស៊ីយ៉ូន
ដូចពួកគេជាកូនចៅរបស់ទីក្រុងនោះ។
Isaiah 49:26
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅស៊ីយ៉ូន ប្រៀបដូចជាមនុស្សម្នាក់។
យើងនឹងឃ្លាលពួកសង្កត់សង្កិនរបស់អ្នកដោយ អោយគេបរិភោគសាច់ខ្លួនឯង
អាចមានន័យថាទី ១)
អ្នកជិះជាន់នឹងឃ្លានខ្លាំងណាស់ពួកគេនឹងស៊ីសាច់របស់មិត្តភក្តិដែលបានស្លាប់ទៅ។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងធ្វើឲ្យអ្នកជិះជាន់របស់អ្នកស៊ីសាច់ខ្លួនឯង» ឬ ទី២)
ព្រះអម្ចាស់មានព្រះបន្ទូលអំពីអ្នកជិះជាន់ដែលកំពុងតែប្រយុទ្ធប្រឆាំង
និងបំផ្លាញខ្លួនឯងដូចជាកំពុងស៊ីផឹក។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងធ្វើឲ្យអ្នកជិះជាន់របស់អ្នកបំផ្លាញខ្លួនឯង
ដូចជាពួកគេកំពុងបរិភោគសាច់របស់ពួកគេ»
ហើយពួកគេនឹងស្រវឹងឈាមរបស់ខ្លួនដូចជាស្រា
អាចមានន័យថាទី ១)
អ្នកជិះជាន់នឹងសម្លាប់ពួកគេយ៉ាងសាហាវ ដោយប្រើកម្លាំងខ្លាំងណាស់រហូតដល់ពួកគេផឹកឈាមមិត្តភក្តិដែលបានស្លាប់ទៅ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកគេនឹងផឹកឈាមរបស់មិត្តភក្តិរបស់ពួកគេ
ឈាមនិងដូចជាមនុស្សទន់ខ្សោយដែលស្រវឹងស្រា»
ព្រះអម្ចាស់មានព្រះបន្ទូលអំពីអ្នកជិះជាន់ដែលកំពុងតែប្រយុទ្ធប្រឆាំង
និងបំផ្លាញខ្លួនឯង ដូចជាកំពុងតែផឹកឈាមរបស់ខ្លួនដែរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកគេនឹងស្រក់ឈាមច្រើនពីមិត្តភក្តិរបស់ពួកគេ។
ឈាមរបស់ខ្លួនហាក់ដូចជាពួកគេស្រវឹងស្រា»

---

50 [1]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «តើសំបុត្រលះលែងដែលយើងឲ្យដល់ម្តាយអ្នក ដើម្បីលែងគ្នានោះនៅឯណា? តើយើងលក់អ្នករាល់គ្នា ដើម្បីសងបំណុលនរណា?
មើល៍! អ្នកត្រូវបានលក់ដោយព្រោះតែអំពើបាបរបស់និងព្រោះការបះបោររបស់អ្នកដែរ ហើយម្តាយអ្នកបានបញ្ជូនទៅឆ្ងាយ។
[2]ហេតុអ្វីបានជាខ្ញុំមកតែគ្មាននរណាម្នាក់នៅទីនេះសោះ? ហេតុអ្វីបានជាខ្ញុំហៅ តែគ្មាននរណាឆ្លើយ? តើដៃរបស់យើងខ្លីពេកដើម្បីលោះអ្នកមែនទេ?
«អ្វីគ្រប់យ៉ាងដែលពួកគេធ្វើគឺអយុត្តិធម៌»
ពួកគេបានដើរតាមផ្លូវកោង វៀច
«ផ្លូវកោងវៀច» តំណាងឲ្យផ្លូវនៃជីវិតដែលពុករលួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនិយាយ និងធ្វើអ្វីដែលមិនស្មោះត្រង់
ពួកគេវង្វេងស្មារតី»។
Isaiah 59:9
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
សេចក្តីយុត្តិធម៌នៅឆ្ងាយពីយើងខ្ញុំ
ត្រង់ពាក្យថា «យើងខ្ញុំ» សំដៅទៅលើលោកអេសាយ និងប្រជាជនអ៊ីស្រាអែល។
«ឆ្ងាយ» តំណាងឲ្យយុត្តិធម៌ដែលបាត់បង់ ហើយពិបាកក្នុងការទទួលបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «យុត្តិធម៌ត្រូវបានបាត់បង់
ហើយពិបាកក្នុងការទទួលបាន»
យើងសង្ឃឹមថានឹងមានពន្លឺ ផ្ទុយទៅវិញ យើងជួបតែភាពងងឹត យើងរង់ចាំថ្ងៃរះ ផ្ទុយទៅវិញ យើងបែរជាដើរក្នុងយប់អន្ធការ
ឃ្លានីមួយៗមានន័យថា ប្រជាជនកំពុងរង់ចាំសេចក្តីល្អរបស់ព្រះជាម្ចាស់
ប៉ុន្តែឃ្លាហាក់ដូចជាព្រះអង្គបានបោះបង់ចោលពួកគេហើយ។
យើងដើរស្ទាបៗ ដូចមនុស្សខ្វាក់ដើរសសៀរ...ក៏ប្រៀបដូចជាមនុស្សស្លាប់ដែរ
ឃ្លានេះមានន័យថា ដោយសារតែព្រះជាម្ចាស់មិនមករកពួកគេ
នោះពួកគេមានអារម្មណ៍អស់សង្ឃឹម មិនបានស្វែងរកផ្លូវត្រឹមត្រូវ
និងគ្មានសង្ឃឹមសម្រាប់អនាគត ដោយគ្មានក្តីសង្ឃឹមសម្រាប់ជីវិតរស់នៅ។
Isaiah 59:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
យើងស្រែកគ្រហឹមដូចខ្លាឃ្មុំ និងថ្ងូរដូចជាសត្វព្រាប
ឃ្លាទាំងនេះសំដៅទៅលើសំឡេងដែលប្រជាជនបានស្រែកព្រោះពួកគេមានទុក្ខព្រួយ
និងយំសោក។
Isaiah 59:12
ព័ត៌មានទូទៅ:
លោកអេសាយបន្តការនិយាយ។
អំពើរំលងរបស់យើងខ្ញុំ បានចម្រើនជាច្រើនឡើង
ត្រង់ពាក្យថា «របស់យើងខ្ញុំ» សំដៅទៅលើអេសាយ និងប្រជាជនអ៊ីស្រាអែល។
ចំពោះព្រះអង្គ
ត្រង់ពាក្យថា «ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។
អំពើបាបរបស់យើងធ្វើជាបន្ទាល់ទាស់នឹងយើង
អេសាយពិពណ៌នាអំពីអំពើបាបជាមនុស្សម្នាក់ដែលចូលទៅចំពោះព្រះជាម្ចាស់
ដើម្បីប្រកាសថាប្រជាជនមានទោស។
អំពើរំលងរបស់យើងខ្ញុំនៅជាប់នឹងយើងជានិច្ច
«ជាប់នឹងយើង» តំណាងឲ្យការយល់ដឹងអំពីពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្រាប់យើងដឹងពីការរំលងរបស់យើង»
Isaiah 59:14
ព័ត៌មានទូទៅ:
លោកអេសាយបន្តការនិយាយ។
យុត្តិធម៌ ត្រឡប់ចេញឆ្ងាយ
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនរុញច្រានយុត្តិធម៌ត្រឡប់មកវិញ»
យុត្តិធម៌...សេចក្តីសុចរិត...សេចក្តីពិត...សេចក្តីពិត...សេចក្តីពិត
ពាក្យទាំងនេះគឺជាគំនិតដែលលោកអេសាយពិពណ៌នាមានសកម្មភាពដូចជាមនុស្ស។
Isaiah 59:16
ព័ត៌មានទូទៅ:
លោកអេសាយបន្តការនិយាយ។
ព្រះអង្គឃើញថា ឥតមាន នរណាម្នាក់អើពើ ហើយព្រះអង្គសោកស្តាយ ដោយពុំឃើញមាននរណាម្នាក់ឈឺឆ្អាល
«ព្រះអម្ចាស់មានព្រះហឫទ័យក្រៃលែងដែលគ្មាននរណាម្នាក់មកជួយអ្នកដែលកំពុងរងទុក្ខ»។
ឬ «ព្រះអម្ចាស់មានការភ្ញាក់ផ្អើលជាខ្លាំង
ដែលគ្មាននរណាម្នាក់មកជួយអ្នកដែលកំពុងរងទុក្ខ» ។
ដូច្នេះ ព្រះហស្តរបស់ព្រះអង្គ បាននាំយកសេចក្តីសង្គ្រោះមកឯទ្រង់
«ព្រះហស្ត» តំណាងឲ្យសមត្ថភាព និងអំណាច។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានប្រើអំណាចផ្ទាល់របស់ព្រះអង្គដើម្បីសង្គ្រោះប្រជាជន»
ដោយអាងលើក្តីសុចរិតរបស់ព្រះអង្គវិញ
«ក្តីសុចរិត» គឺជាគុណសម្បត្តិដែលដើរតួនាទីដូចមនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយព្រះអង្គប្រព្រឹត្តត្រឹមត្រូវដូចដែលព្រះអង្គតែងតែធ្វើ»
Isaiah 59:17
ព្រះអង្គបានពាក់សេចក្តីសុចរិតទុកជាអាវក្រោះព្រះអង្គយកការសង្គ្រោះធ្វើជាមួកដែក ព្រះអង្គយកការសងសឹកធ្វើជាព្រះពស្ត្រ និងសេចក្តីឧឡារឹត ទុកជាព្រះភូសា
«អាវក្រោះ» «មួកដែក» «ព្រះពស្ត្រ» «ព្រះភូសា»
គឺជាសម្លៀកបំពាក់សម្រាប់សង្គ្រាម និងការប្រយុទ្ធគ្នា។
អេសាយពណ៌នាអំពីព្រះអម្ចាស់ដែលដាក់របស់ទាំងនេះដាក់ទោសប្រជារាស្ត្ររបស់ព្រះអង្គ។
ព្រះភូសា
អាវរលុង និងអាវផាយ
ព្រះអង្គបានតបស្នងទៅពួកគេវិញ
អេសាយកំពុងពិពណ៌នាអំពីព្រឹត្តិការណ៍នាពេលអនាគតដូចជាការនេះបានកើតឡើងនៅអតីតកាល។
ឃ្លានេះមានន័យថាវាពិតជានឹងកើតឡើងមែន។
Isaiah 59:19
ព័ត៌មានទូទៅ:
លោកអេសាយបន្តការនិយាយ។
គោរពកោតខ្លាចព្រះនាមព្រះអម្ចាស់
ត្រង់ពាក្យថា «ព្រះនាម» សំដៅទៅលើព្រះកេរ្តិ៍នាម និង
បុគ្គលិកលក្ខណៈរបស់ព្រះអម្ចាស់។របៀបផ្សេងទៀតនៃការបកប្រែ:
«កោតខ្លាចព្រះអម្ចាស់»
ពីទិសខាងលិច...ចាប់តាំងពីថ្ងៃរះ
អេសាយបានបញ្ចូលពាក្យទាំងនេះ
ដើម្បីមានន័យថាមនុស្សនៅគ្រប់ទីកន្លែងនៃពិភពលោក។
ដ្បិតព្រះអង្គនឹងយាងមកដូចទឹកទន្លេត្រូវខ្យល់បក់បោក
ជ្រលងភ្នំតូចចង្អៀតនៅស្រុកយូដាស្ងួតស្ទើរតែពេញមួយឆ្នាំរហូតដល់មានភ្លៀងធ្លាក់មួយរំពេច។
នៅពេលរឿងនោះកើតឡើងមានសម្លេងរំខាន និងខ្យល់យ៉ាងខ្លាំង។
យាងមកដូចទឹកទន្លេត្រូវខ្យល់បក់បោក ហូរមកយ៉ាងខ្លាំង
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដង្ហើមរបស់ព្រះអម្ចាស់យាងមក»
ព្រះអម្ចាស់មានព្រះបន្ទូលថា
នេះអាចត្រូវបានប្រើឡើងវិញ ដូច្នេះនាមអរូបី «ការប្រកាស»
ត្រូវបានបង្ហាញជាកិរិយាស័ព្ទ «ប្រកាស» ឬ «មានព្រះបន្ទូលយ៉ាងឱឡារិក»
សូមបកប្រែពាក្យនេះឲ្យដូចគ្នាទៅនឹងអ្វីដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក
១៤:២១។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះគឺជាអ្វីដែលព្រះអម្ចាស់បានប្រកាស» ឬ
«នេះជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលយ៉ាងឱឡារិក»
Isaiah 59:21
ព្រះបន្ទូលរបស់យើង ហើយពាក្យដែលយើងបានដាក់នៅក្នុងមាត់អ្នក
នេះសំដៅទៅលើការឲ្យនរណាម្នាក់និយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សារដែលខ្ញុំបានអោយអ្នកនិយាយ»

generated on Wed Sep 10 16:16:32 2025

60 [1]ចូរក្រោកឡើង ចូរភ្លឺឡើង ដ្បិតពន្លឺរបស់អ្នកមកដល់ហើយ ហើយសិរីល្អនៃព្រះអម្ចាស់ បានភ្លឺដល់អ្នកដែរ។
[2]ទោះសេចក្តីងងឹតនឹងគ្របលើផែនដី ហើយសេចក្តីសូន្យសុងនឹងគ្របលើអស់ទាំងប្រជាជាតិ ព្រះអម្ចាស់នឹងយាងមកសណ្ឋិត លើអ្នកដែលព្រះអង្គនឹងសំដែង
សិរីរុងរឿងរបស់ព្រះអង្គអោយគេឃើញ។[3]គ្រប់ប្រជាជាតិ នឹងចូលមកក្នុងពន្លឺរបស់អ្នក ហើយស្តេចទាំងឡាយក៏ដើរទៅរកស្មើដែលចាំងចេញពីអ្នកដែរ។
[4]ចូរអ្នកមើលជុំវិញឲ្យឃើញ។ ពួកគេទាំងអស់ជួបជុំគ្នាដើរតម្រង់មករកអ្នក។ ពួកកូនប្រុសៗរបស់អ្នកទាំងអស់នឹងមកពីឆ្ងាយ ហើយនឹងមានគេបីពួកកូនស្រីៗរបស់អ្នកមក
ដែរ។[5]ពេលនោះ អ្នកនឹងឃើញ ហើយមានសេចក្តីរីករាយ នឹងត្រេកអរសប្បាយ ពីព្រោះសេចក្តីបរិបូរណ៌នៃសមុទ្រ
បានបង្ហូរមកឯអ្នកហើយទ្រព្យសម្បត្តិរបស់ប្រជាជាតិនានានឹងមកដល់អ្នក។
[6]សត្វអូដ្ឋទាំងហ្វូងៗនឹងមកពេញទីក្រុង គឺអូដ្ឋរបស់ពួកម៉ាឌាន និងពួកអេផា។ អ្នកស្រុកសេបាទាំងអស់នឹងនាំគ្នាមក ពួកគេយកមាស និងកំញានមកជាមួយផង ហើយ
លើកតម្កើងការអស្ចារ្យ ដែលព្រះអម្ចាស់បានធ្វើ។[7]ហ្វូងសត្វនៅស្រុកកេដារនឹងមកជួបជុំគ្នានៅមុខអ្នក។ អ្នកនឹងទទួលចៀមឈ្មោលពីស្រុកនេបាយ៉ូត សម្រាប់ធ្វើជា
យញ្ញបូជានៅលើ អាសនៈរបស់យើងជាតង្វាយដែលគាប់ចិត្តយើង។ យើងនឹងធ្វើឲ្យដំណាក់ដ៏រុងរឿងរបស់យើង បានថ្កុំថ្កើងឡើង។
[8]តើអ្នកទាំងនោះជានរណា តើនរណាដែលរសាត់ដូចពពក និងដូចព្រាបដែលហើរមករកសំបុកវាវិញ? ។[9]មនុស្សម្នានៅតាមកោះនានានឹងមករកយើង នាវានៅស្រុក
តើស៊ីសនឹងដឹកកូនប្រុសៗ របស់អ្នកពីស្រុកឆ្ងាយវិលត្រឡប់មកវិញ ទាំងនាំមាសប្រាក់របស់ខ្លួនមកជាមួយ ពួកគេនាំគ្នាមកតម្កើងព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះរបស់
អ្នក គឺព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីុស្រាអែល ដែលប្រោសអ្នកឲ្យបានថ្កុំថ្កើង។
[10]កូនរបស់ជនជាតិដ៏ទៃនឹងនាំគ្នាសង់ កំពែងរបស់អ្នកឡើងវិញ ស្តេចរបស់ពួកគេនឹងមកបម្រើអ្នក ដ្បិតកាលពីមុន យើងបានខឹង ហើយវាយអ្នក តែឥឡូវនេះ យើងសម្តែង
ចិត្តអាណិតមេត្តាចំពោះអ្នកវិញ។[11]ទ្វាររបស់អ្នក នៅបើកចំហ ឥតបិទសោះឡើយ ទោះជាយប់ ឬថ្ងៃក្តី ដើម្បីឲ្យភោគទ្រព្យរបស់ប្រជាជាតិទាំងឡាយហូរចូលមក និងឲ្យ
ស្តេចរបស់ពួកគេ មកជាហូរហែដែរ។
[12]ជាការពិតណាស់ ប្រជាជាតិ និងនគរនានា ដែលមិនបម្រើអ្នក មុខជាត្រូវវិនាសមិនខាន ប្រជាជាតិទាំងនោះនឹងត្រូវគេបំផ្លាញ។[13]សេចក្តីលម្អនៃស្រុក
លីបង់និងមានដល់អ្នក គឺជាឈើកកោះ ឈើស្រស់ និងឈើស្រឡៅផង ដើម្បីយកមកធ្វើជាគ្រឿងសង្ហារឹម លំអទីសក្ការៈរបស់យើង។ យើងនឹងធ្វើឲ្យកន្លែងដែលយើង
ស្ថិតនៅនេះ បានប្រកបដោយសិរីរុងរឿង។
[14]ពួកគេនាំគ្នាមកឱនកាយនៅចំពោះមុខអ្នក គឺកូនចៅអ្នកដែលបានប្រមាថអ្នក ពួកគេនឹងមកក្រាបនៅទៀបជើងអ្នក គេនឹងហៅអ្នកថាជាក្រុងរបស់ព្រះអម្ចាស់ ក្រុង
ស៊ីយ៉ូនរបស់ព្រះដ៏វិសុទ្ធ នៃជនជាតិអ៊ីស្រាអែល។
[15]ផ្ទុយទៅវិញ គេបានបោះបង់ចោលអ្នក គេស្អប់អ្នក ហើយគ្មាននរណាដើរកាត់ តែយើងនឹងធ្វើឲ្យអ្នកប្រែទៅជាក្រុងមួយដ៏ថ្លៃថ្នូរ ជាក្រុងដ៏សប្បាយរហូតអស់កល្ប ជា
អង្វែងតរៀងទៅ។[16]ប្រជាជាតិ និងស្តេចទាំងឡាយ នឹងធ្វើជាមេដោះរបស់អ្នក។ អ្នកនឹងទទួលស្គាល់ថា ព្រះសង្គ្រោះរបស់អ្នក គឺព្រះអម្ចាស់ ព្រះដែលលោះអ្នក គឺព្រះរបស់
យ៉ាកុប ជាព្រះប្រកបដោយឫទ្ធិបារមី។
[17]យើងនឹងឲ្យគេយកមាសមកជំនួសលង្ហិន ប្រាក់ជំនួសដែក លង្ហិនជំនួសឈើ ដែកជំនួសថ្ម។ យើងឲ្យសន្តិភាព និងយុត្តិធម៌ គ្រប់គ្រង ហើយកាន់អំណាចលើអ្នក។[18]ក្នុង
ស្រុករបស់អ្នក គេនឹងលែងនិយាយពី អំពើហិង្សាទៀតហើយ ក្នុងទឹកដីរបស់អ្នកក៏លែងមាន ការវិនាសហិនហោចទៀតដែរ។ គេនឹងហៅកំពែងរបស់អ្នកថា សង្គ្រោះ ហៅ
ទ្វាររបស់អ្នកថាទ្វារ សរសើរតម្កើង។
[19]ព្រះអាទិត្យនឹងគ្មានពន្លឺដល់អ្នកនៅពេលថ្ងៃ ហើយក៏មិនមានពន្លឺព្រះច័ន្ទចាំងមកលើអ្នកដែរ ប៉ុន្តែព្រះអម្ចាស់នឹងធ្វើជាពន្លឺបំភ្លឺអ្នករហូតទៅ ហើយជាព្រះអម្ចាស់
នឹងជាសិរីល្អរបស់អ្នកដែរ។[20]ពន្លឺថ្ងៃរបស់អ្នកនឹងមិនលិចបាត់ទេ ពន្លឺព្រះច័ន្ទរបស់អ្នកក៏មិនលិចបាត់ទៅវិញដែរ ដ្បិតព្រះអម្ចាស់នឹងធ្វើជាពន្លឺបំភ្លឺអ្នករហូតទៅ ហើយថ្ងៃ
ដែលអ្នកកាន់ទុក្ខ នឹងត្រូវបញ្ចាប់ដែរ។
[21]ប្រជាជនរបស់អ្នកសុទ្ធតែជាមនុស្សសុចរិត ពួកគេនឹងគ្រប់គ្រងទឹកដីនេះរហូតតទៅ។ ពួកគេប្រៀបដូចជាកូនឈើដែលយើងបានដាំ យើងបង្កើតពួកគេមក ដើម្បីបង្ហាញ
ភាពថ្កុំថ្កើងរបស់យើង។[22]អំបូរដែលតូចជាងគេនឹងកើនចំនួនរាប់ពាន់អ្នក ដែលខ្សោយជាងគេ នឹងប្រែទៅជាប្រជាជាតិមួយដ៏ខ្លាំងពូកែ។ យើងជាព្រះអម្ចាស់ យើងនឹងធ្វើឲ្យ
ការទាំងនេះសម្រេចជារូបរាង យ៉ាងឆាប់ៗ តាមពេលកំណត់។

Isaiah 60:1

ព័ត៌មានទូទៅ:

លោកអេសាយបន្តការនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

ចូរក្រោកឡើង ចូរភ្លឺឡើង ដ្បិតពន្លឺរបស់អ្នកមកដល់ហើយ ហើយសិរីល្អនៃព្រះអម្ចាស់ បានភ្លឺដល់អ្នកដែរ

ឃ្លានេះសំដៅទៅលើសិរីល្អនៃព្រះអម្ចាស់បានធ្វើសម្រាប់ប្រជាជនដែលរស់នៅក្នុងក្រុងយេរូសាឡិមវិញ។ ឥឡូវពួកគេត្រូវបង្ហាញសិរីរុងរឿងតាមរយៈអ្វីដែលពួកគេធ្វើ
និងនិយាយថាមានក្តីសង្ឃឹមនាពេលអនាគត។

Isaiah 60:2

ព័ត៌មានទូទៅ៖

អេសាយកំពុងតែនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែល។

គាត់បន្តពាក្យប្រៀបធៀបអំពី «ពន្លឺ»។ (សូមមើល: 60:1)

ទោះសេចក្តីងងឹតនឹងគ្របលើផែនដី ហើយសេចក្តីសូន្យសុងនឹងគ្របលើអស់ទាំងប្រជាជាតិ

ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយត្រូវបានរួមគ្នាដើម្បីសង្កត់ធ្ងន់លើអត្តន័យ។

ពួកគេសំដៅទៅលើភាពងងឹតខាងវិញ្ញាណ។

ឃ្លានេះមានន័យថាប្រជាជនទាំងអស់នៅលើពិភពលោកនឹងមិនស្គាល់ព្រះអម្ចាស់ ឬរបៀបផ្គាប់ព្រះហឫទ័យរបស់ព្រះអង្គឡើយ។

ឃ្លានេះជាពាក្យប្រៀបធៀបសំរាប់ការជំនុំជំរះរបស់ព្រះជាម្ចាស់។

ព្រះអម្ចាស់នឹងយាងមកសណ្ឋិត

ឃ្លានេះមានន័យថាពន្លឺនៃវត្តមានរបស់ព្រះជាម្ចាស់នឹងលេចមកសំរាប់ប្រជាជនអ៊ីស្រាអែស
ហើយពន្លឺនេះនឹងបង្ហាញផ្លូវដែលពួកគេគួរទៅ។

សិរីរុងរឿងរបស់ព្រះអង្គអោយគេឃើញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ប្រជាជាតិនានានឹងឃើញសិរីរុងរឿងរបស់ព្រះ អង្គ»

Isaiah 60:4

ព័ត៌មានទូទៅ:

នៅត្រង់នេះព្រះអម្ចាស់ចាប់ផ្តើមមានព្រះបន្ទូល។

កូនៗទាំងអស់ជួបជុំគ្នា

«កូនៗ»

សំដៅទៅលើប្រជាជនអ៊ីស្រាអែលដែលនៅសល់នឹងមកជួបជុំគ្នាវិលត្រឡប់មកក្រុងយេរូសាឡិមវិញ។

ដើរតួនាទីឡើងវិញ

ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ពួកគេនឹងបីកូនស្រីរបស់អ្នកនៅក្នុងដៃរបស់ពួកគេ» ឬ

«ពួកគេនឹងបីកូនស្រីរបស់អ្នកលើត្រគាករបស់ពួកគេ»

ពេលនោះ អ្នកនឹងឃើញ ហើយមានសេចក្តីរីករាយ នឹងត្រេកអរសប្បាយ

ឃ្លាទាំងនេះមានអត្ថន័យស្រដៀងគ្នា

ហើយសង្កត់ធ្ងន់ថាពួកគេនឹងរីករាយខ្លាំងណាស់

ដោយសារតែអ្វីដែលនឹងកើតឡើងនៅក្រុងយេរូសាឡិម។

ពីព្រោះសេចក្តីបរិបូរណ៌នៃសមុទ្រ

ឃ្លានេះសំដៅទៅលើទ្រព្យសម្បត្តិ

និងទំនិញដែលនឹងមកក្រុងយេរូសាឡិមតាមការដឹកជញ្ជូនប្រហែលជាមកពីតាមសមុទ្រមេឌីទែរ៉ាណេ។

បានបង្ហូរមកឯអ្នកហើយ

ឃ្លានេះពិពណ៌នាថាភាពបរិបូរណ៌នឹងដូចជាទឹកដែលហូរចេញមក។

Isaiah 60:6

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។

អូដ្ឋ

«អូដ្ឋវ័យជំទង់»

ពួកអេផា...កេដារ...នេបាយ៉ូត

ពាក្យទាំងនេះគឺជាឈ្មោះនៃតំបន់នានានៅក្នុងប្រទេសអារ៉ាប់។

generated on Wed Sep 10 16:16:32 2025

ហ្វូងសត្វនៅស្រុកកេដារនឹងមកជួបជុំគ្នានៅមុខអ្នក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជននៅស្រុកកេដារនឹងប្រមូលហ្វូងចៀមរបស់គេអោយអ្នក»
អ្នកនឹងទទួលចៀមឈ្មោលពីស្រុកនេបាយ៉ូត
នេះសំដៅទៅលើតម្រូវការរបស់ពួកគេសម្រាប់ជាយញ្ញបូជា។
សម្រាប់ធ្វើជាយញ្ញបូជានៅលើ អាសនៈរបស់យើងជាតង្វាយដែលគាប់ចិត្តយើង
«យើងជាព្រះអម្ចាស់នឹងទទួលយកពួកគេនៅលើអាសនៈរបស់យើង»
Isaiah 60:8
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
តើអ្នកទាំងនោះជានរណា តើនរណាដែលរសាត់ដូចពពក និងដូចព្រាបដែលហើរមករកសំបុកវាវិញ?
ព្រះអម្ចាស់ប្រើសំណួរ
និងរូបភាពកំណាព្យដើម្បីទាក់ទាញចំណាប់អារម្មណ៍នៅទីនេះ។
ព្រះអង្គប្រៀបធៀបក្តោងរបស់កប៉ាល់ទៅនឹងពពក និងព្រាប។
ឃ្លានេះក៏ជារូបភាពរបស់ជនជាតិអ៊ីស្រាអែលដែលវិលត្រឡប់មកស្រុកដែលជាកម្មសិទ្ធិរបស់ពួកគេវិញ
របៀបផ្សេងទៀតនៃការបកប្រែ:
«មើលយើងឃើញអ្វីមួយដូចជាពពកហោះឡើងយ៉ាងលឿន
ហើយដូចសត្វព្រាបហើរទៅសំបុកវិញ»។
មនុស្សម្នានៅតាមកោះនានា
ពាក្យនេះសំដៅទៅលើប្រជាជនដែលរស់នៅលើឆ្នេរខ្សាច់
និងពិពណ៌នាអំពីតំបន់ដ៏ខ្សាច់ហាក់ដូចជាមនុស្សស្វែងរក។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជនមកពីតំបន់ឆ្នេរសមុទ្រ»
នាវានៅស្រុកតើស៊ីស
ឃ្លានេះច្រើនតែមានន័យថាកប៉ាល់ធំអ្នកជំនួញសមរម្យសម្រាប់ដំណើរកម្សាន្តវែងឆ្ងាយ
គឺព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល
សូមបកប្រែឃ្លានេះដូចក្នុងជំពូក ១:៤។
ដែលប្រោសអ្នកឲ្យបានថ្កុំថ្កើង
«ព្រះអម្ចាស់បានលើកតម្កើងអ្នករាល់គ្នា ប្រជាជនអ៊ីស្រាអែល»
Isaiah 60:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
នៅបើកចំហ ឥតបិទសោះឡើយ ទោះជាយប់ ឬថ្ងៃក្តី
ត្រង់ពាក្យ «ថ្ងៃ» និង «យប់» ពាក្យទាំងពីរនេះមានន័យថា «គ្រប់ពេល»
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាម្នាក់នឹងបិទទ្វាររបស់អ្នកឡើយ»
ដើម្បីឲ្យភោគទ្រព្យរបស់ប្រជាជាតិទាំងឡាយហូរចូលមក និងឲ្យស្តេចរបស់ពួកគេ មកជាហូរហែដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះប្រជាជននៃប្រជាជាតិនានានឹងនាំយកទ្រព្យសម្បត្តិរបស់ពួកគេជាមួយស្តេចរបស់ពួកគេ
Isaiah 60:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
ប្រជាជាតិទាំងនោះនឹងត្រូវគេបំផ្លាញ
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងកម្ទេចប្រជាជនរបស់ប្រជាជាតិទាំងនោះចោលទាំងស្រុង»
សេចក្តីលម្អនៃស្រុកលីបង់
ឃ្លានេះសំដៅទៅលើស្រុកលីបង់
ដែលល្បីល្បាញដោយសារដើមឈើស្រស់ស្អាតជាពិសេសដើមកកោះ
និងដើមតាត្រៅ។
ការបញ្ជាក់អត្តសញ្ញាណពិតប្រាកដនៃដើមឈើទាំងអស់មិនត្រូវបានគេដឹងនោះទេ។
យើងនឹងធ្វើឲ្យកន្លែងដែលយើង ស្ថិតនៅនេះ
ឃ្លានេះសំដៅទៅលើព្រះដំណាក់របស់ព្រះអម្ចាស់។
Isaiah 60:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
ព្រះដ៏វិសុទ្ធ នៃជនជាតិអ៊ីស្រាអែល
សូមបកប្រែពាក្យពាក្យនេះដូចដែលអ្នកបានបកក្នុងជំពូក ១:៤។
Isaiah 60:15
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
គ្មាននរណាដើរកាត់
«ជាមួយមនុស្សគ្រប់រូបជៀសវាងពីទឹកដីរបស់អ្នក» ឬ
«ជាមួយជនបរទេសទាំងអស់ដែលជៀសវាងដីរបស់អ្នក»
ប្រជាជាតិ និងស្តេចទាំងឡាយ នឹងធ្វើជាមេដោះរបស់អ្នក
ឃ្លានេះសំដៅទៅលើទ្រព្យសម្បត្តិ
និងទ្រព្យសម្បត្តិជាច្រើនដែលនឹងត្រូវបង្ហូរចេញពីប្រជាជាតិបរទេស។
ឃ្លាទាំងពីរនិយាយម្តងទៀតនូវគំនិតដូចគ្នាសម្រាប់ការសង្កត់ធ្ងន់លើអត្តន័យ។
ព្រះដែលលោះអ្នក
សូមបកប្រែពាក្យនេះដូចដែលអ្នកបកនៅក្នុងជំពូក ៤១:១៤។
គឺព្រះរបស់យ៉ាកុប ជាព្រះប្រកបដោយឫទ្ធិបារមី
សូមបកប្រែពាក្យនេះដូចដែលអ្នកបកនៅក្នុងជំពូក ៤៩:២៦។
Isaiah 60:17
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
យើងនឹងឲ្យគេយកមាសមកជំនួសលង្ហិន ប្រាក់ជំនួសដែក
ព្រះអម្ចាស់នឹងប្រគល់សំភារៈសាងសង់ដ៏មានតំលៃជាច្រើនទៀតដល់ពួកគេឥឡូវនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ជំនួសឲ្យឈើយើងនឹងយកលង្ហិន
ហើយជំនួសឲ្យថ្មខ្ញុំនឹងយកដែក»
យើងឲ្យសន្តិភាព និងយុត្តិធម៌ គ្រប់គ្រង ហើយកាន់អំណាចលើអ្នក
ព្រះអម្ចាស់ពិពណ៌នាអំពី «សន្តិភាព» និង «យុត្តិធម៌»
ក្នុងនាមជាអ្នកគ្រប់គ្រងមនុស្ស។ ពាក្យនេះមានន័យថានឹងមានសន្តិភាព
និងយុត្តិធម៌ពេញលេញនៅលើទឹកដីអ៊ីស្រាអែល។
ឃ្លានេះសំដៅទៅលើស្រុករបស់អ្នក គេនឹងលែងនិយាយពី អំពើហិង្សាទៀតហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងលែងមានរឿងអំពីអំពើហឹង្សានៅក្នុងទឹកដីរបស់អ្នកទៀតហើយ»
គេនឹងហៅកំពែងរបស់អ្នកថា សង្គ្រោះ ហៅទ្វាររបស់អ្នកថាទ្វារ សរសើរតម្កើង
ជាវត្ថុខាងសាច់ឈាម មានឈ្មោះជាគុណសម្បត្តិខាងវិញ្ញាណ។
ក្រុងយេរូសាឡិមនឹងក្លាយជាកន្លែងដែលមានសុវត្ថិភាព
ហើយប្រជាជននៅទីនោះនឹងសរសើរតម្កើងព្រះអម្ចាស់។
Isaiah 60:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
ដ្បិតព្រះអម្ចាស់នឹងធ្វើជាពន្លឺបំភ្លឺអ្នករហូតទៅ
ខទាំងពីរនិយាយពីគំនិតដដែលនេះដើម្បីបញ្ជាក់។
ពន្លឺថ្ងៃរបស់អ្នកនឹងមិនលិចបាត់ទេ ពន្លឺព្រះច័ន្ទរបស់អ្នកក៏មិនលិចបាត់ទៅវិញដែរ
ព្រះច័ន្ទនឹងមិនរលាយបាត់ឡើយ។
ឃ្លានេះគឺនិយាយថាបើប្រៀបធៀបនឹងពន្លឺរបស់ព្រះអម្ចាស់ នោះពន្លឺព្រះអាទិត្យ
និងព្រះច័ន្ទនឹងគ្មានពន្លឺទេ។
Isaiah 60:21
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
ពួកគេប្រៀបដូចជាកូនឈើដែលយើងបានដាំ យើងបង្កើតពួកគេមក
ឃ្លាទាំងនេះមានន័យប្រហាក់ប្រហែល
ហើយត្រូវបាននិយាយម្តងទៀតសម្រាប់ការសង្កត់ធ្ងន់លើអត្តន័យ។
(សូមមើលfigs-parallelism)
ពួកគេប្រៀបដូចជាកូនឈើដែលយើងបានដាំ
ព្រះអម្ចាស់ប្រៀបប្រដូចប្រជាជនទៅនឹងពន្លកទើបនឹងលាស់ដែលដុះឡើងដូចគេដាំក្នុងសួនច្បារ។
ព្រះអម្ចាស់បានដាក់ប្រជាជនរបស់ព្រះអង្គនៅក្នុងទឹកដីអ៊ីស្រាអែល។
ឃ្លានេះផ្តល់ក្តីសង្ឃឹមដល់ប្រជាជន។
យើងបង្កើតពួកគេមក
ព្រះអម្ចាស់ប្រៀបធៀបប្រជាជនអ៊ីស្រាអែលទៅនឹងវត្ថុដែលព្រះអង្គបានសូន។
ដើម្បីបង្ហាញភាពថ្កុំថ្កើងរបស់យើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីឲ្យមនុស្សទាំងអស់លើកតម្កើងយើង»
រាប់ពាន់
«១០០០»

generated on Wed Sep 10 16:16:32 2025

61 [1]ព្រះវិញ្ញាណនៃព្រះជាអម្ចាស់ សណ្ឋិតលើខ្ញុំ ដោយព្រោះព្រះអម្ចាស់បានចាក់ប្រេងអភិសេកខ្ញុំ ឲ្យនាំដំណឹងល្អទៅប្រាប់អ្នកដែលត្រូវគេជិះជាន់ ជួយថែទាំអ្នកដែលបាក់ទឹកចិត្ត ប្រកាសប្រាប់ជនជាប់ជាឈ្លើយថា ពួកគេនឹងរួចខ្លួន ហើយបើកឲ្យអ្នកជាប់ឃុំឃាំងរួចពីចំណង។
[2]ព្រះអង្គបានឲ្យខ្ញុំមកប្រកាសពីឆ្នាំដែលព្រះអម្ចាស់សម្តែង ព្រះគុណ និងពីថ្ងៃដែលព្រះជាម្ចាស់របស់យើង នឹងសងសឹក ហើយសម្រាលទុក្ខដល់អ្នកដែលកាន់ទុក្ខ។
[3]ព្រះអង្គបានបញ្ជូនខ្ញុំ ដើម្បីចែកឲ្យដល់អ្នកដែលកាន់ទុក្ខនៅក្រុងស៊ីយ៉ូន បានទទួលមកុដនៅលើក្បាលជំនួសផេះ ប្រេងនៃអំណរ ជំនួសឲ្យការកាន់ទុក្ខ
តាំងគំនិតក្នុងការសសើរ នៅក្នុងទីកន្លែងដែលមានវិញ្ញាណងងឹត ដើម្បីហៅពួកគេថាជាដើមតាត្រៅនៃក្តីសុចរិត ព្រះអម្ចាស់ជាអ្នកដាំ
ហើយព្រះអង្គនឹងត្រូវបានលើកតម្កើង។
[4]ពួកគេនឹងសង់ក្រុង ដែលបាក់បែកពីមុនឡើងវិញ ពួកគេនឹងជួសជុលអ្វីៗដែលខ្ទេចខ្ទីកាលពីបុរាណ ឲ្យមានរូបរាងឡើងវិញ។ ពួកគេជួសជុលក្រុងដែលខ្ទាំងបំផ្លាញ
ចោលជាច្រើន ជំនាន់នោះឡើងវិញ។[5]ជនជាតិដទៃនឹងនាំគ្នាមកហើយ ត្រួតហ្វូងចៀមរបស់អ្នករាល់គ្នា កូនចៅគេនឹងភ្ជួររាស់ដី ហើយដាំទំពាំងបាយជូរឲ្យអ្នករាល់គ្នា។
[6]អ្នករាល់គ្នាត្រូវបានហៅជា បូជាចារ្យរបស់ព្រះអម្ចាស់ គេនឹងហៅអ្នករាល់គ្នាថា អ្នកបម្រើរបស់ព្រះនៃយើង។ អ្នករាល់គ្នានឹងចិញ្ចឹមជីវិតដោយភោគទ្រព្យ របស់ប្រជាជាតិ
ទាំងឡាយ ហើយអ្នកបានអួតដោយសារទ្រព្យរបស់ពួកគេ។[7]ជំនួសអោយភាពអាម៉ាស់ អ្នកនឹងទទួលបានទ្វេដង
ហើយគេមិនបាក់មុខផ្ទុយទៅវិញរីករាយជាមួយនិងការចែកទៅវិញ។ ហើយគេនឹងចែកពីរដងនៃដីរបស់ពួកគេ អ្នករាល់គ្នានឹងមានអំណរ អស់កល្បជានិច្ច។
[8]ដ្បិតយើង ព្រះអម្ចាស់យើងស្រឡាញ់យុត្តិធម៌ ហើយស្អប់ការជំរិតជិះជាន់ និងអំពើឃោរឃៅណាស់។ យើងនឹងសងអ្នករាល់គ្នាវិញយ៉ាងត្រឹមត្រូវ យើងនឹងចងសម្ពន្ធមេត្រី
ដែលនៅស្ថិតស្ថេរ អស់កល្បជានិច្ចជាមួយអ្នករាល់គ្នា។[9]គ្រប់ទាំងប្រជាជាតិនឹងស្គាល់កូនចៅរបស់អ្នករាល់គ្នា ហើយពូជពង្សអ្នករាល់គ្នាក៏នឹងមានឈ្មោះល្បី នៅក្នុង
ចំណោមជាតិសាសន៍នានាដែរ។ អស់អ្នកដែលបានឃើញពួកគេនឹងទទួលស្គាល់ថា ពួកគេជាប្រជាជនដែលព្រះអម្ចាស់បានប្រទានពរ។
[10]ខ្ញុំនឹងមានអំណរយ៉ាងខ្លាំងក្រៃលែង ព្រោះតែព្រះអង្គនៅក្នុងយើង ខ្ញុំរីករាយយ៉ាងអស់ពីចិត្ត ព្រោះតែព្រះរបស់ខ្ញុំ ដ្បិតព្រះអង្គបានសង្គ្រោះខ្ញុំ។ ព្រះអង្គបានយកសេចក្តី
សុចរិត មកពាក់ឲ្យខ្ញុំ ដូចកូនកម្លោះ និងកូនក្រមុំ តែងខ្លួននៅថ្ងៃរៀបមង្គលការ។[11]ដ្បិត ដូចជាផែនដីធ្វើឲ្យមានពន្លកកើតចេញ ហើយដូចគ្រាប់ពូជដុះឡើងនៅក្នុងសួនច្បារ
ជាយ៉ាងណា ដូច្នេះហើយ ព្រះជាម្ចាស់ដ៏ជាព្រះនឹងធ្វើឲ្យសេចក្តីសុចរិត មានការសរសើរតម្កើងផុសចេញពីទឹកដីនេះ នៅចំពោះប្រជាជាតិទាំងមូលយ៉ាងនោះដែរ។

Isaiah 61:1
ព្រះវិញ្ញាណរបស់ព្រះជាអម្ចាស់ សណ្ឋិតលើខ្ញុំ
«ព្រះវិញ្ញាណ» ពាក្យនេះគឺជាព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអម្ចាស់ដែលជំរុញ ឬលើកទឹកចិត្តមនុស្ស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុងជំពូក ១១: ១ ឬក្នុងជំពូក ៤២:១។
ដែលត្រូវគេជិះជាន់
ឃ្លានេះសំដៅទៅលើប្រជាជនក្រីក្រអ្នកដែលមានទុក្ខព្រួយខ្លាំង ឬអ្នកដែលត្រូវគេជិះជាន់ដែលមានបញ្ហា
ដែលពួកគេមិនអាចយកឈ្នះបានដោយខ្លួនឯង។
ពួកគេនឹងរួចខ្លួន ហើយប្រាប់អ្នកជាប់ឃុំឃាំងថាពួកគេនឹងមានសេរីភាព
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
ពួកគេបញ្ជាក់ថាព្រះពិតជានឹងផ្តល់សេរីភាពដល់អ្នកដែលជាប់ជាឈ្លើយ។
Isaiah 61:2
ព័ត៌មានទូទៅ៖
លោកអេសាយបន្តការនិយាយ។
ពីឆ្នាំដែលព្រះអម្ចាស់សម្តែង ព្រះគុណ និងពីថ្ងៃដែលព្រះជាម្ចាស់របស់យើង
ឃ្លាទាំងពីរនេះសំដៅទៅលើរយៈពេលដូចគ្នា។ «ឆ្នាំ» និង «ថ្ងៃ»
ពាក្យទាំងពីរនេះគឺជាឧទាហរណ៍ជាក់លាក់ដែលតំណាងឲ្យទាំងមូល។
ឆ្នាំដែលព្រះអម្ចាស់សម្តែង ព្រះគុណ
«ពេលដែលព្រះអម្ចាស់សំដែងព្រះហឫទ័យសប្បុរសចំពោះប្រជារាស្ត្ររបស់ព្រះអង្គ» (UDB)
Isaiah 61:3
ព័ត៌មានទូទៅ:
លោកអេសាយបន្តការនិយាយ។
ដើម្បីចែក...ដើម្បីចែក
លោកអេសាយនិយាយឡើងវិញអំពីរឿងនេះសម្រាប់ការបញ្ជាក់កាន់តែច្បាស់។
មកុដ
«គ្រឿងប្រដាប់ពាក់ក្បាល» ឬ «ប្រដាប់គ្របក្បាលដ៏ស្រស់ស្អាត»។
ពាក្យនេះគឺជាក្រណាត់វែងដែលរុំជុំវិញក្បាល។
ប្រេងនៃអំណរ...តាំងគំនិតក្នុងការសសើរ
មនុស្សដាក់ប្រេងលើខ្លួនឯង
ហើយស្លៀកពាក់អាវផាយវែងៗស្រស់ស្អាតក្នុងអំឡុងពេលប្រារព្ធបុណ្យ និងរីករាយ។
នៅក្នុងទីកន្លែងដែលមានវិញ្ញាណងងឹត
«ជំនួសឲ្យភាពទុក្ខព្រួយ» ឬ «ជំនួសឲ្យការកាន់ទុក្ខ»
ជាដើមតាត្រៅនៃក្តីសុចរិត ព្រះអម្ចាស់ជាអ្នកដាំ
ឃ្លានេះមានន័យថាព្រះអម្ចាស់បានធ្វើឲ្យប្រជាជនមានកម្លាំង និងរឹងមាំ។
ហើយព្រះអង្គនឹងត្រូវបានលើកតម្កើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីអោយមនុស្សលោកលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ»
Isaiah 61:4
ព័ត៌មានទូទៅ:
លោកអេសាយបន្តនិយាយដោយប្រើភាពស្របគ្នានៅក្នុងជួរនីមួយៗ។
Isaiah 61:6
ព័ត៌មានទូទៅ:
អ្នកបម្រើរបស់ព្រះអម្ចាស់បន្តនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលជាមួយជួរនីមួយៗស្របគ្នា។
អ្នករាល់គ្នាត្រូវបានហៅជា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សនឹងហៅអ្នក»
មួយទ្វេជាពីរ
ពាក្យនេះប្រហែលជាសំដៅទៅលើដីពីរចំណែក។
អ្នករាល់គ្នានឹងទទួលទឹកដីរបស់គេ...អ្នករាល់គ្នានឹង...ទឹកដីរបស់គេ...អ្នករាល់គ្នានឹងទទួល
ឃ្លានេះនៅតែសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ឃ្លានេះអាចត្រូវបានបញ្ជាក់នៅក្នុងមនុស្សទីពីរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនឹងរីករាយចំពោះចំណែករបស់អ្នក...អ្នកនឹង ...ដីរបស់អ្នក ...នឹងក្លាយជាកម្មសិទ្ធិរបស់អ្នក»
Isaiah 61:8
គ្រប់ទាំងប្រជាជាតិនឹងស្គាល់កូនចៅ របស់អ្នករាល់គ្នា ហើយពូជពង្សអ្នករាល់គ្នាក៏នឹងមានឈ្មោះល្បី
នៅក្នុងចំណោមជាតិសាសន៍នានាដែរ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនមកពីប្រទេសដទៃទៀតនឹងស្គាល់កូនចៅរបស់ពួកគេ» (UDB)
នៅក្នុងចំណោមជាតិសាសន៍នានាដែរ
ប្រយោគនេះសន្មតថាជាកិរិយាស័ព្ទដូចគ្នានឹងប្រយោគមុនដែរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«កូនចៅរបស់ពួកគេនឹងត្រូវបានគេស្គាល់ក្នុងចំណោមប្រជាជន»
Isaiah 61:10
ខ្ញុំនឹងមានអំណរយ៉ាងខ្លាំងក្រៃលែង
«ខ្ញុំ»
សំដៅទៅលើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែលនិយាយជាមនុស្សតែម្នាក់ដែលព្រះអម្ចាស់បានស្តារឡើងវិញ
ព្រោះតែព្រះរបស់ខ្ញុំ ដ្បិតព្រះអង្គបានសង្គ្រោះខ្ញុំ ព្រះអង្គបានយកសេចក្តីសុចរិត មកពាក់ឲ្យខ្ញុំ
មនុស្សរបស់ព្រះនិយាយជាមនុស្សតែម្នាក់ដែលទទួលបានសេចក្តីសង្គ្រោះ
និងសេចក្តីសុចរិត ដែលជាមុខមាត់ខុសគ្នាដែលមនុស្សគ្រប់គ្នាអាចមើលឃើញ។
«សម្លៀកបំពាក់» និង «អាវផាយ»
គឺជាសម្លៀកបំពាក់ដែលមនុស្សគ្រប់គ្នាអាចមើលឃើញ។
ដូចកូនកម្លោះ និងកូនក្រមុំ តែងខ្លួននៅថ្ងៃរៀបមង្គលការ
ការប្រៀបធៀបនេះសង្កត់ធ្ងន់ថាអ្នកនិយាយពិតជារីករាយ អរសប្បាយ
ចូលរួមត្រេកអរ។
មកពាក់
សូមបកប្រែពាក្យនេះដូចក្នុងជំពូក ៦១:៣។
ដ្បិត ដីធ្វើឲ្យមានពន្លក និងគ្រាប់ពូជដុះឡើងនៅក្នុងសួនច្បារជាយ៉ាងណា ព្រះជាម្ចាស់នឹងធ្វើឲ្យ

generated on Wed Sep 10 16:16:32 2025

សេចក្តីសុចរិត

ឃ្លានេះកំពុងនិយាយដូចគ្នាតាមពីរវិធី។
ជាការពិតអ្វីដែលព្រះមានបន្ទូលហើយព្រះអង្គនឹងធ្វើប្រាកដជានឹងកើតឡើងជាមិនខាន
បានប្រៀបធៀបទៅនឹងការពិតដែលថាគ្រាប់ពូជដុះបន្ទាប់ពីដាំរួច។

របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាគ្រាប់ពូជដែលបានសាបព្រោះនៅក្នុងសួនច្បារដុះចេញពីដី ហើយដុះឡើង»
ព្រះជាម្ចាស់នឹងធ្វើឲ្យសេចក្តីសុចរិត មានការសរសើរតម្កើងផុសចេញពីទឹកដីនេះ
ឃ្លានេះពិពណ៌នាអំពីគុណធម៌ដែលរីកលូតលាស់ចេញពីគ្រាប់ពូជដូចរុក្ខជាតិ។

---

62 [1]ដ្បិតដើម្បីក្រុងស៊ីយ៉ូន យើងនឹងមិននៅស្ងៀមទេ ដោយយល់ដល់ក្រុងយេរូសាឡឹម យើងនឹងមិននៅសំងំទៀត រហូតក្តីសុចរិតបានចាំងចេញមក ហើយការសង្គ្រោះ
នៃក្រុងនេះ គឺកើតមាន យ៉ាងច្បាស់ដូចភ្លើងចន្លុះ។[2]ប្រជាជាតិទាំងមូលនឹងឃើញ សេចក្តីសុចរិតរបស់អ្នក ហើយស្តេចទាំងអស់នឹងឃើញសិរីរុងរឿងរបស់អ្នកដែរ។
អ្នកនឹងត្រូវហៅតាមឈ្មោះថ្មីថា ព្រះអម្ចាស់បានជ្រើសរើស។
[3]អ្នកនឹងប្រៀបដូចជាភួងជ័យដ៏ល្អប្រណិត នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ និងជាមកុដរាជ្យក្នុងព្រះហស្តរបស់ទ្រង់។[4]នឹងគ្មានការនិយាយទៅអ្នកថា «បោះបង់ចោល»
នឹងគ្មាអ្នកណានិយាយទៅដីរបស់អ្នកថា «ស្ងាត់ជ្រងំ»។ ផ្ទុយទៅវិញ អ្នកនឹងត្រូវហៅអ្នកថា «បណ្តូលចិត្តរបស់បង» ហើយដីរបស់អ្នកថា «រៀបការ» ដ្បិតព្រះអម្ចាស់គាប់
ព្រះហឫទ័យនឹងអ្នក ហើយទឹកដីរបស់អ្នកនឹងបានរៀបមង្គការ។
[5]ពិតណាស់ ដូចកំលោះម្នាក់រៀបការនឹងស្រីក្រមុំ ដូចកូនប្រុសដែលនឹងរៀបមង្គការឲ្យអ្នកដែរ។ ភរិយាថ្មោងថ្មីនិងផ្តល់អំណរសប្បាយឲ្យស្វាមីយ៉ាងណា
ហើយព្រះជាម្ចាស់របស់អ្នកនឹងរីករាយជាមួយអ្នកដែរ។
[6]យើងនឹងដាក់អ្នកយាម នៅតាមកំពែងរបស់អ្នក យេរូសាឡឹមអើយ ទោះបីថ្ងៃក្តីយប់ក្តី អ្នកទាំងនោះមិនត្រូវនៅស្ងៀមឡើយ។ អ្នកត្រូវរំឭកដល់ព្រះអម្ចាស់ មិនត្រូវសម្រាក
ឡើយ។[7]មិនត្រូវអនុញ្ញាតិឲ្យគាត់សម្រាកដរាបណាទាល់តែព្រះអង្គស្តារក្រុងយេរូសាឡិម ហើយធ្វើឲ្យមានកេរ្តិ៍ឈ្មោះល្បីលើផែនដីឡើងវិញ។
[8]ព្រះជាម្ចាស់បានសន្យាយ៉ាងម៉ឺងម៉ាត់ ដោយព្រះហស្តស្តាំដ៏ខ្លាំងក្លារបស់ព្រះអង្គ «យើងមិនប្រគល់ស្រូវរបស់អ្នកទៅឲ្យខ្មាំងសត្រូវទៀតឡើយ សាសន៍ដទៃក៏លែងផឹក ស្រា
ទំពាំងបាយជូរថ្មីដែលអ្នកបាននឿយហត់ នោះទៀតដែរ។[9]ដ្បិតអ្នកដែលច្រូតកាត់ នឹងបានស្រូវបានអង្ករបរិភោគ ហើយនាំគ្នាសរសើរតម្កើងព្រះអម្ចាស់ ហើយអស់អ្នក
ដែលបេះផ្លែទំពាំងបាយជូរ នឹងបានស្រាទំពាំងបាយជូរផឹកនៅ ក្នុងទីធ្លាសក្ការៈរបស់យើង»។
[10]ចូរនាំគ្នាចេញទៅ ចូរនាំគ្នាចេញតាមទ្វារ! ចូររៀបចំផ្លូវសម្រាប់ប្រជារាស្ត្ររបស់យើង! ចូរត្រួសត្រាយ ចូរត្រួសត្រាយផ្លូវ ចូរយកដុំថ្មចេញ! ហើយលើកទង់សញ្ញាមួយឲ្យ
ប្រជាជនទាំងឡាយឃើញ!
[11]មើល៍! ព្រះអម្ចាស់ប្រកាសប្រាប់មនុស្សម្នាដែល នៅទីដាច់ស្រយាលនៃផែនដីដូចតទៅ «ចូរប្រាប់ប្រជាជននៅក្រុងស៊ីយ៉ូនថា មើល៍! ព្រះសង្គ្រោះរបស់អ្នក ទ្រង់យាងមក
ដល់! មើល៍ ព្រះអង្គនាំនូវរង្វាន់ ហើយសំណងរបស់ព្រះអង្គក៏នាំនៅមុខ»។[12]ពួកគេនឹងហៅអ្នកថា «ប្រជារាស្ត្រដ៏វិសុទ្ធ ប្រជារាស្ត្រដែលព្រះអម្ចាស់បានលោះ» ហើយអ្នក
នឹងត្រូវហៅថា «ទីក្រុងសំណប់ចិត្ត ក្រុងដែលគេមិនបោះបង់ចោល»។

Isaiah 62:1

ដ្បិតក្រុងស៊ីយ៉ូនទូលអង្វរ យើងនឹងមិននៅស្ងៀមទេ ដោយប្រយោជន៍ក្រុងយេរូសាឡឹម យើងនឹងមិន
នៅសំងំទៀតទេ

ប្រយោគទាំងពីរនេះមានន័យដូចគ្នា។ ត្រង់ពាក្យថា «ក្រុងស៊ីយ៉ូន» និង
«ក្រុងយេរូសាឡិម»
ពាក្យទាំងពីរនេះតំណាងឲ្យប្រជាជនដែលរស់នៅក្នុងក្រុងយេរូសាឡិម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីជាប្រយោជន៍ដល់ប្រជាជននៅក្រុងយេរូសាឡិមខ្ញុំនឹងមិននៅស្ងៀមឡើយ»
យើងនឹងមិននៅសំងំទៀតទេ
ភាគច្រើនទំនងជា «យើង» សំដៅទៅលើអេសាយ។
រហូតក្តីសុចរិតបានចាំងចេញមក ពីក្រុងនេះដូចថ្ងៃរះ ហើយការសង្គ្រោះកើតមានដល់ក្រុងនេះ យ៉ាង
ច្បាស់ដូចភ្លើងចន្លុះ
ប្រយោគទាំងពីរលើទឹចិត្តដល់ប្រជាជនថាព្រះជាម្ចាស់នឹងយាងមក
ហើយជួយសង្គ្រោះប្រជាជនអ៊ីស្រាអែលនឹងច្បាស់ដូចពន្លឺ។

Isaiah 62:3

អ្នកនឹងប្រៀបដូចជាភួងជ័យដ៏ល្អប្រណិត នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ និងជាមកុដរាជ្យក្នុង
ព្រះហស្តរបស់ទ្រង់

ឃ្លាទាំងនេះមានន័យដូចគ្នា ហើយត្រូវបានដាក់ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។
ពួកគេនិយាយថាក្រុងយេរូសាឡិមនឹងក្លាយជាទីក្រុងរបស់ព្រះរាជាដែលស្ថិតនៅក្រោមអំណាច
និងសិទ្ធិអំណាច «ព្រះហស្ត» របស់ព្រះជាម្ចាស់។
គេនឹងលែងហៅអ្នកថា...គេនឹងហៅអ្នកថា «ព្រលឹងមាសបង»
ពាក្យទាំងនេះមានន័យថារឿងដូចគ្នាត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។
គេនឹងលែងហៅអ្នកថា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សនឹងលែងនិយាយអំពីអ្នកទៀតហើយ»
ក៏នឹងលែងហៅទឹកដីរបស់អ្នកថា ដីដែលគេបោះបង់ចោលដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយមនុស្សនឹងលែងនិយាយអំពីដីរបស់អ្នកទៀតហើយ»
ស្ត្រីដែលជានានឹងប្តីឡើងវិញ
ពាក្យនេះមានន័យថាព្រះអម្ចាស់នឹងស្រឡាញ់ប្រជាជនអ៊ីស្រាអែល
ហើយនឹងនៅជាមួយពួកគេដូចស្វាមីជានិច្ច។

Isaiah 62:5

ដូចកំលោះម្នាក់រៀបការនឹងស្រីក្រមុំ ដូចកូនប្រុស ដែលនឹងរៀបការជាមួយអ្នក
ត្រង់ពាក្យថា «កូនប្រុស» សំដៅទៅលើប្រជាជនអ៊ីស្រាអែល និង «អ្នក»
សំដៅទៅលើស្រុកយូដាទឹកដីអ៊ីស្រាអែល។
ពាក្យនេះមានន័យថាប្រជាជននឹងកាន់កាប់ដីដូចបុរសម្នាក់កាន់កាប់ប្រពន្ធវ័យក្មេងរបស់គេ។
ភរិយាថ្មោងថ្មីនិងផ្តល់អំណរសប្បាយឲ្យស្វាមីយ៉ាងណា អ្នកក៏ផ្តល់អំណរសប្បាយ ដល់ព្រះរបស់អ្នក
យ៉ាងនោះដែរ
ឃ្លានេះសង្កត់ធ្ងន់លើសុភមង្គលរបស់ព្រះអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយប្រជារាស្ត្ររបស់ព្រះអង្គ។

Isaiah 62:6

យើងនឹងដាក់
ត្រង់ពាក្យថា «យើង» ប្រហែលជាសំដៅទៅលើលោកអេសាយ ឬ ព្រះអម្ចាស់។
អ្នកយាម នៅតាមកំពែងរបស់អ្នក
ឃ្លានេះសំដៅទៅលើពួកហោរាមន្ត្រី
ឬពួកទេវតាដែលកំពុងតែអធិស្ឋានជានិច្ចសំរាប់ប្រជាជនក្រុងយេរូសាឡិមដូចជាអ្នកយាមដែលការពារទីក្រ
មើលរបៀបដែលអ្នកបកប្រែពាក្យ «អ្នកយាម» ក្នុងជំពូក ៥២:៧ និងក្នុងជំពូក
៥៦:៩។
ទោះបីថ្ងៃក្តីយប់ក្តី អ្នកទាំងនោះមិនត្រូវនៅស្ងៀមឡើយ
ឃ្លានេះមានន័យថាពួកគេទទូចអង្វរដល់ព្រះអម្ចាស់ជានិច្ច
ឬហៅគ្នាទៅវិញទៅមក។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេកំពុងអធិស្ឋានដល់ព្រះអម្ចាស់ពេញមួយថ្ងៃ»
មិនត្រូវអនុញ្ញតិឲ្យគាត់សំរាក
អំណាចការ
ត្រង់ពាក្យថា «គាត់» សំដៅទៅលើព្រះអម្ចាស់។

Isaiah 62:8

ដោយព្រះហស្តស្តាំដ៏ខ្លាំងក្លារបស់ព្រះអង្គ
ដៃព្រះហស្តស្តាំ និងដៃតំណាងឲ្យអំណាច និងសិទ្ធិអំណាច។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយអំណាច និងសិទ្ធិអំណាចរបស់ព្រះអង្គ»
យើងមិនប្រគល់ស្រូវរបស់អ្នកទៅឲ្យខ្មាំងសត្រូវទៀតឡើយ
ឃ្លានេះមានន័យថាព្រះអម្ចាស់នឹងមិនអនុញ្ញាតឲ្យខ្មាំងសត្រូវច្បាំងឈ្នះជនជាតិអ៊ីស្រាអែលទេ
និងចាប់យកស្រូវរបស់គេទៀតឡើយ។
ប្រហែលជាសត្រូវបានយកគ្រាប់ធញ្ញជាតិពីអតីតកាលទុកជាពន្ធ
ឬដើម្បីចិញ្ចឹមកងទ័ពរបស់ខ្លួន។
យើងមិនប្រគល់ស្រូវរបស់អ្នកទៅឲ្យខ្មាំងសត្រូវទៀតឡើយ សាសន៍ដទៃក៏លែងផឹក ស្រា
ទំពាំងបាយជូរថ្មីដែលអ្នកបាននឿយហត់
ប្រយោគទាំងនេះត្រូវបានកំណត់ជាមួយគ្នាសម្រាប់ការសង្កត់ធ្ងន់ និងការបញ្ចប់។
អស់អ្នកដែលច្រូតកាត់...អស់អ្នកដែលបេះផ្លែទំពាំងបាយ ជូរ
ប្រយោគទាំងនេះត្រូវបានកំណត់ជាមួយគ្នាសម្រាប់ការសង្កត់ធ្ងន់ និងការបញ្ចប់។

Isaiah 62:10

generated on Wed Sep 10 16:16:32 2025

ចូរនាំគ្នាចេញទៅ ចូរនាំគ្នាចេញតាមទ្វារ!
ឃ្លាថា «ចេញតាម» ត្រូវបានធ្វើម្តងទៀតដើម្បីបង្ហាញភាពបន្ទាន់។
ចូរត្រួសត្រាយ ចូរត្រួសត្រាយផ្លូវ
ពាក្យថា «សាងសង់»
ត្រូវបានបញ្ជាក់ម្តងហើយម្តងទៀតដើម្បីបញ្ជាក់ថាព្រះអម្ចាស់ចង់ឲ្យគេរៀបចំផ្លូវជាបន្ទាន់។
«ផ្លូវ» តំណាងឲ្យផ្លូវដែលប្រជាជនអាចវិលត្រឡប់។ ពាក្យនេះស្រដៀងទៅនឹងជំពូក ៤០:៣ និង ៥៧:១៤ ។
ចូរយកដុំថ្មចេញ!
«យកដុំថ្មចេញពីផ្លូវដើម្បីឲ្យវារលូន»។
ថ្មតំណាងឲ្យឧបសគ្គទាំងអស់ក្នុងការធ្វើដំណើរលឿន។
ហើយលើកទង់សញ្ញាមួយឲ្យ ប្រជាជនទាំងឡាយឃើញ!
ទង់សញ្ញាតំណាងឲ្យអ្វីមួយដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នកដទៃ។
នេះមានន័យថាព្រះអម្ចាស់បានហៅមនុស្សពីប្រទេសផ្សេងទៀត
ដើម្បីទទួលយកការជូនដំណឹងនៃស្រុកអ៊ីស្រាអែល
និងដើម្បីមើលឃើញនូវអ្វីដែលព្រះអម្ចាស់បានសម្រេចដូចដែលព្រះអង្គបានមានបន្ទូលអំពីការសង្គ្រោះ។
Isaiah 62:11
មើល!
«សូមកត់សម្គាល់!»
នៅទីដាច់ស្រយាលនៃផែនដី
កន្លែងនៅលើផែនដីដែលនៅឆ្ងាយគឺត្រូវបានគេនិយាយថាជាកន្លែងដែលផែនដីបានបញ្ចប់។
ឃ្លានេះក៏បង្កើតជាការច្របាច់បញ្ចូលគ្នា
និងសំដៅទៅលើគ្រប់ទិសទីនៅចន្លោះចុងបញ្ចប់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅក្នុងជំពូក ៤០:២៧។
របៀបផ្សេងទៀតនៃការបកប្រែ: «កន្លែងឆ្ងាយបំផុតនៃផែនដី» ឬ
«ផែនដីទាំងមូល»
ប្រជាជននៅក្រុងស៊ីយ៉ូន
«ប្រជាជន» តំណាងឲ្យប្រជាជននៅក្រុងយេរូសាឡឹម
មើលហ្ន៎ ព្រះសង្គ្រោះរបស់អ្នក ទ្រង់យាងមកដល់ !មើល៍ ទ្រង់នាំនូវអំណោយ
ហើយសំណងរបស់ព្រះអង្គក៏នាំមុខទៅ
ឃ្លាទាំងនេះតំណាងឲ្យគំនិតដូចគ្នាសម្រាប់ការសង្កត់ធ្ងន់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៤០: ៩។
ឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងសកម្ម «ពួកគេនឹងហៅអ្នក»

---

63 [1]តើនរណាដែលមកពីនៅស្រុកអេដុម ដោយស្លៀកពាក់ដ៏ក្រហមឆ្អិនឆ្អៅពីក្រុង បុសរ៉ា? តើអ្នកនោះជានរណាដែលមានសម្លៀកបំពាក់ជាស្តេច យ៉ាងអង់អាច សម្តែងឫទ្ធិដ៏ខ្លាំងពូកែ? គឺយើងនេះដែលនិយាយដោយក្តីសុចរិត និងពូកែសង្គ្រោះ។[2]ហេតុអ្វីបានជាព្រះភូសារបស់ព្រះអង្គមានពណ៌ក្រហម ហើយដូចជាសម្លៀកបំពាក់របស់អ្នក ដែលបានជាន់និងផ្លែទំពាំងបាយជូរដូច្នេះ?
[3]យើងបានជាន់ផ្លែ ទំពាំងបាយជូរតែម្នាក់ឯង ហើយគ្មាននរណាពីជនជាតិនានាជួយយើងទេ។ យើងបានជាន់ពួកវា ដោយកំហឹងរបស់យើង ដោយជាន់កម្ទេចពួកវា ព្រោះយើងខឹងជាខ្លាំង។ ឈាមរបស់ពួកវាបានខ្ទាតមកលើសម្លៀកបំពាក់របស់យើង ហើយសម្លៀកបំពាក់របស់យើង ប្រឡាក់ពណ៌របស់វា។[4]យើងបានទន្ទឹងរង់ចាំ នឹងដល់ថ្ងៃសងសឹក ហើយឆ្នាំកំណត់ដែលយើងត្រូវប្រោសលោះ ក៏បានមកដល់ដែរ។
[5]យើងមើល៍! ហើយគ្មាននរណាម្នាក់មកជួយយើងទេ។ យើងឆ្ងល់ថាហេតុអីគ្មាននរណាម្នាក់គាំទ្រយើងដូច្នេះ តែយើងដៃរបស់យើងបាននាំជ័យជំនះមកឲ្យយើង ហើយប្រើកំហឹងរបស់យើង ដើម្បីគាំទ្រយើង។[6]យើងជាន់កម្ទេចជាតិសាសន៍ទាំងឡាយ មកពីយើងខឹងយ៉ាងខ្លាំង យើងដាក់ទោសគេយ៉ាងសែនវេទនា យើងនឹងបង្ហូរឈាមរបស់គេនៅលើផែនដី។
[7]ខ្ញុំសូមប្រាប់ពីក្តីសប្បុរសរបស់ព្រះអម្ចាស់ ខ្ញុំសរសើរតម្កើងនៅកិច្ចការដែលព្រះអម្ចាស់បានធ្វើ។ ខ្ញុំសូមថ្លែងអំពីកិច្ចការដ៏ល្អគ្រប់យ៉ាងដែល ព្រះអម្ចាស់ប្រទានមកជនជាតិអ៊ីុស្រាអែល។ ព្រះអង្គបានសម្តែងចំពោះពួកគេ ដោយព្រះហឫទ័យមេត្តា និងព្រះហឫទ័យសប្បុរសផងដែរ ជាមួយសម្ពមេត្រីនៃភាពស្មោះត្រង់ផងដែរ។[8]ដ្បិតព្រះអង្គមានព្រះបន្ទូលថា៖ «ដ្បិតពួកគេពិតជាប្រជារាស្ត្ររបស់យើងមែន ជាអ្នកដែលមិនធ្វើឲ្យយើងខកចិត្ត»។ ព្រះអង្គនិងក្លាយជាព្រះសង្គ្រោះដល់គេ។
[9]តាមរយៈការឈឺចាប់របស់ពួកគេ ព្រះអង្គក៏ឈឺចាប់រួមជាមួយពួកគេដែរ ហើយទេវតារបស់ព្រះជាម្ចាស់នឹងជួយពួកគេ។
នៅក្នុងក្តីស្រឡាញ់ហើយនឹងក្តីមេត្តាព្រះអង្គបានសង្គ្រោះពួកគេ ហើយព្រះអង្គលើកគេឡើង ហើយនាំពួកគេឆ្លងគ្រប់ពេលវេលាទាំងអស់។
[10]ប៉ុន្តែ ពួកគេនាំគ្នាបះបោរ ពួកគេធ្វើឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ខកព្រះហឫទ័យ។ ដូច្នេះ ព្រះអង្គក្លាយជាសត្រូវ ហើយក៏បានប្រហារពួកគេដែរ។
[11]ប្រជារាស្ត្ររបស់ព្រះអង្គបាននឹកដល់ ជំនាន់លោកម៉ូសេ។ ពួកគេនិយាយថា «តើព្រះជាម្ចាស់ដែលបាននាំពួកគេឡើងពីសមុទ្រ ជាមួយមេដឹកនាំរបស់ពួកគេទ្រង់នៅឯណា? តើព្រះជាម្ចាស់ដែលប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យគង់នៅជាមួយពួកគេ ទ្រង់នៅឯណា?
[12]តើព្រះជាម្ចាស់នៅទីណា ហើយតើអ្នកណាបានធ្វើឲ្យសិរីល្អនិងព្រះចេស្តារបស់ព្រះអង្គនៅខាងស្តាំដៃរបស់ម៉ូសេ ហើយធ្វើឲ្យទឹកញែកជាពីរនៅពីមុខគេ
ធ្វើឲ្យឈ្មោះគេល្បីមកដល់រហូតមកនោះ?[13]តើព្រះជាម្ចាស់នៅទីណា ដែលបាននាំគេឆ្លងកាត់ទឹកជ្រៅ? ដូចជាសត្វសេះរត់តាមដីស្មើនោះ ហើយគេមិនដែលជំពប់ឡើយ។
[14]ដូចហ្វូងចៀមចុះទៅសម្រាក នៅតាមជ្រលងភ្នំដែរ ព្រះវិញ្ញាណនៃព្រះអម្ចាស់បានឲ្យគេសម្រាក។ ដូច្នេះអ្នកបានដឹកនាំប្រជាជនរបស់អ្នក ដើម្បីធ្វើឲ្យខ្លួនអ្នកបានការសរសើរ។
[15]សូមទ្រង់ទតមើលពីស្ថានសួគ៌ គឺពីព្រះដំណាក់ដ៏វិសុទ្ធនិងរុងរឿងរបស់ព្រះអង្គ។ តើព្រះហឫទ័យស្រឡាញ់ដ៏ខ្លាំងបំផុត និងភាពអង់អាចរបស់ព្រះអង្គនៅទីណា?
ក្តីអាណិតនិងក្តីមេត្តារបស់ទ្រង់ ហើយកិច្ចការទ្រង់ បាននៅឆ្ងាយពីទូលបង្គំហើយ។[16]ដ្បិតព្រះអង្គពិតជាព្រះបិតារបស់យើង លោកអប្រាហាំពុំដែលបានស្គាល់យើងទេ
ហើយលោកអ៊ីស្រាអែលក៏ពុំដែលបានដឹងពីយើងដែរ គឺព្រះអម្ចាស់ ដែលជាព្រះបិតារបស់យើង។ «ជាព្រះអង្គរំដោះយើង» ដោយព្រះនាមព្រះអង្គតាំងពីដើមរៀងមក។
[17]ព្រះអម្ចាស់អើយ ហេតុអ្វីបានជាព្រះអង្គ បណ្តោយឲ្យយើងវង្វេងឆ្ងាយពីផ្លូវរបស់ព្រះអង្គ ហើយចិត្តរឹងរូស និងមិនព្រមស្តាប់បង្គាប់ព្រះអង្គ? សូមយាងមកវិញ សម្រាប់អ្នកបម្រើ និងជាកុលសម្ព័ន្ធផ្ទាល់របស់ព្រះអង្គផង។
[18]ប្រជារាស្ត្ររបស់ព្រះអង្គ បានគ្រប់គ្រងលើទឹកដីនេះគឺពេលខ្លីណាស់ តែខ្មាំងសត្រូវបានមកជាន់ឈ្លីវិញ។[19]យើងបានក្លាយជាប្រជារាស្ត្រ ដែលមិនធ្លាប់គ្រប់គ្រងចិញ
យើងដូចជាប្រជារាស្ត្រ ដែលមិនត្រូវបានហៅដោយព្រះនាមព្រះអង្គ»។

Isaiah 63:1
តើនរណាដែលមកពីនៅស្រុកអេដុម...បុសរ៉ា
លោកអេសាយនិយាយក្នុងនាមជាអ្នកយាមម្នាក់ដោយប្រើសំណួរ និងទំរង់ចម្លើយ
ដើម្បីបង្ហាញព័ត៌មានអំពីការជំនុំជំរះរបស់ព្រះអម្ចាស់លើអេដុម
ដែលជាសត្រូវរបស់អ៊ីស្រាអែល។
សំនួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាប្រយោគមួយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងជាព្រះអម្ចាស់ដែលមកពីស្រុកអេដុមមានសម្លៀកបំពាក់ពណ៌ក្រហមមកពីបុសរ៉ា
បុសរ៉ា
ពាក្យនេះគឺជាទីក្រុងធំរបស់អេដុម។
គឺយើងនេះ
ត្រង់ពាក្យថា «យើង» សំដៅទៅលើព្រះអម្ចាស់។
ហេតុដូចម្តេចបានជាព្រះភូសារបស់ព្រះអង្គមានពណ៌ក្រហម...ពាំងបាយជូរដូច្នេះ?
សំនួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាឃ្លា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពណ៌ក្រហមនៅលើសម្លៀកបំពាក់របស់អ្នកមើលទៅធ្វើឲ្យអ្នកដូចជាកំពុងជាន់ទំពាំងបាយជូរនៅក្នុងកន្លែ
ជាន់ផ្លែទំពាំងបាយជូរ
កន្លែងដាក់ស្រាគឺជាកន្លែងទាបមួយ
ដែលឆ្លាក់ចេញពីថ្មនៅក្នុងដីដែលកម្មករដើរលើដើមទំពាំងបាយជូរ
ដើម្បីកំទេចផ្លែទំពាំងបាយជូរដោយជើងរបស់ពួកគេ
ដើម្បីយកទឹកទំពាំងបាយជូរចេញ។
Isaiah 63:3
យើងបានជាន់ផ្លែ ទំពាំងបាយជូរតែម្នាក់ឯង

generated on Wed Sep 10 16:16:32 2025

ត្រង់ពាក្យថា «យើង» សំដៅទៅលើព្រះអម្ចាស់។
សកម្មភាពនេះសំដៅទៅលើព្រះអម្ចាស់ដែលបំផ្លាញសត្រូវរបស់ព្រះអង្គ។
យើងបានទន្ទឹងរង់ចាំ នឹងដាក់ទោសពួកគេនៅថ្ងៃនោះ
ត្រង់ពាក្យថា «ថ្ងៃនោះ» សំដៅទៅលើរយៈពេលមួយ។
ដាក់ទោស
ព្រះអម្ចាស់នឹងដាក់ទោសតាមរបៀបដ៏ត្រឹមត្រូវដើម្បីរកយុត្តិធម៌។
ប្រភេទនៃការសងសឹករបស់ព្រះអង្គខុសគ្នាពីការឃ្លាំមើលសងសឹករបស់មនុស្ស។
ឆ្នាំកំណត់ដែលយើងត្រូវលោះ ប្រជារាស្ត្ររបស់យើង
ត្រង់ពាក្យថា «ឆ្នាំ»
សំដៅទៅលើពេលវេលាជាក់លាក់មួយដែលបានកំណត់ដោយព្រះអម្ចាស់សម្រាប់ស្តារអ៊ីស្រាអែលឡើងវិញ។
Isaiah 63:5
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
យើងក៏ប្រើឫទ្ធិបារមីរបស់យើង
ត្រង់ពាក្យថា «ដៃ» តំណាងឲ្យអំណាច។
ហើយប្រើកំហឹងរបស់យើង ដើម្បីគាំទ្រយើង
ឃ្លានេះមានន័យថាព្រះអម្ចាស់ធ្វើឲ្យពួកគេស្រឡាំងកាំង ដោយងឿងឆ្ងល់
និងដាក់ទណ្ឌកម្មយ៉ាងខ្លាំង។
យើងនឹងបង្ហូរឈាមរបស់គេ
ត្រង់ពាក្យថា «ឈាម»
តំណាងឲ្យជីវិតរបស់ខ្មាំងសត្រូវរបស់ព្រះអម្ចាស់ដែលបានបណ្តេញចេញ
ដូច្នេះពួកគេនឹងត្រូវស្លាប់។
Isaiah 63:7
ខ្ញុំសូមប្រាប់
ត្រង់ពាក្យថា «ខ្ញុំ» សំដៅទៅលើលោកអេសាយ។
ព្រះអម្ចាស់ប្រទានមកជនជាតិអ៊ីុស្រាអែល
ត្រង់ពាក្យថា «ជនជាតិអ៊ីុស្រាអែល» សំដៅទៅលើលោកអេសាយ
និងប្រជាជនអ៊ីស្រាអែល។
Isaiah 63:9
តាមរយៈការឈឺចាប់របស់ពួកគេ
«ឆ្លងកាត់ការរងទុក្ខរបស់យើង»។ ត្រង់ពាក្យថា «របស់ពួកគេ»
សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
លោកអេសាយបានរាប់បញ្ចូលខ្លួនគាត់ជាសមាជិករបស់ប្រជាជន។
ព្រះអង្គក៏ឈឺចាប់រួមជាមួយពួកគេដែរ
ត្រង់ពាក្យថា «ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។
ហើយទេវតារបស់ព្រះជាម្ចាស់
ឃ្លានេះគឺជាអ្នកតំណាងម្នាក់ដែលត្រូវបានបញ្ជូនពីវត្តមានរបស់ព្រះ។
ហើយព្រះអង្គលើកគេឡើង ហើយនាំពួកគេ
ឃ្លានេះសំដៅទៅលើពេលដែលព្រះជាម្ចាស់ការពារ
និងសង្គ្រោះប្រជាជនអ៊ីស្រាអែលពីជនជាតិអេស៊ីបជាច្រើនឆ្នាំមុន។
អត្ថន័យពេញលេញនៃប្រយោគនេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
Isaiah 63:10
ប៉ុន្តែ ពួកគេនាំគ្នាបះបោរ
«ប៉ុន្តែ ពួកយើងនាំគ្នាបះបោរ» ត្រង់ពាក្យថា «ពួកគេ»
សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
អេសាយបានរាប់បញ្ចូលខ្លួនគាត់ជាសមាជិករបស់ប្រជាជន។
ព្រះវិញ្ញាណដ៏វិសុទ្ធ
«ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអម្ចាស់»
Isaiah 63:11
ពួកគេនិយាយថា
«ពួកយើងនិយាយ»។ ត្រង់ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
អេសាយបានរាប់បញ្ចូលខ្លួនគាត់ជាសមាជិករបស់ប្រជាជន។
ព្រះអង្គដែលបាននាំពួកគេឡើងពីសមុទ្រ
រឿងរ៉ាវរបស់ព្រះអម្ចាស់បានញែកទឹកសមុទ្រ
សមុទ្រអព្ភូតហេតុយ៉ាងអស្ចារ្យដើម្បីឲ្យប្រជាជនអ៊ីស្រាអែលអាចឆ្លងផុត
និងរត់គេចពីជនជាតិអេស៊ីប។
ជាមួយមេដឹកនាំរបស់ពួកគេ
ពេលខ្លះអ្នកដឹកនាំត្រូវបានគេហៅថា «អ្នកគង្វាល»។
របៀបផ្សេងទៀតនៃការបកប្រែ: «មេដឹកនាំរបស់ប្រជាជនរបស់គេ»

Isaiah 63:12
ព័ត៌មានទូទៅ៖
ប្រជាជនអ៊ីស្រាអែលបន្តការនិយាយ។
ហើយតើអ្នកណាបានធ្វើឲ្យសិរីល្អនិងព្រះចេស្តារបស់ព្រះអង្គនៅខាងស្តាំដៃរបស់ម៉ូសេ
ត្រង់ពាក្យថា «ស្តាំដៃ» តំណាងអំណាចរបស់ព្រះអម្ចាស់តាមរយៈលោកម៉ូសេ។
ឃ្លានេះមានន័យថាពាក្យនេះជាព្រះចេស្តារបស់ព្រះដែលបានជួយឲ្យលោកម៉ូសេញែកទឹកសមុទ្រដើមត្រែង
ដូចជាសត្វសេះរត់តាមដីស្មើនោះ ហើយគេមិនដែលជំពប់ឡើយ
ឃ្លានេះមានន័យថាប្រជាជនអ៊ីស្រាអែលប្រាកដជាមានជំហររឹងមាំដូចសេះនៅតាមទីវាលក្នុងការធ្វើដំណើរ
Isaiah 63:14
ប្រជាជនអ៊ីស្រាអែលបន្តការនិយាយ។
ដូចហ្វូងចៀមចុះទៅសម្រាក នៅតាមជ្រលងភ្នំដែរ...សម្រាក
រូបភាពនេះបង្ហាញពីសត្វគោក្របីចូលទៅក្នុងជ្រលងភ្នំដែលមានស្មៅខៀវខ្ចី និងទឹក
ហើយបញ្ជាក់ថាព្រះបានដឹកនាំជនជាតិអ៊ីស្រាអែល ព្រមទាំងថែរក្សាពួកគេ។
ដើម្បីធ្វើឲ្យព្រះអង្គបានការសរសើរ
ត្រង់ពាក្យថា «ព្រះអង្គបានការសរសើរ» សំដៅទៅលើកិត្តិយស
និងកេរ្តិ៍ឈ្មោះរបស់មនុស្សម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីធ្វើឲ្យប្រាកដថាអ្នកមានកេរ្តិ៍ឈ្មោះ និងកិត្តិយសសម្រាប់ខ្លួនអ្នក»
Isaiah 63:15
ព័ត៌មានទូទៅ:
ប្រជាជនអ៊ីស្រាអែលបន្តការនិយាយ។
តើព្រះហឫទ័យស្រឡាញ់ដ៏ខ្លាំងបំផុត និងភាពអង់អាចរបស់ព្រះអង្គ?
អ្នកនិពន្ធប្រើសំណួរដើម្បីបង្ហាញពីអារម្មណ៍
និងការយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅ
ពីព្រោះឃ្លានេះហាក់ដូចជាព្រះមិនជួយពួកគេទេ។
សំណួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាឃ្លា។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមិនឃើញភាពខ្នះខ្នែង និងសកម្មភាពដ៏អស្ចារ្យរបស់អ្នកទេ!»
ព្រះអង្គ លែងអាណិតមេត្តា លែងមានដល់ទូលបង្គំទៀតហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករក្សាការអាណិតអាសូរ និងអាណិតអាសូរពីយើង»
លោកអប្រាហាំពុំដែលបានស្គាល់យើងទេ អ៊ីស្រាអែលក៏ពុំដែលបានដឹងពីយើងដែរ
បុព្វបុរសនៃជនជាតិអ៊ីស្រាអែលទាំងនេះមិនអាចកំណត់អត្តសញ្ញាណកូនចៅរបស់ពួកគេបានទេ
ពីព្រោះពួកគេបានផ្លាស់ប្តូរច្រើន។ «អ័ប្រាហាំ» និង «អ៊ីស្រាអែល»
តំណាងឲ្យចម្ងាយនៃអតីតកាល។
Isaiah 63:17
ព័ត៌មានទូទៅ:
ប្រជាជនអ៊ីស្រាអែលបន្តការនិយាយ។
ព្រះអម្ចាស់អើយ ហេតុអ្វីបានជាព្រះអង្គ បណ្តោយឲ្យយើងវង្វេងឆ្ងាយពីផ្លូវរបស់ព្រះអង្គ ហើយចិត្ត
រឹងរូស និងមិនព្រមស្តាប់បង្គាប់ព្រះអង្គ?
ឃ្លានេះអ្នកនិពន្ធប្រើសំណួរដើម្បីបង្ហាញពីការតូញតែ្អររបស់ប្រជាជនចំពោះព្រះជាម្ចាស់។
សំណួរនេះអាចត្រូវបានបកប្រែជាឃ្លា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឱព្រះអម្ចាស់អើយ ព្រះអង្គបានធ្វើឲ្យយើងខ្ញុំវង្វេងចេញពីមាគ៌ារបស់ព្រះអង្គ
ហើយក្លាយជារឹងរូសដើម្បីកុំឲ្យយើងខ្ញុំស្តាប់បង្គាប់ព្រះអង្គ»។
ហេតុអ្វីបានជាព្រះអង្គ បណ្តោយឲ្យយើងវង្វេងឆ្ងាយពីផ្លូវរបស់ព្រះអង្គ
កុំធ្វើអ្វីដែលព្រះអម្ចាស់បង្គាប់ឲ្យអ្នកនោះធ្វើដូចជាមនុស្សវង្វេងចេញពីមាគ៌ាត្រឹមត្រូវ។
របៀបផ្សេងទៀតនៃការបកប្រែ: «ហេតុអ្វីបានជាអ្នកធ្វើខុស»
ហើយចិត្តរឹងរូស
ឃ្លានេះមានន័យថាត្រូវចេះទប់ទល់នឹងការបង្រៀនរបស់ព្រះអម្ចាស់ដោយបដិសេធមិនស្តាប់
និងស្តាប់តាម។ «ចិត្ត» តំណាងឲ្យចំណង់អារម្មណ៍ និងបំណងប្រាថ្នារបស់ពួកគេ។
Isaiah 63:18
ព័ត៌មានទូទៅ:
ប្រជាជនអ៊ីស្រាអែលបន្តការនិយាយ។
ដែលមិនត្រូវបានហៅដោយព្រះនាមព្រះអង្គ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ «ព្រះនាម»
សំដៅទៅលើទំនាក់ទំនងគ្រួសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលមិនដែលជាកម្មសិទ្ធិរបស់ក្រុមគ្រួសាររបស់អ្នក»
យើងបានក្លាយជា...ហៅដោយព្រះនាមព្រះអង្គ
កំណែបកប្រែសម័យទំនើបខ្លះបកស្រាយអត្ថបទនេះខុសគ្នា៖
«យើងដូចជាមនុស្សដែលអ្នកមិនបានគ្រប់គ្រងដូចជាអ្នកដែលមិនបានហៅដោយព្រះនាមព្រះអង្គ»។

generated on Wed Sep 10 16:16:32 2025

64 [1]«អូ ប្រសិនបើស្ថានសួគ៌ បានហែកជាពីរហើយធ្លាក់ចុះមក! នោះភ្នំនឹងត្រូវកក្រើករំពើកនៅក្នុងព្រះវត្តមានរបស់ព្រះអង្គ[2]គឺដូចជាភ្លើងបានឆេះគុម្ពព្រៃ
ឬភ្លើងក្តៅដែលធ្វើឲ្យទឹកពុះបាន។ ព្រះនាមរបស់ព្រះអង្គនឹងបានស្គាល់ តាមរយៈសត្រូវរបស់ព្រះអង្គដែរ ហើយប្រជាជាតិទាំងមូលនឹងភ័យខ្លាច
នៅក្នុងព្រះវត្តមានព្រះអង្គផង!
[3]តាំងពីមុនមក នៅពេលដែលព្រះអង្គបានធ្វើការអស្ចារ្យ ដែលយើងពុំដែលរំពឹងទុកនោះ ព្រះអង្គបានយាងមកចុះមក ហើយភ្នំបានក្រាបចុះនៅចំពោះព្រះវត្តមានទ្រង់។
[4]ចាប់តាំងពីបុរាណមកគ្មាន អ្នកណាឮ រឺយល់ និងបានឃើញព្រះអង្គដូចជាអ្នកឡើយ។ អ្នកណាដែលប្រព្រឹត្តអំពើល្អ និងរង់ចាំព្រះអង្គវិញ។
[5]ព្រះអង្គតែងតែប្រោសឲ្យអ្នកនោះមានចិត្តរីករាយ និងធ្វើការត្រឹមត្រូវ គឺដល់ពួកអ្នកនឹកចាំពីទ្រង់ក្នុងគ្រប់ផ្លូវ ទាំងស្តាប់បង្គាប់។ ព្រះអង្គទ្រង់
ព្រះពិរោធនៅពេលដែលយើងធ្វើបាប។ នៅក្នុងមាគ៌ារបស់ទ្រង់ យើងខ្ញុំតែងតែមានសុវត្ថិភាព។
[6]ដ្បិតយើងទាំងអស់គ្នាក្លាយជាមនុស្សមិនស្អាត ហើយអំពើសុចរិតដែលយើងបានធ្វើ ដូចជាក្រណាត់ទ្រាប់ឈាម។ យើងទាំងអស់គ្នាប្រៀបបាននឹងស្លឹកឈើក្រៀម ហើយ
អំពើទុច្ចរិតរបស់យើងនឹងបក់បោកទៅដូចស្លឹកឈើទៅតាមខ្យល់។[7]គ្មាននរណាទូលអង្វររកព្រះនាមព្រះអង្គទេ គ្មាននរណាម្នាក់ភ្ញាក់រឭក ហើយជំពាក់ចិត្តនឹងព្រះអង្គ
ឡើយ។ ដ្បិតព្រះអង្គបានលាក់ព្រះភ័ក្ត្រនឹងយើង ហើយធ្វើឲ្យជំរុះចិត្តអំពើទុច្ចរិតរបស់យើងចេញផងដែរ។
[8]ព្រះអម្ចាស់អើយ ព្រះអង្គជាព្រះបិតារបស់យើង។ យើងគឺជាដីឥដ្ឋដែលនៅក្នុងព្រះហស្តទ្រង់ ដែលព្រះអង្គជាជាងស្មូន។[9]សូមកុំព្រះពិរោធ ព្រះអម្ចាស់អើយ សូមកុំចងចាំ
អំពើបាបរបស់យើងឡើយ។ សូមទតមើលចុះ យើងទាំងអស់គ្នា សុទ្ធតែជាប្រជារាស្ត្ររបស់ព្រះអង្គ។
[10]ក្រុងដ៏វិសុទ្ធរបស់ព្រះអង្គ ក្លាយទៅជាទីរហោស្ថាន ស៊ីយ៉ូនក៏ក្លាយទីរហោស្ថានដែរ យេរូសាឡិមក្លាយទៅជាទីចោលស្ងាត់។[11]ព្រះវិហារបរិសុទ្ធដ៏ល្អ របស់យើង ជាកន្លែង
ដែលដូនតាយើងតែងតែសរសើរតម្កើងព្រះនាមរបស់ព្រះអង្គ បានត្រូវភ្លើងឆេះ ហើយរបស់ទាំងអស់ក៏ត្រូវវិនាសដែរ។[12]តើព្រះអង្គនៅស្ងៀម
ដល់ពេលណាទៀតព្រះអម្ចាស់? តើព្រះអង្គនៅស្ងៀមរហូត ទុកឲ្យយើងអាម៉ាស់មុខឬ?»

Isaiah 64:1

ព័ត៌មានទូទៅ:

ប្រជាជនអ៊ីស្រាអែលបន្តការនិយាយទៅកាន់លោកអេសាយ។ (សូមមើល: ៦៣:១១)

អូ ប្រសិនបើ

អេសាយបង្ហាញពីបំណងប្រាថ្នានេះចំពោះវត្តមានរបស់ព្រះអម្ចាស់នៅក្នុងប្រវត្តិសាស្ត្រអតីតកាលរបស់ពួកគេ។ ការប្រើប្រាស់ពាក្យនេះបង្ហាញពីការអំពាវនាវយ៉ាងខ្លាំងចំពោះព្រះអម្ចាស់ដើម្បីធ្វើសកម្មភាព។

ប្រសិនបើស្ថានសួគ៌បានហែកជាពីរ

ប្រសិនបើព្រះអម្ចាស់បានបង្ហាញព្រះវត្តមានយ៉ាងខ្លាំងដោយបើចំហរមេឃ។ ពាក្យថា «ហែកជាពីរ» ដំដៅទៅលើលើការកាត់ក្រណាត់មួយឡែក។

នោះភ្នំនឹងត្រូវកក្រើករំពើក

ភ្នំទាំងប៉ុន្មាននឹងរញ្ជួយនៅពេលមានរញ្ជួយផែនដី។

គឺដូចជាភ្លើងបានឆេះគុម្ពព្រៃ ឬភ្លើងក្តៅដែលធ្វើឲ្យទឹកពុះបាន

ឃ្លានេះអាចសង្កត់ធ្ងន់ថាតើវត្តមានរបស់ព្រះងាយនឹងធ្វើឲ្យភ្នំ និងប្រជាជនភ័យញាប់ញ័រ។

Isaiah 64:3

ព័ត៌មានទូទៅ៖

ប្រជាជនអ៊ីស្រាអែលបន្តការនិយាយទៅកាន់ព្រះអម្ចាស់។

រឺយល់ និងបានឃើញ

«ឃើញ» សំដៅទៅលើការមើលឃើញអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយក៏គ្មានអ្នកណាម្នាក់បានឃើញដែរ»

Isaiah 64:5

ព័ត៌មានទូទៅ៖

ប្រជាជនអ៊ីស្រាអែលបន្តការនិយាយទៅកាន់ព្រះអម្ចាស់។

គឺដល់ពួកអ្នកនឹកចាំពី

ពាក្យប្រៀបធៀបនេះមានន័យថា «ចងចាំ»។

Isaiah 64:6

ព័ត៌មានទូទៅ៖

ប្រជាជនអ៊ីស្រាអែលបន្តការនិយាយទៅកាន់ព្រះអម្ចាស់។

ហើយអំពើសុចរិតដែលយើងបានធ្វើ ដូចជាក្រណាត់ទ្រាប់ឈាម

«ក្រណាត់ទ្រាប់ឈាម» គឺជាក្រណាត់ដែលស្ត្រីប្រើក្នុងកំឡុងពេលមួយខែ នៅពេលដែលនាងហូរឈាមចេញពីស្បូន។

ឃ្លានេះមានន័យថារាល់ការប៉ុនប៉ងរបស់ពួកគេដើម្បីផ្គាប់ព្រះហឫទ័យព្រះ។

ការកាត់ទោសនេះមានន័យថាគួរឲ្យភ្ញាក់ផ្អើល។

យើងទាំងអស់គ្នាប្រៀបបាននឹងស្លឹកឈើក្រៀម

អេសាយប្រៀបធៀបប្រជាជនអ៊ីស្រាអែលទៅនឹងស្លឹកដែលស្ងួតពេលស្លាប់។

ហើយអំពើទុច្ចរិតរបស់យើងនឹងបក់បោកទៅដូចស្លឹកឈើទៅតាមខ្យល់

ឃ្លានេះមានន័យថា

បាបរបស់ពួកគេក្នុងនាមជាសហគមន៍គឺជាហេតុផលសម្រាប់ការបរាជ័យរបស់ពួកគេ។

លោកអេសាយប្រៀបធៀបភាពទុច្ចរិតទៅនឹងខ្យល់ជាកម្លាំងនៃការរងទុក្ខរបស់ពួកគេចំពោះព្រះអម្ចាស់។

[illegible] នឹងការឧទានយ៉ាងខ្លាំង។

ឃ្លានេះមានន័យថាព្រះជាម្ចាស់បានលះបង់ប្រជាជនរបស់ព្រះអង្គ ហើយឲ្យពួកគេរងទុក្ខ។

Isaiah 64:8

ព័ត៌មានទូទៅ:

ប្រជាជនអ៊ីស្រាអែលបន្តការនិយាយទៅកាន់ព្រះអម្ចាស់។

យើងគឺជាដីឥដ្ឋដែលនៅក្នុងព្រះហស្តទ្រង់ ដែលព្រះអង្គជាជាងស្មូន

ឃ្លានេះមានន័យថាព្រះបានបង្កើតប្រជាជនអ៊ីស្រាអែល។

ចងចាំ

ពាក្យនេះសំដៅទៅលើការចងចាំពីអតីតកាល។

សូមទតមើលចុះ យើងទាំងអស់គ្នា

លោកអេសាយទូលសូមឲ្យព្រះអម្ចាស់យកចិត្តទុកដាក់ចំពោះស្ថានភាពរបស់ពួកគេ។

Isaiah 64:10

ព័ត៌មានទូទៅ:

ប្រជាជនអ៊ីស្រាអែលបន្តការនិយាយទៅកាន់ព្រះអម្ចាស់។

ក្រុងដ៏វិសុទ្ធរបស់ព្រះអង្គ ក្លាយទៅជាទីរហោស្ថាន

ឃ្លានេះសង្កត់ធ្ងន់ថាទីក្រុងនានាត្រូវបានបំផ្លាញ ហើយគ្មាននរណាម្នាក់រស់នៅទីនោះទេ។

ព្រះវិហារបរិសុទ្ធដ៏ល្អ របស់យើង ជាកន្លែងដែលដូនតាយើងតែងតែសរសើរតម្កើងព្រះនាមរបស់ព្រះអង្គ បានត្រូវភ្លើងឆេះ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្មាំងសត្រូវបានបំផ្លាញព្រះវិហារដ៏បរិសុទ្ធ និងល្អរបស់យើងជាកន្លែងដែលបុព្វបុរសរបស់យើងសរសើរអ្នកដោយសារភ្លើង»

ព្រះអម្ចាស់អើយ តើព្រះអង្គនៅស្ងៀមដល់ពេលណាទៀតព្រះអម្ចាស់?តើព្រះអង្គនៅស្ងៀមរហូត ទុកឲ្យយើងអាម៉ាស់មុខឬ?»

ពួកគេប្រើសំណួរដើម្បីបង្ហាញពីការខកចិត្តរបស់ពួកគេ ពីព្រោះព្រះជាម្ចាស់មិនទាន់បានយាងមកជួយពួកគេទេ។

របៀបផ្សេងទៀតនៃការបកប្រែ: «ឱព្រះអម្ចាស់អើយ សូមកុំលាក់ព្រះកាយឡើយ! សូមកុំនៅស្ងៀម ហើយបន្តធ្វើឲ្យយើងអាម៉ាស់មុខ!»

---

65 [1]«យើងបានរួចរាល់ដើម្បីដោះស្រាយ ជាមួយអស់អ្នកដែលមិនបានទូលសូម ហើយយើងក៏នឹងបានរកឃើញ ដោយអ្នកដែលមិនបានស្វែងរកយើងដែរ។
យើងបាននិយាយថា «យើងនៅទីនេះ! យើងនៅទីនេះ!» សម្រាប់ប្រជាជាតិដែលមិនបានស្រែករកព្រះនាមយើង។[2]យើងបានលូកដៃរបស់យើងទៅរកមនុស្សរឹង
ចចេស ជាអ្នកដែលដើរតាមផ្លូវមិនល្អ ក៏ជាអ្នកដែលដើរតាមគំនិតហើយនិងផ្លូវខ្លួនឯងផង!
[3]ពួកគេជាមនុស្សធ្វើឲ្យយើងទាស់ចិត្តជានិច្ច ដោយការអាក្រក់នៅមុខយើង ពួកគេធ្វើយញ្ញបូជានៅក្នុងសួនឧទ្យាន ហើយ អុជធូបបន់ព្រះក្លែងក្លាយ នៅលើអាសនៈធ្វើពី
ឥដ្ឋ។[4]ពួកគេអង្គុយនៅកណ្តាលផ្នូរខ្មោច ទាំងបើកភ្នែកពេញមួយយប់ គេបរិភោគសាច់ជ្រូក និងសំឡតួរខ្ពើមនៅក្នុងចានរបស់គេ។
[5]ពួកគេនិយាយថា «ចូរចៀសចេញ កុំចូលមកជិតខ្ញុំអី ព្រោះខ្ញុំបរិសុទ្ធជាងអ្នក»។ ការទាំងនេះគឺជាផ្សែងហុយដល់ច្រមុះយើង ក៏ជាភ្លើងដែលឆេះពេញមួយថ្ងៃផង។

generated on Wed Sep 10 16:16:32 2025

[6]ចូរមើល៍! មានសេចក្ដីចែងទុកមកនៅចំពោះយើងថា៖ យើងនឹងមិននៅស្ងៀមឡើយ ហើយយើងនឹងសងសឹកនឹងគេវិញ
យើងនឹងឲ្យគេសងទាំងអស់នៅពេលគេចាស់ផង[7]គឺសរុបទាំងអំពើបាបរបស់គេនឹងបាបរបស់ឪពុកគេផង» នេះជាពាក្យរបស់ព្រះអម្ចាស់
«យើងនឹងសងសឹកគេពីកាដុតកំញានដែលនៅលើភ្នំ ហើយធ្វើឲ្យមានផ្សែងនៅតាមជ្រលោងភ្នំដែរ។ យើងនឹងធ្វើដូច្នេះក្នុងការវាស់ពីផ្លូវប្រព្រឹត្តរបស់គេ
ក្នុងពេលគេចាស់ផង»។
[8]នេះគឺជាអ្វីព្រះអម្ចាស់មានព្រះបន្ទូល «នៅពេលទំពាំងបាយជូរមានផ្លែចង្កោម នោះមានម្នាក់និយាយថា កុំបំផ្លាញវាអី ព្រោះផ្លែល្អនៅក្នុងនោះដែរ
ការនេះដែលយើងនឹងធ្វើដាក់ពួកអ្នកបម្រើរបស់យើង យើងនឹងមិនបំផ្លាញពួកគេទាំងអស់ឡើយ។
[9]យើងនឹងធ្វើឲ្យមានពូជពង្សមួយ កើតចេញពីកូនចៅរបស់យ៉ាកុប ហើយឲ្យម្នាក់ដែលគ្រប់គ្រងលើ ភ្នំរបស់យើង កើតចេញពីកូនចៅរបស់យូដា។ អស់អ្នកដែលយើង
ជ្រើសរើស នឹងគ្រប់គ្រងលើទឹកដីនេះ អ្នកបម្រើរបស់យើងក៏នឹងរស់នៅទីនេះដែរ។[10]សារ៉ូននឹងក្លាយជាវាលស្មៅសម្រាប់ហ្វូងចៀម ហើយជ្រលងភ្នំអាកោរជាជម្រកសម្រាប់
ហ្វូងគោ គឺសម្រាប់ប្រជារាស្ត្រយើងដែលស្វែងរកយើង។
[11]ប៉ុន្តែ អ្នករាល់គ្នាដែលបានបោះបង់ចោលព្រះអម្ចាស់ អ្នករាល់គ្នាដែលបំភ្លេចភ្នំដ៏វិសុទ្ធរបស់យើង ហើយបែរជារៀបចំតុសែនព្រះមានលាភ
ហើយក៏ច្រួចស្រាសែនព្រះជោគវាសនាផង។
[12]យើងនឹងប្រហារអ្នកឲ្យស្លាប់ដោយមុខដាវ ហើយអ្នករាល់គ្នានឹងលុតជង្គង់ចុះដើម្បីឲ្យគេសម្លាប់ ព្រោះយើងបានហៅ តែអ្នកមិនឆ្លើយទេ ពេលយើងបាននិយាយ អ្នករាល់
គ្នាមិនស្តាប់ទេ។ ប៉ុន្តែ អ្នករាល់គ្នាបានប្រព្រឹត្តអំពើអាក្រក់នៅមុខយើង ហើយជាអំពើដែលយើងមិនពេញចិត្ត»។
[13]ហេតុនេះហើយ បានជាព្រះជាអម្ចាស់មានព្រះបន្ទូលថា «មើល អ្នកបម្រើរបស់យើងនឹងមានអាហារបរិភោគ តែអ្នករាល់គ្នានឹងឃ្លាន មើល អ្នកបម្រើរបស់យើងនឹងមាន
ទឹកផឹក តែអ្នករាល់គ្នានឹងស្រេក មើល អ្នកបម្រើរបស់យើងនឹងមានអំណរសប្បាយ តែអ្នករាល់គ្នានឹងត្រូវអាម៉ាស់។[14]មើល អ្នកបម្រើរបស់យើងនឹងស្រែកហ៊ោ ព្រោះគេ
សប្បាយចិត្ត តែអ្នករាល់គ្នាបែរជាស្រែកយំ ព្រោះឈឺចុកចាប់នៅក្នុងចិត្ត អ្នករាល់គ្នានឹងសោកសង្រេង បាក់ទឹកចិត្ត។
[15]អ្នកនឹងជាប់ឈ្មោះ សម្រាប់ឲ្យមនុស្សដែលយើងបានជ្រើសរើសយកមកដាក់បណ្តាសា យើងគឺព្រះអម្ចាស់លើទាំងព្រះនឹងសម្លាប់អ្នក
ហើយយើងនឹងហៅអ្នកបម្រើយើងតាមឈ្មោះផ្សេង។[16]អ្នកណាដែលឲ្យពរដល់ផែនដី នឹងបានពរពីយើងដែលជាព្រះនៃសេចក្ដីពិត។ អ្នកណាដែលបានស្បថនៅលើផែនដី
នឹងត្រូវស្បថចំពោះយើងជាព្រះនៃសេចក្ដីពិតដែរ ដោយសារតែបញ្ហាពីមុនត្រូវបានបំភ្លេច ហើយការទាំងនោះក៏បានលាក់បាំងពីភ្នែកយើងដែរ។
[17]មើលនោះ យើងនឹងបង្កើតផ្ទៃមេឃថ្មី និងផែនដីថ្មី អ្វីៗដែលកើតមានកាលពីមុន គេលែងនឹកនាទៀតហើយ គឺគ្មាននរណានឹងឃើញទៀតទេ។[18]ប៉ុន្តែចូរអ្នកអរសប្បាយ
ឡើង ចូរសប្បាយរីករាយរហូតតទៅ ចំពោះអ្វីៗដែលយើងបង្កើតមក គឺយើងបង្កើតក្រុងយេរូសាឡិម ដែលមានអំណរសប្បាយរីករាយ យើងបង្កើតប្រជាជននៅក្រុងនេះ
ដែលមានអំណរ។[19]ក្រុងយេរូសាឡិមនឹងធ្វើឲ្យយើង សប្បាយរីករាយ ប្រជាជនរបស់យើងក៏ធ្វើឲ្យយើងរីករាយ ក្នុងទីក្រុង គេលែងឮសូរសម្រែកយំសោកទៀតហើយ។
[20]នឹងមិនដែលមានទារក ដែលអាចរស់បានតែប៉ុន្មានថ្ងៃទៀតឡើយ ហើយសម្រាប់មនុស្សចាស់ ក៏នឹងមិនស្លាប់មុនអាយុដែរ។
អ្នកដែលស្លាប់ក្នុងវ័យមួយរយឆ្នាំត្រូវរាប់ថានៅវ័យក្មេង។ អ្នកណាដែលរស់មិនបានអាយុមួយរយឆ្នាំទេ អ្នកនោះត្រូវរាប់ថាទទួលបណ្តាសារហើយ។
[21]ពួកគេនឹងសង់ផ្ទះហើយអាស្រ័យនៅក្នុងផ្ទះនោះ ហើយគេដាំដើមទំពាំងបាយជូរ នោះគេនឹងទទួលផលរបស់វាដែរ។
[22]គឺគេមិនសង់ផ្ទះឲ្យអ្នកផ្សេងមកនៅ គេមិនដាំដំណាំទុកឲ្យអ្នកផ្សេង បរិភោគផលឡើយ ដ្បិតប្រជារាស្ត្ររបស់យើងនឹងមានអាយុវែង ដូចអាយុដើមឈើធំៗ អស់អ្នកដែល
យើងជ្រើសរើសនឹងប្រើប្រាស់អ្វីៗដែលខ្លួនបានបង្កបង្កើត ។[23]ពួកគេនឹងមិនធ្វើការនឿយហត់ជាអសារបង់ ហើយគេក៏មិនបង្កើតកូនចៅមក ដើម្បីឲ្យត្រូវអន្តរាយដែរ ដ្បិត
ពួកគេនឹងបានទៅជាពូជពង្សមួយ ដែលព្រះអម្ចាស់ប្រទានពរ កូនចៅរបស់គេនឹងគង់វង្សនៅជាមួយគេ។
[24]មុនពេលដែលគេសូម យើងនឹងឆ្លើយតបចំពោះពួកគេ ហើយកំឡុងពេលពួកគេកំពុងតែទូលអង្វរនោះ យើងសម្រេចតាមពាក្យសុំរបស់គេ រួចស្រេចទៅហើយ។[25]ពេល
នោះ ចចកនិងកូនចៀម នឹងស៊ីស្មៅជាមួយគ្នា សត្វសិង្ហនឹងស៊ីស្មៅដូចគោ។ រីឯសត្វពស់ វានឹងស៊ីធូលីដីជាអាហារ។ ពួកវានឹងលែងស៊ីបំផ្លាញគ្នា នៅលើភ្នំដ៏វិសុទ្ធរបស់
យើងទៀតហើយ» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។

Isaiah 65:1

យើងបានរួចរាល់

ត្រង់ពាក្យថា «យើង» សំដៅទៅលើព្រះអម្ចាស់។

យើងបានលូកដៃរបស់យើងទៅរកមនុស្សរឹង ចចេស

«យើងបានលូកដៃរបស់យើង»
គឺជាកាយវិការរបស់មនុស្សម្នាក់ដើម្បីបង្ហាញការទទូចអង្វរ ឬសំណើរបន្ទាន់។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងតែងតែទទូចអង្វរដល់មនុស្សរឹងចចេសឲ្យទទួលជំនួយពីយើង»។

Isaiah 65:3

ព័ត៌មានទូទៅ៖

ប្រជាជនអ៊ីស្រាអែលបន្តការនិយាយទៅកាន់ព្រះអម្ចាស់។

ក្នុងសួនឧទ្យាន...នៅលើអាសនៈធ្វើពីឥដ្ឋ

ឃ្លាទាំងនេះសំដៅទៅលើកន្លែងរបស់ជនជាតិកាណានសម្រាប់គោរពបូជារូបព្រះ។

អាសនៈសក្ការៈរបស់គេធ្វើពីឥដ្ឋ

ដែលព្រះអម្ចាស់ហាមមិនឲ្យយកអាសនៈរបស់ព្រះអង្គ។

អាសនៈរបស់ព្រះអម្ចាស់ធ្វើពីថ្ម។

អង្គុយនៅកណ្តាលផ្នូរខ្មោច ទាំងបើកភ្នែកពេញមួយយប់

ឃ្លានេះគឺជាឯកសារយោងមួយ ដើម្បីពិគ្រោះជាមួយមនុស្សស្លាប់
ដែលជាការអនុវត្តដែលព្រះអម្ចាស់ហាមឃាត់។

គេបរិភោគសាច់ជ្រូក

ព្រះអម្ចាស់មិនអនុញ្ញាតឲ្យប្រជាជនអ៊ីស្រាអែលបរិភោគសាច់ពីជ្រូកឡើយ។

Isaiah 65:5

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។

ការទាំងនេះគឺជាផ្សែងហុយដល់ច្រមុះយើង

ព្រះអម្ចាស់ប្រៀបធៀបមនុស្សទាំងនេះ ដែលតែងតែរំខានដល់ព្រះអង្គ
ដើម្បីហុយផ្សែងធ្វើឲ្យស្ទះដង្ហើមរបស់មនុស្ស។

ក៏ជាភ្លើងដែលឆេះពេញមួយថ្ងៃផង

ព្រះអម្ចាស់ប្រៀបប្រជាជនអ៊ីស្រាអែលទៅនឹងភ្លើងដែលឆេះសន្ធោសន្ធៅ
ដែលបណ្តាលឲ្យផ្សែងដោយមិនឈប់នៅពេលរលាក។

Isaiah 65:6

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីប្រជាជនអ៊ីស្រាអែល។

ចូរមើល៍! មានសេចក្ដីចែងទុកមក

«កត់ទុក និងយកចិត្តទុកដាក់»

ក្នុងពេលគេចាស់ផង

ឃ្លានេះមានន័យថាព្រះជាម្ចាស់នឹងដាក់ទណ្ឌកម្មពួកគេដល់កំរិតពេញលេញ។

ឃ្លានេះប្រៀបធៀបព្រះអម្ចាស់ដាក់ទណ្ឌកម្មប្រជាជនឲ្យបោះចោលជើងរបស់ពួកគេនៅពេលពួកគេកំពុងអ

Isaiah 65:8

នៅពេលទំពាំងបាយជូរមានផ្លែចង្កោម

ព្រះអម្ចាស់ប្រៀបប្រជាជនអ៊ីស្រាអែលទៅនឹងផ្លែទំពាំងបាយជូរមួយចង្កោមដែលនៅតែមានទឹកល្អនៅ

នៅពេលទំពាំងបាយជូរមានផ្លែចង្កោម

នេះអាចត្រូវបានបញ្ជាក់តាមរបៀបសកម្មភាព។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលអ្នករកទឹកនៅក្នុងចង្កោម»

យើងនឹងមិនបំផ្លាញពួកគេទាំងអស់ឡើយ

នេះអាចត្រូវបានបង្ហាញជាវិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងដោះលែងពួកគេខ្លះដែលជាមនុស្សសុចរិត»

Isaiah 65:9

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

ភ្នំរបស់យើង

ពាក្យនេះសំដៅទៅលើទីតាំងខ្ពស់បំផុតនៃក្រុងយេរូសាឡិម

generated on Wed Sep 10 16:16:32 2025

និងស្រុកយូដាទាំងអស់។
វាលទំនាបសារ៉ូន
ពាក្យនេះគឺជាតំបន់ស៊ីស្មៅដែលមានជីជាតិ។
ហើយជ្រលងភ្នំអាកោរ
ពាក្យនេះជាឈ្មោះជ្រលងភ្នំដែលអាចរត់ពីក្រុងយេរូសាឡិមទៅខាងត្បូងក្រុងយេរីខូ។
ពាក្យនេះក៏ជាតំបន់ស៊ីស្មៅដែលមានជីជាតិផងដែរ។
Isaiah 65:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
ភ្នំដ៏វិសុទ្ធ
សូមបកប្រែពាក្យនេះដូចក្នុងជំពូក ១១:៨។
ហើយបែរជារៀបចំតុ...ហើយក៏ច្រួចស្រាសែនព្រះ
មនុស្សអាចយកមួប
និងភេសជ្ជៈមកដាក់នៅមុខរូបព្រះដែលជាផ្នែកនៃការថ្វាយបង្គំរបស់ពួកគេ។
ច្រួចស្រាសែនព្រះ
ស្រាលាយជាមួយគ្រឿងទេស
មានលាភ...ជោគវាសនាផង
ទាំងនេះគឺជាឈ្មោះរបស់ព្រះមិនពិត។ ពួកគេក៏ត្រូវបានគេហៅថា «កាឌ» និង «មេនី»។
Isaiah 65:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែលដែលគោរពបូជារូបព្រះ។
ប្រហារអ្នកឲ្យស្លាប់ដោយមុខដាវ
«មុខដាវ»
តំណាងឲ្យអាវុធនៃសង្គ្រាមដែលព្រះអម្ចាស់នឹងប្រើដើម្បីដាក់ទោសអ្នកដែលមិនឆ្លើយតប
ព្រោះយើងបានហៅ តែអ្នកមិនឆ្លើយទេ ពេលយើងបាននិយាយ អ្នករាល់គ្នាមិនស្តាប់ទេ
ឃ្លាទាំងពីរមានន័យថាដូចគ្នា
ហើយត្រូវបានធ្វើនិយាយទៀតសម្រាប់ការសង្កត់ធ្ងន់។
Isaiah 65:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែលដែលគោរពបូជារូបព្រះ។
មើល អ្នកបម្រើរបស់យើង
«កត់ទុក និងយកចិត្តទុកដាក់»
ព្រះអម្ចាស់មានព្រះបន្ទូលនេះម្តងទៀតដើម្បីបញ្ជាក់ន័យ។
ព្រោះគេសប្បាយចិត្ត តែអ្នករាល់គ្នាបែរជាស្រែកយំ ព្រោះឈឺចុកចាប់នៅក្នុងចិត្ត អ្នករាល់គ្នានឹងសោកសង្រេង បាក់ទឹកចិត្ត
ប្រយោគទាំងនេះមានន័យដូចគ្នា និងប្រើពាក្យដដែលៗ ដើម្បីបញ្ជាក់ន័យ។
សោកសង្រេង បាក់ទឹកចិត្ត
ប្រយោគនេះប្រៀបធៀបអារម្មណ៍នៃការខកចិត្ត
និងទុក្ខព្រួយដ៏គួរឲ្យភ័យខ្លាចចំពោះអ្វីមួយដែលខូចទ្រង់ទ្រាយដោយសារតែសម្ពាធខ្ពស់។
Isaiah 65:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែលដែលគោរពបូជារូបព្រះ។
នឹងបានពរពីយើងដែលជាព្រះនៃសេចក្តីពិត
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងជាព្រះដែលតែងតែមានព្រះបន្ទូលនៃសេចក្តីពិតនឹងប្រទានពរដល់គេ»
បញ្ហាពីមុនត្រូវបានបំភ្លេច...លាក់បាំងពីភ្នែកយើងដែរ
បញ្ហាមុនៗ នឹងត្រូវគេបំភ្លេចចោល...នឹងត្រូវលាក់។
ឃ្លាទាំងនេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ពួកគេនឹងបំភ្លេចបញ្ហាអតីតកាល
ព្រោះបញ្ហាទាំងនេះនឹងផុតពីការចងចាំរបស់យើង»
ហើយការទាំងនោះក៏បានលាក់បាំងពីភ្នែកយើងដែរ
«លាក់បាំងពីភ្នែកយើង» តំណាងឲ្យការយកចិត្តទុកដាក់
និងការចងចាំរបស់ព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងមិនគិតអំពីពួកគេទៀតទេ»
Isaiah 65:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
មើលនោះ
«កត់ចំណាំ! យកចិត្តទុកដាក់!»
បង្កើតផ្ទៃមេឃថ្មី និងផែនដីថ្មី
ពាក្យទាំងពីរតំណាងឲ្យអ្វីគ្រប់យ៉ាងនៅចន្លោះគ្នាយ៉ាងខ្លាំង។
ដែលកើតមានកាលពីមុន គេលែងនឹកនាទៀតហើយ គឺគ្មាននរណានឹងឃើញទៀតទេ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយត្រូវបានបញ្ចូលគ្នាសម្រាប់ការសង្កត់ធ្ងន់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនត្រូវគិតអំពីអ្វីដែលបានកើតឡើងនៅអតីតកាល»
ប៉ុន្តែចូរអ្នកអរសប្បាយឡើង
ត្រង់ពាក្យថា «អ្នក» សំដៅទៅលើអ្នកបម្រើរបស់ព្រះជាម្ចាស់ទាំងអស់។
ក្នុងទីក្រុង គេលែងឮសូរសម្រែកយំសោកទៀតហើយ
អ្នកអាចបញ្ជាក់ឃ្លានេះជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាម្នាក់នឹងលឺសំលេងយំ និងស្រែកយំពីទុក្ខព្រួយនៅក្នុងទីក្រុងទៀតទេ»
Isaiah 65:20
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីប្រជាជនដែលស្មោះត្រង់របស់ព្រះអង្គ។
មួយរយឆ្នាំ
«១០០ ឆ្នាំ»
អ្នកដែលស្លាប់ក្នុងវ័យមួយរយឆ្នាំត្រូវរាប់ថានៅវ័យក្មេង
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជននឹងចាត់ទុកគាត់ជាមនុស្សវ័យក្មេង»
អ្នកនោះត្រូវរាប់ថាទទួលបណ្តាសារហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សនឹងចាត់ទុកអ្នកនោះថាជាបណ្តាសា»
Isaiah 65:22
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីប្រជាជនដែលស្មោះត្រង់របស់ព្រះអង្គ។
ដ្បិតប្រជារាស្ត្ររបស់យើងនឹងមានអាយុវែង ដូចអាយុដើមឈើធំៗ
«អាយុ» សំដៅទៅលើរយៈពេលនៃជីវិតរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជារាស្ត្ររបស់យើងនឹងរស់នៅដរាបណាដើមឈើនៅរស់«
ព្រះអម្ចាស់ប្រទានពរ កូនចៅរបស់គេ
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេជាកូនចៅរបស់អស់អ្នកដែលព្រះអម្ចាស់បានប្រទានពរ»
Isaiah 65:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីប្រជាជនដែលស្មោះត្រង់របស់ព្រះអង្គ។
ភ្នំដ៏វិសុទ្ធ
សូមបកប្រែពាក្យនេះដូចក្នុងជំពូក ១១:៨។

---

66 [1]នេះគឺជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល «ផ្ទៃមេឃជាបល្ល័ង្ករបស់យើង ហើយផែនដីជាកំណល់ទ្រជើងរបស់យើង។ តើអ្នកនឹងសង់ដំណាក់ឲ្យយើងនៅទីណាទៅ?
តើកន្លែងនោះនៅទីណាហើយយើងនឹងសម្រាកនៅកន្លែងណា?
[2]ដៃរបស់យើងដែលបានបង្កើតរបស់ទាំងនេះ ហើយនេះគឺជាមូលហេតុដែលរបស់ទាំងអស់កើតឡើង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
មនុស្សទាំងនេះដែលយើងពេញចិត្ត គឺជនកម្សត់ទុគ៌ត និងអ្នកបាក់ទឹកចិត្ត ហើយធ្វើតាមពាក្យយើង ដោយញាប់ញ័រផង។
[3]អ្នកដែលសម្លាប់គោ ហើយក៏សម្លាប់មនុស្សផងដែរ ជាអ្នកបានយកចៀមមកធ្វើយញ្ញបូជា ហើយក៏បំបាក់កណ្តែ និងអ្នកដែលយកតង្វាយមកថ្វាយ តែតង្វាយនេះជាឈាមជ្រូក អ្នកដែលដុតគ្រឿងក្រអូប ហើយក៏ឲ្យពរដល់សេចក្តីអាក្រក់។ ពួកគេបានជ្រើសរើសផ្លូវរបស់ពួកគេ ហើយពួកគេចូលចិត្តតែអំពើគួរស្អប់ខ្ពើមរបស់ពួកគេផងដែរ។
[4]ក្នុងរបៀបនេះដែរ យើងនឹងជ្រើសរើសការជំនុំជម្រះរបស់គេដែរ យើងនឹងនាំការភ័យខ្លាចមកដល់ពួកគេ ដោយព្រោះពេលយើងហៅគ្មាននរណាឆ្លើយទេ
ពេលយើងប្រកាសគ្មាននរណាស្តាប់ទេ។ ពួកគេបានធ្វើការអាក្រក់នៅចំពោះយើង ហើយជ្រើសរើសធ្វើអ្វីដែលទាស់ចិត្តយើង»។

generated on Wed Sep 10 16:16:32 2025

[5]ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ អស់អ្នកដែលញាប់ញ័រ និងព្រះបន្ទូលរបស់ព្រះអង្គ «បងប្អូនរបស់អ្នករាល់គ្នា ដែលស្អប់និងបដិសេធអ្នករាល់គ្នា
ដោយព្រោះអ្នកបាននិយាយពីឈ្មោះរបស់យើង «សូមព្រះអម្ចាស់សម្តែងសិរីរុងរឿង ដើម្បីឲ្យយើងឃើញអំណររបស់អ្នក» តែពួកគេនឹងត្រូវអាម៉ាស់វិញ។
[6]មានសំឡេងចម្បាំងឮរំពងពីទីក្រុង មានសំឡេងលាន់ឮពីព្រះវិហារ ហើយជាព្រះសូរសៀងនៃព្រះអម្ចាស់ ដែលសងសឹកដល់សត្រូវរបស់ព្រះអង្គ។
[7]មុនពេលស្ត្រីទៅកន្លែងសម្រាល ដើម្បីផ្តល់កំណើត គឺមុនដែលការឈឺចាប់ ហើយនាងឲ្យកំណើតដល់កូនប្រុស។[8]តើនរណាធ្លាប់បានឮការណ៍ទាំងនេះ? តើនរណាធ្លាប់
បានឃើញការណ៍ទាំងនេះ? តើផែនដីនេះអាចកើតឡើង ក្នុងរយៈពេលតែមួយថ្ងៃបានឬ? តើប្រជាជាតិមួយអាចកើត ក្នុងពេលតែមួយបានឬ? ប៉ុន្តែក្រុងស៊ីយ៉ូនវិញ នាង
ទើបនឹងចាប់ផ្តើមឈឺផ្ទៃ គឺបានសម្រាលកូនទៅហើយ។
[9]តើយើងជាអ្នកនាំកូនក្មេងទៅក្នុងការចាប់កំណើត ហើយមិនអនុញ្ញាតដល់កូនកើតមកឬ? សំនួររបស់ព្រះអម្ចាស់។ ម៉្យាងទៀត
តើយើងបានព្រមផ្តល់កំណើតកូននោះហើយ ក្រោយមកមិនឲ្យវិញឬ? សំនួរព្រះជាម្ចាស់របស់អ្នក»។
[10]ចូររីករាយជាមួយក្រុងយេរូសាឡិម ហើយសប្បាយ នឹងមានអំណរជាមួយទីក្រុងនេះផង អស់អ្នកដែលកាន់ទុក្ខ ដើម្បីក្រុងយេរូសាឡិមក៏ត្រូវអរសប្បាយផងដែរ![11]ដ្បិតអ្នក
រាល់គ្នាបានស្កប់ចិត្តនឹងក្រុងនេះ ដូចកូនដែលបានបៅដោះម្តាយឆ្អែតផងដែរ ហើយសូមសប្បាយជាមួយសិរីរុងរឿងជាបរិបូរណ៌នៃទីក្រុងផង។
[12]នេះគឺជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល «យើងនឹងឲ្យភាពចម្រុងចម្រើនហូរហៀរដល់ក្រុងនេះ ដូចទឹកទន្លេ យើងនឹងបង្ហូរទ្រព្យសម្បត្តិនៃ ប្រជាជាតិទាំងមូលចូលមក
ក្នុងក្រុងនេះ ដូចទឹកហូរប្រៀបមាត់ច្រាំង។ អ្នកនឹងបានការថ្នាក់ថ្នមដូចម្តាយបំបៅកូន បីអ្នក និងថ្នាក់ថ្នមអ្នកនៅលើភ្លៅផង។[13]ដូចម្តាយលួងលោមកូនរបស់នាង យើងនឹង
លួងលោមអ្នករាល់គ្នាយ៉ាងនោះដែរ អ្នករាល់គ្នានឹងរស់នៅក្នុងក្រុងយេរូសាឡិម»។
[14]អ្នកនឹងឃើញការនេះ ហើយដួងចិត្តរបស់អ្នកនឹងរីករាយ ហើយឆ្អឹងរបស់អ្នកនឹងពន្លកឡើង ដូចជាស្មៅទន់។
ព្រះហស្តនៃព្រះអម្ចាស់នឹងធ្វើឲ្យបានស្គាល់ដល់អ្នកបម្រើរបស់ព្រះអង្គ តែព្រះជាម្ចាស់នឹងបង្ហាញសេចក្តីក្រោធដល់សត្រូវព្រះអង្គវិញ។
[15]ដ្បិតមើល៍! ព្រះអម្ចាស់កំពុងតែយាងមក ជាមួយនិងភ្លើង ហើយរាជរថរបស់ព្រះអង្គយាងមក ប្រៀបបាននឹងខ្យល់កួច ដើម្បីនាំព្រះពិរោធដ៏
ខ្លាំងហើយជាមួយសេចក្តីបញ្ជានៃអណ្តាត ភ្លើងផងដែរ។[16]ដ្បិតព្រះអម្ចាស់នឹងវិនិច្ឆ័យទោសមនុស្សទាំងអស់ ដោយប្រើភ្លើងនិងដាវរបស់ព្រះអង្គ។
ព្រះអម្ចាស់សម្លាប់អ្នកដែលជាសត្រូវជាច្រើននោះ។
[17]ពួកគេបានរៀបចំញែកខ្លួន ហើយធ្វើឲ្យខ្លួនបានបរិសុទ្ធផង ដូច្នេះគេអាចចូលទៅក្នុងឧទ្យាន របស់ព្រះក្លែងក្លាយ តាមមេដឹកនាំរបស់គេ ហើយនាំគ្នាបរិភោគសាច់ជ្រូក
ហើយនិងអ្វីៗដ៏គួរឲ្យស្អប់ខ្ពើមផង។ «ពួកគេនឹងត្រូវបញ្ចប់ ហើយនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[18]ដ្បិតយើងដឹងពីកិច្ចការ ហើយអ្វីដែលគេគិតផងដែរ។ ពេលវេលាគឺជិតមកដល់ហើយ ជាពេលដែលយើងប្រមូលប្រជាជាតិនិងភាសារទាំងអស់ផង។
ពួកគេនឹងមកដល់ហើយឃើញសេរីរុងរឿងរបស់យើង។[19]យើងនឹងតាំងសញ្ញាដ៏ធំក្នុងចំណោមពួកគេ។ ក្រោយមកយើងនឹងបញ្ជូនអ្នកដែលរួចជីវិតនៅក្នុងចំណោមគេ
ទៅកាន់ប្រជាជាតិទាំងអស់: គឺតើស៊ីស ពូល និងលូឌ អ្នកបាញ់ព្រួញដ៏ចំណាន ទៅទូបាល យ៉ាវ៉ាន ហើយនិងកោះឆ្ងាយៗ
ជាកន្លែងដែលគេមិនទាន់បានឮអំពីយើងនិងឃើញសិរីរុងរឿងនៃយើង។ ពួកគេនឹងប្រកាសសិរីល្អយើងក្នុងចំណោមប្រជាជាតិទាំងអស់។
[20]ពួកគេនឹងនាំត្រឡប់មកវិញបងប្អូនរបស់អ្នក ចេញពីប្រជាជាតិទាំងនោះ ដូចជាតង្វាយដល់ព្រះអម្ចាស់។ ពួកគេនឹងមកវិញដោយសេះនិងរទេះចម្បាំង ក្រុមរទេះសេះ
លើលា ហើយលើសត្វអូដ្ឋ មកភ្នំយេរូសាឡិមបរិសុទ្ធរបស់យើង ព្រះបន្ទូលនៃព្រះម្ចាស់។ ដ្បិតប្រជាជនអ៊ីស្រាអែលនឹងថ្វាយតង្វាយធញ្ញជាតិ
ដែលស្អាតល្អដាក់ក្នុងដំណាក់នៃព្រះអម្ចាស់។[21]អ្នកទាំងនេះយើងនឹងជ្រើសរើសឲ្យធ្វើជាបូជាចារ្យ និងលេវី ព្រះបន្ទូលនៃព្រះអម្ចាស់។
[22]ដ្បិតផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលយើងនឹងបង្កើត នឹងគង់វង្សនៅចំពោះមុខយើង ដូច្នេះពូជពង្ស និងឈ្មោះរបស់អ្នករាល់គ្នា ក៏គង់វង្សនៅចំពោះមុខយើង រហូតតរៀងទៅ
យ៉ាងនោះដែរ។ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[23]ពីមួយខែ ទៅខែបន្ទាប់ ហើយពីថ្ងៃសប្ប័ទ មនុស្សលោកទាំងអស់នឹងនាំគ្នា មកក្រាបថ្វាយបង្គំយើង
នេះជាព្រះបន្ទូលព្រះអម្ចាស់។
[24]ពួកគេនឹងចេញទៅមើលរូបកាយដែលបានស្លាប់នៃមនុស្ស ដែលបានបះបោរទាស់នឹងយើង ដ្បិតដង្កូវដែលបានស៊ីពួកគេ នឹងមិនអាចស្លាប់ទេ
ហើយភ្លើងដែលបានដុតគេនឹងឆេះរហូត មិនអាចរលត់ឡើយ ហើយវានឹងក្លាយទៅជារបស់គួរស្អប់ខ្ពើម ដល់សាច់ឈាមទាំងអស់»។

Isaiah 66:1

ផ្ទៃមេឃជាបល្ល័ង្ករបស់យើង ហើយផែនដីជាកំណល់ទ្រជើងរបស់យើង

ព្រះអម្ចាស់ប្រៀបធៀបផ្ទៃមេឃទៅនឹងបល្ល័ង្ក និងផែនដីទៅនឹងបាតជើង
ដើម្បីបញ្ជាក់ពីភាពអស្ចារ្យរបស់ព្រះអង្គ។

តើអ្នកនឹងសង់ដំណាក់ឲ្យយើងបែបណាទៅ? តើកន្លែងនោះនៅទីណាហើយយើងនឹងសម្រាក
នៅកន្លែងណា?

ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ថាមនុស្សមិនអាចសង់កន្លែងសម្រាប់ព្រះអង្គបានទេ។

Isaiah 66:2

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

ដៃរបស់យើងដែលបានបង្កើតរបស់ទាំងនេះ

«ដៃ» សំដៅទៅលើអំណាច
និងសិទ្ធិអំណាចរបស់ព្រះអម្ចាស់មិនមែនលើរូបកាយរបស់ព្រះអង្គទេ។

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់

សូមបកប្រែពាក្យនេះដូចក្នុងជំពក ១៤:២១។

ជនកម្សត់ទុគ៌ត និងអ្នកបាក់ទឹកចិត្ត

ត្រង់ពាក្យថា «បាក់ទឹកចិត្ត» និង «កម្សត់ទុគ៌ត»
សំដៅទៅលើមនុស្សដែលមានចិត្តរាបទាប និងទទួលរងទុក្ខសម្រាប់ជំនឿរបស់គេ។

Isaiah 66:3

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

ជាអ្នកដែលសម្លាប់គោ...ហើយក៏ឲ្យពរដល់សេចក្តីអាក្រក់

ឃ្លាទាំងបួននេះពណ៌នាអំពីវិធីផ្សេងគ្នា ដែលមនុស្សអាក្រក់ប្រព្រឹត្ត
ហើយមានអត្ថន័យដូចគ្នាសម្រាប់ការសង្កត់ធ្ងន់។

ពួកគេបានជ្រើសរើសផ្លូវរបស់ពួកគេ

«ពួកគេបានជ្រើសរើសធ្វើអំពើអាក្រក់ដែលបំពានលើមាគ៌ារបស់ព្រះអម្ចាស់»

Isaiah 66:4

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីមនុស្សអាក្រក់។

ពួកគេបានធ្វើការអាក្រក់នៅចំពោះយើង

ត្រង់ពាក្យថា «នៅចំពោះ»
សំដៅទៅលើព្រះអម្ចាស់ព្រះតម្រិះអាកប្បកិរិយារបស់ពួកគេ។

របៀបផ្សេងទៀតនៃការបកប្រែ:

«ពួកគេបានធ្វើអ្វីដែលយើងជ្រាបថាជាអំពើអាក្រក់»

Isaiah 66:5

សូមព្រះអម្ចាស់សម្តែង សិរីរុងរឿង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«សិរីរុងរឿងនៃព្រះអម្ចាស់» ឬ «ព្រះអម្ចាស់សម្តែងសិរីរុងរឿងរបស់ទ្រង់»

តែពួកគេនឹងត្រូវអាម៉ាស់វិញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ប៉ុន្តែយើងនឹងធ្វើឲ្យពួកគេអាម៉ាស់មុខ»

Isaiah 66:6

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់ពិពណ៌នាអំពីការដាក់ទណ្ឌកម្មចំពោះការលាក់ពុតរបស់អ្នកគោរពបូជា។

មានសំឡេងចម្បាំងឮរំពង

សំឡេងនេះតំណាងឲ្យការប្រយុទ្ធពិតៗ
ដែលកំពុងកើតឡើងនៅក្នុងព្រះវិហារនៅពេលដែលព្រះអម្ចាស់កំពុងដាក់ទោស។

Isaiah 66:7

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូល។

មុនពេលស្ត្រីទៅកន្លែងសម្រាល ដើម្បីផ្តល់កំណើត គឺមុនដែលការឈឺចាប់

ហើយនាងឲ្យកំណើតដល់កូនប្រុស

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់មានព្រះបន្ទូលអំពីក្រុងស៊ីយ៉ូនដូចស្ត្រីដែលហៀបនឹងសំរាលកូន។
ទោះបីក្រុងស៊ីយ៉ូនត្រូវបានបំផ្លាញ ហើយប្រជាជនលែងរស់នៅទីនោះក៏ដោយ
ក៏ព្រះអម្ចាស់សន្យាថាដោយគ្មានការពន្យាពេល និងដោយការប្រឹងប្រែងតិចតួច
ប្រជាជាតិទាំងមូលនឹងចេញមកពីក្រុងស៊ីយ៉ូន។
តើនរណាធ្លាប់បានឮការណ៍ទាំងនេះ? តើនរណាធ្លាប់បានឃើញការណ៍ទាំងនេះ? តើផែនដីនេះអាច
កើតឡើង ក្នុងរយៈពេលតែមួយថ្ងៃបានឬ? តើប្រជាជាតិមួយអាចកើត ក្នុងពេលតែមួយបានឬ?
ព្រះអម្ចាស់ប្រើសំនួរដើម្បីបញ្ជាក់ថាព្រឹត្តិការណ៍នេះនឹងមានលក្ខណៈប្លែកយ៉ាងណា។
វគ្គនៃសំណួរបង្កើតភាពតានតឹងរហូតដល់ទីបំផុតក្រុងស៊ីយ៉ូនត្រូវបានលើកឡើង។
Isaiah 66:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិមដូចជាម្តាយ។ (សូមមើល: ៦៦:៧)
តើយើងជាអ្នកនាំកូនក្មេងទៅក្នុងការចាប់កំណើត ហើយមិនអនុញ្ញាតដល់កូនកើតមកឬ?
ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ថាព្រះអង្គនឹងមិនខកខានបំពេញការសន្យារបស់ព្រះអង្គ
Isaiah 66:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិមដូចជាម្តាយ
និងអ្នកក្រុងយេរូសាឡិមដូចជាពួកគេទើបនឹងកើត។ (សូមមើល: ៦៦:៧)
សូមឲ្យអ្នករាល់គ្នាបានស្កប់ចិត្តនឹងក្រុងនេះ ដូចកូនដែលបានបៅដោះម្តាយឆ្អែតផងដែរ
ឃ្លានេះមានន័យថាក្រុងយេរូសាឡិមនឹងក្លាយជាកន្លែងសុវត្ថិភាព
និងការលួងលោមសម្រាប់រាស្ត្ររបស់ព្រះជាម្ចាស់។
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដ្បិតនាងនឹងផ្គាប់ចិត្តអ្នកជាមួយទឹកដោះគោរបស់នាង
នោះនាងនឹងលួងលោមអ្នកដោយសុដន់របស់នាងដែរ»
Isaiah 66:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិមដូចជាម្តាយ។ (សូមមើល: ៦៦:៧)
ដូចទឹកទន្លេ...ដូចទឹកហូរប្រៀបមាត់ច្រាំង
ពាក្យនេះមានន័យថាព្រះជាម្ចាស់នឹងធ្វើឲ្យប្រជាជននៃប្រជាជាតិនានានាំយកទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់ចូលមកក្នុងក្រុងយេរូសាឡិម
និងមានទ្រព្យហូរហៀរ។
អ្នកនឹងបានការថ្នាក់ថ្នមដូចម្តាយបំបៅកូន បីអ្នក និងថ្នាក់ថ្នមអ្នកនៅលើភ្លៅផង
ឃ្លានេះមានន័យថាក្រុងយេរូសាឡិមនឹងក្លាយជាកន្លែងសុវត្ថិភាព
និងការលួងលោមសម្រាប់រាស្ត្ររបស់ព្រះជាម្ចាស់។
បីអ្នក និងថ្នាក់ថ្នមអ្នកនៅលើភ្លៅផង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នាងនឹងដឹកអ្នកនៅក្នុងដៃរបស់នាង
ហើយបីអ្នកលើជង្គង់របស់នាងដោយសេចក្តីរីករាយ»
យើងនឹងលួងលោមអ្នករាល់គ្នាយ៉ាងនោះដែរ អ្នករាល់គ្នានឹងរស់នៅក្នុងក្រុងយេរូសាឡិម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះយើងនឹងសំរាលទុក្ខអ្នកដែលនៅក្រុងយេរូសាឡិម»
Isaiah 66:14
ព័ត៌មានទូទៅ:
លោកអេសាយកំពុងតែនិយាយទៅកាន់មនុស្សស្មោះត្រង់របស់ព្រះ។
ឆ្អឹងរបស់អ្នកនឹងពន្លកឡើង
«ឆ្អឹង» សំដៅទៅលើរាងកាយទាំងមូលដែលជាផ្នែកមួយរបស់ឆ្អឹង។
ពន្លកឡើង ដូចជាស្មៅទន់
«ស្មៅទន់» លូតលាស់លឿន ហើយរឹងមាំ និងប្រៀបធៀបនឹងសុខភាព
ព្រមទាំងភាពរឹងមាំរបស់មនុស្សស្មោះត្រង់របស់ព្រះ។
ព្រះហស្តនៃព្រះអម្ចាស់នឹងធ្វើឲ្យបានស្គាល់ដល់អ្នកបម្រើរបស់ព្រះអង្គ
ត្រង់ពាក្យថា «ព្រះហស្ត» សំដៅទៅលើអំណាចរបស់ព្រះអង្គ។
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងសំដែងព្រះចេស្តារបស់ព្រះអង្គឲ្យអ្នកបម្រើរបស់ព្រះអង្គឃើញ»
Isaiah 66:15
ព័ត៌មានទូទៅ៖
លោកអេសាយកំពុងតែនិយាយទៅកាន់មនុស្សស្មោះត្រង់របស់ព្រះ។
យាងមក ជាមួយនិងភ្លើង
ការយាងមករបស់ព្រះអម្ចាស់នៅគម្ពីរសញ្ញាចាស់ជារឿយៗ ត្រូវបានអមដោយភ្លើង
ដែលតំណាងកំហឹង និងការវិនិច្ឆ័យរបស់ព្រះអម្ចាស់។
ខ្យល់កួច
ព្យុះតំណាងឲ្យសកម្មភាពដ៏មានឥទ្ធិពលរបស់ព្រះអម្ចាស់ដើម្បីធ្វើឲ្យការវិនិច្ឆ័យរបស់ព្រះអង្គមានប្រសិទ្ធភ
ដាវរបស់ព្រះអង្គ
«ដាវ» គឺជាអាវុធមួយដែលតំណាងឲ្យសង្គ្រាម និងការសម្លាប់ទាំងអស់។
ព្រះអម្ចាស់នឹងប្រហារមនុស្សជាច្រើន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងសំលាប់មនុស្សជាច្រើន»
Isaiah 66:17
ព័ត៌មានទូទៅ:
លោកអេសាយបន្តការនិយាយ។
ពួកគេបានរៀបចំញែកខ្លួន
«ពួកគេ» គឺអ្នកដែលគោរពកោតខ្លាចព្រះអម្ចាស់
តែប្រឆាំងក្រឹតវិន័យរបស់ព្រះអង្គ។
អ្នកចំណែនឆ្លងដែន
នេះជាកន្លែងដែលមនុស្សនឹងទៅគោរពបូជារូបព្រះ។
តាមមេដឹកនាំរបស់គេ
នេះពិតណ៎ានាអំពីមេដឹកនាំនៃអ្នកដែលទៅគោរពបូជារូបព្រះ។
នេះគឺជាព្រះអម្ចាស់ដែលមានព្រះបន្ទូល
សូមបកប្រែពាក្យនេះដូចក្នុងជំពូក ១៤:២១។
Isaiah 66:18
ដ្បិតយើងដឹង
ត្រង់ពាក្យថា «យើង» សំដៅទៅលើព្រះអម្ចាស់។
ពីកិច្ចការ...គេគិតផងដែរ
ត្រង់ពាក្យថា «គេ» គឺសំដៅទៅលើអ្នកថ្វាយបង្គំដែលលាក់ពុត
ដែលព្រះអម្ចាស់បានពិពណ៌នាពីមុន។
ពូល...លូឌ...ទូបាល...យ៉ាវ៉ាន
ពាក្យនេះជាឈ្មោះតំបន់ដែលនៅឆ្ងាយពីទឹកដីអ៊ីស្រាអែល។
Isaiah 66:20
ពួកគេនឹងនាំត្រឡប់មកវិញ
[illegible]
និងធ្វើជាសាក្សីដល់ប្រជាជាតិនានា។
ពួកគេនឹងត្រឡប់ទៅក្រុងយេរូសាឡិមវិញជាមួយជនជាតិអ៊ីស្រាអែលដែលត្រូវនិរទេស។
ភ្នំបរិសុទ្ធ
សូមបកប្រែពាក្យនេះដូចក្នុងជំពូក ១១:៨។
Isaiah 66:22
ផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលយើងនឹងបង្កើត
សូមបកប្រែពាក្យនេះដូចក្នុងជំពូក ៦៥:១៧។
នេះជាព្រះបន្ទូលព្រះអម្ចាស់
សូមបកប្រែពាក្យនេះដូចក្នុងជំពូក ១៤:២១។
Isaiah 66:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បញ្ចប់ការមានព្រះបន្ទូល។
ពួកគេនឹងចេញទៅ
ត្រង់ពាក្យថា «ពួកគេ» គឺសំដៅទៅលើប្រជាជនអ៊ីស្រាអែលដែលស្មោះត្រង់
និងជនបរទេសដែលមកថ្វាយបង្គំព្រះអម្ចាស់។
ដង្កូវ...ឆេះរហូត
ឃ្លាទាំងពីរពិពណ៌នាអំពីគំនិតតែមួយដើម្បីបញ្ជាក់ពីការដាក់ទណ្ឌកម្មរបស់ព្រះអម្ចាស់។
ដង្កូវដែលបានស៊ីពួកគេ
ដង្កូវតំណាងឲ្យភាពភ័យរន្ធត់នៃការរលួយ
និងអំពើរលួយដែលជាការដាក់ទណ្ឌកម្មរបស់ព្រះអម្ចាស់លើមនុស្សអាក្រក់។
ដុតគេនឹងឆេះរហូត
ភ្លើងក៏តំណាងឲ្យការជំនុំជម្រះរបស់ព្រះអម្ចាស់ដែរ។
មិនអាចរលត់ឡើយ
ឃ្លានេះអាចត្រូវបានបង្ហាញជាវិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងឆេះជារៀងរហូត»
សាច់ឈាមទាំងអស់
ប្រយោគនេះតំណាងឲ្យសត្វមានជីវិត
ដែលបានបង្កើតទាំងអស់ដែលរួញចុះពីស្លាប់។

generated on Wed Sep 10 16:16:32 2025

យេរេមា

1 [1]ទាំងនេះគឺជាពាក្យដែលលោកយេរេមាបានថ្លែង និងកិច្ចការដែលលោកបានធ្វើ។[2]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្លួន នៅក្នុងឆ្នាំទី១៣ នៃរាជ្យព្រះបាទយ៉ូសៀស
ជាបុត្រព្រះបាទអាំម៉ូន ស្តេចទឹកដីយូដា[3]ព្រះអង្គមានព្រះបន្ទូលម្តងទៀតមកដល់លោក នៅរជ្ជកាលព្រះបាទយេហូយ៉ាគីមជាបុត្ររបស់ព្រះបាទយ៉ូសៀស និងជាស្តេច
ទឹកដីយូដា រហូតដល់ចុងឆ្នាំទីដប់មួយនៃរជ្ជកាលព្រះបាទសេដេគា ជាបុត្ររបស់ព្រះបាទយ៉ូសៀស និងជាស្តេចទឹកដីយូដា ហើយរហូតដល់គ្រាដែលអ្នកក្រុងយេរូសាឡឹម
ត្រូវគេកៀរយកទៅជាឈ្លើយសឹក។
[4]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំថា៖[5]«មុនដែលយើងបានបង្កើតអ្នកនៅក្នុងពោះម្តាយ គឺយើងស្គាល់អ្នកហើយ កាលមុនដែលអ្នកសម្រាលចេញពីផ្ទៃមក នោះយើង
បានញែកអ្នកជាបរិសុទ្ធផង ក៏បានតាំងអ្នកឡើងព្យាការី ដល់គ្រប់ជនជាតិផ្សេងៗ»។[6]«ព្រះអម្ចាស់ដ៏ជាព្រះអើយ» ខ្ញុំបានឆ្លើយថា «ទូលបង្គំគ្មានវោហារអធិប្បាយទេ ដ្បិត
ទូលបង្គំនៅក្មេង»។
[7]ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «កុំនិយាយថា អ្នកក្មេងពេកឡើយ អ្នកត្រូវតែទៅគ្រប់ទីកន្លែងដែលយើងបញ្ជូនអ្នកឲ្យទៅ ហើយនិយាយអ្វី ដែលយើងបង្គាប់
អ្នក នោះអ្នកត្រូវតែប្រាប់ដែរ!"[8]កុំឲ្យខ្លាចចំពោះពួកគេឡើយ ដ្បិតយើងនៅជាមួយ ដើម្បីនឹងជួយឲ្យអ្នករួច នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់»។
[9]បន្ទាប់មក ព្រះអម្ចាស់លូកព្រះហស្តមកពាល់មាត់ខ្ញុំ ហើយមានព្រះបន្ទូលមកខ្ញុំថា៖ «យើងដាក់ពាក្យរបស់យើងក្នុងមាត់អ្នកហើយ។[10]យើងតែងតាំងអ្នកឲ្យមានអំណាច
លើប្រជាជាតិ និងលើអាណាចក្រទាំងឡាយ ដើម្បីឲ្យអ្នករម្លើង និងរំលំ ដើម្បីឲ្យអ្នកកម្ទេច និងបំផ្លាញ ហើយដើម្បីឲ្យអ្នកសង់ និងដាំឡើងវិញ»។
[11]ព្រះបន្ទូលនៃព្រះអម្ចាស់មកខ្ញុំដូចតទៅនេះ៖ «យេរេមាអើយ តើអ្នកឃើញអ្វី?»។ ខ្ញុំឆ្លើយថា៖ «ទូលបង្គំឃើញស្វាយចន្ទីមួយ មែក»។[12]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ
ថា៖ «អ្វីដែលអ្នកឃើញ ត្រឹមត្រូវហើយ ដ្បិតយើងបានមើលលើពាក្យរបស់យើងដើម្បីឲ្យបានសម្រេចជារូបរាង»។
[13]ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់ខ្ញុំជាលើទីពីរថា៖ «តើអ្នកឃើញអ្វី?» ខ្ញុំក៏ទូលតបថា៖ «ទូលបង្គំឃើញថ្លាងទឹកកំពុងតែពុះ ដែលមានមាត់ផ្ងៀងមកពីទិសខាង
ជើង»។[14]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «នឹងកើតមានការអាក្រក់ ផុលចេញពីទិសខាងជើង មកលើពួកអ្នកដែលរស់នៅលើទឹកដីទាំងនោះ។
[15]ដ្បិត យើងនឹងហៅគ្រប់ទាំងប្រជាជននៃនគរទាំងប៉ុន្មាននៅខាងជើង ហើយគេនឹងមកតាំងបល្ល័ង្ករបស់គេរៀងខ្លួន នៅត្រង់មាត់ទ្វារក្រុងយេរូសាឡិម ទល់នឹងកំផែងទីក្រុង
ព័ទ្ធជុំវិញ ហើយទល់នឹងទីក្រុងរបស់ទឹកដីយូដាទាំងអស់ផង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។[16]យើងនឹងធ្វើទោសដល់ទីក្រុងទាំងនោះ ដោយព្រោះអំពើទុច្ចរិតរបស់គេទាំង
ប៉ុន្មាន គឺដែលគេបានបោះបង់ចោលយើង ហើយបានដុតកំញានថ្វាយដល់ព្រះដទៃ ព្រមទាំងថ្វាយបង្គំចំពោះរបស់ដែលដៃខ្លួនគេបានធ្វើផង។
[17]ចូរឲ្យអ្នកក្រវាត់ចង្កេះ! ហើយក្រោកឡើងទៅប្រាប់ដល់គេ តាមគ្រប់ទាំងសេចក្តីដែលយើងបង្គាប់អ្នកចុះ កុំឲ្យស្រយុតចិត្តចំពោះគេឡើយ ក្រែងយើងធ្វើឲ្យអ្នកស្រយុតចិត្ត
នៅមុខគេជាពិត![18]មើល៍! នៅថ្ងៃនេះ យើងបានតាំងអ្នកឡើង ទុកជាទីក្រុងត្រៀមដោយគ្រឿងចម្បាំង ជាសសរដែក ហើយជាកំផែងលង្ហិន សម្រាប់តនឹងទឹកដីទាំងមូល
និងស្តេចទាំងប៉ុន្មាននៃជនជាតិយូដា ព្រមទាំងតនឹងពួកចៅហ្វាយ និងពួកសង្ឃ ហើយនឹងបណ្តាជនទាំងឡាយនៅទឹកដីនេះផង។[19]គេនឹងតជាមួយអ្នក តែមិនឈ្នះអ្នក
ឡើយ ដ្បិតយើងនៅជាមួយ ដើម្បីនឹងជួយអ្នកឲ្យរួច» នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។

Jeremiah 1:1

ហ៊ីលគីយ៉ា...អាំម៉ូន

ឈ្មោះរបស់មនុស្ស

អាណាថោត

ឈ្មោះរបស់ក្រុង

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

នេះគឺជាប្រយោគដែលប្រើសម្រាប់បង្ហាញអ្វីមួយដែលព្រះជាម្ចាស់បានប្រាប់ដល់បូជាចារ្យ
ឬប្រជាជន។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់មានព្រះបន្ទូលបែបនេះ» ឬ
«ព្រះអម្ចាស់មានព្រះបន្ទូលពាក្យនេះ»

ព្រះអម្ចាស់

នេះគឺជាព្រះនាមនៃព្រះជាម្ចាស់ដែលបានបង្ហាញដល់ប្រជាជនរបស់ព្រះអង្គនៅក្នុងព្រះគម្ពីរ
សូមមើលក្នុងទំព័រពាក្យបកប្រែអំពីព្រះអម្ចាស់ ដើម្បីបញ្ជាក់ពីការបកប្រែនេះ។

បានមកដល់ខ្លួន

«បានមកដល់លោកយេរេមា»

នៅក្នុងឆ្នាំទី ១៣...ទីដប់មួយនៃរជ្ជកាល

ជាស្តេច

«ព្រះបាទយ៉ូសៀស និងជាស្តេច»

ម្តងទៀតមកដល់

«ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់»

ខែទីប្រាំ

នេះគឺជាខែទីប្រាំនៃកាលវិភាគរបស់ជនជាតិហេព្រើរ។
គឺនៅក្នុងដំឡុងពេលខែកក្កដា កន្លងមកហើយនៅក្នុងដើមខែកញ្ញា
ក្នុងកាលវិភាគរបស់លោកខាងលិច។

ព្រះបាទយេហូយ៉ាគីម

«ក្នុងរាជ្យរបស់ព្រះបាទយេហូយ៉ាគីម»

Jeremiah 1:4

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។

មកដល់ខ្ញុំ

«មកដល់លោកយេរេមា»

បង្កើតអ្នក

«អភិវឌ្ឍន៍» ឬ «រូបរាង»

Jeremiah 1:7

ព្រះបន្ទូលនៃព្រះអម្ចាស់

«អ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូល» ឬ «អ្វីដែលព្រះម្ចាស់បានថ្លែង»

Jeremiah 1:9

យើងដាក់ពាក្យរបស់យើងក្នុងមាត់អ្នក

ការបកប្រែរបៀបផ្សេងទៀត:
«ផ្តល់ពាក្យយើងដល់អ្នកសម្រាប់អ្នកអាចប្រាប់ដល់មនុស្ស»។

ដកដំណាំរហូតដល់ឫសពីដី ដាក់ដាំក្បាលចុះក្រោមវិញ «ដំណាំ»

រំលំ

គឺផ្ទុយពីការ «សាងសង់»

Jeremiah 1:11

ព្រះបន្ទូលនៃព្រះអម្ចាស់មក

សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:១

ទូលបង្គំឃើញស្វាយចន្ទីមួយមែក

ព្រះអម្ចាស់បង្ហាញពីនិមិតខាងវិញ្ញាណដល់ដល់លោកយេរេមា។

ស្វាយចន្ទី

ដើមស្វាយចន្ទី

ដ្បិតយើងបានមើលលើពាក្យរបស់យើង

ពាក្យនៅក្នុងហេព្រើរ «ឃើញស្វាយចន្ទី» ហើយ «មើលលើ» សម្លេងប្រហែលគ្នា។
ព្រះជាម្ចាស់ចង់ឲ្យលោកយេរេមា
ចងចាំថាព្រះជាម្ចាស់គឺចង់ឲ្យព្រះបន្ទូលរបស់ព្រះអង្គ បានជោគជ័យ
គ្រប់ពេលដែលលោកបានឃើញដើមស្វាយចន្ទី។

Jeremiah 1:13

ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់

សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:១

Jeremiah 1:15

គ្រប់គ្នា

អ្នកដឹកនាំនៃនគរទាំងប៉ុន្មាននៅខាងជើង

នឹងមកតាំងបល្ល័ង្ករបស់គេរៀងខ្លួន នៅត្រង់មាត់ទ្វារក្រុង

ការបកប្រែរបៀបផ្សេងទៀត: «នឹងអង្គុយជំនុំជម្រះ នៅត្រង់មាត់ទ្វារក្រុង»

generated on Wed Sep 10 16:16:32 2025

ធ្វើទោសដល់ទីក្រុងទាំងនោះ
«ប្រកាសអំពីអ្វីដែលយើងនឹងដាក់ទោសដល់ពួកគេ»
Jeremiah 1:17
កុំឲ្យស្រយុតចិត្ត...យើងធ្វើឲ្យអ្នកស្រយុតចិត្ត
«កុំឲ្យអ្នកភ័យខ្លាចខ្លាំងពេកឡើយ... យើងជាអ្នកធ្វើឲ្យគេភ័យខ្លាចវិញ»
ស្រយុតចិត្ត
បំបែកទៅជាចំណែកតូច

មើល៍!
«ជាការផ្ចង់ចិត្ត»
ដែក...លង្ហិន
គឺជាវត្ថុធាតុដើមដែលមាំបំផុតនៅសម័យនោះ
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧

---

2 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំថា៖[2]«ចូរទៅចុះ ហើយប្រកាសឲ្យពួកក្រុងយេរូសាឡិមបានឮ។ ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ គឺយើងនឹកចាំពីអ្នកកាលនៅក្មេង ដែលអ្នកមានចិត្តក្តួចចំពោះយើង ហើយពីសេចក្តីស្រឡាញ់របស់អ្នក កាលទើបនឹងបានគ្នា គឺដែលអ្នកបានដើរតាមយើង នៅក្នុងទីរហោស្ថាន ជាកន្លែងដែលឥតមានអ្នកណាសាបព្រោះឡើយ។[3]អ៊ីស្រាអែលជាពួកបរិសុទ្ធដល់ព្រះអម្ចាស់ ជាផលដំបូងនៃសេចក្តីចម្រើនរបស់ព្រះអង្គ ព្រះអម្ចាស់មានព្រះបន្ទូលថា អស់អ្នកណាដែលស៊ីបង្ហិនគេ នោះនឹងត្រូវមានទោស សេចក្តីអាក្រក់នឹងមកគ្របលើអ្នកនោះ»។
[4]ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ចុះ ពួកវង្សរបស់យ៉ាកុប និងអស់ទាំងគ្រួសារនៃពួកអ៊ីស្រាអែលអើយ។[5]ព្រះអង្គមានព្រះបន្ទូលសួរថា៖ បុព្វបុរសរបស់អ្នករាល់គ្នាបានឃើញមាន អំពើទុច្ចរិតយ៉ាងណានៅក្នុងយើង បានជាគេថយទៅឆ្ងាយពីយើងដូច្នេះ ព្រមទាំងប្រព្រឹត្តតាមសេចក្តីឥតប្រយោជន៍ ហើយក៏ទៅជាឥតប្រយោជន៍គ្រប់គ្នាផង?
[6]គេក៏មិនបានសួរថា៖ ព្រះអម្ចាស់ ដែលនាំយើងរាល់គ្នាឡើងចេញពីទឹកដីអេស៊ីបមក ហើយបាននាំយើងដើរកាត់ទីរហោស្ថាន ជាកន្លែងដែលមានសុទ្ធតែវាលខ្សាច់ និងជង្ហុក គឺជាទីមានតែដីហួតហែង និងម្លប់នៃសេចក្តីស្លាប់ទទេ ជាកន្លែងដែលឥតមានមនុស្សដើរកាត់ ឬមនុស្សណាអាស្រ័យនៅឡើយ តើព្រះអង្គនៅឯណា?
[7]យើងបាននាំអ្នករាល់គ្នាចូលមកនៅក្នុងទឹកដី ដែលមានដំណាំដាំដុះ ដើម្បីឲ្យអ្នករាល់គ្នាបរិភោគ ផ្លែឈើដែលមានរសជាតិ។ ប៉ុន្តែ កាលអ្នករាល់គ្នាចូលមកដល់ អ្នករាល់គ្នាធ្វើឲ្យទឹកដីរបស់យើង ទៅជាសៅហ្មង អ្នករាល់គ្នាធ្វើឲ្យទឹកដីដែលជាមត៌ក របស់យើងក្លាយជាកន្លែងគួរឲ្យស្អប់ខ្ពើម។[8]ក្រុមបូជាចារ្យពុំដែលសួរថា ព្រះអម្ចាស់នៅឯណា? គ្រូអាចារ្យខាងវិន័យក៏មិនស្គាល់យើងដែរ។ មេដឹកនាំរបស់ប្រជាជននាំគ្នាប្រឆាំងនឹងយើង ពួកព្យាការីនិយាយក្នុងនាមព្រះបាល ហើយនាំគ្នារត់ទៅពឹងពាក់ព្រះក្លែងក្លាយដែលពុំអាចជួយពួកគេបានឡើយ។
[9]ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងតវ៉ានឹងអ្នករាល់គ្នាទៀត ព្រមទាំងកូនចៅរបស់អ្នកតទៅដែរ។[10]ដ្បិតមានតែឆ្លងទៅឯកោះទាំងប៉ុន្មាន របស់ពួកគីទីមមើល ហើយចាត់គេទៅទឹកដីកេដារ ឲ្យពិចារណាយ៉ាងអស់ពីចិត្ត នោះនឹងឃើញបើមានអ្វីដូច។[11]តើដែលមានជនជាតិណាផ្លាស់ព្រះរបស់ខ្លួន ដែលមិនមែនជាព្រះផងឬទេ? តែប្រជារាស្ត្ររបស់យើងបានដូរព្រះ ដ៏ជាសិរីល្អរបស់ខ្លួន ឲ្យបានតែរបស់ ដែលឥតមានប្រយោជន៍វិញ។
[12]ព្រះអម្ចាស់បានមានព្រះបន្ទូលថា៖ ផ្ទៃមេឃអើយ ចូរឲ្យនឹកប្លែកពីដំណើរនេះ ហើយឲ្យភ័យស្បើមចុះ ត្រូវឲ្យមានចិត្តត្រមោចនៅ។[13]ដ្បិតប្រជារាស្ត្ររបស់យើងបានប្រព្រឹត្តអំពើអាក្រក់ពីរយ៉ាង គឺបានទាំងបោះបង់ចោលយើង ដែលជាក្បាលទឹករស់ ហើយបានដាប់ធ្វើអាងវិញ ជាអាងប្រេះបែកដែលទុកទឹកមិនបានផង។
[14]តើអ៊ីស្រាអែលជាខ្ញុំបម្រើលោះដោយប្រាក់ ឬជាខ្ញុំបម្រើដែលកើតនៅផ្ទះអ្នកដឹកនាំ? ហេតុអ្វីបានជាត្រូវរឹបយកដូច្នេះ?[15]កូនសិង្ហទាំងប៉ុន្មានបានគ្រហឹម ហើយសន្ធាប់ដាក់គេ បានបំផ្លាញទឹកដី ទីក្រុងរបស់គេទាំងប៉ុន្មានត្រូវឆេះអស់ហើយ ឥតមានអ្នកណានៅទៀត។[16]ពួកក្រុងណូព និងក្រុងតាហាពេនេស គេបានបំបែកកំពូលក្បាលរបស់អ្នកហើយ។[17]តើអ្នកមិនបាននាំការនេះមកលើខ្លួនអ្នកទេឬ? ដោយអ្នកបានបោះបង់ចោលព្រះអម្ចាស់ ជាព្រះរបស់អ្នក ក្នុងកាលដែលព្រះអង្គ កំពុងតែនាំអ្នកតាមផ្លូវនោះ។
[18]ឥឡូវនេះ តើអ្នកមានការអ្វី បានជាទៅតាមផ្លូវទៅឯទឹកដីអេស៊ីប ដោយប្រាថ្នាចង់ផឹកទឹកទន្លេស៊ីហោរដូច្នេះ? ឬមានការអ្វីតាមផ្លូវទៅឯទឹកដីអាសស៊ើរ ដើម្បីផឹកទឹកទន្លេនោះ?[19]អំពើទុច្ចរិតរបស់អ្នក នឹងវាយផ្ចាលអ្នក ហើយការរាថយរបស់អ្នក នឹងស្តីបន្ទោសអ្នកវិញ។ ដូច្នេះ ចូរពិចារណា ហើយដឹងថា ការដែលអ្នកបានបោះបង់ចោលព្រះអម្ចាស់ ជាព្រះនៃអ្នក ឥតមានចិត្តកោតខ្លាច ដល់យើងនៅក្នុងខ្លួន នោះជាការអាក្រក់ ក៏ជូរចត់ណាស់ហើយ នេះជាព្រះបន្ទូល របស់ព្រះអម្ចាស់ដ៏ជាព្រះនៃពិភពទាំងមូល។
[20]តាំងពីយូរមកហើយ អ្នកបានបំបាក់នឹមរបស់ខ្លួន ហើយបានផ្តាច់ចំណងអ្នកចេញ ដោយពាក្យថា យើងមិនបម្រើទៀតទេ ដ្បិតនៅលើគ្រប់ទាំងភ្នំតូចៗ ហើយនៅក្រោមគ្រប់ទាំងដើមឈើខៀវខ្ចី នោះអ្នកបានផិតក្បត់នឹងយើង។[21]យើងបានផ្សាំអ្នកទុកជាទំពាំងបាយជូរសម្រាំង ជាពូជយ៉ាងល្អបំផុត ម្តេចបានជាអ្នកក្លាយទៅជា ខ្នែងរបស់ដើមទំពាំងបាយជូរដទៃ ដល់យើងដូច្នេះ?[22]ទោះបើអ្នកលាងខ្លួនដោយក្សុង ហើយប្រើសាប៊ូជាច្រើនក៏ដោយ គង់តែព្រះអម្ចាស់ដ៏ជាព្រះ ព្រះអង្គមានព្រះបន្ទូលថា៖ អំពើទុច្ចរិតរបស់អ្នក នៅមានកត់ជាប់ ចំពោះយើងនៅឡើយដែរ។
[23]ធ្វើដូចម្តេចឲ្យអ្នកបានថា អ្នកមិនសៅហ្មង ហើយមិនបានគោរពតាមអស់ទាំងព្រះបាលសោះ។ ចូរមើលស្នាមផ្លូវដែលអ្នកដើរនៅវាលច្រកភ្នំ ហើយយល់ពីការដែលអ្នកបានធ្វើនោះចុះ អ្នកជាសត្វអូដ្ឋក្រមុំយ៉ាងលឿន ហើយសាវា។[24]ជាលាព្រៃក្រមុំដែលធ្លាប់នៅទីរហោស្ថាន ក៏ស្រង់ក្លិនខ្យល់ដោយមានសម្រើប លុះដល់រដូវកំណត់របស់វា តើអ្នកណានឹងបំបែរចេញបាន? អ្នកណាដែលរកចាប់វា មិនបាច់នឿយហត់នឹងទៅតាមទេ ដ្បិតដល់រដូវកំណត់ នឹងបានប្រទះហើយ។[25]កុំប្រថុយខ្លួនឲ្យនៅជើងទទេ ហើយខះកនោះឡើយ តែអ្នកបានតបថា ឥតប្រយោជន៍ទេ ដ្បិតខ្ញុំបានស្រឡាញ់ពួកដទៃ ហើយនឹងរត់ទៅតាមគេវិញ។
[26]ចោរដែលគេទាន់ឃើញ តែងមានសេចក្តីខ្មាសយ៉ាងណា នោះពួកវង្សអ៊ីស្រាអែល ក៏មានសេចក្តីខ្មាសយ៉ាងនោះដែរ គឺស្តេចគេ ព្រមទាំងពួកគេ ពួកអ្នកដឹកនាំ ពួកសង្ឃ និងពួកព្យាការីរបស់គេផង![27]ជាពួកអ្នកដែលនិយាយដល់ដុំឈើថា លោកជាឪពុកខ្ញុំ ហើយដល់ដុំថ្មថា លោកបានបង្កើតខ្ញុំ ពីព្រោះគេបានបែរខ្នងឲ្យយើង មិនហ៊ានបែរមុខឡើយ ប៉ុន្តែ ដល់គ្រាដែលគេកើតមានសេចក្តីវេទនា នោះគេនឹងអំពាវនាវដល់យើងថា សូមព្រះអង្គក្រោកឡើង ជួយសង្គ្រោះយើងខ្ញុំផង។[28]ព្រះដែលអ្នកបានធ្វើសម្រាប់ខ្លួនតើនៅឯណា? ចូរឲ្យវាក្រោកឡើងជួយអ្នកចុះ បើវាអាចនឹងជួយសង្គ្រោះអ្នក ក្នុងគ្រាដែលអ្នកកើតមានសេចក្តីវេទនានោះបាន។ ដ្បិត ពួកយូដាអើយ ចំនួនព្រះរបស់អ្នកនោះប្រមាណស្មើនឹងទីក្រុងរបស់អ្នកដែរ។
[29]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ ហេតុអ្វីបានជាអ្នករាល់គ្នាចង់តនឹងយើងដូច្នេះ? អ្នករាល់គ្នាបានរំលងចំពោះយើងហើយ។[30]ការដែលយើងបានវាយផ្ចាលពួកកូនចៅអ្នកនោះជាឥតអំពើទេ វាមិនព្រមរាងចាលឡើយ គឺជាដាវរបស់ខ្លួនអ្នករាល់គ្នា ដែលបានត្របាក់លេបពួកព្យាការីរបស់អ្នក ដូចជាសិង្ហដែលហែកបំផ្លាញវិញ។[31]ចូរមើលព្រះបន្ទូលនៃព្រះអម្ចាស់ តើយើងដូចជាទីរហោស្ថាន ដល់ជនជាតិអ៊ី ស្រាអែល ឬជាទឹងងឹតសូន្យសុងឬ? ហេតុអ្វីបានជាប្រជារាស្ត្ររបស់យើងពោលថា យើងបានផ្តាច់ចំណង ហើយយើងមិនព្រម មកឯព្រះអង្គទៀតឡើយ ដូច្នេះ?
[32]តើស្រីក្រមុំនឹងភ្លេចគ្រឿងប្រដាប់របស់ខ្លួនបានឬទេ? តើប្រពន្ធថ្មោងថ្មីនឹងភ្លេចគ្រឿងតែងខ្លួន សម្រាប់រៀបការឬទេ? ប៉ុន្តែ ប្រជារាស្ត្ររបស់យើង បានភ្លេចយើងជាយូរថ្ងៃហើយ នឹងរាប់មិនបានឡើយ។[33]អ្នកប្រសប់អីម្ល៉េះ នឹងរៀបផ្លូវរក សេចក្តីស្រឡាញ់ដូច្នេះ អ្នកបានទាំងបង្រៀនពួកស្រីៗអាក្រក់ តាមផ្លូវរបស់អ្នកដែរ។[34]មួយទៀត នៅជាយអាវអ្នកឃើញមានឈាមរបស់មនុស្សក្រីក្រ ជាអ្នកដែលឥតមានទោសផង យើងមិនបានដឹងដោយស៊ើបសួររកបែបសម្ងាត់ទេ គឺបានឃើញដោយអំពើទាំងនេះវិញ។
[35]ប៉ុន្តែ អ្នកថា ខ្ញុំគ្មានទោសទេ ប្រាកដជាសេចក្តីក្រោធរបស់ព្រះអង្គ បានបែរចេញពីខ្ញុំហើយ យើងនឹងកាត់ទោសអ្នកដោយព្រោះអ្នកថា អ្នកគ្មានធ្វើបាបឡើយដូច្នេះ។
[36]ហេតុអ្វីបានជាអ្នកអាល័យតែដើរចុះឡើង ដើម្បីបំផ្លាស់ក៏រិយារបស់អ្នក អ្នកនឹងត្រូវមានសេចក្តីខ្មាសចំពោះទឹកដីអេស៊ីប ដូចជាអ្នកបានខ្មាសចំពោះទឹកដីអាសស៊ើរដែរ។
[37]ហើយអ្នកនឹងត្រូវចេញពីទឹកដីនោះ ទៅទាំងដៃខ្ទប់ក្បាល ពីព្រោះព្រះអម្ចាស់ មិនព្រមទទួលពួកដែលអ្នកយកជាទីពឹងនោះទេ ហើយអ្នកនឹងមិនបានចម្រើននៅជាមួយគេដែរ»។

---

generated on Wed Sep 10 16:16:32 2025

Jeremiah 2:1
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។
មកដល់ខ្ញុំ
ដល់លោកយេរេមា
ចូរទៅចុះ ហើយប្រកាសឲ្យពួកក្រុងយេរូសាឡិមបានឮ
ការបកប្រែរបៀបផ្សេងទៀត:
«ទៅហើយនិយាយប្រាប់ដល់មនុស្សដែលរស់នៅក្រុងយេរូសាឡិម»
នឹកចាំពីអ្នកកាលនៅក្មេង
«សម្រាប់ប្រយោជន៍របស់អ្នក» ឬ «បានចំណេញដល់អ្នក»
កាលទើបនឹងបានគ្នា
«ពេលដែលយើងព្រមព្រៀងនឹងរៀបការជាមួយគ្នា»
ជាពេលដែលជនជាតិអ៊ីស្រាអែលស្រឡាញ់គាត់ហើយបានស្មោះត្រង់ជាមួយគាត់ផង
ជាកន្លែងដែលឥតមានអ្នកណាសាបព្រោះឡើយ
ការបកប្រែរបៀបផ្សេងទៀត: «ជាដីដែលគ្មានអ្នកណាមកសាបព្រោះគ្រប់ពូជ»
ព្រះអម្ចាស់មានព្រះបន្ទូល
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
Jeremiah 2:4
ពួកវង្សរបស់យ៉ាកុប និងអស់ទាំងគ្រួសារនៃពួកអ៊ីុស្រាអែលអើយ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នាហើយបញ្ជាក់ថា។
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ទាំងកូនចៅរបស់លោកយ៉ាកុប»
បុព្វបុរសរបស់អ្នករាល់គ្នាបានឃើញមាន អំពើទុច្ចរិតយ៉ាងណានៅក្នុងយើង បានជាគេថយទៅឆ្ងាយ
ពីយើងដូច្នេះ ព្រមទាំងប្រព្រឹត្តតាមសេចក្តីឥតប្រយោជន៍ ហើយក៏ទៅជាឥតប្រយោជន៍គ្រប់គ្នាផង?
ការបកប្រែរបៀបផ្សេងទៀត: «យើងមិនបានធ្វើអ្វីខុសនឹងបុព្វបុរសរបស់អ្នកទេ
ដូច្នេះពួកគេបានធ្វើឲ្យយើងអន់ចិត្ត ដោយមិនស្តាប់បង្គាប់យើង
ហើយក៏បានថ្វាយបង្គំអ្វីឥតប្រយោជន៍!»
ឥតប្រយោជន៍
«គ្មានតម្លៃ»
ព្រះអម្ចាស់ ដែលនាំយើងរាល់គ្នា...អេស៊ីប? ព្រះអម្ចាស់ ដែលនាំយើងរាល់គ្នា...អាស្រ័យនៅ?
«យើងគួររៀនពីអ្វីដែលព្រះអម្ចាស់ចង់ឲ្យពួកយើងធ្វើ។
ព្រះអង្គនេះហើយគឺជាអ្នកបាននាំយើងចេញមកពី...អេស៊ីបហើយព្រះអង្គគឺជាអ្នកដឹកនាំយើង
Jeremiah 2:7
ប៉ុន្តែ កាលអ្នករាល់គ្នាចូលមកដល់ អ្នករាល់គ្នាធ្វើឲ្យទឹកដីរបស់យើង ទៅជាសៅហ្មង អ្នករាល់គ្នាធ្វើ
ឲ្យទឹកដីដែលជាមត៌ក របស់យើងក្លាយជាកន្លែងគួរឲ្យស្អប់ខ្ពើម
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមានបាបធ្វើឲ្យទឹកដីរបស់យើង ទៅជា
សៅហ្មង!»
ក្រុមបូជាចារ្យពុំដែលសួរថា ព្រះអម្ចាស់នៅឯណា? អាចារ្យខាងវិន័យក៏មិនស្គាល់យើងដែរ
ការបកប្រែរបៀបផ្សេងទៀត:
ពួកបូជាចារ្យហើយនិងអ្នកដឹកនាំខាងសាសនាមិនចង់ស្គាល់ខ្ញុំ»។
ព្រះអម្ចាស់នៅឯណា?
«យើងត្រូវស្តាប់បង្គាប់ព្រះអម្ចាស់!»
មេដឹកនាំរបស់ប្រជាជននាំគ្នាប្រឆាំងនឹងយើង
«ពួកអ្នកដឹកនាំបានធ្វើបាបទាស់នឹងយើង»
មេដឹកនាំ
«អ្នកដឹកនាំ»
ហើយនាំគ្នារត់ទៅពឹងពាក់ព្រះក្លែងក្លាយ
ការបកប្រែរបៀបផ្សេងទៀត: ហើយអធិស្ឋានដល់ព្រះ
ក្លែងក្លាយដែលមិនអាចជួយគេបាន»
នាំគ្នារត់ទៅ
«ស្តាប់បង្គាប់»
Jeremiah 2:9
ដូច្នេះយើងតវ៉ានឹងអ្នករាល់គ្នា
«ដូច្នេះហើយយើងនឹងនៅតែរករឿងដល់កូនចៅអ៊ីុស្រាអែល»
ព្រះអម្ចាស់មានព្រះបន្ទូល
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
កូនចៅរបស់អ្នក
«អ្នកបន្តវានរបស់ពេលអនាគត»
ឆ្លងទៅឯកោះទាំងប៉ុន្មាន របស់ពួកគីទីម
«ធ្វើដំណើរឆ្លងទៅសមុទ្រ ហើយទៅកោះគីទីម»
គីទីម
កោះស៊ីប
កេដារ
កោះមួយដែលនៅទិសខាងកើតរបស់អ៊ីុស្រាអែល (មើល:translate-names)
តើដែលមានជនជាតិណាផ្លាស់ព្រះ...ជាព្រះផងឬទេ?
«អ្នកនឹងមិនដែលឃើញជនជាតិមួយបានផ្លាស់ផ្តូព្រះទេ»។
សិរីល្អរបស់ខ្លួន
ការបង្ហាញនេះសំដៅដល់ព្រះជាម្ចាស់ផ្ទាល់ ដែលជាអ្នក «សិរីល្អ»
របស់ប្រជាជនអ៊ីុស្រាអែល។
ដែលឥតមានប្រយោជន៍វិញ
«ព្រះទាំងនោះមិនអាចជួយគេបាន»
Jeremiah 2:12
ផ្ទៃមេឃអើយ ចូរឲ្យនឹកប្លែកពីដំណើរនេះ! ហើយឲ្យភ័យស្បើមចុះ ត្រូវឲ្យមានចិត្តត្រមោច
អ្នកដែលកំពុងនិយាយបានបែរទៅរកផ្ទៃមេឃ ដូចជានិយាយទៅរកមនុស្ស។
បោះបង់ចោលយើង ដែលជាក្បាលទឹករស់
ការបកប្រែរបៀបផ្សេងទៀត: «បោះបង់ចោលយើង ដែលជាប្រភពទឹករបស់គេ»
ហើយបានដាប់ធ្វើអាងវិញ
រូបព្រះប្រៀបធៀបទៅនឹងអាងបាក់បែក។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយការថ្វាយបង្គំព្រះដែលគ្មានប្រយោជន៍»
ជាអាង
«ជិករន្ធជ្រៅសម្រាប់ទុកទឹក»
Jeremiah 2:14
តើអ៊ីស្រាអែលជាខ្ញុំបម្រើលោះដោយប្រាក់? ឬជាខ្ញុំបម្រើដែលកើតនៅផ្ទះអ្នកដឹកនាំ? ហេតុអ្វីបានជា
ត្រូវរឹបយកដូច្នេះ?
ការបកប្រែរបៀបផ្សេងទៀត:
«ជនជាតិអ៊ីស្រាអែលអ្នកមិនបានកើតមកដើម្បីធ្វើជាអ្នកបម្រើទេ»។
ហេតុអ្វីបានជាត្រូវរឹបយកដូច្នេះ?
ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់យ៉ាងដែលអ្នកមានត្រូវបានយកពីអ្នកដោយបង្ខំឬ?»
កូនសិង្ហទាំងប៉ុន្មានបានគ្រហឹម ហើយសន្ធាប់ដាក់គេ បានបំផ្លាញទឹកដី។ ទីក្រុងរបស់គេទាំងប៉ុន្មាន
[illegible]
ការបកប្រែរបៀបផ្សេងទៀត: «សត្រូវអ្នកវាយអ្នក ដូចជាសិង្ហស្ទាវគ្រហឹមដែរ។
ពួកគេបានបំផ្លាញទឹកដី ហើយគេដុតទីក្រុងរបស់អ្នកទាំងអស់
ដូច្នេះហើយគ្មានអ្នកណានឹងរស់នៅទីនោះទេ»។
កូនសិង្ហទាំងប៉ុន្មានបានគ្រហឹម
សម្លេងគ្រហឹមឮខ្លាំងដោយពួកសត្វព្រៃ។
បណ្តាជន
មនុស្សដែលរស់នៅក្នុងកន្លែងជាក់លាក់មួយ
ក្រុងណូព និងក្រុងតាហាពេនេស
ទីក្រុងនៅក្នុងអេស៊ីប
បំបែកកំពូលក្បាលរបស់អ្នក
ជនជាតិអេស៊ីបបានកោរក្បាលអ្នកបម្រើរបស់គេ ដើម្បីធ្វើឲ្យគេក្លាយជាទេសករ។
បំបែកកំពូលក្បាលរបស់អ្នក
នៅក្នុងបរិបថរបស់ហេព្រើរ គឺបកប្រែតាមរយៈការកែសំរួលថ្មីខ្លះ
«បានបំបែកក្បាលអ្នក»។
តើអ្នកមិនបាននាំការនេះមកលើខ្លួនអ្នកទេឬ ដោយអ្នកបានបោះបង់ចោលព្រះអម្ចាស់ជាព្រះរបស់
អ្នក ក្នុងកាលដែលព្រះអង្គ កំពុងតែនាំអ្នកតាមផ្លូវនោះ?
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបានធ្វើការនេះ ដោយអ្នកបានបោះបង់ចោល
ព្រះអម្ចាស់ ជាព្រះរបស់អ្នក ក្នុងកាលដែលព្រះអង្គ កំពុងតែនាំអ្នកតាមផ្លូវ»។
Jeremiah 2:18
ឥឡូវនេះ តើអ្នកមានការអ្វី បានជាទៅតាមផ្លូវទៅឯទឹកដីអេស៊ីប ដោយប្រាថ្នាចង់ផឹកទឹកទន្លេស៊ីហោរ
ដូច្នេះ? ឬមានការអ្វីតាមផ្លូវទៅឯទឹកដីអាសស៊ើរ ដើម្បីផឹកទឹកទន្លេនោះ?
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនគួរណាធ្វើដំណើរទៅស៊ីហោរ
ដើម្បីចូលរួមជាមួយពួកអ្នកគ្រប់គ្រងនៃអេស៊ីប។ អ្នកមិនគួរណាធ្វើដំណើរទៅទន្លេ
អ៊ើប្រាតចូលរួមជាមួយអស៊ីុរីឡើយ!
ទន្លេស៊ីហោរ
ភាគនិរតីជាប់ព្រំដែនរបស់កាណាន ដែលមានទន្លេរឹងហួត
អំពើទុច្ចរិតរបស់អ្នក នឹងវាយផ្ចាលអ្នក ហើយការរាថយរបស់អ្នក នឹងស្តីបន្ទោសអ្នកវិញ
ពាក្យទាំងពីរមានន័យថា

generated on Wed Sep 10 16:16:32 2025

លទ្ធផលនៃការដាក់ទោសពីការប្រព្រឹត្តអាក្រក់របស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត:
«ដោយសារអ្នកាបានធ្វើការអាក្រក់ហើយមិនស្មោះត្រង់ យើងនឹងជំនុំជម្រះអ្នក»។
នោះជាការអាក្រក់ ក៏ជូរចត់ណាស់
ពាក្យថា «ជូរចត់» ពិពណ៌នា «ការអាក្រក់» ការបកប្រែរបៀបផ្សេងទៀត:
«គឺវាជាការជូរចត់ដែលអាក្រក់» ឬ «គឺជាការអាក្រក់បំផុត»។
កោតខ្លាច
ភ័យរន្ធត់
Jeremiah 2:20
តាំងពីយូរមកហើយ អ្នកបានបំបាក់នឹមរបស់ខ្លួន ហើយបានផ្តាច់ចំណងអ្នកចេញ ដោយពាក្យថា យើងមិនបម្រើទៀតទេ
ការបកប្រែរបៀបផ្សេងទៀត: «តាំងពីយូរមកហើយ
យើងបានដោះអ្នកឲ្យរួចពីភាពជាអ្នកបម្រើ តែអ្នកនៅមិនព្រមថ្វាយបង្គំយើង!»
ដ្បិតនៅលើគ្រប់ទាំងភ្នំតូចៗ បានឱនចុះ ហើយគ្រប់ទាំងដើមឈើខៀវខ្ចី នោះអ្នកបានផិតក្បត់នឹងយើង។
«អ្នកបានឱនចុះដល់ព្រះក្លាងក្លាយហើយថ្វាយបង្គំពួកគេ ដូចជាប្រពន្ធលួចក្បត់ប្តី»
ចំណង
ច្រវាក់ប្រើសម្រាប់ចងមនុស្ស ហើយនិងសត្វ
នៅក្រោម
នៅទាបជាង
យើងបានផ្សាំអ្នកទុកជាទំពាំងបាយជូរសម្រាំង ជាពូជយ៉ាងល្អបំផុត
ការបកប្រែរបៀបផ្សេងទៀត: «យើង
ព្រះអម្ចាស់បានចាប់ផ្តើមជាមួយអ្នកដោយការល្អ»។
ផ្សាំអ្នក
ដាក់ក្នុងដីដើម្បីលូតលាស់
ខ្មែងរបស់ដើមទំពាំងបាយជូរដទៃ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបានក្លាយទៅជារលួយ
ហើយជាស្រាដែលប្រើមិនកើត»។
មិន ស្មោះត្រង់
ដែលក្បត់ គ្មានជំនឿ
អំពើទុច្ចរិតរបស់អ្នក នៅមានកត់ជាប់
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនៅតែមានទោសនៃអំពើបាប»
នៅមានកត់ជាប់
នៅក្នុងបរិបថនេះគេប្រើពាក្យជាប់ស្នាមនេះ
គឺដើម្បីរំលឹកដល់អំពើបាបរបស់អ៊ីស្រាអែល
ព្រះអម្ចាស់ដ៏ជាព្រះ ព្រះអង្គមានព្រះបន្ទូលថា
សូមមើលពីរការបកប្រែពាក្យនេះនៅក្នុងជំពូក ១:៧
Jeremiah 2:23
គោរពតាម
«ថ្វាយបង្គំ»
ចូរមើលស្មាមផ្លូវដែលអ្នកដើរនៅវាលច្រកភ្នំ! ហើយយល់ពីការដែលអ្នកបានធ្វើនោះចុះ អ្នកជាសត្វអូដ្ឋក្រមុំយ៉ាងលឿន ដែលបានរត់ទៅតាមផ្លូវរបស់វា!
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកគួរតែមើលអ្វីដែលអ្នកបានធ្វើនៅជ្រលោងភ្នំខាងក្រៅនៃក្រុងយេរូសាឡិម។
អ្នកបានរត់មកក្រោយហើយទៅមុខវិញ
គឺដូចជាសត្វអូដ្ឋដែលមិនដឹងថាតើគួររត់ទៅទីណា»។
យ៉ាងលឿន
«លឿន» ឬ «រហ័ស»
ជាសត្វលាព្រៃក្រមុំដែលធ្លាប់នៅទីរហោស្ថាន ក៏ស្រងក្លិនខ្យល់ដោយមានសម្រើប លុះដល់ដូវកំណត់របស់វា តើអ្នកណានឹងបំបែរចេញបាន? អ្នកណាដែលរកចាប់វា មិនបាច់នឿយហត់នឹងទៅតាមទេ ដ្បិតដល់រដូវកំណត់ នឹងបានប្រទះហើយ
ការបកប្រែរបៀបផ្សេងទៀត: អ្នកប្រៀបដូចជាសត្វលាញី
ដែលរស់នៅតាមទីរហោស្ថាន។ នៅពេលវាក្តៅឡើង
គឺវានឹងគ្រប់គ្រងខ្លួនឯងលែងបាន ហើយជានិច្ចជាកាលវាតែងតែហិតដែលមានសម្រើប។
ឯសត្វលាឈ្មោលវិញមិនបាច់ទៅរកវាទេព្រោះវានឹងមករកអាឈ្មោលដោយខ្លួនឯង»។
យូរអង្វែង
«បំណងចិត្ត»
ដង្ហក់រកខ្យល់
ដកដង្ហើមខ្លាំង ហើយលឿន
កុំប្រថុយខ្លួនឲ្យនៅជើងទទេ ហើយខះកនោះឡើយ តែអ្នកបានតបថា ឥតប្រយោជន៍ទេ ដ្បិតខ្ញុំបានស្រឡាញ់ពួកដទៃ ហើយនឹងរត់ទៅតាមគេវិញ
ការបកប្រែរបៀបផ្សេងទៀត:
«យើងបានប្រាប់អ្នកហើយថាកុំឲ្យរត់ដេញតាមព្រះទាំងនោះនៅទីនេះហើយទីនោះផង
ព្រោះវានឹងធ្វើឲ្យស្បែកជើងរបស់ក្តៅហើយនិងស្រែកទឹកខ្លាំងផង។
តែអ្នកបានប្រាប់យើងថា អ្នកមិនឈប់បានទេ។ អ្នកថាត្រូវតែតាមព្រាបាលទាំងនោះ
ហើយថ្វាយទៀតផង!»
ស្រែកទឹក
ត្រូវការទឹកជាចាំបាច់
ពួកអ្នកដទៃ
មនុស្សដែលយើងមិនដែលបានជួបពីមុន
Jeremiah 2:26
ដែលគេទាន់ឃើញ
«ពេលដែលគេបាច់គាត់»
ពួកគេ
«មនុស្ស»
ជាពួកអ្នកដែលនិយាយដល់ដុំឈើថា លោកជាឪពុកខ្ញុំ ហើយដល់ដុំថ្មថា លោកបានបង្កើតខ្ញុំ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សទាំងនេះជាពួកអ្នកដែលនិយាយដល់ដុំឈើ
ថា «ឯងជាឪពុកយើង» ហើយនិយាយដុំថ្ម «ឯងជាអ្នកផ្តល់កំណើតដល់យើង»
ព្រោះគេបានបែរខ្នងឲ្យយើង មិនហ៊ានបែរមុខឡើយ
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបែបចេញពីយើងហើយមិនថ្វាយបង្គំយើងទៀតឡើយ» ឬ «គេបានបែរខ្នង
យើងអាចមើលឃើញតែខាងក្រោយគេទេ អត់ឃើញមុខគេទេ»
ក្រោកឡើងជួយអ្នកចុះ
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់យងមកហើយសង្គ្រោះយើង»។
Jeremiah 2:29
ហេតុអ្វីបានជាអ្នករាល់គ្នាចង់តនឹងយើងដូច្នេះ? អ្នករាល់គ្នាបានរំលងចំពោះយើងហើយ
ការបកប្រែរបៀបផ្សេងទៀត: «អ៊ីស្រាអែលអើយ
តើអ្នកគិតថាយើងបានធ្វើខុសដោយសារអ្នកស្រែករកយើងជួយ
អ្នកហើយយើងមិនជួយ ទោះបីអ្នកនៅតែបន្តធ្វើបាបហើយទាស់និងយើង»។
វាយផ្ចាល
លទ្ធិភាពដែលអាចធ្វើឲ្យមានការខូចបង់យ៉ាងខ្លាំង
អ្នកជាកម្មសិទ្ធរបស់អ្នកណាដំណាពូជមនុស្សនេះ ចូរមើលព្រះបន្ទូលនៃព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «កូនចៅរបស់យាកុប
អ្នកត្រូវស្តាប់នូវអ្វីដែលយើងបានប្រាប់អ្នក»។
តើយើងដូចជាទីរហោស្ថាន ដល់ជនជាតិ អ៊ីស្រាអែល? ឬជាទឹងងឹតសូន្យសុង
ការបកប្រែរបៀបផ្សេងទៀត: «យើងមិនដែលបោះបង់អ្នកនៅក្នុងទីហោស្ថាន
ឬចាក់ចោលអ្នកឬជាទឹងងឹតសូន្យសុង?»
ហេតុអ្វីបានជាប្រជារាស្ត្ររបស់យើងពោលថា យើងបានផ្តាច់ចំណង ហើយយើងមិនព្រម មកឯព្រះអង្គទៀតឡើយ ដូច្នេះ?
ការបកប្រែរបៀបផ្សេងទៀត: «ហេតុអ្វីបានជានិយាយ ឯងនិយាយថា
គឺយើងទៅណាដែលចង់ទៅហើយឈប់ថ្វាយបង្គំព្រះអម្ចាស់ទៀតហើយ?»
ផ្តាច់ចំណង
ធ្វើដំណើរពីកន្លែងមួយទៅកន្លែងផ្សេងទៀត
ដែលមិនជាក់លាកហើយគ្មានគោលដៅច្បាសលាស់
Jeremiah 2:32
តើស្រីក្រមុំនឹងភ្លេចគ្រឿងប្រដាប់របស់ខ្លួនបានឬទេ?
ព្រះអម្ចាស់ចាប់ផ្តើមបន្ទោសដល់ប្រជាជនរបស់ព្រះអង្គដែលពួកគេបានភ្លេចព្រះអង្គ
ថ្ងៃហើយ នឹងរាប់មិនបានឡើយ
«ពេលយូរណាស់ហើយ»
អ្នកប្រសប់អីម្ល៉ះ នឹងរៀបផ្លូវរក សេចក្តីស្រឡាញ់ដូច្នេះ អ្នកបានទាំងបង្រៀនពួកស្ត្រីៗអាក្រក់ តាមផ្លូវរបស់អ្នក
ព្រះអម្ចាស់មានព្រះបន្ទូលថា
កូនចៅអ៊ីស្រាអែលបានក្លាយទៅជាអ្នកដែលដេញតាមព្រះខាងឯសាច់ឈាម
ហើយបង្រៀនឲ្យពួកស្ត្រីរកស៊ីផ្លូវភេទចេះចេញទៅរកភ្ញៀវ
មួយទៀត នៅជាយអាវអ្នកឃើញមានឈាមរបស់មនុស្សក្រីក្រ ជាអ្នកដែលឥតមានទោសផង
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមានអារម្មណ៍ធ្វើខុសដោយសារបានសំលាប់មនុស្សដែលគ្មានទោស

generated on Wed Sep 10 16:16:32 2025

ហើយនិងមនុស្សដែលមិនបានធ្វើឲ្យអ្នកអាម៉ាស់»។ ព្រះអម្ចាស់មានបន្ទូលថា
កូនចៅអីុស្រាអែលបានសំលាប់មនុស្សដែលមិនបានធ្វើអ្វីខុសទាស់
និងពួកគេទេ។
យើងមិនបានដឹងដោយស៊ើបសួរអ្នកបែបសម្ងាត់ទេ គឺបានឃើញដោយអំពើទាំងនេះវិញ
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមិនបានស្វែងរកមនុស្សដែលជាអ្នកលួចទាំងនោះ»
Jeremiah 2:35
ខ្ញុំ
«ពួកយើង»
ប្រាកដជាសេចក្ដីក្រោធរបស់ព្រះអង្គ បានបែរចេញពីខ្ញុំហើយ
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាព្រះអម្ចាស់នឹងឈប់ក្រោធជាមួយយើង»។
កាត់ទោស
«ជំនុំជម្រះ យ៉ាងខ្លាំង»
តាំងពី
«ពីព្រោះ»
ខ្ញុំបាន
«យើងបាន»
ហេតុអ្វីបានជាអ្នកអាល័យតែដើរចុះឡើង ដើម្បីបំផ្លាស់ការិយារបស់អ្នក?
ព្រះអម្ចាស់បានបន្ទោសដល់កូនចៅអីុស្រាអែល
ដោយព្រោះពួកគេបានផ្ដួចេញពីព្រះរាជ្យរបស់ព្រះអង្គទៅជំនួយផ្សេង
គឺមិនពឹងផ្អែកដល់ជំនួយរបស់ព្រះជាម្ចាស់។
បំផ្លាស់
ដោយមិនខ្វល់ឬបារម្ភ
ខកចិត្ត
អារម្មណ៍កំសត់ឬមិនសប្បាយចិត្ត ដោយព្រោះស្ដេចនៃអេស៊ីប
ដែលមិនព្រមការពារដល់ពួកគេ។
អ្នកនឹងត្រូវចេញពីទឹកដីនោះ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងត្រូវចេញពីទឹកដីអេស៊ីប»
អន់ចិត្ត
កំសត់ដោយព្រោះតែអ្នកមិនបានទទួលអ្វីដែលអេស៊ីបបានសន្យាថានឹងជួយ។
ដៃខ្ទប់ក្បាល
រូបភាពនេះបានបង្ហាញថាមនុស្សម្នាក់កំពុងកាន់ទុក្ខ

3 [1]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «បើអ្នកណាលះលែងប្រពន្ធ ហើយនាងបានចេញពីអ្នក ទៅធ្វើជាប្រពន្ធរបស់អ្នកដទៃ តើដែលត្រឡប់ទៅនៅជាមួយនាងនោះទៀតដែរឬ? តើទឹកដីយ៉ាងនោះមិនត្រូវអាប់ឱនជាខ្លាំងទេឬ? ចំណែកអ្នកវិញ អ្នកបានផិតយើង ដោយមានសហាយជាច្រើន ប៉ុន្តែ ចូរត្រឡប់មករកយើងវិញចុះ។[2]ចូរមើលទៅទីខ្ពស់ត្រងិលទាំងប៉ុន្មាន ហើយមើលចុះ តើមិនមែនជាកន្លែង ដែលអ្នកបានដេកជាមួយទេឬ? អ្នកបានអង្គុយចាំគូកំណាន់តាមផ្លូវ ដូចជាជនជាតិអារ៉ាប់នៅទីរហោស្ថានដែរ។ ហើយអ្នកបានធ្វើឲ្យទឹកដីអាប់ឱន ដោយអំពើផិតក្បត់ និងអំពើទុច្ចរិតរបស់អ្នក។
[3]ដូច្នេះ បានជាឥតមានភ្លៀងមួយមេឡើយ ហើយភ្លៀងចុងរដូវក៏គ្មានដែរ។ អ្នកនៅមានមុខងងើល ដូចជាស្រីពេស្យាទៀត អ្នកមិនព្រមអៀនខ្មាសសោះ។[4]តើអ្នកមិនចង់អំពាវនាវរកយើងវិញទេឬ ដោយថា ព្រះវរបិតានៃខ្ញុំម្ចាស់អើយ ព្រះអង្គជាព្រះដឹកនាំខ្ញុំម្ចាស់ពីកាលនៅក្មេង![5]តើព្រះអង្គនឹងនៅតែខ្ញាល់ជាដរាបឬ? តើព្រះអង្គមានព្រះហឫទ័យក្តៅ ដរាបដល់ចុងបំផុតឬ? តែមើល៍ អ្នកបាននិយាយ ហើយប្រព្រឹត្តអំពើអាក្រក់តាមតែកម្លាំងចិត្ត!»
[6]នៅក្នុងគ្រាស្តេចយ៉ូសៀស ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «តើបានឃើញការដែលអ៊ីស្រាអែល ជាពួករាថយនោះបានប្រព្រឹត្តឬទេ គឺគេបានឡើងទៅលើគ្រប់ទាំងភ្នំខ្ពស់ៗ និងនៅក្រោមដើមឈើខៀវខ្ចីទាំងប៉ុន្មាន ហើយបានប្រព្រឹត្តអំពើផិតក្បត់នៅទីនោះ។[7]ក្រោយដែលគេបានប្រព្រឹត្តអំពើទាំងនោះហើយ យើងបាននិយាយថា ចូរឲ្យគេវិលត្រឡប់មកយើងវិញ តែគេមិនបានវិលមកទេ ហើយយូដា ជាប្អូនគេ ដែលមានចិត្តក្បត់ក៏បានឃើញដែរ។
[8]យូដាបានឃើញថា ទោះបើយើងបានលែងលះអ៊ីស្រាអែលដែលមានចិត្តសាវា ព្រមទាំងចេញសំបុត្រលែងលះដល់នាងហើយ ដោយព្រោះតែនាងផិតក្បត់ក៏ដោយ តែយូដា ជាប្អូន ដែលមានចិត្តក្បត់មិនបានកោតខ្លាចដែរ គឺបានទៅប្រព្រឹត្តអំពើផិតក្បត់ដូចគ្នា។[9]ហើយទឹកដីបានអាប់ឱនទៅ ដោយឮរន្ទឺពីការកំផិតរបស់គេ គេបានកំផិតនឹងដុំថ្ម ហើយដុំឈើផង។[10]ទោះបើមានយ៉ាងនោះក៏ដោយ យូដាជាប្អូនគេ ដែលមានចិត្តក្បត់នោះ មិនបានវិលមកឯយើងដោយអស់ពីចិត្តដែរ គឺមានពុតត្បុត នេះហើយជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[11]ព្រះអម្ចាស់ក៏មានព្រះបន្ទូលមកខ្ញុំថា៖ «អ៊ីស្រាអែលជាពួករាថយ គេបានសម្តែងខ្លួនជាសុចរិត ជាជាងពួកយូដា ដែលមានចិត្តក្បត់នោះទៅទៀត។[12]ចូរទៅប្រកាសប្រាប់ពាក្យទាំងនេះទៅទិសខាងជើង ដោយពាក្យថា៖ ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ អ៊ីស្រាអែល ជាពួករាថយអើយ ចូរវិលមកវិញចុះ យើងនឹងមិនបំភ័យអ្នក ដោយទឹកមុខយើងទេ ដ្បិតយើងមានសេចក្តីមេត្តា។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងនឹងមិនក្រោធជាដរាបឡើយ។
[13]អ្នកមានអំពើទុច្ចរិតមែន ដោយបានរំលងនឹងព្រះអម្ចាស់ជាព្រះរបស់អ្នក ហើយបានចែកអំពើគោរពរបស់អ្នក ឲ្យសុសសាយទៅដល់ព្រះដទៃទាំងប៉ុន្មាន នៅក្រោមដើមឈើខៀវខ្ចីផង តែព្រះអម្ចាស់មានព្រះបន្ទូលថា៖ អ្នករាល់គ្នាមិនបានស្តាប់តាមយើងសោះ។[14]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ពួកក្មេងៗដែលរាថយអើយ ចូរវិលមកវិញចុះ ដ្បិតយើងជាប្តីដល់អ្នករាល់គ្នាហើយ យើងនឹងយកអ្នករាល់គ្នា ម្នាក់ពីក្រុងមួយ ហើយពីរនាក់ពីកុលសម្ព័ន្ធមួយ នាំត្រឡប់ទៅក្រុងស៊ីយ៉ូនវិញ។[15]យើងនឹងឲ្យអ្នករាល់គ្នាមានអ្នកគ្រប់គ្រងដែលគាប់ចិត្តយើង ជាអ្នកដែលឃ្វាលអ្នករាល់គ្នាដោយតម្រិះ និងយោបល់»។
[16]ក្រោយមក ព្រះអម្ចាស់មានព្រះបន្ទូលថា៖ នៅគ្រានោះ កាលណាអ្នករាល់គ្នាមានគ្នាច្រើនឡើងនៅក្នុងទឹកដី នោះគេនឹងលែង «និយាយពីហិបនៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់ទៀតហើយ!» ហិបនោះក៏មិនដែលចូលក្នុងគំនិតគេ ហើយគេមិនដែលនឹកចាំ ឬរឭករក ក៏មិនដែលមានអ្នកណាធ្វើឡើងវិញដែរ។
[17]នៅគ្រានោះ គេនឹងហៅក្រុងយេរូសាឡិមថាជាបល្ល័ង្កនៃព្រះអម្ចាស់ ហើយអស់ទាំងជនជាតិនឹងមូលគ្នា មករកព្រះនាមនៃព្រះអម្ចាស់ ក្នុងក្រុងយេរូសាឡិម គេនឹងមិនរឹងចចេស ធ្វើតាមចិត្តអាក្រក់របស់គេទៀតឡើយ។[18]នៅក្នុងគ្រានោះ ពួកវង្សយូដានឹងដើរជាមួយពួកវង្សអ៊ីស្រាអែល ហើយគេនឹងចេញពីទឹកដីខាងជើងជាមួយគ្នា មកក្នុងទឹកដីដែលយើងបានឲ្យដល់បុព្វបុរសរបស់អ្នកទុកជាមរតក។
[19]យើងគិតថា យើងសប្បាយចិត្ត នឹងចាត់ទុកអ្នកជាកូនប្រុសប្រសើរជាងគេ ព្រមទាំងប្រគល់ទឹកដីដ៏ល្អប្រណីតជាងគេ ក្នុងចំណោមប្រជាជាតិទាំងឡាយឲ្យអ្នក។ យើងគិតថា អ្នកនឹងហៅយើងថា «ព្រះបិតា» ហើយអ្នកនឹងមិនងាកចេញពីយើងទៀតទេ។[20]ប៉ុន្តែ ជនជាតិអ៊ីស្រាអែលអើយ អ្នករាល់គ្នាបានក្បត់ចិត្តយើង ដូចស្ត្រីក្បត់ចិត្តប្តីដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[21]មានសំឡេងលាន់ឮឡើង នៅតាមកំពូលភ្នំ គឺជាសម្រែកយំសោក និងសម្រែកអង្វរករ របស់ជនជាតិអ៊ីស្រាអែល ដ្បិតពួកគេបានវង្វេងចេញពីមាគ៌ា គេបានបំភ្លេចព្រះអម្ចាស់ ជាព្រះរបស់គេ។[22]កូនចៅដែលក្បត់ចិត្តយើងអើយ! ចូរនាំគ្នាវិលត្រឡប់មកវិញ យើងប្រោសឲ្យអ្នករាល់គ្នា លែងមានចិត្តសាវាទៀត។ មើល៍! យើងខ្ញុំមករកព្រះអង្គហើយ ដ្បិតព្រះអង្គជាព្រះអម្ចាស់ ជាព្រះនៃយើងខ្ញុំ។
[23]យើងខ្ញុំបានវង្វេងទៅគោរពព្រះក្លែងក្លាយ នៅលើកំពូលភ្នំ យើងខ្ញុំទៅតាមសំឡេងហ៊ោកញ្ជ្រៀវលើភ្នំខ្ពស់ៗ។ មានតែព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំប៉ុណ្ណោះ ដែលអាចសង្គ្រោះ អ៊ីស្រាអែលបាន។[24]តាំងពីយើងខ្ញុំនៅក្មេង ព្រះគម្រក់បានធ្វើឲ្យអ្វីៗ ដែលដូនតារបស់យើងខ្ញុំបានសន្សំ វិនាសហិនហោចអស់ គឺទាំងហ្វូងចៀម និងហ្វូងគោ ទាំងកូនប្រុស និងកូនស្រី។ សេចក្តីអាម៉ាស់ធ្វើឲ្យយើងខ្ញុំងើបមុខមិនរួច ការបាក់មុខគ្របសង្កត់លើយើងខ្ញុំ![25]តាំងពីក្មេងរហូតមកទល់សព្វថ្ងៃនេះ យើងខ្ញុំ និងដូនតារបស់យើងខ្ញុំ បានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអម្ចាស់ ជាព្រះនៃយើងខ្ញុំ យើងខ្ញុំពុំបានស្តាប់ព្រះសូរសៀង របស់ព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំឡើយ!»

Jeremiah 3:1
ពត៌មានទូទៅ:
ព្រះអម្ចាស់បានបន្តនិយាយនៅក្នុងជំពូក ២ កន្លងមកលោកយេរេមា
តើនាងត្រឡប់ទៅជាមិនស្អាតមែនដែរឬ?
ការបកប្រែរបៀបផ្សេងទៀត: «គឺនាងពិតជាមិនស្អាត់»។
ស្ត្រីនោះគឺជាទឹកដីនេះ!
«ទឹកដីនេះដូចជាស្រីនោះដែរ!» ការនេះ
ព្រះអម្ចាស់បានយកជនជាតិយូដាត្រឡប់មកវិញ

generated on Wed Sep 10 16:16:32 2025

ក៏ដូចមនុស្សប្រុសបានយកប្រពន្ធដែលខ្លួនបានលែងពីមុនមកវិញដែរ។
អ្នកបានផិតយើង ដោយមានសហាយជាច្រើន
«អ្នករាល់គ្នាបានផ្តល់សេចក្តីស្រឡាញ់ទៅឲ្យព្រះដទៃ
ដូចរបៀបដែលស្ត្រីរកសីុផ្លូវភេទ
ដែលឲ្យខ្លួនរបស់នាងទៅបុរសផ្សេងដែលមិនមែនជាប្តីខ្លួន»
តើអ្នកចង់ត្រឡប់មករកយើងវិញ?
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងមិនទទួលអ្នកមកវិញនោះទេ
ពេលដែលអ្នកព្យាយាមត្រឡប់មកយើងនោះ»។
នេះគឺជាព្រះបន្ទូលនៃ ព្រះអម្ចាស់
សូមមើលពីរការបកប្រែពាក្យនេះនៅក្នុងជំពូក ១:៧
ចូរមើលទៅទីខ្ពស់
«មើលទៅលើ»
តើមិនមែនជាកន្លែង ដែលអ្នកបានដេកជាមួយទេឬ?
«អ្នកដូចជាស្ត្រីដែលបានទៅគ្រប់ទីកន្លែង
ហើយបើកឲ្យបុរសមើលរាងហើយគេងជាមួយនាងផង!»
ជនជាតិអារ៉ាប់
ការនេះសំដៅទៅលើពួកអ្នកលួចប្លន់ក្នុងអារ៉ាប់។
Jeremiah 3:3
ដូចជាស្រីពេស្យាទៀត
បានដេកជាមួយដៃគូរច្រើន
មើលចុុះ
«ចំណាប់អារម្មណ៍» ឬ «ស្តាប់»
Jeremiah 3:6
គេបានឡើងទៅលើ
ប្រជាជននៃអីុស្រាអែលបានទៅ
គ្រប់ទាំងភ្នំខ្ពស់ៗ និងនៅក្រោមដើមឈើខៀវខ្ចីទាំងប៉ុន្មាន
ពួកភ្នំខ្ពស់ទាំងឡាយហើយនៅក្រោមម្លប់ដើមឈើជាធម្មតា
ជាកន្លែងថ្វាយបង្គំព្រះក្លែងក្លាយទាំងនោះ។
យូដា ជាប្អូនគេ ដែលមានចិត្តក្បត់ក៏បានឃើញដែរ
«ប្រជាជននៃយូដាដែលមិនបានស្តាប់បង្គាប់យើង បានឃើញ»
Jeremiah 3:8
ពត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលតទៅទៀត។
អ៊ីស្រាអែលដែលមានចិត្តសាវា
«អីុស្រាអែល អ្នកពិតជាបានឈប់ស្តាប់បង្គាប់យើង»
ចិត្តក្បត់
មិនស្មោះត្រង់
នេះហើយជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរការបកប្រែពាក្យនេះនៅក្នុងជំពូក ១:៧
Jeremiah 3:13
ដែលគាប់ចិត្តយើង
អាចមានន័យថា «អ្នកផ្សេងស្រឡាញ់អ្វីដែលយើងស្រឡាញ់» ឬ
«អ្នកណាម្នាក់ព្យាយាមធ្វើឲ្យយើងរីករាយ»។
Jeremiah 3:16
អ្នករាល់គ្នាមានគ្នាច្រើនឡើងហើយកើតផល
ពាក្យថា «កើតផល» គឺដែលមាននយ័ពិសេសដែលអាចនិយាយថានឹង
«រីកចម្រើន» ក្នុងចំនួន។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងបានរីកចំរើនឡើងនៅក្នុងចំនួនយ៉ាងច្រើន»។
Jeremiah 3:17
ពួកវង្សយូដានឹងដើរជាមួយពួកវង្សអ៊ីស្រាអែល
ប្រជាជននៃស្រុកយូដានឹងរស់នៅជាមួយគ្នាជាមួយប្រជាជនអីុស្រាអែល»
Jeremiah 3:19
ចូលសូមយើង
ពាក្យថា «យើង» សំដៅដល់ព្រះអម្ចាស់
ចាត់ទុកអ្នកជាកូនប្រុស ... ដូចស្ត្រី
ការប្តូរនេះពីប្រុសទៅជាស្ត្រីវិញ សម្រាប់ការបញ្ជាក់។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបនៃការបកប្រែនេះក្នុងជំពូក ១:៧
Jeremiah 3:21
មានសំឡេងលាន់ឮឡើង
«មនុស្សឮសម្លេងមួយ»
សម្រែកយំសោក និងសម្រែកអង្វរករ
«ការយំហើយអង្វរដោយខ្លាំង»
មើល!
ពាក្យថា «មើល»
គឺជាការប្រាប់យើងឲ្យដឹងខ្លួនពីពត៌មានដែលភ្ញាក់ផ្អើលដែលនឹងកើតមកតាមក្រោយ។
Jeremiah 3:23
បានវង្វេងទៅគោរពព្រះក្លែងក្លាយ នៅលើកំពូលភ្នំ
ប្រជាជនរំពឹងពីការដឹកនាំហើយបានអ្វីពីការទៅគោរពព្រះក្លែងក្លាយ
តែបានការកុហកវិញ។
សេចក្តីអាម៉ាស់ធ្វើឲ្យយើងខ្ញុំងើបមុខមិនរួច ការបាក់មុខគ្របសង្កត់លើយើងខ្ញុំ
ឃ្លាទាំងពីរមានន័យស្រដៀងគ្នាហើយបញ្ជាក់ថា៖
ពាក្យទាំងនោះគឺទទួលស្គាល់ពីការប្រព្រឹត្តដ៏អាម៉ាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ចូរឲ្យយើងពេញដោយភាពអៀនខ្មាស់»។
តាំងពីពេលដែលយើងនៅវ័យក្មេង
«ពីការចាប់ផ្តើមនៃជនជាតិ»
ព្រះសូរសៀង នៃព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល»

4 [1]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «អីុស្រាអែលអើយ ប្រសិនបើអ្នកចង់វិលមកវិញ ចូរវិលមករកយើងចុះ។ ប្រសិនបើអ្នកយកព្រះដ៏គួរឲ្យស្អប់ខ្ពើម ចេញពីមុខយើង
នោះអ្នកនឹងលែងវង្វេង ដើរគ្មានគោលដៅ ទៀតហើយ។[2]ប្រសិនបើអ្នកស្បថក្នុងនាមព្រះអម្ចាស់ ដែលមានព្រះជន្មគង់នៅ គឺស្បថដោយនិយាយពាក្យពិត ស្របតាម
យុត្តិធម៌ នោះប្រជាជាតិទាំងឡាយ មុខជាចង់បានពរពីយើង ព្រមទាំងបានខ្ពស់មុខ ដោយសារយើងផង។[3]ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់មនុស្សម្នា នៅទឹកដីយូដា និង
នៅក្រុងយេរូសាឡឹមថា ចូរនាំគ្នាកាប់ឆ្ការចម្ការមួយថ្មី កុំសាបព្រោះនៅលើដីដែលមានបន្លាឡើយ។
[4]ចូលធ្វើពិធីកាត់ស្បែកថ្វាយព្រះអម្ចាស់ ហើយក៏ត្រូវយកចេញស្បែកនៃដួងចិត្តរបស់អ្នកដែរ បុរសនៃជនជាតិយូដា ហើយនិងយេរូសាឡិមអើយ ត្រូវតែធ្វើការនេះ
បើមិនដូច្នេះទេ កំហឹងរបស់យើងនឹងឆេះរាលដាល គ្មាននរណាអាចទ្រាំបានទេ ព្រោះតែអំពើអាក្រក់ដែលអ្នករាល់គ្នាប្រព្រឹត្ត។[5]ចូរថ្លែងប្រាប់អ្នកយូដា ហើយប្រកាសប្រាប់
នៅក្រុងយេរូសាឡិម។ ដោយពាក្យថា «ចូរផ្លុំត្រែនៅក្នុងទឹកដី»។ ចូរស្រែកឡើងជាខ្លាំងថា «ចូរមូលគ្នាមក យើងចូលទៅក្នុងទីក្រុងទាំងប៉ុន្មានដែលមានបន្ទាយ»។[6]ចូរលើក
ទង់ឡើងនៅខាងក្រុងស៊ីយ៉ូន ត្រូវរត់ទៅ កុំបង្អង់ឡើយ ព្រោះយើងនឹងនាំសេចក្តីអាក្រក់មកពីទិសខាងជើង ព្រមទាំងការបំផ្លាញយ៉ាងធំផង។
[7]មានសត្វសិង្ហមួយបានឡើងចេញពីព្រៃស្ដុករបស់វាមក ជាមេបំផ្លាញនគរផ្សេងៗ។ វាកំពុងតែមកតាមផ្លូវ វាបានចេញពីកន្លែងរបស់វាមកហើយ ដើម្បីនឹងបំផ្លាញទឹកដីអ្នក
ហើយឲ្យទីក្រុងទាំងប៉ុន្មានរបស់អ្នក ត្រូវបែកបាក់ ចោលឥតមានអ្នកណានៅ។[8]ដោយការនេះ ចូរអ្នករាល់គ្នាស្លៀកសំពត់ធ្មៃ ព្រមទាំងទួញទំនួញ ហើយទ្រហោយំចុះ។ ដ្បិត
សេចក្តីក្រោធដ៏សហ័សរបស់ព្រះអម្ចាស់ មិនបានបែរចេញពីយើងរាល់គ្នាទេ។
[9]ក្រោយមកអ្វីដែលនឹងកើតឡើងនៅថ្ងៃនោះ នេះគឺព្រះអម្ចាស់មានព្រះបន្ទូលថា ព្រះហឫទ័យនៃស្តេច និងចិត្តរបស់ពួកដឹកនាំនឹងរលត់សូន្យទៅ ឯពួកសង្ឃនឹង
ស្រឡាំងកាំង ហើយពួកព្យាការីនឹកប្លែកដែរ។[10]ខ្ញុំបានទូលថា "ព្រះអម្ចាស់ដ៏ជាព្រះអើយ ពិតប្រាកដជាព្រះអង្គបានបញ្ឆោតជនជាតិនេះ ព្រមទាំងក្រុងយេរូសាឡិមជាខ្លាំង
ហើយ ដោយព្រះបន្ទូលថា នឹងមានសេចក្តីសុខដល់អ្នករាល់គ្នា តែមានដាវលូកមករកជីវិតគេវិញ"។
[11]នៅគ្រានោះនឹងមានសេចក្តីប្រាប់ដល់ជនជាតិនេះ ហើយដល់ក្រុងយេរូសាឡិមថា មានខ្យល់ក្តៅបក់មកពីទីខ្ពស់ត្រង់លនៅទីរហោស្ថាន ទៅខាងកូនស្រីរបស់ប្រជារាស្ត្រ
យើង មិនមែនសម្រាប់រោយស្រូវទេ ក៏មិនមែនសម្រាប់សម្អាតដែរ។[12]គឺជាខ្យល់ពេញកម្លាំងនឹងមកជំនួសយើង ឥឡូវនេះ យើងនឹងសម្រេចទោសដល់ពួកគេ។
[13]មើល! អ្នកនោះនឹងឡើងមកដូចជាពពក ហើយរទេះចម្បាំងរបស់គេ នឹងដូចជាខ្យល់កួច ឯសេះរបស់គេក៏លឿនជាងសត្វឥន្ទ្រី វរហើយយើង ដ្បិតយើងត្រូវវិនាសហើយ។
[14]ក្រុងយេរូសាឡិមអើយ ចូរលាងចិត្តអ្នកឲ្យជ្រះចេញពីអំពើទុច្ចរិត ដើម្បីឲ្យអ្នកបានសង្គ្រោះ តើគំនិតអាក្រក់នឹងចេះតែនៅជាប់ក្នុងចិត្តខ្លួន ដល់កាលណាទៀត។[15]ដ្បិតមាន
សំឡេងមួយបន្លឺចេញពីទឹកដីដាន់ ក៏ចេញពីភ្នំអេប្រាអិម មកប្រកាសពីការអាក្រក់។

generated on Wed Sep 10 16:16:32 2025

[16]ចូរឲ្យគ្រប់ជនជាតិគិតអំពីការនេះ៖ ចូរប្រកាសប្រាប់ទាស់នឹងក្រុងយេរូសាឡិមថា មានពួកទ័ពកំពុងតែមកពីទីឆ្ងាយ ដើម្បីឡោមព័ទ្ធអ្នក គេស្រែកទាស់នឹងទីក្រុងទឹកដីយូដាទាំងប៉ុន្មាន។[17]ពួកគេបាននៅព័ទ្ធជុំវិញទីក្រុង ដូចជាពួកចាំមើលចម្ការ ពីព្រោះពួកក្រុងបានបះបោរនឹងយើង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[18]គឺជាផ្លូវដែលអ្នកប្រព្រឹត្ត និងអំពើរបស់អ្នក ដែលបាននាំការទាំងនេះមកលើអ្នក។ នេះគឺជាសំណងនៃអំពើទុច្ចរិតរបស់អ្នក ពិតប្រាកដជាជូរចត់ណាស់ ព្រោះការនេះលូកមកប៉ះពាល់ដល់ចិត្តអ្នកហើយ។
[19]បេះដូងខ្ញុំ បេះដូងខ្ញុំអើយ! ខ្ញុំមានការឈឺចាប់នៅក្នុងចិត្ត។ បេះដូងខ្ញុំប្រដំនៅក្នុងខ្លួន។ ខ្ញុំនៅស្ងៀមមិនបានទេ ដ្បិតខ្ញុំបានឮសូរត្រែ ជាសូរអឺងកងនៃចម្បាំងហើយ។[20]គេស្រែកតឿនគ្នាឲ្យបំផ្លាញហើយលើការបំផ្លាញ ព្រោះទឹកដីទាំងមូលត្រូវខូចអស់ហើយ ទីស្នាក់អាស្រ័យរបស់ខ្ញុំក៏ខូច និងជម្រករបស់ខ្ញុំក៏ត្រូវបំផ្លាញអស់គ្មានសល់ដែរ។
[21]តើត្រូវឲ្យខ្ញុំមើលឃើញទង់ជ័យ? តើខ្ញុំនឹងឮសូរត្រែដល់កាលណាទៀត?[22]ពិតប្រាកដជាប្រជារាស្ត្ររបស់យើងល្ងីល្ងើ គេមិនស្គាល់យើងសោះ គេសុទ្ធតែជាកូនវង្វេងវង្វាន់ឥតមានយោបល់ឡើយ។ គេមានប្រាជ្ញាខាងឯផ្លូវប្រព្រឹត្តអាក្រក់ តែគ្មានចំណេះខាងឯការល្អសោះ។
[23]មើល៍! ខ្ញុំបានឃើញផែនដី។ ឃើញថាខូច ហើយនៅទទេ រួចមើលទៅលើមេឃ ក៏ឥតមានពន្លឺដែរ។[24]ខ្ញុំក្រឡេកមើលទៅភ្នំធំ ឃើញថាញ័រទាំងអស់ ហើយភ្នំតូចទាំងប៉ុន្មានក៏កក្រើករញ្ជួយ។[25]ខ្ញុំសម្លឹងមើលឃើញថា គ្មានមនុស្សណាទៀតសោះ អស់ទាំងសត្វហើរលើអាកាសបានហើរទៅបាត់ហើយ។[26]រួចខ្ញុំក៏មើលទៅឃើញដីដុះដាល បានត្រឡប់ជាវាលស្ងាត់ ហើយអស់ទាំងទីក្រុងក៏ត្រូវរលំចុះ នៅចំពោះព្រះអម្ចាស់ ហើយចំពោះសេចក្ដីក្រោធដ៏សហ័សរបស់ព្រះអង្គ។
[27]ដ្បិតនេះជាអ្វីដែល ព្រះអម្ចាស់មានព្រះបន្ទូល៖ «ទឹកដីទាំងមូលនឹងត្រូវខូចបង់ ប៉ុន្តែ យើងមិនបំផ្លាញអស់រលីងទេ។[28]ដោយហេតុការទាំងនេះ ផែនដីនឹងយំសោក ហើយមេឃខាងលើនឹងទៅជាខ្មៅ ពីព្រោះយើងបានចេញវាចា យើងបានគិតសម្រេចការនេះហើយ យើងនឹងមិនប្រែចិត្ត ឬបែរចេញពីការនេះឡើយ។[29]បណ្តាមនុស្សនៅទីក្រុងទាំងប៉ុន្មានរត់ទៅ ដោយព្រោះសូរពលសេះ និងពលធ្នូ គេចូលទៅក្នុងព្រៃស្តុក ហើយឡើងទៅលើថ្មដា ទីក្រុងទាំងឡាយត្រូវចោលស្ងាត់ ឥតមានអ្នកណានៅឡើយ។
[30]កាលណាអ្នកត្រូវខូចបង់ហើយ តើអ្នកនឹងធ្វើដូចម្តេច? ទោះបើអ្នកស្លៀកពាក់ពណ៌ក្រហម ហើយតែងខ្លួនដោយគ្រឿងមាស ទាំងផាត់រង្វង់ភ្នែកអ្នកដោយថ្នាំក៏ដោយ តែអ្នកខំធ្វើខ្លួនឲ្យល្អមើលនោះជាឥតប្រយោជន៍ទេ។ ពួកសហាយរបស់អ្នក គេស្អប់ខ្ពើមអ្នកហើយ ក៏រកសម្លាប់អ្នកទៀត។[31]ដ្បិតខ្ញុំបានឮសំឡេងមួយ ដូចជាសំឡេងរបស់ស្ត្រីដែលឈឺហៀបនឹងសម្រាលកូន ជាសេចក្ដីព្រួយបារម្ភរបស់ស្ត្រី ដែលសម្រាលកូនជាដំបូង គឺជាសំឡេងកូនស្រីស៊ីយ៉ូន ដែលដកដង្ហើមថ្ងូរ ហើយស្រងាកដៃ ដោយថា វរហើយខ្ញុំ ដ្បិតព្រលឹងខ្ញុំល្វើយណាស់ នៅចំពោះពួកកាប់សម្លាប់នេះ»។

Jeremiah 4:1
អ ីុស្រាអែល ប្រសិនបើអ្នកចង់វិលមកវិញ
«បើសិនជាអ្នកនឹងត្រឡប់មករកយើងវិញ ប្រជាជននៃអ ីុស្រាអែល» ឬ
«ប្រសិនបើអ្នកបានប្តូរការប្រព្រឹត្តរបស់អ្នក ប្រជាជននៃអ ីុស្រាអែល»
ចូរវិលមករកយើងចុះ
អាចមានន័យថា ទី១) នេះគឺជាប្រយោគដំណាងនៃឃ្លាទីមួយ:
«ប្រសិនបើអ្នកនឹងវិលមករកយើង» ការបកប្រែរបៀបផ្សេងទៀត:
«ហើយនឹងមករកយើង» ឬ «រួចថ្វាយបង្គំយើងម្តងទៀត» ឬ ទី២)
នេះគឺជាការបញ្ជា «ចូរមករកយើង»។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
ប្រសិនបើអ្នកយកព្រះដែលគួរឲ្យស្អប់ខ្ពើម ចេញពីចំពោះយើង
ឃ្លានេះសំដៅដល់ព្រះក្លែងក្លាយ ដូចជារបស់អ្វីដែលខ្លាំងគួរឲ្យស្អប់ខ្ពើម។
ការបកប្រែរបៀបផ្សេងទៀត: «យកព្រះដ៏គួរឲ្យស្អប់ខ្ពើម ចេញពីមុខយើង»
នោះអ្នកនឹងលែងវង្វេង ដើរគ្មានគោលដៅ ទៀតហើយ
«ឆ្ងល់» គឺប្រៀបប្រដូចទៅនិងការដែល «គ្មានជំនឿ។ ការបកប្រែរបៀបផ្សេងទៀត:
«សូមឲ្យនៅតែមានជំនឿដល់យើង»
ចូរនាំគ្នាកាប់ឆ្ការចម្ការមួយថ្មី កុំសាបព្រោះនៅលើដីដែលមានបន្លាឡើយ
ព្រះអម្ចាស់ប្រាប់ដល់ប្រជាជន ដើម្បីរៀបចំជីវិតពួកគេ
ដូចជាអ្នកចម្ការរៀបចំដីសម្រាប់ដាំដំណាំដែរ។
Jeremiah 4:4
ចូលធ្វើពិធីកាត់ស្បែកថ្វាយព្រះអម្ចាស់ ហើយក៏ត្រូវយកចេញស្បែកនៃដួងចិត្តរបស់អ្នក
ព្រះអម្ចាស់ពិណ៌នាដល់មនុស្សដែលលះបង់ចំពោះព្រះអង្គ
ក្នុងលក្ខខណ្ឌនៃសញ្ញាសាច់ឈាម នៃសេចក្ដីសញ្ញា។ ការបកប្រែរបៀបផ្សេងទៀត:
«ថ្វាយខ្លួនអ្នកទាំងមូលដល់ព្រះអម្ចាស់»។
ចូលធ្វើពិធីកាត់ស្បែក...យកចេញស្បែកនៃដួងចិត្តរបស់អ្នក
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។ ទាំងអស់គ្នាពួកគេ បញ្ជាក់ពីបញ្ជា។
ចូលធ្វើពិធីកាត់ស្បែកថ្វាយព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «កាត់ស្បែកខ្លួនឯងថ្វាយព្រះអម្ចាស់»
កំហឹងរបស់យើងនឹងឆេះរាលដាល
កំហឹងរបស់ព្រះអម្ចាស់គឺដូចជាភ្លឺដែលបំផ្លាញគ្រប់យ៉ាង។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលយើងបានធ្វើដោយព្រោះ
កំហឹងរបស់យើងនឹងដូចជាភ្លឺង»។
ចូរថ្លែងប្រាប់អ្នកយូដា ហើយប្រកាសប្រាប់នៅក្រុងយេរូសាឡិម
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។ ទាំងអស់គ្នាពួកគេ បញ្ជាក់ពីបញ្ជា។
ប្រកាសប្រាប់នៅក្រុងយេរូសាឡិម
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យប្រជាជនក្នុងក្រុងយេរូសាឡិមបានឮ»
សេចក្ដីអាក្រក់...ការបំផ្លាញយ៉ាងធំផង
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។ ឃ្លាថា «ការដួលរលំ»
បង្ហាញន័យឲ្យពាក្យ «មហ្គរាយ» នឹងកើតឡើង។
មកពីទិសខាងជើង
ការនេះគឺសំដៅដល់កងទ័ពសត្រូវដែលនឹកមកពីទិសខាងជើង។
Jeremiah 4:7
សត្វសិង្ហមួយបានឡើង
ការបកប្រែរបៀបផ្សេងទៀត: «អំណាចហើយនិងកងទ័ពសគ្មានមេត្តានឹងមកដល់»
ព្រៃស្តុក
គឺជាព្រៃដែលជាកន្លែងធំឡើងជាមួយគ្នានៅជិតគ្នាផង។
វាកំពុងតែមកតាមផ្លូវ
ការបកប្រែរបៀបផ្សេងទៀត: «ចាប់ផ្តើមដើម្បីដំណើរ»
បំផ្លាញ
ភ័យ ញញើត ហើយស្លន់
ទ្រហោយំចុះ
សម្លេងឮខ្លាំងយំដោយកំសត់ ហើយនឹងការប្រែចិត្តដែលបាបធ្វើបាប។
Jeremiah 4:9
នេះគឺព្រះអម្ចាស់មានព្រះបន្ទូល
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
តែមានដាវលូកមករកជីវិតគេវិញ
«សត្រូវរបស់យើងបានរួចរាល់ដើម្បីនឹងសម្លាប់យើង ជាមួយនឹងដាវរបស់ពួកគេ»
Jeremiah 4:11
នឹងមានសេចក្ដីប្រាប់
«ព្រះអម្ចាស់នឹងមានព្រះបន្ទូល»
មានខ្យល់ក្តៅបក់មកពីទីខ្ពស់...ខ្យល់ពេញកម្លាំង
កងទ័ពសដែលសាហាវនេងគ្មានមេត្តាកំពុងមក។
កូនស្រីរបស់ប្រជារាស្ត្រយើង
ប្រជាជាតិមួយប្រៀបធៀបទៅ និងកូនក្រមុំ ក្នុងរបៀបដែលស្រឡាញ់។
មិនមែនសម្រាប់ រោយស្រូវទេ ក៏មិនមែនសម្រាប់សម្អាតដែរ
ពាក្យថា «រោយ» ហើយ «សម្អាត»
សំដៅទៅដល់ការយកចេញរបស់ដែលមិនល្អហើយទុកអ្វីដែលជារបស់ល្អវិញ។
ការបកប្រែរបៀបផ្សេងទៀត: «វាមិនមែនយកអំពើបាបពួកគេចេញនោះទេ»។
ខ្យល់...នឹងមកតាមការដែលយើងបង្គាប់
ពាក្យថា «បង្គាប់» គឺសម្រាប់អ្វីដែលព្រះជាម្ចាស់ប្រាប់ឲ្យខ្យល់បកមក។
ការដែលយើងបង្គាប់
ការនេះបានបង្ហាញក្នុងការបកប្រែរបស់ហេព្រើរ តាមរយៈការកែតម្រូវថ្មីខ្លះដូចជា
«សម្រាប់យើង» ឬ «ពីយើង»។
នឹងសម្រេចទោសដល់ពួកគេ
«ប្រកាសពីការជំនុំជម្រះពួកគេ»
Jeremiah 4:13
មើល៍! អ្នកនោះនឹងឡើងមកដូចជាពពក ហើយរទេះចម្បាំងរបស់គេ នឹងដូចជាខ្យល់កួច

generated on Wed Sep 10 16:16:32 2025

ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។ ពាក្យទីពីរបានធ្វើឲ្យមានការច្បាស់លាស
នៅក្នុងឃ្លាទីមួយ។
រអាហើយយើង ដ្បិតយើងត្រូវវិនាសហើយ
ប្រជាជននិយាយបែបនេះ ព្រោះគេឃើញពួកកងទ័ពបានមកដល់។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងត្រូវបំផ្លាញមិនខាន»។
ក្រុងយេរូសាឡិមអើយ ចូរលាងចិត្តអ្នកឲ្យជ្រះចេញពីអំពើទុច្ចរិត
ព្រះជាម្ចាស់ចង់ឲ្យប្រជាជនដែលរស់នៅក្នុងក្រុងយេរូសាឡិមប្រែចិត្ត។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់មានព្រះបន្ទូលឲ្យប្រជាជនដែលរស់នៅក្នុងក្រុង
«អ្នករាល់គ្នាត្រូវប្តូររបៀបដែលអ្នកប្រព្រឹត្ត»។
សំឡេងមួយបន្លឺចេញ
«អ្នកនាំដំណឹងមកប្រកាស»
មកប្រកាសពីការអាក្រក់
«ប្រជាជនឮពីការប្រកាសនៃការបំផ្លាញ»
ពីទឹកដីដាន់...ពីភ្នំអេប្រាអិម
ប្រជាជននឹងស្គាល់ពីទីកន្លែង និងពីការរំលឹកដែលនឹងជិតមកដល់ពួកគេ។
Jeremiah 4:16
ពួកគេបាននៅព័ទ្ធជុំវិញទីក្រុង ដូចជាពួកចាំមើលចម្ការ ពីព្រោះពួកក្រុងបានបះបោរនឹងយើង
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបាននៅព័ទ្ធជុំវិញទីក្រុង»)
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
ប៉ះពាល់ដល់ចិត្តអ្នក
ការបកប្រែរបៀបផ្សេងទៀត: «ប៉ះគ្រប់យ៉ាងដែលអ្នកស្រឡាញ់»
Jeremiah 4:19
បេះដូងខ្ញុំ! បេះដូងខ្ញុំអើយ! ខ្ញុំមានការឈឺចាប់នៅក្នុងចិត្ត។ បេះដូងខ្ញុំប្រដំនៅក្នុងខ្លួន
«ខ្ញុំនៅក្នុងការឈឺចាប់ វាលើសលប់ពេកហើយសម្រាប់ខ្ញុំ»។
ប្រដំ
ពេញដោយច្របូកច្របល់ ច្រឡោត អត់សណ្តាប់ មិនស្ថិរភាព ឬមិនភាពរឹងមាំ
អរិយធម៌មួយ ទៅ អរិយធម៌មួយ ត្រូវបានប្រកាស
«ប្រជាជនបានប្រាប់គ្នាតៗ ពីទីក្រុងដែលត្រូវបានបំផ្លាញ»
ព្រោះទឹកដីទាំងមូលត្រូវខូចអស់
«សត្រូវបានធ្វើឲ្យទឹកដីទាំងមូលខ្លោចផ្សា»
ទីស្នាក់អាស្រ័យរបស់ខ្ញុំ និងជម្រករបស់ខ្ញុំ
ពាក្យថា «ទីស្នាក់អាស្រ័យ» ហើយ «ជម្រក» មានន័យស្រដៀងគ្នា។
អាចមានន័យថា «ម្រករបស់ខ្ញុំមានវាំងននៅក្នុងទីជម្រករបស់ខ្ញុំ» ឬ
«កន្លែងដែលខ្ញុំរស់នៅ»។
Jeremiah 4:21
តើត្រូវឲ្យខ្ញុំមើលឃើញទង់ជ័យ? តើខ្ញុំនឹងឮសូរត្រែដល់កាលណាទៀត?
ប្រយោគទាំងពីរមានន័យស្រដៀងគ្នា។
ពាក្យទីពីរបានជួយធ្វើឲ្យក្នុងការគិតរបស់ពាក្យទីមួយរឹតតែច្បាស។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំសង្ឃឹមថាចម្បាំងនេះនឹងបញ្ចាប់ឆាប់»។
គេសុទ្ធតែជាកូនរង្វេងរង្វាន់
«ប្រជាជនល្ងង់»
Jeremiah 4:23
មើល! ខ្ញុំបានឃើញផែនដី
នេះគឺជាអញ្ជើញឲ្យលោកយេរេមាសម្លឹងទៅកាន់មិនិត្តដែលព្រះជាម្ចាស់បានបើកឲ្យគាត់ឃើញ។
ឃើញថាខូច ហើយនៅទទេ
និមិត្តនេះគឺថ្លែងពីអ្វីដែលនឹងកើតឡើងនៅលើទឹកដីអ៊ីស្រាអែល
បន្ទាប់ពីប្រជាជនត្រូវបានចាប់យកទៅធ្វើជាឈ្លើយសឹក។
មើល!
ពាក្យថា «មើល៍» គឺជាការដាស់យើងឲ្យតាំងចិត្ត
សម្រាប់ពណ៌មានភ្ញាក់ផ្អើយដែលនឹងមកដល់។
Jeremiah 4:27
ផែនដីនឹងយំសោក ហើយមេឃខាងលើនឹងទៅជាខ្មៅ
លោកយេរេមាបានបញ្ជាក់ពីដាក់ទោសដោយព្រះបន្ទូលថា
ផែនដីទាំងមូលបង្ហាញពីការសោកស្តាយដ៏ធំ។
ពលសេះ
ពួកកងទ័ពដែលជិះសេះ
ទីក្រុងទាំងប៉ុន្មានរត់...ទីក្រុងទាំងឡាយត្រូវចោលស្ងាត់
នេះគឺជាបញ្ជាក់ថាប្រជាជនទាំងអស់បានរត់ចេញទៅអស់។
ទីក្រុងទាំងឡាយត្រូវចោលស្ងាត់ ឥតមានអ្នកណានៅឡើយ
ប្រយោគទាំងពីរមានន័យស្រដៀងគ្នា។
ពាក្យទីពីរបានជួយធ្វើឲ្យក្នុងការគិតរបស់ពាក្យទីមួយរឹតតែច្បាស។
ការបកប្រែរបៀបផ្សេងទៀត: «គឺមិនមានអ្នកណានឹងរស់នៅក្នុងក្រុងទៀតដែរ»។
Jeremiah 4:30
អ្នកស្លៀកពាក់ពណ៌ក្រហម...គ្រឿងមាស...រង្វង់ភ្នែក...ដោយថ្នាំ
«អ្នកស្លៀកពាក់ដូចស្រីខូច»
តែងខ្លួន
«តបតែង» ឬ «បន្ថាមដើម្បីធ្វើឲ្យអ្វីមួយលិចឡើងហើយមានការចាប់ចិត្ត ឬ
មានតម្លៃផង»
ពួកសហាយរបស់អ្នក គេស្អប់ខ្ពើមអ្នកហើយ
ចង់បញ្ជាក់ថាជនជាតិដែលអ៊ីស្រាអែលធ្លាប់ពឹងពាក់លើ សម្រាប់ផ្នែកទ្រព្យសម្បត្តិ
ហើយនិងជំនួញគេនឹងបដិសេធពួកគេ
ពេលគេឃើញការដាក់ទោសរបស់ព្រះជាម្ចាស់។
បារម្ភរបស់ស្រី ដែលសម្រាលកូន
«ការបារម្ភ
ដូចដែលនៅក្នុងពេលឈឺចាប់ហើយវេទនាដូចពេលស្ត្រីដែលបានផ្តល់កំណើត»
ខ្ញុំល្ងើយណាស់
«ជីវិតរបស់ខ្ញុំបានចុះខ្សោយពីសោកសៅ»

---

5 [1]«ចូរទៅមកតាមផ្លូវក្រុងយេរូសាឡិមមើល ឲ្យដឹងឥឡូវ ចូរស្វែងរកនៅទីធ្លាទាំងប៉ុន្មាន។ បើមានអ្នកណាមួយ គឺបើមានមនុស្សណា ដែលប្រព្រឹត្តដោយសុចរិត ឬដែល
ស្វែងរកសេចក្តីពិត នោះយើងនឹងអត់ទោសដល់ទីក្រុងនេះ។[2]ទោះបើគេថា គេស្បថដោយព្រះអម្ចាស់ ដ៏មានព្រះជន្មរស់នៅក៏ដោយ គង់តែគេស្បថដោយភូតភរវិញ»។[3]
ព្រះអម្ចាស់! តើព្រះនេត្ររបស់ព្រះអង្គ មិនបានទតឃើញសេចក្តីពិតទេឬ? ព្រះអង្គបានវាយគេ តែគេមិនឈឺអ្វីសោះ។ ព្រះអង្គបានធ្វើឲ្យគេអន្តរធានទៅ តែគេមិនព្រម
ទទួលសេចក្តីប្រៀនប្រដៅទេ គេបានតាំងមុខរឹងជាងថ្ម គេមិនព្រមវិលមកវិញឡើយ។
[4]នោះខ្ញុំបានថា មនុស្សទាំងនេះ ប្រាកដជាទាល់ក្រ ហើយល្ងីល្ងើទេ គេមិនស្គាល់ផ្លូវរបស់ព្រះអម្ចាស់ ឬក្រឹត្យវិន័យរបស់ព្រះនៃគេឡើយ។[5]ខ្ញុំនឹងទៅរកពួកអ្នកធំ ហើយ
និយាយជាមួយពួកគេវិញ ដ្បិតមុខជាគេស្គាល់ផ្លូវរបស់ព្រះអម្ចាស់ និងក្រឹត្យវិន័យរបស់ព្រះនៃគេ ប៉ុន្តែ អ្នកទាំងនោះបានព្រមគ្នាបំបាក់នឹម ហើយផ្តាច់ចំណងចេញហើយ។
[6]ដូច្នេះ សិង្ហមួយដែលចេញពីព្រៃ នឹងសម្លាប់គេ ឆ្កែព្រៃនៅវាលស្ងាត់នឹងបំផ្លាញពួកគេ ហើយខ្លារខិនសម្ងំចាំនៅមុខទីក្រុងរបស់គេ អ្នកណាដែលចេញពីទីក្រុងនោះ នឹងត្រូវ
ហែកខ្ទេចខ្ទី។ ដ្បិតអំពើរំលងរបស់គេមានច្រើនណាស់ ហើយការរាថយរបស់គេ ក៏មានច្រើនដែរ។
[7]ធ្វើដូចម្តេចឲ្យយើងអត់ទោសឲ្យអ្នកបាន? ពួកកូនចៅរបស់អ្នកបានបោះបង់ចោលយើងអស់ហើយ ក៏បានស្បថនឹងរបស់ដែលមិនមែនជាព្រះផង កាលយើងបានឲ្យគេស៊ី
ឆ្អែតជាបរិបូរណ៌ នោះគេក៏បែរជាផិតយើងវិញ ហើយប្រជុំគ្នាទាំងហ្វូងនៅឯផ្ទះស្រីពេស្យា។[8]គេប្រៀបដូចជាសេះដែលចិញ្ចឹមដោយល្អ ហើយរត់ទៅមកតាមតែចិត្ត គឺគេ
ស្រែកកញ្ជ្រៀវរកប្រពន្ធ របស់អ្នកជិតខាងគ្រប់គ្នា។[9]ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ តើយើងមិនត្រូវធ្វើទោសចំពោះអំពើយ៉ាងនោះទេឬ? តើព្រលឹងយើងមិនត្រូវ
សងសឹក នឹងជនជាតិណាយ៉ាងដូច្នេះទេឬ?
[10]ចូរឡើងទៅលើកំផែងទីក្រុងរបស់គេ ហើយបំផ្លាញទៅ តែកុំឲ្យអស់រលីងឡើយ ចូរកាច់ខ្នែងគេចេញ ព្រោះខ្នែងទាំងនោះមិនមែនជារបស់ព្រះអម្ចាស់ទេ។[11]ដ្បិត ពួកវង្ស
អ៊ីស្រាអែល និងពួកវង្សយូដា បានក្បត់នឹងយើងខ្លាំងហើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។ជាលទ្ធផលវិបាកនៃការបោះបង់ព្រះអម្ចាស់[12]គេនិយាយមិនត្រឹមត្រូវ
អំពីព្រះអម្ចាស់ដោយពាក្យថា៖ ព្រះអង្គមិនធ្វើអ្វីនោះទេ ក៏គ្មានសេចក្តីអាក្រក់ណាធ្លាក់មកលើយើងរាល់គ្នា យើងនឹងមិនត្រូវឃើញដាវ ឬគ្រាអំណត់ឡើយ។[13]ពួកព្យាការី
នឹងត្រឡប់ដូចជាខ្យល់ព្រះបន្ទូលមិននៅក្នុងគេទេ សូមឲ្យគេបានយ៉ាងដូច្នោះចុះ។
[14]ដូច្នេះ ព្រះអម្ចាស់ ជាព្រះនៃពួកពលបរិវារ ព្រះអង្គមានព្រះបន្ទូលថា៖ ដោយព្រោះអ្នករាល់គ្នាបានពោលពាក្យយ៉ាងនេះ នោះមើល៍ យើងនឹងធ្វើឲ្យពាក្យ ដែលយើងដាក់
នៅមាត់អ្នក បានដូចជាភ្លើង ហើយឲ្យជនជាតិនេះបានត្រឡប់ជាឧសភ្លើងនោះនឹងឆេះបន្សុសគេអស់ទៅ[15]នេះគឺជាព្រះបន្ទូលព្រះអម្ចាស់៖ មើល! ពួកវង្សអ៊ីស្រាអែលអើយ

generated on Wed Sep 10 16:16:32 2025

យើងនឹងនាំជនជាតិមួយពីឆ្ងាយមកលើអ្នករាល់គ្នា គឺជាជនជាតិមួយយ៉ាងស្វិតស្វាញ ជាជនជាតិចាស់បុរាណ ដែលអ្នកមិនស្គាល់ភាសារបស់គេទេ ក៏ស្តាប់ពាក្យគេមិនបានដែរ។
[16]បំពង់ព្រួញគេ ដូចជាផ្នូរខ្មោចចំហ ពួកគេសុទ្ធតែជាទាហានខ្លាំងពូកែ។[17]គេនឹងស៊ីផលចម្រូត និងអាហាររបស់អ្នកអស់ ជាអាហារដែលទុកសម្រាប់កូនប្រុសកូនស្រីអ្នក ក៏នឹងស៊ីហ្វូងចៀម ហ្វូងគោរបស់អ្នក ហើយស៊ីបំផ្លាញដើមទំពាំងបាយជូរ និងដើមល្វារបស់អ្នកដែរ។ គេនឹងវាយរំលំទីក្រុងមានកំផែង ដែលជាទីទុកចិត្តរបស់អ្នកនោះដោយសារដាវ។
[18]ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ ទោះបើមានគ្រានោះក៏ដោយ ក៏យើងមិនបំផ្លាញអ្នករាល់គ្នាឲ្យអស់រលីងដែរ។[19]កាលណាអ៊ីស្រាអែលនិងយូដាសួរថា៖ ហេតុអ្វីបានជាព្រះអម្ចាស់ជាព្រះនៃយើងព្រះអង្គប្រព្រឹត្តការយ៉ាងនេះដល់យើង? ឯងយេរេមាត្រូវឆ្លើយបែបនេះ គឺដូចអ្នករាល់គ្នាបានបោះបង់ព្រះអម្ចាស់ ទៅគោរពព្រះដទៃនៅក្នុងទឹកដីអ្នកជាយ៉ាងណា នោះអ្នករាល់គ្នានឹងត្រូវគោរពដល់ជនជាតិដទៃ នៅក្នុងទឹកដីមួយដែលមិនមែនជារបស់ខ្លួនយ៉ាងនោះដែរ។
[20]ចូរថ្លែងសេចក្តីនេះនៅក្នុងពួកវង្សយ៉ាកុប ហើយប្រកាសប្រាប់នៅក្នុងពួកយូដាថា៖[21]មនុស្សល្ងីល្ងើ ហើយគ្មានចំណោះដឹងអើយ ជាពួកអ្នកដែលមានភ្នែក តែមើលមិនឃើញ មានត្រចៀក តែស្តាប់មិនឮអើយ ចូរស្តាប់សេចក្តីនេះឥឡូវចុះ។[22]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ តើអ្នករាល់គ្នាមិនកោតខ្លាចដល់យើងទេ តើអ្នករាល់គ្នាមិនញាប់ញ័រនៅចំពោះយើងទេឬ? យើងបានដាក់ខ្សាច់ធ្វើជាព្រំខណ្ឌសមុទ្រ ដោយបញ្ញត្តិដ៏នៅជានិច្ច ដើម្បីមិនឲ្យហូររំលង ហើយទោះបើរលកបោកមាត់ច្រាំង គង់តែនឹងឈ្នះមិនបាន។ ទោះបើឮសន្ធឹកយ៉ាងណាគង់តែនឹងហូររំលងមិនបានដែរ។
[23]ប៉ុន្តែជនជាតិនេះគេមានចិត្តរឹងចចេស ហើយបះបោរវិញ គេបានបះបោរចេញបាត់ទៅហើយ។[24]ដ្បិតគេក៏មិនដែលនឹកក្នុងចិត្តថា ឥឡូវនេះ ចូរយើងកោតខ្លាចដល់ព្រះអម្ចាស់ ជាព្រះនៃយើងវិញ ដែលព្រះអង្គប្រទានភ្លៀងមក គឺទាំងភ្លៀងដើមរដូវ ហើយចុងរដូវ តាមរដូវកាល ហើយក៏កំណត់រក្សាទុកប៉ុន្មានអាទិត្យ ដែលសម្រាប់ច្រូតកាត់ដល់យើងនោះឡើយ។[25]អំពើទុច្ចរិតរបស់អ្នករាល់គ្នាបានបង្វែរការទាំងនោះចេញ។ អំពើបាបរបស់អ្នក បានបង្ខាំងសេចក្តីល្អចេញពីអ្នករាល់គ្នាដែរ។
[26]ដ្បិត នៅក្នុងប្រជារាស្ត្រយើង ឃើញមានមនុស្សដែលប្រព្រឹត្តអាក្រក់ គេរវៃចាំដូចជាអ្នកទាក់សត្វហើរពួនចាំដែរគេដាក់អន្ទាក់ចាប់មនុស្ស។[27]ដូចជាទ្រុងមានពេញដោយសត្វហើរយ៉ាងណា ផ្ទះគេក៏ពេញដោយការឆបោកយ៉ាងនោះដែរ ដូច្នេះ គេបានត្រឡប់ជាធំ ហើយជាអ្នកមានផង។[28]ពួកគេឡើងសាច់ធាត់ ហើយរស់នៅផូផង់ គេប្រព្រឹត្តអំពើអាក្រក់ហួសល្បត់ ឥតដែលកាន់ក្តីជំនួសពួកកំព្រា ដើម្បីឲ្យពួកនោះបានចម្រើនឡើងឡើយ ក៏មិនសម្រេចត្រឹមត្រូវដល់ពួកកម្សត់។[29]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ តើយើងមិនត្រូវកាត់ទោសចំពោះការដូច្នេះទេឬ? តើព្រលឹងយើងមិនត្រូវសងសឹក នឹងជនជាតិយ៉ាងនោះទេឬ?
[30]មានការដ៏អស្ចារ្យ ហើយគួរស្ញែងខ្លាច បានកើតឡើងនៅក្នុងទឹកដី[31]គឺពួកព្យាការីបានថ្លែងទំនាយកុហក ពួកសង្ឃក៏គ្រប់គ្រងដោយកម្លាំងដៃខ្លួន។ ចំណែកប្រជារាស្ត្រយើងក៏ស្រឡាញ់ការយ៉ាងនោះដែរ ដូច្នេះ ដល់ចុងបំផុត តើនឹងមានអ្វីកើតឡើង?»

Jeremiah 5:1
ព័ត៌មានទូទៅ:
លោកយេរេមាកំពុងថ្លែងទៅកាន់ប្រជាជនដែលនៅយេរូសាឡិម។
ចូរទៅតាម
«ប្រញាប់ឡើង»
ដែលស្វែងរកសេចក្តីពិត
«មើលហើយស្វែងរក»
នៅទីធ្លា
ផ្លូវទូលាយ ហើយបើកចំហរដាក់នៅកណ្តាលក្រុង ជាកន្លែងអាចជួបជុំគ្នា។
បើមានអ្នកណាមួយ គឺបើមានមនុស្សណា
«ទោះបើអ្នកអាចរកបានមួយនាក់»
ប្រព្រឹត្តដោយសុចរិត
«បានធ្វើអ្វីដែលត្រឹមត្រូវ»
ទោះបើគេ
ពាក្យថា «ពួកគេ» សំដៅទៅលើមនុស្សនៃក្រុងយេរូសាឡិម។
ដោយព្រះអម្ចាស់ ដ៏មានព្រះជន្មរស់
មនុស្សបានប្រើឃ្លានេះ ពេលធ្វើការស្បថតាមលំដាប់លំដោយទៅចំពោះព្រះអម្ចាស់ ដើម្បីដាក់ទោសគេ បើសិនមិនធ្វើតាមសម្បថ។ សូមមើលពីរបៀបបកប្រែក្នុងជំពូក ៤:១
តើព្រះនេត្ររបស់ព្រះអង្គ មិនបានទតឃើញសេចក្តីពិត
លោកយេរេមាប្រើសំនួរដើម្បីបញ្ជាក់ថា
អ្វីដែលព្រះអម្ចាស់សព្វព្រះហឫទ័យនិងសេចក្តី។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សមានភាពស្មោះត្រង់»។
ព្រះអង្គបានវាយគេ តែគេមិនឈឺអ្វីសោះ
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គដាក់ទោសដល់មនុស្ស តែគេមិនបានយកចិត្តទុកដាក់ឡើយ»។
ព្រះអង្គបានធ្វើឲ្យគេអន្តរធានទៅ
«ត្រូវបានបំភ្លាញទាំងស្រុង»
ទទួលសេចក្តីប្រៀនប្រដៅ
«ដើម្បីរៀនពីមេរៀនរបស់គេ»
គេបានតាំងមុខរឹងជាងថ្ម
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេក្លាយទៅជារឹង ចចេសខ្លាំង»
Jeremiah 5:4
នោះខ្ញុំបានថា
លោកយេរេមាកំពុងនិយាយ។
ប៉ុន្តែ អ្នកទាំងនោះបានព្រមគ្នាបំបាក់នឹម ហើយផ្តាច់ចំណងរបស់ចេញពីព្រះជាម្ចាស់ហើយ។
នឹមហើយច្រវាក់ដំណាងឲ្យច្បាប់ដែលបានធ្វើឲ្យព្រះជាម្ចាសទតមិនឃើញ ហើយប្រជាជននៃព្រះអង្គ។
ដូច្នេះ សិង្ហមួយ ... ឆ្កែព្រៃ ... ខ្លារខិនសម្ងំចាំ
សត្វទាំងនេះគឺគ្រោះថ្នាក់ដែលអាចសម្លាប់មនុស្សបាន។ អាចមានន័យថា ទី១ «សត្វព្រៃនឹងមកហើយសម្លាប់មនុស្ស» ឬទី២) «កងទ័ពរបស់សត្រូវនឹងមកសម្លាប់មនុស្ស»។
ព្រៃ
ព្រៃគុម្ពោតក្រាស ដែលធំឡើងជាមួយគ្នា។
ឆ្កែព្រៃ
ឆ្កែព្រៃគ្រោះថ្នាក់
សម្ងំចាំ
«រង់ចាំ»
ខ្លារខិន
សត្វព្រៃធំហើយគ្រោះថ្នាក់
គេមានច្រើនណាស់
មិនអាចរាប់អស់ទេ
Jeremiah 5:7
ម្តេចឲ្យយើងអត់ទោសឲ្យអ្នកបាន
ព្រះអម្ចាស់ប្រើសំណួរនេះដើម្បីបញ្ជាក់ថា
ព្រះអង្គគ្មានហេតុផលក្នុងការអត់ទោសដល់មនុស្សទាំងនេះឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារតែការដែលពួកគេបានធ្វើ យើងមិនអាចអត់ទោសដល់មនុស្សទាំងនេះទេ»។
ឲ្យអ្នក
ប្រជាជននៅក្រុងយេរូសាឡិម
កូនចៅរបស់អ្នក
ព្រះអម្ចាស់កំពុងនិយាយដល់ក្រុងយេរូសាឡិម គឺដូចជាស្ត្រីដែលមានកូនចៅ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៃក្រុងយេរូសាឡិម»។
យើងបានឲ្យគេស៊ីឆ្អែតជាបរិបូរណ៌
«យើងបានឲ្យគ្រប់យ៉ាងដែលគេត្រូវការ»។
ហើយប្រជុំគ្នាទាំងហ្វូងនៅឯផ្ទះស្រីពេស្យា
«ហើយបាននៅក្នុងក្រុមមនុស្សដ៏ធំនៅឯផ្ទះស្រីពេស្យា»
សេះ
«រួចរាល់ដើម្បីឡើងមេ»
ដៃគូ
ពេលសត្វពាកគ្នាដើម្បីបន្តពូជ
រកប្រពន្ធ របស់អ្នកជិតខាងគ្រប់គ្នា

generated on Wed Sep 10 16:16:32 2025

សេះឈ្មោលស្រែកឮខ្លាំងដើម្បីរកសេះញីពេលចង់ដេកជាមួយគ្នា។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រុសៗក៏ចង់ព្យាយាមដេកជាមួយប្រពន្ធរបស់អ្នកជិតខាងដែរ»។
តើយើងមិនត្រូវធ្វើទោសចំពោះអំពើយ៉ាងនោះ ... តើព្រលឹងយើងមិនត្រូវសងសឹក នឹងជនជាតិណាយ៉ាងដូច្នេះទេឬ?
ព្រះអម្ចាស់ប្រើសំណួរនេះដើម្បីបញ្ជាក់ថា អ្វីដែលពួកគេកំពុងធ្វើគឺអាក្រក់ណាស់
ហើយព្រះនឹងមិនមានសេចក្តីមេត្តា និងដកការដាក់ទោសពីពួកគេឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារពួកគេធ្វើការទាំងនេះ
យើងនឹងជំនុំជម្រះគេ... យើងនឹងសងសឹកឲ្យខ្លួនយើង
ហើយទាស់ជាមួយពួកគេ»។
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
Jeremiah 5:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល
ចូរឡើងទៅលើកំផែងទីក្រុងរបស់គេ
«ឡើងទៅលើជញ្ជាំងក្រុង»។
ព្រះអម្ចាស់បានប្រៀបធៀបទីក្រុងយេរូសាឡិមទៅនឹងរោងទំពាំងបាយជូរដែលមានរបង
ចូរឡើងទៅ
ព្រះអម្ចាស់កំពុងនិយាយដល់សត្រូវរបស់ប្រជាជនដែលរស់នៅក្នុងក្រុងយេរូសាឡិម។
ហើយបំផ្លាញទៅ តែកុំឲ្យអស់រលីងឡើយ
«កុំឲ្យបំផ្លាញទាំងស្រុងដល់ពួកគេ»
ចូរកាច់ខ្នែងគេចេញ ព្រោះខ្នែងទាំងនោះមិនមែនជារបស់ព្រះអម្ចាស់
ព្រះអម្ចាស់ប្រៀបធៀបពីរបៀបដែលសត្រូវរបស់ក្រុងយេរូសាឡិម
នឹងឡើងទៅលើប្រជាជនរបស់គេ ដូចជាគេកាត់ខ្នែងដើមទំពាំងបាយជូរដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«ឡើងជិះលើពួកមនុស្សអាក្រក់ដោយសារពួកគេមិនបានចេញមកពីព្រះអម្ចាស់»។
ដ្បិត ពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដា
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតប្រជាជននៃអ៊ីុស្រាអែលហើយនិងយូដា»។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
ពួកគេបានបដិសេធយើង
អាចបកប្រែបានដូចជា «ពួកគេបានកុហកអំពីយើង»។
ព្រះអង្គមិនធ្វើអ្វី
«ព្រះអម្ចាស់មិនមានពិតនោះទេ»។ អាចបកប្រែបានដូចជា
«ព្រះអង្គនឹងមិនធ្វើការទាំងនេះទេ» ឬ «ព្រះអង្គមិនអាចធ្វើអ្វីទាំងនេះ»
ក៏គ្មានសេចក្តីអាក្រក់ណាធ្លាក់មកលើយើងរាល់គ្នា យើងនឹងមិនត្រូវឃើញដាវ ឬគ្រាអំណត់
ប្រយោគទាំងពីរនេះនិយាយដូចគ្នា ហើយទីពីរគឺច្បាស់ជាងប្រយោគទី ១។
សេចក្តីអាក្រក់ណាធ្លាក់មកលើយើង
ការបង្ហាញន័យនេះ «ការអាក្រក់នឹងមិនកើតឡើងដល់យើងទេ»។
មិនត្រូវឃើញដាវ ឬគ្រាអំណត់ឡើយ
ការបកប្រែរបៀបផ្សេងទៀត: «ហើយយើងនឹងមិនឆ្លងកាត់ចម្បាំងឬគ្រាអំណត់»។
Jeremiah 5:14
ដោយព្រោះអ្នករាល់គ្នា
ពាក្យថា «អ្នក» សំដៅដល់ប្រជាជនអ៊ីស្រាអែលហើយប្រជាជនយូដា។
មានព្រះបន្ទូលថា
សូមមើលអ្វីដែលប្រជាជនបាននិយាយក្នុងជំពូក ៥:១០
មើល៍
ការបកប្រែរបៀបផ្សេងទៀត: «មើល» ឬ «ស្តាប់» ឬ
«តាំងចិត្តដើម្បីអ្វីដែលនឹងជិតនិងកើតឡើងជាមួយអ្នក»
យើងនឹងធ្វើឲ្យពាក្យ ដែលយើងដាក់នៅមាត់អ្នក បានដូចជាភ្លើង
«យើងនឹងធ្វើឲ្យពាក្យដែលយើងមាន នោះអ្នកនឹងនិយាយ
សម្រាប់យើងដូចជាភ្លើងឆេះ»
ដាក់នៅមាត់អ្នក
ពាក្យថា «របស់អ្នក» សំដៅដល់លោកយេរេមា។ សម្រាប់អ្នកទៅនិយាយ»
ជនជាតិនេះ
ប្រជាជនរបស់អ៊ីុស្រាអែល
នឹងឆេះបន្សុសគេអស់
«ចំណែកទីមួយគឺបានឆេះប្រជាជនរបស់អ៊ីុស្រាអែល»
ព្រះបន្ទូលព្រះអម្ចាស់នឹងបំផ្លាញដល់ប្រជាជនដូចជាភ្លើងឆេះឈើ។
ការបកប្រែរបៀបផ្សេងទៀត:
«ដោយព្រោះអ្នកនឹងបំផ្លាញប្រជាជនរបស់អ៊ីុស្រាអែល
នៅពេលអ្នកថ្លែងពាក្យរបស់យើង»។
មកលើអ្នករាល់គ្នា
«ដើម្បីវាយប្រហារ»។ ពាក្យថា «អ្នក» សំដៅដល់ប្រជាជនរបស់អ៊ីុស្រាអែល។
ពួកវង្សអ៊ីស្រាអែល
សូមមើលពីរបៀបបកប្រែក្នុងជំពូក ២:៤
គឺជាជនជាតិមួយយ៉ាងស្ងិតស្ងាញ ជាជនជាតិចាស់បុរាណ
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នាហើយបញ្ជាក់ថា
ជនជាតិនេះកើតមានឡើងយូរប៉ុន្មានហើយ។ ការបកប្រែរបៀបផ្សេងទៀត:
«នេះបានកើតឡើងក្នុងសម័យចាស់ហើយជនជាតិយូរអង្វែង!»
ជនជាតិមួយពីឆ្ងាយ
«ជនជាតិយូរអង្វែង» ឬ «ជាជនជាតិមួយខ្លាំង»
គឺជាជនជាតិមួយយ៉ាងស្ងិតស្ងាញ ជាជនជាតិចាស់បុរាណ ដែលអ្នកមិនស្គាល់ភាសារបស់គេទេ ក៏
ស្តាប់ពាក្យគេមិនបាន
ឃ្លាទីពីរនិយាយក្នុងការអវិជ្ជមានពាក្យដូចគ្នា
ឃ្លាទីមួយដែលបាននិយាយពាក្យវិជ្ជមាន។
បានបញ្ជាក់ថាពួកគេមិនអាចស្គាល់ពីភាសារបស់ប្រជាជន
ដែលជាមនុស្សរស់នៅក្នុងជនជាតិនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«នេះគឺជាជនជាតិមួយដែលអ្នកមិនអាចយល់ភាសាគេបាន»។
Jeremiah 5:16
បំពង់ព្រួញគេ ដូចជាផ្នូរខ្មោចចំហ
គ្របព្រួញដែលបានចេញពីបំពង់
នឹងសម្លាប់មនុស្សជាច្រើនហើយក៏នឹងបញ្ជូនពួកអ្នកទាំងនោះទៅក្នុងផ្នូរផងដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ជនជាតិនោះនឹងប្រើព្រួញសម្លាប់មនុស្សជាច្រើន»។
ផ្លែព្រួញ
ពាក្យថា «របស់វា»
សំដៅដល់ជនជាតិមួយដែលព្រះអម្ចាស់នឹងនាំមកដើម្បីវាយប្រហារអ៊ីុស្រាអែល។
បំពង់ព្រួញ
ប្រអប់មួយសម្រាប់ដាក់ផ្លែព្រួញ
គេនឹងស៊ីផលចម្រូត
ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះហើយកងទ័ពរបស់ជនជាតិនឹងត្រូវស៊ីអ្វីដែលអ្នកបានគិតថានឹងច្រូតកាត់»។
គេនឹងស៊ី
ពាក្យថា «ពួកគេ» សំដៅដល់កងទ័ពរបស់ជនជាតិមួយ។
គេនឹងវាយរំលំទីក្រុងមានកំផែង ដែលជាទីទុកចិត្តរបស់អ្នកនោះ ដោយសារដាវ
ពាក្យថាតំណាងឲ្យទៅលើគ្រប់ទាំងគ្រឿងសស្ត្រាវុធផ្សេងៗ
ដែលមនុស្សបានប្រើក្នុងសម្បាំង។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងប្រើគ្រប់ទាំងគ្រឿងសស្ត្រាវុធរបស់គេ
ដើម្បីវាយចាប់យកទីក្រុងដែលខ្លាំងរបស់អ្នក»។
ដែលជាទីទុកចិត្តរបស់អ្នក
«ដែលអ្នកគិតថាវាមាំបំផុត ហើយនឹងការពារអ្នកបានឲ្យមានសុវត្ថិភាព»
Jeremiah 5:18
ទោះបើមានគ្រានោះក៏ដោយ
ឃ្លាថា «គ្រានោះ» គឺសំដៅដល់ពេលមួយដែលជនជាតិមកពីឆ្ងាយ
ហើយនឹងមកវាយបម្រាបប្រជាជនអ៊ីស្រាអែល។
ព្រះអម្ចាស់មានព្រះបន្ទូលថា
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
មិនបំផ្លាញអ្នករាល់គ្នាឲ្យអស់រលីង
«នឹងមិនបំផ្លាញ»
វានឹងកើតឡើងនៅពេលអ្នក
«ពេលអ្នក» ឬ «ពេលវាកើតឡើងដល់អ្នក»
ប្រព្រឹត្តការយ៉ាងនេះ
ព្រះអម្ចាស់បញ្ជូនកងទ័ពបរទេសឲ្យមកវាយប្រហារអ៊ីុស្រាអែល។
ទៅគោរពព្រះដទៃ
ការកែសំរួលថ្មីក្នុងការបកប្រែជាច្រើន «បម្រើព្រះរបស់បរទេស» ប៉ុន្តែ
នេះគឺជាអត្ថន័យក្នុងការថ្វាយបង្គំពួកគេ។
Jeremiah 5:20

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ:
ព្រះអម្ចាស់កំពុកមានព្រះបន្ទូលទៅប្រជាជនអ៊ីុស្រាអែល។
ចូរថ្លែងសេចក្តីនេះ
«ប្រាប់ពីការនេះ»
ពួកវង្សយ៉ាកុប
សូមមើលពីរបៀបបកប្រែក្នុងជំពូក ២:៤
ហើយប្រកាសប្រាប់នៅក្នុងពួកយូដា
«ប្រកាសវានៅក្នុងយូដា»
មនុស្សល្ងីល្ងើ ហើយគ្មានចំណោះដឹង
«មនុស្សដែលគ្មានគំនិត»។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សដែលមិនអាចមានចំណេះដឹង»។
ពួកអ្នកដែលមានភ្នែក តែមើលមិនឃើញ
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាមានភ្នែក
ប៉ុន្តែអ្នកមិនអាចយល់ពីអ្វីដែលយើងកំពុងធ្វើ»
មានត្រចៀក តែស្តាប់មិនឮ
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាមានត្រចៀក
ប៉ុន្តែអ្នកមិនអាចយល់ពីអ្វីដែលយើងកំពុងធ្វើ»
ព្រះអម្ចាស់មានព្រះបន្ទូល
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧
តើអ្នករាល់គ្នាមិនកោតខ្លាចដល់យើង...ចំពោះយើង?
ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីបញ្ជាក់ថា ដែលមនុស្សសែនល្ងង់នេះ
ដោយព្រោះពួកគេមិនកោតខ្លាចព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«វាគឺជាការល្ងង់ដែលអ្នករាល់មិនកោតខ្លាចយើង...ចំពោះយើង!»
ញាប់ញ័រនៅចំពោះយើង
ការបកប្រែរបៀបផ្សេងទៀត: «ឬ ញ័រដោយភ័យខ្លាចព្រោះតែយើង»។
យើងបានដាក់ខ្សាច់ធ្វើជាព្រំខណ្ឌសមុទ្រ
«យើងបានយកខ្សាច់ធ្វើដូចជាបែងចែករវាងសមុទ្រ»
ដោយបញ្ញត្តិដ៏នៅជានិច្ច ដើម្បីមិនឲ្យហូររំលង
«ការដែលនៅគង់ជារៀងរហូត ហើយកំណត់វាមិនឲ្យមានការឆ្លងកាត់»
ទោះបើរលកបោកមាត់ច្រាំង
«បោកបក់ទៅក្រោយហើយទៅមុខ»
គង់តែនឹងឈ្នះមិនបាន
ការបកប្រែរបៀបផ្សេងទៀត: «មិនអាចជោគជ័យនិងយកឈ្នះព្រំខណ្ឌឡើយ»។
Jeremiah 5:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់កំពុកមានព្រះបន្ទូលទៅប្រជាជនអ៊ីុស្រាអែល។
មានចិត្តរឹងចចេស
ការបកប្រែរបៀបផ្សេងទៀត: «ការរឹងចចេស ហើយនិងបះបោរ»។
គេបានបះបោរចេញបាត់ទៅ
«ពួកគេបែចេញហើយទៅបាត់»។ ការបកប្រែរបៀបផ្សេងទៀត:
«គេមិនស្តាប់បង្គាប់ឬស្តាប់បង្គាប់»។
គេក៏មិនដែលនឹកក្នុងចិត្តថា
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនបានគិតអំពីខ្លួនពួកគេ»។
រក្សាទុកប៉ុន្មានអាទិត្យ ដែលសម្រាប់ច្រូតកាត់ដល់យើង
«ហើយធ្វើប្រកដសម្រាប់យើងដែលនៅក្នុងអាទិត្យនៃការច្រូតកាត់
វានឹងកើតឡើងក្នុងពេលគេតម្រូវឲ្យធ្វើ»
អំពើទុច្ចរិតរបស់អ្នករាល់គ្នា
ពាក្យថា «របស់អ្នក» សមដៅដល់កូនចៅរបស់លោកយ៉ាកុប
ហើយនិងប្រជាជនរបស់យូដា។ អំពើបាបរបស់អ្នក»
រការទាំងនោះ
ការបំផ្លាញ ហើយនិងច្រូតកាត់
Jeremiah 5:26
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
ដ្បិត នៅក្នុងប្រជារាស្ត្រយើង ឃើញមានមនុស្សដែលប្រព្រឹត្តអាក្រក់
ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតយើងបានរកឃើញមនុស្សអាក្រក់នៅក្នុងចំណោមប្រជាជន»។
គេដាក់អន្ទាក់ចាប់មនុស្ស
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបានរៀបចំរបស់ឡើង
ដូច្នេះហើយគេនឹងយកការចំណេញពីមនុស្ស»។
គេបានត្រឡប់ជាធំ ហើយជាអ្នកមានផង
«បានក្លាយទៅជាអំណាចហើយមានទ្រព្យ»
ឡើងសាច់ធាត់ ហើយរស់នៅផូផង់
គឺជា «ហើយរលាប» ឬ «ហើយរលោង»។
ប្រជាជនមើលទៅស្រស់ថ្លាដោយសារមានសាច់ច្រើនវាបានគ្រប់បាំងឆ្អឹងរបស់ពួកគេ។
គេប្រព្រឹត្តអំពើអាក្រក់ហួសល្បត់
«ពួកគេធ្វើការកាន់តែអាក្រក់ជាងការអាក្រក់ជាងមុនទៀត»។
កាន់ក្តីជំនួសពួកកំព្រា
ការនេះសំដៅដល់ចៅក្រម ដែលកូនកំព្រាសុំឲ្យកាត់ក្តីឲ្យពួកបានសំរេច។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិនគាំទ្ររឿងក្តីដែលពួកក្មេងកំព្រានាំមកនោះទេ»។
តើយើងមិនត្រូវកាត់ទោស...ជនជាតិយ៉ាងនោះទេឬ?
របៀបដើម្បីបកប្រែ «តើមិនគួរឲ្យយើងដាក់ទោស...ជនជាតិដែលបែនេះ?»
ក្នុងជំពូក ៥:៧
Jeremiah 5:30
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
មានការដ៏អស្ចារ្យ ហើយគួរស្ញែងខ្លាច បានកើតឡើង
«មានការយល់សុបិន្ត ហើយចេស្តាដ៏អាក្រក់ដែលបានកើតឡើង»
នៅក្នុងទឹកដី
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងទឹកដីរបស់អ៊ីុស្រាអែល»។
ពួកព្យាការីបានថ្លែងទំនាយកុហក
«ពួកព្យាការីកុហក»
ដោយកម្លាំងដៃខ្លួន
«វាពឹងលើការណែនាំរបស់ពួកព្យាការី»
ដូច្នេះ ដល់ចុងបំផុត តើនឹងមានអ្វីកើតឡើង
«ប៉ុន្តែអ្នកនឹងធ្វើអ្វីនៅចុងបញ្ចប់នៃការទាំងនេះ?» ព្រះអម្ចាស់បានប្រើសំនួរនេះ
ដើម្បីបញ្ជាក់ថាមនុស្សនឹងសោកស្តាយនូវអំពើអាក្រក់
ហើយផងដែលបាននោះការដាក់ទោស។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែអ្នកនឹងក្តុងបញ្ចាហើយសោកស្តាយជាមួយការប្រព្រឹត្ត
ពេលនៅចុងបញ្ចប់គឺការដាក់ទោសមែនទេ?»
ចុងបំផុត
ឃ្លា «ចុងបំផុត»
សំដៅដល់ការដាក់ទោសដែលជាផងបានពីការអាក្រក់ដែលមនុស្សបានធ្វើ។

---

6 [1]ចូរស្វែងរកទីសុវត្ថិភាព ពួកកូនចៅបេនយ៉ាមីនអើយ ចូរចេញពីក្រុងយេរូសាឡិមទៅ ហើយផ្លុំត្រែនៅត្រង់តួអា។ ត្រូវដុតភ្លើងទុកជាទីសម្គាល់ នៅត្រង់បេត ហាកេរែម
ដែរ ពីព្រោះមានសេចក្តីអាក្រក់បានចេញពីទិសខាងជើង ព្រមទាំងការបំផ្លាញយ៉ាងធំ។[2]ចំណែកកូនស្រីស៊ីយ៉ូនដ៏ល្អរុងរឿងនោះ យើងនឹងបំផ្លាញចោល។[3]អ្នកគង្វាល
នឹងនាំហ្វូងចៀមរបស់គេទៅក្រុងនោះ គេនឹងបោះជំរំនៅជុំវិញ គេនឹងឃ្វាលហ្វូងចៀមរបស់គេ តាមកន្លែងរៀងៗខ្លួន។
[4]«ចូរចាត់ចែងច្បាំងនឹងទីក្រុងនេះចុះ ចូររៀបចំ យើងនឹងឡើងទៅក្នុងវេលាថ្ងៃត្រង់ វរហើយយើង ពីព្រោះថ្ងៃជ្រេហើយ ស្រមោលល្ងាចក៏កាន់តែវែងទៅ។[5]ប៉ុន្តែ យើងនឹង
ឡើងទៅទាំងយប់ យើងនឹងបំផ្លាញអស់ទាំងបន្ទាយរបស់ពួកគេ»។
[6]ដ្បិតព្រះអម្ចាស់នៃពិភពទាំងមូល ព្រះអង្គបានមានព្រះបន្ទូលដូច្នេះថា៖ ចូរកាប់ដើមឈើ ហើយជីកស្នាមភ្លោះ ទាស់នឹងក្រុងយេរូសាឡិមទៅ នេះហើយជាទីក្រុងដែលត្រូវ
ទោស ដ្បិតនៅកណ្តាលនោះ មានសុទ្ធតែការសង្កត់សង្កិន។[7]អណ្តូងផុសទឹកចេញមកជាយ៉ាងណា ទីក្រុងនេះក៏ផុសចេញជាអំពើអាក្រក់យ៉ាងនោះដែរ មានឮសុទ្ធតែការ
ច្រឡោត និងការបំផ្លាញ ឃើញមានតែជំងឺឈឺ និងរបួសនៅមុខយើងជានិច្ច។[8]ក្រុងយេរូសាឡិមអើយ ចូរឲ្យអ្នករាងចាល បើមិនដូច្នោះក្រែងយើងចាកចេញពីអ្នក ហើយនិង
បំផ្លាញអ្នក ឲ្យទៅជាទឹកដីចោលស្ងាត់ទទេ»។

generated on Wed Sep 10 16:16:32 2025

[9]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «ពួកគេនឹងប្រឡេះពួកសំណល់ជនជាតិអ៊ីស្រាអែលអស់រលីង ដូចជាផ្លែទំពាំងបាយជូរ ចូរដាក់ដៃអ្នកទៅក្នុងកញ្ជើវិញ
ដូចជាអ្នកបេះផ្លែ។[10]តើឲ្យខ្ញុំនិយាយ ហើយធ្វើបន្ទាល់ដល់អ្នកណា ដើម្បីឲ្យគេបានស្តាប់តាម មើលត្រចៀកគេមិនបានកាត់ស្បែកទេ គេស្តាប់មិនឮ
និងមិនយកចិត្តទុកដាក់ឡើយ មើល! ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដើម្បីកែតម្រូវពួកគេ ប៉ុន្តែពួកគេមិនចង់បានឡើយ»។
[11]ដូច្នេះ ខ្លួនខ្ញុំមានពេញដោយសេចក្តីក្រោធ របស់ព្រះអម្ចាស់។ ខ្ញុំហត់នឿយនឹងការទ្រាំទៀតហើយ។ ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា៖ «ចូរចាក់ទៅលើកូនក្មេងតាមផ្លូវ
ហើយទៅលើពួកកំលោះៗ។ ដ្បិតគ្រប់គ្នានឹងត្រូវចាប់យកប្រពន្ធរបស់ពួកគេ ហើយទាំងមនុស្សចាស់ជរាផង។[12]ផ្ទះពួកគេនឹងក្លាយជារបស់អ្នកដទៃ ព្រមទាំងស្រែចម្ការ
និងប្រពន្ធរបស់គេដែរ។ ដ្បិតយើងនឹងលូកដៃទៅលើពួកអ្នកជនជាតិ នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់។
[13]នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ គឺចាប់តាំងពីអ្នកតូចបំផុត ដល់អ្នកធំបំផុតក្នុងពួកគេ សុទ្ធតែលង់ទៅក្នុងសេចក្តីលោភ ហើយចាប់តាំងពីព្យាការីទៅដល់បូជាចារ្យ គ្រប់គ្នា
គឺជាអ្នកបោកប្រាស់។[14]ពួកគេបានព្យាបាលរបួសប្រជារាស្ត្រយើង តែបន្តិចបន្តួចទេ ដោយនិយាយថា សុខសាន្ត! សុខសាន្ត ក្នុងពេលដែលគ្មានសេចក្តីសុខសោះ។[15]គេ
បានប្រព្រឹត្តការគួរស្អប់ខ្ពើម តើគេមានសេចក្តីខ្មាសឬទេ? ពួកគេមិនបានខ្មាសទេ ទាំងមុខក្រាសផងដែរ! ដូច្នេះ គេនឹងដួលទៅជាមួយអ្នកដែលវិនាស
ពួកគេដួលចុះនៅពេលជំរុំជម្រះ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។
[16]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ ចូរអ្នករាល់គ្នាឈរតាមផ្លូវ ហើយមើលចុះ ត្រូវឲ្យសួររកផ្លូវចាស់ទាំងប៉ុន្មាន មើលមានផ្លូវណាដែលល្អ រួចដើរតាមផ្លូវនោះចុះ នោះអ្នក
រាល់គ្នានឹងបានសេចក្តីសម្រាកដល់ព្រលឹង តែគេប្រកែកថា៖ យើងរាល់គ្នាមិនព្រមដើរតាមទេ។[17]យើងក៏បានដាក់ពួកចាំយាមឲ្យត្រួតលើអ្នករាល់គ្នា ឲ្យប្រាប់ថា៖ ចូរប្រុង
ស្តាប់សូរត្រែ តែគេប្រកែកថា៖ យើងមិនព្រមស្តាប់ទេ។[18]ដូច្នេះ ចូរស្តាប់ចុះ អស់ទាំងជនជាតិ ហើយក្រុមជំនុំអើយ ចូរដឹងពីសេចក្តីដែលត្រូវកើតដល់ពួកគេ។[19]ផែនដីអើយ
ចូរស្តាប់ចុះ! មើល៍ យើងនឹងនាំសេចក្តីអាក្រក់មកលើជនជាតិនេះ គឺជាផលនៃគំនិតរបស់គេ ដោយព្រោះគេមិនបានស្តាប់តាមពាក្យរបស់យើងទេ ឯចំណែកក្រឹត្យវិន័យ
របស់យើង នោះគេបានបោះបង់ចោលហើយ។
[20]តើមានប្រយោជន៍អ្វីដែលមានកំញាន មកពីជនជាតិសេបា និងឫសកន្ធាយពីជនជាតិឆ្ងាយ មកឲ្យយើងដូច្នេះ? យើងមិនទទួលតង្វាយដុតរបស់អ្នករាល់គ្នាទេ ហើយ
យញ្ញបូជារបស់អ្នក ក៏មិនគាប់ចិត្តដល់យើងដែរ។[21]ហេតុនោះបានជាព្រះអម្ចាស់ មានព្រះបន្ទូលដូច្នេះថា៖ មើលយើងនឹងដាក់ថ្មចំពប់មួយនៅមុខជនជាតិនេះ ហើយទាំង
ឪពុក ទាំងកូននឹងចំពប់លើថ្មនោះជាមួយគ្នា ហើយទាំងអ្នកជិតខាង និងមិត្តសម្លាញ់របស់គេផង គេនឹងត្រូវវិនាសទាំងអស់។[22]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ មាន
ជនជាតិមកពីទឹកដីខាងជើង គឺជនជាតិមួយយ៉ាងធំ ដែលនៅចុងផែនដីនឹងត្រូវរកម្រើកឡើង។
[23]គេចាប់កាន់ធ្នូ និងលំពែង ជាជនជាតិសាហាវ ឥតត្រាប្រណីសំឡេងគេក៏លាន់ឮសន្ធឹកដូចជាសមុទ្រ គេសុទ្ធតែជិះសេះតម្រៀបជាក្បួនទ័ព ដូចជាមនុស្សដែលចូលទៅ
ច្បាំង ឱកូនស្រីស៊ីយ៉ូនអើយ គឺច្បាំងនឹងអ្នកហើយ។[24]យើងរាល់គ្នាបានឮសូរពីការនោះហើយ ដៃយើងក៏បានខ្សោយទៅ ហើយយើងមានការព្រួយបារម្ភព្រមទាំងឈឺចាប់
ដូចជាស្ត្រីដែលរៀបនឹងសម្រាលកូន។
[25]កុំចេញទៅចម្ការឡើយ ក៏កុំឲ្យដើរតាមផ្លូវដែរ ដ្បិតដាវរបស់ពួកខ្មាំងសត្រូវ និងសេចក្តីស្ញែងខ្លាច បាននៅពាសពេញជុំវិញហើយ។[26]កូនស្រីនៃប្រជារាស្ត្ររបស់យើងអើយ
ចូរស្លៀកសំពត់ធ្មៃ ហើយនៀលក្នុងផេះចុះ ត្រូវកាន់ទុក្ខ ដូចជាកាន់ទុក្ខនឹងកូនតែមួយ ជាទំនួញយ៉ាងជូរចត់បំផុត ពីព្រោះមេបំផ្លាញនឹងមកលើយើងរាល់គ្នាភ្លាមៗ។
[27]«យើងបានតាំងអ្នកយេរេមា ឲ្យបានដូចជាប៉មចាំយាម ហើយជាបន្ទាយនៅកណ្តាលប្រជារាស្ត្រយើង ដើម្បីឲ្យអ្នកបានស្គាល់ ហើយល្បងលផ្លូវប្រព្រឹត្តរបស់គេ។[28]គេសុទ្ធ
តែជាពួកបះបោរ គេដើរទៅមក ទាំងមួលបង្កាច់មនុស្ស គេសុទ្ធតែជាលង្ហិន និងដែក គេប្រព្រឹត្តសេចក្តីដ៏លាមកអាក្រក់គ្រប់ៗគ្នា។[29]ស្នប់ក៏សប់យ៉ាងខ្លាំង សំណបានសូន្យ
បាត់ទៅ ការដែលគេនៅតែសម្រង់ទៀត នោះជាឥតអំពើសោះ ដ្បិតពួកអាក្រក់មិនទាន់បានដកចេញនៅឡើយ។[30]មនុស្សទាំងឡាយនឹងហៅគេជាអាចម៍ប្រាក់ ពីព្រោះ
ព្រះអម្ចាស់បានបោះបង់គេហើយ»។

Jeremiah 6:1

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូល។

ចូរស្វែងរកទីសុវត្ថិភាព

«ទីជម្រកថែទាំ»

ហើយផ្លុំត្រែនៅត្រង់តូអា

ការបកប្រែរបៀបផ្សេងទៀត:

«ប្រជាជនដែលរស់នៅក្នុងទីក្រុងតូអារៀបចំដើម្បីច្បាំង»

តូអា

ជាឈ្មោះរបស់ក្រុងមួយដែលមានចំងាយ១៨គីឡូរ នៅទិសខាង
ជើងពីយេរូសាឡិម។ ឈ្មោះនេះមានន័យថា៖ «ស្នែងផ្លុំត្រែ»។

ទីសម្គាល់ នៅត្រង់បេត ហាកេរែម

ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនដែលរស់នៅក្នុងទីក្រុងបេត
ហាកេរែមរៀបចំដើម្បីឡោមព័ទ្ធ»

បេត ហាកេរែម

ជាឈ្មោះរបស់ក្រុងមួយដែលមានចំងាយ១០គីឡូម៉ែត្រ នៅទិសខាង
ជើងពីយេរូសាឡិម។ ឈ្មោះនេះមានន័យថា៖ «កន្លែងចម្ការទំពាំងបាយជូរ»។

ទីសម្គាល់

ការបកប្រែរបៀបផ្សេងទៀត: «ទី
សម្គាល់ដែលនឹងរំលឹកដល់ប្រជាជនដោយគ្រោះថ្នាក់មកដល់»។

ពីព្រោះមានសេចក្តីអាក្រក់បានចេញ

ការបកប្រែរបៀបផ្សេងទៀត:

«តាំងពីពេលដែលប្រជាជនឃើញមហន្តរាយមកដល់»។

បំផ្លាញយ៉ាងធំ

«ការបំផ្លាញដ៏ធំ»

ចំណែកកូនស្រីស៊ីយ៉ូនដ៏ល្អរុងរឿងនោះ

ព្រះអម្ចាស់ពណ៌នាពីក្រុងយេរូសាឡិម ដូចជាមនុស្សស្រី។

ការបកប្រែរបៀបផ្សេងទៀត: «ចំណែកកូនស្រីស៊ីយ៉ូនដ៏ល្អរុងរឿងនោះ
ហើយដូចជាស្ត្រីដែលទន់ភ្លន់»។

កូនស្រីស៊ីយ៉ូន

សូមមើលពីរបៀបបកប្រែក្នុងជំពូក ៤:៣០

អ្នកគង្វាលនឹងនាំហ្វូងចៀមរបស់គេទៅក្រុងនោះ

ស្តេចបានមានបន្ទូលទៅអ្នកគង្វាលនៅលើប្រជាជន។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេច ហើយនិងទាហានរបស់ទ្រង់ឡោមព័ទ្ធក្រុងយេរូសាឡិម»។

បោះជំរំនៅជុំវិញ

«នៅជិតហើយឡោមព័ទ្ធក្រុង»

គេនឹងឃ្វាលហ្វូងចៀមរបស់គេ តាមកន្លែងរៀងៗខ្លួន

ការបកប្រែរបៀបផ្សេងទៀត:

«ស្តេចនិមួយៗនឹងវាយប្រហារដោយទាហានរបស់ខ្លួន»។

Jeremiah 6:4

ព័ត៌មានទូទៅ:

ស្តេចដែលបានត្រឡប់មកពីចម្បាំងវិញបានមានបន្ទូលទៅទាហានដែលក្រោមព្រះអង្គ។

ថ្វាយខ្លួនរបស់អ្នកដល់ព្រះសម្រាប់ច្បាំង

កងទ័ពដែលចេញទៅច្បាំងព្យាយាមឲ្យប្រកដថាព្រះរបស់គេនឹងជួយដល់ពួកគេនៅក្នុងចម្បាំង
ដោយធ្វើការ បន់ស្រន ហើយនឹងថ្វាយផងដែរ។ ការបកប្រែរបៀបផ្សេងទៀត:
«រៀបចំខ្លួនអ្នកសម្រាប់សង្គ្រាម ដោយធ្វើខ្លួនឲ្យបរិសុទ្ធ
ហើយនិងថ្វាយយញ្ញបូជាដល់ព្រះផងដែរ»។

នឹងឡើង

«ងើបឡើង»

ថ្ងៃត្រង់

ការបកប្រែរបៀបផ្សេងទៀត: «នៅពេលថ្ងៃទោះបីជាវាក្តៅខ្លាំងក៏ដោយ»។

ពីព្រោះថ្ងៃជ្រេហើយ

«ថ្ងៃនោះជិតបញ្ចប់ហើយ»

ស្រមោលល្ងាច

«កាន់តែវែងទៅ»

ទៅទាំងយប់

ការបកប្រែរបៀបផ្សេងទៀត: «នៅពេលយប់ទោះបីជាវាងងឹតក៏ដោយ»។

បន្ទាយរបស់ពួកគេ

generated on Wed Sep 10 16:16:32 2025

«សំណងដែលរឹងមាំរបស់ក្រុងយេរូសាឡិម»
Jeremiah 6:6
កាប់ដើមឈើ
«រលំដើមឈើ» ព្រះអម្ចាស់មានព្រះបន្ទូលពីកងទ័ពនឹងវាប្រហារក្រុងយេរូសាឡិម។
ហើយជីកស្នាមភ្លោះ
«ជីកពំនូក» ទីដែលធ្វើពំនូកពីដី
នឹងអាចអនុញាតិឲ្យសត្រូវរាយចូលតាមជញ្ជាំងរបស់ក្រុងយេរូសាឡិម។
នៅកណ្តាលនោះ មានសុទ្ធតែការសង្កត់សង្កិន
«ដោយសារប្រជាជនពួកវាគឺតែងតែសង្កត់សង្កិនគ្នាទៅវិញទៅមក»
អណ្តូងផុសទឹកចេញមកជាយ៉ាងណា ទីក្រុងនេះក៏ផុសចេញជាអំពើអាក្រក់យ៉ាងនោះដែរ
អណ្តូងគឺគួរតែជាកន្លែងបង្កើតទឹក។ ក៏ជាអណ្តូងដែលតែងតែមានទឹករបស់វា
យេរូសាឡិមក៏នៅតែមានមនុស្សអាក្រក់របស់វាដែរ
ទោះបីព្រះអម្ចាស់បានដាក់ទោសវាក្តី។
មានឮសុទ្ធតែការច្រឡោត និងការបំផ្លាញ
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំឮតែសម្លេងឃោរឃៅ
ហើយការលួចប្លន់នៅក្នុងក្រុង»។
ឃើញមានតែជំងឺឈឺ និងរបួសនៅមុខយើងជានិច្ច
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំតែងតែឃើញជំងឺ ហើយនិងការឈឺចាប់»។
ក្រុងយេរូសាឡិមអើយ ចូរទទួលការកែតម្រូវ
ព្រះអម្ចាស់មានព្រះបន្ទូលទៅក្រុងយេរូសាឡិម ដូចដែលក្រុងនេះជាមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: អ្នកក្រុងយេរូសាឡិមសូមរៀនពីការជំនុំជម្រះ»។
ជាទឹកដីចោលស្ងាត់ទទេ
«គឺជាទឹកដីដែលគ្មានមនុស្សរស់នៅក្នុងនោះ»
Jeremiah 6:9
ពួកគេនឹងប្រឡោះពួកសំណល់ជនជាតិអ៊ីស្រាអែលអស់រលីង ដូចជាផ្លែទំពាំងបាយជូរ
ព្រះអម្ចាស់ប្រៀបធៀបមនុស្សដែលនៅសេសសល់
បន្ទាប់សត្រូវបានបំផ្លាញអ៊ីុស្រាអែលរួចហើយទៅនឹងផ្លែទំពាំងបាយជូរដែលនៅសល់ត្រូវបានច្រូត
ក្រោយមនុស្សបានច្រូតកាត់ហើយ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេពិតណាស់នឹងត្រឡប់មកប្រហារប្រជាជនដែលនៅសេសសល់ក្នុងអ៊ីស្រាអែលដូចដែលពួកគេ
ពួកគេប្រាកដនឹង
ពាក្យថា «ពួកគេ» សំដៅទៅសត្រូវដែលព្រះអម្ចាស់ចាត់ទៅបំផ្លាញអ៊ីុស្រាអែល។
ឈោងម្តងទៀត
ព្រះអម្ចាស់និយាយដល់សត្រូវដែលមកប្រហារអ៊ីុស្រាអែល។
ឈោងម្តងទៀតជាមួយដៃរបស់អ្នកដើម្បី បេះផ្លែទំពាំងបាជូរពីដើមរបស់វា
ការបកប្រែរបៀបផ្សេងទៀត:
«មកហើយប្រហារប្រជាជននៃអ៊ីស្រាអែលដែលនៅសេសសល់»។
អ្នកណាដែលខ្ញុំគួរប្រកាស
លោកយេរេមាកំពុងនិយាយ។
អ្នកណាដែលខ្ញុំគួរប្រកាសហើយរំលឹកដើម្បីពួកគេស្តាប់
ព្រះអម្ចាស់ប្រើសំនួរនេះ
ដើម្បីបញ្ជាក់ថាអត់មានជនជាតិអ៊ីស្រាអែលណាស្តាប់លោកទេ
ទោះបីបានរួចជីវិតពីការប្រហារនៃពួកសត្រូវក៏ដោយ។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មានអ្នកណានៅឲ្យខ្ញុំនិយាយ ហើយក៏មិននៅស្តាប់ខ្ញុំដែរ»។
មើល៍!
ព្រះអម្ចាស់ប្រើពាក្យ «មើល៍» ដើម្បីបញ្ជាក់អ្វីដែលព្រះអង្គមានបន្ទូល។
ត្រចៀករបស់គេមិនបានកាត់ស្បែក
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនព្រមស្តាប់» ឬ
«ពួកគេមិនព្រមស្តាប់បង្គាប់»។
ត្រចៀកពួកគេ
ពាក្យថា «ពួកគេ» សំដៅទៅប្រជាជននៃអ៊ីុស្រាអែល។
Jeremiah 6:11
ប៉ុន្តែ ខ្លួនខ្ញុំ
យេរេមាកំពុងនិយាយ។
ពេញទៅដោយសេចក្តីក្រោធរបស់ព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំពិតជាបានខឹងរួមជាមួយព្រះអម្ចាស់»។
ខ្ញុំបានព្យាយាមនៃការខំទ្រាំការនេះ
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំអស់កម្លាំងពីការសម្តែងចេញពីការខឹងនៃព្រះអម្ចាស់»
ចាក់វាទៅលើកូនក្មេងនៅតាមផ្លូវ
«កូនក្មេងនៅលើផ្លូវ» ឈរសម្រាប់ក្មេងៗដែលមកពីទីក្រុង។
ការបកប្រែរបៀបផ្សេងទៀត: «បង្ហាញពីកំហឹងរបស់ខ្ញុំដល់ក្មេងៗក្នុងទីក្រុងនេះ»
ដ្បិតគ្រប់មនុស្សប្រុសនឹងត្រូវចាប់យកប្រពន្ធរបស់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត:
«ពីព្រោះសត្រូវនឹងចាប់យកទោះបីមនុស្សប្រុសជាមួយប្រពន្ធរបស់គេ»។
គ្រប់ទាំងមនុស្សចាស់ជរាខ្លាំង
«ចាស់ជរាដោយឆ្នាំ» គឺជាប្រយោគមានន័យថា «ចាស់ខ្លាំង»។
វាធ្វើឲ្យឃ្លាកាន់តែងាយយល់ «មនុស្សចាស់»។ ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់មនុស្សចាស់ទាំងអស់»។
នឹងក្លាយជារបស់អ្នកដទៃ
«នឹងក្លាយទៅជាសម្បត្តិរបស់មនុស្សដទៃ»
ព្រមទាំងស្រែចម្ការ និងប្រពន្ធរបស់គេផងដែរ
ការបកប្រែរបៀបផ្សេងទៀត:
«ទាំងពីរគឺចម្ការហើយប្រពន្ធរបស់ពួកគេនឹងក្លាយជាសម្បត្តិនៃមនុស្សដទៃ»។
ដ្បិតយើងនឹងវាយប្រហារមនុស្សនៃទឹកដីនេះជាដៃរបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតយើងប្រើកម្លាំង
ដើម្បីប្រហារប្រជាជនដែលរស់នៅក្នុងទឹកដីនោះ»។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
Jeremiah 6:13
តាំងពីអ្នកតូចបំផុត ដល់អ្នកធំបំផុត
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជននៃអ៊ីុស្រអែលទាំងអស់ដែលនៅសេសសល់
ពីអ្នកមានអំណាចតិចទូចដល់អ្នកមានអំណាចខ្លាំង»។
លោភលន់ សម្រាប់ការមិនស្មោះត្រង់ចម្រើនឡើង
«ធ្វើការអាក្រក់ដាក់អ្នកដទៃទាក់ទងរឿងលុយ»
ប្រជារាស្ត្រយើង
«បញ្ហាធ្ងន់ប្រជារាស្ត្រយើងមាន»
ធ្វើឲ្យរងរបួសធ្ងន់ធ្ងរ ពួកគេបានបំផ្លាញរួចហើយ»។
ពួកព្យាការីហើយបូជាចារ្យប្រព្រឹត្តនឹងមនុស្សអ៊ីុស្រាអែលដែលមានបាប
ដូចពួកគេមានរបួសទិចតូច។ ការបកប្រែរបៀបផ្សេងទៀត:
«ដូចជាវាមិនជាក់លាក់»។
សុខសាន្ត សុខសាន្ត ក្នុងពេលដែលគ្មានសេចក្តីសុខ
«គ្រប់យ៉ាងគឺសុខសាន្ត! គ្រប់យ៉ាងគឺសុខសាន្ត! តែវាគឺមិនសុខសាន្ត»
ពួកគេបានអាម៉ាស់ ពេលអនុវត្តការគួរស្អប់ខ្ពើម?
«ពួកគេចុះចូលជាមួយអំពើបាបដ៏អាក្រក់ ហើយពួកគេមិនបានអាម៉ាស់»
ពួកគេមិនមានសេចក្តីខ្មាសទេ ពួកគេក៏មិនដឹងប្រែទឹកមុខដែរ
ប្រយោគទាំងពីរមានន័យស្រដៀងគ្នា។ ន័យទីពីរធ្វើឲ្យងាយយល់ជាងន័យទីមួយ។
«ពួកគេមិនបានខ្មាស់នៃអ្វីដែលគេបានធ្វើ»
ពួកគេដួល
ការបកប្រែរបៀបផ្សេងទៀត: «នឹងត្រូវសម្លាប់»។
នឹងដួលទៅជាមួយអ្នកដែលវិនាស
«នឹងជំពប់ដួល»។ ការបកប្រែរបៀបផ្សេងទៀត: «នឹងវិនាស» ឬ
«នឹងបាត់អំណាចរបស់ពួកគេ ហើយក្លាយជាគ្មានសង្ឃឹម»។
Jeremiah 6:16
ចូរឈរតាមផ្លូវ
ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់ប្រជារាជរបស់ព្រះអង្គ។
ចូរឈរតាមផ្លូវ...យើងនឹងមិនទៅទេ
ផ្លូវ ហើយផ្នត់សំដៅទៅលើផ្លូវជីវិតរបស់មនុស្សដែលរស់នៅ។
ព្រះអម្ចាស់ចង់ឲ្យអ៊ីុស្រាអែលសួររកផ្លូវល្អសម្រាប់ការរស់នៅនៃជីវិតរបស់ពួកគេ
ហើយឲ្យពួកគេរស់នៅតាមផ្លូវនោះផង។
សួររកផ្លូវចាស់ពីមុន
«សួរអំពីអ្វីដែលដូនតារបស់អ្នកបានធ្វើ»
យើងតាំងអ្នកសម្រាប់ចាំយាម...មិនព្រមស្តាប់ទេ
ព្រះអម្ចាស់ពិពណ៌នាព្យាការីដូចជាអ្នកយាមដែលចាត់ទៅរំលឹកដល់ប្រជាជននៃការគ្រោះថ្នាក់។
តាំងអ្នកសម្រាប់
ពាក្យថា «អ្នក» សំដៅទៅលើប្រជាជននៃអ៊ីុស្រាអែល។
ដើម្បីស្តាប់សូរត្រែ
«ចូរស្តាប់ដល់សម្លេងត្រែ។

generated on Wed Sep 10 16:16:32 2025

«ព្រះអម្ចាស់បង្គាប់ប្រជាជននៃអ៊ីស្រាអែលឲ្យយកចិត្តទុកដាក់ដល់ការរំលឹកដែលព្រះអង្គមានបន្ទូលមកតាមរយៈព្យាការី។
ដូច្នោះហើយ ជនជាតិទាំងឡាយចូរស្តាប់ចុះ! មើល៍! អ្នកគឺជាសាក្សីអ្វីដែលនឹងកើតឡើងដល់ពួកគេ។
ចូរស្តាប់ ផែនដីអើយ! មើល៍
ប្រយោគទាំងបីនេះ គឺបានប្រាប់ប្រជាជនដែលជាជនជាតិដទៃ
ដើម្បីធ្វើជាសាក្សីទៅអ្វីដែលព្រះអម្ចាស់នឹងធ្វើដល់អ្នកបះបោរនៃជនជាតិយូដា។
«អ្នកដែលជាជនជាតិដទៃឃើញអ្វីដែលយើងនឹងធ្វើដល់ប្រជារាជរបស់យើង»
យើងនឹងនាំសេចក្តីមហត្តរាយមកដល់ប្រជាជននេះ
«ឆាប់ៗយើងនឹងដាក់ទោសដល់ប្រជាជនទាំងនេះជាពិតប្រាកដ»
អ្នកគឺជាសាក្សី
«អ្នកដែលគឺជាសាក្សី»
ដែលនឹងកើតឡើងដល់ពួកគេ
ពាក្យថា «ពួកគេ» សំដៅទៅប្រជាជននៃអ៊ីស្រាអែល។
ចូរស្តាប់ ផែនដីអើយ
ការបកប្រែរបៀបផ្សេងទៀត: «ចូរស្តាប់ប្រជាជនដែលរស់នៅលើផែនដី»។
ផលនៃគំនិតរបស់គេ
ព្រះអម្ចាស់ប្រើពាក្យ «ផលផ្លែ»
ក្នុងផ្លូវនៃការសំដៅទៅលើលទ្ធិផលនៃការគិតរបស់គេ។
ការបកប្រែរបៀបផ្សេងទៀត:
«ការមហត្តរាយគឺជាសារៈសំខាន់បើនៃការគិតរបស់គេ»។
ពួកគេមិនស្តាប់តាមពាក្យឬក្រឹត្យវិន័យយើង តែផ្ទុយទៅវិញគេបដិសេធវិញ
«ពួកគេមិនបានស្តាប់បង្គាប់អ្វីដែលយើងបានប្រាប់ពួកគេដើម្បីធ្វើទេ»។
Jeremiah 6:20
តើកំញានអ្វីនេះដែលយកឡើងទៅសេបា មានន័យអីសម្រាប់យើង?
ឬការក្រអូបនេះចេញពីទឹកដីឆ្ងាយមក?
ការបកប្រែរបៀបផ្សេងទៀត: «យើងមិនចង់បានកំញានមកពីសេបាទេ
ឬប្រេងដែលល្អមកពីទឹកដីឆ្ងាយទេ»។ (សូមមើល:figs-rquestion)
ការក្រអូបនេះ
ខ្លឹនក្រអូបនេះគឺសម្រាប់ប្រើដើម្បីថ្វាយបង្គំព្រះជាម្ចាស់នៅព្រះវិហារ។
យើងមិនទទួលតង្វាយ
«កុំចង់ធ្វើឲ្យយើងរំភើប» ឬ «កុំធ្វើឲ្យយើងសប្បាយចិត្ត»
មើល
ពាក្យថា «មើល» នៅទីនេះបញ្ជាក់ដល់អ្វីដែលនឹងមកតាមក្រោយ។
ការបកប្រែរបៀបផ្សេងទៀត: «ទង្វើ»
យើងនឹងដាក់ឧបសគ្គឲ្យទាស់ប្រជាជននេះ
«យើងនឹងដាក់ឧបសគ្គពីខាងមុខនៃមនុស្សទាំងនេះ»។
ព្រះអម្ចាស់ពិពណ៌នាពីការពិបាកដែលព្រះអង្គនឹងប្រទានដល់ប្រជាជនអ៊ីស្រាអែល
«ឧបសគ្គជំពប់ដួល»។
ឧបសគ្គ
ការពិបាក
ដោយសារវា
«នៅលើពួកគេ»
ឪពុកហើយកូនជាមួយគ្នា
ការបកប្រែរបៀបផ្សេងទៀត: «ឪពុកហើយកូនជាមួយគ្នានឹងជំពប់ដួល»។
ហើយប្រជាជននិងអ្នកជិតខាង
«អ្នកជិតខាងហើយមិត្តសំឡាញ់របស់ពួកគេ»
ដោយដម្តៅមកពីទឹកដីឆ្ងាយ
«បានក្លាយជាសកម្មភាពដែលមកពីកន្លែងឆ្ងាយដល់ខាងជើង»
Jeremiah 6:23
ពួកគេនឹងយក
«ពួកគេនឹងកាន់យក»។ ពាក្យថា «ពួកគេ»
សំដៅដល់ប្រជាជនដែលនៅក្នុងកងទ័ពនៃជនជាតិមួយដែលនឹងមកពីទិសខាងជើង។
សំឡេងពួកគេដូចសន្ធឹកដូចជាសមុទ្រ
ការបកប្រែរបៀបផ្សេងទៀត: «សម្លេងដែលពួកគេឮដូចគ្រហឹមនៃសមុទ្រ»។
ក្នុងទ្រង់ទ្រាយច្បាំងដូចអ្នកចម្បាំង
«កងទ័ពគឺរៀបចំសម្រាប់ពួកបុរសរួចរាល់ដើម្បីចម្បាំង»
អ្នកស្រុកស៊ីយ៉ូន
«ប្រឆាំងនឹងអ្នក ក្រុងស៊ីយ៉ូន» ឬ «ទាក់ទងទៅនឹងការប្រហារអ្នកក្រុងស៊ីយ៉ូន»។
មើលពីរបៀបដែលអ្នកបានបកប្រែ «ក្រុងនៃស៊ីយ៉ូន» ក្នុង៤:៣០
យើងបានឮ
ពាក្យថា «យើង»
ពិតណាស់សំដៅលោកយេរេមាកំពុងនិយាយទៅប្រជាជនទាំងអស់នៃយូដា។
ធ្លាក់ទន់ នៅក្នុងការព្រួយបារម្ភ
«ភាពទន់ដោយសារយើងថប់បារម្ភ»
ពិបាកចិត្តនៅលើយើង
ការបកប្រែរបៀបផ្សេងទៀត: «ពួកយើងនៅក្នុងការពិបាកចិត្ត»។
ដូចជាស្រីដែលរៀបនឹងសម្រាលកូន
«ដូចជាស្ត្រីដែលសផ្តល់កំណើត»
Jeremiah 6:25
ពត៌មានទូទៅ:
ការនេះពិតណាស់ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់ក្រុងស៊ីយ៉ូនដែលនឹងបង្ហាញដល់ប្រជាជនទាំងអ
ទីក្រុងនៃប្រជារាស្ត្ររបស់យើង
សូមមើលការបកប្រែក្នុងជំពូកនេះ ៤:១១
ចូរស្លៀកសំពត់ធ្មៃ ហើយនៀលក្នុងធូលីដីនៃការបុណ្យសព្វ សម្រាប់កូនក្មេងមួយ
«កំសត់ខ្លាំងណាស់»
ព្រោះអ្នកបំផ្លាញនឹងមកលើយើងជាមួយរំពេច
«ពីព្រោះកងទ័ពរបស់សត្រូវនឹងប្រហារយើងជាមួយរំពេច»។
លោកយេរេមាបាននិយាយពាក្យនេះទៅកាន់ប្រជាជននៃយេរូសាឡិម។
Jeremiah 6:27
ពត៌មានទូទៅ:
ព្រះអម្ចាស់គឺកំពុងមានព្រះបន្ទូល។
អ្នកដែលបានសាកល្បងប្រជារាស្ត្រយើង ដូចជាអ្នកសាកល្បងលោហធាតុ
«អ្នកដែលបានសាកល្បងប្រជារាស្ត្រយើង»
ព្រះអម្ចាស់គឺបានបៀបធៀបលោកយេរេមាដូចជាសាកប្រាក់
ដើម្បីស្វែងរកតើវាសុទ្ធឬទេ។ មនុស្សគឺដូចជាប្រាក់ដែលលោក
យេរេមាបានសាកល្បង
ហើយអំពើបាបរបស់គេគឺមិនបានសុទ្ធទេដូចជាប្រាក់ដែរ។
នឹងត្រួតពិនិត្យ
«នឹងរកឃើញ»
ផ្លូវរបស់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «គឺជាកិច្ចការដែលពួកគេបានធ្វើ»។
ជាអ្នកនិយាយបង្កាច់បង្ខូចអ្នកផ្សេង
«ហើយតែងតែបង្ខូចមនុស្សដទៃ»
ជាលង្ហិនហើយនិងដែក
មួយណាក៏មិនល្អទាំងដែកនិងប្រាក់ព្រះអម្ចាស់ត្រូវការ។
ប្រាក់ដំណាងឲ្យសេចក្តីសុចរិតដែលព្រះអម្ចាស់ចង់បាន។
ការបកប្រែរបៀបផ្សេងទៀត: «ការមិនសុទ្ធហើយការអាក្រក់»។
ស្នប់បានធ្វើឲ្យភ្លឹងឆេះខ្លាំង ដែលអាចដុតពួកគេឲ្យឆេះ ហើយសំណក៏រលាយក្នុងអណ្តាតភ្លើងអស់
ភ្លើងដែលបានសម្រាំងប្រាក់គឺក្តៅដែលអាចឆេះស្នប់។
(ស្នប់គឺប្រើដើម្បីបក់ខ្យល់ឲ្យខ្លាំងឡើងទៅក្នុងការឆេះរបស់ភ្លើង។)
ការសម្រាំងបាននាំឲ្យប្រាក់អាចដេញចេញអ្វីដែលមិនសុទ្ធ
ប៉ុន្តែអ្នកសម្រាំងបានអស់សំណ។
ឃ្លានេះបញ្ជាក់ថាការសម្រាំងគឺបានធ្វើការយ៉ាងខ្លាំងដើម្បីសម្រាំងយកប្រាក់។
ការកែរឆ្ងៃបន្តក្នុងចំណោមពួកគេ
«អ្នកសម្រាំងបន្តដើម្បីសម្រាំងទៀត»
ពីព្រោះការក្រក់មិនបានដកចេញ
ការបកប្រែរបៀបផ្សេងទៀត: «ពីព្រោះចំណែកនៃការអាក្រក់មិនបានចេញទៅ»។
ពួកគេនឹងត្រូវហៅថាជាប្រាក់បដិសេធ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនឹងហៅពួកគេថា
គ្មានប្រាក់ដែលប្រយោជន៍»

---

7 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកយេរេមាថា៖ [2]«ចូរឈរត្រង់ទ្វារនៃព្រះវិហារហើយប្រកាសប្រាប់នៅទីនោះ តាមពាក្យនេះថា៖ ពួកយូដាអើយ ចូរចូលទៅថ្វាយបង្គំព្រះអម្ចាស់តាមទ្វារទាំងនេះ និងស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ចុះ។

generated on Wed Sep 10 16:16:32 2025

[3]ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះជាម្ចាស់អ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ ចូរកែផ្លូវ និងការប្រព្រឹត្តរបស់អ្នករាល់គ្នាឲ្យល្អទៅ នោះយើងនឹងឲ្យអ្នករាល់គ្នាអាស្រ័យ
នៅទីនេះតទៅ។[4]កុំទុកចិត្តនឹងពាក្យបញ្ឆោត ដែលថា នេះជាព្រះវិហាររបស់ព្រះអម្ចាស់ «ជាព្រះវិហាររបស់ព្រះអម្ចាស់ ព្រះវិហាររបស់ព្រះអម្ចាស់ឡើយ!»
[5]ដ្បិតបើអ្នករាល់គ្នាកែផ្លូវប្រព្រឹត្ត និងចរិតរបស់អ្នកឲ្យល្អ ហើយបើសម្រេចក្តីដល់មនុស្ស និងអ្នកជិតខាងដោយយុត្តិធម៌[6]បើអ្នកមិនសង្កត់សង្កិនមនុស្សជនជាតិដទៃ ពួក
កំព្រា និងពួកស្ត្រីមេម៉ាយ ហើយមិនកម្ចាយឈាមដែលឥតមានទោសនៅទីនេះ ក៏មិនគោរពតាមព្រះដទៃ ឲ្យខ្លួនបានអន្តរាយឡើយ[7]នោះយើងនឹងឲ្យអ្នករាល់គ្នាអាស្រ័យ
នៅទីនេះតទៅ គឺក្នុងទឹកដីដែលយើងបានឲ្យដល់បុព្វបុរសអ្នក ចាប់តាំងពីចាស់បុរាណ ដរាបដល់អស់កល្បជានិច្ច។
[8]មើល៍! អ្នករាល់គ្នាទុកចិត្តនឹងពាក្យកំភូត ដែលគ្មានប្រយោជន៍ និងមិនអាចជួយខ្លួនបាន។[9]កុំអោយលួចប្លន់ កាប់សម្លាប់ ផិតគ្នា ស្បថបំពាន ដុតកំញានថ្វាយព្រះបាល
ហើយគោរពតាមព្រះដទៃ ដែលអ្នកមិនបានស្គាល់ពីដើម[10]រួចមកឈរនៅមុខយើងក្នុងវិហារនេះ ដែលបានហៅតាមឈ្មោះយើង ហើយពោលថា៖ យើងបានសង្គ្រោះហើយ
គឺដើម្បីឲ្យអ្នកបានធ្វើអស់ទាំងការគួរស្អប់ខ្ពើមយ៉ាងនេះឬ?[11]ព្រះវិហារនេះដែលហៅតាមឈ្មោះយើង តើបានត្រឡប់ជារោងចោរនៅភ្នែកអ្នករាល់គ្នាឬ? ព្រះអម្ចាស់មាន
ព្រះបន្ទូលថា៖ គឺខ្លួនយើងបានឃើញការនេះហើយ។
[12]ចូរអ្នករាល់គ្នាទៅទីកន្លែងរបស់យើង ដែលនៅត្រង់ស៊ីឡូរចុះ ជាកន្លែងដែលយើងបានតាំងឈ្មោះយើងឲ្យនៅមុនដំបូង ត្រូវពិចារណាមើល ដែលយើងបានធ្វើដល់កន្លែង
នោះជាយ៉ាងណា ដោយព្រោះអំពើអាក្រក់របស់អ៊ីស្រាអែល ជាប្រជារាស្ត្រយើង[13]ហើយឥឡូវនេះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ ដោយព្រោះអ្នករាល់គ្នាបានប្រព្រឹត្តអំពើ
ទាំងនេះ យើងបាននិយាយនឹងអ្នករាល់គ្នា ទាំងខ្នះខ្នែងរំឭកអ្នកតាំងពីព្រលឹមស្រាងផង តែអ្នករាល់គ្នាមិនបានស្តាប់តាមទេ យើងក៏បានហៅអ្នករាល់គ្នា តែអ្នកមិនបាន
ឆ្លើយតបសោះ។[14]ហេតុនោះ យើងនឹងធ្វើដល់វិហារ ដែលហៅតាមឈ្មោះយើង គឺជាទីដែលអ្នករាល់គ្នាទុកចិត្តនេះ ហើយដល់ទីកន្លែងដែលយើងបានឲ្យដល់អ្នករាល់គ្នា
និងបុព្វបុរសអ្នកផង ដូចជាបានធ្វើដល់ស៊ីឡូរនោះដែរ។[15]យើងនឹងបោះបង់អ្នករាល់គ្នាចេញពីភ្នែកយើង ដូចជាបានបោះបង់ពួកបងប្អូនអ្នកដែរ គឺជាពូជអេប្រាអិមទាំង
ប៉ុន្មាន។
[16]សម្រាប់អ្នក យេរេមាអើយ កុំអធិស្ឋានឲ្យជនជាតិនេះឡើយ ក៏កុំឲ្យបន្លឺសំឡេងអំពាវនាវ ឬអធិស្ឋានឲ្យគេ ឬអង្វរដល់យើងជំនួសគេឲ្យសោះ ព្រោះយើងមិនព្រមស្តាប់អ្នក
ទេ។[17]តើអ្នកមិនឃើញអំពើដែលគេប្រព្រឹត្ត នៅក្នុងក្រុងនានានៃទឹកដីយូដា ហើយនៅតាមផ្លូវក្រុងយេរូសាឡិមទេឬ?[18]គឺកូនក្មេងរើសឧស ឪពុកបង្កាត់ភ្លើង ហើយពួកស្ត្រីៗ
ច្របាច់មេធ្វើនំថ្វាយដល់ព្រះចន្ទ ព្រមទាំងច្រួចតង្វាយថ្វាយដល់ព្រះឯទៀត នេះជាការដែលបណ្តាលឲ្យយើងខឹងក្តៅ។
[19]ព្រះអម្ចាស់មានព្រះបន្ទូលសួរថា៖ តើគេបណ្តាលឲ្យយើងមានសេចក្តីក្រោធមែនឬ? តើមិនមែនខ្លួនគេដែលមានសេចក្តីខ្មាសជ្រប់មុខទេឬ?[20]ហេតុនោះ ព្រះអម្ចាស់មាន
ព្រះបន្ទូលដូច្នេះថា៖ មើល៍ កំហឹង និងសេចក្តីក្រោធរបស់យើង បានចាក់មកលើទីនេះ គឺលើមនុស្ស លើសត្វ ហើយលើដើមឈើនៅចម្ការ និងលើផលដែលកើតពីដីផង
កំហឹងនោះនឹងឆេះឡើងឥតរលត់ឡើយ។
[21]ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ ចូរថ្វាយតង្វាយដុតថែមលើយញ្ញបូជារបស់អ្នករាល់គ្នា ហើយស៊ីសាច់ចុះ[22]ដ្បិត
នៅគ្រាដែលយើងបាននាំបុព្វបុរសអ្នករាល់គ្នាចេញពីទឹកដីអេស៊ីបមក នោះយើងមិនបាននិយាយនឹងគេ ឬបង្គាប់គេ ពីដំណើរតង្វាយដុត និងយញ្ញបូជាទេ[23]គឺយើងបាន
បង្គាប់សេចក្តីនេះដល់គេវិញថា «ចូរស្តាប់តាមពាក្យយើង នោះយើងនឹងធ្វើជាព្រះដល់អ្នករាល់គ្នា ហើយអ្នករាល់គ្នានឹងធ្វើជាប្រជារាស្ត្ររបស់យើង អ្នករាល់គ្នាត្រូវដើរតាម
ផ្លូវដែលយើងបង្គាប់អ្នកគ្រប់ជំពូក ដើម្បីឲ្យអ្នកបានសេចក្តីសុខ»។
[24]ប៉ុន្តែ គេមិនបានស្តាប់តាមសោះ ក៏មិនបានផ្ទៀងត្រចៀកផង។ ពួកគេបានដើរតាមតែគំនិតរបស់ខ្លួនគេ និងសេចក្តីរឹងចចេសក្នុងចិត្តអាក្រក់របស់គេវិញ គេបានរាថយ
ក្រោយ ឥតជឿនទៅខាងមុខទេ។[25]ចាប់តាំងពីថ្ងៃដែលបុព្វបុរសអ្នករាល់គ្នា បានចេញពីទឹកដីអេស៊ីបមក ដរាបដល់សព្វថ្ងៃនេះ យើងបានចាត់ពួកព្យាការី ជាអ្នកបម្រើរបស់
យើងឲ្យមករកអ្នក ដោយខ្នះខ្នែងចាត់គេពីព្រលឹមស្រាងរាល់ថ្ងៃផង។[26]ប៉ុន្តែ អ្នកមិនបានស្តាប់តាមយើង ឬផ្ទៀងត្រចៀកមកសោះ គឺបានតាំងក្បាលរឹង ហើយបានប្រព្រឹត្ត
អាក្រក់ជាងបុព្វបុរសទៅទៀត។
[27]អ្នកត្រូវប្រាប់ដល់គេតាមអស់ទាំងពាក្យនេះ តែគេនឹងមិនស្តាប់តាមអ្នកទេ ហើយអ្នកនឹងស្រែកហៅគេដែរ តែគេមិនព្រមឆ្លើយតបឡើយ។[28]អ្នកត្រូវប្រាប់គេថា នេះហើយ
ជាជនជាតិដែលមិនបានស្តាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ជាព្រះរបស់ខ្លួន ក៏មិនបានទទួលសេចក្តីប្រៀនប្រដៅ។ សេចក្តីពិតបានសូន្យបាត់ គឺបានកាត់ចេញពីមាត់គេ
ហើយ។
[29]ចូរកាត់សក់អ្នកបោះចោលទៅ ហើយចាប់ផ្តើមទួញទំនួញនៅលើទីខ្ពស់ចុះ ព្រោះព្រះអម្ចាស់បានបដិសេធ ហើយបោះបង់ចោលតំណមនុស្ស ដែលត្រូវសេចក្តីក្រោធរបស់
ព្រះអង្គ។[30]ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលថា៖ ពួកកូនចៅយូដាបានប្រព្រឹត្តអំពើដ៏អាក្រក់នៅភ្នែកយើង គេបានដាក់របស់គួរស្អប់ខ្ពើមរបស់គេ នៅក្នុងវិហារដែលហៅតាម
ឈ្មោះយើង ដើម្បីធ្វើឲ្យអាប់ឱន។
[31]ក្រោយមក ពួកគេក៏បានធ្វើទីខ្ពស់ទាំងប៉ុន្មាននៅត្រង់តូផែត ដែលនៅក្នុងច្រកភ្នំនៃពួកកូនចៅហ៊ីនណម ដើម្បីដុតកូនប្រុសកូនស្រីរបស់គេក្នុងភ្លើង ជាការដែលយើងមិន
បានបង្គាប់ឡើយ ក៏មិនដែលចូលក្នុងគំនិតយើងដែរ។[32]ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ មានពេលមកដល់ ដែលគេនឹងលែងហៅទីនោះថា តូផែត ឬថាច្រកភ្នំនៃកូន
ចៅហ៊ីនណមតទៅ គឺនឹងហៅថាច្រកភ្នំនៃការសម្លះវិញ ពីព្រោះគេនឹងបញ្ចុះសពនៅត្រង់តូផែតនោះ ទាល់តែគ្មានកន្លែងទំនេរទៀត។
[33]សាកសពទាំងប៉ុន្មានរបស់ជនជាតិនេះនឹងក្លាយជាចំណីសត្វហើរលើអាកាស សត្វនៅដីផង ឥតមានអ្នកណាបង្អើលវាចេញឡើយ។[34]នៅគ្រានោះ យើងលែងឲ្យមាន
សំឡេងអំណរ និងសំឡេងរីករាយ ជាសំឡេងរបស់ប្តីប្រពន្ធថ្មោងថ្មី ពីក្រុងទឹកដីយូដា ហើយពីផ្លូវក្រុងយេរូសាឡិមទៅ ពីព្រោះទឹកដីនេះនឹងត្រូវវិនាសសូន្យ»។

Jeremiah 7:1

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកយេរេមាថា

«នេះគឺជារាជ្យសារដែលព្រះអម្ចាស់ផ្ញើដល់លោកយេរេមា»

ព្រះបន្ទូលនេះ

រាជ្យសារដែលព្រះអម្ចាស់ដែលនឹងប្រទានដល់លោកយេរេមា

ចូរឈរ ... ប្រកាស

ព្រះអម្ចាស់បានផ្តល់ការបង្គាប់នេះដល់លោកយេរេមា។

ចូរថ្វាយបង្គំព្រះអម្ចាស់

«ក្នុងការថ្វាយបង្គំព្រះអម្ចាស់»

Jeremiah 7:3

ព័តមានទូទៅ:

នេះជាព្រះបន្ទូលដែលព្រះអម្ចាស់ចង់ឲ្យលោកយេរេមាប្រាប់ដល់ប្រជាជនយូដា។

ចូរធ្វើផ្លូវរបស់អ្នកនិងការប្រព្រឹត្តការល្អ

«ដឹកនាំជីវិតឲ្យបានល្អ ហើយប្រព្រឹត្តការល្អ»

អាស្រ័យនៅទីនេះ

ការនេះសំដៅទៅទឹកដីនៃអ ុស្រាអែល ដែលមានព្រះវិហារនៅកណ្តាល។

កុំទុកចិត្តលើពាក្យបញ្ឆោតបញ្ឆាត់ ហើយនិយាយថា

«កុំឲ្យខ្លួនអ្នកទុកចិត្តក្នុងពាក្យនិយាយមិនពិតឡើយ»

ព្រះវិហារនៃព្រះអម្ចាស់! ព្រះវិហារនៃព្រះអម្ចាស់! ព្រះវិហារនៃព្រះអម្ចាស់!

មនុស្សបាននិយាយឃ្លានេះដដែលបី ដង់ដើម្បីបញ្ជាក់ចំណុច។ វាបានបង្កប់ន័យថា
ព្រោះព្រះវិហារជារបស់ព្រះអម្ចាស់
ព្រះអង្គនឹងការពារហើយប្រជាជនយូដានឹងបានសុខសាន្ត។

ការបកប្រែរបៀបផ្សេងទៀត: «នេះគឺជាព្រះវិហារនៃព្រះអម្ចាស់
ដូច្នេះគ្មានអ្នកណានឹងអាចបំផ្លាញ ហើយពួកយើងនឹងសុខសាន្ត»។

Jeremiah 7:5

ព័តមានទូទៅ:

នេះជាព្រះបន្ទូលទៅកាន់ប្រជាជននៃជនជាតិយូដា។

ប្រសិនបើអ្នកពិតជា

«ប្រសិនបើជាជាក់លាក»

កែផ្លូវរបស់អ្នក ហើយប្រព្រឹត្តការល្អ

សូមមើលពីរបៀបបកប្រែរបស់អ្នកក្នុងជំពូក ៧:៣

បើអ្នកពិតជាបានប្រតិបត្តិដោយយុត្តិធម៌

«ប្រសិនបើអ្នកប្រព្រឹត្តជាមួយប្រជាជនដោយត្រឹមត្រូវ»

ប្រសិនបើអ្នកមិនកេងប្រវ័ញ្ចមនុស្សដែលអាស្រ័យនៅ

generated on Wed Sep 10 16:16:32 2025

«ប្រព្រឹត្តដោយត្រឹមត្រូវជាមួយជនជាតិដទៃដែលអាស្រ័យនៅ»
ក្មេងកំព្រា
ក្មេងៗដែលឪពុកម្តាយបានស្លាប់
មិនបង្ហូរ ឈាមអ្នកដែលគ្មានកំហុស
ការបកប្រែរបៀបផ្សេងទៀត: «កុំឲ្យសម្លាប់មនុស្សគ្មានទោស»។
មិនដើរតាម
ការបកប្រែរបៀបផ្សេងទៀត: «កុំឲ្យថ្វាយបង្គំ»។
ឲ្យខ្លួនអ្នកទទួលការអាម៉ាស់
«ដូច្នេះការអាក្រក់នឹងកើតឡើងដល់អ្នក»
នៅទីនេះ
ការនេះសំដៅទៅលើទឹកដីនៃអ៊ុស្រាអែល ដែលមានព្រះវិហារនៅកណ្តាល។
នឹងឲ្យអ្នកអាស្រ័យនៅ
«នឹងឲ្យអ្នករស់នៅ»
ហើយអស់កល្បជានិច្ច
«ហើយជារៀងរហូតនៅក្នុងអនាគត»
Jeremiah 7:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់ប្រជាជននៃយូដាតាមរយៈព្យាការីយេរេមា។
មើល!
ពាក្យថា «ចូរមើល៍» បង្ហាញថាសំនួរបន្ទាប់គឺសំខាន់ខ្លាំង។
អ្នករាល់គ្នាទុកចិត្តនឹងពាក្យបោកប្រាស់ ដែលមិន អាចជួយខ្លួនបាន
«អ្នកគិតថាយើងនឹងសង្គ្រោះយេរូសាឡិម
ពីព្រោះយើងនឹងការពារដំណាក់របស់យើង។ ប៉ុន្តែវាជាការកុហកទេ!»
តើអ្នកលួច សម្លាប់ ហើយបានប្រព្រឹត្តការកំផិត?
«អ្នកលួច សម្លាប់ ហើយប្រព្រឹត្តកំផិត»
តើអ្នកបានស្បថដោយបោកប្រាស់ ហើយបានដុតកំញានថ្វាយព្រះបាល ហើយដើរតាមព្រះដទៃ គឺ
ជាព្រះដែលអ្នកមិនបានស្គាល់?
«អ្នកកហុកក្នុងសម្បថរបស់អ្នកហើយថ្វាយបង្គំព្រះបាល
ហើយព្រះដទៃផ្សេងទៀត»។
ហើយតើអ្នកមកឈរនៅចំពោះយើងក្នុងដំណាក់នេះ ដែលបានហៅដោយឈ្មោះយើង ហើយ
និយាយថា៖ «យើងបានសង្គ្រោះ ដូច្នេះអ្នកអាចធ្វើអស់ទាំងការគួរស្អប់ខ្ពើមយ៉ាងបានឬ?
«ក្រោយមកអ្នកនឹងត្រឡប់មកដំណាក់យើងហើយនិយាយថា៖
«ព្រះអម្ចាស់នឹងសង្គ្រោះយើង» ដូច្នេះអ្នកបន្តធ្វើបាបខ្លាំងលើសដើម»។
តើដំណាក់នេះនៅបន្តរក្សាឈ្មោះយើង ជារូងចោរនៅក្នុងភ្នែកអ្នកឬ?
«ដំណាក់នេះ...គឺជារូងពួកចោរក្នុងភ្នែករបស់អ្នក!» ឬ
«អ្នកប្រព្រឹត្តដូចអ្នកទាំងនោះដែលអ្នកបានគិតពីដំណាក់របស់យើង...គួរតែជាកន្លែងចោរលួចរបស់ទ្រព្យសម្បត្តិរបស់ពួកគេ»។ ការបកប្រែរបៀបផ្សេងទៀត:
រូងចោរ
«ចោរប្លន់» ឬ «មនុស្សដែលលួចរបស់អ្នកដទៃ»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែរបស់អ្នកក្នុងជំពូក ១:៧ ១:៨។
Jeremiah 7:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់ជនជាតិយូដាតាមរយៈព្យាការីយេរេមា។
ចូរទៅកន្លែង
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះចូរចងចាំថា» ឬ «ដូច្នេះគិតអំពីការនេះ»
លើការទទួលខុសត្រូវនៃអ្វីដែលអ្នកកំពុងធ្វើ
«ពីព្រោះអ្នកបានកំពុងធ្វើការទាំងអស់នេះ»
ម្តងហើយម្តងទៀត
«ម្តងហើយម្តងទៀត»
Jeremiah 7:16
កុំអធិស្ឋានឲ្យមនុស្សទាំងនេះឡើយ ហើយកុំបន្លឺសំឡេងទំនុកសោកសៅ ឬនិយាយពាក្យអធិស្ឋាន
ជំនួសឲ្យពួកគេឡើយ ហើយកុំសំណូមពរយើងដែរ
ឃ្លាទាំងបួននេះនិយាយការដូចនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«កុំឲ្យអធិស្ឋានមកកាន់យើងសុំយើងដើម្បីប្រទានពរដល់មនុស្សទាំងនេះ»
កុំបន្លឺសំឡេងទំនុកសោកសៅ
«កុំឲ្យយំស្រែកជាមួយសោកសៅ»
ជំនួសឲ្យពួកគេឡើយ
«សម្រាប់ការប្រយោជន៍របស់គេ» ឬ «ក្នុងចំណេញរបស់គេ»
កុំសំណូមពរយើង
«កុំសុំអ្វីពីយើង»
ធ្វើឲ្យយើងខឹងខ្លាំង
«យើងនឹងខឹង»
Jeremiah 7:19
ពិតប្រាកដជាធ្វើឲ្យយើងខឹងមែនឬ?...ពួកគេខ្លួនជាអ្នកដែលបង្កើតចញ្ចា
«ការពិតជាអ្នកបង្កើតបញ្ហាឲ្យយើង?...ពួកគេជាបញ្ហា»
តើពួកគេពិតប្រាកដជាធ្វើឲ្យយើងខឹងមែនឬ?
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនបានជាបញ្ហាដល់យើងទេ»។
តើវាមិនមែនពួកគេខ្លួនជាអ្នកដែលបង្កើតចញ្ចានេះ ដូច្នោះ សេចក្តីអាម៉ាស់នឹងធ្លាក់លើពួកគេ?
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបង្កើតបញ្ហាឲ្យខ្លួនគេដោយការអាម៉ាស់នឹងការប្រព្រឹត្តគេ»។
មើល!
ពាក្យនេះបានហៅឲ្យមានការចាប់អារម្មណ៍ជាមួយអ្វីដែលកើតឡើង
ការបកប្រែរបៀបផ្សេងទៀត:
«សូមស្តាប់ដោយយកចិត្តទុកដាក់ពីព្រោះការនេះសមខាន់»
កំហឹងនិងសេចក្តីក្រោធរបស់យើង នឹងផុសចេញមកក្នុងទីនេះ
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំនឹងដាក់ទោសប្រជាជនដែលនៅកន្លែងនេះ»។
កំហឹងនិងសេចក្តីក្រោធ
ពាក្យទាំងនេះមានន័យជាក់លាក់ដូចគ្នាបញ្ចាក់ពីគោលបំណងនៃកំហឹងរបស់ព្រះអង្គ។
វានឹងឆេះ
ពាក្យថា «វា» សំដៅដល់ «កំហឹងនិងក្រោធរបស់ព្រះអម្ចាស់»។
ឥតរលត់ឡើយ
«មិនឈប់ឆេះឡើយ» ឬ «មិនដែលឈប់ខឹងឡើយ»
Jeremiah 7:21
ចូរថ្វាយតង្វាយដុតថែមលើយញ្ញបូជារបស់អ្នករាល់គ្នា ហើយស៊ីសាច់ចុះ
ទោះជាព្រះអម្ចាស់តម្រូវយញ្ញបូជាក៏ដោយ ព្រះអង្គមិនចង់បាន
យញ្ញបូជារបស់ពួកគេទៀតទេ ពីព្រោះមនុស្សនៅតែមិនស្តាប់បង្គាប់
បន្ទាប់ពីគេបានមកព្រះវិហារហើយ។
Jeremiah 7:24
ព័ត៌មានទូទៅ
ព្រះអម្ចាស់បន្តរំលឹកដល់ប្រជាជននៃជនជាតិយូដាពីផ្លូវរបស់ប្រជាជននៃអ៊ីស្រាអែលដែលបះបោរ។
នៅក្នុងផែនការរឹងចចេស នៃចិត្តអាក្រក់របស់ពួកគេ
«ផ្អែកលើផែនការណ៍របស់គេ ពីព្រោះពួកគេអាក្រក់ហើយចចេស»
រួចហើយពួកគេទៅក្រោយ ហើយទៅមុខ
«ហើយពួកគេបានបែរខ្នងរបស់ពួកគេដល់យើង
ហើយមិនមែនមុខរបស់ពួកគេទេ»។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយពួកគេបានបដិសេធមិនយកចិត្តទុកដាល់ចំពោះយើង
ផ្ទុយពីការចង់ស្តាប់បង្គាប់យើង»។
យើងបានចាត់អ្នកបម្រើរបស់យើង
«គឺពួកអ្នកបម្រើរបស់យើងទាំងអស់»
ព្យាយាមក្នុងការចាត់ពួកគេ
«ព្យាយាមក្នុងការចាត់ពួកគេរាល់ថ្ងៃ»
ពួកព្យាការីទៅដល់អ្នក
ពាក្យថា «អ្នក» សំដៅដល់ប្រជាជននៃជនជាតិយូដា
ហើយនិងពួកដូនតារបស់ពួកគេផងដែរ។
ពួកគេមិនបានស្តាប់
ពាក្យថា «ពួកគេ» សំដៅដល់ប្រជាជននៃជនជាតិអ៊ីស្រាអែលដែលបានរស់នៅ
តាំងពីពួកដូនតារបស់ពួកគេបានចេញពីអេស៊ីប។
ពួកគេបានប្រព្រឹត្តអាក្រក់ជាង
«គ្រប់ជំនាន់បានធ្វើអំពើអាក្រក់ច្រើនជាងមុខ»
Jeremiah 7:27
ដូច្នោះ ចូរប្រកាសអស់ទាំងពាក្យទាំងនេះដល់ពួកគេ ប៉ុន្តែគេមិនស្តាប់តាមអ្នកទេ។
ប្រកាសការទាំងនេះដល់ពួកគេ តែពួកគេមិនឆ្លើយនិងអ្នកទេ។
ប្រយោគទាំងពីរប្រាប់ដូចគ្នា ចំណុចទីពីរបានបញ្ចាក់ន័យរបស់ទីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាប់ពួកគេពីសាររបស់យើង
តែគេនឹងមិនស្តាប់ហើយមិនផ្លាស់ប្តូរផ្លូវអាក្រក់របស់គេដែរ»។
សម្លេងនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែរបស់អ្នកក្នុងជំពូក ៣:៣៣
សេចក្តីពិតបានត្រូវបំផ្លាញ ហើយបានកាត់ចេញពីមាត់គេ

generated on Wed Sep 10 16:16:32 2025

ប្រយោគពីរនេះមានន័យប្រដៀងគ្នា។
ប្រយោគទីពីរបានជួយឲ្យកាន់តែយល់ជាងប្រយោគទីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សប្រាប់តែរឿងកុហក»
Jeremiah 7:29
កូនចៅយូដា
«ពូជពង្សនៃជនជាតិយូដា»
បដិសេធ ហើយបោះបង់ចោល
ពាក្យទាំងពីរនេះមានន័យស្រដៀងគ្នាហើយបញ្ជាក់ថា
ព្រះអម្ចាស់នឹងមិនមានអ្វីច្រើនដើម្បីធ្វើជាមួយប្រជាជន។
បោះបង់ចោល
«ឲ្យនៅតែឯង» ឬ «មិនរវល់»
នៅភ្នែកយើង
«នៅចំពោះយើង» ឬ «នៅក្នុងការគិតយើង»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែរបស់អ្នកក្នុងជំពូក ១:៧។
Jeremiah 7:31
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តពិពណ៌នាពីការអាក្រក់ដែលប្រជាជននៃជនជាតិយូដាបានធ្វើ។
ទីខ្ពស់ នៃតូផែត
នេះគឺជាឈ្មោះនៃទីកន្លែងដែលប្រជាជននៃអ៊ីស្រអែលបានថ្វាយតង្វាយកូនរបស់ពួកគេ[illegible]
ក្នុងច្រកភ្នំ នៃបិនហ៊ីនណម
នេះគឺជាឈ្មោះនៃជ្រលងភ្នំខាងត្បូងរបស់ទីក្រុងយេរូសាឡិម
ជាកន្លែងដែលគេថ្វាយតង្វាយដល់ព្រះក្លែងក្លាយ។
ក្នុងភ្លើង
ការបកប្រែរបៀបផ្សេងទៀត: «ថ្វាយតង្វាយក្នុងភ្លើង»
ក៏មិនដែលមាននៅក្នុងគំនិតយើងទេ
ការបកប្រែរបៀបផ្សេងទៀត: «ហើយយើងមិនដែលធ្លាប់គិតបង្គាប់បញ្ជាវាដែល»
ដូច្នេះ មើល!
ពាក្យថា «មើល» បានបូកបញ្ចាក់ន័យទៅដល់អ្វីដែលមកតាមក្រោយ។
ការបកប្រែរបៀបផ្សេងទៀត: «ទង្វើ»
ថ្ងៃនោះនឹងមកដល់
ការបកប្រែរបៀបផ្សេងទៀត: «ថ្ងៃមួយនៅពេលអនាគត»។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែរបស់អ្នកក្នុងជំពូក ១:៧។
វាមិនត្រូវហៅថា
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនឹងលែងបានហៅវាទៀតហើយ»។
ច្រកភ្នំនៃការប្រហារ
«ជ្រលងនៃការសម្លាប់»
ពួកគេនឹងបញ្ចុះសព
«ប្រជាជននៃជនជាតិយូដាបានបញ្ចុះសពមនុស្សស្លាប់»
តែគ្មានកន្លែងទំនេរ
«គ្មានកន្លែងនៅសល់ទេ»
Jeremiah 7:33
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
សាកសព
«រូបកាយដែលស្លាប់»
មនុស្សទាំងនេះ
ប្រជាជននៃជនជាតិយូដា
សត្វហើរលើអាកាស
[illegible]
សត្វនៅលើផែនដី
«សត្វព្រៃជាច្រើននៃផែនដី»
នឹងភ័យខ្លាចពួកគេទៀតឡើយ
«ដើម្បីធ្វើពួកគេខ្លាច»
យើងនឹងដាក់ទីបញ្ចាប់ដល់
«យើងនឹងដកចេញពី»
សំឡេងអំណរ និងសំឡេងរីករាយ
«សម្លេងរបស់ប្រជាជនដែលរីករាយ ហើយនឹងសប្បាយចិត្ត»
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនៅទីនោះដែលសប្បាយចិត្ត»
សំឡេងកូនកម្លោះនិងកូនក្រមុំ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សបានរៀបការ»

8 [1]«នៅក្នុងគ្រានោះ ព្រះអម្ចាស់មានព្រះបន្ទូលការទាំងនេះថា៖ ពួកគេនឹងនាំយកឆ្អឹងនៃស្តេចជនជាតិយូដា ហើយនិងឆ្អឹងពួកអ្នកដឹកនាំ និងឆ្អឹងរបស់ពួកសង្ឃ ឆ្អឹងរបស់ពួកព្យាការី និងឆ្អឹងរបស់ពួកអ្នកដែលនឹងទទួលមរតកនៅក្រុងយេរូសាឡិមចេញពីផ្នូរចេញមក។[2]ក្រោយមក ពួកគេនឹងរាយឆ្អឹងទាំងនោះនៅចំពោះព្រះអាទិត្យ ព្រះចន្ទ និងអស់ពួកបរិវារនៅលើមេឃ ជារបស់ដែលពួកគេបានស្រឡាញ់ និងគោរពប្រតិបត្តិ ហើយប្រព្រឹត្តតាម ស្វែងរក ហើយថ្វាយបង្គំផង។ និងគ្មានអ្នកណាប្រមូល ឬកប់ឆ្អឹងទាំងនោះឡើយ គឺនឹងបានសម្រាប់ជាជីនៅដីវិញ។[3]ចំណែកឯ ពួកអ្នកដែលនៅសេសសល់ពីពូជមនុស្សដ៏អាក្រក់ ដែលយើងបំបរបង់ឲ្យទៅនៅគ្រប់ទីកន្លែងនោះវិញ គេចង់ស្លាប់ជាងនៅរស់ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។
[4]អ្នកត្រូវប្រាប់គេថា៖ ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ៖ បើមនុស្សដួល តើមិនក្រោកឡើងវិញទេឬ? បើអ្នកណាបែរចេញ តើមិនវិលមកវិញឬ?[5]តើហេតុអ្វីបានជាប្រជាជននៅក្រុងយេរូសាឡិម ទាំងនេះបានវង្វេងចេញ ហើយជាប់នៅក្នុងការនោះជានិច្ចដូច្នេះ? ពួកគេកាន់ខ្ជាប់តាមពាក្យបញ្ឆោត ហើយមិនព្រមប្រែចិត្តទេ។
[6]យើងនឹងរំពៃមើល៍ ហើយប្រុងស្តាប់ ប៉ុន្តែពួកគេមិនបាននិយាយដោយទៀងត្រង់សោះ គ្មានអ្នកណាមួយបានប្រែចិត្តចេញពីអំពើអាក្រក់របស់ខ្លួន ដោយថា «តើយើងបានធ្វើអ្វីនេះ?» គ្រប់គ្នាបានបែរទៅតាមផ្លូវរបស់ខ្លួនវិញ ដូចជាសេះស្ទុះចូលទៅក្នុងសង្គ្រាម។[7]សត្វកុកដែលហើរលើអាកាសក៏ស្គាល់រដូវរាដែរឯណាលក និងត្រចៀកកាំ ហើយក្រៀល ក៏កាន់ពេលវេលាដែលត្រូវមកដែរ តែប្រជារាស្ត្ររបស់យើង គេមិនស្គាល់ច្បាប់របស់ព្រះអម្ចាស់ទេ។
[8]ធ្វើដូចម្តេចឲ្យអ្នករាល់គ្នាថា៖ «យើងមានប្រាជ្ញា ក៏មានក្រឹត្យវិន័យរបស់ព្រះអម្ចាស់ នៅជាមួយយើងដែរដូច្នេះ?» តែមើល៍ ស្លាបប្រកាក្លែងក្លាយរបស់ពួកអាចារ្យ នោះបានបំផ្លាស់ទៅជាសេចក្តីភូតភរ។[9]ពួកអ្នកប្រាជ្ញត្រូវខ្មាស ត្រូវស្រយុតចិត្ត ហើយចាប់បាន គេបានបោះបង់ព្រះបន្ទូលនៃព្រះអម្ចាស់ ដូច្នេះ តើគេមានប្រាជ្ញាអ្វីនៅក្នុងខ្លួន?[10]ហេតុនោះ យើងនឹងលើកប្រពន្ធគេឲ្យដល់អ្នកដទៃ ហើយស្រែចម្ការរបស់គេដល់ពួកអ្នក ដែលនឹងគ្រប់គ្រងតទៅ ដ្បិតតាំងពីអ្នកតូចបំផុត រហូតដល់អ្នកធំជាងគេ សុទ្ធតែលោភលន់ ចាប់តាំងពីព្យាការី រហូតដល់បូជាចារ្យ គ្រប់គ្នាប្រព្រឹត្តសេចក្តីបោកប្រាស់។
[11]គេបានព្យាបាលរបួសឲ្យប្រជារាស្ត្រយើង បន្តិចបន្តួចទេ ហើយនិយាយថា «សុខសាន្ត សុខសាន្ត» ក្នុងកាលដែលគ្មានសេចក្តីសុខសោះ។[12]កាលគេបានប្រព្រឹត្តអំពើគួរស្អប់ខ្ពើម តើគេមានសេចក្តីខ្មាសឬទេ? ពួកគេគ្មានសេចក្តីខ្មាសទេ ក៏មុខក្រាស់ផង! ដូច្នេះបានជាគេនឹងដួលជាមួយពួកអ្នកដែលត្រូវដួល ព្រះអម្ចាស់មានព្រះបន្ទូលថា៖ នៅវេលាដែលយើងដាក់ទោសដល់គេ នោះគេនឹងត្រូវវិនាស។[13]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងនឹងបំផ្លាញគេអស់រលីង នៅគ្រានោះនឹងគ្មានចង្កោមផ្លែនៅដើមទំពាំងបាយជូរ ឬផ្លែឧទុម្ពរនៅដើមវា។ ស្លឹកទាំងប៉ុន្មាននឹងស្វិតក្រៀម ហើយរបស់ទាំងអស់ដែលយើង បានឲ្យដល់គេនឹងសូន្យបាត់ទៅ។
[14]ហេតុអ្វីបានជាយើងរាល់គ្នាអង្គុយតែស្ងៀមដូច្នេះ? ចូរមូលមក យើងនាំគ្នាចូលទៅក្នុងទីក្រុង ទាំងប៉ុន្មានដែលមានកំផែង ហើយភាំងនៅទីនោះវិញ ដ្បិតព្រះអម្ចាស់ជាព្រះនៃយើង ព្រះអង្គបានធ្វើឲ្យយើងភាំងហើយ ក៏បានឲ្យយើងផឹកទឹកពុលដែរ ពីព្រោះយើងបានធ្វើបាបនឹងព្រះអង្គ។[15]យើងបានទន្ទឹងចាំសេចក្តីសុខ ប៉ុន្តែ ឥតមានអ្វីល្អមកសោះ ក៏សង្ឃឹមនឹងមានពេលប្រោសឲ្យជា តែមើល៍ បានតែសេចក្តីវេទនា។
[16]មានឮសូរសណ្ឋឹក នៃសេះរបស់គេចេញពីដាន់មក កាលណាឮសូរសេះខ្លាំងពូកែរបស់គេស្រែកកញ្ជ្រៀវនោះផែនដីទាំងអស់ក៏ញ័រ ដ្បិតគេបានមកហើយ គេបានស៊ីលេបទឹកដី និងរបស់ទាំងប៉ុន្មានដែលនៅក្នុងទឹកដី ព្រមទាំងទីក្រុង និងពួកអ្នកនៅក្នុងនោះដែរ។[17]ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលថា៖ មើល៍! យើងនឹងចាត់ពស់វែក ឲ្យមកកណ្តាលអ្នករាល់គ្នា ជាពស់ដែលគ្មានគ្រូធ្មប់ណាអាចសណ្តំបាន នឹងចឹកអ្នករាល់គ្នា»។
[18]ខ្ញុំឈឺចុកចាប់ក្នុងចិត្តពន់ប្រមាណ តែគ្មានអ្វីអាចសម្រាលទុក្ខរបស់ខ្ញុំបានទេ[19]មើល៍! សម្រែកយំសោកនៃប្រជាជនរបស់ខ្ញុំ លាន់ឮពីដែនដីដ៏សែនឆ្ងាយ ព្រះអម្ចាស់លែងគង់នៅក្រុងស៊ីយ៉ូនហើយឬ? ក្រុងស៊ីយ៉ូនលែងមានព្រះ មហាក្សត្រហើយឬ? ហេតុអ្វីបានជាពួកគេធ្វើឲ្យយើងខឹង ដោយសារ រូបព្រះក្លែងក្លាយជាព្រះឥតបានការរបស់ជនជាតិដទៃដូច្នេះ?

generated on Wed Sep 10 16:16:32 2025

[20]រដូវចម្រូតកន្លងផុតទៅ រដូវប្រាំងក៏ជិតផុតទៅដែរ តែពួកយើងពុំបានទទួលការសង្គ្រោះសោះ![21]ដួងចិត្តខ្ញុំត្រូវខ្ទេចខ្ទាំដោយសារមហន្តរាយនៃប្រជាជនរបស់ខ្ញុំ ខ្ញុំរំលែរល់ស្មារតី ដោយសារទុក្ខព្រួយដ៏ធ្ងន់។[22]តើនៅទឹកដីកាឡាដលែងមានប្រេង សម្រាប់រឹតឲ្យបានធូរស្រាលហើយឬ? តើនៅទីនោះ លែងមានគ្រូពេទ្យហើយឬ? ហេតុអ្វីបានជាដំបៅនៃប្រជាជនរបស់ខ្ញុំ មិនព្រមជាសះស្បើយដូច្នេះ?

Jeremiah 8:1

ព័ត៌មានទូទៅ:

លោកយេរេមាបានជម្រាបដល់ប្រជាជនយូដា នឹងមានអ្វីកើតឡើងនៅទឹកដីនោះ។

នៅក្នុងគ្រានោះ

នៅក្នុងគ្រាដែលបានកើតឡើង ក្នុងជំពូក ៧:៣១ ៧:៣៣។

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់

សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧

ពួកគេនឹងនាំយក

ពាក្យថា «ពួកគេ» នៅទីនេះសំដៅលើពួកអ្នកដែលបំផ្លាញក្រុងយេរូសាឡិម។

ពួកអ្នកដឹកនាំ

«ពួកអ្នកដឹកនាំនៃស្រុកយូដា»

នឹងរាយឆ្អឹងទាំងនោះ

ពាក្យថា «ឆ្អឹង» សំដៅលើឆ្អឹងរបស់ពួកប្រជាជនយូដា។

របស់ទាំងអស់ដែលនៅលើមេឃ បានតាមមកហើយនិងបម្រើ

«របស់ទាំងអស់ដែលនៅលើមេឃ ដែលពួកគេស្រឡាញ់និងដែលពួកគេបម្រើ»។ ពាក្យថា «ពួកគេ» នៅទីនេះសំដៅលើពួកប្រជាជនយូដា។

ដែលពួកគេបានដើរតាម

ការបកប្រែរបៀបផ្សេងទៀត: «ដែលពួកគេ បានគោរពតាមដោយស្មោះត្រង់»។ សូមមើលពីរបៀបបកប្រែ «ដើរតាម» ក្នុងជំពូក២:២៣។

ហើយស្វែងរក

«ហើយពួកគេបានសាកសួរ»

ឆ្អឹងទាំងនោះនិងមិនអាចប្រមូល ឬយកទៅកប់ឆ្អឹង

ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់ដែលប្រមូលឆ្អឹងរបស់ពួកគេ ហើយយកទៅកប់ឡើយ»។

ពួកគេនឹងដូចអាចម៍ដី

ព្រះជាម្ចាស់បង្ហាញ ពីការមិនពេញចិត្តរបស់ពួកគេ។

ដូចអាចម៍ដី

«ដូចលាមកសត្វ» ឬ «ដូចលាមក»

លើផ្ទៃផែនដីវិញ

«ដែលពាសពេញលើដី»

ដែលយើងបានហាលឆ្អឹងទាំងនោះ

ពាក្យថា «ឆ្អឹងទាំងនោះសំដៅលើពួកប្រជាជនយូដា»។

ពួកគេនឹងជ្រើសរើសការស្លាប់ជំនួសឲ្យជីវិតសម្រាប់គេខ្លួនឯង ជាអ្នកដែលសល់ពីជនជាតិអាក្រក់នេះ

«ពួកអ្នកដែលនៅសេសសល់ពីជនជាតិអាក្រក់នេះ នឹងចង់ស្លាប់ជំនួសឲ្យមានជីវិតរស់នៅ»

Jeremiah 8:4

ដូច្នោះចូរនិយាយ

ព្រះអម្ចាស់មានព្រះបន្ទូលលោកយេរេមា។

ទៅពួកគេ

«ទៅពួកប្រជាជនយូដា»

តើមានអ្នកណាដួល ហើយមិនក្រោកឡើងវិញទេឬ?

ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនបានដឹងថា ពេលអ្នកណាម្នាក់ដួល គេនឹងក្រោកឡើងវិញ»។ .

តើហេតុអ្វីបានជាប្រជាជននៅក្រុងយេរូសាឡិម ទាំងនេះបានវង្វេងចេញ ហើយជាប់នៅក្នុងការនោះជានិច្ចដូច្នេះ?

ព្រះអម្ចាស់ប្រើសំនួរនេះ ដើម្បីបញ្ជាក់ពីរបៀបដែលប្រជាជនយូដាកំពុងប្រព្រឹត្តដែលមិនសមហេតុផលទេ។ ការបកប្រែរបៀបផ្សេងទៀត: «វាមិនសមហេតុផលទេដែលថាប្រជាជននៅក្រុងយេរូសាឡិមនេះបានងាកទៅរកការដែលគ្មានប្រយោជន៍ជារៀងរហូត»

ក្រុងយេរូសាឡិម

ពាក្យថា «ក្រុងយេរូសាឡិម» សំដៅលើពួកប្រជាជនយូដា។

កាន់ខ្ជាប់តាមការបញ្ឆោត

«បន្តថ្វាយបង្គំព្រះក្លែងក្លាយ» ឬ «ប្រកាន់ខ្ជាប់នូវសេចក្តីកុហក»

Jeremiah 8:6

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ពួកប្រជាជនយូដា។

ពួកគេមិនបាននិយាយដោយទៀងត្រង់ទេ

«មិនបាននិយាយអ្វីដែលត្រឹមត្រូវឡើយ»

ពីអំពើអាក្រក់របស់ខ្លួន

«ដោយព្រោះតែអំពើអាក្រក់របស់ខ្លួន»

តើយើងបានធ្វើអ្វីនេះ

ការបកប្រែរបៀបផ្សេងទៀត: «យើងបានធ្វើកិច្ចការដែលអាក្រក់»

គ្រប់គ្នាបានបែរទៅតាមផ្លូវរបស់ខ្លួនចង់

«ប្រជាជនទាំងមូលបន្តងាកចេញ»។

ព្រះអម្ចាស់ប្រៀបធៀបការខ្នះខ្នែងរបស់ពួកគេក្នុងការធ្វើអំពើអាក្រក់ជាមួយនឹងការងាកចេញ។ ការបកប្រែរបៀបផ្សេងទៀត:

«ប្រជាជនទាំងអស់នៅតែបន្តធ្វើអំពើអាក្រក់ដដែល»។

ដូចជាសេះស្ទុះចូលទៅក្នុងចម្បាំង

ប្រជាជនមានចិត្តចង់ធ្វើអំពើអាក្រក់ខ្លាំងណាស់ប្រៀបដូចជាសេះដែលរត់ឆ្ពោះទៅចម្បាំង ព្រោះគេមានចិត្តចង់ចូលសមរភូមិ។

សេះ

ពាក្យថា «សេះ»សំដៅលើ សេះឈ្មោល។

សត្វកុកដែលហើរលើអាកាសក៏ស្គាល់រដូវវាដែរ ហើយលលក និងត្រចៀកកាំ ហើយក្រៀល

«សត្វបក្សីដឹងថាពេលណាពួកវាគួរចាកចេញពីតំបន់ត្រជាក់ ទៅតំបន់ក្តៅ»។

សត្វកុកដែលហើរលើអាកាសក៏ស្គាល់រដូវវាដែរ ហើយលលក និងត្រចៀកកាំ ហើយក្រៀល

ទាំងអស់នេះគឺជាប្រភេទសត្វបក្សីផ្សេងៗគ្នាដែលហោះហើរពីតំបន់ក្តៅមុនពេលទៅកន្លែងផ្សេងទៀតត្រជា

ពួកវាបានទៅប្តូរកន្លែង

ប្តូរកន្លែងពីតំបន់ត្រជាក់ ទៅតំបន់តែក្តៅ»

Jeremiah 8:8

ព័ត៌មានទូទៅ:

ទាំងនេះគឺព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីពួកប្រជាជនយូដា។

ហេតុអ្វីអ្នកនិយាយថា «យើងមានប្រាជ្ញា ហើយក្រឹត្យវិន័យរបស់ព្រះអម្ចាស់ នៅជាមួយយើងដែរ?»

«ហេតុអ្វីបានជាអ្នកនិយាយថា ពួកយើងមានប្រាជ្ញា!

ហើយយើងទទួលបានក្រឹត្យវិន័យរបស់ព្រះអម្ចាស់? ការបកប្រែរបៀបផ្សេងទៀត:

«អ្នកមិនគួរនិយាយថា អ្នកមានប្រាជ្ញាហើយ អ្នកទទួលបានក្រឹត្យវិន័យ របស់ព្រះអម្ចាស់ទេ»។

ធ្វើដូចម្តេចឲ្យអ្នករាល់គ្នាថា

ពាក្យថា «អ្នក» សំដៅលើប្រជាជនយូដា។

ស្លាបប្រកាបោកប្រាស់របស់ពួកអាចារ្យ បានបង្កើតសេចក្តីកុហក

ស្លាបប្រកាតំណាងឱ្យពាក្យរបស់ពួកអាចារ្យដែលបានសរសេរ។

ការបកប្រែរបៀបផ្សេងទៀត: «រឿងក្លែងក្លាយ ដែលពួកអាចារ្យបានសរសេរបានផ្តល់ឱ្យអ្នក នូវគំនិតក្លែងក្លាយពីក្រឹត្យវិន័យរបស់ព្រះអម្ចាស់»។

ពួកមនុស្សមានប្រាជ្ញាត្រូវខ្មាស

«អស់អ្នកដែលគិតថាពួកគេជាមនុស្សមានប្រាជ្ញាត្រូវបានខ្មាស»

ត្រូវស្រយុតចិត្ត ហើយជាប់អន្ទាក់

«ខ្មាំងសត្រូវនឹងយកឈ្នះពួកគេ និងយកពួកគេចេញទៅ»

ដូច្នេះ អ្វីដែលបានប្រើគឺជាប្រាជ្ញាគេខ្លួនឯង?

ការបកប្រែរបៀបផ្សេងទៀត:

«ដូច្នេះប្រាជ្ញាដែលគេបានដឹងនោះមិនបានធ្វើការអ្វីមួយល្អទេ»។

ពួកអ្នកដែលគ្រប់គ្រងផ្សេងទៀត

«ពួកអ្នកដែលគ្រប់គ្រងដែនដីរបស់ពួកគេ»

ដែលគ្មានប្រយោជន៍ជារៀងរហូត ដែលគ្មានប្រយោជន៍ជារៀងរហូត ដែលគ្មានប្រយោជន៍ជារៀងរហូត

សូមមើលពីរបៀបបកប្រែឃ្លានេះក្នុងជំពូក ៦:១៣។
ស្លឹកទាំងប៉ុន្មាននឹងស្វិតក្រៀម
«ស្លឹកនឹងស្ងួត»
ហើយអ្វីដែលយើងបានឲ្យដល់គេនឹងសូន្យបាត់ទៅ
អត្ថន័យនៃភាសាហេប្រឺគឺមិនបានច្បាស់លាស់ទេ។ អាចមានន័យថា ១)
«ខ្ញុំបានផ្តល់ការណែនាំដល់ប្រជារាស្ត្រខ្ញុំ
ប៉ុន្តែប្រជារាស្ត្ររខ្ញុំមិនបានគោរពតាមការណែនាំនេះឡើយ» ឬ ២)
«ដូច្នេះខ្ញុំបានឲ្យប្រជារាស្ត្រទាំងនេះទៅឲ្យសត្រូវរបស់ពួកគេ
ដូច្នេះសត្រូវរបស់ពួកគេនឹងជាន់ឈ្លីពួកគេ»។
Jeremiah 8:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលរបស់ព្រះអង្គដល់យើងពីអ្វីដែលពួកប្រជាជនយូដានៅក្នុងភាសាហេព្រើរត្រូវបានបកស្រាយតាមរបៀបផ្សេងៗគ្នាតាមសម័យកាលថ្មី។ ពីពេលពួកគេត្រូវបានដាក់ទណ្ឌកម្ម។
ហេតុអ្វីបានជាយើងរាល់គ្នាអង្គុយតែស្ងៀមដូច្នេះ?
ការបកប្រែរបៀបផ្សេងទៀត: «យើងមិនគួរនៅទីនេះទេ»។
ចូរយើងនាំគ្នាចូលទៅក្នុងបន្ទាយទីក្រុងទាំងនោះ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៤:៤។
បន្ទាយទីក្រុងទាំងនោះ
«ទីក្រុងទាំងនោះដែលមានជញ្ជាំងខ្ពស់ និងមានទាហានការពារផងដែរ»
ហើយយើងនឹងស្ងៀមនៅទីនោះពេញដោយសេចក្តីស្លាប់វិញ
ការបកប្រែរបៀបផ្សេងទៀត: «ហើយយើងនឹងស្លាប់នៅទីនោះ»។
ដ្បិតព្រះអម្ចាស់ជាព្រះនៃយើង ព្រះអង្គនឹងធ្វើឲ្យយើងនៅស្ងៀម
ការបកប្រែរបៀបផ្សេងទៀត: «ដោយព្រោះតែព្រះអម្ចាស់ជាព្រះនៃយើង
នឹងដាក់ឲ្យយើងស្លាប់»។
ព្រះអង្គឲ្យយើងផឹកទឹកពុលដែរ
«ព្រះអង្គនិងឲ្យយើងផឹកទឹកពុលដែរ» សំដៅលើ
ការការជំនុំជម្រះរបស់ព្រះជាម្ចាស់។
តែមើល ទីនោះមាន
«តែស្តាល់ថា ទីនោះមាន»
Jeremiah 8:16
ព័ត៌មានទូទៅ:
ព្រះជាម្ចាស់ការវាយបម្បោសេះរបស់គេបានឮដល់ដាន់ព្រះបន្ទូលបន្ថែមទៀតពី
ការដាក់ទណ្ឌកម្មទៅជនជាតិយូដា។
ការវាយបម្បោសេះរបស់គេបានឮដល់ដាន់
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនដែលនៅដាន់បានលឺសំលេងពីកងទ័ពសត្រូវដែលមកវាយស្រុកយូដា»។
សេះ
សេះឈ្មោល
ផែនដីទាំងមូលបានកក្រើក
ការបកប្រែរបៀបផ្សេងទៀត:
«ពួកប្រជាជនដែលនៅទឹកដីនោះបានញាប់ញ័រដោយភាពភ័យខ្លាច»
ដោយសម្លេងជើងសេះរត់ឮខ្លាំងរបស់គេ
«នៅពេលពួកគេលឺសំលេងរបស់សេះរបស់ខ្មាំងសត្រូវដ៏ខ្លាំងខ្លា»
ជើងសេះរត់
ជាសំលេងដែលសេះធ្វើ
ដ្បិតគេបានមក
ពាក្យថា «គេ» សំដៅលើខ្មាំងសត្រូវដែលកំពុងឈ្លានពាន។
ដើម្បីនឹងស៊ីលេបទឹកដី
«នឹងបំផ្លាញទឹកដី»។
យើងនឹងចាត់ពស់វែកមកនៅក្នុងកណ្តាលអ្នក
ពស់វែកតំណាងឲ្យទាហានខ្មាំងសត្រូវ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបានចាត់បញ្ជូនទាហានខ្មាំងសត្រូវមកច្បាំងនឹងអ្នក»។
ពូជពស់វែកដែលគ្មានគ្រូមើលជាទេ
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមិនអាចចាត់ពស់វែកដោយប្រើវេទមន្តបានឡើយ»។
ពស់វែក
ជាប្រភេទពស់ដែលពុលហើយមានចង្កូមធំ
ពួកវានឹងចឹកអ្នករាល់គ្នា
ការបកប្រែរបៀបផ្សេងទៀត: «ពួកវានឹងវាយប្រហារអ្នក» ឬ
«ពួកវានឹងបំផ្លាញអ្នក។»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
Jeremiah 8:18
ព័ត៌មានទូទៅ:
លោកយេរេមា និងព្រះអម្ចាស់បានសន្ទនាគ្នាពីប្រជាជនយូដា។
ការឈឺចាប់របស់យើងមិនចប់ទេ ហើយចិត្តរបស់យើង គឺឈឺ
ការឆ្លងកាត់ដ៏លំបាក
ការឈឺចាប់របស់យើងមិនចប់ទេ
ពាក្យថា «របស់យើង» សំដៅលើលោកយេរេមា។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកយើងទុក្ខព្រួយខ្លាំង»។
ហើយចិត្តរបស់យើងគឺឈឺ
ពាក្យថា «របស់យើង» សំដៅលើយេរេមា។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំងក្នុងដួងចិត្តរបស់ខ្ញុំ»។
ចូរមើល៍! សម្រែកយំសោកនៃទីក្រុងរបស់ប្រជាជនរបស់យើង ចេញពីទឹកដីឆ្ងាយ!
លោកយេរេមានិយាយពីពួកប្រជាជនយូដា។ អាចមានន័យថា ១)
«ប្រជាជនយូដាស្រែកហៅពីការនិរទេសខ្លួននៅឯទឹកដីឆ្ងាយ» ឬ ២)
ប្រជាជនយូដាស្រែកហៅពីគ្រប់ទិសទីនៃទឹកដីអ៊ីស្រាអែល»។
ទីក្រុងរបស់ប្រជាជនរបស់យើង
ទឹកដីអ៊ីស្រាអែលជាទីក្រុង។
តើព្រះអម្ចាស់លែងគង់នៅក្រុងស៊ីយ៉ូនហើយឬ?
ក្រុងយេរូសាឡិមសំដៅជាក្រុងស៊ីយ៉ូន។
តើព្រះអម្ចាស់លែងគង់នៅក្រុងស៊ីយ៉ូនហើយឬ? ឬគ្មានមហាក្សត្រនៅក្នុងក្រុងទៀតទេ?
លោកយេរេមាប្រាប់ពីអ្វី ដែលប្រជាជនយូដាកំពុងតែនិយាយ។
សំណួរស្របគ្នាទាំងពីរបង្ហាញថាប្រជាជនយូដាកំពុងឆ្ងល់ថា
ហេតុអ្វីបានជាព្រះអម្ចាស់មិនជួយសង្គ្រោះពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ហេតុអ្វីបានជាព្រះអម្ចាស់មិនជួយសង្គ្រោះយើង
ប្រសិនបើទ្រង់ជាស្តេចនៅក្រុងយេរូសាឡិម?»
ហេតុអ្វីបានជាពួកគេធ្វើឲ្យយើងអន់ចិត្ត ដោយសារការស្វែងរកព្រះរបស់ជនជាតិដទៃ
ពាក្យថា «យើង» សំដៅលើ ព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើពួកគេចង់ឲ្យទ្រង់ជួយសង្គ្រោះពួកគេ
នោះពួកគេមិនគួរធ្វើឲ្យទ្រង់អន់ចិត្តដោយគោរពបូជារូបព្រះរបស់គេឡើយ»។
Jeremiah 8:20
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីពួកប្រជាជនយូដា។
រដូវចម្រូតកន្លងផុតទៅ
«រយៈពេលនៃការច្រូតកាត់បានបញ្ចប់»
តែពួកយើងមិនបានទទួលការសង្គ្រោះសោះ
លោកយេរេមាប្រាប់ពីអ្វីដែលប្រជាជនយូដាកំពុងតែនិយាយ។ ពាក្យថា «យើង»
សំដៅទៅលើប្រជាជនយូដា។ ការបកប្រែរបៀបផ្សេងទៀត:
«តែព្រះអម្ចាស់មិនបានសង្គ្រោះយើងទេ»។
ដួងចិត្តយើងត្រូវឈឺពីព្រោះឈឺនៃទីក្រុងរបស់ប្រជាជនរបស់ខ្ញុំ
ពាក្យ «យើង» សំដៅលើលោកយេរេមា។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមានអារម្មណ៍តូចចិត្តណាស់
ដោយព្រោះប្រជាជនយូដាកំពុងជួបប្រទះរឿងគួរឲ្យភ័យខ្លាច។
តើនៅទឹកដីកាឡាដគ្មានថ្នាំទៀតទេ? តើគ្មានអ្នកព្យាបាលទេនៅទីនោះ?
ការបកប្រែរបៀបផ្សេងទៀត: «មានថ្នាំសង្កូវនៅឯស្រុកកាឡាដ
ហើយនឹងមានអ្នកព្យាបាលផងដែរនៅស្រុកកាឡាដ!»
តើហេតុអ្វីបានជាការព្យាបាលនៃប្រជាជនរបស់យើង មិនកើតឡើងបែបនេះ?
ការបកប្រែរបៀបផ្សេងទៀត:
«តែប្រជាជនរបស់យើងមានរបួសខាងវិញ្ញាណដែលថ្នាំ
និងគ្រូពេទ្យមិនអាចព្យាបាលបានឡើយ»។

---

9 [1]ប្រសិនបើក្បាលខ្ញុំពេញដោយទឹក ហើយភ្នែកខ្ញុំជារន្ធចេញទឹកជានិច្ច ដើម្បីឲ្យខ្ញុំបានយំទាំងយប់ទាំងថ្ងៃ ពីដំណើរពួកអ្នកដែលត្រូវគេសម្លាប់ ក្នុងកូនស្រីនៃជនជាតិ
ខ្ញុំ [2]បើសិនខ្ញុំមានទីស្នាក់អាស្រ័យនៅទីរហោស្ថាន ជាទីសំណាក់របស់អ្នកដំណើរ ដើម្បីឲ្យខ្ញុំបានលះបង់ជនជាតិរបស់ខ្ញុំ ហើយឃ្លាតចេញពីគេទៅ ដ្បិតគេសុទ្ធតែជាពួក

generated on Wed Sep 10 16:16:32 2025

កំផិត គឺជាជំនុំមនុស្សក្បត់![3]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ពួកគេដំឡើងអណ្តាតដូចជាធ្នូ សម្រាប់ពាក្យបោកប្រាស់ ហើយគេបានចម្រើនកម្លាំងនៅក្នុងទឹកដីផង។ ប៉ុន្តែ
មិនមែនសម្រាប់សេចក្តីពិតត្រង់ទេ ដ្បិតគេចេះតែប្រព្រឹត្តអំពើអាក្រក់ពីមួយហើយទៅមួយទៀតមិនឈប់ឡើយ។ ពួកគេមិនស្គាល់យើងទេ»។
[4]ចូរឲ្យគ្រប់គ្នាប្រុងប្រយ័ត្នចំពោះអ្នកជិតខាងខ្លួន កុំទុកចិត្តនឹងបងប្អូនណាមួយឡើយ ដ្បិតគ្រប់ទាំងបងប្អូននឹងដណ្តើមយកប្រយោជន៍អស់រលីង ហើយគ្រប់ទាំងអ្នកជិត
ខាង នឹងដើរទៅមកនិយាយមួលបង្កាច់គេ។[5]គ្រប់គ្នានឹងបញ្ឆោតអ្នកជិតខាងខ្លួន ហើយមិនព្រមពោលសេចក្តីពិតទេ គេបានបង្វឹកអណ្តាតឲ្យកុហក គេខំអស់ពីចិត្តនឹង
ប្រព្រឹត្តអាក្រក់។[6]អ្នកបានរស់នៅក្នុងចំណោមការបោកបញ្ឆោតម្តងហើយម្តងទៀត ពួកគេមិនព្រមទទួលស្គាល់យើងឡើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[7]ព្រះអម្ចាស់នៃពិភពទាំងមូល ព្រះអង្គមានព្រះបន្ទូលថា៖ មើល៍! យើងនឹងរំលាយ ហើយសាកល្បងគេ ដ្បិតតើឲ្យយើងធ្វើយ៉ាងណាទៀត ដល់កូនស្រីរបស់ប្រជារាស្ត្ររបស់
យើងនេះ?[8]អណ្តាតគេជាព្រួញដែលសម្លាប់ ក៏ពោលសុទ្ធតែពាក្យបោកបញ្ឆោត គេនិយាយសេចក្តីមេត្រីនឹងអ្នកជិតខាង ដោយបបូរមាត់ តែក្នុងចិត្តគេលបចាំចាប់វិញ។
[9]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ តើមិនត្រូវឲ្យយើងធ្វើទោសគេ ដោយព្រោះអំពើយ៉ាងនោះទេឬ? តើយើងមិនត្រូវសងសឹក ចំពោះជនជាតិនេះទេឬ?
[10]ខ្ញុំនឹងច្រៀងចំរៀងកាន់ទុក្ខ ដល់ភ្នំទាំងប៉ុន្មាន ទួញចំពោះវាលឃ្វាលសត្វនៅទីរហោស្ថាន ព្រោះបានឆេះអស់ហើយ បានជាគ្មានអ្នកណាដើរតាមនោះទៀត ក៏គ្មានអ្នកណា
ឮសំឡេងរបស់ហ្វូងសត្វដែរ សត្វហើរលើអាកាស និងសត្វជើងបួនបានបាត់អស់ទៅហើយ។[11]យើងនឹងធ្វើឲ្យក្រុងយេរូសាឡិមត្រឡប់ជាកងគំនរ គឺជាទីលំនៅនៃពួកចចក
ហើយធ្វើឲ្យក្រុងទាំងប៉ុន្មាននៅទឹកដីយូដា ត្រូវចោលស្ងាត់ ឥតមានអ្នកណានៅឡើយ»។[12]តើអ្នកណាមានប្រាជ្ញា ដែលអាចយល់សេចក្តីនេះបាន? តើព្រះឧស្ឋនៃ
ព្រះអម្ចាស់បានមានព្រះបន្ទូលចំពោះអ្នកណា ដើម្បីឲ្យគេបានថ្លែងប្រាប់តទៅ? ហេតុអ្វីបានជាទឹកដីត្រូវវិនាស ហើយឆេះសុសដូចជាទីរហោស្ថាន ដែលគ្មានអ្នកណាដើរ
កាត់ទៀតដូច្នេះ?
[13]ព្រះអម្ចាស់មានបន្ទូលថា៖ គឺដោយព្រោះតែគេបានបោះបង់ក្រឹត្យវិន័យរបស់យើង ដែលយើងបានដាក់នៅមុខគេ ហើយមិនបានស្តាប់ ឬដើរតាមពាក្យរបស់យើង
ប៉ុណ្ណោះ។[14]គឺគេបានដើរតាមតែចិត្តរឹងរបស់គេវិញ ព្រមទាំងតាមព្រះបាលទាំងប៉ុន្មាន ដែលបុព្វបុរសគេបានបង្រៀនដល់គេ។
[15]ហេតុនោះ ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ យើងនឹងចិញ្ចឹមជនជាតិនេះដោយស្លែង ហើយនឹងឲ្យទឹកពុលទៅគេ
ផឹក។[16]យើងនឹងកម្ចាត់កម្ចាយគេទៅគ្រប់ទាំងជនជាតិ ដែលខ្លួនគេ ឬបុព្វបុរសគេ ក៏មិនបានស្គាល់ផង ហើយយើងនឹងចាត់ប្រើដាវឲ្យទៅតាមគេ ដរាបដល់បានបំផ្លាញគេ
អស់រលីង។
[17]ព្រះអម្ចាស់នៃពិភពទាំងមូល ព្រះអង្គមានព្រះបន្ទូលថា៖ ចូរអ្នករាល់គ្នាពិចារណាចុះ ហើយហៅពួកស្ត្រីស៊ីឈ្នួលយំឲ្យមក ចូរចាត់គេឲ្យទៅហៅពួកស្ត្រីវាងវៃឲ្យមកដែរ។
[18]ត្រូវឲ្យគេប្រញាប់លើកបទទំនួញឲ្យយើង ដើម្បីឲ្យភ្នែកយើងបានស្រក់ទឹកចុះ ហើយឲ្យត្របកភ្នែកយើងបានចេញទឹកឥតឈប់។
[19]ដ្បិត មានឮសំឡេងទ្រហោយំ ពីក្រុងស៊ីយ៉ូនមកថា៖ តើយើងវេទនាយ៉ាងណាហ្ន៎។ យើងមានសេចក្តីខ្មាសជ្រប់មុខ ដោយព្រោះយើងត្រូវចោលទឹកដី ហើយដោយព្រោះ
គេបានរំលំទីលំនៅ របស់យើងចោល។[20]ប៉ុន្តែ ពួកស្ត្រីៗអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ ហើយឲ្យត្រចៀកទទួលព្រះបន្ទូល ពីព្រះឧស្ឋរបស់ព្រះអង្គផង ត្រូវបង្រៀន
កូនស្រីរបស់អ្នករាល់គ្នា ឲ្យចេះយំសោក ហើយឲ្យអ្នកជិតខាងទាំងប៉ុន្មាន ចេះទួញទំនួញ។
[21]ដ្បិតសេចក្តីស្លាប់បានឡើងចូលមកតាមបង្អួចយើង ក៏បានចូលមកក្នុងដំណាក់របស់យើងដែរ ដើម្បីដកយកជីវិតកូនក្មេងនៅតាមទីធ្លា និងពួកកំលោះៗនៅតាមដងផ្លូវ។
[22]ចូរប្រាប់ចុះ ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ សាកសពរបស់មនុស្សនឹងធ្លាក់ចុះ ដូចជាជីនៅវាលស្រែ ហើយដូចជាកណ្តាប់ស្រូវ តាមក្រោយអ្នកច្រូត ឥតមានអ្នកណា
ប្រមូលវិញឡើយ»។
[23]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «កុំបីឲ្យអ្នកប្រាជ្ញអួតពីប្រាជ្ញារបស់ខ្លួនឡើយ ក៏កុំឲ្យមនុស្សខ្លាំងពូកែអួតពីកម្លាំងខ្លួន ឬអ្នកមានអួតពីទ្រព្យសម្បត្តិរបស់ខ្លួនដែរ។[24]ឯ
អ្នកដែលអួត នោះត្រូវឲ្យអួតតែពីសេចក្តីនេះវិញ គឺថាខ្លួនមានយោបល់ ហើយក៏ស្គាល់ដល់យើងថា យើងជាព្រះអម្ចាស់ដែលប្រោសផ្សាយសេចក្តីសប្បុរស សេចក្តីយុត្តិធម៌
និងសេចក្តីសុចរិតនៅផែនដី ដ្បិតយើងរីករាយចិត្តចំពោះសេចក្តីទាំងនោះហើយនេះជាព្រះបន្ទូលនៃព្រះអម្ចាស់»។
[25]«ព្រះអម្ចាស់មានព្រះបន្ទូលថា៖ មើល៍! នឹងមានគ្រាមកដល់ ដែលយើងនឹងវាយផ្ចាលពួកកាត់ស្បែក ដែលកាត់មិនស្មោះត្រង់។[26]គឺជនជាតិអេស៊ីប ជនជាតិយូដា ជនជាតិ
អេដុម និងពួកកូនចៅអាំម៉ូន និងម៉ូអាប់ ព្រមទាំងអស់អ្នកនៅទីរហោស្ថាន ដែលកាត់ជ្រុងពុកចង្កាផង ដ្បិតបណ្តាជនជាតិទាំងប៉ុន្មាន មិនកាត់ស្បែកទេ ពួកវង្សអ៊ីស្រាអែល
ទាំងអស់ ក៏មិនបានកាត់ស្បែកចិត្តដែរ»។

Jeremiah 9:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់ និងលោកយេរេមាបន្តថ្លែងពីពួកប្រជាជនយូដា។
ប្រសិនបើក្បាលខ្ញុំពេញដោយទឹក ហើយភ្នែកខ្ញុំជារន្ធចេញទឹកភ្នែកជានិច្ច
នេះជាអ្វីដែលលោកយេរេមាបានថ្លែង។ ការបកប្រែរបៀបផ្សេងទៀត:
«យើងចង់ឲ្យយើងយំចេញទឹកភ្នែកកាន់តែច្រើន!»
ទាំងយប់ទាំងថ្ងៃ
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ពេលវេលា»។
ក្នុងទីក្រុងនៃប្រជាជនយើង
សូមមើលពីរបៀបបកប្រែក្នុងជំពូក ៤:១១។
ដែលត្រូវបានសម្លាប់
ការបកប្រែរបៀបផ្សេងទៀត: «ដែលត្រូវបានខ្មាំងសត្រូវសម្លាប់។»
បើសិនមានអ្នកណាឲ្យយើង
នេះគឺអ្វីដែលលោកយេរេមាបានថ្លែង។ «យើងចង់ឲ្យអ្នកណាឲ្យយើង»
ធ្វើដំណើរទៅក្នុងទីរហោស្ថានដើម្បីនិយាយថា
នេះសំដៅទៅលើអគារមួយសម្រាប់មនុស្សដែលធ្វើដំណើរនៅទីរហោស្ថាន
ហើយជាកន្លែងដែលពួកគេអាចឈប់និងគេងពេលយប់បាន។
ចាកចេញពីពួកគេទៅ
«ចេញពីប្រជាជនយើង»
ពួកមនុស្សក្បត់
«ពួកមនុស្សដែលក្បត់មនុស្សផ្សេងទៀត»
ព្រះអម្ចាស់មានព្រះបន្ទូលថា
សូមមើលរបៀបបងប្អូនបកប្រែក្នុងគំនិតដូចគ្នាជំពូក ១:៧។
ពួកគេដំឡើងអណ្តាតដូចជាធ្នូសម្រាប់កុហក
ការនិយាយកុហកត្រូវសំដៅលើការបញ្ចេញដោយអណ្តាតរបស់មនុស្សអាក្រក់។
ដូចគ្នានេះផងដែរដោយសារការនិយាយកុហកមិនអាចត្រូវត្រលប់វិញ
ការនិយាយកុហកត្រូវបានគេសំដៅលើដូចជាការបាញ់ព្រួញ។
មនុស្សបាញ់ធ្នូត្រូវតែឈរបោះជំហានរបស់ពួកគេដើម្បីរឹតខ្សែធ្នូ។
ដូច្នេះពួកអ្នកភូតភរនេះបានគេសំដៅ
ដូចជាពួកគេកំពុងរឹតខ្សែធ្នូរបស់ពួកគេដោយប្រើអណ្តាតរបស់ពួកគេ។
វាមិនមែនដោយព្រោះសេចក្តីស្មោះត្រង់របស់ពួកគេ
វគ្គបទគម្ពីរនេះបញ្ជាក់ថាមនុស្សទាំងនេះមិនស្មោះត្រង់នឹងព្រះជាម្ចាស់ទេ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនស្មោះត្រង់នឹងព្រះអម្ចាស់ទេ»។
វាមិនមែនដោយព្រោះសេចក្តីស្មោះត្រង់របស់ពួកគេ
ឃ្លានេះក្នុងភាសាហេប្រឺត្រូវបានបកស្រាយដោយសម័យការថ្មីប្រៀបដូចជា
«ពួកគេមិនមានអំណាចក្នុងសេចក្តីពិត»។
ពួកគេទៅលើសពីអាក្រក់ទៅអាក្រក់ជាងមុនទៀត
ការប្រព្រឹត្តអំពើអាក្រក់មួយបន្ទាប់ពីការមួយផ្សេងទៀត
ត្រូវបានគេសំដៅលើមនុស្សអាក្រក់បានធ្វើពីសកម្មភាពមួយទៅសកម្មភាពមួយទៀត។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបន្តធ្វើអំពើអាក្រក់»
Jeremiah 9:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលជាមួយនឹងលោកយេរេមា ពីពួកប្រជាជនយូដា។
ចូរឲ្យគ្រប់គ្នា
ពាក្យថា «គ្រប់គ្នា» សំដៅលើប្រជាជនយូដា។
ប្រុងប្រយ័ត្នចំពោះអ្នកជិតខាងខ្លួន ហើយកុំទុកចិត្តនឹងបងប្អូនណាមួយឡើយ
«ប្រុងប្រយ័ត្នកុំទុកចិត្តបងប្អូនរួមជំនឿដែលជាជនជាតិអ៊ីស្រាអែល
ហើយក៏កុំទុកចិត្តបងប្អូនរបស់ខ្លួនឲ្យសោះ»
ហើយគ្រប់ទាំងអ្នកជិតខាងដើរក្នុងការបង្កាច់ បង្ខូច
ការនិយាយកុហកតាមទម្លាប់ពីគ្នាទៅវិញទៅមក

generated on Wed Sep 10 16:16:32 2025

ត្រូវសំដៅលើដូចជាការដែលកំពុងដើរនិយាយបង្កាច់បង្ខូច។
គ្រប់មនុស្សបញ្ឆោតអ្នកជិតខាងខ្លួន ហើយមិនព្រមនិយាយពិតទេ
«មនុស្សទាំងអស់បោកបញ្ឆោតគ្នា ហើយពួកគេមិននិយាយសេចក្ដីពិតទេ»
ពួកគេអស់កម្លាំងនឹងប្រព្រឹត្តការទុច្ចរិត
«ពួកគេធុញទ្រាន់នឹងការប្រព្រឹត្តអំពើបាបដ៏ច្រើន»
អ្នកបានរស់នៅក្នុងចំណោមការបោកបញ្ឆោត
ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់លោកយេរេមា។
ការរស់នៅក្នុងចំណោមមនុស្សកុហកត្រូវបានសំដៅលើដូចជាការដែលកំពុងរស់នៅក្នុងចំណោមពួកអ្នកដែលមិនស្គាល់ព្រះ
ក្នុងការបោកបញ្ឆាត់របស់ពួកគេ គឺមិនព្រមទទួលស្គាល់យើងទេ
«ដោយថ្លែងពីការនិយាយកុហកនេះ
ពួកប្រជាជនយូដាបដិសេធគោរពយើងដែលជាព្រះអម្ចាស់»។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧។
Jeremiah 9:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីប្រជាជនយូដា។
ទីក្រុងនៃប្រជាជនយើង
សូមមើលពីរបៀបដែលអ្នកបានបកប្រែក្នុងជំពូក ៤:១១។
អណ្តាតគេជាព្រួញដែលមុត
អណ្តាតធ្វើឲ្យមនុស្សឈឺចាប់ដោយការភូតកុហកដូចដែលព្រួញមុតស្រួចធ្វើឲ្យមនុស្សឈឺចាប់ដែរ
ក្នុងម៉ាត់គេថ្លែងសុខសាន្តនឹងអ្នកជិតខាង
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេប្រើពាក្យរបស់គេថាពួកគេចង់បានសន្តិភាពជាមួយអ្នកជិតខាង»
តែក្នុងចិត្តគេវិញពេញដោយការកុហករងចាំសម្រាប់គេវិញ
ការបកប្រែរបៀបផ្សេងទៀត:
«តែអ្វីដែលពួកគេចង់បានគឺបំផ្លាញអ្នកជិតខាងរបស់គេ»
តើយើងមិនត្រូវដាក់ទោសគេដោយព្រោះការទាំងនេះទេឬ? នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ តើយើង
មិនត្រូវសងសឹកឲ្យខ្លួនយើង លើជនជាតិដូចនេះទេឬ?
សូមមើលពីរបៀបដែលអ្នកបានបកប្រែដែលស្រដៀងគ្នានៅក្នុងជំពូក ៥: ៧។
Jeremiah 9:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីប្រជាជនយូដា។ នៅក្នុងខ ១២
លោកយេរេមាធ្វើអត្ថាធិប្បាយ។
យើងនឹងច្រៀងចំរៀងកាន់ទុក្ខ ហើយយំសោកដល់ភ្នំទាំងនោះ
ហើយសម្រៀងបុណ្យសព្វនឹងចៀងសម្រាប់វាលស្មៅ
ព្រះអម្ចាស់កាន់ទុក្ខទឹកដីអ៊ីស្រាអែលប្រៀបដូចជាមនុស្សស្លាប់។
វាលស្មៅ
«ទីវាលដែលសម្រាប់សត្វស៊ីស្មៅ»
ដ្បិតវាបានឆេះអស់
«ដោយសារតែមាននរណាម្នាក់បានដុតវាលស្មៅនិងវាលរុក្ខជាតិបៃតង»។
ពួកគេមិនឮសំឡេងរបស់ហ្វូងសត្វដែរ
«គ្មាននរណាម្នាក់នឹងលឺសំលេងហ្វូងសត្វទេ»
ជាទីលំនៅនៃពួកចចក
«ជាទីដែលពួកចចកលាក់ខ្លួន»
ពួកចចក
ជាពពួកឆ្កែព្រៃកំណាច
ជាកន្លែងដែលគ្មានមនុស្សរស់នៅទៀត
«ជាទីកន្លែងដែលគ្មានមនុស្សរស់នៅឡើយ»
តើមនុស្សអាចមានប្រាជ្ញានឹងយល់សេចក្ដីនេះទេ?
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើពួកព្យាការីរបស់អ្នកពិតជាមានប្រាជ្ញា
ពួកគេគួរតែដឹងថាហេតុអ្វីបានជាទឹកដីនេះត្រូវបានបំផ្លាញ»។
តើអ្នកណាទៅដែលព្រះឧស្ដនៃព្រះអម្ចាស់មានព្រះបន្ទូល ហើយអ្នកនោះនឹងប្រកាសតទៅទៀត?
ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើព្រះអម្ចាស់ពិតជាមានព្រះបន្ទូលទៅពួកព្យាការីរបស់អ្នក
ពួកគេគួរតែអាចប្រាប់អ្នកពីអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលអំពីការបំផ្លាញទឹកដីនេះផងដែរ»
ហេតុអ្វីបានជាទឹកដីត្រូវវិនាស
ការបកប្រែរបៀបផ្សេងទៀត: «ព្យាការីរបស់អ្នកមិនមានប្រាជ្ញាទេ
ហើយព្រះអម្ចាស់ក៏មិនបានមានព្រះបន្ទូលថាជាមួយពួកគេដែរ
ដូច្នេះពួកគេមិនដឹងថាហេតុអ្វីបានជាទឹកដីនេះត្រូវបានបំផ្លាញដែរ។
Jeremiah 9:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីពួកប្រជាជនយូដា។
ដោយព្រោះតែពួកគេបានបោះបង់
«ទឹកដីនេះត្រូវបំផ្លាញ ដោយព្រោះតែពួកប្រជាជនយូដាមិនស្តាប់បង្គាប់»
ពួកគេមិនបានស្តាប់សម្លេងរបស់យើង
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិនបានធ្វើតាមច្បាប់ដែលខ្ញុំបានប្រគល់ឲ្យ»
ឬដើរតាមសមសែងនោះ
ការបកប្រែរបៀបផ្សេងទៀត: «រស់នៅតាមរបៀប
ដែលយើងថ្លែងប្រាប់ពួកគេឲ្យរស់នៅ»។
គេបានដើរតាមតែចិត្តរឹងរបស់គេ
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេរឹងចចេសហើយរស់នៅតាមរបៀបដែលពួកគេចង់រស់នៅ»។
ហើយដើរតាមព្រះបាល
«ហើយថ្វាយបង្គំព្រះក្លែងក្លាយ»
Jeremiah 9:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីប្រជាជនយូដា។
ផ្លែចេញ
រុក្ខជាតិដែលមានរសជាតិល្វីង
រួចហើយយើងនឹងកម្ចាត់កម្ចាយគេទៅគ្រប់ទាំងប្រជាជាតិ
«បន្ទាប់មកយើងនឹងបង្ខំពួកគេឲ្យចាកចេញពីទឹកដីនេះហើយរស់នៅក្នុងប្រទេសដទៃទៀត»
យើងនឹងចាត់ដាវឲ្យទៅតាមពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំនឹងបញ្ជូនកងទ័ពទៅប្រយុទ្ធនឹងពួកគេ»។
Jeremiah 9:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលទៅប្រជាជនយូដាអោយកាន់ទុក្ខចំពោះការបំផ្លាញទឹកដីដែលនឹងកើតឡើង។
ហៅពួកអ្នកច្រៀងបុណ្យសព ចូរឲ្យគេមក។ បញ្ជូនស្ត្រីដែលមានជំនាញស្ទូតពីទុក្ខសោក
ចូរឲ្យពួកគេមក
ការបកប្រែរបៀបផ្សេងទៀត: «នាំស្ត្រីមកបណ្តុះបណ្តាលក្នុងការកាន់ទុក្ខ
ហើយនាំស្ត្រីទាំងនោះមកទីនេះ»។
ហៅពួកអ្នកច្រៀងបុណ្យសព
«ហៅពួកស្ត្រីដែលមានអាជីពច្រៀងនៅក្នុងពិធីបុណ្យសព»
ចូរឲ្យគេមក
ការបកប្រែរបៀបផ្សេងទៀត: «ចូរហៅស្ត្រីនោះមក»។
បញ្ជូនស្ត្រីដែលមានជំនាញស្ទូតពីទុក្ខសោក
ការបកប្រែរបៀបផ្សេងទៀត:
«បញ្ជូនក្រុមមនុស្សចេញដើម្បីស្វែងរកស្ត្រីដែលមានជំនាញក្នុងការកាន់ទុក្ខ»។
ត្រូវឲ្យគេប្រញាប់លើកបទច្រៀងពីទំនួញទិក្ខសោកឲ្យយើង
ព្រះអម្ចាស់មានព្រះបន្ទូលអំពីអ្វីដែលប្រជាជនយូដានឹងនិយាយនៅពេលដែលមានការបំផ្លាញកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រាប់ស្ត្រីឲ្យប្រញាប់ហើយច្រៀងបទចម្រៀងកាន់ទុក្ខសម្រាប់យើង»។
ដូច្នេះភ្នែកយើងបានស្រក់ទឹកមក ហើយឲ្យត្របកភ្នែកយើងបានចេញទឹកមកដែរ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះពួកយើងនឹងយំយ៉ាងខ្លាំង»។
Jeremiah 9:19
ព័ត៌មានទូទៅ:
ព្រះបន្ទូលព្រះអម្ចាស់ទាំងនេះ គឺអំពីប្រជាជនយូដា។
ដ្បិត សម្លេងទ្រហោយំបានឮពីក្រុងស៊ីយ៉ូន
ការបកប្រែរបៀបផ្សេងទៀត: «ពួកមនុស្សនៅក្រុង
យេរូសាឡិមកំពុងយំយ៉ាងខ្លាំង»។
តើយើងអោយខ្មេចខ្ចីបែបណា
ព្រះអម្ចាស់មានព្រះបន្ទូលអំពីអ្វីដែលប្រជាជនយូដានឹងនិយាយនៅពេលដែលទឹកដីនោះត្រូវបានបំផ្លាញ។
ការបកប្រែរបៀបផ្សេងទៀត: «យើងមានការខកចិត្តយ៉ាងខ្លាំង»។
ការអាម៉ាស់យ៉ាងខ្លាំង ដ្បិតយើង បោះ បង់ទឹកដីចាប់តាំងពួកគេហែកផ្ទួលដំណាក់របស់យើង
ការអាម៉ាស់របស់យើងគឺយ៉ាងខ្លាំង ព្រោះខ្មាំងសត្រូវបានបំផ្លាញដំណាក់របស់យើង
ហើយយើងត្រូវចាកចេញពីទឹកដីអ៊ីស្រាអែល»
សូមយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលចេញពីព្រះឧស្ឋរបស់ព្រះអង្គ
ឃ្លាទាំងពីរនេះមានន័យដូចគ្នាហើយបញ្ជាក់ថាបញ្ញាតិទាំងឡាយដើម្បីស្តាប់នូវអ្វីដែលព្រះអម្ចាស់មានព្រះ

generated on Wed Sep 10 16:16:32 2025

(សូមមើល: និងfigs-metonymy)
ចូរបង្រៀនអ្នកក្រុងរបស់អ្នកនូវចម្រៀងកាន់ទុក្ខ ហើយឲ្យអ្នកជិតខាងស្រីៗបទបុណ្យសព្វផង
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
វាមានន័យថាការឆ្លើយតបត្រឹមត្រូវចំពោះសារនៃការជំនុំជំរះរបស់ព្រះអម្ចាស់គឺការកាន់ទុក្ខ
ការបកប្រែរបៀបផ្សេងទៀត: «ចូរបង្រៀនមនុស្សផ្សេងទៀតពីរបៀបកាន់ទុក្ខ»។
Jeremiah 9:21
ព័ត៌មានទូទៅ:
ព្រះបន្ទូលព្រះអម្ចាស់ទាំងនេះ គឺអំពីប្រជាជនយូដា។
ដ្បិតសេចក្តីស្លាប់បានចូលមកតាមបង្អួចយើង
ព្រះអម្ចាស់មានព្រះបន្ទូលអំពីអ្វីដែលប្រជាជនយូដានឹងនិយាយនៅពេលដែលព្រះអង្គបំផ្លាញទីក្រុងរបស់ពួកគេ
ប្រជាជនយូដានឹងប្រៀបធៀបសេចក្តីស្លាប់ទៅនឹងមនុស្សដែលឡើងលើបង្អួចដើម្បីវាយប្លន់ផ្ទះ
រាជវាំង
ផ្ទះប្រណិតៗ ដែលព្រះមហាក្សត្រគង់នៅ។
សេចក្តីស្លាប់នឹងមកដល់អ្នកមាននិងអ្នកក្រដូចគ្នា។
វាបានបំផ្លាញជីវិតកូនក្មេងនៅទីធ្លាខាងក្រៅ
«សេចក្តីស្លាប់កំពុងសំលាប់កុមារតាមផ្លូវ»។
ហើយពួកកំលោះៗនៅក្នុងទីក្រុង
«ហើយសេចក្តីស្លាប់កំពុងតែសម្លាប់ពួកកំលោះនៅតាមទីក្រុង»។
ទីក្រុង
ទីផ្សារ
ព្រះអម្ចាស់មានព្រះបន្ទូល
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ៧។
សាកសពរបស់មនុស្សនឹងធ្លាក់ចុះ ដូចជាជីនៅវាលស្រែ
«សាកសពនឹងធ្លាក់នៅគ្រប់ទីកន្លែង»។
សាកសពរបស់មនុស្សនឹងធ្លាក់ចុះ
«សាកសពនឹងត្រូវធ្លាក់ចុះនៅគ្រប់ទីកន្លែងដូចជាលាមកសត្វពាសពេញវាលស្រែ»។
ដូចជាជីនៅវាលស្រែ
«ហើយដូចគុម្ពស្រូវជ្រុះគ្រាប់កន្លែងបន្ទាប់ពីកសិករកាប់វាចោល»។
ហើយគ្មានអ្នកណានឹងប្រមូលពួកគេឡើយ
«ហើយនឹងគ្មាននរណាម្នាក់ប្រមូលសាកសពឡើយ»
Jeremiah 9:23
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។
កុំឲ្យអ្នកប្រាជ្ញអួតពីប្រាជ្ញារបស់ខ្លួនឡើយ
«អ្នកប្រាជ្ញមិនគួរមានអំណួតទេ ព្រោះគេជាមនុស្សមានប្រាជ្ញា»
កុំឲ្យអ្នកមានអួតពីទ្រព្យសម្បត្តិខ្លួនដែរ
«អ្នកមានមិនគួរមានអំណួតទេ ព្រោះគេជាអ្នកមាន»
ដ្បិតយើងជាយោបល់ហើយស្គាល់ដល់យើងវិញ
«ដែលគេបានយល់ថាយើងជានរណា
ហើយរស់នៅតាមរបៀបដែលគាប់ព្រះហឫទ័យយើង»
ដ្បិតយើងជាព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «ព្រោះគ្រប់គ្នាត្រូវយល់ថាយើងជាព្រះអម្ចាស់»។
ដ្បិតអ្វីនៅក្នុងនេះ ដែលយើងមានចិត្តរីករាយ
ព្រះអម្ចាស់មានព្រះបន្ទូលថា ពេលដែលយើងធ្វើការដោយសេចក្តីស្មោះត្រង់ហើយមានសេចក្តីសុចរិតនៅក្នុងចិត្តរបស់យើង
ប្រជាជនយូដានឹងប្រៀបធៀបសេចក្តីស្លាប់ទៅនឹងមនុស្សដែលឡើងលើបង្អួចដើម្បីវាយប្លន់ផ្ទះ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ៧។
Jeremiah 9:25
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។
ថ្ងៃនោះជិតមកដល់ហើយ
ការបកប្រែរបៀបផ្សេងទៀត: «នឹងមានកាលនោះ»
នេះជាព្រះអម្ចាស់មានព្រះបន្ទូលថា
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ៧។
ពេលយើងនឹងដាក់ទោសដល់ពួកកាត់ស្បែក ដែលអ្នកកាត់តែស្បែករូបកាយ
នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែលដែលបានចូលរួមក្នុងសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់តាមរយៈការកាត់
តែពួកគេមិនបានធ្វើតាមបញ្ញាតិរបស់ព្រះអង្គទេ។
ហើយមនុស្សទាំងអស់ដែលជាកាត់សក់ក្បាលគេឲ្យខ្លី
«នេះប្រហែលជាសំដៅទៅលើមនុស្សដែលកាត់សក់ខ្លី
ដើម្បីគោរពដល់ព្រះក្លែងក្លាយ»។
ដ្បិតជនជាតិទាំងនោះ គឺមិនបានកាត់ស្បែកទេ
ជនបរទេសដែលបានត្រូវកាត់ស្បែកជាសញ្ញាសម្គាល់ដែលបញ្ជាក់ថាពួកគេបានចូលរួមក្នុងសម្ព័ន្ធមេត្រីរប
ការបកប្រែរបៀបផ្សេងទៀត:
«ពីព្រោះប្រជាជាតិទាំងនេះមិនចូលរួមក្នុងសម្ព័ន្ធមេត្រីរបស់ព្រះអម្ចាស់ទេតាមរយៈការកាត់ស្បែកទេ»។
ពួកកូនចៅអ៊ីស្រាអែល ក៏មិនបានកាត់ស្បែកចិត្តដែរ
ចិត្តដែលមិនកាត់ស្បែកបង្ហាញពីចរិតរបស់មនុស្សដែលមិនគោរពតាមបញ្ញាតិរបស់ព្រះអម្ចាស់ទេ។
ការបកប្រែរបៀបផ្សេងទៀត: «ហើយប្រជាជនអ៊ីស្រាអែលទាំងអស់
មិនបានគោរពតាមសម្ពន្ធមេត្រីជាមួយព្រះអម្ចាស់ដោយស្តាប់បង្គាប់ទ្រង់នោះទេ»។

---

10 [1]«ជនជាតិអ៊ីស្រាអែលអើយ ចូរនាំគ្នាស្តាប់សេចក្តីដែលព្រះ អម្ចាស់មានព្រះបន្ទូលមកកាន់អ្នករាល់គ្នា![2]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «មិនត្រូវយកតម្រាប់តាម
ប្រជាជាតិនានាឡើយ ហើយក៏មិនត្រូវញ័ររន្ធត់ចំពោះទីសម្គាល់ ផ្សេងៗនៅលើមេឃ ដូចប្រជាជាតិទាំងឡាយដែរ។
[3]ដ្បិតជំនឿសាសនារបស់មនុស្សទាំងនោះ សុទ្ធតែឥតបានការ។ ពួកគេកាប់ដើមឈើពីក្នុងព្រៃ ហើយជាងក៏យកពន្លាកមកដាប់ឆ្លាក់ធ្វើជារូប[4]ក្រោយមកពួកគេយកប្រាក់
និងមាសស្រោបពីលើ។ បន្ទាប់មក គេយកដែកគោល និងញញួរ មកដំភ្ជិតរូបនោះកុំឲ្យរង្គើ។[5]អ្វីដែលគេធ្វើពីដៃទាំងនោះមិនចេះនិយាយទេ គឺប្រៀបបាននឹងទីងមោងចាំ
ចម្ការត្រសក់ ព្រះទាំងនោះមិនចេះដើរឡើយ ទៅណាមកណា ត្រូវតែមានអ្នកលីសែង។ កុំខ្លាចព្រះទាំងនោះអី ព្រះទាំងនោះមិនចេះធ្វើបាបនរណាទេ ហើយក៏មិនចេះប្រព្រឹត្ត
អំពើល្អដែរ»។
[6]ព្រះអម្ចាស់អើយ គ្មានព្រះណាប្រៀបផ្ទឹមនឹងព្រះអង្គបានឡើយ ព្រះអង្គជាព្រះដ៏ឧត្តម ហើយព្រះនាមព្រះអង្គក៏ឧត្តុង្គឧត្តមដែរ ព្រោះព្រះអង្គប្រកបដោយឫទ្ធិបារមី។
[7]តើមនុស្សណាដែលមិនកោតខ្លាចព្រះអង្គ ដ្បិតព្រះអង្គជាព្រះមហាក្សត្ររបស់ប្រជាជាតិនានា? ដ្បិតព្រះអង្គសមនឹងទទួលការនោះ ដ្បិតនៅក្នុងនគរទាំងប៉ុន្មាន គឺគ្មានអ្នក
ប្រាជ្ញណាផ្ទឹមនឹងព្រះអង្គបានឡើយ។
[8]ពួកគេសុទ្ធតែជាមនុស្សល្ងីល្ងើ ជាអ្នកគោរពរូបព្រះ ប៉ុន្តែ ជាដុំឈើ![9]គេនាំយកប្រាក់ផែជាផ្នាំងមកពីទឹកដីតើស៊ីស និងមាសពីទឹកដីអ៊ូផាស ជាស្នាដៃរបស់ជាងទង និងជាង
ស្មិត ក៏មានសំពត់ពណ៌ខៀវ និងពណ៌ស្វាយជាគ្រឿងតែង រូបនោះសុទ្ធតែជាការដែលដៃមនុស្សបានធ្វើទាំងអស់។[10]ប៉ុន្តែ ព្រះអម្ចាស់ជាព្រះដ៏ពិត។ ព្រះអង្គជាព្រះមាន
ព្រះជន្មរស់ ក៏ជាមហាក្សត្រដ៏នៅអស់កល្បជានិច្ច។ ផែនដីក៏ញ័រចំពោះសេចក្តីក្រោធរបស់ព្រះអង្គ ហើយអស់ទាំងជនជាតិមិនអាចនឹងធន់នៅ ចំពោះសេចក្តីក្រោធបស់
ព្រះអង្គបានឡើយ។
[11]ចូរប្រាប់ពួកគេថា ព្រះទាំងឡាយដែលពុំបានបង្កើតផ្ទៃមេឃ និងផែនដី មុខជាត្រូវវិនាសបាត់សូន្យពីផែនដី និងពីក្រោមមេឃនេះពុំខាន។[12]ប៉ុន្តែ ព្រះអម្ចាស់វិញ ព្រះអង្គ
បានសូនផែនដី ដោយឫទ្ធានុភាពរបស់ព្រះអង្គ ហើយបានបង្កើតពិភពលោក ដោយព្រះប្រាជ្ញាញាណរបស់ព្រះអង្គ ទ្រង់បានលាតសន្ធឹងផ្ទៃមេឃ ដោយព្រះតម្រិះរបស់
ព្រះអង្គ។[13]ពេលព្រះអង្គបន្លឺព្រះសូរសៀង ទឹកទាំងឡាយមកមូលផ្តុំគ្នានៅលើមេឃពពករសាត់មកពីជើងមេឃ ផ្លេកបន្ទោរបង្អុរភ្លៀងចុះមកហើយខ្យល់ក៏ចេញពីកន្លែង
របស់វាដែរ។
[14]ពេលឃើញស្នាព្រះហស្តរបស់ព្រះអង្គ មនុស្សទាំងអស់បែរជាងឿងឆ្ងល់ ហើយភ័ន្តភាំងស្មារតី ជាងមាសបែរជាខ្មាសខ្លួនឯង ដោយឆ្លាក់រូបព្រះក្លែងក្លាយឥតបានការ ទាំង
នោះ ដែលគ្មានវិញ្ញាណ។[15]ព្រះទាំងនោះឥតបានការអ្វីសោះ ជាវត្ថុគួរឲ្យមើលងាយ ដែលនឹងត្រូវវិនាសសូន្យ នៅថ្ងៃដែលព្រះជាម្ចាស់ដាក់ទោស។[16]ប៉ុន្តែ ព្រះរបស់លោក
យ៉ាកុបវិញមិនដូច្នោះទេ ព្រះអង្គបានបង្កើតអ្វីៗទាំងអស់ ព្រះអង្គបានជ្រើសរើសអ៊ីស្រាអែល ធ្វើជាប្រជារាស្ត្រផ្ទាល់របស់ទ្រង់ ព្រះអង្គមាននាមថា ព្រះអម្ចាស់នៃពិភពទាំង
មូល។
[17]អស់អ្នកដែលនៅក្នុងកំឡុង ពួកខ្មាំងឡោមព័ទ្ធអ្នកជុំវិញ ចូរប្រមូលអីវ៉ាន់អ្នកចេញពីទឹកដីទៅ។[18]ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលថា៖ «មើល៍! ឥឡូវនេះ យើងនឹងបោះ
ចោលពួកអ្នកទឹកដីនេះ។ យើងមឹងធ្វើទុក្ខដល់ពួកគេ ហើយឲ្យពួកគេស្គាល់ដៃយើង»។

generated on Wed Sep 10 16:16:32 2025

[19]វរហើយខ្ញុំ! ដោយព្រោះសេចក្ដីឈឺចាប់របស់ខ្ញុំ របួសខ្ញុំឈឺខ្លាំងណាស់។ ដូច្នេះហើយខ្ញុំនិយាយថា៖ «នេះហើយជាសេចក្ដីលំបាករបស់ខ្ញុំ ប៉ុន្តែខ្ញុំត្រូវតែទ្រាំទ្រ»។
[20]ត្រសាលរបស់ខ្ញុំបានត្រូវបំផ្លាញបង់ អស់ទាំងខ្សែក៏ដាច់ចេញជាពីរ។ ពួកគេបានយកកូនចៅខ្ញុំចាកចេញពីខ្ញុំ ហើយមិនបានឃើញពួកគេទៀតទេ។ គ្មានអ្នកណានឹងដំឡើងត្រសាល ហើយចងរនាំងខ្ញុំទៀតដែរ។
[21]ដ្បិតពួកគង្វាល បានត្រឡប់ជាមនុស្សល្ងីល្ងើទាំងអស់ ហើយមិនបានសួរដល់ព្រះអម្ចាស់ទេ ហេតុនោះបានជាគេមិនបានចំរុងចម្រើន ហើយពួកគេទាំងប៉ុន្មានក៏ត្រូវខ្ចាត់ខ្ចាយទៅ។[22]មានឮសូរដំណឹងនឹងមកដល់ «មើល! វានឹងកើតឡើង ការរញ្ជួយដីមកពីខាងជើង ដើម្បីធ្វើឲ្យទីក្រុងនានាក្នុងទឹកដីយូដាត្រូវបំផ្លាញ ក្លាយជាទីអាស្រ័យរបស់ចចកវិញ»។
[23]ព្រះអម្ចាស់អើយ ទូលបង្គំដឹងថា ផ្លូវរបស់មនុស្សមិនស្រេចនៅខ្លួនគេទេ ហើយដែលតម្រង់ជំហានរបស់ខ្លួន នោះក៏មិនស្រេចនៅមនុស្សដែលដើរដែរ។[24]ព្រះអម្ចាស់អើយ សូមតំរង់ផ្លូវទូលបង្គំចុះ តែគឺតាមសេចក្ដីទៀងត្រង់ មិនមែនដោយសេចក្ដីក្រោធរបស់ព្រះអង្គឡើយ ក្រែងទ្រង់ធ្វើឲ្យទូលបង្គំសាបសូន្យទៅ។[25]សូមព្រះអង្គចាក់សេចក្ដីក្រោធរបស់ព្រះអង្គ ទៅលើជនជាតិដទៃទាំងប៉ុន្មានដែលមិនស្គាល់ព្រះអង្គ ហើយទៅលើអស់ទាំងគ្រួសារគេ ដែលមិនអំពាវនាវដល់ព្រះនាមព្រះអង្គផង ដ្បិតគេបានត្របាក់លេបពួកយ៉ាកុប គេបានត្របាក់លេប ព្រមទាំងរំលីងអស់ ហើយបំផ្លាញទីលំនៅរបស់គេដែរ។

Jeremiah 10:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បានក្រើនរំលឹកប្រជាជនយូដាក៏ដូចជា អេហ្ស៊ីប អេដុម អាំម៉ូន ម៉ូអាប់ និងប្រជាជនទាំងអស់ថាពួកគេនឹងត្រូវបានដាក់ទោស។
មិនត្រូវយកតម្រាប់តាមប្រជាជាតិនានាឡើយ
«កុំធ្វើតាមអ្វីដែលប្រជាជាតិនានាដែលកំពុងជឿឡើយ»
ញ័ររន្ធត់
«ព្រួយបារម្ភ» ឬ «ភ័យខ្លាច»
ដោយទីសម្គាល់នៅលើមេឃ
ដោយការចម្លែកដែលមកពីលើមេឃ
ដ្បិតជនជាតិទាំងនោះដែលអស់សង្ឃឹមដោយការនេះ
«ប្រជាជាតិនានានឹងខ្លាចអ្វីៗដែលការចម្លែកគេបានឃើញដែលមកលើមេឃ»
Jeremiah 10:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បានក្រើនរំលឹកពួកគេមិនអោយរៀនពីប្រជាជាតិទាំងនោះ ហើយក៏មិនត្រូវព្រួយបារម្ភនឹងអ្វីដែលកើតឡើងនៅលើមេឃឡើយ។
ជាង
មនុស្សដែលមានជំនាញ
ទីងមោង
រូបទីងមោង ដែលដូចនឹងមនុស្ស ដែលត្រូវបានដាក់ឲ្យសត្វបក្សីខ្លាច ហើយរារាំងពួកវាមិនឲ្យស៊ីដំណាំរបស់គេ។
ត្រសក់
បន្លែមួយប្រភេទដែលច្រើនតែវែង មានសំបកពណ៌បៃតង និងសាច់សដែលមានជាតិទឹកច្រើន
Jeremiah 10:6
ព័ត៌មានទូទៅ:
លោកយេរេមាពោលអំពីការគោរពបូជារូបព្រះក្លែងក្លាយ។
តើមនុស្សណាដែលមិនកោតខ្លាចព្រះអង្គ ដ្បិតព្រះអង្គជាព្រះមហាក្សត្ររបស់ប្រជាជាតិនានា?
លោកយេរេមាមិនបានសង្ឃឹមមានចម្លើយចំពោះសំណួរនេះទេ។
នេះជាការពោលឡើងមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នករាល់គ្នាគួរតែកោតខ្លាចព្រះអង្គ ដែលជាព្រះមហាក្សត្រនៃប្រជាជាតិនានា»
ព្រះអង្គសមនឹងទទួលការនោះ
«អ្វីដែលព្រះអង្គ និងទទួលបាន»
Jeremiah 10:8
ពួកគេទាំងអស់គឺដូចគ្នា ពួកគេឃោរឃៅហើយជាល្ងីល្ងើ
ពាក្យថា «ឃោរឃៅ» និង «ល្ងីល្ងើ» មានន័យជាធម្មតាដូចគ្នា ហើយបញ្ជាក់ពីមនុស្សល្ងីល្ងើដែលថ្វាយបង្គំរូបព្រះក្លែងក្លាយ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេម្នាក់ៗគឺឆោតល្ងង់ណាស់»។
សិស្សនៃរូបព្រះដែលគ្មានបានការ តែជាដុំឈើ
«ពួកគេព្យាយាមស្វែងយល់ពីរូបព្រះក្លែងក្លាយដែលជាដុំឈើមួយកង់»
កម្មករ
«ជាងជំនាញ»
តើស៊ីស ហើយមាសពីអ៊ូផាស
ជាទីកន្លែងដែលប្រាក់និងមាសត្រូវបានគេជីក
មាសពីអ៊ូផាស ធ្វើដោយដៃកម្មករនៃការសម្រិតសម្រាំង
«មាសពីអ៊ូផាស ដែលជាងជំនាញ និងអ្នកសម្រិតសម្រាំងបានច្នៃ»
សំពត់ពណ៌ខៀវ និងពណ៌ស្វាយ
ក្រុមមនុស្ស ដែលស្លៀកពាក់ឲ្យរូបព្រះក្លែងក្លាយក្នុងសំលៀកបំពាក់ស្អាត។
Jeremiah 10:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលទៅលោកយេរេមា។
ព្រះអង្គដែលបង្កើតផែនដី ដោយព្រះចេស្តាព្រះអង្គ ហើយបានបង្កើតពិភពលោកដោយព្រះប្រាជ្ញាញាណព្រះអង្គ ហើយដោយការយល់ដឹងរបស់ព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត: «ព្រះបង្កបង្កើត ដែលខ្លាំងពូកែ ហើយឈ្លាសវៃ។ ព្រះអង្គបង្កើតផែនដី និងផ្ទៃមេឃ»។
សម្លេងរបស់ព្រះអង្គបានគ្រហឹមសម្រាប់ទឹកនៅលើមេឃ
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គចាត់ចែងរន្ទះផ្គរលាន់នៅលើមេឃដោយព្រះបន្ទូលរបស់ទ្រង់»
ហើយប្រមូលមកនៅកណ្តាល ពីចុងបំផុតនៃផែនដី
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបង្កើតពពកគ្រប់ទីកន្លែងពាសពេញលើផែនដី»។
កន្លែង
ជាកន្លែងដែលរបស់របរត្រូវបានរក្សាទុក
Jeremiah 10:14
បែរជាងឿងឆ្ងល់
«ដោយមានចំណេះដឹង» ឬ «មិនចេះដឹង»
ព្រះរបស់លោកយ៉ាកុបវិញ
«ដែលប្រជាជនអ៊ីស្រាអែលថ្វាយបង្គំ»
គឺបានបង្កើតអ្វីៗទាំងអស់
«ជាព្រះបង្កបង្កើតអ្វីៗទាំងអស់» ឬ «ព្រះដែលបានបង្កើតអ្វីៗទាំងអស់»
Jeremiah 10:17
ចូរប្រមូលអីវ៉ាន់របស់អ្នក
«ចូរប្រមូលទ្រព្យសម្បត្តិរបស់អ្នក»
មើល!
ពាក្យថា «មើល» គឺបញ្ជាក់ការពោលពាក្យបន្ទាប់ទៀត។
យើងនឹងបោះចោលប្រជាជននៃទឹកដីនេះចេញនៅពេលនេះ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើឲ្យប្រជាជនដែលរស់នៅក្នុងទឹកដីនេះចាកចេញពីទីនេះ»។
ប្រជាជននៃទឹកដីនេះ
«ប្រជាជនដែលរស់នៅក្នុងទឹកដីនេះ»
ធ្វើទុក្ខ
«ដែលឈឺចាប់ ឬរងគ្រោះយ៉ាងខ្លាំង»
Jeremiah 10:19
ព័ត៌មានទូទៅ:
លោកយេរេមាកំពុងថ្លែង ប្រៀបដូចជាគាត់ជាពូជ អំបូរនៃអ៊ីស្រាអែល។
វរហើយខ្ញុំ! ដោយសារការបាក់ឆ្អឹងរបស់ខ្ញុំ របួសខ្ញុំកាន់តែរីកធំ។
ការបកប្រែរបៀបផ្សេងទៀត:
«យើងមានបញ្ហាយ៉ាងខ្លាំងដូចជាមនុស្សម្នាក់ដែលបាក់និងរងរបួស»។
ទីជម្រោកខ្ញុំបានត្រូវបំផ្លាញ អស់ទាំងខ្សែចំណងជម្រោកក៏ដាច់ចេញជាពីរ
«ខ្មាំងសត្រូវបានបំផ្លាញទីក្រុងទាំងមូល»
ពួកគេបានយក
«ខ្មាំងសត្រូវបានចាប់យក»
គ្មានអ្នកណានឹងដំឡើងទីជម្រោកខ្ញុំឲ្យធំឡើយ ឬលើកឡើងរាំងននៃទីជម្រោករបស់ខ្ញុំដែរ
ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«គ្មានអ្នកណានឹងសាងសង់ទីក្រុងរបស់យើងឡើងវិញទេ»។

Jeremiah 10:21

ត្រូវបានខ្ចាត់ខ្ចាយអស់

«ត្រូវបានបំបែក និងចេញឆ្ងាយនៅក្នុងទិសដៅផ្សេងៗ»

ចចក

ជាឆ្កែព្រៃមួយប្រភេទ ត្រូវបានរកឃើញនៅទ្វីបអាហ្វ្រិក

Jeremiah 10:23

សូមចាក់សេចក្ដីក្រោធរបស់ព្រះអង្គ ទៅលើជនជាតិទាំងឡាយ

ការបកប្រែរបៀបផ្សេងទៀត: «សូមដាក់ទោសជនជាតិទាំងនោះយ៉ាងធ្ងន់ធ្ងរ»

បានត្របាក់លេបពួកយ៉ាកុប ហើយស៊ីគាត់ ដូច្នោះគ្រប់យ៉ាងរបស់គាត់បានបំផ្លាញអស់

ពាក្យថា «លេបត្របាក់» និង «ស៊ី» នៅទីនេះ ទាំងពីរមានន័យដូចគ្នាថា

«បំផ្លាញទាំងស្រុង»។

លោកយេរេធ្លាប់បានពោលម្តងហើយនូវគំនិតនេះបីដងដើម្បីបញ្ជាក់ពីការបំផ្លិចបំផ្លាញទឹកដីអ៊ីស្រាអែលទ

ហើយរុះចោលទីលំនៅរបស់គេ

«បំផ្លិចបំផ្លាញទឹកដីដែលគេរស់នៅ»

---

11 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមាថា៖[2]«ចូរស្តាប់អស់ទាំងពាក្យនៃសេចក្តីសញ្ញានេះចុះ រួចនិយាយដល់ពួកមនុស្សនៅទឹកដីយូដា និងនៅក្រុងយេរូសាឡិម។

[3]ប្រាប់គេថា ព្រះអម្ចាស់របស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះ ត្រូវបណ្តាសាហើយ មនុស្សណាដែលមិនស្តាប់តាមអស់ទាំងពាក្យនៃសេចក្តីសញ្ញានេះ[4]គឺជាសេចក្តីដែលយើងបានបង្គាប់ដល់បុព្វបុរសអ្នករាល់គ្នា នៅថ្ងៃដែលយើងនាំគេចេញពីទឹកដីអេស៊ីបមក គឺចេញរួចពីគុកភ្លើងរំលាយដែក ដោយប្រាប់គេថា ចូរស្តាប់ពាក្យរបស់យើង ហើយប្រព្រឹត្តតាមផង គឺតាមគ្រប់ទាំងសេចក្តីដែលយើងបង្គាប់ដល់អ្នករាល់គ្នាចុះ នោះអ្នករាល់គ្នានឹងធ្វើជាប្រជារាស្ត្ររបស់យើង ហើយយើងនឹងធ្វើជាព្រះរបស់អ្នករាល់គ្នា»។[5]ដើម្បីឲ្យយើងបានធ្វើសម្រេចតាមសេចក្តីសម្បថ ដែលយើងបានស្បថនឹងបុព្វបុរសអ្នករាល់គ្នាថា នឹងឲ្យគេបានទឹកដីដែលមានទឹកដោះ និងទឹកឃ្មុំហូរហៀរ ដូចជាសព្វថ្ងៃនេះ»។ នោះខ្ញុំក៏ទូលឆ្លើយថា៖ «អាម៉ែន ព្រះអម្ចាស់អើយ»។

[6]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «ចូរប្រកាសប្រាប់អស់ទាំងពាក្យនេះ នៅក្នុងទីក្រុងទាំងប៉ុន្មានរបស់ទឹកដីយូដា ហើយនៅផ្លូវទាំងប៉ុន្មាននៃក្រុងយេរូសាឡិមដែរថា ចូរស្តាប់អស់ទាំងពាក្យនៃសេចក្តីសញ្ញានេះ ហើយប្រព្រឹត្តតាមចុះ។[7]ដ្បិតនៅថ្ងៃដែលយើងបាននាំបុព្វបុរសអ្នករាល់គ្នាឡើងរួចពីទឹកដីអេស៊ីប ដរាបមកដល់សព្វថ្ងៃនេះ នោះយើងបាននិយាយយ៉ាងម៉ឺងម៉ាត់ដល់គេ ព្រមទាំងខ្នះខ្នែងប្រាប់គេ តាំងពីព្រលឹមស្រាងថា «ចូរស្តាប់តាមពាក្យយើងចុះ»។[8]តែគេមិនបានស្តាប់តាមទេ ក៏មិនបានផ្ទៀងត្រចៀកផង គឺបានប្រព្រឹត្តតាមតែសេចក្តីរឹងចចេសនៅក្នុងចិត្តអាក្រក់របស់គេរៀងខ្លួនវិញ។ ដូច្នេះ យើងបាននាំគ្រប់ទាំងពាក្យនៃសេចក្តីសញ្ញានេះមកលើគេ គឺជាសេចក្តីដែលយើងបានបង្គាប់ឲ្យគេប្រព្រឹត្តតាម តែគេមិនបានប្រព្រឹត្តតាមសោះ»។

[9]បន្ទាប់មក ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «ឃើញមានគំនិតក្បត់កើតឡើង នៅក្នុងពួកមនុស្សនៅទឹកដីយូដា ហើយនៅក្រុងយេរូសាឡិមដែរ។[10]គេបានវិលត្រឡប់ទៅតាមអំពើទុច្ចរិតរបស់បុព្វបុរសគេ ដែលមិនព្រមស្តាប់តាមពាក្យយើង គេបានទៅតាមព្រះដទៃផ្សេងៗ ដើម្បីគោរពបម្រើព្រះទាំងនោះវិញ ពួកអ៊ីស្រាអែល និងពួកយូដាបានផ្តាច់សេចក្តីសញ្ញា ដែលយើងបានតាំងនឹងបុព្វបុរសគេហើយ។

[11]ហេតុនោះ ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «យើងនឹងនាំសេចក្តីអាក្រក់មកលើគេ ជាសេចក្តីដែលគេមិនអាចគេចរួចបានឡើយ គេនឹងអំពាវនាវរកយើង តែយើងមិនស្តាប់ទេ។[12]ទីក្រុងនៅទឹកដីយូដាទាំងប៉ុន្មាន និងពួកអ្នកនៅក្រុងយេរូសាឡិម នឹងទៅអំពាវនាវដល់ព្រះ ដែលគេបានដុតកំញានថ្វាយនោះ តែព្រះទាំងនោះនឹងមិនជួយដោះគេឲ្យរួច ក្នុងគ្រាវេទនារបស់គេឡើយ។[13]ដ្បិតពួកយូដាអើយ ចំនួនព្រះរបស់អ្នកមានច្រើនដូចទីក្រុងទាំងប៉ុន្មានរបស់អ្នកដែរ ហើយដែលមានផ្លូវនៅក្រុងយេរូសាឡិមប៉ុណ្ណា នោះអ្នកក៏បានស្អាងអាសនៈថ្វាយដល់របស់គួរខ្មាសនោះ ចំនួនប៉ុណ្ណោះដែរ គឺជាអាសនៈសម្រាប់ដុតកំញានថ្វាយដល់ព្រះបាលផង។

[14]ចំណែកអ្នកវិញយេរេមា កុំអធិស្ឋានឲ្យជនជាតិនេះឡើយ ក៏កុំឡើងសំឡេងអំពាវនាវ ឬអង្វរឲ្យគេដែរ ដ្បិតនៅគ្រាដែលគេអំពាវនាវរកយើង ដោយកើតមានសេចក្តីវេទនានោះយើងមិនស្តាប់គេទេ។[15]តើស្ងួនសម្លាញ់របស់យើងមានសិទ្ធិអ្វីចូលមកក្នុងដំណាក់របស់យើងទៀត ដ្បិតគេបានប្រព្រឹត្តអំពើដ៏លាមកមកអាក្រក់ជាច្រើន? តើពាក្យបន់ស្រន់របស់គេ និងយញ្ញបូជារបស់គេ ការពារមិនឲ្យគេវិនាសបានឬ? គេវិលរាយនឹងប្រព្រឹត្តតែអំពើអាក្រក់។[16]កាលពីមុនព្រះអម្ចាស់ បានដាក់ឈ្មោះឲ្យអ្នកថា ជាដើមអូលីវស្អាតនិងមានផ្លែដ៏ល្អ តែព្រះអង្គបានបង្កាត់ភ្លើងបញ្ឆេះអស់ទៅ ដោយឮសូរសន្ធឹកយ៉ាងខ្លាំង ហើយមែកវាត្រូវបាក់អស់។

[17]ដ្បិតព្រះអម្ចាស់នៃពិភពទាំងមូល ដែលបានដាំអ្នក ព្រះអង្គបានប្រកាសសេចក្តីអាក្រក់ទាស់នឹងអ្នក ដោយព្រោះអំពើអាក្រក់របស់ពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដា ជាការដែលគេបានប្រព្រឹត្តដល់ខ្លួនគេ ដោយបណ្តាលឲ្យយើងខឹង ព្រោះការដែលដុតកំញានថ្វាយដល់ព្រះបាល»។

[18]ព្រះអម្ចាស់បានសម្តែងឲ្យខ្ញុំដឹងពីការនេះ ព្រះអង្គបានបង្ហាញឲ្យខ្ញុំឃើញកិរិយារបស់គេ។[19]ខ្ញុំដូចជាកូនចៀមស្លូត ដែលគេនាំទៅឯទីសម្លាប់ ខ្ញុំមិនបានដឹងជាគេគិតឧបាយទាស់នឹងខ្ញុំសោះ គេថា «ចូរយើងបំផ្លាញទាំងដើម និងផលផង ចូរយើងកាត់វាចេញពីស្ថានរបស់មនុស្សរស់ទៅ ដើម្បីមិនឲ្យអ្នកណានឹកចាំពីឈ្មោះវាទៀតឡើយ»។[20]ប៉ុន្តែ ព្រះអម្ចាស់ជាព្រះដែលជំនុំជម្រះដោយសុចរិតហើយក៏ល្បងលចិត្តគំនិតអើយ ទូលបង្គំនឹងឃើញព្រះអង្គសងសឹកដល់គេជាមិនខាន ដ្បិតទូលបង្គំបានសម្តែងដើមហេតុរបស់ទូលបង្គំ ថ្វាយព្រះអង្គជ្រាបហើយ។

[21]ហេតុនោះ ព្រះអម្ចាស់ មានព្រះបន្ទូលពីដំណើរពួកមនុស្ស នៅក្រុងអាណាថោត ដែលចង់សម្លាប់ខ្ញុំ ដោយពោលថា៖ «អ្នកមិនត្រូវថ្លែងទំនាយដោយនូវព្រះនាមព្រះអម្ចាស់ទៀតឡើយ ក្រែងអ្នកស្លាប់ដោយដៃរបស់យើង។[22]ហេតុនោះបានជាព្រះអម្ចាស់ នៃពិភពលោក ព្រះអង្គមានព្រះបន្ទូលដូច្នេះថា៖ មើល៍! យើងនឹងធ្វើទោសគេ ពួកកំលោះៗនឹងស្លាប់ដោយដាវ ពួកកូនប្រុសកូនស្រីរបស់គេនឹងស្លាប់ដោយអំណត់។[23]ហើយគ្មានសំណល់សល់សម្រាប់គេឡើយ ដ្បិតនៅឆ្នាំដែលយើងនឹងធ្វើទោសដល់ពួកក្រុងអាណាថោត នោះយើងនឹងនាំសេចក្តីអាក្រក់មកលើគេយ៉ាងពិតប្រាកដ»។

Jeremiah 11:1

ប្រជាជនដែលនៅក្រុងយេរូសាឡិម

«ប្រជាជនដែលរស់នៅក្នុងក្រុងយេរូសាឡិម»

Jeremiah 11:3

រំលាយ

ដុតដែកទៅជាធាតុរាវ

ទឹកដីដែលមានទឹកដោះ និងទឹកឃ្មុំហូរហៀរ

នេះមានន័យថាទឹកដីនេះនឹងសំបូរ និងបង្កបង្កើនផលច្រើន

ដូច្នេះនឹងមានអាហារគ្រប់គ្រាន់សម្រាប់អ្នករាល់គ្នា។ ការបកប្រែរបៀបផ្សេងទៀត:

«ទឹកដីដែលល្អសម្រាប់ចិញ្ចឹមសត្វ និងធ្វើកសិកម្ម»

Jeremiah 11:6

ដ៏ម៉ឺងម៉ាត់

«ហ្មត់ចត់»

មនុស្សម្នាក់បានដើរក្នុងរឹងចចេសនៅក្នុងចិត្តអាក្រក់របស់ពួកគេ

«មនុស្សម្នាក់ៗបានបដិសេធមិនព្រមផ្លាស់ប្តូរហើយបន្តធ្វើអំពើអាក្រក់ដែលពួកគេចង់ធ្វើ

Jeremiah 11:9

គំនិតឃុបឃិត

ដែលជាផែនការសម្ងាត់ដើម្បីធ្វើអ្វីមួយដែលមានគ្រោះថ្នាក់ឬខុសច្បាប់

ប្រជាជននៃក្រុងយេរូសាឡិមដែរ

«ប្រជាជនដែលរស់នៅក្រុងយេរូសាឡិម»

Jeremiah 11:11

មើល៍

ការបកប្រែរបៀបផ្សេងទៀត: «ចូរស្តាប់» ឬ

«យកចិត្តទុកដាក់អ្វីដែលយើងនឹងមានបន្ទូលទៅអ្នក»

Jeremiah 11:14

ដូច្នោះអ្នកខ្លួនឯង យេរេមា មិនត្រូវអធិស្ឋានឲ្យប្រជាជននេះទេ។ អ្នកមិនត្រូវយំសោក ឬអធិស្ឋានជំនួសគេទេ

សូមបកប្រែតាមរបៀបដូចគ្នានឹងអ្នកបានបកប្រែ «ហើយអ្នក...ជំនួសពួកគេ» ក្នុងជំពូក ៧:១៦។

មិនត្រូវយំសោក

generated on Wed Sep 10 16:16:32 2025

«អ្នកមិនត្រូវស្រែកខ្លាំងៗ ពីភាពសោកសៅឡើយ»
ហេតុអ្វីអ្នកដែលយើងស្រឡាញ់ គឺជាអ្នកដែលមានពេញដោយគំនិតអាក្រក់នៅក្នុងដំណាក់យើង?
សំណួរនេះអាចត្រូវបានបង្ហាញជាការថ្លែងដោយស្ដីបន្ទោស។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលយើងស្រឡាញ់អើយ
អ្នកមានចេតនាអាក្រក់ ដោយអ្នកមិនគួរនៅក្នុងដំណាក់យើងឡើយ»។
ហេតុអ្វីអ្នកដែលយើងស្រឡាញ់ គឺជាអ្នកដែលមានពេញដោយគំនិតអាក្រក់នៅក្នុងដំណាក់យើង?
បទគម្ពីរនេះជាភាសាហេព្រើរគឺពិបាកយល់ណាស់ហើយការកែសម្រួលឡើងវិញជាច្រើនបានបង្ហាញ
ត្រូវបានបកប្រែវាតាមវិធីផ្សេងៗគ្នា។
ដំណាក់
វាំង
អ្នកដែលយើងស្រឡាញ់
ប្រជាជនអ៊ីស្រាអែលត្រូវបានគេថ្លែងថា
ប្រៀបដូចជាពួកគេជាស្ត្រីនៅលីវដែលជាទីស្រឡាញ់បំផុត។
កាលពីមុនព្រះអម្ចាស់ បានហៅអ្នកថា ជាស្លឹកដើមអូលីវ
នៅក្នុងគម្ពីរសញ្ញាចាស់
មនុស្សត្រូវបានគេថ្លែងប្រៀបប្រដូចជាញឹកញាប់ថាពួកគេជាដើមឈើ ឬរុក្ខជាតិ។
បង្កាត់ភ្លើងបញ្ឆេះវាអស់ទៅ
ការបញ្ចេញមតិនេះបន្តការប្រៀបធៀបទៅនឹងដើមឈើ។
ភ្លើងតំណាងឲ្យការបំផ្លិចបំផ្លាញនៃប្រជាជន។
Jeremiah 11:17
ដែលព្រះអង្គបានដាំអ្នក
ការបកប្រែរបៀបផ្សេងទៀត: «ដែលព្រះអង្គបានដាក់អ្នក
ដើម្បីរស់នៅក្នុងទឹកដីអ៊ីស្រាអែល និងយូដា»
Jeremiah 11:18
ការបកប្រែរបៀបផ្សេងទៀត:
«ដែលជាខ្មាំងសត្រូវយើងដែលនាំយើងទីកន្លែងសម្លាប់»
នឹកចាំពីឈ្មោះវាទៀតឡើយ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនឹងលែងចងចាំឈ្មោះរបស់គេ»
Jeremiah 11:21
ក្រុងអាណាថោត
ជាក្រុងពិសេសដែលសម្តេចសង្ឃគង់នៅ
ពួកកំលោះ
ជាវ័យដែលមានកម្លាំងខ្លាំងក្នុងជីវិតរបស់គេ
គ្មានពួកគេណានៅសល់ជីវិតទេ
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំនឹងមិនចាកចេញពីពួកគេទេ»

---

12 [1]បពិត្រព្រះអម្ចាស់ដ៏សុចរិត ទូលបង្គំពុំអាចតវ៉ារកខុសត្រូវ ជាមួយព្រះអង្គបានទេ។ ទូលបង្គំសូមសាកសួរអំពីការវិនិច្ឆ័យ របស់ព្រះអង្គ ហេតុអ្វីបានជាមនុស្សអាក្រក់
ចេះតែចម្រុងចម្រើនដូច្នោះ? មនុស្សដែលគ្មានជំនឿកាន់តែជោគជ័យ។[2]ព្រះអង្គបានដាំពួកគេ ហើយពួកគេក៏ចាក់ឫស ចម្រើនឡើង និងមានផ្លែផ្កា។ ពួកគេពោលពី
ព្រះនាមព្រះអង្គមិនដាច់ពីមាត់ តែចិត្តរបស់ពួកគេនៅឆ្ងាយពីព្រះអង្គ។
[3]ព្រះអម្ចាស់អើយ ព្រះអង្គស្គាល់ទូលបង្គំ។ ព្រះអង្គទតឃើញទូលបង្គំ ព្រះអង្គស្វែងយល់ថា ទូលបង្គំជំពាក់ចិត្តនឹងព្រះអង្គ។ រីឯអ្នកទាំងនោះវិញ សូមព្រះអង្គយកពួកគេ
ចេញ ដូចកូនចៀម ដែលគេនាំទៅទីសត្តឃាត សូមញែកពួកគេទុកដោយឡែក សម្រាប់ថ្ងៃប្រហារជីវិត។[4]តើទឹកដីនេះត្រូវកាន់ទុក្ខដល់កាលណា តើតិណជាតិនៅតាមចម្ការ
ទាំងប៉ុន្មាន ត្រូវនៅក្រៀមស្ងួត ដូច្នេះដល់កាលណាទៀត? ដោយសារអំពើអាក្រក់របស់អ្នកទឹកដីនេះសត្វចតុប្បាទ និងបក្សាបក្សីត្រូវវិនាសអស់។ ពួកគេនិយាយថា
«ព្រះជាម្ចាស់មិនជ្រាបទេ នូវអ្វីដែលនឹងកើតឡើងចំពោះយើង»។
[5]ព្រះអម្ចាស់មានបន្ទូលថា «ជាការពិតណាស់ យេរេមាអើយ បើអ្នកបានរត់ជាមួយពួកថ្មើរជើង ហើយគេបាននាំឲ្យអ្នកអស់កម្លាំងដូច្នេះ ធ្វើដូចម្តេចឲ្យអ្នកប្រណាំងនឹងសេះ
បាន ហើយបើនៅក្នុងទឹកដីដ៏មានសន្តិសុខ អ្នកមិនសូវមានសេចក្តីសុខទេ នោះតើអ្នកនឹងធ្វើដូចម្តេចក្នុងកាល ដែលទន្លេយ័រដាន់ជន់ពេញកម្លាំង?[6]ដ្បិតទោះទាំងពួក
បងប្អូនអ្នក និងក្រុមគ្រួសាររបស់អ្នក ក៏បានក្បត់នឹងអ្នកដែរ គេបានស្រែកហៅយ៉ាងខ្លាំងតាមក្រោយអ្នក តែទោះបើនិយាយពាក្យស្រួលល្អក៏ដោយ ក៏មិនត្រូវជឿតាមគេ
ឡើយ។
[7]យើងបានលះលែងគ្រួសាររបស់យើងហើយ ក៏បានបោះបង់ចោលមរតករបស់យើងដែរ ឯអ្នកស្ងួនសម្លាញ់នៃដួងចិត្តយើងនោះបានប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំង
សត្រូវ។[8]ពួកដែលជាមរតករបស់យើង គេបានត្រឡប់ដូចជាសិង្ហ នៅក្នុងព្រៃដល់យើង គេបានបំព្លោញសំឡេងទាស់នឹងយើង ហេតុនោះបានជាយើងស្អប់គេ។[9]តើប្រជាជន
ដែលយើងបានជ្រើសរើស ប្រព្រឹត្តប្រៀបបាននឹងត្មាតពញ្ជាក់ តែខ្លួនគេចោមរោមទៅដោយពពួកត្មាត? ចូរទៅប្រមូលសត្វព្រៃមកស៊ីសាកសព របស់គេឲ្យអស់ទៅ។
[10]មានគង្វាលជាច្រើនបានបំផ្លាញចម្ការ ទំពាំងបាយជូររបស់យើង គេបានជាន់ឈ្លីដី ដែលជាចំណែករបស់យើង គេបានធ្វើឲ្យចំណែកដែលយើងពេញចិត្ត ទៅជាទីខូចអស់
ហើយ។[11]គេបានធ្វើឲ្យទៅជាទីវិនាសអន្តរាយ ទីនោះសោយសោករកយើង ដោយត្រូវខូចបង់ ទឹកដីទាំងមូលត្រូវវិនាស ដោយព្រោះគ្មានមនុស្សណាយកចិត្តទុកដាក់
ឡើយ។
[12]នៅតាមទួលខ្ពស់ៗក្នុងវាលរហោស្ថាន ពួកបំផ្លិចបំផ្លាញកំពុងតែមកដល់។ ដាវរបស់ព្រះអម្ចាស់នឹងប្រហារទឹកដីនេះ ពីជាយដែនម្ខាងទៅជាយដែនម្ខាង គ្មាននរណាម្នាក់
គេចខ្លួនរួចឡើយ។[13]ពួកគេសាបព្រោះស្រូវ លុះដល់ពេលច្រូត គេទទួលបានតែបន្លា គេខំប្រឹងប្រែងធ្វើការ ដោយឥតបានទទួលផលអ្វីឡើយ។ អ្នករាល់គ្នានឹងត្រូវខ្មាស
ដោយសារផលនៃចម្រូត ព្រោះព្រះអម្ចាស់ទ្រង់ព្រះពិរោធយ៉ាងខ្លាំង»។
[14]ព្រះអម្ចាស់មានព្រះបន្ទូល ប្រកាសជំទាស់នឹងនគរជិតខាងដ៏អាក្រក់ ហើយឈ្លានពានទឹកដីដែលយើងបានចែកឲ្យអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង ទុកជាចំណែក
មត៌ក មើល៍! «យើងនឹងដកប្រជាជននៅទឹកដីទាំងនោះចេញពីទឹកដីរបស់ខ្លួន ហើយយើងក៏ដកជនជាតិយូដាចេញពីទឹកដីរបស់ខ្លួនដែរ។[15]ក្រោយមក យើងដកពួកគេ
ចេញពីទឹកដីនោះហើយ យើងនឹងអាណិតមេត្តាពួកគេសារជាថ្មី យើងនាំពួកគេវិលត្រឡប់ទៅកាន់ទឹកដីជាចំណែកមត៌ករបស់ពួកគេរៀងៗខ្លួនវិញ។
[16]ប្រសិនបើពួកគេរៀនអំពីមាគ៌ាដ៏ល្អ ដូចប្រជារាស្ត្ររបស់យើង ប្រសិនបើពួកគេស្បថក្នុងនាមយើងថា ព្រះអម្ចាស់មានព្រះជន្មគង់នៅ ដូចពួកគេធ្លាប់បង្រៀនប្រជារាស្ត្រ
របស់យើង ឲ្យស្បថក្នុងនាមព្រះបាល នោះពួកគេនឹងរស់នៅក្នុងចំណោមប្រជារាស្ត្ររបស់យើង។[17]ប៉ុន្តែ ប្រសិនបើជនជាតិណាមិនព្រមស្តាប់បង្គាប់ទេ យើងនឹងដកពួកគេ
ចេញ ហើយប្រហារពួកគេឲ្យវិនាសសូន្យ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។

Jeremiah 12:1
ព័ត៌មានទូទៅ:
លោកយេរេមាថ្លែងពីព្រះអម្ចាស់។
តែចិត្តរបស់ពួកគេនៅឆ្ងាយពីព្រះអង្គ
«ពួកគេមិនបានស្រលាញ់ ឬគោរពព្រះអង្គឡើយ»
Jeremiah 12:3
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីព្រះអម្ចាស់។
សូមព្រះអង្គយកពួកគេចេញ ដូចកូនចៀម ដែលទៅទីប្រហារ
«សូមរៀបចំដាក់ទោសដល់ពួកមនុស្សអាក្រក់»
តើយូរប៉ុណ្ណាទើបដីនឹងត្រូវស្ងួតវិញ ហើយតិណជាតិនៅតាមចម្ការនឹងត្រូវក្រៀមស្វិត
ដោយព្រោះសេចក្តីអាក្រក់នៃប្រជាជន នៃទីក្រុងនោះ?
«សេចក្តីព្រាងច្បាប់បង្កើតឡើងដោយសារអំពើអាក្រក់របស់ប្រជាជនបានអូសបន្លាយពេលយូរ»
សត្វចតុប្បាទ និងបក្សាបក្សីត្រូវចាប់យកទៅ
សត្វព្រៃ និងសត្វបក្សាបក្សីត្រូវបានសម្លាប់ដោយព្រាងច្បាប់។
ត្រូវក្រៀមស្វិត
«រីងស្ងួត»
ព្រះជាម្ចាស់មិនដឹង អ្វីដែលនឹងកើតឡើងដល់យើងទេ
«ព្រះជាម្ចាស់មិនបានទតឃើញអំពើបាបដែលយើងបានប្រព្រឹត្ត»។
Jeremiah 12:5
ធ្វើដូចម្តេចឲ្យអ្នកប្រណាំងនឹងសេះបាន? បើសិនជាអ្នកបានដល់ ទីសុវត្ថិភាពស្រុកដាក់ស្រយាល តើ
អ្នកធ្វើដូចម្តេចក្នុងកាល ដែលព្រៃក្រាស់នៅតាមទន្លេយ័រដាន់?
សំណួរទាំងពីរនេះមានបំណងបង្កើតសេចក្តីថ្លែងការណ៍។
ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«អ្នកនឹងមិនដែលប្រកួតប្រជែងនឹងសេះបានទេ...អ្នកនឹងបរាជ័យនៅតាមវាលខ្សាច់តាមឃ្លាទាំងនេះ ព្រះអម្ចាស់ចង់ប្រាប់ពីរឿងអ្វីដល់ពួកគេ
បើសិនជាអ្នកបានដល់ទីសុវត្ថិភាព
តាមកំណែបច្ចុប្បន្នថ្មីបានបកប្រែបទគម្ពីរនេះក្នុងភាសាហេប្រឺដូចជា
«ប្រសិនបើអ្នកមានអារម្មណ៍សុវត្ថិភាពនៅក្នុងទីសុវត្ថិភាព»។
ទីសុវត្ថិភាព
នេះសំដៅលើទីវាល បើកចំហដែលងាយស្រួលក្នុងការធ្វើដំណើរយ៉ាងលឿន
ផ្ទុយទៅនឹងព្រៃក្រាស់ដែលដុះនៅតាមបណ្តោយទន្លេយ័រដាន់
ដែលពិបាកក្នុងការធ្វើដំណើរ។
ព្រៃក្រាស់
គុម្ពឈើឬដើមឈើតូចៗដុះជិតគ្នា
Jeremiah 12:7
យើងបានបោះបង់ដំណាក់យើងហើយ យើងបានចាកចេញចោលមរតករបស់យើង។ យើងបាន
ប្រគល់មនុស្សជាទីស្រឡាញ់របស់យើង ទៅក្នុងកណ្តាប់ដៃនៃសត្រូវរបស់គេ
ឃ្លាទាំងបីនេះមានអត្ថន័យស្រដៀងគ្នា។
ឃ្លាទីមួយនិងទីពីរជួយគំនិតនៅក្នុងឃ្លាទីបីប្រសើរឡើង។ (សូមមើល ◌ः
«ភាពស្របគ្នា») ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំបានអនុញ្ញាតឲ្យពួកសត្រូវរបស់ប្រជាជនខ្ញុំយកឈ្នះពួកគេ»។
សត្វស្វាន
ជាប្រភេទសត្វឆ្កែនៅទ្វីបអាស៊ី និងទ្វីបអាព្រិចដែលស៊ីសាច់ខ្មោចសត្វ
សត្វស្លាបជាច្រើន
ជាសត្វស្លាបដែលចេះវាយប្រហារ និងស៊ីសាច់
Jeremiah 12:10
ពួកគេបានជាន់ឈ្លី
«ពួកគេបានជាន់ឈ្លីនៅក្រោមជើងរបស់ពួកគេ» ឬ «ពួកគេបានបំផ្លាញ»
ដីដែលជាចំណែករបស់យើង
«ទឹកដីដែលខ្ញុំបានដាំដុះ»
ពួកគេបានធ្វើឲ្យទីនោះ
ពាក្យថា «ទីនោះ» សំដៅលើទឹកដីសន្យា
ដោយព្រោះការបំផ្លិចបំផ្លាញ
ពាក្យថា «ការបំផ្លិចបំផ្លាញ» សំដៅលើទឹកដីសន្យា
យកចិត្តទុកដាក់លើវា
«ព្រួយបារម្ភ» ឬ «យកចិត្តទុកដាក់»
Jeremiah 12:12
វាល
«ដោយទទេរ» ឬ «ដោយគ្មានអ្វីគ្របដណ្តប់»
ដាវរបស់ព្រះអម្ចាស់នឹងប្រហារ
ព្រះអម្ចាស់បានប្រើប្រាស់ទាហាន ដើម្បីដាក់ទណ្ឌកម្មដល់ប្រជារាស្ត្ររបស់ទ្រង់
ពីម្ខាងទឹកដីទៅដល់ម្ខាងទៀតនៃទឹកដីទាំងមូល
ពួកគេ
«ប្រជាជនរបស់យើង»
បន្លា
ជាប្រភេទរុក្ខជាតិធំមួយដែល ពេញដោយចុងមុតស្រួច
ប្រឹងប្រែង
«នឿយហត់» ឬ «អស់កម្លាំង»
Jeremiah 12:14
ឈ្លានពាន
វាយដណ្តើមយក
ចែកឲ្យអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងទុកជាចំណែកមត៌ក
ការបកប្រែរបៀបផ្សេងទៀត: «ផ្តល់ឲ្យអ៊ីស្រាអែលប្រជារាស្ត្ររបស់យើង
ចាត់ទុកដូចជាចំណែកមត៌ក»
ដកឫស
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:៩។
ដកជនជាតិយូដាចេញពីចំណោមពួកគេ
នឹងឲ្យពួកប្រជាជនយូដាចាកចេញពីទឹកដីរបស់ខ្មាំងសត្រូវរបស់ពួកគេ
ហើយបានវិលត្រឡប់មកស្រុកយូដាវិញ
ចាកចេញ
ឬ «ដកឫស»
យើងដកឫស ជនជាតិទាំងនោះ
ការបកប្រែរបៀបផ្សេងទៀត: «យើងធ្វើអោយ ប្រជាជាតិទាំងនោះ
ចាកចេញពីទឹកដីរបស់គេហើយផ្លាស់ទៅកន្លែងផ្សេងទៀត»
Jeremiah 12:16
ព័ត៌មានទូទៅ:
ព្រះជាម្ចាស់មានព្រះបន្ទូលអំពីស្រុកជិតខាងរបស់ស្រុកយូដា។
វានឹងអាចកើតឡើង ប្រសិនបើ...ព្រះបាល នោះពួកគេ
«នេះគឺជាអ្វីដែលនឹងកើតឡើង...ព្រះបាល៖ ពួកគេ» ឬ «ប្រសិនបើ...ព្រះបាល
បន្ទាប់មកនេះគឺជាអ្វីដែលនឹងកើតឡើង: ពួកគេ»
នៅក្នុងចំណោម
នៅចំកណ្តាល
ពួកគេនឹងរស់នៅក្នុងចំណោមប្រជារាស្ត្ររបស់យើង
«យើងនឹងធ្វើឲ្យពួកគេបានរីកចំរើនឡើង
ហើយពួកគេនឹងរស់នៅក្នុងចំណោមប្រជារាស្ត្ររបស់យើង»
យើងនឹងដកឫសជនជាតិចេញ។ វាពិតណាស់យើងនឹងដកឫស ហើយបំផ្លាញផង
«យើងនឹងបណ្តេញចេញ និងបំផ្លាញប្រជាជាតិទាំងនោះទាំងស្រុង»។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១:៧។

13 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ចូរទៅទិញក្រណាត់ដ៏ល្អយកមកក្រវាត់ចង្កេះ តែកុំបោកទឹកឡើយ»។[2]ខ្ញុំក៏ទៅទិញក្រណាត់យកមកក្រវាត់ចង្កេះ តាមបញ្ជា
របស់ព្រះអម្ចាស់។[3]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំសារជាថ្មីថា[4]«ចូរយកក្រណាត់ដែលអ្នកបានទិញ ហើយក្រវាត់នៅនឹងចង្កេះនោះមក រួចធ្វើដំណើរឆ្ពោះទៅទន្លេ
អឺប្រាត លាក់ក្រណាត់នោះទុកក្នុងកន្លៀតថ្មមួយ»។
[5]ដូច្នេះហើយខ្ញុំក៏ចេញដំណើរទៅ ហើយលាក់ក្រណាត់នៅជិតទន្លេអឺប្រាត តាមបញ្ជារបស់ព្រះអម្ចាស់។[6]យូរថ្ងៃកន្លងមកទៀត ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ចូរ
ក្រោកឡើង ទៅទន្លេអឺប្រាត យកក្រណាត់ដែលយើងបានបង្គាប់ឲ្យអ្នកលាក់នោះ មកវិញ»។[7]ដូច្នេះ ខ្ញុំក៏ត្រឡប់ទៅទន្លេអឺប្រាត កាយយកក្រណាត់ដែលខ្ញុំបានលាក់ទុកមក
វិញ។ ប៉ុន្តែ មើល៍ចុះ! ក្រណាត់នោះពុកអស់ ប្រើការលែងកើត។
[8]ព្រះអម្ចាស់ក៏មានព្រះបន្ទូលមកខ្ញុំបែបនេះ:[9]«យើងនឹងធ្វើឲ្យចិត្តអួតអាងរបស់ប្រជាជនយូដា និងចិត្តក្រអឺតក្រទមរបស់អ្នកក្រុងយេរូសាឡឹម បានដូចក្រណាត់ពុកនោះ
ដែរ។[10]ប្រជាជននេះអាក្រក់ណាស់ ពួកគេមិនព្រមស្តាប់ពាក្យយើងទេ គឺគេធ្វើតាមចិត្តចចេសរឹងរូសរបស់ខ្លួន ដោយរត់តាមព្រះដទៃ ហើយនាំគ្នាគោរពបម្រើ និងក្រាប
ថ្វាយបង្គំព្រះទាំងនោះ។ សូមឲ្យពួកគេបានដូចក្រណាត់នេះ ដែលយកទៅប្រើការលែងកើត![11]ដ្បិត មនុស្សធ្លាប់យកក្រណាត់មកក្រវាត់ចង្កេះរបស់ខ្លួនយ៉ាងណា យើងក៏
ជាប់ចិត្តនឹងជនជាតិអ៊ីុស្រាអែល និងជនជាតិយូដាទាំងមូលយ៉ាងនោះដែរ ដើម្បីឲ្យពួកគេធ្វើជាប្រជាជនរបស់យើង ជាកិត្តិនាម ជាគ្រឿងអលង្ការ និងជាសិរីរុងរឿងរបស់
យើង តែពួកគេមិនព្រមស្តាប់យើងសោះ» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[12] ដូច្នេះអ្នកត្រូវយកពាក្យនេះទៅប្រាប់ពួកគេថា ព្រះអម្ចាស់ ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូចតទៅ: ធម្មតា គេតែងចាក់ស្រាទំពាំងបាយជូរក្នុងថង់
ស្បែក។ ពួកគេនឹងតបមកអ្នកវិញថា តើយើងមិនដឹងទេថា គេតែងចាក់ស្រាទំពាំងបាយជូរក្នុងថង់ស្បែក?[13]ដូច្នេះ អ្នកត្រូវប្រាប់ទៅពួកគេដូចតទៅ: ព្រះអម្ចាស់មាន
ព្រះបន្ទូលថា៖ យើងនឹងបង្កកស្រាដល់ប្រជាជនទាំងអស់នៅទឹកដីនេះ ព្រមទាំងស្តេចរបស់ពួកគេដែលស្នងរាជ្យតពីដាវីឌ ពួកបូជាចារ្យ ពួកព្យាការី និងអ្នកក្រុង
យេរូសាឡឹមទាំងមូល រហូតដល់ស្រវឹង។[14]យើងនឹងបណ្តាលឲ្យពួកគេសម្លាប់គ្នា ទាំងឪពុក ទាំងកូន គឺយើងមិនត្រាប្រណី មិនមេត្តា ឬអាណិតអាសូរពួកគេទេ គ្មានអ្វីរារាំង
យើងមិនឲ្យកម្ទេចពួកគេឡើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[15]ចូរស្តាប់ ហើយផ្ទៀងត្រចៀកចុះ កុំឲ្យតាំងចិត្តឆ្មើងឆ្មៃឡើយ ដ្បិតព្រះអម្ចាស់ បានមានព្រះបន្ទូលហើយ។[16]ចូរសរសើរតម្កើងដល់ព្រះអម្ចាស់ ជាព្រះនៃអ្នករាល់គ្នាចុះ ក្រែង
ព្រះអង្គធ្វើឲ្យងងឹត ហើយអ្នករាល់គ្នាចំពប់ជើងនៅលើភ្នំងងឹត ហើយកំពុងដែលអ្នករាល់គ្នាសង្ឃឹមនឹងបានពន្លឺ នោះព្រះអង្គនឹងបំប្រែឲ្យទៅជាម្លប់នៃសេចក្តីស្លាប់ និងជា
ងងឹតយ៉ាងក្រាស់វិញ។[17]តែបើអ្នករាល់មិនព្រមស្តាប់ទេ នោះព្រលឹងខ្ញុំនឹងយំសោកក្នុងទីសម្ងាត់ ដោយព្រោះសេចក្តីអំនួតរបស់អ្នករាល់គ្នា ហើយភ្នែកខ្ញុំនឹងយំសស្រាក់ ពី
ព្រោះហ្វូងចៀមរបស់ព្រះអម្ចាស់ បានត្រូវគេចាប់ដឹកទៅជាឈ្លើយហើយ។

generated on Wed Sep 10 16:16:32 2025

[18]ចូរទូលស្តេច និងមាតារបស់ស្តេចថា៖ សូមគង់ចុះនៅទីទាបវិញ ដ្បិតមកុដដ៏ល្អរបស់ព្រះករុណា បានធ្លាក់ចុះពីសិរសាហើយ។[19]អស់ទាំងទីក្រុងនៅតំបន់ណេកិបនឹងបិទជិតហើយឥតមានអ្នកណានឹងបើកវិញបានឡើយ ពួកយូដាទាំងអស់បានត្រូវដឹកទៅជាឈ្លើយ គេត្រូវនាំទៅជាឈ្លើយទាំងអស់ហើយ។
[20]ចូរងើបមុខឡើង ហើយមើលពួកអ្នកដែលមកពីទិសខាងជើង ឯហ្វូងចៀមដែលបានប្រគល់ដល់អ្នក គឺជាហ្វូង ដ៏ល្អរបស់អ្នក តើនៅឯណា។[21]តើអ្នកនឹងថាដូចម្តេច ក្នុងកាល ដែលព្រះអង្គតាំងពួកមិត្តសម្លាញ់ របស់អ្នកឡើងឲ្យគ្រប់គ្រងលើអ្នក ដ្បិតគឺអ្នកហើយដែលបានបង្រៀនគេឲ្យធ្វើដូច្នេះ តើសេចក្តីទុក្ខព្រួយដូចជាស្ត្រី ដែលឈឺចាប់នឹងសម្រាលកូនមិនចាប់អ្នកទេឬ?
[22]បើអ្នកនឹកសួរក្នុងចិត្តថា៖ ហេតុអ្វីបានជាការទាំងនេះកើតដល់យើងដូច្នេះ នោះគឺដោយព្រោះអំពើទុច្ចរិតដ៏បរិបូររបស់អ្នកទេ បានជាសំពត់របស់អ្នកត្រូវបើកសើយឡើង ហើយអ្នកត្រូវនៅកែងជើងទទេផង។[23]តើជនជាតិអេធីយ៉ូពី នឹងបំផ្លាស់បំប្រែសម្បុរស្បែករបស់ខ្លួនបានឬទេ? ឬខ្លារខិននឹងផ្លាស់សម្បុរពណ្តាក់របស់វាទៅបានដែរទេ? បើបាននោះអ្នករាល់គ្នាដែលធ្លាប់ប្រព្រឹត្តអាក្រក់ នឹងអាចប្រព្រឹត្តល្អវិញក៏បានដែរ។[24]យើងនឹងកម្ចាត់កម្ចាយអ្នកដូចជាចំបើង ដែលរសាត់ទៅបាត់ដោយខ្យល់ពីទីរហោស្ថាន។
[25]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ នេះហើយជាចំណែករបស់អ្នករាល់គ្នា ជាចំណែកដែលយើងវាល់ឲ្យអ្នក ដោយព្រោះអ្នកបានភ្លេចយើង ហើយទុកចិត្តនឹងពាក្យកុហក។
[26]ហេតុនោះ យើងនឹងបើកសើយសំពត់ របស់អ្នកឡើងគ្របលើមុខអ្នក ហើយកេរ្តិ៍ខ្មាសរបស់អ្នកនឹងបានឃើញច្បាស់។[27]យើងបានឃើញអំពើគួរខ្ពើមឆ្អើមរបស់អ្នកហើយ គឺជាការកំផិត និងសូរឆ្លើយឆ្លងរកគ្នារបស់អ្នក ព្រមទាំងសេចក្តីឥតខ្មាសនៃការកំផិតរបស់អ្នក នោះលើអស់ទាំងទីទួលនៅវាលផង វេទនាដល់អ្នក ក្រុងយេរូសាឡិមអើយ! តើពេលណាទៅទើបអ្នកនឹងស្អាតម្តងទៀត?»

Jeremiah 13:1
សំពត់
ជាប្រភេទក្រណាត់ដែលល្អប្រណិត
ខោអាវទ្រនាប់
ជាប្រភេទសំលៀកបំពាក់ដែលមនុស្សស្លៀកនៅក្រោមសម្លៀកបំពាក់របស់ពួកគេ
ខោទ្រនាប់
ចង្កេះ
ជាផ្នែកកណ្តាលនៃរាងកាយ
ជាទូទៅមានលក្ខណៈតូចហើយនៅចន្លោះរវាងត្រគាកនិងទ្រូង
ព្រះអម្ចាស់មានព្រះបន្ទូលមក
សូមមើលពីរបៀបដែលបកប្រែនៅក្នុង ជំពូក ១:១។
កន្លៀតថ្ម
ចន្លោះរវាងថ្ម ឬស្នាមប្រេះនៅក្នុងថ្ម ដែលវាធំល្មមអាចដាក់អ្វីមួយចូលទៅក្នុងនោះ
Jeremiah 13:5
តើខោអាវទ្រនាប់មានគុណភាពយ៉ាងដូចម្តេចនៅពេលដែលលោកយេរេមាជីករាពីកន្លែងដែលគាត់បានលាក់
ខោអាវទ្រនាប់នោះ មិនសូវល្អឡើយ។
Jeremiah 13:8
ព្រះបន្ទូលនៃព្រះអម្ចាស់មកដល់
សូមមើលពីរបៀបដែលបកប្រែនៅក្នុង ជំពូក ១:១។
ចិត្តអំនួត
«មោទនភាព»
ជនជាតិយូដាហើយក្រុងយេរូសាឡិម
«មនុស្សដែលមកពីស្រុកយូដា និងក្រុងយេរូសាឡិម»
ដែលដើរតាមចិត្តរឹងរូសរបស់គេ
«ដែលមានចិត្តរឹងរូសឥតឈប់ឈរ»
ជនជាតិ
«គ្រប់ប្រជារាស្ត្រទាំងអស់»
មកតោងយើង
«មកនៅជិតនឹងយើង»
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបដែលបកប្រែនេះនៅក្នុងជំពូក ១:៧។
Jeremiah 13:12
បង្កកស្រាដល់ប្រជាជនទាំងអស់ នៅទឹកដីនេះ
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យប្រជាជននៅទឹកដីនេះស្រវឹងស្រា»
ស្តេចរបស់ពួកគេដែលស្នងរាជ្យតពីដាវីឌ
«ស្តេចនៃជនជាតិយូដា»
បណ្តាលឲ្យពួកគេសម្លាប់គ្នា ទាំងឪពុកទាំងកូនក៏ដូចគ្នា
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនឹងវាយតប់អ្នកដទៃ សូម្បីតែឪពុកម្តាយ និងកូនក៏នឹងប្រឆាំងនឹងគ្នាដែរ»
យើងនឹងអាណិតពួកគេទេ
«យើងនឹងមិនមានអារម្មណ៍សោកស្តាយចំពោះ»
នឹងមិនទុកពួកគេពីការបំផ្លាញដែរ
ការបកប្រែរបៀបផ្សេងទៀត: «នឹងមិនដកចេញទណ្ឌកម្មឡើយ» ឬ
«នឹងអនុញ្ញាតឲ្យពួកគេត្រូវបានបំផ្លាញ» ឬ
«នឹងអនុញ្ញាតឲ្យពួកគេប្រឈមមុខនឹងការបំផ្លាញ»
Jeremiah 13:15
កុំឲ្យមានចិត្តអំនួតឡើយ
«កុំមានអារម្មណ៍ថាខ្លួនឯងប្រសើរជាង ឆ្លាតជាង ឬសំខាន់ជាងអ្នកដទៃ»
ព្រះអង្គនាំភាពងងឹត
«ព្រះអង្គបណ្តាលឲ្យភាពងងឹតមកដល់» ភាពងងឹតតំណាងពីបញ្ហា
និងភាពអស់សង្ឃឹមយ៉ាងខ្លាំង។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គនាំមកនូវបញ្ហាធំៗ»
អ្នករាល់គ្នាចំពប់ជើង
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបណ្តាលឲ្យអ្នកទាក់ជើងរបស់ខ្លួនអ្នកដោយអ្វីមួយ
ខណៈពេលអ្នកកំពុងដើរ ឬរត់ ហើយអ្នកនឹងដួល»
ព្រះអង្គនឹងប្រែកន្លែងនោះទៅជាងងឹតខ្លាំង
«ព្រះអង្គនឹងប្រែក្លាយកន្លែងនោះទៅជាងងឹតទាំងស្រុង»
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គនឹងធ្វើឲ្យអ្នកអស់សង្ឃឹម»
Jeremiah 13:18
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅលោកយេរេមា។
ព្រះអង្គមានបន្ទូលប្រាប់លោកយេរេមានូវអ្វីដែលត្រូវថ្លែងទៅកាន់ស្តេចនៃស្រុកយូដា
និងមាតារបស់ស្តេច។
ដ្បិតមកុដលើសិរសារបស់ព្រះករុណា ហើយអំនួតនិងសិរិរុងរឿង នឹងធ្លាក់ចុះពីមក
«ព្រះអង្គនឹងលែងក្លាយព្រះមហាក្សត្រ និងជាមាតា
របស់មហាក្សត្រី» (សូមមើលសកម្មភាពជានិមិត្តសញ្ញា)
មាតារបស់មហាក្សត្រី
ជាមាតារបស់ស្តេច។
អស់ទាំងទីក្រុងនៅតំបន់ណេកិបនឹងបិទជិត
«ខ្មាំងសត្រូវរបស់អ្នកនឹងបិទទីក្រុងទាំងអស់នៅតំបន់ណេកិប»
ពួកយូដាត្រូវដឹកទៅជាឈ្លើយ
«ខ្មាំងសត្រូវនឹងចាប់យកពួកយូដាទៅជាឈ្លើយ»
Jeremiah 13:20
ព័ត៌មានទូទៅ:
ព្រះអង្គមានព្រះបន្ទូលទៅកាន់ប្រជារាស្ត្រនៃក្រុងយេរូសាឡិម។
ចូរងើបមុខឡើង
«ដោយយល់ពីអ្វីដែលនឹងកើតឡើងចំពោះអ្នក»
តើហ្វូងចៀមដែលព្រះអង្គបានប្រគល់ដល់អ្នក គឺជាហ្វូង ដ៏ល្អស្អាតដល់អ្នកនៅទីណា?
«ប្រជាជនទាំងអស់ត្រូវបានគេនាំទៅ។»
តើអ្នកនឹងថាដូចម្តេច ពេលព្រះអង្គតាំងអ្នកដល់មិត្តសម្លាញ់ របស់អ្នកឡើងឲ្យគ្រប់គ្រងលើអ្នក?
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលអ្នកគិតថាជាមិត្តសម្លាញ់របស់អ្នក
នឹងព្យាយាមគ្រប់គ្រងលើអ្នក»។
តើនេះមិនជាផ្តើមនៃការឈឺចាប់ដូចជាស្ត្រីឈឺចាប់នឹងសម្រាលកូនទេឬ?
ព្រះអម្ចាស់មានព្រះបន្ទូលបន្ថែមថា
ការចាប់យករបស់ពួកគេគឺជាការចាប់ផ្តើមនៃការឈឺចាប់ ដែលពួកគេបានឆ្លងកាត់។
Jeremiah 13:22
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បានបន្តព្រះបន្ទូលទៅលោកយេរេមា។
ព្រះអង្គមានបន្ទូលប្រាប់លោកយេរេមាពីរបៀបនៃការថ្លែងទៅកាន់ស្តេចស្រុកយូដានិងមាតាស្តេច។

generated on Wed Sep 10 16:16:32 2025

សំពត់របស់អ្នកត្រូវបើកឡើង
ការបកប្រែរបៀបផ្សេងទៀត:
«ក្រុមទាហាននៃពួកឈ្លានពាននឹងលើកសំពត់របស់ស្ត្រីអ្នកឡើង។
«សម្លៀកបំពាក់ស្ត្រីរបស់ជនជាតិយូដា នឹងត្រូវបានដាច់រហែក
ដូច្នេះពួកទាហានបាប៊ីឡូនចាប់ ហើយរួមដំណេកជាមួយពួកគេ។
តើជនជាតិអេធីយ៉ូពី អាចប្តូរសម្បុរស្បែករបស់គេ
ការបកប្រែរបៀបផ្សេងទៀត: «ជនជាតិអេធីយ៉ូពី
មិនអាចប្តូរសម្បុរស្បែករបស់គេបានទេ»
ខ្លារខិនអាចប្តូរសម្បុរវា
ការបកប្រែរបៀបផ្សេងទៀត: «ខ្លារខិនមិនអាចប្តូរសម្បុររបស់វាបានឡើយ»
បើបាន ចុះអ្នកវិញ ដែលធ្លាប់ប្រព្រឹត្តអាក្រក់ នឹងអាចមកប្រព្រឹត្តល្អទេ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនអាចល្អបានឡើយ
ដោយព្រោះអំពើអាក្រក់របស់អ្នក។
កម្ចាត់កម្ចាយអ្នកដូចជាចំបើង ដែលរសាត់ទៅបាត់ដោយខ្យល់ពីទីរហោស្ថាន
ព្រះអម្ចាស់មានព្រះបន្ទូលថា ព្រះអង្គនឹងកម្ចាត់កម្ចាយប្រជារាស្ត្ររបស់ទ្រង់
ទូទាំងប្រទេស។
Jeremiah 13:25
នេះហើយជាចំណែករបស់អ្នករាល់គ្នា ជាចំណែកដែលយើងរាល់ឲ្យអ្នក
ការបកប្រែរបៀបផ្សេងទៀត: «នេះជាអ្វីដែលយើងធ្វើឲ្យកើតមានឡើងដល់អ្នក»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១: ៧។
យើងខ្លួនឯងនឹងបើករលើយសំពត់ចេញពីអ្នក ហើយកេរ្តិ៍ខ្មាសរបស់អ្នកនឹងបានឃើញ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបើកបង្ហាញអំពើអាក្រក់របស់អ្នក»។
សូមមើល:
ហេកុបដូចសេះ
នេះសំដៅលើសំលេងរបស់សេះឈ្មោលដែលមានចំណង់លើសេះញី។
ការបកប្រែរបៀបផ្សេងទៀត: «ភាពត្រេកត្រអាល»។
តើយូរប៉ុណ្ណាការនេះនឹងបន្ត?
តើយូរប៉ុន្មានមុនពេលដែរអ្នកបានស្អាតម្តងទៀត

---

14 [1]នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ ដែលមកដល់ព្យាការី យេរេមាពីដំណើរគ្រាំងស្ងួត៖[2]ពួកយូដាសោយសោក ហើយទ្វារក្រុងក៏ថយកម្លាំង គេអង្គុយនៅដីដោយចិត្តព្រួយ ហើយសម្រែកនៃក្រុងយេរូសាឡិមក៏ឮឡើង។[3]ពួកអ្នកធំរបស់គេចាត់អ្នកបម្រើឲ្យទៅរកទឹក គេក៏ទៅដល់ស្រះទាំងប៉ុន្មាន តែរកទឹកគ្មានសោះ។ ពួកគេត្រឡប់ទៅវិញដោយក្អមទទេ ដោយសេចក្តីខ្មាស ហើយជ្រប់មុខ និងឃ្លុំក្បាល។
[4]ពីព្រោះដីបែកក្រហែង ដ្បិត ដោយគ្មានភ្លៀងធ្លាក់មកលើទឹកដីនោះសោះឡើយ។ ពួកអ្នកភ្ជួររាស់ក៏ខ្មាស គេឃ្លុំក្បាលគ្រប់គ្នាដែរ។[5]សម្បើសត្វក្តាន់ញីនៅវាលក៏ទម្លាក់កូន រួចទុកចោល ដោយព្រោះតែគ្មានស្មៅ។[6]លាព្រៃក៏ឈរនៅលើទីទួល វាដង្ហក់ដូចជាចចក។ ភ្នែករបស់ពួកវាស្រវាំង ដោយព្រោះគ្មានស្មៅសោះ»។
[7]ទោះបើអំពើទុច្ចរិតរបស់យើងខ្ញុំ ធ្វើបន្ទាល់ទាស់នឹងយើងខ្ញុំក៏ដោយ តែសូមព្រះអង្គប្រោសមេត្តាដោយយល់ដល់ព្រះនាមព្រះអង្គ ដ្បិតការរាថយរបស់យើងខ្ញុំ នោះច្រើនណាស់ យើងខ្ញុំបានធ្វើបាបនឹងទ្រង់។[8]ក្តីសង្ឃឹមនៃជនជាតិអ៊ីស្រាអែល ជាព្រះដ៏ជួយសង្គ្រោះគេ ក្នុងគ្រាលំបាកអើយ ហេតុអ្វីបានជាព្រះអង្គត្រូវដូចជាអ្នកដទៃនៅក្នុងទឹកដី ហើយដូចជាអ្នកដំណើរ ដែលឈប់សំណាក់តែមួយយប់ដូច្នេះ?[9]ហេតុអ្វីបានជាព្រះអង្គត្រូវដូចជាមនុស្សស្រឡាំងកាំង គឺដូចជាមនុស្សខ្លាំងពូកែ ដែលពុំអាចនឹងជួយសង្គ្រោះបាន? ប៉ុន្តែ ព្រះអើយអម្ចាស់អើយ ព្រះអង្គគង់កណ្តាលយើងខ្ញុំរាល់គ្នា ហើយក៏បានហៅតាមព្រះនាមព្រះអង្គដែរ។ សូមកុំលះចោលយើងខ្ញុំឡើយ។
[10]ព្រះអម្ចាស់មានព្រះបន្ទូលពីជនជាតិនេះដូច្នេះថា៖ គេចូលចិត្តដើរសាត់ព្រាត់ គេមិនបានឃាត់ជើងគេឡើយ ហេតុ នោះ ព្រះអង្គក៏មិនព្រមទទួលគេដែរ ក្នុងពេលឥឡូវនេះ ព្រះអង្គកំពុងតែនឹកចាំ ពីអំពើទុច្ចរិតរបស់គេ ហើយនឹងធ្វើទោសដល់គេ ជាពិតប្រាកដ។[11]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «កុំអធិស្ឋានសូមសេចក្តីល្អឲ្យជនជាតិនេះឡើយ។[12]កាលណាគេតមអត់ នោះយើងមិនព្រមស្តាប់សម្រែករបស់គេទេ កាលណាគេថ្វាយតង្វាយដុត និងតង្វាយអាហារ នោះយើងមិនព្រមទទួលឡើយ។ ដ្បិតយើងនឹងធ្វើឲ្យគេសូន្យទៅដោយដាវ អំណត់ និងអាសន្នរោគ»។
[13]ពេលនោះ ខ្ញុំទូលថា៖ «ឱព្រះអម្ចាស់អើយ មើលពួកព្យាការីតែងតែប្រាប់គេថា អ្នករាល់គ្នានឹងមិនឃើញដាវទេ ក៏មិនត្រូវអំណត់ដែរ គឺយើងនឹងឲ្យអ្នករាល់គ្នាមានសេចក្តីសុខនៅទីនេះជាពិត»។[14]ព្រះអង្គមានបន្ទូលមកខ្ញុំថា៖ «ពួកហោរាគេថ្លែងទំនាយកុហកដោយនូវឈ្មោះយើងទេ យើងមិនបានចាត់ប្រើគេឡើយ ក៏មិនបានបង្គាប់គេ ឬនិយាយនឹងគេដែរ គេថ្លែងទំនាយប្រាប់អ្នករាល់គ្នាពីការជាក់ស្តែងដែលមិនពិត ជាទំនាយដែលឥតប្រយោជន៍ទទេ ហើយជាសេចក្តីបញ្ឆោតនៃចិត្តខ្លួនគេវិញ»។
[15]ដូច្នេះហើយ ព្រះអម្ចាស់មានព្រះបន្ទូលបែបនេះ «សម្រាប់ពួកព្យាការីដែលថ្លែងព្រះបន្ទូលនៅក្នុងនាមរបស់យើង ប៉ុន្តែអ្នកណាដែលយើងមិនបានបញ្ជូនឲ្យទៅ គឺជាអ្នកដែលនិយាយថានឹងមិនមានដាវឬការអំណត់ក្នុងទឹកដី: ព្យាការីទាំងនេះនឹងត្រូវវិនាសដោយដាវហើយនិងការអំណត់។[16]មនុស្សដែលគេបានថ្លែងព្រះបន្ទូលប្រាប់នោះនឹងត្រូវបោះចោលទៅក្នុងផ្លូវនៃក្រុងយេរូសាឡិម ដោយព្រោះអំណត់ និងដាវដែរ ដ្បិតអត់មានអ្នកណានឹងបញ្ចុះសពគេឡើយ គឺទាំងខ្លួនគេ ប្រពន្ធគេ និងកូនប្រុសកូនស្រីគេផង ព្រោះយើងនឹងចាក់អំពើលាមកអាក្រក់របស់គេទៅលើគេវិញ។
[17]អ្នកត្រូវប្រាប់ពាក្យនេះដល់គេថា៖ «សូមឲ្យខ្ញុំហូរទឹកភ្នែកសស្រាក់ទាំងយប់ទាំងថ្ងៃ ឥតឈប់ឈរឡើយ ពីព្រោះកូនក្រមុំរបស់ជនជាតិខ្ញុំបានត្រូវខ្ទេចខ្ទី ជាការបាក់បែកយ៉ាងធំ ដោយរបួសជាទម្ងន់។[18]ប្រសិនបើខ្ញុំចេញទៅវាល មើល៍ មានសុទ្ធតែសាកសពដែលស្លាប់ដោយដាវ ហើយបើខ្ញុំចូលទៅក្នុងទីក្រុងវិញ មានសុទ្ធតែមនុស្សដែលឈឺដោយអត់ឃ្លាន ដ្បិតពួកហោរា និងពួកបូជាចារ្យ តែងតែចុះឡើងក្នុងទឹកដីឥតដឹងអ្វីទេ»។
[19]តើព្រះអង្គបោះបង់ពួកយូដាចោលហើយឬ? តើព្រះហឫទ័យព្រះអង្គស្អប់ខ្ពើមក្រុងស៊ីយ៉ូនឬ? ហេតុអ្វីបានជាព្រះអង្គវាយយើងរាល់គ្នា ហើយមិនឲ្យជាឡើងវិញសោះ? យើងខ្ញុំបានរង់ចាំ ថានឹងបានសេចក្តីសុខ តែឥតមានអ្វីល្អមកឡើយ ក៏សង្ឃឹមនឹងបានជា តែបានតែសេចក្តីភ័យ។[20]ព្រះអម្ចាស់អើយ យើងខ្ញុំទទួលស្គាល់អំពើអាក្រក់របស់យើងខ្ញុំហើយ ព្រមទាំងអំពើទុច្ចរិតរបស់បុព្វបុរសយើងខ្ញុំផង ដ្បិតយើងខ្ញុំបានធ្វើបាបទាស់នឹងព្រះអង្គពិត។
[21]សូមកុំស្អប់យើងខ្ញុំឡើយ ដោយយល់ដល់ព្រះនាមព្រះអង្គ សូមកុំបង្អាប់បល្ល័ង្កនៃសិរីល្អរបស់ព្រះអង្គ សូមនឹកចាំឡើងវិញ ហើយកុំផ្តាច់សេចក្តីសញ្ញា ដែលព្រះអង្គបានតាំងនឹងយើងខ្ញុំឡើយ។[22]ក្នុងអស់ទាំងព្រះឥតប្រយោជន៍របស់ជនជាតិដទៃ តើមានណាមួយបង្អុរឲ្យមានភ្លៀងធ្លាក់មកបានឬ? តើផ្ទៃមេឃនឹងឲ្យធ្លាក់ភ្លៀងមួយមេបានឬទេ? ឱព្រះជាម្ចាស់នៃយើងខ្ញុំអើយ តើមិនមែនព្រះអង្គទេឬ? យើងមានសង្ឃឹមលើព្រះអង្គ ដ្បិតគឺព្រះអង្គហើយដែលបានធ្វើគ្រប់ការទាំងនេះ។

Jeremiah 14:1
ព័ត៌មានទូទៅ:
តាមរយៈព្យាការីលោកយេរេមា
ព្រះអម្ចាស់មានព្រះបន្ទូលពីអំពើកំផិតរបស់មនុស្ស។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ ដែលមកដល់
«នេះជាព្រះរាជសារ ដែលព្រះជាម្ចាស់មានព្រះបន្ទូល»
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។
ធ្លាក់មកខ្ទិចខ្ទី
«ធ្លាក់ទៅជាបំណែកៗ»
យំស្រែកសម្រាប់ក្រុងយេរូសាឡិមឮខ្លាំង
«ពួកគេស្រែកទូលអង្វរយ៉ាងខ្លាំង ក្នុងការអធិស្ឋានដល់ក្រុងយេរូសាឡិម»
Jeremiah 14:4
ព័ត៌មានទូទៅ:
តាមរយៈព្យាការីយេរេមា
ព្រះអម្ចាស់បានបន្តព្រះបន្ទូលទៅកាន់មនុស្សពីគ្រោះរាំងស្ងួត។
សត្វក្តាន់ញីនៅវាលក៏ទម្លាក់កូន រួចទុកចោល
ការបកប្រែរបៀបផ្សេងទៀត: «សត្វកាន់ទុកកូនរបស់វានៅតាមវាល»
ចចក
ជាពពួកសត្វឆ្កែព្រៃដែលកាចសាហាវ
Jeremiah 14:7
ព័ត៌មានទូទៅ:
តាមរយៈលោកព្យាការីយេរេមា
ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់មនុស្សពីគ្រោះរាំងស្ងួត។
យល់ដល់ព្រះនាមព្រះអង្គ

generated on Wed Sep 10 16:16:32 2025

«ដើម្បីឲ្យមនុស្សគ្រប់គ្នាអាចឃើញថាទ្រង់គឺអស្ចារ្យណាស់
ហើយគោរពការសន្យារបស់ទ្រង់»។
ក្តីសង្ឃឹមនៃអ៊ីស្រាអែល
ដែលជាព្រះនាមមួយទៀតរបស់ព្រះអម្ចាស់។
ជាព្រះដ៏ជួយសង្គ្រោះគេ
«ជាព្រះសង្គ្រោះ» ឬ «ជាព្រះជួយសង្គ្រោះគេ»
ហេតុអ្វីបានជាព្រះអង្គ ដូចជាមនុស្សដែលវង្វេង ដូចជាមនុស្សពូកែចម្បាំង តែមិនអាចជួយសង្គ្រោះ
អ្នកណាម្នាក់?
ពាក្យថា «ដូច» មានន័យថា «ស្រដៀងគ្នាទៅនឹង»។ (សូមមើល: និងfigs-
parallelism).
ដែលវង្វេង
ដែលមិនអាចវែកញែកយល់បាន ឬគិតឲ្យបានច្បាស់លាស់
Jeremiah 14:10
ព័ត៌មានទូទៅ:
លោកយេរេមាបានអធិស្ឋាន ហើយទូលអង្វរព្រះអម្ចាស់កុំឲ្យទុកគេឲ្យនៅម្នាក់ឯង។
គេចូលចិត្តដើរសាត់ព្រាត់
«ពួកគេចូលចិត្តធ្វើអ្វីដែលប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះ»
បាននឹកចាំ
«ចងចាំ» ឬ «នឹកឃើញ»
ជំនួស
«ដើម្បីជួយ» ឬ «ផ្តល់ជាជំនួយ»
ទុក្ខសោក
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១៤: ១។
Jeremiah 14:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់លោកយេរេមា
កុំឲ្យអធិស្ឋានអង្វរសម្រាប់ជនជាតិយូដាឡើយ។
អ្នករាល់គ្នានឹងមិនឃើញដាវទេ
ពាក្យថា «ដាវ» តំណាងឲ្យ សង្គ្រាម និងពាក្យ «ឃើញ» តំណាងឲ្យ
«បទពិសោធន៍» ឬ «រងទុក្ខ»។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងមិនមានបទពិសោធន៍នឹងសង្គ្រាមណាមួយទេ»
សេចក្តីសុខ
ជាការរស់នៅដោយភាពរុងរឿង
និងដោយគ្មានការបៀតបៀនរបស់ខ្មាំងសត្រូវដែលបានគេពោល
ដូចពីការដែលមនុស្សម្នាក់ផ្តល់ឲ្យមនុស្សម្នាក់ទៀត។
ថ្លែងទំនាយបោកប្រាស់
លក្ខណៈដែលសម្គាល់ថាជាការថ្លែងទំនាយក្លែងក្លាយ
ត្រូវបានគេពោលថាខ្លួនឯងជាហោរា។ ការបកប្រែរបៀបផ្សេងទៀត:
«ការថ្លែងទំនាយដោយភាពបោកប្រាស់»
យើងមិនបានចាត់គេឲ្យទៅទេ
អ្នកបកប្រែអាចសម្រេចចិត្តបញ្ចូលពាក្យបន្ថែមនៃគោលដៅ
និងគោលបំណងនៃសកម្មភាពនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនបានចាត់ឲ្យពួកគេទៅថ្លែងទំនាយដល់មនុស្សផ្សេងទៀតឡើយ»
និមិត្តបោកប្រាស់ដែលគ្មានប្រយោជន៍ទទេ សេចក្តីបញ្ឆោតនិងការបែកបាក់មកពីគំនិតរបស់ពួកគេ
ពាក្យថានិមិត្ត និងថ្លែងទំនាយត្រូវបានគេថ្លែងថាពីកន្លែងមួយទៅកន្លែងមួយទៀត។
ការបកប្រែរបៀបផ្សេងទៀត: «និមិត្តបោកប្រាស់ និងការថ្លែងទំនាយគ្មានប្រយោជន៍
ដែលពួកហោរាទាំងនេះបាននឹកស្រមៃឃើញ»
និមិត្តបោកប្រាស់ដែលគ្មានប្រយោជន៍ទទេ សេចក្តីបញ្ឆោត
ឃ្លាទាំងនេះតំណាងឲ្យសកម្មភាពដែលត្រូវបានគេថ្លែង ប្រៀបដូចជាការទាំងនោះ។
ពីគំនិតរបស់ពួកគេ
ពាក្យថា គំនិតនៅទីនេះត្រូវបានថ្លែង
ប្រៀបដូចជាកន្លែងមួយដែលជំនួសពីសមត្ថភាពនៃការគិត។
Jeremiah 14:15
ព័ត៌មានទូទៅ:
លោកយេរេមាបានថ្លែងជាមួយព្រះអម្ចាស់អំពីរឿងដែលពួកហោរាក្លែងក្លាយដែលបានថ្លែងទំនាយ។
ថ្លែងព្រះបន្ទូលនៅក្នុងនាមរបស់យើង
ពាក្យថា «ព្រះនាម» នៅទីនេះតំណាងឲ្យចំនុចនៃសិទ្ធិអំណាច។
ការបកប្រែរបៀបផ្សេងទៀត:
«ការថ្លែងព្រះបន្ទូលដោយទូលសូមសិទ្ធិអំណាចរបស់យើង ដើម្បីធ្វើការនោះ»
នឹងមិនមានដាវ
ពាក្យថា «ដាវ» នៅទីនេះតំណាងឲ្យចំនុចនៃសង្គ្រាម។
ការបកប្រែរបៀបផ្សេងទៀត: «នឹងមិនមានសង្គ្រាមឡើយ»
យើងនឹងចាក់អំពើអាក្រក់របស់គេទៅលើគេវិញ
លក្ខណៈខាងសីលធម៌ដូចជាអំពើអាក្រក់
ត្រូវបានគេថ្លែងក្នុងភាសាហេប្រឺប្រៀបដូចជាវត្ថុរាវ។
ដូចគ្នានេះលក្ខណៈនៃអំពើអាក្រក់សំដៅលើការដាក់ទណ្ឌកម្មដែលត្រូវបានទទួលដោយពួកមនុស្សអាក្រក់
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងដាក់ទណ្ឌកម្មពួកគេតាមរបៀបដែលសមនឹងពួកគេនឹងទទួលបាន»។
Jeremiah 14:17
ដោយរបួសជាទម្ងន់
ការកាត់ ឬដាច់ស្បែកដែលមិនអាចព្យាបាលបាន
ចុះឡើង
ធ្វើអ្វីមួយដែលគ្មានគោលដៅ
Jeremiah 14:21
ព័ត៌មានទូទៅ:
លោកយេរេមាបន្តសេចក្តីអធិស្ឋានរបស់លោកទៅព្រះអម្ចាស់។

---

15 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «ទោះបីម៉ូសេ និងសាំយូអែល មកអង្វរយើងឲ្យត្រាប្រណីប្រជាជននេះក្តី ក៏យើងមិនអត់ឱនឲ្យពួកគេដែរ។ ចូរបណ្តេញប្រជាជន
នេះឲ្យបាត់ពីមុខយើងទៅ។[2]ពេលគេសួរអ្នកថា តើឲ្យយើងខ្ញុំទៅណា? នោះត្រូវឆ្លើយវិញថា ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ: អ្នកណាដែលតម្រូវឲ្យស្លាប់ អ្នកនោះ
ត្រូវតែស្លាប់ អ្នកណាដែលតម្រូវឲ្យស្លាប់ដោយមុខដាវ អ្នកនោះនឹងស្លាប់ដោយមុខដាវ។ អ្នកណាដែលតម្រូវឲ្យស្លាប់ដោយអត់ឃ្លាន អ្នកនោះនឹងស្លាប់ដោយអត់ឃ្លាន អ្នក
ណាដែលតម្រូវឲ្យជាប់ជាឈ្លើយ អ្នកនោះនឹងត្រូវគេកៀរទៅជាឈ្លើយ។
[3]ដ្បិត យើងនឹងឲ្យមានគ្រោះកាចបួនយ៉ាងកើតឡើង សម្រាប់ដាក់ទោសគេ គឺដាវសម្រាប់កាប់សម្លាប់ ឆ្កែសម្រាប់ហែកស៊ី សត្វហើរលើអាកាស ហើយសត្វព្រៃនៅផែនដី
សម្រាប់ជញ្ជែងស៊ី ហើយបំផ្លាញផង។[4]យើងនឹងបោះទៅកណ្តាលអស់ទាំងជនជាតិនៅផែនដី ដោយព្រោះម៉ាណាសេ ជាបុត្រាហេសេគា ស្តេចទឹកដីយូដា និងការដែលទ្រង់
បានប្រព្រឹត្តនៅក្រុងយេរូសាឡិម។
[5]ដ្បិតក្រុងយេរូសាឡិមអើយ តើអ្នកណានឹងអាណិតប្រណីដល់អ្នក? តើអ្នកណានឹងសោកស្តាយអ្នក? តើអ្នកណានឹងបែរមកសួរពីសេចក្តីសុខទុក្ខរបស់អ្នក?[6]អ្នកបាន
បោះបង់យើងហើយ អ្នកបានរាថយចេញ ហេតុនោះបានជាយើងលូកដៃទៅទាស់នឹងអ្នក ហើយបំផ្លាញអ្នក យើងលែងស្តាយស្រណោះទៀតហើយ។[7]យើងបានអុំគេ
ដោយចង្កេរនៅត្រង់ទ្វារក្រុងក្នុងទឹកដី យើងបានធ្វើឲ្យបាត់បង់កូនអស់ទៅ គឺយើងបានបំផ្លាញប្រជារាស្ត្ររបស់យើងហើយ ព្រោះគេមិនបានបែរត្រឡប់មកពីផ្លូវរបស់គេ
ទេ។
[8]យើងធ្វើឲ្យមានស្ត្រីមេម៉ាយ កាន់តែច្រើនឡើងនៅមុខយើង លើសជាងខ្សាច់នៅមាត់សមុទ្រទៅទៀត យើងបាននាំអ្នកបំផ្លាញម្នាក់មកលើម្តាយ របស់ពួកកំលោះៗទាំងថ្ងៃ
ត្រង់ យើងបានបណ្តាលឲ្យមានសេចក្តីទុក្ខព្រួយ និងសេចក្តីស្ញែងខ្លាចលោមកលើគេភ្លាម។[9]ស្ត្រីណាដែលបានបង្កើតកូនប្រាំពីរនាក់ក៏ល្វើយទៅ រួចប្តូរវិញ្ញាណចេញ ពន្លឺ
របស់នាងបានលិចទៅ ក្នុងកាលដែលនៅថ្ងៃនៅឡើយ។ នាងបានត្រូវអៀនខ្មាស ហើយជ្រប់មុខ ឯពួកដែលនៅសល់ យើងនឹងប្រគល់ដល់ដាវនៅមុខពួកខ្មាំងសត្រូវរបស់
គេ នេះហើយជាព្រះបន្ទូលនៃព្រះជាម្ចាស់»។
[10]ម៉ែអើយ វរហើយខ្ញុំ ដ្បិតម៉ែបានបង្កើតខ្ញុំមកជាមនុស្សទទឹងទាស់ ហើយជជែកបន្ទោសដល់លោកីយ៍ទាំងមូល ខ្ញុំមិនបានឲ្យអ្នកណាខ្ចី ក៏មិនបានខ្ចីពីគេផងដែរ ប៉ុន្តែ គេ
ប្រទេចផ្តាសាខ្ញុំគ្រប់គ្នា។[11]ព្រះម្ចាស់មានព្រះបន្ទូលថា៖ ពិតប្រាកដជាយើងបានចម្រើនកម្លាំងក្នុងជីវិតអ្នក ឲ្យបានសេចក្តីល្អ ពិតប្រាកដជាយើងបានបណ្តាលឲ្យខ្មាំងសត្រូវ
មកអង្វរអ្នកក្នុងគ្រាមានអាសន្ន និងក្នុងគ្រាវេទនា។[12]តើអ្នកណាអាចបំបាក់បំបែកដែកពីទឹកដីខាងជើង និងលង្ហិនបាន?
[13]ចំណែកធនធាន និងទ្រព្យសម្បត្តិរបស់អ្នក យើងនឹងប្រគល់អោយ ខ្មាំងសត្រូវអ្នកវិញ គឺដោយព្រោះអំពើបាបរបស់អ្នក នៅតាមព្រំដែនរបស់អ្នក។[14]យើងនឹងឲ្យអ្នកឆ្លង
ទៅជាមួយពួកខ្មាំងសត្រូវអ្នក ដល់ទឹកដីមួយដែលអ្នកមិនស្គាល់ ដ្បិតមានភ្លើងកាត់ឡើងក្នុងសេចក្តីកំហឹងរបស់យើង ភ្លើងនោះនឹងឆេះដល់អ្នករាល់គ្នា»។

generated on Wed Sep 10 16:16:32 2025

[15]ព្រះជាម្ចាស់អើយ ព្រះអង្គជ្រាបហើយ សូមព្រះអង្គនឹកចាំពីទូលបង្គំ ហើយប្រោសទូលបង្គំផង សូមសងសឹកនឹងពួកអ្នកដែលបៀតបៀនទូលបង្គំ សូមកុំដកទូលបង្គំចេញ
ដោយព្រះអង្គត្រូវរងទ្រាំជាយូរនោះឡើយ សូមជ្រាបថា ទូលបង្គំរងទ្រាំសេចក្ដីដំណៀល ដោយយល់ដល់ព្រះអង្គ[16]ទូលបង្គំបានឃើញព្រះបន្ទូលព្រះអង្គ ទូលបង្គំក៏បាន
ទទួលទានលេបចូលអស់ហើយ ព្រះបន្ទូលរបស់ព្រះអង្គជាអំណរ ហើយជាទីរីករាយចិត្តដល់ទូលបង្គំ ដ្បិតព្រះនៃពិភពទាំងមូល ទូលបង្គំបានហៅតាមព្រះនាមព្រះអង្គ។
[17]ទូលបង្គំមិនបានអង្គុយក្នុងចំណោម នៃពួកអ្នកដែលលេងសប្បាយ ហើយលោតកញ្ឆេងនោះឡើយ គឺទូលបង្គំបានអង្គុយតែម្នាក់ឯង ដោយព្រោះព្រះហស្តរបស់ព្រះអង្គ
ដ្បិតព្រះអង្គបានឲ្យទូលបង្គំ មានពេញដោយសេចក្ដីគ្នាន់ក្នាញ់។[18]ហេតុអ្វីបានជាទូលបង្គំមានសេចក្ដីទុក្ខព្រួយជានិច្ច ហើយរបួសទូលបង្គំមើលមិនព្រមសះសោះដូច្នេះ?
តើព្រះអង្គដូចជាទឹកដែលហូរមិនទៀងទាត់ហើយហួតរីងអស់ឬ?
[19]ហេតុនោះ ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «បើអ្នកវិលមកវិញ នោះយើងនឹងនាំអ្នកទៀត ដើម្បីឲ្យអ្នកបានឈរនៅមុខយើង ហើយបើអ្នកញែករបស់ថ្លៃវិសេស
ចេញពីរបស់ស្មោកគ្រោក នោះអ្នកនឹងបានដូចជាមាត់យើង គេនឹងវិលមកអ្នកវិញ តែអ្នកមិនត្រូវត្រឡប់ទៅឯគេទេ។[20]យើងនឹងធ្វើឲ្យអ្នកជាកំផែងលង្ហិន មានគ្រឿង
សស្ត្រាវុធដល់ជនជាតិនេះ គេច្បាំងនឹងអ្នក តែមិនអាចឈ្នះបានទេ ដ្បិតយើងនៅជាមួយអ្នក ដើម្បីនឹងជួយសង្គ្រោះ ហើយប្រោសអ្នកឲ្យរួច នេះជាព្រះបន្ទូលរបស់
ព្រះជាម្ចាស់។[21]យើងនឹងជួយឲ្យអ្នករួចពីកណ្ដាប់ដៃ នៃមនុស្សអាក្រក់ ហើយលោះអ្នកចេញពីកណ្ដាប់ដៃ នៃមនុស្សដែលគួរស្ញែងខ្លាច»។

Jeremiah 15:1

ព័ត៌មានទូទៅ:

លោកយេរេមាបានបន្តសេចក្ដីអធិស្ឋានរបស់លោកទៅព្រះអម្ចាស់។

ចូរបណ្តេញប្រជាជននេះឲ្យបាត់ពីមុខយើងទៅ

«ចូរបណ្តេញពួកគេឲ្យឆ្ងាយពីយើងទៅ! ចូរឲ្យពួកគេចេញទៅ!
ទ្រង់មានបន្ទូលពីចំណុចនេះឡើងវិញ ដើម្បីការសង្កត់ន័យ។

អ្នកនោះត្រូវតែស្លាប់

ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលព្រះជាម្ចាស់មានព្រះបន្ទូល
នោះនឹងត្រូវស្លាប់» ឬ «អ្នកទាំងនោះពិតជានឹងស្លាប់»

Jeremiah 15:3

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលពួកគេថាព្រះអង្គនឹងចាត់បញ្ជូនពួកគេខ្លះឲ្យស្លាប់
អ្នកខ្លះនឹងត្រូវស្លាប់ដោយដាវ អ្នកខ្លះទៀតនឹងត្រូវស្លាប់ដោយទុរ្ភិក្ស
និងអ្នកខ្លះទៀតត្រូវជាប់ជាឈ្លើយ។

ព្រះបន្ទូលនៃព្រះអម្ចាស់

សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។

យើងនឹងធ្វើឲ្យមានរន្ធត់ញាប់ញ័រដល់នរគទាំងឡាយនៅលើផែនដី ដោយព្រោះអ្វីម៉ាណាសេ ជាបុត្រា
ហេសេគា ស្តេចទឹកដីយូដា បានប្រព្រឹត្តនៅក្រុងយេរូសាឡិម។

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងធ្វើអោយប្រជាជាតិទាំងប៉ុន្មាននៅលើផែនដីភ័យញាប់ញ័រព្រោះតែអំពើដែលម៉ាណាសេ
ជាស្តេចស្រុកយូដាបានប្រព្រឹត្តនៅក្រុងយេរូសាឡិម»។

យើងនឹងឲ្យមានគ្រោះកាចបួនយ៉ាងកើតឡើង

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងចាត់ឲ្យមានគ្រោះកាចបួនយ៉ាងមកលើពួកគេ»

Jeremiah 15:5

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់ពួកគេថាព្រះអង្គនឹងចាត់ឲ្យមានគ្រោះកាចមកសម្លាប់ពួក
គឺដាវ ឆ្កែបក្សី និងសត្វព្រៃ។

ដ្បិត តើអ្នកណានឹងអាណិតដល់អ្នក ក្រុងយេរូសាឡិម? តើអ្នកណានឹងសោកស្តាយអ្នក? តើអ្នកណា
នឹងបែរមកសួរពីសេចក្ដីសុខទុក្ខរបស់អ្នក?

ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្នកណាអាណិតអាសូរអ្នកទេ
អស់អ្នកដែលរស់នៅក្រុងយេរូសាឡិម។

គ្មានអ្នកណានឹងសោកសៅចំពោះការបោះបង់របស់អ្នកដែរ។

គ្មានអ្នកណានឹងសួរថាហេតុអ្វីបានជាអ្នកក្លាយជាមនុស្សវេទនាបែបនេះ?

អ្នកបានបោះបង់យើង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ អ្នកបានរាថយចេញពីយើង

ឃ្លាទាំងពីរមានន័យដូចគ្នា

ហើយបញ្ជាក់ថាពួកគេពិតជាបានបោះបង់ព្រះអម្ចាស់យ៉ាងពិតប្រាកដ។

ចង្ហាយដែក

ឧបករណ៍ផ្នែកកសិកម្មមួយដែលមានដងវែងវែង និងមុខដែកស្រួច
ដែលត្រូវបានប្រើជាពិសេសសម្រាប់លើកនិងចោលគ្រាប់ធញ្ញជាតិនៅលើអាកាសសម្រាប់
ជីកគាស់។

យើងនឹងបាត់បង់ពួកគេ

«យើងនឹងធ្វើឲ្យកូនរបស់គេបានស្លាប់ចោល» ឬ
«យើងនឹងឲ្យខ្មាំងសត្រូវគេសម្លាប់កូនរបស់គេ»

Jeremiah 15:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់ពួកគេថាគ្មាននរណាម្នាក់យកចិត្តទុកដាក់ពីពួកគេទេ
ហើយព្រះអង្គនឹងបំផ្លាញប្រជាជនរបស់ព្រះអង្គចាប់តាំងពីពួកគេមិនងាកចេញពីអំពើអាក្រក់របស់គេ។

ស្ត្រីមេម៉ាយ

ស្ត្រីដែលមានប្តីបានស្លាប់

កាន់តែច្រើនឡើងនៅមុខយើង លើសជាងខ្សាច់នៅមាត់សមុទ្រទៅទៀត

ការបកប្រែរបៀបផ្សេងទៀត: «ចង់រហូតរាប់មិនអស់»

ស្វែងខ្លាចមកលើគេ

«ដែលបានកើតឡើងមកលើគេ»

នាងត្រូវអាម៉ាស់ ហើយអៀនខ្មាស់

ពាក្យថា «អាម៉ាស់» និង «អៀនខ្មាស់» មានន័យដូចគ្នា ហើយត្រូវបានបញ្ជាក់ពី
ការខ្មាស់អៀនកាន់តែច្រើនឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«នាងពិតជាខ្មាស់អៀនយ៉ាងខ្លាំង»។

Jeremiah 15:10

ព័ត៌មានទូទៅ:

នៅខគម្ពីរទាំងនេះ
លោកយេរេមាបានថ្លែងទៅកាន់ព្រះអម្ចាស់អំពីការរងទុក្ខរបស់លោក
ហើយព្រះអម្ចាស់ឆ្លើយតបលោក។

ម៉ែអើយ វរហើយខ្ញុំ

លោកយេរេមាធ្វើពុតនិយាយទៅម្តាយរបស់លោក

ជាវិធីមួយដើម្បីបញ្ជាក់ថាលោកកំពុងពិបាកចិត្តប៉ុណ្ណា។

[illegible]

ពាក្យថា «បង្កហេតុ» និង «ជំលោះ» មានន័យដូចគ្នា។ ពាក្យទាំងពីររួមគ្នាបញ្ជាក់ពី
តើលោកយេរេមាមានជំលោះប៉ុន្មាន។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សម្នាក់ដែលមានជំលោះជាមួយអ្នកដទៃគ្រប់ពេលវេលា»។

ឲ្យអ្នកណាខ្ចី

ផ្តល់ចម្ងីដល់នរណាម្នាក់

តើយើងមិនបានសង្គ្រោះអ្នកសម្រាប់ការល្អទេ?

ចន្លើយជាក់ស្តែងចំពោះសំណួរនេះគឺ «បាទ / ចាស»។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំប្រាកដជានឹងជួយសង្គ្រោះអ្នកសម្រាប់ការល្អ!»

ខ្មាំងសត្រូវ

ពួកគេទាំងនោះគឺជាខ្មាំងសត្រូវរបស់លោកយេរេមាដែលមិនយល់ស្រប
នឹងការថ្លែងទំនាយរបស់លោក។

ក្នុងគ្រាមានអាសន្ន និងក្នុងទុក្ខព្រួយ

ពាក្យថា «អាសន្ន» និង «ទុក្ខព្រួយ» មានន័យដូចគ្នា។
ពាក្យទាំងពីរនេះបញ្ជាក់ពីបរិមាណ ឬទំហំនៃភាពអាសន្ន។
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងគ្រាដែលមានភាពអាសន្នខ្លាំងក្លា»។

តើអ្នកណាអាចបំបាក់ដែកបានទេ?

ចម្លើយមានន័យថាគឺ «ទេ»។ ដូចគ្នានេះដែរ
ដែកតំណាងឲ្យភាពរឹងមាំនៃការជំនុំជម្រះរបស់ព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ការជំនុំជម្រះយើងមិនអាចបែកបាក់បានទេ
ដូចជាដែកមិនអាចបំបាក់បាន»

ជាពិសេសដែកមកពីទឹកដីខាងជើង ដែលលាយនិងលង្ហិននោះ?

សំណួរទីពីរនេះជួយឲ្យសំណួរទីមួយកាន់តែមានន័យហើយប្រើដែករឹងមាំបន្ថែមទៀតនៅក្នុងការប្រៀបធៀ
ការបកប្រែរបៀបផ្សេងទៀត: «លើសពីនេះទៀតការជំនុំជំរះយើង
គឺដូចជាដែកដ៏រឹងមាំយ៉ាងខ្លាំង» (សូមមើល: និងfigs-metaphor)

Jeremiah 15:13

ព័ត៌មានទូទៅ:

នៅខគម្ពីរទាំងនេះ ព្រះអម្ចាស់មានព្រះបន្ទូលទៅជាជាតិអ៊ីស្រាអែល

generated on Wed Sep 10 16:16:32 2025

ប្រៀបដូចជាមនុស្សម្នាក់។
ធនធាន និងទ្រព្យសម្បត្តិ
ពាក្យថា «ទ្រព្យសម្បត្តិ» សំដៅលើអ្វីមនុស្សចាត់ទុកថាជារបស់មានតម្លៃ។
លួចប្លន់
របស់ដែលអ្នកលួចពីទីក្រុង បន្ទាប់ពីវាយយកបាន
ក្នុងទឹកដីមួយដែលអ្នកមិនស្គាល់
«ទៅទឹកដីមួយដែលផ្សេងទៀតចំពោះអ្នក»
ដ្បិតមានភ្លើងកាត់ឡើងក្នុងសេចក្ដីកំហឹងរបស់យើង ភ្លើងនោះនឹងឆេះដល់អ្នកដែរ
សេចក្ដីពិរោធរបស់ព្រះជាម្ចាស់ ត្រូវបានគេនិយាយប្រៀបដូចជាភ្លើងបំផ្ទិចបំផ្លាញ។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបំផ្លាញអ្នកព្រោះយើងខឹងនឹងអ្នក»
Jeremiah 15:15
ព័ត៌មានទូទៅ:
លោកយេរេមាថ្លែងទៅកាន់ព្រះអម្ចាស់។
សូមចងចាំទូលបង្គំ
ការបកប្រែរបៀបផ្សេងទៀត: «សូមនឹកចាំទូលបង្គំ» ឬ«សូមគិតពីបង្គំ
និងស្ថានភាពរបស់ទូលបង្គំ»
អ្នកដើរតាមខ្ញុំ
«អ្នកដែលតាមស្វែងរកខ្ញុំ ដើម្បីធ្វើទុកខ្ញុំ»
ព្រះអង្គអត់ធ្មត់ ប៉ុន្តែសូមកុំឲ្យគេយក ទូលទូលបង្គំចេញឡើយ
ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះមិនបន្តអត់ធ្មត់ជាមួយពួកគេ
ហើយមិនត្រូវអនុញ្ញាតិឲ្យខ្ញុំស្លាប់នៅពេលនេះឡើយ»។
ព្រះបន្ទូលព្រះអង្គ ទូលបង្គំក៏បានឃើញហើយ
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំបានលឺពីព្រះបន្ទូលរបស់ព្រះអង្គ»។
ក៏បានលេបចូលពោះទាំងអស់ដែរ
«ទូលបង្គំបានយល់ដឹងពីព្រះបន្ទូលរបស់ព្រះអង្គ»
ព្រះនាមព្រះអង្គត្រូវបានប្រកាសដល់ទូលបង្គំ
«មនុស្សម្នាបានសំគាល់ទូលបង្គំថារបស់កម្មសិទ្ធទ្រង់»
Jeremiah 15:17
ទូលបង្គំមិនបានអង្គុយក្នុងចំណោម
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំមិនបានចំណាយពេលជាមួយ»
ហេតុអ្វីបានជាទូលបង្គំមានសេចក្ដីទុក្ខព្រួយជានិច្ច ហើយរបួសទូលបង្គំមិនបានជាសះ ស្បើុយ?
ការបកប្រែរបៀបផ្សេងទៀត: «សេចក្ដីទុក្ខព្រួយទូលបង្គំ
និងរបួសរបស់ទូលបង្គំបានជាសះស្បើយឡើយ។
ទូលបង្គំមិនអាចជាសះស្បើយឡើយ»។
តើព្រះអង្គដូចជាទឹកដែលហូរមិនទៀងទាត់ហើយក៏ស្ងួតទៅវិញឬ?
ការបកប្រែរបៀបផ្សេងទៀត: «ពាក្យសន្យារបស់ទ្រង់មកទូលបង្គំដូចជាទឹកហូរ
ដែលទូលបង្គំផឹកតែរកឃើញថារីងស្ងួតមែនទេ?
Jeremiah 15:19
នោះអ្នកនឹងបានដូចជាមាត់យើង
លោកយេរេមាត្រូវបានគេប្រៀបធៀបទៅនឹងព្រះឱស្ឋរបស់ព្រះអម្ចាស់
ពីព្រោះលោកនឹងត្រូវស្គាល់ដើម្បីថ្លែងពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងថ្លែងពីយើង»
តែអ្នក
សព្វនាម «អ្នក»
ត្រូវបានបញ្ជាក់ពីបទបញ្ជាតិជាដែលសំដៅលើលោកយេរេមាជាពិសេស។
ក្លាយជាកំពែងលង្ហិនរឹងមាំដល់មនុស្សទាំងនេះ
ព្រះអម្ចាស់បានប្រៀបធៀបលោកយេរេមាជាជញ្ជាំងដ៏រឹងមាំដែលមនុស្សមិនអាចយកឈ្នះលោកបានឡើយ
ពួកគេនឹងច្បាំងទាស់អ្នក។ តែគេមិនអាចឈ្នះបានទេ
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងច្បាំងទាស់នឹងអ្នក
តែពួកគេមិនអាចឈ្នះអ្នកបានទេ»។
ជួយសង្គ្រោះនិងរំដោះអ្នក
ពាក្យថា «សង្គ្រោះ» និង «រំដោះ»មានន័យដូចគ្នា ហើយបញ្ជាក់ពីសេចក្ដីសុខ
ដែលព្រះជាម្ចាស់បានសន្យា។
នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ៧។
ជួយអ្នកឲ្យរួចពីកណ្ដាប់ដៃ នៃមនុស្សអាក្រក់ ហើយលោះអ្នកចេញពី
ឃ្លាទាំងនេះមានន័យស្រដៀងគ្នា ហើយត្រូវបានប្រើប្រាស់ជាមួយគ្នា
ដើម្បីបញ្ជាក់ពីសេចក្ដីសុខដែលព្រះជាម្ចាស់បានសន្យា។
ជនផ្តាច់ការ
អ្នកដឹកនាំដែលទាមទារឲ្យមានការគោរពប្រតិបត្តិដាច់ខាត
និងមិនរាក់ទាក់សម្រាប់អ្នកដែលនៅក្រោមការដឹកនាំរបស់គេ

---

16 [1]ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានមកដល់ខ្ញុំថា៖ [2]«មិនត្រូវយកប្រពន្ធសម្រាប់តែអ្នក ឬបង្កើតកូនប្រុស កូនស្រីនៅទីនេះទេសម្រាប់អ្នកនោះឡើយ [3]ដ្បិតព្រះ អម្ចាស់
មានព្រះបន្ទូលពីដំណើរកូនប្រុសកូនស្រីដែលកើតនៅទីនេះ ពីម្តាយដែលសម្រាលវាមក និងពីឪពុកដែលបង្កើតវានៅទឹកដីនេះដូច្នេះថា [4]ពួកគេនឹងស្លាប់ដោយ
លំបាកណាស់ ឥតមានអ្នកណាយំសោកឡើយ ក៏គ្មានអ្នកណាបញ្ចុះសពគេដែរ គឺគេនឹងដូចជាជីនៅដី គេនឹងត្រូវវិនាសដោយដាវ និងអំណត់ ហើយសាកសពរបស់គេនឹង
បានសម្រាប់ជាអាហារដល់សត្វហើរលើអាកាស និងសត្វព្រៃនៅផែនដី។
[5]ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ កុំចូលទៅក្នុងផ្ទះដែលគេកាន់ទុក្ខ ក៏កុំទៅយំសោក ឬទួញទំនួញដោយព្រោះគេឡើយ ដ្បិតយើងបានដកសេចក្ដីសុខរបស់យើង
គឺជាសេចក្ដីសប្បុរស និងសេចក្ដីអាណិតអាសូរ ចេញពីជនជាតិនេះហើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។ [6]មនុស្សទាំងអស់ ទាំងធំទាំងតូច នឹងត្រូវស្លាប់នៅទឹកដីនេះ
ឥតមានអ្នកណាបញ្ចុះសពគេឡើយ មនុស្សក៏នឹងមិនយំសោក ឬឆូតសាច់ ឬកោរសក់ដោយព្រោះគេឡើយ។
[7]គ្មានអ្នកណាកាច់នំបុ័ងជូនដល់អ្នកសោយសោក ដើម្បីកម្សាន្តចិត្តពីដំណើរអ្នកដែលស្លាប់សោះ ក៏គ្មានអ្នកណាជូនពែងរំលែកទុក្ខដល់គេ ដោយព្រោះគេបាត់បង់ឪពុក
ម្តាយនោះដែរ។ [8]ឯផ្ទះដែលគេកំពុងស៊ីលៀង អ្នកមិនត្រូវចូលទៅអង្គុយស៊ីផឹកជាមួយគេដែរ។ [9]ដ្បិតព្រះជាម្ចាស់ នៃពិភពទាំងមូលគឺជាព្រះរបស់ជនជាតិអ៊ីស្រាអែល មាន
ព្រះបន្ទូលដូច្នេះថា៖ មើល៍! នៅគ្រាអាយុអ្នក ហើយនៅចំពោះភ្នែកអ្នក យើងនឹងធ្វើឲ្យសំឡេងរីករាយ និងសំឡេងអរសប្បាយ ព្រមទាំងសំឡេងប្តីប្រពន្ធថ្មោងថ្មីបាត់ចេញពី
ទីនេះទៅ។
[10]ពេលណាអ្នកបានប្រាប់ពាក្យទាំងនេះដល់ជនជាតិនេះរួចជាស្រេច ហើយគេសួរអ្នកថា៖ ហេតុអ្វីបានជាព្រះជាម្ចាស់មានព្រះបន្ទូល ពីការអាក្រក់យ៉ាងធំទាំងនេះទាស់នឹង
យើងដូច្នេះ? តើយើងមានអំពើទុច្ចរិតណា ឬបានប្រព្រឹត្តអំពើបាបយ៉ាងណា ទាស់នឹងព្រះអម្ចាស់ជាព្រះនៃយើង? [11]នោះអ្នកត្រូវប្រាប់គេថា៖ ព្រះអង្គមានបន្ទូលថា គឺដោយ
ព្រោះបុព្វបុរសរបស់អ្នករាល់គ្នាបានបោះបង់យើង ទៅតាមព្រះដទៃ ព្រមទាំងគោរព ហើយថ្វាយបង្គំដល់វាផង គេបានបោះបង់យើង ឥតដែលរក្សាច្បាប់យើងឡើយ។
[12]ប៉ុន្តែ ចំណែកអ្នករាល់គ្នានោះបានប្រព្រឹត្តអាក្រក់ លើសជាងបុព្វបុរសអ្នកទៅទៀត ដ្បិតអ្នករាល់គ្នាប្រព្រឹត្តតាមតែសេចក្ដីរឹងចចេសនៅក្នុងចិត្តអាក្រក់របស់អ្នករៀងខ្លួន
បានជាមិនព្រមស្តាប់តាមយើងសោះ។ [13]ដូច្នេះ យើងនឹងបោះអ្នករាល់គ្នាចោលចេញពីទឹកដីនេះ ឲ្យទៅនៅឯទឹកដីមួយដែលអ្នក ឬបុព្វបុរសអ្នកមិនបានស្គាល់ ហើយនៅទី
នោះ អ្នករាល់គ្នានឹងគោរពប្រតិបត្តិតាមព្រះដទៃទាំងយប់ទាំងថ្ងៃ ព្រោះយើងនឹងមិនអាណិតដល់អ្នកទេ។
[14]ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ មើល៍! នឹងមានគ្រាមកដល់ដែលគេលែងស្បថថា ដូចជាព្រះអង្គមានព្រះជន្មរស់ ជាព្រះដែលបាននាំពួកកូនចៅអ៊ីស្រាអែលឡើងរួចពី
ទឹកដីអេស៊ីបមក។ [15]ប៉ុន្តែ ព្រះអង្គដែលមានព្រះជន្មរស់ ដែលព្រះអង្គបាននាំពួកកូនចៅអ៊ីស្រាអែល ចេញពីទឹកដីខាងជើងមក ហើយពីអស់ទាំងប្រទេស ដែលព្រះអង្គបាន
បណ្តេញគេនោះផង។ ដ្បិតយើងនឹងនាំគេឲ្យវិលមកក្នុងទឹកដីរបស់គេ ជាទឹកដីដែលយើងបានឲ្យដល់បុព្វបុរសគេ។
[16]មើល៍! យើងនឹងចាត់មនុស្សឲ្យទៅហៅពួកនេសាទជាច្រើនមក នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់ថា៖ អ្នកទាំងនោះនឹងបង់សំណាញ់ប្រមូលគេ បន្ទាប់មក យើងនឹងចាត់ឲ្យ
ទៅហៅពួកព្រានជាច្រើនមក អ្នកទាំងនោះនឹងដេញចាប់គេនៅលើគ្រប់ទាំងភ្នំធំ និងភ្នំតូច ហើយនៅក្រហែងថ្មទាំងប៉ុន្មានផង។ [17]ហើយគេមិនកំបាំងពីមុខយើងទេ ឯអំពើ
ទុច្ចរិតរបស់គេ ក៏មិនបិទបាំងពីភ្នែកយើងដែរ។ [18]ប៉ុន្តែ មុនដំបូង យើងនឹងសងអំពើទុច្ចរិត និងអំពើបាបរបស់គេមួយជាពីរ ព្រោះគេបានធ្វើឲ្យទឹកដីយើងទៅជាស្មោកគ្រោក
ដោយសាកសពនៃរូបព្រះគួរខ្ពើម ហើយធ្វើឲ្យទឹកដីជាមរតករបស់យើង មានពេញដោយរបស់គួរខ្ពើមឆ្អើមរបស់គេ»។
[19]ព្រះអម្ចាស់អើយ ទ្រង់ជាកម្លាំងនៃទូលបង្គំ ជាទីមាំមួន ហើយជាទីពឹងជ្រកដល់ទូលបង្គំ នៅគ្រាលំបាកអើយ ពួកជនជាតិទាំងប៉ុន្មាននឹងមកឯព្រះអង្គ ពីអស់ទាំងចុង
ផែនដីបំផុត ហើយគេនឹងទូលថា បុព្វបុរសរបស់យើងខ្ញុំបានទទួលតែពាក្យកុហក គឺជាសេចក្ដីអសារឥតការ និងសេចក្ដីដែលឥតមានប្រយោជន៍អ្វីសោះ។ [20]តើមានទំនងឲ្យ

generated on Wed Sep 10 16:16:32 2025

មនុស្សធ្វើព្រះសម្រាប់ខ្លួនឬ? ដែលមិនមែនជាព្រះពិតដែរ។[21]ដូច្នេះ មើល៍! យើងនឹងធ្វើឲ្យគេស្គាល់ ម្តងនេះយើងនឹងធ្វើគេស្គាល់ដៃយើង និងឥទ្ធិឫទ្ធិរបស់យើង នោះគេនឹងស្គាល់ឈ្មោះយើង ថាជាព្រះអង្គម្ចាស់។

Jeremiah 16:1
ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១។
ពួកគេនឹងដូចជាជីដែលដាក់លើដីវិញ
កូនប្រុសកូនស្រីដែលកើតនៅលើទឹកដីត្រូវបានគេប្រៀបធៀបទៅនឹងជី
ពីព្រោះពួកគេនឹងមិនត្រូវបានគេបញ្ចុះបន្ទាប់ពីពួកគេស្លាប់។
ដ្បិតពួកគេនឹងត្រូវដល់ពេលបញ្ចប់
នេះជារបៀបសមរម្យដើម្បីនិយាយថាពួកគេនឹងស្លាប់។
ដោយដាវ
ពាក្យថា «ដាវ» សំដៅលើកងទ័ពខ្មាំងសត្រូវ។
Jeremiah 16:5
យើងបានប្រមូលសេចក្តីសុខសាន្ត សេចក្តីស្មោះត្រង់នៃសម្ពន្ធមេត្រី
និងសកម្មភាពនៃសេចក្តីមេត្តាករុណាទន់ភ្លន់របស់យើង
ព្រះអម្ចាស់ប្រមូលផ្តុំការទាំងនោះ ដែលទ្រង់បានប្រទានពរដល់ជនជាតិអ៊ីស្រាអែល
មានន័យថាទ្រង់លែងប្រទានពរដល់ជនជាតិអ៊ីស្រាអែលទៀតទេ។
ព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ១:៧។
ទាំងអ្នកធំហើយទាំងអ្នកតូច
នេះសំដៅទៅលើមនុស្សគ្រប់ប្រភេទ និងប្រើឋានៈដើម្បីបញ្ជាក់ពី
តើពួកគេមានសារៈសំខាន់ប៉ុណ្ណា។ ទាំងអ្នកដែលមានសារៈសំខាន់ធំ
ឬអ្នកមានសារៈសំខាន់តូច។
គ្មានមនុស្សនឹងកាន់ទុក្ខសម្រាប់ពួកគេ ឬកាត់ពួកគេ ឬកោរសក់សម្រាប់ពួកគេឡើយ។
ឃ្លាទាំងពីរមានអត្ថន័យស្រដៀងគ្នា។ ឃ្លាទី២ជួយឲ្យឃ្លាទី ១
កាន់តែមានន័យច្បាស់លាស់។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មាននរណាម្នាក់នឹងកាន់ទុក្ខពួកគេក្នុងវិធីណាមួយឡើយ»។
កាត់ពួកគេ ឬកោរសក់សម្រាប់ពួកគេឡើយ។
នេះជារបៀបដែលមនុស្សធ្លាប់បានបង្ហាញពេលដែលពួកគេមានសេចក្តីទុក្ខព្រួយ។
Jeremiah 16:7
មិនត្រូវឲ្យអ្នកណាចែកអាហារក្នុងពេលកាន់ទុក្ខទេ ដើម្បីកម្សាន្តចិត្តពួកគេដោយសារសេចក្តីស្លាប់
ហើយមិនត្រូវឲ្យអ្នកណាជូនពែងរំលែកទុក្ខ ដល់ឪពុកឬម្តាយ
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ នេះជាទម្លាប់ក្នុងការយកអាហារ
ឬស្រាទៅមនុស្សដែលជាសាច់ញាតិរបស់គេបានស្លាប់។
ព្រះអម្ចាស់បានដកសេចក្តីកម្សាន្តចិត្តគ្រប់យ៉ាងចេញពីប្រជាជន
ព្រោះតែអំពើបាបរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«កុំកម្សាន្តចិត្តមនុស្សនៅពេលសាច់ញាតិរបស់ពួកគេស្លាប់ឡើយ»
ព្រះជាម្ចាស់នៃពិភពទាំងមូល ជាព្រះនៃជនជាតិអ៊ីស្រាអែល
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៧:៣។
មើល៍!
ការបកប្រែរបៀបផ្សេងទៀត: «សូមស្តាប់» ឬ
«យកចិត្តទុកដាក់នូវអ្វីដែលយើងនឹងថ្លែងប្រាប់អ្នក»
នៅចំពោះភ្នែករបស់អ្នក
ពាក្យថា «របស់អ្នក» នៅទីនេះគឺសំដៅលើប្រជាជនអ៊ីស្រាអែលជាច្រើន។
ការបកប្រែរបៀបផ្សេងទៀត: «នៅពីមុខរបស់អ្នក» ឬ «ពីទីដែលអ្នកបានឃើញ»
នៅក្នុងថ្ងៃរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងអំឡុងពេលនៃជីវិតរបស់អ្នក»
សំឡេងរបស់ប្តីហើយនិងសំឡេងរបស់ប្រពន្ធ
ឃ្លានេះសំដៅទៅលើពេលមនុស្សធ្វើពិធីអាពាហ៍ពិពាហ៍។
Jeremiah 16:10
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
ថ្វាយបង្គំ និងអោនចុះចំពោះពួកព្រះទាំងនោះ
ពាក្យថា «អោនចុះ» មានន័យថាជាមូលដ្ឋានដូចគ្នានឹង «ថ្វាយបង្គំ»
និងពិពណ៌នាអំពីឥរិយាបថ ដែលមនុស្សប្រើក្នុងការថ្វាយបង្គំ។
Jeremiah 16:12
មើល៍
ពាក្យថា «មើល៍» នៅទីនេះដើម្បីបញ្ជាក់ពីអ្វីដែលនៅខាងក្រោយ។
ការបកប្រែរបៀបផ្សេងទៀត: «ជាការពិត»
តាមសេចក្តីរឹងចចេស នៃចិត្តអាក្រក់របស់ពួកគេ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១១:៦។
អ្នកដែលស្តាប់យើង
«អ្នកណាធ្វើអ្វីដែលខ្ញុំប្រាប់ឲ្យគាត់ធ្វើ»
បោះអ្នកចេញពីទឹកដីនេះ
«បង្ខំអ្នកឲ្យចេញពីទឹកដីនេះ»
ទាំងយប់ទាំងថ្ងៃ
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ពេលវេលា» ឬ «ម្តងហើយម្តងទៀត»
Jeremiah 16:14
មើល៍!
ពាក្យថា «មើល៍» នៅទីនេះដើម្បីបញ្ជាក់ពីអ្វីដែលនៅខាងក្រោយ។
ការបកប្រែរបៀបផ្សេងទៀត: «ជាការពិត»
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ៧។
ពេលនោះនៅមិនយូរទៀតទេ
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលមនុស្សនឹងមិននិយាយទៀតទេ»
ដូចជាព្រះអង្គមានព្រះជន្មរស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១២:១៦។
Jeremiah 16:16
នេះគឺជាព្រះបន្ទូលនៃព្រះជាម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
ពួកនេសាទជាច្រើនមក...ពួកព្រានជាច្រើនមក
ព្រះអម្ចាស់ប្រៀបធៀបមនុស្សទៅនឹងការចាប់យកជនជាតិអ៊ីស្រាអែលទៅជាឈ្លើយសឹក
របស់ពួកគេដែលមានជំនាញដាក់អន្ទាក់ដោយការប្រើល្បិចរបស់គេ។
ភ្នែកយើងទេគឺនៅលើផ្លូវរបស់គេ
ការបកប្រែរបៀបផ្សេងទៀត:
«យើងកំពុងសម្លឹងមើលគ្រប់កិច្ចការដែលពួកគេបានធ្វើ»
ពួកគេមិនអាចបិទបាំងពីចំពោះយើងឡើយ
ពាក្យថា «ពួកគេ» ប្រហែលសំដៅលើ មនុស្ស ឬសកម្មភាពរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនអាចបិទបាំងផ្លូវរបស់គេពីខ្ញុំ» ឬ
«ខ្ញុំអាចមើលឃើញគ្រប់កិច្ចការដែលពួកគេបានធ្វើ»
អំពើទុច្ចរិតរបស់គេ មិនអាចលាក់បំបាំពីភ្នែកយើងដែរ
ការបកប្រែរបៀបផ្សេងទៀត: «យើងអាចឃើញគ្រប់ទាំងអំពើបាបរបស់គេ»
ធ្វើឲ្យទឹកដីជាមរតករបស់យើង មានពេញដោយព្រះក៏គួរខ្ពើមឆ្អើមរបស់គេ
ឃ្លានេះពិព័ណនាពី «អំពើទុច្ចរិត និងអំពើបាប» ដែលមនុស្សតែងតែប្រពឹត្ត។
មរតករបស់យើង
ឃ្លានេះសំដៅទៅលើទឹកដីអ៊ីស្រាអែល។
Jeremiah 16:19
ព្រះអម្ចាស់អើយ ព្រះអង្គជាកម្លាំង
ចាប់ពីនេះទៅ លោកយេរេមាចាប់ផ្តើមថ្លែងពីព្រះអម្ចាស់។
ព្រះអង្គជាកម្លាំងហើយជាទីជម្រកទូលបង្គំ ជាទីសុវត្ថិភាពនៅគ្រាជួបទុក្ខព្រួយ
លោកយេរេមាថ្លែងពីព្រះអម្ចាស់ជាកន្លែងដែលខ្មាំងសត្រូវមិនអាចវាយប្រហារលោកបាន។
លោកបានរំឭកនូវគំនិតដដែលនេះបីដង។
ចុងនៃផែនដី
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ទីកន្លែងនៅលើផែនដី»
ដូនតារបស់យើងខ្ញុំជាមរតកនៃការកុហក
ពាក្យថា «កុហក» សំដៅលើព្រះក្លែងក្លាយ។
ពួកគេគ្មានអ្វីទាំងអស់ ក៏អត់មានប្រយោជន៍ក្នុងពួកគេដែរ
ពាក្យថា «ពួកគ» និង «ពួកគេ» នៅទីនេះ សំដៅទៅលើព្រះក្លែងក្លាយ
ដែលបុព្វបុរសបានបង្រៀនពួកគេឲ្យជឿតាម។
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នានឹងពាក្យទី ២ ពន្យល់ពីរបៀបដែលពួកគេ
«គ្មានអ្វីសោះ»។
តើមនុស្សបានធ្វើព្រះសម្រាប់ខ្លួនឬ?

generated on Wed Sep 10 16:16:32 2025

លោកយេរេមាសួរសំនួរនេះ
ដើម្បីបញ្ជាក់ថាមនុស្សមិនអាចធ្វើរូបព្រះសំរាប់ខ្លួនឯងបានទេ។
ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សមិនអាចបង្កើតព្រះសម្រាប់ខ្លួនឯងបានឡើយ»។
ដូច្នេះហើយ មើល៍!
នៅទីនេះព្រះអម្ចាស់ចាប់ផ្តើមថ្លែងព្រះបន្ទូល។ ពាក្យថា «មើល៍!»
បន្ថែមការបញ្ជាក់ន័យលើអ្វីដែលនៅខាងក្រោយ។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះពិតប្រាកដណាស់»
យើងនឹងធ្វើឲ្យគេស្គាល់
ពាក្យថា «គេ» នៅទីនេះសំដៅលើមនុស្សនៅផែនដី។
ព្រះអម្ចាស់បានរំឭកឃ្លានេះសម្រាប់ការបញ្ជាក់។
ដៃយើង និងអំណាចរបស់យើង
ពាក្យថា «ដៃ» សំដៅលើអំណាច និងការផ្តល់សិទ្ធ។
ឃ្លាទាំងពីរមានន័យដូចគ្នាដើម្បីបញ្ជាក់ពីសិទ្ធអំណាចដ៏ធំធេងរបស់ព្រះអម្ចាស់»។
គេនឹងដឹងថាព្រះអង្គម្ចាស់ គឺជានាមរបស់យើង
ពាក្យថា «នាម» នៅទីនេះសំដៅលើ ព្រះអម្ចាស់ជាមនុស្សសុទ្ធសាធ។
ការបកប្រែរបៀបផ្សេងទៀត: ពួកគេនឹងដឹងថាយើងជាព្រះអម្ចាស់
និងជាព្រះពិតប្រាកដ»

---

17 [1]«អំពើបាបរបស់ជនជាតិយូដា មានចារឹកទុកដូចអក្សរចារឹកលើថ្ម ដោយដែកដែលមានត្បូងពេជ្រ នៅខាងចុង។ អំពើបាបនេះបានចារឹកទុកក្នុងចិត្តរបស់ពួកគេ និង
នៅលើជ្រុងអាសនៈរបស់ពួកគេ។[2]ដូច្នេះ កូនចៅរបស់គេនឹងនឹកឃើញ អាសនៈរបស់ពួកគេ ព្រមទាំងនឹកឃើញបង្គោលរបស់ព្រះអាសេរ៉ា នៅក្បែរដើមឈើដ៏ខៀវ
ខ្ចីដែលស្ថិតនៅលើកំពូលភ្នំ។
[3]បង្គោលនៃព្រះក្លែងក្លាយបានដាក់លើភ្នំ និងនៅកន្លែងបើកចំហរនៅតាមតំបន់។ យើងនឹងឲ្យគេចាប់យកធនធាន និងទ្រព្យសម្បត្តិរបស់អ្នក ព្រមទាំងទីខ្ពស់ទាំងប៉ុន្មាន
របស់អ្នក ដោយព្រោះអំពើបាបដែលប្រព្រឹត្តនៅពេញក្នុងព្រំដែនរបស់អ្នក។[4]អ្នកនឹងប្រគល់ទឹកដីដែលយើងបានចែក ឲ្យអ្នក ទៅជនជាតិដទៃ។ យើងនឹងឲ្យអ្នកក្លាយទៅជា
ទាសករ របស់ខ្មាំងក្នុងទឹកដីមួយដែលអ្នកពុំស្គាល់ ដ្បិតអ្នករាល់គ្នាបានបញ្ឆេះកំហឹងរបស់យើង ហើយភ្លើងនៃកំហឹងនេះនឹងឆេះរហូតតទៅ»។
[5]ព្រះអម្ចាស់មានព្រះបន្ទូលទៀតថា «ជនណាធ្វើជីវិតលើមនុស្សហើយទុកចិត្តលើអ្វីៗដែលជាលោកីយ៍ ដោយបែរចិត្តចេញពីព្រះអម្ចាស់ ជននោះមុខជាត្រូវបណ្តាសា
ពុំខាន។[6]ដ្បិតគេប្រៀបបាននឹងដើមឈើក្រិន នៅតាមព្រៃល្បោះ គេពុំអាចជួបនឹងសុភមង្គលឡើយ។ គេរស់នៅតាមកន្លែងក្តៅហួតហែង ក្នុងវាលរហោស្ថានជាដីដែលគ្មាន
អ្វីដុះ និងគ្មានមនុស្សនៅ។
[7]ចំណែកអ្នកណាដែលទុកចិត្តលើព្រះអម្ចាស់ គឺមានពរហើយ ដ្បិត ព្រះអម្ចាស់គឺជាមូលហេតុដែលសម្រាប់ទុកចិត្តបាន។[8]អ្នកនោះប្រៀបបាននឹងដើមឈើ ដុះនៅក្បែរផ្លូវ
ទឹក ដែលមានឫសចាក់ទៅរកទឹកហូរវាមិនខ្លាចកម្តៅ ហើយស្លឹករបស់វានៅខៀវខ្ចីជានិច្ច។ នៅពេលរាំងស្ងួត វាមិនព្រួយបារម្ភអ្វីទេ គឺវានៅតែបង្កើតផ្លែផ្កាដដែល។
[9]ចិត្តរបស់មនុស្សតែងតែវៀចវេរ មិនអាចកែតម្រង់បានឡើយ។ ហើយតើនរណាអាចមើលចិត្តឆ្លុះនេះបាន?[10]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងឈ្វេងយល់ជម្រៅចិត្ត
របស់មនុស្ស។ យើងនឹងតបស្នងឲ្យមនុស្សម្នាក់ៗ តាមកិរិយាមារយាទរបស់ខ្លួន និងតាមអំពើ ដែលខ្លួនបានប្រព្រឹត្ត។[11]អ្នកដែលរកបានទ្រព្យសម្បត្តិដោយអយុត្តិធម៌ ប្រៀប
បាននឹងសត្វទទាក្រាបស៊ុតសត្វដទៃ។ នៅពេលពាក់កណ្តាលអាយុ ទ្រព្យសម្បត្តិនឹងចាកចេញពីអ្នកនោះទៅ ហើយនៅទីបញ្ចប់ គេក្លាយទៅជាមនុស្សមិនដឹងខុសត្រូវ»។
[12]កន្លែងទីបរិសុទ្ធរបស់យើងជាបល្ល័ង្កឧត្តុងឧត្តម ដែលបាន តម្កល់នៅខ្ពស់ ចាប់តាំងពីដើមមក។[13]ព្រះជាម្ចាស់ ជាទីសង្ឃឹមនៃជនជាតិអ៊ីស្រាអែលអើយ អ្នកណាដែល
បោះបង់ព្រះអង្គ នោះនឹងត្រូវខ្មាស អស់អ្នកដែលថយចេញពីព្រះអង្គ នោះនឹងមានឈ្មោះកត់ទុកនៅស្ថានក្រោម ដោយព្រោះគេបានបោះបង់ព្រះអម្ចាស់ ដែលជាប្រភពទឹក
រស់។[14]ព្រះជាម្ចាស់ សូមប្រោសទូលបង្គំឲ្យជាផង នោះទូលបង្គំនឹងបានជា! សូមជួយសង្គ្រោះទូលបង្គំ នោះទូលបង្គំនឹងបានរួច។ ដ្បិតព្រះអង្គជាទីសរសើររបស់ទូលបង្គំ។
[15]មើល៍! គេសួរទូលបង្គំថា៖ តើព្រះបន្ទូលនៃព្រះអម្ចាស់ នៅឯណា? សូមឲ្យវាមកឥឡូវចុះ![16]ទូលបង្គំមិនបានរត់គេចពីការធ្វើជា គង្វាលតាមព្រះអង្គឡើយ ក៏មិនបានប្រាថ្នា
ឲ្យថ្ងៃវេទនានោះមកដែរ ព្រះអង្គជ្រាបហើយពាក្យដែលចេញពីបបូរមាត់ទូលបង្គំ។ ពួកគេសុទ្ធតែនៅចំពោះព្រះអង្គទាំងអស់។
[17]សូមព្រះអង្គកុំបំភ័យទូលបង្គំ ព្រះអង្គជាទីពឹងជ្រកនៃទូលបង្គំក្នុងថ្ងៃអាក្រក់។[18]សូមឲ្យពួកអ្នកដែលបៀតបៀនដល់ទូល បង្គំត្រូវអៀនខ្មាស។ តែកុំឲ្យទូលបង្គំត្រូវខ្មាស
ឡើយសូមឲ្យគេត្រូវស្រយុតចិត្តទៅ។ តែកុំឲ្យទូលបង្គំត្រូវស្រយុតចិត្តអីសូមនាំថ្ងៃអាក្រក់នោះឲ្យមកលើគេ ហើយបំផ្លាញគេ ដោយការបំផ្លាញទ្វេដងទៅ»។
[19]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «ចូរទៅឈរនៅមាត់ “ទ្វារប្រជាជន” ជាទ្វារដែលស្តេចទឹកដីយូដាតែងតែចេញចូល និងទ្វារទាំងប៉ុន្មានទៀតនៅក្រុងយេរូសាឡឹម។
[20]ចូរប្រកាសប្រាប់ពួកគេថា ព្រះមហាក្សត្រ និងប្រជាជនយូដាទាំងមូល ព្រមទាំងអ្នកក្រុងយេរូសាឡឹមទាំងអស់ ដែលចេញចូលតាមទ្វារទាំងនេះអើយ ចូរស្តាប់ព្រះបន្ទូល
របស់ព្រះអម្ចាស់។
[21]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន! កុំលីសែងអ្វីនៅថ្ងៃសប្ប័ទឡើយ ហើយក៏កុំយករបស់ទាំងនោះឆ្លងកាត់ទ្វារក្រុងយេរូសាឡឹមដែរ។[22]កុំលីសែងអ្វី
ចេញពីផ្ទះរបស់អ្នករាល់គ្នា នៅថ្ងៃសប្ប័ទ គឺកុំធ្វើការអ្វីទាំងអស់។ ត្រូវញែកថ្ងៃសប្ប័ទទុកសម្រាប់យើង ដូចយើងបានបង្គាប់ដូនតារបស់អ្នករាល់គ្នាស្រាប់ហើយ»។[23]តែពួក
គេពុំបានត្រងត្រាប់ស្តាប់យើងទេ ពួកគេតាំងចិត្តរឹងរូស មិនព្រមស្តាប់ មិនព្រមទទួលមេរៀនសោះ។
[24]ព្រះអម្ចាស់មានព្រះបន្ទូលទៀតថា៖ ចំណែកអ្នករាល់គ្នាវិញ ប្រសិនបើអ្នករាល់គ្នាយកចិត្តទុកដាក់ស្តាប់យើង មិនលីសែងអ្វីកាត់តាមទ្វារក្រុងនេះ ហើយញែកថ្ងៃសប្ប័ទ
ទុកសម្រាប់យើង ដោយមិនធ្វើការអ្វីទាំងអស់នៅថ្ងៃនោះទេ[25]ស្តេចទាំងឡាយដែលស្នងរាជ្យដាវីឌនឹងជិះរទេះ ជិះសេះកាត់ទ្វារក្រុងនេះតទៅមុខទៀត ដោយមានមេដឹកនាំ
ព្រមទាំងប្រជាជនយូដា និងអ្នកក្រុងយេរូសាឡឹមហែហម ហើយនឹងមានមនុស្សរស់នៅក្នុងក្រុងយេរូសាឡឹមតទៅមុខទៀត។
[26]ប្រជាជននឹងនាំគ្នាមកពីក្រុងនានាក្នុងទឹកដីយូដា តំបន់ជិតខាងក្រុងយេរូសាឡឹម ទឹកដីបេនយ៉ាមីន ទឹកដីដែលនៅខាងលិចជើងភ្នំ ព្រមទាំងតំបន់ភ្នំ និងតំបន់ណេកិប
ដើម្បីនាំយកតង្វាយដុតទាំងមូល យញ្ញបូជា តង្វាយផ្សេងៗ និងគ្រឿងក្រអូប មកថ្វាយ ដើម្បីអរព្រះគុណព្រះអម្ចាស់ នៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។[27]ប៉ុន្តែ ប្រសិន
បើអ្នករាល់គ្នាមិនស្តាប់យើង ដោយមិនញែកថ្ងៃសប្ប័ទទុកសម្រាប់យើង គឺអ្នករាល់គ្នាលីសែងអ្វីកាត់ទ្វារក្រុងយេរូសាឡឹមនៅថ្ងៃសប្ប័ទ នោះយើងនឹងធ្វើឲ្យមានភ្លើងឆេះ
កម្ទេចទ្វារក្រុងនេះ ព្រមទាំងឆេះបំផ្លាញវិមាននៅក្រុងយេរូសាឡឹមទៀតផង ភ្លើងនោះនឹងមិនរលត់ឡើយ»។

Jeremiah 17:1
ព័ត៌មានទូទៅ:
សូមមើល: និង
អំពើបាបរបស់ជនជាតិយូដា មានចារឹកទុកដូចអក្សរ...នៅលើជ្រុងអាសនៈរបស់ពួកគេ
ការពិតដែលថាមនុស្សមិនដែលឈប់ប្រព្រឹត្តអំពើបាបដដែល
ធ្វើឲ្យវាហាក់ដូចជាកំណត់ត្រានៃអំពើបាបទាំងនោះត្រូវបានឆ្លាក់លើដួងចិត្ត
និងអាសនៈរបស់រូបព្រះរបស់គេ។
អំពើបាបរបស់ជនជាតិយូដា មានចារឹកទុក
ឃ្លានេះអាចត្រូវបានបញ្ជាជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ជនជាតិយូដា បានចារឹកទុកអំពើបាបរបស់ពួកគេ»
វាបានឆ្លាក់
ឃ្លានេះអាចត្រូវបានបញ្ជាជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានឆ្លាក់វា»
ឆ្លាក់នៅលើសិលាចារឹកនៃចិត្តរបស់ពួកគេ
ទម្លាប់នៃអំពើបាបបានជ្រួលជ្រាបរបស់ប្រជាជនត្រូវបានគេថ្លែងថា
អំពើបាបរបស់ពួកគេត្រូវបានឆ្លាក់លើដួងចិត្តនិងគំនិតរបស់ពួកគេផ្ទាល់។ ពាក្យថា
«ចិត្ត» សំដៅទៅលើមនុស្សទាំងមូល ទាំងគំនិត អារម្មណ៍
និងសកម្មភាពរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ឆ្លាក់រូបមនុស្សរបស់ពួកគេ»
នៅលើស្នែងនៃអាសនៈរបស់ពួកគេ
ពាក្យថា «ស្នែង» សំដៅទៅលើការការឆ្លុះបញ្ចាំងនៅលើជ្រុងនៃអាសនៈ។
នៅលើជ្រលងភ្នំដែលខ្ពស់។
នៅក្នុងកំណែរទម្រង់ថ្មីមួយចំនួន
បានបន្ថែមឃ្លាទីមួយនៃខគម្ពីរខាងក្រោមទៅឃ្លានេះ ដោយបកប្រែថា
«នៅលើជ្រលងភ្នំដែលខ្ពស់ៗ និងភ្នំនៅលើដីវាលដ៏ធំធេង»។
Jeremiah 17:3

generated on Wed Sep 10 16:16:32 2025

ធនធាន និងទ្រព្យសម្បត្តិរបស់អ្នក ព្រមទាំងទីខ្ពស់ទាំងប៉ុន្មានរបស់អ្នក
ពាក្យថា «ភាពមានបាន» និង «ទ្រព្យសម្បត្តិ» មានន័យដូចគ្នា
ហើយសំដៅលើវត្ថុដែលពួកគេគិតថាមានតម្លៃ។
ពួកលួចប្លន់
នេះសំដៅលើរបស់របរដែលពួកមនុស្សលួច ឬដណ្តើមដោយបង្ខំ។
អំពើបាបដែលប្រព្រឹត្តនៅទឹកដីរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «អំពើបាបរបស់អ្នកនៅគ្រប់ទីកន្លែង»
មរតក
នេះសំដៅលើទឹកដីអ៊ីស្រាអែល។
អ្នករាល់គ្នាបានបញ្ឆេះភ្លើងកំហឹងរបស់យើង ហើយនឹងឆេះ
ព្រះអម្ចាស់ប្រៀបធៀបការជំនុំជម្រះរបស់ទ្រង់ទៅនឹងភ្លើងដែលឆេះ។
ការបកប្រែរបៀបផ្សេងទៀត: «យើងបានខឹង ដោយព្រោះអ្នកបានដុតភ្លើង
នឹងធ្វើឲ្យខ្លួនអ្នកឆេះឡើង»
Jeremiah 17:5
អ្នកណាទុកចិត្តលើមនុស្សគឺត្រូវបណ្តាសាហើយ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងដាក់បណ្តាសាអ្នកណាដែលទុកចិត្តលើមនុស្ស»
គេពឹងលើសាច់ឈាមជាកម្លាំងគេ
ពាក្យថា «សាច់ឈាម» នៅទីនេះសំដៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«គេពឹងលើតែសាច់ឈាមជាកម្លាំងរបស់គេ»
ចិត្តគេវិញបែរចេញពីព្រះអម្ចាស់
ពាក្យថា «ចិត្ត» សំដៅលើគំនិត និងអារម្មណ៍។ ការបកប្រែរបៀបផ្សេងទៀត:
«ភក្តីភាពរបស់គេចំពោះព្រះអម្ចាស់ត្រូវបានបែរចេញ»
ប្រៀបបាននឹងព្រៃឈើតូចៗ
មនុស្សជឿលើមនុស្សជាងជឿលើព្រះអម្ចាស់ដូចជាដើមឈើព្យាយាមដុះនៅលើទឹកដីដែលស្ងួតហួតហែង
ដីដែលគ្មានអ្វីដុះ
ការបកប្រែរបៀបផ្សេងទៀត: «គេនឹងឥតប្រយោជន៍ដូចព្រៃឈើតូចៗ
នៅវាលរហោស្ថាន»
Jeremiah 17:7
នោះដូចជាដើមឈើ ដែលដុះនៅក្បែរផ្លូវទឹក
អ្នកណាដែលទុកចិត្តលើព្រះអម្ចាស់ អ្នកនោះមុខជាមានភាពរីកចម្រើនឡើង
ដូចជាដើមឈើដែលដុះនៅតាមផ្លូវទឹក។ ហើយវាមិនរងគ្រោះឡើយ
នៅពេលគ្មានភ្លៀង។
វានឹងមិនត្រូវកម្តៅដែលនឹងមកដល់ឡើយ
«វានឹងមិនត្រូវបានរំខានដោយកម្តៅដោយអាកាសធាតុក្តៅដែលនឹងមកដល់ឡើយ»
វាមិនបារម្ភ
«វានឹងមិនមានការព្រួយបារម្ភឡើយ»
Jeremiah 17:9
ចិត្តរបស់មនុស្សតែងតែវៀចវេរ
ពាក្យថា «ចិត្ត» នៅទីនេះសំដៅលើ សតិ និងគំនិតរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «គំនិតរបស់មនុស្សគឺពេញដោយការបោកប្រាស់»
តើនរណាអាចមើលចិត្តឆ្លុះនេះបាន?
អ្នកនិយាយប្រើសំនួរនេះដើម្បីថា
គ្មាននរណាម្នាក់អាចយល់បានពីចិត្តរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មាននរណាអាចយល់ពីការនេះបាន»។
យើងស្វែងយល់ជម្រៅចិត្ត
អារម្មណ៍ត្រូវបានគេនិយាយប្រៀបដូចជា ពួកគេស្ថិតនៅកណ្តាលដួងចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «ជាអ្នកល្បងលបំណងប្រាថ្នារបស់មនុស្ស»
ធ្វើរាងខ្លួន
ឃ្លានេះសំដៅលើអាកប្បកិរិយារបស់មនុស្ស
ដែលប្រៀបបានដូចជាផ្លូវដែលជាទម្លាប់របស់គេបានដើរ។
ផលដែលប្រព្រឹត្តរបស់ពួកគេ
ឃ្លានេះសំដៅលើ លទ្ធផលដែលគេបានប្រព្រឹត្ត
ដែលប្រៀបបានដូចជាពួកគេជាផលផ្លែនៃដើមឈើនោះ។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលពួកគេបានប្រព្រឹត្ត»
សត្វមាន់ក្រាបពូងគឺវាមិនបានដេកឡើយ។ អ្នកខ្លះអាចក្លាយទៅជាអ្នកមានដោយមិនត្រឹមត្រូវ
ការប្រៀបធៀបសត្វស្លាបមួយប្រភេទ ដែលក្រាបពងជាមួយសត្វបក្សីផ្សេងទៀត
គឺចង់បង្ហាញពីអ្នកមានម្នាក់ដែលរកលុយដោយប្លន់ពីអ្នកដទៃ។
ពេលពាក់កណ្តាលអាយុរបស់គេបានកន្លងទៅ
ពាក្យថា «អាយុ» សំដៅលើជីវិតរស់នៅទាំងមូលរបស់គេ។
ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលគេបានរស់នៅពាក់កណ្តាលនៃជីវិតរបស់គេ»
ទ្រព្យសម្បត្តិនឹងចាកចេញពីអ្នកនោះទៅ
ទ្រព្យសម្បត្តិត្រូវបានប្រៀបដូចជា ទាសករដែលនឹងបោះបង់ម្ចាស់របស់គេ។
ការបកប្រែរបៀបផ្សេងទៀត: «គេនឹងបាត់បង់ទ្រព្យសម្បត្តិរបស់គេ»
នៅទីបញ្ចប់
«ទីបញ្ចប់នៃជីវិតគេ»
គេក្លាយទៅជាមនុស្សល្ងីល្ងើ
«គេនឹងត្រូវបានបង្ហាញថា គេជាមនុស្សល្ងីល្ងើ»
Jeremiah 17:12
ទីកន្លែងដំណាក់របស់យើង គឺជាបល្ល័ង្កពេញដោយសិរី
លោកយេរេមាប្រៀបធៀប ដំណាក់របស់ទ្រង់ទៅជា «បល្ល័ង្កពេញដោយសិរី»
ព្រោះជាទីកន្លែងដែលព្រះអម្ចាស់គង់នៅ និងគ្រប់គ្រង។
ទីកន្លែងដំណាក់របស់យើង
នេះសំដៅលើ ភ្នំស៊ីយ៉ូន ក្នុងក្រុងយេរូសាឡិម។
អស់អ្នកណាដែលបោះបង់អ្នក
ពាក្យថា «អ្នក» សំដៅលើព្រះអម្ចាស់។
អស់អ្នកណាដែលនៅដែនដីនេះបែរចេញអ្នក នោះនឹងត្រូវកាត់ចេញ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងបោះបង់អស់អ្នកណាដែលបែរចេញពីអ្នក»
ប្រភពនៃទឹករស់
លោកយេរេមាប្រៀបធៀបព្រះអម្ចាស់ទៅនឹងប្រភពទឹកដ៏បរិសុទ្ធ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រភពទឹកដ៏បរិសុទ្ធ ដែលហូររហូត» ឬ
«ប្រភពនៃជីវិតទាំងអស់»
សូមជួយសង្គ្រោះទូលបង្គំ ហើយទូលបង្គំនឹងបានសង្គ្រោះ
ការបកប្រែរបៀបផ្សេងទៀត:
«ទ្រង់បានព្យាបាលទូលបង្គំ...ហើយទ្រង់ក៏បានជួយសង្គ្រោះទូលបង្គំ»
ទំនុកតម្កើងនៃទូលបង្គំ
«ទ្រង់តែមួយគត់ដែលទូលបង្គំលើកតម្កើង»
Jeremiah 17:15
មើល៍!
ការបកប្រែរបៀបផ្សេងទៀត: «ចូរមើល» ឬ «ចូរស្តាប់» ឬ
«ចូរយកចិត្តទុកដាក់នូវអ្វីដែលខ្ញុំនឹងថ្លែងប្រាប់អ្នក»
គេសួរទូលបង្គំថា
ពាក្យថា «ទូលបង្គំ» សំដៅទៅលើ លោកយេរេមា ហើយពាក្យថា «ពួកគេ»
សំដៅទៅលើខ្មាំងសត្រូវរបស់លោក។
តើព្រះបន្ទូលនៃព្រះអម្ចាស់នៅឯណា?
ប្រជាជនប្រើសំណួរនេះ ដើម្បីសើចចំអកលោកយេរេមា
ពីព្រោះរឿងដែលលោកបានថ្លែងប្រាប់មិនទាន់បានកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត:
«តើអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលអ្នកនឹងកើតឡើងនៅកន្លែងណា?» ឬ
«អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលអ្នកថានឹងកើតឡើងតែមិនកើតឡើងទេ»។
សូមឲ្យវាមកចុះ!
ការបកប្រែរបៀបផ្សេងទៀត: «ទុកឲ្យការនោះបានកើតឡើង»
គង្វាលតាមព្រះអង្គ
ព្រះអម្ចាស់បានហៅលោកយេរេមាដើម្បីគ្រប់គ្រងមនុស្ស
ដូចជាអ្នកគង្វាលដឹកសត្វចៀមរបស់ខ្លួនឯង។
ទូលបង្គំក៏មិនរង់ចាំ
«ទូលបង្គំមិនមានបំណងប្រាថ្នាឡើយ»
ពាក្យដែលប្រកាសចេញពីបបូរមាត់ទូលបង្គំ
ការបកប្រែរបៀបផ្សេងទៀត: «ពាក្យប្រកាសចេញពីការថ្លែងពីទូលបង្គំ» ឬ
«ទូលប្រកាសពីការទាំងនោះ»
ពួកគេសុទ្ធតែនៅ
ការបកប្រែរបៀបផ្សេងទៀត: «ទូលបង្គំធ្វើឲ្យពួកគេ»
Jeremiah 17:17
ថ្ងៃទុក្ខវេទនា
ពាក្យថា «ថ្ងៃ»
តំណាងឲ្យរយៈពេលដែលការជំនុំជំរះរបស់ព្រះអម្ចាស់នឹងកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងពេលមានទុក្ខវេទនា»

generated on Wed Sep 10 16:16:32 2025

សូមឲ្យពួកអ្នកដែលបៀតបៀនដល់ទូលបង្គំត្រូវអាម៉ាស់។ សូមឲ្យគេអស់សង្ឃឹម តែកុំឲ្យទូលបង្គំអស់សង្ឃឹម
ការបកប្រែរបៀបផ្សេងទៀត:
«នាំមកនូវភាពអាម៉ាស់ដល់ពួកអ្នកបៀតបៀនទូលបង្គំ
តែមិនត្រូវនាំភាពអាម៉ាស់ដល់ទូលបង្គំឡើយ»
សូមឲ្យគេអស់សង្ឃឹម តែកុំឲ្យទូលបង្គំអស់សង្ឃឹម
ឃ្លានេះមានន័យថាដូចគ្នា និងឃ្លាមុនហើយត្រូវបានប្រើសម្រាប់ការសង្កត់ន័យ។
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យពួកគេភ័យខ្លាចខ្លាំង
ប៉ុន្តែកុំធ្វើឲ្យខ្ញុំភ័យខ្លាច» (សូមមើល: និង figs-activepassive)
ឲ្យគេខ្ជាត់ខ្ជាយ ជាមួយការបំផ្លាញទ្វេដង
ការបកប្រែរបៀបផ្សេងទៀត: «ឲ្យគេខ្ជាត់ខ្ជាយដោយបំផ្លាញទាំងស្រុង» ឬ
«បំផ្លាញពួកគេទ្វេដង»

Jeremiah 17:21

ប្រយោជន៍នៃជីវិតអ្នក
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីជាការការពារជីវិតរបស់អ្នក» ឬ
«ប្រសិនបើអ្នកឲ្យតម្លៃលើជីវិតអ្នក»
ពួកគេមិនស្តាប់យើងទេ ឬយកចិត្តទុកដាក់ទេ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ថា ពួកគេបដិសេធការស្តាប់។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបដិសេធការស្តាប់» ឬ
«ពួកគេបដិសេធការស្តាប់បង្គាប់»។

Jeremiah 17:24

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១:៧។
អ្នកដែលអង្គុយបល្ល័ង្ករបស់ដាវីឌ
សូមមើលពីរបៀបបកប្រែក្នុងជំពូក ១៣:១២។
ទីក្រុងនេះនឹងមានមនុស្សរហូតទៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងរស់នៅទីក្រុងនេះជារៀងរហូត»

Jeremiah 17:26

យើងនឹងធ្វើឲ្យមានភ្លើងឆេះកម្ទេចទ្វារក្រុងនេះ
«យើងនឹងដុតភ្លើងតាមទ្វាក្រុងយេរូសាឡិម»
ហើយភ្លើងមិនរលត់វិញឡើយ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សមិនអាចធ្វើការបន្លត់បានឡើយ»

---

18 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមាដូចតទៅនេះ:[2]«ចូរក្រោកឡើង ទៅផ្ទះរបស់ជាងស្មូន។ នៅទីនោះ អ្នកនឹងឮសេចក្តីដែលយើងប្រាប់អ្នកឲ្យដឹង»។
[3]ដូច្នេះ ខ្ញុំក៏ទៅផ្ទះរបស់ជាងស្មូន ហើយបានឃើញគាត់កំពុងសិតថូមួយនៅលើឈើក្រឡឹង។[4]ប៉ុន្តែ ពេលណាជាងស្មូនឃើញថូដែលគាត់កំពុងសូននៅក្នុងដៃមិនល្អ ដូច្នេះគាត់ក៏យកដីឥដ្ឋមកធ្វើថូមួយផ្សេងទៀត ដែលគាប់ភ្នែករបស់គាត់មកធ្វើ។
[5]ពេលនោះ ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖[6]«កូនចៅអ៊ីស្រាអែលអើយ! យើងនឹងប្រព្រឹត្តចំពោះអ្នករាល់គ្នាដូចជាងស្មូននេះដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ អ្នករាល់គ្នានៅក្នុងដៃយើង ដូចដីឥដ្ឋនៅក្នុងដៃរបស់ជាងស្មូន។[7]ជួនកាល យើងសម្រេចថា រម្លើង និងរលំប្រជាជាតិណាមួយ ឬនគរណាមួយឲ្យវិនាស។[8]ប្រសិនបើប្រជាជាតិណាមួយប្រព្រឹត្តអំពើអាក្រក់ ដែលនាំឲ្យយើងសម្រេចចិត្តដាក់ទោសគេ ហើយគេបែរជាលះបង់អំពើអាក្រក់នោះ យើងនឹងមិនធ្វើទោសពួកគេ តាមការសម្រេចរបស់យើងទេ។
[9]ក្នុងពេលផ្សេង យើងនឹងប្រកាសអំពី ការកសាង និងបណ្តុះបណ្តាលប្រជាជាតិណាមួយ ឬនគរណាមួយឡើង។[10]ប៉ុន្តែ ប្រសិនបើពួកគេមិនព្រមស្តាប់ពាក្យប្រៀនប្រដៅរបស់យើង ហើយបែរទៅប្រព្រឹត្តអំពើអាក្រក់ដែលទាស់ចិត្តយើង នោះយើងនឹងលែងប្រព្រឹត្តល្អចំពោះពួកគេ។
[11]ឥឡូវនេះ យេរេមាអើយ ចូរប្រាប់អ្នកទឹកដីយូដា និងអ្នកក្រុងយេរូសាឡឹមថា ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅនេះ៖ យើងកំពុងរៀបចំគម្រោងការដាក់ទោសអ្នករាល់គ្នា គឺយើងនឹងនាំគ្រោះកាចមួយមកលើអ្នករាល់គ្នា។ ដូច្នេះ ម្នាក់ៗត្រូវងាកចេញពីផ្លូវអាក្រក់របស់ខ្លួន ហើយកែប្រែ កិរិយាមារយាទឈប់ប្រព្រឹត្តបែបនេះតទៅមុខទៀត។[12]ប៉ុន្តែពួកគេនិយាយថា មិនបាច់និយាយទៀតទេ។ យើងនឹងធ្វើតាមគម្រោងការរបស់យើង ហើយយើងនឹងប្រព្រឹត្តតាមទំនើងចិត្តរបស់យើងតទៅមុខទៀត។
[13]ដូច្នេះ ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ ចូរសួរជនជាតិដទៃទាំងប៉ុន្មានចុះ តើដែល មានអ្នកណាឮនិយាយពីការយ៉ាងនេះឬទេ? នាងក្រមុំនៃពួកអ៊ីស្រាអែល បានប្រព្រឹត្តអំពើដ៏អាក្រក់បំផុត។[14]តើហិម:នៅលើភ្នំល្បាណូន លែងមានពីថ្មនៅស៊ីរានឬ? តើទឹកត្រជាក់ដែលហូរចុះមកពីទីឆ្ងាយ នឹងហួតបាត់ទៅឬ?
[15]ប៉ុន្តែរាស្ត្ររបស់យើង បានបំភ្លេចយើង។ គេបានដុតកំញានថ្វាយដល់ព្រះក្លែងក្លាយ ហើយគេត្រូវចំពប់ក្នុងផ្លូវរបស់ខ្លួន គឺជាផ្លូវពីចាស់បុរាណ ហើយដើរវាងតាមផ្លូវ ដែលមិនបានលើក គឺមិនដើរតាមផ្លូវធំសោះ[16]ដោយធ្វើឲ្យទឹកដីរបស់គេត្រឡប់ជាទីស្រឡាំងកាំង ហើយជាទីដែលធ្វើឲ្យមនុស្សហួសចិត្តជានិច្ច។ អស់អ្នកដែលដើរកាត់តាមនោះនឹងព្រឺសម្បុរ ហើយគ្រវីក្បាល។[17]យើងនឹងកម្ចាត់កម្ចាយគេនៅចំពោះពួកខ្មាំងសត្រូវ ហាក់ដូចជាមានខ្យល់ពីទិសខាងកើតផាត់ទៅ ឯយើងនឹងបែរខ្នងដាក់គេ មិនមែនបែរមុខមើលគេ ក្នុងវេលាដែល គេមានសេចក្តីវេទនានោះឡើយ»។
[18]មនុស្សបាននិយាយថា៖ «មក! យើងរៀបផែនការទាស់នឹងយេរេមា ដ្បិតក្រឹត្យវិន័យនឹងមិនដែលសូន្យបាត់ពីពួកសង្ឃ ឬសេចក្តីប្រឹក្សាពីពួកអ្នកប្រាជ្ញ ឬព្រះបន្ទូលពីពួកព្យាការីឡើយ។ មក! យើងនាំគ្នាវាយគាត់ដោយអណ្តាត ហើយកុំយកចិត្តទុកដាក់ស្តាប់តាមពាក្យណារបស់គាត់ឡើយ»។[19]ព្រះអម្ចាស់អើយ សូមព្រះអង្គប្រុងស្តាប់ទូលបង្គំ សូមស្តាប់ពាក្យរបស់ពួកអ្នកសត្រូវនៃទូលបង្គំ។[20]តើនឹងយកការអាក្រក់ស្នងនឹងការល្អឬ? ដ្បិតគេបានជីករណ្តៅ ដើម្បីចាប់ព្រលឹងទូលបង្គំហើយ។ សូមនឹកចាំពីទូលបង្គំ ដែលបានឈរនៅចំពោះព្រះអង្គដើម្បីសូមសេចក្តីល្អឲ្យគេ ហើយបំបែរសេចក្តីក្រោធរបស់ព្រះអង្គចេញពីគេដែរ។
[21]ដូច្នេះ សូមព្រះអង្គឲ្យកូនចៅគេជួបអំណត់ ហើយប្រគល់គេដល់អំណាចដាវ សូមឲ្យប្រពន្ធគេនៅជាឥតមានកូន និងជាមេម៉ាយ ហើយឲ្យពួកប្រុសៗរបស់គេត្រូវស្លាប់ និងពួកកំលោះៗ របស់គេត្រូវរបួសដោយដាវក្នុងសង្គ្រាម។[22]សូមឲ្យមានឮសម្រែកចេញពីផ្ទះគេ ក្នុងកាលដែលព្រះអង្គនាំពួកពលទ័ពមកលើគេភ្លាម ដ្បិតគេបានជីករណ្តៅដើម្បីនឹងចាប់ទូលបង្គំហើយបានលាក់អន្ទាក់ ដើម្បីទាក់ជើងទូលបង្គំផង។[23]ប៉ុន្តែ ព្រះអម្ចាស់អើយ ព្រះអង្គជ្រាបអស់ទាំងគំនិត ដែលគេប្រឹក្សាគ្នា ដើម្បីសម្លាប់ទូលបង្គំហើយ សូមព្រះអង្គកុំអត់ទោសចំពោះអំពើទុច្ចរិតរបស់គេឡើយក៏កុំលុបអំពើបាបរបស់គេពីចំពោះព្រះអង្គដែរ គឺឲ្យគេត្រូវដួលនៅចំពោះព្រះអង្គវិញ សូមព្រះអង្គសម្រេចដល់គេ ក្នុងវេលាដែលព្រះអង្គមានសេចក្តីក្រោធចុះ។

Jeremiah 18:1

នេះគឺជាព្រះបន្ទូលដែលមកកាន់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។
ផ្ទះរបស់ជាងស្មូន
ជាងស្មូនគឺជាអ្នកដែលធ្វើឆ្នាំង និងសំភារៈតូចៗដែលមានប្រយោជន៍ពីដីឥដ្ឋ។
ការបកប្រែរបៀបផ្សេងទៀត: «រោងជាងស្មូន»
មើល!
ពាក្យថា «មើល!» ដាស់តឿនយើងឲ្យស្គាល់មនុស្សថ្មីនៅក្នុងការនេះ។
ពាក្យរបស់អ្នកអាចមានលក្ខណៈបែបនេះ។
នៅលើកង់ក្រឡឹង
កង់ក្រឡឹងគឺជាតុតូចសម្រាប់បង្វិល ជាងស្មូនប្រើដើម្បីបង្កើតឆ្នាំង។
ការបកប្រែរបៀបផ្សេងទៀត: «នៅតុរបស់គេ» ឬ «ដើម្បីបង្កើតជាឆ្នាំង»
ស្មូន
«បង្កើតឡើង» ឬ «ធ្វើឲ្យចេញរូបរៀង»
បានខ្ទិចខ្ទីក្នុងដៃរបស់គាត់
ការបកប្រែរបៀបផ្សេងទៀត: «បែកដាច់ពីដាច់របស់គេ»
ដូច្នេះជាងស្មូនបានប្តូរគំនិត
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះគេបង្កើតជម្រើសផ្សេងពីគ្នា»
គាប់ភ្នែករបស់គាត់
គាប់ភ្នែកតំណាងឲ្យជាងស្មូនខ្លួនគាត់។ ការបកប្រែរបៀបផ្សេងទៀត:
«ចំណុចល្អរបស់គាត់»

Jeremiah 18:5

ព្រះបន្ទូលនៃព្រះអម្ចាស់មកដល់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។

generated on Wed Sep 10 16:16:32 2025

កូនចៅអ៊ីស្រាអែលអើយ! តើមិនគួរឲ្យយើងប្រព្រឹត្តដូចជាងស្មូននេះដល់អ្នកទេ?
ជាមួយនឹងសំណួរនេះ ព្រះអម្ចាស់សង្កត់ធ្ងន់លើសិទ្ធិអំណាចរបស់ទ្រង់
ក្នុងការប្រព្រឹត្ត ដូចដែលទ្រង់បានគាប់ចិត្តជនជាតិអ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំត្រូវបានអនុញ្ញាតឲ្យប្រព្រឹត្តចំពោះអ្នក
ដូចជាងស្មូនអនុវត្តជាមួយដីឥដ្ឋដែរ»
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
ចូរមើល!
ពាក្យថា «មើល៍» នៅទីនេះបញ្ជាក់ពីអ្វីដែលនឹងកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត: «ពិតប្រាកដ!»
ដូចដីឥដ្ឋនៅក្នុងដៃរបស់ជាងស្មូន គឺដូចដែលអ្នកនៅក្នុងដៃរបស់យើងដែរ
ឃ្លានេះត្រូវរំលឹកឡើងវិញ ក្នុងខ្លឹមសារសំខាន់ក្នុងឃ្លាមុនក្នុងលក្ខណៈប្រៀបធៀប។
យើងគួរប្រកាសពីអ្វីមួយ
ការបកប្រែរបៀបផ្សេងទៀត: «យើងអាចនឹងធ្វើការប្រកាសពីអ្វីមួយ» ឬ
«ជាឧទាហរណ៍ យើងនឹងប្រកាសពីអ្វីមួយ»
នឹងប្រហារគេហើយហែកវាឲ្យខ្ទិច
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយបញ្ជាក់លើការជំនុំជំរះរបស់ព្រះអម្ចាស់ពីការបំផ្លាញនោះ។
បន្ទន់ចិត្តពី
«ដកចេញ» ការបកប្រែរបៀបផ្សេងទៀត: «មិននាំយក»
Jeremiah 18:9
ការកសាង និងបណ្តុះបណ្តាល
ពាក្យកិរិយាសព្ទទាំងពីរនេះ មានន័យដូចគ្នា
ហើយបញ្ជាក់ពីការប្រទានពររបស់ព្រះអម្ចាស់។
បណ្តុះបណ្តាល
ឃ្លានេះប្រៀបធៀបពីការប្រទានពររបស់ព្រះអម្ចាស់
ដែលមានការប្រុងប្រយត្ន័ក្នុងការដាំនៅក្នុងសួនច្បារ។
អាក្រក់នៅមុខភ្នែកយើង
ព្រះនេត្ររបស់ព្រះអម្ចាស់សម្លឹងមើលដោយអង្គទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«ការដែលយើងគិតពិចារណាពីអំពើអាក្រក់» ឬ «អំពើអាក្រក់ដែលមកពីយើង»
មិនស្តាប់តាមសម្លេងរបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «មិនស្តាប់បង្គាប់បទបញ្ជាតិយើង» ឬ
«មិនយកចិត្តទុកពីអ្វីដែលយើងមានព្រះបន្ទូល»
Jeremiah 18:11
មើល៍
ការបកប្រែរបៀបផ្សេងទៀត: «ចូរក្រលេកមើល» ឬ «ចូរស្តាប់»
ឬ«ចូរយកចិត្តដាក់នូវអ្វីដែលយើងនឹងមានព្រះបន្ទូលប្រាប់អ្នក»
យើងជិតនឹងដាក់សេចក្តីមហន្តរាយទាស់នឹងអ្នក និងនឹកដល់ផែនការទាស់នឹងអ្នកដែរ
ប្រយោគទាំងពីរ
មានខ្លឹមសារដូចគ្នាដែលបញ្ជាក់ពីទុក្ខលំបាកអ្វីខ្លះពីការក្រើនរំលឹកនេះ។
ដាក់សេចក្តីមហន្តរាយ
ព្រះអម្ចាស់សំដៅលើសេចក្តីមហន្តរាយ ដែលទ្រង់បង្កើតឡើង
ប្រៀបដូចជាជាងស្មូនសូនដីឥដ្ឋ។ ការបកប្រែរបៀបផ្សេងទៀត:
«បង្កើតចេញជារូបរៀង» ឬ «បង្កើតឡើង»
នឹកដល់
«គិតពី» ឬ «មានផែនការ» ឬ «បង្កើត»
ផ្លូវអាក្រក់របស់ខ្លួន
ការបកប្រែរបៀបផ្សេងទៀត: «ផ្លូវនៃការរស់នៅដ៏អាក្រក់របស់ខ្លួន»
ផ្លូវហើយនិងការប្រព្រឹត្តរបស់អ្នក
ពាក្យថា «ផ្លូវ» និង «ការប្រព្រឹត្ត» មានន័យជាមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់ពីផ្លូវនៃជីវិតទាំងស្រុងត្រូវតែមានការផ្លាស់ប្តូរ»
ប៉ុន្តែពួកគេនឹងនិយាយថា
ពាក្យថា «ពួកគេ» សំដៅលើអ្នករស់នៅក្នុងស្រុកយូដា និងក្រុងយេរូសាឡិម។
ការនេះប្លើមិនកើតទេ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងលែងមានសង្ឃឹមហើយ»
តាមអ្វីដែលអាក្រក់ នឹងបំណងចិត្តរឹងរូស
មនុស្សដែលមានអារម្មណ៍ និងរូបកាយរួមជាមួយគ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយតាមបំណងចិត្តអាក្រក់របស់គេ»
Jeremiah 18:13
ចូរសួរជនជាតិទាំងឡាយចុះ តើដែលមានអ្នកណាធ្លាប់ឮនិយាយពីការយ៉ាងដូចនេះទេ?
សំណួរនេះតំណាងឲ្យខ្លឹមសារមួយ។ ការបកប្រែរបៀបផ្សេងទៀត: «នៅលើផែនដី
គ្មានទីកន្លែងណាដែលមនុស្សធ្លាប់បានលឺនិយាយពីការយ៉ាងដូចនេះ»។
នាងក្រមុំនៃពួកអ៊ីស្រាអែល
ការនេះជារឿងធម្មតា ដែលសំដៅទៅលើប្រជាជាតិនានាប្រៀបដូចជាពួកគេជាស្ត្រី។
ចំណែកឯពាក្យ «ក្រមុំ» ដែលមនុស្សម្នាក់ៗគិតពី
នារីវ័យក្មេងម្នាក់ដែលមិនធ្លាប់រៀបការហើយ
ក៏មិនដែលមានឱកាសមិនស្មោះត្រង់នឹងប្តីរបស់នាងដែរ។ ដូច្នេះ
ការហៅអ៊ីស្រាអែលថាជានាងក្រមុំ គឺជាការប្រើប្រាស់ពាក្យភាសាដែលប្រដូច។
ការបកប្រែរបៀបផ្សេងទៀត: «ជនជាតិអ៊ីស្រាអែល
ដែលក្លែងខ្លួនជាអ្នកថ្វាយខ្លួនចំពោះព្រះអម្ចាស់ក្លែងក្លាយ»
តើហិមៈនៅលើភ្នំល្បាណូន នឹងរលាយពីជ្រលងថ្មដោយខ្លួនវាឬ?
សំណួរនេះតំណាងឲ្យខ្លឹមសារមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ហិមៈនៅលើភ្នំល្បាណូន មិនដែលរលាយពីជ្រលងថ្មដោយខ្លួនឯងទេ»
តើទឹកត្រជាក់ដែលហូរចុះមកពីទីឆ្ងាយនឹងបំផ្លាញភាពត្រជាក់នៃទឹកនោះឬ?
សំណួរនេះតំណាងឲ្យខ្លឹមសារមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មានអ្វីដែលអាចបំផ្លាញទឹកត្រជាក់ដែលហូរចុះមកពីទីឆ្ងាយឡើយ»។
Jeremiah 18:15
ចំពប់ដួលក្នុងផ្លូវរបស់ខ្លួន
ពាក្យថា «ខ្លួន» សំដៅលើ «ប្រជារាស្ត្ររបស់យើង។»
ត្រឡប់ជាទីភ័យខ្លាច
ការបកប្រែរបៀបផ្សេងទៀត:
«នឹងប្រែក្លាយអ្វីមួយដែលធ្វើឲ្យមនុស្សមានការភ័យខ្លាច»
ទីគួរឲ្យអាសូរ
នេះជាសូរសំឡេងដែលបង្ហាញពីការមិនពេញចិត្តយ៉ាងខ្លាំង។
ដើរកាត់តាមនោះ
ពាក្យថា «តាមនោះ» សំដៅលើ «ទឹកដីពួកគេ»។
យើងនឹងកម្ចាត់កម្ចាយគេនៅចំពោះពួកខ្មាំងសត្រូវ ដូចជាមានខ្យល់ពីទិសខាងកើត
ព្រះអម្ចាស់ប្រៀបធៀបព្រះអង្គដែលបក់ខ្យល់ពីទិសខាងកើតដែលកម្ចាត់កម្ចាយធូលីដី
ហើយនឹងកំទេចកំទី។
កម្ចាត់កម្ចាយគេ
ពាក្យថា «គេ» សំដៅលើ «ប្រជារាស្ត្រយើង»។
យើងនឹងបែរខ្នងដាក់គេ ហើយមិនបែរមុខមើលគេទេ
សកម្មភាពនេះបង្ហាញពីអត្តសញ្ញាណដែលព្រះអម្ចាស់បដិសេធ
ដើម្បីជួយប្រជារាស្ត្ររបស់ព្រះអង្គ។
Jeremiah 18:18
យើងគម្រោងទាស់នឹងយេរេមា
«យើងមានផែនការទាស់នឹងលោកយេរេមា»
ក្រឹត្យវិន័យនឹងមិនដែលបាត់ចេញពីពួកបូជាចារ្យទេ ឬយោបល់ពីពួកអ្នកប្រាជ្ញា ឬព្រះបន្ទូលពីពួក
ព្យាការី
ការបកប្រែរបៀបផ្សេងទៀត: «បូជាចារ្យនឹងបង្កើតក្រឹត្យវិន័យ
ពួកអ្នកមានប្រាជ្ញានឹងផ្តល់យោបល់ជានិច្ច ហើយព្យាការីនឹងថ្លែងពីព្រះបន្ទូល»
វាយប្រហារគាត់ដោយពាក្យ
«ដោយនិយាយពីអ្វីដែលវាយប្រហារដល់គាត់»
ចូរយកចិត្តទុកដាក់ស្តាប់ពួកខ្ញុំ
ត្រង់ចំណុចនេះ លោកយេរេមាចាប់ផ្តើមថ្លែងពីព្រះអម្ចាស់។
តើការមហន្តរាយដែលមកពីពួកគេពិតជារង្វាន់ទូលបង្គំសម្រាប់ការល្អដល់ពួកគេឬ?
លោកយេរេមាសួរសំណួរនេះ ដើម្បីបញ្ជាក់ថាអំពើល្អៗ
មិនគួរត្រូវបានតបស្នងវិញជាមួយអំពើអាក្រក់ទេ។ ការបកប្រែរបៀបផ្សេងទៀត:
«គ្រោះមហន្តរាយពីពួកគេមិនគួរជារង្វាន់ខ្ញុំ សម្រាប់ការធ្វើល្អចំពោះពួកគេទេ»។
បានជីករណ្តៅសម្រាប់ទូលបង្គំហើយ
ការបកប្រែរបៀបផ្សេងទៀត: «ជីករណ្តៅដើម្បីដាក់អន្ទាក់លើទូលបង្គំ
ហើយសម្រាប់ទូលបង្គំ»
ដើម្បីធ្វើឲ្យសេចក្តីក្រោធរបស់ព្រះអង្គបែរចេញពីពួកគេដែរ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះព្រះអង្គនឹងមិនដាក់ទោសពួកគេដោយសេចក្តី
ក្រោធរបស់ព្រះអង្គឡើយ»
Jeremiah 18:21
ប្រគល់គេទៅក្រោមដៃនៃអ្នកប្រើដាវ
«ដាវ» តំណាងឲ្យសង្គ្រាម។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«នាំពួកគេឲ្យទៅស្លាប់នៅក្នុងសមរភូមិ»
ឲ្យប្រពន្ធពួកគេមិនអាចមានកូន ហើយមេម៉ាយ
«ទុកឲ្យកូនៗ និងប្តីរបស់នាងស្លាប់ទៅ»
ពួកប្រុសៗរបស់គេត្រូវស្លាប់ និងពួកកំលោះៗ របស់គេត្រូវស្លាប់ដោយដាវ
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេសម្លាប់ពួកប្រុសៗ
ហើយសម្លាប់ពួកកំលោះដោយដាវ»
សម្រែកនៃទុក្ខព្រួយចេញពី
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេលឺពីសម្រែកនៃទុក្ខព្រួយ»
ដ្បិតគេបានជីករណ្តៅ ដើម្បីនឹងចាប់ទូលបង្គំ ហើយបានដាក់អន្ទាក់ ដើម្បីជើងរបស់ ទូលបង្គំផង
សត្រូវរបស់លោកយេរេមាកំពុងព្យាយាមចាប់លោក
ប្រៀបដូចជាមនុស្សតាមចាប់សត្វព្រៃ។ លោកយេរេមាថ្លែងដដែល
នូវគំនិតដូចគ្នានេះពីរដងសម្រាប់ការសង្កត់ន័យ។
គេបានជីករណ្តៅ
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ១៨:១៨។
សូមកុំលាងអំពើបាបរបស់ពួកគេចេញពីព្រះអង្គឡើយ
ឃ្លានេះមានន័យថាដូចគ្នាក្នុងឃ្លាមុន។
ឲ្យគេត្រូវដួលនៅចំពោះព្រះអង្គវិញ
ការបកប្រែរបៀបផ្សេងទៀត: «ឲ្យគេដួលក្នុងព្រះវត្តមានទ្រង់»

19 [1]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ ចូរទៅទិញក្អមដីពីជាងស្មូនមក រួចនាំចាស់ទុំខ្លះក្នុងចំណោមប្រជាជន និងចាស់ទុំខ្លះក្នុងចំណោមពួកសង្ឃមកជាមួយអ្នក។
[2]ហើយចេញទៅច្រកភ្នំនៃកូនចៅហ៊ីនណម ដែលនៅត្រង់មុខទ្វារចូលហារស៊ីត ហើយប្រកាសប្រាប់ពាក្យទាំងប៉ុន្មាននៅទីនោះ ដែលយើងនឹងប្រាប់ដល់អ្នក។[3]ត្រូវប្រាប់ថា៖ ពួកស្តេចទឹកដីយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះអង្គចុះ ព្រះអង្គជាព្រះនៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា «មើល៍! យើងនឹងនាំសេចក្តីអាក្រក់មកលើទីនេះ ដែលអ្នកណាឮ នោះនឹងខ្ទរត្រចៀក។
[4]យើងធ្វើការទាំងនេះ ដោយគេបានបោះបង់យើង ហើយបានបង្អាប់ទីនេះ ព្រមទាំងដុតកំញានៅទីនេះថ្វាយដល់ព្រះដទៃ ជាព្រះដែល ទោះទាំងខ្លួនគេ បុព្វបុរសគេ ឬពួកស្តេចជនជាតិយូដា ក៏មិនបានស្គាល់ផង ហើយបានធ្វើឲ្យទីនេះពេញដោយឈាមមនុស្ស ដែលឥតមានទោសដែរ។[5]ពួកគេបានស្អាងអស់ទាំងទីខ្ពស់របស់ព្រះបាលសម្រាប់ដុតកូនប្រុសៗរបស់គេ ទុកជាតង្វាយដុតថ្វាយព្រះបាល ជាការដែលយើងមិនបានបង្គាប់ដល់គេ ឬនិយាយឡើយ ក៏មិនបានចូលក្នុងគំនិតយើងដែរ។
[6]ដូច្នេះ ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ នឹងមានគ្រាមកដល់ ដែលគេលែងហៅទីនេះថា តូផែត ឬច្រកភ្នំរបស់កូនចៅហ៊ីនណមទៀត គឺនឹងហៅថា ច្រកភ្នំសម្លេះវិញ។[7]គ្រានោះ យើងនឹងធ្វើឲ្យសេចក្តីប្រឹក្សារបស់ពួកទឹកដីយូដា និងក្រុងយេរូសាឡិមបាត់ពីទីនេះ ព្រមទាំងធ្វើឲ្យគេដួលដោយដាវ នៅមុខពួកខ្មាំងសត្រូវរបស់គេ ហើយដោយដៃនៃពួកអ្នកដែលរកជីវិតគេផង យើងនឹងប្រគល់សាកសពរបស់គេដល់សត្វហើរលើអាកាស និងសត្វជើងបួននៅផែនដីធ្វើជាអាហារ។[8]យើងនឹងធ្វើឲ្យទីក្រុងនេះទៅជាទីស្រឡាំងកាំង ហើយជាទីដែលគេនឹងធ្វើស៊ីសស៊ូស អ្នកណាដែលដើរមកជិត គេនឹងភាំងឆ្ងល់ ហើយនឹងធ្វើស៊ីសស៊ូស ដោយព្រោះគ្រប់ទាំងសេចក្តីវេទនារបស់ក្រុងនេះ។
[9]យើងនឹងធ្វើឲ្យគេស៊ីសាច់កូនប្រុសកូនស្រីរបស់ខ្លួន ហើយគ្រប់គ្នានឹងស៊ីសាច់ភឿនមិត្តរបស់ខ្លួន ក្នុងគ្រាដែលពួកខ្មាំងឡោមព័ទ្ធ ហើយក្នុងសេចក្តីវេទនា ដែលពួកខ្មាំងសត្រូវនឹងធ្វើដល់គេ ដើម្បីរកប្រហារជីវិតគេ»។
[10]បន្ទាប់មក អ្នកត្រូវបំបែកក្អមនោះ នៅមុខពួកមនុស្សដែលបានទៅជាមួយអ្នក។[11]ហើយត្រូវប្រាប់ដល់គេថា៖ ព្រះអម្ចាស់នៃពិភពលោក ព្រះអង្គមានព្រះបន្ទូលដូច្នេះថា គឺបែបយ៉ាងនេះ ដែលយើងនឹងបំបែកបំបាក់ជនជាតិនេះ និងទីក្រុងនេះផង គឺដូចជាអ្នកណាបំបែកក្អមរបស់ជាងស្មូន ឲ្យផ្ទុំឡើងវិញមិនបានដែរ ហើយមនុស្សនឹងបញ្ចុះសពគេនៅត្រង់តូផែត ទាល់តែគ្មានកន្លែងទៀត។
[12]ព្រះអម្ចាស់បានប្រកាសថា៖ យើងនឹងធ្វើដូច្នេះដល់ទីនេះ ហើយដល់ពួកអ្នកដែលអាស្រ័យនៅ គឺនឹងធ្វើឲ្យទីក្រុងនេះត្រឡប់ទៅដូចជាតូផែត។[13]អស់ទាំងផ្ទះនៅក្រុងយេរូសាឡិម និងដំណាក់នៃស្តេចទឹកដីយូដាទាំងប៉ុន្មាន ដែលគេបានធ្វើឲ្យស្មោកគ្រោកហើយ នោះនឹងបានដូចជាទីតូផែតនេះដែរ គឺអស់ទាំងផ្ទះណាដែលគេបានឡើងទៅលើដំបូល ដើម្បីដុតកំញានថ្វាយដល់ពួកពលបរិវារនៅលើមេឃ ហើយច្រួចតង្វាយថ្វាយដល់ព្រះដទៃនោះ»។
[14]ព្យាការីយេរេមាក៏វិលមកពីតូផែត ជាកន្លែងដែលព្រះជាម្ចាស់បានចាត់ឲ្យលោកទៅថ្លែងទំនាយនោះ លោកក៏ឈរនៅទីលានព្រះវិហារនៃព្រះអម្ចាស់ មានប្រសាសន៍ដល់បណ្តាជនទាំងឡាយថា[15]«ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ មើល៍! យើងនឹងនាំគ្រប់ទាំងសេចក្តីអាក្រក់មកលើក្រុងនេះ និងអស់ទាំងតំបន់នៅជុំវិញ ដូចជាយើងបានប្រកាសប្រាប់ទាស់នឹងគេ ពីព្រោះគេបានតាំងចិត្តរឹងរូស ដើម្បីមិនឲ្យឮពាក្យរបស់យើងឡើយ»។

Jeremiah 19:1
ច្រកភ្នំនៃកូនចៅហ៊ីនណម
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ៧:៣១។
មើល៍
ការបកប្រែរបៀបផ្សេងទៀត: «ចូរស្តាប់» ឬ
«ចូរយកចិត្តទុកដាក់នូវអ្វីដែលយើងនឹងថ្លែងប្រាប់អ្នក»
ហើយអ្នកណាដែលឮពីរនឹងខ្ទរត្រចៀក
ការបកប្រែរបៀបផ្សេងទៀត: «ការនេះនឹងធ្វើឲ្យអ្នករាល់គ្នាភ័យរន្ធត់ ដែលបានលឺ»
Jeremiah 19:4
ដោយគេបានបោះបង់យើង
ពាក្យថា «គេ» សំដៅលើប្រជាជនយូដា។
ធ្វើឲ្យទីនេះពេញដោយឈាមនៃមនុស្ស ដែលគ្មានទោស
ការបកប្រែរបៀបផ្សេងទៀត: «សម្លាប់ពួកមនុស្សដែលគ្មានទោសនៅទីនេះ»
ជាអ្វីដែលយើងមិនបានបង្គាប់
ការបកប្រែរបៀបផ្សេងទៀត: «ជាអ្វីដែលយើងហាមឃាត់គេមិនឲ្យធ្វើ»
ក៏មិនដែលមានក្នុងគំនិតយើងដែរ
ពាក្យថា «គំនិត» នៅទីនេះសំដៅលើ ព្រះបញ្ញាញាណរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ឬក៏យើងមិនបានគិតពីការនេះ»
Jeremiah 19:6
មើល៍
ការបកប្រែរបៀបផ្សេងទៀត: «ចូរស្តាប់» ឬ
«ចូរយកចិត្តទុកដាក់នូវអ្វីដែលយើងនឹងថ្លែងប្រាប់អ្នក»
នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ១:៧។
ទីនេះគេនឹងលែងហៅថា
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនឹងលែងហៅទីកន្លែងនេះ»
តូផែត ជ្រលងភ្នំរបស់ហ៊ីនណម តែគេនឹងហៅថាជ្រលងភ្នំនៃការសម្លាប់
សូមមើលពីរបៀបបកប្រែឈ្មោះទាំងនេះក្នុងជំពូក ៧:៣១។
យើងនឹងធ្វើឲ្យគេដួលដោយដាវ នៅមុខពួកខ្មាំងសត្រូវរបស់គេ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងឲ្យសត្រូវរបស់គេសម្រាប់ពួកគេដោយដាវ»
ដោយដៃនៃពួកអ្នកដែលស្វែងរកជីវិតគេ
ឃ្លានេះមានន័យថាមានមូលដ្ឋានដូចគ្នានឹងឃ្លាមុនដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងអនុញ្ញាតឲ្យអ្នកដែលចង់សម្លាប់ពួកគេសម្លាប់ពួកគេ»
អាសូរ
សំលេង អក្សរ «ស» ដែលបង្ហាញពីការមិនពេញចិត្តខ្លាំង។
យើងនឹងធ្វើឲ្យគេស៊ី
«យើងនឹងធ្វើឲ្យអ្នកដែលរស់នៅក្រុងយេរូសាឡិមស៊ី»
Jeremiah 19:10
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក១:៧។
វានឹងមិនអាចជួលជុលវិញបានទេ
ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្នកណាដែលអាចជួសជុលវិញបានទេ»
Jeremiah 19:12
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ១:៧។
ហើយស្តេចនៃយូដា
ការបកប្រែរបៀបផ្សេងទៀត: «ហើយដំណាក់ស្តេចនៃយូដា»
Jeremiah 19:14
មើល៍

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «ចូរស្តាប់» ឬ
«ចូរយកចិត្តទុកដាក់នូវអ្វីដែលយើងនឹងថ្លែងប្រាប់អ្នក»
មានករឹងរូស ហើយមិនព្រមស្តាប់ពាក្យរបស់យើង

ឃ្លាថា «មិនព្រមស្តាប់» មានន័យជាមូលដ្ឋានដូចគ្នានិងពាក្យ «ករឹងរូស»
ហើយបង្ហាញពីមនុស្សបានប្រព្រឹត្តដូច្នេះ។

---

20 [1]ពេលលោកផាសហ៊ើរ ជាកូនរបស់សង្ឃអ៊ីមមើរ ដែលជានាយកធំក្នុងព្រះវិហារនៃព្រះជាម្ចាស់ បានថាព្យាការីយេរេមាកំពុងថ្លែងទំនាយសេចក្តីទាំងនេះ។
[2]ដូច្នេះលោកផាសហ៊ើរក៏វាយព្យាការីយេរេមា ហើយយកទៅដាក់គុក ដែលនៅត្រង់ទ្វារបេនយ៉ាមីនខាងលើ កំផែងរបស់ព្រះវិហារនៃព្រះជាម្ចាស់។
[3]លុះថ្ងៃបន្ទាប់ លោកផាសហ៊ើរក៏នាំព្យាការីយេរេមាចេញពីគុកមកវិញ ខណៈនោះ ព្យាការីយេរេមាប្រាប់លោកថា៖ «ព្រះជាម្ចាស់ មិនបានហៅឈ្មោះលោកថា ផាសហ៊ើរ
នោះទេ គឺហៅថា ម៉ាកោរ មីស្សាប៊ីបវិញ។[4]ដ្បិតព្រះអង្គមានព្រះបន្ទូលដូច្នេះថា "យើងនឹងធ្វើឲ្យអ្នកជាទីស្ញែងខ្លាចដល់ខ្លួន ហើយដល់អស់ទាំងមិត្តសម្លាញ់របស់អ្នកផង គេ
នឹងដួលដោយដាវរបស់ពួកខ្មាំងសត្រូវ ហើយភ្នែករបស់អ្នកនឹងឃើញដែរ យើងនឹងប្រគល់ទឹកដីយូដាទាំងមូល ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូន ស្តេចនោះនឹងនាំគេទៅ
ជាឈ្លើយដល់ទឹកដីបាប៊ីឡូន ព្រមទាំងសម្លាប់គេដោយដាវផង។
[5]យើងនឹងប្រគល់អស់ទាំងទ្រព្យសម្បត្តិនៃក្រុងនេះ ហើយផលដែលកើតមានទាំងប៉ុន្មាន ព្រមទាំងរបស់ថ្លៃវិសេសទាំងអស់ យើងនឹងប្រគល់ព្រះរាជទ្រព្យរបស់ពួកស្តេច
ទឹកដីយូដាទាំងប៉ុន្មាន ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវគេ ពួកនោះនឹងចាប់យកនាំទៅឯទឹកដីបាប៊ីឡូន។[6]ឯអ្នកផាសហ៊ើរអើយ អ្នក និងអស់អ្នកដែលអាស្រ័យនៅផ្ទះ
អ្នកនឹងត្រូវនាំទៅជាឈ្លើយ គឺអ្នកនឹងត្រូវទៅដល់ក្រុងបាប៊ីឡូន នៅទីនោះអ្នកត្រូវស្លាប់។ ហើយគេនឹងកប់អ្នកនៅទឹកដីនោះ គឺទាំងអ្នក និងពួកមិត្តសម្លាញ់អ្នកដែលអ្នក
បានថ្លែងទំនាយកុហកដល់គេនោះផង»។
[7]ព្រះអម្ចាស់អើយ ព្រះអង្គបានបញ្ឆោតទូលបង្គំ ហើយទូល បង្គំក៏បណ្តោយតាម។ ព្រះអង្គមានកម្លាំងជាងក៏បានឈ្នះទូលបង្គំ។ ទូលបង្គំបានត្រឡប់ជាទីសើចឡកឡរាល់ថ្ងៃ
ជានិច្ច មនុស្សទាំងអស់ចំអកឡកឡឺយឲ្យទូលបង្គំ។[8]ដ្បិតវេលាណាដែលទូលបង្គំនិយាយ នោះទូលបង្គំស្រែកឡើង ទូលបង្គំបន្លឺពីការច្រឡោត និងការបំផ្លាញទទេ ពីព្រោះ
គេយកព្រះបន្ទូលនៃព្រះអម្ចាស់ ធ្វើឲ្យត្រឡប់ជាសេចក្តីដំណៀលដល់ទូលបង្គំ ហើយជាសេចក្តីឡកឡឺយឲ្យទូលបង្គំជានិច្ចរាល់ថ្ងៃ។[9]ប្រសិនបើទូលបង្គំទូលថា
ទូលបង្គំនឹងមិនគិតពីព្រះអម្ចាស់ទៀតទេ។ ទូលបង្គំក៏មិនពោលពីព្រះនាមរបស់ព្រះអង្គទៀតដែរ។ គឺដូចជាភ្លើងដែលឆេះដូងចិត្តនិងឆ្អឹងរបស់ទូលបង្គំដែរ។
ដូច្នេះទូលបង្គំមានបញ្ហាច្រើនដែលមិនអាចធ្វើបាន។
[10]ទូលបង្គំបានឮពាក្យបង្កាច់របស់មនុស្សជាច្រើន ហើយមានសេចក្តីស្ញែងខ្លាចនៅព័ទ្ធជុំវិញ។ អស់ទាំងសម្លាញ់ស្និទ្ធស្នាលរបស់ទូលបង្គំ គេជាពួកអ្នកដែលចាំមើលតែ
ទូលបង្គំដួលដែរ គេថា ចូរបរិហារចុះ នោះយើងនឹងបរិហារដែរ ប្រហែលជាយើងនឹងបញ្ចុះបញ្ចូលវាបានទេដឹង។ ដូច្នេះ យើងនឹងឈ្នះវាបាន នោះ យើងនឹងសងសឹកនឹងវា។
[11]ប៉ុន្តែ ព្រះអង្គគង់ជាមួយទូលបង្គំ ទុកជាមនុស្សខ្លាំងពូកែដែលគួរស្ញែងខ្លាច ហេតុនោះ ពួកអ្នកដែលបៀតបៀនទូលបង្គំ គេនឹងត្រូវចំពប់ដួលឥតឈ្នះបានឡើយ គេនឹងត្រូវ
ខ្មាសជាទីបំផុត។ ពួកគេនឹងធ្វើតាមបំណងចិត្តមិនបាន គឺជាសេចក្តីអាម៉ាស់ខ្មាស វានឹងមិនអាចបំភេចបាន។
[12]ព្រះអម្ចាស់នៃពិភពទាំងមូលអើយ ជាព្រះដែលល្បងលពួកសុចរិត ហើយទតឃើញចិត្ត និងថ្លើមអើយ សូមឲ្យទូលបង្គំឃើញព្រះអង្គសងសឹកនឹងគេ ដ្បិតទូលបង្គំបាន
សម្តែងដើមហេតុ នៃទូលបង្គំដល់ព្រះអង្គហើយ។[13]ចូរច្រៀងថ្វាយព្រះជាម្ចាស់ ចូរសរសើរដល់ព្រះអម្ចាស់ចុះ ដ្បិតព្រះអង្គបានដោះព្រលឹងរបស់មនុស្សវេទនា ឲ្យរួចចេញពី
កណ្តាប់ដៃនៃពួកដែលប្រព្រឹត្តអាក្រក់។
[14]សូមឲ្យថ្ងៃដែលខ្ញុំកើតមកត្រូវបណ្តាសាចុះ កុំឲ្យថ្ងៃដែលម្តាយបានសម្រាលខ្ញុំចេញមកនោះ បានពរឡើយ[15]សូមឲ្យត្រូវបណ្តាសា ដល់អ្នកដែលនាំដំណឹងមកប្រាប់ឲ្យឪពុក
ខ្ញុំ មានអំណរជាខ្លាំង ដោយថា អ្នកបានកូនប្រុសហើយ
[16]សូមឲ្យមនុស្សនោះបានដូចជាអស់ទាំងទីក្រុង ដែលព្រះជាម្ចាស់បានបំផ្លាញឥតស្តាយចុះ ឲ្យគេឮតែសម្រែកនៅពេលព្រឹក ហើយសូរហ៊ោនៅថ្ងៃត្រង់[17]ពីព្រោះគេមិនបាន
សម្លាប់ខ្ញុំ ពីកាលនៅក្នុងផ្ទៃម្តាយនៅឡើយ ឲ្យម្តាយខ្ញុំជាផ្នូររបស់ខ្ញុំ ហើយមានពោះធំរហូតទៅ។[18]ហេតុអ្វីបានជាខ្ញុំបានចេញពីផ្ទៃម្តាយមក ឲ្យឃើញតែការនឿយហត់ និង
សេចក្តីទុក្ខព្រួយ ឲ្យថ្ងៃអាយុខ្ញុំបានសូន្យទៅ ដោយសេចក្តីអាម៉ាស់ខ្មាសដូច្នេះ?

Jeremiah 20:1

ព័ត៌មានទូទៅ:

សូមមើល: និង

ដែលជានាយកធំ

ពាក្យថា «ដែលជាអ្នក» នៅទីនេះសំដៅលើ លោកផាសហ៊ើរ។

លោកផាសហ៊ើរក៏វាយព្យាការីយេរេមា

អាចមានន័យថា ១) លោកផាសហ៊ើរខ្លួនឯងជាអ្នកវាយព្យាការីយេរេមា ឬ ២)
លោកផាសហ៊ើរបញ្ជាអ្នកដទៃវាយព្យាការីយេរេមា។

ដាក់គុក

ច្រវាក់ក ដែលធ្វើជាឈើដែលមនុស្សប្រើដើម្បីចាក់សោរដៃ ជើង
និងក្បាលរបស់អ្នកទោស។

ត្រង់ខ្លោងទ្វារនៃបេនយ៉ាមីនខាងលើ

ច្រកទ្វារនេះគឺខុសគ្នាពីច្រកទ្វារនៅក្នុងជញ្ជាំងទីក្រុងដែលមានឈ្មោះដូចគ្នា។

Jeremiah 20:3

វាបានកើត

ឃ្លានេះត្រូវបានប្រើដើម្បីសម្គាល់កន្លែងដែលសកម្មភាពបានចាប់ផ្តើម។
ប្រសិនបើពាក្យភាសារបស់អ្នកមាន ចូរអ្នកប្រើពាក្យនោះទៅ។

អ្នកម៉ាកោរ មីស្សាប៊ីប

ឈ្មោះនេះមានន័យថា «ឧក្រិដ្ឋកម្មនៅគ្រប់ទីកន្លែង» ឬ
«ពោរពេញដោយឧក្រិដ្ឋកម្ម» ។

មើល៍

ការបកប្រែរបៀបផ្សេងទៀត: «សូមកត់សំគាល់នូវអ្វីដែលយើងនឹងថ្លែងប្រាប់អ្នក»

ពួកគេនឹងដួលដោយដាវរបស់ពួកខ្មាំងសត្រូវរបស់គេ

ការបកប្រែរបៀបផ្សេងទៀត: «ខ្មាំងសត្រូវរបស់គេ នឹងសម្លាប់ពួកគេដោយដាវ»

ភ្នែករបស់អ្នកនឹងឃើញវាដែរ

ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងឃើញវា»

យើងនឹងប្រគល់យូដាទាំងមូល ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូន

ពាក្យថា «កណ្តាប់ដៃ» សំដៅលើសិទ្ធអំណាច។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើអោយស្តេចក្រុងបាប៊ីឡូនច្បាំងឈ្នះស្រុកយូដាទាំងអស់»

Jeremiah 20:5

យើងនឹងប្រគល់

ពាក្យថា «ប្រគល់អស់» សំដៅលើការឲ្យដល់ស្តេចនៃក្រុងបាប៊ីឡូន។

ទាំងទ្រព្យសម្បត្តិ...កើតមានទាំងប៉ុន្មាន ព្រមទាំងរបស់ថ្លៃវិសេសទាំងអស់ យើងនឹងប្រគល់ព្រះរាជ
ទ្រព្យ

ព្រះអម្ចាស់មានព្រះបន្ទូលឡើងវិញ នូវគំនិតដដែលបួនដងដើម្បីបញ្ជាក់។

ស្តេចបាប៊ីឡូននឹងដកហូតទ្រព្យសម្បត្តិទាំងអស់របស់ជនជាតិអ៊ីស្រាអែល
រួមទាំងទ្រព្យសម្បត្តិរបស់ស្តេចផងដែរ។

យើងនឹងឲ្យការទាំងនេះទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ

ពាក្យថា «កណ្តាប់ដៃ» សំដៅលើកម្មសិទ្ធិ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងអនុញ្ញាតឲ្យខ្មាំងសត្រូវរបស់អ្នកយករបស់របរទាំងនេះ» ឬ
«យើងនឹងប្រគល់របស់របរទាំងនោះទៅខ្មាំងសត្រូវរបស់អ្នក»

ទាំងអ្នកនិងមិត្តសម្លាញ់អ្នកដែលអ្នកបានថ្លែងទំនាយកុហកដល់ពួកគេ នឹងត្រូវគប់នៅទីនោះ

ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងបញ្ចុះសពអ្នកនឹងមិត្តសម្លាញ់អ្នក
ដែលអ្នកបានថ្លែងទំនាយកុហក»

Jeremiah 20:7

ព័ត៌មានទូទៅ:

លោកយេរេមាថ្លែងពីព្រះអម្ចាស់

ទូលបង្គំក៏បណ្តោយតាម

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានបញ្ឆោតទូលបង្គំ»

ព្រះអម្ចាស់អើយ ព្រះអង្គបានបញ្ឆោតទូលបង្គំ ហើយទូលបង្គំក៏បណ្តោយតាម

ការកែប្រែពាក្យនាសម័យថ្មី បានបកប្រែបង្ហាញជាភាសាហេប្រឺដូចជា

generated on Wed Sep 10 16:16:32 2025

«ឱព្រះអម្ចាស់អើយ ព្រះអង្គបានបញ្ឆោះបញ្ឆលទូលបង្គំ។
ទូលបង្គំត្រូវបានបញ្ឆោះបញ្ឆលតាម»។
ចំអកឡកឡឺយ
នេះបង្ហាញពីមនុស្សដែលត្រូវបានគេសើចចំអក ឬត្រូវបានគេលេងសើចដាក់។
ការសើចចំអកដល់ទូលបង្គំរាល់ថ្ងៃ
ឃ្លានេះមានន័យថា ដូចគ្នាជាមួយឃ្លាមុន។
បាននិយាយ គឺទូលបង្គំស្រែកឡើង
ឃ្លាទាំងពីរនេះមានអត្ថន័យដូចៗគ្នា
ហើយបញ្ជាក់ថាលោកបានប្រកាសពីព្រះបន្ទូលរបស់ព្រះអម្ចាស់យ៉ាងអង់អាច។
ការបកប្រែរបៀបផ្សេងទៀត: «ប្រកាសដោយបើកចំហរ» ឬ
«ប្រកាសយ៉ាងខ្លាំងខ្លា»
ព្រះបន្ទូលនៃព្រះអម្ចាស់ បានត្រឡប់ជាការប្រមាថ ហើយជាការសើចចំអកដល់ទូលបង្គំរាល់ថ្ងៃ
«ព្រះបន្ទូល» នៅទីនេះសំដៅទៅលើព្រះរាជសាររបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សប្រមាថនិងសើចចំអកទូលបង្គំរាល់ថ្ងៃ
ដោយព្រោះទួលបង្គំប្រកាសព្រះរាជសាររបស់ព្រះអម្ចាស់»
ជាការប្រមាថ ហើយជាការសើចចំអក
ពាក្យថា «ប្រមាថ» និង «សើចចំអក» មានអត្ថន័យដូចៗគ្នា ដើម្បីបញ្ជាក់ថា
មនុស្សបានចំអកមើលងាយលោកយេរេមាដែលបានប្រកាសពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ជាមូលហេតុដែលមនុស្សចំអកមើលងាយទូលបង្គំ»
ទូលបង្គំក៏មិនពោលពីព្រះនាមរបស់ព្រះអង្គទៀតដែរ
អាចមានន័យថា ១) «ទូលបង្គំលែងពោលអ្វីទាំងអស់ពីទ្រង់» (UDB) ២)
«ទូលបង្គំលែងប្រកាសពីព្រះបន្ទូលព្រះអង្គទៀតហើយ»
ជាភ្លើងដែលឆេះដួងចិត្តនិងឆ្អឹងរបស់ទូលបង្គំដែរ
លោកយេរេមាថ្លែងពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ប្រៀបដូចជាភ្លើងដែលមិនអាចគ្រប់គ្រងបាន។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះបន្ទូលរបស់ព្រះអម្ចាស់គឺដូចជាភ្លើងដែលឆាបឆេះនៅក្នុងខ្លួនទូលបង្គំ»
Jeremiah 20:10
ចូរប្រាប់! យើងត្រូវតែប្រាប់ពីវា!
ខ្មាំងសត្រូវរបស់លោកយេរេមាន បាននិយាយពាក្យទាំងនេះ។
គេថា ចូរបរិហារចុះ ... យើងនឹងសងសឹកនឹងវា
ខ្មាំងសត្រូវរបស់លោកយេរេមាន បាននិយាយពាក្យទាំងនេះ។
គេថា ចូរបរិហារចុះ
«ប្រហែលយើងមានកលល្បិចដាក់គេ»
ព្រះអម្ចាស់គង់ជាមួយទូលបង្គំ ដូចជាអ្នកចម្បាំងដ៏ខ្លាំងពូកែ
ព្រះអម្ចាស់ប្រៀបដូចជាអ្នកចម្បាំងដ៏ខ្លាំងពូកែម្នាក់ដែលការពារលោកយេរេមា
និងយកឈ្នះខ្មាំងសត្រូវរបស់លោក។
វានឹងមិនត្រូវបានបំភ្លេចទេ
«មនុស្សនឹងមិនអាចបំភ្លេចបានឡើយ»
Jeremiah 20:12
ទតឃើញគំនិតនិងចិត្តផង
ការបកប្រែរបៀបផ្សេងទៀត: «ដឹងពីអ្វីដែលមនុស្សគិត និងបំណងចង់បាន»
ដោះជីវិតរបស់មនុស្សទុក្ខលំបាក
ការបកប្រែរបៀបផ្សេងទៀត: «ដោះមនុស្សចេញពីទុក្ខលំបាក»
ចេញពីកណ្តាប់ដៃនៃពួកមនុស្សអាក្រក់
ពាក្យថា «កណ្តាប់ដៃ» សំដៅលើ សិទ្ធអំណាច។ ការបកប្រែរបៀបផ្សេងទៀត:
«ពីសិទ្ធអំណាចរបស់ពួកមនុស្សអាក្រក់»
Jeremiah 20:14
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីព្រះអម្ចាស់។
សូមឲ្យថ្ងៃដែលខ្ញុំកើតមកនោះ ត្រូវបណ្តាសាចុះ
ការបកប្រែរបៀបផ្សេងទៀត: «សូមដាក់បណ្តាសា ថ្ងៃដែលខ្ញុំបានកើត»
កុំឲ្យថ្ងៃដែលម្តាយបានផ្តល់កំណើតដល់ខ្ញុំចេញមកនោះ បានពរឡើយ
ការបកប្រែរបៀបផ្សេងទៀត: «សូមកុំឲ្យពរ ថ្ងៃដែលម្តាយរបស់ខ្ញុំបង្កើតខ្ញុំឡើយ»។
សូមឲ្យត្រូវបណ្តាសាដល់អ្នក ដែលនាំដំណឹងមកប្រាប់ឲ្យឪពុកខ្ញុំផង
ការបកប្រែរបៀបផ្សេងទៀត:
«សូមដាក់បណ្តាសារដល់អ្នកដែលនាំដំណឹងប្រាប់ឪពុករបស់ខ្ញុំ»
Jeremiah 20:16
សូមឲ្យមនុស្សនោះ
ដែលសំដៅលើអ្នកដែលនាំដំណឹងប្រាប់ឪពុកលោកយេរេមាពីកំណើតរបស់លោកយេរេមា។
អស់ទាំងទីក្រុង ដែលព្រះជាម្ចាស់បានបំផ្លាញឥតស្តាយចុះ
នេះសំដៅទៅលើក្រុងសូដុមនិងក្រុងកូម៉ូរ៉ា។
ព្រះអង្គមិនមេត្តាដល់វាឡើយ
ពាក្យថា «ព្រះអង្គ» សំដៅលើព្រះអម្ចាស់។
ចូរឲ្យគេឮសម្រែករកជំនួយ
ពាក្យថា «គេ» សំដៅលើ «មនុស្សម្នាក់នោះ»
ធ្វើឲ្យម្តាយខ្ញុំជាផ្នូរ
ផ្ទៃម្តាយរបស់លោកយេរេមា នឹងបានដាក់សាកសពរបស់គាត់
ដូចជាផ្នូរដែលមានសាកសពមនុស្សស្លាប់។
ហេតុអ្វីបានជាខ្ញុំបានចេញពីផ្ទៃម្តាយមក ឲ្យឃើញបញ្ហា និងសេចក្តីទុក្ខព្រួយ ដូច្នោះថ្ងៃអាយុខ្ញុំ
គឺពេញដោយសេចក្តីអាម៉ាស់?
លោកយេរេមាប្រើសំណួរនេះ
ដើម្បីតួញតែ្ពរថាគ្មានមូលហេតុត្រឹមត្រូវដែលលោកត្រូវកើតមកទេ។
ការបកប្រែរបៀបផ្សេងទៀត:
«គ្មានហេតុផលអ្វីដែលខ្ញុំត្រូវកើតមកដើម្បីមើលឃើញពីបញ្ហា និងសេចក្តីទុក្ខ
ព្រួយ...អាម៉ាស់មុខ»។
មើលឃើញពីបញ្ហានិងសេចក្តីទុក្ខព្រួយ
ពាក្យថា «បញ្ហា» និង «សេចក្តីទុក្ខព្រួយ» មានន័យថាដូចៗគ្នា និងបញ្ជាក់ពីចំនួន
និងភាពធ្ងន់ធ្ងរនៃការឈឺចាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ជួបប្រទះនឹងការឈឺចាប់យ៉ាងខ្លាំង»។
ថ្ងៃអាយុខ្ញុំគឺពេញដោយសេចក្តីអាម៉ាស់
ការបកប្រែរបៀបផ្សេងទៀត: «ជីវិតរបស់ខ្ញុំពោពេញដោយសេចក្តីអាម៉ាស់»

---

21 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការីយេរេមា ក្នុងកាលដែលព្រះបាទសេដេគាបានចាត់ផាសហ៊ើរជាកូនម៉ាលគា និងសេផានា ជាកូនរបស់សង្ឃម្នាសេយ៉ា មក
ជួបលោកដោយពាក្យថា៖[2]«សូមទូលសួរដល់ព្រះអង្គឲ្យយើងផង ដ្បិតនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ច្បាំងនឹងយើងហើយ ប្រហែលជាព្រះអម្ចាស់នឹងប្រោសយើង។
តាមអស់ទាំងការអស្ចារ្យរបស់ព្រះអង្គ ដើម្បីឲ្យស្តេចនោះបានថយចេញពីយើងទៅទេដឹង»។
[3]ដូច្នេះ ព្យាការីយេរេមាឆ្លើយតបថា៖ «ចូរអ្នករាល់គ្នាទូលតបនឹងព្រះបាទសេដេគាយ៉ាងនេះ[4]ព្រះជាម្ចាស់ ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា មើល៍! យើង
នឹងបំបែរគ្រឿងសស្ត្រាវុធដែលនៅក្នុងដៃអ្នករាល់គ្នានោះឲ្យត្រឡប់ថយ ជាគ្រឿងដែលប្រើច្បាំងតនឹងស្តេចបាប៊ីឡូន ហើយពួកខាល់ដេ ដែលឡោមព័ទ្ធអ្នករាល់គ្នាខាងក្រៅ
កំផែងយើងនឹងប្រមូលគេមកនៅកណ្តាលទីក្រុងនេះ។[5]ហើយខ្លួនយើងក៏ច្បាំងតនឹងអ្នករាល់គ្នា ដោយដៃលូកចេញ និងដើមដៃខ្លាំងពូកែ គឺដោយកំហឹង សេចក្តីក្រោធ និង
សេចក្តីគ្នាន់ក្នាញ់ជាខ្លាំង។
[6]ដ្បិតយើងនឹងប្រហារពួកអ្នកនៅក្រុងនេះ ទាំងមនុស្ស និងសត្វផង គេនឹងត្រូវស្លាប់ដោយអាសន្នរោគយ៉ាងសាហាវ។[7]បន្ទាប់មក ព្រះអម្ចាស់មានព្រះបន្ទូលថា៖ លំដាប់
នោះ យើងនឹងប្រគល់សេដេគា ជាស្តេចយូដា ហើយពួកមហាតលិក និងបណ្តាជនទាំងឡាយ គឺអស់អ្នកនៅក្នុងទីក្រុងនេះ ដែលសល់ពីអាសន្នរោគ ពីដាវ និងពីអំណត់
ទៅក្នុងកណ្តាប់ដៃនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន គឺក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវគេ ជាពួកអ្នកដែលស្វែងរកជីវិតគេ ស្តេចនោះនឹងប្រហារគេ ដោយមុខដាវ។ ស្តេចនឹងឥត
ប្រណី ឥតមេត្តា ឥតអាណិតអាសូរឡើយ។
[8]សម្រាប់មនុស្សទាំងនេះ អ្នកត្រូវប្រាប់ដល់ជនជាតិនេះថា ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ មើល៍! យើងដាក់ផ្លូវជីវិត និងផ្លូវស្លាប់នៅមុខអ្នករាល់គ្នា។[9]អ្នកណាដែលនៅ
ជាប់ក្នុងក្រុងនេះ នឹងត្រូវស្លាប់ដោយដាវ ដោយអំណត់ ហើយដោយអាសន្នរោគ តែឯអ្នកណាដែលចេញទៅខាងពួកខាល់ដេ ជាខ្មាំងដែលឡោមព័ទ្ធអ្នករាល់គ្នា នោះនឹង
នៅរស់ ហើយនឹងមានជីវិតរស់រួចពីសង្គ្រាម។[10]ដ្បិតព្រះ អម្ចាស់មានព្រះបន្ទូលថា៖ យើងបានតាំងមុខទាស់នឹងទីក្រុងនេះ សម្រាប់ជាការអាក្រក់ មិនមែនជាការល្អទេ ទី
ក្រុងនេះនឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូន ស្តេចនោះនឹងដុតទីក្រុងចោល។

generated on Wed Sep 10 16:16:32 2025

[11]អ្នកត្រូវប្រាប់ពីដំណើរវង្សានៃស្តេចយូដាថា ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ចុះ[12]ពួកវង្សដាវីឌអើយ ព្រះអង្គមានព្រះបន្ទូលដូច្នេះថា៖ ចូរសម្រេចតាមសេចក្តីយុត្តិធម៌ចាប់តាំងពីពេលព្រលឹមស្រាងចុះ។ ហើយដោះអ្នកណាដែលត្រូវគេប្លន់ ឲ្យរួចពីកណ្តាប់ដៃនៃពួកអ្នកដែលសង្កត់សង្កិននោះផង ក្រែងសេចក្តីក្រោធរបស់យើងចេញទៅដូចជាភ្លើង ហើយឆេះជាខ្លាំង ដល់ម៉្លេះបានជាគ្មានអ្នកណាអាចនឹងពន្លត់បានឡើយ ដោយព្រោះអំពើអាក្រក់ដែលអ្នករាល់គ្នាប្រព្រឹត្ត។
[13]នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ថា៖ មើល អ្នកដែលអាស្រ័យនៅច្រកភ្នំ ជាថ្មដានៅវាលអើយ យើងទាស់នឹងអ្នកហើយ អ្នកអួតថា «តើអ្នកណានឹងចុះមកទាស់នឹងយើង?» ឬ «អ្នកណានឹងចូលមកក្នុងទីលំនៅរបស់យើងបាន?»[14]ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ យើងនឹងផ្តាលអ្នកឲ្យសមតាមផល ដែលអ្នកបានប្រព្រឹត្ត គឺយើងនឹងបង្កាត់ភ្លើងនៅក្នុងព្រៃអ្នក ភ្លើងនោះនឹងឆេះបំផ្លាញរបស់ទាំងអស់ដែលនៅជុំវិញ»។

Jeremiah 21:1
ព័ត៌មានទូទៅ:
សូមមើល:
លោកផាសហ៊ើរ
នេះមិនមែនលោកផាសហ៊ើរ ដែលត្រូវបានរៀបរាប់ក្នុងជំពូក ២០:១។
សូមទូលសួរដល់ព្រះអង្គឲ្យយើងផង
ការបកប្រែរបៀបផ្សេងទៀត: «សូមថ្លែងទៅកាន់ព្រះអម្ចាស់ជំនួសពួកយើង។ ចូរសូមទ្រង់ នោះទ្រង់នឹងជួយពួកយើង»
ដូចនៅគ្រាកន្លងទៅ
ការបកប្រែរបៀបផ្សេងទៀត: «ដូចដែលទ្រង់បានធ្វើកន្លងមក»
ធ្វើឲ្យស្តេចនោះបានដកថយចេញពីយើង
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យស្តេចនោះចេញឲ្យឆ្ងាយ»
Jeremiah 21:3
គ្រឿងសស្ត្រាវុធដែលនៅក្នុងដៃអ្នក
ការបកប្រែរបៀបផ្សេងទៀត: «ពួកទាហានដែលអ្នកបានបញ្ជា»
ដែលឡោមព័ទ្ធអ្នករាល់គ្នា
«ដែលមកជិតអ្នករាល់គ្នា»
ដោយដៃលើកឡើង ហើយនិងដៃដែលខ្លាំងពូកែ
ឃ្លាទាំងពីរនេះ
បង្ហាញពីបង្ហាញពីសំនួនវោហារដែលសំដៅទៅលើថាមពលដ៏អស្ចារ្យ។
ការបកប្រែរបៀបផ្សេងទៀត: «ជាមួយនឹងថាមពលដ៏ខ្លាំងអស្ចារ្យ»។
ជាមួយសេចក្តីក្រោធ និង សេចក្តីខ្ញាល់ ហើយសេចក្តីកំហឹងជាខ្លាំង
ពាក្យទាំងនេះមានន័យថាជាដូចៗគ្នា។
ពាក្យទាំងនេះរួមគ្នាបញ្ជាក់ពីលើកំហឹងរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត: «ដោយកំហឹងយ៉ាងខ្លាំង»។
Jeremiah 21:6
ព័ត៌មានទូទៅ:
សូមមើល:
ពួកអ្នកនៅទីក្រុងនេះ
ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកដែលរស់នៅក្រុងយេរូសាឡិម»
Jeremiah 21:8
មនុស្សទាំងនេះ
ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកដែលរស់នៅក្រុងយេរូសាឡិម»
យើងនឹងដាក់នៅចំពោះអ្នកគឺផ្លូវនៃជីវិត ហើយផ្លូវនៃសេចក្តីស្លាប់
ព្រះអម្ចាស់បានប្រទានជម្រើសដល់ប្រជាជននៅក្រុងយេរូសាឡិមដែលកំណត់ថាតើពួកគេនឹងរស់ឬស្លាប់ ឬត្រូវស្លាប់។
លុតជង្គង់នៅមុខ
ការបកប្រែរបៀបផ្សេងទៀត: «ចុះចាញ់ទៅនឹង»
ដែលជិតនឹងច្បាំង
ការបកប្រែរបៀបផ្សេងទៀត: «ដែលនឹងវាយប្រហារគ្រប់ទីតាំង»
យើងបានតាំងមុខទាស់នឹង
ការបកប្រែរបៀបផ្សេងទៀត: «យើងប្តេជ្ញាថានឹងប្រឆាំង» ឬ «យើងបែរមកតទល់»
នោះនឹងបានរួចជីវិតរស់
អ្នកដែលចុះចាញ់ជនជាតិបាប៊ីឡូននឹងរួចជីវិតជាមួយជីវិតរបស់គេ ទោះបីគាត់បាត់បង់ទ្រព្យសម្បត្តិទាំងអស់ក៏ដោយ។
Jeremiah 21:11
ទាក់ទងពីប្រជាជននៃស្តេចយូដា ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ចុះ
ការបកប្រែរបៀបផ្សេងទៀត:
«ចូរស្តាប់សេចក្តីដែលព្រះអម្ចាស់មានព្រះបន្ទូលអំពីស្តេចយូដា ក្រុមគ្រួសារ និងអ្នកបម្រើរបស់ព្រះអង្គ»។
ចូរនាំសេចក្តីយុត្តិធម៌ តាំងពីពេលព្រលឹមចុះ
ការបកប្រែរបៀបផ្សេងទៀត:
«ប្រព្រឹត្តចំពោះមនុស្សដែលអ្នកបានគ្រប់គ្រងដោយភាពយុត្តិធម៌ជារៀងរហូត»
ពួកអ្នកដែលសង្កត់សង្កិន
ការបកប្រែរបៀបផ្សេងទៀត: «សិទ្ធអំណាចនៃអ្នកដែលសង្កត់សង្កិន»
សេចក្តីខ្ញាល់របស់យើងចេញទៅដូចជាភ្លើង ហើយឆេះជាខ្លាំង
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងដាក់ទោស
និងបំផ្លាញអ្នកតាមកំហឹងរបស់យើងយ៉ាងឆាប់រហ័សនិងពេញលេញ»
Jeremiah 21:13
យើងនឹងទាស់នឹងអ្នក ថ្មដារាបស្មើអើយ
ការបកប្រែរបៀបផ្សេងទៀត: «យើងប្រឆាំងទាស់នឹងអ្នកក្រុងយេរូសាឡឹម» ឬ «យើងនឹងដាក់ទោសអ្នកក្រុងយេរូសាឡឹម»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
តើអ្នកណានឹងចុះមកទាស់នឹងយើង?...តើអ្នកណានឹងចូលមកក្នុងផ្ទះរបស់យើងបាន?
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់នឹងវាយប្រហារយើងទេ ហើយក៏គ្មាននរណាម្នាក់ចូលក្នុងផ្ទះរបស់យើងដែរ»
យើងនឹងតាំងឲ្យអ្វីដែលជាផលរបស់អ្នកបានប្រព្រឹត្តគឺមកទាស់នឹងអ្នកវិញ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងដាក់ទោសអ្នកតាមអំពើដែលអ្នកបានប្រព្រឹត្ត
ការបកប្រែរបៀបផ្សេងទៀត: «ផលនៃអំពើរបស់អ្នក»

---

22 [1]នេះជាព្រះបន្ទូលនៃព្រះអម្ចាស់៖ «ចូរចុះទៅដំណាក់ស្តេចយូដា ហើយពោលពាក្យនេះនៅទីនោះ[2]គឺប្រាប់ថា ស្តេចជនជាតិយូដាដែលគង់លើបល្ល័ង្កនៃដាវីឌ ព្រមទាំងពួកមហាតលិក និងបណ្តាជនរបស់ព្រះអង្គដែលចូលតាមទ្វារទាំងនេះអើយ។[3]ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់៖ ចូរសម្រេចសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិត ហើយដោះអ្នកដែលត្រូវគេប្លន់ ឲ្យបានរួចពីកណ្តាប់ដៃនៃពួកអ្នកដែលសង្កត់សង្កិននោះ។ កុំជិះជាន ឬគំហកកំហែងដល់អ្នកដទៃ ដែលមកស្នាក់នៅ ឬដល់ពួកកំព្រា និងស្ត្រីមេម៉ាយឡើយ ក៏កុំកម្ចាយឈាមរបស់មនុស្សដែលឥតទោសនៅទីនេះដែរ។
[4]ដ្បិតប្រសិនបើអ្នករាល់គ្នាពិតជាធ្វើតាមពាក្យនេះ នោះនឹងមានស្តេចដែលគង់លើបល្ល័ង្កដាវីឌជិះរាជរថ និងសេះយោងចូលតាមទ្វារនេះ ព្រមទាំងពួកមហាតលិក និងប្រជារាស្ត្ររបស់ព្រះអង្គផង![5]ប៉ុន្តែ បើអ្នករាល់គ្នាមិនព្រមស្តាប់តាមពាក្យទាំងនេះទេ ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ យើងស្បថនឹងខ្លួនយើងថា ដំណាក់នេះនឹងត្រូវបំផ្លាញអស់រលីង»។
[6]ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ ពីដំណើរដំណាក់នៃស្តេចយូដាថា៖ ចំពោះយើង អ្នកប្រៀបដូចជាទឹកដីកាឡាត និងកំពូលភ្នំល្បាណូន ប៉ុន្តែ យើងប្រាកដជានឹងធ្វើឲ្យអ្នកត្រឡប់ ទៅជាទីរហោស្ថាន ជាទីក្រុងដែលគ្មានមនុស្សរស់នៅ។[7]យើងនឹងតាំងពួកបំផ្លាញឲ្យមកទាស់នឹងអ្នក គ្រប់គ្នានឹងកាន់គ្រឿងអាវុធរបស់ខ្លួន គេនឹងកាប់រំលំដើមតាត្រៅ ដែលជ្រើសរើសរបស់អ្នក ហើយបោះទៅក្នុងភ្លើង។
[8]ជនជាតិជាច្រើននឹងដើរមកតាមទីក្រុងនេះ គ្រប់គ្នានឹងនិយាយដល់គូកនខ្លួនថា «ហេតុអ្វីបានជាព្រះអម្ចាស់ធ្វើដូច្នេះដល់ក្រុងធំនេះ?»[9]គេនឹងឆ្លើយតបថា៖ «ពីព្រោះគេបានបោះបង់សេចក្តីសញ្ញារបស់ព្រះជាម្ចាស់ដែល ជាព្រះរបស់គេ ក៏ថ្វាយបង្គំ ហើយគោរពប្រតិបត្តិដល់ព្រះដទៃ»។
[10]កុំយំនឹងមនុស្សដែលស្លាប់ឡើយ ក៏កុំសោកស្តាយគេដែរ ត្រូវឲ្យយំជាខ្លាំងនឹងអ្នកដែលចាកចេញពីទីនេះវិញ ដ្បិតគេនឹងមិនដែលវិលមកទៀតឡើយ ក៏មិនដែលឃើញទឹកដីកំណើតរបស់ខ្លួនទៀតផង។

generated on Wed Sep 10 16:16:32 2025

[11]ដ្បិត ព្រះអម្ចាស់មានបន្ទូលដូច្នេះថា៖ សាលូម ជាបុត្រយ៉ូសៀស ស្តេចយូដា ដែលសោយរាជ្យជំនួសយ៉ូសៀស ជាបិតា ហើយបានចាកចេញពីទីនេះទៅហើយ គេនឹងមិនមកទីនេះវិញទេ។[12]នៅកន្លែងណាដែលត្រូវចាប់នាំទៅជាឈ្លើយ គេនឹងស្លាប់នៅទីនោះ ឥតដែលឃើញទឹកដីនេះទៀតឡើយ។
[13]វេទនាដល់អ្នកណាដែលសង់ផ្ទះខ្លួន ដោយការទុច្ចរិត ហើយធ្វើបន្ទប់ខ្លួនដោយការមិនទៀងត្រង់ ជាអ្នកដែលប្រើប្រាស់អ្នកជិតខាងខ្លួនទទេ ឥតចេញឈ្នួលឲ្យ[14]ហើយក៏ពោលថា យើងនឹងសង់ផ្ទះមួយធំ ដែលមានបន្ទប់ទូលាយសម្រាប់យើង ក៏ធ្វើបង្អួច ហើយបិទជញ្ជាំងដោយក្តារតាត្រៅ រួចលាបពណ៌ក្រហមស្រស់។
[15]តើអ្នកត្រូវសោយរាជ្យ ដោយព្រោះតែអ្នកមានចិត្តសង្វាត និងចម្រើនឈើតាត្រៅឬ? ឯឪពុកអ្នក តើមិនបានស៊ី ហើយផឹកដែរទេឬ? ប៉ុន្តែ បានប្រព្រឹត្តសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិត បានជាមានសន្តិសុខក្នុងគ្រានោះ។[16]គាត់បានកាត់ក្តីឲ្យពួកក្រីក្រ និងពួកកម្សត់ទុគ៌ត ដូច្នេះ ក៏មានសេចក្តីសុខ ព្រះអម្ចាស់មានព្រះបន្ទូលសួរថា៖ ដែលប្រព្រឹត្តដូច្នោះ តើមិនស្គាល់យើងទេឬ?
[17]ចំណែកភ្នែក និងចិត្តរបស់អ្នក រកតែបំពេញសេចក្តីលោភរបស់អ្នក ក៏កម្ចាយឈាមរបស់មនុស្សដែលឥតមានទោស ព្រមទាំងជិះជាន់ និងប្រព្រឹត្តសេចក្តីច្រឡោតប៉ុណ្ណោះ។[18]ហេតុនេះ ព្រះជាម្ចាស់មានព្រះបន្ទូល ស្តីពីដំណើរយេហូយ៉ាគីម ជាបុត្រយ៉ូសៀស ស្តេចជនជាតិយូដាដូច្នេះថា៖ មនុស្សនឹងមិនសោកស្តាយដោយពាក្យថា ឱបង ឱប្អូនអើយ ក៏មិនដែលសោកស្តាយថា ឱព្រះអម្ចាស់អើយ ឬថាព្រះករុណាដ៏ឧត្តមអើយ នោះឡើយ។[19]គេនឹងបញ្ចុះសពយេហូយ៉ាគីម ដូចជាបញ្ចុះសពសត្វលា គឺគេនឹងអូសទៅបោះចោល នៅខាងក្រៅទ្វារនៃក្រុងយេរូសាឡិម។
[20]ចូរឡើងទៅលើភ្នំល្បាណូន ហើយស្រែកឡើង ចូរបន្លឺសំឡេងនៅទឹកដីបាសាន ហើយស្រែកពីភ្នំអាបារីមចុះ ពីព្រោះសហាយរបស់អ្នកត្រូវបំផ្លាញហើយ។[21]កាលនៅគ្រាសម្បូណ៌ នោះយើងបាននិយាយនឹងអ្នកហើយ តែអ្នកឆ្លើយតបថា៖ យើងមិនស្តាប់ទេ គឺបែបយ៉ាងនេះ ដែលបានប្រព្រឹត្ត តាំងតែពីក្មេងមក គឺមិនព្រមស្តាប់តាមពាក្យយើងឡើយ។
[22]ខ្យល់នឹងស៊ីបំផ្លាញពួកគង្វាលរបស់អ្នក ហើយពួកសហាយរបស់អ្នកនឹងត្រូវដឹកទៅជាឈ្លើយ ដូច្នេះ អ្នកនឹងត្រូវខ្មាស ហើយជ្រប់មុខ ដោយព្រោះអំពើអាក្រក់ដែលអ្នកប្រព្រឹត្តជាមិនខាន។[23]ឱអ្នកដែលអាស្រ័យនៅព្រៃល្បាណូន ដែលធ្វើសម្បុកនៅដើមតាត្រៅអើយ កាលណាសេចក្តីទុក្ខវេទនាមកលើអ្នក ដូចជាស្ត្រីដែលឈឺចាប់សម្រាលកូន នោះអ្នកគួរឲ្យអាណិតយ៉ាងណាទៅ!»
[24]ព្រះជាម្ចាស់ស្បថថា៖ ដូចជាយើងរស់នៅ ទោះបើព្រះបាទកូនាស ជាបុត្រព្រះបាទយេហូយ៉ាគីម ស្តេចជនជាតិយូដា ជាចិញ្ចៀនត្រានៅដៃស្តាំយើងក៏ដោយ គង់តែយើងនឹងកន្ត្រាក់ចេញទៅដែរ។[25]យើងនឹងប្រគល់អ្នកទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលចង់បានជីវិតអ្នក ហើយក្នុងកណ្តាប់ដៃនៃពួកអ្នកដែលអ្នកបានខ្លាចនោះ គឺក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ហើយក្នុងកណ្តាប់ដៃនៃជនជាតិខាល់ដេផង។[26]យើងនឹងបោះអ្នកចោល ព្រមទាំងម្តាយដែលបង្កើតអ្នកផង ទៅក្នុងទឹកដីមួយដែលមិនមែនជាទឹកដីកំណើតរបស់អ្នក ហើយអ្នកនឹងស្លាប់នៅក្នុងទឹកដីនោះ។
[27]ចំពោះទឹកដីដែលចិត្តគេរឭកចង់វិលទៅនៅវិញនោះ គេនឹងមិនត្រឡប់ទៅនៅវិញឡើយ។[28]ចំណែកមនុស្សឈ្មោះកូនាស នេះ តើជាភាជនៈកំបែក ហើយសម្អប់ ជាប្រដាប់ដែលឥតមានអ្នកណាយកចិត្តទុកដាក់ឬ? ហេតុអ្វីបានជាគេ និងកូនចៅរបស់គេត្រូវបោះចោល ហើយគ្រវែងទៅនៅទឹកដីមួយដែលគេមិនស្គាល់នោះ?
[29]ឱផែនដី ផែនដី ផែនដីអើយ! ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ចុះ!![30]ទ្រង់មានព្រះបន្ទូលដូច្នេះ៖ «ត្រូវកត់ឈ្មោះរបស់មនុស្សនេះថាជាគ្មានកូន ជាមនុស្សដែលនឹងមិនចម្រើនក្នុងជំនាន់របស់ខ្លួនឡើយ ដ្បិតនឹងគ្មានពូជពង្សគេណាមួយ ដែលនឹងអាចអង្គុយលើបល្ល័ង្កស្តេចដាវីឌ ហើយគ្រប់គ្រងលើទឹកដីយូដាបានទៀតឡើយ»។

Jeremiah 22:1
គង់លើបល្ល័ង្កនៃដាវីឌ
នេះសំដៅទៅលើការមានអំណាចជាស្តេច ដូចព្រះបាទដាវីឌដែរ។
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់គ្រងបែបជាស្តេច
ដូចព្រះបាទដាវីឌដែលបានដឹកនាំពីមុនមក»
ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «ចូរយកចិត្តទុកដាក់ ព្រះបន្ទូលរបស់ព្រះអម្ចាស់»
ព្រមទាំងពួកមហាតលិក និងបណ្តាជនរបស់ព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបម្រើព្រះអង្គ ហើយបណ្តាជនរបស់ព្រះអង្គ
ដែលរស់នៅក្នុងទឹកដីរបស់ព្រះអង្គ»
ដែលចេញតាមទ្វារទាំងនេះផង
ទ្វានៃដំណាក់របស់ស្តេច។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលបានចូលគាល់ស្តេច»
កណ្តាប់ដៃនៃពួកអ្នកដែលសង្កត់សង្កិននោះ
ពាក្យថា «កណ្តាប់ដៃ» សំដៅលើសិទ្ធអំណាច ឬការគ្រប់គ្រងដោយនរណាម្នាក់។
កុំប្រព្រឹត្តមិនល្អ
កុំប្រព្រឹត្តដាក់នរណាម្នាក់ដោយអាក្រក់ឡើយ
ក្មេងកំព្រា
ក្មេងដែលគ្មានឪពុកម្តាយ
កុំ...កម្ចាយឈាមរបស់មនុស្សដែលគ្មានទោស
ការបកប្រែរបៀបផ្សេងទៀត: «កុំធ្វើការឃោរឃៅ ឬសម្លាប់របស់មនុស្សដែលគ្មាន
ទោស»
នៅទីនេះ
«នៅទីនេះ» សំដៅលើក្រុងយេរូសាឡិម ឬក៏ទូទាំងស្រុកយូដា។
នេះមិនបញ្ជាក់ថាការដែលល្អដែលត្រូវសម្លាប់មនុស្សដែលគ្មានទោសនៅទីនេះឡើយ។
Jeremiah 22:4
ស្តេចក៏គង់លើបល្ល័ង្កនៃដាវីឌ
នេះសំដៅលើស្តេចដែលមានសិទ្ធអំណាចដូចព្រះបាទដាវីឌធ្លាប់មាន។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចដែលកាន់អំណាចបន្ទាប់ពីព្រះបាទដាវីឌ»
ជិះរទេះសេះ និងសេះ
ប្រយោគនេះបានរៀបរាប់ពីស្តេចដែលមានអំណាច និងទ្រព្យសម្បត្តិ។
ស្តេចហើយពួកអ្នកបម្រើ និងប្រជារាស្ត្ររបស់ទ្រង់
ប្រយោគនេះបានរៀបរាប់ពីអ្នកដែលមានអំណាច និងទ្រព្យសម្បត្តិ។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេច និងពួកអ្នកបម្រើ
និងប្រជារាស្ត្ររបស់ទ្រង់នឹងជិះចូលក្នុងរាជវាំងដោយជិះរទេះសេះ និងសេះ»
បើអ្នករាល់គ្នាមិនព្រមស្តាប់តាម
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើអ្នកមិនយកចិត្តទុកដាក់» (UDB) ឬ
«ប្រសិនបើអ្នកមិនព្រមស្តាប់បង្គាប់»
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបដែលកប្រែនៅក្នុងជំពូក ១:៧។
Jeremiah 22:6
តំណាក់របស់ស្តេចយូដា
នេះអាចបកប្រែថា «តំណាក់របស់ស្តេចយូដា» ហើយសំដៅទៅលើគ្រួសារ
និងកូនចៅរបស់ស្តេចយូដា
អ្នកដូចជាកាឡាត ឬដូចជាកំពូលភ្នំនៃល្បាណូន
ព្រះអម្ចាស់ថ្លែងពីព្រះទ័យល្អរបស់ព្រះអង្គចំពោះក្រុមគ្រួសារ
និងកូនចៅរបស់ស្តេចយូដា
ធ្វើឲ្យអ្នកត្រឡប់ ទៅជាទីរហោស្ថាន
ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឲ្យទីក្រុងរបស់អ្នកក្លាយទៅជាទីក្រុងដែលគ្មានមនុស្សរស់នៅ»
Jeremiah 22:8
ក្រោយមក ជនជាតិជាច្រើននឹងដើរមកតាមទីក្រុងនេះ
ការបកប្រែរបៀបផ្សេងទៀត: «ក្រោយមក មនុស្សជាច្រើនពីប្រជាជាតិនានា
នឹងដើរមកតាមទីក្រុងនេះ។»
ក្រាបចុះនិងថ្វាយបង្គំដល់ព្រះដទៃ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ឃ្លាថា «ក្រាបចុះ»
រៀបរាប់ពីឥរិយាបថដែលមនុស្សថ្វាយបង្គំ។
Jeremiah 22:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូល ដោយផ្លាស់ប្តូរដោយថ្លែងពីស្តេចយូដា
ទៅអ្នកស្តាប់ទូទៅ។
គេនឹងមិនឃើញទឹកដីកំណើតម្តងទៀតដែរ
ការបកប្រែរបៀបផ្សេងទៀត: «នឹងឃើញទឹកដីអ៊ីស្រាអែលម្តងទៀត» ឬ
«ឃើញទឹកដីកំណើតគេម្តងទៀត»

generated on Wed Sep 10 16:16:32 2025

Jeremiah 22:11
សាលូម
ឈ្មោះក្នុងភាសាហេព្រឺ «សាលូម»
Jeremiah 22:13
ផ្ទះ
ផ្ទះប្រើនៅទីនេះដើម្បីរៀបរាប់ពីលោកយេហូយ៉ាគីម និងក្រុមគ្រួសាររបស់គាត់។
Jeremiah 22:15
តើនេះជាអ្វីដែលធ្វើឲ្យអ្នកទៅជាស្តេចល្អ ដោយព្រោះតែអ្នកមានចិត្តក្តាជាច្រើននៃឈើតាត្រៅឬ?
ការបកប្រែរបៀបផ្សេងទៀត:
«ការដែលមានតំណាក់ជាឈើតាត្រៅមិនធ្វើឲ្យទ្រង់ក្លាយជាស្តេចល្អទេ»
តើឪពុកអ្នកមិនបានស៊ី ហើយផឹកដែរ តែបានប្រព្រឹត្តសេចក្តីយុតិធម៌ និងសេចក្តីសុចរិតឬ?
ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចយ៉ូសៀសរីករាយជីវិតរបស់ទ្រង់...សេចក្តីសុចរិត»។
តើនេះមិនមែនជាអ្វីដែលវាមានន័យថាដើម្បីស្គាល់យើងទេ?
ការបកប្រែរបៀបផ្សេងទៀត: «នេះជាអ្វីដែលមានន័យថាស្គាល់យើង»។
Jeremiah 22:17
គ្មានអ្វីដែលនៅក្នុងភ្នែក និងចិត្តរបស់អ្នកទេ
«គ្មានអ្វីក្នុងចិត្ត និងគំនិតរបស់អ្នកទេ»
ការចំណេញដែលមិនត្រឹមត្រូវ
ការទទួលបានប្រាក់ដោយការបោកប្រាស់ ឬប្រើគ្រប់មធ្យោបាយដែលមិនត្រឹមត្រូវ។
បង្ហូរឈាមរបស់មនុស្សដែលគ្មានទោស
«សម្លាប់មនុស្សដែលគ្មានទោស»
បំផ្លាញដល់អ្នកដទៃ
«ដោយប្រើអំពើហឹង្សាដល់អ្នកដទៃដើម្បីបានប្រាក់»
វេទនា បងប្អូនអើយ!» ឬ «វេទនា បងប្អូនស្រីអើយ!» ពួកគេមិនទួញសោកសម្រាប់គេទេ និយាយថា «វេទនាចៅហ្វាយអើយ!» ឬ ព្រះករុណាអើយ!
ព្រះអម្ចាស់មានបន្ទូលថា «វេទនា» ជាច្រើនដងដើម្បីសង្កត់ន័យ។
ទ្រង់មានព្រះបន្ទូលទៅកាន់មនុស្សជាច្រើនដែលជាធម្មតាបង្ហាញនូវភាពសោកសៅយ៉ាងខ្លាំង
នៅពេលដែលមាននរណាម្នាក់បានស្លាប់។
គេនឹងបញ្ចុះសពជាមួយសពសត្វលា គឺគេនឹងអូសទៅបោះចោល
«គេនឹងបញ្ចុះសពលោកតាមរបៀបដែល គេបញ្ចុះសត្វលាងាប់។
ពួកគេនឹងអូសវាទៅបោះចោល»
Jeremiah 22:20
ចូរបន្លឺសំឡេង
ការបកប្រែរបៀបផ្សេងទៀត: «ស្រែកឡើងនៅទឹកដីបាសាន»
ភ្នំអាបារីម
យើងបាននិយាយដល់អ្នក ពេលអ្នកបានសុខសាន្ត
ការបកប្រែរបៀបផ្សេងទៀត: «យើងនិយាយទៅអ្នក ពេលដែលអ្នកមិនអី»
ការនេះបានប្រព្រឹត្ត
ការបកប្រែរបៀបផ្សេងទៀត: «នេះជារបៀបរស់នៅរបស់អ្នក»
អ្នកមិនស្តាប់សម្លេងរបស់យើងឡើយ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនបានស្តាប់បង្គាប់យើងឡើយ»
Jeremiah 22:22
ខ្យល់នឹងដឹកនាំចេញ ពួកគង្វាលរបស់អ្នកទាំងអស់
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដឹកនាំរបស់អ្នកនឹងត្រូវបានចាកចេញទៅ»
អ្នកដែលអាស្រ័យនៅក្នុងព្រៃ«ល្បាណូន» ដែលអ្នកធ្វើសម្បុកនៅដើមតាត្រៅ
ការបកប្រែរបៀបផ្សេងទៀត: «តំណាក់ដែលធ្វើពីដើមតាត្រៅនៃ ល្យាណូន»
តើគួរត្រូវអាណិតបែបណា ពេលការឈឺចាប់បានមកលើអ្នក ឈឺដូចជាស្ត្រីសម្រាលកូន!
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងត្រូវបានអាណិត
ដោយព្រោះការឈឺចាប់របស់អ្នក»
Jeremiah 22:24
ដូចជាយើងរស់នៅ
ការបកប្រែរបៀបផ្សេងទៀត: «ប្រាកដណាស់»
ទោះបើជាស្តេចកូនាស ជាបុត្រនៃស្តេចយេហូយ៉ាគីម ហើយស្តេចនៃជនជាតិយូដា ជាចិញ្ចៀនត្រានៅដៃស្តាំយើងក៏ដោយ គង់តែយើងនឹងកន្ត្រាក់ចេញទៅដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ទោះបីអ្នកជាស្តេចកូនាស...
ជាចញ្ចៀនត្រានៅដៃស្តាំយើងក៏ដោយ ក៏យើងនឹងដកចេញពីដៃរបស់ខយើង» ឬ
«កូនាស...ទោះបីអ្នកជាស្តេចដែលយើងបានជ្រើសរើសជាការបង្ហាញពីអំណាចរបស់ខ្ញុំក៏ដោយ
នឹងនៅតែដាក់ទណ្ឌកម្មអ្នក»
យើងនឹងប្រគល់អ្នកទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលចង់បានជីវិតអ្នក
ការបកប្រែរបៀបផ្សេងទៀត:
«យើងបានធ្វើវាបានកើតឡើងសម្រាប់អ្នកដែលចង់បានជីវិតអ្នក និងតាមចាប់អ្នក»
Jeremiah 22:27
ចំពោះទឹកដីដែលចិត្តពួកគេចង់វិលមកវិញ
សំដៅលើទឹកដីស្រុកយូដា
តើការមើលងាយហើយបែកខ្ចាត់ខ្ចាយភាជនៈនេះ? តើមនុស្សមានឈ្មោះកូនាសនេះ តើជាសម្ពប់ដែលគ្មានអ្នកណាពេញចិត្តឬ?
ការបកប្រែរបៀបផ្សេងទៀត: «ឈ្មោះកូនាស គឺឥតប្រយោជន៍
ហើយគ្មាននរណាម្នាក់រីករាយជាមួយគាត់ឡើយ»។
ហេតុអ្វីបានជាពួកគេ បានបោះចោលគេហើយកូនចៅពួកគេទៅក្រៅ ហើយគ្រវែងទៅនៅទឹកដីមួយដែលគេមិនដែលស្គាល់នោះ?
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេគួរតែបោះបង់កូនាស
ហើយគ្រួសាររបស់គាត់ពីទឹកដីនេះ»
Jeremiah 22:29
ទឹកដី ទឹកដី ទឹកដីអើយ!
ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ពួកមនុស្សដែលរស់នៅទឹកដីនោះ
ហើយដោយបានស្រែកហៅទឹកដីដែលគេរស់នៅ។
ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «ស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់»

---

23 [1]«ពួកគង្វាលដែលមិនថែទាំហ្វូងចៀមរបស់យើង តែធ្វើឲ្យគេខ្ចាត់ខ្ចាយមុខជាត្រូវវេទនាពុំខាន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។[2]ព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលអំពីពួកមេដឹកនាំ ដែលឃ្វាលប្រជាជនរបស់ព្រះអង្គថា៖ «អ្នករាល់គ្នាបោះបង់ចោលកូនចៀមរបស់យើងឲ្យខ្ចាត់ខ្ចាយ ហើយអ្នករាល់គ្នាមិនបានយកចិត្តទុកដាក់នឹងពួកគេទេ។ យើងយកចិត្តទុកដាក់នឹងអ្នករាល់គ្នា គឺដាក់ទោសតាមអំពើអាក្រក់ដែលអ្នករាល់គ្នាបានប្រព្រឹត្ត នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[3]គឺយើងនេះហើយ ដែលនឹងប្រមូលសំណល់នៃហ្វូងរបស់យើង ចេញពីគ្រប់ទឹកដី ដែលយើងបានបណ្តេញគេទៅនោះ ហើយនាំវិលត្រឡប់មកក្រោលគេវិញ នោះគេនឹងបង្កើតផល ហើយចម្រើនឡើង។[4]យើងនឹងតាំងគង្វាលលើគេ ដែលនឹងឃ្វាលគេ គ្រានោះ គេនឹងមិនភ័យ ឬស្រយុតចិត្តទៀតឡើយ ក៏មិនដែលបាត់បង់ណាមួយដែរ នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។
[5]ព្រះអម្ចាស់បានប្រកាសថា៖ មើល៍! នឹងមានគ្រាមកដល់ ដែលយើងនឹងបង្កើតឲ្យដាវីឌមានលំពង់សុចរិតមួយ លំពង់នោះទ្រង់នឹងសោយរាជ្យទុកដូចជាស្តេច ហើយនឹងប្រព្រឹត្តដោយវាងវៃ ព្រមទាំងសម្រេចសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិតនៅក្នុងទឹកដី។[6]នៅគ្រារបស់ស្តេចនោះ ពួកយូដានឹងបានសង្គ្រោះ ហើយពួកអ៊ីស្រាអែលនឹងនៅដោយសន្តិសុខ ឯព្រះនាម ដែលគេនឹងហៅព្រះអង្គ នោះគឺ ព្រះអម្ចាស់ដ៏ជាសេចក្តីសុចរិតនៃយើង។
[7]ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ គឺហេតុនោះបានជាមានគ្រាមកដល់ ដែលគេនឹងលែងស្បថថា ដូចជាព្រះអម្ចាស់មានព្រះជន្មរស់ ដែលព្រះអង្គបាននាំពួកកូនចៅអ៊ីស្រាអែលឡើងចេញពីទឹកដីអេស៊ីបមកទៀតហើយ។[8]គឺគេនឹងថា ដូចជាព្រះមានព្រះជន្មអង្គរស់ ដែលព្រះអង្គបាននាំពូជពង្សនៃអ៊ីស្រាអែល ហើយនាំគេចេញពីទឹកដីខាងជើង និងពីគ្រប់ទាំងទឹកដីដែលព្រះអង្គបានបណ្តេញគេនោះវិញ។ ពេលនោះ គេនឹងនៅក្នុងទឹកដីរបស់ខ្លួន»។
[9]ពីដំណើរពួកព្យាការី ចិត្តនៅក្នុងខ្លួនខ្ញុំត្រូវញាំញីហើយ អស់ទាំងឆ្អឹងខ្ញុំក៏ញ័រ ខ្ញុំដូចជាមនុស្សស្រវឹង គឺដូចជាមនុស្សដែលស្រាទំពាំងបាយជូរបានឈ្នះហើយ ដោយព្រោះព្រះអម្ចាស់ហើយ ដោយព្រោះព្រះបន្ទូល ដ៏បរិសុទ្ធរបស់ព្រះអង្គ។[10]ដ្បិតទឹកដីនេះមានពេញដោយមនុស្ស ដែលប្រព្រឹត្តអំពើកំផិត ហើយទឹកដីក៏យំសោក ដោយព្រោះបណ្តាសា អស់ទាំងទីឃ្វាលសត្វនៅទីរហោស្ថាន បានហួតហែងអស់ហើយ គេរត់តាមតែសេចក្តីអាក្រក់ ហើយគេប្រើអំណាចសម្រាប់តែការទុច្ចរិតទេ។

generated on Wed Sep 10 16:16:32 2025

[11]ដ្បិតទាំងព្យាការី និងបូជាចារ្យ សុទ្ធតែស្មោកគ្រោកទាំងអស់គ្នា ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងបានឃើញអំពើអាក្រក់របស់គេ នៅក្នុងព្រះវិហាររបស់យើង[12]ហេតុនោះ ផ្លូវរបស់គេនឹងបានដូចជាកន្លែងរអិល នៅទីងងឹតដល់គេ គេនឹងត្រូវច្រានទៅ ហើយដួលចុះនៅទីនោះ ដ្បិតយើងនឹងនាំសេចក្តីអាក្រក់មកលើគេ គឺជាឆ្នាំដែលត្រូវធ្វើទោសដល់គេ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[13]ដ្បិតក្រុងសាម៉ារី យើងបានឃើញពួកព្យាការី ប្រព្រឹត្តអំពើដ៏អាស្រូវ គឺពួកគេនាំគ្នាទាយក្នុងនាមព្រះបាល ពួកគេនាំអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង ឲ្យវង្វេង។[14]រីឯនៅក្រុងយេរូសាឡឹមវិញ យើងឃើញអំពើគួរឲ្យស្អប់ខ្ពើម គឺពួកគេប្រព្រឹត្តអំពើផិតក្បត់ ពួកគេនិយមការកុហក ពួកគេលើកទឹកចិត្តអ្នកប្រព្រឹត្តអំពើអាក្រក់ ដូច្នេះ គ្មាននរណាអាចងាកចេញពីផ្លូវអាក្រក់ របស់ខ្លួនបានឡើយ។ ចំពោះយើង ពួកគេទាំងអស់គ្នាប្រៀបដូចជា អ្នកក្រុងសូដុម ហើយអ្នកក្រុងយេរូសាឡឹមក៏ប្រៀបដូចជា អ្នកក្រុងកូម៉ូរ៉ាដែរ!»[15]ហេតុនេះ ព្រះអម្ចាស់នៃពិភពទាំងមូល មានព្រះបន្ទូលស្តីអំពីពួកព្យាការីថា៖ «យើងនឹងឲ្យពួកគេបរិភោគផ្លែស្លែង និងឲ្យពួកគេផឹកទឹកដែលមានជាតិពុល ដ្បិតអំពើទុច្ចរិតបានរាលដាលពាសពេញ ទឹកដីទាំងមូល ព្រោះតែពួកព្យាការី នៅក្រុងយេរូសាឡឹមនេះឯង»។
[16]ព្រះអម្ចាស់នៃពិភពទាំងមូល ព្រះបន្ទូលដូច្នេះថា៖ «កុំស្តាប់តាមពាក្យរបស់ព្យាការី ដែលគេថ្លែងទំនាយប្រាប់អ្នករាល់គ្នាឲ្យសោះ គេនាំអ្នករាល់គ្នាឲ្យវង្វេងទេ គេសម្តែងចេញតែពីការដែលគេនឹកឃើញក្នុងចិត្តគេ មិនមែនជាសេចក្តីដែលចេញពីព្រះឧស្ឋរបស់ព្រះអង្គឡើយ។[17]គេចេះតែប្រាប់ដល់ពួកអ្នកដែលមើលងាយយើងថា៖ ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា អ្នករាល់គ្នានឹងមានសន្តិសុខទេ ហើយក៏ប្រាប់ដល់ពួកអ្នកដែលប្រព្រឹត្តតាមតែសេចក្តីរឹងចចេសនៅក្នុងចិត្តថា នឹងគ្មានសេចក្តីអាក្រក់ណាកើតដល់អ្នករាល់គ្នាឡើយ។[18]ដ្បិតតើអ្នកណាបានឈរក្នុងពួកប្រឹក្សានៃព្រះអម្ចាស់ ឲ្យបានឃើញ ហើយឮព្រះបន្ទូលរបស់ព្រះអង្គ? តើអ្នកណាបានប្រុងស្តាប់ ហើយឮព្រះបន្ទូលរបស់ព្រះអង្គ?
[19]មើល៍! ព្យុះសង្ឃរារបស់ព្រះជាម្ចាស់ គឺជាសេចក្តីក្រោធរបស់ព្រះអង្គបានចេញទៅហើយ ជាព្យុះកួចដែលនឹងធ្លាយមកលើក្បាល របស់ពួកមនុស្សអាក្រក់។[20]សេចក្តីក្រោធរបស់ព្រះអម្ចាស់នឹងមិនវិលទៅវិញឡើយ ទាល់តែព្រះអង្គបានធ្វើសម្រេច ហើយបានបង្ហើយតាមបំណងព្រះហឫទ័យព្រះអង្គ នៅថ្ងៃខាងមុខ អ្នករាល់គ្នានឹងយល់ច្បាស់។
[21]យើងមិនបានចាត់ប្រើពួកព្យាការីទាំងនេះទេ តែគេបានរត់ទៅ យើងមិនបាននិយាយនឹងគេសោះ តែគេបានទាយ។[22]ប្រសិនបើគេគ្រាន់តែឈរនៅក្នុងពួកប្រឹក្សារបស់យើង នោះគេនឹងប្រាប់ឲ្យប្រជារាស្ត្ររបស់យើង ស្តាប់ពាក្យរបស់យើងហើយ ព្រមទាំងបំបែរគេចេញពីផ្លូវអាក្រក់ និងពីអំពើដ៏លាមកដែលប្រព្រឹត្តរៀងខ្លួន។
[23]ព្រះអម្ចាស់មានបន្ទូលសួរថា៖ តើយើងជាព្រះដែលនៅឆ្ងាយ ឥតនៅជិតបង្កើយឬអី?[24]ព្រះជាម្ចាស់សួរដូច្នេះទៀតថា៖ តើមានអ្នកណានឹងពួននៅទីស្ងាត់ណា ដែលយើងមើលមិនឃើញបានឬ? តើយើងមិននៅពេញស្ថានសួគ៌ និងផែនដីផងទេឬ? នេះជាព្រះបន្ទូលរបស់ព្រះអង្គ។
[25]យើងបានឮសេចក្តីដែលពួកព្យាការីប្រាប់ ជាពួកអ្នកដែលថ្លែងទំនាយកុហក ដោយនូវឈ្មោះយើងថា ខ្ញុំបានយល់សប្តិ ឃើញដូច្នេះមួយៗ![26]សេចក្តីយ៉ាងនេះនឹងនៅក្នុងចិត្តនៃពួកព្យាការីដែលថ្លែងទំនាយកុហក ជាពួកអ្នកដែលបញ្ឆោតតាមសេចក្តីនៅក្នុងចិត្តគេ តើដល់កាលណាទៀត?[27]គេគិតតែបណ្តាលឲ្យប្រជារាស្ត្ររបស់យើងភ្លេចឈ្មោះយើង ដោយការយល់សប្តិរបស់គេ ដែលថ្លែងប្រាប់ដល់អ្នកជិតខាងគេរៀងខ្លួន ដូចជាបុព្វបុរសគេបានភ្លេចឈ្មោះយើង ឲ្យយកឈ្មោះព្រះបាលវិញដែរ។
[28]ព្យាការីណាដែលយល់សប្តិឲ្យគេប្រាប់តាមសប្តិនោះចុះ ហើយព្យាការីណាដែលបានទទួលពាក្យយើង ត្រូវឲ្យអ្នកនោះប្រាប់ពាក្យយើង ដោយស្មោះត្រង់ទៅ តើចំបើងជាអ្វីចំពោះស្រូវ? នេះជាព្រះបន្ទូលរបស់ព្រះអង្គ [29]ពាក្យរបស់យើង តើមិនមែនដូចជាភ្លើង ហើយដូចជាញញួរ ដែលបំបែកថ្មខ្ទេចខ្ទីទេឬ?[30]ដូច្នេះ មើល៍! ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងទាស់នឹងពួកព្យាការី ដែលជាពួកអ្នកដែលលួចពាក្យពីអ្នកដទៃផ្សេងទៀត ហើយនិយាយថា គឺជាព្រះបន្ទូលរបស់យើងទៅវិញ។
[31]មើល៍! យើងទាស់នឹងពួកព្យាការីដែលប្រើអណ្តាតនិយាយនិង ប្រកាសពីព្រះបន្ទូលព្រះអង្គ។[32]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ មើល៍! យើងទាស់នឹងពួកអ្នកដែលថ្លែងទំនាយកុហកតាមយល់សប្តិ ព្រមទាំងផ្សាយប្រាប់សប្តិនោះ ហើយនាំឲ្យប្រជារាស្ត្ររបស់យើងវង្វេងចេញដោយសារពាក្យកុហករបស់គេ ហើយដោយសារសេចក្តីអំនួតឥតប្រយោជន៍របស់គេដែរ តែព្រះអង្គមានបន្ទូលថា៖ យើងមិនបានចាត់គេ ឬបង្គាប់គេឡើយ គេក៏គ្មានប្រយោជន៍អ្វីដល់ជនជាតិនេះដែរ។
[33]កាលណាប្រជាជននេះ ឬព្យាការីណាម្នាក់ ឬសង្ឃណាម្នាក់ សួរអ្នកថា៖ តើបន្ទុករបស់ព្រះជាម្ចាស់ជាអ្វី? អ្នកត្រូវឆ្លើយតបទៅគេថា៖គឺអ្នករាល់គ្នាហ្នឹងហើយជាបន្ទុក យើងនឹងបោះបង់អ្នករាល់គ្នាចោល នេះជាព្រះបន្ទូលទ្រង់ ។[34]ព្យាការីណា និងបូជាចារ្យណា ឬជនជាតិណាដែលពោលថា នេះជាបន្ទុកពីព្រះអម្ចាស់ហើយ យើងនឹងធ្វើទោសដល់អ្នកនោះ ព្រមទាំងពួកវង្សគេ។
[35]អ្នករាល់គ្នាបន្តសួរអ្នកជិតខាង និងបងប្អូនអ្នករៀងខ្លួនដូច្នេះវិញថា តើព្រះអម្ចាស់ដែលបានតបឆ្លើយយ៉ាងដូចម្តេច? ឬថា តើព្រះជាម្ចាស់បានមានព្រះបន្ទូលយ៉ាងណា?[36]ប៉ុន្តែអ្នករាល់គ្នាមិនត្រូវនិយាយពីបន្ទុករបស់ព្រះអង្គទៀតឡើយ ឯបន្ទុករបស់អ្នករាល់គ្នា នោះគឺជាពាក្យរបស់គ្រប់គ្នាវិញ ពីព្រោះអ្នករាល់គ្នាបានបំផ្លាស់បំប្រែព្រះបន្ទូលនៃព្រះដ៏មានព្រះជន្មរស់ គឺព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះនៃយើងរាល់គ្នា។
[37]អ្នកត្រូវសួរព្យាការីយ៉ាងដូច្នេះថា៖ តើព្រះជាម្ចាស់ឆ្លើយនឹងអ្នកយ៉ាងដូចម្តេច? ឬថា តើព្រះអង្គបានមានព្រះបន្ទូលយ៉ាងណាខ្លះ?[38]ប៉ុន្តែ បើអ្នករាល់គ្នាហ៊ាននិយាយថា៖ នេះជាបន្ទុករបស់ព្រះអម្ចាស់ហើយ នោះព្រះអង្គនិងមានព្រះបន្ទូលដូច្នេះថា៖ ដោយព្រោះអ្នករាល់គ្នាចេញពាក្យថា បន្ទុករបស់ព្រះអម្ចាស់ ហើយយើងបានចាត់គេឲ្យមក ឯអ្នកហាមនិយាយថា «កុំឲ្យនិយាយពីបន្ទុកព្រះអង្គឡើយ»[39]ដូច្នេះ មើល៍ ប្រាកដជាយើងនឹងលើកអ្នករាល់គ្នា ហើយបោះអ្នករាល់គ្នាឲ្យចេញឆ្ងាយពីមុខយើង គឺទាំងអ្នករាល់គ្នា ព្រមទាំងទីក្រុងដែលយើងបានឲ្យដល់អ្នករាល់គ្នា និងបុព្វបុរសរបស់អ្នករាល់គ្នា។[40]យើងនឹងនាំសេចក្តីដំណៀលដ៏នៅជាប់អស់កល្បមកលើអ្នករាល់គ្នា ព្រមទាំងសេចក្តីខ្មាសនៅជាប់ជានិច្ចដែលភ្លេចមិនបានឡើយ»។

Jeremiah 23:1
ពួកគង្វាលដែលបំផ្លាញ ហើយធ្វើឲ្យហ្វូងចៀមខ្ចាត់ខ្ចាយពីវាលស្មៅយើង
ព្រះអម្ចាស់ចាត់ទុកអ៊ីស្រាអែលជាវាលស្មៅរបស់ព្រះអង្គប្រជាជនអ៊ីស្រាអែលប្រៀបដូចជាចៀម និងមេដឹកនាំរបស់ពួកគេនៅស្រុកអ៊ីស្រាអែលប្រៀបដូចជាអ្នកគង្វាល។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
អ្នករាល់គ្នាបោះបង់ចោលកូនចៀមរបស់យើងឲ្យខ្ចាត់ខ្ចាយ
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា។ ឃ្លាទីពីរជួយឲ្យគំនិតនៃឃ្លាទី ១កាន់តែមានន័យ។
ដាក់ទោសដល់អ្នកពីការអាក្រក់ដែលអ្នកបានប្រព្រឹត្ត
ព្រះអម្ចាស់សំដៅទៅលើសអំពើអាក្រក់ដូចជាប្រាក់កម្ចីដែលត្រូវបានផ្តល់ឲ្យហើយត្រូវសងត្រលប់វិញ។ ការបកប្រែរបៀបផ្សេងទៀត: «សងត្រលប់ចំពោះអំពើអាក្រក់»
Jeremiah 23:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីប្រជារាស្ត្រអ៊ីស្រាអែល ប្រៀបដូចជាចៀម និងមេដឹកនាំជនជាតិអ៊ីស្រាអែលគឺជាអ្នកគង្វាល។
នាំវិលត្រឡប់មកក្រោលគេវិញ
ការបកប្រែរបៀបផ្សេងទៀត:
«ទៅកន្លែងដែលតម្រូវការរបស់ពួកគេទាំងអស់នឹងត្រូវផ្គត់ផ្គង់»
គេនឹងបង្កើតផល ហើយចម្រើនឡើង
ពាក្យថា «ចម្រើនឡើង» បង្ហាញពីរបៀបដែលគេនឹង «បង្កើតផល»។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងចម្រើនឡើងជាចំនួនយ៉ាងច្រើន»។
ពួកវានឹងមិនភ័យ ឬខ្ចាត់ខ្ចាយទៀតទេ
ពាក្យថា «ខ្ចាត់ខ្ចាយ» មានន័យថាមាននរណាម្នាក់បានធ្វើឲ្យពួកគេភ័យខ្លាច ហើយមានន័យថាដូចគ្នានឹង «ការភ័យខ្លាច»។ ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់នឹងឱ្យយើងភ័យខ្លាចទៀតទេ»។
ពួកគេនឹងមិន
ប្រជារាស្ត្រយើងនឹងមិន
Jeremiah 23:5
គ្រាមកដល់
ពេលអនាគត ត្រូវបានគេថ្លែងប្រៀបដូចជាការមួយនឹងឆ្ពោះទៅកាន់អ្នកថ្លែង ឬអ្នកស្តាប់។ ការបកប្រែរបៀបផ្សេងទៀត: «ពេលវេលានឹងកើតឡើង»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
«អ្វីដែលព្រះអម្ចាស់បានប្រកាស» ឬ «អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល»។
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
ខ្មែងសុចរិតមួយ

generated on Wed Sep 10 16:16:32 2025

ស្តេចនាពេលអនាគតដែលតពីស្តេចដាវីឌត្រូវបានគេនិយាយថាគាត់គឺជាខ្នែងនៃដើមឈើរបក
ការបកប្រែរបៀបផ្សេងទៀត: «កូនចៅដ៏សុចរិត»
ខ្នែងសុចរិតមួយ
ការបកប្រែនាពេលបច្ចុប្បន្ន បកស្រាយថា
«អ្នកស្នងរាជ្យស្របច្បាប់ចំពោះការគ្រងរាជ្យ»។
ប្រព្រឹត្តសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិតនៅក្នុងទឹកដី
«សេចក្តីយុត្តិធម៌» និង «សេចក្តីសុចរិត» តំណាង
ឲ្យមនុស្សដែលប្រព្រឹត្តត្រឹមត្រូវនិងទៀងត្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឲ្យមនុស្សប្រព្រឹត្តត្រឹមត្រូវ និងទៀងត្រង់»
នៅក្នុងទឹកដី
ពាក្យថា «ទឹកដី» បង្ហាញពីប្រជាជនទាំងអស់នៅក្នុងប្រទេស។
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតប្រជាជនទាំងអស់នៅក្នុងប្រទេស»
ពួកយូដានឹងបានសង្គ្រោះ ហើយពួកអ៊ីស្រាអែលនឹងនៅដោយសន្តិសុខ
ឃ្លាទាំងពីរមានអត្ថន័យស្រដៀងគ្នា។
ពួកយូដានឹងបានសង្គ្រោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទ្រង់នឹងសង្គ្រោះពួកយូដាពីខ្មាំងសត្រូវរបស់ពួកគេ»
Jeremiah 23:7
ដូចជាព្រះអម្ចាស់មានព្រះជន្មរស់
នេះឃ្លាប្រើសម្រាប់ជាពាក្យសម្បថ។
ទឹកដីខាងជើងហើយពីគ្រប់អស់ទាំងទឹកដីដែលគេត្រូវបានចាប់យកទៅ
នេះសំដៅរបៀបដែលកុលសម្ព័ន្ធទាំងដប់ដែលស្ថិតនៅភាគខាងជើងនៃអ៊ីស្រាអែលត្រូវបានចាប់យក
និងបែកខ្ញែកនៅតាមបណ្តាប្រទេសជុំវិញ។
Jeremiah 23:9
ព័ត៌មានទូទៅ:
អ្នកថ្លែងបានផ្លាស់ប្តូរពីព្រះអម្ចាស់មកលោកយេរេមា។
ពីដំណើរពួកព្យាការី ចិត្តនៅក្នុងខ្លួនខ្ញុំត្រូវញាំញីហើយ អស់ទាំងឆ្អឹងខ្ញុំក៏ញ័រ
ចិត្តពួកព្យាការី បានបាក់បែក ហើយឆ្អឹងក៏ញាប់ញ័រ
ព្រោះតែគេភ័យខ្លាចការជំនុំជំរះដែលនឹងបណ្តាលមកពីពាក្យកុហករបស់ពួកព្យាការីក្លែងក្លាយ
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំភ័យខ្លាចយ៉ាងខ្លាំងចំពោះអ្វីដែលនឹងកើតឡើងដោយសារតែពួកព្យាការីក្លែងក្លាយ»
ចិត្តរបស់ខ្លួនខ្ញុំត្រូវបាក់បែកនៅក្នុងខ្ញុំ
អារម្មណ៍ពួកព្យាការីត្រូវបានគេថ្លែងប្រៀបដូចជាចិត្តរបស់គេ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំមានចិត្តក្រៀមក្រំណាស់»
អស់ទាំងឆ្អឹងខ្ញុំភ័យញ័រ
អារម្មណ៍នៃការភ័យញ័រនៅទីនេះត្រូវបានគេថ្លែងប្រៀបដូចជាឆ្អឹងរបស់ពួកព្យាការីញាប់ញ័រ
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំភ័យខ្លាចណាស់»
ខ្ញុំដូចជាមនុស្សស្រវឹង គឺដូចជាមនុស្សដែលស្រាទំពាំងបាយជូរបានឈ្នះហើយ
ការសោកសៅនិងការភ័យខ្លាចនៅទីនេះត្រូវបានគេបានថ្លែងប្រៀបដូចជាអ្នករងគ្រោះដែលស្រវឹង
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំដូចជាមនុស្សស្រវឹង
ហើយមិនអាចគ្រប់គ្រងខ្លួនឯងបានទេ»
ទឹកដីនេះមានពេញដោយមនុស្សកំផិត
ការនិយាយកុហកនេះត្រូវបានប្រើដើម្បីបង្ហាញពីកម្រិតនៃការប្រព្រឹត្តអំពើបាបដែលមានដោយសារតែ
មនុស្សកំផិត
ពាក្យនេះអាចតំណាងឲ្យគំនិតជាក់ស្តែងដែលថាបុរសភាគច្រើននៅក្នុងទឹកដីនេះបានប្រព្រឹត្តអំពើបាប
ហើយដូចគ្នានេះដែរជាពាក្យភាសានៅក្នុងព្រះគម្ពីរសម្រាប់គំនិតដែលពួកគេបោះបង់ព្រះ
ទឹកដីហួតហែង
ការបកប្រែក្នុងសម័យបច្ចុប្បន្នខ្លះ បានបកប្រែឃ្លាភាសាហេព្រើរនេះថា
«ទឹកដីសោកសង្រែង»។
Jeremiah 23:11
ព័ត៌មានទូទៅ:
អ្នកថ្លែងបានផ្លាស់ប្តូរពីព្រះអម្ចាស់មកលោកយេរេមា។
បូជាចារ្យ សុទ្ធតែស្មោកគ្រោក
ការបកប្រែរបៀបផ្សេងទៀត: «ពួកបូជាចារ្យដែលមានអំពើបាប»
ក្នុងព្រះវិហាររបស់យើង
នៅទីនេះព្រះវិហាររបស់ព្រះអម្ចាស់ត្រូវបានគេប្រៀបធៀបទៅនឹងផ្ទះដែលជាកន្លែងដែលពួកបូជាចារ្យ
ព្រះបន្ទូលនៃព្រះអម្ចាស់
«ជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល» ឬ «ជាអ្វីដែលព្រះអម្ចាស់បានប្រកាស»
ដូចជាកន្លែងរអិល នៅទីងងឹត

នៅក្នុងឆ្នាំនៃការជំនុំជម្រះដល់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលការ ជំនុំជម្រះរបស់ពួកគេមកដល់»
Jeremiah 23:13
ដើរក្នុងសេចក្តីបោកប្រាស់
«រស់នៅដោយមិនស្មោះត្រង់»
ចម្រើនពួកមនុស្សទុច្ចរិត
«ពួកគេគាំទ្រអ្នកដែលធ្វើអំពើអាក្រក់»
គ្មាននរណាងាកបែរចេញពីអំពើអាក្រក់ទេ
«ពួកគេបន្តប្រព្រឹត្តអំពើបាប»
កគេទាំងអស់គ្នាប្រៀបដូចជា អ្នកក្រុងសូដុម ហើយមនុស្សក្នុងក្រុងនោះប្រៀបដូចជា អ្នកក្រុងកូម៉ូរ៉ា
ដែរ!
«ពួកគេបានក្លាយជាមនុស្សអាក្រក់»
យើងនឹងឲ្យពួកគេបរិភោគផ្លែស្លែង និងឲ្យពួកគេផឹកទឹកដែលមានជាតិពុល
ផ្លែស្លែងជាផ្លែឪ្យាងដែលជូរចត់ និងមិនល្អក្នុងការបរិភោគ។
ឃ្លានេះពិពណ៌នាអំពីការដាក់ទណ្ឌកម្មដែលព្រះអម្ចាស់នឹងធ្វើទៅលើពួកព្យាការីអាក្រក់។
តាមរបៀបដូចគ្នា ផ្លែស្លែងគឺជូរចត់ហើយទឹកមានជាតិពុល
ដូច្នេះការជំនុំជម្រះរបស់ព្រះអម្ចាស់នឹងស្ថិតនៅលើពួកព្យាការីអាក្រក់។
អំពើទុច្ចរិតបានរាលដាល ដោយសារតែពួកព្យាការី
«អំពើអាក្រក់មកពីពួកព្យាការី»
Jeremiah 23:16
ការបកប្រែរបៀបផ្សេងទៀត: «ពួកព្យាការីបានធ្វើឲ្យ អ្នកជឿអ្វីមួយដែលមិនពិត!»
និមិត្តចេញពីគំនិតរបស់គេ
ការបកប្រែរបៀបផ្សេងទៀត: «និមិត្តដែលពួកគេស្រមៃឃើញ»
មិនមែនចេញពីព្រះឧស្ឋរបស់ព្រះអម្ចាស់ឡើយ
ការបកប្រែរបៀបផ្សេងទៀត: «មិនមែនមកពីព្រះអម្ចាស់ទេ»
ប៉ុន្តែតើអ្នកណាបានឈរក្នុងពួកប្រឹក្សានៃព្រះអម្ចាស់? តើអ្នកណាបានឃើញ ហើយឮព្រះបន្ទូល
តើអ្នកណាបានប្រុងស្តាប់ ហើយឮព្រះបន្ទូលរបស់ព្រះអង្គ?
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់ប្រឹក្សាដល់ព្រះអម្ចាស់ទេ។
គ្មាននរណាម្នាក់យល់ពីអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលទេ។
គ្មាននរណាម្នាក់ប្រតិបត្តិតាមបញ្ជាតិបស់ព្រះអម្ចាស់ទេ»។
Jeremiah 23:19
ព្យុះបានកួចនៅទីនោះ
ការបកប្រែរបៀបផ្សេងទៀត: «វាដូចជាខ្យល់ព្យុះដ៏ធំសម្បើមមួយ»
ព្យុះក៏កួចក្បាល របស់ពួកមនុស្សអាក្រក់
ការបកប្រែរបៀបផ្សេងទៀត: «ដែលបកលើមនុស្សអាក្រក់»
ពួកវាបានចេញអស់ តាមបំណងព្រះហឫទ័យព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត:
«សេចក្តីក្រោធរបស់ព្រះអម្ចាស់នឹងនាំមកនូវការដាក់ទណ្ឌកម្មទាំងអស់ដែលទ្រង់មានផែនការ»។
Jeremiah 23:21
ប្រសិនបើគេគ្រាន់តែឈរនៅក្នុងទីប្រជុំពួកប្រឹក្សារបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើពួកគេពិតជាបានស្តាប់យើង»
Jeremiah 23:23
ការបកប្រែរបៀបផ្សេងទៀត: «យើងគឺជាព្រះដែលនៅជិតបង្កើយ ឬនៅឆ្ងាយ»។
តើមានអ្នកណាអាចពួននៅទីស្ងាត់ ដែលយើងមើលមិនរកគេឃើញទេ?
«គ្មាននរណាម្នាក់អាចលាក់ខ្លួននៅក្នុងទីស្ងាត់បានទេ
ដូច្នេះយើងមិនអាចមើលឃើញគេទេ»។
តើយើងមិនបានបំពេញស្ថានសួគ៌ និងផែនដីផងទេឬ?
«យើងនៅគ្រប់ទីកន្លែង ទាំងនៅលើផ្ទៃមេឃ និងនៅលើផែនដីផងដែរ»។
Jeremiah 23:25
តើការទាំងនេះនឹងកើតមានដល់កាលណាទៀត ពួកព្យាការីដែលថ្លែងទំនាយ
កុហកចេញពីគំនិតរបស់គេ ហើយជាអ្នកដែលថ្លែងទំនាយបញ្ឆោតតាមចិត្តរបស់គេ?
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់មានបន្ទូលថា ប្រជារាស្ត្ររបស់ព្រះអង្គ។
ពួកព្យាការីដែលប្រកាសពាក្យកុហកដែលខ្លួនពួកគេបានថ្លែង»។
ធ្វើឲ្យប្រជារាស្ត្ររបស់យើងភ្លេចឈ្មោះយើង ជាមួយសប្តិដែលបានថ្លែងរបស់គេ ប្រាប់ដល់អ្នកជិត
ខាងគេរៀងខ្លួន ដូចជាដូនតារបស់គេបានភ្លេចឈ្មោះយើង ឲ្យយកឈ្មោះព្រះបាលវិញដែរ

generated on Wed Sep 10 16:16:32 2025

ធ្វើឲ្យប្រជារាស្ត្ររបស់យើងថ្វាយបង្គំព្រះបាលជំនួសយើងវិញ»
Jeremiah 23:28
តើចំបើងនឹងធ្វើអ្វីជាមួយស្រូវ?
ការបកប្រែរបៀបផ្សេងទៀត: «ចំបើង និងស្រូវគឺជាវត្ថុពីរផ្សេងគ្នា»។
តើពាក្យរបស់យើងមិនមែនដូចជាភ្លើងទេឬ? នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយដូចជាញញួរ
ដែលបំបែកថ្មខ្ទេចខ្ទីទេឬ?
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់មានព្រះបន្ទូលដូចភ្លើងឆេះសន្ធោសន្ធៅ»
«និងដូចញញួរដែលវាយបំបែកថ្មខ្ទេចខ្ទី»។
ដូចជាញញួរ ដែលបំបែកថ្មខ្ទេចខ្ទីទេឬ
«មានកម្លាំងដូចញញួរដែលអាចកំទេចថ្មបាន»
Jeremiah 23:31
ថ្លែងទំនាយបោកប្រាស់តាមយល់សប្តិ
«ដែលអះអាងថាខ្លួនបានយល់សប្តិពីព្រះជាម្ចាស់
តែពួកគេមិនមែនមកពីព្រះជាម្ចាស់ទេ»។
Jeremiah 23:33
តើមានការប្រកាសអ្វីខ្លះ?
សំណួរនេះមានន័យថាដូចជាឃ្លាមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មានការប្រកាសអ្វីនោះទេ»។
Jeremiah 23:35
អ្នករាល់គ្នាបានបំផ្លាស់បំប្រែព្រះបន្ទូលនៃព្រះដ៏មានព្រះជន្មរស់
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបានកែព្រះបន្ទូលរបស់ព្រះអម្ចាស់
ដើម្បីថ្លែងពីអ្វីដែលអ្នកចង់ឲ្យគេថ្លែងចេញទៅ»
Jeremiah 23:37
ព័ត៌មានទូទៅ:
សូមមើល:
តើព្រះអង្គបានមានព្រះបន្ទូលបែបណាខ្លះ?
ការបកប្រែរបៀបផ្សេងទៀត: «តើព្រះអម្ចាស់មានព្រះបន្ទូលអ្វីខ្លះ»
ដូច្នោះហើយ មើល!
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះសូមយកចិត្តទុកដាក់»
យើងនឹងលើកអ្នកឡើង ហើយបោះអ្នករាល់គ្នាឲ្យចេញឆ្ងាយពីមុខយើង
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងដេញអ្នកចេញពីយើង»
ជានិច្ចមិនអាចភ្លេចបានឡើយ
ការបកប្រែរបៀបផ្សេងទៀត: «ដែលនឹងនៅចិតថេរ»

---

24 [1]ព្រះជាម្ចាស់បង្ហាញឲ្យខ្ញុំឃើញផ្លែល្វាពីរល្អ ដាក់នៅមុខព្រះវិហារនៃព្រះអង្គ ក្រោយពេលដែលព្រះបាទនេប៊ូក្នេសា ជាស្តេចបាប៊ីឡូនចាប់ព្រះបាទយេកូនាស ជាបុត្រ
ព្រះបាទយេហូយ៉ាគីម ស្តេចយូដា នាំទៅជាឈ្លើយ ព្រមទាំងពួកចៅហ្វាយនៃទឹកដីយូដា និងពួករចនា ហើយពួកជាង ចេញពីក្រុងយេរូសាឡិម ទៅដល់ទឹកដី
បាប៊ីឡូន។[2]ល្អមួយមានផ្លែល្វាល្អណាស់ ដូចជាផ្លែល្វាដែលទុំមុនគេ ឯល្អមួយទៀតមានផ្លែល្វាអាក្រក់ណាស់ ដែលបរិភោគមិនបាន ដោយព្រោះអាក្រក់ពេក។[3]ព្រះជាម្ចាស់
មានព្រះបន្ទូលសួរខ្ញុំថា៖ «យេរេមាអើយ អ្នកឃើញអ្វីនុ៎ះ»។ ខ្ញុំក៏ទូលឆ្លើយថា៖ «ឃើញផ្លែល្វា ឯផ្លែល្អ នោះល្អណាស់ ហើយផ្លែអាក្រក់ ក៏អាក្រក់ណាស់ដែរ បរិភោគមិន
បាន ពីព្រោះអាក្រក់ពេក»។
[4]ពេលនោះ ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់ខ្ញុំថា៖[5]«ព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា "ដូចជាអ្នកបានស្គាល់ផ្លែល្វាល្អនេះ យើងក៏
នឹងស្គាល់ពួកយូដា ដែលត្រូវគេនាំទៅជាឈ្លើយនោះដែរ ដើម្បីនឹងប្រោសឲ្យគេបានសេចក្តីល្អ គឺជាពួកអ្នកដែលយើងបានបណ្តេញចេញពីទីនេះ ទៅដល់ទឹកដីខាល់ដេ
ហើយ។[6]ដ្បិតយើងនឹងតាមមើលគេ ឲ្យបានសេចក្តីល្អ ហើយនឹងនាំគេមកក្នុងទឹកដីនេះវិញ យើងនឹងស្អាងគេឡើង មិនរុះវិញឡើយ ក៏ដាំគេចុះ ឥតរំលើងចេញដែរ។[7]យើង
នឹងឲ្យគេមានចិត្តដែលស្គាល់យើងថា ជាព្រះអម្ចាស់ របស់គេ ហើយពួកគេជាប្រជារាស្ត្ររបស់យើង ពីព្រោះគេនឹងវិលមកឯយើងដោយអស់ពីចិត្ត។
[8]ប៉ុន្តែផ្លែឧទម្ពរអាក្រក់ ដែលបរិភោគមិនបាន ដោយព្រោះអាក្រក់ពេក នោះព្រះអង្គមានព្រះបន្ទូលជាប្រាកដថា យើងនឹងឲ្យសេដេគា ជាស្តេចយូដា បានយ៉ាងដូច្នោះដែរ
ព្រមទាំងពួកចៅហ្វាយ និងសំណល់មនុស្សនៅក្រុងយេរូសាឡិម ដែលសល់នៅក្នុងទឹកដីនេះ និងពួកដែលនៅទឹកដីអេស៊ីបផង។[9]យើងនឹងប្រគល់គេទៅឲ្យត្រូវរសាត់
អណ្តែត នៅកណ្តាលអស់ទាំងនគរនៅផែនដី ឲ្យបានសេចក្តីអាក្រក់ ដើម្បីឲ្យគេបានជាទីដៀលត្មះ ជាពាក្យទំនៀម ជាទីអុចអាល ហើយជាទីផ្តាសា នៅគ្រប់ទីកន្លែងណា
ដែលយើងនឹងបណ្តេញទៅនោះ។[10]យើងនឹងចាត់ដាវ និងអំណត់ ហើយអាសន្នរោគ ឲ្យនៅកណ្តាលពួកគេ ដរាបដល់គេសូន្យបាត់អស់រលីងពីទឹកដីដែលយើងបានឲ្យដល់
គេ ហើយដល់បុព្វបុរសគេទៅ»។

Jeremiah 24:1
មើល!
ពាក្យថា «មើល!» ទីនេះបង្ហាញពីលោកយេរេមាបានឃើញពីអ្វីដែលចាប់អារម្មណ៍។
និមិត្តនេះបានកើតឡើង...ទៅដល់ទឹកដីបាប៊ីឡូន
ផ្នែកនេះត្រូវបានផ្តល់ពីព័ត៌មានប្រវត្តិសាស្ត្រដើម្បីបង្ហាញនៅពេលព្រឹត្តិការណ៍កើតឡើង
ពួករចនា
ពួកមនុស្សដែលពូកែខាងបង្កើតវត្ថុ។
ពួកជាងដែក
ពួកមនុស្សដែលបង្កើតអ្វីដែលចេញពីដែក។
Jeremiah 24:4
ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។
គឺដូចជាផ្លែល្វាល្អ
ផ្លែល្វាល្អដែលល្អ គឺជាពួកអ្នកដែលត្រូវបានបណ្តេញចេញពីស្រុកយូដា
ដែលត្រូវបានបញ្ជូនទៅស្រុកខាល់ដេ។
យើងនឹងចាំមើលពួកគេ សម្រាប់ការល្អ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងប្រទានពរគេ»។
យើងនឹងសាងសង់គេឡើងវិញ ហើយមិនហែកគេឡើយ។យើងនឹងដាំពួកគេ ហើយមិនដកឫសគេ
ចេញដែរ។
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ប្រយោគទី២
បានធ្វើឲ្យគំនិតក្នុងគំនិតទីមួយប្រសើរឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងជួយគេឲ្យរីកចម្រើននៅស្រុកខាល់ដេ»។
យើងនឹងសាងសង់គេឡើងវិញ ហើយមិនហែកគេឡើយ។
ឃ្លានេះប្រៀបធៀបពួកអ្នកដែលត្រូវបានបណ្តេញចេញ
ទៅនឹងអាគារដែលព្រះអម្ចាស់នឹងសាងសង់ ហើយមិនបំផ្លាញគេឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំនឹងជួយគេឲ្យរីកចម្រើនឡើងនៅលើទឹកដីនេះ
ហើយមិនបំផ្លាញពួកគេទេ»
ដកគេចេញ ដាំគេ ហើយមិនដកឫសគេចេញដែរ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងអោយពួកគេរស់នៅលើទឹកដីរបស់យើង
ហើយមិនដកពួកគេចេញទេ»
ពួកគេនឹងបែរមករកយើងជាមួយចិត្តរបស់គេ
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងបែរមករកយើងដោយសុខុមាលភាពរបស់ពួកគេ»
Jeremiah 24:8
ប៉ុន្តែផ្លែឧទម្ពរមិនល្អ ដែលអាក្រក់មិនអាចបរិភោគបាន
ឃ្លានេះប្រៀបធៀបផ្លែឧទម្ពរមិនល្អ ទៅនឹងពួកមនុស្សអាក្រក់។ ផ្លែឧទម្ពរមិនល្អ
គឺជាផ្លែដែលមិនអាចញ៉ាំបាន ឬគ្មានប្រយោជន៍។
ពួកមនុស្សអាក្រក់មិនគោរពតាមព្រះអម្ចាស់ ហើយក៏មិនបានចំណេញអ្វីដែរ។
យើងនឹងគេទៅក្នុងការគួរអោយរន្ធត់ និងមហន្តរាយ
ព្រះអម្ចាស់ប្រៀបធៀបការជំនុំជំរះដែលនឹងមកលើប្រជាជននៅក្រុងយេរូសាឡិមទៅនឹងអ្វីដែលនឹងធ្វើឲ្យអ្ន
យើងនឹងចាត់ដាវ និងគ្រោះទុរ្ភិក្ស ហើយអាសន្នរោគទាស់នឹងពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងប្រហារពួកគេដោយសឹកសង្គ្រាម
គ្រោះទុរ្ភិក្ស និងអាសន្នរោគ។»
យើងនឹងចាត់ដាវ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបញ្ជូនកងទ័ពសត្រូវ»

---

generated on Wed Sep 10 16:16:32 2025

25 [1]នេះជាព្រះបន្ទូលដែលបានមកដល់ព្យាការីយេរេមា ពីដំណើរប្រជាជនទឹកដីយូដា។ ក្នុងឆ្នាំទីបួននៃរជ្ជកាលព្រះបាទយេហូយ៉ាគីម ជាបុត្រព្រះបាទយ៉ូសៀស ស្តេចយូដា។ គឺជាឆ្នាំដំបូងនៃរជ្ជកាលព្រះបាទនេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន។[2]ជាសេចក្តីដែលព្យាការីយេរេមា បានប្រាប់ដល់បណ្តាជននៅទឹកដីយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់។
[3]ចាប់តាំងពីឆ្នាំទីដប់បី ក្នុងរាជ្យយ៉ូសៀសជាបុត្រអាំម៉ូន ស្តេចយូដា ដរាបដល់សព្វថ្ងៃនេះ គឺរយៈពេលម្ភៃបីឆ្នាំហើយ ដែលព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ ហើយខ្ញុំបានក្រោកពីព្រលឹមស្រាងប្រាប់ដល់អ្នករាល់គ្នា តែអ្នករាល់គ្នាមិនបានស្តាប់តាមទេ។[4]ព្រះជាម្ចាស់បានចាត់ពួកព្យាការីទាំងប៉ុន្មាន ជាអ្នកបម្រើរបស់ព្រះអង្គ ឲ្យមករកអ្នករាល់គ្នាជាច្រើនលើក ច្រើនសារ តែអ្នករាល់គ្នាមិនបានស្តាប់តាម ឬផ្ទៀងត្រចៀកស្តាប់សោះ។
[5]ព្យាការីទាំងនោះនិយាយថា៖ ចូរអ្នករាល់គ្នាវិលមកពីផ្លូវអាក្រក់របស់ខ្លួន ហើយពីអំពើអាក្រក់ដែលគ្រប់គ្នាប្រព្រឹត្តឥឡូវចុះ នោះអ្នករាល់គ្នានឹងបាននៅក្នុងទឹកដី ដែលព្រះអម្ចាស់បានប្រទានដល់អ្នក និងបុព្វបុរសអ្នក តាំងពីបុរាណ ហើយរហូតតទៅ។[6]កុំទៅតាមព្រះដទៃ ដើម្បីនឹងគោរព ហើយថ្វាយបង្គំដល់វាឡើយ ក៏កុំបណ្តាលឲ្យយើងខឹង ដោយសារការដែលដៃអ្នករាល់គ្នាធ្វើដែរ យ៉ាងនោះយើងនឹងមិនប្រទូស្តដល់អ្នករាល់គ្នាទេ។
[7]ប៉ុន្តែអ្នកមិនបានស្តាប់តាមពាក្យរបស់យើងឡើយ គឺអ្នកបាននាំអោយយើងខឹង និងកិច្ចការដែលដៃរបស់អ្នកធ្វើ មានការប្រទូស្តសារ៉ាយដល់យើង។[8]ហេតុនោះ ព្រះអម្ចាស់នៃពិភពទាំងមូល មានព្រះបន្ទូលថា៖ ដោយព្រោះអ្នករាល់គ្នាមិនបានស្តាប់តាមពាក្យយើង[9]យើងនឹងចាត់ទៅនាំយកអស់ទាំងពួកគ្រួនៅទឹកដីខាងជើង និងនេប៊ូក្នេសា ស្តេចបាប៊ីឡូន ជាអ្នកបម្រើរបស់យើងមក។ ព្រះជាម្ចាស់មានព្រះបន្ទូលទៀតថា៖ យើងនឹងនាំគេមកទាស់នឹងទឹកដីនេះ និងពួកអ្នកនៅក្នុងទឹកដី ហើយទាស់នឹងជនជាតិទាំងប៉ុន្មាននៅជុំវិញផង យើងនឹងបំផ្លាញពួកអ្នកទឹកដីនេះឲ្យអស់រលីង ព្រមទាំងធ្វើឲ្យទៅជាទីស្រឡាំងកាំង ជាទីដែលគេហួសចិត្ត ហើយជាទីខូចបង់នៅអស់កល្បជានិច្ច។
[10]យើងនឹងបំបាត់សំឡេងអរសប្បាយ សំឡេងរីករាយ សំឡេងប្តីប្រពន្ធថ្មោងថ្មី សូរត្បាល់កិន និងពន្លឺចង្កៀងពីពួកគេ។[11]ដូច្នេះ ទឹកដីនេះទាំងមូលនឹងនៅស្ងាត់ជ្រងំ ហើយជាទីស្រឡាំងកាំង ជនជាតិទាំងនេះនឹងត្រូវបម្រើស្តេចបាប៊ីឡូនអស់ចិតសិបឆ្នាំ។
[12]បន្ទាប់ពីចិតសិបឆ្នាំហើយ យើងនឹងធ្វើទោសស្តេចបាប៊ីឡូន និងពួកជនជាតិនោះ ដោយព្រោះអំពើទុច្ចរិតរបស់គេ ឯទឹកដីរបស់ពួកខាល់ដេ យើងនឹងធ្វើឲ្យស្ងាត់ជ្រងំជារៀងរហូតទៅ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។[13]យើងនឹងសម្រេចតាមអស់ទាំងពាក្យដែលយើងបានប្រកាសទាស់នឹងទឹកដីនោះ គឺតាមគ្រប់ទាំងសេចក្តីដែលបានកត់ទុកក្នុងសៀវភៅ នេះហើយជាពាក្យដែលព្យាការីយេរេមាបានថ្លែងទំនាយទាស់នឹងនគរទាំងប៉ុន្មាន។[14]ដ្បិតជនជាតិជាច្រើន និងស្តេចធំៗ នឹងចាប់ប្រើជនជាតិខាល់ដេនោះវិញ ហើយយើងនឹងសងគេ តាមអំពើដែលគេបានប្រព្រឹត្ត និងតាមការដែលដៃគេបានធ្វើ»។
[15]ដ្បិតព្រះជាម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល ព្រះអង្គមានព្រះបន្ទូលមកខ្ញុំដូច្នេះថា៖ «ចូរយកពែងស្រា ជាសេចក្តីឃោរឃៅពីដៃយើង ទៅបង្អកជនជាតិទាំងប៉ុន្មានដែលយើងចាត់អ្នកឲ្យទៅនោះចុះ។[16]គេនឹងផឹក ហើយដើរវិលវល់ទៅមក ទៅជាឆ្កួតដោយព្រោះដាវ ដែលយើងនឹងចាត់ទៅកណ្តាលពួកគេ»។
[17]ដូច្នេះ ខ្ញុំក៏យកពែងនោះពីព្រះហស្តនៃព្រះជាម្ចាស់ ទៅបង្អកដល់ជនជាតិទាំងប៉ុន្មានដែលព្រះអង្គបានចាត់ខ្ញុំឲ្យទៅនោះ[18]គឺក្រុងយេរូសាឡិម និងទីក្រុងទឹកដីយូដាទាំងប៉ុន្មាន ព្រមទាំងស្តេច និងពួកចៅហ្វាយរបស់គេផង ដើម្បីឲ្យគេទៅជាទីខូចបង់ ជាទីស្រឡាំងកាំង ជាទីដែលគេធ្វើស៊ីសស៊ូស ហើយជាទីផ្តាសាដូចជាសព្វថ្ងៃនេះ។
[19]ជនជាតិដ៏ទៃទៀត ក៏ត្រូវផឹកពីពែងនោះ ដែរ ផារ៉ោន ជាស្តេចទឹកដីអេស៊ីប ពួកមហាតលិក ពួកចៅហ្វាយ និងប្រជាជនទាំងអស់របស់ស្តេច[20]ហើយកុលសម្ព័ននានាទាំងអស់ក្នុងចំណោមពួកគេ ស្តេចទាំងអស់នៅទឹកដីអ៊ូស និងស្តេចទាំងអស់នៅទឹកដីភីលីស្ទីន គឺក្រុងអាសកាឡូន ក្រុងកាសា ក្រុងអេក្រុន និងសំណល់នៃក្រុងអាសដូឌ[21]ជនជាតិម៉ូអាប់ និងពួកកូនចៅអាំម៉ូន។
[22]ស្តេចទាំងអស់នៅក្រុងទីរ៉ុស ស្តេចនៅក្រុងស៊ីដូន និងស្តេចទាំងប៉ុន្មានដែលនៅកោះខាងនាយសមុទ្រ[23]ពួកដេដាន់ ពួកថេម៉ា និងពួកប៊ូស ហើយអស់ពួកអ្នកដែលកាត់ជ្រុងពុកចង្កា ពួកគេត្រូវតែផឹកពីវាដែរ។
[24]មនុស្សទាំងនេះ ក៏នឹងផឹកវា ស្តេចទាំងអស់នៅទឹកដីអារ៉ាប់ និងអស់ទាំងស្តេចនៃកុលសម្ព័ន្ធនានា ដែលអាស្រ័យនៅទីរហោស្ថាន[25]ពួកស្តេចស៊ីមរី ស្តេចអេឡាំ និងអស់ទាំងស្តេចជនជាតិមេឌី[26]ស្តេចទាំងប៉ុន្មាននៃទឹកដីខាងជើង ទាំងជិតទាំងឆ្ងាយជាមួយគ្នា ព្រមទាំងនគរទាំងអស់នៅក្នុងលោកីយ៍ ដែលនៅលើផែនដីផង បន្ទាប់មក ស្តេចសេសាកនឹងត្រូវផឹកក្រោយគេបង្អស់។
[27]ទ្រង់មានបន្ទូលមកខ្ញុំថា «អ្នកត្រូវប្រាប់គេថា៖ ព្រះអម្ចាស់នៃពិភពលោក ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះ ចូរផឹកចុះ ហើយឲ្យស្រវឹងទៅ ចូរក្អួតចេញហើយដួលចុះ ឥតក្រោកឡើងវិញឡើយ ដោយព្រោះដាវដែលយើងនឹងចាត់ទៅកណ្តាលពួកអ្នករាល់គ្នា។[28]បើកាលណាគេមិនព្រមផឹកពីពែងនៅដៃអ្នកទេ នោះអ្នកត្រូវប្រាប់គេថា៖ ព្រះនៃពិភពលោក ព្រះអង្គមានព្រះបន្ទូលដូច្នេះ អ្នករាល់គ្នាត្រូវតែផឹក![29]ដ្បិតមើល៍! យើងចាប់ផ្តើមធ្វើទោសដល់ទីក្រុង ដែលបានហៅតាមឈ្មោះយើង ដូច្នេះតើអ្នករាល់គ្នានឹងរួចខ្លួនឥតមានទោសសោះបានឬ? យើងនឹងហៅឲ្យមានដាវមកលើមនុស្សគ្នានៅផែនដី នេះជាព្រះបន្ទូលនៃព្រះអម្ចាស់នៃពិភពទាំងមូល»។
[30]ដូច្នេះ ចូរថ្លែងទំនាយតាមពាក្យទាំងនេះទាស់នឹងគេ ហើយប្រាប់គេថា ព្រះជាម្ចាស់នឹងគ្រហឹមពីខាងលើ ហើយបញ្ចេញព្រះសូរសៀង ពីទីលំនៅបរិសុទ្ធរបស់ព្រះអង្គ ព្រះអង្គនឹងគ្រហឹមជាខ្លាំងក្រៃលែងទាស់នឹងក្រោលព្រះអង្គ ក៏ស្រែកឡើងទាស់នឹងពួកអ្នកនៅផែនដីទាំងអស់ ដូចជាសម្រែកនៃពួកអ្នកដែលជាន់ផ្លែទំពាំងបាយជូរ[31]ព្រះសូរសៀងនឹងឮរហូតដល់ចុងបំផុតផែនដី ដ្បិតព្រះអង្គមានការណ៍ទាស់ទទឹង នឹងជនជាតិទាំងប៉ុន្មាន ព្រះអង្គនឹងកាត់ក្តីមនុស្សគ្រប់គ្នា ឯពួកមនុស្សអាក្រក់ ព្រះអង្គនឹងប្រគល់ដល់ដាវ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[32]ព្រះអម្ចាស់នៃពិភពទាំងមូល ព្រះអង្គមានព្រះបន្ទូលថា៖ មើល៍ សេចក្តីអាក្រក់នឹងចេញពីនគរមួយ ដល់នគរមួយ ហើយកើតមានព្យុះសង្ឃរាយ៉ាងសម្បើម មកពីចុងផែនដីបំផុត។[33]នៅថ្ងៃនោះ សាកសពរបស់មនុស្ស ដែលព្រះអង្គបានប្រហារ នឹងនៅរាយពេញពីចុងផែនដីម្ខាង ទៅដល់ចុងផែនដីម្ខាង ឥតមានអ្នកណាសោកស្តាយគេ ឬប្រមូលខ្មោចគេទៅកប់ឡើយ គឺគេនឹងទៅជាជីនៅលើដី។
[34]ពួកគង្វាលអើយ ចូរស្រែកទ្រហោយំចុះ! ឱពួកម្ចាស់ហ្វូងចៀមអើយ ចូរដេកនៀលក្នុងផេះទៅ ដ្បិតគ្រាដែលត្រូវសម្លេះនិងកម្ចាត់កម្ចាយអ្នករាល់គ្នាបានមកដល់ហើយ អ្នករាល់គ្នានឹងត្រូវធ្លាក់បែកដូចជាភាជនៈមានតម្លៃ។[35]ពួកគង្វាលនឹងគ្មានផ្លូវរត់រួចឡើយ ហើយពួកម្ចាស់ហ្វូងចៀមក៏គ្មានផ្លូវរួចបានដែរ។[36]មានឮសម្រែកពួកគង្វាល និងសូរទ្រហោយំរបស់ពួកម្ចាស់ហ្វូងចៀម ព្រោះព្រះអម្ចាស់បានបំផ្លាញកន្លែងឃ្វាលរបស់គេ។
[37]ដូច្នេះហើយ ក្រោលសុខសាន្តទាំងប៉ុន្មាន ត្រឡប់ជាស្ងាត់ ដោយព្រោះសេចក្តីក្រោធដ៏សហ័សនៃព្រះជាម្ចាស់។[38]ព្រះអង្គបានចេញពីទីលំនៅរបស់ព្រះអង្គ ដូចជាសិង្ហ ដ្បិតទឹកដីរបស់គេក្លាយជាទីស្ងាត់ជ្រងំ ដោយព្រោះសេចក្តីច្រឡោតនៃពួកជិះជាន់ និងសេចក្តីក្រោធដ៏សហ័សរបស់ព្រះអង្គ»។

Jeremiah 25:1
ក្នុងឆ្នាំទីបួននៃរជ្ជកា...គឺជាឆ្នាំដំបូង
ដល់បណ្តាជននៅទឹកដីយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់
ពួកគេទាំងនេះជាជនជាតិអ៊ីស្រាអែលចុងក្រោយ។
ព្រោះតែទឹកដីភាគខាងជើងបានធ្លាក់ចុះរួចហើយ។
Jeremiah 25:3
អាំម៉ូន
ដរាបដល់សព្វថ្ងៃនេះ
សូមមើលរបៀបបកប្រែនៅក្នុងជំពូក ៧:២៤។
ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានហុចព្រះបន្ទូលរបស់ព្រះអង្គមកខ្ញុំ
ដើម្បីប្រកាសប្រាប់អ្នក»
ពួកគេចង់ចេញទៅក្រៅ
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេចង់ចេញទៅក្រៅដើម្បីចែកចាយពីព្រះបន្ទូលព្រះអម្ចាស់ជាមួយអ្នក»
ស្តាប់ ឬយកចិត្តទុកដាក់
សូមមើលរបៀបបកប្រែនៅក្នុងជំពូក ១១:៦។
Jeremiah 25:5

generated on Wed Sep 10 16:16:32 2025

ផ្លូវអាក្រក់របស់ខ្លួន ហើយពីអំពើអាក្រក់ដែលគ្រប់គ្នាប្រព្រឹត្ត
ពាក្យថា «ផ្លូវអាក្រក់» និង «អំពើអាក្រក់ដែលគ្រប់គ្នាប្រព្រឹត្ត»
គឺមានន័យដូចគ្នាហើយសំដៅលើរាល់អំពើបាបដែលពួកគេប្រព្រឹត្ត។
បែរទៅក្នុងទឹកដី ដែលព្រះអម្ចាស់បានប្រទាន តាំងពីពេល
បុរាណដល់ដូនតារបស់អ្នកហើយឲ្យដល់អ្នករាល់គ្នាផងដែរ ជាអំណោយជារៀងរហូត
ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះអ្នកអាចត្រឡប់ទៅទឹកដីដែលព្រះអម្ចាស់បានសន្យាជាមួយអ្នកហើយរស់នៅលើទឹកដីនោះជារៀងរហូត»
កុំឲ្យខឹងពួកវា ព្រោះវាបានកើតឡើងដោយសារដៃរបស់អ្នក ដូច្នោះវានឹងធ្វើឲ្យអ្នកអាម៉ាស់
ការបកប្រែរបៀបផ្សេងទៀត:
«កុំធ្វើអោយព្រះអម្ចាស់មានព្រះទ័យខ្ញាល់នឹងអំពើអាក្រក់របស់អ្នកឡើយក្រែងលោព្រះអង្គដាក់ទោសអ្នក»
Jeremiah 25:7
អ្នកមិនបានស្តាប់យើងទេ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនបានស្តាប់បង្គាប់យើងទេ»
ហើយនឹងនាំគេមកទាស់នឹងទឹកដីនេះ
ព្រះជាម្ចាស់គ្រោងនឹងប្រើនេប៊ូក្នេសានិងព្រះហស្តរបស់ព្រះអង្គដើម្បីដាក់ទណ្ឌកម្មអ៊ីស្រាអែលហើយ
និងប្រជាជាតិជុំវិញដែលបានបះបោរប្រឆាំងនឹងព្រះអម្ចាស់។
មើល!
សូមមើលរបៀបបកប្រែនៅក្នុងជំពូក ១:៧។
គួរឲ្យអាសូរ
សូមមើលរបៀបបកប្រែនៅក្នុងជំពូក ១៨:១៥។
Jeremiah 25:10
ថ្មត្បាល់កិន
វត្ថុដែលមានថ្មមូលធំពីរ ដែលត្រូវបានប្រើសម្រាប់កិនគ្រាប់ធញ្ញជាតិ។
យើងនឹងធ្វើឲ្យអ្វីៗទាំងអស់បាត់ពីប្រជាជាតិទាំងនេះ
នេះជាសេចក្តីអះអាងដល់ប្រជាជាតិនានាដែលកំពុងត្រូវបំផ្លាញ។
ជនជាតិទាំងនេះនឹងត្រូវបម្រើស្តេចបាប៊ីឡូន
ដោយត្រូវបានបង្ខំចិត្តបង់ពន្ធ ហើយលក់ទៅជាទាសករ។
Jeremiah 25:12
ក្រោយពីចិតសិបឆ្នាំហើយ
ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលការដាក់ទោសរបស់គេត្រូវបានបញ្ចប់»
ធ្វើឲ្យទៅជាទីបញ្ចាប់ ហើយត្រូវបោះ បង់ចោល
ព្រះសន្យានឹងថាធ្វើឲ្យស្រុកបាប៊ីឡូនក្លាយទៅជាវាលខ្សាច់ដូចជាវាលរហោស្ថាន។
យើងនឹងសងគេ តាមអំពើដែលគេបានប្រព្រឹត្ត និងតាមការដែលដៃគេបានធ្វើ
ព្រះនឹងធ្វើឲ្យពួកគេទទួលទណ្ឌកម្មដូចគ្នាដែលពួកគេបានធ្វើទៅលើប្រជាជាតិដែលពួកគេបានធ្វើ
តាមអំពើដែលគេបានប្រព្រឹត្ត និងតាមការដែលដៃគេបានធ្វើ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចៗគ្នា
នាហើយបង្ហាញថាព្រះអម្ចាស់សំដៅទៅលើអ្វីៗទាំងអស់ដែលពួកគេបានធ្វើចំពោះជនជាតិដទៃ។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីគ្រប់យ៉ាងដែលពួកគេបានធ្វើ»។
Jeremiah 25:15
ចូរយកពែងស្រា នៃសេចក្តីខ្ញាល់ពីដៃយើង ទៅបង្អកជនជាតិទាំងឡាយដែលយើងចាត់អ្នកឲ្យ
ទៅផឹកពីវា
ព្រះអម្ចាស់បញ្ជាអោយដាក់ទណ្ឌកម្ម។
យើង ទៅបង្អកជនជាតិទាំងឡាយដែលយើងចាត់អ្នកឲ្យទៅផឹកពីវា
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យជនជាតិនានាមានបទពិសោធន៍ពីការនោះ»
ពួកគេនឹងផឹក ហើយដើរវិលវល់ទៅមក ទៅជាឆ្កួតនៅចំពោះដាវ ដែលយើងនឹងចាត់ទៅកណ្តាលពួក
គេ
អស់អ្នកដែលជួបនឹងផលវិបាកនៃការដាក់ទោសធ្ងន់ធ្ងររបស់ព្រះអម្ចាស់
នឹងធ្វើខ្លួនដូចជាមនុស្សឆ្កួត។
Jeremiah 25:17
ព័ត៌មានទូទៅ:
បទគម្ពីរនេះបន្តប្រៀបធៀបពីសេចក្តីក្រោធរបស់ព្រះអម្ចាស់ដូចជាទឹកដែលនឹងត្រូវហូរចេញ
ខ្ញុំបានបង្អកដល់ជនជាតិទាំងឡាយ ដែលព្រះអម្ចាស់បានចាត់ខ្ញុំឲ្យទៅផឹកវានោះ
សកម្មភាពការផឹកពីពែងស្រា តំណាងឲ្យជំនុំជម្រះរបស់ព្រះអម្ចាស់។
ដើម្បីឲ្យគេទៅជាខ្ទិចខ្ទី ជាទីរន្ធត់ភ័យខ្លាច
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីបំផ្លិចបំផ្លាញពួកគេ»
ជាទីដែលគួរឲ្យអាសូ ហើយបណ្តាសា
ការបកប្រែរបៀបផ្សេងទៀត: «ត្រូវគេមើលងាយឬដាក់បណ្តាសា»
ដូចពួកគេនៅក្នុងសព្វថ្ងៃនេះ
ដូចជាពេលវេលាមួយ រវាងអ្វីដែលបានការកត់ត្រា
និងអ្វីដែលនឹងមានការកើតឡើង។
Jeremiah 25:19
ព័ត៌មានទូទៅ:
លោកយេរេមារាយឈ្មោះជនជាតិទាំងអស់ដែលនឹងត្រូវជំនុំជម្រះ
ប្រជាជនទាំងអស់ដែលបានទទួល កេរ្តិ៍ដំណែល
ជនជាតិទាំងអស់ដែលរស់នៅតំបន់ភាគខាងជើងឆ្ងាយ
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេជាកូនកាត់»
Jeremiah 25:22
ព័ត៌មានទូទៅ:
លោកយេរេមាបន្តរាយឈ្មោះជនជាតិទាំងអស់ដែលស្ថិតនៅក្រោមការជំនុំជម្រះរបស់ព្រះអម្ចាស់
ខាងនាយសមុទ្រ
នេះជាការអះអាងទៅសមុទ្រមេឌីទែរ៉ានេ។
អស់ពួកអ្នកដែលកាត់ជ្រុងពុកចង្កា
ហើយពួកគេកាត់សក់ខ្លីដើម្បីគោរពដល់ព្រះផ្សេងរបស់គេ។
Jeremiah 25:24
ផឹករាំដែរ
នេះសំដៅទៅលើពែងស្រាក្នុងនិមិត្តរបស់លោកយេរេមាដែលតំណាងឲ្យនៃការជំនុំជម្រះរបស់ព្រះអម្ចាស់។
ស៊ីមរី
ស្តេចទាំងឡាយនៃទឹកដីខាងជើង
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចទាំងឡាយដែលមកពីទឹកដីខាងជើង»
Jeremiah 25:27
ព័ត៌មានទូទៅ:
និមិត្តដែលព្រះអម្ចាស់បានប្រទានដល់ព្យាការីយេរេមាឲ្យបន្តកិច្ចការរបស់លោក។
ចូរផឹក ហើយឲ្យស្រវឹងទៅ ចូរក្អួតចេញ ហើយដួលចុះ មិនអាចក្រោកឡើងនៅចំពោះមុខដាវ ដែល
យើងនឹងចាត់ទៅកណ្តាលពួកអ្នករាល់គ្នា
នេះបង្ហាញពីការមិនគេចរួចពីការដាក់ទណ្ឌកម្មនាពេលខាងមុខ
និងភាពឥតប្រយោជន៍នៃការព្យាយាមដើម្បីជៀសវាងពីការនេះ។
ផឹកពីពែងនៅដៃអ្នក
ការបកប្រែរបៀបផ្សេងទៀត: «ជាការដាក់ទោសរបស់ពួកគេ»
អ្នករាល់គ្នាត្រូវតែផឹក
នេះមិនមែនជាពែងដែលជនជាតិនានាអាចបដិសេធមិនផឹកបានឡើយ។
ជនជាតិនានាមិនអាចបដិសេធការជំនុំជំរះរបស់ព្រះអម្ចាស់ ពីសង្គ្រាម
ការបកប្រែរបៀបផ្សេងទៀត:
ត្រូវតែផឹក
ការបកប្រែរបៀបផ្សេងទៀត: «ត្រូវទទួលការដាក់ទណ្ឌកម្ម»
ហៅតាមឈ្មោះយើង
ការបកប្រែរបៀបផ្សេងទៀត: «ប្រជារាស្ត្រនៃក្រុងយេរូសាឡិម»
តើអ្នករាល់គ្នានឹងខ្លួនអ្នកនឹងរួចពីការដាក់ទោសដែរទេ?
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាត្រូវបានដាក់ទោស»។
យើងនឹងហៅដាវមកទាស់នឹងមនុស្សទាំងអស់នៅទឹកដី!
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងដាក់ទោសអ្នកដែលរស់នៅទឹកដីនោះ»
Jeremiah 25:30
នាំការជំនុំជម្រះ
ការបកប្រែរបៀបផ្សេងទៀត: «ប្រកាសកាត់ទោសជនជាតិទាំងឡាយ» ឬ «ជំនុំជំរះ
និងដាក់ទណ្ឌកម្មដល់ជនជាតិទាំងនោះ»
ទ្រង់នឹងគ្រប់គ្រងយុត្តិធម៌ដល់មនុស្សទាំងអស់
រាល់ជនជាតិទាំងអស់នឹងទទួលការជំនុំជម្រះរបស់ព្រះអម្ចាស់។
មនុស្សទាំងអស់
ការបកប្រែរបៀបផ្សេងទៀត: «ទៅកាន់មនុស្សលោកទាំងអស់» ឬ
«ទៅកាន់ប្រជាជាតិ»
នឹងប្រគល់ការអាក្រក់ដល់ដាវ
ការបកប្រែរបៀបផ្សេងទៀត: «សម្លាប់ពួកមនុស្សអាក្រក់»
Jeremiah 25:32
មើល៍
ការបកប្រែរបៀបផ្សេងទៀត: «ចូរយកចិត្តទុកដាក់ការនេះ!»
សូមមើលរបៀបបកប្រែនៅក្នុងជំពូក ៥:១៤។
ព្យុះសង្ឃរាយ៉ាងសម្បើម គឺផ្តើមចេញពីដើមនិងដល់ចុងផែនដីបំផុត

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «ការបំផ្លិចបំផ្លាញនឹងខិតចូលមកដល់»
នៅរាយពេញពីចុងផែនដីម្ខាង ទៅដល់ចុងផែនដីម្ខាង
ការបកប្រែរបៀបផ្សេងទៀត: «នៅពាសពេញផែនដីក្នុងពេលនោះ»
ពួកគេនឹងទៅជាជីនៅលើដី
អាចមានន័យថា ១) មានមនុស្សតិចតួច ឬគ្មាននៅសល់
យកទៅកប់ចំពោះអ្នកដែលព្រះអម្ចាស់បានសម្លាប់ឬ ២)
ដោយមិនសូវមានការព្រួយបារម្ភចំពោះសាកសពអ្នកស្លាប់។
Jeremiah 25:34
ពួកគង្វាលអើយ
នេះជាអំនះអំណាងទៅអ្នកដឹកនាំអ៊ីស្រាអែល។
ចូរដេកននៀលក្នុងដី
នេះជាការសញ្ញានៃការទុក្ខព្រួយ កាន់ទុក្ខ ឬទុក្ខលំបាក។
ដ្បិតថ្ងៃរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតថ្ងៃរបស់អ្នក» ឬ «ជាពេលវេលារបស់អ្នក»
អ្នកនឹងធ្លាក់ដូចចៀមឈ្មោលដែលបានជ្រើសរើស។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងត្រូវបានគេបំផ្លាញបានដោយងាយ»
គ្មានទីជម្រោគសម្រាប់ ហើយពួកគេមិនអាចគេចខ្លួនបានទេ
គ្មានកន្លែងណាដែលអាចលាក់បាំង គេចពីការជំនុំជម្រះ
និងការបំផ្លិចបំផ្លាញបានឡើយ។
ព្រះអម្ចាស់បានបំផ្លាញកន្លែងវាលស្មៅរបស់គេ
ការជំនុំជម្រះរបស់ព្រះអម្ចាស់ គឺមានទាំងអ្នកដឹកនាំ និងប្រជារាស្ត្រ
ដោយគ្មាននរណាម្នាក់អាចរួចខ្លួនបានឡើយ។

Jeremiah 25:37
ដូច្នេះហើយ វាលស្មៅសុខសាន្តទាំងឡាយ ត្រឡប់ជាបំផ្លាញចោល
ពាក្យថា «វាលស្មៅ» នៅទីនេះមានន័យថាជាជនជាតិទាំងមូល។
បំផ្លាញចោល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត:«ទ្រង់នឹងបំផ្លាញជនជាតិនោះទាំងមូល»
សេចក្តីខ្ញាល់
ការពិតដែលថាព្រះអម្ចាស់ទ្រង់មានព្រះទ័យខ្ញាល់ត្រូវបានគេនិយាយដូចជាគោលបំណងមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់មានព្រះទ័យខ្ញាល់»
ដូចជាសិង្ហស្ទាវ ដែលបានចាកចេញពីរូង ដ្បិតទឹកដីរបស់គេក្លាយជាទីរន្ធត់
មិនដូចឯកសារផ្សេងទៀត
ដែលព្រះអម្ចាស់ត្រូវចាត់ទុកដូចជាសិង្ហដែលការពារចំពោះអ៊ីស្រាអែលទេ
នៅក្នុងបទគម្ពីរនេះ ព្រះអម្ចាស់ធ្វើដូចជាសិង្ហដើម្បីដាក់ទោសដល់អ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់យាងមកដូចជាសិង្ហស្ទាវ
ដើម្បីធ្វើឲ្យទឹកដីរបស់ប្រជារាស្ត្រនោះមានការភ័យខ្លាច»
ដ្បិតទឹកដីរបស់គេក្លាយជាទីរន្ធត់
នៅទីនេះ «ទីរន្ធត់» បង្ហាញពីភាពដែលភ័យខ្លាច។ ការបកប្រែរបៀបផ្សេងទៀត:
«ទឹកដីរបស់ពួកគេនឹងប្រែក្លាយជាកន្លែងនៃភាពរន្ធត់» ឬ
«ទឹកដីរបស់ពួកគេនឹងក្លាយជាអ្វីដែលគួរឲ្យភ័យខ្លាចដែលមិនចង់ឃើញ»
សេចក្តីកំហឹងនៃពួកជិះជាន់
នេះសំដៅលើសេចក្តីកំហឹងនៃពួកសត្រូវរបស់ជនជាតិអ៊ីស្រាអែល។

---

26 [1]នៅដើមរជ្ជកាលព្រះបាទយេហូយ៉ាគីម ជាបុត្រយ៉ូសៀស ស្តេចយូដា នោះព្រះបន្ទូលនេះបានមកពីព្រះអម្ចាស់[2]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ ចូរទៅឈរក្នុងទីលានព្រះវិហារនៃព្រះអង្គចុះ ហើយប្រាប់ដល់មនុស្សទាំងអស់នៅក្នុងទីក្រុងនៃទឹកដីយូដា ដែលមកថ្វាយបង្គំក្នុងព្រះវិហារនៃព្រះអម្ចាស់ គ្រប់ពាក្យដែលយើងបង្គាប់ឲ្យអ្នកប្រាប់ដល់គេ កុំឲ្យបន្ថយពាក្យណាមួយឡើយ![3]ប្រហែលជាគេនឹងស្តាប់តាម ហើយបែរចេញពីផ្លូវអាក្រក់ដែលគេប្រព្រឹត្តរៀងខ្លួន ដើម្បីឲ្យយើងបានប្រែគំនិតចេញពីការអាក្រក់ ដែលយើងសម្រេចនឹងធ្វើដល់គេ ដោយព្រោះអំពើអាក្រក់ដែលគេប្រព្រឹត្តនោះ។
[4]អ្នកត្រូវប្រាប់គេថា «ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ បើអ្នករាល់គ្នាមិនព្រមស្តាប់តាមយើង ហើយដើរតាមច្បាប់ ដែលយើងបានដាក់នៅមុខអ្នករាល់គ្នា[5]ឬស្តាប់តាមពាក្យរបស់ពួកហោរា ជាអ្នកបម្រើរបស់យើង ដែលយើងចាត់ឲ្យមកឯអ្នករាល់គ្នា ដោយក្រោកពីព្រលឹមស្រាង និងចាត់គេ បើអ្នករាល់គ្នាមិនបានស្តាប់តាមសោះ![6]នោះយើងនឹងធ្វើឲ្យវិហារនេះបានដូចជាស៊ីឡូរ ហើយនឹងធ្វើឲ្យទីក្រុងនេះត្រឡប់ជាទីផ្តាសា ដល់អស់ទាំងជនជាតិនៅផែនដីផង»។
[7]ពួកបូជាចារ្យ ពួកព្យាការី និងបណ្តាជនទាំងឡាយ ក៏ឮព្យាការីយេរេមា ប្រាប់ពាក្យទាំងនេះនៅក្នុងព្រះវិហារ នៃព្រះអម្ចាស់ដែរ។[8]ពេលព្យាការីយេរេមា បានប្រាប់គ្រប់សេចក្តីដែលព្រះជាម្ចាស់បានបង្គាប់ ឲ្យលោកប្រាប់ដល់ជនទាំងឡាយរួចអស់ហើយ នោះពួកសង្ឃ ពួកព្យាការី និងបណ្តាជនទាំងអស់ ក៏ចាប់លោក ដោយពោលថា អ្នកត្រូវស្លាប់ហើយ![9]ហេតុអ្វីបានជាអ្នកថ្លែងទំនាយដោយនូវព្រះនាមព្រះជាម្ចាស់ថា៖ ព្រះវិហារនេះនឹងបានដូចជាស៊ីឡូរ ហើយទីក្រុងនេះនឹងត្រូវខូចបង់ ឥតមានអ្នកណានៅដូច្នេះ? «ដ្បិតប្រជាជនក៏នាំមូលគ្នាមកព័ទ្ធជុំទាស់នឹងព្យាការីយេរេមា នៅក្នុងព្រះវិហារនៃព្រះអម្ចាស់។
[10]ពេលពួកចៅហ្វាយនៃទឹកដីយូដាបានឮសេចក្តីទាំងនោះហើយ គេក៏ចេញពីដំណាក់ស្តេច ឡើងទៅព្រះវិហារនៃព្រះអម្ចាស់។ រួចអង្គុយត្រង់ទ្វារថ្មីនៃព្រះវិហារព្រះអម្ចាស់។
[11]ពួកបូជាចារ្យ និងពួកព្យាការី គេជម្រាបដល់ពួកចៅហ្វាយ ហើយដល់ជនទាំងអស់ថា៖ «មនុស្សនេះគួរស្លាប់ហើយ ដ្បិតគេបានថ្លែងទំនាយទាស់នឹងក្រុងនេះ ដូចជាអស់លោកបានឮផ្ទាល់នឹងត្រចៀកស្រាប់!»[12]ព្យាការីយេរេមាក៏ជម្រាបដល់ពួកចៅហ្វាយ និងជនទាំងអស់ថា៖ ព្រះអម្ចាស់បានចាត់ខ្ញុំឲ្យមកថ្លែងទំនាយប្រាប់គ្រប់ពាក្យដែលអ្នករាល់គ្នាបានឮ ទាស់នឹងព្រះវិហារ ហើយទីក្រុងនេះ។
[13]ដូច្នេះ ចូរផ្លាស់ប្តូរគំនិត និងកិរិយារបស់អ្នករាល់គ្នាឥឡូវ ហើយស្តាប់តាមព្រះបន្ទូលព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាចុះ នោះព្រះអម្ចាស់នឹងប្រែគំនិតចេញពីសេចក្តីអាក្រក់ ដែលព្រះអង្គបានប្រកាសទាស់នឹងអ្នករាល់គ្នាវិញ។[14]តែឯខ្ញុំនេះ មើល៍ខ្ញុំនៅក្នុងកណ្តាប់ដៃរបស់អ្នករាល់គ្នាហើយ ចូរធ្វើដល់ខ្ញុំតាមដែលអ្នករាល់គ្នាឃើញថាល្អ ហើយទៀងត្រង់ចុះ។[15]មានការមួយដែលអ្នកត្រូវដឹងថា បើអ្នករាល់គ្នាសម្លាប់ខ្ញុំ នោះនឹងនាំឲ្យឈាមដែលឥតមានទោសប្រឡាក់លើខ្លួនអ្នករាល់គ្នា លើទីក្រុងនេះ និងពួកអ្នកដែលអាស្រ័យនៅផង ដ្បិតព្រះជាម្ចាស់បានចាត់ខ្ញុំឲ្យមក ដើម្បីប្រាប់ពាក្យទាំងនេះ ដល់ត្រចៀកអ្នករាល់គ្នាជាពិត»។
[16]ពេលនោះ ពួកចៅហ្វាយ និងប្រជាជនទាំងឡាយ ក៏ពិគ្រោះជាមួយពួកបូជាចារ្យ និងពួកព្យាការីថា៖ «មនុស្សនេះមិនគួរស្លាប់ទេ ដ្បិតគ្រាន់តែបានប្រាប់យើងរាល់គ្នាដោយនូវព្រះនាមព្រះអម្ចាស់ជាព្រះនៃយើងទេតើ»។[17]ក្រោយមក មានពួកចាស់ទុំខ្លះក្នុងទឹកដី ក្រោកឡើងប្រាប់ដល់ប្រជុំជនថា។
[18]ពួកគេថា «មីកា ជាពួកម៉ូរ៉ាស៊ីត បានថ្លែងទំនាយក្នុងរជ្ជកាលព្រះបាទហេសេគា ជាស្តេចយូដា ថ្លែងទៅកាន់ប្រជាជននៅទឹកដីយូដាទាំងអស់ថា
ព្រះអម្ចាស់នៃពិភពលោកមានព្រះបន្ទូលដូច្នេះថា៖ គេនឹងភ្ជួរក្រុងស៊ីយ៉ូន ដូចជាភ្ជួរស្រែចម្ការ ហើយក្រុងយេរូសាឡិមនឹងត្រឡប់ជាគំនរបាក់បែក ឯភ្នំនៃព្រះដំណាក់ ដូចជាទីខ្ពស់នៅព្រៃណាមួយ។[19]តើហេសេគា ជាស្តេចយូដា និងពួកយូដាទាំងអស់បានសម្លាប់លោកឬ? តើទ្រង់មិនបានកោតខ្លាចដល់ព្រះជាម្ចាស់វិញ ហើយទូលអង្វរចំពោះព្រះអង្គទេឬ? ឯព្រះអម្ចាស់ក៏ប្រែគំនិតចេញពីសេចក្តីអាក្រក់ ដែលព្រះអង្គបានប្រកាសទាស់នឹងគេដែរ តើធ្វើដូច្នេះ យើងនឹងឈ្មោះថាបានប្រព្រឹត្តអំពើអាក្រក់យ៉ាងធំ ទាស់នឹងព្រលឹងយើងហើយឬ?»
[20]មួយទៀត ក៏មានម្នាក់ដែលថ្លែងទំនាយដោយនូវព្រះនាមព្រះអម្ចាស់ ឈ្មោះអ៊ូរីយ៉ា ជាកូនរបស់សេម៉ាយ៉ា ពីក្រុងគារយ៉ាត់-យារីម អ្នកនោះថ្លែងទំនាយទាស់នឹងទីក្រុងហើយទឹកដីនេះ តាមអស់ទាំងពាក្យរបស់ព្យាការីយេរេមាដែរ។[21]កាលព្រះបាទយេហូយ៉ាគីម និងមនុស្សខ្លាំងពូកែរបស់ទ្រង់ ព្រមទាំងពួកចៅហ្វាយ បានឮពាក្យរបស់អ្នកនោះ ស្តេចក៏រកសម្លាប់អ៊ូរីយ៉ា តែកាលគាត់បានដឹង ក៏ភ័យ ហើយបានរត់ទៅទឹកដីអេស៊ីប។
[22]បន្ទាប់មក ព្រះបាទយេហូយ៉ាគីមចាត់អែលណាថាន ជាកូនអ័កបោរ និងមនុស្សខ្លះទៀតឲ្យទៅទឹកដីអេស៊ីប[23]អ្នកទាំងនោះក៏នាំអ៊ូរីយ៉ា ពីទឹកដីអេស៊ីបមកថ្វាយព្រះបាទយេហូយ៉ាគីម ហើយទ្រង់ក៏សម្លាប់គាត់ដោយដាវ ព្រមទាំងបោះសាសពទៅក្នុងផ្នូររបស់មនុស្សធម្មតាទៅ។[24]ប៉ុន្តែ អ័ហ៊ីកាម ជាកូនសាផាន លោកជួយខាងព្យាការីយេរេមា ដើម្បីមិនឲ្យគេប្រគល់លោកទៅក្នុងកណ្តាប់ដៃនៃពួកជនឲ្យគេសម្លាប់លោកឡើយ។

Jeremiah 26:1
ទីក្រុងទាំងឡាយនៃជនជាតិយូដា
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនដែលមកទិក្រុងនានានៃស្រុកយូដា»
កុំឲ្យខ្វះពាក្យណាមួយឡើយ!

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «កុំទុកអ្វីដែលយើងប្រាប់ដល់អ្នកឡើយ។
ដូច្នោះយើងនឹងបន្ទន់ចិត្តទាក់ទងនឹងមហន្តរាយ
នេះជាការបំផ្លិចបំផ្លាញបែបមានលក្ខខណ្ឌ។ ប្រសិនជនជាតិយូដាប្រែចិត្ត
ព្រះជាម្ចាស់នឹងមិនបំផ្លាញពួកគេទេ តែទ្រង់នឹងព្យាបាលពួកគេវិញ។
Jeremiah 26:4
បើអ្នករាល់គ្នាមិនព្រមស្តាប់តាមយើង ហើយដើរតាមច្បាប់ ដែលយើងបានដាក់នៅមុខអ្នករាល់គ្នា
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើអ្នកមិនស្តាប់បង្គាប់យើង
និងបញ្ញាតិដែលយើងបានដាក់លើអ្នករាល់គ្នា»
ក្រោយមកយើងនឹងធ្វើឲ្យវិហារនេះបានដូចជាស៊ីឡូរ
«បន្ទាប់មកយើងនឹងបំផ្លាញវិហារនេះ»
ធ្វើឲ្យទីក្រុងនេះក្លាយទៅជាបណ្តាសា
នេះសំដៅទៅលើការដាក់ទោស ដែលព្រះអម្ចាស់នឹងធ្វើចំពោះក្រុងយេរូសាឡិម។
នៅចំពោះភ្នែកនៃជនជាតិនៅផែនដីផង
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីឲ្យជនជាតិទាំងឡាយធ្វើជាសាក្សី»
Jeremiah 26:7
ព្រះវិហារនៃព្រះអម្ចាស់
«ព្រះវិហារ»
បណ្តាជនទាំងអស់ ក៏ចាប់លោក ដោយពោលថា អ្នកត្រូវស្លាប់ហើយ!!
អាចមានន័យថា ១) បណ្តាជនទាំងអស់ជ្រើសរើសជឿសេចក្តីភូតភរនៃសន្តិភាពមិនពិតហើយមិនចង់ប្រែចិត្ត
ឬ ២) បណ្តាជនជឿព្យាការីផ្សេងទៀតដែលប្រកាសសន្តិភាព
ហើយឃើញលោកយេរេមាជាព្យាការីក្លែងក្លាយ ដែលគួរតែគប់នឹងដុំថ្ម
ត្បិតនាំឲ្យពួកគេវង្វេង។
ហេតុអ្វីបានជាអ្នកថ្លែងទំនាយដោយនូវព្រះនាមព្រះជាម្ចាស់ថា៖ ព្រះវិហារនេះនឹងក្លាយដូចជាស៊ីឡូរ
ហើយទីក្រុងនេះនឹងត្រូវខូចបង់ ដោយគ្មានអ្នកណានៅដូច្នេះ?
នេះជាការស្តីបន្ទោស។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមិនគួរថ្លែងទំនាយដោយនូវព្រះនាមរបស់ព្រះអម្ចាស់ថាព្រះវិហាររបស់ទ្រង់នឹងត្រូវ
Jeremiah 26:10
អ្នកដឹកនាំ
អ្នកដឹកនាំគឺជាអ្នកដែលមានតួនាទីសិទ្ធិអំណាច។
ទ្វារថ្មី
នេះជាច្រកចូលជាក់លាក់ទៅព្រះវិហារ។
អស់លោកបានឮផ្ទាល់នឹងត្រចៀកស្រាប់
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាបានលឺ»
ព្រះវិហារនេះ ហើយទីក្រុងនេះ
«បណ្តាជនដែលនៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់ និងនៅក្នុងទីក្រុងយេរូសាឡិម»
Jeremiah 26:13
ដូច្នោះពេលនេះ ចូរផ្លាស់ប្តូរផ្លូវ និងការប្រព្រឹត្តរបស់អ្នក
ប្រជាជនបានវិលត្រឡប់ទៅថ្វាយដង្វាយដល់ព្រះអម្ចាស់ដើម្បីផ្គាប់ចិត្តព្រះអង្គ។
ប៉ុន្តែពួកគេមិនចាប់អារម្មណ៍ក្នុងការដើរតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ឬមិនស្គាល់ព្រះអម្ចាស់ទេ
ស្តាប់សម្លេងនៃព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «ស្តាប់បង្គាប់ព្រះអម្ចាស់»
ចូរប្រព្រឹត្តនឹងខ្ញុំតាមដែលអ្នករាល់គ្នាឃើញថាល្អ តាមការយល់ឃើញរបស់អ្នកចុះ។
ពាក្យថា «ថាល្អ» និង «តាមការយល់ឃើញ» មានន័យដូចគ្នា។
ការបកប្រែរបៀបផ្សេងទៀត: «ចូរប្រព្រឹត្តនឹងខ្ញុំ
តាមអ្វីដែលអ្នកគិតថាជារឿងល្អត្រឹមត្រូវដែលអ្នកត្រូវប្រព្រឹត្ត។
ត្រចៀករបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតអ្នករាល់គ្នាអាចស្តាប់លឺបាន»
Jeremiah 26:16
មនុស្សនេះមិនគួរស្លាប់ទេ
ពួកចាស់ទុំទទួលស្គាល់សាររបស់លោកយេរេមាដែលមកពីព្រះអម្ចាស់
ហើយប្រព្រឹត្តការនេះ។
ដោយនូវព្រះនាមព្រះអម្ចាស់ជាព្រះនៃយើង
«ដោយនូវសិទ្ធអំណាចរបស់ព្រះអម្ចាស់ជាព្រះរបស់យើង»
Jeremiah 26:18
ព័ត៌មានទូទៅ:
សូមមើល:
ក្រុងស៊ីយ៉ូនភ្នូរ ដូចជាដីស្រែចម្ការ
ការបកប្រែរបៀបផ្សេងទៀត: «ក្រុងស៊ីយ៉ូន នឹងត្រូវបានបំផ្លាញ»
ភ្នំនៃព្រះដំណាក់
នេះសំដៅលើភ្នំដែលព្រះដំណាក់ស្ថិតនៅ។
មានព្រៃក្រាស់
ពាក្យនេះសំដៅទៅលើពពួកព្រៃតូចៗ ឬពពួកដើមឈើតូចៗ
ដែលដុះលូតលាស់ឡើងក្រាស់។
តើហេសេគា ជាស្តេចយូដា និងពួកយូដាទាំងអស់បានសម្លាប់លោកទេ?
ការបកប្រែរបៀបផ្សេងទៀត: «ព្រះបាទហេសេគាជាស្តេចស្រុកយូដា
និងប្រជាជននៅស្រុកយូដាមិនបានសម្លាប់លោកមីកាទេ»។
ដូច្នោះហើយព្រះអម្ចាស់អាចនឹងប្រែគំនិតចេញពីសេចក្តីមហន្តរាយ ដែលព្រះអង្គបានប្រកាសទាស់
នឹងគេដែរឬ?
ការបកប្រែរបៀបផ្សេងទៀត: «ទ្រង់គោរពកោតខ្លាចព្រះអម្ចាស់
ហើយធ្វើអោយព្រះអម្ចាស់មានសេចក្តីក្រោធ
ដូច្នេះព្រះអម្ចាស់កែប្រែព្រះហឫទ័យនឹងគ្រោះមហន្តរាយដែលព្រះអង្គមានព្រះបន្ទូលថាព្រះអង្គនឹងដាក់»។
ទូលអង្វរចំពោះព្រះភក្ត្រនៃព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «បន្ថយសេចក្តីក្រោធរបស់ព្រះអម្ចាស់»
ដូច្នោះ តើយើងនឹងប្រព្រឹត្តអំពើអាក្រក់ដ៏ធំនេះ ទាស់នឹងជីវិតយើងឬ?
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើយើងសម្លាប់លោកយេរេមា
នោះយើងនឹងដាក់អំពើអាក្រក់ដ៏ធំមកលើខ្លួនយើង»។
Jeremiah 26:20
ព័ត៌មានទូទៅ:
ព្យាការីទីពីរឈ្មោះអ៊ូរី បញ្ជាក់ពាក្យរបស់លោកយេរេមា
នូវព្រះនាមព្រះអម្ចាស់
សូមមើលពិរបៀបបកប្រែក្នុងជំពូក ២៦:១៦។
អ្នកដឹកនាំ បានឮពាក្យរបស់លោក
ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកដឹកនាំបានលឺពីអ្វីដែលលោកអ៊ូរីបានថ្លែង»
Jeremiah 26:22
ព័ត៌មានទូទៅ:
សាកសព
«រូបកាយមនុស្សស្លាប់»
អ័ហ៊ីកាម
លោកអ័ហ៊ីកាមជាអ្នកដែលជួយលោកយេរេមា ហើយការពារលោក។
អែលណាថាន ជាកូនអ័កបោរ...អ័ហ៊ីកាម ជាកូនសាផាន
នេះជាឈ្មោះរបស់ក្រុមមនុស្ស។
ដូច្នោះលោកមិនត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកប្រជាជន ដើម្បីសម្លាប់លោកឡើយ។
«ដូច្នេះមនុស្សនឹងមិនអាចសម្លាប់លោកបានទេ»។

---

27 [1]នៅដើមរជ្ជកាលព្រះបាទសេដេគា បុត្រព្រះបាទយ៉ូសៀស ជាស្តេចទឹកដីយូដា ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមា ដូចតទៅ។[2]ព្រះអម្ចាស់មាន
ព្រះបន្ទូលមកខ្ញុំថា៖ «ចូរធ្វើនឹម និងវេញខ្សែ យកមកពាក់នៅលើស្មារបស់អ្នក។[3]បន្ទាប់មក ចូរផ្ញើខ្សែ និងនឹមទាំងនោះ ទៅឲ្យស្តេចទឹកដីអេដុម ស្តេចទឹកដីម៉ូអាប់
ស្តេចទឹកដីអាំម៉ូន ស្តេចក្រុងទីរ៉ុស និងស្តេចក្រុងស៊ីដូន តាមរយៈពួករាជទូត ដែលមកគាល់សេដេគា ជាស្តេចទឹកដីយូដា នៅក្រុងយេរូសាឡិម។[4]ចូរផ្តាំអ្នកទាំងនោះឲ្យទៅ
ប្រាប់ស្តេចរបស់ខ្លួនថា: ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូចតទៅ: នេះគឺជាអ្វីដែលអ្នកត្រូវប្រាប់ដល់អ្នកដឹកនាំរបស់អ្នក
[5]«យើងបានបង្កើតផែនដី មនុស្ស និងសត្វនៅលើផែនដីទាំងឡាយ ដោយសារឫទ្ធិអំណាចដ៏អស្ចារ្យរបស់យើង ហើយយើងចង់ប្រគល់ឲ្យអ្នកណា តាមតែយើងគិតថាត្រូវ។
[6]ឥឡូវនេះ យើងបានប្រគល់ទឹកដីទាំងនេះទៅក្នុងកណ្តាប់ដៃនេប៊ូក្នេសា ស្តេចបាប៊ីឡូន ជាអ្នកបម្រើរបស់យើងហើយ ក៏បានឲ្យអស់ទាំងសត្វនៅវាល សម្រាប់នឹងបម្រើគេ
ដែរ។[7]ជនជាតិទាំងអស់នឹងបម្រើស្តេចនោះ និងកូន ហើយចៅរបស់គេដែរ ដរាបដល់កំណត់ទឹកដីគេ នោះជនជាតិជាច្រើន ហើយស្តេចធំនឹងចាប់ស្តេចនោះប្រើជាបាវវិញ។
[8]ប្រសិនបើជនជាតិណា ឬនគរណា ដែលមិនព្រមបម្រើនេប៊ូក្នេសា ស្តេចបាប៊ីឡូននេះ ហើយមិនព្រមឱនកទទួលនឹមរបស់ស្តេចបាប៊ីឡូន យើងនឹងធ្វើទោសដល់
ជនជាតិនោះដោយដាវ ដោយអំណត់ និងអាសន្នរោគ ទាល់តែយើងបានធ្វើឲ្យគេសូន្យបាត់ ដោយដៃរបស់ស្តេចនោះ។ នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

[9]ដូច្នេះ មិនត្រូវស្តាប់តាមពួកព្យាការីរបស់អ្នក ឬតាមពួកគ្រូទាយ ពួកយល់សប្តិ ពួកគ្រូអង្គុយធម៌ ឬពួកគ្រូនក្ខត្តឫក្សនោះឡើយ ដែលនិយាយប្រាប់អ្នករាល់គ្នាថា កុំទៅបម្រើស្តេចបាប៊ីឡូន។[10]គេថ្លែងទំនាយកុហកអ្នករាល់គ្នាទេ ដើម្បីឲ្យអ្នកត្រូវព្រាត់ចាកឆ្ងាយពីទឹកដីរបស់អ្នក គឺឲ្យយើងបានបណ្តេញអ្នករាល់គ្នាចេញ ហើយអ្នកនឹងត្រូវវិនាស។[11]ប៉ុន្តែ ជនជាតិណាដែលឱនកទទួលនឹម ហើយបម្រើដល់ស្តេចបាប៊ីឡូនវិញ នោះយើងនឹងទុកគេ ឲ្យនៅក្នុងទឹកដីរបស់ខ្លួន គេនឹងភ្ជួររាស់ដី ហើយអាស្រ័យនៅផង នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់»។
[12]ខ្ញុំក៏បានទូលដល់ព្រះបាទសេដេគា ជាស្តេចយូដា តាមគ្រប់ទាំងពាក្យនេះថា៖ ចូរអ្នករាល់គ្នាឱនកទទួលនឹម ទៅបម្រើដល់ស្តេចបាប៊ីឡូន និងប្រជារាស្ត្ររបស់គេចុះ នោះនឹងបានរួចជីវិត[13]តើចង់ស្លាប់ធ្វើអី គឺទាំងអង្គទ្រង់ និងប្រជារាស្ត្ររបស់ព្រះអង្គផង ដោយដាវ អំណត់ និងអាសន្នរោគ ដូចជាព្រះជាម្ចាស់បានមានព្រះបន្ទូល ពីដំណើរជនជាតិណា ដែលមិនព្រមបម្រើដល់ស្តេចបាប៊ីឡូនដូច្នេះឬ?
[14]កុំស្តាប់តាមពាក្យរបស់ព្យាការី ដែលនិយាយនឹងអ្នករាល់គ្នាថា៖ «មិនត្រូវបម្រើដល់ស្តេចបាប៊ីឡូននោះឡើយ ដ្បិតគេថ្លែងទំនាយកុហកទេ។[15]ដ្បិត ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងមិនបានចាត់គេឲ្យមកទេ គឺគេថ្លែងទំនាយកុហក ដោយនាមយើង ដើម្បីឲ្យយើងបានបណ្តេញអ្នករាល់គ្នាចេញ ហើយអ្នករាល់គ្នាត្រូវវិនាស គឺទាំងខ្លួនអ្នករាល់គ្នា និងពួកព្យាការីដែលថ្លែងទំនាយនោះផង»។
[16]ខ្ញុំក៏បានប្រាប់ដល់ពួកបូជាចារ្យ និងពួកជនទាំងឡាយថា៖ «ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះ កុំស្តាប់តាមពាក្យរបស់ពួកព្យាការី ដែលថ្លែងទំនាយដល់អ្នករាល់គ្នាថា មើលបន្តិចទៀត គេនឹងនាំយកអស់ទាំងគ្រឿងប្រដាប់របស់ព្រះវិហារនៃព្រះជាម្ចាស់ ពីក្រុងបាប៊ីឡូនមកវិញ ដ្បិតគេថ្លែងទំនាយកុហកដល់អ្នករាល់គ្នាទេ។[17]កុំស្តាប់តាមគេឡើយ ត្រូវបម្រើស្តេចបាប៊ីឡូនចុះ នោះនឹងបានរួចជីវិត តើមានទំនងអ្វី ឲ្យទីក្រុងនេះត្រូវខូចបង់?[18]បើគេជាព្យាការីពិត ហើយបើព្រះបន្ទូលនៃព្រះជាម្ចាស់នៅជាមួយគេ នោះឲ្យគេទូលអង្វរ ដល់ព្រះអម្ចាស់នៃពិភពលោកឥឡូវនេះចុះ ដើម្បីសូមកុំឲ្យគ្រឿងប្រដាប់ដែលនៅសល់ក្នុងព្រះវិហារនៃព្រះជាម្ចាស់ ហើយនៅក្នុងដំណាក់ស្តេចយូដាដែលនៅក្រុងយេរូសាឡិម ត្រូវគេដឹកយកទៅក្រុងបាប៊ីឡូនទៀត។
[19]ព្រះអម្ចាស់នៃពិភពទាំងមូល ព្រះអង្គមានព្រះបន្ទូលពីដំណើរសសរ សមុទ្រ និងជើងថ្កល់ និងប្រដាប់ប្រដាដែលនៅសល់ក្នុងទីក្រុងនេះ[20]ជាគ្រឿងដែលនេប៊ូក្នេសា ស្តេចបាប៊ីឡូនមិនបានយកទៅ ក្នុងកាលដែលចាប់យកយេកូនាស ជាបុត្រយេហូយ៉ាគីម ស្តេចយូដា នាំចេញពីក្រុងយេរូសាឡិមទៅជាឈ្លើយដល់ក្រុងបាប៊ីឡូន ព្រមទាំងពួកអ្នកធំនៃទឹកដីយូដា និងក្រុងយេរូសាឡិមផង។
[21]ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលពីដំណើរគ្រឿងប្រដាប់ទាំងប៉ុន្មាន ដែលនៅសល់ក្នុងព្រះវិហារនៃព្រះជាម្ចាស់ ហើយក្នុងដំណាក់ស្តេចយូដា ដែលនៅក្រុងយេរូសាឡិមថា៖[22]គេនឹងដឹកយកគ្រឿងទាំងនោះ ទៅក្រុងបាប៊ីឡូន ហើយត្រូវនៅទីនោះដរាបដល់ថ្ងៃដែលយើងប្រោស នោះយើងនឹងនាំយកឡើងមក ដាក់នៅត្រង់កន្លែងដើមវិញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់»។

Jeremiah 27:1
នឹម
នេះជាវត្ថុដែលចងមនុស្សមិនឲ្យមានសេរីភាព។
បន្ទាប់មក ចូរធ្វើខ្សែ និងនឹមទាំងនោះ
លោកយេរេមាបានចងនឹងខ្សែទាម
ហើយនឹមពួកគេទៅឲ្យស្តេចនីមួយដែលរៀបរាប់ឈ្មោះ។
តាមដៃពួករាជទូតនៃស្តេចទាំងនោះ
ពាក្យថា «ដៃ» នៅទីនេះសំដៅលើភ្នាក់ងារផ្សេងទៀតរបស់ពួករាជទូត។
ចូរបញ្ជាដល់ពួកគេឲ្យទៅប្រាប់អ្នកដឹកនាំរបស់ពួកគេ
លោកយេរេមាត្រូវបានណែនាំអោយប្រគល់ច្រវាក់និងនឹមទៅអោយរាជទូតនីមួយៗ
និងផ្ញើរសារមួយសំរាប់ស្តេចនីមួយៗទាក់ទងនឹងច្រវាក់និងនឹម។
Jeremiah 27:5
ដោយសារឫទ្ធិអំណាចដ៏អស្ចារ្យនៃដៃរបស់យើង
ពាក្យថា «ដៃ» សំដៅទៅលើឫទ្ធិអំណាចដ៏អស្ចារ្យនិងជំនួយឃ្លាទីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ដោយឫទ្ធិអំណាចដ៏អស្ចារ្យរបស់យើង»។
យើងចង់ប្រគល់ឲ្យអ្នកដែលត្រឹមត្រូវនឹងភ្នែកយើង
«យើងចង់ប្រគល់ឲ្យអ្នកណាដែលយើងចង់ប្រគល់»។
នឹងចាប់ស្តេចនោះប្រើជាបាវិញ
នឹងក្លាយទៅជាខ្លាំង និងយកឈ្នះពួកបាប៊ីឡូន។
Jeremiah 27:8
ហើយមិនព្រមដាក់កនៅក្រោមនឹមនៃស្តេចបាប៊ីឡូនទេ
អ្នកដែលមិនស្បថនឹងស្តេចនេប៊ូក្នេសា ហើយបង់ពន្ធ ឬអាករថ្វាយស្តេច។
ដោយដៃរបស់របស់ពួកគេ
ឃ្លានេះសំដៅលើស្តេចនេប៊ូក្នេសា ហើយកងទ័ពរបស់ទ្រង់។
នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «នេះជាអ្វីដែលព្រះមានបន្ទូលនឹងកើតឡើង»
Jeremiah 27:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលតាមរយៈលោកយេរេមាដល់ជនជាតិយូដា។
ពួកគ្រូទាយ
គ្រូទាយជាអ្នកដែលធ្វើការទស្សទាយពីអនាគត។
ប៉ុន្តែ ជនជាតិណាដែលឱនកទទួលនឹម
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែជនជាតិណាដែលបម្រើស្តេច»
នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
ភ្ជួររាស់
នេះមានន័យថារៀបចំហើយប្រើប្រាស់ដីដើម្បីដាំដំណាំហូបបាន
សង់ផ្ទះនៅផងនៅទីនោះ
ការបកប្រែរបៀបផ្សេងទៀត: «យកទឹកដីបាប៊ីឡូនធ្វើជាទីលំនៅរបស់ពួកគេ»
Jeremiah 27:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលតាមរយៈលោកយេរេមាដល់ស្តេចស្រុកយូដា។
ចូរអ្នករាល់គ្នាឱនកទទួលនឹម ទៅបម្រើដល់ស្តេចបាប៊ីឡូន
ព្រះអង្គមានបំណងចង់ជនជាតិស្រុកយូដាបន្ទាបខ្លួន និងបម្រើស្តេចបាប៊ីឡូន។
ហេតុអ្វីអ្នកនឹងស្លាប់ គឺទាំងអង្គទ្រង់ និងប្រជារាស្ត្ររបស់ព្រះអង្គផង ដោយដាវនិងអំណត់ ហើយនិងអាសន្នរោគ ដូចជាព្រះជាម្ចាស់បានមានព្រះបន្ទូល ទាក់ទងនិងជនជាតិណា ដែលមិនព្រមបម្រើដល់ស្តេចបាប៊ីឡូន?
ការបកប្រែរបៀបផ្សេងទៀត: «អ្នក និងប្រជាជនអ្នកនឹងស្លាប់ដោយមុខដាវ ទុរ្ភិក្ស និងគ្រោះកាចដូចដែលយើងបានថ្លែង
ប្រសិនបើអ្នកមិនបម្រើស្តេចស្រុកបាប៊ីឡូនទេនោះ»
Jeremiah 27:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលតាមរយៈលោកយេរេមាដល់ស្តេច
និងជនជាតិស្រុកយូដា។
កុំស្តាប់តាមពាក្យ
ព្រះអម្ចាស់ព្រមានប្រជារាសអំពីពួកព្យាការីក្លែងក្លាយទាំងអស់ដែលទ្រង់មិនបានចាត់អ្នកដែលនិយាយកុ
ដ្បិតយើងមិនបានចាត់ពួកគេឲ្យទៅនោះទេ
«ដ្បិតយើងមិនបានបញ្ជូនពួកគេឲ្យទៅនោះទេ»
ដោយនាមយើង
ឃ្លានេះមានន័យថា ដោយថ្លែងដោយព្រះចេស្តា និងសិទ្ធិអំណាចរបស់ព្រះអម្ចាស់ ឬព្រះនាមរបស់ទ្រង់។
យើងបានបណ្តេញអ្នករាល់គ្នាចេញ
«យើងនឹងបញ្ជូនអ្នកពីទឹកដីកំណើតរបស់អ្នក»
Jeremiah 27:16
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
អ្វីទាំងអស់ជារបស់ព្រះវិហារនៃព្រះជាម្ចាស់ ដែលយកមកពីក្រុងបាប៊ីឡូនមកវិញ!
«ប្រជាជននៅស្រុកបាប៊ីឡូនបាននាំយកវត្ថុដែលធ្វើពីមាសទាំងអស់មកវិញ ដែលពួកគេបានយកពីព្រះវិហាររបស់ព្រះអម្ចាស់!»
តើហេតុអ្វីបានជាក្រុងនេះត្រូវខូចបង់?
«ទីក្រុងទាំងមូលនឹងត្រូវបានបំផ្លាញ»។
ប្រសិនបើគេជាព្យាការី

generated on Wed Sep 10 16:16:32 2025

ប្រសិនបើអ្វីដែលគេនិយាយគឺជាការពិត
នោះពួកគេគួរតែអធិស្ឋានដើម្បីកុំអោយពាក្យរបស់យើងកើតឡើង
ហើយថាព្រះវិហារ និងមេដឹកនាំនៅតែមាននៅក្រុងយេរូសាឡិម។
Jeremiah 27:19
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
សសរ សមុទ្រ និងជើងថ្កល់
វត្ថុទាំងនេះដែលមាននៅក្នុងព្រះវិហារ។ ពាក្យថា «សមុទ្រ»
គឺតំណាងឲ្យអាងលង្ហិនដែលកំពុងរលាយ។
យេកូនាស
អត្ថបទភាសាហេព្រើរមានពាក្យ «ជេនៀរ៉ា» ដែលប្រែប្រួលពីឈ្មោះ «យេកូនាស»។
ការបកប្រែសម័យថ្មីៗ ពាក្យ «យេកូនាស»
ដើម្បីបញ្ជាក់កាន់តែឲ្យច្បាស់ថាស្តេចដដែលនេះត្រូវបានគេសំដៅទៅ។
Jeremiah 27:21
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។

---

28 [1]ក្នុងឆ្នាំដដែល គឺនៅដើមរាជ្ជកាលព្រះបាទសេដេគា ស្តេចយូដា ក្នុងខែទីប្រាំ ឆ្នាំទីបួន ព្យាការីហាណានា ជាកូនអ័ស៊ើរ ដែលនៅគីបៀន បាននិយាយមកខ្ញុំ នៅក្នុងព្រះវិហារនៃព្រះអម្ចាស់ ចំពោះពួកសង្ឃ និងបណ្តាជនថា៖[2]«ព្រះជាម្ចាស់នៃពិភពលោក ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះ យើងបានបំបាក់នឹមរបស់ស្តេចបាប៊ីឡូនហើយ។
[3]នៅរវាងគម្រប់ពីរឆ្នាំទៀត នោះយើងនឹងនាំយកអស់ទាំងគ្រឿងប្រដាប់របស់ព្រះវិហារនៃព្រះអម្ចាស់ ដែលនេប៊ូក្នេសាជាស្តេចបាប៊ីឡូនបានយកពីទីនេះទៅដល់ទឹកដីបាប៊ីឡូន ត្រឡប់មកឯកន្លែងដើមវិញ។[4]យើងក៏នឹងនាំយេកូនាស ជាបុត្រយេហូយ៉ាគីម ស្តេចយូដា និងពួកយូដាទាំងប៉ុន្មាន ដែលត្រូវចាប់ទៅជាឈ្លើយ ដល់ក្រុងបាប៊ីឡូន ឲ្យវិលមកទីនេះវិញដែរ ដ្បិតយើងនឹងបំបាក់នឹមរបស់ស្តេចបាប៊ីឡូនពិត នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់»។
[5]បន្ទាប់មក ព្យាការីយេរេមាក៏និយាយនឹងព្យាការីហាណានា នៅចំពោះពួកសង្ឃ និងបណ្តាជនដែលឈរនៅក្នុងព្រះវិហារនៃព្រះអម្ចាស់[6]គឺព្យាការីយេរេមានិយាយថា៖ «សូមឲ្យព្រះអម្ចាស់ធ្វើដូច្នោះចុះ សូមឲ្យព្រះជាម្ចាស់សម្រេចតាមពាក្យដែលអ្នកបានថ្លែងទំនាយនោះ ដើម្បីនាំយកអស់ទាំងគ្រឿងប្រដាប់របស់ព្រះវិហារនៃព្រះជាម្ចាស់ និងអស់អ្នកដែលត្រូវចាប់ទៅជាឈ្លើយនោះ ឲ្យត្រឡប់មកពីក្រុងបាប៊ីឡូនដល់ទីនេះវិញ។[7]ប៉ុន្តែ ចូរស្តាប់ពាក្យដែលខ្ញុំពោលនៅត្រចៀកអ្នក និងនៅត្រចៀករបស់បណ្តាជនទាំងនេះឥឡូវចុះ។
[8]ពួកព្យាការីកាលពីដើម ដែលនៅមុនខ្ញុំ និងអ្នក គេបានថ្លែងទំនាយទាស់នឹងទឹកដីជាច្រើន ហើយទាស់នឹងនគរយ៉ាងធំ គឺថ្លែងទំនាយពីចម្បាំង ពីការអាក្រក់ និងពីអាសន្នរោគផង។[9]ប៉ុន្តែ ព្យាការីណាដែលថ្លែងទំនាយពីសន្តិសុខ បើកាលណាទំនាយរបស់ព្យាការីនោះបានសម្រេចហើយ នោះទើបនឹងស្គាល់ព្យាការីនោះថា ព្រះជាម្ចាស់បានចាត់ព្យាការីមកមែន»។
[10]ពេលនោះ ព្យាការីហាណានា ក៏យកនឹមពីកព្យាការីយេរេមាទៅបំបាក់ចោល[11]រួចព្យាការីហាណានានិយាយចំពោះបណ្តាជនទាំងឡាយថា៖ «ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ គឺយ៉ាងនេះ ដែលយើងនឹងបំបាក់នឹមរបស់នេប៊ូក្នេសា ជាស្តេចបាប៊ីឡូន» ចេញពីអស់ទាំងជនជាតិក្នុងរវាងគម្រប់ពីរឆ្នាំទៅមុខនេះ នោះព្យាការីយេរេមាក៏ចេញបាត់ទៅ។
[12]ក្រោយពេលដែលព្យាការីហាណានាបានបំបាក់នឹមពីកព្យាការីយេរេមាចេញហើយ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ព្យាការីយេរេមាថា៖[13]«ចូរទៅប្រាប់ដល់ហាណានាថា ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះ អ្នកបានបំបាក់នឹមដែលធ្វើពីឈើ តែអ្នកបានធ្វើនឹមដែកជំនួសវិញ។[14]ដ្បិតព្រះនៃពិភពលោក ជាព្រះនៃពួកជនជាតិអ៊ីស្រាអែល ព្រះអង្គមានព្រះបន្ទូលដូច្នេះថា យើងបានដាក់នឹមដែកនៅកនៃជនជាតិទាំងនេះហើយ ដើម្បីឲ្យគេត្រូវបម្រើនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ហើយគេនឹងបម្រើពិតមែន យើងក៏បានឲ្យសត្វនៅវាលដល់គេដែរ»។
[15]បន្ទាប់មកព្យាការីយេរេមា និយាយទៅព្យាការីហាណានាថា៖ ហាណានាអើយ «ចូរស្តាប់ចុះ ព្រះជាម្ចាស់មិនបានចាត់អ្នកមកទេ គឺអ្នកនាំឲ្យជនជាតិនេះទុកចិត្តចំពោះពាក្យកុហកហើយ។[16]ហេតុនេះ ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ មើល៍! យើងនឹងបណ្តេញអ្នកឲ្យបាត់ចេញពីផែនដីទៅ គឺអ្នកនឹងត្រូវស្លាប់ក្នុងឆ្នាំនេះ ពីព្រោះអ្នកបានពោលសេចក្តីបះបោរទាស់នឹងព្រះអម្ចាស់»។[17]ដូច្នេះ នៅខែទីប្រាំពីរ ក្នុងឆ្នាំនោះ ព្យាការីហាណានាក៏ស្លាប់ទៅ។

Jeremiah 28:1
ព័ត៌មានទូទៅ:
ហាណានាសអះអាងថាថ្លែងជំនួសព្រះអម្ចាស់។
នៅក្នុងឆ្នាំទីបួន ហើយខែទីប្រាំ
នេះជាខែទីប្រាំនៃប្រតិទិនជនជាតិហេប្រឺ។ នៅក្នុងរដូវប្រាំង។
នេះគឺជាកំឡុងពេលចុងខែកក្កដា និងដើមខែសីហានៅលើប្រតិទិនលោកខាងលិច។
ការបកប្រែរបៀបផ្សេងទៀត: «នៅខែទី៥ នៃឆ្នាំទី៤ របស់គាត់»
អ័ស៊ើរ
យើងបានបំបាក់នឹមរបស់ស្តេចបាប៊ីឡូនហើយ
ការបកប្រែរបៀបផ្សេងទៀត:
«យើងបានបញ្ឈប់ការដឹកនាំរបស់ស្តេចស្រុកបាប៊ីឡូន»
Jeremiah 28:3
ព័ត៌មានទូទៅ:
ហាណានាសបន្តថ្លែង។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
យេកូនាស
អត្ថបទភាសាហេព្រើរមានពាក្យ «ជេនៀរ៉ា» ដែលប្រែប្រួលពីឈ្មោះ «យេកូនាស»។
ការបកប្រែសម័យថ្មីៗ ពាក្យ «យេកូនាស»
ដើម្បីបញ្ជាក់កាន់តែឲ្យច្បាស់ថាស្តេចដដែលនេះត្រូវបានគេសំដៅទៅ។
Jeremiah 28:8
ពួកព្យាការីកាលពីដើម ដែលនៅមុនខ្ញុំ និងអ្នក
ការបកប្រែរបៀបផ្សេងទៀត:
«ពួកព្យាការីដែលរស់នៅមុនអ្នកហើយនឹងខ្ញុំជាយូរមកហើយ»
នោះទើបនឹងស្គាល់ព្យាការីនោះថា ព្រះជាម្ចាស់បានចាត់ព្យាការីមកមែន»។
ការបកប្រែរបៀបផ្សេងទៀត:
«ពេលនោះអ្នកនឹងដឹងថាគាត់ជាព្យាការីដ៏ពិតរបស់ព្រះអម្ចាស់»
Jeremiah 28:12
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។
អ្នកបានបំបាក់នឹមដែលធ្វើពីឈើ តែយើងនឹងធ្វើនឹមដែកជំនួសវិញ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបានបំបែកនឹមដែលខ្សោយ
ប៉ុន្តែយើងនឹងបង្កើតនឹមមួយដែលអ្នកមិនអាចបំបែកបានឡើយ»
Jeremiah 28:15
នៅក្នុងខែទីប្រាំពីរ
នេះជាខែទីប្រាំពីរនៃប្រតិទិនជនជាតិហេប្រឺ។ កំឡុងចុងខែកញ្ញា
និងដើមខែតុលាតាមប្រតិទិនលោកខាងលិច។

---

29 [1]នេះជាសេចក្តីនៅក្នុងសំបុត្រ ដែលព្យាការីយេរេមាបានធ្វើពីក្រុងយេរូសាឡិម ទៅពួកចាស់ទុំ ក្នុងពួកដែលត្រូវចាប់ទៅជាឈ្លើយ ពួកសង្ឃ ពួកព្យាការី និងបណ្តាជនទាំងអស់ ដែលនេប៊ូក្នេសាបានចាប់ជាឈ្លើយ ពីក្រុងយេរូសាឡិម ទៅរស់នៅទឹកដីបាប៊ីឡូន។[2]គឺនៅក្រោយដែលស្តេចយេកូនាស និងអគ្គមហេសី ពួកសេនាបតី ពួកចៅហ្វាយនៃទឹកដីយូដា និងក្រុងយេរូសាឡិម ព្រមទាំងពួកជាងឈើ និងជាងដែក បានចេញពីក្រុងយេរូសាឡិមអស់ហើយ។[3]លោកធ្វើសំបុត្រនោះតាមអេលាសារ ជាកូនសាផាន និងកេម៉ារា ជាកូនហ៊ីលគីយ៉ា ជាអ្នកដែលព្រះបាទសេដេគា ស្តេចយូដាបានចាត់ទៅទឹកដីបាប៊ីឡូន ដល់នេប៊ូក្នេសា ជាស្តេចទឹកដីនោះ។

generated on Wed Sep 10 16:16:32 2025

[4]ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដល់ពួកឈ្លើយទាំងប៉ុន្មាន ដែលព្រះអង្គបានឲ្យគេចាប់ជាឈ្លើយ ចេញពីក្រុងយេរូសាឡិម
ទៅដល់ទឹកដីបាប៊ីឡូនថា[5]ចូរអ្នករាល់គ្នាសង់ផ្ទះ ហើយអាស្រ័យនៅចុះ ចូរដាំដំណាំ ហើយស៊ីផលនោះទៅ។
[6]ចូរយកប្រពន្ធ ហើយបង្កើតកូនប្រុសកូនស្រី ព្រមទាំងរកប្រពន្ធឲ្យកូនប្រុសអ្នក ហើយលើកកូនស្រីរបស់អ្នកឲ្យមានប្តីផង ដើម្បីឲ្យបានបង្កើតកូនប្រុសកូនស្រីដែរ ចូរឲ្យ
ចម្រើនជាច្រើនឡើងនៅទីនោះ កុំឲ្យថយចំនួនអ្នកឡើយ។[7]ប៉ុន្តែ ចូរខំប្រឹងធ្វើឲ្យទីក្រុង ដែលយើងបានឲ្យគេដឹកនាំអ្នកទៅជាឈ្លើយនោះ បានសេចក្តីសុខ ហើយត្រូវ
អធិស្ឋានដល់ព្រះជាម្ចាស់ឲ្យទីនោះផង ដ្បិតក្នុងសេចក្តីសុខរបស់ក្រុងនោះ អ្នករាល់គ្នានឹងបានសេចក្តីសុខដែរ។
[8]ដ្បិតព្រះជាម្ចាស់នៃពិភពទាំងមូល ជាព្រះនៃជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលថា កុំឲ្យពួកព្យាការី និងពួកគ្រូថ្លែងទំនាយរបស់អ្នក ដែលនៅក្នុងចំណោមអ្នករាល់គ្នា
បញ្ឆោតអ្នកឡើយ ក៏កុំទុកចិត្តការយល់សប្តិ ដែលគេយល់សប្តិនោះឡើយ[9]ដ្បិតគេថ្លែងទំនាយកុហកអ្នករាល់គ្នា ដោយនូវឈ្មោះយើងទេ។ យើងមិនបានចាត់គេឡើយ
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។
[10]ដ្បិតព្រះអង្គមានព្រះបន្ទូលដូច្នេះថា លុះកាលបានសម្រេចគ្រប់ចិតសិបឆ្នាំនៅទឹកដីបាប៊ីឡូនហើយ យើងនឹងប្រោសអ្នករាល់គ្នា ហើយធ្វើសម្រេចដល់អ្នករាល់គ្នា តាម
ពាក្យល្អរបស់យើង ដោយធ្វើឲ្យអ្នករាល់គ្នាវិលមកទីនេះវិញ។[11]ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលថា យើងស្គាល់សេចក្តីដែលយើងគិតពីដំណើរអ្នករាល់គ្នា មិនមែនគិតធ្វើ
សេចក្តីអាក្រក់ទេ គឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យអ្នករាល់គ្នាបានសេចក្តីសង្ឃឹម។
[12]អ្នករាល់គ្នានឹងអំពាវនាវដល់យើង ហើយនឹងទៅអធិស្ឋានដល់យើង រួចយើងនឹងយល់ព្រមតាម។[13]អ្នករាល់គ្នានឹងស្វែងរកយើង ហើយនឹងឃើញ គឺកាលណាអ្នកស្វែងរក
យើងឲ្យអស់អំពីចិត្ត។[14]យើងនឹងឲ្យអ្នករាល់គ្នារកយើងឃើញ នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងនឹងដោះអ្នករាល់គ្នាឲ្យរួចពីសណ្ឋានជាឈ្លើយ ហើយប្រមូលអ្នកពី
គ្រប់ជនជាតិ និងពីគ្រប់កន្លែងដែលយើងបានបណ្តេញអ្នក នាំវិលត្រឡប់មកកន្លែងដែលយើងបានឲ្យគេចាប់ទៅជាឈ្លើយនោះវិញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។
[15]តាំងពីពេលអ្នករាល់គ្នានិយាយថា ព្រះអម្ចាស់បានបង្កើតឲ្យយើងមានពួកព្យាការី នៅទឹកដីបាប៊ីឡូននេះ[16]ព្រះអង្គមានព្រះបន្ទូលដូច្នេះ ពីដំណើរស្តេចដែលគង់លើបល្ល័ង្ក
របស់ដាវីឌ ហើយពីដំណើរជនទាំងឡាយដែលអាស្រ័យនៅទីក្រុងនេះ គឺជាបងប្អូនរបស់អ្នករាល់គ្នា ដែលមិនបានចាប់ទៅជាឈ្លើយជាមួយអ្នករាល់គ្នាទេ។[17]ព្រះអម្ចាស់នៃ
ពិភពទាំងមូលមានព្រះបន្ទូលថា មើល៍! យើងនឹងចាត់ដាវ ជាអំណត់ និងអាសន្នរោគមកលើគេ ហើយនឹងធ្វើឲ្យគេត្រឡប់ទៅដូចជាផ្លែល្វាអាក្រក់ ដែលបរិភោគមិនបាន។
[18]យើងនឹងដេញតាមគេ ដោយដាវ អំណត់ និងអាសន្នរោគ ព្រមទាំងប្រគល់គេទៅឲ្យត្រូវរសាត់អណ្តែត នៅកណ្តាលអស់ទាំងជនជាតិនៅផែនដី ឲ្យបានជាទីផ្តាសា ជាទី
ស្រឡាំងកាំង ហើយជាទីដែលគេធ្វើស៊ីសស៊ូសឲ្យ និងជាទីត្មះតិះដៀលនៅកណ្តាលអស់ទាំងជនជាតិ ដែលយើងនឹងបណ្តេញគេនោះ។[19]ដោយព្រោះគេមិនបានយកចិត្ត
ទុកដាក់ស្តាប់ពាក្យរបស់យើង នេះជាព្រះបន្ទូលរបស់ព្រះអង្គ ដែលយើងបានចាត់ពួកហោរា ជាអ្នកបម្រើរបស់យើងមកឯអ្នករាល់គ្នា ជារៀងរហូតមក តែអ្នករាល់គ្នាមិន
បានស្តាប់តាមទេ នេះហើយជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[20]ដូច្នេះ អ្នករាល់គ្នាជាពួកឈ្លើយ ដែលយើងបានបណ្តេញចេញពីក្រុងយេរូសាឡិម ទៅទឹកដីបាប៊ីឡូនអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ចុះ។[21]ព្រះអម្ចាស់នៃ
ពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលពីដំណើរអ័ហាប់ ជាកូនកូឡាយ៉ា និងសេដេគាជាកូនម្អាសេយ៉ា ដែលគេថ្លែងទំនាយជាសេចក្តីកុហកដល់
អ្នករាល់គ្នា ដោយនូវព្រះនាមព្រះអង្គ គឺព្រះអង្គមានព្រះបន្ទូលថា យើងនឹងប្រគល់គេទៅក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ហើយស្តេចនោះនឹងសម្លាប់អ្នក
ទាំងពីរនោះនៅមុខអ្នករាល់គ្នា។
[22]ពេលនោះពួកឈ្លើយ ជាជនជាតិយូដា ដែលនៅក្រុងបាប៊ីឡូន នឹងយករឿងនោះប្រើជាពាក្យផ្តាសាដល់អ្នកដទៃថា សូមព្រះជាម្ចាស់ធ្វើឲ្យអ្នកបានដូចជាសេដេគា និង
អ័ហាប់ ដែលស្តេចបាប៊ីឡូនបានឆ្អើរលើភ្លើងនោះចុះ[23]ពីព្រោះគេបានប្រព្រឹត្តអំពើចម្កួតក្នុងពួកអ៊ីស្រាអែល គេបានសហាយស្មន់នឹងប្រពន្ធរបស់អ្នកជិតខាង ហើយពោល
ពាក្យកុហក ដោយនូវឈ្មោះយើង ជាសេចក្តីដែលយើងមិនបានបង្គាប់ដល់គេឡើយ គឺយើងហើយដែលដឹង យើងជាទីបន្ទាល់ពិត នេះជាព្រះបន្ទូលរបស់ព្រះអង្គ»។
[24]អ្នកត្រូវប្រាប់សេម៉ាយ៉ា ជាអ្នកនៅទឹកដីនេហេលេមថា៖[25]ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា ដោយព្រោះអ្នកបានធ្វើ
សំបុត្រដោយនូវឈ្មោះខ្លួនអ្នក ធ្វើដល់អស់អ្នកនៅក្រុងយេរូសាឡិម និងដល់សេផានា ជាកូនរបស់សង្ឃម្អាសេយ៉ា ហើយដល់ពួកសង្ឃទាំងអស់ផងថា[26]«ព្រះអង្គបានតាំង
អ្នកឡើងធ្វើជាសង្ឃ ជំនួសសង្ឃយេហូយ៉ាដា ដើម្បីឲ្យមានពួកនាយកក្នុងព្រះវិហាររបស់ព្រះជាម្ចាស់ ឲ្យអ្នកបានចាប់អស់អ្នកឆ្កួត ដែលតាំងខ្លួនឡើងធ្វើជាព្យាការី ដាក់គុក
ដាក់ខ្នោះ។
[27]ចុះហេតុអ្វីបានជាមិនបានបន្ទោសដល់យេរេមា ដែលនៅក្រុងអាណាថោត ជាអ្នកដែលតាំងខ្លួនឡើងជាព្យាការីដល់លោករាល់គ្នានោះ?[28]ដ្បិតគាត់បានផ្ញើសំបុត្រទៅយើង
រាល់គ្នា នៅឯទឹកដីបាប៊ីឡូន ប្រាប់ថា ដំណើរនេះនឹងត្រូវយូរនៅ ចូរធ្វើផ្ទះ ហើយអាស្រ័យនៅចុះ ចូរដាំដំណាំ ហើយស៊ីផលទៅ»។[29]ក៏អានមើលសំបុត្រនោះ ឲ្យព្យាការី
យេរេមាស្តាប់។
[30]ពេលនោះ ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ព្យាការីយេរេមាថា[31]«ចូរធ្វើទៅប្រាប់ដល់ពួកអ្នកដែលនៅជាឈ្លើយថា ព្រះជាម្ចាស់មានព្រះបន្ទូលពីដំណើរសេម៉ាយ៉ាជា
អ្នកដែលមកពីទឹកដីនេហេលេមថា ដោយព្រោះសេម៉ាយ៉ា ជាអ្នកដែលយើងមិនបានចាត់ប្រើឡើយ បានថ្លែងទំនាយដល់អ្នករាល់គ្នា ហើយបាននាំអ្នករាល់គ្នាឲ្យទុកចិត្តលើ
ពាក្យកុហក[32]ហេតុនេះហើយបានជាព្រះអង្គមានព្រះបន្ទូលដូច្នេះថា មើល៍! យើងនឹងធ្វើទោសសេម៉ាយ៉ា ជាអ្នកទឹកដីនេហេលេម ព្រមទាំងពូជពង្សរបស់គេដែរ។ គ្មានអ្នក
ណាម្នាក់រស់នៅក្នុងចំណោមប្រជាជននេះឡើយ ក៏មិនឃើញការល្អដែលយើងនឹងប្រោសដល់ប្រជារាស្ត្ររបស់យើងដែរ ព្រោះគេបានប្រកាសបះបោរទាស់នឹងព្រះអម្ចាស់
នេះហើយជាព្រះបន្ទូលរបស់ព្រះអង្គ»។

Jeremiah 29:1

ធ្វើពីក្រុងយេរូសាឡិម

ការបកប្រែរបៀបផ្សេងទៀត: «ដោយបានថ្លែងចេញពីក្រុងយេរូសាឡិម»

យេកូនាស

អត្ថបទភាសាហេព្រើរមានពាក្យ «ជេនៀរី» ដែលប្រែប្រួលពីឈ្មោះ «យេកូនាស»។

ការបកប្រែស័យថ្មីៗ ពាក្យ «យេកូនាស»

ដើម្បីបញ្ជាក់កាន់តែឲ្យច្បាស់ថាស្តេចដដែលនេះត្រូវបានគេសំដៅទៅ។

មាតាអគ្គមហេសី

នេះជារម្យងារប្រើសម្រាប់មាតាស្តេច។

សេនាបតី

ការបកប្រែរបៀបផ្សេងទៀត: «ជាពួកមន្ត្រីដែលមានឋានៈធំៗ»

អេលាសារ ជាកូនសាផាន ហើយកេម៉ារា ជាកូនហ៊ីលគីយ៉ា ជាអ្នកដែលព្រះបាទសេដេគា

ទាំងនេះជាឈ្មោះរបស់ក្រុមមនុស្ស។

Jeremiah 29:4

ដែលព្រះអង្គបានឲ្យគេចាប់ជាឈ្លើយ

ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកដែលទ្រង់បានចាប់» ឬ
«ពួកអ្នកដែលព្រះអម្ចាស់បានចាប់»

សង់ផ្ទះ ហើយអាស្រ័យនៅចុះ។ ចូរដាំដំណាំ ហើយស៊ីផលរបស់វាចុះ

ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់ពួកគេពីរបៀបពួកគេអាចរស់នៅទីនោះបានយូរអង្វែង។

Jeremiah 29:6

ចូរយកប្រពន្ធ ហើយបង្កើតកូនប្រុស

ការបកប្រែរបៀបផ្សេងទៀត: «ដែលមានកូនប្រុសដែលបានរៀបការ»

លើកកូនស្រីឲ្យឲ្យមានប្តីផង

ការបកប្រែរបៀបផ្សេងទៀត: «អនុញ្ញាតឲ្យកូនស្រីរបស់អ្នករៀបការបាន»

ទីនោះផង...របស់ក្រុងនោះ

នេះសំដៅលើទីក្រុងបាប៊ីឡូន

ចូរស្វែងរកក្តីសុខសាន្តនៃទីក្រុង

ស្វែងរកការរស់នៅប្រកបដោយសេចក្តីសុខជាមួយមនុស្សជុំវិញ។

មិនបង្កឲ្យមានបញ្ហា និងទាស់ប្រឆាំងនឹងសិទ្ធអំណាចឡើយ។

Jeremiah 29:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលជនជាតិអ៊ីស្រាអែលដែលជាប់ជាឈ្លើយ។

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។

generated on Wed Sep 10 16:16:32 2025

Jeremiah 29:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីអ្វីដែលនឹងកើតឡើងចំពោះជនជាតិអ៊ីស្រាអែលដែលជាប់ជាឈ្លើយ
អ្នករាល់គ្នា
សំដៅទៅលើជនជាតិអ៊ីស្រាអែលដែលជាប់ជាឈ្លើយ។
ចិតសិបឆ្នាំ
ការបកប្រែរបៀបផ្សេងទៀត: «៧០ ឆ្នាំ»
Jeremiah 29:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីអ្វីដែលនឹងកើតឡើងចំពោះជនជាតិអ៊ីស្រាអែលដែលជាប់ជាឈ្លើយ
អំពាវនាវដល់យើង ហើយនឹងទៅអធិស្ឋានដល់យើង
ឃ្លាទាំងពីរនេះមានន័យដូចគ្នាហើយបញ្ជាក់ថាព្រះអម្ចាស់នឹងឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ចូរអធិស្ឋានមកយើង»។
យើងនឹងស្តាប់ដល់អ្នក
នេះជាឆ្លើយតបដែលព្រះអម្ចាស់ប្រទានតាមអ្វីដែលពួកគេទូលសុំ។
យើងនឹងនាំមក វិញនៅសំណាងរបស់អ្នករាល់គ្នា
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងបង្កើតការល្អប្រសើរសម្រាប់អ្នករាល់គ្នាម្តងទៀត»
Jeremiah 29:15
ព័ត៌មានទូទៅ:
លោកយេរេមាថ្លែងពីជនជាតិអ៊ីស្រាអែលដែលជាប់ជាឈ្លើយ។
អំពីស្តេចដែលគង់លើបល្ល័ង្ករបស់ដាវីឌ
នេះសំដៅលើស្តេចស្រុកយូដាដែលជាកូនចៅរបស់ព្រះបាទដាវីឌ។
មើល៍!
ការបកប្រែរបៀបផ្សេងទៀត: «ចូរមើល» ឬ «ចូរស្តាប់» ឬ «ចូរយកចិត្តទុកដាក់»
យើងនឹងចាត់ដាវ ការអំណត់ និងអាសន្នរោគមកលើគេ
«ដាវ» តំណាងឲ្យការសង្គ្រាម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងដាក់ទណ្ឌកម្មលើគេ»
ដ្បិតយើងនឹងធ្វើឲ្យគេត្រឡប់ទៅដូចជាផ្លែឧទុម្ពរមិនល្អ ដែលបរិភោគមិនបាន
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងដាក់ទណ្ឌកម្មគេយ៉ាងធ្ងន់ធ្ងរ» ឬ
«យើងនឹងធ្វើឲ្យជីវិតរបស់គេកាន់តែលំបាក»
Jeremiah 29:18
ជាទីគួរឲ្យខ្លាច ហើយជាទីដែលឲ្យអាសូណាស់ ហើយវាជាការអាម៉ាស់
ពាក្យទាំងនេះមានអត្ថន័យស្រដៀងគ្នា
ហើយបង្ហាញពីរបៀបដែលប្រជាជននៃជនជាតិនានា
ដែលមានប្រតិកម្មនៅពេលពួកគេឃើញអ្វីដែលព្រះអម្ចាស់បានធ្វើចំពោះជនជាតិយូដា។
ហើយជាទីដែលឲ្យអាសូរណាស់
ពាក្យថា «អាសូរ»
សំដៅទៅលើសំលេងនៃការមិនពេញចិត្តយ៉ាងខ្លាំងដែលមនុស្សបញ្ចេញនៅពេលពួកគេ
ឃ្លាមានអត្ថន័យដូចគ្នានឹង «ការដាក់បណ្តាសា»។
ស្តាប់
ការបកប្រែរបៀបផ្សេងទៀត: «ស្តាប់បង្គាប់»
Jeremiah 29:20
កូឡាយ៉ា និងសេដេគាជាកូនម្អាសេយ៉ា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ដែលជាឈ្លើយ
ការបកប្រែរបៀបផ្សេងទៀត: «ចូរមើល» ឬ «ចូរស្តាប់» ឬ
«ចូរយកចិត្តទុកដាក់នូវអ្វីដែលយើងនឹងប្រាប់អ្នករាល់គ្នា»
យើងនឹងប្រគល់គេទៅក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងឲ្យនេប៊ូក្នេសាយកឈ្នះលើពួកគេ»
Jeremiah 29:22
បណ្តាសានឹងដាក់ទៅដល់មនុស្សដទៃ
ដែលជាឈ្លើយ
ការបកប្រែរបៀបផ្សេងទៀត: «ជនជាតិអ៊ីស្រាអែលដែលជាប់ជាឈ្លើយនឹងនាំគ្នាបណ្តាសាពួកគេ»
ដុតរហូតដល់ស្លាប់
ការបកប្រែរបៀបផ្សេងទៀត: «ដុតរហូតដល់ស្លាប់»
យើងជាអ្នកដែលបានដឹង យើងជាទីបន្ទាល់ពិត
ឃ្លាទាំងពីរមានន័យដូចគ្នា ហើយព្រះអម្ចាស់រំលឹងពួកគេដើម្បីជាការបញ្ជាក់។
Jeremiah 29:24
សេម៉ាយ៉ា.....ម្អាសេយ៉ា.....យេហូយ៉ាដា
នេះជាឈ្មោះរបស់មនុស្ស។
នេហេលេម
នេះជាឈ្មោះនៃក្រុមមនុស្ស។
ដោយនូវឈ្មោះអ្នក
«ឈ្មោះ» សំដៅលើសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ផ្អែកលើសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់អ្នក»
គុក
នេះសំដៅលើបន្ទះស៊ុមឈើសម្រាប់ដាក់ទោសមនុស្សដែលអាចចាក់ច្រវ៉ាក់ដៃជើង
ឬក្បាល។
Jeremiah 29:27
ព័ត៌មានទូទៅ:
នេះបានបញ្ចប់សំបុត្ររបស់សេម៉ាយ៉ាដែលគាត់បានផ្ញើទៅប្រជាជននៅក្រុងយេរូសាឡិម។
ហេតុអ្វីបានជាមិនបានបន្ទោសដល់យេរេមា នៃក្រុងអាណាថោត ជាអ្នកដែលតាំងខ្លួនឡើងជាព្យាការី
ទាស់នឹងអ្នកផង?
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកគួរស្តីបន្ទោសលោកយេរេមាជាអ្នកស្រុកអាណាថោត
ដែលធ្វើឲ្យខ្លួនគាត់ក្លាយជាព្យាការីដែលថ្លែងប្រឆាំងនឹងអ្នក។»
ចូរធ្វើផ្ទះ ហើយអាស្រ័យនៅចុះ ចូរដាំដំណាំចម្ការ ហើយស៊ីផលចុះ
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ២៩:៤។
Jeremiah 29:30
សេម៉ាយ៉ាជា នៅនេហេលេម
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ២៩: ២៤។
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ១:១។
ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ១:៧។

---

30 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការីយេរេមាដូចតទៅ:[2]«ព្រះអម្ចាស់ ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖ ចូរកត់ត្រាទុកក្នុងក្រាំងមួយនូវពាក្យទាំងប៉ុន្មាន ដែលយើងប្រាប់អ្នក។[3]ដ្បិតនៅគ្រាខាងមុខ យើងនឹងស្តារអ៊ីស្រាអែល និងយូដាជាប្រជារាស្ត្ររបស់យើង ដែលជាប់ជាឈ្លើយ។ យើងនឹងនាំពួកគេវិលត្រឡប់មកទឹកដី ដែលយើងបានប្រគល់ឲ្យដូនតារបស់ពួកគេវិញ ហើយពួកគេនឹងកាន់កាប់ទឹកដីនេះ»។
[4]ព្រះអម្ចាស់មានព្រះបន្ទូលស្តីអំពីជនជាតិអ៊ីស្រាអែល និងជនជាតិយូដាដូចតទៅ[5]«ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងឮសម្រែកភ័យខ្លាច ចលាចលកើតមាននៅក្នុងទឹកដី គឺមិនមែនសន្តិភាពទេ។
[6]ចូរស៊ើបសួរឥឡូវ ឲ្យដឹង តើមនុស្សប្រុសដែលឈឺសម្រាលកូនឬ? ចុះហេតុអ្វីបានជាឃើញប្រុសៗទាំងអស់ កំពុងតែយកដៃស្ទឹមចុចចង្កេះ ដូចជាស្ត្រីដែលឈឺចាប់ ហៀបនឹងសម្រាលកូន ហើយមុខគេក៏ស្លេកស្លាំងគ្រប់គ្នាដូច្នេះ?[7]វរហើយ ដ្បិតថ្ងៃនោះជាថ្ងៃគួរស្ញើម ដែលគ្មានថ្ងៃណាមួយឲ្យដូចឡើយ នោះជាគ្រាវេទនារបស់ពួកយ៉ាកុប ប៉ុន្តែគេនឹងបានប្រោសឲ្យរួចចេញពីគ្រានោះ។
[8]ដ្បិតនៅថ្ងៃនោះ ព្រះអម្ចាស់នៃពិភពទាំងមូល មានព្រះបន្ទូលថា៖ យើងនឹងបំបាក់នឹមចេញពីករបស់គេ ក៏នឹងផ្តាច់ចំណងរបស់គេដែរ។ ពួកជនជាតិដទៃនឹងលែងធ្វើជាចៅហ្វាយរបស់គេទៀតហើយ។[9]ប៉ុន្តែគេនឹងគោរពបម្រើព្រះអម្ចាស់ ជាព្រះរបស់គេ និងដាវីឌ ជាស្តេចរបស់គេ ជាអ្នកដែលយើងនឹងតាំងឡើងឲ្យគ្រងរាជ្យលើគេ។
[10]ដូច្នេះ យ៉ាកុប ជាអ្នកបម្រើយើងអើយ កុំខ្លាចឡើយ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ អ៊ីស្រាអែលអើយ កុំស្រយុតចិត្តដែរ។ ដ្បិតយើងនឹងជួយសង្គ្រោះអ្នកមកពីឆ្ងាយ និងពូជពង្សអ្នកមកពីទឹកដីដែលគេនៅជាឈ្លើយ នោះពួកយ៉ាកុបនឹងវិលត្រឡប់មកវិញ ហើយនៅដោយសុខសាន្ត និងស្ងប់ស្ងាត់ ឥតមានអ្នកណាបំភ័យឡើយ។[11]ដ្បិតព្រះមានព្រះបន្ទូលថា៖ យើងនៅជាមួយ ដើម្បីជួយសង្គ្រោះអ្នក ពីព្រោះយើងនឹងធ្វើឲ្យអស់ទាំងនគរ ដែលយើងបានកម្ចាត់កម្ចាយអ្នកទៅនោះ ត្រូវផុតអស់រលីងទៅ តែមិនធ្វើឲ្យអ្នកផុតទេ គឺយើងនឹងវាយផ្ចាលអ្នកតាមខ្នាត យើងមិនបណ្តោយឲ្យអ្នកនៅដោយឥតវាយផ្ចាលឡើយ។

generated on Wed Sep 10 16:16:32 2025

[12]ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា ដំបៅអ្នកមើលមិនជាទេ ហើយរបួសអ្នកក៏ធ្ងន់ណាស់ផង។[13]គ្មានអ្នកណាកាន់ក្តីអ្នក ដើម្បីនឹងរុំរបួសអ្នកសោះ អ្នកក៏គ្មានថ្នាំណាផ្សះ។
[14]មនុស្សដែលអ្នកស្រឡាញ់បានភ្លេចអ្នកហើយ គេមិនរកអ្នកទៀតទេ ព្រោះយើងបានវាយអ្នកឲ្យរបួស ដូចជាខ្មាំងសត្រូវវាយដែរ ហើយបានវាយផ្តាលអ្នក ដូចជាមនុស្សសាហាវ ព្រោះចំនួនអំពើទុច្ចរិតរបស់អ្នកមានច្រើនណាស់ បាបអ្នកបានចម្រើនជាច្រើនឡើងហើយ។[15]ហេតុអ្វីបានជាអ្នកស្រែកដោយព្រោះដំបៅអ្នកដូច្នេះ? សេចក្តីឈឺចាប់របស់អ្នក មើលមិនជាទេ យើងបានធ្វើដល់អ្នកយ៉ាងនេះ ដោយព្រោះចំនួនអំពើទុច្ចរិតរបស់អ្នកមានច្រើនពេក បាបអ្នកបានចម្រើនជាច្រើនឡើងហើយ។
[16]ដូច្នេះ អស់អ្នកណាដែលត្របាក់ស៊ីអ្នក នឹងត្រូវគេត្របាក់ស៊ីវិញ អស់ទាំងខ្មាំងសត្រូវរបស់អ្នក គេនឹងត្រូវចាប់ទៅជាឈ្លើយគ្រប់គ្នាដែរ ពួកអ្នកដែលជិះជាន់អ្នក នឹងត្រូវគេជិះជាន់ដូចគ្នា ហើយអស់អ្នកដែលប្លន់អ្នក យើងនឹងឲ្យមានគេប្លន់អ្នកនោះវិញ។[17]ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងនឹងមើលអ្នកឲ្យជា ហើយនឹងធ្វើឲ្យរបួសអ្នកបានសះ ពីព្រោះគេបានហៅអ្នកជាពួកបំបរបង់ ដោយពាក្យថា នេះជាក្រុងស៊ីយ៉ូន គ្មានអ្នកណារាប់រកសោះ»។
[18]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «មើល៍! យើងនឹងនាំពួកឈ្លើយ ដែលចាប់ពីត្រសាលរបស់យ៉ាកុបឲ្យត្រឡប់មកវិញ យើងនឹងមានសេចក្តីអាសូរដល់ទីលំនៅរបស់គេ ហើយទីក្រុងនឹងបានសង់ឡើងវិញនៅលើគំនរចាស់ ហើយដំណាក់នឹងមាននៅដូចពីដើម។[19]ក៏នឹងឮពាក្យអរព្រះគុណ និងសំឡេងអរសប្បាយ ចេញពីនោះមក យើងនឹងធ្វើឲ្យគេចម្រើនឡើង គេមិនមានគ្នាតិចឡើយ យើងក៏នឹងធ្វើឲ្យគេថ្កុំថ្កើងឡើង គេមិនមែនជាគរតូចទាបទៀតទេ។
[20]កូនចៅរបស់គេនឹងបានដូចកាលពីដើម ហើយក្រុមជំនុំរបស់គេនឹងបានតាំងឡើងនៅចំពោះយើង យើងធ្វើនឹងទោសដល់អស់អ្នកណា ដែលសង្កត់សង្កិនគេ។[21]ពួកអ្នកធំរបស់គេនឹងកើតពីពួកគេមក ហើយចៅហ្វាយរបស់គេនឹងចេញពីកណ្តាលពួកគេដែរ យើងនឹងនាំគេ ហើយគេនឹងចូលមកជិតយើង ទ្រង់មានព្រះបន្ទូលថា៖ តើដែលមានអ្នកណាមានចិត្តក្លាហាន ហ៊ានចូលមកជិតយើងដូច្នេះឬ?[22]អ្នករាល់គ្នានឹងបានជាប្រជារាស្ត្ររបស់យើង ហើយយើងនឹងធ្វើជាព្រះរបស់អ្នករាល់គ្នា។
[23]មើល៍! ព្យុះសង្ឃរារបស់ព្រះជាម្ចាស់ គឺជាសេចក្តីក្រោធរបស់ព្រះអង្គបានចេញមកហើយ គឺជាខ្យល់កួចដែលបោសរំលីង ខ្យល់នោះនឹងធ្លាយមកលើក្បាលរបស់ពួកអាក្រក់។[24]សេចក្តីក្រោធដ៏សហ័សរបស់ព្រះជាម្ចាស់ នឹងមិនវិលមកវិញ ដរាបដល់ព្រះអង្គបានធ្វើសម្រេច ហើយបានបង្ហើយតាមបំណងព្រះហឫទ័យ នៅគ្រាចុងក្រោយបង្អស់ នោះអ្នករាល់គ្នានឹងយល់»។

Jeremiah 30:1
ចូរកត់ត្រាទុកក្នុងក្រាំងមួយនូវពាក្យទាំងប៉ុន្មាន ដែលយើងប្រាប់អ្នក
«ចូរកត់ត្រាទុក ពាក្យរបស់យើងដែលបានថ្លែងប្រាប់អ្នកនៅក្នុងក្រាំង»
ដ្បិតមើល៍!
«ចូរស្តាប់ដោយយកចិត្តទុកដាក់»។
ឃ្លានេះនាំមកនូវការយកចិត្តទុកដាក់ចំពោះអ្វីដែលព្រះអម្ចាស់នឹងមានបន្ទូលបន្ទាប់។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ១:៧។
យើងនឹងស្តារសំណាងនៃប្រជារាស្ត្ររបស់យើង
«យើងនឹងធ្វើឲ្យការទាំងនោះបានល្អសំរាប់ប្រជារាស្ត្ររបស់យើងសារជាថ្មី»
Jeremiah 30:4
យើងឮ
ពាក្យថា «យើង» សំដៅលើ ព្រះអម្ចាស់។ ទ្រង់សំដៅលើទ្រង់ផ្ទាល់ជា «យើង»
សម្លេងភ័យខ្លាច នៃចលាចល គឺមិនមែននៃសន្តិភាពទេ
ការបកប្រែរបៀបផ្សេងទៀត: អាចមានន័យថា ១) មនុស្សទូលអង្វរក្នុងពេលដែលភ័យខ្លាច ដោយព្រោះតែគ្មានសន្តិភាព» ឬ ២) «អ្នករាល់គ្នាទូលអង្វរ...សន្តិភាព»។
Jeremiah 30:6
ចូរស៊ើបសួរឥឡូវ ឲ្យដឹង តើមនុស្សប្រុសដែលឈឺសម្រាលកូនឬ
ការបកប្រែរបៀបផ្សេងទៀត: «គ្មានមនុស្សប្រុសដែលអាចបង្កើតកូនបានឡើយ»
ហេតុអ្វីបានជាឃើញគ្រប់ទាំងក្មេងកម្លេះ ដាក់ដៃពួកគេលើចង្កេះ ដូចជាស្រីដែលឈឺចាប់សម្រាលកូន? ហេតុអ្វីបានជាមុខគេទៅជាស្លេកស្លាំងគ្រប់គ្នាយ៉ាងនេះ?
ព្រះអម្ចាស់ប្រើសំនួរទាំងនេះដើម្បីបញ្ជាក់ពីភាពភ័យខ្លាចរបស់បុរស។
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែមនុស្សប្រុសក្មេងៗ
កាន់ក្បាលពោះដូចជាស្ត្រីសំរាលកូន
ដែលពួកគេមើលទៅហាក់ដូចជាឈឺព្រោះតែខ្លាច» (សូមមើល: និងfigs-rquestion)
សម្រាប់ពួកយ៉ាកុប ប៉ុន្តែ គេនឹងបានប្រោសឲ្យរួចចេញពីគ្រានោះ
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតកូនចៅរបស់លោកយ៉ាកុប
យើងនឹងសង្គ្រោះពួកគេ»
Jeremiah 30:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តថ្លែងព្រះបន្ទូលទៅកាន់ជនជាតិអ៊ីស្រាអែល។
យើងនឹងបំបាក់នឹមចេញពីករបស់អ្នក ក៏នឹងផ្តាច់ចំណងរបស់អ្នកដែរ
ឃ្លាទាំងពីរសំដៅលើព្រះអម្ចាស់បានធ្វើជនជាតិអ៊ីស្រាអែលរបស់ទ្រង់មានសេរីភាពពីទាសភាព
គេនឹងថ្វាយបង្គំព្រះអម្ចាស់
ពាក្យថា «ពួកគេ» សំដៅលើកូនចៅរបស់លោកយ៉ាកុប។
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នានឹងថ្វាយបង្គំព្រះអម្ចាស់»
បម្រើដាវីឌ ជាស្តេចរបស់គេ
នេះសំដៅលើកូនចៅរបស់ដាវីឌ។
Jeremiah 30:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តថ្លែងព្រះបន្ទូលទៅកាន់ប្រជារាស្ត្រអ៊ីស្រាអែល។
យ៉ាកុបជាអ្នកបម្រើរបស់យើង កុំខ្លាចឡើយ ... ហើយកុំស្រយុតចិត្ត អ៊ីស្រាអែលអើយ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ឃ្លាទី២ ជួយគាំទ្រគំនិតក្នុងឃ្លាទីមួយ។
ហើយកុំស្រយុតចិត្ត
«កុំព្រួយបារម្ភឡើយ»
ដ្បិត មើល៍!
«ចូរស្តាប់ដោយប្រុងប្រយត្ន័»
យើងនឹងជួយសង្គ្រោះអ្នកមកពីឆ្ងាយ និងពូជពង្សអ្នកមកពីទឹកដីដែលជាឈ្លើយ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ឃ្លាទី២ ជួយគាំទ្រគំនិតក្នុងឃ្លាទីមួយ។
ពីទឹកដីដែលជាឈ្លើយ
«ពីទឹកដីដែលអ្នកធ្លាប់ជាឈ្លើយសឹក»
យ៉ាកុបនឹងវិលត្រឡប់មកវិញ
«មនុស្សនឹងវិលត្រឡប់មកទឹកដីរបស់ខ្លួនគេ»
គ្មានការភ័យខ្លាចទៀតឡើយ
«មនុស្សនឹងមានសុវត្ថិភាព»
ដែលយើងបានកម្ចាត់កម្ចាយអ្នក
«ជាទីដែលយើងបានចាត់ឲ្យអ្នកទៅ»
តែយើងនឹងមិនធ្វើឲ្យបញ្ចប់ដល់អ្នកទេ
«តែយើង និងមិនបំផ្លាញអ្នកទេ»
នឹងពិតណាស់មិនបោះបង់អ្នក មិនដាក់ទោសដែរ
«នឹងពិតជាដាក់ទណ្ឌកម្មអ្នក»
Jeremiah 30:12
ព័ត៌មានទូទៅ:
លោកយេរេមាថ្លែងព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់ទៅប្រជាជនអ៊ីស្រាអែល។
ដំបៅអ្នកមើលមិនជាទេ ... អ្នកក៏គ្មានថ្នាំណាផ្សះ
នេះមានន័យថាព្រះអម្ចាស់បានដាក់ទោសពួកគេយ៉ាងធ្ងន់ធ្ងររហូតដល់គ្មាននរណាអាចជួយពួកគេបានឡើ
គ្មានអ្នកណាកាន់ក្តីអ្នក
«គ្មានអ្នកណាសុំយើងដើម្បីបង្ហាញក្តីមេត្តាករុណាដល់អ្នកទេ»
Jeremiah 30:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជារាស្ត្រអ៊ីស្រាអែល។
មនុស្សដែលអ្នកស្រឡាញ់
ស្រែកអោ
ព្រះអម្ចាស់មានបន្ទូលរៀបរាប់ពីប្រជារាស្ត្រអ៊ីស្រាអែល
ដូចជាជាភរិយាម្នាក់ដែលមិនស្មោះត្រង់ដែលយក
សេចក្តីស្រលាញ់ផ្សេងក្រៅពីប្តីរបស់នាង។ «សេចក្តីស្រលាញ់»
ត្រង់នេះសំដៅទៅលើប្រជាជាតិដទៃទៀត។
ជនជាតិអ៊ីស្រាអែលបានចងសម្ព័ន្ធភាពជាមួយពួកគេហើយថ្វាយបង្គំព្រះរបស់ពួកគេជាជាងពឹងផ្អែកលើព្រ
ពួកគេមិនរកអ្នកទៀតទេ

generated on Wed Sep 10 16:16:32 2025

«ពួកគេលែងចង់ធ្វើជាមិត្តរបស់អ្នកទៀតហើយ»
យើងបានវាយអ្នកឲ្យរបួស ដូចជាខ្មាំងសត្រូវវាយដែរ
នេះមានន័យថាព្រះអម្ចាស់បានប្រព្រឹត្តចំពោះប្រជារាស្ត្ររបស់ព្រះអង្គដូចព្រះអង្គនឹងធ្វើចំពោះសត្រូវរបស់ព្រះអង្គដែរ។
ហេតុអ្វីបានជាអ្នកស្រែករកជំនួយពីដំបៅអ្នកដូច្នេះ?
ព្រះអម្ចាស់បានសួរសំណួរមួយនៅទីនេះដើម្បីធ្វើឲ្យប្រជារាស្ត្រគិតពី
មូលហេតុអ្វីដែលពួកគេស្រែករកជំនួយពីព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត:
«កុំស្រែករកជំនួយសម្រាប់ពីដំបៅរបស់អ្នក»។
បាបអ្នកគឺច្រើនរាប់មិនអស់
«អំពើបាបរបស់អ្នកគឺច្រើនដែលរាប់មិនអស់»
Jeremiah 30:16
ដូច្នេះ អស់អ្នកណាដែលត្របាក់ស៊ីអ្នក នឹងត្រូវបានត្របាក់ស៊ីវិញ ហើយអស់ទាំងខ្មាំងសត្រូវរបស់
អ្នក នឹងត្រូវចាប់ទៅជាឈ្លើយ
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ឃ្លាទី
២ធ្វើឲ្យគំនិតទីមួយប្រសើរឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«ជនជាតិទាំងអស់ដែលបានធ្វើឲ្យអ្នកក្លាយជាទាសករនឹងក្លាយជាទាសករ»។
ដូច្នេះ អស់អ្នកណាដែលត្របាក់ស៊ីអ្នក នឹងត្រូវបានត្របាក់ស៊ីវិញ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះអ្នកទាំងនោះដែលបំផ្លាញអ្នក
ដែលសត្រូវរបស់គេនឹងបំផ្លាញពួកគេ»
ដ្បិតអស់អ្នកដែលប្លន់អ្នក យើងនឹងឲ្យមានគេប្លន់អ្នកនោះវិញ ហើយយើងនឹងធ្វើឲ្យពួកអ្នកដែលជិះ
ជាន់អ្នក នឹងត្រូវបានជិះជាន់ដូចគ្នា
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ឃ្លាទី
២ធ្វើឲ្យគំនិតទីមួយប្រសើរឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើអោយខ្មាំងសត្រូវដែលលួចយកអ្វីៗពីអ្នកនៅក្នុងសង្គ្រាមទៅលួចយករបស់ទាំងនោះវិញ ហើយយើងនឹងធ្វើឲ្យពួកគេវិញ
គេបានហៅអ្នក ថាជាអ្នកត្រូវបោះបង់
អ្នកដែលត្រូវគេបណ្តេញចេញគឺជាមនុស្សម្នាក់ដែលមនុស្សផ្សេងទៀតមិនទទួលយក
ឬអនុញ្ញាតឲ្យគាត់ចូលរួមជាមួយពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«គេបានហៅអ្នកថា៖ ត្រូវបានបដិសេធ» ឬ «ពួកគេបាននិយាយថា
គ្មានអ្នកណាចង់បានអ្នកទេ»
គ្មានអ្នកខ្វល់សម្រាប់ក្រុងស៊ីយ៉ូននេះទេ
ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្នកខ្វល់ពីប្រជាជនក្រុងស៊ីយ៉ូននេះទេ»
Jeremiah 30:18

ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជារាស្ត្រអ៊ីស្រាអែល
«ចូរស្តាប់ដោយប្រុងប្រយត្ន័»
យើងនឹងស្តារពូជពង្សទីជម្រោករបស់យ៉ាកុបឡើងវិញ ហើយនឹងអាណិតអាសូរក្រុមគ្រួសាររបស់គាត់
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើអោយកូនចៅរបស់លោកយ៉ាកុបរីកចម្រើនហើយយើងនឹងអាណិតអាសូរពួកគេ»
រួចហើយទីក្រុងនឹងសង់នៅលើគំនរបាក់បែកឡើងវិញ
ការបកប្រែរបៀបផ្សេងទៀត: «រួចហើយទីក្រុងយេរូសាឡិមលើគំនរបាក់បែកឡើង
វិញ»
ហើយសម្រៀងនៃការសរសើរ និងសម្លេងអរសប្បាយ ចេញពីពួកគេមក
«ហើយពួកគេច្រៀងចម្រៀងសរសើរ និងសម្លេងអរសប្បាយ»
គេមិនទន់ទាបទៀតទេ។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះគ្មានអ្នកណានឹងទន់ទាបគេទៀតទេ»
Jeremiah 30:20
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
ហើយក្រុមប្រជុំរបស់គេនឹងបានតាំងឡើងនៅចំពោះយើង
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងបង្កើតពួកគេឲ្យធ្វើជាប្រជារាស្ត្រនៅចំពោះមុខយើង»
មេដឹកនាំរបស់គេនឹងកើតចេញពីចំណោមពួកគេ។ គេនឹងកើតពី ចំណោមពួកគេដែរ
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ឃ្លាទី
ធ្វើឲ្យគំនិតទីមួយប្រសើរឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«មេដឹកនាំរបស់គេនឹងត្រូវជ្រើសរើសដោយប្រជាជន»។
តើអ្នកណាអាចចូលមកជិតយើងបានទៅ?
ព្រះអម្ចាស់ប្រើសំនួរមួយដើម្បីបញ្ជាក់ថាគ្មាននរណាម្នាក់នឹងមានភាពក្លាហានដើម្បីស្វែងរកទ្រង់បានទេលើ
Jeremiah 30:23
មើល៍! ព្យុះសង្ឃរារបស់ព្រះជាម្ចាស់ គឺជាសេចក្តីក្រោធរបស់ព្រះអង្គបានចេញមកហើយ
នេះប្រៀបធៀបសេចក្តីក្រោធ និងការដាក់ទោសរបស់ព្រះទៅនឹងព្យុះ។
នេះបញ្ជាក់លើឫទ្ធានុភាព និងចេស្តារបស់ទ្រង់ ដើម្បីបំផ្លាញមនុស្សអាក្រក់។

---

31 [1]«នៅគ្រានោះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖យើងនឹងធ្វើជាព្រះរបស់កុលសម្ព័ន្ធអ៊ីស្រាអែលទាំងមូល ពួកគេនឹងធ្វើជាប្រជារាស្ត្ររបស់យើង»។[2]ព្រះអម្ចាស់មាន
ព្រះបន្ទូលទៀតថា៖ «នៅវាលរហោស្ថានយើងបានសម្តែងការប្រណីសន្តោសដល់ ប្រជាជនដែលសេសសល់ពីស្លាប់ក្នុងចម្បាំង ហើយអ៊ីស្រាអែលនឹងបាន
សុខសាន្តត្រាណ»។[3]ពួកគេពោលថា ព្រះអម្ចាស់បានសម្តែងព្រះអង្គ ឲ្យខ្ញុំឃើញពីចម្ងាយ។ ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «យើងស្រឡាញ់អ្នក ដោយចិត្តស្រឡាញ់ ដែល
ស្ថិតស្ថេរនៅអស់កល្បជានិច្ច។ យើងទាក់ទាញចិត្តអ្នក ព្រោះយើងជំពាក់ចិត្តនឹងអ្នកយ៉ាងខ្លាំង។
[4]យើងនឹងសង់អ្នកឡើងវិញម្តងទៀត នាងព្រហ្មចារីអ៊ីស្រាអែលអើយ! ហើយអ្នកនឹងបានតាំងឡើង អ្នកនឹងបានតាក់តែងដោយក្រាប់ជាថ្មី ព្រមទាំងចេញទៅលោតកញ្ឆេង
ជាមួយពួកអ្នកដែលលេងសប្បាយ។[5]អ្នកនឹងដាំដំណាំទំពាំង បាយជូរ នៅលើភ្នំទឹកដីសាម៉ារីទៀត ម្ចាស់ដំណាំនឹងដាំទៅ ហើយទទួលផលផង។[6]ដ្បិតនឹងមានថ្ងៃមកដល់
ដែលពួកយាមនៅលើភ្នំទឹកដីអេប្រាអិម នឹងស្រែកឡើងថា៖ ចូរក្រោកឡើង យើងនឹងឡើងទៅឯព្រះជាម្ចាស់ ជាព្រះនៃយើងនៅក្រុងស៊ីយ៉ូន។
[7]ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «ចូរច្រៀងដោយចិត្តអរសប្បាយ ព្រោះពួកយ៉ាកុប ហើយស្រែកឡើងដោយអំណរ ដោយព្រោះមេប្រធាននៃអស់ទាំងជនជាតិ ចូរ
ប្រកាសប្រាប់ចុះ ចូរលើកសរសើរ ដោយពាក្យថា ព្រះជាម្ចាស់អើយ សូមជួយសង្គ្រោះសំណល់នៃជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់ព្រះអង្គផង។
[8]មើល៍! យើងនឹងនាំគេមកទឹកដីខាងជើង ហើយប្រមូលគេពីចុងផែនដីបំផុត មានទាំងពួកខ្វាក់ ពួកខ្វិន ស្ត្រីមានទម្ងន់ និងស្ត្រីដែលហៀបសម្រាលកូនផង ជាក្រុមមនុស្ស
យ៉ាងធំ ដែលនឹងវិលមកនៅទីនេះវិញ។[9]ពួកគេនឹងមកទាំងយំ និងទាំងពាក្យទូលអង្វរសូមសេចក្តីមេត្តាករុណា។ យើងនឹងនាំគេត្រឡប់មកវិញ យើងនឹងឲ្យគេដើរក្បែរ
កន្លែងដែលមានទឹកហូរ តាមផ្លូវត្រង់ជាផ្លូវដែលគេមិនចំពប់ដួលឡើយ។ ដ្បិតយើងជាឪពុកដល់ជនជាតិអ៊ីស្រាអែល ហើយពួកអេប្រាអិមជាកូនច្បងរបស់យើង»។
[10]«ចូរអ្នករាល់គ្នាស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជនជាតិដទៃទាំងប៉ុន្មានអើយ ហើយថ្លែងប្រាប់ដល់ពួកកោះដែលនៅឆ្ងាយថា៖ ព្រះដែលបានកម្ចាត់កម្ចាយ
ជនជាតិអ៊ីស្រាអែល ព្រះអង្គនឹងប្រមូលគេមកវិញ ហើយនឹងរក្សាគេដូចជាគង្វាលឃ្វាលហ្វូងចៀមរបស់ខ្លួន។[11]ព្រោះព្រះអម្ចាស់បានលោះយ៉ាកុបហើយ ព្រះអង្គបានដោះ
គេចេញពីកណ្តាប់ដៃ នៃពួកអ្នកដែលខ្លាំងជាងខ្លួន។
[12]គេនឹងមក ហើយច្រៀងនៅលើទីខ្ពស់នៃភ្នំស៊ីយ៉ូន ហើយមកហូរហែដល់សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ គឺមកដល់ស្រូវ ទឹកទំពាំងបាយជូរ ប្រេង និងកូនចៀម កូនគោ
ពីហ្វូងសត្វ ហើយព្រលឹងគេនឹងបានដូចជាសួនច្បារ ដែលមានទឹកស្រោច នោះគេនឹងមិនមាន សេចក្តីព្រួយទៀតឡើយ។
[13]គ្រានោះ នាងក្រមុំនឹងមានចិត្តរីករាយ ក្នុងការលោតកញ្ឆេង ព្រមទាំងពួកកំលោះៗ និងពួកចាស់ៗទាំងអស់គ្នាផង ដ្បិតយើងនឹងបំប្រែសេចក្តីសោកសៅរបស់គេ ទៅជា
អំណរវិញ ហើយកម្សាន្តចិត្តគេ ព្រមទាំងឲ្យគេរីករាយ ចេញពីសេចក្តីទុក្ខព្រួយរបស់គេ។[14]យើងនឹងចម្អែតព្រលឹងពួកសង្ឃ ដោយសេចក្តីបរិបូរ ហើយឲ្យប្រជារាស្ត្ររបស់
យើងបានស្កប់ចិត្ត ដោយសេចក្តីសប្បុរសរបស់យើង នេះហើយជាព្រះបន្ទូលនៃព្រះជាម្ចាស់»។
[15]ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «មានឮសូរសំឡេងនៅរ៉ាម៉ា ជាសូរទំនួញ និងសូរយំយ៉ាងជូរចត់ គឺនាងរ៉ាជែលយំនឹងកូននាង ហើយមិនព្រមកម្សាន្តចិត្ត ពីដំណើរ
កូនសោះ ដ្បិតវាវិនាសបាត់ហើយ»។
[16]ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «ចូរទប់សំឡេងអ្នកមិនឲ្យយំ និងភ្នែកអ្នកមិនឲ្យហូរសស្រាក់ឡើយ ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលថា៖ កិច្ចការរបស់អ្នកនឹងបាន
រង្វាន់ជាពិត ហើយ វារាល់គ្នានឹងវិលមកពីទឹកដីរបស់ខ្មាំងសត្រូវវិញ។[17]ព្រះជាម្ចាស់ក៏មានព្រះបន្ទូលថា៖ មានសេចក្តីសង្ឃឹមសម្រាប់ចុងបំផុតរបស់អ្នក កូនចៅអ្នកនឹងវិល
មកព្រំដែនរបស់គេវិញ»។
[18]«យើងបានឮពួកអេប្រាអិម កំពុងតែតួញត្អែរថា៖ ព្រះអង្គបានវាយផ្ចាលទូលបង្គំ គឺទូលបង្គំត្រូវវាយពង្រាបដូចជាកូនគោ ដែលមិនធ្លាប់ទឹម សូមព្រះអង្គទាញញាក់
ទូលបង្គំមកវិញ នោះទូលបង្គំនឹងវិលបែរមកហើយ ដ្បិតគឺព្រះអង្គហើយជា ជាព្រះនៃទូលបង្គំ។[19]ក្រោយដែលព្រះអង្គបានទាញញាក់ទូលបង្គំមកវិញ នោះទូលបង្គំបានប្រែ

generated on Wed Sep 10 16:16:32 2025

គំនិតឡើងជាពិត កាលទូលបង្គំបានទទួលសេចក្ដីប្រៀនប្រដៅហើយ នោះក៏វាយទះភ្លៅខ្លួន ទូលបង្គំមានសេចក្ដីខ្មាស អើ ក៏ជ្រប់មុខផង ពីព្រោះទូលបង្គំធន់រង សេចក្ដីអាម៉ាស់ខ្មាសនៃវ័យក្មេង។[20]តើអេប្រាអិមជាកូនសម្លាញ់របស់យើងឬ? តើជាកូនសំណព្វឬ? ដ្បិតដែលយើងនិយាយទាស់នឹងវាវេលាណា នោះយើងក៏នឹករឭកដល់វានៅវេលានោះ។ ដូច្នេះ យើងមានចិត្តរំជួលដល់វា និងអាណិតមេត្តាដល់វាជាមិនខាន នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់»។
[21]ចូរធ្វើទីសម្គាល់តាមផ្លូវ ហើយដោតតម្រុយចុះ ចូរតាំងចិត្តតម្រង់ទៅឯថ្នល់ គឺជាផ្លូវដែលអ្នកបានទៅតាមនោះ ព្រហ្មចារីនៃជនជាតិអ៊ីស្រាអែលអើយ ចូរវិលមកវិញ ចូរវិលមកឯទីក្រុងរបស់អ្នកទាំងនេះចុះ។[22]ឱកូនស្រីដែលរាថយអើយ តើនាងនៅតែដើរសាត់អណ្តែតដល់កាលណាទៀត? ដ្បិតព្រះជាម្ចាស់បានបង្កើតការមួយថ្មីនៅលើផែនដី គឺស្ត្រីហ៊ុមព័ទ្ធបុរស។
[23]ព្រះជាម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ «កាលណាយើងនាំពួកគេ ដែលជាឈ្លើយមកវិញ នៅក្នុងទឹកដីយូដា ហើយអស់ទាំងទីក្រុងនៅទឹកដីនោះ គេនឹងនិយាយពាក្យនេះឡើងជាថ្មីទៀត គឺថា ឱទីលំនៅនៃសេចក្ដីសុចរិត ហើយភ្នំនៃសេចក្ដីបរិសុទ្ធអើយ សូមព្រះជាម្ចាស់ប្រទានពរដល់អ្នក។[24]ទឹកដីយូដា និងទីក្រុងទាំងប៉ុន្មានរបស់ទឹកដីនោះ នឹងនៅទីនោះជាមួយគ្នា ហើយពួកអ្នកធ្វើស្រែចម្ការ និងអស់អ្នកដែលដើរចុះឡើង ក៏នៅជាមួយហ្វូងសត្វរបស់គេដែរ។[25]ដ្បិតយើងបានចម្អែតព្រលឹងមនុស្សដែលល្វើយ ឯព្រលឹងព្រួយលំបាក យើងបានឲ្យស្កប់ចិត្តឡើងវិញ»។[26]មកដល់ត្រឹមនេះ ខ្ញុំបានភ្ញាក់ដឹងខ្លួនឡើង ហើយពេលនោះ ខ្ញុំដេកលក់ស្កប់ស្កល់ណាស់។
[27]មើល៍! នឹងមានគ្រាមកដល់ ដែលព្រះជាម្ចាស់មានព្រះបន្ទូលថា៖ ដែលយើងនឹងយកពូជមនុស្ស និងពូជសត្វព្រោះចុះក្នុងពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដា។[28]ដែលយើងបានមើលគេ ដើម្បីនឹងដករំលើង កាច់បំបាក់ រំលំ បំផ្លាញ ហើយធ្វើទុក្ខជាយ៉ាងណា នោះយើងនឹងមើលគេ ដើម្បីនឹងសង់គេឡើង ហើយដាំគេយ៉ាងនោះដែរ នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់។
[29]នៅគ្រានោះ គេលែងនិយាយថា៖ ឪពុកបានស៊ីផ្លែទំពាំងបាយជូរ ហើយកូនបែរជាសង្កៀរធ្មេញ។[30]ដ្បិតគ្រប់គ្នានឹងត្រូវស្លាប់ ដោយព្រោះអំពើទុច្ចរិតរបស់គេរៀងខ្លួន អស់អ្នកណាដែលស៊ីផ្លែទំពាំងបាយជូរ គឺអ្នកនោះឯងដែលនឹងសង្កៀរធ្មេញ។
[31]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ នៅគ្រាខាងមុខយើងនឹងចងសម្ពន្ធមេត្រីថ្មីជាមួយប្រជាជនអ៊ីស្រាអែល និងប្រជាជនយូដា។[32]សម្ពន្ធមេត្រីថ្មីនេះមិនដូចសម្ពន្ធមេត្រី ដែលយើងបានចងជាមួយបុព្វបុរសរបស់ពួកគេ នៅគ្រាដែលយើងដឹកដៃបុព្វបុរសនោះ នាំចេញពីទឹកដីអេស៊ីបទេ។ ទោះបីយើងជាម្ចាស់របស់ពួកគេក្ដី ក៏ពួកគេផ្តាច់សម្ពន្ធមេត្រីរបស់យើងដែរ។ នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[33]សម្ពន្ធមេត្រីថ្មី ដែលយើងនឹងចងជាមួយប្រជាជនអ៊ីស្រាអែលនៅពេលខាងមុខ មានដូចតទៅ: យើងនឹងដាក់ក្រឹត្យវិន័យរបស់យើងនៅក្នុងជម្រៅចិត្តរបស់ពួកគេ យើងនឹងចារក្រឹត្យវិន័យនោះក្នុងចិត្តគំនិតរបស់ពួកគេ យើងនឹងធ្វើជាព្រះរបស់ពួកគេ ពួកគេធ្វើជាប្រជារាស្ត្ររបស់យើង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[34]គេនឹងលែងបង្រៀនជនរួមជាតិរបស់ខ្លួន គេក៏លែងនិយាយប្រាប់បងប្អូនរបស់ខ្លួនថា ត្រូវតែស្គាល់ព្រះអម្ចាស់ ទៀតហើយ ព្រោះតាំងពីអ្នកតូចបំផុតរហូតដល់អ្នកធំបំផុត គេនឹងស្គាល់យើងគ្រប់ៗគ្នា។ យើងអត់ឱនឲ្យគេចំពោះអំពើទុច្ចរិត ដែលគេបានប្រព្រឹត្ត ហើយយើងក៏លែងនឹកនាពីអំពើបាបរបស់គេទៀតដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[35]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ ព្រះដែលប្រទានព្រះ អាទិត្យសម្រាប់ជាពន្លឺនៅពេលថ្ងៃ ហើយតាំងរបៀបនៃព្រះចន្ទ និងតារាទាំងប៉ុន្មានសម្រាប់បំភ្លឺនៅពេលយប់ ជាព្រះដែលបណ្តាលឲ្យសមុទ្រកម្រើកឡើង ដល់ម៉្លេះបានជាឮសន្ធឹករលក ដែលព្រះនាមព្រះអង្គជាព្រះអម្ចាស់នៃពួកពលបរិវារ[36]«បើបញ្ញត្តិច្បាប់ទាំងនេះ ឃ្លាតចេញពីមុខយើងទៅកាលណា នោះព្រះអម្ចាស់មានព្រះបន្ទូលថា៖ ពូជអ៊ីស្រាអែលក៏នឹងលែងធ្វើជានគរ នៅមុខយើងជារៀងរហូតដែរ»។
[37]ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ «បើអាចនឹងវាស់ផ្ទៃមេឃខាងលើ ហើយស្ទង់ឫសផែនដីនៅខាងក្រោមបាន យើងនឹងបោះបង់ចោលពូជអ៊ីស្រាអែល ដោយព្រោះកិច្ចការទាំងប៉ុន្មានដែលគេបានប្រព្រឹត្តដែរ នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់»។
[38]«ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ មើល៍! នឹងមានគ្រាមកដល់ ដែលទីក្រុងនេះនឹងបានសង់ឡើងថ្វាយព្រះជាម្ចាស់ ចាប់តាំងពីប៉មហាណានាល រហូតដល់ទ្វារជ្រុងកំផែង។[39]គេនឹងយកខ្សែរង្វាស់វាស់ចេញទៅដល់ភ្នំការេប ហើយបត់មកដល់កូអាត។[40]ឯច្រកភ្នំទាំងមូលនៃសាកសព និងផេះ ព្រមទាំងចម្ការទាំងប៉ុន្មានរហូតដល់ជ្រោះកេដ្រុន និងដល់ជ្រុងកំផែងទ្វារសេះ ដែលបើកទៅទិសខាងកើត នោះនឹងបានជាទីបរិសុទ្ធដល់ព្រះអម្ចាស់ទាំងអស់ មិនត្រូវដករំលើង ឬរំលំបំផ្លាញទៀតឡើយ នៅជាដរាបតទៅ»។

Jeremiah 31:1
នៅគ្រានោះ
នេះសំដៅលើគ្រាដែលព្រះអម្ចាស់ដាក់ទោសដល់ពួកមនុស្សអាក្រក់។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ៧។
ព្រះអម្ចាស់បានលេចមកឲ្យខ្ញុំ
ពាក្យថា «ខ្ញុំ» សំដៅលើប្រជារាស្ត្រអ៊ីស្រាអែល។
Jeremiah 31:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅប្រជារាស្ត្រអ៊ីស្រាអែល។
យើងនឹងសង់អ្នកឡើងវិញម្តងទៀត ដូច្នោះអ្នកនឹងបានសង់ឡើង
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងធ្វើឲ្យអ្នករឹងមាំម្តងទៀត» ឬ «យើងនឹងធ្វើឲ្យអ្នករីកចម្រើនសារជាថ្មី»
នាងព្រហ្មចារីអ៊ីស្រាអែលអើយ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១៨: ១៣។
ក្រាប់
ឧបករណ៍តន្ត្រីដែលមានក្បាលដូចជាស្គរដែលអាចវាយ
និងមានដុំដែកតូចៗព័ទ្ធជុំវិញវាដែលបញ្ចេញសំលេងនៅពេលដែលឧបករណ៍នោះត្រូវបានរង្គោះ
Jeremiah 31:7
ចូរលើកសរសើរឲ្យបានឮ
ការបកប្រែរបៀបផ្សេងទៀត:
«ចូរឲ្យអ្នករាស់គ្នាបានលឺពីការលើកសរសើររបស់អ្នក»
ពួកដែលនៅសេសសល់នៃអ៊ីស្រាអែល
«ពួកមនុស្សដែលនៅមានជីវិត» (UDB)
Jeremiah 31:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
មើល៍!
«ចូរស្តាប់» ឬ«ចូរយកចិត្តទុកដាក់»
នាំពួកគេចេញមក
ពាក្យថា «ពួកគេ» សំដៅលើប្រជារាស្ត្រអ៊ីស្រាអែល។
យើងជាឪពុកដល់ជនជាតិអ៊ីស្រាអែល ហើយពួកអេប្រាអិមជាកូនច្បងរបស់យើង
ពាក្យថា «អេប្រាអិម» គឺជាឈ្មោះមួយទៀតសម្រាប់ «អ៊ីស្រាអែល»។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងក្លាយជាឪពុករបស់ជនជាតិអ៊ីស្រាអែល ហើយពួកគេនឹងដូចជាកូនច្បងរបស់យើង»
កូនច្បងរបស់យើង
កូនច្បងមានអភ័យឯកសិទ្ធ និងការទទួលខុសត្រូវពិសេស។
Jeremiah 31:10
អ្នកដែលបានកម្ចាត់កម្ចាយជនជាតិអ៊ីស្រាអែល គឺនឹងប្រមូលគេមកវិញ
ការបកប្រែរបៀបផ្សេងទៀត: «យើងបានធ្វើអោយប្រជារាស្ត្ររបស់យើង ត្រូវបានកម្ចាត់កម្ចាយក្នុងចំណោមជាតិសាសន៍នានា ប៉ុន្តែឥឡូវនេះយើងនាំពួកគេវិលត្រឡប់ទៅផ្ទះវិញ»។
ដូចជាអ្នកគង្វាលឃ្វាលហ្វូងចៀមរបស់ខ្លួន
ការបកប្រែរបៀបផ្សេងទៀត: ន័យថាព្រះអម្ចាស់យកចិត្តទុកដាក់និងការពាររាស្ត្ររបស់ទ្រង់ ដូចជាអ្នកគង្វាលថែរក្សាចៀមរបស់គេ។
ព្រោះព្រះអម្ចាស់បានលោះយ៉ាកុបហើយ ព្រះអង្គបានដោះលោកឲ្យចេញពីកណ្តាប់ដៃ នៃពួកអ្នក
ដែលខ្លាំងជាងលោក
ឃ្លាទាំងពីរនេះមានអត្ថន័យដូចៗគ្នាហើយបញ្ជាក់ថាគឺជាព្រះអម្ចាស់ដែលបានជួយសង្គ្រោះប្រជារាស្ត្រអ៊ីស្រ
ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតព្រះអម្ចាស់បានជួយសង្គ្រោះប្រជារាស្ត្រអ៊ីស្រាអែលឲ្យរួចផុតពីខ្មាំងសត្រូវដែលខ្លាំងពូកែជាងពួកគេ
Jeremiah 31:12
សួនច្បារដែលមានទឹកស្រោច

generated on Wed Sep 10 16:16:32 2025

នេះមានន័យថាពួកគេនឹងរឹងមាំនិងមានសុខភាពល្អហើយនឹងរីកចម្រើន។
ពួកគេនឹងមិនមាន សេចក្តីទុក្ខព្រួយម្តងទៀតទេ
នេះគឺជាពាក្យបំផ្លើសរបស់អ៊ីស្រាអែលដែលថាពួកគេមានអំណរ។
Jeremiah 31:13
យើងនឹងបំប្រែ
ពាក្យថា «យើង» សំដៅលើព្រះអម្ចាស់។
ប្រជារាស្ត្ររបស់យើងបាននឹងបំពេញខ្លួនគេ ជាមួយសេចក្តីសប្បុរសរបស់យើង
«សេចក្តីសប្បុរសរបស់យើង នឹងបំពេញចិត្តប្រជារាស្ត្ររបស់យើង»
Jeremiah 31:15
ឮសូរសម្លេងនៅរ៉ាម៉ា
ការបកប្រែរបៀបផ្សេងទៀត: «យើងបានលឺសម្លេងនៅរ៉ាម៉ា»
នាងរ៉ាជែលយំសោកសម្រាប់កូននាង
ពាក្យថា «នាងរ៉ាជែល»
សំដៅទៅលើស្ត្រីជនជាតិអ៊ីស្រាអែលដែលកំពុងយំសោកចំពោះកូនៗរបស់នាង។
នាងមិនព្រមកម្សាន្តចិត្តលើពួកគេ ដ្បិតពួកគេមិនអាចរស់បានយូរទៀតទេ
ការបកប្រែរបៀបផ្សេងទៀត:
«នាងនឹងមិនអនុញ្ញាតឲ្យនរណាម្នាក់កម្សាន្តចិត្តនាងទេ ព្រោះកូន
ៗរបស់នាងបានស្លាប់»
Jeremiah 31:18
ព្រះអង្គបានដាក់ទោសទូលបង្គំ គឺទូលបង្គំត្រូវទទួលទោស
ការប្រើពាក្យ
ដដែលៗនៃឃ្លានេះបង្ហាញពីភាពធ្ងន់ធ្ងរនៃការដាក់ទោសរបស់ព្រះអម្ចាស់
ឬលទ្ធផលនៃការដាក់ទោស។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គដាក់ទោសខ្ញុំយ៉ាងធ្ងន់ធ្ងរ»
ដូចជាគោដែលមិនធ្លាប់ទឹម
អេប្រាអិមទូលសុំព្រះអម្ចាស់បង្រៀនគាត់ដូចជាកូនគោដែលមិនធ្លាប់ទឹម។
ទូលបង្គំមានសេចក្តីខ្មាស ហើយអាម៉ាស់មុខផង
ពាក្យថា «សេចក្តីខ្មាស់» និង «អាម៉ាស់មុខ»
មានន័យដូចគ្នាហើយបង្កើនគំនិតនៃការខ្មាស់អៀន។ ការបកប្រែរបៀបផ្សេងទៀត:
«ទូលបង្គំខ្មាស់អៀនខ្លាំងណាស់»។
តើអេប្រាអិមមិនមែនជាកូនសម្លាញ់របស់យើងទេឬ? តើគេមិនមែនជាកូនសំណព្វចិត្តយើងទេឬ?
ការបកប្រែរបៀបផ្សេងទៀត: «អេប្រាអិមគឺជាកូនដ៏ជាទីស្រឡាញ់របស់យើង។
គេគឺជាកូនប្រុសជាទីកូនសំណព្វចិត្តយើង។
Jeremiah 31:21
ព័ត៌មានទូទៅ:
ព្រះអង្គបន្តមានព្រះបន្ទូលពីជំពូក ៧។
ចូរដាក់សញ្ញាតាមផ្លូវសម្រាប់អ្នក។ ហើយដោតបង្គោលតម្រុយសម្រាប់អ្នក។ ចូរ
តាំងគំនិតនៅលើផ្លូវដ៏ត្រឹមត្រូវ គឺជាផ្លូវដែលអ្នកត្រូវទៅតាមនោះ។ ចូរវិលមកវិញ
បទបញ្ញត្តិនេះថ្លែងទៅដល់ «ព្រហ្មចារីនៃជនជាតិអ៊ីស្រាអែល»។
ចូរតាំងគំនិតនៅលើផ្លូវដ៏ត្រឹមត្រូវ គឺជាផ្លូវដែលអ្នកត្រូវទៅតាមនោះ
ការបកប្រែរបៀបផ្សេងទៀត: «ចូរព្យាយាមចងចាំផ្លូវអ្នកមក
នៅពេលដែលអ្នកត្រូវបានគេចាប់យកទៅជាឈ្លើយ»។
ចូរវិលមកវិញ ព្រហ្មចារីនៃជនជាតិអ៊ីស្រាអែលអើយ!
ព្រះអម្ចាស់ កំពុងតែសំដៅទៅលើជនជាតិអ៊ីស្រាអែលដែលបានផ្លាស់ប្តូរ។
តើអ្នកនៅវង្វេងស្មារតីដល់កាលណាទៀត ប្រជាជនដែលមានជំនឿតិច?
ព្រះអម្ចាស់សួរថា តើប្រជារាស្ត្ររបស់ទ្រង់នឹងមិនស្តាប់បង្គាប់ទ្រង់ដល់ពេលណា។
ការបកប្រែរបៀបផ្សេងទៀត:
«កុំស្ទាក់ស្ទើរក្នុងការចាប់ផ្តើមស្តាប់បង្គាប់យើងឡើយ»
Jeremiah 31:23
ប្រជាជន
ពាក្យនេះសំដៅលើប្រជាជនស្រុកយូដា។
សូមព្រះជាម្ចាស់ប្រទានពរដល់អ្នក ព្រះអង្គសុចរិតហើយកន្លែងដែលព្រះអង្គគង់នៅ
គឺនៅលើភ្នំបរិសុទ្ធនៃព្រះអង្គ
ក្រុងយេរូសាឡិមស្ថិតនៅលើកំពូលភ្នំ
ហើយព្រះវិហារនេះត្រូវបានសង់នៅចំណុចខ្ពស់បំផុតនៅក្រុងយេរូសាឡិម។
ការបកប្រែរបៀបផ្សេងទៀត:
«សូមព្រះអម្ចាស់ប្រទានពរដល់អស់អ្នកដែលរស់នៅក្នុងក្រុងយេរូសាឡិមជាមួយព្រះអម្ចាស់
ដែលជាព្រះដំណាក់របស់ព្រះអង្គគង់នៅ។
Jeremiah 31:27
យើងនឹងសាបព្រោះដល់ពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដា
ជាមួយកូនចៅរបស់មនុស្សហើយនិងសត្វព្រៃ
«យើងនឹងធ្វើឲ្យមនុស្ស និងសត្វកើនចំនួនឡើងដូចជាកសិករដាំដំណាំ» ឬ
«យើងនឹងបង្កើនចំនួនប្រជាជនទាំងសត្វនៅក្នុងរាជាណាចក្រអ៊ីស្រាអែល
និងស្រុកយូដា»។
យើងបានទុកពួកគេ នៅក្រោមការឃ្លាំមើល ដើម្បីនឹងដកឫសពួកគេ
«ស្វែងរកវិធីក្នុងការដកឫសពួកគេ»
ដកឫសពួកគេ ហើយហែកពួកគេឲ្យធ្លាក់ចុះ ដើម្បីបោះបង់ចោល បំផ្លាញ
សូមមើលពីរបៀបបកប្រែក្នុងគំនិតនេះក្នុងជំពូក ១:៩។
Jeremiah 31:31
ចូរមើល!
«ចូរស្តាប់» ឬ «ចូរយកចិត្តទុកដាក់អ្វីដែលយើងនឹងមានបន្ទូលប្រាប់អ្នក»។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ៧។
Jeremiah 31:33
យើងនឹងដាក់ក្រឹត្យវិន័យរបស់យើងនៅក្នុងពួកគេ យើងនឹងចារក្រឹត្យវិន័យនោះក្នុងចិត្តរបស់ពួកគេ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នាហើយបញ្ជាក់ថា
ក្រឹត្យវិន័យរបស់ព្រះអម្ចាស់នឹងក្លាយជាចំណែករបស់ពួកគេ
ជាជាងចារនៅលើបន្ទះថ្ម។ ពាក្យថា «ចិត្ត» តំណាងឱ្យ «អារម្មណ៍» ឬ «គំនិត»។
ការបកប្រែរបៀបផ្សេងទៀត: «ក្រឹត្យវិន័យរបស់យើងនឹងជាផ្នែកមួយនៃគំនិត
និងអារម្មណ៍របស់ពួកគេ»។
ពីអ្នកតូចបំផុតនៃពួកគេដល់អ្នកធំបំផុត
ឃ្លានេះសំដៅទៅលើមនុស្សគ្រប់រូប
ដោយមិនគិតពីពួកគេសំខាន់ប៉ុណ្ណានៅក្នុងសង្គម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេម្នាក់ៗ»។
Jeremiah 31:37
ផ្ទៃមេឃដ៏ខ្ពស់អាចនឹងវាស់បាន ហើយប្រសិនបើគ្រិះរបស់ផែនដី
ឃ្លានេះសំដៅលើការបង្កបង្កើតទាំងស្រុង។
Jeremiah 31:38
ចូរមើល! ថ្ងៃនោះនឹងមកដល់
«ចូរយកចិត្តទុកដាក់! នូវអ្វីដែលនឹងមានបន្ទូលប្រាប់ពីអ្វីដែលនឹងកើតឡើង។»
ប៉មហាណានាល .....ទ្វារជ្រុងកំពែង...ជ្រលោងភ្នំរបស់ការេប...កូអាត...ជ្រលោងកេដ្រុន...ជ្រុង
កំពែងទ្វារសេះ
ទាំងនេះគឺជាឈ្មោះទីកន្លែង។
ញែកទុក
«ជាបរិសុទ្ធ»

---

32 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការីយេរេមា នៅឆ្នាំទីដប់នៃរជ្ជកាលព្រះបាទសេដេគាជាស្តេចទឹកដីយូដា ត្រូវនឹងឆ្នាំទីដប់ប្រាំបីនៃរជ្ជកាលព្រះចៅនេប៊ូក្នេសា។ [2]ពេលនោះ កងទ័ពរបស់ព្រះចៅនេប៊ូក្នេសាឡោមព័ទ្ធក្រុងយេរូសាឡឹម។ ចំណែកលោកព្យាការីយេរេមា ត្រូវបានគេយកទៅឃុំនៅពន្ធនាគារ ក្នុងវាំងស្តេចទឹកដីយូដា។ [3]ព្រះបាទសេដេគាជាស្តេចយូដា បានឃុំលោក ដោយមានរាជឱង្ការថា៖ ហេតុអ្វីបានជាអ្នកថ្លែងទំនាយថា ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះ មើល៍! យើងនឹងប្រគល់ក្រុងនេះ ទៅក្នុងកណ្តាប់ដៃស្តេចបាប៊ីឡូន ហើយគេនឹងចាប់យក។ [4]ហើយសេដេគា ជាស្តេចយូដា នឹងមិនរួចពីកណ្តាប់ដៃនៃពួកខាល់ដេឡើយ គឺត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចទឹកដីបាប៊ីឡូន ហើយនិយាយនឹងគេផ្ទាល់មាត់ ទ្រង់ក៏នឹងឃើញគេផ្ទាល់នឹងភ្នែកដែរ។ [5]គេនឹងនាំស្តេចសេដេគាទៅក្រុងបាប៊ីឡូន ហើយទ្រង់នឹងត្រូវនៅទីនោះទាល់តែយើងចរចាជាមួយនិងគេ នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់។ ទោះបើអ្នករាល់គ្នាតស៊ូនឹងពួកខាល់ដេក៏ដោយ គង់តែនឹងឈ្នះមិនបានដែរ»។
[6]ព្យាការីយេរេមាមានប្រសាសន៍ថា៖ «ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានមកដល់ខ្ញុំថា [7]មើល ហាណាមាល ជាកូនសាលូម ឪពុកមារបស់អ្នក នឹងមកនិយាយជាមួយអ្នកថា «សូមទទួលទិញចម្ការរបស់ខ្ញុំដែលនៅអាណាថោតទៅ ដ្បិតអំណាចដែលនឹងលោះបងប្អូន នោះស្រេចនឹងអ្នកទេ»។
[8]ដូច្នេះ ហាណាមាល ជាកូនរបស់ឪពុកមាខ្ញុំ ក៏មករកខ្ញុំនៅក្នុងទីលានចាំយាម តាមព្រះបន្ទូលនៃព្រះអម្ចាស់ ហើយគាត់និយាយមកខ្ញុំថា៖ សូមទិញចម្ការរបស់ខ្ញុំដែលនៅអាណាថោត ក្នុងទឹកដីបេនយ៉ាមីនទៅ ដ្បិតអ្នកមានច្បាប់នឹងគ្រងបានជាមរតក ហើយអំណាចលោះក៏ស្រេចនៅលើអ្នកដែរ ដូច្នេះ សូមទទួលទិញ ទុកសម្រាប់ខ្លួនអ្នក

generated on Wed Sep 10 16:16:32 2025

ចុះយ៉ាងនោះ ទើបខ្ញុំបានដឹងថា ជាព្រះបន្ទូលនៃព្រះអម្ចាស់។[9]ខ្ញុំក៏ទទួលទិញចម្ការ ដែលនៅអាណាថោត ពីហាណាមាល ជាកូនរបស់ឪពុកមាខ្ញុំ ហើយបានថ្លឹងប្រាក់ដប់ប្រាំពីរសេកែលឲ្យគាត់។
[10]ក៏ធ្វើសំបុត្រ ហើយវាយត្រាព្រមទាំងហៅស្មរបន្ទាល់មក។ រួចថ្លឹងប្រាក់ក្នុងជញ្ជីងប្រគល់ដល់គាត់។[11]បន្ទាប់មក ខ្ញុំបានយកសំបុត្រទិញដី ទាំងសំបុត្រដែលមានវាយត្រាតាមច្បាប់ តាមទំនៀម និងសំបុត្រមួយដែលមិនមានត្រាដែរ[12]ខ្ញុំក៏ប្រគល់សំបុត្រទិញដីដល់បារូក ជាកូននេរីយ៉ាដែលជាកូនម៉ាសេយ៉ានៅចំពោះមុខហាណាមាលជាកូនរបស់ឪពុកមាខ្ញុំ និងនៅចំពោះពួកស្មរបន្ទាល់ ដែលបានចុះឈ្មោះនិងវាយត្រាក្នុងសំបុត្រទិញដីនោះផងដែរ នៅមុខពួកយូដាទាំងប៉ុន្មាន ដែលអង្គុយនៅទីលានចាំយាមនៅទីនោះផង។
[13]ដូច្នេះ ខ្ញុំបានផ្តាំដល់លោកបារូកនៅមុខពួកគេថា[14]ព្រះជាម្ចាស់នៃពិភពលោក ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ ចូរយកសំបុត្រទិញដីនេះ គឺជាសំបុត្រទិញដីដែលបិទត្រា និងសំបុត្រដែលនៅចំហ ទៅដាក់ក្នុងភាជនៈដី ដើម្បីឲ្យបានទុកជាយូរថ្ងៃតទៅ។[15]ដ្បិតព្រះនៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ នឹងមានគេទិញទាំងផ្ទះ និងចម្ការ ហើយនឹងដំណាំទំពាំងបាយជូរនៅក្នុងទឹកដីនេះទៀត»។
[16]ក្រោយមក ខ្ញុំបានប្រគល់សំបុត្រទិញដីដល់បារូកជាកូននេរីយ៉ាហើយ នោះខ្ញុំក៏អធិស្ឋានដល់ព្រះជាម្ចាស់ថា៖[17]ព្រះអម្ចាស់ជាព្រះអើយ ព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដី ដោយសារព្រះចេស្តាដ៏ធំរបស់ព្រះអង្គ និងព្រះពាហុដ៏លើកសម្រេច គ្មានអ្វីដែលពិបាកសម្រាប់ព្រះអង្គទេ។[18]គឺព្រះអង្គសម្តែងសេចក្តីសប្បុរសដល់មនុស្សទាំងពាន់ៗ ហើយក៏សងអំពើទុច្ចរិតរបស់បុព្វបុរស ទៅលើទ្រូងនៃពួកកូនចៅគេ នៅតាមក្រោយ ព្រះអង្គជាព្រះដ៏ធំ ហើយមានឫទ្ធិ ព្រះនាមព្រះអង្គ គឺព្រះជាម្ចាស់នៃពិភពទាំងមូល។
[19]ព្រះអង្គប្រសប់ក្នុងការជួយគំនិត ហើយក៏មានឫទ្ធិធ្វើការផ្សេងៗ ព្រះនេត្ររបស់ព្រះអង្គទតឃើញយើង ទាំងផ្លូវរបស់ពួកមនុស្សជាតិ ដើម្បីនឹងសងគ្រប់គ្នាតាមផ្លូវគេប្រព្រឹត្ត ហើយតាមផលនៃកិរិយារបស់គេរៀងខ្លួន។[20]ព្រះអង្គក៏បានធ្វើទីសម្គាល់ និងការអស្ចារ្យនៅទឹកដីអេស៊ីប ដរាបដល់សព្វថ្ងៃ ព្រមទាំងនៅពួកអ៊ីស្រាអែល ហើយកណ្តាលពួកមនុស្សដទៃផង ព្រះអង្គក៏បានតាំងកិត្តិនាមរបស់ព្រះអង្គឡើងដូចជាមានសព្វថ្ងៃ។[21]ព្រះអង្គបាននាំអ៊ីស្រាអែល ជាប្រជារាស្ត្រព្រះអង្គ ចេញពីទឹកដីអេស៊ីបមកដោយទីសម្គាល់ និងការអស្ចារ្យ ដោយព្រះហស្តខ្លាំងពូកែ និងព្រះពាហុលើកសម្រេច ព្រមទាំងការស្ញែងខ្លាចយ៉ាងធំ។
[22]ព្រះអង្គបានប្រទានទឹកដីនេះឲ្យដល់គេ ជាទឹកដីដែលព្រះអង្គបានស្បថនឹងបុព្វបុរស ថានឹងឲ្យដល់គេ គឺជាទឹកដីមានទឹកដោះ និងទឹកឃ្មុំហូរហៀរ។[23]ដូច្នេះ ពួកគេក៏ចូលមកចាប់យកទឹកដី ប៉ុន្តែ មិនបានស្តាប់តាមព្រះបន្ទូលនៃព្រះអង្គ ឬដើរតាមក្រឹត្យវិន័យរបស់ព្រះអង្គឡើយ ក៏មិនបានធ្វើអ្វីមួយដែលព្រះអង្គបានបង្គាប់ដល់គេដែរ។ ហេតុនោះបានជាព្រះអង្គបណ្តាលឲ្យការអាក្រក់ទាំងនេះមកលើគេ។
[24]មើល៍! ប្រដាប់ចម្បាំងរបស់ពួកខាល់ដេបានមកដល់ ដើម្បីនឹងចាប់យកទីក្រុង។ ដ្បិត ក្រុងនេះបានត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ ដែលមកតយុទ្ធហើយ គឺត្រូវប្រគល់ទៅដោយចាញ់ដាវ អំណត់ និងអាសន្នរោគ អស់ទាំងការដែលព្រះអង្គបានមានព្រះបន្ទូល នោះបានកើតមកហើយ ទ្រង់ក៏ទតឃើញដែរ។[25]ព្រះអង្គបានមានព្រះបន្ទូលមកទូលបង្គំថា៖ «ចូរអ្នកទទួលទិញចម្ការដោយប្រាក់ ហើយហៅស្មរបន្ទាល់មក តែទីក្រុងនេះបានត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេហើយ»។
[26]ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់ព្យាការីយេរេមាថា៖[27]«មើល! យើងជាព្រះជាម្ចាស់ ជាព្រះនៃគ្រប់ទាំងជនជាតិ តើមានការអ្វីដែលពិបាកសម្រាប់យើងឬ?[28]ហេតុនេះព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា មើលយើងនឹងប្រគល់ទីក្រុងនេះទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ គឺក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន។ ហើយគេនឹងចាប់យកបាន។
[29]ពួកខាល់ដេ ដែលតយុទ្ធនឹងទីក្រុងនេះ គេនឹងចូលមកដុតចោល ព្រមទាំងផ្ទះទាំងប៉ុន្មានផង ជាទីដែលមនុស្សបានដុតកំញានថ្វាយដល់ព្រះបាល ហើយច្រួចតង្វាយច្រួចដល់ព្រះដទៃនៅលើដំបូល ជាការដែលបណ្តាលឲ្យយើងខឹង។[30]ពីព្រោះពួកកូនចៅអ៊ីស្រាអែល និងពួកកូនចៅយូដា បានប្រព្រឹត្តសុទ្ធតែការដែលអាក្រក់នៅចំពោះយើងតាំងតែពីក្មេងមក ដ្បិតពួកកូនចៅអ៊ីស្រាអែលបានបណ្តាលឲ្យយើងខឹង ដោយការដែលដៃគេធ្វើ នេះហើយជាព្រះបន្ទូលនៃព្រះជាម្ចាស់។
[31]ព្រះជាម្ចាស់ក៏បានប្រកាសថា ទីក្រុងនេះជាទីអុចអាល ឲ្យយើងមានសេចក្តីក្រោធ និងឃោរឃៅ ចាប់តាំងពីគ្រាដែលគេសង់ឡើង ដរាបដល់សព្វថ្ងៃ បានជាគួរឲ្យយើងបំបាត់ចេញពីមុខយើងទៅ[32]ដោយព្រោះអស់ទាំងអំពើអាក្រក់ ដែលពួកកូនចៅអ៊ីស្រាអែល និងពួកកូនចៅយូដាបានប្រព្រឹត្ត ជាហេតុបណ្តាលឲ្យយើងខឹង គឺទាំងខ្លួនគេ ស្តេចគេ ពួកចៅហ្វាយ ពួកសង្ឃ និងពួកព្យាការីរបស់គេ អស់ទាំងពួកទឹកដីយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នា។
[33]គេបានបែរខ្នងដាក់យើង មិនបែរមុខឡើយ ហើយទោះបើយើងបានបង្ហាត់បង្រៀនគេ ព្រមទាំងក្រោកឡើងពីព្រលឹមស្រាង ដើម្បីនឹងបង្រៀនក៏ដោយ តែគេមិនបានស្តាប់តាម និងទទួលសេចក្តីប្រៀនប្រដៅសោះ។[34]គឺគេបានតាំងរបស់គួរស្អប់ខ្ពើមរបស់គេ នៅក្នុងវិហារដែលហៅតាមឈ្មោះយើង ជាការដែលបង្អាប់ដល់ទីនោះវិញ។[35]គេក៏បានធ្វើទីខ្ពស់ទាំងប៉ុន្មាននៃព្រះបាល ដែលនៅក្នុងច្រកភ្នំរបស់កូនចៅហ៊ីនណម សម្រាប់ធ្វើឲ្យកូនប្រុសកូនស្រីគេដើរកាត់ភ្លើងថ្វាយដល់ព្រះម៉ូឡុក ជាការដែលយើងមិនបានបង្គាប់គេឡើយ ក៏មិនដែលចូលក្នុងគំនិតយើង ឲ្យគេបានធ្វើការគួរស្អប់ខ្ពើមនេះ ដើម្បីនាំឲ្យពួកយូដាបានធ្វើបាបដែរ។
[36]ដោយហេតុនោះ ឥឡូវនេះព្រះអម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលពីដំណើរទីក្រុងដែលអ្នកថា ត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូនដោយសារដាវ អំណត់ និងអាសន្នរោគនេះថា។[37]មើល៍! យើងនឹងប្រមូលគេចេញពីអស់ទាំងទឹកដី ដែលយើងបានបណ្តេញគេទៅនោះ ដោយកំហឹង សេចក្តីឃោរឃៅ និងសេចក្តីគ្នាន់ក្នាញ់ជាខ្លាំងរបស់យើង ក៏នឹងនាំគេមកទីនេះវិញ ព្រមទាំងឲ្យគេនៅដោយសុខសាន្ត។
[38]គេនឹងបានជាប្រជារាស្ត្ររបស់យើង ហើយយើងនឹងធ្វើជាព្រះដល់គេ។[39]យើងនឹងឲ្យគេមានទឹកចិត្តតែមួយ និងផ្លូវប្រព្រឹត្តតែមួយ ប្រយោជន៍ឲ្យគេបានកោតខ្លាចដល់យើងជាដរាប សម្រាប់ជាសេចក្តីល្អដល់គេ និងកូនចៅគេតរៀងទៅ។[40]យើងនឹងតាំងសេចក្តីសញ្ញានឹងគេ ជាសេចក្តីសញ្ញាដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ចថា យើងនឹងមិនបែរចេញពីគេឡើយ គឺនឹងឲ្យគេបានសេចក្តីល្អវិញ យើងនឹងដាក់សេចក្តីកោតខ្លាចដល់យើងក្នុងចិត្តគេ ប្រយោជន៍កុំឲ្យគេឃ្លាតចេញពីយើង។
[41]យើងនឹងយកគេជាទីរីករាយចិត្ត ដើម្បីនឹងប្រោសសេចក្តីល្អដល់គេ។ ពិតប្រាកដជាយើងនឹងដាំគេចុះ នៅក្នុងទឹកដីនេះ ឲ្យអស់ពីចិត្ត ហើយអស់ពីព្រលឹងយើង។[42]ដ្បិតទ្រង់មានព្រះបន្ទូលដូច្នេះថា៖ យើងបាននាំអស់ទាំងការអាក្រក់យ៉ាងធំនេះ មកលើជនជាតិនេះយ៉ាងណា យើងក៏នឹងនាំអស់ទាំងការដែលយើងបានសន្យាដល់គេ មកលើគេយ៉ាងនោះដែរ។
[43]គ្រានោះ មនុស្សនឹងទទួលទិញចម្ការ នៅក្នុងទឹកដីនេះទៀត ជាទឹកដីដែលអ្នករាល់គ្នាថា «បានចោលស្ងាត់ហើយ ឥតមានមនុស្ស ឬសត្វនៅទៀតឡើយ គឺបានប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ។[44]ពួកគេនឹងទទួលទិញស្រែចម្ការដោយប្រាក់ ព្រមទាំងចុះឈ្មោះ និងបិទត្រា ហើយហៅស្មរបន្ទាល់មកផង គឺនៅក្នុងទឹកដីបេនយ៉ាមីននេះ នឹងនៅក្រវល់ក្រុងយេរូសាឡិម នៅអស់ទាំងទីក្រុងរបស់ទឹកដីយូដា នៅទីក្រុងទឹកដីភ្នំ ទីក្រុងទឹកដីទំនាប និងក្នុងទីក្រុងនៃតំបន់ណេកិបទាំងប៉ុន្មានដែរ។ ដ្បិតយើងនឹងធ្វើឲ្យពួកគេដែលជាប់ជាឈ្លើយ បានត្រឡប់មកវិញ នេះហើយជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។

Jeremiah 32:1

ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការីយេរេមា

នេះជាអ្វីដែលព្រះអម្ចាស់មានបន្ទូលដល់លោកយេរេមា»

ត្រូវបានគេយកទៅឃុំនៅពន្ធនាគារ

«ពួកគេបានចាប់គាត់យកទៅដាក់គុកក្នុងទីធ្លា»

ទីធ្លារនៅក្នុងវាំងរបស់ស្តេច នៃជនជាតិយូដា

នេះជាទីវាលនៅក្នុងវាំងរបស់ស្តេច។

Jeremiah 32:3

ហេតុអ្វីបានជាអ្នកថ្លែងទំនាយប្រាប់ថា

ព្រះបាទសេដេគាប្រើសំណួរនេះ ដើម្បីស្តីបន្ទោសលោកយេរេមា។

ការបកប្រែរបៀបផ្សេងទៀត: «នេះជាកំហុសរបស់អ្នក ក្នុងការបន្ត
ថ្លែងទំនាយប្រាប់»

ទៅឲ្យក្នុងកណ្តាប់ដៃស្តេចបាប៊ីឡូន ហើយស្តេចនឹងចាប់យកវា

ពាក្យថា «កណ្តាប់ដៃ» សំដៅលើឫទ្ធានុភាព ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចស្រុកបាប៊ីឡូន និងកងទ័ពរបស់ទ្រង់
នឹងដណ្តើមយកបាន»

generated on Wed Sep 10 16:16:32 2025

ដ្បិត គេនឹងប្រគល់ទៅ
ការបកប្រែរបៀបផ្សេងទៀត: «ត្បិតយើងពិតជាបានប្រគល់គេ»
មាត់របស់គេនឹងនិយាយទៅមាត់របស់ទ្រង់ ហើយភ្នែកគេនឹងឃើញភ្នែករបស់ស្តេចដែរ
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះបាទសេដេគានឹងឃើញហើយនិយាយដោយផ្ទាល់ជាមួយនេប៊ូក្នេសា»
នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
អ្នករាល់គ្នាតស៊ូ
ពាក្យថា «អ្នករាល់គ្នា» គឺជាចំនួនច្រើន ហើយសំដៅលើជនជាតិអ៊ីស្រាអែល។
Jeremiah 32:6
ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។
ហាណាមាល ... ជាកូនសាលូម
ទាំងនេះជាឈ្មោះរបស់មនុស្ស។
អាណាថោត
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។
Jeremiah 32:8
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែង។
ដប់ប្រាំពីរសេកែល
«១៧ សេកែល»។ មួយសេកែលស្មើនឹង ១១ ក្រាម។
Jeremiah 32:10
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែង។
សំបុត្រ ហើយវាយត្រាព្រមទាំងមានសាក្សី និងកសិណសាក្សីឲ្យវា
នេះសំដៅទៅលើសំបុត្រដែលមនុស្សនឹងចុះហត្ថលេខាទិញដី។
មនុស្សផ្សេងទៀតគឺជាសាក្សី ដើម្បីបញ្ជាក់ថាខ្ញុំបានទិញដីនេះ។
មានសាក្សី និងកសិណសាក្សីឲ្យវា
«មានសាក្សីនៅទីនោះ ដើម្បីដឹងថាខ្ញុំបានទិញដីនេះ»
គឺមានវាយត្រា
«ដែលខ្ញុំបានបោះត្រា»
សំបុត្រមួយដែលមិនមានត្រា
«ច្បាប់ចម្លងបើក» ឬ «សំបុត្រដែលមិនមានត្រានៅលើវា»
បារូក...នេរីយ៉ា...ម៉ាសេយ៉ា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ទីលានចាំយាមនៅទីនោះ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣២:១។
Jeremiah 32:13
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែង។
នៅចំពោះមុខពួកគេ
ពាក្យថា «ពួកគេ» នៅទីនេះសំដៅទៅលើហាណាមាលដែលសាក្សី និងពួកយូដា។
ចូរយកសំបុត្រទិញដីនេះ គឺទាំងពីបង្គាន់ដៃទិញដីដែលបិទត្រា និងសំបុត្រចំឡងដែលអត់មានត្រា
«ចូរយកសំបុត្រទិញដីនេះ ទាំងមានបិទត្រា និងអត់មានត្រានេះ»
ផ្ទះនិងចម្ការ ហើយនឹងដំណាំទំពាំងបាយជូរ នឹងត្រូវបានទិញនៅក្នុងទឹកដីនេះ
ការបកប្រែរបៀបផ្សេងទៀត: «ជនជាតិអ៊ីស្រាអែលនឹងទិញផ្ទះ ចម្ការទំពាំងបាយជូរ និងចម្ការនានា ឡើងវិញនៅក្នុងទឹកដីនេះ»
Jeremiah 32:16
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែង។
បង្គាន់ដៃបានទិញដី
នេះសំដៅលើសំបុត្រទិញដីដែលបោះត្រា ហើយនឹងសំបុត្រទិញដីដែលអត់មានត្រា។
វេទនា
«លោកអើយ!»
ដោយសារព្រះចេស្តាដ៏ធំរបស់ព្រះអង្គ និងព្រះហស្តព្រះអង្គបានលើកឡើង
ឃ្លាថា «ព្រះហស្តព្រះអង្គបានលើកឡើង» គឺសំដៅលើព្រះចេស្តា។
ឃ្លាទាំងពីរនេះមានន័យដូចគ្នាទៅនឹងព្រះ ចេស្តារបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដោយព្រះចេស្តារបស់ព្រះអម្ចាស់ដ៏ខ្លាំងអស្ចារ្យ»។
ព្រះអង្គសម្តែងសម្ពន្ធមេត្រីស្មោះត្រង់
«ព្រះអង្គរក្សាការព្រះសន្យារបស់ព្រះអង្គ
ហើយបង្ហាញសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់របស់ទ្រង់ថែមទៀត»
ហើយចាក់អំពើទុច្ចរិតរបស់មនុស្ស ទៅលើពួកកូនចៅគេដែលជំនាន់ក្រោយ
«ហើយព្រះអង្គបានដាក់ទោសកូនចៅគេ
ដោយព្រោះតែអំពើបាបរបស់ឪពុកម្តាយគេ»
Jeremiah 32:19
ព័ត៌មានទូទៅ:
លោកយេរេមាបន្តអធិស្ឋានទៅព្រះអម្ចាស់។
ព្រះនេត្ររបស់ព្រះអង្គទតឃើញផ្លូវរបស់មនុស្សជាតិ
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ទតឃើញគ្រប់កិច្ចការដែលមនុស្សបានធ្វើ»
ផ្តល់គ្រប់គ្នាអ្វីត្រូវប្រព្រឹត្ត ហើយកិច្ចការគួរធ្វើរបស់គេ
«ហើយប្រទានរង្វាន់ដល់អ្នកគ្រប់គ្នា តាមអំពើដែលគេបានប្រព្រឹត្ត»
ព្រះអង្គបានធ្វើទីសម្គាល់ និងការអស្ចារ្យនៅទឹកដីអេស៊ីប
នេះសំដៅលើកាលពីអតីតកាលនៅពេលដែលព្រះអង្គបានប្រើព្រះចេស្តារបស់ទ្រង់ដើម្បីដោះលែងប្រជារាស្ត្រអ៊ីស្រាអែលពីទាសភាពនៅស្រុកអេស៊ីប។
ដរាបដល់សព្វថ្ងៃ
«រហូតដល់បច្ចុប្បន្ននេះ»
ហើយកណ្តាលពួកមនុស្សទាំងអស់
«ហើយក្នុងចំណោមមនុស្សទាំងអស់»
ធ្វើឲ្យព្រះនាមព្រះអង្គល្បី
ពាក្យថា «ព្រះនាម» នៅទីនេះសំដៅលើ កេ រ៉្ត ឈ្មោះរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអង្គបានធ្វើឲ្យអង្គទ្រង់ល្បី»
ជាមួយព្រះហស្តខ្លាំងពូកែ ជាមួយព្រះហស្តដែលលើកឡើង
ឃ្លាទាំងពីរនេះគឺជាការប្រដូចដែលសំដៅទៅលើភាពរឹងមាំ។
បើរួមបញ្ចូលគ្នាបញ្ជាក់ពីភាពអស្ចារ្យនៃព្រះចេស្តារបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ជាមួយព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះអង្គ»។
Jeremiah 32:22
ព័ត៌មានទូទៅ:
លោកយេរេមាបន្តអធិស្ឋានទៅព្រះអម្ចាស់។
ប្រទានទឹកដីនេះឲ្យដល់ពួកគេ
«ប្រទានទឹកដីនេះឲ្យដល់ជនជាតិអ៊ីស្រាអែល»
ទឹកដីមានទឹកដោះ ហើយទឹកឃ្មុំ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១១:៣។
ប៉ុន្តែ ពួកគេមិនបានស្តាប់តាមសម្លេងនៃព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែ ពួកគេមិនបានស្តាប់តាមអ្វីដែលព្រះអង្គមានព្រះបន្ទូល»
Jeremiah 32:24
ព័ត៌មានទូទៅ:
លោកយេរេមាបន្តអធិស្ឋានទៅព្រះអម្ចាស់។
ដើម្បីចាប់យកវា
«ដូច្នេះទាហានខ្មាំងសត្រូវអាចយកបាន»
ដ្បិត ពីព្រោះដាវ
ពាក្យថា ដាវនៅទីនេះសំដៅលើ ការធ្វើសង្គ្រាម ឬការប្រយុទ្ធគ្នា។
ទីក្រុងបានប្រគល់ឲ្យទៅក្នុងដៃរបស់ពួកខាល់ដេ
ពាក្យថា «ដៃ» នៅទីនេះ មានន័យថា អំណាច ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត:
«ទ្រង់បានប្រគល់ក្រុងយេរូសាឡិមដល់កងទ័ពខាល់ដេ»
ហើយត្រូវមានសាក្សីធ្វើជាបន្ទាល់ឲ្យវាផង
«ហើយទុកឲ្យអ្នកដទៃធ្វើជាបន្ទាល់»
ទីក្រុងនេះបានប្រគល់ទៅ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងប្រគល់ទីក្រុងនេះ»
Jeremiah 32:26
ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់យេរេមា ប្រាប់ថា
«នេះជាអ្វីដែលព្រះអម្ចាស់មានបន្ទូលទៅលោកយេរេមា»
តើមានការអ្វីដែលពិបាកសម្រាប់យើងធ្វើឬ?
ព្រះអម្ចាស់បានសួរសំណួរនេះ
ដោយបញ្ជាក់ថាព្រះអង្គអាចធ្វើគ្រប់កិច្ចការទាំងអស់។

generated on Wed Sep 10 16:16:32 2025

ប្រគល់ទីក្រុងនេះទៅក្នុងកណ្ដាប់ដៃនៃពួកខាល់ដេ
ពាក្យថា «កណ្ដាប់ដៃ» សំដៅលើ ព្រះចេស្ដា ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «ទៅកាន់ពួកខាល់ដេ»
Jeremiah 32:29
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅលោកយេរេមា។
គោលបំណងធ្វើឲ្យយើងខឹង
«ដែលធ្វើឲ្យយើងខឹងខ្លាំង»
ប្រព្រឹត្តសុទ្ធការអាក្រក់នៅចំពោះភ្នែកយើង
ការបកប្រែរបៀបផ្សេងទៀត: «ប្រព្រឹត្តអ្វីដែលយើងចាត់ទុកថាជាអំពើអាក្រក់»
តាំងតែពីពួកគេនៅក្មេង
«តាំងពីពួកគេបានក្លាយជាប្រជាជាតិមួយ» (UDB)
ការប្រព្រឹត្តដោយដៃពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «ការអាក្រក់ដែលពួកគេបានប្រព្រឹត្ត»
Jeremiah 32:31
ប្រយោគភ្ជាប់:
ខគម្ពីរនេះគឺជាការបន្តពីខគម្ពីរមុន។
ទីក្រុងនេះជាទីអុចអាល ឲ្យយើងមានសេចក្ដីក្រោធ និងខ្ញាល់ចាប់តាំងពីថ្ងៃដែលគេសង់វា
ពាក្យ «សេចក្ដីក្រោធ» និង «ខ្ញាល់» មានន័យថាដូចគ្នា
ហើយបញ្ជាក់ពីសេចក្ដីក្រោធយ៉ាងខ្លាំងរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជារាស្ត្រក្រុងយេរូសាឡិមបានធ្វើឲ្យយើងមានសេចក្ដីក្រោធយ៉ាងខ្លាំងចាប់តាំងពីថ្ងៃ[illegible]
វាបានត្រឹមត្រូវមកដល់សព្វថ្ងៃនេះ
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេធ្វើឲ្យយើងកាន់តែខ្លាំងនាពេលនេះ»
ចេញពីមុខយើង
ការបកប្រែរបៀបផ្សេងទៀត: «ពីព្រះវត្តមានយើង» ឬ «ទាំងស្រុង»
Jeremiah 32:33
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅលោកយេរេមា។
ពួកគេបានបែរខ្នងដាក់យើង ជំនួសឲ្យមុខរបស់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «ប្រជារាស្ត្ររបស់យើងបដិសេធយើង»
ទទួលការកែតម្រូវ
«ការបង្រៀនពីយើង»
គេបានធ្វើការគួរស្អប់ខ្ពើមនេះ
«រូបព្រះក្លែងក្លាយដែលយើងស្អប់ខ្ពើម»
វិហារដែលហៅតាមឈ្មោះយើង
ការបកប្រែរបៀបផ្សេងទៀត: «វិហារដែលជារបស់យើង»
ជ្រលោងភ្នំនៃបិនហ៊ីនណម
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៧:៣១។
វាក៏មិនដែលចូលក្នុងគំនិតយើង
ពាក្យថា «គំនិត»នៅទីនេះសំដៅលើ គំនិតរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ការដែលយើងមិនដែលគិតថាបានធ្វើ»
Jeremiah 32:36
ដែលអ្នកនិយាយថា
ពាក្យថា «អ្នក» នៅទីនេះសំដៅលើចំនួនពហុវចន:។ អាចមានន័យថា ១) នេះសំដៅលើយេរេមា និងអ្នកដែលនៅជាមួយលោក ឬ ២) នេះសំដៅលើមនុស្សគ្រប់គ្នា។
វានឹងត្រូវប្រគល់ទៅក្នុងកណ្ដាប់ដៃនៃស្ដេចបាប៊ីឡូន
ពាក្យថា «កណ្ដាប់ដៃ» នៅទីនេះមានន័យថាព្រះចេស្ដា ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានប្រគល់វាអោយស្ដេចស្រុកបាប៊ីឡូន»
ប្រមូលគេ
«ប្រមូលប្រជារាស្ត្ររបស់យើង»
សេចក្ដីក្រោធ សេចក្ដីខ្ញាល់ និងកំហឹងយ៉ាងខ្លាំង
ពាក្យទាំងបីមានន័យដូចគ្នា និងបញ្ជាក់ពីកំហឹងដ៏ច្រើនរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «កំហឹងដ៏ខ្លាំង»
Jeremiah 32:38
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
មានចិត្តតែមួយ និងផ្លូវតែមួយ ដើម្បីលើកតម្កើងដល់យើង
នេះមានន័យថា នឹងមានរូបរួមក្នុងចំណោមជនជាតិអ៊ីស្រាអែល
ហើយពួកគេនឹងថ្វាយបង្គំព្រះអម្ចាស់តែមួយគត់។
សម្ពន្ធមេត្រីនឹងគេដ៏ស្ថិតស្ថេរជានិច្ច
«ការព្រមព្រៀងអស់កាលជានិច្ច»
យើងនឹងមិនបែរចេញពីគេក្នុងការធ្វើល្អដល់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងធ្វើល្អទៅពួកគេជានិច្ច»
ដូច្នោះពួកគេនឹងមិនបែរចេញពីយើងឡើយ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នោះពួកគេនឹងស្ដាប់បង្គាប់
និងថ្វាយបង្គំយើងជានិច្ច»
Jeremiah 32:41
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
ធ្វើការល្អដល់ពួកគេ
ពាក្យថា «ពួកគេ» នៅទីនេះសំដៅលើប្រជារាស្ត្រអ៊ីស្រាអែល។
យើងនឹងស្មោះត្រង់នឹងដាំពួកគេនៅក្នុងទឹកដីនេះ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងអោយជនជាតិអ៊ីស្រាអែលរស់នៅលើទឹកដីនេះជារៀងរហូត»
អស់ពីចិត្ត ហើយអស់ពីជីវិតរបស់យើង
ឃ្លាទាំងពីរនេះរួមគ្នា ជាការបង្ហាញដែលសំដៅលើរបស់ភាពមនុស្សទាំងស្រុង។
ការបកប្រែរបៀបផ្សេងទៀត: «ជាមួយអ្វីទាំងអស់ដែលយើងមាន» ឬ «អស់ពីដួងចិត្ត។»
Jeremiah 32:43
ក្រោយមក ដីចម្ការនឹងបានទិញ នៅក្នុងទឹកដីនេះ
ការបកប្រែរបៀបផ្សេងទៀត:
«ក្រោយមកប្រជារាស្ត្រនឹងទិញដីចម្ការនៅក្នុងទឹកដីនេះ»
អ្នកបាននិយាយថា
ពាក្យថា «អ្នក» នៅទីនេះសំដៅលើប្រជារាស្ត្រអ៊ីស្រាអែល។
វាបានប្រគល់ទៅក្នុងកណ្ដាប់ដៃនៃពួកខាល់ដេ
ពាក្យថា «កណ្ដាប់ដៃ» នៅទីនេះមានន័យថាព្រះចេស្ដា ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានប្រគល់វាអោយពួកខាល់ដេ»
សរសេរ និងបិទត្រា។ ពួកនឹងគេហៅសាក្សីមកផង
នេះសំដៅទៅលើសំបុត្រដែលមនុស្សនឹងចុះហត្ថលេខាទិញដី។
មនុស្សផ្សេងទៀតគឺជាសាក្សីដើម្បីបញ្ជាក់ពីការទិញ។
ដ្បិតយើងនឹងនាំគេត្រឡប់មកកាន់ភាពមានបានវិញ
«ដ្បិតយើងនឹងធ្វើឲ្យពួកគេរីកចម្រើនសារជាថ្មី»

---

33 [1]ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់ព្យាការីយេរេមាម្តងទៀត ក្នុងកាលដែលលោកនៅជាប់ឃុំក្នុងទីលានចាំយាមថា៖ [2]«ព្រះជាម្ចាស់ដែលបានបង្កើតផែនដី គឺជាព្រះអម្ចាស់ដែលបានជបសូនមក ដើម្បីតាំងឡើង ដែលមានព្រះនាមជាព្រះអម្ចាស់ ព្រះអង្គមានព្រះបន្ទូលថា [3]ចូរអំពាវនាវដល់យើង នោះយើងនឹងឆ្លើយតបដល់អ្នក។ យើងនឹងបង្ហាញឲ្យអ្នកឃើញការយ៉ាងធំ ហើយមុតមាំ ដែលអ្នកមិនដឹង។
[4]ចំពោះដំណើរអស់ទាំងផ្ទះនៅទីក្រុងនេះ និងពីដំណាក់ពួកស្តេចជនជាតិយូដា ដែលត្រូវរំលំ ដើម្បីការពារទាស់នឹងសត្រូវឡើងមកឡោមព័ទ្ធ ហើយទាស់នឹងដាវ ទ្រង់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ [5]គេចូលមកច្បាំងទាស់នឹងពួកខាល់ដេ ហើយក៏បំពេញផ្ទះទាំងនោះ ដោយសាកសពនៃមនុស្ស ដែលយើងសម្លាប់ដោយកំហឹង និងសេចក្តីឃោរឃៅរបស់យើង ដ្បិតយើងបានគេចមុខចេញពីទីក្រុងនេះ ដោយព្រោះអំពើអាក្រក់ទាំងប៉ុន្មានរបស់គេ។
[6]ប៉ុន្តែមើល! យើងនឹងនាំសុខភាព និងការប្រោសឲ្យជាដល់ទីកដីនោះ យើងនឹងប្រោសគេ ហើយបង្ហាញសេចក្តីចម្រុងចម្រើន និងសេចក្តីសុខសាន្តជាបរិបូរឲ្យគេឃើញ។ [7]យើងនឹងធ្វើឲ្យពួកយូដា និងពួកអ៊ីស្រាអែល ដែលជាឈ្លើយវិលមកវិញ ហើយនឹងសង់គេឡើងដូចកាលដើម [8]ក៏នឹងសម្អាតគេ ឲ្យស្អាតពីអស់ទាំងអំពើទុច្ចរិតរបស់គេ ជាអំពើដែលគេបានប្រព្រឹត្តរំលងនឹងយើង ហើយយើងនឹងអត់ទោសចំពោះអស់ទាំងអំពើទុច្ចរិត ដែលគេបានធ្វើបាប ហើយប្រព្រឹត្តរំលងនឹងយើងនោះ [9]ទីក្រុងនេះ នឹងបានសម្រាប់ជាហេតុនាំឲ្យអរសប្បាយដល់យើង សម្រាប់ជាសេចក្តីសរសើរ និងសិរីល្អផង នៅចំពោះអស់ទាំងនគរនៅផែនដី ជាពួកអ្នកដែលនឹងឮនិយាយពីអស់ទាំងការល្អ ដែលយើងប្រោសដល់គេ រួចគេនឹងកោតខ្លាច ហើយភ័យញ័រដោយព្រោះគ្រប់ទាំងសេចក្តីល្អ និងសេចក្តីសុខទាំងប៉ុន្មាន ដែលយើងផ្តល់ដល់ក្រុងនេះ។

generated on Wed Sep 10 16:16:32 2025

[10]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ នៅទីនេះដែលអ្នករាល់គ្នាថា «ជាទីខូចបង់ឥតមានមនុស្ស ឬសត្វណានៅទៀត» គឺនៅក្នុងទីក្រុងនៃទឹកដីយូដាទាំងប៉ុន្មាន ហើយនៅអស់ទាំងផ្លូវរបស់ក្រុងយេរូសាឡិម ដែលចោលស្ងាត់នេះ ឥតមានអ្នកណាអាស្រ័យនៅ ឬមនុស្ស ឬសត្វណាឡើយ នោះនឹងមានឮសំឡេងមនុស្សម្តងទៀត[11]ជាសំឡេងអរសប្បាយ និងសំឡេងរីករាយ គឺសំឡេងរបស់ប្តីប្រពន្ធថ្មោងថ្មី និងសំឡេងពួកអ្នកដែលពោលថា៖ «ចូរលើកសរសើរព្រះជាម្ចាស់នៃពិភពលោកដ្បិតព្រះអង្គល្អ ពីព្រោះសេចក្តីសប្បុរសរបស់ព្រះអង្គស្ថិតស្ថេរនៅអស់កល្ប ហើយសំឡេងរបស់ពួកដែលនាំយកតង្វាយអរព្រះគុណចូលក្នុងព្រះវិហារនៃព្រះអម្ចាស់ដែរ!» ដ្បិតយើងនឹងធ្វើឲ្យពួកអ្នកទឹកដីនេះ ដែលនៅជាឈ្លើយ បានវិលមកវិញដូចកាលពីដើម នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់។
[12]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «នៅក្នុងក្រុងដែលវិនាសបាក់បែក នឹងគ្មានមនុស្ស គ្មានសត្វ ហើយនៅតាមក្រុងឯទៀតៗ ពួកគង្វាលនឹងនាំគ្នាធ្វើក្រោលជាជម្រកសម្រាប់ហ្វូងសត្វរបស់ខ្លួនសាជាថ្មី។[13]ក្នុងក្រុងនានានៅតំបន់ភ្នំ តំបន់វាលទំនាប តំបន់ណេកិប ក្នុងទឹកដីបេនយ៉ាមីន តំបន់ជុំវិញក្រុងយេរូសាឡឹម និងនៅតាមក្រុងនានាក្នុងទឹកដីយូដា គង្វាលនឹងរាប់ចំនួនចៀមរបស់ខ្លួនសាជាថ្មី» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[14]ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ នឹងមានគ្រាមកដល់ ដែលយើងនឹងសម្រេចតាមពាក្យល្អ ដែលយើងបាននិយាយពីដំណើរពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដា[15]នៅគ្រានោះ គឺនៅជាន់នោះ យើងនឹងធ្វើឲ្យមានលំពង់ដ៏សុចរិតពន្លកឡើងដល់ដាវីឌ លំពង់នោះ ព្រះអង្គនឹងសម្រេចសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិតនៅក្នុងទឹកដី[16]នៅគ្រានោះ ពួកយូដានឹងបានសង្គ្រោះ ហើយក្រុងយេរូសាឡិមនឹងនៅដោយសុខសាន្ត លំពង់នោះ គេនឹងហៅថា «ព្រះជាម្ចាស់ដ៏ជាសេចក្តីសុចរិតនៃយើងរាល់គ្នា»
[17]ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ ដាវីឌនឹងមិនដែលអាក់ខានមានមនុស្សសម្រាប់អង្គុយលើបល្ល័ង្ករបស់ពូជពង្សនៃអ៊ីស្រាអែលឡើយ។[18]ហើយពួកបូជាចារ្យ និងពួកលេវី ក៏មិនដែលអាក់ខានមានមនុស្សនៅចំពោះយើងសម្រាប់ថ្វាយតង្វាយដុត តង្វាយម្សៅ និងយញ្ញបូជាជាប់នៅជានិច្ចដែរ»។
[19]ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់ព្យាការីយេរេមាថា៖[20]«ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ ប្រសិនបើអ្នករាល់គ្នាអាចនឹងផ្តាច់សេចក្តីសញ្ញារបស់យើង ពីដំណើរថ្ងៃ និងយប់ ដើម្បីមិនឲ្យមានថ្ងៃ ឬយប់តាមធម្មតាបាន[21]នោះសេចក្តីសញ្ញាដែលយើងបានតាំងនឹងដាវីឌ ជាអ្នកបម្រើយើង ក៏នឹងផ្តាច់ទៅបានដែរ។ ដើម្បីមិនឲ្យដាវីឌមានកូនចៅណាមួយសោយរាជ្យ នៅលើបល្ល័ង្ករបស់លោក ព្រមទាំងសេចក្តីសញ្ញា ដែលតាំងនឹងពួកលេវី ជាពួកអ្នកដែលទទួលការងាររបស់យើងដែរ។[22]គឺដូចម្ចាស់នៃពិភពទាំងមូល ឬដូចជាខ្សាច់នៅសមុទ្រដែលរាប់មិនអស់ នោះយើងនឹងចម្រើនពូជដាវីឌ ជាអ្នកបម្រើយើង និងពួកលេវី ជាពួកអ្នកទទួលការងាររបស់យើងឲ្យមានច្រើនឡើងយ៉ាងនោះដែរ»។
[23]ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់ព្យាការីយេរេមាថា៖[24]«អ្នកមិនបានពិចារណាសេចក្តីដែលជនជាតិទាំងនេះពោលថា អំបូរទាំងពីរដែលព្រះអម្ចាស់បានរើសតាំងនោះ ព្រះអង្គបានបោះបង់ចោលវិញទេឬអី? គឺយ៉ាងនោះដែលគេមើលងាយដល់ប្រជារាស្ត្រយើង ដោយបំណងនឹងឲ្យគេលែងធ្វើជានគរនៅមុខខ្លួនតទៅ។
[25]ដូច្នេះ ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ ប្រសិនបើសេចក្តីសញ្ញាពីដំណើរថ្ងៃ និងយប់ មិនស្ថិតស្ថេរនៅ បើយើងមិនបានតាំងអស់ទាំងរបៀបនៃផ្ទៃមេឃ និងផែនដីទេ[26]ពេលយើងនឹងបោះបង់ពូជពង្សយ៉ាកុប និងដាវីឌ ជាអ្នកបម្រើរបស់យើងបានដែរ ដើម្បីមិនឲ្យពូជលោកណាមួយបានតាំងឡើងជាអ្នកគ្រប់គ្រង លើពូជនៃអ័ប្រាហាំ អ៊ីសាក និងយ៉ាកុបឡើយ ដ្បិតយើងនឹងនាំពួកគេ ដែលជាប់ជាឈ្លើយ ឲ្យបានមកវិញ ហើយនឹងអាណិតមេត្តាដល់គេផង»។

Jeremiah 33:1

ព័ត៌មានទូទៅ:

សូមមើល: និង

Jeremiah 33:4

សេចក្តីក្រោធ និងកំហឹងដ៏ខ្លាំងរបស់យើង

ពាក្យថា «សេចក្តីក្រោធ» និង «កំហឹង» មានន័យថាដូចគ្នា ហើយបញ្ជាក់ពីកំហឹងដ៏ខ្លាំងរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងកំហឹងខ្លាំងរបស់យើង»។

បិតមុខរបស់យើង

ឃ្លានេះបង្ហាញពីព្រះមិនសព្វព្រះហឫទ័យចំពោះទីក្រុង។ ការបកប្រែរបៀបផ្សេងទៀត: «យើងបានឃ្លាតឆ្ងាយពីអ្នក» ឬ «យើងលែងបារម្ភនឹងអ្នកទៀតហើយ»

Jeremiah 33:6

ជាឈ្លើយវិលមកវិញ

ការបកប្រែរបៀបផ្សេងទៀត: «នឹងនាំមកវិញនូវភាព ចម្រុងចម្រើន»

Jeremiah 33:10

ជាទីខូចបង់អត់មានមនុស្ស ឬសត្វណារស់នៅទេ» ក្នុងទីក្រុងនៃទឹកដីយូដាទាំងឡាយ ហើយនៅអស់ទាំងផ្លូវរបស់ក្រុងយេរូសាឡិម ដែលបានបោះចង់ចោល អត់មានមនុស្សអាស្រ័យនៅ ឬសត្វទេ

ឃ្លាទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា ហើយបញ្ជាក់ថាស្រុកយូដាបានក្លាយទៅជាទីខូចបង់។

ព្រះវិហារនៃព្រះអម្ចាស់

ព្រះវិហារនៅក្នុងក្រុងយេរូសាឡិម

ទ្រព្យ

ការបកប្រែរបៀបផ្សេងទៀត: «ភាពចម្រុងចម្រើន»

Jeremiah 33:12

ដីសំរាប់ចិញ្ចឹមសត្វ

ការបកប្រែរបៀបផ្សេងទៀត: «ជាទីវាលសម្រាប់ចិញ្ចឹមសត្វរបស់ពួកគេ»

Jeremiah 33:14

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។

នៅក្នុងថ្ងៃទាំងនោះ ហើយក្នុងវេលានោះ

ឃ្លា «នៅក្នុងថ្ងៃទាំងនោះ» មានន័យថាមានន័យដូចគ្នានឹង និងឃ្លាថា «ក្នុងវេលានោះ»។ ការបកប្រែរបៀបផ្សេងទៀត: «នៅគ្រានោះ» ឬ «នៅពេលនោះ»។

មានមែកដ៏សុចរិតមួយពន្លកដុះឡើងសម្រាប់ដាវីឌ

កូនចៅប្រុសៗរបស់ដាវីឌជាមនុស្សសុចរិត។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សសុចរិតនឹងកើតចេញពីវង្សត្រកូលដាវីឌដូចជាមែកឈើដុះចេញពីដើមឈើ»។

ទឹកដី

ប្រជាជាតិអ៊ីស្រាអែល

Jeremiah 33:17

មនុស្សម្នាក់ពីពូជពង្សរបស់ដេវិឌ

ការបកប្រែរបៀបផ្សេងទៀត: «កូនចៅប្រុសៗរបស់ដាវីឌ»

Jeremiah 33:19

ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។

សម្ពន្ធមេត្រីរបស់យើង ពីថ្ងៃ និងយប់ ដូច្នោះវាមិនមានពេលថ្ងៃ ឬយប់ដូចតាមធម្មតា នោះអ្នកនឹងអាចផ្តាច់សម្ពន្ធមេត្រីយើងជាមួយដាវីឌ ជាអ្នកបម្រើយើង

ព្រះអម្ចាស់ប្រៀបធៀបសម្ពន្ធមេត្រីរបស់ព្រះអង្គជាមួយដាវីឌទៅនឹងថ្ងៃនិងយប់។ ដោយសារមនុស្សមិនអាចផ្លាស់ប្តូរយប់ និងថ្ងៃបាន ទើបមនុស្សមិនអាចផ្លាស់ប្តូរសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ជាមួយដាវីឌបានឡើយ។

នៅលើបល្ល័ង្ក

«ដើម្បីគ្រប់គ្រងនគរដែលបានប្រគល់ឲ្យលោក» (សូមមើល: igs-metonymy)

ដូចជាអ្វីដែលលើមេឃគឺមិនអាចរាប់អស់ ហើយដូចជាខ្សាច់នៅសមុទ្រក៏មិនអាខវាស់បានដែរ ដូច្នោះយើងនឹងចម្រើនពូជពង្សដាវីឌ ជាអ្នកបម្រើយើង ហើយពួកលេវី ជាពួកអ្នកបម្រើនៅចំពោះយើងដែរ

អត្ថន័យនៃឃ្លាទាំងពីរនេះថ្លែងពី ការសំខាន់ដូចគ្នា និងត្រូវប្រើរួមគ្នាសម្រាប់ការបញ្ជាក់ន័យ។ ការបកប្រែរបៀបផ្សេងទៀត: «ដោយគ្មានអ្នកណាដែលអាចរាប់ផ្កាយនៅលើមេឃ និងគ្រាប់ខ្សាច់នៅតាមឆ្នេរសមុទ្របានទេ តាមរបៀបនេះគ្មានអ្នកណាអាចរាប់កូនចៅរបស់ដាវីឌ និងលេវីដែលបំរើព្រះអម្ចាស់បានទេ»។ (សូមមើល: និងfigs-hyperbole)

Jeremiah 33:23

ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។

អ្នកមិនបានពិចារណាសេចក្តីដែលជនជាតិទាំងនេះបាននិយាយថា «អំបូរទាំងពីរដែលព្រះអម្ចាស់បានជ្រើសរើស ពេលនេះព្រះអង្គបានបដិសេធពួកគេវិញ?»

សំណួរនេះត្រូវបានសួរដោយការសង្កត់ធ្ងន់។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកគួរតែកត់សំគាល់ថាមនុស្សកំពុងតែនិយាយថាយើងបានបដិសេធអំបូរពីរដែលយើងបានជ្រើសរើស»

generated on Wed Sep 10 16:16:32 2025

34 [1]ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមកដល់ព្យាការីយេរេមា ក្នុងកាលដែលព្រះបាទនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន និងពលទ័ពទាំងប៉ុន្មានរបស់គេ ហើយដល់នគរទាំងប៉ុន្មាននៅផែនដីដែលនៅក្រោមអំណាចគេ ព្រមទាំងប្រជាជាតិទាំងឡាយដែលកំពុងច្បាំងនឹងក្រុងយេរូសាឡិម និងទីក្រុងទាំងប៉ុន្មាន[2]ព្រះជាម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលដូច្នេះថា៖ ចូរទៅទូលព្រះបាទសេដេគា ជាស្តេចយូដាថា ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ យើងនឹងប្រគល់ទីក្រុងនេះ ទៅក្នុងកណ្តាប់ដៃស្តេចបាប៊ីឡូន ហើយគេនឹងដុតចោល។[3]ឯអ្នកនឹងមិនរួចពីកណ្តាប់ដៃគេដែរ គឺនឹងត្រូវចាប់បាន ហើយប្រគល់ទៅក្នុងកណ្តាប់ដៃគេជាពិតប្រាកដ អ្នកនឹងឃើញស្តេចបាប៊ីឡូនប្រទល់មុខគ្នា ហើយគេនិយាយនឹងអ្នកផ្ទាល់មាត់ អ្នកនឹងត្រូវទៅក្រុងបាប៊ីឡូន។
[4]ប៉ុន្តែ ឱសេដេគាជាស្តេចយូដាអើយ ចូរស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ចុះ ទ្រង់មានព្រះបន្ទូលពីដំណើរទ្រង់ថា អ្នកនឹងមិនស្លាប់ដោយដាវទេ។[5]គឺអ្នកនឹងស្លាប់ដោយសុខសាន្តវិញ។ ដូចជាគេដុតគ្រឿងក្រអូបអប់សពបុព្វបុរសរបស់អ្នក គឺជាពួកស្តេចដែលសោយរាជ្យមុនអ្នកយ៉ាងណា នោះគេនឹងដុតគ្រឿងក្រអូបអប់សពអ្នក។ ពួកគេយំសោកថា "ឱព្រះករុណាអើយ!" យ៉ាងនោះដែរ។ ដ្បិតយើងបានចេញវាចាហើយ នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់»។
[6]ពេលនោះ ព្យាការីយេរេមាក៏ទូលគ្រប់ទាំងព្រះបន្ទូលនេះដល់ព្រះបាទសេដេគា ជាស្តេចយូដា នៅក្រុងយេរូសាឡិម។[7]ពេលដែលពួកពលទ័ពរបស់ស្តេចបាប៊ីឡូន កំពុងច្បាំងនឹងក្រុងយេរូសាឡិម និងអស់ទាំងទីក្រុងនៃទឹកដីយូដាដែលនៅសល់ គឺក្រុងឡាគីស និងក្រុងអាសេកា ដ្បិតក្នុងទីក្រុងនៃទឹកដីយូដាទាំងប៉ុន្មាន ដែលមានកំផែង នោះសល់នៅតែប៉ុណ្ណោះទេ។
[8]នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់ ដែលមកដល់ព្យាការីយេរេមា ក្នុងពេលក្រោយដែលព្រះបាទសេដេគា និងប្រជាជនទាំងឡាយ ដែលនៅក្រុងយេរូសាឡិម បានតាំងសេចក្តីសញ្ញា ដើម្បីនឹងប្រកាសប្រាប់ពីការប្រោសលោះដល់គេ[9]គឺឲ្យគ្រប់មនុស្សដោះលែងបាវប្រុសបាវស្រីរបស់ខ្លួន ដែលជាជនជាតិ ហេព្រើរចេញទៅ ហើយកុំឲ្យអ្នកណាចាប់ប្រើជនជាតិហេព្រើរ ដែលជាបងប្អូននឹងគ្នា ទុកជាបាវបម្រើទៀតឡើយ។
[10]ពួកចៅហ្វាយទាំងប៉ុន្មាន និងបណ្តាជនទាំងឡាយ ដែលបានចូលក្នុងសេចក្តីសញ្ញានេះ ក៏ស្តាប់បង្គាប់តាម ដើម្បីនឹងលែងបាវប្រុសបាវស្រីរបស់ខ្លួន ឲ្យរួចចេញទៅ ឥតមានអ្នកណាចាប់គេប្រើជាបាវបម្រើទៀត គេក៏ស្តាប់តាម ហើយលែងអ្នកទាំងនោះឲ្យរួចចេញទៅ។[11]ប៉ុន្តែ ក្រោយមក គេក៏បែរជាបង្ខំបាវប្រុសបាវស្រីទាំងប៉ុន្មាន ដែលគេបានលែងទៅហើយនោះ ឲ្យវិលមកនៅក្នុងបង្គាប់ខ្លួន និងធ្វើជាបាវប្រុសបាវស្រីវិញទៀត។
[12]ហេតុនោះ ព្រះបន្ទូលនៃព្រះជាម្ចាស់ បានមកដល់ព្យាការីយេរេមាថា៖[13]«ព្រះជាម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែលព្រះអង្គមានព្រះបន្ទូលដូច្នេះ យើងបានតាំងសេចក្តីសញ្ញានឹងបុព្វបុរសរបស់អ្នករាល់គ្នា នៅថ្ងៃដែលយើងបាននាំគេចេញពីទឹកដីអេស៊ីប ឲ្យរួចពីសណ្ឋានជាបាវបម្រើ ដោយពាក្យថា[14]«លុះផុតប្រាំពីរឆ្នាំហើយ នោះអ្នករាល់គ្នាត្រូវលែងបងប្អូនអ្នក ជាជនជាតិហេព្រើរដែលបានលក់ខ្លួនដល់អ្នក ហើយបានបម្រើអ្នកអស់ប្រាំមួយឆ្នាំ គឺអ្នកត្រូវលែងគេឲ្យរួចចេញពីអ្នកទៅ»។ ប៉ុន្តែ បុព្វបុរសអ្នករាល់គ្នាមិនបានស្តាប់តាមយើងទេ ក៏មិនបានផ្ទៀងត្រចៀកផង។
[15]ពេលអ្នកទើបតែវិលមកធ្វើការ ដែលត្រឹមត្រូវនៅភ្នែកយើង ដោយប្រកាសប្រាប់សេចក្តីប្រោសលោះ ដល់អ្នកជិតខាងអ្នករៀងខ្លួនថ្មីៗ ហើយបានតាំងសញ្ញានៅមុខយើងក្នុងព្រះវិហារដែលហៅតាមឈ្មោះយើង។[16]ប៉ុន្តែ ឥឡូវនេះ បានបែរទៅជាបង្អាប់ដល់ឈ្មោះយើងវិញ ដោយបានបង្ខំឲ្យពួកបាវប្រុសបាវស្រីរបស់អ្នករៀងខ្លួន ដែលអ្នកបានលែងឲ្យរួចចេញតាមបំណងចិត្តគេនោះ ឲ្យវិលមកនៅក្នុងបង្គាប់។ និងធ្វើជាបាវប្រុសបាវស្រីរបស់អ្នករាល់គ្នាវិញទៀត។
[17]ហេតុនោះ ព្រះជាម្ចាស់មានព្រះបន្ទូលដូច្នេះថា៖ អ្នករាល់គ្នាមិនបានស្តាប់តាមយើង ដើម្បីប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់បងប្អូនអ្នករៀងខ្លួន និងដល់អ្នកជិតខាងអ្នករៀងខ្លួនទេ ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ យើងប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់អ្នករាល់គ្នាវិញ គឺឲ្យរួចទៅដល់ដាវ ដល់អាសន្នរោគ ហើយដល់អំណត់ដែរ យើងនឹងធ្វើឲ្យអ្នករាល់គ្នាត្រូវសាត់អណ្តែត នៅក្នុងចំណោមអស់ទាំងនគរនៅផែនដី។[18]យើងនឹងធ្វើតាមសេចក្តីសញ្ញារបស់យើង ហើយមិនបានកាន់តាមពាក្យនៃសេចក្តីសញ្ញា ដែលគេបានតាំងនៅមុខយើង នោះយើងនឹងធ្វើឲ្យគេបានដូចជាគោដែលគេបានពុះជាពីរចំហៀង។ រួចដើរនៅកណ្តាលចំហៀងទាំងពីរនោះ។[19]ក្រុងយេរូសាឡិម ពួកសេនាបតី ពួកបូជាចារ្យ និងពួកជនទាំងឡាយនៅក្នុងទឹកដីដែលបានដើរកណ្តាលចំហៀងនៃកូនគោនោះ។
[20]គឺយើងនឹងប្រគល់គេទៅក្នុងកណ្តាប់ដៃពួកខ្មាំងសត្រូវរបស់គេ ហើយក្នុងកណ្តាប់ដៃនៃពួកអ្នកដែលរកជីវិតគេ ចំណែកសាកសពរបស់គេក្លាយជាចំណីសត្វហើរលើអាកាស និងសត្វជើងបួននៅផែនដី។[21]ដូច្នេះ យើងនឹងប្រគល់សេដេគាជាស្តេចយូដា និងពួកចៅហ្វាយ ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ ហើយក្នុងកណ្តាប់ដៃនៃពួកអ្នកដែលរកជីវិតគេ និងក្នុងកណ្តាប់ដៃនៃពួកទ័ពរបស់ស្តេចបាប៊ីឡូនដែលទើបនឹងថយចេញពីអ្នករាល់គ្នានោះ។[22]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ មើល៍! យើងនឹងបង្គាប់ ហើយធ្វើឲ្យគេវិលមកឯទីក្រុងនេះវិញ គេនឹងច្បាំងចាប់យកទីក្រុងនេះបាន រួចដុតចោល យើងនឹងធ្វើឲ្យទីក្រុងទាំងប៉ុន្មាននៅទឹកដីយូដាត្រូវខូចបង់ ឥតមានអ្នកណានៅ»។

Jeremiah 34:1
ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមកដល់ព្យាការីយេរេមា
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់មានព្រះបន្ទូលទៅ»
ដែលកំពុងច្បាំងទាស់
ការបកប្រែរបៀបផ្សេងទៀត: «ប្រយុទ្ធនឹង»
ទីក្រុងទាំងឡាយ
នេះសំដៅទៅលើទីក្រុងជុំវិញទាំងអស់នៅជិតក្រុងយេរូសាឡិម។
ប្រគល់ទីក្រុងនេះ
បកប្រែពាក្យនេះដូចគ្នានឹងអ្នកបានបកប្រែក្នុងជំពូក៣២:២៦។
ទៅក្នុងកណ្តាប់ដៃស្តេចបាប៊ីឡូន
ពាក្យថា «កណ្តាប់ដៃ» សំដៅលើការគ្រប់គ្រង។ ការបកប្រែរបៀបផ្សេងទៀត: «ទៅក្នុងការគ្រប់គ្រងរបស់ស្តេចបាប៊ីឡូន»។
អ្នកនឹងមិនអាចគេចពីកណ្តាប់ដៃស្តេចបានទេ
«អ្នកនឹងមិនអាចគេចពីការគ្រប់គ្រងរបស់ទ្រង់ឡើយ»
ភ្នែករបស់ទ្រង់នឹងសម្លឹងទៅភ្នែករបស់ ស្តេចបាប៊ីឡូន ហើយស្តេចនឹងនិយាយនឹងអ្នកផ្ទាល់មកកាន់ទ្រង់ ហើយទ្រង់ត្រូវទៅក្រុងបាប៊ីឡូន
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ដែលទ្រង់នឹងទតឃើញស្តេចបាប៊ីឡូនដោយផ្ទាល់។
Jeremiah 34:4
ស្តេចនឹងមិនស្លាប់ដោយដាវទេ គឺទ្រង់នឹងស្លាប់ក្នុងសុខសាន្ត
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចនឹងមិនស្លាប់នៅក្នុងសមរភូមិទេ
ប៉ុន្តែស្តេចនឹងស្លាប់ដោយសុខសាន្ត។
នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
Jeremiah 34:6
ក្រុងឡាគីស និងក្រុងអាសេកា
ទាំងនេះជាឈ្មោះក្រុង។
ក្នុងទីក្រុងរបស់យូដាទាំងឡាយ នៅមានសល់កំពែងក្រុងទាំងនោះ
ការបកប្រែរបៀបផ្សេងទៀត:
«ក្រុងនានាដែលមានកំពែងរឹងមាំក្នុងស្រុកយូដានឹងមិនត្រូវបានកាន់កាប់នៅឡើយទេ»
Jeremiah 34:8
នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់ ដែលមកដល់ព្យាការីយេរេមា
បន្ទាប់ពីឃ្លានេះ
អ្នកអានប្រាកដជានឹងស្វែងយល់ពីខ្លឹមសារនៃព្រះបន្ទូលពីព្រះអម្ចាស់។
តែដោយព្រះបន្ទូលពិតប្រាកដមិនទាន់មានទេរហូតដល់ជំពូក ៣៤:១២។
ដូច្នេះអ្នកបកប្រែអាចធ្វើការលុបឃ្លានេះនៅទីនេះ និងឧទាហរណ៍របស់ UDB។
ព្រះបន្ទូល
«ព្រះរាជ្យសារ»
Jeremiah 34:12
ព្រះបន្ទូលនៃព្រះជាម្ចាស់បានមកដល់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។
នោះអ្នករាល់គ្នាត្រូវលែងបងប្អូនអ្នក ជាជនជាតិហេព្រើរដែលបានលក់ខ្លួនដល់អ្នក
ការបកប្រែរបៀបផ្សេងទៀត:
«អ្នករាល់គ្នាត្រូវដោះលែងជនជាតិហេប្រឺម្នាក់ដែលលក់ខ្លួនឲ្យអ្នកហើយធ្វើជាខ្ញុំបម្រើរបស់អ្នក»
បានដោះលែងគេឲ្យរួច
ការបកប្រែរបៀបផ្សេងទៀត: «អ្នកត្រូវដោះលែងគេឲ្យមានសេរីភាពពីការបម្រើអ្នក»
អ្នករាល់គ្នាមិនបានស្តាប់តាមយើងទេ ក៏មិនបានផ្ទៀងត្រចៀកផង
ឃ្លាទាំងពីរនេះត្រូវថ្លែងពីដូចគ្នា និងត្រូវរួមគ្នាសម្រាប់ការបញ្ជាក់ន័យ។
Jeremiah 34:15

generated on Wed Sep 10 16:16:32 2025

ត្រឹមត្រូវនៅចំពោះភ្នែកយើង
«ត្រឹមត្រូវ» ឬ «អាចទទួលយកបាន»
បែរទៅជាបង្អាប់ដល់ឈ្មោះរបស់យើងវិញ
ការបកប្រែរបៀបផ្សេងទៀត:
«ឈប់ធ្វើអ្វីដែលត្រឹមត្រូវហើយធ្វើអំពើអាក្រក់ដែលធ្វើឲ្យមនុស្សគិតថាយើងជាមនុស្សអាក្រក់»

Jeremiah 34:17

ដូច្នេះ ចូរមើល៍! យើងនឹងប្រកាសប្រាប់ពីសេចក្ដីប្រោសលោះដល់អ្នក នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
គឺឲ្យរួចទៅដល់ដាវ ដល់អាសន្នរោគ ហើយដល់ការអំណត់ដែរ
ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះដោយសារអ្នករាល់គ្នាមិនបានស្តាប់បង្គាប់យើង
យើងនឹងអោយអ្នករាល់គ្នាទទួលទោសដោយដាវ អាសន្នរោគ និងទុរ្ភិក្ស»
ដូច្នេះ ចូរមើល!
«ចូរស្តាប់!» ឬ
«ចូរយកចិត្តទុកដាក់ការសំខាន់ដែលយើងនឹងមានបន្ទូលប្រាប់អ្នក!»
បង្កើតឡើងនៅមុខយើង
ការបកប្រែរបៀបផ្សេងទៀត: «ដែលយល់ស្របជាមួយយើង»

Jeremiah 34:20

អាត្រាស់ជីវិតរបស់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «ស្វែងរកសម្លាប់ពួកគេ»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:៧។
ច្បាំងទាស់នឹង
«មកប្រយុទ្ធនឹង»
ហើយនឹងនាំគេត្រឡប់មក
ពាក្យថា «គេ» សំដៅលើទាហានរបស់ជនជាតិបាប៊ីឡូន។
ការបកប្រែរបៀបផ្សេងទៀត: «ហើយនឹងនាំទាហានបាប៊ីឡូនត្រឡប់មកវិញ»

---

35 [1]នៅរជ្ជកាលព្រះបាទយេហូយ៉ាគីមបុត្ររបស់ព្រះបាទយ៉ូសៀស ជាស្តេចទឹកដីយូដា ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមាដូចតទៅ៖[2]«ចូរទៅជួបពួកអ្នក
ក្នុងអំបូររេកាប ហើយនិយាយជាមួយពួកគេ។ បន្ទាប់មក ចូរនាំពួកគេទៅព្រះដំណាក់ចូលក្នុងបន្ទប់មួយ រួចចាក់ស្រាឲ្យពួកគេផឹក»។
[3]ដូច្នេះ ខ្ញុំក៏ទៅយកយ៉ាសានា ជាកូនយេរេមា ដែលជាកូនហាបា ស៊ីនា បងប្អូនរបស់គាត់ និងកូនចៅរបស់គាត់ទាំងអស់ ព្រមទាំងពូជពង្សនៃពួករេកាបទាំងអស់គ្នា។[4]ខ្ញុំ
បាននាំពួកគេចូលទៅក្នុងព្រះដំណាក់នៃព្រះអម្ចាស់ គឺក្នុងបន្ទប់របស់កូនចៅហាណាន ជាកូនយីកដាលា អ្នកសំណព្វរបស់ព្រះ ដែលនៅជាប់បន្ទប់របស់ពួកចៅហ្វាយ នៅ
ពីលើបន្ទប់របស់ម្ភាសេយ៉ា កូនសាលូម ជាអ្នកឆ្មាំទ្វារ។
[5]រួចខ្ញុំដាក់ដបស្រាទំពាំងបាយជូរ និងពែងនៅមុខកូនចៅពួករេកាប ហើយប្រាប់ថាអញ្ជើញ «ពិសាស្រាទំពាំងបាយជូរចុះ»។[6]ប៉ុន្តែ គេឆ្លើយតបថា៖ «យើងរាល់គ្នាមិនព្រម
ទទួលទានស្រាទំពាំងបាយជូរទេ ព្រោះយ៉ូណាដាប ជាកូនរេកាប បុព្វបុរសយើងបានផ្តាំថាអ្នករាល់គ្នាកុំផឹកស្រាទំពាំងបាយជូរឡើយ ទោះទាំងអ្នក ឬកូនចៅអ្នកតរៀងទៅ។
[7]អ្នកមិនត្រូវធ្វើផ្ទះ ឬសាបព្រោះ ឬដាំ ឬមានចម្ការទំពាំងបាយជូរឡើយ គឺអ្នករាល់គ្នាត្រូវនៅក្នុងត្រសាលអស់មួយជីវិត ដើម្បីឲ្យបានរស់ជាយឺនយូរ នៅក្នុងទឹកដីដែលអ្នក
រាល់គ្នាកំពុងស្នាក់នៅនោះ។
[8]យើងរាល់គ្នាបានស្តាប់បង្គាប់យ៉ូណាដាប ជាកូនរេកាប ដែលជាបុព្វបុរសយើង តាមគ្រប់ទាំងសេចក្តីដែលគាត់បានផ្តាំមក គឺមិនបានទទួលទានស្រាទំពាំងបាយជូរដរាប
ដល់អស់មួយជីវិតយើង ព្រមទាំងប្រពន្ធ និងកូនប្រុសកូនស្រីរបស់យើងផង[9]ក៏មិនបានធ្វើផ្ទះសម្រាប់អាស្រ័យនៅ ហើយគ្មានដំណាំទំពាំងបាយជូរ ឬចម្ការ ឬពូជពង្រោះ
ណាផង[10]គឺយើងរាល់គ្នាបានអាស្រ័យនៅក្នុងត្រសាល ហើយបានស្តាប់បង្គាប់ ទាំងប្រព្រឹត្តតាមគ្រប់សេចក្តីដែលយ៉ូណាដាប ជាបុព្វបុរសយើងបានផ្តាំទុក។[11]ប៉ុន្តែ ពេល
ព្រះបាទនេប៊ូក្នេសា ជាស្តេចបាប៊ីឡូនបានឡើងមកក្នុងទឹកដីនោះយើងបាននិយាយគ្នាថា ចូរយើងចូលទៅក្នុងក្រុងយេរូសាឡិម ឲ្យរួចពីពួកទ័ពខាល់ដេ និងពួកទ័ពស៊ីរីចេញ
ហេតុនោះបានជាយើងរាល់គ្នា អាស្រ័យនៅក្នុងក្រុងយេរូសាឡិមសព្វថ្ងៃនេះ»។
[12]ពេលនោះ ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់ព្យាការីយេរេមាថា៖[13]ព្រះជាម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះ ចូរទៅនិយាយ
នឹងពួកទឹកដីយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមថា តើអ្នករាល់គ្នាមិនព្រមទទួលសេចក្តីប្រៀនប្រដៅ ដើម្បីស្តាប់តាមពាក្យយើងទេឬ? នេះហើយជាព្រះបន្ទូលនៃ
ព្រះអម្ចាស់។[14]ពាក្យរបស់យ៉ូណាដាប ជាកូនរេកាបដែលបានហាមដល់ពួកកូនចៅមិនឲ្យផឹកស្រាទំពាំងបាយជូរ នោះបានសម្រេចហើយ ដ្បិតគេមិនផឹកសោះ ដរាបដល់
សព្វថ្ងៃនេះ។ ពួកគេស្តាប់តាមបង្គាប់របស់បុព្វបុរសគេ ឯយើងវិញ យើងបាននិយាយនឹងអ្នករាល់គ្នា ព្រមទាំងក្រោកឡើងពីព្រលឹមស្រាង ដើម្បីប្រាប់ផង តែអ្នករាល់គ្នាមិន
បានស្តាប់តាមយើងសោះ។
[15]យើងបានចាត់ពួកព្យាការីទាំងប៉ុន្មាន ជាអ្នកបម្រើរបស់យើង ឲ្យមកឯអ្នកដែរ ទាំងក្រោកឡើងពីព្រលឹមស្រាង ដើម្បីចាត់គេ ឲ្យប្រាប់ថា ចូរអ្នកទាំងអស់គ្នាវិលមកពីផ្លូវ
អាក្រក់របស់ខ្លួនឥឡូវ ហើយកែកិរិយារបស់អ្នក កុំទៅតាមព្រះដទៃ ដើម្បីគោរពបម្រើព្រះទាំងនោះឡើយ នោះអ្នករាល់គ្នានឹងបាននៅជាប់ក្នុងទឹកដី ដែលយើងបានឲ្យដល់
អ្នក និងបុព្វបុរសអ្នក តែអ្នករាល់គ្នាមិនបានផ្ទៀងត្រចៀក ឬស្តាប់តាមយើងសោះ។[16]ដ្បិត ដោយឃើញថា ពួកកូនចៅយ៉ូណាដាប ជាកូនរេកាប បានសម្រេចតាមបង្គាប់
របស់បុព្វបុរសគេ ដែលផ្តាំមកនោះ តែជនជាតិទាំងនេះមិនបានស្តាប់តាមយើងទេ»។
[17]ហេតុនោះ ព្រះជាម្ចាស់នៃពិភពទាំងមូល គឺជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា៖ យើងនឹងនាំគ្រប់ទាំងសេចក្តីអាក្រក់មកលើពួកយូដា ហើយលើពួក
អ្នកនៅក្រុងយេរូសាឡិម ដូចជាយើងបានពោលទាស់នឹងគេហើយ ព្រោះយើងបានប្រាប់ដល់គេ តែគេមិនបានស្តាប់ទេ យើងបានហៅគេ តែគេមិនបានឆ្លើយតបឡើយ»។
[18]ព្យាការីយេរេមាថ្លែងទៅកាន់ពួកវង្សរេកាបថា៖ «ព្រះជាម្ចាស់នៃពិភពទាំងមូល ជាព្រះនៃជនជាតិអ៊ីស្រាអែលព្រះអង្គមានព្រះបន្ទូលថា ដោយព្រោះអ្នករាល់គ្នាបានស្តាប់
តាមបង្គាប់យ៉ូណាដាប ជាបុព្វបុរសអ្នក ហើយរក្សាអស់ទាំងបញ្ញត្តិរបស់គាត់ ព្រមទាំងសម្រេចតាមអស់ទាំងពាក្យដែលគាត់បានផ្តាំមក[19]ដូច្នេះ ព្រះជាម្ចាស់នៃពិភពលោក
ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា យ៉ូណាដាបជាកូនរេកាប នឹងមិនដែលខានមានមនុស្សសម្រាប់ឈរនៅមុខយើងឡើយ»។

Jeremiah 35:1

អំបូររេកាប
នេះជាឈ្មោះក្រុម។
ព្រះដំណាក់របស់យើង
នេះសំដៅលើព្រះដំណាក់របស់ព្រះអម្ចាស់។

Jeremiah 35:3

យ៉ាសានា...ហាបា...ហាណាន...យីកដាលា...សាលូម
ទាំងនេះជាឈ្មោះរបស់មនុស្ស។

Jeremiah 35:5

រេកាប
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៥:១។
យ៉ូណាដាប...រេកាប
ទាំងនេះជាឈ្មោះរបស់មនុស្ស។
រស់ជាយឺនយូរ នៅក្នុងទឹកដី
«យឺនយូរ» សំដៅលើរយៈពេលនៃជីវិត។

Jeremiah 35:8

សម្លេងរបស់យ៉ូណាដាប
ពាក្យថា «សម្លេង» នៅទីនេះសំដៅលើបទបញ្ញត្តិ។ ការបកប្រែរបៀបផ្សេងទៀត:
«បទបញ្ញត្តិរបស់យ៉ូណាដាប»
ពេញអស់មួយជីវិតយើង
«មួយជីវិត» សំដៅលើរយៈពេលនៃជីវិត។

Jeremiah 35:12

ព្រះបន្ទូលនៃព្រះអម្ចាស់ បានមកដល់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។ «ព្រះអម្ចាស់មានព្រះបន្ទូលមកដល់»
តើអ្នករាល់គ្នាមិនបានទទួលការកែតម្រូវ ហើយស្តាប់តាមពាក្យយើងទេ?
សំណួរនេះត្រូវបានសួរដើម្បីបន្ទោសជនជាតិអ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងមិនទទួលបានការកែតម្រូវ
ហើយស្តាប់តាមពាក្យរបស់យើងទេ»។
យ៉ូណាដាប...រេកាប
ទាំងនេះជាឈ្មោះរបស់មនុស្ស។

generated on Wed Sep 10 16:16:32 2025

ពាក្យរបស់យ៉ូណាដាប ជាកូនរេកាបដែលបានហាមដល់ពួកកូនចៅមិនឲ្យផឹកស្រា នោះបានប្រកាន់ផ្ចាប់ដល់សព្វថ្ងៃនេះ
ការបកប្រែរបៀបផ្សេងទៀត: «កូនរបស់យ៉ូណាដាប់ ឬជាកូនរបស់រេកាប បានប្រកាន់ភ្ជាប់បទបញ្ញត្តិ របស់ឪពុកពួកគេគឺ កុំផឹកស្រា»។
Jeremiah 35:15
បែរចេញពីផ្លូវអាក្រក់របស់ខ្លួន ហើយធ្វើការល្អវិញ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា និងរួមគ្នាបង្កើតការបញ្ជាក់ន័យ។
ដើរតាមព្រះដទៃ ហើយថ្វាយបង្គំព្រះទាំងនោះ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា និងរួមគ្នាបង្កើតការបញ្ជាក់ន័យ។
អ្នករាល់គ្នាមិនបានស្តាប់តាមយើងទេ ឬយកចិត្តទុកដាក់ដល់យើងដែរ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា និងរួមគ្នាបង្កើតការបញ្ជាក់ន័យ។
Jeremiah 35:17
ចូរមើល៍!
ពាក្យនេះប្រាប់យើងឲ្យយកចិត្តទុកដាក់ខ្លាំងនូវអ្វីដែលនៅបន្ទាប់។
Jeremiah 35:18
រេកាប
នេះជាឈ្មោះក្រុមមនុស្ស។ សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក៣៥: ១។
យ៉ូណាដាប...រេកាប
នេះជាឈ្មោះមនុស្ស។
សូមមើលពីរបៀបបកប្រែឈ្មោះទាំងនេះនៅក្នុងជំពូក៣៥:៥។

---

36 [1]នៅឆ្នាំទីបួនក្នុងរជ្ជកាលព្រះបាទយេហូយ៉ាគីម ជាបុត្រព្រះបាទយ៉ូសៀស ស្តេចយូដា ព្រះបន្ទូលរបស់ព្រះអម្ចាស់ បានមកដល់ព្យាការីយេរេមាថា៖[2]«ចូរយកក្រាំងមួយមកកត់អស់ទាំងពាក្យដែលយើងបានប្រាប់អ្នក ទាស់នឹងពួកអ៊ីស្រាអែល និងពួកយូដា ហើយទាស់នឹងជនជាតិទាំងប៉ុន្មាន ចាប់តាំងពីថ្ងៃដែលយើងបាននិយាយទៅកាន់អ្នក គឺតាំងពីគ្រាយ៉ូសៀសរហូតមកដល់សព្វថ្ងៃ។[3]ប្រហែលជាពួកវង្សយូដានឹងស្តាប់អស់ទាំងសេចក្តីអាក្រក់ ដែលយើងសម្រេចនឹងធ្វើដល់គេទេដឹង ប្រយោជន៍ឲ្យគេបានវិលមកពីផ្លូវអាក្រក់របស់គេវិញ ដើម្បីឲ្យយើងបានអត់ទោសចំពោះអំពើទុច្ចរិត និងអំពើបាបរបស់គេ»។
[4]ដូច្នេះ ព្យាការីយេរេមាក៏ហៅបារូក ជាកូននេរីយ៉ាមក ហើយបារូកក៏សរសេរអស់ទាំងព្រះបន្ទូលនៃព្រះជាម្ចាស់ចុះក្នុងក្រាំងតាមមាត់ព្យាការីយេរេមា ជាព្រះបន្ទូលដែលព្រះអង្គបានមានព្រះបន្ទូលដល់លោក។[5]ព្យាការីយេរេមាប្រាប់បារូកថា៖ «ខ្ញុំនៅជាប់ឃុំ ចូលទៅក្នុងព្រះវិហារនៃព្រះជាម្ចាស់មិនបាន។[6]ដូច្នេះ ចូរអ្នកយកក្រាំងនេះ ដែលអ្នកបានសរសេរតាមមាត់យើង ទៅអានមើលព្រះបន្ទូលនៃព្រះអម្ចាស់ នៅត្រចៀករបស់បណ្តាជនក្នុងព្រះវិហារនៃព្រះជាម្ចាស់ នៅថ្ងៃតមទៅ ហើយអ្នកត្រូវអានឲ្យឮដល់ត្រចៀកពួកជនជាតិយូដាទាំងអស់ ដែលចេញពីទីក្រុងរបស់គេមកដែរ។
[7]ប្រហែលជាគេនឹងទូលអង្វរដល់ព្រះអម្ចាស់ ហើយវិលមកពីផ្លូវអាក្រក់របស់គេរៀងខ្លួនទេដឹង ដ្បិតសេចក្តីក្រោធ និងសេចក្តីឃោរឃៅ ដែលព្រះអម្ចាស់បានពោលទាស់នឹងជនជាតិនេះ នោះធ្ងន់ក្រៃលែង»។[8]ដូច្នេះ បារូក ជាកូននេរីយ៉ា ក៏សម្រេចតាមគ្រប់ទាំងសេចក្តីដែលព្យាការីយេរេមាបានបង្គាប់ គឺបានអានមើលព្រះបន្ទូលនៃព្រះអម្ចាស់ដែលកត់ចុះក្នុងក្រាំង នៅក្នុងព្រះវិហារនៃព្រះជាម្ចាស់។
[9]នៅខែទីប្រាំបួន ក្នុងឆ្នាំទីប្រាំនៃរាជ្យព្រះបាទយេហូយ៉ាគីម ជាបុត្រព្រះបាទយ៉ូសៀសស្តេចយូដានោះប្រជាជនទាំងឡាយនៅក្រុងយេរូសាឡិម ហើយបណ្តាជនដែលមកចំណែកក្រុងយេរូសាឡិម ពីទីក្រុងទឹកដីយូដាទាំងប៉ុន្មាន ក៏ប្រកាសឲ្យមានថ្ងៃតមនៅចំពោះព្រះអម្ចាស់។[10]ពេលនោះ បារូកក៏អានមើលក្រាំង ជាពាក្យរបស់ព្យាការីយេរេមាក្នុងព្រះវិហារនៃព្រះជាម្ចាស់ឲ្យបណ្តាជនស្តាប់ គឺក្នុងបន្ទប់របស់ស្មៀនកេម៉ារា ជាកូនសាផាន ដែលនៅទីលានខាងលើ ត្រង់ទ្វារថ្មីនៃព្រះវិហារព្រះអម្ចាស់។
[11]ពេលមីកា ជាកូនកេម៉ារា ដែលជាកូនរបស់សាផានបានឮអស់ទាំងព្រះបន្ទូលព្រះជាម្ចាស់ ដែលនៅក្នុងក្រាំងនោះហើយ។[12]គាត់ក៏ចុះទៅឯព្រះរាជវាំង ចូលក្នុងបន្ទប់ស្មៀន ឃើញមានពួកចៅហ្វាយទាំងប៉ុន្មាននៅទីនោះ គឺស្មៀនអេលីសាម៉ា ហើយដេឡាយ៉ា ជាកូនសេម៉ាយ៉ា និងអែលណាថាន ជាកូនអ័កបោរ កេម៉ារា ជាកូនសាផាន សេដេគា ជាកូនហាណានា ហើយពួកចៅហ្វាយទាំងអស់ផង។
[13]លោកមីការៀបរាប់នូវសេចក្តីទាំងប៉ុន្មាន ដែលគាត់បានឮលោកបារូកអានឲ្យប្រជាជនស្តាប់។[14]ពេលនោះ គណៈរដ្ឋមន្ត្រីចាត់លោកយេហ៊ូឌី ជាកូនរបស់លោកនេថានា ជាចៅរបស់លោកសេលេមា និងជាចៅទួតរបស់លោកគូស៊ី ឲ្យទៅជួបលោកបារូក ប្រាប់ថា៖ «ចូរយកក្រាំងដែលអ្នកអានឲ្យប្រជាជនស្តាប់នោះមក!»។ លោកបារូក ជាកូនរបស់លោកនេរីយ៉ា ក៏យកក្រាំងទៅជួបពួកមន្ត្រី។[15]ពួកគេបង្គាប់គាត់ថា៖ «សុំអង្គុយចុះ អានឲ្យយើងស្តាប់!»។ លោកបារូកក៏អានឲ្យពួកលោកស្តាប់។
[16]លុះកាលគេបានឮពាក្យទាំងនោះរួចហើយ គេក៏បែរមើលគ្នាទៅវិញទៅមក ដោយភិតភ័យ ហើយនិយាយទៅបារូកថា៖ «យើងនឹងទូលដល់ស្តេច ពីពាក្យទាំងនេះជាមិនខាន»។[17]រួចគេសួរបារូកថា៖ «ចូរប្រាប់យើងមក ធ្វើដូចម្តេចឲ្យអ្នកបានកត់អស់ទាំងពាក្យនេះតាមមាត់គាត់បាន?»។[18]បារូកឆ្លើយថា៖ «លោកបានប្រាប់ពាក្យទាំងនេះដល់ខ្ញុំ ហើយខ្ញុំក៏យកទឹកខ្មៅសរសេរចុះក្នុងក្រាំងនេះ»។[19]ពេលនោះ ពួកចៅហ្វាយប្រាប់បារូកថា៖ «ចូរអ្នក និងយេរេមាទៅលាក់ខ្លួនទៅ កុំឲ្យអ្នកណាដឹងជានៅឯណាឡើយ»។
[20]រួចគេក៏ចូលទៅគាល់ស្តេចនៅក្នុងដំណាក់ តែឯក្រាំង គេបានដាក់ទុកនៅក្នុងបន្ទប់របស់ស្មៀនអេលីសាម៉ា ហើយគេទូលដល់ស្តេចតាមអស់ទាំងពាក្យនោះ។[21]ដូច្នេះ ស្តេចចាត់យេហ៊ូឌី ឲ្យទៅយកក្រាំងពីបន្ទប់ស្មៀនអេលីសាម៉ាមក រួចយេហ៊ូឌីក៏អានថ្វាយស្តេចស្តាប់ និងពួកចៅហ្វាយទាំងអស់ ដែលឈរនៅខាងស្តេចដែរ។[22]ខណៈនោះ ស្តេចគង់ក្នុងដំណាក់សម្រាប់រដូវរងានៅខែទីប្រាំបួន ហើយមានភ្លើងឆេះនៅជើងក្រានក្បែរនោះ។
[23]ពេលយេហ៊ូឌីបានអានបីបួនជួរ ស្តេចយកកាំបិតស្មៀតកាត់ក្រាំងនោះបោះទៅក្នុងភ្លើងជើងក្រាន រហូតទាល់តែក្រាំងទាំងមូលឆេះអស់។[24]ទោះទាំងស្តេច ឬពួកមហាតលិក ដែលឮពាក្យទាំងនោះហើយ គេឥតមានស្លុតចិត្ត ឬហែកសម្លៀកបំពាក់សោះ។
[25]ទោះបីជាអែលណាថាន ដេឡាយ៉ា និងកេម៉ារា ទូលអង្វរស្តេច សូមកុំដុតក្រាំងក៏ដោយ តែស្តេចមិនព្រមស្តាប់តាមទេ[26]រួចស្តេចបង្គាប់យេរ៉ាម្អែល ជាកូនហាម៉ាលេក និងសេរ៉ាយ៉ាជាកូនអាសរាល ហើយសេលេមា ជាកូនអាប់ឌាល ឲ្យទៅចាប់ស្មៀនបារូក និងព្យាការីយេរេមាមក តែព្រះជាម្ចាស់បានលាក់លោកទុក។
[27]ក្រោយដែលស្តេចបានដុតក្រាំងជាពាក្យទាំងនោះ ដែលបារូកបានសរសេរទុកតាមមាត់ព្យាការីយេរេមាហើយ នោះព្រះបន្ទូលនៃព្រះជាម្ចាស់ក៏មកដល់ព្យាការីយេរេមាថា៖
[28]«ចូរយកក្រាំងមួយទៀត ហើយសរសេរទុកពាក្យដើមទាំងប៉ុន្មាន ដូចបានសរសេរចុះក្នុងក្រាំងមុននោះ ដែលយេហូយ៉ាគីម ជាស្តេចយូដាបានដុតចោលទៅហើយនោះ។
[29]បន្ទាប់មក អ្នកត្រូវប្រាប់យេហូយ៉ាគីម ជាស្តេចយូដាថា ព្រះជាម្ចាស់មានព្រះបន្ទូលយ៉ាងដូច្នេះ អ្នកបានដុតក្រាំងនោះចោល ដោយពាក្យថា ហេតុអ្វីបានជាសរសេរដូច្នេះថា ស្តេចបាប៊ីឡូននឹងមក ហើយបំផ្លាញទឹកដីនេះ ព្រមទាំងធ្វើឲ្យលែងមានទាំងមនុស្ស និងសត្វ?»
[30]ហេតុនោះ ព្រះជាម្ចាស់មានព្រះបន្ទូលពីដំណើរយេហូយ៉ាគីម ជាស្តេចយូដាដូច្នេះថា «នឹងគ្មានអ្នកណាសម្រាប់អង្គុយលើបល្ល័ង្ករបស់ដាវីឌឡើយ ហើយសាកសពយេហូយ៉ាគីមនឹងត្រូវបោះចោលទៅក្រៅ ហាលក្តៅនៅពេលថ្ងៃ និងសន្សើមកកនៅពេលយប់។[31]យើងនឹងដាក់ទោសយេហូយ៉ាគីម និងពូជពង្ស ព្រមទាំងពួកមហាតលិកទាំងប៉ុន្មាន ដោយព្រោះអំពើទុច្ចរិតរបស់វារាល់គ្នា ហើយយើងនឹងនាំអស់ទាំងសេចក្តីអាក្រក់មកលើវារាល់គ្នា និងលើពួកអ្នកនៅក្រុងយេរូសាឡិម ហើយលើពួកមនុស្សនៅទឹកដីយូដាទាំងប៉ុន្មានផង តាមដែលយើងបានពោលទាស់នឹងគេរាល់គ្នាហើយ តែគេមិនព្រមស្តាប់តាមសោះ»។
[32]ដូច្នេះ ព្យាការីយេរេមាក៏យកក្រាំងមួយទៀត ឲ្យដល់ស្មៀនបារូក ជាកូននេរីយ៉ា ហើយគាត់ក៏សរសេរទុកអស់ទាំងពាក្យនោះតាមមាត់ព្យាការីយេរេមា ដូចជាមាននៅក្នុងក្រាំងដែលយេហូយ៉ាគីម ស្តេចយូដាបានដុតចោលនោះ ក៏មានសេចក្តីដូចគ្នាជាច្រើនទៀតបានបន្ថែមបញ្ចូលផង។

Jeremiah 36:1
ព័ត៌មានទូទៅ:
សូមមើល: និង
វាបានមកដល់
«វាបានកើតឡើង»។
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃដំណើររឿង។
ប្រសិនបើពាក្យភាសារបស់អ្នក
មានរបៀបដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះបាន។
ឆ្នាំទីបួនក្នុងរជ្ជកាលព្រះបាទយេហូយ៉ាគីម ជាបុត្រព្រះបាទយ៉ូសៀស ស្តេចយូដា
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ២៥: ១ ។
ព្រះបន្ទូល
ឃ្លាថា «ព្រះបន្ទូល»

generated on Wed Sep 10 16:16:32 2025

នៅទីនេះសំដៅលើព្រះរាជសារដែលនឹងកើតឡើងនៅខាងក្រោយនេះ។

ជនជាតិទាំងឡាយ

«គ្រប់ជនជាតិទាំងអស់»

ដែលយើងបានប្រាប់ តាំងពី

«យើងបានប្រាប់អ្នកតាំងពី»

តាំងពីយ៉ូសៀសរហូតមកដល់សព្វថ្ងៃ

ការបកប្រែរបៀបផ្សេងទៀត: «ចាប់តាំងពីយ៉ូសៀសរហូតមកដល់បច្ចុប្បន្ន»

ប្រហែលជាពួកវង្សយូដា

«ប្រហែលជាពួកប្រជាជនយូដា»

យើងសម្រេចនឹងនាំមកលើពួកគេ

«យើងមានផែនការប្រព្រឹត្តទៅពួកគេ»

ប្រហែលពួកគេ

«ដូច្នេះម្នាក់ៗ»

ពីផ្លូវអាក្រក់

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១៨: ១១។

Jeremiah 36:4

បារូកក៏សរសេរអស់ទាំងព្រះបន្ទូលនៃព្រះជាម្ចាស់ចុះក្នុងក្រាំងតាមមាត់ព្យាការីយេរេមា ជាព្រះបន្ទូលដែលព្រះអង្គបានមានព្រះបន្ទូលដល់លោក

«ពេលលោកយេរេមាមានប្រសាសន៍ លោកបារូកបានសរសេរនៅក្នុងក្រាំង គ្រប់ព្រះបន្ទូលទាំងអស់របស់ព្រះអម្ចាស់ ដែលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមា»។

អានពីក្រាំង

«ចូរអានឲ្យលឺពីក្រាំង» ឬ «ប្រកាសពីក្រាំង»

តាមមាត់យើង

«តាមពាក្យដែលខ្ញុំបាននិយាយ»

អានមើល

«ត្រូវអានឲ្យលឺ» ឬ «ត្រូវប្រកាសពី»

ឲ្យបណ្តាជនបានឮក្នុងព្រះវិហារនៃព្រះអង្គ

«ដូច្នេះពួកគេដែលនៅក្នុងព្រះវិហារនៃព្រះអង្គអាចលឺព្រះបន្ទូល»

ហើយឲ្យពួកជនជាតិយូដាទាំងអស់ដែលនៅទីក្រុងទាំងនោះបានឮផងដែរ

«ដូច្នេះពួកជនជាតិយូដាទាំងអស់ដែលបានមកពីទីក្រុងរបស់គេនោះបានលឺពីព្រះបន្ទូលដែលយេរេមាបានថ្លែង»

Jeremiah 36:7

ព័ត៌មានទូទៅ:

លោកយេរេមាបន្តណែនាំបារូក។

ប្រហែលជា

«អាចជា»

ពាក្យទូលអង្វរសម្រាប់ក្តីមេត្តា

ពាក្យថា «របស់ពួកគេ» សំដៅទៅលើប្រជាជននៅក្នុងដំណាក់របស់ព្រះអម្ចាស់ និងប្រជាជនយូដាដែលបានចូលមកក្នុងដំណាក់របស់ព្រះអម្ចាស់ពីទីក្រុងរបស់ពួកគេ។

ពាក្យទូលអង្វរសម្រាប់ក្តីមេត្តានឹងមកដល់ចំពោះព្រះអម្ចាស់

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់យកចិត្តទុកដាក់ពាក្យទូលអង្វរសម្រាប់ក្តីមេត្តា»

ប្រហែលគ្រប់គ្នានឹងបែរពី ផ្លូវអាក្រក់របស់គេ

ប្រហែលពួកគេប្រែចិត្ត ពួកគេចាកចេញពីអំពើអាក្រក់របស់គេ»

ពីផ្លូវអាក្រក់របស់គេ

សូមមើលពីរបៀបដែលអ្នកបានបកប្រែ «ពីផ្លូវអាក្រក់របស់គេ» នៅក្នុងជំពូក ១៨:១១។

សេចក្តីក្រោធ និងកំហឹងខ្លាំង

«កំហឹង និងឆេវឆាវ»

Jeremiah 36:9

បណ្តាជនដែលមក

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៦: ១។

ឆ្នាំទីប្រាំ ហើយក្នុងខែទីប្រាំបួន

នេះជាខែទី ៩ នៃប្រតិទិនជនជាតិហេប្រឺ។ នេះគឺកំឡុងពេលចុងខែវិច្ឆិកា និងដើមខែធ្នូតាមប្រតិទិនលោកខាងលិច។ ការបកប្រែរបៀបផ្សេងទៀត: «នៅខែទីប្រាំបួននៃឆ្នាំទីប្រាំ»។

នៃរាជព្រះបាទយេហូយ៉ាគីម ជាបុត្រព្រះបាទយ៉ូសៀសស្តេចយូដា

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ២៥: ១។

ថ្ងៃតម

«អំពាវនាវឲ្យអ្នករាល់គ្នាចូលរួមក្នុងការតមអាហារ»

សៀនកេម៉ារ ជាកូនរបស់សាផាន

នេះជាឈ្មោះរបស់មនុស្ស។

សៀន

«ជាអ្នកដែលពូកែនិពន្ធ ឬសរសេរ»

ត្រង់ផ្លូវចូលនៃព្រះវិហារនៃព្រះអម្ចាស់

«នៅត្រង់ទ្វារចូលថ្មីនៃព្រះវិហាររបស់ព្រះអម្ចាស់»

លោកបានធ្វើការនេះ

លោកអានសំដីរបស់ពាក្យលោកយេរេមាលឺៗ។

ដើម្បីឲ្យមនុស្សទាំងអស់បានឮ

សូមមើលពីរបៀបបកប្រែ «មនុស្សនៅក្រុងយេរូសាឡិមបានឮ» នៅក្នុងជំពូក ២:១។

Jeremiah 36:11

មីកា

នេះជាឈ្មោះរបស់មនុស្ស។

មីកា ជាកូនកេម៉ារ ដែលជាកូនរបស់សាផាន

«មីកា ជាកូនរបស់លោកកេម៉ារ៉ា ដែលត្រូវជាកូនប្រុសរបស់លោកសាផាន»

ក្នុងបន្ទប់របស់សៀន

«នៅក្នុងបន្ទប់របស់លេខា»

មើល!

ពាក្យថា «មើល!» នៅទីនេះបន្ថែមការសង្កត់ន័យនូវអ្វីនៅខាងក្រោយ។

សេម៉ាយ៉ា

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៦: ២០។

អេលីសាម៉ា...ដេឡាយ៉ា

ទាំងនេះជាឈ្មោះរបស់មនុស្ស។

អែលណាថាន ជាកូនអ័កបោរ

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៦:២២។

កេម៉ារា ជាកូនសាផាន

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ៣៦:៩។

សេដេគា

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ១:១។

ហាណានា

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៨:១។

ហើយពួកមន្ត្រីទាំងអស់

«ហើយទាំងពួកមន្ត្រីដទៃទៀត»

Jeremiah 36:13

លោកមីកា

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ៣៦:១១។

រៀបរាប់នូវសេចក្តីទាំងឡាយ

ពាក្យថា «សេចក្តីទាំងឡាយ» សំដៅលើការរៀបរាប់ដល់ពួកមន្ត្រីនៅក្នុងជំពូក ៣៦: ១១។

ឲ្យប្រជាជនស្តាប់

«ដូច្នេះពួកប្រជាជនអាចលឺ»

យេហ៊ូឌី ... នេថានា ... សេលេមា ... គូស៊ី

ទាំងនេះជាឈ្មោះរបស់មនុស្ស។

អានក្រាំង

«អានក្រាំងលឺៗ»

Jeremiah 36:16

វាបានកើតឡើង

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់នៅក្នុងសាច់រឿង។ ប្រសិនបើភាសារបស់អ្នកមានលក្ខណៈដូចនេះ អ្នកអាចពិចារណាប្រើវានៅទីនេះ។

ពេលពួកគេបានឮ

ពាក្យថា «ពួកគេ» សំដៅលើពួកមន្ត្រី។

ពាក្យទាំងនោះ

ពាក្យដែលលោកបារូកបានអានក្រាំងលឺៗ

តើធ្វើដូចម្តេចទើបអ្នកអាចកត់

«តើអ្នកកត់ដោយរបៀបណា»

ពាក្យតាមអ្វីដែលដែលលោកយេរេមា

សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៣៦:៤។

generated on Wed Sep 10 16:16:32 2025

បានប្រាប់
យេរេមាបានថ្លែងលឺៗ ដើម្បីឲ្យបារូកអាចកត់តាមពាក្យរបស់លោក។
យកទឹកខ្មៅសរសេរចុះ
«សរសេរដោយប្រើទឹកខ្មៅ»
ទឹកខ្មៅ
ថ្នាំទឹកខ្មៅដែលត្រូវបានប្រើសម្រាប់ការសរសេរ
ហើយយេរេមាផង
សូមមើលពីរបៀបបកប្រែ «ហើយយេរេមាគួរលាក់បាំងខ្លួនគាត់ផង»។
ពីកន្លែងដែលអ្នករស់នៅ
ពាក្យថា «អ្នក» សំដៅលើ បារូក ហើយនិងលោកយេរេមា។
Jeremiah 36:20
ដូច្នោះហើយ ពួកគេ
ពាក្យថា «ពួកគេ» សំដៅលើពួកមន្ត្រី។
បានដាក់ក្រាំងទុកនៅក្នុងបន្ទប់របស់ស្មៀនអេលីសាម៉ា
«បានដាក់ក្រាំងនៅទីសុវត្ថិភាពនៅក្នុងបន្ទប់របស់ស្មៀនអេលីសាម៉ា»
ស្មៀនអេលីសាម៉ា
សូមមើលពីរបៀបបកប្រែ «ស្មៀនអេលីសាម៉ា» នៅក្នុងជំពូក ៣៦: ១១។
ពាក្យទាំងនេះ
ពាក្យនៅក្នុងក្រាំង ដែលលោកយេរេមាបានប្រាប់បារូក
យេហ៊ូឌី
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៦: ១៣។
នៅខែទីប្រាំបួន
នេះជាខែទី ៩ នៃប្រតិទិនជនជាតិហេប្រឺ។ នេះគឺនៅចុងរដូវសាបព្រួស
និងដើមរដូវត្រជាក់។ នេះគឺចុងខែវិច្ឆិកា និងដើមខែធ្នូតាមប្រតិទិនលោកខាងលិច។
ហើយមានភ្លើងឆេះនៅជើងក្រានក្បែរនោះ
«ហើយជើងក្រានភ្លើងគឺនៅចំពោះមុខគាត់បានឆេះឡើង»
ភ្លើងជើងក្រាន
ជើងក្រានដែលមនុស្សអាចដូរទីតាំងបាន។
Jeremiah 36:23
វាបានកើតឡើង
ឃ្លានេះត្រូវបានប្រើដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងសាច់រឿង។
ប្រសិនបើពាក្យភាសារបស់អ្នកមានលក្ខណៈដូចនេះ
អ្នកអាចពិចារណាប្រើវានៅទីនេះ។
យេហ៊ូឌី
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក៣៦: ១៣។
ជួរ
ទាំងនេះជាជួរនៃពាក្យនៅលើក្រាំង
មកកាត់ក្រាំងនោះ
«នឹងកាត់ផ្នែកខ្លះ»
បានយកកាំបិត
«ប្រើកាំបិតរបស់ស្មៀន» ឬ «ប្រើកាំបិតប្រភេទដែលស្មៀនប្រើ»
ភ្លើងជើងក្រាន
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៦: ២០។
រហូតទាល់តែក្រាំងទាំងមូលឆេះអស់ទៅ
«រហូតទាល់តែក្រាំងត្រូវបានខូចអស់»
ពាក្យទាំងនោះ
ពាក្យដែលនៅក្នុងក្រាំងដែលបារូកបានសរសេរ តាមពាក្យរបស់លោកយេរេមា
ក៏មិនបានហែកសម្លៀកបំពាក់ពួកគេដែរ
ប្រជាជនហែកខោអាវរបស់ពួកគេ នៅពេលដែលពួកគេមានទុក្ខព្រួយយ៉ាងខ្លាំង។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេក៏មិនបានយំសោកដោយហែកសម្លៀកបំពាក់របស់ពួកគេដែរ»។
Jeremiah 36:25
អែលណាថាន ដេឡាយ៉ា ហើយនិងកេម៉ារា
សូមមើលពីរបៀបបកប្រែឈ្មោះទាំងនេះក្នុងជំពូក ៣៦:១១។
ទូលអង្វរស្តេច
«អង្វរសុំស្តេច» ឬ «ទទួចសុំស្តេច»
យេរ៉ាម្អែល...សេរ៉ាយ៉ា...អាសរាល...សេលេមា ...អាប់ឌាល
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ជាបងប្អូន
«ជាពូជពង្សរបស់ស្តេច»
Jeremiah 36:27
ព្រះបន្ទូលនៃព្រះជាម្ចាស់មកដល់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១: ១។
តាមអ្វីដែលយេរេមាបានប្រាប់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៦: ៤។
ចូរទៅយកក្រាំងមួយទៀត សម្រាប់ខ្លួនអ្នក
«ចូរយកក្រាំងមួយទៀត សម្រាប់ខ្លួនអ្នកម្តងទៀត»
ក្រាំងមុន
«ក្រាំងដំបូង»
ហេតុអ្វីបានជាអ្នកសរសេរលើវា
យេហូយ៉ាគឺមប្រើសំណួរនេះដើម្បីបញ្ជាក់ថាយេរេមាមិនគួរសរសេរថាស្តេចស្រុកបាប៊ីឡូននឹងមកវាយប្រ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនគួរសរសេរឡើយ» ឬ
«អ្នកបានសរសេរខុស»។
ដុតបំផ្លាញ
«ហើយនឹងបំផ្លាញ»
Jeremiah 36:30
អង្គុយលើបល្ល័ង្ករបស់ដាវីឌឡើយ
ការបកប្រែរបៀបផ្សេងទៀត: «នឹងគ្រប់គ្រងមរតករបស់ដាវីឌ»។
សូមមើលពីរបៀបបកប្រែ «អង្គុយនៅលើបល្ល័ង្ករបស់ដាវីឌ» នៅ ២៩:១៥។
ហើយសាកសពយេហូយ៉ាគីមនឹងត្រូវបោះចោល
ការបកប្រែរបៀបផ្សេងទៀត: «គេនឹងបោះចោលសាកសពអ្នកទៅខាងក្រៅ»
សាកសព
«រូបកាយដែលបានស្លាប់»
ទៅក្រោមក្តៅនៅពេលថ្ងៃ
«ដូច្នេះយកទៅដាក់នៅក្រោមកំដៅថ្ងៃ នៅពេលថ្ងៃ»
រាល់គ្នា
«គ្រប់គ្នា»
Jeremiah 36:32
តាមពាក្យដែលយេរេមាប្រាប់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៦: ៤។
ដែលយេហូយ៉ាគីម ស្តេចយូដាបានដុតចោលនោះ
«ដែលយេហូយ៉ាគីម ស្តេចយូដាបានដុតក្នុងភក់ភ្លើង»
លើសពីនោះ មានសេចក្តីដូចគ្នាជាច្រើនទៀតដែលបានបន្ថែមបញ្ចូលក្នុងក្រាំងនេះផង
ការបកប្រែរបៀបផ្សេងទៀត: «លើសពីនេះទៀត យេរេមា
និងបារូកបានបន្ថែមពាក្យជាច្រើនទៀតដែលដូចគ្នានឹងពាក្យដែលមាននៅក្នុងក្រាំងទីមួយ»។

---

37 [1]ព្រះបាទនេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន បានតាំងព្រះបាទសេដេគា ជាបុត្រព្រះបាទយ៉ូសៀសឲ្យឡើងសោយរាជ្យជំនួសព្រះបាទកូនាស ជាបុត្ររបស់ព្រះបាទ
យេហូយ៉ាគីម។[2]ប៉ុន្តែ ទោះទាំងស្តេច ឬពួកមហាតលិក ឬបណ្តាជននៅក្នុងទឹកដីនោះ ក៏មិនបានស្តាប់តាមព្រះបន្ទូលនៃព្រះជាម្ចាស់ ដែលព្រះអង្គមានព្រះបន្ទូលមក
តាមរយៈព្យាការីយេរេមា។
[3]ព្រះបាទសេដេគាបានចាត់យេហ៊ូកាល ជាកូនសេលេមា និងសេផានា ជាកូនរបស់សង្ឃម្នាសេយ៉ា ឲ្យទៅជួបព្យាការីយេរេមា ដោយផ្តាំថា៖ «ចូរអធិស្ឋានដល់ព្រះអម្ចាស់ជា
ព្រះនៃយើងរាល់គ្នាឲ្យយើងឥឡូវផង»។[4]ព្យាការីយេរេមាក៏ទៅមកក្នុងបណ្តាជន ដ្បិតគេមិនទាន់បានឃុំទុកលោកនៅឡើយ។[5]គ្រានោះ ពលទ័ពរបស់ផារ៉ោន ក៏លើកចេញពី
ទឹកដីអេស៊ីបមក កាលពួកខាល់ដេ ដែលកំពុងតែឡោមព័ទ្ធក្រុងយេរូសាឡិម បានឮដំណឹងនោះ គេក៏ថយចេញពីក្រុងយេរូសាឡិមទៅ។
[6]ពេលនោះ ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ព្យាការីយេរេមាថា៖[7]«ព្រះជាម្ចាស់ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះ អ្នកត្រូវឆ្លើយតបនឹងស្តេចយូដា
ដែលចាត់អ្នកឲ្យមកសួរដល់យើងថា ពួកពលទ័ពរបស់ផារ៉ោន ដែលលើកចេញមកជួយអ្នក គេនឹងវិលត្រឡប់ទៅទឹកដីអេស៊ីប ជាទឹកដីរបស់គេវិញ។[8]បន្ទាប់មក ពួក
ខាល់ដេនឹងមកម្តងទៀត។ ច្បាំងនឹងទីក្រុងនេះ ហើយចាប់យក រួចគេនឹងដុតចោល»។

generated on Wed Sep 10 16:16:32 2025

[9]ព្រះជាម្ចាស់មានព្រះបន្ទូលយ៉ាងដូច្នេះថា៖ «កុំបញ្ឆោតខ្លួនអ្នករាល់គ្នាដោយថា» ពួកខាល់ដេនឹងថយចេញពីយើងជាប្រាកដនោះឡើយ ដ្បិតគេមិនថយចេញទៅទេ។
[10]ទោះបើអ្នករាល់គ្នាបានវាយពលទ័ពទាំងមូលរបស់ពួកខាល់ដេដែលច្បាំងនឹងអ្នក ឲ្យសល់តែអ្នករបួសក៏ដោយ ក៏គេនឹងក្រោកឡើង នៅក្នុងត្រសាលគេរៀងខ្លួន មកដុតទីក្រុងនេះចោលដែរ»។
[11]នៅគ្រាដែលពលទ័ពរបស់ពួកខាល់ដេ បានថយចេញពីក្រុងយេរូសាឡិមទៅ ដោយខ្លាចពួកពលទ័ពរបស់ផារ៉ោន[12]ព្យាការីយេរេមាបានចេញពីក្រុងយេរូសាឡិម ទៅទឹកដីបេនយ៉ាមីន ដើម្បីទទួលដីជាចំណែករបស់លោក នៅក្នុងចំណោមអ្នកទឹកដីនោះ។[13]ពេលលោកកំពុងចេញតាមទ្វារបេនយ៉ាមីន នោះមានមេទ័ពពួកល្បាតនៅទីនោះឈ្មោះ យារីយ៉ា ជាកូនសេលេមា ដែលជាកូនហាណានា អ្នកនោះក៏ចាប់ទឹកដីយេរេមា ដោយចោទថា៖ «អ្នកចូលដៃខាងពួកខាល់ដេ»។
[14]ព្យាការីយេរេមាប្រកែកថា៖ «មិនមែនទេ ខ្ញុំមិនចូលទៅខាងពួកខាល់ដេឡើយ»។ ប៉ុន្តែ យារីយ៉ាមិនព្រមជឿលោកសោះ ក៏ចាប់ព្យាការីយេរេមានាំទៅឯពួកចៅហ្វាយ។
[15]ពួកចៅហ្វាយមានសេចក្តីក្រោធនឹងព្យាការីយេរេមា ក៏វាយលោក ហើយនាំទៅឃុំទុកក្នុងផ្ទះស្មៀនយ៉ូណាថាន ដ្បិតគេបានយកផ្ទះនោះធ្វើជាគុក។
[16]កាលព្យាការីយេរេមាបានចូលទៅក្នុងគុក នៅបន្ទប់ក្រោមដី នៅទីនោះជាយូរថ្ងៃ។[17]ព្រះបាទសេដេគាបានចាត់គេឲ្យទៅនាំលោកមក ស្តេចសួរលោកដោយសម្ងាត់នៅក្នុងដំណាក់ថា៖ «តើមានព្រះបន្ទូលណាមកពីព្រះអម្ចាស់ឬទេ?»។ ព្យាការីយេរេមាទូលតបថា៖ «មាន»។ លោកក៏ទូលទៀតថា៖ «ទ្រង់នឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូន»។
[18]មួយទៀត ព្យាការីយេរេមាក៏ទូលសួរព្រះបាទសេដេគាថា៖ «តើទូលបង្គំបានធ្វើខុសអ្វីនឹងទ្រង់ ឬនឹងពួកនាម៉ឺន ឬនឹងពួកជនជាតិនេះ បានជាដាក់ទូលបង្គំនៅក្នុងគុកដូច្នេះ?[19]ឥឡូវ តើពួកព្យាការីរបស់ព្រះអង្គនៅឯណា ដែលគេថ្លែងទំនាយថា ស្តេចបាប៊ីឡូនមិនមកទាស់នឹងទ្រង់ ឬទាស់នឹងទឹកដីនេះឡើយនោះ?[20]ឥឡូវនេះ ឱព្រះករុណាជាអម្ចាស់នៃទូលបង្គំអើយ សូមទ្រង់សណ្តាប់ សូមមេត្តាប្រោសឲ្យទូលបង្គំបានទូលអង្វរបន្តិច សូមកុំឲ្យទូលបង្គំត្រឡប់ទៅក្នុងផ្ទះរបស់ស្មៀនយ៉ូណាថានទៀតឡើយ ក្រែងទូលបង្គំស្លាប់នៅទីនោះ»។
[21]ដូច្នេះ ព្រះបាទសេដេគាបានបង្គាប់ឲ្យគេឃុំលោកទុកនៅទីលានគុកវិញ ហើយឲ្យគេយកនំប៉័ងមួយដុំ ពីផ្លូវនៃពួកដុតនំប៉័ងមកឲ្យលោករាល់ៗថ្ងៃ ដរាបដល់នំប៉័ងទាំងប៉ុន្មាននៅទីក្រុងបានអស់។ ដូច្នេះ ព្យាការីយេរេមាក៏នៅជាប់ក្នុងទីលានគុកនោះ។

Jeremiah 37:1

ព្រះបាទកូនាស

អត្ថបទភាសាហេព្រើរមាន «ព្រះបាទកូនាស» ដែលប្រែប្រួលឈ្មោះពី «ព្រះបាទយ៉ូយ៉ាគីន»។ អត្ថបទនាពេលបច្ចុប្បន្នភាគច្រើនមានពាក្យ «ព្រះបាទយ៉ូយ៉ាគីន» គោលបំណង ដើម្បីបញ្ជាក់ឲ្យច្បាស់ថាជាស្តេចដូចគ្នា។

នៅក្នុងទឹកដីនោះ

«នៅក្នុងទឹកដីស្រុកយូដា»

ព្រះអង្គមានព្រះបន្ទូលមក

«ព្រះអម្ចាស់មានព្រះបន្ទូលមក»

តាមរយៈដៃរបស់ព្យាការីយេរេមា

ការបកប្រែរបៀបផ្សេងទៀត: «តាមរយៈលោកយេរេមាដែលជាព្យាការី»។

Jeremiah 37:3

យេហ៊ូកាល

នេះជាឈ្មោះរបស់មនុស្ស។

សេលេមា

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ៣៦:១៣។

សេផានា ជាកូនរបស់បូជាចារ្យម្ហាសេយ៉ា

សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ២១:១ ។

ជំនួសយើងផងចុះ

«សម្រាប់យើង» ឬ «សម្រាប់ជាប្រយោជន៍យើង»។ ពាក្យថា «យើង» សំដៅលើស្តេចសេដេគា និងប្រជាជនស្រុកយូដាឯទៀត។

យេរេមាបានមកដល់ហើយទៅជួបប្រជាជន

ការបកប្រែរបៀបផ្សេងទៀត:

«លោកយេរេមាអាចទៅគ្រប់ទីកន្លែងដែលលោកចង់ជាមួយមនុស្សគ្រប់គ្នា»។

ដ្បិត លោកមិនទាន់បានឃុំឃាំងឡើយទេ

«ដោយព្រោះតែលោកមិនទាន់មានអ្នកណាចាប់លោកដាក់ឃុំឃាំងឡើយ»

បានចេញពី

«បានធ្វើដំណើរចេញ»

ឡោមព័ទ្ធ

សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៣២:១។

Jeremiah 37:6

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:១។

អ្នកត្រូវឆ្លើយតបនឹង

ពាក្យថា «អ្នក» សំដៅទៅលើមនុស្សពីរនាក់ដែលស្តេចសេដេគាបានបញ្ជូនទៅលោកយេរេមា គឺយេហ៊ូកាល ជាកូនរបស់សេលេមា និងសេផានាជាបូជាចារ្យម្ហាសេយ៉ា។

ឲ្យទៅស្វែងរកយោបល់ពីយើង

ពាក្យថា «យើង» សំដៅលើព្រះអម្ចាស់»។

មើល!

ពាក្យនេះប្រើដេម្បីបង្ហាញលើអ្វីនឹងមាននៅខាងក្រោយ។

ការបកប្រែរបៀបផ្សេងទៀត: «ប្រាកដណាស់»

ពួកគេនឹងច្បាំងទាស់នឹងទីក្រុងនេះ ហើយចាប់យកវា ហើយដុតវាដែរ

ចូរប្រៀបធៀបរបៀបអ្នកបានបកប្រែ «ធ្វើសង្គ្រាមទាស់ជាមួយ ហើយយកវា និងដុតវា» នៅក្នុងជំពូក ៣៤:២០។

Jeremiah 37:9

កុំបញ្ឆោតខ្លួនអ្នករាល់គ្នា

«អ្នករាល់គ្នាគិតថាល្អ»

ពួកខាល់ដេនឹងចាកចេញពីយើងជាប្រាកដនោះឡើយ

ប្រជាជនស្រុកយូដាគិតថាពួកគេនឹងមានសុវត្ថិភាពដោយសារជនជាតិខាល់ដេបានចាកចេញទៅ។

ការបកប្រែរបៀបផ្សេងទៀត: «ប្រាកដណាស់ ដែលជនជាតិខាល់ដេ
បានចាកចេញពីយើង ដូច្នេះយើងនឹងមានសុវត្ថិភាព»។

ពួកគេនឹងក្រោកឡើង

«អស់អ្នករបួស នឹងក្រោកឡើង»

Jeremiah 37:11

នៅគ្រាដែល

«វាបានកើតឡើង»។

ឃ្លានេះប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃសាច់រឿងថ្មី។

ប្រសិនបើភាសារបស់អ្នកមានលក្ខណៈដូចនេះ
អ្នកអាចពិចារណាប្រើពាក្យនេះនៅទីនេះបាន។

ដីដែលជាចំណែកលោក

«ដីមួយដុំ» ឬ «ចំណែកដីខ្លះ»

នៅក្នុងចំណោមប្រជាជនរបស់លោក

«ក្នុងចំណោមសាច់ញាតិរបស់លោក»។

លោកយេរេមាមកពីក្រុងអាណាថោតក្នុងទឹកដីបេនយ៉ាមីន។ (សូមមើល: ១:១)

ទ្វារបេនយ៉ាមីន

នេះជាឈ្មោះនៃទ្វា។

យារីយ៉ា

នេះជាឈ្មោះរបស់មនុស្ស។

សេលេមា

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ៣៦:១៣។

ហាណានា

សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៨:១។

ចូលដៃនឹងពួកខាល់ដេ

«រត់គេចទៅស្រុកខាល់ដេ»

Jeremiah 37:14

ការនេះមិនពិតទេ

«កុហក» ឬ «នោះគឺជាការកុហក»

មិនបានចូលដៃ

«មិនបានរត់គេច»

generated on Wed Sep 10 16:16:32 2025

យារីយ៉ា
សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ៣៧:១១។
ពួកមន្ត្រី
សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ១:១៧។
បានខឹង
«ដែលខឹងខ្លាំង» ឬ «ត្រូវបានគេប្រមាថ»
ស្មៀនយ៉ូណាថាន
«យ៉ូណាថានគឺជាស្មៀន»។ នេះជាឈ្មោះរបស់មនុស្ស។
Jeremiah 37:16
យេរេមាបានដាក់នៅក្នុងគុក បន្ទប់ក្រោមដី
ការបកប្រែរបៀបផ្សេងទៀត:
«ពួកមន្ត្រីបានដាក់លោកយេរេមាទៅក្នុងបន្ទប់នៅក្រោមដី»
ទៅនាំលោកមក
«ទៅនាំយកលោកយេរេមាមក»
ដំណាក់ស្តេច
«ដំណាក់ស្តេចសេដេគា»
ទ្រង់នឹងត្រូវប្រគល់ទៅ
ពាក្យថា «ទ្រង់» សំដៅលើព្រះបាទសេដេគា ហើយនឹងប្រជារាស្ត្ររបស់ទ្រង់។
ត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូន
សូមមើលពីរបៀបបកប្រែឃ្លានេះនៅក្នុងជំពូក ៣២:៣។
Jeremiah 37:18
តើទូលបង្គំបានធ្វើខុសអ្វីនឹងទ្រង់ ហើយនឹងពួកនាម៉ឺន ឬប្រជាជនទាំងនេះ បានជាទ្រង់ដាក់ទូលបង្គំនៅក្នុងគុកដូច្នេះ?
លោកយេរេមាប្រើសំណួរនេះដើម្បីបញ្ជាក់ថា លោកមិនបានធ្វើអ្វីខុសទេ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំមិនបានធ្វើអ្វីខុសនឹងទ្រង់ទេ... នៅក្នុងគុកដូច្នេះ»។
ប្រជាជនទាំងនេះ
ប្រជារាស្ត្រស្រុកយូដា
ដាក់ទូលបង្គំនៅក្នុង
«ទុកទូលបង្គំនៅក្នុង»
តើពួកព្យាការីរបស់ព្រះអង្គនៅទីណា ជាអ្នកដែលថ្លែងទំនាយថ្វាយទ្រង់ ហើយបាននិយាយទៅស្តេចបាប៊ីឡូន នឹងមិនមកទាស់នឹងទ្រង់ ឬទាស់នឹងទឹកដីនេះ?
លោកយេរេមាប្រើសំនួរនេះ ដើម្បីបង្ហាញថាពួកព្យាការីដទៃទៀត និយាយកុហក ប៉ុន្តែលោកមិនបានធ្វើអ្វីខុសទេ ដោយព្រោះលោកបានប្រាប់ការពិត។
ការបកប្រែរបៀបផ្សេងទៀត:
«ព្យាការីរបស់ព្រះអង្គបានថ្លែងទំនាយ...ទាស់នឹងទឹកដីនេះ
ពិតជាខុសប៉ុន្តែឥឡូវនេះ ប្រាកដណាស់ថាទូលបង្គំបានថ្លែងពីការពិត»។
ពួកព្យាការីរបស់ព្រះអង្គ
ពាក្យថា «របស់ព្រះអង្គ»
សំដៅទៅលើស្តេចសេដេគានិងប្រជាជនដទៃទៀតនៃស្រុកយូដា។
នឹងមិនមកទាស់នឹងទ្រង់ ឬទាស់នឹងទឹកដីនេះ?
«នឹងមិនប្រឆាំងជាមួយទ្រង់ ឬប្រឆាំងទឹកដីនេះ»
សូមឲ្យសេចក្តីទូលអង្វរបង្គំបាននៅចំពោះទ្រង់
ចូរប្រៀបធៀបរបៀបបកប្រែ «សេចក្តីទូលអង្វររបស់គេ សម្រាប់សេចក្តីមេត្តាករុណានឹងនៅចំពោះព្រះអម្ចាស់» នៅក្នុងជំពូក ៣៦:៧។
ផ្ទះរបស់ស្មៀនយ៉ូណាថាន
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៣៧:១៤។
Jeremiah 37:21
គុក
«ដែលស្ថិតនៅគ្រប់គ្រងដោយប្រជាជន»
ឲ្យគេយកនំប៉័ងមួយដុំ ពីផ្លូវនៃពួកដុតនំប៉័ងមកឲ្យលោករាល់ៗថ្ងៃ
«អ្នកបំរើស្តេចបានយកនំប៉័ងមួយដុំឲ្យលោក»
ពីផ្លូវនៃពួកដុតនំប៉័ង
«ពីផ្លូវដែលពួកអ្នកដុតនំប៉័ងបានធ្វើការ»

38 [1]លោកសេផាធាជាកូនរបស់លោកម៉ាត់ថាន លោកកេដាលាជាកូនរបស់លោកផាសហ៊ើរ លោកយេហ៊ូកាលជាកូនរបស់លោកសេលេមា និងលោកផាសហ៊ើរជាកូនរបស់លោកម៉ាល់គា បានឮពាក្យដែលលោកយេរេមាធ្លាប់ប្រកាសប្រាប់ប្រជាជនទាំងមូលថា៖ [2]«ព្រះអម្ចាស់មានព្រះបន្ទូលដូចតទៅ: អ្នកដែលនៅក្នុងក្រុងនេះតទៅមុខទៀត នឹងត្រូវស្លាប់ដោយមុខដាវ ដោយទុរ្ភិក្ស និងដោយជំងឺអាសន្នរោគ។ អ្នកដែលចេញទៅចុះចូលនឹងជនជាតិខាល់ដេនឹងបានរួចជីវិត[3]ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលថា ក្រុងនេះពិតជាធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់កងទ័ពស្តេចទឹកដីបាប៊ីឡូន ហើយគេនឹងដណ្តើមយកបានមិនខាន»។
[4]ដូច្នេះ ពួកចៅហ្វាយទាំងប៉ុន្មាន ក៏ទូលស្តេចថា៖ «សូមទ្រង់អនុញ្ញាតឲ្យមនុស្សនេះត្រូវទោសដល់ស្លាប់ចុះ ពីព្រោះវានាំឲ្យពួកទាហានដែលសល់នៅក្នុងទីក្រុង និងពួកបណ្តាជនទាំងឡាយខ្សោយដៃទៅ ដោយពោលពាក្យយ៉ាងនេះដល់គេ ដ្បិតមនុស្សនេះមិនស្វែងរកសេចក្តីល្អ ដល់ជនជាតិនេះទេ គឺឲ្យគេត្រូវអន្តរាយវិញ»។[5]ព្រះបាទសេដេគាមានរាជឱង្ការតបថា៖ «មើល៍! វានៅក្នុងកណ្តាប់ដៃអ្នករាល់គ្នាហើយ ដ្បិតស្តេចមិនអាចនឹងធ្វើអ្វីទាស់ទទឹងនឹងអ្នករាល់គ្នាបានទេ»។
[6]គេក៏ចាប់យកព្យាការីយេរេមាទៅដាក់ក្នុងគុកងងឹតរបស់ម៉ាលគា ជាកូនហាម៉ាលេក ដែលនៅទីលានគុក គេយកខ្សែសម្រូតព្យាការីយេរេមាចុះទៅ រីឯនៅក្នុងគុកងងឹតនោះគ្មានទឹកទេ មានសុទ្ធតែភក់ ហើយព្យាការីយេរេមាក៏ផុងទៅក្នុងភក់នោះ។
[7]លោកអេបេឌ មេលេក ជនជាតិអេត្យូពី ដែលជាមហាតលិកនៅក្នុងវាំង។ គាត់បានឮថា គេដាក់ព្យាការីយេរេមាក្នុងគុកងងឹត។ គ្រានោះ ស្តេចកំពុងគង់នៅត្រង់ទ្វារបេនយ៉ាមីន។[8]អេបេឌ មេលេកក៏ចេញពីព្រះរាជវាំងទៅទូលស្តេចថា៖ [9]«ឱព្រះករុណា ជាអម្ចាស់នៃទូលបង្គំអើយ ក្នុងការទាំងប៉ុន្មានដែលមនុស្សទាំងនេះបានធ្វើដល់ព្យាការីយេរេមា។ ពួកគេបានដាក់លោកឲ្យនៅក្នុងគុកងងឹត ដ្បិតមុខជាលោកនឹងស្លាប់នៅទីនោះ ដោយការអត់ឃ្លានជាមិនខាន ពីព្រោះគ្មានអាហារនៅក្នុងទីក្រុងទេ»។
[10]ដូច្នេះ ស្តេចបង្គាប់ អេបេឌ មេលេក ជាជនជាតិអេត្យូពីថា៖ «ចូរនាំមនុស្សសាមសិបនាក់ពីទីនេះទៅជាមួយអ្នក ហើយយកព្យាការីយេរេមា ចេញពីគុកងងឹតមកក្រែងលោកស្លាប់»។[11]ដូច្នេះ អេបេឌ មេលេកក៏យកមនុស្សទាំងនោះទៅជាមួយ ចូលទៅក្នុងព្រះរាជដំណាក់ គឺទៅកាន់បន្ទប់សម្លៀកបំពាក់នៅក្នុងឃ្លាំង យកក្រណាត់ចាស់ៗ និងសម្លៀកបំពាក់រយ៉ើរយ៉ៃពីកន្លែងនោះ ហើយចងនឹងខ្សែពួរ សម្រូតចុះទៅឲ្យយេរេមានៅក្នុងអណ្តូងងងឹត។
[12]អេបេឌ មេលេក ជាជនជាតិ អេត្យូពី ក៏ប្រាប់ព្យាការី យេរេមាថា៖ «សូមទ្រាប់កំណាត់ចាស់ និងអាវរយ៉ើរយ៉ៃទាំងនេះ នៅក្រោមក្លៀកលោកពីក្រោមខ្សែពួរទៅព្យាការីយេរេមាក៏ធ្វើដូច្នោះ។[13]រួចក្រោយមក ពួកគេយោងទាញព្យាការីយេរេមាឡើងពីគុកងងឹតមក ហើយលោកបាននៅជាប់ក្នុងទីលានគុកចាំយាមវិញ។
[14]ព្រះបាទសេដេគាបានចាត់គេទៅនាំព្យាការីយេរេមា មកនៅត្រង់ទ្វារទីបីក្នុងព្រះវិហារនៃព្រះជាម្ចាស់ ស្តេចមានរាជឱង្ការទៅកាន់ព្យាការីយេរេមាថា៖ «យើងចង់សួរអ្នកនៅការមួយ កុំលាក់នឹងយើងឡើយ»។[15]ព្យាការីយេរេមា ទូលព្រះបាទសេដេគាថា៖ «ប្រសិនបើទូលបង្គំទូលទ្រង់ឲ្យជ្រាប តើទ្រង់មិនសម្លាប់ទូលបង្គំមែនទេ? ហើយបើទូលបង្គំឲ្យជាយោបល់ នោះទ្រង់ក៏មិនព្រមស្តាប់តាមដែរ»។[16]ព្រះបាទសេដេគាស្បថនឹងព្យាការីយេរេមាដោយសម្ងាត់ថា៖ «ដូចជាព្រះជាម្ចាស់មានព្រះជន្មរស់នៅ ដែលព្រះអង្គបានបង្កើតព្រលឹងឲ្យយើង នោះយើងនឹងមិនសម្លាប់ ឬប្រគល់អ្នកទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលរកជីវិតអ្នកឡើយ»។
[17]ព្យាការីយេរេមាទូលព្រះបាទសេដេគាថា៖ «ព្រះជាម្ចាស់ ជាព្រះនៃពិភពទាំងមូល គឺជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះ បើទ្រង់យាងចេញទៅរកអ្នកសឹកនាំរបស់ស្តេចបាប៊ីឡូន នោះទ្រង់នឹងមានព្រះជន្មគង់នៅ ហើយទីក្រុងនេះក៏មិនត្រូវដុតបំផ្លាញដែរ។ គឺទ្រង់ និងពួកវង្សាក៏បានរួចជីវិតដែរ។[18]ប៉ុន្តែ បើទ្រង់មិនព្រមចេញទៅរកពួកអ្នកដឹកនាំរបស់ស្តេចបាប៊ីឡូនទេ ទីក្រុងនេះនឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ។ ពួកគេនឹងដុតចោល ហើយទ្រង់ក៏មិនរួចពីកណ្តាប់ដៃគេដែរ»។
[19]ព្រះបាទសេដេគាមានរាជឱង្ការទៅកាន់ព្យាការីយេរេមាថា៖ «យើងខ្លាចពួកជនជាតិយូដា ដែលចូលដៃខាងពួកខាល់ដេ ហើយក្រែងជនជាតិខាល់ដេប្រគល់យើង ទៅក្នុងកណ្តាប់ដៃគេ ហើយគេប្រព្រឹត្តអាក្រក់មកលើយើង»។
[20]ព្យាការីយេរេមាទូលតបថា៖ «គេមិនប្រគល់ទ្រង់ទៅឲ្យពួកគេទេ។ សូមទ្រង់ស្តាប់តាមព្រះបន្ទូលនៃព្រះជាម្ចាស់ តាមដែលទូលបង្គំទូលដល់ទ្រង់ចុះ នោះទ្រង់នឹងបានសេចក្តីសុខ ហើយនឹងមានព្រះជន្មគង់នៅ។[21]ដ្បិតប្រសិនបើទ្រង់យាងចេញទៅក្រៅនោះគឺជាជម្រកជីវិត ព្រះជាម្ចាស់បានសម្តែងសេចក្តីនេះ ឲ្យទូលបង្គំបានឃើញ។
[22]ស្ត្រីទាំងប៉ុន្មាន ដែលនៅសល់ក្នុងដំណាក់របស់ស្តេចយូដា នឹងត្រូវនាំចេញទៅឯពួកចៅហ្វាយរបស់ស្តេចបាប៊ីឡូន ហើយ ស្ត្រីទាំងនោះនឹងពោលថា ពួកជំនិតរបស់ទ្រង់បានបញ្ឆោតទ្រង់ ហើយក៏ឈ្នះទ្រង់ផង ឥឡូវនេះ ព្រះបាទរបស់ព្រះករុណាផុងជាប់ ទៅក្នុងភក់ហើយ នោះគេងាកចេញពីទ្រង់ទៅ។[23]គេនឹងនាំភរិយា និងព្រះរាជ្យបុត្រ

generated on Wed Sep 10 16:16:32 2025

របស់ព្រះករុណាទាំងប៉ុន្មាន ចេញទៅឯពួកខាល់ដេ ហើយព្រះករុណាផ្ទាល់ក៏មិនរួចពីកណ្តាប់ដៃគេដែរ គឺដៃស្តេចបាប៊ីឡូននឹងចាប់ទ្រង់បាន ហើយទ្រង់នឹងជាហេតុឲ្យទីក្រុងនេះត្រូវភ្លើងឆេះ»។
[24]ព្រះបាទសេដេគាមានរាជឱង្ការទៅកាន់ព្យាការីយេរេមាថា៖ «កុំឲ្យអ្នកណាដឹងពីពាក្យទាំងនេះឡើយ អ្នកមិនត្រូវស្លាប់ទេ។[25]ប៉ុន្តែ បើពួកចៅហ្វាយឮថា យើងបាននិយាយនឹងអ្នក ហើយគេមករកអ្នក ដោយពាក្យថា ចូរប្រាប់យើងពីសេចក្តីដែលអ្នកបានទូលដល់ស្តេច កុំលាក់យើងឲ្យសោះ យើងមិនសម្លាប់អ្នកទេ ហើយប្រាប់យើងពីសេចក្តីដែលស្តេចមានព្រះបន្ទូលនឹងអ្នកដែរ។[26]អ្នកត្រូវប្រាប់ដល់គេថា ខ្ញុំគ្រាន់តែទូលអង្វរស្តេច សូមកុំឲ្យខ្ញុំត្រូវវិលត្រឡប់ទៅក្នុងផ្ទះយ៉ូណាថាន ឲ្យស្លាប់នៅទីនោះប៉ុណ្ណោះទេ»។
[27]បន្ទាប់មក ពួកចៅហ្វាយទាំងប៉ុន្មាន ក៏មកឯយេរេមាសួរយ៉ាងនោះមែន ហើយលោកប្រាប់គេតាមគ្រប់ទាំងពាក្យដែលស្តេចបានបង្គាប់។ ដូច្នេះ គេក៏លែងនិយាយនឹងលោកទៅ ពីព្រោះការនោះមិនបានបើកឲ្យគេឃើញទេ។[28]ដូច្នេះ ព្យាការីយេរេមាក៏នៅជាប់ក្នុងទីលានគុក ដរាបដល់ថ្ងៃដែលគេចាប់យកក្រុងយេរូសាឡិមបាន។

Jeremiah 38:1
សេផាធា...ម៉ាល់គា
ឈ្មោះក្នុងបញ្ជីនេះសំដៅលើមនុស្ស។
នឹងត្រូវស្លាប់ដោយមុខដាវ ដោយទុរ្ភិក្ស និងជំងឺអាសន្នរោគ។
«មុខដាវ ទុរ្ភិក្ស និងជំងឺអាសន្នរោគនឹងសម្លាប់ពួកគេ»
អ្នកដែលចេញទៅចុះចូលនឹងជនជាតិខាល់ដេនឹងបានរួចជីវិត
សូមមើលពីរបៀបបកប្រែឃ្លាស្រដៀងគ្នានេះនៅក្នុងជំពូក ២១:៨។
ទីក្រុងនឹងប្រគល់ទៅក្នុងកណ្តាប់ដៃកងទ័ពស្តេចនៃបាប៊ីឡូន
«យើងនឹងអោយកងទ័ពរបស់ស្តេចស្រុកបាប៊ីឡូនលើកទ័ពមកវាយយកក្រុងយេរូសាឡិម»
គេនឹងដណ្តើមយកបានមិនខាន
«ទាហានរបស់គេចាប់យកវា»
Jeremiah 38:4
ដ្បិត ក្នុងរបៀបនេះគាត់នឹងនាំឲ្យពួកទាហានចុះខ្សោយដៃក្នុងការចម្បាំង
របស់ទាហានដែលនៅសល់នៅក្នុងទីក្រុង ហើយដៃរបស់ពួកបណ្តាជនផងដែរ
ការបកប្រែរបៀបផ្សេងទៀត: «គាត់ធ្វើឲ្យ ទាហាន
និងប្រជារាស្ត្រទាំងអស់ក្នុងទីក្រុងបាត់បង់ភាពក្លាហាន»
ដ្បិត មនុស្សមិនបានធ្វើរកសេចក្តីសុខសាន្ត ដល់ប្រជាជនទេ តែគឺ មហន្តរាយវិញ
ការបកប្រែរបៀបផ្សេងទៀត: «លោកយេរេមាមិនធ្វើការ ដើម្បីជួយប្រជារាស្ត្រនេះទេ
ប៉ុន្តែគាត់ធ្វើបាបប្រជាជននេះវិញ»
មើល៍! វានៅក្នុងកណ្តាប់ដៃអ្នកហើយ
ពាក្យថា «មើល៍» នៅទីនេះបន្ថែមការបញ្ជាក់លើអ្វីដែលមាននៅខាងក្រោយ។
ការបកប្រែរបៀបផ្សេងទៀត: «មើល៍ អ្នកមានអំណាចលើវា»
Jeremiah 38:6
ទៅដាក់ក្នុងគុកងងឹត
«គុកងងឹត» គឺជារណ្តៅជ្រៅមួយនៅក្នុងដីដែលត្រូវបានប្រើសម្រាប់ប្រមូល
និងរក្សាទុកទឹកភ្លៀង។ ការបកប្រែរបៀបផ្សេងទៀត: «ដាក់លោកចូលទៅក្នុងគុក
ងងឹត»
គេយកខ្សែសម្រួតព្យាការីយេរេមាចុះទៅ
នេះប្រាប់ពីរបៀបដែលពួកគេ «បានបោះ» លោកចូលក្នុងគុកងងឹត។
Jeremiah 38:7
លោកអេបេឌ មេលេក ជនជាតិអេត្យូពី
នេះជាឈ្មោះមនុស្សនៃស្រុកគូស។
គ្រានោះ ស្តេច
ពាក្យថា «គ្រានោះ» គឺជាការកាត់ផ្តាច់នៅក្នុងដំណើររឿងសាច់
ដែលអ្នកពោលបង្ហាញពីព័ត៌មានពីអ្វីដែលស្តេចបានប្រព្រឹត្ត។
គង់នៅត្រង់ទ្វារ បេនយ៉ាមីន
សេដេគាបានបើកសវនាការ និងវិនិច្ឆ័យរឿងក្តី។
នៅត្រង់ទ្វារ បេនយ៉ាមីន
នេះជាច្រកចូលទីក្រុងយេរូសាឡិម ដែលមនុស្សដាក់ឈ្មោះថាបេនយ៉ាមីន
ជាកូនប្រុសរបស់យ៉ាកុប។
Jeremiah 38:10
មនុស្សសាមសិបនាក់
ការបកប្រែរបៀបផ្សេងទៀត: «៣០នាក់»
នោះ ហើយចងនឹងខ្សែពួរ សម្រួតចុះទៅដល់
«ពួកគេបានខ្សែពួរ ដើម្បីចុះទៅ»
Jeremiah 38:12
ពីក្រោមខ្សែពួរ
«នៅជិតនឹងខ្សែពួរ»
ពួកគេយោងទាញលោកយេរេមាឡើង
ពាក្យថា «ពួកគេ» នៅទីនេះសំដៅលើមនុស្សសាមសិបនាក់
ដែលនៅជាមួយអេបេឌមេលេក។
Jeremiah 38:14
ប្រសិនបើទូលបង្គំឆ្លើយនឹងទ្រង់ តើទ្រង់មិនសម្លាប់ទូលបង្គំទេ?
លោកយេរេមាសួរសំណួរនេះ ដើម្បីបង្ហាញពីជំនឿរបស់លោកថា
ស្តេចនឹងសម្លាប់លោក ប្រសិនបើលោកឆ្លើយដោយស្មោះត្រង់នោះ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើទូលបង្គំ ថ្លែងប្រាប់ទ្រង់ពីការពិត
ទ្រង់នឹងសម្លាប់ទូលបង្គំ»
ដូចជាព្រះជាម្ចាស់មានព្រះជន្មរស់គង់នៅ ព្រះអង្គដែលបានបង្កើតយើង
ស្តេចមានបន្ទូលដូច្នេះ ដើម្បីបញ្ជាក់ថាអ្វីដែលទ្រង់បានថ្លែងនោះគឺជាការពិត។
ការបកប្រែរបៀបផ្សេងទៀត:
«ដូចជាការពិតដែលថាព្រះអម្ចាស់ដែលបានបង្កើតយើងឲ្យរស់នៅ
នោះគឺជាការពិត»
យើងនឹងមិនសម្លាប់ទេ ឬប្រគល់អ្នកទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលរកប្រមាញជីវិតអ្នកឡើយ
ពាក្យថា «កណ្តាប់ដៃ» សំដៅទៅលើការគ្រប់គ្រងឬអំណាចរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងមិន...អនុញ្ញាតឲ្យមនុស្សទាំងនោះចាប់អ្នកឡើយ»
ដែលរកប្រមាញជីវិតអ្នកឡើយ
ការបកប្រែរបៀបផ្សេងទៀត: «ដែលព្យាយាមសម្លាប់អ្នក»
Jeremiah 38:17
ព្រះជាម្ចាស់របស់អ៊ីស្រាអែល
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់របស់ប្រជារាស្ត្រអ៊ីស្រាអែល»
ទីក្រុងនេះក៏មិនត្រូវដុតដែរ
ការបកប្រែរបៀបផ្សេងទៀត: «កងទ័ពបាប៊ីឡូននឹងមិនដុតបំផ្លាញទីក្រុងនេះទេ»
ទីក្រុងនេះនឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងអនុញ្ញាតអោយជនជាតិខាល់ដេដណ្តើមយកទីក្រុងនេះ»
ទ្រង់ក៏មិនរួចពីកណ្តាប់ដៃគេដែរ
ការបកប្រែរបៀបផ្សេងទៀត: «ទ្រង់នឹងមិនគេចផុតពីអំណាចរបស់ពួកគេទេ»
Jeremiah 38:19
យើងនឹងអាចប្រគល់ ទៅក្នុងកណ្តាប់ដៃរបស់ពួកគេ
ពាក្យថា «កណ្តាប់ដៃ» នៅទីនេះមានន័យថា «ការគ្រប់គ្រង» ឬ «អំណាច»។
ការបកប្រែរបៀបផ្សេងទៀត: «ជនជាតិខាល់ដេឲ្យខ្ញុំដល់ពួកយូដា»
ហើយគេប្រព្រឹត្តអាក្រក់មកលើយើងផង
ពាក្យថា «គេ» សំដៅលើពួកយូដា។
Jeremiah 38:20
ពួកគេនឹងមិនប្រគល់ទ្រង់ទៅឲ្យពួកគេទេ
«ពួកខាល់ដេនឹងមិនប្រគល់ទ្រង់ទៅពួកយូដាឡើយ»។ ពាក្យថា «ទ្រង់»
នៅទីនេះសំដៅទៅលើព្រះបាទសេដេគា។
នេះគឺអ្វីដែលព្រះជាម្ចាស់បានសម្តែងដល់ទូលបង្គំបានឃើញ
ពាក្យថា «នេះ» សំដៅលើអ្វីដែលលោកយេរេមានឹងថ្លែងបន្ទាប់។
Jeremiah 38:22
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងជាមួយព្រះបាទសេដេគា។
ស្ត្រីទាំងអស់ ដែលនៅសល់ក្នុងដំណាក់ទ្រង់ ស្តេចនៃយូដា នឹងត្រូវនាំចេញទៅឲ្យពួកមន្ត្រីរបស់ស្តេច
បាប៊ីឡូន
ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពនឹងនាំស្ត្រីទាំងអស់ដែលនៅសេសសល់...ទៅជួបមន្ត្រីរបស់ស្តេចស្រុកបាប៊ីឡូន»។
ព្រះបាទរបស់ព្រះករុណាផុងជាប់ ទៅក្នុងភក់ហើយ
នេះមានន័យថាស្តេចស្ថិតក្នុងស្ថានភាពលំបាកឬគ្មានទីពឹង។
ដ្បិតភរិយា និងព្រះរាជបុត្ររបស់ព្រះករុណាទាំងអស់ នឹងនាំទៅឲ្យពួកខាល់ដេ

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «កងទ័ពនឹងនាំភិរិយា និងព្រះរាជ្យបុត្រ របស់ទ្រង់ចេញទៅស្រុកខាល់ដេ»
ហើយព្រះករុណាផ្ទាល់ក៏មិនអាចគេចរួចពីកណ្តាប់ដៃគេដែរ
ការបកប្រែរបៀបផ្សេងទៀត: «នឹងមិនអាចគេចផុតពីអំណាចរបស់គេឡើយ»
ទ្រង់នឹងត្រូវចាប់ដោយដៃនៃស្តេចបាប៊ីឡូន ហើយទីក្រុងនេះត្រូវដុត
ពាក្យថា «កណ្តាប់ដៃ» នៅទីនេះសំដៅលើសិទ្ធអំណាចរបស់ស្តេច
ឬកងទ័ពរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពរបស់ស្តេចស្រុកបាប៊ីឡូននឹងចាប់ទ្រង់ ហើយនឹងដុតបំផ្លាញទីក្រុង»

Jeremiah 38:24
យ៉ូណាថាន
សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុង ៣៧:១៤។
Jeremiah 38:27
ដរាបដល់ថ្ងៃដែលទីក្រុងយេរូសាឡិមត្រូវបានចាប់
ការបកប្រែរបៀបផ្សេងទៀត:
«រហូតដល់ថ្ងៃពេលដែលកងទ័ពបាប៊ីឡូនដណ្តើមយកបានក្រុងយេរូសាឡិម»

---

39 [1]នៅខែទីដប់ ក្នុងឆ្នាំទីប្រាំបួន នៃរជ្ជកាលព្រះបាទសេដេគា ជាស្តេចទឹកដីយូដា ព្រះចៅនេប៊ូក្នេសាជាស្តេចទឹកដីបាប៊ីឡូន លើកកងទ័ពទាំងមូលមកដល់ក្រុងយេរូសាឡិម ហើយឡោមព័ទ្ធទីក្រុង។[2]នៅខែទីបួន ថ្ងៃទីប្រាំបួន ក្នុងឆ្នាំទីដប់មួយ នៃរជ្ជកាលព្រះបាទសេដេគាកងទ័ពបាប៊ីឡូន បានទម្លុះកំពែងក្រុង។[3]ពេលនោះមេទ័ពរបស់ស្តេចទឹកដីបាប៊ីឡូន ដណ្តើមយកបានទ្វារកណ្តាល។ មេទ័ពទាំងនោះ គឺលោកនើកាល-សារេស៊ើរ លោកសាំការ-នេប៊ូ លោកសាសេគិម ជាមេលើពួកមហាតលិក លោកមេបញ្ជាការនើកាល-សារេស៊ើរ និងមេទ័ពឯទៀតៗរបស់ស្តេចទឹកដីបាប៊ីឡូន។
[4]រាបានកើតឡើងក្នុងកាលព្រះបាទសេដេគា ជាស្តេចយូដា និងពួកទាហានទាំងប៉ុន្មានបានឃើញគេ។ ហើយពួកគេក៏រត់ចេញពីទីក្រុងទៅទាំងយប់ តាមផ្លូវសួនច្បាររបស់ស្តេច ដែលចេញតាមទ្វារនៅកណ្តាលកំផែងទាំងពីរ។ ស្តេចចេញតម្រង់ទៅឯទឹកដីវាល។[5]ប៉ុន្តែ ពលទ័ពជនជាតិខាល់ដេ ក៏ដេញតាមព្រះបាទសេដេគាទាន់នៅត្រង់វាលយេរីខូរ។ កាលពួកគេចាប់ទ្រង់បានហើយ ក៏នាំទៅព្រះបាទនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ត្រង់រីបឡា នៅទឹកដីហាម៉ាត ហើយនេប៊ូក្នេសាក៏កាត់ទោសព្រះអង្គ។
[6]ស្តេចបាប៊ីឡូនសម្លាប់ពួកបុត្រារបស់ព្រះបាទសេដេគា នៅចំពោះព្រះនេត្ររបស់ព្រះអង្គត្រង់រីបឡានោះ ក៏សម្លាប់ពួកអ្នកមានត្រកូលខ្ពស់ទាំងប៉ុន្មាននៃទឹកដីយូដាដែរ។
[7]ហើយចាក់បង្ខូចព្រះនេត្ររបស់ព្រះបាទសេដេគា រួចដាក់ច្រវាក់នាំទៅឯទឹកដីបាប៊ីឡូន។
[8]ពួកខាល់ដេក៏ដុតព្រះរាជវាំង និងផ្ទះទាំងប៉ុន្មានរបស់បណ្តាជនចោល ព្រមទាំងរំលំកំផែងក្រុងយេរូសាឡិមផង។[9]បន្ទាប់មក នេប៊ូសារ៉ាដាន ជាមេទ័ពធំ លោកដឹកនាំសំណល់ពួកបណ្តាជនដែលនៅក្នុងទីក្រុង។ ហើយក៏រួមទាំងពួកអ្នកដែលចូលខាងលោក ព្រមទាំងសំណល់នៃប្រជាជនទាំងឡាយទៅជាឈ្លើយ ដល់ទឹកដីបាប៊ីឡូន។
[10]ប៉ុន្តែ នេប៊ូសារ៉ាដាន ជាមេទ័ពធំ លោកទុកពួកអ្នកក្រីក្រក្នុងបណ្តាជន ជាពួកអ្នកដែលគ្មានអ្វីសោះ ឲ្យនៅក្នុងទឹកដីយូដា។ ហើយនៅគ្រានោះ ពួកគេក៏ឲ្យដំណាំទំពាំងបាយជូរ និងចម្ការគឺនៅក្នុងថ្ងៃតែមួយ។
[11]ព្រះបាទនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន បានបង្គាប់នេប៊ូសារ៉ាដាន ជាមេទ័ពធំ ពីដំណើរព្យាការីយេរេមាថា៖[12]«ចូរទំនុកបម្រុងព្យាការីយេរេមាឲ្យបានល្អផង កុំធ្វើបាបលោកឡើយ គឺត្រូវប្រព្រឹត្តនឹងលោកតាមដែលលោកប្រាប់ចុះ»។[13]ដូច្នេះ នេប៊ូសារ៉ាដាន ជាមេទ័ពធំ ហើយនេប៊ូសាសបាន រ៉ាប-សារីស នើកាល-សារេស៊ើរ រ៉ាប-ម៉ាក់ ព្រមទាំងចៅហ្វាយធំៗទាំងអស់របស់ស្តេចបាប៊ីឡូន។[14]ក៏ចាត់គេឲ្យទៅយកព្យាការីយេរេមាពីទីលានគុក មកប្រគល់ដល់កេដាលា ជាកូនអ័ហ៊ីកាម ដែលជាកូនសាផាន ឲ្យនាំលោកទៅផ្ទះវិញ ដូច្នេះ លោកយេរេមាបានរស់នៅក្នុងចំណោមប្រជាជនទាំងនោះ។
[15]ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានមកដល់ព្យាការីយេរេមា ពេលលោកជាប់នៅក្នុងទីលានគុកនៅឡើយ នោះថា៖[16]«ចូរទៅប្រាប់អេបេឌ-មេលេកជាជនជាតិអេត្យូពី ដូច្នេះគឺថាព្រះជាម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា មើល៍! យើងនឹងនាំអស់ទាំងពាក្យរបស់យើងមកលើក្រុងនេះ ឲ្យបានសេចក្តីអាក្រក់ មិនមែនជាសេចក្តីល្អទេ។ ពាក្យទាំងនោះនឹងបានសម្រេចនៅមុខអ្នកក្នុងថ្ងៃនោះ។
[17]ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «យើងនឹងជួយអ្នកឲ្យរួចនៅថ្ងៃនោះ ហើយអ្នកមិនត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកមនុស្សនោះ ដែលអ្នកខ្លាចឡើយ។[18]ដ្បិតយើងនឹងជួយសង្គ្រោះអ្នកពិតប្រាកដ អ្នកមិនត្រូវដួលដោយដាវឡើយ គឺនឹងបានរួចជីវិត ពីព្រោះអ្នកបានយកយើងជាទីទុកចិត្ត នេះជាព្រះបន្ទូលនៃព្រះជាម្ចាស់»។

Jeremiah 39:1
នៅក្នុងឆ្នាំទីប្រាំបួន នៃខែទីដប់រជ្ជកាលព្រះបាទសេដេគា ជាស្តេចទឹកដីយូដា
នេះជាខែទីដប់ នៃប្រតិទិនហេប្រឺ។ នេះស្ថិតនៅកំឡុងពេលចុងខែធ្នូ
និងដើមខែមករានៅក្នុងប្រតិទិនលោកខាងលិច។ ការបកប្រែរបៀបផ្សេងទៀត:
«នៅខែទីដប់នៃឆ្នាំទីប្រាំបួននៃរជ្ជកាលព្រះបាទសេដេគាជាស្តេចស្រុកយូដា»។
ទីប្រាំបួន...ទីដប់...ទីដប់មួយ...ទីបួន
សូមមើល:
នៅក្នុងឆ្នាំទីដប់មួយ នៃខែទីបួននៃរជ្ជកាលព្រះបាទសេដេគា ក្នុងថ្ងៃទីប្រាំបួននៃខែនោះ
នេះជាខែទីបួននៃប្រតិទិនហេប្រឺ។ ថ្ងៃទី១១
គឺជិតដល់ដើមខែកក្កដាលើប្រតិទិនលោកខាងលិច។ ការបកប្រែរបៀបផ្សេងទៀត:
«នៅថ្ងៃទីប្រាំបួន នៃខែទីបួន និងនៃឆ្នាំទីដប់មួយនៃរជ្ជកាលព្រះបាទសេដេគា»។
លោកនើកាល សារេស៊ើរ លោកសាំការ នេប៊ូ ហើយលោកសាសេគិម
ទាំងនេះជាឈ្មោះរបស់មនុស្ស។
នៅកណ្តាលទ្វារ
«នៅចំកណ្តាលច្រកចូលនៃទីក្រុង»។ នេះជាធម្មតា
ដែលពួកមេដឹកនាំអង្គុយនៅមាត់ទ្វារក្រុង ដើម្បីពិភាក្សារឿងសំខាន់ៗ»។
Jeremiah 39:4
ពួកគេក៏រត់ចេញពីទីក្រុងទៅទាំងយប់ តាមផ្លូវសួនច្បាររបស់ស្តេច
«ពួកគេបានរត់គេចពីទីក្រុងនៅពេលយប់
ដោយចេញទៅតាមផ្លូវនៅក្នុងសួនច្បាររបស់ស្តេច»
នៅតាមវាលទំនាបទន្លេយ័រដាន់
នេះជាដីរាបស្មើនៅចុងផ្នែកត្បូងនៃជ្រលងភ្នំ។
ត្រង់រីបឡា ក្នុងទឹកដីហាម៉ាត
រីបឡាជាក្រុងមួយក្នុងទឹកដីហាម៉ាត់។ ហើយស្ថិតនៅក្នុងប្រទេសស៊ីរី។
ដេញតាមពួកគេ ហើយតាមទាន់
«ដេញតាមនិងចាប់»
បានកាត់ទោសទ្រង់
«ដែលសម្រេចចិត្តពីការដាក់ទោសទ្រង់»
Jeremiah 39:6
នៅចំពោះព្រះនេត្ររបស់ព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត: «ដែលទ្រង់ទតឃើញពួកគេធ្វើការនោះ»
ចាក់បង្ខូចព្រះនេត្ររបស់ព្រះបាទសេដេគា
«ពួកទាហានស្តេចបានធ្វើឲ្យព្រះបាទសេដេគាពិការភ្នែក» ឬ
«ពួកទាហានស្តេចបានធ្វើឲ្យព្រះបាទសេដេគាជាមនុស្សខ្វាក់»។
Jeremiah 39:8
នេប៊ូសារ៉ាដាន
នេះជាឈ្មោះរបស់មនុស្ស។
អង្គរក្សរបស់ស្តេច
«អង្គរក្សរបស់ស្តេចនេប៊ូក្នេសា»
ពួកបណ្តាជនដទៃទៀតដែលជាអ្នកនៅសល់ក្នុងទីក្រុង
«ពួកមនុស្សដែលនៅសល់ក្នុងទីក្រុង»
Jeremiah 39:11
នេប៊ូក្នេសា...កេដាលា...អ័ហ៊ីកាម...សាផាន
ទាំងនេះជាឈ្មោះរបស់មនុស្ស។
បានចាត់មនុស្សឲ្យចេញទៅ
«បានចាត់មនុស្សឲ្យទៅចាប់លោកយេរេមា»
ក្នុងចំណោមប្រជាជនវិញ
«ក្នុងចំណោមមនុស្សដែលនៅសេសសល់ពីស្រុកយូដា»
Jeremiah 39:15
ព័ត៌មានទូទៅ:
រឿងនេះបានកើតឡើងមុនព្រឹត្តិការណ៍នានានៅក្នុងផ្នែកដំបូងនៃជំពូក។
គ្រានោះ

generated on Wed Sep 10 16:16:32 2025

នេះសំគាល់ផ្នែកថ្មីនៃសាច់រឿង។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានមកដល់យេរេមា ពេលលោកជាប់នៅក្នុងទីលានគុកនៅទីចាំយាម
ប្រាប់ថា
«ព្រះអម្ចាស់មានព្រះបន្ទូលទៅលោកយេរេមា។ លោកប្រាប់ថា»
អេបេឌ មេលេកជាជនជាតិ អេត្យូពី
សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ៣៨:៧។
យើងនឹងនាំអស់ទាំងពាក្យរបស់យើងមកលើទីក្រុងនេះ នូវមហន្តរាយ ហើយមិនមែនជាសេចក្ដីល្អទេ
«យើងនឹងនាំមកនូវមហន្តរាយមកលើទីក្រុងនេះ
ដូចដែលយើងធ្លាប់មានបន្ទូលថាយើងនឹង»
ពាក្យទាំងនោះនឹងបានសម្រេចពិតប្រាកដនៅមុខលោកក្នុងថ្ងៃនោះ
«ត្បិតអ្នករាល់គ្នានឹងបានឃើញការនោះនឹងបានកើតឡើងក្នុងថ្ងៃនោះ»
Jeremiah 39:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅលោកយេរេមា។
នៅថ្ងៃនោះ
នេះសំដៅលើថ្ងៃដែលពួកបាប៊ីឡូនបានវាយកម្ទេចជញ្ជាំងក្រុងយេរូសាឡិមដើម្បីបំផ្លាញទីក្រុងនេះ។
នេះជាព្រះមន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
អ្នកមិនត្រូវប្រគល់ទៅក្នុងកណ្ដាប់ដៃនៃពួកមនុស្ស ដែលអ្នកខ្លាចឡើយ
ពាក្យថា «កណ្ដាប់ដៃ» សំដៅទៅលើអំណាច ឬការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «ពួកមនុស្សដែលអ្នកខ្លាច នឹងមិនធ្វើទុក្ខអ្នកទៀតទេ»
អ្នកមិនត្រូវដួលដោយដាវទេ
ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្នកណាអាចសម្លាប់អ្នកដោយដាវពួកគេឡើយ»
អ្នកនឹងបានគេចចេញរួចជីវិត ពីព្រោះអ្នកបានយកទុកចិត្តក្នុងយើង
«ត្បិតការទុកចិត្តយើង អ្នកនឹងទទួលបានរង្វាន់ដោយរួចផុតពីការស្លាប់»

---

40 [1]ព្រះជាម្ចាស់មានព្រះបន្ទូល មកកាន់ព្យាការីយេរេមា ក្រោយដែលនេប៊ូសារ៉ាដាន ជាមេទ័ពធំ បានលែងលោកនៅត្រង់រ៉ាម៉ា ក្នុងកាលដែលគេបានចាប់លោក ដាក់
ច្រវាក់ ជាមួយពួកក្រុងយេរូសាឡិម និងពួកទឹកដីយូដាទាំងប៉ុន្មាន ដែលគេនាំទៅជាឈ្លើយនៅទឹកដីបាប៊ីឡូននោះ។[2]មេទ័ពធំយកព្យាការីយេរេមាមកនិយាយថា៖
«ព្រះជាម្ចាស់ជាព្រះរបស់អ្នក ព្រះអង្គបានប្រកាសសេចក្ដីអាក្រក់នេះទម្លាក់លើទីនេះ។
[3]ហើយព្រះជាម្ចាស់បាននាំការនេះមក ព្រមទាំងសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គ ពីព្រោះអ្នករាល់គ្នាបានធ្វើបាបនឹងព្រះអង្គ ហើយមិនបានស្ដាប់តាមព្រះបន្ទូលរបស់
ព្រះអង្គឡើយ ហេតុនោះបានជាការនេះកើតដល់អ្នករាល់គ្នា។[4]ដូច្នេះ មើល៍! នៅថ្ងៃនេះ ខ្ញុំដោះច្រវាក់ចេញពីដៃអ្នក។ ប្រសិនបើអ្នកចូលចិត្តទៅទឹកដីបាប៊ីឡូនជាមួយខ្ញុំ ក៏
ចូលមកចុះ ខ្ញុំនឹងទំនុកបម្រុងអ្នកដោយល្អ តែបើមិនពេញចិត្តទៅឯទឹកដីបាប៊ីឡូនជាមួយខ្ញុំទេ នោះតាមតែចិត្តចុះ ទឹកដីទាំងមូលនៅមុខអ្នកហើយ។ នៅកន្លែងណាដែល
អ្នកគិតថាស្រួល ហើយគួរឲ្យអ្នកទៅ អ្នកទៅចុះ»។
[5]ពេលលោកយេរេមាមិនទាន់ឆ្លើយ លោកនេប៊ូសារ៉ាដានក៏ពោលទៀតថា៖ «សុំលោកវិលទៅជួបនឹងលោកកេដាលា ជាកូនរបស់លោកអហ៊ីកាម និងកូនលោកសាផាន
ដែលព្រះចៅក្រុងបាប៊ីឡូនបានតែងតាំងឲ្យគ្រប់គ្រងទឹកដីយូដានោះ។ សូមស្នាក់នៅជាមួយគាត់ ក្នុងចំណោមប្រជាជនទៅ ឬមួយលោកចង់ទៅកន្លែងណាផ្សេងទៀត តាម
ចិត្តលោកប្រាថ្នា»។ លោករាជប្រតិភូបានប្រគល់ស្បៀង និងជំនូនខ្លះទៀត ជូនលោក ហើយប្រាប់ឲ្យលោកចេញទៅ។[6]លោកយេរេមាក៏ទៅជួបលោកកេដាលា ជាកូនរបស់
លោកអហ៊ីកាម នៅក្រុងមីសប៉ា រួចស្នាក់នៅជាមួយគាត់ ក្នុងចំណោមប្រជាជនដែលរស់នៅក្នុងទឹកដីនោះ។
[7]ពេលនោះពួកមេទ័ពទាំងប៉ុន្មាន ដែលពួននៅទឹកដីស្រែចម្ការ ព្រមទាំងពួកទាហានរបស់គេ កាលបានឮថា ស្ដេចបាប៊ីឡូន បានតាំងកេដាលា ជាកូនអ័ហ៊ីកាម ឡើងជា
ចៅហ្វាយលើទឹកដី ហើយបានផ្ទុកផ្ដាក់មនុស្សទាំងប្រុសទាំងស្រី និងកូនក្មេងជាអ្នកក្រីក្របំផុតក្នុងទឹកដី ដែលមិនបានចាប់ទៅជាឈ្លើយ នៅទឹកដីបាប៊ីឡូន ឲ្យនៅក្នុង
អំណាចលោក។[8]ដូច្នេះ ពួកគេក៏មកឯកេដាលា ត្រង់មីសប៉ាគឺមានអ៊ីសម៉ាអែល ជាកូននេថានា យ៉ូហាណាន និងយ៉ូណាថាន ជាកូនការា សេរ៉ាយ៉ា ជាកូនថានហ៊ូមែត និង
ពួកកូនរបស់អេផាយ ពីទឹកដីនថូផា ហើយយេសានា ជាកូនរបស់ម្នាក់នៅម៉ាកាធី ព្រមទាំងពួកទាហានរបស់គេផង។
[9]កេដាលា ជាកូនអ័ហ៊ីកាម និងជាចៅសាផាន ក៏ស្បថនឹងមេទ័ពទាំងនោះ និងទាហានរបស់គេ ដោយពាក្យថា៖ «កុំខ្លាចនឹងបម្រើពួកខាល់ដេឡើយ ចូរអាស្រ័យនៅក្នុង
ទឹកដីនេះ ហើយបម្រើដល់ស្ដេចបាប៊ីឡូនចុះ នោះអ្នករាល់គ្នានឹងបានសេចក្ដីសុខ។[10]មើល៍! ខ្ញុំនឹងនៅត្រង់មីសប៉ា ដើម្បីធ្វើជាអ្នកដំណាង នៅមុខពួកខាល់ដេណាដែលមក
រកយើងរាល់គ្នា។ ដូច្នេះ ចូរទៅប្រមូលផលទំពាំងបាយជូរ និងផលរដូវក្ដៅ ព្រមទាំងប្រេងទុកដាក់ក្នុងភាជនៈរបស់អ្នករាល់គ្នាទៅ។ ហើយរស់នៅក្នុងទីក្រុងទាំងនោះ ដែល
អ្នករាល់គ្នាចាប់បានទៅ»។
[11]មួយទៀត ពួកយូដាទាំងប៉ុន្មាន ដែលនៅទឹកដីម៉ូអាប់ និងនៅកណ្ដាលពួកកូនចៅអាំម៉ូន និងនៅទឹកដីអេដុម ព្រមទាំងនៅគ្រប់ទាំងទឹកដីផ្សេងៗទៀតផង កាលបានឮថា
ស្ដេចបាប៊ីឡូនបានទុកសំណល់ពួកយូដាឲ្យនៅសល់ ហើយបានតាំងកេដាលា ជាកូនអ័ហ៊ីកាម និងជាចៅសាផាន ឲ្យត្រួតត្រាលើគេ។[12]ពួកយូដាទាំងនោះ ក៏ចេញពីគ្រប់ទី
កន្លែងដែលគេត្រូវបណ្ដេញទៅវិលមកក្នុងទឹកដីយូដា ជួបកេដាលាត្រង់មីសប៉ា។ ហើយគេក៏ប្រមូលផលទំពាំងបាយជូរ និងផលរដូវក្ដៅជាច្រើន។
[13]យ៉ូហាណាន ជាកូនការា និងពួកមេទ័ពទាំងប៉ុន្មាន ដែលពួននៅទឹកដីស្រែចម្ការ គេក៏មកជួបកេដាលានៅត្រង់មីសប៉ា។[14]គេជម្រាបលោកថា៖ «តើលោកជ្រាបឬទេថា
ប្អាលីស ជាស្ដេចពួកកូនចៅអាំម៉ូន បានចាត់អ៊ីសម៉ាអែល ជាកូននេថានា ឲ្យមកសម្លាប់លោក?» តែកេដាលា ជាកូនអ័ហ៊ីកាមមិនជឿគេទេ។
[15]ដូច្នេះ យ៉ូហាណាន ជាកូនការា ក៏ពិគ្រោះនឹងកេដាលា ដោយសម្ងាត់នៅត្រង់មីសប៉ាថា៖ «សូមអនុញ្ញាតឲ្យខ្ញុំទៅចុះ ខ្ញុំនឹងសម្លាប់អ៊ីសម៉ាអែល ជាកូននេថានា ឥតឲ្យអ្នក
ណាដឹងឡើយ តើទុកឲ្យវាមកសម្លាប់លោកធ្វើអ្វី? ហេតុអ្វីពួកយូដាទាំងប៉ុន្មាន ដែលបានមូលមកឯលោក គេនឹងត្រូវខ្ចាត់ខ្ចាយទៅ ហើយសំណល់ពួកយូដានឹងត្រូវ
វិនាស?»[16]ប៉ុន្តែ កេដាលា ជាកូនអ័ហ៊ីកាម ប្រាប់ដល់យ៉ូហាណាន ជាកូនការាថា៖ «កុំធ្វើដូច្នោះឡើយ ដ្បិតអ្នកនិយាយកុហកអំពីអ៊ីសម៉ាអែលទេ»។

Jeremiah 40:1
ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការីយេរេមា
«នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់មកលោកយេរេមា»
នេប៊ូសារ៉ាដាន ជាមេទ័ព នៃកងអង្គរក្សរបស់ស្ដេច
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៣០:៨។
កាលលោកឃើញយេរេមា ជាប់ដោយច្រវាក់
ការបកប្រែរបៀបផ្សេងទៀត:
«នោះជាកន្លែងដែលពួកកងទ័ពបាប៊ីឡូនបានចាប់លោកយេរេមាហើយដាក់ច្រវាក់លោក
ដែលបាននាំទៅជាឈ្លើយនៅបាប៊ីឡូននោះ
ការបកប្រែរបៀបផ្សេងទៀត:
«ដែលជាពួកកងទ័ពដែលត្រូវបានបញ្ជូនទៅសនៅស្រុកបាប៊ីឡូន»
Jeremiah 40:3
ព្រះជាម្ចាស់បាននាំការនេះមក។ ព្រះជាម្ចាស់ធ្វើសម្រេចតាមព្រះបន្ទូលរបស់ព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានសម្រេចតាមអ្វីដែលទ្រង់មានបន្ទូលប្រាប់អ្នក»
ពីព្រោះអ្នករាល់គ្នាបានធ្វើបាបទាស់នឹងព្រះអង្គ ហើយមិនបានស្ដាប់តាមបង្គាប់សម្លេងព្រះអង្គ
ការបកប្រែរបៀបផ្សេងទៀត:
«ព្រោះអ្នករាល់គ្នាជាជនជាតិយូដាបានធ្វើបាបទាស់នឹងព្រះអម្ចាស់ហើយមិនស្ដាប់តាមបទបញ្ញត្តិរបស់ព្រ
ការនេះកើតដល់
«គ្រោះមហន្តរាយនេះនឹងកើតឡើង»
ដូច្នេះ មើល៍!
នេប៊ូសារ៉ាដានប្រាប់ ដើម្បីនាំការយកចិត្តទុកដាក់របស់លោកយេរេមានាពេលនេះ។
កន្លែងណាដែលល្អ ហើយគប់ភ្នែកអ្នកចុះ
ការបកប្រែរបៀបផ្សេងទៀត: «អ្នកចង់»
Jeremiah 40:5
កេដាលា ... អហ៊ីកាម ... កេដាលា
សូមមើលពីរបៀបបកប្រែឈ្មោះទាំងនេះនៅក្នុងជំពូក ៣៩:១១។
ក្នុងចំណោមប្រជាជន
«ក្នុងចំណោមប្រជាជនយូដា»
ដែលគប់ភ្នែកលោកចុះ
«អ្វីដែលអ្នកគិតថាល្អ»
ដែលរស់នៅក្នុងទឹកដីនោះ

generated on Wed Sep 10 16:16:32 2025

«ដែលស្នាក់នៅក្នុងស្រុកយូដា»
Jeremiah 40:7
ពេលនោះ
នេះសំគាល់ផ្នែកថ្មីនៃរឿង។
ដែលអ្នកមិនបានចាប់ទៅជាឈ្លើយ នៅក្នុងបាប៊ីឡូន
«អ្នកដែលជាកងទ័ពសត្រូវមិនត្រូវបានចាត់ឲ្យទៅបាប៊ីឡូន»
អ៊ីសម៉ាអែល.....ហើយនិងយេសានា
នៅក្នុងជំពូក ៤០:៨។ ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
កូនរបស់ម៉ាកាធី
នេះសំដៅលើមនុស្សដែលមកពីតំបន់ម៉ាកា។
Jeremiah 40:9
ក៏ស្បថនឹងមេទ័ពទាំងនោះ
«បានស្បថជាមួយមេទ័ពយូដា»
ផលរដូវក្តៅ
នេះសំដៅទៅលើដំណាំតាមរដូវកាល។
ចូររស់នៅក្នុងទីក្រុងទាំងនោះ ដែលអ្នករាល់គ្នាចាប់បានទៅ
«រស់នៅក្នុងទីក្រុងទាំងនោះ»
Jeremiah 40:11
ពួកយូដាទាំងអស់
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣២:១០។
នៅកណ្តាលពួកកូនចៅរបស់
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកស្រុកយូដាទាំងអស់ក្នុងចំណោមកូនចៅអាំម៉ូន»។
ពួកសេសសល់នៃយូដា
«ពួកសេសសល់នៃប្រជាជនយូដា»
បានតាំង...ឲ្យគ្រប់គ្រងលើពួកគេ
«បានដាក់...ឲ្យទទួលបន្ទុកលើពួកគេ»
កេដាលា ជាកូនអ័ហ៊ីកាម និងជាចៅសាផាន
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៩:១១។
លើពួកគេ
«នៅលើប្រជាជនយូដា»
ដែលគេខ្ចាត់ខ្ចាយទៅ
«ដែលពួកគេបានភៀសខ្លួនទៅ» ឬ ការបកប្រែរបៀបផ្សេងទៀត:
«ដែលពួកបាប៊ីឡូនបានដេញពួកគេ»។
ផលទំពាំងបាយជូរ និងផលរដូវក្តៅបានជាបរិបូណ៌
«ចំនួនដ៏ច្រើននៃផលទំពាំងបាយជូ និងផលរដូវក្តៅ»
ផលរដូវក្តៅ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៤០:៩។
Jeremiah 40:13
យ៉ូហាណាន...ការ
សូមមើលពីរបៀបបកប្រែឈ្មោះទាំងនេះនៅក្នុងជំពូក ៤០:៧។
កេដាលា
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៣៩:១១។
តើលោកជ្រាបឬទេថា ប្អាលីស ជាស្តេចនៃប្រជាជនអាំម៉ូន បានចាត់អ៊ីសម៉ាអែល ជាកូននេថានា ឲ្យ
មកសម្លាប់លោក?
«លោកគួរដឹងថា
ស្តេចប្អាលីសនៃប្រជាជនអាំម៉ូនបានចាត់អ៊ីស្មាអែលជាកូនរបស់លោកនេថានាឲ្យទៅសម្លាប់លោក!»។
បាលីស
នេះជាឈ្មោះរបស់ស្តេច។
អ៊ីស្មាអែលជាកូនរបស់លោកនេថានា
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៤០:៧។
អ័ហ៊ីកាម
សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៦:២២។
Jeremiah 40:15
យ៉ូហាណាន...ការ
សូមមើលពីរបៀបបកប្រែឈ្មោះទាំងនេះនៅក្នុងជំពូក ៤០:៧។
បាននិយាយដោយសម្ងាត់នឹង លោកកេដាលា
«បាននិយាយការសម្ងាត់ជាមួយនឹងលោកកេដាលា»
កេដាលា
សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ៣៩:១១។
អ៊ីសម៉ាអែល ជាកូននេថានា
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៤០:៧។
គ្មានអ្នកណាសង្ស័យខ្ញុំឡើយ
«គ្មានអ្នកណាដឹងឡើយ»
ហេតុអ្វីបានជាគាត់ចង់សម្លាប់លោក?
«អ្នកមិនត្រូវឲ្យគេសម្លាប់លោកឡើយ»។
ហេតុអ្វីអនុញ្ញាតពួកយូដា
«មិនត្រូវអនុញ្ញាតឲ្យពួកយូដាជាច្រើន»
ពួកយូដាដែលខ្ចាត់ខ្ចាយប្រមូលគ្នាមកជួបនិងលោក
«ពួកប្រជាជនយូដាដែលមកជួបលោក»
ដែលខ្ចាត់ខ្ចាយ
«ដែលរត់ភៀសខ្លួនទៅទឹកដីផ្សេងៗ»
សំណល់ពួកយូដានឹងត្រូវវិនាស?
«ដោយអនុញ្ញាតឲ្យពួកអ្នកសេសសល់យូដាឲ្យត្រូវវិនាស»
សំណល់ពួកយូដា
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៤០:១១។
អ័ហ៊ីកាម
សូមមើលពីរបៀបបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៦:២២។

41 [1]ប៉ុន្តែវាបានកើតឡើងនៅខែទីប្រាំពីរ អ៊ីសម៉ាអែល ជាកូននេថានា ដែលជាកូនអេលីសាម៉ា ក្នុងវង្សាស្តេច ហើយជានាយកធំម្នាក់របស់ស្តេច ព្រមទាំងដប់នាក់ឯទៀត
ក៏មករកកេដាលាជាកូនអ័ហ៊ីកាម នៅត្រង់មីសប៉ា ហើយគេបានបរិភោគអាហារជាមួយគ្នានៅទីនោះ។[2]អ៊ីសម៉ាអែល ជាកូននេថានា និងដប់នាក់ដែលនៅជាមួយ ក៏
ក្រោកឡើងប្រហារកេដាលា ជាកូនអ័ហ៊ីកាម ដែលជាកូនសាផានដោយដាវ គឺគេសម្លាប់អ្នកដែលស្តេចបាប៊ីឡូនបានតាំងឡើង ធ្វើជាចៅហ្វាយលើទឹកដីនោះ។[3]អ៊ីសម៉ាអែល
ក៏សម្លាប់ពួកយូដាទាំងអស់ ដែលនៅជាមួយកេដាលាត្រង់មីសប៉ាដែរ ព្រមទាំងពួកខាល់ ជាទាហានដែលនៅទីនោះផង។
[4]កន្លងបានពីរថ្ងៃ ក្រោយដែលសម្លាប់កេដាលាហើយ ឥតមានអ្នកណាដឹងសោះ។[5]នោះមានមនុស្សមកពីស៊ីគែម ស៊ីឡូរ និងសាម៉ារី ចំនួនប៉ែតសិបនាក់ គេបានកោរពុកចង្កា
ព្រមទាំងហែកអាវ ហើយអារសាច់ខ្លួន ក៏កាន់តង្វាយម្សៅ និងកំញាន ដើម្បីនាំយកទៅឯព្រះវិហារនៃព្រះអម្ចាស់។
[6]ដូច្នេះ អ៊ីសម៉ាអែល ជាកូននេថានា ក៏ចេញពីមីសប៉ាទៅទទួលគេទាំងយំបណ្តើរ កាលបានទៅដល់គេហើយ ក៏និយាយថា៖ «សូមមករកកេដាលា ជាកូនអ័ហ៊ីកាម!»[7]ពេល
គេចូលទៅក្នុងទីក្រុងហើយ អ៊ីសម៉ាអែល ជាកូននេថានា និងពួកអ្នកដែលនៅជាមួយ ក៏សម្លាប់គេបោះចោលទៅក្នុងអណ្តូង។
[8]ប៉ុន្តែ ក្នុងចំណោមពួកគេ មានដប់នាក់ពោលទៅកាន់លោកអ៊ីស្មាអែលថា៖ «សូមកុំសម្លាប់យើងខ្ញុំអី យើងខ្ញុំមានស្បៀងអាហារលាក់ទុកនៅក្នុងចម្ការ គឺមានស្រូវ មានអង្ករ
ប្រេង និងទឹកឃ្មុំ»។ លោកអ៊ីស្មាអែលក៏ទុកជីវិតឲ្យអ្នកទាំងដប់នោះ។[9]អណ្តូងដែលលោកអ៊ីស្មាអែលបោះសាកសពអ្នកដែលគាត់បានសម្លាប់ ជាអណ្តូងដែលព្រះបាទ
អេសា ជាស្តេចទឹកដីយូដាបានជីក នៅគ្រាធ្វើសឹកជាមួយព្រះបាទបាសា ជាស្តេចទឹកដីអ៊ីស្រាអែល។ លោកអ៊ីស្មាអែលបោះសាកសពពេញក្នុងអណ្តូងនោះ។
[10]បន្ទាប់មក លោកអ៊ីស្មាអែលចាប់ប្រជាជនដែលនៅសេសសល់នៅមីសប៉ា ព្រមទាំងពួកបុត្រីរបស់ស្តេច និងអស់អ្នកដែលរស់នៅមីសប៉ា គឺអស់អ្នកដែលលោក
នេប៊ូសារ៉ាដាន ជារាជប្រតិភូ ផ្ទុកផ្តាក់ទៅឲ្យលោកកេដាលា ជាកូនរបស់លោកអហ៊ីកាម មើលខុសត្រូវ នាំទៅជាឈ្លើយ។ លោកអ៊ីស្មាអែលចាប់អ្នកទាំងនោះជាឈ្លើយនាំ
ទៅទឹកដីអាំម៉ូន។
[11]កាលលោកយ៉ូហាណាន ជាកូនរបស់លោកការ៉ា និងមេទាហានទាំងអស់ដែលនៅជាមួយលោក បានឮពីការអាក្រក់ទាំងប៉ុន្មានដែលលោកអ៊ីស្មាអែល ជាកូនរបស់លោក
នេថានាបានប្រព្រឹត្ត។[12]ដូច្នេះ ពួកគេក៏នាំទាហានទាំងអស់ដែលនៅជាមួយ ចេញទៅតាមវាយលោកអ៊ីស្មាអែល ជាកូនរបស់លោកនេថានា។ ពួកគេតាមគាត់ទាន់នៅបឹង
គីបៀន។
[13]មានការមួយបានកើតឡើង គឺប្រជាជនដែលលោកអ៊ីស្មាអែលចាប់នាំមកជាមួយ ឃើញលោកយ៉ូហាណាន ជាកូនរបស់លោកការ៉ា និងមេទាហានទាំងអស់ដែលនៅជា
មួយលោក គេត្រេកអរយ៉ាងខ្លាំង។[14]ដូច្នេះ ប្រជាជនដែលលោកអ៊ីស្មាអែលចាប់ទៅជាឈ្លើយ នាំគ្នាបកក្រោយ ចូលរួមជាមួយលោកយ៉ូហាណាន ជាកូនរបស់លោកការ៉ា។

generated on Wed Sep 10 16:16:32 2025

[15]ប៉ុន្តែ លោកអ៊ីស្មាអែល ជាកូនរបស់លោកនេថានា និងបក្សពួករបស់គាត់ប្រាំបីនាក់ ដែលបានមកពីលោកយ៉ូហាណាន។ គាត់បានគេចខ្លួនរួច ហើយរត់ទៅដល់ទឹកដីអាំម៉ូន។[16]លោកយ៉ូហាណាន ជាកូនរបស់លោកការ៉ា ព្រមទាំងពួកមេទាហាននៅជាមួយ បាននាំប្រជាជនដែលលោករំដោះពីលោកអ៊ីស្មាអែលនៅគីបៀនមកវិញ គឺទាំងទាហាន ទាំងស្ត្រី ទាំងក្មេងៗ ទាំងមហាតលិកដែលនៅសេសសល់ ហើយត្រូវលោកអ៊ីស្មាអែលចាប់ពីមីសប៉ា ក្រោយបានសម្លាប់លោកកេដាលា ជាកូនរបស់លោកអហ៊ីកាម។
[17]ក្រោយមក ពួកគេនាំគ្នាចេញដំណើរ ហើយឈប់នៅផ្ទះសំណាក់គីមហាំ ជិតភូមិបេថ្លេហិម។ ពួកគេបម្រុងនឹងបន្តដំណើរទៅទឹកដីអេស៊ីប ដោយព្រោះគេចពីពួកខាល់ដេ។[18]ពួកគេនឹកខ្លាច ដោយលោកអ៊ីស្មាអែល ជាកូនរបស់លោកនេថានា បានសម្លាប់លោកកេដាលា ជាកូនរបស់លោកអហ៊ីកាម ដែលស្តេចទឹកដីបាប៊ីឡូនតែងតាំងឲ្យគ្រប់គ្រងទឹកដី។

Jeremiah 41:1
វាបានកើតឡើង
ឃ្លានេះត្រូវបានប្រើដើម្បីបញ្ជាក់ពីការចាប់ផ្តើមនៃផ្នែកសាច់រឿងថ្មី។
ប្រសិនបើភាសារបស់អ្នកមានលក្ខណៈដូចនេះ អ្នកអាចធ្វើប្រើឃ្លានេះបាន។
នៅខែទីប្រាំពីរ
នេះជាខែទីប្រាំពីរនៃប្រតិទិនហេប្រឺ។ ដែលនៅកំឡុងពេលចុងខែកញ្ញា និងដើមខែតុលាតាមប្រតិទិនលោកខាងលិច។
អ៊ីសម៉ាអែល....នេថានា... អេលីសាម៉ា...កេដាលាអ័ហ៊ីកាម
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Jeremiah 41:4
ចំនួនប៉ែតសិបនាក់
«៨០នាក់»
ក្នុងដៃរបស់គេ
ពាក្យថា «ដៃ» បង្ហាញពីពួកមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ក្នុងកម្មសិទ្ធរបស់ពួកគេ»
Jeremiah 41:6
កាលដែលគាត់បានទៅដល់ពួកគេ
«កាលដែលអ៊ីស្មាអែលបានចូលជិតនឹងមនុស្ស ៨០នាក់»
ពេលពួកគេបានចូលទៅ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់នៅក្នុងសាច់រឿង។
ប្រសិនបើភាសារបស់អ្នកមានលក្ខណៈដូចនេះ អ្នកអាចធ្វើប្រើឃ្លានេះបាន។
អ៊ីសម៉ាអែល ជាកូននេថានា ក៏បានសម្លាប់ពួកគេរួចបោះចោលទៅក្នុងរណ្តៅ
គឺលោកហើយនិងពួកមនុស្សដែលនៅជាមួយគាត់
ការបកប្រែរបៀបផ្សេងទៀត: «អ៊ីសម៉ាអែល ជាកូននេថានា
និងពួកមនុស្សដែលនៅជាមួយគាត់ ក៏បានសម្លាប់មនុស្សរួចបោះចោលទៅក្នុងរណ្តៅ»
Jeremiah 41:8
ក្នុងចំណោមពួកគេ មានដប់នាក់
ពាក្យថា «ពួកគេ» សំដៅលើមនុស្ស ៨០នាក់។
ស្បៀងអាហារទុក
ស្បៀងដែលត្រូវបានរក្សាទុកសម្រាប់ការប្រើប្រាស់នាពេលអនាគត។
Jeremiah 41:10
អ៊ីស្មាអែល...នេប៊ូសារ៉ាដាន... កេដាល...អហ៊ីកាម...នេថានា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Jeremiah 41:11
យ៉ូហាណាន...ការ៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
ពួកគេតាមគាត់ទាន់
«ពួកគេតាមទាន់អ៊ីស្មាអែល និងបក្សពួករបស់លោក»
Jeremiah 41:13
រួចហើយវាបានកើតឡើង
ឃ្លានេះត្រូវបានប្រើដើម្បីបញ្ជាក់ពីការចាប់ផ្តើមនៃផ្នែកសាច់រឿងថ្មី។
ប្រសិនបើភាសារបស់អ្នកមានលក្ខណៈដូចនេះ អ្នកអាចធ្វើប្រើឃ្លានេះបាន។
អ៊ីស្មាអែល ... យ៉ូហាណាន ... ការ៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Jeremiah 41:15
អ៊ីស្មាអែល...នេថានា ...កេដាលា...អហ៊ីកាម
សូមមើលពីរបៀបបកប្រែឈ្មោះរបស់មនុស្សទាំងនេះនៅក្នុងជំពូក ៤១:១។
យ៉ូហាណាន...ការ៉ា
សូមមើលពីរបៀបបកប្រែឈ្មោះរបស់មនុស្សទាំងនេះនៅក្នុងជំពូក ៤១:១១។
រំដោះពីអ៊ីស្មាអែល
«លោក និងកងទ័ពរបស់លោកបានរំដោះពីអ៊ីស្មាអែល»
ការនេះក្រោយអ៊ីស្មាអែលបានសម្លាប់លោកកេដាលា ជាកូនរបស់លោកអហ៊ីកាម
អ្នកនិពន្ធបានបញ្ចប់សាច់រឿង ដែលរំលឹកពីព្រឹត្តិការណ៍មុនៗ
ដូច្នេះព្រឹត្តិការណ៍ទៅតាមលំដាប់លំដោយត្រូវបានងាយយល់។
Jeremiah 41:17
ហ្គេរូ គីមហាំ
នេះជាឈ្មោះទីកន្លែង។
ដោយព្រោះគេចពីពួកខាល់ដេ
ការបកប្រែរបៀបផ្សេងទៀត: «ដោយព្រោះពួកគេគិតថាពួកខាល់ដេ
អាចវាយប្រហារពួកគេ»
ឲ្យគ្រប់គ្រងទឹកដី
ការបកប្រែរបៀបផ្សេងទៀត: «ឲ្យគ្រប់គ្រងទឹកដីយូដា»

---

42 [1]ពួកមេទ័ពទាំងអស់ លោកយ៉ូហាណានជាកូនរបស់លោកការ៉ា លោកយេសានាជាកូនរបស់លោកហូសាយ៉ា និងប្រជាជនទាំងមូល ចាប់ពីអ្នកតូចរហូតដល់អ្នកធំ នាំគ្នាទៅជួបព្យាការីយេរេមា។[2]ពួកគេថ្លែងថា៖ «សូមយកការទាំងអស់នេះមកដាក់ចំពោះព្រះអង្គ។ សូមអធិស្ឋានដល់ព្រះអម្ចាស់ជាព្រះរបស់លោក សម្រាប់មនុស្សទាំងនេះដែលមានចំនួនតិច ដូចលោកឃើញហើយ។[3]សូមព្រះអម្ចាស់ ជាព្រះរបស់លោក បង្ហាញឲ្យយើងស្គាល់ផ្លូវដែលពួកយើងត្រូវដើរ និងអ្វីដែលយើងខ្ញុំត្រូវធ្វើផង»។
[4]ព្យាការីយេរេមាតបទៅពួកគេវិញថា៖ «ខ្ញុំបានឮពីអ្នកទាំងអស់គ្នាហើយ។ ខ្ញុំនឹងទូលអង្វរព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា តាមសំណូមពររបស់អ្នក។ ខ្ញុំនឹងប្រាប់ឲ្យអ្នករាល់គ្នាដឹង នូវព្រះបន្ទូល ដែលព្រះអម្ចាស់ឆ្លើយមកអ្នក។ មិនលាក់លៀមពីអ្នកឡើយ»។[5]ពួកគេនិយាយទៅកាន់លោកយេរេមា «សូមព្រះអម្ចាស់ធ្វើជាសាក្សីដ៏ពិតប្រាកដ និងដោយស្មោះត្រង់ ទាស់នឹងយើង ប្រសិនបើយើងខ្ញុំមិនធ្វើតាម អ្វីដែលព្រះអម្ចាស់ ជាព្រះរបស់លោក បង្គាប់មកយើងបានធ្វើ។[6]ទោះបីជាយ៉ាង ការល្អឬអាក្រក់ក្តី យើងនឹងស្តាប់តាមសម្លេងនៃព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់យើង ទៅកាន់អស់អ្នកដែលយើងបញ្ជូនអ្នកទៅគេ ដូច្នេះការនេះនឹងបានល្អសម្រាប់យើង គឺនៅពេលដែលយើងស្តាប់បង្គាប់សម្លេងព្រះអម្ចាស់ជាព្រះ»។
[7]នៅចុងថ្ងៃទីដប់ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមា។[8]ដូច្នេះ លោកក៏ហៅលោកយ៉ូហាណាន ជាកូនរបស់លោកការ៉ា និងពួកមេទ័ពទាំងអស់ដែលនៅជាមួយគាត់ ព្រមទាំងប្រជាជនទាំងមូល តាំងពីអ្នកតូចរហូតដល់អ្នកធំ។[9]លោកបានថ្លែងទៅពួកគេថា៖ «អ្នករាល់គ្នាបានចាត់ខ្ញុំឲ្យទូលអង្វរព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល ព្រះអង្គមានព្រះបន្ទូលដូចតទៅ៖[10]ប្រសិនបើអ្នករាល់គ្នាបន្តរស់នៅក្នុងទឹកដីនេះ យើងនឹងធ្វើឲ្យអ្នករាល់គ្នារឹងមាំ គឺយើងមិនបំផ្លាញអ្នករាល់គ្នាទេ យើងនឹងដាំអ្នករាល់គ្នា គឺយើងមិនដកអ្នករាល់គ្នាទៀតឡើយ យើងនឹងបង្វែការមហន្តរាយចេញពីអ្នករាល់គ្នា។
[11]នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ កុំខ្លាចចំពោះស្តេចបាប៊ីឡូន ដែលអ្នករាល់គ្នាកំពុងតែខ្លាចនោះ ដ្បិតយើងនៅជាមួយ ដើម្បីជួយសង្គ្រោះអ្នករាល់គ្នា ហើយនឹងដោះអ្នករាល់គ្នា ឲ្យរួចពីកណ្តាប់ដៃរបស់គេ។ ដ្បិតយើងនឹងប្រោសមេត្តាដល់អ្នក។[12]ដ្បិត យើងនឹងក្តីមេត្តាដល់អ្នក ហើយនឹងនាំអ្នកឲ្យត្រឡប់ទៅទឹកដីរបស់អ្នកវិញ។

generated on Wed Sep 10 16:16:32 2025

[13]ប៉ុន្តែ បើអ្នករាល់គ្នាថា៖ «យើងខ្ញុំមិនរស់នៅក្នុងទឹកដីនេះទេ» ប្រសិនបើអ្នករាល់គ្នាមិនព្រមស្តាប់សម្លេងរបស់យើង គឺជាសម្លេងនៃព្រះអម្ចាស់ ជាព្រះរបស់អ្នក។[14]ហើយ
អ្នកនិយាយថា៖ «ទេ! យើងរាល់គ្នានឹងទៅរស់នៅក្នុងទឹកដីអេស៊ីបវិញ ជាកន្លែងដែលមិនឃើញចម្បាំង ក៏មិនឮសូរត្រែ ហើយមិនត្រូវអត់ឃ្លានទេ។ ទីនោះដែលយើងនឹង
អាស្រ័យនៅ»។
[15]ពេលនេះ ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ ពួកអ្នកជនជាតិយូដាអើយ។ ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូច្នេះថា "បើអ្នក
រាល់គ្នាកាត់ចិត្តនឹងទៅក្នុងទឹកដីអេស៊ីបពិត ហើយក៏នឹងអាស្រ័យនៅទីនោះ[16]ដូច្នេះ ដាវដែលអ្នករាល់គ្នាខ្លាចនឹងតាមអ្នកទាន់ នៅក្នុងទឹកដីអេស៊ីប។ ហើយគ្រោះទុរ្ភិក្សដែល
អ្នករាល់គ្នាខ្លាច នឹងកើតនៅក្នុងទឹកដីអេស៊ីបដែរ ហើយអ្នកនឹងត្រូវស្លាប់នៅទីនោះ។[17]អស់អ្នកដែលពេញចិត្តនឹងទៅអាស្រ័យនៅក្នុងទឹកដីអេស៊ីប នោះនឹងបានដូច្នោះ គឺគេ
នឹងស្លាប់ដោយដាវ ដោយអំណត់ និងអាសន្នរោគ។ គ្មាននរណាម្នាក់សល់ទេ ឬគេចរួចពីការអាក្រក់ ដែលយើងនឹងនាំមកលើគេនោះឡើយ។
[18]ដ្បិត ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិ អ៊ីស្រាអែលមានព្រះបន្ទូលថា៖ ប្រសិនបើអ្នករាល់គ្នាទៅទឹកដីអេស៊ីប យើងនឹងជះកំហឹងដ៏ខ្លាំងក្លារបស់យើងទៅ
លើអ្នករាល់គ្នា ដូចយើងបានជះទៅលើអ្នកក្រុងយេរូសាឡឹមដែរ។ ប្រជាជាតិទាំងឡាយយកឈ្មោះអ្នករាល់គ្នាទៅដាក់បណ្តាសាជេរ ប្រមាថ និងចំអកឡកឡឺយឲ្យគ្នា អ្នក
រាល់គ្នាពុំបានឃើញទឹកដីនេះវិញឡើយ»។[19]លោកយេរេមាបានថ្លែងថា «ព្រះបន្ទូលនៃព្រះអម្ចាស់ រំលឹកដល់អ្នកដែលជាជនជាតិយូដា។ កុំទៅទឹកដីអេស៊ីបឡើយ!
ពីព្រោះយើងបានប្រាប់អ្នករួចហើយ គឺយើងនឹងទាស់ជាមួយនឹងអ្នករាល់គ្នានៅថ្ងៃនេះ។
[20]ដ្បិត អ្នករាល់បានបោកចិត្តខ្លួនអ្នក ដោយសុំខ្ញុំឲ្យទូលអង្វរព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ទាំងពោលថា៖ សូមអង្វរព្រះអម្ចាស់ ជាព្រះនៃយើង ឲ្យយើងខ្ញុំផង។ អ្វីៗ
ដែលព្រះអម្ចាស់ ជាព្រះនៃយើងខ្ញុំមានព្រះបន្ទូល សូមប្រាប់យើងមក នោះយើងនឹងធ្វើតាមទាំងអស់។[21]ដ្បិតខ្ញុំក៏ប្រាប់ឲ្យអ្នករាល់គ្នាដឹងនៅថ្ងៃនេះ តែអ្នករាល់គ្នាពុំព្រម
ស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយក៏ពុំស្តាប់សេចក្តីទាំងប៉ុន្មានដែលព្រះអង្គបង្គាប់ឲ្យខ្ញុំនាំមកប្រាប់អ្នករាល់គ្នាដែរ។[22]ឥឡូវនេះ ចូរដឹងឲ្យច្បាស់ថា អ្នករាល់គ្នានឹងត្រូវ
ស្លាប់ដោយមុខដាវ ដោយទុរ្ភិក្ស ឬដោយជំងឺអាសន្នរោគ ក្នុងទឹកដីដែលអ្នករាល់គ្នាចង់ទៅរស់នៅ»។

Jeremiah 42:1
ព័ត៌មានទូទៅ:
សូមមើល: [[een:ta:vol2:translate]] និង
យ៉ូហាណាន ... ការ៉ា ... យេសានាជា ... ហូសាយ៉ា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ប្រជាជនទាំងអស់ ចាប់ពីអ្នកតូចរហូតដល់អ្នកធំ
នេះគឺជារបៀបសំដៅលើមនុស្សពីគ្រប់ស្រទាប់ក្នុងសង្គម។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនមកពីគ្រប់ស្រទាប់ក្នុងសង្គម»
សូមយកពាក្យអង្វរទាំងនេះមកដាក់ចំពោះលោក
ការបកប្រែរបៀបផ្សេងទៀត: «ចូរឲ្យយើងបង្ហាញពាក្យអង្វរបន្ទាន់ទៅកាន់លោក»
Jeremiah 42:4
មើល៍!
ការបកប្រែរបៀបផ្សេងទៀត:
«ចូរយកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំនឹងប្រាប់អ្នករាល់គ្នា»
ខ្ញុំនឹងប្រាប់ដល់អ្នក
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងប្រាប់អ្នករាល់គ្នារាល់អ្វីដែលព្រះអម្ចាស់មានបន្ទូលមកកាន់ខ្ញុំ»
ពិតប្រាកដ និងដោយស្មោះត្រង់
ពាក្យទាំងនេះបង្ហាញពីអត្ថន័យស្រដៀងគ្នានៅក្នុងអត្ថបទនេះ។
ពាក្យទាំងពីរនេះពណ៌នាពីព្រះអម្ចាស់ជាទីបន្ទាល់
ដែលគ្មានអ្នកណាអាចជំទាស់បានឡើយ។ ការបកប្រែរបៀបផ្សេងទៀត:
«គួរឲ្យទុកចិត្ត»
ទោះបីជាយ៉ាង ការល្អឬអាក្រក់ក្តី
មនុស្សពោលពាក្យទាំងពីរ
ដើម្បីបញ្ជាក់ថាពួកគេនឹងគោរពតាមអ្វីជាពាក្យរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលទ្រង់មានបន្ទូលឆ្លើយតប»។
សម្លេងនៃព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់យើង
ព្រះអម្ចាស់បញ្ជាក់ពីអ្វីដែលទ្រង់មានបន្ទូលតបពីសំណួររបស់គេ។
Jeremiah 42:7
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:១។
ព្រមប្រជាជនទាំងមូល តាំងពីអ្នកតូចរហូតដល់អ្នកធំ
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៤២:១។
ខ្ញុំឲ្យទូលអង្វរព្រះអម្ចាស់
«ខ្ញុំនឹងទូលសូមទៅព្រះអម្ចាស់»
យើងនឹងធ្វើឲ្យអ្នករាល់គ្នារឹងមាំ មិនបំផ្លាញអ្នករាល់គ្នាទេ
ព្រះអម្ចាស់បានសំដៅលើប្រជារាស្ត្រអ៊ីស្រាអែលប្រៀបបាននឹងជញ្ជាំងដែលត្រូវបានសាងសង់ឡើង
ឬអាចបែកបាក់។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើឱ្យអ្នកបានចម្រើនឡើង ហើយមិនត្រូវបំផ្លាញឡើយ»
យើងនឹងដាំអ្នករាល់គ្នា គឺយើងមិនដកអ្នករាល់គ្នាឡើយ
ព្រះអម្ចាស់ប្រើឧទាហរណ៍មួយទៀតដើម្បីបង្ហាញពីរបៀបដែលទ្រង់នឹងធ្វើឱ្យប្រជារាស្ត្រអ៊ីស្រាអែលរីកចម្រើនឡើងវិញ។ ការបកប្រែរបៀបផ្សេងទៀត:
ទ្រង់ចាត់ទុកពួកគេដូចជារុក្ខជាតិ ដូចគ្នាដែលទ្រង់បានហៅពួកគេថាជាជញ្ជាំង។
យើងនឹងបង្វែការមហន្តរាយចេញពីអ្នករាល់គ្នា
មហន្តរាយសំដៅលើអ្វីមួយដែលមនុស្សដែលធ្វើដាក់លើអ្នកដទៃ។
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងការពារពីមហន្តរាយកើតឡើងចំពោះអ្នករាល់គ្នា»
Jeremiah 42:11
ជួយសង្គ្រោះអ្នក ហើយនឹងដោះអ្នក
ពាក្យថា «សង្គ្រោះ» និង «រំដោះ»
មានន័យដូចគ្នាហើយបញ្ជាក់ថាព្រះអម្ចាស់ពិតជានឹងជួយសង្គ្រោះ។
ការបកប្រែរបៀបផ្សេងទៀត: «ជួយសង្គ្រោះអ្នកយ៉ាងពិតប្រាកដ»។
ឲ្យរួចពីកណ្តាប់ដៃរបស់ទ្រង់
ពាក្យថា «កណ្តាប់ដៃ» សំដៅលើឫទ្ធានុភាព និងសិទ្ធអំណាច។
ការបកប្រែរបៀបផ្សេងទៀត: «រំដោះអ្នកពីសិទ្ធអំណាចទ្រង់»។
Jeremiah 42:13
ប្រសិនបើអ្នករាល់គ្នាមិនព្រមស្តាប់សម្លេងរបស់យើង គឺជាសម្លេងនៃព្រះអម្ចាស់ ជាព្រះរបស់អ្នក
ការមិនស្តាប់បង្គាប់
គឺដូចជាពួកប្រជារាស្ត្រដែលមិនបានស្តាប់តាមបញ្ញត្តិរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើអ្នកមិនគោរពតាមបញ្ញត្តិរបស់យើង
ដែលយើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នក»។
ជាកន្លែងដែលមិនឃើញចម្បាំង ក៏មិនឮសូរត្រែ
ឃ្លាទាំងពីរនេះបង្ហាញថា នឹងមានសង្គ្រាមដោយសារអាចមើលឃើញឬ ឮសូបាន។
ការបកប្រែរបៀបផ្សេងទៀត:
«ជាកន្លែងដែលយើងនឹងមិនធ្លាប់មានការលំបាកក្នុងសង្គ្រាម»
ទីនោះដែលយើងនឹងអាស្រ័យនៅ
ការឃ្លានត្រូវបានប្រើដើម្បីបង្ហាញពីទុរ្ភិក្ស។
Jeremiah 42:15
ដាវដែលអ្នករាល់គ្នាខ្លាចនឹងតាមអ្នកទាន់
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងទទួលបានបទពិសោធន៍គួរឲ្យភ័យខ្លាចនៃសង្គ្រាមនោះ។
គ្រោះទុរ្ភិក្សដែលអ្នករាល់គ្នាខ្លាច នឹងកើតនៅក្នុងទឹកដីអេស៊ីបដែរ
គ្រោះទុរ្ភិក្សសំដៅលើការដែលកើតមានឡើងផ្សេងទៀត។
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាបារម្ភពីគ្រោះទុរ្ភិក្សនៅអ៊ីស្រាអែល
តែបើអ្នករាល់គ្នាទៅស្រុកអេស៊ីប អ្នកនឹងជួបគ្រោះទុរ្ភិក្សនៅទីនោះទៀត»
មនុស្ស
មនុស្សត្រូវបានសំដៅលើពួកប្រជាជន ដោយព្រោះពួកគេជាអ្នកដឹកនាំ
និងគ្រួសាររបស់គេ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នា»
Jeremiah 42:18
សេចក្តីក្រោធនិងកំហឹងរបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «សេចក្តីក្រោធនិងកំហឹងរបស់យើងត្រូវបានជះ»
សេចក្តីក្រោធនិងកំហឹងរបស់យើង
ពាក្យថា «សេចក្តីក្រោធ» និង «កំហឹង» មានន័យថាដូចគ្នា។ ពាក្យទាំងពីររួមគ្នា
[illegible] ការបកប្រែរបៀបផ្សេងទៀត:
«កំហឹងដ៏គួរឲ្យភ័យខ្លាចរបស់យើង»។

generated on Wed Sep 10 16:16:32 2025

ជះសេចក្តីក្រោធនិងកំហឹងរបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងជះកំហឹងយើងលើអ្នករាល់គ្នា»
និងជាមូលហេតុសម្រាប់និយាយបណ្តាសា និងអ្វីដែលជាការប្រមាថអ្នករាល់គ្នា
ឃ្លាទាំងពីរមានអត្ថន័យដូចគ្នា
ហើយបញ្ជាក់ថាប្រជាជាតិនានានឹងធ្វើបាបប្រជាជនយូដាយ៉ាងដូចម្តេចបន្ទាប់ពីព្រះអម្ចាស់បានសង្គ្រោះពួកគេ
សូមមើលពីរបៀបបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ២៥:១៧ និង ២៩:១៨។
យើងជាសាក្សី
ព្រះអម្ចាស់ជាអ្នកដែលធានាថាប្រជារាស្ត្រអ៊ីស្រាអែលនឹងទទួលទោស
ប្រសិនបើពួកគេមិនរក្សាពាក្យសន្យា ស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះអម្ចាស់។

Jeremiah 42:20
យើងនឹងធ្វើតាមទាំងអស់
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងប្រព្រឹត្តតាម»
អ្នករាល់គ្នានឹងត្រូវស្លាប់ដោយមុខដាវ
[illegible]ប្រើសម្រាប់ប្រយុទ្ធ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងស្លាប់នៅក្នុងសង្គ្រាម»។
ក្នុងទឹកដីដែលអ្នករាល់គ្នាចង់ទៅរស់នៅ
ការបកប្រែរបៀបផ្សេងទៀត: «កន្លែងដែលអ្នកគិតថាអ្នកនឹងមានសុវត្ថិភាព
គឺនៅក្នុងប្រទេសអេស៊ីប»

---

43 [1]លោកយេរេមាថ្លែងប្រាប់ប្រជាជន ចប់ហើយពីព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះរបស់ពួកគេ គឺព្រះបន្ទូលដែលព្រះអង្គប្រគល់ឲ្យលោកនាំមកប្រាប់ពួកគេ។[2]លោក
អសារាជាកូនរបស់លោកហូសាយ៉ា លោកយ៉ូហាណានជាកូនរបស់លោកការ៉ា និងពួកដេលអំនួតបាន ពោលមកកាន់លោកយេរេមាថា៖ «លោកនិយាយកុហក។
ព្រះអម្ចាស់ ជាព្រះរបស់យើង ពុំបានចាត់លោកឲ្យមកហាមពួកយើងទៅរស់នៅទឹកដីអេស៊ីបទេ។[3]ដ្បិតបារូក ជាកូនរបស់លោកនេរីយ៉ាទេតើ ដែលអុចអាលលោកឲ្យប្រឆាំង
នឹងពួកយើង ដើម្បីប្រគល់ពួកយើងទៅក្នុងកណ្តាប់ដៃរបស់ពួកខាល់ដេ ហើយអ្នកធ្វើឲ្យយើងស្លាប់ និងចាប់ពួកយើងធ្វើឈ្លើយនៅបាប៊ីឡូន»។
[4]លោកយ៉ូហាណានជាកូនរបស់លោកការ៉ា ពួកមេទ័ព និងប្រជាជនទាំងអស់ មិនព្រមស្តាប់ព្រះបន្ទូលដែលព្រះអម្ចាស់បង្គាប់ឲ្យពួកគេរស់នៅក្នុងទឹកដីយូដាឡើយ។[5]លោក
យ៉ូហាណានជាកូនរបស់លោកការ៉ា និងពួកមេទ័ព នាំប្រជាជនយូដាទាំងអស់ដែលនៅសេសសល់ ដែលបានភៀសខ្លួនទៅនៅក្នុងចំណោមប្រជាជាតិផ្សេងៗ ហើយវិលមក
រស់នៅក្នុងទឹកដីយូដាវិញ។[6]ពួកគេបានយកទាំងប្រុស ទាំងស្រី ទាំងក្មេងៗ រួមទាំងបុត្រីរបស់ស្តេច និងអ្នកផ្សេងទៀត ដែលលោកនេប៊ូសារ៉ាដាន ជារាជប្រតិភូ បានទុកឲ្យ
នៅជាមួយលោកកេដាលា ជាកូនរបស់លោកអហ៊ីកាម និងជាចៅរបស់លោកសាផានទៅជាមួយ។ ពួកគេក៏នាំព្យាការីយេរេមា និងលោកបារូក ជាកូនរបស់លោកនេរីយ៉ាទៅ
ដែរ។[7]គឺពួកគេចេញដំណើរទៅទឹកដីអេស៊ីប ហើយទៅដល់ក្រុងថាផ្នេស ពួកគេមិនព្រមស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ទេ។
[8]ដូច្នេះ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមា នៅថាផ្នេសដោយបន្ទូលថា៖[9]«ចូរយកដុំថ្មធំៗទៅកប់ក្នុងដីឥដ្ឋ ដែលស្ថិតនៅព្រលានធ្វើពីឥដ្ឋខាងមុខមាត់ទ្វារ
ដំណាក់របស់ស្តេចផារ៉ោន នាក្រុងតាផាណែស ឲ្យប្រជាជនយូដាឃើញ»។[10]ក្រោយមកចូលប្រាប់ពួកគេថា «ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល
មានព្រះបន្ទូលដូចតទៅ៖ មើល៍! យើងនឹងប្រើគេឲ្យទៅហៅនេប៊ូក្នេសា ស្តេចទឹកដីបាប៊ីឡូន ជាអ្នកបម្រើរបស់យើងមក។ យើងនឹងដាក់បល្ល័ង្ករបស់នេប៊ូក្នេសាត្រង់កន្លែង
កប់ថ្មនេះ ហើយនេប៊ូក្នេសាក៏ដំឡើងស្វេតច្ឆត្ររបស់ខ្លួននៅកន្លែងនេះដែរ។
[11]នេប៊ូក្នេសានឹងមកវាយទឹកដីអេស៊ីប។ ពេលនោះ អ្នកណាដែលតម្រូវឲ្យស្លាប់ អ្នកនោះត្រូវតែស្លាប់ អ្នកណាដែលតម្រូវឲ្យជាប់ជាឈ្លើយ អ្នកនោះនឹងត្រូវគេកៀរយកទៅ
ជាឈ្លើយ អ្នកណាដែលតម្រូវឲ្យស្លាប់ដោយមុខដាវ អ្នកនោះនឹងស្លាប់ដោយមុខដាវ។[12]យើងនឹងដុតកម្ទេចវិហាររបស់ព្រះនានានៃទឹកដីអេស៊ីប។ គឺនេប៊ូក្នេសានឹងដុត
កម្ទេចរូបបដិមាទាំងនោះ ហើយនាំយកខ្លះទៅជាជយភណ្ឌផង។ នេប៊ូក្នេសានឹងរឹបអូសយកអ្វីៗចេញអស់ពីទឹកដីអេស៊ីប ដូចគេយកចៃចេញពីអាវរោមសត្វដែរ។
នេប៊ូក្នេសាចាកចេញទៅវិញ ដោយជ័យជំនះ។[13]នេប៊ូក្នេសានឹងកម្ទេចស្តូបទាំងឡាយ នៅក្រុងបេតសេម៉ស នៅទឹកដីអេស៊ីប។ ព្រមទាំងដុតកម្ទេចទីសក្ការៈរបស់ព្រះនានា
នៃទឹកដីអេស៊ីបផង»។

Jeremiah 43:1
ព័ត៌មានទូទៅ:
សូមមើល: និង
វាបានកើតឡើង
ឃ្លានេះត្រូវបានប្រើ ដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃសាច់រឿង។
ប្រសិនបើពាក្យភាសារបស់អ្នកមានលក្ខណៈដូចនេះ អ្នកអាចប្រើឃ្លានៅទីនេះបាន។
ហូសាយ៉ា ... យ៉ូហាណាន ... ការ៉ា ... នេរីយ៉ា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
អុចអាល
ធ្វើឲ្យនរណាម្នាក់ចង់ធ្វើបាបអ្នកដទៃ។
Jeremiah 43:4
មិនព្រមស្តាប់សម្លេងនៃព្រះអម្ចាស់
«ដែលមិនស្តាប់បង្គាប់តាមបញ្ញត្តិនៃព្រះអម្ចាស់»
ដែលពួកគេបានខ្ជាត់ខ្ចាយ
«ដែលព្រះអម្ចាស់បានធ្វើឲ្យពួកគេចាកចេញ ហើយដាច់ចេញពីគ្នា»
នេប៊ូសារ៉ាដាន ... កេដាលា ... អហ៊ីកាម .... សាផាន
ទាំងនេះជាឈ្មោះរបស់មនុស្ស។
ថាផ្នេស
នេះជាឈ្មោះទីក្រុង។
Jeremiah 43:8
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:១។
យើងនឹងដាក់បល្ល័ង្ករបស់នេប៊ូក្នេសាត្រង់កន្លែងលើថ្មនេះដែលអ្នកត្រូវបញ្ចុះវា យេរេមា។ នេប៊ូក្នេសា
ក៏ដំឡើងព្រះពន្លានៅលើពួកគេ
ទាំង «បល្ល័ង្ក» និង «ព្រះពន្លា»
របស់ស្តេចត្រូវបានប្រើដើម្បីសំដៅលើសិទ្ធអំណាចរបស់ស្តេច។
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងឲ្យគេឡើងសោយរាជ្យលើប្រជាជននៅស្រុកអេស៊ីប»។
ព្រះពន្លា
ដំណាក់ដ៏ធំ។
Jeremiah 43:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តថ្លែងព្រះបន្ទូលរបស់ព្រះអង្គ។
នេប៊ូក្នេសានឹងមក
ការបកប្រែរបៀបផ្សេងទៀត: «គេនឹងមក»
អ្នកណាដែលតម្រូវឲ្យស្លាប់ អ្នកនោះត្រូវតែស្លាប់ដែរ
ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សរាល់គ្នានឹងស្លាប់ដែលយើងបានសំរេចចិត្តត្រូវតែស្លាប់»
អ្នកណាដែលតម្រូវឲ្យជាប់ជាឈ្លើយ អ្នកនោះនឹងត្រូវគេកៀរយកទៅជាឈ្លើយ
ការបកប្រែរបៀបផ្សេងទៀត: «ពួកបាប៊ីឡូននឹងចាប់អ្នករាល់គ្នា
ដែលយើងបានសំរេច នោះត្រូវចាប់ជាឈ្លើយ»
អ្នកណាដែលតម្រូវឲ្យស្លាប់ដោយមុខដាវ អ្នកនោះនឹងស្លាប់ដោយមុខដាវ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នានឹងស្លាប់នៅក្នុងសមរភូមិ
ដែលយើងបានសំរេចថានឹងស្លាប់នៅក្នុងសមរភូមិ»
នេប៊ូក្នេសានឹងសម្អាតចេញទាំងអស់នៅទឹកដីអេស៊ីប ដូចគេយកចៃចេញពីអាវរោមសត្វដែរ
«លោកនឹងយកអ្វីៗទាំងអស់ដែលមានតម្លៃពីជនជាតិអេស៊ីប
ដូចជាអ្នកគង្វាលយកចិត្តទុកដាក់នឹងយកសត្វល្អិតចង្រៃចេញពីសម្លៀកបំពាក់របស់គេ»
បេតសេម៉ស
ជាឈ្មោះទីក្រុងមួយ ដែលមានឈ្មោះជា «ទីក្រុងព្រះអាទិត្យ»

---

44 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយេរេមា ឲ្យប្រាប់ ជនជាតិយូដាដែលតាំងទីលំនៅក្នុងអេស៊ីប គឺអ្នកនៅក្រុងមីគដូល ក្រុងថាផ្នេស ក្រុងណូប និងនៅទឹកដី
ប៉ាត្រូសដូចតទៅ។[2]«ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖ «អ្នករាល់គ្នាឃើញគ្រោះកាចទាំងប៉ុន្មាន ដែលយើងបានធ្វើ

generated on Wed Sep 10 16:16:32 2025

ឲ្យកើតមាននៅក្រុងយេរូសាឡឹម និងនៅក្រុងនានាក្នុងទឹកដីយូដា។ មើល៍! សព្វថ្ងៃ ក្រុងទាំងនោះនៅសល់តែគំនរបាក់បែក ហើយគ្មានប្រជាជនរស់នៅទេ។[3]ការទាំងនោះកើតមកដោយសារមនុស្សធ្វើបាប ដោយដុតគ្រឿងក្រអូប គោរពបម្រើព្រះដទៃ។ ជាព្រះដែលពួកគេផ្ទាល់ និងដូនតារបស់ពួកគេពុំធ្លាប់ស្គាល់ផងដែរ។
[4]ដូច្នេះ យើងបានចាត់អ្នកបម្រើទាំងប៉ុន្មានរបស់យើង គឺពួកព្យាការីទៅកាន់ពួកគេ។ យើងចាត់ពួកគេឲ្យប្រាប់ថា៖ កុំប្រព្រឹត្តអំពើគួរឲ្យស្អប់ខ្ពើម ដែលយើងស្អប់នោះឡើយ។[5]ប៉ុន្តែ ពួកគេមិនបានស្តាប់ទេ ហើយក៏មិនងាកចេញពីអំពើអាក្រក់ដែរ ហើយនៅតែដុតគ្រឿងក្រអូបថ្វាយដល់ព្រះដទៃទៀត។[6]ដូច្នេះ កំហឹងរបស់យើងក៏ឆេះឆួលឡើង ដូចភ្លើងឆេះកម្ទេចក្រុងនានា នៅក្នុងទឹកដីយូដា និងផ្លូវទាំងប៉ុន្មាននៅក្រុងយេរូសាឡឹម។ នៅសល់តែគំនរបាក់បែក និងក្លាយទៅជាទីស្មសានដូចសព្វថ្ងៃ»។
[7]ឥឡូវនេះ ព្រះអម្ចាស់ ជាព្រះនៃពិភពទាំងមូល និងជាព្រះនៃជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើការអាក្រក់ទាស់នឹងខ្លួនឯង? ហេតុអ្វីបានជានាំប្រជាជនទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងទារក ចេញពីទឹកដីយូដា? នឹងគ្មានអ្នកណាម្នាក់បានរួចជីវិតឡើយ។
[8]តាមរយៈអំពើអាក្រក់របស់អ្នកបានធ្វើឲ្យយើងខឹងជាមួយ និងទង្វើនៃដៃរបស់អ្នករាល់គ្នាដោយថ្វាយតង្វាយដុតដល់ព្រះផ្សេងជាច្រើន នៅក្នុងទឹកដីអេស៊ីប គឺជាកន្លែងដែលអ្នកបានទៅតាំងទីលំនៅ។ អ្នកបានរស់នៅទីនោះដូច្នេះកន្លែងនោះនឹងត្រូវបំភ្លាញ ដូច្នេះពួកអ្នកនឹងក្លាយទៅជាបណ្តាសារ នៅក្នុងចំណោមប្រជាជាតិនានានៅលើផែនដីនេះ។
[9]តើអ្នករាល់គ្នាភ្លេចអំពើអាក្រក់ដែលដូនតារបស់អ្នករាល់គ្នា ស្តេចទឹកដីយូដា ពួកស្រីស្នំ អ្នករាល់គ្នា និងប្រពន្ធរបស់អ្នករាល់គ្នា បានប្រព្រឹត្តក្នុងទឹកដីយូដា និងនៅតាមដងផ្លូវនៃក្រុងយេរូសាឡឹមហើយឬ?[10]រហូតមកទល់សព្វថ្ងៃ គ្មាននរណាម្នាក់នឹកស្តាយដោយខ្លួនបានធ្វើខុស គ្មាននរណាម្នាក់គោរពកោតខ្លាចយើង ហើយក៏គ្មាននរណាម្នាក់ប្រតិបត្តិតាមក្រឹត្យវិន័យ និងច្បាប់ ដែលយើងប្រគល់ឲ្យអ្នករាល់គ្នា និងដូនតារបស់អ្នករាល់គ្នាដែរ»។
[11]ហេតុនេះហើយបានជាព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖ «យើងសម្រេចចិត្តដាក់ទោសអ្នករាល់គ្នា ហើយលុបបំបាត់ជនជាតិយូដាទាំងមូល។[12]ដ្បិត យើងនឹងប្រហារជនជាតិយូដាដែលនៅសេសសល់ ហើយចេញមករស់នៅក្នុងទឹកដីអេស៊ីប។ ពួកគេនឹងត្រូវវិនាសសូន្យនៅទឹកដីអេស៊ីបនេះ ពួកគេនឹងត្រូវស្លាប់ ដោយមុខដាវ និងដោយទុរ្ភិក្ស។ តាំងពីអ្នកតូចរហូតដល់អ្នកធំ ពួកគេត្រូវវិនាសសូន្យទាំងអស់គ្នា ដោយមុខដាវ និងដោយទុរ្ភិក្ស។ ប្រជាជាតិទាំងឡាយយកឈ្មោះពួកគេ ទៅដាក់បណ្តាសា ជេរប្រមាថ នេះគឺជាការក៏អាក្រក់បំផុត។
[13]ដ្បិត យើងនឹងដាក់ទោសអស់អ្នកដែលរស់នៅក្នុងទឹកដីអេស៊ីប ដូចយើងបានដាក់ទោសអ្នកក្រុងយេរូសាឡឹម ឲ្យស្លាប់ដោយមុខដាវ ដោយទុរ្ភិក្ស និងដោយជំងឺអាសន្នរោគដែរ។[14]ពេលនេះ ក្នុងចំណោមជនជាតិយូដា ដែលនៅសេសសល់ ហើយមករស់នៅទឹកដីអេស៊ីបនេះ គ្មាននរណាម្នាក់រត់រួច និងរស់រានមានជីវិតឡើយ។ ទោះបីពួកគេប្រាថ្នាចង់វិលត្រឡប់ទៅទឹកដីយូដាវិញក្តី ក៏ពួកគេវិលទៅវិញមិនបានដែរ លើកលែងតែមនុស្សមួយចំនួនតិចណាស់ដែលបានរួចជីវិត»។
[15]ក្រោយមក ពួកអ្នកដែលដឹងថាប្រពន្ធរបស់ខ្លួនតែងតែដុតគ្រឿងក្រអូបសែនព្រះដទៃ ព្រមទាំងស្ត្រីៗទាំងអស់ដែលប្រជុំគ្នាយ៉ាងច្រើនកុះករនៅទីនោះ និងប្រជាជនទាំងអស់ដែលរស់នៅក្រុងប៉ាត្រូស ក្នុងទឹកដីអេស៊ីប នាំគ្នាតបទៅលោកយេរេមាវិញ។[16]ពួកគេនិយាយបែបនេះថា៖ «ទោះបីលោកមានប្រសាសន៍មកយើងក្នុងនាមព្រះអម្ចាស់ក្តី ក៏យើងមិនចង់ស្តាប់ពាក្យរបស់លោកដែរ។[17]ដ្បិត យើងចង់ធ្វើអ្វីៗតាមការសម្រេចរបស់យើង គឺដុតគ្រឿងក្រអូប និងច្រួចស្រាសែនម្ចាស់ក្សត្រីនៅស្ថានសួគ៌ដូចយើង និងដូនតារបស់យើង ព្រមទាំងស្តេច និងពួកមន្ត្រីធ្លាប់ធ្វើនៅតាមក្រុងនានាក្នុងទឹកដីយូដា និងនៅតាមដងផ្លូវក្នុងក្រុងយេរូសាឡឹម។ ហើយក្រោយមក យើងនឹងមានអាហារបរិភោគបរិបូណ៌ ហើយនឹងជម្រុងចម្រើន ដោយគ្មានការរងទុក្ខវេទនាអ្វីទេ។
[18]ប៉ុន្តែ តាំងពីពេលដែលយើងឈប់ធ្វើការនោះវិញទេ គឺឈប់ដុតគ្រឿងក្រអូប និងឈប់ច្រួចស្រាសែនម្ចាស់ក្សត្រីនៅស្ថានសួគ៌ យើងខ្វះខាតសព្វគ្រប់ ព្រមទាំងត្រូវវិនាសដោយមុខដាវ និងដោយទុរ្ភិក្សផងដែរ»។[19]ហើយពួកស្ត្រីៗទាំងនោះនិយាយបន្ថែមទៀតថា៖ «ពេលយើងដុតគ្រឿងក្រអូប និងច្រួចស្រាថ្វាយម្ចាស់ក្សត្រីនៅស្ថានសួគ៌នោះ តើនេះមិនមែនប្តីរបស់យើងបានយល់ស្របទាំងស្រុងទេឬ ពេលយើងធ្វើនំឲ្យដូចជារូបរបស់ម្ចាស់ក្សត្រី ហើយថ្វាយព្រះនាង ព្រមទាំងច្រួចស្រា ថ្វាយដល់ស់ម្ចាស់ក្សត្រីផងនោះ?»
[20]ពេលនោះ លោកយេរេមាមានប្រសាសន៍ទៅកាន់ប្រជាជនទាំងមូល ទៅកាន់ទាំងប្រុស ទាំងស្រី និងអស់អ្នកដែលបានឆ្លើយតបមកលោកថា៖
[21]«តើព្រះអម្ចាស់មិនបានចាំ គ្រប់ទាំងគ្រឿងក្រអូបដែលអ្នករាល់គ្នា និងដូនតារបស់អ្នករាល់គ្នា ព្រមទាំងស្តេច មន្ត្រី និងអ្នកស្រុក បានដុតតាមទីក្រុងនានាក្នុងទឹកដីយូដា ហើយនិងនៅតាមដងផ្លូវក្នុងក្រុងយេរូសាឡឹម? ដ្បិត ព្រះអម្ចាស់ក៏បានឃើញ និងចងចាំជានិច្ចផងដែរ។
[22]ក្រោយមក ព្រះអម្ចាស់ពុំអាចទ្រាំនឹងអំពើអាក្រក់ ព្រមទាំងអំពើដ៏គួរឲ្យស្អប់ខ្ពើម ដែលអ្នករាល់គ្នាបានប្រព្រឹត្តនោះ តទៅមុខទៀតឡើយ ហេតុនេះហើយបានជាទឹកដីរបស់អ្នករាល់គ្នាក្លាយទៅជាគំនរបាក់បែក ជាទីស្មសាន ជាដីត្រូវបណ្តាសា ហើយគ្មានមនុស្សរស់នៅដូចសព្វថ្ងៃ។[23]ពីព្រោះអ្នករាល់គ្នាដុតគ្រឿងក្រអូប និងប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យរបស់ព្រះអម្ចាស់ គឺអ្នករាល់គ្នាមិនព្រមស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ មិនប្រតិបត្តិតាមក្រឹត្យវិន័យ ច្បាប់ និងដំបូន្មានរបស់ព្រះអង្គ»។
[24]លោកយេរេមាមានប្រសាសន៍ទៅកាន់ប្រជាជនទាំងមូល និងស្ត្រីៗទាំងនោះថា៖ «ជនជាតិយូដាទាំងអស់ដែលរស់នៅទឹកដីអេស៊ីបអើយ ចូរនាំគ្នាស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។[25]ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលដូចតទៅ៖ អ្នករាល់គ្នា និងប្រពន្ធរបស់អ្នករាល់គ្នាបាននិយាយ ហើយធ្វើតាមពាក្យរបស់ខ្លួនភ្លាម គឺអ្នករាល់គ្នានិយាយថា «យើងចង់ធ្វើតាមពាក្យដែលយើងបន់ស្រន់ ដោយដុតគ្រឿងក្រអូប និងច្រួចស្រាសែនម្ចាស់ក្សត្រីនៅស្ថានសួគ៌»។ ដូច្នេះ នឹងមិនបានតាមការបន់ស្រន់ឡើយ។
[26]សូមស្តាប់ ជនជាតិយូដាទាំងអស់ ដែលរស់នៅទឹកដីអេស៊ីបអើយ មើល៍! ព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងសូមស្បថក្នុងនាមដ៏ឧត្តមរបស់យើងផ្ទាល់ថា៖ យើងលែងឲ្យជនជាតិយូដាណាម្នាក់ ដែលរស់នៅទឹកដីអេស៊ីបយកឈ្មោះយើងមកស្បថ ដោយពោលថា ព្រះជាអម្ចាស់ដ៏មានព្រះជន្មគង់នៅទៀតហើយ។[27]មើល៍! យើងតាមមើលពួកគេ ដើម្បីដាក់ទោស គឺមិនមែនផ្តល់សុភមង្គលទេ។ ប្រជាជនយូដាទាំងអស់ដែលរស់នៅទឹកដីអេស៊ីប នឹងត្រូវវិនាសដោយមុខដាវ និងដោយទុរ្ភិក្ស រហូតដល់ផុតពូជ។
[28]មនុស្សមួយចំនួនតូច ដែលគេចផុតពីមុខដាវនឹងចាកចេញពីទឹកដីអេស៊ីប វិលត្រឡប់ទៅទឹកដីយូដាវិញ។ ដូច្នេះ ជនជាតិយូដាដែលនៅសេសសល់ទាំងប៉ុន្មាន ពីចំណោមអស់អ្នកដែលមករស់នៅទឹកអេស៊ីបនេះ មុខជាដឹងថា ពាក្យរបស់នរណាបានសម្រេចជារូបរាង តើពាក្យរបស់យើង ឬពាក្យរបស់ពួកគេ។
[29]ព្រះអម្ចាស់មានព្រះបន្ទូលទៀតថា យើងនឹងផ្តល់ទីសម្គាល់មួយឲ្យអ្នករាល់គ្នាដឹងថា យើងដាក់ទោសអ្នករាល់គ្នាឲ្យរងទុក្ខវេទនានៅលើទឹកដីនេះ ហើយអ្នករាល់គ្នានឹងដឹងថាអ្វីកើតឡើងគឺស្របតាមពាក្យរបស់យើងមែន។[30]ព្រះអម្ចាស់មានព្រះបន្ទូលបែបនេះថា៖ មើល៍! «យើងនឹងប្រគល់ផារ៉ោនហូប្រា ជាស្តេចទឹកដីអេស៊ីប ទៅក្នុងកណ្តាប់ដៃរបស់អស់អ្នក ដែលចង់ប្រហារជីវិតស្តេចនេះ។ ដូចយើងបានប្រគល់សេដេគា ជាស្តេចទឹកដីយូដា ទៅក្នុងកណ្តាប់ដៃរបស់នេប៊ូក្នេសា ស្តេចទឹកដីបាប៊ីឡូន ជាសត្រូវដែលចង់ប្រហារជីវិតសេដេគាយ៉ាងនោះដែរ គឺសត្រូវគេនឹងតាមប្រមាញ់ជីវិតគេដែរ»។

Jeremiah 44:1
ព័ត៌មានទូទៅ:
សូមមើល: និង
ព្រះបន្ទូលដែលមកដល់លោកយេរេមា
«នេះជាព្រះរាជសារព្រះអម្ចាស់ដែលបានដល់លោកយេរេមា»
មីគដូល ... ថាផ្នេស ... ណូប ... ប៉ាត្រូស
ទាំងនេះជាឈ្មោះទីក្រុង។
អ្នករាល់គ្នាបានឃើញ
ពាក្យថា «អ្នករាល់គ្នា»
ត្រូវបានប្រើសម្រាប់ការបញ្ជាក់ពីប្រជាជនយូដាដែលរស់នៅក្នុងប្រទេសអេស៊ីប។
មើល៍!
«ចូរស្តាប់» ឬ «ចូរយកចិត្តទុកដាក់» ឬ«ត្រូវស្វែងយល់ពីការនេះ»
ពួកគេបានធ្វើឲ្យយើងទាស់ចិត្ត
«ប្រជាជនក្រុងយេរូសាឡឹម និងក្រុងនានានៃស្រុកយូដាបានធ្វើឲ្យយើងទាស់ចិត្ត»
ពួកគេផ្ទាល់
«ប្រជាជនមកពីទីក្រុងដែលបាក់បែក»
Jeremiah 44:4
ដូច្នោះ យើងជាដដែលៗបានចាត់

generated on Wed Sep 10 16:16:32 2025

ពាក្យថា «យើង» សំដៅលើព្រះអម្ចាស់។
ដូច្នោះ កំហឹងរបស់យើងនិងសេចក្ដីក្រោធបានដូចភ្លើងឆេះ
នេះបង្ហាញពីការដាក់ទោសពីព្រះអម្ចាស់ជាអ្វីដែលទ្រង់បានទប់
ប្រៀបដូចទឹកនៅក្នុងធុង ប៉ុន្តែពេលដែលទ្រង់មានកំហឹង
នោះទ្រង់ចាប់ផ្តើមដាក់ទោសលើអស់អ្នកដែលធ្វើទ្រង់ខឹង។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានបញ្ចេញកំហឹង និងកំហឹងរបស់ខ្ញុំ»។
កំហឹងរបស់យើងនិងសេចក្ដីក្រោធ
ពាក្យថា «កំហឹង» និង «សេចក្ដីក្រោធ» មានន័យថាដូចគ្នា
និងបញ្ជាក់ពីកំហឹងដ៏ខ្លាំងរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«កំហឹងដ៏គួរឲ្យភ័យខ្លាចរបស់យើង»។
ពួកគេបានក្លាយជាគំនរបាក់បែក និងបំផ្លាញទាំងអស់
ពាក្យថា «បាក់បែក» និង «បំផ្លាញ» មានន័យថាដូចគ្នា។
ពាក្យទាំងពីរបញ្ជាក់ពីភាពខ្ទេចខ្ទីទាំងស្រុងនៃស្រុកយូដា និងក្រុងយេរូសាឡិម។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង»។
Jeremiah 44:7
ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើការអាក្រក់ទាស់នឹងខ្លួនឯង? ហេតុអ្វីធ្វើខ្លួនអ្នកដាច់ចេញពី
ចំណោមជនជាតិយូដា ទាំងប្រុសទាំងស្រីទាំងក្មេង ហើយនិងទារក?
ព្រះអម្ចាស់ប្រើសំនួរទាំងនេះ ដើម្បីបញ្ជាក់ប្រាប់ប្រជារាស្ត្រអ៊ីស្រាអែលថា
ពួកគេគួរតែឈប់ធ្វើអ្វីដែលនាំឲ្យគេទទួលដាក់ទោស។
ទង្វើនៃដៃរបស់អ្នករាល់គ្នា
មនុស្ស សំដៅលើផ្នែករូបកាយរបស់គេ ដែលប្រើដើម្បីថ្វាយតង្វាយដុត។
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលអ្នកបានធ្វើ»
អ្នកនឹងត្រូវបំផ្លាញ
ការបកប្រែរបៀបផ្សេងទៀត: «ដែលធ្វើឲ្យយើងបំផ្លាញអ្នក»
Jeremiah 44:9
តើអ្នករាល់គ្នាបានភ្លេចអំពើអាក្រក់ដែលដូនតារបស់អ្នករាល់គ្នាបានប្រព្រឹត្ត ដោយស្តេចនៃយូដា
ហើយពួកស្រីស្នំស្តេចទាំងនោះទេ?
ព្រះអម្ចាស់ ស្តីបន្ទោសប្រជារាស្ត្រដោយប្រើសំណួរនេះ។
«អ្នករាល់គ្នាបានភ្លេចពីអំពើអាក្រក់ដែលដូនតារបស់អ្នកបានប្រព្រឹត្ត។
អ្នករាល់គ្នាភ្លេចអំពើអាក្រក់ដែលស្តេចស្រុកយូដា និងស្រីស្នំបានប្រព្រឹត្ត»។
តើអ្នកបានបំភ្លេចការអាក្រក់របស់ខ្លួនអ្នក និងប្រពន្ធរបស់អ្នក ក្នុងទឹកដីនៃយូដា ហើយនិងនៅតាម
ដងផ្លូវនៃក្រុងយេរូសាឡិមហើយឬ?
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាបានភ្លេចអំពើអាក្រក់ដែលអ្នក
និងប្រពន្ធរបស់អ្នកបានប្រព្រឹត្ត ... យេរូសាឡិម»។
ដងផ្លូវនៃក្រុងយេរូសាឡិម
ក្រុងយេរូសាឡិម ត្រូវបានសំដៅទៅលើផ្នែកនៃទីក្រុងដែលមនុស្សបានដើរ។
នេះមានន័យថាប្រជាជនបានធ្វើអំពើអាក្រក់នៅតាមទីសាធារណៈ។
«ក្រុងយេរូសាឡិម» ឬ «ទីសាធារណៈនៃក្រុងយេរូសាឡិម»
Jeremiah 44:11
តាំងមុខរបស់យើងទាស់នឹងអ្នក
ការតាំងចិត្ត បង្ហាញពីមនុស្សមិនផ្លាស់ប្តូរគោលដៅដែលពួកគេកំពុងសម្លឹង។
ការបកប្រែរបៀបផ្សេងទៀត: «ដែលបានតាំងចិត្តទាស់នឹងអ្នក»
ពួកគេនឹងត្រូវដួល
នេះជារបៀបនិយាយសមរម្យដែលបង្ហាញថាអ្នកនឹងត្រូវស្លាប់។
ដោយមុខដាវ
សង្គ្រាមត្រូវសំដៅលើអាវុធដែលត្រូវប្រើដោយទាហាន។
តាំងពីអ្នកតូចរហូតដល់អ្នកធំជាងគេ
មនុស្សដែលតូចតាច
និងអ្នកដែលមានការគោរពនៅក្នុងសង្គមដែលបានត្រូវសំដៅលើអ្នករាល់គ្នា»។
Jeremiah 44:13
ជាមួយដាវ ដោយទុរ្ភិក្ស និងដោយជំងឺអាសន្នរោគ
ពាក្យថា «ដាវ» ត្រូវបានប្រើសំដៅលើការធ្វើសង្គ្រាម។
អ្នកគេចរួចខ្លួនឬបានរួចជីវិត
ពាក្យទាំងពីរ សំដៅលើមនុស្សដូចគ្នា។ អ្នកគេចខ្លួនគឺជាអ្នកដែលបានរត់គេច
ពីអ្នកដែលចង់សម្លាប់ពួកគេ ឬចាប់ពួកគេយកទៅជាឈ្លើយ។
Jeremiah 44:15
ក្រុងប៉ាត្រុស
នេះសំដៅលើឈ្មោះតំបន់មួយនៃប្រទេសអេស៊ីប។
ទោះបីលោកមានប្រសាសន៍មកយើងក្នុងនាមព្រះអម្ចាស់ក្តី យើងនឹងមិនស្តាប់លោកទេ
ការបកប្រែរបៀបផ្សេងទៀត: «យើងមិនគោរពតាមបញ្ញត្តិដែលលោកបានដាក់
ដោយអំណាចរបស់ព្រះអម្ចាស់»
ម្ចាស់ក្សត្រីនៅស្ថានសួគ៌
នេះគឺជាឈ្មោះ
ឬឋានៈដែលបានឱ្យងារទៅព្រះចន្ទដោយប្រជាជនយូដានៅប្រទេសអេស៊ីបដែលបានគោរពបូជាជាព្រះ។
យើងនឹងបានពេញដោយអាហារនិងការរីកចម្រើន ដោយគ្មានបទពិសោធ ពីមហន្តរាយផ្សេងៗឡើយ
ការបកប្រែរបៀបផ្សេងទៀត: «នៅគ្រានោះយើងមានស្បៀងអាហារបរិបូរណ៌
ហើយមិនមានមហន្តរាយអ្វីឡើយ»
យើងនឹងបានពេញដោយអាហារ
«យើងនឹងត្រូវបានបំពេញបានល្អ»
រួចហើយ យើងនឹងបានពេញដោយអាហារនិងការរីកចម្រើន ដោយគ្មានបទពិសោធ
ពីមហន្តរាយផ្សេងៗឡើយ
ប្រជាជនស្រុកយូដាបានគិតថាពួកគេនឹងបានទទួលរីកចំរើន ព្រោះម្ចាស់ក្សត្រីនៅ
ស្ថានសួគ៌នឹងប្រទានពរឲ្យពួកគេប្រសិនបើពួកគេគោរពបូជាទ្រង់។
Jeremiah 44:18
ព័ត៌មានទូទៅ:
ប្រជាជននៅសេសសល់ក្នុងប្រទេសអេស៊ីបនៅតែបន្តនិយាយ។
ដោយចាប់ផ្តើមក្នុងខ ១៩ ដែលម្ចាស់ក្សត្រីបានថ្លែងពីលោកយេរេមា។
ម្ចាស់ក្សត្រីនៅស្ថានសួគ៌
សូមមើលព័ត៌មានពីខាងដើមក្នុង JER 44:15.
តើយើងបានធ្វើរឿងទាំងនេះដោយប្តីរបស់យើងមិនដឹងពីការនេះឬ?
ស្ត្រីទាំងនោះអះអាងថា គ្មានទោសពៃរ៍ឡើយ ដោយព្រោះប្តីរបស់ពួកនាងបានដឹង
និងយល់ព្រម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្តីរបស់យើងដឹងថាយើងកំពុងធ្វើអ្វី»។
Jeremiah 44:20
តើព្រះអម្ចាស់មិនបានចាំទេ
«ព្រះអម្ចាស់ចងចាំ»
នឹងចងចាំជានិច្ច
នេះមានន័យថាព្រះអម្ចាស់ បាននឹកចងចាំរឿងនេះដោយការយកចិត្តទុកដាក់
និងព្រះបញ្ញាញាណរបស់ទ្រង់។
Jeremiah 44:22
មិនអាចអត់ទ្រាំជាមួយវាទៀតទេ
«មិនអាចត្រាប្រណីជាមួយវាទៀតទេ»
អត់មានមនុស្សដែលរស់នៅដូចសព្វថ្ងៃនេះ
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់រស់នៅទីនោះដូចសព្វថ្ងៃនេះទេ»។
ដុតគ្រឿងក្រអូប
ហេតុអ្វីបានជាមនុស្សដុតគ្រឿងក្រអូប ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដុតយញ្ញបូជាទៅព្រះក្លែងក្លាយ»
អ្នករាល់គ្នាមិនបានស្តាប់តាមសម្លេងរបស់ព្រះអង្គទេ
ពាក្យថា «សំលេង» សំដៅលើបញ្ញត្តិរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងមិនស្តាប់បង្គាប់តាមបញ្ញាតិរបស់ព្រះអង្គ»
Jeremiah 44:24
និយាយ ជាមួយនិងមាត់របស់អ្នក ហើយធ្វើចេញជាមួយដៃរបស់អ្នក អ្វីអ្នកនិយាយថា
ការបកប្រែរបៀបផ្សេងទៀត: «និយាយ និងប្រព្រឹត្តតាមអ្វីដែលអ្នកបានសន្យាថា
នឹងនិយាយ និងប្រព្រឹត្តទៅ»
ម្ចាស់ក្សត្រីនៅស្ថានសួគ៌
សូមមើលព័ត៌មានពីខាងដើមក្នុង JER 44:15.
Jeremiah 44:26
មើល៍! យើងបានស្បថក្នុងនាមដ៏ឧត្តមរបស់យើង ព្រះបន្ទូលព្រះអម្ចាស់
«ព្រះនាមដ៏ឧត្តម» របស់ព្រះអម្ចាស់
សំដៅទៅលើភាពល្បីល្បាញនិងកេរ្តិ៍ឈ្មោះរបស់ព្រះអង្គ។
គ្រប់គ្នានៃយូដាក្នុងនៅទឹកដីអេស៊ីប នឹងត្រូវវិនាស
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនមួយចំនួនធំពីស្រុកយូដា...នឹងត្រូវវិនាស»
ដោយមុខដាវ និងដោយទុរ្ភិក្ស
ពាក្យថា «ដាវ» តំណាងអោយអ្នកដែលនឹងស្លាប់ក្នុងសង្គ្រាម ហើយនិង «ទុរ្ភិក្ស»
តំណាងឲ្យអ្នកដែលនឹងស្លាប់ដោយអត់អាហារ។
Jeremiah 44:29
ពាក្យយើងនឹងប្រហារអ្នកជាមួយមហន្តរាយពិត
ការបកប្រែរបៀបផ្សេងទៀត: «ពាក្យរបស់យើងបាននិយាយនឹងកើតឡើង

generated on Wed Sep 10 16:16:32 2025

ហើយអ្នកនឹងមានគ្រោះមហន្តរាយ»
យើងនឹងប្រគល់ផារ៉ោនហូប្រា ជាស្តេចនៃអេស៊ីប ទៅក្នុងកណ្តាប់ដៃរនៃសត្រូវរបស់ទ្រង់
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងប្រគល់ឱ្យសត្រូវរបស់ផារ៉ោនហូប្រាចាប់ទ្រង់»

ហូប្រា
នេះជាឈ្មោះរបស់មនុស្ស»
ជាសត្រូវតាមប្រមាញ់ជីវិតទ្រង់ដែរ
ការបកប្រែរបៀបផ្សេងទៀត: «ហើយនឹងអ្នកដែលចង់សម្លាប់ទ្រង់»។

---

45 [1]នេះជាពាក្យដែលព្យាការីយេរេមាបាននិយាយនឹងបារូក ជាកូននេរីយ៉ា ក្នុងកាលដែលបារូកបានសរសេរពាក្យទាំងនេះ ចុះក្នុងក្រាំងតាមមាត់ព្យាការីយេរេមា គឺនៅក្នុងឆ្នាំទីបួននៃរាជ្យព្រះបាទយេហូយ៉ាគីម ជាបុត្រយ៉ូសៀស ស្តេចយូដា ដោយលោកថ្លែងថា៖[2]«ព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលអំពីអ្នកបារូក អើយ[3]អ្នកពោលថា ខ្ញុំត្រូវវេទនាហើយ! ដ្បិតព្រះអម្ចាស់ធ្វើឲ្យខ្ញុំមានទុក្ខកង្វល់ ថែមពីលើការឈឺចាប់ដែលខ្ញុំកំពុងតែមានស្រាប់ ខ្ញុំថ្ងូររហូតដល់អស់កម្លាំង ខ្ញុំមិនអាចសម្រាកបានទេ។
[4]នេះគឺជាអ្វីដែលអ្នកប្រាប់ដល់គេ៖ ព្រះអម្ចាស់បានមានបន្ទូលការនេះ៖ យើងនឹងមិនកម្ទេចចោលនូវអ្វីៗដែលយើងបានសង់ឡើយ យើងនឹងដកចោលនូវអ្វីៗដែលយើងបានដាំ យើងធ្វើដូច្នេះនៅលើផែនដីទាំងមូល។[5]ប៉ុន្តែអ្នក តើអ្នកប្រាថ្នាចង់បានភាពឧត្តុង្គឧត្តមឬ? កុំមានបំណងដូច្នេះទៀតឡើយ។ ដ្បិតយើងនឹងធ្វើឲ្យទុក្ខវេទនា កើតមានដល់សត្វលោកទាំងមូល នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ តែយើងនឹងឲ្យអ្នកបានរួចជីវិត នៅគ្រប់ទីកន្លែងដែលអ្នកទៅ»។

Jeremiah 45:1
ព័ត៌មានទូទៅ:
សូមមើល: និង
បារូក ... នេរីយ៉ា
ទាំងនេះជាឈ្មោះរបស់មនុស្ស។
តាមមាត់ព្យាការីយេរេមា
បារូកបានសរសេរតាមអ្វីដែលលោកយេរេមាបានថ្លែង។
ក្នុងឆ្នាំទីបួននៃរាជ្យព្រះបាទយេហូយ៉ាគីម
«ក្នុងគ្រាដែលយេហូយ៉ាគីម បានគ្រប់គ្រងស្រុកយូដាអស់រយៈពេលបួនឆ្នាំ»
លោកថ្លែងថា
«លោកយេរេមាថ្លែងទៅបារូក»
បន្ថែមលើការឈឺចាប់របស់ខ្ញុំ
«ធ្វើឲ្យខ្ញុំឈឺចាប់ឈឺចាប់កាន់តែខ្លាំង»
ការស្រែកថ្ងូររបស់ខ្ញុំបានធ្វើឲ្យខ្ញុំខ្វាល់
«ខ្ញុំបាននឿយហត់ពីការយំ»

Jeremiah 45:4
នេះគឺជាអ្វីដែលអ្នកត្រូវប្រាប់ដល់គាត់
ព្រះអម្ចាស់មានបន្ទូលប្រាប់លោកយេរេមា ពីអ្វីដែលត្រូវប្រាប់ដល់បារូក
យើងធ្វើដូច្នេះនៅលើផែនដីទាំងមូល
ការបកប្រែរបៀបផ្សេងទៀត: «នេះបានកើតឡើងទូទាំងផែនដី»
ប៉ុន្តែតើអ្នកសង្ឃឹមសម្រាប់អស្ចារ្យដល់ខ្លួនអ្នកឬ?
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមិនសង្ឃឹមពីការធំដែលបានកើតឡើងចំពោះអ្នក»
ដ្បិតមើល៍!
ការបកប្រែរបៀបផ្សេងទៀត: «ចូរស្វែងយល់»
ប្លន់របស់អ្នក
អ្វីមួយដែលត្រូវបានលួចពីកន្លែងមួយដោយប្រើកម្លាំង
ជីវិតរបស់អ្នក ដូចប្លន់របស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងអនុញ្ញាតឱ្យអ្នកអាចរស់នៅ។
នោះនឹងជាអ្វីដែលអ្នកបានរំពឹងទុក»។

---

46 [1]នេះជាព្រះបន្ទូលដែលព្រះអម្ចាស់ថ្លែងមកកាន់លោកយេរេមា ទាក់ទងនិងប្រជាជាតិផ្សេងៗ។[2]នៅឆ្នាំទីបួននៃរជ្ជកាលព្រះបាទយេហូយ៉ាគីម ជាបុត្ររបស់ព្រះបាទយ៉ូសៀស ស្តេចទឹកដីយូដា ព្រះចៅផារ៉ោននេកោ ជាស្តេចទឹកដីអេស៊ីប ស្ថិតនៅក្រុងកើកេមីសជិតទន្លេអឺប្រាត ហើយច្បាំងចាញ់ព្រះចៅនេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន។ ព្រះអម្ចាស់មានព្រះបន្ទូលស្តីអំពីទឹកដីអេស៊ីប និងកងទ័ពរបស់ព្រះចៅផារ៉ោននេកោដូចតទៅ៖[3]ចូរតម្រៀបគ្នាជាក្បួនទ័ពតូច ឬធំ ចូររៀបចំខ្លួនចូលច្បាំង។[4]ទ័ពសេះត្រូវចងបង្កៀរសេះ ហើយឡើងជិះទៅ ចូរតម្រៀបគ្នាជាជួរ ពាក់មួកដែក សំលៀងមុខលំពែង ហើយពាក់អាវក្រោះទៅ។
[5]ហេតុអ្វីបានជាយើងឃើញពួកគេ ធ្លាក់ទឹកចិត្តដូច្នេះ? ពួកគេនាំគ្នាដកទ័ពថយ ទាហានដ៏ខ្លាំងពូកែត្រូវខ្ទាំងសម្លាប់ ពួកគេបាក់ទ័ពរត់ ឥតបែរក្រោយឡើយ។ ការព្រឺខ្លាចស្ថិតនៅគ្រប់ទីកន្លែង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់[6]អ្នករត់លឿនពុំអាចរត់រួចខ្លួនឡើយ ហើយពួកទាហានរបស់ក៏ពុំអាចគេចខ្លួនបានដែរ។ ពួកគេនឹងជំពប់ដួលត្រង់នៅទិសខាងជើង ដែទន្លេអឺប្រាត។
[7]តើនរណាប្រៀបដូចទន្លេនីលជន់ជោរឡើង ហើយប្រៀបដូចទឹកទន្លេហូរលិចច្រាំង?[8]គឺអេស៊ីបនេះហើយដែលប្រៀបដូច ទន្លេនីលជន់ជោរឡើង ហើយប្រៀបដូចទឹកទន្លេហូរលិចច្រាំង។ អ្នកនៅអេស៊ីបថា៖ ខ្ញុំនឹងជន់ឡើងលិចផែនដី។ ខ្ញុំនឹងវាយក្រុង និងសម្បត្តិទ្រព្យទាំងអស់។[9]ចូរនាំគ្នាឡើងជិះសេះ វាយសម្រុកទៅ! រទេះចម្បាំង។ ចូរសម្រុកទៅមុខយ៉ាងលឿន! ទាហានដ៏ខ្លាំងពូកែ ពីទឹកដីអេត្យូពី ទឹកដីពូធ ដែលជាអ្នកកាន់ខែល និងទាហានពីទឹកដីលូឌដែលជាអ្នកបាញ់ព្រួញចូរនាំគ្នាចេញទៅដែរ។
[10]នៅថ្ងៃនោះគឺជាថ្ងៃសងសឹក ដ្បិតព្រះជាអម្ចាស់នៃពិភពទាំងមូល ហើយព្រះជាម្ចាស់នឹងសងសឹកទៅលើខ្មាំងសត្រូវរបស់ព្រះអង្គ។ មនុស្សជាច្រើននឹងស្លាប់ដោយមុខដាវ។ ហើយមានឈាមដាបគ្រប់ទិសទី។ ដ្បិត នៅទីនោះនឹងមានយញ្ញបូជា ថ្វាយដល់ ព្រះអម្ចាស់ដ៏ជាព្រះនៃពិភពទាំងមូល នៅក្នុងទឹកដីខាងជើង តាមមាត់ទន្លេអឺប្រាត។
[11]ឱកូនស្រីក្រមុំនៃទឹកដីអេស៊ីព្ទអើយ ចូរឡើងទៅឯទឹកដីកាឡាត យកប្រទាលមុខសះចុះ អ្នកនឹងប្រើថ្នាំច្រើនមុខ ជាឥតប្រយោជន៍ទេ អ្នកនឹងមើលខ្លួនមិនជាឡើយ។
[12]ប្រជាជាតិនានាទទួលដំណឹងថា អ្នកត្រូវអាម៉ាស់ ព្រោះសម្រែករបស់អ្នក លាន់ឮពាសពេញលើផែនដី។ ទាហានដ៏ខ្លាំងពូកែរត់បុកគ្នា ដួលស្លាប់ទាំងពីរនាក់»។
[13]នេះជាព្រះបន្ទូលដែលព្រះអម្ចាស់បានថ្លែងប្រាប់ដល់ព្យាការីយេរេមាអំពីព្រះចៅនេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន ត្រូវទៅវាយទឹកដីអេស៊ីប៖[14]«ចូរប្រកាសនៅទឹកដីអេស៊ីប ចូរប្រាប់ឲ្យគេដឹងនៅក្រុងមីគដូល ចូរប្រាប់ឲ្យគេដឹងនៅក្រុងណូប និងក្រុងថាផ្នេស! ត្រូវពោលថា ចូររៀបចំខ្លួន និងត្រៀមខ្លួនទៅ ដ្បិតដាវនៃសង្គ្រាមផ្ទុះឡើងនៅជុំវិញអ្នកហើយ។
[15]ហេតុអ្វីបានជាព្រះគោ ដ៏ខ្លាំងពូកែរបស់អ្នក បែរជាអោនមុខទៅដីដូច្នេះ? ពួកព្រះទាំងនោះគឺមិនអាចឈរបានទេ នៅពេលព្រះអម្ចាស់ផ្តួលគេ ឲ្យរលំទៅលើដីនោះ។
[16]ព្រះជាម្ចាស់ក៏បានធ្វើមនុស្សចំនួនច្រើនភ័យញ័រ។ ទាហានបានដួលលើគ្នាម្តងមួយៗ។ ពួកគេបានទាំងពោលថា ចូរយើងក្រោកឡើង។ ត្រឡប់ទៅផ្ទះយើងវិញ។ សូមឲ្យយើងត្រឡប់ទៅរកអ្នកស្រុក និងមាតុភូមិរបស់យើងវិញ។ ដើម្បីគេចឲ្យផុតពីសង្គ្រាមដ៏សាហាវនេះ។[17]ពួកបានគេប្រកាសថា ព្រះចៅផារ៉ោន ជាស្តេចទឹកដីអេស៊ីប គឺបានតែសម្លេង គឺជាស្តេចដែលមានត្រចៀកសរ។
[18]ព្រះមហាក្សត្រដែលមានព្រះនាមថា ព្រះអម្ចាស់នៃពិភពទាំងមូល មានព្រះបន្ទូល ដោយយកព្រះជន្មរបស់ ព្រះអង្គផ្ទាល់ជាសាក្សីថា តាបោរ ពិតជាភ្នំមួយក្នុងចំណោមភ្នំឯទៀតៗ ហើយភ្នំកើមែលនៅជាប់នឹងសមុទ្រយ៉ាងណា។[19]ប្រជាជនទឹកដីអេស៊ីប ចូរវេចបង្ហែទៅ ដ្បិតខ្មាំងនឹងកៀរអ្នកទៅជាឈ្លើយ។ ក្រុងណូបនឹងក្លាយទៅជាទីស្មសាន ជាកន្លែងដែលឆេះខ្ទេចខ្ទី គ្មាននរណារស់នៅ។
[20]ទឹកដីអេស៊ីបប្រៀបបាននឹងគោញីស្អាតដ៏ស្អាត តែនឹងមានមូសដ៏សាហាវ។ ពីទិសខាងជើងមកខាំ។[21]ពួកទាហានដែលទឹកដីអេស៊ីបជួលមកច្បាំង ឲ្យពួកគេ សុទ្ធតែមានសាច់មានឈាមដូចគោបំប៉ន តែទាហានទាំងនោះក៏បកក្រោយដែរ គេរត់ទាំងអស់គ្នា។ គ្មាននរណាស៊ូទ្រាំបានទេ ដ្បិតថ្ងៃមហន្តរាយ គឺជាពេលដែលយើងដាក់ទោសពួកគេ បានធ្លាក់មកលើពួកគេហើយ។[22]ពេលសត្រូវលើកទ័ពមកវាយលុកពួកគេ កងទ័ពអេស៊ីបនាំគ្នារត់ទៅយ៉ាងស្ងៀមស្ងាត់ ដូចពស់ដែលកំពុងលូន។ សត្រូវមកវាយពួកគេ ដូចអ្នកកាប់អុស កាន់ពូថៅ បម្រុងកាប់រំលំដើមឈើ។

generated on Wed Sep 10 16:16:32 2025

[23]ទ័ពសត្រូវនាំគ្នាកាប់ព្រៃឈើ នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ ទោះបីព្រៃនោះពិបាកចូលក៏ដោយ។ ដ្បិតពួកសត្រូវមានចំនួនច្រើនឥតគណនា គឺច្រើនជាងហ្វូងកណ្តូប
ទៅទៀត ហើយមិនអាចរាប់បាននោះទេ។[24]ប្រជាជននៅទឹកដីអេស៊ីបត្រូវអាម៉ាស់។ ពួកគេធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ជនជាតិ ដែលមកពីទិសខាងជើង»។
[25]ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖ «យើងនឹងដាក់ទោសអាំម៉ូន ជាព្រះនៃក្រុងណូ ព្រមទាំងផារ៉ោន ជាស្តេចទឹកដីអេស៊ីប
គឺយើងដាក់ទោសព្រះ និងស្តេចទឹកដីអេស៊ីប យើងដាក់ទោសផារ៉ោន និងអស់អ្នកដែល ផ្ញើជីវិតលើស្តេចនេះ។[26]យើងនឹងប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ អស់អ្នក
ដែលចង់ប្រហារជីវិតពួកគេ គឺក្នុងកណ្តាប់ដៃរបស់នេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន និងក្នុងកណ្តាប់ដៃនាយទាហានរបស់គេ។ ក្រោយមកទៀត ទឹកដីអេស៊ីបនឹងមាន
មនុស្សរស់នៅ ដូចកាលពីមុន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[27]យ៉ាកុបជាអ្នកបម្រើរបស់យើងអើយ កុំភ័យខ្លាចអ្វីឡើយ! កូនចៅអ៊ីស្រាអែលអើយ កុំអស់សង្ឃឹម យើងនឹងសង្គ្រោះអ្នកឲ្យវិលត្រឡប់ មកពីទឹកដីដ៏ឆ្ងាយវិញ យើងនឹង
សង្គ្រោះពូជពង្សរបស់អ្នក ពីទឹកដីដែលគេជាប់ជាឈ្លើយ។ កូនចៅយ៉ាកុបនឹងវិលមកវិញ គេនឹងរស់នៅយ៉ាងសុខក្សេមក្សាន្ត គ្មាននរណាមកធ្វើទុក្ខគេទៀតឡើយ។
[28]យ៉ាកុបជាអ្នកបម្រើរបស់យើងអើយ កុំភ័យខ្លាចអ្វីឡើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងស្ថិតនៅជាមួយអ្នក យើងនឹងលុបបំបាត់ប្រជាជាតិនានា ដែលយើងបាន
កម្ចាត់កម្ចាយអ្នក ឲ្យទៅនៅក្នុងចំណោមពួកគេ តែយើងមិនលុបបំបាត់អ្នកឡើយ។ យើងបានដាក់ទោសអ្នកដោយយុត្តិធម៌ យើងមិនអាចចាត់ទុកអ្នកថា គ្មានទោសបាន
ទេ»។

Jeremiah 46:1

ដ្បិត ទឹកអេស៊ីប

ឃ្លានេះបង្ហាញពីព្រះរាជសារដែលត្រូវបានបម្រុងទុកសម្រាប់ប្រទេសអេស៊ីប។

កើកេមីស

កើកេមីសគឺជាទីក្រុងមួយនៅភាគខាងលិចនៃទន្លេអឺប្រាត។

បង្អៀរសេះ

នេះមានន័យថាត្រៀមសេះសម្រាប់អូសទាញរទេះសេះដែលជារទេះចំបាំងដែលមានកង់ពីរ។

មួកដែក

មួកសុវត្ថិភាពគឺជាគ្រឿងសឹកដែលការពារក្បាលក្នុងសមរភូមិ។

ខាត់មុខលំពែង

ឃ្លានេះមានន័យថា ធ្វើឲ្យលំពែង «មុត»។

Jeremiah 46:5

ព័ត៌មានទូទៅ:

និមិត្តលោកយេរេមាបន្តចំពោះអេស៊ីប។

តើយើងបានកំពុងឃើញអ្វីនៅទីនេះ?

ពាក្យថា «យើង» នៅទីនេះសំដៅទៅលើព្រះអម្ចាស់។

ព្រះអម្ចាស់សួរសំណួរបញ្ឈឺចិត្តនេះ
ដើម្បីបញ្ជាក់ពីអ្វីដែលទ្រង់មានបន្ទូលទាក់ទងនឹងជនជាតិអេស៊ីបបានក្លាយជាការពិត។

អ្នករត់លឿនក៏មិនអាចរត់រួចដែរ ហើយពួកទាហានក៏មិនអាចគេចខ្លួនបានដែរ

ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នាដែលបញ្ជាក់ពី
គ្មាននរណាម្នាក់សូម្បីតែអ្នកខ្លាំង និងរហ័សអាចរត់គេចបាន។
ការបកប្រែរបៀបផ្សេងទៀត: «សូម្បីតែទាហានរហ័សបំផុត
ក៏មិនអាចរត់រួចបានដែរ»។

Jeremiah 46:7

ព័ត៌មានទូទៅ:

លោកយេរេមាបន្តដកស្រង់ព្រះបន្ទូលរបស់ព្រះអម្ចាស់ដល់ជនជាតិអេស៊ីប។

តើនរណាដែលងើបឡើងដូចទន្លេនីល

ការបកប្រែរបៀបផ្សេងទៀត: «អេស៊ីបងើបឡើង ប្រៀបដូចជាទន្លេនីល»។
ព្រះអម្ចាស់សួរសំណួរនេះដើម្បីទាញចំណាប់អារម្មណ៍របស់អ្នកស្តាប់
ចំពោះជនជាតិអេស៊ីប។

អេស៊ីបនេះហើយដែលងើបឡើងដូចជាទន្លេនីល

កងទ័ពអេស៊ីប

ត្រូវបានប្រៀបធៀបទៅនឹងការបំផ្លាញដែលបណ្តាលមកពីទឹកជំនន់ទន្លេនីល។

អេស៊ីបនិយាយថា

ប្រទេសអេស៊ីបកំពុងនិយាយ ប្រៀបដូចជាមនុស្ស។

ខ្ញុំនឹងជន់ឡើងលិចផែនដីនេះ។ ខ្ញុំនឹងបំផ្លាញទីក្រុងទាំងឡាយ និងសម្បត្តិទ្រព្យរបស់គេ។

«ខ្ញុំ»

តំណាងជនជាតិអេស៊ីបដែលប្រកាសដោយមោទនភាពថាកងទ័ពរបស់ខ្លួននឹងបំផ្លាញ

ចូរឡើងទៅលើសេះ។ ចូរខឹង! រទេះចម្បាំង

ព្រះអម្ចាស់បញ្ជាសេះនិងរទេះដូចជាមនុស្ស។ ទាំងពាក្យថា «សេះ» និង
«រទេះចម្បាំង» គឺសំដៅលើផ្នែកនៃរទេះសេះក្នុងសមរភូមិ។
ឃ្លាទាំងនេះបង្គាប់អ្នកកាន់រទេះសេះឲ្យចូលក្នុងសមរភូមិ។

អេត្យូពី ... ពូធ ... លូឌដែម

ទាំងនេះគឺជាឈ្មោះក្នុងព្រះគម្ពីរសម្រាប់ជនជាតិនៃអេត្យូពី លីប៊ី និងលីឌា។

បាញ់ព្រួញរបស់ពួកគេ

ឃ្លានេះមានន័យថាប្រើធ្នូ ដោយទាញខ្សែមកក្រោយជាមួយព្រួញ។

Jeremiah 46:10

ព័ត៌មានទូទៅ:

ការដកស្រង់របស់លោកយេរេមាបន្តព្រះបន្ទូលរបស់ព្រះអម្ចាស់ដល់ជនជាតិអេស៊ីប។

នៅថ្ងៃនោះ

ឃ្លានេះសំដៅលើថ្ងៃដែលពួកជនជាតិអេស៊ីបចាញ់សង្គ្រាមជាមួយពួកបាប៊ីឡូន។

ខ្មាំងសត្រូវរបស់ព្រះអង្គ

ឃ្លានេះមានន័យថាជាសត្រូវរបស់ព្រះអម្ចាស់។

ដាវនឹងត្របាក់លេបហើយដោយពេញចិត្ត។ ហើយនិងផឹកឈាមរបស់ពួកគេ

ពាក្យថាដាវនៅទីនេះបញ្ជាក់ថាជាការសម្លាប់មនុស្ស។
ឃ្លាទាំងពីរនេះថ្លែងស្រដៀងគ្នាហើយត្រូវបានបញ្ចូលគ្នា
ដើម្បីបញ្ជាក់ថានឹងមានការបំផ្លាញទាំងស្រុង។

ដាវនឹងត្របាក់លេប

ពាក្យថា «ដាវ» នៅទីនេះតំណាងឲ្យកងទ័ពរបស់ជនជាតិបាប៊ីឡូន។

មានយញ្ញបូជាថ្វាយដល់ព្រះអម្ចាស់

ពាក្យថា «យញ្ញបូជា»នៅទីនេះគឺជនជាតិអេស៊ីប។ ការបកប្រែរបៀបផ្សេងទៀត:
«អេស៊ីបនឹងក្លាយជាយញ្ញបូជាដល់ព្រះអម្ចាស់»។

Jeremiah 46:11

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បញ្ចប់មានព្រះបន្ទូលរបស់ព្រះអង្គទៅកាន់ជនជាតិអេស៊ីប។

កូនក្រមុំនៃអេស៊ីបអើយ

ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអេស៊ីបដែលបរិសុទ្ធអើយ»។

ត្រូវអាម៉ាស់

ពាក្យនេះមានន័យជាលក្ខណៈនៃការខ្មាស់អៀន ឬការបាត់បង់ការគោរព។

ផែនដីទាំងមូលបានពេញជាមួយការសោកស្តាយអ្នក

ការបកប្រែរបៀបផ្សេងទៀត: អ្នករាល់គ្នាអាចលីពីយំសោករបស់អ្នក។

Jeremiah 46:13

មីគដូល ...ណូប...ថាផ្នេស

ទាំងនេះគឺជាទីក្រុងរបស់កងទ័ពសំខាន់ៗនៅអេស៊ីប។ មែនភីស
គឺជារាជធានីនៃប្រទេសអេស៊ីប។

ដាវនឹងត្របាក់លេបអ្នកនៅជុំវិញអ្នកហើយ

ពាក្យថា «ដាវ» នៅទីនេះតំណាងឲ្យកងទ័ពបាប៊ីឡូន។ ឃ្លាថា
«ដាវនិងលេបត្របាក់» គឺ «ធ្វើឲ្យមានការបំផ្លាញ»។ ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពបាប៊ីឡូនកំពុងតែបំផ្លាញ»។

Jeremiah 46:15

ហេតុអ្វីបានជាព្រះអាភីសរបស់អ្នករត់ចេញ?

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអាភីស របស់អ្នករត់ចេញ»។

អាភីស (Apis)

នេះជាឈ្មោះដែលជនជាតិអេស៊ីបប្រើសម្រាប់គោក្នុងប្រទេសអេស៊ីប។ ពាក្យថា «អាភីស» តំណាងឲ្យ
«ភាពខ្លាំងខ្លាដែលអ្នកបានទុកចិត្ត» (UDB) នៃជនជាតិអេស៊ីប។

ហេតុអ្វីបានជាព្រះគោ - ព្រះរបស់អ្នកមិនឈរ?

ព្រះមិនបានឈរ? - ការបកប្រែរបៀបផ្សេងទៀត: «ព្រះគោ
របស់អ្នកមិនអាចឈរបានទេ» អាភីសតំណាងជារូបព្រះដូចជាសត្វគោ។

ព្រះអម្ចាស់បានបោះចោលរូបព្រះគោទាំងនោះ

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានយកឈ្នះលើអាភីស
ជាព្រះគោរបស់អ្នក។»

ដាវកាប់ផ្តួលយើងចុះ

generated on Wed Sep 10 16:16:32 2025

ពាក្យថា «ដាវ» សំដៅលើកងទ័ពបាប៊ីឡូន។
ផារ៉ោន ជាស្តេចទឹកដីអេស៊ីប គឺបានតែសម្លេង គឺជាស្តេចដែលរកតែពេលរត់ចេញបាត់
ឃ្លាទាំងពីរនេះថ្លែងពីជនជាតិអេស៊ីបមានសារៈសំខាន់តិចតួចណាស់។
ការបកប្រែរបៀបផ្សេងទៀត: «ផារ៉ោនអួតច្រើនដង
ប៉ុន្តែមិនអាចធ្វើអ្វីដែលគាត់បានអួតបានឡើយ»។
Jeremiah 46:18
គេនឹងមកដូចភ្នំតាបោរ ហើយភ្នំកើមែលនៅជាប់នឹងសមុទ្រ
នេះសំដៅទៅលើ
ជនជាតិបាប៊ីឡូនដែលនឹងមានចំនួនច្រើនលើសលប់ចំពោះជនជាតិអេស៊ីប
ដូចភ្នំទាំងនេះស្ថិតនៅលើវាលទំនាបដែលព័ទ្ធជុំវិញពួកវា។
ចូររៀបចំបង្ខេចរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «រៀបចំចេញដំណើរ»
Jeremiah 46:20
អេស៊ីបគឺដូចគោញីស្ទាវដ៏ស្អាត
ជនជាតិអេស៊ីប ត្រូវបានប្រៀបធៀបទៅនឹងគោញីស្ទាវដ៏ស្អាត។
មានន័យថាការប្រៀបធៀបនេះត្រូវបានធ្វើឡើងដើម្បីឲ្យប្រទេសអេស៊ីបក្លាយជាមិត្តរបស់ប៉ាឡេស្ទីន
ការបកប្រែរបៀបផ្សេងទៀត: «អេស៊ីបគឺប្រៀបដូចជាមេគោដ៏ស្រស់ស្អាតបំផុត»។
នឹងមានមូសដ៏សាហាវ
នេះសំដៅលើកងទ័ពរបស់ជនជាតិបាប៊ីឡូន។ សត្វមូសដ៏
សាហាវអាចបណ្តាលឲ្យមានដំបៅឈឺចាប់ប៉ុន្តែបើវាមិនបង្កគ្រោះថ្នាក់ដល់សត្វនោះទេ។
ពួកទាហានស៊ីឈ្នួលដែលនៅកណ្តាលក្រុង ឲ្យពួកគេសុទ្ធតែមានសាច់មានឈាមបំប៉ន ដូចគោ
អ្នកនិពន្ធប្រៀបធៀបពួកទាហានទាំងនោះទៅនឹង «គោបំប៉ន»
ពីព្រោះទាហានត្រូវបានគេយកចិត្តទុកដាក់ និងត្រៀមខ្លួនសម្រាប់ការធ្វើឃាត។
គ្មាននរណាស៊ូទ្រាំជាមួយគ្នាទេ
អ្នកនិពន្ធថ្លែងពីទាហានដែលមិនប្រយុទ្ធថាជាក្រុមមួយ
ប៉ុន្តែនឹងរត់គេចចេញដោយគិតតែធ្វើខ្លួនឯងរួចខ្លួនសិន។
អេស៊ីបគួរឲ្យអាសូ ដូចពស់ដែលកំពុងលូនចេញ
អ្នកនិពន្ធថ្លែងពីជនជាតិអេស៊ីប
គឺប្រៀបដូចជាពស់ដែលមិនអាចធ្វើអ្វីបានក្រៅពីគួរឲ្យអាសូ
ហើយលូនចេញឆ្ងាយដោយភ័យខ្លាច
នៅពេលអ្នកកាប់ឈើរំខានដល់សំបុករបស់ពួកវា។
Jeremiah 46:23
ទ័ពសត្រូវនាំគ្នាកាប់ព្រៃឈើ
កងទ័ពឈ្លានពាន ប្រៀបដូចជាអ្នកកាប់ឈើកាប់ព្រៃទាំងមូល។
ការបកប្រែរបៀបផ្សេងទៀត: «កងទ័ពបាប៊ីឡូន
នឹងបំផ្លាញទីក្រុងនានានៅស្រុកអេស៊ីប»។
ទ័ពសត្រូវ
នេះសំដៅលើកងទ័ពនៃជនជាតិបាប៊ីឡូនដែលឈ្លានពានអេស៊ីប។
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត:
«នេះគឺជាអ្វីដែលព្រះអម្ចាស់បានបន្ទូល» (សូមមើល:ពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧)
ព្រៃនោះពិបាកចូលក៏ដោយ
នេះសំដៅលើចំនួនដ៏ច្រើន និងនៅកៀសគ្នានៃទីក្រុងនានាក្នុងប្រទេសអេស៊ីប
ហ្វូងកណ្តូប
នេះជាប្រភេទសត្វល្អិតដែលធ្វើដំណើរជាក្រុមធំៗ
ហើយស៊ីបំផ្លាញផលដំណាំយ៉ាងខ្លាំង។
ប្រជាជន...ត្រូវអាម៉ាស់
លោកយេរេមាថ្លែងពីប្រជាជនអេស៊ីបនឹងត្រូវអាម៉ាស់មុខនៅចំពោះមុខប្រជាជាតិនានាហើយជាពិសេសដេ
និងក្មេងស្រីនឹងត្រូវបានរំលោភដោយកងទ័ពបាប៊ីឡូន។
កណ្តាប់ដៃរបស់ជនជាតិ ដែលមកពីទិសខាងជើង
ឃ្លានេះមានន័យថា «អំណាចរបស់ជនជាតិបាប៊ីឡូនដែលមកពីភាគខាងជើង»។
Jeremiah 46:25
ទិព
«អាំម៉ូន» គឺជាស្តេចនៃព្រះអេស៊ីប។ «ទិពប៊ី» គឺជារដ្ឋធានីនៃអេស៊ីប
ហើយនៅទីនេះតំណាងឲ្យចក្រភពអេស៊ីបទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត:
«អាំម៉ូន ជាព្រះលើអេស៊ីបទាំងអស់»
យើងនឹងប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ អស់អ្នកដែលចង់ប្រមាញ់ជីវិតពួកគេ ហើយក្នុង
កណ្តាប់ដៃរបស់នេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន និងក្នុងកណ្តាប់ដៃនាយទាហានរបស់ទ្រង់
នៅទីនេះនេប៊ូក្នេសាតំណាងឲ្យជនជាតិបាប៊ីឡូនទាំងមូល ហើយ «កណ្តាប់ដៃ»
របស់លោកតំណាងឲ្យ «ការគ្រប់គ្រង»។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ប្រគល់ការគ្រប់គ្រងអេស៊ីបដល់ជនជាតិបាប៊ីឡូន»។
បន្ទាប់ពីនេះអេស៊ីបនឹងមានមនុស្សរស់នៅដូចកាលពីមុន
ការបកប្រែរបៀបផ្សេងទៀត: «ក្រោយពីការដាក់ទោសរបស់ព្រះអម្ចាស់
ជនជាតិអេស៊ីបនឹងវិលត្រឡប់មកជាជនជាតិមានឯករាជ្យវិញ»។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៩។
Jeremiah 46:27
អ្នកបម្រើរបស់យើងយ៉ាកុប កុំភ័យខ្លាចអ្វីឡើយ។ កុំអស់សង្ឃឹមអ៊ីស្រាអែល
ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
ឃ្លាទាំងពីររួមគ្នាបង្កើនការលើកទឹកចិត្តដល់ជនជាតិយូដា កុំឲ្យភ័យខ្លាច។
(សូមមើល: និងfigs-parallelism)
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
មិនចាកចេញពីអ្នក មិនដាក់ទោសទេ
«នឹងដាក់ទោសអ្នកជាមិនខាន។»

---

47 [1]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ មកកាន់លោកយ៉ាការីយេរេមា និយាយអំពីជនជាតិភីលីស្ទីន។ ព្រះបន្ទូលទាំងនេះបានដល់លោក មុនពេលព្រះចៅផារ៉ោនមក
វាយក្រុងកាសា។ «ព្រះអម្ចាស់មានព្រះបន្ទូលថា៖ មើល៍! មានទឹកជន់ឡើងនៅទិសខាងជើង។[2]ហើយក្លាយទៅជាទន្លេហូរយ៉ាងខ្លាំង លិចទឹកដី និងអ្វីៗដែលនៅ
ក្នុងទឹកដី លិចក្រុងនានា និងប្រជាជន នៅក្នុងក្រុងព្រមទាំងទ្រព្យសម្បត្តិផង មនុស្សម្នានាំគ្នាស្រែករកជំនួយ អ្នកទឹកដីទាំងមូលបន្លឺសំឡេងយ៉ាងរន្ធត់។
[3]ព្រោះឮស្នូរសន្ធឹកជើងសេះ និងសន្ធឹកកង់រទេះចម្បាំងលាន់ឮយ៉ាងទ្រហឹង អឺងអាប់ដូចផ្គរលាន់ ហើយឪពុកវិញក៏មិនអាចជួយកូនៗរបស់ពួកគេបានដែរ
ដោយសារតែពួកមិនមានកម្លាំងគ្រប់គ្រាន់។[4]ដ្បិត នៅថ្ងៃដែលទឹកដីភីលីស្ទីនត្រូវហិនហោច បានមកដល់ហើយ! ថ្ងៃនោះ អ្នកក្រុងទីរ៉ុស និងអ្នកក្រុងស៊ីដូន នឹងគ្មាននរណា
មកជួយពួកគេទៀតឡើយ។ ដ្បិតព្រះអម្ចាស់កម្ទេចទឹកដីភីលីស្ទីន គឺពួកអ្នកដែលនៅសេសសល់ពីកោះកាប់ថោរ។
[5]ក្រុងកាសាគ្មាននៅសល់អ្វីសោះ ក្រុងអាស្កាឡូនក្លាយទៅជាទីស្ងាត់ជ្រងំ។ អ្នកទឹកដីវាលទំនាប ដែលនៅសេសសល់អើយ តើអ្នកនៅតែឆូតសាច់របស់ខ្លួន ដល់កាលណា
ទៀត?[6]អ្នករាល់គ្នាពោលថា ដាវរបស់ព្រះអម្ចាស់អើយ ដល់ពេលណាទើបសម្រាក? ចូរចូលទៅក្នុងស្រោមវិញ ហើយសម្រាកឲ្យស្ងៀមទៅ។[7]បើព្រះអម្ចាស់ចេញបញ្ជាឲ្យវា
ទៅប្រហារ ក្រុងអាស្កាឡូន និងតំបន់តាមមាត់សមុទ្រហើយនោះ តើឲ្យដាវនៅស្ងៀមដូចម្តេចបាន? វាត្រូវតែតម្រង់ទៅរកទីនោះ»។

Jeremiah 47:1
មើល៍!
ពាក្យថា «មើល»
ដាស់តឿនយើងឲ្យយកចិត្តទុកដាក់លើអ្វីដែលជាព្រះបន្ទូលរបស់ព្រះអង្គ។
មានទឹកជន់ឡើងនៅទិសខាងជើង។ ពួកគេនឹងដូចជាទឹកទន្លេហូរ!
ឃ្លាទាំងពីរមានអត្ថន័យស្រដៀងគ្នាហើយរួមគ្នាបង្ហាញការបញ្ជាក់អត្ថន័យ។
ពាក្យថា «ទឹក» និង «ទន្លេ» ទាំងពីរនេះសំដៅលើកងទ័ពមកពីភាគខាងជើង
ទឹកទាំងនោះនឹងហូរលិចនិងទឹកដី
«ពួកគេ» សំដៅលើកងទ័ពដែលមកពីភាគខាងជើង។
Jeremiah 47:3
ព្រោះឮស្នូរសន្ធឹកជើងសេះ និងសន្ធឹកកង់រទេះចម្បាំងលាន់ឮយ៉ាងទ្រហឹង អឺងអាប់ដូចផ្គរលាន់
ឃ្លាទាំងនេះបង្ហាញពីសម្លេងនៃកងទ័ពដែលនឹងមកមកដល់។
សន្ធឹកជើងសេះ និងសន្ធឹកកង់រទេះចម្បាំងលាន់ឮយ៉ាងទ្រហឹង
ឃ្លាទាំងពីរមានអត្ថន័យស្រដៀងគ្នា ហើយរួមគ្នាបង្ហាញការបញ្ជាក់អត្ថន័យ។
កាប់ចោរ
នេះជាឈ្មោះកោះនៃតំបន់ខាងជើងនៃទឹកដីភីលីស្ទីន។
Jeremiah 47:5
ភាពអាម៉ាស់

generated on Wed Sep 10 16:16:32 2025

កោរសក់ក្បាលទាំងមូល ឬផ្នែកខ្លះនៃក្បាល
គឺជាសញ្ញានៃភាពទុក្ខសៅយ៉ាងខ្លាំងដែលបានអនុវត្តតាមដោយអ្នកគោរពបូជាព្រះក្លែង
ដូចជាជនជាតិភីលីស្ទីន។
មនុស្ស ... ក្លាយទៅជាទីស្ងាត់ជ្រងំ
ការបកប្រែរបៀបផ្សេងទៀត: «មនុស្ស...នឹងត្រូវបានសម្លាប់»។
តើអ្នកនឹងកាត់ខ្លួនអ្នកនៅក្នុងការកាន់ទុក្ខដល់ណាទៀត?
ការកាត់ស្បែក
គឺជាការអនុវត្តតាមបែបផ្សេងទៀតដែលធ្វើឡើងដោយអ្នកគោរពបូជាព្រះក្លែងក្លាយនៅ
ដាវនៃព្រះអម្ចាស់អើយ!
ឆ្លងបរទេសក្នុងប្រហែលជាពីទិសខាងជើងដែលព្រះអម្ចាស់បានបញ្ជាដើម្បីដាក់ទោសដល់ពួកភីលីស្ទីន។
អ្នក
នេះសំដៅលើដាវរបស់ព្រះអម្ចាស់ដែលប្រៀបដូចជាមនុស្ស។
ស្រោម
ស្រោមដែលត្រូវបានដើម្បីការពារការមុតដាវ។
តើឲ្យដាវនៅស្ងៀមដូចម្តេច ដ្បិតព្រះអម្ចាស់បានបញ្ជាអ្នក
ឲ្យ[illegible]

---

48 [1]នេះជាព្រះបន្ទូលចំពោះជនជាតិម៉ូអាប់ ព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖ «អ្នកដែលរស់នៅលើភ្នំនេបូ ត្រូវវេទនា
ដ្បិតភ្នំនេះវិនាស។ ក្រុងគារយ៉ាថែមត្រូវអាម៉ាស់ ព្រោះត្រូវខ្មាំងវាយយកបាន បន្ទាយរបស់គេក៏ត្រូវអាម៉ាស់ និងរលំដែរ។[2]ទឹកដីម៉ូអាប់បាត់បង់កេរ្តិ៍ឈ្មោះ។ នៅក្រុង
ហេសបូន ខ្មាំងសត្រូវគិតគូរគ្នាថា ទៅយើងនាំគ្នាលុបក្រុងនេះឲ្យបាត់ពី ចំណោមប្រជាជាតិទាំងឡាយ។ ក្រុងម៉ាដម៉េនក៏ដូច្នោះដែរ អ្នកនឹងត្រូវវិនាស ហើយដាវតាមប្រហារ
អ្នកពីក្រោយ។
[3]សូមស្តាប់! មានសម្លេងមួយបានស្រែកឡើងយ៉ាងខ្លាំង ចេញពីក្រុងហូរ៉ូណែម ជាកន្លែងដែលត្រូវគេកម្ទេច និងបំផ្លាញចោលទាំងស្រុង។[4]ទឹកដីម៉ូអាប់ត្រូវបានបំផ្លាញ
ចោលហើយ។ មនុស្សដែលរស់នៅក្នុងម៉ូអាប់បានស្រែកឮឡើង។[5]ពួកគេនាំគ្នាឡើងទៅក្រុងលូគិត ទាំងយំសោក ដ្បិត នៅលើផ្លូវទៅក្រុងហូរ៉ូណែម
ការស្រែកបានឮដោយសារ តែការបំផ្លាញនោះ។
[6]រត់ទៅសង្គ្រោះជីវិត ដូចគុម្ពបន្លា! នៅតាមវាលរហោស្ថាន។[7]ដ្បិត មកពីអ្នកទុកចិត្តលើស្នាដៃ និងលើទ្រព្យសម្បត្តិរបស់ខ្លួន អ្នកនឹងត្រូវខ្មាំងវាយយកបាន។
ក្រោយមក កេម៉ូសជាព្រះរបស់អ្នក ក៏ត្រូវគេចាប់យកទៅជាឈ្លើយសឹក ជាមួយពួកបូជាចារ្យ និងពួកមន្ត្រីដែរ។
[8]ដ្បិត ការបំផ្លាញកើតឡើងក្នុងក្រុងទាំងអស់ គ្មានក្រុងណាមួយគេចផុតទេ។ ដូច្នេះនៅតាមជ្រលងភ្នំ និងនៅតាមវាលទំនាប នឹងត្រូវវិនាសអន្តរាយទាំងអស់ នេះជា
ព្រះបន្ទូលរបស់ព្រះអម្ចាស់។[9]ចូររៀបចំផ្នូរឲ្យម៉ូអាប់ទៅ ដ្បិតទឹកដីនេះត្រូវអន្តរាយហើយ។ ក្រុងទាំងឡាយនៅទឹកដីម៉ូអាប់នឹងត្រូវ កម្ទេចឲ្យវិនាសហិនហោច គ្មានប្រជាជន
រស់នៅទៀតឡើយ។[10]អ្នកណាបំពេញកិច្ចការរបស់ព្រះអម្ចាស់ ដោយខ្ជីខ្ជា គឺពុំបានធ្វើឲ្យដាវរបស់ខ្លួន ប្រឡាក់ជោកទៅដោយឈាមទេ អ្នកនោះត្រូវបណ្តាសាជាពុំខាន!
[11]តាំងពីក្មេងមក ម៉ូអាប់តែងតែសុខសាន្ត។ ពួកគេដូចជាស្រាទំពាំងបាជួរដែលចាក់ពីដបមួយទៅដបមួយទៀត។ ពួកគេមិនដែលទៅជាឈ្លើយសឹកឡើយ។ ដូច្នេះ
រស់ជាតិរបស់ពួកគេគឺនៅតែល្អ មិនបានផ្លូវខ្លឹននិងរស់ជាតិឡើយ។[12]ហេតុនេះ នៅថ្ងៃខាងមុខ យើងនឹងចាត់មនុស្សឲ្យមកផ្ទេរម៉ូអាប់ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ អ្នក
ទាំងនោះនឹងចាក់ម៉ូអាប់ចេញពីដប ហើយបំបែកពាងរបស់ពួកគេចោល។
[13]ម៉ូអាប់នឹងខ្មាសចំពោះកេម៉ូស ជាព្រះរបស់ខ្លួន ដូចជនជាតិអ៊ីស្រាអែលដែលបានខ្មាសបេតអែល ជាទីពឹងផ្អែកដ៏ពិតរបស់គេ។[14]អ្នកម៉ូអាប់អើយតើអ្នកនិយាយយ៉ាងម៉េច
យើងខ្ញុំជាទាហានដ៏ខ្លាំងពូកែ យើងខ្ញុំជាអ្នកចម្បាំងមែនទេ?
[15]អ្នកម៉ូអាប់បានបំផ្លាញចោល ហើយនិងទីក្រុងផ្សេងៗដ៏ត្រូវវាយបំផ្លាញដែរ។ យុវជនដ៏ខ្លាំងពូកែរបស់ពួកគេ នឹងត្រូវខ្មាំងយកទៅសម្លាប់នៅទីសគ្គឃាត។ នេះជា
ព្រះបន្ទូលរបស់ព្រះមហាក្សត្រដែល មាននាមថា ព្រះអម្ចាស់នៃពិភពទាំងមូល។[16]មហន្តរាយរបស់ម៉ូអាប់ជិតមកដល់ហើយ ទុក្ខវេទនារបស់ពួកគេនៅជិតបង្កើយ។
[17]អ្នកគ្រប់គ្នាដែលនៅជិតខាង ហើយស្គាល់ឈ្មោះម៉ូអាប់យ៉ាងច្បាស់អើយ ចូរនាំគ្នាមកជួយរំលែកទុក្ខម៉ូអាប់ ដោយពោលថា ហេតុអ្វីបានជាមហាអំណាច ត្រូវរលំបែបនេះ។
[18]ប្រជាជនក្រុងឌីបូនអើយ ចូរលះបង់ភាពរុងរឿងរបស់ខ្លួន ហើយអង្គុយនៅលើដីហួតហែងទៅ។ ដ្បិតអ្នកបំផ្លាញទឹកដីម៉ូអាប់កំពុងតែ ឡើងមកវាយអ្នក គេនឹង
បំផ្លាញកំពែងដ៏រឹងមាំរបស់អ្នក។[19]ប្រជាជនក្រុងអារ៉ូអ៊ើរអើយចូរទៅឈរនៅតាមផ្លូវ ហើយចាំឃ្លាំមើលទៅ។ ចូរសាកសួរអ្នកដែលភៀសខ្លួនទៅ តើមានហេតុការណ៍អ្វីកើត
ឡើង?[20]ម៉ូអាប់ត្រូវអាម៉ាស់ ដ្បិតទឹកដីនេះរលំហើយ ចូរនាំគ្នាស្រែកដើម្បីរកជំនួយចុះ។ ចូរប្រកាសនៅតាមស្ទឹងអើណូនថា ទឹកដីម៉ូអាប់វិនាសហិនហោចហើយ។
[21]ឥឡូវនេះ ការវិនិច្ឆ័យទោសមកដល់ទឹកដីនៅតំបន់វាលទំនាបហើយ គឺក្រុងហូឡូន ក្រុងយ៉ាហាស និងក្រុងមេផាត[22]ក្រុងឌីបូន ក្រុងនេបូ ក្រុងបេត និងឌីប្លាថែម[23]ក្រុង
គារយ៉ាថែម ក្រុងបេតកាមូល និងក្រុងបេតមេយ៉ូន[24]ក្រុងកេរីយ៉ុត ក្រុងបូសរ៉ា ក្រុងទាំងប៉ុន្មាននៃទឹកដីម៉ូអាប់ ទាំងជិតទាំងឆ្ងាយផង។[25]អំណាចរបស់ម៉ូអាប់ត្រូវរលំ ហើយ
កម្លាំងរបស់គេក៏ធ្លាក់ទន់ខ្សោយដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[26]ចូរបង្អកម៉ូអាប់ឲ្យស្រវឹងទៅ ព្រោះគេបានបះបោរប្រឆាំងនឹងព្រះអម្ចាស់ ម៉ូអាប់កំពុងនៀលក្នុងកំអួតរបស់ខ្លួន ហើយត្រូវមនុស្សម្នាសើចចំអក។[27]ដ្បិត
តើមិនមែនអ៊ីស្រាអែល បានក្លាយទៅជាអ្នកដែលសើចចំអកដល់អ្នកទេឬ? តើមិនមែនពួកបាននៅក្នុងចំណោមចោរ ហើយអ្នកបានងក់ក្បាលដាក់គេ
ហើយពេលខ្លះអ្នកបាននិយាយពីគេមែនទេ?
[28]ប្រជាជនទឹកដីម៉ូអាប់អើយ ចូរនាំគ្នាបោះបង់ចោលទីក្រុង ហើយទៅរស់នៅតាមក្រហែងថ្ម។ ដូចសត្វព្រាប ធ្វើសំបុកនៅកន្លៀតថ្មតាមមាត់រូងភ្នំចុះ។[29]យើងបានឮគេ
និយាយថា ម៉ូអាប់មានអំនួតខ្លាំងពន់ពេកណាស់ គេវាយឫក ព្រហើន ប្រកាន់ខ្លួន និងមានចិត្តឆ្មើងឆ្មៃខ្លាំងណាស់។
[30]ព្រះអម្ចាស់មានព្រះបន្ទូលថា យើងស្គាល់ឫករបស់ម៉ូអាប់ ហើយអ្វីៗដែលគេនិយាយអួតអាង គ្មានបានការទេ ដូចជាដែលគ្មានប្រយោជន៍។[31]ហេតុនេះហើយបានជាយើង
យំ ហើយសោកសង្រេងស្រណោះម៉ូអាប់ទាំងមូល។ ព្រមទាំងថ្ងូរ ព្រោះតែអ្នកទឹកដីគារ ហារ៉ាសែត។[32]ចម្ការទំពាំងបាយជូរនៅស៊ីបម៉ាអើយ យើងនឹងយំស្រណោះអ្នក ជាង
យំស្រណោះអ្នកក្រុងយ៉ាស៊ើរទៅទៀត មែករបស់អ្នកលូតហួសសមុទ្រ ហើយហួសយ៉ាស៊ើរ។ ប៉ុន្តែ មេបំផ្លាញបានកម្ទេចភោគផល និងផ្លែទំពាំងបាយជូររបស់អ្នក។
[33]អំណរសប្បាយ និងការរីករាយចេញបាត់ពីចម្ការទំពាំងបាយជូរ និងពីទឹកដីម៉ូអាប់។ យើងក៏ធ្វើឲ្យលែងមានស្រានៅក្នុងធុង ហើយក៏លែងមាននរណាជាន់
ផ្លែទំពាំងបាយជូរ។ គេនឹងបានធ្វើឲ្យអ្នកអរសប្បាយទៀតទេ។ ផ្ទុយទៅវិញ មានតែសម្រែកនៃសេចក្តីទុក្ខលំបាកវិញ។
[34]សម្រែករបស់អ្នកក្រុងហេសបូន លាន់ឮទៅដល់ក្រុងអេឡាឡេ គេបន្លឺសំឡេងឮរហូតទៅដល់ក្រុងយ៉ាហាស់ សម្រែករបស់ពួកគេលាន់ឮពីក្រុងសូអារ រហូតដល់ក្រុង
អេក្លាត សេលីស៊ីយ៉ា ដ្បិតប្រភពទឹកនៅនីមរីមរឹងស្ងួតអស់។[35]ដ្បិត យើងនឹងលែងឲ្យមានជនជាតិម៉ូអាប់ឡើងទៅកន្លែងសក្ការៈតាមទួលខ្ពស់ៗ ដើម្បីដុតគ្រឿងក្រអូបបូជា
ព្រះរបស់ខ្លួនទៀតហើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[36]ហេតុនេះបានជាចិត្តយើងស្រណោះស្រណោក ជនជាតិម៉ូអាប់។ ហើយចិត្តយើងក៏ស្រណោះស្រណោកអ្នកក្រុងគារ ហារ៉ាសែតដែរ។ ដ្បិតទ្រព្យរបស់ពួកគេខំសន្សំត្រូវ
វិនាសអស់។[37]ដ្បិត ពួកគេកោរសក់ កោរពុកមាត់ទាំងអស់គ្នា។ ហើយឆូតដៃរបស់ខ្លួនគ្រប់ៗគ្នា ព្រមទាំងស្លៀកបាវកាន់ទុក្ខផង។
[38]នៅតាមដំបូលផ្ទះទាំងអស់ និងនៅតាមផ្លូវមានឮសូរតែសំណោកកាន់ទុក្ខ។ ព្រោះយើងបានបំបែកម៉ូអាប់ ដូចជាដបដែលគេលែងពេញចិត្ត នេះជាព្រះបន្ទូលរបស់
ព្រះអម្ចាស់។[39]ចូរនាំគ្នាស្រែកយំទៅ ព្រោះម៉ូអាប់រលំហើយ! ម៉ូអាប់ងាកមុខចេញដោយអាម៉ាស់ ប្រជាជាតិទាំងអស់នៅជុំវិញ នាំគ្នាសើចចំអកឲ្យម៉ូអាប់ ព្រមទាំង
ស្រឡាំងកាំងទៀតផងទៅនិងអ្វីដេលបានកើតឡើងនៅជុំវិញគេផង»។
[40]ដ្បិត ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «មើល៍! សត្រូវមកវាយប្រហារទឹកដីម៉ូអាប់ ដូចខ្លែងសំកាំងស្លាប រេពីលើ នៅពីលើអ្នកម៉ូអាប់។[41]គេវាយយកបានក្រុងកេរីយ៉ូត ព្រម
ទាំងរំលំកំពែងដ៏រឹងមាំទៀតផង។ ដ្បិត នៅថ្ងៃនោះ ចិត្តរបស់ទាហានដ៏អង់អាច នៃជនជាតិម៉ូអាប់នឹងឈឺចុកចាប់ ដូចស្ត្រីហៀបនឹងសម្រាលកូន។
[42]ដូច្នេះ ម៉ូអាប់នឹងត្រូវវិនាស លែងមានឈ្មោះជាប្រជាជនមួយទៀតហើយ ពីព្រោះគេបានលើកខ្លួនឡើង ទាស់ប្រឆាំងនឹងព្រះអម្ចាស់។[43]ប្រជាជនទឹកដីម៉ូអាប់អើយ អ្នក
រាល់គ្នាមុខតែភ័យខ្លាច ធ្លាក់រណ្តៅ និងជាប់អន្ទាក់ជាមិនខាន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[44]អ្នកដែលភៀសខ្លួនពីការភ័យខ្លាចនឹងធ្លាក់រណ្តៅ ហើយអ្នកដែលឡើងពី
រណ្តៅ នឹងជាប់អន្ទាក់ ដ្បិតយើងធ្វើឲ្យឆ្នាំដែលត្រូវដាក់ទោសម៉ូអាប់ គឺការសងសឹករបស់យើង មកដល់ហើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។

generated on Wed Sep 10 16:16:32 2025

[45]ជនភៀសខ្លួនដែលអស់កម្លាំងរត់មកជ្រក នៅហេសបូន ជាក្រុងដែលស្តេចស៊ីហុន ធ្លាប់គ្រប់គ្រងកាលពីដើម តែមានភ្លើងឆាបឆេះកណ្តាលក្រុង។ ហើយឆេះរាលដាលទៅដល់ព្រំប្រទល់ និងតាមកំពូលភ្នំរបស់ទឹកដីម៉ូអាប់ តាំងពីអ្នកធំដែលជាមនុស្សចូលចិត្តអួតអាង។
[46]ជនជាតិម៉ូអាប់អើយ! អ្នកវេទនាហើយ ប្រជាជនដែលគោរពព្រះកេម៉ូស ត្រូវអន្តរាយជាមិនខាន ដ្បិតកូនប្រុសកូនស្រីរបស់អ្នក ត្រូវគេកៀរយកទៅជាឈ្លើយ។[47]ប៉ុន្តែ នៅគ្រាចុងក្រោយ យើងនឹងស្តារទឹកដីម៉ូអាប់ឡើងវិញ» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការវិនិច្ឆ័យទោសជនជាតិម៉ូអាប់ចប់តែត្រឹមនេះ។

Jeremiah 48:1
នេបូ
នេះជាឈ្មោះនៃភ្នំមួយ ក្នុងស្រុកម៉ូអាប់។
គារយ៉ាថែម
នេះជាឈ្មោះក្រុងមួយ ក្នុងស្រុកម៉ូអាប់។
ក្រុងគារយ៉ាថែមត្រូវបានចាប់ ហើយធ្វើឲ្យអាម៉ាស់មុខ
«សត្រូវបានដណ្តើមយកបានទីក្រុងគារយ៉ាថែម ហើយប្រជាជនទាំងនោះ
នឹងមិនអាចមានមោទនភាពចំពោះវាបានទៀតទេ»។
កេរ្តិ៍ឈ្មោះម៉ូអាប់គឺមិនមានទៀតទេ
នេះមានន័យថាការគោរពដែលម៉ូអាប់ទទួលបានពីអតីតកាលនឹងត្រូវបាត់បង់។
ហេសបូន
នេះជាឈ្មោះរបស់រាជធានីនៃស្តេចជនជាតិអាម៉ូរី។
ក្រុងម៉ាដម៉េននឹងក៏ត្រូវវិនាស
«ម៉ាដម៉េន» ជាទីស្រុកម៉ូអាប់។ «ខ្មាំងសត្រូវរបស់គេនឹងបំផ្លាញទីក្រុងម៉ាដម៉េន»
ដាវតាមប្រហារអ្នកពីក្រោយអ្នក
នេះមានន័យថាកងទ័ពឈ្លានពានស្រុកម៉ូអាប់។
Jeremiah 48:3
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីការបំផ្លិចបំផ្លាញនៃស្រុកម៉ូអាប់។
ហូរ៉ូណែម
នេះជាឈ្មោះទីក្រុងនៅភាគខាងត្បូងនៃស្រុកម៉ូអាប់។
កម្ទេច និងបំផ្លាញចោល
ពាក្យទាំងពីរនេះមានន័យដូចគ្នា។
ពាក្យទាំងពីររួមគ្នាបញ្ជាក់ពីការបំផ្លិចបំផ្លាញទាំងស្រុង។
ក្មេងៗនៃទីក្រុង
នេះសំដៅលើប្រជាជនម៉ូអាប់។
លូគិត
នេះជាឈ្មោះទីកន្លែងដែលនៅស្រុកម៉ូអាប់។
ដោយសារ តែការបំផ្លាញនោះ
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារតែការបំផ្លាញទីក្រុងនោះ»។
Jeremiah 48:6
ដើម្បីឲ្យបានរួចជីវិត
ពាក្យថា «ជីវិត» សំដៅលើប្រជាជនម៉ូអាប់។
ដូចគុម្ពបន្លា
ប្រជាជនដែលរត់គេចពីការបំផ្លាញទីក្រុង ត្រូវបានប្រៀបធៀបទៅនឹងគុម្ពោត
ដែលមានរស់នៅក្នុងស្ថានភាពលំបាកនៅវាលខ្សាច់
ហើយមានស្លឹកបៃតងពេញមួយឆ្នាំ។
ទុកចិត្តលើការប្រព្រឹត្តអ្នក
ការបកប្រែរបៀបផ្សេងទៀត:
«រស់នៅតាមទម្លាប់និងបង្រៀនតាមសាសនារបស់អ្នក»
កេម៉ូស
«កេម៉ូស» គឺជាព្រះធំបំផុតរបស់ជនជាតិម៉ូអាប់។ «កេម៉ូស»
នៅទីនេះតំណាងឲ្យជនជាតិម៉ូអាប់។
Jeremiah 48:8
ដូច្នេះជ្រលងភ្នំនឹងវិនាស ហើយតាមវាលទំនាបនឹងខ្ទេចខ្ទី នឹងត្រូវវិនាសអន្តរាយទាំងអស់
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា
និងសង្កត់ធ្ងន់គ្រប់ផ្នែកនៃទឹកដីនឹងត្រូវបំផ្លាញ។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះអ្នកបំផ្លាញនឹងបំផ្លាញទីក្រុងទាំងអស់នៅជ្រលងភ្នំនិងលើវាលទំនាប»។
ចូរឲ្យស្លាបដល់ម៉ូអាប់
ពាក្យនេះគឺជាពាក្យបំផ្លើស
ដោយព្រោះគ្មានអ្នកណាម្នាក់អាចពាក់ស្លាបលើមនុស្សបានទេ។
ហើយត្រង់ចំណុចនៃការហើរចេញទៅ សំដៅលើចំណុចនៃការរត់ចេញយ៉ាងរហ័ស។
ការបកប្រែរបៀបផ្សេងទៀត: «ជួយប្រជាជនម៉ូអាប់រត់គេចខ្លួន»
«វាជាការល្អប្រសិនបើប្រជាជនម៉ូអាប់មានស្លាបហើយអាចហើរចេញទៅ»។
ការបង្ហូរឈាម
ការបកប្រែរបៀបផ្សេងទៀត: «សម្លាប់មនុស្ស»
Jeremiah 48:11
ម៉ូអាប់មានអារម្មណ៍សុខសាន្តតាំងពីក្មេង
ពាក្យថា «ក្មេង» សំដៅលើជនជាតិម៉ូអាប់ទាំងស្រុង។
ពួកគេដូចជាស្រាទំពាំងបាជួរដែលចាក់ពីដបមួយទៅដបមួយទៀត
ពាក្យថា «គេ» គឺជាជនជាតិម៉ូអាប់។
ជនជាតិម៉ូអាប់ប្រៀបដូចទៅនឹងស្រាដែលមិនបានចាកចេញពីទឹកដីរបស់ខ្លួន។
ដូច្នោះហើយ រស់ជាតិរបស់ពួកគេគឺល្អរហូត ហើយរស់ជាតិនៅដដែលមិនប្តូរ
ឃ្លាទាំងពីរមានន័យដូចគ្នា។
ដូច្នោះមើល៍ នៅថ្ងៃនឹងមកដល់
«ចូរស្តាប់ដោយប្រុងប្រយ័ត្នដោយព្រោះឆាប់ៗនេះ»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
ចាក់ម៉ូអាប់ចេញពីដបទាំងអស់ ហើយបំបែកពាងរបស់ពួកគេចោល
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា និងត្រូវបានរួមបញ្ចូលគ្នាបញ្ជាក់ពីអត្ថន័យ។
ឃ្លាទាំងពីរសំដៅលើការបំផ្លិចបំផ្លាញជនជាតិម៉ូអាប់នាពេលខាងមុខ។
Jeremiah 48:13
តើអ្នកអាចនិយាយថា
ពាក្យថា «អ្នក» មានន័យថាជាកងទ័ពម៉ូអាប់។
តើអ្នកអាចនិយាយថា យើងខ្ញុំជាទាហានដ៏ខ្លាំងពូកែ ជាអ្នកចម្បាំងបានទេ?
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងមិនអាចនិយាយថា «យើងជាទាហាន
និងអ្នកដែលពូកែចម្បាំង»។
Jeremiah 48:15
ដ្បិតយុវជនដ៏ខ្លាំងពូកែរបស់ពួកគេ បានធ្លាក់ទៅដល់កន្លែងទីសត្តឃាត
ការបកប្រែរបៀបផ្សេងទៀត: «យុវជនដ៏ខ្លាំងពូកែរបស់ពួកគេនឹងត្រូវគេសម្លាប់»។
មហន្តរាយរបស់ម៉ូអាប់ជិតមកដល់ហើយ ទុក្ខវេទនារបស់ពួកគេនៅជិតបង្កើយ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា ហើយបញ្ជាក់ពីការខ្ទេចខ្ទីរបស់ម៉ូអាប់
ដែលនឹងកើតឡើងឆាប់ៗនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«សត្រូវរបស់ម៉ូអាប់នឹងបំផ្លាញពួកគេឆាប់ៗនេះ»។
ដំបងដ៏ខ្លាំង ដំបងកិត្តិយស បានបាក់ហើយ
ពាក្យថា «ដំបងដ៏ខ្លាំង» និង «ដំបងកិត្តិយស»សំដៅទៅលើ សិទ្ធអំណាច
និងចូលរួមគាំទ្រផ្នែកនយោបាយដែលជនជាតិម៉ូអាប់បានផ្តល់ជនជាតិដទៃទៀត។
ការបកប្រែរបៀបផ្សេងទៀត:
«សត្រូវរបស់ម៉ូអាប់បានកម្ទេចអំណាចដ៏រឹងមាំរបស់គេ»។
Jeremiah 48:18
អង្គុយនៅលើដីហួតហែងវិញ ប្រជាជនដែលរស់នៅក្នុងក្រុងឌីបូន
ពាក្យថា «ប្រជាជន» សំដៅលើប្រជាជនដែលរស់នៅក្នុងក្រុងឌីបូន។
អ្នកបំផ្លាញទឹកដីម៉ូអាប់
ការបកប្រែរបៀបផ្សេងទៀត: «ពួកខ្មាំងសត្រូវនៃប្រជាជនម៉ូអាប់»
ចូរសាកសួរ
ការបកប្រែរបៀបផ្សេងទៀត: «សាកសួរមនុស្ស» ឬ «សាកសួរទាំងបុរស និងស្ត្រី»
ទ្រហោយំហើយទួញសោកចុះ
ការបកប្រែរបៀបផ្សេងទៀត: «ដែលយំខ្លាំងៗ ដោយភាពឈឺចាប់ និងខឹងសម្បារ»
Jeremiah 48:21
ក្រុងនេបូ ហើយក្រុងបេត និងឌីប្លាថែម...ហើយក្រុងបូសរ៉ា
ទាំងនេះជាទីក្រុងក្នុងស្រុកម៉ូអាប់។
ស្នែងរបស់ម៉ូអាប់ត្រូវរលំ ហើយដៃរបស់គេក៏បាក់ដែរ
ទាំង «ស្នែង» និង «ដៃ» ទាំងពីរមានន័យដូចគ្នា។
ពួកគេមានន័យថាជនជាតិម៉ូអាប់បានរងទុក្ខ។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះក្នុងជំពូក ១:៧។

generated on Wed Sep 10 16:16:32 2025

Jeremiah 48:26
ចូរបង្អកម៉ូអាប់ឲ្យស្រវឹង
ការជំនុំជម្រះដែលព្រះបានដាក់មកលើម៉ូអាប់ ដោយឲ្យពួកគេ
ត្រូវបានមើលងាយដោយខ្មាំងសត្រូវរបស់គេ
ប្រៀបដូចជាអ្នកស្រវឹងដែលត្រូវបានគេសើចចំអក និងប្រមាថ។
ពេលនេះម៉ូអាប់ទះដៃដោយខ្ពើមឆ្អើមនឹងកំអួតរបស់ខ្លួន ដូច្នេះគេនឹងសើចចំអកផងដែរ
ព្រះអង្គបន្តប្រៀបធៀបម៉ូអាប់ទៅនឹងមនុស្សស្រវឹង។
ដ្បិតតើមិន មែនអ្នកដែលធ្លាប់សើចចំអកឲ្យអ៊ីស្រាអែលទេឬ?
ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតអ្នករាល់គ្នាធ្លាប់សើចចំអកឲ្យប្រជារាស្ត្រអ៊ីស្រាអែលរបស់យើង។»
តើមិនមែនពួកគេបាននៅក្នុងចំណោមចោរ ដូច្នោះអ្នកបានងក់ក្បាលដាក់គេ ហើយជារឿយៗអ្នកបាន
និយាយពីគេមែនទេ?
ការបកប្រែរបៀបផ្សេងទៀត: «ទោះបីពួកគេជាចោរក៏ដោយ
ក៏ពួកគេមិនត្រូវបានចាប់ខ្លួនដែរ។ អ្នកងក់ក្បាលដាក់ពួកគេដោយមើលងាយ
និងប្រមាថពួកគេ»។
Jeremiah 48:28
ក្រហែងថ្ម
ក្រហែងថ្ម គឺជាជម្រាលចោទរបស់ភ្នំ។
រូងនៅក្នុងថ្មចុះ
នេះសំដៅលើផ្នែកបើកចំហរនៃរូងថ្ម ដូចជាច្រកចូលទៅរូងភ្នំ។
ការសើចចំអក...អំនួត ...មុខមាត់...ការសាក់បាំងក្នុងចិត្តរបស់គេ
សិរីរុងរឿង ... ស្ថិតនៅក្នុងចិត្តរបស់គេ -
ពាក្យទាំងអស់នេះមានអត្ថន័យស្រដៀងគ្នា។
ពាក្យទាំងនេះត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ពីមោទនភាពខ្លាំងក្លារបស់ជនជាតិម៉ូអាប់។ដែលត្រូវបានបំផ្លិចបំផ្លាញ ឬរំលាយបាត់ទៅ។
Jeremiah 48:30
ព្រះអម្ចាស់មានព្រះបន្ទូលថា
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
រឹងរូស
បដិសេធមិនគោរពតាមនរណាម្នាក់ ឬការណែនាំណាមួយដោយសារតែអំនួត
យើងនឹងយំ ហើយសោកសង្រេងដល់ម៉ូអាប់ ហើយយើងនឹងស្រែកថ្ងូរដោយឈឺចាប់ដល់ម៉ូអាប់ទាំង
មូល
លោកយេរេមាថ្លែងដដែលៗពីរដងដើម្បីបញ្ជាក់ន័យ។
យំ
យំសោកសៅ និងលឺៗយ៉ាងខ្លាំង ដែលមនុស្សប្រព្រឹត្តនៅពេលដែលគេឈឺចាប់
ឬសោកសៅយ៉ាងខ្លាំង
គារ ហារ៉ាសែត
នេះជាឈ្មោះនៃរាជធានីចាស់របស់ម៉ូអាប់។
យ៉ាស៊ើរ ...ស៊ីមម៉ា
ទាំងនេះជាឈ្មោះទីក្រុងពីរនៃម៉ូអាប់។
Jeremiah 48:33
ចូរអបអរសាទរ និងការរីករាយនឹងត្រូវយកចេញ
ការបកប្រែរបៀបផ្សេងទៀត: «ឥឡូវនេះគ្មាននរណាម្នាក់មានក្តីអំណរ
ឬសប្បាយរីករាយនៅស្រុកម៉ូអាប់ឡើយ»។
យើងបានធ្វើឲ្យលែងមានស្រានៅក្នុងធុង
«យើងបានបញ្ឈប់»
គេនឹងបានធ្វើឲ្យអ្នកអរសប្បាយទៀតទេ
«គេនឹងមិនឈឺក្បាលទៀតទេ»។ ពាក្យថា «គេ»
សំដៅទៅលើអ្នកបង្កើតស្រាក្នុងស្រុកម៉ូអាប់។
Jeremiah 48:34
ហេសបូន
នេះជាឈ្មោះទីក្រុងរបស់ស្តេចម៉ូអាប់។
អេឡាឡេ ...យ៉ាហាស់...សូអារ...ហូរ៉ូណែម...អេក្លាត...សេលីស៊ីយ៉ា
ទាំងនេះជាឈ្មោះទីក្រុងផ្សេងទៀតក្នុងស្រុកម៉ូអាប់។
នីមរីម
នេះជាឈ្មោះអូរ ឬទន្លេដែលនៅជិតសមុទ្រមរណៈ។
ព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
Jeremiah 48:36
ចិត្តរបស់យើងបានសោកស្តាយដល់ម៉ូអាប់ដូចជាផ្លុំខ្លុយ
លោកយេរេមាបានប្រៀបធៀបអារម្មណ៍របស់លោកទៅនឹងចម្រៀងដ៏កំសត់មួយ។
ចិត្តរបស់យើងបានសោកស្តាយ
ពាក្យថា «ចិត្ត» សំដៅទៅលើអារម្មណ៍ដ៏ជ្រាលជ្រៅរបស់លោកយេរេមា។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំសោកស្តាយយ៉ាងខ្លាំងចំពោះ»។
គារ ហារ៉ាសែត
គារ ហារ៉ាសែត
ជារដ្ឋធានីបុរាណរបស់ម៉ូអាប់ដែលមានចម្ងាយប្រហែល១៨គីឡូម៉ែត្រខាងកើតសមុទ្រមរណៈ
ដ្បិតពួកគេកោរសក់ កោរពុកមាត់ទាំងអស់គ្នា។ ហើយឆូតដៃរបស់ខ្លួនគ្រប់ៗគ្នា ព្រមទាំងស្លៀកបាវ
នៅចង្កេះពួកគេ
នេះជាអ្វីដែលជនជាតិម៉ូអាប់បានធ្វើនៅពេលពួកគេកាន់ទុក្ខ
ឬសម្តែងភាពសោកសៅ។
ឆូតដៃ
ការរំលាត់ដាច់នៅលើស្បែក
Jeremiah 48:38
ដំបូលផ្ទះដែលរាបស្មើ
«គ្រប់ដំបូលផ្ទះទាំងអស់»
តាមទីលាន
កន្លែងទីសាធារណៈដែលបើកចំហរ ដូចជានៅតាមផ្សារ។
ដ្បិតយើងនឹងបំផ្លាញ
ពាក្យថា «យើង» សំដៅលើព្រះអម្ចាស់
ព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
ត្រូវខ្ចាត់ខ្ចាយ
យំស្រណោះ
ការយំសោកនិង លឺៗខ្លាំងដែលមនុស្សធ្វើនៅពេលគេឈឺចាប់
ដូច្នោះម៉ូអាប់នឹងត្រូវជាហេតុនៃការចំអក
ការបកប្រែរបៀបផ្សេងទៀត:
«ម៉ូអាប់នឹងក្លាយជាជនជាតិមួយដែលជនជាតិដទៃក្បែរនោះសើចចំអក»
Jeremiah 48:40
សត្រូវនឹងមកហើរដូចជាសត្វឥន្ទ្រី ត្រដាងស្លាបលើម៉ូអាប់
ឃ្លាទាំងនេះប្រៀបធៀបនឹងកងទ័ពដ៏ខ្លាំងពូកែយ៉ាងណា ដែលមកលើស្រុកម៉ូអាប់
ហើយយកឈ្នះដូចទៅនឹងសត្វឥន្ទ្រីហែលចុះមកដើម្បីចាប់សត្វ។
កេរីយ៉ូត
ជាទីក្រុងមួយនៃស្រុកម៉ូអាប់។
ក្រុងកេរីយ៉ូតត្រូវចាប់បាន ព្រមទាំងកំពែងដ៏រឹងមាំត្រូវចាប់យក
«ខ្មាំងសត្រូវបានដណ្តើមយកក្រុងកេរីយ៉ូត និងរឹបអូសយកបន្ទាយរបស់គេ»
ដ្បិតនៅថ្ងៃនោះ ចិត្តរបស់ទាហាននៃជនជាតិម៉ូអាប់នឹងដូចចិត្តមនុស្សស្ត្រីរៀបនឹងសម្រាលកូន
ឃ្លានេះប្រៀបធៀបភាពភ័យខ្លាចដែលនឹងធ្វើឱ្យកងទ័ពរបស់ជនជាតិម៉ូអាប់ខ្លាចដូចស្ត្រីដែលមានអារម្មណ៍
Jeremiah 48:42
ដូច្នោះ ម៉ូអាប់នឹងត្រូវបំផ្លាញ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នោះ ខ្មាំងសត្រូវនឹងបំផ្លាញជនជាតិម៉ូអាប់»។
នៅក្នុងឆ្នាំ
ពាក្យថា «ឆ្នាំ» អាចបកប្រែដូចជា «គ្រា» ឬ «រដូវ» ឬ «កំឡុងពេល»។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
Jeremiah 48:45
ពួកអ្នកភៀសខ្លួន
នេះសំដៅលើប្រជាជនដែលបានរត់គេចខ្លួនក្នុងពេលនៃការវិនាសស្រុកម៉ូអាប់។
ម្លប់របស់ក្រុងហេសបូន
ជាទីសុវត្ថិភាពក្នុងទីក្រុងហេសបូន។
ដ្បិតភ្លើងនឹងឆាបឆេះចេញពីកទីក្រុង ហេស បូន អណ្តាតភ្លើងនៅកណ្តាលនៃស៊ីហុន
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា ហើយបញ្ជាក់ពីការវិនាសរបស់ស្រុកម៉ូអាប់
នឹងចាប់ផ្តើមនិងរាលដាលចេញពីក្រុងហេសបូន។
ក្រុងហេសបូនគឺជារាជធានីនៃស្តេចអាម៉ូរី នៃស៊ីហុន។
ម៉ូអាប់ ហើយនៅលើក្បាលនៃពួកមនុស្សដែលមានចិត្តអួតអាង
ឃ្លាទាំងនេះសំដៅលើប្រជាជននៅក្រុងហេសបូន
និងមេដឹកនាំដែលមានមុខមាត់ធំៗ។
ក្បាល

generated on Wed Sep 10 16:16:32 2025

ផ្នែកនៃផ្នែកមុខដែលនៅពីលើភ្នែក តែនៅក្រោមសក់។ ដែលតំណាងឲ្យមោទនភាព។
លើក្បាលនៃពួកមនុស្សដែលមានចិត្តអួតអាង
ឃ្លានេះសំដៅទៅលើពួកមនុស្សដែលមានមុខមាត់នៅស្រុកម៉ូអាប់ ដូចជាពួកស្តេច និងមេដឹកនាំ។ ក៏ដែលតំណាងឲ្យមោទនភាពផងដែរ។
Jeremiah 48:46
ប្រជាជនកេម៉ូស ត្រូវបំផ្លាញ
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនកេម៉ូស ត្រូវបំផ្លាញដោយខ្មាំងសត្រូវរបស់ពួកគេ» ឬ «សត្រូវរបស់ប្រជាជនកេម៉ូស បំផ្លាញពួកគេ»។
កេម៉ូស
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៤៨:៦។
ថ្ងៃចុងក្រោយ
នេះសំដៅលើពេលវេលានាពេលអនាគត ដែលហៅថា «ថ្ងៃចុងក្រោយ»។
ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។

---

49 [1]សម្រាប់ប្រជាជននៃអាំម៉ូន ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «តើអ៊ីស្រាអែលគ្មានកូនតពូជទេឬ? តើមិនមានអ្នកណានឹងទទួលមរតកទេឬ? ហេតុអ្វីបានប្រជាជនរបស់ព្រះម៉ូឡុក មករស់នៅក្នុងក្រុងនានានៃទឹកដីកាដ?[2]ដូច្នេះ នៅពេលខាងមុខ យើងនឹងឲ្យសង្គ្រាមកើតមានដល់ ជនជាតិអាំម៉ូននៅក្រុងរ៉ាបាត់ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ក្រុងនោះនឹងក្លាយទៅជាទីស្មសាន ហើយក្រុងទាំងឡាយដែលនៅជុំវិញនឹងត្រូវ វិនាសដោយភ្លើង។ ដ្បិត អ៊ីស្រាអែលនឹងយកទឹកដីដែល ជនជាតិអាំម៉ូន ដណ្តើមទៅនោះបានមកវិញ» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[3]អ្នកក្រុងហេសបូនអើយ ចូរស្រែកយ៉ាងខ្លាំងទៅ ដ្បិតក្រុងអៃវិនាសសូន្យហើយ! អ្នកក្រុងទាំងឡាយដែលនៅជុំវិញរ៉ាបាតអើយ ចូរស្រែកទ្រហោយំ ចូរនាំគ្នាស្លៀកបាវកាន់ទុក្ខ ចូររត់ទៅរត់មក តាមបណ្តោយកំពែងក្រុង ដ្បិតម៉ូឡុកជាព្រះរបស់អ្នករាល់គ្នា ត្រូវគេចាប់យកទៅជាឈ្លើយ ជាមួយពួកបូជាចារ្យ និងពួកមន្ត្រី។[4]ប្រជាជនដែលបះបោរអើយ ហេតុដូចម្តេចបានជាអ្នកអួតខ្លួនអំពីជ្រលងភ្នំ របស់អ្នកដូច្នេះ? ជ្រលងភ្នំនេះជិតវិនាសអន្តរាយហើយ។ អ្នកទុកចិត្តលើទ្រព្យសម្បត្តិរបស់ខ្លួន ដោយពោលថា តើនរណាហ៊ានមកវាយប្រហារខ្ញុំ?
[5]មើល៍! យើងនឹងធ្វើឲ្យមានទុក្ខភ័យពីគ្រប់ទិសទី កើតមានដល់អ្នក នេះជាព្រះបន្ទូលរបស់ព្រះជាអម្ចាស់នៃ ពិភពទាំងមូល
ហើយការកើតទុក្ខភ័យនេះគឺនៅចំណោមអ្នករាល់គ្នា។ នោះអ្នករាល់គ្នាត្រូវខ្ចាត់ខ្ចាយចេញពីរាដែរ។ ម្នាក់ៗរត់ប្រាសអាយុ គ្មាននរណាប្រមូលផ្តុំអ្នករាល់គ្នាឡើងវិញទេ។
[6]ប៉ុន្តែ ក្រោយមក យើងនឹងស្តារទឹកដីអាំម៉ូនឡើងវិញ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[7]សម្រាប់ជនជាតិអេដុម ព្រះអម្ចាស់នៃពិភពទាំងមូល មានព្រះបន្ទូលថា៖ «តើគ្មានប្រាជ្ញានៅក្នុងក្រុងថេម៉ានទៀតទេឬ? តើសេចក្តីប្រឹក្សាបានសូន្យបាត់ពីពួកមនុស្សឆ្លៀវឆ្លាតឬ? តើប្រាជ្ញារបស់គេបានរលាយបាត់ទៅហើយឬ?[8]អ្នកក្រុងដេដាន់អើយ ចូរនាំគ្នារត់ ចូរចាកចេញពីទីនេះ ចូរនាំគ្នាពួនក្នុងរូងភ្នំទៅ។ ដ្បិតយើងនឹងធ្វើឲ្យមហន្តរាយកើតមាន ដល់ពូជពង្សរបស់អេសាវ គឺដល់ពេលយើងវិនិច្ឆ័យទោសគេហើយ។
[9]ប្រសិនបើពួកបេះផ្លែទំពាំងបាយជូរ មកដល់ទឹកដីអ្នក គេមិនទុកឲ្យមានផ្លែនៅសល់ឡើយ។ ប្រសិនបើពួកចោរចូលប្លន់អ្នកនៅពេលយប់ គេនឹងយកអ្វីៗដែលគេអាចយកបាន។[10]តែយើងនឹងយកអ្វីៗទាំងអស់ចេញពីអេសាវ យើងនឹងបើកកកាយកន្លែងដែលគេពួន គឺគេពុំអាចពួនតទៅទៀតបានឡើយ។ ពូជពង្សរបស់គេ ព្រមទាំងអ្នកជិតខាងរបស់គេ នឹងត្រូវអន្តរាយ។[11]គ្មាននៅសល់នរណាម្នាក់ពោលថា៖ កុំព្រួយបារម្ភនឹងកូនអ្នកដែលនៅកំព្រាឡើយ ខ្ញុំនឹងចិញ្ចឹមពួកវា ប្រពន្ធរបស់អ្នកដែលនៅមេម៉ាយ ក៏អាចទុកចិត្តលើខ្ញុំដែរ»។
[12]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «អស់អ្នកដែលមិនត្រូវផឹកពីពែងនៃទុក្ខលំបាកនេះ ក៏យើងដាក់ទោសឲ្យផឹកដែរ។ ចុះអ្នកវិញ តើអ្នកស្មានថាអាចរួចខ្លួនឬ? ទេ អ្នកពុំអាចរួចខ្លួនបានឡើយ អ្នកត្រូវតែផឹក។[13]យើងសុំស្បថក្នុងនាមយើងផ្ទាល់ថា ក្រុងបូសរ៉ានឹងត្រូវវិនាសអន្តរាយក្លាយទៅជាទីស្មសាន និងជាគំនរបាក់បែក។ ប្រជាជនឯទៀតៗនឹងយកឈ្មោះក្រុងនេះទៅជេរប្រមាថ និងដាក់បណ្តាសាគ្នា។ ទីក្រុងផ្សេងទៀតនឹងវេនាសជារៀងរហូត» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[14]ខ្ញុំបានឮពីព្រះអម្ចាស់ ហើយព្រះបន្ទូលបាននាំទៅ ប្រកាសដល់ប្រជាជាតិនានាថា ចូរប្រមូលគ្នាមកប្រហារទឹកដីអេដុម ចូរក្រោកឡើង វាយលុកទឹកដីនេះទៅ។[15]«អេដុមអើយ យើងនឹងធ្វើឲ្យអ្នកក្លាយទៅ ជាប្រជាជាតិមួយតូចជាងគេ ជាប្រជាជាតិដែលមនុស្សលោកមើលងាយ។
[16]ចិត្តអួតអាងរបស់អ្នកបញ្ឆោតខ្លួនឯង តែគ្មាននរណាខ្លាចអ្នក ដូចអ្នកនឹកស្មាននោះទេ អ្នករស់នៅតាមក្រហែងថ្ម និងនៅតាមកំពូលភ្នំ ប៉ុន្តែ ទោះបីអ្នកលើកទ្រនំរបស់អ្នកឲ្យខ្ពស់ដូចទ្រនំសត្វឥន្ទ្រីក្តី។ ក៏យើងនឹងច្រានអ្នកឲ្យធ្លាក់ចុះពីទីនោះដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[17]ទឹកដីអេដុមនឹងវិនាសហិនហោច អស់អ្នកដែលដើរក្បែរនោះនឹងព្រឺសម្បុរ ដោយឃើញសំណល់បាក់បែកទាំងប៉ុន្មាន។[18]ដូចអេដុមប្រៀបបាននឹងក្រុងសូដុម និងក្រុងកូម៉ូរ៉ាព្រមទាំងក្រុងឯទៀតៗនៅជុំវិញ «ជាព្រះបន្ទូលនៃព្រះអម្ចាស់» គ្មានអ្នកណារស់នៅ ហើយក៏គ្មានអ្នកអាស្រ័យនៅនោះដែរ។
[19]មើល៍! គេនឹងលោតដូចសត្វសិង្ហដែលមកព្រៃមាត់ទន្លេយ័រដាន់។ យើងក៏នឹងធ្វើឲ្យប្រជាជនរត់ចេញពី ទឹកដីអេដុមរហ័សយ៉ាងនោះដែរ ហើយយើងនឹងតែងតាំងអ្នកគ្រប់គ្រងដែលយើងបាន ជ្រើសរើសឲ្យគ្រប់គ្រងលើទឹកដីនេះ។ តើមាននរណាអាចផ្ទឹមស្មើនឹងយើង? តើនរណាហ៊ានប្តឹងយើង? តើអ្នកដឹកនាំណាអាចប្រឆាំងនឹងយើង?»
[20]«ដូច្នេះ សូមស្តាប់អំពីផែនការដែល ព្រះអម្ចាស់សម្រេចធ្វើចំពោះទឹកដីអេដុម និងគម្រោងការដែលព្រះអង្គគ្រោងទុក ដើម្បីដាក់ទោសអ្នកក្រុងថេម៉ាន។ សត្វរពិតជានាំអ្នកទឹកដីនេះចេញទៅ ដូចកូនចៀមដែលគេកៀរយកទៅ។ ព្រមទាំងបំផ្លាញទឹកដីភូមិរបស់ពួកគេ ឲ្យហិនហោចទៀតផង។
[21]សម្លេងនៃផែនដីក៏កក្រើក ហើយរំជួយផង។ ដោយសូរសម្លេងគេធ្លាក់ចុះ ក៏មានឮសម្រែកដែលឮរហូតដល់សមុទ្រក្រហម។[22]មើល៍! នរណាម្នាក់នឹងវាយលុកដូចជាសត្វឥន្ទ្រី ហើយគេនឹងត្រដាងស្លាបលើក្រុងបុសរ៉ា នៅថ្ងៃនោះ ចិត្តរបស់មនុស្សខ្លាំងពូកែនៅទឹកដីអេដុមនឹងឈឺចាប់ដូចជាស្ត្រីដែលហៀបនឹងសម្រាលកូន»។
[23]នេះជាព្រះបន្ទូលស្តីអំពីក្រុងដាម៉ាស។ «អ្នកក្រុងហាម៉ាត់ និងអ្នកក្រុងអើផាត ត្រូវអាម៉ាស់ ដ្បិតពួកគេទទួលដំណឹងមិនល្អ ពួកគេញ័ររន្ធត់យ៉ាងខ្លាំង ពួកគេអន្ទះអន្ទែងដូចទឹកសមុទ្រពុះកញ្ជ្រោល គ្មាននរណាអាចធ្វើឲ្យស្ងប់បានឡើយ។[24]អ្នកក្រុងដាម៉ាសធ្លាក់ទឹកចិត្ត ហើយបែរក្រោយ ដើម្បីរត់គេចខ្លួន ពួកគេភ័យតក់ស្លុតឈឺចុកចាប់អន្ទះអន្ទែង ដូចស្ត្រីហៀបនឹងសម្រាលកូន។[25]តើក្រុងដ៏ល្បីល្បាញ ក្រុងដ៏សប្បាយនេះ ត្រូវគេបោះបង់ចោលមែនឬ?
[26]ដូច្នេះ នៅថ្ងៃនោះពួកយុវជនដួលស្លាប់នៅតាមផ្លូវ ទាហានទាំងអស់ក៏បាត់បង់ជីវិតដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល»។[27]«ដ្បិត យើងនឹងយកភ្លើងទៅដុត កំពែងរបស់ទីក្រុងដាម៉ាស ហើយភ្លើងនោះនឹងឆេះបំផ្លាញវិមានរបស់ស្តេចបេនហាដាដ»។
[28]នេះជាព្រះបន្ទូលស្តីអំពីទឹកដីកេដារ និងនគរទាំងប៉ុន្មាននៅហាសោរ ដែលព្រះចៅនេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន វាយយកបាន។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ចូរក្រោកឡើង ទៅវាយលុកទឹកដីកេដារ ចូរកម្ទេចពួកអ្នកទឹកដីខាងកើតនោះ ឲ្យអន្តរាយទៅ។[29]ចូរដណ្តើមយកជំរំ និងហ្វូងសត្វរបស់ពួកគេ ព្រមទាំងយកក្រណាត់ដ៏ក្រាស់ៗ ហើយនិងអីវ៉ាន់ផ្សេងៗទៀត និងហ្វូងអូដ្ឋរបស់ពួកគេដែរ។ ចូរស្រែកដាក់ពួកគេថា ការព្រឺខ្លាចស្ថិតនៅគ្រប់ទីកន្លែង!»
[30]អ្នកទឹកដីហាសោរអើយ ចូរនាំគ្នារត់ភៀសខ្លួនទៅ ហើយពួនក្នុងរូងភ្នំទៅ! ដ្បិតនេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន បានសម្រេចរៀបចំគម្រោងការវាយប្រហារ អ្នករាល់គ្នាហើយ។ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[31]ចូរក្រោកឡើងទៅវាយលុកប្រជាជាតិ ដែលរស់នៅយ៉ាងសុខសាន្ត គ្មានកង្វល់អ្វី នេះជា«ព្រះបន្ទូលរបស់ព្រះអម្ចាស់»។ ដ្បិតទីលំនៅរបស់គេ គ្មានទ្វារ គ្មានរនុកទេ គេរស់នៅដាច់តែឯង។
[32]ដ្បិត ហ្វូងអូដ្ឋរបស់ពួកគេ ព្រមទាំងរឹបអូសយកហ្វូងសត្វដ៏ច្រើន របស់ពួកគេ ទុកជាជយភណ្ឌទៀតផង។ យើងនឹងកម្ចាត់ប្រជាជនដែលកោរជើងសក់ ឲ្យខ្ចាត់ខ្ចាយទៅគ្រប់ទិសតំបន់ យើងនឹងធ្វើឲ្យទុក្ខវេទនាពីគ្រប់ទិសទី កើតមានដល់ពួកគេ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[33]ទឹកដីហាសោរនឹងក្លាយទៅជាជម្រករបស់ឆ្កែព្រៃ ជាទីស្មសានរហូតតទៅ គឺនឹងគ្មានប្រជាជនរស់នៅ ហើយក៏គ្មានអ្នកណាមកជ្រកអាស្រ័យនៅទៀតដែរ»។
[34]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការីយេរេមា ស្តីអំពីទឹកដីអេឡាំ។ នៅដើមរជ្ជកាលព្រះបាទសេដេគា ជាស្តេចទឹកដីយូដាដោយមានព្រះបន្ទូលថា[35]«ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា: មើល៍! យើងកាច់បំបាក់ធ្នូ ជាអាវុធដ៏ល្បីល្បាញ របស់ជនជាតិអេឡាំ ហើយនឹងទីតាំងមានអំណាចរបស់គេ។[36]ដ្បិត យើងនឹងធ្វើឲ្យខ្យល់

generated on Wed Sep 10 16:16:32 2025

ទាំងបួនទិស បក់មកលើទឹកដីអេឡាំ យើងឲ្យខ្យល់ទាំងនោះកម្ចាត់ពួកគេ ខ្ចាត់ខ្ចាយទៅគ្រប់ទិសទី ជនជាតិអេឡាំទៅនៅខ្យល់ទាំងនោះ។ នឹងមិនមានជនជាតិអេឡាំណាដែលមិនទៅនោះទេ។
[37]ដូច្នេះ យើងនឹងធ្វើឲ្យជនជាតិអេឡាំញ័ររន្ធត់ នៅចំពោះមុខខ្មាំងសត្រូវ និងនៅចំពោះមុខ អស់អ្នកដែលចង់ប្រហារជីវិតពួកគេ។ ដ្បិត យើងនឹងនាំទុក្ខវេទនាមកលើពួកគេ ដោយកំហឹងដ៏ខ្លាំងក្លារបស់យើង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងនឹងឲ្យដាវទៅតាមប្រហារពួកគេ រហូតទាល់តែប្រល័យជីវិតពួកគេ អស់គ្មានសល់។[38]ក្រោយមក យើងនឹងមកគ្រងរាជ្យលើទឹកដីអេឡាំ យើងនឹងប្រហារជីវិតស្តេច និងនាម៉ឺនរបស់ពួកគេ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[39]ប៉ុន្តែ នៅគ្រាក្រោយ យើងនឹងស្តារទឹកដីអេឡាំឡើងវិញ នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់»។

Jeremiah 49:1
ព័ត៌មានទូទៅ:
សូមមើល: និង
តើអ៊ីស្រាអែលគ្មានកូនទេឬ? តើមិនមានអ្នកណាទទួលមរតកអ្វីមួយក្នុងអ៊ីស្រាអែល? ហេតុអ្វីបាន
ម៉ូឡុក បានកាន់កាប់ទឹកដីកាដ ហើយប្រជាជនរបស់គេដែលរស់នៅទីក្រុងទាំងឡាយ?
ការបកប្រែរបៀបផ្សេងទៀត:
«ជនជាតិអ៊ីស្រាអែលជាច្រើនដែលបានទទួលទឹកដីអ៊ីស្រាអែលជាមត៌ក។
ប្រជាជនដែលថ្វាយបង្គំព្រះក្លែងក្លាយ ដែលមានឈ្មោះម៉ូលុច
មិនសមរស់នៅក្នុងទឹកដីកាឌ់ឡើយ»។
ដូច្នេះ នៅពេលខាងមុខ
នេះបានបន្ថែមការបញ្ជាក់ន័យទៅលើអ្វីដែលនៅខាងក្រោយ។
ការបកប្រែរបៀបផ្សេងទៀត: «ចូរមើលហើយចូរស្តាប់»។
ថ្ងៃនោះនឹងមកដល់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៧:៣១។
ព្រះបន្ទូលព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
Jeremiah 49:3
ចូរស្រែកយំ
ស្រែកយំខ្លាំងៗ
ប្រជាជនរ៉ាបាតអើយ!
ពួកស្ត្រីដែលនៅទីក្រុងរ៉ាបាត
ហេតុដូចម្តេចបានជាអ្នកអួតខ្លួនពីកំលាំងរបស់អ្នក?
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនគួរអួតទេព្រោះតែអ្នកមិនខ្លាំងឡើយ»។
តើនរណាហ៊ានមកប្រឆាំងនឹងខ្ញុំ?
«អ្នកគិតខុស ដោយគ្មាននរណាអាចយកឈ្នះអ្នកបានឡើយ»
Jeremiah 49:5
អ្នក
ពាក្យថា «អ្នក» សំដៅលើប្រជាជនអាំម៉ូន។
ត្រូវខ្ចាត់ខ្ចាយ
ការបកប្រែរបៀបផ្សេងទៀត: «ទៅទិសដៅផ្សេងទៀត»។
ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
Jeremiah 49:7
តើការប្រឹក្សាដែលល្អបានបាត់ពីអ្នកដែលមានចំណោះដឹងឬ?តើប្រាជ្ញារបស់គេបានខូចអស់ហើយឬ?
គំនិតដូចគ្នាត្រូវបានបង្ហាញតាមពីរវិធីផ្សេងគ្នា។
តើការប្រឹក្សាដែលល្អបានបាត់ពីអ្នកដែលមានចំណោះដឹងឬ?
«វាហាក់ដូចជាលែងមានមនុស្សមានប្រាជ្ញានៅក្រុងថេម៉ាននៃស្រុក អេដុម!»
តើប្រាជ្ញារបស់គេបានខូចអស់ហើយឬ?
«ការប្រឹក្សារបស់ពួកគេលែងមានប្រាជ្ញាទៀតហើយ»
Jeremiah 49:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលពីអ្វីដែលនឹងកើតឡើងចំពោះអេដុម។
ប្រសិនបើដូវច្រូតកាត់ផ្លែទំពាំងបាយជូរ បានមកដល់
«អ្នកដែលច្រូតកាត់ផ្លែទំពាំងបាយជូរ តែងតែរក្សាទុកខ្លះនៅលើវល្លិ»។
ប្រសិនបើពួកចោរចូលលួច
«នៅពេលពួកចោរចូលមកពេលយប់
ពួកគេប្រាកដជាលួចអ្វីតាមដែលពួកគេចង់បាន»។
Jeremiah 49:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីអ្វីដែលនឹងកើតឡើងចំពោះអេដុម។
មើល!
ការបកប្រែរបៀបផ្សេងទៀត: «ចូរមើល ចូរស្តាប់ ឬចូរយកចិត្តទុកដាក់»
ធឹកពីពែងនោះ
ការបកប្រែរបៀបផ្សេងទៀត: «ទទួលបទពិសោធពីការដាក់ទោស»
តើអ្នកខ្លួនឯងគិតថាអ្នកអាចនឹងរួចដោយមិនបានជំរុំជម្រះឬ?
ការបកប្រែរបៀបផ្សេងទៀត: «ពិតប្រាកដណាស់ អ្នកត្រូវតែដឹងថា
អ្នកនឹងត្រូវទទួលទោសពីយើង ចំពោះអំពើបាបអ្នក។
អ្នកខ្លួនឯង ... អ្នក
ពាក្យថា «អ្នក» និង«អ្នកខ្លួនឯង» សំដៅលើអេដុម? (សូមមើល:
ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
Jeremiah 49:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលពីប្រជាជនអេដុម។
ខ្ញុំបានឮ
ពាក្យថា «ខ្ញុំ» សំដៅលើលោកយេរេមា។
ប្រហារទឹកដីនេះ
ពាក្យថា «ទឹកដី» សំដៅលើ អេដុម។
យើងនឹងបានធ្វើ
ពាក្យថា «យើង» សំដៅលើព្រះអម្ចាស់។
អ្នក
ពាក្យថា «អ្នក» សំដៅលើជនជាតិ អេដុម។
Jeremiah 49:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលពីអ្វីដែលនឹងកើតមាននៅអេដុម។
ឲ្យខ្ពស់ដូចទ្រនំសត្វឥន្ទ្រី
ការបកប្រែរបៀបផ្សេងទៀត: «រស់នៅដោយសុវត្ថិភាពដូចជាឥន្ទ្រីនៅលើកំពូលភ្នំ»
ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
Jeremiah 49:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលពីប្រជាជនអេដុម។
ភ័យខ្លាចនិងហួសចិត្ត
ការបកប្រែរបៀបផ្សេងទៀត: «អង្រួនពីការភ័យខ្លាច
ហើយថ្លែងពីអ្វីដែលមិនពេញចិត្តគេ»
ដូចការបោះ ចោលនៃក្រុងសូដុម និងក្រុងកូម៉ូរ៉ា
ការបកប្រែរបៀបផ្សេងទៀត: «នៅតាមផ្លូវក្រុងសូដុម
និងក្រុងកូម៉ូរ៉ាត្រូវបានបំផ្លាញ»
គ្មានអ្នកណារស់នៅទីនោះទេ ហើយក៏គ្មានអ្នកអាស្រ័យនៅនោះដែរ
ព្រះអម្ចាស់មានព្រះបន្ទូលដដែលៗ
ពីរដងដើម្បីបញ្ជាក់ថាស្រុកអេដុមនឹងគ្មានមនុស្សរស់នៅនោះទេ។
Jeremiah 49:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីអ្វីដែលនឹងកើតឡើងចំពោះអេដុម។
មើល!
ការបកប្រែរបៀបផ្សេងទៀត: «ចូរមើល ចូរស្តាប់ ឬចូរយកចិត្តទុក»។
ដូចសត្វសិង្ហ
នេះជារបៀបនៃការថ្លែងមួយផ្សេងទៀតដែលថា
ការវាយប្រហារដោយភាពសាហាវនិងមិននឹកស្មានដល់។
តើមាននរណាអាចដូចនឹងយើង តើនរណាហៅយើង?
ព្រះអម្ចាស់ប្រើសំនួរដើម្បីចង្អុលបង្ហាញពីមនុស្សតូចប៉ុណ្ណា។
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់អាចដូចយើងទេ

generated on Wed Sep 10 16:16:32 2025

គ្មាននរណាដែលអាចបង្គាប់យើងបានទេ»។
ហៅ
«បង្គាប់ឱ្យនរណាម្នាក់មក»
តើអ្នកគ្រប់គ្រងណាអាចប្រឆាំងនឹងយើង?
ព្រះអម្ចាស់ប្រើសំនួរដើម្បីបង្ហាញថា គ្មាននរណាអាចយកឈ្នះទ្រង់បានឡើយ។
«អ្នកគ្រប់គ្រង» នៅទីនេះគឺជាពាក្យប្រៀបធៀបសម្រាប់ «ស្តេច» «អ្នកដឹកនាំ»។
Jeremiah 49:20
អ្នកក្រុងថេម៉ាន
ពួកប្រជាជនដែលរស់នៅក្រុងថេម៉ាន
ពួកគេពិតជាអូសចេញ ទោះបីកូនចៀមដែលតូច
ការបកប្រែរបៀបផ្សេងទៀត: «ទ្រង់នឹងអូសពួកគេចេញ ទោះបីជាហ្វូងចៀមតូច»
វាលស្មៅរបស់ពួកគេនឹងត្រូវប្រែក្លាយជាសំណង់បាក់បែក
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គនឹងប្រែក្លាយវាលស្មៅរបស់ពួកគេឲ្យទៅជាកន្លែងដែលបាក់បែក»
វាលស្មៅ
វាលស្មៅ គឺជាដីគ្របដណ្តប់ដោយស្មៅដែលសត្វអាចស៊ីនៅលើស្មៅនោះ។
Jeremiah 49:21
របស់គេ
ពាក្យថា «របស់គេ» សំដៅលើអេដុម។
សម្លេងការធ្លាក់បាក់ចុះរបស់គេ និងរំជួយផែនដីផង។ សម្លេងអទុក្ខព្រួយ បានសម្រែកដែលឮរហូតដល់សមុទ្រក្រហម
គោលបំណងនៃការនិយាយបំផ្លើសនេះគឺដើម្បីប្រាប់ពីការបរាជ័យដ៏ធ្ងន់ធ្ងររបស់អេដុម។
មើល៍
ការបកប្រែរបៀបផ្សេងទៀត: «ចូរមើល ចូរស្តាប់ ឬចូរយកចិត្តទុកដាក់»
វាយលុកដូចជាសត្វឥន្ទ្រី ហើយធ្លាក់ចុះនឹងត្រដាងស្លាបរបស់វា
ការវាយប្រហារនឹងសាហាវ និងមិននឹកស្មានដល់។
បុសរ៉ា
ជាទីក្រុងមួយ។
ត្រលប់ដូចដួងចិត្តនៃស្ត្រីដែលនៅក្នុងការសម្រាលកូន
«មានអារម្មណ៍ធុញថប់ និងភ័យខ្លាច»
Jeremiah 49:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្តព្រះបន្ទូលអ្វីដែលនឹងកើតឡើងចំពោះប្រជាជនក្រុងដាម៉ាស។
អើផាត
នេះជាទីក្រុងស៊ីរី។
ពួកគេនឹងរលាយអស់
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងភ័យខ្លាច»
ពួកគេក្លាយទៅជាមានបញ្ហាដូចទឹកសមុទ្រ
អារម្មណ៍របស់ពួកគេត្រូវបានប្រៀបធៀបទៅនឹងសមុទ្រដែលមានបញ្ហា។
ដូចជាការឈឺចាប់នៃស្ត្រីជិតនឹងសម្រាលកូន
ទុក្ខវេទនានៃទីក្រុងនេះត្រូវបានប្រៀបធៀបទៅនឹងការឈឺចាប់របស់ស្ត្រីដែលនឹងសម្រាលកូន។
ហេតុអ្វីបានជាទីក្រុងនៃការសរសើរ មិនត្រូវគេបោះបង់ចោល ក្រុងនៃអំណររបស់យើងឬ?
ការបកប្រែរបៀបផ្សេងទៀត: «វាមិនអាចជាទីក្រុងនៃការសរសើរ
ទីក្រុងដែលពេញដោយសេចក្តីអំណរ
និងសុភមង្គលច្រើនគួរតែមានសម្រាប់ប្រជាជនរស់នៅទីនោះទេ»។
Jeremiah 49:26
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីអ្វីដែលនឹងកើតឡើងចំពោះក្រុងដាម៉ាស។
របស់គេ
ពាក្យថា «របស់គេ» សំដៅទៅលើក្រុងដាម៉ាស។
ព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
បេនហាដាដ
នេះជាឈ្មោះរបស់ស្តេច។
Jeremiah 49:28
ព័ត៌មានទូទៅ:
លោកយេរេមាបន្តថ្លែងពីអ្វីដែលនឹងកើតឡើងចំពោះទឹកដីកេដារ។
កេដារ
ជាឈ្មោះក្រុមមនុស្ស។
ហាសោរ
ជាឈ្មោះទីកន្លែងមួយនៅក្នុងគម្ពីរអ៊ីស្រាអែល និងសម័យបច្ចុប្បន្ន។
Jeremiah 49:30
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីអ្វីដែលនឹងកើតឡើងចំពោះទឹកដីកេដារ។
ស្នាក់នៅក្នុងរូងក្រោមដីចុះ
«លាក់ខ្លួន»
ប្រជាជនហាសោរអើយ
«ពួកប្រជាជនដែលរស់នៅហាសោរ»
ព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
បានសម្រេចរៀបចំគម្រោងការ
«បង្កើតផែនការ»
ពួកគេ...ពួកគេ
ពាក្យថា «ពួកគេ» និង «ពួកគេ»
សំដៅលើប្រជាជនដែលមានអារម្មណ៍ថាសុវត្ថិភាព និងសុខសាន្ត។
Jeremiah 49:32
កម្ចាត់ទៅតាមខ្យល់
«ទៅតាមទិសដៅផ្សេងៗគ្នា»
ហើយយើងនឹងកម្ចាត់ទៅតាមខ្យល់អ្នកដែលកាត់ជើងសក់របស់គេ
ការបកប្រែរបៀបផ្សេងទៀត: «ហើយយើងនឹងចាត់តាមទិសដៅផ្សេងៗគ្នា
អស់អ្នកដែលមិនគោរពតាមបញ្ញត្តិរបស់យើង»
គ្មានអ្នកណារស់នៅទីនោះទេ ហើយគ្មានមនុស្សមកជ្រកអាស្រ័យនៅទីនោះដែរ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ពីហាសោរ
ដែលនឹងគ្មានមនុស្សរស់នៅ។
Jeremiah 49:34
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ្វីដែលនឹងកើតឡើងចំពោះទឹកដីអេឡាំ។
ធ្នូ របស់អេឡាំ
សំដៅលើពួកមនុស្សដែលមានជំនាញប្រើធ្នូ និងព្រួញ
ខ្យល់ទាំងបួនទិស
«ខ្យល់បួនប្រភេទ ពីបួនទិស»។
គឺអត់មានជនជាតិដែលអ្នកខ្លាត់ខ្លាយពីអេឡាំណាដែលមិនទៅនោះទេ
ការបកប្រែរបៀបផ្សេងទៀត: «ជនភៀសខ្លួនមកពីទឹកដីអេឡាំ
នឹងត្រូវបង្ខំចិត្តស្វែងរកជម្រកនៅគ្រប់ទិសទីទូទាំងពិភពលោក»។
Jeremiah 49:37
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលពីអ្វីដែលនឹងកើតឡើងចំពោះទឹកដីអេឡាំ។
ព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:៧។
ចាត់ដាវឲ្យទៅ
ការបកប្រែរបៀបផ្សេងទៀត: «ចាត់ខ្មាំងសត្រូវរបស់ពួកគេទៅសម្លាប់ពួកគេ»
យើងនឹងមកគ្រងរាជ្យ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបង្កើតច្បាប់គ្រប់គ្រងរបស់យើង»

---

50 [1]នេះជាព្រះបន្ទូលដែលព្រះអម្ចាស់ប្រកាស តាមរយៈព្យាការីយេរេមា និយាយអំពីបាប៊ីឡូន និងទឹកដីខាល់ដេ។[2]«ចូរប្រកាសប្រាប់ប្រជាជាតិនានា ចូរប្រាប់ឲ្យពួកគេស្តាប់។ ចូរលើកទង់សញ្ញាឡើង ចូរប្រាប់ឲ្យពួកគេស្តាប់។ កុំលាក់ឲ្យសោះ។ ចូរនិយាយថា: សត្រូវវាយយកបានក្រុងបាប៊ីឡូនហើយ។ ព្រះបាលត្រូវអាម៉ាស់ ព្រះម៉ារ៉ូឌុកត្រូវរលំ។ រូបបដិមារបស់ពួកគេត្រូវអាម៉ាស់ ព្រះក្លែងក្លាយរបស់ពួកគេក៏ត្រូវរលំដែរ។
[3]ប្រជាជាតិមួយនៅទិសខាងជើង លើកទ័ពមកវាយក្រុងបាប៊ីឡូន ធ្វើឲ្យទឹកដីនេះក្លាយទៅជាទីស្មសាន គ្មាននរណារស់នៅទៀតទេ។[4]គឺទាំងមនុស្ស ទាំងសត្វ រត់ចេញពីទីនោះ។ នៅគ្រានោះ កូនចៅអ៊ីស្រាអែល និងកូនចៅយូដា វិលត្រឡប់មកវិញជាមួយគ្នា ពួកគេដើរផង យំផង ហើយស្វែងរកព្រះអម្ចាស់ ជាព្រះរបស់ពួកគេ នេះជាព្រះបន្ទូល

generated on Wed Sep 10 16:16:32 2025

របស់ព្រះអម្ចាស់។[5]ពួកគេនឹងស៊ើបសួររកផ្លូវទៅក្រុងស៊ីយ៉ូន ហើយនាំគ្នាបែរមុខតម្រង់ទៅរកក្រុងនោះ។ ពួកគេរួមរស់ជាមួយព្រះអម្ចាស់ ដោយចងសម្ពន្ធមេត្រី ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច ជាសម្ពន្ធមេត្រីដែលពួកគេមិនបំភ្លេចឡើយ»។
[6]ប្រជាជនរបស់យើងប្រៀបបាននឹងហ្វូងចៀម ដែលវង្វេងបាត់។ ពួកគង្វាលបាននាំពួកគេឲ្យវង្វេង ដោយពង្វាងទៅតាមភ្នំនានា ចៀមរបស់យើងដើរពីភ្នំមួយទៅភ្នំមួយ រហូតដល់ភ្លេចក្រោលរបស់ខ្លួន។[7]អស់អ្នកដែលជួបពួកគេ នាំគ្នាខាំហែកស៊ីសាច់ ហើយបច្ចាមិត្តរបស់ពួកគេពោលថា៖ បើយើងសម្លាប់ពួកគេ យើងគ្មានកំហុសអ្វីទេ ព្រោះពួកគេបានប្រព្រឹត្តអំពើបាប ទាស់នឹងព្រះហឫទ័យរបស់ព្រះអម្ចាស់។ ដូនតារបស់ពួកគេបានសង្ឃឹមលើព្រះអម្ចាស់ ដែលជាប្រភពនៃសេចក្តីសុចរិត។
[8]ចូរនាំគ្នារត់ចេញពីក្រុងបាប៊ីឡូន ចូរចាកចេញពីទឹកដីខាល់ដេ ចូរធ្វើដូចជាពពែឈ្មោល ដែលនៅខាងមុខហ្វូងចៀម។[9]ដ្បិត យើងនឹងប្រមូលប្រជាជាតិនានា ដែលជាមហាអំណាច ពីទឹកដីខាងជើង ឲ្យមកវាយលុកក្រុងបាប៊ីឡូន។ ប្រជាជាតិទាំងនោះនឹងរៀបក្បួនទ័ព វាយយកក្រុងនេះ ព្រួញរបស់ពួកគេបាញ់មិនចេះខុសទេ គឺប្រៀបដូចជាទាហានដ៏មានថ្វីដៃ ដែលឥតត្រឡប់មកវិញ ដោយពុំបានប្រហារជីវិតមនុស្សឡើយ។[10]ខ្មាំងនឹងរឹបអូសយកសម្បត្តិរបស់ទឹកដីខាល់ដេ។ អស់អ្នកដែលរឹបអូសយកសម្បត្តិរបស់ទឹកដីនោះ មុខជាបានស្កប់ស្កល់មិនខាន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[11]ជនជាតិបាប៊ីឡូនអើយ អ្នករាល់គ្នាបានរឹបអូស យកទ្រព្យសម្បត្តិនៃប្រជាជនរបស់យើង ម្តេចក៏មិននាំគ្នារីករាយ និងអរសប្បាយ ចូរលោតដូចគោញី ដែលកំពុងពេញកម្លាំង ចូរស្រែកហ៊ោកញ្ជ្រៀវដូចសេះខ្លាំងពូកែទៅ។[12]ក្រុងបាប៊ីឡូនជាម្តាយរបស់អ្នករាល់គ្នា នឹងត្រូវអាម៉ាស់ បាប៊ីឡូននឹងក្លាយទៅជាប្រជាជាតិមួយ អន់ជាងគេបំផុត ទឹកដីរបស់គេក្លាយទៅជាទីស្មសានជាដីហួតហែង និងជាព្រៃល្បោះ»។[13]ព្រះពិរោធរបស់ព្រះអម្ចាស់បាប៊ីឡូននឹងក្លាយទៅជាកន្លែងដែល គ្មាននរណារស់នៅ គឺក្រុងបាប៊ីឡូនទាំងមូលនឹងវិនាសហិនហោច។ អស់អ្នកដែលដើរកាត់ក្បែរនោះ នឹងព្រឺសម្បុរ ដោយឃើញសំណល់បាក់បែក។
[14]ទ័ពបាញ់ព្រួញអើយ ចូរតម្រៀបគ្នាវាយលុក និងព័ទ្ធជុំវិញក្រុងបាប៊ីឡូនទៅ! ចូរបាញ់ព្រួញតម្រង់ទៅក្រុងនេះ ដោយឥតខ្លាចខាតព្រួញឡើយ ដ្បិតក្រុងនេះបានប្រព្រឹត្តអំពើបាបប្រឆាំងនឹងព្រះអម្ចាស់។[15]ចូរស្រែកជយឃោសពីគ្រប់ទិសទី ដ្បិតក្រុងនេះលើកដៃសុំចុះចាញ់ហើយ។ គ្រឹះរបស់វាត្រូវកក្រើក ហើយកំពែងរបស់វាក៏រលំដែរ ដ្បិតព្រះអម្ចាស់សងសឹកនឹងក្រុងនេះដូច្នេះ ចូរសងសឹកនឹងក្រុងបាប៊ីឡូន! សូមធ្វើដាក់គេនូវអ្វីដែលគេបានធ្វើដែរ!
[16]សូមបំផ្លាញអ្នកសាបព្រោះ និងអ្នកច្រូតកាត់ កុំឲ្យមានអ្នករស់នៅក្នុងទឹកដីបាប៊ីឡូន ទៀតឡើយ។ សូមឲ្យគ្រប់គ្នាបានត្រឡប់ទៅនៅក្នុងក្រុងនេះ
គឺមនុស្សដែលដាវបានធ្វើទុក្ខលំបាក សូមឲ្យពួកគេភៀសខ្លួនទៅលើទឹកដីរបស់គេវិញ។
[17]អ៊ីស្រាអែលប្រៀបបាននឹងចៀមវង្វេង ដែលត្រូវហ្វូងសិង្ហដេញខាំ មុនដំបូង ស្តេចទឹកដីអាស្ស៊ីរីខាំអ៊ីស្រាអែល បន្ទាប់មក នេប៊ូក្នេសាស្តេចទឹកដីបាប៊ីឡូន ហែកស៊ី និងកម្ទេចឆ្អឹង។[18]ហេតុនេះហើយបានជាព្រះអម្ចាស់នៃពិភពទាំងមូល ជាព្រះរបស់ជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា៖ យើងនឹងធ្វើទោសស្តេចទឹកដីបាប៊ីឡូន និងទឹកដីរបស់គេ ដូចយើងបានធ្វើទោសស្តេចទឹកដីអាស្ស៊ីរីដែរ។
[19]យើងនឹងនាំជនជាតិអ៊ីស្រាអែលឲ្យ វិលត្រឡប់មកទឹកដីរបស់ខ្លួនវិញ ពួកគេនឹងរស់នៅលើភ្នំកើមែល និងភ្នំបាសាន ហើយពួកគេនឹងបរិភោគឆ្អែតបរិបូណ៌ នៅលើភ្នំអេប្រាអ៊ីម និងភ្នំកាឡាដ។[20]នៅគ្រានោះ ព្រះអម្ចាស់មានបន្ទូលថា គេរកមើលកំហុសរបស់ ជនជាតិអ៊ីស្រាអែលលែងឃើញ។ រីឯអំពើបាបរបស់ជនជាតិយូដា ក៏ពុំឃើញមានទៀតដែរ ដ្បិតយើងលើកលែងទោសអស់អ្នក ដែលយើងទុកឲ្យនៅសេសសល់ពីស្លាប់»។
[21]«ចូរឡើងទៅវាយលុកទឹកដីមេរ៉ាថែម វាយលុកអ្នកទឹកដីពេកូដ ចូរកម្ទេច និងប្រហារពួកគេឥតទុកឲ្យនៅសល់អ្វីឡើយ ចូរប្រព្រឹត្តតាមពាក្យទាំងប៉ុន្មាន ដែលយើងបានបង្គាប់ដល់អ្នក នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[22]មានឮសូរសំឡេង សឹកសង្រ្គាម និងធំសម្បើម និងវិនាសមហន្តរាយ នៅលើទឹកដី។
[23]បាប៊ីឡូនដែលប្រៀបដូចជាញញួរដំកម្ទេច ផែនដីទាំងមូល បែរជាបាក់បែកខ្ទេចខ្ទីអស់។ ម្តេចក៏បាប៊ីឡូនក្លាយទៅជាទីស្មសាន ក្នុងចំណោមប្រជាជាតិនានាដូច្នេះ។
[24]បាប៊ីឡូនអើយ យើងបានដាក់អន្ទាក់អ្នក ហើយអ្នកក៏ជាប់អន្ទាក់នេះ ដោយមិនដឹងខ្លួន ពេលគេឃើញអ្នក គេចាប់យកភ្លាម ព្រោះអ្នកហ៊ានរករឿងព្រះអម្ចាស់។
[25]ព្រះអម្ចាស់បានបើកឃ្លាំងរបស់ព្រះអង្គ ហើយយកគ្រឿងសស្ត្រាវុធ នៃព្រះពិរោធចេញមក ដ្បិតព្រះអម្ចាស់នៃពិភពទាំងមូល ត្រូវការប្រើគ្រឿងសស្ត្រាវុធទាំងនេះ នៅទឹកដីខាល់ដេ។[26]វាយប្រហារបាប៊ីឡូនពីចំងាយ។ ចូរបើកជង្រុករបស់ពួកគេ ចូរកម្ទេចក្រុងនេះ ហើយបំផ្លាញទាំងអស់ ថ្វាយផ្តាច់ដល់ព្រះអម្ចាស់ កុំទុកឲ្យនៅសេសសល់អ្វីឡើយ។
[27]ចូរសម្លាប់មេទ័ពទាំងអស់នៅទឹកដីនោះ ដូចគោដែលគេសម្លាប់នៅទីសត្តឃាត! ពួកគេមុខជាវេទនាពុំខាន ដ្បិតថ្ងៃដែលពួកគេទទួលទារុណកម្ម មកដល់ហើយ។
[28]ប្រជាជនដែលរត់ភៀសខ្លួនចេញពីក្រុង បាប៊ីឡូន ប្រកាសឲ្យអ្នកក្រុងស៊ីយ៉ូនដឹងថាព្រះអម្ចាស់ ជាព្រះនៃយើង ព្រះអង្គសងសឹកហើយ គឺព្រះអង្គសងសឹកពួកបាប៊ីឡូន ព្រោះគេបានកម្ទេចព្រះវិហាររបស់ព្រះអង្គ»។
[29]ចូរកោះហៅអ្នកបាញ់ព្រួញ គឺអ្នកបាញ់ព្រួញ ដ៏ពូកែទាំងប៉ុន្មាន មកវាយលុកបាប៊ីឡូន ចូរបោះទ័ពជុំវិញក្រុងនេះ កុំឲ្យនរណាម្នាក់រត់រួចឡើយ។ ចូរសងពួកបាប៊ីឡូនវិញតាមអំពើរបស់ពួកគេ ពួកគេធ្លាប់ប្រព្រឹត្តយ៉ាងណា ចូរប្រព្រឹត្តចំពោះពួកគេវិញយ៉ាងនោះដែរ។ ដ្បិតពួកគេវាយឫកព្រហើនដាក់ព្រះអម្ចាស់ ជាព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល។[30]ហេតុនេះហើយបានជានៅថ្ងៃនោះ យុវជនរបស់ពួកគេដួលស្លាប់នៅតាមផ្លូវ ទាហានទាំងអស់ក៏បាត់បង់ជីវិតដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[31]«មើល៍! ក្រុងបាប៊ីឡូនដ៏ព្រហើនអើយ យើងនឹងដាក់ទោសអ្នកថ្ងៃដែលអ្នកទទួលទារុណកម្មមកដល់ហើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះនៃពិភពទាំងមូល។
[32]ដូច្នេះក្រុងដ៏ព្រហើននេះ ត្រូវជំពប់ដួល។ គ្មាននរណាជួយលើកវាឡើងវិញទេ យើងដុតកម្ទេចក្រុងនានានៅទឹកដីបាប៊ីឡូន ហើយភ្លើងនឹងឆាបឆេះគ្រប់ទិសទី។
[33]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ ប្រជាជនអ៊ីស្រាអែល និងប្រជាជនយូដា ត្រូវបាប៊ីឡូនសង្កត់សង្កិនរួមជាមួយគ្នា អស់អ្នកដែលបានកៀរពួកគេទៅជាឈ្លើយ នៅតែឃុំពួកគេទុកដដែល មិនព្រមលែងពួកគេឡើយ»។[34]ព្រះដែលលោះពួកគេ ព្រះអង្គប្រកបដោយឫទ្ធានុភាព ព្រះអង្គមាននាមថា ព្រះអម្ចាស់នៃពិភពទាំងមូល។ ព្រះអង្គពិតជារកយុត្តិធម៌ឲ្យពួកគេ ហើយនាំសេចក្តីសុខមកលើទឹកដី និងធ្វើឲ្យអ្នកទឹកដីបាប៊ីឡូនកើតចលាចល។
[35]ដាវនឹងតាមបំផ្លាញពួកជនជាតិខាល់ដេ នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ ក៏នឹងបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាជន ហើយប្រហារពួកអ្នកដឹកនាំ
រួមទាំងអ្នកប្រាជ្ញរបស់គេដែរ។[36]ចូរយកដាវទៅប្រហារគ្រូហោររបស់ពួកគេ! អ្នកទាំងនោះជាមនុស្សវិកលចរិត! ចូរយកដាវទៅប្រហារទាហានដ៏ខ្លាំងពូកែរបស់ពួកគេ អ្នកទាំងនោះត្រូវរលំហើយ។[37]ចូរយកដាវទៅប្រហារសេះ និងរទេះចម្បាំងរបស់ពួកគេ ហើយប្រហារជនបរទេសដែលមកជួយច្បាំង រួមជាមួយពួកគេដែរ! អ្នកទាំងនោះទន់ខ្សោយដូចមនុស្សស្រី! ចូរយកដាវបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ ហើយរឹបអូសយកទាំងអស់ទៅ។
[38]ចូរយកដាវទៅវាយទឹកទន្លេរបស់ពួកគេ ឲ្យរីងស្ងួត! ដ្បិតទឹកដីនេះពោរពេញដោយរូបបដិមា ពួកគេវង្វេងវង្វាន់ទៅតាមរូបទីងមោង ដ៏គម្រក់របស់ខ្លួន។[39]ហេតុនេះហើយបានជាសត្វព្រៃ និងសត្វសាហាវ នាំគ្នាមកស្នាក់អាស្រ័យនៅក្នុងក្រុងនេះ សត្វត្មាតក៏មកធ្វើសំបុករស់នៅដែរ គ្មានមនុស្សរស់នៅ អស់កល្បជាអង្វែងតរៀងទៅ។[40]ក្រុងនេះប្រៀបបាននឹងក្រុងសូដុម និងកូម៉ូរ៉ា ព្រមទាំងក្រុងឯទៀតៗ ដែលព្រះជាម្ចាស់បានបំផ្លាញ គឺគ្មាននរណាមករស់នៅទៀតឡើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយក៏គ្មានមនុស្សណាមកតាំងទីលំនៅ ទៀតដែរ»។
[41]«មើល៍! មានកងទ័ពមកពីទិសខាងជើង ប្រជាជាតិមួយ និងស្តេចដ៏ខ្លាំងពូកែទាំងឡាយ ចេញដំណើរពីទីដាច់ស្រយាលនៃផែនដី។[42]ពួកគេលើកធ្នូ លើកលំពែងឡើង ពួកគេសាហាវណាស់ ឥតមានចិត្តមេត្តាទេ សន្ធឹកទ័ពរបស់ពួកគេលាន់ឮដូចសន្ធឹកសមុទ្រ ពួកគេជិះសេះមក ហើយតម្រៀបគ្នាជាក្បួនទ័ព ដើម្បីវាយលុកក្រុងបាប៊ីឡូន។
[43]ស្តេចទឹកដីបាប៊ីឡូនបានឮដំណឹងនេះ ក៏ទន់ដៃទន់ជើង អន្ទះសា និងឈឺចាប់ដូចស្ត្រីហៀបនឹងសម្រាលកូន។
[44]គេលោដូចសត្វសិង្ហចេញពីមាត់ទន្លេយ័រដាន់ ចូលទៅក្នុងគុម្ពោតព្រៃរហ័សយ៉ាងណា យើងក៏នឹងធ្វើឲ្យអ្នកទឹកដី បាប៊ីឡូនរត់ចេញទៅរហ័សយ៉ាងនោះដែរ។ យើងនឹងតែងតាំងអ្នកគ្រប់គ្រង ដែលយើងបានជ្រើសរើសឲ្យគ្រប់គ្រងលើទឹកដីនេះ។ តើមាននរណាអាចផ្ទឹមស្មើនឹងយើង? តើនរណាហ៊ានប្តឹងយើង? តើអ្នកដឹកនាំណាអាចប្រឆាំងនឹងយើង?
[45]ដូច្នេះ ចូរនាំគ្នាស្តាប់អំពីការដែលព្រះអម្ចាស់ សម្រេចធ្វើចំពោះបាប៊ីឡូន និងគម្រោងការដែលព្រះអង្គគ្រោងទុក ដើម្បីដាក់ទោសអ្នកទឹកដីខាល់ដេ! សត្វព្រៃពិតជានាំអ្នកទឹកដីនេះចេញទៅ ដូចកូនចៀមដែលគេកៀរយកទៅ ព្រមទាំងបំផ្លាញទឹកដីភូមិរបស់ពួកគេ ឲ្យហិនហោចទៀតផង។[46]ពេលក្រុងបាប៊ីឡូនរលំ ផែនដីក៏កក្រើក មានសម្រែកលាន់ឮឡើងក្នុងចំណោម ប្រជាជាតិទាំងឡាយ»។

generated on Wed Sep 10 16:16:32 2025

Jeremiah 50:1

ព័ត៌មានទូទៅ:

សូមមើល: និង

តាមរយៈដៃនៃព្យាការីយេរេមា

«តាមរយៈសកម្មភាពរបស់លោកយេរេយា»

ចូរប្រាប់ឲ្យពួកគេស្តាប់ ... ចូរប្រាប់ឲ្យពួកគេស្តាប់

ការបញ្ជាក់ដដែលនៃពាក្យនេះសំខាន់គឺជាការបញ្ជា។

ព្រះបាលត្រូវអាម៉ាស់ ព្រះម៉ារ៉ូឌុកត្រូវរលំ។ រូបបដិមារបស់ពួកគេត្រូវអាម៉ាស់ ព្រះក្លែងក្លាយរបស់ពួកគេក៏ត្រូវរលំដែរ។

តាមរយៈនេះគឺមានន័យដូចគ្នាហើយបានបញ្ជាក់ថា

ព្រះជាម្ចាស់បានធ្វើព្រះរបស់បាប៊ីឡូនបាក់មុខ។

ព្រះបាល ... ព្រះម៉ារ៉ូឌុក

ឈ្មោះទាំងពីរនាក់នោះគឺជាព្រះរបស់ពួកបាប៊ីឡូន។

Jeremiah 50:3

លើកទ័ពមកវាយក្រុងបាប៊ីឡូន

ពាក្យថា «វា» សំដៅទៅបាប៊ីឡូន។

ទឹកដីនេះ

ពាក្យថា «របស់នាង» សំដៅទៅលើក្រុងបាប៊ីឡូន។

រស់នៅទៀតទេ

ពាក្យថា «វា» សំដៅទៅលើទឹកដីរបស់បាប៊ីឡូន។

គឺទាំងមនុស្ស ទាំងសត្វ រត់ចេញពីទីនោះ

សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅក្នុងជំពូក ៣៣:១៤។

ពួកគេនឹងស៊ើបសួរ

ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជននៃអ៊ីុស្រាអែល ឬប្រជាជនយូដា។

រួមរស់ជាមួយព្រះអម្ចាស់

នេះគឺជាភាសាប្រៀបធៀប

សម្រាប់ប្រើដើម្បីពន្យល់ពីទំនាក់ទំនងជាមួយព្រះជាម្ចាស់។

ដែលពួកគេមិនបំភ្លេចឡើយ

ការនិយាយពីសម្ពន្ធមេត្រីនេះនឹងបានស្តាប់បង្គាប់ជារៀងរហូត។

ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្នកណាអាចនឹងបំភ្លេចបាន»

Jeremiah 50:6

ហ្វូងចៀម ដែលវង្វេងបាត់

ការនេះគឺប្រៀបបានទៅនឹងប្រជាជនអ៊ីុស្រាអែល

ដូចជាហ្វូងចៀមមួយក្រុមដែលវង្វេងដែរ។

នាំគ្នាខាំហែកស៊ីសាច់

ការនេះគឺប្រៀបបានទៅនឹងការបំផ្លាញ ហើយបានយកអ្វីៗពីពួកគេ

ដើម្បីបរិភោគយ៉ាងអន្ទះសា។

ពួកគេបានប្រព្រឹត្តអំពើបាប

ពាក្យថា «ពួកគេ» សំដៅដល់ប្រជាជនរបស់អ៊ីុស្រាអែល។

Jeremiah 50:8

ដូចជាពពែឈ្មោល ដែលនៅខាងមុខហ្វូងចៀម

នេះគឺជាការដែលព្រះអម្ចាស់បានផ្តល់យោបល់ឲ្យចាកចេញយ៉ាងឆាប់រហ័សដែលអាចធៀបបានទៅនឹងសត្វ

ដូចជាពួកសត្វពពែឈ្មោល ដែលត្រូវឲ្យចាកចេញពីហ្វូងរបស់វា។

បាប៊ីឡូននឹងត្រូវចាប់ចេញពីទីនេះ

«ប្រជាជាតិនឹងចាប់យកបាប៊ីឡូន»

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ១:៧។

Jeremiah 50:11

ចូរលោតដូចគោញី ដែលកំពុងពេញកម្លាំង

ការប្រៀបធៀបនេះទៅ

និងប្រជាជននៃបាប៊ីឡូនដូចជាគោដែលរត់ជុំវិញដោយរីករាយនៅលើវាលស្មៅ។

ដែលកំពុងពេញកម្លាំង

សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅក្នុងជំពូក ៤៧:៣។

ចូរស្រែកហ៊ោកញ្ជ្រៀវដូចសេះខ្លាំងពូកែទៅ

នេះគឺជាការប្រៀបធៀបពីការសប្បាយចិត្តរបស់ពួកគេទៅនឹងការសប្បាយចិត្តរបស់សេះ

ហើយស្រែកឮសម្លេងខ្លាំង។

ក្រុងបាប៊ីឡូនជាម្តាយរបស់អ្នករាល់គ្នា នឹងត្រូវអាម៉ាស់

ឃ្លាទាំងពីរនេះគឺមានន័យមូលដ្ឋានដូចគ្នា

ហើយបញ្ជាក់ច្បាស់ជាងពីការខ្មាស់អៀនរបស់នាង។ ពាក្យថា «ម្តាយ» ហើយ

«ម្នាក់ដែលធុញនឹងអ្នក» គឺសំដៅផងដែលទៅនិងជនជាតិបាប៊ីឡូន

ឬទីក្រុងរបស់បាប៊ីឡូន។

អន់ជាងគេបំផុត ទឹកដីរបស់គេក្លាយទៅជាទីស្មសានជាដីហួតហែង និងជាព្រៃល្មោះ

ពាក្យទាំងនេះគឺមានមូលដ្ឋានដូចគ្នា

ហើយបញ្ជាក់ពីការខ្មាស់អៀនដ៏ពេញនៅលើដីកដីនោះ។

វិនាសហិនហោច

ញាក់ញ័រហើយឃោរឃៅធ្វើអ្នកទាំងនោះខ្លាច

ព្រឹសម្បុរ

ដែលធ្វើសម្លេងដូចពស់មានន័យថា ការមិនពេញចិត្តជាខ្លាំង

Jeremiah 50:14

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បានប្រាប់ដល់ខ្មាំងសត្រូវរបស់បាប៊ីឡូនពីរបៀបវាយលុកចូលយកទឹកដី។

ចូរបាញ់ព្រួញតម្រង់ទៅក្រុងនេះ

ការនេះសំដៅទៅលើទាហានដែលបានប្រើធ្នូរ ហើយនឹងព្រួញដើម្បីធ្វើចម្បាំង។

បាញ់ព្រួញតម្រង់ទៅក្រុងនេះ

ពាក្យថា «នាង» សំដៅទៅលើក្រុងបាប៊ីឡូន។

កំពែងរបស់វាក៏រលំដែរ

ការបកប្រែផ្សេងទៀត: «ប្រជាជាតិទាំងមូលនឹងផ្តួលកំពែងរបស់វា»

Jeremiah 50:16

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បានប្រាប់ដល់ខ្មាំងសត្រូវរបស់បាប៊ីឡូនពីរបៀបវាយលុកចូលយកទឹកដី។

ហើយអ្នកប្រើកណ្តៀវក្នុងរដូវច្រូតកាត់

«កណ្តៀវ» គឺជាឧបករណ៍ដែលមនុស្សយកទៅប្រើសម្រាប់ច្រូតស្រូវ។

ឃ្លានេះរួមជាមួយពាក្យកន្លងមក ព្រះអម្ចាស់គឺនិយាយអំពីការដាំដុះហើយ

និងការច្រូតកាត់នឹងត្រូវឈប់មាននៅបាប៊ីឡូន។

ចូរឲ្យមនុស្សគ្រប់គ្នាបានត្រឡប់មករកប្រជាជនរបស់គេ...ចូរឲ្យពួកគេភៀសខ្លួន

ទៅលើទឹកដីរបស់ខ្លួនវិញ

ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា។

ទាំងពីរឃ្លាគឺជាការប្រើសម្រាប់បញ្ជាឲ្យជនជាតិបរទេសគេចចេញពីបាប៊ីឡូន។

ពីការដាវនៃការប្រយុទ្ធ

ពាក្យថា «ដាវ» សំដៅពីដៃដែលបានវាយប្រហារបាប៊ីឡូន។

Jeremiah 50:17

អ៊ីុស្រាអែលគឺជាចៀមខ្ចាត់ខ្ចាយចេញទៅដោយសារហ្វូងសិង្ហ

ការបកប្រែផ្សេងទៀត:

«អ៊ីុស្រាអែលគឺជាចៀមដែលសិង្ហបានធ្វើឲ្យខ្ចាត់ខ្ចាយហើយដេញចេញទៅ»

ព្រះអម្ចាស់បានប្រៀបធៀបអ៊ីុស្រាអែលទៅ

និងចៀមហើយខ្មាំងសត្រូវរបស់គេគឺជាសិង្ហ។

លេបត្របាក់គេ

ការប្រៀបធៀបនេះសំដៅទៅលើការបំផ្លាញរបស់អ៊ីុស្រាអែលដោយអាស្ស៊ីរី

ដែលបានកេងប្រវ័ញ្ចពួកគេ។

និងបំបាក់ឆ្អឹងរបស់គេ

ការប្រៀបធៀបទៅនឹងការបំផ្លាញរបស់អ៊ីុស្រាអែលដោយនេប៊ូក្នេសា

ដែលបំបាក់ឆ្អឹងផង។ ការបកប្រែផ្សេងទៀត: «ការបំផ្លាញអ៊ីុស្រាអែល»។

មើល! យើងជិតនឹងដាក់

ពាក្យថា «មើល៍» គឺជាតាំងចិត្តស្តាប់អ្វីដែលពិសេសដែលនឹងមកតាមក្រោយ។

Jeremiah 50:19

យើងនឹងស្តារ

ពាក្យថា «យើង» សំដៅទៅលើព្រះអម្ចាស់។

ពួកគេនឹងរស់នៅលើវាលកើមែល និងបាសាន

«អ៊ីុស្រាអែលនឹងចំអែតខ្លួនដោយអាហារនៅក្នុងវាលកើមែល ហើយបាសាន»។

នៅថ្ងៃនោះ ហើយពេលនោះ

សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុងជំពូក ៣៣:១៤។

ទោះបីជាមានការស្វែងរកក៏ដោយ ក៏គ្មានអំពើទុច្ចរិតនៅក្នុងអ៊ីុស្រាអែល តែរកមិនឃើញទេ។ យើងនឹង

ជនជាតិយូដា ប៉ុន្តែគ្មានរកឃើញទេ

ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា។

generated on Wed Sep 10 16:16:32 2025

ទាំងពីរឃ្លាគឺជាការប្រើសម្រាប់បញ្ជាពីព្រះអម្ចាស់នឹងអត់ទោសបាបដល់ប្រជាជនរបស់អ៊ីស្រាអែលដែលយើងនឹងធ្វើនៅពេលអនាគត។

អំពើទុច្ចរិតបានឃើញនៅក្នុងអ៊ីស្រាអែល តែរកមិនឃើញទេ

ការបកប្រែផ្សេងទៀត:

«ព្រះអម្ចាស់នឹងសម្លឹងមើលអំពើទុច្ចរិតនៅក្នុងប្រជាជននៃអ៊ីស្រាអែល
ប៉ុន្តែនឹងមិនអាចរកឃើញទេ»

Jeremiah 50:21

មេរ៉ាថែម

នេះគឺជាឈ្មោះមួយទៀតសម្រាប់បាប៊ីឡូន។ ឈ្មោះនេះមានន័យថា
«បះបោរថ្វេដង»

ពេកូដ

នេះគឺជាឈ្មោះមួយទៀតសម្រាប់ខាល់ដេ។ ឈ្មោះនេះមានន័យថា «ការមកលេង»

ចូរដាក់ពួកគេទៅនិងដាវ

ការនេះសំដៅទៅលើបានទទួលដាវយកមកសម្លាប់ដល់ពួកគេ។

ការបកប្រែផ្សេងទៀត: «សម្លាប់ពួកគេ»

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់

សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុង ១:៧។

Jeremiah 50:23

តើញញួរ របស់ផែនដីទាំងមូលត្រូវបានកាត់ពីគ្នា ហើយត្រូវបំផ្លាញចោល

ពាក្យថា «ញញួរដែលនៅក្នុងដៃអ្នកទាំងនោះ»
គឺជាអំណាចរបស់បាប៊ីឡូនដែលនឹងត្រូវបំផ្លាញ។

ភ័យរន្ធត់

អារម្មណ៍ដែលភ័យខ្លាំង ញាញើត ហើយស្រឡាំងកាំង

ហើយអ្នកក៏ជាប់អន្ទាក់នេះ បាប៊ីឡូន

ការបកប្រែផ្សេងទៀត: «យើងបានចាប់អ្នកជាប់ បាប៊ីឡូន»

នឹងឃើញអ្នកដោយត្រូវចាប់បាន

ការបកប្រែផ្សេងទៀត: «យើងបានឃើញអ្នក ហើយព័ទ្ធជុំវិញអ្នក»

Jeremiah 50:25

ជង្រុក

កន្លែងសម្រាប់ដាក់ស្រូវ

ហើយផ្ដុំវាឡើងឲ្យច្រើនដូចស្រូវ

ការបកប្រែផ្សេងទៀត: «ដាក់សសរឡើងច្រែងឲ្យបានច្រើនគឺដូចជាទំងន់ស្រូវដែរ»

Jeremiah 50:27

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តប្រាប់ពីរបៀបដើម្បីបំផ្លាញប្រជាជនរបស់បាប៊ីឡូន ហើយខាន់ដេ។

ចូរសម្លាប់គោ

ពួកអ្នកប្រយុទ្ធវ័យក្មេងគឺបានប្រៀបធៀបទៅនឹងគោដោយព្រោះតែកម្លាំងរបស់ពួកគេ។

គោរបស់គេ

ពាក្យថា «របស់» សំដៅទៅដល់បាប៊ីឡូន។

ពួកវា...របស់

ពាក្យថា «ពួកគេ» ហើយ «របស់» សំដៅទៅលើប្រជាជនរបស់បាប៊ីឡូន។

អ្នកដែល...នេះជាការ

ពាក្យថា «អ្នកដែល» ហើយ «ទាំងនេះ»
សំដៅទៅលើអ្នកដែលរួចជីវិតមកពីបាប៊ីឡូន
ដែលបានប្រាប់អំពីការសងសឹកនៃព្រះអម្ចាស់

Jeremiah 50:29

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តប្រាប់ពីរបៀបដើម្បីបំផ្លាញប្រជាជនរបស់បាប៊ីឡូន ហើយខាន់ដេ។

ក្រុងនោះ...ទីក្រុងនេះ

ពាក្យថា «របស់» ហើយ «នាង» សំដៅទៅលើបាប៊ីឡូន។

ទាហានទាំងអស់វិនាស

ការបកប្រែផ្សេងទៀត: «យើងនឹងបំផ្លាញអ្នកប្រយុទ្ធរបស់ទីក្រុងនេះ»

Jeremiah 50:31

មើល!

នេះគឺជាណែនាំអ្វីមួយសម្រាប់ការផ្ចង់ចិត្តពិសេស។

អ្នកមានអំនួត

ការនេះព្រះអម្ចាស់បានពណ៌នាអំពីបាប៊ីឡូន។

សម្រាប់ថ្ងៃរបស់អ្នកបានមកដល់...ជាពេលដែលយើងដាក់ទោសអ្នក

ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា។ ឃ្លាទីពីរបញ្ជាក់ន័យពី «ថ្ងៃ»
ដែលឃ្លាទីមួយបាននិយាយដល់។ ការបកប្រែផ្សេងទៀត: «ដ្បិត
ថ្ងៃរបស់អ្នក

ការនេះគឺនិយាយដល់ពេលវេលាមួយកំឡុងពេលដែលការដាក់ទោសដ៏អាក្រក់នឹងមកនៅក្នុងបាប៊ីឡូន។

យើងដុតភ្លើង

ពាក្យថា «យើង» សំដៅទៅលើព្រះអម្ចាស់។

ភ្លើងក្នុងក្រុងទាំងឡាយ

ការនេះសំដៅទៅលើពីរបៀបនៃការបំផ្លាញនឹងមកដល់។

Jeremiah 50:33

ប្រជាជនអ៊ីស្រាអែលត្រូវបានសង្កត់សង្កិន

ការបកប្រែផ្សេងទៀត:

«ជនជាតិបាប៊ីឡូនបានជិះជាន់ដល់ប្រជាជនរបស់អ៊ីស្រាអែល»

បានចាប់ពួកគេ

ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។

ពួកគេមិនព្រម

ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនបាប៊ីឡូន។

ឲ្យពួកគេទៅ

ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។

Jeremiah 50:35

ដាវគឺច្បាំងនឹងពួកជនជាតិខាល់ដេ

«ដាវ» ដំណាងដល់អ្នកដែលបានប្រើពួកវា។ ការបកប្រែផ្សេងទៀត:

«ទហាននៃសត្រូវបានមកជាមួយនឹងដាវដើម្បីទាស់ជាមួយនិងខាល់ដេ»

នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់

សូមមើលពីរបៀបបកប្រែរបស់អ្នកនៅក្នុង ១:៧។

បង្ហាញភាពល្ងង់របស់ពួកគេ

ពាក្យថា «បង្ហាញ» គឺបង្ហាញពីអ្វីដែលសកម្មភាពល្ងង់របស់ពួកគេ
ហើយនឹងបញ្ជាក់ដល់ឲ្យគ្រប់គ្នាបានឃើញ។

ពួកគេនឹងពេញដោយដាររន្ធត់

ការបកប្រែផ្សេងទៀត: «ការរន្ធត់នឹងបំពេញពួកគេ»

ពួកគេទៅជាទន់ខ្សោយដូចមនុស្សស្រី

«ពួកគេនឹងទៅខ្សោយដូចជាមនុស្សស្រី»

ទ្រព្យសម្បត្តិ

ជង្រុកគឺជាកន្លែងដែលសំខាន់សម្រាប់រក្សាទុក។

ហើយរឹបអូសយក

ការបកប្រែផ្សេងទៀត: «ពួកសត្រូវរបស់ទាហាននឹងរឹបអូសពួកគេចេញទៅ»

Jeremiah 50:38

ទន្លេគេ

«ទឹក» ដំណាងឲ្យប្រភពទាំងអស់របស់ទឹកហើយនឹងអ្វីដែលចាំបាច់សម្រាប់ជីវិត
ជាពិសេសទន្លេដែលហូរកាត់ទីក្រុង។

ឆ្កែព្រៃ

វាគឺជាឆ្កែព្រៃដែលរកឃើញនៅក្នុងប្រទេសអាស៊ីហើយនៅអាហ្វ្រិកា។

សត្វអូសទ្រវែចតូចៗរស់នៅទីនោះ

«សត្វអូសទ្រវែច» គឺជាប្រភេទសត្វដែលធំនៅតំបន់អាង្រ្គិកា
គឺវាអាចរត់លឿនតែមិនអាចហើរទេ។ ពាក្យថា «នាង» សំដៅទៅលើបាប៊ីឡូន។

ដ្បិតនឹងគ្មានមនុស្សរស់នៅ អស់កល្បរៀងទៅ។

ពីមួយជំនាន់ទៅមួយជំនាន់គ្មានអ្នករស់នៅក្នុងក្រុងនោះទេ

ឃ្លាទាំងពីរនេះមានន័យដូចគ្នាហើយបានបញ្ជាក់ន័យថាបាប៊ីឡូននឹងមិនមានមនុស្សរស់នៅទៀតទេ។

គ្មានអ្នករស់នៅក្នុងក្រុងនោះទេ

ការបកប្រែផ្សេងទៀត: «គ្មានអ្នកនឹងរស់នៅក្នុងទីនោះទេ»

គ្មានមនុស្សណារស់នៅទីនោះទេ គ្មានអ្នកតាំងទីលំនៅក្នុងក្រុងនេះទេ

ឃ្លាទាំងពីរនេះមានន័យដូចគ្នាហើយបានបញ្ជាក់ន័យថាបាប៊ីឡូននឹងមិនមានមនុស្សរស់នៅទៀតទេ។

Jeremiah 50:41

មើល!

នេះគឺជាណែនាំអ្វីមួយសម្រាប់ការផ្ចង់ចិត្តពិសេសនៅអ្វីដែលព្រះអម្ចាស់នឹងមានព្រះបន្ទូល។

ដ្បិតប្រជាជាតិដ៏ធំមួយ និងស្តេចជាច្រើន

ឃ្លានេះបានសំដៅទៅពេលវេលាដែលមេឌីនិងពើសុីមកកាន់កាប់បាប៊ីឡូន នៅក្នុង
៥៣៩ មុនគ្រិស្តសករាជ។

ក្នុងការរៀបក្បួនទ័ពសម្រាប់ច្បាំង

ជាផ្នែកមួយនៃការឈរជាជួររបស់ទ័ពនៅក្នុងចម្បាំង

ទីក្រុងបាប៊ីឡូន

generated on Wed Sep 10 16:16:32 2025

ឃ្លានេះសំដៅទៅលើប្រជាជនបាប៊ីឡូន។
Jeremiah 50:44
ចូរមើល៍
ពាក្យថា «មើល» កន្លែងនេះបញ្ជាក់ទៅនឹងអ្វីដែលនឹងមកដល់។
គេលោតឡើង
ពាក្យថា «គេ» សំដៅទៅដល់អ្នកឈ្លានពានពីទិសខាងជើង។ (សូមមើល: ៥០:៤១)
ដូចសត្វសិង្ហ
នេះគឺជារបៀបមួយទៀតនៃការនិយាយដែលការវាយប្រហារនឹងត្រូវសាហាវហើយមិនដែលឈប់ឈរ
ដ្បិតយើងក៏នឹងធ្វើឲ្យពួកគេរត់ចេញទៅរហ័សពីវា
ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនរបស់បាប៊ីឡូន ពាក្យថា «វា» សំដៅទៅលើការលុកលុយ។
នរណាម្នាក់ដែលនឹងជ្រើសរើស
ការបកប្រែផ្សេងទៀត: «នរណាម្នាក់ដែលយើងបានជ្រើសរើស»
តើអ្នកណាដូចយើង តើនរណាកោះហៅយើង?
ព្រះអម្ចាស់បានប្រើសំនួរបង្កើតជាចំនុចដែលតូចជាងរបស់មនុស្ស។
ការបកប្រែផ្សេងទៀត: «គ្មានអ្នកណាដូចយើង
ហើយគ្មានមានអ្នកដែលបញ្ជាយើងបាននោះទេ»។
កោះហៅ
បញ្ជាដល់អ្នកម្នាក់ឲ្យមក
តើអ្នកដឹកនាំណាអាចប្រឆាំងនឹងយើង?
ព្រះអម្ចាស់បានប្រើសំនួរដើម្បីបង្ហាញថាគ្មានអ្នកដឹកនាំណាអាចមកទាស់ជាមួយព្រះអង្គបាន ឬបង្កាប់ព្រះអង្គបានឡើយ។
Jeremiah 50:45
ផែនការដែលព្រះអម្ចាស់ សម្រេចទាស់នឹងបាប៊ីឡូន ដែលព្រះអង្គមានគម្រោងទាស់ប្រឆាំងនឹងទឹកដីខាល់ដេ
ឃ្លាទាំងពីរនេះគឺមានន័យដូចគ្នាហើយបានប្រើរួមគ្នាដើម្បីបញ្ជាក់ន័យផងដែរ។
ការបកប្រែផ្សេងទៀត: «ផែនការដែលព្រះអម្ចាស់ សម្រេចទាស់នឹងបាប៊ីឡូន ដែលព្រះអង្គមានគម្រោងទាស់ប្រឆាំងនឹងទឹកដីខាល់ដេ»។
ដែលសាសន៍ដទៃឆ្លងកាត់
ការនេះមានន័យថាប្រជាជនបាប៊ីឡូននឹងត្រូវទាញចេញពីផ្ទះរបស់ពួកគេ ទោះបីពួកចង់ឬក៏មិនចង់ក្តី។
ហើយទីវាលស្មៅរបស់ពួកគេនឹងត្រឡប់ទៅជាទីកន្លែងខូចបង់
«យើងនឹងធ្វើឲ្យវាលស្មៅរបស់ពួកគេទៅជាខូចបង់»
សម្លេងយកឈ្នះក្រុងបាប៊ីឡូន ដូចផែនដីកក្រើក
ឃ្លានេះប្រៀបធៀបពីការធ្លាក់ចុះនៅពេលអំណាចនៃជនជាតិបាប៊ីឡូន ហើយសម្លេងដ៏ខ្លាំងនិងការកក្រើកផែនដីផង។
ទុក្ខព្រួយ
ឈឺបាច់ឬមិនសប្បាយចិត្ត
សម្រែកនៃទុក្ខព្រួយ
«ពួកគេស្រែកដោយឈឺចាប់»

---

51 [1]«ព្រះអម្ចាស់មានព្រះបន្ទូលការនេះ៖ មើល៍! យើងនឹងធ្វើឲ្យខ្យល់ព្យុះ បក់បោកបំផ្លាញក្រុងបាប៊ីឡូន និងប្រជាជនដែលរស់នៅក្រុងនោះ។[2]យើងនឹងប្រើជនជាតិផ្សេងឲ្យទៅក្រុងបាប៊ីឡូន។ ពួកគេនឹងធ្វើឲ្យអ្នករាល់គ្នាខ្ចាត់ខ្ចាយ ហើយមហន្តរាយ របស់អ្នកផងដែរ ពួកគេមកពីគ្រប់ទិសទី វាយលុកក្រុងបាប៊ីឡូន នៅថ្ងៃវេទនានោះ។
[3]មិនត្រូវឲ្យទាហានទាញបាញ់ព្រួញ និងមិនឲ្យគេពាក់អាវក្រោះ ដែល។ កុំត្រាប្រណីយុវជនរបស់ពួកគេ ចូរបំផ្លាញកងទ័ពទាំងមូលរបស់ពួកគេចោលទៅ។[4]ដ្បិត ពួកគេដួលស្លាប់នៅក្នុងទឹកដីខាល់ដេ អ្នកដែលគេចាក់ទម្លុះ ត្រូវស្លាប់នៅតាមដងផ្លូវរបស់ពួកគេដែរ។
[5]ដ្បិត ព្រះអម្ចាស់នៃពិភពទាំងមូល ដែលជាព្រះ របស់ជនជាតិអ៊ីស្រាអែល និងជនជាតិយូដា ទ្រង់មិនបោះបង់ចោលប្រជារាស្ត្រ របស់ព្រះអង្គឡើយ ទោះបីទឹកដីរបស់គេបានពេញទៅដោយ ពួកទាស់ប្រឆាំងនិងព្រះដ៏វិសុទ្ធនៃអ៊ីស្រាអែលក៏ដោយ។[6]ចូររត់ចេញពីក្រុងបាប៊ីឡូនទៅ សូមឲ្យគេសង្គ្រោះខ្លួនឯងទៅ។ មិនគួរឲ្យខ្លួនវិនាសទៅតាមគេឡើយ។ ដ្បិតនេះជាការសងសឹកនៃព្រះអម្ចាស់។ ព្រះអង្គនឹងសងគ្រប់យ៉ាងដល់គេវិញ។
[7]បាប៊ីឡូនប្រៀបបាននឹងពែងមាសនៅក្នុង ព្រះហស្តរបស់ព្រះអម្ចាស់ ជាពែងដែលធ្វើឲ្យពិភពលោកទាំងមូលស្រវឹង ប្រជាជាតិទាំងឡាយបានផឹកស្រាពីពែងនេះ ហើយវង្វេងវង្វាន់។[8]ពេលនោះបាប៊ីឡូនបំផ្លាញខ្ទេចខ្ទីអស់។ ចូរយំសម្រាប់គេ! យកថ្នាំមកព្យាបាលការឈឺចាប់របស់គេ ប្រហែលជាគេអាចជាវិញ។
[9]«ពួកយើងខិតខំព្យាបាលបាប៊ីឡូនដែរ តែវាពុំអាចជាសះស្បើយបានទេ។ ដូច្នេះ ចូរបោះបង់ចោលក្រុងនេះ ហើយវិលទៅទឹកដីរបស់យើងរៀងៗខ្លួនវិញ ដ្បិតទោសរបស់ក្រុងនេះមានទំហំធំជាង ផ្ទៃមេឃ និងអាកាសវេហាស៍ទៅទៀត។[10]ព្រះអម្ចាស់រកយុត្តិធម៌ឲ្យពួកយើង។ មក! យើងនាំគ្នារៀបរាប់ប្រាប់អ្នកក្រុងស៊ីយ៉ូន អំពីស្នាព្រះហស្តរបស់ព្រះអម្ចាស់ជាព្រះនៃយើង»។
[11]ចូរសម្រួចមុខព្រួញ ហើយដាក់ព្រួញពេញបំពង់។ ព្រះអម្ចាស់មានគម្រោងការកម្ទេចក្រុងបាប៊ីឡូន ហេតុនេះបានជាព្រះអង្គជំរុញ ស្តេចទឹកដីមេឌីឲ្យសម្រេចការនេះ ដ្បិតព្រះអម្ចាស់សងសឹកពួកបាប៊ីឡូន ព្រោះពួកគេកម្ទេចព្រះវិហាររបស់ព្រះអង្គ។[12]ចូរលើកទង់សញ្ញាវាយលុកកំពែងក្រុងបាប៊ីឡូន ចូរបន្ថែមកងយាមល្បាត ចូរដាក់អ្នកយាមឲ្យឃ្លាំមើល ចូរបង្កប់ទាហានចាំវាយឆ្មក់ ដ្បិតព្រះអម្ចាស់សម្រេចតាមផែនការ ដែលព្រះអង្គមានព្រះបន្ទូលប្រឆាំង នឹងអ្នកក្រុងបាប៊ីឡូន។
[13]អ្នកដែលបានរស់នៅតាមមាត់ទន្លេ ហើយអ្នកដេលមានទ្រព្យសម្បត្តិដ៏ច្រើន អ្នកមានចិត្តលោភលន់ តែចុងបញ្ចប់របស់អ្នកមកដល់ហើយ។[14]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូល យ៉ាងម៉ឺងម៉ាត់ ក្នុងនាមព្រះអង្គផ្ទាល់ថា «យើងនឹងនាំកងទ័ពដ៏ច្រើនដូចហ្វូងកណ្តូប មកវាយលុកអ្នក ពួកគេនឹងស្រែកដើម្បីទាស់ជាមួយអ្នក»។
[15]ព្រះអម្ចាស់បានបង្កើតផែនដី ដោយព្រះហស្តរបស់ព្រះអង្គ ព្រះជាម្ចាស់បានបង្កើតពិភពលោក ដោយព្រះប្រាជ្ញាញាណរបស់ព្រះអង្គ។ ព្រះអង្គបានលាតសន្ធឹងផ្ទៃមេឃ ដោយព្រះតម្រិះរបស់ព្រះអង្គ។[16]ពេលព្រះអង្គបន្លឺព្រះសូរសៀង ទឹកទាំងឡាយមកមូលផ្តុំគ្នានៅលើមេឃ ពពកសាត់មកពីជើងមេឃ ផ្លេកបន្ទោរបង្អុរភ្លៀងចុះមក ហើយខ្យល់ក៏ចេញពីកន្លែងរបស់វាដែរ។
[17]គ្រប់មនុស្សទៅជាមានអំនួត ដោយគ្មានការយល់ដឹង។ គ្រប់អស់ទាំងរូបព្រះដែលធ្វើពីដែកគឺនាំឲ្យគេខ្មាស់វិញ។ ដ្បិតរូបព្រះទាំងនោះគឺបន្លំ ហើយមិនមានជីវិតក្នុងវាទេ។
[18]ព្រះទាំងនោះគ្មានបានការ ហើយនឹងត្រូវវិនាសសូន្យ នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោស។[19]ប៉ុន្តែព្រះរបស់លោកយ៉ាកុបវិញ មិនដូច្នោះទេ គឺព្រះអង្គបានបង្កើតអ្វីៗទាំងអស់ ព្រះអង្គបានជ្រើសរើសអ៊ីស្រាអែល ធ្វើជាប្រជារាស្ត្រផ្ទាល់របស់ព្រះអង្គ ព្រះអង្គមាននាមថា ព្រះអម្ចាស់នៃពិភពទាំងមូល។
[20]អ្នកប្រៀបបាននឹងញញួរ ជាគ្រឿងសស្ត្រាវុធ យើងបានប្រើអ្នកសម្រាប់វាយដំប្រជាជាតិនានា និងកម្ទេចនគរទាំងឡាយ។[21]យើងបានប្រើអ្នកសម្រាប់កម្ទេចសេះ និងទាហានដែលជិះនៅលើវា យើងបានប្រើអ្នកសម្រាប់កម្ទេច រទេះចម្បាំង និងអ្នកបរដែរ។
[22]យើងបានប្រើអ្នក សម្រាប់ប្រហារមនុស្សប្រុសស្រី យើងបានប្រើអ្នក សម្រាប់ប្រហារចាស់ៗ និងក្មេងៗ យើងបានប្រើអ្នកសម្រាប់ប្រហារយុវជននិងនារីព្រហ្មចារី។[23]យើងបានប្រើអ្នក សម្រាប់ប្រហារគង្វាល និងហ្វូងសត្វរបស់គេ យើងបានប្រើអ្នក សម្រាប់ប្រហារអ្នកភ្ជួរស្រែ និងគោដែលគេទឹម យើងបានប្រើអ្នក សម្រាប់ប្រហារចៅហ្វាយខេត្ត និងមន្ត្រីផង។
[24]យើងនឹងសងទៅក្រុងបាប៊ីឡូន និងអ្នកទឹកដីខាល់ដេទាំងអស់ តាមអំពើ ឃោរឃៅដែលគេបានប្រព្រឹត្ត ចំពោះក្រុងស៊ីយ៉ូន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[25]មើល៍! បាប៊ីឡូនអើយ យើងនឹងដាក់ទោសអ្នក ហើយអ្នកប្រៀបបាននឹងភ្នំមួយ ដែលកម្ទេច ផែនដីទាំងមូល នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងនឹងលើកដៃប្រហារអ្នក យើងប្រមៀលអ្នកចុះពីលើថ្មភ្នំ ធ្វើឲ្យអ្នកក្លាយទៅជាពំនូកភ្លើងមួយ។[26]ដូច្នេះ គេនឹងលែងយកថ្មគ្រឹះដ៏មានតម្លៃ ឬថ្មសម្រាប់ធ្វើជាសសរ ចេញពីអ្នកទៀតឡើយ ដ្បិតអ្នកត្រូវវិនាសហិនហោចរហូតតទៅ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[27]ចូរលើកទង់សញ្ញាវាយលុកទឹកដីនេះ! ចូរផ្លុំស្នែងក្នុងចំណោមប្រជាជាតិទាំងឡាយ! ចូរប្រមូលប្រជាជាតិនានាវាយលុកក្រុងនេះ។ ចូរហៅនគរទាំងឡាយ គឺនគរអារ៉ារ៉ាត មិនី និងអ័សក្នាស មកច្បាំងនឹងក្រុងនេះ ចូរតែងតាំងឲ្យមានអ្នកកេណ្ឌទ័ព ចូរបញ្ជូនទ័ពសេះយ៉ាងច្រើនកុះករដូចកណ្តូប។[28]ចូររៀបចំប្រជាជាតិនានាវាយលុកក្រុងនេះ ដោយរួមជាមួយស្តេចទឹកដីមេឌី ព្រមទាំងពួកចៅហ្វាយខេត្ត និងមន្ត្រី ដែលនៅក្រោមគេផង។

generated on Wed Sep 10 16:16:32 2025

[29]ដ្បិត ផែនដីកក្រើករំពើក និងញាប់ញ័រ នៅពេលដែលព្រះអម្ចាស់ប្រព្រឹត្តចំពោះក្រុងបាប៊ីឡូន តាមគម្រោងការរបស់ព្រះអង្គ គឺធ្វើឲ្យក្រុងនេះក្លាយទៅជាទីស្មសាន គ្មានមនុស្សរស់នៅ។
[30]ពួកទាហានដ៏ពូកែរបស់ទឹកដីបាប៊ីឡូន ឈប់ច្បាំង ហើយសំងំនៅក្នុងបន្ទាយ។ ពួកគេបាត់បង់សេចក្តីក្លាហាន ធ្លាក់ខ្លួនខ្សោយដូចមនុស្សស្រី។ ខ្មាំងសត្រូវដុតបំផ្លាញផ្ទះរបស់ពួកគេ ហើយកម្ទេចរនុកទ្វាររបស់ពួកគេចោលដែរ។[31]អ្នករត់នាំគ្នារត់បណ្តាក់គ្នា អ្នកនាំសារក៏នាំដំណឹងតៗគ្នា ដើម្បីទៅទូលស្តេចទឹកដីបាប៊ីឡូនថា សត្រូវវាយយកបានទីក្រុង ពីជាយម្ខាង ទៅជាយម្ខាងទៀត។[32]ដ្បិត សត្រូវកាន់កាប់ផ្លូវទឹកទាំងឡាយ ហើយព្រមទាំងដុតកម្ទេចបន្ទាយផង ជាហេតុធ្វើឲ្យទាហានបាប៊ីឡូននាំគ្នាធ្លាក់ទឹកចិត្ត។
[33]ព្រះអម្ចាស់នៃពិភពទាំងមូលជាព្រះរបស់ ជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលថា៖ ក្រុងបាប៊ីឡូនប្រៀបបាននឹងលានបោកស្រូវ។ គឺដល់ពេលបោកហើយ។ នៅតែបន្តិចទៀត ដល់ពេលគេច្រូតកាត់ក្រុងនេះហើយ។
[34]នេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន បានលេប និងកម្ទេចខ្ញុំ ធ្វើឲ្យខ្ញុំប្រៀបបាននឹងចានគ្មានអាហារ ស្តេចនេះប្រៀបបាននឹងនាគដែលលេបខ្ញុំ ស្តេចនេះត្របាក់លេបអ្វីៗដ៏មានតម្លៃនៅក្នុងខ្ញុំ រួចខ្ចាក់ខ្ញុំចោល។[35]អ្នកក្រុងស៊ីយ៉ូនពោលថា សូមឲ្យពួកបាប៊ីឡូនរងនូវអំពើឃោរឃៅ ដែលគេបានប្រព្រឹត្តចំពោះខ្ញុំ។ អ្នកក្រុងយេរូសាឡឹមពោលថា សូមឲ្យពួកខាល់ដេទទួលទោស ព្រោះតែបានបង្ហូរឈាមខ្ញុំ។
[36]ហេតុនេះហើយបានជាព្រះអម្ចាស់មានព្រះបន្ទូល មកកាន់ប្រជាជនក្រុងយេរូសាឡឹមថា៖ យើងនឹងរកយុត្តិធម៌ឲ្យអ្នក យើងនឹងសងសឹកជំនួសអ្នក យើងនឹងធ្វើឲ្យទន្លេនៅក្រុងបាប៊ីឡូន ហួតហែងរហូតដល់ប្រភពទឹករបស់វា។[37]ក្រុងបាប៊ីឡូននឹងក្លាយទៅជាគំនរឥដ្ឋ ជាសំបុកឆ្កែព្រៃ ធ្វើឲ្យប្រជាជាតិឯទៀតៗ ស្រឡាំងកាំង និងព្រឺសម្បុរ ជាកន្លែងដែលគ្មានមនុស្សរស់នៅទៀត។
[38]ជនជាតិបាប៊ីឡូននាំគ្នាគ្រហឹមដូចសិង្ហស្ទាវ ហើយពួកគេក៏គ្រហឹមដូចកូនសិង្ហដែរ។[39]ពេលណាពួកគេពុះកញ្ជ្រោលដល់កម្រិតហើយ យើងនឹងរៀបចំជប់លៀងឲ្យពួកគេ យើងនឹងបង្អកពួកគេឲ្យស្រវឹង រហូតទាល់តែគេលេលា ហើយដេកលក់រហូត លែងភ្ញាក់ទៀតឡើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[40]យើងនឹងនាំពួកគេទៅទីសត្តឃាតដូចជា យកសត្វពពែ និងចៀមផងដែរ។
[41]ម្តេចក៏ក្រុងសេសាក ដែលពិភពលោកទាំងមូលធ្លាប់តែលើកតម្កើង ត្រូវធ្លាក់ក្នុងកណ្តាប់ដៃខ្មាំងដូច្នេះ! ម្តេចក៏បាប៊ីឡូនក្លាយទៅជាទីស្មសាន ក្នុងចំណោមប្រជាជាតិនានាបែបនេះ។[42]សមុទ្រជន់លិចទឹកដីបាប៊ីឡូន ហើយទឹករលកក៏បក់បោកលើទឹកដីនេះដែរ!
[43]ក្រុងទាំងឡាយនៅទឹកដីបាប៊ីឡូន ត្រូវវិនាសអន្តរាយ ទឹកដីនោះក្លាយទៅជាទីហួតហែង និងព្រៃល្បោះ ជាទឹកដីដែលគ្មាននរណារស់នៅ ហើយក៏គ្មានមនុស្សណាដើរកាត់ដែរ។[44]យើងនឹងដាក់ទោសបាល ដែលជាព្រះរបស់ជនជាតិ បាប៊ីឡូន អ្វីៗដែលវាលេបចូលទៅនោះ យើងនឹងទាញចេញមកវិញ ប្រជាជាតិទាំងឡាយលែងលើកគ្នា ទៅរកព្រះនោះទៀតហើយ រីឯកំពែងក្រុងបាប៊ីឡូនក៏រលំដែរ។
[45]ប្រជារាស្ត្ររបស់យើងអើយ ចូរនាំគ្នារត់ចេញពីចំណោមគេ។ គ្រប់គ្នារត់ឲ្យបានជីវិត គេចពីកំហឹងរបស់យើង។[46]មិនត្រូវបាក់ទឹកចិត្ត ហើយភ័យខ្លាចដោយឮពាក្យចចាមអារ៉ាម ដែលគេនិយាយក្នុងទឹកដីនោះឡើយ ដ្បិតឆ្នាំនេះមានឮពាក្យចចាមអារ៉ាមមួយ។ ឆ្នាំក្រោយមានឮពាក្យ ចចាមអារ៉ាមមួយទៀត អំពើហិង្សានឹងកើតមាននៅទឹកដីនេះ។ អ្នកមានអំណាចនឹងទាស់និងអ្នកមានអំណាចដែរ។
[47]ហេតុនេះ នៅគ្រាខាងមុខ យើងនឹងដាក់ទោសព្រះក្លែងក្លាយ របស់ទឹកដីបាប៊ីឡូន ទឹកដីនោះទាំងមូលនឹងត្រូវអាម៉ាស់ ហើយនឹងមានមនុស្សដួលស្លាប់ដោយមុខដាវ ពាសពេញក្នុងទីក្រុង។[48]ក្រោយមកនៅលើមេឃ និងនៅលើផែនដី នឹងនាំគ្នាស្រែកហ៊ោយ៉ាងសប្បាយ ដោយបាប៊ីឡូនរលំ ដ្បិតមានសត្រូវពីទិសខាងជើង មកបំផ្លាញក្រុងនេះ!» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[49]«ដូចបាប៊ីឡូនបានធ្វើឲ្យអ៊ីស្រាអែលស្លាប់ច្រើន ឥឡូវនេះបាប៊ីឡូននឹងត្រូវស្លាប់វិញម្តង។
[50]អស់អ្នកដែលគេចផុតពីមុខដាវអើយ ចូររត់ទៅចុះ កុំឈប់ឲ្យសោះ។ ចូរគិតដល់ព្រះអម្ចាស់ពីចម្ងាយ ហើយនឹកដល់ក្រុងយេរូសាឡឹមជានិច្ច។[51]ពួកយើងធ្លាប់អាម៉ាស់ នៅពេលឮខ្មាំងសត្រូវជេរប្រមាថ ពួកយើងបានបាក់មុខ នៅពេលជនជាតិដទៃនាំគ្នាចូលក្នុងទីសក្ការៈនៃព្រះដំណាក់របស់ព្រះអម្ចាស់។
[52]ហេតុនេះហើយបានជានៅគ្រាខាងមុខ យើងនឹងដាក់ទោសព្រះក្លែងក្លាយ របស់ជនជាតិបាប៊ីឡូន ហើយអ្នករបួសនឹងថ្ងូរពាសពេញក្នុងទឹកដីគេ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[53]ទោះបីបាប៊ីឡូនលើកខ្លួនឡើងដល់មេឃ ទោះបីពួកគេសង់បន្ទាយយ៉ាងខ្ពស់ៗក្តី ក៏យើងនឹងចាត់អ្នកបំផ្លាញឲ្យនាំគ្នាមកប្រហារក្រុងនេះដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[54]មានសម្រែកលាន់ឮឡើងពីក្រុងបាប៊ីឡូន ហើយសំឡេងមហន្តរាយលាន់ឮឡើង ពីទឹកដីខាល់ដេ។[55]ដ្បិតព្រះអម្ចាស់កម្ទេចក្រុងបាប៊ីឡូន។ ព្រះអង្គធ្វើឲ្យសម្រែកលាន់ឮក្នុងក្រុងនេះ ប្រែទៅជាស្ងាត់ជ្រងំ កងទ័ពដែលមានសូរសន្ធឹកដូចមហាសាគរ នាំគ្នាវាយលុកក្រុងនេះដោយសម្រែក យ៉ាងខ្លាំង។[56]ពិតមែនហើយ អ្នកបំផ្លាញមកវាយលុកក្រុងបាប៊ីឡូន ទាហានដ៏អង់អាចរបស់ក្រុងនេះ ធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ខ្មាំង។ ធ្នូរបស់ពួកគេត្រូវបាក់ ត្បិត ព្រះអម្ចាស់ជាព្រះដែលតែងតែសងទៅមនុស្ស តាមអំពើដែលម្នាក់ៗប្រព្រឹត្ត។
[57]ដ្បិត យើងនឹងបង្អកមន្ត្រី អ្នកប្រាជ្ញ ចៅហ្វាយខេត្ត ទេសាភិបាល និងទាហានដ៏អង់អាចរបស់ពួកគេ ឲ្យស្រវឹង។ ពួកគេដេកលក់រហូតលែងភ្ញាក់ទៀត នេះជាព្រះបន្ទូលរបស់ព្រះមហាក្សត្រ ដែលមាននាមថាព្រះអម្ចាស់នៃពិភពទាំងមូល។[58]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ កំពែងដ៏ស្តឹមស្តែរបស់ក្រុងបាប៊ីឡូន បាក់បែករហូតដល់គ្រឹះ ទ្វារដ៏ខ្ពស់ៗក៏ឆេះអស់។ គឺស្នាដៃដែលប្រជាជនទាំងឡាយ បានធ្វើក្លាយជាអសារបង់ គ្រប់យ៉ាងដែលប្រជាជាតិនានាខំប្រឹងធ្វើ សម្រាប់តែភ្លើងឆេះអស់»។
[59]នេះជាសេចក្តីដែលព្យាការីយេរេមាបង្គាប់ដល់លោកសេរ៉ាយ៉ា ជាកូនរបស់លោកនេរីយ៉ា និងជាចៅរបស់លោកម៉ាសេយ៉ា នៅពេលដែលគាត់ទៅទឹកដីបាប៊ីឡូន ជាមួយព្រះបាទសេដេគា នៅឆ្នាំទីបួន ក្នុងរជ្ជកាលរបស់ស្តេចនេះ។ លោកសេរ៉ាយ៉ាមានមុខតំណែងជាមេលើពួកមហាតលិក។[60]លោកយេរេមាសរសេរអំពីទុក្ខលំបាកទាំងប៉ុន្មានដែលកើតមានដល់ទឹកដីបាប៊ីឡូន ទុកក្នុងក្រាំងមួយ គឺព្រះបន្ទូលទាំងអស់ស្តីអំពីទឹកដីបាប៊ីឡូន ដែលបានមានចែងទុក។
[61]លោកយេរេមាថ្លែងទៅកាន់លោកសេរ៉ាយ៉ាថា៖ «ពេលអ្នកទៅដល់បាប៊ីឡូន នោះនឹងឃើញហើយអ្នកត្រូវអានសេចក្តីទាំងនេះឲ្យឮ។[62]រួចត្រូវនិយាយថា ព្រះអម្ចាស់ គឺព្រះអង្គផ្ទាល់ដែលមានព្រះបន្ទូលថា ក្រុងនេះនឹងត្រូវបំផ្លាញ លែងមានមនុស្ស មានសត្វរស់នៅទៀតហើយ គឺក្រុងនេះក្លាយទៅជាទីស្មសានរហូតតទៅ។
[63]ពេលអ្នកអានសេចក្តីក្នុងក្រាំងនេះចប់ សូមចងភ្ជាប់នឹងថ្មមួយដុំ រួចយកទៅទម្លាក់នៅកណ្តាលទន្លេអឺប្រាត។[64]ហើយ សូមប្រកាសថា ក្រុងបាប៊ីឡូននឹងត្រូវលិចលង់។ គឺក្រុងនេះមិនអាចងើបឡើងវិញ ដោយសារមហន្តរាយ ដែលយើងធ្វើឲ្យកើតដើម្បីទាស់នឹងពួកគេ ហើយពួកគេនឹងដួលចុះ»។ ពាក្យរបស់លោកយេរេមាបានចប់តែត្រឹមនេះ។

Jeremiah 51:1
ខ្យល់ព្យុះ បក់បោកបំផ្លាញ
ការបកប្រែផ្សេងទៀត: «ការបំផ្លាញដែលមិនអាចឈប់បាន»
ក្រុងលិបកាមឹ
នេះជាពាក្យមួយទៀតសម្រាប់បាប៊ីឡូន។
ខ្ចាត់ខ្ចាយ
ការបែកខ្ចាត់ខ្ចាយគឺជា ហើយនិងការបំផ្លាញផ្សេងទៀត។
នៅថ្ងៃនៃមហន្តរាយនោះ
ឃ្លាថា «ថ្ងៃនៃ» គឺជាប្រៀបធៀបរបស់ភាសាហេព្រើរ «ពេល»
ការបកប្រែផ្សេងទៀត: «នៅពេលទីក្រុងនោះបានបំផ្លាញ»
Jeremiah 51:3
មិនត្រូវឲ្យទាហានទាញបាញ់ព្រួញ និងមិនឲ្យគេពាក់អាវក្រោះដែល
«កុំឲ្យអ្នកជំនាញបាញ់ព្រួញ មានពេលរៀបចំដើម្បីបាញ់ព្រួញឡើយ។
Jeremiah 51:7
បាប៊ីឡូនប្រៀបបាននឹងពែងមាស
ការបកប្រែផ្សេងទៀត: «បាប៊ីឡូនគឺជាជនជាតិដែលប្រើសម្រាប់ជំនុំជម្រះ»
ហើយវង្វេងវង្វាន់
ការបកប្រែផ្សេងទៀត: «គឺជាការដែលពិបាកគិត»

generated on Wed Sep 10 16:16:32 2025

ចូរយំ
នេះគឺជាសម្លេងឮខ្លាំង ហើយយំដោយកំសត់។
Jeremiah 51:9
ដ្បិតទោសរបស់ក្រុងនេះបានឡើងទៅដល់ផ្ទៃមេឃ ហើយវាគឺខ្ពស់ឡើងដល់ពពកដែរ
ការបកប្រែផ្សេងទៀត: «បាប៊ីឡូនគឺមានកំហុសខ្លាំង»
ព្រះអម្ចាស់បានប្រកាសពីអត់ទោសរបស់យើង
ព្រះអម្ចាស់បានជំនុំជម្រះជនជាតិអ៊ីុស្រាអែលសម្រាប់អំពើបាបរបស់គេ
តែពេលនេះសូមឲ្យវិលមករកព្រះអង្គវិញ។
Jeremiah 51:11
អាស្រ័យនៅ
ការនេះនិយាយអំពីមនុស្សដែលរស់នៅកន្លែងមួយដែលជាក់លាក់។
Jeremiah 51:13
រស់នៅក្បែប្រភពទឹកនៃទឹក
«សប្បាយចិត្ត ហើយមានទ្រព្យ»
ខ្សែជីវិត...ខ្លី
«ជីវិតរបស់អ្នកនឹងត្រូវបញ្ចាប់យ៉ាងឆាប់»
ដូចហ្វូងទាហានកណ្តូប
«ជាមួយចំនួនទាហានដ៏ច្រើន»
ដើម្បីចម្បាំង
នេះគឺជាសម្រែកដែលទាហានស្រែកឡើងមុខចម្បាំង។
Jeremiah 51:15
ពេលព្រះអង្គបន្លឺព្រះសូរសៀង គឺទឹកទាំងឡាយមកមូលផ្តុំគ្នានៅលើមេឃ
ឃ្លាទាំងនេះបានប្រៀបធៀបទៅនឹងព្រះសូរសៀងរបស់ព្រះអម្ចាស់
ដែលឮខ្លាំងដោយសម្លេងផ្គរ និងភ្លៀង។
កន្លែងផ្ទុកខ្យល់
ជាកន្លែងទុកដាក់របស់ហើយរក្សាសម្រាប់ថ្ងៃក្រោយ។
Jeremiah 51:17
គ្រប់មនុស្សទៅជាមានអំនួត ដោយគ្មានការយល់ដឹង
ការនេះបង្ហាញថាលោកយេរេមាមានអារម្មណ៍ថាមនុស្សដែលជឿលើព្រះក្លែងក្លាយគឺល្ងង់ខ្លៅ
ការបន្លំ
ការបកប្រែផ្សេងទៀត: «កុហក និងដើម្បីបោកប្រាស់»
Jeremiah 51:20
អ្នក
ការបកប្រែផ្សេងទៀត: «ជាជាតិបាប៊ីឡូនដែលជាទាហាន»
Jeremiah 51:22
អ្នក
ការបកប្រែផ្សេងទៀត: «ជាជាតិបាប៊ីឡូនដែលជាទាហាន»។
Jeremiah 51:24
ក្នុងទីសម្គាល់របស់អ្នក
ការបកប្រែផ្សេងទៀត: «អ្នកបាប៊ីឡូននឹងបានឃើញ»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
ការបកប្រែផ្សេងទៀត: «អ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលយ៉ាងមាំ»
Jeremiah 51:25
ភ្នំ
ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់បាប៊ីឡូន ព្រះបានយកភ្នំមកពណ៌នាពីមនុស្ស។
តាំងពីភ្នំបានបានក្លាយជាកន្លែងសម្រាប់ពួកចោរប្លន់
គឺវាងាយស្រួលសម្រាប់លោកយេរេមាបានមានការនេះនៅក្នុងគំនិតលោកហើយ។
សូមមើល: UDB។ ការបកប្រែផ្សេងទៀត: «ប្រទេសជាតិឲ្យរឹងមាំ»
អ្នកឯទៀត
សំដៅទៅដល់ប្រជាជនបាប៊ីឡូនបានវាយប្រហារ។
ច្រាំងភ្នំ
ច្រាំងភ្នំដែលនៅតាមចង្កេះភ្នំរបស់ភ្នំ ឬច្រលោងភ្នំ។
Jeremiah 51:27
ទង់សញ្ញា
ទង់ជ័យសម្រាប់ទាហានដើម្បីដើរតាមក្នុងចម្បាំង។ ការបកប្រែផ្សេងទៀត:
«ទង់ជ័យ»
ក្រុងនេះ
ការបកប្រែផ្សេងទៀត: «បាប៊ីឡូន»
មិនី...អ័សក្ខាស
នេះគឺជាឈ្មោះរបស់ជនជាតិឬប្រជាជននិងក្រុម។
ចូរនាំទ័ពសេះឡើង ដូចហ្វូងកណ្តូប
ព្រះអម្ចាស់បានប្រៀបធៀបចំនួនសេះដ៏ច្រើនទៅនិងហ្វូងកណ្តូប។
ការបកប្រែផ្សេងទៀត: «ចូលនាំព័លសេះជាមួយទាហានឲ្យឆាប់»។
Jeremiah 51:29
ផែនដីនឹងកក្រើក
ព្រះអម្ចាស់បានសន្យាការភាពចលាចលយ៉ាងខ្លាំងដែលប្រជាជាតិទាំងមូលនឹងញ័រ។
«ទឹកដី» ដំណាងឲ្យប្រជាជនរបស់បាប៊ីឡូនដែលរស់នៅទីនោះ។
ហើយឈឺចិត្ត
បាប៊ីឡូននឹងត្រូវរង់ទុក្ខព្រួយ។
Jeremiah 51:30
ទីក្រុងរបស់ពួកគេត្រូវបានចាប់យក
«ពួកខ្មាំងសត្រូវបានយលឈ្នះលើទីក្រុងទាំងមូល»។
ពីចុងម្ខាង ទៅចុងម្ខាងទៀត
«ពួកខ្មាំងសត្រូវបានគ្រប់គ្រងកន្លែងឆ្លងទន្លេទាំងងស់។
ផ្លូវទឹករាក់
កន្លែងទឹករាក់នៃទន្លេនោះគឺជាកន្លែងមនុស្សអាចដើរឆ្លងដោយស្រួល។
វង្វេងស្មារតី
ការបកប្រែផ្សេងទៀត: «គឺមិនអាចគិតបានច្បាស់»
Jeremiah 51:33
ក្រុងនៃបាប៊ីឡូន
«កូនស្រីរបស់បាប៊ីឡូន» គឺជាឈ្មោះមួយផ្សេងទៀតសម្រាប់អ្នកស្រុកបាប៊ីឡូន។
ដូចទៅនឹងលានបោកស្រូវ
ព្រះអម្ចាស់បានប្រៀបធៀបលានបោក
ស្រូវទៅនិងពេលដ៏អស្ចារ្យដែលលើកទឹកចិត្តដល់បាប៊ីឡូន។
ដល់ពេលនៃការច្រូតកាត់ដល់ក្រុងនេះហើយ
ការច្រូតកាត់គឺជាលទ្ធិផលដែលមនុស្សបានធ្វើពីមុន។
លទ្ធិផងបាបរបស់បាប៊ីឡូននឹងមកដល់។ ការបកប្រែផ្សេងទៀត:
«បាប៊ីឡូននឹងទទួលជុំនំជម្រះ»។
Jeremiah 51:34
កម្ទេចខ្ញុំ ធ្វើឲ្យខ្ញុំប្រៀបបាននឹងចានគ្មានអាហារ
បាប៊ីឡូនបានយកអ្វីៗទាំងអស់ចេញពីអ៊ីុស្រអែល។
ហើយវាបានលេបខ្ញុំ
ប្រៀបធៀបយេរូសាឡិមទៅនឹងការបំផ្លាញដែលបានត្របាក់លេប។
ដូចជាសត្វនាគ
ប្រៀបធៀបបាប៊ីឡូមដូចជាសត្វនាគ។
ស្តេចនេះបានបំពេញពោះដោយអាហារឆ្ងាញរបស់ខ្ញុំ
នេះគឺជាទង្រង់មួយទៀតដែលដែលគ្រាមុខបង្ហាញថាបាប៊ីឡូនបានយកអ្វីទាំងអស់ពីអ៊ីុស្រាអែល។
«អាហារ» ដំណាងឲ្យអ្វីទាំងអស់ដែលពីគ្រាមុន។
រួចហើយក៏ខ្ជាក់ខ្ញុំចេញវិញ
អ្វីដែលបាប៊ីឡូនមិនបានចូលចិត្តបន្ទាប់ពីបានយកគ្រប់យ៉ាង
គេក៏បានបោះចោលដូចខ្ជាក់អាហារដែលសល់នៅក្នុងឆ្នាំងដែរ។
លើអ្នកខាល់ដេ
ការបកប្រែផ្សេងទៀត: «ប្រជាជនដែលរស់នៅក្នុងខាល់ដេ»។
Jeremiah 51:36
ព័ត៌មានទូទៅ:
ការនេះផ្តើមពីការឆ្លើយតបរបស់ព្រះជាម្ចាស់ដល់ក្រុងយេរូសាឡិមបានស្នើរក្នុងខ
៣៤ ដល់ ៣៥។
ក្លាយទៅជាកម្ទេចថ្ម
ការនេះសំដៅទៅលើសំណងដែលបានត្រឡប់ទៅជាទីចោលសំរាម។
ជារុងរបស់ឆ្កែព្រៃ
ការបកប្រែផ្សេងទៀត: «ទីជុំរកសម្រាប់ឆ្កែព្រៃ»
ព្រឺសម្បុរ
អ្វីមួយដែលគួរឲ្យខ្លាចហើយគ្រប់គ្នាមិនចង់មើលវាទេ។ ការបកប្រែផ្សេងទៀត:
«កន្លែងគួរភ័យខ្លាចក្នុងការរស់នៅ»
ស្រឡាំងកាំង
នេះគឺជាសម្លេងដែលបង្ហាញនៃការមិនពេញចិត្តខ្លាំង។
Jeremiah 51:38
គ្រហឹម

generated on Wed Sep 10 16:16:32 2025

នេះគឺសម្លេងឮខ្លាំងពីសិង្ហ។
ស្រែក
នេះគឺជាសម្រែកនៃការគំរាមកំហែងដែលសត្វបានស្រែក។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
ការបកប្រែផ្សេងទៀត: «ជាអ្វីដែលព្រះអម្ចាស់បានប្រកាសដោយឧឡារិក»
Jeremiah 51:41
សមុទ្រ...សម្លេងគ្រហឹមទឹករលក
សត្រូវរបស់បាប៊ីឡូនបានយកឈ្នះលើពួកគេ។ «រលក» ដំណាងឲ្យមនុស្សជាច្រើន
ឬក្រុមដែលបានយកឈ្នះបាប៊ីឡូន។ ពាក្យថា «សមុទ្រ» ហើយ «ទឹក»
ជារឿយៗគឺដំណាងឲ្យប្រជាជាតិ។
Jeremiah 51:43
ក្រុងទាំងឡាយ
ការបកប្រែផ្សេងទៀត: «ក្រុងទាំងឡាយនៅទឹកដីបាប៊ីឡូន»
យើងនឹងដាក់ទោសព្រះបាល
បាលគឺជាព្រះដ៏សំខាន់របស់ជនជាតិបាប៊ីឡូន ហើយវាដំណាងឲ្យប្រទេសទាំងមូល
និងប្រជាជនដែលថ្វាយបង្គំដល់វាផង។
ចេញពីមាត់វាគឺជារបស់ដែលវាបានលេប
ព្រះអម្ចាស់បានបៀបធៀបអ្វីដែលជាយញ្ញាបូជា
និងតង្វាយទៅដល់ព្រះបាលគឺជាការដែលគួរឲ្យស្អប់។
ប្រជាជាតិទាំងឡាយលែងហូរ
ព្រះអម្ចាស់បានប្រៀបធៀបប្រជាជាតិជាច្រើនដែលយកបាប៊ីឡូន
ដើម្បីថ្វាយយញ្ញបូជាដល់ព្រះបាលដូចទន្លេដែលហូរ។
Jeremiah 51:45
ដំណឹង ដែលបានឮ
គឺជាដំណឹងដែលប្រជាជនបានស្តាប់។
អ្នកមានអំណាចនឹងទាស់នឹងអ្នកមានអំណាច
អ្នកដែលមានអំណាចគឺដំណាងប្រជាជាតិដែលនៅក្រោមការគ្រប់គ្រងរបស់ពួកគេ។
Jeremiah 51:47
មើល៍
ការបកប្រែផ្សេងទៀត: «ផ្តង់ចិត្តទុកដាក់»
ទឹកដីទាំងមូល
ការបកប្រែផ្សេងទៀត: «ប្រជាជនរបស់បាប៊ីឡូនទាំងអស់»
នៅលើមេឃនិងនៅលើផែនដី
ស្ថានសួគ៌ហើយ និងផែនដីដូចជារូបភាពដែលបានប្រដូចទៅ និងមនុស្ស។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
ការបកប្រែផ្សេងទៀត: «ជាអ្វីដែលព្រះអម្ចាស់បានប្រកាសដោយឧឡារិក»
ការសម្លាប់
ការបកប្រែផ្សេងទៀត: «ការសម្លាប់មនុស្ស»
Jeremiah 51:50
ព័ត៌មានទូទៅ:
លោកយេរេមាបាននិយាយទៅកាន់កូនចៅអ៊ីុស្រែអែលនៅក្នុងខ៥០។
ការប្រមាថ
ការបកប្រែផ្សេងទៀត: «ការឈឺចាប់ ពាក្យអវជ្ជមាន»
Jeremiah 51:52
ថ្ងូរ
ការស្រែកយំចេញមកជាមួយនិងការឈឺចាប់ហើយអសង្ឃឹម
ដ្បិតទោះបី...ក្រុងនេះដែរ
«របស់» សំដៅដល់បាប៊ីឡូន។
ការនេះគឺជាអ្វីដែលត្រូវនិយាយគឺវាសំខាន់សម្រាប់បាប៊ីឡូន
ដើម្បីគេចចេញពីការជុំនំជម្រះរបស់ព្រះអម្ចាស់។
Jeremiah 51:54
មានសម្រែកទុក្ខព្រួយ ចេញពីក្រុងបាប៊ីឡូន ហើយសំឡេងដូលរលំលាន់ឮចេញពីទឹកដីខាល់ដេ
ការគិតដូចគ្នាហើយបញ្ចាក់ពីរបៀបពីដែលខុសគ្នា។
ពួកសត្រូវសូរសន្ធឹកដូចរលកនៃមហាសាគរ
សម្រែកនៃពួកសត្រូវដែលមកដល់ជាមួយសម្លេងខ្លាំង។
អ្នកចម្បាំងរបស់ក្រុងនេះ ត្រូវបានចាប់ទាំងអស់
ឃ្លានេះអាចប្តូរទៅជាទម្រង់កិរិយាសព្ទសកម្ម។ ការបកប្រែផ្សេងទៀត:
«ពួកគេបានចាប់អ្នកប្រយុទ្ធរបស់ទីក្រុង»។
Jeremiah 51:57
គេ ... ពួកគេ
ទាំងនេះសំដៅទៅលើក្រុងបាប៊ីឡូន។
Jeremiah 51:59
សេរ៉ាយ៉ា...នេរីយ៉ា...ម៉ាសេយ៉ា
ទាំងនេះគឺជាឈ្មោះរបស់មនុស្ស។
Jeremiah 51:61
គ្មានមនុស្ស ឬសត្វនឹងរស់នៅក្នុងវា
សត្វទាំងនេះអាចសាំងជាមួយនឹងមនុស្ស ពីព្រោះ ៥១:៣៦
អាចនិយាយបានថាបាប៊ីឡូននឹងមានតែចចក និងសត្វព្រៃរស់នៅទីនោះ។
Jeremiah 51:63
ក្រុងបាប៊ីឡូននឹងត្រូវលិចលង់
ការបកប្រែរបៀបផ្សេងទៀត:
«ក្រុងបាប៊ីឡូននឹងត្រូវបាត់ទៅដូចជាថ្មដែលបានបាត់ទៅដែរ»។

---

52 [1]ព្រះបាទសេដេគាឡើងសោយរាជ្យ ទ្រង់មានជន្មាយុម្ភៃមួយព្រះវស្សា ទ្រង់សោយរាជ្យបានដប់មួយឆ្នាំ នៅក្រុងយេរូសាឡឹម។ មាតារបស់ស្តេចមាននាមថា
ហាមូថាល់ ជាកូនរបស់លោកយេរេមា ដែលជាអ្នកទឹកដីលីបណា។[2]ព្រះបាទសេដេគា ប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង ទាស់នឹងព្រះអម្ចាស់ ដូចព្រះបាទ
យេហូយ៉ាគីមដែរ។[3]ព្រះអម្ចាស់ព្រះពិរោធចំពោះក្រុងយេរូសាឡឹម និងទឹកដីយូដា ការនេះធ្វើគេឆ្ងាក់ចេញពីចំពោះព្រះអង្គ។ នៅគ្រានោះព្រះបាទសេដេគាបានបះបោរ
ប្រឆាំងនឹងស្តេចទឹកដីបាប៊ីឡូន។
[4]ក្នុងឆ្នាំទីប្រាំបួននៃរជ្ជកាលព្រះបាទសេដេគា នៅថ្ងៃទីដប់នៃខែទីដប់ ព្រះចៅនេប៊ូក្នេសាជាស្តេចទឹកដីបាប៊ីឡូន បានលើកទ័ពទាំងមូលមកវាយក្រុងយេរូសាឡឹម។ ពួក
គេបានបោះជំរំទ័ព ទល់មុខទីក្រុង ហើយនិងសាងសង់ទួលព័ទ្ធជុំវិញក្រុងយេរូសាឡឹមផងដែរ។[5]ដូច្នេះ ពួកគេបានឡោមព័ទ្ធក្រុងនេះ រហូតដល់ឆ្នាំទីដប់មួយ នៃរជ្ជកាល
ព្រះបាទ សេដេគា។
[6]នៅក្នុងថ្ងៃទីប្រាំបួន នៃខែទីបួន នៅក្នុងឆ្នាំនោះ ពេលដែលទុរ្ភិក្សកើតមានយ៉ាងខ្លាំងនៅក្នុងទីក្រុង ប្រជាជននៅក្នុងទឹកដីទាំងមូល លែងមានអាហារបរិភោគទៀតហើយ។
[7]ក្រោយមក ពួកខ្មាំងទម្លុះកំពែងក្រុង ទោះបីកងទ័ពខាល់ដេឡោមព័ទ្ធទីក្រុងក្តី ពួកទាហានយូដាទាំងអស់នាំគ្នាចេញពីទីក្រុង នៅពេលយប់តាមទ្វារដែលស្ថិតនៅចន្លោះ
កំពែងទាំងពីរក្បែរឧទ្យានហ្លួង ហើយរត់តាមផ្លូវឆ្ពោះទៅវាលអារ៉ាបា ហើយនៅជុំវិញទីក្រុងនោះដែរ។[8]ប៉ុន្តែ កងទ័ពខាល់ដេ ក៏នាំគ្នាដេញតាមព្រះបាទសេដេគាទាន់ នៅវាល
ទំនាបនៃទន្លេយូរដានជិតក្រុងយេរីខូ។ ពេលនោះពួកកងទ័ពទាំងមូលរបស់ស្តេចក៏រត់បែកខ្ញែកចេញពីស្តេចអស់ទៅ។
[9]ទាហានខាល់ដេចាប់ស្តេចបញ្ជូនទៅព្រះចៅនេប៊ូក្នេសានៅក្រុងរីបឡា ក្នុងទឹកដីហាម៉ាត់ ព្រះចៅនេប៊ូក្នេសាប្រកាសកាត់ទោសព្រះបាទសេដេគា។[10]ស្តេចទឹកដីបាប៊ីឡូន
បញ្ជាឲ្យគេអារកបុត្រទាំងអស់របស់ព្រះបាទសេដេគា នៅចំពោះព្រះភ័ក្ត្រព្រះបាទសេដេគា ស្តេចទឹកដីបាប៊ីឡូនក៏បានឲ្យគេអារកពួកមន្ត្រីទាំងអស់នៃទឹកដីយូដា នៅក្រុង
រីបឡាដែរ។[11]បន្ទាប់មក ព្រះចៅនេប៊ូក្នេសាឲ្យគេចាក់ភ្នែកព្រះបាទសេដេគា រួចដាក់ច្រវាក់លង្ហិនពីរជាន់។ ស្តេចទឹកដីបាប៊ីឡូននាំព្រះបាទសេដេគាទៅទឹកដីបាប៊ីឡូន ឃុំទុក
រហូតដល់ថ្ងៃសុគត។
[12]នៅពេលនោះ គឺក្នុងថ្ងៃទីដប់ខែទីប្រាំ ក្នុងឆ្នាំទីដប់ប្រាំបួននៃរជ្ជកាលព្រះចៅនេប៊ូក្នេសា ជាស្តេចទឹកដីបាប៊ីឡូន លោកនេប៊ូសារ៉ាដាន ដែលជាមេទ័ពធំ ដែលបានបម្រើ
ស្តេចទឹកដីបាប៊ីឡូនមកដល់ក្រុងយេរូសាឡឹម។[13]លោកដុតកម្ទេចព្រះដំណាក់របស់ព្រះអម្ចាស់ ដំណាក់របស់ស្តេច ហើយព្រមទាំងផ្ទះនៅក្រុងយេរូសាឡឹម ជាពិសេស
គឺដុតកន្លែងដែលសំខាន់ៗរបស់ពួកអភិជនទាំងអស់នៅក្នុងទីក្រុង។[14]ក៏ដូចជាកំពែងជុំវិញក្រុងយេរូសាឡឹម ហើយពួកកងទ័ពរបស់ក្រុងបាប៊ីឡូនដែលមកជាមួយមេទ័ព
លោកនេប៊ូសារ៉ាដាន បានផ្លាញអ្វីទាំងអស់។
[15]លោកនេប៊ូសារ៉ាដាន ជារាជប្រតិភូ កៀរប្រជាជនដែលនៅសេសសល់ក្នុងទីក្រុង គឺជនក្រីក្រមួយចំនួន ទាហានដែលបានរត់ទៅចុះចូលនឹងស្តេចទឹកដីបាប៊ីឡូន ព្រមទាំង
ពួកជាងដែលនៅសេសសល់យកទៅជាឈ្លើយសឹក។[16]ប៉ុន្តែ លោកនេប៊ូសារ៉ាដាន មេទ័ពមេធំ បានទុកឲ្យជនតូចតាចខ្លះរស់នៅក្នុងទឹកដីនោះ ដើម្បីដាំទំពាំងបាយជូរ
ជាអ្នកដែលធ្វើការអារនៅឯទីវាល។

generated on Wed Sep 10 16:16:32 2025

[17]ដ្បិត សសរលង្ហិនដែលនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ សម្រាប់កំណល់អាងធំ ហើយលង្ហិនសមុទ្រ ដែលស្ថិតនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់
ពួកជនជាតិខាត់ដេបានបំផ្លាញសសរទាំងនោះ ទៅជាចំណែលទូចៗ ហើយយកលង្ហិនទាំងប៉ុន្មាននាំទៅក្រុងបាប៊ីឡូន។[18]ពួកគេយកឆ្នាំង វែក កាំបិត ភាជន៍ ពែង និង
គ្រឿងបរិក្ខារឯទៀតៗធ្វើពីលង្ហិន ដែលពួកសង្ឃសម្រាប់ទុកជារបស់ប្រើប្រាស់ក្នុងព្រះវិហារទៅដែរ។[19]លោកដែលជាមេទ័ពធំ ក៏បានយកផងដែរ ដូចជាចានក្លាំ ចង្ក្រាន
ភាជន៍ ឆ្នាំង ជើងចង្កៀង ពែង ចាន គោម និងវត្ថុទាំងប៉ុន្មាន ដែលធ្វើពីមាសពីប្រាក់ គ្មានសល់អ្វីឡើយ។
[20]រីឯសសរទាំងពីរ អាងធំ និងរូបគោលង្ហិនទាំងដប់ពីរជាកំណល់ ដែលព្រះបាទសាឡូម៉ូនបានធ្វើ សម្រាប់ប្រើប្រាស់ក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ គឺវត្ថុទាំងប៉ុន្មានដែល
ធ្វើពីលង្ហិននេះ គ្មាននរណាដឹងថាមានទម្ងន់ប៉ុន្មានទេ។[21]សសរទីមួយមានកម្ពស់ដប់ប្រាំបីហត្ថ ហើយរង្វង់សសរមានប្រវែងដប់ពីរហត្ថ។ សសរនោះប្រហោងក្នុង និងមាន
កម្រាស់បួនហ៊ុន។
[22]នៅពីលើសសរមានក្បាច់ក្បាលសសរ មួយធ្វើពីលង្ហិន ដែលមានកម្ពស់ប្រាំហត្ថ។ នៅជុំវិញក្បាច់ក្បាលសសរមានក្បាច់ក្រឡាអួន និងផ្លែទទឹមជាច្រើន ដែលធ្វើពីលង្ហិន
ទាំងអស់។ រីឯសសរទីពីរមានទំហំ និងមានផ្លែទទឹមដូចគ្នាដែរ។[23]ដូច្នេះ មានផ្លែទទឹមទាំងអស់កៅសិបប្រាំមួយនៅជុំវិញ ហើយផ្លែទទឹមដែលនៅជាប់នឹងក្បាច់ក្រឡាអួន
មានចំនួនទាំងអស់មួយរយ។
[24]លោកដែលជាមេទ័ពធំ បានចាប់ពួកអ្នកទោសដូចជាលោកសេរ៉ាយ៉ា ជាមេក្រុមបូជាចារ្យ ជាមួយលោកសេផានា ជាបូជាចារ្យរង ព្រមទាំងអ្នកយាមទ្វារព្រះវិហារបីនាក់
យកទៅជាមួយ។[25]ចេញពីទីក្រុង លោកក៏ចាប់អ្នកទោស ដែលជា មន្ត្រីមួយរូបដែលជាអ្នកទទួលខុសត្រូវលើពលទាហាន ព្រមទាំងពួក នៅក្នុងវាំង
ដែលមានតួនាទីជាអ្នកផ្តល់យោបល់ គឺជាអ្នកនៅក្នុងទីក្រុងនៅឡើយ។ លោកចាប់អ្នកទោលផ្សេងទៀត គឺស្មៀនរបស់មេទ័ពដែលមានភារកិច្ចកេណ្ឌទាហាន និងប្រជាជន
ហុកសិបនាក់ទៀត ដែលស្ថិតនៅក្នុងទីក្រុងនាពេលនោះ។
[26]លោកនេប៊ូសារ៉ាដាន ដែលជាមេទ័ពធំ បានចាប់អ្នកទាំងនោះ នាំទៅថ្វាយស្តេចទឹកដីបាប៊ីឡូននៅរីបឡា។[27]ស្តេចទឹកដីបាប៊ីឡូនបានប្រហារជីវិតអ្នកទាំងនោះ នៅក្រុង
រីបឡា ក្នុងទឹកដីហាម៉ាត់។ ជនជាតិយូដាត្រូវគេកៀរចេញឆ្ងាយពីទឹកដីរបស់ខ្លួនបែបនេះឯង។
[28]ក្នុងឆ្នាំទីប្រាំពីរនៃរជ្ជកាលព្រះចៅនេប៊ូក្នេសា ស្តេចនេះកៀរជនជាតិយូដាយកទៅជាឈ្លើយ ចំនួន៣០២៣នាក់។[29]ក្នុងឆ្នាំទីដប់ប្រាំបីនៃរជ្ជកាលព្រះចៅនេប៊ូក្នេសា ស្តេច
នេះកៀរអ្នកក្រុងយេរូសាឡឹម យកទៅជាឈ្លើយចំនួន ៨៣២នាក់។[30]ក្នុងឆ្នាំទីម្ភៃបីនៃរជ្ជកាលព្រះចៅនេប៊ូក្នេសា លោកនេប៊ូសារ៉ាដាន ជារាជប្រតិភូកៀរជនជាតិយូដាយក
ទៅជាឈ្លើយចំនួន៧៤៥នាក់។ សរុបទាំងអស់មានចំនួន ៤៦០០នាក់។
[31]ហេតុការទាំងនោះគឺបានកើតឡើង នៅថ្ងៃទីម្ភៃប្រាំខែទីដប់ពីរក្នុងឆ្នាំទីសាមសិបប្រាំពីរ ដែលព្រះបាទយ៉ូយ៉ាគីន ជាស្តេចទឹកដីយូដា ត្រូវគេចាប់យកទៅជាឈ្លើយសឹក ត្រូវ
នឹងឆ្នាំទីមួយ នៃរជ្ជកាលព្រះចៅអេវីល-មេរ៉ូដាក ជាស្តេចទឹកដីបាប៊ីឡូន ព្រះចៅអេវីល មេរ៉ូដាក ដោះលែងព្រះបាទយ៉ូយ៉ាគីនឲ្យមានសេរីភាព។
[32]ស្តេចមានរាជឱង្ការទៅកាន់ព្រះបាទយ៉ូយ៉ាគីន ដោយស្និទ្ធស្នាលព្រមទាំងប្រទានកន្លែងកិត្តិយសជាងស្តេចឯទៀតៗ ដែលជាប់ជាឈ្លើយនៅក្រុងបាប៊ីឡូន។[33]ស្តេច
អនុញ្ញាតឲ្យ ព្រះបាទយ៉ូយ៉ាគីន លែងស្លៀកសម្លៀកបំពាក់ជាឈ្លើយសឹក ហើយព្រះបាទយ៉ូយ៉ាគីនសោយព្រះស្ងោយ រួមតុជាមួយជារៀងរាល់ថ្ងៃ រហូតដល់អស់ព្រះជន្ម។
[34]ស្តេចទឹកដីបាប៊ីឡូន ទំនុកបម្រុងព្រះបាទយ៉ូយ៉ាគីន ជារៀងរាល់ថ្ងៃ អស់មួយជីវិត រហូតដល់ថ្ងៃទ្រង់សោយទីវង្គត។

Jeremiah 52:1

ហាមូថាល់

នេះគឺជាឈ្មោះរបស់ស្ត្រី។

លីបណា

នេះគឺជាឈ្មោះទីកន្លែង។

យេរេមា

ការនេះសំដៅបុរសម្នាក់ផ្សេងដែលមានឈ្មោះយេរេមា
គឺមិនមែនព្យាការីយេរេមាដែលជាអ្នកសរសេរគម្ពីរនេះទេ។

លោក

ការនេះសំដៅដល់សេដេគា។

Jeremiah 52:4

វាបានកើតឡើង

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿងនិទាន។

ក្នុងឆ្នាំទីប្រាំបួន

«ក្នុងឆ្នាំទី៩»

នៅថ្ងៃទីដប់នៃខែទីដប់

នេះគឺជាខែទីដប់តាមប្រតិទិនហេព្រើរ។
នៅថ្ងៃទីដប់គឺនៅជិតនៃការចាប់ផ្តើមរបស់ខែមករាតាមប្រតិទិនលោកខាងលិច។

ពួកគេបានបោះជំរំទ័ពទល់មុខទីក្រុង

«កងទ័ពរបស់នេប៊ូក្នេសាបោះជំរំទល់មុខក្រុងយេរូសាឡិម»

រហូតដល់ឆ្នាំទីដប់មួយ

«រហូតដល់១១ឆ្នាំ»

Jeremiah 52:6

នៅក្នុងខែទីបួន ថ្ងៃទីប្រាំបួន នៅក្នុងឆ្នាំនោះ

«នេះគឺជាខែទីបួន នៃប្រតិទិនរបស់ហេព្រើរ។ គឺវានៅក្នុងពេលរដូវរាំងស្ងួត។ ថ្ងៃទី
ប្រាំបួនគឺជិតដល់ថ្ងៃដំបូងនៃខែប្រាំពីរ នៅក្នុងប្រតិទិននៃលោកខាងលិច។

ទីក្រុង

គឺសំដៅទៅលើក្រុងយេរូសាឡិម។

ពួកខ្មាំងទម្លុះកំពែងក្រុង

ជនជាតិបាប៊ីឡូនបានបំបែកជញ្ជាំងនៅជុំវិញក្រុង។

នៅចន្លោះកំពែងទាំងពីរ

នេះសំដៅទៅលើជញ្ជាំងសួនច្បាររបស់ស្តេច ហើយនិងជញ្ជាំងរបស់ទីក្រុង។

វាលទំនាប

«ដីវាលទំនាប»

Jeremiah 52:9

ក្រុងរីបឡា

នេះគឺជាទីក្រុង។

នៅចំពោះព្រះភ័ក្ត្រ

ការបកប្រែរបៀបផ្សេងទៀត: «នៅពីមុខទ្រង់»

Jeremiah 52:12

ក្នុងខែទីប្រាំ ថ្ងៃទីដប់ នៃខែនោះ

នេះគឺជាខែទីប្រាំនៃប្រតិទិនរបស់ហេព្រើរ។ វាគឺនៅក្នុងពេលដែលរដូវប្រាំ។ ថ្ងៃទី
ដប់គឺនៅជិតនៃការចាប់ផ្តើមខែប្រាំបីនៃប្រតិទិនរបស់លោកខាងលិច។

ក្នុងឆ្នាំទីដប់ប្រាំបួន

«កំឡុងឆ្នាំទីដប់ប្រាំបួន»

នេប៊ូសារ៉ាដាន

នេះគឺជាឈ្មោះរបស់បុរសម្នាក់។

មេទ័ព

នេះសំដៅទៅលើមនុស្សដែលមានតួនាទីអ្នកការពារដល់អ្នកណាម្នាក់។

Jeremiah 52:15

ពួកជាង

នេះសំដៅទៅលើមនុស្សដែលបានធ្វើអោយវត្ថុយ៉ាងស្អាតដើម្បីប្រើនៅក្នុងការថ្វាយបង្គំព្រះអម្ចាស់។

នេប៊ូសារ៉ាដាន

នេះគឺជាឈ្មោះរបស់បុរសម្នាក់។

ជនតូចតាចខ្លះរស់នៅក្នុងទឹកដីនោះ

ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកក្របំផុតដែលនៅលើទឹកដីនោះ»

Jeremiah 52:17

សមុទ្រ

នេះគឺជាអាងទឹកដែលប្រើនៅក្នុងការថ្វាយបង្គំដល់ព្រះអម្ចាស់។

Jeremiah 52:20

ហត្ថ

មួយហត្ថគឺជាការវាស់វែងនៃបណ្តោយ និងទទឹង។

ប្រហោង

នេះគឺមានន័យថាសសរដែលគ្មានអ្វីនៅខាងក្នុងទេ។

Jeremiah 52:22

ក្បាច់ក្បាលសសរ

នេះគឺជាផ្នែកខាងលើនៃសសរនីមួយៗ។

Jeremiah 52:24

generated on Wed Sep 10 16:16:32 2025

សេរ៉ាយ៉ា
សូមមើលពីរបៀបការបកប្រែឈ្មោះនេះរបស់បុរសម្នាក់នៅក្នុងជំពូក ៣៦:២៥។
អ្នកយាមទ្វារព្រះវិហារ
អ្នកយាមទ្វារគឺជាអ្នកដែលយាមទ្វាររបស់ទីក្រុង។
ស្បៀន
ការបកប្រែរបៀបផ្សេងទៀត: «ការកេណ្ឌ» មានន័យដើម្បីនាំអ្នកបម្រើសេវាកម្ម។
Jeremiah 52:26
នេប៊ូសារ៉ាដាន
សូមមើលពីរបៀបការបកប្រែឈ្មោះនេះរបស់បុរសម្នាក់នៅក្នុងជំពូក ៣៩:៨។
រ៉ិបឡា
នេះគឺជាឈ្មោះរបស់ទីក្រុង។
Jeremiah 52:28
ប្រាំពីរ...ដប់ប្រាំបី...ម្ភៃបី
ទីបី - សូមមើល:
លោកនេប៊ូសារ៉ាដាន
សូមមើលពីរបៀបការបកប្រែឈ្មោះនេះរបស់បុរសម្នាក់នៅក្នុងជំពូក ៣៩:៨។
៣០២៣...៨៣២ ...៧៤៥... ៤៦០០
Jeremiah 52:31
នៅក្នុងឆ្នាំទីសាមសិបប្រាំពីរ
ឆ្នាំទីប្រាំពីរ -
ខែទីដប់ពីរ ថ្ងៃទីម្ភៃប្រាំនៃខែនោះ
ថ្ងៃទីដប់ប្រាំនៃខែនោះ- នេះគឺថ្ងៃទីដប់ពីរ
ហើយខែកន្លងទៅតាមប្រតិទិនរបស់ហេព្រើរ។ ថ្ងៃទីម្ភៃ
ប្រាំគឺនៅក្បែរពាក់កណ្តាលខែបីតាមប្រតិទិនរបស់លោកខាងលិច។
ហេតុការទាំងនោះគឺបានកើតឡើង
ឃ្លានេះគឺប្រើនៅកន្លែងនេះ សម្រាប់ការការចាប់ផ្តើមនៃការផ្តើមផ្នែកថ្មីនៃសាច់រឿង។
ព្រះចៅអេវីល មេរ៉ូដាក
មេរ៉ូដាក - ព្រះចៅបានក្លាយទៅជាស្តេចរបស់បាប៊ីឡូន បន្ទាប់ព្រះចៅនេប៊ូក្នេសា។
ព្រះនាមរបស់ទ្រង់មិនបានពណ៌នាពីស្តេចទេ
តែនេះគឺជារបៀបដែលព្រះនាមរបស់ទ្រង់ប្រកបទេ។
Jeremiah 52:32
ស្តេចមានរាជឱង្ការទៅកាន់ព្រះបាទយ៉ូយ៉ាគីន
ការបកប្រែរបៀបផ្សេងទៀត: «អេវីល មេរ៉ូដាក
មានបន្ទូលដោយសប្បុរសទៅកាន់ព្រះបាទយ៉ូយ៉ាគីន»
ប្រទានកន្លែងកិត្តិយស
ការបកប្រែរបៀបផ្សេងទៀត: «ជាកន្លែងដែលអង្គុយនៅក្បែរព្រះចៅ
អេវីលមេរ៉ូដាកគង់ផងដែរ»។

បរិទេវ

1 [1]ទីក្រុងដែលធ្លាប់មាន មនុស្សច្រើនកុះករ ម្តេចឥឡូវបែរជានៅឯកោ នាងដូចជាស្ត្រីមេម៉ាយទៅវិញ ជាក្រុងដ៏រុងរឿងក្នុងចំណោមប្រជាជាតិនានា ជាបុត្រីនៅកណ្តាលខេត្តទាំងប៉ុន្មាន តែឥឡូវនេះ ត្រូវបានបង្ខំឲ្យទៅជាទាសករ។[2]នាងយំឥតឈប់នៅពេលយប់ ហើយទឹកភ្នែករហាមនៅលើថ្ពាល់ផង គ្មានមនុស្សដែលស្រឡាញ់នាងបានជួយដោះទុក្ខឡើយ ពួកមិត្តសម្លាញ់ទាំងអស់បានក្បត់នាងហើយ គេត្រឡប់ជាខ្មាំងសត្រូវវិញ។
[3]ដោយភាពក្រីក្រ និងការរងទុក្ខ ពួកយូដាបានទៅជាឈ្លើយ នាងអាស្រ័យនៅកណ្តាលអស់ទាំងជនជាតិឥតបានសម្រាកទេ ពួកអ្នកបៀតបៀននាងបានតាមនាងទាន់ទាំងឃើញភាពអស់ សង្ឃឹមផង។
[4]ផ្លូវទៅកាន់ក្រុងស៊ីយ៉ូនយំទួញ ដ្បិតគ្មានអ្នកណាមកចូលរួមពិធីបុណ្យសោះ។ ទ្វារទីក្រុងទាំងប៉ុន្មាន នៅស្ងាត់ច្រៀប ហើយពួកសង្ឃក៏ថ្ងូរ ពួកក្រមុំៗមានទុក្ខក្រៀមក្រំ ហើយទីក្រុងទាំងមូលមានពេញដោយភាពជូរចត់។[5]ពួកបច្ចាមិត្តរបស់នាងបានក្លាយជាម្ចាស់ និងពួកខ្មាំងសត្រូវមានសេចក្តីចម្រើនឡើង។ ដ្បិតព្រះអម្ចាស់បានធ្វើទុក្ខនាងដោយព្រោះអំពើរំលងដ៏ច្រើនរបស់នាង ពួកកូនចៅនាងត្រូវចាប់ទៅជាឈ្លើយ។
[6]សម្រស់នៃប្រជាជាតិក្រុងស៊ីយ៉ូន បានបាត់បង់ហើយ ពួកចៅហ្វាយរបស់នាងបានត្រឡប់ដូចជាប្រើស ដែលរកស្មៅមិនបាន ហើយពួកគេចេញទៅដោយល្វើយអស់កម្លាំង។
[7]ក្នុងថ្ងៃដែលរងទុក្ខវេទនា ហើយលំបាក ក្រុងយេរូសាឡិមនឹងនឹកចាំពីសេចក្តីល្អទាំងប៉ុន្មាន ដែលធ្លាប់មានកាលពីដើម ក្នុងគ្រាដែលជនទាំងឡាយបានធ្លាក់ ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ ឥតមានអ្នកណាជួយសោះ នោះពួកខ្មាំងសត្រូវបានឃើញនាង ហើយបានចំអកឲ្យពីដំណើរដែលនាងបានជាប់គាំ។
[8]ក្រុងយេរូសាឡិមបានធ្វើបាបយ៉ាងធ្ងន់ ហេតុនោះបានជាត្រូវត្រឡប់ដូចជារបស់ស្មោកគ្រោក អស់អ្នកដែលធ្លាប់លើកមុខនាងឥឡូវគេមើលងាយវិញ ពីព្រោះគេបានឃើញកេរ្តិ៍ខ្មាសនាង ហើយនាងកំពុងតែថ្ងូរ ហើយបែរថយក្រោយ[9]សេចក្តីស្មោកគ្រោករបស់នាងនៅត្រង់ជាយសំពត់ នាងមិននឹកគិតពីអនាគតទេ នាងត្រូវធ្លាក់ចុះយ៉ាងយ៉ាប់យឺន ឥតមានអ្នកណានឹងជួយដោះទុក្ខឡើយ។ នាងស្រែកអំពាវនាវ «សូមទតមើល៍ សេចក្តីវេទនារបស់ខ្ញុំម្ចាស់ចុះព្រះអម្ចាស់ ដែលខ្មាំងសត្រូវបានឈ្នះហើយ!»។
[10]ពួកខ្មាំងសត្រូវបានលូកដៃមកលើទ្រព្យសម្បត្តិទាំងប៉ុន្មានដែលគាប់ចិត្ត នាងបានឃើញជនជាតិដទៃចូលទៅក្នុងទីបរិសុទ្ធរបស់នាង បើទោះជាទ្រង់បានផ្តាំទុកមិនឲ្យគេចូលទៅក្នុងជំនុំរបស់ព្រះអង្គឡើយ
[11]ប្រជាជនទាំងអស់បានយំថ្ងូរ ដោយគេរកអាហារ ពួកគេបានឲ្យរបស់ដែលមានតំលៃទាំងប៉ុន្មាន ដើម្បីប្តូរនឹងអាហារ សំរាប់រស់នៅវិញ។ មើល៍ សូមព្រះអម្ចាស់ពិចារណា ដ្បិតខ្ញុំម្ចាស់បានត្រឡប់ជាទាបថោកហើយ។[12]អស់អ្នកដែលដើរកាត់តាមទីនេះ? សូមពិចារណាមើល បើមានសេចក្តីទុក្ខព្រួយណា ដូចសេចក្តីទុក្ខព្រួយរបស់ខ្ញុំនេះ ដែលព្រះអម្ចាស់បាននាំមកធ្វើទុក្ខដល់ខ្ញុំ នៅថ្ងៃនៃសេចក្តីក្រោធដ៏សហ័សរបស់ទ្រង់។
[13]ទ្រង់បានចាត់ភ្លើងពីស្ថានដ៏ខ្ពស់ឲ្យចូលក្នុងឆ្អឹងខ្ញុំ ភ្លើងនោះក៏ឈ្នះផង ព្រះអង្គបានដាក់មងសម្រាប់ចាប់ជើងខ្ញុំ និងបង្វែរខ្ញុំឲ្យទៅថយក្រោយ ក៏ធ្វើឲ្យខ្ញុំនៅស្ងាត់ ហើយល្វើយកំលាំង[14]ឯនឹមនៃអំពើរំលងរបស់ខ្ញុំ នោះគឺព្រះហស្តរបស់ព្រះអង្គបានចងជាប់ហើយ ឯអំពើទាំងនោះបានជំពាក់ជាប់គ្នា មកពាក់លើករបស់ខ្ញុំ ព្រះអង្គបានឲ្យកម្លាំងខ្ញុំស្បើយទៅ ព្រះអម្ចាស់បានប្រគល់ខ្ញុំទៅក្នុងកណ្តាប់ដៃគេ ដែលខ្ញុំពុំអាចនឹងទាស់ប្រឆាំងបានឡើយ។
[15]ព្រះអម្ចាស់បានកំចាត់មនុស្សខ្លាំងពូកែ ដែលនៅការពារខ្ញុំ។ ទ្រង់ហៅកងទ័ពឲ្យទាស់នឹងពួកកំលោះៗប្រឆាំងនិងខ្ញុំ ទាំងកំទេចភាពរឹងមាំរបស់មនុស្ស។ ព្រះអម្ចាស់បានកម្ទេចជនជាតិយូដាដូចជាជាន់ធុងទំពាំងបាយជូរ
[16]ព្រោះហេតុការណ៍ទាំងនេះបានជាខ្ញុំយំ ទឹកភ្នែកខ្ញុំហូរសស្រាក់ ដោយព្រោះអ្នកកម្សាន្តចិត្ត ដែលគួរមកលំហើយជីវិតខ្ញុំនោះនៅឆ្ងាយណាស់។ កូនចៅខ្ញុំត្រូវចោលស្ងាត់ដោយព្រោះពួកខ្មាំងសត្រូវបានឈ្នះហើយ។[17]ក្រុងស៊ីយ៉ូនលូកដៃទៅ តែគ្មានអ្នកណានឹងជួយដោះទុក្ខសោះ ព្រះអម្ចាស់បានបង្គាប់ពីដំណើរយ៉ាកុបថា ត្រូវឲ្យពួកអ្នកដែលនៅជុំវិញ ធ្វើជាខ្មាំងសត្រូវនឹងគាត់ ក្រុងយេរូសាឡិមនៅកណ្តាលគេ ទុកដូចជារបស់ស្មោកគ្រោក។
[18]ព្រះអម្ចាស់ដ៏សុចរិត ដ្បិតខ្ញុំបានបះបោរនឹងបញ្ញត្តិព្រះអង្គ សូមស្តាប់ជនជាតិទាំងឡាយ ហើយពិចារណាមើលសេចក្តីទុក្ខព្រួយរបស់ខ្ញុំ ពួកក្រមុំៗ និងពួកកំលោះៗរបស់ខ្ញុំ គេបានទៅជាឈ្លើយអស់ហើយ[19]ខ្ញុំបានហៅមិត្តសំឡាញ់ខ្ញុំ តែគេបានបញ្ឆោតខ្ញុំវិញ ពួកបូជាចារ្យ និងព្រឹទ្ធាចារ្យរបស់ខ្ញុំ បានវិនាសទៅក្នុងទីក្រុង កំពុងដែលគេរកអាហារដើម្បីចិញ្ចឹមជីវិត។
[20]សូមទតមើលព្រះអម្ចាស់ ដ្បិតខ្ញុំម្ចាស់មានសេចក្តីវេទនា ដួងចិត្តខ្ញុំខ្លោចផ្សាជាខ្លាំង ដ្បិតខ្ញុំម្ចាស់បានបះបោរនិងទ្រង់ ហើយនៅខាងក្រៅ ដាវបង្អត់បង់ ហើយនៅឯផ្ទះក៏មានដូចជាសេចក្តីស្លាប់ដែរ។
[21]ពួកគេបានឮថា ខ្ញុំម្ចាស់ថ្ងូរ តែគ្មានអ្នកណានឹងជួយដោះទុក្ខខ្ញុំម្ចាស់ទេ។ ពួកខ្មាំងសត្រូវទាំងប៉ុន្មាន បានឮដំណឹងពីសេចក្តីលំបាករបស់ខ្ញុំម្ចាស់ ហើយគេសប្បាយចិត្តដោយព្រោះព្រះអង្គបានធ្វើយ៉ាងនេះ ។ ព្រះអង្គនឹងឲ្យថ្ងៃដែលព្រះអង្គបានប្រកាសប្រាប់នោះ បានមកដល់ នោះគេនឹងបានដូចជាខ្ញុំម្ចាស់វិញ។[22]សូមឲ្យគ្រប់ទាំងអំពើ

generated on Wed Sep 10 16:16:32 2025

ទុច្ចរិតរបស់គេ បានលេចមក នៅចំពោះព្រះអង្គ ហើយសូមព្រះអង្គធ្វើដល់គេ ដូចជាព្រះអង្គបានធ្វើដល់ខ្ញុំម្ចាស់ ដោយព្រោះអស់ទាំងអំពើរំលងរបស់ខ្ញុំម្ចាស់ដែរ ដ្បិតខ្ញុំម្ចាស់ថ្ងូរជាច្រើន ហើយចិត្តខ្ញុំម្ចាស់ក៏ល្វើយផង។

Lamentations 1:1

ព័ត៌មានទូទៅ៖

សូមមើល and and។

នាង

អ្នកនិពន្ធកណ្ឌបរិទេវសរសេរអំពីទីក្រុងយេរូសាឡឹមដូចជាស្ត្រីម្នាក់។

ស្ត្រីមេម៉ាយ

ឃ្លានេះប្រៀបធៀប ក្រុងយេរូសាឡឹមទៅនឹងស្ត្រីដែលគ្មានការការពារ ពីព្រោះប្តីរបស់នាងបានស្លាប់។

ព្រះនាងជា ព្រះអង្គម្ចាស់ក្សត្រី ចំណោមប្រជាជាតិនានា

ការបកប្រែផ្សេងទៀត «ប្រជាជាតិដទៃទៀតផ្តល់កិត្តិយសដល់ក្រុងយេរូសាឡឹម ដូចជាពួកគេគោរពបុត្រីរបស់ស្តេចដែរ»

បង្ខំឲ្យធ្វើជាទាសករ

ការបកប្រែផ្សេងទៀត «បង្ខំឲ្យក្លាយជាទាសករ»

នាងយំឥតឈប់នៅពេលយប់ ហើយទឹកភ្នែកហូររហាមនៅលើថ្ពាល់ផង

អ្នកនិពន្ធពិពណ៌នាអំពីក្រុងយេរូសាឡឹមមានអារម្មណ៍ដូចជាមនុស្សម្នាក់។ ទីក្រុងនេះក៏តំណាងឲ្យប្រជាជនរបស់នាងផងដែរ។ ការបកប្រែផ្សេងទៀត « អ្នកដែលរស់នៅក្នុងនាងយំនិងទឹកភ្នែករហាម» ។

យំឥតឈប់នៅពេលយប់ ហើយទឹកភ្នែកហូររហាម

ពាក្យថា «ទឹកភ្នែកហូររហាម» សំដៅទៅលើសំឡេងដែលមនុស្សម្នាក់ធ្វើនៅពេលដែលពួកគេ «យំ» ខ្លាំងៗ ។ ការបកប្រែផ្សេងទៀត «យំយ៉ាងខ្លាំង» ។

Lamentations 1:3

ពួកយូដាបានទៅជាឈ្លើយ

ការបកប្រែផ្សេងទៀត «ប្រជាជនយូដាត្រូវបានគេនាំយកទៅក្នុងទឹកដីបរទេស»

នាង

នាងគឺជារាជាណាចក្រយូដាដែលត្រូវបានពិពណ៌នាថាជាស្ត្រីម្នាក់។ នាងក៏តំណាងឲ្យប្រជាជនយូដាដែរ។

ឥតបានសម្រាក

«មិនរកការសម្រាក» ការបកប្រែផ្សេងទៀត «តែងតែភ័យខ្លាច»

ពួកអ្នកបៀតបៀននាងបានតាមនាងទាន់

ការបកប្រែផ្សេងទៀត «អ្នកដែលដេញតាមនាងចង់ចាប់នាង» ឬ «អ្នកដែលកំពុងតាមប្រមាញ់នាងបានរកឃើញនាង»

ទាំងឃើញភាពអស់សង្ឃឹមផង

ការបកប្រែផ្សេងទៀត «នៅពេលនាងអស់សង្ឃឹម»

Lamentations 1:4

ផ្លូវទៅកាន់ក្រុងស៊ីយ៉ូនយំទួញ

អ្នកនិពន្ធនិយាយអំពីផ្លូវដែលនាំទៅក្រុងស៊ីយ៉ូនកាន់ទុក្ខដូចជាពួកគេជាមនុស្ស។

ចូលរួមពិធីបុណ្យសោះ

«ពិធីបុណ្យដែលព្រះបានប្រាប់ពួកគេឲ្យធ្វើ»

ទ្វារទីក្រុង...ពួកបូជាចារ្យ

ពាក្យថា «នាង» សំដៅទៅលើក្រុងស៊ីយ៉ូន។

ពេញដោយភាពជូរចត់

«ជូរចត់» ឬ «កំពុងអស់សង្ឃឹម»

ពួកបច្ចាមិត្តរបស់នាងបានក្លាយជាម្ចាស់

«សត្រូវរបស់ក្រុងស៊ីយ៉ូនគ្រប់គ្រងលើនាង»

ពួកខ្មាំងសត្រូវមានសេចក្តីចម្រើនឡើង

«សត្រូវរបស់នាងក្លាយជាអ្នកមាន» ឬ «ខ្មាំងសត្រូវរបស់នាងកាន់តែអស្ចារ្យ»

ព្រះអម្ចាស់

នេះគឺព្រះនាមរបស់ព្រះជាម្ចាស់ ដែលទ្រង់បានបង្ហាញដល់ប្រជាជនរបស់ព្រះអង្គនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ សូមមើលការបកប្រែពាក្យ «ព្រះអម្ចាស់» អំពីរបៀបបកប្រែអត្ថបទនេះ។

Lamentations 1:6

សម្រស់នៃប្រជាជាតិក្រុងស៊ីយ៉ូន បានបាត់បង់ហើយ

ការបកប្រែផ្សេងទៀត

«អ្វីគ្រប់យ៉ាងដែលស្រស់ស្អាតគឺកូនស្រីក្រុងស៊ីយ៉ូនត្រូវបំផ្លាញហើយ»

កូនស្រីក្រុងស៊ីយ៉ូន

នេះជាឈ្មោះក្រុងយេរូសាឡឹមដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។

ដូចជាប្រើស ដែលរកស្មៅមិនបាន

ពួកចៅហ្វាយត្រូវបានគេប្រៀបធៀបជាមួយសត្វប្រើសដែលមិនមានអ្វីបរិភោគ។

ប្រើស

ប្រើសជាសត្វដែលស៊ីស្មៅនិងមានទំហំមធ្យម ដែលជារឿយៗត្រូវបានបរបាញ់សម្រាប់ធ្វើជាអាហារ។ វាក៏ជាសត្វដ៏ស្រស់ស្អាតផងដែរ។

ដោយល្វើយអស់កម្លាំង

ការបកប្រែផ្សេងទៀត «ប៉ុន្តែមិនរឹងមាំគ្រប់គ្រាន់ដើម្បីរត់ចេញពី»។

អ្នកដេញតាមពួកគេ

«អ្នកដែលតាមរកគេ»

Lamentations 1:7

ក្នុងថ្ងៃដែលរងទុក្ខវេទនា ហើយលំបាក

ការបកប្រែផ្សេងទៀត

«ក្នុងអំឡុងពេលមានទុក្ខព្រួយនិងគ្មានផ្ទះសម្បែងរបស់នាង» ឬ «នៅពេលក្រុងយេរូសាឡឹមរងទុក្ខនិងគ្មានផ្ទះសម្បែង»

ក្រុងយេរូសាឡឹមនឹងនឹកចាំ

ការបកប្រែផ្សេងទៀត «ក្រុងយេរូសាឡឹមនឹងចងចាំ»

សេចក្តីល្អទាំងប៉ុន្មាន

«ទ្រព្យសម្បត្តិ»

កាលពីដើម

ការបកប្រែផ្សេងទៀត «កាលពីមុន» ឬ «មុនពេលគ្រោះមហន្តរាយនេះកើតឡើង»។

ក្នុងគ្រាដែលជនទាំងឡាយបានធ្លាក់ ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ

នៅទីនេះពាក្យថា «ដៃ» សំដៅទៅលើកងទ័ពរបស់សត្រូវ។ ការបកប្រែផ្សេងទៀត «នៅពេលដែលមារសត្រូវបានច្បាំងដណ្តើមហើយចាប់បានប្រជាជនរបស់នាង»

ឥតមានអ្នកណាជួយសោះ

«គ្មានអ្នកជួយនាងទេ»

បានឃើញនាង ហើយបានចំអកឲ្យពីដំណើរដែលនាងបានជាប់គាំ

នេះមានន័យថា ពួកគេរីករាយនឹងចំអកក្រុងយេរូសាឡឹមនៅពេលដែលក្រុងត្រូវបានបំផ្លាញ។

ដំណើរដែលនាងបានជាប់គាំ

ការបកប្រែផ្សេងទៀត «ដោយសារតែនាងត្រូវបានបំផ្លាញ» ឬ «ខណៈពេលដែលពួកគេបំផ្លាញនាង»

Lamentations 1:8

ក្រុងយេរូសាឡឹមបានធ្វើបាបយ៉ាងធ្ងន់

នេះពិពណ៌នាអំពីក្រុងយេរូសាឡឹម ជាមនុស្សដែលបានធ្វើបាប ហើយវាក៏តំណាងឲ្យប្រជាជននៅក្រុងយេរូសាឡឹមដែរ។

ជារបស់ស្មោកគ្រោក

យោងទៅតាមច្បាប់នៃគម្ពីរសញ្ញាចាស់ ស្ត្រីម្នាក់មានភាពមិនស្អាតក្នុងពេលមានរដូវប្រចាំខែ។ អំពើបាបរបស់ក្រុងយេរូសាឡឹមបានធ្វើអោយនាងស្មោកគ្រោក និង មិនស្អាតដូច្នេះព្រះមិនអាចទទួលយកនាងឡើយ។

កេរ្តិ៍ខ្មាសនាង

ក្រុងយេរូសាឡឹមត្រូវបានពិពណ៌នាថាជាស្ត្រីម្នាក់ ដែលផ្នែកឯកជនត្រូវបានបង្ហាញដល់មនុស្សគ្រប់គ្នាឲ្យនាងខ្មាសគេ។

ការបកប្រែផ្សេងទៀត «ភាពអាក្រាតរបស់នាង»

នាងត្រូវធ្លាក់ចុះយ៉ាងយ៉ាប់យឺន

ការបកប្រែផ្សេងទៀត «ការធ្លាក់ចុះរបស់នាងបានធ្វើឲ្យមានការភ្ញាក់ផ្អើល» ឬ «អ្នកដែលបានឃើញការបំផ្លិចបំផ្លាញរបស់នាងមានការភ្ញាក់ផ្អើល»

សូមទតមើល៍ សេចក្តីវេទនារបស់ខ្ញុំម្ចាស់ចុះព្រះអម្ចាស់

អាចមានន័យថា ១) អ្នកនិពន្ធនៃបរិទេវឥឡូវនេះនិយាយដោយផ្ទាល់ទៅកាន់ព្រះអម្ចាស់ឬ ២) ក្រុងយេរូសាឡឹមត្រូវបានពិពណ៌នាថា

generated on Wed Sep 10 16:16:32 2025

កំពុងនិយាយទៅកាន់ព្រះអម្ចាស់ដូចជាមនុស្សម្នាក់ដែរ។
សូមទតមើល៍
ការបកប្រែផ្សេងទៀត «យកចិត្តទុកដាក់ទៅលើ»
Lamentations 1:10
ត្រូវបានលូកដៃមក
ការបកប្រែផ្សេងទៀត « បានកាន់កាប់» ឬ «បានលួច»
ទ្រព្យសម្បត្តិ
«ទ្រព្យសម្បត្តិ»
នាងបានឃើញ
ពាក្យថា «នាង» សំដៅទៅលើក្រុងយេរូសាឡឹម។
ទ្រង់បានផ្តាំទុក
ពាក្យ «ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។ នេះមានន័យថាអ្នកនិពន្ធ ឬ
ទីក្រុងនៅតែនិយាយបន្ទាប់ពីចាប់ផ្តើមនៅជំពូក ១: ៨ ។
Lamentations 1:11
ប្រជាជនទាំងអស់
ពាក្យ «នាង» សំដៅទៅលើក្រុងយេរូសាឡឹម
ដែលត្រូវបានពិពណ៌នាដូចជានាងជាស្ត្រីម្នាក់។ ការបកប្រែផ្សេងទៀត
«អ្នកស្រុករបស់នាង» ឬ «ប្រជាជនទីក្រុង»
របស់ដែលមានតម្លៃ
«ទ្រព្យសម្បត្តិ»
សម្រាប់រស់នៅវិញ
ការបកប្រែផ្សេងទៀត «ដើម្បីជួយសង្គ្រោះជីវិតរបស់ពួកគេ» ឬ
«ដើម្បីស្តារកម្លាំងឡើងវិញ»
មើល៍ សូមព្រះអម្ចាស់ពិចារណា
នៅទីនេះក្រុងយេរូសាឡឹមចាប់ផ្តើមនិយាយផ្ទាល់ទៅកាន់ព្រះអម្ចាស់។
អស់អ្នកដែលដើរកាត់តាមទីនេះ ?
នេះគឺជាការចោទប្រកាន់របស់ប្រជាជន ដែលដើរកាត់ក្រុងយេរូសាឡឹម
ហើយមិនយកចិត្តទុកដាក់។ វាមានទម្រង់ជាសំណួរ
ដើម្បីស្តីបន្ទោសពួកគេយ៉ាងខ្លាំង។ ការបកប្រែផ្សេងទៀត
«អ្នកទាំងអស់គ្នាដែលឆ្លងកាត់គួរតែយកចិត្តទុកដាក់ចំពោះទុក្ខវេទនារបស់ខ្ញុំ!»
តើវាគ្មានអ្វីសម្រាប់អ្នកទេ
នៅទីនេះក្រុងយេរូសាឡឹមបន្តនិយាយ ប៉ុន្តែឥឡូវនេះដល់មនុស្សដែលឆ្លងកាត់។
សូមពិចារណាមើល បើមានសេចក្តីទុក្ខព្រួយណា ដូចសេចក្តីទុក្ខព្រួយរបស់ខ្ញុំនេះ ដែលព្រះអម្ចាស់
បាននាំមកធ្វើទុក្ខដល់ខ្ញុំ
ការជាប់ទាក់ទងនៅទីនេះគឺថា
គ្មាននរណាម្នាក់ផ្សេងទៀតបានទទួលរងនូវផលប៉ះពាល់ច្រើនទេ។
សូមពិចារណាមើល
ពាក្យទាំងនេះមានអត្ថន័យស្រដៀងគ្នា។
ពួកគេរួមគ្នាអញ្ជើញអ្នកអានឲ្យយល់ដោយមើលឃើញថា
គ្មាននរណាម្នាក់រងទុក្ខច្រើនទេ។
ដូចសេចក្តីទុក្ខព្រួយរបស់ខ្ញុំនេះ
ការបកប្រែផ្សេងទៀត «ទុក្ខព្រួយដែលព្រះអម្ចាស់កំពុងធ្វើបាបលើខ្ញុំ»
នៅថ្ងៃនៃសេចក្តីក្រោធដ៏សហ័សរបស់ទ្រង់
ការបកប្រែផ្សេងទៀត «នៅពេលទ្រង់មានសេចក្តីក្រោធខ្លាំង»
Lamentations 1:13
ទ្រង់បានចាត់ភ្លើងពីស្ថានដ៏ខ្ពស់ឲ្យចូលក្នុងឆ្អឹងខ្ញុំ
នៅក្នុងអត្ថបទនេះ «ទ្រង់» សំដៅទៅលើព្រះជាម្ចាស់និង «របស់ខ្ញុំ»
ចំពោះទីក្រុងយេរូសាឡឹម ដែលនៅតែនិយាយទៅកាន់មនុស្សផ្សេងទៀត
ហាក់ដូចជាក្រុងយេរូសាឡឹមជាមនុស្ស។
ទ្រង់បានចាត់ភ្លើងពីស្ថានដ៏ខ្ពស់ឲ្យចូលក្នុងឆ្អឹងខ្ញុំ ភ្លើងនោះក៏ឈ្នះផង
ការបកប្រែផ្សេងទៀត
«បានដាក់ទណ្ឌកម្មដ៏ឈឺចាប់មួយទៅក្នុងខ្លួនខ្ញុំហើយវាបានបំផ្លាញខ្ញុំ» ឬ
«បានបញ្ជូនទណ្ឌកម្មដែលបំផ្លិចបំផ្លាញទៅពាក់កណ្តាលក្រុងយេរូសាឡឹមហើយវាបានឈ្នះ»
បានប្រគល់ខ្ញុំទៅក្នុងកណ្តាប់ដៃគេ
ការបកប្រែផ្សេងទៀត «សូមឲ្យខ្មាំងសត្រូវកម្ចាត់ខ្ញុំទៅ»
Lamentations 1:15
មនុស្សខ្លាំងពូកែ ដែលនៅការពារខ្ញុំ
នៅក្នុងផ្នែកនេះក្រុងយេរូសាឡឹមនៅតែត្រូវបានពិពណ៌នាថា
ជាស្ត្រីម្នាក់កំពុងនិយាយអំពីខ្លួនឯង។
មនុស្សខ្លាំងពូកែ
«ទាហានខ្លាំងបំផុត»
កងទ័ព
កងទ័ពសត្រូវដែលវាយប្រហារក្រុងយេរូសាឡឹម ត្រូវបានគេនិយាយថា
ជាការប្រជុំរបស់មនុស្សដែលបានជួបជុំគ្នាដើម្បីចោទប្រកាន់និងថ្កោលទោសនរណាម្នាក់។
ការបកប្រែផ្សេងទៀត «កងទ័ពមួយ»
ភាពរឹងមាំរបស់មនុស្ស
មនុស្សនៅវេលាខ្លាំងបំផុតនៃជីវិតរបស់ពួកគេ
ព្រះអម្ចាស់បានកម្ទេច...ធុងទំពាំងបាយជូរ
នៅទីនេះការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ត្រូវបានពិពណ៌នាដូចជា
ក្រុងយេរូសាឡឹមគឺជាទំពាំងបាយជូរ ដែលទ្រង់បានជាន់ឈ្លីដើម្បីច្របាច់យកទឹក។
ជនជាតិយូដា
នេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
ពាក្យថា «ព្រហ្មចារី» បង្ហាញថាស្ត្រីនេះគឺបរិសុទ្ធ។
Lamentations 1:16
បានជាខ្ញុំយំ
នេះនៅតែជាក្រុងយេរូសាឡឹមដែលកំពុងនិយាយដូចជាស្ត្រីម្នាក់ឥឡូវនេះមានអារម្មណ៍សោកសៅ។
ក្រុងស៊ីយ៉ូនលូកដៃទៅ
ក្រុងស៊ីយ៉ូនគឺដូចជាមនុស្សម្នាក់ដែលលើកដៃដើម្បីសុំជំនួយ។
នៅទីនេះក្រុងយេរូសាឡឹមលែងនិយាយខ្លួនឯងទៀតហើយ
តែអ្នកនិពន្ធពិពណ៌នាអំពីក្រុងយេរូសាឡឹម។
ពួកអ្នកដែលនៅជុំវិញ
ការបកប្រែផ្សេងទៀត «ប្រជាជននៅជុំវិញលោកយ៉ាកុប» ឬ
«ប្រជាជាតិនៅជុំវិញលោកយ៉ាកុប»
ធ្វើជាខ្មាំងសត្រូវនឹងគាត់
នៅទីនេះពាក្យ «របស់គាត់» សំដៅទៅលើលោកយ៉ាកុប។
Lamentations 1:18
ខ្ញុំបានបះបោរ
នៅទីនេះក្រុងយេរូសាឡឹមចាប់ផ្តើមនិយាយម្តងទៀតដូចជាស្ត្រីម្នាក់។
មើលសេចក្តីទុក្ខព្រួយរបស់ខ្ញុំ
ការបកប្រែផ្សេងទៀត «មើលខ្ញុំពិតជាក្រៀមក្រំណាស់»
ពួកក្រមុំៗ និងពួកកំលោះៗរបស់ខ្ញុំ
ការបកប្រែផ្សេងទៀត «ប្រជាជនខ្ញុំច្រើនណាស់»
ពួកកំលោះៗ
សូមមើលការបកប្រែនៅក្នុងជំពូក ១:១៥ ។
គេបានបញ្ឆោតខ្ញុំវិញ
ការបកប្រែផ្សេងទៀត «ពួកគេក្បត់ខ្ញុំ»
ដើម្បីចិញ្ចឹមជីវិត
ការបកប្រែផ្សេងទៀត «ដើម្បីជួយសង្គ្រោះជីវិតរបស់ពួកគេ» ឬ
«ដើម្បីស្តារកម្លាំងឡើងវិញ»
Lamentations 1:20
ដ្បិតខ្ញុំម្ចាស់មានសេចក្តីវេទនា
ក្រុងយេរូសាឡឹមបន្តនិយាយអំពីខ្លួននាង ដូចជាស្ត្រីម្នាក់
ប៉ុន្តែឥឡូវនេះនិយាយដោយផ្ទាល់ជាមួយព្រះអម្ចាស់។
រមួលពោះ
ពាក្យថា «រមួលពោះ» មានន័យថាធ្វើចលនាជុំវិញដោយអំពើហិង្សា
ជាធម្មតាក្នុងការបង្វិលរាងជារង្វង់។ នេះមិនមានន័យថានិយាយទេ
ប៉ុន្តែវាជាអារម្មណ៍។
ដួងចិត្តខ្ញុំខ្លោចផ្សាជាខ្លាំ
ការបកប្រែផ្សេងទៀត «បេះដូងខ្ញុំខ្ទិចខ្ទាំ» ឬ «ខ្ញុំពិតជាក្រៀមក្រំបំផុត»
ដាវបង្កត់បង់
ដាវតំណាងឲ្យសត្រូវហើយ «យក» មានន័យថា «សម្លាប់» ការបកប្រែផ្សេងទៀត
«ផ្សព្វផ្សាយនៅខាងក្រៅ»
នៅឯផ្ទះក៏មានដូចជាសេចក្តីស្លាប់ដែរ
អាចមានន័យថា ១) នៅក្នុងផ្ទះមនុស្សគ្រប់គ្នាស្លាប់ឬ ២) ផ្ទះគឺដូចជាផ្នូរ។
Lamentations 1:21
ពួកគេបានឮថា ខ្ញុំម្ចាស់ថ្ងូរ
ក្រុងយេរូសាឡឹមបន្តនិយាយដូចជាមនុស្សម្នាក់។
ព្រះអង្គបានធ្វើយ៉ាងនេះ

generated on Wed Sep 10 16:16:32 2025

2 [1]ព្រះអម្ចាស់គ្របបាំងជនជាតិនៃក្រុងស៊ីយ៉ូនដោយពពក ក្នុងកាលដែលព្រះអង្គខ្ញាល់។ ព្រះអង្គធ្វើឲ្យភាពថ្កុំថ្កើងរបស់អ៊ីស្រាអែល ចុះពីស្ថានសួគ៌មកដល់ដី ។ ព្រះអង្គ
មិននឹកចាំពីកំណល់កល់ព្រះបាទរបស់ព្រះអង្គ នៅថ្ងៃដែលព្រះអង្គខ្ញាល់នោះទេ។[2]ព្រះអម្ចាស់បានលេបទីលំនៅរបស់យ៉ាកុបបាត់អស់ ឥតមានប្រណីឡើយ ក្នុងគ្រា
ដែលទ្រង់មានកំហឹង ព្រះអង្គបានរំលំទីមាំមួនទាំងប៉ុន្មានរបស់កូនស្រីយូដា ព្រះអង្គបានពង្រាបទីទាំងនោះដល់ដី ទាំងបន្ទាបបន្ថោកទាំងនគរ និងពួកចៅហ្វាយផង។
[3]នៅពេលដែលព្រះអង្គខ្ញាល់ ព្រះអង្គបានកាត់ស្នែងរបស់អ៊ីស្រាអែល ក៏ដកព្រះហស្តស្តាំចេញពីមុខខ្មាំងសត្រូវ ហើយបានបញ្ឆេះទឹកដីយ៉ាកុប ដូចជាភ្លើងឆាបឆេះគ្រប់ទិស
ទី។[4]ដូចជាខ្មាំងសត្រូវយឺតធ្នូចំពោះយើង ដូចជាអ្នកតតាំង។ ក៏បានប្រហារជីវិតទាំងអស់ដែលគាប់ភ្នែក ឯនៅក្នុងត្រសាលនៃជនជាតិស៊ីយ៉ូន ព្រះអង្គបានចាក់សេចក្ដីក្រោធ
របស់ព្រះអង្គ ចេញដូចជាភ្លើង។
[5]ព្រះអម្ចាស់ត្រឡប់ដូចជាខ្មាំងសត្រូវ ហើយបានលេបអ៊ីស្រាអែលបាត់ទៅ ព្រះអង្គបានលេបអស់ទាំងដំណាក់របស់គេ ហើយបំផ្លាញទីមាំមួនទាំងប៉ុន្មាន ព្រមទាំងចម្រើន
ការសោកសៅ និងការយំទួញក្នុងប្រជាជាតិយូដាជាច្រើនឡើង។[6]ព្រះអង្គបានកន្ត្រាក់យកព្រះពន្លារបស់ព្រះអង្គ ចេញដោយកម្លាំង ទុកដូចជាខ្ទមសួនច្បារ ក៏បានបំផ្លាញ
កន្លែងប្រជុំរបស់ព្រះអង្គចោល ព្រះអម្ចាស់ធ្វើឲ្យពួកក្រុងស៊ីយ៉ូនភ្លេចពិធីបុណ្យ និងថ្ងៃសប្ប័ទ ហើយក្នុងសេចក្ដីក្រោធរបស់ព្រះអង្គ នោះបានស្អប់ខ្ពើមដល់ស្តេច និងសង្ឃ
ផង។
[7]ព្រះអម្ចាស់បានបោះបង់អាសនារបស់ព្រះអង្គចោលហើយ បានខ្ពើមឆ្អើមចំពោះទីបរិសុទ្ធរបស់ព្រះអង្គដែរ ព្រះអង្គបានប្រគល់កំផែងព្រះរាជវាំងទាំងប៉ុន្មានទៅក្នុងកណ្តាប់
ដៃនៃពួកខ្មាំងសត្រូវ គេបានស្រែកហ៊ោនៅក្នុងព្រះវិហារនៃព្រះអម្ចាស់ដូចនៅថ្ងៃបុណ្យធំមួយ។
[8]ព្រះអម្ចាស់បានសម្រេចនឹងបំផ្លាញកំផែងក្រុង នៃប្រជាជាតិស៊ីយ៉ូន ។ ក៏បានលាតខ្សែរង្វាស់ហើយ ឥតដកព្រះហស្តចេញពីការបំផ្លាញឡើយ ព្រះអង្គបានបណ្តាលឲ្យទាំង
របង និងកំពែងបានសោកសង្រេង និងរោយរៀវជាមួយគ្នា ទាំងបោះចេញទៅ[9]ទ្វារទីក្រុងទាំងប៉ុន្មានបានស្រុតចុះក្នុងដី ព្រះអង្គបានបំបាក់រនុកផង។ស្តេច និងពួកចៅហ្វាយ
គេនៅកណ្តាលពួកជនជាតិដ៏ទៃទាំងប៉ុន្មាន ឃ្លាតផុតពីក្រឹត្យវិន័យ ទាំងពួកព្យាការីក៏លែងឃើញការជាក់ស្តែង ពីព្រះអម្ចាស់ទៀតដែរ។
[10]ពួកចាស់ទុំរបស់ប្រជាជនក្រុងស៊ីយ៉ូនអង្គុយផ្ទាល់ដី ទាំងស្ងៀមស្ងាត់។ ពួកគេបានបាចធូលីដីលើក្បាល ហើយស្លៀកបាវកាន់ទុក្ខ។ ស្រីក្រមុំនៃក្រុងយេរូសាឡិម ដើរឱន
មុខទៅដីយ៉ាងអាម៉ាស់។
[11]ទឹកភ្នែករបស់ខ្ញុំហូររហាម ចិត្តខ្ញុំក៏ខ្លោចផ្សា ថ្លើមប្រមាត់ខ្ញុំក៏ខ្ទេចខ្ទាំ ហើយត្រូវស្រលុងចុះដល់ដីផង ដោយព្រោះកូនតូចនឹងកូនស្រីនៃជនជាតិខ្ញុំ ហើយដោយព្រោះ កូន
តូចនឹងកូនដែលនៅបៅដោះរាសន្លប់ទៅនៅតាមផ្លូវទីក្រុង។[12]ពួកគេសួរដល់ម្តាយថា«តើអង្ករ និងស្រាទំពាំងបាយជូរនៅឯណា?» វាក៏សន្លប់ទៅតាមផ្លូវនៃទីក្រុង ដូចជា
មនុស្សរបួស វាដាច់ខ្យល់នៅលើទ្រូងម្តាយ។
[13]តើត្រូវឲ្យខ្ញុំនិយាយអ្វី ប្រជាជននៃក្រុងយេរូសាឡិម? តើឲ្យខ្ញុំធៀបអ្នកដូចជាអ្វី ដើម្បីនឹងកម្សាន្តចិត្តអ្នកបាន ប្រជាជននៃក្រុងស៊ីយ៉ូន? ដ្បិតការអន្តរាយធំដូចជាសមុទ្រ
ហើយតើអ្នកណានឹងមើលឲ្យជាបាន?[14]ពួកព្យាការីបានឃើញការជាក់ស្តែងក្លែងក្លាយ ហើយផ្តេសផ្តាស គេមិនបានបើកឲ្យឃើញអំពើទុច្ចរិតឡើយ ពួកគេនៅតែជាឈ្លើយ
គឺគេបានឃើញតែសេចក្ដីកំភូត និងសេចក្ដីដែលបណ្តាលឲ្យត្រូវនិរទេសវិញប៉ុណ្ណោះ។
[15]អស់អ្នកណាដែលដើរហួសផ្លូវទៅ គេទះដៃឡកឡឺយឲ្យអ្នកវិញ គេធ្វើស៊ីសស៊ូស ហើយគ្រវីក្បាលដល់ប្រជាជនក្រុងយេរូសាឡិម ដោយពាក្យថា «តើទីក្រុងនេះឬ ដែល
មនុស្សហៅថា«ជាទីស្អាតល្អបំផុត» ហើយជាទីរីករាយដល់ផែនដីទាំងមូលនោះ?»[16]ពួកខ្មាំងសត្រូវទាំងប៉ុន្មាន បានហាមាត់ធំដាក់អ្នក គេធ្វើស៊ីសស៊ូស ហើយសង្កៀត
ធ្មេញដោយពាក្យថា«យើងបានលេបវាបាត់ហើយ! ទាំងនេះជាអ្វីដែលយើងកំពុងរង់ចាំ! យើងនិងរស់នៅដើម្បីមើលវា!»។
[17]ព្រះអម្ចាស់បានសំរេចកិច្ចការដែលព្រះអង្គគ្រងនិងធ្វើ ព្រះអង្គបានសម្រេចតាមព្រះបន្ទូលរបស់ទ្រង់។ គឺព្រះអង្គបានរំលំ ឥតត្រាប្រណី ហើយបានធ្វើឲ្យខ្មាំងសត្រូវមាន
អំណរពីដំណើររបស់អ្នក ព្រះអង្គបានលើកតម្កើងស្នែងរបស់ខ្មាំងសត្រូវអ្នកវិញ។
[18]ចិត្តរបស់គេបានស្រែកអំពាវនាវរកព្រះអម្ចាស់ កំផែងនៃក្រុងស៊ីយ៉ូន! ចូរឲ្យមានទឹកភ្នែកហូរសស្រាក់ដូចជាទន្លេទាំងថ្ងៃទាំងយប់ចុះ កុំឲ្យឈប់សម្រាកឡើយ កុំឲ្យភ្នែក
អ្នកឈប់ផ្អាកឲ្យសោះ។[19]ចូរក្រោកឡើង ចូរបន្លឺ សំឡេងទាំងយប់ មុនពេលដែលមេឃភ្លឺឡើង! ចូរថ្លែងទុក្ខព្រួយថ្វាយព្រះអម្ចាស់ ដោយឥតលាក់លៀមអ្វីឡើយ។ ចូរលើក
ដៃឡើងអង្វរព្រះអង្គ សូមទ្រង់ប្រណីសន្តោសជីវិតក្មេងៗ ដែលដេកដួលព្រោះអត់ឃ្លាន នៅគ្រប់ទាំងផ្លូវ»។
[20]សូមទតមើលព្រះអម្ចាស់ ទាំងពិចារណាមើលការទាំងនេះ តើត្រូវឲ្យពួកស្រីៗ ស៊ីកូនខ្លួន ដែលនៅក្នុងផ្ទៃម្តាយ គឺជាកូនដែលពួកគេបានថែរក្សារឺ? តើពួកបូជាចារ្យ និង
ពួកព្យាការីនឹងត្រូវគេសម្លាប់នៅក្នុងទីបរិសុទ្ធ នៃព្រះអម្ចាស់ឬ?
[21]ទាំងពួកជំទង់ និងពួកចាស់ៗ សុទ្ធតែដេកនៅតាមផ្លូវ ឯពួកក្រមុំ និងពួកកំលោះៗរបស់ខ្ញុំម្ចាស់ គេបានដួលស្លាប់ដោយដាវ ព្រះអង្គបានប្រហារជីវិតគេ ទាំងកាប់សម្លាប់
ឥតត្រាប្រណីដល់ពួកគេឡើយ។[22]ព្រះអង្គបានហៅប្រមូល ដូចជានៅថ្ងៃបុណ្យ អំពើភេរវកម្មមាននៅជុំវិញខ្ញុំ ក្នុងថ្ងៃនៃសេចក្ដីខ្ញាល់របស់ទ្រង់ គ្មានអ្នកណារត់រួច ឬ
គេចផុតឡើយ ពួកកូនដែលខ្ញុំបានបីក្រសោបនៅដៃ ហើយបានបីបាច់ចិញ្ចឹមមកនោះខ្មាំងសត្រូវវាបានបំផ្លាញអស់ហើយ។

Lamentations 2:1

ព័ត៌មានទូទៅ៖

កំណាព្យថ្មីមួយចាប់ផ្តើម។

អ្នកនិពន្ធកណ្ឌបរិទេវប្រើវិធីផ្សេងៗគ្នាជាច្រើនដើម្បីបង្ហាញថា
ប្រជាជនអ៊ីស្រាអែលធ្វើឲ្យព្រះជាម្ចាស់មិនពេញព្រះទ័យ។

ពពក ក្នុងកាលដែលព្រះអង្គខ្ញាល់

អាចមានន័យថា ១) ព្រះជាម្ចាស់
កំពុងគម្រាមធ្វើបាបប្រជាជននៅក្រុងយេរូសាឡឹមឬ ២) ព្រះជាម្ចាស់
បានធ្វើបាបប្រជាជនរួចទៅហើយ

ជនជាតិនៃក្រុងស៊ីយ៉ូន...កូនស្រីយូដា

ទាំងនេះគឺជាឈ្មោះសម្រាប់ក្រុងយេរូសាឡឹម
ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រី។

ព្រះអង្គធ្វើឲ្យភាពថ្កុំថ្កើងរបស់អ៊ីស្រាអែល ចុះពីស្ថានសួគ៌មកដល់ដី

«ក្រុងយេរូសាឡឹមបានធ្វើឲ្យព្រះជាម្ចាស់លែងពេញចិត្ត» .

មិននឹកចាំ

«មិនពេញចិត្ត» «មិនយកចិត្តទុកដាក់» ។

កំណល់កល់

នៅទីនេះ «កំណល់កល់»
តំណាងឲ្យកន្លែងដែលព្រះធ្វើល្អគ្រប់គ្រាន់ដើម្បីមានវត្តមាន។
សេចក្ដីយោងដែលអាចមាននៅទីនេះគឺ ១)
«ទីក្រុងយេរូសាឡឹមជាទីស្រឡាញ់របស់ព្រះអង្គ» ឬ ២)
«កិច្ចព្រមព្រៀងរបស់ទ្រង់ជាមួយអ៊ីស្រាអែល» ។

គ្រាដែលទ្រង់មានកំហឹង

រយៈពេលទូទៅមិនមែន២៤ ម៉ោងទេ ការបកប្រែផ្សេងទៀត
«ពេលដែលទ្រង់បង្ហាញកំហឹងរបស់ព្រះអង្គ »

បានលេប

«ត្រូវបំផ្លាញទាំងស្រុង» ដូចជាសត្វមិនទុកអ្វីសោះនៅពេលដែលវាលេបអាហារ

រំលំទីមាំមួនទាំងប៉ុន្មានរបស់កូនស្រីយូដា

អាចមានន័យថា ១) ទីក្រុងដែលមានកំពែងពាសពេញស្រុកយូដាឬ ២)
កំពែងដែលរឹងមាំនៅក្រុងយេរូសាឡឹម។

Lamentations 2:3

ព័ត៌មានទូទៅ៖

អ្នកនិពន្ធបន្តប្រើពាក្យប្រៀបធៀបដើម្បីបង្ហាញការប្រឆាំងរបស់ព្រះចំពោះស្រុកយូដា។

ព្រះអង្គបានកាត់ស្នែងរបស់អ៊ីស្រាអែល

នៅទីនេះ «ស្នែង»

ដកព្រះហស្តស្តាំចេញ

«ឈប់ការពារយើងពីសត្រូវរបស់យើង»

យឺតធ្នូចំពោះយើង ដូចជាអ្នកតតាំង

generated on Wed Sep 10 16:16:32 2025

ទាហានម្នាក់ត្រូវតែពត់ធ្នូរបស់គាត់ដើម្បីបាញ់។ ការបកប្រែផ្សេងទៀត
«គាត់បានដាក់ធ្នូរបស់គាត់ត្រៀមបាញ់យើង»
ក្នុងត្រសាលនៃជនជាតិស៊ីយ៉ូន
ការបកប្រែផ្សេងទៀត «ផ្ទះប្រជាជននៅក្រុងយេរូសាឡឹម»
ជនជាតិស៊ីយ៉ូន
ទាំងនេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រី។
ចាក់សេចក្ដីក្រោធរបស់ព្រះអង្គ ចេញដូចជាភ្លើង
«បានបង្ហាញថាទ្រង់ខឹង
ដោយចង់បំផ្លាញអ្វីៗទាំងអស់ដូចជាមនុស្សម្នាក់ដែលកំពុងឆេះ»
Lamentations 2:5
បានលេប
សូមមើលការបកប្រែក្នុងជំពូក ២: ១ ។
ព្រមទាំងចម្រើនការសោកសៅ និងការយំទួញ
ការបកប្រែផ្សេងទៀត «ទ្រង់បានធ្វើឲ្យមនុស្សកាន់តែច្រើនឡើងៗ
កាន់ទុក្ខនិងយំសោក»
ប្រជាជាតិយូដា
នេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
ខ្មមសួនច្បារ
អគារតូចមួយសម្រាប់ដាក់ឧបករណ៍ធ្វើស្រែរឹសម្រាប់ជាជម្រកដល់អ្នកថែសួន
ធ្វើឲ្យពួកក្រុងស៊ីយ៉ូនភ្លេចពិធីបុណ្យ និងថ្ងៃសប្ប័ទ
ការបកប្រែផ្សេងទៀត
«បណ្ដាលឲ្យប្រជាជននៅក្រុងស៊ីយ៉ូនភ្លេចទាំងការប្រជុំនិងថ្ងៃឈប់សម្រាកដ៏ឧឡារិក»
Lamentations 2:7
ព្រះអង្គបានប្រគល់...ទៅក្នុងកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ
«ព្រះអង្គបានប្រែក្លាយ ... ទៅជាសត្រូវ»
កំផែងព្រះរាជវាំង
នៅទីនេះពាក្យថានាងអាចសំដៅទៅលើក្រុងយេរូសាឡឹម ឬព្រះវិហារ។
អាចមានន័យថា១) «ជញ្ជាំងនៃវិមានរបស់ក្រុងយេរូសាឡឹមឬ ២)
«ជញ្ជាំងនៃព្រះវិហារ» ។
គេបានស្រែកហ៊ោនៅក្នុងព្រះវិហារនៃព្រះអម្ចាស់ដូចនៅថ្ងៃបុណ្យធំមួយ
នេះគឺជាការប្រៀបធៀបដ៏ហួសចិត្តរវាង
ពិធីបុណ្យដ៏រីករាយនិងគ្មានសំឡេងរំខានរបស់អ៊ីស្រាអែល
និងការស្រែកយ៉ាងខ្លាំងពីជ័យជម្នះរបស់ពួកបាប៊ីឡូន។
Lamentations 2:8
ប្រជាជាតិស៊ីយ៉ូន
នេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
ក៏បានលាតខ្សែរង្វាស់
ការបកប្រែផ្សេងទៀត «គាត់បានវាស់ប្រវែងជញ្ជាំង» ដូច្នេះគាត់ដឹងច្បាស់ថា
ត្រូវបំផ្លាញចំនួនប៉ុន្មាន
ឥតដកព្រះហស្តចេញពីការបំផ្លាញឡើយ
ការបកប្រែផ្សេងទៀត
«ព្រះអង្គបានបំផ្លាញដោយប្រើអំណាចទាំងអស់របស់ព្រះអង្គ»
ដកព្រះហស្តចេញ
«រក្សាដៃរបស់គាត់ឲ្យខ្លួនឯង»
ព្រះអង្គបានបណ្ដាលឲ្យទាំងរបង និងកំពែងបានសោកសង្រេង និងរោយរៀវជាមួយគ្នា
ទាំងបោះចេញទៅ
«ដោយសារតែទ្រង់បានបំផ្លាញកំពែង
និងកំពែងពួកគេមើលទៅដូចជាមនុស្សដែលយំសោក
និងបានបាត់បង់កម្លាំងរបស់ពួកគេ»
របង
ទីក្រុងបុរាណមាន «ជញ្ជាំង» សំខាន់ដើម្បីការពារអ្នកវាយប្រហារ
ហើយខ្សែខាងក្រៅនៃ «កំពែង» ដើម្បីការពារអ្នកវាយប្រហារពីជញ្ជាំង។
Lamentations 2:10
ប្រជាជនក្រុងស៊ីយ៉ូន
នេះគឺជាឈ្មោះក្រុងយេរូសាឡឹមដែល ត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
អង្គុយផ្ទាល់ដី
ដើម្បីបង្ហាញថាពួកគេកំពុងកាន់ទុក្ខ
Lamentations 2:11
ព័ត៌មានទូទៅ៖
អ្នកនិពន្ធផ្លាស់ប្តូរការពិពណ៌នាពីក្រុងយេរូសាឡឹមទៅរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់។
ទឹកភ្នែករបស់ខ្ញុំហូររហាម
ការបកប្រែផ្សេងទៀត «ខ្ញុំបានយំរហូតដល់ ខ្ញុំមិនអាចយំទៀតបាន»
ត្រូវស្រលុងចុះដល់ដីផង
ការបកប្រែផ្សេងទៀត «ផ្នែខាងក្នុងរបស់ខ្ញុំទាំងមូលកំពុងមានទុក្ខ»
ព្រោះកូនតូចនឹងកូនស្រីនៃជនជាតិខ្ញុំ
«កូនស្រីរបស់ប្រជាជនខ្ញុំ» គឺជាឈ្មោះនៃក្រុងយេរូសាឡឹមដែល
ត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។ ការបកប្រែផ្សេងទៀត
«ពីព្រោះប្រជាជនរបស់ខ្ញុំត្រូវបានគេវាយកម្ទេច»
តើអង្ករ និងស្រាទំពាំងបាយជូរនៅឯណា?
ឃ្លាថា «អង្ករនិងស្រាទំពាំងបាយជូរ» គឺជាវិធីទូទៅមួយក្នុងការនិយាយថា
«អាហារនិងភេសជ្ជៈ» ។ ការបកប្រែផ្សេងទៀត
«ផ្តល់ឲ្យយើងនូវអ្វីដែលត្រូវញ៉ាំនិងផឹក» ។
Lamentations 2:13
ព័ត៌មានទូទៅ៖
អ្នកនិពន្ធចាប់ផ្តើមនិយាយទៅកាន់ក្រុងយេរូសាឡឹម។
តើត្រូវឲ្យខ្ញុំនិយាយអ្វី...ក្រុងយេរូសាឡឹម ?
គ្មានអ្វីដែលខ្ញុំអាចនិយាយបានទេ គឺក្រុងយេរូសាឡឹម។
ប្រជាជននៃក្រុងយេរូសាឡឹម
នេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
តើឲ្យខ្ញុំធៀបអ្នកដូចជាអ្វី...ក្រុងស៊ីយ៉ូន?
«គ្មានអ្វីដែលខ្ញុំអាចប្រៀបធៀបអ្នកបានទេ ... ស៊ីយ៉ូន» ។
តើអ្នកណានឹងមើលឲ្យជាបាន?
«គ្មាននរណាម្នាក់អាចព្យាបាលអ្នកបានទេ» ។
Lamentations 2:15
គេទះដៃ...ធ្វើស៊ីសស៊ូស ហើយគ្រវីក្បាល
វិធីដែលមនុស្សលេងសើចអ្នកដទៃនិងជេរប្រមាថពួកគេ
ប្រជាជនក្រុងយេរូសាឡឹម
នេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
តើទីក្រុងនេះឬ ដែលមនុស្សហៅថា«ជាទីស្អាតល្អបំផុត» ហើយជាទីរីករាយដល់ផែនដីទាំងមូល
នោះ?
សំណួរនេះត្រូវបានប្រើ ដើម្បីបង្ហាញពីភាពស្រងាកចិត្ត
«ទីក្រុងនេះដែលពួកគេហៅថា «ភាពឥតខ្ចោះនៃភាពស្រស់ស្អាត
ក្តីអំណរសម្រាប់មនុស្សទាំងអស់នៅលើផែនដី គឺមិនមានភាពស្រស់ស្អាត
ឬរីករាយទៀតទេ!»
យើងបានលេបវាបាត់ហើយ
«យើងបានបំផ្លាញក្រុងយេរូសាឡឹមទាំងស្រុង»
ដូចជាសត្វលេបអាហាររបស់វាដែរ។
Lamentations 2:17
ព្រះអង្គបានលើកតម្កើងស្នែងរបស់ខ្មាំងសត្រូវអ្នកវិញ
នៅទីនេះ «ស្នែង»
Lamentations 2:18
ចិត្តរបស់គេបានស្រែកអំពាវនាវ
អាចមានន័យថា ១)
«ប្រជាជននៅក្រុងយេរូសាឡឹមស្រែកចេញពីផ្នែខាងក្នុងរបស់ពួកគេ» ឬ ២)
អ្នកនិយាយចង់អោយជញ្ជាំងស្រែកទៅកាន់ព្រះអម្ចាស់។
កំផែងនៃក្រុងស៊ីយ៉ូន
អ្នកនិពន្ធនិយាយទៅកាន់ជញ្ជាំងក្រុងយេរូសាឡឹម។
គាត់ចង់ឲ្យប្រជាជននៅក្រុងយេរូសាឡឹមធ្វើអ្វី ដែលគាត់កំពុងប្រាប់ឲ្យធ្វើជញ្ជាំង។
ក្រុងស៊ីយ៉ូន
នេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
ចូរឲ្យមានទឹកភ្នែកហូរសស្រាក់ដូចជាទន្លេ
«យំមានទឹកភ្នែកយ៉ាងច្រើន»
ទាំងថ្ងៃទាំងយប់
«គ្រប់ពេលវេលា»
កុំឲ្យឈប់សម្រាកឡើយ
«កុំអនុញ្ញាតឲ្យខ្លួនឯងសម្រាក»
មុនពេលដែលមេឃភ្លឺឡើង
«ច្រើនដងនៅពេលយប់» នោះគឺរាល់ពេលដែលអ្នកយាមមកបំពេញកាតព្វកិច្ច។

generated on Wed Sep 10 16:16:32 2025

ចូរលើកដៃឡើង
នេះជាសកម្មភាពមួយ ដែលអនុវត្តជាញឹកញាប់នៅពេលអធិស្ឋាន។
នៅគ្រប់ទាំងផ្លូវ
«ដែលជាកន្លែងមានផ្លូវរួមគ្នា» ឬ «ដោយផ្លូវ»
Lamentations 2:20
តើត្រូវឲ្យពួកស្ត្រីៗ ស៊ីកូនខ្លួន ដែលនៅក្នុងផ្ទៃម្តាយ...បានចែរក្សារឺ?
ការបកប្រែផ្សេងទៀត «ស្ត្រីមិនគួរបរិភោគកូនខ្លួនឯងទេ ... សម្រាប់!»
ដែលនៅក្នុងផ្ទៃម្តាយ
«កូនៗដែលនៅក្មេង»
Lamentations 2:21
ពួកជំទង់ និងពួកចាស់ៗ
អ្នកទន់ខ្សោយនិងខ្លាំងបំផុតរបស់មនុស្សពេញវ័យ
ភេរវកម្ម
«ការវាយប្រហារដែលខ្ញុំខ្លាច»
ព្រះអង្គបានហៅប្រមូល ដូចជានៅថ្ងៃបុណ្យ
«ដូចជាពួកគេបានកំពុងមកធ្វើបុណ្យ»

---

3 [1]ខ្ញុំជាមនុស្សដែលបានឃើញសេចក្តីវេទនា ដោយដំបងនៃសេចក្តីក្រោធរបស់ព្រះអង្គ[2]ព្រះអង្គបាននាំខ្ញុំចេញទៅ ឲ្យដើរក្នុងសេចក្តីងងឹត ជាជាងក្នុងពន្លឺ[3]ពិត
ប្រាកដណាស់ព្រះអង្គបានបែរព្រះហស្ត មកទាស់នឹងខ្ញុំម្តងហើយ ម្តងទៀត ឥតស្រាកស្រានឡើយ។[4]ព្រះអង្គបានធ្វើឲ្យសាច់ និង ស្បែកខ្ញុំរោយរៀវទៅ ហើយ
បានបំបាក់ឆ្អឹងខ្ញុំផង។
[5]ព្រះអង្គបានសាងសង់របងឃុំឃាំងខ្ញុំ ហើយបានឡោមព័ទ្ធខ្ញុំដោយភាពជូរល្វីង និងការដែលនឿយលំបាក[6]ព្រះអង្គឲ្យខ្ញុំរស់នៅកន្លែងងងឹត ដូចពួកដែលបានស្លាប់ជាយូរ
មកហើយ។[7]ព្រះអង្គបានធ្វើជញ្ជាំងព័ទ្ធជុំវិញខ្ញុំ មិនឲ្យចេញទៅក្រៅឡើយ ក៏ចាក់ច្រវ៉ាក់ចងខ្ញុំយ៉ាងធ្ងន់[8]ទោះបើខ្ញុំខំស្រែកហៅរកជំនួយ ក៏ទ្រង់មិនព្រមទទួលសេចក្តី
អធិស្ឋានរបស់ខ្ញុំឡើយ។
[9]ព្រះអង្គបានបង្ខាំងផ្លូវរបស់ខ្ញុំដោយជញ្ជាំង ទាំងដាក់ថ្មរាំងផ្លូវ ហើយក៏បានពង្វាងផ្លូវខ្ញុំ។[10]ព្រះអង្គប្រៀបដូចជាខ្លាឃ្មុំ ដែលលបសង្កេប ហើយដូចជាសិង្ហពួនចាំប្រហារ
ខ្ញុំ[11]ព្រះអង្គបានបង្វែរផ្លូវរបស់ខ្ញុំ ក៏ហែកខ្ញុំខ្ទេចខ្ទី ហើយឲ្យខ្ញុំនៅកណ្តោចកណ្តែង។
[12]ព្រះអង្គបានយឺតធ្នូ ហើយដាក់ខ្ញុំទុកជារង្វង់សម្រាប់បាញ់ព្រួញ។[13]ព្រះអង្គទម្លុះក្រលៀនខ្ញុំ ជាមួយតួព្រួញពីបំពង់[14]ខ្ញុំបានទៅជាទីសំណើច ដល់ជនជាតិទាំងឡាយរបស់ខ្ញុំ
ហើយជាវត្ថុកំប្លែងរបស់គេជានិច្ចរាល់ថ្ងៃ។[15]ព្រះអង្គបានចម្អែតខ្ញុំ ដោយសេចក្តីជូរចត់ ព្រមទាំងបង្ខំខ្ញុំឲ្យផឹកស្លែងផង។
[16]ព្រះអង្គបានបំបាក់ធ្មេញខ្ញុំដោយក្រួស ហើយរុញខ្ញុំឲ្យធ្លាក់ដល់ដីផេះ[17]ព្រលឹងរបស់ខ្ញុំបានចេញឆ្ងាយពីសេចក្តីសុខ ខ្ញុំបានភ្លេចអស់ទាំងសុភមង្គលជាអ្វីហើយ[18]ខ្ញុំក៏ពោល
ថា៖ «សេចក្តីអត់ធន់របស់ខ្ញុំបាត់អស់ហើយ សេចក្តីសង្ឃឹមលើព្រះអម្ចាស់ក៏លែងមានដែរ»។
[19]សូមនឹកចាំពីទុក្ខលំបាក និងសេចក្តីវេទនារបស់ខ្ញុំ ត្បិតផ្លែស្លែងនិងជូរល្វីងដ៏ម្ល៉េះ។[20]ខ្ញុំបន្តចងចាំបាននៅឡើយថា ហើយក៏ឱនចុះនៅក្នុងខ្លួនខ្ញុំ។[21]តែខ្ញុំនឹកចាំពីសេចក្តី
ទាំងនេះ បានជាខ្ញុំមានសេចក្តីសង្ឃឹម។
[22]គឺជាសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ មិនចេះចប់សេចក្តីមេត្តាករុណារបស់ព្រះអង្គមិនចេះផុតឡើយ[23]សេចក្តីទាំងនោះចេះតែថ្មីរៀងរាល់ព្រឹក សេចក្តីស្មោះត្រង់របស់
ព្រះអង្គធំណាស់។[24]«ព្រះអម្ចាស់ជាមរតករបស់ខ្ញុំ» ខ្ញុំបានពោលថា ដូច្នេះហើយទើបខ្ញុំមានសង្ឃឹមដល់ទ្រង់។
[25]ព្រះអម្ចាស់ល្អដល់អស់អ្នកដែលរង់ចាំព្រះអង្គ គឺដល់អស់អ្នកណាដែលស្វែងរកព្រះអង្គ។[26]វាជាការល្អ ដែលរង់ចាំសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ ។[27]ជាការល្អដែល
មនុស្សទទួលរងនឹម ក្នុងកាលដែលនៅវ័យក្មេងនៅឡើយ។[28]ឲ្យគាត់អង្គុយតែឯង ហើយនៅស្ងៀម នៅពេលដែលទ្រង់ដែលដាក់លើគាត់។[29]ចូរអោយគាត់ដាក់មាត់ចុះក្នុង
ធូលីដី ប្រហែលជាមានទីសង្ឃឹម។
[30]ចូរឲ្យថ្ពាល់គាត់ទៅឲ្យដល់អ្នកដែលចង់ទះគាត់ចុះ ហើយឲ្យគាត់ទ្រាំឲ្យបានពេញ ដោយសេចក្តីត្មះតិះដៀល។[31]ដ្បិតព្រះអម្ចាស់មិនបោះបង់ចោលជាដរាបទេ។[32]ទោះ
បើទ្រង់ធ្វើទុក្ខក៏ដោយ គង់តែទ្រង់ នឹងអាណិតមេត្តាដោយសេចក្តីស្រឡាញ់ដ៏បរិបូរណ៌ដែរ[33]ទ្រង់មិនមានព្រះហឫទ័យក្នុងការធ្វើទុក្ខ ឬឲ្យមនុស្សជាតិត្រូវវេទនានោះទេ។
[34]ពួកគេបានជិះជាន់ពួកអ្នកទោសនៅលើផែនដី[35]មនុស្សបានបដិសេដសេចក្តីយុត្តិធម៌ពីវត្តមាននៅចំពោះព្រះដ៏ខ្ពស់បំផុត។[36]ឬបំភាន់ភាពយុត្តធម៌ពីមនុស្ស នោះជាការ
ដែលព្រះអម្ចាស់ មិនអនុញ្ញាតិឡើយ។
[37]តើនរណាអាចធ្វើឲ្យការនេះកើតឡើងបាន គឺទ្រង់ទេតើដែលអាចថ្លែងទំនាយ ហើយការនោះកើតឡើងបានជាពិត?[38]ចំពោះសេចក្តីសុខ រឺ ទុក្ខ តើមិនមែនចេញពីព្រះឧស្ឋ
របស់ព្រះដ៏ខ្ពស់បំផុតមកទេឬ?[39]ហេតុដូច្នេះហើយកុំឲ្យមនុស្សរស់នៅបានតួញតែ្អរឡើយ? ហេតុអីបានជាមនុស្សមានបាបបានតួញតែ្អរពីការផ្តន្ទាទោសគេទៅវិញ?
[40]ចូរយើងពិនិត្យពិច័យ ហើយល្បងលផ្លូវដែលយើងប្រព្រឹត្ត រួចបែរចិត្តទៅឯព្រះអម្ចាស់វិញចុះ។[41]ចូរឲ្យយើងតម្រង់ចិត្ត ជាមួយដៃរបស់យើង ទៅឯព្រះអម្ចាស់ដែលគង់នៅ
ស្ថានសួគ៌។[42]យើងខ្ញុំបានប្រព្រឹត្តល្មើស ព្រមទាំងបះបោរ ហើយព្រះអង្គមិនបានអត់ទោសឲ្យទេ។[43]ព្រះអង្គបានឃ្លុំអង្គទ្រង់ ដោយសេចក្តីក្រោធ ទាំងដេញតាមយើងខ្ញុំ
ព្រះអង្គបានប្រហារជីវិតឥតប្រណីសោះឡើយ។
[44]ព្រះអង្គបាំងអង្គទ្រង់ក្នុងពពក ដើម្បីមិនឲ្យសេចក្តីអធិស្ឋានណាចូលទៅដល់បានឡើយ។[45]ព្រះអង្គបានធ្វើឲ្យយើងខ្ញុំទៅជាកាកសំរាម
និងទទួលការបដិសេដក្នុងចំណោមប្រជាជាតិ។[46]ពួកខ្មាំងសត្រូវទាំងប៉ុន្មានបានដាក់បណ្តាសាយើងខ្ញុំ[47]សេចក្តីបំផ្លាញ និងសេចក្តីវិនាស បានមកដល់យើងខ្ញុំ គឺជាសេចក្តី
ភ័យខ្លាចនិងការបំផ្លិចបំផ្លាញផង។
[48]ភ្នែករបស់ខ្ញុំបានយំឥតឈប់ ដោយព្រោះតែមហន្តរាយនៃជនជាតិខ្ញុំ។[49]ទឹកភ្នែកខ្ញុំនឹងហូរសស្រាក់ ឥតឈប់ឈរ ឥតស្រាកឡើយ។[50]ទាល់តែព្រះអម្ចាស់ព្រមទតមកពី
ស្ថានសួគ៌ដែរ។
[51]ភ្នែកខ្ញុំធ្វើឲ្យចិត្តខ្ញុំកើតទុក្ខ ដោយព្រោះតែពន្លកជាតិនៃក្រុងរបស់ខ្ញុំ។[52]គេដេញតាមខ្ញុំដូចតាមប្រមាញសត្វស្លាប អស់ពួកអ្នកដែលជាខ្មាំងសត្រូវនឹងខ្ញុំ ដោយឥតហេតុ
ផលទេ។[53]គេបានកាត់ជីវិតខ្ញុំចេញ ហើយបានទាំងបោះថ្មមកពីលើខ្ញុំផង[54]មានទឹកហូរមកលិចក្បាលខ្ញុំ នោះខ្ញុំបានថា «ខ្ញុំស្លាប់ហើយ»។
[55]ទូលបង្គំបានអំពាវនាវដល់ព្រះនាម របស់ព្រះអម្ចាស់ពីក្នុងទីជម្រៅនៃគុកងងឹត។[56]ព្រះអង្គក៏ឮសំឡេងរបស់ទូលបង្គំ «សូមកុំគេចព្រះកាណ៌ព្រះអង្គចេញពីការថ្ងូរ និង
សម្រែករបស់ទូលបង្គំឡើយ»[57]នៅថ្ងៃដែលទូលបង្គំបានអំពាវនាវដល់ព្រះអង្គ នោះព្រះអង្គបានយាងមកជិត ហើយមានព្រះបន្ទូលថា «កុំឲ្យខ្លាចឡើយ»។
[58]ព្រះអង្គបានកាន់ក្តីខាងទូលបង្គំ ហើយបានសង្គ្រោះជីវិតរបស់ទូលបង្គំផង។[59]ព្រះអម្ចាស់បានទតឃើញកំហុសដែលគេបានធ្វើដល់ទូលបង្គំ សូមជំនុំជម្រះក្តីរបស់ទូលបង្គំ
ចុះ។[60]ព្រះអង្គបានឃើញការសងសឹកទាំងប៉ុន្មានរបស់គេ និងអស់ទាំងកិច្ចកល ដែលគេធ្វើដល់ទូលបង្គំដែរ។[61]ព្រះអង្គបានឮពាក្យប្រមាថរបស់គេ និងអស់ទាំងកិច្ចកល
ដែលគេគិតធ្វើដល់ទូលបង្គំហើយ។
[62]ក៏ឮពាក្យសម្តីរបស់ពួកអ្នកលើកគ្នា ទាស់នឹងទូលបង្គំ ហើយជ្រាបការដែលគេគិត ទាស់នឹងទូលបង្គំជានិច្ចដែរ។[63]សូមព្រះអង្គទតក្នុងកាលដែលគេអង្គុយចុះ ហើយក្រោក
ឡើងផង ពួកគេនាំគ្នាច្រៀងឡកឡឺយដាក់ទូលបង្គំហើយ។
[64]ព្រះអង្គនឹងសងដល់គេ ដ្បិតទ្រង់ជាព្រះអម្ចាស់ ឲ្យស្របតាមការដែលគេប្រព្រឹត្ត។[65]ព្រះអង្គនឹងធ្វើឲ្យចិត្តគេអាម៉ាស់ សូមដាក់បណ្តាសាដល់គេទៅ![66]ព្រះអង្គនឹងដេញតាម
គេ ដោយសេចក្តីក្រោធ ហើយបំផ្លាញគេឲ្យសូន្យ ចេញពីក្រោមស្ថានរបស់ព្រះអម្ចាស់ទៅ។

Lamentations 3:1
ឃ្លាភ្ជាប់៖
កំណាព្យថ្មីមួយចាប់ផ្តើម
ដោយដំបងនៃសេចក្តីក្រោធរបស់ព្រះអង្គ
ដំបងជាឈើមួយដែលមនុស្សប្រើដើម្បីវាយ និង ដាក់ទោសមនុស្សណាម្នាក់។
ការបកប្រែផ្សេងទៀត
«ពីព្រោះព្រះអម្ចាស់កំពុងតែវាយទូលបង្គំដោយសេចក្តីក្រោធ» ។
ដើរក្នុងសេចក្តីងងឹត ជាជាងក្នុងពន្លឺ

generated on Wed Sep 10 16:16:32 2025

នេះមានន័យថា រស់នៅក្នុងភាពច្របូកច្របល់និងអាប់អួរ។
ព្រះអង្គបានបែរព្រះហស្ត មកទាស់នឹងខ្ញុំ
ការបកប្រែផ្សេងទៀត «ទ្រង់បានក្លាយជាសត្រូវរបស់ទូលបង្គំ» ឬ
«ទ្រង់ប្រើអំណាចរបស់ព្រះអង្គដើម្បីដាក់ទណ្ឌកម្មខ្ញុំ»
Lamentations 3:5
ព្រះអង្គបានសាងសង់របងឃុំឃាំងខ្ញុំ
ការឡោមព័ទ្ធគឺ អាចជួយឲ្យកងទ័ពវាយលុកឆ្លងកាត់ជញ្ជាំងទីក្រុង
និងវាយលុកចូលទីក្រុងបាន។ ការបកប្រែផ្សេងទៀត «គាត់បានឡោមព័ទ្ធខ្ញុំ
ដូចជាខ្ញុំជាទីក្រុងដែលកំពុងរងការវាយប្រហារ» ។
បានឡោមព័ទ្ធខ្ញុំដោយភាពជូរល្វីង និងការដែលនឿយលំបាក
ការបកប្រែផ្សេងទៀត «ឡោមព័ទ្ធខ្ញុំជាមួយនឹងរបស់ដែលឈឺចាប់និងពិបាកទ្រាំ»
ទ្រង់មិនព្រមទទួលសេចក្តីអធិស្ឋានរបស់ខ្ញុំឡើយ
ការបកប្រែផ្សេងទៀត «ទ្រង់បដិសេធមិនស្តាប់ការអធិស្ឋានរបស់ទូលបង្គំ»
Lamentations 3:9
បានបង្ខាំងផ្លូវរបស់ខ្ញុំ
«រារាំងខ្ញុំមិនឲ្យរត់គេចពីព្រះអង្គ»
ដាក់ថ្មរាំងផ្លូវ
ដុំថ្មដែលគេបានកាត់ជារាងនឹងធ្វើឲ្យជញ្ជាំងរឹងមាំ
ហើយក៏បានពង្វាងផ្លូវខ្ញុំ
អាចមានន័យថា ១) «ដុំថ្មបិទផ្លូវខ្ញុំ ដូច្នេះខ្ញុំមិនអាចទៅកន្លែងណាទេ» ឬ ២)
«ដុំថ្មបិទគ្រប់ផ្លូវ ដែលខ្ញុំដើរទៅកន្លែងណាមិនរួច»
ព្រះអង្គបានបង្វែរផ្លូវរបស់ខ្ញុំ
អាចមានន័យថា ១) «ទ្រង់បានទាញទូលបង្គំចេញពីផ្លូវ» ឬ ២)
«ទ្រង់បានធ្វើអោយផ្លូវទូលបង្គំដើរខុសទិសដៅ»
Lamentations 3:12
ព្រះអង្គបានយឺតធ្នូ
សូមមើលការបកប្រែនៅក្នុងជំពូក ២: ៣ ។
បំពង់
កាបូបដែលពាក់នៅផ្នែកខាងក្រោយដែលផ្ទុកព្រួញ
ក្រលៀន
សរីរាង្គពោះដែលចិញ្ចឹមទឹកនោមចូលប្លោកនោម។ ការបកប្រែផ្សេងទៀត
«ជ្រៅចូលក្នុងខ្លួនខ្ញុំ» ឬ ២) «ចូលក្នុងបេះដូងខ្ញុំ» ។
សំណើច ដល់ជនជាតិទាំងឡាយរបស់ខ្ញុំ
អាចមានន័យថា ១) «នរណាម្នាក់ដែលប្រជាជនអ៊ីស្រាអែលទាំងអស់សើច» ឬ ២)
«នរណាម្នាក់ដែលមនុស្សទាំងអស់នៅលើផែនដីសើច» ។
ព្រះអង្គបានចម្អែតខ្ញុំ ដោយសេចក្តីជូរចត់
«វាហាក់ដូចជាទ្រង់បង្ខំទូលបង្គំឲ្យញុំាឱសថល្វីង»
ស្លែង
ទឹកល្វីងពីស្លឹកនិងផ្ការបស់រុក្ខជាតិ
Lamentations 3:16
ព្រះអង្គបានបំបាក់
នេះជាឃ្លាពីរសម្រាប់ព្រះជាម្ចាស់បន្ទាបខ្លួនអ្នកនិពន្ធ។
ព្រលឹងរបស់ខ្ញុំបានចេញឆ្ងាយពីសេចក្តីសុខ
អ្នកនិពន្ធលែងមានអំណរ ឬភាពរីករាយនៅក្នុងជីវិតរបស់គាត់ទៀតហើយ។
សេចក្តីអត់ធន់របស់ខ្ញុំបាត់អស់ហើយ
ការបកប្រែខ្លះថា «សិរីរុងរឿងរបស់ខ្ញុំបានរលាយបាត់ទៅហើយ» ប៉ុន្តែនៅទីនេះ
«សិរីរុងរឿង» តំណាងឲ្យការស៊ូទ្រាំឬកម្លាំង។
Lamentations 3:19
ផ្លែស្លែងនិងជូរល្វីង
ផ្លែស្លែងគឺជារុក្ខជាតិដែលផ្តល់នូវអង្គធាតុរាវ ដែលមានជាតិជូរ ចត់ក្នុងការផឹក។
«ផ្លែស្លែង» និង «ជូរចត់» មានអត្ថន័យស្រដៀងគ្នាហើយសង្កត់ធ្ងន់ថា
នេះគឺជាអ្វីមួយដែលជូរចត់ណាស់។
ហើយក៏ឱនចុះនៅក្នុងខ្លួនខ្ញុំ
ការបង្ហាញនេះសំដៅទៅលើការធ្លាក់ទឹកចិត្តនិងភាពអស់សង្ឃឹម។
ការបកប្រែផ្សេងទៀត «ព្រលឹងខ្ញុំរលាយក្នុងខ្លួនខ្ញុំ» ឬ «ខ្ញុំអស់សង្ឃឹម»
តែខ្ញុំនឹកចាំពីសេចក្តីទាំងនេះ
អ្នកនិពន្ធហៀបនឹងប្រាប់ទស្សនិកជននូវអ្វីដែលគាត់មានសង្ឃឹម។
Lamentations 3:22
សេចក្តីស្មោះត្រង់របស់ព្រះអង្
អ្នកនិពន្ធនិយាយទៅកាន់ព្រះអម្ចាស់។
ព្រះអម្ចាស់ជាមរតករបស់ខ្ញុំ
«ពីព្រោះព្រះអម្ចាស់គង់នៅជាមួយទូលបង្គំ
ទូលបង្គំមានអ្វីគ្រប់យ៉ាងដែលទូលបង្គំត្រូវការ»
Lamentations 3:25
អ្នកដែលរង់ចាំព្រះអង្គ
អាចមានន័យថា ១) «អស់អ្នកដែលពឹងផ្អែកលើព្រះអង្គ» ឬ ២)
«អ្នកដែលរង់ចាំដោយអត់ធ្មត់ដើម្បីឲ្យ ព្រះអង្គធ្វើសកម្មភាព» ។
អស់អ្នកណាដែលស្វែងរកព្រះអង្គ
ការបកប្រែផ្សេងទៀត «អ្នកដែលស្វែងរកព្រះអង្គ»
ទទួលរងនឹម
«រងទុក្ខ»
នៅពេលដែលទ្រង់ដែលដាក់លើគាត់
«នឹមដែលដាក់លើគាត់»
ចូរអោយគាត់ដាក់មាត់ចុះក្នុងធូលីដី
ការបកប្រែផ្សេងទៀត «លុតជង្គង់ចុះនៅលើដី»
Lamentations 3:30
ព័ត៌មានទូទៅ៖
អ្នកនិពន្ធនិយាយអំពីអ្នកដែលរង់ចាំព្រះអម្ចាស់ (៣:២៥) ។
ចូរឲ្យថ្កាល់គាត់ទៅឲ្យដល់អ្នកដែលចង់ទះគាត់ចុះ
«អនុញ្ញាតឲ្យមនុស្សទះគាត់ចុះ» ឬ
ទោះបើទ្រង់ធ្វើ
«ទោះបីជាព្រះអម្ចាស់ធ្វើឲ្យ»
មនុស្សជាតិ
ការបកប្រែផ្សេងទៀត «មនុស្ស» ឬ «មនុស្ស»
Lamentations 3:34
ពួកគេបានជិះជាន់
«ដើម្បីរំលោភបំពាន» ឬ «ដើម្បីសម្លាប់»
Lamentations 3:37
ចំពោះសេចក្តីសុខ ។ ទុក្ខ តើមិនមែនចេញពីព្រះឧស្ន របស់ព្រះដ៏ខ្ពស់បំផុតមកទេឬ?
ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់សម្រេចអោយមានគ្រោះមហន្តរាយឬជោគជ័យសម្រាប់គ្រប់គ្នា»
Lamentations 3:40
ចូរឲ្យយើងតម្រង់ចិត្ត ជាមួយដៃរបស់យើង
ជាទម្លាប់សម្រាប់ជនជាតិអ៊ីស្រាអែលលើកដៃនៅពេលអធិស្ឋានដល់ព្រះ។
ការបកប្រែផ្សេងទៀត «ចូរយើងអធិស្ឋានដោយស្មោះដោយការលើកដៃ»
យើងខ្ញុំបានប្រព្រឹត្តល្មើស ព្រមទាំងបះបោរ
ពាក្យថា «ប្រព្រឹត្តល្មើស» និង «បះបោរ» មានអត្ថន័យស្រដៀងគ្នា។
ពួកគេរួមគ្នាបង្ហាញថាការបំពានគឺដូចគ្នានឹងការបះបោរប្រឆាំងនឹងព្រះអម្ចាស់ដែរ។
ព្រះអង្គបានឃុំអង្គទ្រង់ ដោយសេចក្តីក្រោធ
នៅទីនេះសេចក្តីក្រោធត្រូវបានគេនិយាយដូចជាសម្លៀកបំពាក់ដែលព្រះជាម្ចាស់បានស្លៀកពាក់។
ភាសាហេព្រើរច្រើនតែនិយាយពីអារម្មណ៍ដូចជាសម្លៀកបំពាក់។
ការបកប្រែផ្សេងទៀត «ព្រះអង្គ ក្រោធ» ។
Lamentations 3:44
ព័ត៌មានទូទៅ៖
ការអធិស្ឋានដែលបានចាប់ផ្តើមនៅជំពូក ៣: ៤០ បន្ត។
ព្រះអង្គបាំងអង្គទ្រង់ក្នុងពពក ដើម្បីមិនឲ្យសេចក្តីអធិស្ឋានណាចូលទៅដល់បានឡើយ
ការបកប្រែផ្សេងទៀត
«ទ្រង់ប្រើពពកជាខែលដើម្បីការពារសេចក្តីអធិស្ឋានរបស់យើងអោយនៅឆ្ងាយ»
ព្រះអង្គបានធ្វើឲ្យយើងខ្ញុំទៅជាកាកសំរាម និងទទួលការបដិសេដ
ពាក្យថា «សំរាម» និង «បដិសេធ»
ទាំងពីរសំដៅទៅលើអ្វីដែលមនុស្សបានបដិសេធ និងបោះចោល។
ការបកប្រែផ្សេងទៀត «អ្នកបានបោះចោលយើង ដូចយើងជាសំរាម» ។
ក្នុងចំណោមប្រជាជាតិ
អាចមានន័យថា ១) ដែលប្រជាជាតិផ្សេងទៀតចាត់ទុកពួកគេជាសំរាម ២)
ដែលព្រះអម្ចាស់បានបោះចោលពួកគេដូចជាសំរាម ក្នុងចំណោមប្រជាជាតិនានា។
សេចក្តីភ័យខ្លាចនិងការបំផ្លិចបំផ្លាញផង
ពាក្យទាំងពីរនេះមានន័យស្រដៀងគ្នា
និងសំដៅទៅលើការបំផ្លាញក្រុងយេរូសាឡឹម។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«ការបំផ្លាញសរុប» ។
Lamentations 3:48
ភ្នែករបស់ខ្ញុំបានយំឥតឈប់
«ទឹកភ្នែកហូរចេញពីភ្នែកខ្ញុំដូចជាទឹកហូរចូលក្នុងទន្លេ» ព្រោះខ្ញុំយំ
ដោយព្រោះតែមហន្តរាយនៃជនជាតិខ្ញុំ
សូមមើលការបកប្រែនៅជំពូក ២:១១ ។
Lamentations 3:51
សូមមើលការបកប្រែនៅ ២:១១ ។
ការបកប្រែផ្សេងទៀត «អ្វីដែលខ្ញុំឃើញធ្វើឲ្យខ្ញុំឈឺចាប់ខ្លាំង»
ជនជាតិនៃក្រុងរបស់ខ្ញុំ
អាចមានន័យថា ១) ស្ត្រីនៅក្រុងយេរូសាឡឹម ឬ ២)
ប្រជាជនទាំងអស់នៅក្រុងយេរូសាឡឹម។
គេបានកាត់ជីវិតខ្ញុំចេញ
ការបកប្រែផ្សេងទៀត «ពួកគេបានសម្លាប់ខ្ញុំដោយទឹកនៅក្នុងអណ្ដូងមួយ» ។
បោះថ្មមកពីលើខ្ញុំផង
អាចមានន័យថា១) «បានគប់ដុំថ្មមកលើខ្ញុំ» ឬ ២) «បានគ្របអណ្ដូងដោយថ្ម» ។
ខ្ញុំស្លាប់ហើយ
ការបកប្រែផ្សេងទៀត «ខ្ញុំត្រូវបានគេសម្លាប់» ឬ «ខ្ញុំកំពុងលង់ទឹក»
Lamentations 3:55
ទូលបង្គំបានអំពាវនាវដល់ព្រះនាម
ការបកប្រែផ្សេងទៀត «ទូលបង្គំបានអំពាវនាវរកព្រះអង្គឲ្យជួយ»
ក្នុងទីជម្រៅនៃគុកងងឹត
អាចមានន័យថា ១) «ពីអណ្ដូងជ្រៅមួយ» ឬ ២) ពីផ្នូរ។
ព្រះអង្គក៏ឮសំឡេងរបស់ទូលបង្គំ
ការបកប្រែផ្សេងទៀត «ទ្រង់បានឮអ្វីដែលទូលបង្គំបានទូលប្រាប់»
សូមកុំគេចព្រះកាណ៌ព្រះអង្គចេញ
ការបកប្រែផ្សេងទៀត «កុំបដិសេធមិនស្តាប់»
Lamentations 3:58
ព្រះអង្គបានកាន់ក្តីខាងទូលបង្គំ ហើយបានសង្គ្រោះជីវិតរបស់ទូលបង្គំផង
នេះបង្ហាញពីរូបភាពនៃបន្ទប់សវនាការ ដែលវាគ្មិនកំពុងជំនុំជម្រះ។
នៅក្នុងរូបភាពនេះព្រះបានជជែកវែកញែកសម្រាប់គាត់
ដូចជាមេធាវីជំទាស់នឹងកូនក្តីរបស់គាត់។ ការបកប្រែផ្សេងទៀត
«អ្នកបានឈ្លោះប្រកែកគ្នាជាមួយខ្ញុំនៅក្នុងតុលាការ»
ជំនុំជម្រះក្តីរបស់ទូលបង្គំចុះ
នៅទីនេះព្រះអម្ចាស់លែងជាមេធាវីទៀតហើយប៉ុន្តែជាចៅក្រម។
ការសងសឹកទាំងប៉ុន្មានរបស់គេ និងអស់ទាំងកិច្ចកល ដែលគេធ្វើដល់ទូលបង្គំ
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នាហើយត្រូវបានផ្សំសម្រាប់ការសង្កត់ធ្ងន់។
ឮពាក្យប្រមាថរបស់គេ
ការបកប្រែផ្សេងទៀត «ឮពួកគេតិះដៀលខ្ញុំ»
Lamentations 3:62
ក៏ឮពាក្យសម្តីរបស់ពួកអ្នកលើកគ្នា ទាស់នឹងទូលបង្គំ
ការបកប្រែផ្សេងទៀត «ពាក្យដែលអ្នកប្រឆាំងនឹងខ្ញុំបាននិយាយ»
ពួកអ្នកលើកគ្នា ទាស់នឹងទូលបង្គំ
ការបកប្រែផ្សេងទៀត «អ្នកដែលវាយប្រហារទូលបង្គំ»
កាលដែលគេអង្គុយចុះ ហើយក្រោកឡើង
ការបកប្រែផ្សេងទៀត «អ្វីគ្រប់យ៉ាងដែលពួកគេធ្វើ»
Lamentations 3:64
ព្រះអង្គនឹងសងដល់គេ ដ្បិតទ្រង់ជាព្រះអម្ចាស់ ឲ្យស្របតាមការដែលគេប្រព្រឹត្ត
ការបកប្រែផ្សេងទៀត «ឱព្រះអម្ចាស់អើយពួកគេបានធ្វើអោយទូលបង្គំរងទុក្ខ
ដូច្នេះសូមមេត្តាធ្វើអោយពួកគេរងទុក្ខឥឡូវនេះ»
ឲ្យចិត្តគេអាម៉ាស់
ការបកប្រែផ្សេងទៀត «ធ្វើឲ្យពួកគេគ្មានអារម្មណ៍អៀនខ្មាស»
ចេញពីក្រោមស្ថានរបស់ព្រះអម្ចាស់ទៅ
ការបកប្រែផ្សេងទៀត «គ្រប់ទីកន្លែងដែលពួកគេនៅលើផែនដី»

4 [1]ម្តេចក៏មាសប្រែជាស្រអាប់ ហើយមាសសុទ្ធប្រែជាបាត់បង់រស្មី! ថ្មបរិសុទ្ធទាំងប៉ុន្មាននៅរាយប៉ាយ គ្រប់ទីកន្លែង ទាំងនៅតាមផ្លូវ[2]កូនប្រុសនៃអ៊ីស្រាអែលដ៏មានតម្លៃ
ថ្លៃដូចជាមាស ប៉ុន្តែឥឡូវនេះពួកគេគ្មានតំលៃជាជាងក្អមដីឡើយ ដូចជាកិច្ចការរបស់ជាងស្មូនដូច្នេះ!
[3]សូម្បីតែឆ្កែព្រៃ ក៏ចេះបំបៅដោះឲ្យកូនដែរ តែប្រជាជនខ្ញុំវិញ បែជាមានចិត្តខ្មៅ សាហាវ ដូចជាសត្វអូទ្រុស នៅទី រហោស្ថាន។
[4]អណ្តាតរបស់កូនតូចៗ ស្រេកទឹកខះក ក្មេងៗនាំគ្នាយំទារកអាហារ តែគ្មានអ្នកណាឲ្យវាឡើយ។[5]ពួកអ្នកដែលធ្លាប់មានអាហារថ្លៃៗបរិភោគ ឥឡូវបែរជាត្រូវដាច់ពោះ
នៅតាមផ្លូវ ពួកអ្នកដែលធ្លាប់ស្លៀកពាក់រុងរឿង ក៏បែរជាកាយសំរាមដើម្បីបរិភោគវិញ។
[6]ដ្បិតអំពើទុច្ចរិតរបស់ជនជាតិខ្ញុំធ្ងន់ជាង អំពើបាបរបស់ក្រុងសូដុមទៅទៀត ដែលត្រូវបានបំផ្លាញក្នុងមួយរំពេច ឥតមានដៃអ្នកណាមកជួយទាន់ឡើយ។
[7]ពួកអ្នកដឹកនាំជាមនុស្ស ដែលបរិសុទ្ធជាងហិមៈ សស្អាតជាងទឹកដោះគោ ខ្លួនរបស់គេក្រហមជាងត្បូងទទឹមទៅទៀត ក៏ភ្លឺដូចជាត្បូងកណ្តៀង។[8]ឥឡូវនេះ រូបរាងរបស់គេ
ខ្មៅជាងធ្យូង គ្មានអ្នកណាស្គាល់គេតាមផ្លូវទេ ស្បែកជាប់នឹងឆ្អឹង ស្វិតក្រៀមដូចជារំកាច់ឈើ។
[9]អស់អ្នកដែលស្លាប់ដោយមុខដាវ គឺរីករាយជាងពួកអ្នក ដែលស្លាប់ដោយស្រេកឃ្លាន ដែលវិនាសបន្តិចម្តងៗទៅ ដោយ ភាពខ្វះខាតស្បៀងអាហារ។[10]មនុស្សស្រី
ដែលធ្លាប់មានចិត្តទន់សន្តោស បានស្ងោរកូនខ្លួនស៊ី ដោយដៃខ្លួនឯង កូនៗទាំងនោះជាអាហាររបស់គេ ក្នុងគ្រាដែលប្រជាជាតិខ្ញុំត្រូវបានបំផ្លាញ។
[11]ព្រះអម្ចាស់បង្ហាញសេចក្តីក្រោធយ៉ាងខ្លាំង ព្រះអង្គបានចាក់សេចក្តីកំហឹងដ៏សហ័សរបស់ទ្រង់។ ព្រះអង្គបានបង្កាត់ភ្លើងដុតក្រុងស៊ីយ៉ូន ឲ្យឆេះរហូតដល់គ្រិះផង។
[12]ពួកស្តេចទាំងឡាយនៅផែនដី ព្រមទាំងមនុស្សដែលនៅក្នុងពិភពលោកនេះ គេមិនបានជឿថាពួកបច្ចាមិត្ត និងពួកខ្មាំងសត្រូវ នឹគូប្រជែង អាចចូលតាមទ្វារក្រុង
យេរូសាឡិមបានទេ។[13]ការនេះកើតឡើងដោយព្រោះតែអំពើបាបរបស់ពួកព្យាការី និងអំពើទុច្ចរិតរបស់ពួកបូជាចារ្យ ជាពួកអ្នកដែលបានកម្ចាយឈាម មនុស្សសុចរិតនៅ
ក្នុងទីក្រុង។
[14]ពួកគេដើរតែលតោលនៅតាមផ្លូវដូចជាមនុស្សខ្វាក់ ពួកគេប្រឡាក់សុទ្ធតែឈាម បានជាគ្មានអ្នកណាហ៊ានពាល់សម្លៀកបំពាក់របស់គេឡើយ។[15]«ចៀសចេញ!
មនុស្សមិនស្អាត! មនុស្សទាំងឡាយស្រែកដាក់គេថា «ចៀស! ចូរចៀសឲ្យឆ្ងាយទៅ! កុំមកប៉ះពាល់អ្វីឡើយ!» គេរត់ទៅហើយដើរសាត់អណ្តែតប្រជាជាតិមួយ
ទៅប្រជាជាតិមួយទៀត «តែគ្មានអ្នកណាឲ្យគេអាស្រ័យនៅឡើយ»។
[16]ព្រះអម្ចាស់បានរកវិធីកម្ចាត់កម្ចាយគេទៅ ព្រះអង្គមិនព្រមទតមើលគេទៀតទេ គ្មាននរណាគោរពប្រតិបត្តិដល់ពួកបូជាចារ្យ រឺក៏អាណិតដល់ពួកចាស់ទុំដែរ។
[17]ភ្នែករបស់យើងឡើងផ្សា ដោយទន្ទឹងរង់ចាំជំនួយ យើងឃ្លាំចាំមើល ហើយចាំមើលទៀត តែគ្មានប្រជាជាតិណាមួយមក ជួយសង្គ្រោះសោះ។[18]គេដេញតាមយើងគ្រប់
ជំហាន បានជាយើងរកចេញទៅផ្លូវមិនបាន។ ទីបញ្ចប់របស់យើងកាន់តែជិតមកដល់ កំណត់យើងក៏សម្រេច ដ្បិតចុងបំផុតរបស់យើងបានមកដល់ហើយ។
[19]ពួកអ្នកដែលដេញតាមយើង គេរហ័សជាងឥន្ទ្រីនៅលើអាកាសទៅទៀត គេបានដេញយើងឲ្យទៅលើភ្នំ ក៏លបចាំយើងនៅទីរហោស្ថាន។
[20]ខ្យល់ដង្ហើមដែលដកតាមរន្ធច្រមុះ គឺព្រះអម្ចាស់បានចាក់ប្រេងតាំង ព្រះអង្គត្រូវគេចាប់ចូលក្នុងអង្គប់ ហើយដែលយើងធ្លាប់ពោលថា «យើងខ្ញុំសូមជ្រកក្រោមម្លប់ដ៏
ត្រជាក់របស់ព្រះអង្គ ក្នុងចំណោមពួកជនជាតិដទៃ»។
[21]ចូរមានចិត្តរីករាយ ហើយសប្បាយឡើង ប្រជាជាតិ អេដុម ដែលជាអ្នកអាស្រ័យនៅទឹកដីអ៊ូស ដ្បិតអ្នកត្រូវទទួលពែងនៃទុក្ខលំបាក ទាំងស្រវឹងហើយនៅខ្លួន
អាក្រាតវិញ។[22]ជនជាតិក្រុងស៊ីយ៉ូនអើយ ទោសនៃអំពើទុច្ចរិតរបស់អ្នកគ្រប់ចំនួនហើយ ព្រះអង្គនឹងមិនបន្តឲ្យអ្នកទៅជាឈ្លើយឡើយ តែគឺជាជនជាតិអេដុមវិញ ព្រះអង្គ
នឹងធ្វើទោសចំពោះអំពើទុច្ចរិតរបស់អ្នកវិញ ព្រះអង្គនឹងមិនគ្របបាំងអំពើបាបរបស់អ្នកឡើយ។

Lamentations 4:1
ព័ត៌មានទូទៅ៖
កំណាព្យថ្មីមួយចាប់ផ្តើម។
ថ្មបរិសុទ្ធ
ថ្មដែលធ្វើជាប្រាសាទ
គ្រប់ទីកន្លែង ទាំងនៅតាមផ្លូវ

generated on Wed Sep 10 16:16:32 2025

សូមមើលការបកប្រែនៅក្នុងជំពូក ២:១៨
កូនប្រុសនៃអ៊ីស្រាអែល
អាចមានន័យថា ១) យុវជនក្រុងយេរូសាឡឹម ឬ ២)
ប្រជាជនទាំងអស់នៅក្រុងយេរូសាឡឹម។
ពួកគេគ្មានតំលៃជាជាងក្អមដីឡើយ ដូចជាកិច្ចការរបស់ជាងស្មូនដូច្នេះ!
ការបកប្រែផ្សេងទៀត
«មនុស្សចាត់ទុកពួកគេថាគ្មានតម្លៃដូចពាងដីឥដ្ឋដែលជាងស្មូនធ្វើ!»
Lamentations 4:3
ឆ្កែព្រៃ ក៏ចេះបំបៅដោះឲ្យកូនដែរ
មានន័យថាមេឆ្កែព្រៃអនុញ្ញាតឲ្យកូនវាបៅដោយសេរី។
ឆ្កែព្រៃ
ឆ្កែព្រៃដ៏សាហាវ គឺជាសត្វមិនស្អាត
ប្រជាជនខ្ញុំ
នេះជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
សូមមើលការបកប្រែនៅជំពូក ២:១១ ។
Lamentations 4:4
ពួកអ្នកដែលធ្លាប់ស្លៀកពាក់រុងរឿង
ការស្លៀកសម្លៀកបំពាក់ពណ៌ក្រហម គឺជាសញ្ញាមួយដែលបង្ហាញថា
មនុស្សម្នាក់នឹងជាអ្នកមាន។
Lamentations 4:6
អំពើទុច្ចរិត
អាចមានន័យថា ១) «ទណ្ឌកម្មសម្រាប់អំពើបាប» ឬ ២) « បាប» ។
ជនជាតិខ្ញុំ
នេះគឺជាឈ្មោះក្រុងយេរូសាឡឹម ដែលត្រូវបានគេនិយាយនៅទីនេះដូចជាស្ត្រីម្នាក់។
ត្រូវបានបំផ្លាញក្នុងមួយរំពេច
«ព្រះជាម្ចាស់បានបំផ្លាញវាចោលមួយភ្លែត»
ឥតមានដៃអ្នកណាមកជួយទាន់ឡើយ
«ទោះបីជាគ្មាននរណាម្នាក់ជួយនាងក៏ដោយ»
Lamentations 4:7
ពួកអ្នកដឹកនាំជាមនុស្ស ដែលបរិសុទ្ធជាងហិម:
អាចមានន័យថា ១) «មេដឹកនាំរបស់យើងពីមុនមើលទៅស្រស់ស្អាត»
ដោយសារពួកគេមានសុខភាពល្អ ឬ ២) ប្រជាជនស្រឡាញ់មេដឹកនាំរបស់ពួកគេ
ពីព្រោះមេដឹកនាំមានសីលធម៌ស្អាតស្អំ ដូចព្រិលនិងទឹកដោះគោថ្មីសុទ្ធ។
ពួកអ្នកដឹកនាំជាមនុស្ស
មេដឹកនាំក្រុងយេរូសាឡឹម
ក្រហម
មើលទៅមានសុខភាពល្អ
ត្បូងទទឹម
ជាវត្ថុក្រហមរឹងដែលកើតចេញពីមហាសមុទ្រ ប្រើដូចជាគ្រឿងអលង្ការ
ត្បូងកណ្តៀង
ថ្មខៀវដែលមានតម្លៃថ្លៃប្រើក្នុងគ្រឿងអលង្ការ
ឥឡូវនេះ រូបរាងរបស់គេខ្មៅជាងធ្យូង
អាចមានន័យថា ១) ដែលព្រះអាទិត្យបានធ្វើឲ្យស្បែករបស់មេដឹកនាំងងឹតឬ ២)
ធ្យូងពីភ្លើងដែលបានដុតក្រុងយេរូសាឡឹម បានគ្របលើមុខពួកគេ។
គ្មានអ្នកណាស្គាល់គេ
ការបកប្រែផ្សេងទៀត «គ្មាននរណាម្នាក់អាចស្គាល់ពួកគេបានទេ»
ស្បែកជាប់នឹងឆ្អឹង ស្វិតក្រៀមដូចជារំកាច់ឈើ
ដោយសារតែពួកគេមិនមានអាហារនិងទឹកគ្រប់គ្រាន់
Lamentations 4:9
អស់អ្នកដែលស្លាប់ដោយមុខដាវ
ការបកប្រែផ្សេងទៀត «អ្នកដែលស្លាប់ដោយសារទាហានសត្រូវសម្លាប់»
ពួកអ្នក ដែលស្លាប់ដោយស្រេកឃ្លាន
ការបកប្រែផ្សេងទៀត «អ្នកដែលស្រេកឃ្លានរហូតដល់ស្លាប់»
ដែលវិនាសបន្តិចម្តងៗទៅ
ការបកប្រែផ្សេងទៀត
«អ្នកដែលស្គមហើយខ្សោយពីព្រោះពួកគេស្លាប់ដោយអត់អាហារ»
ដោយ ភាពខ្វះខាតស្បៀងអាហារ
កង្វះអាហារត្រូវបានគេនិយាយនៅទីនេះវាដូចជាដាវ។ ការបកប្រែផ្សេងទៀត
«អ្នកណាស្លាប់ដោយការឃ្លាន»
មនុស្សស្រីដែលធ្លាប់មានចិត្តទន់សន្តោស
ការបកប្រែផ្សេងទៀត «មនុស្សស្រីដែលធ្លាប់មានចិត្តទន់សន្តោស»
Lamentations 4:11
ព្រះអម្ចាស់បង្ហាញសេចក្តីក្រោធយ៉ាងខ្លាំង ព្រះអង្គបានចាក់សេចក្តីកំហឹងដ៏សហ័សរបស់ទ្រង់
ព្រះអម្ចាស់ព្រះពិរោធយ៉ាងខ្លាំង ហើយព្រះអង្គបានធ្វើអ្វីគ្រប់យ៉ាង
ដែលព្រះអង្គចង់ធ្វើ ដើម្បីបង្ហាញថា ទ្រង់ព្រះពិរោធ។
ព្រះអង្គបានចាក់សេចក្តីកំហឹងដ៏សហ័សរបស់ទ្រង់
សេចក្តីក្រោធរបស់ព្រះជាម្ចាស់គឺដូចជាអង្គធាតុរាវដែលកំពុងឆេះ។
ព្រះអង្គបានបង្កាត់ភ្លើងដុតក្រុងស៊ីយ៉ូន
នេះអាចមានន័យថា ១)
សេចក្តីក្រោធរបស់ព្រះជាម្ចាស់គឺដូចជាភ្លើងដែលបំផ្លាញក្រុងយេរូសាឡឹមឬ ២)
ព្រះជាម្ចាស់បានធ្វើឲ្យសត្រូវដុតក្រុងយេរូសាឡឹមដោយភ្លើង។
Lamentations 4:12
ពួកស្តេចទាំងឡាយនៅផែនដី ព្រមទាំងមនុស្សដែលនៅក្នុងពិភពលោកនេះ គេមិនបានជឿ
«គ្មានអ្នកណាជឿលើគេបានទេ»
ពួកបច្ចាមិត្ត និងពួកខ្មាំងសត្រូវ
ពាក្យទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា ហើយបញ្ជាក់ថាទាំងនេះ
គឺជាមនុស្សដែលចង់ធ្វើបាបក្រុងយេរូសាឡឹម។ ការបកប្រែផ្សេងទៀត
«សត្រូវប្រភេទណាមួយ»
អំពើបាបរបស់ពួកព្យាការី និងអំពើទុច្ចរិតរបស់ពួកបូជាចារ្យ
ខ្សែទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលនិងសង្កត់ធ្ងន់ថា
អ្នកដឹកនាំខាងវិញ្ញាណទាំងនេះ មានទំនួលខុសត្រូវខ្ពស់
ចំពោះការដួលរលំនៃក្រុងយេរូសាឡឹម។ ការបកប្រែផ្សេងទៀត
«អំពើបាបដ៏គួរអោយខ្លាចរបស់ពួកព្យាការី និងបូជាចារ្យរបស់នាង»
ពួកអ្នកដែលបានកម្ចាយឈាម មនុស្សសុចរិត
ទាំងបូជាចារ្យនិងពួកព្យាការីសុទ្ធតែមានទោសពីបទឃាតកម្ម។
ការបកប្រែផ្សេងទៀត «អ្នកដែលបានសម្លាប់មនុស្សសុចរិត»
Lamentations 4:14
គេប្រឡាក់សុទ្ធតែឈាម
ដោយសារពួកគេបានធ្វើឃាតកម្ម
ពួកគេជាមនុស្សស្មោកគ្រោកមិនអាចគោរពបូជាព្រះឬនៅជាមួយមនុស្សសាមញ្ញបានឡើយ។
Lamentations 4:16
កម្ចាត់កម្ចាយគេ
ខ្ចាត់ខ្ចាយពួកព្យាការី និងបូជាចារ្យ
មិនព្រមទតមើលគេទៀតទេ
«មិនបន្តទទួលយកពួកគេទៀតទេ» ឬ «លែងយល់ព្រមនឹងពួកគេទៀត»
Lamentations 4:17
ភ្នែករបស់យើងឡើងផ្សា ដោយទន្ទឹងរង់ចាំជំនួយ
អាចមានន័យថា ១) ពួកគេបានស្វែងរកមនុស្សដើម្បីជួយពួកគេ
ប៉ុន្តែគ្មានជំនួយណាមកទេឬ ២) ពួកគេនៅតែស្វែងរកជំនួយពីមនុស្ស
ដែលមិនធ្លាប់មានលទ្ធភាពជួយពួកគេដដែល។
គេដេញតាមយើងគ្រប់ជំហាន
ការបកប្រែផ្សេងទៀត
«សត្រូវរបស់យើងបានតាមយើងគ្រប់ទីកន្លែងដែលយើងទៅ»
ទីបញ្ចប់របស់យើង
ការបកប្រែផ្សេងទៀត «ពេលវេលាសម្រាប់ពួកយើងត្រូវស្លាប់»
Lamentations 4:19
ខ្យល់ដង្ហើមដែលដកតាមរន្ធច្រមុះ
នេះគឺជាឋានៈរបស់ព្រះរាជា ដែលផ្តល់ជីវិតដល់ប្រជាជនរបស់ទ្រង់
ដូចជាដង្ហើមជួយអោយរាងកាយមានជីវិត។
ត្រូវគេចាប់ចូលក្នុងអង្គប់
នៅទីនេះ «អង្គប់» សំដៅទៅលើអន្ទាក់របស់សត្រូវ
ផែនការរបស់ពួកគេដើម្បីចាប់ស្តេច។ ការបកប្រែផ្សេងទៀត
«ខ្មាំងសត្រូវបានរៀបចំគំរោងដើម្បីចាប់ស្តេចរបស់យើង
ហើយពួកគេបានចាប់ទ្រង់»
Lamentations 4:21
ចូរមានចិត្តរីករាយ ហើយសប្បាយឡើង
ពាក្យទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នានិងបញ្ជាក់ពីតង់ស៊ីតេនៃភាពរីករាយ។
អ្នកនិពន្ធប្រើពាក្យទាំងនេះមើលងាយ។ ការបកប្រែផ្សេងទៀត «រីករាយណាស់» ។

generated on Wed Sep 10 16:16:32 2025

ជនជាតិក្រុងស៊ីយ៉ូនអើយ...ប្រជាជាតិ អេដុម
ទាំងនេះគឺជាឈ្មោះសម្រាប់ប្រជាជនក្រុងយេរូសាឡឹម
និងស្រុកអេដុមដែលត្រូវបានគេនិយាយនៅទីនេះដូចជាពួកគេជាស្ត្រីម្នាក់។
ដ្បិតអ្នកត្រូវទទួលពែងនៃទុក្ខលំបាក
ស្រាដែលមនុស្សនឹងផឹកពីពែងនេះជានិមិត្តរូបនៃកំហឹងរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត «ព្រះអម្ចាស់នឹងវិនិច្ឆ័យទោសអ្នកដែរ» ។
ព្រះអង្គនឹងមិនបន្តឲ្យអ្នកទៅជាឈ្លើយឡើយ
នៅទីនេះពាក្យ «ព្រះអង្គ» សំដៅទៅលើព្រះអម្ចាស់។
មិនគ្របបាំងអំពើបាបរបស់អ្នកឡើយ
«លាតត្រដាងអំពើបាបរបស់អ្នក»

---

5 [1]សូមនឹកចាំពីយើងខ្ញុំព្រះអម្ចាស់ អ្វីដែលកើតមានឡើងដល់យើងរាល់គ្នា ទាំងគេឃើញពីភាពអាម៉ាស់[2]កេរ្តិ៍អាកររបស់យើងក្លាយជារបស់អ្នកដ៏ទៃ ឯផ្ទះសំបែងរបស់
យើងខ្ញុំ ក៏ក្លាយជារបស់ជនបរទេស។[3]យើងក្លាយជាកូនកំព្រាឪពុកម្តាយ ហើយម្តាយយើងទៅជាមេម៉ាយវិញ។[4]យើងត្រូវចំណាយប្រាក់ដើម្បីផឹកទឹករបស់ខ្លួន
ហើយក៏ត្រូវចំណាយប្រាក់សំរាប់ទិញអុសរបស់ខ្លួនឯងដែរ។
[5]អស់ពួកដែលដេញតាមនោះនៅពីក្រោយខ្នងយើងខ្ញុំជានិច្ច យើងខ្ញុំពិតជាអស់កម្លាំង និងឥតមានពេលសម្រាកឡើយ។[6]យើងបានដាក់ខ្លួនទៅសុំពួកជនជាតិអេស៊ីប និង
ពួកជនជាតិអាសស៊ើរ ដើម្បីឲ្យបានអាហារបរិភោគគ្រប់គ្រាន់។[7]ដូនតារបស់យើងបានធ្វើបាប តែគាត់បានស្លាប់អស់ហើយ ដោយព្រោះកំហុសគាត់បានសាង
យើងខ្ញុំត្រូវរងទ្រាំវិញ។
[8]ពួកអ្នកបម្រើបានធ្វើជាចៅហ្វាយលើយើងខ្ញុំ ឥតមានអ្នកណានឹងរំដោះយើងខ្ញុំ ឲ្យរួចពីកណ្តាប់ដៃគេឡើយ។[9]យើងខ្ញុំរកអាហារបានដោយប្រថុយជីវិត ចំពោះមុខដាវនៅទី
រហោស្ថាន។[10]ស្បែកយើងខ្ញុំក្តៅដូចជាជើងក្រាន ព្រោះតែការអត់ឃ្លាន។
[11]ពួកស្ត្រីត្រូវបានគេចាប់រំលោភនៅក្រុងស៊ីយ៉ូន និងពួកក្រមុំៗនៅតាមទីក្រុងក្នុងទឹកដីយូដា។[12]ឯពួកចៅហ្វាយត្រូវបានគេចងដៃព្យួរ ហើយគ្មាននរណាគោរពចាស់ទុំ
ទៀតទេ។
[13]ពួកយុវជនត្រូវបានបង្ខំឲ្យលីសែងត្បាល់កិន ហើយគេប្រើកូនក្មេងឲ្យលីឈើដ៏ធ្ងន់ រហូតដល់ជំពន់ដួល។[14]លែងមានពួកព្រឹទ្ធាចារ្យនៅទ្វារក្រុងទៀតហើយ
រីឯពួកយុវជនក៏ឈប់លេងភ្លេងទៀតដែរ។
[15]អំណរបានចាកចេញបាត់ពីចិត្តខ្ញុំហើយ រីឯការលោតកញ្ឆេងរបស់យើងខ្ញុំ ក៏ត្រឡប់ទៅជាការសោយសោកវិញ។[16]មកុដបានធ្លាក់ចុះពីក្បាលយើង វរហើយ ព្រោះខ្ញុំបានធ្វើ
បាប!។
[17]ហេតុនេះបានជាចិត្តខ្ញុំខ្លោចផ្សា ហើយភ្នែកយើងខ្ញុំក៏ត្រឡប់ទៅជាងងឹត ដោយព្រោះការទាំងនេះដែរ[18]ដ្បិតភ្នំស៊ីយ៉ូនត្រូវចោលស្ងាត់ មានតែឆ្កែចចកដើរប៉ុណ្ណោះ។
[19]ប៉ុន្តែព្រះអង្គ គឺជាព្រះអម្ចាស់ ដែលគង់នៅអស់កល្បជានិច្ច បល្ល័ង្ករបស់ព្រះអង្គស្ថិតស្ថេរ ពីតំណមនុស្សមួយ ទៅតំណមនុស្សមួយទៀត។[20]ហេតុអ្វីបានជាព្រះអង្គភ្លេច
យើងខ្ញុំរហូត? ហេតុអ្វីព្រះអង្គបោះបង់ចោលយើងយូរយ៉ាងនេះ?[21]សូមនាំយើងខ្ញុំឲ្យវិលមកវិញ ព្រះអម្ចាស់អើយ នោះយើងខ្ញុំនឹងបានស្តាឡើងវិញ សូមកែជីវិតរបស់យើង
ដូចកាលពីដើម[22]ឬក៏ព្រះអង្គបានបោះបង់ចោលយើងខ្ញុំហើយ តើព្រះអង្គខ្ញាល់នឹងយើងខ្ញុំហួសកម្រិតបែបនេះរឹ។

Lamentations 5:1
ព័ត៌មានទូទៅ៖
កំណាព្យថ្មីមួយចាប់ផ្តើម។
សូមនឹកចាំ
«គិតអំពី»
ឃើញពីភាពអាម៉ាស់
«មើលស្ថានភាពគួរឲ្យអាម៉ាសដែលយើងកំពុងស្ថិតនៅ»
កេរ្តិ៍អាកររបស់យើងក្លាយជារបស់អ្នកដ៏ទៃ
«អ្នកបានអនុញ្ញាតឲ្យជនចម្លែកចូលកាន់កាប់មរតករបស់យើង»
ឯផ្ទះសំបែងរបស់យើងខ្ញុំ ក៏ក្លាយជារបស់ជនបរទេស
«អ្នកបានអនុញ្ញាតឲ្យជនបរទេសកាន់កាប់ផ្ទះរបស់យើង»
យើងក្លាយជាកូនកំព្រាឪពុកម្តាយ...ម្តាយយើងទៅជាមេម៉ាយវិញ
ប្រជាជននៅក្រុងយេរូសាឡឹម គ្មាននរណាការពារពួកគេទេ
ពីព្រោះពួកគេបានស្លាប់ដោយការប្រយុទ្ធ ឬបាននិរទេសទៅ។
យើងត្រូវចំណាយប្រាក់ដើម្បីផឹកទឹករបស់ខ្លួន
«យើងត្រូវបង់លុយអោយសត្រូវរបស់យើង ដើម្បីផឹកទឹករបស់ខ្លួនឯង»
ត្រូវចំណាយប្រាក់សំរាប់ទិញអុសរបស់ខ្លួនឯងដែរ
«សត្រូវរបស់យើងលក់ឈើរបស់យើងឲ្យយើងវិញ» (សូមមើល figs activepssicve)
Lamentations 5:5
អស់ពួកដែលដេញតាម
កងទ័ពបាប៊ីឡូន។
បានដាក់ខ្លួនទៅសុំ
ការបកប្រែផ្សេងទៀត «បានធ្វើសន្ធិសញ្ញាជាមួយ» ឬ «ចុះចាញ់»
បានអាហារបរិភោគគ្រប់គ្រាន់
ការបកប្រែផ្សេងទៀត «ដូច្នេះយើងនឹងមានអាហារបរិភោគ»
តែគាត់បានស្លាប់អស់ហើយ
ការបកប្រែផ្សេងទៀត «ពួកគេបានស្លាប់ហើយ»
ដោយព្រោះកំហុសគាត់បានសាង យើងខ្ញុំត្រូវរងទ្រាំវិញ
ការបកប្រែផ្សេងទៀត «យើងទទួលទោសចំពោះអំពើបាបរបស់ពួកគេ»
Lamentations 5:8
ពួកអ្នកបម្រើបានធ្វើជាចៅហ្វាយលើយើងខ្ញុំ
អាចមានន័យថា ១)
«ប្រជាជនដែលគ្រប់គ្រងលើយើងគឺជាទាសកររបស់ម្ចាស់គេនៅឯស្រុកបាប៊ីឡូន» ឬ ២)
«មនុស្សដែលធ្លាប់ធ្វើជាទាសករនៅស្រុកបាប៊ីឡូនឥឡូវនេះគ្រប់គ្រងលើយើងហើយ» ។
រំដោះយើងខ្ញុំ ឲ្យរួចពីកណ្តាប់ដៃគេ
ត្រង់នេះពាក្យថា «ដៃ» សំដៅទៅលើអំណាច។ ការបកប្រែផ្សេងទៀត
«ដើម្បីជួយសង្គ្រោះយើងពីអំណាចរបស់ពួកគេ»
ចំពោះមុខដាវនៅទីរហោស្ថាន
ការបកប្រែផ្សេងទៀត
[13]ក្រោយមកអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់ ក្នុងកាលដែលសេចក្តីសម្លាប់របស់គេ បានដេកកណ្តាលរូបព្រះរបស់គេ នៅជុំវិញអាសនា លើគ្រប់ទាំងជ្រលោងគ្រប់
ទាំងកំពូលភ្នំ ហើយក្រោមគ្រប់ទាំងដើមជ្រៃ និងនៅក្រោមដើមម៉ៃសាក់ ជាកន្លែងដែលគេបានដុតគ្រឿងក្រអូប ថ្វាយដល់រូបព្រះនោះរបស់គេ។[14]យើងនឹងលូកដៃទៅលើគេ
និងធ្វើឲ្យទឹកដីគេត្រូវខូចបង់ ហើយបោះបង់ចោល ពីទីរហោស្ថានដែលនៅខាងរីបឡា ទៅតាមគ្រប់ទាំងទីកន្លែងណាដែលគេអាស្រ័យនៅ។ ក្រោយមកគេនឹងដឹងថា យើង
នេះជាព្រះអម្ចាស់»។

Ezekiel 6:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់កំពុងប្រាប់លោកអេសេគាល ឲ្យនិយាយទៅភ្នំដូចជាប្រជាជន
ដូច្នេះប្រជាជនអ៊ីស្រាអែលនឹង ស្តាប់ពាក្យទាំងនោះ
ហើយដឹងថាពាក្យរបស់លោកអេសេគាលគឺសម្រាប់ពួកគេ។
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ
«ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ» ការបកប្រែដូចនៅក្នុងជំពូក ១:១។
កូនមនុស្សអើយ
«កូនប្រុសរបស់មនុស្ស» ឬ «ព្រះរាជបុត្រានៃមនុស្សជាតិ»។
ព្រះជាម្ចាស់ហៅលោកអេសេគាលនេះដើម្បីបញ្ជាក់ថាលោកអេសេគាលគ្រាន់តែជាមនុស្ស
ព្រះមានឫទ្ធានុភាព និងរស់នៅជារៀងរហូតប៉ុន្តែមនុស្សមិនមែនទេ។
ការបកប្រែដូចនៅក្នុងជំពូក ២:១។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សរមែងស្លាប់» ឬ «មនុស្ស»
ចូរបែរមុខទៅភ្នំនៅស្រុកអ៊ីស្រាអែល
«ក្រឡេកមើលទៅលើភ្នំអ៊ីស្រាអែលវិញដោយទឹកមុខក្រហាយ»។
ពាក្យស្រដៀងគ្នានេះលេចចេញនៅក្នុងជំពូក ៤:១
ភ្នំនៅស្រុកអ៊ីស្រាអែល
«ភ្នំនៅក្នុងទឹកដីស្រុកអ៊ីស្រាអែល»។
មើល!
ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់ដ៏ជាព្រះ
ការបកប្រែដូចនៅក្នុងជំពូក ២:៤។
យើងបានយកដាវមកទាស់នឹងអ្នករាល់គ្នា
ពាក្យថា «ដាវ» នៅទីនេះសំដៅលើសង្គ្រាម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងកំពុងនាំសង្គ្រាមមកលើអ្នក» ឬ «យើងនឹងធ្វើសង្គ្រាមប្រឆាំងនឹងអ្នក»។
Ezekiel 6:4
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែល។
រួចហើយ អាសនារបស់អ្នកនឹងត្រូវខូច ហើយបង្គោលរបស់អ្នកនឹងត្រូវបំផ្លាញ
«នឹងលែងមាននរណាមកគោរពបូជានៅលើអាសនៈរបស់អ្នកទៀតហើយ
ខ្ញុំនឹងបោះចោល...ខ្ញុំនឹងដាក់... ហើយខ្ចាត់ខ្ចាយ
ព្រះអម្ចាស់បានមានព្រះបន្ទូលអំពីការបញ្ជូនទាហាន
សាកសព
«ប្រជាជនរបស់អ្នកដែលបានស្លាប់»
Ezekiel 6:6
ព័ត៌មានទូទៅ:
ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់ប្រជាជនអ៊ីស្រាអែល។
ទីក្រុងទាំងនោះនឹងត្រូវវិនាស
«ពួកសត្រូវនឹងបំផ្លាញក្រុងរបស់អ្នក»។
ពួកគេនឹងត្រូវបាក់បែក
«អាសនៈរបស់អ្នកនឹងត្រូវបាក់បែក» ឬ «កងទ័ពសត្រូវនឹងបំបែកពួកគេ»។
បង្គោលរបស់អ្នកដួលរលំ
«ពួកគេនឹងកាត់បន្ថយសរសរគ្រឹះរបស់អ្នក»។ សូមមើលពីរបៀបដែលអ្នកបកប្រែ
«សសរគ្រឹះ» នៅក្នុង ជំពូក ៦:៤។
កិច្ចការរបស់អ្នកត្រូវបោះចោល
«គ្មាននរណាម្នាក់នឹងចងចាំនូវអ្វីដែលអ្នកបានធ្វើ»
សេចក្តីសម្លាប់នឹងធ្លាក់មកក្នុងចំណោមអ្នក
«អ្នកនឹងឃើញសត្រូវសម្លាប់មនុស្សជាច្រើន»
ដឹងថាយើងគឺជាព្រះអម្ចាស់
អត្ថន័យដែលអាចមានគឺ ១) «ដឹងថាតើយើងដែលជាព្រះអម្ចាស់» ឬ ២)
«យល់ថាយើងជាព្រះអម្ចាស់ជាព្រះពិតតែមួយ ឬ៣)
«ដឹងថាយើងជាព្រះអម្ចាស់មានអំណាចធ្វើអ្វីៗដែលយើងបាននិយាយ ខ្ញុំនឹងធ្វើ»។
(UDB)
Ezekiel 6:8
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែល។
ដែលរួចពីដាវ
«អ្នកខ្លះដែលមិនត្រូវបានសម្លាប់ក្នុងសមរភូមិ»។
ដាវតំណាងឲ្យត្រូវបានសម្លាប់នៅក្នុងសង្គ្រាម។
កាលដែលអ្នករាល់គ្នាត្រូវខ្ចាត់ខ្ចាយទៅតាមប្រទេសផ្សេងៗ
«នៅពេលអ្នកទៅរស់នៅក្នុងប្រទេសផ្សេងៗគ្នា»
ដែលត្រូវចាប់ទៅជាឈ្លើយ ដែលយើងបានស្តាយ ដោយចិត្តមិនប្រកាន់របស់គេ ដែលបានបែរចេញ
ពីយើងទៅ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីជនជាតិអ៊ីស្រាអែលប្រៀបដូចជាស្ត្រីដែលដេកជាមួយមនុស្សជាច្រើន។
ការបកប្រែរបៀបផ្សេងទៀត: «យើងសោកស្តាយណាស់
ព្រោះពួកគេដូចជាប្រពន្ធដែលបានទុកឲ្យយើងដេកជាមួយបុរសដទៃទៀត»
ព្រមទាំងភ្នែកពេស្យាតាមរូបរបស់ព្រះរបស់គេ
ព្រះអម្ចាស់មានព្រះបន្ទូលអំពីជនជាតិអ៊ីស្រាអែលដូចជាពួកគេរៀបការជាមួយស្ត្រីដែលសម្លឹងមើលបុរសឯ
ហើយចង់រួមដំណេកជាមួយពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយដោយវិធីដែលពួកគេចង់បានយ៉ាងខ្លាំងដើម្បីគោរពបូជារូបព្រះ»
រួចហើយគេនឹងមើលខ្លួន ដោយខ្ពើមឆ្អើម ព្រោះអំពើអាក្រក់ដែលគេបានប្រព្រឹត្ត
អត្ថន័យដែលអាចមានគឺ ១) «ពួកគេនឹងស្អប់ខ្លួនឯង
ដោយសារតែអំពើអាក្រក់ដែលពួកគេបានធ្វើ» ឬ ២)
«ពួកគេនឹងស្អប់អំពើអាក្រក់ដែលពួកគេបានធ្វើ»។ ការបកប្រែរបៀបផ្សេងទៀត:
«មុខរបស់ពួកគេនឹងបង្ហាញការស្អប់ចំពោះអំពើអាក្រក់ ដែលពួកគេបានធ្វើ»។
Ezekiel 6:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់លោកអេសេគាល។
ព្រះអម្ចាស់
ការបកប្រែដូចនៅក្នុងជំពូក ២:៤។
ចូរទះដៃ ហើយតន្ត្រាំជើង
លោកអេសេគាលត្រូវធ្វើសកម្មភាពជានិមិត្តសញ្ញាដើម្បីទទួលបានការចាប់អារម្មណ៍ពីប្រជាជន។
នេះមិនមែនជាការទះដៃទេ។
បពិត្រ
ពាក្យថា «បពិត្រ» ត្រូវបានប្រើដើម្បីបង្ហាញភាពសោកសៅ។
ពូជពង្សអ៊ីស្រាអែល
ពាក្យថា «ផ្ទះ» គឺជាពាក្យប្រៀបធៀបសម្រាប់គ្រួសារដែលរស់នៅក្នុងផ្ទះ
ដូចជនជាតិអ៊ីស្រាអែលដែលជាកូនចៅរបស់យ៉ាកុបអស់រយៈពេលជាច្រើនឆ្នាំ។
ការបកប្រែរបៀបផ្សេងទៀត: «ក្រុមប្រជាជនអ៊ីស្រាអែល»
ការបកប្រែដូចនៅក្នុងជំពូក ៣:១។
ដ្បិតពួកគេនឹងត្រូវដួលដោយដាវ ដោយគ្រោះទុរ្ភិក្ស និងដោយអាសន្នរោគ។
«ដ្បិត គេនឹងស្លាប់ដោយដាវទុរ្ភិក្ស និងគ្រោះកាច»។ «ដាវ» «ទុរ្ភិក្ស» និង
«គ្រោះកាច» គឺជាវិធីផ្សេងៗដែលពួកគេនឹងត្រូវស្លាប់។ ពាក្យថា «ដាវ»
តំណាងឲ្យសង្គ្រាម។
យើងនឹងតាំងសេចក្តីកំហឹងរបស់យើងទាស់នឹងពួកគេ។
«យើងនឹងបំពេញកំហឹងរបស់យើងចំពោះពួកគេ»
Ezekiel 6:13
ព័ត៌មានទូទៅ :
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែល។
អ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់
អត្ថន័យដែលអាចមានគឺ ១) «ដឹងថាតើយើងដែលជាព្រះអម្ចាស់ ឬ ២)
«យល់ថាយើងជាព្រះយេហូវ៉ាជាព្រះពិត» ឬ ៣)
«ដឹងថាយើងជាព្រះអម្ចាស់ដែលបានធ្វើរឿងនេះ» (UDB) ។
នៅជុំវិញអាសនា លើគ្រប់ទាំងជ្រលងភ្នំ
អត្ថន័យមួយទៀតគឺ «នៅជុំវិញអាសនារបស់ពួកគេដែលស្ថិតនៅលើភ្នំខ្ពស់ៗ»
កំពូលភ្នំ ហើយក្រោមគ្រប់ទាំងដើមជ្រៃ នឹងនៅក្រោមដើមម៉ៃសាក់
អត្ថន័យមួយទៀតគឺ «ជ្រលងភ្នំនៅលើកំពូលភ្នំទាំងអស់
ទាំងនៅក្រោមដើមឈើដុះលូតលាស់ និងនៅក្រោមដើមឈើម៉ៃសាក់»។
រីកចំរើន
មានសុខភាពល្អ និងរីកលូតលាស់
ដើមឈើធំមួយដែលមានឈើរឹងមាំដែលផ្តល់ម្លប់ដល់អ្នកគោរពបូជា
ខាងរីបឡា
អត្ថបទដើមខ្លះនិយាយថារីបឡា។ នេះជាឈ្មោះទីក្រុងមួយនៅភាគខាងជើង។

---

7 [1]ព្រះបន្ទូលនៃព្រះអម្ចាស់មកដល់ខ្ញុំដោយបន្ទូលថា[2]«អ្នក កូនមនុស្សអើយ ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដល់ ស្រុកអ៊ីស្រាអែល» ត្រូវបញ្ចាប់! ត្រូវបញ្ចាប់
កំពុងតែចូលមកតាមទិសទាំងបួន។
[3]ពេលបញ្ចប់បានមកដល់លើមក ដ្បិតយើងនឹងចាត់កំហឹងទៅលើអ្នក ហើយយើងនឹងវិនិច្ឆ័យទោសអ្នក តាមអំពើដែលអ្នកប្រព្រឹត្ត រួចហើយយើងនឹងដាក់ទោសអ្នក ព្រោះ
តែព្រះដ៏គួរស្អប់ខ្ពើមរបស់អ្នក។[4]ដ្បិតភ្នែករបស់យើងនឹងមិនអាណិតមេត្តាអ្នកទេ ហើយយើងនឹងមិនទុកអ្នកទេ។ ផ្ទុយទៅវិញ យើងនឹងនាំការអាក្រក់ដែលអ្នក
បានធ្វើមកលើអ្នក និងការគួរស្អប់ខ្ពើមនៅក្នុងចំណោមរបស់អ្នក ដូច្នោះ អ្នករាល់គ្នានឹងដឹងថា យើងគឺជាព្រះអម្ចាស់»។
[5]ព្រះអម្ចាស់ដ៏ជាព្រហមានព្រះបន្ទូលដូច្នេះ «មហន្តរាយ!មហន្តរាយមួយ! មើល៍ វាកំពុងតែមកហើយ។[6]គ្រាចុងក្រោយនឹងមកដល់ជាពិត។ ពេលបញ្ចប់មកទាស់នឹងអ្នក។
មើល៍វាកំពុងតែមកហើយ![7]សេចក្តីវិនាសរបស់អ្នកមកដល់ហើយ ដែលជាអ្នករស់នៅលើទឹកដី។ ពេលនោះនឹងមកដល់ គឺជាថ្ងៃនៃការបំផ្លាញជិតមកដល់
ហើយតំបន់ភ្នំនឹងមិនមានភាពរីករាយទៀតឡើយ។
[8]ឥឡូវនេះជិតមកដល់ហើយ យើងនឹងចាក់កំហឹងរបស់យើង លើអ្នក ហើយយើងនឹងបំពេញលើអ្នកតាមកំហឹងរបស់យើង ពេលយើងដាក់ទោសអ្នកតាមការដែលអ្នកធ្វើដ៏
គួរស្អប់ខ្ពើមរបស់អ្នក។[9]ដ្បិតភ្នែកយើងនឹងមិនអាណិតមេត្តា ហើយយើងក៏មិនត្រាប្រណីអ្នកដែរ។ ដូចអ្វីដែលធ្លាប់បានធ្វើ យើងនឹងធ្វើការនេះដល់អ្នក ហើយការគួរខ្ពើម
របស់អ្នកវានឹងនៅកណ្តាលអ្នក ដូច្នោះ អ្នកនឹងដឹងថា យើងនេះហើយជាព្រះអម្ចាស់ដែលជាអ្នកជំនុំជម្រះអ្នក។

generated on Wed Sep 10 16:16:32 2025

[10]មើល៍! ថ្ងៃនោះ! មើល៍ វាកំពុងមកដល់ហើយ! សេចក្តីវិនាសបានចេញមកហើយ! ដំបងបានចេញផ្កា ភាពក្រអឺតក្រទមចេញផ្កាក្រពុំ![11]អំពើហិង្សាក៏កើនឡើង
ដល់ដំបងនៃការអាក្រក់ គ្មានពួកគេណា ហើយក៏គ្មានមនុស្សកកកុញ ក៏គ្មានទ្រព្យសម្បត្តិរបស់គេ ហើយក៏គ្មានអ្វីដែលសំខាន់អាចមានទៀតដែរ!
[12]ពេលវេលានឹងមកដល់ ថ្ងៃនោះជិតមកដល់ហើយ។ កុំឲ្យទិញបានរីករាយឡើយ កុំឲ្យអ្នកលក់មិនត្រូវកាន់ទុក្ខដែរ ចាប់តាំងកំហឹងរបស់យើងចូលដល់មនុស្សជាច្រើន!
[13]ដ្បិតអ្នកលក់ពុំអាចប្រមូលយកអ្វីៗដែលខ្លួនបានលក់យកមកវិញបានឡើយ ទោះបីគេនៅមានជីវិតក៏ដោយ ចាប់តាំងពីសេចក្តីនេះបានប្រកាសទាស់ជាមួយមនុស្ស។
ពួកគេនឹងមកវិញ ដ្បិតនឹងគ្មានមនុស្សណាអាចរស់ក្នុងអំពើបាបរបស់គេបានចំរើនឡើង នោះទេ !
[14]ពួកគេបានផ្លុំត្រែ ហើយបានត្រៀមគ្រប់យ៉ាងជាស្រេច តែគ្មានអ្នកណាចេញទៅតស៊ូឡើយ ចាប់តាំងពីកំហឹងរបស់យើង គ្របដណ្តប់លើពួកមនុស្សទាំងអស់។[15]
ដាវបាននៅខាងក្រៅ ហើយមានអាសន្នរោគ និងគ្រោះទុរ្ភិក្សនៅក្នុងផ្ទះ។ អ្នកណាដែលនៅទីវាល នឹងត្រូវស្លាប់ដោយដាវ ហើយអ្នកដែលនៅក្នុងទីក្រុង មានគ្រោះទុរ្ភិក្ស និង
អាសន្នរោគនឹងសម្លាប់គេ។[16]ប៉ុន្តែ ពួកអ្នកដែលរត់រួចបាន នោះនឹងរួចជីវិតទៅនៅតាមលើភ្នំ។ ដូចជាសត្វព្រាបនៅតាមជ្រលងភ្នំ គ្រប់គ្នានឹងយំសោកដោយព្រោះ
អំពើទុច្ចរិតរបស់គេរៀងខ្លួន។
[17]ដៃរបស់ពួកគេនឹងគ្មានកម្លាំង ហើយជង្គង់គ្រប់គ្នានឹងខ្សោយដូចជាទឹក។[18]ហើយពួកគេនឹងស្លៀកសំពត់ធ្មៃ ហើយមានសេចក្តីស្ញែងខ្លាចនឹងគ្របបាំងពួកគេ ហើយសេចក្តី
ខ្មាសនៅលើមុខ ហើយគេនឹងកោរសក់គ្រប់គ្នា។[19]ពួកគេនឹងបោះចោលប្រាក់របស់គេនៅតាមផ្លូវ ហើយមាសក៏គ្មានតម្លៃ។ ទាំងប្រាក់ ទាំងមាសរបស់គេ នឹងជួយគេមិនបាន
ឡើយ នៅថ្ងៃនៃសេចក្តីក្រោធរបស់ព្រះអម្ចាស់ គេនឹងមិនស្កប់ចិត្ត ក៏មិនបានឆ្អែតពោះដោយរបស់នោះដែរ ព្រោះរបស់នោះ ដែលនាំឲ្យគេចំពប់ដួលទៅក្នុងអំពើពើទុច្ចរិត
របស់ខ្លួន។
[20]ក្នុងមោទនភាពរបស់គេ ពួកគេបានតាំងឡើងឲ្យមានភាពស្រស់ស្អាតដោយគ្រឿងលំអរ ហើយពួកគេបានធ្វើរូបព្រះនិងស្វែងរករបស់ដែលគួរឆ្អើម។ ដូច្នេះហើយ យើង
បានធ្វើឲ្យការទាំងនេះរបស់ពួកគេទៅជារបស់មិនស្អាត។[21]ក្រោយមក យើងនឹងប្រគល់ទៅក្នុងកណ្តាប់ដៃ នៃជនជាតិដទៃប្លន់យក និងពួកមនុស្សអាក្រក់នៅផែនដីប្លន់
យកដែរ ហើយពួកគេនឹងរងការប្រមាថផង។[22]បន្ទាប់មក យើងនឹងបែរមុខចេញពីពួកគេ ហើយគេនឹងបង្អាប់ទីកំបាំងរបស់យើងដែរ និងមានចោរប្លន់ចូល
ទៅក្នុងហើយយកអ្វីទាំងអស់។
[23]ចូរធ្វើច្រវាក់ ព្រោះទឹកដីនេះពោពេញដោយការដាក់ទោសនៃឈាម ហើយទីក្រុងពោពេញដោយការឃោរឃៅ។[24]ដូច្នេះ យើងនឹងនាំមនុស្សដែលអាក្រក់បំផុតក្នុងជនជាតិ
ហើយពួកគេចាប់យកផ្ទះរបស់គេ ហើយយើងនឹងបំបាក់អំនួតរបស់មនុស្សខ្លាំងពូកែ ហើយទីបរិសុទ្ធទាំងប៉ុន្មានរបស់គេ នឹងត្រូវអាប់ឱនចុះ![25]ការភ័យខ្លាចនឹងមកសល់!
ពួកគេនឹងស្វែងរកសេចក្តីសុខសាន្ត តែរកមិនបានសោះ។
[26]មហន្តរាយលើមហន្តរាយនឹងមកដល់ ហើយវានឹងក្លាយជាពាក្យចចាមអារាមហើយចចាមអារាមទៀត។ បន្ទាប់មក ពួកគេស្វែងរកនិមិត្តពីពួកព្យាការី ប៉ុន្តែក្រឹត្យវិន័យនឹង
បាត់អស់ ហើយគ្មានការប្រឹក្សាពីចាស់ទុំទៀតដែរ។[27]ស្តេចនឹងកាន់ទុក្ខ ហើយពួកអ្នកដឹងនាំនឹងអស់សង្ឃឹម ក្នុងពេលដែប្រជាជននៅក្នុងទឹកដីត្រូវញ័ររន្ធត់។ ផ្អែកទៅលើការ
ប្រព្រឹត្តរបស់ពួកគេ ហើយនឹងជំនុំជម្រះពួកគេ! យើងនឹងទោសរបស់គេតាមកំរិតរបស់គេ រហូតពួកគេដឹងថា យើងជាព្រះអម្ចាស់»។

Ezekiel 7:1

ព័ត៌មានទូទៅ :

នេះចាប់ផ្តើមការព្យាករណ៍របស់ព្រះអំពីការជំនុំជំរះលើអ៊ីស្រាអែល។

ព្រះបន្ទូលនៃព្រះអម្ចាស់មកដល់ខ្ញុំ

«ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ»។ ការបកប្រែដូចនៅក្នុងជំពូក ១:១។

អ្នក កូនមនុស្សអើយ

«កូនមនុស្សអើយ យើងចង់ឲ្យអ្នកយកចិត្តទុកដាក់ចំពោះអ្វីដែលយើងនឹងនិយាយ»

កូនមនុស្សអើយ

«កូនប្រុសរបស់មនុស្ស» ឬ «កូនប្រុសរបស់មនុស្សជាតិ»។

ព្រះជាម្ចាស់ហៅលោកអេសេគាលនេះដើម្បីបញ្ជាក់ថាលោកអេសេគាល
គ្រាន់តែជាមនុស្សប៉ុណ្ណោះ។ ព្រះមានឫទ្ធានុភាព និងរស់នៅជារៀងរហូត
ប៉ុន្តែមនុស្សមិនមែនទេ។ ការបកប្រែនេះដូចនៅក្នុងជំពូក ២:១។

«មនុស្សរមែងស្លាប់» ឬ «មនុស្ស»

ព្រះអម្ចាស់

ការបកប្រែដូចនៅក្នុងជំពូក ២:៤។

ស្រុកអ៊ីស្រាអែល

«ដល់ប្រជាជនអ៊ីស្រាអែល»។

ត្រូវបញ្ចាប់!

«ទីបញ្ចាប់នឹងមកដល់!»

ចូលមកតាមទិសទាំងបួន

នេះសំដៅទៅលើទឹកដីអ៊ីស្រាអែលទាំងមូល។

Ezekiel 7:3

ព័ត៌មានទូទៅ:

ទាំងនេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់ប្រជាជនអ៊ីស្រាអែល។

ពេលបញ្ចប់បានមកដល់

«ជីវិតរបស់អ្នកត្រូវបានបញ្ចប់» ឬ
«ចុងបញ្ចប់នៃពេលវេលារបស់អ្នកបានមកដល់ហើយ»

តាមអំពើដែលអ្នកប្រព្រឹត្ត

«យោងទៅតាមអ្វីដែលអ្នកធ្វើ» ឬ «ដោយសារតែអំពើអាក្រក់ដែលអ្នកធ្វើ»

យើងនឹងដាក់ទោសអ្នក ព្រោះតែព្រះដ៏គួរស្អប់ខ្ពើមរបស់អ្នក

«យើងនឹងធ្វើឲ្យអ្នកជួបប្រទះផលវិបាកនៃអាកប្បកិរិយាគួរស្អប់ខ្ពើមរបស់អ្នក» ឬ
«យើងនឹងដាក់ទណ្ឌកម្មអ្នកចំពោះការធ្វើរឿង ដែលយើងស្អប់ខ្លាំងណាស់»

គួរស្អប់ខ្ពើម

នៅទីនេះសំដៅទៅលើអាកប្បកិរិយាដែលព្រះស្អប់ខ្ពើម។

ដ្បិតភ្នែករបស់យើងនឹងមិនអាណិតមេត្តាអ្នកទេ

«ដ្បិត យើងនឹងមិនមើលអ្នកដោយសេចក្តីមេត្តាករុណា»

យើងនឹងនាំការអាក្រក់ ដែលអ្នកបានធ្វើមកលើអ្នក

«យើងនឹងធ្វើឲ្យអ្នកជួបប្រទះផលវិបាកនៃអាកប្បកិរិយាអាក្រក់របស់អ្នក» ឬ
«យើងនឹងដាក់ទណ្ឌកម្មអ្នកចំពោះអំពើអាក្រក់ដែលអ្នកធ្វើ» ។

ការគួរស្អប់ខ្ពើមនៅក្នុងចំណោមរបស់អ្នក

«ផលវិបាកនៃអាកប្បកិរិយាគួរស្អប់ខ្ពើមរបស់អ្នកនឹងព័ទ្ធជុំវិញអ្នក» ឬ ២)
«រូបព្រះរបស់អ្នកនឹងនៅជាមួយអ្នក និងគ្មានអំណាច»។

អំពើគួរស្អប់ខ្ពើមនៅទីនេះសំដៅទៅលើការដាក់ទណ្ឌកម្មចំពោះអាកប្បកិរិយាដែលព្រះស្អប់ខ្ពើមឬ
រូបព្រះដែលពួកគេស្អប់ខ្ពើម។ ។

Ezekiel 7:5

ព័ត៌មានទូទៅ:

ទាំងនេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែល។

ព្រះអម្ចាស់

ការបកប្រែដូចនៅក្នុងជំពូក ២:៤។

មហន្តរាយ! មហន្តរាយមួយ! មើល៍ វាកំពុងតែមកហើយ។

ការលាន់មាត់ទាំងនេះគឺមានគោលបំណងធ្វើឲ្យការអនុម័តយ៉ាងខ្លាំង។

ការបកប្រែរបៀបផ្សេងទៀត:

«មើលចុះគ្រោះមហន្តរាយដ៏គួរឲ្យភ័យខ្លាចកំពុងមកដល់ហើយ
ដែលមិនធ្លាប់មាននរណាធ្លាប់មានបទពិសោធពីមុនមក»។

មើល៍

ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។

ការបកប្រែជំនួស៖ «មើល» ឬ «ស្តាប់» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក»។

ពេលបញ្ចប់មកទាស់នឹងអ្នក

ការវិនិច្ឆ័យដែលកំពុងកើតឡើង
គឺត្រូវបានប្រព្រឹត្តដូចជាសត្រូវដែលភ្ញាក់ពីដំណេក។

ភ្នំនឹងមិនមានភាពរីករាយទៀតឡើយ

«ប្រជាជននៅលើភ្នំនឹងមិនមានសេចក្តីរីករាយទៀតទេ»។

Ezekiel 7:8

ព័ត៌មានទូទៅ:

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែល។

ឥឡូវនេះជិតមកដល់ហើយ

«ឆាប់ៗនេះ»

generated on Wed Sep 10 16:16:32 2025

យើងនឹងចាក់កំហឹងរបស់យើង លើអ្នក ហើយយើងនឹងបំពេញលើអ្នកតាមកំហឹងរបស់យើង
ព្រះអម្ចាស់ប្រើពាក្យ «ចាក់ចេញ» និង «បំពេញ»
ដើម្បីប្រៀបធៀបការប្រព្រឹត្តកំហឹងរបស់គាត់ជាមួយនឹងការចាក់ទឹក និងចាក់ពាង។
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋាន
ហើយបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃការដាក់ទណ្ឌកម្មរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងដាក់ទណ្ឌកម្មអ្នកយ៉ាងខ្លាំងព្រោះយើងខឹងខ្លាំងណាស់»។
កំហឹង
«កំហឹង» ឬ «ក្រោធយ៉ាងខ្លាំង»
ដ្បិតភ្នែកយើងនឹងមិនអាណិតមេត្តា
ឃ្លា «ភ្នែកខ្ញុំ» មានន័យថាព្រះជាម្ចាស់ផ្ទាល់។ «ដ្បិត
យើងនឹងមិនមើលដោយមេត្តាករុណា»
មិនត្រាប្រណីអ្នក
«យើងនឹងមិនចាកចេញពីអ្នកដោយគ្មានការដាក់ទណ្ឌកម្ម» ឬ
«យើងនឹងដាក់ទណ្ឌកម្មអ្នក»
ការគួរខ្ពើមរបស់អ្នកវានឹងនៅកណ្តាលអ្នក ដូច្នោះ អ្នកនឹងដឹងថា យើងនេះហើយជាព្រះអម្ចាស់
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៧:៣។
Ezekiel 7:10
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីជនជាតិអ៊ីស្រាអែល។
មើល!
ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
ថ្ងៃនោះ! មើល៍ វាកំពុងមកដល់ហើយ
«ថ្ងៃនៃការដាក់ទណ្ឌកម្មរបស់អ្នកជិតមកដល់ហើយ»។
សេចក្តីវិនាសបានចេញមកហើយ
នេះបង្ហាញពីភាពច្បាស់ថាគ្រោះមហន្តរាយនឹងកើតមានដល់អ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត:
«គ្រោះមហន្តរាយបានចាប់ផ្តើមមកដល់ប្រទេសអ៊ីស្រាអែល» ឬ
«រឿងរ៉ាវគួរឲ្យភ័យខ្លាចបានកើតឡើង»។
ដំបងបានចេញផ្កា ភាពក្រអឺតក្រទមចេញផ្កាក្រពុំ!
«ផ្កាមួយបានចាប់ផ្តើមដុះនៅលើដំបងហើយវាបានរីកធំធាត់ដោយមោទនភាព»។
នៅទីនេះដំបងតំណាងឲ្យអ៊ីស្រាអែល ឬអំពើហឹង្សា។ អត្ថន័យដែលអាចមានគឺ ១)
«ប្រជាជនអ៊ីស្រាអែលមានមោទនភាពខ្លាំងណាស់» ឬ
«ប្រជាជនអ៊ីស្រាអែលបានក្លាយជាមនុស្សឃោរឃៅ
និងមានភាពក្រអឺតក្រទមខ្លាំងណាស់»។
អំពើហិង្សាក៏កើនឡើង ដល់ដំបងនៃការអាក្រក់
«អំពើហឹង្សារបស់ប្រជាជនបាននាំឲ្យពួកគេធ្វើអំពើអាក្រក់កាន់តែច្រើន»
Ezekiel 7:12
ព័ត៌មានទូទៅ :
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីជនជាតិអ៊ីស្រាអែល។
ពេលវេលានឹងមកដល់ ថ្ងៃនោះជិតមកដល់ហើយ
ទាំង «ពេលវេលា» និង «ថ្ងៃ»
សំដៅទៅលើពេលវេលាដែលព្រះនឹងដាក់ទោសប្រជាជនអ៊ីស្រាអែល។
ការបកប្រែជំនួស៖ «ការដាក់ទណ្ឌកម្មរបស់អ៊ីស្រាអែលនឹងកើតឡើងឆាប់ៗនេះ»
សេចក្តីនេះបានប្រកាសទាស់ជាមួយមនុស្ស
«អ្វីដែលព្រះបានបង្ហាញនឹងកើតឡើងដល់ហ្វូងមនុស្ស»
មនុស្សជាច្រើន
មួយចំនួនដ៏ធំនៃប្រជាជន។ ត្រង់នេះវាសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ទោះបីគេនៅមានជីវិតក៏ដោយ
ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែលដែលលក់របស់របរ។
ពួកគេនឹងមកវិញ
«ពួកគេនឹងមិនវិលត្រឡប់ទៅស្រុកអ៊ីស្រាអែលវិញទេ»។
គ្មានមនុស្សណាអាចរស់ក្នុងអំពើបាបរបស់គេបានចំរើនឡើងនោះទេ
ពាក្យថា «ចំរើនឡើង»
សំដៅទៅលើព្រះជាម្ចាស់ជួយមនុស្សម្នាក់បន្តដំណើរទៅមុខនៅពេលដែលអ្វីៗលំបាកពេក
និងថាមពលរាងកាយ។ «គ្មានអ្នកដែលនៅរស់
ដែលមិនគោរពព្រះនឹងត្រូវបានជួយដោយព្រះឡើយ»។
Ezekiel 7:14
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីជនជាតិអ៊ីស្រាអែល។
ពួកគេបានផ្លុំត្រែ
«ពួកគេបានផ្លុំត្រែដើម្បីហៅមនុស្សឲ្យប្រយុទ្ធប្រឆាំងនឹងសត្រូវ»
ដាវបាននៅខាងក្រៅ
ដាវតំណាងឲ្យការប្រយុទ្ធ ឬ សង្គ្រាម។ ការបកប្រែជំនួស៖
«មានការប្រយុទ្ធគ្នានៅខាងក្រៅ»។
មានអាសន្នរោគ និងគ្រោះទុរ្ភិក្សនៅក្នុងផ្ទះ
ពាក្យអគារនេះប្រហែលសំដៅទៅលើទីក្រុង។
ក្នុងទីក្រុង មានគ្រោះទុរ្ភិក្ស និងអាសន្នរោគនឹងសម្លាប់គេ។
នៅទីនេះពាក្យថា «ប្រើប្រាស់» មានន័យថា «បំផ្លាញទាំងស្រុង»។
ការបកប្រែជំនួស៖
«ហើយប្រជាជនភាគច្រើននៅក្នុងទីក្រុងនឹងស្លាប់ដោយសារភាពអត់ឃ្លាន
និងជំងឺ»។
ដូចជាសត្វព្រាបនៅតាមជ្រលងភ្នំ គ្រប់គ្នានឹងយំសោក
ព្រាបធ្វើឲ្យមានសម្លេងរោទ៍ទាប ដែលស្តាប់ទៅដូចជាសម្លេង
ដែលមនុស្សម្នាក់ធ្វើនៅពេលដែលគាត់មានការឈឺចាប់ថេរ ឬសោកសៅ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេទាំងអស់នឹងសោកសៅ ដែលពួកគេនឹងថ្ងូរ
ហើយសម្លេងនឹងដូចជាពួកគេជាហ្វូងសត្វព្រាប»
Ezekiel 7:17
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីជនជាតិអ៊ីស្រាអែល។
ហើយមានសេចក្តីស្ងែងខ្លាចនឹងគ្របបាំងពួកគេ
«ពួកគេនឹងមានការភ័យខ្លាច» ឬ «ហើយពួកគេនឹងភ័យខ្លាចខ្លាំងណាស់»
នៅថ្ងៃនៃសេចក្តីក្រោធរបស់ព្រះអម្ចាស់
«នៅថ្ងៃដែលព្រះអម្ចាស់សំដែងព្រះពិរោធរបស់ព្រះអង្គ» ឬ
«នៅពេលដែលព្រះអម្ចាស់ដាក់ទោសពួកគេ»
គេនឹងមិនស្កប់ចិត្ត ក៏មិនបានឆ្អែតពោះ
«ហើយពួកគេនឹងគ្មានអាហារបរិភោគ»
ដែលនាំឲ្យគេចំពប់ដួលទៅក្នុងអំពើពើទុច្ចរិតរបស់ខ្លួន
អត្ថន័យដែលអាចមានគឺ ១)
«ពីព្រោះការមានមាសនិងប្រាក់ច្រើនបាននាំឲ្យពួកគេធ្វើបាប» ឬ ២)
«ពីព្រោះពួកគេជាមនុស្សអាក្រក់ពួកគេបានប្រព្រឹត្តអំពើបាប
ដែលបង្ហាញថាពួកគេអាក្រក់យ៉ាងណា»។
Ezekiel 7:20
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីជនជាតិអ៊ីស្រាអែល។
ក្រោយមក យើងនឹងប្រគល់ទៅក្នុងកណ្តាប់ដៃ នៃជនជាតិដទៃ
ពាក្យថា «ដៃ» ត្រូវបានប្រើដើម្បីសំដៅទៅលើការគ្រប់គ្រង។
«យើងនឹងប្រគល់រូបចម្លាក់ទាំងនោះទៅក្នុងការគ្រប់គ្រងរបស់មនុស្ស
ដែលពួកគេមិនស្គាល់» ឬ «យើងនឹងប្រគល់រូបចម្លាក់ទាំងនោះដល់មនុស្ស
ដែលពួកគេមិនស្គាល់»
ប្លន់
វត្ថុដែលត្រូវបានគេលួច ឬ យកដោយកម្លាំង
ពួកគេនឹងរងការប្រមាថផង
ជនបរទេស និងមនុស្សអាក្រក់នឹងធ្វើឲ្យរូបព្រះក្លែង
ក្លាយដែលជនជាតិអ៊ីស្រាអែលបានធ្វើ។
យើងនឹងបែរមុខចេញ
«យើងនឹងមិនយកចិត្តទុកដាក់» ឬ «យើងនឹងមើលទៅឆ្ងាយ» ឬ
«យើងនឹងមិនកត់សម្គាល់»
ទីកំបាំងរបស់យើង
«កន្លែងដែលយើងស្រឡាញ់» នេះសំដៅទៅលើព្រះវិហាររបស់ព្រះជាម្ចាស់។
Ezekiel 7:23
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់លោកអេសេគាលអំពីជនជាតិអ៊ីស្រាអែល។
ច្រវាក់ត្រូវបានប្រើដើម្បីទុកទាសករ ឬ អ្នកទោស។
ព្រះមានបន្ទូលដូច្នេះដើម្បីបង្ហាញប្រជាជនថាពួកគេនឹងក្លាយជាទាសករ ឬ
អ្នកទោស។

generated on Wed Sep 10 16:16:32 2025

ទឹកដីនេះពោរពេញដោយការដាក់ទោសនៃឈាម
អត្ថន័យដែលអាចមានគឺ ១) «នៅគ្រប់ទីកន្លែងក្នុងប្រទេស
ព្រះអម្ចាស់កំពុងវិនិច្ឆ័យប្រជាជន ពីព្រោះពួកគេបានសម្លាប់អ្នកដទៃដោយហិង្សា»
២) «តុលាការគ្រប់ទីកន្លែងក្នុងប្រទេសកំពុងសម្លាប់មនុស្ស»។ ពាក្យថា «ឈាម»
នៅទីនេះតំណាងឲ្យការសម្លាប់ និងការស្លាប់។
ទីក្រុងពោរពេញដោយការឃោរឃៅ
«អំពើហឹង្សាកើតឡើងនៅគ្រប់ទីកន្លែងក្នុងទីក្រុង» ឬ
«មនុស្សជាច្រើននៅក្នុងទីក្រុងកំពុងធ្វើអំពើហឹង្សាទៅលើអ្នកដទៃ»
ហើយពួកគេចាប់យកផ្ទះរបស់គេ
«មនុស្សអាក្រក់នឹងរឹបអូសយកស្រុកអ៊ីស្រាអែល»
ហើយយើងនឹងបំបាក់អំនួតរបស់មនុស្សខ្លាំងពូកែ
«យើងនឹងធ្វើអោយមនុស្សមានអំណាចនៅអ៊ីស្រាអែលឈប់មានមោទនភាពចំពោះខ្លួនឯង»
ហើយទីបរិសុទ្ធទាំងប៉ុន្មានរបស់គេ នឹងត្រូវអាប់ឱនចុះ!
«សត្រូវនឹងធ្វើឲ្យស្មោកគ្រោកកន្លែងដែលអ្នកគោរពបូជា»។
ទីបរិសុទ្ធ
កន្លែងដែលពួកគេគោរពបូជារូបព្រះ។
ការភ័យខ្លាចនឹងមកដល់
«ប្រជាជននឹងភ័យខ្លាច»
ពួកគេនឹងស្វែងរកសេចក្តីសុខសាន្ត
«ពួកគេនឹងសង្ឃឹមសម្រាប់សន្តិភាព» ឬ
«ពួកគេនឹងព្យាយាមបង្កើតសន្តិភាពជាមួយសត្រូវរបស់ពួកគេ»

Ezekiel 7:26
ព័ត៌មានទូទៅ:
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីជនជាតិអ៊ីស្រាអែល។
ពួកគេស្វែងរកនិមិត្តពីពួកព្យាការី
«ពួកគេនឹងសួរពួកព្យាការីនូវអ្វីដែលពួកគេបានឃើញ»។
ក្រឹត្យវិន័យនឹងបាត់អស់ ហើយគ្មានការប្រឹក្សាពីចាស់ទុំទៀតដែរ
«បូជាចារ្យនឹងមិនបង្រៀនច្បាប់ទេ
ហើយព្រឹទ្ធាចារ្យនឹងមិនអាចផ្តល់ដំបូន្មានល្អបានទេ»។
នេះក៏ព្រោះតែព្រះអង្គនឹងមិនប្រទានប្រាជ្ញាដល់ពួកគេឡើយ។
ព្រះអង្គម្ចាស់
អត្ថន័យដែលអាចមានគឺ ១) «បុត្រារបស់ស្តេច» (UDB) ឬ ២)
«សមាជិកបុរសម្នាក់ៗនៃគ្រួសាររាជវង្សលើកលែងតែព្រះមហាក្សត្រ។
នឹងស្លៀកពាក់ដោយអស់សង្ឃឹម
អត្ថន័យដែលអាចមានគឺ ១) «នឹងគ្មានសង្ឃឹម» ឬ ២)
«នឹងស្លៀកសម្លៀកបំពាក់ដែលបង្ហាញថាគាត់កំពុងកាន់ទុក្ខ»។
ដៃប្រជាជននៅក្នុងទឹកដីត្រូវញ័ររន្ធត់
«ប្រជាជននៅលើដីនឹងភ័យខ្លាចយ៉ាងខ្លាំង ដែលដៃរបស់ពួកគេនឹងញ័រ»
គេដឹងថា យើងជាព្រះអម្ចាស់
អត្ថន័យដែលអាចមានគឺ ១) «ដឹងថាតើយើងដែលជាព្រះអម្ចាស់» ឬ ២)
«យល់ថាយើងជាព្រះអម្ចាស់ជាព្រះពិតតែមួយ» ឬ ៣) «ដឹងថាយើងជាព្រះអម្ចាស់
មានអំណាចធ្វើអ្វីដែលយើងនិយាយថាយើងនឹងធ្វើ»។ (UDB)

---

8 [1]ដូច្នេះ នៅក្នុងឆ្នាំទីប្រាំមួយ ហើយខែទីប្រាំមួយ នៅក្នុងថ្ងៃទីប្រាំនៃខែនោះ ខ្ញុំកំពុងអង្គុយនៅក្នុងផ្ទះ ហើយមានព្រឹទ្ធាចារ្យនៃជនជាតិយូដាអង្គុយនៅមុខខ្ញុំ ព្រះជាម្ចាស់
ដ៏ជាព្រះអម្ចាស់បានដាក់ព្រះហស្តលើខ្ញុំម្តងទៀតនៅទីនោះ។[2]ដូច្នោះហើយ ខ្ញុំបានឃើញ ហើយមើល មានដូចជាទ្រង់ទ្រាយរបស់មនុស្សម្នាក់។ ពីត្រង់កន្លែងត្រគាកចុះ
ទៅក្រោម គឺមានដូចភ្លើង។ ហើយពីត្រឹមត្រគាកឡើងទៅលើ មានសណ្ឋានដូចជាពន្លឺដ៏ត្រចះត្រចង់ ដូចធ្វើឡើងពីដែក។
[3]ក្រោយមក ព្រះអង្គលូកមក មានរាងដូចជាដៃចាប់សក់ក្បាលខ្ញុំ រួចព្រះវិញ្ញាណព្រះអង្គលើកខ្ញុំពីដីឡើងទៅលើមេឃ ហើយក្នុងនិមិត្តរបស់ព្រះជាម្ចាស់
ហើយព្រះអង្គនាំខ្ញុំទៅក្រុងយេរូសាឡិម ទៅដល់មាត់ទ្វារនៃទីលានខាងក្នុង ដែលបើកទៅទិសខាងជើង ជាកន្លែងដែលមានរូបព្រះ ដែលបង្កើតឲ្យ
ការប្រចណ្ឌយ៉ាងខ្លាំងឈរនៅទីនោះ។[4]ក្រោយមក មើល៍ សិរីល្អនៃព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលនៅទីនោះ ដោយការបើសម្តែងដែលខ្ញុំបានឃើញនៅទីវាលនោះ។
[5]ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «កូនមនុស្សអើយ ចូរបើកភ្នែកសម្លឹងមើលទៅទិសខាងជើង» ដូច្នេះ ខ្ញុំក៏មើលទៅខាងជើងនោះ ជាទ្វារដែលនាំចូលទៅឯអាសនា
នៅកណ្តាលទ្វារចូលគឺមានរូបព្រះនៃច្រណែននៅទីនោះ។[6]ដូច្នោះព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «កូនមនុស្សអើយ តើអ្នកឃើញការដែលគេប្រព្រឹត្តឬទេ? គឺជាការគួរស្អប់
ខ្ពើមខ្លាំង ដែលពូជពង្សអ៊ីស្រាអែលធ្វើនៅទីនេះ ដើម្បីឲ្យយើងបានឃ្លាតឆ្ងាយពីទីបរិសុទ្ធរបស់យើង។ តែចាំមើល អ្នកនឹងឃើញការគួរស្អប់ខ្ពើម យ៉ាងសម្បើមជាងនេះទៅ
ទៀត»។
[7]ពេលនោះ ព្រះអង្គនាំខ្ញុំទៅដល់ទ្វារទីលាន ខ្ញុំបានមើលទៅឃើញមានប្រហោងមួយក្នុងកំផែង។[8]ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «កូនមនុស្សអើយ ចូរជីកទៅក្នុងកំផែង»
ដូច្នោះខ្ញុំបានជីកក្នុងកំផែងហើយ ឃើញមានទ្វារមួយ។[9]បន្ទាប់មកព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «ចូរអ្នកចូលទៅខាងក្នុង មើលការគួរស្អប់ខ្ពើមយ៉ាងអាក្រក់ ដែលពួកគេ
ធ្វើនៅទីនេះ»។
[10]ដូច្នេះ ខ្ញុំក៏ចូលទៅក្នុងហើយមើល ហើយចូលមើល! ហើយឃើញមានគំនូរគ្រប់ទាំងសត្វលូនវារ សត្វសាហាវ! រួមទាំងរូបព្រះរបស់ពូជពង្សជនជាតិអ៊ីស្រាអែល ដែលគេ
គូរលើជញ្ជាំងនៅជុំវិញ។[11]ក៏មានពួកចាស់ទុំនៃពួកអ៊ីស្រាអែលចិតសិបនាក់នៅទីនោះ ហើយមានយ៉ាសានាដែលជាកូនសាផាន បានឈរនៅកណ្តាលពួកគេ។
ពួកគេបានឈរនៅចំពោះរូបភាពនោះហើយគ្រប់គ្នាកាន់ជើងពាននៅនិងដៃ ហើយផ្សែងពីគ្រឿងក្រអូបក៏ហុយឡើងយ៉ាងក្រាស់។
[12]ព្រះអង្គមានព្រះបន្ទូលមកខ្ញុំ «កូនមនុស្សអើយ តើឃើញអំពើដែលពួកចាស់ទុំជនជាតិអ៊ីស្រាអែល ធ្វើនៅទីងងឹតទេ?
ម្នាក់ៗបានធ្វើការនេះហើយលាក់នៅក្នុងបន្ទប់នៃព្រះរបស់គេ ដ្បិតគេនិយាយ ព្រះអម្ចាស់មិនឃើញយើងទេ! ព្រះអម្ចាស់បានបោះបង់ចោលទឹកដីនេះហើយ»។[13]ព្រះអង្គ
មានព្រះបន្ទូលមកខ្ញុំ «បែរមកម្តងទៀត នោះនឹងឃើញការគួរស្អប់ខ្ពើមដែលគេប្រព្រឹត្តជាច្រើនទៀត»។
[14]បន្ទាប់មកទៀត ព្រះអង្គបាននាំខ្ញុំទៅទ្វារចូលព្រះដំណាក់របស់ព្រះអម្ចាស់ ដែលនៅទិសខាងជើង ហើយមើល៍ចុះ! នៅទីនោះមានពួកស្ត្រីអង្គុយយំកាន់ទុក្ខឲ្យព្រះថាមូស
។[15]ដូច្នោះព្រះអង្គមានព្រះបន្ទូលមកខ្ញុំ «តើអ្នកឃើញការនេះឬទេ កូនមនុស្ស? ចូរមើលម្តងទៀតនឹងឃើញអំពើអាក្រក់ជាងនេះទៅទៀត»។
[16]ព្រះអង្គបាននាំខ្ញុំចូលទៅទីលានខាងក្នុងរបស់ព្រះដំណាក់នៃព្រះជាម្ចាស់ ហើយឃើញ! ត្រង់មាត់ទ្វារព្រះវិហារនៃព្រះជាម្ចាស់ នៅរវាងផ្លូវដើរ ហើយនិងអាសនា មាន
មនុស្សប្រហែលជាម្ភៃប្រាំនាក់ បែរខ្នងទៅខាងព្រះវិហារនៃព្រះជាម្ចាស់ ហើយមុខទៅខាងកើត ហើយពួកគេកំពុងតែថ្វាយបង្គំព្រះអាទិត្យ។
[17]ព្រះអង្គមានព្រះបន្ទូលមកខ្ញុំ «កូនមនុស្សអើយ តើអ្នកឃើញឬទេ? តើវាជាតូចតាចឬដែលពួកអ្នកស្រុកយូដា បានកំពុងធ្វើការអាក្រក់គួរខ្ពើមនៅទីនេះ? ដ្បិតគេបានធ្វើឲ្យ
ទឹកដីនេះមានពេញដោយអំពើឃោរឃៅ ហើយបែរទាស់នឹង ធ្វើឲ្យយើងខឹងខ្លាំង ដូចយកមែកឈើរុកចូលច្រមុះគេអញ្ចឹង។[18]ដូច្នេះ យើងនឹងធ្វើការតបទៅពួកគេវិញ
ហើយភ្នែកយើងនឹងមិនប្រណីឡើយ យើងនឹងមិនអាណិតគេទេ។ ទោះបើគេស្រែករកយើង ដោយសំឡេងខ្លាំងក្តី យើងក៏មិនស្តាប់ដែរ»។

Ezekiel 8:1
ព័ត៌មានទូទៅ:
លោកអេសេគាលប្រាប់អំពីនិមិត្តមួយទៀតដែលគាត់បានឃើញ។
ដូច្នេះ នៅក្នុង
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើ
ដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
ក្នុងឆ្នាំទីប្រាំមួយ
ការបកប្រែរបៀបផ្សេងទៀត: «នៅឆ្នាំទី៦ នៃការនិរទេសស្តេចយេហូយ៉ាជីន»
ខែទីប្រាំមួយ នៅក្នុងថ្ងៃទីប្រាំនៃខែនោះ
«ថ្ងៃទី៥ នៃខែទី៦»។ នេះជាខែទីប្រាំមួយនៃប្រតិទិនហេប្រឺ។ ថ្ងៃទី៥
ជិតដល់ដើមខែកញ្ញាលើប្រតិទិនលោកខាងលិច។
ព្រះអម្ចាស់បានដាក់ព្រះហស្តលើខ្ញុំម្តងទៀត
នេះគួរតែត្រូវបានបកប្រែតាមព្យញ្ជនៈដូចជាពេលដែលលោកអេសេគាលបានឃើញអ្វីមួយដូចជាដៃ។
អ្នកផ្សេងទៀតអាចជ្រើសរើសយកដៃជាការប្រៀបធៀបសម្រាប់វត្តមាន
ឬអំណាចរបស់ព្រះអម្ចាស់។
ព្រះអម្ចាស់
ការបកប្រែដូចនៅក្នុងជំពូក ២:៤។

generated on Wed Sep 10 16:16:32 2025

លើខ្ញុំ
«ចាប់យក»
ធ្វើឡើងពីដែក
នៅពេលដែកក្តៅខ្លាំង វាបញ្ចេញពន្លឺពណ៌លឿង ឬ ទឹកក្រូចខ្ចី។
Ezekiel 8:3
ព័ត៌មានទូទៅ:
លោកអេសេគាលបន្តប្រាប់អំពីចក្ខុនិមិត្តដែលមកពីព្រះជាម្ចាស់។
ព្រះអង្គលូកមក
ពាក្យថា «គាត់» ប្រហែលជាសំដៅទៅលើ «តួលេខដូចបុរស» (៨:១)។
ពីដីឡើងទៅលើមេឃ
«រវាងដី និងមេឃ»
ក្នុងនិមិត្តរបស់ព្រះជាម្ចាស់ ហើយព្រះអង្គនាំខ្ញុំទៅក្រុងយេរូសាឡិម
ពាក្យថា «ក្នុងការនិមិត្ត»
មានន័យថាបទពិសោធន៍នេះកំពុងកើតឡើងនៅក្នុងគំនិតរបស់លោកអេសេគាល។
គាត់នឹងនៅតែនៅក្នុងផ្ទះរបស់គាត់
ខណៈពេលដែលព្រះអង្គបង្ហាញគាត់អំពីរឿងទាំងនេះ។
មាត់ទ្វារនៃទីលានខាងក្នុង ដែលបើកទៅទិសខាងជើង
«ទ្វារខាងជើងនៅខាងក្នុងនៃព្រះវិហារ»
រូបព្រះ ដែលបង្កើតឲ្យការប្រចណ្ឌយ៉ាងខ្លាំង
«រូបព្រះដែលធ្វើឲ្យមានការច្រណែនខ្លាំង» ឬ
«រូបព្រះដែលធ្វើឲ្យព្រះជាម្ចាស់ច្រណែន»
ដោយការបើសម្តែង ដែលខ្ញុំបានឃើញនៅទីវាលនោះ
«ដែលមើលទៅដូចគ្នានឹងអ្វីដែលយើងបានឃើញនៅទីវាល»
ទីវាល
តំបន់ធំមួយនៃដីរាបស្មើដែលមានដើមឈើតិចតួច។
Ezekiel 8:5
ព័ត៌មានទូទៅ:
«តួលេខដូចមនុស្ស» (៨:១) និយាយទៅកាន់លោកអេសេគាល។
កូនមនុស្សអើយ
«កូនប្រុសរបស់មនុស្ស» ឬ «ព្រះរាជបុត្រានៃមនុស្សជាតិ»។
ព្រះជាម្ចាស់ហៅលោកអេសេគាលនេះដើម្បីបញ្ជាក់ថាលោកអេសេគាលគ្រាន់តែជាមនុស្សម្នាក់ប៉ុណ្ណោះ
ព្រះមានឫទ្ធានុភាព និងរស់នៅជារៀងរហូតប៉ុន្តែមនុស្សមិនមែនទេ។
ការបកប្រែដូចនៅក្នុងជំពូក ២:១។ «មនុស្សរមែងស្លាប់» ឬ «មនុស្ស»
ចូរបើកភ្នែកសម្លឹងមើល
«មើល» ឬ «បង្វែរក្បាលរបស់អ្នក ហើយមើលទៅ»
ជាទ្វារដែលនាំចូលទៅឯអាសនា
«ច្រកទ្វារដែលមនុស្សអាចដើរបាន ដូច្នេះពួកគេអាចទៅអាសនា»
តើអ្នកឃើញការដែលគេប្រព្រឹត្តឬទេ?
ព្រះអង្គប្រើសំណួរនេះដើម្បីនាំចំណាប់អារម្មណ៍របស់លោកអេសេគាលចំពោះអ្វីដែលប្រជាជនកំពុងធ្វើ
ការបកប្រែរបៀបផ្សេងទៀត: «យើងចង់អោយអ្នកយល់ពីមូលហេតុ
ដែលយើងស្អប់អ្វីដែលប្រជាជននៅទីនេះកំពុងធ្វើ»។
ពូជពង្សអ៊ីស្រាអែល
ពាក្យថា «ផ្ទះ»
គឺជាពាក្យប្រៀបធៀបសម្រាប់គ្រួសារដែលរស់នៅក្នុងផ្ទះក្នុងករណីនេះជនជាតិអ៊ីស្រាអែល
ដែលជាកូនចៅរបស់យ៉ាកុបអស់រយៈពេលជាច្រើនឆ្នាំ។
ការបកប្រែរបៀបផ្សេងទៀត: «ក្រុមប្រជាជនអ៊ីស្រាអែល»
ការបកប្រែដូចនៅក្នុងជំពូក ៣:១។
Ezekiel 8:7
ទីលាន
«ទីធ្លាព្រះវិហារ»
Ezekiel 8:10
ចូលមើល!
ពាក្យថា «មើល»
ត្រង់នេះបង្ហាញថាលោកអេសេគាលមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។
ឃើញមានគំនូរគ្រប់ទាំងសត្វលូនវារ សត្វគួរស្អប់ខ្ពើម
«ចម្លាក់នៅតាមជញ្ជាំងសត្វលូនវារ និងសត្វគួរស្អប់ខ្ពើម»។ ឃ្លាថា «សត្វលូនវារ»
សំដៅទៅលើសត្វល្អិត និងសត្វតូចៗដទៃទៀត។
ពូជពង្សជនជាតិអ៊ីស្រាអែល
ពាក្យថា «ផ្ទះ»
គឺជាពាក្យប្រៀបធៀបសម្រាប់គ្រួសារដែលរស់នៅក្នុងផ្ទះក្នុងករណីនេះជនជាតិអ៊ីស្រាអែលដែលជាកូនចៅ
ការបកប្រែរបៀបផ្សេងទៀត: «ក្រុមប្រជាជនអ៊ីស្រាអែល»
ការបកប្រែដូចនៅក្នុងជំពូក ៣:១។
ឃ្លាសានាដែលជាកូនសាផាន
ជើងពាន
ជាវត្ថុមួយដែលមនុស្សប្រើសំរាប់ដុតធូប នៅពេលពួកគេថ្វាយបង្គំព្រះ ឬ
ព្រះក្លែងក្លាយ
Ezekiel 8:12
តើឃើញអំពើដែលពួកចាស់ទុំជនជាតិអ៊ីស្រាអែល ធ្វើនៅទីងងឹតទេ?
ព្រះអង្គបានសួរសំណួរនេះ ដើម្បីឲ្យលោកអេសេគាលនឹងពិនិត្យមើលអ្វី
ដែលព្រះអង្គកំពុងប្រាប់គាត់ឲ្យមើល។
ជនជាតិអ៊ីស្រាអែល
ពាក្យថា «ផ្ទះ»
គឺជាពាក្យប្រៀបធៀបសម្រាប់គ្រួសារដែលរស់នៅក្នុងផ្ទះក្នុងករណីនេះជនជាតិអ៊ីស្រាអែលដែលជាកូនចៅ
ការបកប្រែរបៀបផ្សេងទៀត: «ក្រុមប្រជាជនអ៊ីស្រាអែល»
ការបកប្រែដូចនៅក្នុងជំពូក ៣:១។
លាក់នៅក្នុងបន្ទប់នៃព្រះរបស់គេ
«បន្ទប់ដែលគ្មានអ្នកណាអាចឃើញគាត់គោរពបូជារូបព្រះរបស់គាត់»
Ezekiel 8:14
ទ្វារចូលព្រះដំណាក់របស់ព្រះអម្ចាស់ ដែលនៅទិសខាងជើង
នេះជាខ្លោងទ្វារខាងជើង មិនមែនជាទ្វារតែមួយដូចនៅក្នុងជំពូក ៨:៣ ទេ។
សូមមើល UDB។
មើល៍ចុះ!
ពាក្យថា «មើល»
ត្រង់នេះបង្ហាញថាលោកអេសេគាលមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។
អង្គុយយំកាន់ទុក្ខ
«សោកសៅ ព្រោះព្រះអង្គមិនពិតថាមូសបានស្លាប់»។
Ezekiel 8:16
ហើយឃើញ!
ពាក្យថា «មើល»
ត្រង់នេះបង្ហាញថាលោកអេសេគាលមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។
រវាងផ្លូវដើរ
គ្របដណ្តប់នៅខាងមុខច្រកចូលមួយ ដែលមានជួរ ឈរ
ឬប្រកាសសម្រាប់ការគាំទ្រ
ហើយមុខទៅទិសខាងកើត
«ហើយពួកគេកំពុងសំលឹងឆ្ពោះទៅទិសខាងកើត»
Ezekiel 8:17
តើវាជាតូចតាច ឬដែលពួកអ្នកស្រុកយូដា បានកំពុងធ្វើការអាក្រក់គួរខ្ពើមនៅទីនេះ
ព្រះអង្គប្រើសំណួរនេះដើម្បីបង្ហាញកំហឹងរបស់ទ្រង់ដែលប្រជាជនយូដាមិនគិតថាការគោរពបូជារូបព្រះគឺអ
ការបកប្រែជំនួស៖
តើប្រជាជនយូដាគិតថាអំពើគួរស្អប់ខ្ពើមរបស់ពួកគេមិនធ្ងន់ធ្ងរទេឬ?
ស្រុកយូដា
ពាក្យថា «ផ្ទះ»
គឺជាពាក្យកាត់សម្រាប់គ្រួសារដែលរស់នៅក្នុងផ្ទះក្នុងករណីនេះកូនចៅរបស់យូដាក្នុងរយៈពេលច្រើនឆ្នាំ។
ការបកប្រែរបៀបផ្សេងទៀត: «ក្រុមប្រជាជនយូដា» ឬ «ប្រជាជនយូដា»
ពាក្យស្រដៀងគ្នានេះលេចឡើងនៅក្នុងជំពូក ៣:១។
ទឹកដីនេះមានពោរពេញដោយអំពើឃោរឃៅ
«ពាសពេញប្រទេសដែលពួកគេធ្វើអំពើហឹង្សា ឬ ពាសពេញប្រទេស
ដែលពួកគេកំពុងវាយប្រហារគ្នាទៅវិញទៅមក»
ធ្វើឲ្យយើងខឹងខ្លាំង
«ធ្វើឲ្យយើងខឹង»
មែកឈើរុកចូលច្រមុះគេអញ្ចឹង
នេះអាចមានន័យថា «កាន់មែកនៅច្រមុះរបស់ពួកគេនៅក្នុងការថ្វាយបង្គំមិនពិត»។
យើងនឹងមិនប្រណីឡើយ
«យើងនឹងនៅតែដាក់ទណ្ឌកម្មពួកគេ»។
គេស្រែករកយើង ដោយសំឡេងខ្លាំងក្តី
ការបកប្រែជំនួស៖ «ទោះបីពួកគេស្រែករកយើងដោយសំលេងខ្លាំងៗក៏ដោយ»
យើងក៏មិនស្តាប់ដែរ
«យើងនឹងមិនស្តាប់ពួកគេទេ»

generated on Wed Sep 10 16:16:32 2025

9 [1]ពេលនោះ ព្រះអង្គមានព្រះបន្ទូលដាក់ត្រចៀកខ្ញុំ ដោយព្រះសៀងយ៉ាងខ្លាំងថា «ចូរឲ្យពួកអ្នកដែលត្រួតត្រាការក្នុងទីក្រុងចូលមក ត្រូវឲ្យគ្រប់គ្នាកាន់គ្រឿងសាស្ត្រាវុធ
ដើម្បីបំផ្លាញនៅដៃ»។[2]មើល៍! មានមនុស្សប្រាំមួយនាក់មកតាមផ្លូវទ្វារខាងលើ ដែលបើកទៅទិសខាងជើង គ្រប់គ្នាក៏កាន់គ្រឿងអាវុធនៅដៃគេ។ មានម្នាក់ស្លៀកពាក់
សំពត់ទេសឯក នៅកណ្តាលគេ មានស្តាយដបទឹកខ្មៅ អ្នកទាំងនោះក៏ចូលទៅឈរក្បែរអាសនាលង្ហិន»។
[3]រួចហើយ សិរីល្អរបស់ព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែលបានឡើងផុតពីចេរូប៊ីន ជាកន្លែងដែលធ្លាប់សណ្ឋិតនៅទៅដល់មាត់ទ្វារព្រះវិហារ ព្រះអង្គមានព្រះបន្ទូលហៅអ្នក
ម្នាក់ដែលស្លៀកពាក់សំពត់ទេសឯក ហើយស្តាយដបទឹកខ្មៅនោះ[4]ព្រះជាម្ចាស់មានព្រះបន្ទូលទៅអ្នកនោះ «ចូរដើរកាត់ទីក្រុង គឺនៅកណ្តាលក្រុងយេរូសាឡិមទៅ ហើយធ្វើ
ទីសម្គាល់នៅថ្ងាសរបស់ពួកមនុស្សដែលដកដង្ហើមធំហើយថ្ងូរ ដោយព្រោះការគួរស្អប់ខ្ពើមដែលមនុស្សប្រព្រឹត្តនៅក្នុងទីក្រុង»។
[5]រួចហើយ ព្រះអង្គមានព្រះបន្ទូលដល់អ្នកផ្សេងហើយខ្ញុំក៏បានឮ «ចូរដើរកាត់ទីក្រុងតាមអ្នកមួយនោះ ហើយសម្លាប់។ កុំឲ្យភ្នែកអ្នកប្រណី ហើយទុកអ្នកណាឲ្យរួចជីវិត។
[6]ត្រូវសម្លាប់ទាំងពួកចាស់ ពួកកំលោះ ពួកក្រមុំ ពួកក្មេង និងពួកស្រីៗ។ សម្លាប់គេទាំងអស់ទៅ! ប៉ុន្តែ កុំចូលទៅជិតមនុស្សណាដែលមានទីសម្គាល់នៅខ្លួនឡើយ ហើយ
ត្រូវចាប់ផ្តើមពីទីបរិសុទ្ធរបស់យើងផង!» ដូច្នេះ អ្នកទាំងនោះក៏ផ្តើមពីពួកចាស់ទុំដែលនៅមុខព្រះដំណាក់។
[7]ព្រះអង្គមានបន្ទូលទៅគេ «ចូរប្រមាថវិហារចុះ ត្រូវសម្លាប់គេធ្វើឲ្យទីលានបានពេញដោយសាកសព។ ទៅ!» ដូច្នេះ ពួកគេក៏ចេញទៅប្រហារនៅក្នុងទីក្រុង។[8]កាលគេកំពុង
តែសម្លាប់ ហើយមានតែខ្ញុំសល់នៅ នោះខ្ញុំក៏ផ្កាប់មុខយំហើយអង្វរថា «ឱព្រះអម្ចាស់អើយ តើព្រះអង្គនឹងបំផ្លាញសំណល់ជនជាតិអ៊ីស្រាអែលទាំងអស់ ដោយចាក់សេចក្តី
ក្រោធរបស់ព្រះអង្គមកលើក្រុងយេរូសាឡិម?»។
[9]ព្រះអង្គមានព្រះបន្ទូលមកខ្ញុំ «ពូជពង្សអ៊ីស្រាអែល និងយូដាមានទោសធ្ងន់ណាស់។ ទឹកដីនេះពោពេញដោយឈាម ហើយទីក្រុងមានពេញដោយភាពមាន:
តាំងពីពួកគេនិយាយថា ព្រះជាម្ចាស់បានបោះបង់ចោលទឹកដីនេះ ហើយព្រះជាម្ចាស់មើលមិនឃើញទេ![10]ដូច្នោះហើយ ភ្នែកយើងនឹងមិនប្រណីទេ យើងមិនអាណិតមេត្តា
ឡើយ យើងនឹងមិនទុកជីវិតឲ្យពួកគេទេ។ យើងនឹងនាំការទាំងអស់មកដាក់លើក្បាលគេ»[11]មើល៍! មនុស្សដែលស្លៀកពាក់សំពត់ទេសឯក ហើយស្តាយដបទឹកខ្មៅក៏
មកវិញ។ គាត់ទូលព្រះអង្គថា «ទូលបង្គំបានធ្វើសម្រេចតាមបង្គាប់របស់ព្រះអង្គហើយ»។

Ezekiel 9:1
ព័ត៌មានទូទៅ:
លោកអេសេគាលបន្តប្រាប់អំពីនិមិត្តដែលព្រះអង្គបានឲ្យគាត់។
វាចាប់ផ្តើមនៅក្នុងជំពូក ៨:១។
ព្រះអង្គមានព្រះបន្ទូលដាក់ត្រចៀកខ្ញុំ
«ខ្ញុំបានលឺទ្រង់ស្រែកហៅ»
អ្នកដែលត្រួតត្រា
មនុស្សដែលការពារអ្វីមួយ។
គ្រឿងសាស្ត្រាវុធដើម្បីបំផ្លាញ
អាវុធសម្រាប់បំផ្លាញមនុស្ស ឬ របស់របរផ្សេងៗ
អាវុធនៃការសំលាប់
អាវុធសម្រាប់សំលាប់មនុស្សជាច្រើន
មើល៍!
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
វាក៏អាចត្រូវបានបកប្រែជា «ពិតមែន!»
សំពត់ទេសឯក
ក្រណាត់រឹង រលោងរឹងមាំធ្វើពីរុក្ខជាតិ។
វាត្រូវបានពាក់ដោយមនុស្សជាច្រើននៅកន្លែងដែលក្តៅ។ ការបកប្រែជំនួស៖
«ក្រណាត់រលោង»
ស្តាយដបទឹកខ្មៅ
ឧបករណ៍ដែលពួកអាចារ្យប្រើដើម្បីសរសេរជាមួយ
លង្ហិន
លោហៈពណ៌មាសងងឹតមួយ។
វាត្រូវបានផលិតចេញពីស្ពាន់ភាគច្រើនជាមួយសំណប៉ាហាំងដើម្បីបន្ថែមកម្លាំង។
Ezekiel 9:3
ពីចេរូប៊ីន ជាកន្លែងដែលធ្លាប់សណ្ឋិត
អត្ថន័យដែលអាចមានគឺ ១) «ពីលើតួរមានជីវិតទាំងបួន»
មាត់ទ្វារព្រះវិហារ
«ផ្ទះ» សំដៅទៅលើព្រះវិហាររបស់ព្រះអង្គ។
សំពត់ទេសឯក
សូមមើលពីររបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៩:១។
ស្តាយដបទឹកខ្មៅ
សូមមើលពីររបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៩:១។
ដកដង្ហើមធំ ហើយថ្ងូរ
ទាំងនេះគឺជាសម្លេងដែលមនុស្សបង្កើត
នៅពេលដែលពួកគេមានអារម្មណ៍សោកសៅ ឬពិបាកចិត្តចំពោះអ្វីមួយ។
ដោយព្រោះការគួរស្អប់ខ្ពើមដែលមនុស្សប្រព្រឹត្តនៅក្នុងទីក្រុង
«អំពើគួរអោយស្អប់ខ្ពើម ដែលកំពុងធ្វើនៅក្នុងទីក្រុង» ឬ «អំពើគួរស្អប់ខ្ពើម
ដែលមនុស្សកំពុងធ្វើនៅក្នុងទីក្រុង»
Ezekiel 9:5
ព្រះអង្គមានព្រះបន្ទូលដល់អ្នកផ្សេងហើយខ្ញុំក៏បានឮ
ពាក្យថា «អ្នកដទៃ» សំដៅលើឆ្មាំយាម។ (សូមមើល: EZK 9:1)
កុំឲ្យភ្នែកអ្នកប្រណី
«កុំអាណិតអាសូរមនុស្សដែលអ្នកឃើញ»។
ទុកអ្នកណាឲ្យរួចជីវិត
«កុំបដិសេធពីការសម្លាប់»
ទីសម្គាល់នៅខ្លួន
អ្នកទាំងនេះជាមនុស្សដែលថ្ងូរអំពីអំពើគួរស្អប់ខ្ពើមដែលកើតមាននៅក្រុងយេរូសាឡិម។
សូមមើលពីរបៀបដែលអ្នកបានបកប្រែ «សញ្ញាសម្គាល់» ក្នុងជំពូក ៩:៣។
ចាប់ផ្តើមពីទីបរិសុទ្ធ
«ចាប់ផ្តើមសម្លាប់អ្នកដែលមិនមានសញ្ញាសំគាល់នៅទីសក្ការៈរបស់យើង»
ពួកចាស់ទុំ
អត្ថន័យដែលអាចមានគឺ ១)
«ចិតសិបនាក់នៃចាស់ព្រឹទ្ធាចារ្យនៃពូជវង្សអ៊ីស្រាអែល» (៨:១០) ឬ ២)
«បុរសចំណាស់» (ខ ៦)។
Ezekiel 9:7
ព័ត៌មានទូទៅ:
ព្រះជាម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ឆ្មាំយាមចៅក្រមដែលវិនិច្ឆ័យប្រជាជនអ៊ីស្រាអែល។
ប្រហារនៅក្នុងទីក្រុង
«ប្រហារប្រជាជននៅក្នុងទីក្រុង»
ខ្ញុំក៏ផ្កាប់មុខ
«យើងក្រាបចុះដល់ដី» ឬ «យើងដេកលើដី»។
លោកអេសេគាលមិនបានដួលដោយចៃដន្យទេ។
គាត់ចុះទៅក្រោមដីដើម្បីបង្ហាញថាគាត់គោរព និងកោតខ្លាចព្រះអម្ចាស់។
បកប្រែដូចនៅក្នុងជំពូក ១:២៧។
ឱព្រះអម្ចាស់អើយ
លោកអេសេគាលនិយាយដូច្នេះ
ពីព្រោះគាត់តប់ប្រមល់នឹងអ្វីដែលព្រះអម្ចាស់បានប្រាប់ពួកបុរសឲ្យធ្វើដល់ក្រុងយេរូសាឡិម។
បកប្រែដូចនៅក្នុង ជំពូក ៤:១៤។
តើព្រះអង្គនឹងបំផ្លាញសំណល់ជនជាតិអ៊ីស្រាអែលទាំងអស់ ដោយចាក់សេចក្តីក្រោធរបស់ព្រះអង្គ
មកលើក្រុងយេរូសាឡិម?
«តើទ្រង់នឹងបំផ្លាញជនជាតិអ៊ីស្រាអែលដែលនៅសេសសល់ដោយយកកំហឹងមកលើក្រុងយេរូសាឡិមឬ?
តាមពិតលោកអេសេគាលកំពុងតែអង្វរព្រះអម្ចាស់ កុំឲ្យបំផ្លាញពួកសំណល់។
ការបកប្រែរបៀបផ្សេងទៀត:
«សូមកុំបំផ្លាញជនជាតិអ៊ីស្រាអែលដែលនៅសេសសល់ទាំងអស់ដោយបង្ហូរកំហឹងរបស់ទ្រង់លើក្រុងយេរូ
Ezekiel 9:9
ពូជពង្សអ៊ីស្រាអែល
ពាក្យថា «ផ្ទះ» គឺជាពាក្យប្រៀបធៀបសម្រាប់គ្រួសារដែលរស់នៅក្នុងផ្ទះ
នៅក្នុងករណីនេះជនជាតិអ៊ីស្រាអែលដែលជាកូនចៅរបស់យ៉ាកុបអស់រយៈពេលជាច្រើនឆ្នាំ។
ការបកប្រែរបៀបផ្សេងទៀត: «ក្រុមប្រជាជនអ៊ីស្រាអែល» បកប្រែដូចនៅក្នុងជំពូក
៣:១។
អស្ចារ្យណាស់

generated on Wed Sep 10 16:16:32 2025

«ប្រពៃណាស់»
ទឹកដីនេះពោរពេញដោយឈាម
«ដីពោរពេញទៅដោយអំពើហឹង្សា» ឬ
«ពាសពេញដីប្រជាជនកំពុងសំលាប់មនុស្ស»
ទីក្រុងមានពេញដោយភាពមាន:
អត្ថន័យដែលអាចមានគឺ ១)
«ទីក្រុងនេះពោពេញទៅដោយមនុស្សដែលបង្ហូចយុត្តិធម៌» ឬ ២)
«ទីក្រុងនេះពោរពេញទៅដោយមនុស្សដែលធ្វើអំពើអាក្រក់»។ ការបកប្រែជំនួស៖
«ទីក្រុងនេះពោពេញទៅដោយមនុស្សដែលប្រព្រឹត្តអយុត្តិធម៌» ឬ
«ទីក្រុងនេះមានមនុស្សជាច្រើនដែលធ្វើអំពើអាក្រក់»។
ភ្នែកយើងនឹងមិនប្រណីទេ
«យើងនឹងមិនមើលពួកគេដោយក្តីមេត្តា» ឬ
«យើងនឹងមិនអាណិតអាសូរពួកគេទេ»។
ភ្នែកនៅទីនេះសំដៅទៅលើរបៀបដែលគាត់គោរពមនុស្ស។
នាំការទាំងអស់មកដាក់លើក្បាលគេ
«នាំមកនូវផលប៉ះពាល់នៃអ្វីដែលពួកគេបានធ្វើលើក្បាលរបស់ពួកគេ»។
នេះមានន័យថា «យើងនឹងសងពួកគេវិញចំពោះអ្វីដែលពួកគេបានធ្វើ»
មើល!
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
នេះក៏អាចត្រូវបានបកប្រែជា «ពិតណាស់!»
សំពត់ទេសឯក
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៩:១។
គាត់ទូលព្រះអង្គថា
«គាត់បានរាយការណ៍ទៅព្រះអម្ចាស់ ហើយបានប្រាប់ទ្រង់»

---

10 [1]កាលដែលខ្ញុំបានសម្លឹងមើលទៅដំបូលខាងលើ ដែលនៅពីលើក្បាលរបស់ចេរូប៊ីន ដែលមានភាពដូចជាត្បូងកណ្តៀង ហើយមើលទៅដូចជាសណ្ឋាននៃបល្ល័ង្ក
លេចឡើងមក។[2]ក្រោយមក ព្រះអង្គមានព្រះបន្ទូលទៅកាន់មនុស្សដែលស្លៀកសំពត់ទេសឯកថា «ចូរចូលទៅកណ្តាលកង់ទាំងនោះ គឺក្រោមចេរូប៊ីន ហើយកើប
រងើកភ្លើងពេញដៃទាំងពីរ ពីកណ្តាលចេរូប៊ីននោះ រួចបាចទៅលើទីក្រុងទៅ»។ បន្ទាប់មក បុរសនោះក៏បានចេញទៅក្នុងពេលដែលខ្ញុំកំពុងមើល។
[3]ពេលបុរសនោះចូលទៅដល់ ពួកចេរូប៊ីនស្ថិតនៅខាងស្តាំនៃព្រះដំណាក់ ហើយមានពពកពាសពេញទីលានខាងក្នុង។[4]សិរីល្អរបស់ព្រះអម្ចាស់អណ្តែតឡើងពីលើពួក
ចេរូប៊ីនឈេ ឆ្ពោះកាន់មាត់ទ្វារព្រះដំណាក់។ មានពពកនៅពេញព្រះដំណាក់ ហើយទីលានក៏ពេញទៅដោយរស្មីនៃសិរីល្អរបស់ព្រះអម្ចាស់។[5]សន្ធឹកស្លាបរបស់ពួកចេរូប៊ីន
លាន់ឮរហូតទៅដល់ទីលានខាងក្រៅ មានសម្លេងដូចនៃព្រះដ៏មានឫទ្ធានុភាពពេលព្រះអង្គមានព្រះបន្ទូល។
[6]នៅក្នុងពេលនោះ ព្រះអម្ចាស់បង្គាប់ទៅបុរសដែលពាក់អាវទេសឯកថា «ចូរយកភ្លើងពីក្នុងកង់ នៅចន្លោះពួកចេរូប៊ីនមក» បុរសនោះក៏បានទៅឈរក្បែរកង់នោះ។[7]ពេល
នោះ ចេរូប៊ីនមួយលូកដៃទៅកាន់ភ្លើង ដែលកំពុងឆេះនៅចន្លោះពួកចេរូប៊ីន ហើយយកភ្លើងហុចទៅឲ្យបុរសដែលពាក់អាវទេសឯកសុទ្ធនោះ។ បុរសនោះក៏ទទួលយក រួច
ចេញទៅវិញ។[8]ខ្ញុំក៏បានឃើញ នៅក្រោមស្លាបរបស់ពួកចេរូប៊ីន មានហាក់ដូចជាដៃរបស់មនុស្សលេចចេញមក។
[9]ដូច្នេះ ខ្ញុំមើល ហើយមើល៍! ឃើញមានកង់បួននៅក្បែរពួកចេរូប៊ីន គឺនៅក្បែរចេរូប៊ីននីមួយៗមានកង់មួយ។ កង់ទាំងនោះភ្លឺចាំងដូចត្បូងពេជ្រ។[10]កង់ទាំងបួនមាន
ទ្រង់ទ្រាយ និងមានសណ្ឋានដូចៗគ្នាទាំងអស់ មើលទៅហាក់ដូចជាកង់មួយស្ថិតនៅក្នុងកង់មួយទៀត។[11]ពេលកង់ទាំងនោះវិលទៅមុខ កង់ទាំងនោះអាចវិលទៅទិសដៅ
ទាំងបួន ដោយគ្មានងាករេចេញពីគ្នាទេ។ ផ្ទុយទៅវិញ ពួកកង់ទាំងនោះវិលទៅមុខ តាមទិសដែលមុខរបស់ចេរូប៊ីនបែរទៅគេកង់ទាំងនោះទៅតាមដែរ។
កង់ទាំងនោះមិនងាកបែរទៅទិសផ្សេងឡើយ។
[12]រូបកាយរបស់ចេរូប៊ីនទាំងមូល រួមទាំងខ្នងរបស់ពួកគេ ដៃរបស់ពួកគេ ស្លាបរបស់ពួកគេ ហើយក៏បានបិតបាំងភ្នែក ហើយភ្នែកនោះទៀត
ក៏បានបិតបាំងដោយកង់ទាំងមូលបួនផងដែរ។[13]ខ្ញុំក៏ស្តាប់ឮថា កង់ទាំងនោះត្រូវបានហៅថា «ខ្យល់កួច»។[14]ហើយពួកចេរូប៊ីននីមួយៗមានមុខបួន មុខទីមួយនោះគឺដូច
ជាទេវតា មុខទីពីរដូចជាមុខមនុស្ស មុខទីបីដូចជាមុខសិង្ហ មុខទីបួនដូចជាមុខឥន្ទ្រី។
[15]ពួកចេរូប៊ីននោះក៏ឡើងទៅ នេះហើយជាសត្វមានជីវិត ដែលខ្ញុំឃើញក្បែរទន្លេកេបារដែលកំពុងជន់ឡើង។[16]កាលណាចេរូប៊ីនធ្វើដំណើរ កង់នោះក៏អមទៅជាមួយ ហើយ
កាលណាចេរូប៊ីនបានលើកស្លាបដើម្បីហោះហើរឡើងផុតពីផែនដី ហើយកង់ក៏ទាំងនោះក៏នឹងមិនបានបែរក្រោយដែរ។[17]កាលណាពួកចេរូប៊ីនទាំងនោះឈប់នៅស្ងៀម
កង់ទាំងនោះក៏ឈប់ដែរ ហើយកាលណាពួកនេះហើរឡើងទៅ ពួកកង់ទាំងនោះក៏ឡើងទៅជាមួយគ្នាដែរ ដ្បិតវិញ្ញាណនៃតួរមានជីវិតសណ្ឋិតនៅក្នុងកង់ទាំងនោះ។
[18]ក្រោយមក សិរីល្អនៃព្រះអម្ចាស់ ក៏ចេញពីប្រឡោះទ្វារនៃព្រះវិហារ ហើយទៅសណ្ឋិតពីលើពួកចេរូប៊ីន។[19]រួចចេរូប៊ីនក៏កាងស្លាប ក្នុងកាលដែលចេញទៅនោះ ហើយហើរ
ឡើងផុតពីផែនដី ខ្ញុំបានឃើញផ្ទាល់ភ្នែក នៅពេលដែលទាំងកង់អមទៅ។ ពួកគេក៏ទៅឈរនៅមាត់ទ្វារកំផែងទិសខាងកើតរបស់ព្រះដំណាក់ នៃព្រះអម្ចាស់ ហើយសិរីល្អ
របស់ព្រះនៃជនជាតិអ៊ីស្រាអែលក៏សណ្ឋិតនៅពីលើ។
[20]នេះហើយគឺជាតួរដែលមានជីវិត ដែលខ្ញុំបានឃើញនៅក្រោមព្រះនៃជនជាតិអ៊ីស្រាអែល ត្រង់ទន្លេកេបារ ខ្ញុំបានដឹងថា នោះជាពួកចេរូប៊ីនដែរ។[21]ពួកគេដែលមានមុខបួន
ហើយមានស្លាបបួនដែរ នៅក្រោមស្លាបនោះក៏មានសណ្ឋានដូចជាដៃមនុស្ស។[22]ហើយមានដូចមុខរបស់តួទាំងនោះ គឺដូចជាមុខដែលខ្ញុំបានឃើញនៅក្បែរទន្លេកេបារ
ហើយតួរទាំងនោះបានហើរត្រង់ទៅខាងមុខរៀងខ្លួន។

Ezekiel 10:1
ព័ត៌មានទូទៅ:
លោកអេសេគាលបន្តប្រាប់អំពីនិមិត្ត ដែលបានចាប់ផ្តើមនៅជំពូក ៨:១។
សម្លឹងមើលទៅដំបូលខាងលើ
«ឆ្ពោះទៅដំបូលកោង»
ចេរូប៊ីន
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៩:៣។
ដូចជាត្បូងកណ្តៀង
ត្បូងកណ្តៀងគឺជាថ្មដ៏មានតម្លៃពណ៌ខៀវ ឬ បៃតង។
ហើយមើលទៅដូចជាសណ្ឋាននៃបល្ល័ង្ក លេចឡើងមក
«នោះមើលទៅដូចជាបល្ល័ង្ក»
មនុស្សដែលស្លៀកសំពត់ទេសឯក
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យថា «ទេសឯក» នៅក្នុងជំពូក ៩:១។
ចូរចូលទៅកណ្តាលកង់
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យថា «កង់» នៅក្នុងជំពូក ១:១៥។
រងើកភ្លើង
ធ្យូងគឺជាបំណែកនៃអុសដែលឆេះបន្ទាប់ពីមានភ្លើងឆេះ។ ពួកវាមានពណ៌ខ្មៅ
ប៉ុន្តែវាមានពណ៌ក្រហម និងពណ៌ទឹកក្រូច នៅពេលដែលពួកវាក្តៅខ្លាំង។
រួចបាចទៅលើទីក្រុងទៅ
«បោះពួកគេលើទីក្រុង» ឬ «រាលដាលពាសពេញទីក្រុង»
Ezekiel 10:3
ចេរូប៊ីន
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១០: ៣។
ស្ថិតនៅខាងស្តាំ
នៅពេលដែលបែរមុខទៅទិសខាងកើត «ផ្នែកខាងស្តាំ» ឆ្ពោះទៅភាគខាងត្បូង។
ការបកប្រែរបៀបផ្សេងទៀត: «នៅផ្នែកខាងត្បូង»
សិរីល្អរបស់ព្រះអម្ចាស់
ការបកប្រែមាននៅក្នុងជំពូក ១:២៧
ពេញព្រះដំណាក់
ពាក្យថា «វា» សំដៅទៅលើសិរីរុងរឿងរបស់ព្រះជាម្ចាស់។
Ezekiel 10:6
នៅក្នុងពេលនោះ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់កន្លែងដែលសកម្មភាពចាប់ផ្តើម។
ប្រសិនបើភាសារបស់អ្នកមានវិធីប្រើ ដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
ព្រះអម្ចាស់បង្គាប់ទៅបុរសដែលពាក់អាវទេសឯកថា
នេះគឺជាព័ត៌មានដដែលៗ ដែលត្រូវបានផ្តល់ឲ្យនៅក្នុងជំពូក ១០:១។
បន្ទាប់ពីនិយាយអំពីចេរូប៊ីននិងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅក្នុងជំពូក ១០:៣-៥
នោះលោកអេសេគាលត្រឡប់ទៅប្រាប់អំពីបុរស ដែលស្លៀកសំពត់ទេសឯក។

generated on Wed Sep 10 16:16:32 2025

បុរសដែលពាក់អាវទេសឯក
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យថា «ទេសឯក» នៅក្នុងជំពូក ៩:១។
ក្បែរកង់
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យថា «កង់» នៅក្នុងជំពូក ១:១៥។
ខ្ញុំក៏បានឃើញ នៅក្រោមស្លាបរបស់ពួកចេរូប៊ីន មានហាក់ដូចជាដៃរបស់មនុស្សលេចចេញមក។
«យើងបានឃើញចេរូប៊ីនមានអ្វីមួយដូចដៃមនុស្សនៅក្រោមស្លាបរបស់ពួកគេ»
Ezekiel 10:9
មើល៍!
ពាក្យថា «មើល»
នៅទីនេះបង្ហាញថាលោកអេសេគាលមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។
កង់
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ១:១៥។
ចេរូប៊ីន
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ១០:១។
ដូចត្បូងពេជ្រ
«ពេជ្រ» គឺជាថ្មរឹង និងមានតម្លៃណាស់។ បីរីនេះប្រហែលជាពណ៌បៃតង
ឬពណ៌ខៀវ។ ត្បូងមរតក គឺជាប្រភេទពណ៌បៃតងនៃបីរីឡិន និងត្បូងទឹកសមុទ្រ
គឺជាប្រភេទត្បូងពណ៌ខៀវ។
ហាក់ដូចជាកង់មួយស្ថិតនៅក្នុងកង់មួយទៀត
ពាក្យ «ប្រសព្វគ្នា» មានន័យថា «ឆ្លងកាត់» ឬ «ការប្រជុំ» ឬ «ប៉ះ»។
ពួកកង់ទាំងនោះវិលទៅមុខ
«នៅទីណាដែលចេរូប៊ីនកំពុងប្រឈម» ឬ «កន្លែងណាដែលចេរូប៊ីនកំពុងទៅ»
ក្បាល
នេះសំដៅទៅលើក្បាលរបស់ចេរូប៊ីនណាមួយ។
Ezekiel 10:12
រូបកាយរបស់ចេរូប៊ីនទាំងមូល
«រូបកាយរបស់ចេរូប៊ីនទាំងមូល»
កង់
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យថា «កង់» នៅក្នុងជំពូក ១:១៥។
កង់ទាំងនោះត្រូវបានហៅថា «ខ្យល់កួច»
ពាក្យថា «ខ្យល់កួច» មានន័យថា «វិល»។ នេះជាឈ្មោះកង់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មានគេហៅកង់ថា» «ខ្យល់កួច»
ពួកចេរូប៊ីននីមួយៗមានមុខបួន
«ចេរូប៊ីននីមួយៗមានមុខបួន ឬ ចេរូប៊ីននីមួយៗមានមុខបួន។
«ចេរូប៊ីននីមួយៗមានមុខនៅខាងមុខ ផ្នែកខាងក្រោយ
និងផ្នែកខាងមុខនៃក្បាលនីមួយៗ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:៤។
ចេរូប៊ីន
សូមមើលពីរបៀបដែលអ្នកបានបកប្រែចេរូប៊ីននៅក្នុងជំពូក ១០:៣។
Ezekiel 10:15
ចេរូប៊ីន
សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះនៅក្នុងជំពូក ១: ១០។
តួរមានជីវិត
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ១:១៣។
ទន្លេកេបារ
នេះជាទឹកទន្លេដែលប្រជាជននៅស្រុកខាល់ដេបានជីក
ដើម្បីផ្តល់ទឹកដល់សួនច្បាររបស់ពួកគេ។ ការបកប្រែដូចនៅក្នុងជំពូក ១:១។
ជន់ឡើង
«ឡើងលើអាកាស»
ពួកគេនៅតែស្ទាក់នៅក្បែរពួកគេ
«កង់ស្ថិតនៅជាមួយចេរូប៊ីន»។ ការបកប្រែជំនួស៖
«កង់បានផ្លាស់ទៅជាមួយចេរូប៊ីន»។
ឈប់នៅស្ងៀម
«នៅស្ងៀម» ឬ «មិនបានផ្លាស់ទីលំនៅ»
ដ្បិតវិញ្ញាណនៃតួរមានជីវិតសណ្ឋិតនៅក្នុងកង់ទាំងនោះ
អត្ថន័យដែលអាចមាន: ១) «វិញ្ញាណរបស់តួរមានជីវិតគ្រប់គ្រងកង់» ឬ ២)
«វិញ្ញាណរបស់តួរមានជីវិតគឺដូចគ្នានឹងវិញ្ញាណដែលស្ថិតនៅក្នុងកង់ដែរ»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១៩។
Ezekiel 10:18
សិរីល្អនៃព្រះអម្ចាស់
ការបកប្រែមាននៅក្នុងជំពូក ១:២៧។
ព្រះវិហារ
នេះសំដៅទៅលើព្រះវិហាររបស់ព្រះអង្គ។
សណ្ឋិតពីលើ
«បាននៅពីលើ»
ឈរ
នៅទីនេះពាក្យថា «ឈរ» មានន័យថា «បញ្ឈប់» ឬ «រង់ចាំ»។
ក៏សណ្ឋិតនៅពីលើ
«បានទៅពីលើពួកចេរូប៊ីន»
Ezekiel 10:20
តួរដែលមានជីវិត
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១៣។
ទន្លេកេបារ
នេះជាទឹកទន្លេដែលប្រជាជននៅស្រុកខាល់ដេបានជីក
ដើម្បីផ្តល់ទឹកដល់សួនច្បាររបស់ពួកគេ។ ការបកប្រែដូចនៅក្នុងជំពូក ១:១។
ត្រង់ទៅខាងមុខ
«បានឆ្ពោះទៅមុខ» ឬ «បានមើលទៅមុខដោយផ្ទាល់»

11 [1]ព្រះវិញ្ញាណលើកខ្ញុំឡើង នាំទៅឯទ្វារកំផែងទិសខាងកើតរបស់ព្រះវិហារនៃព្រះអម្ចាស់ ជាទ្វារដែលបើកទៅទិសខាងកើត នោះឃើញនៅមាត់ទ្វារកំផែង មានមនុស្ស
ម្ភៃប្រាំនាក់ ហើយនៅកណ្តាលអ្នកទាំងនោះ។ ខ្ញុំឃើញមានយ៉ាសានា ជាកូនអស៊ើរ ហើយពេឡាធា ជាកូនបេណាយ៉ា ទាំងពីរនាក់ជាអ្នកដឹកនាំក្នុងចំណោមពួកគេ។
[2]ព្រះអង្គមានព្រះបន្ទូលមកខ្ញុំ «កូនមនុស្សអើយ គឺមនុស្សទាំងនេះហើយដែលគិតគូរបង្កើតការទុច្ចរិត ហើយទូន្មានសេចក្តីអាក្រក់នៅក្នុងទីក្រុងនេះ។[3]ពួកគេនិយាយថា
នេះមិនមែនជាពេលដែលត្រូវសង់ផ្ទះទេ ទីក្រុងនេះជាថ្លាង ហើយយើងរាល់គ្នាជាសាច់។[4]ដូច្នេះហើយ កូនមនុស្សអើយ ចូរថ្លែងព្រះបន្ទូលទាស់នឹងពួកគេ»។
[5]ព្រះវិញ្ញាណនៃព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ហើយព្រះអង្គមានព្រះបន្ទូលមកខ្ញុំ «ចូរនិយាយ នេះគឺជាព្រះអម្ចាស់មានព្រះបន្ទូល៖ ប្រជាជនអ៊ីស្រាអែលអើយ ដ្បិតយើងស្គាល់
អ្វីដែលនៅក្នុងគំនិតរបស់អ្នក។[6]អ្នករាល់គ្នាបានសម្លាប់មនុស្សនៅក្នុងទីក្រុងនេះកាន់តែច្រើនឡើង ហើយទុកសពគេពាសពេញផ្លូវ។[7]ហេតុនោះ ព្រះអម្ចាស់មានព្រះបន្ទូល
ដូចនេះ ពួកអ្នកដែលអ្នករាល់គ្នាបានសម្លាប់ផ្តេកនៅកណ្តាលទីក្រុងយេរូ៉ាសាឡិម គឺជាសាច់នោះ ហើយទីក្រុងនេះជាថ្លាង។ ប៉ុន្តែចំណែកអ្នករាល់គ្នា យើងនឹងនាំចេញទៅ
ក្រៅពីទីក្រុងវិញ។
[8]អ្នករាល់គ្នាខ្លាចដាវ ដូច្នោះ យើងនឹងនាំដាវមកលើដល់អ្នក នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។[9]យើងនឹងនាំអ្នករាល់គ្នាចេញទៅក្រៅទីក្រុង ហើយប្រគល់ទៅក្នុង
កណ្តាប់ដៃនៃជនជាតិដទៃ ព្រមទាំងនាំការជំនុំជម្រះទាស់និងអ្នក។[10]អ្នករាល់គ្នានឹងត្រូវដួលដោយដាវ។ យើងនឹងជំនុំជម្រះអ្នក នៅត្រង់ព្រំប្រទល់ទឹកដីអ៊ីស្រាអែល ហើយ
អ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់។
[11]ទីក្រុងនេះនឹងមិនមែនជាថ្លាងសម្រាប់អ្នករាល់គ្នាឡើយ អ្នករាល់គ្នាក៏មិនត្រូវជាសាច់នៅក្នុងថ្លាងនោះដែរ គឺយើងនឹងជំនុំជម្រះអ្នក នៅត្រង់ព្រំប្រទល់ទឹកដីអ៊ីស្រាអែល
វិញ[12]បន្ទាប់មកអ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់ ជាអ្នកដាក់ច្បាប់ អ្នកមិនដើរតាមក្រឹត្យក្រមរបស់យើងទេ ក៏មិនបានធ្វើតាមបញ្ញត្តិរបស់យើងដែរ។
តែអ្នកបានប្រព្រឹត្តតាមបញ្ញត្តិច្បាប់របស់ជនជាតិដទៃទាំងនោះ ដែលនៅជុំវិញអ្នកវិញ»។
[13]ក្នុងកាលដែលខ្ញុំកំពុងតែថ្លែងព្រះបន្ទូល នោះពេឡាធា ជាកូនបេណាយ៉ាក៏ស្លាប់ទៅ។ ដូច្នោះ ខ្ញុំក៏ក្រាបផ្កាប់មុខយំដោយសំឡេងយ៉ាងខ្លាំងថា «បពិត្រ ព្រះអម្ចាស់អើយ
តើព្រះអង្គនឹងធ្វើឲ្យសំណល់ជនជាតិអ៊ីស្រាអែល វិនាសទាំងអស់ឬ?»
[14]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ[15]«កូនមនុស្សអើយ គឺជាបងប្អូនអ្នកបង្កើតទេតើ! ព្រមទាំងបងប្អូនអ្នក! ដែលជាញាតិសន្តាន និងពូជពង្សអ៊ីស្រាអែលទាំងមូល គឺ
ពួកគេជាពួកអ្នកនៅក្រុងយេរូសាឡិមបានពោលថា «ពួកគេឆ្ងាយពីព្រះអម្ចាស់! ទឹកដីនេះបានប្រគល់មកពួកយើងទុកជាសម្បត្តិហើយ»។

generated on Wed Sep 10 16:16:32 2025

[16]ដូច្នោះហើយចូរនិយាយ «ព្រះជាអម្ចាស់មានព្រះបន្ទូលដូចនេះ ទោះបីយើងបណ្តេញអ្នករាល់គ្នាទៅក្នុងចំណោមប្រជាជាតិទាំងនោះ ទោះបីយើងកម្ចាត់កម្ចាយអ្នករាល់គ្នាទៅតាមទឹកដីផ្សេងៗក្តី ក៏យើងនឹងធ្វើជាទីសក្ការៈសម្រាប់អ្នករាល់គ្នានៅក្នុងទឹកដីទាំងនោះដែរ» ។[17]ដូចោះហើយចូរនិយាយ «ព្រះជាអម្ចាស់មានព្រះបន្ទូលដូចនេះ យើងនឹងនាំអ្នករាល់គ្នាចេញពីកណ្តាលចំណោមជនជាតិទាំងនោះមកវិញ យើងនឹងប្រមូលអ្នករាល់គ្នាពីទឹកដីទាំងឡាយ ដែលអ្នករាល់គ្នាខ្ចាត់ខ្ចាយទៅ ហើយយើងនឹងប្រគល់ទឹកដីដល់អ៊ីស្រាអែល។[18]រួចហើយពួកគេនឹងនាំគ្នាត្រឡប់មកវិញ ហើយដកព្រះក្លែងក្លាយដ៏ចង្រៃគួរឲ្យស្អប់ខ្ពើមទាំងប៉ុន្មាន ចេញពីទឹកដីនេះ។
[19]យើងនឹងឲ្យគេមានចិត្តតែមួយ ហើយនឹងដាក់វិញ្ញាណថ្មីមួយក្នុងគេ យើងនឹងដកចិត្តដែលរឹងដូចថ្មពីរូបសាច់គេចេញ ហើយនឹងឲ្យមានចិត្តជាសាច់វិញ[20]ដើម្បីឲ្យគេបានប្រព្រឹត្តតាមក្រឹត្យក្រមរបស់យើង ហើយរក្សាបញ្ញត្តិច្បាប់របស់យើង ព្រមទាំងប្រព្រឹត្តតាមផង នោះគេនឹងបានជាប្រជារាស្ត្ររបស់យើង ហើយយើងនឹងធ្វើជាព្រះជាម្ចាស់ដល់គេ។[21]ប៉ុន្តែអស់អ្នកដែលមានចិត្តប្រព្រឹត្តតាមរូបព្រះគួរឆ្អើម និងសេចក្តីគួរស្អប់ខ្ពើមរបស់គេ យើងនឹងទម្លាក់អំពើរបស់គេទៅលើក្បាលគេវិញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់»។
[22]ពួកចេរូប៊ីនក៏កាងស្លាបហោះទៅ កង់ទាំងនោះក៏ទៅជាមួយដែរ ហើយសិរីល្អរបស់ព្រះនៃជនជាតិអ៊ីស្រាអែលសណ្ឋិតពីលើ[23]ក្រោយមក សិរីល្អរបស់ព្រះអម្ចាស់យាងចេញពីកណ្តាលបណ្តាលជនឡើងទៅទីក្រុង ហើយក៏សណ្ឋិតលើភ្នំនៅទិសខាងកើតនៃទីក្រុង។
[24]ព្រះវិញ្ញាណក៏លើកខ្ញុំឡើង ហើយព្រះអង្គនាំខ្ញុំទៅដល់ស្រុកខាល់ដេ ទៅរកពួកនិរទេស ក្នុងនិមិត្តដោយនូវព្រះវិញ្ញាណនៃព្រះជាម្ចាស់ ហើយក្នុងនិមិត្តដែលខ្ញុំបានឃើញក៏ចេញបាត់ពីខ្ញុំទៅ។[25]រួចហើយខ្ញុំនិយាយប្រកាស់ប្រាប់ដល់ពួកអ្នកដែលនៅជាឈ្លើយ តាមគ្រប់ទាំងការដែលព្រះអម្ចាស់បានបង្ហាញខ្ញុំ។

Ezekiel 11:1

ព័ត៌មានទូទៅ:

លោកអេសេគាលបន្តប្រាប់អំពីនិមិត្តដែលបានចាប់ផ្តើមនៅក្នុងជំពូក ៨:១។

បែរមុខទៅទិសខាងកើត

«ដែលប្រឈមមុខនឹងខាងកើត»។ «ច្រកទ្វារខាងកើត» បែរមុខទៅទិសខាងកើត។

មើល

ពាក្យថា «មើល»

នៅទីនេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើងនេះ។

ព្រះវិហារនៃព្រះអម្ចាស់

បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើនៅក្នុងជំពូក ៨:១៦។

ក្នុងចំណោមពួកគេ

«ក្នុងចំណោមបុរស ២៥ នាក់»

Ezekiel 11:2

ព័ត៌មានទូទៅ:

លោកអេសេគាលបន្តប្រាប់អំពីនិមិត្តរបស់គាត់។

កូនមនុស្សអើយ

«កូនប្រុសរបស់មនុស្ស» ឬ «កូនមនុស្សជាតិ»។

ព្រះជាម្ចាស់ហៅលោកអេសេគាលនេះដើម្បីបញ្ជាក់ថាលោកអេសេគាលគ្រាន់តែជាមនុស្សប៉ុណ្ណោះ។

ព្រះមានឫទ្ធានុភាព និងរស់នៅជារៀងរហូត ប៉ុន្តែមនុស្សមិនមែនទេ។

«មនុស្សរមែងស្លាប់» ឬ «មនុស្ស»

ទីក្រុងនេះជាថ្លាង ហើយយើងរាល់គ្នាជាសាច់

ប្រជាជននិយាយអំពីខ្លួនពួកគេ ដូចជាពួកគេគឺជាអ្នកកាត់សាច់

និងទីក្រុងហាក់ដូចជាវាជាឆ្នាំងដែលសាច់ត្រូវបានរក្សាទុក ឬចម្អិន។

ពាក្យប្រៀបធៀបបង្ហាញថាពួកគេសំខាន់ និងមានសុវត្ថិភាពនៅក្នុងទីក្រុង។

ការបកប្រែរបៀបផ្សេងទៀត:

«ទីក្រុងនេះប្រៀបដូចជាឆ្នាំងដែលនឹងការពារយើងដូចជាឆ្នាំងការពារសាច់»។

ថ្លាង

អត្ថន័យដែលអាចមានគឺ ១) ឆ្នាំងសំរាប់ទុកសាច់ ឬ ២) ឆ្នាំងសំរាប់ចម្អិនសាច់។

Ezekiel 11:5

ព័ត៌មានទូទៅ :

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅព្យាការីលោកអេសេគាល។

ព្រះវិញ្ញាណនៃព្រះអម្ចាស់សណ្ឋិតលើខ្ញុំ

លោកអេសេគាលនិយាយអំពីព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ដែលបំផុសគំនិត

និងផ្តល់កម្លាំងចិត្តឲ្យលោកទាយដូចជាព្រះវិញ្ញាណរបស់ព្រះអម្ចាស់មកសណ្ឋិតលើលោកវាង

ការបកប្រែរបៀបផ្សេងទៀត:

«ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានប្រទានអំណាចដល់ខ្ញុំ»

ប្រជាជនអ៊ីស្រាអែល

ពាក្យថា «ផ្ទះ»

គឺជាពាក្យកាត់សម្រាប់គ្រួសារក្នុងករណីជនជាតិអ៊ីស្រាអែលដែលជាកូនចៅរបស់យ៉ាកុប

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៣:១។

ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអ៊ីស្រាអែល»

ចូរនិយាយ

«អ្នកកំពុងនិយាយរឿងទាំងនេះ»។

នេះសំដៅទៅលើអ្វីដែលប្រជាជនបាននិយាយនៅក្នុងជំពូក ១១: ២។

ពួកអ្នកដែលអ្នករាល់គ្នាបានសម្លាប់ផ្តេកនៅកណ្តាលទីក្រុងយេរូសាឡិម គឺជាសាច់នោះ ហើយទីក្រុងនេះជាថ្លាង

ព្រះអម្ចាស់មានព្រះបន្ទូលទៅប្រជាជនដែលពួកគេបានសម្លាប់

ដូចជាពួកគេបានកាត់សាច់ និងទីក្រុងសក្ការុនពលដែលសាច់ត្រូវបានរក្សាទុក

ឬចំអិន។ សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យប្រៀបធៀបនេះនៅក្នុងជំពូក ១១:២។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលអ្នកបានសម្លាប់...

គឺដូចជាសាច់នៅក្នុងឆ្នាំង ហើយទីក្រុងនេះគឺជាថ្លាង។

ប៉ុន្តែចំណែកអ្នករាល់គ្នា យើងនឹងនាំចេញទៅ

ការបកប្រែរបៀបផ្សេងទៀត: ការនេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ប៉ុន្តែយើងនឹងនាំអ្នកចេញ»

Ezekiel 11:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តផ្តល់សាររបស់ទ្រង់ដល់ជនជាតិអ៊ីស្រាអែល។

អ្នករាល់គ្នាខ្លាចដាវ ដូច្នោះ យើងនឹងនាំដាវមកលើអ្នក

ពាក្យថា «ដាវ»

គឺជាពាក្យប្រៀបធៀបសម្រាប់កងទ័ពសត្រូវដែលនឹងវាយប្រហារដោយដាវរបស់ពួកគេ។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកខ្លាចសង្គ្រាម

ដូច្នេះយើងនឹងនាំកងទ័ពសត្រូវមកវាយប្រហារអ្នករាល់គ្នា»

ព្រះជាម្ចាស់ប្រើប្រាស់ពាក្យ «ដៃ» ដើម្បីបញ្ជាក់ពីការគ្រប់គ្រងរបស់ទ្រង់។

ព្រះមានឫទ្ធានុភាព និងរស់នៅជារៀងរហូត ប៉ុន្តែមនុស្សមិនមែនទេ។

«មនុស្សរមែងស្លាប់» ឬ «មនុស្ស»

ទីក្រុងនេះជាថ្លាង ហើយយើងរាល់គ្នាជាសាច់

ប្រជាជននិយាយអំពីខ្លួនពួកគេ ដូចជាពួកគេគឺជាអ្នកកាត់សាច់

និងទីក្រុងហាក់ដូចជាវាជាឆ្នាំងដែលសាច់ត្រូវបានរក្សាទុក ឬចម្អិន។

ពាក្យប្រៀបធៀបបង្ហាញថាពួកគេសំខាន់ និងមានសុវត្ថិភាពនៅក្នុងទីក្រុង។

ការបកប្រែរបៀបផ្សេងទៀត:

«ទីក្រុងនេះប្រៀបដូចជាឆ្នាំងដែលនឹងការពារយើងដូចជាឆ្នាំងការពារសាច់»។

ថ្លាង

អត្ថន័យដែលអាចមានគឺ ១) ឆ្នាំងសំរាប់ទុកសាច់ ឬ ២) ឆ្នាំងសំរាប់ចម្អិនសាច់។

Ezekiel 11:5

ព័ត៌មានទូទៅ :

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅព្យាការីលោកអេសេគាល។

ព្រះវិញ្ញាណនៃព្រះអម្ចាស់សណ្ឋិតលើខ្ញុំ

លោកអេសេគាលនិយាយអំពីព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ដែលបំផុសគំនិត

និងផ្តល់កម្លាំងចិត្តឲ្យលោកទាយដូចជាព្រះវិញ្ញាណរបស់ព្រះអម្ចាស់មកសណ្ឋិតលើលោកវាង

ការបកប្រែរបៀបផ្សេងទៀត:

«ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានប្រទានអំណាចដល់ខ្ញុំ»

ប្រជាជនអ៊ីស្រាអែល

ពាក្យថា «ផ្ទះ»

គឺជាពាក្យកាត់សម្រាប់គ្រួសារក្នុងករណីជនជាតិអ៊ីស្រាអែលដែលជាកូនចៅរបស់យ៉ាកុប

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៣:១។

ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអ៊ីស្រាអែល»

ចូរនិយាយ

«អ្នកកំពុងនិយាយរឿងទាំងនេះ»។

នេះសំដៅទៅលើអ្វីដែលប្រជាជនបាននិយាយនៅក្នុងជំពូក ១១: ២។

ពួកអ្នកដែលអ្នករាល់គ្នាបានសម្លាប់ផ្តេកនៅកណ្តាលទីក្រុងយេរូសាឡិម គឺជាសាច់នោះ ហើយទីក្រុងនេះជាថ្លាង

ព្រះអម្ចាស់មានព្រះបន្ទូលទៅប្រជាជនដែលពួកគេបានសម្លាប់

ដូចជាពួកគេបានកាត់សាច់ និងទីក្រុងសក្ការុនពលដែលសាច់ត្រូវបានរក្សាទុក

ឬចំអិន។ សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យប្រៀបធៀបនេះនៅក្នុងជំពូក ១១:២។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលអ្នកបានសម្លាប់...

គឺដូចជាសាច់នៅក្នុងឆ្នាំង ហើយទីក្រុងនេះគឺជាថ្លាង។

ប៉ុន្តែចំណែកអ្នករាល់គ្នា យើងនឹងនាំចេញទៅ

ការបកប្រែរបៀបផ្សេងទៀត: ការនេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ប៉ុន្តែយើងនឹងនាំអ្នកចេញ»

Ezekiel 11:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តផ្តល់សាររបស់ទ្រង់ដល់ជនជាតិអ៊ីស្រាអែល។

អ្នករាល់គ្នាខ្លាចដាវ ដូច្នោះ យើងនឹងនាំដាវមកលើអ្នក

ពាក្យថា «ដាវ»

គឺជាពាក្យប្រៀបធៀបសម្រាប់កងទ័ពសត្រូវដែលនឹងវាយប្រហារដោយដាវរបស់ពួកគេ។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកខ្លាចសង្គ្រាម

ដូច្នេះយើងនឹងនាំកងទ័ពសត្រូវមកវាយប្រហារអ្នករាល់គ្នា»

ព្រះជាម្ចាស់ប្រើប្រាស់ពាក្យ «ដៃ» ដើម្បីបញ្ជាក់ពីការគ្រប់គ្រងរបស់ទ្រង់។

នៅទីនេះពាក្យថា «ដៃ» នៅទីនេះតំណាងឲ្យអំណាច ឬការគ្រប់គ្រង។

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងប្រគល់អ្នកទៅក្នុងអំណាចរបស់ជនបរទេស» ឬ

«យើងនឹងអនុញ្ញាតឲ្យជនបរទេសចាប់អ្នករាល់គ្នា»

អ្នករាល់គ្នានឹងត្រូវដួលដោយដាវ

ពាក្យថា «ដាវ»

គឺជាពាក្យប្រៀបធៀបសម្រាប់កងទ័ពសត្រូវដែលនឹងវាយប្រហារពួកគេដោយដាវ។

ចំពោះ «ដួលដោយដាវ» មានន័យថាពួកគេនឹងត្រូវស្លាប់ដោយដាវ។

ការបកប្រែរបៀបផ្សេងទៀត:

«ពួកគេនឹងសម្លាប់អ្នកដោយដាវរបស់ពួកគេ» (UDB) ឬ

«អ្នកនឹងស្លាប់នៅក្នុងសមរភូមិ»

អ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់

អត្ថន័យដែលអាចមានគឺ ១) «អ្នកនឹងយល់ថាតើយើងដែលជាព្រះអម្ចាស់» ឬ ២) «អ្នកនឹងយល់ថាយើងជាព្រះអម្ចាស់ជាព្រះពិតតែមួយ» ឬ ៣) «អ្នកនឹងដឹងថាយើងជាព្រះអម្ចាស់មានអំណាចធ្វើ

រឿងដែលយើងនិយាយថាយើងនឹងធ្វើ» (UDB)

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៦:៦។

Ezekiel 11:11

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តផ្តល់សារដល់ជនជាតិអ៊ីស្រាអែល។

ទីក្រុងនេះនឹងមិនមែនជាថ្លាងសម្រាប់អ្នករាល់គ្នាឡើយ អ្នករាល់គ្នាក៏មិនត្រូវជាសាច់

សូមមើលកំណត់ចំណាំនៅក្នុងជំពូក ១១:២។

នៅត្រង់ព្រំប្រទល់

ឃ្លានេះប្រើព្រំប្រទល់ដើម្បីតំណាងឲ្យអ៊ីស្រាអែល។

ព្រំប្រទល់

តែមខាងក្រៅនៃប្រទេស ឬ ទឹកដី

អ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៦:៦។

Ezekiel 11:13

ក្នុងកាលដែល

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ព្រឹត្តិការណ៍សំខាន់មួយនៅក្នុងរឿង។ ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។

ពេឡាធា ជាកូនបេណាយ៉ា

គាត់ជាមេដឹកនាំអាក្រក់ម្នាក់របស់អ៊ីស្រាអែលដែលបានរៀបរាប់នៅក្នុងជំពូក ១១:១។

ខ្ញុំក៏ក្រាបផ្កាប់មុខ

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:២៧។

បពិត្រ

លោកអេសេគាលនិយាយបែបនេះដើម្បីបង្ហាញការភ័យខ្លាចរបស់គាត់អំពីអ្វីដែលនឹងកើត

Ezekiel 11:14

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់មានព្រះបន្ទូលមកលោក»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។

បងប្អូនអ្នកបង្កើតទេតើ! ព្រមទាំងបងប្អូនអ្នក!

នេះត្រូវបានបញ្ជាក់ពីរដងសម្រាប់ការសង្កត់ធ្ងន់។

ពូជពង្សអ៊ីស្រាអែល

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។

ពូជពង្សអ៊ីស្រាអែលទាំងមូល គឺពួកគេជាពួកអ្នកនៅក្រុងយេរូសាឡិមបានពោលថា

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេទាំងអស់គឺជាអ្នកដែលប្រជាជននៅក្រុងយេរូសាឡិមកំពុងនិយាយ» ឬ «ប្រជាជនដែលរស់នៅក្នុងក្រុងយេរូសាឡិមនិយាយអំពីពួកគេ»

ពូជពង្សអ៊ីស្រាអែលទាំងមូល គឺពួកគេជាពួកអ្នកដែលបានពោលថា

ជំនាន់ទំនើបខ្លះមាន «ទាំងអស់នោះគឺជាអ្វីដែលត្រូវបានគេនិយាយ»។

Ezekiel 11:16

ព័ត៌មានទូទៅ:

ព្រះអម្ចាស់ឲ្យសារទៅលោកអេសេគាលអំពីអ៊ីស្រាអែលជនដែលខ្ចាត់ខ្ចាយ។

យើងនឹងធ្វើជាទីសក្ការៈសម្រាប់អ្នករាល់គ្នា

ការបកប្រែរបៀបផ្សេងទៀត: «យើងបាននៅជាមួយពួកគេ ដើម្បីថែរក្សាពួកគេ»។

អ្នករាល់គ្នានៅក្នុងទឹកដីទាំងនោះដែល

ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជាតិនានាដែលពួកគេត្រូវបានចាប់ខ្លួន»

យើងនឹងប្រមូលអ្នករាល់គ្នាពីទឹកដីទាំងឡាយ ដែលអ្នករាល់គ្នាខ្ចាត់ខ្ចាយទៅ ហើយយើងនឹងប្រគល់ទឹកដី

ព្រះអម្ចាស់មានបន្ទូលការសន្យានេះពីរដងតាមរបៀបផ្សេងៗគ្នាដើម្បីបង្ហាញថាវាសំខាន់។

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងនាំអ្នកចេញពីប្រជាជាតិនានា»

ស្អប់ខ្ពើម

ការបកប្រែរបៀបផ្សេងទៀត: «គួរឲ្យរន្ធត់» ឬ «វាយលុក»

Ezekiel 11:19

ព័ត៌មានទូទៅ:

ព្រះអង្គនៅតែបន្តទំនាយអំពីអ្វីដែលនឹងកើតឡើងចំពោះជនជាតិអ៊ីស្រាអែលជនដែលខ្ចាត់ខ្ចាយ។

ចិត្តដែលរឹងដូចថ្មពីរូបសាច់គេចេញ

នេះគឺជាវិធីនៃការនិយាយថាព្រះអង្គនឹងផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេពីការបះបោររឹងរូស។

ការបកប្រែរបៀបផ្សេងទៀត: «ភាពរឹងចចេសរបស់ពួកគេ»

ចិត្តជាសាច់

នឹងផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេដើម្បីទទួលយកការគ្រប់គ្រ

ការបកប្រែរបៀបផ្សេងទៀត: «ឆន្ទៈក្នុងការគោរពតាម»

គេបានប្រព្រឹត្តតាមក្រឹត្យក្រមរបស់យើង ហើយរក្សាបញ្ញត្តិច្បាប់របស់យើង ព្រមទាំងប្រព្រឹត្តតាមផង

ឃ្លានីមួយៗពិពណ៌នាអំពីប្រជាជនថាគោរពតាមអ្វីដែលព្រះអម្ចាស់បានបញ្ជាពួកគេអោយធ្វើ។

មានឥទ្ធិពល

ការបកប្រែរបៀបផ្សេងទៀត: «ភក្តីភាព»

គួរស្អប់ខ្ពើម

ការបកប្រែរបៀបផ្សេងទៀត: «រឿងដែលគួរឲ្យធុញទ្រាន» ឬ «រឿងប្រមាថ»

អំពើរបស់គេ

ការបកប្រែរបៀបផ្សេងទៀត: «សកម្មភាព»

ទៅលើក្បាលគេវិញ

ការបកប្រែរបៀបផ្សេងទៀត: «ត្រលប់ទៅមនុស្សទាំងនោះ»។

សេចក្តីប្រកាស

ការបកប្រែរបៀបផ្សេងទៀត: «សេចក្តីថ្លែងការណ៍»

Ezekiel 11:22

ព័ត៌មានទូទៅ:

ចេរូប៊ីននៃជំពូកទី ១០ ចេញពីព្រះវិហារ

និងទីក្រុងរួមជាមួយសិរីរុងរឿងរបស់ព្រះជាម្ចាស់។

កង់ទាំងនោះក៏ទៅជាមួយដែរ

សូមមើលពីរបៀបដែលបានបកប្រែ «កង់» នៅក្នុងជំពូក ១:១៥។

Ezekiel 11:24

និរទេស

«ជននិរទេសខ្លួន»

សំដៅទៅលើជនជាតិអ៊ីស្រាអែលដែលត្រូវបានបង្ខំឲ្យរស់នៅក្នុងស្រុកខាល់ដេ។

---

12 [1]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំដោយព្រះបន្ទូល[2]«កូនមនុស្សអើយ អ្នករស់នៅក្នុងចំណោមពូជបះបោរជាពួកអ្នកដែលមានភ្នែកសម្រាប់មើល តែមើលមិនឃើញទេ ហើយមានត្រចៀកសម្រាប់ស្តាប់ តែស្តាប់មិនឮដែរ ដ្បិតគេជាពូជទាស់ប្រឆាំង។
[3]ដូច្នោះហើយសម្រាប់អ្នក កូនមនុស្សអើយ ចូររៀបចំអីវ៉ាន់ សម្រាប់ដំណើរនិរទេស ហើយដើរចេញទៅ ទាំងថ្ងៃនៅចំពោះភ្នែកគេចុះ អ្នកត្រូវរើចេញពីកន្លែងអ្នក ទៅកន្លែងមួយទៀត។ ប្រហែលជាគេនឹងពិចារណាយល់ ទោះបើពួកគេជាពូជរឹងទទឹងក៏ដោយ។
[4]អ្នកត្រូវរើយកអីវ៉ាន់អ្នកចាកចេញនៅពេលថ្ងៃ ចំពោះភ្នែកគេ ធ្វើដូចជារៀបចំនឹងត្រូវនិរទេសទៅ ហើយខ្លួនអ្នកត្រូវចេញទៅនៅពេលល្ងាចចំពោះភ្នែកគេ បែបដូចជាមនុស្សដែលត្រូវនិរទេស។[5]ចូរជីកទម្លុះកំផែងនៅចំពោះភ្នែកគេ ហើយបញ្ចេញអីវ៉ាន់ទៅតាមនោះចុះ។[6]អ្នកត្រូវលីអីវ៉ាន់អ្នកនៅមុខគេ
លើកអីវ៉ាន់ដាក់លើស្មារហើយចេញទៅទាំងយប់។ ត្រូវបាំងមុខ ដ្បិតអ្នកនឹងមិនឲ្យឃើញទឹកដីឡើយ យើងតាំងអ្នកទុកជាទីសម្គាល់ ដល់ពូជពង្សអ៊ីស្រាអែល»។
[7]ដូច្នេះខ្ញុំក៏ធ្វើការនេះ ដូចអ្វីដែលយើងបង្គាប់។ ខ្ញុំបានយកអីវ៉ាន់ ធ្វើនិរទេសចេញទាំងថ្ងៃ ហើយនៅពេលល្ងាចខ្ញុំជីកទម្លុះរូងឲ្យដល់កំផែងដោយដៃខ្ញុំ។ ខ្ញុំក៏បានយកអីវ៉ាន់របស់ខ្ញុំក្នុងពេលទីងងឹត ហើយលីអីវ៉ាន់ឡើងដាក់លើស្មាយកទៅនៅចំពោះភ្នែកពួកគេ។
[8]បន្ទាប់មកព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំនៅពេលព្រឹកដោយបន្ទូលថា[9]កូនមនុស្សអើយ តើប្រជាជនអ៊ីស្រាអែលជាអ្នកបះបោរ មិនសួរអ្នកទេថា «តើអ្នកកំពុងធ្វើអ្វី?»[10]ចូរប្រាប់គេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ការថ្លែងព្រះបន្ទូលនេះ ដោយបារម្ភពីអ្នកដឹកនាំនៃក្រុងយេរូសាឡិម ហើយប្រជាជនអ៊ីស្រាអែលទាំងអស់គ្នា។
[11]ចូរនិយាយថា ខ្ញុំជាទីសម្គាល់ដល់អ្នករាល់គ្នា។ ដូច្នោះវានឹងបានធ្វើកើតឡើង ពួកគេនឹងទៅជានិរទេសហើយទៅជាឈ្លើយ។[12]អ្នកដដឹកនាំដែលនៅក្នុងចំណោមពួកគេនឹងលីអីវ៉ាន់ដាក់ លើស្មារបស់គាត់ចេញទៅក្នុងងងឹត ហើយនឹងឆ្លងកាត់ ជញ្ជាំង។ ពួកគេនឹងជិះរូងឆ្លងទៅដល់ជញ្ជាំង ដើម្បីយកអីវ៉ាន់របស់ពួកគេ។ គាត់នឹងបាំងមុខខ្លួនឯង ដូច្នោះគាត់នឹងមិនឃើញទឹកដីដោយភ្នែកឡើយ។[13]យើងនឹងដាក់សំណាញរបស់យើងលើគេ ហើយគាត់នឹងជាប់អន្ទាក់របស់យើង ហើយយើងនឹងនាំគាត់ទៅបាប៊ីឡូន ជាទឹកដីពួកខាល់ដេ ប៉ុន្តែគេនឹងមិនឃើញវាទេ។ គាត់នឹងស្លាប់នៅទីនោះ។
[14]យើងនឹងកម្ចាត់កម្ចាយពួកអ្នកដែលនៅជុំវិញលោក និងកងទ័ពរបស់លោកទាំងប៉ុន្មានទៅតាមខ្យល់គ្រប់ទិស រួចយើងនឹងហូតដាវទៅតាមក្រោយគេ។[15]ដូច្នេះ កាលណាយើងបានបែងចែកគេ ទៅនៅកណ្តាលអស់ទាំងជនជាតិ ហើយបានកម្ចាត់កម្ចាយគេទៅនៅគ្រប់ប្រទេស នោះគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់។[16]ប៉ុន្តែ យើងនឹងឲ្យមានពួកគេខ្លះរួចពីដាវ ពីអំណត់ និងពីអាសន្នរោគដែរ ដើម្បីឲ្យគេបានថ្លែងប្រាប់ពីគ្រប់ទាំងអំពើគួរស្អប់ខ្ពើមរបស់ខ្លួន នៅកណ្តាលពួកជនជាតិដទៃទាំងប៉ុន្មាន ដែលគេត្រូវទៅនៅនោះ ដូច្នេះ គេនឹងដឹងថា យើងនេះជាព្រះអម្ចាស់»។
[17]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំដោយបន្ទូលថា[18]«កូនមនុស្សអើយ ចូរបរិភោគអាហាររបស់អ្នក ដោយរន្ធត់ ព្រមទាំងផឹកទឹកដោយញាប់ញ័រ ហើយថប់ព្រួយចុះ។
[19]ក្រោយមក ចូរប្រាប់ប្រជាជនក្នុងទឹកដីថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលការនេះ បារម្ភពីអ្នកក្រុងយេរូសាឡឹម ហើយអ្នកនៅក្នុងទឹកដីអ៊ីស្រាអែល ពួកគេនឹងបរិភោគអាហាររបស់គេ ដោយភ័យខ្លាច ហើយផឹកទឹករបស់គេដោយតក់ស្លុត ដ្បិតទឹកដីគេនឹងត្រូវខូចបង់ ព្រមទាំងរបស់ទាំងអស់ដែលនៅក្នុងទឹកដីនោះដែរ ព្រោះ

generated on Wed Sep 10 16:16:32 2025

ការយោរយៅរបស់ពួកអ្នកដែលរស់នៅទឹកដីនោះ។[20]ដូច្នោះទីក្រុងទាំងអស់ ដែលមានមនុស្សនៅ នឹងត្រូវបំផ្លាញ ហើយទឹកដីនឹងត្រូវខូចបង់ទៅ អ្នកនឹងដឹងថាយើងនេះជាព្រះអម្ចាស់»។
[21]ម្តងទៀតព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំថា[22]«កូនមនុស្សអើយ តើពាក្យសុភាសិត ដែលអ្នករាល់គ្នាធ្លាប់និយាយ នៅទឹកដីអ៊ីស្រាអែល ដោយនិយាយ កំណត់ថ្ងៃបានបន្ថយទៅ ហើយគ្រប់ទាំងនិមិត្តក៏ខានមាន?[23]ដូច្នោះហើយ ត្រូវប្រាប់គេថា ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ យើងនឹងធ្វើឲ្យពាក្យសុភាសិតត្រូវចប់ ហើយប្រជាជនអ៊ីស្រាអែលមិនប្រើទៀតទេ។ ចូរប្រាប់ពួកគេថា ថ្ងៃកំណត់ជិតដល់ហើយ នៅពេលគ្រប់ទាំងនិមិត្តបានកើតឡើង។
[24]ដ្បិតនឹងគ្មាននិមិត្តក្លែងក្លាយ ឬពាក្យទំនាយបញ្ជើច នៅក្នុងប្រជាជនសអ៊ីស្រាអែលទៀតឡើយ។[25]ដ្បិតយើងគឺជាព្រះអម្ចាស់ យើងនឹងចេញបង្គាប់ ហើយពាក្យដែលយើងប្រាប់។បញ្ហាមិនត្រូវពន្យាពេលឡើយ។ ដ្បិតយើងនឹងថ្លែងពាក្យបែរនេះក្នុងសម័យរបស់អ្នក ដែលជាប្រជាជនបះបោរ ហើយនឹងធ្វើឲ្យវាកើតឡើង! នេះជាគឺព្រះអម្ចាស់ដ៏ជាព្រះបានប្រកាស»។
[26]ម្តងទៀតព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំថា[27]«កូនមនុស្សអើយ! មើល៍ ប្រជាជនអ៊ីស្រាអែល គេនិយាយថា និមិត្តដែលគាត់ឃើញ
នឹងកើតឡើងនាពេលខាងមុខចាប់ពីពេលនេះ ហើយគាត់ថ្លែងព្រះបន្ទូល សម្រាប់ពេលអនាគត។[28]ដូច្នោះហើយចូរប្រាប់គេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូចនេះ ពាក្យរបស់យើងមិនត្រូវពន្យាពេលទេ តែពាក្យដែលយើងថ្លែង នោះនឹងកើតឡើង នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះបានប្រកាស»។

Ezekiel 12:1
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ
«ព្រះអម្ចាស់មានព្រះបន្ទូលមកលោក»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១។
ពួកអ្នកដែលមានភ្នែកសម្រាប់មើល តែមើលមិនឃើញទេ ហើយមានត្រចៀកសម្រាប់ស្តាប់ តែស្តាប់មិនឮដែរ
ឃ្លាទាំងពីរនេះកំពុងប្រើទាំងភ្នែក ឬ
ត្រចៀកដើម្បីសំដៅទៅលើសមត្ថភាពរបស់ប្រជាជនក្នុងការរៀនសូត្រ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមានសមត្ថភាពរៀន ប៉ុន្តែជ្រើសរើសមិនបាន»
Ezekiel 12:3
ព័ត៌មានទូទៅ:
លោកអេសេគាលកំពុងតែសំដែងនូវរឿងប្រៀបប្រដូចមួយទៀត។
ដូច្នោះហើយសម្រាប់អ្នក
«ដូច្នេះនេះគឺសម្រាប់អ្នករាល់គ្នា»
ប្រហែលជាគេនឹងពិចារណាយល់ ទោះបើពួកគេជាពូជរឹងទទឹងក៏ដោយ
ការបកប្រែរបៀបផ្សេងទៀត:
«ប្រហែលជាពួកគេនឹងចាប់ផ្តើមយល់ពីអ្វីដែលអ្នកកំពុងពិពណ៌នា ពាក្យថា «មើល»
ត្រូវបានប្រើដើម្បីយោងទៅលើសមត្ថភាពរបស់ប្រជាជនយូដាក្នុងការយល់។
Ezekiel 12:4
ព័ត៌មានទូទៅ:
ព្រះអង្គកំពុងមានព្រះបន្ទូលទៅលោកអេសេគាលដើម្បីពិពណ៌នាអំពីរបៀបដែលគាត់គួរតែធ្វើការ
ចំពោះភ្នែកគេ
ពាក្យថា «របស់ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ពូជពង្សអ៊ីស្រាអែល
សូមមើលការបកប្រែនៅក្នុងជំពូក ៣:១៦។
តាំងអ្នកទុកជាទីសម្គាល់
ការបកប្រែរបៀបផ្សេងទៀត: «បានដាក់អ្នកជាការកែតម្រូវការគិតរបស់ពួកគេ»
Ezekiel 12:7
ព័ត៌មានទូទៅ :
លោកអេសេគាលបង្ហាញប្រជាជនអ៊ីស្រាអែលថាពួកគេនឹងត្រូវបង្ខំឲ្យនិរទេសទៅឆាប់ៗ
ជីកទម្លុះរូងឲ្យដល់កំផែងដោយដៃខ្ញុំ
ការបកប្រែរបៀបផ្សេងទៀត: «ជីករន្ធមួយតាមជញ្ជាំងដោយដៃយើង»
ក្នុងពេលទីងងឹត
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលយប់ ខណៈពេលវាងងឹត»
Ezekiel 12:8
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់មានព្រះបន្ទូលមក»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១: ១។
ប្រជាជនអ៊ីស្រាអែល
សូមមើលការបកប្រែនៅក្នុងជំពូក ៣:១៦។
កូនមនុស្សអើយ តើប្រជាជនអ៊ីស្រាអែលជាអ្នកបះបោរ មិនសួរអ្នកទេថា «តើអ្នកកំពុងធ្វើអ្វី?»
ព្រះអង្គសួរសំនួរនេះទៅកាន់លោកអេសេគាលដើម្បីបង្ហាញថាប្រជាជនអ៊ីស្រាអែលបានកត់សម្គាល់
ការបកប្រែរបៀបផ្សេងទៀត:
«លោកអេសេគាលថាប្រជាជនអ៊ីស្រាអែលដែលមិនស្តាប់បង្គាប់យើងបានកត់សម្គាល់
នៅក្នុងពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «តើអ្នកណានៅក្នុងចំណោមពួកគេ»
Ezekiel 12:11
ក្នុងងងឹត
«នៅពេលយប់ខណៈពេលដែលវាងងឹត»
យើងនឹងដាក់សំណាញរបស់យើងលើគេ ហើយគាត់នឹងជាប់អន្ទាក់របស់យើង
ពាក្យថា «បណ្តាញ» និង «អន្ទាក់»
ត្រូវបានគេប្រើព្រោះទាំងនេះជាវិធីផ្សេងគ្នាដើម្បីចាប់សត្វ។
ព្រះអម្ចាស់ជ្រាបនូវអ្វីដែលមេដឹកនាំក្រុងយេរូសាឡិមនឹងធ្វើ
ហើយបានរៀបចំព្រឹត្តិការណ៍ផ្សេងៗ
ដើម្បីឲ្យគាត់ត្រូវគេចាប់បាននៅពេលដែលគាត់ព្យាយាមរត់គេច។
យើងនឹងនាំគាត់ទៅបាប៊ីឡូន
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងនាំគាត់ទៅស្រុកបាប៊ីឡូន»
Ezekiel 12:14
រួចយើងនឹងហូតដាវទៅតាមក្រោយគេ
ពាក្យថា «ដាវ» ត្រូវបានប្រើដើម្បីសំដៅទៅលើកងទ័ពរបស់បុរសដែលកាន់ដាវ។
កាលណាយើងបានបែងចែកគេ ទៅនៅកណ្តាលអស់ទាំងជនជាតិ ហើយបានកម្ចាត់កម្ចាយគេទៅ
នៅគ្រប់ប្រទេស នោះគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលយើងឲ្យពួកគេបំបែកចេញពីគ្នា
ហើយរស់នៅក្នុងប្រទេសផ្សេងគ្នា»។
រួចពីដាវ
ការបកប្រែរបៀបផ្សេងទៀត: «ពីការសម្លាប់»
Ezekiel 12:17
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់មានព្រះបន្ទូល»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១: ១។
កូនមនុស្សអើយ
សូមមើលការបកប្រែនៅក្នុងជំពូក ២:១។
ចូរបរិភោគអាហាររបស់អ្នក ដោយរន្ធត់ ព្រមទាំងផឹកទឹកដោយញាប់ញ័រ ហើយថប់ព្រួយចុះ
ការបកប្រែរបៀបផ្សេងទៀត:
«រស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកដោយភាពភ័យខ្លាច»។
ការស៊ីផឹកគឺជារឿងធម្មតាដែលបានធ្វើក្នុងជីវិត
ហើយដូច្នេះសូមប្រាប់លោកអេសេគាលឲ្យរស់នៅដោយភ័យខ្លាចបំផុត។
Ezekiel 12:19
ពួកគេនឹងបរិភោគអាហាររបស់គេ ដោយភ័យខ្លាច ហើយផឹកទឹករបស់គេដោយតក់ស្លុត
ឃ្លាទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា
ហើយសង្កត់ធ្ងន់ថាប្រជាជននឹងមានការភ័យខ្លាចខ្លាំងណាស់
សូម្បីតែពេលធ្វើអ្វីៗដែលសំខាន់បំផុតដូចជាការញ៉ាំ និងផឹក។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងរស់នៅក្នុងជីវិតប្រចាំថ្ងៃដោយការភ័យខ្លាចយ៉ាងខ្លាំង»។
ទីក្រុងទាំងអស់ ដែលមានមនុស្សនៅ នឹងត្រូវបំផ្លាញ
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៅក្នុងទីក្រុងនឹងចាកចេញ ឬស្លាប់»
សូមមើលការបកប្រែឃ្លានេះនៅក្នុងជំពូក ៦:៦។

generated on Wed Sep 10 16:16:32 2025

Ezekiel 12:21

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់មានព្រះបន្ទូល»។ សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១: ១។

កំណត់ថ្ងៃបានបន្ថយទៅ ហើយគ្រប់ទាំងនិមិត្តក៏ខានមាន

នេះជាសម្តីរបស់ជនជាតិអ៊ីស្រាអែលដែលមិនជឿថាព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសពួកគេ។

ការបកប្រែរបៀបផ្សេងទៀត:

«ជាច្រើនថ្ងៃបានកន្លងផុតទៅដោយគ្មានការវិនិច្ឆ័យរបស់ព្រះអង្គ

ការព្រមានរបស់ព្យាការីគឺមិនពិត»

ថ្ងៃជិតមកដល់ហើយ

ឃ្លានេះសំដៅទៅលើថ្ងៃដែលអ៊ីស្រាអែលនឹងត្រូវវិនិច្ឆ័យទោស។

ការបកប្រែរបៀបផ្សេងទៀត: «ថ្ងៃវិនិច្ឆ័យនឹងមកដល់ឆាប់ៗ»

គ្រប់ទាំងនិមិត្តបានកើត

ការនិមិត្តដែលព្រះប្រទានដល់ព្យាការីនឹងក្លាយជាការពិត។

ការបកប្រែរបៀបផ្សេងទៀត: «រាល់ការព្យាករណ៍នឹងកើតឡើង»

Ezekiel 12:24

ព័ត៌មានទូទៅ :

ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។

ប្រជាជនអ៊ីស្រាអែល

មើលការបកប្រែមាននៅក្នុងជំពូក ៣:១។

បញ្ហាមិនត្រូវពន្យាពេលឡើយ

«អ្វីដែលយើងទាយនឹងកើតឡើងឆាប់ៗនេះ»

នេះជាអ្វីដែលព្រះអម្ចាស់ដ៏ជាព្រះបានប្រកាស

សូមមើលការបកប្រែនៅក្នុងជំពូក ៥:១១។

ថ្លែងពាក្យបែរនេះ

អត្ថន័យដែលអាចមាន គឺ១) «អ្វីៗដែលយើងនិយាយនឹងកើតឡើង» (UDB) ឬ ២) «និយាយសារនេះ» ឬ ៣) «និយាយទំនាយនេះ»

ក្នុងសម័យរបស់អ្នក

«ខណៈពេលដែលអ្នកនៅរស់»

Ezekiel 12:26

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់មានព្រះបន្ទូល»។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១: ១។

មកឯខ្ញុំ ...និមិត្តដែលគាត់បានឃើញ ...ហើយគាត់ទាយ

ពាក្យថា «ខ្ញុំ» និង «គាត់» សំដៅទៅលើលោកអេសេគាល។

ចូរប្រាប់គេថា

ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។

មើល៍

ពាក្យថា «មើល»

នៅទីនេះដាស់តឿនយើងឱ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើង។

និមិត្តដែលគាត់ឃើញ នឹងកើតឡើងនាពេលខាងមុខចាប់ពីពេលនេះ ហើយគាត់ថ្លែងព្រះបន្ទូល

សម្រាប់ពេលអនាគត

ឃ្លាទាំងនេះគឺជាវិធីទាំងពីរដែលប្រជាជនអ៊ីស្រាអែលកំពុងនិយាយថាការព្រមានរបស់លោកអេសេគាលនឹ

ប៉ុន្តែវានឹងកើតឡើងឆ្ងាយនៅពេលអនាគត។

ពាក្យរបស់យើងមិនត្រូវពន្យាពេលទេ តែពាក្យដែលយើងថ្លែង នោះនឹងកើតឡើង

ឃ្លាទាំងនេះគឺជាវិធីទាំងពីរដែលព្រះអង្គកំពុងប្រាប់ប្រជាជនអ៊ីស្រាអែលថាអ្វីដែលគាត់បានព្រមាននឹងកើត

នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះបានប្រកាស

សូមមើលការបកប្រែមាននៅក្នុងជំពូក ៥:១១។

---

13 [1]ម្តងទៀត ព្រះបន្ទូលរបស់អម្ចាស់បានមកដល់ខ្ញុំ[2]«កូនមនុស្សអើយ ចូរថ្លែងព្រះបន្ទូលទាស់នឹងពួកព្យាការីនៃជនជាតិអ៊ីស្រាអែល ហើយប្រាប់អ្នកដែលថ្លែងទំនាយចេញពីការអំនួត ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។[3]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូចនេះ វេទនាដល់ពួកព្យាការីល្ងីល្ងើ ដែលថ្លែងទំនាយតាមតែចិត្តរបស់ខ្លួន តែមិនបានឃើញអ្វីសោះ។[4]អ៊ីស្រាអែលអើយ ពួកព្យាការីរបស់អ្នកធ្វើដូចជាឆ្កែចចក នៅទីស្ងាត់។
[5]អ្នករាល់គ្នាមិនបានឡើងទៅ កន្លែងដែលបាក់បែកជុំវិញនៃជញ្ជាំងក្រុង នៃប្រជាជនអ៊ីស្រាអែលហើយសង់ឡើងវិញទេ ដើម្បីអាចឈរនៅក្នុងគ្រាចម្បាំង នៅថ្ងៃនៃព្រះអម្ចាស់។[6]មនុស្សបានឃើញសេចក្តីភូតភរ «និងពាក្យទំនាយកុហក ហើយក៏ថា ព្រះអម្ចាស់មានព្រះបន្ទូល»។ ព្រះអម្ចាស់មិនបានចាត់គេសោះ ហើយគេធ្វើឲ្យមនុស្សសង្ឃឹមថា ពាក្យនោះនឹងបានសម្រេចជាពិត។[7]តើការដែលអ្នករាល់គ្នាថា ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ តែយើងមិនបានពោលសោះ «ការនេះគឺជាការដែលព្រះអម្ចាស់បានប្រកាស» តាំងយើងមិនបានថ្លែងអ្វីសោះឬ?
[8]ដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលថា ព្រោះអ្នករាល់គ្នាបញ្ចេញនិមិត្តប្រាប់មិនពិត ដូចោះហើយបានជាព្រះអម្ចាស់អម្ចាស់មានព្រះបន្ទូលទាសនិងអ្នក[9]ដៃយើងនឹងប្រហារពួកព្យាការី ជាមនុស្សប្រាប់និមិត្តកុហក ហើយដែលថ្លែងទំនាយមិនពិត។ ពួកគេនឹងមិនអាចនៅក្នុងការប្រជុំរបស់ប្រជាជនរបស់យើងឡើយ ឬមិនបានកត់ទុកក្នុងបញ្ជីប្រជាជនអ៊ីស្រាអែល គេមិនអាចចូលក្នុងទឹកដីអ៊ីស្រាអែលទេ។ ដ្បិតអ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់។
[10]ដោយព្រោះតែគេបានលួងបញ្ឆោតប្រជារាស្ត្ររបស់យើង ដោយពោលថា «មានសន្តិភាពហើយ» ពេលគ្មានសន្តិភាព ពួកគេសាងសង់កំពែងដែលពួកគេនឹងលាបថ្នាំពណ៌ស។[11]ចូរប្រកាសប្រាប់អស់អ្នកដែលបូកបាយអនោះថា កំពែងនោះនឹងត្រូវរលំ ដោយមានភ្លៀងធ្លាក់យ៉ាងខ្លាំង ហើយយើងនឹងចាត់គ្រាប់ព្រឹលឲ្យធ្លាក់មក ហើយខ្យល់ព្យុះយ៉ាងខ្លាំងក៏បំបាក់ឲ្យរលំដែរ។[12]ឃើញទេ ជញ្ជាំងនឹងរលំចុះ។ តើគេនឹងមិនសួរអ្នកទេ «តើបាយអដែលអ្នកបានបូកនោះអ្នកដាក់ទីណា?»
[13]ដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូចនេះ យើងនឹងខ្យល់គំហុក ក្នុងកំហឹងរបស់យើង ហើយនឹងមានជន់ លិចដោយភ្លៀងធ្លាក់យ៉ាងខ្លាំង ដោយកំហឹងរបស់យើង! គ្រាប់ព្រឹលនឹងធ្លាក់ដោយកំហឹងរបស់យើង បំផ្លាញកំពែងនោះ។[14]ដ្បិតយើងនឹងរំលំកំពែងដែលអ្នករាល់គ្នាបានបូកបាយអនោះ ហើយយើងនឹងរលំចុះដល់ដីគ្រឹះត្រូវរលើងឡើង។ ដូច្នេះវានឹងរំលំចុះ ហើយអ្នករាល់គ្នានឹងត្រូវវិនាសនៅក្នុងនោះដែរ។ រួចហើយអ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់។
[15]គឺយ៉ាងនោះដែលយើងនឹងសម្រេចសេចក្តីក្រោធរបស់យើង នៅលើកំផែងនោះ ហើយលើពួកអ្នកដែលបានបូកបាយអដែរ។ យើងនឹងនិយាយមកអ្នករាល់គ្នាថា «កំផែងនោះមិនមានទៀតទេ ព្រមទាំងពួកអ្នកដែលបូកផង[16]គឺជាពួកព្យាការីរបស់ជនជាតិអ៊ីស្រាអែល ដែលថ្លែងទំនាយពីដំណើរក្រុងយេរូសាឡឹម ហើយឃើញនិមិត្តពីសេចក្តីសុខសម្រាប់ទីក្រុង។ តែឥតមានសេចក្តីសុខឡើយ! នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់»។
[17]សម្រាបអ្នក កូនមនុស្សអើយ ចូរតាំងមុខទាស់នឹងពួកអ្នកក្រុងរបស់ជនជាតិអ្នក ដែលថ្លែងទំនាយចេញពីគំនិតខ្លួនគេ ហើយថ្លែងទំនាយទាស់នឹងគេ។[18]ចូរនិយាយព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ វេទនាដល់ពួកស្រីៗដែលធ្វើអំបោះពាក់នៅកដៃមនុស្ស ហើយធ្វើស្បៃបាំងមុខ សម្រាប់ក្បាលគ្រប់មនុស្ស ទោះទាំងធំទាំងតូច ដើម្បីនឹងចាប់ព្រលឹងគេ អ្នករាល់គ្នារកចាប់ព្រលឹងរបស់ជនជាតិយើងដូច្នេះ។ តើអ្នកបរបាញ់ជីវិតប្រជាជនរបស់យើង តែសង្គ្រោះជីវិតជីវិតខ្លួនមែនទេ?
[19]អ្នករាល់គ្នាបានប្រមាថយើងនៅកណ្តាលប្រជារាស្ត្រយើង ឲ្យតែបានស្រូវឱកមួយកំប៉ុងឬពីរ និងចំណិតនំប៉ុងខ្លះ ដើម្បីនឹងសម្លាប់ព្រលឹងមនុស្សដែលមិនគួរស្លាប់ ហើយនឹងរក្សាជីវិតអ្នកដែលមិនគួររស់នៅ ដោយអ្នកកុហកដល់ប្រជាជនយើង ដែលស្តាប់តាមសេចក្តីកុហកនោះ។
[20]ដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ យើងទាស់នឹងខ្សែយ័ន្តរបស់អ្នករាល់គ្នា ដែលប្រើសម្រាប់ប្រមាញ់ជីវិតមនុស្ស ដូចប្រមាញ់សត្វស្លាប។ យើងនឹងហែកវាចេញពីដៃអ្នករាល់គ្នា ហើយនឹងដោះលែងព្រលឹងទាំងនោះឲ្យរួច គឺជាព្រលឹងដែលអ្នកបានតាមប្រមាញ់ ដូចប្រមាញ់សត្វស្លាបនោះ។[21]យើងនឹងហែកស្បៃរបស់អ្នករាល់គ្នាដែរ ព្រមទាំងជួយឲ្យប្រជាជនរបស់យើងរួចពីកណ្តាប់ដៃអ្នករាល់គ្នា ដូច្នោះគេនឹងមិននៅក្នុងកណ្តាប់ដៃអ្នករាល់គ្នាទៀតទេ។ អ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់។
[22]ដោយព្រោះអ្នករាល់គ្នាបានបញ្ឈឺចិត្តពួកសុចរិត ដោយសេចក្តីកុហក ជាពួកអ្នកដែលយើងមិនបានឲ្យព្រួយចិត្តសោះ ហើយអ្នកបានចម្រើនកម្លាំងដៃនៃមនុស្សអាក្រក់ ដើម្បីមិនឲ្យគេលះចោលផ្លូវអាក្រក់របស់ខ្លួន ឲ្យបានសង្គ្រោះជីវិតរបស់ពួកគេទេ[23]ដូច្នោះហើយ អ្នករាល់គ្នានឹងមិនអាចប្រាប់និមិត្តកុហក ឬថ្លែងទំនាយទៀតទេ យើងនឹងជួយប្រជាជនរបស់យើងឲ្យរួចពីកណ្តាប់ដៃរបស់អ្នក។ នោះអ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់»។

---

generated on Wed Sep 10 16:16:32 2025

Ezekiel 13:1

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់មានព្រះបន្ទូល»។ សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១: ១។

កូនមនុស្ស

លោកអេសេគាល (ខ្ញុំ)

ថ្លែងទំនាយចេញពីការអំនួត

ទាយពីគំនិតផ្ទាល់ខ្លួនរបស់ពួកគេ

ដែលថ្លែងទំនាយតាមតែចិត្តរបស់ខ្លួន

ឃ្លានេះត្រូវបានប្រើដើម្បីសំដៅទៅលើពួកហោរាដែលធ្វើអ្វីដែលពួកគេចង់បាន។

ពាក្យថា «វិញ្ញាណ» សំដៅទៅលើគំនិតរបស់ពួកគេ ហើយពាក្យថា «តាម» គឺសំដៅទៅលើអ្វីដែលពួកគេធ្វើ។

ឆ្កែចចក

សត្វព្រៃដូចជាឆ្កែ ឬ ឆ្កែចចកតូច។

ដូចជាឆ្កែចចក នៅទីស្ងាត់

ដូចជាសត្វចចកដែលលួចចំណីពីសត្វដទៃទៀតនៅវាលរហោស្ថានពួកហោរាបានលួចពីប្រជាជនអ៊ីស្រាអែល

Ezekiel 13:5

ប្រជាជនអ៊ីស្រាអែល

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។

ឈរនៅក្នុងគ្រាចម្បាំង

«ការពារ»

តើអ្នកមិនមាននិមិត្តមិនពិតទេ... នៅពេលដែលខ្ញុំផ្ទាល់មិនបាននិយាយ?

ព្រះអម្ចាស់ប្រើសំនួរមួយដើម្បីស្តីបន្ទោសព្យាការីក្លែងក្លាយ។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកមានចក្ខុវិស័យមិនពិត...

ព្រោះយើងផ្ទាល់មិនបាននិយាយទេ។

មាននិមិត្តមិនពិត និងមានការព្យាករណ៍មិនពិត

ចាប់តាំងពីព្យាការីក្លែងក្លាយមិនបានទទួលសារពីព្រះអម្ចាស់

អ្វីដែលពួកគេទាយអំពីអនាគតគឺមិនពិត។

ការនេះគឺជាការ

នេះគឺជាឃ្លាដែលប្រើដើម្បីសំដៅទៅលើអ្វីដែលហោរាបាននិយាយ។

ភាសារបស់អ្នកអាចមានវិធីមួយផ្សេងទៀត ដើម្បីនិយាយបែបនេះ។

«ព្រះអម្ចាស់បានប្រាប់យើងពីរឿងនេះ» (UDB)

ព្រះអម្ចាស់បានប្រកាស

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។

Ezekiel 13:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល

ហើយឃ្លានេះបាននិយាយឡើងវិញតាមវិធីផ្សេងៗគ្នាដើម្បីបង្ហាញថាពួកគេជានរណា។

អ្នករាល់គ្នាបញ្ឆេញនិមិត្តប្រាប់មិនពិត

ការបកប្រែរបៀបផ្សេងទៀត: «បានកុហកអំពីព្រះរាជសារមកពីព្រះអង្គ»

ព្រះអម្ចាស់បានប្រកាស

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។

ដៃយើងនឹងប្រហារពួកព្យាការី

ពាក្យថា «ដៃ» ត្រូវបានប្រើជាញឹកញាប់យោងទៅតាមអំណាចរបស់ព្រះអម្ចាស់។

កុហក ហើយដែលថ្លែងទំនាយមិនពិត

ការបកប្រែរបៀបផ្សេងទៀត: «អ្នកណាមានសារមកពីព្រះអង្គ ប៉ុន្តែនិយាយកុហក»

ប្រជុំរបស់ប្រជាជនរបស់យើងឡើយ ឬមិនបានកត់ទុកក្នុងបញ្ជីប្រជាជនអ៊ីស្រាអែល គេមិនអាចចូលក្នុងទឹកដីអ៊ីស្រាអែលទេ

ការបកប្រែរបៀបផ្សេងទៀត: «បានចុះបញ្ជីជាប្រជាជនម្នាក់របស់យើង»

នេះជាវិធីពីរយ៉ាងដើម្បីពិពណ៌នាអំពីរឿងតែមួយ។

ប្រជាជនអ៊ីស្រាអែល

សូមមើលការបកប្រែនៅក្នុងជំពូក ៣:១។

យើងនេះជាព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់

សូមមើលពីការបកប្រែនេះនៅក្នុងជំពូក ៦:៦។

Ezekiel 13:10

ដោយព្រោះតែ

ពាក្យថា «នេះ»

សំដៅទៅលើការសន្យារបស់ព្រះអម្ចាស់ដែលបានបង្ខំពួកហោរាក្លែងក្លាយចេញពីស្រុក

គេបានលួងបញ្ឆោតប្រជារាស្ត្ររបស់យើង

ពាក្យថា «ពួកគេ» សំដៅទៅលើពួកហោរាក្លែងក្លាយនៅក្នុងទឹកដីអ៊ីស្រាអែល។

ពួកគេសាងសង់កំពែង ដែលពួកគេនឹងលាបថ្នាំពណ៌ស

នៅទីនេះ «កំផែង»

តំណាងឲ្យសន្តិភាពនិងសន្តិសុខដែលព្យាការីក្លែងក្លាយបានប្រាប់ប្រជាជនថាព្រះអម្ចាស់បានសន្យាថានឹង

ការលាងសម្អាត ... ការធ្វើឲ្យស

«ការធ្វើឲ្យស» គឺជាល្បាយរាវពណ៌សដែលត្រូវបានប្រើសម្រាប់ការបង្កើតផ្ទៃ (ដូចជាជញ្ជាំង ឬរបង) ពណ៌ស។

ទឹកភ្លៀងមានភ្លៀងធ្លាក់ ...ព្យុះព្រឹល ... ព្យុះ

ទាំងអស់នេះគឺជាផ្នែកនៃព្យុះដ៏អាក្រក់មួយ។

ព្រះអង្គប្រើព្យុះដើម្បីសំដៅលើកងទ័ពដែលនឹងវាយប្រហារក្រុងយេរូសាឡិម។

គ្រាប់ព្រឹល

បាល់ទឹកកកដែលពេលខ្លះធ្លាក់ពីលើមេឃក្នុងពេលមានព្យុះភ្លៀង។

តើគេនឹងមិនសួរអ្នកទេ

លោកអេសេគាលសួរសំណួរនេះជាសំនួរដើម្បីរកចំលើយ។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកផ្សេងទៀតបាននិយាយទៅអ្នក...វា!»

Ezekiel 13:13

ព្រះអម្ចាស់មានព្រះបន្ទូលនៅពេលពួកគេនិយាយកុហកអំពីការមានសារពីព្រះអង្គ។

ខ្យល់ព្យុះ ... ជំនន់ទឹកភ្លៀង ... ព្យុះព្រិល

ទាំងអស់នេះគឺជាផ្នែកនៃព្យុះដ៏អាក្រក់មួយ។

ព្រះអង្គប្រើព្យុះដើម្បីសំដៅលើកងទ័ពដែលនឹងវាយប្រហារក្រុងយេរូសាឡិម។

យើងនឹងខ្យល់គំហុក

«នៅពេលដែលធ្វើឱ្យយើងខឹង នោះយើងនឹងនាំព្យុះ»

ហើយនឹងជន់លិចដោយភ្លៀងធ្លាក់យ៉ាងខ្លាំងដោយព្រោះកំហឹង

«នៅពេលដែលធ្វើឱ្យយើងខឹង នោះយើងនឹងនាំមកនូវបរិមាណទឹកភ្លៀងដ៏ច្រើន»

គ្រាប់ព្រិលនឹងធ្លាក់ដោយកំហឹងរបស់យើង បំផ្លាញកំពែងនោះ

«នៅពេលដែលយើងធ្វើតាមកំហឹងរបស់យើង

នោះនឹងនាំព្យុះព្រិលមកបំផ្លាញជញ្ជាំងដែលប្រជាជនកំពុងសាងសង់»

គ្រឹះត្រូវរលើងឡើង

«ត្រូវបានរកឃើញ»

ត្រូវវិនាស

«នាំដល់ទីបញ្ចប់របស់អ្នក» ឬ «បំផ្លាញទាំងស្រុង»

ដឹងថា យើងនេះជាព្រះអម្ចាស់

អត្ថន័យដែលអាចមានគឺ ១) «ដឹងថាតើយើងដែលជាព្រះអម្ចាស់» ឬ ២) «យល់ថាយើងជាព្រះអម្ចាស់ជាព្រះពិតតែមួយ» ឬ ៣) «ដឹងថាយើងជាព្រះអម្ចាស់មានអំណាចធ្វើអ្វីដែលយើងនិយាយថាយើងនឹងធ្វើ» (UDB)

Ezekiel 13:15

យើង

សំដៅទៅព្រះអម្ចាស់

យើងនឹងសម្រេចសេចក្តីក្រោធរបស់យើង

«នៅពេលដែលធ្វើឲ្យខឹង យើងនឹងនាំអោយទីបញ្ចប់»

អ្នកដែលបូក

«លាបជញ្ជាំងស» (សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ១៣:១០)

កំផែងនោះមិនមានទៀតទេ ព្រមទាំងពួកអ្នកដែលបូកផង

«ជញ្ជាំងលែងនៅទីនោះ ហើយប្រជាជនក៏មិនមានដែរ»

និមិត្តពីសេចក្តីសុខ

ពាក្យថា «នាង» សំដៅទៅលើក្រុងយេរូសាឡិម។

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។

Ezekiel 13:17

កូនមនុស្សអើយ

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ២:១។

ចូរតាំងមុខទាស់នឹង

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៤:១។

ពួកអ្នកក្រុងរបស់ជនជាតិអ្នក

ស្ត្រីជនជាតិអ៊ីស្រាអែល

ថ្លែងទំនាយចេញពីគំនិតខ្លួនគេ

នេះមានន័យថាពួកគេកំពុងបង្កើតទំនាយតាមការស្រមើស្រមៃរបស់ពួកគេ។

ការបកប្រែរបៀបផ្សេងទៀត: «ស្រមៃមើលការថ្លែងទំនាយដោយខ្លួនឯង»

សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ៤:៦។

generated on Wed Sep 10 16:16:32 2025

ដើម្បីនឹងចាប់
វត្ថុដែលគេជឿថាមានថាមពលវេទមន្ត។

ធ្វើស្បៃបាំងមុខ សម្រាប់ក្បាលគ្រប់មនុស្ស ទោះទាំងធំទាំងតូច ដើម្បីនឹងចាប់ព្រលឹងគេ អ្នករាល់គ្នារកចាប់ព្រលឹងរបស់ជនជាតិយើងដូច្នេះ
ការតុបតែងដែលពាក់ដោយព្យាការីគឺដូចជា «អន្ទាក់»
ពីព្រោះពួកគេបានប្រើភាពស្រស់ស្អាតក្នុងការកុហកដើម្បីបោកបញ្ឆោតប្រជាជនដើម្បីឲ្យពួកគេធ្វើបាប និងធ្វើបាបប្រឆាំងនឹងព្រះអង្គ។
Ezekiel 13:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលប្រឆាំងនឹងពួកហោរាក្លែងក្លាយនៅអ៊ីស្រាអែល។

ឲ្យតែបានស្រូវឱកមួយកំប៉ុងឬពីរ និងចំណិតនំប៉ុងខ្លះ
ស្រូវឱកគឺជាគ្រាប់ធញ្ញជាតិដែលត្រូវបានប្រើសម្រាប់ធ្វើនំប៉ុង ហើយពាក្យថា «កំទេច» គឺជាចំនួននំប៉ុង។ ឃ្លាទាំងពីរនេះគឺជាអាហារតិចតួច ហើយត្រូវបានប្រើដើម្បីបញ្ជាក់ពីការបង់ប្រាក់តិចតួចដល់ហោរា។
Ezekiel 13:20
ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៥:៥។

ខ្សែយ័ន្ត
វត្ថុដែលត្រូវបានគេជឿថាមានថាមពលវេទមន្ត

ប្រមាញ់
«ដាក់អន្ទាក់» អន្ទាក់គឺជាខ្សែពួរដែលមានរង្វិលជុំតូចដែលចាប់អ្វីមួយដោយជើង។

រស់នៅក្នុងជីវិតរបស់ប្រជាជនដូចជាសត្វស្លាប ...មនុស្សដែលអ្នកបានជាប់ដូចជាសត្វស្លាប
ព្រះអម្ចាស់ប្រៀបធៀបការប្រៀបធៀបរបស់ព្យាការីទៅនឹងអន្ទាក់សំរាប់សត្វស្លាប។

ហែកវាចេញពីដៃអ្នក
ពាក្យថា «ដៃ» សំដៅទៅលើការគ្រប់គ្រងរបស់ពួកហោរា។
សេចក្តីភូតភរដែលពួកគេប្រើដើម្បីគ្រប់គ្រងប្រជាជនអ៊ីស្រាអែលប្រៀបបាននឹងអារុងដែលប្រើដើម្បីចាប់សត្វ
ការបកប្រែរបៀបផ្សេងទៀត: «យកពួកវាចេញពីកន្លែងដែលអ្នកត្រួតត្រា»

គេនឹងមិននៅក្នុងកណ្តាប់ដៃអ្នករាល់គ្នាទៀតទេ
ដើម្បីនិយាយថា ពួកគេនឹងមិនត្រូវបានជាប់
គឺដូចគ្នានឹងការនិយាយថាពួកគេនឹងមានសេរីភាព។ ឃ្លាដែលថា «ជាប់ក្នុងដៃរបស់អ្នក»
សំដៅទៅលើប្រជាជនអ៊ីស្រាអែលដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ហោរាក្លែងក្លាយ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងមិនមានសេរីភាពពីការគ្រប់គ្រងរបស់អ្នក»

អ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់
អត្ថន័យដែលអាចមានគឺ ១) «ដឹងថាតើយើងដែលជាព្រះអម្ចាស់» ឬ ២) «យល់ថាយើងជាព្រះអម្ចាស់ជាព្រះពិតតែមួយ» ឬ ៣) «ដឹងថាយើងជាព្រះអម្ចាស់មានអំណាចធ្វើអ្វីដែលនិយាយថានឹងធ្វើ» (UDB)
Ezekiel 13:22
បានបញ្ឈឺចិត្តពួកសុចរិត
ដួងចិត្តរបស់មនុស្សសុចរិតត្រូវបានប្រើដើម្បីសំដៅទៅលើអារម្មណ៍របស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «បំបាក់ទឹកចិត្តមនុស្សសុចរិត»

លះចោលផ្លូវអាក្រក់របស់ខ្លួន
ដើម្បីឈប់ធ្វើអ្វីមួយត្រូវបានគេសំដៅទៅលើការបង្វែរទិសដៅផ្សេង។
ការបកប្រែរបៀបផ្សេងទៀត: «បញ្ឈប់អ្វីដែលគាត់កំពុងធ្វើ»

មិនអាចប្រាប់និមិត្តកុហក ឬថ្លែងទំនាយទៀតទេ
ឃ្លាទាំងពីរនេះសំដៅទៅលើការនិយាយអំពីអ្វីដែលនឹងកើតឡើងនាពេលអនាគត។
ការបកប្រែរបៀបផ្សេងទៀត: «បន្តធ្វើការព្យាករណ៍មិនពិត»

រួចពីកណ្តាប់ដៃរបស់អ្នក
ពាក្យថា «ដៃ» ត្រូវបានប្រើដើម្បីសំដៅទៅលើការគ្រប់គ្រងរបស់ហោរា។
ការបកប្រែរបៀបផ្សេងទៀត: «ចេញពីការគ្រប់គ្រងរបស់អ្នក»

ដឹងថា យើងនេះជាព្រះអម្ចាស់
អត្ថន័យដែលអាចមានគឺ ១) «ដឹងថាតើយើងដែលជាព្រះអម្ចាស់» ឬ ២) «យល់ថាយើងជាព្រះអម្ចាស់ជាព្រះពិតតែមួយ» ឬ ៣) «ដឹងថាយើងជាព្រះអម្ចាស់មានអំណាចធ្វើអ្វីដែលនិយាយថាយើងនឹងធ្វើ» (UDB)

---

14 [1]ពួកចាស់ទុំនៃជនជាតិអ៊ីស្រាអែលខ្លះបានមករកខ្ញុំ ហើយក៏អង្គុយនៅចំពោះមុខខ្ញុំ។[2]ក្រោយមក ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ[3]«កូនមនុស្សអើយ ពួកអ្នកទាំងនេះបានតាំងរូបព្រះរបស់គេ នៅក្នុងចិត្តគេ ក៏បានជំពប់ដួលនៃអំពើទុច្ចរិតខ្លួននៅចំពោះមុខគេ។ តើគួរយើងសួរទាំងអស់នេះតាមរយៈពួកគេ?
[4]ដូច្នោះហើយ ចូរប្រកាសការនេះដល់គេ ហើយនិយាយថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ បុរសទាំងអស់ក្នុងពួកកូនចៅអ៊ីស្រាអែល ដែលបានយករូបព្រះដាក់ក្នុងចិត្តខ្លួន ឬដាក់ការភ័យខ្លាចនៃអំពើទុច្ចរិតរបស់ខ្លួននៅចំពោះមុខខ្លួន រួចហើយមករកព្យាការី យើងព្រះអម្ចាស់ នឹងឆ្លើយដល់គេតាមចំនួនរូបព្រះរបស់គេវិញ។[5]យើងនឹងធ្វើការនេះ ដូច្នោះយើងអាចនឹងយកកូនចៅអ៊ីស្រាអែលមកវិញ ក្នុងចិត្តរបស់គេបាននាំទៅឆ្ងាយពីយើងដោយសាររូបព្រះរបស់គេ។
[6]ដូច្នោះហើយ ចូរនិយាយទៅកាន់កូនចៅអ៊ីស្រាអែលថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ចូរប្រែចិត្ត និងបែរចេញពីរូបព្រះរបស់អ្នកទៅ! ហើយងាកមុខពីអស់ទាំងការគួរស្អប់ខ្ពើមរបស់អ្នកដែរ។
[7]ដ្បិត គ្រប់គ្នាពីប្រជាជនអ៊ីស្រាអែល ហើយពួកជនជាតិដទៃ ជាអ្នកស្នាក់នៅក្នុងទឹកដីអ៊ីស្រាអែល ដែលញែកខ្លួនចេញពីយើង ជាអ្នកដែលយករូបព្រះដាក់ក្នុងចិត្ត ហើយដាក់ហេតុចំពប់នៃសេចក្តីទុច្ចរិតរបស់ខ្លួនចំពោះមុខខ្លួន រួចនឹងមករកព្យាការី ដើម្បីស្វែងរកយើង យើងគឺព្រះអម្ចាស់ នឹងឆ្លើយដល់អ្នកនោះ ដោយខ្លួនយើង។[8]ដូច្នេះយើងនឹងតាំងមុខទាស់នឹងអ្នកនោះ ព្រមទាំងធ្វើឲ្យជាទីស្រឡាំងកាំង ជាទីសម្គាល់ ហើយនិងពាក្យសុភាសិត ដ្បិតយើងក៏នឹងកាត់អ្នកនោះចេញពីកណ្តាលចំណោមមនុស្សយើង ហើយអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់។
[9]ប្រសិនបើព្យាការីណាត្រូវបញ្ឆោត ហើយបាននិយាយពាក្យ រួចហើយ យើងព្រះអម្ចាស់ នឹងត្រូវបញ្ឆោតព្យាការី ហើយយើងនឹងលូកដៃទៅលើគេ ព្រមទាំងបំផ្លាញគេចេញពីពួកអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើងដែរ។[10]ពួកគេនឹងត្រូវទ្រាំទ្រចំពោះសេចក្តីទុច្ចរិតរបស់ខ្លួន សេចក្តីទុច្ចរិតរបស់ព្យាការី នោះនឹងបានដូចជាសេចក្តីទុច្ចរិតរបស់អ្នកដែលរកគេដែរ។[11]ដោយព្រោះការនេះកូនចៅអ៊ីស្រាអែលរង្វេងចេញពីយើង ឬនាំឲ្យខ្លួនបានស្មោកគ្រោក ដោយអំពើរំលងទាំងប៉ុន្មានរបស់ខ្លួនទៀតឡើយ គឺឲ្យគេបានធ្វើជាប្រជារាស្ត្ររបស់យើងវិញ ហើយឲ្យយើងបានជាព្រះរបស់គេ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។
[12]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[13]«កូនមនុស្សអើយ ពេលទឹកដីណាធ្វើបាបនឹងយើង ដោយប្រព្រឹត្តបាប ដូច្នោះយើងនឹងលូកដៃទាស់នឹងគេ ហើយបំផ្លាញអាហារនឹងអ្វីដែលគេមាន ហើយឲ្យគេកើតមានទុរភិក្ស ព្រមទាំងសម្លាប់មនុស្ស ហើយនិងសត្វពីទឹកដីនេះ[14]ទោះបើមនុស្សទាំងបីនាក់នេះ គឺណូអេ ដានីយ៉ែល និងយ៉ូប បាននៅក្នុងទឹកដីនោះ ពួកគេនឹងរួចជីវិតដោយសារសេចក្តីសុចរិតខ្លួនតែប៉ុណ្ណោះ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះបានថ្លែង។
[15]ប្រសិនបើ យើងចាត់សត្វកំណាចឲ្យទៅក្នុងទឹកដីនេះ ហើយធ្វើឲ្យវាវិនាស ដូច្នោះហើយទឹកដីនោះនឹងត្រូវលាងសម្អាត ហើយក៏គ្មានអ្នកណាហ៊ានដើរតាមនោះដែរ ដោយព្រោះសត្វទាំងនោះ[16]ទោះបើមនុស្សទាំងបីនាក់នោះនៅក្នុងទឹកដីនេះ ដូចដែលយើងនៅរស់ នេះជាការប្រកាស់នៃព្រះអម្ចាស់ដ៏ជាព្រះ គឺពួកគេនឹងមិនអាចដើម្បីជួយដល់កូនប្រុសកូនស្រីខ្លួនឲ្យរួចទេ គឺរួចបានតែជីវិតគេប៉ុណ្ណោះ តែទឹកដីនោះនឹងត្រូវចោលស្ងាត់វិញ។
[17]ឬប្រសិនបើយើងនាំដាវមកលើទឹកដីនោះ ដោយបង្គាប់ថា ដាវអើយ ចូរទៅក្នុងទឹកដីនេះ ហើយយើងកាត់ទាំងមនុស្ស និងសត្វចេញពីវាផង[18]ទោះបើមនុស្សទាំងបីនាក់នោះនៅក្នុងទឹកដីនេះ ដូចដែលយើងនៅរស់ នេះជាការប្រកាស់នៃព្រះអម្ចាស់ដ៏ជាព្រះ គឺពួកគេនឹងមិនអាចដើម្បីជួយដល់កូនប្រុសកូនស្រីខ្លួនឲ្យរួចទេ គឺរួចបានតែជីវិតពួកគេប៉ុណ្ណោះ។
[19]ឬប្រសិនបើយើងចាត់អាសន្នរោគ ទៅក្នុងទឹកដីនោះ ហើយដាក់កំហឹងរបស់យើងទាស់ទៅលើពួកគេ ដោយកម្ចាយឈាម ហើយសម្លាប់ទាំងមនុស្ស និងសត្វចេញផង[20]ទោះបើណូអេ ដានីយ៉ែល និងយ៉ូបបាននៅក្នុងទឹកដីនោះក៏ដោយ ដូចដែលយើងនៅរស់ នេះជាការប្រកាស់នៃព្រះអម្ចាស់ដ៏ជាព្រះ គង់តែនឹងជួយកូនប្រុសកូនស្រីខ្លួនឲ្យរួចមិនបានដែរ គឺសេចក្តីសុចរិតរបស់អ្នកទាំងនោះ នឹងជួយបានជីវិតរបស់ខ្លួនឲ្យរួចបាន។
[21]ដ្បិតព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូលដូច្នេះ យើងចាត់សេចក្តីវេទនាតាមរយៈការទាំងបួនយ៉ាងនេះ ទៅលើក្រុងយេរូសាឡិម គឺជាដាវ ជាអំណត់ ជាសត្វសាហាវ និងអាសន្នរោគ ដើម្បីនឹងសម្លាប់ទាំងមនុស្ស និងសត្វចេញផងពីក្រុងនោះ។
[22]ប៉ុន្តែ មើល៍! នឹងមានអ្នករួចជីវិតនៅក្នុងក្រុងនោះ គេនឹងត្រូវនាំចេញមក ទាំងកូនប្រុសហើយនិងកូនស្រី។ មើល!ៈ ពួកគេនឹងចេញទៅរកអ្នករាល់គ្នា ហើយអ្នកនឹងឃើញផ្លូវ និងអំពើរបស់គេ រួចអ្នកនឹងបានក្សាន្តចិត្ត ពីដំណើរការអាក្រក់ ដែលយើងបានទម្លាក់ទៅលើក្រុងយេរូសាឡិម គឺពីគ្រប់ទាំងការដែលយើងបាននាំទៅលើក្រុងនោះ។

generated on Wed Sep 10 16:16:32 2025

[23]ពួកអ្នករួចជីវិតនឹងកម្សាន្តចិត្តអ្នករាល់គ្នា ដោយអ្នកឃើញផ្លូវ និងអំពើដែលគេប្រព្រឹត្តទាំងនោះ ហើយអ្នករាល់គ្នានឹងដឹងថា ការដែលយើងបានធ្វើដល់គេ នោះមិនមែនដោយគ្មានប្រយោជន៍ទេ! នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់»។

Ezekiel 14:1

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ព្រះអង្គ»។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១

បានតាំងរូបព្រះរបស់គេនៅក្នុងចិត្តគេ

ការបកប្រែរបៀបផ្សេងទៀត: «ចាត់ទុករូបព្រះរបស់គេគឺសំខាន់ណាស់» ឬ «មានសេចក្តីស្រលាញ់ចំពោះរូបព្រះរបស់គេ»

នៅចំពោះមុខគេ

ព្រះអង្គកំពុងតែមានព្រះបន្ទូលថាបុរសទាំងនោះបានដាក់រូបព្រះដែលពួកគេអាចមើលឃើញនៅក្នុងចិត្តរបស់ពួកគេ។ នេះបង្ហាញថារូបព្រះមានសារៈសំខាន់ចំពោះពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «កន្លែងដែលអាចមើលឃើញ»

ជំពប់ដួលនៃអំពើទុច្ចរិត

រូបព្រះទាំងនោះសំដៅទៅលើអ្វីមួយដែលបាបរបស់ពួកគេធ្វើឲ្យពួកគេធ្វើដំណើរហើយជំពប់ដួល។ ការបកប្រែរបៀបផ្សេងទៀត: «ឱកាសដែលនាំឲ្យជំពប់ដួល»

តើគួរយើងសួរទាំងអស់នេះតាមរយៈពួកគេ?

ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនគួរសួរយើងពីអ្វីទាំងអស់នោះទេ»។

Ezekiel 14:4

ដូច្នោះហើយ ចូរប្រកាសការនេះដល់គេ

ពាក្យថា «ពួកគេ» សំដៅទៅលើ «បុរសពីពួកព្រឹទ្ធាចារ្យនៃអ៊ីស្រាអែល» ។

ដែលបានយករូបព្រះដាក់ក្នុងចិត្តខ្លួន

ការបកប្រែរបៀបផ្សេងទៀត:

«អ្នកណាចាត់ទុករូបព្រះរបស់គាត់ថាសំខាន់ខ្លាំងណាស់» ឬ «អ្នកណាស្រឡាញ់រូបព្រះរបស់គាត់»

ការភ័យខ្លាចនៃអំពើទុច្ចរិតរបស់ខ្លួននៅចំពោះមុខខ្លួន

ពាក្យថា «មុនមុខរបស់គាត់» មានន័យថា «ដោយការយកចិត្តទុកដាក់ទាំងស្រុងរបស់គាត់»។ ការបកប្រែរបៀបផ្សេងទៀត: «រូបព្រះដែលគាត់បានប្រើដើម្បីធ្វើបាបដោយការគោរពបូជា»

រួចហើយមករកព្យាការី

មនុស្សម្នាក់ទៅរកព្យាការីដើម្បីស្តាប់អ្វីដែលព្រះអង្គមានព្រះបន្ទូល។

ចំនួនរូបព្រះរបស់គេ

ការបកប្រែរបៀបផ្សេងទៀត: «តើគាត់មានរូបព្រះប៉ុន្មាន»

យើងអាចនឹងយកកូនចៅអ៊ីស្រាអែលមកវិញ ក្នុងចិត្តរបស់គេ

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងធ្វើអោយប្រជាជនអ៊ីស្រាអែលស្រឡាញ់យើងម្តងទៀត»

យកត្រឡប់មកវិញ... ទៅឆ្ងាយពីយើង

ទ្រង់មានព្រះបន្ទូលថានឹងនាំពួកគេត្រឡប់មកវិញដើម្បីឲ្យពួកគេស្រឡាញ់ទ្រង់ ទោះបីជារូបព្រះរបស់ពួកគេបានរុញច្រានពួកគេចេញពីព្រះអង្គក៏ដោយ។

Ezekiel 14:6

កូនចៅអ៊ីស្រាអែល

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។

ចូរប្រែចិត្ត និងបែរចេញពីរូបព្រះរបស់អ្នកទៅ! ហើយងាកមុខពីអស់ទាំងការគួរស្អប់ខ្ពើមរបស់អ្នកដែរ។

ឃ្លាទាំងពីរនេះគឺជាវិធីដើម្បីប្រាប់ប្រជាជនអ៊ីស្រាអែលឲ្យឈប់ថ្វាយបង្គំរូបព្រះទៅ។

ចូរប្រែចិត្ត និងបែរចេញ

ពាក្យ «ប្រែចិត្ត» និង «បែរចេញ» មានន័យថាជាមូលដ្ឋានដូចគ្នា។ ពួកគេរួមគ្នាពង្រឹងបទបញ្ជាឲ្យឈប់ថ្វាយបង្គំរូបព្រះ។

Ezekiel 14:7

អ្នកដែលយករូបព្រះដាក់ក្នុងចិត្ត

ការបកប្រែរបៀបផ្សេងទៀត:

«អ្នកណាចាត់ទុករូបព្រះរបស់គាត់គឺសំខាន់ខ្លាំងណាស់» ឬ «អ្នកណាស្រឡាញ់រូបព្រះរបស់គាត់»

ហេតុចំពប់នៃសេចក្តីទុច្ចរិតរបស់ខ្លួនចំពោះមុខខ្លួន

ការបកប្រែរបៀបផ្សេងទៀត:

«រូបព្រះដែលគាត់បានប្រើដើម្បីធ្វើបាបដោយគោរពបូជាវា»

យើងនឹងតាំងមុខទាស់នឹងអ្នកនោះ

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងប្រឆាំងនឹងគាត់» ឬ «យើងនឹងយកចិត្តទុកដាក់ចំពោះការធ្វើបាបគាត់»

ជាទីសម្គាល់ ហើយនិងពាក្យសុភាសិត

នៅទីនេះពាក្យ «សញ្ញា» និង «សុភាសិត» សំដៅទៅលើអ្វីមួយដែលជាការព្រមានដល់អ្នកដទៃអំពីផលវិបាកអាក្រក់នៃអាកប្បកិរិយា។

Ezekiel 14:9

យើងនឹងលូកដៃទៅលើគេ ព្រមទាំងបំផ្លាញគេ

ព្រះហស្តរបស់ព្រះសំដៅទៅលើអ្វីដែលគាត់ធ្វើ។ ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងធ្វើការប្រឆាំងនឹងគាត់»

នឹងត្រូវទ្រាំទ្រចំពោះសេចក្តីទុច្ចរិតរបស់ខ្លួន

ការបកប្រែរបៀបផ្សេងទៀត:

«ពួកគេនឹងទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានធ្វើខុស»

នឹងលែងវង្វេងចេញពីខ្ញុំទៀតហើយ

ឃ្លានេះសំដៅទៅលើការវង្វេងចេញឆ្ងាយពីយើង»

ប្រៀបធៀបនឹងការមិនធ្វើអ្វីដែលព្រះអង្គចង់ដើរចេញពីគាត់។

Ezekiel 14:12

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ព្រះអង្គ»

សូមមើលរបៀបនៃការបកប្រែនៅក្នុងជំពូក ១:១។

Ezekiel 14:15

មនុស្សទាំងបីនាក់

លោកណូអេ ដានីយ៉ែល និង យ៉ូប

ដូចដែលយើងនៅរស់ នេះជាការប្រកាសនៃព្រះអម្ចាស់ដ៏ជាព្រះ

នេះអាចត្រូវបានបញ្ជាក់៖ «ព្រះជាអម្ចាស់មានព្រះបន្ទូលប្រកាសប្រាប់ «ដូចដែលយើងនៅរស់»

គឺរួចបានតែជីវិតគេប៉ុណ្ណោះ

«ព្រះអម្ចាស់នឹងជួយសង្គ្រោះជីវិតពួកគេឲ្យបានរស់នៅ»

Ezekiel 14:17

មនុស្សទាំងបីនាក់

លោកណូអេ ដានីយ៉ែល និង យ៉ូប

ដូចដែលយើងនៅរស់ នេះជាការប្រកាសនៃព្រះអម្ចាស់ដ៏ជាព្រះ

នេះអាចត្រូវបានបញ្ជាក់៖ «ព្រះជាអម្ចាស់មានព្រះបន្ទូលប្រកាសប្រាប់ «ដូចដែលយើងនៅរស់»

Ezekiel 14:19

ដាក់កំហឹងរបស់យើង

ដូចជាពាងមួយអាចទប់ទឹកបាន

នោះព្រះជាម្ចាស់ទ្រង់កំពុងតែធ្វើការវិនិច្ឆ័យទោសវិញ។ ដូច្នេះ «ចាក់កំហឹងរបស់យើង»

មានន័យថាព្រះជាម្ចាស់នឹងមិនឈប់សកម្មភាពកំហឹងរបស់ព្រះអង្គទៀតឡើយ

ប៉ុន្តែព្រះអង្គនឹងសំដែងព្រះហឫទ័យនឹងប្រជាជនអ៊ីស្រាអែល។

សម្លាប់ទាំងមនុស្ស និងសត្វចេញផង

ឃ្លានេះសំដៅទៅលើការសម្លាប់ដែលជាសកម្មភាពនៃការជំនុំជំរះរបស់ព្រះអង្គចំពោះអំពើបាប។

ការបកប្រែរបៀបផ្សេងទៀត: «សម្លាប់ទាំងមនុស្ស និងសត្វ»

Ezekiel 14:21

ចេញផងពីក្រុងនោះ

ពាក្យថា «នាង» សំដៅទៅលើក្រុងយេរូសាឡិម។

Ezekiel 14:22

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូលជាមួយនឹងលោកអេសេគាលអំពីការដាក់ទោសរបស់ជនជាតិអ៊ីស្រាអែល។

មើល!

ពាក្យថា «មើល!»

នៅទីនេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានដែលមាននៅខាងក្រោម។

ទុកនៅក្នុងនាង ...ធ្វើទាស់នឹងនាង

ពាក្យថា «នាង» សំដៅទៅលើក្រុងយេរូសាឡិម។

ផ្លូវ និងអំពើដែលគេប្រព្រឹត្តទាំងនោះ

ឃ្លាទាំងពីរនេះសំដៅទៅលើអ្វីដែលប្រជាជនអ៊ីស្រាអែលបានធ្វើ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: «របៀបរស់នៅរបស់ពួកគេ» ឬ «អ្វីដែលពួកគេធ្វើ»។

15 [1]ក្រោយមកព្រះបន្ទូលនៃព្រះជាម្ចាស់មកខ្ញុំប្រាប់ថា៖[2]«កូនមនុស្សអើយ តើដើមទំពាំងបាយជូរ ប្រសើរជាងដើមឈើហើយនិងមែកផ្សេង ដែលនៅក្នុងព្រៃទាំងមូលឬ?
[3]តើមនុស្ស អាចយកឈើពីដើមទំពាំងបាយជូរទៅធ្វើអ្វីមួយ? ឬក៏ពួកគេយកទៅធ្វើជាស្នួលហាលរបស់លើរា?[4]មើល៍! ប្រសិនបើ ដាក់វាដុតក្នុងភ្លើងជាអុស ហើយបើភ្លើងឆេះកន្ទុយអុសទាំងសងខាង និងឆេះផ្នែកកណ្តាលអស់ដែរ តើវាអាចយកទៅធ្វើអ្វីបាន?
[5]មើល៍! កាលវានៅទាំងមូល វាមិនអាចប្រើការអ្វីបានទេ ពិតប្រាកដណាស់ ពេលភ្លើងបានឆេះអស់ ក្រោយមកវានៅតែមិនអាចយកទៅប្រើបានជាប្រយោជន៍ដដែល។
[6]ហេតុនេះហើយបានជាព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ មិនចូលចិត្តដើមឈើដែលនៅក្នុងព្រៃ យើងបានឲ្យដើមទំពាំងបាយជូរធ្វើជាអុសសម្រាប់ដុត
យើងនឹងធ្វើបែបនេះដាក់ប្រជាជននៃក្រុងយេរូសាឡិមដែរ។
[7]ដ្បិត យើងនឹងតាំងមុខយើងទាស់នឹងពួកគេ។ ទោះបីគេនឹងចេញពីភ្លើងមក តែភ្លើងនោះនឹងឆេះពួកគេ ដូច្នោះអ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់ ក្នុងកាល
ដែលយើងតាំងមុខទាស់នឹងពួកគេ។[8]រួចយើងនឹងធ្វើឲ្យទឹកដីនេះត្រូវចោលស្ងាត់ ដោយព្រោះគេបានធ្វើបាប នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 15:1

ព័ត៌មានទូទៅ:

ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់លោកអេសេគាលក្នុងផ្នែកនេះ។

ព្រះបន្ទូលនៃព្រះជាម្ចាស់មកខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១។

តើដើមទំពាំងបាយជូរ ប្រសើរជាងដើមឈើហើយនិងមែកផ្សេង ដែលនៅក្នុងព្រៃទាំងមូលឬ?

ការបកប្រែរបៀបផ្សេងទៀត:

«ដើមទំពាំងបាយជូរមិនល្អជាងដើមឈើណាដែលមានមែកឈើដែលស្ថិតនៅក្នុងចំណោមព្រៃឈើទាំងមូលទេ»។

តើមនុស្ស អាចយកឈើពីដើមទំពាំងបាយជូរទៅធ្វើអ្វីមួយ?

ការបកប្រែរបៀបផ្សេងទៀត:

«មនុស្សមិនយកឈើពីដើមទំពាំងបាយជូរទៅធ្វើអ្វីផ្សេងទេ»។

ឬក៏ពួកគេយកទៅធ្វើជាស្នួលហាលរបស់លើរា?

ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនធ្វើអ្វីពីវាដើម្បីព្យួររបស់របរនោះទេ»។

ប្រសិនបើ ដាក់វាដុតក្នុងភ្លើងជាអុស ហើយបើភ្លើងឆេះកន្ទុយអុសទាំងសងខាង និងឆេះផ្នែក
កណ្តាលអស់ដែរ តើវាអាចយកទៅធ្វើអ្វីបាន?

ការបកប្រែរបៀបផ្សេងទៀត:

«បើអណ្តាតភ្លើងឆេះទាំងចុងទាំងកណ្តាលវាពិតជាមិនល្អសម្រាប់អ្វីទាំងអស់!

Ezekiel 15:5

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូល អំពីដើមទំពាំងបាយជូរ។

Ezekiel 15:7

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលកាន់លោកអេសេគាលអំពីជនជាតិអ៊ីស្រាអែល។

ត្រូវចោលស្ងាត់

ជាកន្លែងដែលមនុស្សគ្រប់គ្នាបានចាកចេញ។

ដោយព្រោះគេបានធ្វើបាប

«ពួកគេបានធ្វើបាប»

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ

សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៥:១១។

---

16 [1]រួចហើយព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ចូរធ្វើប្រាប់ក្រុងយេរូសាឡិមពីអំពើគួរស្អប់ខ្ពើមអ្នកក្រុង[3]ហើយប្រាប់ថា
ព្រះអម្ចាស់មានព្រះបន្ទូលនឹងក្រុងយេរូសាឡិមដូច្នេះ ការចាប់ផ្តើមកំណើតរបស់អ្នក គឺនៅលើទឹកដីរបស់ជនជាតិកាណានមក ឪពុកអ្នកជាជនជាតិអាម៉ូរី ហើយម្តាយ
អ្នកជាជនជាតិហេត។
[4]នៅថ្ងៃកំណើតរបស់អ្នក គឺនៅថ្ងៃដែលអ្នកកើតមក គេមិនបានកាត់ផ្តិតអ្នកទេ ក៏មិនបានលាងជម្រះអ្នកដោយទឹក ឬលាបអំបិល ឬរុំសំពត់ឲ្យផង។[5]គ្មានភ្នែកណា
គួរឲ្យអាណិតឡើយ ប៉ុន្តែអ្នកបានធ្វើការទាំងនោះដើម្បីខ្លួនអ្នក ឲ្យមានការអាណិតអាសូរចំពោះអ្នកវិញ។ នៅថ្ងៃដែលអ្នកបានកើតមកនោះ គឺគេបោះអ្នកចោលនៅទីវាល ពី
ព្រោះគេខ្ពើមជីវិតរបស់អ្នក។
[6]ប៉ុន្តែ យើងបានដើរតាមនោះជិតអ្នក ឃើញអ្នកលង់នៅក្នុងឈាមខ្លួន ហើយយើងបាននិយាយទៅអ្នក ក្នុងពេលដែលនៅក្នុងឈាមនោះថា «ជីវិត!» យើងបាននិយាយ
ទៅអ្នកពេលក្នុងឈាមខ្លួនអ្នក «ជីវិត!»[7]យើងធ្វើឲ្យអ្នកចម្រើនឡើង ដូចដំណាំលូតលាស់នៅក្នុងចម្ការ។ អ្នកនឹងមានគ្នាច្រើន
ហើយហើយអស្ចារ្យមានតម្លៃដូចគ្រឿងអលង្ការ។ ទ្រូងរបស់អ្នកដុះពេញរាង ហើយសក់ក៏លូតវែង តែពីមុន អ្នកធ្លាប់អាក្រាត ហើយនៅកណ្តាលវាល។
[8]យើងបានដើរកាត់តាមទីនោះម្តងទៀត ហើយយើងឃើញអ្នក។ មើល៍! អ្នកដល់វ័យដែលគេស្រឡាញ់ហើយ យើងក៏បានលាតជាយអាវរបស់យើងគ្របលើអ្នក គឺបិទបាំង
កុំឲ្យឃើញភាពអាក្រាតរបស់អ្នក។ ហើយយើងបានស្បថនឹងអ្នក ហើយតាំងសញ្ញានឹងអ្នក នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ ហើយអ្នកបានត្រឡប់ជារបស់យើង។
[9]ដូច្នោះយើងបានលាងអ្នកដោយទឹក យើងបានជម្រះឈាមអ្នកចេញយ៉ាងស្អាត រួចចាក់ប្រេងលាបឲ្យអ្នក។[10]យើងបានតែងអ្នកដោយសំពត់ប៉ាក់ ក៏បំពាក់ស្បែកជើងធ្វើពី
ស្បែកផ្សោតឲ្យអ្នក។ ហើយយើងក្រវាត់អ្នកដោយសំពត់ទេសឯក រួចបិតបាំងដោយសំពត់ព្រៃ។[11]បន្ទាប់មក យើងក៏បានតាក់តែងអ្នកដោយគ្រឿងអលង្ការ បានបំពាក់កង
នៅដៃអ្នក ហើយខ្សែនៅក។[12]យើងបំពាក់ក្រវិលនៅច្រមុះអ្នក ហើយទំហូរនៅត្រចៀកអ្នក ហើយនិងបូយ៉ាងល្អនៅក្បាលអ្នក។
[13]ដូច្នេះ អ្នកបានប្រដាប់ដោយមាស និងប្រាក់ ហើយអ្នកបានពាក់សំពត់ទេសឯកយ៉ាងម៉ដ្ត ហើយសំពត់ប៉ាក់ អ្នកបរិភោគ ម្សៅមីដែលល្អ ទឹកឃ្មុំ និងប្រេង អ្នកមាន
រូបស្អាតខ្លាំងណាស់ ហើយអ្នកនឹងក្លាយជាអគ្គមហេសី។[14]កិត្តិសព្ទនិងសិរីរុងរឿងរបស់អ្នក បានខ្ចរខ្ចាយទៅដល់អស់ទាំងនគរ ពីព្រោះភាពស្រស់ស្អាតរបស់អ្នក
ដ្បិតអ្នកបានគ្រប់លក្ខណ៍ ដោយតេជានុភាព ដែលយើងបានប្រទានដល់អ្នក នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[15]ប៉ុន្តែ អ្នកបានទុកចិត្តលើភាពស្រស់ស្អាត ហើយអ្នកធ្វើ ដូចជាស្រីពេស្យាដោយសារសម្រស់អ្នក ដោយប្រគល់ខ្លួនឲ្យអស់អ្នកដែលដើរកាត់
ដូច្នេះភាពស្អាតរបស់អ្នកនឹកក្លាយជារបស់គេ។[16]ក្រោយមក អ្នកយកសម្លៀកបំពាក់របស់អ្នក ជាមួយសម្លៀកបំពាក់ពួកគេ ធ្វើពីក្រណាត់ចម្រុះពណ៌ ទៅតាក់តែងទីសក្ការៈ
នៅតាមទួលខ្ពស់ៗ ហើយប្រព្រឹត្តអំពើពេស្យាចារនៅទីនោះ។ ការនេះមិនគួរកើតឡើងទេ។ មិនដែលមានរឿងដូច្នេះកើតឡើងទេ ។
[17]អ្នកយកគ្រឿងអលង្ការអ្នក ដែលធ្វើពីមាស និងប្រាក់ ដែលយើង ប្រទានដល់អ្នកនោះ ទៅធ្វើទាក់ទាញមនុស្សប្រុស ហើយអ្នកបានធ្វើជាមួយពួកគេក្នុងភាព
ពេស្យាដែលគួរធ្វើ។[18]អ្នកបានយកសម្លៀកបំពាក់ប៉ាក់របស់អ្នក ទៅគ្របបាំងគេ ព្រមទាំងលាបប្រេង និងកំញានរបស់យើងនៅមុខគេ។[19]អាហារដែលយើងបានឲ្យដល់អ្នក
គឺជាម្សៅយ៉ាងម៉ដ្ត ប្រេង និងទឹកឃ្មុំនោះ អ្នកបានរៀបនៅមុខគេ ដ្បិតក្លិនពិដោរ នេះគឺជាអ្វីដែលបានកើតឡើង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[20]រួចហើយ អ្នកបានយកកូនប្រុសស្រីអ្នក ដែលបានបង្កើតឲ្យយើង ទៅថ្វាយជាយញ្ញបូជាដល់ព្រះទាំងនោះ ឲ្យវាស៊ីធ្វើដូចជាអាហារ។ តើការប្រព្រឹត្តកំផិតរបស់
អ្នកជាបញ្ហាតូចទៀតឬ?[21]អ្នកបានសម្លាប់កូនយើង ហើយប្រគល់ទៅឲ្យត្រូវចូលក្នុងភ្លើង។[22]ក្នុងការគួរស្អប់ខ្ពើម ហើយនិងការកំផិតរបស់អ្នក នោះអ្នកមិនបាននឹកពីកាល
អ្នកនៅក្មេង ក្នុងគ្រាដែលអ្នកនៅអាក្រាត ហើយនៅកណ្តាលវាល ព្រមទាំងលង់នៅក្នុងឈាមរបស់អ្នក»។
[23]វេទនា! វេទនាដល់អ្នក! នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលថា ដ្បិតក្រោយអស់ទាំងអំពើដ៏លាមកអាក្រក់របស់អ្នក[24]អ្នកបានសង់ផ្ទះបនសម្រាប់ខ្លួន ហើយធ្វើ
កន្លែងសំខាន់សម្រាប់ខ្លួន នៅគ្រប់កន្លែង។
[25]អ្នកបានធ្វើកន្លែងសំខាន់នោះ នៅគ្រប់ច្រកផ្លូវ ហើយបានធ្វើឲ្យសេចក្តីលម្អរបស់អ្នកទៅទីខ្ពើមឆ្អើមវិញ អ្នកបានបើកជើងទទួលគ្រប់ប្រុសៗដែលដើរមកតាមនោះ ហើយ
បានចម្រើនការកំផិតរបស់អ្នកកាន់តែខ្លាំងឡើង។[26]អ្នកបានធ្វើដូចជាពេស្យា នឹងជនជាតិអេស៊ីប ជាមួយពួកជិតខាងអ្នកធ្វើកាន់តែច្រើន ក្នុងការកំផិតរបស់អ្នក ដែល
បណ្តាលឲ្យយើងមានកំហឹង។

generated on Wed Sep 10 16:16:32 2025

[27]មើល៍! យើងនឹងវាយអ្នកដោយដៃរបស់យើង ហើយដកយកអាហាររបស់អ្នកផងដែរ។ យើងនឹងប្រគល់ជីវិតរបស់អ្នកទៅឲ្យសត្រូវរបស់អ្នក ហើយកូនស្រីជនជាតិ
ភីលីស្ទីន ដែលបានខ្មាសចំពោះទង្វើអាសអាភាសរបស់អ្នក។[28]អ្នកបានប្រព្រឹត្តជាពេស្យាជាមួយនឹងជនជាតិអាសស៊ើរដែរ ដ្បិតអ្នកមិនចេះឆ្អែតឆ្អន់ឡើយ។ អ្នកបាន
រួមបវេណីនឹងគេ ក៏នៅតែមិនស្កប់ស្កល់ដែរ។[29]អ្នកបានប្រព្រឹត្តជាពេស្យាកាន់ច្រើនឡើង រហូតដល់ទឹកដីនៃពួកឈ្មួញ ជាជនជាតិខាល់ដេ នៅក្នុងទឹកដីកាណាន
ហើយទោះជាយ៉ាងនេះក្តីនៅតែមិនស្កប់ចិត្តអ្នក។
[30]តើចិត្តរបស់អ្នកឈឺយ៉ាងណាទៅ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលថា ដែលអ្នកបានប្រព្រឹត្តអំពើទាំងនេះ ហើយងារជាស្រីពេស្យាមិនខ្មាសគេទេ?[31]អ្នកបានសង់
ផ្ទះបនរបស់អ្នក នៅត្រង់មុខច្រកផ្លូវ និងកន្លែងសំខាន់របស់អ្នកនៅតាមកន្លែងទីសាធារណៈ។ អ្នកមិនមែនដូចជាស្រីពេស្យាទេ ពីព្រោះអ្នកមិនយកប្រាក់ពីគេឡើយ។
[32]អ្នកជាស្រីដែលកំផិត អ្នកទទួលមនុស្សដទៃ ជំនួសឲ្យប្តីរបស់ខ្លួន។[33]មនុស្សឲ្យប្រាក់ដល់ស្រីពេស្យាទាំងនោះ តែអ្នកវិញ អ្នកឲ្យប្រាក់ទាំងនោះដល់
មនុស្សដែលអ្នកស្រឡាញ់វិញ ហើយឲ្យគេមករកអ្នកពីគ្រប់ទិសទីជុំវិញ ដើម្បីដេកជាមួយអ្នកទៀត។[34]ដូច្នោះហើយអ្នកគឺខុសគ្នាពីស្រីទាំងនោះផ្សេងទៀត
ចាប់តាំងពីគ្មានអ្នកណាមកសុំអ្នកដើម្បីដេកជាមួយពួកគេ។ ផ្ទុយទៅវិញ អ្នកឲ្យប្រាក់ដល់ពួកគេ។ អត់មាននរណាឲ្យប្រាក់ដល់អ្នកទេ។
[35]ដូច្នេះហើយ ស្រីពេស្យាអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់។[36]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ពីព្រោះអ្នកបានបើកចំហរតណ្ហារបស់អ្នកនៅទីសំងាត់
ហើយធ្វើការពេស្យា ជាមួយពួកដែលអ្នកស្រឡាញ់ ហើយរួមទាំងព្រះដ៏គួរស្អប់ខ្ពើមរបស់អ្នក និងឈាមរបស់កូនចៅអ្នកដែលអ្នកបានថ្វាយដល់
ព្រះទាំងនោះ[37]ដូច្នោះហើយ ចូរមើល៍! យើងនឹងប្រមូលពួកសហាយរបស់អ្នក ដែលអ្នកបានជួបជាមួយគ្នា និងពួកទាំងដែលអ្នកបានស្រឡាញ់ ព្រមទាំងពួកដែលអ្នកបាន
ស្អប់ផង ហើយយើងនឹងប្រមូលគេឲ្យមកទាស់នឹងអ្នកនៅគ្រប់ទិស។ យើងនឹងបើកកេរ្តិ៍ខ្មាសអ្នកឲ្យគេឃើញ ដើម្បីឲ្យគេបានឃើញភាពអាក្រាត់អ្នក។
[38]ដ្បិតយើងនឹងជំនុំជម្រះអ្នក សម្រាប់ការដែលផិតប្តី និងកម្ចាយឈាមផង ហើយយើងនឹងទម្លាក់ឈាមទៅលើអ្នក ដោយកំហឹងហើយនិងចិត្តចង់របស់យើង។[39]យើងនឹង
ប្រគល់អ្នកទៅក្នុងកណ្តាប់ដៃរបស់គេ នោះគេនឹងបំផ្លាញផ្ទះបនរបស់អ្នក ហើយរំលំអស់ទាំងទីសំខាន់របស់អ្នកដែរ គេនឹងបកសម្លៀក បំពាក់អ្នកចេញ ហើយ
យកគ្រឿងអលង្ការរបស់អ្នក។ ពួកគេបោះបង់អ្នកឲ្យនៅអាក្រាត ហើយនៅកណ្តាលវាល។
[40]ក្រោយមក ពួកគេនឹងនាំហ្វូងមនុស្សឡើងមកទាស់នឹងអ្នក ហើយគប់អ្នកនឹងថ្ម ហើយចាក់ទម្លុះអ្នកដោយដាវរបស់គេ។[41]ពួកគេនឹងដុតផ្ទះអ្នកចោល ហើយសម្រេច
យុត្តិធម៌ដល់អ្នក នៅចំពោះភ្នែកពួកស្រីៗជាច្រើន ដូច្នេះ យើងនឹងធ្វើឲ្យអ្នកលែងប្រព្រឹត្តការពេស្យា ហើយអ្នកនឹងមិនចេញថ្លៃឈ្នួលឲ្យគេទៀតឡើយ។[42]បន្ទាប់មក យើង
នឹងសម្រាលសេចក្តីកំហឹងរបស់យើងចំពោះអ្នក ហើយការក្រោធរបស់យើង នឹងថយចេញពីចំពោះអ្នកដែរ ដ្បិតយើងនឹងនៅស្កប់ចិត្ត ហើយនិងមានកំហឹងទៀតទេ។
[43]ដោយព្រោះអ្នកមិនបាននឹកពីកាលអ្នកនៅក្មេង ហើយបានធ្វើឲ្យយើងពេញទៅដោយកំហឹងដោយសារការទាំងនេះ ហេតុនេះហើយ សូមមើល៍!
យើងខ្លួនឯងនឹងនាំក្បាលរបស់អ្នក មកដាក់ទោសតាមទង្វើរដែលអ្នកបានធ្វើ នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់។
តើអ្នកមិនបានដាក់អំពើពេស្យាដែលគួរខ្ពើមដើម្បីប្រព្រឹត្តតាមទេឬ?
[44]មើល៍! គ្រប់គ្នាណាដែលធ្លាប់ប្រើពាក្យសុភាសិត អ្នកនឹងពោលពាក្យនេះទាស់នឹងអ្នកថា «ម្តាយយ៉ាងណា កូនស្រីក៏យ៉ាងនោះដែរ»។[45]អ្នកជាកូនស្រីរបស់ម្តាយអ្នក ដែល
ជាអ្នកបានស្អប់ប្តី និងកូនខ្លួន អ្នកក៏ជាប្អូនស្រីរបស់ពួកបងស្រីខ្លួន ដែលជាអ្នកបានស្អប់ប្តី និងកូនគេដែរ។ ម្តាយអ្នកជាជនជាតិហេត ហើយឪពុកអ្នកជាជនជាតិអាម៉ូរី
[46]បងស្រីរបស់អ្នក ជាអ្នកសាម៉ារី ហើយកូនស្រីរបស់នាង ជាអ្នកដែលរស់នៅខាងតំបន់ខាងជើង ហើយប្អូនស្រីអ្នកវិញបានរស់នៅខាងត្បូងពីអ្នក នោះគឺជាសូដុម និងកូន
ស្រីរបស់នាង។
[47]អ្នកមិនត្រឹមតែដើរតាមផ្លូវរបស់គេ ឬប្រព្រឹត្តតាមអំពើគួរស្អប់ខ្ពើមរបស់គេទេ គឺអ្នកបានប្រព្រឹត្តខូចអាក្រក់ជាងគេ ក្នុងអស់ទាំងផ្លូវរបស់អ្នកទៅទៀត ដោយស្មានថាអំពើ
របស់គេតិចតួចទេ។[48]ដូចដែលយើងរស់នៅ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះបានថ្លែងព្រះបន្ទូល នោះប្រាកដជាសូដុម ជាប្អូនអ្នក ព្រមទាំងកូនមិនបានប្រព្រឹត្តដូចជាអ្នក និង
កូនស្រីរបស់អ្នកបានធ្វើ។
[49]មើល! នេះគឺជាអំពើបាបរបស់សូដុម ជាប្អូនស្រីអ្នក ព្រមទាំងកូន គឺមានអំនួត មានអាហារបរិភោគឆ្អែត ហើយមិនយកចិត្តទុកដាក់ គ្មានកង្វល់ពីអ្វីទេ។ នាងមិនដែល
ចម្រើនកម្លាំងដៃនៃពួកក្រីក្រ និងមនុស្សកម្សត់ទុគ៌តឡើយ។[50]នាងក៏មានចិត្តឆ្មើងឆ្មៃ ហើយបានប្រព្រឹត្តអំពើគួរស្អប់ខ្ពើម នៅចំពោះយើង ដូច្នោះ យើងដកគេចេញ
ដូចដែលអ្នកបានឃើញហើយ។
[51]ចំណែកសាម៉ារីវិញ មិនបានធ្វើបាបពាក់កណ្តាលបាបរបស់អ្នកទេ ផ្ទុយទៅវិញអ្នកបានធ្វើនូវទង្វើដែលគួរស្អប់ខ្ពើម ច្រើនជាងពួកគេបានធ្វើផង ហើយអ្នក
បានបង្ហាញថាប្អូនស្រីអ្នកមើលទៅប្រសើរជាងអ្នក ដោយព្រោះគ្រប់ទាំងការអ្រាក់ដែលអ្នកបានប្រព្រឹត្តនោះ![52]ជាពិសេសអ្នក បានបង្ហាញពីភាពអាម៉ាស់ខ្លួនឯង
ក្នុងរបៀបនេះអ្នកបានបង្ហាញថាប្អូនស្រីអ្នក គឺប្រសើរជាងអ្នក ដោយសារតែបាបដែលអ្នកបានធ្វើ ក្នុងរបៀបដែលចកឈ្មប់ខ្ពើម។
ប្អូនស្រីរបស់អ្នកពេលនេះមើលទៅដូចជាប្រសើរជាងអ្នក បង្ហាញការអាម៉ាស់របស់អ្នក ដ្បិតក្នុងផ្លូវនេះអ្នកបង្ហាញថាប្អូនស្រីបានប្រសើរជាងអ្នក។
[53]ដ្បិតយើងនឹងនាំពួកគេដែលជាឈ្លើយឲ្យមកវិញ គឺសូដុម ព្រមទាំងកូនដែលនៅជាឈ្លើយ សាម៉ារី ព្រមទាំងកូនដែលនៅជាឈ្លើយ និងពួកអ្នកទាំងប៉ុន្មានដែលនៅជា
ឈ្លើយ ឲ្យមកកណ្តាលគេផង។[54]ដើម្បីឲ្យមានតម្លាភាពនៃការអ្វីដែលអ្នកបង្ហាញពីសេចក្តីខ្មាសខ្លួន ហើយអ្នកនឹងមានការអាម៉ាស់មុខដោយព្រោះគ្រប់ការដែលអ្នកបានធ្វើ
ហើយនេះគឺជារបៀបដែលអ្នកអាចកម្សាន្តចិត្តដល់ពួកគេ។[55]ដូច្នេះ ប្អូនស្រីអ្នក គឺសូដុម និងកូនស្រីរបស់នាង នឹងត្រឡប់ទៅក្នុងភាពដើមរបស់ខ្លួន ហើយសាម៉ារី និងកូន
របស់នាង នឹងត្រឡប់ទៅសណ្ឋាននដើមរបស់ខ្លួនវិញ។ ចំណែកអ្នក និងកូនអ្នកនឹងវិលត្រឡប់ទៅដូចជាសណ្ឋាននដើមរបស់អ្នកដែរ។
[56]សូដុមជាប្អូនស្រីអ្នក មិនបាននិយាយដល់ដែលចេញពីមាត់អ្នកទេ ក្នុងពេលអ្នកមានពេញដោយភាពអំនួត[57]មុនពេលដែលសេចក្តីទុច្ចរិតរបស់អ្នកបានបើកបង្ហាញ។
ប៉ុន្តែពេលនេះអ្នកមានគោលបំណងប្រមាថ ដល់ពួកកូនស្រីស៊ីរី ហើយនិងពួកកូនស្រីភីលីស្ទីន ហើយអ្នកនៅជុំវិញនោះ។ មនុស្សគ្រប់គ្នានឹងមើលងាយអ្នក។[58]អ្នកនឹងត្រូវ
ទទួលភាពអាម៉ាស់ ហើយនិងទង្វើគួរស្អប់ខ្ពើមរបស់អ្នក! នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់!
[59]ដ្បិតព្រះអម្ចាស់ដ៏ជាព្រះ មានព្រះបន្ទូលដូច្នេះ យើងនឹងប្រព្រឹត្តចំពោះជាមួយអ្នក តាមអ្វីដែលគួនឹងទទួល អ្នកបានមើលងាយដល់ពាក្យសម្បថ ដោយផ្តាច់សេចក្តីសញ្ញា
ចេញ។
[60]ប៉ុន្តែ យើងនឹងនឹកចាំពីសេចក្តីសញ្ញា ដែលយើងបានតាំងនឹងអ្នក ក្នុងកាលដែលអ្នកនៅក្មេងនោះ ហើយយើងនឹងតាំងសញ្ញាមួយនឹងអ្នក ដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ច
ទៀត។[61]រួចហើយអ្នកនឹងនឹកឃើញពីផ្លូវរបស់អ្នក ហើយមានសេចក្តីខ្មាស ក្នុងកាលដែលអ្នកទទួលបងស្រីរបស់អ្នក និងប្អូនស្រីរបស់អ្នកផង។ យើងនឹងឲ្យបងប្អូននោះ
ដល់អ្នក ទុកជាកូនស្រីវិញ តែមិនមែនតាមសេចក្តីសញ្ញារបស់អ្នកទេ។
[62]យើងនឹងតាំងសេចក្តីសញ្ញារបស់យើងដល់អ្នក នោះអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់។[63]ដោយព្រោះការទាំងនេះ អ្នកបាននឹកចាំគ្រប់ការទាំងងស់ ហើយដោយអ្នក
អៀនខ្មាស ដូច្នោះអ្នកមិនអាចបើកម៉ាត់ដើម្បីនិយាយបាន ព្រោះការអាម៉ាស់ យើងបានអត់ទោស គ្រប់ទាំងអំពើដែលអ្នកបានប្រព្រឹត្ត នេះជាព្រះបន្ទូលរបស់
ព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 16:1

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអេសេគាលអំពីដើមកំណើតនៃជនជាតិអ៊ីស្រាអែលអ្នក

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១។

ការចាប់ផ្តើមកំណើតរបស់អ្នក

ទាំងពីរនេះនិយាយអំពីពេលដែលទីក្រុងយេរូសាឡិមត្រូវបានបង្កើតឡើង។

ដែលអ្នកជាជនជាតិអាម៉ូរី ហើយម្តាយអ្នកជាជនជាតិហេត

ប្រជាជាតិទាំងពីរនេះបានអភិវឌ្ឍទីក្រុងយេរូសាឡិមមុនពេលដែលប្រជាជនអ៊ីស្រាអែលមាន។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកត្រូវបានបង្កើតឡើងដោយជនជាតិអាម៉ូរី
និងពួកហេត»

generated on Wed Sep 10 16:16:32 2025

Ezekiel 16:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់ប្រៀបធៀបក្រុងយេរូសាឡិមទៅនឹងទារកដែលមិនចង់បាន។
គ្មានភ្នែក
«គ្មាននរណា»
គេខ្ពើមជីវិតរបស់អ្នក
«មនុស្សស្អប់អ្នក»
Ezekiel 16:6
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិមជាទារកដែលមិនចង់បានដែលត្រូវបានបោះបង់ចោល
ប៉ុន្តែ យើងបានដើរតាមនោះជិតអ្នក
ព្រះអម្ចាស់កំពុងតែដើរនៅក្បែរទារកទើបនឹងកើត។
សក់
រោមខ្លួន
មានតម្លៃដូចគ្រឿងអលង្ការ
នៅទីនេះស្ត្រីដែលតំណាងអោយក្រុងយេរូសាឡិមត្រូវបានគេនិយាយថា
នាងបានក្លាយជាគ្រឿងអលង្ការល្អបំផុត
ដូចជានាងបានក្លាយជាស្រីស្អាតជាងគេក្នុងចំណោមស្ត្រីទាំងអស់។
មានតម្លៃដូចគ្រឿងអលង្ការ
សំណៅសម័យទំនើបខ្លះបកប្រែថា «អ្នកចាស់ទុំល្មមក្នុងការពាក់គ្រឿងអលង្ការ»។
អាក្រាត ហើយនៅកណ្តាលវាល
ពាក្យទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ថានាងអាក្រាតទាំងស្រុង។
ការបកប្រែរបៀបផ្សេងទៀត: «អាក្រាតទាំងស្រុង»
Ezekiel 16:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិមនិងប្រជាជនអ៊ីស្រាអែលកាលនៅក្មេង
យើងបានដើរកាត់តាមទីនោះម្តងទៀត
នេះគឺចង់និយាយថាព្រះអម្ចាស់បានដើរដោយក្មេងស្រីនោះ។
អ្នកដល់វ័យដែលគេស្រឡាញ់ហើយ
នេះគឺចង់និយាយថា ព្រះអម្ចាស់ទតឃើញស្ត្រីក្រមុំចាស់ទុំល្មម នឹងរៀបការហើយ។
Ezekiel 16:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិមនិងប្រជាជនអ៊ីស្រាអែលកាលនៅក្មេង
សំពត់ប៉ាក់
បំណែកពណ៌ផ្សេងគ្នានៃក្រណាត់ ដែលបានដេរភ្ជាប់គ្នាដើម្បីបង្កើតជាការរចនា។
បានតាក់តែងអ្នក
«យើងបានបន្ថែមការតុបតែងដល់អ្នក»
Ezekiel 16:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិមនិងប្រជាជនអ៊ីស្រាអែលកាលនៅក្មេង
ប្រដាប់
«តុបតែង»
កិត្តិសព្ទ
ត្រូវបានគេស្គាល់ និងការគោរពពីមនុស្សជាច្រើន។
Ezekiel 16:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលអំពីក្រុងយេរូសាឡិម និងប្រជាជនអ៊ីស្រាអែលជាភរិយា។
ប៉ុន្តែ អ្នកបានទុកចិត្តលើភាពស្រស់ស្អាត
«គិតថាសម្រស់ផ្ទាល់ខ្លួនរបស់អ្នកអាចផ្គត់ផ្គង់តម្រូវការរបស់អ្នកបាន»
ដូចជាស្រីពេស្យា
នេះប្រៀបធៀបប្រជាជនអ៊ីស្រាអែលគោរពបូជារូបព្រះជាមួយស្ត្រីម្នាក់ដែលត្រូវបានគេ
ប្រគល់ខ្លួន
ខាងសីលធម៌ ឬ អសីលធម៌នូវសកម្មភាពទាំងឡាយណា
ត្រូវបានគេនិយាយនៅក្នុងព្រះគម្ពីរដូចជាវត្ថុរាវ។ ការបកប្រែរបៀបផ្សេងទៀត:
«ប្តេជ្ញាចិត្តដោយសេរី»
ពួកគេបានសម្រាប់ពួកគេ
អំពើពេស្យាចារត្រូវបានប្រព្រឹត្តចំពោះអ្នកដែលបានឆ្លងកាត់។
ពួកគេបានសម្រាប់ពួកគេ
ឃ្លាភាសាហេព្រើរនេះត្រូវបានបកប្រែតាមវិធីផ្សេងៗគ្នាជាច្រើន
ទៅតាមជំនាន់ទំនើបផ្សេងៗគ្នា។
Ezekiel 16:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
ទាក់ទាញមនុស្សប្រុស
«រូបចម្លាក់របស់មនុស្ស» ឬ «រូបចម្លាក់ដែលមើលទៅដូចជាបុរស»
អ្នកបានធ្វើជាមួយពួកគេក្នុងភាពពេស្យាដែលគួរធ្វើ
នេះជាវិធីគួរសមក្នុងការនិយាយថានារីវ័យក្មេងរូបនេះកំពុងដេកជាមួយមនុស្សប្រុស។
ស្រីស្អាត
«ដាក់ជាតង្វាយនៅមុខពួកគេ»
Ezekiel 16:20
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
បានបង្កើតឲ្យយើង
«បានផ្តល់កំណើតឲ្យ»
តើការប្រព្រឹត្តកំផិតរបស់អ្នកជាបញ្ហាតូចទៀតឬ?
ការបកប្រែរបៀបផ្សេងទៀត: «អ្នកធ្វើដូចជាអំពើពេស្យាចាររបស់អ្នក
មិនមែនជាអំពើបាបធ្ងន់ធ្ងរទេ»។
សម្លាប់
សំលាប់
អាក្រាត ហើយនៅកណ្តាលវាល
សូមមើលការបកប្រែនេះនៅក្នុងជំពូក ១៦:៦។
Ezekiel 16:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ក្រុងយេរូសាឡិម និងប្រជាជនអ៊ីស្រាអែល។
ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលថា
សូមមើលការបកប្រែនេះនៅក្នុងជំពូក ៥:១១។
អ្នកបានសង់ផ្ទះបនសម្រាប់ខ្លួន ហើយធ្វើកន្លែងសំខាន់សម្រាប់ខ្លួន នៅគ្រប់កន្លែង។
ឃ្លានេះសំដៅទៅលើការកសាងកន្លែងសម្រាប់គោរពបូជារូបព្រះ។
Ezekiel 16:25
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
នៅគ្រប់ច្រកផ្លូវ
ការចាប់ផ្តើមនៃផ្លូវត្រូវបានគេសំដៅទៅលើក្បាលរបស់វា។
Ezekiel 16:27
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
យើងនឹងវាយអ្នកដោយដៃរបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងធ្វើបាបអ្នកដោយអំណាចរបស់យើង»
ដកយកអាហាររបស់អ្នក
សំដៅទៅលើការបញ្ឈប់ការផ្គត់ផ្គង់អាហារ។
យើងនឹងប្រគល់ជីវិតរបស់អ្នកទៅ
«យើងនឹងលះបង់ជីវិតអ្នក»
កូនស្រីជនជាតិភីលីស្ទីន
ចាប់តាំងពីក្រុងយេរូសាឡិមត្រូវបានគេហៅថាជានារីវ័យក្មេងនោះសត្រូវរបស់នាងគឺពួកភីលីស្ទីនក៏ត្រូវបាន
Ezekiel 16:30
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
ហេតុអ្វីបានជាចិត្តអ្នកទន់ខ្សោយដូច្នេះ?
នៅទីនេះពាក្យថា «ចិត្ត» សំដៅទៅលើសេចក្តីស្រឡាញ់ និងភាពស្មោះត្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ហេតុអ្វីបានជាអ្នកស្រឡាញ់យើងតិចតួចដូច្នេះ»?
មិនរើសមុខ និង គ្មានភាពអៀនខ្មាស់
ពាក្យថា «មិនរើសមុខ»
គឺសំដៅទៅលើមនុស្សដែលដេកជាមួយមនុស្សផ្សេងៗគ្នាជាច្រើន។ ពាក្យថា

generated on Wed Sep 10 16:16:32 2025

«គ្មានភាពខ្មាស់អៀន» គឺសំដៅទៅលើមនុស្សដែលធ្វើបាបដោយបើកចំហ។
ពាក្យទាំងពីរនេះពិតណ៌នាអំពីគំនិតមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មានការអៀនខ្មាស និងមិនរើសមុខ»
មុខច្រកផ្លូវ
សូមមើលពីរបៀបនេះគឺជាការបកប្រែនៅក្នុងជំពូក ១៦:២៥។
Ezekiel 16:32
ព័ត៌មានទូទៅ :
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
អ្នកទទួលមនុស្សដទៃ
នេះសំដៅទៅលើការទទួលយកនរណាម្នាក់ឲ្យគេងជាមួយពួកគេ
Ezekiel 16:35
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
អ្នកបានបើកចំហរតណ្ហា
សកម្មភាពដែលមានគុណសម្បត្តិខាងសីលធម៌ត្រូវបានគេនិយាយជាញឹកញាប់ដូចជាវត្ថុរាវ
អ្នកបានបើកចំហរតណ្ហា
ការបកប្រែសម័យទំនើបខ្លះបកប្រែ «ចាក់បញ្ចូលទ្រព្យសម្បត្តិរបស់អ្នក»។
ឈាមរបស់កូនចៅអ្នកដែលអ្នកបានថ្វាយដល់ព្រះទាំងនោះ
នេះសំដៅទៅលើការសម្លាប់កុមារជាការបូជាដល់រូបព្រះ។
ចូរមើល!
ដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះអ្វីដែលនៅខាងក្រោម។
ភាពអាក្រាត
ពាក្យថា «អាក្រាត» គឺសំដៅទៅលើមនុស្សម្នាក់ដែលគ្មានសម្លៀកបំពាក់
ប៉ុន្តែក៏សំដៅទៅលើការមើលឃើញកំហុសរបស់មនុស្សទាំងអស់ផងដែរ។
Ezekiel 16:38
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីកងទ័ពរបស់ខ្មាំងសត្រូវដែលស្រឡាញ់ទីក្រុងយេរូសាឡិម
បោះចោលពំនូករបស់អ្នក ...រំលំអស់ទាំងទីសំខាន់របស់អ្នកដែរ
ឃ្លាទាំងនេះត្រូវបានគេនិយាយដូចគ្នានៅក្នុងវិធីផ្សេងគ្នា។
នេះបន្ថែមការសង្កត់ធ្ងន់ទៅលើឃ្លា។
អាក្រាត ហើយនៅកណ្តាលវាល
សូមមើលការបកប្រែនៅក្នុងជំពូក ១៦:៦។
Ezekiel 16:40
ព័ត៌មានទូទៅ :
ព្រះអម្ចាស់មានព្រះបន្ទូលអំពីកងទ័ពរបស់ខ្មាំងសត្រូវ
ដែលស្រឡាញ់ទីក្រុងយេរូសាឡិម។
យើងនឹងសម្រាលសេចក្តីកំហឹងរបស់យើងចំពោះអ្នក ហើយការក្រោធរបស់យើង នឹងថយចេញពី
ចំពោះអ្នកដែរ
ពាក្យថា «ក្រោធ» និង «កំហឹង» សំដៅទៅលើការដាក់ទណ្ឌកម្ម
ដែលព្រះអម្ចាស់ធ្វើដោយសារតែខឹង។ ឃ្លាទាំងពីរនេះមានន័យដូចគ្នា។
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងឈប់ដាក់ទោសអ្នកព្រោះយើងនឹងមិនខឹងនឹងអ្នកទៀតទេ»។
Ezekiel 16:43
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូល អំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
កាលអ្នកនៅក្មេង ហើយបានធ្វើឲ្យយើងពេញទៅដោយកំហឹង
ព្រះអម្ចាស់កំពុងតែសំដៅទៅលើគ្រាមុនៗ។ ការបកប្រែរបៀបផ្សេងទៀត:
«សេចក្តីសប្បុរសរបស់យើងចំពោះអ្នកនៅពេលអ្នកនៅក្មេង»
សូមមើល!
នេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះអ្វីដែលនៅខាងក្រោម។
យើងខ្លួនឯងនឹងនាំក្បាលរបស់អ្នក មកដាក់ទោសតាមទង្វើរដែលអ្នកបានធ្វើ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងដាក់ទណ្ឌកម្មអ្នកចំពោះរបៀបដែលអ្នកបានធ្វើ»
Ezekiel 16:44
ព័ត៌មានទូទៅ :
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីក្រុងយេរូសាឡិម
និងប្រជាជនអ៊ីស្រាអែលក្នុងនាមជាភរិយាដែលមិនស្មោះត្រង់។
មើល!
«មើល» នេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះអ្វីដែលនៅខាងក្រោម។
បានស្អប់ប្តី
«ដែលស្អប់ប្តីរបស់នាង»
Ezekiel 16:47
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តសំដៅទៅប្រជាជាតិដទៃជាញាតិនៃក្រុងយេរូសាឡិម។
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើដើម្បីសម្គាល់ការសម្រាកនៅក្នុងការបង្រៀន។
ព្រះអម្ចាស់ប្តូរពីរឿងប្រៀបប្រដូចរបស់ព្រះអង្គទៅបញ្ជាប្រជាជនក្រុងយេរូសាឡិមវិញ។
កុំដើរតាមគន្លងរបស់គេឬដើរតាមអំពើគួរស្អប់ខ្ពើមរបស់គេ
ការបកប្រែរបៀបផ្សេងទៀត: «កុំធ្វើដូចពួកគេ ឬ
ធ្វើអ្វីដែលគួរស្អប់ខ្ពើមដែលពួកគេធ្វើ»
Ezekiel 16:49
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តសំដៅទៅប្រជាជាតិដទៃជាញាតិនៃក្រុងយេរូសាឡិម។
គឺមានអំនួត មានអាហារបរិភោគឆ្អែត ហើយមិនយកចិត្តទុកដាក់ គ្មានកង្វល់ពីអ្វីទេ
ព្រះអម្ចាស់ពណ៌នាអំពីក្រុងសូដុមថាជាស្ត្រីអ្នកមានម្នាក់
ដែលមានទ្រព្យសម្បត្តិគ្រប់គ្រាន់ និងមានសុវត្ថិភាព។
នាងមិនដែលចម្រើនកម្លាំងដៃនៃពួកក្រីក្រ និងមនុស្សកម្សត់ទុគ៌តឡើយ
ពាក្យថា «អ្នកក្រ» និង «អ្នកខ្វះខាត»
បញ្ជាក់ថាអ្នកទាំងនេះជាមនុស្សដែលមិនអាចជួយខ្លួនឯងបាន។
ការបកប្រែរបៀបផ្សេងទៀត:
«នាងមិនបានជួយមនុស្សដែលមិនអាចជួយខ្លួនឯងបានទេ»។
Ezekiel 16:51
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តសំដៅទៅប្រជាជាតិដទៃជាញាតិនៃក្រុងយេរូសាឡិម។
ហើយអ្នកបានបង្ហាញថាប្អូនស្រីអ្នកមើលទៅប្រសើរជាងអ្នក
ព្រះអម្ចាស់ប្រើឃ្លានេះបីដងដើម្បីបញ្ជាក់ថាក្រុងសាម៉ារី
និងក្រុងសូដុមអាក្រក់ជាងក្រុងយេរូសាឡិម។
ជាពិសេសអ្នក បានបង្ហាញពីភាពអាមាស់ខ្លួនឯង
ព្រះអម្ចាស់ប្រើឃ្លានេះពីរដងដើម្បីបញ្ជាក់ពីរបៀបដែលប្រជាជនក្រុងយេរូសាឡិមបានប្រព្រឹត្តយ៉ាងអាម៉ាស
Ezekiel 16:53
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តសំដៅទៅប្រជាជាតិដទៃជាញាតិនៃក្រុងយេរូសាឡិម។
ជាឈ្លើយ
«ទ្រព្យសម្បត្តិ»
អ្នកបង្ហាញពីសេចក្តីខ្មាសខ្លួន ហើយអ្នកនឹងមានការអាម៉ាស់មុខ
ឃ្លាទាំងពីរនេះសំដៅទៅលើព្រះអម្ចាស់ដាក់ទោសប្រជាជននៅក្រុងយេរូសាឡិមជាសាធារណៈ។
Ezekiel 16:56
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តសំដៅទៅប្រជាជាតិដទៃជាញាតិនៃក្រុងយេរូសាឡិម។
សូដុមជាប្អូនស្រីអ្នក មិនបាននិយាយដល់ដែលចេញពីមាត់អ្នកទេ
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងមិននិយាយឈ្មោះសូដុមជាបងស្រីរបស់អ្នកទេ»
អ្នកមានគោលបំណងប្រមាថ
សំដៅទៅលើក្រុងយេរូសាឡិមជាអ្វីមួយដែលមនុស្សនិយាយអាក្រក់។
មើលងាយ
«ស្អប់»
អ្នកនឹងត្រូវទទួលភាពអាមាស់ ហើយនិងទង្វើគួរស្អប់ខ្ពើមរបស់អ្នក
«អ្នកនឹងត្រូវអាម៉ាស់មុខ
ហើយអ្នករាល់គ្នានឹងយល់ថាតើអ្នកបានធ្វើបាបអ្នកយ៉ាងម៉េចហើយ»
Ezekiel 16:59
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ក្រុងយេរូសាឡិម។
អ្នកបានមើលងាយដល់ពាក្យសម្បថ ដោយផ្តាច់សេចក្តីសញ្ញាចេញ
ការបកប្រែរបៀបផ្សេងទៀត:
«សម្រេចចិត្តថាការសន្យារបស់អ្នកគ្មានន័យអ្វីទាំងអស់

generated on Wed Sep 10 16:16:32 2025

ដូច្នេះអ្នកអាចផ្តាច់កិច្ចព្រមព្រៀងជាផ្លូវការ»
Ezekiel 16:60
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែចាត់ទុកក្រុងយេរូសាឡិមថាជាភរិយាដែលមិនស្មោះត្រង់ និងជាតិសាសន៍ដទៃទៀតជាសាច់ញាតិនៃក្រុងយេរូសាឡិម។
នឹកឃើញ
«នឹកចាំ»
Ezekiel 16:62
អ្នកបាននឹកចាំគ្រប់ការទាំងអស់
«នឹកចាំគ្រប់អ្វីទាំងអស់»
អ្នកមិនអាចបើកម៉ាត់ដើម្បីនិយាយបាន
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងមិននិយាយអ្វីទៀតទេ»

---

17 [1]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ចូរនិទានរឿងមួយនឹងដាក់ជាប្រស្នាដល់ប្រជាជនអ៊ីស្រា អែលទៅ។[3]ចូរប្រាប់ពួកគេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូចតនេះ មានសត្វឥន្ទ្រីមួយយ៉ាងធំ ផ្នាំងស្លាបវែង ស្លាបវាក្រាស់ ហើយចម្រុះពណ៌ ហើយឥន្ទ្រីនោះហើរទៅដល់ភ្នំលីបង់ រួចហើយកាច់ចុងដើមតាត្រៅ។[4]ឥន្ទ្រីក៏កាច់មែកខ្ពស់ជាងគេ ហើយពាំយកទៅទឹកដីកាណាន ដាក់មែកឈើក្នុងក្រុងរបស់អ្នកជំនួញ។
[5]មនុស្សក៏យកពូជចេញពីទឹកដីនោះមក ហើយយកទៅដាំនៅក្នុងដី ដែលមានជីជាតិ។[6]គាត់បានយកដាក់ដាំនៅក្បែរប្រភពទឹកដ៏ធំដូចជាដើមដើមសូល។ រួចហើយដើមនោះក៏ដុះឡើងត្រឡប់ជាដើមទំពាំងបាយជូរលូតលាស់ទាបទៅដី។ ខ្នែងរបស់វាក៏បែរមកទៅរកគាត់ ហើយឫសក៏នៅពីក្រោមវាដែរ។ ដូច្នេះ ដើមនោះបានត្រឡប់ជាដើមទំពាំងបាយជូរ ហើយក៏បែកខ្នែង ហើយចេញត្រួយផង។
[7]ប៉ុន្តែមានសត្វឥន្ទ្រីធំមួយទៀត ដែលមានស្លាបធំ ហើយចំអេងស្លាបយ៉ាងសម្បើម។ ចូរមើល៍! នេះគឺជាដើមទំពាំងបាយជូរ នោះបានចាក់ឫសពីដីដែលដាំនោះទៅខាងឥន្ទ្រីវិញ ហើយបោះមែកចេញទៅខាងវាដែរ ដើម្បីឲ្យវាបានស្រោចទឹក។[8]ដើមនោះបានដាំក្នុងដីល្អនៅក្បែរទឹកធំ ដើម្បីឲ្យបានបែកខ្នែង ហើយកើតផលផ្លែ ប្រយោជន៍ឲ្យបានជាដើមទំពាំងបាយជូរយ៉ាងប្រយោជន៍។
[9]ចូរប្រាប់មនុស្សថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ តើដើមនោះនឹងចម្រើនឡើងបានឬ? តើដើមមិនចាក់ឫស ហើយកាត់ផ្លែចេញ នោះវាទៅជាស្វិតទៅ ហើយឲ្យអស់ទាំងស្លឹកខ្ចីៗបានក្រៀមទៅដែរទេឬ? គឺមិនចាំបាច់មានដៃខ្លាំង ឬមនុស្សជាច្រើនមកដករំលើងឫសរបស់វាឡើយ។[10]ដូច្នេះមើល៍! ចាប់តាំងពីវាបានដាំហើយ តើដើមនេះអាចធំឡើងបានទេ? តើមិនស្វិតក្រៀមទៅទាំងអស់ ដោយគ្រាន់តែមានខ្យល់ពីខាងកើត បក់មកប៉ះវា? វានឹងត្រូវស្វិតក្រៀមនៅកន្លែងដែលដុះនោះ»។
[11]ហើយព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[12]«ចូរនិយាយទៅប្រជាជនដែលបះបោរថា តើអ្នករាល់គ្នាយល់ពីន័យទាំងនេះដែលទេ? ចូរមើល៍! ស្តេចបាប៊ីឡូនបានមកដល់ក្រុងយេរូសាឡិម កៀរយកទាំងស្តេច និងពួកអ្នកដឹកនាំទីក្រុង យកទៅជាមួយដល់ក្រុងបាប៊ីឡូន។
[13]រួចហើយ ស្តេចបាប៊ីឡូនក៏យកពូជស្តេចមួយអង្គ មកតាំងសញ្ញានឹងគ្នា ហើយក៏នាំគាត់ឲ្យស្បថ។ ស្តេចនាំពួកអ្នកខ្លាំងពូកែក្នុងទឹកដីចេញទៅ។[14]ដូច្នេះ ដើម្បីឲ្យរាជ្យនោះបានទាបថោក ហើយមិនដែលងើបឡើងទៀតបានឡើយ។ ដោយការរក្សាសេចក្តីសញ្ញាទឹកដីនឹងបានរួចជីវិត។
[15]ប៉ុន្តែ ស្តេចបានបះបោរនឹងព្រះអង្គវិញ ដោយចាត់រាជទូតទៅទឹកដីអេស៊ីប ដើម្បីឲ្យគេបានឲ្យសេះ និងពលទ័ពមកជាច្រើន ដូច្នេះ តើនឹងចម្រើនឡើងបានឬ? តើអ្នកដែលប្រព្រឹត្តដូច្នេះរួចខ្លួនឬ? តើអាចផ្តាច់សេចក្តីសញ្ញា ហើយរួចខ្លួនបានឬ?[16]ដូចជាយើងរស់នៅ ព្រះអម្ចាស់ដ៏ជាព្រះស្បថថា នោះប្រាកដជាស្តេចនឹងត្រូវស្លាប់ នៅកន្លែងក្នុងទឹកដីដែលបានតាំងទ្រង់ឡើងឲ្យសោយរាជ្យ ដែលទ្រង់បានមើលងាយពាក្យសម្បថ ហើយផ្តាច់សេចក្តីសញ្ញារនោះ។ ស្តេចនឹងស្លាប់ នៅកណ្តាលក្រុងបាប៊ីឡូន។
[17]ផារ៉ោននិងពលទ័ពដ៏ខ្លាំងពូកែរបស់ទ្រង់ នឹងកងទ័ពជាច្រើនទៀតចូលទៅក្នុងសង្គ្រាម តែមិនអាចការពារទ្រង់ពីចម្បាំងបានទេ
ពេលពួកទាហានបាប៊ីឡូនបោះជំរុំព័ទ្ធកំពែងដើម្បីសម្លាប់មនុស្សជាច្រើន។[18]ដ្បិតស្តេចបានមើលងាយពាក្យសម្បថ ដោយផ្តាច់សេចក្តីសញ្ញានោះចេញ។ ចូរមើល៍! ស្តេចលើដៃឡើងស្បថនិងធ្វើការសន្យា ប៉ុន្តែទ្រង់នៅតែធ្វើការទាំងនោះដដែល។ ស្តេចមិនអាចរួចខ្លួនទេ។
[19]ដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដូចជាយើងរស់នៅ តើមិនមែនពាក្យសម្បថរបស់យើង ដែលគេបានមើលងាយ និងសម្ពន្ធមេត្រីរបស់យើង ដែលគេធ្វើឲ្យខូច? ដូច្នេះយើងនឹងនាំការដាក់ទោសលើក្បាលគេដែរ![20]យើងនឹងដាក់សំណាញ់យើងទៅលើគេ ហើយនឹងត្រូវជាប់នៅក្នុងអន្ទាក់របស់យើង យើងនឹងនាំគេទៅក្រុងបាប៊ីឡូន ហើយនឹងមានរឿងនៅទីនោះ ដោយព្រោះអំពើរំលងដែលគេបានក្បត់យើង![21]អស់អ្នកដែលចំណានៗទាំងប៉ុន្មានក្នុងកងទ័ពរបស់គេ នឹងត្រូវដួលដោយដាវ ហើយពួកអ្នកដែលរួចជីវិត គេនឹងត្រូវខ្ចាត់ខ្ចាយទៅគ្រប់កន្លែង។ អ្នករាល់គ្នានឹងដឹងថា យើងនេះគឺព្រះអម្ចាស់ យើងបានប្រកាស ហើយវានឹងកើតឡើង»។
[22]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូចនេះ ដូច្នោះយើងខ្លួនឯងនឹងកាច់យកចុងដើមតាត្រៅដែលខ្ពស់ ហើយយកទៅដាំ ឆ្ងាយពីមែកដែលទន់។ យើងនឹងកាច់វាចេញ ហើយយើងខ្លួនឯងនឹងដាំវា នៅលើកំពូលភ្នំយ៉ាងខ្ពស់។[23]យើងនឹងដាំនៅលើភ្នំយ៉ាងខ្ពស់នៃទឹកដីអ៊ីស្រាអែល ដើមនោះនឹងបោះមែក ហើយកើតផល ហើយវានឹងក្លាយជាដើមតាត្រៅយ៉ាងល្អ ដូច្នោះហើយ អស់ទាំងសត្វស្លាបទាំងនោះនឹងជ្រកនៅក្រោមវា។ ពួកគេនឹងធ្វើសម្បុក នៅក្រោមម្លប់នៃមែកវា។
[24]ក្រោយមក ដើមឈើទាំងអស់នៅផែនដីនឹងដឹងថា យើងគឺជាព្រះអម្ចាស់។ យើងបន្ទាបដើមឈើខ្ពស់ចុះមក ហើយបានតម្កើងដើមឈើដែលទាបឲ្យខ្ពស់វិញ។ យើងនឹងធ្វើដើមឈើស្វិតនិងក្រៀមអាចចេញផ្កា។ យើងគឺព្រះអម្ចាស់ យើងបានប្រកាស់ការនោះនឹងកើតឡើង ហើយយើងបានធ្វើវា»។

Ezekiel 17:1
ព័ត៌មានទូទៅ:
លោកអេសេគាលរាយការណ៍នូវអ្វីដែលព្រះប្រទានដល់គាត់។
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកខ្ញុំ
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ព្រះអង្គ» សូមមើលការបកប្រែនៅក្នុងជំពូក ១:១។
កូនមនុស្ស
នេះសំដៅទៅលើលោកអេសេគាល។
ឃ្លានេះគឺជាការចាប់ផ្តើមនៃពាក្យដែលព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់លោកអេសេគាល
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២: ១។
ចូរនិទានរឿងមួយនឹងដាក់ជាប្រស្នា
«ផ្តល់ឲ្យពួកគេនូវគំនិតដើម្បីគិតអំពី» ឬ «ប្រាប់រឿងនេះជារូបភាព» (UDB)
ប្រជាជនអ៊ីស្រាអែល
សូមមើលការបកប្រែនៅក្នុងជំពូក ៣:១។
ឥន្ទ្រីដ៏ធំ
«ឥន្ទ្រីដ៏ធំសម្បើម»
ស្លាបវែង ស្លាបវាក្រាស់
ពាក្យថា «ស្លាប» មានន័យថាចុងស្លាបខាងក្រៅ។ ការបកប្រែជំនួស៖ «ចុងស្លាបរបស់វាវែងហើយពេញដោយរោម»។
ហើយចម្រុះពណ៌
នេះសំដៅទៅលើឥន្ទ្រី។
ឥន្ទ្រីក៏កាច់មែកខ្ពស់ជាងគេ
«វាបានផ្តាច់ចេញពីផ្នែកខ្ពស់បំផុតនៃដើមឈើ»
ពាំយកទៅ
«យកកំពូលដើមឈើ» ឬ «យកមែកឈើ»
ដាក់មែកឈើក្នុងក្រុងរបស់អ្នកជំនួញ
អ្នកជំនួញគឺជាអ្នកដែលលក់របស់របរ។
«ដាំវានៅក្នុងទីក្រុងមួយដែលមានឈ្មួញជាច្រើន» ឬ «ឥន្ទ្រីបានរស់នៅកំពូលដើមឈើនៅក្នុងទីក្រុងមួយដែលត្រូវបានគេស្គាល់ថាជាទីផ្សាររបស់វា»។
Ezekiel 17:5
ព័ត៌មានទូទៅ:
នេះគឺជាសាច់រឿងបន្តនៃការប្រៀបប្រដូចអំពីសត្វឥន្ទ្រី។
មនុស្សក៏យក
ពាក្យថា «គាត់» គឺជាសត្វឥន្ទ្រីក្នុងរឿងប្រៀបប្រដូច។
ដីរួចរាល់សម្រាប់ការសាបព្រួស
«វាលស្រែដែលត្រៀមរួចជាស្រេចសម្រាប់គ្រាប់ពូជត្រូវដាំនៅក្នុងនោះ។
ការបកប្រែជំនួស: «ដីស្រែដែលមានជីជាតិ» ឬ «នៅក្នុងដីល្អ»។
គាត់បានដាំវានៅក្បែរផ្លូវទឹកដ៏ធំ
«សត្វឥន្ទ្រីបានដាំគ្រាប់ពូជនៅកន្លែងដែលមានទឹកច្រើន»

generated on Wed Sep 10 16:16:32 2025

ដាំវា...ដូចជាដើមសូល
ដើមសូលបានដុះនៅកន្លែងដែលមានទឹកច្រើន។
ប្រសិនបើសត្វឥន្ទ្រីបានដាំគ្រាប់ពូជដូចជាមេមាន់
វាមានន័យថាគាត់បានដាំវានៅកន្លែងដែលមានទឹកច្រើន។ ការបកប្រែជំនួស:
«ហើយដាំគ្រាប់ពូជដូចជាដើមសូលនៅក្បែរទឹក»។
ដើមនោះក៏បានដុះឡើង
«បន្ទាប់មកគ្រាប់ពូជបានចាប់ផ្តើមលូតលាស់ទៅជារុក្ខជាតិ»
ជាដើមទំពាំងបាយជូរលូតលាស់ទាបទៅដី
«វល្លិដែលរីករាលដាលនៅលើដី»
ខ្នែងរបស់វាក៏បែរមកទៅរកគាត់
មែកឈើរបស់ដើមខ្នែងបែរទៅរកសត្វឥន្ទ្រី។
ឫសក៏នៅពីក្រោមវាដែរ
ឫសរបស់ខ្នែងបានដុះឡើងនៅក្រោមសត្វឥន្ទ្រី។
ដូច្នេះ ដើមនោះបានត្រឡប់ជាដើមទំពាំងបាយជូរ
«នោះហើយជារបៀបដែលដើមទំពាំងបាយជូរបានដុះឡើង»
ក៏បែកខ្នែង ហើយចេញផ្លែយផង
«ការរីករាលដាលបានកើនឡើងខ្នែង និងពន្លកបស់វា»។
Ezekiel 17:7
ព័ត៌មានទូទៅ :
ការណែនាំ «ប៉ុន្តែ»
បង្ហាញពីភាពខុសគ្នារបស់សត្វឥន្ទ្រីដែលត្រូវបានពិពណ៌នាពីមុនមក។
សត្វឥន្ទ្រីធំមួយ
សត្វឥន្ទ្រីមានទំហំធំមានថាមពល និងគួរឲ្យចាប់អារម្មណ៍។
ចូរមើល៍!
ពាក្យថា «មើល៍»
នៅទីនេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើងនេះ
គឺជាដើមទំពាំងបាយជូរ នោះបានចាក់ឫសពីដីដែលដាំនោះ ទៅខាងឥន្ទ្រីវិញ
ការបកប្រែរបៀបផ្សេងទៀត: «ឫសនៃដើមទំពាំងបាយជូរដុះឡើងដល់សត្វឥន្ទ្រី»
ដើម្បីឲ្យវាបានស្រោចទឹក
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះឥន្ទ្រីនឹងស្រោចទឹកដើមទំពាំងបាយជូរ»
ដើមនោះបានដាំ
ការបកប្រែរបៀបផ្សេងទៀត: « សត្វឥន្ទ្រីទីមួយបានដាំដើមទំពាំងបាយជូរ»។
ដាំក្នុងដីល្អនៅក្បែរទឹកធំ
ការបកប្រែរបៀបផ្សេងទៀត: «នៅកន្លែងដែលមានទឹកច្រើន»
ដើម្បីឲ្យបានបែកខ្នែង ហើយកើតផលផ្លែ ប្រយោជន៍ឲ្យបានជាដើមទំពាំងបាយជូរយ៉ាងប្រយោជន៍
«ដូច្នេះដើមទំពាំងបាយជូរនឹងបង្កើតមែក
និងផ្លែហើយក្លាយជាដើមទំពាំងបាយជូរដ៏គួរឲ្យចាប់អារម្មណ៍»
Ezekiel 17:9
តើដើមនោះនឹងចម្រើនឡើងបានឬ?
ការបកប្រែរបៀបផ្សេងទៀត: «វានឹងមិនរីកចម្រើនទេ»។
គាត់នឹងមិនចាក់ឫសហើយដកផ្លែវាចេញទេដូច្នេះស្លឹកឈើទាំងអស់នឹងរីងស្ងួតអស់ទៅមែនទេ?
ការបកប្រែរបៀបផ្សេងទៀត: «គាត់នឹងដកឫសគល់ និងបេះផ្លែរបស់វាចេញ
ដូច្នេះស្លឹកឈើទាំងអស់នឹងរីងស្ងួត»។
មើល៍!
ពាក្យថា «មើល!» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
(«ពិតណាស់!» «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក!»
តើដើមនេះអាចធំឡើងបានទេ?
ការបកប្រែរបៀបផ្សេងទៀត: « វានឹងមិនលូតលាស់ទេ»។
តើមិនស្ងិតក្រៀមទៅទាំងអស់ ដោយគ្រាន់តែមានខ្យល់ពីខាងកើត បក់មកប៉ះវា?
ការបកប្រែរបៀបផ្សេងទៀត:
«វានឹងក្រៀមស្ងិតនៅពេលដែលខ្យល់បក់ពីទិសខាងកើតប៉ះវា»។ .
Ezekiel 17:11
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១: ១។
តើអ្នករាល់គ្នាយល់ពីន័យទាំងនេះដែលទេ?
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកគួរតែដឹងថាតើរឿងទាំងនេះមានន័យយ៉ាងម៉េច»។
ចូរមើល៍!
«មើល!» ឬ «ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក!»
Ezekiel 17:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីស្តេចក្រុងយេរូសាឡិមដែលបះបោរប្រឆាំងនឹងស្តេចបាប៊ីឡូន។
តើនឹងចម្រើនឡើងបានឬ?
ការបកប្រែរបៀបផ្សេងទៀត: «គាត់ប្រាកដជាមិនជោគជ័យទេ»
តើអ្នកដែលប្រព្រឹត្តដូច្នេះរួចខ្លួនឬ?
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលធ្វើអ្វីៗទាំងនេះនឹងមិនរួចខ្លួនឡើយ!»។
តើអាចផ្តាច់សេចក្តីសញ្ញា ហើយរួចខ្លួនបានឬ?
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើគាត់ផ្តាច់កិច្ចព្រមព្រៀង
គាត់ច្បាស់ជាមិនរត់គេចទេ!»
Ezekiel 17:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីស្តេចក្រុងយេរូសាឡិម។
ពលទ័ពដ៏ខ្លាំងពូកែរបស់ទ្រង់ នឹងកងទ័ពជាច្រើនទៀតចូលទៅក្នុងសង្គ្រាម
ឃ្លាទាំងពីរនេះមានន័យថាជាមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់ថាតើកងទ័ពរបស់ផារ៉ោនមានទំហំប៉ុនណាហើយខ្លាំងប៉ុនណា។
មិនអាចការពារទ្រង់
ពាក្យថា «គាត់» នៅទីនេះសំដៅទៅលើស្តេចយូដា។
ព័ទ្ធជញ្ជាំង
នេះសំដៅទៅលើប៉មមួយដែលមានកាំជណ្តើរដែលអាចដាក់នៅជាប់នឹងជញ្ជាំង
ហើយអនុញ្ញាតឲ្យទាហានចូលទៅដល់លើជញ្ជាំង និងចូលទៅទីក្រុង។
ចូរមើល៍!
«មើល» បន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាស់»។
ស្តេចលើដៃឡើងស្បថនិងធ្វើការសន្យា
នេះសំដៅទៅលើការកាន់ដៃរបស់មនុស្សម្នាក់ទៀតជាសញ្ញានៃមិត្តភាព
និងកិច្ចព្រមព្រៀង។
Ezekiel 17:19
តើមិនមែនពាក្យសម្បថរបស់យើង ដែលគេបានមើលងាយ និងសម្ពន្ធមេត្រីរបស់យើង
ដែលគេធ្វើឲ្យខូច?
«វាគឺជាពាក្យសម្បថរបស់យើងខ្ញុំ ដែលស្តេចក្រុងយេរូសាឡិមបានមើលងាយ
និងសេចក្តីសញ្ញារបស់យើងដែលបានបែកបាក់»។ .
ដូច្នេះយើងនឹងនាំការដាក់ទោសលើក្បាលគេដែរ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងដាក់ទណ្ឌកម្មគេ»។
ត្រូវដួលដោយដាវ
ការបកប្រែរបៀបផ្សេងទៀត: «ត្រូវបានសម្លាប់ដោយកងទ័ពរបស់បាប៊ីឡូន»
Ezekiel 17:22
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីក្រុងយេរូសាឡិមដូចមែកដែលដាំនៅលើភ្នំអ៊ីស្រាអែល។
បោះមែក
«លូតលាស់បែកមែកសាខាថ្មី»
Ezekiel 17:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីដើមឈើដូចជាក្រុងនានាដែរ។
ក្រោយមក ដើមឈើទាំងអស់នៅផែនដីនឹងដឹងថា យើងគឺជាព្រះអម្ចាស់
ដើមឈើខ្ពស់....ដើមឈើទាប
ដើមឈើស្ងិត
នៅពេលដែលរុក្ខជាតិស្ងួតហើយងាប់។

---

18 [1]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំម្តងទៀតប្រាប់ថា[2]«តើអ្នកចង់មានន័យដូចម្តេច អ្នកជាបានប្រើសុភាសិតនេះ និយាយអំពីទឹកដីអ៊ីស្រាអែលប្រាប់ថា ឪពុក
បានស៊ីផ្លែជូរដែលមានរស់ជាតិជូរ ហើយធ្មេញកូនត្រូវសង្កៀរវិញឬ?

generated on Wed Sep 10 16:16:32 2025

[3]ដូចជាយើងរស់នៅ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល ប្រាកដជាអ្នករាល់គ្នាមិនមានឱកាសនឹងនិយាយសុភាសិតនេះ នៅក្នុងទឹកដីអ៊ីស្រាអែលទៀតទេ។[4]មើល! ជីវិតទាំងនោះជារបស់យើង ទោះជាជីវិតរបស់ឪពុក និងជីវិតរបស់កូន គឺជារបស់យើងដូចគ្នា! ជីវិតអ្នកមានបាប គឺជាអ្នកដែលត្រូវស្លាប់!
[5]តើអាចនិយាយពីមនុស្សដែលសុចរិត ហើយជាអ្នកប្រព្រឹត្តសេចក្តីត្រឹមត្រូវ ហើយភាពសុចរិត[6]ប្រសិនបើគាត់មិនបាន ស៊ីនៅតាមលើភ្នំទាំងនោះទេ ឬមិនបានងើបមើលទៅរូបព្រះរបស់ជនជាតិអ៊ីស្រាអែលទេ ហើយគាត់មិនបានបង្អាប់ប្រពន្ធរបស់អ្នកជិតខាងខ្លួន នឹងទាក់ទងស្រីដែលមានរដូវ តើគាត់នោះជាមនុស្សសុចរិតឬអី?
[7]តើអាចនិយាយបែបណាបាន មនុស្សម្នាក់មិនដែលកេញចំណេញពីនរណាម្នាក់សោះ ហើយគាត់បានសងគ្រប់ទាំងការជំពាក់ដល់អ្នកដែលបានឲ្យខ្ចីយ៉ាងតឿងទាត់ ហើយក៏មិនបានលួចទ្រព្យអ្នកដ៏ទៃដែរ តែងតែឲ្យអាហារនិងសម្លៀកបំពាក់ក្រីក្រវិញ តើអ្នកនោះគឺជាមនុស្សសុចរិតឬ?[8]តើនឹងនិយាយយ៉ាងណាចំពោះអ្នកឲ្យប្រាក់គេខ្ចី ដោយឥតយកការ ឬទារកម្រៃហួសហេតុ ពីអ្វីដែលគាត់បានរកស៊ី? អាចនិយាយបានថាគាត់រក្សានូវភាពយុតិធម៌ ហើយបានសាងទំនុកចិត្តដល់មនុស្សឯទៀត។[9]បើគាត់ប្រព្រឹត្តតាមក្រឹត្យក្រមរបស់យើង ហើយរក្សាបញ្ញត្តិច្បាប់របស់យើង ដើម្បីនឹងប្រព្រឹត្តដោយស្មោះត្រង់ ហើយសេចក្តីសន្យាមនុស្សសុចរិតគឺដូចនេះ គាត់នឹងរស់នៅជាប្រាកដ។ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល។
[10]ប៉ុន្តែ ប្រសិនបើមនុស្សសុចរិតនោះមានកូនប្រុសម្នាក់លួចប្លន់កាប់សម្លាប់ និងធ្វើអំពើអាក្រក់បែបនេះ[11]ទោះបីជាឪពុក គាត់មិនបានធ្វើការទាំងនោះក្តី ប៉ុន្តែគាត់បានបរិភោគនៅលើភ្នំទាំងនោះដែរ ហើយគាត់បង្អាប់ប្រពន្ធរបស់អ្នកជិតខាង តើយើងអាចនិយាយយ៉ាងដូចម្តេចអំពីគាត់?
[12]អ្នកនោះក៏បាន ទាំងសង្កត់សង្កិនពួកអ្នកក្រីក្រ អ្នកកម្សត់ទុគ៌ត ឬប្លន់គេ ក៏មិនបានប្រគល់របស់បញ្ចាំទៅវិញ ហើយបានងើបមើលទៅរូបព្រះ គឺបានប្រព្រឹត្តការដ៏គួរស្អប់ខ្ពើម[13]ហើយ បានទាំងឲ្យគាត់ខ្ចីប្រក់ដោយយកការ ហើយយកកម្រៃផង តើអ្នកនោះនឹងរស់នៅ ឬវាមិនត្រូវរស់ទេ? ពិតប្រាកដណាស់ អ្នកនេះនឹងមិនអាចរស់បានទេ! ដោយការប្រព្រឹត្តអំពើគួរស្អប់ខ្ពើមទាំងនោះ ដូច្នេះ អ្នកនោះនឹងត្រូវស្លាប់ជាមិនខាន ឈាមវានឹងធ្លាក់ទៅលើវាវិញ។
[14]ប៉ុន្តែចូលមើល៍! បើអ្នកនោះបង្កើតកូនប្រុសមក ដែលឃើញអស់ទាំងអំពើបាបដែលឪពុកប្រព្រឹត្ត ក៏ពិចារណា ហើយមិនប្រព្រឹត្តតាមអំពើយ៉ាងនោះទេ។
[15]ដែលកូនប្រុសនោះគឺមិនបានបរិភោគនៅលើភ្នំ ហើយក៏មិនងើបមើលទៅរូបព្រះរបស់ពួកវង្សអ៊ីស្រាអែល ហើយក៏មិនបានបង្អាក់ប្រពន្ធរបស់អ្នកជិតខាងខ្លួន តើនឹងនិយាយបែបណាវិញ ពីកូនប្រុសរបស់គាត់?
[16]កូនប្រុសដែលមិនសង្កត់សង្កិនអ្នកណា ឬទទួលបញ្ចាំរបស់គេ ក៏មិនបានប្លន់ដែរ គឺបានចែកអាហាររបស់ខ្លួន ដល់ពួកអ្នកដែលឃ្លាន ហើយបិទបាំងអ្នកដែលនៅខ្លួនអាក្រាតទទេ ដោយសម្លៀកបំពាក់។[17]កូនប្រុសដែលមិនសង្កត់សង្កិនអ្នកណា ហើយមិនបានយកការប្រាក់ ឬកម្រៃអ្វីឡើយ ប៉ុន្តែធ្វើតាមច្បាប់ បស់យើង ហើយប្រព្រឹត្តតាមបញ្ញត្តិរបស់យើង កូននោះនឹងមិនស្លាប់ ដោយព្រោះសេចក្តីទុច្ចរិតរបស់ឪពុកខ្លួនឡើយ គាត់នឹងមានជីវិតរស់នៅជាមិនខាន!
[18]ឪពុករបស់គាត់ ចាប់តាំងគាត់ បានសង្កត់សង្កិនដល់អ្នកដទៃយ៉ាងកំណាច ហើយបានប្លន់បងប្អូន ព្រមទាំងប្រព្រឹត្តអំពើដែលមិនល្អក្នុងចំណោមជនជាតិរបស់ខ្លួន មើល៍គាត់នឹងស្លាប់ក្នុងសេចក្តីទុច្ចរិតរបស់គាត់។
[19]ប៉ុន្តែអ្នកនិយាយថា ហេតុអ្វីបានជាកូនមិនត្រូវរងសេចក្តីទុច្ចរិតរបស់ឪពុកដូច្នេះ? ពីព្រោះកូនបានប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ ហើសុចរិត ហើយរក្សាក្រឹត្យក្រមរបស់យើង គាត់ប្រព្រឹត្តតាមទាំងអស់។ គាត់នឹងមានជីវិតរស់នៅ![20]អស់អ្នកណាដែលធ្វើបាប គឺអ្នកនោះហើយនឹងត្រូវស្លាប់។ កូនមិនត្រូវរងអំពើទុច្ចរិតរបស់ឪពុកទេ ហើយឪពុកក៏មិនត្រូវរងសេចក្តីទុច្ចរិតរបស់កូនដែរ សេចក្តីទុច្ចរិតរបស់មនុស្សសុចរិត នឹងនៅលើអ្នកនោះ ហើយសេចក្តីទុច្ចរិតរបស់មនុស្សទុច្ចរិតនឹងនៅលើខ្លួនអ្នកទុច្ចរិត។
[21]ប៉ុន្តែមនុស្សទុច្ចរិត បែរចេញពីអំពើបាបដែលខ្លួនបានធ្វើ ហើយរក្សាច្បាប់របស់យើង ព្រមទាំងប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ ហើយទៀងត្រង់វិញ អ្នកនោះនឹងមានជីវិតរស់នៅ ហើយមិនត្រូវស្លាប់ទេ។[22]អំពើរំលងទាំងអស់ដែលខ្លួនបានប្រព្រឹត្តនោះ នឹងមិននឹកដើម្បីនឹងទាស់នឹងគាត់ទេ។ គាត់នឹងរស់នៅដោយសារសេចក្តីសុចរិតដែលខ្លួនបានប្រព្រឹត្ត។
[23]តើយើងមានអំណរដោយមនុស្សទុច្ចរិតស្លាប់ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល ហើយមិនមែនក្នុងការបែរចេញរបស់គាត់ ពីផ្លូវគាត់ ដូច្នោះហើយគាត់អាចរស់បានឬ?
[24]ប៉ុន្តែបើមនុស្សសុចរិត បែរចេញពីអំពើសុចរិតរបស់ខ្លួនទៅប្រព្រឹត្តទុច្ចរិត ហើយធ្វើគ្រប់ការគួរស្អប់ខ្ពើម គឺដូចដែលមនុស្សទុច្ចរិតតែងបានធ្វើ តើមនុស្សអាក្រក់គួនឹងរស់ទេ? ការសុចរិតទាំងអស់ដែលអ្នកនោះបានធ្វើ នឹងមិនត្រូវបាននឹកចាំទៀតទេ ពេលដែលមនុស្សនេះបានបោកប្រាស់យើង ក្នុងសេចក្តីក្បត់របស់គាត់។ ដូច្នោះហើយគាត់នឹងត្រូវស្លាប់ក្នុងអំពើបាប ដែលគាត់បានប្រព្រឹត្ត។
[25]ប៉ុន្តែអ្នកនិយាយថា ផ្លូវរបស់ព្រះអម្ចាស់មិនអាចទទួលយកបាន! ចូរស្តាប់ ជនជាតិអ៊ីស្រាអែល! តើផ្លូវរបស់យើងអយុត្តិធម៌ឬ?[26]កាលណាមនុស្សសុចរិត បែរចេញពីអំពើសុចរិតរបស់ខ្លួន ហើយទៅប្រព្រឹត្តទុច្ចរិតវិញ ហើយត្រូវស្លាប់ទៅដោយសារពួកគេខ្លួនឯង គឺនឹងត្រូវស្លាប់ក្នុងអំពើទុច្ចរិត ដែលខ្លួនបានប្រព្រឹត្ត។
[27]ប៉ុន្តែ កាលណាមនុស្សទុច្ចរិតបែរចេញពីអំពើទុច្ចរិត ដែលខ្លួនបានធ្វើ ហើយធ្វើការដែលត្រឹមត្រូវ ហើយភាពសុចរិត ដូច្នេះគាត់នឹងធ្វើឲ្យជីវិតខ្លួនរស់។
[28]ដ្បិតគាត់បានឃើញថាបានបែរចេញពីអំពើអាក្រក់ដែលគាត់ធ្លាប់បានប្រព្រឹត្តិ។ គាត់ប្រកដជារស់នៅ ហើយក៏មិនស្លាប់ដែរ។
[29]ប៉ុន្តែ ជនជាតិអ៊ីស្រាអែលនិយាយថា ផ្លូវរបស់ព្រះអម្ចាស់អយុត្តិធម៌! តើផ្លូវរបស់យើងអយុត្តិធម៌បែបណាជនជាតិអ៊ីុស្រាអែល? គឺផ្លូវរបស់អ្នករាល់គ្នាទេដែលមិនត្រឹមត្រូវ។[30]ដូច្នោះហើយ យើងនឹងជំនុំជម្រះមនុស្សម្នាក់ៗនៅក្នុងចំណោមអ្នក តាមអំពើប្រព្រឹត្តរបស់អ្នក ជនជាតិអ៊ីស្រាអែល! នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល។ ចូរប្រែចិត្តហើយបែរចេញពីអំពើរំលងរបស់អ្នក ដូច្នោះហើយសេចក្តីទុច្ចរិតទាំងនោះ នឹងមិនបំផ្លាញអ្នកទេ។
[31]ចូលរះចោលអំពើរំលងទាំងឡាយរបស់អ្នក ដែលអ្នករាល់គ្នាធ្លាប់បានធ្វើ ហើយឲ្យខ្លួនមានចិត្តថ្មី ហើយវិញ្ញាណថ្មី។ ហេតុអ្វីបានជាអ្នកស្លាប់ជនជាតិអ៊ីុស្រាអែល?
[32]ដ្បិតយើងមិនបានសប្បាយចិត្តក្នុងសេចក្តីស្លាប់ ដែលអ្នកបានស្លាប់ទេ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល ដូច្នោះហើយប្រែចិត្តហើយរស់នៅ!»

Ezekiel 18:1

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។

តើអ្នកចង់មានន័យដូចម្តេច អ្នកជាបានប្រើសុភាសិតនេះ និយាយអំពីទឹកដីអ៊ីស្រាអែលប្រាប់ថា ឪពុកបានស៊ីផ្លែជូរដែលមានរស់ជាតិជូរ ហើយធ្មេញកូនត្រូវសង្កៀរវិញឬ?

ព្រះជាម្ចាស់កំពុងស្តីបន្ទោសប្រជាជនចំពោះការគិតថាពួកគេត្រូវបានដាក់ទណ្ឌកម្មចំពោះអំពើបាបរបស់ឪពុកម្តាយ ប៉ុន្តែជឿថាពួកគេគឺជាមនុស្សគ្មានបាប។

ឪពុកបានស៊ីផ្លែជូរដែលមានរស់ជាតិជូរ ហើយធ្មេញកូនត្រូវសង្កៀរវិញឬ

សុភាសិតនេះមានន័យថាកូនត្រូវទទួលទណ្ឌកម្មដោយសារអំពើអាក្រក់របស់ឪពុកម្តាយ

ទឹកដីអ៊ីស្រាអែល

នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។

Ezekiel 18:3

មើល!

ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។ វាក៏អាចត្រូវបានបកប្រែដូចជា «ការពិតណាស់!» នេះក៏អាចត្រូវបានបកប្រែដូចជា «មើល!» ឬ «ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក!»

Ezekiel 18:5

មិនបានស៊ីនៅតាមលើភ្នំ ... មិនបានងើបមើលទៅរូបព្រះ

ឃ្លាទាំងនេះសំដៅទៅលើការគោរពបូជារូបព្រះ។

ប្រជាជនបរិភោគអាហារនៅតាមទីសក្ការៈនៅលើភ្នំដើម្បីគោរពដល់រូបព្រះ។ ឃ្លាថា «ងើបមើលទៅរូបព្រះ» ក៏សំដៅទៅលើការសម្លឹងមើលរូបព្រះ និងគោរពពួកគេ។

Ezekiel 18:7

បានត្រឡប់មកវិញតាមការសន្យា

ព្រះអង្គមានការចាប់អារម្មណ៍ចំពោះអ្នកឲ្យខ្ចីប្រាក់ដែលប្រគល់តាមការសន្យាឲ្យទៅម្ចាស់កម្ចីវិញ មុនពេលដែលម្ចាស់កម្ចីមកទាវិញ។

តែងតែឲ្យអាហារនិងសម្លៀកបំពាក់ក្រីក្រវិញ

ព្រះអង្គមានការចាប់អារម្មណ៍ចំពោះអ្នកដែលមានចិត្តសប្បុរសចំពោះអ្នកដែលខ្វះស្បៀងអាហារ និងសម្លៀកបំពាក់។

Ezekiel 18:10

generated on Wed Sep 10 16:16:32 2025

កាប់សម្លាប់
ឃ្លានេះសំដៅទៅលើការសម្លាប់នរណាម្នាក់។
ធ្វើអំពើអាក្រក់បែបនេះ
នេះសំដៅទៅលើអំពើបាបដែលបានរៀបរាប់នៅក្នុងជំពូក ១៨:១១ - ១៨:១២។
Ezekiel 18:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តនិយាយអំពីកូនប្រុសដ៏ឃោរឃៅនេះ។
អ្នកក្រីក្រ អ្នកកម្សត់ទុគ៌ត
ពាក្យថា «អ្នកក្រ» និង «អ្នកខ្វះខាត»
បញ្ជាក់ថាទាំងនេះជាមនុស្សដែលមិនអាចជួយខ្លួនឯងបាន។
ដោយយកការប្រាក់
ពាក្យថា «ការប្រាក់» សំដៅទៅលើប្រាក់ដែលបានបន្ថែមទៅបំណុល។
ការប្រាក់
ពាក្យនេះសំដៅទៅលើប្រាក់ដែលមនុស្សម្នាក់បង់ដើម្បីប្រើប្រាស់ប្រាក់កម្ចី។
ទោះយ៉ាងណាក៏ដោយកំណែទំនើបមួយចំនួនបកប្រែ «ចំណាប់អារម្មណ៍ណាមួយ»
នៅក្នុងអត្ថបទនេះថាជា «ការប្រាក់ខ្ពស់ពេក»។
តើអ្នកនោះនឹងរស់នៅទេ?
«គាត់មិនគួររស់នៅទេ!»
ឈាមរានឹងធ្លាក់ទៅលើវាវិញ
ឃ្លានេះមានន័យថាគាត់ទទួលខុសត្រូវចំពោះការស្លាប់របស់គាត់។
Ezekiel 18:14
ចូលមើល!
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ប្រព្រឹត្តតាម
«រួចរាល់»
Ezekiel 18:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលអំពីកូនប្រុសដែលមិនប្រព្រឹត្តអំពើបាបដូចឪពុករបស់ខ្លួន
ខ្លួនអាក្រាត
នេះអាចមានន័យថាមនុស្សដែលមិនមានសម្លៀកបំពាក់ទាល់តែសោះ
ប៉ុន្តែភាគច្រើនប្រហែលជាមានន័យថាមនុស្សដែលស្លៀកពាក់ខោអាវដែលជាសម្លៀកបំពាក់
បិទបាំងអ្នកដែលនៅខ្លួនអាក្រាតទទេ ដោយសម្លៀកបំពាក់
ការផ្តល់សម្លៀកបំពាក់ដល់មនុស្សដែលត្រូវការពួកគេត្រូវបានគេនិយាយដូចជាកំពុងដាក់សម្លៀកបំពាក់ទៅលើរូបកាយ
ព្រះអង្គដកព្រះហស្តពីជនក្រីក្រវិញ
ពាក្យថា «ដៃ» នៅទីនេះតំណាងឲ្យការប្រព្រឹត្តអំពើមិនត្រឹមត្រូវ។
ការប្រាក់
ពាក្យនេះសំដៅទៅលើប្រាក់ដែលមនុស្សម្នាក់បង់ដើម្បីប្រើប្រាស់ប្រាក់កម្ចី។
ទោះយ៉ាងណាក៏ដោយកំណែទំនើបមួយចំនួនបកប្រែ «ចំណាប់អារម្មណ៍»
នៅក្នុងអត្ថបទនេះថាជា «ការប្រាក់ខ្ពស់ពេក»។
Ezekiel 18:18
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីឪពុករបស់កូនប្រុសដែលមិនបានគោរពតាមវិន័យរបស់ព្រះអង្គ
សង្កត់សង្កិន
ដើម្បីយកអ្វីមួយពីនរណាម្នាក់ផ្សេងទៀតដោយប្រើការគំរាមកំហែង ឬកម្លាំង។
មើល៍
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
Ezekiel 18:19
ហេតុអ្វីបានជាកូនមិនត្រូវរងសេចក្តីទុច្ចរិត
ការបកប្រែរបៀបផ្សេងទៀត:
«ហេតុអ្វីបានជាកូនប្រុសមិនទទួលខុសត្រូវចំពោះអំពើទុច្ចរិត»
សេចក្តីសុចរិតរបស់អ្នកដែលប្រព្រឹត្តដោយត្រឹមត្រូវនឹងស្ថិតនៅលើខ្លួនគាត់ផ្ទាល់
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកណាដែលធ្វើអ្វីដែលត្រឹមត្រូវនឹងត្រូវចាត់ទុកជាមនុស្សសុចរិត»
សេចក្តីទុច្ចរិតរបស់មនុស្សទុច្ចរិតនឹងនៅលើខ្លួនអ្នកទុច្ចរិត
ការបកប្រែរបៀបផ្សេងទៀត: «ម្នាក់ដែលប្រព្រឹត្តអំពើអាក្រក់
អ្នកនោះនឹងត្រូវចាត់ទុកជាមនុស្សអាក្រក់»
Ezekiel 18:21
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីមនុស្សអាក្រក់ដែលផ្លាស់ប្តូរ និងប្រព្រឹត្តអំពើសុចរិត។
នឹកដើម្បីនឹង
ការបកប្រែរបៀបផ្សេងទៀត: «ត្រូវបានចងចាំ»
គាត់នឹងរស់នៅដោយសារសេចក្តីសុចរិតដែលខ្លួនបានប្រព្រឹត្ត
«គាត់នឹងបន្តរស់នៅ ពីព្រោះគាត់ធ្វើអ្វីដែលត្រឹមត្រូវ»
Ezekiel 18:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីបំណងព្រះហឫទ័យរបស់ព្រះអង្គចំពោះមនុស្សអាក្រក់។
តើយើងមានអំណរដោយមនុស្សទុច្ចរិតស្លាប់...ហើយមិនមែនក្នុងការបែរចេញរបស់គាត់ ពីផ្លូវគាត់
ដូច្នោះហើយគាត់អាចរស់បានឬ?
«យើងមិនរីករាយចំពោះការស្លាប់របស់មនុស្សអាក្រក់នោះទេ
ប៉ុន្តែយើងពិតជារីករាយណាស់ប្រសិនបើគាត់ងាកចេញពីអំពើអាក្រក់
និងការរស់នៅរបស់គាត់»
នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល
សូមមើលការបកប្រែនៅក្នុងជំពូក ៥:១១។
មិនមែនក្នុងការបែរចេញរបស់គាត់ ពីផ្លូវគាត់
«មិនមែនផ្លាស់ប្តូរអំពើបាបរបស់គាត់ដើម្បីធ្វើអ្វីមួយដែលត្រឹមត្រូវទេ។
Ezekiel 18:24
ព័ត៌មានតទូទៅ :
ព្រះអម្ចាស់អោយគំរូមួយពីបុរសម្នាក់ដែលងាកចេញពីសេចក្តីសុចរិតទៅជាអំពើអាក្រក់។
តើមនុស្សអាក្រក់គួរនឹងរស់នៅទេ?
ការបកប្រែរបៀបផ្សេងទៀត: «គាត់ត្រូវតែស្លាប់»
នឹងមិនត្រូវបាននឹកចាំទៀតទេ
ការបកប្រែរបៀបផ្សេងទៀត: «នឹងមិនត្រូវបានគេចងចាំ»
សេចក្តីក្បត់
ឧក្រិដ្ឋកម្មដែលបានធ្វើប្រឆាំងនឹងប្រទេសមួយ ឬប្រឆាំងនឹងព្រះអង្គ
ដោយអ្នកណាម្នាក់ដែលត្រូវបានគេរំពឹងថានឹងស្មោះត្រង់។
ដូច្នោះហើយគាត់នឹងត្រូវស្លាប់ក្នុងអំពើបាប ដែលគាត់បានប្រព្រឹត្ត
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះ
គាត់នឹងស្លាប់ដោយអំពើបាបដែលគាត់បានធ្វើ»។
Ezekiel 18:25
ត្រូវស្តីបន្ទោសចាស់ទាំងអ
ឃ្លាទាំងនេះរំលឹកពីគំនិតរបស់បុរសម្នាក់ដែលបានស្លាប់
ការសម្លៀកបំពាក់ដែលមិនសមរម្យ
និងមិនមែនជាកំហុសរបស់អ្នកណាម្នាក់ឡើយ។
Ezekiel 18:27
គាត់បានឃើញថា
គាត់បានដឹងអ្វីមួយ។
Ezekiel 18:29
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តបង្រៀនជនជាតិអ៊ីស្រាអែល
ថាហេតុអ្វីបានជាមាគ៌ារបស់ព្រះអង្គគឺត្រឹមត្រូវ។
«ប្រជាជនអ៊ីស្រាអែលអើយ ផ្លូវរបស់យើងគឺត្រឹមត្រូវហើយ»។ .
តើផ្លូវរបស់អ្នកមិនអយុត្តិធម៌យ៉ាងដូចម្តេច?
«តើផ្លូវរបស់អ្នកយុត្តិធម៌យ៉ាងម៉េច?» ឬ «តើវាជាផ្លូវដែលមិនត្រឹមត្រូវសំរាប់អ្នក»។
មនុស្សម្នាក់ៗនៅក្នុងចំណោមអ្នក តាមអំពើប្រព្រឹត្តរបស់អ្នក
«សកម្មភាពរបស់មនុស្សម្នាក់ៗ»។
ដូច្នោះហើយពួកគេនិងមិន
«ពួកគេ» គឺសំដៅទៅលើការរំលងរបស់ជនជាតិអ៊ីស្រាអែលទាំងអស់។
Ezekiel 18:31
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
ឲ្យខ្លួនមានចិត្តថ្មី ហើយវិញ្ញាណថ្មី
ការបកប្រែរបៀបផ្សេងទៀត: «ផ្លាស់ប្តូរទាំងស្រុងនូវអ្វីដែលជាអ្នក»
ជនជាតិអ៊ីុស្រាអែល
សូមមើលការបកប្រែនេះនៅក្នុងជំពូក ៣:១។
នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល
សូមមើលការបកប្រែនេះនៅក្នុងជំពូក ៥:១១។

generated on Wed Sep 10 16:16:32 2025

19 [1]«ពេលនេះអ្នក ចាប់យកទំនុកបទទំនួញទាស់ប្រឆាំងនឹងពួកអ្នកដឹកនាំនៃជនជាតិអ៊ីស្រាអែល[2]ហើយនិយាយ តើនរណាជាម្តាយរបស់អ្នក? គឺជាសិង្ហញី ដែលបានក្រាបនៅកណ្តាលសិង្ហឈ្មោលក៏បំបៅកូននៅកណ្តាលពួកសិង្ហស្ទាវផង។[3]សិង្ហញីបានចិញ្ចឹមកូន ដែលវានឹងក្លាយទៅជាសិង្ហស្ទាវ ហើយបានហ្វឹកហាត់ចាប់រំពា ហើយវាក៏ត្របាក់លេបមនុស្សដែរ។[4]ក្រោយមក គ្រប់ទាំងជនជាតិផ្សេងៗបានឮនិយាយអំពីវា។ វាត្រូវបានគេចាប់ដោយអន្ទាក់របស់ពួកគេ ហើយពួកគេក៏នាំវាទៅទឹកដីអេស៊ីប។
[5]រួចហើយសិង្ហញីបានឃើញការនោះ ហើយក៏រង់ចាំសម្រាប់សិង្ហស្ទាវត្រឡប់មកវិញ ក្តីសង្ឃឹមក៏បានបាត់ទៅ ហើយក៏យកកូនផ្សេងមកចិញ្ចឹមឲ្យក្លាយជាសិង្ហស្ទាវ។[6]សិង្ហស្ទាវនេះក៏ដើរទៅមកជាមួយពួកសិង្ហឈ្មោល។ វាគឺជាសិង្ហស្ទាវ ហើយក៏ហាត់ចាប់រំពា វាក៏ត្របាក់លេបមនុស្សដែរ។[7]វាបានចាប់យកស្ត្រីមេម៉ាយ ហើយបានបំផ្លាញទីក្រុងរបស់គេ។ ទឹកដីនិងទាំងមូល ត្រូវបានបោះបង់ចោល ដោយសារតែសំឡេងគ្រហឹមរបស់វា។
[8]ប៉ុន្តែ ជនជាតិទាំងឡាយក៏នាំគ្នាមកទាស់នឹងវា ពីគ្រប់ទីតំបន់ទាំងអស់ ពួកគេដាក់សំណាញពីលើវា។ ហើយវាត្រូវបានចាប់ដោយអន្ទាក់។[9]ពួកគេបានទាក់វាដាក់ក្នុងទ្រុង ហើយក្រោយមក ពួកគេក៏យកវាទៅថ្វាយស្តេចបាប៊ីឡូន។ ពួកគេនាំវាចូលទៅក្នុងទីមាំមួន ដើម្បីមិនឲ្យឮសូរសំឡេងវានៅលើភ្នំនៃទឹកដីអ៊ីស្រាអែលទៀតឡើយ។
[10]ម្តាយអ្នកប្រៀបបាននឹង ដើមទំពាំងបាយជូរដុះនៅក្បែរមាត់ទឹក។ ទំពាំងបាយជូរនោះមានផ្លែផ្កា ហើយបែកមែក ដោយសារសម្បូណទឹកច្រើន។[11]ទំពាំងបាយជូរនោះមានមែករឹងមាំ ដែលក្លាយទៅជាដំបងរាជ្យ ហើយវាលូតឡើងខ្ពស់ជាងមែកផ្សេង ហើយកម្ពស់របស់វាអាចមើលឃើញដោយសារ ស្លឹកច្រើនរបស់វា។
[12]ប៉ុន្តែ ដើមទំពាំងបាយជូរនោះត្រូវគេរម្លើង យ៉ាងកំហឹង ហើយរលំទៅលើដី ហើយខ្យល់ដែលមកពីទិសខាងកើតបក់មក ធ្វើឲ្យផ្លែវាស្វិតក្រៀម។ មែកដែលរឹងមាំរបស់វា ក៏ដាច់ចេញពីដើមនិងស្វិត ហើយភ្លើងឆេះអស់ពួកវាអស់។[13]ដូច្នេះហើយ ទំពាំងបាយជូរនេះដាំនៅក្នុងវាលរហោស្ថាន លើដីហួតហែងគ្មានទឹក។
[14]ដ្បិត ភ្លើងដែលឆេះចេញពីមែកដ៏ធំរបស់វា ធ្វើឲ្យឆេះផ្លែរបស់វាដែរ។ លែងមានមែកដែលរឹងមាំនៅលើវាទៀតទេ មិនអាចធ្វើដំបងរាជ្យដរ។ នេះជាបទទំនួញសោសៅ ហើយនឹងច្រៀងបែបនោះ»។

Ezekiel 19:1

ព័ត៌មានទូទៅ:

ព្រះអម្ចាស់ប្រាប់លោកអេសេគាលឲ្យនិយាយទៅកាន់ប្រជាជាតិអ៊ីស្រាអែល។ គាត់និទានរឿងមួយដែលប្រទេសអ៊ីស្រាអែលជាសត្វតោ ហើយស្តេចខ្លះពីអតីតកាលនៅក្នុងនគរយូដាគឺជាកូនតោ។

Ezekiel 19:5

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តរៀបរាប់អំពីប្រជាជាតិអ៊ីស្រាអែលថាជាសត្វតោ ហើយស្តេចនៃស្តេចស្រុកយូដាប្រៀបដូចជាកូនតោ។

ហើយក៏យកកូនផ្សេងមកចិញ្ចឹម

ឥឡូវនេះព្រះអម្ចាស់ប្រៀបធៀបយេហូយ៉ាជីនជាមួយនឹងកូនតោវ័យក្មេង។

គាត់បានរំលោភស្ត្រីមេម៉ាយហើយបំផ្លាញទីក្រុងរបស់គេ

ឃ្លាទាំងនេះគឺជាការបង្ហាញរបស់ព្រះអង្គដែលអនុញ្ញាតឲ្យសត្រូវរបស់អ៊ីស្រាអែលធ្វើរឿងទាំងនេះ។

ទាំងមូល ត្រូវបាន

«និងអ្វីគ្រប់យ៉ាងនៅក្នុងវា»

Ezekiel 19:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តរៀបរាប់អំពីប្រជាជាតិអ៊ីស្រាអែលថាជាសត្វតោ ហើយស្តេចនៃស្តេចស្រុកយូដាប្រៀបដូចជាកូនតោ។

ទាស់នឹងវា

ពាក្យ «គាត់» សំដៅទៅលើសត្វតោវ័យក្មេង ទីពីរដែលតំណាងឲ្យយេហូយ៉ាឈីន។

ពីគ្រប់ទីតំបន់ទាំងអស់

ការបកប្រែរបៀបផ្សេងទៀត: «មកពីបណ្តាខេត្តដែលព័ទ្ធជុំវិញទឹកដីអ៊ីស្រាអែល»។

តំបន់

បណ្តាប្រទេសដែលត្រូវបានគ្រប់គ្រងដោយបាប៊ីឡូន

Ezekiel 19:10

ម្តាយ

ព្រះអម្ចាស់ពណ៌នាអំពីប្រជាជាតិអ៊ីស្រាអែលប្រៀបដូចជាមាតារបស់មេដឹកនាំអ៊ីស្រាអែល។

ដើមទំពាំងបាយជូរដុះនៅក្បែរមាត់ទឹក

អាចមានន័យថា «ឈាម» តំណាងឲ្យ ១)
អំពើហឹង្សារបស់ស្តេចយូដាដែលបានសម្លាប់មនុស្ស ឬ ២)
ស្រាដ៏បរិបូរណ៍នៃប្រទេសយូដា ដែលបានក្លាយជានិមិត្តរូបនៃភាពរុងរឿង។

ការបកប្រែរបៀបផ្សេងទៀត: «វល្លិដាំដោយអំពើហឹង្សា» ឬ «វល្លិដែលដាំដោយភាពរុងរឿងរបស់អ្នក»

Ezekiel 19:12

ទាំងអស់នេះ។

ព្រះអម្ចាស់នៅតែប្រៀបធៀបអ៊ីស្រាអែលជាមួយដើមទំពាំងបាយជូរ និងមេដឹកនាំរបស់នាងជាមួយមែកឈើដ៏រឹងមាំ។

ដាច់ចេញពីដើម

«គាត់បានផ្តាច់ចេញ»

Ezekiel 19:14

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែប្រៀបធៀបអ៊ីស្រាអែលជាមួយដើមទំពាំងបាយជូរ និងមេដឹកនាំរបស់នាងជាមួយមែកឈើដ៏រឹងមាំ។

ដំបងរាជ្យ

«ស្តេចនោះអាចនឹងប្រើច្បាប់ក្នុងការគ្រប់គ្រង»

---

20 [1]ចូលមកដល់ក្នុងឆ្នាំទីប្រាំពី នៅថ្ងៃទីដប់ក្នុងខែទីប្រាំ ពួកចាស់ទុំនៃជនជាតិអ៊ីស្រាអែលបានមក ដើម្បីទូលសួរដល់ព្រះអម្ចាស់ ហើយគេអង្គុយនៅមុខខ្ញុំ។
[2]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[3]«កូនមនុស្សអើយ ចូរប្រកាស់ដល់ពួកចាស់ទុំនៃជនជាតិអ៊ីស្រាអែលថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ តើអ្នករាល់គ្នាបានមកសួរដល់យើងឬ? ដូចយើងមានជីវិត យើងមិនបាច់ឆ្លើយសំនួររបស់អ្នកឡើយ! នេះគឺជាសេចក្តីប្រកាសនៃព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់។
[4]តើអ្នកនឹងជំនុំជម្រះពួកគេឬ? តើអ្នកជំនុំជម្រះ កូនមនុស្ស? ចូរប្រាប់ពួកគេឲ្យដឹងពីការដែលគួរស្អប់ខ្ពើមរបស់បុព្វបុរសពួកគេ។[5]និយាយប្រាប់ពួកគេ ព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូលដូច្នេះ នៅថ្ងៃដែលយើងបានជ្រើសរើស អ៊ីស្រាអែល ហើយយើងបានលើកដៃឡើងស្បថដល់ពូជពង្សនៃកូនចៅរបស់យ៉ាកុប ហើយព្រមទាំងសម្តែងឲ្យពួកគេស្គាល់យើងនៅស្រុកអេស៊ីប គ្រាដែលយើងបានលើកដៃស្បថដល់ពួកគេ។ យើងនិយាយថា «យើងគឺជាព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា»។[6]នៅថ្ងៃនោះ យើងបានលើកដៃស្បថដល់ពួកគេថា នឹងនាំគេចេញពីទឹកដីអេស៊ីប ទៅក្នុងទឹកដីមួយដែលយើងបានស្វែងរកឲ្យពួកគេ។ ជាទឹកដីមានទឹកដោះ និងទឹកឃ្មុំ ជាទីកន្លែងស្អាតបំផុតនៅក្នុងចំណោមទឹកដី។
[7]យើងបាននិយាយថា «ចូរឲ្យគ្រប់គ្នាបោះចោលអ្វីដែលគួ ស្អប់ខ្ពើម ចេញពីមុខភ្នែករបស់គេ ហើយដោយរូបព្រះរបស់ទឹកដីអេស៊ីប។ កុំធ្វើឲ្យខ្លួនអ្នកទៅជាមិនស្អាតឡើយ យើងគឺជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា»។
[8]ប៉ុន្តែ ពួកគេបានទាស់នឹងយើង មិនព្រមស្តាប់តាមយើងទេ។ បុរសម្នាក់ៗមិនបានលះចោលរបស់គួរស្អប់ខ្ពើម ចេញពីមុខភ្នែករបស់ពួកគេ ក៏មិនបោះបង់ចោលរូបព្រះរបស់ជនជាតិ អេស៊ីបដែរ ដូច្នេះ យើងនឹងចាក់សេចក្តីកំហឹងរបស់យើង ទៅលើពួកគេ ដើម្បីឲ្យសេចក្តីក្រោធរបស់យើងបានស្កប់ចិត្ត ក្នុងពួកគេនៅកណ្តាលទឹកដីអេស៊ីប។
[9]យើងបានប្រព្រឹត្តដោយយល់ដល់ឈ្មោះយើង ដើម្បីមិនត្រូវទាបថោក នៅចំពោះភ្នែកជនជាតិដទៃ ជាជនជាតិដែលស្នាក់នៅទីនោះ។ យើងបានសម្តែងឲ្យគេស្គាល់យើង នៅក្នុងភ្នែករបស់ពួកគេ ដោយនាំគេចេញពីទឹកដីអេស៊ីប។
[10]ដូច្នេះ យើងបានបញ្ជូនពួកគេចេញពីទឹកដីអេស៊ីប ហើយបាននាំចូលទៅក្នុងទីរហោស្ថាន។[11]រួចហើយយើងក៏ឲ្យច្បាប់ ហើយឲ្យពួកគេស្គាល់បញ្ញត្តិរបស់យើង តាមរយៈការនេះមនុស្សនឹងរស់នៅ បើគេស្តាប់តាមច្បាប់នោះ។[12]យើងក៏តាំងថ្ងៃសប្ប័ទ សម្រាប់ជាទីសម្គាល់ដល់យើង ហើយពួកគេ ដើម្បីឲ្យគេដឹងថា យើងជាព្រះអម្ចាស់ដែលបានធ្វើឲ្យគេបរិសុទ្ធ។

generated on Wed Sep 10 16:16:32 2025

[13]ប៉ុន្តែ កូនចៅអ៊ីស្រាអែលបានបះបោរទាស់នឹងយើង នៅទីរហោស្ថាន។ ពួកគេមិនបានប្រព្រឹត្តតាមច្បាប់យើងទេ ផ្ទុយទៅវិញ ពួកគេបានបដិសេធបញ្ញត្តិរបស់យើង
មនុស្សនឹងរស់នៅបើេពួកគេប្រព្រឹត្តតាម។ ពួកគេបានមើលងាយថ្ងៃសប្ប័ទរបស់យើង ហើយយើងបាននិយាយថា យើងនឹងចាក់សេចក្តីឃោរឃៅរបស់យើង ទៅលើគេ
នៅក្នុងទីរហោស្ថាន ដើម្បីនឹងបញ្ចាប់ពួកគេ។[14]ប៉ុន្តែ យើងបានប្រព្រឹត្តដោយយលដល់ឈ្មោះយើងវិញ ហើយនៅចំពោះភ្នែកជនជាតិដ៏ទៃ
និងទីសម្គាល់ដែលយើងបាននាំពួកគេចេញពីអេស៊ីប។
[15]ដូច្នោះ យើងខ្លួនឯងបានលើកដៃស្បថនឹងគេ នៅទីរហោស្ថានថា មិននាំគេចូលទៅក្នុងទឹកដី ដែលយើងចង់ឲ្យដល់ពួកគេ ជាស្រុកមានទឹកដោះ និងទឹកឃ្មុំ ដែលជា
ទឹកដីដែលស្អាតជាងគេបំផុតនៅលើផែនដីនេះ។[16]យើងបានស្បថបែបនេះ ពីព្រោះពួកគេបានបោះបង់ក្រឹត្យក្រមរបស់យើង ហើយមិនដើរតាមបញ្ញត្តិច្បាប់របស់យើង
ហើយពួកគេប្រមាថថ្ងៃសប្ប័ទរបស់យើងដែរ ដ្បិតចិត្តគេជាប់តាមរូបព្រះរបស់គេវិញ។[17]ប៉ុន្តែ ភ្នែកយើងបានប្រណីដល់គេ ពីការបំផ្លាញ ហើយយើងមិនបានឲ្យ ពួកគេ
វិនាស នៅក្នុងទីរហោស្ថានទេ។
[18]យើងបាននិយាយ កូនប្រុសស្រីរបស់ពួកគេ នៅទីរហោស្ថានថា «កុំដើរតាមច្បាប់របស់បុព្វបុរសអ្នករាល់គ្នា កុំកាន់តាមបញ្ញត្តិរបស់គេ ឬធ្វើឲ្យខ្លួនសៅហ្មង ដោយរូបព្រះ
របស់គេឡើយ។ [19]យើងនេះ គឺជាព្រះអម្ចាស់ជាព្រះជាម្ចាស់របស់អ្នក ចូរដើរតាមក្រឹត្យក្រមហើយរក្សាបញ្ញត្តិច្បាប់របស់យើង ហើយស្តាប់តាមផង។[20]ចូររក្សាថ្ងៃសប្ប័ទរបស់
យើងឲ្យបរិសុទ្ធ សម្រាប់ជាទីសម្គាល់ដល់យើង ហើយនិងអ្នក ដូច្នោះអ្នកបានដឹងថា យើងនេះគឺជាព្រះអម្ចាស់ជាព្រះរបស់អ្នក»។
[21]ប៉ុន្តែ កូនប្រុសហើយកូនស្រីរបស់គេបះបោរទាស់នឹងយើង។ ពួកគេមិនបានដើរតាមច្បាប់របស់យើង ឬរក្សាបញ្ញត្តិរបស់យើង
មនុស្សអាចរស់នៅប្រសិនបើពួកគេស្តាប់តាម។ ពួកគេបានបង្អាប់ថ្ងៃសប្ប័ទរបស់យើង ដូច្នេះយើងនឹងចាក់សេចក្តីឃោរឃៅរបស់យើងទៅលើគេ ដើម្បី
ឲ្យស្កប់ចិត្តតាមសេចក្តីកំហឹងរបស់យើងនៅលើគេ នៅក្នុងទីរហោស្ថាន។[22]ប៉ុន្តែ យើងបានដកដៃរបស់យើងចេញវិញ ហើយប្រព្រឹត្តដោយយល់ដល់ឈ្មោះយើង ដើម្បី
មិនត្រូវទាបថោក នៅភ្នែកនៃជនជាតិដទៃ ដែលជាទីសម្គាល់យើងបាននាំកូនចៅអ៊ីុស្រាអែលចេញ។
[23]យើងខ្លួនឯងបានលើកដៃស្បថនឹងពួកគេនៅទីរហោស្ថានថា យើងនឹងកម្ចាត់កម្ចាយគេទៅនៅកណ្តាលជនជាតិទាំងឡាយ ហើយបែងចែកគេទៅនៅក្នុងទឹកដីទាំងនោះ។
[24]យើងបានសម្រេចនឹងធ្វើការនេះ ចាប់តាំងពួកគេមិនបានស្តាប់តាមក្រឹត្យក្រមរបស់យើង ហើយចាប់តាំងបោះបង់ចោលបញ្ញត្តិច្បាប់របស់យើង ហើយបង្អាក់ថ្ងៃសប្ប័ទ
របស់យើង។ ហើយភ្នែករបស់ពួកគេក៏ជាប់តាមរូបព្រះរបស់បុព្វបុរសគេដែរ។
[25]ក្រោយមក យើងក៏ឲ្យក្រឹត្យក្រមដល់ពួកគេដែលមិនល្អ ហើយបញ្ញត្តិច្បាប់ដែលមិនអាចឲ្យពួកគេរស់បាន។[26]យើងបានធ្វើឲ្យគេស្មោកគ្រោក ដោយសារតង្វាយរបស់គេ
ពេលពួកគេថ្វាយនោះ ពីកូនកើតផ្ទៃដំបូងរបស់ខ្លួនដាក់ទៅក្នុងភ្លើង។ យើងបានធ្វើឲ្យពួកគេភ័យខ្លាច ប្រយោជន៍ឲ្យគេបានដឹងថា យើងនេះជាព្រះអម្ចាស់!
[27]ដូច្នោះហើយ កូនមនុស្សអើយ ចូរនិយាយទៅពួកកូនចៅអ៊ីស្រាអែល ហើយប្រាប់គេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ បុព្វបុរសអ្នករាល់គ្នាបានប្រមាថដល់
យើងក្នុងការនេះទៀត គឺគេបានប្រព្រឹត្តអំពើរំលងទាស់នឹងយើង។[28]គ្រាយើងបាននាំគេចូលមកក្នុងទឹកដី ដែលយើងបានស្បថថានឹងឲ្យដល់គេ ពេលណាពួកគេបានឃើញ
ទួលខ្ពស់ ហើយគ្រប់ទាំងដើមឈើស៊ុបទ្រុប ពួកគេក៏ថ្វាយយញ្ញបូជារបស់គេនៅលើទីនោះ ពួកគេបានថ្វាយតង្វាយជាគ្រឿងដុតដាល នៅទីនោះ គេក៏បានថ្វាយតង្វាយ
សម្រាប់ជាក្លិនឈ្ងុយរបស់គេ ហើយបានច្រួចតង្វាយច្រួចរបស់គេដែរ។[29]រួចហើយ យើងបានប្រាប់គេថា «តើទីខ្ពស់អ្វីដែលអ្នកតែងតែថ្វាយដង្វាយនោះ?» ដូច្នេះទីនោះហៅ
ថា បាម៉ា រហូតដល់សព្វថ្ងៃ។
[30]ដូច្នោះហើយ ចូលនិយាយទៅពួកកូនចៅស្រាអែលថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ អ្នករាល់គ្នាតែងធ្វើឲ្យខ្លួនស្មោកគ្រោក តាមផ្លូវបុព្វបុរសអ្នក?
ហេតុអ្វីបានអ្នកប្រព្រឹត្តដូចពេស្យា តាមអ្វីដែលគួរស្អប់ខ្ពើម?[31]ដ្បិតកាលណាអ្នករាល់គ្នាថ្វាយតង្វាយរបស់ខ្លួន ហើយអ្នកដាក់កូនទៅក្នុងភ្លើង ដរាបដល់សព្វថ្ងៃនេះ
ហើយធ្វើឲ្យខ្លួនស្មោកគ្រោក ជាមួយរូបព្រះរបស់អ្នក។ ដូច្នេះ តើយើងនឹងឲ្យអ្នករាល់គ្នាសួរដល់យើងឬ? ដូចជាយើងរស់នៅ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល
យើងមិនឲ្យអ្នកសួរដល់យើងទេ។[32]ការគិតដែលកើតក្នុងគំនិតអ្នករាល់គ្នា នឹងមិនអាចកើតឡើយទេ។ អ្នកនិយាយថា សូមឲ្យយើងដូចជាជនជាតិដទៃ ដូចជាអំបូរដែលនៅ
ទឹកដីផ្សេង ជាអ្នកថ្វាយបង្គំឈើ និងថ្មផង»។
[33]ដូចជាយើងរស់នៅ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល យើងនឹងសោយរាជ្យលើអ្នកដោយដៃដ៏ខ្លាំងពូកែ ដៃបានលើកឡើង ហើយចាក់កំហឹងខ្លាំងមកលើអ្នក។
[34]យើងនឹងនាំអ្នករាល់គ្នាចេញពីមនុស្សដទៃ ហើយនឹងប្រមូលអ្នករាល់គ្នាមកពីស្រុកទាំងឡាយដែលអ្នកត្រូវខ្ចាត់ខ្ចាយទៅនោះ។
យើងនឹងធ្វើការនេះជាមួយដៃដ៏ខ្លាំងពូកែនិងកំហឹងដែលចាក់លើអ្នក។[35]រួចហើយយើងនឹងនាំអ្នករាល់គ្នាទៅ ទីសូន្យស្ងាត់នៃមនុស្សហើយនៅទីនោះ យើងនឹង
ជំនុំជម្រះអ្នកមុខទល់និងមុខ។
[36]ដូចជាយើងបានជំនុំជម្រះបុព្វបុរសអ្នករាល់គ្នា នៅក្នុងទីរហោស្ថាននៃស្រុកអេស៊ីបជាយ៉ាងណា យើងក៏នឹងធ្វើអ្នករាល់គ្នាយ៉ាងនោះដែរ នេះជាព្រះបន្ទូលនៃ
ព្រះអម្ចាស់ដ៏ជាព្រះ។[37]យើងនឹងឲ្យអ្នករាល់គ្នាចូលក្រោមដំបង រួចនាំឲ្យជាប់ចំណងនៃសេចក្តីសញ្ញា។[38]យើងនឹងញែកពួករឹងចចេសពីអ្នកចេញ ព្រមទាំងពួកអ្នកដែល
តែងតែប្រព្រឹត្តរំលង ទាស់នឹងយើងផង យើងនឹងនាំគេចេញពីទឹកដីដែលគេស្នាក់នៅនោះ តែគេមិនបានចូលទៅក្នុងទឹកដីអ៊ីស្រាអែល។ នោះអ្នករាល់គ្នានឹងដឹងថា យើង
នេះជាព្រះអម្ចាស់។
[39]ចំណែកអ្នក កូនចៅអ៊ីស្រាអែលអើយព្រះអម្ចាស់ដ៏ជាព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះថា ចូរទៅចុះ ពីនេះទៅមុខអ្នករាល់គ្នាមិនព្រមស្តាប់តាមយើងទេ ដូច្នេះចូរទៅគោរព
ដល់រូបព្រះរបស់អ្នករៀងខ្លួនចុះ តែមិនត្រូវបង្អាក់ឈ្មោះបរិសុទ្ធរបស់យើង ដោយតង្វាយ និងរូបព្រះរបស់អ្នក។
[40]ដ្បិតនៅលើភ្នំបរិសុទ្ធរបស់យើង គឺជាភ្នំមានកំពូលខ្ពស់របស់ស្រុកអ៊ីស្រាអែល នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល កូនចៅស្រាអែលទាំងមូលនឹងថ្វាយបង្គំយើង
គ្រប់គ្នានៅក្នុងទឹកដីរបស់ខ្លួន។ យើងនឹងពេញចិត្ត ទទួលតង្វាយរបស់អ្នករាល់គ្នានៅទីនោះ និងផលដំបូងពីតង្វាយអ្នកផងដែរ ព្រមទាំងគ្រឿងបរិសុទ្ធរបស់អ្នកទាំង
នោះផង។[41]យើងនឹងទទួលអ្នក ដូចជាក្លិនក្រអូបក្នុងកាលដែលយើងបាននាំអ្នកចេញពីពួកជនជាតិដទៃ ហើយប្រមូលអ្នកពីអស់ទាំងទឹកដីដែលអ្នកត្រូវខ្ចាត់ខ្ចាយទៅ។
យើងខ្លួនឯងនឹងបានវិសុទ្ធក្នុងចំណោមអ្នក ហើយជនជាតិដទៃនឹងបានឃើញ។
[42]ក្រោយមក ពេលយើងនាំអ្នកចូលទៅក្នុងទឹកដីអ៊ីស្រាអែល គឺក្នុងទឹកដីដែលយើងបានលើកដៃស្បថថា នឹងឲ្យដល់បុព្វបុរសអ្នកហើយ នោះអ្នកនឹងដឹងថាយើងនេះជា
ព្រះអម្ចាស់។[43]ហើយអ្នកនឹងនឹកចាំពីអំពើគ្រប់យ៉ាង និងការប្រព្រឹត្តរបស់អ្នកដែលអ្នកធ្វើឲ្យខ្លួនស្មោកគ្រោក ហើយអ្នករាល់គ្នានឹងខ្ពើមខ្លួន ដោយព្រោះអំពើអាក្រក់ទាំង
នោះ ដែលអ្នកបានធ្វើ។[44]ដូច្នេះ អ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់ ក្នុងកាលដែលយើងបានប្រព្រឹត្តនឹងអ្នក ដោយយល់ដល់ឈ្មោះយើង មិនមែនតាម
ការអាក្រក់ ឬកិច្ចការថោកទាបរបស់អ្នកទេ កូនចៅនៃអ៊ីុស្រាអែល នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។
[45]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[46]«កូនមនុស្សអើយ ចូរបែរមុខទៅខាងត្បូង ហើយប្រកាសទាស់នឹងទឹកដីខាងត្បូងនោះ ត្រូវថ្លែងទំនាយទាស់នឹងទឹកដី
ព្រៃក្នុងតំបន់ណេកិបចុះ។[47]និយាយទៅកាន់ព្រៃតំបន់ណេកិបថា ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ចុះ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ យើងនឹងបង្កាត់ភ្លើងនៅ
ក្នុងចំណោមអ្នក។ វានឹងឆេះអស់ទាំងឈើស្រស់ និងដើមឈើសោះកក្រោះនៅក្នុងចំណោមអ្នក។ ការឆេះត្រគោលនឹងមិនរលត់ទេ ចាប់តាំងពីខាងត្បូងរហូតដល់ខាងជើង
នឹងត្រូវឆេះទាំងអស់។
[48]ដូច្នេះ គ្រប់គ្នានឹងឃើញថា យើងគឺជាព្រះអម្ចាស់ ពេលយើងដែលបានបង្កាត់ភ្លើង ហើយវានឹងមិនរលត់ឡើយ»។[49]រួចហើយខ្ញុំទូលថា «បពិត្រព្រះអម្ចាស់ដ៏ជាព្រះអើយ
គេនិយាយពីទូលបង្គំថា តើគាត់មិនមែនជាអ្នកនិយាយសុទ្ធតែពាក្យប្រៀបធៀបទេឬ?»។

Ezekiel 20:1

ចូលមកដល់

ឃ្លានេះត្រូវបានប្រើដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។

ក្នុងឆ្នាំទីប្រាំពីរ

ការបកប្រែរបៀបផ្សេងទៀត: «នៅឆ្នាំទីប្រាំពីរនៃការនិរទេសស្តេចយេហូយ៉ាជីន»

នៅថ្ងៃទីដប់ក្នុងខែទីប្រាំ

generated on Wed Sep 10 16:16:32 2025

នេះជាខែទីប្រាំនៃប្រតិទិនហេប្រឺ។
ថ្ងៃទីដប់គឺនៅជិតដើមខែសីហានៅលើប្រតិទិនលោកខាងលិច។
នៅមុខខ្ញុំ
«នៅពីមុខខ្ញុំ»
Ezekiel 20:2
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។ សូមមើលពីរបៀបបកប្រែនេះនៅក្នុងជំពូក ១:១។
ដូចយើងមានជីវិត
សូមមើលការបកប្រែនេះនៅក្នុងជំពូក ៥:១១។
យើងមិនបាច់ឆ្លើយសំនួររបស់អ្នកឡើយ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងមិនអនុញ្ញាតឲ្យអ្នកស្នើសុំសារពីយើងទេ»។
Ezekiel 20:4
តើអ្នកនឹងជំនុំជម្រះពួកគេឬ? តើអ្នកជំនុំជម្រះ កូនមនុស្ស
ការបកប្រែរបៀបផ្សេងទៀត: «អ្នកវិនិច្ឆ័យពួកគេកូនមនុស្ស»។
ជាទឹកដីមានទឹកដោះ និងទឹកឃ្មុំ
«ដីដែលមានទឹកដោះគោ និងទឹកឃ្មុំហូរច្រើន»។ ការបកប្រែរបៀបផ្សេងទៀត: «វាជាដីមានជីជាតិណាស់» ឬ «វាជាដីដែលសត្វ និងរុក្ខជាតិលូតលាស់បានល្អ»។
Ezekiel 20:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ដល់ពួកចាស់ទុំអ៊ីស្រាអែល។
ពួកគេ
«ដល់កូនចៅនៃប្រជាជនលោកយ៉ាកុប»
ចេញពីមុខភ្នែករបស់គេ
ឃ្លានេះមានន័យថា «គាត់ស្រឡាញ់» ឬ «គាត់គោរពបូជា»។
Ezekiel 20:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ដល់ពួកចាស់ទុំអ៊ីស្រាអែល។
ពួកគេបានទាស់នឹងយើង
ពាក្យថា «ពួកគេ» សំដៅទៅលើ «កូនចៅរបស់ពូជពង្សយ៉ាកុប»។
មិនព្រមស្តាប់តាមយើងទេ
«នឹងមិនគោរពយើង»
ដើម្បីមិនត្រូវទាបថោក នៅចំពោះភ្នែកជនជាតិដទៃ
ឃ្លានេះមានន័យថា
«ដូច្នេះប្រជាជាតិនានានឹងមិនគិតថាឈ្មោះរបស់ខ្ញុំមិនបរិសុទ្ធឡើយ»។
ដែលស្ថាក់នៅទីនោះ
«ពួកគេកំពុងរស់នៅ»។
យើងបានសម្តែងឲ្យគេស្គាល់យើង
«យើងបានបង្ហាញប្រជាជាតិដែលជារបស់យើង»
ក្នុងភ្នែករបស់ពួកគេ
«តាមរបៀបមួយដែលប្រជាជាតិនានាអាចមើលឃើញ»
ដោយនាំគេ
«នាំប្រជាជនរបស់លោកយ៉ាកុប»
Ezekiel 20:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ដល់ពួកចាស់ទុំអ៊ីស្រាអែល។
យើងបានបញ្ជូនពួកគេ
ពាក្យថា «ពួកគេ» សំដៅទៅលើ «កូនចៅរបស់វង្សយ៉ាកុប»។
Ezekiel 20:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ដល់ពួកចាស់ទុំអ៊ីស្រាអែល។
ចាក់សេចក្តីឃោរឃៅរបស់យើង
សូមមើលការបកប្រែនេះនៅក្នុងជំពូក ២០:៨។
យើងបានប្រព្រឹត្តដោយយល់ដល់ឈ្មោះយើងវិញ ហើយនៅចំពោះភ្នែកជនជាតិដ៏ទៃ
សូមមើលការបកប្រែនេះនៅក្នុងជំពូក ២០:៨។
Ezekiel 20:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ដល់ពួកចាស់ទុំអ៊ីស្រាអែល។
បានលើកដៃស្បថនឹងគេ
សូមមើលការបកប្រែនេះនៅក្នុងជំពូក ២០:៤។
ពួកគេ
«ដល់ពូជវង្សអ៊ីស្រាអែល»
តែភ្នែករបស់យើងបានអាណិតពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែយើងនៅតែអាណិតពួកគេ»។
ប្រណីដល់គេពីការបំផ្លាញ
«ហើយយើងមិនបានបំផ្លាញពួកគេទេ»
Ezekiel 20:18
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ដល់ពួកចាស់ទុំរបស់អ៊ីស្រាអែល។
កុំដើរតាមច្បាប់របស់បុព្វបុរសអ្នករាល់គ្នា
«កុំធ្វើអ្វីដែលឪពុកម្តាយអ្នកបានបញ្ជាឲ្យអ្នកធ្វើ»
កុំកាន់តាមបញ្ញត្តិរបស់គេ
«មិនគោរពច្បាប់របស់ពួកគេ»
រក្សាបញ្ញត្តិច្បាប់របស់យើង ហើយស្តាប់តាមផង
«រក្សា» ក្រឹត្យវិន័យរបស់ព្រះអម្ចាស់គឺដូចគ្នានឹងការ «ស្តាប់តាម» ដែរ។
បានដឹងថា យើងនេះគឺជាព្រះអម្ចាស់ជាព្រះរបស់អ្នក
សូមមើលការបកប្រែនេះនៅក្នុងជំពូក ៦:៦។
Ezekiel 20:21
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ដល់ពួកចាស់ទុំរបស់អ៊ីស្រាអែល។
ពួកគេមិនបានដើរតាមច្បាប់របស់យើង
សូមមើលការបកប្រែនៅក្នុង ២០:១៣។
ដូច្នេះយើងនឹងចាក់សេចក្តីឃោរឃៅរបស់យើងទៅលើគេ ដើម្បីឲ្យស្កប់ចិត្តតាមសេចក្តីកំហឹងរបស់យើងនៅលើគេ
សូមមើលការបកប្រែនៅក្នុង ២០:៨។
Ezekiel 20:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារដល់ពួកចាស់ទុំរបស់អ៊ីស្រាអែល។
បានលើកដៃស្បថនឹងពួកគេ
វាជាទម្លាប់ធម្មតាក្នុងការស្បថដោយលើកដៃទៅលើមេឃ។
យើងនឹងកម្ចាត់កម្ចាយគេទៅនៅកណ្តាលជនជាតិទាំងឡាយ ហើយបែងចែកគេទៅនៅក្នុងទឹកដីទាំងនោះ
សូមមើលពីររបៀបការបកប្រែនៅក្នុងជំពូក ១២:១៤។
ហើយភ្នែករបស់ពួកគេក៏ជាប់តាមរូបព្រះរបស់បុព្វបុរសគេដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេចង់គោរពបូជារូបព្រះដែលឪពុកម្តាយពួកគេបានគោរពបូជា។
Ezekiel 20:25
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារដល់ពួកចាស់ទុំរបស់អ៊ីស្រាអែល។
ក្រោយមក យើងក៏ឲ្យក្រឹត្យក្រមដល់ពួកគេដែលមិនល្អ ហើយបញ្ញត្តិ
ច្បាប់ដែលមិនអាចឲ្យពួកគេរស់បាន
ពាក្យដែលមានចែងក្នុងឃ្លានេះមិនសំដៅទៅលើច្បាប់របស់ព្រះទេ។
ដោយព្រះអង្គបានអនុញ្ញាតឲ្យពួកគេរស់នៅដោយច្បាប់
និងការវិនិច្ឆ័យរបស់មនុស្សដែលមិនល្អ។
ដល់ពួកគេ
ពាក្យថា «ពួកគេ»
សំដៅទៅលើកូនចៅរបស់អ្នករាល់គ្នាដែលព្រះអម្ចាស់បាននាំចេញពីស្រុកអេស៊ីប។
ដោយពួកគេថ្វាយ
ការបកប្រែរបៀបផ្សេងទៀត: «ដោយអំណោយដែលពួកគេបានផ្តល់ឲ្យយើង»។
ដាក់ទៅក្នុងភ្លើង
នេះមានន័យថាលះបង់កូនទៅរូបព្រះដោយដុតពួកគេទាំងរស់។
Ezekiel 20:27
តើទីខ្ពស់អ្វីដែលអ្នកតែងតែថ្វាយដង្វាយនោះ
ការបកប្រែរបៀបផ្សេងទៀត: «នេះមិនមែនជាទីខ្ពស់ទេ ដែលអ្នកត្រូវថ្វាយតង្វាយ!
»
ទីនោះហៅថា បាម៉ា
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនបានហៅកន្លែងនោះថាបាម៉ា» «បាម៉ា»
មានន័យថា «កន្លែងខ្ពស់» ជាកន្លែងសំរាប់គោរពបូជារូបព្រះ។

generated on Wed Sep 10 16:16:32 2025

Ezekiel 20:30
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារដល់កូនចៅរបស់អ៊ីស្រាអែល។
ដាក់កូនទៅក្នុងភ្លើង
នេះមានន័យថាលះបង់កូនទៅរូបព្រះដោយដុតពួកគេទាំងរស់។
តើយើងនឹងឲ្យអ្នករាល់គ្នាសួរដល់យើងឬ?
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមិនមានសិទ្ធិដើម្បីសួរយើងឡើយ...អ៊ីស្រាអែល»។
Ezekiel 20:33
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារដល់កូនចៅរបស់អ៊ីស្រាអែល។
ដៃដ៏ខ្លាំងពូកែ ដៃបានលើកឡើង
ឃ្លាទាំងពីរនេះសំដៅទៅលើថាមពលដ៏អស្ចារ្យ។
Ezekiel 20:36
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារដល់កូនចៅរបស់អ៊ីស្រាអែល។
Ezekiel 20:39
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារដល់កូនចៅរបស់អ៊ីស្រាអែល។
កូនចៅអ៊ីស្រាអែល
សូមមើលពីររបៀបការបកប្រែនៅក្នុងជំពូក ៣:១។
ស្តាប់តាមយើ
«ស្តាប់បង្គាប់យើង» ឬ «យកចិត្តទុកដាក់ចំពោះយើង»
Ezekiel 20:40
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសារដល់កូនចៅរបស់អ៊ីស្រាអែល។
ទទួល
«បញ្ជាឲ្យនាំយក»
ផលដំបូងពីតង្វាយអ្នកផងដែរ
ពាក្យថា «ផលដំបូង»
នៅទីនេះប្រហែលជាមានន័យថារបស់ល្អបំផុតក្នុងចំណោមតង្វាយទាំងអស់ដែលទុកដើម្បីថ្វាយដល់ព្រះអង្គ។
គ្រឿងបរិសុទ្ធរបស់អ្នក
«តង្វាយដែលអ្នកទុកដោយឡែកដើម្បីអោយយើង»
នាំអ្នកចេញពីពួកជនជាតិដទៃ ហើយប្រមូលអ្នកពីអស់ទាំងទឹកដី
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយបញ្ជាក់ថាព្រះអម្ចាស់នឹងនាំប្រជារាស្ត្ររបស់ព្រះអង្គវិលត្រឡប់មកវិញពីប្រជាជាតិទាំងអស់ដែលព្រះអង្គបានខ្ចាត់ខ្ចាយពីពួកគេ។
អ្នកត្រូវខ្ចាត់ខ្ចាយទៅ
ការបកប្រែរបៀបផ្សេងទៀត: «យើងបានខ្ចាត់ខ្ចាយពីអ្នករាល់គ្នា»។
យើងខ្លួនឯងនឹងបានវិសុទ្ធក្នុងចំណោមអ្នក ហើយជនជាតិដទៃនឹងបានឃើញ។
«យើងនឹងប្រើអ្នកដើម្បីបង្ហាញប្រជាជាតិនានាថាយើងគឺបរិសុទ្ធ»
Ezekiel 20:42
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារដល់កូនចៅរបស់អ៊ីស្រាអែល។
បានលើកដៃស្បថថា
ឃ្លានេះមានន័យថា «បានស្បថ» ឬ «បានសន្យា»។
អ្នកនឹងដឹងថាយើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ៦:៦។
ព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 20:45
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។
Ezekiel 20:48
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅព្រៃរបស់ណេណេវ។
នឹងឃើញថា
«នឹងយល់»
បពិត្រ
ពាក្យដែលបង្ហាញពីទុក្ខកង្វល់ ឬ ទុក្ខព្រួយ
មិនមែនជាអ្នកនិយាយសុទ្ធតែពាក្យប្រៀបធៀបទេឬ?
ការបកប្រែរបៀបផ្សេងទៀត: «គាត់ទើបតែនិទានរឿងប៉ុណ្ណោះ»

---

21 [1]រួចហើយព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំថា៖[2]«កូនមនុស្សអើយ ចូរដាក់មុខអ្នកទៅរកក្រុងយេរូសាឡិម ហើយថ្លែងទាស់នឹងទីបរិសុទ្ធទាំងនោះ រួចថ្លែងព្រះបន្ទូលទាស់នឹងទឹកដីអ៊ីស្រាអែលចុះ។[3]ហើយប្រាប់ដល់ទឹកដីអ៊ីស្រាអែលថា ព្រះអម្ចាស់ដ៏ជាព្រះ មានព្រះបន្ទូលដូច្នេះ មើល៍! យើងទាស់នឹងអ្នក យើងនឹងហូតដាវរបស់យើងចេញពីស្រោម ហើយកាត់ទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតចេញពីអ្នកផង!
[4]ដ្បិតយើងនឹងកាត់ទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតចេញពីអ្នក នោះដាវរបស់យើងនឹងចេញពីស្រោម ទៅទាស់នឹងគ្រប់ទាំងមនុស្ស ចាប់តាំងពីខាងត្បូងរហូតដល់ខាងជើង។[5]គ្រប់គ្នានឹងដឹងថា យើងគឺព្រះអម្ចាស់ បានហូតដាវរបស់យើងពីស្រោមចេញមក ដាវនោះនឹងមិនបានសឹកចូលទៅវិញឡើយ!
[6]ចំណែកអ្នកវិញ កូនមនុស្សអើយ ចូរថ្ងូរដូចសិង្ហឈឺចាប់ ក្នុងការថ្ងូរល្វីងជូរចត់នៅចំពោះមុខគេ។[7]រួចហើយវានឹងកើតឡើង ពួកគេនឹងសួរអ្នកថា ហេតុអ្វីបានជាថ្ងូរដូច្នេះ? អ្នកត្រូវប្រាប់ថា គឺដោយព្រោះបានឮដំណឹងដែលកំពុងតែមក ដ្បិតចិត្តមនុស្សទាំងអស់នឹងរលាយទៅ ដៃទាំងអស់នឹងអន់ខ្សោយ! វិញ្ញាណទាំងអស់នឹងស្រយុតចុះ ហើយក្បាលជង្គង់ទាំងប៉ុន្មាននឹងទន់ដូចជាទឹក ការនោះកំពុងតែមកហើយ ក៏នឹងបានសម្រេច នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ»។
[8]រួចហើយព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[9]«កូនមនុស្សអើយ ចូរថ្លែងព្រះបន្ទូលថា ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ មានដាវ! ជាដាវ! វានឹងមសំលៀង ហើយខាត់ឲ្យភ្លឺផ្លេកផង!
[10]វានឹងបានសំលៀងតាមការណែនាំ ដើម្បីឲ្យវាបានក្លាយជាអាវុធប្រហារដ៏ខ្លាំង! ហើយត្រូវខាត់វាជានិច្ចដើម្បីឲ្យភ្លឺដូចផ្លេកបន្ទោរ!
តើយើងគួរនឹងរីករាយជាដំបងរបស់កូនទេ? ហើយដាវដ៏មុតនេះគឺវាស្អាប់ពួកអ្នកដែលលួចប្លន់ខ្លាំងណាស់![11]ដូច្នេះ ដាវនោះបានប្រគល់ឲ្យគេខាត់ ដើម្បីឲ្យបានកាន់នៅដៃជា។ ដាវនោះបានសំលៀងហើយ ហើយក៏បានខាត់ឲ្យភ្លឺធ្ហើដោយដៃដែរ ហើយប្រគល់ឲ្យទៅក្នុងដៃរបស់អ្នកប្រហារ!
[12]ចូរស្រែករកជំនួយហើយសោកសៅ កូនមនុស្សអើយ! ដ្បិតដាវនោះបានមកលើប្រជារាស្ត្ររបស់យើង! វាមកទាស់នឹងពួកអ្នកដឹកនាំ នៃជនជាតិអ៊ីស្រាអែល។ ពួកគេក៏ទាស់ជាមួយដាវនិងប្រជារាស្ត្រយើង។ ដូច្នេះចូរទះភ្លៅអ្នកចុះ![13]ដ្បិតនឹងមានការជំនុំជម្រះមួយ ប៉ុន្តែតើនឹងមានអ្វីកើតឡើងបើដំបងនោះមិននៅទៀតទេ? នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[14]គ្រានោះ កូនមនុស្សអើយ ចូរអ្នកថ្លែងព្រះបន្ទូល ហើយទះដៃទាំងពីរផង ដ្បិតដាវបានកាប់ដល់ទៅបីដង! ដាវនោះសម្រាប់អ្នកដែលកាប់សម្លាប់! វាជាដាវដែលធ្វើឲ្យមនុស្សជាច្រើនស្លាប់ ហើយក៏ចាក់ទំលុះពួកគេគ្រប់ទីកន្លែងដែរ!
[15]ដើម្បីរៀបចំរំលាយចិត្តរបស់គេ ហើយធ្វើឲ្យគេធ្លាក់ចុះកាន់តែខ្លាំង យើងបានដាក់ដាវនៃការប្រហារទាស់នឹងគេនៅមាត់ទ្វារទាំងនោះ! វរហើយ! ដាវនោះបានធ្វើដូចជាផ្លេកបន្ទោរ ត្រៀមរួចសម្រាប់ប្រហារ![16]អ្នក ជាដាវ! កាប់ទៅខាងស្តាំ! កាប់ទៅខាងឆ្វេង! មុខបែរទៅខាងណាកាប់ទៅខាងនោះទៅ។[17]ដ្បិតយើងនឹងទះដៃទាំងពីរបស់យើងដែរ ហើយសេចក្តីក្រោធរបស់យើងនឹងបង្ហើយតាមក្រោយ! យើង ព្រះអម្ចាស់ បានប្រកាសហើយ!»
[18]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកកាន់ខ្ញុំម្តងទៀតប្រាប់ថា[19]«ពេលនេះកូនមនុស្សអើយ យើងតាំងអ្នកឲ្យទៅយាមផ្លូវទាំងពីរ ដែលផ្លូវដាវរបស់ស្តេចបាប៊ីឡូននឹងមកបាន។ ផ្លូវទាំងពីរនោះត្រូវចេញពីទឹកដីតែមួយ ហើយត្រូវធ្វើជាសញ្ញាចង្កុលដាក់នៅត្រង់ដើមផ្លូវចូលទៅក្នុងទីក្រុង។[20]ចូរធ្វើផ្លូវមួយសម្រាប់ទាហាន ពួកបាប៊ីឡូនបានទៅដល់ក្រុងរ៉ាបាត ជាក្រុងរបស់កូនចៅអាំម៉ូន។ ធ្វើមួយទៀតដើម្បីដឹកនាំទាហានយូដា ហើយក្រុងយេរូសាឡិម ជាទីក្រុងមាំមួន។
[21]ដ្បិតស្តេចរបស់បាប៊ីឡូននឹងឈប់នៅត្រង់ផ្លូវបំបែក នៅចំកន្លែងទីប្រសព្វហើយក៏ធ្វើការទស្សន៍ទាយ។ ហើយស្តេចបានពីធីអង្រួនព្រួញផ្សងដល់ព្រះផ្សេងៗ ទាំងពិចារណាអំពីជីវិតផងដែរ។[22]ចំណែកផ្លូវដែលនៅខាងដៃស្តាំ បានទស្សន៍ ទាយថាក្រុងយេរូសាឡិម ដើម្បីរៀបចំការចម្បាំងទាស់និងក្រុងនោះ ហើយបើកម៉ាត់

generated on Wed Sep 10 16:16:32 2025

ឡើងបញ្ជាធ្វើការកាប់សម្លាប់ និងបន្លឺសំឡេងហ៊ោក្នុងចម្បាំង ហើយតាំងគ្រឿងសម្រាប់ទម្លាយទ្វារ ដើម្បីជីកទីលាន ហើយសង់បន្ទាយ។
[23]វានឹងមើលទៅដូចជាគ្មានប្រយោជន៏ដល់អ្នក ដែលរស់នៅក្នុងក្រុងយេរូសាឡិម អ្នកដែលបានហូតដាវហើយស្បថទៅស្តេចបាប៊ីឡូន! ប៉ុន្តែស្តេចស្រុកបាប៊ីឡូន
នឹងចោទពួកគេពីការបំពានសន្ធិសញ្ញ ក្នុងការឡោមព័ទ្ធពួកគេ។
[24]ហេតុនោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ពីព្រោះអ្នករាល់គ្នាបានរឭកអំពើទុច្ចរិតរបស់ខ្លួន ដោយបើកអំពើរំលងរបស់ខ្លួនឲ្យឃើញ! ហើយអំពើបាបរបស់
អ្នកក៏បានឃើញច្បាស់ ក្នុងគ្រប់ការដែលអ្នកធ្វើ! ដ្បិតមូលហេតុនេះនឹងរំលឹកអ្នកឲ្យដឹងថា គ្រប់គ្នានឹងត្រូវចាប់ធ្វើជាឈ្លើយ ដោយដៃសត្រូវរបស់អ្នក!
[25]ចំណែកអ្នក ជាអ្នកមេដឹកនាំប្រមាថ និងអាក្រក់របស់ជនជាតិអ៊ីស្រាអែល ថ្ងៃដែលជំនុំជម្រះបានមកដល់ ហើយពេលអ្នកដែលប្រព្រឹត្តអំពើទុច្ចរិត
ត្រូវបញ្ចាប់[26]ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលថា គេនឹងយកឈ្នួតហើយដកមកុដរាជ្យចេញពីក្បាលអ្នក! ការទាំងនេះនឹងផ្លាស់ប្រែ តម្កើងមនុស្សទន់ទាបនឹង
បន្ទាប់ខ្លួនត្រូវគេលើកតម្កើង![27]បំផ្លាញ! បំផ្លាញ! វានឹងមិនអាចសង់ឡើងវិញទេ ដរាបដល់ម្នាក់ដែលយើងតាំងឲ្យមានអំណាចដាក់ទោសប្រហារជីវិត។
[28]កូនមនុស្សអើយ ចូរថ្លែងពាក្យដោយពោលថាព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល ដល់ជនជាតិអាំម៉ូនដែលទាក់ទងនិងការអាម៉ាស់របស់ពួកគេដែលនឹងមកដល់ ដាវ!
ដាវដកចេញ! វាគឺបានសំលាងខាត់យ៉ាងមុត សម្រាប់បំប្រហារធ្វើឲ្យរលាប់ដូចជាផ្លេកបន្ទោរ![29]កាលព្យាការីមិនបានឃើញនិមិត្តសម្រាប់អ្នក
ជាពេលពួកគេធ្វើបង្ក្រាប់កិច្ចដោយប្រមាថ ដើម្បីមករកអ្នកជាមួយពាក្យកុហក ដាវនេះនឹងកាត់កមនុស្សអាក្រក់ ជាអ្នកដែលនឹងត្រូវសម្លាប់
ជាអ្នកដែលថ្ងៃជីវិតត្រូវជំនុំជម្រះបានមកដល់ ហើយជាពេលអ្នកធ្វើការទុច្ចរិត នឹងជិតបញ្ចាប់។
[30]ចូរសិកដាវក្នុងស្រោមវិញទៅ។ យើងនឹងវិនិច្ឆ័យទោសអ្នក នៅកន្លែងដែលអ្នកកើត គឺស្រុកកំណើតរបស់អ្នក![31]យើងនឹងជះកំហឹងរបស់យើងលើអ្នក! យើងនឹងផ្លុំភ្លើងនៃ
កំហឹងរបស់យើងទៅលើអ្នក ហើយប្រគល់អ្នកទៅក្នុងកណ្តាប់ដៃរបស់មនុស្សកំរោល ដែលប៉ិនប្រសប់ខាងបំផ្លាញ!
[32]អ្នកនឹងវិនាសនៅក្នុងភ្លើង! ឈាមរបស់អ្នកនឹងដកនៅក្នុងទឹកដី ហើយក៏គ្មាននរណានឹកដល់អ្នកទៀតដែរ។ គ្មាននរណានឹងនឹកចាំពីអ្នកទៀតទេ
ដ្បិតនេះជាពាក្យរបស់យើង គឺជាព្រះអម្ចាស់ដ៏ជាព្រះ!»

Ezekiel 21:1

កូនមនុស្សអើយ

«កូនប្រុសរបស់មនុស្ស» ឬ «ព្រះរាជបុត្រានៃមនុស្សជាតិ»។

ព្រះជាម្ចាស់ហៅលោកអេសេគាលនេះដើម្បីបញ្ជាក់ថាលោកអេសេគាលគ្រាន់តែជាមនុស្សប៉ុណ្ណោះ។

ព្រះមានឫទ្ធានុភាពនិងរស់នៅជារៀងរហូតប៉ុន្តែមនុស្សមិនមែនទេ។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សរមែងស្លាប់» ឬ «មនុស្ស»

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់បានប្រទានសារមកខ្ញុំ»។

សូមមើលពីរបៀបដែលបកប្រែឃ្លានេះក្នុងជំពូក ១: ១។

ចូរដាក់មុខអ្នកទៅរកក្រុងយេរូសាឡិម

នេះគឺជាលេខសម្គាល់។

នេះមានន័យថាព្រះអម្ចាស់កំពុងវិនិច្ឆ័យទោសក្រុងយេរូសាឡិម
ហើយកំពុងប្រាប់លោកអេសេគាល
ឲ្យមើលទៅក្រុងយេរូសាឡិមហើយនិយាយអំពីការវិនិច្ឆ័យរបស់គាត់ប្រឆាំងនឹងក្រុងយេរូសាឡិម

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៤:៦។

ការបកប្រែរបៀបផ្សេងទៀត: «មើលការវិនិច្ឆ័យលើក្រុងយេរូសាឡិម» ឬ
«មើលទៅក្រុងយេរូសាឡិមដោយការវិនិច្ឆ័យ»

យើងនឹងហូតដាវរបស់យើងចេញពីស្រោម ហើយកាត់ទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតចេញពីអ្នកផង!

នេះនិយាយអំពីព្រះអម្ចាស់ដែលធ្វើឲ្យប្រជាជនទាំងនេះស្លាប់ដូចជាព្រះអង្គបានសម្លាប់ពួកគេដោយដាវរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត: «យើងប្រឆាំងនឹងអ្នក
ហើយវាហាក់ដូចជាយើងដកដាវរបស់អ្នកចេញពីស្រោមដើម្បីសម្លាប់ទាំងមនុស្សសុចរិត
និងមនុស្សអាក្រក់ក្នុងចំណោមអ្នករាល់គ្នា»

មនុស្សសុចរិត និងមនុស្សទុច្ចរិត

«មនុស្សសុចរិត និងមនុស្សអាក្រក់»។

នេះសំដៅទៅលើមនុស្សជាច្រើនមិនត្រឹមតែមនុស្សសុចរិតម្នាក់និងមនុស្សអាក្រក់ប៉ុណ្ណោះ

ស្រោម

អ្វីដែលកាន់ និងដាវនៅពេលដែលគ្មាននរណាម្នាក់ប្រើប្រាស់វា

កាត់

នេះគឺជាការលួងលោមចិត្តមានន័យថាសម្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«សម្លាប់»

Ezekiel 21:4

ព័ត៌មានទូទៅ:

ព្រះអម្ចាស់នៅតែបន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅកាន់ទឹកដីអ៊ីស្រាអែល

កាត់

នេះគឺជាការលួងលោមចិត្តដែលមានន័យថាសម្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«សម្លាប់»

មនុស្សសុចរិត...មនុស្សទុច្ចរិត

នេះសំដៅទៅលើមនុស្សសុចរិត និងមនុស្សអាក្រក់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលសុចរិត...អ្នកដែលទុច្ចរិត» ឬ «មនុស្សសុចរិត... មនុស្សអាក្រក់»

ចេញពីអ្នក

«ក្នុងចំណោមអ្នករាល់គ្នា»

នោះដាវរបស់យើងនឹងចេញពីស្រោមទៅទាស់

ការបកប្រែរបៀបផ្សេងទៀត: «វានឹងដូចជាយើងដកដាវរបស់យើងចេញពីស្រោម
ហើយវាយ»

ទាំងមនុស្ស

ពាក្យថា «សាច់ឈាម» នៅទីនេះគឺជាពាក្យសំដីសម្រាប់ «ប្រជាជន»។

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សទាំងអស់»

ចាប់តាំងពីខាងត្បូងរហូតដល់ខាងជើង

នេះគឺជាការបង្រួបបង្រួមមួយ ដែលសំដៅទៅលើតំបន់នៅខាងជើង និងខាងត្បូង
និងគ្រប់ទីកន្លែង។ ការបកប្រែរបៀបផ្សេងទៀត: «នៅគ្រប់ទិសដៅ» ឬ
«គ្រប់ទីកន្លែង»

យើងគឺព្រះអម្ចាស់ បានហូតដាវរបស់យើងពីស្រោមចេញមក

នេះនិយាយអំពីព្រះអម្ចាស់ដែលធ្វើឲ្យមនុស្សស្លាប់ដូចជា
សម្លាប់ពួកគេដោយដាវផ្ទាល់របស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«វាដូចជាយើងដែលជាព្រះអម្ចាស់បានវាយប្រហារប្រជាជនដោយដាវរបស់យើង»

មិនបានសិកចូលទៅវិញឡើយ!

នេះនិយាយអំពីព្រះអម្ចាស់មិនកាន់ដាវរបស់ខ្លួនមិនឱ្យវាយប្រហារប្រជាជនដូចជាដាវរបស់គាត់គឺជាមនុស

ការបកប្រែរបៀបផ្សេងទៀត: «ហើយយើងនឹងមិនដាក់វាចូលក្នុងស្រោមវិញទេ» ឬ

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងមិនរារាំងការវាយប្រហាររបស់ប្រជាជន»

Ezekiel 21:6

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអេសេគាល។

កូនមនុស្ស

«កូនប្រុសរបស់មនុស្ស» ឬ «បុត្ររបស់មនុស្សជាតិ» ឬ «មនុស្សរមែងស្លាប់» ឬ
«មនុស្ស»។

ព្រះជាម្ចាស់ហៅលោកអេសេគាលនេះដើម្បីបញ្ជាក់ថាលោកអេសេគាលគ្រាន់តែជាមនុស្សប៉ុណ្ណោះ។

ព្រះមានឫទ្ធានុភាព និងរស់នៅជារៀងរហូត ប៉ុន្តែមនុស្សមិនមែនទេ។

បកប្រែដូចនៅក្នុងជំពូក ២:១។

ចូរថ្ងូរដូចសិង្ហឈឺចាប់

ព្រះអម្ចាស់ប្រាប់លោកអេសេគាល ឲ្យថ្ងូរជាសញ្ញាដើម្បីធ្វើសាររបស់គាត់។

ទ្រង់ប្រាប់គាត់ឲ្យថ្ងូរយ៉ាងខ្លាំងដូចជាពោះរបស់គាត់ឈឺចាប់ខ្លាំង។

«ថ្ងូរយ៉ាងខ្លាំងដូចជាចង្កេះរបស់អ្នកកំពុងឈឺចាប់យ៉ាងខ្លាំង» ឬ
«ថ្ងូរយ៉ាងខ្លាំងពេលកើតទុក្ខ»។

ថ្ងូរល្វីងជូរចត់

«ដោយមានការឈឺចាប់យ៉ាងខ្លាំង» ឬ «ដោយមានទុក្ខព្រួយយ៉ាងខ្លាំង»

ចំពោះមុខគេ

នៅទីនេះជនជាតិអ៊ីស្រាអែលត្រូវបានយោងដោយ «ភ្នែក»
របស់ពួកគេដើម្បីបញ្ជាក់ពីអ្វីដែលពួកគេបានឃើញ។ ការបកប្រែរបៀបផ្សេងទៀត:
«មុនពួកគេ» ឬ «មុនប្រជាជនអ៊ីស្រាអែល»

generated on Wed Sep 10 16:16:32 2025

បានឮដំណឹង
នេះនិយាយពី «ដំណឹង» ដូចជាវាជាមនុស្សម្នាក់ដែលនឹងមករកគេឆាប់ៗនេះ។ ការបកប្រែរបៀបផ្សេងទៀត: «ព័ត៌មានដែលពួកគេនឹងស្តាប់ឆាប់ៗនេះ»
ចិត្តមនុស្សទាំងអស់នឹងរលាយទៅ
នេះនិយាយពីមនុស្សដែលភ័យខ្លាចដូចជាដួងចិត្តរបស់ពួកគេបានដួលសន្លប់។ ដូចគ្នានេះផងដែរនេះនិយាយពីការភ័យខ្លាចថាជាការប្រឌិត។ ការបកប្រែរបៀបផ្សេងទៀត: «សម្រាប់មនុស្សគ្រប់គ្នានឹងមានការភ័យខ្លាច» (សូមមើល: និងfigs-metaphor)
អន់ខ្សោយ
«នឹងអន់ខ្សោយទៅ»
វិញ្ញាណទាំងអស់នឹងស្រយុតចុះ
នេះនិយាយពីមនុស្សដែលមានការភ័យខ្លាចនៅក្នុងស្មារតីរបស់ពួកគេហាក់ដូចជាវិញ្ញាណ[illegible] ការបកប្រែរបៀបផ្សេងទៀត: «មនុស្សគ្រប់គ្នានឹងមានការភ័យខ្លាចនៅក្នុងខ្លួនរបស់ពួកគេ»
ក្បាលជង្គង់ទាំងប៉ុន្មាននឹងទន់ដូចជាទឹក
«ជង្គង់ទាំងអស់នឹងខ្សោយដូចជាទឹក»
Ezekiel 21:8
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់បានថ្លែងព្រះបន្ទូលរបស់ទ្រង់»។ សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១: ១។
វានឹងសំលៀង ហើយខាត់ឲ្យភ្លឺផ្លេកផង
ការបកប្រែរបៀបផ្សេងទៀត: «សំលៀងវាឲ្យរលោង»។ ឃ្លានេះចង្អុលបង្ហាញថាដាវត្រៀមខ្លួនសម្រាប់នរណាម្នាក់ប្រើវា។
ខាត់ឲ្យភ្លឺ
មាននរណាម្នាក់ធ្វើឲ្យដាវភ្លឺរលោង
និងស្អាតដោយត្រដុសវាជាមួយសម្ភារៈសំរាប់ដុសខាត់។
Ezekiel 21:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលប្រកាសថ្លែងសារទៅកាន់ប្រជាជននៅក្រុងយេរូសាឡិម[illegible]
និងទឹកដីអ៊ីស្រាអែល។
វានឹងត្រូវបានសំលៀង ...វានឹងត្រូវបានប៉ូលាតាមលំដាប់លំដោយ
ទាំងនេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងសំលៀងវា...យើងនឹងខាត់វាដូច្នេះវានឹង»
ដើម្បីឲ្យភ្លឺដូចផ្លេកបន្ទោរ
នេះមានន័យថាដាវ នឹងភ្លឺរលោងខ្លាំងណាស់
ដែលពន្លឺឆ្លុះបញ្ចាំងពីវាយ៉ាងងាយស្រួល និងយ៉ាងភ្លឺ។ ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះវាបញ្ចេញពន្លឺដូចផ្លេកបន្ទោរ» ឬ «ដូច្នេះពន្លឺឆ្លុះបញ្ចាំងពីវាយ៉ាងភ្លឺដូចជាផ្លេកបន្ទោរ»
តើយើងគួរនឹងរីករាយជាមួយដំបងរបស់កូនទេ?
វោហានេះសង្កត់ធ្ងន់ថាប្រជាជនអ៊ីស្រាអែលនឹងមិនអបអរអំណាចរបស់ស្តេចរបស់ពួកគេឡើយ ព្រោះវាមិនអាចទប់ទល់នឹង «ដាវ» បានឡើយ។ ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៅស្រុកយូដានឹងមិនអបអរអំពីដំបងរាជ្យរបស់ស្តេចឡើយ»។ ឬ «យើងមិនគួរអបអរអំណាចនៃដំបងរបស់ស្តេចរបស់យើង»
តើយើងគួរ
ពាក្យថា «យើង» គឺសំដៅទៅលើលោកអេសេគាល និងប្រជាជនអ៊ីស្រាអែល
ជាដំបងរបស់កូនទេ
នៅទីនេះព្រះអម្ចាស់ចាត់ទុកស្តេចនៃស្រុកយូដាថាជាបុត្ររបស់គាត់។ ដំបងរាជ្យរបស់ស្តេចតំណាងការគ្រប់គ្រងរបស់ព្រះអង្គជាស្តេច។ វាមានសារៈសំខាន់ណាស់ក្នុងការថែរក្សារូបភាពនៃដំបងរបស់ស្តេចនៅទីនេះព្រោះវាជាងារ[illegible] ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងដំបងរបស់ស្តេច» ឬ «នៅក្នុងអំណាចដែលតំណាងដោយដំបងរបស់ស្តេច»
ដាវដ៏មុតនេះគឺវាស្អប់ពួកអ្នកដែលលួចប្លន់ខ្លាំងណាស់!
នៅទីនេះ «ដាវ»
ត្រូវបានបង្ហាញជាលក្ខណៈថាកំពុងចូលមកវាយប្រហារប្រជាជន។
និយាយពីស្តេចដែលមិនអាចទប់ទល់នឹង «ដាវ» ដូចជា «ដាវ»
ដែលស្អប់ដំបងរបស់ស្តេច។ ការបកប្រែរបៀបផ្សេងទៀត: «ដាវនឹងយកឈ្នះស្តេចរបស់គាត់ ដូចស្តេចដទៃទៀតដែរ» ឬ «ស្តេចនឹងមិនអាចទប់ទល់បាន
នៅពេលដាវត្រូវបានគេលើកមកប្រឆាំងនឹងគាត់»។
លួចប្លន់ខ្លាំង
ឃ្លានេះត្រូវបានប្រើដើម្បីចំអកដំបងរាជ្យដោយហៅវាថាជា «ដំបង»។ ការបកប្រែរបៀបផ្សេងទៀត: «ដំបងជាច្រើន»
ដាវនោះបានប្រគល់ឲ្យគេខាត់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងខាត់ដាវ»
ដើម្បីឲ្យបានកាន់នៅដៃជា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «បន្ទាប់មកមនុស្សត្រឹមត្រូវនឹងកាន់វានៅក្នុងដៃរបស់គាត់» (UDB)
ហើយប្រគល់ឲ្យទៅក្នុងដៃរបស់អ្នកប្រហារ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ឈ្លើយសឹកពួកគេនឹងត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការប្រើប្រាស់»
Ezekiel 21:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅប្រជាជននៅក្រុងយេរូសាឡិម និងទឹកដីរបស់អ៊ីស្រាអែល។
ពួកគេក៏ទាស់ជាមួយដាវនិងប្រជារាស្ត្រយើង
«ពួកគេត្រូវបានសម្លាប់ដោយដាវរួមជាមួយប្រជាជនរបស់យើង»
ប៉ុន្តែតើនឹងមានអ្វីកើតឡើងបើដំបងនោះមិននៅទៀតទេ?
ការបកប្រែរបៀបផ្សេងទៀត: «ហើយវានឹងមានការភ័យខ្លាចយ៉ាងខ្លាំង ប្រសិនបើដាវបំផ្លាញដំបង និងដំបងបាត់ទៅ»។
Ezekiel 21:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់។
រាជាដាវដែលធ្វើឲ្យមនុស្សជាច្រើនស្លាប់
ការបកប្រែរបៀបផ្សេងទៀត: «ដាវសំរាប់សំលាប់មនុស្ស»
ចាក់ទំលុះពួកគេ
ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជននៅក្រុងយេរូសាឡិម និងទឹកដីអ៊ីស្រាអែល។
Ezekiel 21:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅប្រជាជននៅក្រុងយេរូសាឡិម និងទឹកដីរបស់អ៊ីស្រាអែល។
ធ្វើឲ្យគេធ្លាក់ចុះកាន់តែខ្លាំង
ពាក្យថា «ធ្លាក់»
នៅទីនេះសំដៅទៅលើមនុស្សដែលត្រូវបានសម្លាប់នៅក្នុងសមរភូមិ។ ការបកប្រែរបៀបផ្សេងទៀត: «សម្លាប់មនុស្សជាច្រើនក្នុងចំណោមពួកគេ»
មាត់ទ្វារ
ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនរបស់ក្រុងយេរូសាឡិម។
[illegible]! កាប់ទៅខាងស្តាំ!...មុខបែរទៅខាងណាកាប់ទៅខាងនោះទៅ គឺដូចជាព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់ដាវដែរ។
មុខបែរទៅខាងណាកាប់ទៅខាងនោះទៅ
«គ្រប់ទីកន្លែងដែលខ្ញុំបានបង្វែរផ្លែដាវរបស់អ្នក»។
មុខរបស់អ្នក
ពាក្យថា «មុខ» នៅទីនេះតំណាងឲ្យគែមដាវ។
Ezekiel 21:18
ព្រះបន្ទូលនៃព្រះអម្ចាស់បានមក
«ព្រះអម្ចាស់បានថ្លែងព្រះបន្ទូលរបស់ទ្រង់»។ [illegible] សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។
កូនមនុស្សអើយ
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ២:១។
ដាវ
ការបកប្រែរបៀបផ្សេងទៀត: «ពលទ័ព»
Ezekiel 21:21
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់។
បើកម៉ាត់ឡើងបញ្ជា
ម៉ាស៊ីនធំៗ ដែលមនុស្សធ្លាប់រំលំជញ្ជាំង ឬ ប៉ម

generated on Wed Sep 10 16:16:32 2025

ចម្បាំងទាស់
«ប្រឆាំងទាស់ក្រុងយេរូសាឡិម»
ដើម្បីជីកទីលាន
នេះជាជង្គុកធំៗ
ដែលស្តេចស្រុកបាប៊ីឡូនបានសាងសង់ដើម្បីឲ្យទាហានរបស់គាត់ចូលទៅដល់កំពែងរបស់ក្រុងយេរូសាឡិម។
សង់បន្ទាយ
ទាំងនេះជាប៉មឈើដែលស្តេចស្រុកបាប៊ីឡូនបានសាងសង់នៅជុំវិញក្រុងយេរូសាឡិម ដើម្បីឲ្យទាហានបាប៊ីឡូនបាញ់ព្រួញមកលើកំពែងរបស់ក្រុងយេរូសាឡិម។
Ezekiel 21:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសារទៅប្រជាជនរបស់ក្រុងយេរូសាឡិម។
ពីព្រោះអ្នករាល់គ្នាបានរឭកអំពើទុច្ចរិតរបស់ខ្លួន ដោយបើកអំពើរំលង
«ពីព្រោះអ្នករំលឹកយើងពីកំហុសរបស់អ្នក»
បើកអំពើរំលងរបស់ខ្លួនឲ្យឃើញ! ហើយអំពើបាបរបស់អ្នកក៏បានឃើញច្បាស់ ក្នុងគ្រប់ការដែលអ្នកធ្វើ
«ដោយបង្ហាញការរំលងរបស់អ្នកអំពើបាបរបស់អ្នកនឹងត្រូវបានបង្ហាញយ៉ាងច្បាស់ដល់ភ្នែកអ្នក»
មូលហេតុនេះនឹងរំលឹកអ្នកឲ្យដឹងថា
«ដោយសារមូលហេតុនេះទើបមនុស្សគ្រប់គ្នានឹងយល់ថា»
ត្រូវចាប់ធ្វើជាឈ្លើយ ដោយដៃសត្រូវរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: ស្តេចស្រុកបាប៊ីឡូននឹងចាប់អ្នកយកទៅ»។
Ezekiel 21:25
ព័ត៌មានទូទៅ:
ព្រះអម្ចាស់អោយលោកអេសេគាលថ្លែងសារសាររបស់ទ្រង់ឲ្យទៅមេដឹកនាំអ៊ីស្រាអែល។
ថ្ងៃដែលជំនុំជម្រះបានមកដល់
ឃ្លានេះមានន័យថា «តើអ្នកណាដែលព្រះអម្ចាស់នឹងដាក់ទណ្ឌកម្ម»។
ពេលអ្នកដែលប្រព្រឹត្តអំពើទុច្ចរិតត្រូវបញ្ចាប់
«នៅពេលដែលព្រះអម្ចាស់បញ្ចប់អំពើទុច្ចរិត»
ឈ្នួត
ក្រណាត់ដ៏ស្រស់ស្អាតមួយដែលស្តេចពាក់លើក្បាលជានិមិត្តរូបនៃសិទ្ធិអំណាចរបស់ពួកគេ
បន្ទាបខ្លួនត្រូវគេលើកតម្កើង
«ហើយធ្វើអោយអ្នកដែលមានឋានៈទាប»
Ezekiel 21:26
កូនមនុស្សអើយ
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ២:១។
ដកចេញ
«គឺផុតពីស្រោមហើយ»
កាលព្យាការីមិនបានឃើញនិមិត្តសម្រាប់អ្នក
ពាក្យថា «អ្នក» គឺសំដៅទៅលើប្រជាជាតិអាំម៉ូន។
នៅក្នុងភាសាដើមវាជាឯកវចនៈនារី
ពីព្រោះប្រជាជាតិជាច្រើនត្រូវបានគេគិតថាជាស្ត្រី។ រឿងនេះបន្តតាមរយៈខ ៣២។ .
មិនបានឃើញនិមិត្ត
«និមិត្តដែលមិនពិត»
Ezekiel 21:30
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅប្រជាជនអាំម៉ូន។
ស្រោម
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ២១:១។
នៅកន្លែងដែលអ្នកកើត
«នៅកន្លែងដែលយើងបានបង្កើតអ្នករាល់គ្នា»
Ezekiel 21:32
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅប្រជាជនអាំម៉ូន។
អ្នកនឹងវិនាសនៅក្នុងភ្លើង
«ភ្លើងនឹងឆេះអ្នករាល់គ្នា»

---

22 [1]ក្រោយមក ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[2]«ពេលនេះកូនមនុស្សអើយ តើអ្នកនឹងដាក់ទោស? តើអ្នកនឹងដាក់ទោសទីក្រុងដែលពេញដោយឈាម? សូមប្រាប់ក្រុងនេះឲ្យដឹងពីសេចក្តីគួរខ្ពើមរបស់ខ្លួន។[3]អ្នកត្រូវនិយាយថា ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ទីក្រុងនេះបានបង្ហូរឈាមនៅកណ្តាលក្រុង ដូច្នោះពេលរបស់ក្រុងនេះជិតមកដល់ហើយ គឺជាក្រុងដែលធ្វើរូបព្រះ ធ្វើឲ្យក្រុងខ្លួនឯងទៅជាមិនស្អាត។
[4]អ្នកមានទោសដោយសារឈាមដែលអ្នកបានកម្ចាយទាំងនោះ ហើយក៏ស្មោកគ្រោកដោយរូបព្រះដែលអ្នកបានធ្វើ។ ដ្បិត អ្នកធ្វើឲ្យថ្ងៃកំណត់ជិតមកដល់ ហើយត់ឆ្នាំរបស់អ្នកក៏ជិតដែរ។ ដូច្នោះហើយ យើងធ្វើឲ្យអ្នកត្រឡប់ទៅទីត្មះដៀលដល់ជនជាតិ ទាំងនោះ ហើយជាទីចំអកឡកឡឺយដល់កន្លែងផ្សេងទៀត។[5]ពួកអ្នកដែលនៅជិត ហើយពួកអ្នកដែលនៅឆ្ងាយ គេនឹងចំអកឡកឡឺយឲ្យអ្នក អំពីទីក្រុងដែលស្មោកគ្រោក ជាមួយនឹងកេរ្តិ៍ឈ្មោះមិនល្អនៅគ្រប់ទីកន្លែង ហើយពេញទៅដោយការចលាចល។
[6]មើល! ពួកអ្នកដឹកនាំរបស់អ៊ីស្រាអែល អ្នកគ្រប់គ្នាបាននៅក្នុងអំណាចរៀងខ្លួន ដែលអ្នកបានយកវាមកកម្ចាយឈាម។[7]ពួកគេបានមើលងាយទាំងឪពុកម្តាយផងទាំងអ្នកផង ហើយពួកគេបានសង្កត់សង្កិន លើជនជាតិបរទេសនៅមុខអ្នក។ ពួកគេបានជិះជាន់ពួកកំព្រា និងស្ត្រីមេម៉ាយទាំងអ្នកដែរ។[8]អ្នកបានមើលងាយវត្ថុវិសុទ្ធរបស់យើង ហើយបានបង្អាប់ថ្ងៃសប្ប័ទរបស់យើងដែរ។[9]នៅក្នុងអ្នកមានមនុស្សដែលនិយាយបង្កាច់គេ ដើម្បីនឹងកម្ចាយឈាម ហើយពួកគេបានស៊ីនៅលើភ្នំ។ ពួកគេបានប្រព្រឹត្តការអាក្រក់ជាច្រើននៅចំពោះអ្នក។
[10]ភាពអាម៉ាស់របស់ឪពុកត្រូវបានបង្ហាញដោយសារអ្នក។ ពួកគេបានបំពានដល់ស្ត្រីដែលមិនទាន់ស្អាត កំឡុងពេលនាងកំពុងមករដូវ។[11]មនុស្សប្រុសបានប្រព្រឹត្តអំពើគួរស្អប់ខ្ពើមជាមួយប្រពន្ធរបស់អ្នកជិតខាងខ្លួន ហើយបុរសផ្សេងទៀត បានធ្វើឲ្យកូនប្រសារស្ត្រីខ្លួនមានសៅហ្មង ដោយការអាស្រូវបំផុត និងមនុស្សប្រុសបានបំពានលើកូនស្រីរបស់របស់ប្អូនស្ត្រីខ្លួន ជាកូនរបស់ឪពុកខ្លួន ការទាំងនេះនៅក្នុងចំណោមអ្នក។[12]មនុស្សប្រុសទាំងនេះ បានស៊ីសំណូកនៅក្នុងចំណោមអ្នក ដើម្បីកម្ចាយឈាម។ អ្នកបានយកការប្រាក់ ហើយមកចំណេញច្រើនពេក អ្នកបានបំផ្លាញអ្នកជិតខាងអ្នក តាមរយៈការសង្កត់សង្កិន ហើយអ្នកបំភ្លេចយើង នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល។
[13]មើល៍! ដៃរបស់យើងបានវាយការមិនត្រឹមត្រូវ ដែលអ្នកបានធ្វើ ហើយការកម្ចាយឈាមដែលនៅក្នុងចំណោមអ្នក។[14]តើចិត្តរបស់អ្នកអាចតតាំង តើដៃរបស់អ្នកមានកម្លាំងក្នុងថ្ងៃ ពេលយើងខ្លួនឯងដោះស្រាយជាមួយអ្នក? យើងព្រះអម្ចាស់ប្រកាសពីការនេះ ហើយយើងនឹងធ្វើវាដែរ។[15]ដូច្នោះយើងនឹងកម្ចាត់ កម្ចាយអ្នក ទៅក្នុងចំណោមជនជាតិជាច្រើន ហើយគេមើលងាយអ្នក ពេញផែនដី។ ក្នុងរបៀបនេះ យើងនឹងលុបបំបាត់ការមិនស្អាតរបស់អ្នកចេញពីអ្នក។
[16]ដូច្នោះអ្នកនឹងក្លាយមិនស្អាតនៅក្នុងភ្នែកនៃប្រជាជាតិទាំងមូល។ រួចហើយអ្នកនឹងដឹងថា យើងគឺជាព្រះអម្ចាស់»។
[17]ក្រោយមក ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[18]«កូនមនុស្សអើយ កូនចៅអ៊ីស្រាអែលបានត្រឡប់ជាគ្មានតម្លៃដល់យើងទេ។ ពួកគេសុទ្ធតែជាលង្ហិន ហើយស៊ីវិឡាត ដែក និងសំណនៅក្នុងចំណោមអ្នក។ ពួកគេដូចជាអាចម៍ប្រាក់នៅក្នុងឡរបស់អ្នក»។[19]ហេតុនោះ ព្រះអម្ចាស់ដ៏ជាព្រះ មានព្រះបន្ទូលដូច្នេះ «ដោយព្រោះអ្នករាល់គ្នាបានត្រឡប់ជាអាចម៍ប្រាក់ទាំងអស់គ្នាទៅហើយ ចូលមើល៍! យើងនឹងប្រមូលអ្នករាល់គ្នាទៅកណ្តាលក្រុងយេរូសាឡិម។
[20]ដូចជាគេប្រមូលប្រាក់ លង្ហិន ដែក សំណ និងស៊ីវិឡាត ដាក់ក្នុងឡ ដើម្បីសប់ភ្លើងរំលាយទៅដែរ គឺយ៉ាងនោះដែលយើងនឹងប្រមូលអ្នករាល់គ្នា ដោយសេចក្តីកំហឹង និងសេចក្តីឃោរឃៅរបស់យើង គឺយើងនឹងដាក់អ្នករាល់គ្នានៅទីនោះ ហើយចាក់អ្នកឲ្យចេញ។[21]ដូច្នេះ យើងនឹងប្រមូលអ្នក ហើយផ្លុំលើអ្នក ដោយភ្លើងនៃសេចក្តីក្រោធរបស់យើង នោះអ្នករាល់គ្នានឹងត្រូវរលាយទៅ នៅកណ្តាលទីក្រុង។[22]ដូចប្រាក់ត្រូវរលាយទៅក្នុងឡយ៉ាងណា នោះអ្នករាល់គ្នានឹងត្រូវរលាយទៅ នៅកណ្តាលនោះយ៉ាងនោះដែរ ដូច្នេះ អ្នករាល់គ្នានឹងដឹងថា យើង គឺជាព្រះអម្ចាស់ យើងបានចាក់សេចក្តីក្រោធរបស់យើងទៅលើអ្នករាល់គ្នា!»
[23]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[24]«កូនមនុស្សអើយ ចូរប្រាប់ដល់ទីក្រុងថា អ្នកជាទឹកដីដែលមិនបានជម្រះសម្អាតឡើយ។ ក៏គ្មានភ្លៀងធ្លាក់មកលើអ្នកក្នុងថ្ងៃសេចក្តីក្រោធ។[25]គមានការឃុបឃិត របស់ពួកព្យាការីរបស់វានៅកណ្តាលក្រុង ដូចជាសិង្ហដែលគ្រហឹមកំពុងហែករំពាស៊ី។ ពួកគេបានត្របាក់លេបជីវិតមនុស្ស គេយកទ្រព្យសម្បត្តិ និងរបស់មានតម្លៃទៅ ហើយគេធ្វើឲ្យមានពួកស្ត្រីមេម៉ាយជាច្រើននៅកណ្តាលទីក្រុង!
[26]ពួកបូជាចារ្យក៏បានធ្វើទទឹងនឹងក្រឹត្យវិន័យរបស់យើង ព្រមទាំងបង្អាប់របស់បរិសុទ្ធទាំងប៉ុន្មានរបស់យើង គេមិនបានចេះញែករបស់បរិសុទ្ធចេញពីរបស់ធម្មតាទេ ក៏មិនបានបង្ហាញឲ្យមនុស្សចេះសម្គាល់របស់មិនស្អាត និងរបស់ស្អាតដែរ គេគេចភ្នែកចេញពីថ្ងៃសប្ប័ទរបស់យើង ហើយយើងក៏ត្រូវអាប់ឱននៅក្នុងពួកគេ។[27]ពួកអ្នកដឹកនាំនៅ

generated on Wed Sep 10 16:16:32 2025

កណ្ដាលទីក្រុងប្រព្រឹត្តដូចជាសត្វស្វាន ដែលកំពុងហែករំពា គេប្រព្រឹត្តដូច្នោះ ដើម្បីនឹងកម្ចាយឈាម ហើយបំផ្លាញព្រលឹងមនុស្ស ប្រយោជន៍ឲ្យបានកម្រៃទុច្ចរិត។[28]ពួកព្យាការីបានបូកឈ្មាប់ឲ្យគេ ដោយឃើញនិមិត្តជាសេចក្ដីកំភូត។ ហើយថ្លែងទំនាយកុហកដល់គេថា «ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ» ក្នុងកាលដែលព្រះអម្ចាស់មិនបានមានព្រះបន្ទូលសោះ។
[29]មនុស្សនៅលើទឹកដីធ្លាប់សង្កត់សង្កិន ហើយប្លន់ គេបៀតបៀនមនុស្សក្រីក្រ និងពួកកម្សត់ទុគ៌ត ហើយបានសង្កត់សង្កិនមនុស្ស ដែលស្នាក់នៅ ដោយគ្មានយុត្តិធម៌។
[30]ដូច្នេះយើងបានស្វែងរកមនុស្សម្នាក់ក្នុងពួកគេ ដែលនឹងសង់កំផែង ហើយឈរនៅចន្លោះបាក់បែកនៅមុខយើងជំនួសគេ ដើម្បីឲ្យយើងមិនបំផ្លាញទឹកដីគេឡើយ ប៉ុន្តែយើងរកមិនបានអ្នកណាមួយសោះ។[31]ដូច្នោះហើយ បានជាយើងចាក់សេចក្ដីគ្នាន់ក្នាញ់របស់យើងទៅលើពួកគេ។ យើងបានរំលីងគេ ដោយភ្លើងនៃសេចក្ដីក្រោធរបស់យើង ក៏បានទម្លាក់ផ្លូវរបស់គេទៅលើក្បាលគេវិញ» នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 22:1

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១

ពេលនេះកូនមនុស្សអើយ តើអ្នកនឹងដាក់ទោស? តើអ្នកនឹងដាក់ទោសទីក្រុងដែលពេញដោយឈាម?

ការបកប្រែរបៀបផ្សេងទៀត: «កូនមនុស្សអើយចូរទៅវិនិច្ឆ័យ ហើយទៅវិនិច្ឆ័យក្រុងឈាម»។

ទីក្រុងដែលពេញដោយឈាម

ព្រះអម្ចាស់ចាត់ទុកក្រុងយេរូសាឡិមជាទីក្រុងឈាម។ នេះសំដៅទៅលើឃាតកម្ម និងអំពើហិង្សាដែលកើតឡើងនៅក្រុងយេរូសាឡិម។

នាង...ខ្លួននាង

ពាក្យថា «នាង» សំដៅទៅលើក្រុងយេរូសាឡិម។ ទីក្រុងជាច្រើនត្រូវបានគេគិតថាជាស្ត្រី។ រឿងនេះបន្តតាមរយៈខ ៣២។ ។

Ezekiel 22:4

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូលតាមរយៈលោកអេសេគាលទៅកាន់ប្រជាជនយេរូសាឡិម

អ្នកធ្វើឲ្យថ្ងៃកំណត់ជិតមកដល់ ហើយឆ្នាំរបស់អ្នកក៏ជិតដែរ

ឃ្លាទាំងពីរនេះមានន័យថាពេលវេលាដែលព្រះអម្ចាស់នឹងដាក់ទោសក្រុងយេរូសាឡិមគឺជិតមកដល់ហើយ

ពេញទៅដោយការចលាចល

មនុស្សជាច្រើននៅក្រុងយេរូសាឡិមយល់ច្រឡំ

Ezekiel 22:6

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលអំពីមេដឹកនាំអ៊ីស្រាអែលនៅក្រុងយេរូសាឡិម។

មើល

ការបកប្រែរបៀបផ្សេងទៀត: «មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក»។

មករកអ្នក...នៅចំពោះអ្នក

ពាក្យថា «អ្នក» និង «របស់អ្នក» សំដៅទៅលើក្រុងយេរូសាឡិម។

ពួកគេបានស៊ីនៅលើភ្នំ

ពាក្យថា «ភ្នំ» នៅទីនេះសំដៅទៅលើអាសនៈរូបព្រះដែលមាននៅលើភ្នំ។ ពួកគេបរិភោគសាច់ដែលបានបូជាដល់រូបព្រះ ដើម្បីទទួលបានពរពីព្រះមិនពិត។

ពួកគេបានប្រព្រឹត្តការអាក្រក់ជាច្រើននៅចំពោះអ្នក

នេះមានន័យថាពួកគេធ្វើអំពើអាក្រក់នៅខាងក្នុងក្រុងយេរូសាឡិម។

Ezekiel 22:10

ព័ត៌មានទូទៅ:

ព្រះជាម្ចាស់បន្តមានព្រះបន្ទូលតាមរយៈលោកអេសេគាលអំពីការដ៏អាក្រក់ដែលប្រជាជនយេរូសាឡិមបានធ្វើ

អ្នក...ពួកគេ

សព្វនាមទាំងនេះសំដៅទៅលើក្រុងយេរូសាឡិម (ប្រជាជននៅក្រុងយេរូសាឡិម)។

ភាពអាម៉ាស់របស់ឪពុកត្រូវបានបង្ហាញ

នេះជាភរិយារបស់ឪពុក។

វាជាភាពអាក្រាតដែលមានអត្ថន័យសម្រាប់គាត់ក្នុងការមើលឃើញ។

រំលោភបំពាន ... ធ្វើអំពើគួរស្អប់ខ្ពើមជាមួយ...បានធ្វើឲ្យកូនប្រសារស្រីខ្លួនមានសៅហ្មង ដោយការអាស្រូវបំផុត

តាមច្បាប់ ភាពមិនស្អាតស្មំ

គឺគួរឲ្យខ្មាស់អៀនទាំងនេះគឺជាវិធីទាំងអស់ដើម្បីបង្ហាញថាបុរសបានរួមដំណេកជាមួយ

ការប្រាក់

ពាក្យនេះសំដៅទៅលើប្រាក់ដែលមនុស្សម្នាក់បង់ដើម្បីប្រើប្រាស់ប្រាក់កម្ចី។ ទោះយ៉ាងណាក៏ដោយកំណែទំនើបមួយចំនួនបានបកប្រែ «ចំណាប់អារម្មណ៍» នៅក្នុងអត្ថបទនេះថា «ការប្រាក់ខ្ពស់ខ្លាំងពេក»។

អ្នកបំភ្លេចយើង

ការបដិសេធមិនស្តាប់បង្គាប់ព្រះអម្ចាស់គឺដូចជាភ្លេចថាខ្លួនពិតជាមានមែន។

Ezekiel 22:13

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ប្រជាជននៅក្រុងយេរូសាឡិមដោយផ្ទាល់ ក៏ដូចជាទីក្រុងយេរូសាឡិម។

យើងបានវាយការមិនត្រឹមត្រូវ... កម្ចាយឈាម

ពាក្យថា «វាយ» សំដៅទៅលើព្រះអម្ចាស់ចាត់វិធានការប្រឆាំងនឹងរឿងទាំងនោះ។

តើចិត្តរបស់អ្នកអាចតតាំង តើដៃរបស់អ្នកមានកម្លាំងក្នុងថ្ងៃ ពេលយើង ខ្លួនឯងដោះស្រាយជាមួយអ្នក?

«បេះដូងរបស់អ្នកនឹងមិនឈរ ដៃរបស់អ្នកនឹងមិនរឹងមាំនៅថ្ងៃដែលយើងនឹងដោះស្រាយជាមួយអ្នកឡើយ»។

យើងនឹងកម្ចាត់កម្ចាយអ្នក ទៅក្នុងចំណោមជនជាតិជាច្រើន ហើយគេមើលងាយអ្នកពេញផែនដី

សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ១២:១៤។

លុបបំបាត់

លុបចោលនូវអ្វីដែលមិនចង់បាន។

ក្នុងភ្នែកនៃប្រជាជាតិទាំងមូល

«នៅក្នុងគំនិតរបស់ប្រជាជននៅក្នុងប្រជាជាតិផ្សេងទៀត»

Ezekiel 22:17

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង ១: ១។

អាចម៍

ការបកប្រែរបៀបផ្សេងទៀត: «គ្មានតម្លៃ»

ពួកគេសុទ្ធតែជាលង្ហិន ហើយស៊ីវិឡាត ដែក និងសំណនៅក្នុងចំណោមអ្នក

ការបកប្រែរបៀបផ្សេងទៀត: «មនុស្សទាំងអស់ដែលនៅជុំវិញអ្នកគ្មានតំលៃ»

Ezekiel 22:20

ព័ត៌មានទូទៅ:

ព្រះអង្គនៅតែបន្តពិពណ៌នាអំពីការដាក់ទណ្ឌកម្មចំពោះប្រជាជន

ប្រសិនបើអ៊ីស្រាអែលនៅក្រុងយេរូសាឡិមដូចជាលោហធាតុត្រូវបានរលាយ និងបន្សុទ្ធនៅក្នុងឡ។

ខ្ញុំនិងរំលាយអ្នក

ការដាក់ទណ្ឌកម្មរបស់ព្រះអង្គ

ត្រូវបានគេហៅថាភ្លើងនៅក្នុងឡដែលនឹងធ្វើឲ្យទីក្រុងយេរូសាឡិមដូចជាឡដែលបំបែកវត្ថុធាតុដើមដែលមិ

Ezekiel 22:23

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលទៅលោកអេសេគាលឲ្យទៅនិយាយប្រាប់ក្រុងយេរូសាឡិម។

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង ១: ១។

ក៏គ្មានភ្លៀងធ្លាក់មកលើអ្នក ក្នុងថ្ងៃសេចក្ដីក្រោធ

ភ្លៀងត្រូវបានប្រើជាឧទាហរណ៍នៃព្រះពររបស់ព្រះ។ ការបកប្រែរបៀបផ្សេងទៀត: «នឹងគ្មានព្រះពរទេនៅថ្ងៃដែលមានកំហឹង»

ការឃុបឃិត

ផែនការសម្ងាត់បង្កើតឡើងដោយមនុស្សពីរនាក់ឬច្រើននាក់ដើម្បីធ្វើអ្វីមួយដែលមានគ្រោះថ្នាក់

ពួកគេមិនគួរមាននិងថាតើទង្វើរបស់ពួកគេមានបាបយ៉ាងណា។

Ezekiel 22:26

នាង

សព្វនាមនេះសំដៅទៅលើក្រុងយេរូសាឡិម។

ដើម្បីនឹងកម្ចាយឈាម ហើយបំផ្លាញព្រលឹងមនុស្ស

generated on Wed Sep 10 16:16:32 2025

ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នាជាមូលដ្ឋានហើយសង្កត់ធ្ងន់ទៅលើអំពើហឹង្សាដែលមើលឃើញ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេសម្លាប់មនុស្ស»

Ezekiel 22:30

ព័ត៌មានទូទៅ:

ព្រះអម្ចាស់ប្រៀបធៀបពួកមេដឹកនាំក្រុងយេរូសាឡឹមទៅនឹងកំផែងមួយ និងខ្លួនគាត់ផ្ទាល់ទៅនឹងកងទ័ពដែលលុកលុយ។

មនុស្សម្នាក់ក្នុងពួកគេ ដែលនឹងសង់កំផែង

មេដឹកនាំដែលដាក់ខ្លួនគេរវាងព្រះអម្ចាស់ និងប្រជាជនដោយមានទំនួលខុសត្រូវដឹកនាំពួកគេឲ្យវិលត្រឡប់ទៅរកភាពសុចរិតវិញ។ ការបកប្រែរបៀបផ្សេងទៀត: «បុរសម្នាក់មកពីពួកគេដែលនឹងធ្វើដូចជញ្ជាំង»

ឈរនៅចន្លោះបាក់បែក

ដើម្បីកុំឲ្យក្រុងត្រូវបំផ្លាញ ខ្ញុំបានស្វែងរកមនុស្សម្នាក់ ដែលអាចឈរនៅចន្លោះជញ្ជាំងដែលបាក់ និងការពារក្រុងកុំឲ្យត្រូវបំផ្លាញ ប៉ុន្តែខ្ញុំមិនបានរកឃើញអ្នកណាម្នាក់ឡើយ។

មេដឹកនាំការពារប្រជាជនអ៊ីស្រាអែលប្រៀបបានទៅនឹងអ្នកចម្បាំងការពារទីក្រុងក្នុងសមរភូមិ។

យើងចាក់សេចក្ដីគ្នាន់ក្នាញ់របស់យើងទៅលើពួកគេ

ការវិនិច្ឆ័យដែលអាចចាក់ស្រោចដូចជាទឹកចេញពីចាន។

ភ្លើងនៃសេចក្ដីគ្នាន់ក្នាញ់

ការវិនិច្ឆ័យរបស់ព្រះជាម្ចាស់គឺដូចជាភ្លើងពីព្រោះវាខ្លាំងណាស់។

ទម្លាក់ផ្លូវរបស់គេទៅលើក្បាលគេវិញ

ការដាក់អ្វីមួយនៅលើក្បាលរបស់មនុស្សសំដៅទៅលើការធ្វើឲ្យពួកគេកាន់វា ឬទទួលខុសត្រូវចំពោះវា។ ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យពួកគេទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានធ្វើ»

---

23 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ គឺមានស្ត្រីពីរនាក់ដែលជាកូនស្រីកើតចេញពីម្តាយតែមួយ។[3]ពួកគេបានធ្វើពេស្យា នៅទឹកដីអេស៊ីប កាលពីពេលដែលពួកគេនៅវ័យក្មេង។ គឺពួកគេធ្វើជាពេស្យានៅទឹកដីនោះ។ ដោះរបស់គេបានអង្អែលតាំងពីវ័យក្រមុំមក។[4]ឈ្មោះរបស់ពួកគេ គឺឈ្មោះថា អូហូឡា ជាបងស្រី ហើយឈ្មោះអូហូលីបា គឺជាប្អូនស្រី។ រួចហើយពួកគេក៏ត្រឡប់ជារបស់យើង ហើយបង្កើតបានកូនប្រុស និងកូនស្រី។ ឈ្មោះពួកគេមានន័យ បែរនេះ អូហូឡា មានន័យថាសាម៉ារី ហើយអូហូលីបា មានន័យ ថាយេរូសាឡិម។

[5]ប៉ុន្តែអូហូឡា នាងប្រព្រឹត្តដូចជាពេស្យា ទោះបីកាលនាងជារបស់យើង នាងជាប់ចិត្តនឹងសហាយនាង ដ្បិតជនជាតិអាស្ស៊ីរី ដែលជាកងទ័ព[6]ពួកមន្ត្រីដែលស្លៀកពាក់ដោយសំពត់ពណ៌ខៀវ សុទ្ធតែជាអ្នកដឹកនាំ ហើយជាអ្នកមានកម្លាំង ហើយសង្ហារពួកគេក៏ជិះសេះគ្រប់គ្នា។[7]ដូច្នេះ នាងបានឲ្យដូចជាពេស្យានឹងពួកគេ ដែលសុទ្ធតែជាមនុស្សជ្រើសរើសក្នុងជនជាតិអាស្ស៊ីរី ហើយវាក៏ធ្វើឲ្យខ្លួនទៅជាស្មោកគ្រោក នាងមានតណ្ហាជាមួយគ្រប់គ្នា ហើយនឹងជាមួយរូបព្រះរបស់គេផង។

[8]ដ្បិត នាងមិនបានលះចោលការធ្វើពេស្យា ដែលធ្លាប់ប្រព្រឹត្តក្នុងទឹកដីអេស៊ីបទេ កាលពួកគេដេកជាមួយនាងគឺតាំងតែនាងក្មេង ហើយបានអង្អែលដោះនៃវ័យក្រមុំរបស់នាង ជាពេលដែលពួកគេចាក់ការកំផិតរបស់គេប្រព្រឹត្តលើនាង។[9]ហេតុនោះ យើងបានប្រគល់នាងទៅក្នុងកណ្តាប់ដៃនៃពួកសហាយរបស់នាង គឺក្នុងកណ្តាប់ដៃនៃពួកជនជាតិអាស្ស៊ីរី ដែលនាងមានតណ្ហាជាមួយ។[10]ពួកគេបានបើកកេរ្តិ៍ខ្មាសរបស់នាង។ ហើយចាប់យកកូនប្រុសកូនស្រីរបស់នាង ហើយពួកគេសម្លាប់នាងដោយដាវ ហើយនាងការអាម៉ាស់នៅក្នុងពួកជំណោមស្ត្រីៗ ដូច្នេះគេបានដាក់ទោសដល់នាង។

[11]អូហូលីបា ដែលជាប្អូននាង ក៏ឃើញដូការនេះ ប៉ុន្តែនាងមានតណ្ហាកាមគុណ ហើយបានប្រព្រឹត្តដូចជាស្រីពេស្យា គឺខ្លាំងជាងបងស្រីរបស់នាងទៀត។

[12]នាងមានតណ្ហាជាមួយពួកជនជាតិអាស្ស៊ីរីដែលជាមន្ត្រី ហើយពួកអ្នកគ្រប់គ្រងដែលសំខាន់ ហើយស្លៀកពាក់មានការទាក់ទាញ ពួកបុរសទាំងនោះគឺជិះសេះ។ ពួកគេមានកម្លាំងហើយនឹងសង្ហារផង។[13]យើងបានឃើញនាងបានធ្វើខ្លួនឯងស្មោកគ្រោក។ ពីរនាក់បងប្អូនគឺអ្រាកក់ដូចគ្នា។

[14]ប៉ុន្តែ នាងបានចម្រើនអំពើពេស្យារបស់ខ្លួនកាន់តែច្រើន។ នាងបានឃើញរូបមនុស្សដែលបានគូរនៅជញ្ជាំង គឺជារូបពួកជនជាតិខាល់ដេ ដែលគូរដោយពណ៌ក្រហម[15]មានពាក់ទាំងខ្សែក្រវាត់នៅចង្កេះ ហើយជាមួយឈ្នួតមានរំភាយសំយុងនៅលើក្បាល។ គ្រប់គ្នាមើលទៅដូចជាមន្ត្រីនៃទ័ពសេះ ហើយដូចជាកូនចៅស្តេចក្រុងបាប៊ីឡូន ជាអ្នកស្រុកខាល់ដេ។

[16]កាលណានាងបានឃើញពួកគេ មានតណ្ហាលើពួកគេដូច្នោះនាងបានបញ្ជូនសារទៅរកពួកគេ ក្នុងទឹកដីខាល់ដេ។[17]ក្រោយមក ពួកក្រុងបាប៊ីឡូនក៏មករកនាងហើយបានរួមដំណេកនៅលើគ្រែណ្តារបស់នាង ហើយពួកគេក៏ធ្វើឲ្យនាងទៅជាស្មោកគ្រោកដោយការកំផិតរបស់គេ។ តាមការដែលនាងបានធ្វើ គឺនាងបានសៅហ្មងដោយសារ ដូច្នោះនាងក៏បែរខ្លួននាងចេញពីពួកគេក្នុងការគួរខ្ពើម។

[18]នាងបានបើកបង្ហាញអំពើកំផិតរបស់នាង ហើយបើកបង្ហាញកេរ្តិ៍ខ្មាសរបស់នាងឲ្យគេឃើញ ដូច្នេះចិត្តយើងក៏ជិនណាយចេញពីនាងដែរ ក៏ដូចដែលយើងធ្លាប់បានជិនណាយជាមួយបងនាងដែរ។[19]ក្រោយមក នាងកាន់តែធ្វើការពេស្យារបស់នាងច្រើនឡើងទៀត ដោយរំលឹកកាលពីនៅក្មេងនៅឡើយ ហើយជាពេលដែលនាងបានធ្វើជាពេស្យានៅក្នុងទឹកដីអេស៊ីបនោះ។

[20]ដូច្នេះ នាងបានជាប់ចិត្តតណ្ហាជាមួយគូរស្នេហ៍របស់នាង ដែលមានប្រដាប់ភេទដូចជាសត្វលា ហើយទឹកកាមក៏ដូចជាទឹកកាមរបស់សេះ។[21]នេះគឺជាអ្វី ដែលអ្នកចង់ប្រព្រឹត្តតាមកាមតណ្ហាវ័យក្មេងរបស់អ្នក កាលពួកអេស៊ីបបានប៉ះពាល់ដើមទ្រូងរបស់អ្នក ហើយច្របាច់ដោះវ័យក្រមុំរបស់អ្នក។

[22]ហេតុនោះហើយ អូហូលីបាអើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល៍! យើងនឹងធ្វើឲ្យគូស្នេហ៍របស់អ្នកស្អប់អ្នក។ យើងនឹងនាំឲ្យគេមកទាស់នឹងអ្នកនៅគ្រប់ផ្លូវរបស់អ្នក[23]គឺជាពួកក្រុងបាប៊ីឡូន ពួកខាល់ដេទាំងនោះ ពួកពេកូឌ ពួកសូអា និងពួកកូអា ព្រមទាំងពួកអាស្ស៊ីរីផងដែរ និងពួកកំលោះសង្ហា ជាអ្នកដឹកនាំនិងពួកអ្នកគ្រប់គ្រងទាំងអស់គ្នា ព្រមទាំងពួកមន្ត្រី និងមនុស្សល្បីឈ្មោះ គ្រប់គ្នាសុទ្ធតែជិះសេះទាំងអស់។

[24]ពួកគេនឹងលើកគ្នាមកទាស់នឹងអ្នក ដោយមានគ្រឿងសស្ត្រាវុធ រទេះ និងយន្តចម្បាំង ព្រមទាំងនាំកងទ័ពមកជាច្រើន ពួកទាំងនោះនឹងតម្រៀបគ្នានៅជុំវិញអ្នក ទាំងកាន់ខែលធំខែលតូច និងពាក់មួកសឹកផង។ យើងនឹងប្រគល់ការជំនុំជម្រះដល់គេ គេនឹងជំនុំជម្រះអ្នកតាមច្បាប់របស់ពួកគេ។[25]ដ្បិតយើងនឹងតាំងសេចក្ដីប្រចណ្ឌរបស់យើងទាស់នឹងអ្នក ហើយគេនឹងប្រព្រឹត្តនឹងអ្នក ដោយសេចក្ដីឃោរឃៅ គេនឹងកាត់ច្រមុះ កាត់ត្រចៀកអ្នក ហើយសំណល់របស់អ្នកនឹងដួលដោយដាវ គេនឹងចាប់យកកូនប្រុសកូនស្រីរបស់អ្នកទៅ ពួកអ្នកដែលនៅសល់ នឹងត្រូវភ្លើងស៊ីបំផ្លាញទាំងអស់។

[26]ពួកគេនឹងបកយកសម្លៀកបំពាក់អ្នក ហើយយកគ្រឿង អលង្ការរបស់អ្នកទៅដែរ។[27]ដូច្នោះយើងនឹងលុបចោលការអាម៉ាស់របស់អ្នក ព្រមទាំងការពេស្យារបស់អ្នក ដែលវាបានជាប់នឹងអ្នកពីអេស៊ីបមក។ ភ្នែករបស់អ្នកមិនបាច់មើលពួកគេ ហើយរង់ចាំពាក្យគេ និងមិនបាច់គិតពីអ្វីដែលបានកើតនៅអេសីុបទៀតដែរ។

[28]ដ្បិតព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល៍! យើងនឹងប្រគល់អ្នកទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលអ្នកស្អប់ គឺទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលចិត្តអ្នកបានណាយចេញពីគេនោះ។[29]ពួកគេនឹងប្រព្រឹត្តចំពោះអ្នកដោយចិត្តស្អប់ គេនឹងដកយកអស់ទាំងផលរបស់អ្នកទៅ ទុកឲ្យអ្នកគ្មានសំលៀកបំពាក់ ហើយនៅកណ្តាលវាល។ ការអាក្រាតនៃអាម៉ាស់គឺជាការកំផិតរបស់អ្នកនឹងបានបើកនៅចំហ ហើយការអាស្រូវ និងការពេស្យារបស់អ្នកផង។

[30]ការទាំងនេះនឹងត្រូវធ្វើដល់អ្នក ក្នុងការប្រព្រឹត្តដូចជាបេស្យាហើយតណ្ហាសម្រាប់ជនជាតិដទៃ ដោយធ្វើឲ្យខ្លួនស្មោក គ្រោកដោយរូបព្រះរបស់គេ។[31]អ្នកបានដើរតាមកិរិយារបស់បងស្រីអ្នក ដូច្នេះយើងនឹងដាក់ពែងនៃការជំនុំជម្រះនៅក្នុងទឹកដៃរបស់អ្នក។

[32]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ អ្នកនឹងត្រូវផឹកពីពែងរបស់បងស្រីអ្នក ជាពែងយ៉ាងជ្រៅហើយធំ។ អ្នកនឹងត្រូវបានគេសើចឡកឡឺយ ហើយទុកសម្រាប់ជាការមើលងាយ ពែងនោះដាក់បានចំណុះជាច្រើន។

[33]អ្នកនឹងបានពេញដោយការស្រវឹង ហើយទុក្ខព្រួយ គឺជាពែងនៃសេចក្ដីភ័យខ្លាច ហើយខ្លោចផ្សា! ជាពែងរបស់សាម៉ារីបងស្រីអ្នក។[34]អ្នកនឹងត្រូវផឹកពីពែងនោះ ព្រមទាំងសម្រេងផង រួចនឹងកកេរបំណែក ហើយហែកដោះអ្នកទៅ ដ្បិតយើងនេះបានចេញវាចាហើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។

[35]ដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដោយព្រោះអ្នកបានភ្លេចយើង ហើយបោះចោលយើងទៅពីក្រោយខ្នងអ្នក ដូច្នេះនោះអ្នកត្រូវរងទ្រាំនឹងអំពើអាស្រូវគ្រប់បែបយ៉ាង និងការកំផិតរបស់អ្នក»។

generated on Wed Sep 10 16:16:32 2025

[36]ព្រះអម្ចាស់មានព្រះបន្ទូលនឹងខ្ញុំ «កូនមនុស្សអើយ តើអ្នកនឹងជំនុំជម្រះអូហូឡា និងអូហូលីបាទេ? បើដូច្នេះ ចូររំលឹកឲ្យនាងដឹងពីអំពើគួរស្អប់ខ្ពើមរបស់នាង។
[37]ចាប់តាំងពីពួកនាងប្រព្រឹត្តសេចក្តីកំផិត ហើយចាប់តាំងមានឈាមប្រឡាក់នៅដៃពួកគេ។ ពួកគេបានកំផិតជាមួយរូបព្រះរបស់ខ្លួន ហើយបានយកកូនដាក់ទៅក្នុងភ្លើង ជាអាហារដល់រូបព្រះទាំងនោះរបស់ខ្លួន។
[38]រួចហើយ ពួកនាងបានបន្តធ្វើការនេះដល់យើង ពួកគេធ្វើឲ្យទីបរិសុទ្ធរបស់យើងស្មោកគ្រោក ហើយនៅថ្ងៃមួយពួកគេបង្អាប់ថ្ងៃសប្ប័ទរបស់យើង។[39]ដ្បិតពេលពួកគេបានសម្លាប់កូនរបស់ខ្លួន ថ្វាយដល់រូបព្រះទាំងនោះ រួចហើយពួកនាងក៏ចូលក្នុងទីបរិសុទ្ធរបស់យើងដើម្បីនឹងបង្អាប់ទីនោះ! ដូច្នោះ មើល៍! នេះគឺជាអ្វីដែលពួកនាងបានធ្វើ នៅកណ្តាលដំណាក់របស់យើង។
[40]អ្នកបានចាត់ឲ្យទៅរកមនុស្សមកពីទីឆ្ងាយ ទៅដល់ពួកអ្នកដែលបានចាត់ទូតឲ្យទៅហៅពេលនេះចូរមើល៍។ ពួកគេក៏មក អ្នកបានងូតទឹកគេ ផាត់រង្វង់ភ្នែក ហើយតែងខ្លួនដោយគ្រឿងអលង្ការ សម្រាប់ទទួលគេ។[41]អ្នកបានអង្គុយលើគ្រែដ៏ស្អាត មានតុរៀបជាស្រេចនៅពីមុខ អ្នកបានដាក់កំញានិងប្រេងរបស់យើងនៅលើតុនោះ។
[42]ដូច្នោះ មានឮសូរសំឡេងរបស់មនុស្សយ៉ាងសន្ធឹក ដែលនៅជុំវិញនាង រួមបញ្ចូលមនុស្សគ្រប់ប្រភេទ ទោះបីសេបា បាននាំមកពីទីរហោស្ថាន ហើយពួកគេបានបំពាក់កងនៅដៃពួកនាង ហើយមុកដ៏ស្រស់ស្អាតនៅលើក្បាលរបស់នាង។
[43]ក្រោយមកខ្ញុំបានប្រាប់ អំពីនាងដែលបានកើតមកសេចក្តីកំផិត ឥឡូវនេះ ពួកគេនឹងរួមភេទជាមួយនឹងនាង ហើយនាងនៅជាមួយពួកគេ។[44]ពួកគេក៏ចូលទៅរកនាង ហើយដេកជាមួយនាង ដូចមនុស្សប្រុសទៅរកស្រីពេស្យា។ ក្នុងរបៀបដែលគេដេកជាមួយ អូហូឡានិងអូហូលីបា ជាស្រីអសីលធម៌។[45]ប៉ុន្តែ នឹងមានមនុស្សសុចរិតជំនុំជម្រះនាងទាំងពីរ តាមមាត្រាច្បាប់ដែលត្រូវខាងស្រីកំផិត ហើយតាមមាត្រាច្បាប់ត្រូវខាងស្រីដែលកម្ចាយឈាម ពីព្រោះនាងទាំងពីរជាស្រីកំផិត ហើយដៃគេក៏ប្រឡាក់ដោយឈាមផង។
[46]ដូច្នោះ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ យើងនឹងលើើមនុស្សមួយពួកឡើងមកទាស់នឹងនាង ហើយនឹងប្រគល់ពួកគេនូវការភ័យខ្លាយហើយការលួចប្លន់។
[47]ក្រោយមក ពួកមនុស្សទាំងនោះនឹងយកថ្មគប់នាង ហើយថ្មដែលបានកាត់ដោយដាវរបស់ពួកគេ។ ពួកគេនឹងសម្លាប់កូនប្រុសកូនស្រីរបស់នាង ហើយដុតផ្ទះនាងចោល។
[48]ដ្បិតយើងនឹងលុបចោលការប្រព្រឹតអាស្រូវចេញពីទឹកដី នឹងបង្រៀនពួកស្រីៗ កុំឲ្យប្រព្រឹត្តតាមការអាស្រូវដែលជារបស់នាងទៀតទេ។[49]ដូច្នេះ ពួកគេនឹងសងការអាស្រូវរបស់អ្នកទៅលើអ្នកវិញ។ ហើយនាងនឹងត្រូវរងទោសនៃបាបរបស់អ្នកការគោរពដល់រូបព្រះរបស់អ្នក។ ហើយរបៀបនេះអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 23:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់ប្រាប់លោកអេសេគាលរឿងមួយអំពីនារីវ័យក្មេងពីរនាក់នៅអេស៊ីប ដើម្បីបង្ហាញពីទស្សនៈរបស់គាត់ចំពោះអាកប្បកិរិយារបស់ប្រជាជនអ៊ីស្រាអែល។
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។
ដោះរបស់គេបានអង្អែល
ការបកប្រែរបៀបផ្សេងទៀត: «បុរសច្របាច់ដើមទ្រូង»។
ក្បាលដោះព្រហ្មចារីរបស់ពួកគេត្រូវបានគេស្ទាបអង្អែល
ឃ្លានេះមានអត្ថន័យដូចគ្នានឹងឃ្លាមុនហើយសង្កត់ធ្ងន់ទៅលើអាកប្បកិរិយាអសីលធម៌របស់ស្ត្រីវ័យក្មេងទាំងពីរ។
ការបកប្រែរបៀបផ្សេងទៀត:
«នៅទីនោះបុរសចូលចិត្តក្បាលដោះព្រហ្មចារីរបស់ពួកគេ»។
អង្អែល
ត្រូវបានប៉ះពាល់ដោយក្តីស្រឡាញ់ ឬ ទន់ភ្លន់
អូហូឡា
នេះគឺជាឈ្មោះស្រីដែលមានន័យថា «តង់របស់នាង»។
អូហូលីបា
នេះគឺជាឈ្មោះស្រីដែលមានន័យថា «តង់របស់យើងស្ថិតនៅក្នុងនាង»។
Ezekiel 23:5
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តប្រាប់រឿងដល់លោកអេសេគាលអំពីប្រពន្ធដែលមិនស្មោះត្រង់របស់គាត់អូហូឡានិងអូហូលីបា។
ជាកងទ័ព
«ក្នុងការគ្រប់គ្រង»
ជ្រើសរើសក្នុងជនជាតិអាស្សីរី
នេះបញ្ជាក់ថាតើពាក្យ «ពួកគេ» សំដៅទៅលើអ្នកណា។
Ezekiel 23:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តប្រាប់រឿងដល់លោកអេសេគាលអំពីប្រពន្ធដែលមិនស្មោះត្រង់របស់គាត់អូហូឡានិងអូហូលីបា។
ជាពេលដែលពួកគេចាក់ការកំផិតរបស់គេ
ឃ្លាថា «ចាក់ចេញ»
ប្រើគំនិតនៃការចាក់ទឹកដើម្បីបង្ហាញពីអ្វីដែលកំពុងកើតឡើងក្នុងចំនួនដ៏ច្រើន។
ប្រគល់នាងទៅក្នុងកណ្តាប់ដៃនៃពួកសហាយរបស់នាង គឺក្នុងកណ្តាប់ដៃនៃពួកជនជាតិអាស្សីរី
ពាក្យថា «ដៃ» សំដៅទៅលើអំណាច ឬសិទ្ធិអំណាច។ ឃ្លាទីពីរពន្យល់ថា «គូស្នេហ៍របស់នាង» គឺ «ជនជាតិ អាសស៊ើរ»។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបានប្រគល់នាងទៅឲ្យគូស្នេហ៍របស់នាងគឺជនជាតិអាសស៊ើរ»។
Ezekiel 23:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់ចាប់ផ្តើមប្រាប់រឿងនេះដល់លោកអេសេគាលអំពីភរិយាដែលមិនស្មោះត្រង់របស់គាត់ឈ្មោះអូ
អូហូលីបា
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ២៣:១។
ស្លៀកពាក់មានការទាក់ទាញ ពួកបុរសទាំងនោះគឺជិះសេះ
ឃ្លាទាំងពីរនេះពិពណ៌នាអំពីបុរសដែលជាអ្នកមាន។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ»
ពីរនាក់បងប្អូនគឺអ្រាកក់ដូចគ្នា
ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនស្រីទាំងពីរបានក្លាយទៅជាមិនស្អាតតាមរយៈអំពើពេស្យាចាររបស់ពួកគេ»
Ezekiel 23:14
ឃ្លានេះមានអត្ថន័យដូចគ្នានឹងឃ្លាមុនហើយសង្កត់ធ្ងន់ទៅលើអាកប្បកិរិយាអសីលធម៌របស់ស្ត្រីវ័យក្មេងទាំងពីរ។
ព្រះអម្ចាស់នៅតែបន្តនិទានរឿងអំពីភរិយាមិនស្មោះត្រង់ឈ្មោះអូហូលីបាដល់អេសេគាល។
ឈ្នួត
មួកធ្វើពីក្រណាត់វែង និងរុំព័ទ្ធជុំវិញក្បាលរបស់មនុស្សប្រុស។
Ezekiel 23:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តនិទានរឿងអំពីភរិយាមិនស្មោះត្រង់ឈ្មោះអូហូលីបាដល់អេសេគាល។
នាងក៏បែរខ្លួននាងចេញពីពួកគេក្នុងការគួរខ្ពើម
ការបកប្រែរបៀបផ្សេងទៀត:
«អារម្មណ៍របស់នាងទាក់ទងនឹងពួកគេបានផ្លាស់ប្តូរពីបំណងដែលស្អប់ខ្ពើម»
Ezekiel 23:18
អូហូឡានិងអូហូលីបាកាលពីនៅក្មេងនៅឡើយ
ការបកប្រែរបៀបផ្សេងទៀត:
«ចងចាំនិងធ្វើដូចគ្នានឹងនាងបានធ្វើនៅពេលនាងនៅក្មេង »
Ezekiel 23:20
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បញ្ចប់ការមានព្រះបន្ទូលអំពីអូហូលីបា និង ជនជាតិអាសស៊ើរ ហើយចាប់ផ្តើមមានព្រះបន្ទូលទៅកាន់អូហូលីបា។
ដែលមានរាងធំដូចជាសេះ ហើយទឹកកាមក៏ដូចជាទឹកកាមរបស់សេះ
ធំមិនអាចទៅរួចទេដើម្បីបង្ហាញពីបំណងអាក្រក់របស់អូហូលីបា។
Ezekiel 23:22
មើល៍
ការបកប្រែរបៀបផ្សេងទៀត: «មើល» ឬ «ស្តាប់» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក»។
ពួកពេកូឌ ពួកសូអា និងពួកកូអា
ទាំងនេះគឺជាក្រុមមនុស្សដែលរស់នៅក្នុងបាប៊ីឡូន។
Ezekiel 23:24
គ្រឿងសស្ត្រាវុធ

generated on Wed Sep 10 16:16:32 2025

ពាក្យហេព្រើរដែលបានបកប្រែនៅទីនេះថា «អាវុធ» គឺកម្រណាស់។
ជំនាន់ទំនើបជាច្រើនបកប្រែវាតាមរបៀបនេះប៉ុន្តែកំណែខ្លះទុកវាចោល។
ខែលធំខែលតូច និងពាក់មួកសឹកផង។ យើងនឹងប្រគល់ការជំនុំជម្រះដល់គេ
របស់របរការពារទាំងនេះត្រូវបានប្រើដើម្បីសំដៅទៅលើទាហានប្រភេទផ្សេងៗគ្នានៅក្នុងកងទ័ព។
គេនឹងកាត់ច្រមុះ កាត់ត្រចៀកអ្នក
នេះពិតណាស់អំពីការដាក់ទណ្ឌកម្មនៅបាប៊ីឡូនចំពោះស្ត្រីដែលរៀបការហើយដែលបានផ្តួចផ្តើមប្រើប្រាស់ប្រយុទ្ធនៅ
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងដាក់ទណ្ឌកម្មអ្នកដោយព្រោះការផិតក្បត់»
Ezekiel 23:26
ភ្នែករបស់អ្នកមិនបាច់មើល
នេះគឺជាមធ្យោបាយដើម្បីសំដៅទៅលើមនុស្សម្នាក់ងាកក្បាលមើលអ្វីមួយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងមិនមើល»
មិនបាច់គិតពីអ្វីដែលបានកើតនៅអេស៊ីុបទៀតដែរ
ឃ្លា «គិតអំពីប្រទេសអេស៊ីប»
សំដៅទៅលើអំពើពេស្យាចារដែលនាងបានរៀននៅប្រទេសអេអេស៊ីប។
នាងនឹងលែងគិតអំពីពួកគេទៀតហើយព្រោះនាងបានដឹងថាពួកគេនឹងមិនផ្តល់របស់ណាមួយ
ដែលជនជាតិអេស៊ីបជនជាតិបាប៊ីឡូន និងជនជាតិអាសស៊ើរមានទេ។
ផ្ទុយទៅវិញអំពើពេស្យាចារបានធ្វើឲ្យនាងត្រូវបានដាក់ទណ្ឌកម្ម
ហើយនាងនឹងមិនចង់គិតអំពីការធ្វើបាបពួកគេម្តងទៀតទេ។
Ezekiel 23:28
មើល៍
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាស់»
គ្មានសំលៀកបំពាក់ ហើយនៅកណ្តាលវាល
ពាក្យទាំងពីរនេះមានន័យដូចគ្នាហើយបញ្ជាក់ថានាងនឹងអាក្រាតទាំងស្រុង។
អាម៉ាស់គឺជាការកំផិតរបស់អ្នកនឹងបានបើកនៅចំហ ហើយការអាស្រូវ និងការពេស្យារបស់អ្នកផង
ឃ្លាទាំងពីរនេះពិពណ៌នាអំពីពេស្យាចាររបស់នាង
និងសង្កត់ធ្ងន់ថាអាកប្បកិរិយានេះអាក្រក់យ៉ាងណា។
Ezekiel 23:30
ការប្រព្រឹត្តដូចជាពេស្យាហើយតណ្ហាសម្រាប់ជនជាតិដទៃ
មូលហេតុដែលឃ្លានេះនិយាយថាអូហូលីបាដើរតួដូចជាស្រីពេស្យាជាមួយប្រជាជាតិនានាគឺដោយសារតែ
យើងនឹងដាក់ពែង
ពាក្យថា «ពែង» គឺសំដៅលើការដាក់ទណ្ឌកម្មរបស់អូហូលីបា។
វាតំណាងឲ្យអ្វីដែលនាងបានទទួល។
Ezekiel 23:32
អ្នកនឹងត្រូវផឹកពីពែងរបស់បងស្រីអ្នក
ការផឹកពីពែងតែមួយគឺជាវិធីមួយទៀតដើម្បីនិយាយថាពួកគេនឹងជួបប្រទះរឿងដូចគ្នា។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកនឹងត្រូវទទួលទណ្ឌកម្មដូចគ្នានឹងប្អូនស្រីរបស់អ្នក»
យ៉ាងជ្រៅហើយធំ
នេះសំដៅទៅលើចំនួនទោសដែលបានទទួល។ ការបកប្រែរបៀបផ្សេងទៀត:
«នោះគឺធ្ងន់ធ្ងរ»
សើចឡកឡឺយ ...ហើយទុកសម្រាប់ជាការមើលងាយ
ឃ្លាទាំងពីរនេះសំដៅទៅលើមនុស្សដែលសើចចំអកនិងរិះគន់ដោយសារតែអាកប្បកិរិយាលើសលប់
ពែងនោះដាក់បានចំណុះជាច្រើន
ការកាត់ទោសនេះមិនបាននិយាយពីអ្វីដែលនៅក្នុងពែងទេពីព្រោះវាត្រូវបានយល់ដោយស្រាលនៅ
២៣:៣០។ ការបកប្រែរបៀបផ្សេងទៀត:
«ពែងនេះផ្ទុកនូវការដាក់ទណ្ឌកម្មយ៉ាងច្រើន»
Ezekiel 23:33
ពែងនៃសេចក្តីភ័យខ្លាច ហើយខ្លោចផ្សា!
«ពែងដែលបង្កឲ្យមានភាពភ័យរន្ធត់និងការបំផ្លិចបំផ្លាញ»។ ពាក្យថា «រន្ធត់» និង
«ការបំផ្លិចបំផ្លាញ» មានអត្ថន័យស្រដៀងគ្នានៅទីនេះ
ហើយសង្កត់ធ្ងន់ថាតើការដាក់ទណ្ឌកម្មរបស់នាងគួរឲ្យភ័យខ្លាចយ៉ាងដូចម្តេច។
ជាពែងរបស់សាម៉ារីបងស្រីអ្នក
ប្អូនស្រីរបស់អូហូលីបា គឺអូហូឡាបានតំណាងជនជាតិសាម៉ារី។
សាម៉ារីត្រូវបានគេហៅតាមឈ្មោះរបស់វាប៉ុន្តែនៅតែសំដៅដល់បងស្រីម្នាក់។
ពែងគឺជានិមិត្តរូបសម្រាប់ការដាក់ទណ្ឌកម្មដែលនាងបានទទួល។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 23:35
ហើយបោះចោលយើងទៅពីក្រោយខ្នងអ្នក
ព្រះអម្ចាស់កំពុងតែមានបន្ទូលថាអូហូលីបាមិនខ្វល់ពីគាត់ទេ។
Ezekiel 23:36
«កូនមនុស្សអើយ តើអ្នកនឹងជំនុំជម្រះអូហូឡា និងអូហូលីបាទេ
[illegible]
អ្នកនឹងថ្កោលទោសអូហូឡានិងអូហូលីបា!»
មានឈាមប្រឡាក់នៅដៃពួកគេ
ឈាមគឺជាលទ្ធផលនៃការសម្លាប់មនុស្ស ដូច្នេះតំណាងឲ្យឃាតកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេបានសម្លាប់មនុស្ស»។
Ezekiel 23:38
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអេសេគាលអំពីអូហូឡា និង អូហូលីបា។
ហើយនៅថ្ងៃមួយពួកគេបង្អាប់ថ្ងៃសប្ប័ទរបស់យើង
ឃ្លា «នៅថ្ងៃដដែល» សំដៅទៅលើឃ្លាមុន «ធ្វើឲ្យទីជម្រករបស់យើងមិនស្អាត»។
ការបកប្រែរបៀបផ្សេងទៀត:
«ហើយនៅថ្ងៃដដែលពួកគេធ្វើឲ្យទីសក្ការៈរបស់យើងក្លាយទៅជាស្មោកគ្រោកពួកគេធ្វើឲ្យសៅហ្មងថ្ងៃសប្ប
ចូលក្នុងទីបរិសុទ្ធរបស់យើងដើម្បីនឹងបង្អាប់ទីនោះ
ការបកប្រែរបៀបផ្សេងទៀត:
«បានមកបំផ្លាញទីសក្ការៈរបស់យើងនៅថ្ងៃតែមួយដូចជាការសំលាប់កូនៗរបស់ពួកគេសំរាប់រូបព្រះរបស់ព
មើល៍!
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាស់!»
Ezekiel 23:40
ព័ត៌មានទូទៅ:
អេសេគាលនិយាយទៅកាន់អូហូឡា និង អូហូលីបា។
មើល៍!
«មើល!» ឬ «ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក!»
អ្នកបានងូតទឹកគេ ផាត់រង្វង់ភ្នែក ហើយតែងខ្លួនដោយគ្រឿងអលង្ការ
ទាំងនេះជាអ្វីដែលស្ត្រីធ្វើដើម្បីឲ្យនាងមានសម្រស់ស្រស់ស្អាតចំពោះបុរស។
[illegible]
ជាវត្ថុក្នុងការប្រើប្រាស់សំរាប់ការថ្វាយបង្គំដល់ព្រះជាម្ចាស់
Ezekiel 23:42
សំឡេងនៃហ្វូងមនុស្សដែលមានការព្រួយបារម្ភគឺនៅជាមួយអ្នក
សំឡេងរបស់ហ្វូងមនុស្សត្រូវបានប្រើដើម្បីសំដៅទៅលើហ្វូងមនុស្ស។
មនុស្សប្រមឹក
មនុស្សដែលស្រវឹងញឹកញាប់។
ទោះយ៉ាងណាក៏ដោយក៏ណែទំនើបមួយចំនួនបកប្រែថា «សេបា»
នោះគឺបុរសមកពីសេបា។
ដែលតុបតែង
តុបតែង ឬ ឆ្លាក់ដើម្បីឲ្យកាន់តែស្រស់ស្អាត។
Ezekiel 23:43
ដែលបានកើតមកសេចក្តីកំផិត
[illegible]
អូហូលីជាមួយការពិពណ៌នា។
[illegible]
ការបកប្រែរបៀបផ្សេងទៀត:
«ដូចដែលពួកគេនឹងជ្រាបចូលទៅក្នុងស្ត្រីពេស្យាណាមួយ»
ដៃគេក៏ប្រឡាក់ដោយឈាម
ឃ្លានេះគេប្រើជាភស្តុតាងនៃអំពើហឹង្សាដើម្បីនិយាយថាពួកគេមានពិរុទ្ធភាពនៃអំពើហិង្សា។
Ezekiel 23:46
នឹងលើកមនុស្សមួយពួក
ឃ្លា «លើកឡើង» សំដៅលើការកើនឡើងចំនួនប្រជាជន។
ការបកប្រែរបៀបផ្សេងទៀត: «ប្រមូលផ្តុំមនុស្សមួយក្រុមធំ»
នឹងប្រគល់ពួកគេ
ព្រះអម្ចាស់បោះបង់ចោលការទទួលខុសត្រូវក្នុងការថែរក្សាពួកគេនិងអនុញ្ញាតឲ្យពួកគេរងទុក្ខចំពោះជម្រើ
នូវការភ័យខ្លាចហើយការលួចប្លន់
ការបកប្រែរបៀបផ្សេងទៀត: ដើម្បីឲ្យអំពើភេរវកម្ម និង ប្លន់ពួកគេ។
Ezekiel 23:48

generated on Wed Sep 10 16:16:32 2025

24 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ នៅក្នុងឆ្នាំទីប្រាំបួន ខែដប់ និងថ្ងៃទីដប់ក្នុងខែនោះ ដោយប្រាប់ថា[2]«កូនមនុស្សអើយ សូមកត់ថ្ងៃនេះទុក ដ្បិតនៅថ្ងៃនេះ
ហើយ គឺជាថ្ងៃពិតប្រាកដ ដែលស្តេចនៃបាប៊ីឡូនបានឡោមព័ទ្ធក្រុងយេរូសាឡិម។
[3]ដូច្នេះ សូមនិយាយជាពាក្យសុភាសិត ទាស់ជាមួយពូជបះបោរទាំងនោះ ដោយពាក្យប្រៀបធៀប សូមប្រាប់គេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ចូរដាក់ថ្លាង
នៅលើភ្លើង។ សូមចាក់ទឹកក្នុងវាផង។[4]សូមប្រមូលដុំសាច់ គឺអស់ទាំងដុំល្អៗ និងភ្លៅ ហើយស្មាផង ត្រូវឲ្យបំពេញដោយឆ្អឹងផងដែរ។[5]ត្រូវរើសយកចៀមយ៉ាងល្អ
ហើយដាក់ឆ្អឹងនៅពីក្រោមវា។ នាំវាយកទៅស្ងោរហើយនិងឆ្អឹងក៏ត្រូវដាក់ចូលស្ងោរដែរ។
[6]ហេតុនោះ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ វរដល់ ទីក្រុងដែលប្រឡាក់ដោយឈាម គឺជាឆ្នាំងសម្រាប់ចំអិនមានក្អែលក្នុងនោះ ហើយក្អែលនោះមិនបានដុស
ចេញ។ ដាក់សាច់ចេញមួយដុំម្តងៗពីវា ប៉ុន្តែកុំធ្វើបែបមិនយកទុកដាក់។
[7]ដ្បិតឈាមរបស់នាងគឺនៅកណ្តាលនោះ។ នាងបានរៀបចំនៅលើថ្មរលោង នាងមិនបានចាក់ទៅលើដីទេ ដើម្បីយកដីមកគ្របបាំងវានោះទេ។
[8]ដូច្នេះហើយនាងនឹងបណ្តាលឲ្យមានការសងសឹក។ យើងបានដាក់ឈាមនាងទៅលើថ្មរលោង ដូច្នេះនឹងគ្មានអ្វីគ្របបាំងឡើយ។
[9]ដូច្នេះ ព្រះអម្ចាស់អម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ វេទនាដល់ទីក្រុងដែលប្រឡាក់ដោយឈាម។ យើងនឹងធ្វើគំនរអុសកាន់តែធំឡើង។[10]ជង់អុសឡើង ហើយ
បង្កាត់ភ្លើងឡើង។ ហើយឆ្អិនសាច់ឲ្យបានល្អ រួចបង់គ្រឿងផង ហើយឆ្អឹងឆេះខ្លោច។
[11]ក្រោយមក ត្រូវឲ្យយកឆ្នាំធ្យូងថ្មទទេ ដាក់លើរងើកភ្លើងឲ្យក្តៅ ហើយខ្លោចលង្ហិនរបស់វា ដើម្បីឲ្យគ្រឿងស្មោកគ្រោកបានរលាយចេញ ហើយឲ្យច្រេះបានឆេះឲ្យសុស។
[12]នាងបាននឿយហត់ជាមួយការទុក្ខលំបាក ប៉ុន្តែស្នឹមយ៉ាងក្រាស់របស់នាងមិនចេះជ្រះឡើយ ត្រូវដុតចោលក្នុងភ្លើង។
[13]ការប្រព្រឹត្តក្តីអាម៉ាស់ និងសេចក្តីស្មោកគ្រោករបស់អ្នក គឺយើងបានដុសជម្រះអ្នក តែអ្នកមិនចង់ស្អាត់។ ដូច្នេះ អ្នកនឹងមិនបានស្អាតពីសេចក្តីស្មោកគ្រោករបស់អ្នកឡើយ
ដរាបដល់យើងឲ្យដកសេចក្តីក្រោធរបស់យើង ពីអ្នកវិញ។
[14]យើង គឺជាព្រះអម្ចាស់បានប្រកាសវា។ យើងនឹងធ្វើឲ្យវាកើតឡើង។ យើងមិនព្រមដកថយ ហើយក៏មិនសម្រាកពីវាដែរ។
ផ្លូវរបស់អ្នកបែបណាហើយនិងការប្រព្រឹត្តរបស់អ្នក ពួកគេនឹងជំនុំជម្រះអ្នក! នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។
[15]ក្រោយមក ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[16]«កូនមនុស្សអើយ! ចូលមើល៍ យើងនឹងដកយកអ្វីដែលបានទាក់ភ្នែកអ្នកចេញ ដោយអាសន្នរោគ ប៉ុន្តែអ្នក
មិនត្រូវសោយស្តាយឬយំទេ ហើយមិនត្រូវហូរទឹកភ្នែកដែរ។[17]អ្នកនឹងពិបាកចិត្តដោយស្ងៀមស្ងាត់។ កុំធ្វើបុណ្យសព្វសម្រាប់អ្នកស្លាប់ឡើយ។
ចងឈ្នួតនៅលើអ្នកនៅកន្លែងអ្នក ហើយពាក់ស្បែកជើងរបស់អ្នក មិនត្រូវឲ្យស្បែបាំងមុខនិងសក់អ្នក ឬបរិភោគអាហាររបស់បុរសដែលកាន់ទុក្ខ
ប្រពន្ធបានស្លាប់ទាំងនោះ»។
[18]ដូច្នេះ ខ្ញុំក៏បាននិយាយ ទៅកាន់បណ្តាជននៅពេលព្រឹក ហើយពេលល្ងាចប្រពន្ធខ្ញុំស្លាប់។ ពេលព្រឹកឡើងខ្ញុំបានធ្វើដូចជាព្រះអង្គបង្គាប់ឲ្យធ្វើ។
[19]មនុស្សទាំងនោះក៏សួរខ្ញុំថា «តើអ្នកនឹងមិនប្រាប់យើងពីអ្វីទាំងនេះមានន័យដូចម្តេច និងកិច្ចការដែលអ្នកកំពុងធ្វើ?»[20]ដូច្នេះ ខ្ញុំបាននិយាយទៅគេ «ព្រះបន្ទូលនៃ
ព្រះអម្ចាស់មកដល់ខ្ញុំ ប្រាប់ថា[21]ចូរប្រាប់ដល់កូនចៅអ៊ីស្រាអែលថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល៍! យើងនឹងប្រមាថទីបរិសុទ្ធរបស់យើង សេចក្តី
អំនួតនិងកម្លាំងអ្នក ហើយអ្វីដែលភ្នែកអ្នកចូលចិត្ត ហើយចំណង់ខ្លាំងនៃព្រលឹងរបស់អ្នក និងពួកកូនប្រុសកូនស្រីដែលអ្នកបានទុកចោល នោះនឹងត្រូវដួលស្លាប់ដោយ
ដាវ។
[22]គ្រានោះ អ្នករាល់គ្នានឹងធ្វើដូចជាខ្ញុំបានធ្វើនេះដែរ គឺអ្នកនឹងមិនបិទាំមុខដោយសក់របស់អ្នក ឬបរិភោគអាហាររបស់អ្នកកាន់ទុក្ខទេ![23]ផ្ទុយទៅវិញ សំពត់ឈ្នួតនឹងនៅជាប់
លើក្បាល ហើយស្បែកជើងនៅជាប់នឹងជើង អ្នកនឹងមិនកាន់ទុក្ខ អត់យំដែរ ដ្បិតអ្នកនឹងរលាយទៅក្នុងអំពើទុច្ចរិតរបស់ខ្លួន ហើយ
បុរសទាំងនោះស្រែកថ្ងូរដាក់បងប្អូនខ្លួន។[24]ដូច្នេះ អេសេគាល នឹងជាទីសម្គាល់ដល់អ្នក ហើយអ្វីដែលគាត់បានធ្វើអ្នកនឹងធ្វើដែរនៅវេលាមកដល់។ អ្នកនឹងដឹងថា យើងនេះ
ជាព្រះអម្ចាស់ដ៏ជាព្រះ!»
[25]ចំណែកអ្នកវិញ កូនមនុស្សអើយ! នៅថ្ងៃដែលយើងដកយកទីមាំមួនពីគេចេញ ព្រមទាំងអំណរចំពោះសិរីល្អរបស់គេ និងអ្វីៗដែលគប់ភ្នែក ហើយសំណព្វចិត្តរបស់គេ គឺ
ទាំងកូនប្រុសកូនស្រីរបស់គេដែរ[26]នៅថ្ងៃនោះ ជនភៀសខ្លួន នឹងមករកអ្នក ដើម្បីនឹងប្រាប់ពីការនោះឲ្យអ្នកឮដោយត្រចៀក![27]នៅថ្ងៃនោះ មាត់របស់អ្នកនឹងបើកឡើង
និយាយដល់ជនភៀសខ្លួន ហើយអ្នកនឹងនិយាយ ហើយមិនត្រូវនៅស្ងៀមដែរ។ អ្នកនឹងធ្វើជាទីសម្គាល់ដល់ពួកគេ ដូច្នេះពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់»។

Ezekiel 24:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលទៅលោកអេសេគាល។
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។
នៅក្នុងឆ្នាំទីប្រាំបួន
ការបកប្រែរបៀបផ្សេងទៀត: «នៅឆ្នាំទី៩ នៃការនិរទេសស្តេចយេហូយ៉ាជីន»
ខែដប់ និងថ្ងៃទីដប់ក្នុងខែនោះ
«ថ្ងៃទី១០ ខែ១០»។ នេះជាខែទី១០ នៃប្រតិទិន ហេប្រឺ។
ថ្ងៃទីដប់គឺនៅជិតដើមខែមករានៅលើប្រតិទិនលោកខាងលិច។
ស្តេចនៃបាប៊ីឡូនបានឡោមព័ទ្ធក្រុងយេរូសាឡិម
កងទ័ពបាប៊ីឡូន គឺសំដៅទៅលើអ្នកដឹកនាំ។
Ezekiel 24:3
ដាក់ឆ្អឹងនៅពីក្រោមវា
វប្បធម៌ខ្លះបន្ថែមឆ្អឹងទៅក្នុងភ្លើងព្រោះវាឆេះយូរជាងអុស។
ការបកប្រែរបៀបផ្សេងទៀត: «ដាក់ឆ្អឹងដែលនៅសល់នៅក្រោមឆ្នាំងដើម្បីដុតភ្លើង»
Ezekiel 24:6
ឆ្នាំងសម្រាប់ចំអិន
ព្រះអម្ចាស់ប្រៀបធៀបក្រុងយេរូសាឡិមទៅនឹងឆ្នាំងដាំបាយ។
ក្អែល
សម្ភារៈពណ៌ក្រហមដែលបង្កើតនៅលើលោហៈ។
ច្រែះស៊ីនៅលោហៈហើយទីបំផុតត្រូវបានបំផ្លាញវា
យក
ព្រះអម្ចាស់មិនផ្តល់បទបញ្ជានេះដល់មនុស្សជាក់លាក់ទេផ្ទុយទៅវិញទ្រង់បញ្ជាមនុស្សដែលស្រមើលស្រ
ប៉ុន្តែកុំធ្វើបែបមិនយកទុកដាក់
ការបោះឆ្នោតច្រើនគឺជាវិធីមួយដើម្បីជ្រើសរើសបំណែកសាច់ណាដែលត្រូវយកចេញ
ប៉ុន្តែដោយសារតែព្រះអម្ចាស់ចង់ដកបំណែកទាំងអស់ចេញគឺមិនចាំបាច់បោះច្រើនទេ។
Ezekiel 24:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសារទៅប្រជាជននៅក្រុងយេរូសាឡិម។
នាង
ពាក្យថា «នាង» សំដៅទៅលើក្រុងយេរូសាឡិម ដែលតំណាងដោយឆ្នាំងដាំបាយ។
បានរៀបចំនៅលើថ្មរលោង
«បានដាក់ឈាមលើថ្មទទេ»
យកដីមកគ្របបាំង
«ហើយគ្របវាដោយភាពកខ្វក់»
Ezekiel 24:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែប្រៀបធៀបក្រុងយេរូសាឡិមទៅនឹងឆ្នាំងដាំបាយ។
យើងនឹងធ្វើគំនរអុសកាន់តែធំ
មានន័យថាគំនរឈើស្ថិតនៅក្រោមឆ្នាំងដាំដែលតំណាង ឲ្យក្រុងយេរូសាឡិម។

«យើងនឹងធ្វើឲ្យគំនរឈើនៅលើភ្លើងឆេះនៅក្រោមអ្នកកាន់តែធំ»

ដាក់ជង់ ...បង្កាត់ ...ចំអិន...ឲ្យឆ្អឹងត្រូវបានដុត

ព្រះអម្ចាស់ប្រទានបទបញ្ជាទាំងនេះដល់មនុស្សស្រមើលស្រមៃដែលជាផ្នែកមួយនៃការ

ហើយដុតឆ្អឹងឆេះខ្លោច

«ដុតឆ្អឹង»

Ezekiel 24:11

ខ្លោច

ដើម្បីដុតផ្ទៃរបស់អ្វីមួយ។

ច្រេះ

ពេលមានអ្វីមួយបណ្តាលឲ្យលោហៈធាតុដាច់ពីគ្នានិងខូច។

ឆេះឲ្យសុស

«ដុតកំទិច»

នាងបាននឿយហត់ជាមួយការទុក្ខលំបាក

ការបកប្រែរបៀបផ្សេងទៀត: «ក្រុងយេរូសាឡិមមានការនឿយហត់ណាស់»

ស្នឹម

ពលកម្មលំបាក។

Ezekiel 24:13

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់ក្រុងយេរូសាឡិមដោយប្រៀបធៀបវាទៅនឹងឆ្នាំង

Ezekiel 24:14

ការប្រព្រឹត្តរបស់អ្នក ពួកគេនឹងជំនុំជម្រះអ្នក

អ្វីដែលពួកគេបានធ្វើបង្ហាញថាពួកគេមានកំហុស។

នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៥:១១។

Ezekiel 24:15

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់ «មើលរបៀបដែលបកប្រែនេះនៅក្នុងជំពូក ១:១។

យកអ្វីដែលបានទាក់ភ្នែក

នេះសំដៅទៅលើប្រពន្ធរបស់លោកអេសេគាល។

ព្រះអម្ចាស់សំដៅលើលោកអេសេគាលដោយផ្នែកនៃរាងកាយរបស់គាត់បានប្រើដើម្បី

។

អ្នកមិនត្រូវសោយស្តាយឬយំទេ ហើយមិនត្រូវហូរទឹកភ្នែកដែរ

ឃ្លាទាំងនេះមានអត្ថន័យដូចគ្នានឹងអ្វីដែលសង្កត់ធ្ងន់ថាអេសេគាលមិនត្រូវយំអំពីការស្លាប់

ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនត្រូវបង្ហាញពីទុក្ខព្រួយរបស់អ្នកទេ»។

ឈូត

គម្របក្បាលធ្វើពីក្រណាត់វែងរុំព័ទ្ធក្បាល។

ស្បែកជើង

ស្បែកជើងសាមញ្ញមួយដាក់លើជើងដោយខ្សែជុំវិញកជើង។

មិនត្រូវឲ្យស្មៃបាំងមុខនិងសក់អ្នក

នៅប្រទេសអ៊ីស្រាអែលបុរសៗកោរសក់ ដើម្បីបង្ហាញពីភាពទុក្ខព្រួយ

បន្ទាប់មកគ្របមុខរបស់ពួកគេរហូតដល់សក់មុខរបស់ពួកគេត្រឡប់មកវិញ។

ព្រះអម្ចាស់បានប្រាប់លោកអេសេគាលកុំឲ្យបាំងសក់មុខរបស់គាត់

ដើម្បីបង្ហាញថា

Ezekiel 24:19

ព័ត៌មានទូទៅ:

ជនជាតិអ៊ីស្រាអែលសួរលោកអេសេគាល ហើយ

លោកអេសេគាលបានប្រាប់ពួកគេអំពីអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ពួកគេ។

ព្រះបន្ទូលនៃព្រះអម្ចាស់មកដល់

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់» សូមមើលរបៀបដែលបកប្រែនេះនៅក្នុងជំពូក ១: ១។

សេចក្តីអំនួតនិងកម្លាំងអ្នក

ការបកប្រែរបៀបផ្សេងទៀត: «មោទនភាពចំពោះអគារដែលអ្នកបានបង្កើត»

ភ្នែកអ្នកចូលចិត្ត

ការបកប្រែរបៀបផ្សេងទៀត: «អគារដែលអ្នករាល់គ្នារីករាយនឹងមើល»

ត្រូវដួលស្លាប់ដោយដាវ

ការបកប្រែរបៀបផ្សេងទៀត: «ត្រូវបានសំលាប់នៅក្នុងសង្គ្រាម»

Ezekiel 24:22

អ្នកនឹងរលាយទៅឆ្ងាយ

ដោយសារតែ

អំពើទុច្ចរិតរបស់ខ្លួន

នេះបញ្ជាក់ថាព្រះអង្គនឹងមិនអត់ទោសបាបរបស់មនុស្សទាំងនេះទេ។

ទោះយ៉ាងណាក៏ដោយក៏ណែទំនើបមួយចំនួនបកប្រែថា

«ដោយសារតែភាពទុច្ចរិតរបស់អ្នក»។

ស្រែកថ្ងូរ

សំឡេងនៃមនុស្សម្នាក់ដែលត្រូវការជំនួយ ប៉ុន្តែការឈឺចាប់ ឬ

ទុក្ខព្រួយខ្លាំងណាស់ដែលពួកគេមិនមានសមត្ថភាពនិយាយ។

Ezekiel 24:25

ជនភៀសខ្លួន

នរណាម្នាក់ដែលត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសរបស់ពួកគេ

ដោយសារតែសង្គ្រាមឬគ្រោះមហន្តរាយផ្សេងទៀត។

«ព្រះអម្ចាស់នឹងបើកមាត់របស់អ្នក»

នេះពិតណ៎ានាអំពីនរណាម្នាក់ដែលត្រូវបានផ្តល់ការយល់ដឹង

អ្នកនឹងដឹងពីអ្វីដែលត្រូវនិយាយ

អ្នកនឹងនិយាយ — ហើយមិនត្រូវនៅស្ងៀមដែរ

ទាំងពីរនេះមានន័យថាប្រជាជនអ៊ីស្រាអែលនឹងនិយាយ។

វាត្រូវបានគេនិយាយម្តងទៀតថាជាអវិជ្ជមានដើម្បីសង្កត់ធ្ងន់លើវិជ្ជមាន។

ធ្វើជាទីសម្គាល់

នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែលជាសញ្ញាមួយពីព្រោះពួកគេនឹងជួយជនភៀសខ្លួនឲ្យយល់ពីមូលហេ

---

25 [1]ក្រោយមក ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ! ចូរតាំងមុខអ្នកដើម្បីទាស់ នឹងប្រជាជននៃអាំម៉ូន
ហើយថ្លែងព្រះបន្ទូលទាស់នឹងពួកគេផង។
[3]ចូរប្រាប់ដល់ប្រជាជននៃអាំម៉ូនថា ស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។ នេះគឺជាអ្វីដែលព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល ដោយអ្នកបាននិយាយ «បពិត្រ!» នៅលើទី
បរិសុទ្ធរបស់យើង ពេលដែលទីនោះត្រូវបានប្រមាថ ហើយទាស់នឹងទឹកដីអ៊ីស្រាអែល ពេលដែលត្រូវចោលស្ងាត់ ហើយទាស់នឹងកូនចៅយូដា
គ្រាដែលពួកគេបាននិរទេស។[4]ហេតុនោះ មើល៍! យើងនឹងប្រគល់អ្នកដល់ប្រជាជនដែលនៅទិសខាងកើតទុកជាកេរអាករ។ ពួកគេនឹងតាំងបន្ទាយទាស់និងអ្នក ហើយធ្វើទី
លំនៅរបស់គេនៅក្នុងចំណោមអ្នក។ ពួកគេនឹងបានស៊ីផល ហើយផឹកទឹកដោះសត្វរបស់អ្នក។[5]យើងនឹងធ្វើឲ្យក្រុងរ៉ាបាត ទៅជាក្រោលសម្រាប់សត្វអូដ្ឋ ហើយ
ប្រជាជននៃអាំម៉ូនធ្វើទីវាលសម្រាប់ហ្វូងចៀម។ រួចហើយអ្នកនឹងដឹងថា យើងគឺជាព្រះអម្ចាស់។
[6]ដ្បិតព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ អ្នកបានទះដៃ ហើយតន្ត្រីហើយឈរដោយជើងរបស់អ្នក ហើយមានសេចក្តីរីករាយ ជាមួយគ្រប់ទាំងសេចក្តីស្អប់នៅក្នុង
អ្នកទាស់និងទឹកដីអ៊ីស្រាអែល។[7]ហេតុនោះ មើល៍! យើងនឹងវាយអ្នកជាមួយដៃយើង ហើយប្រគល់អ្នកជាចោរប្លន់ដល់ជនជាតិដទៃ។ យើងនឹងកាត់អ្នកចេញពី
ប្រជាជនផ្សេង ហើយយើងធ្វើឲ្យអ្នកវិនាសបាត់ពីប្រទេសផ្សេងៗ! យើងនឹងបំផ្លាញអ្នក ហើយអ្នកនឹងដឹងថា យើងគឺជាព្រះអម្ចាស់។
[8]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដោយព្រោះម៉ូអាប់ និងសៀរនិយាយថា «មើល៍! ពួកយូដាគេក៏ដូចជាជនជាតិផ្សេងទៀតដែរ»។[9]ហេតុនោះ មើល៍! យើងនឹងបើក
ជាយស្រុកម៉ូអាប់ ចាប់តាំងពីទីក្រុងរបស់គេដល់ព្រំប្រទល់ ភាពរុងរឿងនៃក្រុងបេត យេស៊ីម៉ូត ក្រុងបាល មេយ៉ូន និងក្រុងគារយ៉ាថែម[10]ទៅដល់ប្រជាជននៅទឹកដីខាងកើត
ដែលជាអ្នកបានទាស់នឹងប្រជាជននៃអាំម៉ូន។ យើងនឹងឲ្យដល់ពួកគេនូវសម្បត្តិ ទុកជាកេរអាករ ដូច្នោះប្រជាជននៃពួកអាំម៉ូននឹងមិនបាននឹកចាំ ក្នុងចំណោមជនជាតិទាំង
ទាំងនោះ[11]ដូច្នេះ យើងនឹងជំនុំជម្រះ ជនជាតិម៉ូអាប់ ហើយយពួគគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់»។
[12]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ «ជនជាតិអេដុមបានប្រព្រឹត្តទាស់នឹងពួកយូដាដោយការសងសឹក ដោយបានធ្វើការដែលមិនត្រឹមត្រូវដូច្នេះ។[13]ហេតុនោះ
ព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់មានព្រះបន្ទូលដូច្នេះ៖ យើងនឹងប្រហារទឹកដីអេដុមជាមួយដៃរបស់យើង នឹងបំផ្លាញទាំងមនុស្ស ហើយនិងសត្វផង។ យើងនឹងធ្វើឲ្យទឹកដី
នោះរលាយអស់ តាំងពីក្រុងថេម៉ាន ទៅដល់ដេដាន់។ ពួកគេនឹងដួលស្លាប់ដោយសារដាវ។

generated on Wed Sep 10 16:16:32 2025

[14]យើងនឹងដាក់ការសងសឹករបស់យើង ទៅលើជនជាតិអេដុម ដោយសារដៃនៃជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្រយើង ហើយពួកគេនឹងធ្វើដល់ជនជាតិអេដុម តាមកំហឹង
និងសេចក្តីក្រោធរបស់យើង ហើយពួកគេនឹងស្គាល់សេចក្តីសងសឹករបស់យើង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[15]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ «ជនជាតិភីលីស្ទីនបានដាក់ការសងសឹកដោយព្យាបាទ ហើយពួកគេព្យាយាម ដើម្បីបំផ្លាញយូដាម្តងហើយម្តងទៀត។[16]ដូច្នេះ
នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល មើល៍! យើងនឹងលាដៃយើងចេញទៅទាស់ជាមួយជាតិភីលីស្ទីន យើងនឹងកាត់ចេញ ពួកកេរេធីមផង ក៏បំផ្លាញសំណល់មនុស្ស
ដែលនៅសល់តាមឆ្នេរសមុទ្រដែរ។[17]ដ្បិតយើងនឹងសម្រេចការសងសឹកយ៉ាងធំដល់គេ ដោយសេចក្តីផ្ចាញ់ផ្ចាលដ៏ក្តៅក្រហាយ ពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់
ពេលដែលយើងទម្លាក់សេចក្តីសងសឹកទៅលើពួកគេ»។

Ezekiel 25:1

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។

កូនមនុស្សអើយ

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។

ចូរតាំងមុខអ្នកដើម្បីទាស់

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៤:១។

ប្រជាជននៃអាំម៉ូន

«កូនចៅអាំម៉ូន» ឬ «អ្នកទាំងនោះដែលរស់នៅក្នុងទឹកដីអាំម៉ូន»

ហើយថ្លែងព្រះបន្ទូលទាស់

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៤:៦។

Ezekiel 25:3

ព័ត៌មានទូទៅ:

ព្រះអម្ចាស់ប្រាប់លោកអេសេគាលនូវអ្វីដែលត្រូវនិយាយទៅកាន់ប្រជាជនអាំម៉ូន។

ប្រជាជននៃអាំម៉ូន

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២៥:៣។

ស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ

«ស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់»

អ្នកបាននិយាយ «បពិត្រ!»

ពាក្យថា «បពិត្រ»

គឺជាសំលេងដែលមនុស្សបង្កើតនៅពេលដែលពួកគេសប្បាយចិត្តនឹងអ្វីមួយ។

ក្នុងករណីនេះប្រជាជនសប្បាយរីករាយពីព្រោះមានរឿងអាក្រក់កើតឡើងចំពោះអ៊ីស្រាអែល។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកសើច» ឬ «អ្នកស្រែកហ៊ោ»

នៅលើទីបរិសុទ្ធរបស់យើង ពេលដែលទីនោះត្រូវបានប្រមាថ

«ប្រឆាំងនឹងទីជម្រករបស់យើងនៅពេលដែលសត្រូវបានបង្អាប់វា»។

ការបកប្រែរបៀបផ្សេងទៀត:

«នៅពេលដែលកងទ័ពសត្រូវបានបំផ្លាញព្រះវិហាររបស់យើង»

ទាស់នឹងទឹកដីអ៊ីស្រាអែល ពេលដែលត្រូវចោលស្ងាត់

ការបកប្រែរបៀបផ្សេងទៀត:

«នៅពេលដែលស្រុកអ៊ីស្រាអែលស្ថិតក្នុងការបាក់បែក»

ទាស់នឹងកូនចៅយូដា ត្រាដែលពួកគេបាននិរទេស

ការបកប្រែរបៀបផ្សេងទៀត:

«នៅពេលពួកគេយកប្រជាជនយូដាទៅធ្វើជាទាសករ»។

មើល៍!

ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ

«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»

យើងនឹងប្រគល់អ្នកដល់ប្រជាជនដែលនៅទិសខាងកើតទុកជាកេរអាករ

«យើងនឹងធ្វើឲ្យកងទ័ពមួយមកពីស្រុកខាងកើតអ្នករាល់គ្នាចូលមក
និងវាយដណ្តើមយកឈ្នះអ្នករាល់គ្នា»។

ពួកគេនឹងតាំងបន្ទាយទាស់និងអ្នក ហើយធ្វើទីលំនៅរបស់គេនៅក្នុងចំណោមអ្នក

នេះអាចត្រូវបានបកប្រែជាប្រយោគថ្មី:

«ពួកគេនឹងរៀបចំតង់និងរស់នៅក្នុងប្រទេសរបស់អ្នក»។

ប្រជាជននៃអាំម៉ូនធ្វើទីវាលសម្រាប់ហ្វូងចៀម

ពាក្យថា «ប្រជាជនអាំម៉ូន»

នៅទីនេះសំដៅលើទឹកដីដែលជាកម្មសិទ្ធិរបស់ប្រជាជនអាំម៉ូន។

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងធ្វើឲ្យដីសល់នៃទឹកដីអាំម៉ូនធ្វើជាវាលស្មៅសម្រាប់ហ្វូងចៀម»។

Ezekiel 25:6

គ្រប់ទាំងសេចក្តីស្អប់នៅក្នុងអ្នកទាស់និងទឹកដីអ៊ីស្រាអែល

«ជាមួយនឹងការស្អប់ខ្ពើមដែលអ្នកមានចំពោះប្រជាជនអ៊ីស្រាអែលដែលរស់នៅទាំងអស់»។

មើល៍!

ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ

«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»

យើងនឹងវាយអ្នកជាមួយដៃយើង

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងវាយអ្នកដោយដៃដ៏មានឫទ្ធានុភាពរបស់យើង» ឬ

«យើងនឹងដាក់ទណ្ឌកម្មអ្នក»

ហើយប្រគល់អ្នកជាចោរប្លន់ដល់ជនជាតិដទៃ

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងអោយប្រជាជាតិនានាដកហូតអ្វីៗពីអ្នក»។

យើងនឹងកាត់អ្នកចេញពីប្រជាជនផ្សេង ហើយយើងធ្វើឲ្យអ្នកវិនាសបាត់ពីប្រទេសផ្សេងៗ

ឃ្លាទាំងនេះមានអត្ថន័យដូចគ្នានឹងរឿងហើយសង្កត់ធ្ងន់ថាព្រះអម្ចាស់នឹងបំផ្លាញប្រជាជនអាំម៉ូនទាំងស្រុ

ដើម្បីកុំឲ្យពួកគេក្លាយជាប្រជាជាតិមួយទៀត។ ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងបំផ្លាញអ្នកទាំងស្រុងដើម្បីកុំឲ្យអ្នកក្លាយជាប្រជាជាតិមួយទៀត»

អ្នកនឹងដឹងថា យើងគឺជាព្រះអម្ចាស់

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦

Ezekiel 25:8

មើល៍!

ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ

«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»

យើងនឹងបើកជាយស្រុកម៉ូអាប់ ចាប់តាំងពីទីក្រុងរបស់គេដល់ព្រំប្រទល់

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងបើកផ្លូវទៅស្រុកម៉ូអាប់ដោយកម្ទេចក្រុងនានានៅតាមព្រំដែន»។

អេសេបូន អេឡាឡេ យេស៊ីម៉ូត ក្រុងបាល មេយ៉ូន និងក្រុងគារយ៉ាថែម

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងចាប់ផ្តើមនៅតាមក្រុងធំៗ

ដូចជាបេតសៃហ្សិម បាលបាលម៉ូន និង គីរីរ៉ាហីម»។

ទៅដល់ប្រជាជននៅទឹកដីខាងកើត ដែលជាអ្នកបានទាស់នឹងប្រជាជននៃអាំម៉ូន

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងបញ្ជូនកងទ័ពតែមួយពីប្រជាជាតិនានានៅភាគខាងកើតដែលវាយប្រហារអាំម៉ូន»។

យើងនឹងឲ្យដល់ពួកគេនូវសម្បត្តិ ទុកជាកេរអាករ ដូច្នោះប្រជាជននៃពួកអាំម៉ូននឹងមិនបាននឹកចាំ

ក្នុងចំណោមជនជាតិទាំងទាំងនោះ

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងធ្វើអោយកងទ័ពវាយឈ្នះអាំម៉ូនដើម្បីកុំឲ្យមាននរណានឹកដល់ពួកគេទៀតឡើយ»។

ពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។

Ezekiel 25:12

យើងនឹងប្រហារទឹកដីអេដុមជាមួយដៃរបស់យើង

សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នា

«យើងនឹងវាយអ្នកដោយដៃរបស់ខ្ញុំ» នៅក្នុងជំពូក ២៥:៦។

ពីក្រុងថេម៉ាន ទៅដល់ដេដាន់

នេះជាទីក្រុងពីរនៅចុងខាងជើងនៃស្រុកអេដុម។

នេះមានន័យថាព្រះអង្គនឹងបំផ្លាញស្រុកអេដុមទាំងអស់។

ពួកគេនឹងដួលស្លាប់ដោយសារដាវ

ពាក្យថា «ការដួល» តំណាងឲ្យការសម្លាប់ និង «ដាវ» សំដៅទៅលើការប្រយុទ្ធ។

ការបកប្រែរបៀបផ្សេងទៀត:

«សត្រូវរបស់ពួកគេនឹងសម្លាប់ពួកគេដោយដាវរបស់ពួកគេ» (សូមមើល:

Ezekiel 25:14

យើងនឹងដាក់ការសងសឹករបស់យើង ទៅលើជនជាតិអេដុម ដោយសារដៃនៃជនជាតិអ៊ីស្រាអែល

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងប្រើអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងអោយសងសឹកនឹងប្រជាជនអេដុម»។

ពួកគេនឹងធ្វើដល់ជនជាតិអេដុម តាមកំហឹង និងសេចក្តីក្រោធរបស់យើង

ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងបង្ហាញកំហឹង

generated on Wed Sep 10 16:16:32 2025

និងសេចក្ដីក្រោធរបស់យើង» ឬ
«ពួកគេនឹងដាក់ទណ្ឌកម្មលើស្រុកអេដុមស្របតាមកំហឹង
និងសេចក្ដីក្រោធរបស់យើងប្រឆាំងនឹងប្រជាជនអេដុម»
កំហឹង និងសេចក្ដីក្រោធ
ពាក្យ «សេចក្ដីក្រោធ» មានន័យជាមូលដ្ឋានដូចគ្នាទៅ និងពាក្យថា «កំហឹង»។
ការបកប្រែរបៀបផ្សេងទៀត: «កំហឹងខឹងរបស់យើង» ឬ
«កំហឹងដ៏ខ្លាំងរបស់យើង»
ពួកគេនឹងស្គាល់សេចក្ដីសងសឹករបស់យើង
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជននៅស្រុកអេដុមនឹងដឹងថាយើងបានសងសឹកពួកគេវិញ»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
ការបកប្រែរបៀបផ្សេងទៀត: «នេះជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលប្រាប់» ឬ
«នេះជាអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូលថានឹងកើតឡើង»។
Ezekiel 25:15
ជនជាតិភីលីស្ទីនបានដាក់ការសងសឹកដោយព្យាបាទ ហើយពួកគេព្យាយាម
ដើម្បីបំផ្លាញយូដាម្តងហើយម្តងទៀត
ការបកប្រែរបៀបផ្សេងទៀត: «ពីព្រោះពួកភីលីស្ទីនស្អប់ប្រជាជននៅស្រុកយូដា
ហើយព្យាយាមសងសឹកពួកគេម្តងហើយម្តងទៀត»
មើល៍!
ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
យើងនឹងលាដៃយើងចេញទៅទាស់ជាមួយជាតិភីលីស្ទីន
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងប្រគល់ដៃដ៏ខ្លាំងពូកែរបស់យើងទៅនឹងពួកភីលីស្ទីន» ឬ
«យើងនឹងបង្វែរកម្លាំងដ៏ខ្លាំងរបស់យើងប្រឆាំងនឹងពួកភីលីស្ទីន»
យើងនឹងកាត់ចេញ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបំផ្លាញ» ឬ «យើងនឹងកម្ចាត់» (UDB)
កេរេធីម
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនកេរេធីម»។
ប្រជាជននេះរស់នៅស្រុកភីលីស្ទីន
ពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែឃ្លាស្រដៀងគ្នានេះថា
«អ្នកនឹងដឹងថាយើងជាព្រះអម្ចាស់» នៅក្នុងជំពូក ៦:៦។

---

26 [1]ដូច្នោះ វាកើតឡើងនៅឆ្នាំទីដប់មួយ ថ្ងៃទីមួយនៅក្នុងខែនោះ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ដោយព្រោះក្រុងទីរ៉ុស
បាននិយាយទាស់នឹងក្រុងយេរូសាឡឹមថា «បពិត្រ! ទ្វាររបស់មនុស្សទាំងនោះនឹងត្រូវបាក់បែក! ហើយនាងនឹងវិលមករកយើង យើងនឹងបានពេញបរិបូណ៌
ដោយសារនាងបានវិនាស។
[3]ហេតុនោះ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល៍! យើងទាស់នឹងអ្នកទីរ៉ុសអើយ ហើយយើងនឹងលើកឲ្យមាន ជនជាតិជាផ្សេងៗមកទាស់នឹងអ្នក ដូចជាសមុទ្រ
មានរលកធំ។[4]ពួកគេនឹងបំផ្លាញកំផែងនៃក្រុងទីរ៉ុស ហើយនឹងផ្ដួលប៉មទាំងអស់នោះ។ យើងនឹងគាស់យកទាំងធូលីដីចេញទៅ ឲ្យទីក្រុងនោះនៅជាថ្មដា
រដែលនៅតាមទីវាល។
[5]ក្រុងទីរ៉ុសនឹងក្លាយទៅជាកូនកោះមួយនៅដណ្ដាលសមុទ្រ ដែលគេប្រើសម្រាប់ហាលសំណាញ់ ចាប់តាំងពីយើងជាព្រះជាអម្ចាស់បានប្រកាសការនេះ
អ្នកនឹងក្លាយជាកន្លែងជនជាតិផ្សេងៗប្លន់យកទៅ។[6]កូនស្រីរបស់នាងដែលនៅឯចម្ការវិញនឹងត្រូវដោយមុខដាវ ហើយគេនឹងស្គាល់ថា យើងពិតជាព្រះអម្ចាស់»។
[7]ដ្បិតនេះជាព្រះអម្ចាស់មានព្រះបន្ទូលថា ចូរមើល៍! ពីទិសខាងជើងយើងនឹងនាំនេប៊ូក្នេសាជាស្តេចនៃបាប៊ីឡូន ជាស្តេចលើអស់ទាំងស្តេច មកវាយប្រហារអ្នក គឺមាន
កងពលសេះ រទេះចម្បាំង ព្រមទាំងមនុស្សជាច្រើនដែរ។[8]ទ្រង់នឹងសម្លាប់ប្រជាជនរបស់អ្នកនៅឯចម្ការ។ ស្តេចនឹងរៀបការឡោមព័ទ្ធ ហើយនិងលើកកំពែងការពារខ្លួន
ដើម្បីវាយជញ្ជាំងក្រុងអ្នក ហើយលើកខែលទាស់នឹងអ្នកដែរ។
[9]ស្តេចនឹងប្តូរគ្រឿងអាវុធដើម្បីវាយទម្លុះកំពែងរបស់អ្នក ហើយឧបករណ៍របស់ទ្រង់នឹងកម្ទេចប៉មរបស់អ្នក។[10]កង ទ័ពសេះច្រើន នឹងធ្វើឲ្យធូលីហុយឡើងគ្របលើអ្នក
កំផែងរបស់អ្នកនឹងញ័រ ដោយសូរសន្ធឹកនៃពលសេះនិងរទេះចម្បាំងទាំងប៉ុន្មានរបស់គេ ក្នុងកាលដែលគេចូលទៅតាមទ្វារក្រុងរបស់អ្នក ដូចជាចូលទៅក្នុងទីក្រុងណា
ដែលគេបានរំលំកំពែងហើយ។[11]ជើងសេះរបស់ទ្រង់នឹងជាន់កម្ទេចផ្លូវទាំងប៉ុន្មានរបស់អ្នក។ ទ្រង់នឹងសម្លាប់ជនជាតិអ្នកដោយដាវ ហើយបង្គោលថ្មនៃកម្លាំងអ្នក នឹងត្រូវ
រំលំដល់ដី។
[12]ពួកគេទាំងនោះ នឹងដណ្ដើមយកទ្រព្យសម្បត្តិរបស់អ្នក គេរឹបអូសយកទំនិញរបស់អ្នក។ ពួកគេនឹងរំលំកំពែងរបស់អ្នក បំផ្លាញវិមានរបស់អ្នក។ ថ្ម ឈើ និងអ្វីៗទាំងនោះ
ពួកគេបោះទៅក្នុងទឹក។[13]យើងនឹងបំបាត់ចម្រៀងរបស់អ្នក។ ហើយសំឡេងពិណរបស់អ្នកក៏នឹងលែងឮទៀតដែរ។[14]យើងនឹងធ្វើក្លាយជាថ្មមួយនៅទីវាល
អ្នកនឹងក្លាយជាកន្លែងហាលសំណាញ់។ អ្នកមិនសង់អ្វីឡើងវិញឡើយ ដ្បិតយើងជាព្រះជាអម្ចាស់ដែលបានថ្លែងបន្ទូល នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះបានប្រកាស។
[15]ព្រះជាអម្ចាស់ដ៏ជាព្រះមានបន្ទូលដូច្នេះទៅកាន់ក្រុងទីរ៉ុស តើអ្នកតាមកោះមិនញ័ររន្ធត់ និងសម្លេងនៃការធ្លាក់ចុះរបស់អ្នក
ហើយនិងសម្លេងថ្ងូរពីការសម្លាប់ក្នុងចំណោមអ្នក?។[16]ក្រោយមក ស្តេចទាំងឡាយដែលនៅតាមឆ្នេរសមុទ្រនឹងនាំគ្នាចុះពីបល្ល័ង្ក ហើយបានដោះសម្លៀកបំពាក់ និងអាវប៉ាក់
ដែលធ្វើពីក្រណាត់ចេញ។ ពួកអ្នកធំបានពាក់ការភ័យខ្លាចមកជំនួសវិញ ហើយអង្គុយផ្ទាល់ដី ទាំងភ័យញាប់ញ័រនៅក្នុងពេលនោះ
ហើយពួកគេតក់ស្លុតដោយសារតែអ្នក។
[17]ពួកគេស្មូត្រទំនួញសោកសៅសម្រាប់អ្នក ហើយនិយាយទៅកាន់អ្នកថា តើអ្នកដែលរស់នៅដោយទាហានជើងទឹក គឺបានបំផ្លាញចោល។
ទីក្រុងដែលល្បីហើយធ្លាប់ជាក្រុងដែលរឹងមាំបំផុត ពេលនេះត្រូវរលាយបាត់ពីឆ្នេរសមុទ្រ។ ពួកអ្នកក្រុងដែលរស់នៅទីនេះ
ឥឡូវនេះបានរសាត់ទៅគ្រប់ទីកន្លែងដែលក្បែរពួកគេ។[18]ឥឡូវ ប្រជាជននៅតាមឈូងសមុទ្រ ភ័យញាប់ញ័រ ប្រជាជននៅតាមឆ្នេរសមុទ្ររន្ធត់ចិត្ត ព្រោះ
យើញការស្លាប់របស់អ្នក។
[19]ដ្បិតព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូល ពេលយើងធ្វើឲ្យអ្នក ក្លាយទៅជាក្រុងដែលសល់តែសំណល់បាក់បែក គឺដូចក្រុងដែលគ្មានមនុស្សរស់នៅ ហើយពេលយើងធ្វើឲ្យ
ទឹកពីទីជម្រៅ និងមហាសាគរជន់ឡើងគ្របពីលើអ្នក[20]ក្រោយមក យើងនឹងនាំអ្នកចុះទៅជាមួយអស់អ្នកដែលធ្លាក់ក្នុងរណ្ដៅមុនអ្នក យើងនឹងឲ្យអ្នករស់នៅក្នុងទីជម្រៅនៃ
ផែនដី ជាមួយអស់អ្នកដែលធ្លាក់ក្នុងរណ្ដៅ ជាកន្លែងវិនាសបង់អស់កល្បជានិច្ច។ អ្នកនឹងមិនវិលត្រឡប់មកផែនដីទទួលកន្លែងក្នុងពិភពរបស់អស់អ្នកដែលមានជីវិត
ឡើយ។[21]យើងនឹងដាក់មហត្តរាយលើអ្នក ហើយនឹងលែងមានអ្នកទៀតហើយ។ រួចហើយអ្នកនឹងស្វែងរក តែអ្នកនឹងមិនអាចរកឃើញឡើយ នេះជាព្រះបន្ទូលរបស់
ព្រះជាអម្ចាស់ដ៏ជាព្រះ»។

Ezekiel 26:1
ឆ្នាំទីដប់មួយ
ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងឆ្នាំទីដប់មួយនៃការនិរទេសរបស់ស្តេចយេហូយ៉ាគីម» (សូមមើល: និង
ថ្ងៃទីមួយនៅក្នុងខែ
វាមិនប្រាកដថាខែណាមួយនៃប្រតិទិនហេប្រឺដែលលោកអេសេគាលចង់មានន័យ។
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២:១។
ក្រុងទីរ៉ុសបាននិយាយទាស់នឹងក្រុងយេរូសាឡឹម
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនក្រុងទីរ៉ុសបាននិយាយទាស់នឹងប្រជាជននៅក្រុងយេរូសាឡឹម។
បពិត្រ!
ការបកប្រែរបៀបផ្សេងទៀត: «ចាស/បាទ!» ឬ «ល្អណាស់»

generated on Wed Sep 10 16:16:32 2025

ទ្វាររបស់មនុស្សទាំងនោះនឹងត្រូវបាក់បែក
ប្រជាជននៅក្រុងទីរ៉ុសប្រើពាក្យទាំងនេះ
ដើម្បីសំដៅទៅក្រុងយេរូសាឡិមហាក់ដូចជាទ្វារក្រុងដែលអ្នកជំនួញមកពីប្រទេសជុំវិញធ្លាប់ធ្វើការជួញដូរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពបានបំបែកទ្វារប្រជាជន» ឬ
«កងទ័ពបានបំផ្លាញក្រុងយេរូសាឡិមដែលដូចជាទ្វារ
នៃប្រជាជនពីប្រទេសជាច្រើនបានឆ្លងកាត់»។
នាងនឹងរិលមករកយើង
ពាក្យថា «នាង» នៅទីនេះសំដៅទៅលើពាក្យ «ច្រកទ្វារ» ដែល «បានប្រែក្លាយ»
លើចង្កេះរបស់ពួកគេដើម្បីបើកទៅកាន់ក្រុងទីរ៉ុស។
ឃ្លានេះមានន័យថាឥឡូវនេះក្រុងទីរ៉ុសបានជំនួសក្រុងយេរូសាឡិមជាទីក្រុងដែលឈ្មួញមកពីប្រទេសជុំវិញ
ការបកប្រែរបៀបផ្សេងទៀត: «ផ្លូវចេញចូលបានបើកឲ្យយើង»
យើងនឹងបានពេញបរិបូណ៌
នៅទីនេះដើម្បី «បំពេញ» មានន័យថាមានភាពរុងរឿង។ «យើងនឹងរីកចម្រើន»
នាងបានវិនាស
«ក្រុងយេរូសាឡិមត្រូវបានបំផ្លាញ»
Ezekiel 26:3
មើល!
ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក!»
យើងទាស់នឹងអ្នកទីរ៉ុសអើយ ហើយយើងនឹងលើកឲ្យមាន ជនជាតិជាផ្សេងៗមកទាស់នឹងអ្នក ដូច
ជាសមុទ្រមានរលកធំ
ពាក្យថា «ប្រជាជាតិនានា» នៅទីនេះសំដៅទៅលើកងទ័ពរបស់ខ្លួន។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងប្រមូលកងទ័ពពីប្រជាជាតិនានា
ដែលមានកម្លាំងខ្លាំងដូចរលកសមុទ្របក់បោក»។
ប៉ម
ប៉មគឺជាអគារខ្ពស់មួយដែលប្រើសម្រាប់មើលសត្រូវ ឬលាក់ខ្លួន។
យើងនឹងគាស់យកទាំងធូលីដីចេញទៅ ឲ្យទីក្រុងនោះនៅជាថ្មដារដែលនៅតាមទីវាល
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងធ្វើឲ្យកងទ័ពបំផ្លាញទីក្រុងទាំងស្រុង
ហើយពួកគេនឹងមិនទុកអ្វីនៅទីនោះទៀតឡើយក្រែងលោវាប្រៀបដូចផ្នាំងថ្មគ្មានអ្វីនៅលើនោះ»
Ezekiel 26:5
ក្រុងទីរ៉ុសនឹងក្លាយ
ទីក្រុងនានាជារឿយៗត្រូវបានគេហៅថា « នាង»។ ការបកប្រែរបៀបផ្សេងទៀត:
«ទីរ៉ុសនឹងក្លាយជា» ឬ «វានឹងក្លាយទៅជា»។
ជាកូនកោះមួយនៅដណ្តាលសមុទ្រ
ផ្នែកមួយនៃក្រុងទីរ៉ុសគឺជាកោះមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«កោះទទេដែលត្រូវបានប្រើសម្រាប់សម្ងួតអួននេសាទ» ឬ
«កោះវាលខ្សាច់ដែលប្រជាជនហាលនូវសំណាញ់ចាប់ត្រី»។
ព្រះជាអម្ចាស់បានប្រកាសការនេះ
សូមមើលពីរបៀបដែលបានបកប្រែក្នុងជំពូក ៥:១១។
ប្លន់
វត្ថុដែលមនុស្សបានលួច
អ្នកនឹងក្លាយជាកន្លែងជនជាតិផ្សេងៗប្លន់
ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពមកពីប្រជាជាតិនានានឹងលួចយកអ្វីៗទាំងអស់ពីក្រុងទីរ៉ុស»។
កូនស្រីរបស់នាងដែលនៅឯចម្ការវិញនឹងត្រូវដោយមុខដាវ
ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពសត្រូវនឹងសំលាប់កូនស្រីរបស់នាងដែលកំពុងនៅឯចំការ»។
កូនស្រីរបស់នាងដែលនៅឯចម្ការ
ឃ្លានេះអាចត្រូវបានគេហៅថាជាកូនស្រីរបស់ទីក្រុង ដែលគ្រប់គ្រងលើពួកគេ។
អាចមានន័យថា គឺ១) ភូមិតូចៗនៅលើដីគោកដែលក្រុងទីរ៉ុសគ្រប់គ្រង ឬ ២)
ស្ត្រីវ័យក្មេងនៅក្រុងទីរ៉ុស ដែលកំពុងធ្វើការនៅចម្ការ។
គេនឹងស្គាល់ថា យើងពិតជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែឃ្លានេះស្រដៀងគ្នាថា
«អ្នកនឹងដឹងថាយើងជាព្រះអម្ចាស់» នៅក្នុងជំពូក ៦:៦។
Ezekiel 26:7
ចូរមើល៍!
ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក!»
យើងនឹងនាំនេប៊ូក្នេសា
ព្រះអង្គកំពុងប្រើនេប៊ូក្នេសាដើម្បីសំរេចបំណងប្រាថ្នារបស់ទ្រង់។
ស្តេចលើអស់ទាំងស្តេច
«ស្តេចដែលមានអំណាចបំផុត»
ព្រមទាំងមនុស្សជាច្រើនដែរ
ការឧទាហរណ៍នេះ សង្កត់ធ្ងន់ទៅលើទំហំដ៏ធំនៃកងទ័ពនេប៊ូក្នេសា។
ទ្រង់នឹងសម្លាប់ប្រជាជនរបស់អ្នក
ពាក្យថា «គាត់» នៅទីនេះសំដៅទៅលើនេប៊ូក្នេសាហើយនិង សម្រាប់គឺកងទ័ព។
ការបកប្រែរបៀបផ្សេងទៀត: «កងទ័ពរបស់គាត់នឹងសំលាប់កូនស្រីរបស់អ្នក»
Ezekiel 26:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ស្តេចនឹងបួរ
ពាក្យថា «គាត់» សំដៅទៅលើនេប៊ូក្នេសាជាស្តេចស្រុកបាប៊ីឡូន។
គ្រឿងអាវុធ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤:១។
ឧបករណ៍របស់ទ្រង់
«ឧបករណ៍នៃសង្គ្រាមរបស់ទ្រង់»
Ezekiel 26:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
Ezekiel 26:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
តើអ្នកតាមកោះមិនញ័ររន្ធត់ .. ក្នុងចំណោមអ្នក
«កោះរញ្ជួយ ...នៅកណ្តាលអ្នក»។
Ezekiel 26:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
Ezekiel 26:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ធ្វើឲ្យអ្នក
ពាក្យថា «អ្នក» គឺសំដៅទៅលើទីក្រុងទីរ៉ុស។ នៅក្នុងភាសាដើមវាជាឯកវចន:
ពីព្រោះប្រជាជាតិជាច្រើនត្រូវបានគេគិតថាជាស្ត្រី។

---

27 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំម្តងទៀតប្រាប់ថា[2]«ឥឡូវអ្នក កូនមនុស្សអើយ! ចូរច្រៀងទំនួញទុក្ខសោកឲ្យទីក្រុងទីរ៉ុស[3]ហើយប្រាប់ដល់ក្រុងទីរ៉ុសថា អ្នកណាដែលនៅត្រង់ជាមួយទ្វារសមុទ្រ ជាអ្នកជំនួញសម្រាប់ជនជាតិនៅកោះជាច្រើនអើ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះថា ទីរ៉ុសអើយ អ្នកបាននិយាយថា យើងគ្រប់លក្ខណ៍ល្អបំផុត។

[4]ព្រំដែនរបស់អ្នកនៅកណ្តាលសមុទ្រ ពួកអ្នកដែលបានសង់អ្នកគេបានធ្វើឲ្យអ្នកមានស្រស់ស្អាត។[5]ក្តាររបស់អ្នកសុទ្ធតែជាឈើកកោះពីទឹកដីសេនារ គេបានយកដើមតាត្រៅពីព្រៃល្បាណូន មកធ្វើជាដងក្តោងសម្រាប់អ្នក។

[6]ពួកគេយកឈើម៉ៃសាក់ពីទឹកដីបាសាន ពួកគេធ្វើជាពិតាន យកឈើគ្រញូងពីកោះគីប្រុស មកក្រាលជាមួយ ហើយពួកគេខាត់ឈើទាំងនោះជាមួយភ្លុក។[7]ក្តោងរបស់អ្នកធ្វើពីក្រណាត់ប៉ាក់ដ៏ល្អ មកពីទឹកដីអេស៊ីប សម្រាប់ឲ្យអ្នកប្រើជាទង់ផង!

[8]ពួកអ្នករស់នៅក្រុងស៊ីដូន និងអើវ៉ាឌ ជាអ្នកចែវសំពៅរបស់អ្នក ទីរ៉ុសអើយ ពួកអ្នកប្រាជ្ញនៅក្នុងអ្នក ពួកគេជាអ្នកបើកសំពៅ។[9]ពួកអ្នកចាស់ៗ ដែលមានបពិសោធន ពីក្រុងកេបាលបានជួយបិតប៉ះ ហើយនាវាទាំងអស់នៅសមុទ្រ និងពួកចែវសំពៅនៅក្នុងចំណោមអ្នក បានបន្តយកទំនិញរបស់អ្នកទៅលក់។

generated on Wed Sep 10 16:16:32 2025

[10]ជនជាតិពើស៊ី និងជនជាតិលូឌ និងជនជាតិពូតនៅក្នុងកងទ័ពរបស់អ្នក ពួកអ្នកចម្បាំងរបស់អ្នក។ ពួកគេបានពាក់ព្យួរខែលនិងមួកសឹកនៅក្នុងអ្នក ពួកគេបង្ហាញសេចក្តីរុងរឿងរបស់អ្នក។[11]មនុស្សក្រុងអើវ៉ាឌ និងពួកហេឡិច ជាអ្នកការពារនៅលើកំផែងជុំវិញ ហើយមានមនុស្សក្លៀវក្លានៅក្នុងប៉មរបស់អ្នក។ ពួកគេបានពាក់ព្យួរអស់ទាំងខែលរបស់គេនៅជញ្ជាំងជុំវិញអ្នក! ពួកគេបានធ្វើឲ្យបានស្រស់ស្អាត។
[12]ក្រុងតើស៊ីសជាអ្នកជំនួញជាមួយអ្នក ដោយព្រោះអ្នកមានទ្រព្យសម្បត្តិគ្រប់មុខជាបរិបូរសម្រាប់លក់ គឺរុប្រាក់ ដែក ស៊ីវិឡាត និងសំណ។ ពួកគេបានទំនិញហើយលក់សម្រាប់សង្គាម![13]ពួកយ៉ាវ៉ាន ពួកទូបាល ហើយពួកមែសេកជាអ្នកជំនួញជាមួយអ្នក ពួកគេដូរអ្នកបម្រើ ហើយព្រមទាំងគ្រឿងប្រដាប់លង្ហិនឲ្យបានទំនិញរបស់អ្នក។
[14]បេត តូកាម៉ា ពួកគេលក់សេះជិះ សេះចម្បាំង និងលាកាត់ឲ្យបានទំនិញរបស់អ្នក។[15]មនុស្សមកដេដាន់ដែលធ្វើជំនួញជាមួយអ្នក។ ទំនិញបាននៅក្នុងដៃរបស់អ្នក ហើយពួកគេបានបញ្ជូនមកវិញភ្លុក និងឈើគ្រញូងមកឲ្យអ្នកវិញ។
[16]អារ៉ាមបានទិញទំនិញពីអ្នកជាច្រើន ពួកគេបានដូរកែវមរកត សំពត់ពណ៌ស្វាយ សំពត់ប៉ាក់ សំពត់ទេសឯកយ៉ាងម៉ដ្ដ ផ្កាថ្ម និងត្បូងទទឹមឲ្យបានទំនិញរបស់អ្នក។[17]យូដា និងអ្នកនៅអ៊ីស្រាអែល ជាអ្នកជំនួញជាមួយអ្នក។ ពួកគេយកស្រូវសាលីពីមីនីត បង្អែម ទឹកឃ្មុំ និងប្រេង ហើយក្រែមមុខសះមកដូរនឹងទំនិញរបស់អ្នក។[18]ដាម៉ាសក៏ជួញដូជារបស់អ្នក អ្វីដែលអ្នកធ្វើបាន ដោយព្រោះអ្នកមានទ្រព្យសម្បត្តិគ្រប់មុខ ហើយនិងស្រាទំពាំងបាយជូរ ពីទឹកដីហេលបូន និងរោមចៀមស។
[19]ដាន់ និងយ៉ាវ៉ាន គេបានដូរអំបោះនិងទំនិញរបស់អ្នក មានទាំងដែកថែប ឈើអែម និងឫសកន្ធាយ នៅក្នុងទំនិញរបស់អ្នក។[20]ពួកអ្នកស្រុកដាន់ធ្វើជំនួញជាមួយអ្នក ដោយយកប្រដាប់ប្រដាសម្រាប់សេះចម្បាំងមកលក់ឲ្យអ្នក។[21]ពួកអារ៉ាប់ ហើយពួកអ្នកសឹកនាំនៅទឹកដីកេដារទាំងអស់ ជាអ្នកជំនួញជាមួយអ្នក គេលក់កូនចៀម ចៀម ឈ្មោល និងពពែដល់អ្នក។
[22]ពួកអ្នកឈ្មួញពីសេបា ហើយពីរ៉ាម៉ា ជាអ្នកជួញក៏ជាអ្នកលក់ គ្រឿងម្ហូបយ៉ាងវិសេស ត្បូងមានតម្លៃ និងមាសដូរនឹងទំនិញរបស់អ្នក។[23]ខារ៉ាន ហើយអ្នកកាននេ និងអ្នកអេដែន ព្រមទាំងពួកឈ្មួញនៃដែលមកពីសេបា អាសស៊ើរ និងគីលម៉ាឌ។
[24]ពួកគេគឺជាឈ្មួញរបស់អ្នក មានសំពត់ពណ៌ខៀវ ហើយប៉ាក់ក្រណាត់ ហើយភួយនៃក្រណាត់ភ្លឺរលោង ក្រហម វេចយ៉ងល្អជាមួយក្រណាត់ យកមកលក់ដូរជាមួយអ្នក។[25]គ្រប់ទាំងសំពៅរបស់អ្នកតើស៊ីសជាពួកដឹកទំនិញអ្នក អ្នកបានចម្រើនជាពោរពេញឡើង ហើយបានថ្កុំថ្កើងយ៉ាងក្រៃលែងនៅកណ្តាលសមុទ្រនោះ!
[26]ពួកអ្នកដើរសំពៅរបស់អ្នកបាននាំអ្នកទៅក្នុងសមុទ្រធំ ខ្យល់ពីទិសខាងកើតបានធ្វើឲ្យសំពៅអ្នកបែកធ្លាយ នៅក្នុងកណ្តាលសមុទ្រ។[27]ទ្រព្យសម្បត្តិរបស់អ្នក និងរបស់លក់ដូរ ហើយទំនិញរបស់អ្នក ព្រមទាំងពួកជើងឈ្នួល ពួកនាយសំពៅ ពួកបិទពរ និងពួកអ្នកលក់ដូរទំនិញរបស់អ្នក ហើយពួកទាហានដែលនៅក្នុងអ្នក និងបណ្តាជនទាំងប៉ុន្មានដែលនៅកណ្តាលអ្នក គេនឹងត្រូវលិចលង់នៅផ្នែសមុទ្រ ក្នុងថ្ងៃដែលអ្នកត្រូវអន្តរាយនោះ។
[28]ក្រុងដែលនៅខាងសមុទ្របានញ័ររន្ធត់ដោយសារសម្រែកពួកអ្នកសំពៅ។[29]ពួកអ្នកដែលធ្វើការលើសំពៅ ពួកអ្នកជំនួញ និងពួកនាយសំពៅតាមផ្លូវសមុទ្រ គេនឹងឡើងពីនាវារបស់គេមកឈរនៅលើច្រាំង។[30]ក្រោយមក ពួកគេបានបន្លឺសំឡេងឡើង ឲ្យអ្នកបានឮ ហើយទ្រហោយំដោយយ៉ាងល្វីងជូចត់ ព្រមទាំងបាចធូលីដីទៅលើក្បាល។ ពួកគេដេកនៀលនៅក្នុងផេះ។
[31]ពួកគេនឹងកោរសក់ទំពែកសម្រាប់អ្នក ព្រមទាំងស្លៀកពាក់ធ្មៃ ហើយយំស្តាយអ្នក ដោយចិត្តជូរចត់ ហើយដោយការស្រែកចេញមក។[32]ពួកគេកំពុងតែទ្រហោយំ នោះគេនឹងចាប់ផ្តើមទួញទំនួញដោយព្រោះអ្នក គេនឹងទួញថា តើអ្នកណាដូចជាទីរ៉ុស ជាអ្នកដែលបាននាំដល់កន្លែងស្ងាត់នៅក្នុងកណ្តាលសមុទ្រ?[33]ពេលណាទំនិញរបស់អ្នកចេញទៅតាមផ្លូវសមុទ្រ នោះអ្នកបានចម្អែតដល់ជនជាតិជាច្រើន អ្នកបានធ្វើឲ្យពួកស្តេចនៅផែនដីមានជាច្រើនឡើង ដោយសារទ្រព្យសម្បត្តិ និងទំនិញដ៏បរិបូររបស់អ្នក!
[34]ប៉ុន្តែពេលដែលអ្នកត្រូវអន្តរាយនៅក្នុងសមុទ្រ នោះទំនិញ និងពួកអ្នកទាំងប៉ុន្មានបានធ្លាក់ទៅបាទសមុទ្រជាមួយអ្នកដែរ![35]ពួកអ្នកនៅកោះទាំងនោះមានសេចក្តីរន្ធត់ពីដំណើរអ្នក ហើយពួកស្តេចភ័យខ្លាចជាខ្លាំង ក៏មានមុខភ័យ![36]ពួកអ្នកជំនួញនៃមនុស្សទាំងនោះ គេធ្វើហូចដាក់អ្នក អ្នកបានត្រឡប់ជាទីស្ញែងខ្លាច ហើយលែងមានជារៀងរហូតតទៅ»។

Ezekiel 27:1
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»
សូមមើលរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ១:១។
អ្នកណាដែលនៅត្រង់ជាមួយទ្វារសមុទ្រ
«ដែលរស់នៅឯច្រកចូលសមុទ្រ» ឃ្លានេះមានន័យថា ១)
«ដែលរស់នៅតាមកំពង់ផែសមុទ្រ» ឬ ២) «ដែលគ្រប់គ្រងលើកំពង់ផែសមុទ្រ»។
Ezekiel 27:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ព្រំដែនរបស់អ្នក
«ព្រំដែននៃនគររបស់អ្នក»
ដងក្តោង
បង្គោលធំមួយនៅលើកប៉ាល់ ដែលទប់ក្តោងនៃកប៉ាល់
Ezekiel 27:6
ព័ត៌មានទូទៅ :
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ឈើម៉ៃសាក់
បំណែកឈើវែង ដែលមនុស្សប្រើដើម្បីធ្វើឲ្យទូកមានចលនា
ពិតាន
ជាផ្នែកមួយនៃទូកដែលមនុស្សអាចដើរបាន
ភ្លុក
ជាវត្ថុធាតុដើមពណ៌សស្រស់ស្អាត និងរឹងដែលត្រូវបានផលិតចេញពីធ្មេញសត្វ
ក្តោង
ក្រណាត់ធំៗ នៃកប៉ាល់មួយនៅពេលខ្យល់បក់មកលើពួកវា
Ezekiel 27:8
ព័ត៌មានទូទៅ :
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
អ្នកបើកសំពៅ
មនុស្សដែលគ្រប់គ្រងកន្លែងដែលកប៉ាល់ត្រូវទៅ
ជួយបិតប៉ះ
«ជួសជុលស្នាមប្រេះ» ឬ «ជួសជុលការលេចធ្លាយ»
ពួកចែវសំពៅ
មនុស្សដែលជិះទូកនៅលើសមុទ្រ
Ezekiel 27:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ពួកអ្នកចម្បាំងរបស់អ្នក
«បុរសដែលបានប្រយុទ្ធនៅក្នុងសង្គ្រាមរបស់អ្នក» ឬ
«បម្រើជាអ្នកចម្បាំងរបស់អ្នក»
ពួកគេបង្ហាញសេចក្តីរុងរឿងរបស់អ្នក
«ពួកគេបានផ្តល់ឲ្យអ្នកនូវភាពរុងរឿង!»
Ezekiel 27:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ដែក
ជាដែករឹងដែលល្អសម្រាប់ផលិតអាវុធនិងរបស់របរផ្សេងៗ
ស៊ីវិឡាត
លោហៈដែលសល់បន្ទាប់ពីបន្សុទ្ធមាស ប្រាក់ ឬជាតិដែក
សំណ
ជាលោហៈមានតម្លៃដែលមានទម្ងន់ធ្ងន់ និងទន់ជាងលោហធាតុផ្សេងទៀត
ពួកយ៉ាវ៉ាន
ប្រជាជាតិមួយនៅលើឆ្នេរខាងលិចនៃទ្វីបអាស៊ី។ វាត្រូវបានគេស្គាល់ផងដែរថាឡូនា
Ezekiel 27:14

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
សេះចម្បាំង
សេះឈ្មោលដែលខ្លាំង
ទំនិញបាននៅក្នុងដៃរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «អ្នកជាម្ចាស់ទំនិញ»។
Ezekiel 27:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ពណ៌ស្វាយ
«ក្រណាត់ពណ៌ស្វាយ» ឬ «អំបោះពណ៌ស្វាយ»
ផ្កាថ្ម
បំណែកដ៏ស្រស់ស្អាតនៃសម្ភារៈពណ៌សរឹងដែលបានមកពីសត្វនៅក្នុងសមុទ្រ
បង្អែម
អត្ថន័យនៃពាក្យភាសាហេព្រើរដែលបានបកប្រែនៅទីនេះថាជា «នំខេក» គឺមិនប្រាកដប្រជាទេ។ សំណៅសម័យទំនើបខ្លះបកប្រែវាថា «ប្រទាល» ឬ «អាហារល្អធ្វើពីគ្រាប់ធញ្ញជាតិ»។
ត្បូងទទឹម
ថ្មក្រហមដែលមានតម្លៃណាស់
ក្រែម
ក្លិនស្ករកៅស៊ូ ឬ ជ័រដែលមានក្លិនផ្អែមដែលកើតចេញពីដើមឈើ
Ezekiel 27:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ឈើអែម
ប្រភេទនៃគ្រឿងទេស ដែលបានមកពីសំបកឈើ។ «គ្រឿងទេសកាស៊ី» គឺជាឈ្មោះមួយផ្សេងទៀតសម្រាប់គ្រឿងទេសនេះ។
ឫសកន្ធាយ
ស្មៅមួយប្រភេទដែលមនុស្សប្រើជាទឹកអប់ និងថ្នាំ
ប្រដាប់ប្រដាសម្រាប់សេះចម្បាំង
ក្រណាត់មួយដុំដែលមនុស្សដាក់លើសេះចម្បាំងនៅក្រោមកែប
Ezekiel 27:22
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ត្បូងមានតម្លៃ
«ថ្មមានតំលៃ»
Ezekiel 27:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
មានសំពត់ពណ៌ខៀវ ហើយប៉ាក់ក្រណាត់
«អាវពណ៌ស្វាយដែលមានពណ៌ផ្សេងៗគ្នាជាច្រើន»
ភួយនៃក្រណាត់ភ្លឺរលោង ក្រហម វេចយ៉ងល្អជាមួយក្រណាត់
ក្រណាត់ត្បាញ - «ភួយដែលមានពណ៌ជាច្រើនដែលមនរចនា និងមានគុណភាពខ្ពស់»
នៅកណ្តាលសមុទ្រនោះ
«នៅពាក់កណ្តាលផ្លូវពាណិជ្ជកម្មទាំងអស់សម្រាប់ពាណិជ្ជកម្មតាមសមុទ្រ»។
Ezekiel 27:26
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ពួកអ្នកដើរសំពៅរបស់អ្នកបាននាំអ្នកទៅក្នុងសមុទ្រធំ
«មនុស្សដែលចែទូកនៅជួរអ្នក បាននាំអ្នកទៅសមុទ្រឆ្ងាយ»
នៅក្នុងកណ្តាលសមុទ្រ
«នៅកណ្តាលសមុទ្រ»
Ezekiel 27:28
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
ទ្រហោយំដោយយ៉ាងល្វីងជូចត់
«នឹងស្រែកថ្ងូរដោយទុក្ខព្រួយយ៉ាងខ្លាំង»
Ezekiel 27:31
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
នឹងកោរសក់ទំពែកសម្រាប់អ្នក
«នឹងកោរសក់របស់ពួកគេដើម្បីកុំអោយពួកគេមានសក់»
អ្នកណាដូចជាទីរ៉ុស
ការបកប្រែរបៀបផ្សេងទៀត: «គ្មានទីក្រុងណាដូចក្រុងទីរ៉ុសទេ»។
ជាអ្នកដែលបាននាំដល់កន្លែងស្ងាត់
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលត្រូវបានបំផ្លាញ»
ត្រើយម្ខាង
«នៅលើដី»
Ezekiel 27:34
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅទីក្រុងទីរ៉ុស។
សេចក្តីរន្ធត់ពីដំណើរអ្នក
«មានការភ្ញាក់ផ្អើលនិងភិតភ័យចំពោះអ្វីដែលបានកើតឡើងចំពោះអ្នក»
ហូចដាក់អ្នក
«ហូចចេញពីទុក្ខព្រួយសម្រាប់អ្នក»។ ការហូច គឺជាវិធីនៃការបង្ហាញភាពទុក្ខព្រួយ។
អ្នកបានត្រឡប់ជាទីស្ញែងខ្លាច
«វាបានក្លាយជាការគួរឲ្យភ័យខ្លាចសម្រាប់មនុស្សក្នុងការគិតអំពីអ្នក»

28 [1]បន្ទាប់មក ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ចូរប្រាប់ស្តេចក្រុងទីរ៉ុសទៅ ព្រះជាអម្ចាស់មានព្រះបន្ទូលដូចេ្នះ ចិត្តអ្នកព្រហើនណាស់! អ្នកហាននិយាយថា «ខ្ញុំជាព្រះ! ខ្ញុំគង់លើបល្ល័ង្ករបស់ព្រះ ដែលស្ថិតនៅកណ្តាលសមុទ្រ!» ទោះបីជា អ្នកជាមនុស្សមិនមែនជាព្រះទេ អ្នកធ្វើចិត្តខ្លួនឲ្យស្មើនឹងចិត្តរបស់ព្រះ[3]អ្នកគិតខ្លួនថា មានប្រាជ្ញាជាងដានីយ៉ែល ហើយថាគ្មានការអ្វីលាក់កំបាំងចំពោះអ្នកឡើយ!
[4]អ្នកបានខំធ្វើឲ្យខ្លួនមានទ្រព្យសម្បត្តិ ដោយប្រាជ្ញា និងជំនាញរបស់អ្នក ហើយទទួលបានមាសប្រាក់ដាក់ក្នុងឃ្លាំងរបស់អ្នក។[5]អ្នកមានប្រាជ្ញាជាមួយការរកស៊ី ហើយសម្បត្តិក៏ចម្រើនឡើងដូចេ្នះចិត្តអ្នកបានមានអំណួត ដោយសារទ្រព្យសម្បត្តិរបស់អ្នក។
[6]ហេតុនោះ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលថា ដោយព្រោះ អ្នកបានធ្វើចិត្តរបស់អ្នក ដូចជាចិត្តរបស់ព្រះជាម្ចាស់[7]យើងនឹងនាំជនជាតិដទៃ គឺជាពួកអ្នកគួរស្ញែងខ្លាចពីគ្រប់ជនជាតិមកលើអ្នក។ ពួកគេនឹងហូតដាវទៅទាស់នឹងភាពស្រស់ស្អាតនៃប្រាជ្ញារបស់អ្នក ហើយពួកគេនឹងប្រមាថក្តីរុងរឿងរបស់អ្នក។
[8]ពួកគេនឹងវាយទម្លាក់អ្នកទៅក្នុងរណ្តៅ អ្នកនឹងត្រូវស្លាប់ ដោយគេចាក់ទម្លុះនៅកណ្តាលសមុទ្រ។[9]តើអ្នកហ៊ាននិយាយថា «ខ្ញុំគឺជាព្រះ»
នៅចំពោះមុខអ្នកដែលចង់សម្លាប់អ្នកឬទេ? អ្នកគឺជាមនុស្សមិនមែងជាព្រះជាម្ចាស់ទេ ហើយអ្នកស្ថិតនៅក្នុងកណ្តាប់ដៃរបស់ពេជ្ឈឃាត។[10]អ្នកនឹងត្រូវស្លាប់ដោយដៃអ្នកមិនបានកាត់ស្បែក ដែលជាជនជាតិផ្សេង ដ្បិតយើងបានប្រកាសការនេះ នេះគឺជាព្រះបន្ទូលរបស់ព្រះជាអម្ចាស់ដ៏ជាព្រះ»។
[11]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំម្តងទៀតប្រាប់ថា[12]«កូនមនុស្សអើយ ចូរលើកបទទំនួញអំពីស្តេចក្រុងទីរ៉ុស ហើយប្រាប់ស្តេចនោះថា ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូចេ្នះ អ្នកជាគំរូពេញលក្ខណៈ អ្នកពោរពេញទៅដោយប្រាជ្ញា ហើយល្អដាច់គេបំផុត។[13]អ្នកស្ថិតនៅអេដែន ជាសួននៃព្រះជាម្ចាស់។ មានត្បូងគ្រប់មុខនៅលើខ្លួនអ្នក គឺត្បូងទទឹម ត្បូងជម្ពរ័ត្ន ត្បូងពេជ្រ ត្បូងប៊ុតលឿង ត្បូងដៃរគៀម ត្បូងមណីរ័ត្ន ត្បូងកណ្តៀង ត្បូងនិលរ័ត្ន ហើយមរកត។
កន្លែងអង្គុយរបស់អ្នកបានគឺបានធ្វើពីមាស។ វាជាថ្ងៃដែលអ្នកបានបង្កើ ហើយថ្ងៃនោះវាបានរៀបចំជាស្រេច។
[14]យើងបានតាំងអ្នកឡើងនៅលើភ្នំបរិសុទ្ធនៃព្រះដូចជាចេរូប៊ីន ដែលយើងបានចាក់ប្រេងតាំងសម្រាប់ឲ្យការពារដល់មនុស្សលោក។ អ្នកក៏បានដើរទៅមកនៅកណ្តាលត្បូងភ្លឺចាំងល្អ។[15]អ្នកបានគ្រប់លក្ខណ៍ក្នុងគ្រប់ផ្លូវរបស់អ្នក តាំងពីថ្ងៃដែលអ្នកបានកើតមកម្លេះ រហូតដល់ពេលដែលឃើញមាន សេចក្តីទុច្ចរិតនៅក្នុងអ្នក។
[16]តាមការរីកចម្រើននៃជំនួញរបស់អ្នក នាំឲ្យអ្នកពោរពេញដោយអំពើឃោរឃៅ និងអំពើបាប។ ដូចេ្នះយើងដេញអ្នកចុះពីភ្នំរបស់ព្រះជាម្ចាស់ ឲ្យអ្នកក្លាយទៅជាមនុស្សសាមញ្ញ ហើយយើងនឹងបំភ្លាញឯង ចេរូប៊ីនដែលជាអ្នកការពារអើយ យើងដេញអ្នកចេញពីចំណោមថ្មដ៏ភ្លឺផ្លេក។[17]អ្នកមានចិត្តព្រហើន ព្រោះតែរូបសម្បត្តិដ៏ល្អស្អាតរបស់ខ្លួន អ្នកបានធ្វើឲ្យខ្លួនអាប់ប្រាជ្ញា ព្រោះតែភាពរុងរឿងរបស់អ្នក។ យើងបញ្ជូនអ្នកឲ្យមកលើផែនដី។ យើងធ្វើទោសអ្នកឲ្យស្តេចទាំងឡាយ ឲ្យឃើញអ្នក។

generated on Wed Sep 10 16:16:32 2025

[18]អ្នកបានបង្ខាប់អស់ទាំងទីបរិសុទ្ធរបស់អ្នក ដោយអំពើទុច្ចរិតដ៏បរិបូររបស់អ្នក ហើយដោយសេចក្ដីទុច្ចរិតនៃការជួញប្រែរបស់អ្នក ហេតុនោះ យើងបានធ្វើឲ្យមានភ្លើងចេញពីកណ្ដាលអ្នកមក ភ្លើងនោះបានឆេះបំផ្លាញអ្នក។ យើងបានឲ្យអ្នកទៅជាផេះនៅលើផែនដី នៅចំពោះភ្នែកនៃអស់អ្នកដែលឃើញអ្នក។[19]ពួកអ្នកដែលស្គាល់ក្នុងចំណោមអ្នកនឹងងឿងឆ្ងល់ពីអ្នក ពួកគេភ័យតក់ស្លុត ហើយអ្នកនឹងមិនចង់ជួបបែបនេះជារៀង រហូតទៅ»។
[20]បន្ទាប់មក ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[21]«កូនមនុស្សអើយ ចូរត្រៀមខ្លួនដើម្បីទាស់ជាមួយស៊ីដូន ហើយថ្លែងព្រះបន្ទូលទាស់នឹងទីក្រុងនោះ។
[22]ពោលថាព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់មានព្រះបន្ទូលដូច្នេះ មើល៍! ស៊ីដូនអើយ យើងទាស់នឹងអ្នក ហើយយើងនឹងបានតម្កើងឡើងនៅកណ្ដាលអ្នក ហើយគេនឹងដឹងថាយើងនេះជាព្រះអម្ចាស់ កាលដែលយើងបានសម្រេច សេចក្ដីយុត្តិធម៌ដល់អ្នក។ យើងនឹងបានញែកជាបរិសុទ្ធនៅក្នុងអ្នក។
[23]យើងនឹងចាត់អាសន្នរោគទៅក្នុងវា និងឈាមទៅគ្រប់ផ្លូវរបស់វា ពួកអ្នកដែលត្រូវរបួសនឹងដួលនៅកណ្ដាលវា ដោយមានដាវគ្របសង្កត់នៅគ្រប់ទិស នោះគេនឹងដឹងថាយើងនេះជាព្រះអម្ចាស់។[24]បន្ទាប់មក លែងមានមុតបន្លាហើយឈឺចាប់ដល់កូនចៅស្រាអែល ពីអ្នកដែលនៅព័ទ្ធជុំវិញក្រុង ដែលគេធ្លាប់មើលងាយដល់មនុស្សក្នុងក្រុងទៀតហើយ ពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់ដ៏ជាព្រះ!
[25]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ពេលយើងបានប្រមូលពួកវង្សអ៊ីស្រាអែល មកពីគ្រប់ជនជាតិ ដែលគេត្រូវខ្ចាត់ខ្ចាយទៅនោះ ហើយយើងបានញែកពួកគេចេញចំពោះភ្នែកនៃជនជាតិដទៃ ពួកគេនឹងអាស្រ័យនៅក្នុងទឹកដីរបស់ខ្លួន ដែលយើងបានឲ្យដល់យ៉ាកុបជាអ្នកបម្រើយើង។[26]ក្រោយមក ពួកគេនឹងរស់នៅក្នុងក្រុង នោះដោយសុខសាន្ត គេនឹងសង់ផ្ទះ ព្រមទាំងដាំដំណាំទំពាំងបាយជូរ និងអាស្រ័យនៅដោយសុខសាន្តផង ក្នុងកាលដែលយើងសម្រេចសេចក្ដីយុត្តិធម៌ដល់ពួកអ្នកនៅជុំវិញដែលបានប្រព្រឹត្ត នឹងគេដោយសេចក្ដីមើលងាយ គេនឹងដឹងថា យើងគឺជាព្រះអម្ចាស់ របស់ពួកគេ!»

Ezekiel 28:1
ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ១:១។
នៅកណ្ដាលសមុទ្រ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២៧:៤។
អ្នកធ្វើចិត្តខ្លួនឲ្យស្មើនឹងចិត្តរបស់ព្រះ
«អ្នកគិតថាអ្នកមានគំនិតរបស់ព្រះជាម្ចាស់»
Ezekiel 28:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តផ្តល់សាររដល់លោកអេសេគាល ពីការគ្រប់គ្រងទីក្រុងទីរ៉ុស។
ដោយប្រាជ្ញា និងជំនាញរបស់អ្នក
«ដោយប្រាជ្ញានិងការយល់ដឹងរបស់អ្នក»
និងទទួលបាន
«និងបង្កើនការរក្សាទុក»
ឃ្លាំង
កន្លែងសម្រាប់ទុកវត្ថុមានតម្លៃ និងរក្សាឲ្យមានសុវត្ថិភាព
Ezekiel 28:6
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តផ្តល់សាររដល់លោកអេសេគាល ពីការគ្រប់គ្រងទីក្រុងទីរ៉ុស។
អ្នកបានធ្វើចិត្តរបស់អ្នក ដូចជាចិត្តរបស់ព្រះជាម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែ
«អ្នកធ្វើឱ្យបេះដូងរបស់អ្នកដូចជាបេះដូងរបស់ព្រះ» នៅក្នុងជំពូក ២៨:១។
ភាពស្រស់ស្អាតនៃប្រាជ្ញា
ការបកប្រែរបៀបផ្សេងទៀត:
«ទីក្រុងដ៏ស្រស់ស្អាតដែលអ្នកបានកសាងជាមួយអ្នកមានប្រាជ្ញា»។
Ezekiel 28:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តផ្តល់សាររដល់លោកអេសេគាល ពីការគ្រប់គ្រងទីក្រុងទីរ៉ុស។
តើអ្នកហ៊ាននិយាយថា «ខ្ញុំគឺជាព្រះ»
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនគួរហ៊ាននិយាយថា «ខ្ញុំជាព្រះទេ»។
នេះគឺជាព្រះបន្ទូលរបស់ព្រះជាអម្ចាស់ដ៏ជាព្រះ
សូមមើលពីការបកប្រែនេះនៅក្នុងជំពូក ៥:១១។
Ezekiel 28:11
ព្រះអម្ចាស់មានព្រះបន្ទូលមក
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១:១។
ចូរលើកបទទំនួញ
«ច្រៀងចម្រៀងបុណ្យសព» ឬ «ច្រៀងបទចម្រៀងសោកសៅ» ឬ «ច្រៀងបទចម្រៀងសោកសៅ» (UDB)
អ្នកជាគំរូពេញលក្ខណៈ
ការបកប្រែជំនួស៖ «អ្នកល្អឥតខ្ចោះ»។
ពោរពេញទៅដោយប្រាជ្ញា ហើយល្អដាច់គេបំផុត
«ឆ្លាតណាស់ ហើយសង្ហាណាស់»
មានត្បូងគ្រប់មុខនៅលើខ្លួនអ្នក
«អ្នកបានពាក់ថ្មគ្រប់ប្រភេទ»។ នេះបង្ហាញថាព្រះរាជាមានទ្រព្យស្តុកស្តម្ភណាស់។
ត្បូងទទឹម ត្បូងជម្ងរ័ត្ន ត្បូងពេជ្រ ត្បូងប៊ុតលឿង ត្បូងដៃរគៀម ត្បូងមណីរ័ត្ន ត្បូងកណ្តៀង ត្បូងនិលរ័ត្ន ហើយមរកត
ទាំងនេះគឺជាត្បូងដ៏មានតម្លៃនៃពណ៌ផ្សេងគ្នា។
Ezekiel 28:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តផ្តល់សាររដល់លោកអេសេគាល ពីការគ្រប់គ្រងទីក្រុងទីរ៉ុស។
ត្បូងភ្លឺចាំងល្អ
«ថ្មនៃភ្លើង»។ នេះប្រហែលជាសំដៅទៅលើថ្មដែលមានពណ៌ស្រស់ឆើតនិងភ្លឺដែលបានរៀបរាប់នៅជំពូក ២៨:១១។
តាំងពីថ្ងៃដែលអ្នកបានកើតមក
ការបកប្រែរបៀបផ្សេងទៀត: «ចាប់តាំងពីថ្ងៃដែលខ្ញុំបានបង្កើតអ្នកមក»
Ezekiel 28:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តផ្តល់សាររដល់លោកអេសេគាល ពីការគ្រប់គ្រងទីក្រុងទីរ៉ុស។
ថ្មដ៏ភ្លឺផ្លេក
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ២៨:១៤។
ពីមុន
«នៅពីមុខ»
Ezekiel 28:18
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តផ្តល់សាររដល់លោកអេសេគាល ពីស្តេចនៃទីក្រុងទីរ៉ុស។
ពួកគេភ័យតក់ស្លុត ហើយអ្នកនឹងមិនចង់ជួបបែបនេះជារៀងរហូតទៅ
សូមមើលពីរបៀបដែលអ្នកបកប្រែ «អ្នកបានក្លាយជាភាពភ័យរន្ធត់ ហើយអ្នកនឹងមិនជួបទៀតទេ» នៅក្នុងជំពូក ២៧:៣៤។
Ezekiel 28:20
បន្ទាប់មក ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ១:១។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២:១។
ចូរត្រៀមខ្លួនដើម្បីទាស់
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៤:១។
ថ្លែងព្រះបន្ទូលទាស់
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៤:៦។
មើល៍!
ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
Ezekiel 28:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅស៊ីដូន។
បន្ទាប់មក លែងមានមុតបន្លាហើយឈឺចាប់ដល់កូនចៅស្រាអែល ពីអ្នកដែលនៅព័ទ្ធជុំវិញក្រុង ដែលគេធ្លាប់មើលងាយដល់មនុស្សក្នុងក្រុងទៀតហើយ

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត:
«នឹងមិនមានមនុស្សនៅគ្រប់ទីកន្លែងនៅជុំវិញអ៊ីស្រាអែល
ដែលបានធ្វើបាបពួកគេដូចជាអ្នកដែលកោស
និងធ្វើបាបពួកគេដូចជាបន្លាដែលបង្កឲ្យមានការឈឺចាប់
ហើយអ្នកដែលបដិសេធមិនគោរពពួកគេទេ»។
Ezekiel 28:25
នៅក្នុងក្រុង
«ក្នុងទឹកដី»

---

29 [1]នៅឆ្នាំទីដប់ ខែទីដប់ និងថ្ងៃទីដប់ពីរ នៃខែនោះ ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ត្រៀមខ្លួនដើម្បីទាស់ជាមួយផារ៉ោន ជាស្តេចនៃអេស៊ីប
ហើយថ្លែងពាក្យក្នុងនាមយើងប្រឆាំងនឹងស្តេចនោះ រួមទាំងប្រជាជនអេស៊ីបផងដែរ។[3]សូមប្រកាសថា ព្រះជាអម្ចាស់មានព្រះបន្ទូលដូចនេះ មើល៍! ផារ៉ោនជាស្តេចនៃ
អេស៊ីបអើយ យើងទាស់ប្រឆាំងនឹងអ្នក។ អ្នកជាសត្វសមុទ្រធំសម្បើម ដេកនៅតាមដៃទន្លេ ហើយពោលថា «ទន្លេនេះគឺយើងជាម្ចាស់វា។ យើងបង្កើតទន្លេ
នេះសម្រាប់ខ្លួនយើង»។
[4]ដ្បិតយើងនឹងឃ្លុំមាត់របស់អ្នក យើងយកត្រីនៅតាមទន្លេមកដាក់នឹងជញ្ជីងរបស់អ្នក យើងនឹងអូសអ្នកចេញពីក្នុងទឹកទន្លេ ដោយមានត្រីនៅជាប់នឹងស្រកាអ្នកទៅជាមួយ
ផង។[5]យើងនឹងបោះអ្នកចោលក្នុងទីរហោស្ថាន អ្នកហើយនិងត្រីទាំងអស់ដែលចេញពីទន្លេដាក់ជញ្ជីងផង។ អ្នកនឹងធ្លាក់ទៅនៅទីវាល ឥតដែលបានប្រមូលផ្តុំគ្នាទៀត
ឡើយ។ យើងបានឲ្យអ្នកទៅជាអាហារ ដល់អស់ទាំងសត្វនៅផែនដី ហើយនិងឲ្យសត្វដែលហើរនៅលើអាកាសផងដែរ។
[6]ក្រោយមក ប្រជាជនទាំងអស់នៅស្រុកអេស៊ីបនឹងទទួលស្គាល់ថា យើងជាព្រះអម្ចាស់ ពីព្រោះពួកគេធ្លាប់បានដូចជាដើមត្រែង ដែលកូនចៅអ៊ីស្រាអែលយកធ្វើជាបង្អែក។
[7]នៅពេលពួកគេតោងអ្នកដោយដៃគេ ស្រាប់តែអ្នកបាក់ ហើយធ្វើឲ្យពួកគេមុតដៃ ដាច់រហូតដល់ស្មា ហើយនៅពេលពួកគេផ្អែកលើអ្នក តែអ្នកបែរជាដួលចុះមក ហើយធ្វើ
ឲ្យពួកគេថ្កោះចង្កេះ។
[8]ដូច្នេះហើយ ព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូលដូច្នេះ មើល! យើងនឹងយកដាវមកទាស់និងអ្នក។ យើងនឹងកាត់ទាំងមនុស្សហើយនិងសត្វពីអ្នកចេញ។[9]ដូច្នេះ ទឹកដី
អេស៊ីបនឹងត្រូវហិនហោច ក្លាយជាគំនរបាក់បែក។ ក្រោយមកគេនឹងស្គាល់យើងថាជាព្រះអម្ចាស់ តាមរៈម្ចាស់នៃសមុទ្រដែលបានថ្លែងប្រាប់ «ទន្លេគឺជារបស់យើង
ដ្បិតយើងគឺជាអ្នកបង្កើតវាមក»។[10]ដូច្នេះមើល! យើងនឹងទាស់នឹងអ្នកហើយនិងទន្លេរបស់អ្នកផង ដ្បិតយើងនឹងប្រគល់ទឹកដីរបស់អេស៊ីបដែលខូចបង់អស់រលីង តាំងពី
ក្រុងមីគដូល រហូតដល់ក្រុងស៊ីយេន និងព្រំប្រទល់ទឹកដីអេត្យូពី។
[11]នឹងគ្មានជើងមនុស្ស ំហើយគ្មានជើងសត្វណាដើរកាត់ទឹកដីនោះឡើយ ក៏នឹងគ្មានអ្នកណាអាស្រ័យនៅផង។ ក្នុងនៅរវាងសែសិបឆ្នាំ។[12]ដ្បិត យើងនឹងធ្វើឲ្យទឹកដី
អេស៊ីបទទៅជាទីស្ងាត់ច្រៀប នៅកណ្តាលអស់ទាំងទឹកដីស្ងាត់ជ្រងំ និងទីក្រុងនានានៅស្ងាត់ច្រៀបអស់សែសិបឆ្នាំ នៅកណ្តាលអស់ទាំងទីក្រុងដែលខូចបង់នោះ យើងនឹង
កម្ចាត់កម្ចាយពួកជនជាតិអេស៊ីបឲ្យទៅនៅកណ្តាលអស់ទាំងជនជាតិផ្សេងៗ ហើយបែងចែកគេទៅក្នុងទឹកដីនោះ»។
[13]ដ្បិត ព្រះអម្ចាស់ដ៏ជាព្រះមានបន្ទូលដូចនេះ ដល់ផុតពីសែសិបឆ្នាំទៅ យើងនឹងប្រមូលពួកជនជាតិអេស៊ីប ពួកគេបានត្រូវខ្ចាត់ខ្ចាយ។[14]យើងនឹងស្តារសំណាងពួក
អេស៊ីបហើយនាំអ្នកជាឈ្លើយឲ្យមកវិញ ហើយឲ្យគេត្រឡប់ទៅស្រុកដីប៉ាត្រូស ជាទីកំណើតរបស់ខ្លួន គេនឹងបានជានគរយ៉ាងតូចនៅទីនោះ។
[15]វានឹងបានតូចទាបជាងអស់ទាំងនគរផ្សេងៗ ហើយឥតដែលមានអ្នកណាលើកវាឡើងខ្ពស់ជាងនគរឯទៀតដែរ។ យើងនឹងធ្វើឲ្យអន់ថយ ដើម្បីមិនឲ្យគេគ្រប់គ្រងលើ
ជនជាតិដទៃទៀតឡើយ។[16]ជនជាតិអេស៊ីបនឹងគ្មានហេតុតទៅទៀតទេ ដើម្បីនឹងគ្រប់គ្រងទៅលើទឹកដីរបស់អ៊ីស្រាអែល។ ផ្ទុយទៅវិញ ពួកគេនឹងរំឭកពីអំពើ
ទុច្ចរិតដែលអ៊ីស្រាអែលបានធ្វើ ដ៏ជាពេលដែលគេងាកបែរដើម្បីរកជំនួយពីអេស៊ីបវិញ។ គេនឹងដឹងថាយើងគឺជាព្រះអម្ចាស់ដ៏ជាព្រះ»។
[17]នៅឆ្នាំទីម្ភៃប្រាំពី ខែទីមួយនៃឆ្នាំនោះ ដែលព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់បានមកដល់ខ្ញុំប្រាប់ថា[18]«កូនមនុស្សអើយ នេប៊ូក្នេសា ជាស្តេចបាប៊ីឡូនបាន
ឲ្យកងទ័ពរបស់ខ្លួនធ្វើការងារបម្រើយ៉ាងធំ ទាស់នឹងក្រុងទីរ៉ុស។ គ្រប់ទាំងក្បាលត្រូវកៅស៊ូរហូតដល់ទំពែក ហើយគ្រប់ទាំងស្មាត្រូវរបក។ ប៉ុន្តែ ស្តេចព្រមទាំងពួកពលទ័ព
ឥតបានទទួលកម្រៃអ្វីពីក្រុងទីរ៉ុស សម្រាប់ការដែលខ្លួនបានទាស់នឹងទីក្រុងនោះឡើយ។
[19]ហេតុនោះ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល! យើងនឹងឲ្យទឹកដីអេស៊ីបដល់នេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ស្តេចនោះនឹងដឹកនាំពួកជនទាំងឡាយរបស់ទឹកដី
នោះ ទៅជាឈ្លើយ ហើយយកទ្រព្យសម្បត្តិ និងរឹបអូសយកធ្វើជារបស់ពួកគេផង។[20]យើងបានឲ្យទឹកដីអេស៊ីបដល់គេ ជាថ្លៃឈ្នួលនៃការដែលគេបានបម្រើ ពីព្រោះគេបាន
ធ្វើការនោះបម្រើដល់យើង នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់។
[21]នៅថ្ងៃនោះ យើងនឹងឲ្យស្នែងមួយប៉ុចឡើង សម្រាប់ដល់កូនចៅអ៊ីស្រាអែល ហើយយើងនឹងអ្នកនិយាយនៅកណ្តាលចំណោមពួកគេ នោះគេនឹងដឹងថា យើងនេះជា
ព្រះអម្ចាស់»។

Ezekiel 29:1
នៅឆ្នាំទីដប់
ការបកប្រែរបៀបផ្សេងទៀត: «នៅឆ្នាំទីដប់នៃការនិរទេសស្តេចយេហូយ៉ាគីម»
នៅឆ្នាំទីដប់ ខែទីដប់ និងថ្ងៃទីដប់ពីរ នៃខែនោះ
«នៅថ្ងៃទី១២ នៃខែទី១០»។ នេះជាខែទី១០ នៃប្រតិទិនហេប្រឺ។ ថ្ងៃទី១២
គឺជិតដល់ដើមខែមករានៅលើប្រតិទិនលោកខាងលិច។
ព្រះអម្ចាស់មានព្រះបន្ទូលមក
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ១:១ ។
សត្វសមុទ្រធំសម្បើម
«សត្វចម្លែកដែលរស់នៅក្នុងទឹក»។ ព្រះអម្ចាស់ចាប់ផ្តើមប្រៀបធៀបផារ៉ោន
ជាសត្វចម្លែកមួយ ដែលរស់នៅក្នុងទឹក។ សត្វចម្លែកនេះប្រហែលជាក្រពើ។
Ezekiel 29:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ ទៅស្តេចផារ៉ោន
ដោយប្រៀបធៀបគាត់ជាមួយសត្វចម្លែកនៅក្នុងទឹក។
ឃ្លុំមាត់
បំណែកដែក ឬ ឈើមុតៗ និងកោងដែលមនុស្សប្រើដើម្បីចាប់ត្រី
និងសត្វដទៃទៀតនៅក្នុងទឹក
ជញ្ជីង
ស្បែកវែង ដែលមានលើត្រី ក្រពើ និងសត្វដទៃៗទៀត
Ezekiel 29:6
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅស្តេចផារ៉ោន។
ពួកគេធ្លាប់បានដូចជាដើមត្រែង
ព្រះអម្ចាស់ប្រៀបធៀបប្រជាជននៅស្រុកអេស៊ីប និងស្តេចផារ៉ោនទៅនឹងដើមត្រែង
ព្រោះជនជាតិអ៊ីស្រាអែលពឹងផ្អែកលើជនជាតិអេស៊ីបដើម្បីជួយពួកគេក្នុងសង្គ្រាម
ប៉ុន្តែជនជាតិអេស៊ីបមិនមានកម្លាំងគ្រប់គ្រាន់ជួយពួកគេទេ។
ត្រែង
រុក្ខជាតិដុះជិតទឹកហើយមើលទៅដូចជាស្មៅធំណាស់
ដើមត្រែង
ផ្នែកមួយនៃដើមត្រែងដែលវែង ហើយដូចជាដំបងក្រាស់មួយ។
មនុស្សអាចប្រើវាដូចជាដំបង ប៉ុន្តែដើមត្រែងមិនរឹងមាំដូចឈើ
ហើយអាចបាក់ភ្លាមៗ។
ពួកគេតោងអ្នក
ពាក្យថា «អ្នក» សំដៅទៅលើស្តេចផារ៉ោន។
អ្នកបាក់ជើងហើយធ្វើអោយត្រគាករបស់ពួកគេរញ្ជួយ
«ព្រះអម្ចាស់មានបន្ទូលអំពីការរងទុក្ខដែលជនជាតិអ៊ីស្រាអែលបានជួបប្រទះនៅពេលពួកគេទុកចិត្តលើជ
Ezekiel 29:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តរឲ្យអេសេគាលថ្លែងសាររបស់ទ្រង់ទៅស្តេចផារ៉ោន។
មើល!
«មើល!» ឬ «ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
ដាវមកទាស់និងអ្នក

generated on Wed Sep 10 16:16:32 2025

ពាក្យថា «អ្នក» គឺជាឯកវចន:ហើយសំដៅទៅលើប្រទេសអេហ្ស៊ីប។
ប្រជាជាតិជាច្រើនត្រូវបានគេគិតថាដូចជាស្ត្រីម្នាក់ៗ។
ទាស់និងអ្នក
ពាក្យថា «អ្នក» គឺមានលក្ខណៈឯកត្តជនហើយសំដៅទៅលើស្តេចផារ៉ោន។
តាំងពីក្រុងមីគដូល រហូតដល់ក្រុងស៊ីយេន
ការបកប្រែរបៀបផ្សេងទៀត: «នៅទូទាំងប្រទេសអេហ្ស៊ីប» ឬ «
ពីព្រំប្រទល់ខាងជើង
នៃប្រទេសអេហ្ស៊ីបរហូតដល់ព្រំប្រទល់ខាងត្បូងនៃប្រទេសអេហ្ស៊ីប»។
Ezekiel 29:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តរឲ្យអេសេគាលថ្លែងសាររបស់ទ្រង់ទៅស្តេចផារ៉ោន។
គ្មានជើងសត្វណាដើរកាត់ទឹកដីនោះឡើយ ក៏នឹងគ្មានអ្នកណាអាស្រ័យនៅផង
«សូម្បីតែសត្វក៏មិនដើរកាត់វាដែរ»
Ezekiel 29:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តរឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ទៅស្តេចផារ៉ោន។
ពួកគេបានត្រូវខ្ចាត់ខ្ចាយ
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានខ្ចាត់ខ្ចាយពួកគេ»។
នឹងស្តាសំណាងពួកអេស៊ីប
«នឹងផ្តល់ឲ្យអេស៊ីបនូវអ្វីដែលវាបានបាត់បង់»
ស្រុកដ៏ប៉ាត្រូស
ផ្នែកខាងត្បូងនៃប្រទេសអេស៊ីបរវាងដែនដីសណ្តរនិងដែនដីកោះខឹស។
នេះត្រូវបានគេហៅថាអេស៊ីបខាងលើ។
Ezekiel 29:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តរឲ្យអេសេគាលថ្លែងសាររបស់ទ្រង់ទៅស្តេចផារ៉ោន។
ជនជាតិអេស៊ីបនឹងគ្មានហេតុតទៅទៀតទេ ដើម្បីនឹងគ្រប់គ្រងទៅលើទឹកដីរបស់អ៊ីស្រាអែល
«ប្រជាជាតិអ៊ីស្រាអែលនឹងលែងទុកចិត្តលើប្រជាជនអេស៊ីបទៀតហើយ»
ពេលដែលគេងាកបែរដើម្បីរកជំនួយពីអេស៊ីបវិញ
«ពេលណាដែលពួកគេទៅស្រុកអេស៊ីបដើម្បីរកជំនួយ»
Ezekiel 29:17
នៅឆ្នាំទីម្ភៃប្រាំពី
ឆ្នាំទីប្រាំពីរ - «នៅឆ្នាំទី ២៧ នៃការនិរទេសខ្លួនរបស់ស្តេចយេហូយ៉ាគីម»
ខែទីមួយនៃឆ្នាំនោះ
«នៅថ្ងៃដំបូង នៃខែដំបូង»។ នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។
ថ្ងៃដំបូងគឺជិតដល់ដើមខែមេសា។
ព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ១: ១។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២:១។
Ezekiel 29:19
មើល!
«មើល!» ឬ «ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
Ezekiel 29:21
យើងនឹងឲ្យស្នែងមួយប៉ុចឡើង សម្រាប់ដល់កូនចៅអ៊ីស្រាអែល
ឃ្លានេះមានន័យថា
«យើងនឹងចាប់ផ្តើមស្តារអំណាចរបស់វង្សអ៊ីស្រាអែលឡើងវិញ» ។
កណ្តាលចំណោមពួកគេ
«ពួកគេនោះ»

---

30 [1]ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា៖[2]កូនមនុស្សអើយ! ចូលថ្លែងពាក្យយើងប្រាប់គេថា ព្រះអម្ចាស់ដល់ជាដ៏ព្រះមានព្រះបន្ទូលបែបនេះ ចូលទុក្ខសោក
«ទុក្ខវេទនានោះនឹងមកដល់ថ្ងៃ។[3]ថ្ងៃនោះជិតមកដល់ហើយ។ ថ្ងៃនៃព្រះអម្ចាស់ជិតមកដល់ហើយ។ គឺវាជាថ្ងៃដែលមានពពក ជាពេលកំណត់របស់ប្រជាជាតិ។
[4]ក្រោយមក ដាវនឹងមកសម្លាប់អេស៊ីប ហើយទុក្ខវេទនានឹងកើតមាននៅទឹកដីអេត្យូពី ពេលដែលជនជាតិអេស៊ីបនឹងត្រូវគេសម្លាប់រង្គាល សត្រូវរឹបអូសយកសម្បត្តិរបស់
ស្រុកអេស៊ីប ព្រមទាំងកម្ទេចទឹកដីផង។[5]អ្នកអេត្យូពី អ្នកស្រុកពូត អ្នកស្រុកលូឌ ពួកកូនកាត់ទាំងប៉ុន្មាន និងអ្នកស្រុកគូប ព្រមទាំងប្រជាជនរបស់យើងផ្ទាល់ ពួកគេនឹង
ត្រូវស្លាប់ដោយមុខដាវ។
[6]ព្រះអម្ចាស់មានព្រះបន្ទូលការនេះ ដូច្នេះអ្នកណាដែលគាំទ្រអេស៊ីបនឹងត្រូវដួលចុះ ហើយអំណាចអួតអាងរបស់អេស៊ីបក៏ត្រូវរលាយសូន្យទៅដែរ។ ចាប់តាំងពីក្រុងមីគដូល
រហូតដល់ក្រុងស៊ីយេន នឹងត្រូវវិនាសទៅដែរដោយមុខដាវ នេះគឺជាព្រះបន្ទូលរបស់ព្រះជាអម្ចាស់ដ៏ជាព្រះលើទាំងអស់។[7]ពួកគេនឹងត្រូវស្ងាត់ច្រៀប នៅក្នុងទឹកដីនោះ
ដែលត្រូវចោលស្ងាត់អស់ទាំងទីក្រុងរបស់គេ នឹងនៅក្នុងពួកទីក្រុងផ្សេងក៏ត្រូវខូចបង់ដែរ។
[8]ក្រោយមក ពួកគេនឹងទទួលស្គាល់ថា យើងពិតជាព្រះអម្ចាស់ ពេលណាយើងដុតទឹកដីអេស៊ីប ហើយពេលពួកអ្នកជួយត្រូវបានបំផ្លាញ។[9]នៅថ្ងៃយើងដាក់ទោសស្រុក
អេស៊ីប យើងនឹងចាត់អ្នកឲ្យធ្វើដំណើរតាមសំពៅ នាំដំណឹងទៅប្រាប់អ្នកនៅអេត្យូពី ធ្វើឲ្យពួកគេភ័យតក់ស្លុត។ ដ្បិត ចូរមើល៍! ថ្ងៃនោះកំពុងមកដល់ហើយ។
[10]ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលបែបនេះ យើងនឹងធ្វើឲ្យបញ្ចាប់នៃជនជាតិអេស៊ីប ដោយសារដៃរបស់នេប៊ូក្នេសាជាស្តេចបាប៊ីឡូន។[11]ស្តេចនេប៊ូក្នេសា ហើយនិង
កងទ័ពនៅជាមួយទ្រង់ មានការភ័យខ្លាចដល់ជនជាតិទាំងឡាយ នាំគ្នាមកកម្ទេចទឹកដី ពួកគេបានដកដាវរបស់គេវាយប្រហារអេស៊ីប
ហើយផែនដីនេះពេញទៅដោយមនុស្សស្លាប់។
[12]យើងនឹងធ្វើឲ្យដៃទន្លេនីលរីងស្ងួត ហើយយើងនឹងប្រគល់ទឹកដីនោះទៅក្នុងកណ្តាប់ដៃរបស់មនុស្សអាក្រក់។ យើងនឹងធ្វើឲ្យទឹកដី
ហើយពេញទៅដោយការបំផ្លាញពីដៃនៃដទៃ យើងជាព្រះអម្ចាស់បានថ្លែងពាក្យទាំងនោះ»។
[13]ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ យើងនឹងបំផ្លាញរូបព្រះទាំងនោះ ហើយយើងនឹងបំបាត់រូបព្រះក្លែងក្លាយពីក្រុងណូប។ ពេលនោះ ក្នុងទឹកដីអេស៊ីបនឹងលែង
មានអ្នកដឹកនាំ ហើយយើងនឹងធ្វើឲ្យមានការភ័យខ្លាចនៅទឹកដីអេស៊ីប។[14]ក្រោយមក យើងនឹងបំផ្លាញក្រុងប៉ាត្រុស យើងនឹងដុតកម្ទេចក្រុងសូអាន ហើយដាក់ទោសក្រុង
នរ។
[15]ដ្បិត យើងនឹងចាក់កំហឹងរបស់យើងលើក្រុងស៊ីន ជាក្រុងដែលមានកំពែងរឹងមាំរបស់ទឹកដីអេស៊ីប យើងនឹងដកជីវិតប្រជាជនដ៏ច្រើននៅក្រុងនរ។[16]ក្រោយមកយើងនឹង
ដុតទឹកដីអេស៊ីប ក្រុងស៊ីននឹងភ័យតក់ស្លុត ក្រុងនរនឹងត្រូវខ្មាំងឡោមព័ទ្ធ ហើយក្រុងណូបនឹងប្រឈរមុខជាមួយខ្មាំងសត្រូវរាល់ថ្ងៃ។
[17]ពួកយុវជននៅក្រុងអាវេន និងក្រុងពីបែសែត នឹងដួលស្លាប់ដោយមុខដាវ ហើយអ្នកក្រុងទាំងនោះនឹងត្រូវខ្មាំងកៀរយកទៅជាឈ្លើយ។[18]ក្នុងក្រុងតាហាពេនេស ថ្ងៃប្រែជាងងឹត ពពកអាប់អួគ្របដណ្តប់ពាសពេញក្រុង នៅពេលដែលយើងបំបាក់នឹមរបស់ទឹកដីអេស៊ីប គឺជាពេលដែលអំណាចអួតអាងរបស់ពួកគេ ត្រូវរលាយសូន្យ។[19]យើងនឹង
ធ្វើទោសដោយការជំនុំជម្រះ មកលើអេស៊ីប ដូច្នេះ ពួកគេនឹងទទួលស្គាល់ថា យើងពិតជាព្រះអម្ចាស់»។
[20]ក្រោយមក បានចូលមកដល់ នៅក្នុងឆ្នាំទីដប់មួយ ខែទីមួយ ថ្ងៃទីប្រាំពីនៃខែនោះ ហើយព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[21]«កូនមនុស្សអើយ យើងបាន
កាច់បំបាក់ដៃ របស់ផារ៉ោន ដែលជាស្តេចរបស់អេស៊ីប។ មើល៍! គ្មាននរណារុំរបួស ឬដាក់ថ្នាំឲ្យ ហើយក៏គ្មាននរណាយកក្រណាត់មកចងអប ដើម្បីឲ្យស្តេចនេះអាចកាន់
ដាវបាន។
[22]ហេតុនោះ ព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូលដូច្នេះ ចូរមើល៍ យើងទាស់នឹងផារ៉ោន ជាស្តេចស្រុកអេស៊ីប។ ដ្បិតយើងនឹងបំបាក់ដៃវាទាំងសងខាង គឺដៃដែលនៅមាំ
និងដៃដែលបាក់ហើយនោះ ហើយយើងនឹងធ្វើឲ្យដាវធ្លាក់ចុះពីដៃ។[23]ក្រោយមក យើងនឹងរំលាយជនជាតិអេស៊ីបក្នុងចំណោមប្រជាជាតិនានា យើងនឹងកម្ចាត់កម្ចាយពួក
គេឲ្យទៅទឹកដីផ្សេងៗ។[24]យើងនឹងចម្រើនកម្លាំងដៃស្តេចបាប៊ីឡូន ហើយដាក់ដាវយើងទៅក្នុងដៃស្តេច តែយើងនឹងបំបាក់ដៃទាំងពីររបស់ផារ៉ោន។ ហើយស្តេចស្រុកអេស៊ីប
នឹងស្រែកថ្ងូរនៅចំពោះមុខស្តេចទឹកដីបាប៊ីឡូន ជាមួយសេចក្តីស្លាប់ជិតនកដល់។
[25]ដ្បិតយើងនឹងពង្រឹងកម្លាំងរបស់ស្តេចទឹកដីបាប៊ីឡូន ក្នុងពេលដៃរបស់ស្តេចផារ៉ោនទាំងពីរបានធ្លាក់ចុះ។ រួចហើយពួកគេនឹងសឹងថា យើងពិតជាព្រះអម្ចាស់ ពេលយើង
ប្រគល់ដាវរបស់យើងឲ្យស្តេចទឹកដីបាប៊ីឡូន ហើយពេលស្តេចនេះលើកដាវតម្រង់ទៅរកអេស៊ីប។[26]ដូច្នេះ យើងនឹងរំលាយជនជាតិអេស៊ីបក្នុងចំណោមប្រជាជាតិផ្សេងៗ
យើងនឹងតាមប្រហារពួកគេទៅគ្រប់ទីកន្លែងទាំងអស់។ ហើយពួកគេនឹងដឹងថា យើងពិតជាព្រះអម្ចាស់»។

generated on Wed Sep 10 16:16:32 2025

Ezekiel 30:1

ព័ត៌មានទូទៅ:

លោកអេសេគាលប្រាប់អំពីសារដែលព្រះអម្ចាស់បានឲ្យគាត់។

ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់មានព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ១:១។

កូនមនុស្សអើយ

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២:១។

ចូលថ្លែងពាក្យយើងប្រាប់គេថា

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុង EZK 21:8.

ចូលទុក្ខសោក

«ស្រែកយំដោយទុក្ខព្រួយ» ពាក្យបញ្ជានេះគឺទៅកាន់ប្រទេសអេហ្ស៊ីប
និងប្រជាជាតិនានានៅជុំវិញប្រទេសអេស៊ីប។

ទុក្ខវេទនាគឺនឹងមកដល់ថ្ងៃ

«ថ្ងៃនោះគួរឲ្យខ្លាចណាស់» ឬ «រឿងអាក្រក់ៗ ជាច្រើននឹងកើតឡើងនៅថ្ងៃនោះ»

ថ្ងៃនោះជិតមកដល់ហើយ

វាត្រូវបានបញ្ជាក់ថា «ថ្ងៃ» គឺជាពេលវេលាដែលប្រជាជននឹងយំ។

ការបកប្រែជំនួស៖ «វានឹងក្លាយជាថ្ងៃដែលអ្នកនឹងយំ»។

ថ្ងៃនៃព្រះអម្ចាស់ជិតមកដល់ហើយ

វាបញ្ជាក់ថានៅថ្ងៃនោះព្រះអម្ចាស់នឹងដាក់ទោសប្រជាជន។ ការបកប្រែជំនួស៖
«ឆាប់ៗនេះនឹងជាថ្ងៃដែលព្រះអម្ចាស់នឹងដាក់ទោសប្រជាជន»។

ជាថ្ងៃដែលមានពពក

ការបកប្រែជំនួស៖ «វានឹងដូចជាថ្ងៃដែលមានពពកខ្មៅងងឹត» ឬ
«វានឹងគួរឲ្យភ័យខ្លាចដូចថ្ងៃដែលមានពពកខ្មៅ»។ .

ជាពេលកំណត់របស់ប្រជាជាតិ

ការបកប្រែជំនួស៖ «គ្រាលំបាកដែលនឹងកើតឡើងចំពោះប្រជាជាតិនានា» ឬ
«វានឹងជាពេលដែលប្រជាជននៃប្រជាជាតិនានានឹងរងទុក្ខវេទនា»

Ezekiel 30:4

ព័ត៌មានទូទៅ:

ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីស្រុកអេស៊ីប។

ក្រោយមក ដាវនឹងមកសម្លាប់អេស៊ីប

ពាក្យថា «ដាវ» នៅទីនេះសំដៅទៅលើសង្គ្រាម ឬការវាយប្រហារ។

ការបកប្រែជំនួស៖ «នឹងមានសង្គ្រាមប្រឆាំងនឹងអេស៊ីប» ឬ
«កងទ័ពសត្រូវនឹងវាយប្រហារប្រទេសអេស៊ីប»។

ហើយទុក្ខវេទនានឹងកើតមាននៅទឹកដីអេត្យូពី

«នឹងក្រៀមក្រំណាស់» ឬ «ប្រជាជន នឹងមានភាពទុក្ខព្រួយ»

ពេលដែលជនជាតិអេស៊ីបនឹងត្រូវគេសម្លាប់រង្គាល

«នៅពេលដែលមនុស្សជាច្រើននៅអេហ្ស៊ីបត្រូវបានសម្លាប់» ឬ
«នៅពេលដែលប្រជាជនអេហ្ស៊ីបជាច្រើនបានស្លាប់នៅក្នុងសង្គ្រាម»។

សត្រូវរឹបអូសយកសម្បត្តិ

«អ្នកវាយប្រហារនឹងដកហូតទ្រព្យសម្បត្តិរបស់អេស៊ីប»

ព្រមទាំងកម្ទេចទឹកដីផង

«អ្នកវាយប្រហារនឹងបំផ្លាញគ្រឹះអគារនៅអេស៊ីប»

អ្នកស្រុកពូត

លីប៊ីជាប្រទេសមួយនៅភាគខាងលិចនៃប្រទេសអេស៊ីប។
លោកអេសេគាលបានហៅថាជាតំបន់ពូត។

អ្នកស្រុកលូឌ

នេះប្រហែលជាសំដៅទៅលើនគរលីឌាដែលមាននៅក្នុងអ្វីដែលឥឡូវនេះជាប្រទេសតួកគី
លោកអេសេគាលបានហៅថាជាតំបន់លូឌ។

ព្រមទាំងប្រជាជនរបស់យើងផ្ទាល់

អាចមានន័យថា គឺ១) «ជ្វីហ្វដែលរស់នៅក្នុងប្រទេសអេស៊ីប» ឬ ២)
«ប្រជាជនផ្សេងទៀតនៅក្នុងទឹកដីនៃសម្ព័ន្ធមិត្តរបស់អេស៊ីប» ។
វាមិនច្បាស់ទេថាតើ «កិច្ចព្រមព្រៀង»
សំដៅទៅលើកិច្ចព្រមព្រៀងដែលព្រះអម្ចាស់បានធ្វើជាមួយជនជាតិអ៊ីស្រាអែល
ឬកិច្ចព្រមព្រៀងដែលអេស៊ីបបានធ្វើជាមួយក្រុមមនុស្សផ្សេងទៀត។

ត្រូវស្លាប់ដោយមុខដាវ

«ទាំងអស់នឹងស្លាប់ក្នុងសមរភូមិ» ឬ «ទាំងអស់នឹងស្លាប់នៅក្នុងសង្គ្រាម»។
នេះមិនមានន័យថាមនុស្សគ្រប់គ្នានឹងស្លាប់នោះទេប៉ុន្តែមនុស្សជាច្រើនមកពីប្រទេសទាំងអស់នឹងត្រូវស្លាប់

Ezekiel 30:6

ព្រះអម្ចាស់មានព្រះបន្ទូលការនេះ

«នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។

ប្រយោគនេះណែនាំនូវអ្វីដែលព្រះអម្ចាស់នឹងមានបន្ទូល។

ដូច្នេះអ្នកណា

«តាមរបៀបនេះប្រជាជន» ឬ «តាមរបៀបនេះប្រជាជាតិនានា»

ដែលគាំទ្រអេស៊ីប

«នរណាដែលជួយអេស៊ីប»

ត្រូវដួលចុះ

«នឹងស្លាប់» ឬ «មកបំផ្លាញ»

អំណាចអួតអាងរបស់អេស៊ីបក៏ត្រូវរលាយសូន្យ

«កម្លាំងរបស់អេស៊ីបដែលធ្វើឲ្យមានមោទនភាពនឹងត្រូវបាត់បង់» ឬ
«កម្លាំងដែលធ្វើឲ្យអេស៊ីបមានមោទនភាពនឹងត្រូវបំផ្លាញ»

ចាប់តាំងពីក្រុងមីគដូល រហូតដល់ក្រុងស៊ីយេន

លោកអេសេគាលដាក់ឈ្មោះទីក្រុងនានានៅតាមព្រំដែននៃប្រទេសអេស៊ីបដើម្បីយោងទៅស្រុកអេស៊ីបទាំ

ការបកប្រែជំនួស៖ «នៅទូទាំងប្រទេសអេស៊ីប» ឬ
«ពីព្រំប្រទល់ខាងជើងនៃប្រទេសអេស៊ីបរហូតដល់ព្រំប្រទល់ខាងត្បូងនៃប្រទេសអេស៊ីប»។

ត្រូវវិនាសទៅដែរដោយមុខដាវ

«ទាហានអេស៊ីបនឹងត្រូវស្លាប់ដោយដាវ»។ ការបកប្រែជំនួស៖
«កងទ័ពដែលវាយប្រហារនឹងសម្លាប់ទាហានអេស៊ីបនៅក្នុងសមរភូមិ»។

ពួកគេនឹងត្រូវស្ងាត់ជ្រៀប នៅក្នុងទឹកដីនោះ ដែលត្រូវចោលស្ងាត់

«ទាហាននៃសម្ព័ន្ធមិត្តរបស់អេស៊ីបនឹងត្រូវបាត់បង់នៅពេលដែលពួកគេត្រូវបានព័ទ្ធជុំវិញដោយគ្មានអ្វីក្រេ
»

នៅក្នុងចំណោម

«ក្នុងចំណោម» ឬ «ហ៊ុំព័ទ្ធដោយ»

ទីក្រុងរបស់គេ នឹងនៅក្នុងពួកទីក្រុងផ្សេងក៏ត្រូវខូចបង់ដែរ

«ទីក្រុងរបស់ពួកគេនឹងព័ទ្ធជុំវិញដោយទីក្រុងដែលបាក់បែកនៅប្រទេសក្បែរនោះ»

Ezekiel 30:8

ព័ត៌មានទូទៅ:

ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីស្រុកអេស៊ីប។

ក្រោយមក ពួកគេ

អាចមានន័យថា គឺ១) «បន្ទាប់មកប្រជាជន» ឬ ២) «បន្ទាប់មកប្រជាជនអេស៊ីប»។

នឹងទទួលស្គាល់ថា យើងពិតជាព្រះអម្ចាស់

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ៦:៦។

ពេលណាយើងដុតទឹកដីអេស៊ីប

អគ្គិភ័យសំដៅទៅលើអគ្គិភ័យដែលកើតឡើងជាញឹកញាប់នៅក្នុងសង្គ្រាម។

ការបកប្រែជំនួស៖ «នៅពេលដែលយើងបំផ្លាញអេស៊ីបដោយភ្លើង» ឬ
«នៅពេលដែលយើងចាត់កងទ័ពវាយលុកដើម្បីដុតអេស៊ីបដោយភ្លើង»។

ហើយពេលពួកអ្នកជួយត្រូវបានបំផ្លាញ

ការបកប្រែជំនួស៖ «យើងបំផ្លាញសម្ព័ន្ធមិត្តអេស៊ីបទាំងអស់» ឬ
«យើងបំបែកអស់អ្នកដែលជួយអេស៊ីប»។

នៅថ្ងៃយើងដាក់ទោសស្រុកអេស៊ីប យើងនឹងចាត់អ្នកឲ្យធ្វើដំណើរតាមសំពៅ នាំដំណឹងទៅប្រាប់អ្នក
នៅអេត្យូពី

អ្នកនាំសារនឹងនាំដំណឹងអំពីការបំផ្លាញស្រុកអេស៊ីបមកស្រុកគុបដែលនឹងត្រូវភ័យរន្ធត់។

ដំណឹងទៅប្រាប់អ្នកនៅអេត្យូពី

«ដើម្បីបំភ័យអេត្យូពីដែលមានអារម្មណ៍ថាមានសុវត្ថិភាពពីគ្រោះថ្នាក់»

នឹងថ្ងៃដែលជនជាតិអេស៊ីបវិនាសអន្តរាយពួកគេនឹងមានទុក្ខព្រួយ

«ប្រជាជនអេត្យូពីក៏នឹងមានការឈឺចាប់យ៉ាងខ្លាំងដែរនៅពេលដែលយើងដាក់ទណ្ឌកម្មអេស៊ីប»

ចូរមើល!

ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
វាក៏អាចត្រូវបានបកប្រែជា «ពិតណាស់!»

ថ្ងៃនោះកំពុងមកដល់ហើយ

ពាក្យថា «វា» គឺសំដៅទៅលើ «ការឈឺចុកចាប់ខ្លាំង» ឬ
«ការសោកសៅយ៉ាងខ្លាំង» ដែលអេត្យូពីនឹងមាន
នៅពេលដែលពួកគេត្រូវបានដាក់ទណ្ឌកម្មរួមជាមួយអេស៊ីប។

Ezekiel 30:10

generated on Wed Sep 10 16:16:32 2025

ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលបែបនេះ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ៥:៥។
យើងនឹងធ្វើឲ្យបញ្ឈប់នៃជនជាតិអេស៊ីប
ការបកប្រែជំនួស៖
«យើងនឹងធ្វើវាឡើងដើម្បីកុំឲ្យអេស៊ីបលែងមានប្រជាជនច្រើនទៀត»។
ដោយសារដៃរបស់នេប៊ូក្នេសា
នេប៊ូក្នេសានឹងជាអ្នកដែលដាក់ទោសនេះ។
កងទ័ពនៅជាមួយទ្រង់ ... នាំគ្នាមកកម្ទេចទឹកដី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងនាំនេប៊ូក្នេសា និងកងទ័ពរបស់គាត់ទៅ ...ដើម្បីបំផ្លាញទឹកដី»
កងទ័ពនៅជាមួយទ្រង់ មានការភ័យខ្លាចដល់ជនជាតិទាំងឡាយ
ព្រះអម្ចាស់ហៅនេប៊ូក្នេសាថាជា «ភាពភ័យរន្ធត់របស់ប្រជាជាតិនានា»
ពីព្រោះប្រជាជាតិទាំងអស់ខ្លាចកងទ័ពរបស់ព្រះអង្គខ្លាំងណាស់។
កម្ទេចទឹកដី
«ដូច្នេះពួកគេនឹងបំផ្លាញទឹកដី»។
ព្រះអម្ចាស់នឹងនាំនេប៊ូក្នេសានិងប្រជាជនរបស់គេមកបំផ្លាញស្រុក។
បានដកដាវរបស់គេវាយប្រហារអេស៊ីប
«ប្រយុទ្ធប្រឆាំងនឹងអេស៊ីប»
ផែនដីនេះពេញទៅដោយមនុស្សស្លាប់
នេះគឺជាការបំផ្លើសមួយដើម្បីបង្ហាញថាពួកបាប៊ីឡូននឹងសម្លាប់ជនជាតិអេស៊ីបជាច្រើន។
វានឹងមានប្រជាជនអេស៊ីបស្លាប់ជាច្រើនដែលវាហាក់ដូចជាសាកសពរបស់ពួកគេគ្របដណ្តប់លើទឹកដី
ការបកប្រែជំនួស៖ «ពួកគេនឹងសម្លាប់មនុស្សជាច្រើន
ដូច្នេះវាហាក់ដូចជាសាកសពរបស់ពួកគេនៅគ្រប់ទីកន្លែង» .
Ezekiel 30:12
ព័ត៌មានទូទៅ:
ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីស្រុកអេស៊ីប។
យើងនឹងធ្វើឲ្យដៃទន្លេនីលរីងស្ងួត
«យើងនឹងធ្វើឲ្យទន្លេនៅស្រុកអេស៊ីបរីងស្ងួត»
យើងនឹងប្រគល់ទឹកដីនោះទៅក្នុងកណ្តាប់ដៃរបស់មនុស្សអាក្រក់
ព្រះអម្ចាស់នឹងប្រគល់ស្រុកបាប៊ីឡូនមកអោយអ្នកស្រុកអេស៊ីបដូចអ្នកដែលលក់ទំនិញ
ការបកប្រែជំនួស៖ «ខ្ញុំនឹងប្រគល់ទឹកដីដល់មនុស្សអាក្រក់»។
យើងនឹងធ្វើឲ្យទឹកដី ហើយពេញទៅដោយការបំផ្លាញពីដៃនៃដទៃ
«យើងនឹងធ្វើឲ្យប្រជាជនពីប្រជាជាតិមួយផ្សេងទៀតបំផ្លាញទឹកដីនិងអ្វីៗទាំងអស់ដែល
ពេញទៅដោយ
«អ្វីគ្រប់យ៉ាងដែលមាននៅក្នុងដី»
Ezekiel 30:13
ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ៥:៥។
ហើយយើងនឹងបំបាត់រូបព្រះក្លែងក្លាយ
«បំផ្លាញរូបព្រះដែលឥតប្រយោជន៍»
ក្រុងណូប
ក្រុងណូប គឺជាទីក្រុងសំខាន់មួយនៅអេស៊ីប។
វានៅជិតទីក្រុងកាអ៊ីរ៉ូរសម័យទំនើប។
ទឹកដីអេស៊ីបនឹងលែងមានអ្នកដឹកនាំ
«មេដឹកនាំដ៏សំខាន់ម្នាក់នៅស្រុកអេស៊ីប»
យើងនឹងធ្វើឲ្យមានការភ័យខ្លាចនៅទឹកដីអេស៊ីប
«យើងនឹងធ្វើឲ្យប្រជាជនអេស៊ីបភ័យខ្លាច»
ក្រុងប៉ាត្រុស
នេះគឺជាតំបន់មួយនៅភាគខាងត្បូងប្រទេសអេស៊ីប។
នឹងដុតកម្ទេចក្រុងសូអាន
«ខ្ញុំនឹងដុតសូអានដោយភ្លើង»
ក្រុងសូអាន
ទីក្រុង សូអាន គឺជាទីក្រុងសំខាន់មួយទៀតនៅក្នុងប្រទេសអេស៊ីប។
ក្រុងនរ
នេះគឺជាទីក្រុងរដ្ឋធានីនៃប្រទេសអេស៊ីបភាគខាងត្បូង។
Ezekiel 30:15
ព័ត៌មានទូទៅ:
ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីស្រុកអេស៊ីប។
ដ្បិត យើងនឹងចាក់កំហឹងរបស់យើងលើក្រុងស៊ីន
«ដ្បិត ព្រោះយើងខឹងនឹងទីក្រុងស៊ីន» ឬ «ព្រោះយើងខឹងខ្លាំងណាស់
នឹងដាក់ទណ្ឌកម្មក្រុងស៊ីនយ៉ាងធ្ងន់ធ្ងរ»
ក្រុងស៊ីន
នេះគឺជាទីក្រុងសំខាន់មួយនៅភាគខាងជើងប្រទេសអេស៊ីប។
ដកជីវិតប្រជាជនដ៏ច្រើននៅក្រុងនរ
«សម្លាប់មនុស្សមួយចំនួនធំនៅ ក្រុងនរ»
ក្រុងនរ
សូមមើលពីរបៀបដែលបានបកប្រែឈ្មោះទីក្រុងនេះនៅជំពូក ៣០:១៣។
ក្រោយមកយើងនឹងដុតទឹកដីអេស៊ីប
«យើងនឹងដុតអេស៊ីបដោយភ្លើង»
នឹងភ័យតក់ស្លុត
«នឹងមានការឈឺចាប់ខ្លាំង» ឬ «នឹងមានអារម្មណ៍ឈឺចាប់ខ្លាំង»
ក្រុងនរនឹងត្រូវខ្ទាំងឡោមព័ទ្ធ
«ក្រុងនរនឹងត្រូវបំផ្លាញចោល»។ ការបកប្រែជំនួស៖
«សត្រូវនឹងយកឈ្នះលើក្រុងនរ»។
ក្រុងណូប
សូមមើលពីរបៀបដែលបានបកប្រែឈ្មោះទីក្រុងនេះនៅ ៣០:១៣។
ក្រុងណូបនឹងប្រឈមមុខជាមួយខ្មាំងសត្រូវរាល់ថ្ងៃ
ការបកប្រែជំនួស៖ «ប្រជាជននៅក្រុងណូប នឹងព្រួយបារម្ភជារៀងរាល់ថ្ងៃ»
Ezekiel 30:17
ដណ្តើមយកទឹកដីអេស៊ីបទាំងអស់។
ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីស្រុកអេស៊ីប។
ក្រុងអាវេន និងក្រុងពីបែសែត
ទាំងនេះជាទីក្រុងនៅភាគខាងជើងប្រទេសអេស៊ីប។
នឹងដួលស្លាប់ដោយមុខដាវ
ពាក្យថា «ដាវ» ត្រូវបានប្រើនៅទីនេះដើម្បីសំដៅទៅលើការប្រយុទ្ធ ឬសង្គ្រាម។
ការបកប្រែជំនួស៖ «នឹងស្លាប់ក្នុងសមរភូមិ» ឬ «នឹងស្លាប់ក្នុងសង្គ្រាម»។
ក្រុងទាំងនោះនឹងត្រូវខ្មាំងកៀរយកទៅជាឈ្លើយ
«ប្រជាជននៅទីក្រុងរបស់ពួកគេនឹងក្លាយជាឈ្លើយ សឹក» ឬ
«
ក្រុងតាហាពេនេស
នេះគឺជាទីក្រុងសំខាន់មួយនៅភាគខាងជើងប្រទេស អេស៊ីប។
ថ្ងៃនឹងងងឹត
ថ្ងៃត្រូវបានគេនិយាយដូចជាវាអាចរក្សាពន្លឺរបស់វាផ្ទាល់ពីពន្លឺ។
ការបកប្រែរបៀបផ្សេងទៀត: «ថ្ងៃនឹងងងឹត»
យើងបំបាក់នឹមរបស់ទឹកដីអេស៊ីប
ពាក្យថា «នឹម» នៅទីនេះសំដៅទៅលើអំណាចរបស់
ប្រទេសអេស៊ីបក្នុងការគាបសង្កត់ប្រជាជន។ ការបកប្រែជំនួស៖ «
នៅពេលដែលយើងបញ្ឈប់ប្រទេសអេស៊ីបពីការគាបសង្កត់ប្រជាជន» ឬ
«នៅពេលដែលខ្ញុំបញ្ចប់អំណាចរបស់ប្រទេសអេស៊ីបដើម្បីគ្រប់គ្រងប្រទេសដទៃដោយសាហាវ»។
អំណាចអួតអាងរបស់ពួកគេ ត្រូវរលាយសូន្យ
«ប្រទេសអេស៊ីបនឹងមិនមានមោទនភាពចំពោះភាពរឹងមាំទៀតទេ» ឬ
«ប្រទេសនោះនឹងលែងមានមោទនភាពចំពោះភាពខ្លាំងទៀតឡើយ»
វានឹងមានពពកគ្របដណ្តប់នាង
«ពពកនឹងគ្របលើប្រទេសអេហ្ស៊ីប» ឬ
«វានឹងដូចជាមានពពកពាសពេញប្រទេសអេស៊ីប» ។ អាចមានន័យថា គឺ១)
ពពកខ្មៅតំណាងភាពសោកសៅរបស់ប្រជាជនអេស៊ីប ឬ ២)
វានឹងមានពពកធូលីពីលើអេស៊ីបចេញពីអ្វីៗទាំងអស់ដែលត្រូវបានបំផ្លាញ។
ប្រជារាស្ត្រ
អាចមានន័យថា គឺ១) ប្រជាជននៅទីប្រជុំជនអេស៊ីប ឬ ២)
កូនស្រីរបស់ប្រជាជនអេស៊ីប
យើងនឹងធ្វើទោសដោយការជំនុំជម្រះ
«យើងនឹងដាក់ទណ្ឌកម្មអេស៊ីបតាមរបៀបជាច្រើន»
ដូច្នេះ ពួកគេ
«ដូច្នេះជនជាតិអេស៊ីប»
ទទួលស្គាល់ថា យើងពិតជាព្រះអម្ចាស់
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ៦:៦។
Ezekiel 30:20
ក្រោយមក បានចូលមកដល់

generated on Wed Sep 10 16:16:32 2025

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់
បង្ហាញដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
នៅក្នុងឆ្នាំទីដប់មួយ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២៦:១ ។
ខែទីមួយ ថ្ងៃទីប្រាំពីរនៃខែនោះ
«នៅថ្ងៃទីប្រាំពីរនៃខែដំបូង»។ នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ថ្ងៃទី ៧
ជិតដល់ដើមខែមេសាតាមប្រតិទិនលោកខាងលិច។
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ១: ១។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២: ១។
យើងបានកាច់បំបាក់ដៃ របស់ផារ៉ោន
ពាក្យថា «ដៃ» នៅទីនេះតំណាងឲ្យអំណាចរបស់ស្តេច។
មើល!
ពាក្យថា «មើល»
នៅទីនេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើង។
គ្មាននរណារុំរបួស ឬដាក់ថ្នាំឲ្យ
ការបកប្រែរបៀបផ្សេងទៀត:
«ដៃរបស់គាត់មិនរុំហើយវាមិនមានថ្នាំអ្វីទេដូច្នេះវាអាចជាសះស្បើយ»
ក្រណាត់មកចងអប
ក្រណាត់ទន់មួយដុំដែលមនុស្សដាក់លើមុខរបួសដើម្បីឲ្យពួកគេជាសះស្បើយ។
ឲ្យស្តេចនេះអាចកាន់ដាវបាន
ពាក្យថា «ដាវ» នៅទីនេះតំណាងអំណាចរបស់ស្តេចក្នុងសង្គ្រាម។
«ដូច្នេះដៃរបស់គាត់នឹងមិនមានកម្លាំងគ្រប់គ្រាន់ក្នុងការប្រើប្រាស់ដាវទេ»
Ezekiel 30:22
ព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូលដូច្នេះ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ៣:១០។
ទាំងសងខាង គឺដៃដែលនៅមាំ និងដៃដែលបាក់ហើយនោះ
«ទាំងដៃដែលមានសុខភាពល្អនិងដៃដែលខូចរួចទៅហើយ»
យើងនឹងធ្វើឲ្យដាវធ្លាក់ចុះពីដៃ
«យើងនឹងដកដាវចេញពីដៃរបស់ស្តេចផារ៉ោន»
យើងនឹងរំលាយជនជាតិអេស៊ីបក្នុងចំណោមប្រជាជាតិនានា យើងនឹងកម្ចាត់កម្ចាយពួកគេឲ្យទៅទឹកដីផ្សេងៗ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២០:២៣។
ទឹកដី
«ប្រទេស»
យើងនឹងចម្រើនកម្លាំងដៃស្តេចបាប៊ីឡូន
« យើងនឹងធ្វើអោយដៃស្តេចស្រុកបាប៊ីឡូនរឹងមាំ»
ស្រែកថ្ងូរនៅចំពោះមុខស្តេចទឹកដីបាប៊ីឡូន
នៅពេលដែលស្តេចបាប៊ីឡូនមកវាយប្រហារស្រុកអេស៊ីបនោះផារ៉ូនឹងស្រែកថ្ងូរ។
ស្រែកថ្ងូរ
ការថ្ងូរគឺជាសំលេងខ្លាំងៗ
ដែលមនុស្សធ្វើនៅពេលដែលពួកគេមានការឈឺចាប់ច្រើន ឬកំពុងតែស្លាប់។
ជាមួយសេចក្តីស្លាប់ជិតនឹងមកដល់
«ដូចជាបុរសម្នាក់ដែលកំពុងស្លាប់កំពុងតែថ្ងូរ» ឬ «ដូចជាបុរសដែលកំពុងស្លាប់»
Ezekiel 30:25
ដ្បិត យើងនឹងពង្រឹងកម្លាំងរបស់ស្តេចទឹកដីបាប៊ីឡូន ក្នុងពេលដៃរបស់ស្តេចផារ៉ោន
ពេលដៃរបស់ស្តេចផារ៉ោនទាំងពីរបានធ្លាក់ចុះ
«ប៉ុន្តែស្តេចផារ៉ោននឹងមិនអាចប្រើដៃរបស់គាត់» ឬ
«ដៃរបស់ស្តេចផារ៉ោននឹងទន់ខ្សោយ ដូច្នេះគាត់មិនអាចប្រើពួកគេ»
ហើយពួកគេ
ពាក្យថា «ពួកគេ» អាចសំដៅទៅលើ ១) «ប្រជាជនអេស៊ីប» ឬ ២)
«ប្រជាជនទាំងអស់ដែលលឺអ្វីដែលព្រះអម្ចាស់បានធ្វើ» ។
យើងពិតជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង ៦:៦
ហើយពេលស្តេចនេះលើកដាវតម្រង់ទៅរកអេស៊ីប
«ស្តេចស្រុកបាប៊ីឡូននឹងវាយប្រហារដាវនៅស្រុកអេស៊ីបដោយដាវរបស់យើង»
រំលាយជនជាតិអេស៊ីបក្នុងចំណោមប្រជាជាតិផ្សេងៗ យើងនឹងតាមប្រហារពួកគេទៅ
គ្រប់ទីកន្លែងទាំងអស់
សូមមើលពីរបៀបដែលបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ២០:២៣។

---

31 [1]ក្រោយ មកដល់នៅ ក្នុងឆ្នាំទីដប់មួយ ខែទីបី ថ្ងៃទីមួយនៅក្នុងខែនោះ ដែលព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ចូរប្រាប់ដល់ផារ៉ោន ស្តេចប្រទេសអេស៊ីប ហើយនិងពួកបរិវារនៅជុំវិញស្តេ យ៉ាងច្រើន ក្នុងភាពធំសម្បើម តើអ្នកធៀបដូចជាអ្វី?
[3]ចូរមើល! អាស៊ីរីដូចជាដើមតាត្រៅនៅលើភ្នំលីបង់ ដែលបែកមែកសាខា និងមានម្លប់ដ៏ត្រជាក់ ហើយដើមតាត្រៅនោះលូតទៅខាងលើ ចុងវាខ្ពស់ក៏ខ្ពស់ឡើងដែរ។[4]ទឹកទន្លេធ្វើឲ្យវាដុះខ្ពស់ឡើង ទឹកនៅទីជម្រៅធ្វើឲ្យវាធំឡើង។ ហើយទឹកទន្លេនោះដ៏ហូរជុំវិញតំបន់នោះ រួចបែកជាដៃទន្លេ ដោយហូរទៅស្រោចស្រព ដើមឈើទាំងប៉ុន្មាននៅតាមទីវាលដែរ។
[5]ដូច្នេះហើយ បានជាវាធំនិងលូតខ្ពស់ជាង អស់ទាំងដើមឈើនៅទីវាលនោះ និងមែកវាចម្រើនជាច្រើនឡើង ហើយក៏លូតចេញវែង ដោយមានទឹកជាច្រើន
ដូច្នេះហើយបានជាធ្វើឲ្យបែកមែកកាន់តែច្រើន។[6]អស់ទាំងសត្វហើរលើអាកាស បានធ្វើសម្បុកនៅមែកវា ហើយគ្រប់ទាំងសត្វនៅដី បានបង្កើតកូននៅក្រោមដើមវាដែរ។
ហើយប្រជាជាតិនានា ក៏អាស្រ័យនៅក្រោមម្លប់របស់កើមនោះដែរ។[7]ដ្បិត ដោយសារតែសម្រស់ដ៏ស្អាត់និងភាពធំអស្ចារ្យហើយមានមែកវែង ដ្បិត ឫសរបស់វាបាននៅក្បែរផ្លូវទឹក។
[8]ដើមតាត្រៅនៅដែលក្នុងសួនរបស់ព្រះជាម្ចាស់ មិនអាចប្រៀបផ្ទឹមនឹងវាបានទេ។ ចំណែកឯដើមគគីរ ឬដើមកកោះ ក៏មិនអាចផ្ទឹមស្មើនឹងវាដែរ។ គឺគ្មានដើមឈើណាក្នុងសួនរបស់ព្រះជាម្ចាស់ដែលល្អនិងមានភាពស្រស់ស្អាត់ដូចវាដែរ។[9]យើងបានតុបតែងវាឲ្យមានមែកជាច្រើន ដើមឈើទាំងប៉ុន្មាននៅក្នុងសួនអេដែន ដែលជាសួនរបស់ព្រះជាម្ចាស់នាំគ្នាច្រណែននឹងវាណាស់។
[10]ដូច្នេះហើយ យើងគឺជាព្រះជាអម្ចាស់ដ៏ជាព្រះមានបន្ទូលដូច្នេះ ដោយព្រោះដើមតាត្រៅនេះមានកម្ពស់ខ្ពស់ណាស់ ចុងរបស់វាលូតឡើងកប់ពពក ហើយចិត្តរបស់វាក៏ព្រហើនដែរ។[11]យើងបានប្រគល់វាទៅក្នុងកណ្តាប់ដៃរបស់មេដឹកនាំនៃប្រជាជាតិទាំងឡាយ អ្នកនោះនឹងប្រព្រឹត្តចំពោះវា តាមអំពើអាក្រក់របស់វា។ យើងបានបោះបង់វាចោលហើយ។
[12]ជនបរទេសដែលជាអ្នកសាហាវជាងគេទាំងអស់ក្នុងចំណោមប្រជាជាតិទាំងឡាយ បានកាប់ដើមឈើនោះ រួចទុកចោល។ មែករបស់វារលំបាក់ទៅលើតំបន់ភ្នំ និងជ្រលងភ្នំទាំងអស់។ ចំណែកមែកតូចៗរបស់វាបាក់ធ្លាក់ទៅតាមជ្រោះទាំងឡាយ នៅក្នុងទឹកដីនោះ។ ដ្បិតជនជាតិទាំងនោះដែលនៅផែនដីនាំគ្នាចាកចេញពីម្លប់របស់វា ហើយបោះបង់វាចោល។
[13]សត្វស្លាបទាំងអស់នោះដែលរស់តាមមែកឈើបាក់បែក បាននាំគ្នាមកទំនៅតាមមែករបស់វា ហើយសត្វផ្សេងឯទៀតដែលនៅទីវាលក៏មកស្នាក់អាស្រ័យនៅ តាមមែករបស់វាដែរ។[14]ការទាំងនេះកើតឡើង ដើម្បីកុំឲ្យដើមឈើដែលដុះក្បែរប្រភពទឹកនឹងលូតខ្ពស់ ហើយចាក់ឫសទៅឆ្ងាយជាងដើមឈើដែលខ្ពស់ផ្សេងទៀត
ហើយក៏គ្មានដើមណាផ្សេងដែលដុះក្បែរប្រភពទឹកអាចលូតខ្ពស់បែបនោះឡើយ។ ពីព្រោះដើមទាំងនោះនឹងត្រូវស្លាប់ ធ្លាក់ទៅបាតដី រួមជាមួយអស់អ្នកដែលចុះទៅក្នុងរណ្តៅ។
[15]ព្រះជាអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ នៅថ្ងៃដែលដើមតាត្រៅចុះទៅស្ថានមច្ចុរាជ យើងបានឲ្យធម្មជាតិកាន់ទុក្ខ។ ព្រោះតែដើមតាត្រៅនោះងាប់ យើងបានបិទប្រភពទឹកនៅក្រោមដី និងទប់ទឹកសមុទ្រ។ យើងនឹងរក្សាទឹកដ៏ធំនេះ ហើយយើងនឹងនាំភាពសោយសោកទៅលើភ្នំលីបង់សម្រាប់គាត់។ ដូច្នេះ
ដើមឈើទាំងអស់នៅទីវាលនឹងកាន់ទុក្ខដោយសារតែវា។

generated on Wed Sep 10 16:16:32 2025

[16]យើងបានធ្វើឲ្យប្រជាជាតិទាំងនោះញ័ររន្ធត់ នៅពេលឮសម្លេងដើមតាត្រៅនោះរលំចុះ ពេលយើងទម្លាក់វាទៅស្ថានមច្ចុរាជ ជាមួយអស់អ្នកដែលធ្លាក់ក្នុងរណ្តៅ។ ដូច្នេះ យើងនឹងធ្វើ ឲ្យដើមឈើទាំងប៉ុន្មាននៅអេដែនមានទំនុកចិត្ត ព្រមទាំងដើមឈើដែលតូចៗនៅលើផែនដីផង។ ការនេះជាជម្រើសដ៏ល្អបំផុត ដែលដើមឈើដុះលើបង់ដើមឈើដែលផឹកទឹក។
[17]ដ្បិត ដើមឈើទាំងនោះក៏ធ្លាក់ចុះទៅស្ថានមច្ចុរាជ ទៅជាមួយអស់អ្នកដែលស្លាប់ដោយមុខដាវដែរ ព្រោះដើមឈើទាំងនោះជាបក្សសម្ព័ន្ធ ដែលស្ថិតនៅក្រោមម្លប់របស់ដើមតាត្រៅ ក្នុងចំណោមប្រជាជាតិទាំងឡាយ។[18]ក្នុងចំណោមដើមឈើនៅអេដែន តើមានដើមណារុងរឿងឧត្តុង្គឧត្តមដូចអ្នក? ដ្បិត យ៉ាងនេះក្តី ក៏អ្នកនឹងត្រូវគេទម្លាក់ទៅក្នុងរណ្តៅដូចដើមឈើឯទៀតៗដែរ អ្នកនឹងវិនាសជាមួយពួកទមិឡ ជាមួយអស់អ្នកដែលស្លាប់ដោយមុខដាវ។ នេះគឺស្តេចផារ៉ោន និងប្រជាជនដ៏ច្រើនឥតគណនារបស់ខ្លួន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 31:1

ក្រោយ មកដល់នៅ

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។ ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើប្រាស់វានៅទីនេះ

ក្នុងឆ្នាំទីដប់មួយ

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២៦:៦។

ខែទីបី ថ្ងៃទីមួយនៅក្នុងខែនោះ

«នៅថ្ងៃដំបូងនៃខែទីបី»។ នេះជាខែទីបីនៃប្រតិទិនហេប្រឺ។ ថ្ងៃដំបូងនេះជិតដល់ដើមខែមិថុនាលើប្រតិទិនលោកខាងលិច។

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ១: ១។

កូនមនុស្សអើយ

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២:១។

ក្នុងភាពធំសម្បើម តើអ្នកធៀបដូចជាអ្វី?

«តើអ្នកណាអស្ចារ្យជាងអ្នក?»

ព្រះអម្ចាស់ប្រើសំណួរនេះដើម្បីណែនាំប្រធានបទថ្មីមួយ។ ស្តេចផារ៉ោនបានគិតថាប្រជាជាតិរបស់លោកគឺអស្ចារ្យជាងគេតែព្រះជាម្ចាស់បំរុងនឹងនិយាយថាគ្មានអ្វីអស្ចារ្យជាងដើមតាត្រៅទេ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកគិតថាមិនមានប្រទេសណាដែលមានអំណាចខ្លាំងដូចអំណាចរបស់ប្រទេសអ្នកទេ»។

Ezekiel 31:3

ព័ត៌មានទូទៅ:

ទាំងនេះជាព្រះបន្ទូលរបស់ព្រះអង្គដែលប្រាប់ស្តេចផារ៉ោនអំពីស្រុកអាស្ស៊ីរី។ ព្រះទ្រង់ប្រទានសាររបស់ទ្រង់ជាទម្រង់នៃរឿងប្រៀបប្រដូចអំពីដើមតាត្រៅដ៏អស្ចារ្យ។

មើល!

ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»

ដើមតាត្រៅ

អាចមានន័យថា គឺ១) «មានមែកឈើជាច្រើនដែលវាផ្តល់ម្លប់ល្អ» ឬ ២) «ដែលផ្តល់ម្លប់ដល់ដើមឈើដទៃទៀតនៅក្នុងព្រៃ»។

លូតទៅខាងលើ

«និងខ្ពស់ណាស់»

ចុងវាខ្ពស់ក៏ខ្ពស់ឡើងដែរ

អាចមានន័យថា គឺ១) «កំពូលរបស់ដើមឈើស្ថិតនៅលើពពក» ឬ ២) «របស់វាស្ថិតនៅពីលើមែកឈើដទៃទៀត»។

ទឹកទន្លេធ្វើឲ្យវាដុះខ្ពស់ឡើង

«ដោយសារដើមតាត្រៅមានទឹកច្រើនវាដុះខ្ពស់ណាស់»

ទឹកនៅទីជម្រៅធ្វើឲ្យវាធំឡើង

«ទឹកនៅលើដីធ្វើឱ្យដើមតាត្រៅរីកធំណាស់»

រួចបែកជាដៃទន្លេ ដោយហូរទៅស្រោចស្រព ដើមឈើទាំងប៉ុន្មាននៅតាមទីវាលដែរ

«និងទឹកហូរដ៏ខ្លាំង បានហូរពីទន្លេទៅកាន់ដើមឈើទាំងអស់នៃទីវាល»។

Ezekiel 31:5

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅបន្ត។

ដូច្នេះហើយ បានជាវាធំនិងលូតខ្ពស់ជាង អស់ទាំងដើមឈើនៅទីវាលនោះ

«ដើមតាត្រៅមានកំពស់ខ្ពស់ជាងដើមឈើឯទៀតៗនៅក្នុងចំការ»

មែកវាចម្រើនជាច្រើនឡើង

«វាបានបែកមែកសាខាជាច្រើន»

ដោយមានទឹកជាច្រើន ដូច្នេះហើយបានជាធ្វើឲ្យបែកមែកកាន់តែច្រើន

«ពីព្រោះវាមានទឹកច្រើន»

អស់ទាំងសត្វហើរលើអាកាស បានធ្វើសម្បុកនៅមែកវា

«បក្សាបក្សីគ្រប់ប្រភេទដែលហោះហើរនៅលើមេឃបានធ្វើសំបុកនៅតាមមែករបស់វា»

ហើយគ្រប់ទាំងសត្វនៅដី បានបង្កើតកូននៅក្រោមដើមវាដែរ

«និងសត្វទាំងអស់ដែលរស់នៅក្នុងវាលផ្តល់កំណើតនៅក្រោមមែកឈើតាត្រៅ»

ហើយប្រជាជាតិនានា ក៏អាស្រ័យនៅក្រោមម្លប់របស់កើមនោះដែរ

«ប្រជាជាតិដែលមានអំណាចទាំងអស់រស់នៅក្រោមម្លប់» ឬ «ប្រជាជាតិដ៏អស្ចារ្យទាំងអស់បានរស់នៅក្រោមម្លប់ឈើនោះ» (UDB)

សម្រស់ដ៏ស្អាតនិងភាពធំអស្ចារ្យហើយមានមែកវែង

«វាស្អាតណាស់ព្រោះវាធំណាស់ហើយមែករបស់វាវែងណាស់»

Ezekiel 31:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅបន្ត។

ដើមតាត្រៅនៅដែលក្នុងសួនរបស់ព្រះជាម្ចាស់ មិនអាចប្រៀបផ្ទឹមនឹងវាបានទេ

ដោយសារទាំងនេះជាព្រះបន្ទូលរបស់ព្រះចំពោះ ផារ៉ោនវាក៏អាចត្រូវបានបកប្រែជា «ដើមតាត្រៅនៅក្នុងសួនរបស់ខ្ញុំមិនអស្ចារ្យដូចដើមឈើនោះដែរ»។

សួនរបស់ព្រះជាម្ចាស់

នេះគឺជាវិធីមួយទៀតដើម្បីសំដៅទៅលើ «សួនច្បារអេដែន»។

[illegible]

ព្រះអម្ចាស់ប្រៀបធៀបដើមឈើដែលមានមែកឈើ។ ការបកប្រែរបៀបផ្សេងទៀត: «គ្មានដើមពោធិណាដែលមានមែកធាងច្រើនដូចដើមឈើតាត្រៅទេ»។

ដើមគគី

ដើមឈើគគីមានសាខាជាច្រើន។ ពួកគេអាចលូតលាស់ខ្ពស់ណាស់។

ក៏មិនអាចផ្ទឹមស្មើនឹងវាដែរ

វាត្រូវបានបញ្ជាក់ថាព្រះអម្ចាស់ប្រៀបធៀបមែកឈើវែងនៃដើមតាត្រៅនិងមែកឈើវែងនៃមែកឈើ។ ការបកប្រែរបៀបផ្សេងទៀត: «ការដាំដើមឈើមិនមានសាខាដូចដើមឈើតាត្រៅទេ»។ ឬ «គ្មានការដាំឈើណាដែលមានមែកធាងណាមួយដូរាបណាមែកឈើតាត្រៅ»

ដើមឈើ

ដើមឈើមានដើមឈើធំៗ មានស្លឹកមានមែករឹងមាំ។ ពួកវាស្រដៀងនឹងដើមឈើដើមស្វា។

មានភាពស្រស់ស្អាតដូចវាដែរ

«គឺស្រស់ស្អាតដូចជាដើមតាត្រៅ»

យើងបានតុបតែងវាឲ្យមានមែកជាច្រើន

«យើងបានធ្វើឲ្យដើមតាត្រៅស្រស់ស្អាតដោយផ្តល់ឲ្យវានូវសាខាវែងជាច្រើន»។

ច្រណែននឹងវា

«ច្រណែននឹងដើមតាត្រៅ»

Ezekiel 31:10

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅបន្ត។

ចុងរបស់វាលូតឡើងកប់ពពក

អាចមានន័យថា គឺ១) «លើកកំពស់កំពូលរបស់គាត់ពីលើមែកឈើដទៃទៀត» ឬ ២) «លើកកំពូលដើមឈើរបស់គាត់ទៅក្នុងពពក» ។

សូមមើលពីរបៀបដែលបកប្រែប្រយោគស្រដៀងគ្នានៅក្នុងជំពូក ៣១:៣

កម្ពស់ខ្ពស់ណាស់

អត្ថបទគម្ពីរនេះបន្តសំដៅទៅលើស្តេចស្រុកអាសស៊ើរដែលតំណាងដោយដើមតាត្រៅ។

យើងបានប្រគល់វាទៅក្នុងកណ្តាប់ដៃរបស់មេដឹកនាំនៃប្រជាជាតិទាំងឡាយ

«យើងបានដាក់គាត់ក្នុងអំណាចនៃប្រទេសខ្លាំងបំផុត»។ ពាក្យថា «ប្រគល់» តំណាងឲ្យការគ្រប់គ្រង។ យើងបានប្រគល់អំណាចខ្លាំងបំផុតមកលើគាត់»។

យើងបានបោះបង់វាចោលហើយ

«យើងបានយកដើមតាត្រៅនេះចេញពីដីតាត្រៅពីព្រោះដើមតាត្រៅនោះជាមនុស្សអាក្រក់»។

generated on Wed Sep 10 16:16:32 2025

Ezekiel 31:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅបន្ត។
ជាអ្នកសាហាវជាងគេទាំងអស់ក្នុងចំណោមប្រជាជាតិ
«ដែលបានធ្វើឲ្យប្រជាជាតិទាំងអស់ភ័យខ្លាច»
បានកាប់
«កាត់ដើមតាត្រៅនោះចោល»
មែកតូចៗរបស់វាបាក់ធ្លាក់
«ជនបរទេសបំបាក់ខ្នែងនៃដើមតាត្រៅ»
ខ្នែង
ខ្នែងគឺជាមែកធំណាស់ដែលដុះលើដើមឈើ។
ជាធម្មតាមានសាខាតូចៗជាច្រើនដុះនៅលើខ្នែង។
នាំគ្នាចាកចេញពីម្លប់
«បន្សល់ទុកម្លប់ដើមតាត្រៅ»
Ezekiel 31:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តបានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅ។
សត្វស្លាបទាំងអស់នោះ
«គ្រប់បក្សាបក្សីទាំងអស់ហើរលើមេឃ»
ដែលរស់តាមមែកឈើ
នេះអាចត្រូវបានបកប្រែជា «រស់នៅលើអដ្ឋិធាតុនៃដើមតាត្រៅ» ឬ
«រស់នៅលើឈើងាប់ពីលើដើមតាត្រៅដែលកំពុងដេកនៅលើដី»
មែកឈើ
គល់ឈើគឺជាផ្នែកមួយដ៏ក្រាស់នៃមែកធាងដែលចេញ
ពីដីហើយផ្ទុកដើមឈើដែលនៅសល់។
សត្វផ្សេងឯទៀតដែលនៅទីវាលក៏មកស្នាក់អាស្រ័យនៅ
«សត្វព្រៃរស់នៅក្នុងមែកឈើនៃដើមតាត្រៅ»
ដើមឈើដែលដុះក្បែរប្រភពទឹក
«ដើមឈើដែលទទួលបានទឹកច្រើន»
ហើយក៏គ្មានដើមណាផ្សេងដែលដុះក្បែរប្រភពទឹកអាចលូតខ្ពស់បែបនោះឡើយ
អាចមានន័យថា គឺ១) «នឹងមិនមានកំពស់ខ្ពស់ជាងមែកឈើដទៃទៀត» ឬ ២)
«នឹងមិនដាក់កំពូលភ្នំទៅក្នុងពពកឡើយ»។
ការទាំងនេះកើតឡើង ដើម្បីកុំឲ្យដើមឈើដែលដុះក្បែរប្រភពទឹកនឹងលូតខ្ពស់
«ហើយគ្មានដើមឈើណាផ្សេងទៀតដែលទទួលបានទឹកច្រើននឹងដុះកំពស់ម្តងទៀតទេ
ពីព្រោះដើមទាំងនោះនឹងត្រូវស្លាប់
«ដ្បិតយើងបានប្រគល់ពួកគេទៅឲ្យស្លាប់» ឬ
«យើងបានធ្វើឲ្យវាទាំងអស់នឹងស្លាប់»។ ព្រះអម្ចាស់កំពុងតែមានបន្ទូល។
ធ្លាក់ទៅបាតដី
«ហើយយើងបានបង្កើតវាឡើងដូច្នេះពួកគេទាំងអស់នឹងត្រូវចុះទៅក្រោមដី»។
រួមជាមួយអស់អ្នកដែលចុះទៅក្នុងរណ្តៅ
«ដើម្បីនៅជាមួយមនុស្សទាំងនោះដែលបានស្លាប់ និងបានចុះទៅផ្នូរ»
Ezekiel 31:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តបានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅ។
នៅថ្ងៃដែលដើមតាត្រៅចុះទៅស្ថានមច្ចុរាជ
ឃ្លា «ចុះទៅស្ថានឃុំព្រលឹងមនុស្សស្លាប់» មានន័យថា «ស្លាប់»។
ការបកប្រែរបៀបផ្សេងទៀត: «នៅថ្ងៃដែលដើមតាត្រៅបានស្លាប់» ឬ
«នៅថ្ងៃដែលដើមតាត្រៅត្រូវបានគេកាប់»។
យើងបានឲ្យធម្មជាតិកាន់ទុក្ខ
«យើងបានធ្វើឲ្យផែនដីកាន់ទុក្ខ»។ ព្រះអម្ចាស់បានធ្វើឲ្យ ទឹកសមុទ្រលីបង់
និងដើមឈើទាំងអស់នាំគ្នាកាន់ទុក្ខសម្រាប់ដើមតាត្រៅ។
យើងបានបិទប្រភពទឹកនៅក្រោមដី
ពាក្យថា «គ្របបាំង»
អាចសំដៅទៅលើការស្មៀកសម្លៀកបំពាក់សម្រាប់ការកាន់ទុក្ខ។
ការបកប្រែរបៀបផ្សេងទៀត:
«យើងបានធ្វើឲ្យប្រភពទឹកយំសោកចំពោះដើមតាត្រៅ» ឬ
«វាដូចជាទឹកហូរដែលស្រោចទឹកវាយំសម្រាប់វា»។
ទប់ទឹកសមុទ្រ
«យើងបានរក្សាទឹកនៅក្នុងមហាសមុទ្រពីការស្រោចទឹកលើផែនដី»
យើងនឹងរក្សាទឹកដ៏ធំនេះ
«យើងបានបង្កើតវាឡើងដើម្បីកុំអោយមានទឹកច្រើនទៀត»
នឹងនាំភាពសោយសោកទៅលើភ្នំលីបង់សម្រាប់គាត់
«ហើយយើងបានធ្វើអោយលីបង់សោកសៅចំពោះដើមតាត្រៅនេះ»
Ezekiel 31:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តបានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅ។
ពេលយើងទម្លាក់វាទៅស្ថានមច្ចុរាជ
«ពេលយើងបោះមែកឈើនោះទៅស្ថានឃុំព្រលឹងមនុស្សស្លាប់»។
ឃ្លានេះមានន័យថា «ពេលយើងសម្លាប់ដើមតាត្រៅ»។
ជាមួយអស់អ្នកដែលធ្លាក់ក្នុងរណ្តៅ
«ជាមួយមនុស្សគ្រប់គ្នាដែលបានស្លាប់ហើយបានចូលទៅក្នុងដី»
ដែលតូចៗនៅលើផែនដីផង
«ដែលត្រូវបានគេជីកជ្រៅនៅក្នុងដីរួចទៅហើយ»។ ឃ្លានេះមានន័យថា
«ដែលបានស្លាប់ទៅហើយ»។
ជម្រើសដ៏ល្អបំផុត ដែលដើមឈើដុះលើបង់ ដើមឈើដែលផឹកទឹក
«ដើមឈើល្អៗ
នៅស្រុកលីបង់ដែលមនុស្សគ្រប់គ្នាចង់បានគឺដើមឈើដែលមានទឹកច្រើន»។
ទាំងនេះជាដើមឈើអេដែន ដែលស្ថិតនៅផ្នែកខាងក្រោមបំផុតនៃផែនដី។
ជម្រើស
នេះគឺជាអ្វីដែលមនុស្សគ្រប់គ្នាចង់បានព្រោះវាល្អណាស់។
Ezekiel 31:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តបានប្រើរឿងប្រៀបប្រដូចអំពីតាត្រៅ។
ដើមឈើទាំងនោះក៏ធ្លាក់ចុះទៅស្ថានមច្ចុរាជ
ដើមឈើទាំងនោះនៅស្រុកលីបង់ក៏ងាប់ហើយចុះទៅស្ថានឃុំព្រលឹងជាមួយនឹងដើមតាត្រៅ»។
ដែលស្លាប់ដោយមុខដាវដែរ
ការបកប្រែរបៀបផ្សេងទៀត: «ខ្មាំងសត្រូវដែលបានសម្លាប់ដោយដាវ» ឬ
«ដែលបានស្លាប់នៅក្នុងសមរភូមិ» (សូមមើល: និង)
ស្ថិតនៅក្រោមម្លប់របស់ដើម
«ដើមឈើទាំងនេះនៃប្រទេសលីបង់គឺជាដៃដ៏រឹងមាំរបស់វា»។ ឃ្លាថា «ដៃខ្លាំង»
មានន័យថា «អំណាច»។ ការបកប្រែរបៀបផ្សេងទៀត: «ដើមឈើទាំងនេះគឺលីបង់
ជាអំណាចនៃដើមតាត្រៅ» ឬ «ដើមឈើទាំងនេះពង្រឹងដើមតាត្រៅ»។
ក្នុងចំណោមដើមឈើនៅអេដែន តើមានដើមណារុងរឿងឧត្តុង្គឧត្តមដូចអ្នក?
«តើដើមឈើណាខ្លះនៅក្នុងសួនអេដែនដែលមានសិរីរុងរឿងដូចអ្នក
ហើយមានកំពស់ខ្ពស់ដូចអ្នកដែរ?»។
ព្រះបានសួរសំណួរនេះដល់ផារ៉ោនដើម្បីបង្ហាញគាត់ថារឿងប្រៀបប្រដូចនេះទាក់ទងនឹងគាត់
និងប្រទេសរបស់គាត់។ វាអាចចាប់ផ្តើមជាមួយ «ដូច្នោះ ផារ៉ោន» ឬ «ដូច្នោះ
អេស៊ីប»។
នឹងត្រូវគេទម្លាក់ទៅក្នុង
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតយើងនឹងនាំអ្នកចុះ»
ដើមឈើនៅអេដែន
ការបកប្រែរបៀបផ្សេងទៀត: «ដូចជាដើមឈើដទៃទៀតនៅអេដែន»
ត្រូវគេទម្លាក់ទៅក្នុងរណ្តៅ
«ទៅកន្លែងជ្រៅមួយនៅក្នុងដី»
ក្នុងចំណោមមនុស្សដែលមិនកាត់ស្បែក
ការបកប្រែរបៀបផ្សេងទៀត:
«កន្លែងដែលអ្នកនឹងនៅជាមួយមនុស្សដែលមិនកាត់ស្បែក»
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៥:១១។

---

32 [1]ក្រោយមកវាបានកើតឡើង នៅឆ្នាំទីដប់ពីរ ខែទីដប់ពីរ ថ្ងៃទីមួយ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ចូរផ្តើមពាក្យទំនួញ
ទាក់ទងនឹងផារ៉ោន ជាស្តេចរបស់អេស៊ីប ហើយប្រាប់ថា អ្នកប្រៀបដូចជាសិង្ហស្ទាវរបស់ជនជាតិទាំងឡាយ ប៉ុន្តែ អ្នកដូចជាសត្វសម្បើមនៅក្នុងសមុទ្រ អ្នកបាន
ធ្លាយចេញមកជាមួយទន្លេ ហើយបានធ្វើឲ្យទឹកខ្វល់ឡើងដោយជើងអ្នក ព្រមទាំងឲ្យទន្លេរបស់អ្នកល្អក់ដែរ។

generated on Wed Sep 10 16:16:32 2025

[3]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដូច្នោះយើងនឹងបោះសំណាញ់របស់យើងទៅលើអ្នក ដែលប្រជុំគ្នាមានចំនួនមនុស្សច្រើន ហើយពួកគេនឹងលើលឡើងដោយអ្នកជាប់ក្នុងសំណាញ់របស់យើង។[4]យើងនឹងបោះបង់អ្នកទៅលើដី។ ហើយនឹងបោះអ្នកឲ្យនៅកណ្តាលវាល យើងនឹងឲ្យសត្វត្មាតមកពីមេឃចោមរោមអ្នក ហើយឲ្យសត្វសាហាវទាំងអស់នៅលើផែនដីនឹងស្កប់ចិត្តក្នុងការស៊ីអ្នកផងដែរ។
[5]ដ្បិត យើងនឹងយកសាច់អ្នកទៅដាក់នៅលើភ្នំ ហើយយើងបំពេញជ្រលងភ្នំជាមួយដង្កូវពេញសោយសាកសពដែរ។[6]ក្រោយមក យើងនឹងចាក់ស្រោចឈាមអ្នកនៅលើភ្នំ ហើយតាមស្ទឹង និងគ្រែជាច្រើននឹងពេញទៅដោយឈាមរបស់អ្នក។
[7]ក្រោយពេលយើងពន្លត់ចង្កៀងអ្នក យើងនឹងបិតបាំងផ្ទៃមេឃ ឲ្យផ្កាយប្រែជាងងឹត យើងនឹងដាក់ពពកបិតបាំងពន្លឺព្រះអាទិត្យ ហើយឲ្យព្រះច័ន្ទលែងមានពន្លឺទៀត។[8]អស់ទាំងតួពន្លឺនៅលើមេឃ យើងនឹងធ្វើឲ្យងងឹតលើអ្នក ហើយយើងនឹងដាក់ភាពងងឹតនៅលើផែនដី នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ។
[9]ដូច្នោះ យើងនឹងធ្វើឲ្យស្រយុតចិត្តនៃមនុស្សជាច្រើន ក្នុងទឹកដីដែលអ្នកមិនបានដឹង ពេលយើងនាំទៅដាក់ក្នុងស្រុករបស់អ្នក ទៅកណ្តាលប្រជាជាតិ ក្នុងទឹកដីជាច្រើនទៀតដែលអ្នកមិនបានស្គាល់។[10]យើងនឹងធ្វើឲ្យជនជាតិជាច្រើនតក់ស្លុត ខ្វល់ខ្វាយពីអ្នក។ ស្តេចរបស់ពួកគេភ័យខ្លួននឹងញ័ររន្ធត់ខ្វល់ខ្វាយពីអ្នក ពេលយើងក្រវីដាវរបស់យើងនៅមុខពួកគេ។ គ្រប់ពេលវេលា គ្រប់គ្នានឹងភ័យញាប់ញ័រដោយព្រោះតែអ្នក នៅថ្ងៃនៃសេចក្តីស្លាប់របស់អ្នក។
[11]ដ្បិតព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដាវរបស់ស្តេចនៃបាប៊ីឡូននឹងប្រហារអ្នក។[12]យើងនឹងធ្វើឲ្យប្រជាជនដ៏ច្រើនរបស់អ្នកស្លាប់ដោយមុខដាវរបស់អ្នកចម្បាំង អ្នកចម្បាំងម្នាក់ធ្វើឲ្យប្រជាជាតិនានាភ័យខ្លាច។ ចម្បាំងទាំងនេះនឹងបំបាក់អំនួតរបស់ទឹកដីអេស៊ីប ហើយបំផ្លាញប្រជាជនរបស់គេទាំងអស់។
[13]ដ្បិតយើងនឹងបំផ្លាញហ្វូងសត្វទាំងអស់ចាប់តាំងពី នៅក្បែរទន្លេទឹកច្រើន ជើងរបស់មនុស្សមិនអាចធ្វើឲ្យល្អក់ទឹកទៀតហើយ។[14]ក្រោយមក យើងនឹងធ្វើឲ្យទឹកនៅស្ងប់ស្ងៀម ហើយធ្វើឲ្យទន្លេហូរដូចប្រេង នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ។
[15]ពេលយើងធ្វើឲ្យទឹកដីអេស៊ីប ក្លាយទៅជាកន្លែងគេបោះបង់ចោល ពេលទឹកដីគឺធ្វើនៅកណ្តាលវាលគ្រប់របស់បានពេញ ពេលយើងប្រហារប្រជាជនអេស៊ីប ពួកគេនឹងដឹងថា យើងពិតព្រះអម្ចាស់។[16]នេះជាបទទំនួញដែលពួកកូនស្រីនៃជនជាតិត្រូវស្មូត្រនៅតាមក្រុង ពួកគេនឹងស្មូត្រទំនួញនេះស្រណោះទឹកដីអេស៊ីប ហើយនៅលើប្រជាជនពួកគេនឹងស្មូត្រទំនួញនេះ នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ»។
[17]ក្រោយមកវាកើតឡើង នៅក្នុងឆ្នាំទីដប់ពីរ ខែទីដប់ប្រាំ ថ្ងៃទីដប់ប្រាំក្នុងខែនោះ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំប្រាប់ថា[18]«កូនមនុស្សអើយ ចូរយំស្រណោះប្រជាជនដ៏ច្រើននៅអេស៊ីបទៅ ហើយទម្លាក់ពួកគេចុះ ទាំងក្រុងហើយនិងប្រជាជនអស្ចារ្យនៃប្រជាជាតិទាំងមូល គឺទៅទាបបំផុតនៃផែនដីជាមួយអស់អ្នកដែលធ្លាក់ទៅក្នុងរណ្តៅ។
[19]តើអ្នកពិតជាស្អាត់ជាងអ្នកណាទាំងអស់? ចូរទៅខាងក្រោមហើយដេកចុះជាមួយអ្នកដែលមិនបានកាត់ស្បែកទៅ។[20]ពួកគេនឹងដួលក្នុងចំណោមអ្នកដែលត្រូវសម្លាប់ដោយដាវ។ ដាវហូតចេញពីស្រោមហើយ! ទីក្រុងនេះបានទទួលផ្លែដាវ ពួកគេនឹងប្រហារទីក្រុងនេះ ហើយនិងប្រជាជនរបស់គេផង។[21]ពួកអ្នកចម្បាំងដ៏អង់អាចនៃស្ថានមច្ចុ នឹងប្រកាស់អំពីអេស៊ីប និងសម្ពន្ធមិត្តរបស់ពួកគេ! ពួកគេត្រូវតែមកទីនេះ! ពួកគេនឹងដេកដួលជាមួយពួកមិនកាត់ស្បែក
ជាមួយពួកអ្នកដែលត្រូវបានសម្លាប់ដោយដាវ។
[22]អាស្ស៊ីរីនៅទីនោះ ជាមួយកងទ័ព។ ផ្នូរទាហាននៅព័ទ្ធជុំវិញពួកគេ ហើយពួកគេទាំងនោះបានសម្លាប់ដោយដាវ។[23]ហើយផ្នូរទាំងអស់នោះគឺជារបស់គេបានធ្វើនៅទីបំផុតនៃជង្ហុកធំ ជាមួយកងទ័ពរបស់គេ។ ផ្នូររបសគេព័ទ្ធជុំវិញដោយអ្នកដែលបានស្លាប់ គឺអ្នកត្រូវដួលស្លាប់ដោយដាវ ជាពួកអ្នកដែលនាំឲ្យមានសេចក្តីស្ញែងខ្លាចមកលើទឹកដីដែលមនុស្សរស់នៅ។
[24]អេឡាំគឺនៅទីនោះ ជាមួយប្រជាជនរបស់ខ្លួន។ ផ្នូរជាច្រើនទៀតបាននៅជុំវិញផ្នូររបស់គាត់ អ្នកទាំងនោះត្រូវបានសម្លាប់។ គ្រប់គ្នាត្រូវដួលស្លាប់ដោយដាវ គឺជាអ្នកដែលបានទៅក្រោមអ្នកដែលមិនកាត់ស្បែកទៅទីដែលទាបបំផុតនៃផែនដី ក៏ជាអ្នកបាននាំការភ័យក្លាយរបស់ពួកគេមកលើទឹកដីដែលគេរស់នៅ ហើយក៏ជាអ្នកនាំមកនូវការអាម៉ាស់ដែរ រួមជាមួយអ្នកដែលបានធ្លាក់ទៅក្នុងរណ្តៅនោះ។[25]ពួកគេរៀបចំរមាលគ្រែរបស់អេឡាំ
ហើយនឹងប្រជាជនរបស់គាត់នៅកណ្តាលនៃការប្រហារនោះ ផ្នូររបស់គាត់នៅជុំវិញគាត់។ ពួកគេទាំងអស់គឺមិនបានកាត់ស្បែកត្រូវចាក់ទំលុះដោយដាវ ពីព្រោះពួកគេបាននាំការភ័យខ្លាចមកលើទឹកដីដែលគេរស់នៅ។ ដូច្នោះពួកគេនាំទៅជាមួយការអាម៉ាស់របស់គេ
រួមជាមួយគ្នានិងអ្នកដែលបានធ្លាក់ចុះទៅក្នុងរណ្តៅនិងជាមួយចំណោមអ្នកដែលបានសម្លាប់។ អស់អ្នកណាដែលាបានធ្លាក់ទៅក្រោមរណ្តៅ។
អេឡាំគឺនៅក្នុងចំណោមពួកអ្នកដែលបានស្លាប់។
[26]មែសេក និងទូបាល ព្រមទាំងពួកប្រជាជនដ៏នៅទីនោះដែរ! ហើយផ្នូររបស់គេនៅព័ទ្ធជុំវិញគេ។ គ្រប់គ្នាជាមនុស្សដែលមិនទទួលកាត់ស្បែក ហើយត្រូវស្លាប់ដោយដាវ ដ្បិតគេបានធ្វើឲ្យមានសេចក្តីស្ញែងខ្លាចដល់ទឹកដីដែលគេរស់នៅ។[27]ពួកគេមិនបានដេកជាមួយអ្នកចម្បាំង ដែលមិនកាត់ស្បែកក្នុងពួកអ្នកដែលត្រូវសម្លាប់ ជាមនុស្សដែលបានចុះទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់ ទាំងកាន់គ្រឿងចម្បាំងរបស់គេ ព្រមទាំងដាក់ដាវគេកើយក្បាល ហើយមានអំពើទុច្ចរិតរបស់គេជាប់នៅឆ្អឹងផងនោះទេ ដ្បិតគេជាទីស្ញែងខ្លាចដល់ពួកខ្លាំងពូកែ នៅក្នុងស្ថានរបស់មនុស្សរស់។
[28]ប៉ុន្តែអេស៊ីបអ្នក នឹងត្រូវបាក់បែកនៅក្នុងពួកដែលមិនបានកាត់ស្បែក! ហើយអ្នកដេកនៅជាមួយពួកអ្នកដែលត្រូវស្លាប់ដោយដាវដែរ។[29]អេដុមក៏នៅទីនោះ ព្រមទាំងពួកស្តេច និងពួកអ្នកដឹកនាំគេផង។ ពួកអ្នកដែលទោះបើខ្លាំងពូកែក៏ដោយ គង់តែត្រូវដេកនៅជាមួយពួកអ្នកដែលស្លាប់ដោយដាវដែរ គេត្រូវដេកនៅជាមួយពួកដែលមិនទទួលកាត់ស្បែក ហើយជាមួយពួកអ្នកដែលធ្លាក់ទៅក្នុងរណ្តៅដ៏ធំ។
[30]ពួកអ្នកដឹកនាំទាំងឡាយនៃផ្នែកខាងជើង ពួកគេទាំងអស់ហើយពួកស៊ីដូនទាំងអស់ក៏បានទៅកនលែងដែលពួកគេបាបចាក់ទំលុះ។
ពួកគេមានអំណោចហើយបានធ្វើអ្នកដទៃខ្លាច តែគេពេលនេះពួកគេនៅក្នុងភាពអាម៉ាស់ មិនបានកាត់ស្បែក រួមជាមួយអ្នកដែលបានចាក់ទំលុះដោយដាវ។
ពួកគេនាំទៅជាមួយការខ្មាសរបស់ខ្លួន ជាមួយពួកអ្នកដែលធ្លាក់ទៅក្នុងរណ្តៅដ៏ធំ។
[31]ផារ៉ោននឹងឃើញគេដែរ ហើយមានសេចក្តីក្សាន្តចិត្ត ពីដំណើរពួកកកកុញរបស់វា គឺផារ៉ោននោះ និងពួកកងទ័ព ដែលត្រូវស្លាប់ដោយដាវ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ។[32]ដ្បិតយើងបានធ្វើឲ្យសេចក្តីស្ញែងខ្លាចរបស់យើងកើតឡើងនៅក្នុងស្ថានរបស់មនុស្សរស់ ហើយវានឹងត្រូវផ្តេកនៅកណ្តាលពួកអ្នកដែលមិនទទួលកាត់ស្បែក ជាមួយពួកអ្នកដែលត្រូវស្លាប់ដោយដាវដែរ គឺផារ៉ោននោះ ព្រមទាំងពួកកកកុញ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 32:1

ក្រោយមកវាបានកើតឡើង

ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង។ ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ពន្យល់ដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។

នៅឆ្នាំទីដប់ពីរ...ខែទីដប់ពីរ ថ្ងៃទីមួយ

នេះជាខែទី ១២ និងចុងក្រោយនៃប្រតិទិនហេប្រឺ។ ថ្ងៃដំបូងគឺជិតដល់ចុងខែកុម្ភៈ។

នៅឆ្នាំទីដប់ពីរ

«ក្នុងឆ្នាំទីដប់ពីរនៃការនិរទេសខ្លួនរបស់ស្តេច យេហូយ៉ាគីម» (សូមមើល: និងfigs-explicit)

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ១:១។

កូនមនុស្សអើយ

សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ២:១។

អ្នកប្រៀបដូចជាសិង្ហស្ទាវ...ដូចជាសត្វសម្បើមនៅក្នុងសមុទ្រ

អាចមានន័យថា គឺ១) គាត់គិតថាគាត់ដូចជាសត្វតោ ប៉ុន្តែគាត់ពិតជាមានតែបិសាច ឬ ២) គាត់ដូចជាតោនិងបិសាច។

ប្រៀបដូចជាសិង្ហស្ទាវរបស់ជនជាតិទាំងឡាយ

ស្រុកអេស៊ីបខ្លាំងជាងប្រជាជាតិឯទៀតៗដូចជាសិង្ហមានកម្លាំងជាងសត្វដទៃទៀត។

សត្វសម្បើមនៅក្នុងសមុទ្រ

generated on Wed Sep 10 16:16:32 2025

ព្រះចៅផារ៉ោនមានអំណាចតែគាត់បានបង្កបញ្ហាដល់អ្នកដទៃដូចជាការពិពណ៌នាអំពីសត្វមួយនៅក្នុងទឹក។
សត្វសម្បើម
សត្វចម្លែកគឺជាសត្វដែលធំនិងគ្រោះថ្នាក់។ មួយនេះប្រហែលជាក្រពើ។
សូមមើលពីរបៀបដែលបានបកប្រែពាក្យនេះនៅក្នុងជំពូក ២៩:១។
Ezekiel 32:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់ផារ៉ោន
និងប្រៀបធៀបគាត់ទៅនឹងបិសាចដែលរស់នៅក្នុងទឹក។
ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៥:៥។
ដូច្នោះយើងនឹងបោះសំណាញ់របស់យើងទៅលើអ្នក ដែលប្រជុំគ្នាមានចំនួនមនុស្សច្រើន
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះយើងនឹងប្រមូលមនុស្សជាច្រើន
ហើយបោះសំណាញ់របស់អ្នកលើអ្នក»។
ជាប់ក្នុងសំណាញ់របស់យើង
ការបកប្រែរបៀបផ្សេងទៀត:
«ដោយប្រើសំណាញ់របស់យើងប្រជាជននឹងទាញអ្នកចេញពីទឹក»
យើងនឹងបោះបង់អ្នកទៅលើដី
«យើងនឹងទុកឲ្យអ្នកអស់សង្ឃឹមនៅលើដី»។
បិសាចដែលគួរឲ្យខ្លាចនៅពេលដែលវានៅក្នុងទឹកមិនអាចធ្វើអ្វីបានទេនៅពេលវាទុកនៅលើដី
គ្រប់ទាំងបក្សាបក្សីទាំងអស់នៅលើមេឃ
«សត្វស្លាបទាំងអស់ដែលហើរនៅលើមេឃ»
ឲ្យសត្វសាហាវទាំងអស់នៅលើផែនដីនឹងស្កប់ចិត្តក្នុងការស៊ីអ្នកផងដែរ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងអោយសត្វទាំងអស់នៅលើផែនដីស៊ីសាច់របស់អ្នករហូតដល់ពួកគេមិនឃ្លានទៀតឡើយ»
Ezekiel 32:5
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់ផារ៉ោន
និងប្រៀបធៀបគាត់ទៅនឹងបិសាចដែលរស់នៅក្នុងទឹក។
ដង្ហូរពេញសោយសាកសពដែរ
«រាងកាយរលួយរបស់អ្នក»
យើងនឹងចាក់ស្រោចឈាមអ្នកនៅលើភ្នំ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងជន់លិចដីដោយឈាមរបស់អ្នករហូតដល់ភ្នំ»។
ត្រែជាច្រើននឹងពេញទៅដោយឈាមរបស់អ្នក
«យើងនឹងបំពេញដោយឈាមរបស់អ្នក» ឬ
«ហើយពួកគេនឹងបំពេញហូរហៀរដោយឈាមរបស់អ្នក»
Ezekiel 32:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលជាមួយផារ៉ោនពីអ្វីដែលទ្រង់នឹងធ្វើចំពោះអេស៊ីប។
ក្រោយពេលយើងពន្លត់ចង្កៀងអ្នក
«នៅពេលដែលយើងដកដង្ហើមចេញអណ្តាតភ្លើងរបស់អ្នក»។
ព្រះអម្ចាស់ប្រៀបធៀបវិធីដែលទ្រង់នឹងបំផ្លាញផារ៉ោនទៅនឹងរបៀបដាក់ភ្លើងចេញ។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលយើងបំផ្លាញអ្នក»
យើងនឹងបិតបាំងផ្ទៃមេឃ
ព្រះអម្ចាស់នឹងគ្របបាំងផ្ទៃមេឃដើម្បីកុំអោយមនុស្សនៅលើផែនដីអាចមើលឃើញពន្លឺរបស់ព្រះអង្គ
ឲ្យងងឹតលើអ្នក
«យើងនឹងធ្វើឲ្យផ្កាយងងឹត»។ ពួកគេនឹងមិនមានពន្លឺទេ។
យើងនឹងដាក់ភាពងងឹតនៅលើផែនដី
«យើងនឹងធ្វើឲ្យវាងងឹតនៅក្នុងទឹកដីរបស់អ្នក»
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 32:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់ផារ៉ោន។
យើងនឹងធ្វើឲ្យស្រយុតចិត្តនៃមនុស្សជាច្រើន
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំនឹងធ្វើអោយចិត្តរបស់ប្រជាជនជាច្រើនភ័យខ្លាច»
ឬ «យើងនឹងធ្វើអោយមនុស្សជាច្រើនភ័យខ្លាច»
ក្នុងទឹកដីដែលអ្នកមិនបានដឹង
របៀបដែលព្រះអម្ចាស់បំផ្លាញស្រុកអេស៊ីបនឹងជាការគួរឲ្យខ្លាចណាស់សូម្បីតែប្រជាជនដែលមិនស្គាល់ព្រះអង្គក៏ញាប់ញ័រដែរ។
ផ្លាស់ប្តូរនៅក្នុងទឹក
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលប្រជាជាតិនានាបានលឺ
អំពីផ្លូវដែលយើងបានបំផ្លាញអ្នក»
យើងនឹងធ្វើឲ្យជនជាតិជាច្រើនតក់ស្លុត ខ្ញល់ខ្ញាយពីអ្នក
«យើងនឹងធ្វើឲ្យប្រជាជនជាច្រើនភ័យរន្ធត់ព្រោះតែអ្វីដែលកើតឡើងចំពោះអ្នក»
ស្តេចរបស់ពួកគេភ័យខ្លួននឹងញ័ររន្ធត់ខ្ញល់ខ្ញាយពីអ្នក
ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចរបស់ពួកគេនឹងភ័យខ្លាចយ៉ាងខ្លាំងចំពោះអ្វីដែលកើតឡើងចំពោះអ្នកដែលពួកគេនឹងរញ្ជួយ»
គ្រប់ពេលវេលា គ្រប់គ្នានឹងភ័យញាប់ញ័រដោយព្រោះតែអ្នក
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេម្នាក់ៗនឹងនៅតែបន្តរង្គោះរង្គើដោយសារតែការភ័យខ្លាចរបស់ពួកគេ»
នៅថ្ងៃនៃសេចក្តីស្លាប់របស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលយើងបំផ្លាញអ្នក»
Ezekiel 32:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់ផារ៉ោន។
ដាវរបស់ស្តេចនៃបាប៊ីឡូននឹងប្រហារអ្នក
ពាក្យថា «ដាវ» សំដៅលើកងទ័ពមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«កងទ័ពរបស់ស្តេចស្រុកបាប៊ីឡូននឹងវាយប្រហារអ្នក»
យើងនឹងធ្វើឲ្យប្រជាជនដ៏ច្រើនរបស់អ្នកស្លាប់ដោយមុខដាវ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើឲ្យប្រជារាស្ត្ររបស់អ្នកដួលដោយមុខដាវរបស់មនុស្សខ្លាំងពូកែ»។
អ្នកចម្បាំងម្នាក់ធ្វើឲ្យប្រជាជាតិនានាភ័យខ្លាច
ការបកប្រែរបៀបផ្សេងទៀត: «អ្នកចម្បាំងម្នាក់ៗបំភ័យប្រជាជាតិនានា» ឬ
«ពួកគេម្នាក់ៗធ្វើឲ្យប្រជាជាតិនានាខ្លាច»
ហើយបំផ្លាញប្រជាជនរបស់គេទាំងអស់
«និងសំលាប់មនុស្សមួយចំនួនធំ ដែលរស់នៅក្នុងប្រទេសអេស៊ីប»
Ezekiel 32:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូល
ហ្វូងសត្វទាំងអស់
បសុសត្វគឺជាសត្វដែលមនុស្សត្រូវបរិភោគ និងសម្រាប់ហេតុផលផ្សេងទៀត។
សត្វគោ ចៀម និង ពពែគឺជាសត្វចិញ្ចឹមទាំងអស់។
នៅក្បែរទន្លេទឹកច្រើន
«ពីកន្លែងដែលមានទឹកច្រើន»
ជើងរបស់មនុស្ស
«ជើងមនុស្ស»
ក្រោយមក យើងនឹងធ្វើឲ្យទឹកនៅស្ងប់ស្ងៀម
អាចមានន័យថា គឺ១) «យើងនឹងធ្វើឲ្យទឹកស្ងប់» ឬ ២) «យើងនឹងធ្វើឲ្យទឹកថ្លា» ។
នៅពេលដែលគ្មាននរណាម្នាក់កូរទឹកឡើងភាពកខ្វក់នឹងធ្លាក់ចុះ
ហើយទឹកនឹងប្រែជាថ្លាល្អ។
ហើយធ្វើឲ្យទន្លេហូរដូចប្រេង
ប្រេងហូរយឺតៗ និងរលូន។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឲ្យទឹកទន្លេហូររលូនដូចប្រេង»
ព្រះអម្ចាស់នឹងធ្វើឲ្យស្រុកអេស៊ីបត្រឡប់ទៅជាទីស្ងាត់ជ្រងំ
សូមមើលពីរបៀបដែលអ្នកការបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 32:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូល។
ទឹកដីដែលពេញទៅដោយ
ការបកប្រែរបៀបផ្សេងទៀត: «ដីដែលពោរពេញទៅដោយតួរមានជីវិត» ឬ
«ដីដែលពេញទៅដោយជីវិត»
ពេលយើងប្រហារប្រជាជន
«នៅពេលដែលយើងបំផ្លាញអស់អ្នកដែលរស់នៅទីនោះ»
នឹងដឹងថា យើងពិតព្រះអម្ចាស់
សូមមើលពីរបៀបដែលអ្នកការបកប្រែនៅក្នុងជំពូក ៦:៦។
នេះជាបទទំនួញ
ការបកប្រែរបៀបផ្សេងទៀត:
«នៅស្រីៗជាតែងតែច្រៀងបទទំនួញនេះដែរ។

generated on Wed Sep 10 16:16:32 2025

កូនស្រីនៃជនជាតិ
អាចមានន័យថា គឺ១) «ស្ត្រីនៃប្រជាជាតិដទៃទៀត» ឬ
«ប្រជាជននៃប្រជាជាតិដទៃទៀត»
នឹងសូត្រទំនួញនេះស្រណោះទឹកដីអេស៊ីប
ពាក្យថា «នាង» សំដៅទៅលើប្រទេសអេស៊ីប។
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 32:17
ក្រោយមកវាកើតឡើង
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការចាប់ផ្តើមនៃសារថ្មី។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះអ្នកអាចពិចារណាប្រើវានៅទីនេះ។
នៅក្នុងឆ្នាំទីដប់ពីរ
អត្ថន័យដែលអាចមានគឺ ១) រឿងនេះបានកើតឡើងក្នុងឆ្នាំទី ១២
បន្ទាប់ពីពួកបាប៊ីឡូនបានយកជនជាតិអ៊ីស្រាអែលទៅស្រុកបាប៊ីឡូនឬ ២)
រឿងនេះបានកើតឡើងក្នុងឆ្នាំទី ១២ បន្ទាប់ពីពួកបាប៊ីឡូនបានយក
យេហូយ៉ាគីមទៅស្រុកបាប៊ីឡូន។
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមក
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១ ។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលអ្នកបកប្រែវានៅក្នុងជំពូក ២:១។
ចូរយំស្រណោះប្រជាជនដ៏ច្រើននៅអេស៊ីបទៅ
«ស្រែកខ្លាំងៗ ដល់កងទ័ពអេស៊ីប»
ទម្លាក់ពួកគេចុះ—ទាំងក្រុងហើយនិងប្រជាជនអស្ចារ្យនៃប្រជាជាតិ
ការបកប្រែរបៀបផ្សេងទៀត: «បោះចោលស្រុកអេស៊ីប
និងកូនស្រីរបស់ប្រជាជាតិនានា»
ប្រជាជនអស្ចារ្យនៃប្រជាជាតិទាំងមូល
អត្ថន័យដែលអាចមានគឺ ១) «ប្រជាជននៃប្រទេសមានអំណាច» ឬ ២)
«ប្រទេសមានអំណាចដទៃទៀត» ។
ទាបបំផុតនៃផែនដី
«ទៅកន្លែងក្រោមដី»។ នៅពេលមនុស្សស្លាប់ពួកគេត្រូវបានគេដាក់ក្នុងដី។ ដូច្នេះ
«បោះវាចុះ ... ទៅផែនដីទាបបំផុត» មានន័យថា «ធ្វើឲ្យពួកគេស្លាប់» ។
ជាមួយអស់អ្នកដែលធ្លាក់ទៅក្នុងរណ្តៅ
«ជាមួយមនុស្សគ្រប់គ្នាដែលបានស្លាប់ហើយចូលទៅក្នុងដី»
រណ្តៅ
ពាក្យថា «រណ្តៅ» សំដៅទៅលើផ្នូរ។
វាគឺជាប្រហោងនៅក្នុងដីដែលមនុស្សចូលទៅបន្ទាប់ពីពួកគេបានស្លាប់។
Ezekiel 32:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់អេសេគាល។
សួរពួកគេ
«សួរអេស៊ីប និងកងទ័ពរបស់នាង»
ចូរទៅខាងក្រោម
វាបញ្ជាក់ថាពួកគេចុះទៅស្ថានឃុំព្រលឹងមនុស្សស្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «ចុះទៅស្ថានមនុស្សស្លាប់»។
ពួកគេ
«អេស៊ីបនិងកងទ័ពរបស់នាង»
នឹងដួល
«នឹងស្លាប់»
ដែលត្រូវសម្លាប់ដោយដាវ
ការបកប្រែរបៀបផ្សេងទៀត: «ខ្មាំងសត្រូវដែលបានសម្លាប់ដោយដាវ» ឬ
«អ្នកដែលបានស្លាប់នៅក្នុងសមរភូមិ»
ទីក្រុងនេះបានទទួលផ្លែដាវ
ការបកប្រែរបៀបផ្សេងទៀត: «សត្រូវនឹងវាយប្រហារប្រទេសអេស៊ីប»
ពួកគេនឹងប្រហារទីក្រុងនេះ ហើយនិងប្រជាជនរបស់គេផង
«ខ្មាំងសត្រូវរបស់នាងនឹងអូសទាញជនជាតិអេស៊ីប និងពួកអ្នកបំរើរបស់នាង»។
អ្នកបំរើនាង
អត្ថន័យដែលអាចមានគឺ ១) ប្រជាជនអេស៊ីប ឬ ២) កងទ័ពអេស៊ីប។
អេស៊ីប និងសម្ពន្ធមិត្តរបស់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «អំពីជនជាតិអេស៊ីប
និងអ្នកដែលចូលរួមជាមួយពួកគេ»
Ezekiel 32:22
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់អេសេគាលអំពីប្រជាជាតិនានានៅហ្សីអូល។
ពីព្រោះអ្វីដែលព្រះកំពុងបង្ហាញអេសេគាលប្រហែលសម្រាប់ពេលអនាគតទាំងភាពតានតឹងបច្ចុប្បន្ន
(ដូចជានៅយូអិលប៊ី) ឬភាពតានតឹងនាពេលអនាគត (ដូចជានៅ UDB)
គឺសមស្របសម្រាប់ខទាំងនេះនិងខគម្ពីរដូចខាងក្រោម។
អាស្ស៊ីរីនៅទីនោះ ជាមួយកងទ័ព
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៅស្រុកអាស្ស៊ីរី
និងកងទ័ពទាំងអស់របស់នាងស្ថិតនៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់»
ពួកគេទាំងនោះបានសម្លាប់ដោយដាវ
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេទាំងអស់បានស្លាប់ដោយដាវ» ឬ
«ពួកគេទាំងអស់បានស្លាប់នៅក្នុងសមរភូមិ»។ សូមមើលពីរបៀបដែលបកប្រែ
«អ្នកដែលត្រូវបានគេសម្លាប់ដោយដាវ» នៅក្នុង ៣១:១៧។
បានធ្វើនៅទីបំផុតនៃជង្ហុកធំ
«ស្ថិតនៅក្នុងរណ្តៅជ្រៅបំផុត»
ហើយពួកគេទាំងនោះបានសម្លាប់ដោយដាវ
ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលសត្រូវបានសម្លាប់ដោយដាវ» ឬ
«អ្នកដែលបានស្លាប់នៅពេលដែលសត្រូវបានសម្លាប់ពួកគេនៅក្នុងសមរភូមិ»
ពួកអ្នកដែលនាំឲ្យមានសេចក្តីស្ញែងខ្លាចមកលើទឹកដីដែលមនុស្សរស់នៅ
«អ្នកដែលបានធ្វើឲ្យប្រជាជននៅលើដីនៃការរស់នៅមានការភ័យខ្លាចយ៉ាងខ្លាំង»។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលនៅពេលពួកគេនៅរស់បានបណ្តាលឲ្យមនុស្សភ័យខ្លាចយ៉ាងខ្លាំង»
Ezekiel 32:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់អេសេគាលអំពីប្រជាជាតិនានានៅហ្សីអូល។
អេឡាំគឺនៅទីនោះ
ពាក្យថា «អេឡាំ» នៅទីនេះសំដៅទៅលើប្រជាជននៃប្រទេសនោះ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនអេឡាំក៏មាននៅហ្សីអូលដែរ»
ប្រជាជនរបស់ខ្លួន
អត្ថន័យដែលអាចមានគឺ ១) មនុស្សជាច្រើន ឬ ២) កងទ័ពរបស់នាង
ផ្នូរជាច្រើនទៀតបាននៅជុំវិញ
សូមមើលពីរបៀបដែលបានបកប្រែ «ផ្នូររបស់នាងព័ទ្ធជុំវិញនាង» នៅក្នុងជំពូក
៣២:២២។
អ្នកទាំងនោះត្រូវបានសម្លាប់
ការបកប្រែរបៀបផ្សេងទៀត: «សត្រូវរបស់នាងបានសម្លាប់ពួកគេទាំងអស់»
គ្រប់គ្នាត្រូវដួលស្លាប់ដោយដាវ
«ដែលបានដួលដោយដាវ» នៅក្នុងជំពូក ៣២:២២។
អ្នកដែលបានទៅក្រោមអ្នកដែលមិនកាត់ស្បែក
«អ្នកណាដែលមិនកាត់ស្បែកនៅពេលពួកគេបានធ្លាក់ចុះ»
ទីដែលទាបបំផុតនៃផែនដី
«ទៅកន្លែងជ្រៅៗ នៅក្នុងដី» ឬ «ទៅដីជ្រៅនៅក្នុងដី»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែ «នៅក្នុងអាណាចក្រទាបបំផុតនៃផែនដី»
នៅក្នុងជំពូក ២៦:១៩។
ជាអ្នកបាននាំការភ័យភ្លាយរបស់ពួកគេមកលើទឹកដីដែលគេរស់នៅ
សូមមើលពីរបៀបដែលអ្នកបកប្រែ
«ធ្វើអោយមានការភ័យខ្លាចនៅលើទឹកដីនៃអ្នករស់នៅ» នៅក្នុងជំពូក ៣២:២២។
ក៏ជាអ្នកនាំមកនូវការអាម៉ាស់ដែល
«ដែលមានអារម្មណ៍ខ្មាស់អៀន» ឬ «ដែលឥឡូវនេះអាម៉ាស់មុខ»
ពួកគេរៀបចំរមាលគ្រែរបស់អេឡាំ ហើយនឹងប្រជាជនរបស់គាត់
«ពួកគេបានអោយគ្រែដល់អេឡាំនិងអ្នកបំរើទាំងអស់របស់នាង»។
នៅកណ្តាលនៃការប្រហារនោះ
«ជាមួយមនុស្សទាំងអស់ដែលត្រូវបានសម្លាប់»។
ពួកគេទាំងអស់គឺមិនបានកាត់ស្បែក
ជនជាតិអេស៊ីបស្អប់មនុស្សដែលមិនកាត់ស្បែក។
អេឡាំគឺនៅក្នុងចំណោមពួកអ្នកដែលបានស្លាប់
នេះគឺស្រដៀងនឹងផ្នែកដំបូងនៃខ។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សស្លាប់បានផ្តល់កន្លែងអេឡាំឲ្យនៅដេកក្នុងចំណោមពួកគេ»

generated on Wed Sep 10 16:16:32 2025

Ezekiel 32:26
ខ្លឹមសារភ្ជាប់:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់អេសេគាលអំពីប្រជាជាតិនានានៅហ្សីអូល។
ព្រមទាំងពួកប្រជាជន
អត្ថន័យដែលអាចមានគឺ ១) «កងទ័ពរបស់ពួកគេទាំងអស់» ឬ ២) «ប្រជាជនជាច្រើនរបស់ពួកគេ»។
ហើយផ្នូររបស់គេនៅព័ទ្ធជុំវិញគេ
សូមមើលពីរបៀបដែលអ្នកបកប្រែ «ផ្នូររបស់នាងនៅជុំវិញនាង» នៅក្នុង ៣២:២២។
ដ្បិតគេបាន....ដល់ទឹកដីដែលគេរស់នៅ
សូមមើលពីរបៀបដែលបានបកប្រែ «ពួកគេទាំងអស់...ទឹកដីនៃការរស់នៅ» នៅក្នុងជំពូក ៣២:២៤។
អំពើទុច្ចរិតរបស់គេជាប់នៅឆ្អឹងផងនោះទេ
មិនដូចជនជាតិដទៃដែលមិនបានកាត់ស្បែកទេប្រជាជនមេសច
និងធូលត្រូវបានគេបញ្ចុះសពត្រឹមត្រូវ។
ដ្បិតគេជាទីស្ញែងខ្លាចដល់ពួកខ្លាំងពូកែ នៅក្នុងស្ថានរបស់មនុស្សរស់
«ពីព្រោះនៅពេលដែលពួកគេនៅរស់ពួកគេបានធ្វើឲ្យអ្នកចម្បាំងភ័យខ្លាច»
Ezekiel 32:28
ព័ត៌មានទូរទៅ:
ព្រះអម្ចាស់បន្តមានបន្ទូល
នឹងត្រូវបាក់បែក
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបំផ្លាញអ្នក»។
នៅក្នុងពួកដែលមិនបានកាត់ស្បែក
ការបកប្រែរបៀបផ្សេងទៀត: «រួមជាមួយមនុស្សដែលមិនកាត់ស្បែក»
ពួកអ្នកដែលត្រូវស្លាប់ដោយដាវ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣២:២៤។
អេដុមក៏នៅទីនោះ ព្រមទាំងពួកស្តេច និងពួកអ្នកដឹកនាំគេផង
«អេដុមស្ថិតនៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ជាមួយស្តេច
និងមេដឹកនាំទាំងអស់របស់នាង»។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជននៅស្រុកអេដុមស្ថិតនៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ជាមួយស្តេច
និងមេដឹកនាំរបស់ពួកគេ»។
ពួកគេមានអំណាច
«ពួកគេធ្លាប់មានអំណាចជាច្រើន»
Ezekiel 32:30
ដឹកនាំទាំងឡាយនៃផ្នែកខាងជើង
«មេដឹកនាំដែលគ្រប់គ្រងប្រទេសនៅភាគខាងជើង»
នៅទីនោះ
«នៅក្នុងស្ថានឃុំព្រលឹង»
ធ្លាក់ចុះ
«ធ្លាក់ចុះទៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់»
ជាមួយសេចក្តីស្លាប់
«ជាមួយអ្នកដែលត្រូវបានសម្លាប់»
ដែលបានចាក់ទំលុះដោយដាវ
សូមមើលពីរបៀបដែលបានបកប្រែ «អ្នកដែលត្រូវគេសម្លាប់ដោយដាវ» នៅក្នុងជំពូក ៣១:១៧។
ពួកគេនាំទៅជាមួយការខ្មាសរបស់ខ្លួន ជាមួយពួកអ្នកដែលធ្លាក់ទៅក្នុងរណ្តៅដ៏ធំ
សូមមើលពីរបៀបដែលអ្នកបកប្រែ
«ពួកគេបញ្ចោញភាពអៀនខ្មាស់របស់ពួកគេរួមគ្នាជាមួយអ្នកដែលនឹងត្រូវធ្លាក់ទៅក្នុងរណ្តៅ» នៅក្នុងជំពូក ៣២:២៤។
Ezekiel 32:31
ផារ៉ោននឹងឃើញគេដែរ
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះចៅផារ៉ោននឹងឃើញមនុស្សស្លាប់ទាំងអស់ដែលមកពីប្រជាជាតិនានា»។
ហើយមានសេចក្តីក្សាន្តចិត្ត ពីដំណើរពួកបំរើ
វាបញ្ជាក់ថាព្រះចៅផារ៉ោននឹងត្រូវបានលួងលោមព្រោះកងទ័ពរបស់ស្តេចដ៏អស្ចារ្យផ្សេងទៀតក៏ស្លាប់ដែរ។
ការបកប្រែរបៀបផ្សេងទៀត:
«ហើយនឹងលួងលោមខ្លួនឯងថាគាត់មិនមែនជាស្តេចតែមួយគត់ដែលកងទ័ពទាំងមូលបានស្លាប់ទេ»។
ដែលត្រូវស្លាប់ដោយដាវ
សូមមើលពីរបៀបដែលបានបកប្រែ «អ្នកដែលត្រូវគេសម្លាប់ដោយដាវ» នៅក្នុងជំពូក ៣១:១៧។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
ឲ្យសេចក្តីស្ញែងខ្លាចរបស់យើងកើតឡើងនៅក្នុងស្ថានរបស់មនុស្សរស់
ការបកប្រែរបៀបផ្សេងទៀត: «ពេលព្រះចៅផារ៉ោននៅរស់
យើងបានអនុញ្ញាតឲ្យគាត់ធ្វើឲ្យប្រជាជនភ័យខ្លាច»
វានឹងត្រូវផ្តេកនៅកណ្តាលពួកអ្នកដែលមិនទទួលកាត់ស្បែក
ពាក្យថា «ដេក» នៅទីនេះសំដៅទៅលើដងខ្លួនរបស់គាត់ដែលត្រូវបានដាក់ក្នុងផ្នូរ
នៅពេលគាត់ស្លាប់ទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«សាកសពរបស់គាត់នឹងត្រូវបញ្ចុះជាមួយអ្នកដែលមិនកាត់ស្បែក»

---

33 [1]ក្រោយមក ព្រះបន្ទូលនៃព្រះអម្ចាស់មកខ្ញុំប្រាប់ថា[2]«កូនមនុស្សអើយ ចូរប្រកាស់ប្រាប់ប្រជាជនរបស់អ្នក និយាយទៅគេ ពេលយើងនាំដាវមកប្រហារទឹកដី
ហើយប្រជាជននៅទឹកដីនោះជ្រើសរើសយកនរណាម្នាក់ក្នុងចំណោមពួកគេ ឲ្យធ្វើជាអ្នកយាមល្បាត។[3]អ្នកយាមចាំមើលដាវចុះមកលើទឹកដី គាត់ផ្លុំស្នែងប្រកាស
អាសន្នឲ្យប្រជាជនដឹង![4]ប្រសិនបើមនុស្សបានឮសូរត្រែ តែមិនបានយកចិត្តទុកដាក់ស្តាប់ ហើយដាវមកសម្លាប់ជីវិតពួកគេ បន្ទាប់ឈាមរបស់ម្នាក់ៗនឹងធ្លាក់ទៅលើក្បាល
គេផងដែរ។
[5]ប្រសិនបើអ្នកណាម្នាក់បានឮសូរត្រែ តែមិនអើពើសោះ ដូច្នេះ គេនឹងជាប់មានទោសចំពោះឈាមរបស់ខ្លួនវិញ ដ្បិតបើបានអើពើ នោះនឹងបានរួចជីវិត។
[6]ទោះបីជាយ៉ាងណាដ៏ដោយ ប្រសិនបើអ្នកចាំយាមឃើញដាវមក ហើយមិនផ្លុំត្រែឲ្យបណ្តាជនបានដឹង រួចដាវក៏មកដល់ យកជីវិតអ្នកណាចេញពីពួកគេទៅ អ្នកនោះនឹង
ត្រូវស្លាប់ក្នុងអំពើទុច្ចរិតរបស់ខ្លួន តែយើងនឹងទារឈាមរបស់អ្នកនោះពីដៃអ្នកចាំយាម។
[7]ចំណែកអ្នកវិញ កូនមនុស្សអើយ យើងបានតែងតាំងអ្នកឲ្យធ្វើជាអ្នកយាមល្បាត សម្រាប់កូនចៅអ៊ីស្រាអែល
អ្នកនឹងឮពាក្យចេញពីម៉ាត់របស់យើងរំលឹកគេដោយក្នុងនាមយើង។[8]បើយើងនិយាយទៅកាន់មនុស្សអាក្រក់ គឺមនុស្សអាក្រក់ អ្នកនោះនឹងត្រូវស្លាប់!
ប៉ុន្តែប្រសិនបើមិនបានប្រាប់ការនេះដើម្បីឲ្យពួកមនុស្សអាក្រក់បានដឹងពីផ្លូវរបស់គេទេ ដូច្នេះពួកមនុស្សអាក្រក់នឹងស្លាប់ដោយអំពើបាបរបស់គេ
ប៉ុន្តែយើងនឹងគិតគូបំណលឈាមនេះពីដៃរបស់អ្នកវិញ![9]ផ្ទុយទៅវិញ ប្រសិនបើអ្នកប្រាប់មនុស្សអាក្រក់ឲ្យលះបង់ចោល កិរិយាមារយាទអាក្រក់របស់ខ្លួន តែគេមិនព្រម
លះបង់ទេនោះ គេពិតជាស្លាប់ ព្រោះតែអំពើបាបរបស់គេពុំខាន ចំណែកអ្នកវិញនឹងរួចជីវិត។
[10]ដូច្នោះអ្នក កូនមនុស្សអើយ ចូរប្រាប់កូនចៅអ៊ីស្រាអែល អ្នកត្រូវនិយាយដូច្នេះ «អំពើរំលង និងអំពើបាបរបស់យើង គ្របសង្កត់លើយើងហើយ យើងកំពុងតែរោយរៀវទៅ
ក្នុងអំពើទាំងនោះ ដូច្នេះ ធ្វើដូចម្តេចឲ្យយើងរស់នៅបាន?»[11]ចូរប្រាប់គេថា ដូចជាយើងរស់នៅ ព្រះអម្ចាស់ដ៏ជាព្រះបានស្បថថា ប្រាកដជាយើងមិនរីករាយចំពោះសេចក្តី
ស្លាប់របស់មនុស្សអាក្រក់ឡើយ គឺចូលចិត្តឲ្យគេលះចោលផ្លូវរបស់ខ្លួន ហើយមានជីវិតរស់ ចូរអ្នករាល់គ្នាបែរមក ចូរបែរពីផ្លូវអាក្រក់របស់ខ្លួនចុះ! ដ្បិតហេតុអ្វីបានអ្នកស្លាប់
កូនចៅអ៊ីស្រាអែល?
[12]ដូច្នេះ កូនមនុស្សអើយ ចូរប្រាប់ដល់ជនជាតិអ្នកថា សេចក្តីសុចរិត នៃមនុស្សសុចរិត នឹងមិនអាចជួយសង្គ្រោះគាត់ ប្រសិនបើគាត់ធ្វើបាប! អាក្រក់របស់មនុស្សអាក្រក់
វិញ នឹងមិនធ្វើឲ្យគាត់វិនាស បើគាត់ប្រែចិត្តពីអំពើបាប! ដ្បិតមនុស្សសុចរិតក៏មិនអាចនឹងរស់នៅ ដោយសារអំពើសុចរិតរបស់ខ្លួន ប្រសិនបើគាត់ធ្វើបាប។[13]ប្រសិនបើយើង
ប្រាប់ដល់មនុស្សសុចរិតថា «គាត់នឹងមានជីវិតរស់នៅ!» ហើយបើគាត់ទុកចិត្តក្នុងសេចក្តីសុចរិតរបស់ខ្លួន ហើយទៅធ្វើអំពើទុច្ចរិតវិញ នោះនឹងគ្មានអ្នកណានឹកចាំពីអំពើ
សុចរិតទាំងប៉ុន្មានរបស់អ្នកនោះទេ។ គាត់នឹងស្លាប់សម្រាប់អាក្រក់ ដែលគាត់បានធ្វើ។
[14]ដូច្នេះ ប្រសិនបើយើងនិយាយដល់មនុស្សអាក្រក់ «អ្នកនឹងត្រូវស្លាប់ជាពិត» បើគេបែរចេញពីអំពើបាបរបស់ខ្លួន ទៅប្រព្រឹត្តសេចក្តីដែលទៀងត្រង់ ហើយត្រឹមត្រូវ
វិញ[15]ប្រសិនបើមនុស្សអាក្រក់នោះ នឹងប្រគល់របស់បញ្ចាំដល់ម្ចាស់វិញ ហើយប្រគល់របស់ដែលខ្លួនបានលួចទៅវិញដែរ ព្រមទាំងដើរតាមអស់ទាំងច្បាប់ដែលផ្តល់ជីវិត

generated on Wed Sep 10 16:16:32 2025

ហើយមិនប្រព្រឹត្តទុច្ចរិតទៀត នោះគេនឹងបានរស់ ឥតត្រូវស្លាប់ទេ។[16]គ្មានអ្នកណានឹកចាំពីអំពើបាបទាំងប៉ុន្មាន ដែលគាត់បានប្រព្រឹត្ត ឲ្យទាស់នឹងខ្លួនទៀតឡើយ ដ្បិតគេបានប្រព្រឹត្តតាមសេចក្តីទៀងត្រង់ត្រឹមត្រូវហើយ គេនឹងមានជីវិតរស់នៅ!
[17]ប៉ុន្តែ ប្រជាជនអ្នកបាននិយាយថា «ផ្លូវរបស់ព្រះអម្ចាស់មិនត្រឹមត្រូវទេ!» ប៉ុន្តែ គឺផ្លូវរបស់គេទេតើដែលមិនត្រឹមត្រូវ![18]កាលណាមនុស្សសុចរិតបែរចេញពីសេចក្តីសុចរិតរបស់ខ្លួន ទៅប្រព្រឹត្តអំពើទុច្ចរិតវិញ នោះគេនឹងត្រូវស្លាប់ដោយព្រោះអំពើនោះ។[19]ពេលមនុស្សអាក្រក់បែរចេញពីសេចក្តីអាក្រក់របស់ខ្លួន ទៅប្រព្រឹត្តតាមសេចក្តីទៀតត្រង់ ហើយត្រឹមត្រូវវិញ នោះគេនឹងរស់នៅដោយសារអំពើនោះ។[20]ប៉ុន្តែ អ្នករាល់គ្នាថា «ផ្លូវរបស់ព្រះអម្ចាស់មិនត្រឹមត្រូវទេ!» ពួកវង្សអ៊ីស្រាអែលអើយ យើងនឹងជំនុំជម្រះអ្នករាល់គ្នាតាមផ្លូវរបស់អ្នករៀងខ្លួន!»
[21]ការនេះកើតឡើង នៅថ្ងៃប្រាំ ខែទីដប់ ឆ្នាំទីដប់ពីរ ដែលគេបានចាប់យើងនាំទៅជាឈ្លើយ នោះមានម្នាក់ដែលរត់រួចពីក្រុងយេរូសាឡិម បានមកដល់ខ្ញុំប្រាប់ថា «គេចាប់ទីក្រុងបានហើយ!»[22]ព្រះហស្តនៃព្រះអម្ចាស់បានស្ថិតនៅលើខ្ញុំ នៅពេលល្ងាច មុនដែលអ្នករត់រួចបានមកដល់ ព្រះអង្គក៏បើកមាត់ខ្ញុំ ចាំតែអ្នកនោះមកដល់នៅពេលព្រឹក ដូច្នេះមាត់ខ្ញុំបានបើកឡើង ខ្ញុំនឹងមិននៅស្ងៀមទៀតឡើយ!
[23]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំថា៖[24]«កូនមនុស្សអើយ ពួកអ្នកដែលអាស្រ័យនៅកន្លែងបាក់បែក ក្នុងទឹកដីអ៊ីស្រាអែល គេថា លោកអ័ប្រាហាំជាមនុស្សតែម្នាក់ទេ ហើយលោកបានទទួលទឹកដីនេះទុកជាមរតក ប៉ុន្តែយើងរាល់គ្នាមានគ្នាច្រើន! ទឹកដីនេះក៏បានប្រគល់មកយើងទុកជាសម្បត្តិ។
[25]ដូច្នេះហើយ ចូរប្រាប់គេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ អ្នករាល់គ្នាបានផឹកឈាម ក៏ងើបភ្នែកមើលទៅរូបព្រះទាំងប៉ុន្មានរបស់អ្នករាល់គ្នា ហើយអ្នកបានបង្ហូរឈាមមនុស្ស។ តើអ្នកនឹងចាន់កាប់ទឹកដីនេះឬ?[26]អ្នករាល់គ្នាពឹងតែដាវរបស់អ្នក ក៏ប្រព្រឹត្តការគួរស្អប់ខ្ពើម ម្នាក់ៗប្រមាថប្រពន្ធរបស់អ្នកជិតខាងអ្នករៀងខ្លួន។ តើអ្នករាល់គ្នានឹងបានទឹកដីនេះឬ?
[27]អ្នកត្រូវប្រាប់ដល់គេដូច្នេះថា ព្រះអម្ចាស់ដ៏ជាព្រះអម្ចាស់ស្បថថា ដូចជាយើងរស់នៅ នោះប្រាកដជាពួកអ្នកដែលអាស្រ័យនៅកន្លែងបាក់បែកនេះ នឹងដួលដោយដាវ ហើយអ្នកណាដែលនៅឯទីវាល យើងនឹងឲ្យសត្វព្រៃហែកស៊ី ហើយពួកអ្នកដែលនៅក្នុងទីមាំមួន និងក្នុងរអាងភ្នំ គេនឹងស្លាប់ដោយអាសន្នរោគ។[28]ក្រោយមក យើងនឹងធ្វើឲ្យទឹកដីនេះស្ងាត់ជ្រងំ ហើយជាទីស្រឡាំងកាំង នោះសេចក្តីឆ្មើងឆ្មៃនៃអំណាចវានឹងផុតទៅ ហើយភ្នំទាំងឡាយរបស់អ៊ីស្រាអែល នឹងត្រូវចោលស្ងាត់នៅឥតមានអ្នកណាដើរកាត់ឡើយ។[29]ដូច្នោះពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់ ក្នុងកាលដែលយើងបានធ្វើឲ្យទឹកដីនេះស្ងាត់ជ្រងំ ហើយជាទីស្រឡាំងកាំង ដោយព្រោះអំពើគួរស្អប់ខ្ពើមដែលគេបានធ្វើ។
[30]សម្រាប់អ្នក កូនមនុស្សអើយ ពួកជនជាតិរបស់អ្នក ពួកគេនិយាយគ្នាពីអ្នកនៅក្បែរកំផែង ហើយនៅមាត់ទ្វារផ្ទះ គេនិយាយគ្នា គឺគ្រប់គ្នានិយាយនឹងបងប្អូនខ្លួនថា ចូរយើងទៅស្តាប់ព្រះបន្ទូល ដែលបានថ្លែងមកពីព្រះអម្ចាស់![31]ដូច្នោះនឹងមានមនុស្សជាច្រើនមករកអ្នក ដូចគេធ្លាប់ធ្វើពីមុន ហើយគេអង្គុយនៅមុខអ្នក ហើយក៏ស្តាប់អស់ទាំងពាក្យរបស់អ្នក តែគេមិនធ្វើតាមពាក្យទាំងនោះទេ។ ដ្បិតបបូរមាត់គេសម្តែងចេញជាសេចក្តី តែចិត្តគេដេញរកកម្រៃដែលមិនត្រឹមត្រូវដល់ខ្លួនវិញ។
[32]ដ្បិត អ្នកគឺដូចជាបទចម្រៀងដ៏ពីរោះដល់ពួកគេ ហើយមានសំឡេងយ៉ាងល្អ ហើយក៏ចេះលេងភ្លេងខ្សែយ៉ាងប្រសប់ ដ្បិតគេស្តាប់អស់ទាំងពាក្យរបស់អ្នក ប៉ុន្តែ មិនប្រព្រឹត្តតាមទេ។[33]ដូច្នេះ ពេលណាការនេះកើតមក មើល៍! នោះគេនឹងដឹងថា មានព្យាការីបាននៅក្នុងពួកគេ»។

Ezekiel 33:1
ព្រះបន្ទូលនៃព្រះអម្ចាស់មក
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់» សូមមើលរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ១:១។
កូនមនុស្សអើយ
សូមមើលរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២:១។
ដាវមកប្រហារទឹកដី
ពាក្យថា«ដាវ» សំដៅទៅលើកងទ័ពសត្រូវដែលវាយប្រហារ។
ធ្វើជាអ្នកយាមល្បាត
«តែងតាំងគាត់ជាអ្នកយាម» ឬ «ធ្វើឲ្យគាត់ក្លាយជាអ្នកយាម»
តែមិនបានយកចិត្តទុកដាក់
«មិនអើពើការព្រមាន»
បន្ទាប់ឈាមរបស់ម្នាក់ៗនឹងធ្លាក់ទៅលើក្បាលគេផងដែរ
ឃ្លានេះពិពណ៌នាអំពីរបៀបដែលព្រះនឹងទទួលខុសត្រូវចំពោះការស្លាប់របស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «វាគឺជាកំហុសរបស់ពួកគេប្រសិនបើពួកគេស្លាប់។
Ezekiel 33:5
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារដល់អេសេគាល ក្នុងការប្រាប់ដល់ជនជាតិអ៊ីស្រាអែល។
ចំពោះឈាមរបស់ខ្លួនវិញ
ការបកប្រែរបៀបផ្សេងទៀត: «វាជាកំហុសរបស់គាត់ដែលគាត់បានស្លាប់»
នោះនឹងបានរួចជីវិត
«នឹងរក្សាខ្លួនគាត់ពីការស្លាប់»
ដាវមកហើយ
ពាក្យថា «ដាវ» សំដៅទៅលើកងទ័ពសត្រូវ។
ដាវក៏មកដល់ យកជីវិតអ្នកណាចេញពីពួកគេទៅ
«ដាវមកដល់ហើយសម្លាប់នរណាម្នាក់»
អ្នកនោះនឹងត្រូវស្លាប់ក្នុងអំពើទុច្ចរិតរបស់ខ្លួន
«មនុស្សនោះស្លាប់ដោយសារអំពើបាបរបស់ខ្លួន»
Ezekiel 33:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលជាមួយអេសេគាល
កូនចៅអ៊ីស្រាអែល
សូមមើលពីបរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣:១។
ចេញពីមាត់
ការបកប្រែរបៀបផ្សេងទៀត: «ពីយើង»
រំលឹកគេដោយក្នុងនាមយើង
«ព្រមានពួកគេក្នុងនាមជាតំណាងរបស់យើង» ឬ
«ផ្តល់ការព្រមានដល់ពួកគេពីយើង»
មិនបានប្រាប់ការនេះ
«កុំឲ្យនិយាយការនេះ»
ពីផ្លូវរបស់គេ
«របៀបដែលគាត់ធ្វើ» ឬ «អ្វីដែលគាត់ធ្វើ»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែ «ផ្លូវរបស់អ្នក» នៅក្នុងជំពូក ៧:៣។
នឹងស្លាប់ដោយអំពើបាប
នេះបញ្ជាក់ថាព្រះអង្គនឹងមិនអត់ទោសបាបរបស់បុគ្គលនេះទេ។ ទោះយ៉ាងណាក៏ដោយក៏ណែទំនើបមួយចំនួនបកប្រែថា «ដោយសារតែអំពើបាបរបស់គាត់»។
គិតគូបំណលឈាមនេះពីដៃរបស់អ្នកវិញ
សូមមើលពីរបៀបដែលបកប្រែឃ្លានេះនៅក្នុងជំពូក ៣:១៦។
ឲ្យលះបង់ចោល កិរិយាមារយាទអាក្រក់របស់ខ្លួន
«មិនឈប់ធ្វើអំពើអាក្រក់របស់គាត់» ឬ «មិនឈប់ធ្វើអំពើអាក្រក់»
ចំណែកអ្នកវិញនឹងរួចជីវិត
«នឹងរក្សាខ្លួនអ្នកឲ្យនៅរស់»
Ezekiel 33:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារដល់អេសេគាល ក្នុងការប្រាប់ដល់ជនជាតិអ៊ីស្រាអែល។
កូនចៅអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣:១។
អ្នកត្រូវនិយាយដូច្នេះ
ការបកប្រែរបៀបផ្សេងទៀត: «នេះជាអ្វីដែលអ្នកបាននិយាយ»
អំពើរំលង និងអំពើបាបរបស់យើង គ្របសង្កត់លើយើងហើយ
អត្ថន័យដែលអាចទៅរួច
គឺថាពួកគេមានអារម្មណ៍ថាខ្លួនមានកំហុសចំពោះការរំលង
និងអំពើបាបរបស់ពួកគេ ឬ ២)
ពួកគេដឹងថាព្រះអម្ចាស់កំពុងតែដាក់ទណ្ឌកម្មពួកគេចំពោះការរំលង
និងអំពើបាបរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

យើងកំពុងតែរោយរៀវទៅក្នុងអំពើទាំងនោះ
«យើងកំពុងតែរលួយដោយសារតែវា»។
ឃ្លានេះប្រៀបធៀបវិធីដែលបាបបំផ្លាញមនុស្សទៅនឹងរបៀបដែលសាច់ឈាម។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេកំពុងតែបំផ្លាញយើង» ឬ
«ពួកគេកំពុងតែសំលាប់យើង»។
ក្នុងពួកគេ
នេះបញ្ជាក់ថាប្រជាជនដឹងថាព្រះនឹងមិនអភ័យទោសឲ្យពួកគេទេ។
ទោះយ៉ាងណាក៏ដោយកំណែទំនើបមួយចំនួនបកប្រែថា «ដោយសារតែពួកគេ»។
ធ្វើដូចម្តេចឲ្យយើងរស់នៅបាន?
ប្រជាជនសួរសំណួរនេះដើម្បីបញ្ជាក់ថាពួកគេគ្មានសង្ឃឹមរស់ទេ។
ការបកប្រែរបៀបផ្សេងទៀត: «យើងគ្មានសង្ឃឹមរស់ទេ» ឬ
«យើងនឹងស្លាប់ជាមិនខាន»
ដូចជាយើងរស់នៅ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
ព្រះអម្ចាស់ដ៏ជាព្រះបានស្បថថា
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
ចូរអ្នករាល់គ្នាបែរមក ចូរបែរពីផ្លូវអាក្រក់របស់ខ្លួនចុះ
«ប្រសិនបើមនុស្សអាក្រក់ឈប់ធ្វើអំពើអាក្រក់»
ដ្បិតហេតុអ្វីបានអ្នកស្លាប់
ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីបញ្ជាក់ថា
ទ្រង់មិនចង់បានប្រជាជនអ៊ីស្រាអែលសព្វថ្ងៃនេះទេ។ ការបកប្រែរបៀបផ្សេងទៀត:
«កុំជ្រើសរើសស្លាប់ឡើយ»។
Ezekiel 33:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារដល់អេសេគាលក្នុងការប្រាប់ដល់ជនជាតិអ៊ីស្រាអែល។
សេចក្តីសុចរិត នៃមនុស្សសុចរិត នឹងមិនអាចជួយសង្គ្រោះគាត់ ប្រសិនបើគាត់ធ្វើបាប!
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើមនុស្សសុចរិតចាប់ផ្តើមធ្វើបាបនោះ
ជាការពិតដែលថាពួកគេសុចរិតពីមុននឹងមិនជួយសង្គ្រោះពួកគេទេ»
ហើយបើគាត់ទុកចិត្តក្នុងសេចក្តីសុចរិតរបស់ខ្លួន
«ប្រសិនបើគាត់ពឹងផ្អែកលើភាពសុចរិតរបស់គាត់»។
មនុស្សនោះគិតថាដោយសារគាត់ជាមនុស្សសុចរិតព្រះអម្ចាស់នឹងមិនដាក់ទោសគាត់ទេ
ធ្វើអំពើទុច្ចរិតវិញ
«ធ្វើអ្វីដែលអាក្រក់» ឬ «ធ្វើការអាក្រក់ៗ»
គាត់នឹងស្លាប់សម្រាប់អាក្រក់ ដែលគាត់បានធ្វើ
«ដោយសារការអាក្រក់ដែលគាត់បានធ្វើ»
Ezekiel 33:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារដល់អេសេគាល ក្នុងការប្រាប់ដល់ជនជាតិអ៊ីស្រាអែល។
ប្រសិនបើមនុស្សអាក្រក់នោះ នឹងប្រគល់របស់បញ្ចាំ
«ប្រសិនបើគាត់ផ្តល់ការធានាប្រាក់កម្ចីមកវិញ»
របស់បញ្ចាំ
អ្វីមួយដែលមនុស្សម្នាក់ទុកចោលជាមួយមនុស្សម្នាក់ផ្សេងទៀតដើម្បីបង្ហាញថាគាត់នឹង
ហើយប្រគល់របស់ដែលខ្លួនបានលួចទៅវិញដែរ ព្រមទាំងដើរតាមអស់ទាំងច្បាប់
«ប្រគល់មកវិញនូវអ្វីដែលគាត់បានលួច» ឬ
«សងមកវិញឲ្យស្មើរតំលៃដែលគាត់បានលួច»
ព្រមទាំងដើរតាមអស់ទាំងច្បាប់ដែលផ្តល់ជីវិត
ការបកប្រែរបៀបផ្សេងទៀត: «រស់នៅស្របតាមច្បាប់ដែលផ្តល់ជីវិត»
គ្មានអ្នកណានឹកចាំពីអំពើបាបទាំងប៉ុន្មាន ដែលគាត់បានប្រព្រឹត្ត ឲ្យទាស់នឹងខ្លួនទៀតឡើយ
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងមិនប្រកាន់ទោសគាត់ណាមួយឡើយ»។
Ezekiel 33:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារដល់អេសេគាល ក្នុងការប្រាប់ដល់ជនជាតិអ៊ីស្រាអែល។
ប្រជាជនអ្នក
ទាំងនេះជាប្រជាជនអ៊ីស្រាអែល។ ពាក្យ «របស់អ្នក»សំដៅទៅលើអេសេគាល។
ប៉ុន្តែ គឺផ្លូវរបស់គេទេ
ពាក្យថា«របស់អ្នក» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែវាគឺជាផ្លូវរបស់ពួកគេ»។
ស្លាប់ដោយព្រោះអំពើនោះ
«ស្លាប់ដោយសារបាប»
បែរចេញពីសេចក្តីអាក្រក់របស់ខ្លួន
ការបកប្រែរបៀបផ្សេងទៀត: «ឈប់ធ្វើអំពើអាក្រក់»
ដោយសារអំពើនោះ
«ពីព្រោះគាត់ធ្វើអ្វីដែលត្រឹមត្រូវនិងសុចរិត»
អ្នករាល់គ្នា
ទាំងនេះជាប្រជាជនអ៊ីស្រាអែល។
Ezekiel 33:21
ឆ្នាំទីដប់ពីរ
នៅថ្ងៃប្រាំ ខែទីដប់
នេះជាខែទី ១០ នៃប្រតិទិនហេប្រឺ។ ថ្ងៃទី ៥
ជិតដល់ដើមខែមករាលើប្រតិទិនលោកខាងលិច។
យើងនាំទៅជាឈ្លើយ
ពាក្យថា «របស់យើង» នៅទីនេះសំដៅទៅលើលោកអេសេគាល។
និងជនជាតិអ៊ីស្រាអែលដែលបានរស់នៅក្នុងបាប៊ីឡូនដែលបង្ខំស្តេចយេហូយ៉ាគីមឲ្យចាកចេញពីយេរូសា
។ ការបកប្រែរបៀបផ្សេងទៀត: «បន្ទាប់ពីយើងបានក្លាយជាឈ្លើយសឹក» ឬ
«បន្ទាប់ពីពួកបាប៊ីឡូនបានយកយើងធ្វើជាឈ្លើយទៅបាប៊ីឡូន»។
នោះមានម្នាក់ដែលរត់រួចពីក្រុងយេរូសាឡឹម
«មានគេរត់គេចពីក្រុងយេរូសាឡឹមមករកយើង»។
ពួកបាប៊ីឡូនបានបំផ្លាញក្រុងយេរូសាឡិម
ហើយបានសម្លាប់ប្រជាជនក្រុងយេរូសាឡិមតែមានមនុស្សពីរបីនាក់បានរត់គេចខ្លួន។
គេចាប់ទីក្រុងបានហើយ
ការបកប្រែរបៀបផ្សេងទៀត: «ពួកបាប៊ីឡូនបានបំផ្លាញទីក្រុងនេះ»។ ឃ្លា «ទីក្រុង»
សំដៅទៅលើ «ក្រុងយេរូសាឡិម»។
ព្រះហស្តនៃព្រះអម្ចាស់បានស្ថិតនៅលើខ្ញុំ
សូមមើលពីរបៀបដែលបកប្រែ «ព្រះហស្តរបស់ព្រះអម្ចាស់មកលើគាត់»
នៅក្នុងជំពូក ១:១។
ពេលព្រឹក
«អរុណរះ» គឺជាពេលវេលាព្រឹកព្រលឹមនៅពេលពន្លឺព្រះអាទិត្យលេចចេញដំបូង។
ដូច្នេះមាត់ខ្ញុំបានបើកឡើង
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានបើកមាត់យើង»។
សូមមើលពីរបៀបដែលបានបកប្រែ «យើងនឹងបើកមាត់របស់អ្នក» នៅក្នុងជំពូក
៣:២៦។
ខ្ញុំនឹងមិននៅស្ងៀមទៀតឡើយ
«យើងមិនអាចនិយាយបានទៀតទេ» ឬ «យើងអាចនិយាយបាន»។
អេសេគាលមិនអាចនិយាយអ្វីបានទេលើកលែងតែពាក្យទំនាយចាប់តាំងពីជំពូក
៣:២៦។
Ezekiel 33:23
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១:១។
កន្លែងបាក់បែក
អត្ថន័យដែលបានបង្កប់ន័យ: ទីក្រុងដែលបាក់បែកទាំងនោះ ឬ
«ទីក្រុងដែលបាក់បែកទាំងនោះ»
ទឹកដី
«ទឹកដីអ៊ីស្រាអែល»
ទឹកដីនេះក៏បានប្រគល់មកយើង
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានឲ្យទឹកដីនោះមកយើង»
ទុកជាសម្បត្តិ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះយើងអាចកាន់កាប់វា» ឬ «ជាមរតក»។
ពួកគេបានអះអាងថាចាប់តាំងពីពួកគេមានច្រើនពួកគេគួរតែកាន់កាប់វា។
Ezekiel 33:25
ព័ត៌មានទូរទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅអេសេគាល
អំពីមនុស្សដែលរស់នៅក្រោមការគ្រប់គ្រងរបស់អ៊ីស្រាអែល។
អ្នករាល់គ្នាបានផឹកឈាម
វាបញ្ជាក់ថាពួកគេបរិភោគឈាមដោយបរិភោគសាច់ដែលនៅតែមានឈាមនៅក្នុងវា។
ព្រះអម្ចាស់បានបញ្ជាពួកគេឲ្យបង្ហូរឈាមចេញ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកញុំសាច់ជាមួយឈាម»។
ក៏ងើបភ្នែកមើលទៅរូបព្រះ

generated on Wed Sep 10 16:16:32 2025

«អ្នកសម្លឹងមើលរូបព្រះរបស់អ្នក» នេះមានន័យថា
«អ្នកគោរពបូជារូបព្រះក្លែងក្លាយ» .
អ្នកបានបង្ហូរឈាមមនុស្ស
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបានបង្ហូរឈាម»។ នេះមានន័យថា
«អ្នកសម្លាប់មនុស្ស»។
តើអ្នកនឹងចាន់កាប់ទឹកដីនេះឬ?
ព្រះអម្ចាស់ប្រើសំណួរនេះដើម្បីស្តីបន្ទោសប្រជាជន។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមិនគួរកាន់កាប់ទឹកដីនេះទេ» ឬ «អ្នកមិនសមនឹងទទួលបានទឹកដីនេះទេ»។
អ្នករាល់គ្នាពឹងតែដាវរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកបានប្រើដាវរបស់អ្នកដើម្បីទទួលបានអ្វីដែលអ្នកចង់បាន»។
ក៏ប្រព្រឹត្តការគួរស្អប់ខ្ពើម
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើអ្វីដែលយើងស្អប់ខ្លាំងណាស់»
ម្ចាក់ៗប្រមាថប្រពន្ធរបស់អ្នកជិតខាងអ្នករៀងខ្លួន
វាបញ្ជាក់ថាពួកគេធ្វើឲ្យប្រពន្ធអ្នកជិតខាងរបស់ខ្លួនស្មោកគ្រោកដោយដេកជាមួយពួកគេ
Ezekiel 33:27
ព័ត៌មានទូរទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅលោកអេសេគាល
អំពីមនុស្សដែលរស់នៅក្រោមការគ្រប់គ្រងរបស់អ៊ីស្រាអែល។
ដូចជាយើងរស់នៅ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។
ដួលដោយដាវ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។
ពួកអ្នកដែលនៅក្នុងទីមាំមួន និងក្នុងរអាងភ្នំ គេនឹងស្លាប់ដោយអាសន្នរោគ
«គ្រោះកាចនឹងសម្លាប់ប្រជាជនដែលរស់នៅក្នុងបន្ទាយនិងរូងភ្នំ»
បន្ទាយ
បន្ទាយគឺជាអគារមួយដែលមនុស្សសាងសង់ដើម្បីការពារខ្លួនពីសត្រូវដែលវាយប្រហារ
រអាងភ្នំ
រអាយភ្នំ គឺជាប្រហោងធម្មជាតិនៅម្ខាងនៃភ្នំ ឬចុះក្រោមទៅក្នុងដី។
ពួកវាជាធម្មតាធ្វើពីថ្ម។
ជាទីស្រឡាំងកាំង
«ភាពភ័យរន្ធត់»
គឺជាអ្វីមួយដែលធ្វើឱ្យមនុស្សភ័យខ្លាចយ៉ាងខ្លាំងនៅពេលដែលពួកគេបានឃើញ។
ការបកប្រែរបៀបផ្សេងទៀត: «ហើយប្រជាជននឹងភ័យខ្លាចដោយសារតែវា»
នោះសេចក្តីឆ្អើងឆ្មៃនៃអំណាចវានឹងផុតទៅ
ពាក្យថា «វា» សំដៅទៅលើដីដែលសំដៅទៅលើប្រជាជននៃលើទឹកដី។
ការបកប្រែជំនួស៖ «ប្រជាជននៅលើដីនឹងមិនមានមោទនភាពទៀតទេ
ដែលពួកគេរឹងមាំ»។
ភ្នំទាំងឡាយរបស់អ៊ីស្រាអែល នឹងត្រូវចោលស្ងាត់
«គ្មាននរណានឹងរស់នៅលើភ្នំអ៊ីស្រាអែលទេ»
ឥតមានអ្នកណាដើរកាត់ឡើយ
«នឹងគ្មាននរណាម្នាក់ចាកចេញដើម្បីធ្វើដំណើរឆ្លងកាត់ដី ឬលើភ្នំឡើយ»
ដឹងថា យើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។
ដែលគេបានធ្វើ
«ប្រជាជនបានធ្វើរួចរាល់ហើយ»
ដោយព្រោះអំពើគួរស្អប់ខ្ពើម ដែលគេបានធ្វើ
«គ្រប់រឿងដែលពួកគេបានធ្វើ ដែលយើងស្អប់»
Ezekiel 33:30
ព័ត៌មានទូរទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់លោកអេសេគាល
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។
ដែលបានថ្លែងមកពីព្រះអម្ចាស់!
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់ចាត់» ឬ
«ព្រះអម្ចាស់ប្រគល់អោយគាត់»
បបូរមាត់គេសម្តែងចេញជាសេចក្តីត្រឹមត្រូវ
អត្ថន័យដែលអាចមានគឺ ១) «ពាក្យស្រលាញ់គឺនៅក្នុងមាត់របស់ពួកគេ» ឬ ២)
«ពាក្យដែលលោភលន់ គឺស្ថិតនៅក្នុងមាត់របស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ដោយមាត់ពួកគេនិយាយថាពួកគេស្រឡាញ់យើង
(UDB) ឬ «មាត់ពួកគេនិយាយពីរឿងដែលពួកគេដេញតាម»។
ចិត្តគេដេញរកកម្រៃដែលមិនត្រឹមត្រូវដល់ខ្លួនវិញ
ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងចិត្តពួកគេចង់ទទួលបានប្រាក់ចំណេញអយុត្តិធម៌របស់ពួកគេ» ឬ
«ពួកគេចង់ទទួលបានអ្វីៗតាមរបៀបមិនត្រឹមតែ»។
ពួកគេអាចធ្វើរឿងនេះដោយលួចរបស់គេ ឬបោកមនុស្ស។
Ezekiel 33:32
ព័ត៌មានទូរទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅលោកអេសេគាលអំពីជនជាតិអ៊ីស្រាអែល។
អ្នកគឺដូចជាបទចម្រៀងដ៏ពីរោះដល់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេគិតថាអ្នកដូចជាបទចម្រៀងដែលគួរឲ្យស្រឡាញ់» ឬ
«ពួកគេគិតថាពាក្យរបស់អ្នកដូចជាបទចម្រៀងគួរឲ្យស្រឡាញ់»
ចម្រៀងដ៏ពីរោះ
អត្ថន័យដែលអាចមានគឺ ១) «ចម្រៀងពិរោះ» ឬ ២) «ចម្រៀងស្នេហា» ឬ
«ចម្រៀងអំពីសេចក្តីស្រឡាញ់»។
ភ្លេងខ្សែ
អ្វីមួយដែលមានខ្សែ ហើយមនុស្សប្រើដើម្បីបង្កើតតន្ត្រី
ហើយក៏ចេះលេងភ្លេងខ្សែយ៉ាងប្រសប់
ការបកប្រែរបៀបផ្សេងទៀត:
«មាននរណាម្នាក់លេងបានយ៉ាងល្អនៅលើឧបករណ៍ដែលមានខ្សែអក្សរ»។
ពេលណាការនេះកើតមក
ពាក្យថា «នេះ»
គឺសំដៅទៅលើអ្វីៗទាំងអស់ដែលព្រះបានមានបន្ទូលថានឹងកើតឡើងហើយលោកអេសេគាលបានប្រាប់ប្រ
មើល!
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាស់!»
មានព្យាការីបាននៅក្នុងពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «យើងពិតជាបានចាត់អ្នកឲ្យធ្វើជាហោរា»

---

34 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំថា[2]«កូនមនុស្សអើយ ចូរថ្លែងទំពាក្យទាស់នឹងពួកគង្វាលនៃជនជាតិអ៊ីស្រាអែលចុះ ត្រូវថ្លែងពាក្យប្រាប់គេ គឺពួកគង្វាល
នោះថាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូចនេះ វេទនាដល់ពួកគង្វាលនៃជនជាតិអ៊ីស្រាអែល ដែលឃ្វាលតែខ្លួនអ្នក។ តើមិនត្រូវឲ្យពួកគង្វាលនោះ ឃ្វាលហ្វូង
ចៀមទេឬ?[3]អ្នករាល់គ្នាស៊ីខ្លាញ់ ហើយស្លៀកពាក់ដោយសាររោមវា។ អ្នកសម្លាប់សត្វបំប៉នដែរ។ អ្នកមិនបានឃ្វាលហ្វូងចៀមទេ។
[4]អ្នករាល់គ្នាមិនបានចម្រើនកម្លាំង ដល់សត្វណាដែលអន់កម្លាំង ហើយសត្វណាដែលឈឺ មិនបានមើលឲ្យជាទេ ណាដែលបាក់ជើង អ្នកមិនបានរុំអប ណាដែលត្រូវ
កម្ចាត់កម្ចាយ អ្នកមិនបាននាំមកវិញ ហើយណាដែលវង្វេង ក៏មិនបានស្វែងរកដែរ។[5]ក្រោយមក អ្នករាល់គ្នាបានគ្រប់គ្រងលើវា ដោយកម្លាំង ហើយតឹងរ៉ឹងវិញ។ ដូច្នេះ វា
ត្រូវកម្ចាត់កម្ចាយទៅ ដោយព្រោះឥតមានគង្វាល វាត្រឡប់ជាអាហារដល់អស់ទាំងសត្វព្រៃ ហើយត្រូវខ្ចាត់ខ្ចាយអស់ទៅ។[6]ហ្វូងចៀមរបស់យើងបានដើរចុះឡើង នៅលើ
អស់ទាំងភ្នំធំ និងភ្នំតូចទាំងប៉ុន្មាន ហ្វូងចៀមរបស់យើងត្រូវកម្ចាត់កម្ចាយ នៅពេញពាសលើផែនដី។ អត់មានអ្នកណាទៅស្វែងរកពួកវាទេ។
[7]ហេតុនោះ ពួកគង្វាលរាល់គ្នាអើយ ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់[8]ដូចជាយើងរស់នៅព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់ ព្រះអង្គស្បថថាដោយព្រោះហ្វូងចៀមយើងក្លាយ
ទៅជារំពា ហើយត្រឡប់ទៅជាអាហារដល់អស់ទាំងសត្វព្រៃ ដោយឥតមានគង្វាល ហើយដោយព្រោះគង្វាលទាំងប៉ុន្មានរបស់យើង មិនបានស្វះស្វែងរកចៀមយើង គឺបាន
ឃ្វាលតែខ្លួនឯង អត់មានអ្នកឃ្វាលហ្វូងចៀមយើងទេ។
[9]ដូច្នេះហើយ ពួកអ្នកគង្វាលអើយ ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់[10]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ចូរមើល! យើងទាស់នឹងពួកអ្នកគង្វាល ហើយយើងនឹង
យកចៀមរបស់យើងពីដៃពួកគេមកវិញ។ បន្ទាប់មក យើងនឹងមិនអនុញ្ញាតិឲ្យពួកគេមកឃ្វាលហ្វូងចៀមរបស់យើងទៀតឡើយ
ហើយពួកដ៏នឹងមិនអាចបន្តធ្វើជាអ្នកគង្វាល បាប់តាំងពីយើងយកចៀមយើងពីម៉ាត់របស់គេ ដូច្នេះចៀមយើងនឹងមិនក្លាយជាអាហាររបស់គេទៀតឡើយ។

generated on Wed Sep 10 16:16:32 2025

[11]ដ្បិតព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ចូរមើល! យើង គឺយើងនេះហើយ នឹងស្វែងរកចៀមរបស់យើង[12]ដូចគង្វាលតែងមើលហ្វូងចៀមខ្លួន នៅថ្ងៃដែលគេនៅជាមួយហ្វូងចៀមដែលខ្ចាត់ខ្ចាយជាយ៉ាងណា។ នោះយើងនឹងថែមើលហ្វូងចៀមរបស់យើង ហើយជួយឲ្យវារួចចេញពីគ្រប់កន្លែងដែលវាត្រូវកម្ចាត់កម្ចាយនោះ នៅថ្ងៃដែលមេឃមីរស្រទំ ហើយងងឹតយ៉ាងនោះដែរ។[13]ក្រោយមក យើងនឹងនាំវារាល់គ្នាចេញពីជនជាតិទាំងនោះ ហើយប្រមូលវាពីគ្រប់ទាំងទឹកន្លែ រួចនាំចូលទៅក្នុងទឹកដីរបស់វាវិញ។ យើងនឹងឃ្វាលវានៅលើភ្នំនៃទឹកដីអ៊ីស្រាអែល ហើយតាមផ្លូវទឹក និងនៅគ្រប់ទាំងកន្លែងដែលមានមនុស្សនៅក្នុងទឹកដីនោះ។
[14]យើងនឹងឃ្វាលវានៅទីវាលល្អ ហើយក្រោលវានឹងនៅលើភ្នំខ្ពស់ៗនៃទឹកដីអ៊ីស្រាអែល នៅទីនោះវានឹងដេកចុះក្នុងក្រោលយ៉ាងល្អ ហើយនឹងរកស៊ីនៅវាលដ៏ល្អ នៅលើអស់ទាំងភ្នំនៃទឹកដីអ៊ីស្រាអែលផងដែរ។[15]យើងខ្លួនឯងនឹងធ្វើជាគង្វាលដល់ហ្វូងចៀមរបស់យើង ហើយយើងនឹងឲ្យវាដេក នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ។
[16]យើងនឹងស្វែងរកសត្វណាដែលវង្វេងបាត់ ហើយនាំសត្វណាដែលត្រូវប្រដេញឲ្យមកវិញ សត្វណាដែលបាក់ជើង យើងនឹងរុំអបឲ្យ ហើយយើងនឹងចម្រើនកម្លាំងដល់សត្វណាដែលឈឺ តែសត្វណាដែលធាត់ ហើយមានកម្លាំង យើងនឹងបំផ្លាញវាចោល គឺយើងនឹងឃ្វាលវាដោយយុត្តិធម៌។
[17]ដូច្នោះអ្នកគឺជាហ្វូងរបស់យើងអើយ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលពីអ្នកដូច្នេះ ចូរមើល! យើងនឹងជំនុំជម្រះរវាងចៀមនឹងចៀម ហើយរវាងចៀមឈ្មោលនឹងពពែឈ្មោលផង។[18]តើស៊ីស្មៅល្អដែលនៅទីវាលមិនគ្រប់សម្រាប់អ្នក បានជាអ្នកជាន់ឈ្លីស្មៅដែលនៅសល់ ហើយដែលអ្នករាល់គ្នាបានផឹកទឹកថ្លានោះ បានជាអ្នកទៅកកូរឡើងឲ្យល្អក់ ដោយជើងដូច្នេះ?[19]ចំណែកហ្វូងចៀមរបស់យើង តើវាត្រូវស៊ីស្មៅ ដែលអ្នករាល់គ្នាជាន់ឈ្លី ហើយផឹកទឹកដែលអ្នកបានធ្វើឲ្យល្អក់បានទេ?
[20]ហេតុនោះហើយ ព្រះអម្ចាស់មានព្រះមានព្រះបន្ទូលការនេះដល់ពួកវា មើល! យើងខហលួនឯង នឹងជំនុំជម្រះរវាងចៀមធាត់នឹងចៀមស្គម[21]ដ្បិត អ្នករាល់គ្នាតែងរុញគេចេញដោយយកស្មាទៅបុក ហើយប្រើស្នែងបុះចៀមដែលខ្សោយៗ រហូតបានកម្ចាត់កម្ចាយគេទៅបាត់អស់ពីទឹកដី។
[22]យើងនឹងជួយសង្គ្រោះហ្វូងចៀមរបស់យើង នោះវានឹងលែងក្លាយជារំពាទៀត ហើយយើងនឹងជំនុំជម្រះរវាងចៀមនឹងអ្នកផ្សេង![23]យើងនឹងតាំងគង្វាលតែមួយ ឲ្យថែមើលវា អ្នកនោះនឹងឃ្វាលវា គឺដាវីឌ ជាអ្នកបម្រើរបស់យើង គាត់នឹងកៀងនាំវាទៅឲ្យស៊ី ហើយធ្វើជាគង្វាលដល់ហ្វូង។[24]ដ្បិតយើងនេះ គឺព្រះអម្ចាស់នឹងជាព្រះជាម្ចាស់របស់វារាល់គ្នា ហើយដាវីឌ ជាអ្នកបម្រើរបស់យើង និងធ្វើជាចៅហ្វាយលើគេ គឺយើងនេះ ជាព្រះអម្ចាស់ យើងបានប្រកាសបែបនេះ។
[25]បន្ទាប់មក យើងនឹងតាំងសញ្ញាដែលផ្តល់សេចក្តីសុខសាន្តជាមួយពួកគេ ហើយនឹងធ្វើឲ្យសត្វកំណាចផុតចេញពីទឹកដីវាទៅ ដូច្នេះ វានឹងអាស្រ័យនៅទីរហោស្ថានដោយសុខសាន្ត ហើយដេកនៅក្នុងព្រៃផង។[26]យើងនឹងព្រះពរដល់គេ ព្រមទាំងទីកន្លែងនៅជុំវិញភ្នំតូចរបស់យើង ដ្បិតយើងនឹងបង្អុរឲ្យភ្លៀងធ្លាក់មកតាមរដូវកាល។ ការនោះនឹងមានព្រះពរធ្លាក់មក។[27]ក្រោយមក ដើមឈើនៅផែនដីនឹងបង្កើតផ្លែ ហើយដីនឹងបានផលចម្រើន វារាល់គ្នានឹងនៅក្នុងស្រុករបស់ខ្លួន ដោយសុខសាន្ត ហើយនឹងដឹងថាយើងនេះជាព្រះអម្ចាស់ពិតម៉ែន ក្នុងកាលដែលយើងបានបំបាក់នឹមចេញពីវា ហើយបានជួយឲ្យវារួចពីកណ្តាប់ដៃនៃពួកអ្នកដែលចាប់វាទៅប្រើ។
[28]ពួកគេនឹងមិនបានជាក្តីវិនាសដល់ជនជាតិដ៏ទៃឡើយ ហើយសត្វព្រៃនៅផែនដីក៏មិនហែកពួកគេស៊ីដែរ គឺគេនឹងនៅដោយសុខសាន្ត ឥតមានអ្នកណាបំភ័យឡើយ។
[29]ដ្បិតយើងនឹងធ្វើឲ្យមានដំណាំមួយយ៉ាងល្បីល្បាញកើតឡើង នោះពួកគេរាល់គ្នានឹងមិនត្រូវសាបសូន្យទៅ ដោយអំណត់នៅក្នុងទឹកដីឡើយ ក៏មិនត្រូវរងទ្រាំសេចក្តីខ្មាសនៃអស់ទាំងជនជាតិផ្សេងដែរ។
[30]បន្ទាប់មក ពួកគេនឹងដឹងថាយើងជាព្រះអម្ចាស់គឺជាព្រះជាម្ចាស់របស់ពួកគេ និងគង់នៅជាមួយពួកគេ។ ពួកគេជារាស្ត្ររបស់យើងទាំងទឹកដីអ៊ីស្រាអែលផង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។[31]ដ្បិតអ្នករាល់គ្នាដែលជាហ្វូងចៀមរបស់យើង គឺជាហ្វូងចៀមនៅទីឃ្វាលរបស់យើង អ្នករាល់គ្នាជាមនុស្ស ហើយយើងជាព្រះរបស់អ្នក នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 34:1

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។

ពួកគង្វាលនៃជនជាតិអ៊ីស្រាអែល

ឃ្លានេះប្រៀបធៀបមេដឹកនាំអ៊ីស្រាអែលដែលត្រូវមើលថែរក្សាប្រជាជនរបស់ពួកគេជាមួយគង្វាលដែលត្រូវបានគេសន្មតថាថែរក្សាហ្វូងចៀមរបស់ពួកគេ។

ការបកប្រែរបៀបផ្សេងទៀត: «មេដឹកនាំអ៊ីស្រាអែលដែលប្រៀបដូចជាគង្វាល»។

ត្រូវថ្លែងពាក្យប្រាប់គេ

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២១:៨។

ដែលឃ្វាលតែខ្លួនអ្នក

ការបកប្រែរបៀបផ្សេងទៀត: «កំពុងចិញ្ចឹម និងថែរក្សាខ្លួនឯង»។

មិនត្រូវឲ្យពួកគង្វាលនោះ ឃ្វាលហ្វូងចៀមទេឬ?

ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីស្តីបន្ទោសអ្នកដឹកនាំដែលមិនបានថែរក្សាប្រជាជន។

ការបកប្រែរបៀបផ្សេងទៀត: «ពួកគង្វាលគួរចិញ្ចឹមហ្វូងចៀមហើយថែរក្សាវា»។

អ្នករាល់គ្នាស៊ីខ្លាញ់

វាបញ្ជាក់ថាផ្នែកខ្លាញ់ចេញពីចៀមនិងពពែ។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកញ៉ាំផ្នែកខ្លាញ់នៃចៀមនិងពពែ» ឬ «អ្នកញ៉ាំផ្នែកល្អបំផុតនៃចៀមនិងពពែ»។

ស្លៀកពាក់ដោយសារោមវា

«ពាក់រោមចៀមពីចៀម»

អ្នកសម្លាប់សត្វបំប៉នដែរ

ការបកប្រែរបៀបផ្សេងទៀត: «អ្នកសំលាប់សត្វចៀមដែលមានខ្លាញ់ ហើយបរិភោគវា»

សត្វបំប៉ន

«ចៀម និងពពែដែលមានសុខភាពល្អបំផុត» ឬ «ចៀមនិងពពែដែលមានខ្លាញ់បំផុត»

អ្នកមិនបានឃ្វាលហ្វូងចៀមទេ

«កុំចិញ្ចឹម និងថែរក្សាហ្វូងចៀម»

Ezekiel 34:4

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តផ្តល់សាររដល់លោកអេសេគាល ទៅប្រាប់ដល់មេដឹកនាំអ៊ីស្រាអែល។

ដែលឈឺ

អត្ថន័យដែលអាចមានគឺ ១) «ឈឺ» ឬ ២) «ខ្សោយ»

បានរុំអប

«អ្នកមិនរុំក្រណាត់នៅជុំវិញរបួស និងឆ្អឹងដែលបាក់»

ណាដែលត្រូវកម្ចាត់កម្ចាយ

ការបកប្រែរបៀបផ្សេងទៀត: «ចៀមដែលបាក់ឆ្អឹង» ឬ «ចៀមដែលរងរបួស»

មិនបានស្វែងរក

«អ្នកមិននាំត្រឡប់មកវិញ»

កម្ចាត់កម្ចាយ

«ចៀមដែលត្រូវបានដេញចេញ» ឬ «ចៀមទន់ខ្សោយដែលចៀមខ្លាំងជាងបានដេញចេញ»

ដែលវង្វេង

ការបកប្រែរបៀបផ្សេងទៀត: «ចៀម ឬពពែដែលបានវង្វេងបាត់» ឬ «ចៀមដែលវង្វេងចេញ»

ដោយកម្លាំង ហើយតឹងរ៉ឹងវិញ

«ដោយបង្ខំ និងសាហាវឃោរឃៅ»

ឥតមានគង្វាល

«ពីព្រោះពួកគេមិនមានអ្នកគង្វាល»។ ការបកប្រែរបៀបផ្សេងទៀត: «ពីព្រោះអ្នកមិនបានធ្វើអ្វីដែលអ្នកគង្វាលគួរធ្វើនោះទេ»។

វាត្រឡប់ជាអាហារដល់អស់ទាំងសត្វព្រៃ

ការបកប្រែរបៀបផ្សេងទៀត: «សត្វព្រៃទាំងអស់អាចវាយប្រហារនិងស៊ីវាបាន»

ហ្វូងចៀមរបស់យើងត្រូវកម្ចាត់កម្ចាយ នៅពេញពាសលើផែនដី

«ហ្វូងចៀមរបស់យើងត្រូវបានពាសពេញលើផែនដី»

Ezekiel 34:7

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តផ្តល់សាររដល់អេសេគាល ទៅប្រាប់ដល់មេដឹកនាំអ៊ីស្រាអែល។

ព្រះបន្ទូលរបស់ព្រះអម្ចាស់

សូមមើលពីរបៀបដែលបកប្រែ «នេះជាសេចក្តីប្រកាសរបស់ព្រះអម្ចាស់» នៅក្នុងជំពូក ៥:១១។

ដូចជាយើងរស់នៅ

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលបកប្រែនៅក្នុងជំពូក ៥:១១។
ព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់
សូមមើលពីរបៀបដែលបកប្រែនៅក្នុងជំពូក ៥:១១។
ដោយព្រោះហ្វូងចៀមយើងក្លាយទៅជារំពា ហើយត្រឡប់ទៅជាអាហារដល់អស់ទាំងសត្វព្រៃ
«ពីព្រោះសត្វនៅក្នុងវាលអាចលួចចៀមរបស់ខ្ញុំហើយស៊ីវា»
ត្រឡប់ទៅជា
វត្ថុដែលត្រូវបានគេលួច។ ការបកប្រែរបៀបផ្សេងទៀត: «ងាយលួច» ឬ «ងាយសម្លាប់»
សត្វព្រៃនៅតាមវាល
ការបកប្រែរបៀបផ្សេងទៀត: «សត្វព្រៃ»
ដោយឥតមានអ្នកគង្វាល
«ពីព្រោះពួកគេមិនមានអ្នកគង្វាល»
គង្វាលទាំងប៉ុន្មានរបស់យើង មិនបានស្វះស្វែង
«គ្មានគង្វាលរបស់ខ្ញុំព្យាយាមរកហ្វូងចៀមរបស់យើងទេ»
បានឃ្វាលតែខ្លួនឯង
«ឃ្វាលខ្លួនពួកគេ» ឬ «ចិញ្ចឹមនិងថែរក្សាខ្លួនឯង»
អត់មានអ្នកឃ្វាលហ្វូងចៀមយើងទេ
«មិនបានចិញ្ចឹម និងថែទាំក្រោលរបស់យើងទេ»
Ezekiel 34:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារទៅអេសេគាលអំពីមេដឹកនាំអ៊ីស្រាអែល។
ដូច្នេះហើយ ពួកអ្នកគង្វាលអើយ ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣៤:៧។
មើល!
ពាក្យ «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាស់!»
យើងទាស់នឹងពួកអ្នកគង្វាល
ការបកប្រែរបៀបផ្សេងទៀត: «នឹងដាក់ទណ្ឌកម្មពួកគង្វាល»
យើងនឹងយកចៀមរបស់យើងពីដៃពួកគេមកវិញ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងឲ្យពួកគេទទួលខុសត្រូវចំពោះអំពើអាក្រក់ទាំងអស់ដែលកើតឡើងចំពោះហ្វូងចៀមរបស់យើង»
ឬ
«យើងនឹងដាក់ទណ្ឌកម្មពួកគេចំពោះអំពើអាក្រក់ទាំងអស់ដែលពួកគេបានធ្វើចំពោះហ្វូងចៀមរបស់យើង»
យើងនឹងមិនអនុញ្ញាតិឲ្យពួកគេមកឃ្វាលហ្វូងចៀមរបស់យើង
«យើងនឹងមិនអនុញ្ញាតឲ្យពួកគេឃ្វាលហ្វូងចៀមទៀតទេ» ឬ
«យើងនឹងមិនអនុញ្ញាតឲ្យពួកគេក្លាយជាអ្នកគង្វាលចៀមទៀតទេ»
ឃ្វាលតែខ្លួនឯង
«ចិញ្ចឹមនិងថែរក្សាខ្លួនឯង»
ពីម៉ាត់របស់គេ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះពួកគេនឹងមិនអាចបរិភោគវាបានទេ»។
ចៀមយើងនឹងមិនក្លាយជាអាហាររបស់គេទៀតឡើយ
«ពួកគង្វាលនឹងលែងស៊ីចៀម និងពពែនៃហ្វូងចៀមយើងទៀតហើយ»
Ezekiel 34:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារទៅលោកអេសេគាលអំពីមេដឹកនាំអ៊ីស្រាអែល។
ចូរមើល!
ពាក្យថា «មើលចុះ»
នៅទីនេះដាស់តឿនពួកគង្វាលឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើង។
ហើយ នឹងស្វែងរក
«នឹងរកមើល»
ដែលគេនៅជាមួយហ្វូងចៀមដែលខ្ចាត់ខ្ចាយជាយ៉ាងណា
«ជាមួយហ្វូងចៀមបែកខ្ញែករបស់គាត់»
ខ្ចាត់ខ្ចាយ
ហ្វូងចៀមមិននៅស្រែងតែមួយទេ។ ចៀម
និងពពែស្ថិតនៅកន្លែងផ្សេងៗគ្នាជាច្រើនដែលពួកគេបាត់បង់ហើយមានគ្រោះថ្នាក់។
នៅថ្ងៃដែលមេឃមីរស្រទំ ហើយងងឹតយ៉ាងនោះដែរ
«នៅថ្ងៃមានពពកនិងងងឹត»។
នេះសំដៅទៅលើពេលមានគ្រោះមហន្តរាយជាច្រើនកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលមានគ្រោះមហន្តរាយដ៏អាក្រក់កើតឡើងចំពោះពួកគេ»។
យើងនឹងនាំវា
«នាំចៀមនិងពពែរបស់យើងមក»
ចេញពីជនជាតិទាំងនោះ
«ពីកន្លែងដែលពួកគេរស់នៅជាមួយប្រជាជនផ្សេងទៀត»
វាលស្មៅ
ដីដែលមានស្មៅនិងរុក្ខជាតិតូចៗដែលចៀម និងពពែអាចស៊ីបាន
មនុស្សនៅក្នុងទឹកដី
ជាកន្លែងដែលមនុស្សរស់នៅ។ ជាធម្មតាពួកគេរស់នៅក្នុងផ្ទះដែលតាំងទីលំនៅ។
ការបកប្រែរបៀបផ្សេងទៀត: «ភូមិ»
Ezekiel 34:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារទៅលោកអេសេគាលអំពីមេដឹកនាំអ៊ីស្រាអែល។
ហើយនឹងរកស៊ីនៅវាលដ៏ល្អ
«កន្លែងដែលពួកគេអាចបរិភោគបាន»
នៅវាលដ៏ល្អ
ដីដែលមានស្មៅនិងរុក្ខជាតិច្រើន
ស្មៅ
បរិភោគស្មៅនិងរុក្ខជាតិដទៃទៀត
យើងខ្លួនឯង
ពាក្យ «ខ្លួនយើង» បន្ថែមការសង្កត់ធ្ងន់។
ព្រះអង្គនឹងធ្វើដូច្នេះពីព្រោះពួកគង្វាលមិនបានធ្វើត្រឹមត្រូវទេ។
នឹងធ្វើជាគង្វាល
«នឹងចិញ្ចឹម ហើយថែរក្សា»
ហើយយើងនឹងឲ្យវាដេក
«នឹងឲ្យពួកគេដេក»
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
ដែលវង្វេងបាត់
«អ្នកដែលវង្វេងបាត់»។ ការបកប្រែរបៀបផ្សេងទៀត: «ចៀម
ចៀមណាដែលវង្វេងបាត់»
សត្វណាដែលត្រូវប្រដេញឲ្យមកវិញ
ការបកប្រែរបៀបផ្សេងទៀត: «នាំអ្នកដែលត្រូវគេដេញចេញមកវិញ»
សត្វណាដែលបាក់ជើង យើងនឹងរុំអបឲ្យ
«រុំក្រណាត់នៅជុំវិញឆ្អឹងដែលបាក់របស់ចៀម» ឬ «រុំក្រណាត់រុំរបួសចៀម»
Ezekiel 34:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែបន្តផ្តល់សារដល់លោកអេសេគាល។
ឥឡូវនេះវាគឺសម្រាប់ប្រជាជនអ៊ីស្រាអែល។
មើល
ពាក្យថា« មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែជំនួស៖ «ពិតណាស់»
យើងនឹងជំនុំជម្រះរវាងចៀមនឹងចៀម
«យើងនឹងវិនិច្ឆ័យរវាងចៀមហើយនិងចៀមឈ្មោល និងពពែ»
ចៀមឈ្មោលនឹងពពែឈ្មោល
ចៀមឈ្មោល
និងពពែជាធម្មតាខ្លាំងបំផុតនៅក្នុងហ្វូងហើយអាចទទួលបានអ្វីដែលពួកគេចង់បានពីសត្វដទៃទៀតនៅក្នុ
នឹងជំនុំជម្រះរវាងចៀមនឹងចៀម...ជើង
នេះជាសំនួរដំបូងដែលព្រះប្រើដើម្បីស្តីបន្ទោសអ្នកខ្លាំងពីព្រោះពួកគេជាមនុស្សមិនល្អចំពោះអ្នកទន់ខ្សោយ
Ezekiel 34:20
មើល!
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែជំនួស៖ «ពិតណាស់»
យើងខ្លួនឯង
ពាក្យថា «ខ្លួនយើង» បញ្ជាក់ថាវាគឺជាព្រះអម្ចាស់ដែលនឹងវិនិច្ឆ័យ។
នឹងជំនុំជម្រះរវាងចៀមធាត់នឹងចៀមស្គម
«នឹងធ្វើឲ្យប្រាកដថាចៀមដែលខ្លាញ់ និងពពែ ទាំងចៀមស្គម និងពពែ
គឺមានការមើលថែស្មើភាពគ្នា»
សំរាប់អ្នក

generated on Wed Sep 10 16:16:32 2025

ពាក្យ «អ្នក»
សំដៅទៅលើចៀមនិងពពែដែលមិនបានព្យាបាលចៀមនិងពពែផ្សេងទៀត។
នៅម្ខាងអ្នក
«ជាមួយនឹងផ្នែកនៃរាងកាយរបស់អ្នក»
ស្នែងបុះ
អត្ថន័យដែលអាចមានគឺ ១) «បានរុញ» ឬ «បានរុញច្រាន» ២) «បានចាក់» ឬ «បានចាក់»
កម្ចាត់កម្ចាយគេ
«ធ្វើឲ្យពួកគេដើរតាមទិសដៅផ្សេងៗគ្នាជាច្រើន »
ទៅបាត់អស់ពីទឹកដី
«ឆ្ងាយពីទឹកដីអ៊ីស្រាអែល»
Ezekiel 34:22
ជារំពា
«របស់ដែលត្រូវបានគេលួច»។ គង្វាល និងសត្វព្រៃបានលួចចៀម
និងពពែពីហ្វូងចៀមរបស់ព្រះអម្ចាស់។
យើងនឹងជំនុំជម្រះរវាងចៀមនឹងអ្នកផ្សេង
សូមមើលពីរបៀបដែលបានបកប្រែ «យើងនឹងក្លាយជាចៅក្រមក្នុងចំណោមចៀម»
នៅក្នុងជំពូក ៣៤:១៧។
យើងនឹងតាំងគង្វាលតែមួយ
«យើងនឹងតែងតាំងអ្នកគង្វាលម្នាក់ឲ្យមើលការខុសត្រូវលើចៀមនិងពពែរបស់យើង»។
គឺដាវីឌ ជាអ្នកបម្រើរបស់យើង
ព្រះអម្ចាស់បានមានបន្ទូលថា« ដាវីឌ» ដើម្បីសំដៅទៅលើកូនចៅរបស់ដាវីឌ។
ការបកប្រែរបៀបផ្សេងទៀត: «កូនចៅរបស់ដាវីឌជាអ្នកបម្រើរបស់យើង»។
យើងនេះ គឺព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១១:១៩។
ជាអ្នកបម្រើរបស់យើង និងធ្វើជាចៅហ្វាយលើគេ
«នឹងធ្វើជាអ្នកគ្រប់គ្រងរបស់ពួកគេ»
គឺយើងនេះ ជាព្រះអម្ចាស់ យើងបានប្រកាសបែបនេះ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១៥។
Ezekiel 34:25
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារដល់អេសេគាល និងប្រជាជនអ៊ីស្រាអែល។
តាំងសញ្ញាដែលផ្តល់សេចក្តីសុខ
«សេចក្តីសញ្ញាមួយដែលនាំមកនូវសន្តិភាព»
សត្វកំណាច
ទាំងនេះគឺជាសត្វព្រៃដែលអាចសម្លាប់ចៀម និងពពែបាន។
យើងនឹងព្រះពរដល់គេ ព្រមទាំងទីកន្លែងនៅជុំវិញភ្នំតូចរបស់យើង
ការបកប្រែសម័យទំនើបខ្លះបកប្រែថា «យើងក៏នឹងប្រែក្លាយពួកគេ
និងកន្លែងនៅជុំវិញភ្នំរបស់យើងទៅជាពរជ័យ»។
តាមរដូវកាល
«នៅពេលត្រឹមត្រូវ»
ការនោះនឹងមានព្រះពរធ្លាក់មក
«ភ្លៀងនេះនឹងត្រូវបានផ្តល់ជាពរជ័យ»
ផែនដីនឹងបង្កើតផ្លែ
«ផែនដីនិងបង្កើតអាហារ » ការបកប្រែរបៀបផ្សេងទៀត: អាហារ
និងមានការដាំដុះនៅលើផែនដី។
ដោយសុខសាន្ត
«ទទួលបានសុវត្ថិភាព»
យើងនេះជាព្រះអម្ចាស់ពិតម៉ែន
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៦:៦។
យើងបានបំបាក់នឹមចេញពីវា
«រនាំងដែលកាន់នឹមរបស់ពួកគេ»
Ezekiel 34:28
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារដល់អេសេគាល និងប្រជាជនអ៊ីស្រាអែល។
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៧:២០។
មានដំណាំមួយយ៉ាងល្បីល្បាញកើតឡើង
អត្ថន័យដែលអាចមានគឺ ១) «សួនច្បារដែលពួកគេអាចមានសន្តិភាព» ឬ ២) «សួនច្បារដែលល្បីល្បាញ»
សាបសូន្យទៅ ដោយអំណត់
ការបកប្រែរបៀបផ្សេងទៀត: «អត់ឃ្លាន» ឬ «អត់ឃ្លានដោយសារតែខ្វះអាហារ»
Ezekiel 34:30
យើងជាព្រះអម្ចាស់គឺជាព្រះជាម្ចាស់របស់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «យើងជាព្រះអម្ចាស់ជាព្រះរបស់គេយើងជួយគេ»
ពួកគេជារាស្ត្ររបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «ហើយថាពួកគេជាប្រជាជនរបស់យើង»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
យើងជាព្រះរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «យើងជាព្រះរបស់អ្នក»

---

35 [1]ក្រោយមក ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ[2]«កូនមនុស្សអើយ ចូរងើយមុខឡើងរួចទាស់នឹងស្រុកភ្នំសៀរ ចូរថ្លែងទំនាយទាស់នឹងពួកគេថា។
[3]និយាយទៅវា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល! ទឹកដីភ្នំសៀរអើយ យើងទាស់នឹងអ្នក យើងនឹងលូកដៃយើងទៅលើអ្នក ព្រមទាំងធ្វើឲ្យអ្នកទៅជាស្ងាត់ជ្រងំ ហើយភ័យខ្លាច។
[4]យើងនឹងធ្វើឲ្យទីក្រុងទាំងឡាយរបស់អ្នកខូចអស់ ហើយអ្នកខ្លួនឯងនឹងត្រូវចោលស្ងាត់ ក្រោយមកអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់។[5]ពីព្រោះអ្នកបានធ្វើជាសត្រូវដល់កូនចៅអ៊ីស្រាអែល ហើយអ្នកបានរួញពួកគេទៅក្នុងក្រោមដៃនៃដាវ នៅក្នុងពេលនៃទុក្ខព្រួយ
ក្នុងពេលការជំនុំជម្រះរបស់ពួកគេបានកើតឡើងយ៉ាងធំបំផុត។[6]ដូច្នោះហើយ ដូចជាយើងរស់នៅព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលបែបនេះ យើងនឹងត្រៀមអ្នកទុកសម្រាប់បង្ហូរឈាម ហើយឈាមនឹងដេញតាមអ្នក! តាំងពីអ្នកមិនបានស្អប់ឈាម ហើយឈាមនឹងដេញតាមអ្នក។
[7]យើងនឹងធ្វើឲ្យភ្នំសៀរទៅជាទី ស្ងាត់ជ្រងំ ពេលយើងបានកាត់វាចេញនោះ អ្នកណាដែលដើរឆ្លងកាត់ ហើយត្រឡប់មកវិញ ម្តងទៀត។[8]ក្រោយមក យើងនឹងឲ្យភ្នំរបស់វាពេញទៅដោយមនុស្សសម្លាប់។ តាមភ្នំតូចរបស់អ្នក ហើយច្រកភ្នំហើយនៅក្នុងផ្លូវទឹករបស់អ្នកផង ពួកអ្នកដែលត្រូវស្លាប់ដោយដាវ។[9]យើងនឹងធ្វើឲ្យអ្នកនៅស្ងាត់ច្រៀបជានិច្ច។ ទីក្រុងទាំងរបស់អ្នកនឹងគ្មានមនុស្សណានៅទេ តែអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់។
[10]អ្នកបាននិយាយថា «ជនជាតិទាំងពីរ និងទឹកដីទាំងពីរនោះ នឹងក្លាយជារបស់យើង ហើយយើងនឹងកាន់កាប់ជារបស់យើង» ទោះបើពេលព្រះអម្ចាស់គង់នៅទីនោះក៏ដោយ។[11]ដូច្នេះហើយ នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះបានមានបន្ទូលថា យើងនឹងធ្វើតាមកំហឹងរបស់អ្នក ហើយតាមសេចក្តីច្រណែនដែលអ្នកបានស្អប់ដល់អ៊ីស្រាអែល ហើយយើងនឹងបង្ហាញខ្លួនយើងដល់ពួកគេ នៅពេលយើងជំនុំជម្រះអ្នក។
[12]ដូច្នេះ អ្នកនឹងដឹងថា យើងនេះគឺព្រះអម្ចាស់។ យើងបានឮអស់ទាំងពាក្យឡកឡឺយ ដែលអ្នកបានថ្លែងទាស់នឹងភ្នំនៃអ៊ីស្រាអែល «ពួកគេធ្លាប់បានបំផ្លាញ ពួកគេធ្លាប់បានប្រគល់មកឲ្យយើងដើម្បីត្របាក់លេប»។[13]អ្នករាល់គ្នាបានតម្កើងខ្លួនទាស់នឹងយើង ជាមួយនឹងអ្វីដែលអ្នកបាននិយាយ ព្រមទាំងចម្រើនពាក្យរបស់អ្នកទាស់នឹងយើងផង យើងបានឮវាទាំងអស់។
[14]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ យើងនឹងធ្វើឲ្យអ្នកស្ងាត់ជ្រងំ នៅពេលផែនដីទាំងមូលរីករាយ។[15]អ្នកបានអរសប្បាយពីដំណើរមរតកនៃកូនចៅអ៊ីុស្រាអែល ដោយព្រោះនៃការចោលស្ងាត់របស់វា យើងនឹងធ្វើដូចគ្នាដល់អ្នកដែរ។ អ្នកនឹងត្រូវចោលស្ងាត់ ភ្នំសៀរហើយអ្នកអេដុមទាំងមូលអើយ! នោះគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់»។

---

generated on Wed Sep 10 16:16:32 2025

Ezekiel 35:1

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលរបស់ទ្រង់»

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១:១។

កូនមនុស្សអើយ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ២:១។

ចូរងើយមុខឡើងរួចទាស់

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤:១។

ស្រុកភ្នំសៀរ

«ភ្នំសៀរ»។

នេះសំដៅទៅលើប្រជាជនដែលរស់នៅស្រុកអេដុមព្រោះពួកគេរស់នៅជួរភ្នំសៀរ។

«ប្រជាជនអេដំម» ឬ «ប្រជាជននៅលើភ្នំសៀរ»

ទៅវា

«ទៅឯភ្នំ» ឬ «មនុស្សនៅស្រុកអេដុម»

មើល!

ពាក្យ «មើលចុះ» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។

ការបកប្រែជំនួស៖ «ពិតណាស់!»

យើងទាស់នឹងអ្នក

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ២១:១។

យើងនឹងលូកដៃយើងទៅលើអ្នក

ការបកប្រែរបៀបផ្សេងទៀត: «យើងបានលាតដៃលើអ្នកហើយមានន័យថា «យើងហៀបនឹងវាយអ្នក»។

ទៅជាស្ងាត់ជ្រងំ ហើយភ័យខ្លាច

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣៣:២៧។

Ezekiel 35:4

ព័ត៌មានទូទៅ:

នេះជាសាររបស់ព្រះអម្ចាស់ចំពោះប្រជាជននៅភ្នំសៀរ។

នឹងដឹងថា យើងនេះជាព្រះអម្ចាស់

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៦:៦។

អ្នកបានរួញពួកគេទៅក្នុងក្រោមដៃនៃដាវ

អត្ថន័យដែលអាចមានគឺ ១) «អ្នកបានប្រគល់ពួកគេទៅឲ្យសត្រូវរបស់ពួកគេដែលបានសម្លាប់ពួកគេដោយដាវ» ឬ ២) «អ្នកបានសម្លាប់ពួកគេដោយដាវ»

នៅក្នុងពេលនៃទុក្ខព្រួយ

«នៅពេលដែលពួកគេស្ថិតក្នុងគ្រោះមហន្តរាយ»

យើងរស់នៅ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។

ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលបែបនេះ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។

យើងនឹងត្រៀមអ្នកទុកសម្រាប់បង្ហូរឈាម

«យើងនឹងរៀបចំអ្នកឲ្យបាត់បង់ឈាម»។ នេះសំដៅទៅលើការរងរបួសឬស្លាប់។

ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងអនុញ្ញាតឲ្យសត្រូវរបស់អ្នកសម្លាប់អ្នកយ៉ាងសាហាវព្រៃផ្សៃ»

ឈាមនឹងដេញតាមអ្នក

ព្រះអម្ចាស់បង្ហាញនូវការបង្ហូរឈាមដូចជាមនុស្សម្នាក់ដែលអាចដេញតាមពួកគេ។

ការបកប្រែរបៀបផ្សេងទៀត: «សត្រូវរបស់អ្នកនឹងបន្តសម្លាប់អ្នក»

តាំងពីអ្នកមិនបានស្អប់ឈាម

ការបកប្រែរបៀបផ្សេងទៀត:

«ចាប់តាំងពីអ្នកបានស្អប់វានៅពេលដែលមនុស្សផ្សេងទៀតត្រូវបានសម្លាប់យ៉ាងសាហាវ»

Ezekiel 35:7

ព័ត៌មានទូទៅ:

នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះប្រជាជននៅភ្នំសៀរ។

ពេលយើងបានកាត់វាចេញនោះ អ្នកណាដែលដើរឆ្លងកាត់ ហើយត្រឡប់មកវិញ ម្តងទៀត

អត្ថន័យដែលអាចមានគឺ ១) «យើងនឹងបំផ្លាញអ្នកណាម្នាក់ដែលចូលវា ឬទុកវាចោល» ឬ ២) «យើងនឹងបង្កើតវាឡើងដើម្បីកុំឲ្យមនុស្សធ្វើដំណើរឆ្លងកាត់វាបាន»។

ស្លាប់ដោយដាវ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣១:១៧។

នៅស្ងាត់ច្រៀបជានិច្ច

«ត្រូវបំផ្លាញចោលជារៀងរហូត»។ នេះគឺជាការបំផ្លើសដើម្បីបញ្ជាក់ពីការបំផ្លាញ។

ទីក្រុងទាំងរបស់អ្នកនឹងគ្មានមនុស្សណានៅទេ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។

វាអាចជាការបំផ្លើសសម្រាប់ការសង្កត់ធ្ងន់។ ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននឹងមិនរស់នៅក្នុងទីក្រុងរបស់អ្នកទេ»

តែអ្នកនឹងដឹងថា

ពាក្យថា «អ្នក» នៅទីនេះមានពហុវចនៈ។

ព្រះអង្គកំពុងតែមានបន្ទូលទៅកាន់ប្រជាជននៅភ្នំសៀរជាជាងភ្នំតែមួយ។

អ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៦:៦។

Ezekiel 35:10

ព័ត៌មានទូទៅ:

នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះប្រជាជននៅភ្នំសៀរ។

អ្នកបាននិយាយថា

ពាក្យថា «អ្នក» គឺសំដៅទៅលើភ្នំសៀរដែលតំណាងឲ្យប្រជាជាតិអេដុម។

ហើយយើង

ពាក្យថា «យើង» សំដៅទៅលើប្រជាជនអេដុម។

ទោះបើពេលព្រះអម្ចាស់គង់នៅទីនោះក៏ដោយ

វាបញ្ជាក់ថាព្រះអម្ចាស់កំពុងការពារអ៊ីស្រាអែល និងយូដា។

ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែព្រះអម្ចាស់នៅទីនោះការពារអ៊ីស្រាអែល និងយូដា»

ដូចដែលខ្ញុំរស់

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។

នេះគឺជាព្រះអម្ចាស់ដ៏ជាព្រះបានមានបន្ទូលថា

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។

យើងនឹងធ្វើតាមកំហឹងរបស់អ្នក ហើយតាមសេចក្តីច្រណែន

អត្ថន័យដែលអាចមានគឺ ១) «យើងនឹងដាក់ទណ្ឌកម្មអ្នកដោយសារតែកំហឹងនិងការច្រណែនរបស់អ្នក» ឬ ២) «យើងនឹងធ្វើអ្វីគ្រប់យ៉ាងចំពោះអ្នកដោយកំហឹងដូចជាកំហឹងរបស់អ្នកនិងដោយការច្រណែនដូចជាការច្រ

Ezekiel 35:12

ព័ត៌មានទូទៅ:

នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះប្រជាជននៅភ្នំសៀរ។

អ្នកនឹងដឹងថា យើងនេះគឺព្រះអម្ចាស់

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៦:៦។

ពួកគេធ្លាប់បានប្រគល់មកឲ្យយើងដើម្បីត្របាក់លេប

ការបកប្រែរបៀបផ្សេងទៀត: «ភ្នំនៃអ៊ីស្រាអែលគឺសម្រាប់យើងដើម្បីលេបត្របាក់» ឬ «ពួកគេនៅទីនេះសម្រាប់ពួកយើងដើម្បីគ្រប់គ្រងពួកគេ» ឬ «យើងអាចយកអ្វីដែលយើងចង់បានពីពួកគេ»

Ezekiel 35:14

ព័ត៌មានទូទៅ:

នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះប្រជាជននៅភ្នំសៀរ។

ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣:១០។

ធ្វើឲ្យអ្នកស្ងាត់ជ្រងំ

ពាក្យថា «អ្នក» សំដៅទៅលើ «ភ្នំសៀរ» ដែលតំណាងឲ្យទឹកដីស្រុកអេដុម។

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងធ្វើឲ្យដីរបស់អ្នកក្លាយទៅជាទីស្ងាត់ជ្រងំ»។

យើងនឹងធ្វើដូចគ្នាដល់អ្នកដែរ

អត្ថន័យដែលអាចមានគឺ ១) «យើងនឹងធ្វើឱ្យទឹកដីរបស់អ្នកក្លាយទៅជាទីស្ងាត់ស្ងៀម» ឬ ២) «យើងនឹងរីករាយនៅពេលដែលទឹកដីរបស់អ្នកក្លាយទៅជាទីស្ងាត់ជ្រងំ» ឬ ៣) «យើងនឹងធ្វើឲ្យមនុស្សដទៃទៀតអរសប្បាយដោយសារតែការបំផ្លិចបំផ្លាញរបស់អ្នក»

ភ្នំសៀរ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣៥:១។

នោះគេនឹងដឹងថា

ពាក្យថា «ពួកគេ» អាចសំដៅទៅលើ ១) «ប្រជាជននៅលើផែនដី» ឬ ២) «ប្រជាជនអ៊ីស្រាអែលនិងយូដា»។

នឹងដឹងថា យើងនេះជាព្រះអម្ចាស់

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៦:៦។

generated on Wed Sep 10 16:16:32 2025

36 [1]«សម្រាប់អ្នក កូនមនុស្សអើយ ចូរថ្លែងព្រះបន្ទូលទៅកាន់អ្នកភ្នំនៃអ៊ីស្រាអែលដែរថា ភ្នំអ៊ីស្រាអែលអើយ ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ចុះ។
[2]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ខ្មាំងសត្រូវបាននិយាយពីអ្នក «ហាសហា!» ហើយ «ទីខ្ពស់ពីបុរាណទាំងនេះបានត្រឡប់ជារបស់យើងហើយ»។
[3]ដូច្នេះហើយ ចូរថ្លែងព្រះបន្ទូលថា ហើយនិយាយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដោយព្រោះអ្នកនៅស្ងាត់ស្ងៀម ហើយនិងការវាយប្រហារមកកាន់អ្នក
នោះអ្នកដ៏បានក្លាយទៅជាទឹកដីចំណុះឲ្យជនជាតិផ្សេងៗ អ្នកនឹងនៅក្រោមការត្រួតត្រានៃការបង្កាច់បង្ខូច បបូរមាត់និងអណ្តាតគឺនិយាយមិនល្អពីអ្នក។
[4]ដូច្នោះហើយ អ្នកភ្នំអ៊ីស្រាអែលអើយ! ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ទៅដល់អស់ទាំងភ្នំនិងជ្រលងភ្នំទាំងឡាយ ផ្លូវ
ទឹក និងច្រកភ្នំ ព្រមទាំងកន្លែងស្ងាត់ជ្រងំ ហើយទីក្រុងដែលគេបោះចោល វាបានត្រឡប់កន្លែងប្លន់ ហើយក្នុងគោលបំណងនៃការឡកឡឺយដល់ជនជាតិផ្សេងៗដែលនៅ
ព័ទ្ធជុំពួកគេ[5]ដូច្នោះហើយព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូលដូច្នេះ យើងបានតបនឹងពួកគេដោយភ្លើងនៃកំហឹងរបស់យើង ទាស់នឹងជនជាតិផ្សេងៗ ហើយអេដុមទាំង
មូល ដែលជាអ្នកយកទឹកដីរបស់យើងទុកសម្បត្តិពួកគេ ហើយទាស់ជាមួយពួកអ្នកមានចិត្តរីករាយ ហើយអ្នកដែលមានចិត្តមើលងាយ
ពួកគេចាប់យកដីរបស់យើងហើយក៏យកវាលស្មៅធ្វើជាខ្លួនឯង។[6]ដូច្នោះហើយ ចូរថ្លែងព្រះបន្ទូលទៅកាន់ទឹដីអ៊ីស្រាអែល ហើយប្រាប់ដល់ភ្នំធំនិងជ្រលងភ្នំ ផ្លូវទឹក និង
ច្រកភ្នំតូចទាំងអស់ ព្រះអម្ចាស់អម្ចាស់មានព្រះបន្ទូលដូច្នេះ មើល៍! ក្នុងកំហឹងខ្លាំងហើយការក្រោធរបស់យើង យើងថ្លែងការនេះដោយសារតែអ្នក
បានកើតមកដើម្បីប្រម៉ាត់ប្រជាជាតិ។
[7]ហេតុដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ យើងខ្លួនឯងនឹងលើកដៃស្បថថា ជនជាតិទាំងនោះដែលនៅជុំវិញអ្នក នឹងប្រកដជារង់សេចក្តីខ្មាសរបស់ខ្លួន
គេវិញ។
[8]ប៉ុន្តែ អ្នកភ្នំអ៊ីស្រាអែល! អ្នករាល់គ្នានឹងបែកមែក ហើយបង្កើតផលរបស់អ្នក ឲ្យអ៊ីស្រាអែលជាប្រជារាស្ត្រយើង ពីព្រោះគេរៀបនឹងមកហើយ។[9]ដ្បិត ចូរមើល! យើងកាន់
ខាងអ្នក ហើយយើងនឹងវិលមកឯអ្នកវិញ នោះនឹងមានគេភ្ជួររាស់ ហើយសាបព្រោះអ្នក។
[10]ដូច្នេះ យើងនឹងឲ្យមនុស្សចម្រើនឡើងនៅក្នុងអ្នក គឺជាពួកវង្សអ៊ីស្រាអែលទាំងមូល។ ដូច្នេះ ទីក្រុងទាំងប៉ុន្មានរបស់អ្នកនឹងមានមនុស្សនៅ ហើយអស់ទាំងកន្លែងបាក់
បែកនឹងបានសង់ឡើងវិញ។[11]យើងនឹងធ្វើឲ្យទាំងមនុស្ស និងសត្វបានចម្រើនឡើងនៅក្នុងអ្នក គេនឹងចម្រើនឡើង ហើយសាយគ្រាយចេញទៅ យើងនឹងឲ្យមានមនុស្ស
អាស្រ័យនៅក្នុងអ្នកដូចពីដើម ហើយប្រព្រឹត្តនឹងអ្នកដោយល្អជាងជាន់ដើមទៅទៀត នោះអ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់ពិតមែន។[12]យើងនឹងឲ្យមានមនុស្ស
ដើរលើអ្នក គឺអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង គេនឹងបានអ្នកជារបស់គេ ហើយអ្នកនឹងបានជាមរតកដល់គេ នោះអ្នកនឹងមិនធ្វើឲ្យកូនរបស់គេស្លាប់ឡើយ។
[13]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ដោយព្រោះពួកគេនិយាយពីអ្នកថា «អ្នកដែលលេបសីុមនុស្សបាត់ ហើយកូនចៅរបស់ជនជាតិអ្នកនឹងស្លាប់»។[14]ដូច្នេះហើយ
អ្នកនឹងលែងលេបស៊ីមនុស្សទៀតទេ ហើយអ្នកមិនជនជាតិរបស់កាន់ទុក្ខសេចក្តីស្លាប់ទៀតដែរ។ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ។[15]យើងមិនឲ្យអ្នកឮពាក្យ
ត្មះតិះដៀលរបស់ជនជាតិដទៃទាំងប៉ុន្មានទៀតទេ អ្នកមិនត្រូវរងទ្រាំសេចក្តីប្រមាថមើលងាយរបស់គេ អ្នកនឹងមិនធ្វើជាហេតុ ឲ្យជនជាតិរបស់អ្នកចំពប់ដួលទៀតឡើយ
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់»។
[16]បន្ទាប់មក ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ[17]«កូនមនុស្សអើយ! កាលពួកវង្សអ៊ីស្រាអែលបាននៅក្នុងទឹកដីរបស់ខ្លួន គេបានបង្អាប់ ដោយផ្លូវប្រព្រឹត្ត និងកិរិយា
របស់ខ្លួន ផ្លូវដែលគេប្រព្រឹត្តនៅមុខយើង ប្រៀបដូចជាសេចក្តីស្មោកគ្រោកនៃស្ត្រីដែលមានរដូវ។[18]ដូច្នេះ យើងចាក់សេចក្តីក្រោធរបស់យើងទាស់នឹងពួកគេ ដ្បិតឈាម
ដែលគេបានកម្ចាយនៅលើទឹកដីនោះ ហើយសម្រាប់ការបំពុលរបស់វាតាមរយៈរូបព្រះរបស់គេ។
[19]យើងបានកម្ចាត់កម្ចាយពួកគេទៅក្នុងចំណោមជនជាតិផ្សេង ពួកគេត្រូវបែងចែកទៅនៅគ្រប់ទីកន្លែង។ យើងបានជំនុំជម្រះគេតាមការប្រព្រឹត្ត ហើយកិច្ចការរបស់គេ។
[20]ក្រោយមក ពួកគេបានចូលទៅដល់ជនជាតិ កន្លែងដែលគេទៅពួកគេប្រមាថឈ្មោះបរិសុទ្ធរបស់យើង ពេលមនុស្សបាននិយាយពីពួកគេ តើពួកនេះជា
រាស្ត្ររបស់ព្រះអម្ចាស់? ដ្បិតពួក គេបានបោះចេញពីទឹកដីរបស់ព្រះអង្គ។[21]ប៉ុន្តែ យើងបានយល់ដល់ឈ្មោះបរិសុទ្ធរបស់យើង ដែលជាកូនអ៊ីស្រាអែលបានបង្អាប់ នៅ
កណ្តាលជនជាតិផ្សេងៗ ពេលគេបានទៅដល់ទីនោះ។
[22]ដូច្នេះហើយ ចូរប្រាប់ដល់កូនចៅអ៊ីស្រាអែលថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ យើងមិនមែនធ្វើការនេះ ដោយយល់ដល់អ្នកអ៊ីស្រាអែល តែយល់ដល់ឈ្មោះ
ដ៏វិសុទ្ធរបស់យើង ជាឈ្មោះដែលអ្នករាល់គ្នាបានបង្អាប់ នៅកណ្តាលជនជាតិផ្សេងៗដែលអ្នកបានទៅដល់នោះ។[23]ដ្បិតយើងនឹងញែកឈ្មោះដ៏ធំរបស់យើង ដែលត្រូវ
បង្អាប់នៅកណ្តាលជនជាតិផ្សេងៗ ដែលអ្នករាល់គ្នាបានបង្អាប់នៅក្នុងពួកគេ ដ៏វិសុទ្ធដែរ។ ក្រោយមក ផ្សេងនឹងដឹងថា យើងនេះជាព្រះអម្ចាស់ពិតមែន
ហើយការនេះព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូល ពេលដែលអ្នកឃើញថាយើងបរិសុទ្ធ។
[24]យើងនឹងយកអ្នកចេញពីជនជាតិដ៏ទៃ ហើយប្រមូលអ្នកពីគ្រប់ទីកន្លែង ហើយយើងនាំអ្នកមកក្នុងទឹកដីរបស់អ្នកវិញ។[25]បន្ទាប់មក យើងនឹងប្រោះទឹកស្អាតទៅលើអ្នក
ដូច្នេះអ្នកនឹងបានស្អាត យើងនឹងជម្រះអ្នករាល់គ្នាឲ្យស្អាត ពីគ្រប់សេចក្តីស្មោកគ្រោក ហើយយើងសម្អាតអ្នកពីអស់ទាំងរូបព្រះទាំងនោះ។
[26]យើងនឹងឲ្យអ្នកមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងអ្នកដែរ យើងនឹងដកចិត្តដែលរឹងដូចថ្មចេញពីរូបសាច់អ្នក ហើយឲ្យមានចិត្តជាសាច់វិញ។[27]យើងនឹងដាក់
វិញ្ញាណរបស់យើងនៅក្នុងអ្នករាល់គ្នា បណ្តាលឲ្យអ្នករាល់គ្នាដើរតាមក្រឹត្យក្រម ហើយរក្សាបញ្ញត្តិច្បាប់របស់យើង ព្រមទាំងប្រព្រឹត្តតាមផង។[28]បន្ទាប់មក អ្នករាល់គ្នានឹង
រស់នៅក្នុងទឹកដីដែលយើងបានឲ្យដល់បុព្វបុរសអ្នក អ្នករាល់គ្នានឹងធ្វើជាប្រជារាស្ត្ររបស់យើង ហើយយើងជាព្រះជាម្ចាស់ដល់អ្នក។
[29]ដ្បិតយើងនឹងជួយសង្គ្រោះអ្នក ពីអ្វីទាំងអស់ដែលមិនស្អាតរបស់អ្នក។ យើងនឹងបង្កាប់ដល់ស្រូវ ឲ្យបានចម្រើនឡើង។ យើងនឹងមិនធ្វើឲ្យកើតមានការអំណត់ដក់អ្នកទេ។
[30]យើងនឹងចម្រើនផ្លែឈើ និងផលចម្ការឡើងដែរ ដើម្បីមិនឲ្យអ្នករាល់គ្នាត្រូវពាក្យជំណៅលរបស់ជនជាតិដទៃ ដោយព្រោះអំណត់ទៀត។[31]អ្នករាល់គ្នានឹងនឹកចាំពីកិរិយា
អាក្រក់របស់អ្នក ហើយពីអំពើដែលអ្នករាល់គ្នាប្រព្រឹត្តមិនល្អ ដូច្នេះ អ្នករាល់គ្នានឹងមើលខ្លួនដោយខ្ពើមឆ្អើម ដោយព្រោះអំពើទុច្ចរិត និងអំពើគួរស្អប់ខ្ពើមរបស់អ្នក»។
[32]យើងមិនធ្វើការនេះដើម្បីឲ្យអ្នកបានប្រយោជន៍ទេ នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ សូមឲ្យអ្នកបានដឹង។ ដូច្នេះ អ្នកនឹងអាម៉ាស់ ហើយបាក់មុខ ដោយព្រោះ
កិរិយាអ្នកបានធ្វើ កូនចៅអ៊ីស្រាអែល។[33]ព្រះអម្ចាស់ដ៏ជាព្រះលើទាំងអស់មានព្រះបន្ទូលដូច្នេះថា៖ នៅថ្ងៃដែលយើងជម្រះអ្នក ឲ្យស្អាតពីអស់ទាំងអំពើទុច្ចរិតរបស់អ្នក នោះ
យើងនឹងឲ្យអស់ទាំងទីក្រុងរបស់អ្នក មានមនុស្សរស់នៅវិញ ហើយឲ្យអស់ទាំងកន្លែងបាក់បែកបានសង់ឡើង។[34]ដ្បិត ដែលនៅស្ងាត់ និងមានគេភ្ជួររាស់ ទឹកដីដែលពីដើម
នៅស្ងាត់ច្រៀប ចំពោះភ្នែកនៃអស់អ្នកដែលដើរកាត់នោះ។
[35]ក្រោយមកពួកគេនឹងនិយាយថា «ទឹកដីនេះដែលត្រូវបោះចោល ត្រឡប់ដូចជាសួនច្បារអេដែន ហើយទីក្រុងទាំងនោះត្រូវបោះចោល ហើយបាក់បែក
ដែលបានដាច់ចុះក្រោម ពេលនេះបានមាំមួនឡើង ហើយមានមនុស្សអាស្រ័យនៅ»។[36]ដូច្នេះ អស់ទាំងជនជាតិដែលសល់នៅព័ទ្ធជុំវិញអ្នក គេនឹងដឹងថា យើងជា
ព្រះអម្ចាស់ យើងបានសង់ទីដែលបាក់បែក ហើយបានសាងសារជាថ្មីកន្លែងបោះបង់ចោល។ យើងជាព្រះអម្ចាស់។ យើងបានថ្លែងពីវា ហើយយើងនឹងធ្វើវា។
[37]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ម្តងទៀតយើងនឹងបានសូមដោយកូនចៅអ៊ីស្រាអែលដើម្បីធ្វើការនេះសម្រាប់ពួកគេ ដើម្បីឲ្យចម្រើនគ្នាជាច្រើនដូចជាហ្វូងចៀម។
[38]ដូចជាហ្វូងចៀម ដែលបានត្រៀមសម្រាប់យញ្ញបូជា ដូចជាហ្វូងចៀមនៅក្រុងយេរូសាឡិម នៅក្នុងថ្ងៃបុណ្យដែលបានកំណត់ ដូច្នោះនឹងដូចក្រុងដែលខូចអស់
ហើយបានពេញដោយហ្វូងមនុស្សហើយពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់»។

Ezekiel 36:1

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់លោកអេសេគាល។
ឥឡូវនេះសាររបស់ព្រះអង្គគឺទៅដល់ភ្នំអ៊ីស្រាអែល។

កូនមនុស្សអើយ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ២:១។

ចូរថ្លែងព្រះបន្ទូលទៅកាន់អ្នកភ្នំនៃអ៊ីស្រាអែល

ព្រះអង្គសព្វព្រះហឫទ័យ ឲ្យអេសេគាលនិយាយទៅកាន់ភ្នំដូចជាពួកគេជាមនុស្ស។

ហាសហា

នេះគឺជាការបង្ហាញអំណរ។ វាអាចត្រូវបានបកប្រែថា «យើងពិតជារីករាយ» ឬ

generated on Wed Sep 10 16:16:32 2025

«នេះពិតជាអស្ចារ្យណាស់»។
ទីខ្ពស់ពីបុរាណ
នេះសំដៅទៅលើភ្នំខ្ពស់ៗ នៅស្រុកអ៊ីស្រាអែល។ ការបកប្រែរបៀបផ្សេងទៀត:
«ភ្នំចាស់មានវ័យចំណាស់»។
បានត្រឡប់ជារបស់យើងហើយ
«ឥឡូវជាកម្មសិទ្ធយើង»
ដោយព្រោះអ្នកនៅស្ងាត់ស្ងៀម
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារតែអ្នកភ្នំបានក្លាយទៅជាទីស្ងាត់ជ្រងំ»
ដោយព្រោះអ្នកនៅស្ងាត់ស្ងៀម ហើយនិងការវាយប្រហារមកកាន់អ្នក
«ពីព្រោះអ្នកត្រូវបានវាយប្រហារពីគ្រប់ទិសទី» ឬ
«ពីព្រោះសត្រូវរបស់អ្នកបានវាយប្រហារអ្នកពីគ្រប់ទិសដៅ»
អ្នកនឹងនៅក្រោមការត្រួតត្រានៃការបង្កាច់បង្ខូច បបូរមាត់និងអណ្តាតគឺនិយាយមិនល្អពីអ្នក
ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សកំពុងនិយាយអាក្រក់អំពីអ្នកហើយប្រជាជាតិនានាកំពុងនិយាយរឿងអាក្រក់អំពីអ្នក»
បង្កាច់បង្ខូច បបូរមាត់និងអណ្តាត
ការបកប្រែរបៀបផ្សេងទៀត: «ពាក្យបង្កាច់បង្ខូច»
Ezekiel 36:4
ព័ត៌មានទូទៅ:
នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះភ្នំអ៊ីស្រាអែល។
វាអាចមានប្រយោជន៍ក្នុងការប្រើខនៅទីនេះដូចជា UDB
ធ្វើដើម្បីរៀបចំអត្ថបទតាមលំដាប់លំដោយ។
ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៦:១។
ទីក្រុងដែលគេបោះចោល
«ទីក្រុងដែលស្ងាត់ជ្រងំដែលគ្មានប្រជាជនរស់នៅ»
ទីក្រុងដែលគេបោះចោល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទីក្រុងដែលមនុស្សបានបន្សល់ទុក»
វាបានត្រឡប់កន្លែងប្លន់
«សត្រូវដែលបានលួចពី»
ប្រធានបទនៃការចំអកឱ្យប្រជាជាតិផ្សេងទៀតដែលនៅជុំវិញពួកគេ
«ប្រទេសផ្សេងទៀតដែលនៅជុំវិញនោះចំអក»
ភ្លើងនៃកំហឹងរបស់យើង
ព្រះអម្ចាស់ស្រឡាញ់អ៊ីស្រាអែលយ៉ាងខ្លាំងដូច្នេះព្រះអង្គក៏មានព្រះហឫទ័យក្រអឺតក្រទមចំពោះប្រជាជាតិដែលបានធ្វើបាបពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារតែការច្រណែនឈ្នានីសរបស់យើង» ឬ
«ដោយសារតែកំហឹងរបស់យើងខ្លាំង»
ទាស់នឹងជនជាតិផ្សេងៗ ហើយអេដុមទាំងមូល
«និងប្រឆាំងនឹងអេដុមទាំងអស់»
ហើយទាស់ជាមួយពួកអ្នកមានចិត្តរីករាយ ហើយអ្នកដែលមានចិត្តមើលងាយ
UDB បញ្ជាសលំដាប់នៃឃ្លាទាំងនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«បានជេរប្រមាថប្រជាជនអ៊ីស្រាអែលរបស់អ្នក...ត្រូវបានគេចាប់យកដោយសប្បាយរីករាយ
មានចិត្តរីករាយ
«ដោយសេចក្តីរីករាយនៅក្នុងដួងចិត្តរបស់ពួកគេ» ឬ
«ខណៈពេលដែលពួកគេកំពុងរីករាយ»
ដែលមានចិត្តមើលងាយ
វាបញ្ជាក់ថាការមើលងាយរបស់ពួកគេគឺសម្រាប់អ៊ីស្រាអែល។
«នៅមើលងាយស្មារតីរបស់ពួកគេចំពោះអ៊ីស្រាអែល» ឬ
«ខណៈពេលមើលងាយអ៊ីស្រាអែល» (សូមមើល:
មើល!
ពាក្យ «មើលចុះ» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាស់!»
ក្នុងកំហឹងខ្លាំងហើយការក្រោធរបស់យើង
ពាក្យថា «កំហឹង» និង «សេចក្តីក្រោធ» មានន័យដូចគ្នា។
ពួកគេរួមគ្នាសង្កត់ធ្ងន់លើសេចក្តីក្រោធនៃកំហឹងរបស់ព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រោះយើងខឹងខ្លាំងណាស់»
អ្នកបានកើតមកដើម្បីប្រម៉ាត់ប្រជាជាតិ
«ប្រជាជាតិផ្សេងទៀតបានជេរប្រមាថអ្នក» ឬ
«ប្រជាជាតិផ្សេងទៀតបានមើលងាយអ្នក»
Ezekiel 36:7
ព័ត៌មានទូទៅ:
នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះភ្នំអ៊ីស្រាអែល។
យើងខ្លួនឯងនឹងលើកដៃស្បថថា
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងលើកដៃរបស់យើងហើយស្បថ»។
ការលើកដៃបង្ហាញថាគាត់នឹងធ្វើអ្វីដែលគាត់បានស្បថ។
ជនជាតិទាំងនោះដែលនៅជុំវិញអ្នក នឹងប្រកដជារង់សេចក្តីខ្មាសរបស់ខ្លួនគេវិញ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សនឹងចំអកប្រជាជាតិដែលនៅជុំវិញអ្នក»
នៅជុំវិញអ្នក
ពាក្យថា «អ្នក» គឺសំដៅទៅលើភ្នំអ៊ីស្រាអែល។
Ezekiel 36:8
ព័ត៌មានទូទៅ:
នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះភ្នំអ៊ីស្រាអែល។
អ្នករាល់គ្នានឹងបែកមែក ហើយបង្កើតផលរបស់អ្នក
ការបកប្រែរបៀបផ្សេងទៀត: «ដើមឈើរបស់អ្នកនឹងរីកដុះដាលបែកមេឃសាខា
និងបង្កើតផលផ្លែ»។
ចូរមើល!
ពាក្យថា «មើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែរបៀបផ្សេងទៀត: «ពិតណាស់»។
យើងកាន់ខាងអ្នក
«យើងចង់ធ្វើអ្វីដែលល្អចំពោះអ្នក»។ ពាក្យថា «អ្នក»
អ្នកគឺសំដៅទៅលើភ្នំអ៊ីស្រាអែល។
ហើយយើងនឹងធ្វើការល្អដល់អ្នក
«យើងនឹងមានក្តីមេត្តាដល់អ្នក» (UDB)
នោះនឹងមានគេភ្ជួររាស់ ហើយសាបព្រោះអ្នក
ការបកប្រែរបៀបផ្សេងទៀត: « ប្រជាជនអ៊ីស្រាអែលអើយ
យើងនឹងភ្ជួរដីរបស់អ្នកហើយសាបព្រោះគ្រាប់ពូជ»។
ភ្ជួររាស់មានន័យថាកាត់ជួរដេកនៅក្នុងដីដើម្បីដាំគ្រាប់ពូជនៅក្នុងនោះ។
Ezekiel 36:10
ព័ត៌មានទូទៅ:
នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះភ្នំអ៊ីស្រាអែល។
ពួកវង្សអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣:១។
ទីក្រុងទាំងប៉ុន្មានរបស់អ្នកនឹងមានមនុស្សនៅ ហើយអស់ទាំងកន្លែងបាក់បែកនឹងបានសង់ឡើងវិញ
[illegible]
ហើយនឹងកសាងនូវអ្វីដែលបានបាក់បែកឡើងវិញ»។
គេនឹងចម្រើនឡើង ហើយសាយគ្រាយចេញទៅ
«ពួកគេនឹងក្លាយជាមនុស្សជាច្រើនហើយមានកូនច្រើន»
អ្នកដូចពីដើម ហើយប្រព្រឹត្តនឹងអ្នកដោយល្អជាងជាន់ដើមទៅទៀត
«ប្រជាជនរស់នៅលើភ្នំដូចអ្នកបានធ្វើពីមុន»
នឹងដឹងថា យើងនេះជាព្រះអម្ចាស់ពិតមែន
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៦:៦។
គេនឹងបានអ្នកជារបស់គេ
ពាក្យថា «អ្នក» គឺជាឯកវចន:ហើយសំដៅទៅលើ «ទឹកដីអ៊ីស្រាអែល»។
អ្នកនឹងបានជាមរតកដល់គេ នោះអ្នកនឹងមិនធ្វើឲ្យកូនរបស់គេស្លាប់ឡើយ
វាបញ្ជាក់ថាកាលពីមុនកុមារបានស្លាប់ដោយសារតែមិនមានស្បៀងអាហារគ្រប់គ្រាន់នៅលើដី។
ឥឡូវដីនេះអាចផលិតស្បៀងអាហារបានគ្រប់គ្រាន់។
Ezekiel 36:13
ព័ត៌មានទូទៅ:
នេះបន្តជាសាររបស់ព្រះអម្ចាស់ចំពោះភ្នំអ៊ីស្រាអែល។
ពួកគេនិយាយពីអ្នកថា
«ប្រជាជាតិផ្សេងទៀតកំពុងនិយាយទៅកាន់អ្នកថាជាភ្នំ»
អ្នកដែលលេបសីុមនុស្ស
«អ្នកបណ្តាលឲ្យមនុស្សជាច្រើនស្លាប់»។
ពាក្យថាអ្នកគឺជាឯកវចន:ហើយសំដៅទៅលើ «ទឹកដីអ៊ីស្រាអែល»។
ហើយកូនចៅរបស់ជនជាតិអ្នកនឹងស្លាប់
អ្នកធ្វើឲ្យកូនរបស់ប្រជាជនអ្នកស្លាប់។
វាបញ្ជាក់ថាភ្នំធ្វើបែបនេះដោយមិនដាំដំណាំល្អ។
នេះអាចត្រូវបានធ្វើឲ្យច្បាស់ដូចជានៅក្នុង UDB។ សូមមើល
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
យើងមិនឲ្យអ្នកឮពាក្យត្មះតិះដៀលរបស់ជនជាតិដទៃទាំងប៉ុន្មានទៀតទេ
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងមិនអនុញ្ញាតឲ្យប្រជាជាតិផ្សេងទៀតជេរប្រមាថអ្នកទេ»។
អ្នកមិនត្រូវរងទ្រាំសេចក្តីប្រមាថមើលងាយរបស់គេ
«ប្រជាជននឹងលែងធ្វើឲ្យអ្នកខ្មាស់អៀនទៀតឡើយ»
ឲ្យជនជាតិរបស់អ្នកចំពប់ដួលទៀតឡើយ
«និងភ្នំទាំងឡាយធ្វើឲ្យប្រជាជាតិរបស់អ្នករងនូវការបរាជ័យ» (UDB)
Ezekiel 36:16
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំ
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១: ១។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។
ពួកវង្សអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។
ដោយផ្លូវប្រព្រឹត្ត និងកិរិយារបស់ខ្លួន
«ដោយវិធីដែលពួកគេរស់នៅនិងអ្វីដែលពួកគេបានធ្វើ»
ផ្លូវដែលគេប្រព្រឹត្តនៅមុខយើង ប្រៀបដូចជាសេចក្តីស្មោកគ្រោកនៃស្ត្រីដែលមានរដូវ
«វិធីរបស់ពួកគេគួរស្អប់ខ្ពើមដល់យើង ដូចជាការមករដូវមិនស្អាតរបស់ស្ត្រី»
សេចក្តីស្មោកគ្រោកនៃស្ត្រី
ឈាមដែលចេញពីស្ត្រីគ្រប់ខែនៅពេលនាងមិនមានផ្ទៃពោះ
យើងចាក់សេចក្តីក្រោធរបស់យើងទាស់នឹងពួកគេ
«យើងបានធ្វើរឿងទាំងនោះទៅពួកគេដែលបង្ហាញថាយើងខឹងយ៉ាងម៉េច»។
ដ្បិតឈាមដែលគេបានកម្ចាយនៅលើទឹកដីនោះ
ការបកប្រែរបៀបផ្សេងទៀត:
«ពីព្រោះពួកគេបានធ្វើឲ្យឈាមរបស់មនុស្សជាច្រើនហូរលើដី» ឬ
«ពីព្រោះពួកគេបានសម្លាប់មនុស្សជាច្រើន»។
ហើយសម្រាប់ការបំពុលរបស់វាតាមរយៈរូបព្រះរបស់គេ
«ហើយពីព្រោះពួកគេបានស្មោកគ្រោកជាមួយទឹកដីរូបព្រះរបស់គេ»
Ezekiel 36:19
ព័ត៌មានទូទៅ:
នេះជាសាររបស់ព្រះអម្ចាស់ចំពោះភ្នំអ៊ីស្រាអែល។
យើងបានកម្ចាត់កម្ចាយពួកគេទៅក្នុងចំណោមជនជាតិផ្សេង ពួកគេត្រូវបែងចែកទៅនៅគ្រប់ទីកន្លែង
សូមមើលពីរបៀបដែលបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក ១២:១៤។
ពួកគេត្រូវបែងចែកទៅនៅគ្រប់ទីកន្លែង
ការបកប្រែរបៀបផ្សេងទៀត: «យើងបានបំបែកពួកគេនៅលើទឹកដី»
តាមការប្រព្រឹត្ត ហើយកិច្ចការរបស់គេ
ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលពួកគេបានធ្វើ»
ពេលមនុស្ស
«ពីព្រោះមនុស្សផ្សេងទៀតនិយាយ»
ទឹកដីរបស់ព្រះអង្គ
នេះសំដៅលើទឹកដីអ៊ីស្រាអែល។
យើងបានយល់ដល់ឈ្មោះបរិសុទ្ធរបស់យើង
«ខ្ញុំយកចិត្តទុកដាក់ចំពោះឈ្មោះដ៏បរិសុទ្ធរបស់យើង»។
ការបកប្រែរបៀបផ្សេងទៀត: «យើងចង់ឲ្យមនុស្សដឹងថាខ្ញុំជាមនុស្សបរិសុទ្ធ»។
ជាកូនអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។
Ezekiel 36:22
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅកាន់អេសេគាល
ហើយឲ្យថ្លែងសាររបស់ទ្រង់ទៅអ៊ីស្រាអែល ។
កូនចៅអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។
ដោយយល់ដល់
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារតែអ្នក» ឬ «ដើម្បីជួយអ្នក»
តែយល់ដល់ឈ្មោះដ៏វិសុទ្ធរបស់យើង
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីឲ្យមនុស្សដឹងថាយើងជាព្រះបរិសុទ្ធ» ឬ
«ដូច្នេះមនុស្សនឹងគោរពយើងជាព្រះបរិសុទ្ធ»
យើងនេះជាព្រះអម្ចាស់ពិតមែន
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។
ការនេះព្រះអម្ចាស់ដ៏ជាព្រះបានមានព្រះបន្ទូល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។
Ezekiel 36:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយអេសេគាលថ្លែងសាររបស់ទ្រង់ ទៅអ៊ីស្រាអែល។
ប្រោះទឹកស្អាត
«ធ្វើឲ្យទឹកសុទ្ធស្រក់លើអ្នក» ឬ «ចាក់ទឹកបរិសុទ្ធ»
ពីគ្រប់សេចក្តីស្មោកគ្រោក
«គ្រប់រឿងទាំងអស់ដែលធ្វើឲ្យអ្នកមិនបរិសុទ្ធ»
Ezekiel 36:26
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយអេសេគាលថ្លែងសាររបស់ទ្រង់ ទៅអ៊ីស្រាអែល។
មានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មី
សូមមើលពីរបៀបដែលបានបកប្រែ «ដួងចិត្ត» និង «វិញ្ញាណ» នៅក្នុងជំពូក ១១:១៩។
ក្នុងអ្នកដែរ យើងនឹងដកចិត្ត
«នៅក្នុងអ្នក» ឬ «នៅខាងក្នុងអ្នក»
ចិត្តដែលរឹងដូចថ្ម
នេះប្រៀបធៀបដួងចិត្តរឹងរូសរបស់ប្រជាជនទៅនឹងថ្មរឹង។
«បេះដូងដែលរឹងដូចដុំថ្ម»។ សូមមើលពីរបៀបដែលបកប្រែ «បេះដូងដុំថ្ម»
នៅក្នុងជំពូក ១១:១៩។
រូបសាច់អ្នក
«រូបកាយអ្នករាល់គ្នា»
ចិត្តជាសាច់វិញ
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១១:១៩។ នេះជាដួងចិត្ត
ដែលមិនរឹងចចេសតែសុខចិត្តស្តាប់បង្គាប់ព្រះ។
គ្នាដើរតាមក្រឹត្យក្រម
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១១:១៩។
រក្សាបញ្ញត្តិច្បាប់របស់យើង ព្រមទាំងប្រព្រឹត្តតាមផង
សូមមើលពីរបៀបដែលអ្នកបានបកប្រែ «នឹងអនុវត្តតាមក្រឹត្យរបស់ខ្ញុំហើយធ្វើវា»
នៅក្នុងជំពូក ១១:១៩។
ប្រជារាស្ត្ររបស់យើង
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១១:១៩។
Ezekiel 36:29
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ទ្រង់ ទៅជនជាតិអ៊ីស្រាអែល។
យើងនឹងបង្គាប់ដល់ស្រូវ ឲ្យបានចម្រើន
យើងនឹងហៅគ្រាប់ស្រូវដែលត្រូវមក។
ឃ្លានេះបង្ហាញពីគ្រាប់ធញ្ញជាតិដែលជាអ្នកបំរើរបស់ព្រះអម្ចាស់។
«នឹងធ្វើអោយមានស្រូវនៅស្រុកអ៊ីស្រាអែល»។
អ្នករាល់គ្នាត្រូវពាក្យដំណៀលរបស់ជនជាតិដទៃ ដោយព្រោះអំណត់ទៀត
«ប្រជាជាតិនានានឹងលែងធ្វើឲ្យអ្នកខ្មាស់អៀនទៀត ហើយព្រោះអ្នករងគ្រោះទុរ្ភិក្ស»
អំពើគួរស្អប់ខ្ពើមរបស់អ្នក
សូមមើលពីរបៀបដែលបកប្រែ «សកម្មភាពគួរស្អប់ខ្ពើម» នៅក្នុងជំពូក ៥:៩។
Ezekiel 36:32
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅកាន់អេសេគាល អំពីអ៊ីស្រាអែល។
បានប្រយោជន៍ទេ
«សំរាប់អ្នក»
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។
សូមឲ្យអ្នកបានដឹង
ការបកប្រែរបៀបផ្សេងទៀត: «ដឹងរឿងនេះ» ឬ «អ្នកអាចប្រាកដអំពីរឿងនេះ»។
ព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះដើម្បីបញ្ជាក់ថាមិនមែនទេ
ព្រោះប្រជាជនល្អដែលព្រះអង្គនឹងស្តារពួកគេឡើងវិញ។
ឃ្លានេះអាចត្រូវបានផ្លាស់ទៅផ្នែកដំបូងនៃខ។
ដូច្នេះ អ្នកនឹងអាម៉ាស់ ហើយបាក់មុខ

generated on Wed Sep 10 16:16:32 2025

ពាក្យ «អាម៉ាស់» និង «បាក់មុខ» មានអត្ថន័យស្រដៀងគ្នា។
ពួកគេរួមគ្នាសង្កត់ធ្ងន់ទៅលើភាពខ្មាស់អៀន។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះគួរឲ្យខ្មាស់អៀនណាស់»។
ដោយព្រោះកិរិយាអ្នកបានធ្វើ
«ព្រោះអ្វីដែលអ្នកបានធ្វើ»
កូនចៅអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។
ដែលនៅស្ងាត់ និងមានគេភ្ជួររាស់ ទឹកដី
«អ្នកនឹងធ្វើស្រែចំការដែលបាក់បែក»
ចំពោះភ្នែកនៃអស់អ្នកដែលដើរកាត់នោះ
ការបកប្រែរបៀបផ្សេងទៀត:
«ហើយអ្នកទាំងអស់ដែលធ្វើដំណើរលើដីនឹងឃើញវា»។
Ezekiel 36:35
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គ ទៅជនជាតិអ៊ីស្រាអែល។
ក្រោយមកពួកគេ
ពាក្យថា «ពួកគេ» សំដៅទៅលើប្រជាជនដែលដើរឆ្លងកាត់ទឹកដីអ៊ីស្រាអែល។
ត្រូវបោះចោល ហើយបាក់បែក
«បាក់បែកដែលគ្មាននរណារស់នៅ»
ដែលបានដាច់ចុះក្រោម
អត្ថន័យដែលអាចមានគឺ ១) «សត្រូវបានដួលរលំ» ឬ ២)
«ដែលមនុស្សមិនអាចចូលបាន»។
គេនឹងដឹងថា យើងជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។
បានសង់ទីដែលបាក់បែក
«ហើយយើងបានបង្កើតទីក្រុងនានាដែលខ្មាំងសត្រូវបានវាយបំផ្លាញ»
បានសាងសារជាថ្មីកន្លែងបោះបង់ចោល
«ដាំដំណាំលើដីដែលស្ងាត់ជ្រងំ»
Ezekiel 36:37
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅលោកអេសេគាល។
ដើម្បីឲ្យចម្រើនគ្នាជាច្រើនដូចជាហ្វូងចៀម
«ដើម្បីធ្វើឲ្យពួកគេមានចំនួនច្រើនដូចហ្វូងចៀម»។
ចៀមដែលចំរើនថ្វេរគុណយ៉ាងឆាប់រហ័ស។
«ដើម្បីធ្វើឲ្យប្រជាជនកើនឡើងយ៉ាងឆាប់រហ័សដូចជាចៀម»។
ដឹងថា យើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។

---

37 [1]ព្រះហស្តនៃព្រះអម្ចាស់បានដាក់លើខ្ញុំ ហើយព្រះអង្គក៏នាំយកខ្ញុំ ដោយព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ទៅដាក់ចុះនៅកណ្តាលច្រកភ្នំមួយ ដែលពេញដោយឆ្អឹងខ្មោច។[2]ព្រះអង្គឲ្យខ្ញុំដើរឆ្លងកាត់ទៅឆ្អឹងទាំងនោះជុំវិញហើយជុំវិញ។ ចូរមើល៍! នៅវាលច្រកនោះ មានឆ្អឹងយ៉ាងសន្ធឹក។ ឆ្អឹងទាំងនោះស្ងួតហែងណាស់។[3]ព្រះអង្គមានព្រះបន្ទូលមកខ្ញុំ «កូនមនុស្សអើយ តើឆ្អឹងទាំងនេះនឹងរស់ម្តងទៀតទេ?» ដូច្នេះខ្ញុំក៏បាននិយាយថា «ព្រះអម្ចាស់ដ៏ជាព្រះ មានតែព្រះអង្គទេទើបដឹង»។
[4]រួចហើយព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «ចូរថ្លែងព្រះបន្ទូលដល់ឆ្អឹងទាំងនេះ ហើយប្រាប់ថាឆ្អឹងស្ងួតហែង ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។[5]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដល់ឆ្អឹងទាំងនេះដូច្នេះ ចូរមើល! យើងនឹងឲ្យមានខ្យល់ដង្ហើមចូលក្នុងអ្នករាល់គ្នា ហើយអ្នកនឹងមានជីវិតរស់។[6]យើងនឹងដាក់ឲ្យមានសរសៃ ធ្វើឲ្យមានសាច់ដុះលើអ្នករាល់គ្នា ហើយគ្របរុំដោយស្បែក ព្រមទាំងបញ្ចូលខ្យល់ដង្ហើមទៅក្នុងអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងមានជីវិតរស់ ដូច្នេះអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់»។
[7]ដូច្នេះ ខ្ញុំក៏ថ្លែងព្រះបន្ទូល ដូចជាព្រះអង្គបានបង្គាប់ ដូចដែលខ្ញុំកំពុងថ្លែងព្រះបន្ទូលនោះ មានឮសម្លេងក្រិកៗ។ រួចហើយឆ្អឹងទាំងនោះបានកម្រើកផ្គុំជាប់គ្នា ឆ្អឹងមួយភ្ជាប់ឆ្អឹង។[8]ខ្ញុំសម្លឹងមើល ហើយមើល៍! មានសរសៃនិងសាច់កើតឡើងនៅឆ្អឹងទាំងនោះ រួចមានស្បែករុំគ្របទៀត។ តែអត់មានខ្យល់ដង្ហើមនៅក្នុងពួកគេទេ។
[9]ហើយព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «ចូរថ្លែងព្រះបន្ទូលទៅ ដល់ខ្យល់ ចូរថ្លែងព្រះបន្ទូល កូនមនុស្សអើយ ហើយនិយាយទៅខ្យល់ថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ខ្យល់ដង្ហើម ចូរមកពីខ្យល់ទាំងបួនទិស ហើយខ្យល់ដង្ហើមលើអ្នកបានស្លាប់ទាំងនេះ គេនឹងរស់ឡើង»។[10]ដូច្នេះខ្ញុំក៏ថ្លែងព្រះបន្ទូលដូចជាព្រះអង្គបានបង្គាប់មក ហើយខ្យល់ដង្ហើមក៏ចូលទៅក្នុងសពទាំងនោះ ហើយគេក៏រស់ឡើង បានទាំងឈរឡើងជាកងទ័ពយ៉ាងធំ។
[11]ក្រោយព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា «កូនមនុស្សអើយ ឆ្អឹងទាំងនេះគឺជាកូនចៅអ៊ីស្រាអែលទាំងមូល។ មើល៍! ពួកគេនិយាយថា ឆ្អឹងយើងរបស់រាល់គ្នាស្ងួតហែងហើយក្តីសង្ឃឹមរបស់យើងក៏បាត់អស់ដែរ។ យើងរាល់គ្នាត្រូវកាត់ចេញហើយ។[12]ដូច្នេះហើយ ចូរថ្លែងព្រះបន្ទូល ដោយនិយាយថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល! ប្រជារាស្ត្ររបស់យើងអើយ យើងនឹងបើកផ្នូររបស់អ្នករាល់គ្នា ហើយនឹងធ្វើឲ្យអ្នករាល់គ្នាឡើងចេញពីផ្នូរមក រួចនឹងនាំអ្នកឲ្យចូលទៅក្នុងទឹកដីអ៊ីស្រាអែលវិញ។
[13]រួចហើយអ្នករាល់គ្នានឹងដឹងថា យើងនេះជាព្រះអម្ចាស់ ពេលយើងបើកផ្នូររបស់អ្នក ឲ្យអ្នកបានឡើងចេញពីទីនោះមក។[14]យើងនឹងដាក់វិញ្ញាណយើងនៅក្នុងអ្នករាល់គ្នា អ្នកនឹងមានជីវិតរស់ ហើយយើងនឹងធ្វើអ្នក ដើម្បីសម្រាកនៅក្នុងទឹកដីរបស់អ្នក នោះអ្នករាល់គ្នានឹងដឹងថា គឺយើង ជាព្រះអម្ចាស់ បានមានបន្ទូលហើយ នឹងកើតឡើងមែន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[15]រួចហើយព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ខ្ញុំថា[16]«កូនមនុស្សអើយ! ចូរយកបន្ទះឈើមួយមកសរសេរចុះថា សម្រាប់ពួកយូដា និងប្រជាជនរបស់អ៊ីស្រាអែល ជាមិត្តនិងគ្នា។ រួចយកបន្ទះឈើមួយទៀតសរសេរថា សម្រាប់ពួកយ៉ូសែប ជាបន្ទះឈើរបស់ពួកអេប្រាអិម និងពួកប្រជាជននៃអ៊ីស្រាអែលជាមិត្តរបស់គេ។[17]រួចនាំអ្នកទាំងពីរនោះមកជាមួយគ្នា ធ្វើជាបន្ទះឈើតែមួយធ្វើដំបង ដើម្បីឲ្យបានជាប់ជាមួយគ្នានៅដៃអ្នក។
[18]ពេលប្រជាជនអ្នកនឹងនិយាយទៅអ្នក ហើយប្រាប់ថា តើអ្នកនឹងមិនប្រាប់ឲ្យយើងដឹងពីអ្វីដែលអ្នកចង់ធ្វើទេ?[19]ហើយនិយាយទៅគេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល៍! យើងនឹងយកបន្ទះឈើរបស់យ៉ូសែប ដែលនៅដៃអេប្រាអិម និងកុលសម្ព័ន្ធអ៊ីស្រាអែល ដែលជាគូកនរបស់គេ ដាក់ភ្ជាប់ជាមួយបន្ទះឈើរបស់យូដា រួចហើយគេធ្វើជាបន្ទះឈើតែមួយវិញ ដើម្បីឲ្យគេរួមមកតែមួយនៅក្នុងដៃរបស់យើង។[20]សូមកាន់នៅក្នុងដៃអ្នកបន្ទះឈើទាំងពីរដែលអ្នកបានសរសេរដោយនៅចំពោះភ្នែកគេ។
[21]ចូរប្រកាសប្រាប់គេថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល៍! យើងនឹងយកពួកកូនចៅអ៊ីស្រាអែលចេញពីអស់ទាំងជនជាតិដែលគេបានទៅនោះ។ យើងនឹងប្រមូលមកពីគ្រប់ទិស នាំចូលទៅក្នុងទឹកដីរបស់ផងខ្លួន។[22]យើងនឹងធ្វើឲ្យគេក្លាយជាជនជាតិមួយនៅក្នុងទឹកដីនេះ គឺនៅលើអស់ទាំងភ្នំនៃស្រុកអ៊ីស្រាអែល ហើយនឹងមានស្តេចតែមួយអង្គធ្វើជាស្តេចលើពួកគេ ហើយពួកគេនឹងលែងជាជនជាតិពីរទៀតហើយ។ ពួកគេនឹងមិនបែងចែកទៅជាជនជាតិពីរទៀតឡើយ។
[23]រួចហើយពួកគេនឹងមិនត្រូវរងការប្រមាថដោយគោរពដល់រូបព្រះរបស់គេ ដែលវត្ថុគួរស្អប់ខ្ពើមរបស់គេដែរ ឬអំពើបាបរបស់ផ្សេងទៀតរបស់គេ។ ដ្បិតយើងនឹងជួយសង្គ្រោះគេ ចេញពីការជឿលើជំនឿផ្សេងៗដែលនឹងធ្វើឲ្យគេមានបាប ហើយយើងនឹងលាងសម្អាតពួកគេ ដូច្នោះគេនឹងជាប្រជាជនរបស់យើង
ហើយយើងនឹងជាព្រះជាម្ចាស់របស់ពួកគេ។
[24]ដាវីឌជាអ្នកបម្រើរបស់យើង នឹងធ្វើជាស្តេចលើពួកគេ។ ហើយពួកគេនឹងមានអ្នកគង្វាលតែម្នាក់លើពួកគេ ហើយពួកគេនឹងដើរតាមច្បាប់របស់យើង ហើយរក្សាបញ្ញត្តិទាំងនោះរបស់យើង ហើយស្តាប់បង្គាប់តាមទាំងអស់ផង។[25]ពួកគេនឹងរស់នៅក្នុងទឹកដីដែលយើងបានឲ្យដល់យ៉ាកុបជាអ្នកបម្រើយើង ជាទឹកដីដែលបុព្វបុរសរបស់អ្នករាល់គ្នាបានអាស្រ័យនៅ។ ពួកគេនឹងរស់នៅទីនោះ ជាមួយកូនចៅរបស់ពួកគេជាប់ជារៀងរហូត ដ្បិតដាវីឌជាអ្នកបម្រើយើង នឹងធ្វើជាអ្នកដឹកនាំលើគេ ជារៀងរហូត។
[26]យើងនឹងតាំងសញ្ញានៃសេចក្តីសុខសាន្តជាមួយពួកគេ។ វានឹងនៅជាប់នឹងពួកគេអស់កល្បជានិច្ច។ យើងនឹងតាំងពួកគេឡើង ហើយចម្រើនពួកគេ ហើយដាក់ទីបរិសុទ្ធរបស់យើង នៅកណ្តាលពួកគេអស់កល្បជានិច្ច។[27]ដំណាក់របស់យើងនឹងនៅជាមួយពួកគេ យើងក៏នឹងធ្វើជាព្រះដល់គេ ហើយគេនឹងបានជាប្រជារាស្ត្ររបស់យើង។
[28]រួចហើយគ្រប់ទាំងជនជាតិនឹងដឹងថា យើងនេះជាព្រះអម្ចាស់ ជាអ្នកញែកពួកអ៊ីស្រាអែលជាបរិសុទ្ធ ពេលដែលទីបរិសុទ្ធរបស់យើងបានតាំងនៅកណ្តាលគេ អស់កល្បជានិច្ច»។

---

generated on Wed Sep 10 16:16:32 2025

Ezekiel 37:1
ព័ត៌មានទូទៅ:
អេសេគាលកំពុងនិយាយ
ព្រះហស្តនៃព្រះអម្ចាស់បានដាក់លើខ្ញុំ
សូមមើលពីរបៀបដែលបានបកប្រែ «ព្រះហស្តរបស់ព្រះអម្ចាស់មកលើគាត់» នៅក្នុងជំពូក ១:១។
នៅកណ្ដាល
ការបកប្រែរបៀបផ្សេងទៀត: «នៅកណ្ដាល»
ជុំវិញហើយជុំវិញ
ការបកប្រែរបៀបផ្សេងទៀត: «នៅគ្រប់ទិសដៅ»
មើល!
ពាក្យថា «មើល»
នៅទីនេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើង។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២:១។
Ezekiel 37:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលទៅអេសេគាល
ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ១៣:១។
ចូរមើល!
«មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក»។
សរសៃ
ផ្នែកនៃរាងកាយមនុស្សដែលដូចជាខ្សែរឹង ហើយកាន់ឆ្អឹង និងសាច់ដុំជាមួយគ្នា
ទាំងបញ្ចូលខ្យល់ដង្ហើមទៅក្នុង
ពាក្យថា «ដង្ហើម» នៅទីនេះសំដៅទៅលើសកម្មភាពនៃការដកដង្ហើម។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងធ្វើឲ្យអ្នកអាចដកដង្ហើមបាន»។
ខ្យល់ដង្ហើម
ពាក្យហេប្រើដែលបានបកប្រែ «ដង្ហើម» នៅក្នុងខទាំងនេះត្រូវបានបកប្រែជា «វិញ្ញាណ» ដោយសំណៅសម័យទំនើបមួយចំនួន។ វាក៏ត្រូវបានបកប្រែជា «ខ្យល់» នៅក្នុងជំពូក ៣៧:៩។
នឹងដឹងថា យើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។
Ezekiel 37:7
ព័ត៌មានទូទៅ:
លោកអេសេគាលបាននិយាយ
ដូចជាព្រះអង្គបានបង្គាប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
«ដូចដែលព្រះអម្ចាស់បានបញ្ជាលោកយើងនិយាយ»។
មើល!
ពាក្យថា «មើល»
ត្រង់នេះបង្ហាញថាលោកអេសេគាលមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។
សរសៃ
នេះសំដៅទៅលើផ្នែកនៃរាងកាយមនុស្សដែលដូចជាខ្សែរឹងហើយកាន់ឆ្អឹងនិងសាច់ដុំ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣៧:៤។
តែអត់មានខ្យល់ដង្ហើមនៅក្នុងពួកគេទេ
នៅទីនេះ «ដង្ហើម» សំដៅទៅលើសកម្មភាពនៃការដកដង្ហើម។
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែពួកគេមិនដកដង្ហើម» ឬ «ប៉ុន្តែពួកគេមិនបានរស់ទេ»
Ezekiel 37:9
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។
ខ្យល់ដង្ហើម
អត្ថន័យដែលអាចមានគឺ: ១) «ដង្ហើម» ឬ ២) «វិញ្ញាណ» ឬ ៣) «ខ្យល់»។
ពីខ្យល់ទាំងបួនទិស
ការបកប្រែរបៀបផ្សេងទៀត: «មកពីទិសទាំងបួនដែលខ្យល់អាចបក់ចូល» ឬ «ពីគ្រប់ទិសដៅ»
ហើយខ្យល់ដង្ហើមលើអ្នកបានស្លាប់ទាំងនេះ
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនទាំងនេះដែលសត្រូវ
និងគ្រោះមហន្តរាយបានសម្លាប់»។
ដូចជាព្រះអង្គបានបង្គាប់មក
ការបកប្រែរបៀបផ្សេងទៀត: «ដូចដែលព្រះអម្ចាស់បានបញ្ជាយើង»
Ezekiel 37:11
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។
នេះគឺជាកូនចៅអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។
មើល!
ពាក្យ «មើលចុះ» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។
ការបកប្រែជំនួស៖ «ពិតហើយ!»
ចូរថ្លែងព្រះបន្ទូលហើយនិយាយថា
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុង EZK 21:8.
មើល
ការបកប្រែរបៀបផ្សេងទៀត: «មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក»
Ezekiel 37:13
ព័ត៌មានទូទៅ:
ទាំងនេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់កូនចៅអ៊ីស្រាអែល។
នឹងដឹងថា យើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។
ដើម្បីសម្រាកនៅក្នុងទឹកដីរបស់អ្នក
«ដើម្បីរស់នៅដោយសន្តិភាពនៅក្នុងទឹកដីរបស់អ្នក»
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមមើលពីរបៀបដែលអ្នកបកប្រែ «នេះជាសេចក្តីប្រកាសរបស់ព្រះអម្ចាស់» នៅក្នុងជំពូក ៥:១១។
Ezekiel 37:15
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។
សម្រាប់ពួកយូដា
ការបកប្រែរបៀបផ្សេងទៀត: «តំណាងឲ្យស្រុកយូដា» ឬ «ជាកម្មសិទ្ធិរបស់យូដា»។
យូដា
កុលសម្ព័ន្ធយូដារស់នៅក្នុងរាជាណាចក្រអ៊ីស្រាអែលខាងត្បូងដែលមានឈ្មោះថាយូដា។
នៅទីនេះឈ្មោះត្រូវបានប្រើដើម្បីយោងទៅនគរខាងត្បូងទាំងមូល។
ប្រជាជនរបស់អ៊ីស្រាអែល ជាមិត្តនិងគ្នា
នេះសំដៅទៅលើជនជាតិអ៊ីស្រាអែលដែលរស់នៅក្នុងរាជាណាចក្រយូដាខាងត្បូង។
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់កុលសម្ព័ន្ធយូដា» (UDB) ឬ «កុលសម្ព័ន្ធអ៊ីស្រាអែលដែលជាផ្នែកនៃនគរយូដា»
ពួកអេប្រាអិម
កុលសម្ព័ន្ធអេប្រាអិមរស់នៅក្នុងព្រះរាជាណាចក្រអ៊ីស្រាអែលខាងជើង។
នៅទីនេះឈ្មោះត្រូវបានប្រើដើម្បីយោងទៅនគរខាងជើងទាំងមូល។
ពួកប្រជាជននៃអ៊ីស្រាអែលជាមិត្តរបស់គេ
នេះសំដៅទៅលើជនជាតិអ៊ីស្រាអែលដែលរស់នៅក្នុងព្រះរាជាណាចក្រអ៊ីស្រាអែលខាងជើង។
«គ្រប់កុលសម្ព័ន្ធអ៊ីស្រាអែល» (UDB) ឬ «ជនជាតិអ៊ីស្រាអែលដែលជាចំណែកនៃព្រះរាជាណាចក្រអ៊ីស្រាអែល»
ជាបន្ទះឈើតែមួយ
ដូច្នេះពួកគេក្លាយជាដំបងតែមួយ
Ezekiel 37:18
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅអេសេគាល។
និយាយទៅអ្នក ហើយប្រាប់ថា
សូមមើលពីរបៀបដែលបានបកប្រែ «កំពុងនិយាយនិងនិយាយ» នៅក្នុងជំពូក ៣៣:២៣។
តើអ្នកនឹងមិនប្រាប់ឲ្យយើងដឹងពីរអ្វីដែលអ្នកចង់ធ្វើទេ
ការបកប្រែរបៀបផ្សេងទៀត: «តើដំបងរបស់អ្នកមានន័យអ្វី» ឬ

generated on Wed Sep 10 16:16:32 2025

«ហេតុអ្វីបានជាអ្នកមានដំបងទាំងនេះ»
មើល!
ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
បន្ទះឈើរបស់យ៉ូសែប
«ដំបងរបស់យ៉ូសែប» នេះតំណាងឲ្យព្រះរាជាណាចក្រអ៊ីស្រាអែល។
ដែលនៅដៃអេប្រាអិម
ពាក្យថា«ដៃ» សំដៅទៅលើអំណាច។ «នោះជាអំណាចរបស់អេប្រាអិម» ឬ
«កុលសម្ព័ន្ធអេប្រាអិមគ្រប់គ្រង»
កុលសម្ព័ន្ធអ៊ីស្រាអែល ដែលជាគូកនរបស់គេ
ការបកប្រែរបៀបផ្សេងទៀត:
«កុលសម្ព័ន្ធអ៊ីស្រាអែលផ្សេងទៀតដែលជាដៃគូរបស់គាត់» ឬ
«កុលសម្ព័ន្ធអ៊ីស្រាអែលផ្សេងទៀតដែលជាផ្នែកនៃនគរនោះ»
បន្ទះឈើរបស់យូដា
«ដំបងរបស់ស្រុកយូដា»។ នេះតំណាងឲ្យនគរយូដា។
នៅចំពោះភ្នែកគេ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២១:៦។
Ezekiel 37:21
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅអេសេគាល។
មើល!
ការបកប្រែរបៀបផ្សេងទៀត: «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក!»
វត្ថុគួរស្អប់ខ្ពើម
សូមមើលពីរបៀបដែលអ្នកបកប្រែ «អ្វីដែលគួរឲ្យស្អប់» នៅក្នុងជំពូក ៥:១១។
គេនឹងជាប្រជាជនរបស់យើង ហើយយើងនឹងជាព្រះជាម្ចាស់របស់ពួកគេ
សូមមើលពីរបៀបដែលអ្នកបកប្រែនេះនៅក្នុងជំពូក ១១:១៩។
Ezekiel 37:24
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានព្រះបន្ទូលទៅលោកអេសេគាល។
ដាវីឌជាអ្នកបម្រើរបស់យើង
សូមមើលពីរបៀបដែលអ្នកបកប្រែ «ដាវីឌជាអ្នកបម្រើរបស់យើង» នៅក្នុងជំពូក ៣៤:២២។
លើពួកគេ
ការបកប្រែរបៀបផ្សេងទៀត: «លើប្រជាជនអ៊ីស្រាអែល»
អ្នកគង្វាលតែម្នាក់លើពួកគេ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៣៤:២២។
នឹងដើរតាមច្បាប់របស់យើង
ការបកប្រែរបៀបផ្សេងទៀត: «នឹងរស់នៅដូចយើងបានបញ្ជា»
រក្សាបញ្ញត្តិទាំងនោះរបស់យើង ហើយស្តាប់បង្គាប់តាមទាំងអស់ផង
សូមមើលពីរបៀបដែលបានបកប្រែ «រក្សាបញ្ញត្តិទាំងអស់របស់ខ្ញុំ ហើយធ្វើតាម» នៅក្នុងជំពូក ១៨:១៩។
បានអាស្រ័យនៅ
ការបកប្រែរបៀបផ្សេងទៀត: «ធ្លាប់រស់នៅ»
អ្នកដឹកនាំ
សូមមើលពីរបៀបដែលបានបកប្រែ «ព្រះអង្គម្ចាស់» នៅក្នុង EZK 7:26)
Ezekiel 37:26
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានព្រះបន្ទូលអំពីប្រជាជនអ៊ីស្រាអែល។
យើងនឹងតាំង
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងរៀបចំ»
សញ្ញានៃសេចក្តីសុខសាន្ត
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៣៤:២៥។
យើងនឹងតាំងពួកគេឡើង
នេះបានបញ្ជាក់ថាព្រះអម្ចាស់នឹងបង្កើតពួកគេនៅក្នុងទឹកដីអ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងដាក់ពួកគេនៅក្នុងទឹកដីអ៊ីស្រាអែល»។
ចម្រើន
សូមមើលពីរបៀបដែលបានបកប្រែ«ថ្វេគុណ» នៅក្នុងជំពូក ៣៦:១០។
ទីបរិសុទ្ធ
ការបកប្រែរបៀបផ្សេងទៀត: «ទីសក្ការៈរបស់យើង» ឬ
«ប្រាសាទរបស់យើង» (UDB)
ដំណាក់របស់យើង
ការបកប្រែរបៀបផ្សេងទៀត: «កន្លែងដែលយើងរស់នៅ»
យើងក៏នឹងធ្វើជាព្រះដល់គេ ហើយគេនឹងបានជាប្រជារាស្ត្ររបស់យើង
សូមមើលពីរបៀបដែលបានបកប្រែថា «ពួកគេនឹងធ្វើជាប្រជារាស្ត្ររបស់យើង ហើយយើងនឹងធ្វើជាព្រះរបស់ពួកគេ» នៅក្នុងជំពូក ១១:១៩។
នឹងដឹងថា យើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែ នៅក្នុងជំពូក ៦:៦។
ទីបរិសុទ្ធ
«ទីសក្ការៈរបស់យើង» ឬ «ប្រាសាទរបស់យើង»
នៅកណ្តាលគេ
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងចំណោមគេ»

38 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់ខ្ញុំថា[2]«កូនមនុស្សអើយ ចូរត្រៀទាស់នឹងជនជាតិកុកនៃទឹកដីម៉ាកុក ជាអ្នកដឹកនាំនៃពួករ៉ុស ពួកមែសេក និងពួកទូបាល ត្រូវថ្លែងព្រះបន្ទូលទាស់នឹងគេ។[3]ព្រះអម្ចាស់ដ៏ជាព្រះលើទាំងឋសមានព្រះបន្ទូលដូច្នេះ ចូរមើល! គឺយើងទាស់នឹងអ្នក កុក ជាអ្នកដឹកនាំនៃពួកមេសេក និងពួកទូបាល។
[4]រួចហើយយើងនឹងធ្វើឲ្យអ្នកត្រឡប់មកវិញ យើងនឹងដាក់ទំពក់នៅថ្គាមអ្នក ហើយយើងនឹងយកអ្នកចេញ ជាមួយទាហានរបស់អ្នក រួមទាំងសេះ និងពលទ័ពសេះផង គ្រប់គ្នាស្លៀកពាក់ជាគ្រឿងសឹក កងទ័ពយ៉ាងធំ មានទាំងខែលធំ ខែលតូច ហើយកាន់ដាវគ្រប់គ្នាផង![5]ជនជាតិពើស៊ី ជាតិអេត្យូពី និងជនជាតិពូថមកជាមួយគ្នា គ្រប់គ្នាមានខែល ហើយមួកដែរ![6]ជនជាតិកូមើរ និងពួកគេទាំងប៉ុន្មានផង ក៏មានកូនចៅតូកាម៉ា ពីទឹកដីខាងជើងបំផុត ហើយពួកគ្នាគេទាំងអស់របស់គេ គឺមានជនជាតិជាច្រើនមកជាមួយអ្នកផង!
[7]ចូររៀបចំខ្លួន ត្រូវហើយ រួចចូររៀបចំខ្លួនអ្នក និងពួកកងទ័ពទាំងអស់ដែលបាននៅជាមួយអ្នកផង ហើយឲ្យអ្នកធ្វើជាមេទ័ពដល់ពួកគេ។[8]អ្នកនឹងត្រូវបានហៅ ក្រោយយូរថ្ងៃមក ហើយ ដល់ប៉ុន្មានឆ្នាំកន្លងទៅ ដែលអ្នកនឹងចូលមកក្នុងទឹកដី ដែលបានស្វែងរកដោយសារដាវមកវិញ ដែលបានប្រមូលយកមកវិញពីប្រជាជនជាច្រើន ប្រមូលមកវិញពីអស់ទាំងភ្នំនៃអ៊ីស្រាអែល ជាទឹកដីដែលបានខូចបង់។ ប៉ុន្តែដីរបស់ប្រជាជនដែលបានយកបានយកចេញពីមនុស្សផ្សេង ហើយពួកគេនឹងរស់នៅក្នុងក្តីសុខសាន្ត គឺពួកគេទាំងអស់គ្នា![9]ដូច្នោះអ្នកនឹងឡើងទៅ ដូចជាខ្យល់ព្យុះ អ្នកនឹងបានដូចជាពពកគ្របលើទឹកដី អ្នកហើយពួកកងទ័ពរបស់អ្នក
និងទាហានទាំងអស់ដែលនៅជាមួយអ្នក។
[10]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះថា វាបានកើតឡើងនៅថ្ងៃនោះគឺផែនការដែលមានក្នុងចិត្តរបស់អ្នក ហើយអ្នកនឹងបង្កើតកិច្ចកាលអាក្រក់។[11]ក្រោយមក អ្នកនឹងនិយាយថា ខ្ញុំនឹងឡើងទៅទឹកដីដែលនៅចំទំនេ ខ្ញុំនឹងទៅរកពួកមនុស្ស ដែលនៅដោយស្ងៀមស្ងាត់ ហើយដោយសុខសាន្ត
ពួកគេរស់នៅកន្លែងដែលគ្មានញញ្ជាំងឬរបង ហើយជាកន្លែងដែលគ្មានទ្វារសម្រាប់ទីក្រុង។[12]យើងនឹងចាប់យកជ័យភណ្ឌ ហើយនិងការលួចប្លន់ ហើយទាស់នឹងកន្លែងបាក់បែក ដែលមានមនុស្សថ្មីរស់នៅទីនោះ ហើយទាស់នឹងមនុស្ស ដែលបានប្រមូលចេញពីគ្រប់ទាំងជនជាតិ ជាអ្នកដែលមានហ្វូងសត្វ និងទ្រព្យសម្បត្តិ
ហើយក៏ជាអ្នកដែលរស់នៅចំកណ្តាលផែនដី។
[13]ពួកសេបា ហើយពួកដេដាន់ ពួកជំនួញរបស់ទឹកដីតើស៊ីស ជាមួយអ្នកចម្បាំងវ័យក្មេង នឹងនិយាយមកអ្នកថា តើលោកមកប្លន់ពីយើងឬ? តើអ្នកបានប្រមូលពួកទាហានរបស់លោក ដើម្បីនឹងយកទ្រព្យ នឹងដឹកយកប្រាក់ និងមាស ហើយនាំយកហ្វូងសត្វ ទ្រព្យសម្បត្តិ ហើយយកជ័យភណ្ឌយ៉ាងច្រើនឬ?
[14]ដូច្នេះហើយ ចូរថ្លែងព្រះបន្ទូល កូនមនុស្សអើយ ប្រាប់ដល់ជនជាតិកុកថា «ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ នៅថ្ងៃនោះ ពេលអ៊ីស្រាអែលប្រជាជនរបស់យើងបាននៅដោយសុខសាន្ត តើអ្នកនឹងមិនបានរៀនពីពួកគេទេឬ?[15]អ្នកនឹងចេញពីកន្លែងរបស់អ្នក គឺពីខាងជើងបំផុតមក មានជនជាតិជាច្រើនមកជាមួយអ្នកផង ជាពួកគ្នា

generated on Wed Sep 10 16:16:32 2025

យ៉ាងសន្ធឹក ហើយជាពលទ័ពខ្លាំងពូកែ ដែលសុទ្ធតែជិះសេះគ្រប់ៗគ្នា។[16]អ្នកនឹងឡើងមកទាស់នឹងអ៊ីស្រាអែល។ នៅគ្រាចុងក្រោយបំផុត យើងនឹងនាំអ្នកឲ្យមកទាស់នឹងទឹកដីយើង ដូច្នោះជនជាតិទាំងនោះនឹងគួរតែបានស្គាល់យើង ពេលដែលយើងខ្លួនឯងបានគិតពីកុក ដើម្បីឲ្យជាបរិសុទ្ធ នៅចំពោះភ្នែកពួកគេ។
[17]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ តើអ្នកមិនមែនជាម្នាក់ដែលយើងបាននិយាយកាលពីពេលមុន តាមរយៈដៃពួកអ្នកបម្រើរបស់យើង និងពួកព្យាការីនៃជនជាតិអ៊ីស្រាអែល ជាអ្នកដែលបានថ្លែងព្រះបន្ទូលក្នុងពេលរបស់ពួកគេ ដ្បិតយើងនឹងនាំអ្នកឲ្យមកទាស់នឹងពួកគេទេឬ?[18]ដូច្នោះវានឹងមកដល់ក្នុងថ្ងៃនោះ
ពេលជនជាតិកុកវាយទឹកដីអ៊ីស្រាអែល នេះគឺជាព្រះអម្ចាស់មានព្រះបន្ទូលថា សេចក្តីក្រោធរបស់យើងនឹងឆួលឡើងដូចជាភ្នំ។
[19]ក្នុងសេចក្តីប្រចណ្ឌរបស់យើង និងភ្លើងនៃសេចក្តីក្រោធរបស់យើង ដែលយើងបានថា ពិតប្រាកដជានៅថ្ងៃនោះ នឹងមានការកក្រើករំពើកជាខ្លាំង នៅក្នុង
ទឹកដីអ៊ីស្រាអែល។[20]ពួកគនឹងញាប់ញ័រនៅចំពោះយើង បានជាទាំងត្រីសមុទ្រ និងសត្វហើរលើអាកាស សត្វព្រៃ និងសត្វលូនវារនៅផែនកីដី
ហើយមនុស្សទាំងអស់ដែលរស់នៅទឹកដីផងដែរ។ ភ្នំទាំងនោះនឹងត្រូវបោះចោល ហើយច្រាំងភ្នំនឹងដួលចុះ រហូតដល់កំពែងបាក់មកលើផែនដី។
[21]យើងនឹងបង្គាប់ដាវមកទាស់នឹងគេ នៅលើភ្នំទាំងអស់នោះរបស់យើង នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ ដាវរបស់ព្ួកគេនឹងទាស់ជាមួយបងប្អូនខ្លួន។[22]រួចហើយយើងនឹងដាក់ទោសដល់ពួកគេ ដោយអាសន្នរោគ និងឈាម ហើយយើងនឹងបង្អុរភ្លៀងច្រើនខ្លាំង ព្រមទាំងព្រឹលយ៉ាងធំ និងភ្លើងឆេះ ហើយស្ពាន់ធ័រមកលើគេ និងពួកគ្មារបស់ពួកគេ ហើយលើបណ្តាជនជាតិជាច្រើនដែលមកជាមួយគេដែរ។[23]ដ្បិតយើងនឹងតម្កើងខ្លួនយើង ហើយតាំងខ្លួនយើងជាបរិសុទ្ធ ព្រមទាំងធ្វើឲ្យជនជាតិជាច្រើនស្គាល់យើងនៅនឹងមុខ ហើយពួកគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់»។

Ezekiel 38:1

ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់

«ព្រះអម្ចាស់ថ្លែងព្រះបន្ទូលទ្រង់»។

សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ១:១។

កុក

នេះគឺជាឈ្មោះមេដឹកនាំ ឬ ស្តេចដែលគ្រប់គ្រងលើទឹកដីម៉ាកុក។

ទឹកដីម៉ាកុក

មានន័យថានេះជាដីដែលកុកត្រួតត្រា។ ការបកប្រែរបៀបផ្សេងទៀត:

«អ្នកណាគ្រប់គ្រងលើទឹកដីម៉ាកុក»។

ម៉ាកុក

ឈ្មោះរបស់ប្រជាជាតិបុរាណមួយដែលប្រហែលជារស់នៅក្នុងទឹកដីដែលឥឡូវជាប្រទេសទួរគី។

ម៉ាកុកប្រហែលជាប្រទេសលីឌាពីបុរាណ។

ជាអ្នកដឹកនាំនៃពួកមេសេក និងពួកទូបាល

ឃ្លានេះកើតឡើងពីរដងនៅក្នុងខទាំងនេះ។

ទោះយ៉ាងណាកំណែសម័យថ្មីខ្លះបកប្រែការបកស្រាយភាសាហេព្រើរថាជា

«ប្រធានរ៉ូសមេសេក និងទូបាល»។

Ezekiel 38:4

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលពីកុក។

ដាក់ទំពក់នៅថ្គាមអ្នក

មនុស្សដាក់ទំពក់ក្នុងមាត់សត្វដើម្បីឲ្យពួកគេអាចដឹកនាំសត្វបានគ្រប់ទីកន្លែងដែលពួកគេចង់បាន។

ដាក់

ប្រទេសមួយដែលរស់នៅក្នុងប្រទេសលីប៊ីឥឡូវនេះ។

កូមើរ

ជាប្រជាជាតិមួយដែលរស់នៅខាងជើងសមុទ្រខ្មៅ

កូនចៅតូកាម៉ា

សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២៧:១៤។

Ezekiel 38:7

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលពីកុក។

អ្នកនឹងត្រូវបានហៅ

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងហៅអ្នកឲ្យមកធ្វើសង្គ្រាម»។

និងពួកកងទ័ពទាំងអស់ដែលបាននៅជាមួយអ្នកផង

«កងទ័ពរបស់អ្នកទាំងអស់ដែលអ្នកបានប្រមូលមកសំរាប់ខ្លួនអ្នក» ឬ

«កងទ័ពរបស់អ្នកទាំងអស់ដែលអ្នកបានប្រមូលមកសំរាប់ខ្លួនអ្នក»

បានប្រមូលយកមកវិញ

«ហើយយើងបានប្រមូលមនុស្ស»

Ezekiel 38:10

វាបានកើតឡើងនៅថ្ងៃនោះ

«នៅក្នុងពេលនោះ»

គឺផែនការដែលមានក្នុងចិត្តរបស់អ្នក

«គំនិតនឹងចូលមកក្នុងគំនិតរបស់អ្នក»

Ezekiel 38:13

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលពីកុក

សេបា

សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២៧:២២។

ដេដាន់

សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ២៥:១២។

ហ្វូងសត្វ

ចៀម ពពែ គោ

Ezekiel 38:14

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកុក។

សង្ឃឹមថា...រៀនអំពីពួកគេ

ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីបញ្ជាក់ថាកុកពិតជានឹងដឹងអំពីប្រជាជនអ៊ីស្រាអែល។

ការបកប្រែរបៀបផ្សេងទៀត:

«នៅថ្ងៃនោះនៅពេលដែលអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងកំពុងរស់នៅដោយមានសុវត្ថិភាពអ្នកនឹងដឹ

គួរតែបានស្គាល់យើង

«ប្រហែលជាដឹងថាយើងជានរណា»

Ezekiel 38:17

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកុក។

តើអ្នកមិនមែនជាម្នាក់ដែល...ពួកគេ?

ព្រះអម្ចាស់ប្រើសំនួរនេះដើម្បីបញ្ជាក់ថាទ្រង់គឺជាអ្នកដែលនាំក្រុងកុកមកស្រុកអ៊ីស្រាអែល។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកគឺជាម្នាក់ក្នុងចំណោមពួកគេ... ពួកគេ»។

ម្នាក់ដែលយើងបាននិយាយ

«ដែលយើងបាននិយាយអំពី»

ទាស់នឹងពួកគេ

«ប្រឆាំងនឹងប្រជាជនអ៊ីស្រាអែល»

Ezekiel 38:19

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។

ភ្នំទាំងនោះនឹងត្រូវបោះចោល

«ព្រះអម្ចាស់នឹងធ្វើឲ្យភ្នំនានារលំ»។ (សូមមើល:

Ezekiel 38:21

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។

បង្អុរភ្លៀងច្រើនខ្លាំង ព្រមទាំងព្រឹលយ៉ាងធំ និងភ្លើងឆេះ ហើយស្ពាន់ធ័រមកលើគេ

«ហើយយើងនឹងបង្អុរភ្លៀងដែលកំពុងលិចដោយទឹកជំនន់ និងព្រឹល
ទាំងស្ពាន់ធ័រដែលកំពុងឆេះ»

ព្រឹលយ៉ាងធំ

ទឹកកកដែលធ្លាក់ពីលើមេឃ

ស្ពាន់ធ័រ

«ស្ពាន់ធ័រ»

តាំងខ្លួនយើងជាបរិសុទ្ធ

«បង្ហាញថាយើងអស្ចារ្យ និងបរិសុទ្ធ»

generated on Wed Sep 10 16:16:32 2025

39 [1]«ដូច្នេះអ្នក កូនមនុស្សអើយ ចូរថ្លែងព្រះបន្ទូលទាស់នឹងកុក ហើយប្រាប់ថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ មើល៍! យើងទាស់នឹងអ្នក កុក ជាអ្នកដឹកនាំនៃ
ពួកមេសេក ហើយពួកទូបាលអើយ។[2]យើងនឹងធ្វើឲ្យអ្នកបែរមក ហើយនាំអ្នកទៅមុខ ក៏នឹងបណ្តាលឲ្យអ្នកឡើងមកពីទឹកដីខាងជើងបំផុត ព្រមទាំងនាំអ្នកមកលើភ្នំ
ទាំងប៉ុន្មានរបស់ទឹកដីអ៊ីស្រាអែល។[3]ហើយយើងនឹងវាយបំបាកធ្នូចេញពីដៃឆ្វេងរបស់អ្នក ហើយនឹងធ្វើឲ្យព្រួញធ្លាក់ចេញពីដៃស្តាំអ្នក។
[4]អ្នកនឹងដួលស្លាប់លើភ្នំរបស់អ៊ីស្រាអែល គឺទាំងអ្នក និងពួកគ្នារបស់អ្នក ហើយជនជាតិទាំងប៉ុន្មានដែលនៅជាមួយផង យើងនឹងប្រគល់អ្នកដល់សត្វហើរផ្សេងៗដែលស៊ី
គំរង ហើយដល់សត្វព្រៃឲ្យវាស៊ីទៅ។[5]អ្នកនឹងដួលស្លាប់ទីវាលទទេ ដ្បិតយើងបានប្រកាសហើយ នោះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។[6]ក្រោយមក យើងនឹងចាត់ភ្លើង
ទៅលើទឹកដីម៉ាកុក ហើយលើពួកអ្នកដែលអាស្រ័យនៅ ដោយសុខសាន្តនៅកោះទាំងឡាយ នោះគេនឹងដឹងថា យើងនេះជាព្រះអម្ចាស់។
[7]ដ្បិតយើងនឹងធ្វើឲ្យឈ្មោះយើងបានបរិសុទ្ធ នៅកណ្តាលប្រជាជនអ៊ីស្រាអែលរបស់យើង ហើយមិនឲ្យឈ្មោះបរិសុទ្ធរបស់យើងត្រូវប្រមាថ ជនជាតិនានានឹងដឹងថា យើង
ជាព្រះអម្ចាស់គឺជាព្រះដ៏បរិសុទ្ធនៅក្នុងអ៊ីស្រាអែល។[8]ចូរមើល៍! ថ្ងៃនោះកំពុងតែមកដល់ ហើយនឹងហើយនឹងជំនួសអ្វីនៅពេលនេះផង
នេះគឺជាព្រះបន្ទូលព្រះអម្ចាស់ដ៏ជាព្រះ។
[9]ពួកអ្នកដែលរស់នៅក្នុងទីក្រុងរបស់អ៊ីស្រាអែល នឹងចាកចេញទៅ ហើយពួកគេនឹងប្រើគ្រឿងសស្ត្រាវុធដើម្បីបង្កាត់ភ្លើង ហើយដុតឆេះរួចដុតចោល ទាំងខែលតូច ខែលធំ
ទាំងធ្នូ និងព្រួញ ដែកពួយ និងលំពែងផង គេនឹងដុតគ្រឿងទាំងនោះអស់ប្រាំពីរឆ្នាំ។[10]ពួកគេមិនត្រូវការរើសរកាច់ឈើនៅទីវាល ឬកាប់ឧសនៅក្នុងព្រៃឡើយ តាំងពីគេ
បានដុតគ្រឿងសស្ត្រាវុធ ពួកគេនឹងយកពីពួកអ្នកដែលបានយកពីខ្លួនមកវិញពីពួកគេ ពួកគេប្លន់ពីពួកអ្នកដែលបានប្លន់ពីខ្លួនដែរ នេះជាព្រះបន្ទូលនៃ
ព្រះអម្ចាស់ដ៏ជាព្រះ»។
[11]ក្រោយមកវានឹងកើតឡើងនៅថ្ងៃនោះដែល យើងនឹងធ្វើកន្លែងមួយសម្រាប់ពួកកុក សម្រាប់ជាទីបញ្ចុះសពក្នុងអ៊ីស្រាអែល នឹងជ្រលងភ្នំរបស់អ្នកដំណើរខាងកើត
សមុទ្រ។ វាបានបិទបាំងអស់អ្នកដែលចង់ធ្វើដំណើរឆ្លងកាត់។ ពួកគេនឹងកប់សាកសពពួកកុកនៅទីនោះ ជាមួយប្រជាជនរបស់គាត់។ ពួកគេនឹងហៅជ្រលងភ្នំរបស់ហាមុន
កុក។
[12]ដ្បិតប្រាំពីរខែដែលកូនចៅអ៊ីស្រាអែលនឹងបញ្ចុះសពពួកគេ ទើបបានហើយ ដើម្បីនឹងសម្អាតទឹកដី។[13]ដ្បិតមនុស្សទាំងអស់នៅទឹកដីនោះនឹងធ្វើការបញ្ចុះសពពួកគេ
ហើយការនោះនឹងល្បីដល់គេ ក្នុងថ្ងៃដែលយើងបានតម្កើងឡើង នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[14]ក្រោយមក ពួកគេនឹងតម្រូវទុកមនុស្សមួយក្រុម បន្តធ្វើដំណើរកាត់ទឹកដីនោះ ដើម្បីទៅរកអ្នកដែលបានឆ្លងកាត់ពីមុនប៉ុន្តែអ្នកបានស្លាប់ហើយសពនៅសេសសល់លើ
ទឹកដី ដូច្នោះពួកគេនឹងបានបញ្ចុះសពទាំងនោះ ដើម្បីសម្អាតទឹកដី។ ក្រោយចប់ប្រាំពីរខែនោះមក ពួកគេនឹងដើរពិនិត្យមើល។[15]រួចមនុស្សដែលដើរកាត់ទឹកដី ពួកគេ
នឹងនឹងឃើញឆ្អឹង ពួកគេនឹងតាំងទីសម្គាល់មួយនៅជិតវា ទាល់តែពួកបញ្ចុះសពបានមកកប់ចោល នៅក្នុងច្រកភ្នំហាមុន កុក។[16]នៅទីនោះមានទីក្រុងមួយដែលមានឈ្មោះ
ហៅថា ហាម៉ូណា។ ក្នុងការនេះពួកគេនឹងសម្អាតទឹកដីបាន។
[17]ឥឡូវដល់អ្នកវិញ កូនមនុស្សអើយ ព្រះអម្ចាស់អម្ចាស់មានព្រះបន្ទូលដូច្នេះ ចូរនិយាយទៅសត្វស្លាបគ្រប់យ៉ាង និងដល់អស់ទាំងសត្វព្រៃនៅទីវាល ចូរន្រមូលគ្នាមក។ ចូរ
ប្រជុំគ្នាពីគ្រប់ទីកន្លែង ទៅទីយញ្ញបូជារបស់យើង ដែលយើងធ្វើសម្រាប់អ្នក ជាយញ្ញបូជាយ៉ាងធំ នៅលើភ្នំរបស់អ៊ីស្រាអែល ដូច្នោះឲ្យអ្នកបានស៊ីសាច់ ហើយផឹកឈាម។
[18]អ្នកនឹងស៊ីសាច់របស់អ្នកចម្បាំង ហើយផឹកឈាមរបស់ពួកអ្នកដឹកនាំនៅផែនដី ទាំងចៀមឈ្មោល កូនចៀម ពពែ និងគោផង សុទ្ធតែជាសត្វបំប៉នពីទឹកដីបាសាន។
[19]រួចហើយអ្នករាល់គ្នានឹងស៊ីខ្លាញ់ទាល់តែឆ្អែត ហើយអ្នកនឹងផឹកឈាម ទាល់តែស្រវឹង ដោយសារយញ្ញបូជា ដែលយើងធ្វើសម្រាប់អ្នក។[20]អ្នករាល់គ្នានឹងបានឆ្អែតនៅតុ
យើងដោយសាច់សេះ រទេះចម្បាំង ពួកអ្នកចម្បាំង និងពួកទាហានទាំងប៉ុន្មានដែរ នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[21]យើងនឹងតាំងសិរីល្អរបស់យើង ក្នុងចំណោមជនជាតិហើយអស់ទាំងជនជាតិនឹងឃើញការដាក់ទោសរបស់យើង ដែលយើងបានធ្វើ ហើយដៃរបស់យើងដែលបាន
ដាក់ទាស់នឹងពួកគេ។[22]កូនចៅអ៊ីស្រាអែលនឹងបានដឹងថា យើងនេះជាព្រះអម្ចាស់ គឺជាព្រះរបស់ពួកគេ តាំងតែពីថ្ងៃនេះតទៅ។
[23]ប្រជាជាតិទាំងមូល នឹងដឹងថាកូនចៅអ៊ីស្រាអែលបានចាប់យកទៅជាឈ្លើយ ដោយព្រោះអំពើទុច្ចរិតរបស់ពួកគេ ដោយសារពួកគេក្បត់នឹងយើង ដូច្នោះយើងបានបាំង
មុខពីពួកគេ បានជាយើងប្រគល់គេ ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវរបស់គេ ហើយពួកគេត្រូវដួលដោយដាវ។[24]យើងបានធ្វើដល់ពួកគេតាមសេចក្តីស្មោកគ្រោក
និងបាបរបស់ពួកគេ ពេលយើងបានបាំងចេញពីពួកគេ។
[25]ដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ឥឡូវនេះ យើងនឹងកសាងវាសនាពួកយ៉ាកុប ហើយយើងនឹងមានសេចក្តីមេត្តាដល់កូនចៅសអ៊ីស្រាអែល ហើយ
ធ្វើការខ្នះខ្នែង សម្រាប់ឈ្មោះបរិសុទ្ធរបស់យើង។[26]រួចហើយពួកគេនឹងរងការអាម៉ាស់ និងគ្រប់ទាំងអំពើក្បត់ដែលពួកគេបានមិនស្មោះនឹងយើង។ ពួកគេ
នឹងភ្លេចគ្រប់ការទាំងនេះពេលពួកគេសម្រាក់ដោយសុខសាន្តក្នុងទឹកដីរបស់គេ។[27]ពេលយើងស្តាគេឡើងវិញរួចពីមនុស្ស ហើយប្រមូលពួកគេពីទឹកដីផ្សេងៗចេញពីដៃខ្មាំង
សត្រូវរបស់ពួកគេ យើងនឹងបង្ហាញខ្លួនយើងថាបរិសុទ្ធ នៅក្នុងភ្នែកជនជាតិជាច្រើន។
[28]រួចហើយគេនឹងដឹងថា យើងគឺជាព្រះជាម្ចាស់ ដ្បិតយើងបានបញ្ជូនពួកគេទៅជាឈ្លើយ ក្នុងចំណោមជនជាតិទាំងនោះ ប៉ុន្តែយើងប្រមូលគេត្រឡប់មកវិញ ទៅក្នុងទឹកដី
របស់គេវិញ។ យើងមិនបានទុកពួកគេខ្លះក្នុងចំណោមជនជាតិទាំងនោះឡើយ។[29]យើងនឹងមិនលាក់មុខពីពួកគេទៀតដែរ ពេលយើងចាក់វិញ្ញាណយើងចេញទៅលើកូនចៅ
អ៊ីស្រាអែល នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 39:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកុក។
មើល៍!
ការបកប្រែជំនួស៖ «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
ដឹកនាំនៃពួកមេសេក ហើយពួកទូបាល
ឃ្លានេះកើតឡើងពីរដងនៅក្នុងខទាំងនេះ។
ទោះយ៉ាងណាកំណែសម័យថ្មីខ្លះបកប្រែការបកស្រាយភាសាហេព្រើរថាជា
«ព្រះអម្ចាស់របស់រ៉ូស មេសេក និង ទូបាល»
យើងនឹងវាយបំបាកធ្នូចេញពីដៃឆ្វេងរបស់អ្នក ហើយនឹងធ្វើឲ្យព្រួញធ្លាក់ចេញពីដៃស្តាំអ្នក
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបំផ្លាញអំណាចយោធារបស់អ្នក»។
Ezekiel 39:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកុក។
ម៉ាកុក
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣៨:១។
គេនឹងដឹងថា យើងនេះជាព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៦:៦។
Ezekiel 39:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកុក។
យើងនឹងធ្វើឲ្យឈ្មោះយើងបានបរិសុទ្ធ នៅកណ្តាលប្រជាជនអ៊ីស្រាអែលរបស់យើង
ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងធ្វើអោយប្រជាជនអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងស្គាល់ព្រះនាមដ៏វិសុទ្ធរបស់យើង»
។
ប្រជាជនអ៊ីស្រាអែលនឹងមានការយល់ដឹងកាន់តែច្បាស់អំពីចរិតលក្ខណៈរបស់ព្រះអម្ចាស់។
មើល៍!
ការបកប្រែជំនួស៖ «មើល!» ឬ «ស្តាប់!» ឬ
«យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក!»
Ezekiel 39:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។
ដែកពួយ
ដំបងឈើប្រើជាអាវុធ
បានប្លន់

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលបានបកប្រែ «ប្លន់» នៅក្នុងជំពូក ២៣:៤៦។
Ezekiel 39:11
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។
វានឹងកើតឡើង....ដែល
សញ្ញាសម្គាល់ព្រឹត្តិការណ៍សំខាន់មួយ។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់កំណត់ដូចនេះអ្នកអាចប្រើវានៅទីនេះ។
សមុទ្រខាងកើត
សំណៅសម័យថ្មីមួយចំនួនបកស្រាយឃ្លាភាសា ហេព្រើរនៅទីនេះថា
«ខាងកើតឆ្ពោះទៅសមុទ្រ»។
វាបានបិទបាំង
អត្ថន័យដែលអាចមានគឺ ១) «ផ្នូរនឹងរាំងខ្ទប់» ឬ ២) «កងទ័ពស្លាប់ នឹងរារាំង»
ពួកគេនឹង
«មានពូជវង្សអ៊ីស្រាអែល»
ពួកគេនឹងហៅ
«មនុស្សនឹងហៅវា»
ជ្រលងភ្នំរបស់ហាមុន កុក
ជ្រលងភ្នំនៃកងទ័ពដ៏អស្ចារ្យនៃកុក
Ezekiel 39:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។
ប្រាំពីរខែ
«ប្រាំពីរខែ»
បញ្ចុះសពពួកគេ
«កប់ប្រជាជនរបស់កងទ័ពកុក»
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៥:១១។
Ezekiel 39:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។
ប្រាំពីរខែ
ដើរកាត់ទឹកដី
«ឆ្លងកាត់ទឹកដីអ៊ីស្រាអែល»
ហាម៉ូណា
ឈ្មោះនេះមានន័យថា «កងទ័ពដ៏អស្ចារ្យ»។
Ezekiel 39:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅបក្សាបក្សី និងសត្វព្រៃ។
ទីយញ្ញបូជា
«ទៅបុណ្យ» ឬ «ដើម្បីសំលាប់»។
ព្រះអម្ចាស់មានន័យថាព្រះអង្គនឹងឲ្យបក្សីនិងសត្វមានអាហារបរិភោគដ៏ឆ្ងាញ់ហើយមិនអាចឆ្អែតឆ្អន់បាន។
សុទ្ធតែជាសត្វបំប៉នពីទឹកដីបាសាន
ការបកប្រែរបៀបផ្សេងទៀត:
ពួកគេទាំងអស់បានធាត់នៅពេលកំពុងស៊ីស្មៅនៅបាសាន។
Ezekiel 39:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅបក្សាបក្សី និងសត្វព្រៃ។
រទេះចម្បាំង
ការបកប្រែរបៀបផ្សេងទៀត: «បុរសដែលជិះរទេះសេះ»។
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 39:21
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។
យើងនឹងតាំងសិរីល្អរបស់យើង ក្នុងចំណោមជនជាតិ
«យើងនឹងធ្វើអោយប្រជាជាតិនានាឃើញសិរីរុងរឿងរបស់យើង»
ការដាក់ទោសរបស់យើង ដែលយើងបានធ្វើ ហើយដៃរបស់យើងដែលបានដាក់ទាស់នឹងពួកគេ។
ឃ្លាទាំងពីរនេះសំដៅទៅលើការដាក់ទណ្ឌកម្មដែលព្រះអម្ចាស់នឹងដាក់ទោសលើអ៊ីស្រាអែល។
ដៃរបស់យើង
ពាក្យថា« ដៃ»
នៅទីនេះសំដៅទៅលើឫទ្ធានុភាពរបស់ព្រះអម្ចាស់ដែលព្រះអង្គប្រើដើម្បីដាក់ទោស។
ដាក់ទាស់នឹងពួកគេ
«ប្រឆាំងនឹងប្រជាជននៃកងទ័ពដ៏អស្ចារ្យរបស់កុក»
Ezekiel 39:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីកុក។
យើងបានបាំងមុខ
«យើងឈប់ការពារពួកគេ ហើយថែរក្សាពួកគេទៀតឡើយ»។
ដួលដោយដាវ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣២:២២។
Ezekiel 39:25
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីពូជវង្សអ៊ីស្រាអែល។
យើងនឹងកសាងវាសនាពួកយ៉ាកុប
សូមមើលពីរបៀបដែលបានបកប្រែ «នឹងស្តារសំណាងរបស់ពួកគេឡើងវិញ«
នៅក្នុងជំពូក ១៦:៥៣។
ទោះយ៉ាងណាក៏ដោយកំណែទំនើបខ្លះបកប្រែឃ្លាភាសាហេព្រើរនៅទីនេះថា
«នឹងនាំយ៉ាកុបពីការជាប់ជាឈ្លើយ»។
អំពើក្បត់
«ភាពមិនស្មោះត្រង់»
យើងនឹងបង្ហាញខ្លួនយើងថាបរិសុទ្ធ នៅក្នុងភ្នែកជនជាតិជាច្រើន
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជាតិជាច្រើននឹងយល់ថាយើងជាមនុស្សបរិសុទ្ធដោយសារអ្វីដែលបានធ្វើសម្រាប់កូនចៅអ៊ីស្រាអែ
Ezekiel 39:28
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តលោកអេសេគាលថ្លែងសាររបស់ព្រះអង្គអំពីពូជវង្សអ៊ីស្រាអែល។
ពេលយើងចាក់វិញ្ញាណយើងចេញទៅលើកូនចៅអ៊ីស្រាអែល
«នៅពេលដែលយើងបំពេញវង្សអ៊ីស្រាអែលពោរពេញទៅដោយព្រះវិញ្ញាណរបស់យើង»

---

40 [1]នៅក្នុងឆ្នាំទីម្ភៃប្រាំ នៃការជាប់ជាឈ្លើយនៅដើមឆ្នាំ នៅថ្ងៃទីដប់ នៃខែនោះ នៅក្នុងឆ្នាំទីដប់បួន ក្រោយពីទីក្រុងត្រូវគេវាយយក នៅថ្ងៃនោះ ព្រះហស្តនៃព្រះអម្ចាស់
បានដាក់នៅលើខ្ញុំ ហើយព្រះអង្គនាំខ្ញុំទៅទីនោះ។[2]ក្នុងនិមិត្តពីព្រះជាម្ចាស់ ព្រះអង្គបាននាំខ្ញុំមកដល់ទឹកដីអ៊ីស្រាអែលវិញ។ ព្រះអង្គបាននាំខ្ញុំឲ្យបានសម្រាកលើភ្នំ
មួយយ៉ាងខ្ពស់ នៅទិសខាងត្បូងមានអ្វីមួយបានលេចមកក្នុងអាគានៃទីក្រុង។
[3]ហើយព្រះអង្គនាំខ្ញុំទៅទីនោះ។ ចូរមើល៍ មានមនុស្សម្នាក់! រូបរាងរបស់លោកដូចជាលក្ខណៈជាលង្ហិន។ មានខ្សែខ្លូតទេស និងបបុសសម្រាប់វាស់នៅនិងដៃរបស់គាត់
លោកឈរនៅក្នុងទ្វារក្រុង។[4]មនុស្សនោះក៏និយាយមកខ្ញុំថា «កូនមនុស្សអើយ ចូរមើលដោយភ្នែក ហើយស្តាប់ដោយត្រចៀករបស់អ្នក រួចយកចិត្តទុកដាក់គ្រប់ទាំងអស់
ដែលយើងបង្ហាញដល់អ្នក ដ្បិតបាននាំអ្នកមកនៅទីនេះ ប្រយោជន៍ឲ្យយើងបានបង្ហាញទាំងអស់នេះដល់អ្នក។ ចូរប្រាប់ការទាំងអស់ដែលអ្នកនឹងឃើញដល់កូនចៅ
អ៊ីស្រាអែលផង»។
[5]នៅទីនោះមានកំពែងបានសង់ជុំវិញព្រះវិហារ។ ប្រវែងឈើសម្រាប់វាស់នៅក្នុងដៃរបស់បុរសនោះ មានប្រាំមួយហត្ថ ដែលក្នុងមួយហត្ថនោះ ត្រូវជាមួយហត្ថមួយ
កំណាត់ដៃប្រវែង។ បុរសនោះ ក៏បានវាស់កំពែង វាមានមួយខ្នាតនៃឈើវាស់ ហើយកម្ពស់របស់ក៏មួយខ្នាតមានឈើដែរ។[6]បន្ទាប់មក លោកទៅដល់ទ្វារព្រះវិហារ ដែល
បែបមុខទៅទិសខាងកើត។ លោកក៏ឡើងជណ្តើរទៅទ្វារនោះ ទៅវាស់ទទឹងមាត់ទ្វារបានមួយខ្នាត ហើយទទឹងមួយទៀត ក៏បានមួយខ្នាត ជម្រៅដូចគ្នា។[7]គ្រប់បន្ទប់ចាំយាម
មានបណ្តោយមួយខ្នាតឈើ និងទទឹងមួយខ្នាតឈើ ចំណែកប្រឡោះកណ្តាលបន្ទប់ចាំយាមទាំងនោះ មានប្រាំហត្ថឈើ កម្រិតពន្លឺមាត់ទ្វារព្រះវិហារ
តាមរយៈដំបូលផ្លូវដើរនៃព្រះវិហារគឺមានមួយឈើជម្រៅ។

generated on Wed Sep 10 16:16:32 2025

[8]លោកវាស់ដំបូលផ្លូវដើរ នៃខ្លោងទ្វារ វាមានប្រវែងមួយឈើរង្វាស់។[9]លោកបានវាស់ដំបូលផ្លូវដើរនៃខ្លោងទ្វារនោះ។ វាមានមួយឈើជម្រៅ។
ហើយក្របទ្វារមានពីរហត្ថក្នុងប្រវែងទទឹង។ ហើយដំបូលផ្លូវដើរនៃខ្លោងទ្វារនោះបែរមុខទៅរកព្រះវិហារ។[10]មានចំនួនបន្ទប់យាមបីនៅសងខាងនៃខ្លោងទ្វារ
ហើយបន្ទប់នីមួយមានទំហំដូចគ្នា ហើយរបងខណ្ឌបន្ទប់ទាំងនោះមានកម្ពស់ដូចគ្នា។
[11]ក្រោយមក បុរសនោះបានវាស់ទទឹងខ្លោងទ្វារផ្លូវចូល មានប្រវែងដប់ហត្ថ ហើយលោកបានវាស់ប្រវែងច្រកចូលមានដប់បីហត្ថ។[12]លោកបានរបងដែលជាព្រំខាងមុខ
បន្ទប់ទាំងនោះមានប្រវែងមួយហត្ថ។ ហើយបានវាស់បន្ទប់មានប្រវែងប្រាំមួយហត្ថនៃជ្រុងម្ខាងៗ។[13]រួចហើយលោកវាស់
ច្រកចូលតាំងពីដំបូលនៃបន្ទប់ទៅរបស់បន្ទប់មួយទៀត មានម្ភៃប្រាំហត្ថ ចាប់តាំងពីច្រកចូលនៃបន្ទប់ទីមួយទៅដល់នៃបន្ទប់ទីពីរ។
[14]រួចហើយលោកក៏វាស់ជញ្ជាំងដែលនៅរវាងបន្ទប់យាម មានក្នុងប្រវែងហុកសិបហត្ថ លោកបានវាស់កាន់តែឆ្ងាយដែលអាចធ្វើបានពីដំបូលផ្លូវដើរ។[15]តាំង
ពីច្រកចូលខាងមុខដល់ចុងបំផុតម្ខាងទៀតនៃដំបូលផ្លូវដើរ មានហាសិបហត្ថ។[16]មានបិទបង្ហួចជិត ឆ្ពោះទៅដល់បន្ទប់ហើយក៏សំដៅទៅសសររបស់វា នៅក្នុងខ្លោងទ្វារព័ទ្ធ
ជុំវិញ ហើយមានបាំងសាចដូច្នោះដែរ។ ហើយមានបង្ហួចនៅព័ទ្ធជុំវិញនៅផ្នែកខាងក្នុង ហើយនិងមេបង្ហួចមានឆ្លាក់រូបដើមលម៉ើ។
[17]រួចហើយ បុរសនោះបាននាំខ្ញុំទៅទីលានខាងក្រៅនៃព្រះវិហារ។ ចូរមើល! នៅទីនោះមានបន្ទប់ ហើយមានក្រាលថ្មនៅទីលាន ជាមួយសាមសិបបន្ទប់
ដែលបានក្បែរនឹងក្រាលថ្ម។[18]កម្រាលថ្មស្ថិតនៅជាប់ខ្លោងទ្វារ ហើយមានទទឹងស្មើនឹងប្រវែងរបស់ខ្លោងទ្វារ។ កម្រាលថ្មនេះមានកម្ពស់ទាបជាង។[19]រួចហើយ
បុរសនោះបានវាស់ពីពីចំងាយពីខាងមុខ នៃខ្លោងទ្វារទាប ទៅដល់បរិវេនខ្លោងទ្វារខាងក្នុង គឺមានមានប្រវែងមួយរយហត្ថ នៅទិសខាងកើត រហូតដល់ទិសខាងជើង។
[20]រួចហើយលោកបានវាស់បណ្តោយ និងទទឹងរបស់ខ្លោងទ្វារដែលនៅខាងជើងនៃទីជំនុំចម្រុះក្តីខាងក្រៅ។[21]មានបន្ទប់បី នៃម្ខាងៗរបស់ខ្លោងទ្វារ ហើយខ្លោងទ្វារ
ហើយនិងដំបូលផ្លូវដើរ មានទំហំដូចគ្នាទៅនិងខ្លោងទ្វារធំ គឺបណ្តោយហាសិបហត្ថ និងទទឹងម្ភៃប្រាំហត្ថ។
[22]ចំណែកបង្ហួច ដំបូលផ្លូវដើរ បន្ទប់ និងដើមលម៉ើ មានដូច ជានិងដូចខ្លោងទ្វារដែលបែរមុខទៅទិសខាងកើត។ ជណ្តើរដែលឡើងទៅខ្លោងទ្វារមានប្រាំពីរកាំ
ហើយទៅដំបូលផ្លូវដើរ។[23]មានខ្លោងទ្វារទីលានខាងក្នុង នៅខាងមុខខ្លោងទ្វារបែរមុខខាងជើង ហើយវាក៏មានខ្លោងទ្វារខាងកើត លោកវាស់ពីខ្លោងទ្វារមួយទៅខ្លោងទ្វារ
មួយទៀត ឃើញមានប្រវែងមួយរយហត្ថ។
[24]បន្ទាប់មក បុរសនោះនាំខ្ញុំទៅខ្លោងទ្វារទិសខាងត្បូង ច្រកផ្លូវ ហើយជញ្ជាំងរបស់វា ហើយដំបូលផ្លូវដើរ លោកវាស់មាន ទំហំដូចគ្នានិងខ្លោងទ្វារខាងក្រៅផ្សេងទៀត។
[25]មានបង្ហួចបិតនៅក្នុងផ្លូវចូលហើយដំបូលផ្លូវដើររបស់វា ក៏ដូចខ្លោងទ្វារនោះដែរ។ ខ្លោងទ្វារខាងជើង ហើយដំបូលផ្លូវដើររបស់វា
មានបណ្តោយហាសិបហត្ថនិងទទឹងមានម្ភៃប្រាំហត្ថ។
[26]មានជណ្តើរដែលឡើងទៅខ្លោងទ្វារមានប្រាំពីរកាំ ហើយដំបូលផ្លូវដើររបស់វា មានឆ្លាក់ក្បាច់ដើមចាកលើជញ្ជាំងនៅសងខាង។[27]ទីលានខាងក្នុងក៏មានខ្លោងទ្វារមួយនៅ
ខាងត្បូង ហើយលោកវាស់ពីខ្លោងទ្វារមួយទៅខ្លោងទ្វារមួយទៀត នៅខាងត្បូងនៅច្រកផ្លូវចូលមានប្រវែងមួយរយហត្ថ ដែលនៅពីចំងាយ។
[28]ហើយបន្ទាប់មក បុរសនោះក៏បាននាំខ្ញុំចូលទៅទីលានខាងក្នុង តាមខ្លោងទ្វារដែលនៅទិសខាងត្បូង ដែលមានទំហំដូចទៅនិងខ្លោងទ្វារម្ខាងទៀត។[29]ហើយបន្ទប់ ជញ្ជាំង
និងដំបូលផ្លូវដើរ ក៏មានទំហំដូចគ្នា ខ្លោងទ្វារផ្សេងទៀងដែរ ហើយដំបូលផ្លូវដើរ គឺមានបង្ហួចនៅជុំវិញទាំងអស់។ ហើយខ្លោងទ្វារខាងក្នុងហើយនិងដំបូលផ្លូវដើរ មាន
បណ្តោយហាសិបហត្ថ ទទឹងម្ភៃប្រាំហត្ថ។[30]ដំបូលផ្លូវដើរ ដែលនៅជំវិញជញ្ជាំងខាងក្នុងមានបណ្តោយម្ភៃប្រាំហត្ថ និងទទឹងប្រាំហត្ថ។[31]ដំបូលផ្លូវដើរបែរមុខទៅនឹងទីលាន
ខាងក្រៅ ដែលលើជញ្ជាំងមានឆ្លាក់ក្បាច់ដើមចាក ហើយមានជណ្តើរដែលឡើងទៅខាងលើ។
[32]ហើយក្រោយមក លោកបាននាំខ្ញុំចូលទៅទីលានខាងក្នុង តាមខ្លោងទ្វារខាងកើត ដែលលោកវាស់ខ្លោងទ្វារមានទំហំដូចគ្នា។[33]បន្ទប់ទាំងនោះ ជញ្ជាំង និងដំបូលផ្លូវដើរ ក៏
មានទំហំដូចគ្នាដែរ ខ្លោងទ្វារ ហើយមានបង្ហួចជុំវិញ។ ខ្លោងទ្វារខាងក្នុងហើយដំបូលផ្លូវដើរ មានបណ្តោយហាសិបហត្ថ ទទឹងម្ភៃប្រាំហត្ថ។[34]ដំបូលផ្លូវដើរបែរមុខទៅនឹង
ទីលានខាងក្រៅ វាមានឆ្លាក់ក្បាច់ដើមចាកលើសងខាងវា ហើយមានជណ្តើរប្រាំបីកាំដែលឡើងទៅលើ។
[35]បន្ទាប់មក លោកក៏បាននាំខ្ញុំទៅខ្លោងទ្វារខាងជើង ហើយធ្វើការវាស់ខ្លោងទ្វារឃើញមានទំហំដូចគ្នាទៅនិងខ្លោងទ្វារផ្សេង។[36]ចំណែកបន្ទប់ទាំងនោះ ជញ្ជាំង និង
ដំបូលផ្លូវដើរ មានទំហំដូចគ្នានិងខ្លោងទ្វារផ្សេងដែរ ហើយមានបង្ហួចជុំវិញ។ ច្រកផ្លូវចូល ហើយដំបូលផ្លូវដើរមានបណ្តោយហាសិបហត្ថ ទទឹងម្ភៃប្រាំហត្ថ។[37]
ដំបូលផ្លូវដើរបែរមុខនឹងទីលានខាងក្រៅ មានឆ្លាក់ក្បាច់ដើមចាកទាំងសងខាងលើវា ហើយមានជណ្តើរប្រាំឡើងទៅខាងលើ។
[38]មានបន្ទប់មួយដែលមានទ្វារនៅតាមផ្លូវច្រកចូលទៅខាងក្នុង។ កន្លែងដែលគេលាងជំរះតង្វាយដុត។[39]មានតុពីរនៅនៅសងខាងនៃដំបូលផ្លូវដើរ សម្រាប់ថ្វាយជាតង្វាយ
ដុត ដែលបានសម្លាប់រួចហើយ និងយញ្ញបូជាសុំឲ្យរួចពីបាប និងយញ្ញបូជាសុំលើកលែងទោស។
[40]តាមជញ្ជាំងនៃទីធ្លា ទៅដល់ខ្លោងទ្វារខាងជើង មានតុពីរ។ ហើយនៅម្ខាងទៀត នៅនោះមានតុពីរដែរខ្លោងទ្វារដំបូលផ្លូវដេើរ។[41]មានតុបួន នៅម្ខាងតាមខ្លោងទ្វារ ពួកគេ
ធ្វើការសម្លាប់សត្វ នៅលើតុទាំងប្រាំបី។
[42]មានតុបួនទៀតដែលធ្វើពីថ្មាំងថ្ម សម្រាប់ធ្វើពិធីយញ្ញបូជា មានបណ្តោយមួយហត្ថកន្លះ ទទឹងមួយហត្ថកន្លះ និងកម្ពស់មួយហត្ថ។ នៅលើតុទាំងនោះពួកគេបានដាក់
ឧបករណ៍សម្រាប់អារ កសត្វថ្វាយតង្វាយដុត និងថ្វាយយញ្ញបូជាផង។[43]មានទំពក់ពីរ ចងទទឹងនិងឈើតាមបណ្តោយចងយ៉ាងជាប់ជាមួយនិងដំបូលផ្លូវដើរជុំវិញ
ហើយចំណែកឯសាច់សម្រាប់ធ្វើយញ្ញបូជា ពួកគេបានដាក់នៅលើតុ។
[44]ជិតខ្លោងទ្វារខាងក្នុង នៅទីធ្លាខាងក្នុង មានបន្ទប់សម្រាប់អ្នកចម្រៀង។ បន្ទប់មួយក្នុងចំណោមនោះនៅខាងជើង ហើយមួយទៀតខាងត្បូង។[45]លោកប្រាប់ខ្ញុំថា៖ «បន្ទប់
បែរមុខទៅទិសខាងត្បូង សម្រាប់ពួកបូជាចារ្យដែលបំពេញការងារក្នុងព្រះដំណាក់។
[46]បន្ទប់បែរមុខទៅទិសខាងជើង សម្រាប់ពួកបូជាចារ្យដែលបំពេញការងារនៅទីអាសនៈ។ អ្នកទាំងនោះជាកូនចៅរបស់លោកសាដុក ក្នុងកុលសម្ព័ន្ធលេវី»។[47]បន្ទាប់មក
លោកវាស់ទីធ្លាដែលមានរាងបួនជ្រុងស្មើ បណ្តោយមានប្រវែងមួយរយហត្ថ និងទទឹងមានមួយហត្ថ ជាមួយនិងអាសនៈស្ថិតនៅមុខនៃព្រះដំណាក់។
[48]បន្ទាប់មកបុរសនោះនាំខ្ញុំចូលទៅក្នុងដំបូលផ្លូវដើរនៃព្រះដំណាក់ហើយ លោកវាស់ក្របទ្វាររបស់វា ដែលមានប្រវែងប្រាំហត្ថ ក្រាស់ទាំងសងខាង។ ផ្លូវចូលរបស់វាមាន
ទទឹងដប់បួនហត្ថ ហើយជញ្ជាំងសងខាងរបស់វាមាន ប្រវែងបីហត្ថ។[49]បណ្តោយដំបូលផ្លូវដើរមានម្ភៃហត្ថ និងទទឹងដប់មួយហត្ថ។ មានជណ្តើរឡើងទៅកាន់បន្ទប់ ហើយ
មានសសរ គឺម្ខាងៗមានបង្គោលមួយផងដែរ។

Ezekiel 40:1

នៅក្នុងឆ្នាំទីម្ភៃប្រាំ ... ឆ្នាំទីដប់បួន
ឆ្នាំទី ៥ ... ឆ្នាំទី១៤ -
ការជាប់ជាឈ្លើយ
ពាក្យថា «របស់យើង» នៅទីនេះសំដៅទៅលើលោកអេសេគាល
និងអ៊ីស្រាអែលដែលធ្លាប់នៅក្នុងបាប៊ីឡូនចាប់តាំងពីស្តេច
យេហូយ៉ាគីមចាកចេញពីយេរូសាឡិម។ ការបកប្រែរបៀបផ្សេងទៀត:
«បន្ទាប់ពីយើងបានក្លាយជាឈ្លើយសឹក» ឬ «បន្ទាប់ពីពួក
បាប៊ីឡូនបានយកយើងធ្វើជាឈ្លើយទៅបាប៊ីឡូន»។
នៅដើមឆ្នាំ នៅថ្ងៃទីដប់ នៃខែនោះ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។ ថ្ងៃទី ១០
គឺនៅខែមេសាតាមប្រតិទិនលោកខាងលិច។
ទីក្រុងត្រូវគេវាយយក
ការបកប្រែរបៀបផ្សេងទៀត: «ពួកបាប៊ីឡូនបានកាន់កាប់ទីក្រុងយេរូសាឡិម»
ព្រះហស្តនៃព្រះអម្ចាស់
សូមមើលពីរបៀបដែលអ្នកបកប្រែ «ព្រះហស្តនៃព្រះអម្ចាស់» នៅក្នុងជំពូក ១: ១។
ព្រះអង្គបាននាំខ្ញុំឲ្យបានសម្រាក
«ព្រអង្គបានដាក់យើងចុះ»

Ezekiel 40:3

ព្រះអង្គនាំខ្ញុំទៅទីនោះ
«ព្រះអម្ចាស់បាននាំយើងទៅដល់កន្លែងដែលមានអាគារ»
ចូរមើល៍

generated on Wed Sep 10 16:16:32 2025

ពាក្យថា «មើល»
នៅទីនេះបង្ហាញថាលោកអេសេគាលមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។

បុបុសសម្រាប់វាស់
«ខ្សែពួរធ្វើពីក្រណាត់»។ នេះគឺជាឧបករណ៍សម្រាប់វាស់ចម្ងាយ។

ខ្លួតទេស
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៩:១។

សម្រាប់វាស់
នេះគឺជាឧបករណ៍សម្រាប់វាស់ចម្ងាយខ្លី។

កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២:១។

រួចយកចិត្តទុកដាក់គ្រប់ទាំងអស់
«យកចិត្តទុកដាក់ចំពោះ» ឬ «គិតអំពី»។

កូនចៅអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។

Ezekiel 40:5

នៅទីនោះមានកំពែងបានសង់ជុំវិញព្រះវិហារ
«ធ្វើដំណើរជុំវិញតំបន់ប្រាសាទ»

មានប្រាំមួយហត្ថ
«ប្រាំមួយហត្ថ» នេះមានប្រវែង ៣,២ ម៉ែត្រ។

ដែលក្នុងមួយហត្ថនោះ ត្រូវជាមួយហត្ថមួយកំណាត់ដៃប្រវែង
ហត្ថវែងនីមួយៗមានប្រវែងប្រហែល ៥៤ សង់ទីម៉ែត្រ។

អ្នកអាចជ្រើសរើសមិនរួមបញ្ចូលព័ត៌មាននេះ
ប្រសិនបើអ្នកផ្តល់ការវាស់វែងបែបទំនើបជំនួសឲ្យ «ហត្ថ» ដូច UDB។

ការបកប្រែរបៀបផ្សេងទៀត:
«ទាំងនេះគឺជាបណ្តោយវែងដែលជាប្រវែងនៃមួយហត្ថធម្មតាបូកនឹងដៃ។

កំណាត់ដៃ
«ទទឹងនៃដៃ»។ នេះគឺប្រហែល ៨ សង់ទីម៉ែត្រ។

វាស់កំពែង
«តើជញ្ជាំងធំប៉ុនណា» ជញ្ជាំងគឺប្រហោងដូចអាគារ។

ឈើវាស់
«វាមានទទឹងមួយឈើ»។ នេះគឺប្រហែល ៣,២ ម៉ែត្រ។

ឈើវាស់ ហើយមួយខ្នាត
ការបកប្រែរបៀបផ្សេងទៀត: «និងមួយខ្ពស់»

ដែលបែបមុខទៅ
«ហើយគាត់បានឡើងជណ្តើរទ្វារ»

ជម្រៅដូចគ្នា
«ពីគែមខាងមុខនៃកម្រិតចាប់ផ្តើម ដល់គែមខាងក្រោយ»

គ្រប់បន្ទប់ចាំយាម
ទាំងនេះគឺជាបន្ទប់ដែលត្រូវបានសាងសង់នៅខាងក្នុងនៃច្រកទ្វារដែលឆ្មាំងបានការពារ

ប្រាំហត្ថឈើ
ប្រហែល២.៧សង់ទីម៉ែត

ប្រឡោះកណ្តាលបន្ទប់ចាំយាមទាំងនោះ
«រវាងបន្ទប់»

ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៨:១៦។

Ezekiel 40:8

ដំបូលផ្លូវ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៨:១៦។

មួយឈើ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៤០:៥។

ពីរហត្ថ
ប្រហែលមួយម៉ែត្រ។

ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។

នោះមានកម្ពស់ដូចគ្នា
«មានទំហំដូចគ្នា»

Ezekiel 40:11

ខ្លោងទ្វារផ្លូវចូល
«ការបើកទ្វារដែលជាផ្លូវចូលខ្លោងទ្វារ»

ដប់ហត្ថ
ប្រហែល ៥,៤ ម៉ែត្រ

ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុង ៤០: ៥។

ដប់បីហត្ថ
ប្រហែល៧ ម៉ែត្រ

វាស់បន្ទប់
«ជួរភ្នំ» ឬ «បន្ទប់»

ប្រាំមួយហត្ថ
ប្រហែល ៣.២ ម៉ែត្រ

មួយហត្ថ
«៥៤ សង់ទីម៉ែត្រ» ឬ «ប្រហែលកន្លះម៉ែត្រ» (UDB)

ម្ភៃប្រាំហត្ថ
ប្រាំហត្ថ - ប្រហែល ១៣.៥ ម៉ែត្រ

នៃបន្ទប់ទីពីរ
«ច្រកចូលទីផ្សារពិសេសទី ២»

Ezekiel 40:14

បន្ទប់យាម
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤០:៥។

ហុកសិបហត្ថ
ប្រហែលសាមសិបពីរម៉ែត្រ។

ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។

ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៨:១៦។

កំណាត់ដៃ
ទោះយ៉ាងណាក៏ដោយជំនាន់ទំនើបបកប្រែពាក្យនេះតាមរបៀបផ្សេងៗគ្នា។
អត្ថន័យរបស់វាមិនច្បាស់ទេ។

ហាសិបហត្ថ
ប្រហែល ២៧ម៉ែត្រ

ឆ្ពោះទៅដល់បន្ទប់
«បំបែកភាពពិសេសរបស់អ្នកយាម»

មានបង្អួចនៅព័ទ្ធជុំវិញនៅផ្នែកខាងក្នុង
«បង្អួចនៅជុំវិញខាងក្នុង»

Ezekiel 40:17

ទីលានខាងក្រៅ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១០:៣។

ចូរមើល!
ពាក្យថា «មើល»
ខាងលើបង្ហាញយើងថាលោកអេសេគាលបានឃើញអ្វីដែលគួរឲ្យចាប់អារម្មណ៍។

ក្រាលថ្ម
ជាន់រាបស្មើដែលធ្វើពីថ្ម

ជាមួយសាមសិបបន្ទប់ ដែលបានក្បែរនៅលើក្រាលថ្ម
ការបកប្រែរបៀបផ្សេងទៀត: «ហើយមានសាមសិបបន្ទប់នៅជុំវិញកំរាលថ្ម»។

ស្ថិតនៅជាប់
«បានទៅទាំងអស់ទៅ»

ប្រវែងមួយរយហត្ថ
ប្រហែលហាសិបបួនម៉ែត្រ។

ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។

Ezekiel 40:20

បន្ទប់
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៤០:៥។

ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៨:១៦។

មានទំហំដូចគ្នា
«មានរង្វាស់ដូចគ្នា»

ហាសិបហត្ថ
ប្រហែលម្ភៃប្រាំម៉ែត្រ។

ហត្ថ

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុង ៤០: ៥។
ម្ភៃប្រាំហត្ថ
ប្រាំហត្ថ - ប្រហែល ១៣.៥ ម៉ែត្រ
ខ្លោងទ្វារធំ
ក្លោងទ្វារដែលស្ថិតនៅប៉ែកខាងកើតនៃព្រះវិហារ
Ezekiel 40:22
ព័ត៌មានទូទៅ:
លោកអេសេគាលបន្តរៀបរាប់អំពីចក្ខុនិមិត្តនៃព្រះវិហារ
និងបុរសដែលមើលទៅដូចជាលង្ហិន។
ចំណែកបង្ហួច
ពាក្យថា «វា» គឺសំដៅទៅលើខ្លោងទ្វារដែលស្ថិតនៅខាងជើងទីលានខាងក្រៅ។
បន្ទប់
សូមមើលពីរបៀបដែលបានបកប្រែក្នុងជំពូក ៤០:៥។
ដូចខ្លោងទ្វារដែលបែរមុខទៅទិសខាងកើត
«គឺដូចជាអ្នកដែលនៅខ្លោងទ្វារដែលបែរមុខទៅទិសខាងកើត»
ខ្លោងទ្វារទីលានខាងក្នុង
សូមមើលពីរបៀបដែលបានបកប្រែក្នុងជំពូក ៨:១៦។
នៅខាងមុខខ្លោងទ្វារបែរមុខខាងជើង
«ឆ្លងកាត់ដោយផ្នាល់ពីខ្លោងទ្វារបែរមុខទៅខាងជើង» ឬ
«កាត់ទីធ្លាខាងក្រៅពីខ្លោងទ្វារខាងជើង» (UDB)
ហើយវាក៏មានខ្លោងទ្វារខាងកើត
«ដូចជាមានខ្លោងទ្វារមួយទៅទីធ្លាខាងក្នុងទល់មុខខ្លោងទ្វារដែលបែរមុខទៅទិសខាងកើត»
ខ្លោងទ្វារមួយទៅខ្លោងទ្វារមួយទៀត
«ពីទ្វារខាងក្រៅនៅខាងជើងទៅទ្វារខាងក្នុងនៅខាងជើង»
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ប្រវែងមួយរយហត្ថ
ប្រហែលហាសិបបួនម៉ែត្រ
Ezekiel 40:24
ដូចគ្នានិងខ្លោងទ្វារខាងក្រៅផ្សេងទៀត
«ដូចជាច្រកទ្វារខាងជើងនិងខាងកើត»
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ហាសិបហត្ថ
ប្រហែលម្ភៃប្រាំម៉ែត្រ។
ម្ភៃប្រាំហត្ថ
ប្រាំហត្ថ - ប្រហែល ១៣.៥ ម៉ែត្រ។
Ezekiel 40:26
ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ប្រវែងមួយរយហត្ថ
ប្រហែលហាសិបបួនម៉ែត្រ (សូមមើល: tran slate-bdistance)
Ezekiel 40:28
ទីលានខាងក្នុង
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
បន្ទប់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ហាសិបហត្ថ
ប្រហែល២៧ម៉ែត្រ ។
ម្ភៃប្រាំហត្ថ
ប្រាំហត្ថ - ប្រហែល ១៣.៥ ម៉ែត្រ
ប្រាំហត្ថ
ប្រហែល ២.៧ ម៉ែត្រ
ដំបូលផ្លូវដើរបែរមុខទៅនឹងទីលានខាងក្រៅ
«បន្ទប់ក្រោមដីនោះស្ថិតនៅឆ្ពោះទៅទីធ្លាខាងក្រៅ»។
ប្រជាជនអាចចូលនិងចេញពីវាពីទីធ្លា។
មានឆ្លាក់ក្បាច់ដើមចាក
«ហើយវាមានចម្លាក់ដើមត្នោត»
Ezekiel 40:32
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ហាសិបហត្ថ
ប្រហែលម្ភៃប្រាំម៉ែត្រ។
ម្ភៃប្រាំហត្ថ
ប្រាំហត្ថ - ប្រហែល ១៣.៥ ម៉ែត្រ
Ezekiel 40:35
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ហាសិបហត្ថ
ប្រហែលម្ភៃប្រាំម៉ែត្រ។ (សូមមើល: translate-bdistance)
ម្ភៃប្រាំហត្ថ
ប្រាំហត្ថ - ប្រហែល ១៣.៥ ម៉ែត្រ
Ezekiel 40:38
នៅតាមផ្លូវច្រកចូលទៅខាងក្នុង
«នៅតាមទ្វារខាងក្នុងនីមួយៗ»
កន្លែងដែលគេលាងជំរះតង្វាយដុត
ពាក្យថា«ពួកគេ» សំដៅទៅលើមនុស្ស ឬ
បូជាចារ្យដែលបានយកតង្វាយមកថ្វាយ។
នៅសងខាង
«ទាំងសងខាង»
សម្លាប់រួចហើយ និងយញ្ញបូជាសុំឲ្យរួចពីបាប
«ពួកគេបានសម្លាប់ដង្វាយដុត» ឬ
«ពួកគេបានសម្លាប់សត្វដែលពួកគេនឹងដុតជាដង្វាយ»។
Ezekiel 40:40
តើមានតុបួន នៅម្ខាងតាមខ្លោងទ្វារនីមួយៗត្រូវបានប្រើសម្រាប់អ្វី?
តុបួននៅសងខាងទ្វារនីមួយៗត្រូវបានប្រើសម្រាប់សម្លាប់សត្វ។
Ezekiel 40:42
ធ្វើពីផ្ទាំងថ្ម
«ដែលត្រូវបានធ្វើពីថ្មដែលត្រូវបានកាត់»
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ទទឹងមួយហត្ថកន្លះ
ប្រហែល ០,៨ ម៉ែត្រ។
មួយហត្ថ
ប្រហែលកន្លះម៉ែត្រ
មានទំពក់ពីរ ចងទទឹងនិងឈើតាមបណ្តោយចងយ៉ាងជាប់ជាមួយនិងដំបូលផ្លូវដើរជុំវិញ
ទំពក់ដែលមានភ្ជាប់ដៃវែងត្រូវបានគេដាក់នៅក្បែរ សសរស្តម្ភនៅជុំវិញ -
ការបកប្រែរបៀបផ្សេងទៀត:
«នៅជុំវិញកំពង់ផែនេះមនុស្សបានភ្ជាប់ទំពក់ដែលមានប្រវែងវែងហើយមានព្រំពីរ»។
ទំពក់ពីរ
ទំពក់ជាប់នឹង - អ្វីមួយដែលមានចំនុចកោងវែងពីរដែលមនុស្សអាចចងជាប់បាន
ទទឹងនិងឈើតាមបណ្តោយ
ប្រហែលប្រាំបីសង់ទីម៉ែត្រ។ .
សាច់សម្រាប់ធ្វើយញ្ញបូជា ពួកគេបានដាក់នៅលើតុ
«ពួកគេនឹងដាក់សាច់នៃតង្វាយនៅលើតុ»
Ezekiel 40:44
ទ្វារខាងក្នុង
នេះគឺជាច្រកទ្វារខាងក្នុងនៅខាងជើង។
បន្ទប់សម្រាប់អ្នកចម្រៀង
«បន្ទប់សំរាប់អ្នកចំរៀង»
ទោះយ៉ាងណាមកដល់ជំនាន់បុរាណនិងសម័យទំនើបគេអានតែ «អង្គជំនុំជម្រះ»
ប៉ុណ្ណោះដោយបន្សល់ទុកនូវគំនិតរបស់អ្នកចំរៀង។

generated on Wed Sep 10 16:16:32 2025

បន្ទប់មួយក្នុងចំណោមនោះនៅខាងជើង
ឃ្លានេះមានន័យថា «បន្ទប់ដែលមានច្រកចូលសំខាន់នៅខាងត្បូង»។
ដែលបំពេញការងារក្នុងព្រះដំណាក់
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលកំពុងធ្វើការនៅក្នុងព្រះវិហារ» (UDB) ឬ «អ្នកទទួលខុសត្រូវក្នុងការការពារប្រាសាទ»
Ezekiel 40:46
ព័ត៌មានទូទៅ:
បុរសនោះបន្តនិយាយទៅកាន់lokអេសេគាលនៅក្នុងនិមិត្ត។
បន្ទប់បែរមុខទៅទិសខាងជើង
«ដែលមានច្រកចូលសំខាន់របស់វានៅផ្នែកខាងជើង»
គាត់
«បុរសនោះ»
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
មួយរយហត្ថ
ប្រហែលហាសិបបួនម៉ែត្រ។
ជាមួយនិងអាសនៈ
«ហើយអាសនៈនោះគឺ»
ព្រះដំណាក់
នេះសំដៅទៅលើប្រាសាទ។
Ezekiel 40:48
ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៨:១៦។
ក្របទ្វាររបស់វា
«ច្រកទ្វារចូលផ្ទះ»
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
ប្រវែងប្រាំហត្ថ
ប្រហែល ២,៧ ម៉ែត្រ
ដប់បួនហត្ថ
ប្រហែល ៧.៥ ម៉ែត្រ
បីហត្ថ
ប្រហែល ១.៦ ម៉ែត្រ
ម្ភៃហត្ថ
ប្រហែល ១១ ម៉ែត្រ
ដប់មួយហត្ថ
ប្រហែល ៦ ម៉ែត្រ
សសរ
បំណែកនៃដុំថ្មដែលមានកម្ពស់ និងតួចចង្អៀត និងទ្រទ្រង់អគារ

41 [1]ហើយក្រោយមក លោកក៏បាននាំខ្ញុំចូលទៅក្នុងព្រះដំណាក់ទីសក្ការៈ លោកវាស់ក្របទ្វារទាំងនោះមានទទឹងប្រាំមួយហត្ថ។[2]ផ្លូវចូលមានទទឹងដប់ហត្ថ
ជញ្ជាំងទាំងសងខាងវិញ មានបណ្តោយប្រាំហត្ថ។ ហើយក្រោយមក លោកវាស់ទំហំនៃទីសក្ការៈ មានបណ្តោយសែសិបហត្ថ ហើយទទឹងម្ភៃហត្ថផងដែរ។
[3]បន្ទាប់មក បុរសនោះចូលទៅខាងក្នុងទីបរិសុទ្ធវាស់សសរមាត់ទ្វារ ឃើញមានកម្រាស់ពីរហត្ថ ហើយមានទទឹងទ្វារចូលប្រាំមួយហត្ថ។
ជញ្ជាំងទាំងពីរនៅសងខាងមានប្រាំពីរហត្ថ។[4]ហើយក្រោយមក លោកក៏បានវាស់បណ្តោយនៃបន្ទប់ ទីសក្ការៈ ដែលមានម្ភៃហត្ថ។ ហើយនិងទទឹងម្ភៃហត្ថ
នៅខាងមុខនៃព្រះវិហារ។ រួចហើយលោកក៏បាននិយាយប្រាប់ខ្ញុំថា «នេះជាទីកន្លែងសក្ការៈបរិសុទ្ធបំផុត»។
[5]ហើយលោកក៏បានវាស់ជញ្ជាំងខណ្ឌព្រះដំណាក់ ឃើញមានកម្រាស់ប្រាំមួយហត្ថ។ បន្ទប់អមជុំវិញព្រះដំណាក់មានទទឹងបួនហត្ថ។[6]បន្ទប់អមជុំវិញទាំងនោះមានបីជាន់
ក្នុងមួយជាន់មានសាមសិបបន្ទប់។ បន្ទប់នីមួយៗស្ថិតនៅតាមជញ្ជាំងខាងក្រៅដែលព័ទ្ធជុំវិញព្រះដំណាក់ គឺមិននៅតាមជញ្ជាំងទីសក្ការៈទេ។ បន្ទប់ជាន់ខាងលើទូលាយ
ជាងបន្ទប់នៅជាន់ក្រោម ព្រោះផ្នែកខាងលើ កម្រាស់ជញ្ជាំងដែលព័ទ្ធជុំវិញព្រះវិហារតូចជាងកម្រាស់ផ្នែកខាងក្រោម។[7]ហេតុនេះហើយបានជាកាលណាគេឡើងទៅខាង
លើកាន់តែខ្ពស់ នោះកាន់តែមានកន្លែងទូលាយជាង តាមរយៈនោះពួកគេអាចឡើងពីជាន់ក្រោមទៅជាន់កណ្តាល រួចទៅជាន់ខាងលើផងដែរ។
[8]ក្រោយមក ខ្ញុំមើលឃើញផ្នែកមួយនៅជុំវិញព្រះដំណាក់ គ្រិះសម្រាប់ទំហំមានពេញមួយឈើរង្វាស់ គឺបណ្តោយប្រាំមួយហត្ថ។[9]ទទឹងនៃជញ្ជាំងដែលនៅខាងក្រៅមានប្រាំ
ហត្ថ។ មានទីធ្លាដែលនៅចន្លោះខាងក្រៅ នៃបន្ទប់ក្នុងទីសក្ការៈ។
[10]នៅផ្នែកម្ខាងទៀត របស់ទីធ្លាបើកចំហរជាកន្លែងបូជាចារ្យបន្ទប់ខាងក្រៅ ទំហំនេះមានប្រវែងម្ភៃហត្ថ ដែលសង់ឡើងនៅជុំវិញកន្លែងទីសក្ការៈ។[11]មាន
ទ្វារចូលទៅខាងក្នុងបន្ទប់ពីទីធ្លាចំហរម្ខាងទៀត ច្រកចូលដែលនៅទិសខាងជើង ច្រកមួយទៀតគឺនៅទិសខាងត្បូងផងដែរ។ ប្រវែងទទឹងមានប្រាំហត្ថជុំវិញ។
[12]មានអាគារមួយបែរមុខទៅទីធ្លានៅទិសខាងលិច មានទទឹងចិតសិបហត្ថ។ បណ្តោយកៅសិបហត្ថ ហើយជញ្ជាំងមានកម្រាស់ប្រាំហត្ថ។[13]ក្រោយមកទៀត បុរសទាំងនោះ
ក៏វាស់ព្រះដំណាក់ ឃើញមានបណ្តោយប្រវែងមួយរយហត្ថ។ ហើយចំណែកទីធ្លា អាគារ និងជញ្ជាំង ក៏មានបណ្តោយប្រវែងមួយរយហត្ថផងដែរ។[14]សម្រាប់ជញ្ជាំងខាង
មុខនៃព្រះដំណាក់ និងទីធ្លាដែលនៅទិសខាងកើតវិញ គឺមានប្រវែងមួយរយហត្ថដូចគ្នា ចេញពីកន្លែងទីសក្ការៈ។
[15]ហើយបុរសនោះក៏បានវាស់បណ្តោយរបស់អាគារ ដែលស្ថិតនៅខាងក្រោយទីសក្ការៈនៅទិសខាងលិច ហើយវិចិត្រសាល នៅសងខាងផង ឃើញមានប្រវែងមួយរយ
ហត្ថ។ កន្លែងបរិសុទ្ធ ហើយដំបូលផ្លូវដើរ[16]នៅខាងក្នុងបង្អួច មានដាក់បង្អួចចម្រឹងដែក ហើយវិចិត្រសាលនៅជុំវិញដែលជាន់ទីបីមានបន្ទះឈើ។[17]ចាប់ពីលើទ្វាររហូតដល់
ក្នុងទីសក្ការៈ ហើយទីធ្លាជាមួយជញ្ជាំងមានក្បាច់លំអ។
[18]វាមានក្បាច់ចេរូប៊ីន និងក្បាច់ដើមចាក ដែលមានរូបដើមចាកមួយ រូបចេរូប៊ីន ពីរ នៅឆ្លាស់គ្នាផងដែរ ហើយចេរូប៊ីនមានមុខពីរ។[19]មុខរបស់បុរសនោះមើលទៅរកដើមចាក
ម្ខាង ហើយមុខសិង្ហមើលទៅរកដើមចាកនៅម្ខាងទៀត។ រូបទាំងនោះគឺនៅបន្តបន្ទាប់គ្នាព័ទ្ធជុំវិញព្រះដំណាក់។[20]តាំងពីដីដល់ទីខ្ពស់នៃផ្លូវចូល ចេរូប៊ីន និងក្បាច់ដើមចាក
មានឆ្លាកនៅលើជញ្ជាំងខាងក្រៅនៃព្រះដំណាក់។
[21]ក្របទ្វារនៃកន្លែងបរិសុទ្ធមានរាងបួនជ្រុង។ លក្ខណៈរបស់វាគឺដូចទៅនឹង[22]ដូចអាសនៈធ្វើពីឈើ ខាងមុខនៃកន្លែងបរិសុទ្ធ កម្ពស់បីហត្ថ និងបណ្តោយពីរហត្ថ
ទាំងសងខាង។ បង្គោលវានៅតាមកាច់ជ្រុង គោល ដាក់ក្រប បានធ្វើពីឈើ។ បុរសនោះពោលមកខ្ញុំថា៖ «នេះជាតុតម្កល់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»។
[23]មានទ្វារពីរសម្រាប់កន្លែងចរិសុទ្ធ ហើយនិងនៅទីបរិសុទ្ធបំផុត។[24]ទ្វារទាំងនេះបត់បានពីរបត់ នៃទ្វារបន្ទះនីមួយៗ ពីរបន្ទះសម្រាប់ទ្វារមួយ ហើយពីរបន្ទះ
សម្រាប់ផ្សេងមួយទៀត។
[25]មានឆ្លាក់នៅលើទ្វារទាំងនោះ នៅលើទ្វារនៃកន្លែងបរិសុទ្ធមានក្បាច់ចេរូប៊ីន និងដើមចាក ដូចនៅតាមជញ្ជាំងដែរ ហើយធ្វើពីឈើសម្រាប់ដំបូលផ្លូវដើរ នៅផ្នែកខាងមុខ។
[26]មានបង្អួចចម្រឹងដែក និងក្បាច់ដើមចាកនៅម្ខាងទៀតនៃដំបូលផ្លូវដើរ។ នេះគឺជាទំហំបន្ទប់នៃព្រះដំណាក់ ហើយបន្ទប់ទាំងនោះក៏មានដំបូលលយចេញដែរ។

Ezekiel 41:1
ព័ត៌មានទូទៅ:
បុរសនៅក្នុងនិមិត្តរបស់លោកអេសេគាល (៤០:៣)
បន្តបង្ហាញលោកអេសេគាលនៅជុំវិញព្រះវិហារ។
Ezekiel 41:3
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថនេះនៅក្នុងជំពូក ៤០: ៥។
នៅខាងមុខនៃព្រះវិហារ
«ដូចជាទទឹងនៃទីបរិសុទ្ធ» ឬ «ត្រូវនឹងទទឹងនៃទីបរិសុទ្ធ»
Ezekiel 41:8
ពេញមួយឈើរង្វាស់
សូមមើលពីរបៀបដែលបានបកប្រែ «ឈើ» នៅក្នុងជំពូក ៤០:៥។
Ezekiel 41:10
កន្លែងបូជាចារ្យបន្ទប់ខាងក្រៅ
«បន្ទប់របស់ក្រុមបូជាចារ្យដែលនៅឆ្ងាយពីទីសក្ការៈ»
Ezekiel 41:12

generated on Wed Sep 10 16:16:32 2025

បែរមុខទៅ
សូមមើលពីរបៀបដែលបានបកប្រែនេះនៅក្នុងជំពូក ៤០:២៨។
Ezekiel 41:15
រិចិត្រសាល
«រានហាល» រានហាល
គឺជាកន្លែងដែលត្រូវបានសាងសង់ខ្ពស់ជាងកន្លែងដែលនៅសល់។
ប្រជាជនអាចចូលទៅក្នុងរានហាលហើយមើលទៅជាន់ក្រោមនៃអាគារ។
ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
Ezekiel 41:18
មានក្បាច់
ដើម្បីធ្វើឲ្យអ្វីដែលស្រស់ស្អាតជាធម្មតាដោយដាក់អ្វីមួយនៅលើវា
ព្រះដំណាក់
«ទីសក្ការៈ»
Ezekiel 41:21
មានទ្វារពីរសម្រាប់កន្លែងចរិសុទ្ធ ហើយនិងនៅទីបរិសុទ្ធបំផុត
«ទីបរិសុទ្ធ និង ទីបរិសុទ្ធបំផុតមានទ្វារពីរ»
ទ្វារទាំងនេះបត់បានពីរបត់ នៃទ្វារបន្ទះនីមួយៗ
ទ្វារនីមួយៗមានពីរផ្នែកដែលស្ថិតនៅលើគន្លាក់ឆ្អឹង។ គន្លាក់ឆ្អឹង
តោងភ្ជាប់ទ្វារទៅនឹងជញ្ជាំង និងអនុញ្ញាតឲ្យទ្វាររុញ។
ពីរបន្ទះសម្រាប់ទ្វារមួយ ហើយពីរបន្ទះសម្រាប់ផ្សេងមួយទៀត
«ទ្វារទាំងពីរសម្រាប់ទីបរិសុទ្ធនិងទីបរិសុទ្ធបំផុតមានពីរផ្នែក»
Ezekiel 41:25
ដូចនៅតាមជញ្ជាំងដែរ
«ដូចជញ្ជាំងក៏មានចម្លាក់ចេរូប៊ីន និងដើមត្នោតដែរ»។
ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។

---

42 [1]បន្ទាប់មក បុរសនោះបញ្ជូនខ្ញុំចេញទៅទីធ្លាខាងក្រៅ ផ្នែកខាងជើង ហើយនាំខ្ញុំទៅបន្ទប់ផ្សេងៗ ដែលនៅមុខទីធ្លាខាងក្រៅនិងទិសខាងជើងនៃជញ្ជាំងខាងក្រៅ។
[2]បន្ទប់ទាំងនោះមាន មានបណ្តោយមួយរយហត្ថ ហើយនៅពីខាងមុខមានទទឹងហាសិបហត្ថ។[3]មានបន្ទប់ខ្លះបែរមុខទៅទីធ្លាខាងក្នុង ហើយដែលមានប្រវែងម្ភៃ
ហត្ថចេញពីទីសក្ការៈ។ មានបីជាន់នៃបន្ទប់ទាំងនោះ ហើយមួយផ្នែកខាងលើអាចមើលមកមួយខាងក្រោមបាន ហើយគ្រប់ជាន់ទាំងអស់គឺមានផ្លូវដើរ។
បន្ទប់ខ្លះទៀតក៏អាចមើលឃើញទីធ្លាខាងក្រៅផងដែរ។
[4]នៅពីមុខបន្ទប់ទាំងនោះមានច្រកមួយ ទទឹងដប់ហត្ថ និងបណ្តោយមួយរយហត្ថ។ ទ្វារបន្ទប់ទាំងនោះបែរមុខទៅទិសខាងជើង។[5]ប៉ុន្តែបន្ទប់ជាន់ខាងលើតូចជាង
សម្រាប់ផ្លូវដើរ ដោយសារមិនសូវមានកន្លែងធំ ដូចដែលគេបានធ្វើនៅខាងក្រោមនិងជាន់កណ្តាលនៃអាគារ។[6]ដ្បិត នៅជាន់ទីបីនៃអាគារនោះ គឺអត់មានសសរដូចសសរនៅ
ក្នុងទីធ្លាទេ។ ហេតុនេះហើយ បានជាបន្ទប់នៅជាន់ខ្ពស់ តូចជាងក្នុងទំហំបើប្រៀបទៅនិងបន្ទប់ ដែលនៅជាន់ក្រោមនិងកណ្តាល។
[7]នៅជញ្ជាំងខាងក្រៅ នៅតាមបណ្តោយបន្ទប់ ដើម្បីចេញទៅទីធ្លាខាងក្រៅ គឺមានប្រវែងហាសិបហត្ថ ដែលវានៅចំពីមុខបន្ទប់តែម្តង។[8]ដ្បិតបន្ទប់ដែលនៅជាប់នឹងទីលាន
ខាងក្រៅនោះ មានប្រវែងហាសិបហត្ថដែរ ហើយបន្ទប់ទាំងនោះបែរមុខទៅរកទីសក្ការៈ មានប្រវែងមួយរយហត្ថ។[9]នៅក្រោមបន្ទប់ទាំងនោះ មានទ្វារចូលពីទីលានខាងក្រៅ
តាមទិសខាងកើត សម្រាប់ឲ្យចូលពីទីធ្លាខាងក្រៅ។
[10]នៅតាមជញ្ជាំងនៃទីធ្លាផ្នែកខាងកើតនៃទីធ្លាខាងក្រៅ ដែលនៅទល់មុខធ្លាផ្នែកខាងក្នុង ដែលទលនិងទីសក្ការៈ ក៏មានបន្ទប់ជាច្រើនដែរ។[11]ជាមួយផ្លូវដើរនៅពីមុខ បន្ទប់
ទាំងនោះ។ បន្ទប់ទាំងនោះគឺមានច្រកមួយដូចនៅមុខបន្ទប់ជួរខាងជើង។ បន្ទប់ទាំងនោះ គឺមានបណ្តោយ មានទទឹងដូចគ្នា ហើយមានផ្លូវចេញចូល មានទ្រង់ទ្រាយ
ដូចទៅនិងទ្វារដែល។[12]នៅទិសខាងត្បូង មានទ្វារមួយចូលទៅបន្ទប់ទាំងនោះ ហើយវាក៏ដូចគ្នានិងទិសខាងជើងដែរ។ ផ្លូវឆ្លង នៅខាងក្នុងមានទ្វារ នៅលើក្បាលរបស់វា
ហើយផ្លូវឆ្លងឆ្ពោះទៅកាន់បនប្ទប់ផ្សេងទៀត។ នៅទិសខាងកើតក៏មានទ្វារចូល ទៅក្នុងផ្លូវឆ្លងដល់ចុងបំផុត។
[13]បុរសនោះប្រាប់ខ្ញុំថា៖ «បន្ទប់ជួរខាងជើង និងបន្ទប់ជួរខាងត្បូង ដែលនៅទល់មុខនឹងទីធ្លាក្រៅ ជាបន្ទប់ទីសក្ការៈ ជាកន្លែងដែលពួកបូជាចារ្យចូលទៅថ្វាយបង្គំព្រះអម្ចាស់
ពួកគេបរិភោគអាហារបរិសុទ្ធបំផុត។ ក្នុងបន្ទប់ទាំងនោះ មានដាក់របស់បរិសុទ្ធនៅទីនោះ តង្វាយអាំហារ តង្វាយលោះបាប តង្វាយលើកលែងទោស ដ្បិតកន្លែងនោះជា
កន្លែងបរិសុទ្ធ។[14]ពេលពួកបូជាចារ្យចូលទៅទីនោះ គេពុំអាចចេញមកទីបរិសុទ្ធទៅលានខាងក្រៅទេ គឺត្រូវទុកសម្លៀកបំពាក់ដែលគេស្លៀកពាក់ ពេលបំពេញមុខងារនោះ
នៅក្នុងទីបរិសុទ្ធ។ ពួកគេត្រូវស្លៀកពាក់ផ្សេងមុខចេញទៅខាងក្រៅជួយមនុស្ស»។
[15]បុរសនោះបានបញ្ចាប់វាស់ព្រះដំណាក់ខាងក្នុងរួចរាល់ហើយ ហើយលោកនាំខ្ញុំចេញតាមខ្លោងទ្វារដែលបែរមុខទៅខាងកើត ហើយវាស់នៅបរិវេណដែលនៅជុំវិញនោះ។
[16]លោកវាស់នៅជ្រុងទិសខាងកើតជាមួយឈើវាស់ មានប្រវែងប្រាំរយហត្ថជាមួយឈើរង្វាស់។[17]លោកក៏បានវាស់ជ្រុងទេសខាងជើង ហើយក៏ឃើញមានប្រវែងប្រាំរយ
ហត្ថឈើរង្វាស់។[18]លោកក៏បានទៅវាស់ជ្រុងទិសខាងត្បូង ហើយក៏ឃើញមានប្រវែងប្រាំរយហត្ថឈើរង្វាស់។[19]លោកក៏បែរទៅជ្រុងទិសខាងលិច ហើយវាស់ឃើញមាន
ប្រវែងប្រាំរយហត្ថឈើរង្វាស់ដូចគ្នាផងដែរ។
[20]លោកវាស់ទាំងបួនជ្រុង។ វាមានជញ្ជាំងនៅជុំវិញវាមានបណ្តោយ ប្រវែងប្រាំរយឈើរង្វាស់ ហើយមានទទឹងប្រាំរយហត្ថ ដើម្បីញែកឬចទីបរិសុទ្ធចេញពីកន្លែងទូទៅ។

Ezekiel 42:1
ទីធ្លាខាងក្រៅ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១០:៣។
ទីធ្លាខាងក្នុង
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
មើលមកមួយ
«ហើយក្រឡេកមើលទៅទីធ្លាខាងក្នុង»
គឺមានផ្លូវដើរ
«ពីព្រោះមានកន្លែងដែលអ្នកអាចដើរនៅតាមបន្ទប់»
Ezekiel 42:4
តូចជាងក្នុងទំហំបើប្រៀបទៅនិងបន្ទប់
«តូចជាងបន្ទប់»
Ezekiel 42:7
បែរមុខទៅ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤០:៨។
Ezekiel 42:10
ក្បាលរបស់វា
«នៅពេលចាប់ផ្តើម»
Ezekiel 42:13
តង្វាយអាហារ
នេះជាតង្វាយម្សៅ ឬ ម្សៅ។ ប្រជាជនបានថ្វាយ «តង្វាយជាអាហារ»
ដើម្បីបង្ហាញថាពួកគេអរព្រះគុណដល់ព្រះជាម្ចាស់។
Ezekiel 42:16
លោកវាស់
ពាក្យថាគាត់សំដៅទៅលើបុរសដែលមើលទៅដូចជាលង្ហិន។ (សូមមើល៖ ៤០:៣)
ឈើវាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤០:៥។
Ezekiel 42:20
វាមានជញ្ជាំងនៅជុំវិញវាមានបណ្តោយ
នេះអាចត្រូវបានបកប្រែជាប្រយោគថ្មីថា
«ផ្ទះមានជញ្ជាំងព័ទ្ធជុំវិញដែលមានប្រវែងវែង»។

---

43 [1]បុរសនោះក្រោយនកបាននាំខ្ញុំទៅកាន់ខ្លោងទ្វារខាងកើត។[2]មើល៍! សិរីរុងរឿងរបស់ព្រះជាម្ចាស់នៃជនជាតិអ៊ីស្រាអែលមកពីទិសខាងកើត សម្លេងរបស់ព្រះអង្គដូច
ជាទឹកធ្លាក់ជាច្រើន ហើយផែនដីភ្លឺដោយសិរីរុងរឿងរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[3]វាបានផ្អែកទៅលើលក្ខណៈនិមិត្តដែលខ្ញុំបានឃើញនៅពេលនោះ ដោយផ្អែកទៅលើនិមិត្តដែលខ្ញុំបានឃើញ នៅពេលព្រះអង្គយាងមកកម្ទេចក្រុងយេរូសាឡិម
ហើយនិមិត្តទាំងពីរនេះក៏ដូចជានិមិត្ត ដែលខ្ញុំបានឃើញនៅមាត់ទន្លេកេបារដែរ ពេល ខ្ញុំក្រាប មុខដល់ដី។[4]ដូច្នោះសិរីរុងរឿងរបស់ព្រះអម្ចាស់ចូលមកក្នុងព្រះដំណាក់
តាមខ្លោងទ្វារខាងកើត។[5]ក្រោយមកព្រះវិញ្ញាណក៏លើកខ្ញុំឡើង ហើយនាំខ្ញុំទៅដាក់កណ្តាលទីលានខាងក្នុង។ មើល៍! សិរីល្អរបស់ព្រះអម្ចាស់ស្ថិតនៅក្នុងព្រះដំណាក់។
[6]ពេលបុរសនោះនៅក្បែរខ្ញុំ ខ្ញុំឮមនុស្សម្នាក់និយាយចេញពីព្រះដំណាក់មកកាន់ខ្ញុំថា។[7]លោកបាននិយាយថា «កូនមនុស្សអើយ! កន្លែងនេះជាបល្ល័ង្ករបស់យើង និងជា
កន្លែងដាក់ជើងរបស់យើងផង ហើយយើងនឹងស្ថិតនៅកន្លែងនេះជាមួយប្រជាជនអ៊ីស្រាអែលរហូតតទៅ។ កូនចៅសអ៊ីស្រាអែល និងមិនប្រមាថនាមយើងទៀតទេ
ឬស្តេចរបស់ពួកគេ ជាមួយនិងភាពគ្មានជំនឿរបស់គេ ឬជាមួយនិងកសាកសពស្តេចមកតម្កល់ទុកនៅទីខ្ពស់។[8]ពួក
គេនឹងមិនប្រមាថនាមយើងដោយដាក់ច្រកចូលបន្ទាប់និងច្រកចូលយើងទេ ហើយក៏មិនដាក់ខ្លោងទ្វារបិតនៅជិតខ្លោងទ្វារយើងដែរ
គឺគ្មានអ្វីទេតែជញ្ជាំងរវាងយើងហើយពួកគេ។ ពួកគេធ្លាប់បានប្រមាថនាមបរិសុទ្ធយើងជាមួយការប្រព្រឹត្តអំពើស្អប់ខ្ពើម ដូច្នោះយើយលេបត្របាក់គេជាមួយកំហឹងយើង។
[9]ឥឡូវនេះ ចូរឲ្យពួកគេយកចេញការខ្ទេះជំនឿ ហើយនិងសពស្តេចរបស់ពួកគេចេញឆ្ងាយពីយើង ហើយយើងនឹងនៅក្នុងចំណោមពួកគេរហូតតទៅ។
[10]កូនមនុស្សអើយ អ្នកខ្លួនឯងត្រូវប្រាប់កូនចៅអ៊ីស្រាអែល ពីដំណាក់របស់យើង ដើម្បីឲ្យពួកគេខ្មាស់ដោយភាពទុច្ចរិតរបស់ពួកគេគួរគិតពីពាក្យទាំងអស់នេះ។[11]ដ្បិត
ប្រសិនបើពួកគេបានខ្មាស ដោយព្រោះការអាក្រក់ដែលខ្លួនបានធ្វើ ហើយចូរប្រាប់ពួកគេឲ្យដឹងពីរបៀបនៃព្រះដំណាក់ ទ្រង់ទ្រាយ ច្រកចេញចូល ហើយនិងរបៀបតុបតែង
ព្រមទាំងរបៀបចាត់ចែង និងក្បួនតម្រាសព្វបែបយ៉ាង។ ចូរកត់ត្រាទុកដើម្បីឲ្យពួកគេឃើញនិងភ្នែកផង ដូច្នោះគេនឹងរក្សារបៀបតុបតែង ហើយច្បាប់ទាំងអស់
ដូចដែលគេស្តាប់តាម។
[12]នេះហើយជាបទបញ្ជានៃព្រះដំណាក់ នៅលើកំពូលភ្នំនោះ ទៅជុំវិញទាំងមូលនៃព្រំប្រទល់វា ហើយវាត្រូវជាទីបរិសុទ្ធបំផុត។ ចូរមើល! នេះគឺជាបទបញ្ជា
សម្រាប់ព្រះដំណាក់។
[13]នេះជាទំហំនៃអាសនាដែលវាស់នៅក្នុងហត្ថ គឺហត្ថធំដែលត្រូវជាមួយហត្ថមួយទះ បាតនៃអាសនា ហើយបានកម្ពស់មួយហត្ថ បណ្តោយមួយហត្ថ។ ដូច្នោះគែមនៅជុំវិញ
នៃអាសនា បានមួយហត្ថជម្រៅនៃទទឹងក៏មានមួយហត្ថដែរ។ ហើយព្រំព្រទល់ជុំវិញ ហើយព័ទជុំវិញគែមវានឹងមានមួយចំអាម។ នេះនឹងជាមូលដ្ឋាននៃអាសនា។[14]ពីបាត
ដែលនៅលើដី ឡើងទៅដល់គន្លាក់ខាងក្រោមផ្នេកល នៃអាសនាមានពីរហត្ថ ហើយនិងទទឹងមួយហត្ថផងដែរ បន្ទាប់មក គឺរាប់តាំងពីគន្លាក់ក្រោម កម្ពស់នៃអាសនា
គឺឡើងទៅដល់គន្លាក់ខាងលើ ដែលមានបួនហត្ថ ហើយនិងទទឹងមួយហត្ថតាមរង្វាស់។
[15]ជើងក្រានអាសនាសម្រាប់ថ្វាយតង្វាយដុត គឺមានបួនហត្ថ កម្ពស់ ហើយនិងមានស្នែងបួនចេញពីអាសនាឡើងទៅផងដែរ។[16]ជើងក្រានប្រទាសអាសនា មានបណ្តោយ
ដប់ពីរហត្ថ ទទឹងដប់ពីរហត្ថ បួនជ្រុងស្មើ។[17]វាមានគន្លាក់ប្រវែងដប់បួនហត្ថ ទទឹងដប់បួនហត្ថ ទាំងបួនជ្រុងនីមួយៗ ហើយក៏មានគែមនៅព័ទ្ធជុំវិញកន្លះហត្ថ។ ហើយបាត
ក៏មួយហត្ថទាំងបួនជ្រុង ឯជណ្តើរនោះ បែរមុខទៅទិសខាងកើត»។
[18]បន្ទាប់មក ព្រះអង្គមានបន្ទូលមកខ្ញុំថា «កូនមនុស្សអើយ ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ នេះគឺជាបទបញ្ជារសម្រាប់អាសនា នៅថ្ងៃដែលគេធ្វើវាឡើង ដើម្បី
ថ្វាយតង្វាយដុត ហើយប្រោះឈាមទៅលើអាសនានោះ។[19]អ្នកនឹងត្រូវទទួលបានគោឈ្មោលស្ទាវមួយ សម្រាប់ជាតង្វាយលោះបាប ដល់ពួកលេវីដែលជាបូជាចារ្យ ក្នុង
ពូជពង្សសាដុក ជាពួកអ្នកដែលចូលមកជិត ដើម្បីធ្វើការងារសម្រាប់យើង នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[20]ហើយអ្នកនឹងត្រូវយកឈាមខ្លះនៃយញ្ញបូជាទៅប្រឡាក់ នៅអាសនានៃស្នែងទាំងបួន និងនៅគន្លាក់ទាំងបួនជ្រុង ហើយនៅគែមព័ទ្ធជុំវិញដែរ គឺយ៉ាងនោះដែលអ្នកត្រូវ
សម្អាត ហើយថ្វាយតង្វាយឲ្យធួននឹងអាសនា។[21]បន្ទាប់មក យកគោឈ្មោលដែលសម្រាប់ជាតង្វាយលោះបាបដែរ ហើយត្រូវដុតនៅកន្លែងសម្រាប់ការនោះ នៅក្នុង
ព្រះវិហារខាងក្រៅទីសក្ការៈ។
[22]បន្ទាប់មក ដល់ថ្ងៃទីពីរអ្នកត្រូវថ្វាយពពែឈ្មោលល្អឥតខ្ចោះ សម្រាប់ជាតង្វាយលោះបាប ហើយគេនឹងសម្អាតអាសនា ដូចជាបានសម្អាតដោយគោឈ្មោលនោះដែរ។
[23]ពេលអ្នកបានសម្អាតអាសនារួចហើយ អ្នកត្រូវថ្វាយគោឈ្មោលស្ទាវមួយល្អឥតខ្ចោះ និងចៀមឈ្មោលមួយល្អឥតខ្ចោះ ពីហ្វូងចៀមទៀត។[24]ថ្វាយសត្វទាំងពីរនោះនៅ
ចំពោះព្រះអម្ចាស់ រួចត្រូវឲ្យពួកបូជាចារ្យបាចអំបិលទៅលើ ហើយថ្វាយជាតង្វាយដុតដល់ព្រះអម្ចាស់។
[25]អ្នកត្រូវរៀបពពែឈ្មោលមួយសម្រាប់ជាតង្វាយលោះបាបរាល់ៗថ្ងៃ ក្នុងរវាងប្រាំពីរថ្ងៃ គេត្រូវរៀបគោឈ្មោលស្ទាវមួយ និងចៀមឈ្មោលល្អឥតខ្ចោះមួយពីហ្វូងសត្វដែរ។
[26]ពួកគេថ្ងៃត្រូវឲ្យគេថ្វាយតង្វាយឲ្យធួននឹងអាសនា ក្នុងពេលប្រាំពីរថ្ងៃ ហើយញែកចេញជាបរិសុទ្ធ គឺយ៉ាងនោះដែលគេត្រូវឆ្លងអាសនា ហើយញែកចេញជាបរិសុទ្ធ។[27]ពួក
គេបានសម្រេចកំណត់ថ្ងៃទាំងនោះហើយ ហើយដល់ថ្ងៃទីប្រាំបី ហើយតទៅមុខ ត្រូវឲ្យពួកបូជាចារ្យរៀបចំថ្វាយតង្វាយដុតរបស់អ្នក និងតង្វាយមេត្រីរបស់អ្នកដែរ នៅលើ
អាសនា ហើយយើងនឹងទទួលអ្នក នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 43:1
មើល៍!
ពាក្យថា «មើល»
នៅទីនេះដាស់តឿនយើងឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឲ្យភ្ញាក់ផ្អើលដែលកើតឡើង។
ដូចជាទឹកធ្លាក់ជាច្រើន
សូមមើលពីរបៀបដែលអ្នកបកប្រែ« ដូចជាសំលេងរំខាននៃទឹកដែលហូរខ្លាំង»
នៅក្នុងជំពូក ១:២៤។
ផែនដីភ្លឺ
«ផែនដីពោរពេញទៅដោយពន្លឺភ្លឺ»
Ezekiel 43:3
នេះក៏ដូចជា
ពាក្យថា «វា»
សំដៅទៅលើចក្ខុវិស័យនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ដែលមកពីទិសខាងកើត។
ពេលព្រះអង្គយាងមកកម្ទេចក្រុង
អត្ថន័យដែលអាចមានគឺ ១)
«នៅពេលដែលព្រះនៃអ៊ីស្រាអែលបានមកបំផ្លាញទីក្រុង» ឬ ២)
«នៅពេលដែលយើងបានមកឃើញព្រះនៃអ៊ីស្រាអែលបំផ្លាញទីក្រុងនោះ»។
Ezekiel 43:6
សាកសពស្តេចមកតម្កល់
ពាក្យថា «សាកសព»
នៅទីនេះសំដៅទៅលើរូបព្រះដែលស្តេចរបស់ប្រជាជនគោរពបូជា។
រូបព្រះទាំងនោះត្រូវបានគេហៅថាសាកសពពីព្រោះពួកគេមិនមានជីវិតទេ។
ប្រមាថ
«ពូជពង្សអ៊ីស្រាអែលបានបង្អាប់»
ប្រព្រឹត្តអំពើស្អប់ខ្ពើម
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:៩។
លេបត្របាក់គេជាមួយកំហឹងយើង
ដំណាក់កាលនេះមានន័យថា
«យើងបានបំផ្លាញពួកគេចោលទាំងស្រុងពីព្រោះយើងខឹង»។
Ezekiel 43:9
សពស្តេចរបស់ពួកគេ
ពាក្យថា «សាកសព»
នៅទីនេះសំដៅទៅលើរូបព្រះដែលស្តេចរបស់ប្រជាជនគោរពបូជា។
រូបព្រះទាំងនោះត្រូវបានគេហៅថាសាកសព ពីព្រោះពួកគេមិនមានជីវិតទេ។
Ezekiel 43:10
ពាក្យទាំងអស់នេះ
«លំនាំនេះ» ឬ «ផែនការនេះ»
ពួកគេឃើញនិងភ្នែកផង
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ២១:៦។
គេនឹងរក្សារបៀបតុបតែង
«នឹងរក្សាលំនាំ»
Ezekiel 43:12
បទបញ្ជា
«ការណែនាំ» ឬ «ច្បាប់»

generated on Wed Sep 10 16:16:32 2025

ជុំវិញទាំងមូលនៃព្រំប្រទល់វា
ពាក្យថា «ព្រំដែន»
ប្រហែលជាសំដៅទៅលើជញ្ជាំងដែលពាសពេញដោយប្រាសាទ។
បរិសុទ្ធបំផុត
«បរិសុទ្ធបំផុត»
ចូរមើល!
ពាក្យ «ចូរមើល» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។ វាក៏អាចត្រូវបានបកប្រែថាជាការពិត!
Ezekiel 43:13
ព្រំព្រទល់ជុំវិញ ហើយព័ទជុំវិញគែមវា
«ព្រំដែននៅជុំវិញគែមរបស់វា»
នេះនឹងជាមូលដ្ឋាននៃអាសនា
«ទាំងនេះនឹងជារង្វាស់របស់អាសនៈ»។
មូលដ្ឋាននៃអាសនា
«បាតផ្ទៃទ្រទ្រង់អាសនៈ» ឬ «គ្រឹះរបស់អាសនៈ»
ផ្នែកលយ
ផ្នែតូចចង្អៀត និងរាបស្មើដែលនៅជាប់នឹងជញ្ជាំង
Ezekiel 43:15
ជើងក្រាន
កន្លែងដែលមានបូជាឬដុតដោយភ្លើង
ស្នែង
ស្នែងជាផ្នែកនៃអាសនៈនៅជ្រុងទាំងបួននៃអាសនៈដែលស្ថិតនៅជាប់នឹងអាសនៈដែលនៅសាងសង់
Ezekiel 43:18
មានបន្ទូល
«ព្រះអម្ចាស់មានព្រះបន្ទូល»
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ២:១។
បទបញ្ជារ
«ច្បាប់» ឬ «ការណែនាំ»
អ្នកនឹង
ពាក្យថា «អ្នក» គឺជាឯកវចនៈ។
Ezekiel 43:20
ហើយអ្នកនឹងត្រូវយក
សូមមើលពីរបៀបដែលបានបកប្រែ «អ្នក» នៅក្នុងជំពូក ៤៣:១៨។
ស្នែងទាំងបួន
សូមមើលពីរបៀបដែលបានបកប្រែ «អ្នក» នៅក្នុងជំពូក ៤៣:១៥។
Ezekiel 43:22
ដល់ថ្ងៃទីពីរអ្នកត្រូវ
សូមមើលពីរបៀបដែលបានបកប្រែ «អ្នក» នៅក្នុងជំពូក ៤៣:១៨។
ថ្វាយសត្វទាំងពីរនោះនៅចំពោះព្រះអម្ចាស់
អាសនៈដែលពួកគេថ្វាយគោឈ្មោល
និងចៀមឈ្មោលស្ថិតនៅខាងមុខព្រះវិហារដែលព្រះតំណាក់។
Ezekiel 43:25
អ្នក
សូមមើលពីរបៀបដែលបានបកប្រែ «អ្នក» នៅក្នុងជំពូក ៤៣:១៨។
ហើយតទៅមុខ ត្រូវឲ្យ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ផ្នែកសំខាន់នៃការណែនាំ។
ប្រសិនបើភាសារបស់អ្នកមានវិធីសម្រាប់ធ្វើដូចនេះ
ពិចារណាប្រើវានៅទីនេះ។
តង្វាយដុតរបស់អ្នក ... តង្វាយមេត្រី ... ទទួលអ្នក
ពាក្យ «របស់អ្នក» និង «អ្នក» គឺជាពហុវចនៈមនុស្សទីពីរ
ហើយសំដៅទៅលើប្រជាជនអ៊ីស្រាអែលជាទូទៅ។
នឹងទទួលអ្នក
«នឹងទទួលបានការពេញចិត្ត» ឬ «នឹងបំពេញចិត្តអ្នក»

---

44 [1]រួចហើយនាំខ្ញុំវិលទៅតាមផ្លូវនៃទ្វារខាងក្រៅរបស់ទីសក្ការៈ ដែលបែរទៅទិសខាងកើត ទ្វារនោះនៅបិទ។[2]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ទ្វារនេះត្រូវបិទជានិច្ចជិត វានឹងមិនបើកឡើយ។ គ្មានមនុស្សណាចូលតាមទ្វារនេះដែរ ដ្បិតព្រះអម្ចាស់គឺព្រះជាម្ចាស់នៃអ៊ីស្រាអែល បានយាងចូលតាមទ្វារនេះហើយ ហេតុនោះនឹងត្រូវបិទរហូត។[3]អ្នកដឹកនាំ នៅលើពួកអ៊ីស្រាអែល គឺអង្គុយបរិភោគពិធីជប់លៀងនៅចំពោះមុខព្រះអម្ចាស់។ ពួកគេចូលមកតាមខ្លោងទ្វារដំបូលផ្លូវដើរ ហើយចេញទៅវិញតាមច្រកដដែល»។

[4]បន្ទាប់មក លោកនាំខ្ញុំទៅតាមផ្លូវនៃទ្វារខាងជើង ពីមុខព្រះដំណាក់។ ហើយខ្ញុំមើលហើយ ចូលមើល៍! សិរីល្អនៃព្រះអម្ចាស់ នៅពេញក្នុងព្រះវិហាររបស់ព្រះអម្ចាស់ រួចខ្ញុំដួលក្រាបផ្កាប់មុខចុះ។[5]ហើយព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំ «កូនមនុស្សអើយ ចូរផ្ចង់ចិត្តរបស់អ្នក ត្រូវមើលដោយភ្នែក ហើយស្តាប់ដោយត្រចៀក តាមគ្រប់ទាំងសេចក្ដីដែលយើងនិយាយ ពីដំណើរបៀបទាំងប៉ុន្មានក្នុងព្រះវិហារនៃព្រះអម្ចាស់ ហើយពីបទបញ្ជាផង។ ចូរគិតចំពោះផ្លូវចូលព្រះដំណាក់ គឺទាំងផ្លូវចូលនិងចេញផង។[6]រួចហើយអ្នកត្រូវនិយាយដល់ពួកអ្នកបះបោរ កូនចៅអ៊ីស្រាអែលថា ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ចូរឲ្យអំពើគួរស្អប់ខ្ពើមទាំងអស់របស់អ្នកលួមចប់ សម្រាប់អ្នកកូនចៅអ៊ីស្រាអែល[7]អ្នកបាននាំពួកជនជាតិដទៃ ជាមនុស្សដែលមិនទទួលកាត់ស្បែកខាងចិត្ត ហើយខាងរូបសាច់ផង ឲ្យចូលមកនៅក្នុងទីសក្ការៈយើង ប្រមាថដំណាក់យើង ពេលអ្នកបានថ្វាយតង្វាយអាហារដល់យើង ព្រមទាំងខ្លាញ់និងឈាម ហើយបានផ្តាច់សេចក្ដីសញ្ញារបស់យើង តាមរយៈទង្វើគួរស្អប់ខ្ពើម។[8]អ្នកមិនបានរក្សាបញ្ញើ ដែលនៅទីបរិសុទ្ធរបស់យើងទេ ប៉ុន្តែអ្នកបានតាំងជនជាតិដទៃ ឲ្យរក្សាបញ្ញើរបស់យើង និងឲ្យគេរក្សាទីបរិសុទ្ធរបស់យើងទៀត។

[9]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ គ្មានជនជាតិដទៃណាមួយ ដែលមិនទទួលកាត់ស្បែកខាងចិត្ត និងខាងរូបសាច់ ឲ្យនៅចំណោមពួកអ៊ីស្រាអែល និងចូលក្នុងទីបរិសុទ្ធរបស់យើងទេ។

[10]ប៉ុន្តែ ពួកលេវីដែលបានឃ្លាតឆ្ងាយពីយើង ពួកគេបានវង្វេងចេញពីយើង ទៅតាមរូបព្រះរបស់ពួកគេ តែគេនឹងត្រូវបង់ថ្លៃសម្រាប់អំពើបាបរបស់គេ។[11]ពួកគេជាអ្នកបម្រើនៅក្នុងទីសក្ការៈរបស់យើង ជាអ្នកមើលលើអស់ទាំងទ្វារនៃព្រះដំណាក់ហើយទាំងបម្រើក្នុងដំណាក់យើងរផង ពួកគេជាអ្នកសម្លាប់និងតង្វាយដុត និងយញ្ញបូជាសម្រាប់បណ្តាជន ហើយពួកគេត្រូវឈរនៅមុខប្រជាជន ហើយបម្រើអ្នកទាំងនោះ។[12]ដោយព្រោះគេបានធ្វើការប្រមាថយញ្ញបូជានៅចំពោះរូបព្រះរបស់គេ
គឺពួកគេបានដួលធ្លាក់ចុះសម្រាប់អំពើបានដល់កូនចៅអ៊ីស្រាអែលផង។ ដូច្នេះហើយ យើងនឹងលើកដៃរបស់យើងស្បថនឹងទាស់ជាមួយពួកគេ
នេះជាព្រះបន្ទូលនៃព្រះម្ចាស់ដ៏ជាព្រះ ពួកគេនឹងត្រូវទទួលការដាក់ទោសរបស់គេ។

[13]ពួកគេមិនត្រូវចូលមកជិតយើង ដើម្បីធ្វើការងារជាសង្ឃដល់យើង ឬចូលទៅជិតរបស់បរិសុទ្ធណាមួយ ក្នុងអស់ទាំងវត្ថុបរិសុទ្ធបំផុតរបស់យើង ផ្ទុយទៅវិញ ពួកគេនឹងបានផលអាម៉ាស់ហើយកំហុសរបស់ពួកគេ សម្រាប់ទង្វើគួរស្អប់ខ្ពើមដែលគេបានធ្វើនោះ។[14]ប៉ុន្តែ យើងនឹងតាំងគេជាអ្នករក្សាបញ្ញើនៃព្រះដំណាក់ សម្រាប់គ្រប់ការងារទាំងនោះ និងគ្រប់កិច្ចការហើយអ្វីគ្រប់យ៉ាងដែលធ្វើបានសម្រេច។

[15]ពួកលេវីដែលជាបូជាចារ្យ ជាកូនសាដុក ដែលបានធ្វើបញ្ញើទីសក្ការៈយើង នៅវេលាដែលពួកកូនចៅអ៊ីស្រាអែល បានវង្វេងចេញឆ្ងាយពីយើង ពួកគេនឹងចូលមកជិតយើង ដើម្បីថ្វាយបង្គំយើងវិញ។ ពួកគេនឹងឈរនៅចំពោះយើង ដើម្បីថ្វាយខ្លាញ់ និងឈាម នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។[16]ពួកគេនឹងចូលមកក្នុងទីសក្ការៈរបស់យើង ក៏ចូលមកជិតតុរបស់យើង ដើម្បីថ្វាយបង្គំយើង ព្រមទាំងរក្សាបញ្ញើរបស់យើង។

[17]ដូច្នោះវានឹងបែបនេះ ពេលគេចូលទៅតាមទ្វារកំពែង ទីធ្លាខាងក្នុង ពួកគេនឹងត្រូវស្លៀកពាក់ដោយសំពត់ទេសឯក ដ្បិតគេមិនត្រូវពាក់អ្វីធ្វើពីរោមសត្វទេ ក្នុងទ្វារទីលានខាងក្នុង និងក្នុងព្រះដំណាក់។[18]បានរុំឈ្នួតធ្វើពីសំពត់ទេសឯកនៅលើក្បាល ហើយស្លៀកពាក់ខោស្ទាប់ភ្លៅទេសឯកដែរ គេមិនត្រូវក្រវាត់ខ្លួនដោយអ្វីដែលនាំឲ្យបែកញើសទេ។

[19]កាលណាពួកគេចេញទៅទីលានខាងក្រៅ គឺទៅរកប្រជាជន ដែលនៅទីលានខាងក្រៅ នោះគេត្រូវដោះសម្លៀក បំពាក់ដែលគេស្លៀកពាក់សម្រាប់ធ្វើការងារចេញ ដាក់ទុកក្នុងបន្ទប់បរិសុទ្ធទាំងនោះ ហើយត្រូវស្លៀកពាក់ផ្សេងវិញ ដើម្បីមិនធ្វើឲ្យប្រជាជនបានបរិសុទ្ធ ដោយសារសម្លៀកបំពាក់របស់គេ។

generated on Wed Sep 10 16:16:32 2025

[20]ពួកគេក៏មិនត្រូវកោរសក់ កុំទុកឲ្យសក់របស់គេដុះវែងដល់ចងបាននោះឡើយ តែពួកគេត្រូវកាត់តម្រឹមសក់ក្បាលរបស់ពួកគេ។[21]គ្មានបូជាចារ្យណាម្នាក់ផឹកស្រាទំពាំងបាយជូរ ក្នុងកាលដែលចូលទៅក្នុងទីលានខាងក្នុងឡើយ។[22]ក៏មិនត្រូវយកតែស្ត្រីមេម៉ាយ ឬស្រីប្តីលែង ធ្វើជាប្រពន្ធខ្លួនដែរ គឺត្រូវយកស្រីក្រមុំ ពីពូជកូនចៅអ៊ីស្រាអែល ឬស្ត្រីមេម៉ាយណាដែលជាប្រពន្ធរបស់បូជាចារ្យកាលពីមុន។
[23]ដ្បិតពួកគេត្រូវបង្រៀនប្រជាជនយើងឲ្យចេះសម្គាល់រវាងបរិសុទ្ធ និងអ្វីដែលប្រមាថ ហើយឲ្យគេមើលដឹងរបស់ស្អាត និងរបស់ដែលមិនស្អាត។[24]ក្នុងការទាស់ទែងគ្នា ពួកគេឈរជំនុំជម្រះក្តី ត្រូវឲ្យគេជំនុំជម្រះការនោះ តាមច្បាប់របស់យើង ព្រមទាំងរក្សាអស់ទាំងក្រឹត្យក្រម និងបញ្ញត្តិច្បាប់របស់យើង នៅអស់ទាំងបុណ្យមានកំណត់របស់យើងផង ហើយត្រូវឲ្យគេរក្សាថ្ងៃសប្ប័ទរបស់យើង ទុកជាបរិសុទ្ធដែរ។
[25]ពួកគេនឹងមិនចូលទៅជិតខ្មោចស្លាប់ ឲ្យខ្លួនត្រូវសៅហ្មងទេ លើកលែងតែខ្មោចឪពុកឬម្តាយ កូនប្រុស ឬកូនស្រី បងប្អូនប្រុស ឬបងប្អូនស្រី ដែលមិនទាន់មានប្តីនៅឡើយ នោះគេនឹងឲ្យខ្លួនសៅហ្មង ដោយព្រោះខ្មោចអ្នកទាំងនោះបាន។[26]បន្ទាប់ ពីបូជាចារ្យក្លាយជាមិនស្អាត់ ពួកគេត្រូវរាប់ប្រាំពីរថ្ងៃសម្រាប់បូជាចារ្យនោះ។[27]លុះដល់ថ្ងៃដែលចូលទៅក្នុងទីលានខាងក្នុងនៃទីបរិសុទ្ធ ក្នុងទីបរិសុទ្ធដើម្បីបម្រើ ត្រូវថ្វាយតង្វាយលោះបាបរបស់ខ្លួន នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ។
[28]ការនេះនឹងជាមរតករបស់គេ គឺយើងជាមរតករបស់គេ ហើយអ្នករាល់គ្នាឲ្យមិនបានឲ្យទ្រព្យសម្បត្តិ នៅក្នុងអ៊ីស្រាអែលទេ យើងនឹងជាទ្រព្យរបស់គេហើយ![29]ពួកគេនឹងស៊ីតង្វាយអាហារ តង្វាយលោះបាប ហើយគ្រប់របស់ទាំងអស់ដែលបានថ្វាយដាច់ដល់ព្រះអម្ចាស់ នៅក្នុងពួកអ៊ីស្រាអែល នោះបានជារបស់គេទាំងអស់។
[30]ផលដំបូងដែលល្អបំផុតនៃអ្វីទាំងអស់ ហើយគ្រប់ទាំងចំណែក អ្វីៗគ្រប់យ៉ាងដែលបានពីចំណែករបស់អ្នក វាជារបស់ពួកបូជាចារ្យ ហើយយើងនឹងថ្វាយម្សៅល្អបំផុតដល់អ្នកដល់ពួកបូជាចារ្យ ដូច្នោះព្រះពរនឹងនៅក្នុងព្រះដំណាក់នៃព្រះអង្គ។[31]ពួកបូជាចារ្យមិនត្រូវស៊ីសាច់សត្វ ដែលស្លាប់ដោយជំងឺ ឬស្លាប់ដែលសត្វផ្សេងបានខាំហែក ទោះបើជាសត្វហើរ ឬសត្វជើងបួន។

Ezekiel 44:1
បែរទៅទិសខាងកើត
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤0:៥។
វានឹងមិនបើកឡើយ
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់បើកវាទេ»
ព្រះជាម្ចាស់នៃអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:៣។
ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុង ៨:១៦។
មុខព្រះអម្ចាស់
«នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់» ឬ «នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់»
Ezekiel 44:4
បន្ទាប់មក លោក
អត្ថន័យដែលអាចមានគឺ ១) «បុរសបន្ទាប់» ឬ ២) «បន្ទាប់មកព្រះអម្ចាស់»។
ចូលមើល!
ពាក្យថា« មើល»
នៅទីនេះបង្ហាញថាអេសេគាលមានការភ្ញាក់ផ្អើលចំពោះអ្វីដែលគាត់បានឃើញ។
សិរីល្អនៃព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣:១២។
ខ្ញុំដួលក្រាបផ្កាប់មុខចុះ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១:២៧។
ចូរផ្តង់ចិត្តរបស់អ្នក
សូមមើលពីរបៀបដែលអ្នកបកប្រែ «ផ្តង់ចិត្តលើ» ក្នុងជំពូក ៤0: ៣។
ពីបទបញ្ជាផង
«ការណែនាំទាំងអស់អំពីដំណាក់របស់ព្រះអម្ចាស់»
Ezekiel 44:6
ចូរឲ្យអំពើគួរស្អប់ខ្ពើមទាំងអស់របស់អ្នកល្មមចប់ សម្រាប់អ្នក
«សកម្មភាពគួរស្អប់ខ្ពើមរបស់អ្នកគឺគ្រប់គ្រាន់សម្រាប់អ្នក» ឬ
«អ្នកបានធ្វើអំពើគួរស្អប់ខ្ពើមច្រើនពេក»
អំពើគួរស្អប់ខ្ពើម
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:៩។
Ezekiel 44:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
Ezekiel 44:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
ជាអ្នកបម្រើនៅក្នុងទីសក្ការៈរបស់យើង
«នឹងធ្វើជាបាវបំរើនៅក្នុងព្រះវិហាររបស់យើង»
មើលលើអស់ទាំងទ្វារនៃព្រះដំណាក់
«បំពេញកាតព្វកិច្ចយាមនៅមាត់ទ្វារផ្ទះ»
ពួកគេត្រូវឈរនៅមុខប្រជាជន ហើយបម្រើអ្នកទាំងនោះ
«ពួកលេវីទាំងនេះនឹងឈរនៅមុខប្រជាជន ដូច្នេះពួកគេអាចបម្រើប្រជាជនបាន»
យើងនឹងលើកដៃរបស់យើងស្បថនឹងទាស់
សូមមើលពីរបៀបដែលអ្នកបកប្រែ «យើងបានលើកដៃឡើងដើម្បីស្បថ»
នៅក្នុងជំពូក ២0:៤។
Ezekiel 44:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
ពួកគរ
«ពួកលេវីទាំងនេះ»
ពួកគេមិនត្រូវចូលមកជិតយើង
សូមមើលពីរបៀបដែលបកប្រែ «ចូលមកជិត» នៅក្នុងជំពូក ៤0:៤៦។
ពួកគេនឹងបានផលអាម៉ាស់
«នឹងត្រូវខ្មាស់អៀននិងទទួលរងផលវិបាកសម្រាប់»
ទង្វើគួរស្អប់ខ្ពើម
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:៩។
រក្សាបញ្ញើ
មនុស្សម្នាក់ដែលមានការងារត្រូវការពារ ឬ ថែរក្សាអ្វីមួយ ឬ នរណាម្នាក់
ដែលធ្វើបានសម្រេច
ការបកប្រែរបៀបផ្សេងទៀត: «ថាពួកគេត្រូវការធ្វើនៅក្នុងវា»។
Ezekiel 44:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
ជាកូនសាដុក ដែលបានធ្វើ
«ដែលជាកូនចៅរបស់សាដុក និងបានបំពេញ»
បានវង្វេងចេញឆ្ងាយពីយើង
ឃ្លានេះមានន័យថា «ឈប់ស្តាប់ ហើយ ស្តាប់បង្គាប់តាមយើង»។
នឹងចូលមកជិតយើង
«នឹងមករកយើង»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 44:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែលអំពីកូនចៅរបស់លោកស
ដូច្នោះវានឹងបែបនេះ
«ដូច្នោះ»
ទីធ្លាខាងក្នុង
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
សំពត់ទេសឯក
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៩:១។
រោមសត្វ
ក្រណាត់ ឬ សម្លៀកបំពាក់ធ្វើពីរោមចៀមទន់
ឈ្នួតធ្វើពីសំពត់ទេសឯកនៅលើក្បាល
ឈ្នួតក្បាលគឺជាគម្របក្បាលមួយដែលធ្វើពីក្រណាត់វែងរុំជុំវិញក្បាល។
Ezekiel 44:19

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែលអំពីកូនចៅរបស់លោកសាដុក
ដែលបំពេញមុខងារជាបូជាចារ្យ។

ទីលានខាងក្រៅ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១០:៣។

Ezekiel 44:20

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែលអំពីកូនចៅរបស់លោកសាដុក
ដែលបំពេញមុខងារជាបូជាចារ្យ។

កោរសក់

កាត់សក់របស់មនុស្សឲ្យខ្លីដូច្នេះវាងាយស្រួលក្នុងការមើលឃើញស្បែករបស់មនុស្ស

កាត់តម្រឹមសក់ក្បាលរបស់ពួកគេ

«កាត់សក់លើក្បាលរបស់ពួកគេដើម្បីកុំអោយវែងនិងខ្លីពេក»

ស្ត្រីមេម៉ាយ

ស្ត្រីម្នាក់ដែលប្តីរបស់នាងបានស្លាប់

ពីពូជកូនចៅអ៊ីស្រាអែល

«ដែលជាកូនចៅរបស់ប្រជាជនអ៊ីស្រាអែល»

កូនចៅអ៊ីស្រាអែល

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៣:១។

Ezekiel 44:23

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែលអំពីកូនចៅរបស់លោកសាដុក

ការទាស់ទែងគ្នា

«ជម្លោះ»

Ezekiel 44:25

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែលអំពីកូនចៅរបស់លោកសាដុកដែលបំពេញមុខងារជាបូជាចារ្យ។

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៥:១១។

Ezekiel 44:28

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែលប្រាប់កូនចៅអ៊ីស្រាអែលអំ

ហើយអ្នក

ពាក្យថា «អ្នក» គឺសំដៅទៅលើប្រជាជនអ៊ីស្រាអែល។

ចៅរបស់លោកសាដុក

ទឹកដីដែលមនុស្សម្នាក់កាន់កាប់ និងប្រើប្រាស់ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារ

ក្នុងពួកអ៊ីស្រាអែល

«នៅស្រុកអ៊ីស្រាអែល»

Ezekiel 44:30

ព័ត៌មានទូទៅ:

ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែលអំពីកូនចៅរបស់លោកស

ផលដំបូង

ពាក្យថា «ផលដំបូង» នៅទីនេះប្រហែលជាមានន័យថារបស់ល្អបំផុត
ក្នុងចំណោមតង្វាយទាំងអស់ដែលទុកសម្រាប់ថ្វាយដល់ព្រះអង្គ។

ហើយគ្រប់ទាំងចំណែក អ្វីៗគ្រប់យ៉ាងដែលបានពីចំណែករបស់អ្នក

«និងអំណោយគ្រប់ប្រភេទពីអំណោយទាំងអស់របស់អ្នក» ឬ
«និងអំណោយគ្រប់ប្រភេទនៃអំណោយទាំងអស់របស់អ្នក»

ព្រះពរនឹងនៅក្នុងព្រះដំណាក់នៃព្រះអង្គ។

និងអ្វីៗទាំងអស់ដែលជាកម្មសិទ្ធិរបស់អ្នក»។

ឬស្លាប់ដែលសត្វផ្សេងបានខាំហែក ទោះបើជាសត្វហើរ ឬសត្វជើងបួន

ការបកប្រែរបៀបផ្សេងទៀត: «ឬ សត្វណាមួយដែលបក្សីឬ
សត្វព្រៃបានហែកចេញ»។

---

45 [1]ពេលណាអ្នករាល់គ្នាចាប់ឆ្នោត ដើម្បីបែងចែកទឹកដីដែលជាមត៌ក អ្នកត្រូវញែកដីមួយចំណែកទុកជាដីសក្ការៈសម្រាប់ព្រះអម្ចាស់ ការថ្វាយដីគឺត្រូវតែកន្លែងបរិសុទ្ធ
ដីនោះមានបណ្តោយពីរម៉ឺនប្រាំពាន់ហត្ថ និងទទឹងមួយម៉ឺនហត្ថ។ វានឹងបរិសុទ្ធ នៅកន្លែងជុំវិញរបស់វាផងដែរ។[2]ចេញពីទីនោះ មានទំហំប្រាំរយហត្ថ បួនជ្រុង
ដែលនៅទីធ្លាព័ទ្ធជុំវិញ ទីសក្ការៈជាមួយព្រំទ្រល់ជុំវិញ មានទទឹងហាសិបហត្ថទៀត។
[3]ពីកន្លែងនេះអ្នកនឹងវាស់ដំបូលផ្លូវដើរ មានបណ្តោយពីរម៉ឺនប្រាំពាន់ហត្ថ និងទទឹងមួយម៉ឺនហត្ថ ហើយនឹងវាស់ទីសក្ការៈជាក្លែងបរិសុទ្ធបំផុត។[4]វាជាកន្លែង
បរិសុទ្ធនៅក្នុងទឹកដីនោះ សម្រាប់ពួកបូជាចារ្យ ដែលបម្រើព្រះអម្ចាស់ជាអ្នកដែលចូលទៅជិតព្រះអម្ចាស់ដើម្បីបម្រើព្រះអង្គ។ ទីនោះជាកន្លែងសម្រាប់សង់ផ្ទះពួកគេហើយ
ហើយជាកន្លែងបរិសុទ្ធសម្រាប់ទីបរិសុទ្ធ។[5]ដូច្នោះវានឹងមានបណ្តោយពីរម៉ឺនប្រាំពាន់ហត្ថ និងទទឹងមួយម៉ឺនហត្ថទៀត ហើយវានឹងសម្រាប់ក្រុងពួកលេវី ដែលធ្វើការនៅក្នុង
ព្រះដំណាក់។
[6]អ្នកនឹងត្រូវរៀបចំទុកសម្រាប់ទីក្រុងទទឹងប្រាំពាន់ បណ្តោយពីរម៉ឺនប្រាំពាន់ កន្លែងបន្ទាប់ទីនោះ ត្រូវបម្រុងទុកសម្រាប់ជាទីកន្លែងបរិសុទ្ធ
ទីក្រុងនេះគឺជារបស់កូនចៅអ៊ីស្រាអែលទាំងអស់។[7]ដីមួយចំណែកសម្រាប់អ្នកដឹកនាំ គឺនៅទាំងសងខាងកន្លែងទុកបម្រុងសម្រាប់ទីបរិសុទ្ធហើយទីក្រុង។ គឺពីព្រំប្រទល់
ខាងលិចហើយទៅខាងកើត។ ប្រវែងដីនោះ គឺបានស្មើគ្នាទៅនឹងបណ្តោយដីរបស់ខ្លោងទ្វារដែលមានដំបូលផ្លូវដើរ ពីខាងលិចទល់ទៅដល់ខាងកើត។
[8]ដីនេះគឺជាសម្បត្តិសម្រាប់ អ្នកដឹកនាំក្នុងអ៊ីស្រាអែល។ អ្នកដឹកនាំរបស់យើង នឹងមិនសង្កត់សង្កិនប្រជាជនរបស់យើងទៀតទេ ពួកគេនឹងចែកដីដល់កូនចៅអ៊ីស្រាអែល
តាមកុលសម្ព័ន្ធរបស់គេ។
[9]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ គឺវាគ្រប់គ្រាន់សម្រាប់អ្នក ពួកអ្នកដឹកនាំនៃអ៊ីស្រាអែល! ចូរលះបង់សេចក្តីឃោរឃៅ ហើយការជិះជាន់ សូមធ្វើតាមយុត្តិធម៌ និង
សេចក្តីសុចរិត! ឈប់បណ្តេញប្រជាជនរបស់យើងចេញ! នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ។[10]អ្នកត្រូវមានជញ្ជីងត្រឹមត្រូវ គីរង្វាល់ពេញខ្នាត និងស្មាត់ស្មុំ!
[11]ហើយនិងត្រូវមានចំណុះស្មើគ្នា ដើម្បីឲ្យបានមួយនោះ ដូច្នោះត្រូវជាមួយភាគក្នុងដប់ ក្នុងមួយចាំង។ ហើយឲ្យរង្វាល់នោះ ត្រូវជាមួយភាគក្នុងដប់ ក្នុងមួយចាំងដូចគ្នា
រង្វាល់នោះរាប់តាមចាំង។[12]សេកែល ត្រូវជាម្ភៃកេរ៉ា ហើយម៉ានេ ត្រូវជាម្ភៃ សេកែលបូកនឹងម្ភៃប្រាំសេកែល បូកនឹងដប់ប្រាំសេកែល សម្រាប់អ្នក។
[13]នេះគឺជាចំណែកដែលអ្នករាល់គ្នាត្រូវថ្វាយ គឺក្នុងស្រូវរង្វាល់ភោជ្ជសាលី មួយចាំង ត្រូវថ្វាយមួយភាគក្នុងប្រាំមួយ ក្នុងមួយរង្វាល់ ហើយក្នុងស្រូវឱកមួយចាំង ត្រូវថ្វាយ
មួយភាគក្នុងប្រាំមួយ ក្នុងមួយរង្វាល់ដែរ។[14]តាមទបបញ្ជាថ្វាយតង្វាយប្រេង គឺមួយបាថពីគំរនីមួយៗ ត្រូវថ្វាយមួយភាគក្នុងដប់ (ឯគំរស្មើនឹងហូមើរ គឺត្រូវជាដប់បាថ) ឬ។
[15]ចំណែកហ្វូងចៀមឬពពែ ត្រូវយកមួយក្នុងពីររយសត្វ ដែលរកស៊ីតំបន់ដែលមានទឹកនៃអ៊ីស្រាអែល នឹងប្រើសម្រាប់ថ្វាយតង្វាយដុត ឬនិងតង្វាយមេត្រី ដើម្បីឲ្យបានធួន
នឹងប្រជាជន នេះគឺជាព្រះបន្ទូលនៃអម្ចាស់ដ៏ជាព្រះ។
[16]ប្រជាជនទាំងឡាយដែលនៅក្នុងទឹកដី ត្រូវតម្រូវឲ្យថ្វាយតង្វាយនេះសម្រាប់អ្នកដឹកនាំនៃជនជាតិអ៊ីស្រាអែល។[17]គឺអ្នកដឹកនាំដែលមានចំណែកទទួលខុសត្រូវ
ក្នុងការតង្វាយដុត តង្វាយម្សៅ និងតង្វាយច្រួច នៅថ្ងៃបុណ្យ នៅថ្ងៃដើមខែ ហើយនៅថ្ងៃឈប់សម្រាក គឺនៅគ្រប់បុណ្យមានកំណត់របស់ពួកវង្សអ៊ីស្រាអែល នោះស្រេច
នៅលើអ្នកដឹកនាំ លោកត្រូវរៀបចំតង្វាយសម្រាប់លោះបាប តង្វាយម្សៅ តង្វាយដុត និងតង្វាយមេត្រី ដើម្បីឲ្យបានធួន នឹងជំនួសឲ្យពួកវង្សកូនចៅជនជាតិអ៊ីស្រាអែល។
[18]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ក្នុងខែដំបូង នៅថ្ងៃទីមួយ ក្នុងខែនោះ អ្នកត្រូវយកគោឈ្មោលស្ទាវមួយល្អឥតខ្ចោះ ហើយត្រូវសម្អាតទីបរិសុទ្ធ។
[19]ចំណែកពួកបូជាចារ្យត្រូវយកឈាមតង្វាយលោះបាបនោះ ទៅប្រឡាក់នៅក្របទ្វារនៃព្រះដំណាក់ ហើយនៅគន្លាក់នៃអាសនាទាំងបួនជ្រុង ព្រមទាំងនៅក្របទ្វារកំផែងនៃ
ទីលានខាងក្នុងផង។[20]អ្នកត្រូវធ្វើការនេះ គឺនៅថ្ងៃទីប្រាំពីរខែនោះ សម្រាប់មនុស្សម្នាក់ៗមានបាបដោយមិនតាំងចិត្ត ឬបដិសេធ ក្នុងផ្លូវនេះអ្នកត្រូវយកដង្វាយធួន
ទៅថ្វាយនៅព្រះវិហារ។
[21]ក្នុងខែដំបូង នៃថ្ងៃទីដប់បួន នៃខែនោះ គឺនឹងមាន ដ្បិតអ្នករាល់គ្នាត្រូវធ្វើបុណ្យរំលង ជាបុណ្យដែលត្រូវធ្វើអស់ប្រាំពីរថ្ងៃ ហើយត្រូវស៊ីតែនំបុ័ងឥតដំបែម៉្យាង។[22]នៅថ្ងៃ
នោះ អ្នកដឹកនាំត្រូវរៀបចំគោឈ្មោលមួយ ទុកជាតង្វាយលោះបាប សម្រាប់ខ្លួនលោក និងបណ្តាជននៅក្នុងទឹកដីនោះផង។

generated on Wed Sep 10 16:16:32 2025

[23]ដ្បិតក្នុងរវាងប្រាំពីរថ្ងៃនៃបុណ្យ អ្នកដឹកនាំត្រូវរៀបចំតង្វាយដុតថ្វាយព្រះអម្ចាស់ គឺគោឈ្មោលប្រាំពីរ និងចៀមឈ្មោលប្រាំពីរ ឥតខ្ចោះ រាល់ថ្ងៃគ្រប់ប្រាំពីរថ្ងៃនោះ ព្រមទាំងពពែឈ្មោលមួយរាល់ថ្ងៃដែរ ទុកជាតង្វាយលោះបាប។[24]ហើយអ្នកដឹកនាំត្រូវរៀបតង្វាយម្សៅដែរ គឺត្រូវយកមួយចាំងសម្រាប់គោមួយ និងមួយចាំងសម្រាប់ចៀមឈ្មោលមួយ ហើយប្រេងប្រាំបីកំប៉ុងសម្រាប់ម្សៅមួយចាំង។
[25]នៅក្នុងខែទីប្រាំពីរ ក្នុងថ្ងៃទីដប់ប្រាំ ក្នុងខែនោះ ក្នុងពេលបុណ្យនោះ អ្នកដឹកនាំត្រូវធ្វើដូច្នោះទៀតគ្រប់ប្រាំពីរថ្ងៃ តង្វាយដុត តង្វាយលោះបាប តង្វាយម្សៅ ហើយតង្វាយប្រេងដែរ។

Ezekiel 45:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
នៅកន្លែងជុំវិញរបស់វាផងដែរ
«តំបន់ទាំងអស់នៃព្រំដែនដែលនៅជុំវិញវា»
Ezekiel 45:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
ពីកន្លែងនេះ
ប្រាសាទនិងព្រំដែនជុំវិញប្រាសាទ
ដំបូលផ្លូវដើរ
«ចំណែកដី»
ហត្ថ
សូមមើលពីរបៀបដែលបានបកប្រែ «ប្រវែង» ហត្ថទាំងនេះនៅក្នុងជំពូក ៤០:៥។
Ezekiel 45:6
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
ត្រូវបម្រុងទុកសម្រាប់ជាទីកន្លែងបរិសុទ្ធ
ការបកប្រែរបៀបផ្សេងទៀត: «ដែលអ្នកបានផ្តល់ឲ្យសម្រាប់កន្លែងបរិសុទ្ធ»។
ប្រវែងដីនោះ គឺបានស្មើគ្នាទៅនឹងបណ្តោយដីរបស់ខ្លោងទ្វារដែលមានដំបូលផ្លូវដើរ
មានន័យថាលោកអេសេគាលកំពុងប្រៀបធៀបដីរបស់ព្រះអង្គម្ចាស់ទៅនឹងទំហំដីដែលបានបែងចែកសម្រាប់ពួកអ៊ីស្រាអែលម្នាក់ៗ
ការបកប្រែរបៀបផ្សេងទៀត:
«ប្រវែងនឹងដូចគ្នានឹងប្រវែងនៃផ្នែកមួយនៃផ្នែកដែលត្រូវបានផ្តល់ឲ្យកុលសម្ព័ន្ធ»។
ពីខាងលិចទល់ទៅដល់ខាងកើត
វាបានបញ្ជាក់ថាទាំងនេះជាព្រំប្រទល់ខាងលិចនិងខាងកើតនៃទឹកដីអ៊ីស្រាអែល។
ការបកប្រែរបៀបផ្សេងទៀត: «ពីព្រំប្រទល់អ៊ីស្រាអែលនៅលើសមុទ្រ» ឬ
«ពីព្រំដែនអ៊ីស្រាអែលនៅភាគខាងលិច»។
Ezekiel 45:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
ដីនេះគឺជាសម្បត្តិសម្រាប់ អ្នកដឹកនាំក្នុងអ៊ីស្រាអែល
«នៅលើទឹកដីនេះគឺជាទ្រព្យសម្បត្តិរបស់មេដឹកនាំក្នុងចំណោមប្រជាជនអ៊ីស្រាអែល»
Ezekiel 45:9
គឺវាគ្រប់គ្រាន់សម្រាប់អ្នក
«អ្នកបានធ្វើរឿងនេះច្រើនពេក» ឬ
«អ្នកបានធ្វើបែបនេះអស់រយៈពេលជាយូរមកហើយ»
ជញ្ជីង
ឧបករណ៍ដែលត្រូវបានប្រើសម្រាប់ថ្លឹងវត្ថុដែលមនុស្សបានលក់ឬទិញ
ហើយឲ្យរង្វាល់នោះ ត្រូវជាមួយភាគក្នុងដប់
«ដូច្នេះដប់រង្វាល់ទឹកនឹងមានចំនួនដូចគ្នានឹងចាំង»
ចាំង
ប្រហែល ២២០ លីត្រ
សេកែល
ប្រហែល ១១ ក្រាម
កេរ៉ា
ប្រហែល ០,៥៥ ក្រាម
ម៉ានេ
ប្រហែល ៦៦០ក្រាម
Ezekiel 45:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
រង្វាល់ភោជសាលី មួយចាំង
នេះបានបញ្ជាក់ថានេះគឺជាបរិមាណស្រូវសាលីដែលប្រជាជនប្រមូលផល។
ការបកប្រែរបៀបផ្សេងទៀត: «សម្រាប់ស្រូវសាលីគ្រប់ប្រភេទពីការប្រមូលផល»។
តាមទបបញ្ជាថ្វាយតង្វាយប្រេង គឺមួយ
«នេះគឺជាច្បាប់អំពីប្រេងអំពីការរាល់ប្រេង»
ទឹកនៃអ៊ីស្រាអែល
«ផ្នែកនៃអ៊ីស្រាអែលដែលទទួលបានបរិមាណទឹកល្អ »
នឹងប្រើសម្រាប់
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនឹងប្រើវិភាគទានទាំងនេះសម្រាប់»។
Ezekiel 45:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅកូនចៅអ៊ីស្រាអែល។
បុណ្យមានកំណត់
«ពិធីបុណ្យដែលបានតែងតាំងឡើង»
ពួករង្សអ៊ីស្រាអែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៣:១។
Ezekiel 45:18
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
ក្នុងខែដំបូង នៅថ្ងៃទីមួយ ក្នុងខែនោះ
នេះជាខែដំបូងនៃប្រតិទិនហេប្រឺ។
ថ្ងៃនៃបុណ្យនៅសប្តាហ៍ទីមួយនៃប្រតិទិនលោកខាងលិច។ (សូមមើល: និង
អ្នកត្រូវយក
ពាក្យថា «អ្នក» គឺជាឯកវចន:
ហើយសំដៅទៅលើអ្នកណាគឺជាព្រះអង្គម្ចាស់នៅអ៊ីស្រាអែល។
នៅថ្ងៃទីប្រាំពីរខែ
«នៅថ្ងៃទីប្រាំពីរ នៃខែទីមួយ»
សម្រាប់មនុស្សម្នាក់ៗមានបាបដោយមិនតាំងចិត្ត
«សម្រាប់មនុស្សម្នាក់ៗដែលបានធ្វើបាបដោយគ្មានន័យ» ឬ
«សម្រាប់មនុស្សម្នាក់ៗដែលបានធ្វើបាបដោយចៃដន្យ»
ឬ បដិសេធ
ឬ គាត់បានធ្វើបាប ព្រោះគាត់មិនបានដឹងអ្វីដែលប្រសើរជាង រឺ
គាត់បានធ្វើបាបព្រោះគាត់មិនបានដឹងថាអ្វីដែលត្រូវនោះទេ»។
Ezekiel 45:21
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
ក្នុងខែដំបូង នៃថ្ងៃទីដប់បួន នៃខែនោះ
នេះគឺជាខែដំបូងនៃប្រតិទិនហេប្រឺ។ ថ្ងៃទីដប់បួនគឺជិតដល់ដើមខែមេសា។
ដ្បិត អ្នករាល់គ្នា
ពាក្យថា «អ្នក» គឺជាពហុវចន: ហើយសំដៅទៅលើស្តេច
និងប្រជាជនដទៃទៀតនៃពូជវង្សអ៊ីស្រាអែល។
Ezekiel 45:23
ព័ត៌មានទូទៅ :
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
តង្វាយម្សៅ
នេះក៏ត្រូវបានគេហៅថាជា «តង្វាយធញ្ញជាតិ»។
គឺគោឈ្មោលប្រាំពីរ និងចៀមឈ្មោលប្រាំពីរ ឥតខ្ចោះ
«គោប្រាំពីរ និងចៀមឈ្មោលប្រាំពីរដែលមានសុខភាពល្អទាំងស្រុង»
ចាំង
អ្នកអាចប្តូរវាទៅជាវិធានការទំនើប។ ការបកប្រែរបៀបផ្សេងទៀត: «ម្ភៃពីរលីត្រ»
កំប៉ុង
អ្នកអាចប្តូរវាទៅជាវិធានការទំនើប។ ការបកប្រែរបៀបផ្សេងទៀត: «បួនលីត្រ»
Ezekiel 45:25

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
នៅក្នុងខែទីប្រាំពីរ ក្នុងថ្ងៃទីដប់ប្រាំ ក្នុងខែនោះ
នេះជាខែទីប្រាំពីរ នៃប្រតិទិនហេប្រឺ។ ថ្ងៃទីដប់ប្រាំគឺជិតដល់ដើមខែតុលា។
ក្នុងពេលបុណ្យនោះ
នេះគឺជាពិធីបុណ្យខុសពីពិធីបុណ្យដែលអេសេគាលបានពិពណ៌នាពីមុន។

46 [1]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ «ខ្លោងទ្វារនៃទីលានខាងក្នុង បែរមុខទៅទិសខាងកើត ត្រូវបិទក្នុងរវាងប្រាំមួយថ្ងៃដែលធ្វើការ តែដល់ថ្ងៃសប្ប័ទត្រូវបើកវិញ ព្រមទាំងនៅថ្ងៃចូលខែបើកដែរ។[2]អ្នកដឹកនាំ នឹងចូលតាមផ្លូវទីលានខាងក្រៅ តាមផ្លូវខ្លោងទ្វារហើយច្រកដំបូលផ្លូវដើរពីខាងក្រៅ ហើយលោកឈរនៅពីមុខបង្គោលទ្វារខាងក្នុង ពេលពួកបូជាចារ្យ នឹងរៀបចំតង្វាយដុត និងតង្វាយមេត្រីរបស់លោក។ ហើយលោកនឹងថ្វាយបង្គំនៅត្រង់ទ្វារខាងក្នុងនោះ រួចលោកបែរជាចេញក្រៅទៅវិញ តែទ្វារនោះមិនត្រូវបិទទេរហូតដល់ពេលល្ងាច។
[3]មនុស្សនៅក្នុងទឹកដី នឹងថ្វាយបង្គំនៅចំពោះព្រះអម្ចាស់ នៅមាត់ទ្វារនោះរាល់ថ្ងៃសប្ប័ទ និងថ្ងៃចូលខែដែរ។[4]តង្វាយដុតដែលពួកអ្នកដឹកនាំត្រូវថ្វាយដល់ព្រះអម្ចាស់នៅថ្ងៃសប្ប័ទ គឺកូនចៀមប្រាំមួយឥតខ្ចោះ និងចៀមឈ្មោលមួយឥតខ្ចោះ។[5]តង្វាយម្សៅ ត្រូវជាមួយចាំងសម្រាប់ចៀមឈ្មោលនោះ ហើយតង្វាយម្សៅដែលសម្រាប់កូនចៀមទាំងនោះ ត្រូវតាមដែលលោកអាចនឹងថ្វាយបាន ព្រមទាំងប្រេងប្រាំបីកំប៉ុងសម្រាប់ម្សៅមួយចាំងផង។
[6]នៅថ្ងៃចូលខែចូលមកដល់ លោកត្រូវថ្វាយគោឈ្មោលស្ទាវមួយឥតខ្ចោះ កូនចៀមប្រាំមួយនិងចៀមឈ្មោលមួយ សុទ្ធតែឥតខ្ចោះទាំងអស់។[7]លោកត្រូវតែថ្វាយតង្វាយម្សៅមួយចាំងសម្រាប់គោឈ្មោល និងមួយចាំងសម្រាប់ចៀមឈ្មោលនោះ តែឯកូនចៀមវិញ នោះត្រូវតាមដែលលោកអាចនឹងថ្វាយបាន ព្រមទាំងប្រេងប្រាំបីកំប៉ុងសម្រាប់ម្សៅមួយចាំងផង។[8]ពេលអ្នកដឹកនាំត្រូវចូលតាមផ្លូវទ្វារដំបូលផ្លូវដើរ ហើយក៏ត្រូវចេញទៅវិញ តាមផ្លូវដដែរ។
[9]ប៉ុន្តែ ពេលប្រជាជនក្នុងទឹកដីចូលមក នៅចំពោះព្រះអម្ចាស់ នៅវេលាថ្ងៃបុណ្យមានកំណត់ នោះអ្នកណាដែលចូលតាមផ្លូវទ្វារទិសខាងជើង ដើម្បីនឹងថ្វាយបង្គំ ត្រូវតែចេញទៅតាមផ្លូវនៃទ្វារខាងត្បូងវិញ ហើយអ្នកណាដែលចូលតាមទ្វារទិសខាងត្បូង នោះត្រូវតែចេញតាមផ្លូវទ្វារខាងជើងទៅ គេមិនត្រូវវិលទៅវិញ តាមផ្លូវនៃទ្វារដែលគេបានចូលនោះឡើយ គឺត្រូវចេញទៅតាមផ្លូវត្រង់ខាងមុខជារហូតទៅ។[10]ពួកដឹកនាំត្រូវចូលទៅនៅចំណោមពួកគេ រួចពេលគេចេញទៅ នោះនឹងចេញទៅជាមួយគ្នាដែរ។
[11]នៅថ្ងៃបុណ្យ ត្រូវថ្វាយតង្វាយម្សៅជាមួយចាំងសម្រាប់គោឈ្មោលមួយ និងមួយចាំងសម្រាប់ចៀមឈ្មោលមួយ ហើយកូនចៀមទាំងប៉ុន្មាននោះត្រូវតាមតែលោកអាចនឹងថ្វាយបាន ហើយប្រេងត្រូវជាប្រាំបីកំប៉ុងសម្រាប់ម្សៅមួយចាំង។[12]ពេលអ្នកដឹកនាំថ្វាយតង្វាយស្ម័គ្រពីចិត្ត ជាតង្វាយដុត ឬតង្វាយមេត្រី ទុកជាតង្វាយថ្វាយដល់ព្រះអម្ចាស់ស្ម័គ្រពីចិត្ត នោះត្រូវឲ្យគេបើកទ្វារខាងកើតនោះជូនលោក។ រួចលោកនឹងរៀបតង្វាយដុត និងតង្វាយមេត្រីរបស់លោក ដូចជាធ្លាប់ធ្វើនៅថ្ងៃសប្ប័ទដែរ។ ស្រេចហើយ លោកនឹងចេញទៅ លុះលោកបានចេញទៅហើយ នោះគេនឹងបិទទ្វារវិញ។
[13]ក្នុងចំណុចនេះ អ្នកត្រូវឲ្យរៀបកូនចៀមមួយឥតខ្ចោះ អាយុមួយខួប ទុកជាតង្វាយដុតថ្វាយដល់ព្រះអម្ចាស់ ត្រូវថ្វាយតង្វាយនេះរាល់តែព្រឹកជានិច្ច។[14]រាល់ព្រឹក ត្រូវរៀបតង្វាយម្សៅជាមួយផង គឺជាម្សៅមួយភាគក្នុងប្រាំមួយក្នុងមួយចាំង និងប្រេងផ្សើមមួយភាគក្នុងបីក្នុងមួយហីន ដើម្បីលាយនឹងម្សៅយ៉ាងម៉ដ្ដនោះ ជាតង្វាយដែលថ្វាយដល់ព្រះអម្ចាស់ជានិច្ច តាមច្បាប់ដ៏នៅជាដរាបតទៅ។[15]ពួកគេនឹងរៀបចំកូនចៀម តង្វាយម្សៅ និងប្រេងរាល់ព្រឹក ទុកជាតង្វាយដុតជានិច្ច។
[16]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ ប្រសិនអ្នកដឹកនាំចែកអំណោយអ្វីឲ្យកូនខ្លួន វាចេញពីទ្រព្យខ្លួនដែរ។ នោះនឹងបានជារបស់កូននោះ គឺជាទ្រព្យសម្បត្តិរបស់គេទុកជាកេរអាករ។[17]ប៉ុន្តែបើលោកចែកអំណោយអ្វីពីមរតករបស់លោក ឲ្យដល់បាវរបស់ខ្លួនវិញ នោះនឹងបានជារបស់ផងបាវនោះ ដរាបដល់ឆ្នាំដែលមានសេរីភាព រួចនឹងត្រឡប់មកជាអ្នកដឹកនាំវិញ។ ទ្រព្យរបស់លោកផ្ទាល់ខ្លួនទើបជាមរតករបស់កូនលោកបាន។[18]អ្នកដឹកនាំមិនអាចយកមរតកពីអ្នកដទៃទេ មកចែកឲ្យកូនខ្លួនបានទេ ដូច្នេះប្រជាជនយើងនឹងមិនខ្ចាត់ខ្ចាយទេ ប្រជាជនគ្រប់គ្នានឹងបានសម្បត្តិរបស់គេ»។
[19]បន្ទាប់នោះ បុរសនោះបាននាំខ្ញុំទៅតាមផ្លូវចូល តាមទ្វារ ទៅក្នុងបន្ទប់បរិសុទ្ធសម្រាប់ពួកបូជាចារ្យ ដែលបែរមុខទៅទិសខាងជើង ហើយមើល៍! ឃើញមានកន្លែងមួយដែលឆ្ពោះទៅខាងលិច។[20]លោកប្រាប់ខ្ញុំថា «នេះជាកន្លែងដែលពួកបូជាចារ្យត្រូវស្ងោរតង្វាយ ដែលថ្វាយដោយព្រោះការរំលង និងតង្វាយលោះបាប ព្រមទាំងចម្អិនតង្វាយម្សៅ។ ពួកគេមិនត្រូវយកតង្វាយចូលទៅទីលានខាងក្រៅឡើយ ដ្បិតប្រជាជននឹងទៅជាបរិសុទ្ធ»។
[21]រួចហើយបុរសបាននាំខ្ញុំចេញទៅទីលានខាងក្រៅ ឲ្យខ្ញុំដើរទៅតាមទាំងបួនជ្រុងទីលាននោះ នោះឃើញមានទីលានមួយៗនៅគ្រប់ទាំងជ្រុងនៃទីលាននិងទីធ្លាក់ដទៃផង។[22]គឺនៅជ្រុងទាំងបួននៃទីលាន មានទីលានតូចៗ បណ្តោយសែសិបហត្ថ ទទឹងសាមសិបហត្ថ ទីលានទាំងបួននោះមានទំហំប៉ុនគ្នា។[23]មានរបងមួយជុវធ្វើឡើងពីថ្មព័ទ្ធជុំវិញទីធ្លាទាំងបួន ហើយមានចង្ក្រានធ្វើម្ហូបដែលនៅពីក្រោមរបងថ្មនោះ ។[24]បុរសនោះប្រាប់ខ្ញុំថា «នេះជាន្លែងអ្នកបម្រើការងារក្នុងព្រះដំណាក់ នឹងស្ងោរយញ្ញបូជារបស់មនុស្សទាំងឡាយ»។

Ezekiel 46:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
ទីលានខាងក្នុង
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៨:១៦។
បែរមុខទៅទិសខាងកើត
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១១:១។
ទ្វារខាងក្នុង
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤០:១៧។
Ezekiel 46:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
នៅចំពោះព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤៣:២២។
Ezekiel 46:6
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
ដំបូលផ្លូវដើរ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤០:៨។
Ezekiel 46:9
នៅចំពោះព្រះអម្ចាស់
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤៤:១។
វេលាថ្ងៃបុណ្យមានកំណត់
សូមមើលពីរបៀបដែលបកប្រែ «ពិធីជប់លៀងដែលបានចាត់តាំង» នៅក្នុងជំពូក ៣៦:៣៧។
Ezekiel 46:11
សម្រាប់វា
«សម្រាប់ខ្លួនគាត់ផ្ទាល់»
Ezekiel 46:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅស្តេចអ៊ីស្រាអែល។
ផ្សើម
«ដែលនឹងជ្រលក់»
Ezekiel 46:16
ឆ្នាំដែលមានសេរីភា
នេះគឺជាឆ្នាំដែលអ្នកបំរើទទួលបានសេរីភាព។ នេះក៏ត្រូវបានគេហៅថា «ឆ្នាំនៃមេត្តាករុណា»។
Ezekiel 46:19
ដែលបែរមុខទៅទិសខាងជើង
«ដែលមានច្រកចូលសំខាន់ៗនៅខាងជើង»
មើល៍!
ពាក្យថា «មើល»
នៅទីនេះបង្ហាញថាអេសេគាលបានឃើញអ្វីដែលគួរអោយចាប់អារម្មណ៍។
ទីលានខាងក្រៅ

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១០:៣។
Ezekiel 46:21
ទីលានខាងក្រៅ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ១០:៣។

---

47 [1]បន្ទាប់មក បុរសនោះក៏បាននាំខ្ញុំត្រឡប់ទៅទ្វារនៃព្រះវិហារ នៅទីនោះមានទឹកហូរចេញពីក្រោមមាត់ទ្វារនៃព្រះវិហារ ព្រះដំណាក់បែរមុខទៅទិសខាងកើត
ដ្បិតខាងមុខព្រះវិហារនោះគឺបែរមុខខាងកើត ហើយទឹកនោះហូរមកក្រោម ពីខាងត្បូងនៃព្រះវិហារទៅខាងស្តាំមនៃអាសនា។[2]ដូច្នេះហើយ លោកនាំខ្ញុំចេញទៅតាម
ផ្លូវនៃទ្វារកំផែងខាងជើង ហើយនាំវាងទៅតាមផ្លូវខាងក្រៅ រហូតដល់ទ្វារកំផែងខាងក្រៅដែលបើកទៅខាងកើត ឃើញមានទឹកហូរចេញមកខាងស្តាំទៅរកទិសខាងត្បូង។
[3]ក្នុងពេលដែលបុរសនោះបានចេញទៅខាងកើត នៅទីនោះបានរង្វាស់ខ្សែរនៅក្នុងដៃគាត់ លោកវាស់មួយពាន់ហត្ថ ហើយ នាំខ្ញុំដើរកាត់ទឹក ហើយទឹកនោះបានត្រឹមភ្នែក
គោល។[4]រួចហើយលោកក៏វាស់មួយពាន់ហត្ថទៀត រួចឲ្យខ្ញុំដើរកាត់ទៅ ទឹកត្រង់នោះបានត្រឹមក្បាលជង្គង់ រួចលោកវាស់មួយពាន់ហត្ថទៀត ក៏ឲ្យខ្ញុំលុយកាត់ទៅ ត្រង់នោះ
ទឹកដល់ត្រឹមចង្កេះ។[5]ហើយក្រោយមកទៀត លោកវាស់មួយពាន់ហត្ថទៀត ប៉ុន្តែមានទន្លេដែលខ្ញុំមិនអាចដើរឆ្លងកាត់បានទេ ដ្បិតទឹកបានឡើងកាន់តែខ្ពស់ ដែលទឹកនោះ
អាចលុមនឹងហែលបាន គឺជាទន្លេដែលមិនអាចដើរឆ្លងកាត់បាននោះទេ។
[6]បុរសនោះនិយាយមកខ្ញុំ «កូនមនុស្សអើយ តើបានឃើញហើយឬ?» ហើយលោកនាំខ្ញុំឲ្យត្រឡប់ទៅមាត់ទន្លេនោះវិញ។[7]ដូចដែលខ្ញុំដើរមកវិញ តាមមាត់ទន្លេមានដើម
ឈើជាច្រើនទាំងសងខាង។[8]បុរសនោះប្រាប់ខ្ញុំ «ទឹកនេះហូរចេញទៅទិសខាងកើត ធ្លាក់ចុះទៅដល់តំបន់អារ៉ាប់ ហើយហូរធ្លាក់ទៅសមុទ្រអំបិល លុះហូរធ្លាក់ទៅក្នុងសមុទ្រ
ហើយ ទឹកសមុទ្រនឹងទៅជាទឹកសាបវិញ។
[9]កន្លែងណាដែលទឹកទន្លេនោះហូរទៅ សត្វទាំងអស់ និងមានជីវិតរស់ ក៏មានត្រីច្រើន ដោយព្រោះទឹកនេះហូរទៅដល់ទីនោះ។ វានឹងធ្វើឲ្យទឹកប្រៃទៅជាទឹកសាបវិញ។
កន្លែងណាដែលទឹកទន្លេនេះហូរទៅដល់ នោះគ្រប់យ៉ាងនឹងមានជីវិតរស់។[10]រួចហើយវានឹងកើតឡើងជាមួយពួកនេសាទត្រីនៃអេនកេឌី នឹងឈរក្បែរទឹកនោះ
ហើយនឹងមានកន្លែងសម្រាប់ហាលសំណាញ់ នៅកន្លែងអេនអេកលែម។ ទីនោះមានស្រីច្រើនប្រភេទនៅក្នុងសមុទ្រអំបិល ដូចជាត្រីនៅក្នុងសមុទ្រធំដែរ
ដែលពួកគេបានបោះបង់ចោល។
[11]ប៉ុន្តែ សមុទ្រអំបិលវាលភក់ល្បប់ហើយដីភក់ នឹងមិនបានសាបល្អទេ កន្លែងទាំងនោះនឹងបានទុកសម្រាប់ធ្វើអំបិលវិញ។[12]ចំណែកឯតាមមាត់ច្រាំងទាំងសងខាងទន្លេនោះ
នឹងមានដុះដើមឈើគ្រប់យ៉ាង សម្រាប់ជាអាហារ។ ស្លឹកវាមិនស្វិតស្រពោនឡើយ ហើយផ្លែរបស់វាក៏មិនធ្លាក់ចុះដែរ។ មួយខែម្តងដើមឈើនឹងឲ្យផ្លែថ្មី ពីព្រោះទឹកនោះ
ចេញពីទីសក្ការៈមក ហូរស្រោចដើមឈើទាំងនោះ។ ផ្លែឈើបានសម្រាប់ជាអាហារ ចំណែកស្លឹកសម្រាប់យកទៅធ្វើថ្នាំព្យាបាល។
[13]ព្រះអម្ចាស់ដ៏ជាព្រះមានព្រះបន្ទូលដូច្នេះ «នេះជារបៀបដែលអ្នករាល់គ្នានឹងចែងចែកដីសម្រាប់ កុលសម្ព័ន្ធអ៊ីស្រាអែលទាំងដប់ពីរ លោកយ៉ូសែបនឹងត្រូវបានពីរចំណែក។
[14]អ្នករាល់គ្នានឹងបែងចែកស្មើគ្នា ដ្បិតយើងបានលើកដៃស្បថនឹងឲ្យទឹកដីនេះដល់បុព្វបុរសអ្នករាល់គ្នាហើយ។ ទឹកដីនេះនឹងត្រូវឲ្យដល់អ្នករាល់គ្នា ទុកជាមរតកដែរ។
[15]នេះគឺជាព្រំដែននៃទឹកដីនៅទិសខាងជើង ចាប់ពីសមុទ្រធំដោយតាមផ្លូវទៅហេតឡូន រួចហើយដល់សេដាត។[16]បន្ទាប់មកព្រំដែននឹងទៅដល់ បេរ៉ូថា ហើយដល់ស៊ីបរ៉ែម
ដែលនៅចន្លោះព្រំដែនដាម៉ាស ហើយនិង ហាសា ហាទីកុន ដែលនៅក្បែរព្រំដែននៃហារ៉ុន។[17]ដូច្នេះព្រំដែនចាប់ពីសមុទ្រទៅដល់ ហាសាអេណាន នៅនិងព្រំប្រទល់ជាមួយ
ដាម៉ាស ហើយហាម៉ាត់នៅខាងជើង។ នេះគឺជាផ្នែកនៃទឹកដីខាងជើង។
[18]នៅផ្នែកខាងកើត នៅក្នុងចន្លោះទឹកដីហាវរ៉ុន និងទឹកដីដាម៉ាស ហើយចន្លោះទឹកដីកាឡាត របស់ទឹកដីអ៊ីស្រាអែលតាមដងទន្លេយ័រដាន់។
អ្នកត្រូវវាស់ចាប់ពីព្រំប្រទល់រហូតដល់សមុទ្រខាងកើត ទាំងអស់នេះគឺជាផ្នែកខាងកើតនៃព្រំប្រទល់។[19]រួចហើយផ្នែកខាងត្បូង លាតសន្ធឹងចាប់ពីតាម៉ារ រហូតដល់ទឹក
មេរីបា កាដេស តាមជ្រោះទឹកអេស៊ីប ដែលហូរធ្លាក់ទៅសមុទ្រធំ ហើយនេះជាព្រំដែនខាងត្បូង។[20]ហើយព្រំដែនខាងលិច គឺជាសមុទ្រធំ ចាប់ពីទល់ដែននឹងទ្វារ
ទឹកដីហាម៉ាត។ នេះគឺជាផ្នែកខាងលិច។
[21]ក្នុងរបៀបនេះអ្នកត្រូវបែងចែកទឹកដីនេះ សម្រាប់អ្នក សម្រាប់កុលសម្ព័ន្ធនៃតិអ៊ីស្រាអែល។[22]អ្នកត្រូវចែកគ្នាដោយចាប់ឆ្នោត ទុកជាមរតកសម្រាប់អ្នករាល់គ្នា ហើយ
សម្រាប់ពួកជនជាតិដទៃ ដែលអាស្រ័យនៅជាមួយអ្នករាល់គ្នា ជាពួកអ្នកដែលនឹងបង្កើតកូន នៅកណ្តាលអ្នកដែរ អ្នកទាំងនោះនឹងបានដូចអ្នកដែលកើតនៅក្នុងទឹកដី
អ៊ីស្រាអែល។ អ្នករាល់គ្នានឹងចាប់ឆ្នោត សម្រាប់មរតកនៅក្នុងកុលសម្ព័ន្ធនៃអ៊ីស្រាអែល។[23]ហើយវានឹងកើតដែលជនជាតិដទៃទាំងនោះអាស្រ័យនៅជាមួយ កុលសម្ព័ន្ធ
ក្នុងចំណោមអ្នកដែលកំពុងរស់នៅ។ អ្នកត្រូវឲ្យមរតកដល់គេដែល នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ»។

Ezekiel 47:1
បែរមុខទៅទិសខាងកើត
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤០:៥។
ទៅខាងស្តាំនៃអាសនា
នេះគឺជាផ្នែកខាងស្តាំនៃអាសនៈនៅពេលមនុស្សម្នាក់សំឡឹងមើលវាពេលពួកគេបែរមុខទៅទិសខាងកើត។
ដូច្នេះវាស្ថិតនៅខាងត្បូងនៃអាសនៈ។ ការបកប្រែរបៀបផ្សេងទៀត:
«នៅផ្នែកខាងត្បូងនៃអាសនៈ»។
Ezekiel 47:3
រង្វាស់ខ្សែរ
ខ្សែរសៃ ឬ ខ្សែដែលមនុស្សប្រើដើម្បីវាស់ចម្ងាយដែលឆ្ងាយៗ។
Ezekiel 47:6
កូនមនុស្សអើយ
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ២:១។
តើបានឃើញហើយឬ
ការបកប្រែរបៀបផ្សេងទៀត: «យកចិត្តទុកដាក់លើរឿងនេះ» ឬ
«គិតអំពីរឿងនេះដោយប្រុងប្រយ័ត្ន»
Ezekiel 47:9
រួចហើយវានឹងកើតឡើង
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ២១:៦។
អេនកេឌី
រដូវផ្ការីកដ៏ធំមួយនៅផ្នែកខាងលិចនៃសមុទ្រទឹកប្រៃ
សម្រាប់ហាល
«សម្រាប់ប្រជាជនសួតហួតហែង»
អេនអេកលែម
រដូវផ្ការីកដ៏ធំមួយនៅផ្នែកខាងកើតនៃសមុទ្រប្រៃ
Ezekiel 47:11
ភក់ល្បប់
កន្លែងដែលមានទឹក ប៉ុន្តែក៏មានភក់ផងដែរ។
ទិសខាងកើត។
កន្លែងដែលមានទឹករាក់
Ezekiel 47:13
លោកយ៉ូសែបនឹងត្រូវបានពីរចំណែក
ការបកប្រែរបៀបផ្សេងទៀត: «កូនចៅរបស់យ៉ូសែបនឹងទទួលបានដីពីរផ្នែក»។
បងប្អូនប្រុសស្រីម្នាក់ៗក្នុងចំណោមអ្នករាល់គ្នា
ឃ្លានេះមានន័យថា «មនុស្សម្នាក់ៗទទួលបានដីស្មើៗគ្នា»។
យើងបានលើកដៃស្បថ
សូមមើលពីរបៀបដែលអ្នកបកប្រែ «យើងបានលើកដៃឡើងដើម្បីស្បថ»
នៅក្នុងជំពូក ២០:៤។
នៅក្នុងវិធីដូចគ្នានេះ
«ដូច្នេះ ពិតណាស់នេះ»
Ezekiel 47:15
ហេតឡូន
ឈ្មោះនៃកន្លែងដែលប្រហែលជាវិធីតូចមួយខាងជើង និងខាងកើតនៃទ្រីប៉ូលី។
សេដាត
ឈ្មោះទីក្រុងមួយនៅលីបង់ដែលប្រហែលជានៅកន្លែងដដែលសេដាតសព្វថ្ងៃនេះ។
សេដាតមានចម្ងាយប្រហែល ៥៣
គីឡូម៉ែត្រភាគឥសាននៃកន្លែងដែលលីហាវហាតប្រហែលជា។
បេរ៉ូថា

generated on Wed Sep 10 16:16:32 2025

កន្លែងមួយនៅលើបង់ដែលស្ថិតនៅខាងត្បូងនៃកន្លែងដែលបាបាលបេនេះ
ស៊ីបរ៉ែម
កន្លែងរវាងក្រុងដាម៉ាសនិងហាម៉ាស
ហាសា ហាទីកុន
កន្លែងដែលប្រហែលជារវាងក្រុងដាម៉ាស និងហូរ៉ាន
ហារ៉ុន
នេះជាកន្លែងនៅខាងកើតសមុទ្រកាលីឡេ។
វាប្រហែលជាជិតកន្លែងដែលអេសស៊ូវេដា។
ហាសាអេណាន
កន្លែងមួយនៅប្រទេសស៊ីរី។
វាប្រហែលជានៅកន្លែងតែមួយជាមួយអាល់ឃៀរីតាយ៉ានដែលមានចម្ងាយប្រហែល ១១៣ គីឡូម៉ែត្រភាគឥសានក្រុងដាម៉ាស
Ezekiel 47:18
តាម៉ារ
ទីក្រុងចម្ងាយប្រហែលសាមសិបពីរគីឡូម៉ែត្រភាគនិរតីពីភាគខាងត្បូងនៃសមុទ្រប្រៃ។
មេរីបា កាដេស
កន្លែងមួយនៅជាប់ព្រំដែនអ៊ីស្រាអែលនិងអេស៊ីបពាក់កណ្តាលរវាងសមុទ្រក្រហមនិងសមុទ្រមេឌីទែរ៉ាណេ
ជ្រោះទឹកអេស៊ីប
ជ្រោះជ្រៅធំសម្បើម នៅភាគឥសាននៃស៊ីណាយ
Ezekiel 47:21
សម្រាប់អ្នក
ពាក្យ «ខ្លួនអ្នក» គឺជាពហុវចនៈ ហើយសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ហើយវានឹងកើតដែល
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ២១:៦។
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏ជាព្រះ
មមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៥:១១។

---

48 [1]ទាំងនេះគឺជាឈ្មោះកុលសម្ព័ន្ធទាំងឡាយ។ កុលសម្ព័ន្ធដាន់នឹងទទួលមួយចំណែកពីទឹកដីដែលស្ថិតនៅតាមព្រំប្រទល់ចុងខាងជើងបំផុតគឺជាព្រំប្រទល់
នៃអ៊ីុស្រាអែល គឺនៅតាមបណ្តោយផ្លូវពីហេតឡូនទៅ លីបូហាម៉ាត់។ ហើយព្រំប្រទល់ម្ខាងទៀតទៅដល់ ហាសាអេណាន ព្រំប្រទល់ដាម៉ាស គឺទៅដល់ខាងជើង
ហាម៉ាត់។ ព្រំប្រទល់ដាន់លាតសន្ធឹង ទៅដល់ទិសខាងលិច ទៅរហូតដល់សមុទ្រធំ។[2]កុលសម្ព័ន្ធអេស៊ើរស្ថិតនៅជាប់នឹងទឹកដីដាន់ ចាប់ពីខាងកើតទៅខាងលិច
អេសើុរបានមួយចំណែកដែរ។[3]ជិតគ្នានិងព្រំប្រទល់អេស៊ើរដែលនៅផ្នែកកើតដល់ខាងលិច ណែបថាលីនឹងបានមួយចំណែកដែរ។
[4]នៅជាប់ព្រំប្រទល់គ្នាណែបថាលីនៅជាប់នឹងគ្នាចាប់ពីខាងកើតទៅខាងលិច ម៉ាណាសេចាប់ពីខាងកើតទៅខាងលិច នឹងបានមួយចំណែកផងដែរ។
[5]នៅជាប់ព្រំប្រទល់គ្នាម៉ាណាសេចាប់ពីខាងកើតទៅខាងលិច អេប្រាអ៊ីមនឹងបានមួយចំណែកដែរ។[6]នៅជាប់គ្នាព្រំប្រទល់អេប្រាអ៊ីម ចាប់ពីខាងកើតទៅខាងលិច
រូបេននឹងបានមួយចំណែកដែរ។[7]នៅជាប់គ្នាព្រំប្រទល់រូបេន ចាប់ពីខាងកើតទៅខាងលិច យូដានឹងបានមួយចំណែកដែរ។
[8]ដីសម្រាប់តង្វាយដែលអ្នកនឹងធ្វើ គឺជាប់នឹងព្រំប្រទល់ជាមួយយូដា ហើយពង្រីកចាប់ពីខាងកើតរហូតដល់ខាងលិច គឺមានទទឹងពីរម៉ឺនប្រាំពាន់ខ្នាត។ ហើយបណ្តោយក៏
ប៉ុននឹងចំណែកទឹកដីឯទៀត គឺចាប់តាំងពីខាងកើត រហូតដល់ខាងលិច ហើយព្រះវិហារត្រូវនៅកណ្តាលទីនោះ។[9]ដីនៅត្រង់កន្លែងនេះ ជាតង្វាយដែលអ្នករាល់គ្នាត្រូវថ្វាយ
ដល់ព្រះអម្ចាស់ នោះត្រូវបណ្តោយពីរម៉ឺនប្រាំពាន់ហត្ថ ហើយទទឹងមួយម៉ឺនហត្ថ។
[10]កន្លែងនេះត្រូវតែ ញែកចេញជាកន្លែងដ៏មួយចំណែកដែលបរិសុទ្ធ ពួកបូជាចារ្យនឹងត្រូវបានទទួលចំណែកដីនេះ ដោយវាស់តាំងពីខាងជើងនោះ បណ្តោយពីរម៉ឺនប្រាំពាន់
ហត្ថ ហើយខាងលិច មានទទឹងជាមួយម៉ឺនហត្ថ ខាងកើតទទឹងមួយម៉ឺនហត្ថ ហើយខាងត្បូងបណ្តោយពីរម៉ឺនប្រាំពាន់ហត្ថ ចំណែកនៃកន្លែងបរិសុទ្ធរបស់ព្រះអម្ចាស់នឹងនៅ
កណ្តាលនោះ។[11]ដីនោះនឹងទុកសម្រាប់ពួកបូជាចារ្យ ជាកូនចៅសាដុក ដែលបានញែកជាបរិសុទ្ធ ហើយក៏រក្សាបញ្ញើរបស់យើង មិនដែលវង្វេងចេញពីយើង ក្នុងកាលដែល
ពួកអ៊ីស្រាអែលបានវង្វេង ដូចជាពួកលេវីបានវង្វេងនោះឡើយ។[12]តង្វាយបរិសុទ្ធសម្រាប់ពួកបូជាចារ្យ គឺជាចំណែកនៃដីដែលបរិសុទ្ធបំផុត។ ជាប់នឹងព្រំប្រទល់របស់ពួក
លេវី។
[13]ព្រំប្រទល់ទឹកដីពួកលេវី ជាប់ជាមួយទឹកដីពួកពូជាចារ្យ ដែលមានបណ្តោយពីរម៉ឺនប្រាំពាន់ហត្ថ ហើយទទឹងមួយម៉ឺនហត្ថផងដែល។ ទាំងមូលមានពីរប៉ណ្ណកាន់កាប់
ហើយបណ្តោយពីរម៉ឺនប្រាំពាន់ហត្ថ និងទទឹងពីរម៉ឺនហត្ថ។[14]ពួកគេមិនត្រូវឲ្យគេលក់អ្វីពីនោះឡើយ ក៏មិនត្រូវប្តូរ ឬបញ្ជូនផលដំបូងចេញពីដីរបស់អ៊ីុស្រាអែល ទៅ
ទីកន្លែងផ្តេងទៀតដែរ អ្នកត្រូវញែកផលទាំងនោះជារបស់បរិសុទ្ធ ដើម្បីថ្វាយដល់ព្រះអម្ចាស់។
[15]ហើយដីដែលនៅសល់ គឺដីប្រាំពាន់ខ្នាតដែលសល់នៅតាមទទឹងនៅខាងមុខចំណែកពីរម៉ឺនប្រាំពាន់ងត្ថ នោះសម្រាប់ប្រើជុំគ្នាសម្រាប់ទីក្រុង ឲ្យធ្វើទីលំនៅ ហើយសម្រាប់
ជាដីទំនេរ ចំណែកទីក្រុង ត្រូវនៅកណ្តាលនោះ។[16]ចំណែកនេះ គឺជាទំហំទីក្រុងដែលបានវាស់ទុក្ខរួចហើយ គឺខាងជើង ត្រូវជា ៤៥០០ ខ្នាតតាមបណ្តោយដល់ ខាង
ត្បូង៤៥០០ ហត្ថដែលតាមបណ្តោយ ដល់ខាងកើតក៏មាន ៤៥០០ ហត្ថតាមបណ្តោយដែលទៅដល់ខាងលិច៤៥០០ ហត្ថដែរ។
[17]ទីក្រុងនោះត្រូវមានវាលទំនេរដែលនៅជុំវិញ គឺខាងជើង ត្រូវមានទំហំ ២៥០ហត្ថជំរៅ ចំណែកទៅខាងត្បូង មានទំហំ ២៥០ហត្ថជំរៅ ខាងកើតមានទំហំ២៥០ហត្ថជំរៅ
និងខាងលិចក៏ត្រូវមានទំហំ ២៥០ហត្ថជំរៅផងដែរ។[18]ដីដែលសល់នៅតាមបណ្តោយជាប់តពីដីបរិសុទ្ធ ខាងកើតត្រូវជាមួយម៉ឺនខ្នាត ហើយខាងលិចមួយម៉ឺនខ្នាត នោះជា
ដីជាប់តពីដីបរិសុទ្ធ ចំណែកផលចម្រើនពីដីនោះ នឹងបានសម្រាប់ជាអាហារដល់ពួកអ្នកដែលធ្វើការនៅក្នុងទីក្រុង។
[19]ប្រជាជនដែលបានធ្វើការនៅក្នុងទីក្រុង ពីគ្រប់ទាំងកុលសម្ព័ន្ធអ៊ីស្រាអែល គេនឹងភ្ជួររាស់ដីនោះ។[20]ដីទាំងអស់ដែលថ្វាយជាតង្វាយ ទាំងអស់បណ្តោយត្រូវជាពីរម៉ឺនប្រាំ
ពាន់ខ្នាត ហើយទទឹងពីរម៉ឺនប្រាំពាន់ហត្ថ។ នៅក្នុងរបៀបនេះអ្នកទាំងអស់គ្នាត្រូវថ្វាយដ៏បរិសុទ្ធនៃដីទាំងនោះ ព្រមទាំងដីសម្រាប់ទីក្រុងផង។
[21]ដីដែលសល់គ្រប់ផ្នែកទាំងអស់ពីការថ្វាយដ៏បរិសុទ្ធ ហើយនិងដីសម្រាប់ទីក្រុងនឹងឲ្យទៅអ្នកដឹកនាំ។ ការកាន់កាប់ដីរបស់អ្នកដឹកនាំគឺតាំងពីខាងកើតពង្រីកដល់ទំហំ ពីរ
ម៉ឺនប្រាំពាន់ហត្ថ ចេញទៅព្រំប្រទល់ទៅដ៏ថ្វាយជាទីវិសុទ្ធ ទៅដល់និងព្រំប្រទល់ខាងកើត ហើយក៏កាន់កាប់ដល់ទិសខាងលិចទំហំ ពីរម៉ឺនប្រាំពាន់ហត្ថ ចេញទៅព្រំប្រទល់
ខាងលិច។ ប៉ុន្តែនៅកណ្តោលនោះត្រូវថ្វាយសម្រាប់ទីបរិសុទ្ធនៃព្រះវិហារ ត្រូវនៅកណ្តាលនោះ។[22]ហើយដីដែលត្រូវបានពង្រីកពីដីរបស់ពួកលេវី ហើយនិងពីដី
ដែលសម្រាប់ទីក្រុងនោះ ដែលនៅកណ្តាលទឹកដីសម្រាប់អ្នកដឹកនាំ គឺពីព្រំប្រទល់នៃយូដា ហើយនិងព្រំប្រទល់នៃបេនយ៉ាមីន ហើយនិងយូដា ដីនេះ
សម្រាប់ពួកអ្នកដឹកនាំ។
[23]សម្រាប់កុលសម្ព័ន្ធផ្សេងទៀត ចាប់តាំងពីខាងកើតរហូតដល់ខាងលិច។ កុលសម្ព័ន្ធបេនយ៉ាមីន នឹងបានទទួលមួយចំណែក។[24]ជាប់នឹងទឹកដីរបស់បេនយ៉ាមីន ចាប់តាំង
ពីខាងកើតរហូតដល់ខាងលិច កុលសម្ព័ន្ធស៊ីម្មាននឹងបានមួយចំណែក។[25]ជាប់នឹងទឹកដីរបស់ស៊ីម្មាន ចាប់តាំងពីខាងកើតរហូតដល់ខាងលិច កុលសម្ព័ន្ធអ៊ីសាខារ
នឹងបានមួយចំណែក។[26]ជាប់នឹងទឹកដីរបស់អ៊ីសាខារ ចាប់តាំងពីខាងកើតរហូតដល់ខាងលិច កុលសម្ព័ន្ធសាប់យូឡូន នឹងបានមួយចំណែក។
[27]ខាងត្បូងនៃសាប់យូឡូន ចាប់តាំងពីខាងកើតរហូតដល់ខាងលិច មានចំណែកមួយសម្រាប់កុលសម្ព័ន្ធកាដ។[28]ហើយនៅខាងត្បូងព្រំប្រទល់កាដ ត្រូវលាតសន្ធឹងចាប់ពី
ក្រុងតាម៉ារ ទៅដល់ទឹកធ្លាក់ មេរីបាកាដេស ជាប្រភពទឹកជ្រោះអេស៊ីប រហូតដល់សមុទ្រធំ។[29]នេះជាទឹកដីដែលអ្នករាល់គ្នាត្រូវចាប់ឆ្នោត បែងចែកដល់កុលសម្ព័ន្ធទាំង
នោះនៃអ៊ីស្រាអែល ទុកជាមរតករបស់គេ។ ទាំងនេះគឺជាចំណែកពួកគេ។ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ។
[30]នេះគឺជាច្រកចេញពីទីក្រុង គឺខាងជើងមានទំហំបណ្តោយ ៤៥០០ ហត្ថតាមរង្វាស់។[31]ហើយមានទ្វារបី ហើយនឹងមានឈ្មោះរបស់វា ទៅតាមឈ្មោះអស់ទាំងកុលសម្ព័ន្ធ
ជនជាតិអ៊ីស្រាអែល ទ្វារទីមួយរូបេនមួយ ទ្វារទីពីរយូដាមួយ និងទ្វារទីបីលេវី។[32]ហើយនៅខាងកើតដែលត្រូវវាស់មាន ៤៥០០ ហត្ថប្រវែងនោះ ហើយទ្វារបី គឺទ្វារយ៉ូសែប
មួយ ទ្វារបេនយ៉ាមីនមួយ និងទ្វារដាន់មួយ។
[33]នៅខាងត្បូងមានទំហំ ៤៥០០ ហត្ថបណ្តោយ ហើយទ្វារបី គឺទ្វារសម្រាប់ស៊ីម្មានមួយ និងទ្វារសម្រាប់អ៊ីសាខារមួយ និងទ្វារសម្រាប់សាប់យូឡូនមួយ។[34]នៅខាងលិច
ដែលបានវាស់មានទំហំ ៤៥០០ហត្ថ ហើយមានទ្វារបី គឺទ្វារសម្រាប់កាដមួយ និងទ្វារសម្រាប់អេស៊ើរមួយ ហើយនិងទ្វារសម្រាប់ ណែបថាលីមួយដែរ។[35]ទំហំដេលជុំវិញទី
ក្រុង ត្រូវជាមួយម៉ឺនប្រាំបីពាន់ហត្ថ តាំងពីថ្ងៃនោះតទៅ ទីក្រុងនោះត្រូវមានឈ្មោះថា «ព្រះអម្ចាស់គង់នៅទីនោះ»។

---

generated on Wed Sep 10 16:16:32 2025

Ezekiel 48:1
មួយចំណែកពីទឹកដី
«ដីមួយដុំដែលអ្នកនឹងចែកចាយ»
ហេតឡូន...លីបូហាម៉ាត់...ហាសាអេណាន
សូមមើលពីរបៀបដែលបានបកប្រែវានៅក្នុងជំពូក ៤៧:១៥។
Ezekiel 48:4
មួយចំណែក
សូមមើលពីរបៀបដែលបានបកប្រែ «ចំណែកមួយនៃដី» នៅក្នុងជំពូក ៤៨:១។
ចាប់ពីខាងកើតទៅខាងលិច
សូមមើលពីរបៀបដែលបានបកប្រែនៅក្នុងជំពូក ៤៨:១។
Ezekiel 48:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តអោយលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅប្រជាជនអ៊ីស្រាអែល។
ហត្ថ
សូមមើលពីរបៀបដែលអ្នកបកប្រែ «ប្រវែង» ហត្ថទាំងនេះនៅក្នុងជំពូក ៤០:៥។
ទទឹង
«ពីខាងជើងទៅខាងត្បូង»
Ezekiel 48:10
តង្វាយបរិសុទ្ធសម្រាប់ពួកបូជាចារ្យ គឺជាចំណែកនៃដីដែលបរិសុទ្ធបំផុត
«ចំណែកតូចជាងនេះនៅក្នុងដីដ៏វិសុទ្ធជាកម្មសិទ្ធិរបស់បូជាចារ្យទាំងនេះ
ដែលជាចំណែកដ៏វិសុទ្ធជាងចំណែកដ៏វិសុទ្ធនៃទឹកដី»។
Ezekiel 48:13
ផលដំបូង
«ដីនេះគឺជាផលដំបូងបង្អស់»។ ពាក្យថា «ផលដំបូង»
នៅទីនេះប្រហែលជាមានន័យថារបស់ល្អបំផុតក្នុងចំណោមតង្វាយទាំងអស់ដែលទុកសម្រាប់ព្រះអម្ចាស់។
ដីនេះត្រូវបានគេនិយាយតាមរបៀបនេះដូចជាដីដែលទុកសម្រាប់ការប្រើប្រាស់របស់ព្រះអម្ចាស់
Ezekiel 48:15
នោះសម្រាប់ប្រើជុំគ្នាសម្រាប់ទីក្រុង
«នឹងក្លាយជាតំបន់មួយដែលត្រូវបានចែករំលែកក្នុងចំណោមប្រជាជនទីក្រុង»
ឲ្យធ្វើទីលំនៅ ហើយសម្រាប់ជាដីទំនេរ
«ជាកន្លែងសម្រាប់ផ្ទះ និងកន្លែងទំនេរ»
Ezekiel 48:17
ដីនោះ នឹងបានសម្រាប់
«អ្វីដែលដាំដុះនៅទីនោះ»
Ezekiel 48:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តឲ្យលោកអេសេគាលថ្លែងសាររបស់ព្រះអង្គទៅប្រជាជនអ៊ីស្រាអែល។
នៅក្នុងរបៀបនេះអ្នកទាំងអស់គ្នាត្រូវថ្វាយដ៏បរិសុទ្ធនៃដីទាំងនោះ ព្រមទាំងដីសម្រាប់ទីក្រុងផង
«អ្នកនឹងថ្វាយតង្វាយដ៏វិសុទ្ធព្រមទាំងទ្រព្យសម្បត្តិរបស់ក្រុង»។
អ្នក
នេះជាពហុវចនៈហើយសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ថ្វាយដ៏បរិសុទ្ធ
ទឹកដីដែលជនជាតិអ៊ីស្រាអែលបានប្រគល់ជូនព្រះអម្ចាស់សម្រាប់កុលសម្ព័ន្ធលេវីក្រុមបូជាចារ្យ
និងព្រះវិហារ
Ezekiel 48:21
ការថ្វាយដ៏បរិសុទ្ធ
សូមមើលពីរបៀបការបកប្រែនៅក្នុងជំពូក ៤៨:១៧។
Ezekiel 48:23
មួយចំណែក
សូមមើលពីរបៀបដែលបកប្រែ «ដីមួយចំណែក» នៅក្នុងជំពូក ៤៨:១។
Ezekiel 48:27
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តផ្តល់សារទៅលោកអេសេគាលពីប្រជាជនអ៊ីស្រាអែល។
តាម៉ារ...មេរីបាកាដេស...ប្រភពទឹកជ្រោះអេស៊ីប
សូមមើលពីរបៀបដែលបកប្រែនៅក្នុងជំពូក ៤៧:១៨។
អ្នក
នេះគឺជាពហុវចនៈ ហើយសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ចាប់ឆ្នោត
សូមមើលពីរបៀបដែលបកប្រែនៅក្នុងជំពូក ៤៥:១។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដ៏ជាព្រះ
សូមមើលពីរបៀបដែលបកប្រែនៅក្នុងជំពូក ៥:១១។
Ezekiel 48:30
ហត្ថ
សូមមើលពីរបៀបដែលអ្នកបកប្រែ «ប្រវែង» ហត្ថទាំងនេះនៅក្នុងជំពូក ៤០:៥។
៤៥០០ ហត្ថ
ប្រហែល ២,៤ គីឡូម៉ែត្រ។
Ezekiel 48:33
ហត្ថ
សូមមើលពីរបៀបដែលអ្នកបកប្រែទាំងនេះ «ប្រវែង» ហត្ថទាំងនេះនៅក្នុងជំពូក ៤០:៥។
៤៥០០ ហត្ថ
ប្រហែល ២,៤ គីឡូម៉ែត្រ។

ដានីយ៉ែល

1 [1]នៅក្នុងឆ្នាំទីបីនៃរជ្ជកាលព្រះបាទយេហូយ៉ាគីម ជាស្តេចនៃស្រុកយូដា ព្រះចៅនេប៊ូក្នេសា ជាស្តេចនៃបាប៊ីឡូន
បានលើកទ័ពមកឡោមព័ទ្ធក្រុងយេរូសាឡឹមដើម្បីសម្រាប់កាត់ផ្តាច់ផ្លូវស្បៀងផង។[2]ព្រះអម្ចាស់បានប្រគល់ឲ្យព្រះចៅនេប៊ូក្នេសា
បានទទួលជោគជ័យលើព្រះបាទយេហូយ៉ាគីម ជាស្តេចនៃយូដា ហើយប្រគល់ប្រដាប់ប្រដាខ្លះៗពីព្រះវិហារនៃព្រះជាម្ចាស់។
ស្តេចក៏បាននាំយកប្រដាប់ប្រដាទាំងនោះទៅកាន់ទឹកដីបាប៊ីឡូន ហើយទៅដាក់នៅក្នុងដំណាក់នៃព្រះរបស់ទ្រង់
ហើយក៏ដាក់របស់សក្ការៈនៅក្នុងរតនាគាររបស់ព្រះនៃទ្រង់។
[3]ព្រះមហាក្សត្របានមានបន្ទូលទៅកាន់លោកអាសផ្នាស ដែលជាមេលើពួកមន្ត្រីឱ្យនាំជនជាតិអ៊ីស្រាអែលទាំងអ្នកដែលជាប់ពូជពង្សខ្សែស្រឡាយស្តេច
និងពួកអ្នកដែលមានត្រកូលជាអភិជន[4]ពួកយុវជនដែលមានលក្ខណៈសម្បត្តិល្អឥតខ្ចោះ មានរូបសម្បត្តិល្អ ហើយឆ្លាតវាងវៃ ពេញទៅដោយចំណេះដឹង និងការយល់ដឹង
ដែលអាចបម្រើនៅក្នុងដំណាក់របស់ព្រះមហាក្សត្រ។ លោកនឹងបង្រៀនយុវជននោះនូវផ្នែកអក្សរសាស្ត្រ និងភាសាផងដែរ។
[5]ព្រះមហាក្សត្របានតម្រូវឱ្យគេយកចំណែកនៃអាហាររបស់ពួកហ្លួង ទៅចែកដល់ពួកគេរាល់ថ្ងៃ ព្រមទាំងស្រាដែលទ្រង់ផ្សាប់តែសោយផងដែរ។
ពួកយុវជនទាំងនោះត្រូវទទួលការអប់រំអស់រយៈពេលបីឆ្នាំ មុននឹងចូលបម្រើស្តេច។
[6]ក្នុងចំណោមយុវជនទាំងនោះមាន ដានីយ៉ែល ហាណានា មីសាអែល និងអ័សារាជាជនជាតិកយូដាខ្លះទៀត។
[7]លោកដែលជាមេលើមន្ត្រីបានដាក់ឈ្មោះឲ្យពួកគេទាំងនោះ៖ ដានីយ៉ែល លោកហៅថាបែលថិស្សាសារ ហើយហាណានាថា លោកហៅថាសាដ្រាក់
មីសាអែលលោកហៅថាមែសាក់ ហើយ អ័សារាលោកហៅថា អ័បែឌនេកោ។
[8]ប៉ុន្តែដានីយ៉ែលបានតាំងចិត្តថា គាត់នឹងមិនធ្វើឲ្យខ្លួនឯងមិនបរិសុទ្ធដោយសារអាហារ និង ស្រាដែលស្តេចបានសោយនោះទេ។ ដូច្នេះគាត់ក៏សុំការអនុញ្ញាតពីមេលើមន្ត្រី
ដើម្បីកុំឲ្យគាត់ត្រឡប់ទៅជាមិនបរិសុទ្ធ។[9]ព្រះជាម្ចាស់ បានប្រទានឲ្យដានីយ៉ែលទទួលបានការសន្តោស
និងការអាណិតអាសូរពីការគោរពដែលមេលើមន្ត្រីបានមានដល់លោក។[10]លោកមេលើមន្ត្រីលើបានពោលទៅកាន់ដានីយ៉ែលថា «ខ្ញុំខ្លាចព្រះករុណាជាម្ចាស់នៃខ្ញុំណាស់
ត្បិតទ្រង់បានបញ្ជាឲ្យខ្ញុំយកអាហារ និង ស្រាទាំងនេះមកឲ្យពួកលោកបរិភោគ។ ហេតុអ្វីអ្នកចង់ឲ្យទ្រង់ឃើញអ្នកក្នុងសភាពអាក្រក់ជាង
យុវជនផ្សេងទៀតដែលមានវ័យស្រករអ្នកដូច្នេះ? ព្រះករុណាជាម្ចាស់នឹងកាត់ក្បាលខ្ញុំជាមិនខានដោយសារតែអ្នក»។
[11]គ្រានោះដានីយ៉ែលក៏បាននិយាយទៅកាន់ម្នាក់ដែលជាមន្ត្រីលើពួកមន្ត្រីតាំងឲ្យមើលលើដានីយ៉ែល ហាណានា មីសាអែល និងអ័សារាថា[12]លោកនិយាយថា
«សូមសាកល្បងលជាមួយយើងខ្ញុំជាអ្នកបម្រើលោក ក្នុងរយៈពេលដប់ថ្ងៃសិនចុះ។ សូមឲ្យយើងខ្ញុំបរិភោគតែបន្លែ និងទឹកសិនចុះ។

generated on Wed Sep 10 16:16:32 2025

[13]រួចហើយចាំលោកប្រៀបធៀបរូបរាងរបស់យើងខ្ញុំជាមួយនឹងយុវជនផ្សេងទៀតដែលបានបរិភោគអាហាររបស់ស្តេច
ហើយលោកអាចនឹងប្រព្រឹត្តិនឹងយើងខ្ញុំដែលជាអ្នកបម្រើលោក តាមដែលលោកយល់ឃើញទៅចុះ»។
[14]ដូច្នេះលោកនោះក៏យល់ព្រមតាមសំណើររបស់គាត់ដើម្បីធ្វើការនោះ ហើយនឹងសាកល្បងរយៈពេលដប់ថ្ងៃ។[15]លុះកន្លងបានដប់ថ្ងៃ មុខមាត់របស់ពួកគេបែរជាស្រស់ថ្លា
ហើយរាងកាយស្វាហាប់ជាងពួកយុវជនដែលបរិភោគអាហាររបស់ស្តេចទៅទៀត។[16]ដូច្នេះលោកមន្ត្រីត្រួតត្រានោះក៏ដកយក អាហារ និងស្រាចេញ
ហើយឲ្យតែបន្លែដល់ពួកគេប៉ុណ្ណោះ។
[17]ចំណែកយុវជនទាំងបួននាក់នោះ ព្រះជាម្ចាស់បានប្រទាន ឲ្យពួកគេមានប្រាជ្ញាវៀងវៃ ខាងអក្សរសាស្ត្រ
និងមានចំណេះដឹងហើយដានីយ៉ែលមានសមត្ថភាពអាចយល់កាត់ស្រាយរាល់ទាំងនិមិត្ត និងសុបិន្តផ្សេងៗ។[18]ដល់ពេលកំណត់មកដល់ស្តេចបានបញ្ជាឲ្យនាំពួកគេចូល
លោកជាមេមន្ត្រីក៏បាននាំពួកគេទៅគាល់ពីមុខព្រះចៅនេប៊ូក្នេសា។
[19]ស្តេចក៏បានមានបន្ទូលទៅកាន់ពួកគេ ហើយដោយក្នុងចំណោមនោះពុំមាននណារអាចប្រៀបស្មើនឹង ដានីយ៉ែល ហាណានា មីសាអែល និង អ័សារាបានឡើយ។
ពួកគេឈរនៅចំពោះមុខស្តេច ទាំងត្រៀមខ្លួនរួចរាល់ក្នុងការបម្រើទ្រង់។[20]គ្រប់អស់ទាំងសំនួរផ្សេងៗ ដែលពេញដោយតំរិះ និងប្រាជ្ញាដែលស្តេចបានសួរ
ស្តេចឃើញថាពួកគេពូកែជាងដប់ដងបើប្រៀបនិងគ្រូមន្តអាគមន៍ និង គ្រូអង្គុយធម៌ទាំងប៉ុន្មាននៅក្នុងនគររបស់ស្តេច។[21]ដានីយ៉ែលក៏នៅទីនោះ
រហូតដល់រជ្ជកាលទីមួយនៃព្រះបាទស៊ីរូស។

Daniel 1:1

ព្រះចៅនេប៊ូក្នេសា ជាស្តេចស្រុកបាប៊ីឡូន

នេះគឺសំដៅទៅលើស្តេចនេប៊ូក្នេសា ហើយទាហានរបស់ទ្រង់
គឺមិនមែនតែស្តេចនេប៊ូក្នេសាទេ។ ការបកប្រែរបៀបផ្សេងទៀត:
«ទាហានរបស់ស្តេចនេប៊ូក្នេសា» ឬ «នេប៊ូក្នេសាជាស្តេចនៃស្រុកបាប៊ីឡូន
និងទាហានរបស់ទ្រង់»

ដើម្បីកាត់ផ្តាច់ការផ្គត់ផ្គងដល់ទីក្រុងផង

«ដើម្បីបញ្ឈប់ប្រជាជនពីការទទួលបានការផ្គត់ផ្គង់ណាមួយ»

ព្រះបាទយេហូយ៉ាគីម ជាស្តេចនៃស្រុកយូដា

នេះសំដៅទៅលើយេហូយ៉ាគីម និងទាហានរបស់ទ្រង់
គឺមិនមែនតែស្តេចយេហូយ៉ាគីមទេ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកទាហាននៃស្តេចយេហូយ៉ាគីម ជាស្តេចនៃស្រុកយូដា»

ស្តេចបានប្រគល់ដល់នេប៊ូក្នេសា

ស្តេចយេហូយ៉ាគីមបានប្រទានឲ្យដល់ស្តេចនេប៊ូក្នេសា

ស្តេចក៏បាននាំយក...នៅក្នុងព្រះដំណាក់

ទោះបីជាស្តេចនេប៊ូក្នេសា មិនបានធ្វើការទាំងនេះតែម្នាក់ឯងក៏ដោយ
វាងាយស្រួលសម្រាប់អ្នកអានដើម្បីរក្សានាមឯកវចន:។

ស្តេចក៏បាននាំយកប្រដាប់ប្រដា

នៅទីនេះ «ពួកគេ» ប្រហែលជាសំដៅទៅលើស្តេចយេហូយ៉ាគីម
ហើយនិងអ្នកទោសផ្សេងទៀត ក៏ដូចជាវត្ថុដ៏ពិសិដ្ឋ។

នៅក្នុងព្រះដំណាក់នៃព្រះរបស់ទ្រង់

នេះគឺជាការប្រព្រឹត្តសម្រាប់ថ្វាយដល់ព្រះរបស់ទ្រង់។

Daniel 1:3

ព្រះមហាក្សត្រក៏បានបញ្ជា

នេះសំដៅទៅដល់នេប៊ូក្នេសា។

ពួកមហាតលិក

នេះគឺជាមេលើពួកមន្ត្រី។

ត្រកូលជាអភិជន

នេះគឺជាពួកអ្នកដែលមានត្រកូលជាអភិជន។

មានលក្ខណៈសម្បត្តិល្អឥតខ្ចោះ

ពាក្យទម្រង់បដិសេធទាំងពីរនេះគឺបញ្ជាក់ពីគំនិតវិជ្ជមានមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ជាមួយលក្ខណៈដែលល្អឥតខ្ចោះ។

ប៉ិនប្រសប់ឆ្លាតវាងវៃ ហើយមានចំណេះដឹង

ប្រយោគមួយនេះ។ ការនេះមានន័យថាពួកគេដឹងច្រើនហើយស្គាល់
និងអាចប្រើព័ត៌មាននោះបាន។

ដំណាក់របស់ព្រះមហាក្សត្រ

នេះគឺជាដំណាក់ដ៏ធំឬអាគារដែលស្តេចបានរស់នៅ។

ហើយត្រូវឱ្យបង្រៀនយុវជន

«អាផេនហ្សាស បានបង្រៀនពួកគេ»

ព្រះមហាក្សត្របានតម្រូវឱ្យគេ

មន្ត្រីរបស់ស្តេចធ្វើការទាំងនេះសម្រាប់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកមន្ត្រីរបស់ស្តេចបានរាប់ជំនួយសម្រាប់ពួកគេ»

ចំណែកនៃអាហាររបស់ពួកហ្លួង

ជាពិសេស មិនសូវមាន ជាអាហារដែលស្តេចសោយ

ពួកគេទាំងនោះត្រូវទទួលការអប់រំ

ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អាផេនហ្សាស បានបណ្តុះបណ្តាលពួកយុវជនទាំងនោះ»

ការអប់រំ

«បង្រៀនជំនាញ»

Daniel 1:6

ក្នុងចំណោមយុវជនទាំងនោះ

«ចំណោមយុវជនពីអ៊ីស្រាអែល»

មន្ត្រីលើពួកមហាតលិក

ការនេះសំដៅទៅអាផេនហ្សាស ដែលជាមន្ត្រីដ៏ធំរបស់ស្តេចនេប៊ូក្នេសា។

បែលថិស្សាសារ...សាដ្រាក់...មែសាក់...អ័បែឌ នេកោ

នេះគឺជាឈ្មោះរបស់មនុស្ស។

Daniel 1:8

ដានីយ៉ែលបានតាំងចិត្តថា

ពាក្យថា «គំនិត» នៅទីនេះសំដៅទៅលើលោកដានីយ៉ែលខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត: «ដានីយ៉ែលបានសម្រេចចិត្តសម្រាប់ខ្លួនគាត់»

មិនធ្វើឱ្យខ្លួនឯងមិនបរិសុទ្ធ

ដើម្បី «បំពុល» អ្វីមួយដែលធ្វើឲ្យមិនស្អាត។

អាហារខ្លះនិងគ្រឿងផឹកខ្លះដែលនៅបាប៊ីឡូន

និងធ្វើឲ្យពិធីរបស់ដានីយ៉ែលទៅជាមិនស្អាត ផ្អែកទៅលើវិន័យរបស់ព្រះជាម្ចាស់។
នេះជាច្បាប់ដែលតម្រូវ។ ការបកប្រែរបៀបផ្សេងទៀត:
«បានធ្វើខ្លួនគេទៅជាមិនស្អាតផ្អែកទៅវិន័យរបស់ព្រះជាម្ចាស់»

ដោយសារអាហារ

ការនេះសំដៅទៅលើអ្វីដែលពិសេស មិនសូវមាន
អាហារដ៏ល្អដែលស្តេចបានសោយ។ សូមមើលការបកប្រែរបស់អ្នកនៅក្នុងជំពូក
១:១។

ហេតុអ្វីអ្នកចង់ឲ្យទ្រង់ឃើញអ្នកក្នុងសភាពអាក្រក់ជាង
យុវជនផ្សេងទៀតដែលមានវ័យស្រករអ្នកដូច្នេះ?

ពួកមន្ត្រីបានប្រើសំនួរនេះដើម្បីពន្យល់អ្វីដែលគេគិតថានឹងកើតឡើង។
វាគួរតែជាសេចក្តីប្រកាសមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«គេមិនចង់ឃើញពួកអ្នកមើលទៅមិនល្អជាងយុវជនដទៃទៀតនៃអាយុរបស់អ្នកទេ»។

ព្រះករុណាជាម្ចាស់នឹងកាត់ក្បាលខ្ញុំជាមិនខាន

នេះគឺជាប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត: «ស្តេចនឹងកាត់ក្បាលរបស់ខ្ញុំ» ឬ
«ស្តេចនឹងសម្លាប់ខ្ញុំមិនខាន»

Daniel 1:11

ប្រៀបធៀបរូបរាង មុខយើងខ្ញុំជាមួយនឹងយុវជនផ្សេងទៀត

ដានីយ៉ែលបានសុំឲ្យអ្នកបំរើមើលមកគាត់ ហើយនិងមិត្តរបស់លោក
មើលទៅអាក្រក់ជាងយុវជនដ៏ទៃទៀត។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រៀបធៀបពីរូបរាងរបស់យើងមើលថា
ប្រសិនបើយើងអាក្រក់ជាងរូបរាងរបស់ពួកគេ»

Daniel 1:14

បានសាកល្បងពួកគេ...មុខមាត់របស់ពួកគេ...ពួកគេបែរជា...

បរិភោគអាហាររបស់ស្តេច...ស្រាចេញ

អស់ទាំងសព្វនាមគឺសំដៅទៅដានីយ៉ែល ហាណានា មីសាអែល និង អ័សារាថា។

មាំមួន

នេះមានន័យថាបានសុខភាពល្អពីអ្វីដែលអ្នកបានបរិភោគ។

generated on Wed Sep 10 16:16:32 2025

Daniel 1:17

ព្រះជាម្ចាស់បានប្រទាន ឲ្យពួកគេមានប្រាជ្ញារៀងវៃ ប៉ិនប្រសព្វ

ការនេះអាចបានប្រើឡើងវិញ ហើយនេះគឺជានាមអរូបិយ «ចំណេះដឹង» ហើយ «ការយល់ដឹង» ដែលអាចបង្ហាញដូចជាកិរិយាស័ព្ទ «រៀន» ហើយ «ការយល់» ការបកប្រែរបៀបផ្សេងទៀត:

ព្រះជាម្ចាស់បានប្រទានដល់ពួកគេនៅលទ្ធិភាពដើម្បីរៀន
និងយល់ដឹងដ៏ច្បាស់នៅក្នុង»

អក្សរសាស្ត្រ និង មានតម្រិះគ្រប់បែបយ៉ាង

នេះគឺជាការនិយាយបំផ្លើសដើម្បីបង្ហាញដល់គេថា មានចំណេះដឹងយ៉ាងល្អ និងមានការយល់ដឹង។

Daniel 1:19

ស្តេចក៏បានមានបន្ទូលទៅកាន់ពួកគេ

ស្តេចបានមានព្រះបន្ទូលជាមួយ «យុវជនទាំងបួន» នៅក្នុងជំពូក(១:១៧)។

ដោយក្នុងចំណោមនោះពុំមាននណារអាចប្រៀបស្មើរនឹង ដានីយ៉ែល ហាណានា មីសាអែល និង អ័សារ

ការនេះអាចចាប់ផ្តើមពីទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត: «ដានីយ៉ែល ហាណានា មីសាអែល និង អ័សារ
បានធ្វើឲ្យព្រះអង្គពេញព្រះទ័យជាខ្លាំងជាងអ្នកផ្សេងដែលនៅក្នុងក្រុមទាំងមូល»

ដានីយ៉ែល ហាណានា មីសាអែល និង អ័សារ

នេះគឺជាឈ្មោះរបស់មនុស្ស។ សូមមើលការបកប្រែរបស់អ្នកនៅក្នុងជំពូក១:៦។

ក្នុងនគររបស់ស្តេច ដប់ដង

ពាក្យថា «ដប់ដង» នៅទីនេះគឺបង្ហាញការនិយាយបំផ្លើសពីគុណភាពដ៏អស្ចារ្យ។ ការបកប្រែរបៀបផ្សេងទៀត: «ល្អប្រសើជាង»

ដល់រជ្ជកាលទីមួយនៃព្រះបាទស៊ីរូស

«នៅក្នុងឆ្នាំទីមួយដែលស្តេចស៊ីរូសគ្រប់គ្រងលើបាប៊ីឡូន»

---

2 [1]នៅក្នុងឆ្នាំទីពីរនៃរជ្ជកាលរបស់ព្រះចៅនេប៊ូក្នេសា ទ្រង់ក៏បានយល់សុបិន្ត។ ព្រះទ័យរបស់ទ្រង់ខ្វល់ខ្វាយ ហើយស្តេចផ្ទុំពុំលក់ឡើយ។
[2]រួចហើយស្តេចក៏បានហៅអស់ទាំងគ្រូមន្តអាគមដែលអាចហៅវិញ្ញាណអ្នកដែលបានស្លាប់មកនិយាយគ្នាបាន។ ស្តេចក៏ហៅពួកអាគមហោរាទាំងឡាយដែរ។
ស្តេចចង់ឲ្យពួកគេកាត់ស្រាយសុបិន្តថ្វាយស្តេច។ ដូច្នេះពួកគេក៏នាំគ្នាមកគាល់នៅចំពោះស្តេច។
[3]ស្តេចមានបន្ទូលទៅពួកគេថា «យើងបានសុបិន្តឃើញការមួយ ហើយយើងមានព្រះទ័យខ្វល់ខ្វាយណាស់ ដោយមិនដឹងថាតើសុបិន្តនោះមានន័យដូចម្តេច»។
[4]រួចពួកគ្រូទាយទាំងនោះក៏ទូលទៅស្តេចវិញជាភាសាអារ៉ាមថា «បពិត្រព្រះរាជា សូមទ្រង់មានព្រះជន្មយឺនយូរ! ព្រះករុណាសូមមានរាជឱង្ការប្រាប់យើងខ្ញុំមក
យើងខ្ញុំជាអ្នកបម្រើទ្រង់នឹងកាត់ស្រាយអត្ថន័យថ្វាយ»។
[5]ស្តេចមានរាជឱង្ការទៅកាន់គ្រូទាយទាំងនោះថា «យើងបានសម្រេចនឹងធ្វើយ៉ាងដូចនេះ។ ប្រសិនបើអ្នករាល់គ្នាមិនប្រាប់យើង ពីសុបិន្តនិមិត្តនោះ និង
កាត់ស្រាយឲ្យយើងដឹងពីអត្ថន័យទេនោះ យើងនឹងកាត់ចិញ្ច្រាំអ្នករាល់គ្នា ហើយនឹងបំផ្លាញផ្ទះអ្នករាល់គ្នាឱ្យខ្ទេចខ្ទីគ្មានសល់ទេ។
[6]ប៉ុន្តែប្រសិនបើអ្នករាល់គ្នាប្រាប់យើងឲ្យដឹងពីអត្ថន័យវិញ យើងនឹងប្រទានអំណោយនិងរង្វាន់ ព្រមទាំងកិត្តិយសយ៉ាងធំពីយើងវញ។ ដូច្នេះចូរប្រាប់យើង
ហើយកាត់ស្រាយពីសុបិន្តនេះដល់យើង»។
[7]ពួកគេក៏បានទូលឆ្លើយម្តងទៀតថា «សូមព្រះករុណាប្រាប់យើងខ្ញុំដែលជាអ្នកបម្រើទ្រង់ឲ្យដឹងពីសុបិន្ត រួចហើយយើងខ្ញុំនឹងកាត់ស្រាយអត្ថន័យថ្វាយ»។
[8]ស្តេចតបទៅពួកគេថា «យើងជ្រាបច្បាស់ហើយថា អ្នករាល់គ្នាចង់ពន្យាពេលពីព្រោះអ្នករាល់គ្នាឃើញថាយើងបានសម្រេចចិត្តយ៉ាងមុតមាំពីការនេះ។
[9]ប៉ុន្តែប្រសិនបើអ្នករាល់គ្នាមិនប្រាប់សុបិន្តនោះដល់យើងទេ នោះអ្នករាល់គ្នានឹងមានទោសតែមួយប៉ុណ្ណោះសម្រាប់អ្នករាល់គ្នា។ អ្នករាល់គ្នាបានរៀបចំឃុបឃិតគ្នា
ប្រឌិតរឿងក្លែងក្លាយបញ្ឆោតយើងទៅ រហូតដល់យើងមិនទាន់ផ្លាស់ប្តូរព្រះទ័យ។ ដូច្នេះចូរប្រាប់យើងពីសុបិន្តនោះមក
នោះយើងនឹងបានជ្រាបថាអ្នករាល់គ្នាពិតជាអាចកាត់ស្រាយអត្ថន័យថ្វាយយើងបានមែន»។
[10]ពួកគ្រូទាយទាំងនោះបានទូលតបទៅស្តេចវិញថា «គ្មានអ្នកណាម្នាក់នៅលើផែនដីនេះ ដែលអាចធ្វើតាមបញ្ជារបស់ព្រះករុណាបានឡើយ។
ហើយក៏គ្មានស្តេចអង្គណាមួយដែលអស្ចារ្យ ហើយមានអំណាចយ៉ាងណា ធ្លាប់បង្គាប់បញ្ជាយ៉ាងដូច្នេះមកកាន់គ្រូមន្តអាគម គ្រូអង្គុយធម៌
និងអាចហៅអ្នកស្លាប់មកនិយាយគ្នាបាន ឬពីមន្តអាគមហោរាផង។[11]អ្វីដែលព្រះករុណាបង្គាប់បញ្ជានេះគឺពិបាកណាស់
ហើយក៏គ្មានមនុស្សណាអាចទូលថ្វាយស្តេចបានក្រៅពីព្រះប៉ុណ្ណោះ ហើយព្រះទាំងនោះមិនគង់នៅជាមួយយើងជាមនុស្សទេ»។
[12]ការនេះបានធ្វើឲ្យព្រះរាជាមានព្រះទ័យក្រេវក្រោធ និងខ្ញាល់ជាខ្លាំង រួចហើយទ្រង់ក៏បញ្ជាឲ្យបំផ្លាញពួកគ្រូទាំងនោះ ដែលនៅក្រុងបាប៊ីឡូន។
[13]ដូច្នេះរាជសារក៏បានផ្សាយចេញអំពីពួកអ្នកប្រាជ្ញនិងពួកគ្រូមន្តអាគមដែលបានយកទៅសម្លាប់។ ដោយសារតែរាជសារនេះ ពួកគេក៏បានស្វែងរកដានីយ៉ែល និង
ក្រុមមិត្តភក្តិរបស់គាត់ ដើម្បីពួកគេនឹងត្រូវបានសម្លាប់ដែរ។
[14]ពេលនោះដានីយ៉ែលបានឆ្លើយតបដោយប្រាជ្ញាទៅកាន់អើយ៉ុក ដែលជាមេកងអង្គរក្សរបស់ស្តេច
ជាម្នាក់ដែលបានចេញមកដើម្បីសម្លាប់ពួកអ្នកប្រាជ្ញដែលមានឈ្មោះល្បីនៅក្នុងក្រុងបាប៊ីឡូន។[15]ដានីយ៉ែលបានសួរទៅកាន់មេកងអង្គរក្សរបស់ស្តេចថា «ហេតុអ្វីបានជា
រាជបញ្ជារបស់ព្រះរាជាបន្ទាន់យ៉ាងនេះ?» ដូច្នោះហើយលោកអើយ៉ុកក៏បានប្រាប់ដានីយ៉ែលនៅអ្វីដែលបានកើតឡើង។[16]រួចហើយដានីយ៉ែលក៏ចូលទៅគាល់ស្តេច
ដើម្បីស្នើសុំឱកាសក្នុងការដែលគាត់អាចកាត់ស្រាយថ្វាយព្រះរាជា។
[17]រួចហើយដានីយ៉ែលក៏ត្រឡប់ទៅផ្ទះវិញ និងពន្យល់ប្រាប់ ហាណានា មីសាអែល និងអ័សារនូវអ្វីដែលបានកើតឡើង។
[18]លោកនាំគ្នាទូលអង្វរសុំក្តីមេត្តាពីព្រះជាម្ចាស់នៃស្ថានសួគ៌ សូមឲ្យទ្រង់បើកសម្តែងការអាថ៌កំបាំងនេះ ដើម្បីកុំឱ្យគេប្រហារជីវិតពួកគេ
និងអស់ពួកអ្នកប្រាជ្ញទាំងឡាយផ្សេងទៀតដែលនៅក្នុងក្រុងបាប៊ីឡូន។
[19]នៅយប់នោះមានបើកសម្តែងការអាថ៌កំបាំង មកដល់ដានីយ៉ែលតាមរយៈនិមិត្ត។ លោកដានីយ៉ែលក៏លើកតម្កើងដល់ព្រះជាម្ចាស់នៃស្ថានសួគ៌[20]ដោយពោលថា
«សូមសរសើរតម្កើងដល់ព្រះជាម្ចាស់ដែលគង់នៅអស់កល្បជានិច្ច ត្បិតព្រះប្រាជ្ញាញាណ និងអំណាចចេស្តាគឺជារបស់ព្រះអង្គ។
[21]ព្រះអង្គបានធ្វើឲ្យពេលវេលា និងរដូវកាលផ្លាស់ប្តូរ ព្រះអង្គបានទម្លាក់ស្តេច ហើយតែងតាំងស្តេចផ្សេងឲ្យឡើងគ្រងរាជ្យ ព្រះអង្គប្រទានប្រាជ្ញាដល់អ្នកប្រាជ្ញ និង
ប្រទានចំណេះដឹងដល់អ្នកដែលចេះគិតពិចារណា។[22]ព្រះអង្គបើកសម្តែងការអាថ៌កំបាំងដ៏ជ្រៅ ដោយព្រះអង្គជ្រាប់អំពីអ្វីដែលនៅក្នុងទីងងឹត
ហើយពន្លឺបានរស់នៅជាមួយព្រះអង្គដែរ។
[23]ព្រះជាម្ចាស់នៃបុព្វបុរសអើយ ទូលបង្គំសូមអរព្រះគុណហើយលើកដម្កើងព្រះអង្គ ដោយព្រោះព្រះអង្គបានប្រទានប្រាជ្ញា និងអំណាចចេស្តាមកដល់ទូលបង្គំ។
ពេលនេះព្រះអង្គបានឆ្លើយតបមកទូលបង្គំនូវអ្វីដែលទូលបង្គំបានទូលសូមព្រះអង្គ
ហើយព្រះអង្គក៏បានសម្តែងឲ្យយើងខ្ញុំដឹងពីហេតុការណ៍ដែលនឹងកើតឡើងចំពោះព្រះរាជាដែរ»។
[24]រួចហើយលោកដានីយ៉ែលក៏ទៅជួបលោកអើយ៉ុក (ជាម្នាក់ដែលស្តេចបានតាំងឲ្យទៅសម្លាប់ពួកអ្នកប្រាជ្ញនៅក្នុងបាប៊ីឡូន)។ លោកបានទៅហើយនិយាយទៅកាន់គាត់ថា
«សូមលោកកុំសម្លាប់ពួកអ្នកប្រាជ្ញនៅស្រុកបាប៊ីឡូនឡើយ។ សូមនាំខ្ញុំចូលទៅគាល់ព្រះករុណា ហើយខ្ញុំនឹងកាត់ស្រាយអាថ៌កំបាំងនៃសុបិន្តនោះថ្វាយព្រះរាជា»។
[25]ក្រោយមកលោកអើយ៉ុកក៏ប្រញាប់ប្រញាល់នាំដានីយ៉ែលទៅគាល់នៅចំពោះស្តេច ហើយទូលថា
«ទូលបង្គំបានរកឃើញបុរសម្នាក់ក្នុងចំណោមពួកនិរទេសនៃជនជាតិយូដា គាត់អាចកាត់ស្រាយសុបិន្តនោះថ្វាយព្រះករុណាបាន»។
[26]ព្រះរាជាមានរាជឱង្ការទៅកាន់ដានីយ៉ែលថា (ដែលត្រូវបានហៅថាបេលថិស្សាសារ) «តើអ្នកពិតជាអាចប្រាប់យើងឲ្យដឹងពីសុបិន្ត
ហើយកាត់ស្រាយអត្ថន័យវាបានមែនឬ?»
[27]ដានីយ៉ែលទូលឆ្លើយទៅព្រះរាជាថា «អាថ៌កំបាំងដែលព្រះករុណាចង់ដឹងនោះ ពុំមានអ្នកប្រាជ្ញហោរា គ្រូមន្តអាគម ឬគ្រូទាយ
ឬហោរាសាស្ត្រណាមួយអាចកាត់ស្រាយថ្វាយព្រះករុណាបានទេ។[28]យ៉ាងណាក៏ដោយ គឺមានព្រះជាម្ចាស់មួយអង្គដែលគង់នៅស្ថានសួគ៌

generated on Wed Sep 10 16:16:32 2025

ដែលអាចបើកសម្តែងគម្រោងការដ៏អាថ៌កំបាំងទាំងនេះ ហើយព្រះអង្គនឹងបើកឲ្យទ្រង់បានដឹង ព្រះករុណានេប៊ូក្នេសា
នឹងជ្រាបពីហេតុការណ៍ដែលនឹងកើតមានឡើងនៅពេលអនាគតដែលនឹងមកដល់។ ការទាំងនេះគឺជាសេចក្តីសុបិន
និងនិមិត្តដែលនៅក្នុងព្រះគំនិតរបស់ព្រះករុណាគឺនៅពេលទ្រង់ផ្ទំនៅលើគ្រែរបស់ព្រះអង្គ។
[29]បពិត្រព្រះករុណា នៅពេលដែលទ្រង់ផ្ទំលក់នោះ ព្រលឹងរបស់ទ្រង់បានឃើញពីហេតុការណ៍ដែលនឹងកើតឡើង ហើយព្រះដែលសម្តែងការអាថ៌កំបាំងនោះ
នឹងឲ្យព្រះករុណាជ្រាបពីការអ្វីដែលនឹងកើតឡើង។[30]ដ្បិតទូលបង្គំបានយល់ពីគម្រោងការដ៏លាក់កំបាំងនេះ
មិនមែនដោយសារទូលបង្គំមានប្រាជ្ញាលើសមនុស្សផ្សេងនោះទេ។ ការអាថ៌កំបាំងនេះបានបើកមកទូលបង្គំដើម្បីឲ្យទ្រង់ ព្រះករុណាបានជ្រាបពីន័យ
ហើយទ្រង់នឹងជ្រាបពីគំនិតដែលមាននៅក្នុងព្រះករុណាផង។
[31]បពិត្រព្រះករុណា ទ្រង់បានទតឃើញរូបបដិមាករមួយយ៉ាងធំ។ រូបបដិមាកនេះមានអំណាច និងពន្លឺ ឈរនៅចំពោះព្រះភ័ក្ត្រព្រះករុណា។ វាបានភ្លឺគួរឲ្យស្ញែងខ្លាច។
[32]ក្បាលនៃរូបបដិមាកនោះធ្វើឡើងពីមាសសុទ្ធ។ ដើមទ្រូង និងដៃវាគឺធ្វើពីប្រាក់។ ពោះហើយនិងភ្លៅវាគឺធ្វើពីលង្ហិន[33]ហើយជើងទាំងពីរវាគឺធ្វើពីដែក។
ហើយប្រអប់ជើងមួយធ្វើពីដែក ហើយមួយទៀតធ្វើពីដីឥដ្ឋ។
[34]ព្រះករុណាបានងើបទតទៅខាងលើ ហើយមានថ្មមួយដុំធ្លាក់មកចុះមកមិនមែនដោយដៃមនុស្សនោះទេ ហើយបុកទង្គិចនឹងប្រអប់ជើងដែលធ្វើពីដែក
និងដីឥដ្ឋនោះបែកខ្ទេចខ្ទីអស់។[35]រួចហើយដែក និងដីឥដ្ឋហើយលង្ហិន ប្រាក់និងមាសក្នុងពេលតែមួយក៏បែកខ្ទេចខ្ទី ជាបំណែកតូចៗ
ហើយក្លាយទៅជាចំបើងនៅទីកន្លែងបោកស្រូវក្នុងរដូវក្តៅ។ ហើយខ្យល់បក់ផាត់ពួកវាទៅអស់គ្មានចំណែករបស់វាណានៅសល់ទេ។ ប៉ុន្តែដុំថ្មដែលប៉ះ
ទង្គិចនឹងរូបបដិមាកនោះ បានក្លាយទៅជាភ្នំយ៉ាងធំនៅពេញផែនដីទាំងមូល។
[36]នេះហើយជាសុបិន្តរបស់ព្រះករុណា។ ពេលនេះពួកយើងនឹងកាត់ស្រាយន័យថ្វាយព្រះករុណា។[37]បពិត្រព្រះរាជាដែលជាព្រះមហាក្សត្រលើអស់ទាំងព្រះមហាក្សត្រ
ត្បិតព្រះជាម្ចាស់នៃស្ថានសួគ៌បានប្រទានអាណាចក្រ និងអំណាចហើយកម្លាំង និងព្រះកិត្តិយសផងដែរ។[38]ព្រះអង្គបានប្រទានមនុស្សលោក
ហើយសត្វទាំងពួងនៅគ្រប់ទីកន្លែង និងបក្សាបក្សីនៅលើមេឃមកក្នុងព្រះហស្តព្រះករុណា ព្រះអង្គបានតាំងព្រះករុណាឲ្យគ្រប់គ្រងលើរបស់ទាំងនោះ។
ព្រះករុណាគឺជាក្បាលនៃរូបបដិមាករដែលធ្វើពីមាស។
[39]បន្ទាប់ពីព្រះករុណា នឹងមានរាជាណាចក្រមួយទៀតកើតឡើង ប៉ុន្តែរាជាណាចក្រនោះនឹងខ្សោយជាងរាជាណាចក្ររបស់ព្រះករុណា រួចហើយមានរាជាណាចក្រទីបីគឺ
លង្ហិនដែលនឹងគ្រប់គ្រងលើផែនដីទាំងមូល។
[40]ហើយនឹងមានរាជាណាចក្រទីបួនដែលរឹងមាំដូចជាដែក ត្បិតដែកនោះនឹងកម្ទេចអ្វីៗទាំងអស់ទៅជាចំណែកតូចៗគ្រប់យ៉ាង។
ហើយវាក៏ត្រូវខ្ទិចខ្ទីអស់និងកម្ទេចបំបែកអ្វីៗទាំងអស់ដែរ។
[41]ព្រះករុណាបានទតឃើញប្រអប់ជើង និងម្រាមជើងដែលមួយផ្នែកធ្វើពីដីឥដ្ឋ និងមួយផ្នែកទៀតធ្វើពីដែកនោះ គឺអាណាចក្រនោះនឹងបែងចែកជាពីរ
ហើយកម្លាំងរបស់ដែកនឹងនៅក្នុងវាដែរ ត្បិតព្រះករុណាបានឃើញហើយថាដែកនៅជាប់ជាមួយនឹងដីឥដ្ឋដែលជ្រាយ។[42]ដូចម្រាមជើងរបស់បដិមាករ មួយផ្នែកធ្វើពីដែក
និងមួយផ្នែកទៀតធ្វើពីដីឥដ្ឋ គឺមានន័យថាអាណាចក្រមួយ នឹងមានអំណាចខ្លាំងក្លា ហើយមួយផ្នែកទៀតខ្សោយដែរ។
[43]ត្បិតព្រះករុណាបានទតឃើញហើយថាដែកនៅភ្ជាប់ជាមួយដីឥដ្ឋ ដូច្នេះមនុស្សនឹងនៅជាមួយគ្នា តែពួកគេមិនរស់នៅចូលគ្នាទេ
ដូចជាដែកមិនរលាយចូលគ្នាជាមួយដីឥដ្ឋយ៉ាងដូច្នោះដែរ។
[44]នៅក្នុងរជ្ជកាលនៃស្តេចទាំងនោះ ព្រះជាម្ចាស់នៃស្ថានសួគ៌នឹងធ្វើឲ្យអាណាចក្រមួយទៀត ដែលមិនមានប្រជាជាតិណាអាចវាយលុក
ឬគ្រប់គ្រងដោយមនុស្សណាបានឡើយ។ អាណាចក្រនេះនឹងកម្ទេចអាណាចក្រផ្សេងទៅជាចំណែកតូចហើយពួកគេនឹងវិនាសអស់ទៅ
ហើយអាណាចក្រនេះនឹងស្ថិតនៅគង់វង្សជាយូអង្វែងទៅ។[45]បពិត្រព្រះករុណាបានទតឃើញថ្មដែលធ្លាក់ចុះមកពីលើភ្នំតែមិនមែនដោយដៃមនុស្សឡើយ។
វាបានកម្ទេចដែក លង្ហិន ដីឥដ្ឋ ប្រាក់ និងមាសទៅជាចំណែកតូចៗ។ ព្រះជាម្ចាស់ដ៏មហិមាព្រះអង្គបានសម្តែងឲ្យព្រះករុណាជ្រាបពីអ្វីដែលកើតឡើងនាពេលបន្ទាប់ពីនេះ។
សុបិន្តរបស់ព្រះករុណានេះគឺជាសេចក្តីពិត ហើយអត្ថន័យនេះគួរឲ្យជឿទុកចិត្តបាន»។
[46]ព្រះចៅនេប៊ូក្នេសា ឱនព្រះភ័ក្ត្រចុះថ្វាយបង្គំនៅចំពោះ ដានីយ៉ែលដោយគោរពដល់លោក ទ្រង់ក៏បញ្ជាឲ្យមន្ត្រីធ្វើយញ្ញបូជា និងដុតគ្រឿងក្រអូបជូនលោក។
[47]ស្តេចមានបន្ទូលទៅដានីយ៉ែលថា «ពិតប្រាកដណាស់ព្រះរបស់លោក គឺពិតជាព្រះលើអស់ទាំងព្រះមែនហើយ
ជាព្រះអម្ចាស់លើអស់ទាំងស្តេចហើយជាព្រះតែមួយអង្គដែលបើកសម្តែងពីគម្រោងការដ៏អាថ៌កំបាំង សម្រាប់អ្នកដែលអាចបើកបង្ហាញអាថ៌កំបាំងនេះ»។
[48]បន្ទាប់មកព្រះរាជាបានលើកតម្កើងដានីយ៉ែលខ្ពស់ឡើង ហើយបានប្រទានអំណោយដ៏អស្ចារ្យ។ ស្តេចក៏បានតែងតាំងឲ្យដានីយ៉ែលត្រួតលើខេត្តរបស់បាប៊ីឡូនទាំងមូល។
ដានីយ៉ែលក៏ក្លាយទៅជាប្រមុខលើពួកអ្នកប្រាជ្ញទាំងអស់នៅក្នុងបាប៊ីឡូន។[49]ដានីយ៉ែលបានទូលសូមព្រះរាជា ឲ្យតែងតាំងលោកសាដ្រាក់ លោកមែសាក់
និងលោកអបេឌនេកោ គ្រប់គ្រងលើខេត្តបាប៊ីឡូន។ តែលោកសុំទៅបម្រើស្តេចនៅព្រះរាជវាំងវិញ។

Daniel 2:1
នៅក្នុងឆ្នាំទីពីរ
«ក្នុងទីឆ្នាំពីរ» (សូមមើល:|Ordinal Numbers)
ទ្រង់ក៏បានយល់សុបិន្ត
«នេប៊ូក្នេសាបានយល់សុបិន្ត»
ទ្រង់មានព្រះទ័យខ្វល់ខ្វាយ
ពាក្យថា «ព្រះទ័យ» នៅទីនេះសំដៅទៅលើការគិតរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ការគិតរបស់ទ្រង់បានរំខានស្តេច» (សូមមើល:|Metonymy)
ហើយផ្ទំពុំលក់ឡើយ
ការខ្វល់ខ្វាយរបស់ទ្រង់បានហាមព្រះអង្គមិនផ្ទំឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះហើយទ្រង់មិនអាចផ្ទំបាន»
ស្តេចក៏បានហៅអស់ទាំងគ្រូមន្តអាគម
«ក្រោយមកស្តេចក៏បានហៅអស់ទាំងគ្រូមន្តអាគម»
ពួកដែលបានស្លាប់
«អ្នកដែលបានស្លាប់ទៅហើយ»
គេក៏នាំគ្នាមក
«ពួកគេចូលមកក្នុងរាជវាំង»
មកគាល់ស្តេច
«នៅចំពោះមុខស្តេច»
Daniel 2:3
ព្រះទ័យខ្វល់ខ្វាយណាស់
ពាក្យថា «ព្រះទ័យ» នៅទីនេះសំដៅទៅលើស្តេចខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត: «យើងខ្វល់ខ្វាយ»
ខ្វល់ខ្វាយ
«បញ្ហា»
ភាសាអារ៉ាម
នេះគឺជាភាសាដែលប្រជាជននៅក្នុងបាប៊ីឡូនបាននិយាយ។
ព្រះរាជា សូមទ្រង់មានព្រះជន្មយឺនយូរ
មនុស្សនោះអាចនិយាយការនេះដើម្បីបង្ហាញដល់ស្តេចពីការឲ្យតម្លៃ
និងគោរពដល់ស្តេច។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះរាជា
យើងសង្ឃឹមថាព្រះនឹងមានព្រះជន្មយឺនយូរ!»
ព្រះករុណា សូមមានរាជឱង្ការដល់យើងខ្ញុំផង
បុរសទាំងនោះហៅខ្លួនឯងថាជាអ្នកបម្រើរបស់ស្តេច
ដើម្បីបង្ហាញពីការគោរពដល់ទ្រង់។
យើងខ្ញុំនឹងកាត់ស្រាយអត្ថន័យ
ឃ្លាថា «យើងខ្ញុំ» សំដៅទៅលើមនុស្សដែលស្តេចមានបន្ទូលទៅកាន់
ហើយមិនបានរាប់បញ្ចូលស្តេចនោះទេ។

generated on Wed Sep 10 16:16:32 2025

Daniel 2:5
យើងបានសម្រេចយ៉ាងដូច្នេះថា
ការនេះអាចនឹងត្រូវចាប់ផ្តើមជាមួយទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបានសម្រេចចិត្តរួចហើយពីអ្វីដែលនឹងត្រូវធ្វើពីបញ្ហានេះ»
កាត់ចិញ្ច្រាំអ្នករាល់គ្នា ហើយនឹងបំផ្លាញផ្ទះអ្នករាល់គ្នាឱ្យខ្ទេចខ្ទីគ្មានសល់
ការនេះអាចនឹងត្រូវចាប់ផ្តើមជាមួយទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងបញ្ជាទាហានរបស់យើងឲ្យទៅបំផ្លាញរូបកាយរបស់អ្នកជាចំណែក
ហើយធ្វើឲ្យផ្ទះរបស់អ្នកទៅជាខ្ទេចខ្ទីគ្មានសល់ដែរ»
យើងនឹងប្រទានអំណោយ និង រង្វាន់
ការនេះអាចនឹងត្រូវចាប់ផ្តើមជាមួយទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងប្រទានដល់អ្នកនៅអំណោយជាច្រើន»
Daniel 2:7
សូមព្រះករុណាប្រាប់យើងខ្ញុំ
ពួកហោរាបានទូលទៅកាន់ស្តេចនៅក្នុងនាមជនទីបី ជាសញ្ញាប្រាប់ពីការគោរព។
អ្នករាល់គ្នាឃើញថាយើងបានសម្រេចចិត្តយ៉ាងមុតមាំហើយ
ការសម្រេចចិត្តដែលមិនបានផ្លាស់ប្តូរ ហើយការថ្លែងចេញអ្វីមួយដោយមុតមាំ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកឃើញហើយថា
យើងនឹងមិនប្តូរការសម្រេចចិត្តរបស់យើងពីការនេះទេ»
នោះអ្នករាល់គ្នានឹងមានទោសតែមួយប៉ុណ្ណោះ
«នឹងមានការដាក់ទោសសម្រាប់អ្នករាល់គ្នា»
ឃុបឃិតគ្នា ប្រឌិតរឿងក្លែងក្លាយបញ្ឆោត
ពាក្យទាំងពីរនេះមានន័យថា ប្រហាក់ប្រហែលគ្នា ឬស្រដៀងគ្នា
ហើយបញ្ជាក់ពីការទាំងនេះ «កុហកបម្រុងនឹងបោកប្រាស់»។
Daniel 2:10
ដែលអស្ចារ្យ ហើយមានអំណាច
ពាក្យទាំងពីរនេះមានន័យជាមូលដ្ឋានគឺដូចគ្នា
ហើយបញ្ជាក់ពីការដ៏ធំអស្ចារ្យនៃអំណាចរបស់ស្តេច។ ការបកប្រែរបៀបផ្សេងទៀត:
«អំណាចដ៏សម្បើម»
គ្មានមនុស្សណាអាចធ្វើបាន ក្រៅពីព្រះប៉ុណ្ណោះ
នេះគឺជាចាប់ផ្តើមក្នុងទម្រង់បដិសេធ សម្រាប់បញ្ជាក់ន័យ។
វាអាចចាប់ផ្តើមពីទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មានតែព្រះទេទើបអាចប្រាប់ពីការទាំងនេះបានដល់ស្តេច»
Daniel 2:12
ព្រះទ័យក្រេវក្រោធឥតឧបមា
ពាក្យទាំងនេះមានន័យថាជាមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់យ៉ាងខ្លាំងនៃកំហឹងរបស់ទ្រង់។ ការបកប្រែរបៀបផ្សេងទៀត:
«សេចក្តីក្រោធយ៉ាងខ្លាំង»
ពួកគ្រូទាំងនោះ នៅស្រុកបាប៊ីឡូន
«មនុស្សប្រុសនៅក្នុងបាប៊ីឡូន»
ដូច្នេះបន្ទាប់ពីមានរាជបញ្ជា
រាជបញ្ជាបានថ្លែងដូចជាមានជីវិត
ហើយនិងអាចយកទៅខាងក្រៅដោយខ្លួនរបស់វា។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះស្តេចក៏ចេញរាជបញ្ជា» ឬ «ដូច្នេះស្តេចក៏បានប្រទានរាជបញ្ជា»
ឱ្យចាប់ពួកអ្នកប្រាជ្ញយកទៅសម្លាប់
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកទាហានបានសម្លាប់ពួកអ្នកដែលបានដឹងថា មានប្រាជ្ញា»
ក្រុមមិត្តភក្តិរបស់គេយកទៅសម្លាប់ដែរ
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ក្នុងការបញ្ជាឲ្យទៅសម្លាប់ពួកគេ»
Daniel 2:14
បានឆ្លើយតបដោយប្រាជ្ញា
ពាក្យទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា
ហើយបញ្ជាក់អំពីភាពធំអស្ចារ្យនៃប្រាជ្ញារបស់លោក។ ការបកប្រែរបៀបផ្សេងទៀត:
«ការប្រុង និងប្រយ័ត្នដល់ការជំនុំជម្រះ»
អើយ៉ុក
នេះគឺជាឈ្មោះរបស់មេទ័ពរបស់ស្តេច។
មេកងសន្តិសុខរបស់ស្តេច
ការងាររបស់មនុស្សទាំងនោះគឺសម្រាប់ការពារស្តេច។
ដែលបានចេញមកដើម្បីសម្លាប់
«ជាអ្នកដែលស្តេចបានបញ្ជាឲ្យទៅសម្លាប់»
ដានីយ៉ែលក៏ចូលទៅ
ដានីយ៉ែលប្រហែលជាទៅរាជវាំង។ ការបកប្រែរបៀបផ្សេងទៀត:
«ដានីយ៉ែលបានចេញទៅរាជវាំង» ឬ
«ដានីយ៉ែលបានទៅដើម្បីទូលថ្វាយដល់ស្តេច»
ដើម្បីស្នើរសុំឱកាសក្នុងការដែលគាត់អាចកាត់ស្រាយថ្វាយព្រះរាជា
«សុំដើម្បីរៀបចំពេលក្នុងការចូលទៅជួបជាមួយស្តេច»
Daniel 2:17
ដានីយ៉ែលក៏ត្រឡប់ទៅផ្ទះ
ការនេះក៏សំដៅទៅលើផ្ទះរបស់ដានីយ៉ែល។
អ្វីដែលបានកើតឡើង
«អំពីរាជបញ្ជារបស់ស្តេច»
ទូលអង្វរដល់ព្រះជាម្ចាស់ សូមឲ្យទ្រង់អាណិតមេត្តា
«លោកបានសុំពួកគេដើម្បីអធិស្ឋានសម្រាប់ក្តីមេត្តា»
ដើម្បីកុំឱ្យគេប្រហារជីវិតពួកគេ
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះស្តេចនឹងមិនប្រហារជីវិតពួកគេ» ឬ «ដូច្នេះពួកអង្គរក្សរបស់ស្តេចនឹងមិន
សម្លាប់ពួកគេឡើយ»
Daniel 2:19
នៅយប់នោះព្រះជាម្ចាស់ក៏បានបើកសម្តែងការអាថ៌កំបាំង
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅយប់នោះព្រះជាម្ចាស់បានបើកបង្ហាញការអាថ៌កំបាំង»
ការអាថ៌កំបាំង
ការនេះសំដៅទៅលើអត្ថន័យនៅក្នុងសុបិន្តរបស់ស្តេច។
សូមសរសើរតម្កើងដល់ព្រះជាម្ចាស់
ពាក្យថា «នាម» នៅទីនេះសំដៅទៅលើព្រះជាម្ចាស់ខ្លួនព្រះអង្គផ្ទាល់។
ការបកប្រែរបៀបផ្សេងទៀត: «សរសើរព្រះជាម្ចាស់»
Daniel 2:21
ព័ត៌មានទូទៅ:
ខគម្ពីរទាំងនេះក៏ជាចំណែកនៃពាក្យអធិស្ឋានរបស់ដានីយ៉ែល។
ទ្រង់បានទម្លាក់ស្តេចនានា
«ព្រះអង្គដកចេញសិទ្ធអំណាចរបស់ដែលបានគ្រប់គ្រង»
ជ្រើសតាំងស្តេចនានាឲ្យឡើងគ្រងរាជ្យ
ការឈរលើ «បល្ល័ង» នៅទីនេះសំដៅទៅលើការគ្រប់គ្រងលើអាណាចក្រ។
ការបកប្រែរបៀបផ្សេងទៀត:
«តាំងឲ្យមានស្តេចថ្មីគ្រប់គ្រងនៅលើអាណាចក្ររបស់ពួកគេ»
ត្បិតពន្លឺនៅក្នុងទ្រង់
«ពន្លឺគឺមកពីព្រះជាម្ចាស់»
Daniel 2:23
ព័ត៌មានទូទៅ:
ខគម្ពីរទាំងនេះក៏ជាចំណែកនៃពាក្យអធិស្ឋាន។
លោកឈប់ទូលសូមព្រះជាម្ចាស់សម្រាប់បុគ្គលទីបី
ហើយប្តូរទៅទូលសូមជាភាពផ្ទាល់ខ្លួនសម្រាប់បុគ្គលទីពីរវិញ។
ឆ្លើយតបមកទូលបង្គំនូវអ្វីដែលទូលបង្គំបានទូលសូមព្រះអង្គ
«ប្រាប់ទូលបង្គំអ្វីដែលដែលមិត្តរបស់ទូលបង្គំ
ហើយនិងទូលបង្គំទូលសូមឲ្យព្រះអង្គប្រាប់មកកាន់យើង» (UDB)
សម្តែងឲ្យយើងខ្ញុំដឹងពីហេតុការណ៍ដែលនឹងកើតឡើងចំពោះព្រះរាជា
«សូមប្រាប់យើងនៅអ្វីដែលស្តេចចង់បានឲ្យយើងដឹងផង»
Daniel 2:24
អើយ៉ុក
នេះគឺជាឈ្មោះរបស់មេទ័ពរបស់ស្តេច។
សូមមើលពីរការបកប្រែពាក្យនេះនៅក្នុងជំពូក ២:១៤
ពួកអ្នកប្រាជ្ញ
«ពួកមនុស្សដែលមានប្រាជ្ញា»
Daniel 2:25
បេលទិស្សាសារ
នេះគឺជាឈ្មោះដែលបាប៊ីឡូនបានដាក់ឲ្យដានីយ៉ែល។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះនេះក្នុងជំពូក ១:៦
Daniel 2:27

generated on Wed Sep 10 16:16:32 2025

អាថ៌កំបាំងដែលព្រះករុណាចង់ដឹងនោះ...ពុំមានអ្នកប្រាជ្ញ ហោរា
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកអ្នកដែលមានប្រាជ្ញា និងពួកអ្នកដែលអាចនិយាយជាមួយមនុស្ស
ដែលបានស្លាប់ គ្រូមន្តអាគម ឬគ្រូទាយ ក៏មិនអាចបើកបង្ហាញអាថ៌កំបាំង
ដែលស្តេចបានសួរនោះដែរ»
អាថ៌កំបាំងដែលព្រះករុណាចង់ដឹងនោះ
ឃ្លានេះសំដៅទៅលើសុបិន្តរបស់ស្តេច។
Daniel 2:29
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
ព្រះដែលសម្តែងការអាថ៌កំបាំងនោះ
ឃ្លានេះសំដៅទៅលើព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ដែលបានបើកសម្តែងការអាថ៌កំបាំងឲ្យបានដឹង»
ការដ៏លាក់កំបាំងនេះ មិនមែនដោយសារទូលបង្គំ
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់មិនបានបើកបង្ហាញការលាក់កំបាំងនេះដល់ទូលបង្គំទេ»
ការដែលព្រះជាម្ចាស់បានបើកសម្តែងឱ្យទូលបង្គំបានយល់ពីគម្រោងការដ៏លាក់កំបាំងនេះ
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានបើកបង្ហាញដល់ខ្ញុំ ហើយនិងអ្នកដែរ»
ជ្រាបពីគំនិតដែលមាននៅក្នុងព្រះករុណាផ្ទាល់
ឃ្លានេះគឺប្រើជាពាក្យ «អ្នក» សំដៅទៅលើគំនិតផ្ទាល់ខ្លួន។
ការបកប្រែរបៀបផ្សេងទៀត: «ជ្រាបពីអ្វីដែលជ្រៅនៅក្នុងការគិតរបស់អ្នក»
Daniel 2:31
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
ធ្វើឡើងពីមាសសុទ្ធ
«គឺជាមាសដ៏ល្អ» ឬ «គឺជាមាសសុទ្ធ»
ធ្វើពីដែក ហើយប្រអប់ជើងមួយធ្វើពីដែក និង មួយទៀតធ្វើពីដីឥដ្ឋ
«ប្រអប់ជើងមួយធ្វើពីដែក និង មួយទៀតធ្វើពីដីឥដ្ឋ» ឬ «ប្រអប់ជើងមួយធ្វើពីដែក
និង មួយទៀតធ្វើពីដីឥដ្ឋ»
Daniel 2:34
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
មានថ្មមួយដុំធ្លាក់មក ទោះបីមិនមែនដោយដៃរបស់មនុស្ស ហើយវា
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម បើវាបានបែងចែកទៅជាពីរប្រយោគ។
ការបកប្រែរបៀបផ្សេងទៀត: «មានអ្នកណាម្នាក់បានកាត់ថ្មពីភ្នំមក»
តែមិនមែនជាមនុស្សដែលកាត់នោះទេ។ គឺថ្ម»
ដូចជាចំបើងនៅក្នុងទីលានបោកស្រូវនៅរដូវប្រាំង
ឃ្លានេះបានប្រៀបធៀបទៅចំណែកនៃរូបដែលបានបែកតូច
ហើយស្រាលរហូតអាចបកទៅតាមខ្យល់បាត់ទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«ដូចជាកំទិចស្មៅដែលស្ងួត ហើយបក់ទៅតាមខ្យល់ដែរ»
ហើយខ្យល់បក់ផាត់ទៅគ្មានសល់
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេគឺបានទៅអស់ហើយ»
នៅពេញផែនដី
«ពាសពេញនៅលើផែនដីទាំងមូល»
Daniel 2:36
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
ដែលទូលបង្គំនឹងកាត់ស្រាយដូចតទៅ
ពាក្យថា «យើង» នៅទីនេះសំដៅតែលើដានីយ៉ែល។
លោកគួរតែបានប្រើជាទម្រង់ពហុវចន:
នៅក្នុងភាពជាមនុស្សគួរជៀសវាងពីកិត្តិយសដែលដឹងពីអត្ថន័យនៃសុបិន្ត
ដែលព្រះជាម្ចាស់បានបើកសម្តែងដល់លោក។
ព្រះមហាក្សត្រលើអស់ទាំងព្រះមហាក្សត្រ
«ព្រះមហាក្សត្រដ៏សំខាន់» ឬ «គឺជាបហាក្សត្រដែលបានគ្រប់គ្រងនៅលើផែនដី»
ឬទ្ធានុភាព អំណាចចេស្តា
ពាក្យទាំងនេះមានន័យមូលដ្ឋានដូចគ្នា។
ដើម្បីគ្រប់គ្រងលើរបស់ទាំងនោះ
ពាក្យ «ដៃ» នៅទីនេះសំដៅទៅលើការគ្រប់គ្រង។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គបានប្រទានដល់ទ្រង់បានគ្រប់គ្រងលើទីកន្លែង»
ព្រះអង្គបានប្រទានមនុស្សលោក
ជាកន្លែងដែលប្រើដើម្បីតំណាងដល់មនុស្សដែលបានរស់នៅទីនោះ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលរស់នៅលើទឹកដីនោះ»
ព្រះអង្គបានប្រទានមនុស្សលោក សត្វទាំងពួង...នៅគ្រប់ទីកន្លែង
ពាក្យថា «ដៃ» នៅទីនេះសំដៅទៅលើការគ្រប់គ្រង។ ការបកប្រែរបៀបផ្សេងទៀត:
«សត្វទាំងពួងនៅគ្រប់ទីកន្លែង និង បក្សាបក្សីនៅលើមេឃ»
បក្សាបក្សីនៅលើមេឃ
ពាក្យថា «មេឃ» នៅទីនេះគឺប្រើសំដៅទៅលើ «ផ្ទៃមេឃ»
ព្រះករុណានេះហើយជាក្បាលរូបបដិមាករដែលធ្វើពីមាស
នៅក្នុងការសុបិន្តរបស់ស្តេច ក្បាលនៃរូបបដិមាកគឺតំណាងឲ្យស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «ក្បាលមានជារូបសញ្ញានៃទ្រង់
ហើយនិងអំណាចរបស់ទ្រង់ដែរ»
Daniel 2:39
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
នឹងមានរាជាណាចក្រមួយទៀតកើតឡើង
នៅក្នុងការសុបិន្តរបស់ស្តេច អាណាចក្រទ្រង់គឺពណ៌មាស
ហើយអាណាចក្រទាបជាងគួរតែពណ៌ប្រាក់។ ការបកប្រែរបៀបផ្សេងទៀត:
«អាណាចក្រផ្សេងទៀត ដែលពណ៌ប្រាក់នឹងងើបឡើង» ឬ
«អាណាចក្រដែលតំណាងដោយប្រាក់ជាផ្នែកនៃរូបសំណាក់ នឹងងើបឡើង»
ណាចក្រទីបីគឺ លង្ហិន
«តែអាណាចក្រទីបីនេះ ដែលជាលង្ហិន» ឬ «ហើយនៅតែមានអាណាចក្រ
ដែលគឺជាតំណាងដោយលង្ហិនជាផ្នែកនៃរូបសំណាក់»
Daniel 2:40
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
នឹងមានរាជាណាចក្រទីបួន
«នឹងមានអាណាចក្រទីបួន»
ដែលរឹងមាំដូចជាដែក
អាណាចក្រទីបួន គឺបាននិយាយពីភាពរឹងមាំដូចជាដែក។
រាជាណាចក្រនោះក៏នឹងកម្ទេចបំបែកអ្វីៗទាំងអស់យ៉ាងដូច្នោះ
នៅក្នុងភាសាសញ្ញានេះមានន័យថាអាណាចក្រទីបួននឹងបំផ្លាញ
ហើយសាងសង់ឡើងវិញ អាណាចក្រមួយទៀត។
អ្វីៗទាំងអស់
«នគរពីមុនៗ» (UDB)
Daniel 2:41
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
ព្រះករុណាបានទតឃើញ
នេប៊ូក្នេសាបានទតឃើញប្រអប់ជើង បានគិតពីដីឥដ្ឋ ហើយនិងដែក។
ព្រះអង្គមិនបានទតឃើញពីដំណើរការធ្វើប្រអប់ជើងទេ។
ដែលមួយផ្នែកធ្វើពីដីឥដ្ឋ និង មួយផ្នែកទៀតធ្វើពីដែក
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មានអ្នកលាយដីឥដ្ឋ និងដែក»
តែពួកគេមិនរស់នៅចូលគ្នាទេ
«ពួកគេនឹងមិនអាចរួមគ្នាបានទេ»
Daniel 2:44
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តរៀបរាប់ទៅកាន់ស្តេច។
នៅក្នុងរជ្ជកាលនៃស្តេចទាំងនោះ
ពាក្យថា «ស្តេចទាំងនោះ» នៅទីនេះសំដៅទៅលើអ្នកគ្រប់គ្រងនៃអាណាចក្រ
ជាសញ្ញាដោយចំណែកផ្សេងគ្នារបស់រូបសំណាក់។
អាណាចក្រមួយទៀតកើតឡើងដែលរឹងមាំ មិនមានប្រជាជាតិណាអាចវាយលុក
ឬគ្រប់គ្រងបានឡើយ
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មានអ្នកណាអាចនឹងបំផ្លាញបានឡើយ
ហើយក៏គ្មានអ្នកណាអាចកាន់កាប់បានឡើយ»

generated on Wed Sep 10 16:16:32 2025

ថ្មដែលធ្លាក់ចុះមកពីលើភ្នំដោយឯកឯង ដែលបំបែកកម្ទេចដែក
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មានអ្នកណាម្នាក់បានកាត់យកថ្មមកពីភ្នំ តែមិនមែនជាមនុស្សទេ
ដែលបានកាត់យកវាមកនោះ»
គួរឲ្យជឿទុកចិត្តបាន
ទុកចិត្តហើយត្រឹមត្រូវ
Daniel 2:46
ឱនព្រះភ័ក្ត្រចុះ
នេះជាសញ្ញាដែលបង្ហាញថាស្តេចបានគោរពដល់ដានីយ៉ែល។
ការបកប្រែរបៀបផ្សេងទៀត: «ឱនព្រះភ័ក្ត្រចុះដល់ដី»
ទ្រង់ក៏បញ្ជាឱ្យគេធ្វើយញ្ញបូជា និង ដុតគ្រឿងក្រអូបជូនលោក
ការនេះអាចចាប់ផ្តើមនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកបម្រើរបស់ស្តេចធ្វើយញ្ញបូជា និង ដុតគ្រឿងក្រអូបជូនដានីយ៉ែល»
ប្រាកដណាស់ព្រះរបស់លោក
«វាគឺជាការពិតណាស់ ដែលព្រះជាម្ចាស់ជារបស់អ្នក»
គឺពិតជាព្រះលើអស់ទាំងព្រះនានា ជាព្រះអម្ចាស់លើអស់ទាំងស្តេចនានា
«អស្ចារ្យជាងព្រះដទៃផ្សេងទៀត
ហើយជាស្តេចលើអស់ទាំងស្តេចផ្សេងទៀតផងដែរ» (UDB)
ព្រះតែមួយអង្គដែលបើកសម្តែងពីគម្រោងការដ៏អាថ៌កំបាំង
ការបកប្រែ «ជាព្រះអង្គដែលបើកបង្ហាញពីការអាថ៌កំបាំង» ដូចនៅក្នុងជំពូក
២:២៩។
បើកសម្តែងពីគម្រោងការដ៏អាថ៌កំបាំង
«ដើម្បីបើកបង្ហាញអាថ៌កំបាំងនៃសុបិន្តរបស់យើង»
Daniel 2:48
ស្តេចក៏បានតែងតាំងឲ្យដានីយ៉ែល
«ស្តេចបានតែងតាំងដានីយ៉ែលអោយធ្វើជាអ្នកគ្រប់គ្រង»
សាដ្រាក់...មែសាក់...អបេឌ-នេកោ
នេះជាឈ្មោះបាប៊ីឡូនរបស់បុរសជនជាតិយូដាបីនាក់ដែលត្រូវបានគេនាំទៅបាប៊ីឡូនជាមួយដានីយ៉ែល។
សូមមើលការបកប្រែរបស់អ្នកពីឈ្មោះនៅក្នុងជំពូក ១:៦

---

3 [1]ព្រះចៅនេបូ⁻ក្នេសាបានសាងសង់រូបបដិមាករមាសមួយដែលមានកំពស់ហុកសិបហត្ថ និងទទឹងប្រាំមួយហត្ថ។ ទ្រង់តំឡើងរូបបដិមាកររនោះនៅត្រង់វាលទំនាបឌូរ៉ា
ក្នុងអាណាខេត្តបាប៊ីឡូន។[2]បន្ទាប់មកព្រះចៅនេបូ⁻ក្នេសាបានចេញរាជសារ ឲ្យគេទៅប្រមូលចៅហ្វាយខេត្ត មន្ត្រីរដ្ឋបាលតាមតំបន់ មន្ត្រីមូលដ្ឋាន ជាមួយទីព្រឹក្សា
និងមន្ត្រីរក្សាព្រះរាជទ្រព្យ មន្ត្រីតុលាការ ព្រះរាជអាជ្ញាចៅក្រម និងនាម៉ឺនសព្វមុខមន្ត្រីនៅតាមអាណាខេត្តនានាក៏មកជួបជុំគ្នា ដើម្បីប្រារព្ធពិធីសម្ពោធរូបបដិមាករ
ដែលទ្រង់បានសង់ឡើង។
[3]រួចហើយចៅហ្វាយខេត្ត មន្ត្រីរដ្ឋបាលតាមតំបន់ មន្ត្រីមូលដ្ឋាន ជាមួយទីព្រឹក្សា និងមន្ត្រីរក្សាព្រះរាជទ្រព្យ មន្ត្រីតុលាការ ព្រះរាជអាជ្ញាចៅក្រម
និងនាម៉ឺនសព្វមុខមន្ត្រីនៅតាមអាណាខេត្តនានាក៏មកជួបជុំគ្នា ដើម្បីប្រារព្ធពិធីសម្ពោធរូបបដិមាករ ដែលព្រះចៅនេបូ⁻ក្នេសាបានសង់ឡើងនោះ។
ពួកមន្ត្រីទាំងនោះបានឈរនៅចំពោះរូបបដិមាករ។[4]ពេលនោះមានអាមាត្យម្នាក់បានស្រែកឡើងយ៉ាងខ្លាំងៗថា «អ្នករាល់គ្នាត្រូវទទួលបញ្ជាដល់មនុស្សជាតិ
និងជាតិសាសន៍ ហើយភាសាទាំងឡាយ[5]ពេលណាដែលអ្នករាល់គ្នាឮសម្លេងស្នែង ខ្លុយ ចាប៉ី ទ្រប៉ីគែន និងតន្ត្រីគ្រប់យ៉ាងប្រគុំឡើង
ត្រូវឲ្យអ្នករាល់គ្នាឱនកាយក្រាបថ្វាយបង្គំរូបបដិមាករមាស ដែលព្រះករុណា នេបូក្នេសាបានសង់ឡើង។
[6]ចំពោះអ្នកណាដែលមិនព្រមក្រាបថ្វាយបង្គំទេ គឺនៅក្នុងពេលនោះ អ្នកនោះនឹងត្រូវបោះចូលទៅក្នុងភ្លើងដែលឆេះយ៉ាងសន្ធោសន្ធៅភ្លាមៗ»។
[7]ដូច្នេះនៅពេលដែលប្រជាជនទាំងឡាយ បានឮសម្លេង ស្នែង ខ្លុយ ចាប៉ីទ្រប៉ីគែន និង តន្ត្រីគ្រប់យ៉ាងប្រគុំឡើង នោះប្រជាជាតិ និងជនជាតិនានា ហើយភាសាទាំងឡាយ
ត្រូវឱនកាយក្រាបថ្វាយបង្គំរូបបដិមាករមាសដែលព្រះចៅនេបូ⁻ក្នេសាបានកសាង។
[8]នៅក្នុងពេលជាមួយគ្នានោះដែរ ពួកខាល់ដេបាននាំគ្នាចូលទៅប្តឹង ដើម្បីចោទប្រកាន់ទាស់និងពួកជនជាតិយូដា។[9]ពួកគេទូលព្រះចៅនេបូ⁻ក្នេសាថា «បពិត្រព្រះករុណា
សូមឲ្យព្រះមានព្រះជន្មយឺនយូរតរៀងទៅ![10]ត្បិតព្រះអង្គ ព្រះករុណាបានចេញរាជបញ្ជាឲ្យមនុស្សគ្រប់គ្នា ក្រាបថ្វាយបង្គំរូបបដិមាករមាស នៅពេលគេឮសម្លេងស្នែង ខ្លុយ
ចាប៉ី ទ្រ ប៊ី គែន និង តន្ត្រីគ្រប់យ៉ាងប្រគុំឡើង។
[11]ហើយបើមានអ្នកណាមិនព្រមក្រាបថ្វាយបង្គំទេ នឹងត្រូវ បោះចូលទៅក្នុងភ្លើង។[12]នៅពេលនេះមានជនជាតិយូដាខ្លះ
ដែលព្រះករុណាបានតែងតាំងឲ្យគ្រប់គ្រងលើអាណាខេត្ត នៃបាប៊ីឡូន ឈ្មោះរបស់ពួកគេគឺលោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោ។ បពិត្រព្រះករុណា
ពួកអ្នកទាំងនេះ មិនស្តាប់បង្គាប់របស់ទ្រង់ទេ។ ពួកគេក៏មិនបានគោរពថ្វាយបង្គំ ឬបម្រើព្រះបដិមាកររបស់ទ្រង់ដែរ
ហើយពួកគេនឿយដែលឈរនៅចំពោះព្រះបដិមាករមាសដែលព្រះករុណាបានកសាងឡើយ»។
[13]ក្រោយមកព្រះចៅនេបូ⁻ក្នេសា មានព្រះទ័យខ្ញាល់ពន់ពេក ហើយចេញរាជបញ្ជាថា លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោ នាំមកគាល់ទ្រង់។
ដូច្នេះគេក៏នាំពួកលោកទាំងនោះមកគាល់ស្តេច។[14]ព្រះចៅនេបូ⁻ក្នេសាបានមានបន្ទូលទៅកាន់ពួកគេថា «លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោ
អស់លោកពិតជាមិនបានគោរពព្រះរបស់យើង ហើយមិនព្រមថ្វាយបង្គំរូបព្រះមាសដែលយើងបានកសាងមែនឬ?
[15]ឥឡូវនេះចូរប្រុងប្រៀបខ្លួនជាស្រេច នៅពេលណាពួកអ្នក បានឮសម្លេងស្នែង ខ្លុយ ចាប៉ី ទ្រ ប៊ី គែន និង តន្ត្រីគ្រប់យ៉ាងប្រគុំឡើង ហើយចូរឱនកាយក្រាបចុះ
ហើយថ្វាយបង្គំរូបបដិមាករដែលយើងសង់នេះចុះនោះគ្រប់យ៉ាងនឹងមិនអីទេ។ តែបើពួកអ្នកមិនក្រាបថ្វាយបង្គំទេ នោះពួកអ្នកនឹងត្រូវបោះចូលទៅក្នុងភ្លើងភ្លាមៗ។
តើមានព្រះឯណាអាចនឹងមកជួយពួកអ្នកពីកណ្តាប់ដៃយើងបានឡើយនោះ?»
[16]លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោ បានទូលឆ្លើយតបទៅព្រះករុណាវិញថា៖ «ព្រះករុណានេបូ⁻ក្នេសា
ទូលបង្គំមិនចាំបាច់ឆ្លើយនឹងព្រះករុណាអំពីរឿងនេះទេ។[17]ចម្លើយគឺមានតែមួយទេ បពិត្រព្រះរាជា ព្រះជាម្ចាស់ដែលយើងខ្ញុំគោរពថ្វាយបង្គំ
គឺពិតជាអាចជួយសង្គ្រោះពួកទូលបង្គំពីភ្លើងដែលឆេះសន្ធោសន្ធៅ ហើយទ្រង់ក៏នឹងរំដោះយើងខ្ញុំពីកណ្តាប់ដៃព្រះករុណាបានដែរ។[18]ប៉ុន្តែ បពិត្រព្រះករុណា
សូមជ្រាបថាយើងខ្ញុំនឹងមិនគោរពព្រះទាំងប៉ុន្មានរបស់ព្រះករុណាឡើយ ហើយក៏មិនក្រាបថ្វាយបង្គំរូបបដិមាកររមាសដែលព្រះករុណាសង់ឡើយ»។
[19]គ្រានោះព្រះចៅនេបូ⁻ក្នេសាពេញដោយកំហឹងក្រៀវក្រោធនឹងលោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោជាខ្លាំង។ ព្រះភ័ក្ត្រទ្រង់ក៏ផ្លាស់ប្តូរ។
ទ្រង់ក៏បញ្ជាឲ្យគេបង្កើនកម្តៅឲ្យក្តៅខ្លាំងជាងធម្មតាប្រាំពីរដង។[20]រួចទ្រង់ក៏មានរាជបញ្ជាឲ្យមេទ័ពដែលមានកម្លាំងខ្លាំងក្លាចាប់ចងលោកសាដ្រាក់ លោកមែសាក់
និងលោកអបេឌនេកោ ហើយបោះពួកគេចូលទៅក្នុងភ្លើងនោះ។
[21]ពួកគេត្រូវបានគេចាប់ចងទាំងមានសម្លៀកបំពាក់ និង ឈ្នួត ព្រមទាំងសម្លៀកបំពាក់ផ្សេងៗផង
រួចពួកគេត្រូវបានគេបោះចូលទៅក្នុងគុកភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ។[22]ដោយសារនោះជារាជបញ្ជាដ៏តឹងរឹងរបស់ព្រះរាជា ហើយកុកភ្លើងនោះមានកម្តៅជាខ្លាំង
អណ្តាតភ្លើងនោះបានសម្លាប់បុរសដែលបានយកលោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោ ទៅក្នុងគុកភ្លើងនោះ។[23]អ្នកទាំងបីនាក់នេះគឺ លោកសាដ្រាក់
លោកមែសាក់ និងលោកអបេឌនេកោត្រូវគេបោះចូលទៅក្នុងភ្លើងទាំងខ្លួនជាប់ចំណង។
[24]ពេលនោះ ព្រះចៅនេបូ⁻ក្នេសាមានព្រះទ័យរន្ធត់ ហើយក្រោកឈរជាប្រញាប់។ ព្រះរាជាមានរាជឱង្ការទៅកាន់ក្រុមប្រឹក្សារបស់ទ្រង់ថា៖
«តើយើងមិនបានបោះបុរសបីនាក់នោះទៅក្នុងភ្លើង ទាំងជាប់ចំណងទេឬអី?» ពួកគេក៏ទូលតបទៅទ្រង់ថា៖ «ពិតប្រាកដណាស់ ព្រះករុណា»។[25]ប៉ុន្តែ
ព្រះរាជាមានរាជឱង្ការថា៖ «ហេតុអ្វីយើងឃើញមានបុរសបួននាក់ដែលគ្មានជាប់ចំណង កំពុងដើរនៅក្នុងភ្លើងដោយមិនរលាកអ្វីសោះ។
ចំណែកឯអ្នកទីបួននោះមានរូបរាងដូចជាទេវតា»។
[26]ព្រះចៅនេប៊ូក្នេសាបានយាងចូលទៅជិតទ្វារឡភ្លើងហើយហៅពួកគេថា៖ «លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោ ជាអ្នកបម្រើព្រះ
ជាម្ចាស់ដ៏ខ្ពស់បំផុតអើយ សូមចេញមក! ហើយមកទីនេះ!»។ ពេលនោះ លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ នេកោក៏ចេញពីភ្លើងមក។[27]ពួកចៅហ្វាយខេត្ត

generated on Wed Sep 10 16:16:32 2025

មន្ត្រីតាមតំបន់ និងពួកមន្ត្រីផ្សេងៗទៀត ហើយនិងពួកមន្ត្រីក្រុមប្រឹក្សារបស់ព្រះរាជា ដែលបានជុំគ្នាបានឃើញបុរសទាំងនេះ។
ភ្លើងមិនបានមានឥទ្ធិពលអ្វីដល់ខ្លួនរបស់ពួកគេឡើយ សក់នៅលើក្បាលក៏មិនឆេះដែរ សម្លៀកបំពាក់ពួកគេមិនឆេះដែរ ហើយក៏គ្មានធុំក្លិនឈ្មៀមពីពួកគេដែរ។
[28]ព្រះចៅនេប៊ូក្នេសាមានរាជឱង្ការថា៖ «ចូរយើងសូមសរសើរតម្កើងដល់ព្រះជាម្ចាស់របស់លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌនេកោ
ដែលបានចាត់ទេវតារបស់ទ្រង់មករំដោះអ្នកបម្រើទ្រង់។ ពួកគេបានទុកចិត្តលើព្រះអង្គ ហើយមិនព្រមធ្វើតាមរាជបញ្ជារបស់ព្រះរាជាទេ
ពួកគេបានលះបង់រូបកាយរបស់ពួកគេជាជាងថ្វាយបង្គំ ឬ លុតក្រាបខ្លួនរបស់ពួកគេនៅចំពោះព្រះឯណាទៀត ក្រៅអំពីព្រះអង្គឡើយ។
[29]ដូច្នេះ យើងចេញរាជបញ្ជាទៅកាន់មនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសាទាំងអស់ថា ប្រសិនបើ អ្នកណាហ៊ាននិយាយប្រឆាំងនឹងព្រះជាម្ចាស់របស់លោកសាដ្រាក់
លោកមែសាក់ និងលោកអបេឌនេកោ អ្នកនោះនឹងត្រូវមានទោសដល់ជីវិត ហើយផ្ទះរបស់អ្នកនោះនឹងត្រូវដុតកម្ទេចចោល
ពីព្រោះគ្មានព្រះឯណាដែលអាចសង្គ្រោះពួកគេបានដូច្នេះឡើយ»។[30]បន្ទាប់មកព្រះរាជាក៏ប្រទានឲ្យលោកសាដ្រាក់ លោកមែសាក់
និងលោកអបេឌនេកោមានឋានៈខ្ពស់ជាងមុន នៅក្នុងអាណាខេត្តបាប៊ីឡូន។

Daniel 3:1

ព្រះចៅនេប៊ូ◌ក្នេសាបានសាងសង់រូបបដិមាករ...ទ្រង់តំឡើងរូបបដិមាកនោះ

ទាហានរបស់ព្រះចៅនេប៊ូ◌ក្នេសាបានធ្វើរូបសំណាក់ឡើង
ដោយការបញ្ជារបស់ស្តេចដែលថ្លែងដោយព្រះចៅនេប៊ូ◌ក្នេសា
ហើយបានសាងសង់រូបបដិមាករ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះចៅនេប៊ូ◌ក្នេសាបញ្ជាអោយទាហានរបស់ទ្រង់ដើម្បីធ្វើរូបបដិមាករមាស...ពួកគេ**សាងសង់រូបបដិមាកនោះ**ឡើង»

មានកំពស់ហុកសិបហត្ថ និង ទទឹងប្រាំមួយហត្ថ

«កំពស់ប្រមាណ២៧ម៉ែត និងទទឹង៣ម៉ែត»

នៅត្រង់វាលទំនាបឌូរ៉ា

នេះគឺជាទីកន្លែងនៅក្នុងអាណាចក្របាប៊ីឡូន។

ចៅហ្វាយខេត្ត...មន្ត្រីរដ្ឋបាល...ទីប្រឹក្សា

មន្ត្រីទាំងនេះដែលបានមានសិទ្ធនៅលើទំហំខុសគ្នានៃតំបន់នីមួយៗ។

មន្ត្រីរក្សាព្រះរាជទ្រព្យ

មន្ត្រីទាំងនេះគឺគ្រប់គ្រងថវិកា។

Daniel 3:3

ចៅហ្វាយខេត្ត មន្ត្រីរដ្ឋបាល មន្ត្រីតុលាការ ... មន្ត្រីនៅតាមអាណាខេត្តនានា

បកប្រែបញ្ជីទាំងនេះដូចនៅក្នុងជំពូក ៣:១។

រូបបដិមាករដែលព្រះចៅនេប៊ូក្នេសាបានសង់ឡើងនោះ

ទាហានរបស់ព្រះចៅនេប៊ូក្នេសាបានធ្វើរូបសំណាក់ឡើង
ដោយការបញ្ជារបស់ស្តេចដែលថ្លែងដោយព្រះចៅនេប៊ូក្នេសា
ហើយបានសាងសង់រូបបដិមាករ។ ការបកប្រែរបៀបផ្សេងទៀត:
«រូបបដិមាករដែលទាហានរបស់ព្រះចៅនេប៊ូក្នេសាបានសាងសង់ឡើង»

អាមាត្យ

មនុស្សរបស់មន្ត្រីដែលជាអ្នកនាំសារទៅថ្វាយស្តេច។

ចូរស្តាប់រាជបញ្ជា

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ «ស្តេចបានបញ្ជាដល់អ្នក»

មនុស្សជាតិសាសន៍ទាំងឡាយអើយ! ចូរស្តាប់រាជបញ្ជា

ពាក្យថា «ជនជាតិ» និង «ភាសាជាច្រើន»
នៅទីនេះតំណាងអោយមនុស្សដែលមកពីជនជាតិផ្សេងៗ
ដែលនិយាយភាសាផ្សេងពីគ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សដែលមកពីជនជាតិផ្សេងៗដែលនិយាយភាសាផ្សេងពីគ្នា»

ចាប៉ី

នេះគឺជាឧបករណ៍តន្ត្រីដែលស្រដៀងទៅនឹងពិណ។ ពួកវាមានរាងដូចជាត្រីកោណ
ហើយមានខ្សែជាច្រើនផង។

ឱនកាយក្រាប

ពាក្យថា «ក្រាបចុះ» នៅទីនេះមានន័យថា «អោនចុះយ៉ាងប្រញាប់»

ក្រាបថ្វាយបង្គំខ្លួនអ្នក

«ផ្ទួលខ្លួនអ្នកទៅលើដីដោយអោនមុខចុះ ហើយថ្វាយបង្គំ»

Daniel 3:6

អស់អ្នកណាដែលមិនក្រាបថ្វាយបង្គំទេ

អ្នកនោះនឹងត្រូវបោះចូលទៅក្នុងភ្លើងដែលឆេះយ៉ាងសន្ធោសន្ធៅភ្លាមៗ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកទាហាននឹងបោះទៅក្នុងភ្លើងអស់អ្នកណាដែលមិនព្រមក្រាបថ្វាយបង្គំដល់រូបបដិមាកនោះ
នៅក្នុងពេលដែលពួកគេបានឮសម្លេងភ្លេងដែលបានប្រគុំឡើង»

ក្រាបថ្វាយ

ឃ្លាថា «ក្រាបចុះ» នៅទីនេះមានន័យ «ប្រញាប់អោនចុះ»

ក្នុងភ្លើងដែលឆេះយ៉ាងសន្ធោសន្ធៅ

នេះគឺជាបន្ទប់ដ៏ធំដែលពេញទៅដោយភ្លើងយ៉ាងក្តៅ។

ប្រជាជនជាតិសាសន៍ទាំងឡាយ និង មនុស្សគ្រប់ភាសា

ពាក្យថា «ទាំងអស់» នៅទីនេះមានន័យថាប្រជាជនទាំងអស់ដែលមានវត្តមាន។

មនុស្ស ជនជាតិ និងគ្រប់ភាសា

ពាក្យថា «ជនជាតិ» និង «ភាសា»
នៅទីនេះតំណាងឲ្យមនុស្សដែលមកពីជនជាតិដទៃ
សាងសង់រូបបដិមាកនោះឡើង។

សូមមើលពីរការបកប្រែពាក្យនេះនៅក្នុងជំពូក ៣:៣។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សដែលមកពីជនជាតិដទៃ ហើយដែលនិយាយភាសាផ្សេងគ្នាដែរ»

ស្មែង ខ្លុយ ចាប៉ីទ្រប៉ីគែន

នេះគឺជាឧបករណ៍តន្ត្រី។

ការបកប្រែពីបញ្ជីនេះដូចដែលអ្នកបានបកប្រែ◌ នៅក្នុងជំពូក ៣:៣។

ក្រាបថ្វាយបង្គំ

ឃ្លាថា «ក្រាបចុះ» នៅទីនេះមានន័យថា «អោនចុះយ៉ាងប្រញាប់»

ពួកគេឱនកាយក្រាបថ្វាយបង្គំ

«អោនក្រាបខ្លួនរបស់ពួកគេចុះទៅលើដី ផ្តាប់មុខដល់ដីថ្វាយបង្គំដល់អ្វីមួយ»

រូបបដិមាករមាសដែលព្រះចៅនេប៊ូក្នេសាបានកសាង

ទាហានរបស់ព្រះចៅនេប៊ូក្នេសាបានធ្វើរូបសំណាក់ឡើង
ដោយការបញ្ជារបស់ស្តេចដែលថ្លែងដោយព្រះចៅនេប៊ូក្នេសាហើយបានសាងសង់រូបបដិមាករ។
ការបកប្រែរបៀបផ្សេងទៀត:
«រូបបដិមាករដែលទាហានរបស់ព្រះចៅនេប៊ូក្នេសាបានសង់ឡើង»

Daniel 3:8

នៅក្នុងពេល

ពាក្យទាំងនេះប្រើដើម្បីបង្កើតឲ្យមានការឈប់ នៅក្នុងរឿងរ៉ាវទាំងមូល។
នៅទីនេះអ្នកនិពន្ធចង់ប្រាប់អំពីមនុស្សថ្មីខ្លះដែលនៅក្នុងសាច់រឿង។

ព្រះករុណា ដែលមានព្រះជន្មយឺនយូរអើយ

នេះគឺជាសេចក្តីបង្គាប់សម្រាប់ការស្វាគមន៍ដល់ស្តេច។

សម្លេងស្មែង ខ្លុយ...និង តន្ត្រីគ្រប់យ៉ាងប្រគុំឡើង

ឧបករណ៍តន្ត្រីទាំងនេះ។ ការបកប្រែបញ្ជីទាំងនេះដូចដែលបានបកប្រែនៅក្នុងជំពូក
៣:៣។

ក្រាបថ្វាយបង្គំ

ឃ្លាថា «ក្រាបចុះ» នៅទីនេះមានន័យថា «អោនចុះយ៉ាងប្រញាប់»

មនុស្សគ្រប់គ្នា ក្រាបថ្វាយបង្គំ

«អោនក្រាបខ្លួនរបស់ពួកគេចុះទៅលើដី ផ្តាប់មុខដល់ដី
ក្នុងការថ្វាយបង្គំដល់អ្វីមួយ»

Daniel 3:11

ហើយបើអ្នកណាមិនក្រាបថ្វាយបង្គំទេ អ្នកនោះនឹងត្រូវ បោះចូលទៅក្នុងភ្លើង

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកទាហាននឹងបោះទៅក្នុងភ្លើងអស់អ្នកណាដែលមិនព្រមក្រាបថ្វាយបង្គំ» (សូមមើល: [[(en:ta:vol2:translate]])

ក្រាបថ្វាយបង្គំ

ឃ្លាថា «ក្រាបចុះ» នៅទីនេះមានន័យថា «អោនចុះយ៉ាងប្រញាប់»

អ្នកនោះនឹងត្រូវ បោះចូលទៅក្នុងភ្លើង

នេះគឺជាបន្ទប់ដ៏ធំដែលពេញទៅដោយភ្លើងយ៉ាងក្តៅ។

បកប្រែការនេះដូចអ្នកបានបកប្រែនៅក្នុងជំពូក ៣:៦។

ឲ្យគ្រប់គ្រងលើ

«រឿងក្តី» ឬ «ការងារ»

សាដ្រាក់...មែសាក់...អបេឌ នេកោ

ទាំងនេះជាឈ្មោះបាប៊ីឡូនរបស់មិត្តដានីយ៉ែលទាំងបីរបស់ដានីយ៉ែល។

generated on Wed Sep 10 16:16:32 2025

សូមមើលការបកប្រែរបស់អ្នកពីឈ្មោះនៅក្នុងជំពូក ១:៦។
ពួកគេទាំងនេះ មិនស្តាប់បង្គាប់ព្រះរាជា
«មិនបានយកចិត្តទុកដាក់ស្តាប់ដល់ទ្រង់»
ហើយមិនបានគោរពថ្វាយបង្គំ
«អោនក្រាបខ្លួនរបស់ពួកគេចុះទៅលើដី ផ្កាប់មុខដល់ដីថ្វាយបង្គំដល់អ្វីមួយ»
ព្រះបដិមាករ ដែលព្រះករុណាបានកសាងឡើយ
ទាហានរបស់ព្រះចៅនេប៊ូក្នេសាបានធ្វើរូបសំណាក់ឡើង
ដោយការបញ្ជារបស់ស្តេចដែលថ្លែងដោយព្រះចៅនេប៊ូក្នេសា
ហើយបានសាងសង់រូបបដិមាករ។ ការបកប្រែរបៀបផ្សេងទៀត:
«រូបបដិមាករដែលទាហានរបស់ព្រះចៅនេប៊ូក្នេសាបានសង់ឡើង»
Daniel 3:13
មានព្រះទ័យខ្ញាល់ពន់ពេក ក៏ចេញរាជបញ្ជា
សេចក្តីកំហឹងរបស់ព្រះចៅនេប៊ូក្នេសា ហើយព្រះទ័យខ្ញាល់គឺបានយ៉ាងខ្លាំង
ដែលធ្វើឲ្យព្រះបន្ទូលទាំងនោះចេញមកដោយកំហឹងនៅក្នុងស្តេច។ ពាក្យថា
«កំហឹង» និង «ខ្ញាល់»
ដែលមានន័យថាដូចគ្នាហើយប្រើសម្រាប់បញ្ជាក់ពីការទាស់ព្រះទ័យដល់ស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «កំហឹងដ៏ខ្លាំង»
លោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ នេកោ
ទាំងនេះជាឈ្មោះបាប៊ីឡូនរបស់មិត្តដានីយ៉ែលទាំងបីរបស់ដានីយ៉ែល។
សូមមើលការបកប្រែរបស់អ្នកពីឈ្មោះនៅក្នុងជំពូក ១:៦។
អស់លោកពិតជាមិនបានគោរពព្រះរបស់យើង
ពាក្យថា «គំនិត» នៅទីនេះសំដៅដល់ការសម្រេច។ ដើម្បី «តាំងចិត្តរបស់អ្នក»
គឺជាពាក្យប្រៀបធៀបដែលមានន័យ ការធ្វើការសម្រេចចិត្តដ៏មាំទាំ។
ការបកប្រែរបៀបផ្សេងទៀត: «តើអ្នកបានសម្រេចចិត្តដ៏តឹងតែង»
ហើយមិនព្រមថ្វាយបង្គំព្រះដែលយើង
«អោនក្រាបខ្លួនរបស់ពួកគេចុះទៅលើដី ផ្កាប់មុខដល់ដីថ្វាយបង្គំដល់អ្វីមួយ»
ព្រះដែលយើងបានកសាង
ទាហានរបស់ព្រះចៅនេប៊ូក្នេសាបានធ្វើរូបសំណាក់ឡើង
ដោយការបញ្ជារបស់ស្តេចដែលថ្លែងដោយព្រះចៅនេប៊ូក្នេសា
ហើយបានសាងសង់រូបបដិមាករ។ ការបកប្រែរបៀបផ្សេងទៀត:
«រូបបដិមាករដែលទាហានរបស់ព្រះចៅនេប៊ូក្នេសាបានសង់ឡើង»
Daniel 3:15
សម្លេងស្នែង ខ្លុយ និង តន្ត្រីគ្រប់យ៉ាងប្រគុំឡើង
ឧបករណ៍តន្ត្រីទាំងនេះ។ ការបកប្រែបញ្ជីទាំងនេះដូចដែលបានបកប្រែនៅក្នុងជំពូក
៣:៣។
ក្រាបចុះ
ឃ្លាថា «ក្រាបចុះ» នៅទីនេះមានន័យ «អោនចុះយ៉ាងប្រញាប់»
ឱនកាយក្រាបចុះ ហើយថ្វាយបង្គំ
«អោនក្រាបខ្លួនរបស់ពួកគេចុះទៅលើដី
ផ្កាប់មុខដល់ដីក្នុងការថ្វាយបង្គំដល់អ្វីមួយ»
នេះឲ្យបានខ្ជាប់ខ្ជួន
«គឺអត់មានបញ្ហាអ្វីទៀតទេ» ឬ «អ្នកនឹងមានសិរីភាពដើម្បីចេញទៅ»
រូបបដិមាករដែលយើងសង់
ទាហានរបស់ព្រះចៅនេប៊ូក្នេសាបានធ្វើរូបសំណាក់ឡើង
ដោយការបញ្ជារបស់ស្តេចដែលថ្លែងដោយព្រះចៅនេប៊ូក្នេសា
ហើយបានសាងសង់រូបបដិមាករ។ ការបកប្រែរបៀបផ្សេងទៀត:
«រូបបដិមាករដែលទាហារបស់ព្រះចៅនេប៊ូក្នេសាបានសង់ឡើង»
លោកនឹងត្រូវបោះចូលទៅក្នុងភ្លើងជាពុំខាន
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកទាហានរបស់យើងនឹងបោះអ្នកទៅក្នុងភ្លើងដែលកំពុងឆេះ»
បោះចូលទៅក្នុងភ្លើង
នេះគឺជាបន្ទប់ដ៏ធំដែលពេញទៅដោយភ្លើងយ៉ាងក្តៅ។
បកប្រែការនេះដូចអ្នកបានបកប្រែនៅក្នុងជំពូក ៣:៦។
ព្រះឯណា...កណ្តាប់ដៃយើង?
ស្តេចមិនរំពឹងនឹងឆ្លើយតបទៅអ្វីទេ។ ស្តេចបានបោះបុរសទាំងបីនោះ។
ការបកប្រែរបៀបផ្សេងទៀត:
«គ្មានព្រះឯណាអាចជួយសង្គ្រោះអ្នកពីអំណាចរបស់យើងឡើយ!»
ជួយពួកលោកពីកណ្តាប់ដៃយើងបាន
ពាក្យថា «ដៃ» នៅទីនេះសំដៅដល់អំណាចនៃការជំនុំជម្រះ។
ការបកប្រែរបៀបផ្សេងទៀត: «ចេញពីការជំនុំជម្រះរបស់យើង»
Daniel 3:16
ពីភ្លើងដែលឆេះសន្ធោសន្ធៅ
នេះគឺជាបន្ទប់ដ៏ធំដែលពេញទៅដោយភ្លើងយ៉ាងក្តៅ។
បកប្រែការនេះដូចអ្នកបានបកប្រែនៅក្នុងជំពូក ៣:៦។
ពីកណ្តាប់ដៃព្រះករុណា
ពាក្យថា «ដៃ» សំដៅដល់អំណាចនៃការជំនុំជម្រះ។ ការបកប្រែរបៀបផ្សេងទៀត:
«ចេញពីការជំនុំជម្រះរបស់យើង»
ប៉ុន្តែ បពិត្រព្រះករុណាសូមជ្រាបថាយើងខ្ញុំ
«ប៉ុន្តែស្តេច យើងត្រូវតែឲ្យអ្នកបានដឹងថា
ទោះបីព្រះជាម្ចាស់ក៏មិនអាចជួយពួកយើងបានទេ»
ហើយក៏មិនក្រាបថ្វាយបង្គំព្រះបដិមាករ
«អោនក្រាបខ្លួនរបស់ពួកគេចុះទៅលើដី
ផ្កាប់មុខដល់ដីក្នុងការថ្វាយបង្គំដល់អ្វីមួយ»
ក្រាបថ្វាយបង្គំព្រះបដិមាករដែលព្រះករុណាសង់ឡើយ
ទាហានរបស់ព្រះចៅនេប៊ូក្នេសាបានធ្វើរូបសំណាក់ឡើង
ដោយការបញ្ជារបស់ស្តេចដែលថ្លែងដោយព្រះចៅនេប៊ូក្នេសាហើយបានសាងសង់រូបបដិមាករ។
ការបកប្រែរបៀបផ្សេងទៀត:
«រូបបដិមាករដែលទាហានរបស់ព្រះចៅនេប៊ូក្នេសាបានសង់ឡើង»
Daniel 3:19
ព្រះចៅនេប៊ូក្នេសាពេញដោយកំហឹងក្រៀវក្រោធ
សេចក្តីកំហឹងរបស់ព្រះចៅនេប៊ូក្នេសា ហើយព្រះទ័យខ្ញាល់យ៉ាងខ្លាំង
ដែលធ្វើឲ្យបន្ទូលទាំងនោះចេញមកដោយកំហឹងនៅក្នុងស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះចៅនេប៊ូក្នេសាមានកំហឹងយ៉ាងខ្លាំង»
ទ្រង់ក៏បញ្ជាឲ្យគេបង្កើនកម្តៅឲ្យក្តៅខ្លាំងជាងធម្មតាប្រាំពីរដង
ឃ្លាថា «ក្តៅឡើងប្រាំពីរដង» នៅទីនេះគឺប្រៀបធៀបដែលមានន័យថា
ធ្វើឱ្យវាកាន់តែក្តៅ។ ការនេះអាចនិយាយអំពីទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត:
ស្តេចបានបញ្ជាទាហានរបស់ទ្រង់ដើម្បីធ្វើឲ្យវាក្តៅខុសពីធម្មតា។
Daniel 3:21
ឈ្នួត
ឈ្នួតគឺជារបស់គ្របលើក្បាលដែលធ្វើពីក្រណាត់សម្រាប់ចង។
ភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ
នេះគឺជាបន្ទប់ដ៏ធំដែលពេញទៅដោយភ្លើងយ៉ាងក្តៅ។
បកប្រែការនេះដូចអ្នកបានបកប្រែនៅក្នុងជំពូក ៣:៦។
ដោយសារនោះជារាជបញ្ជាដ៏តឹងរ៉ឹងបំផុតរបស់ស្តេច
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពីព្រោះទាហានបានធ្វើដូចអ្វីដែលមេទ័ពរបស់ស្តេចបានបញ្ជា។
Daniel 3:24
តើយើងមិនបានបោះពួកគេបីនាក់ទៅក្នុងភ្លើង ទាំងជាប់ចំណង
«យើងមិនបានបោះពួកគេបីនាក់ទៅក្នុងភ្លើង ទាំងជាប់ចំណងផង ត្រូវទេ»
ចំណែកឯអ្នកទីបួននោះមានរូបរាងដូចជាកូននៃព្រះ
ព្រះបានជឿ ហើយជះចែងចាំងដ៏ភ្លឺជាមួយពន្លឺ។ ការបកប្រែរបៀបផ្សេងទៀត:
«បួននាក់នោះបានចែងចាំងពន្លឺជាមួយភ្លើងដូចជាព្រះដែលចែងចាំងពន្លឺ»
Daniel 3:26
ពួកចៅហ្វាយខេត្ត មន្ត្រីរដ្ឋបាល ទីប្រឹក្សា មន្ត្រីរក្សាព្រះរាជទ្រព្យ មន្ត្រីតុលាការ ព្រះរាជអាជ្ញា ចៅក្រម
ពួកមន្ត្រីដែលមានសិទ្ធនៅលើតំបន់ផ្សេងៗគ្នា។
សូមមើលពីរការបកប្រែពាក្យនេះនៅក្នុងជំពូក ៣:១។
សក់ក្បាលមិនឆេះ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយភ្លើងមិនអាចឆេះសក់ក្បាលពួកគេឡើយ»
ឆេះ
«ភ្លើងឆេះបំភ្លឺឡើង»
សម្លៀកបំពាក់ពួកគេ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ភ្លើងនោះមិនធ្វើឲ្យមានការខូចខាតសម្លៀកបំពាក់ពួកគេឡើយ»
មិនមានក្លិនឈ្ងៀមដែរ
«ពួកគេមិនបានមានក្លិនដូចភ្លើងឆេះដែរ»
Daniel 3:28

generated on Wed Sep 10 16:16:32 2025

ហើយមិនព្រមធ្វើតាមបញ្ជារបស់ស្តេចទេ
មិនបានស្តាប់បង្គាប់របស់ស្តេចដែលមានបន្ទូលអំពីអ្វីដែលរូបកាយរបស់ពួកគេបានចា
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេមិនខ្វាល់ពីបញ្ជារបស់យើង»
ពួកគេសុខចិត្តលះបង់ជីវិត
ឃ្លានេះសំដៅទៅលើបុរសបីនាក់ដែលព្រមលះបង់ជីវិតសម្រាប់ជំនឿរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេសុខចិត្តស្លាប់»
ដោយមិនក្រាបថ្វាយបង្គំ
«អោនក្រាបខ្លួនរបស់ពួកគេចុះទៅលើដី
ផ្កាប់មុខដល់ដីក្នុងការថ្វាយបង្គំដល់អ្វីមួយ»
ព្រះឯណាទៀតក្រៅអំពីព្រះអង្គឡើយ
«ព្រះណាផ្សេងទៀតលើកលែងតែព្រះជាម្ចាស់របស់គេ»
Daniel 3:29
ទៅកាន់មនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសាទាំងអស់...អ្នកនោះនឹងត្រូវមានទោសដល់ជីវិត
ហើយផ្ទះរបស់អ្នកនោះនឹងត្រូវដុតកម្ទេចចោល
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនរបស់យើងនឹងកម្ទេចចោលប្រជាជន ជនជាតិ ឬភាសាណាមួយ...
ឃើញថ្នើរផ្ទះ
ផ្ទះរបស់ពួកគេទៅជាគំនរសំរាម»
មនុស្សគ្រប់ជាតិសាសន៍ គ្រប់ភាសាទាំងអស់ថា
ពាក្យថា «ជនជាតិ» និង «ភាសា»
នៅទីនេះតំណាងឲ្យប្រជាជនដែលមកពីជនជាតិផ្សេងដែលនិយាយភាសាខុសគ្នា។
សូមមើ ីលពីរបៀបបកប្រែដែលស្រដៀងទៅនឹងឃ្លាក្នុងជំពូក ៣:៣។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជនខ្លះមកពីជនជាតិផ្សេង
ឬអ្នកដែលនិយាយភាសាដែលពោលថា»
និយាយប្រឆាំងនឹងព្រះ
«បាននិយាយអ្វីដែលមិនគោរពព្រះជាម្ចាស់»
ត្រូវកម្ទេចចោល
«ត្រូវឲ្យរូបកាយរបស់ពួកគេកម្ទេចជាចំណែក»
គ្មានព្រះឯណាដែលអាចសង្គ្រោះពួកគេបានដូច្នេះឡើយ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មានតែព្រះជាម្ចាស់របស់ពួកគេទេ ទើបអាចសង្គ្រោះបានដូច្នេះ»

---

4 [1]ព្រះចៅនេប៊ូក្នេសាបានបញ្ជូនរាជសារនេះទៅដល់ប្រជាជនទាំងអស់ ហើយគ្រប់ជាតិសាសន៍ និងគ្រប់ភាសាទាំងមូល ដែលរស់នៅលើផែនដីទាំងមូល:
«សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្តីសុខសាន្ត។[2]គ្រប់ទាំងការល្អបានកើតដល់យើង ដើម្បីប្រាប់អ្នករាល់គ្នាឲ្យបានដឹងពីទីសម្គាល់ និងការអស្ចារ្យទាំងឡាយ
ដែលព្រះដ៏ខ្ពង់ខ្ពស់បានធ្វើសម្រាប់យើង។[3]តើទីសម្គាល់របស់ព្រះអង្គអស្ចារ្យយ៉ាងណាទៅ និងវិន្ទិនុភាពដ៏អស្ចារ្យយ៉ាងទៅ!
ហើយព្រះរាជ្យរបស់ព្រះអង្គគង់នៅអស់កល្បជានិច្ចតទៅ ហើយអំណាចត្រួតត្រារបស់ព្រះអង្គគង់នៅអស់កល្បជានិច្ចពីជំនាន់មួយទៅដល់ជំនាន់ដែល»។
[4]យើង នេប៊ូក្នេសាកំពុងតែរស់នៅយ៉ាងមានសុភមង្គលនៅក្នុងព្រះរាជដំណាក់របស់យើង ហើយយើងក៏រីករាយនៅក្នុងទ្រព្យសម្បត្តិនៅក្នុងរាជវាំងរបស់យើងដែរ។
[5]ប៉ុន្តែសុបិន្តដែលយើងឃើញពិតជាធ្វើឲ្យយើងភ័យខ្លាចណាស់។ សូម្បីតែពេលយើងផ្ទំនៅទីនោះ រូបភាពដែលយើងឃើញហើយនិងនិមិត្តដែលនៅក្នុងគំនិតរបស់យើង
បានធ្វើឲ្យយើងព្រួយព្រះហឫទ័យ។
[6]ដូច្នេះហើយបានជាយើងចេញរាជសារដើម្បីប្រមូលអស់អ្នកប្រាជ្ញនៅស្រុកបាប៊ីឡូនដែលមានប្រាជ្ញាអាចកាត់ស្រាយសុបិន្តនោះថ្វាយយើងបាន។
[7]រួចហើយពួកគ្រូមន្តអាគម ហើយនិងអ្នកអាចហៅអ្នកស្លាប់មកនិយាយបាន ពួកអ្នកប្រាជ្ញហើយនឹងគ្រូធ្មបផង។ យើងបានប្រាប់ពួកគេពីសុបិន្តនោះ
តែពួកគេពុំមាននរណាម្នាក់អាចកាត់ស្រាយអត្ថន័យឲ្យយើងបានទេ។[8]ប៉ុន្តែចុងក្រោយ ដានីយ៉ែលបានមកគាល់យើង ម្នាក់ដែលមានឈ្មោះថាលោកបេលថិស្សាសារ
ជាឈ្មោះតាមព្រះរបស់យើង គឺម្នាក់ដែលមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយ ហើយយើងបានរៀបរាប់ប្រាប់លោកពីសុបិន្តនោះ។[9]«លោកបេលថិស្សាសារអើយ!
ជាប្រមុខលើគ្រូមន្តអាគម យើងដឹងថាមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងលោក ហើយក៏គ្មានការលាក់កំបាំងណាដែលពិបាកសម្រាប់លោកដែរ។
សូមជួយប្រាប់យើងនូវអ្វីដែលយើងឃើញនៅក្នុងសុបិន្តរបស់យើង ហើយវាមានន័យយ៉ាងណាដែរ។
[10]នៅពេលដែលយើងផ្ទំ យើងនិមិត្តឃើញដូចតទៅ៖ពេល យើងទតទៅឃើញមានដើមឈើមួយនៅចំកណ្តាលផែនដី ដើមឈើនោះខ្ពស់អស្ចារ្យ។
[11]ដើមឈើនោះលូតកាន់តែធំឡើងៗ។ ចុងរបស់វាខ្ពស់ដល់មេឃ ហើយ សូម្បីតែមនុស្សនៅចុងផែនដីក៏អាចមើលឃើញដើមឈើនេះដែរ។[12]ស្លឹកវា ខៀវខ្ចី
មានផ្លែជាបរិបូណ៌ ដែលអាចចិញ្ចឹមជីវិតមនុស្សទាំងអស់បាន។ សត្វគ្រប់ប្រភេទមកជ្រកក្រោមម្លប់របស់វា ហើយបក្សាបក្សីនានានាំគ្នាមកទំលើមែករបស់វា។
ហើយសត្វលោកទាំងអស់រស់រានចិញ្ចឹមជីវិតដោយសារដើមឈើមួយដើមនេះ។
[13]យើងបានឃើញនៅក្នុងព្រលឹងរបស់យើង នៅក្នុងពេលយើងផ្ទំហើយឃើញទេវតាដ៏វិសុទ្ធមួយបានចុះមកពីស្ថានសួគ៌។[14]ទេវតាស្រែកនិងពោលថា
«ចូរកាប់រំលំដើមឈើនោះ ហើយកាត់មែករបស់វាចោល ចូរលះស្លឹកចេញហើយជម្រុះផ្លែរបស់វាផង។ ចូរឲ្យសត្វទាំងឡាយចេញពីម្លប់របស់វា ហើយឲ្យបក្សាបក្សី
ហើរចេញពីមែករបស់វាដែរ។
[15]ចូរទុកគល់នៃឫសរបស់វានៅក្នុងដី ហើយយកច្រវ៉ាក់ដែក និងលង្ហិន មកចង់វាទុកនៅក្នុងកណ្តាលទីវាលស្មៅ។ ហើយចូរទុកចោលឲ្យវាត្រូវទឹកសន្សើមពីលើមេឃចុះ។
ចូរឲ្យវារស់នៅជាមួយនិងសត្វនៅក្នុងចំណោមរុក្ខជាតិដែលនៅលើផែនដី។[16]ចូរឲ្យដើមឈើនោះលែងមានចិត្តគំនិតជាមនុស្សទៀតទៅ គឺឲ្យមានចិត្តគំនិតដូចជាសត្វវិញ
រហូតដល់គម្រប់ប្រាំពីរឆ្នាំបានកន្លងផុត។
[17]ការសម្រេចចិត្តគឺតាមរយៈរាជសារថ្លែងដោយពួកទេវតា។វាគឺជាសម្រេចចិត្តដែលធ្វើឡើងដោយពួកដ៏វិសុទ្ធ
ដូច្នេះមនុស្សគ្រប់គ្នាដែលរស់នៅគួរស្គាល់ព្រះដ៏ខ្ពង់ខ្ពស់បំផុតដែលគ្រប់គ្រងលើអាណាចក្ររបស់មនុស្ស ហើយប្រទានដល់អ្នកណា ដែលព្រះអង្គចង់គង់នៅជាមួយពួកគេ
ហើយព្រះអង្គនឹងលើកអស់អ្នកដែលបន្ទាបខ្លួនឡើងដែរ។[18]យើង ព្រះចៅនេប៊ូក្នេសា បានសុបិន្តឃើញការនេះ។ ពេលនេះលោកបេលថិស្សាសារបានប្រាប់យើង
ពីការកាត់ស្រាយសុបិន្តនោះ ត្បិតគ្មានអ្នកប្រាជ្ញណាដែលនៅក្នុងអាណាចក្រយើងអាចកាត់ស្រាយបានឡើយ។ ប៉ុន្តែលោកអាចកាត់ស្រាយបាន
ដោយសារលោកមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងលោក»។
[19]រួចហើយដានីយ៉ែលដែលមានឈ្មោះថា បេលថិស្សាសារ ក៏បានស្រឡាំងកាំងមួយសន្ទុះ ដោយគាត់ដឹងក្នុងចិត្តហើយថា ការនោះនឹងរំលឹកដល់លោក
«ព្រះករុណាក៏មានរាជឱង្ការថា បេលថិស្សាសារ សូមកុំឲ្យចិត្តលោកភ័យខ្លាចដោយសារសុបិន្តមួយនេះ និងអត្ថន័យរបស់វាអី»។ បេលថិស្សាសារក៏ទូលតបទៅវិញថា
«បពិត្រព្រះករុណា សូមឲ្យសុបិន្តនេះកើតឡើងចំពោះអស់អ្នកដែលស្អប់ព្រះករុណា ហើយសូមឲ្យអត្ថន័យរបស់វាបានកើតឡើងលើខ្មាំងសត្រូវរបស់ព្រះករុណាចុះ។
[20]ដើមឈើដែលព្រះករុណាបានឃើញនោះ នឹងលូតកាន់តែធំឡើងហើយរឹងមាំដែរ ហើយចុងរបស់វាខ្ពស់ដល់មេឃ ហើយ
សូម្បីតែមនុស្សនៅចុងផែនដីក៏អាចមើលឃើញដើមឈើនេះដែរ។[21]ស្លឹកវាទាំងអស់ខៀវខ្ចី ហើយមានផ្លែជាបរិបូណ៌ ហើយនៅក្នុងវាអាចជាអាហារសម្រាប់គ្រប់គ្នាបាន។
សត្វគ្រប់ប្រភេទមកជ្រកក្រោមម្លប់របស់វា ហើយបក្សាបក្សីនានានាំគ្នាមករស់នៅលើមែករបស់វា។[22]ដើមឈើនោះគឺជាព្រះករុណា ទ្រង់បានចម្រើនឡើងហើយរឹងមាំ។
ហើយអំណាចចេស្តា ខ្ពង់ខ្ពស់រហូតដល់មេឃ ហើយសិទ្ធអំណាចរបស់ទ្រង់ពេញរហូតដល់ចុងផែនដីទាំងមូល។
[23]បពិត្រព្រះករុណា ទ្រង់បានទតឃើញទេវតាយាងចុះមកពីស្ថានសួគ៌ហើយថ្លែងថា «ចូរកាប់រំលំដើមឈើនោះ ហើយបំផ្លាញវាចោល ប៉ុន្តែចូរទុកគល់
និងឫសរបស់វានៅក្នុងដី ហើយយកច្រវ៉ាក់ដែក និងលង្ហិនមកចង់វាទុកនៅកណ្តាលទីវាលស្មៅ។ ចូរទុកវាចោលឲ្យត្រូវទឹកសន្សើមធ្លាកពីលើមេឃចុះ។
ចូរឲ្យវារស់នៅជាមួយនិងសត្វទាំងឡាយដែលនៅក្នុងទីវាល រហូតដល់គម្រប់ប្រាំពីរឆ្នាំចុះ»។
[24]បពិត្រព្រះករុណា នេះគឺជាអត្ថន័យសុបិន្តដែលជារាជសារនៃព្រះដ៏ខ្ពង់ខ្ពស់បានប្រទានព្រះករុណាដែលជាស្តេចនៃទូលបង្គំ។
[25]ព្រះករុណានឹងត្រូវគេបណ្តេញចេញពីចំណោមមនុស្ស ហើយនឹងត្រូវរស់នៅជាមួយសត្វតាមវាល។ ហើយគេនឹងយកស្មៅឲ្យព្រះរាជាសោយដូចជាគោដែរ
ហើយព្រះកាយរបស់ព្រះករុណានឹងសើមដោយសារទឹកសន្សើមដែលធ្លាក់មកពីលើមេឃ នឹងរហូតដល់គម្រប់ប្រាំពីរឆ្នាំ គឺទាល់តែដល់ពេលមួយដែលព្រះរាជា
ទទួលស្គាល់ព្រះដ៏ខ្ពង់ខ្ពស់បំផុតជាអ្នកគ្រប់គ្រងលើអាណាចក្ររបស់មនុស្សលោក ហើយព្រះអង្គចង់ប្រទានឲ្យអ្នកណាតាមព្រះហឫទ័យរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

[26]គឺមានការបញ្ជាឲ្យទុកគល់ឈើ នៃឫសរបស់ដើមឈើ គឺមានន័យថាអានាចក្ររបស់ទ្រង់នឹងប្រគល់មកឲ្យព្រះករុណាវិញ
នៅពេលដែលព្រះរាជាទទួលស្គាល់ព្រះដ៏ខ្ពង់ខ្ពស់និងការគ្រប់គ្រងនៃស្ថានសួគ៌។[27]ដូច្នេះហើយ ព្រះករុណាសូមទ្រង់មេត្តាទទួលយោបល់ពីទូលបង្គំ។
សូមទ្រង់លះចោលអំពើបាប ហើយធ្វើអ្វីដែលត្រឹមត្រូវវិញ។ សូមបែរចេញពីការទុច្ចរិតដោយបង្ហាញព្រះទ័យមេត្តាដល់អ្នកដែលត្រូវគេសង្កត់សង្កិន
ធ្វើដូច្នេះព្រះករុណានឹងមានភាពរុងរឿងជាយូរអង្វែងទៅ»។
[28]ហេតុការណ៍ទាំងអស់នេះបានកើតឡើងចំពោះព្រះចៅនេប៊ូក្នេសា។[29]ដប់ពីរខែកន្លងទៅ
ទ្រង់កំពុងយាងក្រសាលនៅលើដំបូលព្រះបរមរាជវាំងនៅក្រុងបាប៊ីឡូន[30]ហើយទ្រង់មានរាជអង្ការថា «តើនេះមិនមែនជាបាប៊ីឡូនដ៏អស្ចារ្យទេឬ
ដែលយើងបានបានសង់ឡើង សម្រាប់ប្រជារាស្ត្ររបស់យើង ដើម្បីបង្ហាញសិរីរុងរឿងនៃរិទ្ធានុភាពរបស់យើងទេឬ?»
[31]ខណៈពេលដែលស្តេចកំពុងតែមានរាជអង្ការនៅឡើយ ក៏មានសម្លេងពីស្ថានសួគ៌: «ព្រះចៅនេប៊ូក្នេសាអើយ សេចក្តីទាំងនេះគឺសម្តៅមករកទ្រង់
ហើយអាណាចក្រនេះនឹងត្រូវយកចេញពីទ្រង់។[32]ព្រះករុណានឹងត្រូវគេបណ្តេញចេញពីចំណោមមនុស្ស ហើយដំណាក់ទ្រង់នឹងរស់នៅតាមវាលដូចជាសត្វព្រៃ។
ហើយគេនឹងឲ្យទ្រង់ស៊ីស្មៅដូចជាគោ។ រហូតដល់កន្លងប្រាំពីរឆ្នាំ គឺទ្រង់ទទួលស្គាល់ថាព្រះដ៏ខ្ពង់ខ្ពស់បំផុតជាអ្នកគ្រប់គ្រងលើអាណាចក្ររបស់មនុស្សលោក
ហើយព្រះអង្គចង់ប្រទានដល់ពួកគេស្រេចតែព្រះហឫទ័យទ្រង់»។
[33]រាជសារនេះគឺមកទាស់ប្រឆាំងនិងព្រះចៅនេប៊ូក្នេសា ដែលនឹងនាំចេញមកភ្លាមៗ។ ព្រះករុណាត្រូវគេបណ្តេញចេញពីចំណោមមនុស្ស។
ទ្រង់សោយស្មៅជាអាហារដូចជាគោ ហើយព្រះកាយទ្រង់សើមដោយទឹកសន្សើមពីលើមេឃ។ ព្រះកេសាទ្រង់ដុះវែងដូចស្លាបឥន្ទ្រី
ចំណែកក្រចករបស់ទ្រង់ប្រៀបដូចជាក្រចករបស់សត្វស្លាប។
[34]នៅថ្ងៃចុងក្រោយ យើង ព្រះចៅនេប៊ូក្នេសា បានងើបភ្នែកឡើងទៅលើមេឃ ហើយបានធ្វើឲ្យយើងដឹងខ្លួនឡើងវិញ។ «យើង សូមសរសើតម្កើងដល់ព្រះដ៏ខ្ពស់បំផុត
និងសូមថ្វាយព្រះកិត្តិយស និង សិរីរុងរឿងដល់ព្រះដ៏គង់នៅអស់កល្បជានិច្ច។ ត្បិតរាជទ្រង់សោយរាជ្យនៅអស់កល្បជានិច្ច
ហើយព្រះរាជ្យព្រះអង្គនៅអស់កល្បពីជំនាន់មួយទៅដល់គ្រប់ជំនាន់ទាំងអស់។
[35]មនុស្សជាតិទាំងអស់នៅលើផែនដី គឺបានពិចារណាដោយព្រះអង្គថាគ្មានតម្លៃអ្វីឡើយ ព្រះអង្គប្រព្រឹត្តចំពោះទាហាននៃស្ថានសួគ៌ និងមនុស្សជាតិនៃផែនដី
ស្របតាមព្រះទ័យរបស់ព្រះអង្គ។ គ្មាននរណាម្នាក់អាចប្រឆាំង ឬទាស់និងព្រះអង្គបានឡើយ។ គ្មាននរណាម្នាក់ពោលទៅកាន់ព្រះអង្គថា
«ហេតុដូចម្តេចបានជាទ្រង់ធ្វើដូច្នេះ?»
[36]ក្នុងពេលតែមួយដែលការដឹងខ្លួនរបស់យើងបានត្រឡប់មកវិញ រិទ្ធានុភាពនិងពន្លឺរបស់យើងបានត្រឡប់មកកាន់យើង គឺជាភាពថ្កុំថ្កើងក្នុងអាណាចក្ររបស់យើង។
ក្រុមប្រឹក្សា និងនាម៉ឺនមន្ត្រីរបស់យើងស្វែងរកក្តីមេត្តារបស់យើង។ យើងបាននាំត្រឡប់មកគ្រងរាជ្យឡើងវិញ ហើយភាពថ្កុំថ្កើងបានប្រគល់មកកាន់យើង។[37]ឥឡូវនេះយើង
ព្រះចៅនេប៊ូក្នេសា សូមលើកតម្កើង ថ្វាយព្រះកិត្តិយសដល់ព្រះដ៏ខ្ពង់ខ្ពស់នៅស្ថានសួគ៌ ត្បិតស្នាព្រះហស្តរបស់ព្រះអង្គសុទ្ធតែត្រឹមត្រូវ ហើយមាគ៌ាព្រះអង្គគឺសុចរិត។
ព្រះអង្គនឹងបន្ទាបអស់អ្នកដែលមានអំណួត។

Daniel 4:1

ព័ត៌មានទូទៅ:

នៅក្នុងជំពូកនេះ ព្រះចៅនេប៊ូក្នេសាបានប្រាប់ពីអ្វីដែលព្រះបានធ្វើនៅក្នុងទ្រង់។

នៅក្នុងខ ១-១៨

ព្រះចៅនេប៊ូក្នេសាបានពណ៌នាពីបុគ្គលទីមួយដែលនៅក្នុងសុបិន្តរបស់ទ្រង់ពីព្រះជាម្ចាស់។

ក្នុងខ ១៩-៣៣

គឺត្រឡប់ទៅនិយាយដល់បុគ្គលទីបីវិញពណ៌នាអំពីការជំនុំជម្រះរបស់ព្រះចៅនេប៊ូក្នេសា។

ក្នុងខ ៣៤-៣៧

បានប្តូរមកនិយាយពីបុគ្គលទីមួយវិញគឺដូចព្រះចៅនេប៊ូក្នេសាពណ៌នាពីការឆ្លើយតបទៅនឹងសុបិន្តរបស់ទ្រង់។

ព្រះចៅនេប៊ូក្នេសាបានបញ្ជូន

នៅក្នុងឃ្លានេះបានសំដៅទៅអ្នកនាំសាររបស់ស្តេច ដូចជាស្តេចខ្លួនឯងផ្ទាល់។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះចៅនេប៊ូក្នេសាបានបញ្ជូនអ្នកនាំសារទៅជាមួយ»

ប្រជាជនទាំងអស់ គ្រប់ជាតិសាសន៍ គ្រប់ភាសា

ពាក្យថា «ជនជាតិ» និង «ភាសា»

នៅទីនេះតំណាងឲ្យមនុស្សដែលមកពីជនជាតិដទៃ

ហើយដែលនិយាយភាសាផ្សេងគ្នាដែរ។ សូមមើលការបកប្រែរបស់អ្នកនៅក្នុងជំពូក ៣-៣។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលមកពីជនជាតិដទៃ
ហើយដែលនិយាយភាសាផ្សេងគ្នាដែរ»

ដែលរស់នៅលើផែនដីទាំងមូល

ស្តេចតែងតែនិយាយអំពីអាណាចក្រដែលធំប៉ុណ្ណោះ។

ព្រះចៅនេប៊ូក្នេសាបានគ្រប់គ្រងទៅលើពិភពលោកទាំងមូលនៅពេលសម័យព្រះគម្ពីរ។

ការបកប្រែរបៀបផ្សេងទៀត:
ពួកអ្នកដែលបានរស់នៅក្នុងអាណាចក្ររបស់បាប៊ីឡូន»

សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្តីសុខសាន្ត

នេះគឺជារបៀបនៃការស្វាគមន៍

ទីសម្គាល់ និង ឫទ្ធិបាដិហារិយ៍

ពាក្យទាំងនេះមានអត្ថន័យស្រដៀងគ្នា

ហើយសំដៅទៅលើការអស្ចារ្យដែលព្រះជាម្ចាស់បានធ្វើ។

ត្បិតទីសម្គាល់ដែលទ្រង់សម្តែងគឺពិតជាអស្ចារ្យណាស់

បដិហារិយ៍របស់ព្រះអង្គពោពេញដោយឫទ្ធិបារមី!

ឃ្លាទាំងពីរនេះគឺមានន័យដូចគ្នា

ហើយបានប្រើដើម្បីបញ្ជាក់អំពីការអស្ចារ្យដែលទីសម្គាល់របស់ព្រះជាម្ចាស់
ហើយបាដិហារិយ៍នានា។

ព្រះរាជ្យរបស់ព្រះអង្គ...គង់នៅអស់កល្បជានិច្ចតទៅ

ពាក្យទាំងពីរនេះគឺមានន័យដូចគ្នា ហើយបានបញ្ជាក់ម្តងហើយម្តងទៀត
ពីរបៀបដែលព្រះជាម្ចាស់បានសោយរាជ្យជារៀងរហូត។

Daniel 4:4

ព័ត៌មានទូទៅ:

នៅក្នុងជំពូក ព្រះចៅនេប៊ូក្នេសាបានប្រាប់ពីអ្វីដែលព្រះបានធ្វើនៅក្នុងទ្រង់។

នៅក្នុងខ ១-១៨

ព្រះចៅនេប៊ូក្នេសាបានពណ៌នាពីបុគ្គលទីមួយដែលនៅក្នុងសុបិន្តរបស់ទ្រង់ពីព្រះជាម្ចាស់។

ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានរស់នៅដោយមានសុភមង្គល...គ្រួសាររបស់យើងនៅក្នុងព្រះ
ឃ្លាទាំងពីរនេះគឺជាប្រាស្នារ ហើយមានន័យស្រដៀងគ្នា។

ជាមួយគ្រួសារ...នៅក្នុងព្រះរាជវាំង

ឃ្លាទាំងពីគឺមានន័យមូលដ្ឋានដូចគ្នា។

សុបិន្ត...រូបភាព...និមិត្ត

ឃ្លាទាំងនេះគឺមានន័យមូលដ្ឋានដូចគ្នា។

យើងព្រួយព្រះទ័យ...យើងកាន់តែខ្វល់ខ្វាយ

ឃ្លាទាំងពីនេះគឺជាប្រាស្នារ ហើយមានន័យស្រដៀងគ្នា។

អស់អ្នកប្រាជ្ញនៅស្រុកបាប៊ីឡូនឲ្យមកកាត់ស្រាយសុបិន្តនិមិត្ត

«អស់ពួកអ្នកប្រាជ្ញរបស់បាប៊ីឡូន»

Daniel 4:7

ព័ត៌មានទូទៅ:

នៅក្នុងខ ១-១៨

ព្រះចៅនេប៊ូក្នេសាបានពណ៌នាពីបុគ្គលទីមួយដែលនៅក្នុងសុបិន្តរបស់ទ្រង់ពីព្រះជាម្ចាស់។

ដែលយើងបានដាក់ឈ្មោះឲ្យថាលោកបេលថិស្សាសារ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ជាអ្នកដែលយើងបានដាក់ឈ្មោះឲ្យថាលោកបេលថិស្សាសារ»

លោកបេលថិស្សាសារ

នេះគឺជាឈ្មោះដែលបាប៊ីឡូនបានដាក់ឲ្យដានីយ៉ែល។

សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះនេះនៅក្នុងជំពូក១:៦។

ព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះចៅនេប៊ូក្នេសាបានជឿថាអំណាចរបស់ដានីយ៉ែលបានចេញពីព្រះក្លែងក្លាយដែលព្រះចៅនេប៊ូក្នេសាថ្វា

គ្មានការលាក់កំបាំងណាដែលពិបាកសម្រាប់លោកដែរ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកត្រូវយល់ពីអត្ថន័យនៃការលាក់កំបាំងទាំងអស់»

generated on Wed Sep 10 16:16:32 2025

Daniel 4:10

ព័ត៌មានទូទៅ:

នៅក្នុងខ ១-១៨

ព្រះចៅនេប៊ូក្នេសាបានពណ៌នាពីបុគ្គលទីមួយដែលនៅក្នុងសុបិន្តរបស់ទ្រង់ពីព្រះជាម្ចាស់។

និមិត្តឃើញ

អ្វីដែលអាចមើលឃើញ

នោះខ្ពស់អស្ចារ្យ

«គឺវាខ្ពស់ខ្លាំងណាស់»

ចុងរបស់វាខ្ពស់ដល់មេឃ...សូម្បីតែមនុស្សនៅចុងផែនដីក៏អាចមើលឃើញដើមឈើនេះដែរ

សញ្ញានេះគឺជាភាសាដែលគេនិយាយពីកម្ពស់របស់វាហើយពីការទទួលស្គាល់ពីដើមឈើ។ សូមមើល

ការបកប្រែរបៀបផ្សេងទៀត: «វាមើលទៅចុងរបស់វាខ្ពស់ដល់មេឃ
ហើយមនុស្សគ្រប់គ្នាដែលនៅលើផែនដីនេះអាចមើលឃើញវាផងដែរ»

មានផ្លែជាបរិបូណ៌

«ហើយមានផ្លែជាបរិបូណ៌នៅដើមឈើនោះ»

ដែលអាចចិញ្ចឹមជីវិតមនុស្សទាំងអស់បាន

«អាចចិញ្ចឹមជីវិតមនុស្ស និងព្រមទាំងសត្វទាំងអស់ផងដែរ»

Daniel 4:13

ព័ត៌មានទូទៅ:

នៅក្នុងខ ១-១៨

ព្រះចៅនេប៊ូក្នេសាបានពណ៌នាពីបុគ្គលទីមួយដែលនៅក្នុងសុបិន្តរបស់ទ្រង់ពីព្រះជាម្ចាស់។

នោះព្រលឹងយើងបានឃើញ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«យើងបានឃើញនៅក្នុងសុបិន្តរបស់យើង»

លោកស្រែកយ៉ាងខ្លាំងថា

វាច្បាស់ណាស់ដែលអ្នកនាំសារដ៏បរិសុទ្ធ
ដែលបាននិយាយទៅកាន់មនុស្សច្រើនជាងមួយនាក់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកនោះបានស្រែកដាក់ទៅមនុស្ស
ហើយនិយាយថា»

ចូរដេញសត្វទាំងឡាយចេញពី...ចេញពីមែករបស់វា

«ពួកសត្វទាំងនោះបានគេចពីក្រោមដើមរបស់វា
ហើយសត្វស្លាបនឹងហើរចេញពីមែករបស់វាដែរ»

Daniel 4:15

ព័ត៌មានទូទៅ:

នៅក្នុងខ ១-១៨

ព្រះចៅនេប៊ូក្នេសាបានពណ៌នាពីបុគ្គលទីមួយដែលនៅក្នុងសុបិន្តរបស់ទ្រង់ពីព្រះជាម្ចាស់។

ព័ត៌មានទូទៅ:

អ្នកនាំសារដ៏បរិសុទ្ធនៅក្នុងនិមិត្តបន្តស្រែកដាក់មនុស្សខ្លះ។

គល់ និង ឫសរបស់វា

នេះគឺជាចំណែកនៃដើមឈើដែលនៅសល់នៅលើដីបន្ទាប់ពីគេកាប់ដើមឈើរលំចុះក្រោម។

ទឹកសន្សើម

សំណើមនៅលើដីដែលបានរកឃើញនៅពេលព្រឹក

ឲ្យដើមឈើនោះលែងមានចិត្តគំនិត... រហូតដល់គម្រប់ប្រាំពីរឆ្នាំ

ចាប់តាំងដើមឈើបានបង្ហាញដល់ព្រះចៅនេប៊ូក្នេសា សព្វនាមភាពជាប្រុស
«របស់គាត់» និង «គាត់» ក្នុងខទី ១៦
សំដៅទៅលើដើមឈើនោះដដែលដូចជាសព្វនាម «វា» នៅក្នុងខ ១៥។

ការបកប្រែរបៀបផ្សេងទៀត:

«គំនិតរបស់មនុស្សនឹងប្តូរពីមនុស្សទៅក្នុងគំនិតរបស់សត្វ សម្រាប់ពេលប្រាំពីរឆ្នាំ»

Daniel 4:17

ព័ត៌មានទូទៅ:

នៅក្នុងខ ១-១៨

ព្រះចៅនេប៊ូក្នេសាបានពណ៌នាពីបុគ្គលទីមួយដែលនៅក្នុងសុបិន្តរបស់ទ្រង់ពីព្រះជាម្ចាស់។

ការសម្រេចចិត្តរបស់ទេវតាជារាជបញ្ជារបស់ពួកដ៏វិសុទ្ធ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ជាអង្គដែលបរិសុទ្ធហើយបានសម្រេចការនេះ»

ពួកដ៏វិសុទ្ធ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ទេវតាដ៏បរិសុទ្ធ»

គ្រងលើរាជ្យរបស់មនុស្ស

«គ្រប់របស់ដែលមានជីវិត» ឬ «មនុស្សគ្រប់គ្នា»

ព្រះអង្គចង់ប្រគល់រាជ្យ

«ប្រទានអាណាចក្រ»

បេលថិស្សាសារ

នេះគឺជាឈ្មោះដែលបាប៊ីឡូនបានដាក់ឲ្យដានីយ៉ែល។

សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះនេះនៅក្នុងជំពូក ១:៦។

លោកអាចកាត់ស្រាយបាន

«អ្នកក៏អាចបកប្រែការទាំងនេះបាន»

មានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយលោក

ព្រះចៅនេប៊ូក្នេសាបានជឿថាអំណាចរបស់ដានីយ៉ែលបានចេញពីព្រះក្លែងក្លាយដែលព្រះចៅនេប៊ូក្នេសាថ្វា
ការនេះកឺមិនដូចគ្នាទេ «គឺជាព្រះដ៏បរិសុទ្ធ» ក្នុងខ ១៧។

សូមមើលពីរការបកប្រែឃ្លានេះនៅក្នុងជំពូក ៤:៧។

Daniel 4:19

ព័ត៌មានទូទៅ:

ខគម្ពីរ ១៩-៣៣

ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។

ដែលហៅថា បេលថិស្សាសារ

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«ដែលយើងបានដាក់ឈ្មោះឲ្យហៅ បេលថិស្សាសារ»

ដោយគាត់ដឹងក្នុងចិត្តហើយថា ការនោះនឹងធ្វើឲ្យលោកភ័យខ្លាច

ការយល់ដឹងរបស់ដានីយ៉ែលអំពីនិមិត្តដែលបានធ្វើឲ្យទ្រង់ខ្វាល់ខ្វាយ។

នេះគឺជាទម្រង់ជាក់លាក់។ ការបកប្រែរបៀបផ្សេងទៀត:

មិនមែននិយាយអ្វីដែលដដែលគ្រប់ពេលនោះទេ

ពីព្រោះយើងបានខ្វល់ខ្វាយពីសុបិន្ត»

សូមឲ្យសុបិន្តនេះកើតឡើងចំពោះអស់អ្នកដែលស្អប់ព្រះករុណា

ហើយសូមឲ្យអត្ថន័យរបស់វាធ្លាក់លើខ្មាំងសត្រូវរបស់ព្រះករុណា

ដានីយ៉ែលគឺបានថ្លែងចេញពីប្រាថ្នា

ដែលសុបិន្តនោះមិនមែននិយាយអំពីព្រះចៅនេប៊ូក្នេសា

ទោះបីជាលោកដឹងថាសុបិន្តនោះនិយាយអំពីស្តេចក៏ដោយ។

Daniel 4:20

ព័ត៌មានទូទៅ:

ខគម្ពីរ ១៩-៣៣

ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។

ព័ត៌មានទូទៅ:

ពាក្យជាច្រើននៅក្នុងខទាំងនេះស្ទើរតែដូចគ្នានឹងជំពូក ៤:១០ ដែរ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែខទាំងនោះ។

មានផ្លែជាបរិបូណ៌

«កើតផលជាច្រើន»

ដើមឈើនោះគឺជាព្រះករុណា

«នេះគឺដើមឈើដែលតំណាងឲ្យទ្រង់ គឺស្តេច»

ទ្រង់បានចម្រើនឡើង...មានឫទ្ធិអំណាចចេស្តា

ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា។

ទ្រង់បានចម្រើនឡើង

ឃ្លានេះគឺប្រើជាមួយនឹងពាក្យ «លូតលាស់» គឺដូចជារបៀបដែលបាននិយាយថា
ស្តេចបានចម្រើនឡើង។ ការបកប្រែរបៀបផ្សេងទៀត:

«ភាពអស្ចារ្យរបស់ទ្រង់បានចម្រើនឡើង»

រហូតដល់មេឃ...ពេញផែនដីទាំងមូល

ឃ្លាទាំងនេះដែលបាននិយាយថា មនុស្សគ្រប់គ្នា
នៅគ្រប់ទីកន្លែងដឹងពីការអស្ចារ្យរបស់ព្រះចៅនេប៊ូក្នេសា។

Daniel 4:23

ព័ត៌មានទូទៅ:

ខគម្ពីរ ១៩-៣៣

ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។

ព័ត៌មានទូទៅ:

ខគម្ពីរត្រង់នេះវាប្រហែលដូចទៅនឹងជំពូក ៤:១៣ ហើយនិងជំពូក ៤:១៥។

សូមមើលពីរបៀបដែលអ្នកបានបកប្រែពីខទាំងនោះ។

ទុកគល់ និង ឫសរបស់វា

នេះគឺជាចំណែកនៃដើមឈើដែលនៅសល់នៅលើដីបន្ទាប់ពីគេកាប់ដើមឈើរលំចុះក្រោម។

ហើយយកច្រវ៉ាក់ដែក និង លង្ហិនមកចង់រាទុកនៅទីវាលស្មៅ

«វាបានព័ទ្ធជុំវិញដោយស្មៅទន់ ដែលនៅលើទីវាល»

ទឹកសន្សើម

generated on Wed Sep 10 16:16:32 2025

សន្សើមដែលបានបន្សល់នៅលើដីនៅពេលព្រឹក
Daniel 4:24
ព័ត៌មានទូទៅ:
ខគម្ពីរ ១៩-៣៣
ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។
ព័ត៌មានទូទៅ:
ខគម្ពីរត្រង់នេះវាប្រហែលដូចទៅនឹងជំពូក ៤:១៥។
សូមមើលពីរបៀបដែលអ្នកបានបកប្រែខទាំងនោះ។
បានសម្រេចការនេះចំពោះព្រះករុណា
«ដែលយើងបានឮ»
ព្រះករុណានឹងត្រូវគេបណ្តេញចេញពីចំណោមមនុស្ស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សនឹងដេញអ្នកចេញពីពួកគេ»
ហើយគេនឹងយកស្មៅឲ្យព្រះរាជាសោយ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គនឹងសោយស្មៅ»
Daniel 4:26
ព័ត៌មានទូទៅ:
ខគម្ពីរ ១៩-៣៣
ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។
ច្បាប់នៃនគរស្ថានសួគ៌
ពាក្យថា «ស្ថានសួគ៌»
នៅទីនេះសំដៅទៅព្រះជាម្ចាស់ដែលមានព្រះជន្មរស់នៅលើនគរស្ថានសួគ៌។
«ព្រះជាម្ចាស់នៅក្នុងនគរស្ថានសួគ៌គ្រប់គ្រងលើទាំងអស់»
សូមទ្រង់មេត្តាទទួល យោបល់ពីទូលបង្គំ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សូមទទួលយកយោបល់របស់ទូលបង្គំ»
បែរមកមានព្រះទ័យអាណិតមេត្តាដល់អ្នក
ពាក្យបដិសេធទៅលើអំពីទុច្ចរិត គឺនិយាយពីការបែរចេញពីអំពើបាបទាំងនោះ។
ការបកប្រែរបៀបផ្សេងទៀត: «រីករាយជាមួយអំពីទុច្ចរិតរបស់អ្នក»
សង្កត់សង្កិន
ដើរតួជាគុណនាមដែលសំដៅទៅលើមនុស្សដែលត្រូវបានសង្កត់សង្កិន។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលសង្កត់សង្កិន»
ធ្វើដូច្នេះព្រះករុណានឹងមានភាពរុងរឿងជាយូរអង្វែងទៅ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងពន្យាភាពរុងរឿងរបស់ទ្រង់»
Daniel 4:28
ព័ត៌មានទូទៅ:
ខគម្ពីរ ១៩-៣៣
ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។
ហេតុការណ៍ទាំងនេះ...នៅក្រុងបាប៊ីឡូន
ព័ត៌មាននៅក្នុងជំពូក ៤:២៨ គឺបានរៀបឡើងវិញ
ដូច្នេះន័យរបស់វាអាចនឹងងាយស្រួលយល់ជាងមុន។
មួយឆ្នាំ
«១២ ខែ»
តើនេះមិនមែនជាក្រុងបាប៊ីឡូនមហា...ដើម្បីបង្ហាញកិត្តិយស និង សិរីរុងរឿងរបស់យើងទេឬ?
ព្រះចៅនេប៊ូក្នេសាបានសួរសំនួរនេះដើម្បីបញ្ជាក់ពីសិរីរុងរឿងរបស់ទ្រង់។
ការនេះអាចបកប្រែបានថាជាសេចក្តីប្រកាស។ ការបកប្រែរបៀបផ្សេងទៀត:
«នេះគឺជាបាប៊ីឡូនដ៏អស្ចារ្យ...សម្រាប់សិរីរុងរឿង និងព្រះចេស្តា!»
សម្រាប់សិរីរុងរឿងនិងព្រះចេស្តា
«ដើម្បីបង្ហាញដល់មនុស្សពីកិត្តិយស ហើយការអស្ចារ្យរបស់យើង»
Daniel 4:31
ព័ត៌មានទូទៅ:
ខគម្ពីរ ១៩-៣៣
ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។
ខណៈពេលដែលស្តេចកំពុងតែមានរាជអង្គារ
ការប្រៀបធៀបនេះគឺមានន័យថាស្តេចកំពុងតែមានបន្ទូល។
ការបកប្រែរបៀបផ្សេងទៀត: «ក្នុងពេលដែលស្តេចកំពុងតែមានបន្ទូល»
មានសម្លេងពីស្ថានសួគ៌
ស្តេចបានឮសម្លេងពីស្ថានសួគ៌»
ស្តេចនេប៊ូក្នេសាអើយ...អ្នកត្រូវបាត់បង់រាជសម្បត្តិហើយ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ស្តេចនេប៊ូក្នេសា
ច្បាប់បានចេញមកហើយទាស់នឹងទ្រង់
ហើយអាណាចក្រមិនមែនជារបស់ទ្រង់ទៀតទេ»
អ្នកនឹងត្រូវគេបណ្តេញចេញពីចំណោមមនុស្ស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជននឹងបណ្តេញទ្រង់ចេញពីពួកគេ»
ចង់ប្រទានរាជនោះទៅឲ្យនរណា
«ជាអ្នកដែលទ្រង់បានជ្រើសរើស»
Daniel 4:33
ព័ត៌មានទូទៅ:
ខគម្ពីរ ១៩-៣៣
ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការដាក់ទោសរបស់ព្រះចៅនេប៊ូក្នេសា។
រំពេចនោះហេតុការណ៍នោះក៏កើតមានឡើងចំពោះព្រះចៅនេប៊ូក្នេសាមែន
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ច្បាប់នេះបានទាស់នឹងព្រះ ចៅនេប៊ូក្នេសាកើតឡើងមួយរំពេច»
ទ្រង់ត្រូវគេបណ្តេញចេញពីចំណោមហ្វូងមនុស្ស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនបានបណ្តេញទ្រង់ចេញពីពួកគេ»
ព្រះកេសាទ្រង់ដុះរែងដូចស្លាបឥន្ទ្រី
«ព្រះកេសារបស់ទ្រង់មើលទៅដូចជាសត្វស្លាប»
Daniel 4:34
ព័ត៌មានទូទៅ:
ខគម្ពីរ ១៩-៣៣
ប្រើលើបុគ្គលទីបីដើម្បីពណ៌នាពីការការឆ្លើយតបរបស់ព្រះចៅនេប៊ូក្នេសា។
លុះដល់ពេលកំណត់មកដល់
ការនេះសំដៅទៅលើរយៈពេលប្រាំពីរឆ្នាំត្រឡប់មកវិញ នៅក្នុងជំពូក ៤:៣១។
ហើយយើងដឹងខ្លួនឡើងវិញ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ចិត្តនឹងធឹងរបស់យើងបានត្រឡប់មកយើងវិញ» ឬ
«យើងបានត្រឡប់មកភាពដូចដើមវិញ»
យើងសូមសរសើតម្កើង...សូមថ្វាយព្រះកិត្តិយស
ឃ្លាទាំងពីរនេះសំដៅទៅលើសកម្មភាពដូចគ្នា។
ត្បិតរាជទ្រង់សោយរាជ្យនៅអស់កល្បជាអង្វែង... ព្រះអង្គគ្រងរាជ្យអស់កល្បជាយូរអង្វែងទៅ
ឃ្លាទាំងពីរនេះមានមូលដ្ឋានដូចគ្នា
ហើយគឺប្រើដើម្បីបញ្ជាក់ន័យពីរបៀបដែលព្រះជាម្ចាស់គ្រងរាជ្យជារៀងរហូត។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអង្គគ្រងរាជ្យអស់កល្បជាយូរអង្វែងមិនបញ្ចប់ឡើយ»
Daniel 4:35
ព័ត៌មានទូទៅ:
ខគម្ពីរ ៣៤-៣៧
ព្រះចៅនេប៊ូក្នេសាមានបន្ទូលទៅក្នុងបុគ្គលទីមួយដើម្បីពណ៌នាអំពីការឆ្លើយតបទៅកាន់ព្រះជាម្ចាស់។
មនុស្សនៅលើផែនដី គឺគ្មានតម្លៃអ្វីសោះសម្រាប់ព្រះអង្គ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទ្រង់បានគិតថាមនុស្សទាំងអស់នៅលើផែនដីគឺឥតបានការ»
មនុស្សនៅលើផែនដី
«មនុស្សទាំងអស់ដែលនៅលើផែនដី»
ទាហាននៃស្ថានសួគ៌
«ពួកទេវតាជាទាហាននៅក្នុងស្ថានសួគ៌» (UDB)
ស្រេចតែព្រះទ័យរបស់ព្រះអង្គ
«អ្វីដែលត្រូវជាមួយនឹងគោលបំណង» ឬ «ការអ្វីដែលព្រះអង្គចង់បាន»
គ្មាននណារម្នាក់អាចប្រឆាំង ឬ បញ្ឈប់ព្រះអង្គបានឡើយ
វាប្រហែលជាជំនួយដ៏ប្រសើរក្នុងការបកបន្ថែមព័ត៌មានជាក់លាក់។
ការបកប្រែរបៀបផ្សេងទៀត:
«គ្មានអ្នកណានឹងបញ្ឈប់ទ្រង់ពីអ្វីដែលស្តេចបានសម្រេចហើយនោះទេ»
គ្មាននណារម្នាក់ពោលទៅកាន់ព្រះអង្គថា «ហេតុដូចម្តេចបានទ្រង់ធ្វើដូច្នេះ?»
នេះអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មានអ្នកណាអាចសួររកអ្វីដែលទ្រង់បានធ្វើពីពេលមុន»

generated on Wed Sep 10 16:16:32 2025

Daniel 4:36

ព័ត៌មានទូទៅ:

ខគម្ពីរ ៣៤-៣៧

ព្រះចៅនេប៊ូក្នេសាមានបន្ទូលទៅក្នុងបុគ្គលទីមួយដើម្បីពណ៌នាអំពីការឆ្លើយតបទៅកាន់ជីវិតដែលបានស្តារ...

ប្រគល់កិត្តិយស រាជសម្បត្តិ និងភាពថ្កុំថ្កើងមកយើងវិញ

នេះគឺភាពថ្កុំថ្កើងរបស់យើង ដែលបានត្រឡប់មកយើងវិញដោយអំណាចរបស់វា។

ការបកប្រែរបៀបផ្សេងទៀត: «យើងបានត្រឡប់មកភាពដូចដើមវិញ»

រាជសម្បត្តិ និងភាពថ្កុំថ្កើងមកយើងវិញ

នៅទីនេះរាជសម្បត្តិ

និងភាពរុងរឿងរបស់ព្រះអង្គត្រូវបានគេនិយាយដូចជាពួកគេអាចវិលត្រឡប់មកវិញដោយ...

ការបកប្រែរបៀបផ្សេងទៀត: «យើងបានទទួលនូវរាជសម្បត្តិ

និងភាពរុងរឿងរបស់យើងវិញម្តងទៀត»

រាជសម្បត្តិ និងភាពថ្កុំថ្កើង

ពាក្យទាំងពីរនេះគឺបានបញ្ជាក់ន័យជាមូលដ្ឋានពីរបៀបដ៏អស្ចារ្យដែលទ្រង់សរសើរតម្កើងព្រះជាម្ចាស់។

យើងឱ្យគ្រងរាជ្យឡើងវិញ

«រាជ្យរបស់យើងបានត្រឡប់មកយើងម្តងទៀត»

...យើងក៏ទទួលបានភាពថ្កុំថ្កើង

ពាក្យថា «បល្ល័ង្ក» នៅទីនេះសំដៅទៅលើសិទ្ធអំណាចដើម្បីគ្រប់គ្រង។

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«យើងនឹងត្រឡប់ទៅគ្រងរាជ្យលើអាណាចក្រម្តងទៀត

ហើយយើងនឹងទទួលការអស្ចារ្យជាច្រើនផងដែរ»

សូមលើកតម្កើង ថ្វាយព្រះកិត្តិយស ដល់ព្រះដ៏ខ្ពង់ខ្ពស់

ពាក្យទាំងពីរនេះគឺបានបញ្ជាក់ន័យជាមូលដ្ឋានពីរបៀបដ៏អស្ចារ្យដែលទ្រង់សរសើរតម្កើងព្រះជាម្ចាស់។

អស់អ្នកដែលមានអំនួតក្អេងក្អាង

ឃ្លានេះប្រើថា «ដើរ» សំដៅទៅដល់បុគ្គលដែលប្រព្រឹត្តដោយអំនួត។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលអំនួត»

---

5 [1]ព្រះចៅបេលសាសារបានចាត់ឲ្យគេ រៀបចំពិធីជប់លៀងសម្រាប់ពួកអភិជនចំនួនមួយមឺុននាក់ ហើយទ្រង់បានសោយ ស្រានៅមុខពួកមួយមឺុននាក់នោះ។
[2]នៅពេលដែលព្រះចៅបេលសាសារ ក្រេបស្រារួចហើយ ទ្រង់ក៏បញ្ជាឲ្យគេយកពែងមាសពែងប្រាក់ ដែលព្រះចៅនេប៊ូក្នេសា
ជាបិតាទ្រង់បានរឹបអូសយកពីព្រះវិហារនៅក្នុងក្រុងយេរូសាឡឹម ហើយទ្រង់ចង់យកពែងនោះមកដាក់ស្រាសម្រាប់ អភិជន ពួកមហេសី ហើយពួកស្នំ អាចផឹកស្រាបាន។
[3]ពួកអ្នកបម្រើបានយកពែងមាសដែលបានយកមកពីព្រះវិហារដែលជាដំណាក់នៃព្រះជាម្ចាស់នៅក្នុងក្រុងយេរូ៉សាឡឹម។ ព្រះរាជា និងពួកអភិជនហើយមហេសី
និងស្នំបានប្រើពែងទាំងនោះដើម្បីក្រេបស្រា។[4]ពួកគេបានស្រវឹងស្រា ហើយ ថ្វាយបង្គំរូបព្រះរបស់គេដែលបានធ្វើពីមាស ហើយនិងប្រាក់ លង្ហិន និងដែក ឈើ និងថ្ម។
[5]នៅក្នុងពេលនោះស្រាប់តែមានម្រាមដៃលេចចេញមក នៅពីមុខចង្កៀង ហើយសរសេរនៅលើជញ្ជាំងក្នុងព្រះបរមរាជវាំងរបស់ព្រះរាជា។
ព្រះរាជាក៏បានឃើញនូវចំណែកដែលម្រាមដៃនោះបានសរសេរនោះ។[6]បន្ទាប់មកស្តេចប្រែព្រះភ័ក្ត្រ ហើយព្រះហឫទ័យរបស់ព្រះករុណាទៅជារន្ធត់
ព្រះកាយទ្រង់មិនអាចជួយស្តេចបាន ហើយជង្គង់ខ្សោយទាំងពីរ។
[7]ព្រះរាជាបានប្រកាសព្រះរាជបញ្ជាឲ្យគេទៅកោះហៅពួកហោរា គ្រូទាយ គ្រូមន្តអាគម គ្រូធ្មប់អ្នកប្រាជ្ញនានា។
ព្រះរាជាបានមានព្រះរាជបន្ទូលទៅដល់អ្នកដែលមានប្រាជ្ញានៅស្រុកបាប៊ីឡូន «បើនរណាអាចបកស្រាយពីអត្ថន័យនៃអក្សរដែលបានសសេរនេះ
ទ្រង់នឹងបំពាក់អាវពណ៌ស្វាយ និងខ្សែកមាសជូនជាកិត្តិយស។ អ្នកនោះនឹងប្រទានឋានៈជាអ្នកគ្រប់គ្រងទីបីនៅក្នុងរាជាណាចក្រនេះ»។
[8]រួចហើយគ្រប់ទាំងហោរាគ្រូធ្មប់ ហើយពួកអ្នកប្រាជ្ញនានាក៏នាំគ្នាមក ប៉ុន្តែពួកគេមិនអាចអាន
ឬយល់និងមិនអាចបកស្រាយពីអត្ថន័យនៃអក្សរនោះថ្វាយព្រះរាជបានឡើយ។[9]រួចហើយព្រះចៅបេលសាសារក៏កាន់តែខ្វល់ខ្វាយ
ភ័យរន្ធត់ញាប់ញ័រនៅលើព្រះភក្ត្រ៍របស់ទ្រង់។ ហើយពួកនាមឺុនមន្ត្រីនានាក៏ទាល់គំនិតដែរ។
[10]នៅពេលនេះព្រះមហាក្សត្រិយានីឮពីរាជឱង្ការ និងពីអ្វីដែលពួកនាមឺុននាំបានពិភាក្សាគ្នា ទ្រង់ក៏យាងចូលក្នុងសាលជប់ លៀង។
ព្រះមហាក្សត្រិយានីមានរាជសរសើរយ៉ថា៖ «បពិត្រព្រះករុណា សូមទ្រង់មានព្រះជន្មយឺនយូរ! សូមកុំឲ្យព្រះគំនិតធ្វើឲ្យទ្រង់ខ្វល់ខ្វាយឡើយ។
ហើយកុំឲ្យព្រះភ័ក្ត្ររបស់ទ្រង់ប្រែឡើយ។
[11]នៅក្នុងរាជាណាចក្ររបស់ព្រះអង្គមានបុរសម្នាក់ដែលមានព្រះវិញ្ញាណ ដ៏វិសុទ្ធគង់នៅជាមួយ។ នៅក្នុងរជ្ជកាលនៃព្រះបិតាព្រះអង្គ
បុរសម្នាក់នោះគឺជាម្នាក់ដែលដឹងការលាក់កំបាំង មានតម្រិះ ប្រាជ្ញាមកពីព្រះនៅក្នុងអ្នកនោះ។ ព្រះចៅនេប៊ូសា
ព្រះបិតាទ្រង់បានតែងតាំងលោកធ្វើជាមេប្រមុខលើអស់ទាំងពួកគ្រូ គ្រូមន្តអាគមហោរា គ្រូទាយគ្រូធ្មប់ និងអ្នកប្រាជ្ញនានា។[12]ដោយឃើញថាបុរសនោះ
លោកមានប្រាជ្ញាវាងវៃ ចំណេះដឹងជ្រៅជ្រះ អាចកាត់ស្រាយសុបិន្ត ហើយអាចដោះស្រាយរាល់បញ្ហាពិបាកៗផ្សេងៗ លោកនោះមានឈ្មោះថាដានីយ៉ែល
ដែលព្រះបិតាទ្រង់ប្រទាននាមថា បេលថិស្សាសារ។ ពេលនេះសូមអនុញ្ញាតឲ្យគេហៅលោកនោះមក ដើម្បីឲ្យលោកបានកាត់ស្រាយអត្ថន័យអក្សរដែលបានសសេរនោះ»។
[13]រួចហើយគេក៏នាំដានីយ៉ែលមកគាល់ព្រះរាជា។ ព្រះរាជាបានមានរាជឱង្ការទៅកាន់គាត់ថា «តើលោកគឺជាដានីយ៉ែល
ដែលបានជម្លៀសចេញពីស្រុកយូដាដែលព្រះបិតាយើងបាននាំចេញពីយូដា។[14]យើងបានឮអំពីលោកថាមានព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះគង់នៅក្នុងលោក
ដែលមានភាពវាងវៃ និងមានចំណេះដឹងជ្រាលជ្រៅ ហើយប្រាជ្ញាដ៏អស្ចារ្យនៅក្នុងលោកផងដែរ។
[15]ពេលនេះពួកគ្រូអ្នកប្រាជ្ញ និងពួកអ្នកដែលអាចហៅវិញ្ញាណអ្នកស្លាប់មកជួប គឺបាននាំមកគាល់យើងដើម្បីអានអក្សរទាំងនេះ ហើយបកស្រាយអត្ថន័យដល់យើង
ប៉ុន្តែក្នុងចំណោមពួកគេគ្មានអ្នកណាអាចកាត់ស្រាយបានឡើយ។[16]យើងបានឮថាលោកអាចកាត់ស្រាយអត្ថន័យ និងដោះស្រាយរាល់បញ្ហាបាន។
ពេលនេះប្រសិនបើលោកអាចអានអក្សរនៅលើជញ្ជាំងនេះ ហើយអាចកាត់ស្រាយអត្ថន័យវា លោកនឹងបំពាក់អាវពណ៌ស្វាយ និងខ្សែកមាសជូនជាកិត្តិយស
ហើយមានសិទ្ធអំណាចជាអ្នកគ្រប់គ្រងទីបីនៅក្នុងរាជាណាចក្រផង»។
[17]គ្រានោះដានីយ៉ែលក៏ទូលឆ្លើយទៅព្រះរាជាថា «បពិត្រព្រះករុណា សូមព្រះអង្គទុករង្វាន់ទាំងនោះ សម្រាប់អ្នកដ៏ទៃចុះ។ ទោះបីជាយ៉ាងណាក៏ដោយ
ទូលបង្គំសូមអានអក្សរថ្វាយព្រះរាជា និងកាត់ស្រាយអត្ថន័យថ្វាយទ្រង់ផងដែរ។[18]បពិត្រព្រះរាជា
ដូចទ្រង់ជ្រាបថាព្រះដ៏ខ្ពង់ខ្ពស់បំផុតព្រះជាម្ចាស់បានប្រទានដល់ព្រះចៅនេប៊ូក្នេសាជាបិតាទ្រង់នៅអាណាចក្រ ជាមហាកិត្តិយសនិងវិទ្ធានុភាព។
[19]ដោយសារដែលព្រះជាម្ចាស់បានប្រទានមកព្រះបិតាទ្រង់ ហើយប្រជាជាតិ គ្រប់ជាតិសាសន៍ និងគ្រប់ភាសាគោរពកោតខ្លាចញាប់ញ័រចំពោះទ្រង់។
ទ្រង់ដាក់ទោសប្រហារជីវិតដល់អ្នកដែលគួរនឹងស្លាប់ ហើយទុកជីវិតដល់អ្នកដែលគួរនឹងរស់។ ទ្រង់លើកអស់អ្នកណាដែលស្តេចសព្វព្រះហឫទ័យ
ហើយទ្រង់បន្ទាបអស់អ្នកដែលចង់បាន។
[20]ប៉ុន្តែដោយសារព្រះរាជាមានចិត្តរឹងរូស និងអំណួតហើយប្រព្រឹត្តបំពាន នោះទ្រង់ត្រូវគេទម្លាក់ពីរាជបល្ល័ង្ក ហើយគេបានយកសិរីរុងរឿងរបស់ទ្រង់។
[21]ទ្រង់ត្រូវបានបណ្តេញចេញពីចំណោមមនុស្សជាតិ ហើយទ្រង់បែរជាមានគំនិតដូចជាសត្វតិរច្ឆាន ហើយទ្រង់រស់នៅជាមួយសត្វលាព្រៃ។
ទ្រង់សោយស្មៅដូចជាសត្វគោ។ ព្រះកាយទ្រង់សើមដោយទឹកសន្សើមពីលើមេឃ រហូតដល់ពេលដែលទ្រង់ដឹងស្មារតី
និងទទួលស្គាល់ព្រះដ៏ខ្ពង់ខ្ពស់គ្រប់គ្រងលើអាណាចក្រមនុស្ស ហើយទ្រង់សោយរាជលើពួកគេ លើអ្នកដែលទ្រង់សព្វព្រះហឫទ័យ។
[22]ព្រះករុណាបេសសាសារ ព្រះរាជាគឺជាព្រះរាជបុត្រទ្រង់ ហើយទ្រង់មិនទាន់បានបន្ទាបចិត្តទ្រង់ទេ ទោះបីព្រះករុណាបានដឹងពីរឿងទាំងនេះហើយក្តី។
[23]ទ្រង់បានតម្កើងខ្លួនទាស់ប្រឆាំងនឹងព្រះអម្ចាស់នៃនគរស្ថានសួគ៌។ ដោយទ្រង់បានបញ្ជាឲ្យគេយកពែងពីព្រះវិហារនៃព្រះជាម្ចាស់ សម្រាប់ចាក់ស្រាឲ្យព្រះករុណាផ្ទាល់
សម្រាប់នាម៉ឺនមន្ត្រី មហេសី និងស្នំ ហើយទ្រង់បានក្រាបថ្វាយបង្គំអស់ព្រះដែលធ្វើពី មាស លង្ហិន ដែក ឈើ និងពីថ្ម ដែលព្រះទាំងនោះមើលមិនឃើញ ស្តាប់មិនឮ
និងមិនដឹងអ្វីទាំងអស់។ ព្រះករុណាមិនបានសសើរតម្កើងដល់ព្រះជាម្ចាស់ដែលកាន់ខ្យល់ដង្ហើមនៅក្នុងព្រះហស្តព្រះអង្គ ហើយស្គាល់ពីព្រះករុណាគ្រប់ផ្លូវទាំងអស់។
[24]ហេតុដូច្នោះហើយ បានជាព្រះជាម្ចាស់ចាត់ម្រាមដៃព្រះវត្តមានរបស់ព្រះអង្គមកសសេរអក្សរនេះ។

generated on Wed Sep 10 16:16:32 2025

[25]អក្សរនេះបានសសេរថា: «ម៉េណេ ម៉េណេ តេកែល និងអ៊ូប៉ារស៊ីន»។[26]ពាក្យទាំងនេះមានន័យថា «ម៉ែណ» «ព្រះជាម្ចាស់បានរាប់ថ្ងៃនៃរាជ្យរបស់ព្រះករុណា
ហើយនឹងបញ្ចប់រាជនេះផង»។[27]ពាក្យថា «តេកែល» «បានថ្លឹងព្រះករុណានៅលើជញ្ជីង ហើយឃើញថាព្រះករុណានៅខ្វះ»។[28]«ពេរេស»
«អាណាចក្ររបស់ព្រះករុណាបែកជាពីរ គឺមួយចំណែកឱ្យទៅជនជាតិមេឌី និងមួយចំណែកទៀតឲ្យទៅជនជាតិពែរ្ស»។
[29]រួចហើយព្រះចៅបេលសាសារាជបញ្ជា ហើយគេបានយកសម្លៀកបំពាក់ពណ៌ស្វាយស្លៀកឲ្យដានីយ៉ែល។ ខ្សែរកមាសមកបំពាក់ឲ្យដានីយ៉ែល
ព្រះរាជាចេញរាជប្រកាសថា លោកនឹងមានឋានៈគ្រប់គ្រងទីបីនៅក្នុងរាជាណាចក្រនេះ។[30]នៅរាត្រីនោះ
ព្រះចៅបេលសាសារជាព្រះរាជានៃជនជាតិបាប៊ីឡូនត្រូវបានធ្វើគុត[31]ហើយព្រះចៅដារីយូស និងជនជាតិមេឌីបានគ្រងរាជ្យបន្តនៅក្នុងព្រះជន្មហុកសិបពីរព្រះវស្សា។

Daniel 5:1
ព្រះចៅបេលសាសារ
នេះគឺជាកូនរបស់ព្រះចៅនេប៊ូក្នេសាដែលបានក្លាយជាស្តេចបន្ទាប់ពីបិតារបស់ខ្លួន។
មួយពាន់នាក់
«សម្រាប់ ១០០០ នាក់»
ទ្រង់បានសោយ ស្រានៅមុខ
«ទ្រង់បានផឹកស្រានៅក្នុងវត្តមាននៃ»
យកពែងមាស ពែងប្រាក់
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ពែងមាស
ពែងប្រាក់គឺកូនចៅរបស់អ៊ីុស្រាអែលបានធ្វើពួកវាមក»
ពែង
គឺជាពែង ឬរបស់ដែលតូចល្មមសម្រាប់ឲ្យមនុស្សយកទៅកាន់ផឹកបាន។
ព្រះចៅនេប៊ូក្នេសា ជាបិតាទ្រង់បានរឹបអូស
ឃ្លានេះបានប្រើឈ្មោះរបស់នេប៊ូក្នេសាគឺបានសំដៅទៅលើកងទ័ពរបស់ស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «កងទ័ពនេប៊ូក្នេសាដែលជាបិតាទ្រង់បានចាប់យក»
Daniel 5:3
ពែងដែករឹបអូសយកមកពីព្រះវិហារ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គឺជាពែងមាសដែលកងទ័ពរបស់នេប៊ូក្នេសាបានយកចេញពីព្រះវិហារ»
យកមកពីព្រះវិហារនៅក្រុងយេរូសាឡឹម
«យកចេញពីព្រះវិហារនៃព្រះជាម្ចាស់»។ ឃ្លាថា «ព្រះវិហារនៃព្រះជាម្ចាស់»
បានប្រាប់យើងថែមទៀតអំពីព្រះវិហារ។
Daniel 5:5
ភ្លាមៗនោះស្រាប់តែ
«កាន់តែឆាប់គឺកាន់តែល្អ» ឬ «រំពេចនោះ» (UDB)
នៅលើជញ្ជាំង
សីុម៉ង់ ឬកំបោរដែលបានរាលទៅលើជញ្ជាំង
ឬពិដានដើម្បីធ្វើឲ្យវារលោងនៅក្នុងផ្ទៃទាំងមូល
ស្តេចប្រែព្រះភ័ក្ត្រ
«ព្រះភ័ក្ត្ររបស់ទ្រង់ក្លាយទៅជាស្លាំង» (UDB)។
ការនេះកើតឡើងដោយសារការភ័យខ្លាចរបស់ទ្រង់។
ព្រះបាទា
«ជើងរបស់ទ្រង់»
ហើយព្រះបាទាញាប់ញ័រចុះ
ការនេះគឺជាលទ្ធផលនៃការភ័យខ្លាចយ៉ាងខ្លាំង។
Daniel 5:7
អ្នកប្រាជ្ញនានានៅស្រុកបាប៊ីឡូន
ការនេះសំដៅទៅលើអ្នកដែលអាចហៅមនុស្សដែលស្លាប់មកនិយាយជាមួយបាន
គឺជាគ្រូវមន្តអាគម ហើយគ្រូធ្មប់។
បើនណារអាចបកស្រាយពីអត្ថន័យនៃអក្សរដែលបានសសេរនេះ ទ្រង់នឹងបំពាក់អាវពណ៌ស្វាយ និង
ខ្សែកមាសជូនជាកិត្តិយស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងឲ្យបំពាក់អាវពណ៌ស្វាយ និង
ខ្សែកមាសដល់អ្នកណាដែលបានពន្យល់ពីសេចក្តីដែលបានសរសេរហើយនិងអត្ថន័យរបស់វា»
បំពាក់អាវពណ៌ស្វាយ
បំពាក់អាវពណ៌ស្វាយ ដែលបានត្រៀមសម្រាប់ពួកមន្ត្រី។
ការបកប្រែរបៀបផ្សេងទៀត: «សម្លៀកបំពាក់សម្រាប់ពួករាជវង្ស»
ឋានៈជាអ្នកគ្រប់គ្រងទីបី
«អ្នកគ្រប់គ្រងកំរិតទីបី»
Daniel 5:8
ព្រះចៅបេលសាសារ
នេះគឺជាកូនរបស់ព្រះចៅនេប៊ូក្នេសាដែលបានក្លាយជាស្តេច
បន្ទាប់ពីបិតារបស់ខ្លួន។
សូមមើលពីរបៀបដែលអ្នកបានសរសេរឈ្មោះរបស់ទ្រង់នៅក្នុងជំពូក ៥:១។
ព្រះចៅបេលសាសារក៏កាន់តែខ្វល់ខ្វាយ ភ័យរន្ធត់ញាប់ញ័រ
«ព្រះភ័ក្ត្ររបស់ទ្រង់ក្លាយទៅជាស្លាំង»
ព្រះភ័ក្ត្ររបស់ស្តេចបានឡើងស្លាំងលើសដើម នៅក្នុងជំពូក ៥:៥។
ទាល់គំនិត
«វង្វេងហើយ»
Daniel 5:10
ព្រះមហាក្សត្រីយានី
នៅក្នុងការបកប្រែថ្មីខ្លះបានយល់ឃើញថា ការនេះគឺតំណាងឲ្យព្រះមហាក្សត្រីយានី
គឺជាមាតារបស់ស្តេច។
ព្រះមហាក្សត្រីយានីគឺបានទទួលការគោរពយ៉ាងខ្លាំងនៅក្នុងសម័យបុរាណនៃបាប៊ីឡូន។
បពិត្រព្រះករុណា សូមទ្រង់មានព្រះជន្មយឺនយូរ
នេះគឺជារបៀបគោរព និងស្វាគមន៍ដល់ស្តេច។
សូមព្រះករុណាកុំខ្វល់ខ្វាយ ភ័យរន្ធត់ ហើយ កុំប្រែព្រះភ័ក្ត្រយ៉ាងដូច្នេះឡើយ
«កុំឲ្យព្រះភ័ក្ត្ររបស់ទ្រង់ប្រែទៅជាស្លេកស្លាំងឡើយ»
Daniel 5:11
ព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិត
ព្រះមហាក្សត្រីយានីបានជឿថាអំណាចរបស់ព្រះមិនពិត
ដែលព្រះចៅនេប៊ូសាបានថ្វាយបង្គំចេញពីដានីយ៉ែល។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ៤:៧។
នៅក្នុងរជ្ជកាលនៃព្រះបិតាព្រះអង្គ
«នៅក្នុងគ្រាដែលព្រះបិតាទ្រង់គ្រងរាជ្យ»
បុរសម្នាក់នោះគឺជាម្នាក់ដែលដឹងការលាក់កំបាំង មានតម្រិះ ប្រាជ្ញា
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បុរសម្នាក់នោះគឺជាម្នាក់ដែលដឹងការលាក់កំបាំង
ហើយមានប្រាជ្ញាដូចជាប្រាជ្ញារបស់ព្រះដែរ»
ព្រះចៅនេប៊ូសា ព្រះបិតាទ្រង់
«ព្រះបិតារបស់ទ្រង់ ព្រះចៅនេប៊ូសា»
អាចកាត់ស្រាយសុបិន្តនិមិត្តនានា ហើយអាចដោះស្រាយរាល់បញ្ហាពិបាកៗផ្សេងៗ
លោកនោះគឺដានីយ៉ែល ដែលព្រះបិតាទ្រង់ប្រទាននាមថា បេលថិស្សាសារ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នេះគឺដានីយ៉ែលតែមួយដែលស្តេចបានដាក់ឈ្មោះបេលថិស្សាសារ
ដែលមានគ្រប់ទាំងគុណភាព»
ដែលបានសសេរនោះ
«អ្វីដែលបានសរសេរនៅលើជញ្ជាំង»។ ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «ដៃអ្វីទៅដែលបានសរសេរនៅលើជញ្ជាំងនោះ»
Daniel 5:13
បន្ទាប់មកគេក៏នាំដានីយ៉ែលមកគាល់ស្តេច
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បន្ទាប់មកពួកគេបាននាំដានីយ៉ែលមកនៅចំពោះស្តេច» ឬ
«ក្រោយមកពួកទាហានបាននាំដានីយ៉ែលមកនៅចំពោះស្តេច»
ដែលស្តេចជាបិតាយើងបានជម្លៀសចេញពីស្រុកយូដានោះមែនឬ
នៅក្នុងឃ្លានេះ «បិតា» គឺបានប្រើសម្រាប់តំណាងពួកទាហានទាំងឡាយ។
ការបកប្រែរបៀបផ្សេងទៀត:
«ដែលទាហានរបស់បិតាយើងបាននាំចេញពីស្រុកយូដា»
លោកមានព្រះវិញ្ញាណដ៏វិសុទ្ធ
បេលសាសារបានជឿថាអំណាចរបស់ដានីយ៉ែលមកពីព្រះមិនពិតដែលបេលសាសារបានគោរពបូជា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ៤:៧។
ដែលដឹងអស់ទាំងការលាក់កំបាំង មានប្រាជ្ញាវាងវៃ មានចំនេះជ្រាលជ្រៅ មានតម្រិះខាងពិចារណា

generated on Wed Sep 10 16:16:32 2025

ហើយចេះកាត់ស្រាយសុបិន្ត
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកមានការបើកសម្តែង និងការយល់ដឹង ហើយនិងប្រាជ្ញាដ៏អស្ចារ្យ»
Daniel 5:15
ឥឡូវនេះមនុស្សគ្រប់គ្នាបានដឹង...បាននាំយកមកនៅចំពោះយើង
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ឥឡូវនេះមនុស្សគ្រប់គ្នាបានដឹង...បាននាំយកមកនៅចំពោះយើង»
បកស្រាយអត្ថន័យដល់យើង
«ចូលប្រាប់យើង»
យើងនឹងបំពាក់អាវពណ៌ស្វាយ និង ខ្សែកមាសជូនជាកិត្តិយស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងបំពាក់អាវពណ៌ស្វាយ និង
ខ្សែកមាសជូនជាកិត្តិយសដល់លោកផងដែរ»
បំពាក់អាវពណ៌ស្វាយ
បំពាក់អាវពណ៌ស្វាយ ដែលបានត្រៀមសម្រាប់ពួកមន្ត្រី។
ការបកប្រែរបៀបផ្សេងទៀត: «សម្លៀកបំពាក់សម្រាប់ពួករាជវង្ស»
ឋានៈជាអ្នកគ្រប់គ្រងទីបី
«មានតួនាទីបីក្នុងការគ្រប់គ្រង»
Daniel 5:17
បពិត្រព្រះករុណា សូមព្រះអង្គទុករង្វាន់ និង
«ដូច្នេះទូលបង្គំមិនចង់បានអំណោយទ្រង់ទេ»
អស់ទាំងប្រជាជាតិ គ្រប់ជាតិសាសន៍ គ្រប់ភាសា
នៅក្នុងឃ្លានេះប្រើជាមួយនឹងពាក្យ «ទាំងអស់»
ជាទូទៅពាក្យនេះតំណាងឲ្យចំនួនលេខដែលច្រើន។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សមានចំនួនដ៏ច្រើន មកពីជនជាតិនានា និងភាសាជាច្រើនផងដែរ»
ប្រជាជាតិ គ្រប់ជាតិសាសន៍ គ្រប់ភាសា
ពាក្យថា «ជនជាតិ» និង «ភាសា» នៅទីនេះតំណាងឲ្យមនុស្សមកពីប្រជាជាតិ
ហើយនិយាយភាសាផ្សេងៗពីគ្នា។ សូមមើលពីរបៀបបកប្រែរបស់អ្នកនៅក្នុងជំពូក
៣:៣។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលមកពីជនជាតិផ្សេងៗ
ហើយដែលនិយាយភាសាផ្សេងៗដែរ»
កោតខ្លាចញាប់ញ័រចំពោះទ្រង់
ពាក្យទាំងនេះមានន័យមូលដ្ឋានដូចគ្នា
ហើយបានបញ្ជាក់ពីការញាប់ញ័រនៃការភ័យខ្លាច។ ការបកប្រែរបៀបផ្សេងទៀត:
«វាបានភ័យខ្លាចយ៉ាងខ្លាំងជាមួយទ្រង់»
ទ្រង់ចង់ប្រហារជីវិត ឬទុកជីវិតដល់នណារក៏បាន
ឃ្លានេះមិនមានន័យថាព្រះចៅនេប៊ូក្នេសា
គឺបានដាក់ទោសឲ្យមនុស្សស្លាប់ដោយទ្រង់
តែសម្រាប់ពួកអ្នកដែលទ្រង់បានបញ្ជានោះ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះចៅនេប៊ូក្នេសាបានបញ្ជាដល់ទាហានទៅសម្លាប់អ្នកដែលចង់ស្លាប់»
ហើយចង់លើក នណារក៏បាន
«ទ្រង់នឹងលើកអ្នកណា ដែលទ្រង់ចង់លើកឡើង»
ទ្រង់ចង់...ហើយចង់
ពាក្យទាំងនេះគឺមានន័យដូចគ្នា។
ឬទម្លាក់ នណារក៏បាន
«ទ្រង់បន្ទាបខ្លួនដល់អ្នកដែលបានបន្ទាបខ្លួនដែរ»
Daniel 5:20
ព្រះរាជាមានចិត្តអំណួតក្អេងក្អាង
ពាក្យថា «ចិត្ត» នៅទីនេះសំដៅទៅស្តេចផ្ទាល់ខ្លួន។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចមានអំនួត»
មានចិត្តរឹងរូស
ពាក្យថា «វិញ្ញាណ» នៅទីនេះសំដៅទៅលើស្តេចខ្លួនឯង។
ចិត្តរឹងរូសរបស់ទ្រង់គឺមានបន្ទូលនៃពីការរឹងរូស។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចបានក្លាយទៅជារឹងរូស»
ក្អេងក្អាង
មនុស្សឆ្មើងឆ្មៃ ហើយមានទំនុកចិត្តជ្រុល
ទើបទ្រង់ត្រូវគេទម្លាក់ពីរាជសម្បត្តិ
ពាក្យថា «បល្ល័ង្ក» នៅទីនេះសំដៅទៅលើសិទ្ធអំណាចនៃការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សទម្លាក់ពីរាជសម្បត្តិរបស់ទ្រង់»
បណ្តេញព្រះរាជាចេញពីចំណោមមនុស្ស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបណ្តេញទ្រង់ចេញពីចំណោមពួកគេ»
ហើយទ្រង់បែរជាមានចិត្តគំនិតដូចជាសត្វតិរច្ឆាន
ពាក្យថា «គំនិត» នៅទីនេះតំណាងឲ្យការគិតរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «មានចិត្តគំនិតដូចជាសត្វតិរច្ឆាន»
ទឹកសន្សើម
សំណើមនៅលើដីដែលឃើញនៅពេលព្រឹក
ព្រះអង្គចង់ប្រទានឲ្យអ្នកណាស្រេចតែព្រះហឫទ័យទ្រង់
«អស់អ្នកណាដែលទ្រង់បានជ្រើសរើស»
Daniel 5:22
ព្រះករុណាបេលសាសារ
នេះគឺជាកូនរបស់ព្រះចៅនេប៊ូក្នេសាដែលបានក្លាយជាស្តេចបន្ទាប់ពីបិតារបស់ខ្លួន។
សូមមើលពីរបៀបដែលអ្នកបានសរសេរឈ្មោះរបស់ទ្រង់នៅក្នុងជំពូក ៥:១។
ក៏ទ្រង់មិនបានបន្ទាបខ្លួនដែរ
ពាក្យថា «ចិត្ត» នៅទីនេះសំដៅទៅស្តេចផ្ទាល់ខ្លួន។ ការបកប្រែរបៀបផ្សេងទៀត:
«មិនបានបន្ទាបខ្លួន»
ទ្រង់បានតម្កើងខ្លួនទាស់ប្រឆាំងនឹងព្រះអម្ចាស់
បានបះបោរទាស់ប្រឆាំងជាមួយព្រះជាម្ចាស់ហើយមានបន្ទូលលើកខ្លួនឯងឡើងទាស់នឹងព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ទ្រង់បានបះបោរទាស់ប្រឆាំងជាមួយព្រះជាម្ចាស់»
ពីព្រះវិហាររបស់ព្រះអង្គ
អ្វី និង នៅទីណា «ព្រះដំណាក់របស់ព្រះអង្គ» ការនេះគឺបាននិយាយយ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ចេញពីព្រះវិហាររបស់ព្រះអង្គនៅក្នុងក្រុងយេរូសាឡិម»
ព្រះដែលជាម្ចាស់លើ ខ្យល់ដង្ហើមជីវិត
ពាក្យថា «ដង្ហើម» នៅទីនេះសំដៅទៅលើជីវិត ហើយ «ដៃ»
សំដៅទៅលើអំណាចដែលគ្រប់គ្រង។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ដែលបានប្រទានឲ្យដល់អ្នកខ្យល់ដកដង្ហើម» ឬ
«ព្រះជាម្ចាស់ដែលបានគ្រប់គ្រងនៅលើជីវិតរបស់អ្នកទាំងមូល»
លើដំណើរជីវិតរបស់ព្រះអង្គ
«គ្រប់យ៉ាងដែលអ្នកបានធ្វើ»
មកសរសេរអក្សរនេះ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«វាបានសរសេរសារទាំងនេះឡើង»
Daniel 5:25
អក្សរនេះបានសរសេរថា
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នេះគឺជាសារដែលដៃបានសរសេរឡើង»
ម៉េណេ ម៉េណេ តេកែល និង អ៊ូផារស៊ីន
ពាក្យទាំងនេះគឺជាពាក្យនៃភាសាអារ៉ាម ដែលបានសរសេរនៅលើជញ្ជាំង។
ប្រកបពាក្យទាំងនេះជាមួយសម្លេង ដែលត្រូវជាមួយនឹងភាសារបស់អ្នក។
ម៉ាណេ ព្រះជាម្ចាស់បានរាប់
«ម៉េណេ មានន័យថាព្រះជាម្ចាស់ដឹងពីចំនួន»
តេកែល ព្រះជាម្ចាស់បានថ្លឹងព្រះករុណានៅលើជញ្ជីង
«តេកែល មានន័យថា ទ្រង់គឺជាជញ្ជីង»
ពេរេស រាជាណាចក្ររបស់ព្រះករុណា
«ពេរេស មានន័យថាអាណាចក្ររបស់ទ្រង់»។
ពេរេស
នេះគឺជាទម្រង់ទំរង់ឯកវចនៈនៃពាក្យ «ផាសស៊ីន» នៅក្នុងជំពូក ៥:២៥។
ព្រះករុណានៅលើជញ្ជីង ហើយឃើញថាព្រះករុណាស្រាលពេក
វិនិច្ឆ័យក្នុងភាពថ្លៃថ្នូររបស់ស្តេចដែលបានគ្រប់គ្រង គឺនិយាយអំពីទំងន់របស់ទ្រង់។
នេះគឺមានន័យថាស្តេចមិនស័ក្តិសមគ្រប់គ្រងទេ។
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានពិនិត្យមើលពីភាពថ្លៃថ្នូរដើម្បីគ្រប់គ្រង
ព្រះអង្គរកឃើញថាទ្រង់មិនស័ក្តិសមទេ»
រាជាណាចក្ររបស់ព្រះករុណាជាពីរ គឺមួយចំណែកឱ្យទៅជនជាតិមេឌី និង
មួយចំណែកទៀតឲ្យទៅជនជាតិពែរ្ស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានបំបែកអាណាចក្រទ្រង់ទៅជាពីរ ហើយប្រគល់ឲ្យមេឌី
ហើយនិងជនជាតិពែរ្ស»

generated on Wed Sep 10 16:16:32 2025

Daniel 5:29

ព្រះចៅបេលសាសារ
នេះគឺជាកូនរបស់ព្រះចៅនេប៊ូក្នេសាដែលបានក្លាយជាស្តេចបន្ទាប់ពីបិតារបស់ខ្លួន។ សូមមើលពីរបៀបដែលអ្នកបានសរសេរឈ្មោះរបស់ទ្រង់នៅក្នុងជំពូក ៥:១។

ខ្សែរកមាសមកបំពាក់ឲ្យ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «គេបានដាក់ខ្សែកនៅជុំវិញករបស់ទ្រង់»

មានឋានៈគ្រប់គ្រងទីបី
«មានតួនាទីលេខបីក្នុងការគ្រប់គ្រង»

គ្រងរាជ្យបន្ត
«បានក្លាយទៅជាអ្នកគ្រប់គ្រងនៃអាណាចក្រ»

នៅក្នុងព្រះជន្មហុកសិបពីរព្រះវស្សា
ពីរឆ្នាំក្រោយមក «នៅពេលទ្រង់មានព្រះជន្ម៦២ឆ្នាំ»

6

[1]ព្រះចៅដារីយូសសព្វព្រះទ័យតែងតាំងចៅហ្វាយខេត្តចំនួន១២០រូបដើម្បីមន្ត្រីគ្រប់គ្រងលើអាណាចក្រទាំងមូល។[2]នៅពីលើពួកគេមានមហាមន្ត្រីបីរូប
ដែលត្រូវបានតែងតាំងឲ្យធ្វើជាប្រមុខលើមន្ត្រីទាំងអស់ ហើយដានីយ៉ែលជាម្នាក់ក្នុងចំណោមអ្នកទាំងនោះ។
ពួកមហាមន្ត្រីត្រូវតែងតាំងឡើងសម្រាប់មើលពីលើពួកមន្ត្រីតាមខេត្ត ដូច្នេះព្រះរាជនឹងមិនបាត់អ្វីទៀតឡើយ។[3]ដានីយ៉ែលមានកិត្តិយសជាងពួកមហាមន្ត្រីមតាមខេត្ត
ដោយលោកមានព្រះវិញ្ញាណអស្ចារ្យគង់នៅជាមួយ។ ហើយព្រះរាជាមានបំណងចង់តែងតាំងលោកឲ្យគ្រប់គ្រងលើអាណាចក្រទាំងមូល។
[4]ដូច្នេះហើយពួកមហាមន្ត្រីផ្សេងទៀត ហើយនិងពួកចៅហ្វាយខេត្តក៏បានខំរកកំហុសនៅក្នុងការងាររបស់លោកដានីយ៉ែលដែលបានធ្វើសម្រាប់អាណាចក្រ
ប៉ុន្តែពួកគេមិនអាចចាប់កំហុសគាត់បានឡើយ ឬភាពខ្សោយនៅក្នុងកិច្ចការរបស់គាត់ពីព្រោះគាត់គឺជាមនុស្សស្មោះត្រង់។
គ្មានកំហុសឬការធ្វេសប្រហែសអាចរកឃើញនៅក្នុងលោកឡើយ។[5]ដូច្នេះពួកគេទាំងនោះបាននិយាយថា
«យើងមិនអាចរកហេតុផលនិងបន្ទោសទាស់និងដានីយ៉ែលនេះបានឡើយ មានតែចាប់កំហុសគាត់តាមរយៈក្រិត្យវិន័យព្រះជាម្ចាស់របស់គាត់ប៉ុណ្ណោះ»។
[6]រួចហើយពួកមហាមន្ត្រី និងពួកមន្ត្រីក៏បាននាំផែនការទៅគាល់នៅចំពោះព្រះរាជា។ ពួកគេបានទូលទៅកាន់ព្រះរាជាថា «បពិត្រព្រះករុណា ដារីយុស
សូមឲ្យព្រះអង្គមានព្រះជន្មយឺនយូរ![7]ពួកមហាមន្ត្រីទាំងអស់នៃអាណាចក្រ ហើយនិងពួកមន្ត្រីតាមតំបន់ និងពួកមន្ត្រីចៅហ្វាយខេត្ត ហើយពួកទីប្រឹក្សា
និងពួកមន្ត្រីទាំងអស់បានមូលមតិរួមគ្នាសម្រេចទូលព្រះករុណា សូមឲ្យព្រះរាជាចេញរាជឱង្ការមួយច្បាប់ ប្រកាស់បំរាមយ៉ាងតឹងតែងបំផុត
ដោយក្នុងរយៈពេលសាមសិបថ្ងៃ បើអ្នកណាសូមអ្វីពីព្រះណាផ្សេង ឬមនុស្ស ណាក្រៅអំពីព្រះករុណា អ្នកនោះនឹងត្រូវបោះចូលទៅក្នុងរូងសឹង្ហ។
[8]ពេលនេះ បពិត្រព្រះរាជា សូមទ្រង់ចេញច្បាប់នេះ ហើយឡាយព្រះហស្តលេខាលើច្បាប់នោះ ដើម្បីកុំឲ្យមានការផ្លាស់ប្តូរបាន ហើយឲ្យស្របទៅនឹងច្បាប់របស់សាសន៍មេឌី
និង សាសន៍ពើស៊ីដូច្នេះវាមិនអាចកែប្រែបានឡើយ»។[9]រួចហើយព្រះបាទដារីយុស ក៏ឡាយព្រះហស្តលេខាលើឯកសារន និងបានធ្វើច្បាប់នេះឡើង។
[10]នៅពេលដានីយ៉ែលបានដឹងថា ច្បាប់នោះបានចុះហត្ថលេខារួចរាល់ហើយ លោកក៏ចូលទៅផ្ទះរបស់លោក
(ពេលនេះដែលទ្វារបន្ទប់ខាងលើបានបើកចំហរឆ្ពោះទៅកាន់ទីក្រុងយេរូសាឡឹម) ហើយលោកលុតជង្គង់ចុះ គឺលោកបានធ្វើបីដងក្នុងមួយថ្ងៃ ហើយអធិស្ឋាន
និងអរព្រះគុណនៅចំពោះព្រះជាម្ចាស់ដូចដែលគាត់ធ្លាប់ធ្វើពីពេលមុន។[11]រួចហើយពួកមនុស្សដែលបានបង្កើតច្បាប់រួមគ្នាបាន
ឃើញដានីយ៉ែលកំពុងតែអធិស្ឋានទៅព្រះជាម្ចាស់ស្វែងរកជំនួយ។
[12]ពេលនោះពួកគេនាំគ្នាទៅទូលព្រះរាជាពីច្បាប់បំរាមដែលបានចែង «បពិត្រព្រះករុណា តើទ្រង់មិនបានឡាយព្រះហស្តលេខាលើច្បាប់ ដែលចែងថាក្នុងរយៈពេល៣០ថ្ងៃ
បើអ្នកណាទូលសូមអ្វីពី ព្រះណាផ្សេង ឬពីនណាម្នាក់ក្រៅអំពីព្រះករុណា អ្នកនោះនឹងត្រូវបោះចូលទៅក្នុងរូងសឹង្ហទេឬអី»? ព្រះរាជាក៏មានរាជឱង្ការតបវិញថា
«សេចក្តីនោះគឺពិតប្រាកដមែន ដោយស្របតាមច្បាប់របស់សាសន៍មេឌី និងសាសន៍ពើស៊ី គឺមិនអាចកែប្រែបានឡើយ»។
[13]រួចហើយពួកគេទូលឆ្លើយទៅព្រះរាជាវិញថា «ម្នាក់នោះគឺជាលោក ដានីយ៉ែល ដែលជាម្នាក់ក្នុងចំណោមប្រជាជនជាឈ្លើយដែលមកពីយូដា មិនបានខ្វល់នឹងព្រះករុណា
ឬមិនគោរពច្បាប់ដែលព្រះករុណាបានឡាយព្រះហស្តទេ។ លោកបានអធិស្ឋានទៅព្រះជាម្ចាស់របស់លោកមួយថ្ងៃបីដង»។[14]ពេលព្រះរាជាបានឮការនេះ
ទ្រង់ព្រួយព្រះទ័យជាខ្លាំង ហើយទ្រង់ក៏គិតក្នុងព្រះគំនិតថា ដើម្បីអាចជួយរំដោះដានីយ៉ែលពីច្បាប់ទាំងនេះ។ ព្រះរាជាបានខំប្រឹងរក វិធីជួយដានីយ៉ែលរហូតដល់ថ្ងៃលិច។
[15]រួចហើយបុរសទាំងនោះដែលបានប្តឹងក៏នាំគ្នាមកគាល់ព្រះរាជា ហើយទូលទៅកាន់ទ្រង់ថា «បពិត្រព្រះករុណា ទ្រង់ជ្រាបហើយថា រាល់ច្បាប់របស់ពួកសាសន៍មេឌី
និងសាសន៍ពើស៊ី ដែលគ្មានច្បាប់ឬសេចក្តីណាដែលព្រះរាជាបានចេញរួចហើយអាចនឹងប្តូរវិញបាននោះទេ»។
[16]គ្រានោះស្តេចក៏ចេញរាជបញ្ជា ហើយពួកគេក៏បាននាំយកលោក ដានីយ៉ែលបោះទៅក្នុងរូងសឹង្ហ។ ព្រះរាជាមានរាជឱង្ការទៅកាន់ដានីយ៉ែលថា
«សូមឲ្យព្រះជាម្ចាស់របស់លោកដែលលោកបានបម្រើនោះជួយ សង្គ្រោះលោកផងចុះ»។
[17]ថ្មមួយផ្ទាំងត្រូវបានយកមកសង្កត់បិទមាត់រូងសឹង្ហ ហើយព្រះរាជាក៏បានប្រថាប់ត្រាព្រះទម្រង់ និងចិញ្ចៀនត្រារបស់ពួកសេនាបតីនាមី ុនមន្ត្រី
ដើម្បីមិនឲ្យមានការផ្លាស់ប្តូរទាក់ទងទៅនឹងលោកដានីយ៉ែល។[18]រួចហើយព្រះរាជាក៏យាងត្រឡប់ទៅ ព្រះរាជវាំងវិញ ដោយមិនសោយអ្វីសោះពេញមួយរាត្រីនោះ។
ពុំមានការប្រគុំតន្ត្រីឬការសំដែងថ្វាយទ្រង់ឡើយ ហើយទ្រង់ក៏ផ្ទំមិនលក់ដែរ។
[19]កាលព្រលឹមឡើងស្រាងៗព្រះរាជាក៏តើនឡើង ហើយរួសរាន់យាងទៅឯរូងសឹង្ហ។[20]ពេលព្រះរាជាយាងមកដល់ជិតរូងសឹង្ហ ទ្រង់ក៏ស្រែកហៅ
ពាក្យ «ងាកចេញ» មានន័យថាអ៊ីស្រាអែលឈប់គោរពច្បាប់របស់ព្រះ។
មានចែងទុកក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលលោកម៉ូសេបានសរសេរនៅក្នុងច្បាប់»
បានធ្លាក់មកលើយើងខ្ញុំ
ការដាក់បណ្តាសា
និងសម្បថដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានគេនិយាយដូចជាត្រូវបានបង្ហូរចេញដូចជាទឹក។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកបាននាំមកលើពួកយើង»
Daniel 9:12
ព័ត៌មានទូទៅ:
ដានីយ៉ែលបន្តអធិស្ឋានដល់ព្រះអម្ចាស់អំពីជនជាតិអ៊ីស្រាអែល។
ត្បិតនៅក្រោមមេឃ...អ្វីដែលបានកើតឡើងនៅក្រុងយេរូសាឡិមឡើយ
ដានីយ៉ែលកំពុងនិយាយបំផ្លើសដើម្បីបង្ហាញពីទុក្ខព្រួយដ៏អស្ចារ្យរបស់គាត់អំពីក្រុងយេរូសាឡិម។
ទីក្រុងជាច្រើនត្រូវបានបំផ្លាញទាំងស្រុង។
ពុំមានហេតុការណ៍អ្វីដែលអាច
«គ្មានអ្វីត្រូវបានធ្វើទេ»
អ្វីដែលបានកើតឡើងនៅក្រុងយេរូសាឡិម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលអ្នកបានធ្វើចំពោះក្រុងយេរូសាឡិម»
ដោយមានចែងនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត:«ដូចម៉ូសេបានសរសេរនៅក្នុងច្បាប់»
បានបែរចេញពីអំពើបាប
នៅទីនេះបញ្ឈប់សកម្មភាពអាក្រក់ត្រូវបានគេនិយាយថាជាការងាកចេញពីពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «ការបញ្ឈប់អំពើអាក្រក់របស់យើង»
ព្រះអម្ចាស់ បាននាំហេតុការណ៍អាក្រក់នោះធ្លាក់មកលើយើង
«ព្រះអម្ចាស់បានរៀបចំគ្រោះមហន្តរាយនេះ»
យើងខ្ញុំមិនបានស្តាប់បង្គាប់តាមព្រះបន្ទូលទ្រង់ឡើយ
ពាក្យថា «សំឡេង» នៅទីនេះសំដៅទៅលើអ្វីដែលព្រះអម្ចាស់បានបញ្ជា។
ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនបានធ្វើអ្វីដែលទ្រង់បានប្រាប់យើងឲ្យធ្វើទេ»
Daniel 9:15
ព្រះហស្តដ៏ខ្លាំងអស្ចារ្យ
ពាក្យថា «ដៃដ៏ខ្លាំង» គឺជាឈ្មោះប្រើសម្រាប់កម្លាំង។ការបកប្រែរបៀបផ្សេងទៀត:
«ដោយកម្លាំងដ៏ខ្លាំង»

generated on Wed Sep 10 16:16:32 2025

ហើយបានធ្វើឱ្យព្រះនាមរបស់ព្រះអង្គល្បីសុះសាយ ដល់សព្វថ្ងៃ

«ព្រះបានធ្វើអោយមនុស្សដឹងថាព្រះអង្គអស្ចារ្យប៉ុណ្ណាដូចទ្រង់នៅតែធ្វើសព្វថ្ងៃ»

យើងរាល់គ្នាបានប្រព្រឹត្តអំពើបាបយ៉ាងអាក្រក់

ឃ្លាទាំងពីរនេះមានន័យថាជាមូលដ្ឋានដូចគ្នា និងត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់ថា តើអំពើបាបអាក្រក់យ៉ាងណា។

ព្រោះអំពើបាបរបស់យើងខ្ញុំ និងអំពើទុច្ចរិត

ដានីយ៉ែល និងអ៊ីស្រាអែលបានធ្វើបាប ហើយបានធ្វើអំពើអាក្រក់ ប៉ុន្តែ «យើង» មិនរាប់បញ្ចូលព្រះទេ។

សូមទ្រង់ដកសេចក្តីក្រោធចេញ

ពាក្យថា «កំហឹង» និង «សេចក្តីក្រោធ» មានន័យដូចគ្នានឹងរឿងដដែលៗហើយបញ្ជាក់ថា តើកំហឹងរបស់ព្រះគួរឲ្យខ្លាចប៉ុណ្ណានៅពេលដែលគាត់ធ្វើវា។

ពីភ្នំបរិសុទ្ធ

ភ្នំនេះអាចបរិសុទ្ធ ពីព្រោះព្រះវិហាររបស់ព្រះនៅទីនោះ។ ការបកប្រែរបៀបផ្សេងទៀត: «ភ្នំដ៏បរិសុទ្ធគឺជាកន្លែងរបស់អ្នកស្ថិតនៅ»

អំពើបាបរបស់យើងខ្ញុំ...បុព្វបុរសយើង

ពាក្យថា «របស់យើង» នៅទីនេះសំដៅទៅលើដានីយ៉ែល និងអ៊ីស្រាអែល ប៉ុន្តែមិនមែនចំពោះព្រះទេ។

នៅជុំវិញយើងមើលងាយ

«គោលដៅនៃការមិនគោរព»

Daniel 9:17

ឥឡូវនេះ

នេះមិនមានន័យថា «នៅពេលនេះ» ប៉ុន្តែវាជាវិធីដើម្បីបង្ហាញថាដំណាក់កាលបន្ទាប់នៅក្នុងការអធិស្ឋានរបស់ដានីយ៉ែលជិតមកដល់ហើយ

អ្នកបម្រើទ្រង់...សូមទ្រង់សណ្តាប់ពាក្យអធិស្ឋាន

ពាក្យថា «អ្នកបំរើរបស់ទ្រង់» និង «របស់ទ្រង់» នៅទីនេះសំដៅលើដានីយ៉ែល។ គាត់និយាយអំពីខ្លួនគាត់នៅក្នុងមនុស្សទីបីដែលជាសញ្ញានៃការគោរពចំពោះព្រះ។

សូមទ្រង់សណ្តាប់

«សំណូមពរមេត្តាករុណា»

សូមឲ្យព្រះភ័ក្ត្រព្រះអង្គបានចែងចាំង

អ្នកនិពន្ធនិយាយអំពីព្រះអម្ចាស់សំដែងការប្រសើរដូចជាព្រះភ័ក្ត្ររបស់ព្រះអម្ចាស់បញ្ចេញពន្លឺ។

ការបកប្រែរបៀបផ្សេងទៀត: «ប្រព្រឹត្តដោយសប្បុរសចំពោះ»

ទីបរិសុទ្ធរបស់ព្រះអង្គ

នេះសំដៅទៅលើព្រះវិហារនៅក្រុងយេរូសាឡិម។

សូមផ្ទៀងព្រះកាណ៌សណ្តាប់ សូមបើកព្រះនេត្រទតមើល

ដើម្បី «បើកត្រចៀក» គឺជាពាក្យសំដីដែលមាន ន័យថាស្តាប់។ ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ពីបំណងប្រាថ្នារបស់ដានីយ៉ែលដែលចង់អោយព្រះស្តាប់ការអធិស្ឋានរបស់គាត់។

ការបកប្រែរបៀបផ្សេងទៀត: «សូមស្តាប់»

សូមបើកព្រះនេត្រទតមើល

ដើម្បី «បើកភ្នែក» គឺមានន័យថាមើលឃើញ។ ឃ្លាទាំងពីរនេះមានន័យដូចគ្នា ហើយបញ្ជាក់ពីបំណងប្រាថ្នារបស់ដានីយ៉ែលដែលចង់អោយព្រះជាម្ចាស់យកចិត្តទុកដាក់នឹងការអធិស្ឋានរបស់គាត់។

ការបកប្រែរបៀបផ្សេងទៀត: «កត់សំគាល់ពួកយើង» ឬ «យកចិត្តទុកដាក់»

ស្រែករកព្រះនាមព្រះអង្គ»

ពាក្យថា «ឈ្មោះ» នៅទីនេះតំណាងឲ្យភាពជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត: «គឺជាទីក្រុងរបស់អ្នក» ឬ «ជាកម្មសិទ្ធិរបស់អ្នក»

សូមកុំព្រងើយ

នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត: «ធ្វើសកម្មភាពយ៉ាងលឿន»

Daniel 9:20

ប្រជាជនអ៊ីស្រាអែល

«ប្រជាជនអ៊ីស្រាអែលដែលខ្ញុំជាកម្មសិទ្ធិ»

ភ្នំបរិសុទ្ធរបស់ព្រះខ្ញុំ

ភ្នំនេះអាចបរិសុទ្ធដោយសារប្រាសាទ។ ការបកប្រែរបៀបផ្សេងទៀត: «ភ្នំដែលជាព្រះវិហារបរិសុទ្ធរបស់ព្រះ»

លោកដែលមានឈ្មោះ កាព្រីយ៉ែល

នេះគឺជាទេវតាតែមួយឈ្មោះកាព្រីយ៉ែល ដែលបានបង្ហាញខ្លួនជាទម្រង់មនុស្សនៅក្នុងជំពូក ៨:១៥។ «កាព្រីយ៉ែល ដែលបានបង្ហាញខ្លួនជាបុរស»

និមិត្តឃើញពីដំបូងនោះ

នេះប្រហែលជាសំដៅទៅលើនិមិត្តដំបូង ដែលដានីយ៉ែលបានឃើញនៅពេលគាត់កំពុងភ្ញាក់។ «នៅក្នុងនិមិត្តមុន» ឬ «នៅក្នុងនិមិត្តដែលខ្ញុំបានឃើញពីមុន» ឬ «នៅក្នុងនិមិត្តពីមុន»

បានហោះយ៉ាងលឿនចូលមករកខ្ញុំ

«ហោះហើរមករកខ្ញុំយ៉ាងលឿន»

ចំពេលនៃការថ្វាយដង្វាយពេលល្ងាច

ប្រជាជនយូដាបានថ្វាយយញ្ញបូជាដល់ព្រះរៀងរាល់ល្ងាចមុនពេលព្រះអាទិត្យលិច។

Daniel 9:22

ពន្យល់ឲ្យលោកបានយល់

ពាក្យថា «ពន្យល់» និង «ការយល់ដឹង» មានន័យដូចគ្នា ហើយសង្កត់ធ្ងន់ថា កាព្រីយែលនឹងជួយដានីយ៉ែលឲ្យយល់ពីសារនេះទាំងស្រុង។

ចាប់ផ្តើមទូលអង្វរ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះបានបញ្ជា»

រិះគិតពីព្រះបន្ទូលនេះ

ពាក្យថា «សម្តី» នៅទីនេះសំដៅទៅលើសារទាំងមូល។ ការបកប្រែរបៀបផ្សេងទៀត: «គិតអំពីសារនេះ»

យល់ពីអត្ថន័យ

នេះសំដៅទៅលើការព្យាករណ៍របស់យេរេមានៅក្នុងជំពូក ៩: ១។

Daniel 9:24

ចិតសិបឆ្នាំ ប្រាំពីរដង ទៅកាន់ប្រជាជន និង ទីក្រុងបរិសុទ្ធរបស់ព្រះអង្គ

ច្បាប់របស់ព្រះជាម្ចាស់ដែលព្រះអង្គគួរនឹងធ្វើការទាំងអស់នៅក្នុងខ សម្រាប់ហើយ ប្រជាជនដែលនៅក្នុងទីក្រុងដ៏បរិសុទ្ធ។

ចិតសិបឆ្នាំប្រាំពីរដង... ប្រាំពីរប្រាំពីរដង...ហុកសិបពីរដងទៀត

ប្រាំពីរដល់ទៅពីរដង - នេះគឺមិនមែនធម្មតាក្នុងរបៀបជនជាតិអ៊ីស្រាអែលរាប់។ ប្រសិនបើអាចទៅរួច ព្យាយាមបកប្រែរបៀបណាដែលនៅតែទុកលេខប្រាំពីរនេះ។ ការបកប្រែរបៀបផ្សេងទៀត: «ចិតសិបដងប្រាំពីរឆ្នាំ ... ប្រាំពីរដងប្រាំពីរឆ្នាំ ... និងហុកសិបពីរដងប្រាំពីរឆ្នាំ»

ប្រជាជន និង ទីក្រុងបរិសុទ្ធ

ពាក្យថា «របស់អ្នក» កន្លែងនេះសំដៅទៅលើដានីយ៉ែល។ ប្រជាជនរបស់អ៊ីស្រាអែល ហើយនិងទីក្រុងយេរូសាឡិមដ៏បរិសុទ្ធ។

ដើម្បីលុបបំបាត់អំពើរំលង និង អំពើបាប

គំនិតនេះគឺរំលឹកដើម្បីបញ្ជាក់ពីរបៀបដែលវានឹងកើតឡើងជាពិត។

ហើយសម្រេចតាមនិមិត្ត

ពាក្យថា «នាំចេញ» គឺមានន័យស្រដៀងទៅនឹងពាក្យធ្វើឲ្យសម្រេច។ ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឲ្យនិមិត្តបានសម្រេច» ឬ «ធ្វើឲ្យនិមិត្តបានសម្រេច»

ពាក្យទាំងនេះគឺប្រើសម្រាប់រួមគ្នាដើម្បីធ្វើឲ្យចំណុចសំខាន់បានច្បាស់លាស់។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកត្រូវឲ្យប្រកដថាបានយល់» ឬ «អ្នកត្រូវឲ្យបានច្បាស់»

ពាក្យទាំងអស់ដែលនៅក្នុងបរិបទនេះគឺមានន័យដូចគ្នា។

ពាក្យទាំងនោះចង់បញ្ជាក់ដានីយ៉ែលថានិមិត្តរបស់លោកយេរេមាគឺជាការពិតហើយនិងការថ្លែងទំនាយផង

បានចាក់ប្រេងតាំង

ការចាក់ប្រេងតាំងគឺជាសញ្ញានៃការប្រព្រឹត្តដើម្បីបង្ហាញដល់អ្នកណាម្នាក់ពីការជ្រើសរើស។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលព្រះបានចាក់ប្រេងតាំង» ឬ «មនុស្សដែលព្រះបានជ្រើសរើស»

ប្រាំពីរប្រាំពីរដង...ប្រាំពីរឆ្នាំហុកសិបពីរដង

ពីរប្រាំពីដល់ - ការបូកបញ្ចូលគ្នាជាមួយ៦៩ នៃ៧០ប្រាំពី ដល់ហើយនិយាយនៅក្នុង២៤ខ។

ហើយសង់ក្រុងយេរូសាឡិមឡើងវិញ

ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននឹងសង់ក្រុងយេរូសាឡិមឡើងវិញ»

កំពែង

ការជីករណ្តៅវែងនៅជុំវិញទីក្រុង ឬអាគារ ជាទូទៅជាមួយទឹកនៅក្នុងវា

ជាគ្រាដែលវេទនា

«ពេលវេលាដែលមានបញ្ហាធំបំផុត»

Daniel 9:26

generated on Wed Sep 10 16:16:32 2025

ប្រាំពីរឆ្នាំហុកសិបពីរដង
ប្រាំពីរដល់ទៅពីរដង - នេះគឺមិនមែនធម្មតាក្នុងរបៀបជនជាតិអ៊ីស្រាអែលរាប់។ ប្រសិនបើអាចទៅរួច ព្យាយាមបកប្រែរបៀបណាដែលនៅតែទុកលេខប្រាំពីរនេះ។ សូមមើលពីរបៀបអ្នកបានបកប្រែចំនួនលេខទាំងនេះ នៅក្នុងជំពូក ៩:២៤។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាំពីរឆ្នាំហុកសិបពីរដង»

លោកដែលត្រូវអភិសេកតែងតាំងនឹងត្រូវគេបំផ្លាញគ្មានសល់
ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «លោកដែលត្រូវអភិសេកតែងតាំងនឹងត្រូវគេបំផ្លាញគ្មានសល់»

អភិសេកតែងតាំង
ការចាក់ប្រេងតាំងគឺជាសញ្ញានៃការប្រព្រឹត្តដើម្បីបង្ហាញដល់អ្នកណាម្នាក់ពីការជ្រើសរើសរបស់ព្រះ។ សូមមើលពីរបៀបបកប្រែពាក្យនៅក្នុងជំពូក ៩:២៤។ ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលព្រះជាម្ចាស់ចាក់ប្រេងតាំង» ឬ «មនុស្សដែលព្រះជ្រើសរើស»

ស្តេចមួយអង្គនឹងមក
ការនេះអ្នកគ្រប់គ្រងជាបរទេស មិនមែន «អ្នកដែលត្រូវបានចាក់ប្រេងតាំង»។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកដទៃនឹងត្រូវមកគ្រប់គ្រង» ឬ «អ្នកគ្រប់គ្រងដែលមានអំណាចនឹងមកដល់»

ហើយនៅទីបញ្ចប់នឹងមានទឹកជំនន់
ពួកទាហាននឹងបំផ្លាញទីក្រុង ហើយកន្លែងដែលបរិសុទ្ធ ដូចទឹកជន់លេចបំផ្លាញអ្វីៗដែរ។

ត្បិតសេចក្តីវេទនានេះបានកំណត់មកហើយ
ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់មានច្បាប់សម្រាប់ទីក្រុងដែលបាក់បែក ហើយនិងទីសក្ការៈ» ឬ «ព្រះជាម្ចាស់បានប្រកាស់ថាពួកសត្រូវទាហាននឹងបំផ្លាញអ្វីៗទាំងអស់»

Daniel 9:27

ស្តេចនោះនឹង...ស្តេចនេះនឹង
ការនេះសំដៅដល់អ្នកគ្រប់គ្រងដែលនឹងមកដល់ ដែលនឹងបំផ្លាញអ្នកបានចាក់ប្រេងតាំង។

ប្រាំពីរឆ្នាំ...ហើយនៅរយៈពេលបីឆ្នាំកន្លះ
ពាក្យថា «ប្រាំពីរ» គឺប្រើសំដៅទៅលើរយៈពេលប្រាំពីរឆ្នាំ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រាំពីរឆ្នាំ...ហើយនៅរយៈពេលបីឆ្នាំកន្លះ»

នឹងបញ្ឈប់
«ឈប់» ឬ «ពាក់កណ្តាល»

ការថ្វាយយញ្ញបូជា និង ការថ្វាយដង្វាយ
ពាក្យទាំងពីរនេះមានមូលដ្ឋានដូចគ្នា។ ពាក្យដដែលៗគឺបង្ហាញថាអ្នកគ្រប់គ្រងនឹងរារាំងការលះបង់គ្រប់ប្រភេទ។
ការបកប្រែរបៀបផ្សេងទៀត: «ការលះបង់គ្រប់បែបយ៉ាង» ឬ «ការលះបង់គ្រប់យ៉ាងនៃការថ្វាយដង្វាយ»

ការអាក្រក់ចង្រៃគួរឲ្យស្អប់ខ្ពើម
ការនេះសំដៅទៅលើកន្លែងការពារតួរអាគារខាងលើនៃជញ្ជាំងរបស់ព្រះវិហារ ដែលបានហៅថា «គួរឲ្យស្អប់ខ្ពើម» ពីព្រោះនៅទីនោះគឺពេញទៅដោយរូបព្រះ។
ការបកប្រែរបៀបផ្សេងទៀត: «នៅលើជញ្ជាំងនៃព្រះវិហារគឺពេញទៅដោយអំពើគួរឲ្យស្អប់ខ្ពើម»

មេបំផ្លាញ
«មនុស្សដែលជាអ្នកបំផ្លាញ»

ការបញ្ចប់ និងការបំផ្លាញនៃបញ្ញត្តិនឹងត្រូវចេញមក
ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានដាក់បញ្ញត្តិពីការចុងក្រោយបង្អាស់»

ការបំផ្លាញចុងក្រោយបង្អាស់
ពាក្យទាំងពីរ ឬជាការស្តែងចេញពីមូលដ្ឋានដូចគ្នា។ ពាក្យទាំងពីរបានបញ្ជាក់ពីការច្បាស់លាស់ ហើយការបំផ្លាញដែលនឹងកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត: «ការបំផ្លាញដ៏ពេញលេញ»

ជាអ្នកដែលបានធ្វើឲ្យមានការបំផ្លាញ
«មនុស្សដែលបានធ្វើឲ្យមានការបំផ្លាញ»

---

10 [1]នៅក្នុងឆ្នាំទីបីនៃរជ្ជកាលរបស់ព្រះចៅស៊ីរូស ជាស្តេចរបស់ពើស៊ី គឺជាសារមួយបានបើកសម្តែងដល់ដានីយ៉ែល ដែលត្រូវគេហៅថា បេលទិស្សាសារ។
សារនេះជាសេចក្តីពិត។ គឺវាមានការចំបាំងដ៏ខ្លាំងក្លា។ ដានីយ៉ែលបានយល់ពីសារនោះ នៅពេលដែលលោកមានការយល់ដឹងពីនិមិត្ត។
[2]នៅក្នុងសម័យនោះខ្ញុំ ដានីយ៉ែលបានកាន់ទុក្ខអស់រយៈពេលបីអាទិត្យ។[3]ខ្ញុំមិនបានទទួលទានអាហារដ៏ឆ្ងាញ់ឡើយ ខ្ញុំមិនបានបរិភោគសាច់
ខ្ញុំមិនបានផឹកស្រាហើយខ្ញុំក៏មិនបានលាបប្រេងលើខ្លួនឯង រហូតដល់គ្រប់បីអាទិត្យ។
[4]នៅថ្ងៃទីម្ភៃបួននៃខែទីមួយ ក្នុងពេលខ្ញុំកំពុងឈរនៅមាត់ទន្លេធំ (គឺជាហ៊ីដេកែល)[5]ខ្ញុំបានសម្លឹងមើលទៅ បានឃើញបុរសម្នាក់ស្លៀកសំពត់ឯកទេស និង
មានក្រវ៉ាត់ចង្កេះដោយមាសសុទ្ធមកពីទឹកដីអ៊ូផាស។[6]ខ្លួនប្រាណរបស់លោកមើលទៅដូចជាត្បូងបេរីល ហើយមុខលោកចាំងដូចផ្លេកបន្ទោរ។
ភ្នែករបស់លោកវិញដូចជាភ្លើងដែលឆេះ ហើយដៃលោកនិងជើងរបស់លោក ដូចជាលង្ហិនដែលគេខាត់យ៉ាងរលោង។
សម្លេងលោកឮត្រហឹងអឺងកងប្រៀបបានទៅនឹងសម្លេងហ្វូងមនុស្ស។
[7]ខ្ញុំ ដានីយ៉ែល ក៏បានឃើញនិមិត្ត ដ្បិតមនុស្សម្នាក់ដែលបាននៅជាមួយខ្ញុំ គឺមិនបានឃើញនិមិត្តដូចនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការភ័យរន្ធត់ជាខ្លាំង
បានធ្លាក់មកលើពួកគាត់ ហើយពួកគេក៏បាននាំគ្នាទៅលាក់ខ្លួន។[8]ដូច្នោះហើយ បានជាខ្ញុំនៅតែម្នាក់ឯងហើយឃើញនិមិត្តដ៏អស្ចារ្យនេះ។
ខ្ញុំអត់មានកម្លាំងកំហែងនៅក្នុងខ្លួនខ្ញុំទៀតទេ មុខមាត់របស់ខ្ញុំក៏ស្លេកស្លាំង។[9]ក្រោយមកខ្ញុំបានឮពាក្យលោក នៅពេលខ្ញុំឮសម្លេងទាំងនោះ ខ្ញុំបានក្រាបមុខចុះលង់ស្មារតី
ជាមួយមុខរបស់ខ្ញុំក្រាបចុះដល់ដី។
[10]មានដៃមួយបានពាល់ខ្ញុំ ហើយធ្វើឲ្យជង្គង់ខ្ញុំ ហើយប្រអប់ដៃខ្ញុំញាប់ញ័រ។[11]ទេវតាក៏ពោលមកខ្ញុំថា «ដានីយ៉ែលអើយ លោកជាមនុស្សមានតម្លៃខ្លាំងណាស់
សូមឲ្យបានយល់ពីសេចក្តីដែលខ្ញុំកំពុងនិយាយមកកាន់លោកចុះ។ សូមឈរឲ្យបានត្រង់ ត្បិតព្រះជាម្ចាស់បានចាត់ខ្ញុំឲ្យមកជួបលោក»។
ពេលព្រះជាម្ចាស់បានព្រះបន្ទូលនេះមកកាន់ខ្ញុំ ហើយខ្ញុំក៏បានឈរឡើងដោយញាប់ញ័រដែរ។
[12]រួចហើយលោកក៏បាននិយាយមកខ្ញុំថា «សូមកុំភ័យខ្លាចអី ដានីយ៉ែល។ តាំងពីថ្ងៃដំបូងដែលលោកបានប្រុងចិត្តកើម្បីចង់យល់ ហើយបានបន្ទាបខ្លួនចំពោះព្រះជាម្ចាស់
ពាក្យរបស់លោកក៏បានឮ ហើយខ្ញុំក៏មកដោយសារតែពាក្យលោកដែរ។[13]ម្ចាស់នៃនគរពើស៊ីបានប្រឆាំងតទល់នឹងខ្ញុំ
ហើយខ្ញុំបានជាប់នៅជាមួយស្តេចពើស៊ីអស់រយៈពេលម្ភៃមួយថ្ងៃ។ តែទេវតាមីកែល ដែលជាប្រមុខនៃទេវតាបានមកជួយខ្ញុំ។
[14]ឥឡូវនេះខ្ញុំមក ដើម្បីជួយដល់លោកឲ្យបានយល់ពីអ្វីដែលនឹងកើតឡើងចំពោះប្រជាជនរបស់លោកនៅគ្រាចុងក្រោយ។ ត្បិតនិមិត្ត
សម្រាប់ថ្ងៃទាំងនោះមិនទាន់កើតឡើងនោះទេ»។[15]នៅពេលទេវតានោះកំពុងនិយាយមកកាន់ខ្ញុំជាមួយនឹងពាក្យទាំងនោះ ខ្ញុំក៏ក្រាបមុខចុះទៅដល់ដី
ហើយមិនអាចនិយាយបានទេ។
[16]មានម្នាក់ដែលមានរូបរាងដូចជាកូនមនុស្សបានមកប៉ះបបូរមាត់ខ្ញុំ ហើយខ្ញុំក៏បើកមាត់និយាយទៅកាន់លោកដែលឈរនៅមុខខ្ញុំថា: «លោកម្ចាស់អើយ
ខ្ញុំតានតឹងក្នុងចិត្តដោយសារតែនិមិត្តនេះ ខ្ញុំគ្មានកម្លាំងកំហែងទេ។[17]ខ្ញុំជាអ្នកបម្រើលោក។ តើធ្វើដូចម្តេចឱ្យខ្ញុំអាចនិយាយជាមួយជាមួយម្ចាស់ខ្ញុំបានទៅ?
ត្បិតពេលនេះខ្ញុំគ្មានកម្លាំងទេ ហើយក៏គ្មានទាំងខ្យល់ដង្ហើមនៅក្នុងខ្ញុំដែរ»។
[18]ម្តងទៀតម្នាក់ដែលមានសណ្ឋានដូចមនុស្ស បានប៉ះខ្ញុំហើយចម្រើនកម្លាំងខ្ញុំ។[19]លោកបាននិយាយថា «កុំខ្លាចអី មនុស្សដែលមានតម្លៃដ៏អស្ចារ្យអើយ។
សូមឲ្យសេចក្តីសុខសាន្តមានដល់លោក! សូមឲ្យមានមានកម្លាំងពេលនេះ ចូរឲ្យមានកម្លាំងចុះ!» ខណៈដែលលោកកំពុងតែនិយាយមកកាន់ខ្ញុំ នោះខ្ញុំស្រាប់តែមានកម្លាំង។
ខ្ញុំក៏និយាយថា «សូមលោកម្ចាស់មានប្រសាសន៍ចុះ ត្បិតលោកបានចម្រើនកម្លាំងដល់ខ្ញុំហើយ»។
[20]លោកបានថ្លែងថា «តើលោកដឹងទេថា ហេតុអ្វីបានជាខ្ញុំមកជួបលោកដូច្នេះ? ត្បិតខ្ញុំនឹងត្រឡប់ទៅប្រយុទ្ធនឹងទេវតាដែលជាម្ចាស់នៃនគរពើស៊ី។ នៅពេលខ្ញុំចេញទៅ
នោះទេវតាដែលជាម្ចាស់នៃក្រិកនឹងចេញមក។[21]តែខ្ញុំនឹងប្រាប់លោកនូវសេចក្តីពិតដែលមានចែងក្នុងសៀវភៅនៃសេចក្តីពិត។
នឹងគ្មានអ្នកណាដែលខ្លាំងហើយនៅជាមួយខ្ញុំដើម្បីនឹងតយុទ្ធជាមួយនឹងពួកវាឡើយ គឺមានតែមីកែលដែលជាទេវតារបស់លោកប៉ុណ្ណោះ»។

generated on Wed Sep 10 16:16:32 2025

Daniel 10:1

នៅឆ្នាំទីបីនៃរជ្ជកាលរបស់ព្រះចៅស៊ីរូស ជាស្តេចនៃស្រុកពើស៊ី

«ឆ្នាំទី៣នៃការសោយរាជ្យរបស់ព្រះចៅស៊ីរូស ជាស្តេចនៃស្រុកពើស៊ី»

បានបើកសម្តែងឲ្យដានីយ៉ែល

ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានបើកសម្តែងឲ្យដានីយ៉ែល»

បាននិមិត្តឃើញ

«បានយល់ពីអត្ថន័យ»

Daniel 10:2

មិនបានទទួលទានអាហារដ៏ឆ្ងាញ់ឡើយ

ទាំងនេះជាអាហារថ្លៃៗ ឬកម្រ។ ការបកប្រែរបៀបផ្សេងទៀត: «អាហារឆ្ងាញ់»

រហូតដល់គ្រប់បីអាទិត្យ

«គឺរហូតដល់បីអាទិត្យ»

Daniel 10:4

នៅថ្ងៃទីម្ភៃបួននៃខែទីមួយ

ថ្ងៃទីបួននៃខែទីមួយ - នេះគឺជាខែទីមួយនៃហេព្រើរប្រតិទិន។ នៅថ្ងៃទីម្ភៃបួនគឺនៅជិតពាក់កណ្តាលខែមេសាតាមប្រតិទិនលោកខាងលិច។

និង ក្រវ៉ាត់ចង្កេះ

«ហើយលោកបានពាក់ខ្សែក្រវ៉ាត់»

អ៊ូផាស

អ៊ូផាសគឺជាទីកន្លែង។ ជាកន្លែងមួយដែលយើងមិនស្គាល់

ខ្លួនប្រាណលោកមើលទៅដូចជាត្បូងបេរីល

រូបកាយរបស់លោកមានពន្លឺខ្សោយ ជាមួយពណ៌ខៀវ ឬពណ៌លឿង ហើយភ្លឺដូចជាជាត្បូងបេរីល។ ការបកប្រែរបៀបផ្សេងទៀត: «រូបកាយរបស់លោកមានពន្លឺខ្សោយដូចជាត្បូងបេរីល»

ត្បូងបេរីល

មានពន្លឺខ្សោយ ជាមួយពណ៌ខៀវ ឬពណ៌លឿង ដែលស្គាល់ថាជាកណ្តៀង ជាត្បូងខៀវ ឬមរតក

ហើយមុខលោកចាំងដូចផ្លេកបន្ទោរ

មុខរបស់លោកចាំងដូចផ្លេកបន្ទោរ ដែលបានចាំងចេញមក។ ការបកប្រែរបៀបផ្សេងទៀត: «មុខរបស់គាត់ចាំងពន្លឺជាមួយភ្លើងដែលភ្លឺចាំងដូចផ្លេកបន្ទោរ»

រឹងភ្នែកវិញដូចជា គប់ភ្លើងដែលឆេះ

ភ្នែករបស់លោកភ្លឺជាមួយនិងភ្លើង ហើយពួកវាទាំងពីរចាំងដូចភ្លើងឆេះ។ ការបកប្រែរបៀបផ្សេងទៀត: «ភ្នែករបស់គាត់ចាំងពន្លឺជាមួយភ្លើងដែលភ្លឺចាំងដូចជាភ្លើងកំពុងតែឆេះ»

ដៃហើយនិងជើងរបស់លោក ដូចជាលង្ហិនដែលគេខាត់យ៉ាងរលោង

ដៃហើយនិងជើងរបស់លោក ដូចជាលង្ហិនដែលគេខាត់យ៉ាងរលោង។ ការបកប្រែរបៀបផ្សេងទៀត: «ដៃហើយនិងជើងរបស់លោក ដូចជាលង្ហិនដែលគេខាត់យ៉ាងរលោង ហើយមានភ្លើងជះចាំងនៅជុំវិញវាផង»

សម្លេងលោកឮត្រហឹងអឺងកងប្រៀបបានទៅនឹងសម្លេងហ្វូងមនុស្ស

សម្លេងលោកឮត្រហឹងអឺងកងប្រៀបបានទៅនឹងសម្លេងហ្វូងមនុស្សដូចជាក្រុមមនុស្សកំពុងប្រជុំគ្នា។ ការបកប្រែរបៀបផ្សេងទៀត: «សម្លេងរបស់លោកឮខ្លាំងដូចជាហ្វូងមនុស្សដ៏ធំដែលបានមកជុំគ្នា»

Daniel 10:7

សល់តែខ្ញុំម្នាក់ឯងដែលបានឃើញ

ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ «គ្មានអ្នកណានៅជិតខ្ញុំទេពេលដែលខ្ញុំបានឃើញ»

ខ្ញុំទន់ដៃទន់ជើងគ្មានកម្លាំងកំហែង មុខខ្ញុំក៏ស្លេកស្លាំង

ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ «មុខមាត់របស់ខ្ញុំបានប្រែទៅជាស្លេកស្លាំង»

មុខខ្ញុំក៏ស្លេកស្លាំង

នេះគឺជាការពណ៌នាអំពីមុខរបស់អ្នកណាម្នាក់ដែលមិនមានសុខភាពល្អ។ ការបកប្រែរបៀបផ្សេងទៀត: «សុខភាពរបស់ខ្ញុំ មើលឃើញតាមរយៈមុខ»

គ្មានកម្លាំងកំហែង

នេះគឺជាការពណ៌នាអំពីម្នាក់ដែលមិនមានសុខភាពល្អ

មុខស្លេកស្លាំងគឺដូចជាអាគារដែលត្រូវបានបំផ្លាញ។ ការបកប្រែរបៀបផ្សេងទៀត: «ស្លេកស្លាំង»

ខ្ញុំបានឮសម្លេងលោកនិយាយ

នេះគឺជាការឮសម្លេងអ្នកណាម្នាក់និយាយនៅក្នុងនិមិត្ត។ ការនេះគឺបានឮយ៉ាងច្បាស់។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានឮសម្លេងអ្នកណាម្នាក់កំពុងនិយាយ»។

ខ្ញុំលង់ស្មារតី ហើយខ្ញុំក៏ក្រាបមុខចុះដល់ដី

ពាក្យដែលអាចបកប្រែបានគឺ ១) ដានីយ៉ែលបានភ័យខ្លាចនៅអ្វីដែលបានឃើញ ដូច្នេះហើយបានជាគាត់ដេកទៅដល់ដី នៅកន្លែងដែលកាត់បានសន្លប់ឬ ២) ដានីយ៉ែលបានសន្លប់ហើយដេកទៅដល់ដី។

Daniel 10:10

ដៃលោកបានពាល់ខ្ញុំ

នេះគឺបង្កប់ន័យក្នុងការប្រៀបធៀប

នៅពេលមានដៃរបស់អ្នកណាម្នាក់មកបះអ្នកផ្សេងទៀត

នេះគឺជាមនុស្សដែលដានីយ៉ែលបានឃើញនៅក្នុងជំពូក ១០:៤។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកណាម្នាក់បានបះខ្ញុំដោយដៃរបស់គាត់»

ដានីយ៉ែលអើយ លោកជាទីគាប់ព្រះហឫទ័យ

ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ដានីយ៉ែលអើយ លោកជាទីគាប់ព្រះហឫទ័យ»

ជាទីគាប់ព្រះហឫទ័យ

ដែលមានតម្លៃ និងសេចក្តីស្រឡាញ់

Daniel 10:12

ដែលលោកចង់យល់ពីហេតុការណ៍នោះ

«អ្នកមានសេចក្តីប្រាថ្នាដើម្បីឲ្យបានយល់ដល់និមិត្ត»

បានឮពាក្យរបស់លោក

ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានឮពាក្យរបស់លោក»

ម្ចាស់

ពាក្យនៅទីនេះសំដៅទៅលើអំណាចនៃវិញ្ញាណ ដែលនៅលើប្រជាជាតិ។ ការបកប្រែរបៀបផ្សេងទៀត: «វិញ្ញាណគ្រប់គ្រង»

ស្តេចពើស៊ី

នេះប្រហែលជាសំដៅទៅលើស្តេច ដែលគ្រប់គ្រងនៅលើប្រជាជាតិនៅក្នុងចក្រភពពើស៊ី ហើយជាអ្នកដែលបានស្តាប់បង្គាប់ស្តេចរបស់ពើស៊ីដែរ។

មីកែល ដែលជាទេវតាដ៏សំខាន់នៃពួកទេវតា

«មីកែលគឺជាមេលើពួកទេវតា» ឬ «មីកែល ជាម្ចាក់នៃអ្នកទេវតាចម្បាំង»

Daniel 10:14

ព័ត៌មានទូទៅ:

ទេវតាបានបន្តថ្លែងទៅកាន់លោកដានីយ៉ែល។

ពាក្យទាំងនោះ ខ្ញុំក៏ក្រាបមុខចុះ

«ខ្ញុំបានសម្លឹងទៅដី»។ ដានីយ៉ែលគួរតែបានធ្វើការនេះដើម្បីបង្ហាញពីការគោរព ឬ ដោយសារលោកមានការភ័យខ្លាច។

Daniel 10:16

លោកម្នាក់មានរូបរាងដូចមនុស្ស

[illegible] ដែលបាននិយាយទៅកាន់លោកដានីយ៉ែល។ ទោះបីជាយ៉ាងណាដ៏ដោយ ការបកប្រែថ្មីក៏បានសំដៅទៅមនុស្សផ្សេង។ ការបកប្រែរបៀបផ្សេងទៀត: «ម្នាក់នេះមានរូបរាងដូចជាមនុស្ស»

ដូចជាកូនមនុស្ស

នៅទីកន្លែងគឺសម្តែងចេញពីភាពជាមនុស្សទូទៅ។ ការបកប្រែរបៀបផ្សេងទៀត: «ដូចជាមនុស្ស»

តានតឹងក្នុងចិត្ត

គឺមានអារម្មណ៍ឈឺចាប់

ខ្ញុំជាអ្នកបម្រើទ្រង់ ធ្វើដូចម្តេចឱ្យហ៊ាននិយាយជាមួយនឹងលោកម្ចាស់បានទៅ?

ដានីយ៉ែលទូលសូមការទាំងនេះ

មានន័យថាលោកមិនអាចនិយាយបានទៅកាន់ទេវតា ដោយព្រោះលោកមិនស្មើជាមួយនឹងទេវតាឡើយ។ ប្រយោគទាំងនេះអាចរួមគ្នាបាន។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំមិនអាចឆ្លើយនឹងលោកបានទេ ដោយខ្ញុំគ្រាន់តែជាអ្នកបម្រើប៉ុណ្ណោះ»

ហើយក៏គ្មានទាំងខ្យល់ដង្ហើមទៀត

ការប្រៀបធៀបនេះសំដៅទៅលើដង្ហើម។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំមិនអាចដកដង្ហើមបានទេ» ឬ «វាពិបាកដកដង្ហើមណាស់» .

Daniel 10:18

generated on Wed Sep 10 16:16:32 2025

ម្នាក់ដែលមានសណ្ឋានដូចមនុស្ស
«គឺជាអ្នកដែលមើលទៅដូចជាមនុស្ស»
សូមឲ្យលោកមានកម្លាំងឡើង
ពាក្យថា «ចូលឲ្យមានកម្លាំងឡើង» ត្រូវបានធ្វើម្តងទៀតសម្រាប់ដើម្បីបញ្ជាក់។
គាប់ព្រះហឫទ័យនឹងលោក
ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកគឺជាអ្នកដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ»
នោះខ្ញុំស្រាប់តែមានកម្លាំងឡើងវិញ
ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំក៏បានទៅជាមានកម្លាំងឡើងវិញ»
Daniel 10:20
ដែលជាម្ចាស់នៃនគរពើស៊ី
ពាក្យថា «ម្ចាស់» សំដៅទៅខាងឯវិញ្ញាណ
ដែលវាបានគ្រប់គ្រងនៅយាមមនុស្សជាតិ។
សូមមើលពីការបកប្រែដែលស្រដៀងគ្នានៅក្នុងជំពូក ១០:១២។
ការបកប្រែរបៀបផ្សេងទៀត: «គឺជាវិញ្ញាណដែលគ្រប់គ្រងនៅលើពើស៊ី»
តែខ្ញុំនឹងពន្យល់ប្រាប់លោក
ការនេះមានន័យថាទេវតា និងប្រាប់លោកដានីយ៉ែលភ្លាមៗ
មុនពេលលោកនឹងចាក់ចេញទៅនោះ។ ការបកប្រែរបៀបផ្សេងទៀត: «ជាដំបូង
យើងនឹងប្រាប់ដល់អ្នក»
នូវសេចក្តីពិតដែលមានចែងក្នុងក្រាំង
ការនេះអាចនិយាយនៅក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលសៀវភៅនៃសេចក្តីពិតបាននិយាយ» ឬ
«អ្នកណាបានសរសេរអ្វីដែលសៀវភៅនៃសេចក្តីពិតនេះ»
នរណានិងជួយខ្ញុំដើម្បីនឹងតយុទ្ធ
«អ្នកដែលបង្ហាញថាខ្លួនឯងខ្លាំង»
ពុំមាននរណានិងជួយខ្ញុំដើម្បីនឹងតយុទ្ធជាមួយនឹងពួកទាំងនោះឡើយ
មានតែមីកែលដែលជាទេវតារបស់លោកប៉ុណ្ណោះ
«មីកែលជាម្ចាស់របស់លោកតែម្នាក់គត់ដែលបង្ហាញថាមានកម្លាំងអាចនឹងទាស់ជាមួយពួកគេបាន» ឬ
«មីកែលម្ចាស់របស់លោកតែម្នាក់គត់ដែលជួយឲ្យខ្ញុំអាចនឹងទាស់ជាមួយពួកគេបាន»
មីកែលដែលជាទេវតារបស់លោក
ពាក្យថា «របស់អ្នក» គឺជាពហុវចនៈ។ វាគឺសំដៅទៅលោកដានីយ៉ែល
និងប្រជាជនអ៊ីស្រាអែលទាំងមូល» ការបកប្រែរបៀបផ្សេងទៀត: «មីកែល
ជាព្រះជាម្ចាស់នៃប្រជាជនរបស់អ្នក»
មីកែលដែលជាទេវតារបស់លោក
«មីកែលគឺជាទេវតាដែលដឹកនាំ»។ បកប្រែថា «ម្ចាស់»
នៅពេលដែលនិយាយអំពីមីកែលដូចដែលអ្នកបានធ្វើនៅក្នុងជំពូក ១០:១២។

---

11 [1]នៅឆ្នាំទីមួយនៃរជ្ជកាលរបស់ព្រះចៅដារីយុសជាជនជាតិមែឌី ខ្ញុំខ្លួនឯងបានមកជួយនិងការពារទេវតាមីកែល។[2]ពេលនេះខ្ញុំនឹងប្រាប់លោកពីការពិត។
នឹងមានស្តេចបីអង្គនឹងឡើងសោយរាជ្យនៅលើពើស៊ី ហើយស្តេចទីបួននឹងមានទ្រព្យសម្បត្តិហូរហៀរជាងស្តេចផ្សេង។នៅពេលដែលស្តេចនោះកាន់តែមានអំណាច
តាមរយៈទ្រព្យសម្បត្តិរបស់ស្តេចហើយស្តេចនោះនឹងលើកគ្នាមកទាស់ប្រឆាំងនឹងអាណាចក្រក្រិក។
[3]នឹងមានស្តេចមួយអង្គដែលខ្លាំងពូកែ នឹងឡើងគ្រងរាជ្យ លើអាណាចក្រដ៏អស្ចារ្យ ហើយស្តេចនោះឯងនឹងប្រព្រឹត្តអ្វីតាមតែអំពើចិត្តខ្លួន។
[4]ដល់ពេលដែលស្តេចនោះបានឡើងគ្រងរាជ្យហើយ នគរនោះនឹងត្រូវបាក់បែក ហើយបែងចែងជាបួនទិសខ្យល់នៃស្ថានសួគ៌ តែពុំបានបែងចែកសម្រាប់ពូជពង្សស្តេចទេ
ហើយស្តេចមិនបានគ្រប់គ្រងដោយអំណាចទ្រង់ដែរ។ ត្បិតរាជ្យរបស់ស្តេចនេះនឹងត្រូវគេផ្តួលរំលំ ហើយធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកផ្សេងវិញ
[5]ស្តេចនៅទិសខាងត្បូងនឹងមានកម្លាំងខ្លាំង ប៉ុន្តែមានមេទ័ពមួយរបស់ស្តេចដែលមានខ្លាំងពូកែជាងទ្រង់ទៅទៀត
ដែលនឹងឡើងគ្រប់គ្រងអាណាចក្ររបស់ស្តេចជាមួយនិងអំណាចក៏អស្ចារ្យ។[6]ហើយប៉ុន្មានឆ្នាំក្រោយមក ដល់ពេលកំណត់មកដល់ ពួកគេនឹងចងសម្ព័ន្ធនឹងគ្នា។
គឺបុត្រីរបស់ស្តេចអាណាចក្រខាងត្បូងនឹងទៅជួបស្តេចអាណាចក្រខាងជើង ដើម្បីបញ្ចាក់ពីកិច្ចព្រមព្រៀងនេះ។ ប៉ុន្តែនាងមិនអាចរក្សាអំណាចបានគង់វង្សទេ
ទាំងរាជវង្សស្តេចខាងជើងក៏មិនស្ថិតស្ថេរដែរ។ នាងនឹងត្រូវគេបោះបង់ចោលទាំងអ្នកហែហមនាង បិតានាង និងអស់អ្នកដែលគាំទ្រនាងនៅក្នុងពេលនោះផង។
[7]ប៉ុន្តែនឹងមានស្តេចមួយអង្គកើតចេញពីត្រកូលរបស់នាងនឹងឡើងស្នងរាជ្យជំនួសនាង។ ស្តេចនោះនឹងលើកទ័ពទៅច្បាំងនឹងបន្ទាយស្តេចខាងជើង។
ស្តេចនោះនឹងប្រយុទ្ធនិងពួកគេ ហើយដណ្តើមជ័យជម្នះលើពួកគេផងដែរ។[8]ស្តេចនឹងនាំយកទៅអេស៊ីុបគឺព្រះរបស់ពួកគេ និង រូបសិតទាំងប៉ុន្មាន
ព្រមទាំងរបស់មានតម្លៃធ្វើពីប្រាក់នឹងមាស។ ត្បិតប៉ុន្មានឆ្នាំនោះស្តេចនេះនឹងនៅឲ្យឆ្ងាយពីស្តេចខាងជើង។[9]រួចមកស្តេចខាងជើងក៏ឈ្លានពានចូលអាណាចក្រខាងត្បូង
តែទីបំផុតស្តេចក៏ត្រូវត្រឡប់មកទឹកដីខ្លួនវិញ។
[10]បុត្រាទាំងនោះរបស់ស្តេចប្រុងប្រៀបនិងប្រមូលកម្លាំងទ័ពយ៉ាងច្រើនឲ្យបានច្រើន។ កងទ័ពទាំងនោះក៏ចេញទៅដូចជាទឹកជំនន់ហើយហូរយកគ្រប់យ៉ាងទៅជាមួយ
វានឹងហូរកាត់ផ្លូវទាំងអស់រហូតដល់បន្ទាយរបស់គេ។
[11]រួចហើយស្តេចនៃអាណាចក្រខាងត្បូងនឹងត្រឡប់ទៅជាខ្ញាល់យ៉ាងខ្លាំង ហើយស្តេចនឹងចេញទៅហើយច្បាំងទាស់ប្រឆាំងជាមួយទ្រង់
ហើយស្តេចនៃអាណាចក្រខាងជើង។ ស្តេចនៃអាណាចក្រខាងជើងបានលើកទ័ពជាច្រើន តែទីបំផុតក៏ត្រូវធ្លាក់ក្នុងកណ្តាប់ដៃរបស់ស្តេចខាងត្បូង។
[12]ពួកទ័ពនឹងបាននាំចេញទៅ ហើយព្រះហឫទ័យស្តេចក៏បានលើកឡើង ហើយសម្លាប់ពួកគេរាប់ម៉ឺនរាប់សែននាក់ តែស្តេចនេះនៅតែមិនអាចយកជ័យជម្នះបានទេ។
[13]រួចហើយស្តេចខាងជើងក៏បានលើកទ័ពក្រុមផ្សេងទៀត ទ័ពនេះគឺធំជាងលើកមុន។ ប៉ុន្មានឆ្នាំក្រោយមក ស្តេចខាងជើងនឹងលើកទ័ពយ៉ាងធំ
រួមទាំងគ្រឿងសាស្ត្រាវុធជាច្រើនមកជាមួយផង។
[14]នៅពេលនោះមានមនុស្សជាច្រើនបានប្រឆាំងបះបោរនឹងស្តេចខាងត្បូង។ហើយកូនមនុស្សកំណាចនៅក្នុងចំណោមប្រជាជនរបស់អ្នកបានលើកគ្នាទាស់ប្រឆាំងដែរ
ដើម្បីឲ្យស្របតាមនិមិត្តនោះ ប៉ុន្តែពួកគេនឹងជំពប់ដួល។
[15]ស្តេចខាងជើងនឹងចូលមក ហើយលើកដីយ៉ាងខ្ពស់ជាពំនូក និងព័ទ្ធជុំវិញទីក្រុង ជាមួយនិងបន្ទាយ។ ពួកទ័ពរបស់ស្តេចខាងត្បូងមិនអាចឈរបាន សូម្បីតែ
ទ័ពខ្លាំងពូកែរបស់ពួកគេ។ ពួកគេអាចទប់ទល់បានដែរ។ ពួកគេពុំមានកម្លាំងតទល់ទៀតឡើយ។[16]ម៉្យាងវិញទៀត ស្តេចមួយអង្គដែលមកនឹងធ្វើអ្វីតាមតែអំពើចិត្ត
ទាស់ប្រឆាំងនឹងទ្រង់។ ហើយស្តេចនឹងឈរនៅលើទឹកដីដ៏ស្រស់ស្អាត ហើយការបំផ្លាញនឹងនៅក្នុងដៃទ្រង់។
[17]ស្តេចនៃអាណាចក្រខាងជើង បានតាំងព្រះភក្ត្រដើម្បីចូលទៅជាមួយនិងកម្លាំងនៃអាណាចក្រទាំងមូល
ហើយរួមជាស្តេចខាងត្បូងនឹងមានការព្រមព្រៀងថាស្តេចនឹងតាំងសម្ព័ន្ធជាមួយស្តេចខាងត្បូង។ ស្តេចនឹងលើកបុត្រីខ្លួនឲ្យធ្វើជាមហេសីស្តេចខាងត្បូង
ដើម្បីប្រើល្បិចបោកបញ្ឆោត។ ប៉ុន្តែផែនការនោះមិនបានជោគជ័យឬអាចជួយទ្រង់បានឡើយ។[18]បន្ទាប់មកស្តេចខាងជើងក៏បែរទៅតាមកោះផ្សេងៗ
ហើយវាយយកកោះទាំងនោះ។ តែមានមេទ័ពម្នាក់នឹងបញ្ឈប់ភាពអំនួតហើយអំនួតរបស់ស្តេច បានធ្លាក់មកលើទ្រង់វិញ។
[19]រួមហើយស្តេចបានបែរទៅមើលបន្ទាយនៅក្នុងទឹកដីរបស់ខ្លួនវិញ ប៉ុន្តែស្តេចនឹងត្រូវបរាជ័យ ហើយទ្រង់នឹងបាត់ខ្លួនផង។
[20]បន្ទាប់មកនឹងមានស្តេចមួយនឹងឡើងសោយរាជ្យជំនួសស្តេចនេះ នឹងចាត់តាំងអ្នកយកពន្ធម្នាក់ ដើម្បីរក្សាភាពថ្កុំថ្កើងរបស់អាណាចក្រ។
ប៉ុន្តែមិនយូរប៉ុន្មានរាជ្យស្តេចនេះនឹងត្រូវបាក់បែក តែមិនដោយសារកំហឹង ឬដោយចម្បាំងទេ។[21]មានម្នាក់ទៀតដែលនឹងឡើងសោយរាជ្យជំនួសស្តេចនេះ
ជាមនុស្សគួរឲ្យស្អប់ ជាស្តេចដែលគ្មាននរណាម្នាក់ប្រគល់រាជសម្បត្តិឲ្យស្តេចនេះឡើយ ហើយស្តេចនេះចូលមក ហើយដណ្តើមយករាជ្យដោយប្រើល្បិចកល។
[22]ពួកទ័ពនឹងត្រូវលាងសំអាតជាមួយនឹងទឹកជំនន់នៅចំពោះស្តេចនេះ។ ទ័ពទាំងពីរក្រុមនៃសម្ពន្ធមេត្រីនឹងត្រូវបានបំផ្លាញ។
[23]តាំងពីពេលដែលបានចងសម្ព័ន្ធភាពហើយ ស្តេចនោះកាន់តែមានឧបាយកល ហើយស្តេចនេះនឹងកាន់តែខ្លាំងឡើង ជាមួយមនុស្សមួយចំនួនតូច
ស្តេចនោះនឹងក្លាយទៅខ្លាំងពូកែ។[24]ដោយមិនមានការរំលឹកមុនទេស្តេចនេះក៏បានចូលទៅក្នុងកន្លែងដែលមានបំផុតនៃអាណាខេត្ត
ហើយស្តេចនេះប្រព្រឹត្តអ្វីៗដែលបុព្វបុរសទ្រង់មិនដែលបានប្រព្រឹត្តពីមុន។ ស្តេចបាននឹងផ្សព្វផ្សាយដល់អ្នកដើរតាមទ្រង់ពីជ័យភណ្ឌដែលប្លន់បាននិងទ្រព្យសម្បត្តិ។
ស្តេចនឹងមានផែនការដើម្បីវាយលុក យកបន្ទាយទាំងឡាយ តែបានតែមួយរយៈទេ។

generated on Wed Sep 10 16:16:32 2025

[25]ស្តេចនឹងខំព្រឹងប្រមូលកម្លាំង និងចិត្តទ្រង់ដើម្បីទាស់ប្រឆាំងនិងស្តេចខាងត្បូង ជាមួយកម្លាំងទ័ពដ៏ធំ។ ស្តេចខាងត្បូងនឹងបង្កសង្គ្រាមដ៏ធំមួយ
ជាមួយនិងទ័ពដែលខ្លាំងពូកែ ប៉ុន្តែស្តេចមិនអាចយកជ័យបានទេដោយសារស្តេចខាងជើងបានប្រើល្បិចកលទាស់នឹងស្តេចខាងត្បូង។
[26]ទោះបីអ្នកដែលបរិភោគអាហារជាមួយស្តេច នឹងបំផ្លាញស្តេចដែរ។ កងទ័ពរបស់ស្តេចនឹងត្រូវខ្ចាត់ខ្ចាយ ហើយពួកគេទាំងនោះជាច្រើនត្រូវដួលស្លាប់គ្មានសល់។
[27]ស្តេចទាំងពីរនោះ មានចិត្តអាក្រក់ចំពោះគ្នា ហើយអង្គុយចចារគ្នាទាំងមានល្បិចកលដាក់គ្នាដោយកុហកគ្នាទៅវិញទៅមក ប៉ុន្តែគ្មានប្រយោជន៍សោះឡើយ។
ត្បិតមិនទាន់ដល់ពេលវេលា ដែលបានកំណត់ឡើយ។
[28]បន្ទាប់មកស្តេចខាងជើងក៏ត្រឡប់ទៅទឹកដីខ្លួនវិញ ជាមួយនិងទ្រព្យសម្បត្តិយ៉ាងច្រើនផង ស្តេចនេះនៅតែមានចិត្តមានៈទាស់ប្រឆាំងនឹងសម្ពន្ធមេត្រីដ៏បរិសុទ្ធ។
ស្តេចធ្វើអ្វីតាមតែអំពើចិត្តរួចក៏ត្រឡប់ទៅទឹកដីខ្លួនវិញ។
[29]ដល់ពេលកំណត់មកដល់ស្តេចនឹងត្រឡប់ហើយទាស់ប្រឆាំងនឹងស្តេចខាងត្បូងម្តងទៀត។ ប៉ុន្តែលើកនេះមិនដូចពេលមុនៗទេ។
[30]ត្បិតនឹងមាននាវាមកពីស្រុកគីទីមមកទាស់នឹងទ្រង់ ហើយធ្វើឲ្យស្តេចភ័យខ្លាចរួចដកថយទៅវិញ។ ស្តេចនឹងក្រៀវក្រោធចំពោះសម្ពន្ធមេត្រីដ៏បរិសុទ្ធ
ហើយទ្រង់នឹងផ្តល់គុណដល់អ្នកដែលក្បត់សម្ពន្ធមេត្រីដ៏វិសុទ្ធ។
[31]ពួកកងទ័ពដែលស្ថិតនៅក្រោមបញ្ជារបស់ស្តេចនឹងនាំគ្នាមើលងាយបន្ទាយនៃទីសក្ការៈ។ ពួកគេនឹងដកយកថ្វាយដង្វាយដុត
ហើយពួកគេនាំយករបស់ដែលជាទីស្អប់ខ្ពើមមកតាំងជំនួសវិញ។[32]ត្បិតអស់អ្នកដែលប្រព្រឹត្តិអំពើអាក្រក់ ទាស់នឹងសម្ពន្ធមេត្រីដ៏បរិសុទ្ធ ស្តេចនឹងបោកប្រាស់គេ
និងធ្វើឲ្យគេទៅជាអាក្រក់។ ប៉ុន្តែអស់អ្នកដែលស្គាល់ព្រះរបស់គេច្បាស់នឹងឈរមាំតយុទ្ធវិញ។
[33]អ្នកដែលមានប្រាជ្ញានៅក្នុងចំណោមប្រជាជននឹងជួយឲ្យមនុស្សជាច្រើនបានយល់ដឹងដែរ។ ប៉ុន្តែពួកគេត្រូវដួលចុះដោយដាវ ហើយអណ្តាតភ្លើង:
ពួកគេធ្លាក់ចុះទៅធ្វើជាឈ្លើយ ហើយក៏ត្រូវប្លន់យកទ្រព្យសម្បត្តិ។[34]នៅក្នុងពេលពួកគេដួលចុះ ហើយពួកគេមកជួយពួកគេខ្លះដែរ។
ពួកមនុស្សលាក់ពុតជាច្រើនបានចូលរួមជាមួយពួកគេ។[35]អ្នកប្រាជ្ញទាំងនោះនឹងត្រូវដួលចុះ ដើម្បីឲ្យបានជំរះនឹងកើតឡើងដល់គេ និងសម្អាត់ ហើយបានបរិសុទ្ធផង
រហូតដល់ពេលចុងក្រោយ។ ត្បិតវេលានោះត្រូវតែមកដល់តាមការកំណត់។
[36]ស្តេចនោះនឹងធ្វើតាមតែអំពើចិត្តរបស់ទ្រង់។ ស្តេចបានតម្កើងខ្លួនឡើង ហើយតាំងខ្លួនលើសខ្ពស់ជាងព្រះ។ ហើយប្រឆាំងទាស់នឹងព្រះជាម្ចាស់លើអស់ទាំងព្រះ
ហើយស្តេចនឹងពោលអ្វីដែលភ្ញាក់ផ្អើល ត្បិតទ្រង់នឹងជោគជ័យគ្រប់កិច្ចការរហូតទាល់តែព្រះពិរោធបានកើតឡើង។
ត្បិតរាជសារដែលបានប្រកាសនឹងត្រូវតែបានសម្រេច។[37]ស្តេចនឹងមិនខ្វល់ដល់ព្រះដែលបុព្វបុរសទ្រង់ធ្លាប់គោរព ឬព្រះដែលអស់ពួកស្ត្រីគោរពប្រាថ្នាចង់បាន។
ស្តេចនឹងមិនខ្វល់ពីព្រះណាទាំងអស់។ ត្បិតទ្រង់បានតម្កើងខ្លួនលើសអស់ទាំងអ្វីៗទាំងអស់។
[38]ស្តេចនឹងគោរពព្រះដែលការពារបន្ទាយជំនួសឲ្យព្រះទាំងនេះ។ ជាព្រះដែលបុព្វបុរសស្តេចមិនដែលស្គាល់ ហើយស្តេចនឹងថ្វាយដោយមាស និងប្រាក់ ហើយត្បូង
រួមទាំងអំណោយដ៏មានតម្លៃផ្សេងទៀត។[39]ស្តេចនឹងវាយលុកយក បន្ទាយដែលរឹងមាំបំផុត ដោយពឹងអាងលើព្រះជនជាតិផ្សេង។
គឺជាអ្នកណាដែលបានទទួលស្គាល់ព្រះនោះ ស្តេចនឹងលើកតម្កើងខ្លាំង។ ស្តេចនឹងឲ្យពួកគេត្រួតត្រាលើប្រជាជនជាច្រើន នឹងចែកទឹកដីដល់ពួកគេទុកជារង្វាន់ផង។
[40]ដល់គ្រាចុងក្រោយ ស្តេចខាងត្បូងនឹងទៅច្បាំង។ ស្តេចខាងជើងនឹងលើកទ័ពទាស់ប្រឆាំងវិញដោយប្រើ រទេះច្បាំង ទ័ពសេះ និងនាវាចម្បាំងជាច្រើន។
ស្តេចនឹងសម្រុកចូលយ៉ាងសន្ធឹកសន្ធាប់ដូចជាទឹកជំនន់ ឆ្លងកាត់ទឹកដីទាំងមូល។[41]ស្តេចនឹងចូលទៅក្នុងទឹកដីដ៏ស្រស់ស្អាត
ហើយសាសន៍អ៊ីស្រាអែលរាប់ម៉ឺននាក់ត្រូវដួលចុះ។ ប៉ុន្តែពួកអ្នកទាំងនេះគេចផុតពីកណ្តាប់ដៃរបស់ស្តេច គឺជនជាតិអេដុម ជនជាតិម៉ូអាប់
និងពួកអ្នកដឹកនាំសំខាន់នៃជនជាតិអាំម៉ូន។
[42]ស្តេចនោះនឹងលូកដៃទៅទឹកដីនោះ ហើយទឹកដីអេស៊ីបក៏គេចមិនរួចដែរ។[43]ស្តេចនឹងកាន់កាប់លើទ្រព្យសម្បត្តិគឺ មាស និងប្រាក់
ហើយលើរបស់ទ្រព្យទាំងអស់ដែលមានតម្លៃនៅក្នុងអេស៊ីប ចំណែកជនជាតិលីប៊ី និងជនជាតិអេធីយ៉ូពីនឹងនឹងដើរតាមជំហាននោះដែរ។
[44]ប៉ុន្តែដំណឹងចេញពីទឹកដីខាងកើត និងខាងត្បូងបានធ្វើឲ្យស្តេចភិតភ័យជាខ្លាំង ហើយទ្រង់បានយាងចេញទៅទាំងក្រេវក្រោធ ដើម្បីបំផ្លាញ
ហើយញែកចេញកើម្បីសម្លាប់មនុស្សជាច្រើនផង។[45]ស្តេចនឹងតម្លើងពន្លាធ្វើជារាជដំណាក់នៅរវាងសមុទ្រ និងជិតភ្នំដ៏ស្រស់ស្អាតដ៏បរិសុទ្ធ។
ប៉ុន្តែជីវិតស្តេចនឹងដល់ទីបញ្ចប់របស់ទ្រង់ហើយ ដោយគ្មានអ្នកណាអាចជួយទ្រង់បានដែរ។

Daniel 11:1

ព័ត៌មានទូទៅ:

នៅក្នុងដានីយ៉ែលជំពូក ១១:១ រហូត ១២:៤

ម្នាក់ដែលបាននិយាយមកកាន់ដានីយ៉ែល នៅក្នុងជំពូក ១០

ប្រាប់លោកអំពីអ្វីដែលបានសរសេរក្នុងសៀវភៅនៃសេចក្តីពិត។

នេះអ្វីដែលលោកបាននិយាយថាពីអ្វីដែលអ្នកនឹងធ្វើ នៅក្នុងជំពូក ១០:២០។

នៅឆ្នាំទីមួយនៃរជ្ជកាលរបស់ព្រះចៅដារីយុស

ដារីយុសគឺជាស្តេចនៃមេឌី។ «ឆ្នាំទី ១»

គឺសំដៅទៅលើឆ្នាំដំបូងដែលទ្រង់គឺជាស្តេច។ ការបកប្រែរបៀបផ្សេងទៀត:

«នៅក្នុងឆ្នាំទីមួយនៃរជ្ជកាលរបស់ដារីយុស»

ស្តេចបីអង្គនឹងឡើងសោយរាជ្យនៅស្រុកពើស៊ី

«ស្តេចបីអង្គនឹងគ្រប់គ្រងលើពើស៊ី»

ស្តេចទីបួននឹងមានទ្រព្យសម្បត្តិហូរហៀរជាងស្តេចណាៗ

«បន្ទាប់ពីពួកគេជាស្តេចទីបួននឹងឡើងកាន់អំណាចដែលនឹងមានប្រាក់ច្រើនជាងស្តេចទីបីទាំងអស់»

អំណាច

អត្ថន័យដែលអាចមានគឺ ១) សិទ្ធអំណាចឬ ២) អំណាចយោធា។

ស្តេចនឹងធ្វើឱ្យមនុស្សម្នាក់ទាស់ប្រឆាំង

«គាត់នឹងបណ្តាលឲ្យអ្នករាល់គ្នាចង់ប្រយុទ្ធ»

Daniel 11:3

ព័ត៌មានទូទៅ:

ទេវតាបន្តនិយាយជាមួយដានីយ៉ែល។

ស្តេចមួយអង្គដែលខ្លាំងពូកែ

គំនិតនៃការក្រោកឈរឡើង ឬ

ឈរជារឿយៗត្រូវបានប្រើសម្រាប់អ្នកដែលក្លាយជាអ្នកមានអំណាច។

ការបកប្រែរបៀបផ្សេងទៀត: «ស្តេចដ៏ខ្លាំងពូកែមួយអង្គនឹងចាប់ផ្តើមសោយរាជ្យ»

គ្រងរាជ្យជាស្តេចដែលមានអំណាចខ្លាំងក្រៃ

អត្ថន័យដែលអាចមានគឺ ១) ទំហំនៃនគរនេះនឹងធំធេងណាស់ ឬ ២)

ដែលព្រះរាជានឹងសោយរាជ្យដោយអំណាចខ្លាំងក្លាបំផុត។

នគរនោះនឹងត្រូវបាក់បែក ហើយបែងចែង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«នគររបស់គាត់នឹងបែកបាក់និងបែងចែក» ឬ

«នគររបស់គាត់នឹងបែកជាចំណែកៗ»

បែងចែងជាបួនទិស

បកប្រែវាដូចនៅក្នុងជំពូក ៧: ១។

តែពុំបានបែងចែកសម្រាប់ពូជពង្សស្តេចទេ

គំនិតនៃការមិនត្រូវបានបែងចែក និងចែករំលែកត្រូវបានបញ្ជាក់នៅទីនេះ។

ការបកប្រែរបៀបផ្សេងទៀត:

«ប៉ុន្តែនឹងមិនត្រូវបានបែងចែកសម្រាប់កូនចៅរបស់គាត់» ឬ

«ប៉ុន្តែវានឹងមិនត្រូវបានចែករំលែកដោយកូនចៅរបស់គាត់ទេ»

ត្បិតរាជ្យរបស់ស្តេចនេះនឹងត្រូវគេផ្តួលរំលំ ហើយធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកផ្សេងវិញ

នគរនេះត្រូវបានគេនិយាយថា

វាជារុក្ខជាតិដែលនរណាម្នាក់បានបំផ្លាញដោយដកហូតវា។

គំនិតនេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

«អំណាចមួយទៀតនឹងដកហូតនិងបំផ្លាញនគររបស់ព្រះអង្គ

និងអ្នកផ្សេងទៀតដែលមិនមែនជាកូនចៅរបស់ព្រះអង្គ នឹងគ្រប់គ្រងលើនគរនេះ»

Daniel 11:5

ព័ត៌មានទូទៅ:

ទេវតាបន្តនិយាយជាមួយដានីយ៉ែល។

generated on Wed Sep 10 16:16:32 2025

មានមេទ័ពមួយរបស់ស្តេចដែលមានកម្លាំងខ្លាំងជាងទ្រង់ទៅទៀត
ដែលនឹងឡើងគ្រប់គ្រងអាណាចក្រមួយដែលខ្លាំងជាងអាណាចក្ររបស់ស្តេច
មេបញ្ជាការនៃស្តេចខាងត្បូងនឹងក្លាយជាស្តេចខាងជើង។
ពួកគេនឹងចងសម្ព័ន្ធនឹងគ្នា
ស្តេចខាងត្បូងនឹងចងសម្ព័ន្ធភាពជាមួយស្តេចខាងជើង។ សម្ព័ន្ធភាពនេះគឺជា
កិច្ចព្រមព្រៀងផ្លូវការមួយ ដែលប្រទេសទាំងពីរត្រូវអនុវត្តតាម។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចខាងត្បូង និងស្តេចខាងជើង
នឹងសន្យាធ្វើការជាមួយគ្នា»។
បុត្រីរបស់ស្តេចអាណាចក្រខាងត្បូងនឹងទៅ..ដើម្បីបញ្ជាក់ពីកិច្ចព្រមព្រៀងនេះ
ស្តេចខាងត្បូងនឹងអោយបុត្រីរបស់ព្រះអង្គរៀបការជាមួយស្តេចខាងជើង។
អាពាហ៍ពិពាហ៍នឹងបញ្ជាក់ពីកិច្ចព្រមព្រៀងរវាងព្រះមហាក្សត្រទាំងពីរ។
នាងមិនអាចរក្សាអំណាចបានគង់វង្សទេ... ក៏មិនស្ថិតស្ថេរដែរ
នៅទីនេះ «ដៃ» តំណាងឲ្យអំណាច។
នាងនឹងត្រូវគេបោះបង់ចោល
នេះហាក់ដូចជាសំដៅទៅលើផែនការសម្លាប់នាង និងអ្នកដែលបង្កើតសម្ព័ន្ធភាព។
ឃ្លានេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងបោះបង់នាងចោល»
Daniel 11:7
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
មានស្តេចមួយអង្គកើតចេញពីត្រកូល
ក្រុមគ្រួសារនេះត្រូវបានគេនិយាយដូចជាដើមឈើមួយ។ ឫសតំណាងឲ្យបុព្វបុរស
ហើយសាខាតំណាងឲ្យកូនចៅ។ ការបកប្រែរបៀបផ្សេងទៀត:
«កូនចៅរបស់ជីដូនជីតារបស់នាង» ឬ «កូនចៅម្នាក់របស់នាង»
កើតចេញ
ពាក្យថា «នាង» សំដៅទៅលើបុត្រីរបស់ស្តេចខាងត្បូងនៅក្នុងជំពូក ១១:៥។
ស្តេចនោះនឹងលើកទ័ពទៅច្បាំង
ពាក្យថា «គាត់»
គឺសំដៅទៅលើកូនចៅរបស់នាងហើយនៅទីនេះវាក៏សំដៅទៅលើកងទ័ពរបស់គាត់ដែរ។
ការបកប្រែរបៀបផ្សេងទៀត: «គាត់នឹងកងទ័ពរបស់គាត់
នឹងវាយប្រហារកងទ័ពរបស់ស្តេចខាងជើង»
ស្តេចនោះនឹងប្រយុទ្ធ
នៅទីនេះ «ពួកគេ» តំណាងឲ្យទាហាននៃកងទ័ពសត្រូវ។
ការបកប្រែរបៀបផ្សេងទៀត: «គាត់នឹងប្រយុទ្ធជាមួយពួកទាហានសត្រូវ»
តែទីបំផុតស្តេចក៏ត្រូវត្រឡប់មក
ពាក្យថា «គាត់» សំដៅទៅលើស្តេចខាងជើង។
Daniel 11:10
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
កូនប្រុសៗ
«បុត្រានៃស្តេចខាងជើង»
ប្រមូលកម្លាំងទ័ពយ៉ាងច្រើនសន្ធឹកសន្ធាប់
«ប្រមូលផ្តុំបុរសជាច្រើនដែលអាចប្រយុទ្ធនៅក្នុងសមរភូមិ»
ដូចជាទឹកជំនន់
ផ្លូវកងទ័ពធំគ្របលើដីនឹងដូចជាទឹកជំនន់។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងមានចំនួនច្រើនណាស់ដែលពួកគេនឹងគ្របដណ្តប់លើផ្ទៃដីទាំងអស់»
Daniel 11:11
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
រៀបទ័ពយ៉ាងច្រើនកុះករដែរ
«នឹងប្រមូលផ្តុំកងទ័ពដ៏អស្ចារ្យមួយ»
ត្រូវធ្លាក់ក្នុងកណ្តាប់ដៃរ
នៅទីនេះ «ដៃ» តំណាងឲ្យការគ្រប់គ្រងរបស់ស្តេចខាងត្បូង។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចនឹងប្រគល់កងទ័ពទៅស្តេចខាងត្បូង»
ដោយជ័យជម្នះធ្វើឱ្យ
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចខាងត្បូងនឹងចាប់យកកងទ័ពខាងជើង»
មានចិត្តអួតបំប៉ោង
ការលើកខ្លួនឡើងបង្ហាញពីគំនិតនៃការមានមោទនភាព។
ការបកប្រែរបៀបផ្សេងទៀត: «នឹងមានមោទនភាព»
ហើយសម្លាប់ពួកគេរាប់ម៉ឺនរាប់សែននាក់
ការធ្លាក់ចុះនេះតំណាងឱ្យការស្លាប់នៅក្នុងសមរភូមិ។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងអោយកងទ័ពរបស់គាត់សម្លាប់សត្រូវរបស់គាត់រាប់ពាន់នាក់» រឺ
«នឹងសំលាប់សត្រូវរបស់គាត់រាប់ពាន់នាក់»
រាប់ម៉ឺនរាប់សែននាក់
«រាប់ពាន់នាក់»
Daniel 11:13
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
លើកទ័ពយ៉ាងធំ រួមទាំងគ្រឿងសាស្ត្រាវុធជាច្រើនមកជាមួយផង
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទ័ពយ៉ាងធំ រួមទាំងគ្រឿងសាស្ត្រាវុធជាច្រើន»
Daniel 11:14
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
មនុស្សជាច្រើនប្រឆាំងបះបោរនឹងស្តេច
គំនិតទាំងនេះបានលើកឡើងដើម្បីបះបោរ។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សជាច្រើនប្រឆាំងបះបោរនឹងស្តេច»
មានមនុស្សកំណាចក្នុងចំណោមប្រជាជន
ការថ្លែងពីការអាក្រក់ដែលមនុស្សបានប្រព្រឹត្ត។
ពួកគេនៅតែមិនអាចសម្រេច
ពួកគេនឹងជំពប់ដួលដែលតំណាងឲ្យការធ្លាក់ចុះ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិនអាចជោគជ័យបានទេ»
Daniel 11:15
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
ស្តេចខាងជើងនឹង...ហើយលើកដី
«ស្តេចខាងជើង» នៅកន្លែងនេះគឺនិយាយដល់ក័ងទពដែលជាទាហានរបស់ស្តេច
ដែលជាពួកអ្នកបានព័ទ្ធជុំវិញភ្នំ។ ការបកប្រែរបៀបផ្សេងទៀត:
«ទាហានរបស់ស្តេចខាងជើងនឹងចាក់ដី ដើម្បីធ្វើជាឡោមព័ទ្ធជុំវិញ» (សូមមើល:|
Metonymy)
ស្តេចខាងជើងនឹងចូលមក
ពាក្យថា «ស្តេចខាងជើង» រួមបញ្ចូលជាមួយទាហានដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចខាងជើងនឹងចូលមក» (សូមមើល:|
Metonymy)
ហើយលើកដីយ៉ាងខ្ពស់ព័ទ្ធជុំវិញក្រុង
នេះសំដៅទៅលើការប្រមូលដីដើម្បីឱ្យទាហានឈានដល់កម្ពស់ជញ្ជាំងទីក្រុងដើម្បីវាយប្រហារពួកគេ។
ទាហាននិងទាសករនឹងដាក់ដីរលុងក្នុងកន្ត្រកដឹកទៅកន្លែងដែលត្រឹមត្រូវ
ហើយចាក់ដីនោះដើម្បីលើកភ្នំឡើង។
មានកំពែងយ៉ាងមាំ
ជញ្ជាំងហើយនិងអ្វីមួយដែលបានសង់ឡើងដើម្បីការពារទីក្រុង
ឬពីការវាយប្រហាររបស់ទាហានរបស់សត្រូវ
មិនអាចទប់ទល់បាន
ការនេះតំណាងឲ្យពីលទ្ធិភាពដើម្បីប្រយុទ្ធ។ ការបកប្រែរបៀបផ្សេងទៀត:
«វានឹងមិនអាចច្បាំងជាមួយនឹងពួកគេបានឡើយ» (សូមមើល:|Metonymy)
ស្តេចមួយអង្គដែលមកវាយលុកនឹងធ្វើអ្វីតាមតែអំពើចិត្ត
«ស្តេចដែលឈ្លានពាននឹងធ្វើតាមដែលចិត្តចង់បាន
ហើយទាស់នឹងស្តេចផ្សេងទៀត»
ស្តេចនឹងឈរនៅក្នុង
ការឈររបស់ស្តេចគឺតំណាងអោយការគ្រប់គ្រង។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចនោះនឹងចាប់ផ្តើមគ្រប់គ្រង» (សូមមើល:|Metonymy)
ស្រុកដ៏ស្រស់ស្អាត
ការនេះសំដៅទៅលើទឹកដីអ៊ីុស្រាអែល។
សូមមើលការបកប្រែរបស់អ្នកនៅក្នុងជំពូក ៨:៩។
ហើយបំផ្លាញអ្វីៗទាំងអស់ដោយដៃទ្រង់
ពាក្យថា «បំផ្លាញ» តំណាងអោយអំណាចដើម្បីបំផ្លាញ។ ដូចគ្នាដែរ
អំណាចដែលបំផ្លាញគឺនិយាយដល់អ្វីមួយ
ដែលអ្នកណាម្នាក់ដែលមានអំណាចនៅនឹងដៃ។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ស្តេចនឹងមានអំណាចក្នុងការបំផ្លាញគ្រប់យ៉ាង» (សូមមើល:|Metaphor)
Daniel 11:17
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
មានបំណងចូលទៅកាន់
«បំណង» (សូមមើល:|Idiom)
ជាមួយនឹងឫទ្ធិអំណាចដែលខ្លួនមាន
ការនេះសំដៅទៅលើអំណាចខាងកងទ័ព។ ការបកប្រែរបៀបផ្សេងទៀត:
«មកជាមួយនឹងអំណាចដែលទ្រង់មាន» (សូមមើល:|Metonymy)
នឹងលើកបុត្រីខ្លួន
នេះគឺជាពាក្យមិនល្អដោយនិយាយថា «មនុស្សស្រី»។ (សូមមើល:|Idiom)
ផែនការទ្រង់ត្រូវបរាជ័យ
«នឹងធ្វើឲ្យស្តេចដែលមកពីខាងជើងឈប់មានអំនួត»
បែរទៅមើលបន្ទាយនៅក្នុងស្រុករបស់ខ្លួនវិញ
«ធ្វើឲ្យស្តេចដែលមកពីខាងជើងបានឈឺចាប់
ពីព្រោះស្តេចបានមានអំនួតដល់អ្នកផ្សេង»
ស្តេចនឹងផ្ចង់ចិត្ត
«ស្តេចដែលមកពីខាងជើងនឹងយកចិត្តទុកដាក់»
គ្មាននណារកឃើញឡើយ
ការនេះគឺជារបៀបដែលនិយាយថាទ្រង់នឹងស្លាប់។
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចនឹងបាត់ទៅរហូត» ឬ «ទ្រង់នឹងស្លាប់» (សូមមើល:|Idiom និង|Active or Passive)
Daniel 11:20
ព័ត៌មានទូទៅ:
ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
ស្តេចមួយនឹងឡើងសោយរាជ្យជំនួស ស្តេច
លើកអ្នកណាម្នាក់ឲ្យធ្វើជាស្តេចជំនួសកន្លែងស្តេច
គឺមានន័យថាអ្នកនឹងឡើងសោយរាជ្យជំនួសស្តេចមុន។
ការបកប្រែរបៀបផ្សេងទៀត:
«មានម្នាក់នឹងឡើងធ្វើជាស្តេចនៅខាងជើងដែលជំនួសស្តេចមុន»
នឹងចាត់តាំងអ្នកចំរឹតពន្ធម្នាក់
អ្នកចំរឹតពន្ធនឹងទៅគ្រប់ទីកន្លែងដើម្បីបង្ខំឲ្យគេបង់ពន្ធ។
ការបកប្រែរបៀបផ្សេងទៀត: «បញ្ជូនអ្នកណាម្នាក់ដើម្បីយកពន្ធពីប្រជាជន»
ស្តេចនេះនឹងត្រូវបាក់បែក
ពាក្យថា «គាត់» សំដៅទៅលើស្តេច។ ការបាក់បែកសំដៅទៅលើការស្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចថ្មីនឹងស្លាប់»
តែមិនដោយសារកំហឹងទេ
ពាក្យដែលអាចបកប្រែបានគឺ ១) គ្មានអ្នកខឹងជាមួយនឹងស្តេចទេ ឬ២)
នោះគឺជាឱកាសដែលធ្វើឲ្យស្តេចស្លាប់ ហើយរក្សាជាការសម្ងាត់។
ជាមនុស្សគួរឲ្យស្អប់ ជាស្តេចដែលគ្មាននរណាម្នាក់ប្រគល់រាជសម្បត្តិឲ្យស្តេចនេះឡើយ
ប្រជាជននឹងបដិសេធមិនទទួលស្គាល់អ្នកនោះជាស្តេចឡើយ
ពីព្រោះអ្នកនេះមិនមែនជាកូនចៅរបស់ស្តេច។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សដែលប្រជាជនមើលងាយហើយមិនឲ្យតម្លៃធ្វើជាស្តេចនោះទេ»
មានមេទ័ពមួយដ៏ខ្លាំងពូកែមួយនឹងត្រូវចុះចាញ់ស្តេចនេះ
ការបញ្ជូនចេញតំណាងអោយការបំផ្លាញ។
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទាហានរបស់ស្តេចនោះនឹងកំទេចពួកទាហានដ៏ខ្លាំងពីមុនដែលបានរាំងមុខរបស់ពួកគេ»
ទាំងកងទ័ពនិងទាហាននៃសម្ពន្ធមេត្រីក៏នឹងត្រូវបំផ្លាញដែរ
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចនឹងបំផ្លាញទាំងកងទ័ពនិងទាហាននៃសម្ពន្ធមេត្រី»
អ្នកដឹកនាំនៃសម្ពន្ធមេត្រី
ឃ្លានេះសំដៅទៅលើអ្នកដែលបំពេញតួនាទីខាងសាសនាដ៏សំខាន់បំផុតដែលព្រះជាម្ចាស់បានតែងតាំង
នៃពួកមហាបូជាចារ្យ។
Daniel 11:23
ព័ត៌មានទូទៅ:
ព័ត៌មានទូទៅ: ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
តាំងពីពេលដែលបានចងសម្ព័ន្ធភាព
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលអ្នកគ្រប់គ្រងណាបានសាងសន្តិភាពជាមួយនឹងទ្រង់»
ពង្រីកទឹកដីយកទឹកដីដែលល្អនៅក្នុងអាណាខេត្ត
«នឹងចែកចាយទៅកាន់អ្នកដែលដើរតាមព្រះអង្គ»
គឺទ្រង់រឹបអូសយកទ្រព្យសម្បត្តិដែលប្លន់ទាំងប៉ុន្មាន
«គឺជារបស់ដែលមានតម្លៃ
ដែលស្តេចនឹងពួកទាហានបានយកមកពីប្រជាជនដែលបានចាញ់សង្គ្រាម»
Daniel 11:25
ព័ត៌មានទូទៅ:
ព័ត៌មានទូទៅ: ទេវតាបន្តនិយាយជាមួយដានីយ៉ែល។
ស្តេចនៅតែមានកម្លាំង និង ចិត្តក្លាហាន
អំណាច និងដួងចិត្ត
ចិត្ត
នេះបង្ហាញពីការលើកទឹកចិត្ត។
រួមទាំងកម្លាំងទ័ពធំ
«ជាមួយទាហានដ៏ធំអស្ចារ្យ ដែលស្តេចនឹងប្រមូលផ្តុំ»
មកតយុទ្ធជាមួយ
«នឹងធ្វើសង្គ្រាមទាស់នឹងទ្រង់»
មិនអាចយកជ័យបានទេ
មិនអាចតំណាងឲ្យការបរាជ័យបានទេ។ ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចដែលមកពីទិសខាងត្បូងនឹងត្រូវបរាជ័យ» ឬ
«ពួកទាហាននឹងត្រូវបែកខ្ញែកអស់ហើយ»
អ្នកដែលបរិភោគអាហារជាមួយស្តេច
ការនេះសំដៅទៅទីប្រឹក្សារបស់ស្តេច។
ជាទូទៅគឺអ្នកដែលជាទីប្រឹក្សាទុកចិត្តបំផុតទើបស្តេចឲ្យមករួមតុបរិភោគអាហារជាមួយនឹងស្តេច។
ការបកប្រែរបៀបផ្សេងទៀត: «ទីប្រឹក្សាដ៏ល្អរបស់ស្តេច»
កងទ័ពរបស់ស្តេចនឹងត្រូវខ្ចាត់ខ្ចាយ
ការបរាជ័យរបស់ពួកទាហានគឺជាការបាក់បែកមួយ
ដូចជាទឹកជំនន់ដែលបានហូរនាំយកទៅអស់។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកទាហាននឹងមកបំផ្លាញកងទ័ពរបស់ស្តេច» ឬ
«ពួកទាហាននឹងមកបំផ្លាញកងទ័ពរបស់ស្តេចដូចជាទឹកដែលបានហូរយកទៅអស់»
ពួកគេទាំងនោះជាច្រើនត្រូវដួលស្លាប់
ពាក្យថា «ដួល» គឺជាពាក្យដែលស្រដៀងទៅនឹងការស្លាប់នៅក្នុងសង្គ្រាម។ ដូច្នេះ
«ដួល» ហើយ «ស្លាប់» មានន័យមូលដ្ឋានដូចគ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកទាហានទាំងនេះបានស្លាប់ក្នុងសង្គ្រាមជាច្រើន»
មានគំនិតអាក្រក់ចំពោះគ្នា
ពាក្យថា «ចិត្ត» តំណាងឲ្យបំនងចិត្តរបស់មនុស្ស។
សេចក្តីប៉ងប្រាថ្នាត្រូវបានគេនិយាយនៅទីនេះដូចជាពួកគេជាវត្ថុដែលនរណាម្នាក់អាចកំណត់
ឬដាក់នៅក្នុងទីតាំងជាក់លាក់មួយ។ ការបកប្រែរបៀបផ្សេងទៀត:
«គឺជាល្បិចរៀបឡើងដើម្បីធ្វើអាក្រក់ដល់អ្នកណាម្នាក់»
ហើយអង្គុយចចារ
ការអង្គុយរួមតុជាមួយគ្នាគឺតំណាងឲ្យការជជែកគ្នាទៅវិញទៅមក។
ប៉ុន្តែគ្មានប្រយោជន៍សោះឡើយ
«តែការនិយាយរបស់ពួកគេនឹងមិនបានជួយអ្វីដល់ពួកគេទេ»
ត្បិតមិនទាន់ដល់ពេលបញ្ចប់តាមការកំណត់
ការនេះបានប្រាប់ថាកិច្ចប្រជុំរបស់ពួកគេមិនបានជោគជ័យឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «លទ្ធផលនៃសកម្មភាពរបស់ពួកគេនឹងកើតឡើង
នៅពេលដែលព្រះជាម្ចាស់បានកំណត់»
Daniel 11:28
យកទ្រព្យសម្បត្តិយ៉ាងច្រើនកុះករទៅជាមួយផង ស្តេចនេះនៅតែមានចិត្តមាន:ទាស់ប្រឆាំង
ការនេះសំដៅបំណងចិត្តរបស់ស្តេចដែលទាស់ជាមួយនឹងសម្ពន្ធមេត្រីនៅក្នុងអ៊ីស្រាអែល។
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ទ្រព្យ។
ស្តេចនឹងមានបំណងបំផ្លាញសម្ពន្ធមេត្រីដ៏បរិសុទ្ធ»
ចិត្តរបស់ស្តេច
ការនេះសំដៅទៅលើបំណងចិត្តរបស់ស្តេច។
ទាស់ប្រឆាំងនឹងសេចក្តីសញ្ញាដ៏បរិសុទ្ធ
ស្តេចមានបំណងចិត្តក្នុងការទាស់ទៅនឹងសម្ពន្ធមេត្រី
តំណាងឲ្យចិត្តដែលបញ្ឈប់ពួកអ៊ីស្រាអែលមិនឲ្យស្តាប់បង្គាប់ព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត:
«បញ្ឈប់ពួកអ៊ីស្រាអែលមិនឲ្យស្តាប់បង្គាប់សម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់»

generated on Wed Sep 10 16:16:32 2025

សេចក្ដីសញ្ញាដ៏បរិសុទ្ធ
ពាក្យថា «បរិសុទ្ធ» ពណ៌នាពីសម្ពន្ធមេត្រីដែលមានជាមួយអ៊ីស្រាអែល។ ត្រូវតែយកសម្ពន្ធមេត្រីទៅស្តាប់តាម ព្រោះថាវាមកពីព្រះជាម្ចាស់ផ្ទាល់។ ការបកប្រែរបៀបផ្សេងទៀត: «សម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ដែលអ៊ីុស្រាអែលទាំងអស់ត្រូវស្តាប់បង្គាប់»

ធ្វើអ្វីតាមតែអំពើចិត្ត
នេះគឺជាច្បាប់ដែលស្តេចត្រូវតែប្រព្រឹត្តនៅអ៊ីុស្រាអែល។ ការបកប្រែរបៀបផ្សេងទៀត: «ស្តេចនឹងធ្វើអ្វីដែលទ្រង់ចង់បាននៅអ៊ីុស្រាអែល»

Daniel 11:29

នាវាមកពីស្រុកគីទីមមកទាស់នឹងស្តេច
នាវាគឺតំណាងពីទាហានដែលបានចុះទៅលើទូក។ ការបកប្រែរបៀបផ្សេងទៀត: «នាវាមកពីស្រុកគីទីមមកទាស់នឹងស្តេចដែលចុះទៅលើទូក ហើយចម្បាំងជាមួយទាហានផ្សេង»

ស្រុកគីទីម
ការនេះសំដៅទៅលើអ្នកចុះទូកដែលនៅតាមកោះរបស់ស៊ីបដែលនៅតាមសមុទ្រមេឌីតេរ៉ាណេ

ស្តេចនឹងក្រៀវក្រោធ
«ស្តេចខឹងយ៉ាងខ្លាំង»

នឹងបង្ហាញក្តីមេត្តាដល់អ្នកទាំងនោះ
«នឹងប្រព្រឹត្តដោយមេត្តាដល់អ្នកទាំងនោះ» ឬ «នឹងជួយដល់អ្នកនោះ»

Daniel 11:31

ពួកកងទ័ពដែលស្ថិតនៅក្រោមបញ្ជា
«ទាហានរបស់ស្តេចបានលេចមក» ឬ «ទ័ពរបស់ស្តេចនឹងមកដល់»។ ពាក្យថា «របស់គាត់» សំដៅទៅលើស្តេចដែលមកពីខាងជើង។

បន្ទាយទីសក្ការៈ
«ទីសក្ការៈដែលមនុស្សបានប្រើសម្រាប់ជាបន្ទាយ»

ហើយដកមិនឲ្យមានការថ្វាយដង្វាយដុត
បានយកតង្វាយចេញពីការតំណាងអោយការការពារដល់ប្រជាជនពីតង្វាយនោះ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងបញ្ឈប់បូជាចារ្យពីថ្វាយតង្វាយដុតជាប់លាប់នោះផងដែរ»

ជាទីស្អប់ខ្ពើមមកតាំងជំនួសវិញ
នេះសំដៅទៅលើរូបចម្លាក់មួយដែលនឹងធ្វើឲ្យព្រះហារនេះក្លាយទៅជាទីសក្ការៈដែលនឹងធ្វើឲ្យព្រះវិហាររបស់ព្រះអង្គ។ ការបកប្រែរបៀបផ្សេងទៀត: «គឺជារូបព្រះដែលគួរស្អប់ខ្ពើម ដែលធ្វើអោយព្រះជាម្ចាស់បង្ខាំងព្រះវិហារ» ឬ «រូបព្រះដែលគួរស្អប់ខ្ពើមដែលធ្វើព្រះជាម្ចាស់បង្ខាំងព្រះវិហារទៅជាមិនស្អាត»

ប្រព្រឹត្តិទាស់ប្រឆាំងនឹងសេចក្ដីសញ្ញា
«ការអាក្រក់នៃការមិនស្តាប់បង្គាប់សម្ពន្ធមេត្រី»

ដែលប្រព្រឹត្តិទាស់ប្រឆាំង
«បញ្ចុះបញ្ចូលឲ្យពួកគេធ្វើអំពើអាក្រក់»

អ្នកដែលស្គាល់ព្រះរបស់គេ
ពាក្យថា «ស្គាល់» មានន័យថា «ត្រូវស្មោះត្រង់» ការបកប្រែរបៀបផ្សេងទៀត: «តើអ្នកណាដែលបានស្មោះត្រង់ជាមួយព្រះជាម្ចាស់របស់គេ»

នឹងឈរមាំតយុទ្ធវិញ
«នឹងត្រូវឈរឹងមាំ ហើយតបតនឹងពួកគេវិញ»

Daniel 11:33

ពួកគេត្រូវសម្លាប់
ពាក្យថា «សម្លាប់» តំណាងឲ្យបទពិសោធនៃការបរាជ័យរបស់ស្តេចមួយអង្គ ឬស្តេចផ្សេងទៀត រួមបញ្ចូលការស្លាប់របស់វាដែរ។

ពួកគេ
នេះសំដៅទៅលើពួកអ្នកដែលនៅក្នុងចំណោមអ៊ីស្រាអែល។

ដោយដាវ
ពាក្យថា «ដាវ» តំណាងអោយចម្បាំង ហើយនិងសង្គ្រាម។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងស្លាប់នៅក្នុងសង្គ្រាម»។

ដោយភ្លើង
ពាក្យថា «អណ្តាតភ្លើង» តំណាងឲ្យភ្លើង។ ការបកប្រែរបៀបផ្សេងទៀត: «ហើយដោយការដុតរហូតដល់ស្លាប់»

ត្រូវគេចាប់យកទៅ
«ធ្លាក់ទៅក្នុងភាពជាទាសករ»

ហើយក៏ត្រូវប្លន់
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ពួកសត្រូវរបស់គេនឹងប្លន់យកទ្រព្យរបស់ពួកគេដែរ»

ក៏មានអ្នកមកជួយពួកគេខ្លះដែរ
នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកផ្សេងទៀតនឹងផ្តល់ជំនួយបន្តិចបន្តួចដល់ពួកគេ»

ក៏មានមនុស្សជាច្រើនបានចូលរួមជាមួយពួកគេ
ការនេះសំដៅទៅលើអ្នកផ្សេង ដែលមកធ្វើជាចង់ជួយ គឺជាមនុស្សដែលមានប្រាជ្ញា តែមិនមែនមកដើម្បីជួយពួកគេដោយពិតប្រាកដនោះទេ។

ចូលរួមជាមួយពួកគេ
នៅទីនេះ «ចូលរួមជាមួយពួកគេ» តំណាងអោយ «មកជួយ»។ ការបកប្រែរបៀបផ្សេងទៀត: «នឹងមកដើម្បីជួយពួកគេ»

នឹងមានអ្នកខ្លះត្រូវស្លាប់
ពាក្យថា «ដួល» តំណាងអោយបទពិសោធការបរាជ័យរបស់ស្តេច ឬអ្នកផ្សេងរួមជាមួយការស្លាប់របស់វាផងដែរ។

ដើម្បីឲ្យខ្លួនបានសស្អាត ខ្លះឲ្យបានបរិសុទ្ធ
ពាក្យថា «ដូច្នោះហើយ» មានន័យថា «ជាមួយលទ្ធផលដែល»។ ការបកប្រែរបៀបផ្សេងទៀត: «ជាមួយនឹងលទ្ធផលដែលបានសម្អាតនឹងបានកើតឡើងដល់ពួកគេ»

ដើម្បីឲ្យខ្លួនបានសស្អាត ខ្លះឲ្យបានបរិសុទ្ធ រហូតគ្រាចុងក្រោយបានមកដល់ និងឥតខ្ចោះ
ពាក្យទាំងបីនេះគឺជាសកម្មភាពដែលថ្លែងចេញនៅទីនេះប្រសិនបើពួកគេមានអ្វី។ ទោះបីជាយ៉ាងណា ពួកគេត្រូវបានបង្ហាញពីសកម្មភាព គឺនៅក្នុងទម្រង់អកម្ម ឬជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ពួកគេនឹងសម្អាត បានស្អាត និងល្អឥតខ្ចោះ» ឬ «ការឈឺចាប់របស់ពួកគេនឹងបានសម្អាត ហើយបានឥតខ្ចោះផងដែរ»

ក្នុងចំណោមអ្នកប្រាជ្ញទាំងនោះក៏មានអ្នកខ្លះ នឹងមានអ្នកខ្លះត្រូវស្លាប់...រហូតគ្រាចុងក្រោយ
ការឈឺចាប់នេះនឹងបន្តរហូតដល់ពេលវេលាដែលព្រះជាម្ចាស់បានសម្រេចថាត្រូវបញ្ចាប់។

បានសស្អាត
ការនេះសំដៅទៅការឥតខ្ចោះនៃការចម្រាញ់ដែកដោយរំលាយវាក្នុងភ្លើង។ នៅពេលព្រះជាម្ចាស់ធ្វើឲ្យប្រជាជនកាន់តែស្មោះត្រង់ដល់ព្រះអង្គ ការនេះបាននិយាយអំពីអ្វីដែលពួកគេបានធ្វើជាដែកដែលកម្ទេចម្នាក់ធ្វើឲ្យវាទៅជាឥតខ្ចោះ

ធ្វើឲ្យព្រះវិហាររបស់ព្រះអង្គ
ការនេះសំដៅទៅដល់ធ្វើឲ្យមនុស្ស ទីកន្លែង ឬគោលបំណងដែលព្រះជាម្ចាស់បានប្រើក្នុងការញែកពួកគេចេញពីអំពើបាប ហើយនិងចេញពីអំពើអាក្រក់។ វានិយាយពីការអាក្រក់ដែលមិនស្អាត ដែលត្រូវរើចេញដោយការលាងសម្អាត។

ការឥតខ្ចោះ
គំនិតទាំងនេះស្រដៀងទៅនឹងការសម្រាំង ដែលបាននិយាយមុននេះបន្តិច។ ដែកដែលបានសម្រាំងក៏អាចធ្វើឲ្យទៅជាឥតខ្ចោះបានដែរ។

គ្រាចុងក្រោយ
«ថ្ងៃចុងក្រោយ» ឬ «ការចុងក្រោយនៃពិភពលោក»។ សូមមើលការបកប្រែនៅក្នុងជំពូក ៨:១៥។

គ្រានោះត្រូវតែមកដល់តាមការកំណត់
ពាក្យថា «ពេលកំណត់» បញ្ជាក់ថាព្រះបានកំណត់ពេលហើយ។ នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានកំណត់ពេលសម្រាប់អនាគតហើយ»

Daniel 11:36

ស្តេចនោះនឹងធ្វើអ្វីតាមតែអំពើចិត្ត
«ស្តេចនឹងធ្វើតាមអ្វីដែលទ្រង់ចង់បាន»

ស្តេច
នេះសំដៅទៅលើស្តេចដែលមកពីទិសខាងជើង។

ហើយតម្កើងខ្លួន ហើយតាំងខ្លួនជាធំឧត្តម
ឃ្លាថា «លើកទ្រង់ឡើង» និង «ធ្វើឲ្យទ្រង់អស្ចារ្យ» មានន័យដូចគ្នា ហើយបង្ហាញថាស្តេចនឹងមានមោទនភាព។

តម្កើងខ្លួន ហើយតាំងខ្លួន
ពាក្យនេះមានន័យថាមានមោទនភាពយ៉ាងខ្លាំង។

តាំងខ្លួនជាធំឧត្តម
ពាក្យនេះតំណាងអោយការសម្តែងចេញពីការដែលសំខាន់ និងមានអំណាច។

ត្បិតគ្រប់ហេតុការណ៍

generated on Wed Sep 10 16:16:32 2025

«រឿងគួរឱ្យខ្ពាច» ឬ «រឿងគួរឱ្យភ្ញាក់ផ្អើល»

រហូតទាល់តែព្រះពិរោធកើនដល់កម្រិត

ឃ្លានេះបង្ហាញថាព្រះអង្គកំពុងរក្សាកំហឹងរបស់គាត់រហូតដល់បន្ទប់ផ្ទុកទំនិញរបស់ទ្រង់ពេញហើយ
ព្រះអង្គបានត្រៀមខ្លួនដើម្បីធ្វើតាមវា។ ការបកប្រែរបៀបផ្សេងទៀត:
«រហូតដល់ព្រះជាម្ចាស់បានក្រោធជាមួយស្តេច» ឬ
«រហូតដល់ព្រះជាម្ចាស់បានក្រោធល្មមដល់ប្រព្រឹត្តទាស់ជាមួយស្តេច»

ព្រះជាម្ចាស់លើអស់ទាំងព្រះ

ការនេះសំដៅទៅដល់ព្រះជាម្ចាស់ដ៏ពិត។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ខ្ពស់លើទាំងអស់» ឬ «ព្រះជាម្ចាស់តែមួយ»

ព្រះដែលអស់ពួកស្ត្រីគោរព

នេះហាក់ដូចជាចង់សំដៅទៅលើព្រះមិនជឿ ដែលមានឈ្មោះថាតាមូស។
Daniel 11:38

បន្ទាយជំនួសឲ្យព្រះទាំងនោះ

ស្តេចគួរតែជឿថាព្រះក្លែងក្លាយអាចនឹងជួយដល់ស្តេចដើម្បីវាយប្រហារដល់បន្ទាយមនុស្សរបស់ព្រះ។
ការបកប្រែរបៀបផ្សេងទៀត: «ជាព្រះដែលរក្សាបន្ទាយ»

ជំនួសឲ្យព្រះទាំងនោះ

ពាក្យថា «ទាំងនេះ» សំដៅទៅលើព្រះដែលបាននិយាយនៅក្នុងជំពូក ១១:៣៦

នឹងចែកទឹកដីដល់ពួកគេទុកជារង្វាន់

អត្ថន័យដែលអាចមានគឺ ១) «ស្តេចនឹងបែងចែកដីដល់អ្នកដើរតាមជារង្វាន់» ឬ ២)
«ស្តេចក៏នឹងលក់ដីទៅឲ្យពួកអ្នកដើរតាមទ្រង់ដែរ»
Daniel 11:40

ដល់គ្រាចុងក្រោយ

«នៅថ្ងៃចុងក្រោយ» ឬ «គ្រាចុងក្រោយនៃពិភពលោក»។
សូមមើលការបកប្រែនៅក្នុងជំពូក ៨:១៥។

ស្តេចខាងត្បូង...ស្តេចខាងជើង

ឃ្លានេះគឺនិយាយពីស្តេច ហើយនិងទាហានរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចខាងត្បូង ហើយនិងទាហាន...ស្តេចខាងជើង
ហើយនិងទាហាន»

លើកទ័ពទាស់ប្រឆាំង

ការវាយប្រហារដ៏ឃោរឃៅជាមួយទាហាន គឺនិយាយអំពីព្យុះដែលបានកើតឡើង។
ការបកប្រែរបៀបផ្សេងទៀត: «នឹងវាយប្រហារស្តេចដូចជាខ្យល់ព្យុះដែរ» ឬ
«នឹងអំពើឃោរឃៅវាយប្រហារស្តេច»

ទឹកជំនន់

នៅពេលទាហានរត់ចូលយ៉ាងខ្លាំងនៅក្នុងស្រុកនោះ វាគឺនិយាយពីទឹកហូរជន់។
សូមមើលការបកប្រែនៅក្នុងជំពូក ១១:១០។

ឆ្លងកាត់

គ្មានអ្វីដែលអាចបញ្ឈប់ទាហាននោះបានទេ។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងឆ្លងកាត់ទឹកដីហើយគ្មានអ្នកណាអាចបញ្ឈប់គេបានទេ»

ស្រុកដ៏ស្រស់ស្អាត

នេះសំដៅទៅលើទឹកដីអ៊ីស្រាអែល។ សូមមើលការបកប្រែនៅក្នុងជំពូក ៨:៩ និង
១១:១៥។

ត្រូវដួលចុះ

ការដួលនៅទីនេះតំណាងអោយសកម្មភាពដែលត្រូវស្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «នឹងស្លាប់»

ប៉ុន្តែអស់អ្នកដែលរួចផុតពីកណ្តាប់ដៃ

ពាក្យថា «ដៃ» នៅទីនេះតំណាងអោយអំណាច។ ការបកប្រែរបៀបផ្សេងទៀត:
«តែគ្មានអ្នកណានឹងគេចចេញពីអំណាច» ឬ
«ប៉ុន្តែស្តេចនឹងមិនអាចបំផ្លាញប្រជាជាតិនេះបានទេ»
Daniel 11:42

ព័ត៌មានទូទៅ:

ការនេះនៅតែនិយាយអំពីស្តេចនៅទិសខាងជើង។

ស្តេចនោះនឹងលូកដៃទៅទាស់នឹងស្រុកនានា

ពាក្យថា «ដៃ» តំណាងអោយអំណាច ហើយនិងការគ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត: «ស្តេចបន្តពង្រីកការគ្រប់គ្រងនៅលើទឹកដីផ្សេង»

នៅក្នុងស្រុក

គំនិតទាំងនេះនិយាយអំពីទឹកដីជាច្រើន ឬ ដីផ្សេងទៀត។

ស្រុកអេស៊ីបក៏គេចមិនរួចដែរ

ស្តេចនឹងដណ្តើមយកទ្រព្យសម្បត្តិ និងប្រាក់ទាំងអស់ដែលមានតម្លៃនៅស្រុកអេស៊ីប
ការបកប្រែរបៀបផ្សេងទៀត:
«ទឹកដីរបស់អេស៊ីបនឹងមិនគេចផុតទេ»

សាសន៍លីប៊ី និង សាសន៍អេធីយ៉ូពីនឹងសុំជាចំណុះ

ពាក្យថា «ដើរតាម» តំណាងពីការចុះចូល។ ការបកប្រែរបៀបផ្សេងទៀត:
«សាសន៍លីប៊ី និង សាសន៍អេធីយ៉ូពី នឹងមកបម្រើស្តេច»

សាសន៍លីប៊ី និង សាសន៍អេធីយ៉ូពី

«ប្រជាជននៃលីប៊ី និងអេធីយ៉ូពី»។ លីប៊ីគឺជាស្រុកនៅខាងលិចនៃអេធីយ៉ូពី
និងអេធីយ៉ូពីនៅខាងត្បូងនៃអេស៊ីប។
Daniel 11:44

ព័ត៌មានទូទៅ:

ការនេះនៅតែនិយាយអំពីស្តេចនៅទិសខាងជើង។

ហើយទ្រង់នឹងលើកទ័ពចេញទៅទាំងក្រេវក្រោធ

នាមអរូបី «ក្រេវក្រោធ» ពាក្យនេះក៏អាចនិយាយបានថា «ខឹង»។
វាអាចនិយាយឲ្យកាន់តែច្បាស់ដែលស្តេចនឹងទៅជាមួយនឹងពួកទាហានរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត:
«ស្តេចបានខឹងខ្លាំងហើយចេញទៅជាមួយពួកទាហាន» ឬ
«ស្តេចបានខឹងយ៉ាងខ្លាំង ហើយក៏ចេញទៅជាមួយនឹងទាហាន»

ចេញទៅ

ពាក្យនេះតំណាងឲ្យការចេញទៅវាយប្រហារពួកសត្រូវ។

លើកទ័ពចេញទៅទាំងក្រេវក្រោធ ហើយបំផ្លាញ

«ដើម្បីបំផ្លាញប្រជាជនជាច្រើន»

តម្លើងពន្លាធ្វើជារាជដំណាក់

ការនេះសំដៅទៅលើព្រះដំណាក់ដ៏ល្អរបស់ស្តេច ដែលស្តេចបានស្នាក់នៅ
នៅពេលស្តេចនៅជាមួយពួកទាហាននៅក្នុងពេលសង្គ្រាម។

ដំណាក់នៅកណ្តាលសមុទ្រ និងជិតភ្នំដ៏បរិសុទ្ធ

ការនេះគួរតែបានសំដៅទៅតាមតំបន់រវាងសមុទ្រ មេឌីទែរ៉ានេ
និងភ្នំនៃព្រះវិហារនៅក្នុងយេរូសាឡិម។

និងជិតភ្នំដ៏បរិសុទ្ធ

ការនេះសំដៅទៅលើជ្រលងនៅក្នុងក្រុងយេរូសាឡិមគឺជាទីកន្លែងព្រះវិហារបានសាងសង់។
សូមមើលការបកប្រែដែលមានឃ្លាស្រដៀងគ្នានៅក្នុងជំពូក ៩:១៥ និង៩:២០។

---

12 [1]«នៅគ្រានោះមហាទេវតាមីកែល ដែលថែរក្សាប្រជាជនរបស់លោកបានក្រោកឡើង។ នឹងមានគ្រាដ៏វេទនា ដែលមិនដែលកើតមានពីមុន
តាំងពីមានជាតិសាសន៍ផ្សេងៗរហូតដល់ពេលនេះ។ នៅគ្រានោះប្រជាជនរបស់លោកនឹងត្រូវបានសង្គ្រោះ គឺអស់អ្នកដែលមានឈ្មោះបានកត់នៅក្នុងក្រាំង។
[2]មនុស្សជាច្រើនដែលបានដេកនៅលើធូលីដីនឹងក្រោកឡើង ខ្លះទទួលបានជីវិតអស់កល្បជានិច្ច ខ្លះទទួលបានភាពអាម៉ាស់ព្រមទាំងទទួលបានទោសអស់កល្បជានិច្ច។
[3]ចំពោះអ្នកដែលមានប្រាជ្ញា នឹងបញ្ចេញពន្លឺភ្លឺពីមេឃ ហើយអស់អ្នកដែលជួយណែនាំមនុស្សជាច្រើនឲ្យប្រព្រឹត្តិអំពើសុចរិតវិញ
នឹងបានភ្លឺដូចជាផ្កាយដែលនៅអស់កល្បវិញ។[4]ប៉ុន្តែ លោក ដានីយ៉ែល សូមបិតពាក្យទាំងនោះ នឹងរក្សាសៀវភៅត្រា រហូតដល់ពេលចុងក្រោមមកដល់។
មនុស្សជាច្រើននឹងរត់មកពីនេះនិងជានោះ ហើយចំណេះរបស់គេនឹងបានរីកចម្រើនឡើង»។
[5]បន្ទាប់មក ខ្ញុំដានីយ៉ែល បានមើលទៅបានឃើញមនុស្សពីរនាក់កំពុងឈរនៅទីនោះ។ គឺម្នាក់បានឈរនៅម្ខាងនៃទន្លេហើយម្នាក់ទៀតក៏ឈរនៅត្រើយទន្លេម្ខាងទៀត។
[6]ម្នាក់នៃពួកគេបាននិយាយទៅកាន់បុរសដែលស្លៀកឈុតក្លឹរលើប ដែលកំពុងឈរនៅលើទឹកទន្លេនោះថា «តើហេតុការណ៍នេះនឹងត្រូវបញ្ចប់នៅពេលណាទៅ?»
[7]ខ្ញុំបានឮបុរសដែលស្លៀកឈុតក្លឹរលើប ដែលកំពុងឈរនៅលើទឹកទន្លេនេះលោកបានលើកដៃទាំងពីរឡើងទៅលើមេឃ ហើយខ្ញុំឮលោកប្រកាសខ្លាំងៗ
ក្នុងព្រះនាមព្រះជាម្ចាស់ដែលមានព្រះជន្មរស់ថា ហេតុការណ៍នេះនឹងមានរយៈពេលមួយខួប ហើយពីរខួបកន្លះ។
ពេលណាដែលអំណាចរបស់ប្រជាជនដ៏វិសុទ្ធត្រូវបានបាក់បែកអស់ នោះគ្រប់ការទាំងអស់នឹងត្រូវបានកើតឡើង។
[8]ខ្ញុំបានស្តាប់ឮ តែខ្ញុំមិនអាចយល់បានទេ។ ដូច្នេះខ្ញុំក៏សួរថា «លោកម្ចាស់អើយ! តើអ្វីទៅផលដែលបានមកពីគ្រប់ការទាំងនេះ»?[9]លោកក៏ឆ្លើយថា «ដានីយ៉ែលអើយ
ចូលបន្តលើផ្លូវអ្នកទៅ ព្រោះពាក្យទាំងនោះបានបិតហើយ ហើយបិតត្រារហូតដល់ពេលចុងបញ្ចាប់។

generated on Wed Sep 10 16:16:32 2025

[10]មនុស្សជាច្រើននឹងបានជាបរិសុទ្ធ សម្អាត ហើយបានជំនះ តែមនុស្សអាក្រក់នឹងនៅតែប្រព្រឹត្តិអាក្រក់។ ហើយមនុស្សអាក្រក់ក៏មិនយល់បានដែរ
ប៉ុន្តែអស់អ្នកដែលមានប្រាជ្ញានឹងអាចយល់។[11]ចាប់ពីពេលដែលគេបញ្ឈប់មិនឲ្យមានការថ្វាយដង្វាយដុត ហើយមានការតាំងរបស់ដែលគួរឲ្យស្អប់ខ្ពើមឡើង
នោះនឹងមានរយៈពេល ១២៩០ ថ្ងៃ។
[12]មានពរដល់អ្នកដែលបានរង់ចាំរហូតដល់ពេលចុងក្រោយ ១៣៣៥ថ្ងៃ។[13]លោកត្រូវបន្តលើផ្លូវរបស់អ្នករហូតដល់ទីបញ្ចប់ចុះ ហើយលោកនឹងបានសម្រាក។
លោកនឹងក្រោកវិញនៅកន្លែងដែលរៀបចំសម្រាប់អ្នក នៅថ្ងៃចុងក្រោយ»។

Daniel 12:1

ព័ត៌មានទូទៅ:

ទេវតាដែលបានលេចមកកាន់ដានីយ៉ែលនៅក្នុងជំពូក ១០:៤ បានបន្តនិយាយ។

មហាទេវតាមីកែល

មីកែលគឺជាមហាទេវតា។ នៅទីនេះលោកក៏បានផ្តល់ងារមួយទៀត
«ម្ចាស់ដ៏អស្ចារ្យ»។

មីកែល...បានក្រោកឡើង

ពាក្យថា «ងើបឡើង» គឺវាស្រដៀង និងពាក្យលេចចេញមក។
ការបកប្រែរបៀបផ្សេងទៀត: «មីកែល...នឹងលេចមក»

ប្រជាជនរបស់លោកនឹងត្រូវរំដោះ

នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ អ្នកក៏អាចធ្វើវាឲ្យកាន់តែច្បាស់ថា
ព្រះជាម្ចាស់នឹងសង្គ្រោះប្រជាជន។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងសង្គ្រោះប្រជាជនរបស់អ្នក»

ពួកអ្នកដែលមានឈ្មោះបានកត់នៅក្នុងក្រាំង

នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ អ្នកក៏អាចធ្វើវាឲ្យកាន់តែច្បាស់ថា
ព្រះជាម្ចាស់បានសរសេរឈ្មោះរបស់អ្នកនៅក្នុងសៀវភៅ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកដែលមានឈ្មោះបានកត់នៅក្នុងសៀវភៅ»

មនុស្សដែលដេកនៅលើធូលីដីនឹងក្រោកឡើង

ឃ្លាថា «ដេកនៅក្នុងធូលីនៃផែនដី» គឺជារបៀបមួយទៀត
ដែលសំដៅទៅកាន់មនុស្សដែលស្លាប់។ ពាក្យថា «ងើបឡើង»
គឺស្រដៀងទៅនឹងពាក្យថារស់ឡើងវិញ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលបានស្លាប់នឹងត្រឡប់មកកាន់ជីវិតវិញ»

Daniel 12:3

អ្នកដែលមានប្រាជ្ញាវិញ គេនឹងបញ្ចេញពន្លឺភ្លឺដូចមេឃ

ការនេះសំដៅទៅកាន់ប្រជាជនរបស់ព្រះជាម្ចាស់ដែលនឹងចែករំលែកប្រាជ្ញាជាមួយអ្នកដែលនៅជុំវិញពួកគេ។

មនុស្សជាច្រើនឲ្យប្រព្រឹត្តិអំពើសុចរិតវិញ

ការនេះសំដៅទៅលើអ្នកដែលបានជួយមនុស្សដទៃឲ្យយល់ថាគេបានបែកចេញពីព្រះជាម្ចាស់
ក្នុងពេលពួកគេកុំពុងតែប្តូរទិសដៅដែលពួកធ្វើដំណើរទៅ។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលបានបង្រៀនអ្នកដទៃឲ្យរស់នៅយ៉ាងសុចរិត»

អស់អ្នកដែលជួយណែនាំ...គេនឹងបានភ្លឺដូចជាផ្កាយដែលនៅអស់កល្បវិញ

មនុស្សទាំងនេះត្រូវបានគេប្រៀបធៀបទៅនឹងផ្កាយដែលរះ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលងាក ... នឹងភ្លឺដូចផ្កាយជារៀងរហូត
និងជារៀងរហូត»

សូមលាក់សៀវភៅដែលបានកត់ត្រាពាក្យទាំងនោះឲ្យជិត

ពាក្យថា «ពាក្យ» នៅទីនេះតំណាងអោយសៀវភៅ។ ការបកប្រែរបៀបផ្សេងទៀត:
«ចូលបិទសៀវភៅនេះនិងរក្សាត្រាផង»

ដល់ពេលកំណត់មកដល់

«នៅថ្ងៃចុងក្រោយ» ឬ «នោះជាថ្ងៃចុងក្រោយនៃពិភពលោក»។
សូមមើលការបកប្រែនៅក្នុងជំពូក ៨:១៥។

នឹងមានមនុស្សជាច្រើននឹងស្វែងយល់ ហើយចំណេះរបស់គេនឹងបានរីកចម្រើនឡើង

ការនេះដូចជាបានកើតឡើងពីមុនមកហើយ «ពេលវេលាចុងក្រោយ»
កំឡុងពេលដែលសៀវភៅបិទត្រា។ ការនេះអាចបញ្ជាក់ន័យថែមទៀត។
ការបកប្រែរបៀបផ្សេងទៀត: «មុនពេលនេះកើតឡើង
មនុស្សនឹងធ្វើដំណើរទៅទីនេះ និងទៅទីនោះ ហើយរៀនពីអ្វីច្រើនទៀត»

Daniel 12:5

ព័ត៌មានទូទៅ:

ដានីយ៉ែលបានចេញទៅហើយប្រាប់ពីអ្វីដែលលោកបានឃើញនៅក្នុងនិមិត្តដែលចាប់ផ្តើមនៅក្នុងជំពូក
១០:១។

មនុស្សពីរនាក់កំពុងឈរនៅទីនោះ

«មានទេវតាពីររូបទៀតកំពុងឈរនៅទីនោះ»

ទេវតាដែលស្លៀកឈុតភ្លឺរលើប

ការនេះសំដៅទៅទេវតាដែលលេចមកដល់ដានីយ៉ែលនៅក្នុងជំពូក ១០:៤
គឺមិនមែនម្នាក់ដែលកំពុងឈរនៅម្ខាងទៀតនៃទន្លេនោះទេ។

នៅលើទឹកទន្លេនោះ

អត្ថន័យដែលអាចមានគឺ ១) ទេវតាស្លៀកឈុតភ្លឺរលើបដែលនៅលើទន្លេ ឬ ២)
ទេវតាបាននៅលើខ្សែទឹកហូរនៃទន្លេ។

តើហេតុការណ៍នេះនឹងត្រូវបញ្ចប់នៅពេលណា?

«តើហេតុការណ៍នេះនឹងត្រូវបញ្ចប់នៅពេលណា?»

ការនេះសំដៅទៅលើពេលចាប់ផ្តើម ដល់បញ្ចប់ទៅវិញនៃហេតុការណ៍នេះ។

ហេតុការណ៍នេះ

នៅក្នុងពេលទេវតាបាននិយាយទៅកាន់ដានីយ៉ែល
គឺគ្មានហេតុការណ៍ណាដែលមានដូចនេះទៀតទេ។

ការអស្ចារ្យនេះសំដៅទៅហេតុការណ៍ដែលនៅក្នុងជំពូក ១២:១
ហើយវាក៏អាចទៅរួចដែរ បើយើងរួមបញ្ចូលហេតុការណ៍ដែលនៅក្នុងជំពូក ១១។

Daniel 12:7

ទេវតាដែលស្លៀកឈុតភ្លឺរលើប

នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បុរសដែលបានស្លៀកឈុតភ្លឺរលើប» ឬ «ទេវតាដែលបានស្លៀកឈុតភ្លឺរលើប»

ឈរនៅលើទឹកទន្លេនេះ

អត្ថន័យដែលអាចមានគឺ ១) ទេវតាស្លៀកឈុតភ្លឺរលើបដែលនៅលើទន្លេ ឬ ២)
ទេវតាបាននៅលើខ្សែទឹកហូរនៃទន្លេ។

ក្នុងព្រះនាមព្រះជាម្ចាស់

«ព្រះជាម្ចាស់ដែលរស់នៅជារៀងរហូត»

ហេតុការណ៍នេះនឹងមានរយៈពេល មួយខួប ពីរខួប និងកន្លះខួប

វាគឺជាការណ៍ដែលត្រូវចាកចេញពីវា នៅពេលដែលវាជិតនឹងកើតឡើង។
ប្រសិនបើអ្នកបានជ្រើសរើសពីកន្លែងចាប់ផ្តើមបីឆ្នាំកន្លះវាគួរតែជាកន្លែងចាប់ផ្តើមជាមួយហេតុការណ៍នៃជំ

មានរយៈពេល មួយខួប ពីរខួប និងកន្លះខួប

ការនេះសំដៅទៅលើ «ពេលវេលា មួយឆ្នាំ ពីរឆ្នាំ និងកន្លះ» (UDB)។ ការនេះ «ពេលវេលា»
ជាទូទៅត្រូវបានយល់ថាជាការសំដៅទៅលើឆ្នាំជាច្រើន។ មួយ និងពីរ
និងកន្លះស្មើនឹងបី ហើយនិងកន្លះ។

គ្រប់ការទាំងអស់នឹងត្រូវបានបញ្ចប់

នេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់ការទាំងនេះនឹងត្រូវកើតឡើង»

គ្រប់ការទាំងអស់

នៅពេលដែលទេវតាបានស្លៀកឈុតភ្លឺរលើបបាននិយាយមកកាន់ដានីយ៉ែល
គឺគ្មានហេតុការណ៍ណាអាចនឹងកើតឡើងទេ។
ការនេះសំដៅទៅហេតុការណ៍នៅក្នុងជំពូក ១២:១
ហើយវាក៏អាចរួមបញ្ចូលជាមួយនឹងហេតុការណ៍ពីជំពូក ១១។

Daniel 12:8

ឱលោកម្ចាស់អើយ

ដានីយ៉ែលបានសំដៅទៅលើទេវតាស្លៀកឈុតភ្លឺរលើបដូចជា «ឱលោកម្ចាស់»
ដើម្បីបង្ហាញពីការគោរពដល់ទេវតា។

ហេតុការណ៍នេះនឹងបានសម្រេចជាអ្វី

នៅពេលដែលទេវតាបានស្លៀកឈុតភ្លឺរលើប បាននិយាយមកកាន់ដានីយ៉ែល
គឺគ្មានហេតុការណ៍ណាអាចនឹងកើតឡើងទេ។
ការនេះសំដៅទៅហេតុការណ៍នៅក្នុងជំពូក ១២:១
ហើយវាក៏អាចរួមបញ្ចូលជាមួយនឹងហេតុការណ៍ពីជំពូក ១១។

សូមលាក់ការនេះជាសម្ងាត់ ហើយរក្សាក្រាំងនេះទុក

ដានីយ៉ែលត្រូវបានប្រទានដល់ដានីយ៉ែលគឺមិនបានមានការពន្យល់នោះទេ។
សៀវភៅនេះបានបិទជិតហើយគ្មាននរណាម្នាក់អាចចូលបានទេ។
ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតអ្នកនឹងបិទត្រានៅលើសៀវភៅដែលអ្នកបានសរសេរ»

ពេលកំណត់មកដល់ចុះ

«នៅថ្ងៃចុងក្រោយ» ឬ «គ្រាចុងក្រោយនៃពិភពលោក»។

generated on Wed Sep 10 16:16:32 2025

សូមមើលការបកប្រែនេះនៅក្នុងជំពូក ៨:១៥។

Daniel 12:10

ព័ត៌មានទូទៅ:

ទេវតាដែលបានស្លៀកឈុតភ្លឺរលើបបាននិយាយមកកាន់ដានីយ៉ែល។

មនុស្សជាច្រើននឹងបានសម្អាត បន្សុទ្ធជាបរិសុទ្ធ

ព្រះអម្ចាស់បានធ្វើឲ្យបរិសុទ្ធ។ នៅក្នុងកាលទាំងបីនេះដែលមានមូលដ្ឋានដូចគ្នា។

ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់បានធ្វើឲ្យបរិសុទ្ធ សម្អាត និង បន្សុទ្ធដល់មនុស្សជាច្រើន»

បន្សុទ្ធ

បន្សុទ្ធដោយយករបស់ដែលមិនមាននៅក្នុងរបស់ទាំងនោះចេញ

មនុស្សអាក្រក់នឹងនៅតែប្រព្រឹត្តិអាក្រក់

មនុស្សអាក្រក់នឹងធ្វើការអាក្រក់ ឬអំពើបាប។

មនុស្សអាក្រក់នឹងមិនយល់អ្វីទេ

មនុស្សអាក្រក់មិនអាចយល់ពីការចេះដឹងខាងឯវិញ្ញាណទេ។

ប៉ុន្តែអស់អ្នកដែលមានប្រាជ្ញានឹងយល់ពីការនេះ

សំដៅទៅលើអ្នកដែលស្តាប់បង្គាប់ព្រះអម្ចាស់ដែលមានប្រាជ្ញាអាចយល់បាន។

ការថ្វាយដង្វាយដុត...មានការតាំងរបស់

ស្តេចដែលនៅទិសខាងជើងគឺជាអ្នកបញ្ឈប់ការថ្វាយតង្វាយ។

ការបកប្រែរបៀបផ្សេងទៀត: «ស្តេចខាងជើងដែលបានបញ្ឈប់មិន ឲ្យមានការថ្វាយដង្វាយដុត ហើយមានការតាំងរបស់ដែលគួរឲ្យស្អប់ខ្ពើមឡើង»

របស់ដែលគួរឲ្យស្អប់ខ្ពើមឡើងដែលធ្វើឲ្យមានការបំផ្លាញទាំងមូលបានកើតឡើង

ការនេះសំដៅទៅលើព្រះក្លែងក្លាយដែលនឹងធ្វើអោយព្រះវិហារនេះក្លាយទៅជាទីសក្ការៈដែលនឹងធ្វើឱ្យព្រះជាម្ចាស់ចាកចេញពីព្រះវិហារ។

សូមមើលការបកប្រែនេះនៅក្នុងជំពូក ១១:៣១។ ការបកប្រែរបៀបផ្សេងទៀត: «របស់ដែលគួរឲ្យស្អប់ខ្ពើមគឺជាព្រះក្លែងក្លាយដែលនឹងធ្វើឲ្យព្រះជាម្ចាស់បិទបាំងព្រះវិហារ» ឬ

«របស់ដែលគួរឲ្យស្អប់ខ្ពើមគឺជាព្រះក្លែងក្លាយដែលនឹងធ្វើឲ្យព្រះវិហារទៅជាមិនស្អាត»

១២៩០ ថ្ងៃ

ពាក្យថា «ថ្ងៃ» នៅទីនេះសំដៅទៅរយៈពេលមួយ។ ភាគច្រើនត្រូវបានបកប្រែជាថ្ងៃ ប៉ុន្តែក៏អាចបញ្ជាក់ពីឆ្នាំដែរ។

Daniel 12:12

ព័ត៌មានទូទៅ:

ទេវតាដែលបានស្លៀកឈុតភ្លឺរលើបបានបន្តនិយាយមកកាន់ដានីយ៉ែល។

មានពរហើយអស់អ្នកដែលចាំយាម

«មានពរហើយមនុស្សណាដែលចាំយាម» ឬ «មានពរហើយអស់អ្នកដែលចាំយាម»

ចាំយាម

«ស៊ូទ្រាំ» ឬ «នៅតែស្មោះត្រង់» (UDB)

១៣៣៥ ថ្ងៃ

ពាក្យថា «ថ្ងៃ» នៅទីនេះគឺសំដៅទៅលើរយៈពេលមួយដែលត្រូវបានបកប្រែជាថ្ងៃ។ ទោះយ៉ាងណាក៏ដោយ វាក៏អាចបញ្ជាក់ពីឆ្នាំដែរ។

លោកត្រូវទៅវិញ

«ដានីយ៉ែល អ្នកត្រូវទៅហើយ»។ ការនេះសំដៅពីដានីយ៉ែលដែលនឹងត្រូវរស់នៅ ហើយបន្តបម្រើស្តេចតទៅទៀត រហូតដល់ពេលលោកស្លាប់។

លោកនឹងបានសម្រាក

នេះគឺជារបៀបគោរពក្នុងការនិយាយថា «អ្នកនឹងស្លាប់»។

លោកនឹងក្រោកវិញ

ការនេះសំដៅទៅលើការរស់ឡើងវិញជាលើកទីមួយនៃការរស់ឡើងវិញ ការរស់ពីស្លាប់នៅពេលដែលអ្នកសុចរិតបានក្រោកឡើងវិញ។

ដើម្បីទទួលចំណែករបស់លោកនៅគ្រាកំណត់

ឬជាកន្លែងដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់អ្នក»

ហូសេ

1 [1]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលមកដល់លោកហូសេ ជាកូនបេរ៉ី ក្នុងរជ្ជកាលព្រះបាទអូសៀស ព្រះបាទយ៉ូថាម ព្រះបាទអេហាស និងព្រះបាទហេសេគា ជាស្តេចស្រុកយូដា និងក្នុងគ្រាដែលព្រះបាទយេរ៉ូបោម ជាបុត្ររបស់ព្រះបាទយ៉ូអាស ជាស្តេចស្រុកអ៊ីស្រាអែល។[2]កាលព្រះអម្ចាស់ចាប់ផ្តើមមានព្រះបន្ទូលតាមរយៈហូសេ ព្រះអង្គមានព្រះបន្ទូលមកកាន់លោកថា៖ «ចូរទៅយកស្ត្រីពេស្យាម្នាក់មកធ្វើជាប្រពន្ធ ហើយបង្កើតកូនពីស្ត្រីពេស្យានោះ។ ដ្បិតទឹកដីនេះចេះតែប្រព្រឹត្តអំពើពេស្យាចារដោយបោះបង់ចោលព្រះអម្ចាស់»។
[3]ដូច្នេះ លោកហូសេក៏ទៅរៀបការជាមួយនាងកូមើរ ជាកូនឌីប្លែម ហើយនាងមានទម្ងន់ បង្កើតបានកូនប្រុសមួយឲ្យហូសេ។[4]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ហូសេថា៖ «ចូរហៅឈ្មោះកូននេះថា យេសរាល។ ដ្បិតនៅតែបន្តិចទៀត យើងនឹងដាក់ទោសពូជពង្សយេហ៊ូវ ព្រោះតែឈាមយេសរាល ហើយយើងនឹងធ្វើឲ្យរាជ្យនៃពូជពង្សអ៊ីស្រាអែលត្រូវចប់។[5]វានឹងកើតឡើងនៅថ្ងៃនោះ ដែលយើងនឹងបំបាក់ធ្នូរបស់អ៊ីស្រាអែល នៅជ្រលងភ្នំយេសរាល»។
[6]នាងកូមើរមានទម្ងន់ម្តងទៀត ហើយបង្កើតបានកូនស្រី។ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ហូសេថា៖ «ចូរហៅឈ្មោះកូននេះថា ឡូរូហាម៉ា ដ្បិតយើងនឹងលែងមេត្តាដល់ពូជពង្សអ៊ីស្រាអែល ដែលយើងមិនអត់ទោសឲ្យគេដែរ។[7]ប៉ុន្តែយើងនឹងមេត្តាដល់ពូជពង្សយូដា ហើយយើងនឹងសង្គ្រោះគេដោយខ្លួនយើង ព្រះអម្ចាស់ជាព្រះរបស់គេ។ យើងនឹងមិនសង្គ្រោះគេដោយធ្នូ ដាវ សង្គ្រាមសេះ ឬពលសេះឡើយ»។
[8]កាលនាងបានផ្តាច់ដោះឡូរូហាម៉ារួចហើយ នាងក៏មានទម្ងន់ទៀត បង្កើតបានកូនប្រុសមួយទៀត។[9]រួចហើយព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ចូរហៅឈ្មោះកូននេះថា ឡូអាំមី ដ្បិតអ្នកមិនមែនជាប្រជារាស្ត្ររបស់យើងទេ ហើយយើងក៏មិនមែនជាព្រះរបស់អ្នក។
[10]ប៉ុន្តែកូនចៅអ៊ីស្រាអែល នឹងដូចខ្សាច់នៅសមុទ្រ ដែលមិនអាចរាប់ ដឹងពីចំនួនបានឡើយ។ គឺនឹងមានពាក្យនិយាយទៅកាន់ពួកគេថា៖ «អ្នករាល់គ្នាមិនមែនជាប្រជារាស្ត្ររបស់យើងទេ» នឹងត្រូវនិយាយពួកគេថា៖ «អ្នករាល់គ្នាជាប្រជាជនរបស់ព្រះដ៏មានព្រះជន្មរស់»។[11]ប្រជាជននៃយូដា និងប្រជាជនអ៊ីស្រាអែលនឹងមកជួបជុំគ្នា។ ពួកគេនឹងតាំងឲ្យមានមេដឹកនាំតែមួយគ្រប់គ្រងលើគេ ហើយគេនឹងឡើងចេញពីទឹកដីនោះ ដ្បិតថ្ងៃរបស់យេសរាល នឹងបានជាថ្ងៃមួយដ៏ធំ។

Hosea 1:1

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលមក

នេះជាគ្រាមភាសា។ របៀបផ្សេងទៀតនៃការបកប្រែ: «ជាព្រះបន្ទូលដែលព្រះអម្ចាស់ជាព្រះមានបន្ទូល»។

បេរ៉ី

ជាឈ្មោះរបស់បុរសម្នាក់។

អូសៀស យ៉ូថាម អេហាស ហេសេគាល យេរ៉ូបោម យ៉ូអាស

ព្រឹត្តិការណ៍នៅក្នុងគម្ពីរនេះកើតឡើងក្នុងរាជរបស់ស្តេចទាំងនេះ។

ព្រះអម្ចាស់

ជាឈ្មោះរបស់ព្រះដែលព្រះអង្គបើកសំដែងទៅដល់មនុស្សរបស់ព្រះអង្គនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់

សូមមើលពាក្យបកប្រែអំពីព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែពាក្យនេះ។

ស្ត្រីពេស្យា

នៅទីនេះស្ត្រីពេស្យាសំដៅលើអ្នកដែលមិនស្មោះត្រង់ជាមួយព្រះអម្ចាស់។

Hosea 1:3

កូមើរ ឌីប្លែម

ជាឈ្មោះរបស់មនុស្ស។

ពូជពង្សយេហ៊ូវ

នៅទីនេះ «ពូជពង្ស» មានន័យថា «គ្រួសារ» រួមទាំងកូនចៅរបស់យេហ៊ូវ។

ពូជពង្សអ៊ីស្រាអែល

ការលើកឡើងនេះសំដៅទៅលើអាណាចក្រអ៊ីស្រាអែល។

ធ្នូរបស់អ៊ីស្រាអែល

ពាក្យ «ធ្នូ» សំដៅទៅលើអំណាចរបស់ទ័ព។ របៀបផ្សេងទៀតនៃការបកប្រែ: **ដើម្បីបំផ្លាញកងទ័ពរបស់**អ៊ីស្រាអែល»។

Hosea 1:6

ឡូរូហាម៉ា

ឈ្មោះនេះមានន័យថា «គ្មានព្រះគុណ»។

generated on Wed Sep 10 16:16:32 2025

អ្នកបកប្រែអាចប្រើពាក្យន័យនេះដំណាងឲ្យឈ្មោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានព្រះគុណ»

Hosea 1:8

ឡូរូហាម៉ា

ឈ្មោះនេះមានន័យថា «គ្មានព្រះគុណ»។
អ្នកបកប្រែអាចប្រើពាក្យន័យនេះតំណាងឲ្យឈ្មោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានព្រះគុណ» សូមមើលនៅក្នុង ១:៦

ឡូ អាំមី

ឈ្មោះនេះមានន័យថា «មិនមែនប្រជាជនរបស់យើង»។
អ្នកបកប្រែអាចប្រើពាក្យន័យនេះ តំណាងឲ្យឈ្មោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនមែនប្រជាជនរបស់យើង»

Hosea 1:10

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់មានបន្ទូលមកកាន់លោកហូសេ។

មានចំនួនដូចខ្សាច់នៅសមុទ្រ

ការនេះបញ្ជាក់អំពីចំនួនប្រជាជនអ៊ីស្រាអែល។

ដែលមិនអាចរាប់បាន

ការនេះអាចលើកឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលគ្មាននរណាម្នាក់អាចវាស់ ឬរាប់បាន»។

គឺនឹងមានពាក្យនិយាយទៅកាន់ពួកគេថា

ការនេះអាចលើកឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅកន្លែងដែលព្រះអម្ចាស់មានបន្ទូលមកកាន់ពួកគេ»។

នោះនឹងបែរទៅជាមានពាក្យថា

ការលើកឡើងនេះប្រហែលជាចង់សំដៅទៅលើយេសរាល
ជាក្រុងដែលបានប្រព្រឹត្តបទឧក្រិដ្ឋដោយស្តេចអ៊ីស្រាអែល
ហើយជានិមិត្តរូបនៃការដាក់ទោសរបស់ព្រះអម្ចាស់លើពួកគេ។

នឹងនិយាយទៅកាន់ពួកគេថា

ការនេះអាចលើកឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងមានបន្ទូលមកកាន់ពួកគេ»។

គេនឹងមកជួបជុំគ្នា

ការនេះអាចលើកឡើងជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងមានបន្ទូលមកកាន់ពួកគេ»។

ឡើងចេញពីទឹកដីនោះ

ការលើកឡើងនេះអាចសំដៅទៅលើទឹកដីដែលប្រជាជនអ៊ីស្រាអែលវាយដណ្តើមបាន។
(សូមមើល: UDB)

ថ្ងៃរបស់យេសរាល

ការនេះសំដៅលើពេលវេលាដែលព្រះអម្ចាស់នាំប្រជារាស្ត្ររបស់ព្រះអង្គមកទឹកដីអ៊ីស្រាអែលវិញ។
អត្ថន័យពេញរបស់ប្រយោគនេះអាចបំភ្លឺឲ្យច្បាស់ជាងនេះ។

---

2 [1]ចូរនិយាយទៅកាន់បងប្អូនប្រុស «រាស្ត្ររបស់យើងអើយ!» ហើយបងប្អូនស្រីរបស់អ្នកថា «គឺអ្នកបានបង្ហាញចិត្តក្តួលអាណិតហើយ»។
[2]ចូរនាំពាក្យបណ្តឹងទាស់និងម្តាយរបស់អ្នក ចូរនាំពាក្យបណ្តឹងទៅចុះ ដ្បិតនាងមិនមែនជាប្រពន្ធយើងទេ យើងក៏មិនមែនជាប្តីរបស់នាងដែរ។ ចូរឲ្យនាងលះចោលអំពើពេស្យាចារពីមុខនាងចេញ ហើយអំពើផិតក្បត់ពីចន្លុះទ្រូងនាងផង។[3]ពុំនោះទេ យើងនឹងសម្រាតឲ្យនាងនៅខ្លួនទទេ ហើយធ្វើឲ្យនាងត្រឡប់ដូចជាថ្ងៃដែលកើតមក។ យើងឲ្យនាងបានដូចជាទីរហោស្ថាន គឺដូចជាដីហួតហែង ក៏នឹងធ្វើឲ្យនាងស្លាប់ដោយស្រេកទឹក។
[4]យើងនឹងមិនអាណិតមេត្តាដល់កូនរបស់នាងទេ ព្រោះគេសុទ្ធតែជាកូននៃអំពើពេស្យាចារ។[5]ដ្បិតម្តាយរបស់គេបានធ្វើជាស្ត្រីពេស្យា ហើយនាងដែលបានពរពោះពួកគេបានប្រព្រឹត្តអំពើដ៏អាម៉ាស់។ នាងបាននិយាយថា «ខ្ញុំនឹងទៅតាមគូស្នេហ៍របស់ខ្ញុំ ដ្បិតពួកគេបានឲ្យនំប៉័ងនិងទឹកដល់ខ្ញុំ ហើយឲ្យរោមចៀម ខ្លូតទេស ប្រេង និងស្រាមកខ្ញុំទៀតផង»។
[6]ដូច្នេះហើយ យើងនឹងសង់របងបិតផ្លូវនាងជាមួយបន្លា។ យើងសង់កំពែងទាស់នឹងនាង ដូច្នោះកុំឲ្យនាងរកផ្លូវរបស់នាងឃើញឡើយ។[7]នាងនឹងរត់តាមគូស្នេហ៍របស់នាង តែតាមរកស្នេហានាងមិនទាន់ឡើយ។ នាងនឹងស្វែងរកគូស្នេហ៍របស់នាង តែនាងនឹងមិនបានជួបគេឡើយ។ រួចហើយ នាងនឹងនិយាយថា «ខ្ញុំនឹងវិលទៅរកប្តីដើមខ្ញុំវិញ ដ្បិតនៅគ្រាកន្លង គឺប្រសើរជាងពេលនេះ»។
[8]ដ្បិត នាងមិនបានដឹងថា គឺយើងនេះហើយដែលបានផ្តល់ស្រូវ និងស្រាថ្មី ហើយប្រេងដល់នាង ហើយបានផ្តល់ប្រាក់និងមាសជាច្រើនដល់នាង ដែលពួកគេនឹងប្រើសម្រាប់ថ្វាយព្រះបាលទៅវិញ។[9]ដូច្នេះយើងនឹងដកយកស្រូវរបស់យើងនៅរដូវចម្រូត យើងនឹងដកស្រាថ្មីរបស់យើងវិញ នៅរដូវរបស់វា។ យើងក៏នឹងដកយករោមចៀម និងខ្លូតទេសរបស់យើង ដែលសម្រាប់បិទបាំងភាពអាក្រាតរបស់នាង។
[10]ក្រោយមក យើងនឹងបើកកេរ្តិ៍ខ្មាសរបស់នាង នៅមុខគូស្នេហ៍របស់នាង គ្មានអ្នកណាអាចជួយនាងចេញពីដៃយើងទេ។[11]យើងនឹងធ្វើឲ្យការអបអរសាទរត្រូវបញ្ឈប់ ពិធីបុណ្យផ្សេងៗ បុណ្យចូលខែ បុណ្យថ្ងៃសប្ប័ទ និងបុណ្យដែលបានកំណត់ទាំងឡាយរបស់នាង។
[12]«យើងនឹងបំផ្លាញដើមទំពាំងបាយជូរ និងដើមឧទម្ពររបស់នាង ដែលនាងធ្លាប់និយាយថា «ចម្ការទាំងនេះជាឈ្នួលដែលគូស្នេហ៍របស់ខ្ញុំបានឲ្យ»។ យើងនឹងធ្វើឲ្យចម្ការទាំងនោះត្រឡប់ទៅជាព្រៃ ហើយសត្វព្រៃនឹងស៊ីបង្ហិនអស់។[13]យើងនឹងដាក់ទោសនាងសម្រាប់អស់ទាំងថ្ងៃ ដែលនាងបានដុតកំញានថ្វាយព្រះបាល ពេលដែលនាងបានតែងខ្លួន ជាមួយចិញ្ចៀនគ្រឿងអលង្ការរបស់នាង ហើយនាងរត់តាមគូស្នេហ៍របស់នាង រួចហើយបំភ្លេចយើងចោល នេះជាព្រះបន្ទូលនៃព្រះអម្ចាស់»។
[14]ដូច្នេះ យើងនឹងឈ្នះចិត្តនាងមកវិញ។ យើងនឹងនាំនាងទៅទីរហោស្ថាន ហើយនិយាយលួងលោមចិត្តនាង។[15]យើងនឹងប្រគល់ចម្ការទំពាំងបាយជូរ របស់នាងឲ្យនាងវិញ ហើយធ្វើឲ្យជ្រលងភ្នំអាកោរ ក្លាយជាទ្វារនៃសេចក្តីសង្ឃឹម។ នៅទីនោះ នាងនឹងឆ្លើយតបមកយើង ដូចគ្រានៅពីក្មេង គឺដូចគ្រាដែលនាងបានចេញពីស្រុកអេស៊ីប។
[16]«ព្រះអម្ចាស់មានព្រះបន្ទូលថា វានឹងកើតឡើងនៅថ្ងៃនោះ ដែលនាងនឹងហៅយើងថា «លោកប្តីខ្ញុំអើយ» ហើយនាងនឹងមិនដែលហៅយើងថា «ព្រះបាល»។[17]ដ្បិតយើងនឹងដកឈ្មោះព្រះបាលទាំងនោះចេញពីមាត់នាង ហើយនឹងមិនមានអ្នកណានៅចាំពីឈ្មោះរបស់ពួកគេទៀតឡើយ»។
[18]«នៅថ្ងៃនោះ យើងក៏នឹងតាំងសម្ពន្ធមេត្រីសម្រាប់ពួកគេ ជាមួយសត្វព្រៃនៅតាមទីវាល ជាមួយនិងសត្វហើរលើអាកាស ហើយជាមួយនិងសត្វលូនវារលើដីផងដែរ។ យើងនឹងបំបាត់ធ្នូ និងដាវ ហើយនិងសង្គ្រាមចេញពីទឹកដី ហើយយើងនឹងធ្វើឲ្យអ្នកដេកយ៉ាងសុខសាន្ត។
[19]យើងសន្យាថានឹងជាប្តីរបស់នាងជារៀងរហូត។ យើងសន្យាថានឹងធ្វើជាប្តីរបស់នាង ដោយសេចក្តីសុចរិត និងសេចក្តីយុត្តិធម៌ ដោយសេចក្តីសប្បុរស និងសេចក្តីមេត្តា។
[20]យើងនឹងរៀបចំខ្លួនយើងសម្រាប់នាង ដោយសេចក្តីស្មោះត្រង់ ហើយនាងនឹងស្គាល់ព្រះអម្ចាស់។
[21]នៅថ្ងៃនោះ ព្រះអម្ចាស់មានព្រះបន្ទូលថា យើងនឹងឆ្លើយតប ដែលយើងនឹងឆ្លើយតបដល់ផ្ទៃមេឃ ហើយផ្ទៃមេឃនឹងឆ្លើយតបដល់ផែនដី។[22]ចំណែកផែនដីនឹងឆ្លើយតបដល់ស្រូវ ហើយស្រាថ្មី និងប្រេង គេនឹងឆ្លើយតបដល់យេសរាល។
[23]យើងនឹងសាបព្រោះពូជគេនៅលើផែនដីសម្រាប់យើង ហើយយើងនឹងផ្តល់មេត្តាដល់ឡូរូហាម៉ា។ យើងនឹងនិយាយទៅឡូអាំមីថា «អ្នកឡូអាំមី អាតា» រួចហើយគេនឹងពោលមកយើងថា «ព្រះអង្គជាព្រះជាម្ចាស់នៃទូលបង្គំ»។

Hosea 2:1

ប្រយោគភ្ជាប់

ព្រះអម្ចាស់បានមានបន្ទូលមកកាន់លោកហូសេ។

រាស្ត្ររបស់យើង

ការពន្យល់នេះអាចបង្ហាញថាជាការលើកឡើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជារាស្ត្ររបស់យើង!»

អ្នកបានបង្ហាញចិត្តក្តួលអាណិត

ការនេះអាចលើកឡើងជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានបង្ហាញចិត្តក្តួលអាណិតដល់អ្នក»

ការក្តួលអាណិត

«ចិត្តសណ្តោស» ឬ «ព្រះគុណ»។

Hosea 2:2

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់មានបន្ទូលមកកាន់លោកហូសេ។

generated on Wed Sep 10 16:16:32 2025

ការចោទប្រកាន់

ការចោទប្រកាន់នេះគឺធ្វើឡើងដោយមនុស្សម្នាក់ប្រឆាំងនឹងមនុស្សម្នាក់ទៀតនៅក្នុងតុលាការ

ម្តាយរបស់អ្នក

នៅទីនេះ «ម្តាយ» សំដៅលើប្រជាជាតិអ៊ីស្រាអែល។

ដ្បិត នាងមិនមែនជាប្រពន្ធយើងទេ

ព្រះអម្ចាស់បានលើកឡើងថាអ៊ីស្រាអែល ជាស្ត្រី
ដែលមិនមែនជាភរិយារបស់ព្រះអម្ចាស់ទៀតទេ។
ផ្ទុយទៅវិញអ៊ីស្រាអែលបានបែរឆ្ងាយពីព្រះអង្គ និងការថ្វាយបង្គំព្រះអង្គ។

យើងក៏មិនមែនជាប្តីរបស់នាងដែរ

ព្រះអម្ចាស់មិនអាចមានទំនាក់ទំនងជាមួយជាតិសាសន៍អ៊ីស្រាអែលក្នុងនាមជាស្វាមីចំពោះ

ហើយអំពើផិតក្បត់

ស្ត្រីដែលក្បត់បានចាកចេញពីប្តីរបស់នាងទៅរួមរស់ជាមួយបុរសផ្សេង។
នេះគឺជាអ្វីដែលអ៊ីស្រាអែលបានប្រព្រឹត្តចំពោះព្រះអម្ចាស់។

ពីកណ្តាលទ្រូងនាង

រូបភាពនេះបានបង្ហាញថាអ៊ីស្រាអែលបានពឹងផ្អែកលើរូបព្រះ
ហើយមិនពឹងព្រះអម្ចាស់។

យើងនឹងសម្រាតឲ្យនាងនៅខ្លួនទទេ ហើយធ្វើឲ្យនាងត្រឡប់ដូចជាថ្ងៃដែលកើតមក

ព្រះអម្ចាស់នឹងមិនការពារ និងផ្តត់ផ្គង់អ៊ីស្រាអែលទៀតទេ
ព្រោះជាតិសាសន៍នេះបានបែរចេញពីព្រះអង្គ។

នៅក្នុងស្រុកអ៊ីស្រាអែលច្បាប់តម្រូវឲ្យប្តីផ្តត់ផ្គង់សំលៀកបំពាក់សម្រាប់ប្រពន្ធរបស់ពួកគេ

បើពួកគេមិនធ្វើបែបនេះទេ ជាសញ្ញាបញ្ជាក់ថាពួកគេបោះបង់ចោលប្រពន្ធរបស់ខ្លួន
អត្ថន័យពេញអាចធ្វើឲ្យដឹងច្បាស់។

ឲ្យនាងបានដូចជាទីរហោស្ថាន

ព្រះអម្ចាស់នឹងផ្លាស់ប្តូរអ៊ីស្រាអែលឲ្យទៅដូចជាទីរហោស្ថាន
ដែលជាតំបន់ដែលនៅទទេ ហើយមិនបង្កើតផល។

នឹងធ្វើឲ្យនាងស្លាប់ដោយស្រេកទឹក

នៅទីនេះ «ស្រេកទឹក» សំដៅទៅលើការត្រូវការការថ្វាយបង្គំ
និងការពឹងផ្អែកលើព្រះអម្ចាស់ មិនមែនលើរូបព្រះទេ
ឬមួយក៏អ៊ីស្រាអែលនឹងមិនអាចបន្តរស់ជាជាតិសាសន៍មួយបានទៀតទេ។

Hosea 2:4

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់មានបន្ទូលមកកាន់ហូសេ។

គេសុទ្ធតែជាកូននៃអំពើពេស្យាចារ

ប្រជាជនអ៊ីស្រាអែលធ្វើដូចជាពួកគេមិនមែនជាកម្មសិទ្ធរបស់ព្រះអម្ចាស់។
ដូចដែលឪពុកម្តាយរបស់ពួកគេមិនថ្វាយបង្គំព្រះអម្ចាស់ ពួកគេក៏មិនថ្វាយបង្គំដែរ។

ម្តាយរបស់គេបានធ្វើជាស្ត្រីពេស្យា

អ្នកជំនាន់មុនដែលស្វែងរកព្រះដទៃបានចាត់ទុកជាស្ត្រីពេស្យាដោយសារពួកគេមិនស្មោះត្រង់

ខ្ញុំនឹងទៅតាមគូស្នេហ៍របស់ខ្ញុំ ព្រោះគេបានឲ្យនំប៉័ង ឲ្យទឹកមកខ្ញុំ គេឲ្យរោមចៀម ខ្លូតទេស ប្រេង និង
ស្រាមកខ្ញុំទៀតផង

នៅទីនេះ «គូស្នេហ៍របស់ខ្ញុំ» សំដៅលើព្រះបាល និងព្រះក្លែងក្លាយដទៃទៀត
ដែលអ៊ីស្រាអែលជ្រើសរើសថ្វាយបង្គំជំនួសព្រះអម្ចាស់។
បញ្ជីនៃរឿងទាំងនេះជារបស់សំខាន់ដែលអាចឲ្យមនុស្សបន្តរស់នៅបាន។

Hosea 2:6

ព័ត៌មានទូទៅ

ព្រះអម្ចាស់មានបន្ទូលមកលោកហូសេ។

ដូច្នេះ យើងនឹងស្រាស់ផ្លូវនាងដោយបន្លា ហើយសង់កំផែងទាស់នឹងនាង ដើម្បីកុំឲ្យនាងរកផ្លូវឃើញ
ឡើយ

អត្ថបទនេះបង្ហាញថាព្រះអម្ចាស់នឹងរារាំងប្រជារាស្ត្ររបស់ព្រះអង្គពីការស្វែងរកជ័យជម្នះ

ព្រោះពួកគេនៅតែបន្តថ្វាយបង្គំរូបព្រះ។

ខ្ញុំនឹងវិលទៅរកប្តីដើមខ្ញុំវិញ ដ្បិតនៅគ្រាកន្លង គឺប្រសើរជាងពេលនេះ

អ៊ីស្រាអែលនឹងត្រឡប់មកព្រះអម្ចាស់វិញ
មិនមែនដោយសារតែសេចក្តីស្រឡាញ់ដែលពួកគេមានសម្រាប់ព្រះអង្គទេ
ប៉ុន្តែដោយសារពួកគេបាក់ទឹកចិត្តពីការថ្វាយបង្គំព្រះបាល។

Hosea 2:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូលមកកាន់លោកហូសេ។

យើងក៏នឹងដកយករោមចៀម និងខ្លូតទេសរបស់យើង ដែលសម្រាប់បិទបាំងភាពអាក្រាតរបស់នាង
មកវិញដែរ

នេះប្រហែលជាមានន័យថាការច្រូតកាត់
និងហ្វូងសត្វរបស់អ៊ីស្រាអែលនឹងគ្មានកើតផល។

ព្រះអម្ចាស់នឹងដកព្រះពររបស់ព្រះអង្គចេញពីអ៊ីស្រាអែល
ហើយប្រជាជននឹងនៅឯកកោរ ហើយស្ថិតក្នុងការរាយប្រហារដ៏គ្រោះថ្នាក់។

ដែលសម្រាប់បិទបាំងភាពអាក្រាតរបស់នាង

ការនេះលើកឡើងក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលមនុស្សប្រើសម្រាប់បិតបាំងកាយរបស់ពួកគេ»។

Hosea 2:10

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូលមកលោកហូសេ។

នៅមុខគូស្នេហ៍របស់នាង

មានន័យថាព្រះអម្ចាស់នឹងធ្វើឲ្យប្រជាជនអ៊ីស្រាអែលអាម៉ាស់នៅចំពោះមុខជាតិសាសន៍ផ្សេងទៀតនៅជិ

សូមមើលការបកប្រែនៅក្នុងជំពូក ២:២។

គ្មានអ្នកណាអាចដោះនាងចេញពីដៃយើងបានឡើយ

គ្មាននរណាម្នាក់នឹងព្យាយាមជួយអ៊ីស្រាអែលឡើយ។ នៅទីនេះ «ដៃ»
សំដៅលើអំណាចនៃការដាក់ទោសរបស់ព្រះអង្គ។

Hosea 2:12

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូលមកលោកហូសេ។

ចម្ការទាំងនេះជាឈ្នួលដែលគូស្នេហ៍របស់ខ្ញុំបានឲ្យ

ការនេះសំដៅលើឈ្នួលដែលអ៊ីស្រាអែលបានទទួលពីព្រះក្លែងក្លាយ ឬព្រះបាល។
ការលើកឡើងចំៗ អាចថាជាការលើកឡើងចំៗ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះជាឈ្នួលដែលគូស្នេហ៍របស់នាងបានប្រគល់ឲ្យនាង»។

ធ្វើឲ្យចម្ការទាំងនោះត្រឡប់ទៅជាព្រៃ

ព្រះអម្ចាស់ នឹងបំផ្លាញដើមទំពាំងបាយជូរ និងដើមឈើផ្តល់ផ្លែ
ដោយអនុញ្ញាតិឲ្យដើមឈើ និងព្រៃដុះក្នុងចំណោមដើមទាំងនោះ។

នេះជាព្រះបន្ទូលនៃព្រះអម្ចាស់

«អ្វីដែលព្រះអម្ចាស់បានប្រកាស» ឬ
«អ្វីដែលព្រះអម្ចាស់បានមានបន្ទូលយ៉ាងម៉ត់ចត់»។

Hosea 2:14

ឃ្លាភ្ជាប់៖

ព្រះអម្ចាស់មានបន្ទូលមកអ៊ីស្រាអែល។

យើងនឹងឈ្នះចិត្តនាងមកវិញ

«យើង ព្រះអម្ចាស់សូមនាំនាងមកយើងវិញ»។

ធ្វើឲ្យជ្រលងភ្នំអាកោរ ក្លាយជាទ្វារនៃសេចក្តីសង្ឃឹម

ដូចដែលព្រះអម្ចាស់បាននាំជនជាតិអ៊ីស្រាអែលចេញពីអេស៊ីប
ព្រះអង្គនឹងនាំអ៊ីស្រាអែលទៅជ្រលងភ្នំអាកោរ
ដូច្នេះអ៊ីស្រាអែលនឹងមានក្តីសង្ឃឹមម្តងទៀតក្នុងព្រះអម្ចាស់។

ជ្រលងភ្នំអាកោរជាកន្លែងដែលប្រជាជនអ៊ីស្រាអែលបានគប់សម្លាប់អេកានតាមបញ្ជារបស់ព្រះអម្ចាស់
ព្រោះអេកានមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់។

អត្ថន័យពេញនៃពាក្យនេះអាចបកស្រាយបន្ថែមទៀត។

នាងនឹងឆ្លើយតបមកយើង ដូចគ្រានៅពីក្មេង គឺដូចគ្រាដែលនាងបានចេញពីស្រុកអេស៊ីប

ព្រះអម្ចាស់សង្ឃឹមថាជាតិសាសន៍អ៊ីស្រាអែលនឹងប្រែចិត្ត
ហើយជ្រើសរើសថ្វាយបង្គំព្រះអង្គជាព្រះរបស់ពួកគេម្តងទៀត។

នាងនឹងឆ្លើយតប

ការបកប្រែថ្មីខ្លះដែលយល់ភាសាហេព្រើរបកថា: «នាងនឹងច្រៀង»។

Hosea 2:16

នៅថ្ងៃនោះ

អត្ថបទនេះបង្ហាញថាអ៊ីស្រាអែលជ្រើសរើសថ្វាយបង្គំព្រះអម្ចាស់តែមួយគត់។

ព្រះអម្ចាស់មានព្រះបន្ទូល

«អ្វីដែលព្រះអម្ចាស់មានបន្ទូល» ឬ
«អ្វីដែលព្រះអម្ចាស់មានបន្ទូលយ៉ាងម៉ឺងម៉ាត់»។ សូមមើលការបកប្រែនៅក្នុងជំពូក
២:២។

លោកប្តី

ពាក្យនេះមានន័យថាប្រជារាស្ត្រអ៊ីស្រាអែលនឹងស្រឡាញ់
និងស្មោះត្រង់ចំពោះព្រះអម្ចាស់ ដូចដែលប្រពន្ធធ្វើចំពោះប្តីខ្លួន។

ព្រះបាល

«ព្រះបាល» មានន័យថា «ចៅហ្វាយ»
ហើយក៏សំដៅទៅលើព្រះក្លែងក្លាយដែលជនជាតិកាណានថ្វាយបង្គំ។

បិតយើងនឹងដកឈ្មោះព្រះបាលទាំងនោះចេញពីមាត់នាង

generated on Wed Sep 10 16:16:32 2025

ប្រជាជនអ៊ីស្រាអែលនឹងមិននិយាយពីនាមរបស់ព្រះបាល និងរូបព្រះទៀតទេ។
Hosea 2:18
ឃ្លាភ្ជាប់:
ព្រះអម្ចាស់មានបន្ទូលមកលោកហូសេអំពីអ្វីដែលលោកនឹងប្រព្រឹត្តចំពោះអ៊ីស្រាអែល។
នៅថ្ងៃនោះ
ឃ្លានេះគឺប្រើក្នុងការនិយាយអំពីអនាគតនៃការស្តារឡើងវិញរវាងអ៊ីស្រាអែល
និងព្រះអម្ចាស់។
នឹងតាំងសញ្ញាមួយសម្រាប់ពួកគេ
សម្ពន្ធមេត្រីថ្មីរបស់ព្រះអម្ចាស់នឹងរួមបញ្ចូលទាំងសន្តិភាពជាមួយសត្វ។
យើងនឹងបំបាត់ធ្នូ ដាវ និងសង្គ្រាមចេញពីទឹកដី ហើយយើងនឹងធ្វើឲ្យអ្នកដេកយ៉ាងសុខសាន្ត
ព្រះអម្ចាស់នឹងឲ្យសត្រូវរបស់អ៊ីស្រាអែលនៅឆ្ងាយពីពួកគេ នឹងគ្មានសង្គ្រាមទៀតទេ
ប្រជាជននឹងរស់ដោយសុវត្ថិភាព។
ដេកយ៉ាងសុខសាន្ត
ការលើកឡើងនេះសំដៅលើការរស់នៅដោយសុវត្ថិភាព។
Hosea 2:19
ព័ត៌មានទូទៅ:
ព្រះអម្ចាស់គឺកំពុងមានបន្ទូលទៅលោកហូសេអំពីអ្វីដែលព្រះអង្គនឹងធ្វើជាមួយអ៊ីស្រាអែល។
យើងសន្យាថានឹងជាប្តីរបស់នាងជារៀងរហូត
ព្រះអម្ចាស់នឹងដូចជាស្វាមី ហើយអ៊ីស្រាអែលនឹងដូចជាភរិយារបស់ព្រះអង្គ។
យើងសន្យាថានឹងធ្វើជាប្តីរបស់នាង ដោយសេចក្តីសុចរិត
ព្រះអម្ចាស់នឹងស្មោះត្រង់ចំពោះសម្ពន្ធមេត្រីរបស់ព្រះអង្គជាមួយអ៊ីស្រាអែល។
ប្តីដោយសេចក្តីសុចរិត
«ជាប្តីដ៏ស្មោះត្រង់»
ហើយនាងនឹងស្គាល់យើងជាព្រះអម្ចាស់
នៅទីនេះ «ស្គាល់» មានន័យថាទទួលស្គាល់ព្រះអម្ចាស់ជាព្រះរបស់ពួកគេ
ហើយស្មោះត្រង់នឹងព្រះអង្គ។
Hosea 2:21
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់គឺកំពុងនិយាយទៅលោកហូសេអំពីអ្វីដែលព្រះអង្គនឹងប្រព្រឹត្តជាមួយអ៊ីស្រាអែល។
ព្រះអម្ចាស់មានព្រះបន្ទូល
«អ្វីដែលព្រះអម្ចាស់មានបន្ទូល» ឬ
«អ្វីដែលព្រះអម្ចាស់មានបន្ទូលយ៉ាងម៉ឺងម៉ាត់»។ សូមមើលការបកប្រែនៅក្នុងជំពូក ២:១២។
ចំណែកផែនដីនឹងឆ្លើយតបដល់ស្រូវ ហើយស្រាថ្មី និងប្រេង គេនឹងឆ្លើយតបដល់យេសរាល
ដីនឹងផ្តល់នូវធញ្ញជាតិគ្រប់យ៉ាង ស្រាថ្មី និងប្រេងអូលីវ។
របស់ទាំងអស់នេះក៏បំពេញសេចក្តីត្រូវការរបស់យេសរាល។
ទឹកដីនឹងផលិតផលទាំងនេះ
គឺនិយាយដូចជាមនុស្សអាចបំពេញតម្រូវការដល់អ្នកដទៃ។
យេសរាល
នៅទីនេះឈ្មោះជ្រលងភ្នំសំដៅទៅលើប្រជាជនអ៊ីស្រាអែលទាំងមូល។
Hosea 2:23
ព័ត៌មានទូទៅ:
ព្រះអម្ចាស់គឺកំពុងមានបន្ទូលមកលោកហូសេអំពីអ្វីដែលព្រះអង្គនឹងប្រព្រឹត្តចំពោះអ៊ីស្រាអែល។
យើងនឹងសាបព្រោះពូជគេនៅលើផែនដីសម្រាប់យើង
នៅពេលដែលព្រះជាម្ចាស់ធ្វើឲ្យប្រជារាស្ត្ររបស់ព្រះអង្គមានសុវត្ថិភាព
និងចម្រុងចម្រើននៅក្នុងទឹកដីរបស់ពួកគេម្តងទៀត
ថាពួកគេនិយាយពីដំណាំកសិកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
យើងនឹងថែរក្សាប្រជាជនអ៊ីស្រាអែល ដូចមនុស្សម្នាក់ដាំដំណាំរបស់ខ្លួន
ហើយថែរក្សាដំណាំនោះ»។
ឡូរូហាម៉ា
ឈ្មោះនេះមានន័យថា: «គ្មានព្រះគុណ»។
អ្នកបកប្រែក៏អាចប្រើពាក្យនេះជាឈ្មោះបានដែរ។
សូមមើលការបកប្រែនៅក្នុងជំពូក ១:៦។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានព្រះគុណ»
ឡូ អាំមី
ឈ្មោះនេះមានន័យថា «មិនមែនជាប្រជារាស្ត្ររបស់យើង»។
អ្នកបកប្រែអាចប្រើពាក្យនេះជាឈ្មោះ។ សូមមើលការបកប្រែនៅក្នុង ១:៨។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនមែនជាប្រជារាស្ត្ររបស់យើង»។
អ្នកជាប្រជារាស្ត្ររបស់យើង
ឈ្មោះនេះមានន័យថា «អ្នកជាប្រជារាស្ត្ររបស់យើង»។
អ្នកបកប្រែអាចប្រើពាក្យនេះជាឈ្មោះ។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកជា
ប្រជារាស្ត្ររបស់យើង»។

3 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ចូរទៅម្តងទៀត ស្រឡាញ់ស្ត្រីនេះ ដូចជាប្តីរបស់នាង តែនាងជាស្រីផិតក្បត់។ ចូរស្រឡាញ់នាង ដូចព្រះអម្ចាស់ស្រឡាញ់ជនជាតិ
អ៊ីស្រាអែល ទោះបីពួកគេបែរចិត្តទៅរកព្រះដទៃ ហើយចូលចិត្តនំទំពាំងបាយជូរក៏ដោយ»។[2]ដូច្នោះខ្ញុំក៏លោះនាងមកវិញ ដោយបង់ប្រាក់បួនតម្លឹងកន្លះ និងស្រូវប្រាំមួយ
ចាំង។[3]ខ្ញុំបាននិយាយនាងថា «នាងត្រូវរស់នៅជាមួយខ្ញុំឲ្យបានច្រើនថ្ងៃ ចូរឈប់ធ្វើស្ត្រីពេស្យា ហើយឈប់ស្រឡាញ់បុរសផ្សេងទៀតទៅ នោះខ្ញុំនឹងប្រព្រឹត្តចំពោះនាងវិញ
ដូច្នោះដែរ»។
[4]ដ្បិតជនជាតិអ៊ីស្រាអែល នឹងរស់នៅរយៈពេលយូរ ដោយគ្មានស្តេច គ្មានមេដឹកនាំ គ្មានយញ្ញបូជា គ្មានស្លុប គ្មានអាវបូជាចារ្យ ឬអសនៈព្រះក្លែងក្លាយ ។[5]ក្រោយមក
ជនជាតិអ៊ីស្រាអែលនឹងនាំគ្នាវិលមកវិញ ពួកគេស្វែងរកព្រះអម្ចាស់ជាព្រះរបស់ពួកគេ ព្រមទាំងព្រះបាទដាវីឌជាស្តេចរបស់ពួកគេ នៅថ្ងៃចុងក្រោយ ពួកគេ
នឹងញាប់ញ័រចំពោះ ព្រះអម្ចាស់ ហើយស្វែងរកព្រះទ័យរបស់ព្រះអង្គ។

Hosea 3:1
ចូរទៅស្រឡាញ់ស្ត្រីនេះ ដូចជាប្តីរបស់នាង តែនាងជាស្រីផិតក្បត់
ការនេះសំដៅត្រឡប់ទៅរក ១:១។
ព្រះអម្ចាស់បានប្រាប់លោកហូសេម្តងទៀតឲ្យស្រឡាញ់ស្រីផិតក្បត់។
ចូរស្រឡាញ់នាង ដូចព្រះអម្ចាស់ស្រឡាញ់ជនជាតិអ៊ីស្រាអែល
ដោយការស្រឡាញ់ស្រីផិតក្បត់
លោកហូសេនឹងក្លាយជាគំរូនៃក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះអ៊ីស្រាអែល។
ពួកគេបែរចិត្តទៅរកព្រះដទៃ ហើយចូលចិត្តនំទំពាំងបាយជូរ
ប្រជាជនបរិភោគនំធ្វើពីទំពាំងបាយជូរ
ឬពីផ្លែឧទម្ពរក្នុងពេលមានពិធីបុណ្យនៅកន្លែងដែលគេថ្វាយបង្គំព្រះដទៃ។
បង់ប្រាក់បួនតម្លឹងកន្លះ និងស្រូវប្រាំមួយចាំង
នេះជាតម្លៃមួយស្មើរការទិញទាសករ។
បួនតម្លឹងកន្លះ
«ដប់ប្រាំចំនែក»
ស្រូវប្រាំមួយចាំង
«មួយចាំង»
Hosea 3:4
ជនជាតិអ៊ីស្រាអែលនឹងគ្មានស្តេច គ្មានមេដឹកនាំ គ្មានយញ្ញបូជា គ្មានស្លុប គ្មានឧបករណ៍ ឬគ្រឿង
ប្រដាប់សម្រាប់ទស្សន៍ទាយ និងបួងសួងទេ
ដូចដែលលោកហូសេរស់នៅដោយគ្មានប្រពន្ធរបស់គាត់ ដោយសារនាងផិតក្បត់
ជនជាតិអ៊ីស្រាអែលនឹងរស់នៅដោយគ្មានស្តេច និងគ្មានការថ្វាយបង្គំព្រះជាម្ចាស់
ព្រោះពួកគេបានផិតក្បត់។
ស្វែងរកព្រះអម្ចាស់ជាព្រះរបស់ពួកគេ
នៅទីនេះ «ស្វែងរក» មានន័យថាពួកគេសុំឲ្យព្រះជាម្ចាស់ទទួលពួកគេ
និងការថ្វាយបង្គំរបស់ពួកគេ។
ព្រះបាទដាវីឌជាស្តេចរបស់ពួកគេ
នៅទីនេះ «ដាវីឌ» ដំណាងឲ្យពូជពង្សទាំងអស់របស់ដាវីឌ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពូជពង្សរបស់ព្រះបាទដាវីឌម្នាក់នឹងធ្វើជាព្រះមហាក្សត្រលើពួកគេ»។
នៅថ្ងៃចុងក្រោយ
នៅទីនេះ «ថ្ងៃចុងក្រោយ» សំដៅទៅលើកំឡុងពេលមួយនៅក្នុងថ្ងៃអនាគត។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្នុងថ្ងៃអនាគត»
ពួកគេនឹងញាប់ញ័រចំពោះព្រះអម្ចាស់ ហើយស្វែងរកព្រះទ័យរបស់ព្រះអង្គ
នៅទីនេះ «ញាប់ញ័រ» សំដៅលើអារម្មណ៍នៃការគោរព និងបន្ទាបខ្លួន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងត្រឡប់មកព្រះអម្ចាស់វិញ
ហើយពួកគេនឹងបន្ទាបខ្លួន គោរពព្រះអង្គ និងសូមព្រះពរពីព្រះអង្គ»។

generated on Wed Sep 10 16:16:32 2025

4 [1]ជនជាតិអ៊ីស្រាអែលអើយ ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់។ ព្រះអម្ចាស់កំពុងតែទាស់នឹងមនុស្សដែលនៅលើទឹកដីនេះ ដោយព្រោះគ្មានអ្នកណាស្មោះត្រង់ គ្មានភក្តីភាព ហើយក៏គ្មាននរណាទទួលស្គាល់ព្រះជាម្ចាស់ក្នុងទឹកដីដែរ។[2]គឺជាការដាក់បណ្តាសាគ្នា ការបោកប្រាស់គ្នា សម្លាប់គ្នា អំពើចោរកម្ម និងការផិតក្បត់។ មនុស្សបំបាក់ឆ្អឹងទាំងនោះ ហើយឈាមនឹងហូរចុះមកមិនចេះដាក់។
[3]ដូច្នេះទឹកដីគឺរាំងស្ងួត ហើយមនុស្សទាំងអស់ដែលរស់នៅលើទឹកដីនេះនឹងវិនាសអស់ទៅ រួមទាំងសត្វព្រៃដែលនៅទីវាល និងបក្សាបក្សីដេលនៅលើមេឃ ហើយត្រីដែលនៅក្នុងសមុទ្រក៏ត្រូវវិនាសសូន្យអស់។
[4]ប៉ុន្តែ មិនត្រូវឲ្យនរណានាំនូវការពាក្យបណ្តឹង ហើយកុំឲ្យនរណាម្នាក់ចោទប្រកាន់នរណាម្នាក់ឡើយ។ ដ្បិតគឺជាអ្នក ដែលជាបូជាចារ្យទទួលការបន្ទោសពីយើង។
[5]អ្នកគឺបូជាចារ្យនឹងជំពប់ដួលនៅពេលថ្ងៃ ពួកព្យាការីនឹងជំពប់ដួលជាមួយអ្នកនៅពេលយប់ ហើយយើងនឹងបំផ្លាញម្តាយរបស់អ្នក។
[6]ប្រជាជនរបស់យើងត្រូវបានបំផ្លាញ ពីព្រោះពួកគេខ្វះការចេះដឹង។ ដោយអ្នកជាបូជាចារ្យបានបដិសេធការទទួលស្គាល់ យើងនឹងបដិសេធអ្នកជាបូជាចារ្យរបស់យើង។ ដោយអ្នកបានបំភ្លេចក្រឹត្យវិន័យរបស់យើង ទោះយើងជាព្រះជាម្ចាស់របស់អ្នក យើងនឹងបំភ្លេចកូនចៅរបស់អ្នកដែរ។[7]ពួកបូជាចារ្យកាន់តែចម្រើនឡើង អំពើបាបក៏កាន់តែទាស់ប្រឆាំងនឹងយើង។ ពួកគេប្តូរកិត្តិយសរបស់ខ្លួន សម្រាប់ការអាម៉ាស់វិញ។
[8]ពួកគេបានឆ្អែតដោយសារប្រជាជនរបស់យើង ហើយពួកគេល្មោបប្រព្រឹត្តអំពើអាក្រក់។[9]បូជាចារ្យក៏ដូចជាប្រជាជនដែរ យើងនឹងដាក់ទោសពួកគេតាមអំពើដែលខ្លួនប្រព្រឹត្ត យើងនឹងសងសឹកពួកគេសម្រាប់ការប្រព្រឹត្តរបស់ពួកគេ។
[10]ពួកគេបរិភោគតែមិនចេះឆ្អែត ពួកគេប្រព្រឹត្តអំពើពេស្យាចារ តែមិនបានចម្រុងចម្រើនទេ ដោយព្រោះពួកគេចាកឆ្ងាយពីយើង ព្រះអម្ចាស់។
[11]ពួកគេចូលចិត្តការអសីលធម៌ អំពើពេស្យាចារ ហើយចូលចិត្តស្រា និងស្រាថ្មី ដែលបានធ្វើឲ្យស្មារតីរបស់ពួកវង្វេង។[12]ប្រជារាស្ត្ររបស់យើងទៅរកព្រះដែលធ្វើពីឈើ ឲ្យទស្សន៍ទាយ ដំបងរបស់គេប្រាប់សេចក្តីដែលគេចង់ដឹង។ ដ្បិតគំនិតពេស្យាចារបាននាំពួកគេឲ្យវង្វេង ហើយពួកគេប្រព្រឹត្តអំពើពេស្យាចារ ដោយងាកចេញពីព្រះជាម្ចាស់របស់ខ្លួន។
[13]ពួកគេថ្វាយយញ្ញបូជានៅតាមកំពូលភ្នំ ហើយដុតគ្រឿងកំញានតាមជ្រលោងភ្នំ នៅក្រោមដើមជ្រៃ ក្រោមដើមពោធិ និងក្រោមដើមម៉ៃសាក់ ដោយព្រោះមានម្លប់ដ៏ត្រជាក់ល្អ។ ដូច្នេះកូនស្រីរបស់អ្នក ប្រព្រឹត្តអំពើពេស្យាចារ ហើយកូនប្រសាស្រីរបស់អ្នក ប្រព្រឹត្តអំពើផិតក្បត់ដែរ។[14]យើងមិនដាក់ទោសកូនស្រីរបស់អ្នក ពេលគេបានជ្រើសរើសប្រព្រឹត្តអំពើពេស្យាចារ ហើយក៏មិនដាក់ទោសកូនប្រសាស្រីរបស់អ្នក នៅពេលគេប្រព្រឹត្តអំពើផិតក្បត់។ ដ្បិតពួកបុរសបានឲ្យខ្លួនគេរួមជាមួយសេចក្តី កំផិតដែរ និងគេថ្វាយយញ្ញបូជា ដើម្បីពួកគេអាចធ្វើអំពើអសីលធម៌ ជាមួយស្រីពេស្យាដែរ។ ដូច្នោះប្រជាជនទាំងនេះដែលមិនបានយល់ នឹងទំលាក់ចុះ។
[15]អ៊ីស្រាអែលអើយ ទោះបើអ្នកប្រព្រឹត្តអំពើពេស្យាចារក្តី យូដាមិនបានទៅជាមានទោសទេ។ មនុស្សអើយ កុំឲ្យទៅគីលកាល់ និងកុំទៅបេតអាវេន ហើយកុំឲ្យស្បថដោយនិយាយថា «ដូចព្រះអម្ចាស់ដ៏មានព្រះជន្មរស់»។[16]ដ្បិតអ៊ីស្រាអែលមានចិត្តរឹងរូសដូចគោញី។ តើព្រះអម្ចាស់នឹងនាំពួកគេទៅវាលស្មៅដូចកូនចៀម នៅតាមវាលស្មៅបាននោះ?
[17]អេប្រាអ៊ីមចូលរួមជាមួយព្រះក្លែងក្លាយ ចូរចាកចេញពីគេទៅ។[18]ទោះបីពួកគេបានស្វាងស្រាទៅហើយនោះ ពួកគេនៅតែប្រព្រឹត្តអំពើពេស្យាចារ អ្នកដឹកនាំរបស់ពួកគេចូលចិត្តភាពអាម៉ាស់។[19]ខ្យល់នឹងកួចពួកគេយកទៅជាមួយនឹងស្លាបវា ហើយពួកគេនឹងត្រូវខ្មាស ព្រោះតែយញ្ញបូជារបស់ខ្លួន។

Hosea 4:1
ព័ត៌មានទូទៅ:
នៅក្នុងជំពូកនេះនិយាយអំពីការវែកញែករបស់ព្រះអម្ចាស់ចំពោះជនជាតិអ៊ីស្រាអែលដែលព្រះអង្គមិនសប្បាយព្រះទ័យ
ព្រះអម្ចាស់កំពុងតែទាស់នឹងមនុស្សដែលនៅលើទឹកដីនេះ
ព្រះអម្ចាស់លើកឡើងថាប្រជាជនអ៊ីស្រាអែលប្រព្រឹត្តអំពើបាបប្រឆាំងនឹងព្រះអង្គ ហើយបានផ្តាច់សម្ពន្ធមេត្រីរបស់ព្រះអង្គ
គឺមានបន្ទូលឡើងដូចជាព្រះអម្ចាស់ចោទពួកគេនៅក្នុងតុលាការដែរ។
បណ្តឹង
នេះជាការចោទប្រកាន់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតនៅក្នុងតុលាការ។
សូមមើលការបកប្រែនៅក្នុងជំពូក ២:២។
មនុស្សាបានបំបាក់ឆ្អឹង
នៅទីនេះ «ឆ្អឹង» សំដៅទៅលើដែនកំណត់ដែលច្បាប់អនុញ្ញាតិ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនមិនស្តាប់បង្គាប់ច្បាប់នូវអ្វីដែលគេអាចធ្វើបាន»។
ឃាតកម្ម ជាបន្តបន្ទាប់គ្នា
នៅទីនេះ «ឃាតកម្ម» សំដៅទៅលើ «ការសម្លាប់មនុស្សឥតទោស» ដែលតែងតែធ្វើឲ្យជនរងគ្រោះមានឈាម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកសំលាប់ជនឥតទោសម្នាក់ហើយម្នាក់ទៀត»
Hosea 4:3
ទឹកដីក៏រាំងស្ងួត
ការលើកឡើងនេះសំដៅទៅលើភាពរាំងស្ងួត
នៅពេលដែលគ្មានភ្លៀងអស់រយៈពេលយ៉ាងយូរ។
ធ្លាក់ទន់ខ្សោយ
ការធ្លាក់ទន់ខ្សោយ និងស្លាប់ដោយសារជំងឺ ឬខ្វះអាហារ។
ត្រូវវិនាសសូន្យ
ការនេះលើកឡើងក្នុងទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «កំពុងស្លាប់»
Hosea 4:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលពីអ៊ីស្រាអែល។
ការប្តឹង
ការប្តឹងផ្តល់ពីមនុស្សម្នាក់លើមនុស្សម្នាក់ទៀតនៅក្នុងតុលាការ។
កុំឲ្យនរណាម្នាក់ស្តីបន្ទោសនរណាម្នាក់ឡើយ
មិនត្រូវឲ្យនរណាម្នាក់ចោទប្រកាន់គេដោយហេតុណាមួយឡើយ
ព្រោះមិនមានបញ្ហាត្រង់ណាមានកំហុសអ្វីមួយ។
ព្យាការីអើយអ្នកនឹងជំពប់ដួល
នៅទីនេះ «ជំពប់ដួល» មានន័យថាការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ឬក៏ឈប់ទុកចិត្តព្រះអង្គ។
យើងនឹងធ្វើឲ្យម្តាយរបស់អ្នកត្រូវវិនាស
នៅទីនេះ «ម្តាយ» សំដៅទៅលើជាតិសាសន៍អ៊ីស្រាអែល។
សូមមើលការបកប្រែនៅក្នុងជំពូក ២:២។
Hosea 4:6
ព័ត៌មានទូទៅ:
នៅក្នុងជំពូក ៤:៦
ព្រះអម្ចាស់មានបន្ទូលទៅកាន់ពួកបូជាចារ្យអំពីប្រជាជនអ៊ីស្រាអែល។ ប៉ុន្តែនៅក្នុងជំពូក ៤:៧ ព្រះអង្គមានបន្ទូលអំពីពួកបូជាចារ្យ មិនមែនទៅកាន់ពួកគេទេ។
សម្រាប់អ្នកបកប្រែក៏អាចយកគំរូតាម UDB,
ដែលបានរៀបរាប់ថាព្រះអម្ចាស់មានបន្ទូលទៅកាន់ពួកបូជាចារ្យ ទាំងនៅក្នុងជំពូក ៤:៧។
ប្រជាជនរបស់យើងត្រូវវិនាស ពីព្រោះពួកគេគ្មានប្រាជ្ញា
ការនេះអាចលើកឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនរបស់យើងគឺកំពុងតែវិនាសដោយសារអ្នកជាបូជាចារ្យ
អ្នកមិនបានបង្រៀនគេឲ្យបានត្រឹមត្រូវដើម្បីឲ្យគេគោរពយើងទេ»។
ប្រាជ្ញា
នៅកន្លែងនេះ «ប្រាជ្ញា» សំដៅលើចំណេះដឹងពីព្រះជាម្ចាស់។
កិត្តិយសរបស់ពួកគេ ទៅជាការអាម៉ាស់វិញ
អត្ថន័យដែលអាចទៅរួចគឺ ១) «ការគោរព»
នេះជាការប្រៀបធៀបដែលដំណាងឲ្យព្រះអម្ចាស់ ហើយ «ការអាម៉ាស់»
គឺជាការប្រៀបធៀបដែលតំណាងឲ្យរូបព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេឈប់ថ្វាយបង្គំយើង ជាព្រះដែលពួកគេត្រូវគោរព
ហើយឥឡូវនេះបានថ្វាយបង្គំរូបព្រះដ៏គួរឲ្យអាម៉ាស់» ឬ
២)ការបកប្រែគម្ពីរខ្លះបកប្រែថា «យើងនឹងបូរពីការគោរពទៅជាភាពអាម៉ាស់វិញ»។
ការនេះមានន័យថាព្រះអម្ចាស់នឹងដកការដែលពួកបូជាចារ្យត្រូវគោរព

generated on Wed Sep 10 16:16:32 2025

ហើយធ្វើឲ្យពួកបូជាចារ្យត្រូវអាម៉ាស់។
Hosea 4:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តនិយាយអំពីបូជាចារ្យ។
ពួកគេបានឆ្អែតដោយសារបាបរបស់ប្រជាជនរបស់យើង
នៅពេលដែលប្រជាជនប្រព្រឹត្តអំពើបាប ពួកគេនឹងថ្វាយយញ្ញបូជាដូច្នេះ
ព្រះជាម្ចាស់នឹងអត់ទោសបាបដល់គេ។
ពួកបូជាចារ្យត្រូវបានអនុញ្ញាតិឲ្យបរិភោគយញ្ញបូជាទាំងនោះ។
ពួកបូជាចារ្យបរិភោគយញ្ញបូជាទាំងនេះគឺហាក់បីដូចជាពួកគេត្រូវចិញ្ចឹមខ្លួនដោយសារអំពើ
ពួកគេលោភប្រព្រឹត្តអំពើអាក្រក់
ពួកបូជាចារ្យចង់ឲ្យប្រជាជនប្រព្រឹត្តអំពើបាបច្រើនជាងមុន ដូច្នេះ
ប្រជាជននឹងថ្វាយយញ្ញបូជាកាន់តែច្រើន ដូច្នេះ ពួកគេនឹងបរិភោគរបស់ទាំងនោះ។
បូជាចារ្យក៏ដូចជាប្រជាជនដែរ យើងនឹងដាក់ទោសពួកគេ
«ប្រជាជន និងពួកបូជាចារ្យនឹងត្រូវទទួលការដាក់ទោសដូចគ្នា»។
ការប្រព្រឹត្តរបស់ពួកគេ
«ទម្លាប់របស់ពួកគេ» ឬ «អំពើរបស់ពួកគេ»។
Hosea 4:10
ព័ត៌មានទូទៅ
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
តែមិនបានចម្រុងចម្រើនទេ
«ប៉ុន្តែ មិនមានកូនទេ»។
ពួកគេទៅឆ្ងាយ
មនុស្សបានឈប់ថ្វាយបង្គំ និងដើរតាមព្រះអម្ចាស់។
ពីព្រះអម្ចាស់
អ្នកបកប្រែអាចប្តូរពី «ព្រះអម្ចាស់» ទៅជា «យើង»
ព្រោះព្រះអម្ចាស់ជាអ្នកមានបន្ទូល។ យើងក៏អាចមើលក្នុង UDB។
Hosea 4:11
ឃ្លាភ្ជាប់
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
អំពើពេស្យាចារ ចិត្តប្រាថ្នាចង់ បានស្រាចាស់ ហើយនិងស្រាថ្មី បាននាំពួកគេឲ្យវង្វេង
ប្រជាជនអ៊ីស្រាអែលមានទំនាក់ទំនងផ្លូវភេទក្រៅរង្វង់អាពាហ៍ពិពាហ៍
ហើយផឹកស្រាជ្រុល។
ក្នុងការប្រព្រឹត្តរឿងទាំងអស់នេះពួកគេភ្លេចការបង្គាប់របស់ព្រះអម្ចាស់។
ការនេះយើងអាចនិយាយបានថាជានរណាម្នាក់ដែលរារាំងមិនឲ្យមនុស្សបានយល់ពីសេចក្តីពិត
ដំបងរបស់គេប្រាប់សេចក្តីដែលគេចង់ដឹង
អ្នកថ្វាយបង្គំរូបព្រះបានប្រើដំបងរបស់គេដើម្បីទាយពីថ្ងៃអនាគត។
ដំបងនៅទីនេះគឺចង់សំដៅលើអ្នកដែលថ្លែងទំនាយ។
គំនិតពេស្យាចារបាននាំពួកគេឲ្យវង្វេង
ការថ្វាយបង្គំរូបព្រះ
និងការរួមរស់ជាមួយពួកស្ត្រីពេស្យានៅក្នុងវិហារទាំងនោះបានកើនឡើងច្រើនក្នុងចំណោមប្រជាជនអ៊ីស្រាអែល
គេប្រាថ្នាចង់ប្រព្រឹត្តបាបទាស់នឹងព្រះអម្ចាស់នៅពេលនោះ។ នៅទីនេះ «គំនិត»
គឺចង់សំដៅលើអ្នកដែលអាចលួងលោមមនុស្សកុំឲ្យស្តាប់បង្គាប់ព្រះជាម្ចាស់។
នាំពួកគេឲ្យវង្វេង
ការជំរុញឲ្យមនុស្សប្រព្រឹត្តបាប។ (សូមមើល: figs-metaphor)
Hosea 4:13
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
នៅតាមកំពូលភ្នំ
ជាទូទៅមនុស្សមនុស្សបានដាក់រូបព្រះនៅកន្លែងទាំងនេះ ជាទូទៅគេហៅថា
«ទីខ្ពស់» នៅក្នុងគម្ពីរសញ្ញាចាស់។
ស្រីពេស្យាសក្ការៈ
ស្ត្រីទាំងនេះជាអ្នកដែលមានទំនាក់ទំនងផ្លូវភេទជាមួយប្រុសៗដែលមកថ្វាយបង្គំរូបព្រះនានា។
ទាំងនេះជាការចាត់ទុកថាជាអំពើសក្ការៈក្នុងការគោរពដល់ព្រះក្លែងក្លាយទាំងនោះ។
ប្រជាជនដែលមិនចេះគិតពិចារណានោះ នឹងបោះជំហានទៅរកសេចក្តីវិនាស
ព្រះអម្ចាស់នឹងបំផ្លាញប្រជាជាតិអ៊ីស្រាអែល ព្រោះពួកគេមិនយល់
ឬមិនបានស្តាប់តាមបញ្ញាត្តិរបស់ព្រះអម្ចាស់។
Hosea 4:15
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តនិយាយអំពីយូដា និងអ៊ីស្រាអែល។
មិនគប្បីឲ្យយូដាធ្វើខុសទេ
ព្រះជាម្ចាស់ជ្រាបថាតើអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបអ្វីខ្លះ
ហើយមិនចង់ឲ្យយូដាធ្វើបែបនេះដែលឡើយ។
កុំទៅគីលកាល់ កុំឡើងទៅបេតអាវេន
ប្រជាជននៅក្នុងស្រុកយូដាត្រូវបានប្រមានថាកុំឲ្យឡើងទៅគីលកាល
ឬទីបេតអាវេនដើម្បីថ្វាយបង្គំរូបព្រះនៅក្នុងកន្លែងទាំងនោះ។
គីលកាលគឺជាកន្លែងមួយដែលគេធ្លាប់ថ្វាយបង្គំព្រះអម្ចាស់ ប៉ុន្តែ
វាក្លាយទៅជាកន្លែងថ្វាយបង្គំរូបព្រះ។
បេតអាវែន
ជាទីក្រុងដែលនៅឯព្រំប្រទល់នៃអាណាចក្រអ៊ីស្រាអែលភាគខាងជើង
និងកុលសម្ព័ន្ធបេនយ៉ាមីននៅភាគខាងត្បូង។
ដូចគោញីកៀច
អ៊ីស្រាអែលប្រៀបដូចជាគោស្ទាវដែលមិនស្តាប់តាមម្ចាស់របស់វា។
តើព្រះអម្ចាស់នឹងឃ្វាលពួកគេដូចឃ្វាលកូនចៀម នៅតាមវាលស្មៅបានដូច្នេះទៅ?
ព្រះអម្ចាស់បានប្រើសំណួរដើម្បីបញ្ជាក់ថាព្រះអង្គមិនអាចបន្តថែរក្សាមនុស្សព្រោះពួកគេរឹងរូស។
ព្រះអម្ចាស់នឹងមិនថែរក្សាប្រជាជនរបស់ព្រះអង្គទៀតទេ
ប្រៀបបីដូចជាអ្នកគង្វាលដែលមិនអាចយកចៀមរបស់ខ្លួនទៅឯវាលដើម្បីឲ្យវាស៊ីចំណីបានដោយសារវារឹង
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងមិនឃ្វាលមនុស្សដែលបះបោរឡើយ»។ ឬ
«ដូច្នេះព្រះអម្ចាស់នឹងមិនបន្តមើលថែពួកគេទៀតឡើយ»។
តើព្រះអម្ចាស់នឹងអាច
នៅទីនេះព្រះអម្ចាស់មានបន្ទូលពីអង្គទ្រង់ផ្ទាល់នៅក្នុងទំរង់បុរសទីបី។
យើងក៏អាចលើកឡើងជាបុរសទីមួយដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើយើងអាច»
ការគោរពព្រះអម្ចាស់។
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
អេប្រាអ៊ីមចូលរួមជាមួយព្រះក្លែងក្លាយ សូមទុកឲ្យគេធ្វើការនោះចុះ
នៅទីនេះ «អេប្រាអ៊ីម»
សំដៅទៅលើមនុស្សដែលរស់នៅភាគខាងជើងនៃស្រុកអ៊ីស្រាអែល។
ជាជាងព្រះអម្ចាស់។
ព្រះអម្ចាស់បានបង្គាប់ដល់លោកហូសេកុំឲ្យព្យាយាមកែតម្រូវពួកគេ។
ប្រជាជនអ៊ីស្រាអែលទាំងនេះនឹងមិនស្តាប់ឡើយ។
អ្នកដឹកនាំរបស់ពួកគេចូលចិត្តភាពអាម៉ាស់
អ្នកដឹកនាំមិនចេះអៀនខ្មាសនូវអ្វីដែលពួកគេបានធ្វើឡើយ
នៅពេលដែលពួកគេថ្វាយបង្គំរូបព្រះ ហើយងាកមកប្រឆាំងនឹងព្រះអម្ចាស់វិញ។
ខ្យល់កំបុតត្បូងនឹងក្លួចពួកគេយកទៅ
នៅទីនេះ «ខ្យល់» ដំណាងឲ្យការកាត់ទោសរបស់ព្រះអម្ចាស់
និងកំហឹងរបស់ព្រះអង្គប្រឆាំងនឹងជាតិសាសន៍អ៊ីស្រាអែល។
ព្រះអម្ចាស់នឹងអនុញ្ញាតិឲ្យសត្រូវរបស់គេវាយប្រហារប្រជាជនអ៊ីស្រាអែល
ហើយយកពួកគេធ្វើជាឈ្លើយ។

---

5 [1]«បូជាចារ្យអើយ ចូរស្តាប់ការនេះ! ដោយយកចិត្តទុកដាក់ ពូជពង្សអ៊ីស្រាអែលអើយ! សូមស្តាប់ ញាតិវង្សរបស់ស្តេចអើយ! ដ្បិតការជំនុំជម្រះនឹងមកទាស់
និងអ្នករាល់គ្នា។ អ្នករាល់គ្នាដាក់អន្ទាក់នៅមីសប៉ា អ្នករាល់គ្នាដាក់សំណាញ់នៅលើតាបោរ[2]អ្នកបះបោរឈរជ្រៅក្នុងការសម្លាប់
ប៉ុន្តែយើងនឹងដាក់ទោសពួកគេទាំងអស់។
[3]យើងស្គាល់អេប្រាអ៊ីម ហើយយើងអ៊ីស្រាអែលលាក់បាំងពីយើងបានទេ។ អេប្រាអ៊ីមអើយ អ្នកបានដូចពេស្យាចារ អ៊ីស្រាអែលគឺស្មោកគ្រោក។[4]អំពើដែលពួកគេប្រព្រឹត្ត
មិនអាចឲ្យពួកគេត្រឡប់មករកព្រះជាម្ចាស់បានទេ ដ្បិតគំនិតនៃការកំផិតគឺនៅក្នុងពួកគេ ពួកគេពុំស្គាល់ព្រះអម្ចាស់ដែរ។
[5]អំនួតរបស់អ៊ីស្រាអែលទីបន្ទាល់ទាស់និងខ្លួនគេ ដូច្នេះអ៊ីស្រាអែល និងអេប្រាអ៊ីម នឹងជំពប់ដួល ដោយកំហុសរបស់ខ្លួន ហើយយូដាក៏ជំពប់ដួលជាមួយពួកគេដែរ។[6]ពួកគេ
នាំគ្នាស្វែងរកព្រះអម្ចាស់ ដោយយកចៀម និងគោទៅជាមួយ តែពួកគេរកព្រះអង្គមិនឃើញទេ ដ្បិតព្រះអង្គបានដកចេញពីពួកគេ។[7]ពួកគេ
មិនស្មោះត្រង់ដល់ព្រះអម្ចាស់ ដោយបង្កើតកូនដែលគ្មានខាន់ស្លា។ ឥឡូវនេះ បុណ្យចូលខែថ្មីនឹងលេបត្របាក់ពួកគេ ជាមួយស្រែចម្ការរបស់ពួកគេដែរ។

generated on Wed Sep 10 16:16:32 2025

[8]ចូរផ្លុំស្នែងប្រកាសសឹកនៅគីបៀរ ចូរផ្លុំត្រែប្រកាសភាពអាសន្ននៅរ៉ាម៉ា។ ចូរឲ្យសម្រែកចម្បាំងឮនៅបេតអាវេន «យើងនឹងតាមពីក្រោយអ្នកបេនយ៉ាមីន!»[9]អេប្រាអ៊ីម
នឹងទៅជាខូចបង់នៅថ្ងៃនៃចេសក្តីជំនុំជម្រះ។ នៅក្នុងចំណោម កុលសម្ព័ន្ធទាំងឡាយ នៃអ៊ីស្រាអែលយើងបានប្រកាសពីអ្វីដែលនឹងកើតឡើងហើយ។
[10]ពួកអ្នកដឹកនាំនៃជនជាតិយូដា ដូចអ្នកដែលដកបង្គោលរបងថ្ម។ យើងនឹងជះកំហឹងរបស់យើងលើពួកគេដូចជាទឹក។[11]អេប្រាអ៊ីមនឹងត្រូវកំទេច
គេត្រូវរងការកំទេចក្នុងការជំនុំជម្រះ ដោយព្រោះពួកគេពេញចិត្តដើរតាមព្រះក្លែងក្លាយ។
[12]ដូច្នេះយើងដូចជាអង្កែដល់ពួកអេប្រាអ៊ីម ហើយដូចដំបៅដល់ពួកយូដា។[13]ពេលអេប្រាអ៊ីមឃើញជំងឺរបស់ខ្លួន យូដាក៏ឃើញដំបៅរបស់ខ្លួនដែរ រួចហើយអេប្រាអ៊ីមទៅពឹង
អាស្ស៊ីរី ហើយយូដាចាត់អ្នកនាំសារឲ្យទៅគាល់ស្តេចអធិរាជ។ ប៉ុន្តែ ស្តេចនោះពុំអាចកែរោគអ្នករាល់គ្នា ឬព្យាបាលដំបៅអ្នករាល់គ្នា ឲ្យជាសះបានឡើយ។
[14]ដូច្នោះយើងដូចសិង្ហដល់អេប្រាអ៊ីម និងដូចសិង្ហស្ទាវដល់កូនចៅយូដា។ យើងទោះបើយើងនឹងហែកពួកគេ នោះយើងនឹងយកពួកគេចេញទៅ គ្មាននរណាអាចជួយពួក
គេបានឡើយ។[15]ហើយត្រឡប់មកដំណាក់របស់យើងវិញ រហូតដល់ពួកគេទទួលស្គាល់ទោសកំហុសរបស់គេ ហើយស្វែងរកមុខយើង រហូតដល់គេមានភាពស្មោះត្រង់
ស្វែងរកយើងក្នុងទុក្ខព្រួយរបស់គេ»។

Hosea 5:1
ប្រយោគភ្ជាប់
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
អ្នករាល់គ្នាដាក់អន្ទាក់នៅមីសប៉ា អ្នករាល់គ្នាបោះសំណាញ់នៅភ្នំតាបោរ
អន្ទាក់ និងសំណាញ់ របស់ទាំងពីរនេះប្រើសម្រាប់ចាប់សត្វ។ នៅក្នុងករណីនេះ
ពួកបូជាចារ្យ និងអ្នកនៅក្នុងវាំងបានប្រើវិធីដើម្បីឲ្យមនុស្សនៅឆ្ងាយពីព្រះអម្ចាស់
ហើយនាំឲ្យពួកគេទៅរកបូជាព្រះ។ មីសបា
និងតាបោរជាកន្លែងសម្រាប់ថ្វាយបង្គំរូបព្រះនៅក្នុងទឹកដីអ៊ីស្រាអែល។
អ្នករាល់គ្នាជីករណ្តៅដ៏ជ្រៅ
នៅទីនេះ «បះបោរ» សំដៅទៅលើមនុស្សទាំងឡាយដែលងាកឆ្ងាយពីព្រះអម្ចាស់
ហើយ «នៅក្នុងរណ្តៅដ៏ជ្រៅ» អាចសំដៅទៅលើការសម្លាប់មនុស្សឥតទោស
និងការសម្លាប់សត្វដើម្បីថ្វាយដល់រូបព្រះ។
ការបះបោរ
អ្នកបកប្រែអាចបកកន្លែងនេះថា «អ្នកជាអ្នកបះបោរ»
ព្រោះព្រះអម្ចាស់ពិតមានបន្ទូលពីអ្នកបះបោរនៅក្នុងស្រុកអ៊ីស្រាអែល។
នៅក្នុងរណ្តៅ
ការបកប្រែខ្លះដែលមកពីភាសាហេ ព្រីរថាការឈរនៅខាងការអាក្រក់។
យើងនឹងជំនុំជម្រះពួកគេទាំងនោះ
អ្នកបកប្រែអាចបកថា «យើងនឹងដាក់ទោសអ្នកទាំងអស់គ្នា»។
Hosea 5:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
យើងស្គាល់អេប្រាអ៊ីមយ៉ាងច្បាស់ យើងមើលអ៊ីស្រាអែលធ្លុះទាំងអស់
នៅទីនេះ «អេប្រាអ៊ីម» និង «អ៊ីស្រាអែល»
ទាំងពីរនេះសំដៅទៅលើមនុស្សដែលរស់នៅភាគខាងជើងស្រុកអ៊ីស្រាអែល។
នៅទីនេះព្រះជាម្ចាស់មានបន្ទូលថាព្រះអង្គជ្រាបថាគេយ៉ាងណា
និងជ្រាបពីអ្វីដែលពួកគេធ្វើ។
អេប្រាអ៊ីមអើយឥឡូវនេះអ្នកដូចជាស្ត្រីពេស្យាចារ
នៅត្រង់នេះបង្ហាញថាអេប្រាអ៊ីមដូចជាស្ត្រីពេស្យា
ព្រោះមនុស្សទាំងអស់ក្លាយជាអ្នកមិនស្មោះត្រង់ចំពោះព្រះជាម្ចាស់
ដូចជាស្ត្រីពេស្យាដែលមិនស្មោះត្រង់ចំពោះបុរស។
ដ្បិតពួកគេគិតតែពីប្រព្រឹត្តអំពើពេស្យាចារ
ការនេះមានន័យថាពួកគេមានបំណងថាមិនចង់ស្មោះត្រង់ជាមួយព្រះជាម្ចាស់ទេ។
ពួកគេចង់ថ្វាយបង្គំរូបព្រះ។
វិលត្រឡប់មករកព្រះជាម្ចាស់...ពួកគេពុំស្គាល់ព្រះអម្ចាស់ទេ
អ្នកបកប្រែអាចបកថា «ពួកគេវិលមករកយើង តែពួកគេមិនស្គាល់យើងទេ» ឬ
«ពួកគេវិលមករកយើង តែពួកគេមិនស្គាល់យើងជាព្រះអម្ចាស់ទេ» ។
ហើយពួកគេមិនស្គាល់យើងជាព្រះអម្ចាស់ទេ
អ៊ីស្រាអែលនឹងមិនស្តាប់បង្គាប់ព្រះអម្ចាស់ទៀតទេ។
ពួកគេមិនចាត់ទុកព្រះអម្ចាស់ជាព្រះរបស់ពួកគេទៀតឡើយ។
Hosea 5:5
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
អំនួតរបស់អ៊ីស្រាអែលចោទប្រកាន់ខ្លួនគេ
នៅត្រង់នេះរៀបរាប់ពី «អំនួត»
ថាជាមនុស្សដែលចោទប្រកាន់ប្រឆាំងនឹងអ៊ីស្រាអែលនៅក្នុងតុលាការ។ ឥរិយាបថ
និងអាកប្បកិរិយាអួតបំប៉ោងរបស់គេបានបង្ហាញថាពួកគេមិនស្តាប់បង្គាប់ព្រះអម្ចាស់ឡើយ
ដូច្នេះ អ៊ីស្រាអែល និងអេប្រាអ៊ីម នឹងជំពប់ដួល ដោយកំហុសរបស់ខ្លួន ហើយយូដាក៏ជំពប់ដួលជា
មួយពួកគេដែរ
អាណាចក្រទាំងពីរនេះនឹងលែងស្តាប់បង្គាប់ព្រះជាម្ចាស់ទាំងស្រុង
ដោយសារតែអំនួត និងអំពើបាបរបស់ពួកគេ។
ពួកគេបានក្បត់ព្រះអម្ចាស់ ដោយបង្កើតកូនឥតខាន់ស្លា
អត្ថន័យដែលអាចទៅរួចគឺ ១)
មានន័យថាប្រជាជនអ៊ីស្រាអែលបានរៀបការជាមួយមនុស្សមកពីជាតិសាសន៍ផ្សេង
ហើយមានកូនជាមួយពួកគេ ឬ ២)
មានន័យថាឪពុកម្តាយជាជនជាតិអ៊ីស្រាអែលមិនស្មោះត្រង់ជាមួយព្រះអម្ចាស់
ហើយបានបង្រៀនកូនរបស់ពួកគេឲ្យថ្វាយបង្គំរូបព្រះ។
ឥឡូវនេះ បុណ្យចូលខែថ្មីក្លាយទៅជា មហន្តរាយដល់ពួកគេ និងទឹកដីរបស់ពួកគេ
ប្រជាជនអ៊ីស្រាអែលបានប្រារព្ធបុណ្យចូលខែ។
នៅត្រង់នេះការបញ្ជាក់ហាក់បីដូចជារៀបរាប់អំពីបុណ្យចូលខែដែលនឹងសត្វតិរច្ឆានដែលនឹងស៊ីមនុស្ស
និងស្រែរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ
វាពិបាកក្នុងការបកប្រែការលើកឡើងនេះ មានការបកប្រែជាច្រើនដែលបកមិនត្រូវ។
ទោះជាយ៉ាងណាក៏ដោយ
អត្ថន័យទូទៅគឺថាព្រះជាម្ចាស់នឹងដាក់ទោសមនុស្សដោយសារភាពមិនស្មោះត្រង់របស់ពួកគេចំពោះព្រះអ
Hosea 5:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
ចូរផ្លុំស្នែងប្រកាសសឹកនៅគីបៀរ! ចូរផ្លុំត្រែប្រកាសភាពអាសន្ននៅរ៉ាម៉ា
នៅទីនេះ «ស្នែង» និង «ត្រែ» មានន័យដូចគ្នា។
ការបង្គាប់នេះបានឲ្យដល់មនុស្សនៅគីបៀរ និងរ៉ាម៉ា
ដើម្បីបញ្ជាក់ថាសត្រូវកំពុងតែមក។
ចូរស្រែកហ៊ោនៅបេតអាវេន! បេនយ៉ាមីនអើយ យើងនឹងទៅតាមអ្នក
នេះប្រហែលជាសំណើដែលពួកទាហាននៅក្នុងកុលសម្ព័ន្ធបេនយ៉ាមីននឹងដឹកនាំប្រជាជនទៅក្នុងសមរភូមិ
ប៉ុន្តែ ការបកប្រែថ្មីបានប្រើការលើកឡើងផ្សេង។
បេតអាវេន
នេះជាក្រុងនៅព្រំដែនរវាងស្រុកអ៊ីស្រាអែលភាគខាងជើង
និងកុលសម្ព័ន្ធបេនយ៉ាមីនភាគខាងត្បូង។ សូមមើលការបកប្រែនៅក្នុងជំពូក
៤:១៥។
យើងប្រាប់ដំណឹងដ៏ពិតឲ្យកុលសម្ព័ន្ធនានា នៃជនជាតិអ៊ីស្រាអែលដឹងជាមុន
«យើងនឹងប្រព្រឹត្តជាមួយនឹងកុលសម្ព័ន្ធអ៊ីស្រាអែលនូវអ្វីដែលយើងបានប្រកាស»។
Hosea 5:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីយូដា និងអ៊ីស្រាអែល។
អ្នកដឹកនាំស្រុកយូដាគឺដូចជាអ្នកដែលបង្ខិតបង្គោលរបង
ការ «បង្ខិតបង្គោលរបង»
គឺជាការបង្ខិតព្រំដែលបានដៅសម្គាល់ព្រំដែននៃទ្រព្យរបស់នរណាម្នាក់
ដែលជាបទឧក្រដ្ឋតចំពោះច្បាប់អ៊ីស្រាអែល។
យើងនឹងជះកំហឹងរបស់យើងលើពួកគេ ដូចទឹកហូរយ៉ាងខ្លាំង
កំហឹងរបស់ព្រះអម្ចាស់ប្រឆាំងនឹងយូដានឹងដូចជាទឹកហូរយ៉ាងខ្លាំងដែលនឹងបំផ្លាញពួកគេ។
នៅក្នុងបទគម្ពីរគុណតម្លៃនៃអារម្មណ៍
និងក្រមសីលធម៌គឺតែងតែប្រៀបទៅនឹងវត្ថុរាវ។
អេប្រាអ៊ីមរងនូវការនិន្ទ័យទោស ហើយត្រូវគេជិះជាន់សង្កត់សង្កិន
ការនេះលើកឡើងក្នុងទម្រង់សកម្ម។ នៅក្នុងកថាខណ្ឌនេះគឺមានលើឡើងពីរដង។
នៅទីនេះ «អេប្រាអ៊ីម» សំដៅទៅលើអាណាចក្រភាគខាងជើងរបស់អ៊ីស្រាអែល។
ការបកប្រែផ្សេងទៀតនៃការបកប្រែ:
«យើងនឹងដាក់ទោសប្រជាជនអ៊ីស្រាអែលយ៉ាងធ្ងន់ធ្ងរ»។

generated on Wed Sep 10 16:16:32 2025

ដើរតាមរូបព្រះ
នៅទីនេះ «ដើរ» តំណាងឲ្យគំនិតនៃការថ្វាយបង្គំ។
រូបព្រះ
ក្នុងភាសាហេព្រើរពាក្យថា «រូបព្រះ» គឺគ្មានអត្ថន័យច្បាស់លាស់ទេ
ហើយការបកប្រែគេប្រើពាក្យផ្សេងៗគ្នា។
Hosea 5:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីយូដា និងអ៊ីស្រាអែល។
យើងប្រៀបបាននឹងអង្កែ ដែលស៊ីពួកអេប្រាអ៊ីម ហើយដូចដំបៅស៊ីរូងពួកយូដា
អង្កែនៅលើរោមសត្វ និងដំបៅនៅលើឈើទាំងពីរសុទ្ធតែបំផ្លាញ។
ព្រះជាម្ចាស់នឹងបំផ្លាញជាតិសាសន៍ទាំងពីរនេះ។
អង្កែ...ដំបៅ
ទាំងពីរនេះអាចបកប្រែតាមរបៀបផ្សេងៗ
ព្រោះពាក្យជាភាសាហេព្រើរគឺទាំងទូលំទូលាយ ហើយមិនច្បាស់លាស់។
ពេលអេប្រាអ៊ីមឃើញរោគរបស់ខ្លួន យូដាក៏ឃើញដំបៅរបស់ខ្លួនដែរ
ទាំងអេប្រាអ៊ីម
ដូច្នេះ អេប្រាអ៊ីមទៅពឹងអាស្ស៊ីរី ហើយយូដាចាត់អ្នកនាំសារឲ្យទៅគាល់ស្តេចអធិរាជ
អេប្រាអ៊ីម និងយូដាបានសុំឲ្យស្តេចអាស្ស៊ីរីជួយ ជាជាងសុំជំនួយពីព្រះអម្ចាស់។
«ស្តេចអធិរាជ» គឺតួចតាចណាស់សម្រាប់ស្តេចអាស្ស៊ីរី។
ប៉ុន្តែ ស្តេចនោះពុំអាច
នៅទីនេះ «គាត់» សំដៅលើស្តេចស្រុកអាស្ស៊ីរី។
Hosea 5:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលពីយូដា និងអ៊ីស្រាអែល។
ដូច្នេះ យើងប្រៀបដូចសិង្ហដែលប្រហារអេប្រាអ៊ីម
ព្រះអង្គម្ចាស់នឹងដេញ និងវាយប្រហារអេប្រាអ៊ីមដូចជាសត្វតោ។
ដូចសិង្ហស្ទាវហែកកូនចៅយូដាស៊ី
ព្រះអម្ចាស់នឹងប្រព្រឹត្តចំពោះយូដាក្នុងរបៀបស្រដៀងគ្នា។
ព្រះអម្ចាស់នឹងបង្ហាញការមិនពេញចិត្តទាំងចំពោះអាណាចក្រខាងជើង
និងខាងត្បូង។
យើងនឹង
ព្រះអម្ចាស់បញ្ជាក់ថាព្រះអង្គជាម្ចាក់ដែលនាំការកាត់ទោសចំពោះប្រជារាស្ត្ររបស់ព្រះអង្គទាំងអស់។
នឹងហែក
ដូចជាសិង្ហហែកសត្វនៅពេលវាស៊ីសត្វនោះ
ព្រះអម្ចាស់នឹងហែកប្រជារាស្ត្ររបស់ព្រះអង្គចេញឆ្ងាយពីផ្ទះ
និងប្រទេសរបស់ពួកគេ។
យើងនឹងវិលទៅដំណាក់របស់យើងវិញ
ព្រះអម្ចាស់នឹងចាកចេញពីមនុស្សបះបោរ។
ហើយស្វែងរកយើង
ពួកគេព្យាយាមមកក្នុងវត្តមានរបស់ព្រះជាម្ចាស់ដោយការថ្វាយបង្គំ
និងការថ្វាយយញ្ញបូជា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយសុំឲ្យយើងយកចិត្តទុកដាក់នឹងពួកគេ»។

6 [1]«មក! សូមយើងវិលទៅរកព្រះអម្ចាស់វិញ។ ដ្បិតព្រះអង្គបានធ្វើហែកយើងជាចំណែក តែព្រះអង្គក៏នឹងប្រោសពួកយើងឲ្យជាវិញ ព្រះអង្គធ្វើឲ្យយើងរបួស តែព្រះអង្គក៏
នឹងរុំរបួសឲ្យពួកយើងដែរ។[2]ពីរថ្ងៃក្រោយមក ព្រះអង្គនឹងកែតម្រូវយើង នៅថ្ងៃទីបី ព្រះអង្គនឹងលើកពួកយើងឡើង ហើយពួកយើងនឹងរស់នៅចំពោះព្រះអង្គ។
[3]សូមឲ្យយើងស្គាល់ព្រះអម្ចាស់ ឲ្យយើង ឈានទៅស្គាល់ព្រះអម្ចាស់។ ការយាងរបស់ព្រះអង្គពិតដូចជាព្រឹកព្រលឹម។ ព្រះអង្គនឹងយាងមករកពួកយើងទឹកចាក់ស្រោច
ដូចជាភ្លៀងធ្លាក់ស្រោចស្រពផែនដីតាមរដូវកាល»។
[4]អេប្រាអ៊ីមអើយ! តើឲ្យយើងធ្វើអ្វីដល់អ្នកទៅ? យូដាអើយ! តើឲ្យយើងធ្វើអ្វីដល់អ្នកបាន? ភាពស្មោះត្រង់របស់អ្នកមកលើយើង ប្រៀបដូចជាពពកនៅពេលព្រលឹម និងទឹក
សន្សើម ដែលបាត់ទៅវិញយ៉ាងឆាប់ដែរ។[5]ដូច្នោះ យើងកាត់ពួកគេជាចំណែកដោយពួកព្យាការី យើងបានសម្លាប់ពួកគេ ដោយពាក្យដែលចេញពីម៉ាត់យើង។
ច្បាប់របស់អ្នកគឺដូចជាពន្លឺដែលចាំងចេញក្រៅ។
[6]ដ្បិតយើងចង់បានភាពស្មោះត្រង់ គឺមិនមែនយញ្ញបូជាទេ ហើយការទទួលស្គាល់ព្រះជាម្ចាស់ ជាជាងយកតង្វាយដុត។[7]ដូចអដាំ ដែលបានបំផ្លាញសម្ពន្ធមេត្រី
ពួកគេមិនបានស្មោះត្រង់និងយើង។
[8]កាឡាដគឺជាទីក្រុងនៃពួកអ្នកដែលធ្វើអាក្រក់ ជាមួយស្នាមជើងនៃឈាម។[9]ដូចពួកចោរប្លន់ដែលចាំមនុស្សម្នាក់ ដូច្នោះពួកបូជាចារ្យរួមគ្នា
ដើម្បីប្រព្រឹត្តការសម្លាប់នៅតាមផ្លូវទៅស៊ីគែម ពួកគេប្រព្រឹត្តអំពើដ៏អាម៉ាស់បំផុត។
[10]ក្នុងចំណោមប្រជាជនអ៊ីស្រាអែល យើងបានឃើញការដែលគួរឱ្យរន្ធត់ គឺអំពើពេស្យាចាររបស់អេប្រាអ៊ីមនៅទីនោះ ហើយអ៊ីស្រាអែលទៅជាមិនស្អាត់។[11]យូដាអើយ អ្នកក៏
ដូច្នោះដែរ យើងបានកំណាត់ពេលច្រូតកាត់រួចហើយ ពេលយើងនឹងសាងសង់ជោគវាសនានៃប្រជារាស្ត្រយើងឡើងវិញ។

Hosea 6:1
ប្រយោគភ្ជាប់
ប្រជាជនអ៊ីស្រាអែលសារភាពពីសេចក្តីត្រូវការរបស់ពួកគេរហូតដល់ការប្រែចិត្ត។
ព្រះអង្គបានធ្វើឲ្យពួកយើងរបួស...ព្រះអង្គបានប្រហារពួកយើង
ព្រះជាម្ចាស់បានដាក់ទោសប្រជារាស្ត្រអ៊ីស្រាអែលដោយសារគេមិនស្តាប់បង្គាប់ព្រះអង្គ
ហើយថ្វាយបង្គំរូបព្រះ។
ព្រះអង្គក៏នឹងប្រោសពួកយើងឲ្យជាវិញ ...ព្រះអង្គក៏នឹងរុំរបួសឲ្យពួកយើងដែរ
ជនជាតិអ៊ីស្រាអែលជឿថាព្រះអម្ចាស់នឹងមានក្តីមេត្តាដល់ពួកគេនៅពេលលដែលពួកគេ
ហើយព្រះអង្គនឹងរំដោះពួកគេពីបញ្ហារបស់ពួកគេ។
ពីរថ្ងៃទៀត ព្រះអង្គនឹងបង្ហាញដល់យើង នៅថ្ងៃទីបី ព្រះអង្គនឹងលើកពួកយើងឡើង
ការនេះបង្ហាញពីខណៈពេលដ៏ខ្លីមួយ។
អ៊ីស្រាអែលជឿថាព្រះជាម្ចាស់នឹងមកជាឆាប់ដើម្បីរំដោះពួកគេពីសត្រូវរបស់ពួកគេ។
ពីរថ្ងៃ...បីថ្ងៃ
«២ថ្ងៃ...៣ថ្ងៃ»
យើងត្រូវយកចិត្តទុកដាក់ស្គាល់ព្រះអម្ចាស់
នៅទីនេះ «ស្គាល់» មានន័យថាមិនត្រឹមតែរៀនពីបុគ្គលិកលក្ខណៈ
និងច្បាប់របស់ព្រះអង្គប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវតែស្មោះត្រង់ចំពោះព្រះអង្គដែរ។
(សូមមើល: UDB)
ព្រះអង្គនឹងយាងមកប្រោសពួកយើង
ព្រះអម្ចាស់នឹងយាងមកដើម្បីជួយប្រជារាស្ត្ររបស់ព្រះអង្គ
គឺច្បាស់ដូចជាថ្ងៃរះនៅពេលព្រឹក។
Hosea 6:4
ប្រយោគភ្ជាប់
ព្រះអម្ចាស់មានបន្ទូល។
តើឲ្យយើងធ្វើអ្វីដល់អ្នកទៅ?
ព្រះជាម្ចាស់សង្កត់ធ្ងន់ថាការអត់ធ្មត់របស់ព្រះអង្គមកដល់ទីបញ្ចប់ហើយ
ហើយអ្វីដែលនៅសល់គឺការជំនុំជម្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាពិតជាពិបាកក្នុងការសម្រេចថាត្រូវធ្វើអ្វីជាមួយអ្នករាល់គ្នា!»
ដូច្នេះហើយបានជាយើងប្រើពួកព្យាការី ឲ្យទៅវាយអ្នក យើងប្រហារអ្នករាល់គ្នា
ភាពមិនច្បាស់:ពួកព្យាការី
ព្រះអម្ចាស់បានប្រកាសអំពីមហន្តរាយទៅលើប្រជាជាតិដែលបះបោរ។
មហន្តរាយនេះព្រះអង្គហៅថា «ការកាត់ជាបំណែក»
នេះគឺប្រាកដជាការកាត់ទោស។
ការវិនិច្ឆ័យរបស់យើង មកដល់ដូចផ្លេកបន្ទោរ
នៅទីនេះព្យាការីហូសេបាននិយាយទៅកាន់ព្រះអម្ចាស់។
គាត់អាចចង់និយាយថានៅពេលដែលព្រះអម្ចាស់ប្រទានក្រិតវិន័យដល់នរណាម្នាក់ឲ្យទទួលទោសដល់ស្ល
គឺដូចជាផ្លេកបន្ទោរ
ការវិនិច្ឆ័យរបស់ព្រះអង្គ
«ការបង្គាប់របស់ព្រះអម្ចាស់»
Hosea 6:6
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
ដ្បិត យើងចង់បានតែចិត្តភក្តីប៉ុណ្ណោះ គឺមិនចង់បានយញ្ញបូជាទេ
ជាវេយ្យាករណ៍ជាភាសាហេព្រើរមានន័យថា «លើសជាង» ដូចនៅខាងក្រោម

generated on Wed Sep 10 16:16:32 2025

(«ហើយប្រាជ្ញារបស់ព្រះជាម្ចាស់លើលជាងយញ្ញបូជា»)។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយសារតែយើងចង់បានភាពស្មោះត្រង់ជាងយញ្ញបូជា»។
ដូចអដាំ
អត្ថន័យដែលអាចទៅរួចគឺ ១) សំដៅលើអដាំ ជាបុរសដំបូង ២)
នេះគឺប្រៀបធៀបទៅមនុស្សដែលរស់នៅក្រុងមួយរបស់អ៊ីស្រាអែលហៅថាក្រុងអដាំ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូចជាមនុស្សនៅក្នុងក្រុងអដាំ» ឬ ៣)
សំដៅទៅលើមនុស្សទូទៅ។ ពាក្យថា «អដាំ» មានន័យថា «បុរស» ឬ
«មនុស្សជាតិ»។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូចជាមនុស្សជាតិទាំងអស់»
Hosea 6:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
កាឡាដ...ជាមួយជំហានដែលបង្ហូរឈាម
«ដានជើងនៃឈាម» ប្រហែលជាចង់សំដៅទៅលើអ្នកប្រព្រឹត្តអំពើថោកទាប
និងអំពើឧក្រិដ្ឋរបស់ពួកគេ។
ក្រុមបូជាចារ្យ ប្រហារជីវិតមនុស្ស នៅតាមផ្លូវទៅស៊ីគែម
យើងមិនដឹងថាតើចង់សំដៅទៅលើអ្វីទេ។
តើពួកបូជាចារ្យពិតជាបានប្រហារមនុស្សតាមផ្លូវទៅស៊ីគែម
ដែលជាកន្លែងសំខាន់សម្រាប់សាសនា និងជាទីប្រជុំនយោបាយ?
ឬលោកព្យាការីនិយាយថាពួកព្យាការីបាន «សម្លាប់» អ្នកដែលស្គាល់
និងថ្វាយបង្គំព្រះជាម្ចាស់? នេះជាជម្រើសល្អបំផុតក្នុងការបញ្ជាក់ពីការអាចទៅរួច។
Hosea 6:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
អំពើពេស្យាចាររបស់អេប្រាអ៊ីម
នៅទីនេះ «អំពើពេស្យាចារ»
សំដៅទៅលើការថ្វាយបង្គំព្រះក្លែងក្លាយរបស់អេប្រាអ៊ីម។
អ៊ីស្រាអែលទៅជាមិនស្អាត
អ៊ីស្រាអែលក្លាយទៅជារាស្ត្រដែលមិនអាចទទួលយកបានសម្រាប់ព្រះជាម្ចាស់។
យូដាអើយ អ្នកក៏ដូច្នោះដែរ យើងបានត្រៀមវិនិច្ឆ័យទោសអ្នក
ការនេះអាចលើកឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានកំណត់ពេលត្រូវច្រូតសម្រាប់អ្នកដែរ យូដាអើយ»
ច្រូត
នៅទីនេះ «ច្រូត»
សំដៅទៅលើការជំនុំជម្រះចុងក្រោយរបស់ព្រះជាម្ចាស់ទៅលើអ៊ីស្រាអែល
និងយូដា។
ខ្សែជីវិត
ភាពរុងរឿង និងសន្តិសុខ

---

7 [1]នៅពេលយើងចង់ប្រោសអ៊ីស្រាអែល អំពើបាបរបស់អេប្រាអ៊ីមបានលាតត្រដាង ដូចជាអំពើទុច្ចរិតរបស់សាម៉ារី ដ្បិតពួកគេប្រព្រឹត្តអំពើបោកប្រាស់ មានចោរ
ចូលមកក្នុង ហើយនឹងក្រុមចោរមួយហ្វូងធ្វើសកម្មភាពនៅលើផ្លូវ។[2]ពួកគេមិនដឹងនៅក្នុងចិត្តគេថា យើងនឹកចាំពីអំពើអាក្រក់ ដែលពួកគេប្រព្រឹត្ត។ ពេលនេះ
ការប្រព្រឹត្តរបស់ពួកគេ បានឡោមព័ទ្ធពួកគេ ហើយពួកគេនៅចំពោះមុខយើង។
[3]ជាមួយការអាក្រក់របស់គេ ពួកគេធ្វើឲ្យស្តេចរីករាយ ហើយតាមរយៈកុហករបស់គេដល់ពួកមន្ត្រី។[4]ពួកគេទាំងអស់ជាមនុស្សកំផិត ដូចជាឡកម្តៅមួយដោយអ្នកដុតនំ
ឈប់ដាក់ភ្លើងចាប់ពីពេលច្របាចម្សៅរហូតដល់វាឡើងដំបែ។[5]នៅថ្ងៃនៃស្តេចរបស់យើង ពួកមន្ត្រីធ្វើឲ្យខ្លួនគេឈឺជាមួយផឹកស្រាខ្លាំង។ គេបានឈោងដៃរបស់គេ ទៅជា
មួយមនុស្សដែលឡកឡឺយ។
[6]ដ្បិតនៅក្នុងចិត្តដូចជាឡភ្លើង ពួកគេបង្កើតផែនការបោកប្រាស់។ កំហឹងរបស់គេក្តៅខ្លាំងពេញពេលយប់ នៅព្រលឹមឡើង វាឆេះឡើងខ្ពស់ដូចជាអណ្តាតភ្លើង។[7]ពួកគេទាំង
អស់គ្នាក្តៅដូចជាឡភ្លើង ហើយពួកគេលេបត្របាក់ អ្នកដែលគ្រប់គ្រងលើពួកគេ។ ស្តេចរបស់គេទាំងអស់បានធ្លាក់ចុះ ហើយគ្មាននរណាស្រែករកយើងទេ។
[8]អេប្រាអ៊ីមលាយបញ្ចូលគ្នាខ្លួនលោក ក្នុងចំណោមមនុស្ស។ អេប្រាអ៊ីមដូចជានំសំប៉ែតដែលគេមិនបានប្រែ។[9]ជនបរទេសលេបត្របាក់កម្លាំងខ្លួនគេ ប៉ុន្តែគេនៅតែមិនដឹង
ខ្លួនទេ។ សក់ស្កូវបានរោយលើគាត់ហើយ តែគាត់អស់ដឹងពីវាទេ។
[10]អំនួតរបស់អ៊ីស្រាអែល ជាសាក្សីទាស់នឹងគេ ទោះជាយ៉ាងក៏ដោយ ពួកគេមិនបានត្រឡប់មករកព្រះអម្ចាស់ជាព្រះរបស់ពួកគេ គ្មានពួកគេណាទៅស្វែងរកគេ
ក្នុងរណ្តៅអស់ទាំងនេះ។[11]អេប្រាអ៊ីមដូចជាសត្វព្រាប វាចេះនិយាយតែគ្មានប្រាជ្ញា ពួកវាស្រែកហៅទៅរកអេស៊ីប រួចហើយហើរទៅអាស្ស៊ីរីវិញ។
[12]ពេលពួកគេហើរទៅទីនោះ យើងនឹងលាតសំណាញ់យើងទៅលើពួកគេ យើងនឹងទំលាក់គេចុះដូចសត្វស្លាបនៅលើមេឃ។ យើងនឹងដាក់ទោសពួកគេ
នៅក្នុងហ្វូងរបស់គេទាំងអស់គ្នា។[13]វេទនាដល់ពួកគេហើយ! ដ្បិតពួកគេបានវង្វេងចេញពីយើង។ អន្តរាយកំពុងមកដល់ពួកគេ! ពួកគេបានបះបោរប្រឆាំងនឹងយើង! យើង
អាចសង្គ្រោះពួកគេ តែពួកគេបាននិយាយកុហក ទាស់នឹងយើង។
[14]ពួកគេមិនបានស្រែករកយើងដោយអស់ពីចិត្តទេ តែពួកគេទុក្ខសោកនៅលើគ្រែរបស់គេ។ ពួកគេបានជួបជុំគ្នាសម្រាប់ស្រូវ និងស្រាទំពាំងបាយជូរ ហើយពួកគេ
បែរចេញពីយើង។[15]ទោះបីជាយើងបានបណ្តុះបណ្តាល និងចម្រើនកម្លាំងដៃរគេ ពួកគេក្នុងពេលនេះ មានគម្រោងអាក្រក់ប្រឆាំងនឹងយើង។
[16]ពួកគេវិលមកវិញ តែមិនមែនមករកយើងទេ ជាទីខ្ពស់បំផុត។ ពួកគេដូចជាគ្រប់ព្រួញដែលវៀច។ ពួកមេដឹកនាំរបស់គេនឹងដួលស្លាប់ដោយមុខដាវ ដោយព្រោះពាក្យសម្តី
ព្រហើនក្នុងអណ្តាតរបស់ខ្លួន។ ការទាំងនេះនឹងក្លាយជាការចំអករបស់គេ នៅក្នុងទឹកដីរបស់អេស៊ីប។

Hosea 7:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
យើងចង់ប្រោស អ៊ីស្រាអែលឲ្យបានជា
ធ្វើឲ្យអ៊ីស្រាអែលស្តាប់បង្គាប់ព្រះជាម្ចាស់ម្តងទៀត
និងជាអ្នកទទួលព្រះពររបស់ព្រះអង្គ ហើយនិយាយថាអ៊ីស្រាអែលអាចនឹងបានជា។
ដ្បិត ពួកគេបោកប្រាស់គ្នាទៅវិញទៅមក
មនុស្សលក់ និងទិញទំនិញដោយមិនស្មោះត្រង់។
ចោរប្លន់
នេះជាក្រុមមនុស្សដែលវាយប្រហារអ្នកដទៃដោយឲ្យឥតហេតុផល។
អំពើបាបរបស់ពួកគេ ឡោមព័ទ្ធពួកគេជុំជិត
ការអាក្រក់របស់មនុស្សដែលនិយាយនៅទីនេះគឺមានអ្នកដែលចាំចោទប្រកាន់ឧក្រិដ្ឋកម្ម**ររបស់ខ្លួន**ដែលដោយរួមរស់ជាមួយអ្នកផ្សេង។
ពួកគេនៅចំពោះយើង
«ចំពោះមុខ» សំដៅទៅលើព្រះវត្តមានរបស់ព្រះ ឬ ការដែលព្រះអង្គជ្រាប។
«សាក្សី» ដែលប្រព្រឹត្តការអាក្រក់ គឺនៅក្នុងវត្តមានរបស់ព្រះជាម្ចាស់
ដើម្បីនាំយកការចោទប្រកាន់មក។
Hosea 7:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។ នៅកន្លែងផ្សេងៗភាសាហេព្រើរមិនច្បាស់លាស់ឡើយ។
ទោះជាយ៉ាងណាក៏ដោយ
មនុស្សជាច្រើនបកប្រែដោយរៀបរាប់អំពីអ្នកនៅក្នុងវាំងដែលមិនស្មោះត្រង់ជាមួយព្រះជាម្ចាស់
ហើយរៀបគម្រោងបញ្ចប់ជីវិតនយោបាយរបស់ស្តេច
ហើយបន្ទាប់មកក៏យកគម្រោងរបស់គេមក។
ការនេះហាក់បីដូចជាកើតឡើងច្រើនជាមួយលើក។
អំពើឧក្រិដ្ឋនេះគឺលើកឡើងជាការបង្ហាញពីអំពើអាក្រក់ដែលធ្វើឲ្យជាតិសាសន៍នេះលេចលង់។
ពួកគេសុទ្ធតែជាមនុស្សផិតក្បត់
ប្រជាជនបានប្រព្រឹត្តអំពើផិតក្បត់ខាងវិញ្ញាណដោយការថ្វាយបង្គំរូបព្រះ
និងភាពមិនស្មោះត្រង់ចំពោះព្រះអម្ចាស់។
ពួកគេក៏ប្រហែលជាមិនស្មោះត្រង់ចំពោះប្តី
ខ្លួនដែលដោយរួមរស់ជាមួយអ្នកផ្សេង។
ពួកគេប្រៀបដូចជាឡនំបុ័ងដ៏ក្តៅ ដែលអ្នកដុតនំបុ័ង
ការនេះលើកឡើងក្នុងទម្រង់សកម្ម។
មានន័យថាមនុស្សមានបំណងប្រាថ្នាយ៉ាងខ្លាំងក្នុងការប្រព្រឹត្តការអាក្រក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូចជាឡដែលត្រូវអ្នកដុតនំដុតកំដៅ»។
រៀបចំម្សៅ
នេះជាផ្នែកមួយដែលជាដំណើរការក្នុងការធ្វើនំបុ័ង។

generated on Wed Sep 10 16:16:32 2025

នៅថ្ងៃបុណ្យស្តេចរបស់យើង
នេះប្រហែលជាកម្មវិធីបុណ្យដែលបង្កើតឡើងដោយស្តេច។
ហើយចូលដៃ
នេះប្រហែលជាមានន័យថាការរួបរួម ឬការចូលរួមជាមួយនរណាម្នាក់។
វាអាចមានន័យថាស្តេចចូលរួមជាមួយមន្ត្រីរបស់ព្រះអង្គដើម្បីឡកឡឺយរឿងអ្វីមួយ
ឬឡកឡឺយនរណាម្នាក់ដែលត្រូវឡកឡឺយ ទោះបីជាព្រះជាម្ចាស់ក៏ដោយ។
Hosea 7:6
ព័ត៌មានទូទៅ:
រៀបរាប់អំពីការរៀបគម្រោងរបស់តុលាការ។
កំហឹងរបស់ពួកគេដែលជំរុញឲ្យគេសម្លាប់ស្តេច។
ចិត្តកំរោលនោះក៏ឆាបឆេះ ដូចអគ្គីភ័យ
ប្រៀបដូចជាភ្លើងដែលឆេះនៅក្នុងឡ
មនុស្សទាំងនេះមានបំណងប្រាថ្នាអាក្រក់នៅក្នុងពួកគេ។ (សូមមើល: និងfigs-metonymy)
ចិត្តកំរោលរបស់គេសម្ងំ
ពាក្យថា «សំម៉ុំ» មានន័យថាអ្វីមួយដែលកំពុងឆេះយឺតៗ និងដោយស្ងប់ស្ងាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «កំហឹងរបស់ពួកគេកើងឡើងយឺតៗ
ហើយស្ងប់ស្ងាត់»។
ចិត្តកំរោលនោះក៏ឆាបឆេះ ដូចអគ្គីភ័យ
កំរិតនៃកំហឹងរបស់ពួកគេហាក់បីដូចជានិយាយអំពីភ្លើងយ៉ាងក្តៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «វាខ្លាំងណាស់»
ពួកគេទាំងអស់គ្នាមានចិត្តក្តៅដូចឡភ្លើង
កន្លែងនេះប្រៀបធៀបកំហឹងរបស់ពួកគេទៅនឹងកម្តៅដែលចេញពីឡ។
ពួកគេប្រហារអ្នកដឹកនាំរបស់ខ្លួន
វាហាក់បីដូចជាមានន័យថាតុលាការបានសម្លាប់ស្តេចរបស់ពួកគេជាផ្លូវការ។
Hosea 7:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
អេប្រាអ៊ីមនៅកណ្តាលចំណោមមនុស្សដទៃ
នេះប្រហែលជាសំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដែលធ្វើឡើងដោយស្តេចអាណាចក្រខាងជើងដែលសម្របខ្លួនរបស់ពួកគេជាមួយជាតិសាសន៍ផ្សេងដើម្បីការពារពីការរាយប្រហារ។
អេប្រាអ៊ីមប្រៀបដូចជានំដែលគេអាំមិនបានប្រែ
នេះអាចលើកឡើងជាទម្រង់សកម្ម។ នៅទីនេះ «អេប្រាអ៊ីម»
សំដៅទៅលើអាណាចក្រខាងជើងរបស់អ៊ីស្រាអែល។ ជាតិសាសន៍ខ្សោយ
ដូចជានំដែលមិនទាន់បានអាំនៅក្នុងឡដោយអ្នកដុតនំដែលធ្វើឲ្យរឹងនៅឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «អេប្រាអ៊ីមប្រៀបដូចជានំដែលគេអាំមិនបាន
ប្រែ»។
ពួកគេចាស់សក់ស្កូវប៉ុណ្ណឹងហើយ
នៅទីនេះ «សក់ស្កូវ» តំណាងឲ្យអាយុច្រើន។
តែមិនដឹងខ្លួនទៀត
យ៉ាងណាមិញ «អាយុច្រើន»
គឺចង់សំដៅលើអាណាចក្រខាងជើងកាន់តែខ្សោយទៅៗ
ព្រោះប្រជាជាតិនេះមិនដឹងថាគេកំពុងតែមានវ័យ «ចំណាស់» ហើយទេ។
Hosea 7:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
អំនួតរបស់អ៊ីស្រាអែលចោទប្រកាន់ខ្លួនឯង
ការរៀបរាប់
ពួកគេមិនស្វែងរកព្រះអង្គទេ
ការមិនចាប់អារម្មណ៍របស់អ៊ីស្រាអែលចំពោះព្រះអម្ចាស់ គឺប្រៀបដូចជាពួកគេវង្វេង
ហើយពួកគេមិនព្យាយាមស្វែងរកព្រះអង្គទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «
ពួកគេមិនស្វែងរកព្រះអង្គទេ ហើយក៏មិនផ្តោតអារម្មណ៍លើព្រះអង្គដែរ»។
ហេតុការណ៍ទាំងនេះកើតឡើង
នៅត្រង់នេះ «ទាំងនេះ»
សំដៅទៅលើការដែលព្រះជាម្ចាស់អនុញ្ញាតិជនបរទេសវាយប្រហារពួកគេដើម្បីធ្វើឲ្យពួកគេខ្សោយ។
អេប្រាអ៊ីមប្រៀបបាននឹងសត្វព្រាបដ៏ល្ងីល្ងើ គ្មានប្រាជ្ញាទាល់តែសោះ
សត្វព្រាបគឺជាសត្វដែលគេគិតថាគ្មានប្រាជ្ញាទាល់តែសោះ។
អេស៊ីប...អាស្ស៊ីរី
ជាតិសាសន៍ទាំងនេះជាជាតិសាសន៍ដែលខ្លាំងពូកែដែលអ៊ីស្រាអែលអាចសុំជំនួយ។
Hosea 7:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
យើងបោះសំណាញ់របស់យើងលើពួកគេ
នេះជាវិធីដែលគេចាប់សត្វស្លាប។
ព្រះអម្ចាស់នៅតែប្រៀបធៀបប្រជាជនអ៊ីស្រាអែលទៅនឹងសត្វព្រាប។
នៅពេលដែលពួកគេទៅអេស៊ីប ឬអាស្ស៊ីរីសុំជំនួយ
ព្រះអម្ចាស់នឹងដាក់ទោសពួកគេ។
យើងធ្វើឲ្យពួកគេធ្លាក់ដូចសត្វស្លាប
ព្រះអម្ចាស់មានបន្ទូលពីរបៀបដែលព្រះអង្គនឹងដាក់ទោសដល់អ៊ីស្រាអែលដូចជារបៀបដែលគេចាប់សត្វ
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងចាប់គេដូចចាប់សត្វស្លាប» ឬ
«យើងនឹងចាប់ពួកគេដូចអ្នកប្រមាញ់ចាប់សត្វស្លាប»។
នៅពេលយើងឮថា ពួកគេជួបជុំគ្នា
ការលើកឡើងនេះប្រៀបធៀបនឹងសត្វស្លាប។
Hosea 7:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
ពួកគេចូលដំណេក ទាំងសោកសង្រេង
វាជារឿងធម្មតាសម្រាប់អ្នកថ្វាយបង្គំរូបព្រះក្នុងការបរិភោគអាហារសែនដែលដាក់លើធ្នើរ
ឬយើងស្រែ
អេប្រាអ៊ីមប្រៀបដូចជានំដែលគេអាំមិនបានប្រែ
ពួកគេធ្វើដូច្នេះ ប្រឆាំងនឹងយើង
នៅទីនេះការថ្វាយបង្គំព្រះជាម្ចាស់មិនបាននិយាយថាជាការចេញឆ្ងាយពីព្រះជាម្ចាស់ឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយពួកគេមិនថ្វាយបង្គំយើងទៀតឡើយ»។
យើងបានបណ្តុះបណ្តាល និងចម្រើនកម្លាំងឲ្យពួកគេ
នេះជាការប្រៀបធៀបទៅនឹងទាហាន
គឺព្រះជាម្ចាស់បានហ្វឹកហ្វឺនអ៊ីស្រាអែលឲ្យស្រឡាញ់ព្រះអង្គ និងស្តាប់បង្គាប់ព្រះអង្គ
គឺប្រៀបដូចជាព្រះអង្គបង្វឹកមនុស្សរបស់ព្រះអង្គសម្រាប់សង្គ្រាមដែរ។
Hosea 7:16
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
ពួកគេមានចិត្តរៀចវេរធ្នូរបូតខ្សែ
នេះសំដៅទៅលើធ្នូដែលគ្មានខ្សែ ឬខ្សែរលុង។
ព្រោះពាក្យសម្តីព្រហើនកោងកាចរបស់ខ្លួន
នៅទីនេះ «ពាក្យសំដី» សំដៅទៅលើអ្វីដែលគេនិយាយជាផ្លូវការ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រោះពួកគេប្រមាថយើង» ឬ
«ព្រោះពួកគេដាក់បណ្តាសាយើង»។
ការទាំងនេះបាននាំឲ្យជនជាតិអេស៊ីប សើចចំអកដល់គេ
«នេះជាមូលហេតុដែលអេស៊ីបនឹងសើចចំអក ហើយសើចចំពោះអ៊ីស្រាអែល»។

---

8 [1]«ចូរដាក់ត្រែនៅលើបបូរមាត់អ្នក! ដូចសត្វឥន្ទ្រី ដែលនឹងមកលើដំណាក់នៃជាព្រះអម្ចាស់ ដោយព្រោះប្រជាជនបានធ្វើឲ្យខូចសម្ពន្ធមេត្រីរបស់យើង ហើយបះបោរ
ទាស់នឹងច្បាប់យើង។[2]ពួកគេស្រែករកយើងថា ព្រះជាម្ចាស់នៃទូលបង្គំអើយ យើងនៅក្នុងអ៊ីស្រាអែល ស្គាល់ព្រះអង្គ។[3]ប៉ុន្តែអ៊ីស្រាអែលបានបដិសេធការល្អ
ហើយសត្រូវដេញតាមពួកគេ។
[4]ពួកគេតាំងស្តេចឡើង តែមិនបានខ្វល់ពីយើង។ ពួកគេតាំងមេដឹកនាំ តែអត់មានប្រាជ្ញាពីយើង។ ពួកគេយកប្រាក់ហើយមាសធ្វើជារូបព្រះក្លែងក្លាយសម្រាប់ខ្លួន
ប៉ុន្តែវាបានតែរូបព្រះ ដូច្នោះពួកគេនឹងកាត់ចេញ»។[5]«ព្រះគោរបស់អ្នកត្រូវបានបដិសេធ សាម៉ារីអើយ។ កំហឹងរបស់យើងឆេះឡើង ទាស់និងមនុស្សទាំងនេះ។ តើ
យូរប៉ុណ្ណាទៀតទើបពួកគេរស់នៅដោយគ្មានទោស?
[6]ដ្បិត រូបព្រះនេះចេញមកពីអ៊ីស្រាអែល មានជាងឆ្លាក់វា គឺវាមិនមែនជាព្រះទេ! រូបគោរបស់សាម៉ារី នឹងត្រូវបាក់បែកខ្ទេចខ្ទីជាចំណែកៗ។[7]ដ្បិត ពួកគេសាបព្រោះខ្យល់ ពួក
គេនឹងទទួលផលជាព្យុះ។ ស្រូវស្កកមិនបានលូតក្បាលទេ គ្រាប់វាគ្មានម្សៅទេ។ ប្រសិនបើវាដុះមកចេញពេញលក្ខណៈ ជនជាតិផ្សេងនឹងស៊ីត្របាក់វាអស់។

generated on Wed Sep 10 16:16:32 2025

[8]អ៊ីស្រាអែលត្រូវខ្ទាំងលេបបាត់ហើយ ឥឡូវនេះពួកគេស្ថិតនៅក្នុងចំណោមជាជាតិផ្សេង ដូចអ្វីដែលគ្មានប្រយោជន៍។[9]ដ្បិតពួកគេបានទៅអាស្ស៊ីរី ដូចជាសត្វលាព្រៃនៅតែម្នាក់ឯង។ អេប្រាអ៊ីមបែរជាជួលមនុស្ស សម្រាប់បំពេញបំណងខ្លួនឯង។[10]ទោះបីពួកគេបានជួលមនុស្សគួរឲ្យស្រលាញ់ ពីចំណោមជនជាតិដទៃ យើងនឹងប្រមូលពួកគេ។ ពួកគេនឹងចាប់ផ្តើមលាងសម្អាតចេញ ដោយព្រោះនៃការជិះជាន់ពីស្តេចហើយពួកមន្ត្រីទាំងនោះ។
[11]ដ្បិតអេប្រាអ៊ីមសង់អាសនៈកាន់តែច្រើន សម្រាប់តង្វាយ លោះបាប តែអាសនៈទាំងនោះក្លាយទៅជាកន្លែង សម្រាប់ប្រព្រឹត្តអំពើបាបជំនួសវិញ។[12]ទោះជាយើងសរសេរចុះក្រឹត្យវិន័យរបស់យើង សម្រាប់ពួកគេពីរពាន់ដង ប៉ុន្តែពួកគេបានមើលច្បាប់យើង ហើយថាជាអ្វីដែលចម្លែកដល់ពួកគេវិញ ។
[13]សម្រាប់យញ្ញបូជានៃតង្វាយយើង ព្រោះពួកជាសាច់ហើយក៏បរិភោគវា ប៉ុន្តែយើង ព្រះអម្ចាស់ មិនពេញទទួលតង្វាយរបស់ពួកគេទេ។ ឥឡូវនេះយើងគិតពីអំពើទុច្ចរិតហើយការដាក់ទោសដល់បាបពួកគេ។ ពួកគេនឹងត្រូវត្រឡប់ទៅអេស៊ីបវិញ។[14]អ៊ីស្រាអែលបានបំភ្លេចយើង អ្នកបង្កើតគេ ហើយបានសង់វិមានជាច្រើន។ យូដាក៏បានសង់ទីក្រុង និងកំពែងរឹងមាំកាន់តែច្រើន តែយើងចាត់ភ្លើងទៅលើទីក្រុងទាំងអស់របស់គេ វានឹងបំផ្លាញកំពែងរឹងមាំពួកគេដែរ។

Hosea 8:1

ព័ត៌មានទូទៅ:

ព្រះអម្ចាស់និយាយពីការដែលទ័ពអាស្ស៊ីរីមកវាយប្រហារអាណាចក្រខាងជើង។

ដូចសត្វឥន្ទ្រី មកលើទឹកដីរបស់យើង ជាព្រះអម្ចាស់

សត្វឥន្ទ្រីជាសត្វដែលប្រម៉ាញ់

គឺពេលខ្លះប្រើដើម្បីប្រៀបធៀបទៅនឹងសត្រូវរបស់អ៊ីស្រាអែល។

របៀបផ្សេងទៀតនៃការបកប្រែ: «សត្វឥន្ទ្រីប្រម៉ាញ់សត្វដទៃទៀត

សត្រូវរបស់អ៊ីស្រាអែលមកចាប់ប្រជារាស្ត្ររបស់យើង»។

រំលោភលើសម្ពន្ធមេត្រី

នៅទីនេះ «រំលោភ» ដំណាងឲ្យ «មិនស្តាប់បង្គាប់» «រំលោភលើ»។

ស្គាល់ព្រះអង្គ

«ស្មោះត្រង់ជាមួយព្រះអង្គ»។

Hosea 8:4

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

ដែលបណ្តាលឲ្យខ្លួនត្រូវវិនាស

ការនេះលើកឡើងក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ

លទ្ធផលគឺថាយើងនឹងបំផ្លាញប្រជារាស្ត្ររបស់យើង»។ (សូមមើល:»

អ្នកក្រុងសាម៉ារីអើយ ចូរយករូបព្រះគោរបស់អ្នកបោះចោលទៅ

អត្ថន័យដែលអាចទៅរួចគឺ ១) នេះជាពាក្យរបស់ព្យាការី

រូបគោរបស់អ្នក

ស្តេចយេរ៉ូបោមជាស្តេចទីពីររបស់អ៊ីស្រាអែល

កំហឹងរបស់យើងឆាបឆេះទៅលើប្រជាជនទាំងនេះ

កំហឹងតែងតែលើកឡើងប្រៀបទៅនឹងភ្លើង។ របៀបផ្សេងទៀតនៃការបកប្រែ:

«យើងខឹងនឹងប្រជាជននេះខ្លាំងណាស់»។

តើដល់ពេលណាទើបពួកគេអាចរស់នៅ ដោយឥតសៅហ្មង?

ព្រះអម្ចាស់បានសួរសំណួរនេះដើម្បីបង្ហាញកំហឹងរបស់ព្រះអង្គដោយសារប្រជាជនរបស់ព្រះអង្គ[illegible]។

«យើងខឹងនឹងប្រជាជននេះខ្លាំងណាស់

ព្រោះពួកគេគ្មានបំណងក្នុងការធ្វើការល្អនោះទេ។

Hosea 8:6

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់មានបន្ទូល។

ដ្បិត ពួកគេសាបព្រោះខ្យល់ ពួកគេនឹងទទួលផលជាព្យុះ

ការព្រោះ ឬដាំខ្យល់គឺជាសកម្មភាពដែលឥតប្រយោជន៍

ឬផ្លូវនាំទៅរកភាពអន្តរាយ។

ការច្រូតបានជាខ្យល់ព្យុះគឺជាការរងទុក្ខនៃមហន្តរាយដោយសារសកម្មភាពរបស់ម្នាក់ៗ[illegible]

គ្រាប់ស្រូវងើយ មិនដាក់គ្រាប់ទេ

នៅទីនេះ «ដាក់គ្រាប់»

គឺសំដៅទៅលើផ្នែកមួយនៃរុក្ខជាតិដែលជាកន្លែងមានគ្រាប់។

ដើមស្រូវដែលមិនមានគ្រាប់មិនផ្តល់អ្វីសោះដល់កសិករ។

ដូចគ្នានេះសកម្មភាពរបស់អ៊ីស្រាអែល គឺជាលទ្ធផលគ្មានអ្វីល្អឡើយ។

ប្រសិនបើមាន ក៏គង់តែជនជាតិផ្សេង មកលេបយកទៅបាត់ដែរ

បើអ្វីដែលអ៊ីស្រាអែលធ្វើបានផលល្អ

នោះសត្រូវរបស់អ៊ីស្រាអែលនឹងមកហើយយកវាពីពួកគេទៅ។

Hosea 8:8

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

អ៊ីស្រាអែលត្រូវខ្ទាំងលេបបាត់ហើយ

«លេប» មានន័យថាត្រូវគេវាយ ហើយត្រូវគៀងយកទៅជាឈ្លើយ។

ការនេះអាចលើកឡើងជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«សត្រូវរបស់អ៊ីស្រាអែលបានយកអ៊ីស្រាអែលទៅឆ្ងាយទៅទឹកដីផ្សេងទៀត។

ដូចសត្វលាព្រៃតែនៅដាច់ពីគេ

មនុស្សតែងតែគិតថាសត្វលាគឺជាសត្វដែលរឹងរូស។

ការនេះមានន័យថាប្រជាជនអ៊ីស្រាអែលបដិសេធក្នុងការស្តាប់ព្រះអម្ចាស់

ប៉ុន្តែផ្ទុយទៅវិញពួកគេបានទៅរកប្រជាជនអាស្ស៊ីរីឲ្យមកជួយ។

អេប្រាអ៊ីមបែរជាលក់ខ្លួន

ការដែលអេប្រាអ៊ីមចងសម្ពន្ធភាពជាមួយសាសន៍ដទៃ

គឺដូចជាពួកគេបានបង់ថ្លៃឲ្យអ្នកទាំងនោះក្លាយជាពេស្យារបស់អេប្រាអ៊ីមដែរ។

របៀបផ្សេងទៀតនៃការបកប្រែ:

«ប្រជាជនអ៊ីស្រាអែលបានព្យាយាមបង់ថ្លៃឲ្យសាសន៍ដទៃការពារពួកគេ

ក្រោមអំណាចព្រះចៅអធិរាជ

នេះដោយសារតែស្តេចអាស្ស៊ីរី ដែលហៅថា «ស្តេចអធិរាជ»

ដែលធ្វើឲ្យមនុស្សរងទុក្ខវេទនា។

Hosea 8:11

ព័ត៌មានទូទៅ:

ព្រះអម្ចាស់[illegible]។

យើងអាចសរសេរក្រឹត្យវិន័យសម្រាប់ពួកគេមួយម៉ឺនដង

ការនេះមានន័យថាព្រះអម្ចាស់មានប្រទានក្រិតវិន័យរបស់ព្រះអង្គដល់អ៊ីស្រាអែលរួចហើយតាមរយៈ

ពួកព្យាការី និងប្រាប់ពួកគេថាតើព្រះអង្គចង់បានអ្វីពីពួកគេ។

មួយម៉ឺនដង

«១០,០០០»

Hosea 8:13

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

[illegible]

ដោយសារអំពើបាបរបស់ពួកគេ

ព្រះជាម្ចាស់នឹងបញ្ជូនប្រជារាស្ត្ររបស់ព្រះអង្គទៅឆ្ងាយឲ្យធ្វើជាទាសកររបស់អេស៊ីប។

---

9 [1]អ៊ីស្រាអែលអើយ កុំត្រេកអរឡើយ! ជាអំណរដូចជនជាតិផ្សេង។ ដ្បិតអ្នកមិនបានស្មោះត្រង់ ដោយបោះបង់ចោលព្រះជាម្ចាស់របស់ខ្លួន។ អ្នកចូលចិត្តឲ្យប្រាក់ដល់ពួកពេស្យាហើយបំពេញតម្រូវការ នៅតាមទីលានបោកស្រូវ។[2]ប៉ុន្តែនៅទីលានបោកស្រូវហើយនិងកន្លែងជាន់ទំពាំងបាយជូរ
នឹងមិនបានឲ្យផលដល់ពួកគេទេ ស្រាទំពាំងបាជូរថ្មីនឹងធ្វើឲ្យគេស្រវឹង។
[3]ពួកគេនឹងមិនអាចបន្តរស់នៅ ក្នុងទឹកដីព្រះអម្ចាស់ទៀតទេ ផ្ទុយទៅវិញ អេប្រាអ៊ីមនឹងត្រឡប់ទៅអេស៊ីបវិញ ហើយថ្ងៃមួយពួកគេនឹងបរិភោគអាហារមិនស្អាត នៅក្នុងស្រុកអាស្ស៊ីរី។[4]ពួកគេចាក់ស្រាថ្វាយព្រះអម្ចាស់ ហើយពួកគេមិនគាប់ព្រះហឫទ័យដល់ព្រះអង្គដែរ។ យញ្ញបូជារបស់ពួកគេនឹងសម្រាប់ពួកគេដូចជាអាហារសម្រាប់អ្នកកាន់ទុក្ខ អស់អ្នកដែលបរិភោគវានឹងស្មោកគ្រោក។ អាហាររបស់គេសម្រាប់គេខ្លួនឯងប៉ុណ្ណោះ វាមិនអាចយកចូលមកក្នុងដំណាក់នៃព្រះអម្ចាស់បានទេ។
[5]តើអ្នកនឹងធ្វើអ្វីនៅថ្ងៃបុណ្យដែលបានកំណាត់ ហើយនៅថ្ងៃបុណ្យនៃព្រះអម្ចាស់?[6]ដ្បិត មើលចុះ! ប្រសិនបើពួកគេចាកគេចចេញពីការបំផ្លាញ អេស៊ីបនឹងប្រមូលពួកគេ ហើយក្រុងណូបនឹងបញ្ចុះសព្វពួកគេ។ ដ្បិតទ្រព្យសម្បត្តិរបស់ពួកគេធ្វើពីប្រាក់ ហើយអញ្ចាញដែលមុតជាម្ចាស់ពួកវា ហើយបន្លាដុះនៅពេញត្រសាលរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[7]ក្នុងថ្ងៃនៃសម្រាប់ជំនុំជម្រះ កំពុងតែមកដល់ហើយ ហើយថ្ងៃនៃសងសឹកកំពុងតែមកដល់ហើយ។ ចូរឲ្យអ៊ីស្រាអែលបានដឹងពីការទាំងនេះ។ ពួកព្យាការីគឺជាមនុស្ស
ឡប់ល្ងីល្ងើ ហើយពួកអ្នកលើកទឹកចិត្តគឺឆ្កួត ដោយសារតែអំពើទុច្ចរិតរបស់អ្នក និងអំពើឃោរឃៅដ៏ច្រើនរបស់អ្នក ហើយកាចសាហាវណាស់។
[8]ពួកព្យាការីគឺចាំយាមសម្រាប់ព្រះជាម្ចាស់របស់ខ្ញុំ នៅលើអេប្រាអ៊ីម។ ប៉ុន្តែអន្ទាក់បក្សីគឺនៅលើផ្លូវរបស់គេ ហើយការដ៏សាហាវមករកគេ នៅក្នុងដំណាក់នៃព្រះរបស់គេ។
[9]ពួកគេផុងខ្លួនទៅក្នុងអំពើពុករលួយខ្លួនគេ ដូចគ្រានៅគីបៀរដែរ។ ព្រះជាម្ចាស់នឹកនឹកចាំពីអំពើទុច្ចរិតរបស់ពួកគេ ហើយព្រះអង្គនឹងដាក់ទោស តាមអំពើបាបពួកគេ។
[10]ព្រះអម្ចាស់មានព្រះបន្ទូលថា «ពេលយើងបានឃើញអ៊ីស្រាអែល ដូចជាផ្លែទំពាំងបាយជូរនៅវាលរហោស្ថាន។ ដូចជាផ្លែដំបូងរបស់ដើមឧទុម្ពរ
ហើយយើងបានឃើញដូចតាអ្នកដែរ។ ប៉ុន្តែពួកគេទៅដល់ បាលពេអ៊រ ហើយនាំគ្នាបំផាញខ្លួន ទៅក្នុងការអាម៉ាស់នៃព្រះនោះ។ ពួកគេក្លាយទៅជាគួរស្អប់ខ្ពើម ដូចព្រះ
ដែលគេស្រឡាញ់ដែរ។
[11]សម្រាប់អេប្រាអ៊ីម កិត្តិយសរបស់គេនឹងហើរចេញ ដូចសត្វស្លាប។ គឺគ្មានទារកកើតទៀតទេ ហើយគ្មានទារកនៅក្នុងផ្ទៃ ហើយមានមានគភ៌ដែរ។[12]ពួក
គេបានមើលថែក្មេងៗឡើង យើងនឹងយកក្មេងទាំងនោះចេញ ដូច្នោះគ្មានគ្មានណានឹងមានជីវិតបានទេ។ វេទនាដល់ពួកគេ នៅពេលយើងបែរចេញពីពួកគេ!
[13]យើងបានឃើញថាអេប្រាអ៊ីម ក៏ដូចក្រុងទីរ៉ុស បានដាំនៅក្នុងវាលស្មៅ តែអេប្រាអ៊ីមនឹងបញ្ជូនកូនរបស់ខ្លួនទៅដល់អ្នកណាម្នាក់ដើម្បីប្រហារ»។[14]ប្រគល់ដល់ពួកគេ
ព្រះអម្ចាស់អើយ តើអ្វីទៅដែលព្រះអង្គនឹងប្រទានដល់ពួកគេ? ប្រគល់ដល់គេនៅការរលូតកូនពីផ្ទៃ ហើយសុដនដែលគ្មានទឹកដោះ។
[15]«ដោយព្រោះអំពើទុច្ចរិតទាំងឡាយនៅក្នុងគីលកាល់ នេះហើយដែលធ្វើឲ្យយើងស្អប់ពួកគេ។ ដោយពួកគេប្រព្រឹត្តអំពើបាប យើងនឹងដេញពួកគេចេញ ពីដំណាក់របស់
យើង។ យើងនឹងមិនស្រឡាញ់ពួកគេទៀតទេ ហើយអ្នកដឹកនាំទាំងឡាយបះបោរ។
[16]អេប្រាអ៊ីមគឺជាជំងឺ ហើយឫសរបស់ពួកគេស្ងួតអស់ ពួកគេមិនអាចបង្កើតផលបានទេ។ ប្រសិនបើពួកគេបង្កើតកូន យើងនឹងធ្វើឲ្យកូនដ៏ជាទីស្រឡាញ់ របស់ពួកគេបាត់
បង់ជីវិត»។[17]ព្រះជាម្ចាស់របស់ខ្ញុំនឹងបដិសេធពួកគេ ព្រោះពួកគេមិនបានស្តាប់ព្រះអង្គទេ។ ពួកគេនឹងវង្វេង នៅក្នុងចំណោមប្រជាជាតិទាំងឡាយ។

Hosea 9:1

ព័ត៌មានទូទៅ:

លោកព្យាការីហូសេនិយាយ។

ប៉ុន្តែ ពួកគេនឹងមិនស្គាល់រសជាតិស្រូវ ដែលគេបោកបែន ឬស្រាទំពាំងបាយជូរដែលគេគាបឡើយ

ការនេះរៀបរាប់អំពីស្រូវ
និងស្រាទំពាំងបាយជូរប្រៀបដូចជាមនុស្សដែលអាចចិញ្ចឹមនរណាម្នាក់។
ការនេះមានន័យថាដូចចម្រូតនឹងមិនអាចផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់សម្រាប់តម្រូវការរបស់មនុស្សឡើយ
ហើយនឹងមិនអាចផ្គត់ផ្គង់ទំពាំងបាយជូរសម្រាប់ធ្វើស្រាទំពាំងបាយជូរបាន។

វាលស្រែ
នេះជាវាលមិនត្រឹមតែប្រើសម្រាប់ធ្វើស្រែប៉ុណ្ណោះទេ ប៉ុន្តែ
ក៏សម្រាប់ប្រើប្រាស់ក្នុងសហគមន៍ និងពិធីបុណ្យសាសនាដែរ។
ពួកពេស្យាចារមកដើម្បីជួយឲ្យប្រុសៗប្រារព្ធពីធីបុណ្យរដូវចំរូតថ្វាយរូបព្រះ។

ស្រាទំពាំងបាយជូរថ្មី ធ្វើឲ្យពួកគេវង្វេង
នឹងមិនមានផ្លែទំពាំងបាយជូរគ្រប់គ្រាន់ដើម្បីធ្វើស្រាឡើយ។

Hosea 9:3

ព័ត៌មានទូទៅ:

លោកព្យាការីហូសេនិយាយ។

ទឹកដីរបស់ព្រះអម្ចាស់
ការលើកឡើងនេះបញ្ជាក់ថាព្រះអម្ចាស់នៅតែបន្តចាត់ទុកថាទឹកដីអ៊ីស្រាអែលជាសម្បត្តិរបស់ព្រះអង្គ
មិនមែនជារបស់ប្រជាជនអ៊ីស្រាអែលឡើយ។

អាហារមិនបរិសុទ្ធ
នេះជាអាហារដែលប្រជាជនអ៊ីស្រាអែលតែងតែបដិសេធមិនបរិភោគព្រោះធ្វើឲ្យព្រះជាអម្ចាស់មិនទទួលស្គាល់ពួកគេ។

សាច់នៃយញ្ញបូជាដែលពួកគេបរិភោគ ប្រៀបដូចជាអាហារសម្រាប់អ្នកកាន់ទុក្ខ
នៅទីនេះ «អាហារកាន់ទុក្ខ»
សំដៅទៅលើអ្វីដែលប្រជាជនអ៊ីស្រាអែលបរិភោគនៅពេលពួកគេកាន់ទុក្ខ
ព្រោះពួកគេឃ្លាតឆ្ងាយ និងព្រះជាម្ចាស់មិនទទួលស្គាល់ពួកគេ។
ការនេះមានន័យថាព្រះអម្ចាស់នឹងមើលយញ្ញបូជារបស់មនុស្សពីចំងាយ
ហើយមិនទទួលស្គាល់ពួកគេឡើយ។

អាហាររបស់គេបានត្រឹមតែ ចម្អែតក្រពះប៉ុណ្ណោះ គេមិនអាចយកចូលមកក្នុងដំណាក់របស់
ព្រះអម្ចាស់បានឡើយ
ប្រជាជនអ៊ីស្រអែលនឹងមានអាហារបរិភោគ ប៉ុន្តែ
ព្រះអម្ចាស់នឹងមិនទទួលអាហារនេះជាយញ្ញបូជាឡើយ។

គេមិនអាចយកចូលមកក្នុងដំណាក់របស់ ព្រះអម្ចាស់បានឡើយ
អាហារមិនបរិសុទ្ធគឺនិយាយឡើងដូចជាវាអាចចេញបីកន្លែងមួយទៅកន្លែងមួយទៀតបានដែរ
តាមពិតទៅមនុស្សជាអ្នកយកវាទៅជាមួយ។

Hosea 9:5

ព័ត៌មានទូទៅ:

លោកព្យាការីហូសេនិយាយ។

តើអ្នករាល់គ្នាធ្វើយ៉ាងណានៅថ្ងៃបុណ្យ សំខាន់ៗ និងថ្ងៃបុណ្យរបស់ព្រះអម្ចាស់?

លោកហូសេបានប្រើសំណួរដើម្បីបញ្ជាក់ថាប្រជាជននឹងមិនអាចធ្វើកម្មវិធីបុណ្យរបស់ព្រះអម្ចាស់បានឡើយ
និងគៀរពួកគេទៅជាឈ្លើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនឹងមិនអាចប្រារព្ធពិធីបុណ្យដែលព្រះអម្ចាស់ប្រទានដល់អ្នកបានទៀតទេ»។

ថ្ងៃបុណ្យ សំខាន់ៗ...ថ្ងៃបុណ្យរបស់ព្រះអម្ចាស់
ទាំងពីរនេះមានន័យដូចគ្នា។

បើពួកគេរត់គេច
នៅទីនេះ «ពួកគេ» នៅតែសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
អ្នកអាចលើកឡើងពាក្យនេះជាបុរសទីពីរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បើពួកគេរត់គេច»

ពួកគេ ពួកគេនឹងស្លាប់ចោលឆ្អឹងនៅក្រុងណូប
អេស៊ីប និងណូប គឺសំដៅទៅលើមនុស្សដែលស្នាក់នៅទីនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទាហានរបស់អេស៊ីបនឹងឡោមព័ទអ្នក។
អ្នកនឹងស្លាប់នៅទីនោះ ហើយមនុស្សនៅក្រុងណូបនឹងកប់អ្នក»។

ចោលទ្រព្យសម្បត្តិធ្វើពីប្រាក់ នៅក្នុងគុម្ពខ្ញែ
ខ្ញែដុះនៅកន្លែងដែលប្រជាជនអ៊ីស្រាអែលទុកប្រាក់
គឺចង់និយាយថាខ្ញែជាសត្រូវរបស់មនុស្សដែលអាចយកទ្រព្យសម្បត្តិរបស់អ៊ីស្រាអែលទៅធ្វើជារបស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញែមុតស្រួចនឹងដុះនៅកន្លែងដែលពួកគេទុកប្រាក់»។

នៅក្នុងគុម្ពខ្ញែ ហើយបន្លាដុះនៅពេញទីលំនៅរបស់ពួកគេ
នៅទីនេះ «ខ្ញែ» និង «បន្លា» មានន័យដូចគ្នា។ ការដែលដុះខ្ញែ
និងដុះបន្លាដំណាងឲ្យដីដែលមិនបង្កើតផល ហើយដូចជាវាលរហោស្ថាន។

ការដែលព្រះអង្គ
នៅទីនេះ «ជំរំ» តំណាងឲ្យផ្ទះរបស់ជនជាតិអ៊ីស្រាអែល។

Hosea 9:7

ព័ត៌មានទូទៅ:

លោកព្យាការីហូសេនិយាយ។

គ្រាដែលព្រះជាម្ចាស់ដាក់ទោស មកដល់ហើយ គឺគ្រាដែលម្នាក់ៗទទួលផលតាមអំពើ ដែលខ្លួនបាន
ប្រព្រឹត្ត
លោកហូសេបាននិយាយឃ្លាស្រដៀងគ្នាទាំងពីរនេះមកដើម្បីបញ្ជាក់ថាព្រះអម្ចាស់នឹងកាត់ទោសប្រជាជន

ព្យាការីក្លាយទៅជាមនុស្សឡប់សតិ ហើយអ្នកដែលមានវិញ្ញាណភ្លឺស្វាង ក្លាយទៅជាមនុស្សវង្វេង
ស្មារតី
ប្រយោគទាំងនេះជាធម្មតាមានន័យដូចគ្នា។ អត្ថន័យដែលអាចទៅរួចគឺ ១)
ពួកអ្នកដែលទាក់ទងនឹងពួកព្យាការីជាមនុស្សឡប់សតិ ឬ២)
គឺថាពួកព្យាការីបានត្រឡប់ទៅជាឆ្កួតដោយសារតែអំពើបាបដែលប្រជាជនបានធ្វើ។

ព្យាការីក្លាយទៅជាមនុស្សឡប់សតិ ហើយអ្នកដែលមានវិញ្ញាណភ្លឺស្វាង ក្លាយទៅជាមនុស្សវង្វេង
ស្មារតី
នៅទីនេះ «ព្យាការី» និង «អ្នកលើកទឹកចិត្ត»
ទាំងពីរនាក់ជាមនុស្សដែលទទួលព្រះបន្ទូលពីព្រះអម្ចាស់។
ការនេះបានបរិយាយថាអ្នកទាំងនេះគឺជាហោរាក្លែងក្លាយ
ហើយទោះជាយ៉ាងណាក៏គេទទួលព្រះបន្ទូលពីព្រះអម្ចាស់ដែរ។

ព្រោះតែកំហុសដ៏ធ្ងន់ និងអំពើឃោរឃៅដ៏ច្រើនរបស់អ្នក
ឃ្លាថា «កំហុសដ៏ធ្ងន់» និង «អំពើឃោរឃៅដ៏ច្រើន» មានន័យស្រដៀងគ្នា។

និងជាមួយព្យាការីរបស់ព្រះអង្គ។

Hosea 9:8

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ:

លោកព្យាការីហូសេនិយាយ។

អ្នកយាមល្បាតឲ្យអេប្រាអ៊ីម គឺព្យាការី ស្ថិតនៅជាមួយព្រះរបស់ខ្ញុំ

«អ្នកយាមល្បាត» មើលខាងក្រៅក្រុងថាតើអាសន្នអ្វីកើតឡើងឬទេ។

ព្យាការីព្រមាននៅពេលពួកគេប្រព្រឹត្តអំពើបាប
ហើយស្ថិតក្នុងគ្រោះថ្នាក់ពីការដាក់ទោសពីព្រះជាម្ចាស់
គឺប្រៀបដូចជាអ្នកយាមទ្វារក្រុង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្យាការីគឺដូចជាអ្នកយាមរបស់ព្រះជាម្ចាស់លើអេប្រាអ៊ីម»។

អ្នកយាមល្បាតឲ្យអេប្រាអ៊ីម គឺព្យាការី ស្ថិតនៅជាមួយព្រះរបស់ខ្ញុំ

ការបកប្រែខ្លះបកកន្លែងនេះថា
«ព្យាការីជាមួយនឹងព្រះជាម្ចាស់របស់ខ្ញុំគឺជាអ្នកយាមល្បាតលើអេប្រាអ៊ីម»។

ព្យាការីគឺ

សំដៅទៅលើព្យាការីជាទូទៅដែលព្រះអម្ចាស់បានចាក់ប្រេងតាំងឲ្យ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកព្យាការីគឺ» ឬ «ព្យាការីពិតប្រាកដគឺ»។

អេប្រាអ៊ីម

នៅទីនេះ «អេប្រាអ៊ីម» ដំណាងឲ្យប្រជាជនអ៊ីស្រាអែលទាំងអស់។

គេដាក់អន្ទាក់ចាំចាប់គាត់ពីគ្រប់ទិសទី

«អន្ទាក់ចាប់សត្វស្លាប» គឺជាអន្ទាក់ដែលគេប្រើសម្រាប់ចាប់សត្វស្លាប។
មានន័យថាប្រជាជនអ៊ីស្រាអែលធ្វើអ្វីៗគ្រប់យ៉ាងដែលគេអាចធ្វើបានដើម្បីបញ្ឈប់ព្យាការីមិនឲ្យប្រាប់ពីសារដែលព្រះជាម្ចាស់ប្រទានមកគេ
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនដាក់អន្ទាក់គ្រប់កន្លែងទាំងអស់ដែលគាត់ទៅ» ឬ
«ប្រជាជនធ្វើអ្វីគ្រប់យ៉ាងដើម្បីឲ្យគាត់មានបញ្ហា។

ពួកគេផុងខ្លួនទៅក្នុងអំពើពុករលួយ កាន់តែខ្លាំងឡើងៗ ដូចគ្រានៅគីបៀរដែរ

«ប្រជាជនអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាប
ហើយកាន់តែពុករលួយដូចដែលពួកគេធ្លាប់ធ្វើយូរណាស់មកហើយនៅ៊ែគីបៀរ»។
នេះប្រហែលជាសំដៅទៅលើសកម្មភាពដ៏រន្ធត់ដែលកុលសម្ពន្ធបេនយ៉ាមីនបានធ្វើនៅក្នុងជំពូក
១៩ដល់២១។

Hosea 9:10

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

ពីដើម យើងឃើញអ៊ីស្រាអែល

ការនេះនិយាយពីពេលដែលព្រះអម្ចាស់ចាប់ផ្តើមមានទំនាក់ទំនងដំបូងជាមួយប្រជាជនអ៊ីស្រាអែលតាមរយៈលោកម៉ូសេ

ដូចជាផ្លែទំពាំងបាយជូរនៅវាលរហោស្ថាន យើងបានឃើញដូនតារបស់អ្នករាល់គ្នា ដូចជាផ្លែដំបូង
របស់ដើមឧទុម្ពរ

ឃ្លាទាំងពីរនេះបញ្ជាក់ពីស្ថានភាពដែលធ្វើឲ្យមនុស្សម្នាក់ពេញចិត្ត។
មានន័យថាព្រះអម្ចាស់មានអំណរខ្លាំងណាស់នៅពេលដែលទំនាក់ទំនងរបស់ព្រះអង្គជាមួយប្រជាជនអ៊ីស្រាអែលចាប់ផ្តើម។ លោកហូសេចាប់ផ្តើមនិយាយនៅក្នុងខ
បាល ពេអ៊ុរ

នេះជាឈ្មោះរបស់ភ្នំមួយនៅក្នុងទឹកដីម៉ូអាប់ជាកន្លែងដែលគេថ្វាយបង្គំព្រះក្លែងក្លាយគឺព្រះបាលនិងព្រះផ្សេងទៀត

Hosea 9:11

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

កិត្តិយសនឹងចាកចេញពីគេ ដូចសត្វស្លាបដែលហើរបាត់ទៅ

ប្រជាជនអេប្រាអ៊ីម ឬក៏អាណាចក្រខាងជើងរបស់អ៊ីស្រាអែល
នឹងបាត់បង់ការគោរពគ្រប់យ៉ាងពីជាតិសាសន៍ដទៃ។
សិរីរុងរឿងរបស់ពួកគេនឹងរលាយបាត់យ៉ាងរហ័ស ដូចជាសត្វស្លាបហើរទៅឆ្ងាយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សិរីរុងរឿងរបស់ពួកគេដូចជាសត្វស្លាបដែលហើរទៅឆ្ងាយពីពួកគេ»។

កាលណាយើងចាកចេញពីពួកគេ

នៅពេលដែលព្រះអម្ចាស់ឈប់ជួយអាណាចក្រខាងជើង
គឺហាក់បីដូចជាព្រះអង្គចេញឆ្ងាយពីពួកគេ។

Hosea 9:13

ព័ត៌មានទូទៅ:

លោកព្យាការីហូសេនិយាយ។

យើងឃើញថា អេប្រាអ៊ីមប្រៀបបាននឹង ក្រុងទីរ៉ុសដែលស្ថិតនៅកន្លែងសុខស្រួល

«ស្ថិតនៅ» មានន័យថាការនៅកន្លែងសុខសាន្ត។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានពេលមួយដែលជាតិសាសន៍អ៊ីស្រាអែលស្រស់ស្អាត
និងជាទីពេញចិត្តដូចក្រុងទីរ៉ុស ដូចជាដើមឈើដែលគេដាំនៅកន្លែងសុខស្រួល»។

តែអេប្រាអ៊ីមត្រូវបញ្ជូនកូនរបស់ខ្លួន

«កូន» គឺមនុស្សក្នុងជាតិសាសន៍នេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«តែប្រជាជនអ៊ីស្រាអែលនឹងត្រូវបញ្ជូនកូនរបស់ខ្លួន»។

ព្រះអម្ចាស់មានបន្ទូលថា ព្រះអម្ចាស់ធ្វើទោសពួកគេដូច្នេះ តើត្រូវធ្វើទោសពួកគេរបៀបណា?

លោកហូសេប្រើសំណួរដើម្បីបញ្ជាក់ថាលោកចង់ឲ្យព្រះអម្ចាស់ផ្តល់ដល់ប្រជាជនអ៊ីស្រាអែលនូវអ្វីដែលពួក
របៀបផ្សេងទៀតនៃការបកប្រែ: «នេះជាអ្វីដែលទូលបង្គំទូលសុំ ពីព្រះអង្គ
ព្រះអម្ចាស់អើយ សូមប្រទានដល់គេ: «ប្រទានដល់គេ»។

ផ្ទៃដែលមិនអាចបង្កើតកូន

«មិនអាចបង្កើតកូន» មានន័យថាការពពោះបញ្ចប់ឆាប់ពេក ហើយទារកត្រូវស្លាប់។
លោកហូសេបានសុំថាសូមឲ្យស្ត្រីៗក្នុងជាតិសាសន៍នេះកើតឡើងដូចច្នេះ។

[illegible] ជំពូក

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

យើងនឹងដេញពួកគេចេញពី ដំណាក់របស់យើង

ព្រះអម្ចាស់លើកឡើងថាព្រះអង្គនឹងបង្ខំប្រជាជនអ៊ីស្រាអែលឲ្យចេញពីទឹកដីរបស់គេ
គឺចេញពីទឹកដីកាណាន។

ការនេះនិយាយពីពេលដែលព្រះអម្ចាស់ប្រទានទឹកដីកាណានដល់ពួកគេ

ព្រះអម្ចាស់ប្រកាសថាពួកគេជាប្រជាជនផ្ទាល់របស់ព្រះអង្គ។
គឺអ្នកដែលបម្រើស្តេច។

Hosea 9:16

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូលពីប្រជាជនអ៊ីស្រាអែលដែលមិនស្តាប់បង្គាប់ព្រះអង្គ។ លោកហូសេចាប់ផ្តើមនិយាយនៅក្នុងខ
១៧។

ព្រះជាម្ចាស់នឹងបដិសេធពួកគេ ដូចជាមិនស្តាប់ពាក្យបណ្តាសាហើយ ឫសរបស់ពួកគេក្រៀមស្ងួតអស់ ពួកគេពុំអាចបង្កើតផលបានឡើយ

ព្រះអម្ចាស់មានបន្ទូលពីប្រជាជនអ៊ីស្រាអែលដូចជាពួកគេជាដើមឈើដែលមានជំងឺដែលមិនផ្តល់ផលផ្លែ
ហើយរង់ចាំការកាប់ចោល។ នេះជាឃ្លាដែលមនុស្សចុះខ្សោយ
ហើយសត្រូវរបស់ពួកគេនឹងវាយប្រហារពួកគេជាឆាប់។

---

10 [1]អ៊ីស្រាអែល គឺដូចជាទំពាំងបាយជូរប្រណិត ដែលបង្កើត ផលផ្លែ។ ហើយផ្លែកាន់តែចម្រើនឡើង ត្រូវតែសង់រោងឲ្យបានច្រើន។ ដីដែលបង្កើតកាន់ផលបានច្រើន គេ
ត្រូវសង់សសរថ្មកាន់ តែធំដែរ។[2]ចិត្តរបស់គេពេញដោយការបោកប្រាស់ ពេលនេះពួកគេត្រូវទទួលផលនៃទោស។ ព្រះអម្ចាស់នឹងផ្តួលរំលំអាសនៈទាំងឡាយរបស់
ព្រះអង្គនឹងកម្ទេចសសររបស់ពួកគេដែរ។
[3]ដ្បិតពួកគេនឹងនិយាយគ្នាថា «យើងគ្មានស្តេចទេ ព្រោះយើងមិនបានកោតខ្លាចព្រះអម្ចាស់ ហើយស្តេច តើស្តេចអាចធ្វើអ្វីបានសម្រាប់យើង?»[4]ពួកគេពោលពាក្យ
គ្មានបានការ ហើយធ្វើសម្ពន្ធមេត្រីក្នុងការស្បថមិនពិត។ ដូច្នោះយុត្តិធម៌ប្រៀបបាននឹង តិណជាតិពុល ដុះនៅតាមចម្ការដែលគេភ្ជួររាស់។
[5]ប្រជាជនសាម៉ារីនឹងភ័យខ្លាច ព្រោះតែរូបគោញី របស់បេតអាវេន។ ប្រជាជនគេនិងធ្វើពិធីកាន់ទុក្ខឲ្យពួកគេ
ដូចជាបូជាចារ្យបានធ្វើដល់ព្រះក្លែងក្លាយដែលបានរីករាយលើពួកគេ ហើយការលូចប្លន់របស់ពួកគេ ប៉ុន្តែពួកគេមិនមាននៅទីនោះទៀតទេ។[6]ពួកគេនឹងយកនឹងនាំទៅ
អាស្ស៊ីរី សម្រាប់ថ្វាយព្រះចៅអធិរាជ។ អេប្រាអ៊ីមនឹងត្រូវអាម៉ាស់ ហើយអ៊ីស្រាអែលនឹងត្រូវខ្មាស់ដោយព្រះក្លែងក្លាយ។
[7]ស្តេចនៃសាម៉ារីនឹងត្រូវបំផាញ ដូចជាបន្ទះឈើ អណ្តែតនៅលើផ្ទៃទឹក។[8]ទីខ្ពស់សក្ការៈនៃសេចក្តីអាក្រក់ទាំងឡាយនឹងត្រូវបំផ្លាញ។ នេះគឺជាបាបរបស់អ៊ីស្រាអែល! បន្លា
និងអញ្ចាញ នឹងដុះឡើងលើអាសនៈរបស់គេ។ ពេលនោះ គេនឹងនិយាយទៅកាន់ភ្នំធំៗថា៖ «ចូរជួយលាក់យើងផង!» ហើយមនុស្សនឹងនិយាយទៅកាន់ភ្នំថា
«គ្រប់បាំងយើង!» ហើយជ្រលោងភ្នំ «ធ្លាក់លើយើងមក!»
[9]«អ៊ីស្រាអែល អ្នកបានធ្វើបាបចាប់តាំងពីពេលនៅគីបៀរ នៅទីនោះអ្នកបានបន្សល់ទុក។ ប្រព្រឹត្តអំពើបាប ឥតរាងចាលឡើយ។ តើមិនគួរឲ្យសង្គ្រាមកើតឡើងនៅក្នុង
គីបៀរទេ?
[10]នៅពេលយើងសម្រេចចិត្ត យើងនឹងបង្រៀនដល់ពួកគេ។ ជនជាតិទាំងឡាយនឹងលើកគ្នាមកទាស់និងពួកគេ ហើយដាក់ចំណងពួកគេ សម្រាប់ការទុច្ចរិតផ្នែនគ្នាដែលគេ
ប្រព្រឹត្ត។[11]អេប្រាអ៊ីមប្រៀបបានបង្ហាត់គោញី ឲ្យចូលចិត្តបញ្ជាន់ស្រូវ ដូច្នោះយើងនឹងដាក់នឹមលើករបស់គោញី។ យើងនឹងដាក់ទឹមលើអេប្រាអ៊ីម ជនជាតិយូដានឹងភ្ជួរ
ហើយយ៉ាកុបនឹងរាស់ដោយខ្លួនឯង។

generated on Wed Sep 10 16:16:32 2025

[12]ចូរសាបព្រោះសេចក្ដីសុចរិត សម្រាប់ខ្លួនអ្នក ហើយច្រូតកាត់ផលនៃសម្ពន្ធមេត្រីស្មោះត្រង់។ ចូរបំបែកដីដែលមិនទាន់បានភ្ជួរ ដ្បិតវាជាពេលត្រូវស្វែងរកព្រះអម្ចាស់
រហូតដល់ព្រះអង្គយាងមក ហើយចាក់ភ្លៀងនៃសេចក្ដីសុចរិតលើអ្នក។[13]អ្នកបានភ្ជួររាស់អំពើអាក្រក់ ហើយអ្នកនឹងច្រូតកាត់អំពើទុច្ចរិត។ អ្នករាល់គ្នាបានបរិភោគផ្លែនៃ
បោកប្រាស់ ដោយព្រោះអ្នកទុកចិត្តក្នុងផែនការរបស់អ្នក ហើយនឹងព្រះទាំងឡាយរបស់អ្នក។
[14]ដូច្នេះ ការរឹករបូរនៃសង្គ្រាមនឹងងើបឡើង ក្នុងចំណោមប្រជាជនអ្នក កំពែងទីក្រុងដ៏រឹងមាំរបស់អ្នកនឹងត្រូវបំផ្លាញ។ វាគឺជាសាលម៉ានបានបំផ្លាញ ក្រុងបេតអើបេល នៅថ្ងៃ
ធ្វើចម្បាំង ពេលម្តាយបានកម្ទេចជាចំណែកតូចៗ ជាមួយកូនរបស់ខ្លួន។[15]ដូច្នោះវានឹងកើតដល់អ្នក បេតអែល ពីព្រោះអំពើអាក្រក់របស់អ្នក។ ពេលថ្ងៃរះ
ស្តេចនៃអ៊ីស្រាអែលពិតជាត្រូវកាត់ចោល»។

Hosea 10:1

ព័ត៌មានទូទៅ:

លោកហូសេនិយាយ។

អ៊ីស្រាអែល ប្រៀបដូចជាចម្ការទំពាំងបាយជូរ

អ៊ីស្រាអែលប្រៀបបាននឹងដើមទំពាំងបាយជូរដែលមានផលផ្លែជាច្រើន។
ក្នុងមួយរយៈពេលដែលប្រជាជនមានភាពរុងរឿង និងជាប្រជាជនដ៏ខ្លាំង។

ជាទំពាំងបាយជូរដ៏អស្ចារ្យ

ដើមទំពាំងបាយជូរនេះផ្តល់ផលច្រើនជាងធម្មតា។

ផ្លែចេះតែចម្រើនឡើង...ទឹកដីរបស់គេកាន់បង្កើតផលឡើង

ឃ្លាទាំងពីរនេះមានន័យថាប្រជាជនអ៊ីស្រាអែលរុងរឿង ហើយកាន់តែខ្លាំងឡើង
ហើយសំបូរសប្បាយឡើងដែរ។

ចិត្តរបស់គេពេញបោកប្រាស់

«ចិត្ត» សំដៅទៅលើមនុស្សខាងក្នុងរបស់ពួកគេ។ «ពួកគេពេញបោកប្រាស់»។

ឥឡូវនេះពួកគេត្រូវតែទទួលទោស

«ឥឡូវនេះជាពេលដែលព្រះអម្ចាស់នឹងដាក់ទោសពួកគេដោយសារអំពើបាបរបស់ពួកគេ»។

Hosea 10:3

ព័ត៌មានទូទៅ:

លោកហូសេនិយាយ។

យើងមានស្តេច តើស្តេចអាចជួយយើងបានឬទេ?

ប្រជាជននឹងនិយាយថាស្តេចរបស់ពួកគេមិនអាចជួយអ្វីពួកគេបានឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទោះបីជាឥឡូវនេះយើងមានស្តេច
ក៏ទ្រង់មិនអាចជួយអ្វីយើងបានដែរ»។

ពួកគេពោលពាក្យឥតបានការ

នៅទីនេះ«ពាក្យឥតបានការ» សំដៅទៅលើពាក្យកុហក។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនិយាយកុហក»។

យុត្តិធម៌ប្រៀបបាននឹង ពន្លកតិណជាតិមានជាតិពុល ដុះនៅតាមចម្ការដែលគេភ្ជួររាស់

អ្វីដែលប្រជាជនរបស់ពួកគេហៅថាយុត្តិធម៌នៅក្នុងច្បាប់
និងនៅក្នុងការសម្រេចចិត្តរបស់ពួកគេគឺដូចជារុក្ខជាតិដែលដុះពន្លកឡើង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះការសម្រេចចិត្តរបស់ពួកគេគឺមិនត្រឹមតែមិនយុត្តិធម៌ទេ
តែពេញទៅដោយការឈឺចាប់ទៀតផង»។

ដូចជាពន្លកតិណជាតិមានជាតិពុល ដុះនៅតាមចម្ការដែលគេភ្ជួររាស់

ការកុហករបស់ពួកគេ
និងភាពអយុត្តិធម៌បានបាចសាចពេញជាតិសាសន៍របស់ពួកគេ
ហើយធ្វើឲ្យគ្រប់គ្នាមានបញ្ហាដូចជារុក្ខជាតិពុល។

Hosea 10:5

ព័ត៌មានទូទៅ:

លោកហូសេមានបន្ទូល។

បេត អាវែន

នេះជាក្រុងមួយនៅព្រំប្រទល់រវាងអាណាចក្រខាងជើងរបស់អ៊ីស្រាអែល
និងកុលសម្ពន្ធបេនយ៉ាមីននៅអាណាចក្រខាងជើង។
សូមមើលការបកប្រែក្នុងជំពូក ៤:១៥។

គេនឹងយករូបកូនគោនេះទៅស្រុកអាស្ស៊ីរី

ការនេះលើកឡើងជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអាស្ស៊ីរីនឹងនាំពួកគេទៅឆ្ងាយ»។

អេប្រាអ៊ីមនឹងត្រូវអាម៉ាស់ អ៊ីស្រាអែលនឹងត្រូវខ្មាស់ដោយព្រះក្លែងក្លាយ

ការនេះលើកឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយប្រជាជនអ៊ីស្រាអែលនឹងត្រូវអាម៉ាសយ៉ាងខ្លាំងដោយសារពួកគេថ្វាយបង្គំរូបព្រះយ៉ាង

រូបព្រះរបស់ពួកគេ

មានការបកប្រែជាច្រើនមានការបកប្រែចេញពីភាសាហេព្រើរនៅត្រង់នេះថា
«ដំបូន្មាន» ឬ «គម្រោង» ឬ «ចេតនា»។

Hosea 10:7

ស្តេចស្រុកសាម៉ារីនឹងត្រូវបំផ្លាញ

ការនេះលើកឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអាស្ស៊ីរីនឹងបំផ្លាញស្តេចស្រុកសាម៉ារី»។

ប្រៀបបីដូចកម្ទេចឈើអណ្តែតត្រសែតនៅលើផ្ទៃទឹក

មានន័យថាស្តេចស្រុកសាម៉ារីនឹងគ្មានអ្នកជួយសង្គ្រោះ
គឺដូចជាកំណាត់ឈើដែលអណ្តែតត្រសែតលើផ្ទៃទឹក។

ចំណែកឯទីសក្ការទាំងឡាយក៏ត្រូវបំផ្លាញចោលដែរ

ការនេះលើកឡើងជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអាស្ស៊ីរីនឹងបំផ្លាញទីសក្ការៈទាំងឡាយ
ជាកន្លែងដែលប្រជាជនប្រព្រឹត្តការអាក្រក់»។

គេនឹងនិយាយទៅកាន់ភ្នំធំៗថា «ចូរជួយលាក់យើងផង!» ហើយគេក៏និយាយទៅកាន់ភ្នំតូចៗថា «ចូរ
រលំសង្កត់លើយើងមក!»

មនុស្សមិនទម្រាប់និយាយទៅអ្វីដែលមិនចេះគិត ឬមិនចេះស្តាប់ពួកគេឡើយ។
អ្នកបកប្រែអាចជ្រើសរើសក្នុងការប្រើពាក្យផ្សេងៗគ្នានៅក្នុងអត្ថបទនេះបើភាសារបស់គេមិនអាចប្រើពាក្យ
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សនឹងនិយាយថា៖
«យើងសង្ឃឹមថាភ្នំនឹងគ្របលើយើង!» ហើយ
«យើងចង់ឲ្យភ្នំតូចៗសង្កត់លើយើងដែរ!»

Hosea 10:9

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

ពីគ្រានៅគីបៀរ

នេះប្រហែលជាសំដៅទៅលើព្រឹត្តការណ៍ដ៏រន្ធត់ដែលកុលសម្ពន្ធបេនយ៉ាមីនបានធ្វើដែលមាននៅក្នុងគម្ពីរ
១៩ដល់ ២១។ សូមមើលការបកប្រែនៅក្នុងជំពូក ៩:៨

ប្រព្រឹត្តអំពើបាប ឥតរាងចាលឡើយ

ក្នុងឃ្លានេះប្រហែលជាមានន័យថាប្រជាជននៅក្នុងពេលនោះនៅតែបន្តប្រព្រឹត្តរឿងដដែលតាមអ្វីដែលដូន
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយអ្នកគិតដូចអ្វីដែលពួកគេបានធ្វើ»។

តើគួរឲ្យសង្គ្រាមកើតមាននៅគីបៀរ សម្រាប់ដាក់ទោសជនពាលទេ?

ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ថាអ្នកដែលនៅគីបៀរហើយបានប្រព្រឹត្តខុសនឹងធ្លាក់ទៅក្នុងសង្គ្រាម។
ហើយសម្តីទាំងនេះរបស់មនុស្សគឺនាំឲ្យកើតសង្គ្រាម
នៅពេលដែលសត្រូវរបស់ពួកគេមក
គឺហាក់បីដូចជាសង្គ្រាមជាមនុស្សម្នាក់ដែលអាចមានទំនាក់ទំនងជាមួយពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សង្គ្រាមនឹងធ្លាក់លើអ្នកដែលបានធ្វើខុសនៅគីបៀរ» ឬ
«សត្រូវនឹងមកវាយប្រហារអ្នកដែលបានធ្វើខុសនៅគីបៀរ»។

កូនដែលធ្វើខុស

នៅទីនេះ «កូន» គឺជាគ្រាមភាសាដែលមានន័យថា «មានលក្ខណៈដូច» ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលធ្វើខុស» ឬ «មនុស្សអាក្រក់»។

Hosea 10:10

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានបន្ទូល។

កំហុសទាំងពីរ

សំដៅទៅលើអំពើបាបដ៏ច្រើនរបស់អ៊ីស្រាអែល។

អេប្រាអ៊ីមប្រៀបបាននឹងគោញី ដែលគេបង្ហាត់ឲ្យចូលចិត្តបញ្ជាន់ស្រូវ

គោញីចូលចិត្តដើរបញ្ជាន់ស្រូវព្រោះវាអាចដើរជុំវិញដោយគ្មាននឹម។
ព្រះអម្ចាស់ចង់មានន័យថាព្រះអង្គអនុញ្ញាតឲ្យប្រជាជនអ៊ីស្រាអែលមានសេរីភាព
ហើយមានជីវិតដែលរីករាយ។

យើងនឹងដាក់នឹមលើករបស់នាង។ យើងនឹងដាក់នឹមលើអេប្រាអ៊ីម

នៅទីនេះ «នឹម» សំដៅទៅលើទុក្ខវេទនាឬក៏ទាសភាព។
ព្រះអម្ចាស់ធ្លាប់មានចិត្តល្អចំពោះប្រជាជនអ៊ីស្រាអែល ប៉ុន្តែ
មនុស្សមិនស្មោះត្រង់ចំពោះព្រះអង្គ។ ដូច្នេះ ព្រះអង្គដាក់ទោសពួកគេ

generated on Wed Sep 10 16:16:32 2025

ហើយឲ្យគេធ្វើជាទាសករ។
យូដាកំពុងភ្ជួរ ហើយយ៉ាកុបកំពុងរាស់
នៅទីនេះ «យូដា» សំដៅទៅលើប្រជាជននៅអាណាចក្រខាងត្បូង ហើយ
«យ៉ាកុប» គឺជាមនុស្សនៅអាណាចក្រខាងត្បូង។
មានន័យថាព្រះអម្ចាស់នឹងធ្វើឲ្យមានពេលវេលាលំបាកសម្រាប់អាណាចក្រទាំងពីរ។
រនាស់
ឧបករណ៍ដើម្បីវាយដីឲ្យម៉ត់ និងដើម្បីគ្រប់លើគ្រាប់ពូជក្រោយពីភ្ជួររួច។
Hosea 10:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
ចំណែកឯអ្នករាល់គ្នាវិញ ចូរនាំគ្នាសាបព្រោះសេចក្ដីសុចរិត អ្នករាល់គ្នានឹងច្រូតបានភក្ដីភាពយ៉ាង
បរិបូណ៌
សេចក្ដីសុចរិត និងសម្ពន្ធមេត្រីស្មោះត្រង់គឺប្រៀបដូចជាគ្រាប់ពូជដែលគេអាចព្រោះ
និងច្រូតកាត់បាន។
ចូរកាប់គាស់ដីចម្ការថ្មី
នៅពេលដែលដីមិនទាន់ «ភ្ជួរ» នោះយើងមិនអាចដាំដុះបានទេ។
ព្រះអម្ចាស់ចង់ឲ្យមនុស្សប្រែចិត្ត ដូច្នេះ គេអាចចាប់ផ្តើមធ្វើអ្វីដែលត្រឹមត្រូវ។
អ្នករាល់គ្នាសាបព្រោះអំពើអាក្រក់ នោះអ្នករាល់គ្នាទទួលផលជាអំពើអយុត្តិធម៌
អំពើអាក្រក់ និងអំពើអយុត្តិធម៌ គឺប្រៀបបីដូចជាដំណាំដែលអាចព្រោះបាន
ហើយប្រមូលផលបាន។
អ្នករាល់គ្នានឹងបរិភោគផ្លែបោកប្រាស់
លទ្ធផលនៃការបោកប្រាស់គឺប្រៀបដូចជាអាហារដែលអាចបរិភោគបាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ឥឡូវនេះអ្នករងទុកដោយសារផលនៃការដែលអ្នកបោកប្រាស់គ្នាទៅវិញទៅមក»។
Hosea 10:14
ដូចស្តេចសាលម៉ាន បានបំផ្លាញក្រុងបេត អើបេល នៅថ្ងៃធ្វើសឹកសង្គ្រាម
សង្គ្រាមដែលនឹងមកដល់គឺប្រៀបធៀបជាមួយសមភូមិដែលមានតាំងពីយូរលង់មកហើយ។
សាលម៉ាន
ជាឈ្មោះរបស់ស្តេចដែលបំផ្លាញក្រុងបេតអើបេលក្នុងចន្លោះឆ្នាំ៧៤០មុនគ្រិស្តសករាជ។
ទាហានរបស់ស្តេចបានសម្លាប់ស្ត្រី និងកូនក្មេងពេលវាយប្រហារម្តងៗ។
បេតអើបេល
ស្រដៀងនឹងឈ្មោះរបស់ក្រុងមួយក្នុងកុលសម្ពន្ធណែបថាលី។
នេះជាផលវិបាកនៃអំពើអាក្រក់ដ៏ហួសហេតុ ដែលអ្នករាល់គ្នាបានប្រព្រឹត្តនៅបេតអែល
នៅទីនេះ «បេតអែល» តំណាងឲ្យមនុស្សដែលរស់នៅទីនោះ។
ព្យាការីបានលើកឡើងពីអ្នកដែលរស់នៅបេតអែលថាហាក់បីដូចជាពួកគេស្តាប់លោកអ៊ីចឹង។

---

11 [1]«កាលអ៊ីស្រាអែលនៅពីក្មេង យើងបានស្រឡាញ់គេ ហើយយើងហៅកូនប្រុសរបស់យើងចេញពីអេស៊ីបមក។[2]ពួកគេស្រែកហៅយើងយ៉ាងណា ហើយគេក៏ងាក
ចេញឆ្ងាយពីយើងយ៉ាងនោះដែរ។ គេថ្វាយយញ្ញបូជាដល់ព្រះបាល ហើយដុតគ្រឿងកំញានថ្វាយព្រះក្លែងក្លាយ។
[3]ប៉ុន្តែ គឺយើងដែលបានបង្ហាត់អេប្រាអ៊ីមឲ្យចេះដើរ។ គឺយើងដែលបានលើកពួកគេដោយដៃរបស់គេ ប៉ុន្តែពួកគេមិនបានដឹងថាយើងយកចិត្តទុកដាក់សម្រាប់ពួកគេទេ។
[4]យើងបានដឹកនាំគេដោយរំពាត់ នៃមនុស្សលោក ជាមួយចំណងនៃសេចក្ដី ស្រលាញ់។ យើងបានធ្វើដល់គេដូចនរណាម្នាក់បានសម្រាល នឹមផ្គាមរបស់គេ ហើយយើងឱន
កាយបញ្ចុកចំណីដល់គេ។
[5]តើពួកគេនឹងមិនវិលទៅស្រុកអេស៊ីបវិញទេ? តើជនជាតិអាស្ស៊ីរីនឹងគ្រប់គ្រងលើពួកគេ ពីព្រោះពួកគេមិនព្រមវិលត្រឡប់មករកយើងវិញទេ?[6]គឹដាវនឹងធ្លាក់មកលើទី
ក្រុងឡាយរបស់ពួកគេ ហើយបំផ្លាញរបាំងនៃខ្លោងទ្វាររបស់គេ វានឹងបំផ្លាញពួកគេដោយសារផែនការរបស់គេខ្លួនឯង។[7]ប្រជាជនរបស់យើងមានបំណង បែរចេញពីយើង។
ទោះបីពួកគេស្រែកដល់ទីខ្ពស់បំផុត គ្មាននរណានឹងជួយពួកគេទេ។
[8]អេប្រាអ៊ីមអើយ តើឲ្យយើងលើកលែងដល់អ្នកដូចម្តេច? អ៊ីស្រាអែលអើយ តើធ្វើដូចម្តេចឲ្យយើងដកដៃចេញពីអ្នក? តើយើងគួរធ្វើអ្វីឲ្យអ្នកដូចក្រុងអាដម៉ា? តើ
យើងគួរធ្វើអ្វីឲ្យអ្នកដូចក្រុងសេបោ? ចិត្តរបស់យើងបានប្តូរនៅខាងក្នុងយើង ហើយសេចក្ដីមេត្តារបស់យើងបានរំជួលឡើង។[9]យើងមិនអាចប្រតិបត្តិ តាមកំហឹងដ៏ខ្លាំង
របស់យើងទេ យើងនឹងមិនបំផ្លាញអេប្រាអ៊ីមម្តងទៀតទេ។ ព្រោះយើងជាព្រះជាម្ចាស់ មិនមែនជាមនុស្សទេ យើងជាព្រះដ៏វិសុទ្ធដែលស្ថិតក្នុងចំណោមអ្នក ហើយយើង
នឹងមិនមក ដោយកំហឹងឡើយ។
[10]ពួកគេនឹងដើរតាមព្រះអម្ចាស់ ហើយព្រះអង្គនឹងក្រហឹមដូចសត្វសិង្ហ។ ពេលព្រះអង្គបន្លឺព្រះសូរសៀង កូនចៅរបស់ព្រះអង្គនឹងមកដោយញាប់ញ័រ ពីទិសខាងលិច។[11]ពួក
គេញាប់ញ័រដូចជាចាបមកពីអេស៊ីប ហើយដូចព្រាបមកពីអាស្ស៊ីរី។ យើងនឹងឲ្យពួកគេរស់នៅក្នុងផ្ទះរបស់ខ្លួន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[12]អេប្រាអិមឡោមព័ទ្ធ យើងដោយសេចក្ដីភូតភរ ហើយពួកកូនចៅអ៊ីស្រាអែល ជាមួយសេចក្ដីបោកបញ្ឆោត។ ប៉ុន្តែយូដាគឺនៅតែទៅជាមួយនិងយើង ព្រះជាម្ចាស់ ហើយក៏
ស្មោះត្រង់ចំពោះយើង ដល់ព្រះដ៏វិសុទ្ធ»។

Hosea 11:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់និយាយពីការដែលព្រះអង្គយកចិត្តទុកដាក់នឹងអ៊ីស្រាអែលដូចជាឪពុកម្តាយ
កាលអ៊ីស្រាអែលនៅពីក្មេង
ព្រះអម្ចាស់មានបន្ទូលថាអ៊ីស្រាអែលប្រៀបដូចជាកូនក្មេងម្នាក់។
ព្រះអម្ចាស់សំដៅទៅលើពេលដែលព្រះអង្គចាប់ផ្តើមទំនាក់ទំនងរបស់ព្រះអង្គជាមួយជាតិសាសន៍អ៊ីស្រាអែល
យើងហៅបុត្ររបស់យើងចេញពីស្រុកអេស៊ីប
«បុត្រ» និយាយពីប្រជាជនរបស់ព្រះបិតា។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបាននាំបុត្ររបស់យើងចេញពីអេស៊ីប»។
យើងហៅគេច្រើនយ៉ាងណា គេក៏ងាកចេញឆ្ងាយពីយើងយ៉ាងនោះដែរ
ការនេះលើកឡើងក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងហៅគេច្រើនយ៉ាងណាដើម្បីក្លាយជាប្រជាជនរបស់យើង
នោះគេបដិសេធយើងកាន់តែច្រើនដែរ»។
Hosea 11:3
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីការដែលព្រះអង្គយកចិត្តទុកដាក់នឹងអ៊ីស្រាអែល។
យើងនេះហើយដែលបានកាន់ដៃ និងបង្ហាត់អេប្រាអ៊ីមឲ្យចេះដើរ
ព្រះអម្ចាស់ប្រៀបធៀបអ៊ីស្រាអែលទៅនឹងកូនក្មេងដែលព្រះអង្គបង្រៀនឲ្យដើរ។
លើកគេឡើងដោយកាន់ដៃរបស់ពួកគេ
ការលើកឡើងនេះជាការប្រៀបធៀប។ របៀបផ្សេងទៀតនៃការបកប្រែ:
«មើលថែពួកគេ»។
យើងបានណែនាំគេដោយចិត្តអាណិតអាសូរ និងដោយចិត្តស្រឡាញ់
ព្រះអម្ចាស់ស្រឡាញ់ប្រជាជនរបស់ព្រះអង្គក្នុងរបៀបមួយដែលមនុស្សអាចយល់បាន
ហើយអាចអរគុណបាន។
ពួកគេដូចជាអ្នកដែលបន្ធូរនឹមនៅលើស្មារបស់ពួកគេ
ព្រះអម្ចាស់និយាយពីជាតិសាសន៍អ៊ីស្រាអែលដូចជាសត្វដែលធ្វើការយ៉ាងធ្ងន់
តែព្រះអង្គមានធ្វើឲ្យធូស្រាល។
ការលើកឡើងនេះនៅតែបន្តប្រៀបធៀបថាអ៊ីស្រាអែលជាក្មេងតូច។
អាចមានន័យថាព្រះអម្ចាស់ផ្គត់ផ្គង់គ្រប់ទាំងតម្រូវការទាំងអស់របស់ពួកគេ។
Hosea 11:5
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល។
តើពួកគេនឹងមិនវិលទៅស្រុកអេស៊ីបវិញទេឬ?
សំណួរនេះមានន័យថាប្រជាជាតិអ៊ីស្រាអែលនឹងក្លាយទៅជាទាសករម្តងទៀតនៅស្រុកអេស៊ីប។
តើជនជាតិអាស្ស៊ីរីនឹងមិនគ្រប់គ្រងលើពួកគេ ដោយសារពួកគេមិនព្រមវិលត្រឡប់មករកយើងវិញ
ទេឬ?
ប្រជាជាតិអ៊ីស្រាអែលនឹងត្រូវអាស្ស៊ីរីគៀរយកទៅជាឈ្លើយព្រោះពួកគេមិនស្មោះត្រង់ជាមួយព្រះអម្ចាស់។
ដាវនឹងធ្លាក់លើក្រុងរបស់ពួកគេ
នៅទីនេះ «ដាវ»
តំណាងឲ្យសត្រូវរបស់អ៊ីស្រាអែលដែលនឹងត្រូវបំផ្លាញទីក្រុងរបស់អ៊ីស្រាអែល។
បំផ្លាញរនុកទ្វារក្រុងរបស់ពួកគេ
ទ្វារផ្តល់សុវត្ថិភាពពីការទន្ទ្រានពីសត្រូវរបស់ពួកគេ
ហើយរនុកការពារទ្វារដែលបិត។

generated on Wed Sep 10 16:16:32 2025

ការបំផ្លាញរនុកទ្វារមានន័យថាការដកសុវត្ថិភាពរបស់មនុស្សចេញ។
ទោះពួកគេស្រែកទៅទីដ៏ខ្ពស់
នៅទីនេះព្រះអម្ចាស់មានបន្ទូលពីអង្គទ្រង់ផ្ទាល់ជាបុរសទីបី។
ក៏អាចលើកឡើងជាបុរសទីមួយដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទោះបីជាពួកគេស្រែករកយើង នៅទីដ៏ខ្ពស់»។
គ្មាននរណាម្នាក់ជួយពួកគេទេ
ព្រះអម្ចាស់មិនអនុញ្ញាតិឲ្យនរណាម្នាក់ជួយអ៊ីស្រាអែលឡើយ
ព្រោះពួកគេបានងាកឆ្ងាយពីព្រះអង្គ។
Hosea 11:8
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលពីអ៊ីស្រាអែល។
អេប្រាអ៊ីមអើយ តើយើងត្រូវធ្វើអីឲ្យអ្នក? អ៊ីស្រាអែលអើយ តើយើងអាចធ្វើអីឲ្យដល់អ្នក?
ព្រះអម្ចាស់ស្រឡាញ់ប្រជារាស្ត្ររបស់ព្រះអង្គណាស់
ព្រះអង្គមិនបំផ្លាញពួកគេទាំងស្រុងឡើយ។
សំណួរនេះត្រូវបកប្រែជាប្រយោគស្រប។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងមិនបោះបង់ចោលអ្នកឡើយ អេប្រាអ៊ីមអើយ។
យើងនឹងមិនប្រគល់អ្នកទៅសត្រូវរបស់អ្នកឡើយ អ៊ីស្រាអែលអើយ»។
តើយើងត្រូវប្រព្រឹត្តចំពោះអ្នកដូច ក្រុងអាដម៉ាឬ? តើយើងគួរធ្វើឲ្យអ្នកបានដូច ក្រុងសេបោឬ?
ព្រះអម្ចាស់ស្រឡាញ់ប្រជារាស្ត្ររបស់ព្រះអង្គណាស់ព្រះអង្គមិនបំផ្លាញពួកគេទាំងស្រុងឡើយ
សំណួរនេះត្រូវបកប្រែជាប្រយោគស្រប។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមិនចង់ប្រព្រឹត្តចំពោះអ្នកដូចយើងបានធ្វើចំពោះអាដម៉ាឡើយ
ឬធ្វើឲ្យអ្នកដូចក្រុងសេបោឡើយ
ជាក្រុងដែលយើងបំផ្លាញរួមជាមួយក្រុងសូដុម» (UDB)។
ព្រោះយើងជាព្រះជាម្ចាស់ មិនមែនជាមនុស្សទេ
ព្រះជាម្ចាស់មិនដូចមនុស្សឡើយ ដែលតែងតែសម្រេចចិត្តលឿនក្នុងការសងសឹក។
ចិត្តរបស់យើងប្ដូរនៅក្នុងយើង
នៅទីនេះ «ចិត្ត» តំណាងឲ្យបំណងប្រាថ្នារបស់ព្រះអម្ចាស់
និងការសម្រេចចិត្តរបស់ព្រះអង្គ។
យើងមិនមែនមក ដោយកំហឹងឡើយ
ពាក្យជានាមថា «កំហឹង» អាចលើកឡើងជាគុណនាម «ខឹង»។

របៀបផ្សេងទៀតនៃការបកប្រែ: «យើងមិនអាចមករកអ្នក ហើយខឹងអ្នកបានទេ»
Hosea 11:10
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលពីពេលវេលាដែលព្រះអង្គស្តារប្រជារាស្ត្ររបស់ព្រះអង្គវិញ។
ពួកគេនឹងដើរតាមយើងជាព្រះអម្ចាស់
ថ្វាយបង្គំនឹងគោរពព្រះអម្ចាស់គឺនិយាយដូចជាពួកគេដើរតាមព្រះអង្គ
យើងនឹងបន្លឺសំលេងដូចសត្វសិង្ហ
ព្រះអម្ចាស់ផ្តល់ឱកាសដល់ប្រជារាស្ត្ររបស់ព្រះអង្គក្នុងការត្រឡប់មកកាន់ទឹកដីរបស់ព្រះអង្គវិញ
គឺដូចជាព្រះអង្គហៅប្រជារាស្ត្ររបស់ព្រះអង្គ។
ពួកគេប្រញាប់រត់ចេញពីអេស៊ីប ដូចហ្វូងចាបទាំងញ៊ីរន្ធត់...ដូចហ្វូងព្រាប
ពួកគេនឹងត្រឡប់មកផ្ទះរបស់ពួកគេវិញដូចជាបក្សីមករកសំបុករបស់វា។
«ញាប់ញ័រ» អាចសំដៅទៅលើការទទះស្លាបរបស់សត្វស្លាប (សូមមើល UDB)។
វាក៏អាចជាសញ្ញានៃអារម្មណ៍របស់មនុស្ស និងចំពោះព្រះជាម្ចាស់។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
«ជាអ្វីដែលព្រះអម្ចាស់បានប្រកាស» ឬ
«អ្វីដែលព្រះអម្ចាស់មានបន្ទូលយ៉ាងម៉ឺងម៉ាត់»។ សូមមើលការបកប្រែក្នុងជំពូក ២:១២។
Hosea 11:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលអំពីអ៊ីស្រាអែល និងយូដា។
អេប្រាអិមឡោមព័ទ្ធយើងដោយសេចក្ដីភូតភរ ហើយពូជពង្សអ៊ីស្រាអែល ឡោមព័ទ្ធយើងដោយ
សេចក្ដីបោកបញ្ឆោត
ការកុហក និងការបោកប្រាស
គឺនិយាយប្រៀបដូចជារបស់អ្វីមួយដែលមនុស្សក្នុងអាណាចក្រខាងជើងប្រព្រឹត្តចំពោះព្រះអម្ចាស់។
តែយូដាវិញ នៅតែជាមួយព្រះនៅឡើយ
ប្រជាជននៅអាណាចក្រខាងត្បូងនៅតែស្មោះត្រង់ជាមួយព្រះអម្ចាស់នៅឡើយ។
នៅទីនេះ «នៅជាមួយយើង» តំណាងឲ្យការប្រកបជាមួយព្រះជាម្ចាស់។
ទោះជាយ៉ាងណាក៏ដោយ
មានការបកប្រែជាច្រើនលើកឡើងថានេះជាការពិបាកបកប្រែ។

---

12 [1]អេប្រាអិមចំអែតខ្លួនដោយខ្យល់ ហើយចេះតែដេញតាមខ្យល់ពីទិសខាងកើត។ គេបន្តចម្រើនសេចក្ដីភូតភរ និងអំពើឃោរឃៅ។ ពួកគេតាំងសម្ពន្ធមេត្រីជាមួយ
អាសស៊ើរ ហើយនាំយកប្រេងអូលីវទៅអេស៊ីប។[2]ព្រះអម្ចាស់មានបណ្ដឹងទាស់និងយូដា ហើយនឹងដាក់ទោសយ៉ាកុបតាម សម្រាប់អ្វីដែលគាត់បានធ្វើ
ព្រះអង្គនឹងសងគេសម្រាប់អ្វីដែលគេបានប្រព្រឹត្ត។
[3]ពេលនៅក្នុងផ្ទៃនៅឡើយ យ៉ាកុបបានចាប់កែងជើងរបស់បង ហើយមានវ័យពេញកម្លាំង យ៉ាកុបបានបោកចំបាប់ជាមួយព្រះជាម្ចាស់។[4]លោកបានបោកចំបាប់ជាមួយ
ទេវតា ហើយក៏បានឈ្នះ។ លោកបានយំ ហើយអង្វរសុំការប្រណីសន្ដោស។ លោកបានជួបព្រះជាម្ចាស់នៅបេតអែល នៅទីនោះ ព្រះជាម្ចាស់មានព្រះបន្ទូលជាមួយ
លោក។
[5]នេះគឺព្រះអម្ចាស់ ជាព្រះនៃពិភពទាំងមូល «ព្រះអម្ចាស់» គឺជានាមដើម្បីសម្រាប់ហៅ។[6]ដូច្នេះ ចូរវិលមករកព្រះជាម្ចាស់របស់អ្នក។ ចូររក្សាកិច្ចព្រមព្រៀង ស្មោះត្រង់ ហើយ
យុត្តិធម៌ ហើយរង់ចាំចំពោះសម្រាប់ព្រះជាម្ចាស់របស់អ្នក។
[7]ពួកឈ្មួញដែលប្រើជញ្ជីងមិនត្រឹមត្រូវ នៅក្នុងដៃគេ ហើយពួកគេចូលចិត្តបន្លំ។[8]អេប្រាអិមបាននិយាយថា «ខ្ញុំពិតជាអ្នកមានទ្រព្យ ខ្ញុំរកបានទ្រព្យសម្បត្តិសម្រាប់ខ្លួនខ្ញុំ។
ក្នុងការងារទាំងឡាយរបស់ខ្ញុំ គ្មានអ្នកណាឃើញអំពើទុច្ចរិតនៅក្នុងខ្ញុំទេ ឬអ្វីដែលជាអំពើបាប»។
[9]«យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នកតាំងពីនៅអេស៊ីប។ យើងនឹងធ្វើឲ្យអ្នកបាននៅក្នុងក្រសាលម្ដងទៀត ដូចនៅថ្ងៃបុណ្យដែលបានកំណត់។[10]យើងបាននិយាយទៅ
កាន់ពួកព្យាការី គឺយើងនេះហើយដែលសម្ដែង ឲ្យឃើញនិមិត្តកាន់តែច្រើនសម្រាប់អ្នក។ តាមរយៈដៃពួកព្យាការីដែរ យើងនឹងឲ្យជាពាក្យប្រៀបធៀប»។
[11]បើសិនមានអំពើទុច្ចរិតនៅក្នុងកាឡាត ពិតណាស់មនុស្សនឹងទៅជាគ្មានប្រយោជន៍។ ក្នុងគីលកាល គេថ្វាយគោជាយញ្ញបូជា អាសនារបស់គេប្រៀបដូចជាគំនរដុំថ្ម នៅ
តាមគន្លងដែលគេភ្ជួរក្នុងចម្ការ។[12]យ៉ាកុបបានគេចទៅដល់អើរ៉ាម អ៊ីស្រាអែលបានធ្វើការបម្រើ ដើម្បីបានប្រពន្ធ ហើយរក្សាហ្វូងចៀមដើម្បីឲ្យបានប្រពន្ធ។
[13]ព្រះអម្ចាស់បាននាំអ៊ីស្រាអែល ឡើងចេញពីស្រុកអេស៊ីប ដោយសារព្យាការី ព្រះអង្គបានការពារពួកគេ។[14]អេប្រាអិមបានធ្វើឲ្យព្រះអម្ចាស់ខ្ញាល់។ ដូច្នេះ ព្រះអម្ចាស់របស់
គេនឹងធ្វើឲ្យឈាមរបស់គេ នៅជាប់លើខ្លួនគេ ហើយព្រះអង្គនឹងបង្វែសេចក្ដីអាម៉ាស់ របស់គេទៅលើគេវិញ។

Hosea 12:1
ព័ត៌មានទូទៅ:
លោកព្យាការីហូសេនិយាយ។
អេប្រាអ៊ីមចិញ្ចឹមខ្លួនដោយខ្យល់
នៅទីនេះ «អេប្រាអ៊ីម» តំណាងឲ្យប្រជាជនទាំងអស់របស់អ៊ីស្រាអែល។ «ខ្យល់»
តំណាងឲ្យអ្វីដែលគ្មានប្រយោជន៍ ឬក៏បណ្ដោះអាសន្ន។
ប្រជាជនអ៊ីស្រាអែលធ្វើការដែលមិនអាចជួយពួកគេបាន
គឺប្រៀបដូចជាពួកគេបានបរិភោគខ្យល់។
ហើយចេះតែដេញតាមខ្យល់ពីទិសខាងកើត
ខ្យល់ពីទិសខាងកើតគឺជាខ្យល់ក្តៅខ្លាំង ហើយបំផ្លាញដី។
នៅទីនេះតំណាងឲ្យអ្វីដែលបំផ្លាញ។ ប្រជាជនបានធ្វើអ្វីដែលបំផ្លាញខ្លួនឯង
គឺដូចជាពួកគេដើរតាមខ្យល់ពីទិសខាងកើត។
ហើយបញ្ជូនប្រេងទៅអេស៊ីប
ប្រជាជនអ៊ីស្រាអែលបានបញ្ជូនប្រេងអូលីវទៅថ្វាយស្តេចអេស៊ីបដើម្បីបញ្ចុះបញ្ចូលឲ្យស្តេចជួយពួកគេ។
ព្រះអម្ចាស់មានក្តីក្តាំងនឹងយូដា
ព្រះអម្ចាស់លើកឡើងថាប្រជាជនយូដាបាបប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គ
ហើយបានផ្តាច់សម្ពន្ធមេត្រី
គឺប្រៀបដូចជាព្រះអម្ចាស់ចោទប្រកាន់ពួកគេនៅក្នុងតុលាការ។
សូមមើលការបកប្រែស្រដៀងគ្នានៅក្នុងជំពូក ៤:១។
ប្រឆាំងនឹងយូដា...ដាក់ទោសយ៉ាកុបតាមអំពើរបស់គេសងដល់គេតាមអំពើដែលគេបានប្រព្រឹត្ត

generated on Wed Sep 10 16:16:32 2025

នៅទីនេះ «យូដា» និង«យ៉ាកុប»ទាំងពីរនេះដំណាងឲ្យប្រជាជនយូដា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រឆាំងនឹងប្រជាជនយូដា...ដាក់ទោសពួកគេនូវអ្វីដែលពួកគេបានប្រព្រឹត្ត...សងដល់ពួកគេ
ប្តឹង
នេះជាការប្តឹងប្តល់របស់មនុស្សម្នាក់ចំពោះម្នាក់ទៀតនៅក្នុងតុលាការស្របតាមច្បាប់។
សូមមើលការបកប្រែនៅក្នុងជំពូក ២:២។
Hosea 12:3
ព័ត៌មានទូទៅ:
លោកព្យាការីហូសេនិយាយពីលោកយ៉ាកុបដែលជាបុព្វបុរសរបស់ប្រជាជនអ៊ីស្រាអែល។
កាលនៅក្នុងផ្ទៃនៅឡើយ យ៉ាកុបបានចាប់កែងជើងរបស់បង
លោកយ៉ាកុបចង់ដណ្តើមកន្លែងបងរបស់គាត់ជាកូនច្បង ដូច្នេះ
គាត់មិនចង់ឲ្យបងរបស់គាត់កើតមុនឡើយ។
លោកបានបោកចំបាប់ជាមួយទេវតា ហើយក៏បានឈ្នះ
លោកយ៉ាកុបបានបោកចំបាប់ជាមួយទេវតាមួយរូបដូច្នេះទេវតាត្រូវតែឲ្យពរគាត់។
Hosea 12:5
ព័ត៌មានទូទៅ:
លោកព្យាការីហូសេនិយាយ។
ជានាមដ៏ជាទីរំឭក
ការនេះលើកឡើងក្នុងទម្រង់សកម្ម។ នៅទីនេះ «នាម»
តំណាងឲ្យចរិកលក្ខណទាំងស្រុងរបស់ព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«គឺនាមរបស់ព្រះអង្គហើយដែលយើងអធិស្ឋានទៅរក» ឬ
«គឺនាមរបស់ព្រះអង្គហើយដែលយើងថ្វាយបង្គំ»
ចូរកាន់ចិត្តសប្បុរស និងយុត្តិធម៌
សំដៅទៅលើស្តាប់បង្គាប់ច្បាប់របស់ព្រះអង្គ ហើយធ្វើអ្វីដែលត្រឹមត្រូវ។
Hosea 12:7
ព័ត៌មានទូទៅ:
លោកព្យាការីហូសេបាននិយាយពីអ៊ីស្រាអែល។
ជញ្ជីងមិនត្រឹមត្រូវ
ឈ្មួញប្រើជញ្ជីងដែលមិនត្រឹមត្រូវសម្រាប់ថ្លឹងប្រាក់
ឬក៏របស់របរដែលពួកគេទិញលក់។
ពួកគេចូលចិត្តបោកប្រាស់
ពួកឈ្មួញបោកប្រាស់អតិថិជនរបស់ពួកគេដោយកុហកពួកគេ
ហើយយកប្រាក់ពីគេច្រើនជាងអ្វីដែលជាការពិត។
ខ្ញុំជាអ្នកមានស្តុកស្តម្ភ ខ្ញុំរកបានទ្រព្យសម្បត្តិយ៉ាងច្រើន
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយមានន័យថាប្រជាជនអេប្រាអ៊ីមចាត់ទុកខ្លួនឯងថាជាអ្នកស្តុកស្តម្ភ។
ខ្ញុំរកបានទ្រព្យសម្បត្តិ
ការក្លាយជាអ្នកមានដោយការរកស៊ី គឺជារបៀបរកទ្រព្យ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងរកបានប្រាក់ច្រើន»។
ក្នុងមុខរបរទាំងប៉ុន្មានរបស់ខ្ញុំ គ្មានអ្នកណាឃើញអំពើទុច្ចរិត ឬអំពើបាបអ្វីឡើយ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយបញ្ជាក់ថាប្រជាជនអេប្រាអ៊ីមចាត់ទុកខ្លួនឯងជាអ្នកមិនមានកំហុស។
យើងរៀនបានថាអ្នកដែលបានប្រព្រឹត្តអំពើបាប
គឺនិយាយដូចជាគេមិនបានប្រព្រឹត្តបាបសោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងមិនអាចរកឃើញថាខ្ញុំបានប្រព្រឹត្តអំពើបាបអ្វីឡើយ»។
Hosea 12:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នកតាំងពីនៅអេស៊ីប
អត្ថន័យដែលអាចទៅរួច ១) «យើងជាព្រះអម្ចាស់ជាព្រះរបស់អ្នក
ដែលនាំដូនតារបស់អ្នកចេញពីអេស៊ីប» ២)
«យើងធ្លាប់ជាព្រះរបស់អ្នកតាំងពីអ្នកនៅក្នុងទឹកដីអេស៊ីបនៅឡើយ» ឬ ៣)
«យើងក្លាយជាព្រះរបស់អ្នកនៅពេលដែលអ្នកនៅក្នុងទឹកដីអេស៊ីប»។
យើងនឹងធ្វើឲ្យអ្នកបាននៅក្នុងតង់ម្តងទៀត
អត្ថន័យដែលអាចទៅរួច ១)
«ព្រះអម្ចាស់គម្រាមក្នុងការបណ្តេញប្រជាជនអ៊ីស្រាអែលពីផ្ទះរបស់ពួកគេ
ហើយឲ្យគេរស់នៅក្នុងតង់។ ដូច្នេះ នៅទីនេះ «ការរស់ក្នុងតង់»
តំណាងឲ្យការបញ្ជូនទៅជាឈ្លើយ» ឬ ២)
«នេះជាព្រះបន្ទូលសន្យាថាក្រោយពេលពួកគេចេញពីទាសភាពមកវិញប្រជាជននឹងរស់នៅក្នុងតង់ម្តងទៀ
ហើយព្រះអម្ចាស់នឹងថែរក្សាពួកគេដូចដែលព្រះអង្គធ្លាប់ធ្វើនៅពេលដែលប្រជាជនអ៊ីស្រាអែលចេញពីអេស
ដូច្នេះ នៅទីនេះ «ការរស់នៅក្នុងតង់»
តំណាងឲ្យការពិតដែលព្រះអម្ចាស់ថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គ។
ដោយដៃរបស់ពួកព្យាការី
នៅទីនេះ «ដៃ» សំដៅទៅលើម្នាក់ដែលធ្វើសកម្មភាព។
របៀបផ្សេងទៀតនៃការបកប្រែ: «តាមរយៈព្យាការី»។
Hosea 12:11
ព័ត៌មានទូទៅ:
លោកព្យាការីហូសេនិយាយ។
អាសនារបស់គេប្រៀបដូចជាគំនរដុំថ្ម នៅតាមគន្លងដែលគេភ្ជួរក្នុងចម្ការ
អាសនាដែលប្រជាជនថ្វាយបង្គំនឹងត្រូវគេទម្លាក់ចុះ ហើយក្លាយជាគំនរថ្ម។
លោកយ៉ាកុបបានរត់ទៅដល់ស្រុកអើរ៉ាម នៅទីនោះ អ៊ីស្រាអែលបានបម្រើគេ ព្រោះចង់បានប្រពន្ធ
នៅទីនេះ «យ៉ាកុប» និង «អ៊ីស្រាអែល» គឺសំដៅទៅលើមនុស្សតែម្នាក់។
លោកយ៉ាកុបត្រូវប្តូរឈ្មោះមកអ៊ីស្រាអែលវិញ។
Hosea 12:13
ព័ត៌មានតាមទូទៅ:
លោកព្យាការីនិយាយ។
ដោយសារព្យាការី
គឺលោកម៉ូសេ។
យ៉ាងល្វីងជូរចត់
មនុស្សធ្វើឲ្យព្រះអម្ចាស់ព្រះពិរោធយ៉ាងខ្លាំង។
ដូច្នេះ ព្រះអម្ចាស់របស់គេនឹងធ្វើឲ្យឈាមរបស់គេ នៅជាប់លើខ្លួនគេ
នៅទីនេះ «ឈាម» សំដៅទៅលើអំពើអាក្រក់ដែលមនុស្សបានសម្លាប់អ្នកដទៃ។
ព្រះជាម្ចាស់នឹងអត់ទោសបាបពួកគេ។
ហើយព្រះអង្គនឹងសងសេចក្តីដំណៀល របស់គេទៅលើគេវិញ
គំនិតដែលធ្វើឲ្យនរណាម្នាក់រងទុក្ខដោយសារតែអំពោះរបស់គេផ្ទាល់
គឺប្រៀបដូចជាអំពើនោះជារបស់អ្វីមួយដែលអាចបោះត្រឡប់ទៅគេវិញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងធ្វើឲ្យគេរងទុក្ខដោយសារអំពើរបស់គេផ្ទាល់»។

---

13 [1]«កាលអេប្រាអិមនិយាយ មនុស្សរន្ធត់ញាប់ញ័រ។ គេបានតម្កើងក្នុងពួកអ៊ីស្រាអែល ប៉ុន្តែគេមានទោសពីដំណើរព្រះបាល ហើយក៏ស្លាប់ទៅ។[2]ឡូវនេះ ពួកគេនៅតែប្រព្រឹត្តអំពើបាប ថែមហើយថែមទៀត។ ពួកគេបានបន្សុទ្ធដែកស្វែងរកប្រាក់របស់គេ ធ្វើជារូបព្រះដែលមានជំនាញធ្វើការបានសម្រេច រូបព្រះទាំងនោះជាស្នាដៃរបស់ពួកជាង។ មនុស្សនិយាយពីរូបទាំងនោះថា មនុស្សដែលថ្វាយយញ្ញបូជា ចូរថើបរូបគោនេះ។
[3]ដូច្នោះ ពួកគេនឹងបានដូចជាអ័ព្ទនៅពេលព្រលឹម ហើយដូចជាទឹកសន្សើមដែលសូន្យបាត់យ៉ាងឆាប់ ដូចជាអង្កាមដែលខ្យល់កួចផាត់ចេញពីលានស្រូវ ហើយដូចជាផ្សែងដែលហុយចេញពីជើងក្រាន។
[4]ប៉ុន្តែ យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នកតាំងពីអេស៊ីប។ អ្នកមិនស្គាល់ព្រះណាក្រៅពីយើងឡើយ ហើយក្រៅពីយើង ក៏គ្មានព្រះសង្គ្រោះណាដែរ។[5]យើងបានស្គាល់អ្នកនៅក្នុងទីរហោស្ថាន ក្នុងនៅលើទឹកដីហួតហែង។[6]ពេលអ្នកមកដល់កន្លែងវាលស្មៅ អ្នកក៏បានបរិភោគឆ្អែត ហើយកាលគេបានស្កប់ស្កល់ហើយ ចិត្តរបស់អ្នកលើកឡើង។ ដ្បិតមូលហេតុនេះហើយដែលអ្នកបំភ្លេចយើង។
[7]ដូច្នេះ យើងនឹងត្រឡប់ដូចជាសិង្ហដល់គេ ដូចជាខ្លារខិន យើងចាំមើលនៅតាមផ្លូវ។[8]យើងនឹងសង្គ្រប់លើពួកគេ ដូចខ្លាឃ្មុំដែលលួចកូនរបស់វា។ យើងនឹងហែកបេះដូងរបស់គេ ហើយនៅទីនោះ យើងនឹងត្របាក់ស៊ីគេដូចសិង្ហ គឺនឹងហែកគេ ដូចសត្វព្រៃហែកទៅជាចំណែកៗ។
[9]អ៊ីស្រាអែលអើយ យើងនឹងបំផ្លាញអ្នក តើអ្នកណាអាចជួយអ្នកបាន?[10]តើស្តេចរបស់អ្នកនៅទីណា ដែលស្តេចអ្នកនឹងជួយសង្គ្រោះអ្នកនិងក្រុងទាំងឡាយ? តើពួកមេដឹកនាំរបស់អ្នក តើអំពីអ្នកណាដែលអ្នកបាននិយាយមកយើង ចូរឲ្យយើងមានស្តេចហើយពួកមេដឹកនាំមក?[11]យើងបានឲ្យអ្នកមានស្តេច ទាំងកំហឹងរបស់យើង ហើយយើងបានដកស្តេចចេញ ក្នុងការក្រោធរបស់យើង។

generated on Wed Sep 10 16:16:32 2025

[12]អំពើទុច្ចរិតរបស់អេប្រាអិមបានរក្សាទុកហើយ កំហុសរបស់គេក៏បានសន្សំទុកដែរ។[13]ការឈឺចាប់ដូចស្ត្រីសម្រាលកូន បានមកដល់លើគេហើយ តែគេជាកូនដែលគ្មានប្រាជ្ញា ដ្បិតដល់ពេលកំណត់វាបានកើតមក ហើយវាមិនព្រមចេញមកពីផ្ទៃម្តាយមកទេ។
[14]តើយើងត្រូវសង្គ្រោះគេចេញពីស្ថានឃុំព្រលឹងទេ? តើយើងត្រូវសង្គ្រោះគេឲ្យរួចពីសេចក្តីស្លាប់? តើសេចក្តីស្លាប់និងគ្រោះកាចអ្នកនៅឯណា? តើស្ថានឃុំព្រលឹងមនិងការហិនវិនាសរបស់អ្នកនៅទីណា? សេចក្តីអាណិតមេត្តាបានបាំងពីភ្នែករបស់យើងហើយ»។
[15]ទោះបើអេប្រាអិមបានចម្រើន នៅក្នុងចំណោមពួកបងប្អូនរបស់ខ្លួនក៏ដោយ ហើយខ្យល់ពីទិសខាងកើតនឹងមក ខ្យល់នៃព្រះអម្ចាស់នឹងបក់មកពីមុខទីរហោស្ថាន។ អេប្រាអិមក្បាលទឹកនឹងរីងស្ងួត ហើយអណ្តូងទឹករបស់គេគ្មានទឹកដែរ។ សត្រូវរបស់គេនឹងប្លន់យកពីឃ្លាំងរបស់គេ និងគ្រប់របស់ទ្រព្យដ៏មានតម្លៃ។
[16]សាម៉ារីនឹងត្រូវមានទោស ដោយព្រោះគេបានបះបោរប្រឆាំងនឹងព្រះរបស់ខ្លួន។ ពួកគេនឹងដួលស្លាប់ដោយដាវ កូនក្មេងតូចៗរបស់គេ នឹងត្រូវបោកខ្ទេចជាចំណែក ហើយស្ត្រីដែលមានទម្ងន់នឹងត្រូវវះពោះ។

Hosea 13:1
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
កាលអេប្រាអ៊ីមនិយាយ
លោកហូសេប្រើពាក្យថា «អេប្រាអ៊ីម»
សំដៅទៅលើអាណាចក្រអ៊ីស្រាអែលទាំងមូល
ហើយក៏ជាឈ្មោះមួយក្នុងចំណោមកុលសម្ពន្ធទាំងដប់ដែរ។
លោកហូសេហាក់បីដូចជានិយាយពីពេលដ៏យូរកន្លងមកហើយ
គឺនៅពេលដែលអាណាចក្រខាងជើងនៅខ្លាំង និងស្មោះត្រង់ មិនដូចពេលនេះទេ។
មនុស្សរន្ធត់ញាប់ញ័រ
ឃ្លាដែលបាត់ «ក្នុងចំណោមជាតិសាសន៍» គឺអាចឲ្យយើងយល់បាន។
ជាតិសាសន៍ផ្សេងទៀតមិនចុះចូលជាមួយអាណាចក្រខាងជើងទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «មានការញាប់ញ័រក្នុងចំណោមអ្នកដទៃ»។
គេបានលើកខ្លួនឡើងក្នុងពួកអ៊ីស្រាអែល
នៅទីនេះ «លើកខ្លួន» មានន័យថាធ្វើឲ្យនរណាម្នាក់ក្លាយជាមនុស្សសំខាន់។
តែគេមានទោសពីដំណើរព្រះបាល ហើយក៏ស្លាប់ទៅ
នៅពេលដែលប្រជាជនអេប្រាអ៊ីមចាប់ផ្តើមថ្វាយបង្គំព្រះបាល ពួកគេធ្លាក់ខ្សោយ
ហើយសត្រូវរបស់ពួកគេវាយប្រហារពួកគេ។ នៅទីនេះ «ស្លាប់»
សំដៅទៅលើជាតិសាសន៍ដែលធ្លាក់ខ្សោយ។
ឥឡូវនេះ អំពើបាបរបស់ពួកគេកាន់តែច្រើនឡើងៗ
នៅទីនេះ «ពួកគេ» សំដៅទៅលើកុលសម្ព័ន្ធបេនយ៉ាមីន
និងជាតិសាសន៍អ៊ីស្រាអែលទាំងមូល ដែលដើរតាមគំរូរបស់អេប្រាអ៊ីម។
ចូរឲ្យអស់អ្នកដែលថ្វាយយញ្ញបូជា មកថើបរូបកូនគោនេះទៅ
ផ្នែកមួយនៃការថ្វាយបង្គំរូបព្រះគឺការថើបរូបព្រះនោះដែលមានរូបរាងដូចកូនគោ។
Hosea 13:3
ហេតុនេះ គេនឹងបានដូចជាអ័ព្ទ...ដូចជាទឹកសន្សើម...ដូចជាអង្កាម...ដូចជាផ្សែងដែលហុយចេញពីជើងក្រាន
ការលើកឡើងនេះបញ្ជាក់ថាអ៊ីស្រាអែលនឹងត្រូវវិនាសបើពួកគេនៅតែបន្តថ្វាយបង្គំរូបព្រះ
ដែលខ្យល់កួចផាត់ចេញពីលានស្រូវ
ការនេះអាចលើឡើងជាទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលត្រូវខ្យល់ផាត់ទៅឆ្ងាយ»។
Hosea 13:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូលពីប្រជាជនរបស់ព្រះអង្គប្រៀបដូចជាហ្វូងចៀមដែលព្រះអង្គរកឃើញ
ព្រះអង្គមានបន្ទូលថាព្រះអង្គនឹងយកគេជាកម្មសិទ្ធរបស់ព្រះអង្គ។
យើងស្គាល់អ្នកនៅទីរហោស្ថាន
ព្រះអម្ចាស់ចាត់ទុកប្រជាជនហេព្រើរថាជាមនុស្សពិសេសរបស់ព្រះអង្គ
ហើយព្រះអង្គថែរក្សាពួកគេនៅទីនេះ។
នៅពេលយើងគ្វាលអ្នក អ្នកក៏បានឆ្អែត
រូបភាពនៃចៀមនៅតែបន្តក្នុងការលើកឡើងនេះ។
ចិត្តរបស់អ្នកក៏ប៉ោងឡើង
នៅទីនេះ «ចិត្ត» សំដៅទៅលើមនុស្សនៅខាងក្នុង។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកក្លាយជាមានអំនួត»។
ប៉ោងឡើង
ក្លាយជាឆេវឆាវ គឺដូចជាមានចិត្តប៉ោងឡើង។
Hosea 13:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
ដូចជាសិង្ហ...ដូចជាខ្លារខិន...ដូចជាខ្លាឃ្មុំ...ដូចជាសិង្ហ...ដូចជាសត្វព្រៃ
សត្វព្រៃទាំងនេះជាសត្វដែលវាយប្រហារ និងសំលាប់សត្វដទៃទៀត។
ព្រះអម្ចាស់បន្តមានបន្ទូលថាព្រះអង្គនឹងបំផ្លាញប្រជាជនរបស់ព្រះអង្គដោយសារអំពើបាបរបស់ពួកគេ។
ដូចខ្លាឃ្មុំដែលព្រាត់កូន
ពាក្យថា «នឹងវាយប្រហារ» មិនបានលើកឡើងទេដោយសារគេអាចយល់បាន។
ការនេះអាចលើកឡើងក្នុងទំរង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាខ្លាឃ្មុំដែលនឹងវាយប្រហារសត្វមួយទៀតដែលយកកូនរបស់វា»។
ដូចជាសិង្ហ
ពាក្យថា «នឹងត្រូវបំផ្លាញគេ» គឺមិនបានលើកឡើងទេ ព្រោះគេអាចយល់បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូចជាតោដែលនឹងត្រូវបំផ្លាញគេ»។
Hosea 13:9
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
តើអ្នកណានឹងជួយអ្នក?
ព្រះអម្ចាស់ប្រើសំណួរដើម្បីបញ្ជាក់ថាគ្មាននរណាម្នាក់អាចជួយប្រជាជនអ៊ីស្រាអែលបានទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាម្នាក់អាចជួយអ្នកបានទេ»។
ឥឡូវនេះ តើស្តេចរបស់អ្នកនៅទីណា ម្តេចមិនឃើញគេជួយសង្គ្រោះអ្នក នៅតាមទីក្រុងទាំងប៉ុន្មាន
របស់អ្នកផងទៅ? តើពួកមេដឹកនាំរបស់អ្នក គឺអស់អ្នកដែលអ្នកបានពោលទៅគេថា «សូមឲ្យយើង
មានស្តេច និងពួកមេដឹកនាំមក» នោះនៅឯណា?
ព្រះអម្ចាស់សួរសំណួរទាំងនេះចង់ប្រាប់ដល់អ៊ីស្រាអែលថា
នៅពេលពួកគេបះបោរប្រឆាំងនឹងព្រះអង្គ គ្មានស្តេច
ឬមេដឹកនាំណាអាចជួយពួកគេបានទេ។
មានតែព្រះអម្ចាស់ប៉ុណ្ណោះអាចជួយពួកគេពីមហន្តរាយបាន។
Hosea 13:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
អំពើទុច្ចរិតរបស់អេប្រាអ៊ីមបានខ្ជប់ទុកហើយ អំពើបាបរបស់គេក៏បានសន្សំទុកដែរ
ឃ្លាទាំងពីរនេះស្រដៀងគ្នា ហើយមានន័យដូចគ្នា។
ដែលមិនប្រែចិត្តដើរតាមព្រះអម្ចាស់។
អំពើទុច្ចរិត និងអំពើបាបរបស់អាណាចក្រខាងជើង
គឺប្រៀបដូចជារបស់អ្វីមួយដែលគេអាចទុកដើម្បីគោលបំណងណាមួយ។
ការឈឺចាប់ដូចស្ត្រីសម្រាលកូន បានមកដល់គេហើយ
នៅទីនេះព្រះអម្ចាស់មានបន្ទូលពីទុក្ខវេទនារបស់ប្រជាជនអ៊ីស្រាអែល
គឺរងទុកដូចជាស្ត្រីដែលបង្កើតកូន។
ដែលមិនប្រែចិត្តប្រាជ្ញា ដ្បិត ដល់ពេលកើត វាមិនព្រមចេញពីផ្ទៃម្តាយមកទេ
ឥឡូវនេះ
ព្រះអម្ចាស់រៀបរាប់ថាប្រជាជនអ៊ីស្រាអែលដូជាទារកដែលម្តាយទើបតែបង្កើតមក។
ទារកនោះគ្មានប្រាជ្ញាព្រោះមិនចង់កើតចេញមក។ ប្រជាជនមិនចង់ប្រែចិត្ត
និងមិនចង់ស្តាប់បង្គាប់ព្រះអម្ចាស់។
Hosea 13:14
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
តើយើងត្រូវដោះគេចេញពីអំណាច នៃស្ថានឃុំព្រលឹងមនុស្សស្លាប់ឬ? តើយើងត្រូវលោះគេឲ្យរួចពី
សេចក្តីស្លាប់ឬ?
ព្រះអម្ចាស់ប្រើសំណួរនេះដើម្បីប្រាប់ប្រជាជនអ៊ីស្រាអែលថាព្រះអង្គនឹងមិនសង្គ្រោះពួកគេពីសេចក្តីស្លាប់។
ព្រះអង្គនឹងដាក់ទោសពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងមិនជួយសង្គ្រោះពួកគេពីសេចក្តីស្លាប់ទេ
និងមិនសង្គ្រោះគេពីស្ថានមច្ចុរាជដែរ»។)
សេចក្តីស្លាប់អើយ តើទុក្ខវេទនារបស់ឯងនៅឯណា? ស្ថានឃុំព្រលឹងមនុស្សស្លាប់អើយ តើការហិន
វិនាសរបស់ឯងនៅទីណា?

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់មានបន្ទូលទៅកាន់ «សេចក្តីស្លាប់» និង «ស្ថានឃុំព្រលឹង»
ដូចជាពួកគេជាមនុស្ស។
ព្រះអម្ចាស់ប្រើសំណួរដើម្បីមានបន្ទូលថាព្រះអង្គនឹងបំផ្លាញមនុស្សឆាប់ៗនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឥឡូវនេះយើងនឹងធ្វើឲ្យមានការហិនវិនាស
ហើយនឹងធ្វើឲ្យប្រជាជនអ៊ីស្រាអែលស្លាប់។
យើងនឹងបំផ្លាញគេហើយបញ្ជូនពួកគេទៅស្ថានឃុំព្រលឹង»។
សេចក្តីអាណិតអាសូរពួនបាត់
ការដែលមានការអាណិតអាសូរគឺហាក់បីដូចជាវាជារបស់អ្វីមួយ។
សេចក្តីអាណិតអាសូរពួនបាត់ ពីភ្នែករបស់យើង
មិនត្រូវគិតទៅលើការអាណិតអាសូឡើង
ព្រោះនៅទីនេះនិយាយថាក្តីអាណិតអាសូរបានពួនបាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងគ្មានក្តីអាណិតអាសូរដល់ពួកគេទេ»។
Hosea 13:15
ព័ត៌មានទូទៅ:
លោកព្យាការីហូសេនិយាយ។
បងប្អូនរបស់ខ្លួន
ការលើកឡើងនេះហាក់បីដូចជាសំដៅទៅលើជាតិសាសន៍ដែលនៅជុំវិញអាណាចក្រខាងជើង
ជាពិសេសយូដាដែលជាអាណាចក្រខាងត្បូង។
ខ្យល់ពីទិសខាងកើតនឹងបក់មក គឺជាខ្យល់របស់ព្រះអម្ចាស់
ខ្យល់ពីទិសខាងកើតក្តៅខ្លាំង ហើយបង្កមហន្តរាយ។
សំដៅទៅលើសត្រូវពីទិសខាងកើតដែលព្រះអម្ចាស់បញ្ជូនពួកគេឲ្យទៅបំផ្លាញប្រជាជនអ៊ីស្រាអែល។
នោះក្បាលទឹករបស់អេប្រាអ៊ីមនឹងរីងស្ងួត រន្ធទឹករបស់គេនឹងហួតហែងទៅ
លោកហូសេបន្តរៀបរាប់ពីរបៀបដែលព្រះជាម្ចាស់នឹងដាក់ទោសប្រជាជនអ៊ីស្រាអែល។
នៅទីនេះទឹកតំណាងឲ្យជីវិត ភាពឧត្តុង្គឧត្តម និងកម្លាំង។
ឃ្លាំងរបស់គេ
សំដៅទៅលើទ្រព្យសម្បត្តិទាំងអស់របស់ប្រជាជន។
Hosea 13:16
ព័ត៌មានទូទៅ:
លោកព្យាការីហូសេនិយាយ។
សាម៉ារីនឹងត្រូវរងទ្រាំទោសរបស់ខ្លួន ព្រោះគេបានបះបោរប្រឆាំងនឹងព្រះរបស់ខ្លួន
នៅទីនេះ «សាម៉ារី» សំដៅទៅលើប្រជាជននៅក្នុងក្រុងសាម៉ារី
ដែលបានបះបោរប្រឆាំងនឹងព្រះអម្ចាស់។
គេនឹងដួលស្លាប់
ប្រជាជននឹងស្លាប់។
ដោយដាវ
នៅក្នុងសង្គ្រាម។
ទារកតូចៗរបស់គេនឹងត្រូវសត្រូវបោកខ្ទេចខ្ទី ហើយស្ត្រីដែលមានទម្ងន់នឹងត្រូវវះពោះ
ប្រយោគនេះអាចដាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«សត្រូវរបស់ពួកគេនឹងត្រូវសត្រូវបោកកូនតូចៗរបស់គេខ្ទេចខ្ទី ហើយពួកគេនឹងវះ
ពោះស្ត្រីដែលមានទម្ងន់»។

---

14 [1]អ៊ីស្រាអែលអើយ ចូរវិលមករកព្រះអម្ចាស់ ដែលជាព្រះរបស់អ្នក ដ្បិតអ្នកបានធ្លាក់ចុះ ដោយអំពើទុច្ចរិតរបស់អ្នក។[2]ចូរទទួលយកព្រះបន្ទូល ហើយវិលមករក
ព្រះអម្ចាស់វិញ។ ទូលព្រះអង្គថា «សូមដកអំពើទុច្ចរិតរបស់យើងចេញ ហើយទទួលអ្វីដែលល្អ ដូច្នោះយើងខ្ញុំបានថ្វាយផល នៃបបូរមាត់របស់យើងខ្ញុំ។
[3]អាសស៊ើរីមិនអាចសង្គ្រោះយើងឡើយ ពួកយើងក៏មិនជិះសេះទៅធ្វើសង្គ្រាមដែរ។ យើងក៏លែងនិយាយពីការងារនៃដៃរបស់ពួកយើងថា «អ្នកជាព្រះរបស់យើង»
ទៀតដែរ ដ្បិតនៅក្នុងព្រះអង្គមនុស្សកំព្រារកឃើញសេចក្តីមេត្តា»។
[4]«យើងនឹងព្យាបាលផ្លូវបះបោរពួកគេឲ្យជា យើងនឹងស្រឡាញ់គេដោយស្ម័គ្រពីចិត្ត ដ្បិតកំហឹងរបស់យើង បានបែរចេញពីគេហើយ។[5]យើងនឹងបានដូចទឹកសន្សើមដល់
អ៊ីស្រាអែល គេនឹងចេញផ្កាដូចផ្កាលីលី ហើយចាក់ឫសដូចដើមឈើនៅព្រៃល្បាណូន។[6]មែករបស់វានឹងលូតចេញភាពល្អរបស់វា នឹងបានដូចដើមអូលីវ ហើយមានក្លិន
ដូចក្លិននៅព្រៃល្បាណូន។
[7]មនុស្សដែលជ្រកក្រោមម្លប់របស់វា នឹងត្រឡប់មកវិញ ពួក គេនឹងលាស់ឡើងដូចស្រូវចេញផ្កា ដូចដើមទំពាំងបាយជូរ។ កិក្តិយសនាមរបស់គេ នឹងដូចជា
ស្រាទំពាំងបាយជូរ មកពីល្បាណូន។[8]អេប្រាអិមអើយ តើយើងនឹងធ្វើយ៉ាងណាជាមួយរូបព្រះរបស់អ្នក? យើងគឺជាចម្លើយគេ ហើយថែរក្សាគេ។ យើងប្រៀបដូចជាដើម
កកោះស្លឹកខៀវខ្ចី ចេញពីយើងអ្នកអាចបង្កើតផលបាន»។
[9]តើអ្នកណាដែលមានប្រាជ្ញា ដែលនឹងយល់សេចក្តីទាំងនេះបាន? បើអ្នកណាមានចំណេះដឹងអំពីការនេះ ដូច្នេះគេនឹងយល់បានទេ? ដ្បិតផ្លូវនៃព្រះអម្ចាស់គឺទៀងត្រង់
ហើយអ្នកសុចរិតនឹងដើរក្នុងផ្លូវទាំងនោះ តែមនុស្សបះបោរនឹងភ័យខ្លាចនៅក្នុងពួកគេ។

Hosea 14:1
ព័ត៌មានទូទៅ៖:
លោកព្យាការីហូសេនិយាយ។
ដ្បិត អ្នកបានធ្លាក់ចុះ ព្រោះតែអំពើទុច្ចរិតរបស់អ្នក
ចំពោះបាបនៅទីនេះគឺនិយាយថាបានធ្លាក់ចុះ។
សូមទទួលយកព្រះបន្ទូល
នេះប្រហែលជាមានន័យថាជាពាក្យសារភាព និងសរសើរតម្កើង
«សារភាពអំពើបាបរបស់អ្នក»។
ផល នៃបបូរមាត់របស់យើងខ្ញុំ
អ្វីដែលមនុស្សនិយាយគឺជាផលនៃបបូរមាត់របស់អ្នកនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពាក្យសម្តីរបស់យើង
និងចម្រៀងនៃការសរសើរ»។ ការបកប្រែផ្សេងៗបកប្រែឃ្លានេះផ្សេងៗពីគ្នា។
Hosea 14:3
ព័ត៌មានទូទៅ:
លោកហូសេនិយាយ។
អ្វីដែលកើតពីដៃ
«ដៃ» សំដៅទៅលើមនុស្សធ្វើការអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទៅកាន់រូបព្រះដែលយើងធ្វើឡើង»។
អ្នកដែលកំព្រា
ការលើកឡើងនេះប្រហែលជាសម្រាប់ជាតិសាសន៍ទាំងមូល។
វាបញ្ជាក់ពីសេចក្តីមេត្តាសម្រាប់ប្រជាជនរបស់ព្រះអង្គ។
នឹងបានសេចក្តីមេត្តាករុណា
នៅទីនេះសេចក្តីមេត្តារបស់ព្រះអម្ចាស់គឺប្រៀបបាននឹងអ្វីមួយដែលមនុស្សម្នាក់មានបន្ទុកនិងការទទួលខុសត្រូវ
Hosea 14:4
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
យើងនឹងប្រោសចិត្តដែលផិតក្បត់របស់គេឲ្យជា
បញ្ឈប់មនុស្សពីការបែរចេញពីព្រះជាម្ចាស់គឺដូចជាព្យាបាលពួកគេ។
ចិត្តដែលផិតក្បត់របស់គេ
ការបរាជ័យក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់គឺដូចជាពួកគេបានបែរឆ្ងាយពីព្រះអង្គ។
យើងនឹងបានដូចទឹកសន្សើមដល់អ៊ីស្រាអែល គេនឹងចេញផ្កាដូចផ្កាច័ន្ទ
ព្រះជាម្ចាស់មានបន្ទូលថាព្រះអង្គប្រៀបដូចជាទឹកសន្សើមដែលនាំសំណើមដល់រុក្ខជាតិ
ហើយអ៊ីស្រាអែលប្រៀបដូចជាមនុស្សម្នាក់
ហើយអ៊ីស្រាអែលជាផ្កាដែលអាចរីកស្គុសស្គាយ។
ហើយចាក់ឫសដូចដើមឈើនៅព្រៃល្បាណូន
រូបភាពរបស់អ៊ីស្រាអែលដែលប្រៀបបាននឹងរុក្ខជាតិនៅតែបន្តនៅទីនេះ ប៉ុន្តែ
ពេលនេះប្រៀបបាននឹងដើមតាត្រៅដ៏ខ្ពស់នៅស្រុកលីបង់
ដែលដើមឈើទាំងអស់ស្គាល់។
មែករបស់គេនឹងត្រសាយចេញទៅ...ដូចជាដើមតាត្រៅនៅលីបង់
ឃ្លានេះនៅតែបន្តជារូបភាពដូចគ្នា។
Hosea 14:7
ព័ត៌មានទូទៅ:
ព្រះអម្ចាស់មានបន្ទូល។
មនុស្សនឹងវិលមកវិញ ហើយជ្រកនៅក្រោមម្លប់របស់យើង
ប្រជាជនអ៊ីស្រាអែលនឹងមករស់នៅក្រោមការថែរក្សារបស់ព្រះជាម្ចាស់ម្តងទៀត។
អ៊ីស្រាអែលនឹងរស់នៅក្រោមម្លប់របស់ព្រះអង្គ។
គេនឹងលាស់ឡើងដូចសម្ជួងបែកគុម្ព គេនឹងចេញផ្កា ដូចដើមទំពាំងបាយជូរ
ភាពល្អរបស់គេនឹងដូចជាស្រាទំពាំងបាយជូរ
កេរ្តិ៍ឈ្មោះរបស់គេនឹងបានដូចជាស្រាទំពាំងបាយជូរ មកពីស្រុកល្បាណូន
ដូចជាស្រារបស់ល្បាណូនល្បី ដូចគ្នាអ៊ីស្រាអែលនឹងល្បីឈ្មោះ។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់កន្លែងទាំងអស់នឹងស្គាល់ជាតិសាសន៍អ៊ីស្រាអែល»។
តើយើងនឹងធ្វើយ៉ាងណាជាមួយរូបព្រះរបស់អ្នក?
អត្ថបទនេះបញ្ជាក់ថាព្រះជាម្ចាស់នឹងបញ្ឈប់ប្រជាជនអ៊ីស្រាអែលពីការថ្វាយបង្គំរូបព្រះ។
ប្រៀបដូចជាដើមកកោះខៀវខ្ចី
ដើមកកោះគឺជាដើមដែលមានស្លឹកបៃតងពេញមួយឆ្នាំ។ សំដៅទៅលើព្រះអម្ចាស់និងព្រះពររបស់ព្រះអង្គចំពោះអ៊ីស្រាអែល។
ខ្លួនអ្នកនឹងចេញផលរបស់យើង
នៅទីនេះ «ផលផ្លែ» ដំណាងឲ្យការល្អគ្រប់យ៉ាងដែលមកពីព្រះអម្ចាស់។
Hosea 14:9
ព័ត៌មានទូទៅ:
លោកព្យាការីហូសេនិយាយ។
តើអ្នកណាដែលមានប្រាជ្ញា ដែលនឹងយល់សេចក្តីទាំងនេះបាន? បើអ្នកណាមានចំណេះដឹងអំពីការនេះ ដូច្នេះ គេនឹងយល់បានទេ?
លោកព្យាការីប្រើសំណួរទាំងនេះដើម្បីនិយាយថាអ្នកណាមានប្រាជ្ញានឹងយល់និងស្តាប់អ្វីដែលគេប្រាប់ខ្លួន។
ដ្បិត អស់ទាំងផ្លូវរបស់ព្រះអម្ចាស់គឺទៀងត្រង់ មនុស្សទៀងត្រង់នឹងដើរក្នុងផ្លូវទាំងនោះ
ក្រិតវិន័យរបស់ព្រះអម្ចាស់គឺប្រៀបដូចជាផ្លូវដែលអាចដើរចូលបាន។
ជាប់គាំង
ការមិនស្តាប់បង្គាប់ព្រះអម្ចាស់គឺប្រៀបដូចជាជាប់គាំងនៅពេលដែលកំពុងដើរ។

យ៉ូអែល

1 [1]នេះជាព្រះបន្ទូលដែលព្រះអម្ចាស់ ថ្លែងមកកាន់លោកយ៉ូអែល ជាកូនរបស់លោកពេធូអែល។[2]ពួកព្រឹទ្ធាចារ្យទាំងឡាយអើយ សូមស្តាប់ការនេះចុះ ពួកអ្នកស្រុកអើយ ចូរផ្ទៀងត្រចៀកស្តាប់។ តើហេតុការណ៍បែបនេះដែលកើតមាន ក្នុងគ្រារបស់អ្នករាល់គ្នា ឬក្នុងជំនាន់ដូនតាអ្នករាល់គ្នាឬទេ?[3]សូមប្រាប់ការទាំងនេះដល់កូនរបស់អ្នក និងឲ្យកូនរបស់អ្នក ប្រាប់ដល់ចៅ រួចឲ្យចៅប្រាប់ដល់ជំនាន់ក្រោយៗទៀតផង។
[4]អ្វីៗដែលដង្កូវទុកឲ្យនៅសល់ នោះមានកណ្តូបស៊ីបង្ហិន អ្វីៗដែលកណ្តូបទុកឲ្យនៅសល់ នោះមានចង្រិតស៊ីបង្ហិន ហើយអ្វីៗដែលចង្រិតទុកឲ្យនៅសល់ នោះមានក្រាស៊ីបង្ហិន។
[5]ពួកអ្នកប្រមឹកអើយ ចូរភ្ញាក់ឡើង ហើយយំផង ពួកអ្នកដែលផ្អើបផឹកស្រាទំពាំងបាយជូរទាំងឡាយ ទ្រហោយំចុះ ដោយព្រោះតែស្រាទំពាំងបាយជូរផ្អែម គឺបានកាត់ចេញពីអ្នកទាំងអស់គ្នាហើយ។[6]ត្បិត ជនជាតិមួយនឹងមករស់នៅលើទឹកដីរបស់ខ្ញុំ ពួកគេរឹងមាំហើយចំនួនរាប់មិនអស់។
ធ្មេញរបស់ពួកគេគឺជាធ្មេញនៃសត្វសិង្ហ ក៏មានថ្គាមដូចថ្គាមរបស់សិង្ហញី។[7]វាបានបំផ្លាញដើមទំពាំងបាយជូររបស់យើង ក៏បានស៊ីកម្ទេចដើមឧទុម្ពររបស់យើង វាហែកសម្បកហើយគ្រវែងចោល វាធ្វើឲ្យមែកទាំងអស់ប្រែទៅជាពណ៌ស។
[8]ចូរកាន់ទុក្ខ ដូចស្រីក្រមុំដែលស្លៀកពាក់សំពត់ធ្មៃ យំសោកនឹងគូដណ្តឹងរបស់នាងស្លាប់។[9]ចំណែកតង្វាយម្សៅ និងតង្វាយច្រួច នោះបានផ្តាច់ចេញពីព្រះដំណាក់របស់ព្រះអម្ចាស់ហើយ។ ពួកសង្ឃដែលបម្រើការងារថ្វាយព្រះអម្ចាស់ នាំគ្នាកាន់ទុក្ខដែរ។[10]ស្រែចម្ការត្រូវខូចបង់ ហើយស្រុកកំពុងសោយសោក ដ្បិតស្រូវត្រូវបំផ្លាញ។ ស្រាទំពាំងបាយជូរថ្មីក៏រីងហួត និងប្រេងក៏ខ្វះទៅដែរ។
[11]ពួកអ្នកធ្វើស្រែចម្ការអើយ ចូរស្រងាកចិត្តទៅ ពួកអ្នកធ្វើចម្ការទំពាំងបាយជូរអើយ ចូរទ្រហោយំចុះ ដោយព្រោះស្រូវសាលី និងស្រូវឱក។ ដ្បិតចម្រូតនៅស្រែចម្ការខូចអស់ហើយ។[12]ដើមទំពាំងបាយជូរស្វិតក្រៀម ហើយដើមល្វាស្វិតស្រពោនអស់ហើយ ហើយដើមទទឹម ដើមលម៉ី និងដើមសារី គឺអស់ទាំងដើមឈើនៅចម្ការ ក៏ស្វិតក្រៀមទៅដែរ។ អំណរក៏ស្ងួតពីមនុស្សលោកដែរ។
[13]ពួកសង្ឃអើយ! ចូរស្លៀកសំពត់ធ្មៃ ហើយពួកអ្នកដែលបម្រើនៅលើអាសនាអើយ ចូរទ្រហោរយំចុះ។ ពួកអ្នកបម្រើព្រះជាម្ចាស់អើយ ចូរនាំគ្នាចូលមក ចូរដេកឃ្លុំខ្លួនដោយសំពត់ធ្មៃពេញមួយយប់ចុះ។ ដ្បិតតង្វាយម្សៅ និងតង្វាយច្រួច ត្រូវដកហូតចេញពីព្រះដំណាក់ នៃព្រះរបស់អ្នករាល់គ្នាហើយ។[14]ចូរតមអាហារឲ្យបានបរិសុទ្ធ ចូរប្រកាសឲ្យមានការប្រជុំក្នុងចំណោមអ្នកបរិសុទ្ធ។ ត្រូវប្រមូលពួកចាស់ទុំ និងពួកអ្នកស្រុកទាំងអស់ ឲ្យមកព្រះដំណាក់នៃព្រះអម្ចាស់ជាព្រះអង្គរបស់អ្នក ហើយស្រែកអំពាវនាវរកព្រះអម្ចាស់ផង។
[15]វេទនាហើយថ្ងៃនោះ ដ្បិតជាថ្ងៃនៃព្រះអម្ចាស់ ជិតមកដល់ហើយ។ ថ្ងៃនោះនឹងមកដល់ដូចជាការបំផ្លាញ មកពីព្រះអង្គពេញដោយអំណាច។[16]តើអាហារមិនបានរលាយបាត់ពីភ្នែករបស់យើង ហើយអំណរនិងការសប្បាយរីករាយ ពីព្រះដំណាក់របស់ព្រះជាម្ចាស់នៃយើងឬទេ?[17]គ្រាប់ពូជពង្រោះរលួយអស់នៅក្នុងដី ឃ្លាំងនៅទទេហើយ ជង្រុកស្រូវក៏រលំអស់ ព្រោះស្រូវស្វិតក្រៀមអស់ហើយ។
[18]សត្វទាំងប៉ុន្មានស្រែកយំ ហ្វូងគោស្រឡាំងកាំង ដ្បិតគ្មានស្មៅស៊ីសោះ ទាំងហ្វូងចៀមក៏ត្រូវរីងរៃដែរ។[19]ព្រះអម្ចាស់អើយ ទូលបង្គំទូលអង្វរព្រះអង្គ។ ដ្បិតភ្លើងបានឆេះវាលស្មៅនៅទីរហោស្ថាន ហើយអណ្តាតភ្លើងបានឆេះអស់ទាំងដើមឈើនៅវាលដែរ។[20]សូម្បីតែសត្វនៅដីទាំងប៉ុន្មាន ក៏ដង្ហក់រកព្រះអង្គដែរ ព្រោះប្រភពទឹកទាំងប៉ុន្មានរីងស្ងួតទៅ ហើយភ្លើងក៏បានឆេះវាលស្មៅ នៅទីរហោស្ថានអស់ដែរ។

Joel 1:1
ព័ត៌មានទូទៅ:
ព្រះមានបន្ទូលតាមរយៈលោកយ៉ូអែល ទៅកាន់ប្រជាជនអ៊ីស្រាអែលដោយការប្រើប្រាសកំណាព្យ។
«ព្រះបន្ទូលដែលព្រះអម្ចាស់ ថ្លែងមក»
«ព្រះបន្ទូលដែលព្រះអម្ចាស់ ទ្រង់មានបន្ទូល»។
ព្រះអម្ចាស់
នេះជាព្រះនាមនៃព្រះដែលទ្រង់បានបើកសម្តែងទៅកាន់រាស្ត្ររបស់ទ្រង់នៅក្នុងជំនាន់សញ្ញាចាស់។
សូមមើលនៅទំព័រដែលការបកប្រែពាក្យ
អំពីព្រះអម្ចាស់ដែលទាក់ទងពីរបៀបបកប្រែនេះ។
លោកពេធូអែល
ឪពុករបស់លោកលោកយ៉ូអែល។
តើហេតុការណ៍បែបនេះដែលកើតមាន ក្នុងគ្រារបស់អ្នករាល់គ្នា ឬក្នុងជំនាន់ដូនតាអ្នករាល់គ្នាឬទេ?
របៀបផ្សេងទៀតនៃការបកប្រែ:
«ហេតុការណ៍នេះមិនដែលបានកើតឡើងពីមុនមកចំពោះអ្នករាល់គ្នា ឬដូនតាអ្នករាល់គ្នាទេ»។
Joel 1:4
ដង្កូវ
ជាក្រុមដ៏ធំនៃពួកសត្វល្អិតដូចជាសត្វចង្រិតដែលហើរជាហ្វូង
និងស៊ីផលដំណាំជាច្រើនជាអាហារ
ដង្កូវ...កណ្តូប...ចង្រិត...ក្រា
ទាំងនេះគឺផ្សេងៗគ្នា កណ្តូបជំទង់ដែលអាចហើរបាន
កណ្តូបមានមាឌធំអាចហើរយ៉ាងងាយស្រួល
កណ្តូបដែលមានស្លាបគឺនៅខ្ចីក្នុងការហោះហើរ
និងកណ្តូបដែលទើបតែកើតមិនទាន់បានលូតលាស់ស្លាបនៅឡើយ។
សូមប្រើប្រាស់ឈ្មោះដែលនឹងងាយយល់ក្នុងភាសារបស់អ្នក។
Joel 1:5
ព័ត៌មានទូទៅ:
ព្រះដាស់តឿនប្រជាជនអ៊ីស្រាអែលពីការមកដល់នៃទ័ពកណ្តូប។
ពួកអ្នកប្រមឹកអើយ ហើយយំផង ពួកអ្នកដែលផ្អើបផឹកស្រាទំពាំងបាយជូរទាំងឡាយ ទ្រហោយំចុះ
ប្រសិនបើ ក្នុងភាសារបស់អ្នកមានតែមួយសំរាប់ពាក្យ «យំ» និង «ទ្រហោយំ» អ្នកអាចបង្រួមប្រយោគ «មនុស្សរាល់គ្នាដែលស្រឡាញ់ស្រាអើយ ចូរស្រែកទ្រហោយំពេលមានទុក្ខព្រួយ»។
ជនជាតិមួយ
ដង្កូវប្រៀបដូចជាទ័ពឈ្លានពាន។
ធ្មេញរបស់ពួកគេ ក៏មានថ្គាម វាបានបំផ្លាញ វាហែកសម្បក
សត្វកណ្តូបប្រៀបដូចជាជនជាតិមួយដែលដូចជាមនុស្សម្នាក់។
អ្នកអាចសំដៅទៅលើជនជាតិមួយថា «វា» ឬក៏ចំពោះសត្វកណ្តូបថា «ពួកគេ»

generated on Wed Sep 10 16:16:32 2025

ឬក៏ចំពោះអ្នកឈ្លានពានដូចជាមនុស្សម្នាក់ (ULB)។
ធ្មេញរបស់ពួកគេគឺជាធ្មេញនៃសត្វសិង្ហ ក៏មានថ្គាមដូចថ្គាមរបស់សិង្ហញី។
ប្រយោគទាំងពីរបង្ហាញពីអត្ថន័យស្រដៀងគ្នា។ យោងតាមការបញ្ជាក់
ធ្មេញរបស់សត្វកណ្តូបមានរាងដូចធ្មេញរបស់សត្វសិង្ហ
ដែលសំដៅលើភាពឃោរឃៅដែលពួកគេបំផ្លាញទាំងស្រុងនៃដំណាំនៅលើដីទាំងអស់។
ទឹកដីរបស់ខ្ញុំ ដើមទំពាំងបាយជូររបស់យើង ដើមឧទុម្ពររបស់យើង
ទឹកដី ដើមទំពាំងបាយជូរ និងដើមឧទុម្ពរជារបស់ព្រះអម្ចាស់
Joel 1:8
ព័ត៌មានទូទៅ:
ព្រះបន្តមានព្រះបន្ទូលមកកាន់ប្រជាជនអ៊ីស្រាអែល។
ទឹកដីបានធ្លាក់ចុះខ្សោយ
នៅទីនេះទឹកដីត្រូវបានិយាយ ប្រៀបដូចជាមនុស្ស។ យ៉ាងណាមិញ
មានការបកប្រែកំណែផ្សេងទៀតនៅក្នុងអត្ថបទនេះទៅជាពាក្យប្រៀបធៀបផ្សេង
«ស្រុកកំពុងយំសោក»។
Joel 1:11
ព័ត៌មានទូទៅ:
ព្រះបន្តមានព្រះបន្ទូលមកកាន់ប្រជាជនអ៊ីស្រាអែល។
ស្រូវឱក
ជាប្រភេទស្មៅ
ដូចជាស្រូវសាលីដែលមានគ្រាប់ពូជដែលអាចយកមកធ្វើនំបុ័ងបាន។
ស្វិតក្រៀម
ស្វិតក្រៀម និងស្លាប់
ល្ង...ទទឹម...សារី
ជាប្រភេទនៃផ្លែឈើ
Joel 1:13
ព័ត៌មានទូទៅ:
ព្រះមានបន្ទូលមកកាន់ពួកបូជាចារ្យក្នុងជនជាតិអ៊ីស្រាអែល។
ពួកសង្ឃអើយ! ចូរស្លៀកសំពត់ធ្មៃ ហើយពួកអ្នកដែលបម្រើនៅលើអាសនាអើយ ចូរទ្រហោរយំចុះ។
ពួកអ្នកបម្រើព្រះជាម្ចាស់អើយ ចូរនាំគ្នាចូលមក ចូរដេកឃ្លុំខ្លួនដោយសំពត់ធ្មៃពេញមួយយប់ចុះ។
ព្រះកំពុងតែប្រាប់ដល់ពួកបូជាចារ្យឲ្យបន្ទាបខ្លួន និងស្រែក
អំពាវនាវក្នុងភាពទុក្ខព្រួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកបូជាចារ្យអើយ
ចូរទួញសោក និង ទ្រហោរយំ និង បន្ទាបខ្លួនដោយការចំណាយពេលឃ្លុំខ្លួនដោយ
សំពត់ធ្មៃពេញមួយយប់ចុះ»។
តង្វាយម្សៅ និងតង្វាយច្រួច
ជាដង្វាយទូទៅនៅក្នុងព្រះវិហារ។
ព្រះដំណាក់នៃព្រះអង្គរបស់អ្នក
ព្រះវិហារក្នុងក្រុងយេរូសាឡិម។
Joel 1:15
ព័ត៌មានទូទៅ:
នេះជាអ្វីដែលព្រះនឹងមានបន្ទូលប្រាប់ទៅពួកបូជាចារ្យឲ្យនិយាយ។
តើអាហារមិនបានរលាយបាត់ពីភ្នែករបស់យើង ហើយអំណរនិងការសប្បាយរីករាយ ពីព្រះដំណាក់
របស់ព្រះជាម្ចាស់នៃយើងឬទេ?
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងធ្លាប់បានឃើញការផ្គត់ផ្គង់នៃអាហារបស់យើងបានប្រើប្រាស់អស់
ហើយពួកគេបានកាត់ផ្តាច់សេចក្តីអំណរ
និងការសប្បាយរីករាយពីព្រះដំណាក់របស់ព្រះនៃយើង»។
ពីភ្នែករបស់យើង
«របស់យើងសំដៅលើប្រជាជនអ៊ីស្រាអែលទាំងអស់» ។
អំណរ និងការសប្បាយរីករាយ
ពាក្យទាំងពីរនេះមានន័យដូចគ្នា។ ទាំងពីរចង្អុរបង្ហាញថា
ទាំងនេះមិនមែនជាប្រភេទនៃសេចក្តីអំណរដែលជាសកម្មភាពកើតឡើងនៅព្រះវិហារទេ។
ដី
ដុំដី
Joel 1:18
ព័ត៌មានទូទៅ:
ព្រះបន្តមានបន្ទូលប្រាប់ដល់ពួកបូជាចារ្យពីរបៀបដែលពួកគេគួរអធិស្ឋានសម្រាប់ប្រជាជនអ៊ីស្រាអែល។
ស្រែកយំ
ធ្វើសំលេងធ្ងន់ដោយសារតែការឈឺចាប់។
ភ្លើងបានឆេះ អណ្តាតភ្លើងបានឆេះ
ប្រយោគស្រដៀងគ្នាទាំងពីរនេះបង្ហាញពីទឹកដីទាំងអស់ ទាំងបានដាំដុះនិង
មិនបានដាំដុះត្រូវបានបំផ្លាញ។
ជ្រោះ
ប្រព័ន្ធទឹកហូរតូចៗ

---

2 [1]ចូរផ្លុំត្រែនៅក្រុងស៊ីយ៉ូន ហើយចូរធ្វើសូរសញ្ញានៅលើភ្នំបរិសុទ្ធរបស់យើង! ត្រូវឲ្យអ្នកស្រុកទាំងអស់ញាប់ញ័រនឹងភ័យខ្លាចផង ដ្បិតថ្ងៃរបស់ព្រះអម្ចាស់កំពុងតែ
មកហើយ ថ្ងៃនោះនៅជិតបង្កើយ។[2]គឺជាថ្ងៃងងឹត ហើយមេឃស្រទំ ជាថ្ងៃមានពពក ហើយងងឹតយ៉ាងក្រាស់។ មានជនជាតិមួយយ៉ាងធំ ហើយខ្លាំងពូកែចូលមក ដូច
ពន្លឺថ្ងៃដែលទើបនឹងរះលាតត្រដាងលើភ្នំ តាំងពីដើមមកមិនដែលមានដូច្នេះឡើយ ហើយនៅពេលខាងមុខ គ្រប់ជំនាន់តរៀងទៅក៏មិនមានទៀតដែរ។
[3]មានភ្លើងឆេះបន្សុសនៅពីមុខវា ហើយខាងក្រោយវាក៏មានអណ្តាតភ្លើងឆេះដែរ។ នៅពីមុខវា ផែនដីប្រៀបដូចជា សួនអេដែន តែខាងក្រោយវា ប្រៀបដូចជា
ទីរហោស្ថានហួតហែង គ្មានរបស់អ្វីគេចផុតពីវាបានឡើយ។
[4]រូបរាងរបស់វាមើលទៅដូចជាសេះ ហើយពួកវាក៏រត់ដូចជាសេះចម្បាំងផងដែរ។[5]ពួកវាកញ្ជលឮសន្ធឹកដូចរទេះចម្បាំងនៅលើកំពូលភ្នំ គឺដូចសន្ធឹកអណ្តាតភ្លើងដែលឆេះ
ជញ្ជ្រាំង ហើយដូចជាកងទ័ពដ៏ខ្លាំងពូកែ ដែលរួចរាល់ក្នុងការចូលទៅច្បាំង។
[6]មនុស្សមានសេចក្តីថប់ព្រួយនៅមុខគេ ហើយមុខអ្នកទាំងអស់នោះទៅជាស្លេកស្លាំង។[7]ពួកគេសម្រុកទៅមុខដូចមនុស្សខ្លាំងពូកែ ក៏ឡើងកំផែងដូចមនុស្សថ្នឹកច្បាំង ម្នាក់ៗ
សម្រុកទៅមុខ ឥតងាកចេញពីផ្លូវរបស់ខ្លួនឡើយ។
[8]ម្យ៉ាងវិញទៀត ពួកគេមិនរុញគ្នាទៅវិញទៅមកទេ គឺម្នាក់ៗដើរតាមជួររៀងខ្លួនជានិច្ច ពួកគេវាយលុកទៅមុខបំបែកអ្នកការពារ ដោយរក្សាជួររបស់គេដ៏ដែរ។
[9]ពួកគេគំហុកចូលទៅក្នុងទីក្រុង ក៏រត់នៅលើកំផែង ហើយគេតោងឡើងទៅក្នុងផ្ទះទាំងប៉ុន្មាន ដោយគេចូលតាមបង្អួចដូចជាចោរ។
[10]ផែនដីកក្រើកនៅមុខគេ ផ្ទៃមេឃក៏ញ័ររន្ធត់ ព្រះអាទិត្យ និងព្រះចន្ទប្រែជាងងឹត ហើយផ្កាយទាំងប៉ុន្មានក៏លែងបញ្ចេញពន្លឺ។[11]ព្រះអម្ចាស់បញ្ចេញព្រះសូរសៀង នៅមុខ
កងទ័ពរបស់ព្រះអង្គ ដ្បិតជំរំទ័ពរបស់ព្រះអង្គធំណាស់ អស់អ្នកដែលធ្វើតាមបញ្ជារបស់ព្រះអង្គ នោះមានច្រើនឥតគណនា ដ្បិតថ្ងៃរបស់ព្រះអម្ចាស់ជាថ្ងៃដ៏អស្ចារ្យ ហើយ
គួរស្ញែងខ្លាចណាស់។ តើអ្នកណាអាចរួចជីវិតពីវាបាន?
[12]ព្រះអម្ចាស់បានមានព្រះបន្ទូលថា៖ ឥឡូវនេះ ចូរនាំគ្នាបែរមករកយើងឲ្យអស់ពីចិត្ត ទាំងតមអត់ទាំងយំសោក ហើយកាន់ទុក្ខផង។[13]មិនគ្រាន់តែហែកអាវខ្លួនទេ គឺត្រូវ
យំក្នុងចិត្ត ហើយបែរមករកព្រះអម្ចាស់ជាព្រះរបស់អ្នកវិញ ដ្បិតព្រះអង្គប្រកបដោយព្រះគុណ និងព្រះហឫទ័យមេត្តាករុណា ព្រះអង្គយឺតនឹងខ្ញាល់ ហើយមានព្រះហឫទ័យ
សប្បុរសជាបរិបូរ ព្រះអង្គមិនសព្វព្រះហឫទ័យនឹងការជំនុំជម្រះទេ។
[14]តើនរណានឹងដឹង? ប្រហែលជាព្រះអង្គនឹងលើកលែងទោស ហើយចាត់ព្រះទានពរមកដល់អ្នករាល់គ្នា ជំនួសឲ្យបណ្តាសា។ គឺឲ្យមានតង្វាយម្សៅ និងតង្វាយច្រួច
សម្រាប់ថ្វាយព្រះអម្ចាស់ ជាព្រះរបស់អ្នក។
[15]ចូរផ្លុំត្រែឡើងនៅក្រុងស៊ីយ៉ូន ចូរញែកពេលចេញសម្រាប់តមអត់ ចូរហៅអ្នកបរិសុទ្ធមកប្រជុំគ្នា។[16]ចូរប្រមូលប្រជាជន ចូរញែកក្រុមជំនុំចេញជាបរិសុទ្ធ ចូរប្រជុំពួកចាស់ទុំ
ចូរប្រមូលកូនក្មេង ព្រមទាំងកូនដែលនៅបៅដោះមកផង។ ត្រូវឲ្យប្តីថ្មោងថ្មីចេញពីបន្ទប់មក ហើយប្រពន្ធថ្មោងថ្មីចេញពីវាំងននមកដែរ។
[17]ចូរឲ្យពួកបូជាចារ្យ ជាពួកអ្នកបម្រើរបស់ព្រះអម្ចាស់ យំនៅចន្លោះច្រកចូល និងអាសនា។ ត្រូវឲ្យគេពោលថា «ព្រះអម្ចាស់អើយ សូមមេត្តដល់ប្រជារាស្ត្ររបស់ព្រះអង្គផង
សូមកុំឲ្យគេមាក់ងាយមរតករបស់ព្រះអង្គ ឲ្យពួកជនជាតិដទៃបានគ្រប់គ្រងលើគេឡើយ។ តើមានទំនងអ្វីឲ្យគេនិយាយគ្នា នៅកណ្តាលជនជាតិទាំងឡាយថា តើព្រះរបស់
គេនៅឯណាវិញ?»

generated on Wed Sep 10 16:16:32 2025

[18]ដ្បិត ព្រះអម្ចាស់ប្រចណ្ឌ ចំពោះទឹកដីរបស់ព្រះអង្គហើយមានព្រះហឫទ័យអាណិតអាសូរ ដល់ប្រជារាស្ត្ររបស់ព្រះអង្គ។[19]ព្រះអម្ចាស់ឆ្លើយតបនឹងប្រជារាស្ត្ររបស់ព្រះអង្គថា «មើល៍ យើងនឹងផ្ញើស្រូវ ស្រាទំពាំងបាយជូរថ្មី និងប្រេងមកអ្នករាល់គ្នា។ អ្នករាល់គ្នានឹងបានស្កប់ចិត្ត យើងនឹងមិនធ្វើឲ្យអ្នកទៅជាទីត្មះតិះដៀល ក្នុងចំណោមជនជាតិទាំងផ្រេងៗ។
[20]យើងនឹងដកយកកងទ័ពនៅទិសខាងជើង ចេញឆ្ងាយពីអ្នករាល់គ្នា យើងនឹងបណ្តេញគេទៅទឹកដីមួយដែលហួតហែង ហើយស្ងាត់ច្រៀប ក៏បោះទ័ពជួរមុខរបស់គេទៅក្នុងសមុទ្រខាងកើត ហើយទ័ពជួរក្រោយ ទៅក្នុងសមុទ្រខាងលិច។ ក្លិនស្អុយអសោចរបស់គេនឹងសាយឡើង»។ ដ្បិតគេបានធ្វើការយ៉ាងអស្ចារ្យ។
[21]ទឹកដីអើយ កុំភ័យខ្លាច! ចូរត្រេកអរ ហើយសប្បាយរីករាយឡើង ដ្បិតព្រះអម្ចាស់បានធ្វើការយ៉ាងអស្ចារ្យ។[22]សត្វទាំងឡាយនៅទីវាលអើយ កុំភ័យខ្លាច! ដ្បិតវាលស្មៅនៅទីរហោស្ថានកំពុងលាស់ខៀវខ្ចី ហើយដើមឈើទាំងប៉ុន្មានក៏មានផ្លែ ដើមឧទម្ពរ និងដើមទំពាំងបាយជូរ ក៏ចេញផ្លែជាបរិបូរដែរ។[23]ពួកកូនក្រុងស៊ីយ៉ូនអើយ ចូរអរសប្បាយ ចូរត្រេកអរក្នុងព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាចុះ ដ្បិតព្រះអង្គប្រទានភ្លៀងដំបូងមកតាមខ្នាតត្រឹមត្រូវ ព្រះអង្គបង្អុរឲ្យភ្លៀងធ្លាក់ចុះ សម្រាប់អ្នករាល់គ្នា គឺជាភ្លៀងដើមរដូវ និងភ្លៀងចុងរដូវដូចកាលពីមុន។
[24]ក្នុងទីលានបោកស្រូវ នឹងមានពេញដោយស្រូវសាលី ហើយធុងទាំងប៉ុន្មាននឹងពេញហូរហៀរ ដោយស្រាទំពាំងបាយជូរ និងប្រេងផងដែរ។[25]យើងនឹងសងអ្នករាល់គ្នាវិញនូវឆ្នាំទាំងប៉ុន្មាន ដែលត្រូវកណ្តូបចង្រិត ដង្កូវនិងក្រាស៊ីបង្ហិច គឺជាកងទ័ពធំរបស់យើង ដែលយើងបានចាត់មក ក្នុងចំណោមអ្នករាល់គ្នា។
[26]អ្នករាល់គ្នានឹងបរិភោគជាបរិបូរ ហើយឆ្អែតស្កប់ស្កល់ រួចសរសើរតម្កើងព្រះនាមព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា ដែលព្រះអង្គបានប្រព្រឹត្តនឹងអ្នកយ៉ាងអស្ចារ្យ។ ប្រជារាស្ត្ររបស់យើងនឹងមិនត្រូវអាម៉ាស់ទៀតឡើយ។[27]អ្នករាល់គ្នានឹងដឹងថា យើងគង់នៅកណ្តាលជនជាតិអ៊ីស្រាអែល ហើយថា យើងនេះ គឺព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា គ្មានព្រះណាទៀតឡើយ ប្រជារាស្ត្ររបស់យើងនឹងមិនត្រូវអាម៉ាស់ទៀតដែរ។
[28]ក្រោយមកទៀត យើងនឹងចាក់បង្ហូរ ព្រះវិញ្ញាណរបស់យើងទៅលើមនុស្សទាំងអស់ កូនប្រុសកូនស្រីរបស់អ្នកនឹងថ្លែងព្រះបន្ទូល ពួកចាស់ៗរបស់អ្នកនឹងយល់សប្តិឃើញ ហើយពួកកំលោះៗរបស់អ្នកនឹងឃើញនិមិត្ត។[29]សូម្បីតែពួកអ្នកបម្រើប្រុសស្រី ក៏យើងនឹងចាក់បង្ហូរព្រះវិញ្ញាណ របស់យើងទៅលើពួកគេដែរ។
[30]យើងនឹងសម្តែងការអស្ចារ្យនៅលើមេឃ និងនៅលើផែនដី គឺជាឈាម ភ្លើងនិងកម្បួលផ្សែង។[31]ព្រះអាទិត្យនឹងប្រែទៅជាងងឹត ព្រះចន្ទនឹងទៅជាឈាម គឺមុនថ្ងៃដ៏អស្ចារ្យ ហើយគួរស្ញែងខ្លាចរបស់ព្រះអម្ចាស់មកដល់។
[32]ការនោះនឹងកើតឡើង អស់អ្នកដែលអំពាវនាវរកព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ ដ្បិតនៅភ្នំស៊ីយ៉ូន និងនៅក្រុងយេរូសាឡិម នោះនឹងមានអស់អ្នកដែលរត់គេចដូចព្រះអម្ចាស់បានមានព្រះបន្ទូលហើយ ក្នុងចំណោមពួកអ្នកដែលបានរួចជីវិត គឺជាអស់អ្នកដែលព្រះអម្ចាស់ត្រាស់ហៅ។

Joel 2:1

ព័ត៌មានទូទៅ:

លោកយ៉ូអែលបន្តកំណាព្យដែលបានចាប់ផ្តើមនៅក្នុងជំពូកមុន

ផ្លុំត្រែ...សូរសញ្ញា

លោកយ៉ូអែលកំពុងតែបង្ហាញពីសារសំខាន់នៃការហៅប្រជាជនឲ្យជួបជុំគ្នាក្នុងការត្រៀមខ្លួនសម្រាប់ការវិនិច្ឆ័យដែលនឹងមក។

ថ្ងៃងងឹត ហើយមេឃស្រទុំ

ពាក្យ «ងងឹត» និង «មេឃស្រទុំ» បង្ហាញពីន័យស្រដៀងគ្នា
និងចង្អុរបង្ហាញពីភាពល្អិតល្អន់នៃភាពងងឹត។
ពាក្យទាំងពីរសំដៅលើពេលវេលាមហន្តរាយ ឬក៏ការជំរំជំរះមកពីព្រះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ថ្ងៃដែលពេញដោយភាពងងឹត» ឬក៏
«ថ្ងៃជំនុំជម្រះដ៏គួឲ្យស្ញែងខ្លាច»។

មេឃស្រទុំ

ទាំងស្រុង ឬក៏ ងងឹតមួយផ្នែក

ថ្ងៃមានពពក ហើយងងឹតយ៉ាងក្រាស់

ប្រយោគនេះមានន័យដូចគ្នា ហើយនិងបង្ហាញពីគំនិតនៃប្រយោគមុន។
ដូចជានៅក្នុងប្រយោគទាំងពីរ «ពពក» និង «ងងឹតយ៉ាងក្រាស់»
សំដៅលើសេចក្តីជំនុំជំរះមកពីព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ថ្ងៃដែលមានពេញដោយព្យុះពពកងងឹត»។

មានជនជាតិមួយយ៉ាងធំ ហើយខ្លាំងពូកែចូលមក ដូចពន្លឺថ្ងៃដែលទើបនឹងរះលាតត្រដាងលើភ្នំ

របៀបផ្សេងទៀតនៃការបកប្រែ: «មានជនជាតិមួយយ៉ាងធំ ហើយខ្លាំង
ពូកែចុះមកពីតំបន់ភ្នំមកកាន់តំបន់រាប។
ពួកគេដើរពាសពេញដីដូចជាពន្លឺនៃព្រះអាទិត្យដែលរះ»។

មានជនជាតិមួយយ៉ាងធំ ហើយខ្លាំងពូកែ

ពាក្យ «យ៉ាងធំ» និង «ខ្លាំងពូកែ» បង្ហាញពីន័យស្រដៀងគ្នានៅត្រង់នេះ
និងបង្ហាញពីភាពខ្លាំក្លានៃកងទ័ព។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហ្វូងសត្វដង្កូវដ៏ធំ»

Joel 2:3

ព័ត៌មានទូទៅ:

យ៉ូអែលពណ៌នាពីការបន្តមកនៃពួកកងទ័ព។

ផែនដីប្រៀបដូចជា សួនអេដែន

សួនអេដែនជាកន្លែងដ៏ស្រស់ស្អាត។

ផែនដីប្រៀបដូចជា សួនអេដែន តែខាងក្រោយវា ប្រៀបដូចជា ទីរហោស្ថានហួតហែង

ត្រង់នេះបង្ហាញពីភាពផ្ទុយគ្នាពីការលេចមកនៃមហន្តរាយដែលកំពុងបង្កឡើងដោយភ្លើង

Joel 2:4

ព័ត៌មានទូទៅ:

ការពណ៌នានៅតែបន្តមានជាមួយនឹងសន្ធឹកនៃកងទ័ពសេះ។

សេះ

មានមាឌធំ ហើយជាសត្វដែលលឿនមានជើងបួន។

រូបរាងរបស់វាមើលទៅដូចជាសេះ

ក្បាលនៃសត្វកណ្តូបមើលទៅមានរាងដូចក្បាលកូនសេះ ទាំងខ្លាំងក្លា
និងលឿនដូចសត្វសេះ។

ពួកកងទ័ពផ្លាស់ប្តូរយ៉ាងលឿន ដូចជាបុរសដែលជិះលើសេះ។

កង្ហែល

សេះកង្ហែល ឬលោតផ្លោះយ៉ាងលឿនដូចរត់។

ឮសន្ធឹកដូចរទេះចម្បាំង...ដូចសន្ធឹកអណ្តាតភ្លើងដែលឆេះ... ដូចជាកងទ័ពដ៏ខ្លាំងពូកែ ដែល
រួចរាល់ក្នុងការចូលទៅច្បាំង

ត្រង់នេះប្រៀបប្រដូចទៅនឹងសន្ធឹកនៃទ័ពកណ្តូប

Joel 2:6

ព័ត៌មានទូទៅ:

លោកយ៉ូអែលបន្តពណ៌នាពីកងទ័ពកណ្តូបរបស់ព្រះអម្ចាស់។

ពួកគេសម្រុកទៅមុខដូចមនុស្សខ្លាំងពូកែ ក៏ឡើងកំផែងដូចមនុស្សថ្នឹកច្បាំង

កងទ័ពនៃសត្វកណ្តូបដែលបានពណ៌នាដូចទៅនឹងសកម្មភាពនៃកងទ័ពពិតប្រាកដ។

កំផែង

កំផែងដែលនៅជុំវិញទីក្រុង។

Joel 2:8

ព័ត៌មានទូទៅ:

ការពណ៌នានៃទ័ពកណ្តូបរបស់ព្រះអម្ចាស់នៅតែបន្ត។

ពួកគេរាយលុកទៅមុខបំបែកអ្នកការពារ

របៀបផ្សេងទៀតនៃការបកប្រែ: ពួកគេយកឈ្នះលើកងទ័ពដែលការពារទីក្រុង។

Joel 2:10

ផែនដីកក្រើកនៅមុខគេ ផ្ទៃមេឃក៏ញ័ររន្ធត់ ព្រះអាទិត្យ និងព្រះចន្ទប្រែជាងងឹត ហើយផ្កាយទាំង
ប៉ុន្មានក៏លែងបញ្ចេញពន្លឺ

មានសត្វកណ្តូបជាច្រើន ផែនដីកក្រើក ផ្ទៃមេឃក៏ញ័ររន្ធត់
ហើយវាជារបស់ដែលបិតបាំងផ្ទៃមេឃមិនអាចឲ្យមើលឃើញ។

ព្រះអម្ចាស់បញ្ចេញព្រះសូរសៀង

ព្រះអម្ចាស់សម្តែងពីអំណាចរបស់ទ្រង់ និងបញ្ជាលើកងទ័ព។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់មានអំណាច»។

ថ្ងៃដ៏អស្ចារ្យ ហើយគួរស្ញែងខ្លាចណាស់

ក្នុងប្រយោគទាំងពីរនេះពណ៌នាពីអត្ថន័យតែមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យ៉ាងគួរឲ្យស្ញែងខ្លាច»។

តើអ្នកណាអាចរួចជីវិតពីវាបាន?

របៀបផ្សេងទៀតនៃការបកប្រែ:
«មិនមានអ្នកណាខ្លាំងក្លាគ្រប់គ្រាន់អាចគេចរួចផុតពីការជំនុំជម្រះរបស់ព្រះអម្ចាស់ទេ»។

generated on Wed Sep 10 16:16:32 2025

Joel 2:12
ចូរនាំគ្នាបែរមករកយើងឲ្យអស់ពីចិត្ត
របៀបផ្សេងទៀតនៃការបកប្រែ: «បែរចេញពីអំពើបាបរបស់អ្នក ហើយថ្វាយខ្លួនទាំងស្រុងមកយើង»។
មិនគ្រាន់តែហែកអាវខ្លួនទេ គឺត្រូវយំក្នុងចិត្ត
ហែកអាវមួយគឺជាសម្មភាពខាងក្រៅបង្ហាញពីសេចក្ដីខ្មាស់ និងការកែប្រែចិត្ត។ «ត្រូវយំក្នុងចិត្ត» សំដៅលើកិរិយាខាងក្នុងដូចជាការកែប្រែចិត្តដែរ។
បែរចេញ
បញ្ឈប់
Joel 2:14
ប្រហែលជាព្រះអង្គនឹងលើកលែងទោស... ជាព្រះ?
«ប្រហែលជាព្រះអម្ចាស់នឹងបែរពីព្រះពិរោធរបស់ទ្រង់...ព្រះ»។
Joel 2:15
វាំងនន
បន្ទប់
ជាធម្មតានៅផ្ទះខាងមាតាបិតាជាកន្លែងដែលកូនក្រមុំនឹងរង់ចាំពិធីអាពាហ៍ពិពាហ៍របស់ពួកគេ
Joel 2:17
មរតករបស់ព្រះអង្គ
ប្រជាជនអ៊ីស្រាអែល ជាប្រជាជនពិសេសរបស់ព្រះ។
តើមានទំនងអ្វីឲ្យគេនិយាយគ្នា នៅកណ្ដាលជនជាតិទាំងឡាយថា តើព្រះរបស់គេនៅឯណាវិញ?
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនផ្សេងមិនគួរនិយាយថាព្រះនៃប្រជាជនអ៊ីស្រាអែលបានបោះបង់ចោលប្រជាជនរបស់ទ្រង់ទេ»
Joel 2:18
ទឹកដីរបស់ព្រះអង្គ
ប្រជាជនអ៊ីស្រាអែល
ប្រជារាស្ត្ររបស់ព្រះអង្គ
ប្រជាជនអ៊ីស្រាអែល
មើល៍
ចូរប្រុងស្ដាប់នូវអ្វីដែលយើងនឹងមានបន្ទូល
ត្មះតិះដៀល
មិនមានតម្លៃគួរឲ្យគោរព
Joel 2:20
ព័ត៌មានទូទៅ:
ព្រះបន្តសេចក្ដីសន្យារបស់ទ្រង់ទៅជនជាតិអ៊ីស្រាអែល។
ខាងជើង...ខាងកើត...ខាងលិច
ទិសដៅទាំងនេះជាទស្សនៃការរស់នៅរបស់ប្រជាជននៅក្នុងទឹកដីអ៊ីស្រាអែល។
Joel 2:21
ទឹកដីអើយ កុំភ័យខ្លាច
«ប្រជាជនរាល់គ្នានៅទឹកដីអើយ ចូរកុំភ័យខ្លាច»។
ទីរហោស្ថានកំពុងលាស់ខៀវខ្ចី
រុក្ខជាតិល្អៗសម្រាប់ជាអាហារនឹងលូតលាស់លើទឹកដី។
ភ្លៀងដើមរដូវ និងភ្លៀងចុងរដូវ
ភ្លៀងដើមដំបូងនៃរដូវភ្លៀងមាននៅដើមខែធ្នូ ហើយភ្លៀងចុងក្រោយក្នុងខែមេសា និងខែឧសភា។
Joel 2:24
ធុង
ធុងស្ដុកយ៉ាងធំសម្រាប់វត្ថុរាវ
ឆ្នាំទាំងប៉ុន្មាន ដែលត្រូវកណ្ដូបចង្រិតស៊ីបង្ហូច
គ្រាប់ពូជដែលអ្នកថែរក្សាអស់ពេញមួយឆ្នាំ តែត្រូវកណ្ដូបចង្រិតបានស៊ីអស់។
កណ្ដូបចង្រិត ដង្កូវនិងក្រា
សូមមើលពីរបៀបដែលបានបកប្រែពាក្យនេះនៅក្នុងជំពូក ១:៤។
Joel 2:26
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តសេចក្ដីសន្យាពីការល្អសម្រាប់ប្រជាជនអ៊ីស្រាអែល។
Joel 2:28
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តសេចក្ដីសន្យាពីការល្អសម្រាប់ប្រជាជនអ៊ីស្រាអែល។
ចាក់បង្ហូរ ព្រះវិញ្ញាណរបស់យើង
«យើងនឹងប្រទានមកយ៉ាងសប្បុរសដូចដែលមនុស្សបង្ហូរទឹកចេញដែរ»។
លើមនុស្សទាំងអស់
ប្រជាជនទាំងអស់
Joel 2:30
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលពីការដែលទ្រង់នឹងធ្វើនាពេលខាងមុខ។
ឈាម ភ្លើងនិងកម្បួលផ្សែង
«ឈាម» ជាសញ្ញាបង្ហាញពីការស្លាប់របស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «ការស្លាប់ ភ្លើងនិងកម្បួលផ្សែង»។
ព្រះចន្ទនឹងទៅជាឈាម
ពាក្យ «ឈាម» សំដៅលើពណ៌ក្រហម។
អ្នកអាចប្រើពាក្យជាកិរិយាស័ព្ទសំរាប់ប្រយោគនេះ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយព្រះចន្ទនឹងប្រែពណ៌ក្រហមដូចឈាម»។
ថ្ងៃដ៏អស្ចារ្យ ហើយគួរស្ញែងខ្លាច
ពាក្យ«ដ៏អស្ចារ្យ» ចង្អុរបង្ហាញឲ្យពាក្យ «ស្ញែងខ្លាច»
របៀបផ្សេងទៀតនៃការបកប្រែ: «ថ្ងៃយ៉ាងអស្ចារ្យគួរស្ញែងខ្លាច»។
Joel 2:32
នៅភ្នំស៊ីយ៉ូន និងនៅក្រុងយេរូសាឡិម
ត្រង់នេះសំដៅទៅលើទឹកន្លែងតែមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅភ្នំស៊ីយ៉ូន ក្នុងក្រុងយេរូសាឡិម»។
ក្នុងចំណោមពួកអ្នកដែលបានរួចជីវិត គឺជាអស់អ្នកដែលព្រះអម្ចាស់ត្រាស់ហៅ
របៀបផ្សេងទៀតនៃការបកប្រែ: «អស់អ្នកដែលព្រះអម្ចាស់ត្រាស់ហៅនឹងបានសង្គ្រោះ»។
អ្នកសង្គ្រោះ
ប្រជាជនដែលនៅរស់ដែលឆ្លងកាត់ព្រឹត្តិការណ៍អាក្រក់ៗគួរឲ្យស្ញែងខ្លាចដូចជាសង្គ្រាម ឬគ្រោះមហន្តរាយ។

---

3 [1]មើល៍! នៅថ្ងៃនោះ និងនៅវេលានោះ កាលយើងបានស្តារស្រុកយូដា និងក្រុងយេរូសាឡិម ដូចដើមឡើងវិញ[2]នោះយើងនឹងប្រមូលជនជាតិទាំងអស់ ហើយនាំគេចុះទៅក្នុងជ្រលងភ្នំយេហូសាផាត នៅទីនោះយើងនឹងជំនុំជម្រះទោសពួកគេ ដោយព្រោះប្រជារាស្ត្ររបស់យើង គឺអ៊ីស្រាអែលជាមរតករបស់យើង ដែលគេកម្ចាត់កម្ចាយទៅគ្រប់ទឹកន្លែង ហើយគេបានបែងចែកទឹកដីរបស់យើង។[3]គេយកប្រជារាស្ត្ររបស់យើងទៅចាប់ឆ្នោតចែកគ្នា គេដោះដូរក្មេងប្រុសយកស្រីពេស្យា ហើយគេលក់ក្មេងស្រី ដើម្បីទិញស្រាផឹក ហើយក៏ស្រវឹងដោយស្រានោះ។
[4]តើហេតុអ្វីបានជាអ្នកខឹងនឹងយើង ក្រុងទីរ៉ុស ក្រុងស៊ីដូន និងតំបន់នានាទាំងប៉ុន្មាននៅស្រុកភីលីស្ទីនអើយ? តើអ្នករាល់គ្នាគិតសងសឹកនឹងយើងឬ? ប្រសិនបើអ្នករាល់គ្នាសងយើង នោះយើងនឹងទម្លាក់ទៅលើក្បាលអ្នកវិញភ្លាមមួយរំពេច។[5]ដ្បិតអ្នករាល់គ្នាបានយកប្រាក់ និងមាសរបស់យើង ហើយបានដឹកយកសម្បត្តិដ៏មានតម្លៃរបស់យើងទៅទុកនៅក្នុងវិហាររបស់អ្នក។[6]អ្នកបានលក់ប្រជាជនយូដា និងអ្នកក្រុងយេរូសាឡិមឲ្យពួកជនជាតិក្រិក ដើម្បីយកគេចេញទៅឆ្ងាយពីព្រំដែនរបស់ខ្លួន។
[7]មើល៍! យើងនឹងដាស់គេឡើង ឲ្យចេញពីទីកន្លែងដែលអ្នកបានលក់គេទៅ ហើយនឹងសងអំពើនោះ ទៅលើក្បាលរបស់អ្នករាល់គ្នាវិញ។[8]យើងនឹងលក់កូនប្រុសកូនស្រីរបស់អ្នករាល់គ្នា ទៅក្នុងកណ្តាប់ដៃរបស់ប្រជាជនយូដាវិញ ហើយគេនឹងលក់វាទៅឲ្យពួកសេបា គឺដល់ជនជាតិមួយដែលនៅឆ្ងាយ ដ្បិតព្រះអម្ចាស់បានមានព្រះបន្ទូលហើយ។
[9]ចូរប្រកាសការនេះក្នុងចំណោមជនជាតិទាំងឡាយថា៖ សូមត្រៀមខ្លួនចូលច្បាំង ចូរដាស់មនុស្សខ្លាំងពូកែឡើង ត្រូវឲ្យពួកទាហានទាំងប៉ុន្មានចូលមកជិត ត្រូវឲ្យគេនាំគ្នាឡើងមក។[10]ចូរដំដែកផាលនង្គ័លរបស់អ្នករាល់គ្នាធ្វើជាដាវ ហើយដង្ការរបស់អ្នករាល់គ្នាធ្វើជាលំពែងទៅ ត្រូវឲ្យអ្នកខ្សោយពោលថា «ខ្ញុំខ្លាំងពូកែ»។
[11]ពួកជនជាតិទាំងឡាយដែលនៅព័ទ្ធជុំវិញអើយ ចូរប្រញាប់មកប្រជុំគ្នា។ ព្រះអម្ចាស់ សូមឲ្យពួកខ្លាំងពូកែរបស់ព្រះអង្គចុះមក។
[12]ត្រូវឲ្យជនជាតិទាំងប៉ុន្មានភ្ញាក់ឡើង ហើយមកឯជ្រលងភ្នំយេហូសាផាត ដ្បិតនៅទីនោះ យើងនឹងអង្គុយជំនុំជម្រះ ជនជាតិទាំងប៉ុន្មានដែលនៅព័ទ្ធជុំវិញ។[13]ចូរដាក់កណ្តៀវទៅ ដ្បិតចម្រូតទុំហើយ ចូរមកជាន់ផ្លែចុះ ដ្បិតធុងបញ្ចាន់ផ្លែពេញហើយ ធុងត្រងទឹកទំពាំងបាយជូរក៏ពេញហៀរដែរ ដ្បិតអំពើអាក្រក់របស់គេសម្បើមណាស់។

generated on Wed Sep 10 16:16:32 2025

[14]នៅទីនោះមានមនុស្សមួយហ្វូង ហើយមនុស្សទាំងនោះនៅជ្រលងភ្នំនៃការជំនុំជម្រះទោស ដ្បិតថ្ងៃរបស់ព្រះអម្ចាស់ជិតដល់ហើយ នៅក្នុងច្រកភ្នំនៃកាត់ទោស។
[15]ព្រះអាទិត្យ និងព្រះចន្ទងងឹតសូន្យ ហើយផ្កាយទាំងប៉ុន្មានក៏លែងភ្លឺដែរ។
[16]ព្រះអម្ចាស់នឹងស្រែកគ្រហឹមពីភ្នំស៊ីយ៉ូន ហើយបញ្ចេញព្រះសៀងពីក្រុងយេរូសាឡិម ផ្ទៃមេឃ និងផែនដីកក្រើករំពើក តែព្រះអម្ចាស់ជាជម្រកដល់ប្រជារាស្ត្ររបស់ព្រះអង្គ ជាទីមាំមួនដល់ប្រជាជនអ៊ីស្រាអែល។[17]«យ៉ាងនោះ អ្នករាល់គ្នានឹងដឹងថា យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នា យើងគង់នៅភ្នំស៊ីយ៉ូន ជាភ្នំបរិសុទ្ធរបស់យើង ក្រុងយេរូសាឡិមនឹងបានបរិសុទ្ធ ហើយគ្មានអ្នកដទៃណាដើរកាត់ទៀតឡើយ។
[18]នៅគ្រានោះ ភ្នំធំៗនឹងស្រក់ស្រាទំពាំងបាយជូរផ្អែម ហើយភ្នំតូចៗនឹងហូរដោយទឹកដោះ អស់ទាំងជ្រោះនៅទឹកដីយូដានឹងមានទឹកហូរ ហើយនឹងមានក្បាលទឹកមួយ ហូរចេញពីព្រះដំណាក់របស់ព្រះអម្ចាស់ មកស្រោចស្រពជ្រលងភ្នំស៊ីទីម។[19]ទឹកដីអេស៊ីប នឹងទៅជាស្ងាត់ជ្រៀប ហើយស្រុកអេដុមនឹងទៅជាទីរហោស្ថាន ព្រោះតែអំពើឃោរឃៅដែលគេ បានប្រព្រឹត្តចំពោះប្រជាជនយូដា ដ្បិតគេបានកម្ចាយឈាមមនុស្សស្លូតត្រង់ នៅលើទឹកដីរបស់គេ។
[20]ប៉ុន្តែ យូដានឹងរស់នៅរហូតតទៅ ហើយក្រុងយេរូសាឡិមដែរ គឺគ្រប់ជំនាន់តរៀងទៅ។[21]យើងនឹងសងសឹកឲ្យឈាមរបស់គេ គឺឈាមដែលយើងមិនទាន់បានសងសឹកឲ្យ នៅឡើយ» ដ្បិតព្រះអម្ចាស់គង់នៅក្រុងស៊ីយ៉ូន។

Joel 3:1
ព័ត៌មានទូទៅ:
ព្រះបន្តមានព្រះបន្ទូលពីព្រឹត្តិការណ៍នាពេលអនាគត។
មើល៍
ពាក្យ «មើល៍» នៅត្រង់នេះបញ្ជាក់ន័ត្ថមឲ្យពាក្យដែលនៅបន្ទាប់។
នៅថ្ងៃនោះ និងនៅវេលានោះ
ប្រយោគ «នៅថ្ងៃនោះ» មានន័យដូចគ្នា និងបង្គ្រប់ន័យឲ្យប្រយោគ «នៅវេលានោះ» របៀបផ្សេងទៀតនៃការបកប្រែ: «នៅថ្ងៃនោះ» ឬ «នៅខណៈវេលានោះ»។
កាលយើងបានស្តារស្រុកយូដា និងក្រុងយេរូសាឡិម ដូចដើមឡើងវិញ
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលយើងបញ្ជូនការនិរទេសត្រលប់មកដល់ស្រុកយូដា និងក្រុងយេរូសាឡិម»។
ប្រជារាស្ត្ររបស់យើង គឺអ៊ីស្រាអែលជាមរតករបស់យើង
ប្រយោគទាំងពីរនេះចង្អុរបង្ហាញពីរបៀបដែលព្រះអម្ចាស់សម្តែងមកថាប្រជាជនអ៊ីស្រាអែលជាមរតករបស់ទ្រង់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជនអ៊ីស្រាអែល ជាមរតករបស់យើង»។
គេដោះដូរក្មេងប្រុសយកស្រីពេស្យា ហើយគេលក់ក្មេងស្រី ដើម្បីទិញស្រាផឹក ហើយក៏ស្រវឹងដោយស្រានោះ
គំរូនៃកិច្ចការទាំងនេះដែលពួកគេបានធ្វើ
មិនបង្ហាញពីអ្វីដែលពួកគេប្រព្រឹត្តចំពោះក្មេងទាំងពីរនាក់នោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយប្រព្រឹត្តការទាំងនេះ ដោយដោះដូរក្មេងប្រុសយកស្រីពេស្យា ហើយគេលក់ក្មេងស្រី ដើម្បីទិញស្រាផឹក ហើយក៏ស្រវឹងដោយស្រានោះ»។
Joel 3:4
ព័ត៌មានទូទៅ:
ព្រះមានបន្ទូលទៅប្រជាជនដែលជាប្រជាជាតិនៅព័ទ្ធជុំវិញអ៊ីស្រាអែល។
តើហេតុអ្វីបានជាអ្នកខឹងនឹងយើង
ព្រះទ្រង់ប្រើប្រាស់សំណួរនេះ ដើម្បីស្តីបន្ទោសដល់ប្រជាជននៅក្រុងទីរ៉ុស ក្រុងស៊ីដូន និងស្រុកភីលីស្ទីន។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាមិនមានសិទ្ធិខឹងដល់យើងនោះទេ»។
តើអ្នករាល់គ្នាគិតសងសឹកនឹងយើងឬ?
«តើអ្នករាល់នឹងសងសឹកនឹងយើងឬ?»
ព្រះទ្រង់ប្រើប្រាស់សំណួរនេះដើម្បីធ្វើឲ្យប្រជាជនគិតអំពីអ្វីដែលពួកគេកំពុងប្រព្រឹត្ត។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាគិតថា
អ្នករាល់គ្នាអាចសងសឹកនឹងយើងបានឬ?»
យើងនឹងទម្លាក់ទៅលើក្បាលអ្នកវិញភ្លាមមួយរំពេច
ពាក្យ«ក្បាល» សំដៅទៅមនុស្ស។
ការសងសឹកដែលពួកគេចង់សំដៅឆ្ពោះទៅព្រះអម្ចាស់
ដែលទ្រង់នឹងធ្វើឲ្យកើតឡើងដល់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងបណ្តាលឲ្យអ្នករាល់គ្នារងទុក្ខដោយព្រោះអ្នករាល់គ្នាព្យាយាមសងសឹកនឹងយើង»
ទម្លាក់
«សងសឹក» ឬ «បង់ថ្លៃ»។
Joel 3:7
ចេញពីទីកន្លែងដែលអ្នកបានលក់គេទៅ
ប្រជាជនអ៊ីស្រាអែលនឹងចាកចេញពីទីកន្លែងដែលពួកគេធ្លាប់ជាទាសករ
ហើយត្រលប់មកទឹកដីនៃអ៊ីស្រាអែលវិញ
សងអំពើនោះ
របៀបផ្សេងទៀតនៃការបកប្រែ: «យកមកវិញនូវអ្វីដែលអ្នកគួរនឹងទទួលបាន»។
ទៅក្នុងកណ្តាប់ដៃរបស់ប្រជាជនយូដាវិញ
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយអំណាចនៃប្រជាជនស្រុកយូដា» ឬ «ដោយប្រជាជននៃស្រុកយូដា»។
ពួកសេបា
ប្រជាជនសេបា ហើយក៏ត្រូវបានហៅថាសេបា។
ប្រជាជននេះរស់នៅភាគខាងត្បូងនៃប្រទេសអ៊ីស្រាអែល។
Joel 3:9
សូមត្រៀមខ្លួនចូលច្បាំង...ចូរដាស់មនុស្សខ្លាំងពូកែឡើង
ប្រយោគទាំងពីរនិយាយពីការរៀបចំកងទ័ពសម្រាប់ចូលច្បាំង។
ចូរដាស់មនុស្សខ្លាំងពូកែឡើង
ដាស់មនុស្សខ្លាំងពូកែឲ្យត្រៀមសំរាប់ការច្បាំង។
ចូរដំដែកផាលនង្គ័លរបស់អ្នករាល់គ្នាធ្វើជាដាវ ហើយដង្ការរបស់អ្នករាល់គ្នាធ្វើជាលំពែងទៅ
ប្រយោគទាំងពីរនេះបង្ហាញន័យស្រដៀងគ្នា។
ប្រយោគទាំងពីរបង្រៀនប្រជាជនឲ្យប្រើប្រាស់ឧបករណ៍កសិកម្មទៅជាអាវុធច្បាំង
ប្រយោគទាំងពីរបង្រៀនប្រជាជនឲ្យប្រើប្រាស់ឧបករណ៍កសិកម្មទៅជាអាវុធច្បាំង
ឧបករណ៍ដែលប្រើប្រាស់សម្រាប់បំបែកដីដើម្បីដាំដំណាំ។
ដង្កាវ
កាំបិតដែលប្រើប្រាស់សំរាប់កាត់មែកឈើតូចៗ។
Joel 3:11
មកប្រជុំគ្នា
មកប្រជុំគ្នាដើម្បីច្បាំង
ព្រះអម្ចាស់ សូមឲ្យពួកខ្លាំងពូកែរបស់ព្រះអង្គចុះមក
ជាចំណុចកណ្តាលនៃរាជ្យសារទៅកាន់ពួកខ្មាំងសត្រូវនៃប្រជាជនអ៊ីស្រាអែល
ប្រយោគនេះបានបង្ហាញមកពីវត្តមានព្រះអម្ចាស់។
ប្រហែលជាត្រង់នេះនឹងធ្វើឲ្យពួកខ្មាំងសត្រូវស្ទែងខ្លាចដល់កងទ័ពព្រះអម្ចាស់។
Joel 3:12
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បន្តមានបន្ទូលទៅប្រជាជារបស់ទ្រង់។
ត្រូវឲ្យជនជាតិទាំងប៉ុន្មានភ្ញាក់ឡើង... ជនជាតិទាំងប៉ុន្មានដែលនៅព័ទ្ធជុំវិញ
ពាក្យ «ជនជាតិ» និង «ជនជាតិទាំងប៉ុន្មានដែលនៅព័ទ្ធជុំវិញ»
សំដៅលើជនជាតិតែមួយដែលនៅព័ទ្ធជុំវិញស្រុកយូដា។
ព្រះអម្ចាស់នឹងជំនុំជម្រះពួកគេនៅជ្រលងនៃយេហូសាផាតសម្រាប់អ្វីដែលពួកគេបានប្រព្រឹត្តនៅក្រុងយេរូ
ចូរដាក់កណ្តៀវទៅ...ធុងបញ្ចាន់ផ្លែពេញហើយ
អាចមានន័យ ១)
ការវាយដណ្តើមលើជនជាតិដែលពេញដោយបាបប្រៀបដូចជាការចម្រូតផលដំណាំ
និងគាបផ្លែទំពាំងបាយជូរ ឬ ២)
ជាការជំនុំជម្រះជនជាតិដែលមានបាបដូចជាអ្នកដែលប្រមូលផលចម្រូត
និងគាបផ្លែទំពាំងបាយជូរ។
ចូរដាក់កណ្តៀវទៅ ដ្បិតចម្រូតទុំហើយ
ព្រះអម្ចាស់មានបន្ទូលទៅជនជាតិថាពួកគេដូចជាទីវាលចម្ការនៃដំណាំដែលទុំត្រូវប្រមូលផល។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរដាក់កណ្តៀវទៅ ដ្បិត
ជនជាតិប្រៀបទៅនឹងការចម្រូតនៃផលដំណាំ»។
ចូរដាក់កណ្តៀវទៅ
បង្វិលកណ្តៀវច្រូតកាត់ដំណាំ
កណ្តៀវ
កាំបិតកោងរាងវែងដែលមនុស្សប្រើប្រាស់សម្រាប់ច្រូតកាត់ដំណាំ។
ដំណាំទុំ
ដំណាំដែលដល់ពេលត្រូវប្រមូល
ចូរមកជាន់ផ្លែចុះ ដ្បិត ធុងបញ្ចាន់ផ្លែពេញហើយ

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់មានបន្ទូលពីជនជាតិមួយដែលពួកគេដូចជាចង្កោមនៃទំពាំងបាយជូរដែលនៅក្នុងធុងបញ្ចាន់ផ្លែដែលរៀបរយសំរាប់ការច្របាច់វា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរមក កម្ទេចជនជាតិនេះ ដ្បិតពួកគេជាទំពាំងបាយជូរដែលនៅក្នុងធុងបញ្ចាន់ផ្លែ»។
ធុងត្រងទឹកទំពាំងបាយជូរក៏ពេញហៀរដែរ ដ្បិតអំពើអាក្រក់របស់គេសម្បើមណាស់
ព្រះអម្ចាស់មានបន្ទូលពីអំពើអាក្រក់
របស់ប្រជាជាតិមួយដែលប្រៀបទៅនឹងទឹកផ្លែឈើដែលពេញហៀរនៅក្នុងធុងដែលបានរៀបចំរួចរាល់
ធុងដែលផ្ទុកភោគផលមិនធំគ្រប់គ្រាន់ក្នុងការផ្ទុកចំនួននៃអំពើ
អាក្រក់ដែលបង្ហូរចូលក្នុងវានោះទេ។
Joel 3:14
មនុស្សមួយហ្វូង ហើយមនុស្សទាំងនោះ
មនុស្សមួយហ្វូងឮសន្ធឹកដោយសារតែមានហ្វូងមនុស្សច្រើន។
ការដែលនិយាយបន្ទរដោយសារតែចង់បញ្ជាក់ថាវាឮសន្ធឹកយ៉ាងខ្លាំងពីមនុស្សទាំងអស់នោះ
ជ្រលងភ្នំនៃការជំនុំជម្រះទោស...ជ្រលងភ្នំនៃការជំនុំជម្រះទោស
ប្រយោគនេះនិយាយបន្ទរដោយព្រោះថាការ
ជំនុំជម្រះទោសនឹងកើតមកជាពិតប្រាកដ។
Joel 3:16
ព្រះអម្ចាស់នឹងស្រែកគ្រហឹមពីភ្នំស៊ីយ៉ូន ហើយបញ្ចេញព្រះសៀងពីក្រុងយេរូសាឡិម
ប្រយោគទាំងពីរមានន័យថា ព្រះអម្ចាស់នឹងស្រែកជាសំលេងយ៉ាងខ្លរខ្ទារ ច្បាស់
ហើយនិងមានព្រះចេស្តាពីក្រុងយេរូសាឡិមមក។
បើសិនជាក្នុងភាសារបស់អ្នកមានតែមួយពាក្យនោះ
ពាក្យស្រែកនឹងត្រូវបានប្រើក្នុងប្រយោគនេះ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងស្រែកពីក្រុងយេរូសាឡិមមក»។
ព្រះអម្ចាស់នឹងស្រែកគ្រហឹម
អាចមានន័យ ១) «ព្រះអម្ចាស់នឹងស្រែកគ្រហឹមដូចសត្វសឹង្ហ» ២) «ព្រះអម្ចាស់នឹងស្រែកគ្រហឹមដូចសន្ធឹកផ្គរលាន់»។
ផ្ទៃមេឃ និងផែនដីកក្រើករំពើក
ព្រះអម្ចាស់ស្រែកគ្រហឹមមានអស់ទាំងព្រះចេស្តាដែលនឹងបណ្តាលឲ្យផ្ទៃមេឃ និងផែនដីកក្រើកញាប់ញ័រ។
ព្រះអម្ចាស់ជាជម្រកដល់ប្រជារាស្ត្ររបស់ព្រះអង្គ ជាទីមាំមួនដល់ប្រជាជនអ៊ីស្រាអែល
ប្រយោគទាំងពីរមានន័យថាព្រះអម្ចាស់នឹងថែរក្សាប្រជារាស្ត្ររបស់ទ្រង់។
ទីមាំមួនជាខែលយ៉ាងរឹងមាំដែលប្រើសម្រាប់ការពារមនុស្សកំឡុងពេលច្បាំង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងជាទីដ៏មាំមួនសម្រាប់ប្រជារាស្ត្ររបស់ទ្រង់»។
Joel 3:18
ព័ត៌មានទូទៅ:
ព្រះបន្តមានបន្ទូលពីថ្ងៃនៃព្រះអម្ចាស់
ភ្នំធំៗនឹងស្រក់ស្រាទំពាំងបាយជូរផ្អែម
«ស្រាទំពាំងបាយជូរផ្អែមនឹងស្រក់មកពីភ្នំ»
ភ្នំធំៗ ជាការប្រៀបធៀបជាមួយនឹងភ្នំតូចៗ ដើម្បីបង្ហាញថាទឹកដីដែលសម្បូរជីជាតិ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លើកំពូលភ្នំនឹងមានចម្ការទំពាំងបាយជូរដែលអាចផលិតស្រាទំពាំងបាយជូរផ្អែមបានយ៉ាងច្រើន។
ហើយភ្នំតូចៗនឹងហូរដោយទឹកដោះ
«ទឹកដោះនឹងហូរមកពីភ្នំតូចៗ» របៀបផ្សេងទៀតនៃការបកប្រែ:
«លើភ្នំតូចៗគោក្របី ហើយពពែនឹងផលិតទឹកដោះបានយ៉ាងច្រើន។
ស្រុកយូដានឹងមានទឹកហូរ
ទឹកនឹងហូរមកកាត់តាមជ្រោះទាំងឡាយនៅស្រុកយូដា។
មកស្រោចស្រពជ្រលងភ្នំស៊ីទីម
«នឹងបញ្ជូនទឹកមកស្រោចស្រពជ្រលងភ្នំនាងនួន» «ស៊ីទីម»
គឺជាឈ្មោះនៃទីកន្លែងនៅភាគខាងកើតនៃទន្លេយ័រដាន់
«មានន័យថាដើមនាងនួន»។
ស្រុកអេស៊ីប នឹងទៅជាបោះបង់ចោលត្រូវបំផ្លាញ
របៀបផ្សេងទៀតនៃការបកប្រែ: «ទឹកដីអេស៊ីបនឹងត្រូវបំផ្លាញ
ហើយប្រជាជននឹងចាកចេញ» ឬ «ប្រជាជនជាខ្មាំងសត្រូវនឹងបំផ្លាញទឹកដីអេស៊ីប
ហើយប្រជាជនអេស៊ីបនឹងចាកចេញពីទឹកដីរបស់ពួកគេ»។
ស្រុកអេដុមនឹងទៅជាទីរហោស្ថាន
«ស្រុកអេដុមនឹងទៅជាទីរហោស្ថាន ហើយប្រជាជននឹងចាកចេញ»។
ព្រោះតែអំពើឃោរឃៅដែលគេ បានប្រព្រឹត្តចំពោះប្រជាជនយូដា
ព្រោះតែអំពើឃោរឃៅជាការដែលប្រជាជនអេស៊ីប និងប្រជាជនស្រុកអេដុមបាន
ប្រព្រឹត្តចំពោះប្រជាជនយូដា។
ដ្បិត គេបានកម្ចាយឈាមមនុស្សស្លូតត្រង់ នៅលើទឹកដីរបស់គេ
«ឈាមមនុស្សស្លូតត្រង់» សំដៅលើមនុស្សស្លូតត្រង់ដែលត្រូវបានសម្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រោះតែប្រជាជនអេស៊ីប
និងប្រជាជនស្រុកអេដុមបានសម្លាប់មនុស្សស្លូតត្រង់នៅស្រុកយូដា»។
Joel 3:20
ព័ត៌មានទូទៅ:
ព្រះបន្តមានបន្ទូលពីថ្ងៃនៃព្រះអម្ចាស់។
យូដានឹងរស់នៅរហូតតទៅ
វាអាចជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជននឹងរស់នៅស្រុកយូដារហូតតទៅ»។
ក្រុងយេរូសាឡិមដែរ គឺគ្រប់ជំនាន់តរៀងទៅ
របៀបផ្សេងទៀតនៃការបកប្រែ: «គ្រប់ជំនាន់តរៀងទៅ
ប្រជាជននឹងរស់នៅក្រុងយេរូសាឡិម»។
យើងនឹងសងសឹកឲ្យឈាមរបស់គេ គឺឈាមដែលយើងមិនទាន់បានសងសឹកឲ្យនៅឡើយ
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងជំនុំជម្រះពួកខ្មាំងសត្រូវដែលបានសម្លាប់ប្រជាជនអ៊ីស្រាអែល
ហើយនៅតែមិនទាន់បានជំនុំជម្រះនៅឡើយ»។

អេម៉ុស

1 [1]នេះជាពាក្យរបស់លោកអេម៉ុស ជាអ្នកគង្វាលចៀមនៅភូមិតូអា ជាការបើកសម្តែងពីនិមិត្តហេតុអស្ចារ្យ។ លោកបានទទួលការទាំងនោះ
នៅក្នុងរជ្ជកាលព្រះបាទអូសៀលនៃស្តេចស្រុកយូដា និងនៅក្នុងរជ្ជកាលព្រះបាទយេរ៉ូបោម ជាបុត្រព្រះបាទយ៉ូសអាស ស្តេចអ៊ីស្រាអែល គឺពីរឆ្នាំ
មុនពេលរញ្ជួយផែនដី។[2]លោកបានមានប្រសាសន៍ថា «ព្រះអម្ចាស់ស្រែកគ្រហឹមពីភ្នំស៊ីយ៉ូនហើយព្រះអង្គនឹងបន្លឺព្រះសូរសៀងពីក្រុងយេរូសាឡឹម។
កន្លែងវាលស្មៅរបស់ពួកអ្នកគង្វាលក៏ក្រៀមស្វួត ហើយកំពូលភ្នំកើមែលក៏ហួតហែងអស់ដែរ»។
[3]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នោះថា «ដោយព្រោះអំពើបាបទាំងបីរបស់ក្រុងដាម៉ាស ដែលប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនព្រមលើកលែងទោសឲ្យពួកគេឡើយ
ព្រោះពួកគេបានប្រហារអ្នកស្រុកកាឡាដដោយឧបករណ៍ធ្វើពីដែក។[4]យើងនឹងបញ្ជូនភ្លើងឲ្យឆាបឆេះដំណាក់របស់ស្តេចហាសែល
ហើយភ្លើងនឹងឆេះបំផ្លាញបន្ទាយរបស់ស្តេច បេន ហាដេឌ ផងដែរ។
[5]យើងនឹងបំបាក់រនុកទ្វាររបស់ក្រុងដាម៉ាសហើយលប់បំបាត់ប្រជាជនដែលរស់នៅតាមជ្រលងភ្នំអាវេន និងព្រមទាំងអ្នកដែលកាន់អំណាចនៅបេតអេដែនផង។
ហើយអ្នកស្រុកអើរ៉ាមនឹងត្រូវគេកៀរយកទៅធ្វើជាឈ្លើយនៅស្រុក គៀរ» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[6]ព្រះអម្ចាស់មានព្រះបន្ទូលដូច្នោះថា៖ «ដោយអ្នកក្រុងកាសាបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
ដោយព្រោះពួកគេបានចាប់ប្រជាជនធ្វើជាឈ្លើយ ហើយយកទៅលក់ឲ្យជនជាតិអេដុម។[7]យើងនឹងបញ្ជូនភ្លើងឲ្យឆាបឆេះកំផែងក្រុងសាកា
ហើយភ្លើងនឹងឆេះក្រុងនោះអស់ទៅ។
[8]យើងនឹងដកប្រជាជនទាំងអស់ដែលរស់នៅអាសដូឌចេញ ហើយព្រមទាំងដកអ្នកកាន់កាប់អំណាចពីក្រុងអាស្កាឡូនចេញ។ យើងនឹងលើកដៃទៅទាស់នឹងក្រុងអេក្រុន
ហើយអ្នកស្រុកភីលីស្ទីនដែលនៅសេសសល់នឹងត្រូវវិនាសសូន្យអស់» នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។
[9]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់៖ «ដោយអ្នកក្រុងទីរ៉ុសបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
ដោយព្រោះពួកគេបានប្រគល់ពួកឈ្លើយទាំងអស់ដល់ជនជាតិអេដុម ហើយពួកគេមិនបាននឹកចាំសម្ព័ន្ធមេត្រីដែលពួកគេបានចុះជាមួយអ៊ីស្រាអែលឡើយ។
[10]យើងនឹងបញ្ជូនភ្លើងឲ្យឆាបឆេះបន្ទាយក្រុងទីរ៉ុស ហើយភ្លើងនឹងឆាបឆេះប្រាសាទក្រុងនោះផង»។

generated on Wed Sep 10 16:16:32 2025

[11]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ «ដោយអ្នកស្រុកអេដុមបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
ដោយព្រោះពួកគេបានកាន់ដាវវាយប្រហារបងប្អូនរបស់ខ្លួនដោយឥតប្រណី។ ពួកគេគិតតែបំផ្លាញតាមកំហឹងរបស់គេ ហើយចេះតែចងកំហឹងឥតឈប់ឡើយ។
[12]យើងនឹងបញ្ជូនភ្លើងឲ្យឆាបឆេះក្រុងថេម៉ាន ហើយភ្លើងនឹងឆាបឆេះប្រាសាទរបស់ក្រុងបូសរ៉ាផង»។
[13]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ «ដ្បិតអ្នកស្រុកអាំម៉ូនបានប្រព្រឹត្តអំពើបាបបីឬបួនដងផង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ ដោយព្រោះពួកគេឡើយ
ព្រោះគេបានវះពោះរបស់ពួកស្ត្រីៗដែលមានទម្ងន់ នៅស្រុកកាឡាដ ដើម្បីវាតទឹកដីរបស់ខ្លួនឲ្យធំជាងមុន។
[14]យើងនឹងបញ្ឆេះភ្លើងឲ្យឆេះកំផែងរ៉ាបាត ហើយភ្លើងនឹងឆាបឆេះប្រាសាទក្រុងនោះអស់ទៅ នៅថ្ងៃមានចម្បាំង
ក៏មានសម្រែកសឹកសង្គ្រាមទាំងមានព្យុះសង្ឃរាមកយ៉ាងខ្លាំង។[15]ស្តេចរបស់ពួកគេនឹងត្រូវចាប់ធ្វើជាឈ្លើយ ព្រមទាំងពួកមេដឹកនាំរបស់គេផងដែរ»
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។

Amos 1:1

នេះជាពាក្យ...ដែលលោកអេម៉ុស...បានទទួលការបើកសម្តែង

អ្វីដែលព្រះជាម្ចាស់ធ្វើឲ្យលោកអេម៉ុសយល់តាមរយៈអ្វីដែលលោកអេម៉ុសបានឃើញ និងឮ។

ព្រះអម្ចាស់ស្រែកគ្រហឹមពីភ្នំស៊ីយ៉ូនហើយព្រះអង្គនឹងបន្លឺព្រះសូរសៀងពីក្រុងយេរូសាឡឹម

ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា។ ពាក្យទាំងពីរបញ្ជាក់ថា
ព្រះអម្ចាស់ស្រែកគ្រហឹមខ្លាំងៗ
ខណៈពេលដែលទ្រង់បានត្រៀមដើម្បីវិនិច្ឆ័យជាតិទាំងមូល។

ព្រះជាម្ចាស់នឹងស្រែកគ្រហឹម

ដូចជា ១) សត្វតោ ឬ ២)ផ្គរលាន់

ព្រះអម្ចាស់

នេះគឺជាព្រះនាមរបស់ព្រះជាម្ចាស់ដែលទ្រង់បានបើកសម្តែងដល់ប្រជារាស្ត្ររបស់ទ្រង់នៅក្នុងគម្ពីរ
សូមមើលទៅក្នុងទំព័រនៃអត្ថបទសម្រាយអំពីព្រះម្ចាស់ដែលបានពាក់ព័ន្ធពីរបៀបដើម្បីស្វែងយល់បន្ថែម។

Amos 1:3

ដោយព្រោះអំពើបាបទាំងបី...ឬក៏បួន

«ដោយសារតែអំពើបាបដ៏ច្រើន...ឬដោយសារអំពើបាបច្រើនពេក» ឬ
«ដោយសារតែ...បានប្រព្រឹត្តបាបជាច្រើន ប្រព្រឹត្តបាបច្រើនជាងខ្ញុំបានសារភាព»។

យើងនឹងមិនព្រមលើកលែងទោសឲ្យពួកគេឡើយ

«យើងនឹងដាក់ទោសឲ្យខ្លាំងដល់មនុស្សទាំងនោះ»។

Amos 1:5

បំបាត់ប្រជាជន

នៅទីនេះ «បំបាត់» ក៏មានដូចនឹង «កម្ទេចចោល» ឬ «កម្ចាត់ចេញ»។

ព្រមទាំងអ្នកដែលកាន់អំណាចនៅបេតអេដែនផង

នៅក្នុងគម្ពីរបកប្រែថ្មីគឺមានន័យស្រដៀងនឹងអ្នកដែលរស់នៅតាមជ្រលងភ្នំអាវេន។

អ្នកដែលរស់នៅក្នុងតាមជ្រលងភ្នំអាវេន

នៅក្នុងគម្ពីរបកប្រែថ្មីគឺមានន័យថា «មនុស្សដែលរស់នៅជ្រលងភ្នំអេវេន»។
របកគំហើញដែលថាមាន «បុរសម្នាក់»
ជាធម្មតាត្រូវបានគេសម្រួលឃ្លានេះថាជាស្តេច។

អេវេន...បេតអេដែន...ឬក៏ គៀរ

ជាឈ្មោះរបស់ទីក្រុង

អេដែន

គឺខុសគ្នាពីសួនអេដែន។

អ្នកដែលកាន់អំណាច

គឺជាស្តេច ឬជាប្រមុខ

Amos 1:6

ដោយអ្នកក្រុងកាសាបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ

សូមមើលពីរបៀបដែលអ្នកសម្រួលពាក្យទាំងនេះនៅក្នុង ជំពូក១ ខ៣។

Amos 1:8

បំបាត់

នៅទីនេះ «បំបាត់» ក៏មានដូចនឹង «កម្ទេចចោល» ឬ «កម្ចាត់ចេញ»។

ប្រជាជនទាំងអស់ដែលរស់នៅអាសដូឌ

នៅក្នុងគម្ពីរបកប្រែថ្មីខ្លះមានន័យថា «មនុស្សដែលរស់នៅក្នុងអាសដូឌ»
របកគំហើញដែលមាន «ប្រជាជន»
ជាធម្មតាត្រូវបានគេសម្រួលឃ្លានេះថាជាស្តេច។

អ្នកកាន់កាប់អំណាចពីក្រុងអាស្កាឡូន

នៅក្នុងគម្ពីរបកប្រែថ្មីគឺមានន័យស្រដៀងនឹងអ្នកដែលរស់នៅអាសដូឌ។

[illegible]

ក្រុងអេក្រុន

[illegible]

Amos 1:9

ដោយអ្នកក្រុងទីរ៉ុសបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ

សូមមើលពីរបៀបដែលអ្នកសម្រួលពាក្យទាំងនេះនៅក្នុង ជំពូក១ ខ៣។

សម្ពន្ធមេត្រីនៃភាតរភាពរបស់គេ

«កិច្ចព្រមព្រៀងដែលពួកគេបានបង្កើតឡើងដើម្បីរាប់អ្នកជាបងប្អូន»។

Amos 1:11

ដោយអ្នកក្រុងទីរ៉ុសបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ

សូមមើលពីរបៀបដែលអ្នកសម្រួលពាក្យទាំងនេះនៅក្នុង ជំពូក១ ខ៣។

ហើយចេះតែចងកំហឹងឥតឈប់ឡើយ

«ហើយកំហឹងរបស់គេបានកើតឡើងរហូតដល់ពេលឥឡូវ»។

ក្រុងបូសរ៉ា

Amos 1:13

ដោយអ្នកក្រុងទីរ៉ុសបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ

សូមមើលពីរបៀបដែលអ្នកសម្រួលពាក្យទាំងនេះនៅក្នុង ជំពូក១ ខ៣។

Amos 1:14

មានសម្រែកសឹកសង្គ្រាមទាំងមានព្យុះសង្ឃរាមកយ៉ាងខ្លាំង

«ក៏មានហេតុការណ៍អាក្រក់ៗបានកើតឡើងទាំងអស់នៅក្នុងពេលតែមួយ»។

សម្រែកសឹកសង្គ្រាម...ព្យុះសង្ឃរា

ទាំងពីរនេះជាព្យុះយ៉ាងយោរយៅ។

ព្យុះសង្ឃរា

ជាព្យុះមួយដែលមានខ្យល់បក់បោកជុំវិញ។

---

2 [1]នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ «ដ្បិតពួកអ្នកស្រុកម៉ូអាប់បានប្រព្រឹត្តអំពើបាបបួនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
ព្រោះគេបានដុតឆ្អឹងស្តេចរបស់អេដុមឲ្យជាផេះ។
[2]យើងនឹងបញ្ជូនភ្លើងឲ្យឆាបឆេះម៉ូអាប់ ហើយភ្លើងនោះនឹងឆេះបន្ទាយក្រុងកេរីយ៉ុតផងដែរ។ ស្រុកម៉ូអាប់នឹងត្រូវស្លាប់ក្រោមសម្រែកច្រួលច្របល់ ដោយសម្រែក
និងសូសំឡេងត្រែ។[3]យើងនឹងបំផ្លាញចៅក្រមចេញពីចំណោមពួកគេ ព្រមទាំងប្រហារជីវិតមេដឹកនាំទាំងអស់ដែរ» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[4]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់៖ «ដ្បិតពួកអំពើបាបបីដង ឬបួនដងផងរបស់យូដា យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ ព្រោះពួកគេបានបដិសេធ
ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ហើយមិនបានកាន់តាមច្បាប់របស់ព្រះអង្គ។ សេចក្តីភូតភរបរបស់ពួកគេ បានធ្វើឲ្យគេវង្វេងចេញ ដូចដូនតារបស់ពួកគេដែរ។
[5]យើងនឹងបញ្ជូនភ្លើងឲ្យឆាបឆេះយូដា ហើយភ្លើងនោះឆេះបន្ទាយរបស់ក្រុងយេរូសាឡឹមផង»។
[6]នេះជាព្រះបន្ទូលនៃព្រះអម្ចាស់៖ «ដ្បិតអ្នកស្រុកអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបបីដងឬបួនដងផង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
ដោយព្រោះពួកគេបានលក់មនុស្សគ្មានទោសដើម្បីប្រាក់ ឬដើម្បីស្បែកជើងមួយគូរ។
[7]ពួកគេជាន់ឈ្លីជិះជាន់ដល់ជនក្រីក្រហើយជាន់ឈ្លីពន្លិចក្នុងដី ហើយរំលោភសិទ្ធប្រជាជនតូចតាច។ បុរសនោះ និងឪពុករបស់គាត់
បានរួមដំណេកជាមួយមនុស្សស្រីតែម្នាក់ ពួកគេធ្វើដូច្នេះប្រមាថនាមដ៏វិសុទ្ធរបស់យើង។[8]នៅក្បែរអាសនៈរបស់ពួកគេ
ពួកគេដេកលើសម្លៀកបំពាក់ដែលពួកអ្នកក្រយកមកបញ្ចាំ ហើយនៅក្នុងដំណាក់ព្រះរបស់ពួកគេ ជាកន្លែងដែលពួកគេផឹកស្រាជាមួយគ្នាកនគេទៅវិញ។

generated on Wed Sep 10 16:16:32 2025

[9]ប៉ុន្តែយើងវិញ យើងបានបំផ្លាញអ្នកស្រុកអាម៉ូរី ដែលមានកម្ពស់ដូចដើមតាត្រៅ និងមានកម្លាំងដូចដើមម៉ៃសាក់។ យើងបានបំផ្លាញទាំងដើម ទាំងឫសនៅមុខពួកគេ។
[10]ហើយយើងនាំអ្នករាល់គ្នាចេញពីអេស៊ីប នៅក្នុងទីរហោស្ថាន សែសិបឆ្នាំ ដើម្បីចាប់យកទឹកដីអាម៉ូរីដើម្បីទុកជាកេរ្តិ៍អាករ។
[11]យើងបានតាំងកូនចៅខ្លះរបស់ពួកអ្នករាល់គ្នាឡើងធ្វើជាព្យាការី និងឲ្យពួកណាសារីតងើបឡើងពីចំណោមពួកយុវជនរបស់អ្នករាល់។
តើយ៉ាងនេះមែនទេកូនចៅអ៊ីស្រាអែល? នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[12]ប៉ុន្តែអ្នករាល់គ្នាបង្ខំឲ្យពួកណាសារីតផឹកស្រា
ហើយបានហាមដល់ពួកព្យាការីថាកុំឲ្យថ្លែងព្រះបន្ទូលទៀតផង។
[13]មើល៍ យើងនឹងកិនអ្នករាល់គ្នាឲ្យខ្ទិចខ្ទី ដូចរទេះដឹកស្រូវកិនអ្វីៗទាំងអស់ដែលនៅក្រោមកង់។[14]អ្នករហ័សរហួនពុំអាចគេចខ្លួនបានឡើយ
ចំណែកមនុស្សមានកម្លាំងខ្លាំងក៏មិនអាចបញ្ចេញកម្លាំងរបស់ខ្លួនបានដែរ អ្នកចម្បាំងក៏មិនអាចសង្គ្រោះជីវិតរបស់ខ្លួនបានឡើយ។
[15]អ្នកពូកែបាញ់ធ្នូមិនអាចឈរនៅបាន អ្នកពូកែរត់ក៏រត់គេចមិនរួច អ្នកជិះសេះក៏មិនអាចសង្គ្រោះខ្លួនបានដែរ។
[16]ទោះបើជាអ្នកចម្បាំងមានចិត្តក្លាហានជាងគេនឹងរត់ទៅទាំងខ្លួននៅអាក្រាតផង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។

Amos 2:1
ដោយអ្នកក្រុងទីរ៉ុសបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
សូមមើលពីរបៀបដែលអ្នកសម្រួលពាក្យទាំងនេះនៅក្នុង ជំពូក១ ខ៣។
ផេះ
ជាកម្ទេចផេះដែលនៅសល់ នៅពេលដែលខ្យងសមុទ្រ
និងប្រភេទថ្មផ្សេងៗដែលត្រូវបានដុតហើយ។
Amos 2:2
ក្រុងកេរីយ៉ុត
ស្រុកម៉ូអាប់នឹងត្រូវស្លាប់
«ប្រជាជនម៉ូអាប់នឹងត្រូវស្លាប់»។
Amos 2:4
ដោយអ្នកក្រុងទីរ៉ុសបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
សូមមើលពីរបៀបដែលអ្នកសម្រួលពាក្យទាំងនេះនៅក្នុង ជំពូក១ ខ៣។
សេចក្តីភូតភរបស់ពួកគេ
នៅទីនេះ ឃ្លានេះអាចមានន័យថា «ព្រះក្លែងក្លាយ» ឬ «រូបព្រះ» ។
វង្វេងចេញ...ដើរចេញ
ការថ្វាយបង្គំរូបរូប
គឺត្រូវបានគេប្រៀបប្រដូចទៅនឹងមនុស្សដែលកំពុងពីក្រោយព្រះក្លែងក្លាយទាំងនេះ។
Amos 2:6
ដោយអ្នកក្រុងទីរ៉ុសបានប្រព្រឹត្តអំពើបាបជាច្រើនដង យើងនឹងមិនលើកលែងទោសឲ្យពួកគេឡើយ
សូមមើលពីរបៀបដែលអ្នកសម្រួលពាក្យទាំងនេះនៅក្នុង ជំពូក១ ខ៣។
Amos 2:7
ជាន់ឈ្លីជិះជាន់
អន្តរាយដោយការជិះជាន់យ៉ាងខ្លាំងក្លា ម្តងហើយម្តងទៀត។
ពួកគេរំលោភសិទ្ធិប្រជាជនតូចតាច
«ពួកមិនព្រមស្តាប់ នៅពេលដែលអ្នកដែលបានគេជិះជាន់និយាយថា
ពួកគេកំពុងត្រូវបានគេប្រព្រឹត្តដាក់ដោយភាពអយុត្តិធម៌»។
Amos 2:9
អ្នកដែលមានកម្ពស់ដូចដើមតាត្រៅ និងមានកម្លាំងដូចដើមម៉ៃសាក់
«ចំពោះអ្នកដែលមានកម្ពស់ខ្ពស់ដូចដើមឈើដែលខ្ពស់បំផុត
នោះអ្នកនឹងមានកម្លាំងខ្លាំងដូចជាឈើដែលរឹងមាំបំផុត»។
Amos 2:11
ព្រះបន្ទូលរបស់ព្រះអម្ចាស់
ព្យាយាមសម្រួលពាក្យទាំងនេះឲ្យដូចគ្នានៅពេលដែលព្រះបន្ទូលទាំងនេះកើតមាននៅក្នុងព្រះគម្ពីរនេះ។
Amos 2:13
សូមមើល
«សូមស្តាប់» ឬ
«សូមផ្តោតអារម្មណ៍ទៅលើអ្វីដែលយើងកំពុងមានបន្ទូលទៅកាន់អ្នករាល់គ្នា»។
Amos 2:15
អ្នកពូកែបាញ់ធ្នូនឹងមិនអាចឈរនៅបាន
«អ្នកពូកែបាញ់ធ្នូនឹងរត់ចេញឆ្ងាយ»។
អ្នកពូកែរត់នឹងរត់គេចមិនរួច
«អ្នកពូកែរត់នឹងត្រូវបានគេចាប់ខ្លួន»។
អ្នកជិះសេះក៏នឹងមិនអាចសង្គ្រោះខ្លួនបានដែរ
«អ្នកជិះសេះនឹងស្លាប់»។
ខ្លួននៅអាក្រាត
វាអាចមានន័យថា ១) រត់ចេញទៅដោយគ្មានអាវុធនៅក្នុងដៃ «ឬក៏ ២)
រតចេញទៅដោយមិនស្លៀកសម្លៀកបំពាក់»។
ព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមសម្រួលពាក្យទាំងនេះឲ្យអ្វីដែលបានសរសេរនៅក្នុងជំពូក ២:១១។

---

3 [1]ជនជាតិអ៊ីស្រាអែលអើយ! ចូរស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលព្រះអង្គមានបន្ទូលទាស់ប្រឆាំងនឹងអ្នករាល់គ្នា គឺទាស់នឹងគ្រួសារទាំងមូល
ដែលយើងបាននាំចេញពីអេស៊ីប[2]«យើងបានជ្រើសរើសអ្នកតែម្នាក់ពីគ្រួសារផ្សេងៗនៅផែនដី។ ហេតុនេះយើងនឹងដាក់ទោសអ្នករាល់គ្នា
ដោយព្រោះអំពើទុច្চរិតទាំងប៉ុន្មានដែលអ្នករាល់គ្នាបានប្រព្រឹត្ត»។
[3]តើមនុស្សពីរនាក់អាចដើរជាមួយគ្នាបានលុះត្រាពួកគេព្រមព្រៀងនឹងគ្នាសិនមែនទេ?[4]តើសត្វសិង្ហនឹងគ្រហឹមនៅក្នុងព្រៃពេលដែលគ្មានសព្វចាប់ជាចំណីទេ?
ហើយបើសិង្ហស្ទាវចាប់មិនទាន់បានអ្វីសោះ តើឲ្យវាគ្រហឹមក្នុងរូងម្តេចបាន?
[5]បើគ្មាននុយបញ្ឆោតទេ តើសត្វស្លាបហើរមកជាប់អន្ទាក់នៅដីបានឬ? បើគ្មានសត្វជាប់ទេ តើឲ្យអន្ទាក់រាត់ឡើងដូចម្តេចបាន?[6]បើគេផ្លុំត្រែប្រកាសអាសន្ននៅក្នុងក្រុងមួយ
តើប្រជាជនមិនច្រួលច្របល់ទេឬ? បើព្រះអម្ចាស់មិនបានដាក់ទោសទេ តើមានមហន្តរាយអាចកើតមានឡើងដល់ក្រុងណាមួយឬ?
[7]ពិតប្រាកដណាស់ នៅពេលដែលព្រះជាអម្ចាស់ធ្វើការអ្វីមួយ ព្រះអង្គមិនសម្តែងការលាក់កំបាំងរបស់ព្រះអង្គពីពួកព្យាការីដែលជាអ្នកបម្រើរបស់ព្រះអង្គនោះឡើយ។
[8]ពេលសត្វសិង្ហគ្រហឹម តើនរណាមិនខ្លាច? ពេលព្រះជាម្ចាស់មានបន្ទូល តើនរណាមិនថ្លែងពាក្យទាំងនោះ?
[9]ចូរប្រកាសប្រាប់នៅតាមបន្ទាយក្រុងអាសដូស និងនៅតាមបន្ទាយនៃអេស៊ីបថា «ចូរជួបជុំគ្នានៅលើភ្នំនៃសាម៉ារី ហើយសង្កេតមើលការច្រួសច្របល់ និងការសង្កត់សង្កិន
ដែលកើតមានឡើងនៅទីនោះ។[10]ព្រះអម្ចាស់មានព្រះបន្ទូលថា ពួកគេមិនចេះប្រព្រឹត្តអំពើទៀងត្រង់ទេ ពួកគេយករបស់របរដែលលួចឆក់ប្លន់
មកដាក់ពេញបន្ទាយរបស់ខ្លួន»។
[11]ហេតុនេះ ព្រះអម្ចាស់មានព្រះបន្ទូលថា «ខ្មាំងសត្រូវនឹងឡោមព័ន្ធទឹកដី។ គេនឹងធ្វើឲ្យកម្លាំងរបស់អ្នកថយចុះ ហើយបំផ្លាញបន្ទាយរបស់អ្នកទៀតផង»។
[12]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ «ដូចពួកអ្នកគង្វាលចៀមដែលដណ្តើមសត្វពីមាត់សិង្ហវិញ ហើយនៅសល់តែជើងពីរ ឬ ត្រចៀកមួយដុំ
ដូចជាជនជាតិអ៊ីស្រាអែលនៅក្រុងសាម៉ារី ដែលដេកនៅលើគ្រែ និងលើកម្រាលព្រំដ៏មានតម្លៃពីទឹកដីស៊ីរី»។
[13]ចូរស្តាប់ ហើយធ្វើទីបន្ទាល់ទាស់នឹងពូជពង្សលោកយ៉ាកុបផង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះនៃពិភពទាំងមូល[14]«ដ្បិតនៅថ្ងៃដែលយើងដាក់ទោសអ៊ីស្រាអែល
ដោយព្រោះអំពើរំលង យើងក៏នឹងដាក់ទោសដល់គេ ដោយព្រោះតែអាសនៈនៅបេតអែលដែរ។ ហើយស្នែងអាសនៈនោះនឹងត្រូវកាត់ចេញឲ្យធ្លាក់ដល់ដី។
[15]យើងនឹងធ្វើឲ្យដំណាក់នៅរដូវរងា និងដំណាក់នៅរដូវក្តៅរលំលើគ្នា។ ចំណែកដំណាក់ភ្លុកនឹងត្រូវវិនាសទៅ ហើយដំណាក់ធំៗនឹងត្រូវសូន្យបាត់
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។

---

generated on Wed Sep 10 16:16:32 2025

Amos 3:3
ព័ត៌មានទូទៅ:
ព្រះជាម្ចាស់នឹងប្រទានចម្លើយនូវសំណួរទាំងនេះ នៅក្នុងជំពូក៣ ខ៧។
Amos 3:5
ព័ត៌មានទូទៅ:
ព្រះជាម្ចាស់នឹងប្រទានចម្លើយនូវសំណួរទាំងនេះ នៅក្នុងជំពូក៣ ខ៧។
Amos 3:7
ពិតប្រាកដណាស់ នៅពេលដែលព្រះជាអម្ចាស់ធ្វើការអ្វីមួយ
ព្រះអង្គមិនសម្តែងការលាក់កំបាំង...ពួកព្យាការី
«ព្រះអម្ចាស់នឹងបើកសម្តែងដល់ពួក ព្យាការីជាមុនទ្រង់ធ្វើអ្វីផ្សេងទៀត»។
Amos 3:9
ការប្រកាសរបស់ព្រះជាម្ចាស់
សូមប្រែសម្រួលពាក្យទាំងនេះដែលអ្នកបានប្រែសម្រួលនៅក្នុង ជំពូក ២:ខ១១។
Amos 3:11
កន្លែងដេក
ជាកៅអីធំមួយល្មមដើម្បីសម្រាក
ដោយសារតែជ្រុងនៃកន្លែងដេក គ្រាន់តែជាជ្រុងនៃគ្រែដេក
សារនេះនៅក្នុងគម្ពីរហេព្រើរគឺពិបាកយល់ណាស់
ហើយខគម្ពីរមួយចំនួនប្រែសម្រួលខុសគ្នា។ ការប្រែសម្រួលនៅក្នុង
Amos 3:13
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមព្យាយាមសម្រួលពាក្យទាំងនេះឲ្យដូចគ្នា រៀងរាល់ពេល
ព្រះបន្ទូលទាំងនេះមាននៅក្នុងព្រះគម្ពីរ។
ដោយព្រោះអំពើរំលង
ទាំងនេះដូចជាស្នែងគោជល់ដែលចេញពីទិសតែមួយនៅចុងកំពូល
ហើយជាសញ្ញាដើម្បីបង្ហាញថាតើព្រះជាម្ចាស់អស្ចារ្យប៉ុណ្ណា។
Amos 3:15
ដំណាក់នៅរដូវរងា និងដំណាក់នៅរដូវក្តៅ
«ដំណាក់ទាំងអស់»។
ដំណាក់ភ្លុក
ធ្មេញ និងស្នែងរបស់សត្វចតុបាត។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
សូមសម្រួលខនេះដូចដែលអ្នកធ្លាប់បានធ្វើ នៅក្នុងជំពូក ២:១១។

---

4 [1]ចូរស្តាប់ពាក្យនេះចុះ គោពីស្រុកបាសានអើយ! អ្នករាល់គ្នាដែលនៅលើភ្នំសាម៉ារី ដែលជិះជាន់ដល់អ្នកក្រីក្រ ហើយជិះជាន់ដល់មនុស្សកម្សត់ទុគ៌ត
ក៏និយាយទៅប្តីរបស់ខ្លួនថា «ចូរយកស្រាមកផឹក»។[2]ព្រះជាម្ចាស់បានស្បថដោយសេចក្តីបរិសុទ្ធរបស់ព្រះអង្គថា «មើល៍! នៅថ្ងៃនោះនឹងធ្លាក់មក លើអ្នករាល់គ្នា
ជាគ្រាដែលពួកគេនឹងអូសអ្នករាល់គ្នាចេញដោយទម្គក់ ហើយនឹងដោតអ្នករាល់គ្នាដូចផ្លែសន្ទូច។
[3]អ្នករាល់គ្នានឹងចេញទៅតាមប្រឡោះកំផែងក្រុងបាក់បែក ម្នាក់ៗទៅត្រង់រៀងៗខ្លួន ហើយអ្នករាល់គ្នានឹងត្រូវគេបោះទៅកាន់ហាម៉ូន នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[4]«ចូរទៅបេតអែល ហើយធ្វើបាបទៅ ចូរទៅគីលកាល ហើយនាំគ្នាធ្វើបាបកាន់តែច្រើនចុះ ចូរយកយញ្ញបូជារបស់អ្នករាល់គ្នារាល់ព្រឹក
ហើយថ្វាយតង្វាយមួយភាគដប់ជារៀងរាល់ពេលបីថ្ងៃម្តង។[5]កូនចៅអ៊ីស្រាអែលអើយ ចូរធ្វើយញ្ញបូជាអរព្រះគុណជាមួយដំបែ
ចូរស្រែកប្រកាសឲ្យថ្វាយតង្វាយស្ម័គ្រចិត្តទៅ ដ្បិតអ្នករាល់គ្នាចូលចិត្តធ្វើដូច្នេះនេះជា ព្រះបន្ទូលរបស់ព្រះជាម្ចាស់។
[6]យើងបានធ្វើឲ្យអ្នករាល់គ្នាមានធ្មេញស្អាតនៅគ្រប់ទាំងទីក្រុងរបស់អ្នករាល់គ្នា ហើយគ្រប់ផ្ទះនឹងខ្វះអាហារបរិភោគ។ តែទោះជាយ៉ាងណា
អ្នករាល់គ្នាក៏មិនព្រមវិលមករកយើងវិញដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[7]យើងបានបង្ខាំងមិនឲ្យមានភ្លៀងធ្លាក់មកដល់រាល់គ្នា រហូតដល់បីខែមុនរដូវចម្រូត។
យើងធ្វើឲ្យមានភ្លៀងធ្លាក់លើក្រុងមួយ ហើយក្រុងមួយទៀត មិនមែនភ្លៀងទេ ចម្ការមួយទទួលបានទឹកភ្លៀង។ ប៉ុន្តែចម្ការមួយទៀត
ត្រូវស្ងួតហួតហែងដោយព្រោះគ្មានទឹកភ្លៀង។
[8]ទីក្រុងពីរ ឬ ទីក្រុងបីនាំគ្នាដើររកទឹកផឹកនៅក្រុងមួយទៀត តែមិនបានឆ្អែតឡើយ។ ប៉ុន្តែ អ្នករាល់គ្នាក៏មិនព្រមវិលមករកយើងវិញដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[9]យើងបានធ្វើឲ្យស្រូវរបស់អ្នករាល់គ្នាស្កក និងមានក្រាស៊ី។ សួនដំណាំជាច្រើន និងចម្ការទំពាំងបាយជូរ ព្រមទាំងដើមឧទុម្ពរ និងដើមអូលីវរបស់អ្នករាល់គ្នា
ក៏ត្រូវដង្កូវស៊ីបំផ្លាញអស់ដែរ។ តែទោះជាយ៉ាងនេះក្តី ក៏អ្នករាល់គ្នាមិនព្រមវិលមករកយើងវិញដែរ។ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[10]យើងបានបញ្ជូនជំងឺអាសន្នរោគឲ្យរាតត្បាតដល់អ្នករាល់គ្នាដូចនៅលើទឹកដីអេស៊ីបដែរ។ យើងបានសម្លាប់យុវជនរបស់អ្នករាល់គ្នាដោយមុខដាវ
ហើយចាប់សេះរបស់អ្នករាល់គ្នាយកទៅ ក៏ធ្វើឲ្យមានក្លិនស្អុយ សាយឡើងពីទីតាំងទ័ពរបស់អ្នករាល់គ្នា។ ប៉ុន្តែអ្នករាល់គ្នាមិនព្រមវិលមករកយើងវិញដែរ
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[11]យើងបានបំផ្លាញទីក្រុងរបស់អ្នករាល់គ្នា ដូចដែលយើងបានបំផ្លាញទីក្រុងសូដុម និងក្រុងកូម៉ូរ៉ា។
ហើយអ្នករាល់គ្នាប្រៀបបានដូចជាអង្កត់អុស ដែលយកចេញពីភ្លើង។ ប៉ុន្តែអ្នករាល់គ្នាមិនព្រមវិលមករកយើងវិញដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[12]ហេតុនេះ អ៊ីស្រាអែលអើយ យើងនឹងដាក់ទោសអ្នករាល់គ្នា ដោយព្រោះយើងនឹងដាក់ទោសអ្នករាល់គ្នាដូច្នេះ ចូរឲ្យរៀបចំខ្លួនជួបនឹងព្រះរបស់អ្នកទៅ
អ៊ីស្រាអែលអើយ!។[13]ដ្បិតមើល៍ ព្រះដែលសូនធ្វើភ្នំ ហើយបង្កើតខ្យល់ ព្រះដែលបង្ហាញឲ្យមនុស្សស្គាល់ ព្រះដែលធ្វើឲ្យពន្លឺថ្ងៃរះប្រែជាងងឹត
ព្រះដែលយាងទៅតាមទីខ្ពស់ៗនៃផែនដី។ ព្រះអង្គដែលមានព្រះនាមថា ព្រះនៃពិភពលោកទាំងមូល»។

Amos 4:1
អូសអ្នករាល់គ្នាចេញដោយទម្គក់ ហើយនឹងដោតអ្នករាល់គ្នាដូចផ្លែសន្ទូច
ឃ្លាទាំងនេះ មានន័យស្រដៀងគ្នា
ហើយបានបញ្ជាក់ថាសត្រូវនឹងឆក់ចាប់យកអ្នកដែលដូចដែលអ្នកចាប់ត្រី។
«យកឈ្នះលើអ្នក ហើយបង្ខំឲ្យអ្នកចេញទៅជាមួយពួកគេ» ឬ
«ដាក់អ្នកនៅលើសន្ទូចដូចជាត្រី ហើយថ្កក់អ្នកចេញទៅ»។
Amos 4:3
បំបែកកំផែងក្រុងបាក់បែក
ទីកន្លែងដែលសត្រូវបានបំបែកទីក្រុងឲ្យបាក់បែកដើម្បីចូលទៅ។
អ្នករាល់គ្នានឹងត្រូវគេបោះទៅកាន់ហាម៉ូន
«ពួកគេនឹងបោះអ្នកទៅកាន់ហាម៉ូន» ឬ
«សត្រូវរបស់អ្នកនឹងបង្ខំអ្នកឲ្យចាកចេញពីទីក្រុងឲ្យទៅកាន់ហាម៉ូន»។
ហាម៉ូន
នេះប្រហែលជាទីកន្លែងដែលយើងមិនស្គាល់ ឬវាប្រហែលជាសំដៅទៅលើភ្នំហាម៉ូន
ហើយនៅក្នុងខគម្ពីរថ្មីខ្លះបានបកប្រែបែបនេះឯង។
នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់
នៅក្នុងឃ្លានេះ គឺត្រូវបានគេបង្ហាញថា
អ្វីដែលព្រះជាម្ចាស់មានបន្ទូលពីអ្វីប្រាកដនឹងកើតឡើង។
សូមប្រែសម្រួលឃ្លានេះឲ្យដូចដែលអ្នកបានបកប្រែនៅក្នុង ជំពូក២:១១។
Amos 4:4
ចូរទៅបេតអែល ហើយធ្វើបាបទៅ ចូរទៅគីលកាល ហើយនាំគ្នាធ្វើបាបកាន់តែច្រើនចុះ
«ដោយសារតែអ្នកបដិសេធមិនសារភាព ការបូជាដែលអ្នកបានធ្វើនៅបេតអែល
និងគីលកាល វាមានតែធ្វើឲ្យយើងខ្ញាល់ជាងនឹងទៅទៀត»។
ចូរយកយញ្ញបូជារបស់អ្នក .....ហើយថ្វាយតង្វាយ...ចូរធ្វើយញ្ញបូជាអរព្រះគុណ.....ស្រែកប្រកាសឲ្យថ្វាយតង្វាយស្ម័គ្រចិត្ត...
បើសិនជាភាសារបស់អ្នកមានវិធីដើម្បីបង្ហាញថា
មនុស្សបដិសេធមិនយល់ថាការធ្វើដូច្នេះនឹងធ្វើឲ្យពួកគេគ្មានលទ្ធផលល្អ
ប៉ុន្តែពួកគេនឹងឈប់ធ្វើអញ្ចឹងទេ អ្នកប្រហែលជាចង់ប្រើវានៅទីនេះហើយ។
ថ្វាយតង្វាយមួយភាគដប់ជារៀងរាល់ពេលបីថ្ងៃម្តង
ជំនួសឲ្យថ្វាយតង្វាយមួយភាគដប់ «រៀងរាល់បីថ្ងៃ» ខគម្ពីរខ្លះមាន
«រៀងរាល់បីថ្ងៃ»
នេះគឺដោយសារតែសាសន៍អ៊ីស្រាអែលគឺត្រូវបានឲ្យនាំយកតង្វាយមួយភាគដប់ទៅព្រះជាម្ចាស់រាល់បីថ្ងៃម្ត
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
សូមប្រែសម្រួលខនេះឲ្យដូចដែលអ្នកបានធ្វើនៅក្នុង ជំពូក ៣:១៣។
Amos 4:6
មានធ្មេញស្អាត
«ភាពស្រេកឃ្លាន» ឬ «ការអត់បាយ»។

generated on Wed Sep 10 16:16:32 2025

អ្នករាល់គ្នាក៏មិនព្រមវិលមករកយើងវិញ
«អ្នកមិនបានបញ្ឈប់ប្រព្រឹត្តបាបជំទាស់ប្រឆាំងនឹងយើង»។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
សូមប្រែសម្រួលខនេះឲ្យដូចដែលអ្នកបានធ្វើនៅក្នុង ជំពូក ២:១១។
Amos 4:8
យើងបានធ្វើឲ្យស្រូវរបស់អ្នករាល់គ្នាស្កក និងមានក្រាស៊ី
«ពេលខ្លះយើងបានប្រទានឲ្យអ្នករាល់គ្នាតិចពេក និងច្រើពេក»។
ការបំផ្លិចបំផ្លាញ
ជាជម្ងឺដែលធ្វើឲ្យដំណាំក្រៀមស្ងួត ហើយស្លាប់តែម្តង។
ដុះផ្សិត
ជាការដុះឡើងនៅរូបរាងអាក្រក់នៅលើដំណាំដែលវាស្ថិតនៅសើមយូរពេក។
អ្នករាល់គ្នាក៏មិនព្រមវិលមករកយើងវិញ
សូមប្រែសម្រួលខនេះឲ្យដូចដែលអ្នកបានធ្វើនៅក្នុង ជំពូក ៦:៤។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
សូមប្រែសម្រួលខនេះឲ្យដូចដែលអ្នកបានធ្វើនៅក្នុង ជំពូក ២:១១។
Amos 4:10
ធ្វើឲ្យមានក្លិនស្អុយ សាយឡើងពីទីតាំងទ័ពរបស់អ្នករាល់គ្នា
«ចូលទៅក្នុងបរិយាកាសដោយក្លិនស្អុយ សាយឡើងពីទីតាំងទ័ពរបស់អ្នក» ឬ
«អ្នកមិនអាចគេចចេញពីការសាយភាពឡើងពីទីតាំងទ័ពរបស់អ្នករាល់គ្នា»។
ក្លិនស្អុយ
ជាក្លិនដែលអាក្រក់ ជាពិសេសដូចជាសាកសពមនុស្សដែលស្លាប់។
អ្នករាល់គ្នាប្រៀបបានដូចជាអង្កត់អុស ដែលយកចេញពីភ្លើង
«យើងបានទាញយកអ្នករាល់គ្នាចេញពីភ្លើង ដុតអ្នកជាប់នៅភ្លើងដែលកំពុងឆេះ»
ឬ «យើងនឹងឲ្យអ្នកដុតវាសិន មុនពេលដែលយើងទាញយកអ្នកចេញពីភ្លើង»។
អ្នករាល់គ្នាក៏មិនព្រមវិលមករកយើងវិញ
សូមប្រែសម្រួលខនេះឲ្យដូចដែលអ្នកបានធ្វើនៅក្នុង ជំពូក ៦:៤។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
សូមប្រែសម្រួលខនេះឲ្យដូចដែលអ្នកបានធ្វើនៅក្នុង ជំពូក ២:១១។

---

5 [1]កូនចៅអ៊ីស្រាអែលអើយ ចូនាំគ្នាស្តាប់ពាក្យ ទំនួញដែលខ្ញុំស្មូត្រអំពីអ្នករាល់គ្នាចុះ។[2]ស្ត្រីព្រហ្មចារីអ៊ីស្រាអែលបានដួលចុះហើយ នាងនឹងមិនអាចក្រោកឡើងវិញឡើយ
នាងត្រូវគេបោះបង់ចោលលើទឹកដីរបស់ខ្លួន គ្មាននរណាលើកនាងឡើយ។
[3]ដ្បិតព្រះជាអម្ចាស់មានព្រះបន្ទូលថា «ក្រុងរបស់អ៊ីស្រាអែលដែលលើកទ័ពចេញទៅមួយពាន់នាក់ឲ្យទៅច្បាំង ហើយពួកគេត្រលប់មកវិញឃើញតែមួយរយនាក់
ហើយក្រុងមួយចាត់កងទ័ពអោយទៅច្បាំងមួយរយនាក់ ឃើញពួកគេត្រលប់មកវិញតែដប់អ្នកប៉ុណ្ណោះ»។
[4]ដ្បិតព្រះអម្ចាស់មានបន្ទូលមកកូនចៅអ៊ីស្រាអែលថា៖ «ចូរស្វែង រកយើងនោះអ្នករាល់គ្នានឹងមានជីវិត![5]កុំស្វែង បេតអែល ឬទៅគីលកាលឡើយ
កុំធ្វើដំណើរទៅបៀរសេបាឡើយ។ ដ្បិតអ្នកក្រុងគីលកាលនឹងត្រូវទៅជាឈ្លើយ ហើយ បេតអែល និងត្រូវសូន្យបាត់ទៅ។
[6]ចូរស្វែងរកព្រះអម្ចាស់ នោះអ្នករាល់គ្នានឹងមានជិវិត ចូរប្រយ័ត្ន ក្រែងព្រះអង្គឆាបឆេះឡើងដូចជាភ្លើងក្នុងពូជពង្សយ៉ូសែប។ ហើយនឹងបញ្ឆេះអស់រលីងទៅ
គ្មាននរណានៅបេត អែលអាចពន្លត់បានឡើយ។[7]អ្នករាល់គ្នាបានធ្វើឲ្យយុត្តិធម៌ប្រែទៅជាពិសពុល ហើយជាន់ឈ្លីសេចក្តីសុចរិតទៀតផង!»
[8]ព្រះអង្គបានបង្កើតផ្កាយកូនមាន់និងផ្កាយនង្គ័ល ព្រះអង្គធ្វើឲ្យភាពអន្ធការប្រែទៅជាពន្លឺនៅពេលថ្ងៃរះ ហើយធ្វើឲ្យថ្ងៃត្រលប់ទៅជាយប់ងងឹត
ព្រមទាំងហៅទឹកសមុទ្រមកចាក់ស្រោចស្រពលើផែនដី។ ព្រះនាមរបស់ព្រះអង្គ គឺព្រះអម្ចាស់![9]ព្រះអង្គធ្វើឲ្យមហន្តរាយកើតដល់មនុស្សខ្លាំងពូកែយ៉ាងទាន់ហន់
ហើយធ្វើឲ្យបន្ទាយដ៏រឹងមាំត្រូវវិនាស។
[10]ពួកគេស្អប់អស់អ្នកដែលកែតំរង់គេនៅ មាត់ទ្វា ហើយពួកគេស្អប់ខ្ពើមអ្នកដែលនិយាយសេចក្តីពិត។[11]ដោយព្រោះអ្នករាល់គ្នាជាន់ឈ្លីមនុស្សក្រីក្រ
ហើយរឹបអូសយកស្រូវរបស់ពួកគេ ទោះអ្នករាល់គ្នាសាងសង់ផ្ទះថ្មដ៏រឹងមាំ តែអ្នករាល់គ្នាមិនបានរស់នៅក្នុងផ្ទះនោះដែរ។ អ្នករាល់គ្នាបានដាំស្រាទំពាំងបាយជូរដ៏ឆ្ងាញ់
ប៉ុន្តែអ្នករាល់គ្នាមិនបានផឹកស្រាទំពាំងបាយជូរពីចំម្ការនោះឡើយ។
[12]ដ្បិតយើងដឹងហើយថាអ្នករាល់គ្នាប្រព្រឹត្តអំពើទុច្ចរិតជាច្រើន ហើយអំពើបាបរបស់អ្នករាល់គ្នាក៏ធ្ងន់ធ្ងរណាស់ អ្នករាល់គ្នានេះហើយដែលធ្វើទុក្ខដល់មនុស្សសុចរិត
និងស៊ីសំណូក ហើយមិនរកយុត្តិធម៌ឲ្យជនក្រីក្រទេ។[13]ហេតុនេះហើយបានជាមនុស្សឈ្លាសវៃ សុខចិត្តនៅស្ងៀម ដ្បិតនេះជាគ្រាមួយដ៏លំបាក។
[14]ចូរស្វែងរកអំពើល្អ កុំស្វែងរកអំពើអាក្រក់ឡើយ នោះអ្នករាល់គ្នានឹងមានជីវិត។ ហើយព្រះអម្ចាស់ជាព្រះនៃពិភពលោកទាំងមូល នឹងគង់នៅជាមួយអ្នករាល់គ្នា
ដូចអ្នករាល់គ្នាធ្លាប់និយាយហើយ។[15]ចូរស្អប់អំពើអាក្រក់ ហើយស្រលាញ់អំពើល្អ ចូរតាំងឲ្យមានយុត្តធម៌នៅត្រង់ទ្វារក្រុង នោះព្រះអម្ចាស់ជាព្រះនៃពិភពទាំងមូល
នឹងសម្តែងព្រះគុណដល់ពូជពង្សលោកយ៉ូសែបដែលនៅសេសសល់។
[16]ហេតុនេះព្រះអម្ចាស់ជាព្រះនៃពិភពលោកទាំងមូលមានព្រះបន្ទូលថា «មនុស្សម្នានឹងទ្រហោយំនៅតាមទីសាធារណៈទាំងអស់ ហើយនៅតាមផ្លូវគេនឹងនិយាយថា
វរហើយ! វរហើយ! ពួកគេហៅអ្នកភូវរាស់មកយំសោក ហើយពួកអ្នកដែលប្រសព្វទួញទំនួញមកទ្រហោយំ សម្រាប់ពិធីបញ្ចុះសព។[17]នៅគ្រប់ទាំងចម្ការទំពាំងបាយជូរ
មនុស្សម្នានឹងទ្រហោយំក្នុងគ្រាដែលយើងដើរកាត់ចំណោមអ្នករាល់គ្នា» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[18]អ្នកនោះមុខជាវេទនាពុំខាន អស់អ្នកណាដែលសង្វាតចង់បានថ្ងៃរបស់ព្រះអម្ចាស់! តើហេតុអ្វីបានជាអ្នករាល់គ្នាចង់បានថ្ងៃរបស់ព្រះអម្ចាស់? ថ្ងៃនោះនឹងងងឹត
មិនមែនភ្លឺទេ[19]ប្រៀបដូចជាមនុស្សម្នាក់រត់រួចពីសិង្ហ ហើយទៅជួបខ្លាឃ្មុំ ឬចូលទៅក្នុងផ្ទះ ហើយច្រត់ដៃនឹងជញ្ជាំង រួចត្រូវពស់ចឹក។
[20]តើថ្ងៃរបស់ព្រះអម្ចាស់មិនមែនជាថ្ងៃងងឹត ហើយឥតពន្លឺទេឬ? តើជាថ្ងៃអន្ធការ គ្មានពន្លឺរស្មីទេឬ?
[21]«ហើយយើងក៏មិនរីករាយនឹងពិធីបុណ្យផ្សេងៗរបស់អ្នករាល់គ្នាប្រារព្ធដែរ។[22]ទោះបីអ្នករាល់គ្នាថ្វាយដង្វាយដុត និងដង្វាយម្សៅមកឲ្យយើង
ក៏យើងមិនទទួលដង្វាយរបស់អ្នករាល់គ្នាដែរ ហើយយើងនឹងមិនអើពើសត្វធាត់ៗដែលអ្នករាល់គ្នាថ្វាយ ជាដង្វាយមេត្រីឡើយ។
[23]ចូរឈប់ច្រៀងចម្រៀងដ៏កងរំពងរបស់អ្នករាល់គ្នាចេញពីយើងទៅ យើងនឹងមិនចង់ស្តាប់សម្លេងពិណរបស់អ្នករាល់គ្នាទេ។[24]ផ្ទុយទៅវិញ
ចូរឲ្យមានសេចក្តីយុត្តិធម៌ហូរដូចជាទឹក និងសេចក្តីសុចរិតដូចជាស្ទឹងមិនចេះរីងស្ងួត។
[25]កូនចៅអ៊ីុស្រាអែលអើយ ក្នុងរយៈពេលសែសិបឆ្នាំនៅទីវាលហោស្ថាន តើអ្នករាល់គ្នាមានយកយញ្ញបូជានឹងដង្វាយផ្សេងៗមកឲ្យយើងដែរឬទេ?
[26]ដោយអ្នករាល់គ្នាបានថ្វាយបង្គំស៊ីគុក ដូចជាសេចរបស់អ្នក និងគីយ៉ូនជារូបព្រះរបស់អ្នករាល់គ្នា ព្រមទាំងរូបផ្កាយរបស់ព្រះ ដែលអ្នករាល់គ្នាបានសូនដោយដៃខ្លួនឯង។
[27]ដូច្នេះ យើងនឹងនាំអ្នករាល់គ្នាទៅជាឈ្លើយនៅក្រុងដាម៉ាស» នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលមានព្រះនាមជាព្រះនៃពិភពលោកទាំងមូល។

Amos 5:1
ស្ត្រីព្រហ្មចារីអ៊ីស្រាអែលបានដួលចុះហើយ...នាងនឹងមិនអាចក្រោកឡើងបានទេ...គ្មាននរណាម្នាក់លើកនាងឡើងបានទេ
«ប្រជាជនអ៊ីស្រាអែលបានស្លាប់យ៉ាងឃោរឃៅ...ពួកគេនឹងមិនអាចក្រោកឡើងបានទេនិងនាំគ្នាមកវិលត្រឡប់ទៅរកយើងវិញ»។
Amos 5:4
ចូរស្វែង រកយើង
«សូមចូលមករកយើងដើម្បីសុំជំនួយ»។
បេតអែល និងត្រូវសូន្យបាត់ទៅ
«បេតអែលនឹងត្រូវបានគេបំផ្លាញទាំងស្រុង» «មនុស្សនឹងចូលមក
ហើយបំផ្លាញបេតអែល»។
Amos 5:6
ព្រះអង្គនឹងឆាបឆេះឡើងដូចជាភ្លើង
ព្រះអង្គនឹងយាងមកដូចជាភ្លើងដែលឆាបឆេះ
ធ្វើឲ្យយុត្តិធម៌ប្រែទៅជាពិសពុល ហើយជាន់ឈ្លីសេចក្តីសុចរិតទៀតផង
ធ្វើឲ្យការអាក្រក់ទៅជាល្អ ហើយការល្អប្រែក្លាយទៅការឥតសំខាន់។
ធ្វើឲ្យយុត្តិធម៌ប្រែទៅជាពិសពុល
ឬ «យុត្តិធម៌ទ្វេរដង» ឬ «ធ្វើអ្វីដោយមិនគ្រាន់តែធ្វើ ប៉ុន្តែនិយាយអ្វីដែលធ្វើ»។
ហើយជាន់ឈ្លីសេចក្តីសុចរិតទៀតផង
ឬ «រាប់សេចក្តីសុចរិតដូចជាការដែលឥតប្រយោជន៍ ឬដូចជាធូលី»។
Amos 5:8

generated on Wed Sep 10 16:16:32 2025

ផ្ការួយកូនមាន់ និងផ្ការួយនង្គ័ល
ហ្វូងតារា
Amos 5:10
ជាន់ឈ្លី
«សង្កត់សង្កិនយ៉ាងធ្ងន់ធ្ងរ»។
Amos 5:12
មិនរកយុត្តិធម៌ឲ្យជនក្រីក្រទេ
«មិនអនុញ្ញាតឲ្យជនក្រីក្រនាំយករឿងរបស់ពួកគេចូលមកជំនុំជម្រះ»។
មនុស្សឈ្លាសវៃ សុខចិត្តនៅស្ងៀម
អ្នកទាំងនោះមិនចង់មនុស្សអាក្រក់ធ្វើបាបពួកគេ
នឹងមិននិយាយជំទាស់ប្រឆាំងនឹងអំពើអាក្រក់។
Amos 5:14
ចូរតាំងឲ្យមានយុត្តធម៌នៅត្រង់ទ្វារក្រុង
ឬ «សូមមើលឃើញថា
ភាពយុត្តធម៌ត្រូវបានកើតឡើងនៅក្នុងតុលាការនៅឯទីក្រុង»។
Amos 5:16
មនុស្សម្នា
វែងឆ្ងាយ សម្លេងអឺងកង សម្លេងយំសោកសង្រែង។
Amos 5:18
តើហេតុអ្វីបានជាអ្នករាល់គ្នាចង់បានថ្ងៃរបស់ព្រះអម្ចាស់
«អ្នកមិនគួរចង់បានថ្ងៃរបស់ព្រះជាម្ចាស់ទេ!»
ថ្ងៃនោះនឹងងងឹត មិនមែនភ្លឺទេ
«ការអាក្រក់ នឹងមិនល្អ នឹងមិនកើតឡើងនៅថ្ងៃនោះទេ»។
តើថ្ងៃរបស់ព្រះអម្ចាស់មិនមែនជាថ្ងៃងងឹត ហើយឥតពន្លឺទេឬ?
«ថ្ងៃរបស់ព្រះជាម្ចាស់ពិតជានឹងមិនមែនជាថ្ងៃងងឹត ហើយឥតពន្លឺទេ!» ឬ
«ការអាក្រក់ នឹងមិនល្អ នឹងមិនកើតឡើងនៅថ្ងៃរបស់ព្រះជាម្ចាស់ទេ!»
Amos 5:21
យើងក៏មិនរីករាយនឹងពិធីបុណ្យផ្សេងៗរបស់អ្នករាល់គ្នាទេ
ពាក្យថា «ស្អប់» គឺជាពាក្យដែលមាននឹងពាក្យ «មិនរីករាយ»
ពាក្យទាំងពីរនេះបញ្ជាក់ពីលក្ខណៈនៃការមិនពេញចិត្តរបស់ព្រះជាម្ចាស់ចំពោះពិធីបុណ្យសាសនាផ្សេងៗ។
«យើងមិនរីករាយនឹងពិធីបុណ្យរបស់ជាខ្លាំង»។
Amos 5:23
កងរំពង
សម្លេងមិនរីករាយ។
Amos 5:25
តើអ្នករាល់គ្នាមានយកយញ្ញបូជានឹងតង្វាយផ្សេងៗមកឲ្យយើងដែរឬទេ...អ៊ីស្រាអែល?
អាចមានន័យ ១)
«យើងមិនបានបញ្ជាឲ្យអ្នករាល់គ្នានាំយកយញ្ញបូជាមកឲ្យយើងទេ...អ៊ីស្រាអែល!»
ឬ ២) «វាមិនមែនសម្រាប់យើងទេ
ការដែលអ្នកនាំយកយញ្ញបូជាមកនោះ...អ៊ីស្រាអែល!»
ស្តេចស៊ីគុក និងគីយ៉ូន
ព្រះសាសន៍ដទៃ
ស្តេចគីយ៉ូន
ឬ «ស្តេចគីយ៉ុន»

---

6 [1]វេទនាដល់អស់អ្នកណាដែលរស់ដោយឥតខ្វល់នៅក្រុង ស៊ីយ៉ូន និងអស់អ្នកដែលរស់យ៉ាងសុខសាន្តនៅលើភ្នំសាម៉ារី
ហើយអ្នករាល់គ្នាជាប្រមុខនៃប្រជាជាតិដ៏សំខាន់ជាងគេក្នុងចំណោមប្រជាជាតិទាំងឡាយ ដែលពូជពង្សអ៊ីស្រាអែលយកអ្នករាល់គ្នាជាបង្អែក!
[2]មេដឹកនាំរបស់អ្នករាល់គ្នានិយាយថា «ចូរនាំគ្នាទៅកាល់ណេហើយសង្កេតមើលចុះ ចូរទៅដល់ក្រុងហាម៉ាតដែលជាក្រុងដ៏ធំ រួចចុះទៅក្រុងកាថ ក្នុងស្រុកភីលីស្ទីន។
តើក្រុងទាំងនោះវិសេសជាងនគររបស់អ្នករាល់គ្នាឬ? តើទឹកដីរបស់គេធំជាងទឹកដីរបស់អ្នករាល់គ្នាឬ?»
[3]អ្នករាល់គ្នាចង់ពន្យាពេលកុំឲ្យថ្ងៃមហន្តរាយមកដល់ ហើយបែជាធ្វើឲ្យរាជ្យដ៏ឃោឃៅកាន់តែខិតចូលមកជិត។[4]អ្នករាល់គ្នាដេកនៅលើគ្រែភ្លុក
ហើយទម្រេតខ្លួននៅលើកម្រាលព្រំ។ ព្រមទាំងបរិភោគសាច់ចៀមពីហ្វូងសត្វ និងកូនគោដែលគេបំប៉នទុក។
[5]អ្នករាល់គ្នាច្រៀងចម្រៀងឡូឡាតាមសំឡេងពិណ ហើយបង្កើតគ្រឿងភ្លេងចង់ធ្វើដូចជាស្តេចដាវីឌ។[6]អ្នករាល់គ្នាផឹកស្រាពីចានគោមធំៗ
ហើយលាបខ្លួនដោយប្រេងដ៏មានតម្លៃ តែអ្នករាល់គ្នាមិនព្រួយចំពោះការវិនាសរបស់កូនលោកយ៉ូសែបទេ។
[7]ដូច្នេះហើយគេនឹងនាំអ្នកទៅជាឈ្លើយជាមួយអស់អ្នកដែលជាឈ្លើយមុនគេ ហើយពួកខ្ជិលច្រអូសដូចអ្នករាល់គ្នានឹងលែងស្គាល់ការសប្បាយទៀតហើយ។
[8]«ព្រះអម្ចាស់ជាព្រះនៃពិភពទាំងមូលមានព្រះបន្ទូលយ៉ាងម៉ឺងម៉ាត់ថា យើងស្អប់ខ្ពើមនឹងអំនួតរបស់ពួកកូនចៅយ៉ាកុប យើងស្អប់ប្រាសាទរបស់ពួកគេ។ ហេតុដូច្នេះ
យើងនឹងប្រគល់ទីក្រុង និងរបស់អ្វីៗដែលនៅក្នុងទីក្រុងនេះ ទៅក្នុងកណ្តាប់ដៃរបស់សត្រូវ»។
[9]ប្រសិនបើក្នុងផ្ទះមួយមានមនុស្សដប់នាក់នៅសល់ នោះមុខជាត្រូវស្លាប់ទាំងដប់នាក់។[10]ពេលនរណាម្នាក់យកសាកសពសាច់ញាតិរបស់ខ្លួនចេញពីផ្ទះទៅបូជា
នោះគាត់នឹងស្រែកសួរអ្នកដែលនៅក្នុងផ្ទះថា «តើមាននរណានៅជាមួយអ្នកទៀតទេ?» អ្នកនោះនឹងឆ្លើយមកវិញថា «គ្មានទេ»។ បន្ទាប់មកគាត់នឹងក៏ពោលទៀតថា
«កុំមាត់អី យើងមិនត្រូវលើកពីព្រះនាមព្រះអម្ចាស់ទេ»។
[11]ចូរមើល៍ចុះ ដ្បិតព្រះអម្ចាស់ចេញរាជបញ្ជា នោះផ្ទះដែលធំៗនឹងត្រូវបាក់បែកខ្ទេចខ្ទីអស់ ហើយសូម្បីតែផ្ទះតូចៗក៏ត្រូវបាក់ខ្ទេចខ្ទីអស់ដែរ។
[12]តើសេះបោលនៅលើផ្នាំងថ្មឬ? តើគេយកគោទៅភ្ជួរនៅលើផ្នាំងថ្មឬ? តែអ្នករាល់គ្នាបានធ្វើឲ្យយុត្តិធម៌ប្រែទៅជាពិសពុល ហើយបង្ហូរផលនៃសេចក្តីសុចរិត
ទៅជាល្វីងដូចជាស្លែង។[13]អ្នករាល់គ្នាអរសប្បាយក្នុងក្រុងឡូដាបា ហើយអ្នករាល់គ្នាពោលថា «តើយើងមិនវាយយកបានក្រុងកាណាអ៊ីម
ដោយសារតែកម្លាំងរបស់ខ្លួនយើងទេឬ?»
[14]ប៉ុន្តែមើល៍! ព្រះអម្ចាស់ជាព្រះនៃពិភពទាំងមូល មានព្រះបន្ទូលថា ពូជពង្សអ៊ីស្រាអែលអើយ យើងនឹងធ្វើឲ្យប្រជាជាតិមួយងើបមកទាស់នឹងអ្នករាល់គ្នា។
ពួកគេនឹងធ្វើទុក្ខវេទនាដល់អ្នករាល់គ្នា ចាប់តាំងពីច្រកចូលហាម៉ាត់ រហូតដល់ស្ទឹងអារ៉ាបា»។

Amos 6:1
ឥតខ្វល់ខ្វាយ
ដែលមានផាសុខភាព
និងមិនខ្វល់ខ្វាយពីអ្វីដែលព្រះជាម្ចាស់នឹងវិនិច្ឆ័យដល់ពួកគេឡើយ។
តើក្រុងទាំងនោះវិសេសជាងនគររបស់អ្នករាល់គ្នាឬ?
«ពួកគេលែងវិសេសជាងនគររបស់អ្នករាល់គ្នាហើយ» ។
តើទឹកដីរបស់គេធំជាងទឹកដីរបស់អ្នករាល់គ្នាឬ?
«ទឹកដីរបស់ពួកគេតូចជាងរបស់អ្នកអ្នករាល់គ្នា» ឬ
«ប្រទេសរបស់គេតូចជាងទឹកដីយូដា និងសាម៉ារី»។
Amos 6:3
រាជ្យដ៏ឃោរឃៅកាន់តែខិតចូលមកជិតហើយ
«ចូរប្រព្រឹត្តតាមអ្វីដែលព្រះជាម្ចាស់នឹងនាំមនុស្សឃោរឃៅមកដើម្បីជំនុំជម្រះអ្នក។
រាជ្យដ៏ឃោរឃៅ
«ជារាជ្យនៃសត្រូវដ៏កំណាចឃោរឃៅ»។
ដេក...ទម្រេតខ្លួន
សាសន៍អ៊ីស្រាអែលនៅពេលនោះ
ជាធម្មតាបានហូបខណៈពេលដែលអង្គុយនៅលើកម្រាលក្រណាត់ ឬកៅធម្មតា។
គ្រែភ្លុក
«ជាគ្រែដែលក្រាលដោយភ្លុកដើម្បីធ្វើពួកគេមើលទៅមានលក្ខណៈប្រសើរ» ឬ
«គ្រែដែលថ្លៃថ្នូរ»។
ភ្លុក
ធ្មេញ និងស្នែងរបស់សត្វចតុបាត។
ទម្រេតខ្លួន
«សម្រាកលេងដូចជាមនុស្សដែលគ្មានធ្វើការអ្វីទាំងអស់»។
កម្រាលព្រំ
កន្លែងអង្គុយដែលទន់ល្មើយ ធំគ្រប់គ្រាន់ដើម្បីសម្រាកលេង។
Amos 6:5
ពួកគេបានបង្កើតគ្រឿងភ្លេង

generated on Wed Sep 10 16:16:32 2025

វាអាចមានន័យថា ១)ពួកគេបានបង្កើតចម្រៀងថ្មីៗ និងរបៀបលេងភ្លេង ឬក៏
២)ពួកគេបង្កើតឧបករណ៍ភ្លេងថ្មី។
ចានគោមធំៗ
ជាចានគោមប្រើដើម្បីបម្រើនៅក្នុងព្រះវិហារ
ហើយវាធំជាងចានដែលប្រើដោយមនុស្សនៅពេលញ៉ាំអាហារ។
ពួកគេមិនព្រួយបារម្ភឡើយ
«ពួកគេមិនមានអារម្មណ៍ពិបាកចិត្ត
ហើយមិនប្រព្រឹត្តដូចជាស្រលាញ់អ្នកបានស្លាប់បាត់បង់ជីវិតទៅហើយ»។
Amos 6:7
ព្រះបន្ទូលនៃព្រះនៃពិភពទាំងមូល
សូមប្រែសម្រួលខនេះឲ្យដូចដែលអ្នកបានប្រែនៅក្នុងជំពូក ៣:១៣។
យើងស្អប់ប្រាសាទរបស់ពួកគេ
«យើងមិនរីករាយនឹងប្រជារាស្ត្រអ៊ីស្រាអែល
ដោយសារតែពួកគេជឿជាក់និងគោរពបន្ទាយថាការពារពួកគេជាងគោរពយើង»។
បន្ទាយ
ជាជញ្ជាំងដែលសង់ឡើងជុំវិញទីក្រុងដើម្បីការពារពួកគេពីខ្មាំងសត្រូវ។
Amos 6:9
ពេលនរណាម្នាក់យកសាកសពសាច់ញាតិរបស់ខ្លួនចេញពីផ្ទះទៅបូជា
នោះគាត់នឹងស្រែកសួរអ្នកដែលនៅក្នុងផ្ទះថា «តើមាននរណានៅជាមួយអ្នកទៀតទេ?»
អត្ថន័យនៃពាក្យទាំងនេះគឺមិនច្បាស់ទេ។ ន័យដែលអាចទៅរួចគឺ
១)សាច់ញាតិរបស់ខ្លួន «គឺជាអ្នកណាម្នាក់ដែលនឹង» យកខ្លួនរបស់ពួកគេ
«ហើយបូជា...សាកសព»
ហើយនិយាយទៅកាន់អ្នកណាម្នាក់ដែលបានលាក់ខ្លួននៅក្នុងផ្ទះក្រោយពេលសមាជិកគ្រួសារម្នាក់ស្លាប់
២) សាច់ញាតិរបស់ខ្លួន ដែល «ចូលមកដោយយកខ្លួនរបស់ពួកគេ»
គឺជាបុគ្គលម្នាក់ដែលខុសពី «អ្នកដែលត្រូវបូជា.....សាកសព»
រួចពួកគេបាននិយាយជាមួយគ្នានៅក្នុងផ្ទះ
សាច់ញាតិរបស់ខ្លួនចូលមកដោយយកខ្លួនរបស់គេជាមួយនរណាម្នាក់ដែលនឹងបូជាសាកសព
បើសិនជានៅពេលពួកគេនៅក្នុងផ្ទះ សាច់ញាតិនិយាយទៅកាន់អ្នកបូជាសាកសព
«តើជាអ្នកឬ?»
បូជា
បូជាសាកសព
សាកសព
រាងកាយដែលស្លាប់
Amos 6:11
ចូរមើល៍ចុះ
«សូមស្តាប់» ឬ
«សូមផ្តោតអារម្មណ៍ទៅលើអ្វីដែលយើងនឹងមានបន្ទូលទៅកាន់អ្នករាល់គ្នា»។
ផ្ទះដែលធំៗនឹងត្រូវបាក់បែកខ្ទេចខ្ទីអស់ ហើយសូម្បីតែផ្ទះតូចៗក៏ត្រូវបាក់ខ្ទេចខ្ទីអស់ដែរ
ឃ្លាទាំងពីរនេះមានន័យស្រដៀងនឹងគ្នា។ ន័យផ្ទុយរវាង «ផ្ទះធំ» ហើយ «ផ្ទះតូច»
មានន័យថាការនេះសំដៅទៅលើផ្ទះទាំងអស់។ ន័យដែលអាចទៅរួច ១)
ព្រះជាម្ចាស់នឹងបញ្ជាអ្នកដទៃផ្សេងទៀតដើម្បីកម្ទេចផ្ទះនីមួយៗ ឬ ២)
ព្រះជាម្ចាស់ផ្ទាល់នឹងកម្ចាយផ្ទះនីមួយៗដោយអង្គទ្រង់ផ្ទាល់
ដោយមានបន្ទូលយ៉ាងសាមញ្ញ។
ផ្ទះដែលធំៗនឹងត្រូវបាក់បែកខ្ទេចខ្ទីអស់
«សត្រូវនឹងកម្ទេចផ្ទះធំជាចំណែកៗ»
បាក់ខ្ទេចខ្ទី...ជាចំណែកតូចៗ
អ្នកអាចប្រើពាក្យស្រដៀងគ្នាចំពោះឃ្លាទាំងពីរនេះ។
ផ្ទះតូចនឹងត្រូវបាក់ខ្ទេចខ្ទីជាចម្រៀកៗ
«ផ្ទះតូចនឹងត្រូវបានកម្ទេចជាចំណែកតូចៗ»
Amos 6:12
ព័ត៌មានទូទៅ:
លោកអេមុសបានប្រើសំណួរបំភ្លៃដើម្បីទាញចំណាប់អារម្មណ៍ដើម្បីស្តីបន្ទោសដូចខាងក្រោម:
តើសេះបោលនៅលើថ្នាំងថ្មឬ?
វាមិនអាចទៅរួចទេដែលសេះអាចបោលនៅលើថ្នាំងថ្ម ដោយគ្មានការឈឺចាប់។
លោកអេមុសប្រើសំណួរបំភ្លៃនេះដើម្បីស្តីបន្ទោសដល់ពួកគេចំពោះទង្វើរបស់ពួកគេ។
តើគេយកគោទៅភ្ជួរនៅលើថ្នាំងថ្មឬ?
គោមួយមិនអាចភ្ជួរនៅលើថ្នាំងថ្មបានទេ។ លោកអេមុសប្រើសំណួរបំភ្លៃនេះ
ដើម្បីស្តីបន្ទោសដល់ពួកគេចំពោះទង្វើរបស់ពួកគេ។
តែអ្នករាល់គ្នាបានធ្វើឲ្យយុត្តិធម៌ប្រែទៅជាពិសពុល
ប៉ុន្តែអ្នករាល់គ្នាបានធ្វើឲ្យយុត្តិធម៌ប្រែទៅជាពិសពុល
ហើយបង្វែរផលនៃសេចក្តីសុចរិត ទៅជាល្វីងដូចជាស្លែង
«រួចអ្នកដាក់ពិន័យដល់អស់អ្នកដែលធ្វើអ្វីដែលត្រឹមត្រូវ»។
ក្រុងឡូដាបា...ក្រុងកាណាអ៊ីម
Amos 6:14
សូមមើល៍
«សូមស្តាប់» ឬ
«ផ្តោតអារម្មណ៍ទៅលើអ្វីដែលយើងនឹងមានបន្ទូលប្រាប់អ្នករាល់គ្នា»។
ព្រះបន្ទូលរបស់ព្រះនៃប្រភពទាំងមូល
សូមប្រែសម្រួលខនេះឲ្យដូចអ្វីដែលអ្នកបានប្រែសម្រួលនៅក្នុងជំពូក ៣:១៣។
ចាប់តាំងពីច្រកចូលហាម៉ាត់ រហូតដល់ស្ទឹងអារ៉ាបា
«ចាប់ពីច្រកទ្វារខាងជើងទៅច្រកខាងត្បូងនៃប្រទេសរបស់អ្នករាល់គ្នា»។
បឹងតូច
ជាទន្លេតូចដែលហូរក្នុងអំឡុងរដូវវស្សា។

---

7 [1]នេះគឺជាអ្វីដែលព្រះអម្ចាស់ជាព្រះ បានបង្ហាញដល់ខ្ញុំ។ មើល៍! កាលគេកាត់ស្មៅយកទៅថ្វាយស្តេច ហើយពេលដែលស្មៅកំពុងលូតឡើងសាជាថ្មី
ស្រាប់តែមានហ្វូងកណ្តូបហើរមក។[2]កាលកណ្តូបទាំងនោះបានស៊ីបន្លែអស់ពីស្រុក ខ្ញុំក៏ទូលថា «ព្រះអម្ចាស់ជាព្រះនៃទូលបង្គំអើយ សូមអត់ទោសឲ្យយើងខ្ញុំផង
ដូចដែលយ៉ាកុបរួចជីវិតនោះដែរ? ដ្បិតគេតូចណាស់»។[3]ព្រះអម្ចាស់ប្តូរព្រះហឫទ័យអំពីរឿងនេះ ហើយមានព្រះបន្ទូលថា «ហេតុការណ៍នេះនឹងមិនកើតឡើងទេ»។
[4]ព្រះអម្ចាស់ជាព្រះបានបង្ហាញដល់ខ្ញុំ៖ មើល៍! ព្រះអម្ចាស់បានហៅភ្លើងមកដើម្បីជំនុំជម្រះទោស។ នោះភ្លើងធ្វើឲ្យទឹកនៅទីជម្រៅរីងស្ងួត
ព្រមទាំងធ្វើឲ្យស្រុកទាំងនោះហួតហែង។[5]ពេលនោះ ខ្ញុំទូលព្រះអង្គថា «ព្រះអម្ចាស់ជាព្រះនៃទូលបង្គំអើយ សូមព្រះអង្គឈប់ធ្វើដូច្នេះទៅ
តើធ្វើដូចម្តេចឲ្យយ៉ាកុបរួចជីវិតរស់នៅបាន? ដ្បិតគេតូចណាស់»។[6]ព្រះអម្ចាស់ដូរព្រះហឫទ័យ ហើយមានព្រះបន្ទូលថា «ហេតុការណ៍នេះនឹងមិនកើតឡើងទេ»។
[7]ព្រះជាម្ចាស់បានបង្ហាញដល់ខ្ញុំថា៖ មើល៍ ព្រះអម្ចាស់ឈរនៅលើជញ្ជាំង សង់ដោយខ្សែប្រឡោល ព្រះអង្គកាន់ខ្សែប្រឡោល។[8]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា
«អេម៉ុសអើយ តើអ្នកឃើញអ្វី?» ខ្ញុំក៏ទូលថា «ទូលបង្គំឃើញខ្សែប្រឡោល» បន្ទាប់មកព្រះអម្ចាស់ទូលថា «មើល៍
យើងនឹងឲ្យមានខ្សែប្រឡោលនៅកណ្តាលចំណោមពួកអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង។ ដ្បិតយើងនឹងមិនអធ្យាស្រ័យឲ្យពួកគេទៀតឡើយ។
[9]អស់ទាំងទីខ្ពស់ៗរបស់អីុសាកនឹងត្រូវបំផ្លាញចោល ហើយកន្លែងទីសក្ការៈរបស់អ៊ីស្រាអែលនឹងត្រូវវិនាសដែរ
យើងនឹងក្រោកឡើងទាស់ប្រឆាំងនឹងស្តេចយេរ៉ូបោមដោយមុខដាវ»។
[10]ពេលនោះ លោកអម៉ាស៊ាជាបូជាចារ្យនៅបេតអែល ចាត់គេឲ្យទៅទូលព្រះបាទយេរ៉ូបោម នៃស្តេចអ៊ីស្រាអែលថា «លោកអេម៉ុសកំពុងរួមគំនិតទាស់ប្រឆាំងនឹងព្រះករុណា
នៅកណ្តាលប្រជាជនអ៊ីស្រាអែល។ ទឹកដីទាំងមូលនឹងមិនអាចទ្រាំបាននឹងពាក្យគាត់ឡើយ។[11]ដ្បិតអេម៉ុសបានពោលដូច្នេះថា
ព្រះបាទយេរ៉ូបោមនឹងត្រូវសុគតដោយមុខដាវ ហើយប្រជាជនអ៊ីស្រាអែលនឹងត្រូវនិរទិសចេញពីទឹកដីរបស់ខ្លួន»។
[12]លោកអម៉ាស៊ាក៏ពោលទៅកាន់លោកអេម៉ុសថា «គ្រូ ទាយឆុតអើយ ចូរចេញពីទីនេះហើយរត់ទៅយូដា ហើយរកស៊ីទាយចិញ្ចឹមជីវិតនៅទីនោះចុះ។
[13]កុំទាយនៅត្រង់បេតអែលទៀតអី ដ្បិតទីនេះជាទីសក្ការៈរបស់ស្តេច និងជាដំណាក់ហ្លួង»។
[14]ពេលនោះលោកអេម៉ុសឆ្លើយទៅលោក អម៉ាស៊ាថា «ខ្ញុំមិនមែនជាព្យាការីទេ ហើយក៏មិនមែនជាកូនរបស់ព្យាការីដែរ។ ខ្ញុំគឺជាអ្នកឃ្វាលសត្វ ហើយជាអ្នកបេះផ្លែឧទុម្ពរ។
[15]ប៉ុន្តែព្រះអម្ចាស់បានយកខ្ញុំចេញពីឃ្វាលហ្វូងសត្វ ហើយព្រះអង្គមានព្រះបន្ទូលមកកាន់ខ្ញុំថា ចូរទៅ ថ្លែងព្រះបន្ទូលរបស់យើងដល់ប្រជាជនអ៊ីស្រាអែល។
[16]ដូច្នេះ ចូរលោកស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ឥឡូវនេះចុះ។ លោកប្រាប់ខ្ញុំថា ហើយកុំនិយាយទាស់នឹងជនជាតិអ៊ីស្រាអែល
ហើយកុំនិយាយទាស់ជាមួយនឹងពូជពង្សលោកអ៊ីសាកដែរ។[17]ហេតុនេះ ព្រះអម្ចាស់មានព្រះបន្ទូលថា ប្រពន្ធរបស់លោកនឹងធ្វើជាស្ត្រីពេស្យានៅកណ្តាលទីក្រុង កូនប្រុស

generated on Wed Sep 10 16:16:32 2025

និងកូនស្រីរបស់លោកនឹងត្រូវស្លាប់ដោយមុខដាវ ដីធ្លីរបស់លោកនឹងត្រូវគេវាស់ចែកគ្នា ហើយខ្លួនលោកនឹងត្រូវស្លាប់នៅលើទឹកដីមិនបរិសុទ្ធ
ហើយប្រជាជនអ៊ីស្រាអែលនឹងត្រូវនិរទេសចេញឆ្ងាយពីទឹកដីរបស់ខ្លួន»។

Amos 7:1

សូមមើល សូមមើល

អ្នកនិពន្ធកំពុងប្រាប់អ្នកអានថា គាត់នឹងនិយាយអ្វីដែលភ្ញាក់ផ្អើល។
ភាសារបស់អ្នកវាល់គ្នានឹងមានវិធីមួយចំពោះការនេះ។

តើលោកយ៉ាកុបនឹងរួចជីវិតដោយរបៀបណា?

«លោកយ៉ាកុបមិនអាចមានជីវិតរបស់បានទេ»។

Amos 7:4

សូមមើល

អ្នកនិពន្ធកំពុងប្រាប់អ្នកអានថា គាត់នឹងនិយាយអ្វីដែលភ្ញាក់ផ្អើល។
ភាសារបស់អ្នកវាល់គ្នានឹងមានវិធីមួយចំពោះការនេះ។

តើលោកយ៉ាកុបនឹងរួចជីវិតដោយរបៀបណា?

«លោកយ៉ាកុបនឹងច្បាស់ជាមិនមានជីវិតរស់ទេ!» ឬ
«សូមប្រាប់លោកយ៉ាកុបពីអ្វីដែលគាត់ត្រូវធ្វើ ដូច្នេះគាត់អាចនឹងមានជីវិតរស់!»

Amos 7:7

ខ្សែប្រយោល

ខ្សែពួរស្តើងដែលមានទង់នៅខាងចុងត្រូវបានប្រើនៅក្នុងអគារដើម្បីឲ្យប្រាកដថាជញ្ជាំងត្រង់ឬមិនទេ។ ទង់ដែលមានរូបខ្សែពួរនៅលើវាត្រូវបានហៅថា «ទង់ខ្សែពួរ» ឬ «ទង់ប្លាមាប» ក្នុងភាសាខ្លះ
និងក្រោម។

Amos 7:9

អ៊ីសាក...អ៊ីស្រាអែល

ប្រជារាស្ត្រដែលនៅអណាចក្រខាងជើងនៃប្រទេសអ៊ីស្រាអែល។

Amos 7:10

បូជាចារ្យ

ន័យដែលអាចទៅរួច ១) លោកអម៉ាស៊ា គឺជាបូជាចារ្យតែម្នាក់គត់នៅបេតអែល ឬ
២) លោកអម៉ាស៊ាគឺជាអ្នកដឹកនាំរបស់ពួកបូជាចារ្យនៅបេតអែល។

លោកអេម៉ុសកំពុងរួមគំនិតទាស់ប្រឆាំងនឹងព្រះករុណា នៅកណ្តាលប្រជាជនអ៊ីស្រាអែល

«លោកអេម៉ុសនៅទីនេះក្នុងទឹកដីរបស់អ៊ីស្រាអែល
ហើយទ្រង់កំពុងមានគម្រោងដើម្បីធ្វើការអាក្រក់ដាក់អ្នករាល់គ្នា»។

ទឹកដីទាំងមូលនឹងមិនអាចទ្រាំបាននឹងពាក្យគាត់ឡើយ

«ប្រជារាស្ត្រប្រហែលជាជឿគាត់ បន្ទាប់មកធ្វើអ្វីដែលបំផ្លាញមនុស្សជាតិ»។

Amos 7:12

រកស៊ីទាយចិញ្ចឹមជីវិតនៅទីនោះចុះ

«ឃើញទេអ្នកអាចនាំប្រជារាស្ត្រមកទីនោះដើម្បីឲ្យអ្នករាល់គ្នា»។

Amos 7:14

អ្នកគង្វាលសត្វ

នៅទីនេះប្រហែលមានន័យថា «អ្នកដែលអាចមើលថែចៀម»
ដែលមានន័យថា «អ្នកដែលអាចមើលថែចៀម» នៅក្នុងជំពូក ១:១។

Amos 7:16

ទឹកដីមិនបរិសុទ្ធ

ឃ្លានេះសំដៅទៅលើទឹកដីបរទេសដែលជាទីដែលមនុស្សមិនទទួលស្គាល់ព្រះជាម្ចាស់។

---

8 [1]នេះគឺជាអ្វីដែលព្រះអម្ចាស់ជាព្រះបានបង្ហាញខ្ញុំ។ មើល៍! មានកន្ត្រក់មួយពេញដោយផ្លែឈើនៅរដូវក្តៅ![2]ព្រះអង្គមានព្រះបន្ទូលថា «អេម៉ុសអើយ តើអ្នកឃើញអ្វី?»
ខ្ញុំក៏ទូលទៅព្រះអង្គថា «មានកន្ត្រក់មួយពេញដោយផ្លែឈើនៅរដូវក្តៅ»។ រួចព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ចុងបញ្ចប់បានមកដល់ប្រជាជនអ៊ីស្រាអែល
ដែលជារាស្ត្ររបស់យើង យើងនឹងមិនអធ្យាស្រ័យឲ្យគេទៀតទេ។[3]នៅថ្ងៃនោះ បទចម្រៀងដែលច្រៀងនៅក្នុងវិហារហ្លួង និងត្រឡប់ជាសម្រែកទ្រហោយំ
មានសាកសពជាច្រើននឹងត្រូវគេបោះចោលនៅកន្លែងស្ងាត់ជ្រងំគ្រប់ទីកន្លែង!» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[4]ចូរស្តាប់ចុះ អស់អ្នកណាដែលជិះជាន់មនុស្សកម្សត់ ហើយធ្វើឲ្យអ្នកក្រីក្រចេញពីទឹកដី។[5]ពួកគេនិយាយថា «តើពេលណាទើបផុតបុណ្យចូលខែថ្មី
ដើម្បីឲ្យយើងបានលក់ស្រូវ? តើពេលណាទើបផុតបុណ្យសប្ប័ទ ដើម្បីឲ្យយើងបានលក់ភោជ្ជសាលី? យើងនឹងបង្រួមរង្វាស់ឲ្យតូចហើយដំឡើងថ្លៃ
ព្រមទាំងកេងប្រវ័ញ្ចគេដោយបំបាត់ភ្នែកជញ្ជីងទៀតផង។[6]អ្នករាល់គ្នាបានទិញមនុស្សក្រីក្រដោយប្រាក់ និងមនុស្សកម្សត់ ដោយស្បែកជើងមួយគូរ
សូម្បីតែអង្កាមក៏អ្នករាល់គ្នាលក់ដែរ»។
[7]ព្រះអម្ចាស់បានស្បថដោយអំនួតរបស់លោកយ៉ាកុបថា «ប្រាកដណាស់ យើងនឹងមិនភ្លេចអំពើអាក្រក់ណាមួយដែលគេបានប្រព្រឹត្តឡើយ»។[8]តើនឹងមិនមានរំញ្ជួយផែនដី
ហើយគ្រប់គ្នាដែលរស់នៅលើផែនដី តើមិនកាន់ទុក្ខទេឬ? ផែនដីទាំងមូលនឹងកក្រើកឡើងដូចជាទន្លេនីល រួចក៏ស្រប់ទៅវិញ
ដូចទន្លេនៅអេស៊ីបដែលជន់ឡើងរួចក៏ស្រកទៅវិញ។
[9]ការទាំងនោះនឹងកើតឡើងនៅពេលថ្ងៃ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ យើងនឹងធ្វើឲ្យមានព្រះអាទិត្យលេចបាត់ នៅពេលថ្ងៃត្រង់
ហើយធ្វើឲ្យផែនដីងងឹតសូន្យនៅពេលមេឃស្រឡះ[10]យើងនឹងធ្វើឲ្យពិធីបុណ្យរបស់អ្នក ត្រឡប់ទៅជាពិធីកាន់ទុក្ខ ហើយបទចម្រៀងរបស់អ្នក
ត្រឡប់ទៅជាពាក្យទំនួញវិញ។ យើងនឹងធ្វើឲ្យអ្នករាល់គ្នាស្លៀកពាក់កាន់ទុក្ខ និងកោសក់ផង។ យើងនឹងធ្វើឲ្យមានការកាន់ទុក្ខ ដូចគេកាត់ទុក្ខកូនតែមួយ
ហើយនៅថ្ងៃចុងបញ្ចប់អ្នករាល់គ្នាស្គាល់តែភាពល្វីងជូរចត់។
[11]ព្រះអម្ចាស់ ជាព្រះមានព្រះបន្ទូលថា មើល៍! ថ្ងៃនោះនឹងមកដល់ យើងនឹងបញ្ជូនការអត់ឃ្លានឲ្យដល់ទឹកដីអ្នក មិនមែនជាការអត់ឃ្លានខាងអាហារ ឬស្រែកទឹកនោះទេ
គឺជាការស្រែកឃ្លានដែលមិនបានឮព្រះបន្ទូលរបស់ព្រះអម្ចាស់។[12]ពួកគេនឹងដើរចុះឡើងពីសមុទ្រម្ខាងទៅសមុទ្រម្ខាង ហើយនឹងរត់ពីទិសខាងជើង រហូតដល់ទិសខាងកើត
ដើម្បីស្វែងរកព្រះបន្ទូលនៃព្រះអម្ចាស់ តែពួកគេរកមិនឃើញឡើយ។
[13]នៅថ្ងៃនោះ ក្រមុំស្អាតៗ និងកំលោះៗនឹងអស់កម្លាំងដោយសារស្រែកទឹក។[14]អស់អ្នកដែលស្បថដោយអំពើបាបរបស់សាម៉ារី
នោះគេនឹងដួលស្លាប់ហើយក្រោកឡើងវិញមិនរួចឡើយ»។

Amos 8:1

សូមមើល

អ្នកនិពន្ធកំពុងប្រាប់អ្នកអានថា គាត់នឹងនិយាយអ្វីដែលភ្ញាក់ផ្អើល។
ភាសារបស់អ្នកវាល់គ្នានឹងមានវិធីមួយចំពោះការនេះ។

ព្រះបន្ទូលរបស់ព្រះនៃប្រភពទាំងមូល

សូមប្រែសម្រួលខនេះឲ្យដូចអ្វីដែលអ្នកបានប្រែសម្រួលនៅក្នុងជំពូក ៣:១៣។

នៅគ្រប់ទីកន្លែង

«នៅកន្លែងជាច្រើន»។

Amos 8:4

អស់អ្នកណាដែលជិះជាន់...បណ្តេញអ្នកក្រចេញ

លោកអេម៉ុសកំពុងនិយាយទៅកាន់អ្នកដែល «លក់» និង «ទីផ្សារ»។

ជិះជាន់

សូមមើលពីរបៀបដែលអ្នកប្រែសម្រួលនៅក្នុងខនេះ នៅក្នុងជំពូក ២ ខ៧។

ពួកគេនិយាយថា «តើពេលណាទើបផុតបុណ្យចូលខែថ្មី ដើម្បីឲ្យយើងបានលក់ស្រូវ?
តើពេលណាទើបផុតបុណ្យសប្ប័ទ ដើម្បីឲ្យយើងបានលក់ភោជ្ជសាលី?»

«ពួកគេតែងតែសួរថា នៅពេលណាផុតបុណ្យចូលខែថ្មី
ដូច្នេះពួកគេអាចលក់ដូរម្តងទៀតបាន ហើយនៅពេលណាថ្ងៃបុណ្យសប្ប័ទផុតទៅ
ដូច្នេះ ពួកគេអាចលក់ភោជ្ជសាលី»។

យើងនឹងបង្រួមរង្វាស់ឲ្យតូចហើយដំឡើងថ្លៃ

ព្រមទាំងកេងប្រវ័ញ្ចគេដោយបំបាត់ភ្នែកជញ្ជីងទៀតផង

ពាណិជ្ជករនឹងប្រើភ្នែកជញ្ជីងក្លែងក្លាយដើម្បីបង្ហាញថាចំនួននៃគ្រាប់ធញ្ញជាតិដែលពួកគេកំពុងលក់នោះ
ហើយចំនួននៃការចំណាយតិចជាងហ្នឹងទៀត។

មនុស្សកម្សត់ ដោយស្បែកជើងមួយគូ

«ហើយទិញមនុស្សកម្សត់ ដោយស្បែកជើងមួយគូ»។

generated on Wed Sep 10 16:16:32 2025

Amos 8:7
ព្រះអម្ចាស់បានស្បថដោយអំនួតរបស់លោកយ៉ាកុប
«ព្រះអម្ចាស់បានស្បថដោយអង្គទ្រង់ដោយបន្ទូល» ឬ
«ព្រះអម្ចាស់ដែលជាព្រះរបស់លោកយ៉ាកុបដែលមានអំនួតបានស្បថ»។
ទន្លេនៅអេស៊ីប
ជាឈ្មោះផ្សេងមួយទៀតរបស់ទន្លេនីល។
Amos 8:9
ព្រះបន្ទូលរបស់ព្រះនៃប្រភពទាំងមូល
សូមប្រែសម្រួលខនេះឲ្យដូចអ្វីដែលអ្នកបានប្រែសម្រួលនៅក្នុងជំពូក ៣:១៣។
Amos 8:11
ព្រះបន្ទូលរបស់ព្រះនៃប្រភពទាំងមូល
សូមប្រែសម្រួលខនេះឲ្យដូចអ្វីដែលអ្នកបានប្រែសម្រួលនៅក្នុងជំពូក ៣:១៣។
ពួកគេនឹងដើរចុះឡើង...ហើយនឹងរត់
មានអ្នកខ្លះនឹងដើរយឺតៗ ហើយងាយនឹងដួលចុះ
ដូចជាមនុស្សម្នាក់ដែលកំពុងស្រេកឃ្លាន ចំណែក អ្នកដទៃទៀតដែលនៅទីនេះ
និងទីនោះនឹងដើរយ៉ាងលឿន។
ពីសមុទ្រម្ខាងទៅសមុទ្រម្ខាង
ពួកគេនឹងរត់ចេញពីទិសខាងជើងទៅទិសខាងកើតដើម្បីស្វែងរកព្រះបន្ទូលរបស់ព្រះអង្គ
ន័យដែលអាចទៅរួច ១) សូមមើល UDB ២)
«ពីសមុទ្រម្ខាងទៅសមុទ្រម្ខាងចេញពីទិសខាងជើងទៅទិសខាងកើត។
ពួកគេនឹងរត់ដើម្បីស្វែងរកព្រះបន្ទូលរបស់ព្រះជាម្ចាស់»។
ពីសមុទ្រម្ខាងទៅសមុទ្រម្ខាង...ពីទិសខាងជើងទៅទិសខាងកើត
ដោយសារតែបុគ្គលម្នាក់ឈរនៅបេតអែល នេះអាចជារង្វង់មួយ។
ទន្លេនៃសេចក្តីស្លាប់ (ខាងត្បូង) ទៅសមុទ្រឬមេឌីទែរ៉ាណេ (ខាងលិច)
ទៅទិសខាងកើត។
Amos 8:13
អស់កម្លាំង
បាត់បង់ថាមពលរបស់ពួកគេ។
សោយសារតែផ្លូវទៅបៀស៊ីបានៅមាន
នេះប្រហែលជាសេចក្តីយោងមួយចំពោះផ្លូវដែលអ្នកធម្មយាត្រាអាចនឹងដើរទៅបៀស៊ីបាដើម្បីថ្វាយបង្គំគរ

9 [1]ខ្ញុំបានឃើញព្រះអម្ចាស់ឈរនៅក្បែរអាសនា ហើយព្រះអង្គមានព្រះបន្ទូលថា៖ «ចូរវាយក្បាលសសរឲ្យកក្រើក រហូតដល់ជើងសសរ។
ហើយកិនកំទេចមេដឹកនាំរបស់ពួកគេទាំងអស់ រួចអស់អ្នកដែលនៅសល់យើងនឹងសម្លាប់ពួកគេដោយមុខដាវ។ គ្មាននរណាម្នាក់អាចរត់ចេញ
ហើយក៏គ្មាននរណាម្នាក់គេចផុតបានឡើយ។[2]ទោះបើគេជីកទម្លុះទៅដល់ស្ថានមនុស្សស្លាប់ក៏ដោយ ក៏ដៃរបស់យើងនឹងអូសយកមកវិញ។
ហើយទោះបើគេប្រឹងឡើងទៅដល់ស្ថានសួគ៌ ក៏យើងទាញទម្លាក់មកវិញដែរ។
[3]ទោះបើពួកគេទៅពួននៅលើកំពូលភ្នំកើមែលក៏ដោយ ក៏យើងនឹងរកពួកគេហើយចាប់យកមកវិញ។ ទោះបើពួកគេលាក់ខ្លួនពីភ្នែករបស់យើងដល់បាតសមុទ្រក៏ដោយ
ក៏យើងប្រើពស់ឲ្យទៅខាំពួកគេដែរ។[4]ទោះបើពួកគេត្រូវចាប់ទៅជាឈ្លើយនៅពីមុខខ្មាំងសត្រូវ ក៏យើងនឹងបញ្ជាដាវឲ្យទៅតាមសម្លាប់ពួកគេដែរ។
យើងនឹងតាមមើលពួកគេដើម្បីឲ្យពួកគេវេទនា ហើយមិនឲ្យពួកគេមានក្តីសុខឡើយ»។
[5]ព្រះអម្ចាស់ជាព្រះនៃពិភពទាំងមូលបានពាល់ផែនដី ហើយផែនដីក៏រញ្ជួយ និងអ្នកដែលនៅផែនដីក៏នាំគ្នាសោកសៅកាន់ទុក្ខ ផែនដីទាំងមូលនឹងកក្រើកឡើងដូចទឹកទន្លេ
ហើយក៏ស្ងប់ទៅវិញដូចជាទន្លេដែលនៅអេស៊ីប។[6]ព្រះអង្គសង់ព្រះដំណាក់ដ៏ខ្ពស់នៅលើស្ថានសួគ៌ ហើយព្រះអង្គដាក់លំហអាកាសនៅពីលើផែនដី។
ព្រះអង្គហៅទឹកសមុទ្រហើយចាក់ស្រោចស្រពមកលើផែនដី ព្រះអង្គមានព្រះនាមថា ព្រះអម្ចាស់។
[7]កូនចៅអ៊ីស្រាអែលអើយ តើយើងមិនចាត់ទុកអ្នកដូចជាជនជាតិអេត្យូពី ទេឬអី? នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់។
តើមិនមែនជាយើងដែលបាននាំជនជាតិអ៊ីស្រាអែលចេញពីអេស៊ីប និងពួកភីលីស្ទីនចេញពីកាប់ថោរ ព្រមទាំងនាំជនជាតិស៊ីរីចេញពីគៀរទេឬ?[8]មើល៍!
ព្រះនេត្រនៃព្រះអម្ចាស់នឹងទតមើលនគរដែលមានបាប ហើយនឹងបំផ្លាញនគរនេះឲ្យវិនាសបាត់ពីផែនដី ប៉ុន្តែយើងនឹងមិនបំផ្លាញកូនចៅលោកយ៉ាកុបទាំងអស់ទេ
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[9]មើល៍! យើងនឹងបញ្ជាហើយរែងពូជពង្សអ៊ីស្រាអែលក្នុងចំណោមប្រជាជាតិទាំងអស់ ដូចគេរែងអង្ករនៅក្នុងកញ្រែង តែមិនមានគ្រាប់ថ្មតូចណាមួយធ្លាក់ដល់ដីឡើយ។
[10]អស់មនុស្សដែលមានបាបក្នុងប្រជារាស្ត្ររបស់យើងនឹងត្រូវស្លាប់ដោយមុខដាវ អ្នកទាំងនោះពោលថា ទុក្ខវេទនានឹងមិនចូលមកជិត ឬកើតមានដល់ពួកយើងឡើយ។
[11]នៅថ្ងៃនោះ យើងនឹងលើកទីលំនៅរបស់ដាវីឌដែលបាន ដួលរលំនោះឡើងវិញ និងជួសជុលកន្លែងធ្លុះធ្លាយឲ្យជិត។ យើងនឹងលើកកន្លែងដែលខូចបង់ឡើង
ហើយសង់ខ្ទមនោះឲ្យបានល្អដូចដើមវិញ។[12]ដើម្បីឲ្យជនជាតិអ៊ីស្រាអែលចាប់យកអេដុមដែលនៅសល់ និងទឹកដីបស់ប្រជាជាតិទាំងអស់
ដែលជាកម្មសិទ្ធរបស់យើងកាលពីដើម នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ ដែលព្រះអង្គបានធ្វើការទាំងនេះ។
[13]ព្រះអម្ចាស់មានព្រះបន្ទូលថា មើល៍! ថ្ងៃនោះជិតមកដល់ហើយ កាលណាគេច្រូតស្រូវរួចរាល់ហើយនោះអ្នកភ្ជួររាស់នឹងមកភ្ជួរភ្លាម
ហើយអ្នកដែលជាន់ផ្លែទំពាំងបាយជូរនឹងតាមទាន់អ្នកដែលសាបព្រោះពូជ។ ទឹកទំពាំងបាយជូរនឹងហូរស្រក់តាមភ្នំធំៗ ហើយអស់ទាំងភ្នំតូចៗ ក៏នឹងហូរមកដែរ។
[14]យើងនឹងនាំប្រជាជនអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើងដែលជាប់ជាឈ្លើយឲ្យមកវិញ។ ពួកគេនឹងសង់ទីក្រុងដែលខូចទាំងប៉ុន្មានឡើងវិញដើម្បីស្នាក់នៅ
ពួកគេនឹងដាំទំពាំងបាយជូរ ហើយផឹកស្រាពីចម្ការទំពាំងបាយជូរនោះ ពួកគេធ្វើចម្ការហើយក៏បរិភោគផលផ្លែពីចម្ការនោះដែរ។
[15]យើងនឹងឲ្យពួកគេរស់នៅលើទឹកដីរបស់ខ្លួន ហើយគ្មាននរណាអាច បណ្តេញពួកគេចេញពីទឹកដី ដែលយើងបានប្រគល់ឲ្យទៅពួកគេបានឡើយ»
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។

Amos 9:1
បំបែកពួកគេ
ន័យដែលអាចទៅរួច ១) បំបែកវិហារជាចំណែកតូចៗ ឬ ២)
បំបែកពីចុងកំពូលនៃសរសរទាំងអស់
ទោះបើគេជីកទម្លុះទៅដល់ស្ថានមនុស្សស្លាប់ក៏ដោយ ក៏ដៃរបស់យើងនឹងអូសយកមកវិញ។
ហើយទោះបើគេប្រឹងឡើងទៅដល់ស្ថានសួគ៌ ក៏យើងទាញទម្លាក់មកវិញដែរ
«មិនថាកន្លែងណាដែលពួកគេព្យាយាមទៅ
យើងនឹងគង់នៅទីនោះដើម្បីចាប់ពួកគេ»។
Amos 9:3
សត្វពស់
ជាសត្វសមុទ្រកំណាចឃោរឃៅដែលមិនស្គាល់
មិនមែនពស់ដែលនៅក្នុងសួនអេដែន ហើយមិនមែនជាពស់ធម្មតា។
យើងនឹងតាមមើលពួកគេ
បើសិនជាភាសារបស់អ្នកមានពាក្យដែលមានន័យជាធម្មតាថា
អ្នកនិយាយចង់ធ្វើការល្អសម្រាប់អ្នកដទៃ ប៉ុន្តែ
ក៏អាចត្រូវបានគេប្រើនៅពេលដែលនិយាយចង់ធ្វើបាបពួកគេផងដែរ
អ្នកប្រហែលជាចង់ប្រើវានៅទីនេះដែរ។
មិនមែនដើម្បីការល្អទេ
ពាក្យទាំងនោះត្រូវប្រាកដថាអ្នកស្តាប់យល់ពីពាក្យថា «ដើម្បីធ្វើបាបពួកគេ»។
Amos 9:5
ព្រះអង្គសង់ព្រះដំណាក់ដ៏ខ្ពស់នៅលើស្ថានសួគ៌
ការទាំងនេះដំណាក់ដែលមនុស្សជំនាន់ដើមស្រមើលស្រមៃចង់ទៅរាជ្យវាំងរបស់ព្រះជាម្ចាស់នៅក្នុងស្ថាន
ទោះបីជាយ៉ាងណា
ការបកស្រាយតាមបែបទំនើបខ្លះៗចង់អានអត្ថន័យនៃនៅក្នុងគម្ពីរហេព្រើរមួយគឺ
«រាជ្យវាំង» ឬ «បន្ទប់» នៅទីនេះ «ដំណាក់របស់ព្រះជាម្ចាស់»
ប្រហែលជាបម្រើជាការប្រៀបសម្រាប់រាជ្យវាំងរបស់ព្រះជាម្ចាស់។
ហើយព្រះអង្គដាក់លំហអាកាសនៅពីលើផែនដី
នៅក្នុងការប្រែសម្រួលថ្មីបកប្រែថា «ទ្រង់បានបង្កើតការគាំទ្រនៅលើផែនដី»
គឺជារចនាសម្ព័ន្ធដែលផែនដីសម្រាក។
Amos 9:7
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
សូមប្រែសម្រួលឃ្លានេះឲ្យដូចការដែលអ្នកបានប្រែនៅក្នុងជំពូក ២:១១។
Amos 9:9
គេរែងអង្ករនៅក្នុងកញ្រែង តែមិនមានគ្រាប់ថ្មតូចណាមួយធ្លាក់ដល់ដីឡើយ។

generated on Wed Sep 10 16:16:32 2025

រូបភាពនៅទីនេះគឺដូចជាអង្ករដែលធ្លាក់ចូលទៅក្នុងកញ្ច្រែង
ហើយមិនមានគ្រាប់ថ្មតូចៗណាមួយទេ។ របកគំហើញថ្មីខ្លះយល់ថា
«មិនមានគ្រាប់ថ្មតូចៗនៅក្នុងកញ្ច្រែងទេ»
មានន័យថាគ្រាប់អង្ករដែលល្អនឹងមិនធ្លាក់ចូលទៅក្នុងកញ្ច្រែងជាមួយនឹងសម្ភារដែលគេប្រើដើម្បីធ្វើ
កញ្ច្រែង
ផ្នែកមុខមួយដែលប្រហោងជាច្រើនដែលអាចឲ្យរបស់អ្វីដែលតូចៗអាចឆ្លងកាត់បាន
ហើយរបស់ដែលធំៗមិនបានចេញបានទេ។
Amos 9:11
តង់សំណាក់...កន្លែងធ្លុះធ្លាយ...ការខូចបង់
ក្រោយពេលដែលព្រះជាម្ចាស់បំផ្លាញអាណាចក្រអ៊ីស្រាអែល
វានឹងមានរាងដូចជាតង់នឹងបាក់ធ្លាក់ចុះ
ជញ្ជាំងនឹងដួលប្រេះស្រាំនៅតាមកន្លែងមួយចំនួន ហើយផ្ទះនឹងត្រូវធ្លុះធ្លាយ។
កន្លែងធ្លុះធ្លាយ
ជាផ្នែកនៃជញ្ជាំងមួយចំនួនបានធ្លាក់បាក់ចុះ
ការខូចបង់
ជាអ្វីដែលនៅសេសសល់ នៅពេលដែលអគារត្រូវបានបំផ្លាញ។
ផ្នែកសេសសល់នៃក្រុងអេដុម
មិនថាជាផ្នែកដែលណាមួយនៃអ៊ីស្រាអែលដែលត្រូវបានគេលុកលុយ
ស្រុកឲ្យមានភរិយា
ស្ត្រីនៅស្រុកអេដុមនោះទេ។
Amos 9:13
សូមមើល
អ្នកនិពន្ធកំពុងប្រាប់អ្នកអានថា គាត់នឹងនិយាយអ្វីដែលភ្ញាក់ផ្អើល។
ភាសារបស់អ្នកវាល់គ្នានឹងមានវិធីមួយចំពោះការនេះ។
ទឹកទំពាំងបាយជូរនឹងហូរស្រក់តាមភ្នំធំៗ ហើយអស់ទាំងភ្នំតូចៗ ក៏នឹងហូរមកដែរ
ឃ្លាទាំងពីរនេះមានន័យស្រដៀងគ្នា
ហើយបញ្ជាក់ថាទឹកដីនោះនឹងត្រូវបង្កើតផលផ្លែ។
Amos 9:14
គ្មាននរណាអាច បណ្តេញពួកគេចេញពីទឹកដីបានទេ
«គ្មាននរណាម្នាក់អាចនឹងបណ្តេញពួកគេចេញពីទឹកបានទេ»។
«ពួកគេនឹងរស់នៅលើទឹកដីនោះជារៀងរហូតដូចជារុក្ខជាតិដែលរក្សាឫសនៅក្នុងដី»។

អូបាឌា

1 [1]នេះជានិមិត្តរបស់ព្យាការីអូបាឌា។ ព្រះអម្ចាស់ដ៏ជាព្រះ មានព្រះបន្ទូល ពីដំណើរជនជាតិអេដុមដូច្នេះថា៖ ពួកយើងបានឮដំណឹងមកពីព្រះអម្ចាស់ ព្រះអង្គបានចាត់អ្នក
នាំពាក្យម្នាក់ ឲ្យទៅក្នុងចំណោមជនជាតិទាំងឡាយថាចូរក្រោកឡើង! «ចូរក្រោកឡើង! ចូរនាំគ្នាយើងលើកគ្នាទៅច្បាំងនឹងគេ!»[2]មើល៍ យើងនឹងធ្វើឲ្យអ្នកក្លាយជានគរ
មួយតូចជាងគេក្នុងចំណោមនគរទាំងប៉ុន្មាន អ្នកនឹងត្រូវបានគេប្រមាថមាក់ងាយយ៉ាងខ្លាំង។
[3]ចិត្តអំនួតរបស់អ្នកបានបញ្ឆោតអ្នកហើយ អ្នកដែលរស់នៅតាមក្រហែងថ្ម ហើយមានទីលំនៅតាមកន្លែងខ្ពស់ៗ អ្នកគិតក្នុងចិត្តថា «តើអ្នកណាអាចទម្លាក់ខ្ញុំចុះដល់ដី
បាន?»[4]អ្នកគិតថានឹងហើរឡើងទៅយ៉ាងខ្ពស់ ដូចឥន្ទ្រី ហើយធ្វើសម្បុកនៅកណ្តាលអស់ទាំងផ្កាយក៏ដោយក៏យើងនឹងទាញទម្លាក់ពីទីនោះដែរ នេះជាព្រះបន្ទូលរបស់
ព្រះអម្ចាស់។
[5]បើមានពួកចោរមកលួចអ្នក ហើយបើពួកចោរប្លន់ចូលមកនៅពេលយប់ (តើអ្នកនឹងបាត់បង់អ្វីខ្លះ!) តើចោរមិនត្រឹមតែលួចឲ្យល្មមសម្រាប់ខ្លួនពួកគេទេ? ប្រសិនបើពួកបេះ
ផ្លែទំពាំងបាយជូរ មកដល់ទឹកដីអ្នកតើគេមិនទុកផ្លែខ្លះឲ្យបានបេះតាមក្រោយទេឬ?[6]តើអេសាវមិនត្រូវបានគេគាស់កកាយហើយប្រមូលយកកំណប់ទ្រព្យទេរឺ!
[7]អស់ទាំងសម្ព័ន្ធមិត្តរបស់អ្នកបានបញ្ឆោតអ្នកគេបានបណ្តេញអ្នករហូតដល់ព្រំដែន។ មនុស្សដែលចងស្ពានមេត្រីជាមួយអ្នក បោកបញ្ឆោតអ្នក
និងបាននាំគ្រោះប្រឆាំងនិងអ្នក។ ពួកគេដែលចង់បានបរិភោគអាហាររបានដាក់អន្ទាក់ចាប់អ្នក ។ដោយព្រោះអ្នកគ្មានការយល់ដឹងអ្វីឡើយ។
[8]«តើយើងគួរមិនធ្វើទេនៅថ្ងៃនោះ» គឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ «យើងនឹងបំផ្លាញពួកអ្នកប្រាជ្ញឲ្យអស់ពីទឹកដីអេដុម ហើយអ្នកចេះដឹងឲ្យអស់ពីទឹកដីភ្នំរបស់
អេសាវ?»[9] មនុស្សខ្លាំងពូកែរបស់អ្នកនឹងត្រូវញាប់ញ័រចម៉ាន ដើម្បីឲ្យគ្រប់គ្នាត្រូវកាត់ចេញពីភ្នំរបស់អេសាវដោយសម្លាប់រង្គាល។
[10]ដោយព្រោះអ្នកបានធ្វើអំពើដ៏ឃោរឃៅចំពោះប្អូនប្រុសយ៉ាកុប នោះអ្នកនិងមានពេញដោយសេចក្តីខ្មាសអៀន ហើយអ្នកនឹងត្រូវកាត់ចេញជារៀងរហូត។[11]នៅថ្ងៃដែល
អ្នកបានឈរមើលពីចំងាយ នៅថ្ងៃដែលពួកប្រទេសក្រៅបានចាប់យក ទ្រព្យសម្បត្តិរបស់គេទៅ ហើយជនជាតិដទៃចូលទៅក្នុងទ្វារក្រុងរបស់គេ រួចចាប់ឆ្នោតយកក្រុង
យេរូសាឡិម នោះអ្នកក៏ដូចជាពួកគេអច្នឹងដែល។
[12]ប៉ុន្តែ អ្នកមិនគួរព្រងើយកន្តើយរមើលប្អូនរបស់អ្នក ក្នុងថ្ងៃដែលគេជួបទុក្ខវេទនាឡើយ ក៏មិនគួរមានចិត្តរីករាយនឹងប្រជាជនយូដា នៅថ្ងៃដែលគេត្រូវបំផ្លាញនោះដែរ អ្នក
មិនគួរអួតខ្លួននៅថ្ងៃដែលគេមានភាពតានតឹងឡើយ។[13]អ្នកមិនគួរចូលទៅក្នុងទ្វារក្រុងរបស់ប្រជារាស្ត្ររបស់យើងក្នុងគ្រាមហន្តរាយទេ ។ អ្នកមិនគួរនាំគ្នាឈរមើលទាំង
ត្រេកអរ នឹងគេក្នុងថ្ងៃដែលគេរងទុក្ខឡើយ។ នៅថ្ងៃដែលគេជួបមហន្តរាយ អ្នកមិនគួរឆ្លៀតលួចយកទ្រព្យសម្បត្តិរបស់គេសោះ។[14]អ្នកមិនគួរឈរស្កាត់នៅត្រង់ផ្លូវបំបែក
ដើម្បីសម្លាប់ជនភៀសខ្លួន ក៏មិនគួរធ្វើអាក្រក់ដល់អ្នកដែលនៅមានជីវិតរស់ក្នុងទុក្ខលំបាកឡើយ។
[15]ដ្បិតថ្ងៃរបស់ព្រះអម្ចាស់នៅជិតបង្កើយ ដើម្បីទាស់នឹងអស់ទាំងជនជាតិ។ អ្នកបានប្រព្រឹត្តយ៉ាងណា ព្រះក៏នឹងប្រព្រឹត្តចំពោះអ្នកយ៉ាងនោះដែរ អំពើដែលអ្នកបានប្រព្រឹត្ត
នោះនឹងធ្លាក់មកលើក្បាលអ្នកវិញ។[16]ដ្បិតដែលអ្នកបានផឹកស្រវឹងនៅលើភ្នំបរិសុទ្ធរបស់យើងជាយ៉ាងណា អស់ទាំងជនជាតិនៅជុំវិញអ្នកក៏នឹងបន្តផឹកយ៉ាងនោះដែរ
ពួកគេនឹងផឹក ហើយគេនឹងលេបចូលទៅ រួចគេនឹងវិនាសសូន្យទៅ។
[17]ប៉ុន្តែនៅលើភ្នំស៊ីយ៉ូននឹងមានអស់អ្នកដែលគេចរួចជីវិត នោះនឹងបានបរិសុទ្ធ ពូជពង្សយ៉ាកុបនឹងបានកេរ្តិ៍អាកររបស់ខ្លួនវិញ។[18]ពូជពង្សយ៉ាកុបនឹងបានដូចជាភ្លើង
ចំណែក ពូជពង្សយ៉ូសែបជាអណ្តាតភ្លើង ចំណែកពូជពង្សអេសាវនឹងបានដូចជាជញ្ជ្រាំង ហើយភ្លើងនោះនឹងឆាបឆេះគេ រួចបន្សុសគេអស់ទៅ គ្មានអ្នកណាសល់នៅក្នុង
ពូជពង្សអេសាវឡើយ ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលហើយ»។
[19]អស់អ្នកនៅតំបន់ណេកិបនឹងកាន់កាប់ភ្នំរបស់អេសាវ ហើយអស់អ្នកនៅទឹកដីទំនាប នឹងកាន់កាប់ទឹកដីរបស់ពួកភីលីស្ទីន។ ពួកគេនឹងកាន់កាប់ទឹកដីវាលរបស់អេប្រាអិម
និងទឹកដីរបស់សាម៉ារី ហើយបេនយ៉ាមីននឹងកាន់កាប់ទឹកដីកាឡាត។
[20]ការនិរទេសខ្លួនរបស់ជនជាតិនៃកូនចៅអ៊ីស្រាអែលដែលជាប់ជាឈ្លើយ នឹងកាន់កាប់ទឹកដីរបស់ពួកកាណាន រហូតដល់ក្រុងសារិបតា។ ហើយពួកក្រុងយេរូសាឡិម ដែល
ជាប់ជាឈ្លើយនៅសេផារ៉ាឌ នឹងកាន់កាប់ក្រុងនានានៅតំបន់ណេកិប។[21]អស់អ្នកដែលបានរំដោះនឹងឡើងមកភ្នំស៊ីយ៉ូន ដើម្បីគ្រប់គ្រងភ្នំរបស់អេសាវ ហើយរាជ្យនោះនឹង
បានជារបស់ព្រះអម្ចាស់។

Obadiah 1:1
ព្រះអម្ចាស់
នេះគឺជាព្រះនាមរបស់ព្រះជាម្ចាស់ដែលទ្រង់បានសំដែងដល់ប្រជារាស្ត្ររបស់ព្រះអង្គដែលមានមានទៅក្នុងសម្ព័ន្ធមេត្រីចាស់។
(សូមមើល: translationWord page about Yahweh concerning how to translate this.)
បានចាត់អ្នកនាំពាក្យ
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គបានចាត់អ្នកនាំពាក្យម្នាក់»។
ក្រោកឡើង
«ចូរក្រោកឡើង» ឃ្លានេះត្រូវបានប្រើដើម្បីប្រាប់មនុស្សអោយបានរួចរាល់។
មើល៍
របៀបផ្សេងទៀតនៃការបកប្រែ: «មើល៍» ឬ «ស្តាប់»
សូមប្រុងប្រយ័ត្នពីអ្វីដែលខ្ញុំនឹងប្រាប់ទៅដល់អ្នក។
«ជាតិសាសន៍ដទៃនឹងស្អប់អ្នក»។
Obadiah 1:3
ព័ត៌មានទូទៅ:
និមិត្តរបស់អូបាឌាសំដៅលើស្រុកអេដុមតទៅមុខ។
ចិត្តអំនួតរបស់អ្នក
ព្រះអម្ចាស់ប្រើផ្នែកនៃរូបកាយរបស់មនុស្សដែលភ្ជាប់ជាមួយនឹងផ្លូវអារម្មណ៍
សំដៅអារម្មណ៍នៃអំនួតរបស់អ្នកស្រុកអេដុម។

generated on Wed Sep 10 16:16:32 2025

នៅតាមក្រហែងថ្ម
«នៅតាមចន្លោះថ្ម»។
ទីលំនៅតាមកន្លែងខ្ពស់ៗ
«នៅផ្ទះរបស់អ្នកដែលបានសាងសង់ឡើងនៅលើទីទួលខ្ពស់»។
តើអ្នកណាអាចទម្លាក់ខ្ញុំចុះដល់ដីបាន?
សំណួរនេះបង្ហាញថាតើសាសន៍អេដុមបានមានអារម្មណ៍សុវត្ថិភាព
និងអំនួតបែបណា។របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមានសុវត្ថិភាពពីគ្រប់ពួកវាយប្រហារទាំងអស់»។
អ្នកគិតថានឹងហើរឡើងទៅយ៉ាងខ្ពស់ ដូចឥន្ទ្រី ហើយធ្វើសម្បុកនៅកណ្តាលអស់ទាំងផ្កាយ
ប្រយោគទាំងពីរនេះនិយាយថាស្រុកអេដុមត្រូវបានសាងសង់ឡើងខ្ពស់ជាងអ្វីដែលអាចធ្វើបាន
និយាយទៅវាបានសាងសង់នៅលើទីទួលដ៏ខ្ពស់។
យើងនឹងទាញទម្លាក់ពីទីនោះដែរ
អំនួតគឺទាក់ទងជាមួយនឹងកម្ពស់ ឯការបន្ទាបខ្លួនទាក់ទងជាមួយភាពទន់ទាប។
ព្រះអម្ចាស់មានព្រះបន្ទូលថាទ្រង់នឹងទាញស្រុកអេដុមចុះ
និយាយទៅគឺទ្រង់នឹងបន្ទាបស្រុកនេះ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងបន្ទាបឯងចុះ»។

Obadiah 1:5

ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែប្រទានអោយលោកអូបាឌាជាអ្នកនាំសារទៅអោយស្រុកអេដុម។
ពួកចោរប្លន់ចូលមកនៅពេលយប់
«ឬប្រសិនបើចោរបានចូលមកនៅពេលយប់»។
ចោរ
មនុស្សដែលបង្កភាពចលាចលដោយការលួចរបស់អ្នកដទៃ។
តើអ្នកនឹងបាត់បង់អ្វីខ្លះ
ព្រះអម្ចាស់បន្ថែមឃ្លានេះនៅពាក់កណ្តាលនៃប្រយោគដទៃដើម្បីបញ្ជាក់ពីការដាក់ទោសដែលនឹងកើតមានដល់ពួកគេ
របៀបផ្សេងទៀតនៃការបកប្រែ: «ឱ ឯងត្រូវបានបំផ្លាញទាំងស្រុង»។
តើចោរមិនត្រឹមតែលួចឲ្យល្មមសម្រាប់ខ្លួនពួកគេទេ?
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងលួចឲ្យល្មមសម្រាប់ខ្លួនគេ»។
អេសាវអើយ គេគាស់កកាយទឹកដីអ្នក ហើយប្រមូលយកកំណប់ទ្រព្យរបស់អ្នក
របៀបផ្សេងទៀតនៃការបកប្រែ: «ឱ ពួកទាហានបានស្វែងរកអេសាវ
ពួកគេបានតាមរកទ្រពសម្បត្តិដែលគាត់បានលាក់ទុក»។
គាស់កកាយ
ការស្វែងរករបស់ដើម្បីនឹងលួចវា។

Obadiah 1:7

ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែឲ្យលោកអូបាឌាធ្វើជាអ្នកនាំសារទៅស្រុកអេដុម
សម្ព័ន្ធមិត្តរបស់អ្នក
ពាក្យថា «របស់អ្នក» សំដៅទៅលើប្រជាជននៃស្រុកអេដុម។
បណ្តេញអ្នករហូតដល់ព្រំដែន
«នឹងបណ្តេញអ្នកចេញពីទឹកដីរបស់ពួកគេ»។
សាសន៍អេដុមព្យាយាមស្វែងរកជំរកនៅលើទឹកដីរបស់សម្ព័ន្ធមិត្តរបស់ពួកគេ ប៉ុន្តែ
សម្ព័ន្ធមិត្តរបស់ពួកគេមិនអនុញ្ញាតឲ្យសាសន៍អេដុមរស់នៅលើទឹកដីរបស់ពួកគេឡើយ
អ្នកគ្មានការយល់ដឹងអ្វីឡើយ
«អេដុមមិនអាចយល់ទេ»។
«តើយើងគួរមិនធ្វើទេនៅថ្ងៃនោះ» គឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ «យើងនឹងបំផ្លាញពួកអ្នកប្រាជ្ញឲ្យ
អស់ពីទឹកដីអេដុម ហើយអ្នកចេះដឹងឲ្យអស់ពីទឹកដីភ្នំរបស់អេសាវ?»
«នៅថ្ងៃនោះ ព្រះអម្ចាស់មានព្រះបន្ទូល «យើងនឹងបំផ្លាញពួកអ្នកប្រាជ្ញឲ្យអស់
ពីទឹកដីអេដុម ហើយអ្នកចេះដឹងឲ្យអស់ពីទឹកដីភ្នំរបស់អេសាវ?»
មនុស្សខ្លាំងពូកែ របស់អ្នកនឹងត្រូវស្រយុតចិត្ត
«អ្នកចម្បាំងដ៏ខ្លាំងពូកែរបស់អ្នកនឹងមានភាពភ័យខ្លាច»។
ថេម៉ាន
ឈ្មោះតំបន់មួយដែលមាននៅក្នុងស្រុកអេដុម។
គ្រប់គ្នាត្រូវកាត់ចេញពីភ្នំរបស់អេសាវដោយសម្លាប់រង្គាល
របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះនៅលើភ្នំរបស់អេសាវនឹងមិនមានអ្នកណារស់នៅទីនោះទៀតឡើយ
ព្រោះពួកទាហានបានសម្លាប់ពួកគេអស់ហើយ»។
ភ្នំរបស់អេសាវ
ទឹកដីជាច្រើនរបស់អេសាវគឺជាភ្នំ
ដូច្នេះនេះគឺជាវិធីមួយនៃការសំដៅទៅលើទឹកដីរបស់អេសាវ។

Obadiah 1:10

ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែឲ្យលោកអូបាឌាធ្វើជាអ្នកនាំសារទៅស្រុកអេដុម។
យ៉ាកុប ជាបងប្អូនរបស់អ្នក
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលជាកូនចៅរបស់យ៉ាកុបជាពូជពង្សរបស់អ្នក»។
សេចក្តីអាម៉ាស់ខ្មាសនឹងគ្របលើអ្នក
«អ្នកនឹងទទួលបានការអាម៉ាសទាំងស្រុង»។
នឹងត្រូវកាត់ចេញជារៀងរហូត
«នឹងមិនមានជារៀងរហូត»។
បានឈរមើល
«សម្លឹងមើលនឹងមិនបានជួយអ្វីទាំងអស់»។
ជនជាតិដទៃ
ប្រជាជនដែលមកពីជាតិសាសន៍ដទៃ។
ទ្រព្យសម្បត្តិរបស់គេ
ពាក្យ «របស់គេ» សំដៅលើ «យ៉ាកុប»
ដែលជាវិធីមួយសំដៅទៅកាន់សាសន៍អ៊ីស្រាអែល។
ចាប់ឆ្នោតយកក្រុងយេរូសាឡិម
ឃ្លានេះមានន័យថា
«ពួកគេសម្រេចចិត្តចាប់ឆ្នោតរើសអ្នកដែលអាចយករបស់មានតំលៃដែលពួកគេបានយកចេញពីទីក្រុងយេ
អ្នកក៏ដូចជាពួកគេណាមួយដែរ
«ដែលគិតថាអ្នកគឺជាម្នាក់ក្នុងចំណោមជនជាតិដទៃ និងសាសន៍ដទៃ»។

Obadiah 1:12

ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែឲ្យលោកអូបាឌាធ្វើជាអ្នកនាំសារទៅស្រុកអេដុម។
ទាំងត្រេកអរ
«មិនត្រូវសប្បាយដោយព្រោះ» ឬ «កុំយកភាពរីករាយដាក់ក្នុង»។
បងប្អូនរបស់អ្នក
នេះគឺជាវិធីមួយដើម្បីសំដៅលើសាសន៍អ៊ីស្រាអែល ព្រោះយ៉ាកុប និង
អេសាវគឺជាបងប្អូននឹងគ្នា។
ថ្ងៃ
របៀបផ្សេងទៀតនៃការបកប្រែ: «ជាថ្ងៃដែលត្រូវដាក់ទោស» ឬ
«ពេលវេលានៃការដាក់ទោស»។
ទុក្ខវេទនា
«គ្រោះមហន្តរាយ» ឬ «បញ្ហា»។
នៅថ្ងៃដែលគេត្រូវបំផ្លាញនោះដែរ
«នៅថ្ងៃដែលពួកទាហានរបស់គេបានកម្ទេចពួកគេ»។
នៅថ្ងៃដែលគេមានទុក្ខលំបាក
«ពីព្រោះជាពេលវេលាដែលពួកគេកំពុងរងទុក្ខលំបាក»។
មហន្តរាយ...មហន្តរាយ...មហន្តរាយ...
ទាំងនេះគឺជាការបកប្រែខុសគ្នានៃពាក្យដូចគ្នា។
អ្នកបកប្រែគួរប្រើពាក្យតែមួយដើម្បីបកប្រែពាក្យទាំងបីនេះ។
គេរងទុក្ខ
«ដោយព្រោះការអាក្រក់កើតឡើងចំពោះពួកគេ»។
មិនគួរឆ្លៀតលួចយកទ្រព្យសម្បត្តិ របស់គេ
«មិនត្រូវយកទ្រព្យសម្បត្តិរបស់គេ» ឬ «មិនលួចទ្រព្យសម្បត្តិរបស់គេ»។
ផ្លូវបំបែក
ជាកន្លែងដែលផ្លូវពីរនឹងមកប្រសប់គ្នា
ដើម្បីសម្លាប់អ្នកដែលរត់គេចខ្លួន
«ដើម្បីសម្លាប់សាសន៍អ៊ីស្រាអែលដែលកំពុងព្យាយាមរត់គេចខ្លួន» ឬ
«តាមចាប់អស់អ្នកដែលព្យាយាមរត់គេចខ្លួន» (UDB)។
មិនគួរប្រគល់អ្នកដែលនៅមានជីវិតរស់
«មិនត្រូវចាប់ខ្លួនអស់អ្នកដែលនៅមានជីវិតហើយប្រគល់ទៅឲ្យទាហានរបស់ពួកគេទេ»។

Obadiah 1:15

ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅតែឲ្យលោកអូបាឌាធ្វើជាអ្នកនាំសារទៅស្រុកអេដុម។
ដ្បិត ថ្ងៃរបស់ព្រះអម្ចាស់នៅជិតបង្កើយ ទាស់នឹងអស់ទាំងជនជាតិ
«ពេលនឹងមកដល់ឆាប់ៗនេះ
ជាពេលដែលព្រះអម្ចាស់នឹងបង្ហាញដល់ប្រជាជាតិទាំងអស់ថា ទ្រង់

generated on Wed Sep 10 16:16:32 2025

គឺជាព្រះអម្ចាស់»។
អ្នកបានប្រព្រឹត្តយ៉ាងណា នោះអ្នកក៏នឹងបានទទួលយ៉ាងនោះដែរ
«យើងនឹងប្រព្រឹត្តចំពោះអ្នកដូចដែលអ្នកបានធ្វើចំពោះអ្នកដទៃដែរ»។
ការប្រព្រឹត្តរបស់អ្នក នឹងធ្លាក់មកលើក្បាលអ្នកវិញ
ត្រង់៖ «អ្នកនឹងរងឈឺចាប់ពីផលដែលអ្នកបានប្រព្រឹត្ត»។
ដ្បិតអ្នក
ពាក្យថា «អ្នក» សំដៅលើអ្នកស្រុកអេដុម។
ដ្បិត អ្នកបានស្រវឹង
ព្យាការីរៀបរាប់ពីមនុស្សដែលព្រះអម្ចាស់បានដាក់ទោស
ដូចកំពុងធឹកការដាក់ទោសពីព្រះអម្ចាស់ ត្រង់ «ដ្បិត
យើងបានដាក់ទោសអ្នកហើយ»។
ភ្នំបរិសុទ្ធរបស់យើង
នេះជារបៀបដែលសំដៅលើ ក្រុងយេរូសាឡិម។
ប្រជាជាតិទាំងអស់ក៏នឹងធឹកជាបន្តបន្ទាប់
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងដាក់ទោសប្រជាជាតិទាំងអស់ដោយមិនឈប់ឡើយ»។
ព្រះអម្ចាស់បានដាក់ទោសក្រុងយេរូសាឡិម ប៉ុន្តែ
ព្រះអង្គបានបញ្ឈប់មុនពេលព្រះអង្គបំផ្លាញមនុស្សទាំងអស់។ យ៉ាងណាក៏ដោយ
ព្រះអង្គនឹងដាក់ទោសប្រជាជាតិទាំងអស់រហូតដល់គ្មានពួកគេតទៅទៀត។
Obadiah 1:17
ព័ត៌មានទូទៅ:
ព្រះអម្ចាស់នៅបន្តឲ្យលោកអូបេឌាធ្វើជាអ្នកនាំពាក្យរបស់ព្រះអង្គ។
រួចជីវិត
«រួចជីវិតពីការដាក់ទោសរបស់ព្រះអម្ចាស់»។ អ្នកទាំងនេះ
គឺអស់អ្នកដែលរួចជីវិតបន្ទាប់ពីព្រះអង្គបានដាក់ទោសរួច។
ហើយភ្នំ
ពាក្យថា «ភ្នំ» គឺសំដៅលើ «ភ្នំស៊ីយ៉ូន»។
ពូជពង្សយ៉ាកុប...យ៉ូសែបជាអណ្តាតភ្លើង
ព្រះអម្ចាស់ប្រៀបប្រដូចពូជពង្សលោកយ៉ាកុប និងលោកយ៉ូសែបទៅនឹងភ្លើង
ពីព្រោះពួកគេនឹងកម្ចាត់ពូជពង្សអេសាវដូចជាភ្លើងយ៉ាងលឿន
ហើយដុតកំឡោចទាំងស្រុងដូចចម្បើង។
ជញ្ជាំង
«ចម្បើង» ឬ «អង្កាម»
បំណែកនៃរុក្ខជាតិដែលស្ងួតត្រូវបោះបង់ចោលបន្ទាប់ពីបានច្រូតកាត់រួច។
ហើយភ្លើង
ពាក្យថា «ភ្លើង» សំដៅលើពូជពង្សរបស់លោកយ៉ាកុប និងយ៉ូសែប។
នឹងឆាបឆេះគេ
ពាក្យថា «គេ» សំដៅលើ កូនចៅរបស់អេសាវ ដែលជាជាតិសាសន៍អេដុម។
គ្មានអ្នកណាសល់នៅក្នុងពូជពង្សអេសាវឡើយ
«គ្មានសូម្បីតែម្នាក់នៃពូជពង្សរបស់លោកអេសាវដែលនឹងនៅរស់រានមានជីវិត»។
Obadiah 1:19
បេនយ៉ាមីន
«កុលសម្ព័ន្ធបេនយ៉ាមីន» ឬ «កូនចៅបេនយ៉ាមីន»។
Obadiah 1:20
ពលទ័ពនៃកូនចៅអ៊ីស្រាអែលដែលជាប់ជាឈ្លើយ
«ពលទ័ពរបស់អ៊ីស្រាអែលដែលត្រូវបានគេជន្លាស»។
ពលទ័ព
ជាក្រុមមនុស្សដ៏ច្រើន។
សារិបតា
នេះជាឈ្មោះរបស់ក្រុងមួយដែលនៅជាប់ឆ្នេរសមុទ្រមេឌីទែរ៉ាណេ
ដែលនៅចន្លោះក្រុងទីរ៉ុស និងក្រុងស៊ីដូន។
សេផារ៉ាឌ
នេះគឺជាឈ្មោះកន្លែងមួយដែលមិនមានទីតាំងច្បាស់លាស់។
អ្នកជួយសង្គ្រោះ
គឺសំដៅលើអ្នកដឹកនាំកងទ័ពអ៊ីស្រាអែលផ្សេងៗដែលព្រះជាម្ចាស់នឹងប្រើដើម្បីវាយប្រហារប្រជាជាតិអេដុម

យ៉ូណាស

1 [1]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកយ៉ូណាស ជាកូនរបស់អ័មីថាយថា៖[2]ចូរងើបឡើងហើយចេញទៅនីនីវេ ជាទីក្រុងធំ ហើយប្រកាសទាស់នឹងក្រុងនោះ ព្រោះ
អំពើអាក្រក់របស់គេបានល្បីរន្ទឺ នៅចំពោះមុខយើងហើយ។[3]ប៉ុន្តែ លោកយ៉ូណាសក្រោកឡើង រត់ចេញពីព្រះភក្ត្រនៃព្រះអម្ចាស់ទៅឯក្រុងតើស៊ីសវិញ។ លោកចុះទៅ
ដល់ក្រុងយ៉ុបប៉េ បានជួបនឹងសំពៅមួយ ដែលកំពុងរៀបចេញទៅក្រុងតើស៊ីស។ លោកក៏បង់ថ្លៃធ្វើដំណើរ ហើយក៏ចុះសំពៅនោះទៅឯក្រុងតើស៊ីសជាមួយគេ ដើម្បី
គេចចេញពីព្រះភក្ត្ររបស់ព្រះអម្ចាស់។
[4]ប៉ុន្តែ ព្រះអម្ចាស់បានធ្វើឲ្យមានខ្យល់យ៉ាងខ្លាំង បក់មកលើសមុទ្រ បង្កើតជាព្យុះយ៉ាងធំនៅលើសមុទ្រ។ បណ្តាលឲ្យសំពៅស្ទើរតែបែកបាក់។[5]ឯពួកអ្នកសំពៅក៏ភ័យខ្លាច
យ៉ាងខ្លាំង ម្នាក់ៗបានស្រែកបន់ព្រះរបស់គេរៀងៗខ្លួន។ ពួកគេបានបោះទំនិញទាំងប៉ុន្មាន ដែលនៅក្នុងសំពៅចោលទៅក្នុងសមុទ្រ ដើម្បីឲ្យសំពៅស្រាល។ ឯលោក
យ៉ូណាសបានចុះទៅដេកលក់នៅខាងក្នុងសំពៅ។
[6]ដូច្នេះ នាយសំពៅក៏មកសួរលោកថា៖ «អ្នកទ្រមក់អើយ អ្នកធ្វើអីដូច្នេះ? ក្រោកឡើង ចូរទូលអង្វរដល់ព្រះរបស់អ្នកទៅ ក្រែងលោព្រះរបស់អ្នកនឹកចាំពីយើង ដើម្បីមិនឲ្យ
យើងត្រូវវិនាស»។[7]ពួកអ្នកសំពៅនិយាយគ្នាថា៖ «មក! ចូរយើងចាប់ឆ្នោត ដើម្បីឲ្យដឹងថា ការអាក្រក់កើតឡើងដល់យើងនេះ ដោយព្រោះអ្នកណា»។ ដូច្នេះ ពួកគេក៏បាន
ចាប់ឆ្នោត ហើយឆ្នោតនោះក៏ត្រូវលើលោកយ៉ូណាស។
[8]ហើយពួកគេសួរលោកយ៉ូណាសថា៖ «ចូរប្រាប់យើង តើអ្នកណាបាននាំការអាក្រក់នេះមកលើយើង។ តើលោកមានមុខរបរអ្វី? ហើយលោកមកពីណា? តើលោកនៅស្រុក
ណា? ហើយលោកជាជាតិសាសន៍អ្វី?»[9]លោកយ៉ូណាសប្រាប់គេថា៖ «ខ្ញុំជាជនជាតិហេព្រើរ ហើយខ្ញុំកោតខ្លាចព្រះអម្ចាស់ ជាព្រះនៃស្ថានសួគ៌ ដែលបានបង្កើតសមុទ្រ
និងដីគោក។»[10]ហើយពួកអ្នកសំពៅកាន់តែភ័យខ្លាចក៏សួរលោកយ៉ូណាសថា៖ «តើលោកបានធ្វើអ្វីដូច្នេះ?» ដ្បិតពួកគេបានដឹងថា លោកបានកំពុងរត់គេចពីព្រះភក្ត្រ
របស់ព្រះអម្ចាស់ ដោយសារតែលោកបានប្រាប់ពួកគេ។
[11]បន្ទាប់មកពួកគេសួរលោកយ៉ូណាសថា៖ «តើត្រូវឲ្យយើងធ្វើដូចម្តេចដល់អ្នក ដើម្បីឲ្យសមុទ្របានស្ងប់ឡើងវិញ?» ដ្បិតសមុទ្រចេះតែកម្រើករឹតតែខ្លាំងឡើង។
[12]លោកយ៉ូណាសប្រាប់ពួកគេថា៖ «សូមលើកបោះខ្ញុំចូលក្នុងសមុទ្រចុះ។ នោះសមុទ្រនឹងស្ងប់ទៅវិញហើយ ដ្បិតខ្ញុំដឹងថា ដោយព្រោះខ្លួនខ្ញុំ ខ្យល់ព្យុះយ៉ាងខ្លាំងនេះកើត
ឡើងដល់ពួកអ្នក»។[13]ទោះជាពួកគេព្យាយាមចែវត្រឡប់ ដើម្បីឲ្យពួកគេទៅច្រាំងវិញ ប៉ុន្តែទៅមិនបានសោះ ដ្បិតសមុទ្រចេះតែបក់បោកមកកាន់តែខ្លាំងឡើងៗ។
[14]ពេលនោះ ពួកគេក៏ទូលអង្វរដល់ព្រះអម្ចាស់ថា៖ «ឱព្រះអម្ចាស់អើយ យើងខ្ញុំសូមអង្វរព្រះអង្គ សូមកុំឲ្យយើងខ្ញុំត្រូវវិនាសឡើយ ដោយព្រោះជីវិតបុរសនេះឡើយ
ហើយកុំទម្លាក់ទោសរបស់គាត់ មកលើយើងខ្ញុំរាល់គ្នាដែរ ដ្បិតព្រះអម្ចាស់អើយ ព្រះអង្គបានសម្រេចតាមដែលព្រះអង្គគាប់ព្រះហឫទ័យ»។[15]ហើយពួកគេក៏ចាប់លោក
យ៉ូណាស បោះចូលទៅក្នុងសមុទ្រ រួចសមុទ្រក៏ស្ងប់ទៅ។[16]ពួកគេទាំងនោះកោតខ្លាចព្រះអម្ចាស់យ៉ាងខ្លាំង។ ហើយពួកគេក៏ថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ ព្រមទាំងបន់
ស្រន់ផង។
[17]ព្រះអម្ចាស់ក៏បានធ្វើឲ្យមានត្រីមួយយ៉ាងធំដើម្បីលេបលោកយ៉ូណាស ហើយលោកយ៉ូណាសបាននៅក្នុងពោះត្រីនោះអស់បីថ្ងៃបីយប់។

Jonah 1:1
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់
នេះជាសញ្ញាមួយដែលមានន័យថា ព្រះអម្ចាស់មានព្រះបន្ទូល។
«ព្រះអម្ចាស់មានព្រះបន្ទូលមកលោក»។
ព្រះអម្ចាស់មានព្រះបន្ទូល
នៅទីនេះ «ពាក្យ» តំណាងឲ្យព្រះបន្ទូលនៃព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «សាររបស់ព្រះអម្ចាស់»
ព្រះអម្ចាស់

generated on Wed Sep 10 16:16:32 2025

នេះគឺជានាមរបស់ព្រះដែលព្រះអង្គបានបង្ហាញដល់ប្រជាជនរបស់ព្រះអង្គនៅក្នុងគម្ពីរ
សូមមើលការបកប្រែពាក្យនេះក្នុងទំព័រអំពីពាក្យព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែអត្ថន័យនេះ
អ័មីថាយ
នេះជាឈ្មោះឪពុករបស់លោកយ៉ូណាស។
ចូរងើបឡើងហើយចេញទៅនីនីវេ ជាទីក្រុងធំ
«ទៅទីក្រុងសំខាន់នីនីវេ»
ចូរងើបឡើងហើយចេញទៅ
នេះគឺជាការបញ្ជូនមតិទូទៅសម្រាប់ការធ្វើដំណើរទៅកន្លែងឆ្ងាយ។
ប្រកាសទាស់នឹងក្រុងនោះ
«ព្រមានប្រជាជន» (UDB)។ ព្រះជាម្ចាស់កំពុងសំដៅទៅលើប្រជាជននៃទីក្រុង។
អំពើអាក្រក់របស់គេបានល្បីរន្ទឺ នៅចំពោះមុខយើងហើយ
«យើងដឹងថាពួកគេបានធ្វើបាបជាបន្ត»
ក្រោកឡើង រត់ចេញពីព្រះភក្ត្រនៃព្រះអម្ចាស់
«បានរត់ចេញពីព្រះអម្ចាស់»។ «បានក្រោកឡើង»
គឺសំដៅទៅលើយ៉ូណាសចាកចេញពីកន្លែងដែលគាត់នៅ។
ព្រះភក្ត្រនៃព្រះអម្ចាស់
យ៉ូណាសបានព្យាយាមរត់ចេញពីព្រះអម្ចាស់។
ទៅឯក្រុងតើស៊ីសវិញ
ហើយបានទៅក្រុងតើស៊ីស។ ក្រុងតើស៊ីសគឺស្ថិតនៅទិសដៅផ្ទុយនឹងនីនីវេ។
នេះអាចត្រូវបានធ្វើឲ្យច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយបានទៅទិសដៅផ្ទុយឆ្ពោះទៅតើស៊ីស»
លោកចុះទៅដល់ក្រុងយ៉ុបប៉េ
«លោកយូណាសបានចេញទៅទីក្រុងយ៉ុបប៉េ»
សំពៅ
«នាវា» មួយគឺជាទូកប្រភេទធំមួយដែលអាចធ្វើដំណើរលើសមុទ្រ
និងដឹកអ្នកដំណើរ ឬដឹកទំនិញបានច្រើន។
លោកក៏បង់ថ្លៃធ្វើដំណើរ
«នៅទីនោះយ៉ូណាសបានបង់ថ្លៃចំណាយសម្រាប់ការធ្វើដំណើរ»
ហើយក៏ចុះសំពៅ
«ហើយឡើងលើសំពៅ»
ជាមួយគេ
ពាក្យថា «ពួកគេ» សំដៅទៅលើអ្នកផ្សេងទៀតដែលកំពុងធ្វើដំណើរលើកប៉ាល់។
ដើម្បីគេចចេញពីព្រះភក្ត្ររបស់ព្រះអម្ចាស់
យ៉ូណាសសង្ឃឹមថា ព្រះអម្ចាស់មិននៅក្រុងតើស៊ីសទេ។
Jonah 1:4
មិនយូរប៉ុន្មានវាបានលេចចេញមក
ឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ដែលគិតថា នាវានេះនឹងត្រូវបែកបាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «បុរសគិត»
ស្ទើរតែបែកបាក់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បំបែកគ្នា»
អ្នកសំពៅ
បុរសដែលធ្វើការនៅលើកប៉ាល់
ព្រះរបស់គេ
ពាក្យថា «ព្រះ» សំដៅទៅលើព្រះក្លែងក្លាយ
និងរូបព្រះក្លែងក្លាយដែលមនុស្សគោរពបូជា។
ពួកគេបានបោះទំនិញទាំងប៉ុន្មាន ដែលនៅក្នុងសំពៅ
បុរសបានបោះរបស់របរធ្ងន់ៗ ចេញពីសំពៅ។ នេះត្រូវបានធ្វើដើម្បីកុំឲ្យសំពៅលិច។
ដើម្បីឲ្យសំពៅស្រាល
ធ្វើឲ្យសំពៅស្រាលជាងមុននឹងធ្វើប្រសិនបើអណ្តែតល្អជាង។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីជួយឲ្យសំពៅអណ្តែតកាន់តែប្រសើរ»
ឯលោកយ៉ូណាសបានចុះទៅក្នុងសំពៅ
យ៉ូណាសបានធ្វើដូច្នេះមុនពេលព្យុះចាប់ផ្តើម។
បានចុះទៅខាងក្នុងផ្នែកនៃសំពៅ
«នៅខាងក្នុងសំពៅ»
ដេកលក់នៅខាងក្នុងសំពៅ
«កំពុងដេកនៅទីនោះយ៉ាងលឿន» ឬ
«កំពុងដេកនៅទីនោះហើយដេកយ៉ាងលក់ស្រួល»។
ដោយហេតុផលនេះព្យុះមិនបានធ្វើឲ្យគាត់ភ្ញាក់ទេ។
ដូច្នេះសំពៅក៏មកសួរលោកថា
«បុរសដែលទទួលបន្ទុកជាអ្នកបើកសំពៅបានទៅជួបយ៉ូណាស ហើយនិយាយថា»
អ្នកទ្រមក់អើយ អ្នកធ្វើអីដូច្នេះ?
«ហេតុអ្វីបានជាអ្នកដេកលក់?» គាត់បានប្រើសំណួរវោហារនេះ
ដើម្បីស្តីបន្ទោសយ៉ូណាស។ របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់ដេក!»
ក្រោកឡើង!
នេះសំដៅទៅលើការធ្វើសកម្មភាពមួយចំនួន។
ចំពោះយ៉ូណាសប្រធានក្រុមកំពុងប្រាប់គាត់ឲ្យភ្ញាក់ឡើង
ហើយអធិស្ឋានដល់ព្រះរបស់គាត់សម្រាប់ការឆ្លងកាត់ដោយសុវត្ថិភាព។
ចូរទូលអង្វរដល់ព្រះរបស់អ្នកទៅ!
«សូមអធិស្ឋានដល់ព្រះរបស់អ្នក!» «ហៅ»
សំដៅទៅលើការយកចិត្តទុកដាក់ពីនរណាម្នាក់។
ក្រែងលោព្រះរបស់អ្នកនឹកចាំពីយើង ដើម្បីមិនឲ្យយើងត្រូវវិនាស
ព័ត៌មានជាក់លាក់ដែលព្រះរបស់យ៉ូណាអាចជួយសង្គ្រោះពួកគេអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រហែលជាព្រះរបស់អ្នកនឹងឮ
ហើយជួយសង្គ្រោះយើង ដូច្នេះយើងនឹងមិនស្លាប់ទេ»
ពួកអ្នកសំពៅនិយាយគ្នាថា
«អ្នកសំពៅទាំងអស់និយាយគ្នាថា»
មក! ចូរយើងចាប់ឆ្នោត ដើម្បីឲ្យដឹងថា ការអាក្រក់កើតឡើងដល់យើងនេះ ដោយព្រោះអ្នកណា
យើងគួរតែបោះឆ្នោតឲ្យ បានច្រើនដើម្បីដឹងថាអ្នកណាជាអ្នកបង្កបញ្ហានេះ។
បុរសទាំងនោះជឿថា ព្រះនឹងគ្រប់គ្រងរបៀបដែលចាប់ឆ្នោតធ្លាក់ចុះ
ដើម្បីប្រាប់ពួកគេពីអ្វីដែលពួកគេចង់ដឹង។ នេះគឺជាទម្រង់នៃការទស្សន៍ទាយ។
ការអាក្រក់
នេះសំដៅទៅលើព្យុះដ៏គួរឲ្យខ្លាច។
ឆ្នោតនោះក៏ត្រូវលើលោកយ៉ូណាស
បានបង្ហាញថាយ៉ូណាសគឺជាមនុស្សដែលមានទោស។
Jonah 1:8
ហើយពួកគេសួរលោកយ៉ូណាសថា
«បន្ទាប់មកបុរសដែលកំពុងធ្វើការនៅលើសំពៅនិយាយទៅកាន់លោកយ៉ូណាស»
ចូរប្រាប់យើង តើអ្នកណាបាននាំការអាក្រក់នេះមកលើយើង
តើអ្នកណាបង្កអំពើអាក្រក់ដែលកំពុងកើតឡើងចំពោះយើង?
កោតខ្លាចព្រះអម្ចាស់
ពាក្យថា «ការភ័យខ្លាច» សំដៅទៅលើយ៉ូណាសការគោរពព្រះយ៉ាងជ្រាលជ្រៅ។
តើលោកបានធ្វើអ្វីដូច្នេះ?
បុរសនៅលើកសំពៅបានប្រើសំណួរវោហារស័ព្ទនេះ ដើម្បីបង្ហាញថា
ពួកគេតូចចិត្តនឹងយ៉ូណាស។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកបានធ្វើរឿងដ៏គួរឲ្យភ័យខ្លាច»។
លោកកំពុងរត់គេចពីព្រះភក្ត្ររបស់ព្រះអម្ចាស់
យ៉ូណាសបានរត់ចេញពីព្រះអម្ចាស់។ លោកយ៉ូណាសចង់រត់គេចពីព្រះអម្ចាស់
ដូចព្រះអម្ចាស់មានតែនៅស្រុក អ៊ីស្រាអែលប៉ុណ្ណោះ។
ដោយសារតែលោកបានប្រាប់ពួកគេ
អ្វីដែលគាត់បានប្រាប់ពួកគេអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីព្រោះគាត់បានប្រាប់ពួកគេថា
ខ្ញុំកំពុងព្យាយាមចាកឆ្ងាយពីព្រះអម្ចាស់»
Jonah 1:11
ពួកគេសួរលោកយ៉ូណាសថា
«រស់នៅលើកសំពៅបាននិយាយទៅកាន់យ៉ូណាស» ឬ
«អ្នកសំពៅបាននិយាយទៅកាន់យ៉ូណាស»
ធ្វើដូចម្តេចដល់អ្នក ដើម្បីឲ្យសមុទ្របានស្ងប់ឡើងវិញ
«គួរធ្វើអ្វីជាមួយអ្នកដើម្បីធ្វើអោយសមុទ្រស្ងប់» (UDB)
សមុទ្រចេះតែកម្រើករឹតតែខ្លាំងឡើង
នេះជាមូលហេតុដែលពួកបុរសសួរយ៉ូណាសថា តើពួកគេគួរធ្វើអ្វី។
ហេតុផលក៏អាចត្រូវបានរកឃើញនៅដើមខ ១១ ក្នុង UDB។
ដ្បិតខ្ញុំដឹងថា ដោយព្រោះខ្លួនខ្ញុំ ខ្យល់ព្យុះយ៉ាងខ្លាំងនេះកើតឡើងដល់ពួកអ្នក
«ព្រោះខ្ញុំដឹងថាព្យុះដ៏ធំនេះជាកំហុសរបស់ខ្ញុំ»
ទោះជាពួកគេព្យាយាមចែវត្រឡប់ ដើម្បីឲ្យពួកគេទៅច្រាំងវិញ
បុរសទាំងនោះមិនចង់បោះយ៉ូណាសទៅក្នុងសមុទ្រទេ
ដូច្នេះពួកគេបានតម្រង់ជួរយ៉ាងវែងហាក់ដូចជាកំពុងជីកចូលទៅក្នុងទឹកដើម្បីចូលដីវិញ។

generated on Wed Sep 10 16:16:32 2025

សមុទ្រចេះតែបក់បោកមកកាន់តែខ្លាំងឡើងៗ
«ព្យុះកាន់តែអាក្រក់ទៅៗ ហើយរលកកាន់តែខ្លាំងឡើងៗ»
Jonah 1:14
ពេលនោះ
ជាលទ្ធផលនៃព្យុះកាន់តែអាក្រក់ដែលបង្កឲ្យមានការឆ្លើយតបបន្ទាប់ទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយសារតែសមុទ្រកាន់តែមានអំពើហឹង្សា»
ពួកគេក៏ទូលអង្វរដល់ព្រះអម្ចាស់
«ពួកគេអធិស្ឋានដល់ព្រះអម្ចាស់»
សូមកុំឲ្យយើងខ្ញុំត្រូវវិនាសឡើយ ដោយព្រោះជីវិតបុរសនេះឡើយ
«សូមកុំសម្លាប់យើងព្រោះយើងបានបណ្តាលឲ្យបុរសនេះស្លាប់» ឬ
«យើងនឹងបណ្តាលឲ្យបុរសនេះស្លាប់។ តែសូមមេត្តាកុំសម្លាប់យើង»
ហើយកុំទម្លាក់ទោសរបស់គាត់ មកលើយើងខ្ញុំវាល់គ្នាដែរ
«ហើយសូមមេត្តាកុំបន្ទោសយើងចំពោះការស្លាប់របស់គាត់» ឬ
«ហើយកុំគិតថាយើងមានកំហុសនៅពេលដែលបុរសនេះស្លាប់»។
អ្នកនិពន្ធនិយាយអំពី «កំហុស»
ដូចជាវាជាវត្ថុដែលអាចត្រូវបានដាក់នៅលើកំពូលនៃមនុស្សម្នាក់។
សំដៅទៅលើការធ្វើឲ្យបុគ្គលនោះទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ។
សមុទ្រក៏ស្ងប់ទៅ
«សមុទ្រឈប់ធ្វើចលនាដោយហិង្សា» ឬ «សមុទ្របានស្ងប់» (UDB)
កោតខ្លាចព្រះអម្ចាស់យ៉ាងខ្លាំង
«បានកោតស្ញើចនឹងព្រះចេស្តារបស់ព្រះអម្ចាស់» (UDB)
Jonah 1:17
ព័ត៌មានទូទៅ៖
ជំនាន់ខ្លះមានលេខខនេះជាខដំបូងនៃជំពូក ២។
អ្នកប្រហែលជាចង់រាប់លេខខយោងតាមកំណែដែលក្រុមភាសារបស់អ្នកប្រើ។
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើជាភាសាអង់គ្លេសដើម្បីណែនាំផ្នែកថ្មីនៃរឿង។
បីថ្ងៃបីយប់
«បីថ្ងៃបីយប់»

---

2 [1]ពេលនោះ លោកយ៉ូណាសបានអធិស្ឋានដល់ព្រះអម្ចាស់ជាព្រះរបស់ខ្លួន នៅក្នុងពោះត្រី។[2]លោកទូលថា៖ «ទូលបង្គំបានទូលអង្វរព្រះអម្ចាស់ អំពីទុក្ខលំបាករបស់ទូលបង្គំ ហើយព្រះអង្គក៏បានឆ្លើយមកទូលបង្គំ ពីក្នុងពោះនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ ទូលបង្គំបានស្រែកហៅព្រះអង្គជួយ! ហើយព្រះអង្គព្រះសណ្តាប់ពាក្យរបស់ទូលបង្គំ។
[3]ព្រះអង្គបានបោះទូលបង្គំទៅក្នុងទីជម្រៅ គឺចុះទៅក្នុងផ្នែបាតនៃសមុទ្រ ហើយខ្សែរទឹកបាននៅព័ទ្ធជុំវិញទូលបង្គំ ហើយគ្រប់ទាំងរលក និងអស់ទាំងខ្សែទឹករបស់ព្រះអង្គ បានហូរពីលើទូលបង្គំ។[4]ទូលបង្គំបានពោលថា៖ «ទូលបង្គំត្រូវបោះចោលពីព្រះនេត្ររបស់ព្រះអង្គហើយ ប៉ុន្តែ ទូលបង្គំនឹងសម្លឹងឆ្ពោះទៅរកព្រះវិហារបរិសុទ្ធរបស់ព្រះអង្គ»។
[5]ទឹកបានព័ទ្ធជុំវិញទូលបង្គំ រហូតដល់ករបស់ទូលបង្គំ ដែលសេចក្តីអន្តរាយបានហ៊ុមទូលបង្គំជិត ហើយសារ៉ាយបានរុំព័ទ្ធក្បាលទូលបង្គំ។[6]ទូលបង្គំបានចុះទៅដល់បាតនៃភ្នំទាំងឡាយ ហើយផែនដីបានបិទខ្ទប់ពីលើ ទូលបង្គំទុកជាដរាបតទៅ។ ប៉ុន្តែ ឱព្រះអម្ចាស់ ជាព្រះនៃទូលបង្គំ ព្រះអង្គបាននាំទូលបង្គំងើបចេញពីរណ្តៅ!
[7]កាលព្រលឹងទូលបង្គំបានសន្លប់ក្នុងទូលបង្គំ នោះទូលបង្គំស្រែកហៅព្រះអម្ចាស់ មកនៅក្នុងចិត្តរបស់ទូលបង្គំ ហើយសេចក្តីអធិស្ឋានរបស់ទូលបង្គំបានទៅព្រះអង្គ គឺចូលទៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះអង្គ។[8]អស់ពួកអ្នកដែលជឿលើព្រះដែលក្លែងក្លាយ សូមលះបង់ភាពស្មោះត្រង់របស់អ្នកចំពោះពួកគេ។
[9]ប៉ុន្តែ ទូលបង្គំនឹងថ្វាយយញ្ញបូជាដល់ព្រះអង្គដោយសំឡេងនៃពាក្យអរព្រះគុណ ហើយទូលបង្គំនឹងលាបំណន់របស់ទូលបង្គំផង។ ឯសេចក្តីសង្គ្រោះនោះកើតមកតែពីព្រះអម្ចាស់»។[10]ពេលនោះព្រះអម្ចាស់ បង្គាប់ត្រី ឲ្យខ្ជាក់លោកយ៉ូណាសចេញនៅលើដីគោក។

Jonah 2:1
ព្រះអម្ចាស់ជាព្រះរបស់ខ្លួន
នេះមានន័យថា «ព្រះអម្ចាស់ជាព្រះដែលគាត់បានគោរពបូជា»។ ពាក្យថា
«ព្រះអង្គ» មិនមែនមានន័យថាយ៉ូណាសជារបស់ព្រះទេ។
លោកទូលថា
«លោកយ៉ូណាសទូលថា»
ទូលបង្គំបានទូលអង្វរព្រះអម្ចាស់ អំពីទុក្ខលំបាករបស់ទូលបង្គំ
ខ្ញុំបានអធិស្ឋានទូលដល់ព្រះអម្ចាស់អំពីបញ្ហាដ៏ធំរបស់ខ្ញុំ។
ទោះបីយ៉ូណាសបានអធិស្ឋានដល់ព្រះអម្ចាស់ក៏ដោយ
តែគាត់បានប្រើព្រះនាមរបស់ព្រះអម្ចាស់នៅទីនេះហើយមិនបានប្រើពាក្យអ្នកទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់ខ្ញុំបានអំពាវនាវដល់អ្នកអំពីទុក្ខព្រួយរបស់ខ្ញុំ»
ព្រះអង្គក៏បានឆ្លើយមកទូលបង្គំ
«ព្រះអម្ចាស់បានឆ្លើយតបមកខ្ញុំ» ឬ «ព្រះអង្គបានជួយខ្ញុំ»
ពីក្នុងពោះនៃស្ថានឃុំព្រលឹងមនុស្សស្លាប់
«ស្ថានឃុំព្រលឹងមនុស្សស្លាប់» ឬពីផ្នែកជ្រៅនៃស្ថានឃុំ ព្រលឹង។
អត្ថន័យដែលអាចមានគឺ ១)
យ៉ូណាសកំពុងនិយាយថាក្បាលពោះរបស់ត្រីបាឡែនកំពុងស្ថិតនៅក្នុងស្ថានឃុំ
ព្រលឹងមនុស្សស្លាប់ ឬ ២) យ៉ូណាសជឿថាគាត់ជិតស្លាប់ ហើយទៅស្ថានឃុំ
ព្រលឹងមនុស្សស្លាប់ ឬ ៣) គាត់និយាយដូចជាគាត់បានស្លាប់ហើយទៅនៅទីនោះ។
Jonah 2:3
ព័ត៌មានទូទៅ៖
នេះគឺជាការបន្តការអធិស្ឋានរបស់យ៉ូណាស ដែលបានចាប់ផ្តើមនៅជំពូក ២: ១។
នៅក្នុងខ ៤
យ៉ូណាសបាននិយាយអំពីអ្វីមួយដែលគាត់បានអធិស្ឋានមុនពេលអធិស្ឋាននេះ។
ទៅក្នុងទីជម្រៅ គឺចុះទៅក្នុងផ្នែបាតនៃសមុទ្រ
នេះនិយាយអំពីមហាសមុទ្រដ៏ធំសម្បើមដែលយ៉ូណាសស្ថិតនៅ។
ទៅក្នុងផ្នែបាតនៃសមុទ្រ
«ដល់បាតសមុទ្រ»
ខ្សែរទឹកបាននៅព័ទ្ធជុំវិញទូលបង្គំ
«ទឹកសមុទ្រនៅជុំវិញជិតខ្ញុំ»
រលក និងអស់ទាំងខ្សែទឹក
ទាំងនេះគឺជាការរំខាននៅលើផ្ទៃមហាសមុទ្រ។
ទូលបង្គំត្រូវបោះចោល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកបានដេញខ្ញុំចេញ» ឬ «អ្នកបានបញ្ជូនខ្ញុំទៅឆ្ងាយ»
ពីព្រះនេត្ររបស់ព្រះអង្គ
«ពីអ្នក»។ ពេលយ៉ូណាសនិយាយថា «ភ្នែកអ្នក»
គាត់បាននិយាយអំពីព្រះអម្ចាស់ទាំងស្រុង។
ទូលបង្គំនឹងសម្លឹងឆ្ពោះទៅរកព្រះវិហារបរិសុទ្ធរបស់ព្រះអង្គ
យ៉ូណាសសង្ឃឹមថា ទោះបីគាត់ឆ្ងងកាត់អ្វីក៏ដោយគាត់នឹងឃើញព្រះវិហារ។
Jonah 2:5
ព័ត៌មានទូទៅ៖
នេះគឺជាការអធិស្ឋានរបស់យ៉ូណាសបន្តទៀត គឺបានចាប់ផ្តើមនៅជំពូក ២: ១។
ទឹក
«ទឹក» សំដៅទៅលើសមុទ្រ។
ករបស់ទូលបង្គំ
ជំនាន់ខ្លះយល់ពីពាក្យហេព្រើរនៅក្នុងកន្សោមនេះមានន័យថា «ជីវិតរបស់ខ្ញុំ»។
នៅក្នុងការបកស្រាយនោះទឹកគឺជិតនឹងដកជីវិតរបស់យ៉ូណាស។
សេចក្តីអន្តរាយបានហ៊ុមទូលបង្គំជិត
«ទឹកជ្រៅនៅជុំវិញខ្ញុំ»
សារ៉ាយ
«ស្មៅដុះនៅសមុទ្រ»
ផែនដីបានបិទខ្ទប់ពីលើ ទូលបង្គំទុកជាដរាបតទៅ
យ៉ូណាសបានប្រើពាក្យប្រៀបធៀប ដើម្បីប្រៀបធៀបផែនដីទៅនឹងគុក។
របៀបផ្សេងទៀតនៃការបកប្រែ:
«ផែនដីគឺដូចជាគុកដែលហៀបនឹងចាក់សោខ្ញុំជាប់ជារៀងរហូត»
ព្រះអង្គបាននាំទូលបង្គំងើបចេញពីរណ្តៅ

generated on Wed Sep 10 16:16:32 2025

យ៉ូណាសនិយាយអំពីកន្លែងដែលមនុស្សស្លាប់ហាក់ដូចជារណ្តៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែអ្នកបានសង្គ្រោះជីវិតខ្ញុំពីកន្លែងស្លាប់» ឬ «ប៉ុន្តែអ្នកបានសង្គ្រោះខ្ញុំពីកន្លែងដែលមានមនុស្សស្លាប់»
ឱព្រះអម្ចាស់ ជាព្រះនៃទូលបង្គំ!
នៅក្នុងភាសាខ្លះពាក្យនេះប្រើជាការធម្មតាទេ
ក្នុងការដាក់នៅដើមនៃប្រយោគឬនៅជាប់នឹងពាក្យ «អ្នក»។

Jonah 2:7

ព័ត៌មានទូទៅ៖
នេះគឺជាការអធិស្ឋានរបស់យ៉ូណាសបន្តទៀត ដែលបានចាប់ផ្តើមនៅជំពូក ២: ១។
ទូលបង្គំស្រែកហៅព្រះអម្ចាស់ មកនៅក្នុងចិត្តរបស់ទូលបង្គំ
ចាប់តាំងពីយ៉ូណាសបានអធិស្ឋានដល់ព្រះអម្ចាស់ឃ្លានេះអាចច្បាស់ជាងនេះនៅក្នុងភាសាខ្លះ
ដែលនិយាយថា «ខ្ញុំបានគិតអំពីព្រះអម្ចាស់» (UDB)
ហើយសេចក្តីអធិស្ឋានរបស់ទូលបង្គំបានទៅព្រះអង្គ គឺចូលទៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះអង្គ
យ៉ូណាសនិយាយដូចជា ការអធិស្ឋានរបស់គាត់អាចធ្វើដំណើរទៅដល់ព្រះ
និងព្រះវិហាររបស់ព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់មកអ្នកនៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះអង្គបានឮការអធិស្ឋានរបស់ខ្ញុំ»
អស់ពួកអ្នកដែលជឿលើព្រះដែលក្លែងក្លាយ
«មនុស្សដែលយកចិត្តទុកដាក់ចំពោះព្រះដែលគ្មានប្រយោជន៍»
សូមលះបង់ភាពស្មោះត្រង់របស់អ្នកចំពោះពួកគេ
«កំពុងបដិសេធអ្នកដែលស្មោះត្រង់នឹងគេ»

Jonah 2:9

ព័ត៌មានទូទៅ៖
នេះគឺជាការអធិស្ឋានរបស់យ៉ូណាសបន្តទៀត ដែលបានចាប់ផ្តើមនៅជំពូក ២: ១។
ប៉ុន្តែ ទូលបង្គំ
ការបញ្ចេញមតិនេះជាភាសាអង់គ្លេសបង្ហាញថា
មានភាពផ្ទុយគ្នារវាងមនុស្សដែលយ៉ូណាសទើបតែបាននិយាយ
និងខ្លួនគាត់ផ្ទាល់។ ពួកគេយកចិត្តទុកដាក់ចំពោះព្រះដែលឥតបានការ
ប៉ុន្តែលោកគោរពបូជាព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែខ្ញុំ»
ទូលបង្គំនឹងថ្វាយយញ្ញបូជាដល់ព្រះអង្គដោយសំឡេងនៃពាក្យអរព្រះគុណ
នេះមានន័យថាយ៉ូណាសអរគុណដល់ព្រះខណៈពេលដែលគាត់បានថ្វាយយញ្ញបូជាដល់ព្រះអង្គ។
ឃ្លានេះមិនច្បាស់ទេថាតើយ៉ូណាសគ្រោងនឹងអរគុណព្រះដោយច្រៀង
ឬស្រែកដោយអំណរ។
សេចក្តីសង្គ្រោះនោះកើតមកតែពីព្រះអម្ចាស់
នេះអាចត្រូវបានប្រើឡើងវិញ ដូច្នេះនាមអរូបី «សេចក្តីសង្គ្រោះ»
ត្រូវបានបង្ហាញជាកិរិយាស័ព្ទ «រក្សាទុក»។
«ព្រះអម្ចាស់ជាព្រះដែលសង្គ្រោះមនុស្ស»
ចេញនៅលើដីគោក
«លើដី» ឬ «ទៅច្រាំង»

---

3 [1]ព្រះបន្ទូលរបស់ព្រះអម្ចាស់មកកាន់លោកយ៉ូណាសម្តងទៀតថា៖ [2]«ចូរក្រោកឡើងទៅឯនីនីវេ ជាក្រុងធំ ហើយប្រកាសប្រាប់គេ តាមសេចក្តីដែលយើងបង្គាប់»។ [3]ដូច្នេះ
លោកយ៉ូណាសក៏ក្រោកឡើងទៅក្រុងនីនីវេតាមការបង្គាប់របស់ព្រះអម្ចាស់។ នីនីវេជាទីក្រុងដ៏ធំសម្បើមអស្ចារ្យ ដែលដើរអស់រយៈពេលបីថ្ងៃ ទើបបានសព្វ។
[4]លោកយ៉ូណាសបានចាប់ផ្តើមដើរចូលទៅទីក្រុង បន្ទាប់ពីធ្វើដំណើរអស់មួយថ្ងៃហើយ នោះលោកប្រកាសថា «នៅតែសែសិបថ្ងៃទៀតក្រុងនីនីវេនឹងត្រូវបំផ្លាញហើយ»។
[5]ពួកបណ្តាជននៅក្រុងនីនីវេក៏ជឿលើព្រះអង្គ ដូច្នេះគេក៏ប្រកាសឲ្យមានពេលតមអត់។ ពួកគេស្លៀកពាក់កាន់ទុក្ខចាប់តាំងពីអ្នកធំបំផុត រហូតដល់អ្នកតូចជាងគេ។
[6]ភ្លាមនោះដំណឹងក៏បានទៅដល់ស្តេចនៃក្រុងនីនីវេ។ ស្តេចក៏យាងចុះពីបល្ល័ង្ក ដោះព្រះពស្ត្រចេញ ហើយឃ្លុំអង្គដោយសំពត់កាន់ទុក្ខ និងគង់នៅក្នុងផេះវិញ។
[7]ដែលស្ថិតនៅក្រោមការបង្គាប់របស់ស្តេច និងពួករដ្ឋមន្ត្រីថា៖ «មិនត្រូវឲ្យពួកមនុស្ស ឬសត្វ ហ្វូងគោ ឬហ្វូងចៀមភ្លក់អ្វីឡើយ។ កុំឲ្យពួកវាស៊ី ឬផឹកឲ្យសោះ។
[8]ប៉ុន្តែទាំងមនុស្ស និងសត្វត្រូវឃ្លុំខ្លួនដោយសំពត់កាន់ទុក្ខ ហើយគ្រប់គ្នាត្រូវអំពាវនាវយ៉ាងខ្លាំងដល់ព្រះ។ ត្រូវឲ្យអ្នករាល់គ្នាលាចេញពីផ្លូវអាក្រក់របស់គេរៀងខ្លួន ហើយ
ចេញពីការច្រឡោតដែលនៅដៃខ្លួនគេផងដែរ។ [9]ក្រែងលោព្រះជាម្ចាស់ប្រែព្រះហឫទ័យលែងព្រះពិរោធ ដូច្នេះ យើងនឹងមិនត្រូវវិនាសអន្តរាយឡើយ»។
[10]ពេលព្រះទតឃើញការទាំងប៉ុន្មានដែលពួកគេប្រព្រឹត្តនោះ ដែលគេបានលះបង់ពីផ្លូវអាក្រក់របស់គេ។ ហើយព្រះក៏ប្រែគំនិតពីការដាក់ទណ្ឌកម្ម ដែលព្រះអង្គ
ធ្លាប់មានបន្ទូលថា ទ្រង់នឹងធ្វើដល់ពួកគេ ហើយព្រះអង្គក៏លែងធ្វើទៅ។

Jonah 3:1

ព្រះបន្ទូលរបស់ព្រះអម្ចាស់មកកាន់
នេះជាសញ្ញាណមួយដែលមានន័យថា ព្រះអម្ចាស់មានព្រះបន្ទូល។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុងជំពូក ១: ១។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់មានព្រះបន្ទូលមកលោក»
ព្រះបន្ទូលរបស់ព្រះអម្ចាស់
ពាក្យថា «ព្រះបន្ទូល» តំណាងឲ្យសាររបស់ព្រះអម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «សាររបស់ព្រះអម្ចាស់»
ចូរក្រោកឡើងទៅឯនីនីវេ ជាក្រុងធំ
«ទៅទីក្រុងសំខាន់នីនីវេ»
ចូរក្រោកឡើង
ឃ្លានេះសំដៅទៅលើការចាកចេញពីកន្លែងមួយដែលស្ថិតនៅ។
ប្រកាសប្រាប់គេ តាមសេចក្តីដែលយើងបង្គាប់
«ប្រាប់ប្រជាជននូវអ្វីដែលខ្ញុំប្រាប់អ្នក ដើម្បីប្រាប់ពួកគេ»
ដូច្នេះ លោកយ៉ូណាសក៏ក្រោកឡើងទៅក្រុងនីនីវេតាមការបង្គាប់របស់ព្រះអម្ចាស់
នៅគ្រានេះយ៉ូណាសបានស្តាប់បង្គាប់ព្រះអម្ចាស់ ហើយបានទៅក្រុងនីនីវេ
ដូច្នេះ លោកយ៉ូណាសក៏ក្រោកឡើង
«ដូច្នេះយ៉ូណាសបានចាកចេញពីឆេរខ្សាច់»។ «បានក្រោកឡើង»
សំដៅទៅលើការចាកចេញពីកន្លែងដែលយ៉ូណាសស្នាក់នៅ។
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការផ្លាស់ប្តូរពីរឿងរ៉ាវទៅជាព័ត៌មានអំពីនីនីវេ។
ដែលដើរអស់រយៈពេលបីថ្ងៃ
«ការធ្វើដំណើរទៅទីក្រុងបីថ្ងៃ»។ មនុស្សម្នាក់ត្រូវដើររយៈពេលបីថ្ងៃ
ដើម្បីឆ្លងកាត់ទីក្រុងទាំងស្រុង។

Jonah 3:4

បន្ទាប់ពីធ្វើដំណើរអស់មួយថ្ងៃហើយនោះលោកប្រកាសថា
អត្ថន័យដែលអាចមានគឺ ១)
«បន្ទាប់ពីយ៉ូណាសបានដើរមួយថ្ងៃហើយគាត់បានស្រែក» ឬ ២)
«ខណៈពេលដែលយ៉ូណាសដើរនៅថ្ងៃទីមួយគាត់បានស្រែក»។
បន្ទាប់ពីធ្វើដំណើរអស់មួយថ្ងៃ
«បន្ទាប់ពីដើរមួយថ្ងៃ»។ ការធ្វើដំណើរមួយថ្ងៃគឺជា
ចម្ងាយដែលមនុស្សទូទៅនឹងធ្វើដំណើរក្នុងមួយថ្ងៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពីយ៉ូណាសបានដើរមួយថ្ងៃ»
នោះលោកប្រកាសថា
«គាត់បានប្រកាស» ឬ «គាត់បានស្រែក»
សែសិបថ្ងៃ
៤០ សិបថ្ងៃ
ពួកគេស្លៀកពាក់កាន់ទុក្ខ
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេក៏បានដាក់ក្រណាត់រដុប
ដើម្បីបង្ហាញថាពួកគេសោកស្តាយដែលបានធ្វើបាប»
ចាប់តាំងពីអ្នកធំបំផុត រហូតដល់អ្នកតូចជាងគេ
«ពីមនុស្សសំខាន់រហូតដល់មនុស្សសំខាន់តិចបំផុត» ឬ
«រាប់បញ្ចូលទាំងមនុស្សសំខាន់ៗ និងប្រជាជនដែលមិនសំខាន់ទាំងអស់» (UDB)

Jonah 3:6

ដំណឹង
«ដំណឹងរបស់យ៉ូណាស»
ស្តេចក៏យាងចុះពីបល្ល័ង្ក
«ស្តេចបានឡើងពីបល្ល័ង្ករបស់ព្រះអង្គ» ឬ
«ស្តេចបានឈរឡើងពីបល្ល័ង្ករបស់ទ្រង់»។ ព្រះរាជាបានចាកចេញពីរាជបល្ល័ង្ក
ដើម្បីបង្ហាញថាព្រះអង្គកំពុងសំដែងអាកប្បកិរិយារាបសា។
បល្ល័ង្ក

generated on Wed Sep 10 16:16:32 2025

បល្ល័ង្កគឺជាកៅអីដែលស្តេចគង់លើ។ ពាក្យនេះបង្ហាញថាគាត់ជាស្តេច។
ព្រះរាជាចេញបញ្ជាឲ្យប្រកាសប្រាប់
«គាត់បានចេញសេចក្តីប្រកាសជាផ្លូវការមួយដែលនិយាយថា» ឬ
«ព្រះអង្គបានចាត់អ្នកនាំសាររបស់ព្រះអង្គអោយទៅប្រកាសប្រាប់ប្រជាជននៅក្រុងនីនីវេ»
រដ្ឋមន្ត្រី
«ទីប្រឹក្សា» (UDB)។ បុរសសំខាន់ទាំងនេះដែលបានជួយស្តេចគ្រប់គ្រងទីក្រុង។
ហ្វូងគោ ឬហ្វូងចៀម
នេះសំដៅទៅលើសត្វពីរប្រភេទដែលមនុស្សយកចិត្តទុកដាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «គោ ឬ ចៀម»
កុំឲ្យពួកវាស៊ី ឬផឹកឲ្យសោះ
«ពួកគេមិនត្រូវបរិភោគ ឬផឹកអ្វីឡើយ»។
មូលហេតុដែលពួកគេមិនត្រូវបរិភោគឬផឹកអ្វីអាចត្រូវបានបញ្ជាក់ឲ្យច្បាស់ដោយបន្ថែម
«ដើម្បីបង្ហាញថាពួកគេមានការសោកស្តាយចំពោះអំពើបាបរបស់ពួកគេ»។
Jonah 3:8
ព័ត៌មានទូទៅ៖
នេះគឺជាការអ្វីមួយដែលព្រះរាជាបានបន្តប្រាប់ប្រជាជននីនីវេ។
ប៉ុន្តែទាំងពីរ
«សូមឲ្យអ្នកទាំងពីរ»
ប៉ុន្តែទាំងមនុស្ស និងសត្វត្រូវឃ្លុំខ្លួនដោយសំពត់កាន់ទុក្ខ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អោយមនុស្ស និងសត្វស្លៀកសំពត់» ឬ «ទុកអោយមនុស្សគ្របខ្លួន
ហើយសត្វរបស់ពួកគេជាមួយនឹងសំពត់»
សត្វ
ពាក្យថា «សត្វ» សំដៅទៅលើសត្វដែលជាកម្មសិទ្ធិរបស់មនុស្ស។
ទូលអង្វរយ៉ាងខ្លាំងដល់ព្រះ
«អធិដ្ឋានទៅព្រះជាម្ចាស់ឲ្យអស់ពីចិត្ត»។
អ្វីដែលពួកគេត្រូវអធិស្ឋានអាចពន្យល់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទូលអង្វរយ៉ាងខ្លាំងៗ ដល់ព្រះ
ហើយសុំសេចក្តីមេត្តាករុណា»
ការច្រឡោតដែលនៅក្នុងដៃរបស់គាត់
ឃ្លានេះមានន័យថា «អំពើហឹង្សាដែលគាត់ធ្វើ»
តើនរណាដឹង?
ព្រះរាជាបានប្រើសំនួរនេះ
ដើម្បីឲ្យប្រជាជនគិតអំពីអ្វីមួយដែលពួកគេប្រហែលជាមិនបានគិតថាអាចធ្វើទៅបាន
ប្រសិនបើពួកគេនឹងឈប់ធ្វើបាបព្រះជាម្ចាស់ ប្រហែលជាមិនសម្លាប់ពួកគេទេ។
ឃ្លានេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍ថា «យើងមិនដឹងទេ»។
ឬឃ្លានេះអាចត្រូវបានបញ្ជាក់ជាពាក្យ និងជាផ្នែកនៃប្រយោគបន្ទាប់:
«ប្រហែលជា»។
ឃ្លាប្រៀបដូចជាការនាំមនុស្សម្នាក់នៅក្នុងទីងងឹតទៅក្នុងពន្លឺ»

Micah 7:10

គ្រានោះ ខ្មាំងសត្រូវរបស់ខ្ញុំ

មីកាមិនត្រឹមតែសំដៅទៅលើខ្លួនគាត់ប៉ុណ្ណោះទេ។ គាត់មានន័យថា
សត្រូវរបស់ប្រជាជនអ៊ីស្រាអែលទាំងអស់។

តើព្រះអម្ចាស់ជាព្រះរបស់អ្នកនៅឯណា?

សត្រូវប្រើសំនួរមួយដើម្បីចំអកប្រជាជនអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់ជាព្រះរបស់អ្នកមិនអាចជួយអ្នក»

ភ្នែករបស់ខ្ញុំ

របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំ» ឬ «យើង»

នឹងឃើញនាង

ត្រង់ថា «នាង» សំដៅទៅលើសត្រូវដែលបានធ្វើបាបប្រជាជនអ៊ីស្រាអែល។

នាងនឹងត្រូវគេជាន់ឈ្លី

របៀបផ្សេងទៀតនៃការបកប្រែ: «សត្រូវរបស់ពួកគេនឹងជាន់ឈ្លីពួកគេ»

Micah 7:11

នៅថ្ងៃដែលកំពែងក្រុងឯងនឹងបានសង់ឡើង

ពាក្យថា «ជញ្ជាំង» សំដៅទៅលើជញ្ជាំងជុំវិញទីក្រុងដែលផ្តល់សុវត្ថិភាព
និងសន្តិសុខពីសត្រូវរបស់ពួកគេ។

ទឹកដីនឹងត្រូវលាតសន្ធឹងកាន់តែឆ្ងាយ

របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់នឹងពង្រីកព្រំប្រទល់ទឹកដីរបស់អ្នក»
ឬ «ព្រះអម្ចាស់នឹងបង្កើនទំហំនៃនគររបស់អ្នកយ៉ាងខ្លាំង»

ទឹកដីទាំងនោះនឹងត្រូវបោះបង់

របៀបផ្សេងទៀតនៃការបកប្រែ: «ទឹកដីទាំងនោះនឹងនៅទទេ» ឬ
«គ្មាននរណាម្នាក់នឹងរស់នៅក្នុងទឹកដីទាំងនោះ»

Micah 7:14

ព្រះអម្ចាស់អើយ សូមថែរក្សាប្រជារាស្ត្រផ្ទាល់របស់ព្រះអង្គ ដូចអ្នកគង្វាលថែរក្សាហ្វូងសត្វ
ដែលជាមរតករបស់ព្រះអង្គ

មីកាកំពុងអធិស្ឋានដល់ព្រះយេហូវ៉ាហើយសុំឲ្យព្រះអង្គការពារប្រជាជនអ៊ីស្រាអែលជាថ្មីម្តងទៀត។

ត្រង់ថា «ដំបង» សំដៅទៅលើការដឹកនាំ
និងការណែនាំរបស់ព្រះដូចជាអ្នកគង្វាលម្នាក់ប្រើដំបង ដើម្បីដឹកនាំ
និងការពារចៀមរបស់គាត់។

ពួកគេនៅព្រៃតែម្នាក់ឯង

មីកាមានន័យថា ប្រជាជនមួយចំនួនកំពុងរស់នៅកន្លែងដែលដីក្រីក្រ
ហើយពួកគេនៅដាច់ឆ្ងាយ ហើយមិនអាចទទួលបាននូវទំនិញចាំបាច់។

សូមឲ្យពួកគេរកស៊ីនៅស្រុកបាសាន និងនៅស្រុកកាឡាត

តំបន់ទាំងនេះត្រូវបានគេស្គាល់ថា ជាដីសំបូរបែបសម្រាប់ដាំដំណាំ។
ដូច្នេះមីកាកំពុងស្នើសុំពង្រីកទឹកដីបន្ថែមទៀតដែលជាទឹកដីមួយ
ដែលត្រូវបានបាត់បង់ដោយការឈ្លានពានកាលពីប៉ុន្មានឆ្នាំមុន។

ដូចកាលពីដើម

នេះប្រហែលជាសំដៅទៅលើពេលដែលសាឡូម៉ូនជាស្តេច។

យើងនឹងឲ្យគេឃើញ

ពាក្យថា «យើង» សំដៅលើព្រះអម្ចាស់។

Micah 7:16

ពួកទាំងនោះនឹងដាក់ដៃខ្ទប់មាត់ហើយត្រចៀកគេនឹងត្រូវថ្លង់ទៅដែរ

ឃ្លានេះបង្ហាញថា
ពួកគេមានអារម្មណ៍ស្រងាកចិត្តយ៉ាងខ្លាំងដូច្នេះពួកគេមិនអាចឆ្លើយតបបានទេ។
សូមមើល UDB។

គេនឹងលិលធូលីដីដូចជាពស់ គឺដូចជាសត្វលូនវារនៅផែនដី

ឃ្លាទាំងពីរមានន័យដូចគ្នា។ ខ្មាំងសត្រូវរបស់ព្រះនឹងត្រូវអាម៉ាស់មុខទាំងស្រុង
របើម្ចាស់ជាទីស្រ័ឡាន់ប
ន្ទាប់ពីពួកគេបានឃើញការអស្ចារ្យដែលគាត់បានធ្វើ។

Micah 7:18

តើមានអ្នកណាជាព្រះឲ្យដូចព្រះអង្គ

មីកាប្រើសំនួរមួយដើម្បីបញ្ជាក់ថា
គ្មានអ្នកណាទៀតដែលធ្វើអ្វីដែលព្រះអម្ចាស់ធ្វើទេ។

មរតកព្រះអង្គដែលនៅសេសសល់

generated on Wed Sep 10 16:16:32 2025

«ពួកយើងជាមនុស្សដែលអ្នកបានជ្រើសរើសដែលបានរួចផុតពីទណ្ឌកម្មរបស់អ្នក»
Micah 7:19
ព្រះអង្គនឹង
ពាក្យថា «ព្រះអង្គ» សំដៅលើព្រះអម្ចាស់។
ដល់យើងរាល់គ្នា
ពាក្យថា «យើង» សំដៅទៅលើលោកមីកា និងប្រជាជនអ៊ីស្រាអែល។
ព្រះអង្គនឹងជាន់សេចក្តីទុច្ចរិតរបស់យើងនៅក្រោមព្រះបាទ ហើយព្រះអង្គនឹងបោះអស់ទាំងអំពើបាបរបស់យើងទៅក្នុងសមុទ្រជ្រៅ
នេះមានន័យថា ព្រះនឹងអភ័យទោសឲ្យអំពើបាបរបស់ប្រជាជនទាំងស្រុង ហើយនឹងលែងដាក់ទណ្ឌកម្មប្រជាជនចំពោះពួកគេទៀត។
សម្រេចតាមសេចក្តីពិតដល់លោកយ៉ាកុបនិងតាមសេចក្តីសប្បុរសដល់អ័ប្រាហាំ
ពាក្យថា «យ៉ាកុប» និងអ័ប្រាហាំ ដែលជាបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែល គឺសំដៅទៅលើជនជាតិអ៊ីស្រាអែលឥឡូវនេះ។
ពួកឰយុកោយើងរាល់គ្នា
នេះសំដៅទៅលើអាប្រាហាំ និងយ៉ាកុប ហើយប្រហែលជាអ្នកផ្សេងទៀត ដែលនៅរស់នៅពេល ដែលព្រះបានធ្វើកិច្ចព្រមព្រៀងជាមួយអ៊ីស្រាអែល។

ណាហ៊ូម

1 [1]នេះជាសេចក្តីប្រកាសអំពីក្រុងនីនីវេ។ សៀវភៅនេះចែងអំពីនិមិត្តហេតុដ៏អស្ចារ្យដែលលោកណាហ៊ូមជាអ្នកភូមិអែលកូស។
[2]ព្រះអម្ចាស់គឺជាព្រះប្រចណ្ឌ ព្រះអង្គក៏សងសឹក ព្រះ អម្ចាស់ សងសឹក ហើយក៏មានពេញដោយសេចក្តីក្រោធព្រះអម្ចាស់សងសឹក ដល់ពួកអ្នកតតាំងនឹងព្រះអង្គ ហើយព្រះ អង្គរក្សាសេចក្តីក្រោធ សម្រាប់ពួកខ្មាំងសត្រូវ។[3]ព្រះ អម្ចាស់យឺតនឹងខ្ញាល់ ហើយមានព្រះចេស្តាយ៉ាងខ្លាំងព្រះអង្គមិនលើកលែងទោសដល់ខ្មាំងសត្រូវឡើយ។ ផ្លូវរបស់ព្រះអម្ចាស់ នៅក្នុងខ្យល់កួច ហើយក្នុងព្យុះសង្សារ ពពកទាំងឡាយជាធូលីហុយពីព្រះបាទរបស់ព្រះអង្គ។
[4]ព្រះអង្គគំរាមសមុទ្រ ឲ្យទៅជាដីគោក ព្រះអង្គធ្វើឲ្យទន្លេទាំងប៉ុន្មានរីងស្ងួតដែរ។ ចំណែកទឹកដីបាសាន ទៅជាខ្សោយរួមទាំងទឹកដីកើមែលដែរ ផ្កាព្រៃល្បាណូនក៏ស្រពោន។[5]ភ្នំធំៗទាំងឡាយកក្រើកនៅចំពោះព្រះវត្តមានទ្រង់ ហើយភ្នំតូចទាំងប៉ុន្មានក៏រលាយ ផែនដី និងពិភពលោកទាំងមូល និងអ្វីៗទាំងអស់នៅក្នុងលោកនេះ និងដួលរលំនៅចំពោះព្រះវត្តមានទ្រង់។
[6]តើមានអ្នកណាអាចនឹងឈរនៅមុខ សេចក្តីក្រោធព្រះអង្គបាន? តើអ្នកណានឹងធន់នៅបានក្នុងពេលដែល សេចក្តីខ្ញាល់ដ៏សហ័សរបស់ព្រះអង្គឆួលឡើង? សេចក្តីក្រោធរបស់ព្រះអង្គក៏ចាក់ចេញដូចជាភ្លើង ហើយថ្មទាំងប៉ុន្មានក៏ត្រូវបែកខ្ចាយ ដោយសារព្រះអង្គ។
[7]ព្រះអម្ចាស់ល្អ ហើយជាទីពឹងមាំមួននៅថ្ងៃដ៏លំបាក ព្រះអង្គក៏ស្មោះត្រង់ដល់អស់អ្នកដែលជ្រកកោនក្នុងទ្រង់។[8]ប៉ុន្តែ ព្រះអង្គនឹងបំផ្លាញពួកបច្ចាមិត្តរបស់សត្រូវ ឲ្យវិនាសសាបសូន្យ ដោយទឹកជំនន់ ហើយនឹងដេញពួកខ្មាំងសត្រូវរបស់ព្រះអង្គទៅក្នុងទីងងឹត។
[9]តើអ្នករាល់គ្នាគិតបង្កើតគម្រោង ទាស់នឹងព្រះអម្ចាស់? ព្រះអង្គនឹងធ្វើឲ្យវាវិនាសទៅ មិនឲ្យវាធ្វើទុក្ខជាលើកទីពីរទេ។[10]ដ្បិតពួកគេនឹងត្រូវឆេះអស់រលីងដូចជាចំបើងស្ងួត ក៏ស្រវឹងដូចជាបានផឹកស្រាហើយ ពួកគេត្រូវបានលេបត្របាកដោយភ្លើង ដូចភ្លើងឆេះគំនរចំបើង។[11]មានម្នាក់ដែលនឹងងើបឡើងចេញពីចំណោមអ្នក គឺនីនីវេ ដែលគិតគូរការអាក្រក់ទាស់នឹងព្រះអម្ចាស់ គឺជាអ្នកដែលប្រឹក្សាសុទ្ធតែអំពើអាក្រក់។
[12]នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់៖ «ទោះបីខ្មាំងសត្រូវមានចំនួនច្រើន និងមានកម្លាំងយ៉ាងណាក្តី ពួកគេមុខជារលាយសូន្យ គ្មានសល់ឡើយ។ ប៉ុន្តែអ្នកវិញយូដាអើយ យើងបានបន្ទាបអ្នកម្តងហើយ តែយើងនឹងមិនបន្ទាបអ្នកទៀតទេ។[13]ឥឡូវនេះ យើងនឹងបំបាក់នឹមរបស់គេចេញពីឯង ហើយបណ្តាច់ចំណងឯងផង»។
[14]ព្រះអម្ចាស់បានផ្តល់សេចក្តីបង្គាប់អំពីអ្នក ក្រុងនីនីវេ «អ្នកនឹងមិនមានកូនចៅដើម្បីបន្តវេនឈ្មោះទៀតឡើយ។ យើងនឹងដកអស់ទាំងរូបឆ្លាក់ និងរូបសិត ចេញពីវិហាររបស់ព្រះទាំងប៉ុន្មានចេញពីរបស់ឯង។ យើងនឹងជីករណ្តៅដីហើយរៀបចំផ្នូរសម្រាប់ឯង ដ្បិតឯងគម្រក់ណាស់»។
[15]មើល៍! នៅលើភ្នំទាំងឡាយ ឃើញជើងរបស់អ្នកដែលនាំដំណឹងល្អមក គឺជាអ្នកដែលប្រកាសប្រាប់ពីសេចក្តីសុខ ចូររក្សាថ្ងៃបុណ្យទាំងប៉ុន្មានរបស់ឯង យូដាចូរលាបំណន់ឯងចុះ ដ្បិតមនុស្សពាលនឹងមិនដែល ធ្វើទុក្ខឯងទៀតឡើយ គេត្រូវវិនាសអស់ទៅ»។

Nahum 1:1
ព័ត៌មានទូទៅ៖
ណាហ៊ុមពណ៌នាអំពីការបំផ្លាញនីនីវេនៅក្នុងកំណាព្យ។
សេចក្តីប្រកាសអំពីក្រុងនីនីវេ
«រាជ្យសារពីព្រះជាម្ចាស់អំពីទីក្រុងនីនីវេ»។
អែលកូស
មនុស្សម្នាក់ដែលមកពីភូមិអែលកូស
Nahum 1:2
ព្រះអម្ចាស់
នេះគឺជាឈ្មោះរបស់ព្រះជាម្ចាស់ដែលគាត់បានបង្ហាញដល់ប្រជាជនរបស់គាត់នៅក្នុងគម្ពីរសញ្ញាចាស់។ សូមមើលការបកប្រែពាក្យនៅទំព័រពីព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។
ព្រះអង្គនឹងមិនលើកលែងទោសដល់មនុស្សឡើយ
នេះមានន័យថាព្រះអម្ចាស់នឹងវិនិច្ឆ័យទោស និងដាក់ទោសសត្រូវរបស់ព្រះអង្គ នៅពេលពួកគេមិនស្តាប់បង្គាប់ព្រះអង្គ។
ផ្លូវរបស់ព្រះអម្ចាស់ នៅក្នុងខ្យល់កួច ហើយក្នុងព្យុះសង្សារ
មានខ្យល់បក់ខ្លាំងដូចព្យុះសង្សារ ព្រះអម្ចាស់ផ្លាស់ប្តូរដោយអំណាច។
របៀបផ្សេងទៀតនៃការបកប្រែ: «មកជាអំណាច»
ធូលីហុយពីព្រះបាទរបស់ព្រះអង្គ
«ធូលីដីដែលមកពីព្រះបាទរបស់ព្រះអង្គហើរឡើង»
Nahum 1:4
ព័ត៌មានទូទៅ៖
ណាហ៊ុមនៅតែបន្តរៀបរាប់អំពីព្រះចេស្តារបស់ព្រះអម្ចាស់លើពិភពលោកទាំងមូល។
ភ្នំធំៗទាំងឡាយកក្រើកនៅចំពោះព្រះអង្គ ហើយភ្នំតូចទាំងប៉ុន្មានក៏រលាយ ផែនដី ពិភពលោកទាំងមូល
របៀបផ្សេងទៀតនៃការបកប្រែ: «ភ្នំធំៗ ទាំងភ្នំតូចៗ
សូម្បីតែដីក៏កោតខ្លាចព្រះអម្ចាស់ដែរ»
កក្រើក
ដូចជាមនុស្សដែលខ្លាច
ដួលរលំ
«ដួលទៅដីដោយភ័យខ្លាច»
Nahum 1:6
ព័ត៌មានទូទៅ៖
ណាហ៊ុមនិយាយអំពីអំណាចរបស់ព្រះអម្ចាស់
សេចក្តីខ្ញាល់ដ៏សហ័សរបស់ព្រះអង្គ
«កម្លាំងនៃកំហឹងរបស់ព្រះអង្គ» ឬ «ចំនួននៃកំហឹងរបស់ព្រះអង្គ»
ធូលីដីដែលមកពីព្រះបាទរបស់ព្រះអង្គ ... ព្រះអង្គក៏ចាក់ចេញដូចជាភ្លើង ហើយថ្មទាំងប៉ុន្មានក៏ត្រូវបែកខ្ចាយ ដោយសារព្រះអង្គ
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានបញ្ចេញកំហឹងរបស់ទ្រង់ដូចជាភ្លើងនិងបំបែកថ្ម»។
Nahum 1:7
ជាទីពឹងមាំមួន
កន្លែងមានសុវត្ថិភាពដែលបង្កើតឡើងសម្រាប់ការពារប្រឆាំងនឹងសត្រូវ
នៅគ្រាលំបាក
នៅពេលដែលសត្រូវវាយប្រហារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលមានរឿងអាក្រក់កើតឡើង»
Nahum 1:9
ព័ត៌មានទូទៅ៖
ណាហ៊ុមប្រាប់ប្រជាជននៅក្រុងនីនីវេពីរបៀបដែលព្រះអម្ចាស់នឹងដោះស្រាយជាមួយពួកគេ។
ធ្វើឲ្យគេវិនាស
«បញ្ឈប់អ្វីដែលអ្នកធ្វើ»
មិនឲ្យគេធ្វើទុក្ខជាលើកទីពីរទេ
របៀបផ្សេងទៀតនៃការបកប្រែ: «គាត់នឹងមិនវាយប្រហារអ្នកជាលើកទីពីរទេ»

generated on Wed Sep 10 16:16:32 2025

ពួកគេ...ពួកគេ...របស់ពួកគេ...របស់ពួកគេ
ណាហ៊ុមនិយាយយ៉ាងខ្លីទៅកាន់ជនជាតិអ៊ីស្រាអែលអំពីប្រជាជននីនីវេ។
ត្រូវឆេះអស់រលីងដូចជាចំបើងស្ងួត
«ប្រឈមមុខនឹងបញ្ហាជាច្រើនដែលនឹងរារាំងពួកគេពីការវាយប្រហារ» .
ពួកគេនឹងត្រូវស៊ីបំផ្លាញទាំងស្រុង
ព្រះអម្ចាស់នឹងបំផ្លាញក្រុងនីនីវេ
ប្រឹក្សាសុទ្ធតែអំពើអាក្រក់
ការលើកទឹកចិត្តឲ្យមនុស្សធ្វើអំពើអាក្រក់
Nahum 1:12
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ជនជាតិអ៊ីស្រាអែលអំពីនីនីវេ។
ពួកគេ...ពួកគេ...របស់ពួកគេ
ប្រជាជននីនីវេ
ពួកគេមុខជារលាយសូន្យ
«ពួកគេនឹងត្រូវកាត់ផ្តាច់»។
ព្រះអម្ចាស់ប្រើរូបភាពនៃការកាត់រោមចៀមចេញពីចៀម
ដើម្បីបង្ហាញពីរបៀបដែលគាត់នឹងកាត់កងទ័ពនីនីវេទោះបីជាពួកគេមានចំនួនច្រើនក៏ដោយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេមុខជារលាយសូន្យ»។
បំបាក់នឹមរបស់គេចេញពីឯង
របៀបផ្សេងទៀតនៃការបកប្រែ: «ដោះលែងអ្នកទោសដល់មនុស្សទាំងនោះ»
បណ្តាច់ចំណងឯងផង
«ផ្តាច់ច្រវាក់ដែលគេចងអ្នកធ្វើជាទាសករ»
Nahum 1:15
នៅលើភ្នំទាំងឡាយ ឃើញជើងរបស់អ្នកដែលនាំដំណឹងល្អមក
«នរណាម្នាក់ដែលកំពុងនាំយកដំណឹងល្អមក»
មនុស្សពាល...គេ
ណាហ៊ុមសំដៅទៅលើពួកនីនីវេថាពួកគេជាមនុស្សតែម្នាក់។
គេត្រូវវិនាសអស់ទៅ
ណាហ៊ុមកំពុងនិយាយអំពីព្រឹត្តិការណ៍នាពេលអនាគតដូចជាវាបានកើតឡើងរួចហើយ។

---

2 [1]អ្នកដែលកម្ចាត់កម្ចាយបានឡើងមកទាស់នឹងឯងហើយ។ ចូរការពារបន្ទាយ ត្រូវយាមផ្លូវ ចូរក្រវាត់ចង្កេះឲ្យខ្ជែងរឹង ហើយចម្រើនកម្លាំងទព័យ៉ាងសន្ធឹកចុះ។
[2]ដ្បិតព្រះអម្ចាស់កំពុងកសាងសេចក្តីរុងរឿង របស់យ៉ាកុបឡើងវិញ ដូចជារាជ្យអ៊ីស្រាអែលដែរ ដ្បិតពួកចោរប្លន់បានបំផ្លាញខ្មែង ទំពាំងបាយជូររបស់គេអស់។
[3]ខែលនៃមនុស្សខ្លាំងពូកែរបស់គេ ពណ៌ក្រហម ទាហានរបស់គេស្លៀកពាក់ពណ៌ក្រហមឆ្អៅ ចំណែក ឯរទេះចម្បាំងភ្លឺផ្លេកៗនៅថ្ងៃដែលគេប្រមូលផ្តុំទ័ព ទាំងគ្រឿលំពែងដងកកោះ។[4]រទេះចម្បាំងរត់យ៉ាងសម្បើមទៅតាមផ្លូវ រត់ចុះឡើងតាមផ្លូវ មានភាពដូចជាចន្លុះ ហើយរត់លឿនដូចជាផ្លេកបន្ទោរ។
[5]ម្នាក់ដែលនឹងមកបំផ្លាញអ្នកទៅជាចំណែកតូចៗ បានហៅជាមេទ័ព តែពួកគេភ័យញ័រនៅក្នុងចំណោមគេទាំងញ័ររជើងផង ពួកគេប្រញាប់ប្រញាល់ដើម្បីវាយកំផែងក្រុង។ ខែលធំទាំងនេះគឺធ្វើសម្រាប់ការពារទ័ពប្រយុទ្ធទាំងនោះ។
[6]ទ្វារខាងទន្លេបានបង្ខំឲ្យរបើកឡើង ហើយដំណាក់ស្តេចក៏រលំចុះក្រោម។[7]ព្រះនាងហ៊ូសាបត្រូវគេយកសំលៀកបំពាក់និងចាប់ជាឈ្លើយ ពួកបាវបម្រើស្រីរបស់ព្រះនាងក៏យំថ្ងូរដូចជាសត្វព្រាបទាំងគក់ទ្រូងផង។
[8]ក្រុងនីនីវេប្រៀបដូចជាអាងទឹកដែលធ្លាយ គឺមនុស្សបានរត់ភៀសខ្លួន ដូចជាទឹកបុកគំហុក។ គេឯទៀតស្រែកថា «ឈប់សិន ឈប់សិន» តែគ្មាននរណាមួយបែរក្រោយឡើយ។[9]ចូរយកប្រាក់ជាជ័យភ័ណ្ឌ យកមាសជាជ័យភ័ណ្ឌចុះ ដ្បិតរបស់ទ្រព្យមិនចេះអស់មិនចេះហើយទេ សុទ្ធតែជាប្រដាប់ប្រដាយ៉ាងល្អវិសេស។[10]ទីក្រុងនីនីវេនៅទទេ ក៏ខូចបង់ មនុស្សក៏រសាយចិត្តទៅ ទាំងទន់ជង្គង់ ញ័រខ្លួន ហើយមុខរបស់គេទាំងអស់គ្នាក៏ស្លេកស្លាំង។
[11]តើរូងសិង្ហនោះបាត់ទៅណាហើយ ប្រៀបដូចជាកន្លែងដែលចិញ្ចឹមពួកសិង្ហស្ទាវ សិង្ហឈ្មោល និងសិង្ហញីឲ្យដើរនៅទីនោះ ព្រមទាំងកូនសិង្ហ ឥតមានអ្នកណាបំភ័យវាឡើយ?[12]ឯសិង្ហឈ្មោល វាតែងតែហែកវំពាលមមែតកូនក៏ខាំកសត្វយកមកឲ្យញី ព្រមទាំងពាំសាច់សត្វមកដាក់ពេញក្នុងរូងវាទៀតផង។
[13]«មើល៍! យើងទាស់នឹងឯង នេះគឺជាការប្រកាសរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។ យើងនឹងដុតអស់ទាំងរទេះចម្បាំងរបស់ឯង ឲ្យទៅជាផេះ ហើយដាវនឹងស៊ីកូនសិង្ហរបស់ឯង យើងនឹងបំបាត់ជ័យភ័ណ្ឌចេញពីទឹកដីរបស់ឯង ហើយគេនឹងលែងឮសំឡេងរបស់អ្នកនាំសារទៀតឡើយ»។

Nahum 2:1
ព័ត៌មានទូទៅ៖
ណាហ៊ុមបន្តរៀបរាប់អំពីការបំផ្លាញនីនីវេនៅក្នុងកំណាព្យដែលបានចាប់ផ្តើមនៅជំពូក ១: ១។
សត្រូវបានឡើងមកទាស់នឹងឯងហើយ
រូបភាពនេះគឺជារបស់នរណាម្នាក់ដែលបំបែកឆ្នាំង។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គដែលនឹងបំផ្លាញអ្នក»
សត្រូវបានឡើងមក
បុគ្គលដែលជា «ម្នាក់» មិនច្បាស់ទេដូច្នេះបកប្រែដោយប្រើពាក្យទូទៅថា «អ្នកដែលនឹងបំបែកអ្នកទៅជាបំណែកៗ»។
ចូរការពារបន្ទាយ ត្រូវយាមផ្លូវ ចូរក្រវាត់ចង្កេះឲ្យខ្ជែងរឹង ហើយចម្រើនកម្លាំងយ៉ាងសន្ធឹកចុះ
ត្រៀមសម្រាប់សង្គ្រាម
ចូរការពារបន្ទាយ
«ដាក់ឆ្មាំដើម្បីការពារបន្ទាយ»
ដ្បិតព្រះអម្ចាស់កំពុងកសាងសេចក្តីរុងរឿង របស់យ៉ាកុបឡើងវិញ ដូចជាអ៊ីស្រាអែលដែរ
នេះមានន័យថា ព្រះអម្ចាស់នឹងធ្វើអោយយ៉ាកុប និងអ៊ីស្រាអែលប្រសើរ ហើយប្រជាជននឹងកោតសរសើរពួកគេម្តងទៀត។
ចោរប្លន់
មនុស្សដែលលួចរបស់របរដោយកម្លាំងជាធម្មតានៅក្នុងសង្គ្រាម
បានបំផ្លាញពួកគេ
បំផ្លាញអ្វីៗទាំងអស់
បំផ្លាញខ្មែង ទំពាំងបាយជូររបស់គេអស់
ប្រទេសនេះត្រូវបានគេនិយាយនៅទីនេះដូចវាជាចំការទំពាំងបាយជូរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយដកប្រទេសរបស់អ្នកដូចវាជាចម្ការទំពាំងបាយជូរ»។
Nahum 2:3
មនុស្សខ្លាំងពូកែ
ទាហានម្នាក់ «មួយដែលនឹងលោត» នីនីវេ «ទៅជាបំណែក» (២: ១)។
ដើមស្រល់
ដើមឈើមួយប្រភេទដែលជាឈើល្អសម្រាប់ធ្វើអាវុធ
រទេះចម្បាំងរត់យ៉ាងសម្បើមទៅតាមផ្លូវ
«អ្នកបើករទេះសេះបើកបរយ៉ាងលឿននៅតាមផ្លូវ»
រត់ចុះឡើងតាមផ្លូវ មានភាពដូចជាចន្លុះ
នេះសំដៅទៅលើពន្លឺរបស់រទេះសេះនៅពេលពួកគេឆ្លុះបញ្ចាំងពន្លឺពីព្រះអាទិត្យ។
Nahum 2:5
បំផ្លាញអ្នកទៅជាចំណែកតូចៗ
ការបកប្រែនេះដូចដែរអ្នកបានធ្វើក្នុងជំពូក ២: ១។
បានហៅពលទ័ពរបស់ខ្លួនមក
អត្ថន័យដែលអាចមាន ១) «កោះហៅមន្ត្រីរបស់គាត់» ឬ ២) គិតអំពីមន្ត្រីរបស់គាត់
ពួកគេ...របស់ពួកគេ...ពួកគេ
ទាហានដែលនឹងវាយប្រហារនីនីវេ
ការដើរក្បួនរបស់ពួកគេ
«នៅពេលពួកគេដើរក្បួន»
Nahum 2:6
ព្រះនាងហ៊ូសាប
ឈ្មោះនេះប្រហែលជាឈ្មោះរបស់មហាក្សត្រីស្រុកអាស្ស៊ីរី ឬឈ្មោះរូបព្រះនៅអាសស៊ើរ។
ប្រសិនបើវានិយាយអំពីមហាក្សត្រីបន្ទាប់មកការអនុម័តមានន័យថាទាហានវាយប្រហារបានដោះសម្លៀក
ប្រសិនបើនិយាយអំពីរូបចម្លាក់បន្ទាប់មកការអនុម័តមានន័យថា អ្នកវាយប្រហារបានដោះមាស និងប្រាក់ចេញពីរូបភាពនោះ។
ពួកបាវបម្រើស្រីរបស់ព្រះនាងក៏ថ្ងូរដូចជាព្រាប
«អ្នកបំរើស្រីរបស់មហាក្សត្រីស្តាប់ទៅដូចជាសត្វព្រាបនៅពេលដែលពួកគេស្រែកថ្ងូរ»

generated on Wed Sep 10 16:16:32 2025

ដើម្បីកាន់ទុក្ខការបាត់បង់អំណាចរបស់នាង
Nahum 2:8
រឺបអូស
វត្ថុដែលត្រូវបានលួចដោយកម្លាំងជាធម្មតានៅក្នុងសង្គ្រាម។
មិនចេះអស់មិនចេះហើយ
នេះគឺជាមធ្យោបាយដើម្បីនិយាយថា មានបរិមាណដ៏ច្រើន។
របៀបផ្សេងទៀតនៃការបកប្រែ: «វាមានបរិមាណច្រើន»
សុទ្ធតែជាប្រដាប់ប្រដាយ៉ាងល្អវិសេស
អត្ថន័យដែលអាចមាន ១) «ភាពសម្បូរបែបនៃរបស់ល្អទាំងអស់» ឬ ២)
«ចំនួនរបស់ដែលស្រស់ស្អាតទាំងអស់»
មនុស្សក៏រសាយចិត្តទៅ
«ប្រជាជនទាំងអស់បាត់បង់ភាពក្លាហាន»
Nahum 2:11
រូងសិង្ហ
នីនីវេកំពុងត្រូវបានគេប្រៀបធៀបទៅនឹងរូងតោពីព្រោះជាកន្លែង
ដែលឃាតករស់នៅ
និងជាកន្លែងដែលពួកគេយកអ្វីដែលពួកគេបានលួចពីមនុស្សដែលពួកគេបានសម្លាប់។
ខាំក
«ញាក់»។ សត្វតោខាំបំពង់ករបស់ជនរងគ្រោះ
ដើម្បីការពារពួកគេពីការដកដង្ហើម។
ពាសាច់សត្វមកដាក់ពេញក្នុងរូងវាទៀតផង
ឃ្លាទាំងពីរនេះកំពុងនិយាយដូចគ្នាតាមវិធីផ្សេងគ្នា។
រូងរបស់សត្វតោដែលជាកន្លែងលាក់ខ្លួនរបស់វាច្រើនតែនៅក្នុងរូងភ្នំ។
Nahum 2:13
មើល៍
«យល់ពីរឿងនេះ»
ដាវនឹងស៊ីកូនសិង្ហរបស់ឯង
«ទាហានរបស់អ្នកនឹងត្រូវស្លាប់ដោយអំពើហឹង្សា»
ដាវ
«ទាហានកាន់ដាវ»
ស៊ី
«ស៊ីអ្វីៗទាំងអស់»
កូនសិង្ហរបស់ឯង
«កូនសិង្ហដែលនៅតូច»
យើងនឹងបំបាត់ការចាប់រំពារបស់ឯងពីផែនដី
ពាក្យថា «ប្លន់» សំដៅទៅលើទ្រព្យសម្បត្តិដែលនីនីវេបានចាប់យក
និងបានមកពីទឹកដីផ្សេងទៀត។ នេះមានន័យថា
ព្រះអម្ចាស់នឹងបំផ្លាញសមត្ថភាពរបស់នីនីវេក្នុងការលួចពីប្រជាជាតិផ្សេងទៀត។

---

3 [1]វេទនាដល់ទីក្រុងដែលប្រឡាក់ដោយឈាម! វាមានពេញដោយការកុហក និងការលួចប្លន់មិនឈប់ឈរ អំពើឃោរឃៅ គឺតែងតែកើតឡើងនៅក្នុងទីក្រុងនេះ។
[2]ប៉ុន្តែពេលនេះ មានតែសូរសម្លេងយំសោក ហើយនិងសម្លេងសូរសន្ធឹកកង់ សូរសេះបោល និងសូររទេះចម្បាំងវិញ។
[3]មានកងទ័ពប្រយុទ្ធសេះបានសំរុកចូល ជាមួយដាវដែលភ្លឺចាំង ហើយលំពែងផ្លេកៗ មានសាកសពគរលើគ្នាយ៉ាងច្រើន មានមនុស្សស្លាប់យ៉ាងសន្ធឹក
វាគ្មានទីបញ្ចប់ឡើយ អ្នកដែលវាយប្រហារគេបានជំពប់ដួលលើសាកសពនោះ។[4]នេះគឺដោយព្រោះការកំផិតយ៉ាងសន្ធឹករបស់ស្រីពេស្យា ដែលមានរូបឆោមឆាយជាមេនៃ
អស់ទាំងអំពើអាបធ្មប់ ជាអ្នកដែលលក់ជនជាតិទាំងឡាយ ដោយសារការកំផិតរបស់វា ព្រមទាំងគ្រួមនុស្សផង ដោយសារអំពើអាបធ្មប់របស់វា។
[5]«មើល៍! យើងទាស់ប្រឆាំងនិងឯង នេះព្រះអម្ចាស់នៃពិភពទាំងមូល មានព្រះបន្ទូលថា យើងនឹងសើយសំពត់ឯងឡើងគ្របមុខឯង ហើយនឹងបង្ហាញឲ្យពួកជនជាតិទាំង
ប៉ុន្មាន ឃើញកាយអាក្រាត និងឲ្យអស់ទាំងនគរ ឃើញកេរ្តិ៍ខ្មាសរបស់ឯង។[6]ហើយយើងនឹងបោះសេចក្តីកខ្វក់ គួរខ្ពើមទៅលើឯង ឲ្យឯងទៅជាស្មោកគ្រោក រួចនឹងតាំងឯង
ឲ្យមនុស្សមើលលេង។[7]នោះអស់អ្នកណាដែលឃើញឯង និងគេចរត់ពីឯងទៅ ដោយពាក្យថា «ក្រុងនីនីវេបានត្រូវខូចបង់ហើយ តើអ្នកណានឹងយំសោក» តើនឹងរកអ្នក
ណាអាចជួយរំលែកទុក្ខអ្នកបាន?»
[8]នីនីវេ! តើឯងវិសេសជាងក្រុងថេប ដែលនៅជាប់ទាំងទន្លេនីលហើយមានទឹកនៅព័ទ្ធជុំវិញនោះ ក៏មានសមុទ្រការពារ គឺសមុទ្រទុកជាកំផែងឬអី?[9]ទឹកដីអេត្យូពី និងទឹកដី
អេស៊ីប ជាកម្លាំងដែលមិនចេះសាបសូន្យរបស់គេ រីឯអ្នកទឹកដីពូថ និងអ្នកទឹកដីលីប៊ី ក៏ជាពួកសម្ព័ន្ធមិត្តរបស់គេដែរ។
[10]ទោះបីបោះបង់យ៉ាងនេះក្តី នាងក៏ទៅជាឈ្លើយដែរ ទារករបស់គេត្រូវខ្ទាំងជាន់សម្លាប់នៅតាមផ្លូវ ពួកអ្នកធំរបស់គេត្រូវខ្ទាំងចាប់ឆ្នោតចែកគ្នា មេដឹកនាំរបស់គេជាប់ច្រវាក់
ទាំងអស់គ្នា។[11]ឯងនិងត្រូវស្រវឹងដូច្នោះដែរ អ្នកនឹងព្យាយាមលាក់ខ្លួន ហើយនឹងស្វែងរកទីកន្លែងពួន ឲ្យរួចផុតពីខ្មាំងសត្រូវ។
[12]អស់ទាំងបន្ទាយរបស់ឯងនឹងដូចជាដើមល្វា ដែលមានផ្លែទុំជាដំបូង បើអ្នកណាអង្រួន នោះផ្លែក៏ជ្រុះចូលក្នុងមាត់របស់អ្នកដែលស៊ី។[13]មើល៍
នៅក្នុងចំណោមពួកស្រីៗរបស់ពួកអ្នក ទ្វារនៃទឹកដីឯងបើកចំហសម្រាប់ខ្មាំងសត្រូវ ភ្លើងបានឆេះរនុកអ្នកអស់ទៅហើយ។
[14]ចូរដងទឹកទុកសម្រាប់ពេលដែលសត្រូវឡោមព័ទ្ធឯងជុំជិត ត្រូវរៀបចំបន្ទាយឯងឲ្យមាំមួនឡើង ចូរចុះទៅលាយដីឥដ្ឋ ហើយជួសជុលឡឥដ្ឋឲ្យមាំមួន។[15]ភ្លើងនឹងឆេះ
បន្សុសអ្នកគ្មានសល់ ហើយនឹងមានដាវកាត់អ្នកផងដែរ។ គឺវានឹងស៊ីបង្ហិនអ្នកដូចជាកណ្តូប។ ចូរចម្រើនគ្នាឲ្យច្រើនឡើងដូចកណ្តូបទៅ ត្រូវឲ្យមានគ្នាច្រើនដូចជាកណ្តូប
ផង។
[16]អ្នកបានចម្រើនពួកជំនួញរបស់ឯង ឲ្យមានច្រើនជាងផ្កាយនៅលើមេឃ តែពួកគេដូចជាកណ្តូបតូចៗ ក៏ត្រូវបានដង្កូវស៊ីបង្ហិននៅលើដី រួចទៅបាត់ហើយ។[17]ពួកចៅហ្វាយ
របស់ឯងប្រៀបដូចជាកណ្តូប ហើយពួកមេទ័ពរបស់ឯងក៏ដូចជាហ្វូងកណ្តូប ដែលទំក្នុងរបងនៅពេលថ្ងៃរងា។ ប៉ុន្តែ កាលណាថ្ងៃរះឡើង នោះវាហើរទៅបាត់
ទៅកន្លែងណាក៏មិនដឹងដែរ។
[18]ស្តេចជនជាតិអាសស៊ីរី ពួកគង្វាលរបស់អ្នក គេដេកលក់អស់ហើយ ការគ្រប់គ្រងដែលពេញដោយកុហកនិងដួលទៅ ប្រជាជនរបស់អ្នកត្រូវកំចាត់កំចាយទៅលើភ្នំ ឥត
មានអ្នកណានឹងប្រមូលគេឡើយ។[19]គ្មានអ្វីអាចព្យាបាលអ្នកឲ្យបាត់របួសឡើយ ព្រោះរបួសអ្នកធ្ងន់ណាស់។ គ្រប់គ្នាដែលឮដំណឹងពីអ្នក គេទះដៃអរសប្បាយដាក់អ្នកដែរ។
តើមានអ្នកណាដែលបានគេចពីអំពើកំណាច របស់អ្នកបាននោះ?

Nahum 3:1
ព័ត៌មានទូទៅ៖
ណាហ៊ុមបន្តរៀបរាប់អំពីការបំផ្លាញនីនីវេនៅក្នុងកំណាព្យដែលបានចាប់ផ្តើមនៅជំពូក
១: ១។
ទីក្រុងដែលប្រឡាក់ដោយឈាម
ទាហានរបស់នីនីវេបានសម្លាប់មនុស្សជាច្រើន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទីក្រុងទទួលខុសត្រូវចំពោះការស្លាប់មនុស្សជាច្រើន»
Nahum 3:3
មានមនុស្សស្លាប់យ៉ាងសន្ធឹក សាកសពគរលើគ្នាយ៉ាងធំ ឃើញមានសាកសពនៅគ្រប់កន្លែង
អ្នកនិពន្ធកំពុងបញ្ជាក់ទៅលើការសំលាប់យ៉ាងជ្រៅប្រឆាំងនឹងនីនីវេចាប់តាំងពីត្រូវបានដើម
៣ ដង។
សាកសព
សាកសពមនុស្សដែលបានស្លាប់
សាកសពគរលើគ្នា
«មានសាកសពជាច្រើន»
ស្រីពេស្យាដែលមានរូបឆោមឆាយ...មេនៃអស់ទាំងអំពើអាបធ្មប់
នៅពេលដែលស្រីពេស្យាលក់ភាពរីករាយខាងរាងកាយ
និងអាបធ្មប់លក់ចំណេះដឹង
និងអំណាចដែលទទួលបានតាមរយៈមន្តអាគមប្រជាជននីនីវេលក់មនុស្ស
ដែលពួកគេបានធ្វើសង្គ្រាម ហើយទាញយកចំណេញពីអំពើបាបរបស់ពួកគេ។
Nahum 3:5
មើល៍
ពាក្យនេះជួយទាក់ទាញការយកចិត្តទុកដាក់ចំពោះអ្វីដែលកើតឡើងបន្ទាប់។
ដើម្បីអ្នកណានឹងយំសោក? តើនឹងរកអ្នកណាអាចជួយរំលែកទុក្ខអ្នកបាន?
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាម្នាក់យំជំនួសនាងឡើយ»
Nahum 3:8
ព័ត៌មានទូទៅ៖
ណាហ៊ុមនិយាយទៅកាន់ប្រជាជននីនីវេហាក់ដូចជាពួកគេជាទីក្រុងផ្ទាល់។

generated on Wed Sep 10 16:16:32 2025

តើឯងវិសេសជាងក្រុងថេប...ខ្លួនវាឬអី?
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនប្រសើរជាងក្រុងថេប...ខ្លួនវាទេឬអី»។
ក្រុងថេប
អតីតរដ្ឋធានីនៃប្រទេសអេហ្ស៊ីបដែលប្រជាជនអាសស៊ើរបានវាយយកបាន
ក៏មានសមុទ្រការពារ គឺសមុទ្រទុកជាកំផែងឬអី
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។ ពាក្យថា «មហាសមុទ្រ» និង «សមុទ្រ»
ទាំងពីរសំដៅទៅលើទន្លេនីលដែលបានរត់ជិតទីក្រុង
ហើយធ្វើឲ្យការវាយប្រហារពិបាក។
ការពារ...កំផែង
ទីក្រុងបុរាណមាន «កំផែង» ដើម្បីកុំអោយអ្នកវាយប្រហារចេញ
និងខ្សែការពារខាងក្រៅ ដើម្បីការពារអ្នកវាយប្រហារពីកំផែង។
Nahum 3:10
ព័ត៌មានទូទៅ៖
ណាហ៊ុមនិយាយទៅកាន់ប្រជាជននីនីវេហាក់ដូចជាពួកគេជាទីក្រុងផ្ទាល់។
ទោះបីយ៉ាងនេះក្តី
នេះបន្តការប្រៀបធៀបក្រុងនីនីវេ និងក្រុងនរក្នុងជំពូក ៣: ៨។
អត្ថន័យដែលអាចមាន (UDB) «យ៉ាងណាក៏ដោយ»
ក៏នរ-អាម៉ូន
អតីតរដ្ឋធានីនៃប្រទេសអេហ្ស៊ីបដែលប្រជាជនអាសស៊ើរបានវាយយកបាន
នាង...របស់នាង
ក៏នរ-អាម៉ូន។
ដាច់ជាបំណែកៗ
ពួកឈ្លានពានបានសម្លាប់កូនៗរបស់ក៏នរ-
អាម៉ូនយ៉ាងងាយស្រួលនៅពេលដែលពួកគេបំបែកឆ្នាំងដីឥដ្ឋ។
ជាប់ច្រវាក់
ដាក់ចូលទៅក្នុងទាសករ។ របៀបផ្សេងទៀតនៃការបកប្រែ: «ក្លាយជាទាសករ»
Nahum 3:12
ព័ត៌មានទូទៅ៖
ណាហ៊ុមនិយាយទៅកាន់ប្រជាជននីនីវេហាក់ដូចជាពួកគេជាទីក្រុងផ្ទាល់។
បន្ទាយ
ពាក្យនេះដែលអាចត្រូវបានបកប្រែជា: «បន្ទាយ» សំដៅទៅលើទីក្រុងនីនីវេ
និងចក្រភពអាសស៊ើរទាំងអស់។
អស់ទាំងបន្ទាយរបស់ឯងនឹងដូចជាដើមល្វា ដែលមានផ្លែទុំជាដំបូង បើអ្នកណាអង្រួន នោះផ្លែក៏ជ្រុះ
ចូលក្នុងមាត់របស់អ្នកដែលស៊ី
ទីក្រុងនីនីវេនឹងងាយស្រួលយកដូចជាបេះផ្លែឈើពីដើមឈើ។
នៅក្នុងចំណោមពួកស្រីៗរបស់ពួកអ្នក
«ប្រជាជនរបស់អ្នកខ្សោយហើយមិនអាចការពារខ្លួនបានទេ»
Nahum 3:14
ព័ត៌មានទូទៅ៖
ណាហ៊ុមនិយាយទៅកាន់ប្រជាជននីនីវេហាក់ដូចជាពួកគេជាទីក្រុងផ្ទាល់។
គឺវានឹងស៊ីបង្ហិនអ្នកដូចជាកណ្តូប
វានឹងបំផ្លាញដូចកណ្តូបបំផ្លាញអ្វីៗគ្រប់យ៉ាងតាមផ្នែករបស់វា។
វា
ពាក្យ «ភ្លើងឆេះ» និង «ដាវ»
ចូរចម្រើនគ្នាឲ្យច្រើនឡើងដូចកណ្តូបទៅ ត្រូវឲ្យមានគ្នាច្រើនដូចជាកណ្តូបផង
ដុះលូតលាស់ «អោយច្រើនឡើងដូចកណ្តូប ដើម្បីឱ្យមានភាពប្លែកគ្នារវាងកណ្តូប!»
ពាក្យទាំងនេះប្រហែលជាចាប់ផ្តើមវគ្គថ្មី។
ចូរចម្រើនគ្នាឲ្យច្រើនឡើងដូចកណ្តូបទៅ
នេះមានន័យថាពួកគេនឹងក្លាយជាទីក្រុងធំមួយដែលមានមនុស្សជាច្រើន
និងបំផ្លាញទឹកដីជាច្រើន។
Nahum 3:16
ព័ត៌មានទូទៅ៖
ណាហ៊ុមនិយាយទៅកាន់ប្រជាជននីនីវេហាក់ដូចជាពួកគេជាទីក្រុងផ្ទាល់។
អ្នកបានចម្រើនពួកជំនួញរបស់ឯង ឲ្យមានច្រើនជាងផ្កាយនៅលើមេឃ
ពួកជំនួញនីនីវេមិនអាចរាប់បានដូចផ្កាយនៅលើមេឃទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមានជាឈ្មួញគឺច្រើនមិនអាចរាប់អស់បានទេ»។
ពួកជំនួញ
«ពាណិជ្ជករ» ឬ «អ្នកដែលទិញនិងលក់របស់របរ»
ចៅហ្វាយ
ប្រើពាក្យសម្រាប់ «មេដឹកនាំ» នយោបាយ (UDB)។
ពួកមេទ័ព
ប្រើពាក្យសម្រាប់មេដឹកនាំ «យោធា» ឬអាជ្ញាធររដ្ឋាភិបាលផ្សេងទៀត។
Nahum 3:18
ពួកគង្វាល
«គង្វាល» ត្រង់នេះតំណាងអោយអភិបាលនៃប្រជាជនអាសស៊ើរ។
តើមានអ្នកណាដែលបានគេចពីអំពើកំណាច របស់អ្នកបាននោះ?
របៀបផ្សេងទៀតនៃការបកប្រែ:
«សកម្មភាពអាក្រក់ឥតឈប់ឈររបស់អ្នកបានធ្វើឲ្យមនុស្ស
និងប្រជាជាតិជាច្រើនបានឈឺចាប់»។

ហាបាគូក

1 [1]នេះគឺជាសេចក្តីប្រកាសដែលឲ្យព្យាការីហាបាគូកបានឃើញ[2]«ព្រះអម្ចាស់អើយ តើទូលបង្គំត្រូវស្រែកឲ្យព្រះអង្គជួយដល់ពេលណាទៅ
តើព្រះអម្ចាស់បានឮទូលបង្គំទេ? ទូលបង្គំស្រែកដល់ព្រះអម្ចាស់ដោយក្តីរន្ធត់ «អំពើឃោរឃៅ!» ប៉ុន្តែព្រះអង្គមិនសង្គ្រោះទូលបង្គំទេ។
[3]ហេតុអ្វីបានជាព្រះអង្គឲ្យទូលបង្គំឃើញតែសេចក្តីទុច្ចរិត ហើយនិងក្តីមិនត្រឹមត្រូវយ៉ាងនេះ? ហើយនៅជុំវិញទូលបង្គំឃើញតែសេចក្តីហិនវិនាស និងអំពើឃោឃៅ
ការឈ្លោះទាស់ទែង និងប្តឹងផ្តល់គ្នា។[4]ច្បាប់ទៅជាខ្សោយហើយភាពយុត្តិធម៌ ក៏មិនមាននរណាធ្វើតាមដែរ។ ដ្បិតមនុស្សអាក្រក់នៅជុំវិញមនុស្សសុចរិត
ហើយក្តីអយុត្តិធម៌កើតឡើង»។ ព្រះអម្ចាស់ក៏តបទៅលោកហាបាគូក
[5]«ចូរមើលទៅប្រជាជាតិនានា ហើយនាំគ្នាពិចារណាអំពីពួកគេទៅ ហើយមានការអស្ចារ្យបានកើតឡើង! ដ្បិត យើងជឿថា អ្វីដែលកំពុងតែកើតមាននៅជំនាន់អ្នករាល់គ្នា
បើសិនអ្នកគ្រាន់តែឮ នោះអ្នកនឹងមិនជឿឡើយ។[6]មើល៍! យើងនឹងតាំងជនជាតិខាល់ដេឡើង ហើយជនជាតិនេះសាហាវកោងកាចបំផុត!
គេនឹងលើកគ្នាដើរកាត់ផែនដីទាំងមូល ដើម្បីដណ្តើមយកទឹកដីពីជនជាតិផ្សេង ដែលមិនមែនជារបស់ខ្លួន[7]ពួកគេជាមនុស្សដែលគួរឲ្យភ័យខ្លាច និងភ័យញ័រ
ពួកគេបង្កើតច្បាប់ និងសិទ្ធអំណាច មកតែពីខ្លួនគេទេ។
[8]សេះរបស់ពួកគេបោលលឿនជាខ្លារខិន ហើយសាហាវជាងឆ្កែចចកដែលរកស៊ី នៅពេលព្រលប់ទៅទៀត។ កងទ័ពសេះរបស់ពួកគេសម្រុកចូលដោយឥតញញើត
ដូចសត្វឥន្ទ្រីបោះពួយមកចាប់រំពារ[9]ពួកគេនាំគ្នាមកដើម្បីបំផ្លាញ ទឹកមុខរបស់ពួកគេពិតជាសាហាវណាស់ ហើយពួកគេចាប់ឈ្លើយសឹកដូចជាខ្សាច់។
[10]ពួកគេសើចចំអកឡកឡើយឲ្យស្តេចនានា ហើយមើលងាយដល់មេដឹកនាំទាំងឡាយ ពួកគេនឹងមិនញញើតនឹងកំផែងក្រុងទាំងនោះឡើយ
ដ្បិតពួកគេគ្រាន់តែលើកសម្លេងឡើង ផែនដីនឹងជារបស់គេ។[11]ពេលពួកគេមានកម្លាំងគេក៏បន្តរដំណើរទៅមុខដូចជាខ្យល់ព្យុះ ដើម្បីប្រព្រឹត្តអំពើអាក្រក់
ពួកគេចាត់ទុកកម្លាំងរបស់ខ្លួនដូចជាព្រះ»។ ព្យាការីហាបាគូកទូលសួរទៅព្រះអម្ចាស់នូវសំនួរផ្សេងទៀត
[12]«ព្រះអម្ចាស់ជាព្រះនៃទូលបង្គំ ជាព្រះដ៏បរិសុទ្ធនៃទូលបង្គំអើយ! ព្រះអង្គគង់នៅតាំងពីដើមរៀងមក យើងខ្ញុំនឹងមិនស្លាប់ទេ ព្រះអង្គដែលជាថ្មដានៃទូលបង្គំអើយ!
ព្រះអង្គបានតាំងខ្មាំងសត្រូវឡើងដើម្បីវាយផ្ចាលយើងខ្ញុំ ព្រះអង្គឲ្យកម្លាំងដល់គេដើម្បីវាយប្រដៅយើងខ្ញុំ។
[13]ព្រះអង្គមានព្រះនេត្របរិសុទ្ធ ហើយព្រះអង្គទ្រាំ មើលការអាក្រក់មិនបានទេ ព្រះអង្គក៏ពុំអាចទតមើលការទុច្ចរិតមិនបានដែរ ហេតុអ្វីបានជាព្រះអង្គទតមើលពួកអ្នក
ដែលប្រព្រឹត្តការក្បត់? ហេតុអ្វីបានជាព្រះអង្គធ្វើព្រងើយ ពេលឃើញមនុស្សអាក្រក់បំផ្លាញអ្នកដែលសុចរិតជាងពួកគេ?[14]ព្រះអង្គធ្វើឲ្យមនុស្សដូចជាត្រីដែលនៅក្នុងសមុទ្រ
ឬដូចសត្វលូនវា ដែលគ្មានអ្នកណាគ្រប់គ្រងលើពួកគេ។

generated on Wed Sep 10 16:16:32 2025

[15]ប្រជាជនទាំងអស់ត្រូវខ្មាំងចាប់ដូចជាត្រីជាប់សន្ទូង និងជាប់សំណាញ់ ខ្មាំងបង់សំណាញ់ចាប់ពួកគេ យកទៅ ទាំងមានចិត្តអរសប្បាយហើយរីករាយ
[16]ហេតុនោះបានជាគេថ្វាយយញ្ញបូជាដល់សំណាញ់របស់គេ ព្រោះគេបានអាហារឆ្ងាញ់យ៉ាងបរិបូណ៌ដោយសាររបស់ទាំងនោះ[17]ដូច្នេះ តើពួកសម្លាត់សំណាញ់របស់ពួកគេ
ហើយបន្តប្រហារជីវិតប្រជាជាតិនានាដោយគ្មានការប្រណីបែបនេះមែនទេ?»

Habakkuk 1:1
នេះគឺជាសេចក្តីប្រកាសដែលឲ្យព្យាការីហាបាគូកបានឃើញ
ពាក្យទាំងនេះណែនាំពីរជំពូកដំបូងនៃព្រះគម្ពីរ។ ប្រសិនបើ
ភាសារបស់អ្នកត្រូវការប្រយោគពេញលេញនៅទីនេះ
«នេះគឺជាសារដែលព្យាការីហាបាគុកបានទទួលពីព្រះជាម្ចាស់»។
ព្រះអម្ចាស់
នេះគឺជាព្រះនាមរបស់ព្រះជាម្ចាស់
ដែលព្រះអង្គបានបង្ហាញដល់ប្រជារាស្ត្ររបស់ព្រះអង្គ នៅក្នុងគម្ពីរសញ្ញាចាស់។
សូមមើលការបកប្រែទំព័រពាក្យអំពីព្រះអម្ចាស់ទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។
តើទូលបង្គំត្រូវស្រែកឲ្យព្រះអង្គជួយដល់ពេលណាទៅ តើព្រះអម្ចាស់បានឮទូលបង្គំទេ?
របៀបផ្សេងទៀតនៃការបកប្រែ
«ខ្ញុំបានស្រែករកជំនួយអស់រយៈពេលជាយូរមកហើយ
ប៉ុន្តែអ្នកធ្វើហាក់ដូចជាអ្នកមិនស្តាប់ខ្ញុំ!»
Habakkuk 1:3
ព័ត៌មានទូទៅ៖
ហាបាគុកបន្តអធិស្ឋានដល់ព្រះ។
ប្តឹងផ្តល់គ្នា
«ការវាយប្រយុទ្ធគ្នាក្នុងចំណោមប្រជាជនកំពុងតែក្លាយជារឿងធម្មតា»
មនុស្សអាក្រក់នៅជុំវិញមនុស្សសុចរិត
នេះអាចមានន័យថា មនុស្សសុចរិតទទួលរងនូវភាពអយុត្តិធម៌ពីព្រោះគឺ ទី១) «មនុស្សអាក្រក់មានអំណាចច្រើនជាងមនុស្សសុចរិត» ឬទី២) គឺ «មានមនុស្សអាក្រក់ច្រើនជាងមនុស្សសុចរិតទៅទៀត»។
ហើយក្តីអយុត្តិធម៌កើតឡើង
របៀបផ្សេងទៀតនៃការបកប្រែ: «អំពើអាក្រក់កើតឡើងជំនួសអំពើយុត្តិធម៌» ឬ «ភាពអយុត្តិធម៌កើនឡើង»
Habakkuk 1:5
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់ឆ្លើយតបការអធិស្ឋានរបស់ហាបាគុក។
ចូរមើលទៅប្រជាជាតិនានា ហើយនាំគ្នាពិចារណាអំពីពួកគេទៅ
«រៀនពីអ្វីដែលកំពុងកើតឡើងនៅក្នុងប្រជាជាតិដទៃទៀត»
ផែនដីទាំងមូល
នេះអាចមានន័យថាទី១) គ្រប់ទីកន្លែងនៅស្រុកយូដា ឬ ទី២) ថា គ្រប់ទីកន្លែងក្នុងពិភពលោក។
ដណ្តើមយក
កាន់កាប់ដោយកម្លាំង ឬលួចពីម្ចាស់កម្មសិទ្ធ
ផ្ទះ
«ផ្ទះ»
ពួកគេ...ពួកគេ...ខ្លួនគេ
ទាហានខាល់ដេ។ ព្រះជាម្ចាស់នឹងលើកតម្កើងប្រជាជាតិខាល់ដេ
ហើយពួកទាហានរបស់ខាល់ដេនឹងវាយលុកទឹកដីយូដា។
ពួកគេជាមនុស្សដែលគួរឲ្យភ័យខ្លាច និងភ័យញ័រ
ពាក្យថា «ភ័យខ្លាច» និង «ភ័យញ័រ» មានន័យជារឿងមូលដ្ឋានតែមួយ
ហើយសង្កត់ធ្ងន់ថា ពួកគេបានធ្វើឲ្យអ្នកដទៃខ្លាចខ្លាំងណាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេធ្វើឲ្យអ្នកដទៃភ័យខ្លាចខ្លាំងណាស់»។
មកតែ
«មក»
Habakkuk 1:8
សេះរបស់ពួកគេ...សេះរបស់ពួកគេ
សេះរបស់ទាហានខាល់ដេ
សាហាវជាងឆ្កែចចកដែលរកស៊ីនៅពេលព្រលប់ទៅទៀត
សេះរបស់ពួកខាល់ដេត្រូវបានគេប្រៀបធៀបទៅនឹងសត្វចចកដ៏កាចសាហាវ
ដែលរត់បន្ទាប់ពីសត្វព្រៃរបស់ពួកគេនៅពេលល្ងាច នៅពេលដែលពួកគេឃ្លានខ្លាំង
ដោយសារពួកគេមិនបានស៊ីពេញមួយថ្ងៃ។
កងទ័ពសេះរបស់ពួកគេ
ទាហានរបស់ជនជាតិខាល់ដេជិះសេះ។
ខ្លារខិន
សត្វឆ្មាដែលធំហើយរហ័ស
ដូចសត្វឥន្ទ្រីបោះពួយ
«អ្នកជិះសេះ ជិះលឿនដូចឥន្ទ្រីហើរ»
ទឹកមុខរបស់ពួកគេពិតជាសាហាវណាស់ ហើយពួកគេចាប់ឈ្លើយសឹកដូចជាខ្សាច់
ជនជាតិខាល់ដេមានចំនួនច្រើន ហើយដូចគ្រាប់ខ្សាច់
ដែលខ្យល់បក់ឡើងនៅក្នុងព្យុះមានចំនួនច្រើនណាស់ ដែលមិនអាចរាប់បាន
ដូច្នេះគ្មាននរណាម្នាក់អាចរាប់មនុស្សដែលពួកគេចាប់បានទេ
ហើយធ្វើជាអ្នកទោសបានឡើយ។
Habakkuk 1:10
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់នៅតែបន្តរៀបរាប់អំពីទាហានខាល់ដេ។
ទៅមុខដូចជាខ្យល់ព្យុះ
ទាហានខាល់ដេកំពុងលុកលុយត្រូវបានគេប្រៀបធៀបទៅនឹងខ្យល់ដែលបក់បោកកាត់តំបន់មួយ
ហើយបន្តដំណើរទៅកន្លែងបន្ទាប់ទៀត។
Habakkuk 1:12
ព័ត៌មានទូទៅ៖
ហាបាគុកនិយាយទៅកាន់ព្រះអម្ចាស់អំពីប្រជាជនខាល់ដេ។
ឱព្រះនៃទូលបង្គំអើយ តើព្រះអង្គជាព្រះដ៏បរិសុទ្ធរបស់ទូលបង្គំតាំងពីដើមរៀងមកមែនទេ?
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គនៅស្ថិតស្ថេរអស់កល្បជានិច្ច
ព្រះអម្ចាស់របស់ទូលបង្គំ ជាព្រះដ៏វិសុទ្ធ»។
គេ...គេ
ប្រជាជនខាល់ដេ
ថ្មដា
អ្នកការពារអ៊ីស្រាអែល
ឲ្យកម្លាំងដល់គេដើម្បីវាយប្រដៅយើងខ្ញុំ
«ឲ្យកម្លាំងពួកគេសម្រាប់គោលបំណងកែតម្រង់ អ៊ីស្រាអែល»
Habakkuk 1:13
ព័ត៌មានទូទៅ៖
លោកហាបាគុកបន្តនិយាយទៅកាន់ព្រះអម្ចាស់អំពីប្រជាជនខាល់ដេ។
ពួកអ្នក ដែលប្រព្រឹត្តការក្បត់
«ប្រជាជនខាល់ដេ ដែលគ្មាននរណាអាចទុកចិត្តបាន»
បំផ្លាញ
«បំផ្លាញ» (UDB)
ដូចជាត្រីដែលនៅក្នុងសមុទ្រ...ដូចសត្វលូនវា
ឃ្លាទាំងពីរនេះបង្ហាញពីគំនិតតែមួយ
ដែលព្រះជាម្ចាស់បានអនុញ្ញាតឲ្យពួកខាល់ដេធ្វើអំពើលើប្រជាជន
អ៊ីស្រាអែលដូចជា ពួកគេជាសត្វដែលមានតម្លៃតិចតួចខ្លាំង
ហើយមិនដូចមនុស្សគួរតែត្រូវបានគេយកចិត្តទុកដាក់។
Habakkuk 1:15
ព័ត៌មានទូទៅ៖
ហាបាគុកបន្តនិយាយទៅកាន់ព្រះអម្ចាស់អំពីប្រជាជនខាល់ដេ។
សន្ទូង...សំណាញ់
ឧបករណ៍ប្រើដើម្បីចាប់ត្រី
សំណាញ់
ឧបករណ៍ដែលប្រើដើម្បីចាប់ «សត្វលូនវារ» (១:១៣)
បានអាហារឆ្ងាញ់យ៉ាងបរិបូណ៌ដោយសាររបស់ទាំងនោះ
របៀបផ្សេងទៀត នៃការបកប្រែ: «សត្វដែលល្អបំផុត និងសាច់ដែលល្អបំផុតគឺ
ជាចំណែករបស់ពួកគេ»
ចំណែក
ផ្នែកតូចមួយនៃអ្វី ដែលធំជាងដែលចែករវាងមនុស្សជាច្រើន
ពួកសម្លាត់សំណាញ់របស់ពួកគេ
អ្នកនេសាទបានសម្លាតសំណាញ់របស់ពួកគេ ដើម្បីបោះម្តងទៀត

generated on Wed Sep 10 16:16:32 2025

ហើយចាប់បានត្រីថែមទៀត។

2 [1]ខ្ញុំនឹងឈរចាំយាម ខ្ញុំនឹងទទ្ឹងរង់ចាំនៅលើប៉ម ហើយខ្ញុំនឹងសម្លឹងមើលដោយយកចិត្តទុកដាក់ តើព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំដូចម្តេច
ហើយខ្ញុំគួរបែរចេញពីការអ្ន ទាំរបស់ខ្ញុំដែរ។
[2]ព្រះអម្ចាស់មានព្រះបន្ទូលតបមកខ្ញុំថា «ចូរកត់ត្រានិមិត្តហេតុដ៏អស្ចារ្យនេះ ត្រូវឲ្យចារទុកនៅលើបន្ទះថ្ម
ដើម្បីឲ្យមនុស្សងាយស្រួលអាន[3]ហើយនិមិត្តហេតុដ៏អស្ចារ្យនឹងទុកដល់វេលាកំណត់ គឺនឹងមានព្រឹត្តការណ៍កើតឡើង
ស្របតាមនិមិត្តហេតុដ៏អស្ចារ្យនេះដោយមិនខុសត្រង់ណាឡើយ ប្រសិនបើបង្អង់យូរ ចូរទន្ទឹងរង់ចាំចុះ។ ដ្បិតព្រឹត្តការណ៍ពិតកើតមានឡើង
ពិតប្រាកដមិនក្លែងក្លាយឡើយ។
[4]មើល៍! មនុស្សកោងកាចនឹងត្រូវវិនាសតែមនុស្សឲ្យសុចរិតនឹងរស់នៅដោយសារជំនឿរបស់ខ្លួន[5]មួយទៀត ស្រាទំពាំងបាយជូរ ជាគ្រឿងបញ្ឆោតដល់មនុស្ស
ដែលអួតបំប៉ោងមិនដែលមានចិតស្កប់ទេ គេបើកមាត់ចំហយ៉ាងធំដូចស្ថានមនុស្សស្លាប់ គេប្រៀបដូចជា មច្ចុរាជដែលមិនចេះស្កប់ចិត្ត ហើយគេកៀប្រមូលអស់
ទាំងជាតិសាសន៍ អោយមកនៅក្រោមអំណាចរបស់ខ្លួន។
[6]ប៉ុន្តែពួកគេទាំងនោះនាំគ្នានិយាយពាក្យចំអក និងប្រមាថមាក់ងាយពួកគេថា វេទនាដល់មនុស្សដែលប្រមូលទ្រព្យរបស់អ្នកដទៃ យកមកធ្វើជាទ្រព្យរបស់ខ្លួន!
តើអ្នកនៅប្រព្រឹត្តដូច្នេះដល់កាលណាទៀត? ហើយអ្នកនឹងជំពាក់បំណុលគេកាន់តែធ្ងន់ទៅៗ[7]ម្ចាស់បំណុលនឹងក្រោកឡើងហើយនឹងខាំឯង ជាមួយរំពេច
ហើយពួកគេនឹងរឹបអូសយកទ្រព្យរបស់ពួកឯង ដូចដែលឯងបានប្រព្រឹត្តចំពោះអ្នកដ៏ទៃដែរ[8]ពីព្រោះឯងបានប្លន់រឹបអូសយកទ្រព្យសម្បត្តិរបស់ប្រជាជាតិផ្សេងៗ
ក៏នឹងប្លន់រឹបអូសយកទ្រព្យសម្បត្តិពីឯងយ៉ាងនោះដែរ ព្រោះឯងបានបង្ហូរឈាមមនុស្ស ហើយប្រព្រឹត្តអំពើយ៉ាងឃោឃៅចំពោះប្រជាជនទាំងអស់ ដែលរស់នៅក្នុងទឹកដី
នឹងទីក្រុងនោះផង។
[9]វេទនាដល់មនុស្សដែលបានកម្រៃដោយ ការទុច្ចរិតដើម្បីធ្វើឲ្យក្រុមគ្រួសាររបស់ខ្លួន ក្លាយទៅជាអ្នកមាន ហើយសង់ផ្ទះរបស់ខ្លួនយ៉ាងខ្ពស់ដើម្បីគេចផុតពីសេចក្តីអាក្រក់។
[10]ឯងគិតគូរបង្កើតសេចក្តីអាម៉ាសដល់ក្រុមគ្រួសារឯង ដោយឯងកម្ទេចជាតិសាសន៍ជាច្រើន
ដូច្នេះឯងនឹងធ្វើឲ្យជីវិតរបស់ឯងត្រូវវិនាស[11]ដ្បិតថ្មកំផែងក្រុងក៏ចោទប្រកាន់ឯងដែរ ហើយឈើធ្នឹមនឹងស្រែកបន្ទរយល់ស្របផងដែរ។
[12]វេទនាដល់អ្នកណាដែលបានសង់ទីក្រុង ដោយបង្ហូរឈាមនឹងប្រព្រឹត្តអំពើទុច្ចរិត[13]តើព្រះអម្ចាស់នៃពិភពលោកទាំងមូលនឹងធ្វើឲ្យស្នាដៃរបស់ជាតិសាសន៍រលាយទៅ
ក្នុងភ្លើង ហើយអោយកិច្ចការដែលជាតិសាសន៍ប្រឹងប្រែងទាំងប៉ុន្មាន ទៅជាគ្មានប្រយោជន៍?[14]សមុទ្រពោពេញដោយទឹក យ៉ាងណា
នៅផែនដីក៏ពេញដោយចំណេះដឹងនិងសិរីរុងរឿងរបស់ព្រះអម្ចាស់យ៉ាងនោះដែរ។
[15]វេទនាដល់អ្នកណាដែលបង្អកស្រាដល់អ្នកជិតខាងខ្លួនប្រៀបបាននឹងពីសពុលឲ្យអ្នកដ៏ទៃផឹកស្រវឹង ដើម្បីបានមើលការអាក្រាតរបស់គេ។
[16]ឯងនឹងមិនទទួលបានកិត្តិយសទេ ផ្ទុយទៅវិញនឹងទទួលបានភាពអាម៉ាសយ៉ាងខ្លាំងវិញ។ ចូរផឹកស្រានេះខ្លួនឯង ហើយបើកភាពអាក្រាតរបស់ឯង
ដែលមិនកាត់ស្បែកឲ្យគេឃើញទៅ ព្រះអម្ចាស់នឹងបែទៅដាក់ទោសឯង ដោយព្រះហស្តស្តាំរបស់ព្រះអម្ចាស់ ការរុងរឿងរបស់ឯងនឹងក្លាយទៅជាភាពអាម៉ាស់វិញ។
[17]ឯងមុខជាត្រូវបំផ្លាញ ដោយព្រោះតែអំពើ ឃោឃៅដែលឯងបានប្រព្រឹត្តនៅលីបាណូន ឯងបានសម្លាប់សត្វយ៉ាងព្រៃផ្សៃ ដែលនាំឲ្យពួកវាភ័យខ្លាច។
ដោយព្រោះឈាមមនុស្ស ហើយប្រព្រឹត្តអំពើព្រៃផ្សៃចំពោះប្រជាជនទាំងអស់ដែលរស់នៅលើទឹកដីនឹងទីក្រុងផ្សេងៗផង។
[18]តើជាងឆ្លាក់រូបបដិមាករទទួលបានប្រយោជន៍អ្វី? គេប្រើរូបដែលធ្វើពីលង្ហិនដើម្បីប្រៀនប្រដៅសេចក្តីកំភូតនោះ ហេតុអ្វីបានជាជាងចម្លាក់ធ្វើជីវិតលើព្រះក្លែងក្លាយ
មិនចេះនិយាយហើយជារូបដែលគេសូនដោយដៃខ្លួនឯងដូច្នោះ។[19]វេទនាដល់អ្នកណាដែលនិយាយទៅកាន់រូបឈើថា សូមក្រោកឡើង! ឬនិយាយទៅកាន់ថ្ម
ដែលមិនចេះនិយាយថា សូមតើនឡើង! តើថ្មទាំងនេោះអាចបង្រៀនបានឬ? មើល៍! គេស្រោបវាដោយមាស និងប្រាក់ តែសុទ្ធសឹងតែជារូបដែលគ្មានវិញ្ញាណ។
[20]ឯព្រះអម្ចាស់គង់នៅក្នុងព្រះវិហារដ៏វិសុទ្ធរបស់ព្រះអង្គ ចូរឲ្យផែនដីទាំងមូលស្ងៀមស្ងាត់នៅចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ»។

Habakkuk 2:1

ខ្ញុំ...របស់ខ្ញុំ...ខ្ញុំ

លោកហាបាគុក

ព្រះអង្គ

ព្រះអម្ចាស់

ខ្ញុំនឹងឈរចាំយាម ខ្ញុំនឹងទទ្ឹងរង់ចាំនៅលើប៉ម ហើយខ្ញុំនឹងសម្លឹងមើលដោយយកចិត្តទុកដាក់

ឃ្លាទាំងនេះនិយាយដូចគ្នា តាមពីរវិធីផ្សេងគ្នា។

«ខ្ញុំនឹងឈរកន្លែងចាំយាមនៅលើប៉មរបស់ខ្ញុំ»។ ហាបាគុកប្រើឃ្លាទាំងនេះ

ដើម្បីប្រៀបធៀបខ្លួនគាត់

ដែលកំពុងរង់ចាំស្តាប់ពីព្រះជាម្ចាស់ទៅនឹងទាហានឈរយាមនៅលើប៉ម។

ខ្ញុំគួរបែរចេញពីការអ្ន ទាំរបស់ខ្ញុំដែរ

ពាក្យថា «បែរ» និយាយពីការផ្លាស់ប្តូរចិត្តរបស់មនុស្សម្នាក់ដូចជា

កំពុងងាកចេញពីរឿងមួយទៅរឿងមួយផ្សេងទៀត។

របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំគួរតែបញ្ឈប់ការតួញតែរ

ហើយយល់ព្រមជាមួយព្រះជាម្ចាស់»។

Habakkuk 2:2

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់មានព្រះបន្ទូលតបមកលោកហាបាគុក។

ចូរកត់ត្រានិមិត្តហេតុដ៏អស្ចារ្យនេះ ត្រូវឲ្យចារទុកនៅលើបន្ទះថ្ម

ឃ្លាទាំងពីរនេះនិយាយដូចគ្នា តាមពីរវិធីផ្សេងគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:

«បានសរសេរយ៉ាងច្បាស់នៅលើបន្ទះថ្មនូវអ្វី ដែលព្រះជាម្ចាស់នឹងប្រាប់អ្នក»

បន្ទះថ្ម

ទាំងនេះគឺជាបំណែកថ្ម ឬដីឥដ្ឋដែលត្រូវបានប្រើសម្រាប់សរសេរលើ។

ដើម្បីឲ្យមនុស្សងាយស្រួលអាន

នេះអាចមានន័យថា ទី១) នរណាម្នាក់នឹងធ្វើតាមបន្ទះថ្ម ហើយអានទៅមនុស្ស

ឬទី២) ថា អ្នកដែលបានអាននឹងអាចអានបានដោយងាយស្រួល

មានព្រឹត្តការណ៍កើតឡើង

អ្វីដែលបានសរសេរនឹងកើតឡើង ឬក្លាយជាការពិត។

មិនក្លែងក្លាយឡើយ

នេះអាចមានន័យថា ទី១) «ហើយនឹងមិនរង់ចាំ» ឬទី ២) គឺ

«ហើយនឹងមិនមកយឺតៗ»

Habakkuk 2:4

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់នៅតែមានព្រះបន្ទូលនឹងហាបាគុក។

មើល៍!

ពាក្យថា «មើល៍!» នៅទីនេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលនៅខាងក្រោម។

មនុស្សកោងកាចនឹងត្រូវវិនាសតែមនុស្សឲ្យសុចរិត...ជាគ្រឿងបញ្ឆោតដល់មនុស្ស...ដែលមានចិតស្កប់ទេ

គេបើកមាត់ចំហយ៉ាងធំ...គេកៀប្រមូលអស់

ទាំងជាតិសាសន៍...អោយមកនៅក្រោមអំណាចរបស់ខ្លួន

ព្រះអម្ចាស់មានព្រះបន្ទូលអំពីជនជាតិខាល់ដេថា ពួកគេជាមនុស្សតែម្នាក់។

គេកៀប្រមូលអស់ទាំងជាតិសាសន៍ អោយមកនៅក្រោមអំណាចរបស់ខ្លួន

នេះត្រូវបានគេនិយាយដូចគ្នា តាមវិធីពីរផ្សេងគ្នា។

«គេប្រមូលមនុស្សទាំងអស់ពីគ្រប់ជាតិសាសន៍» «គេ»

សំដៅទៅលើជនជាតិខាល់ដេហាក់ដូចជា ពួកគេជាមនុស្សតែម្នាក់។

កៀប្រមូល

«ប្រមូល»

គ្រប់អស់ទាំង...

មួយចំនួនធំណាស់

Habakkuk 2:6

ព័ត៌មានទូទៅ៖

ព្រះអម្ចាស់នៅតែមានព្រះបន្ទូលទៅកាន់ហាបាគុក។

ព្រះអង្គសំដៅទៅលើពួកខាល់ដេហាក់ដូចជា ពួកគេជាមនុស្សតែម្នាក់។

generated on Wed Sep 10 16:16:32 2025

តើអ្នកនៅប្រព្រឹត្តដូច្នេះដល់កាលណាទៀត?
«ពេលខ្លះអ្នកនឹងមិនអាចទទួលបានការសន្យាពីប្រជាជនទៀតទេ»។
នេះអាចមានន័យទី១) គឺជនជាតិខាល់ដេប្រៀបដូចជា ចោរប្លន់ដែលបានសន្យាថា
ពួកគេបាន បង្ខំឲ្យមនុស្សផ្សេងទៀតចុះហត្ថលេខា ឬទី២) គឺ
ព្រះអម្ចាស់កំពុងធ្វើកំណត់ហេតុអំពីអ្វី ដែលពួកខាល់ដេបានលួច
ហើយនឹងនៅថ្ងៃណាមួយពួកគេទាមទារឲ្យសងវិញ។
ការសន្យា
កំណត់សម្គាល់សន្យាដែលបានផ្តល់សម្រាប់បំណុលដែលជំពាក់ជាញឹកញាប់ត្រូវបានសរសេរនៅលើក្រដាស
ម្ចាស់បំណុលនឹងក្រោកឡើងហើយនឹងខាំឯង ជាមួយរំពេច
ហើយពួកគេនឹងរឹបអូសយកទ្រព្យរបស់ពួកឯង
សំណួរនេះត្រូវបានសួរដើម្បីធ្វើឲ្យពួកខាល់ដេគិតអំពីចម្លើយ។
«អ្នកដែលខឹងអ្នកនឹងមកប្រឆាំនឹងអ្នក
ហើយម្ចាស់បំណុលដែលអ្នកខ្លាចនឹងចាប់ផ្តើមការវាយប្រហារ»
ហើយនឹងខាំឯង
នេះគឺជាពាក្យដែលមានន័យថា អ្នកដែលមានបំណុលដែលពួកគេត្រូវសង។
ទោះយ៉ាងណាក៏ដោយកំណែ សម័យថ្មីមួយចំនួនបកស្រាយឃ្លានេះមានន័យថា
ម្ចាស់បំណុលមិនមែនកូនបំណុលទេ។
ហើយពួកគេនឹងរឹបអូសយកទ្រព្យរបស់ពួកឯង
នេះសំដៅទៅលើកូនបំណុលដូចគ្នាដែរ។ ពួកគេនឹងបំភ័យពួកខាល់ដេ
ដោយវាយប្រហារពួកគេ
ដើម្បីសងសឹកចំពោះបំណុលអយុត្តិធម៌ដែលពួកគេត្រូវបង្ខំឲ្យមាន។
ក្រោកឡើង
«ក្លាយជាចំនួនច្រើន» ឬ «កាន់តែមានឥទ្ធិពល»
ប្លន់រឹបអូស
លួច ឬយកដោយប្រើកម្លាំង។
Habakkuk 2:9
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលតបទៅកាន់ហាបាគុក។
ព្រះអង្គសំដៅទៅលើពួកខាល់ដេហាក់ដូចជា ពួកគេជាមនុស្សតែម្នាក់។
មនុស្សដែលបានកម្រៃដោយ ការទុច្ចរិតដើម្បីធ្វើឲ្យក្រុមគ្រួសាររបស់ខ្លួន
«អ្នកដែលធ្វើការ
ដើម្បីទទួលបានប្រាក់ចំណេញមិនស្មោះត្រង់សម្រាប់គ្រួសាររបស់គេ»
ហើយសង់ផ្ទះរបស់ខ្លួនយ៉ាងខ្ពស់
«សង់ផ្ទះរបស់គាត់អោយឆ្ងាយពីបញ្ហា»
សេចក្តីអាក្រក់
របៀបផ្សេងទៀតនៃការបកប្រែ: «ដៃនៃអំពើអាក្រក់» ប្រព្រឹត្ត «អំពើអាក្រក់»
ជាមនុស្សម្នាក់ ឬ «មនុស្សអាក្រក់» .
ឯងគិតគូរបង្កើតសេចក្តីអាម៉ាសដល់ក្រុមគ្រួសារឯង ដោយឯងកម្ទេចជាតិសាសន៏ជាច្រើន
«ដោយសារតែអ្នកកម្ទេចមនុស្សជាច្រើន គ្រួសាររបស់អ្នកនឹងត្រូវរងការខ្មាស់អៀន»
អ្នក
ឯកវចន:
កម្ទេច
ការបំផ្លាញ
នឹងធ្វើឲ្យជីវិតរបស់ឯងត្រូវវិនាស
«ធ្វើបាបខ្លួនឯង»
ថ្ម...ឈើធ្នឹម
«ថ្ម» និង «ឈើធ្នឹម» តំណាងឲ្យប្រជាជនឈឺចាប់នៅក្នុងអគារនៃផ្ទះ
អ្នកតំណាងឲ្យប្រជាជន ដែលត្រូវបានបំផ្លាញដោយពួកខាល់ដេ។
ស្រែកបន្ទរ
«ចោទប្រកាន់ព្រះជាម្ចាស់ប្រឆាំងនឹងអ្នកសាងសង់ផ្ទះ»
យល់ស្រប
យល់ស្របជាមួយនឹងការចោទប្រកាន់
Habakkuk 2:12
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលតមទៅកាន់ហាបាគុក។
ព្រះអង្គសំដៅទៅលើពួកខាល់ដេហាក់ដូចជា ពួកគេជាមនុស្សតែម្នាក់។
វេទនាដល់អ្នកណាដែលបានសង់ទីក្រុង ដោយបង្ហូរឈាមនឹងប្រព្រឹត្តអំពើទុច្ចរិត
ឃ្លាទាំងពីរនេះនិយាយដូចគ្នា តាមវិធីផ្សេងគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការព្រមានដល់ពួកខាល់ដេ
ដែលបានកសាងទីក្រុងរបស់ពួកគេជាមួយនឹងអ្វីដែលពួកគេបានលួចពីប្រជាជនដែលពួកគេបានសម្លាប់»
ដោយបង្ហូរឈាម
ដោយសម្លាប់មនុស្ស ។ របៀបផ្សេងទៀត នៃការបកប្រែ: «អ្នកដែលសម្លាប់មនុស្ស
និងលួចរបស់គេ ដើម្បីកសាងទីក្រុង»។
ការលួចប្លន់ដែលបានធ្វើឡើងដោយ
ហើយអោយកិច្ចការដែលជាតិសាសន៍ប្រឹងប្រែងទាំងប៉ុន្មាន ទៅជាគ្មានប្រយោជន៍?
ព្រះជាម្ចាស់បានបំផ្លាញអ្វីៗ ដែលមនុស្សបានសាងសង់។
គឺត្រូវបាននិយាយតាមពីរវិធីផ្សេងគ្នា ដើម្បីធ្វើឲ្យអត្ថន័យកាន់តែច្បាស់។
របៀបផ្សេងទៀត នៃការបកប្រែ:
«ព្រះអម្ចាស់គឺជាព្រះដែលធ្វើអោយមនុស្សខំធ្វើការ ដើម្បីបំផ្លាញដោយភ្លើង
ហើយគ្មានលទ្ធផលអ្វីឡើយ»។
Habakkuk 2:15
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលតមទៅកាន់ហាបាគុក។
ព្រះអង្គសំដៅទៅលើពួកខាល់ដេហាក់ដូចជា ពួកគេជាមនុស្សតែម្នាក់។
ប្រៀបបាននឹងពីសពុល
«បន្ថែមជាតិពុលរបស់អ្នកទៅក្នុងភេសជ្ជៈរបស់ពួកគេ»
ឯងនឹងមិនទទួលបានកិត្តិយសទេ ផ្ទុយទៅវិញនឹងទទួលបានភាពអាម៉ាសយ៉ាងខ្លាំងវិញ
«កាលដែលអ្នកស្វែងរកសិរីរុងរឿងដ៏អស្ចារ្យ
ព្រះជាម្ចាស់នឹងធ្វើអោយអ្នកអាម៉ាស់មុខជាខ្លាំង»
ឯង
ឯកវចន:
ចូរផឹកស្រានេះ
«ផឹកពីពែងដែលមានជាតិពុល»
ព្រះអម្ចាស់នឹងបែទៅដាក់ទោសឯង ដោយព្រះហស្តស្តាំរបស់ព្រះអម្ចាស់
«ព្រះអម្ចាស់បានដាក់ទោសប្រជាជាតិនានា ដោយព្រះចេស្តារបស់ព្រះអង្គ
ដូច្នេះព្រះអង្គនឹងដាក់ទោសអ្នករាល់គ្នាដោយឫទ្ធានុភាពរបស់ព្រះអង្គ»
ពែង
«ជាស្រាដែលមានជាតិពុល»
ព្រះហស្តស្តាំ
ជាដៃដែលខ្លាំង
នឹងបែទៅដាក់ទោសឯង
«នឹងមករកអ្នកដូចដែលបានធ្វើចំពោះអ្នកដទៃ»
ការរុងរឿងរបស់ឯងនឹងក្លាយទៅជាភាពអាម៉ាស់វិញ
«អ្នករាល់គ្នានឹងឃើញភាពអាម៉ាស់របស់អ្នក
ហើយក៏គ្មាននរណាម្នាក់មើលឃើញកិត្តិយសរបស់អ្នកដែរ»
Habakkuk 2:17
ព័ត៌មានទូទៅ៖
ព្រះជាម្ចាស់នៅតែបន្តមានព្រះបន្ទូលអំពីរបៀប
ដែលព្រះអង្គនឹងដាក់ទោសដល់ជនជាតិខាល់ដេ
សម្លាប់សត្វយ៉ាងព្រៃផ្សៃ ដែលនាំឲ្យពួកវាភ័យខ្លាច
«សេចក្តីស្លាប់របស់សត្វនឹងធ្វើឲ្យអ្នកភ័យខ្លាច»
Habakkuk 2:18
អ្នក
ពាក្យថា «អ្នក» សំដៅទៅលើប្រជាជនខាល់ដេ។
រូបដែលគេសូន
នេះគឺជាដំណើរការនៃការបង្កើតរូបសំណាកមួយដោយចាក់លោហៈរាវចូលទៅក្នុងវត្ថុឆ្លាក់តាមទំរង់
ដែលចង់បាន។ លោហៈធាតុនឹងយកជាទម្រង់តួ ហើយរឹងដូចរូប ឬរូបចម្លាក់។
លង្ហិន
នេះគឺជាពាក្យសម្រាប់លោហៈនៅពេលវាស្ថិតនៅក្នុងទម្រង់រាវ។
ព្រះក្លែងក្លាយ
ឃ្លានេះគឺសំដៅទៅលើអ្នកដែលឆ្លាក់ ឬសូនរូប។ ដោយការធ្វើឲ្យព្រះក្លែងក្លាយ
គាត់បង្រៀនសេចក្តីក្លែងក្លាយ។

[1]នេះជាពាក្យអធិស្ឋានរបស់ព្យាការីហាបាគូក[2]ព្រះអម្ចាស់អើយ ទូលបង្គំបានឮសេចក្តីដែលព្រះអង្គមានបន្ទូល ហើយទូលបង្គំស្ញប់ស្ញែងស្មាព្រះហស្តដែលព្រះអង្គបានធ្វើ
សូមសម្តែងឲ្យមនុស្សលោកបានស្គាល់ ស្មាព្រះហស្តទាំងនេះ ហើយក្នុងគ្រាដែលព្រះអង្គក្រោធ សូមនឹកចាំដល់ព្រះហឫទ័យអាណិតមេត្តារបស់ព្រះម្ចាស់ផង។
[3]ព្រះជាម្ចាស់យាងមកពីស្រុកថេម៉ាន ហើយព្រះដ៏បរិសុទ្ធយាងមកពីភ្នំប៉ារ៉ាន។ សម្រាក។ សិរីល្អរបស់ព្រះអង្គចែងចាំង ពាសពេញផ្ទៃមេឃហើយនិងផែនដីទាំងមូល
គឺពេញដោយការ សរសើរតម្កើងព្រះអង្គ។
[4]សិរីរុងរឿងព្រះអង្គប្រកបទៅដោយពន្លឺដ៏ត្រចះត្រចង់ពីព្រះហស្តរបស់ព្រះអង្គដែលបង្គប់ទុកនូវព្រះចេស្តារបស់ព្រះអង្គ។
[5]ព្រះអង្គចាត់ជំងឺអាសន្នរោគឲ្យចេញពីចំពោះព្រះអង្គ ហើយព្រះអង្គយាងទៅទីណា កន្លែងនោះជំងឺរាតត្បាតនឹងចេញពីព្រះបាទរបស់ព្រះអង្គ។
[6]ព្រះអង្គឈរហើយវាស់ទំហំនៃផែនដី ព្រះអង្គទតធ្វើឲ្យប្រជាជាតិនាំគ្នាភ័យញាប់ញ័រ។ ភ្នំធំទាំងនោះត្រូវខ្ចាត់ខ្ចាយទៅ ហើយភ្នំតូចដែលនៅជាដរាបចុះ។
ផ្លូវរបស់ព្រះអង្គនឹងមិនសាបសូន្យឡើយ។
[7]ទូលបង្គំបានឃើញជំរំរបស់ជនជាគូសានរលាយសូន្យ ចំណែកជម្រករបស់ជនជាតិម៉ាឌានក៏ញ័រកក្រើក។[8]តើព្រះអម្ចាស់មានព្រះហឫទ័យខ្ញាល់នឹងទន្លេទាំងនោះឬ?
តើព្រះអង្គក្រោធនឹងទន្លេឬក៏ក្រោធទៅលើសមុទ្រ នៅគ្រាដែលព្រះអង្គជិះសេះនិងរទេះចម្បាំង វាយយកជ័យជម្នះមែនទេ?
[9]ព្រះអង្គបានទាញធ្នូចេញ ដោយមិនមានស្រោម ហើយព្រះអង្គបានគ្រប់ព្រួញនៅលើធ្នូរបស់ព្រះអង្គ! សម្រាក។ ព្រះអង្គបានញែកផែនដីជាពីរដោយទន្លេ។
[10]ពួកភ្នំបានឃើញព្រះអង្គ ក៏នាំគ្នាភ័យញាប់ញ័រដោយឈឺចាប់។ ទឹកជម្រៅនៃទឹកក៏ពុះកញ្ជ្រោលយ៉ាងខ្លាំង។ ហើយក៏ធ្វើឲ្យមានរលកធំៗ។
[11]ព្រះអាទិត្យ និងព្រះច័ន្ទក៏ឈប់នៅទីដ៏ខ្ពស់ ដើម្បីជាបំភ្លឺដល់គ្រាប់ព្រួញរបស់ព្រះអង្គដែលហោះទៅ និងចាងពន្លឺដូចជាផ្នែកបន្ទោលមកលើលំពែងរបស់ព្រះអង្គផង។
[12]ព្រះអង្គបានយាងកាត់ផែនដីដោយកំហឹង។ ព្រះអង្គជាន់កម្ទេចប្រជាជាតិនានាដោយសេចក្តីក្រោធ។
[13]ព្រះអង្គបានយាងចេញមកដើម្បីសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ និងសង្គ្រោះអ្នកដែលព្រះអង្គបានចាក់ប្រេងតាំង។ ព្រះអង្គវាយប្រហារមេគ្រួសាររបស់មនុស្សអាក្រក់
ក៏បំផ្លាញពួកគេឲ្យវិនាសសូន្យទាំងអស់។ សម្រាក
[14]ព្រះអង្គបានចាក់ទម្លុះក្បាលមេដឹកនាំរបស់ពួកគេ ដោយគ្រប់ព្រួញរបស់ពួកគេ ព្រួញទាំងនោះដូចខ្យល់ព្យុះដើម្បីកម្ចាត់កម្ចាយយើង ទាំងស្រែកហ៊ោសប្បាយ
ហើយពួកគេពួនស្ទាក់ប្រហារជនក្រីក្រ។[15]ព្រះអង្គបានធ្វើដំណើរលើសមុទ្រដោយសេះរបស់ព្រះអង្គ ដែលទឹកកំពុងបោកបក់យ៉ាងខ្លាំង។
[16]ខ្ញុំបានឮហើយខ្ញុំក៏ភ័យញ័ររន្ធត់ ហើយបបូរមាត់ខ្ញុំក៏ញ័រដោយឮសម្លេងនោះ។ ហើយឆ្អឹងរបស់ខ្ញុំកាន់តែពុកទៅៗ ខ្ញុំក៏ទន់ជើងនៅស្ងៀមឥតកម្រើក
ព្រោះទន្ទឹងរង់ចាំថ្ងៃវេទនានោះដែលមកដល់ ពួកអ្នកដែលបានឈ្លានពានលើយើង។
[17]ទោះបើដើមឧទុម្ពរមិនមែនផ្កា ទំពាំងបាយជូរមិនមែនផ្លែ ហើយដើមអូលីវលែងមានប្រេង ស្រែចម្ការឥតមានបង្កើតផលជាអាហារ
ហើយនិងពួកចៀមក៏បានកាត់ចេញពីក្រោល ហើយក៏លែងមានគោនៅក្នុងក្រោលទៀតដែរនោះ ការទាំងនេះគឺជាអ្វីដែលយើងនឹងធ្វើ។
[18]ចំណែកខ្ញុំវិញ ខ្ញុំនឹងអររីករាយជាមួយព្រះអម្ចាស់។ ខ្ញុំនឹងមានអំណរដ៏លើសលប់ ដោយព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ។[19]ព្រះជាម្ចាស់ជាព្រះនៃកម្លាំងរបស់ខ្ញុំ
ព្រះអង្គនឹងធ្វើឲ្យជើងរបស់ខ្ញុំរត់លឿន ដូចឈ្លូស។ ព្រះអង្គប្រទានឲ្យខ្ញុំដើរនៅលើទីខ្ពស់។ ទំនុករបស់គ្រូចម្រៀង ប្រគំដោយតន្ត្រីដែលមានខ្សែរ។

Habakkuk 3:1
ទូលបង្គំបានឮសេចក្តីដែលព្រះអង្គមានបន្ទូល
អាចមានន័យថាទី១) គឺ «ខ្ញុំបានឮសេចក្តីដែលមនុស្សបាននិយាយ
អំពីអ្វីដែលអ្នកបានធ្វើ» ឬ ទី២) គឺ «ខ្ញុំបានឮអ្វីដែលអ្នកទើបតែនិយាយ»។
ដែលព្រះអង្គបានធ្វើ សូមសម្តែង
«ធ្វើឲ្យការងាររបស់អ្នកដំណើរការវិញ» ឬ
«ធ្វើម្តងទៀតនូវអ្វីដែលអ្នកបានធ្វើពីមុន»
បានស្គាល់
«ធ្វើឲ្យគេស្គាល់ការងាររបស់អ្នក»
Habakkuk 3:4
ព័ត៌មានទូទៅ៖
ហាបាគុកបន្តរៀបរាប់អំពីនិមិត្តរបស់គាត់ចំពោះព្រះអម្ចាស់។
ពន្លឺ
ទាំងនេះគឺជាបន្ទាត់នៃពន្លឺ ដែលបានមកពីប្រភពពន្លឺដូចជា ព្រះអាទិត្យ។
របស់ព្រះអង្គ...របស់ព្រះអង្គ...របស់ព្រះអង្គ
របស់ព្រះអម្ចាស់
Habakkuk 3:6
ព័ត៌មានទូទៅ៖
ហាបាគុកបន្តរៀបរាប់អំពីនិមិត្តរបស់គាត់ចំពោះព្រះអម្ចាស់។
វាស់ទំហំនៃផែនដី
អាចមានន័យទី១) គឺ ព្រះអង្គបានស្ទាបស្ទង់អំពីវិធី
ដែលអាចមានជ័យជំនះមុននឹងប្រគល់ចំណែកដល់អភិបាលរបស់គេ ឬទី២) គឺ
ព្រះអង្គធ្វើឲ្យផែនដីរញ្ជួយ។
ភ្នំធំ... ភ្នំតូចដែលនៅជាដរាប
«ភ្នំដែលមានតាំងពីដើម...ភ្នំដែលនឹងមានរហូតដល់ទីបញ្ចប់នៃពេលវេលា។
ប្រសិនបើភាសារបស់អ្នកមិនមានពាក្យខុសគ្នាសម្រាប់ «កូនភ្នំ» និង «ភ្នំ»
ឬសម្រាប់ «អស់កល្បជានិច្ច» និង «ជាដរាប» អ្នកអាចផ្សំពាក្យទាំងនេះដូចជា
ULB បានធ្វើ។
ក្រាបចុះ
ក្នុងការថ្វាយបង្គំព្រះ។ «ត្រូវបានក្រាបទៅនឹងដី»
Habakkuk 3:7
ព័ត៌មានទូទៅ៖
ហាបាគុកបន្តរៀបរាប់អំពីនិមិត្តរបស់គាត់ចំពោះព្រះអម្ចាស់។
ជំរំរបស់ជនជាតិគូសានរលាយសូន្យ និងចំណែកជម្រក...ជនជាតិម៉ាឌានក៏ញ័រកក្រើក
ប្រជាជននៅស្រុកម៉ាឌាន និងគូសានដែលញាប់ញ័រ
ឬភ័យខ្លាចប្រៀបបាននឹងក្រណាត់តង់ ដែលរើចេញនៅពេលមានខ្យល់បក់។
ជនជាតិគូសាន
អាចមានន័យថាទី១អាចជា ឈ្មោះក្រុមមនុស្សដែលមិនដឹង ឬទី២
ដូចគ្នានឹងទឹកដីគូលដែរ។
តើព្រះអម្ចាស់មានព្រះហឫទ័យខ្ញាល់នឹងទន្លេទាំងនោះឬ?
តើព្រះអម្ចាស់ក្រោធនឹងទន្លេឬក៏ក្រោធទៅលើសមុទ្រ...វាយយកជ័យជម្នះមែនទេ?
ប្រសិនបើភាសារបស់អ្នកមិនមានពាក្យដាច់ដោយឡែកសម្រាប់ «ខឹង» និង
«កំហឹង» និង «ខឹងខ្លាំង» អ្នកអាចច្របាច់បញ្ចូលគ្នានូវជួរនានា
«តើព្រះអម្ចាស់ខ្ញាល់នឹងទន្លេឬ?
តើព្រះអង្គខ្ញាល់នឹងសមុទ្រ...រទេះចម្បាំងដែលមានជ័យជំនះឬ?»។
របៀបផ្សេងទៀតនៃការបកប្រែ «ព្រះអម្ចាស់មិនខ្ញាល់ងទន្លេទេ។
សេចក្តីរបស់ព្រះអង្គមិនប្រឆាំងនឹងទន្លេហើយក៏មិនខ្ញាល់នឹងសមុទ្រ...រទេះចំបាំងដែលមានជ័យជំនះ។
ព្រះអង្គជិះសេះនិងរទេះចម្បាំង វាយយកជ័យជម្នះ
នៅពេលដែលទាហានចង់ជិះសេះ
ឬរទេះចំបាំងព្រះអម្ចាស់បានយាងមកជួយសង្គ្រោះប្រជាជនអ៊ីស្រាអែល។
Habakkuk 3:9
សម្រាក
ពាក្យនេះមានន័យថា «ឈប់ហើយឆ្លុះបញ្ចាំង» ឬ «លើកតម្កើង លើកសរសើរ»។
ភ្នំបានឃើញព្រះអង្គ ក៏នាំគ្នាភ័យញាប់ញ័រដោយឈឺចាប់
កាលដែលព្រះជាម្ចាស់បានបែងចែកផែនដី ភ្នំបានធ្វើចលនាដូចជា
ពួកគេអាចមើលឃើញសកម្មភាពរបស់ព្រះជាម្ចាស់
ហើយមានប្រតិកម្មដោយងាកចេញពីកន្លែងដែលផែនដីត្រូវបានបែងចែក។
ទឹកជម្រៅនៃទឹកក៏ពុះកញ្ជ្រោលយ៉ាងខ្លាំង
សំឡេងនៃរលកធំៗនៅសមុទ្រ
ហើយក៏ធ្វើឲ្យមានរលកធំៗ
កម្រិតទឹកកើនឡើង
Habakkuk 3:11
ព័ត៌មានទូទៅ៖
ហាបាគុកបន្តរៀបរាប់អំពីនិមិត្តរបស់គាត់ចំពោះព្រះអម្ចាស់។
ជាបំភ្លឺដល់គ្រាប់ព្រួញរបស់ព្រះអង្គ
ដោយសារពន្លឺព្រួញរបស់ព្រះអម្ចាស់ភ្លឺខ្លាំងណាស់
ព្រះអង្គបានយាងកាត់ផែនដីដោយកំហឹង។ ព្រះអង្គជាន់កម្ទេចប្រជាជាតិនានាដោយសេចក្តីក្រោធ។
ប្រយោគទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។

generated on Wed Sep 10 16:16:32 2025

ពួកគេរួមជាមួយព្រះអម្ចាស់ដាក់ទោសប្រជាជាតិនានាចំពោះអំពើទុច្ចរិតរបស់ពួកគេ។
កំហឹង
ខឹងនឹងអ្វីដែលខុស
Habakkuk 3:13
ព័ត៌មានទូទៅ៖
ហាបាគុករៀបរាប់អំពីព្រះអម្ចាស់។
ព្រះអង្គបានចាក់ប្រេងតាំង
មានន័យថា ទី១) «ព្រះមេស្ស៊ីរបស់អ្នក» ប៉ុន្តែឯកសារយោងគឺច្បាស់ចំពោះ
«ប្រជាជនរបស់អ្នក» ដូច្នេះប្រើនាមធម្មតានៅត្រង់នេះ
មិនមែនជាឈ្មោះត្រឹមត្រូវទេ។
ព្រះអង្គវាយប្រហារមេគ្រួសាររបស់មនុស្សអាក្រក់
«ព្រះអង្គបានបំផ្លាញមេដឹកនាំរបស់មនុស្សអាក្រក់»
Habakkuk 3:14
ព័ត៌មានទូទៅ៖
ហាបាគុកពិពណ៌នាអំពីព្រះអម្ចាស់បំផ្លាញពួកខាល់ដេ។
ព្រួញទាំងនោះមកដូចខ្យល់
អំណាច និងភាពរហ័សរហួនរបស់ពួកខាល់ដេ
នៅពេលពួកគេវាយប្រហារប្រជាជនអ៊ីស្រាអែលត្រូវបានគេប្រៀបធៀបទៅនឹងព្យុះដែលនឹងបក់បោក
ស្រែកហ៊ោ
«ការអួតខ្លួន»
ពួនស្ទាក់ប្រហារជនក្រីក្រ
រកមនុស្សក្រីក្រដែលកំពុងលាក់ខ្លួនពីពួកគេ ហើយសម្លាប់ពួកគេ
និងយករបស់របរទាំងអស់របស់ពួកគេផង
ប្រហារ
បរិភោគអ្វីគ្រប់យ៉ាងលឿន
Habakkuk 3:16
ព័ត៌មានទូទៅ៖
ហាបាគុកពិពណ៌នាអំពី
ការភ័យខ្លាចរបស់គាត់នៅពេលគាត់គិតអំពីរបៀបដែលព្រះអម្ចាស់នឹងដាក់ទោសជនជាតិខាល់ដេ។
ខ្ញុំក៏ភ័យញ័ររន្ធត់ ហើយបបូរមាត់ខ្ញុំក៏ញ័រ...ហើយឆ្អឹងរបស់ខ្ញុំកាន់តែពុកទៅៗ...នៅស្ងៀមឥតកម្រើក
ឃ្លាទាំងនេះសំដៅទៅលើការភ័យខ្លាច
ដែលបង្កឡើងដោយការគិតអំពីព្រឹត្តិការណ៍នាពេលអនាគត។
ហាបាគុកប្រើផ្នែកជាច្រើននៃរាងកាយរបស់គាត់ ដើម្បីបង្ហាញថា
គ្រប់ផ្នែករបស់គាត់ភ័យខ្លាច។
ពុក
រលួយ
Habakkuk 3:17
ដើមឧទុម្ពរ...ទំពាំងបាយជូរ...ដើមអូលីវ...ស្រែចម្ការ...ពួកចៀម...គោ
គ្មានអាហារទេ។ ទាំងនេះគឺជាប្រភពអាហារស្ទើរតែទាំងអស់
ដែលត្រូវរកឃើញនៅក្នុងទឹកដីអ៊ីស្រាអែល។
Habakkuk 3:18
ព័ត៌មានទូទៅ៖
ហាបាគុកសរសើរដល់ព្រះអម្ចាស់។
ពាក្យទាំងពីរមានន័យថា «រីករាយ»។
ប៉ុន្តែប្រសិនបើភាសារបស់អ្នកមានពាក្យពិសេសសម្រាប់ពាក្យរីករាយបន្ទាប់ពីឈ្នះការប្រយុទ្ធសូមប្រើពាក្
«អរសប្បាយ» នេះ។
ធ្វើឲ្យជើងរបស់ខ្ញុំរត់លឿន ដូចឈ្លូស ព្រះអង្គប្រទានឲ្យខ្ញុំដើរនៅលើទីខ្ពស់
ជើងដូចជាសត្វក្តាន់នឹងផ្តល់ឲ្យហាបាគុកនូវសមត្ថភាពក្នុងការឡើងលើច្រាំងថ្មចោត។
ពាក្យ «ទីខ្ពស់» សំដៅទៅលើកន្លែងដែលផុតពីគ្រោះថ្នាក់។ គាត់កំពុងនិយាយថា
ព្រះជាម្ចាស់កំពុងប្រទានឲ្យគាត់នូវសមត្ថភាពក្នុងការរកកន្លែងសុវត្ថិភាព។

សេផានា

1

[1]នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់លោកសេផានាដែលជាកូនប្រុសរបស់គូស៊ីជាចៅរបស់លោកកេដាលាជាកូនរបស់លោកអាម៉ារា និងជាកូនរបស់លោកហេសេគា
ក្នុងសម័យកាលរបស់លោកយ៉ូសៀសជាកូនប្រុសរបស់អម៉ូនជាស្តេចនៃស្រុកយូដា។[2]«យើងនឹងបំផ្លាញអ្វីៗទាំងអស់ ចេញពីផ្ទៃនៃផែនដី
នេះជាសេចក្តីប្រកាសរបស់ព្រះអម្ចាស់។[3]យើងនឹងបំផ្លាញមនុស្សសត្វ យើងនឹងបំផ្លាញសត្វស្លាបលើមេឃ ត្រីនៅក្នុងសមុទ្រ យើងនឹងកំទេចមនុស្សអាក្រក់។ ដ្បិត
យើងនឹងដកមនុស្សពីផែនដី នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[4]យើងនឹងប្រហារទឹកដីយូដាដោយដៃយើង និងប្រជាជនទាំងអស់នៃក្រុងយេរូសាឡឹម។ យើងនឹងបំផ្លាញសំណល់នៃព្រះបាលចេញពីទីកន្លែងនេះ
និងមនុស្សដែលថ្វាយបង្គំបូជាចារ្យ[5]ហើយអស់អ្នកដែលនៅលើផ្ទះថ្វាយបង្គំព្រះអាទិត្យ និងមនុស្សដែលថ្វាយបង្គំ
ព្រមទាំងស្បថទៅកាន់ព្រះអម្ចាស់ប៉ុន្តែក៏បានស្បថចំពោះស្តេចរបស់ពួកគេ។[6]យើងនឹងបំផ្លាញអស់អ្នកដែលងាកចេញឆ្ងាយពីការដើរតាមព្រះអម្ចាស់
និងអស់អ្នកដែលស្វែងរកព្រះអម្ចាស់ តែមិនបានធ្វើតាមការណែនាំរបស់ព្រះជាម្ចាស់»។
[7]ចូរស្ងៀមនៅចំពោះព្រះអម្ចាស់! នៅថ្ងៃដែលព្រះអម្ចាស់យាងមក ព្រះអម្ចាស់បានរៀបចំថ្វាយយញ្ញបូជា ហើយបានញែកភ្ញៀវរបស់ព្រះអង្គដោយឡែក។
[8]«នៅថ្ងៃថ្វាយយញ្ញបូជារបស់ព្រះអម្ចាស់ យើងនឹងដាក់ទោសមេដឹកនាំនិងកូនៗរបស់ស្តេច និងគ្រប់គ្នាដែលពាក់សំលៀកបំពាក់ជនជាតិដទៃ។
[9]នៅថ្ងៃនោះយើងនឹងដាក់ទោសអស់អ្នកដែលលោតរំលងទ្វារ និងអស់អ្នកដែលបំពេញផ្ទះចៅហ្វាយរបស់ពួកគេដោយអំពើហឹង្សានឹងការបោកប្រាស។
[10]នេះគឺសេចក្តីប្រកាសរបស់ព្រះអម្ចាស់នៅថ្ងៃនោះនឹងមកដល់ អ្នកដែលមានសេចក្តីទុក្ខព្រួយនឹងចេញមកពីមាត់ទ្វារត្រី និងទ្រហោយំចេញមកពីស្រុកទីពីរ
និងសម្លេងទោកសោកចេញពីភ្នំ។[11]សម្រែកទ្រហោយំរបស់ប្រជាជនដែលរស់នៅស្រុកម៉ាកថេស ដែលជាអ្នកជំនួញទាំងអស់នឹងបំផ្លាញ
អ្នកដែលទារប្រាក់នឹងត្រូវកាត់ចេញ។
[12]នៅគ្រានោះ យើងនឹងកាន់ចន្លុះ រុករកអស់អ្នកដែលយើងត្រូវដាក់ទោស នៅក្រុងយេរូសាឡឹម អ្នកទាំងនោះសម្ងំ ហើយគិតថា ព្រះអម្ចាស់ មិនអាចធ្វើអាក្រក់ ឬល្អបាន
ទេ។[13]ទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវគេប្លន់ ហើយផ្ទះរបស់ពួកគេនឹងត្រូវបំផ្លិចបំផ្លាញ! ពួកគេនឹងសង់ផ្ទះប៉ុន្តែមិនអាចនៅបាន ហើយគេនឹងធ្វើចម្ការទំពាំងបាយជូរ
តែមិនបានផឹកស្រាចេញពីផលទំពាំងបាយជូរបានដែរ។
[14]នៅថ្ងៃដ៏អស្ចារ្យរបស់ព្រះអម្ចាស់ជិតមកដល់ហើយ និងមកដល់ក្នុងពេលឆាប់ៗ! សម្លេងនៃថ្ងៃព្រះអម្ចាស់នឹងមានអ្នកចម្បាំងស្រែកយំយ៉ាងខ្លោចផ្សា![15]ថ្ងៃនោះ
ជាថ្ងៃនៃកំហឹង ជាថ្ងៃនៃទុក្ខព្រួយ និងវេទនា ថ្ងៃមួយនៃព្យុះសង្ឃរានិងការបំផ្លិចបំផ្លាញ ថ្ងៃនៃយប់ខ្មៅងងឹត ជាថ្ងៃដែលមានពពកក្រាស់ខ្មៅ។[16]ជាថ្ងៃនៃសម្លេងត្រែ
និងសម្រែកសឹកសង្គ្រាមច្បាំងនឹងក្រុងដែលមានកំផែងការពារទីក្រុង និងប៉មខ្ពស់ៗ។
[17]យើងនឹងនាំយកសេចក្តីទុក្ខព្រួយមកដាក់លើមនុស្សជាតិ ដូច្នេះពួកគេនឹងដើរដូចមនុស្សខ្វាក់ចាប់តាំងពីពួកគេប្រព្រឹត្តអំពើបាបទាស់ប្រឆាំងនឹងព្រះអម្ចាស់។
ឈាមរបស់ពួកគេនឹងត្រូវចាក់បង្ហូរដូចជាធូលីដីហើយផ្នែកខាងក្នុងដូចជាលាមក។[18]ទាំងប្រាក់ ឬមាសមិនអាចជួយពួកគេរួចពីកំហឹងរបស់ព្រះអម្ចាស់បានទេ។
ដោយភ្លើងប្រចណ្ឌរបស់ព្រះអម្ចាស់ ផែនដីទាំងមូលនឹងត្រូវឆេះ ទ្រង់នឹងបញ្ចប់សេចក្តីអាក្រក់របស់ប្រជាជនដែលរស់នៅលើផែនដី»។

Zephaniah 1:1
ព្រះបន្ទូលរបស់ព្រះអម្ចាស់
«ជាអ្វីដែលព្រះអម្ចាស់បានមានបន្ទូល»
ព្រះអម្ចាស់
នេះគឺជាព្រះនាមព្រះអម្ចាស់ដែលបើកសម្តែងដល់មនុស្សនៅក្នុងសម្ព័ន្ធមេត្រីចាស់។
សូមមើលទំព័រនៃការបកប្រែពាក្យអំពី ព្រះអម្ចាស់ទាក់ទងនឹងការបកប្រែនេះ។
យើងនឹងបំផ្លាញអ្វីៗទាំងអស់ ចេញពីផ្ទៃនៃផែនដី...យើងនឹងដកមនុស្សពីផែនដី
ទាំងនេះជាចេតនាបំផ្លើសដែលព្រះអម្ចាស់ដើម្បីបង្ហាញពីកំហឹងរបស់ព្រះអង្គចំពោះអំពើបាបរបស់មនុស្ស

generated on Wed Sep 10 16:16:32 2025

(សូមមើល:figs-hyperbole)

ដក

ការបំផ្លាញដែលគេនិយាយប្រៀបដូចជាការកាត់អ្វីមួយចេញពីផ្នែកណាមួយ។

Zephaniah 1:4

មីលកូម

«មីលកូម» អាចជាឈ្មោះផ្សេងទៀតរបស់រូបព្រះ «ម៉ូឡិច»។

Zephaniah 1:7

ព្រះអម្ចាស់បានរៀបចំថ្វាយយញ្ញបូជា ហើយបានញែកភ្ញៀវរបស់ព្រះអង្គដោយឡែក

ភាសានេះគឺបង្ហាញផែនការចុងក្រោយរបស់ព្រះជាម្ចាស់ និង
ពីរបៀបដែលព្រះអង្គប្រើខ្មាំងសត្រូវរបស់ប្រជាជន
របស់ព្រះអង្គដើម្បីសម្រេចផែនការនោះ។ ។

គ្រប់គ្នាដែលពាក់សំលៀកបំពាក់ជនជាតិដទៃ

ឃ្លានេះណែនាំឲ្យប្រជាជនអ៊ីស្រាអែលស្លៀកពាក់ដូចគ្នាទៅនឹងសាសន៍ដទៃ
ដើម្បីបង្ហាញចិត្តអាណិតអាសូរចំពោះទំនៀមទម្លាប់ និង
ការថ្វាយបង្គំព្រះដទៃរបស់ពួកគេ។ ។

នៅថ្ងៃនោះ

«នៅថ្ងៃរបស់ព្រះអម្ចាស់»

អស់អ្នកដែលលោតរំលងទ្វារ

នេះគឺជាឯកសារយោងចំពោះមនុស្សដែលថ្វាយបង្គំទេវរូបពិសេសមួយដែលហៅថា
«ដាកាន» ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលក្រាបថ្វាយបង្គំ ដាកាន» ។

Zephaniah 1:10

សេចក្តីប្រកាសរបស់ព្រះអម្ចាស់

ការបកប្រែរបៀបផ្សេងទៀត: «អ្វីដែលព្រះអម្ចាស់បានប្រកាស» ឬ
«អ្វីដែលព្រះអម្ចាស់បានមានបន្ទូល»

មាត់ទ្វារត្រី

មាត់ទ្វារត្រីជាទ្វារមួយនៅក្នុងទីក្រុង។

ទ្រហោយំចេញមកពីស្រុកទីពីរ

ការបកប្រែរបៀបផ្សេងទៀត: «សម្រែកយំសោកខ្លាំងៗចេញពីស្រុកទីពីរ»
ស្រុកទីពីរជាផ្នែកថ្មីមួយនៃក្រុងយេរូសាឡិម។

ចេញពីភ្នំ

នេះសំដៅទៅលើភ្នំដែលនៅជុំវិញក្រុងយេរូសាឡិម។ ការបកប្រែរបៀបផ្សេងទៀត:
«ចេញពីភ្នំដែលនៅជុំវិញក្រុងយេរូសាឡិម»

ដែលជាអ្នកជំនួញទាំងអស់នឹងបំផ្លាញ អ្នកដែលទារប្រាក់នឹងត្រូវកាត់ចេញ

ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលលក់ដូរទំនិញ
អ្នកជំនួញនឹងត្រូវសម្លាប់ចោល»

Zephaniah 1:12

យើងនឹងកាន់ចន្លុះ រុករកអស់អ្នកដែលយើងត្រូវដាក់ទោស នៅក្រុងយេរូសាឡឹម

គ្មាននណារម្នាក់អាចលាក់ខ្លួនពីព្រះអម្ចាស់បានឡើយ។

នៅសម្ងំ

ពួកគេគិតថារួចខ្លួនពីបញ្ហា។

គិតនៅក្នុងចិត្ត

ពួកគេយ៉ាងច្បាស់។

Zephaniah 1:14

ជិតមកដល់ហើយ និងមកដល់ក្នុងពេលឆាប់ៗ

ពាក្យដដែលៗនៃពាក្យ «ជិត» រួមជាមួយឃ្លា «មកដល់ក្នុងពេលឆាប់ៗ»
បញ្ជាក់ថាថ្ងៃដែលព្រះអម្ចាស់នឹងជំនុំជំរះមនុស្សនឹងមកដល់ឆាប់ៗ។
ការបកប្រែរបៀបផ្សេងទៀត: «ជិត ហើយមកដល់ឆាប់ៗ»

ថ្ងៃនោះ ជាថ្ងៃនៃកំហឹង...ប៉ម

ប្រយោគនេះគឺបញ្ជាក់ឲ្យឃើញថាការជំនុំជំរះរបស់ព្រះជាម្ចាស់នឹងគួរឲ្យខ្លាចប៉ុណ្ណា។
ការនឹងមានការលើកឡើងមកនិយាយជាច្រើន
ហើយបង្ហាញពីការដែលនឹងបំផ្លាញនៃការជំនុំជំរះលើកចុងក្រោយដោយព្រះជាម្ចាស់។
វាបង្កើតការសង្កត់ធ្ងន់បែបនេះ។

ជាថ្ងៃនៃទុក្ខព្រួយ និងវេទនា

ពាក្យថា «ទុក្ខព្រួយ» និង «វេទនា» មានន័យដូចគ្នា ហើយបញ្ជាក់កម្រិតទុក្ខព្រួយ
ឈឺចាប់របស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ថ្ងៃមួយដែលមនុស្សនឹងមានអារម្មណ៍សោកសង្រេងខ្លាំង»

ថ្ងៃមួយនៃព្យុះសង្ឃរានិងការបំផ្លិចបំផ្លាញ

ពាក្យនៅទីនេះ «ព្យុះសង្ឃរា» សំដៅទៅលើការថ្លែងពីការជំនុំជំរះ។ ពាក្យថា
«ការបំផ្លិចបំផ្លាញ» ពិពណ៌នាអំពីឥទ្ធិពលនៃការជំនុំជំរះនោះ។
ការបកប្រែរបៀបផ្សេងទៀត: «ថ្ងៃនៃព្យុះសង្ឃរាដែលបំផ្លាញ» ឬ
«ថ្ងៃនៃការជំនុំជំរះដែលបំផ្លិចបំផ្លាញ»

ថ្ងៃនៃយប់ខ្មៅងងឹត ជាថ្ងៃដែលមានពពកក្រាស់ខ្មៅ

ពាក្យថា «យប់ខ្មៅងងឹត» និង «ពពកក្រាស់ខ្មៅ» មានន័យដូចគ្នា
ហើយបញ្ជាក់ពីកម្រិតខ្មៅងងិត។
ពាក្យទាំងពីរនេះសំដៅទៅលើពេលវេលានៃគ្រោះមហន្តរាយ ឬ ការជំនុំជំរះ។
ការបកប្រែរបៀបផ្សេងទៀត: «ថ្ងៃដែលពេញដោយភាពខ្មៅងងិត» ឬ «
ថ្ងៃនៃការជំនុំជំរះដ៏គួរឲ្យខ្លាច»

ជាថ្ងៃនៃសម្លេងត្រែ និងសម្រែកសឹកសង្គ្រាមច្បាំង

ពាក្យថា «សម្លេងត្រែ» និង «សម្រែកសឹកសង្គ្រាមច្បាំង»
មានន័យដូចគ្នានៅទីនេះ។
ពាក្យទាំងពីរមានន័យសំដៅចំពោះទាហានដែលត្រៀមច្បាំង»

កំផែងការពារទីក្រុង និងប៉មខ្ពស់ៗ

ឃ្លាទាំងពីរនេះសំដៅទៅលើបន្ទាយយោធា។ ការបកប្រែរបៀបផ្សេងទៀត:
«ទីក្រុងដែលមានកំពែងការពាររឹងមាំ»

Zephaniah 1:17

ដើរដូចមនុស្សខ្វាក់...ចាក់បង្ហូរដូចជាធូលីដី...ផ្នែកខាងក្នុងដូចជាលាមក

ឃ្លាទាំងបីនេះបង្ហាញពីការប្រៀបធៀបដើម្បីបង្ហាញពីអ្វីដែលពួកគេមានជាធម្មតា។

ដោយភ្លើងប្រចណ្ឌ

នេះសំដៅទៅលើអំណាចនៃកំហឹងរបស់ព្រះអម្ចាស់។

---

2 [1]ចូរប្រមូលផ្តុំគ្នា និងប្រជុំប្រជាជាតិដែលមិនមានភាពអៀនខ្មាស[2]មុនពេលដែលថ្ងៃនៃព្រះជាម្ចាស់ដាក់ទោសមនុស្សគ្រប់គ្នា
នឹងត្រូវខ្ចាត់ខ្ចាយដូចជាអង្កាមហោះតាមខ្យល់ មុនពេលព្រះអម្ចាស់ព្រះពិរោធមកលើអ្នករាល់គ្នា។[3]ស្វែងរកព្រះអម្ចាស់ដោយបន្ទាប់ខ្លួន
ចំពោះអ្នកដែលស្តាប់បង្គាប់ការណែនាំរបស់ព្រះអម្ចាស់! ស្វែងរកសេចក្តីសុចរិត។ ស្វែងរកព្រះអម្ចាស់ដោយបន្ទាបខ្លួននោះ
អ្នកនឹងទទួលបានការការពារនៅថ្ងៃដែលព្រះអម្ចាស់យាងមកដល់។
[4]តំបន់ហ្គាហ្សានឹងត្រូវបោះបង់ចោល និងក្រុងអាស្កាឡូននឹងត្រូវបំផ្លិចបំផ្លាញ។ ពួកគេនឹងទៅក្រៅអាសដូឌនៅពេលល្ងាច ហើយក្រុងអេក្រូននឹងត្រូវដកចេញ!
ប្រជាជនកេរេរស់នៅឆ្នេរខ្សាច់នឹងត្រូវវេទនា![5]ព្រះអម្ចាស់មានព្រះបន្ទូលប្រឆាំងនឹងអ្នកកាណានៃទឹកដីភីលីស្ទីន។
យើងនៅតែកំទេចប្រជាជាតិរបស់អ្នកមិនឲ្យនៅសល់ទៀតទេ។
[6]ដូច្នេះតាមឆ្នេរសមុទ្រនឹងក្លាយទៅជាវាលស្មៅ សម្រាប់អ្នកគង្វាល និងសម្រាប់សត្វចៀម។[7]តាមតំបន់ច្រាំងសមុទ្រនឹងក្លាយជាសំណល់ផ្ទះនៃទឹកដីយូដា
ជាអ្នកគង្វាលឃ្វាលហ្វូងសត្វរបស់ពួកគេនៅទីនោះ។ ប្រជាជនរបស់ពួកគេនឹងសម្រាកក្នុងផ្ទះរបស់អាសកាឡូននៅពេលល្ងាច
ដ្បិតព្រះអម្ចាស់ជាព្រះរបស់ពួកគេនឹងមើលថែទាំ ហើយស្តារពួកគេឡើងវិញ។
[8]យើងបានឮពាក្យចំអកមើលងាយដល់ម៉ូអាប់ និងការត្មិះតិះដៀលនៃពួកអាំម៉ូន នៅពេលដែលពួកគេចំអកមកប្រជាជនរបស់យើង
និងការរំលោភបំពានព្រំដែនរបស់ពួកគេ។[9]ហេតុនេះហើយ ព្រះអម្ចាស់ដែលមានព្រះជន្មរស់ យើងនឹងប្រកាសក្នុងនាមព្រះអម្ចាស់ជាព្រះនៃអ៊ីស្រាអែល
ហើយម៉ូអាប់នឹងក្លាយដូចជាសូដុម ហើយនិងប្រជាជនអាំម៉ូនក៏ដូចជាក្រុងកូម៉ូរ៉ា ទៅជាទីកន្លែងនៃដើមកន្ទេចអាល និងរណ្តៅអំបិល ជាវាលខ្សាច់ជារៀងរហូត។
ប៉ុន្តែប្រជាជនដែលនៅសល់ពួកគេនឹងយកជ័យភ័ណ្ឌ ហើយទុកជាការរំលឹកនៃប្រជាជាតិរបស់យើង នឹងកាន់កាប់លើពួកគេ។
[10]ហេតុការណ៍នេះនឹងកើតឡើងលើទឹកដីម៉ូអាប់ និងអាំម៉ូនដោយព្រោះតែការក្រអឺតក្រទមរបស់ពួកគេ ចាប់តាំងពីពួកគេចំអកឡកឡើយ
និងសើចចំអកប្រជាជនរបស់ព្រះអម្ចាស់ជានៃពិភពទាំងមូល។[11]ពួកគេនឹងភ័យខ្លាចចំពោះព្រះអម្ចាស់ នឹងធ្វើឲ្យព្រះទាំងអស់លើផែនដីសាបសូន្យ។
គ្រប់គ្នានឹងក្រាបថ្វាយបង្គំព្រះអម្ចាស់ គ្រប់គ្នាដែលមកពីតាមឆ្នេរ និងគ្រប់ទីកន្លែង។

generated on Wed Sep 10 16:16:32 2025

[12]អ្នកដែលជាជនជាតិអេត្យូពីនឹងទំលាក់ដោយដាវរបស់យើង[13]ហើយព្រះហស្តរបស់ព្រះអម្ចាស់នឹងវាយប្រហារ ហើយបំផ្លាញលើស្រុកអាស្ស៊ីរី
ដូច្នេះក្រុងនីនីវេនឹងត្រូវបោះបង់ចោលហើយបំផ្លិចបំផ្លាញឲ្យរីងស្ងួតដូចខ្សាច់។[14]ហ្វូងសត្វនឹងសម្រាក់នៅទីនោះទាំងសត្វគ្រប់ប្រភេទ ទាំងស្មៅញ
និងខ្វែកនឹងទំលើក្បាលសសរ។ សម្លេងបានច្រៀងឡើងតាមបង្អួចហើយគ្រប់ទាំងទ្វារផ្ទះបាក់បែក ដើមតាត្រៅដែលឆ្លាក់ហើយធ្មឹមនឹងត្រូវជ្រុះអស់។
[15]នេះជាទីក្រុងដែលរស់នៅដោយសប្បាយដោយគ្មានភាពភ័យខ្លាច នេះជាពាក្យដែលនិយាយពីក្នុងចិត្ត «មានតែយើងហើយគ្មានអ្វីស្មើនិងយើងទេ»។
ទីក្រុងនោះក្លាយជាទីកន្លែងរន្ធត់ ជាកន្លែងជម្រកសត្វព្រៃសម្រាក។ គ្រប់មនុស្សទាំងអស់នឹងឆ្លងកាត់ទីនេះ សត្វទាំងនោះនឹងហួចចំអក ហើយអង្រន់ដៃ។

Zephaniah 2:1

ចូរប្រមូលផ្តុំគ្នា និងប្រជុំប្រជាជាតិ

ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ ពាក្យទាំងពីរនេះរួមចូលគ្នាដើម្បីពង្រឹងបទបញ្ញត្តិ ដើម្បីឲ្យមនុស្សប្រែចិត្តពីអំពើបាបរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត: «ប្រមូលផ្តុំគ្នា»

ប្រជាជាតិដែលមិនមានភាពអៀនខ្មាស

ប្រជាជាតិមិនមានការសោកស្តាយចំពោះអំពើបាបរបស់ពួកគេ។

ថ្ងៃនោះត្រូវខ្ចាត់ខ្ចាយដូចជាអង្កាម

អង្កាមជាផ្នែកមិនសំខាន់មួយរបស់រុក្ខជាតិ ដែលត្រូវគេបោះចោល
ដូច្នេះថ្ងៃនោះក៏នឹងកន្លងទៅលឿន។ ។

មុនពេលដែលថ្ងៃនៃព្រះជាម្ចាស់ដាក់ទោសមនុស្សគ្រប់គ្នា

នឹងត្រូវខ្ចាត់ខ្ចាយដូចជាអង្កាមហោះតាមខ្យល់ មុនពេលព្រះអម្ចាស់ព្រះពិរោធមកលើអ្នករាល់គ្នា

ព្យាការីថ្លែងដដែលៗពីឃ្លាដូចគ្នានេះស្ទើរតែទាំងស្រុង
ដើើម្បីបញ្ជាក់ពីការជំនុំជំរះរបស់ព្រះអម្ចាស់ថាគួរឲ្យខ្លាចប៉ុណ្ណា និង
លឿនប៉ុណ្ណាដើម្បីឲ្យមនុស្សត្រូវតែប្រែចិត្ត។ ។

ព្រះពិរោធរបស់ព្រះអម្ចាស់

នេះតំណាងឲ្យចេតនារបស់ព្រះជាម្ចាស់ក្នុងការកាត់ទោស។

Zephaniah 2:4

ពួកគេនឹងទៅក្រៅអាសដូឌនៅពេលល្ងាច ហើយក្រុងអេក្រូននឹងត្រូវដកចេញ

ប្រជាជននឹងត្រូវគេដេញចេញពីទីក្រុងទាំងនោះជាបន្ទាន់។

រហូតដល់គ្មានអ្នករស់នៅ

ការបកប្រែរបៀបផ្សេងទៀត: «រហូតដល់គ្មាននណារម្នាក់នៅទីនោះ»។

Zephaniah 2:6

ដូច្នេះតាមឆ្នេរសមុទ្រនឹងក្លាយទៅជា...សម្រាប់សត្វចៀម

ផ្នែកនៃខ មានន័យមិនច្បាស់លាស់ និង បកប្រែក្នុងរបៀបផ្សេងទៀតតាមជំនាន់ថ្មី។

ទ្រុងចៀម

ទ្រុងចៀមជាកន្លែងតូចមួយនៅជុំវិញរបង ដើម្បីឲ្យចៀមនៅជាមួយគ្នា។

សម្រាក

មានន័យថាគេងនៅលើគ្រែ

Zephaniah 2:8

សេចក្តីប្រកាសរបស់ព្រះអម្ចាស់នៃសកលលោក

«អ្វីដែលព្រះអម្ចាស់បានប្រកាស» ឬ
«អ្វីដែលព្រះអម្ចាស់នៃសកលលោកបានប្រកាស»

Zephaniah 2:12

កំពូលជួរសរសររបស់នាង

នៅពេលដែលអគារត្រូវគេបំផ្លាញ និង រលំដួល សរសរគេប្រើដើម្បីតុបតែង និង
ទ្រអាគារនោះវាតែងតែនៅឈរដដែល។

ធ្មឹម

ធ្មឹមជាឈើវែង ហើយមាំដែលគេប្រើដើម្បីរក្សាឲ្យអគារនៅរឹងមាំ។

Zephaniah 2:15

ហួចចំអក ហើយអង្រន់ដៃ

ហួចចំអកជាសម្លេងកំហឹង។

ឃ្លានេះបង្ហាញអំពីកំហឹងរបស់ប្រជាជនចំពោះក្រុងនីនីវេ។

---

3 [1]វេទនាដល់អ្នកដែលប៉ះបោរក្នុងទីក្រុង! អំពើហិង្សាក្នុងទីក្រុងមានកាន់តែស្មោកគ្រោក។[2]ពួកគេនេះមិនបានស្តាប់សម្លេងរបស់ព្រះអម្ចាស់
ឬការទទួលយកការកែតម្រូវពីព្រះអម្ចាស់។ ពួកគេមិនបានទុកចិត្តព្រះអម្ចាស់ ហើយមិនអាចចូលជិតព្រះអម្ចាស់បានឡើយ។
[3]ក្រុមមេដឹកនាំកណ្តាលក្រុង នាំគ្នាគ្រហឹមដូចសត្វសិង្ហ។ ពួកចៅក្រមដូចជាសត្វចចកដែលចេញនៅពេលល្ងាចស៊ីរហូតដល់ព្រឹកឡើង។[4]ពួកព្យាការីគេព្រហើន
ហើយជាមនុស្សក្បត់។ ពួកបូជាចារ្យនាំគ្នាប្រមាថអ្វីៗដែលបរិសុទ្ធ ហើយប្រព្រឹត្តក្បត់នឹងច្បាប់។
[5]ព្រះអម្ចាស់គឺនៅកណ្តាលហើយព្រះអង្គសុចរិត។ ព្រះអង្គមិនបានធ្វើអ្វីខុសឡើយ។ នៅរាល់ពេលព្រឹកទ្រង់បង្ហាញសេចក្តីយុត្តិធម៌! គ្មានអ្វីដែលអាចលាក់កំបាំងក្នុងពន្លឺ
តែមនុស្សទុច្ចរិតមិនចេះខ្មាស់ឡើយ។
[6]យើងបានកំទេចជនជាតិនេះ បន្ទាយរបស់ពួកគេត្រូវបានបាក់បែក។ ហើយយើងធ្វើឲ្យផ្លូវរបស់ពួកគេខូតខាត ដូច្នេះគ្មាននរណាម្នាក់អាចដើរកាត់ទីនោះឡើយ។
ទីក្រុងរបស់ពួកគេត្រូវបានខ្ទេចខ្ទី ដូច្នេះគ្មានមនុស្សណាស្នាក់អាស្រ័យបានឡើយ។[7]ព្រះអម្ចាស់មានព្រះបន្ទូលថា «ប្រាកដណាស់អ្នកនឹងភ័យខ្លាចយើង។
ការទទួលយកការកែតម្រូវមិនត្រូវកាត់ចេញពីផ្ទះរបស់អ្នក ដោយយើងជាអ្នករៀបចំគំរោងការណ៍ទាំងអស់»។ ប៉ុន្តែពួកគេចាប់ផ្តើមប្រព្រឹត្តអំពើពុករលួយរៀងរាល់ព្រឹក។
[8]ហេតុនេះហើយ បានជាព្រះអម្ចាស់មានសេចក្តីប្រកាសថា ចូររងចាំរហូតដល់ថ្ងៃដែលព្រះអម្ចាស់លើកអ្នកដែលជាជនរងគ្រោះឡើង។
ការសម្រេចចិត្តរបស់យើងនឹងប្រមូលផ្តុំជនជាតិក្នុងនគរនេះ ហើយជាសេចក្តីក្រោធរបស់យើងទៅលើពួកគេ ជាសេចក្តីក្រោធដ៏សាហាវ
ដូច្នេះគ្រប់ទាំងផែនដីនឹងត្រូវលេបត្របាក់ដោយភ្លើងនៃកំហឹងរបស់យើង។
[9]ប៉ុន្តែនៅពេលនោះយើងនឹងឲ្យប្រជាជនមានបបូរមាត់ស្អាត យើងនឹងហៅពួកគេក្នុងព្រះនាមព្រះអម្ចាស់ជាអ្នកបម្រើ យើងឈរដោយប្រកៀកស្មាគ្នាទៅវិញទៅមក។
[10]អ្នកដែលថ្វាយបង្គំយើងនឹងត្រូវទៅឆ្ងាយនៅនាយទន្លេទឹកដីអេត្យូពី និងនាំយកដង្វាយមកកាន់យើង។
[11]នៅថ្ងៃនោះអ្នកនឹងលែងខ្មាស់ព្រោះអំពើរបស់អ្នកដែលបានប្តេជ្ញាចិត្តទាស់ប្រឆាំងនឹងយើងចាប់តាំងពីនោះមកយើងនឹងដកចេញពីក្នុងចំណោមអ្នកដែលក្រអឺតក្រទម
ដូច្នេះអ្នកក៏លែងវាយឫកខ្ពស់នៅលើភ្នំដ៏បរិសុទ្ធរបស់យើងទៀតដែរ។
[12]ប៉ុន្តែយើងនឹងចាកចេញទៅយឺតៗ ចេញពីប្រជាជនក្រីក្រហើយអ្នកនឹងបដិសេដនៅក្នុងព្រះនាមព្រះអម្ចាស់ដ៏ជាព្រះ។
[13]ប្រជាជនអ៊ីស្រាអែលដែលនៅសេសសល់នឹងប្រព្រឹត្តអំពើអយុត្តិធម៌ ឬការនិយាយកុហក ហើយពោលពាក្យបោកបញ្ឆោតនៅក្នុងមាត់ដែរ
ដូច្នេះពួកគេនឹងដេកចុះដូចសត្វ ហើយគ្មាននរណាម្នាក់ធ្វើឲ្យពួកគេភ័យខ្លាចឡើយ»។
[14]ក្រុងស៊ីយ៉ូនបន្លឺសម្លេងឡើង! អ៊ីស្រាអែលចូរស្រែកឡើង។ ចូរអរសប្បាយដោយអស់ពីដួងចិត្តរបស់អ្នក កូនចៅនៃក្រុងយេរូសាឡឹមអើយ។
[15]ព្រះអម្ចាស់ទ្រង់បានដកការផ្តន្ទាទោសហើយ ទ្រង់បង្វែខ្មាំងសត្រូវរបស់អ្នកចេញ! ព្រះអម្ចាស់គឺជាស្តេចនៃរាស្ត្រអ៊ីស្រាអែលទាំងអស់។
អ្នកនឹងមិនភ័យខ្លាចការអាក្រក់ទៀតឡើយ![16]នៅថ្ងៃនោះប្រជាជនទាំងអស់នឹងនិយាយទៅកាន់ក្រុងយេរូសាឡឹមថា «កុំឲ្យភ័យខ្លាចនឹងក្រុងស៊ីយ៉ូន។
កុំអនុញ្ញាតិឲ្យដៃរបស់អ្នកធ្លាក់ចុះឡើយ។
[17]ព្រះអម្ចាស់ជាព្រះក្នុងចំណោមអ្នករាល់គ្នា ជាព្រះអម្ចាស់ដ៏ខ្លាំងពូកែជាព្រះដែលជួយសង្គ្រោះអ្នក។ ព្រះអង្គទ្រង់អបអរសាទរចំពោះអ្នកដោយអំណរ
ហើយទ្រង់មានព្រះហឫទ័យស្រលាញ់ចំពោះអ្នកដោយស្ងៀមស្ងាត់។ ព្រះជាម្ចាស់មានអរសប្បាយចំពោះអ្នកហើយទ្រង់នឹងស្រែកដោយអំណរ[18]នៅថ្ងៃនៃបុណ្យតែងតាំង។
យើងនឹងរំដោះអ្នកចេញពីគ្រោះមហន្តរាយ អ្នកនឹងមិនត្រូវអាម៉ាស់ទៀតឡើយ។
[19]មើល៍! យើងនឹងដោះស្រាយចំពោះអស់អ្នកដែលសង្កត់សង្កិនអ្នក។ នៅថ្ងៃនោះ យើងនឹងជួយសង្គ្រោះចៀម ហើយប្រមូលចៀមដែលវង្វេង។
យើងនឹងធ្វើឲ្យពួកគេទៅជាសរសើរ ហើយនឹងបំផ្លាស់ភាពអាម៉ាស់របស់គេទៅជាមានកិត្តិនាមនៅលើផែនដីទាំងមូល។[20]នៅថ្ងៃនោះយើងនឹងដឹកនាំអ្នក

generated on Wed Sep 10 16:16:32 2025

នៅថ្ងៃនោះយើងនឹងប្រមូលអ្នករាល់គ្នា។ យើងនឹងឲ្យគ្រប់ជនជាតិទាំងអស់នៃផែនដីគោរពសរសើរអ្នករាល់គ្នា នៅពេលដែលអ្នកឃើញការស្តារឡើងវិញរបស់យើង» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។

Zephaniah 3:1
ពួកគេនេះមិនបានស្តាប់សម្លេងរបស់ព្រះអម្ចាស់
ប្រជាជននៅក្រុងយេរូសាឡិមមិនបានស្តាប់បង្គាប់នូវអ្វីដែលព្រះជាម្ចាស់ចាត់ឲ្យព្យាការីនិងអ្នកបម្រើរបស់ទ្រង់ប្រាប់ពួកគេ
មិនអាចចូលជិតព្រះអម្ចាស់បានឡើយ
មនុស្សគេមិនមានដួងចិត្តក្នុងការថ្វាយបង្គំព្រះ និង ស្តាប់បង្គាប់ព្រះជាម្ចាស់ឡើយ។
Zephaniah 3:3
ក្រុមមេដឹកនាំកណ្តាលក្រុង នាំគ្នាគ្រហឹមដូចសត្វសិង្ហ
ការបកប្រែរបៀបផ្សេងទៀត: «មេដឹកនាំរបស់ក្រុងយេរូសាឡិមប្រើអំពើហឹង្សា»
ពួកចៅក្រមដូចជាសត្វចចកដែលចេញនៅពេលល្ងាចស៊ីរហូតដល់ព្រឹកឡើង
ការបកប្រែរបៀបផ្សេងទៀត:
ចៅក្រមគេជាមនុស្សអាក្រក់ដែលរឹបយករបស់ដែលជាកម្មសិទ្ធរបស់អ្នកដទៃ»។
នេះក៏ជាពាក្យប្រៀបធៀបដែរ។
ពួកព្យាការីគេព្រហើន ហើយជាមនុស្សក្បត់
ការបកប្រែរបៀបផ្សេងទៀត: «ព្យាការីរបស់គេមិនស្តាប់បង្គាប់ និង
ជាមនុស្សមិនស្មោះត្រង់»។
Zephaniah 3:5
គ្មានអ្វីដែលអាចលាក់កំបាំងក្នុងពន្លឺ
ការបកប្រែរបៀបផ្សេងទៀត:
«ភាពយុត្តិធម៌របស់គាត់គឺត្រូវបានបង្ហាញយ៉ាងច្បាស់នៅចំពោះមនុស្សគ្រប់គ្នា»
Zephaniah 3:6
យើងធ្វើឲ្យផ្លូវរបស់ពួកគេខូតខាត ដូច្នេះគ្មាននរណាម្នាក់អាចដើរកាត់ទីនោះឡើយ។
ទីក្រុងរបស់ពួកគេត្រូវបានខ្ទេចខ្ទី ដូច្នេះគ្មានមនុស្សណាស្នាក់អាស្រ័យបានឡើយ
ព្រះអម្ចាស់បញ្ជាក់ពីគំនិតពីផ្សេងគ្នាដើម្បីបញ្ជាក់ពីការបង្ហាញពីទីក្រុងទាំងស្រុង។
Zephaniah 3:8
សេចក្តីប្រកាសរបស់ព្រះអម្ចាស់
នេះមានន័យថាអ្វីដែលព្រះអម្ចាស់បានប្រកាស។
យើងក្រោកឡើងដើម្បីជនរងគ្រោះឡើង
«យើងក្រោកឡើងដើម្បីបំផ្លាញជនរងគ្រោះ»
ប្រមូលផ្តុំជនជាតិក្នុងនគរនេះ
ឃ្លាទាំងពីរនេះមានន័យដូចគ្នា
ហើយបញ្ជាក់ថាព្រះអម្ចាស់នឹងកាត់ទោសប្រជាជាតិទាំងអស់។ (សូមមើល:figs-parallelism)
សេចក្តីក្រោធរបស់យើង ជាសេចក្តីក្រោធដ៏សាហាវ
ពាក្យថា «សេចក្តីក្រោធ» និង «សេចក្តីក្រោធដ៏សាហាវ»
មានន័យមូលដ្ឋានដូចគ្នាហើយបញ្ជាក់ពីកម្រិតកំហឹងរបស់ព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត:«សេចក្តីក្រោធដ៏សាហាវរបស់យើង»
ដូច្នេះគ្រប់ទាំងផែនដីនឹងត្រូវលេបត្របាក់ដោយភ្លើងនៃកំហឹងរបស់យើង
ឃ្លានេះអាចបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះភ្លើងកំហឹងនឹងឆេះបំផ្លាញស្រុកទាំងប៉ុន្មាន»
[illegible]
កំហឹងនៅទីនេះចង់និយាយថាវាប្រៀបដូចជាភ្លើងដែលអាចឆេះបំផ្លាញអ្វីៗ។
Zephaniah 3:9
យើងនឹងឲ្យប្រជាជនមានបបូរមាត់ស្អាត
នេះគឺជារបៀបផ្សេងទៀតក្នុងការដែលនិយាយថា
ព្រះជាម្ចាស់នឹងធ្វើឲ្យមនុស្សនិយាយសេចក្តីត្រឹមត្រូវ។
បម្រើ យើងឈរដោយប្រកៀកស្មាគ្នាទៅវិញទៅមក
ប្រជាជននឹងរួមគ្នាក្នុងការមានដួងចិត្តបម្រើព្រះជាម្ចាស់ ដូចជាមនុស្សសាមគ្គីគ្នា
នៅពេលគេឈរជាមួយគ្នាប្រកៀកស្មាគ្នា។
Zephaniah 3:12
គ្មានពាក្យបោកបញ្ឆោតនៅក្នុងមាត់ពួកគេ
ការបកប្រែរបៀបផ្សេងទៀត:
«គ្មានរកឃើញពាក្យបោកបញ្ឆោតដែលចេញពីមាត់របស់ពួកគេឡើយ» ឬ
«ពួកគេនឹងមិនពោលពាក្យបោកបញ្ឆោតឡើយ»
ពួកគេនឹងដេកចុះ
ព្រះអម្ចាស់មានបន្ទូលពីប្រជាជនអ៊ីស្រាអែលដូចជាហ្វូងចៀមដែលស៊ីស្មៅ
ហើយសម្រាកដោយសុវត្ថិភាព។
Zephaniah 3:14
កូនស្រីក្រុងស៊ីយ៉ូនអើយ
«នេះមានន័យប្រជាជននៅក្រុងយេរូសាឡិម»។
កុំអនុញ្ញាតិឲ្យដៃរបស់អ្នកធ្លាក់ចុះឡើយ
នេះមានន័យថា ចូរកុំអស់កម្លាំង ឬ អស់សង្ឃឹមដូចជាដៃដែលខ្សោយល្វើយឡើយ។
Zephaniah 3:19
យើងនឹងជួយសង្គ្រោះចៀម ហើយប្រមូលចៀមដែលរងេង
នេះហាក់បីដូចជាសំដៅទៅលើចៀមដែលខ្វិន និង
រងេងដែលវាដូចជារូបភាពនៃប្រជាជនអ៊ីស្រាអែលដែលត្រូវគេនិរទេស។
ខ្វិន
នេះសំដៅទៅលើមនុស្ស ឬ សត្វដែលមិនអាចដើរបាន។
យើងនឹងធ្វើឲ្យពួកគេទៅជាសរសើរ
គំនិតពេញលេញនៅទីនេះគឺ «យើងនឹងធ្វើឲ្យពួកគេក្លាយទៅជាវត្ថុនៃការសរសើរ»
នោះគឺ «យើងនឹងធ្វើឲ្យពួកគេទទួលបានការសរសើរពីអ្នកដទៃ»។
នៅថ្ងៃនោះយើងនឹងដឹកនាំអ្នក នៅថ្ងៃនោះយើងនឹងប្រមូលអ្នករាល់គ្នា
ឃ្លាទាំងពីរនេះមានន័យមូលដ្ឋានដូចគ្នា ព្រះអម្ចាស់នឹងនាំប្រជាជនដែលគេនិរទេស
ត្រឡប់មកស្រុកកំណើតវិញ។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលនោះយើងនឹងប្រមូលអ្នករាល់គ្នា ហើយនាំទៅស្រុកកំណើតវិញ»។

ហាកាយ

1 [1]នៅឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយុស នៅខែទីប្រាំមួយ នៃថ្ងៃទីមួយ ព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈ ព្យាការីហាកាយ មកកាន់លោកសូរ៉ូបាបិល
ជាកូនលោកសាលធាល ជាមន្ត្រីនៃជនជាតិយូដា និងដល់សម្តេចសង្ឃយេសួរ ជាកូនរបស់លោកយ៉ូសាដាកថា
ពោលថា[2]«ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ប្រជាជនទាំងនេះពោលថា វាមិនទាន់ដល់ពេលដែលត្រូវសង់ព្រះដំណាក់នៃព្រះអម្ចាស់ឡើងវិញទេ។
[3]ក្រោយមក ព្រះអម្ចាស់ក៏មានព្រះបន្ទូលមកពួកគេតាមរយៈព្យាការីហាកាយថា[4]«ពេលដំណាក់របស់យើងបាក់បែកនៅឡើយ តើជាវេលាដែលឲ្យអ្នករាល់គ្នាគួរ
រស់នៅក្នុងផ្ទះដែលរៀបចំដោយឈើដ៏មានតម្លៃដូច្នេះឬ?»[5]ឥឡូវនេះព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ចូរអ្នករាល់គ្នារិះគិតផ្លូវប្រព្រឹត្តរបស់ខ្លួនចុះ។
[6]អ្នករាល់គ្នាសាបព្រោះ ច្រើន ប៉ុន្តែច្រូតបានផលតិច អ្នករាល់គ្នាបរិភោគ តែមិនចេះឆ្អែត អ្នករាល់គ្នាផឹកស្រា តែមិនចេះស្កប់ស្កល់ អ្នករាល់គ្នាស្លៀកពាក់ តែមិនកក់ក្តៅ
អ្នកធ្វើការទទួលប្រាក់ឈ្នួល តែដូចជាទុកក្នុងថង់ធ្លុះ!
[7]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា «ចូរអ្នករាល់គ្នារិះគិតផ្លូវប្រព្រឹត្តរបស់ខ្លួនចុះ»[8]ចូរនាំគ្នាឡើងទៅលើភ្នំ ហើយយកឈើមកសង់ជាដំណាក់របស់យើង
ដូច្នេះយើងពេញចិត្តដំណាក់នេះ ហើយយើងនឹងបង្ហាញសិរីរុងរឿងរបស់យើង នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[9]អ្នករាល់គ្នាប្រថ្នាចង់បានផលច្រើន
តែអ្នករាល់គ្នាទទួលបានតិច អ្នករាល់គ្នាយកផលទាំងនោះដាក់ចូលទៅក្នុងផ្ទះ តែយើងបានផ្លុំបំបាត់អស់ទៅ! តើហេតុអ្វី? ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា
«គឺមកពីដំណាក់របស់យើងបាក់បែកនៅឡើយ ខណៈពេលដែលអ្នករាល់គ្នាខ្នះខ្នែងពីរឿងផ្ទះសំបែងរបស់ខ្លួន។
[10]ហេតុដូច្នេះបានជាមេឃទប់មិនឲ្យមានភ្លៀងធ្លាក់ ហើយដីក៏មិនបង្កើតផលផ្លែឲ្យអ្នករាល់គ្នាដែរ[11]យើងនឹងធ្វើឲ្យកើតរាំងស្ងួត គ្មានភ្លៀងធ្លាក់មកលើផែនដី ហើយលើភ្នំ
តាមវាលស្រែ លើចំការទំពាំងបាយជូ ចំការអូលីវ លើផលដំណាំនៅផែនដីនេះ លើមនុស្ស លើសត្វ និងកិច្ចការដែលអ្នករាល់គ្នាធ្វើ នោះនឹងមិនបង្កើតផលផ្លែឡើយ!»
[12]ព្យាការីហាកាយបាននាំយកព្រះបន្ទូលដែលព្រះអម្ចាស់មានបន្ទូលមកកាន់លោក ទៅជម្រាបលោកសូរ៉ូបាបិល ជាកូនរបស់លោកសាលធាល
និងលោកមហាបូជាចារ្យយេសួរ ជាកូនរបស់លោក យ៉ូសាដាក ព្រមទាំងប្រជាជនទាំងប៉ុន្មានដែលនៅសល់
ចូរឲ្យពួកគេស្តាប់បង្គាប់សេចក្តីដែលព្រះអម្ចាស់ជាព្រះរបស់ពួកគេ តាមរយៈព្យាការីហាកាយ ដោយកោតខ្លាចដល់ព្រះអម្ចាស់[13]ពេលនោះលោកហាកាយ

generated on Wed Sep 10 16:16:32 2025

បាននាំយកព្រះបន្ទូលព្រះអម្ចាស់ដែលមានប្រសាសន៍ ទៅកាន់ប្រជាជន តាមរយៈព្រះបន្ទូលរបស់ព្រះអម្ចាស់ «យើងស្ថិតនៅជាមួយអ្នករាល់គ្នា
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់!»
[14]ខណៈនោះព្រះអម្ចាស់បានដាស់តឿនស្មារតី លោកស៊ូរ៉ូបាបិល ជាកូនរបស់លោកសាលធាល និងជាមន្ត្រីរបស់អាណាខេត្តយូដា ព្រមទាំងលោកមហាបូជាចារ្យយេសួរ
ជាកូនរបស់លោកយ៉ូសាដាក ហើយព្រះអម្ចាស់ក៏បានដាស់តឿនស្មារតីប្រជាជនដែលនៅសេសសល់ ពួកគេនាំគ្នាមក ហើយចាប់ផ្តើមសង់ព្រះដំណាក់ព្រះអម្ចាស់
ជាព្រះរបស់ពួកគេ[15]នៅថ្ងៃទីម្ភៃបួនក្នុងខែទីប្រាំមួយ ក្នុងឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស។

Haggai 1:1
នៅឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស
«នៅឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស»
ដារីយូស...ហាកាយ...សូរ៉ូបាបិល...សាលធាល...សូរ៉ូបាបិល
ទាំងនេះសុទ្ធតែឈ្មោះរបស់មនុស្ស។
នៅខែទីប្រាំមួយ នៃថ្ងៃទីមួយ
«ថ្ងៃទីមួយនៃខែទីប្រាំមួយ» នេះគឺជាខែទីប្រាំមួយនៃប្រតិទិនរបស់ហេប្រឺ។
ថ្ងៃទីមួយគឺជិតពាក់កណ្តាលខែសីហា នៅលើប្រតិទិនលោកខាងលិច។
ព្រះអម្ចាស់មានព្រះបន្ទូល
«ព្រះអម្ចាស់មានព្រះបន្ទូល»
ព្រះអម្ចាស់
នេះគឺជាព្រះនាមនៃព្រះជាម្ចាស់ដែលបើកសម្តែងដល់មនុស្សនៅក្នុងសម្ព័ន្ធមេត្រីចាស់។
សូមមើលទំព័រការបកប្រែពាក្យអំពី ព្រះអម្ចាស់
ទាក់ទងទៅនឹងរបៀបបកប្រែពាក្យនេះ។
តាមរយៈ ហ្គាកាយ
ហ្គាកាយ ជាអ្នកនាំសារ។
Haggai 1:3
ព្រះអម្ចាស់ក៏មានព្រះបន្ទូលមក
«ព្រះអម្ចាស់មានបន្ទូល» សូមមើលពីរបៀបអ្នកបកប្រែឃ្លានេះនៅក្នុង ១:១។
តាមរយៈហ្គាកាយ
ការបកប្រែរបៀបផ្សេងទៀត: «ចេញមកពីពាក្យ (ឬមាត់) របស់ហ្គាកាយ»។
តើជាវេលាដែលឲ្យអ្នករាល់គ្នាគួរ រស់នៅក្នុងផ្ទះដែលរៀបចំដោយឈើដ៏មានតម្លៃដូច្នេះឬ?
ការបកប្រែរបៀបផ្សេងទៀត: សូមមើល: UDB ។
ពេលដំណាក់របស់យើងបាក់បែកនៅឡើយ
ពាក្យថា «ដំណាក់» នៅទីនេះសំដៅទៅលើដំណាក់របស់ព្រះជាម្ចាស់។ ។
តែមិនចេះស្កប់ស្កល់
អត្ថបទនេះមិននិយាយ ឬបញ្ជាក់ថាការស្រវឹងជាការល្អទេ។
ផ្ទុយទៅវិញគ្មានស្រាណាដែលគ្រប់គ្រាន់នឹងបំពេញសេចក្តីត្រូវការ
ការស្រេកឃ្លានរបស់មនុស្ស និង មិនគ្រប់គ្រាន់សម្រាប់ស្រវឹងដែរ។
អ្នកធ្វើការទទួលប្រាក់ឈ្នួល តែដូចជាទុកក្នុងថង់ធ្លុះ
ការបកប្រែរបៀបផ្សេងទៀត:
«លុយដែលគេរកបានពីការងារគឺមិនអាចទិញអ្វីគ្រប់គ្រាន់» ។
Haggai 1:7
យកឈើ
នេះតំណាងតែមួយផ្នែកចំពោះអ្វីដែលពួកគេត្រូវការដើម្បីសង់ដំណាក់។ ។
ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូល
«អ្វីដែលព្រះអម្ចាស់នៃសកលលោកមានព្រះបន្ទូល» ឬ
«អ្វីដែលព្រះអម្ចាស់ប្រកាសជាឱឡារិក»។
Haggai 1:10
ស្ថានសួគ៌
ការបកប្រែរបៀបផ្សេងទៀត: «មេឃ»
មិនឲ្យមានភ្លៀងធ្លាក់
ការបកប្រែរបៀបផ្សេងទៀត: «មិនមានភ្លៀងធ្លាក់» ។
រាំងស្ងួត
ភាពរាំងស្ងួតដែលនឹងធ្វើឲ្យមានការរាំងមិនឲ្យរុក្ខជាតិលូតលាស់
ហើយហួតជាតិទឹកអស់សម្រាប់សត្វ ឬ មនុស្សនៅក្នុងតំបន់នោះ។
លើចំការទំពាំងបាយជូ ចំការអូលីវ
ស្រាសំដៅទៅលើទំពាំងបាយជូរ និង ប្រេងសំដៅទៅលើប្រេងអូលីវ។ ។
កិច្ចការដែលអ្នករាល់គ្នាធ្វើ
«គ្រប់ទាំងការងារលំបាកដែលអ្នកបានធ្វើ» ហើយ UDB ។
Haggai 1:12
តាមរយៈហ្គាកាយ
«នៅពេលដែលពួកគេឮពីពាក្យសម្តីដែលហ្គាកាយបាននិយាយ» ។
ព្រះភ័ក្រព្រះអម្ចាស់
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់» ។
ជាព្រះបន្ទូលនៃព្រះអម្ចាស់
«អ្វីដែលព្រះអម្ចាស់បានមានបន្ទូល» ឬ «អ្វីដែលព្រះអម្ចាស់បានប្រកាស»។
Haggai 1:14
បានដាស់តឿនស្មារតី
នេះមានន័យថាលើកទឹកចិត្ត ឬ ជះឥទ្ធិពល។ ។
នៅសេសសល់
ពាក្យថា «នៅសេសសល់» សំដៅទៅលើមនុស្សដែលនៅរស់
បន្ទាប់ពីពួកគេត្រឡប់ពីការចាប់ជាឈ្លើយនៅក្នុងក្រុងបាប៊ីឡូន ហើយ
ចាប់ផ្តើមសង់ក្រុងយេរូសាឡិម
នៅថ្ងៃទីម្ភៃបួនក្នុងខែទីប្រាំមួយ
បួនថ្ងៃនៃខែទីប្រាំមួយ នេះទើបតែ២៣ថ្ងៃបន្ទាប់ពីពួកគេទទួលនិមិត្ត។
នេះគឺជាខែទីប្រាំមួយនៃប្រតិទិនរបស់ពួកហេប្រឺ។
ថ្ងៃទីម្ភៃបួនគឺជិតពាក់កណ្តាលខែកញ្ញានៃប្រតិទិន នៅលោកខាងលិច។
ឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស
«ឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស» ។

---

2 [1]ក្នុងខែទីប្រាំពីរ នៅថ្ងៃទីម្ភៃមួយ ព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈព្យាការីហាកាយថា[2]«ចូរទៅប្រាប់សូរ៉ូបាបិល កូនសាលធាល ជាមន្ត្រីនៃជនជាតិយូដា
និងមហាបូជាចារ្យយេសួរ ជាកូនរបស់លោកយ៉ូសាដាក ព្រមទាំងប្រជាជនដែលនៅសេសសល់។ ដោយពោលថា
[3]នៅក្នុងចំណោមអ្នករាល់គ្នា តើនរណាធ្លាប់បានឃើញព្រះដំណាក់ដ៏រុងរឿងកាលពីជំនាន់មុន ហើយឥឡូវនេះអ្នករាល់គ្នាឃើញព្រះដំណាក់ថ្មីមានសភាពដូចម្តេចដែរ
អ្នករាល់គ្នាឃើញដំណាក់ថ្មីនេះ មិនល្អទាល់តែសោះ[4]សូរ៉ូបាបិលអើយ ចូរមានកម្លាំងចុះ! នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ មហាបូជាចារ្យយេសួរ
ជាកូនរបស់លោកយ៉ូសាដាកអើយ ចូរមានកម្លាំងចុះ ប្រជាជនដែលនៅក្នុងទឹកដីអើយចូរមានកម្លាំងចុះ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ចូរនាំគ្នាធ្វើការទៅ
ដ្បិតយើងនឹងនៅជាមួយអ្នករាល់គ្នា នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល[5]ដ្បិតព្រះវិញ្ញាណរបស់យើងស្ថិតនៅជាមួយអ្នករាល់គ្នា ដូចដែលយើងបានសន្យា
នៅគ្រាដែលអ្នករាល់គ្នាចាកចេញពីអេស៊ីុប។ សូមកុំភ័យខ្លាចអ្វីឡើយ!
[6]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា នៅបន្តិចទៀត យើងនឹងធ្វើឲ្យផ្ទៃមេឃ និងផែនដី ព្រមទាំងសមុទ្រ និងដីគោក កក្រើក[7]យើងនឹងធ្វើឲ្យប្រជាជាតិកក្រើក
ហើយគ្រប់ទាំងទ្រព្យសម្បត្តិដែលមានតម្លៃ និងហូរចូលមកក្នុងដំណាក់របស់យើង ហើយយើងនឹងធ្វើឲ្យដំណាក់នេះពេញដោយសិរីរុងរឿង
នេះជាព្រះបន្ទូលរបស់អម្ចាស់នៃពិភពទាំងមូល។
[8]ប្រាក់ និងមាសជាកម្មសិទ្ធរបស់យើង! នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពលោកទាំងមូល[9]សិរីរុងរឿងនៅក្នុងដំណាក់នេះនឹងថ្កុំថ្កើងឡើង
ជាងសិរីរុងរឿងរបស់ដំណាក់កាលពីជំនាន់មុនផងដែរ នេះគឺព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពលោកទាំងមូល ហើយយើងនឹងធ្វើឲ្យមានសេចក្តីសុខសាន្តនៅទីនេះផង!
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពលោកទាំងមូល»
[10]នៅថ្ងៃទីម្ភៃបួន ក្នុងខែទីប្រាំបួន នៅក្នុងឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស
ព្រះអម្ចាស់មានព្រះបន្ទូលមកតាមរយៈព្យាការីហាកាយថា[11]ព្រះអម្ចាស់នៃពិភពលោកទាំងមូលមានបន្ទូលថា

generated on Wed Sep 10 16:16:32 2025

ចូរសួរទៅពួកបូជាចារ្យអំពីក្រិត្យវិន័យថា[12]បើមានបុរសម្នាក់យកសាច់មកដាក់ក្នុងថ្នក់អាវដែលគេបានញែកជាសក្ការៈ ហើយបើអាវរបស់អ្នកនោះប៉ះនំបុ័ង បន្លែ ស្រា ប្រេង
ឬអាហារផ្សេងទៀត តើរបស់ទាំងនោះអាចចាត់ទុកជាបរិសុទ្ធដែរទេ? ពួកបូជាចារ្យឆ្លើយថា «ទេ»
[13]បន្ទាប់មក លោកហាកាយបានមានប្រសាសន៍ទៀតថា«ប្រសិនបើមាននរណាម្នាក់មិនស្អាតដោយព្រោះទៅប៉ះសាកសព ហើយក៏ទៅប៉ះរបស់ផ្សេងទៀត
តើរបស់ទាំងនោះត្រឡប់ទៅជាមិនស្អាតដែរឬ?» ពួកបូជាចារ្យបានឆ្លើយថា «ត្រូវហើយ
របស់ទាំងនោះនឹងមិនស្អាតប្រាកដណាស់»[14]ដូច្នេះលោកហាកាយបានមានប្រសាសន៍ថា «ប្រជាជននេះក៏ដូច្នោះដែរ ហើយយើងចាត់ទុកប្រជាជាតិនេះមិនស្អាត
ហើយរបស់អ្វីៗដែលគេធ្វើដោយដៃរបស់ពួកគេ ហើយពួកគេយកមកថ្វាយយើងនៅទីនេះក៏ចាត់ទុកជារបស់មិនស្អាតដែរ នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[15]ដូច្នេះ ចូរអ្នករាល់គ្នាគិតពិចារណាដែលកើតមានចាប់ពីពេលនេះតទៅខាងមុខ មុនពេលដែលពួកអ្នករាល់គ្នាយកថ្មមកដាក់ត្រួតលើគ្នា
ដើម្បីសាងសង់ព្រះវិហាររបស់ព្រះអម្ចាស់[16]តើអ្នកគិតដូចម្តេចដែរ? នៅពេលដែលអ្នកទៅជង្រុកដើម្បីនឹងកើបស្រូវម្ភៃចាំង ប៉ុន្តែវាមានតែដប់ចាំងទេ
ហើយពេលដែលអ្នករាល់គ្នាទៅកន្លែងបញ្ជាន់ស្រាទំពាំងបាយជូរ ដើម្បីដួសយកស្រាហាសិបធុង ប៉ុន្តែវាមានម្ភៃធុងប៉ុណ្ណោះ[17]យើងបានធ្វើឲ្យអ្នករាល់គ្នារងទុក្ខវេទនា
ដោយធ្វើឲ្យដំណាំរបស់អ្នករាល់គ្នានឹងខូចខាត ស្រូវអ្នករាល់គ្នានឹងស្កក ហើយក៏មានព្រិលធ្លាក់មកបំផ្លាញអស់ តែទោះបីយ៉ាងណាក៏ដោយ
អ្នករាល់គ្នាមិនវិលមករកយើងវិញដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[18]ដូច្នេះ ចូរឲ្យអ្នករាល់គ្នាគិតពិចារណាពីពេលនេះតទៅមុខ ចាប់តាំងពីថ្ងៃទីម្ភៃបួន ក្នុងខែទីប្រាំបួន ចាប់តាំងពីថ្ងៃដែលគេចាក់គ្រឹះសាងសង់ព្រះវិហាររបស់ព្រះអម្ចាស់
ចូរអ្នករាល់គ្នាគិតពិចារណាមើលចុះ![19]តើនៅក្នុងជង្រុកមានគ្រាប់ពូជទៀតទេ? សូម្បីតែ ចំមារទំពាំងបាយជូរ ដើមឧទុម្ពរ ដើមទទឹម
និងដើមអូលីវក៏មិនមានផ្តល់ផលទៀតដែរ! ប៉ុន្តែ ចាប់ពីថ្ងៃនេះទៅយើងនឹងប្រទានពរដល់អ្នក!»
[20]បន្ទាប់មកព្រះបន្ទូលរបស់ព្រះអម្ចាស់ក៏មានព្រះបន្ទូលមកលោកហាកាយជាលើកទីពីរ នៅថ្ងៃទីម្ភៃបួន ដដែលនោះថា[21]«ចូរប្រាប់សូរ៉ូបាបិល ដែលជាមន្ត្រីរបស់នៃយូដាថា
យើងនឹងធ្វើឲ្យផ្ទៃមេឃ និងផែនដីកក្រើកឡើង។[22]ដ្បិត យើងនឹងទម្លាក់បល្ល័ង្កស្តេចរបស់នគរទាំងឡាយ ហើយបំផ្លាញកម្លាំងរបស់ប្រជាជាតិផ្សេងៗផងដែរ!
យើងនឹងផ្តួលរំលំរទេះចម្បាំង ព្រមទាំងអស់ អ្នកដែលបរទេះ យើងនឹងផ្តួសរំលំសេះ ព្រមទាំងអ្នកជិះឲ្យធ្លាក់ចុះ ហើយបងប្អូននឹងកាប់សម្លាប់គ្នាទៅវិញទៅមក។
[23]នៅថ្ងៃនោះ ព្រះអម្ចាស់នៃពិភពលោកទាំងមូលមានព្រះបន្ទូលថា សូរ៉ូបាបិល ជាកូនរបស់សាលធាល ជាអ្នកបម្រើរបស់យើងអើយ យើងនឹងតែងតាំងអ្នក
នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ យើងនឹងតែងតាំងអ្នកឲ្យធ្វើជាអ្នកត្រួតត្រារបស់យើង ព្រោះយើងបានជ្រើសរើសអ្នកហើយ
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពលោកទាំងមូល!»

Haggai 2:1
ក្នុងខែទីប្រាំពីរ នៅថ្ងៃទីម្ភៃមួយ
ថ្ងៃទីមួយនៃខែ នេះគឺជាខែទីប្រាំពីរនៃប្រតិទិនរបស់ពួកហេប្រឺ។
នៅថ្ងៃទីម្ភៃមួយគឺជិតពាក់កណ្តាលនៃខែតុលាលើប្រតិទិននៃលោកខាងលិច។ ។
ព្រះអម្ចាស់មានព្រះបន្ទូល
«ព្រះអម្ចាស់បានថ្លែងព្រះបន្ទូលរបស់ព្រះអង្គ»
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១។ (សូមមើល:figs-idiom)
តាមរយៈព្យាការីហាកាយ
.
ហាកាយ...សូរ៉ូបាបិល...សាលធាល...យ៉ូសាដាក
។
Haggai 2:3
អ្នករាល់គ្នាឃើញដំណាក់ថ្មីនេះ មិនល្អទាល់តែសោះ
«អ្នកប្រាកដជាគិតថាវាមិនសំខាន់ទាល់តែសោះ» .
ឥឡូវនេះ ចូរមានកម្លាំងចុះ
«ចាប់ពីពេលនេះចូរមានកម្លាំង»
Haggai 2:6
ធ្វើឲ្យផ្ទៃមេឃ និងផែនដីកក្រើក
ជាការរំខានខ្លាំង
Haggai 2:8
ប្រាក់ និងមាសជាកម្មសិទ្ធរបស់យើង
ពាក្យថា «ប្រាក់ និង មាស» សំដៅទៅលើទ្រព្យសម្បត្តិដែលនាំយកទៅព្រះវិហារ។
Haggai 2:10
នៅថ្ងៃទីម្ភៃបួន ក្នុងខែទីប្រាំបួន
ថ្ងៃទីបួននៃខែទីប្រាំបួន នេះគឺជាខែទីប្រាំបួននៃប្រតិទិនពួកហេប្រឺ។
នៅថ្ងៃទីម្ភៃបួនគឺជិតពាក់កណ្តាលនៃខែធ្នូលើប្រតិទិនលោកខាងលិច។
នៅក្នុងឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស
«នៅក្នុងឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស» ។
ដារីយូស...ហាកាយ
។
ព្រះអម្ចាស់មានព្រះបន្ទូលមក
«ព្រះអម្ចាស់បានថ្លែងព្រះបន្ទូលរបស់ព្រះអង្គ»
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១ (សូមមើល:figs-idiom)។
Haggai 2:13
ប្រជាជននេះក៏ដូច្នោះដែរ ហើយយើងចាត់ទុកប្រជាជាតិនេះមិនស្អាត
ហើយរបស់អ្វីៗដែលគេធ្វើដោយដៃរបស់ពួកគេ
ហើយពួកគេយកមកថ្វាយយើងនៅទីនេះក៏ចាត់ទុកជារបស់មិនស្អាតដែរ
«នេះគឺជាសេចក្តីពិតនៃប្រជាជនអ៊ីស្រាអែល! ឬ
«គោលការណ៍ដូចគ្នានេះរក្សាសេចក្តីពិតរបស់ប្រជាជនអ៊ីស្រាអែល»
Haggai 2:15
ម្ភៃធុង
មួយ«រង្វាល់» ជាចំនួនទឹកប្រាក់ដែលមិនស្គាល់។ ។
ហាសិបធុង
មួយ«រង្វាល់» ជាចំនួនទឹកប្រាក់ដែលមិនស្គាល់។ ។
យើងបានធ្វើឲ្យអ្នករាល់គ្នារងទុក្ខវេទនា
«យើងដាក់បណ្តាសាចំពោះកិច្ចការដែលអ្នករាល់គ្នាធ្វើ និង ផលដំណាំផង» ។
Haggai 2:18
ថ្ងៃទីម្ភៃបួន ក្នុងខែទីប្រាំបួន
ថ្ងៃទីបួននៃខែទីប្រាំបួន សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ២:១០
តើនៅក្នុងជង្រុកមានគ្រាប់ពូជទៀតទេ?
ចម្លើយដែលរំពឹងទុកគឺ «គ្មាន»។
សំណួរនេះគឺប្រើសម្ភាល់ចំនុចសំខាន់ដែលអ្នកអាចបានដឹងរួចមកហើយ។ ។
ដើមឧទុម្ពរ ដើមទទឹម និងដើមអូលីវ
ទាំងនេះជាផ្លែឈើដែលដុះលើដី។
Haggai 2:20
ព្រះអម្ចាស់មានព្រះបន្ទូលមក
«ព្រះអម្ចាស់បានថ្លែងព្រះបន្ទូលរបស់ព្រះអង្គ»
សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ១:១ (សូមមើល:figs-idiom)
ហាកាយ...សូរ៉ូបាបិល
ទាំងនេះជាឈ្មោះរបស់មនុស្ស។
នៅថ្ងៃទីម្ភៃបួន
ថ្ងៃទីបួននៃខែ ការបកប្រែរបៀបផ្សេងទៀត: «នៅថ្ងៃទីម្ភៃបួននៃខែទីប្រាំបួន»
យើងនឹងធ្វើឲ្យផ្ទៃមេឃ និងផែនដីកក្រើកឡើង
ព្រះអម្ចាស់នឹងធ្វើឲ្យមានការរំខានដល់ពិភពលោក។
ផ្ទៃមេឃ និងផែនដី
ការបកប្រែរបៀបផ្សេងទៀត: «សកលលោកទាំងមូល»
ដ្បិត យើងនឹងទម្លាក់បល្ល័ង្កស្តេចរបស់នគរទាំងឡាយ
រដ្ឋាភិបាលនឹងមានការបែកបាក់គ្នា នៅក្នុងភាពវឹកវរ។
បល្ល័ង្កស្តេចរបស់នគរ
ការបកប្រែរបៀបផ្សេងទៀត: «រដ្ឋាភិបាលដែលគ្រប់គ្រងដោយស្តេច»។
បងប្អូននឹងកាប់សម្លាប់គ្នា
ការបកប្រែរបៀបផ្សេងទៀត: «ដាវនៅលើទាហានផ្សេងទៀត»។
Haggai 2:23
សូរ៉ូបាបិល...សាលធាល
(សូមមើល:translate-names)

generated on Wed Sep 10 16:16:32 2025

សាការី

1 [1]នៅខែទីប្រាំបី នៃឆ្នាំទីពីរក្នុងរជ្ជកាលព្រះចៅដារីយូស ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ព្យាការី សាការី ត្រូវជាកូនលោកបេរេគា
និងជាចៅរបស់លោកអ៊ីដោថា[2]«ព្រះអម្ចាស់ក្រោធនឹងដូនតារបស់អ្នកខ្លាំងណាស់![3]ចូរនិយាយប្រាប់ពួកគេថា ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលយ៉ាងនេះថា៖
ចូរត្រលប់មករកយើងវិញ! ហើយយើងនឹងត្រលប់ទៅរកអ្នកវិញដែរ នេះគឺជាសេចក្តីប្រកាសរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។
[4]កុំធ្វើដូចដូនតារបស់អ្នកឡើយ ជាពួកព្យាការីដែលបានស្រែកថា ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលដូច្នេះថា ចូលបែរចេញពីផ្លូវអាក្រក់ និង
ការប្រព្រឹត្តអំពើទុច្ចរិត!» ប៉ុន្តែពួកគេមិនស្តាប់ និងមិនបានយកចិត្តទុកដាក់នឹងពាក្យរបស់យើងឡើយ នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[5]តើដូនតារបស់អ្នកនៅទីណា?
តើពួកព្យាការីនៅទីណា តើពួកគេអាចនៅទីនេះជារៀងរហូតឬ?[6]ប៉ុន្តែពាក្យ និងបញ្ញត្តិដែលបានបង្គាប់ដល់ពួកព្យាការី ជាអ្នកបម្រើរបស់យើង
តើពួកគេមិនបានវិលត្រលប់មកធ្វើតាមដូនតារបស់អ្នកវិញទេឬ? ដូច្នេះ ពួកគេបានប្រែចិត្តហើយនិយាយថា ព្រះអម្ចាស់នៃពិភពលោកទាំងមូល
មានផែនការសម្រាប់ពួកយើង តាមផ្លូវនិងការប្រព្រឹត្តដែលយើងបានធ្វើយ៉ាងនោះដែរ ដូច្នេះព្រះអង្គបានធ្វើជាមួយយើងយ៉ាងនោះដែរ»។
[7]នៅថ្ងៃទីម្ភៃបួន នៃខែទីដប់មួយ ដែលត្រូវជាខែមាឃ ក្នុងឆ្នាំទីពីរនៃរជ្ជកាលព្រះចៅដារីយូស ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់ ព្យាការី សាការីត្រូវជាកូនលោកបេរេគា
និងជាចៅរបស់លោកអ៊ីដោថា ដោយព្រះបន្ទូលថា៖[8]«នៅពេលយប់យើងបានមើលឃើញបុរសម្នាក់ដែលកំពុងជិះសេះពណ៌ក្រហម នៅកណ្តាលដើមយីថោ ក្នុងជ្រលងភ្នំ
ហើយនៅពីក្រោយគាត់មានសេះពណ៌ក្រហម ត្នោត និងស ជាច្រើនទៀត»។[9]ខ្ញុំក៏បានពោលថា៖ «ព្រះជាម្ចាស់អើយ តើការទាំងនេះគឺជាអ្វីទៅ?» បន្ទាប់មកទេវតា
ដែលនិយាយជាមួយខ្ញុំប្រាប់ថា «យើងនឹងបង្ហាញអ្នកថាតើការទាំងអស់នេះគឺជាអ្វី»។
[10]បន្ទាប់មកបុរសដែលឈរនៅកណ្តាលដើមយីថោ និយាយថា «អ្នកទាំងអស់នេះជាអ្នកដែលព្រះអម្ចាស់បានបញ្ជូនមកឲ្យធ្វើដំណើរឆ្លងកាត់ផែនដី»។
[11]ពួកគេក៏ឆ្លើយប្រាប់ទៅកាន់ទេវតានៃព្រះអម្ចាស់ជាអ្នកដែលឈរនៅកណ្តាលដើមយីថោថា «យើងបានធ្វើដំណើរឆ្លងកាត់ផែនដី
ក៏ឃើញផែនដីទាំងមូលនៅដោយស្ងប់ស្ងាត់ ហើយដោយសេចក្តីសុខ»។
[12]បន្ទាប់មកទេវតានៃព្រះអម្ចាស់ក៏និយាយថា «ព្រះអម្ចាស់នៃពិភពទាំងមូលអើយ តើពេលណាទើបព្រះអង្គបង្ហាញការអាណិតមេត្តាដល់ក្រុងយេរូសាឡឹម
ហើយនិងទីក្រុងផ្សេងៗទៀតនៃស្រុកយូដាទៅ?»[13]ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ទេវតាដែលនិយាយជាមួយខ្ញុំដោយពាក្យល្អៗ ហើយជាពាក្យកម្សាន្តចិត្ត។
[14]ដូច្នេះហើយ ទេវតាដែលនិយាយជាមួយខ្ញុំនោះក៏ប្រាប់ខ្ញុំថា «ចូរប្រកាសថា ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលទាំងនេះថា យើងបានប្រច័ណ្ឌយ៉ាងខ្លាំង
ចំពោះក្រុងយេរូសាឡឹម និងភ្នំស៊ីយ៉ូន![15]យើងពិតជាខឹងយ៉ាងខ្លាំង ចំពោះជនជាតិណាដែលអាងលើកម្លាំងខ្លួនឯង។ តែនៅពេលដែលយើងខឹងនឹងគេតិចតួច
គេបែរជាបង្កើតគ្រោះមហន្តរាយកាន់តែខ្លាំងទៅវិញ។
[16]ហេតុនេះហើយ ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលយ៉ាងនេះថា យើងនឹងវិលមកក្រុងយេរូសាឡឹមវិញដោយចិត្តអាណិតអាសូរ។
ដំណាក់របស់យើងនឹងត្រូវសង់ឡើងវិញ ហើយនឹងមានខ្សែវាស់លាតសន្ធឹងជុំវិញក្រុងយេរូសាឡឹម![17]ចូរប្រកាសម្តងទៀតថា
ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលទាំងនេះថា ទីក្រុងរបស់យើងជាច្រើនផ្សេងទៀតនឹងមានភោគទ្រព្យហូរហៀរឡើងវិញ ហើយព្រះអម្ចាស់នឹងសម្រាលទុក្ខក្រុង
ស៊ីយ៉ូនសាជាថ្មី ហើយព្រះអង្គនឹងជ្រើសរើសក្រុងយេរូសាឡឹមម្តងទៀត»។
[18]ខ្ញុំក្រឡេកភ្នែកមើលទៅ ឃើញស្នែងបួន![19]ខ្ញុំបានសួរទៅទេវតាដែលនិយាយជាមួយខ្ញុំថា «តើទាំងអស់នេះគឺជាអ្វី?» លោកក៏ប្រាប់ខ្ញុំថា «ទាំងអស់នេះគឺជាស្នែងដែលមក
កម្ចាត់កម្ចាយពួកយូដា ពួកអ៊ីស្រាអែល និងពួកក្រុងយេរូសាឡិម»។
[20]បន្ទាប់មក ព្រះអម្ចាស់បង្ហាញខ្ញុំឲ្យឃើញជាងដែកបួននាក់។[21]ខ្ញុំក៏សួរថា «តើមនុស្សទាំងអស់នេះមកធ្វើអ្វី?» ព្រះអង្គមានបន្ទូលថា
«ទាំងការនេះគឺជាស្នែងដែលមកកម្ចាត់ពួកយូដា ដូច្នេះហើយគ្មានមនុស្សណាម្នាក់អាចតទល់នឹងពួកគេបានឡើយ។ ប៉ុន្តែ មនុស្សទាំងនេះមក ដើម្បីបំភ័យ និងកម្ទេចស្នែង
នៃប្រជាជាតិណាដែលបានប្រើកម្លាំងវាយទឹកដីយូដា និងកម្ចាត់កម្ចាយគេ»។

Zechariah 1:1

នៅខែទីប្រាំបី

នេះជាខែទី ប្រាំបី នៃប្រតិទិនហេព្រើរ។

ឃ្លានេះគឺជាកំឡុងពេលចុងក្រោយនៃខែតុលា
និងផ្នែកដំបូងនៃខែវិច្ឆិកានៅលើប្រតិទិនភាគខាងលិច។

នៃឆ្នាំទីពីរក្នុងរជ្ជកាលព្រះចៅដារីយូស

«ឆ្នាំទីពីរ ចាប់តាំងពីដារីយូសឡើងសោយរាជ្យជាស្តេច»

ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់

«ព្រះអម្ចាស់មានព្រះបន្ទូលដូចលោកមានប្រសាសន៍»

ព្រះអម្ចាស់

នេះគឺជាឈ្មោះរបស់ព្រះដែលព្រះអង្គបានបង្ហាញដល់ប្រជាជនរបស់ព្រះអង្គនៅក្នុងគម្ពីរ[illegible]
សូមមើលការបកប្រែពាក្យពីព្រះអម្ចាស់ដែលទាក់ទងនឹងរបៀបបកប្រែអត្ថបទនេះ។

បេរេគា...អ៊ីដោថា

ទាំងនេះគឺជាឈ្មោះមនុស្សប្រុស។

ក្រោធនឹងដូនតារបស់អ្នកខ្លាំងណាស់

«ខឹងនឹងបុព្វបុរសរបស់អ្នកណាស់»

ចូរត្រលប់មករកយើងវិញ

ពាក្យថា «ត្រលប់មក» ត្រូវបានប្រើដើម្បីយោងទៅលើការផ្លាស់ប្តូរ។
ព្រះអម្ចាស់បានប្រាប់ប្រជាជនអ៊ីស្រាអែលឲ្យ ផ្លាស់ប្តូរពីការមិនស្តាប់បង្គាប់ព្រះអង្គ
ដើម្បីមកស្តាប់បង្គាប់ព្រះអង្គវិញ។

នេះគឺជាសេចក្តីប្រកាសរបស់ព្រះអម្ចាស់នៃពិភពទាំងមូល

ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូលថា» នៅក្នុង
UDB។ អ្នកអាចបកប្រែគំនិតនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។

យើងនឹងត្រលប់ទៅរកអ្នកវិញ

ដោយនិយាយថាព្រះអង្គនឹងវិលត្រឡប់ទៅរកប្រជាជន អ៊ីស្រាអែលវិញ
ព្រះអម្ចាស់កំពុងតែមានបន្ទូលថា
ពួកគេនឹងមានរឿងល្អកើតឡើងដោយសារព្រះអង្គកំពុងជួយពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងប្រទានពរអ្នក»។

Zechariah 1:4

ស្រែកថា

«ស្រែកហៅ»

ចូលបែរចេញ

«ផ្លាស់ប្តូរ»

ប៉ុន្តែពួកគេមិនស្តាប់ និងមិនបានយកចិត្តទុកដាក់នឹងពាក្យរបស់យើងឡើយ

ឃ្លាទាំងពីរនេះមានន័យថា
[illegible]
របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែពួកគេមិនព្រមស្តាប់ពាក្យបញ្ជារបស់យើងទេ»

នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់

ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូលថា» នៅក្នុង
UDB។ អ្នកអាចបកប្រែគំនិតនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។

តើដូនតារបស់អ្នកនៅឯណា? តើពួកព្យាការីនៅទីណា តើពួកគេអាចនៅទីនេះជារៀងរហូតឬ?

សំណួរទាំងពីរនេះត្រូវបានសួរដើម្បីចង្អុលបង្ហាញការពិតដែលថាមនុស្សស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ឪពុកអ្នកបានស្លាប់ហើយ។
ពួកព្យាការីក៏នឹងត្រូវស្លាប់ដែរ»។

ប៉ុន្តែពាក្យ និងបញ្ញត្តិដែលបានបង្គាប់ដល់ពួកព្យាការី ជាអ្នកបម្រើរបស់យើង

តើពួកគេមិនបានវិលត្រលប់មកធ្វើតាមដូនតារបស់អ្នកវិញទេឬ?

សំណួរនេះត្រូវបានប្រើដើម្បីបង្ហាញដល់ប្រជាជនអ៊ីស្រាអែលថា
អ្វីៗទាំងអស់ដែលព្រះអម្ចាស់បានប្រាប់ដល់ព្យាការីរបស់ព្រះអង្គ
ដើម្បីដាស់តឿនដូនតារបស់គេបានកើតឡើង។

generated on Wed Sep 10 16:16:32 2025

ពាក្យ និងបញ្ញត្តិរបស់យើង
ទាំងពីរនេះគឺសំដៅទៅលើអ្វីដែលព្រះបានមានបន្ទូលទៅកាន់ពួកព្យាការី។
វិលត្រលប់មកធ្វើតាមដូនតារបស់អ្នក
ព្រះអម្ចាស់មានព្រះបន្ទូលអំពីការព្យាករណ៍របស់ព្រះអង្គដូចពួកគេកំពុងតែរត់ដើម្បីចាប់យកនៅពេលដែលពួកគេត្រឡប់មកវិញ។
ពាក្យថា «វិលត្រលប់មកធ្វើតាម» មានន័យថាបានផុតទៅ។
តាមផ្លូវនិងការប្រព្រឹត្តដែលយើងបានធ្វើ
«ឥរិយាបទ និងសកម្មភាពរបស់យើង»
Zechariah 1:7
នៅថ្ងៃទីម្ភៃបួន នៃខែទីដប់មួយ ដែលត្រូវជាខែមាឃ
ថ្ងៃទីបួននៃខែទីដប់មួយដែលជាខែមាឃ «ខែមាឃ» គឺជាខែទី១១
នៃប្រតិទិនហេព្រើរ។
ថ្ងៃទីម្ភៃបួនគឺនៅជិតពាក់កណ្តាលខែកុម្ភៈនៅលើប្រតិទិនភាគខាងលិច។
ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់
«ព្រះអម្ចាស់មានព្រះបន្ទូលមកលោកថា»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លានេះ នៅក្នុងជំពូក ១:១។
បេរេគា...អ៊ីដោថា
ទាំងនេះគឺជាឈ្មោះមនុស្សប្រុស។
ដើមយីថោ
ប្រភេទដើមឈើតូចមួយដែលមានផ្កាចម្រុះពណ៌។ (សូមមើល: tanslate-unknown)
Zechariah 1:10
អ្នកទាំងអស់នេះជាអ្នកដែល...ពួកគេក៏ឆ្លើយប្រាប់
ពាក្យថា «ទាំងនេះ» និង «ពួកគេ»
សំដៅទៅលើសេះក្នុងចំណោមដើមឈើយីថោ។
ធ្វើដំណើរឆ្លងកាត់ផែនដី
អាចមានន័យថា ទី១) «កងល្បាត់ពិភពលោកទាំងមូល» ឬទី២)
«ដើរពាសពេញផែនដី»
នៅកណ្តាលដើមយីថោ
សូមមើលរបៀបការបកប្រែនៅក្នុងជំពូក ១:៧។
ផែនដីទាំងមូលនៅដោយស្ងប់ស្ងាត់ ហើយដោយសេចក្តីសុខ
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនទាំងអស់នៅលើពិភពលោកមានសន្តិភាព»
ស្ងប់ស្ងាត់ ហើយដោយសេចក្តីសុខ
ឃ្លាទាំងពីរនេះសំដៅទៅលើការដែលអាចបន្ធូរអារម្មណ៍ដោយមិនចាំបាច់ព្រួយបារម្ភ។
Zechariah 1:12
ខ្ញាល់នឹងក្រុងទាំងនេះ
អាចមានន័យថាទី១) «អ្នកខឹងនឹង» (UBD) ឬទី ២)
«ត្រូវបានគេគោរពដោយគ្មានសេចក្តីគោរព»
និយាយជាមួយខ្ញុំដោយពាក្យល្អៗ ហើយជាពាក្យកម្សាន្តចិត្ត
ឃ្លាទាំងនេះពណ៌នាអំពីពាក្យដែលល្អៗ និងពាក្យកម្សាន្តចិត្ត។
របៀបផ្សេងទៀតនៃការបកប្រែ: «លើកទឹកចិត្តខ្ញុំ»
Zechariah 1:14
យើងពិតជាខឹងយ៉ាងខ្លាំង ចំពោះជនជាតិណាដែលអាងលើកម្លាំងខ្លួនឯង
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងខឹងនឹងប្រជាជាតិណាដែលចូលចិត្តសេចក្តីសុខសាន្ត និងសន្តិសុខ»
យើងខឹងតិចតួច
របៀបផ្សេងទៀតនៃការបកប្រែ: «យើងខឹងនឹងប្រជាជនយូដាតិចតួច»
Zechariah 1:16
យើងនឹងវិលមកក្រុងយេរូសាឡឹមវិញដោយចិត្តអាណិតអាសូរ
ការត្រឡប់ទៅក្រុងយេរូសាឡិមវិញ
គឺសំដៅលើការថែរក្សាប្រជាជនអ៊ីស្រាអែលដូចស្តេចដែលវិលត្រឡប់មកដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គអោ
ឃ្លានេះត្រូវបានបកប្រែជាអ៊ីស្រាអែលវិញដែរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិហាររបស់យើងនឹងត្រូវសង់ឡើងវិញនៅក្រុងយេរូសាឡឹម»
ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូលថា» នៅក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
មានខ្សែវាស់លាតសន្ធឹងជុំវិញក្រុងយេរូសាឡឹម!
របៀបផ្សេងទៀតនៃការបកប្រែ:
«ក្រុងយេរូសាឡឹមនឹងត្រូវបានស្ទង់មតិមុនពេលសាងសង់ឡើងវិញ»
ទីក្រុងរបស់យើងជាច្រើនផ្សេងទៀតនឹងមានភោគទ្រព្យហូរហៀរឡើងវិញ
ព្រះអម្ចាស់គឺសំដៅលើការល្អដែលព្រះអង្គនឹងធ្វើសម្រាប់ជនជាតិអ៊ីស្រាអែល
ដូចជាវត្ថុរាវដែលអាចបំពេញទីក្រុង និងហូរមកលើកំពែង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទីក្រុងនានារបស់អ៊ីស្រាអែលនឹងមានភាពរុងរឿងឡើងវិញ»
ព្រះអម្ចាស់នឹងសម្រាលទុក្ខក្រុងស៊ីយ៉ូនសាជាថ្មី
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់នឹងលើកទឹកចិត្តប្រជាជនអ៊ីស្រាអែល»
Zechariah 1:18
ព័ត៌មានទូទៅ៖
សាការីបន្តរៀបរាប់អំពីចក្ខុវិស័យរបស់គាត់។
ខ្ញុំក្រឡេកភ្នែកមើលទៅ
ឃ្លានេះសំដៅទៅលើការងៀកក្បាលរបស់អ្នកមើលទៅ។
ស្នែងដែលមកកម្ចាត់កម្ចាយពួកយូដា
ស្នែងទាំងនេះតំណាងឲ្យកងទ័ពដែលវាយប្រហារប្រជាជនអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ:
«ស្នែងទាំងនោះតំណាងឲ្យប្រជាជាតិនានា» (UDB)។
Zechariah 1:20
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់នៅតែបន្តរៀបរាប់អំពីចក្ខុវិស័យរបស់សាការីចំពោះគាត់។
ជាងដែក
អ្នកដែលមានការងារធ្វើអ្វីៗពីដែក។
ពាក្យនេះត្រូវបានប្រើដើម្បីសំដៅទៅលើដាវរបស់កងទ័ព។
ស្នែងដែលមកកម្ចាត់ពួកយូដា
សូមមើលកំណត់សម្គាល់នៅក្នុងជំពូក ១:១៨។
គ្មានមនុស្សណាម្នាក់អាចតទល់នឹងពួកគេបានឡើយ
ឃ្លានេះពិពណ៌នាអំពីមនុស្សម្នាក់ដែលខ្លាចពេកក្នុងការមើលអ្វីដែលធ្វើឲ្យគាត់ភ័យខ្លាច។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាម្នាក់នឹងមានភាពក្លាហាន»
បំភ័យពួកគេ
«ដេញប្រជាជាតិទាំងនោះចេញ»
ដើម្បីកម្ទេចស្នែងចោល
«ដើម្បីកម្ចាត់កងទ័ព»
វាយទម្លាក់ស្នែង
នេះសំដៅទៅលើការធ្វើស្នែងដើម្បីបញ្ជាកងទ័ព។

---

2 [1]ក្រោយមកខ្ញុំក៏ក្រឡេកភ្នែកមើលឃើញបុរសម្នាក់ជាមួយខ្សែវាស់នៅក្នុងដៃរបស់លោក។[2]ខ្ញុំក៏សួរថា «តើលោកអញ្ជើញទៅណា?» ដូច្នេះគាត់បាននិយាយមកកាន់ខ្ញុំថា
«ទៅវាស់ក្រុងយេរូសាឡឹម ដើម្បីឲ្យដឹងប្រវែងទទឹង និងបណ្តោយ»។
[3]បន្ទាប់មកទេវតាដែលបាននិយាយជាមួយខ្ញុំក៏ចាក់ចេញទៅ ហើយមានទេវតាមួយផ្សេងទៀតបានមកជួបលោក។[4]ទេវតាទីពីរបាននិយាយទៅកាន់គាត់ថា
«ចូររត់ទៅប្រាប់មនុស្សកំលោះនោះថា ក្រុងយេរូសាឡឹមនឹងទៅជាក្រុងដែលគ្មានកំផែង ពីព្រោះមានមនុស្ស និងសត្វរស់នៅជាច្រើន។[5]ដ្បិត
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងនឹងធ្វើជាកំផែងភ្លើងនៅជុំវិញក្រុង ហើយយើងនឹងត្រូវលើកតម្កើងនៅកណ្តាលក្នុងទីក្រុងផងដែរ។
[6]ចូរប្រញាប់! ភៀសខ្លួនចេញពីទឹកដីខាងជើងមក នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងបានបែងចែកអ្នករាល់គ្នាដូចជាខ្យល់តាមទិសទាំងបួន!
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[7]ចូរងើបឡើង! គេចចេញពីពួកស៊ីយ៉ូនដែលរស់នៅជាមួយកូនស្រីក្រុងបាប៊ីឡូនអើយ!»
[8]ក្រោយមក ព្រះអម្ចាស់នៃពិភពទាំងមូល ប្រទានអំណាច និងបានចាត់ខ្ញុំឲ្យទៅប្រឆាំងនឹងប្រជាជាតិណាដែល បានប្លន់យកទឹកដីអ្នករាល់គ្នា អ្នកណាប៉ះពាល់អ្នករាល់គ្នា
នោះគឺប៉ះពាល់ដល់ប្រស្រីភ្នែករបស់ព្រះហើយ បន្ទាប់មកព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា[9]«យើងនឹងលើកដៃរបស់យើងប្រហារពួកគេ
ហើយពួកគេនឹងក្លាយទៅជាឈ្លើយនៃពួកទាសកររបស់ពួកគេវិញ»។ ពេលនោះគេនឹងដឹងថា ព្រះអម្ចាស់នៃពិភពទាំងមូលបានចាត់ឲ្យខ្ញុំមកមែន។

generated on Wed Sep 10 16:16:32 2025

[10]«ប្រជាជននៃក្រុងស៊ីយ៉ូនអើយ ចូរច្រៀងដោយអំណរ ដ្បិតយើងមករកអ្នកហើយ យើងនឹងស្ថិតនៅក្នុងចំណោមអ្នកហើយ! នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[11]ពេលនោះ ប្រជាជនជាច្រើននឹងចូលរួមជាមួយព្រះអម្ចាស់នៅថ្ងៃនោះ។ ព្រះអង្គមានព្រះបន្ទូលថា ពេលនោះអ្នករាល់គ្នានឹងក្លាយទៅជាប្រជារាស្ត្ររបស់យើង ហើយយើងនឹងនៅកណ្តាលឯងរាល់គ្នា» នោះអ្នកនឹងទទួលស្គាល់ថាព្រះអម្ចាស់នៃពិភពទាំងមូល បានចាត់ខ្ញុំឲ្យមករកអ្នកមែន។
[12]ព្រះអម្ចាស់នឹងយកយូដាធ្វើជាមរតករបស់ព្រះអង្គ ក្នុងទឹកដីដ៏វិសុទ្ធ ព្រះអង្គនឹងជ្រើសរើសក្រុងយេរូសាឡឹមម្តងទៀត។[13]ចូរស្ងៀមស្ងាត់ មនុស្សទាំងឡាយអើយ នៅចំពោះព្រះអម្ចាស់ ត្បិតព្រះអង្គតើនឡើងហើយយាងចេញពីព្រះដំណាក់ដ៏វិសុទ្ធរបស់ព្រះអង្គ!

Zechariah 2:1

ព័ត៌មានទូទៅ៖

សាការីបន្តរៀបរាប់អំពីទស្សនៈវិស័យរបស់គាត់។

ខ្ញុំក៏ក្រឡេកភ្នែក

របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំក្រឡេកមើល»

ខ្សែវាស់

ខ្សែពួរដែលមានប្រវែងជាក់លាក់ប្រើសម្រាប់វាស់របស់ធំៗ។

ដូច្នេះគាត់បាននិយាយមកកាន់ខ្ញុំថា

«ដូច្នេះបុរសម្នាក់ជាមួយខ្សែវាស់បាននិយាយមកកាន់ខ្ញុំ»

Zechariah 2:3

មានទេវតាមួយផ្សេងទៀតបានមកជួបលោក

ទេវតានេះគឺជាមនុស្សថ្មី

ហើយមិនបានបង្ហាញខ្លួនពីមុនទេដូច្នេះគួរតែត្រូវបានណែនាំយ៉ាងច្បាស់ក្នុងនាមជាអ្នកចូលរួមថ្មី

របៀបផ្សេងទៀតនៃការបកប្រែ: «ទេវតាថ្មីបានចេញទៅជួបគាត់»

ទេវតាទីពីរបាននិយាយទៅកាន់គាត់ថា «ចូររត់ទៅប្រាប់មនុស្សកំលោះនោះថា

ទេវតាទីពីរបាននិយាយទៅកាន់ទេវតាដែលសន្ទនាជាមួយលោកសាការីថា៖

«សូមប្រញាប់ប្រាប់បុរសនោះអោយមកជាមួយនឹងខ្សែវាស់ផង»។

ក្រុងយេរូសាឡឹមនឹងទៅជាក្រុងដែលគ្មានកំផែង

ឃ្លានេះមានន័យថា ក្រុងយេរូសាឡឹមនឹងមិនមានកំផែងព័ទ្ធជុំវិញ។

នឹងធ្វើជាកំផែងភ្លើងនៅជុំវិញក្រុង

ព្រះអម្ចាស់មានព្រះបន្ទូលថាព្រះអង្គនឹងការពារក្រុងយេរូសាឡឹម

ហើយក៏ប្រៀបធៀបការការពាររបស់ព្រះអង្គទៅនឹងកំផែងភ្លើង។

នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់

ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូលថា» នៅក្នុង UDB។

អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។

ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។

Zechariah 2:6

ចូរប្រញាប់!

ឃ្លាទាំងពីរនេះត្រូវបាននិយាយម្តងទៀត

ហើយបង្ហាញពីភាពបន្ទាន់ចំពោះសារដែលនៅបន្ត។

ឃ្លានេះត្រូវបានប្រើពីរដងពីព្រោះសារនេះសំខាន់ខ្លាំង។

ទឹកដីខាងជើង

ឃ្លានេះសំដៅទៅលើក្រុងបាប៊ីឡូន។

យើងបានបែងចែកអ្នករាល់គ្នាដូចជាខ្យល់តាមទិសទាំងបួន

នេះមានន័យថា ប្រជាជនអ៊ីស្រាអែលដែលនៅឆ្ងាយពីគ្នា។

ខ្យល់ទាំងបួននេះគឺសំដៅទៅលើផ្នែកផ្សេងគ្នានៃផែនដី។

កូនស្រីក្រុងបាប៊ីឡូន

ឃ្លានេះសំដៅទៅលើទីក្រុងបាប៊ីឡូន។

Zechariah 2:8

ព័ត៌មានទូទៅ៖

សាការីប្រាប់ពីរបៀបដែលព្រះអម្ចាស់ចាត់គាត់អោយមកវិនិច្ឆ័យទោសប្រជាជាតិដែលបានប្លន់យកក្រុងយេរូសាឡឹម។

បានប្លន់យក

«បានលួចរបស់របរពីក្រុងយេរូសាឡឹមបន្ទាប់ពីត្រូវបានគេវាយប្រហារ»

អ្នកណាប៉ះពាល់អ្នករាល់គ្នា

ពាក្យថា «ប៉ះ» សំដៅទៅលើការប៉ះមានន័យថា ផលអាក្រក់។

របៀបផ្សេងទៀតនៃការបកប្រែ: «សម្រាប់អ្នកណាដែលធ្វើឱ្យអ្នកឈឺចាប់»

ប្រស្រីព្រះនេត្ររបស់ព្រះ

ប្រស្រីសំដៅទៅលើផ្នែកងងឹតនៅខាងក្នុងនៃកែវភ្នែកដែលអាចឲ្យមនុស្សមើលឃើញ។

នេះគឺជាផ្នែកសំខាន់និងទេវទានរម្ងាស់របស់រាងកាយ។

ឃ្លានេះត្រូវបានប្រើដើម្បីនិយាយថា

ក្រុងយេរូសាឡឹមមានសារៈសំខាន់ណាស់ចំពោះព្រះ ហើយព្រះអង្គនឹងការពារ។

លើកដៃរបស់យើងប្រហារពួកគេ

នេះគឺជាកាយវិការដែលត្រូវបានប្រើដើម្បីបង្ហាញថា

ព្រះជាម្ចាស់ជ្រើសរើសបំផ្លាញអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:

«សញ្ញាដែលពួកគេនឹងត្រូវបំផ្លាញ»

ហើយពួកគេនឹងក្លាយទៅជាអ្នកលួចប្លន់

ទីក្រុងរបស់ពួកគេត្រូវបានបំផ្លាញរួចហើយ

និងទុកឱ្យមនុស្សលួចអ្វីដែលពួកគេចង់បាន។

Zechariah 2:10

កូនស្រីនៃក្រុងស៊ីយ៉ូន

នេះគឺជាឈ្មោះមួយទៀតសម្រាប់ទីក្រុងយេរូសាឡឹមដែលសំដៅទៅលើទីក្រុងដូចជាកូនស្រីរបស់ទីក្រុងស៊ី

ស្ថិតនៅ

រៀបចំ និងប្រើប្រាស់ជំរំមួយ

នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់

ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូលថា» នៅក្នុង UDB។

អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។

ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។

ប្រជាជនជាច្រើននឹងចូលរួមជាមួយព្រះអម្ចាស់

«ប្រជាជនជាច្រើននឹងស្មោះត្រង់ចំពោះព្រះអម្ចាស់»

នៅថ្ងៃនោះ

របៀបផ្សេងទៀតនៃការបកប្រែ: «ខណៈពេលនោះ»

Zechariah 2:12

ព្រះអម្ចាស់នឹងគ្រងជាមត៌ក...នៅលើទឹកដីដ៏វិសុទ្ធ

ព្រះអម្ចាស់នឹងធ្វើអោយស្រុកយូដាក្លាយជាចំណែកមត៌ករបស់គេផ្ទាល់។

មនុស្សទាំងឡាយ

ព្រះអម្ចាស់សំដៅទៅលើសត្វមានជីវិតទាំងអស់ដោយហៅពួកគេថាជារូបកាយ។

រូបកាយគឺជាអ្វីមួយក្នុងចំណោមសត្វមានជីវិតទាំងអស់។

តើនឡើងហើយយាងចេញពីព្រះដំណាក់ដ៏វិសុទ្ធរបស់ព្រះអង្គ!

ឃ្លានេះសំដៅទៅលើព្រះអម្ចាស់ដែលត្រូវបានបង្កឲ្យមានសកម្មភាពនៅលើផែនដី។

តើនឡើង

ដើម្បីឲ្យភ្ញាក់ឡើង ឬធ្វើឲ្យប្រុងប្រយ័ត្នបន្ថែមទៀត

---

3 [1]បន្ទាប់មក ព្រះអម្ចាស់បានបង្ហាញខ្ញុំឲ្យឃើញ លោកមហាបូជាចារ្យយេសួរ ឈរនៅមុខទេវតានៃព្រះអម្ចាស់ និងសាតាំងឈរនៅខាងស្តាំ ដើម្បីតវ៉ានឹងលោក។
[2]ទេវតានៃព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់សាតាំងថា «សូមព្រះអម្ចាស់ផ្តន្ទាទោសអ្នកសាតាំងអើយ សូមព្រះអម្ចាស់ ដែលបានជ្រើសរើសក្រុងយេរូសាឡឹម ផ្តន្ទាទោសអ្នកហើយ! តើមិនមែនជាអង្កត់អុសដែលគេយកចេញពីភ្លើងទេឬអី?»[3]ចំណែកលោកយេសួរ ស្លៀកសម្លៀកបំពាក់កខ្វក់ ឈរនៅមុខទេវតា។
[4]ទេវតាពោលទៅកាន់អ្នកដែលឈរនៅពីមុខលោកថា «ចូរយកសម្លៀកបំពាក់កខ្វក់ចេញពីលោក»។ បន្ទាប់មក លោកពោលទៅកាន់ លោកយេសួរថា «ចូរមើល៍! ខ្ញុំបានដកអំពើទុច្ចរិតចេញពីអ្នកហើយ ខ្ញុំនឹងពាក់សម្លៀកបំពាក់ដ៏រុងរឿងឲ្យអ្នកវិញ»។[5]ទេវតាពោលឡើងថា «សូមឲ្យគេយកឈ្នួតស្អាតមកបំពាក់លើក្បាលរបស់លោក!» ដូច្នេះហើយ ពួកគេរៀបចំឈ្នួតស្អាតមួយលើក្បាលរបស់លោកយេសួរ និងស្លៀកពាក់ជូនលោក ដោយមានទេវតានៃព្រះអម្ចាស់ឈរនៅទីនោះដែរ។
[6]ក្រោយមក ទេវតានៃព្រះអម្ចាស់បង្គាប់លោកយេសួរយ៉ាងមុតមាំថា[7]«ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលយ៉ាងនេះថា ប្រសិនបើអ្នកនឹងដើរក្នុងផ្លូវរបស់យើង ហើយបើអ្នកនឹងរក្សាបញ្ជើររបស់យើង នោះអ្នកនឹងគ្រប់គ្រងដំណាក់របស់យើង និងរក្សាទីលានរបស់យើងដែរ
ត្បិតយើងនឹងឲ្យអ្នកចូលរួមក្នុងចំណោមអ្នកដែលនៅពីមុខខ្ញុំដែរ។

generated on Wed Sep 10 16:16:32 2025

[8]ចូរស្តាប់ មហាបូជាចារ្យយេសួរ ព្រមទាំងពួកដៃគូររបស់អ្នកដែលរស់នៅជាមួយអ្នកផងដែរ! ត្បិតពួកគេគឺជាទីសម្គាល់ យើងនឹងនាំ ពន្លកជាអ្នកបម្រើរបស់យើងមក។
[9]ចូរមើល៍! ទៅកាន់ថ្មដែលយើងបានដាក់នៅពីមុខ េលោកយេសួរ។ ថ្មមួយមានភ្នែកប្រាំពីរ ហើយយើងនឹងចារអក្សរលើថ្មនោះ
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល ហើយយើងនឹងដកអំពើបាបចេញពីទឹកដីនេះនៅថ្ងៃណាមួយ។
[10]នៅថ្ងៃនោះ មនុស្សម្នាក់ៗនឹងអញ្ជើញអ្នកជិតខាងរបស់លោក ដើម្បីអង្គុយនៅក្រោមដើមទំពាងបាយជូរ និងដើមឧទុម្ពររបស់លោក»។

Zechariah 3:1
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់បង្ហាញនិមិត្តមួយដល់សាការី។
តើមិនមែនជាអង្កត់អុសដែលគេយកចេញពីភ្លើងទេឬអី?
របៀបផ្សេងទៀតនៃការបកប្រែ: «យ៉ូស្វេគឺដូចជាដំបងដែលទាញចេញពីភ្លើង»
អង្កត់អុសដែលគេយកចេញពីភ្លើង
អង្កត់អុសគឺជាបំណែកនៃអុសដែលត្រូវបានយកចេញពីភ្លើងមុនពេលត្រូវបានឆេះទាំងស្រុង
នេះសំដៅទៅលើយ៉ូស្វេដែលបានរួចផុតពីការជាប់ឃុំឃាំងនៅបាប៊ីឡូន
ហើយត្រឡប់ទៅក្រុងយេរូសាឡិមវិញ។
ស្លៀកសម្លៀកបំពាក់កខ្វក់
នៅក្នុងចក្ខុវិស័យនេះសម្លៀកបំពាក់កខ្វក់កំពុងត្រូវបានប្រើជានិមិត្តរូបដើម្បីបង្ហាញពីភាពមានបាបកម្ម។
Zechariah 3:4
សម្លៀកបំពាក់ដ៏រុងរឿងឲ្យអ្នកវិញ
ឃ្លាសម្លៀកបំពាក់ដ៏រុងរឿង ជាសញ្ញាពីភាពត្រឹមត្រូវ។
ឈ្នួត
បំណែកនៃក្រណាត់វែងរុំជុំវិញក្បាល
Zechariah 3:6
បង្គាប់លោកយេសួរយ៉ាងមុតមាំថា
«បានបញ្ជាលោកយ៉ូស្វេក្នុងលក្ខណៈដ៏ធ្ងន់ធ្ងរបំផុត»
នឹងដើរក្នុងផ្លូវរបស់យើង
ការដើរតាមរបៀបដដែលគឺសំដៅទៅលើការធ្វើអ្វីមួយដូចគ្នា។
បើអ្នកនឹងរក្សាបញ្ជើររបស់យើង
របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រសិនបើអ្នកនឹងចងចាំហើយស្តាប់បញ្ជើររបស់យើង»
រក្សាទីលានរបស់យើង
«ទទួលខុសត្រូវចំពោះទីធ្លារបស់យើង»
Zechariah 3:8
ព័ត៌មានទូទៅ៖
ទេវតានៃព្រះអម្ចាស់បាននិយាយបន្តទៅកាន់លោកយ៉ូស្វេ។
ព្រមទាំងពួកដៃគូររបស់អ្នកដែលរស់នៅជាមួយអ្នកផងដែរ
របៀបផ្សេងទៀតនៃការបកប្រែ:
«មហាបូជាចារ្យផ្សេងទៀតដែលរស់នៅជាមួយអ្នក»
ពន្លកជាអ្នកបម្រើរបស់យើង
ចំណងជើងថា «ពន្លក»
ត្រូវបានបកប្រែតាមរបៀបដូចគ្នានឹងពន្លករបស់ដើមឈើដែរ។ ឃ្លាមានន័យថា
អ្នកបំរើរបស់ព្រះអម្ចាស់នឹងមកពីព្រះអម្ចាស់ដូចជាពន្លកចេញពីមែកឈើ។
ភ្នែកប្រាំពីរ
នោះគឺប្រាំពីរជ្រុង។
«ឆ្លាក់»
អក្សរចារឹក
ពាក្យដែលត្រូវបានសរសេរនៅលើអ្វីមួយ ឬកាត់ទៅលើអ្វីមួយ
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
Zechariah 3:10
នៅថ្ងៃនោះ
របៀបផ្សេងទៀតនៃការបកប្រែ: «ខណៈពេលនោះ»
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។

---

4 [1]បន្ទាប់មក ទេវតាដែលបាននិយាយជាមួយខ្ញុំពីមុនត្រលប់មកវិញហើយដាស់ខ្ញុំឲ្យភ្ញាក់ ដូចជាមនុស្សភ្ញាក់ពីដេក។[2]លោកនិយាយមកកាន់ខ្ញុំថា «តើអ្នកបានឃើញអ្វី?»
ខ្ញុំឆ្លើយថា «ខ្ញុំឃើញជើងចង្កៀងមួយធ្វើអំពីមាស មានទាំងចានប្រេងនៅពីលើវាផង។ ចង្កៀងប្រាំពីរនៅពីលើជើងចង្កៀងនោះ
ហើយមានបញ្ចេះចង្កៀងប្រាំពីរនៅលើចង្កៀងនីមួយៗ។[3]មានដើមអូលីវពីរដើមនៅក្បែរនោះ មួយនៅខាងស្តាំ ហើយមួយដើមទៀតនៅខាងឆ្វេងនៃចានប្រេងនោះ»។
[4]ខ្ញុំក៏សួរទៅកាន់ទេវតាដែលនិយាយជាមួយខ្ញុំម្តងទៀតថា «តើរបស់ទាំងនេះមានន័យដូចម្តេចទៅ លោកម្ចាស់?»[5]ទេវតាឆ្លើយមកកាន់ខ្ញុំវិញថា
«តើអ្នកមិនស្គាល់របស់ទាំងនេះមានន័យថាយ៉ាងមិចទេឬ?» ខ្ញុំឆ្លើយថា «ទេ លោកម្ចាស់»។
[6]ទេវតាក៏និយាយមកកាន់ខ្ញុំថា «នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់មកកាន់ លោកសូរ៉ូបាបិលថា មិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ
ប៉ុន្តែដោយសារព្រះវិញ្ញាណរបស់យើងវិញ ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូល។[7]ភ្នំធំអើយ តើអ្នកជាអ្វី? នៅចំពោះមុខ សូរ៉ូបាបិលអ្នកនឹងក្លាយទៅជាដីរាបស្មើវិញ
ហើយលោកនឹងយកកំពូលថ្មមក ដើម្បីស្រែកថា ព្រះគុណ! ព្រះគុណដល់ថ្មនេះ!»
[8]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា[9]«ដៃរបស់លោកសូរ៉ូបាបិលបានចាក់គ្រឹះព្រះដំណាក់នេះ ហើយដៃរបស់លោកនឹងនាំការបង្ហើយនៃការសាងសង់ដែរ។
នោះគេនឹងដឹងថាព្រះអម្ចាស់នៃពិភពទាំងមូលបានបញ្ជូលខ្ញុំមកមែន។[10]តើអ្នកណាដែលបានមើលងាយនៅថ្ងៃនៃកិច្ចការតូចនោះ? មនុស្សទាំងនេះនឹងសប្បាយរីករាយ
ហើយនឹងឃើញថ្មប្រយោលនៅក្នុងដៃរបស់លោកសូរ៉ូបាបិល។ (ចង្កៀងទាំងប្រាំពីរនេះគឺជាព្រះនេត្ររបស់ព្រះអម្ចាស់ដែលទតមើលជុំវិញផែនដីទាំងមូល)»។[11]បន្ទាប់មក
ខ្ញុំក៏សួរទេវតាថា «តើដើមអូលីវទាំងពីរ ដែលនៅខាងស្តាំ និងខាងឆ្វេងនៃជើងចង្កៀងនោះជាអ្វីទៅ?»
[12]ខ្ញុំសួរលោកម្តងទៀតថា «តើមែកអូលីវទាំងពីរនៅក្បែរបំពង់មាសដែលហូរចេញប្រេងមាសមកនេះជាអ្វីទៅ?»[13]លោកក៏និយាយមកកាន់ខ្ញុំថា
«តើអ្នកមិនស្គាល់ទាំងនេះជាអ្វីទេឬ?» ខ្ញុំឆ្លើយថា «អត់ស្គាល់ទេ លោកម្ចាស់»។
[14]ដូច្នេះលោកនិយាយថា «ទាំងអស់នេះគឺជាកូនប្រុសនៃប្រេងអូលីវស្រស់ ជាអ្នកដែលឈរនៅពីមុខព្រះជាម្ចាស់នៃផែនដីទាំងមូល»។

Zechariah 4:1
ដាស់ខ្ញុំឲ្យភ្ញាក់ ដូចជាមនុស្សភ្ញាក់ពីដេក
ធ្វើអោយខ្ញុំមានការប្រុងប្រយ័ត្នកាន់តែខ្លាំងឡើងៗ
ដូចជាបុរសដែលភ្ញាក់ពីដំណេករបស់ខ្លួន»
ជើងចង្កៀង
ផ្នែកនៃចង្កៀងដែលត្រូវបានភ្លឺនៅលើភ្លើង
នៅខាងឆ្វេង
របៀបផ្សេងទៀតនៃការបកប្រែ: «នៅខាងឆ្វេងនៃចានគោម»
Zechariah 4:6
ប្រយោគភ្ជាប់៖
ទេវតាដែលនិយាយជាមួយសាការីបន្តពន្យល់អំពីចក្ខុវិស័យ។
សូរ៉ូបាបិល
នេះគឺជាឈ្មោះបុរសម្នាក់។
មិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ

generated on Wed Sep 10 16:16:32 2025

អាចមានន័យថាទី ១) ដែលពាក្យថា «ឥទ្ធិឫទ្ធិ» និង «អំណាច» មានន័យថា
ជាមូលដ្ឋានរឿងតែមួយ ហើយបញ្ជាក់លើភាពខ្លាំងនៃកម្លាំងរបស់សូរ៉ូបាបិល ឬទី
២) ដែលពាក្យថា «ឥទ្ធិឫទ្ធិ» សំដៅទៅលើកម្លាំងយោធា និងពាក្យថា «អំណាច»
សំដៅទៅលើសមត្ថភាពរាងកាយរបស់សូរ៉ូបាបិល។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនមែនដោយកម្លាំងផ្ទាល់របស់អ្នកឡើយ» ឬ
«មិនមែនដោយកម្លាំងយោធា ឬដោយអំណាចផ្ទាល់ខ្លួនរបស់អ្នកទេ»។
ភ្នំធំអើយ តើអ្នកជាអ្វី?
ព្រះអម្ចាស់សួរសំណួរនេះទៅកាន់ភ្នំ
ដើម្បីចង្អុលបង្ហាញថាតាមរយៈព្រះវិញ្ញាណរបស់ព្រះអម្ចាស់សូម្បីតែភ្នំមួយដែលមិនអាចឡើងកម្រិតមួយ
លោកនឹងយកកំពូលថ្មមក
ថ្មខាងលើគឺជាថ្មចុងក្រោយដែលបានដាក់នៅពេលដែលសាងសង់អ្វីមួយ។
Zechariah 4:8
ប្រយោគភ្ជាប់៖
ទេវតាដែលបាននិយាយជាមួយសាការីបន្តពន្យល់អំពីចក្ខុវិស័យ។
ព្រះអម្ចាស់មានព្រះបន្ទូលមកថា
«ព្រះអម្ចាស់បានមានព្រះបន្ទូលរបស់ព្រះអង្គថា»។
សូមមើលពីរបៀបដែលអ្នកបកប្រែឃ្លានេះនៅក្នុងជំពូកជំពូក ១:១។
ដៃរបស់លោកសូរ៉ូបាបិល..ដៃរបស់លោកនឹងនាំការបង្ហើយនៃការសាងសង់ដែរ
សូរ៉ូបាបិលត្រួតត្រាលើការកសាងព្រះវិហារ។ អាគារនេះគឺសំដៅទៅលើ
«ដៃរបស់គាត់» ទោះបីជាដៃរបស់គាត់ផ្ទាល់មិនបានដាក់ថ្មក៏ដោយ។
ចាក់គ្រឹះ
មូលដ្ឋានគ្រឹះគឺជាមូលដ្ឋានគ្រឹះនៃអាគារ និងផ្នែកដំបូងនៃគម្រោងអាគារ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានចាប់ផ្តើមសាងសង់»
តើអ្នកណាដែលបានមើលងាយ...កិច្ចការតូចនោះ?
សំណួរនេះមិនត្រូវបានគេស្នើសុំឲ្យទទួលបានចម្លើយទេ
ប៉ុន្តែដើម្បីប្រាប់ប្រជាជនកុំឲ្យមើលងាយ «នៅថ្ងៃនៃកិច្ចការតូចនោះ»។
នៅថ្ងៃនៃកិច្ចការតូចនោះ
ឃ្លានេះគឺជាចំណងជើងសម្រាប់រយៈពេលថ្ងៃនិមួយៗនៃកិច្ចការសាមញ្ញត្រូវបានធ្វើ។
រួមគ្នាធ្វើកិច្ចការតូចៗទាំងនេះដើម្បីកសាងព្រះវិហារនេះ។
ពេលវេលានៃការសាងសង់ទាំងមូលត្រូវបានគេហៅថាដូចមួយថ្ងៃទោះបីជាត្រូវចំណាយពេលច្រើនឆ្នាំដើម្
ថ្មប្រឡោល
ថ្មដែលត្រូវបានភ្ជាប់ទៅនឹងខ្សែពួរ។ នេះត្រូវបានប្រើដើម្បីកំណត់ថា
តើជញ្ជាំងអគារមួយកំពុងត្រូវបានសាងសង់ត្រង់ ឬកោង។
ចង្កៀងទាំងប្រាំពីរគឺជាសញ្ញានៃព្រះនេត្ររបស់ព្រះអម្ចាស់។
ព្រះនេត្ររបស់ព្រះអម្ចាស់
ពាក្យថា «ភ្នែក»
សំដៅទៅលើព្រះដែលទតឃើញពីព្រោះភ្នែកត្រូវបានប្រើសម្រាប់ការមើលឃើញ។
Zechariah 4:12
រំពង់មាសពីរ
«បំពង់បង្ហូរទឹកមាសទាំងពីរ»
តើអ្នកមិនស្គាល់ទាំងនេះជាអ្វីទេឬ?
«អ្នកគួរតែដឹងថាទាំងនេះគឺជាអ្វី ប៉ុន្តែអ្នកមិនដឹង»។
Zechariah 4:14
កូនប្រុសនៃប្រេងអូលីវស្រស់
នេះគឺជាវិធីកំណាព្យនៃការនិយាយថា «បុរសដែលបានរើសតាំង
(ដែលត្រូវបានជ្រើសរើស)»។
ឈរនៅចំពោះមុខ
ឃ្លានេះតំណាងពីគំនិតនៃការបម្រើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បំរើព្រះអម្ចាស់»

---

5 [1]បន្ទាប់មក ខ្ញុំក្រឡេកភ្នែកមកវិញ ខ្ញុំបានឃើញ ក្រាំងមួយកំពុងហោះ![2]ទេវតានិយាយមកកាន់ខ្ញុំថា «តើអ្នកឃើញអ្វី?» ខ្ញុំឆ្លើយថា «ខ្ញុំឃើញក្រាំងមួយកំពុងហោះ
បណ្តោយម្ភៃហត្ថ និងទទឹងដប់ហត្ថ»។
[3]បន្ទាប់មក គាត់និយាយមកកាន់ខ្ញុំថា «នេះគឺជាបណ្តាសារ ដែលកើតមាននៅក្នុងទឹកដីទាំងមូល ផ្នែកម្ខាងនៃក្រាំងនេះសរសេរថា ត្បិតចោរនឹងត្រូវកាត់ចេញ
ហើយផ្នែកម្ខាងទៀតសរសេរថា អស់អ្នកណាដែលស្បថបំពាននឹងត្រូវកាត់ចេញដែរ។[4]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា យើងនឹងបញ្ជូនបណ្តាសារមក
ដូច្នេះ បណ្តាសារនេះនឹងចូលក្នុងផ្ទះពួកចោរ និងផ្ទះពួកអស់អ្នកដែលស្បថបំពានដោយឈ្មោះរបស់យើង។ បណ្តាសារនឹងបន្តរនៅផ្ទះរបស់ពួកគេ ហើយនិងធ្វើឲ្យផ្ទះគេ
វិនាស ទាំងនៅលើនិងថ្មផងដែឬ»។
[5]បន្ទាប់មក ទេវតាដែលបាននិយាយជាមួយខ្ញុំក៏ចាក់ចេញទៅហើយនិយាយមកកាន់ខ្ញុំថា «ចូរបើកភ្នែករបស់អ្នកឡើង ហើយឃើញនូវអ្វីដែលចេញមកនោះ!»[6]ខ្ញុំឆ្លើយថា
«តើនេះគឺជាអ្វី?» គាត់និយាយថា «នេះគឺជាកញ្ជើដែលចេញមក គឺជា អំពើទុច្ចរិតរបស់ពួកគេក្នុងទឹកដីទាំងមូល»។[7]បន្ទាប់មក មានសំណរចេញមកពីកញ្ជើ
ហើយមានស្ត្រីម្នាក់នៅក្នុងកញ្ជើនោះ!
[8]ទេវតាពោលថា «នេះគឺជាអំពើ ទុច្ចរិត!» លោកបានបោះនាងចូលទៅក្នុងកញ្ជើវិញ ហើយលោកបានបោះសំណរបិទមាត់កញ្ជើផង។[9]ខ្ញុំក៏ក្រឡេកភ្នែករបស់ខ្ញុំ
ឃើញស្ត្រីពីរនាក់ចេញជិតៗខ្ញុំ ហើយខ្យល់បក់មកប៉ះស្លាបរបស់ពួកនាង មានស្លាបដូចស្លាបសត្វក្រសា។ ពួកគេហោះឡើងចេញពីកញ្ជើរវាងផែនដី និងឋានសួគ៌។
[10]ខ្ញុំក៏និយាយទៅទេវតាដែលបាននិយាយជាមួយខ្ញុំថា «តើពួកគេយកកញ្ជើទៅកន្លែងណា?»[11]លោកនិយាយមកកាន់ខ្ញុំថា
«ដើម្បីសាងសង់ប្រាសាទមួយនៅលើទឹកដីស៊ីណើរ ហើយនៅពេលដែលប្រាសាទរួចរាល់ ពួកនាងនឹងយកកញ្ជើទៅដាក់កន្លែងនោះ»។

Zechariah 5:1
បន្ទាប់មក ខ្ញុំក្រឡេក
ពាក្យ «ខ្ញុំ» សំដៅទៅលើលោកសាការី។
ខ្ញុំក្រឡេកភ្នែក
នេះមានន័យថារកមើលអ្វីមួយ។ គាត់និយាយថា «ខ្ញុំបានក្រឡេកភ្នែក»
ពីព្រោះនោះគឺជាផ្នែកនៃរាងកាយដែលមនុស្សម្នាក់បានឃើញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្រឡេកមើល»
សង្កេតមើល
ពាក្យថា «មើល»
នេះបង្ហាញថាលោកសាការីភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអ្វីដែលគាត់បានឃើញ។
ហត្ថ
មួយហត្ថគឺ ៤៦ សង់ទីម៉ែត្រ។
Zechariah 5:3
ព័ត៌មានទូទៅ៖
ទេវតានិយាយបន្តទៅកាន់លោកសាការី។
ផ្នែកម្ខាងនៃក្រាំងនេះសរសេរថា
«ផ្នែកម្ខាងនៃក្រាំងដែលបានសរសេរនៅម្ខាងទៀត»
ហើយផ្នែកម្ខាងទៀតសរសេរថា
«អ្វីដែលក្រាំងបានសរសេរនៅម្ខាងទៀត»
បើយោងតាមពាក្យរបស់ពួកគេ
ឃ្លានេះ «ពាក្យរបស់ពួកគេ»
សំដៅទៅលើអ្វីដែលបាននិយាយនៅក្នុងសម្បថរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «យោងទៅតាមអ្វីដែលពួកគេបាននិយាយ»
យើងនឹងបញ្ជូនបណ្តាសារមក
ពាក្យ «វា» សំដៅទៅលើបណ្តាសា។
ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
ផ្ទះ
នេះសំដៅទៅលើគ្រួសាររបស់បុរស និងអ្វីៗទាំងអស់ដែលពួកគេមាន។
អស់អ្នកដែលស្បថ
«បុរសម្នាក់ដែលបានស្បថ»
ធ្នឹម
ឈើប្រើសម្រាប់សាងសង់

generated on Wed Sep 10 16:16:32 2025

Zechariah 5:5
ចូរបើកភ្នែករបស់អ្នកឡើង
ឃ្លានេះបញ្ជាឲ្យមនុស្សម្នាក់រកមើលអ្វីដោយសំដៅទៅលើភ្នែករបស់ពួកគេ។
មានសំណ
នេះសំដៅទៅលើគម្របធ្ងន់។ សំណគឺជាលោហៈធ្ងន់។
មានស្ត្រីម្នាក់អង្គុយនៅក្នុងកញ្ជើនោះ
ស្ត្រីម្នាក់មិនអាចសមនឹងព្យញ្ជនៈនៅខាងក្នុងកញ្ជើនៃទំហំនេះទេ។
ទោះជានៅក្នុងចក្ខុនិមិត្តរបស់សាការីក៏ដូច្នោះដែរសមនឹងកញ្ចប់នោះ។
ជាធម្មតានៅក្នុងចក្ខុវិស័យរបស់លោកសាការីទំហំនៃវត្ថុត្រូវបានគេបំផ្លើស។
ទាំងកញ្ជើនិងស្ត្រីគឺជានិមិត្តរូប និងតំណាងឲ្យវត្ថុផ្សេងៗទៀត។
Zechariah 5:8
នេះគឺជាអំពើ ទុច្ចរិត
ស្ត្រីតំណាងឲ្យភាពអាក្រក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឈ្មោះរបស់នាងគឺអាក្រក់»
ខ្យល់បក់មកប៉ះស្លាបរបស់ពួកនាង
ឃ្លានេះពិពណ៌នាអំពីរបៀបដែលស្ត្រីប្រើស្លាបរបស់ពួកគេត្រូវបានអនុវត្តដោយខ្យល់
និងហោះហើរ។
មានស្លាបដូចស្លាបសត្វក្រសា
ស្ត្រីមានស្លាបដែលមើលទៅដូចជាស្លាបរបស់ស្តេច។
សត្វក្រសាគឺជាប្រភេទបក្សីធំមួយដែលមានស្លាបពី ២ ទៅ ៤ ម៉ែត្រ។
រវាងផែនដី និងឋានសួគ៌
កញ្ជើត្រូវបានលើកទៅលើមេឃ។ ឃ្លានេះនិយាយពី «រវាងផែនដី និងស្ថានសួគ៌»
ដើម្បីទាក់ទាញចំណាប់អារម្មណ៍ដល់ពួកគេ
និងបង្ហាញពីកន្លែងដែលកញ្ជើមានទំនាក់ទំនងជាមួយពួកគេ។
Zechariah 5:10
តើពួកគេយកកញ្ជើទៅកន្លែងណា?
«តើស្ត្រីកំពុងយកធុងនៅឯណា?»
ហើយនៅពេលដែលព្រះវិហាររួចរាល់...ទៅដាក់កន្លែងនោះ
«ហើយនៅពេលដែលព្រះវិហារបានត្រៀមរួចរាល់នោះធុងនឹងត្រូវដាក់នៅកន្លែងដែលបានរៀបចំសម្រាប់វ

---

6 [1]ខ្ញុំក៏ក្រឡេកភ្នែករបស់ខ្ញុំមកវិញ ឃើញរទេះបួនចេញមកពីចន្លោះភ្នំពីរ ហើយភ្នំទាំងពីរនោះកើតឡើងពីលង្ហិន។[2]រទេះទីមួយមានសេះពណ៌ក្រហម
រទេះទីពីរមានសេះពណ៌ខ្មៅ[3]រទេះទីបីមានពណ៌ស រទេះទីបួនសេះមានស្មាមអុចពណ៌ប្រផេះ។[4]ដូច្នេះ
ខ្ញុំក៏ឆ្លើយដោយបាននិយាយទៅកាន់ទេវតាដែលជាអ្នកនិយាយជាមួយខ្ញុំថា «តើការទាំងនេះគឺជាអ្វីទៅ លោកម្ចាស់?»
[5]ទេវតាក៏ឆ្លើយដោយនិយាយមកកាន់ខ្ញុំថា «នេះគឺជាខ្យល់ទាំងបួនទិសនៃឋានសួគ៌ ដែលចេញពីទីកន្លែងដែលពួកគេឈរនៅពីមុខព្រះជាម្ចាស់នៃផែនដីទាំងមូល។
[6]រទេះដែលមានសេះពណ៌ខ្មៅចេញទៅទឹកដីខាងជើង សេះពណ៌សចេញទៅទឹកដីខាងលិច ហើយសេះស្មាមអុចពណ៌ប្រផេះចេញទៅទឹកដីខាងត្បូង»។
[7]សេះខ្លាំងទាំងនេះបានចេញទៅហើយប្រឹងប្រែងរកផ្លូវដើម្បីធ្វើដំណើរឆ្លងកាត់ជុំវិញផែនដី ទេវតាក៏ពោលឡើងថា «ចូរចេញទៅ ហើយធ្វើដំណើរជុំវិញផែនដី!»
ពួកគេបានចេញទៅជុំវិញផែនដីទាំងមូល។[8]បន្ទាប់មក គាត់ហៅខ្ញុំហើយនិយាយមកកាន់ខ្ញុំថា «មើល៍ ទៅកាន់រទេះសេះដែលចេញទៅទឹកដីខាងជើង ពួកគេនឹង
រំងាប់វិញ្ញាណរបស់យើងនៅទឹកដីខាងជើងនោះ»។
[9]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំថា[10]«ទទួលយកដង្វាយពីពួកអ្នកដែលជាប់ជាឈ្លើយ ពីលោកហែលដាយិង លោកថូប៊ីយ៉ា និងយេដាយ៉ា
ហើយនៅថ្ងៃនោះដដែលត្រូយកដង្វាយទៅផ្ទះរបស់យូ៉ស៊ីសៀល ជាកូនរបស់សេផានា ជាអ្នកដែលមកពីបាប៊ីឡូន។[11]បន្ទាប់មក ទទួលយកមាស និងប្រាស់
ធ្វើជាមកុដដំពាក់លើក្បាលរបស់មហាបូជាចារ្យយេសួរ ជាកូនរបស់យូសាដាក់។
[12]ចូរប្រាប់លោកថា ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា បុរសនេះឈ្មោះរបស់លោកគឺ លំពង់ និងពន្លកដែលដុះចេញពីកន្លែងរបស់ខ្លួន
ហើយលោកនឹងសាងសង់ព្រះវិហាររបស់ព្រះអម្ចាស់![13]គឺលោកនោះហើយនឹងដែលជាអ្នកសាងសង់ព្រះវិហាររបស់ព្រះអម្ចាស់ ហើយនឹងតាំងភាពរុងរឿងឡើង
ហើយនឹងអង្គុយគ្រប់គ្រង់លើបល្ល័ង្ករបស់លោក។ លោកនឹងក្លាយជាបូជាចារ្យលើបល្ល័ង្ករបស់លោក
ហើយនិងការយល់ដឹងនៃសន្តិភាពដែលបានកើតឡើងរវាងការទាំងពីរនោះ។
[14]មកុដនឹងទុកដាក់នៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់ ដើម្បីគោរពដល់ លោកហែលដាយ លោកថូប៊ីយ៉ា និងលោកយេដាយ៉ា ព្រមទាំងជាការរំឭកដើម្បីចិត្តសប្បុរសនៃកូន
របស់សេផានា។[15]បន្ទាប់មក អស់អ្នកណាដែលនៅឆ្ងាយនឹងមកសាងសង់ព្រះវិហារនៃព្រះអម្ចាស់
ដូច្នេះអ្នកនឹងដឹងថាព្រះអម្ចាស់នៃពិភពទាំងមូលបានបញ្ជូនខ្ញុំមកអ្នកមែន ការនេះនឹងកើតឡើង
បើសិនស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នកពិតប្រាកដមែន!»

Zechariah 6:1
ក្រឡេកភ្នែករបស់ខ្ញុំ
នេះមានន័យថាការមើលទៅអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «មើល»
ភ្នំទាំងពីរនោះកើតឡើងពីលង្ហិន
«ភ្នំទាំងពីរធ្វើពីលង្ហិន»
រទេះទីមួយ...រទេះទីពីរ
«រទេះសេះ ទី១... រទេះសេះទី២»
Zechariah 6:5
នេះគឺជាខ្យល់ទាំងបួនទិសនៃឋានសួគ៌
ទេវតាពន្យល់ថារទេះសេះដែលមានសេះជានិមិត្តរូបនៃខ្យល់ទាំងបួននៃឋានសួគ៌។
ខ្យល់ទាំងបួនទិស
ពាក្យថា «ខ្យល់» សំអាងលើទិសដៅទាំងបួនគឺខាងជើងខាងកើតខាងត្បូង
និងខាងលិច។
ទោះយ៉ាងណាកំណែសម័យថ្មីខ្លះបកប្រែការបកស្រាយភាសាហេព្រើរនេះមានន័យថា
«វិញ្ញាណទាំងបួន»។
សេះពណ៌សចេញទៅទឹកដីខាងលិច
«កំណែសម័យថ្មីខ្លះបកប្រែឃ្លាភាសាហេព្រើរនេះមានន័យថា
«សេះពណ៌សក៏ចេញទៅក្រោយពួកគេ»។
Zechariah 6:7
មើល៍ ទៅកាន់រទេះសេះ
«មើលទៅសេះពណ៌ខ្មៅ»
Zechariah 6:9
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់
«ព្រះម្ចាស់មានព្រះបន្ទូលរបស់ព្រះអង្គ»
ចូរមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ១:១។
លោកហែលដាយិង លោកថូប៊ីយ៉ា លោកយេដាយ៉ា...យូសាដាក់
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
បន្ទាប់មក ទទួលយកមាស និងប្រាស់ ធ្វើជាមកុដ
របៀបផ្សេងទៀតនៃការបកប្រែ:
បន្ទាប់មកត្រូវប្រើប្រាក់និងមាសដើម្បីធ្វើជាមកុដមួយ។
មហាបូជាចារ្យយេសួរ ជាកូនរបស់យូសាដាក់
នេះមិនមែនជាបុរសដូចគ្នាដែលជាជំនួយការរបស់លោកម៉ូសេទេ
នេះជាមហាបូជាចារ្យមកពីសៀវភៅហាកាយ។
Zechariah 6:12
ចូរប្រាប់លោកថា
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ទៅទេវតាឲ្យនិយាយទៅកាន់លោកសាការី
ហើយពោល»
ឈ្មោះរបស់លោកគឺ ពន្លក
ទេវតារបស់ព្រះអម្ចាស់ដាក់ឈ្មោះនេះអោយលោកយ៉ូស្វេដែលជាស្តេចថ្មី។
បកប្រែឈ្មោះនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូក ៣: ៨។
គាត់នឹងលូតលាស់
ពាក្យ «លូតលាស់» គឺជារូបភាពពាក្យនៃមែកដែលចាប់ផ្តើមដុះពន្លក។
របៀបផ្សេងទៀតនៃការបកប្រែ: «គាត់នឹងដុះពន្លក»

generated on Wed Sep 10 16:16:32 2025

តាំងភាពរុងរឿងឡើង
អាចមានន័យថាទី ១) «បង្កើនភាពរុងរឿងរបស់ព្រះវិហារ» ឬ ទី២) «លើកខ្លួនឡើង
ហើយបំពាក់លើភាពរុងរឿងរបស់ព្រះវិហារសម្រាប់ខ្លួនគាត់
ដូចជាមនុស្សម្នាក់អាចស្លៀកសម្លៀកបំពាក់»
ការយល់ដឹងនៃសន្តិភាពដែលបានកើតឡើងរវាងការទាំងពីរនោះ
របៀបផ្សេងទៀតនៃការបកប្រែ: «តួនាទីរបស់គាត់ដែលជាស្តេច
និងមហាបូជាចារ្យនឹងត្រូវបានរួបរួម»
Zechariah 6:14
មកុដនឹងទុកដាក់នៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងទុកដាក់មកុដនៅក្នុងព្រះវិហាររបស់យើង»
មកុដ
ពាក្យថា «មកុដ» សំដៅទៅលើស្តេចដែលជាស្តេចពាក់មកុដ។
ទុកដាក់នៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់
ឃ្លានេះសំដៅលើព្រះរាជាដែលជាបូជាចារ្យផងដែរក្នុងនាមជាបូជាចារ្យបម្រើក្នុងព្រះវិហារ។
លោកហែលដាយ លោកថូប៊ីយ៉ា លោកយេដាយ៉ា
សូមមើលពីរបៀបការបកប្រែឈ្មោះទាំងនេះនៅក្នុងជំពូក ៦:៩។
ព្រមទាំងជាការរំឭកដើម្បីចិត្តសប្បុរសនៃកូនរបស់សេផានា
កណែសម័យថ្មីខ្លះបកស្រាយឃ្លានេះថា
«ជាការរំលឹកដល់ហេនដែលជាកូនប្រុសរបស់សេផានា» ឬ
«ជាអនុស្សាវរីយ៍ដល់អ្នកដែលមានចិត្តសន្តោសប្រណីជាកូនរបស់សេផានា»។
ដូចគ្នាផងដែរ ជំនាន់សម័យទំនើបមួយចំនួនបកប្រែឈ្មោះ «ហេន»
ដែលមានន័យថាឈ្មោះ «យ៉ូសៀស»។
អស់អ្នកណាដែលនៅឆ្ងាយ
នេះសំដៅទៅលើជនជាតិអ៊ីស្រាអែលដែលនៅបាប៊ីឡូន។
ដូច្នេះអ្នកនឹងដឹងថា
ពាក្យ «អ្នក» សំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ស្តាប់តាម
«ស្តាប់ដោយស្មោះ»

7

[1]នៅពេលដែលព្រះចៅដារីយូសគ្រប់គ្រងបានបួនឆ្នាំ នៅក្នុងថ្ងៃទីបួននៃខែមិគ្គសិរ (ជាខែទីប្រាំបួន) ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់សាផានា។
[2]ប្រជាជននៅក្រុងបេតអែលបានបញ្ជូនលោកសារេស៊ើរ និងលោករេគេមមែឡេក ព្រមទាំងមនុស្សមួយក្រុម ដើម្បីទូលអង្វរទៅព្រះអម្ចាស់។
[3]ពួកគេនិយាយទៅកាន់ពួកបូជាចារ្យជាអ្នកដែលនៅព្រះដំណាក់របស់ព្រះអម្ចាស់នៃពិភពលោកទាំងមូល និងពួកព្យាការីថា
«តើខ្ញុំត្រូវកាន់ទុក្ខនៅខែទីប្រាំដោយការតមអាហារ ដូចខ្ញុំធ្លាប់បានធ្វើជាច្រើនឆ្នាំមកហើយឬ?»
[4]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលមកកាន់ខ្ញុំថា[5]«ចូរនិយាយប្រាប់ទៅមនុស្សគ្រប់គ្នា និងពួកបូជាចារ្យដែលរស់នៅលើទឹកដីថា
«នៅពេលដែលអ្នកតមហើយកាន់ទុក្ខនៅក្នុងខែទីប្រាំ និងខែទីប្រាំពីរ រយៈពេលចិតសិបឆ្នាំមកនេះ តើអ្នកពិតជាតមអាហារដើម្បីយើងមែនទេ?
[6]នៅពេលដែលអ្នកបរិភោគអាហារ ឬផឹកតើអ្នកមិនបានបរិភោគអាហារ ឬផឹកដើម្បីខ្លួនឯងមែនឬទេ?
[7]តើទាំងនេះមិនមែនជាអ្វីដែលព្រះអម្ចាស់បានប្រកាសប្រាប់តាមរយៈមាត់របស់ព្យាការី នៅពេលដែលអ្នករស់នៅក្រុងយេរូសាឡឹម
ហើយនៅជុំវិញក្រុងដោយភាពចម្រុងចម្រើន និងមានស្ថេរភាពតំបន់ណេកិប និងតំបន់ទំនាបខាងលិចទេឬអី?»
[8]ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកសាការីថា[9]«ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ចូរវិនិច្ឆ័យដោយយុត្តិធម៌ ចូរមានចិត្តសប្បុរស
និងមានចិត្តមេត្តាអោយគ្នាទៅវិញទៅមក។[10]មិនត្រូវជិះជាន់ដល់ស្ត្រីមេម៉ាយ ក្មេងកំព្រា ជនបរទេស និងមនុស្សទ័លក្រឡើយ
ហើយកុំឲ្យនរណាម្នាក់នៃអ្នករាល់គ្នាប្រព្រឹត្តអំពើអាក្រក់ចំពោះគ្នាទៅវិញទៅមកដែរ។
[11]ប៉ុន្តែពួកគេមិនព្រមយកចិត្តទុកដាក់ស្តាប់ទេ ពួកគេមានចិត្តរឹងរូស។ ពួកគេខ្ទប់ត្រចៀករបស់គេ ដូច្នេះពួកគេមិនអាចឮទេ។[12]ពួកគេមានចិត្តរឹងរូសដូចជាថ្ម
ដូច្នេះហើយពួកគេមិនអាចឮក្រឹត្យវិន័យ ឬព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូលឡើយ។ ព្រះអង្គបានចាត់ព្រះបន្ទូលទៅកាន់មនុស្សតាមរយៈព្រះវិញ្ញាណ
របស់ព្រះអង្គតាំងពីដើមមកម៉្លេះ តាមរយៈមាត់របស់ពួកព្យាការី។ ប៉ុន្តែពួកគេបដិសេដមិនស្តាប់ឡើយ ដូច្នេះហើយ ព្រះអម្ចាស់នៃពិភពទាំងមូល
ព្រះពិរោធនឹងពួកគេយ៉ាងខ្លាំង។
[13]ការនេះកើតឡើងនៅពេលដែលព្រះអង្គហៅ តែពួកគេមិនស្តាប់»។ ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា «ពួកគេនឹងហៅយើង
ប៉ុន្តែយើងនឹងមិនស្តាប់ពួកគេឡើយ។[14]ត្បិតយើងនឹងកម្ចាត់កម្ចាយគេដោយខ្យល់ព្យុះ ដល់អស់ទាំងប្រជាជាតិដែលពួកគេមិនធ្លាប់បានឃើញ
ហើយទឹកដីនឹងទៅជាខូចបង់ដោយសារពួកគេ។ ដ្បិតគ្មាននរណាម្នាក់នឹងដើរកាត់ទឹកដីឬត្រលប់ទៅវិញឡើយ តាំងពីមនុស្សបានបង្កើតទឹកដីដោយរីករាយ
ហើយគ្មានមនុស្សរស់នៅ»។

Zechariah 7:1
នៅពេលដែលព្រះចៅដារីយូសគ្រប់គ្រងបានបួនឆ្នាំ
«រយៈពេលបួនឆ្នាំតាំងពីព្រះចៅដារីយូសបានក្លាយជាស្តេច»
នៅក្នុងថ្ងៃទីបួននៃខែមិគ្គសិរ (ជាខែទីប្រាំបួន)
«ខែមិគ្គសិរ» គឺជាខែទី៩ នៃប្រតិទិនហេព្រើរ។
ថ្ងៃទីបួនគឺនៅជិតចុងខែវិច្ឆិកានៅលើប្រតិទិនភាគខាងលិច។
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់
«ព្រះអម្ចាស់បានមានព្រះបន្ទូលរបស់ព្រះអង្គ»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ១:១។
លោកសារេស៊ើរ និងលោករេគេមមែឡេក
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។ ។
ពួកគេពោលថា «តើខ្ញុំត្រូវកាន់ទុក្ខ...ប៉ុន្មានឆ្នាំ?
ពាក្យ «ពួកគេ» សំដៅទៅលើលោកសារេស៊ើរ និងលោករេគេមមែឡេក។
នៅខែទីប្រាំ
ប្រជាជនយូដាបានតមក្នុងអំឡុងពេលមួយនៅខែទីប្រាំនៃប្រតិទិនហេព្រើរ
ពីព្រោះនេះជាពេលដែលពួកបាប៊ីឡូនបានបំផ្លាញព្រះវិហារនៅយេរូសាឡិម។ ខែទី
៥ គឺនៅអំឡុងចុងខែកក្កដា និងផ្នែកទី១ នៃខែសីហាតាមប្រតិទិនភាគខាងលិច។
Zechariah 7:4
ក្នុងខែទីប្រាំ
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងខែទីប្រាំ»
ខែទីប្រាំពីរ
ជនជាតិយូដាបានកាន់ទុក្ខក្នុងអំឡុងពេលមួយនៃខែទី៧ នៃប្រតិទិនហេព្រើរ
ពីព្រោះនៅក្នុងខែនេះជនជាតិយូដាដែលនៅសេសសល់នៅទីក្រុងយេរូសាឡិមបានភៀសខ្លួនទៅស្រុកអេ
ដែលស្តេចបាប៊ីឡូនបានតែងតាំងជាអភិបាលលើស្រុកយូដា។ ខែទី៧
គឺជាអំឡុងពេលចុងក្រោយនៃខែកញ្ញានិងផ្នែកទី១
នៃខែតុលាតាមប្រតិទិនភាគខាងលិច។ (សូមមើល: និងtranslate-ordinal)
រយៈពេលចិតសិបឆ្នាំមកនេះ
ប្រជាជនអ៊ីស្រាអែលដែលជាទេសកនៅក្នុងបាប៊ីឡូនអស់រយៈពេល ៧០ ឆ្នាំ។
នៅពេលដែលអ្នកបរិភោគអាហារ ឬផឹក
ឃ្លានេះសំដៅទៅលើពេលដែលពួកគេបរិភោគនិងផឹកនៅពិធីជប់លៀង
ដើម្បីគោរពពរពីបៀបដែលព្រះអម្ចាស់បានផ្តត់ផ្តង់ពួកគេ។
តើអ្នកពិតជាតមអាហារដើម្បីយើងមែនទេ?
សំណួរនេះត្រូវបានប្រើដើម្បីចោទប្រកាន់ប្រជាជនអ៊ីស្រាអែលពីបទមិនគោរពដល់ព្រះអម្ចាស់
នៅពេលពួកគេតមអាហារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនបានតមដើម្បីគោរពយើងទេ»
តើអ្នកមិនបានបរិភោគអាហារ ឬផឹកដើម្បីខ្លួនឯងមែនឬទេ?
សំណួរនេះត្រូវបានប្រើដើម្បីចោទប្រកាន់ជនជាតិអ៊ីស្រាអែល
ដែលបានប្រារព្ធពិធីបុណ្យដោយមិនគោរពដល់ព្រះដោយការជប់លៀងរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គឺសម្រាប់ខ្លួនអ្នកដែលអ្នកបានបរិភោគនិងផឹក»
ព្រះអម្ចាស់បានប្រកាសប្រាប់តាមរយៈមាត់របស់ព្យាការី

generated on Wed Sep 10 16:16:32 2025

សាការីសំដៅទៅលើព្យាការី ដោយសំដៅទៅលើផ្នែកនៃរាងកាយរបស់ពួកគេ
ដែលបាននិយាយសាររបស់ព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានប្រកាសតាមរយៈពួកព្យាការីមុនៗ»
តើទាំងនេះមិនមែនជាអ្វីដែល...ខាងលិចទេឬអី?»
សំណួរនេះអាចត្រូវបានសរសេរជាសេចក្តីថ្លែងការណ៍។
ទាំងនេះពិតជាពាក្យដដែលៗទៅទិសខាងលិច។
ភាពចម្រុងចម្រើន
«បានរស់នៅក្នុង»
តំបន់ទំនាប
ទាំងនេះគឺជាកូនភ្នំតូចៗដែលមានមុនពេលអ្នកទៅដល់ភ្នំ។
Zechariah 7:8
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់
«ព្រះអម្ចាស់បានមានព្រះបន្ទូលរបស់ព្រះអង្គ»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ១:១។
ចូរវិនិច្ឆ័យ
ពាក្យថា «នេះ» សំដៅទៅលើរបៀបដែលមនុស្សម្នាក់គួរតែវិនិច្ឆ័យ។
ស្ត្រីមេម៉ាយ
ស្ត្រីម្នាក់ដែលប្តីស្លាប់ចោល
ក្មេងកំព្រា
ក្មេងដែលឪពុកម្តាយស្លាប់ចោល
ជនបរទេស
អ្នកណាម្នាក់ដែលធ្វើដំណើរពីទឹកដីរបស់ខ្លួនទៅទឹកដីផ្សេងៗទៀត
កុំឲ្យនរណាម្នាក់នៃអ្នករាល់គ្នាប្រព្រឹត្តអំពើអាក្រក់ចំពោះគ្នាទៅវិញទៅមកដែរ
«អ្នកមិនត្រូវមានផែនការដើម្បីប្រព្រឹត្តការអាក្រក់ឡើយ»
Zechariah 7:11
ពួកគេមានចិត្តរឹងរូស
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេដូចជាសត្វគោដែលមិនព្រមចាប់នឹម» ឬ
«ពួកគេដូចជាគោដែលបដិសេធមិនស្តាប់បង្គាប់»
ពួកគេខ្ទប់ត្រចៀករបស់គេ
«គេបានបិទត្រចៀករបស់ពួកគេ»
ពួកគេមានចិត្តរឹងរូសដូចជាថ្ម
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេមានគំនិតដើម្បីបដិសេធព្រះបន្ទូលរបស់ព្រះអម្ចាស់»
តាមរយៈមាត់របស់ពួកព្យាការី
របៀបផ្សេងទៀតនៃការបកប្រែ: «តាមរយៈសាររបស់ពួកព្យាការី»
Zechariah 7:13
យើងនឹងកម្ចាត់កម្ចាយគេដោយខ្យល់ព្យុះ
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងកម្ចាត់កម្ចាយពួកគេដូចជាខ្យល់កួចបែកស្លឹក»
ខ្យល់ព្យុះ
ជាខ្យល់បក់ខ្លាំងដែលបក់បោកនៅពេលវាសាយភាយពាសពេញគ្រប់ទីកន្លែង

---

8 [1]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលមកកាន់ខ្ញុំថា[2]«ព្រះអម្ចាស់នៃពិភពទាំងមូលមានបន្ទូលយ៉ាងនេះ
យើងប្រចណ្ឌចំពោះក្រុងស៊ីយ៉ូនដោយចិត្តខ្នះខ្នែងយ៉ាងខ្លាំង ហើយប្រចណ្ឌកចំពោះក្រុងនេះដោយការក្រោធយ៉ាងខ្លាំង!
[3]ព្រះអម្ចាស់នៃពិភពទាំងមូលមានបន្ទូលថា
យើងនឹងត្រលប់ទៅក្រុងស៊ីយ៉ូនវិញ ហើយនឹងរស់នៅកណ្តាលក្រុងយេរូសាឡឹម ដ្បិតក្រុងយេរូសាឡឹមនឹងហៅថាជា ក្រុងនៃសេចក្តីពិត
ហើយភ្នំរបស់ព្រះអម្ចាស់នៃពិភពទាំងមូលនឹងហៅថាជា ភ្នំបរិសុទ្ធ!
[4]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា មនុស្សចាស់ទាំងប្រុសទាំងស្រីនឹងអង្គុយនៅតាមផ្លូវនៃក្រុងយេរូសាឡឹម ហើយមនុស្សម្នាក់ៗនឹងត្រូវការឈើច្រត់នៅក្នុងដៃ
ព្រោះដោយសារពួកគេមានវ័យចាស់ណាស់ទៅហើយ។[5]តាមផ្លូវនៃក្រុងនឹងពេញទៅដោយក្មេងប្រុស និងក្មេងស្រីជាច្រើនលេងនៅតាមផ្លូវនោះ។
[6]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា បើសិនការនេះមើលទៅមិនសមនៅក្នុងភ្នែករបស់មនុស្សសំណល់នៅក្នុងថ្ងៃនោះ
តើការនោះវាអាចទៅរួចនៅក្នុងភ្នែករបស់យើងដែរឬទេ? នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[7]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ចូរមើល៍!
យើងជាអ្នកសង្គ្រោះប្រជារាស្ត្ររបស់យើងពីទឹកដីខាងកើត និងពីទឹកដីខាងលិច![8]ដ្បិតយើងនឹងនាំពួកគេមកវិញ ហើយគេនឹងរស់នៅកណ្តាលក្រុងយេរូសាឡឹម
ដូច្នេះហើយ ពួកគេនឹងក្លាយជាប្រជារាស្ត្រយើងម្តងទៀត ហើយយើងនឹងក្លាយជាព្រះជាម្ចាស់របស់ពួកគេដោយសេចក្តីពិត និងសេចក្តីសុចរិត!
[9]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា អស់អ្នកណាដែលបន្តស្តាប់ពាក្យទាំងប៉ុន្មានដែលបានចេញមកពីមាត់ពួកព្យាការីនៅពេលចាក់គ្រឹះសង់ដំណាក់យើង
បានដាក់ដំណាក់នេះជារបស់យើង ព្រះអម្ចាស់នៃពិភពទាំងមូល ពង្រឹងដៃរបស់អ្នកនោះព្រះវិហារអាចសាងសង់បាន។
[10]ដ្បិតមុនថ្ងៃនោះគ្មានផលណាប្រមូលផ្តុំគ្នាដោយនរណាម្នាក់ឡើយ ក៏គ្មានប្រយោជន៍សម្រាប់មនុស្ស ឬសត្វដែរ
ហើយគ្មានក្តីសុខសាន្តសម្រាប់អ្នកដែលចេញចូលតាមនោះដែរ។ យើងបានធ្វើឲ្យគ្រប់គ្នាទាល់ជាមួយអ្នកជិតខាងរបស់គេផង។
[11]ប៉ុន្តែ ឥឡូវនេះមិនដូចពីថ្ងៃមុនទៀតទេ យើងនឹងនៅជាមួយមនុស្សសំណល់ទាំងនេះ ហើយនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។
[12]ដ្បិតពូជនៃសន្តិភាពនឹងត្រូវសាបព្រោះ ដើមជំពាំងបាយជូរនឹងមានផ្លែឡើងវិញ ហើយផែនដីនឹងបង្កើតផលឲ្យ មេឃនឹងឲ្យទឹកសន្សើមដល់ពួកគេ
ដ្បិតយើងនឹងធ្វើឲ្យសំណល់នៃមនុស្សទាំងអស់នេះទទួលការទាំងនេះទុកជាមរតក។
[13]អ្នកគឺជាគំរូដល់ប្រជាជាតិផ្សេងៗនៃបណ្តាសា ពួកកូនចៅយូដា និងពួកកូនចៅអ៊ីស្រាអែល។ ដូច្នេះយើងនឹងសង្គ្រោះអ្នកហើយអ្នកនឹងទទួលបានព្រះពរ។ កុំភ័យខ្លាចអី
ចូរឲ្យដៃរបស់អ្នករឹងមាំឡើង![14]ដ្បិតព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ដូចយើងបានបង្កគ្រោះអន្តរាយដល់អ្នក
ដោយបុព្វបុរសរបស់អ្នកបញ្ឆេះកំហឹងរបស់យើង ដោយឥតនឹកស្តាយ[15]ដូច្នេះហើយយើងនឹងគិតធ្វើល្អដល់ក្រុងយេរូសាឡឹម និងកូនចៅរបស់យូដា ម្តងទៀតនៅថ្ងៃនេះ!
ចូរកុំខ្លាចអ្វីឡើយ!
[16]នេះគឺជាការងារដែលអ្នកត្រូវតែធ្វើ ចូរនិយាយសេចក្តីពិតទៅកាន់អ្នកជិតខាង។ ចូរវិនិច្ឆ័យដោយសេចក្តីពិត យុត្តិធម៌ និងដោយសន្តិភាពនៅតាមច្រកទ្វាររបស់អ្នក។
[17]ចូរកុំគិតធ្វើអំពើអាក្រក់នៅក្នុងចិត្តរបស់អ្នកទាល់ជាមួយអ្នកណាម្នាក់ឡើយ កុំស្រឡាញ់ការស្បថមិនត្រឹមត្រូវ យើងស្អប់ការទាំងអស់នោះ
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់»។
[18]បន្ទាប់មក ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលមកកាន់ខ្ញុំ[19]«ព្រះអម្ចាស់នៃពិភពទាំងមូលមានបព្រះបន្ទូលថា ការតបអាហារនៃខែទីបួន ខែទីប្រាំ ខែទីប្រាំពីរ
និងខែទីដប់នឹងក្លាយជាពេលនៃអំណរ រីករាយ និងពិធីបុណ្យ សប្បាយរីរាយសម្រាប់កូនចៅយូដា! ចូរស្រឡាញ់សេចក្តីពិត និងក្តីសុខសាន្ត!
[20]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា មនុស្សនឹងមកវិញម្តងទៀត។[21]ទោះបីអ្នកណាដែលរស់នៅក្រុងផ្សេងៗក៏ដោយ។
ប្រជាជននៃក្រុងមួយនឹងទៅហៅក្រុងមួយទៀតដោយនិយាយថា។[22]«ចូរពួកយើងប្រញាប់ទូលអង្វរនៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់
ហើយស្វែងរកព្រះអម្ចាស់នៃពិភពទាំងមូល! យើងខ្ញុំផ្ទាល់ក៏ទៅដែរ។ មនុស្សជាច្រើន
និងប្រជាជាតិដែលខ្លាំងពូកែរជាច្រើននឹងទៅស្វែងរកព្រះអម្ចាស់នៃពិភពទាំងមូលនៅក្រុងយេរូសាឡឹម និងអង្វរដល់ព្រះអម្ចាស់!
[23]ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា នៅក្នុងថ្ងៃនោះមានបុរសដប់នាក់មកពីគ្រប់ជនជាតិ និងគ្រប់ភាសានឹងចាប់កាន់ជាយអាវរបស់ជនជាតិយូដាម្នាក់
ហើយនិយាយថា ចូរឲ្យពួកយើងទៅជាមួយអ្នកផង ពីព្រោះយើងបានដឹងថាព្រះជាម្ចាស់គង់នៅជាមួយអ្នក!»

Zechariah 8:1
ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលមកកាន់ខ្ញុំថា
ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលមកខ្ញុំថា
យើងប្រចណ្ឌកចំពោះក្រុងនេះដោយការក្រោធយ៉ាងខ្លាំង
របៀបផ្សេងទៀតនៃការបកប្រែ: «យើងខឹងនឹងក្រុងស៊ីយ៉ូន»
ភ្នំរបស់ព្រះអម្ចាស់នៃពិភពទាំងមូល

generated on Wed Sep 10 16:16:32 2025

ពាក្យនេះសំដៅទៅលើភ្នំស៊ីយ៉ូន។
ភ្នំបរិសុទ្ធ
ពាក្យថា «បរិសុទ្ធ» មានន័យថា «ជាកម្មសិទ្ធរបស់ព្រះអម្ចាស់»។
Zechariah 8:4
នៅតាមផ្លូវនៃក្រុងយេរូសាឡិម
«ត្រូវរស់នៅក្នុងក្រុងយេរូសាឡិម»
នៅក្នុងដៃ ព្រោះដោយសារពួកគេមានវ័យចាស់ណាស់ទៅហើយ
ការមានឪកាសចាស់ជរាគឺជាសញ្ញានៃសេចក្តីសុខសាន្តនិងវិបុលភាព។
តាមផ្លូវនៃក្រុងនឹងពេញទៅដោយ
តំបន់សាធារណៈនៃទីក្រុងនឹងពោរពេញទៅ
ដោយមនុស្សនៅក្នុងសកម្មភាពធម្មតារបស់ពួកគេ។
Zechariah 8:6
បើសិនការនេះមើលទៅមិនសមនៅក្នុងភ្នែក
«ប្រសិនបើការនេះមើលទៅមិនទំនងអាចធ្វើទៅបាន»
មនុស្សសំណល់
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជននៅស្រុកយូដាដែលបានរួចជីវិត»
តើការនោះវាអាចទៅរួចនៅក្នុងភ្នែករបស់យើងដែរឬទេ?
ព្រះកំពុងសួរសំណួរនេះ
ដើម្បីបញ្ចុះបញ្ចូលប្រជាជនរបស់ព្រះអង្គឲ្យទុកចិត្តលើការសន្យារបស់ព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាកដជាអាចទៅរួចសម្រាប់ខ្ញុំ!»
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
យើងជាអ្នកសង្គ្រោះប្រជារាស្ត្ររបស់យើង
«យើងជាអ្នកសង្គ្រោះប្រជារាស្ត្ររបស់យើងពីស្រុកយូដាដែលបានត្រូវគេនិរទេសទៅ»
Zechariah 8:9
នៅពេលចាក់គ្រឹះសង់ដំណាក់របស់យើង
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលគ្រឹះនៃព្រះវិហាររបស់ខ្ញុំត្រូវបានតំឡើង» ទៅ
«នៅពេលអ្នកកំពុងចាក់គ្រឹះសង់ដំណាក់របស់យើង»
ពង្រឹងដៃរបស់អ្នក
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រឹងប្រែងធ្វើការ»
ដ្បិតមុនថ្ងៃនោះ
របៀបផ្សេងទៀតនៃការបកប្រែ:
«មុនពេលអ្នកចាប់ផ្តើមសាងសង់ព្រះវិហារឡើងវិញ»
គ្មានផលណាប្រមូលផ្តុំគ្នា
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មានហេតុផលណាដែលត្រូវច្រូតកាត់ឡើយ»
ក៏គ្មានប្រយោជន៍សម្រាប់មនុស្ស ឬសត្វដែរ
ជាការឥតប្រយោជន៍សម្រាប់មនុស្ស និងសត្វរបស់ពួកគេក្នុងការធ្វើស្រែចំការ
ពីព្រោះពួកគេគ្មានអាហារពីវាទេ។
Zechariah 8:11
មិនដូចពីថ្ងៃមុនទៀតទេ
«ដូចនៅអតីតកាល»
យើងនឹងនៅជាមួយមនុស្សសំណល់ទាំងនេះ
របៀបផ្សេងទៀតនៃការបកប្រែ: «ឥឡូវនេះយើងនឹង ឲ្យ ពរដល់ប្រជាជនទាំងនេះ»
ឬ «ឥឡូវនេះយើងនឹងប្រព្រឹត្តចំពោះមនុស្សទាំងនេះដោយសប្បុរស»
ពូជនៃសន្តិភាពនឹងត្រូវសាបព្រោះ
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងធ្វើឲ្យប្រជាជនមានសន្តិភាព»។
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
ផែនដីនឹងបង្កើតផលឲ្យ
របៀបផ្សេងទៀតនៃការបកប្រែ: «នៅទីវាលនឹងមានការច្រូតកាត់ល្អ»
មេឃនឹងឲ្យទឹកសន្សើមដល់ពួកគេ
ទឹកសន្សើមជានិមិត្តរូបនៃភាពរុងរឿង។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងមានភ្លៀងធ្លាក់ច្រើន»
ទទួលការទាំងនេះទុកជាមរតក
របៀបផ្សេងទៀតនៃការបកប្រែ: «មានរបស់ទាំងអស់នេះគ្រប់ពេល»
Zechariah 8:13
អ្នកគឺជាគំរូដល់ប្រជាជាតិផ្សេងៗនៃបណ្តាសា
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលដែលខ្ញុំដាក់ទណ្ឌកម្មអ្នក
នោះប្រជាជាតិដទៃទៀតបានដឹងពីអ្វីដែលកើតឡើងនៅពេលខ្ញុំដាក់បណ្តាសាដល់នរណាម្នាក់»
ពួកកូនចៅយូដា និងពួកកូនចៅអ៊ីស្រាអែល
«ប្រជាជននៃយូដា និងអ៊ីស្រាអែល»
ចូរឲ្យដៃរបស់អ្នករឹងមាំឡើង!
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រឹងប្រែងធ្វើការ»
បង្កគ្រោះអន្តរាយដល់អ្នក
«ដាក់ទណ្ឌកម្មអ្នក»
បញ្ជេះកំហឹងរបស់យើង
«ខឹងខ្ញុំ»
ដោយឥតនឹកស្តាយ
«មិនបានសំរេចក្នុងការដាក់ទណ្ឌកម្មពួកគេសោះឡើយ»
Zechariah 8:16
ដែលអ្នកត្រូវតែធ្វើ
ពាក្យ «អ្នក» សំដៅទៅលើប្រជាជនយូដា។
ចូរនិយាយសេចក្តីពិតទៅកាន់អ្នកជិតខាង
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាប់ការពិតទៅមនុស្សគ្រប់គ្នា»
ចូរវិនិច្ឆ័យដោយសេចក្តីពិត យុត្តិធម៌ និងដោយសន្តិភាពនៅតាមច្រកទ្វារបស់អ្នក
របៀបផ្សេងទៀតនៃការបកប្រែ:
«ចៅក្រមធ្វើការប្រកែកគ្នាដោយយុត្តិធម៌នៅក្នុងកន្លែងវិនិច្ឆ័យរបស់អ្នក
ដើម្បីឲ្យមនុស្សអាចរស់នៅដោយសុខសាន្តជាមួយគ្នា»
កុំស្រឡាញ់ការស្បថមិនត្រឹមត្រូវ
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនយល់ព្រមនៅពេលដែលមនុស្សនិយាយកុហកនៅក្នុងរឿងក្តីរបស់តុលាការ»
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
Zechariah 8:18
បន្ទាប់មក ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលមកកាន់ខ្ញុំ
ពាក្យ «ខ្ញុំ» សំដៅទៅលើលោកសាការី។
ការតបអាហារនៃខែទីបួន
ជនជាតិយូដាបានកាន់ទុក្ខក្នុងអំឡុងពេលខែបួននៃប្រតិទិនហេព្រើរ
ពីព្រោះនេះជាពេលដែលពួកបាប៊ីឡូនបានបំបែកកំពែងក្រុងយេរូសាឡិម។ ខែទី ៤
គឺនៅក្នុងអំឡុងពេលចុងក្រោយនៃខែមិថុនា
និងផ្នែកទីមួយនៃខែកក្កដាតាមប្រតិទិនភាគខាងលិច។
ខែទីប្រាំ
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ៧:១។
ខែទីប្រាំពីរ
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ៧:៤។
ខែទីដប់
ជនជាតិយូដាបានកាន់ទុក្ខក្នុងអំឡុងខែទី ១០ នៃប្រតិទិនហេព្រើរ
ពីព្រោះនេះជាពេលដែលពួកបាប៊ីឡូនបានឡោមព័ទ្ធទីក្រុងយេរូសាឡិម។ ខែទី ១០
គឺនៅចុងខែធ្នូ និងផ្នែកទី ១ នៃខែមករាតាមប្រតិទិនភាគខាងលិច។ (សូមមើល: និងtranslate-ordinal)
Zechariah 8:20
មនុស្សនឹងមកវិញម្តងទៀត
«មនុស្សនឹងមកក្រុងយេរូសាឡិមម្តងទៀត»
មនុស្សជាច្រើន និងប្រជាជាតិដែលខ្លាំងពូកែរជាច្រើននឹងទៅស្វែងរក
មនុស្សជាច្រើននឹងមក រួមទាំងមនុស្សមកពីប្រជាជាតិធំៗទៀតផង។
Zechariah 8:23
នឹងចាប់កាន់ជាយអាវរបស់ជនជាតិយូដាម្នាក់
«នឹងចាប់កាន់សម្លៀកបំពាក់របស់អ្នកដើម្បីទទួលបានការយកចិត្តទុកដាក់»

generated on Wed Sep 10 16:16:32 2025

ចូរឲ្យពួកយើងទៅជាមួយអ្នកផង
«សូមឲ្យពួកយើងធ្វើដំណើរទៅក្រុងយេរូសាឡឹមជាមួយអ្នកផង»

ព្រះជាម្ចាស់គង់នៅជាមួយអ្នក
«ព្រះជាម្ចាស់គង់នៅជាមួយអ្នករាល់គ្នា»

---

9 [1]នេះគឺសេចក្ដីប្រកាសរបស់ព្រះអម្ចាស់ អំពីទឹកដីរបស់ហាត្រាក និងដាម៉ាស។ ដ្បិតព្រះនេត្ររបស់ព្រះអម្ចាស់គឺនៅលើមនុស្សទាំងអស់
ព្រមទាំងកុលសម្ព័ន្ធទាំងអស់របស់អ៊ីស្រាអែលផង។[2]សេចក្ដីប្រកាសនេះក៏និយាយអំពីក្រុងហាម៉ាត ដែលព្រំប្រទល់ជាប់ និងក្រុងដាម៉ាស ហើយក៏និយាយអំពីទីរ៉ុស
និងស៊ីដូនទោះបីជាពួកគេមានប្រាជ្ញាយ៉ាងណាក៏ដោយ។
[3]ក្រុងទីរ៉ុសបានសង់កំពែងមួយដ៏រឹងមាំសម្រាប់ខ្លួន ហើយបានប្រមូលប្រាក់ច្រើនដូចជាធូលីដី និងមាសល្អៗជាច្រើនដូចជាភក់នៅតាមផ្លូវ។[4]មើល៍!
ព្រះជាម្ចាស់នឹងបំបែកពួកគេ ហើយបំផ្លាញកម្លាំងនៅលើសមុទ្រ ដូច្នេះហើយពួកគេនឹងលេបត្របាក់ដោយសារភ្លើងវិញ។
[5]ក្រុងអាស្កាឡូននឹងឃើញ ហើយនឹងភ័យខ្លាច! ក្រុងកាសានឹងញាប់ញ័រជាខ្លាំង! ក្រុងអេក្រូននឹងបាត់បង់សេចក្ដីសង្ឃឹមអស់! ស្ដេចនឹងលែងមាននៅក្រុងកាសា
ហើយក្រុងអាស្កាឡូននឹងលែងមានមនុស្សរស់នៅទៀតដែរ![6]ជនបរទេសជាច្រើននឹងធ្វើផ្ទះពួកគេនៅក្រុងអាស្ដូឌ ហើយយើងនឹងយើងបំបាត់អំនួតរបស់ពួកគេពីភីលីស្ទីន។
[7]ដ្បិតយើងនឹងយកឈាមចេញពីមាត់របស់ពួកគេ និងដកអំពើដ៏អាក្រក់ចេញពីចន្លោះធ្មេញរបស់ពួកគេ។
នោះពួកគេនឹងក្លាយទៅជាមនុស្សសំណល់នៃព្រះជាម្ចាស់របស់យើង ដូចជាអំបូរយូដា ហើយក្រុងអេក្រូនឹងក្លាយទៅជាពួកក្រុងយេបូសដែរ។
[8]យើងនឹងបោះជំរុំទ័ពជុំវិញទឹកដីរបស់យើងដើម្បីទាស់និងសត្រូវ ដូច្នេះហើយគ្មាននរណាម្នាក់អាចដើរកាត់ឬត្រលបទៅវិញបានឡើយ
ដ្បិតគ្មានការសង្កត់សង្កិនណានៅលើពួកគេទៀតឡើយ។ ដ្បិតយើងនឹងមើលថែរក្សាទឹកដីរបស់យើងដោយភ្នែករបស់យើងដោយផ្ទាល់!
[9]កូនស្រីនៃក្រុងស៊ីយ៉ូនអើយ ចូរស្រែកដោយអំណរជាខ្លាំង! ស្រែកជាមួយសុភមង្គល កូនស្រីនៃក្រុងយេរូសាឡឹមអើយ! មើល៍!
ស្ដេចរបស់អ្នកគឺនឹងមកនៅជាមួយអ្នកហើយ ជាមួយសេចក្ដីសុចរិតនឹងមកសង្គ្រោះអ្នក។ ព្រះអង្គបន្ទាប់ខ្លួន ហើយព្រះអង្គគង់នៅលើខ្នងសត្វលា ខ្នងកូនលា។
[10]ហើយយើងនឹងដករទេះចេញពីស្រុកអេប្រាអ៊ីម ហើយដកសេះចេញពីក្រុងយេរូសាឡឹម និងធ្នូនឹងដកចេញពីចំបាំង
ដ្បិតព្រះអង្គនឹងមានបន្ទូលពីក្ដីសុខសាន្តចំពោះប្រជាជាតិនានា អំណាចគ្រប់គ្រង់របស់ព្រះអង្គនឹងចាប់តាំងពីសមុទ្រម្ខាងទៅសមុទ្រម្ខាង
ហើយពីទន្លេរហូតដល់ចុងផែនដី!
[11]ចំណែកអ្នកវិញ ដោយព្រោះយល់ដល់លោកហិតនៃសម្ពន្ធមេត្រីរបស់យើងចំពោះអ្នក យើងនឹងដោះលែងអ្នកទោសឲ្យមានសេរីភាពចេញពីរណ្ដៅដែលគ្មានទឹក។
[12]អ្នកទោសនៃសេចក្ដីសង្ឃឹមអើយ ចូរត្រលប់ទៅរកកំផែងដែលរឹងមាំវិញ!
ថ្ងៃនេះយើងប្រកាសថាយើងនឹងសង់អ្នកមួយជាពីរវិញ[13]ដ្បិតយើងបានធ្វើឲ្យយូដាដូចជាធ្នូរបស់យើង។ យើងបានបំពេញព្រួញរបស់យើងជាមួយអ៊ីប្រាអ៊ីម។ ស៊ីយ៉ូនអើយ
យើងបានតាស់តឿនកូនៗប្រុសរបស់អ្នក ប្រឆាំងនឹងជាមួយកូនៗប្រុសរបស់ជនជាតិក្រិក ដូចជាដាវរបស់អ្នកចំបាំង!
[14]ព្រះអម្ចាស់នឹងលេចមកពួកគេ ហើយគ្រាប់ព្រួញរបស់ព្រះអង្គនឹងបាញ់ចេញមកដូចជាផ្លេកបន្ទោរ! ដ្បិតព្រះជាម្ចាស់ដ៏ជាព្រះរបស់យើងនឹងផ្លុំត្រែ
ហើយនឹងរុលទៅមុខក្នុងព្យុះចេញពីថេម៉ាន។[15]ព្រះអម្ចាស់នៃពិភពទាំងមូលនឹងការពារពួកគេ ហើយពួកគេនឹងលាបត្របាក់ពួកគេ និងយកឈ្នះថ្មនៃខ្សែដង្ហក់។ បន្ទាប់មក
ពួកគេនឹងផឹក ហើយស្រែកដូចជាមនុស្សស្រវឹងស្រា ហើយពួកគេនឹងពេញដោយស្រាដូចជាចាន ដូចជាជ្រុងអាសនៈ។
[16]ដូច្នេះ ព្រះអម្ចាស់ជាព្រះជាម្ចាស់របស់ពួកគេនឹងសង្គ្រោះពួកគេនៅក្នុងថ្ងៃនោះ ពួកគេនឹងដូចជាហ្វូងចៀមនៃរាស្ត្ររបស់ព្រះអង្គ
ពួកគេនឹងដូចជាគ្រឿងអលង្ការនៃមកុដមួយបំពាក់លើែទឹកដីរបស់ព្រះអង្គ។[17]តើពួកគេនឹងទៅជាល្អ និងស្រស់ស្អាតយ៉ាងណាទៅ! ពួកកំលោះៗនឹងចម្រើនក្នុងការធ្វើស្រូវ
និងស្រីៗក្រមុំចម្រើនខាងស្រាទំពាំងបាយជូរដែរ!

Zechariah 9:1
នេះគឺសេចក្ដីប្រកាសរបស់ព្រះអម្ចាស់
របៀបផ្សេងទៀតនៃការបកប្រែ: «នេះគឺជាព្រះបន្ទូលរបស់ព្រះអង្គម្ចាស់អំពី»
អំពីទឹកដីរបស់ហាត្រាក និងដាម៉ាស
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជននៃទឹកដីហាត្រាក និងទីក្រុងដាម៉ាស»
ដ្បិតព្រះនេត្ររបស់ព្រះអម្ចាស់គឺនៅលើមនុស្សទាំងអស់
របៀបផ្សេងទៀតនៃការបកប្រែ: «ត្បិតព្រះអម្ចាស់កំពុងទតមើលមនុស្សទាំងអស់»
ទោះយ៉ាងណា មានជំនាន់ថ្មីជាច្រើនបកប្រែអត្ថបទគម្ពីរនេះថាជា
«ភ្នែករបស់មនុស្សលោក
និងកុលសម្ព័ន្ធអ៊ីស្រាអែលទាំងអស់ស្ថិតនៅលើព្រះអម្ចាស់»។
ក្រុងហាម៉ាត
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជននៃទឹកដីហាម៉ាត»
ទីរ៉ុស និងស៊ីដូន
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជននៃទីរ៉ុស និងស៊ីដូន»
ទោះបីជាពួកគេមានប្រាជ្ញាយ៉ាងណាក៏ដោយ
សាការីប្រហែលជាមិនមានន័យថា ប្រជាជនហាម៉ាត់ឆ្លាតនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទោះបីពួកគេគិតថាពួកគេមានប្រាជ្ញាយ៉ាងណាក៏ដោយ»
Zechariah 9:3
បានសង់កំពែងមួយដ៏រឹងមាំសម្រាប់ខ្លួន
នៅទីនេះទីក្រុងទីរ៉ុសត្រូវបានតំណាងជាស្ត្រី។ របៀបផ្សេងទៀតនៃការបកប្រែ:
«សាងសង់បន្ទាយរឹងមាំ» ឬ «បានកសាងកំផែងខ្ពស់»
បានប្រមូលប្រាក់ច្រើនដូចជាធូលីដី និងមាសល្អៗជាច្រើនដូចជាភក់នៅតាមផ្លូវ
របៀបផ្សេងទៀតនៃការបកប្រែ: «មានប្រាក់និងមាសច្រើនដូចធូលីដីនៅតាមផ្លូវ»
មើល៍! ព្រះជាម្ចាស់នឹងបំបែកពួកគេ
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរប្រុងប្រយ័ត្ន!
ព្រះអម្ចាស់នឹងដកហូតទ្រព្យសម្បត្តិរបស់ក្រុងទីរ៉ុស»
ហើយបំផ្លាញកម្លាំងនៅលើសមុទ្រ
របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងបំផ្លាញកាប៉ាល់ទីរ៉ុសដែលបុរសប្រយុទ្ធនៅលើសមុទ្រ»
ដូច្នេះហើយពួកគេនឹងលេបត្របាក់ដោយសារភ្លើងវិញ
របៀបផ្សេងទៀតនៃការបកប្រែ: «និងដុតទីក្រុងទៅដល់ដី»
Zechariah 9:5
នឹងឃើញ
«នឹងឃើញទីក្រុងទីរ៉ុសត្រូវបានបំផ្លាញ»
ជនបរទេសជាច្រើននឹងធ្វើផ្ទះពួកគេនៅក្រុងអាស្ដូឌ
របៀបផ្សេងទៀតនៃការបកប្រែ: «ជនបរទេសនឹងដណ្ដើមកាន់កាប់ក្រុងអាស្ដូឌ
ហើយរស់នៅទីនោះ»
ហើយយើងនឹងយើងបំបាត់អំនួតរបស់ពួកគេពីភីលីស្ទីន
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងធ្វើឲ្យពួកភីលីស្ទីនលែងមានមោទនភាពចំពោះខ្លួនគេទៀតហើយ»
យើងនឹងយកឈាមចេញពីមាត់របស់ពួកគេ និងដកអំពើដ៏អាក្រក់ចេញពីចន្លោះធ្មេញរបស់ពួកគេ
ទាំងនេះសំដៅទៅលើសាច់ដែលមានឈាមនៅក្នុង
និងសាច់ដែលថ្វាយដល់រូបព្រះ។ UDB ធ្វើឲ្យមានភាពច្បាស់លាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងមិនអនុញ្ញាតឲ្យពួកគេបរិភោគសាច់ដែលនៅតែមានឈាមនៅក្នុងទេ
ហើយខ្ញុំនឹងហាមឃាត់ពួកគេឲ្យបរិភោគអាហារដែលពួកគេបានថ្វាយរូបព្រះ» (UDB)
Zechariah 9:8
យើងនឹងបោះជំរុំទ័ពជុំវិញទឹកដីរបស់យើង
ព្រះកំពុងមានបន្ទូលអំពីព្រះអង្គម្ចាស់ផ្ទាល់ ដូចព្រះអង្គជាកងទ័ព។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងការពារដីរបស់យើង»
Zechariah 9:9
កូនស្រីនៃក្រុងស៊ីយ៉ូនអើយ ចូរស្រែកដោយអំណរជាខ្លាំង! ស្រែកជាមួយសុភមង្គល
កូនស្រីនៃក្រុងយេរូសាឡឹមអើយ!
ប្រយោគទាំងពីរនេះមានន័យដូចគ្នា ហើយពង្រឹងបទបញ្ជាឱ្យរីករាយ។
កូនស្រីនៃក្រុងស៊ីយ៉ូនអើយ...កូនស្រីនៃក្រុងយេរូសាឡឹមអើយ

generated on Wed Sep 10 16:16:32 2025

«ទីក្រុងស៊ីយ៉ូន» គឺដូចគ្នានឹង «ក្រុងយេរូសាឡិមដែរ»។
ព្យាការីនិយាយអំពីទីក្រុងដូចជាកូនស្រី។ សូមមើលពីរបៀបដែលអ្នកបានបកប្រែថា
«កូនស្រីស៊ីយ៉ូន» នៅក្នុងជំពូក ២:១០។
គង់នៅលើខ្នងសត្វលា ខ្នងកូនលា
ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា និងសំដៅទៅលើសត្វមួយ។
ឃ្លាទីពីរបញ្ជាក់យ៉ាងច្បាស់ថានេះគឺជាសត្វលាជំទង់។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅលើសត្វលាជំទង់»។
ដករទេះចេញពីស្រុកអេប្រាអ៊ីម
របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរបំផ្លាញរទេះចំបាំងនៅស្រុកអ៊ីស្រាអែលដែលប្រើសម្រាប់ធ្វើសឹកសង្គ្រាម»
ដកសេះចេញពីក្រុងយេរូសាឡឹម
របៀបផ្សេងទៀតនៃការបកប្រែ: «សេះនៅក្រុងយេរូសាឡិម»
ធ្នូនឹងដកចេញពីចំបាំង
នៅទីនេះធ្នូតំណាងឲ្យអាវុធទាំងអស់ដែលប្រើក្នុងសង្គ្រាម។
របៀបផ្សេងទៀតនៃការបកប្រែ: «រាល់សង្គ្រាមនឹងត្រូវបំផ្លាញ»
ដ្បិតព្រះអង្គនឹងមានបន្ទូលពីក្តីសុខសាន្តចំពោះប្រជាជាតិនានា
នៅទីនេះសកម្មភាពនៃការប្រកាសសន្តិភាពតំណាងឲ្យសកម្មភាពនៃការបង្កើតភាពសុខសាន្ត
របៀបផ្សេងទៀតនៃការបកប្រែ:
«សម្រាប់ស្តេចរបស់អ្នកនឹងនាំមកនូវសន្តិភាពដល់ប្រជាជាតិនានា»
អំណាចគ្រប់គ្រងរបស់ព្រះអង្គនឹងចាប់តាំងពីសមុទ្រម្ខាងទៅសមុទ្រម្ខាង
ហើយពីទន្លេរហូតដល់ចុងផែនដី!
រាជាណាចក្ររបស់ព្រះអង្គនឹងគ្រប់គ្រងផែនដីទាំងមូល!
Zechariah 9:11
ចំណែកអ្នកវិញ
ត្រង់ថា «អ្នក» សំដៅទៅលើប្រជាជននៃអ៊ីស្រាអែល។
ណ្តៅដែលគ្មានទឹក
រណ្តៅនេះតំណាងឱ្យការនិរទេសខ្លួន។
ចូរត្រលប់ទៅរកកំផែងដែលរឹងមាំវិញ
របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរត្រលប់ទៅប្រទេសរបស់អ្នកវិញដែលអ្នកនឹងមានសុវត្ថិភាព»
អ្នកទោសនៃសេចក្តីសង្ឃឹមអើយ
ពាក្យនេះសំដៅទៅលើជនជាតិអ៊ីស្រាអែល
ដែលនិរទេសខ្លួនដែលនៅតែទុកចិត្តលើព្រះដើម្បីសង្គ្រោះពួកគេ។
បានធ្វើឲ្យយូដាដូចជាធ្នូរបស់យើង
ប្រជាជននៅស្រុកយូដាត្រូវបានគេសំដៅថា
ពួកគេដូចជាធ្នូដែលត្រូវបានលើកយកមកដោយព្រះជាម្ចាស់ក្នុងការធ្វើសង្គ្រាម។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំនឹងប្រើប្រជាជនយូដា
ដើម្បីប្រយុទ្ធប្រឆាំងនឹងប្រជាជនក្រិក»
បានបំពេញព្រួញរបស់យើងជាមួយអ៊ីប្រាអ៊ីម
ប្រជាជនអ៊ីស្រាអែលដែលជារាជាណាចក្រខាងជើងត្រូវបានគេហៅថាជាព្រួញដែលព្រះ
ព្រួញគឺជាកាបូបដែលកាន់ព្រួញរបស់ទាហាន។
ស៊ីយ៉ូនអើយ យើងបានតាស់តឿនកូនៗប្រុសរបស់អ្នក
ប្រឆាំងនឹងជាមួយកូនៗប្រុសរបស់ជនជាតិក្រិក
ព្រះកំពុងមានបន្ទូលទៅកាន់ប្រជាជននៃប្រជាជាតិពីរផ្សេងគ្នាក្នុងពេលតែមួយ។

Zechariah 9:14
ព័ត៌មានទូទៅ៖
ផ្នែកនៃព្យាករណ៍នេះបន្តដោយពាក្យរបស់ហូសេជំនួសឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់
ដែលបានព្រះបន្ទូលតាមរយៈគាត់។
នឹងលេចមកពួកគេ
ពាក្យថា «ពួកគេ» សំដៅទៅលើរាស្ត្ររបស់ព្រះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងត្រូវបានគេមើលឃើញនៅលើមេឃដោយប្រជារាស្ត្ររបស់ព្រះអង្គ» ឬ
«នឹងមករកប្រជារាស្ត្ររបស់ទ្រង់»
នឹងបាញ់ចេញមកដូចជាផ្លេកបន្ទោរ!
ពេលខ្លះជនជាតិអ៊ីស្រាអែលគិតថា ផ្លេកបន្ទោរជាព្រួញដែលព្រះបានបាញ់។
ផ្លុំត្រែ
ត្រែគឺជាស្នែងចៀម។ ប្រជាជននឹងផ្លុំចូលទៅពួកគេ
ដើម្បីផ្តល់សញ្ញានៅក្នុងសមរភូមិ និងក្នុងឱកាសផ្សេងទៀត។
នឹងរុលទៅមុខក្នុងព្យុះចេញពីថេម៉ាន
ពេលខ្លះជនជាតិអ៊ីស្រាអែលគិតអំពីព្រះពេលកំពុងធ្វើដំណើរតាមព្យុះដ៏ខ្លាំងក្លាដែលមកពីទិសខាងត្បូង។
នឹងលាបត្របាក់
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងបរាជ័យទាំងស្រុង»
និងយកឈ្នះថ្មនៃខ្សែដង្ហក់
ជនជាតិអ៊ីស្រាអែលនឹងវាយឈ្នះពួកទាហានដែលប្រយុទ្ធដោយទះកំផ្លៀង។
ទាហានទាំងនេះតំណាងឲ្យសត្រូវទាំងអស់របស់អ៊ីស្រាអែលមិនថាពួកគេកាន់អាវុធអ្វីក៏ដោយ។
បន្ទាប់មក ពួកគេនឹងផឹក ហើយស្រែកដូចជាមនុស្សស្រវឹងស្រា
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងស្រែកអបអរសាទរចំពោះជ័យជំនះរបស់ពួកគេ ដោយស្រែកលឺៗ
ដូចជាស្រវឹងស្រា»។
ពួកគេនឹងពេញដោយស្រាដូចជាចាន
នេះប្រហែលជាសំដៅទៅលើចានដែលពួកបូជាចារ្យប្រើឈាមសត្វទៅអាសនៈ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងពេញទៅដោយស្រាទំពាំងបាយជូរដូចអាងដែលពួកបូជាចារ្យយកឈាមទៅឯអាសនៈ»
។
ដូចជាជ្រុងអាសនៈ
អាសនៈជាជ្រុងដែលប្រមូលពីឈាមសត្វ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាជ្រុងអាសនៈពេញទៅដោយឈាម»។

Zechariah 9:16
ព័ត៌មានទូទៅ៖
សាការីបន្តនិយាយទៅកាន់ប្រជាជន។
ពួកគេនឹងដូចជាគ្រឿងអលង្ការនៃមកុដមួយ
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅលើទឹកដីរបស់យើងពួកគេនឹងប្រៀបដូចជាត្បូងដ៏ស្រស់ស្អាតនៅលើមកុដ»
ពួកកំលោះៗនឹងចម្រើនក្នុងការធ្វើស្រូវ
និងស្រីៗក្រមុំចម្រើនខាងស្រាទំពាំងបាយជូរដែរ
ស្ត្រីវ័យក្មេងនឹងចូលចិត្តស្រាថ្មីៗ។ សេចក្តីយោងទាំងនេះចំពោះយុវជន
និងយុវនារីតំណាងអោយប្រជាជនអ៊ីស្រាអែលទាំងមូល។

10 [1]ចូរទូលសូមទឹកភ្លៀងពីព្រះអម្ចាស់នៅចុងរដូវ ព្រះអម្ចាស់ជាអ្នកដែលបង្កើតឲ្យមានខ្យល់ព្យុះ ហើយព្រះអង្គប្រទានទឹកភ្លៀងបរិបូរដល់មនុស្សគ្រប់គ្នា
ហើយមានរុក្ខជាតិនៅក្នុងស្រែ។[2]ចំណែក រូបព្រះក្លែងក្លាយនិយាយមិនពិត ពួកព្យាការីថ្លែងអំពីនិមិត្តហេតុក្លែងក្លាយ សប្តិក៏សម្តែងជាសេចក្តីកំភូតក៏កម្សាន្តចិត្តដោយ
សេចក្តីឥតប្រយោជន៍ដែរ ហេតុនោះបានជាគេដើរតាមផ្លូវ របស់ខ្លួនដូចជាហ្វូងចៀមរងទុក្ខ ដោយព្រោះគ្មានគង្វាល។
[3]សេចក្តីក្រោធរបស់យើងទាស់នឹងពួកអ្នកគង្វាល យើងនឹងដាក់ទោសដល់ពួកអ្នកដឹកនាំពពែឈ្មោលផងដែរ។
ព្រះអម្ចាស់នៃពិភពទាំងមូលនឹងចូលរួមដើម្បីហ្វូងចៀមរបស់ព្រះអង្គ កូនចៅយូដា ហើយព្រះអង្គនឹងធ្វើឲ្យពួកគេដូចជាសេះចំបាំងរបស់ព្រះអង្គនៅក្នុងសង្គ្រាម!
[4]នៅក្នុងចំណោមពួកគេនឹងមានអ្នកក្លាយជាសសរគ្រឹះយ៉ាងឯក ពួកគេនឹងក្លាយជាដែកគោល ពួកគេនឹងក្លាយជាធ្នូចំបាំង ពួកគេនឹងក្លាយជាអ្នកដឹកនាំទាំងអស់គ្នា។
[5]ពួកគេនឹងដូចជាអ្នកចំបាំងដែលជាន់ឈ្លីសត្រូវរបស់ពួកគេដូចជា ភក់នៅតាមផ្លូវនៅក្នុងសង្គ្រាម ពួកគេនឹងបង្កើតសង្គ្រាម ដ្បិតព្រះអម្ចាស់គឺគង់នៅជាមួយពួកគេ
ហើយពួកគេនឹងត្រូវអាម៉ាស់មុខអ្នកណាដែលជិះសេះចំបាំង។
[6]យើងនឹងពង្រឹងកម្លាំងកូនចៅយូដា និងសង្គ្រោះកូនចៅយូសែប ដ្បិតយើងនឹងស្តារពួកគេ និងមានក្តីអាណិតអាសូរលើពួកគេ។
ពួកគេនឹងក្លាយជាប្រជាជនដែលយើងមិនបានបោះបង់ចោល ដ្បិតយើងជាព្រះអម្ចាស់ ជាព្រះរបស់ពួកគេ យើងនឹងឆ្លើយតបទៅកាន់ពួកគេវិញ។[7]បន្ទាប់មក
អេប្រាអ៊ីមនឹងដូចជាអ្នកចំបាំងម្នាក់ ហើយចិត្តរបស់ពួកគេនឹងរីករាយឡើង ដូចជាបានផឹកស្រា កូនៗរបស់ពួកគេនឹងមានចិត្តរីករាយ។
ចិត្តរបស់ពួកគេនឹងរីករាយជាមួយយើង!
[8]យើងនឹងផ្លុំសម្លេងសម្រាប់ពួកគេ ហើយប្រមូលផ្តុំពួកគេ ដ្បិតយើងនឹងរំដោះពួកគេ ហើយពួកគេនឹងត្រលប់ជាចម្រើនឡើងដូចកាលពីមុន!
[9]យើងសាបព្រោះពួកគេក្នុងចំណោមមនុស្សនានា ប៉ុន្តែពួកគេនឹងចងចាំយើងពីចម្ងាយ ដូច្នេះហើយ ពួកគេ និងកូនចៅរបស់គេនឹងត្រលប់មករស់នៅវិញ។

generated on Wed Sep 10 16:16:32 2025

[10]ដ្បិតយើងនឹងស្តារពួកគេឡើងចេញពីទឹកដីអេស៊ីប និងប្រមូលផ្តុំពួកគេចេញពីអាស្ស៊ីរី។ យើងនឹងនាំពួកគេទៅស្រុកកាឡាដ និងស្រុកលីបង់
រហូតទាល់តែគ្មានកន្លែងសស់ទៀតសម្រាប់ពួកគេ។
[11]យើងនឹងដើរកាត់សមុទ្រនៃទុក្ខវេទនារបស់ពួកគេ យើងនឹងវាយទឹករលកនៃសមុទ្រនោះ ហើយនឹងសម្ងួតជម្រៅទឹកទាំងអស់នៃទន្លេនីលដែរ។
ឫទ្ធានុភាពនៃស្រុកអាស្ស៊ីរីនឹងត្រូវទម្លាក់ចុះ ហើយដំបងនៃអេស៊ីបនឹងបាត់ចេញពីជនជាតិអេស៊ីប។[12]យើងនឹងពង្រឹងពួកគេឡើងដោយយើងផ្ទាល់
ហើយពួកគេនឹងដើរនៅក្នុងនាមរបស់យើង នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។

Zechariah 10:1
ព័ត៌មានទូទៅ៖
សាការីបន្តនិយាយទៅកាន់ប្រជាជន។
បង្កើតឲ្យមានខ្យល់ព្យុះ
«ធ្វើឱ្យពពកព្យុះ»
រូបព្រះក្លែងក្លាយនិយាយមិនពិត
របៀបផ្សេងទៀតនៃការបកប្រែ: «រូបព្រះក្លែងក្លាយផ្តល់សារមិនពិត»
ពួកព្យាការីថ្លែងអំពីនិមិត្តហេតុក្លែងក្លាយ
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកព្យាការីមើលឃើញចក្ខុវិស័យមិនពិត»
សប្តិក៏សម្តែងជាសេចក្តីកំភូត
«ពួកព្យាការីថ្លែងអំពីក្តីសុបិន្តរបស់ពួកគេដើម្បីបញ្ឆោតមនុស្ស»
គេដើរតាមផ្លូវ របស់ខ្លួនដូចជាហ្វូងចៀមរងទុក្ខ
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជនមិនដឹងថាត្រូវទៅណាទេ»
Zechariah 10:3
សេចក្តីក្រោធរបស់យើងទាស់នឹងពួកអ្នកគង្វាល
«គង្វាល» តំណាងឲ្យមេដឹកនាំនៃប្រជាជនរបស់ព្រះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សេចក្តីក្រោធរបស់យើងចំពោះគង្វាលរបស់ប្រជាជនខ្ញុំគឺខ្លាំង» ឬ
«យើងខ្ញាល់យ៉ាងខ្លាំងចំពោះអ្នកដឹកនាំប្រជាជនរបស់យើង»
យើងនឹងដាក់ទោសដល់ពួកអ្នកដឹកនាំពពែឈ្មោលផងដែរ
«ពពែឈ្មោល» តំណាងឲ្យមេដឹកនាំដែលជិះជាន់។
ព្រះអម្ចាស់នៃពិភពទាំងមូលនឹងចូលរួមដើម្បីហ្វូងចៀមរបស់ព្រះអង្គ កូនចៅយូដា
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងថែរក្សាកូនចៅយូដា»
ព្រះអង្គនឹងធ្វើឲ្យពួកគេដូចជាសេះចំបាំងរបស់ព្រះអង្គនៅក្នុងសង្គ្រាម
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងផ្តល់កម្លាំងដ៏អង់អាចក្លាហានដល់ពួកគេ»
Zechariah 10:4
នៅក្នុងចំណោមពួកគេនឹងមានអ្នកក្លាយជាសសរគ្រឹះ
«មូលដ្ឋានគ្រឹះនឹងមកពីពួកគេ»។ អ្នកគ្រប់គ្រងដ៏សំខាន់ម្នាក់ត្រូវបានគេនិយាយថា
ប្រសិនបើគាត់មានថ្មគ្រឹះនៃអាគារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«កូនចៅខ្លះរបស់ពួកគេនឹងក្លាយជាអ្នកគ្រប់គ្រងដ៏សំខាន់បំផុត»
ពួកគេនឹងក្លាយជាដែកគោល
«ដែកគោលនឹងចេញពីពួកគេ»។
មេដឹកនាំសំខាន់ៗត្រូវបានគេនិយាយថាពួកគេជាប៉ែលធំដែលផ្ទុកតង់នៅនឹងកន្លែង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងក្លាយជាមេដឹកនាំដែលនឹងធ្វើឲ្យប្រទេសជាតិរួមគ្នា»
ពួកគេនឹងក្លាយជាធ្នូចំបាំង
ធ្នូចំបាំងនឹងចេញមកពីពួកគេ។
មេដឹកនាំយោធាត្រូវបានគេនិយាយដូចជាពួកគេជាធ្នូ
ដែលត្រូវបានប្រើក្នុងសមរភូមិ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងក្លាយជាមេដឹកនាំយោធា»
ពួកគេនឹងដូចជាអ្នកចំបាំង
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងខ្លាំងពូកែនៅក្នុងចំបាំង»
ដែលជាន់ឈ្លីសត្រូវរបស់ពួកគេដូចជា ភក់នៅតាមផ្លូវនៅក្នុងសង្គ្រាម
របៀបផ្សេងទៀតនៃការបកប្រែ: «ដែលកម្ចាត់សត្រូវរបស់ពួកគេទាំងស្រុង»
ហើយពួកគេនឹងត្រូវអាម៉ាស់មុខអ្នកណាដែលជិះសេះចំបាំង
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងវាយឈ្នះខ្មាំងសត្រូវរបស់ពួកគេនៅលើសេះដែលច្បាំងជាមួយនឹងពួកគេ»
Zechariah 10:6
យើងនឹងពង្រឹងកម្លាំងកូនចៅយូដា
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងធ្វើឲ្យប្រជាជនយូដាខ្លាំងពូកែ»
កូនចៅយូដា
នេះសំដៅទៅលើប្រជាជននៃព្រះរាជាណាចក្រខាងជើងនៃអ៊ីស្រាអែល។
យើងមិនបានបោះបង់ចោល
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនបានបដិសេធពួកគេទេ»
អេប្រាអ៊ីមនឹងដូចជាអ្នកចំបាំងម្នាក់
«អេប្រាអ៊ីម»
នេះសំដៅទៅលើប្រជាជននៃព្រះរាជាណាចក្រខាងជើងនៃអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ: «អេប្រាអ៊ីមនឹងខ្លាំងពូកែ»
ចិត្តរបស់ពួកគេនឹងរីករាយឡើង ដូចជាបានផឹកស្រា
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយពួកគេនឹងសប្បាយចិត្តខ្លាំងណាស់»
កូនៗរបស់ពួកគេនឹងមានចិត្តរីករាយ។ ចិត្តរបស់ពួកគេនឹងរីករាយជាមួយយើង!
របៀបផ្សេងទៀតនៃការបកប្រែ: «កូនៗ
របស់ពួកគេនឹងបានឃើញហេតុការណ៍ដែលបានកើតឡើង
ពួកគេនឹងសប្បាយរីករាយព្រោះតែព្រះអម្ចាស់បានជួយពួកគេ!»
Zechariah 10:8
យើងនឹងផ្លុំសម្លេង
ការផ្លុំសម្លេងគឺដើម្បីបង្កើតសម្លេងគ្រហឹមខ្ពស់ៗ
ដោយខ្យល់តាមរយៈបបូរមាត់តូចចង្អៀត។
ឃ្លាត្រូវបានធ្វើឡើងជាញឹកញាប់ដើម្បីផ្តល់សញ្ញាដល់មនុស្សផ្សេងទៀតដូចជានៅទីនេះ។
រហូតទាល់តែគ្មានកន្លែងសស់ទៀតសម្រាប់ពួកគេ
ប្រជាជននឹងវិលត្រឡប់ទៅស្រុកយូដាវិញ
ហើយលែងមានកន្លែងសំរាប់ប្រជាជនរស់នៅទៀត។
Zechariah 10:11
យើងនឹងដើរកាត់សមុទ្រនៃទុក្ខវេទនារបស់ពួកគេ
បទគម្ពីរច្រើនតែសំដៅលើសមុទ្រជារូបភាពនៃបញ្ហា និងការលំបាកជាច្រើន។
ហើយនឹងសម្ងួតជម្រៅទឹកទាំងអស់នៃទន្លេនីលដែរ
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងធ្វើអោយទឹកទន្លេនីលបាត់បង់ទឹកទាំងអស់»
ឫទ្ធានុភាពនៃស្រុកអាស្ស៊ីរីនឹងត្រូវទម្លាក់ចុះ
ត្រង់ថា «ឫទានុភាពនៃស្រុកអាស្ស៊ីរី» ប្រហែលជាសំដៅទៅលើកងទ័ពអាស្ស៊ីរី។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងបំផ្លាញកងទ័ពដែលមានមោទនភាពរបស់ជនជាតិអាស្ស៊ីរី»។
ហើយដំបងនៃអេស៊ីបនឹងបាត់ចេញពីជនជាតិអេស៊ីប
របៀបផ្សេងទៀតនៃការបកប្រែ:«អំណាចរបស់ស្រុកអេស៊ីបនឹងគ្រប់គ្រងលើប្រជាជាតិនានានឹងត្រូវចប់»។
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។

---

11 [1]ទឹកដីលីបង់អើយ ចូរបើទ្វាររបស់អ្នក ដ្បិតអាចមានភ្លើងឆេះដើមតាត្រៅរបស់អ្នក![2]ដើមកកោះអើយ ចូរស្រែកឲ្យអស់ទំហឹងទៅ ដ្បិតដើម តាត្រៅដួលហើយ!
ដើមឈើដ៏ល្អប្រណិតរលំអស់ហើយ! ឱដើមមៃសាក់នៅបាសានអើយ ចូរស្រែកឲ្យអស់ទំហឹងឡើង ពីព្រោះព្រៃស្រោងវិនាសអស់ហើយ។[3]ពួកគង្វាលស្រែកទ្រហោយំ
ដ្បិតសេចក្តីរុងរឿងរបស់គេត្រូវបានបំផ្លាញហើយ! សំលេងនៃសិង្ហស្ទាវស្រែកឡើង ដ្បិតអំនួតនៃទន្លេយ័រដាន់ត្រូវបានហិនហោចអស់ហើយ!
[4]នេះគឺជាអ្វីដែលព្រះអម្ចាស់ជាព្រះជាម្ចាស់របស់យើងមានព្រះបន្ទូល «ដូចអ្នកគង្វាល ឃ្វាលហ្វូងចៀមដែលទុកសម្រាប់សម្លាប់!
[5](អស់អ្នកណាដែលទិញចៀមយកទៅសម្លាប់ នោះគ្មានទោសទេ ហើយអ្នកលក់និយាយថា សូមថ្វាយព្រះពរដល់ព្រះអម្ចាស់! ខ្ញុំបានក្លាយជាអ្នកមានហើយ!
ដ្បិតពួកអ្នកគង្វាលបានធ្វើការសម្រាប់ហ្វូងចៀម គ្មានម្ចាស់ណានឹកអាណិតចៀមនោះទេ)។[6]ដ្បិតយើងនឹងមិនប្រណីដល់ប្រជាជននៅលើផែនដីទៀតទេ!

generated on Wed Sep 10 16:16:32 2025

នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ មើល៍! យើងនឹងប្រគល់ពួកគេទៅក្នុងកណ្ដាប់ដៃអ្នកជិតខាង និងស្ដេចរបស់ពួកគេ ហើយពួកគេនឹងបំផ្លាញទឹកដី
តែយើងនឹងមិនរំដោះនរណាម្នាក់ឲ្យរួចទេ»។
[7]ដូច្នេះយើងនឹងក្លាយជាអ្នកគង្វាលនៃហ្វូងចៀមដែលទុកសម្រាប់សម្លាប់នោះ គឺជាចៀមដែលវេទនាជាងគេ។ ខ្ញុំយកដំបងពីរ ដំបងមួយខ្ញុំហៅថា «ចំណងមេត្រី»
និងដំបងមួយទៀតខ្ញុំហៅថា «មិត្តភាព»។[8]នេះគឺជារបៀបដែលខ្ញុំឃ្វាលហ្វូងចៀម។ ក្នុងមួយខែខ្ញុំកម្ចាត់អ្នកគង្វាលបីនាក់ ព្រោះខ្ញុំអត់ទ្រាំនឹងពួកគេលែងបាន
ហើយពួកគេក៏ស្អប់ខ្ញុំវិញដែល។[9]បន្ទាប់មកខ្ញុំក៏និយាយទៅកាន់ម្ចាស់ថា «ខ្ញុំនឹងលែងធ្វើការជាអ្នកគង្វាលសម្រាប់អ្នកទៀតហើយ។ ចៀមដែលងាប់ ចូរឲ្យពួកគេងាប់
ចៀមណាដែលត្រូវវិនាសឲ្យពួកវាវិនាសចុះ។ ចូរឲ្យចៀមដែលនៅសល់ឲ្យវាហែកគ្នាវាស៊ីទៅ»។
[10]ដូច្នេះខ្ញុំយកដំបងរបស់ខ្ញុំ «ចំណងមេត្រី» មកកាច់បំបាក់ចោល ដើម្បីផ្តាច់សម្ពន្ធមេត្រីដែលខ្ញុំបានចង់ជាមួយពូជអំបូរខ្ញុំទាំងអស់។[11]នៅថ្ងៃនោះសម្ពន្ធមេត្រីត្រូវបែកបាក់
ហើយអស់អ្នកណាដែលវេទនាជាងគេក្នុងចៀម និងចៀមដែលមើលមកខ្ញុំនឹងបានដឹងថាព្រះអម្ចាស់បានមានព្រះបន្ទូលពិតមែន។[12]ខ្ញុំនិយាយទៅកាន់ពួកគេថា
«បើសិនមើលទៅល្អចំពោះអ្នក ចូរបង់ប្រាក់ឈ្នួលមកឲ្យខ្ញុំ។ ប៉ុន្តែ បើសិនមើលទៅមិនល្អចំពោះអ្នក មិនបាច់បង់ទេ។ «ដូច្នេះ
គេថ្លឹងប្រាក់សាមសិបស្លឹងទុកជាប្រាក់ឈ្នួលរបស់ខ្ញុំ។
[13]បន្ទាប់មក ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ចូរដាក់ប្រាក់ទៅក្នុងឃ្លាំង គឺជាតម្លៃដ៏ល្អឥតខ្ចោះដែលពួកគេឲ្យតម្លៃអ្នក!» ដូច្នេះខ្ញុំយកប្រាប់សាមសិមស្លឹង
និងដាក់ប្រាក់នេះទៅក្នុងឃ្លាំងនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។[14]បន្ទាប់មក ខ្ញុំបំបាក់ដំបងទីពីររបស់ខ្ញុំ «មិត្តភាព» ដើម្បីផ្តាច់ចំណងភាតរភាពរវាងពួកយូដា
និងពួកអ៊ីស្រាអែល។
[15]ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ចូរយកគ្រឿងប្រដាប់របស់អ្នកគង្វាលល្ងីល្ងើម្តងទៀតទៅ![16]ដ្បិតមើល៍! យើងនឹងឲ្យមានអ្នកគង្វាលមួយកើតឡើងនៅក្នុងទឹកដី។
អ្នកគង្វាលនោះនឹងមិនខ្វល់ខ្វាយចំពោះចៀមវិនាសឡើយ។ លោកនឹងមិនស្វែងរកចៀមដែលបាត់បង់ ឬព្យាបាលចៀមដែលមានរបួលឡើយ។
លោកនឹងមិនឲ្យចំណីចៀមណាដែលសុខភាពល្អទេ ប៉ុន្តែលោកនឹងបរិភោគសាច់របស់ចៀមធាត់ៗ ហើយលោកនឹងហែកក្រចករបស់ចៀមវិញ។
[17]វេទនាហើយដល់អ្នកគង្វាលគ្មានតម្លៃដែលបង់បោះហ្វូងចៀមចោល! សូមឲ្យដាវបានប្រហារដៃរបស់គេ និងភ្នែកខាងស្ដាំរបស់គេចុះ! សូមឲ្យដៃរបស់គេស្វិតលែងប្រើការ
ហើយភ្នែកខាងស្ដាំរបស់គេទៅជាខ្វាក់វិញ!»

Zechariah 11:1

ទឹកដីលីបង់អើយ ចូរបើទ្វាររបស់អ្នក ដ្បិតអាចមានភ្លើងឆេះដើមតាត្រៅរបស់អ្នក

ព្យាការីកំពុងនិយាយទៅកាន់ទឹកដីលីបង់ដូចជាមនុស្ស។

របៀបផ្សេងទៀតនៃការបកប្រែ:

«ប្រជាជននៅស្រុកលីបង់ត្រៀមភ្លើងសម្រាប់ដុតដើមតាត្រៅរបស់អ្នក»

ដើមកកោះអើយ ចូរស្រែកឲ្យអស់ទំហឹងទៅ ដ្បិតដើម តាត្រៅដួលហើយ

របៀបផ្សេងទៀតនៃការបកប្រែ:

«ប្រសិនបើដើមឈើជាមនុស្សពួកគេនឹងស្រែកយំដោយទុក្ខព្រួយ»។

ដើមតាត្រៅឈរតែឯងព្រោះដើមតាត្រៅបានឆេ និងរលំដួល។

ឱដើមមៃសាក់នៅបាសានអើយ ចូរស្រែកឲ្យអស់ទំហឹងឡើង ពីព្រោះព្រៃស្រោងវិនាសអស់ហើយ

របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើដើមមៃសាក់នៅស្រុកបាសានជាមនុស្ស
ពួកគេនឹងយំព្រោះព្រៃក្រាស់របស់ពួកគេត្រូវបានកាប់បំផ្លាញ»។

ពួកគង្វាលស្រែកទ្រហោយំ

របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគង្វាលស្រែកទ្រហោយំយ៉ាងខ្លាំង»

ដ្បិតសេចក្ដីរុងរឿងរបស់គេត្រូវបានបំផ្លាញហើយ

«ភាពរុងរឿងរបស់ពួកគេ» ប្រហែលជាតំណាងឲ្យវាលស្មៅសម្បូរបែប
ដែលពួកគង្វាលបានដឹកនាំចៀមរបស់ពួកគេទៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សម្រាប់វាលស្មៅសម្បូរបែបរបស់ពួកគេត្រូវបានបំផ្លាញ»។

ដ្បិតអំនួតនៃទន្លេយ័រដាន់ត្រូវបានហិនហោចអស់ហើយ

របៀបផ្សេងទៀតនៃការបកប្រែ: «ពីព្រោះដើមឈើ
និងដើមឈើតូចៗដែលពួកគេរស់នៅក្បែរទន្លេយ័រដាន់ត្រូវបានបំផ្លាញ»។

Zechariah 11:4

ព័ត៌មានទូទៅ៖

នៅទីនេះព្រះអម្ចាស់ចាប់ផ្តើមណែនាំដល់លោកសាការីជាទម្រង់នៃរឿងប្រៀបប្រដូចអំពីអ្នកគង្វាល
និងចៀម។

ប្រជាជននៅលើផែនដីទៀតទេ

«ប្រជាជននៃទឹកដីនេះ»

នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់

ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង
UDB។

អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។

ប្រគល់ពួកគេទៅក្នុងកណ្ដាប់ដៃអ្នកជិតខាង

របៀបផ្សេងទៀតនៃការបកប្រែ:

«អនុញ្ញាតឲ្យមនុស្សម្នាក់ៗត្រូវបានគ្រប់គ្រងដោយមនុស្សម្នាក់ទៀត»

ក្នុងកណ្ដាប់ដៃស្ដេច

របៀបផ្សេងទៀតនៃការបកប្រែ: «ចូលទៅក្នុងការគ្រប់គ្រងអយុត្តិធម៌របស់ស្ដេច»

ពួកគេនឹងបំផ្លាញទឹកដី

របៀបផ្សេងទៀតនៃការបកប្រែ:

«ពួកគេនឹងលែងមានចិត្តមេត្តាករុណាចំពោះប្រជាជនរបស់ស្រុកនេះ»

តែយើងនឹងមិនរំដោះនរណាម្នាក់ឲ្យរួចទេ

របៀបផ្សេងទៀតនៃការបកប្រែ:

«ប៉ុន្តែយើងនឹងមិនរំដោះប្រជាជនយូដាពីអំណាចរបស់ពួកគេទេ»

Zechariah 11:7

ព័ត៌មានទូទៅ៖

រឿងប្រៀបប្រដូចអំពីអ្នកគង្វាលនិងចៀមនៅតែបន្ត។

ហ្វូងចៀមដែលទុកសម្រាប់សម្លាប់

«ហ្វូងចៀមដែលត្រូវបានបម្រុងទុកសម្រាប់សម្លាប់»។

ដំបង

ដំបង

គឺជាដំបងឈើដែលត្រូវបានប្រើសម្រាប់គោលបំណងផ្សេងៗរួមទាំងអ្នកដឹកនាំចៀម។
ដំបងអាចមានប្រភេទផ្សេងៗគ្នានៃទំពក់នៅចុង។

ចំណងមេត្រី

ការបកប្រែផ្សេងៗក៏ដូចបកប្រែពាក្យហេព្រើរនៅក្នុងអត្ថបទនេះថា «ព្រះគុណ» និង
«សម្រស់»។

មិត្តភាព

នេះគឺជាគំនិតនៃភាពជាបងប្អូនរវាងផ្នែកទាំងពីរនៃ
អ៊ីស្រាអែលគឺរាជាណាចក្រខាងជើង និងខាងត្បូង។

ព្រោះខ្ញុំអត់ទ្រាំនឹងពួកគេលែងបាន

របៀបផ្សេងទៀតនៃការបកប្រែ:

«ខ្ញុំមិនអាចទ្រាំនឹងម្ចាស់ចៀមដែលបានជួលខ្ញុំបានទេ»។

Zechariah 11:10

ព័ត៌មានទូទៅ៖

រឿងប្រៀបប្រដូចអំពីអ្នកគង្វាល និងចៀមនៅតែបន្ត។

មកកាច់បំបាក់ចោល ដើម្បីផ្តាច់សម្ពន្ធមេត្រីដែលខ្ញុំបានចង់ជាមួយពូជអំបូរខ្ញុំទាំងអស់

ព្យាការីកំពុងនិយាយហើយធ្វើសកម្មភាពសំរាប់ព្រះអម្ចាស់នៅទីនេះ។

មានព្រះបន្ទូល

របៀបផ្សេងទៀតនៃការបកប្រែ: «បាននិយាយសារទៅកាន់ពួកគេ»

ថ្លឹងប្រាក់សាមសិបស្លឹង

ប្រាក់ ៣៣០ ក្រាម។ មួយដុំមានទម្ងន់ដប់មួយក្រាម។

Zechariah 11:13

ព័ត៌មានទូទៅ៖

រឿងប្រៀបប្រដូចអំពីអ្នកគង្វាល និងចៀមនៅតែបន្ត។

ឃ្លាំង

ឃ្លាំងនៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់

គឺជាតម្លៃដ៏ល្អឥតខ្ចោះ

នេះមានន័យថាការនិយាយពីតម្លៃនេះតូចណាស់សម្រាប់អ្នកគង្វាលដែលធ្វើកិច្ចការរបស់ព្រះអម្ចាស់។
សូមមើល UDB ដែលដកចេញនូវភាពមិនត្រឹមត្រូវ៖

generated on Wed Sep 10 16:16:32 2025

«ចំនួនទឹកប្រាក់តិចតួចគួរឲ្យអស់សំណើច»។
ថ្លឹងប្រាក់សាមសិបស្លឹង
ប្រាក់ ៣៣០ ក្រាម។ មួយដុំមានទម្ងន់ដប់មួយក្រាម។
Zechariah 11:15
ព័ត៌មានទូទៅ៖
រឿងប្រៀបប្រដូចអំពីអ្នកគង្វាល និងចៀមនៅតែបន្ត។
ចៀមធាត់ៗ
ចៀមដែលមានសុខភាពល្អ និងលូតលាស់បានល្អ
នឹងហែកក្រចករបស់ចៀមវិញ
ប្រហែលជាសកម្មភាពនៃភាពសាហាវឃោរឃៅ
Zechariah 11:17
ព័ត៌មានទូទៅ៖
រឿងប្រៀបប្រដូចអំពីអ្នកគង្វាល និងចៀមនៅតែបន្ត។
វេទនាហើយដល់អ្នកគង្វាលគ្មានតម្លៃ
របៀបផ្សេងទៀតនៃការបកប្រែ:
«តើការសោកសៅអ្វីដែលរង់ចាំដល់អ្នកគង្វាលដែលគ្មានតម្លៃនេះ»
បានប្រហារដៃរបស់គេ និងភ្នែកខាងស្តាំរបស់គេចុះ
របៀបផ្សេងទៀតនៃការបកប្រែ: «របួសដៃខាងស្តាំ និងចោះភ្នែកខាងស្តាំរបស់គេ!»
សូមឲ្យដាវបានប្រហារ
«ដាវ» នៅទីនេះតំណាងឲ្យសត្រូវដែលនឹងវាយប្រហារអ្នកគង្វាល។
ដៃរបស់គេ
អំណាចរបស់គេដើម្បីប្រយុទ្ធប្រឆាំង
ភ្នែកខាងស្តាំរបស់គេ
គាត់មានសមត្ថភាពដើម្បីមើលពេលកំពុងប្រយុទ្ធ។

---

12 [1]នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ថ្លែងអំពីទឹកដីអ៊ីស្រាអែល ព្រះអម្ចាស់ជាព្រះដែលបានលាតស្ទឹងផ្ទៃមេឃ និងចាក់គ្រឹះផែនដី
ជាព្រះដែលបង្កើតវិញ្ញាណនៅក្នុងខ្លួនមនុស្ស មានព្រះបន្ទូលថា[2]«មើល៍!
យើងជាអ្នកធ្វើឲ្យក្រុងយេរូសាឡឹមទៅក្នុងពែងបណ្តាលឲ្យប្រជាជនដែលនៅជុំវិញក្រុងភ្ញាក់ផ្អើល។
ការនេះនឹងដូចជាពេលដែលជនជាតិយូដាឡោមព័ទ្ធប្រឆាំងនឹងក្រុងយេរូសាឡឹមដែរ។[3]នៅក្នុងថ្ងៃនោះ យើងនឹងបង្កើតថ្មដែលធ្ងន់ឲ្យក្រុងយេរូសាឡឹមដល់ប្រជាជនគ្រប់គ្នា។
អ្នកណាមួយដែលព្យាយាមលើកថ្មនោះនឹងឈឺចាប់ខ្លួនឯងវិញយ៉ាងខ្លាំង ហើយប្រជាជាតិទាំងអស់នៅលើផែនដីនឹងប្រមូលផ្តុំគ្នាប្រឆាំងនឹងទីក្រុងនោះវិញ។
[4]ព្រះអម្ចាស់មានព្រះបន្ទូលថា នៅក្នុងថ្ងៃនោះយើងនឹងប្រហារទាំងអស់ណាដែលភ័យខ្លាំង និងអស់ទាំងអ្នកជិះសេះណាដែលឆ្កួតលីលា។
យើងនឹងពេញចិត្តលើសេះរបស់ក្រុងយេរូសាឡឹមដែលនឹងប្រហារអស់ទាំងសេះរបស់កងទ័ពណាដែលខ្វាក់។[5]បន្ទាប់មក
ពួកមេដឹកនាំរបស់យូដានឹងនិយាយនៅក្នុងចិត្តរបស់ពួកគេថា ប្រជាជននៃក្រុងយេរូសាឡឹមជាកម្លាំងរបស់ពួកយើង ព្រោះព្រះអម្ចាស់នៃពិភពទាំងមូលជាព្រះរបស់ពួកគេ។
[6]នៅថ្ងៃនោះ យើងនឹងបង្កើតមេដឹកនាំនៃពួកយូដាដូចជា ធើងភ្លើងនៅកណ្តាលឈើ និងដូចជាភ្លើងពិលនៅកណ្តាលស្រូវឈរ
ដ្បិតពួកគេនឹងប្រើប្រាស់ប្រជាជននៅជុំវិញទាំងអស់នៅខាងឆ្វាង និងខាងស្តាំ។ ក្រុងយេរូសាឡឹមនឹងរស់នៅក្នុងទីក្រុងរបស់ខ្លួនវិញ»។
[7]ព្រះអម្ចាស់នឹងសង្គ្រោះត្រសាលរបស់ពួកយូដាជាមុន ដូច្នេះហើយកិត្តិយសរបស់កូនចៅរបស់ព្រះបាទដាវិឌ
និងកិត្តិយសរបស់អ្នកដែលរស់នៅក្រុងយេរូសាឡឹមមិនអាចធំជាងពួកយូដានោះទេ។[8]នៅថ្ងៃនោះ ព្រះអម្ចាស់នឹងធ្វើជាអ្នកការពាររបស់ប្រជាជនរបស់ក្រុងយេរូសាឡឹម
ហើយនៅថ្ងៃនៅក្នុងចំណោមពួកគេនោះអស់អ្នកណាដែលខ្សោយនោះនឹងបានដូចជាព្រះបាទដាវិឌ ហើយពូជពង្សរបស់ព្រះបាទដាវិឌនឹងបានដូចជាព្រះ
ដូចជាទេវតានៃព្រះអម្ចាស់នៅពីមុខពួកគេ។[9]នៅថ្ងៃនោះយើងនឹងចាប់ផ្តើមបំផ្លាញប្រជាជាតិទាំងអស់ណាប្រឆាំងនឹងក្រុងយេរូសាឡឹម។
[10]ប៉ុន្តែ យើងនឹងចាក់បង្ហូរវិញ្ញាណនៃសេចក្តីមេត្តា និងទូលអង្វរដល់ពូជពង្សរបស់ព្រះបាទដាវិឌ ហើយនិងប្រជាជនរបស់ក្រុងយេរូសាឡឹម
ដូច្នេះហើយពួកគេនឹងមើលមកយើង ជាម្នាក់ដែលពួកគេបានចាក់ទំលុះ។ ពួកគេនឹងកាន់ទុក្ខសម្រាប់ខ្ញុំ ដូចជាមនុស្សម្នាក់ដែលកាន់ទុក្ខសម្រាប់កូនប្រុសរបស់គាត់តែមួយ
ពួកគេនឹងសោកសង្រេងយ៉ាងឈឺផ្សាសម្រាប់ព្រះអង្គ ដូចជាគេសោកសង្រេងការស្លាប់របស់កូនប្រុសច្បង។
[11]នៅថ្ងៃនោះទុក្ខសោកនៅក្រុងយេរូសាឡឹមនឹងបានដូចជាទុក្ខសោក ព្រះហាដាដ រីម៉ូននៅវាលមេគីដោ។
[12]ផែនដីនឹងត្រូវកាន់ទុក្ខ អំបូរនីមួយៗបែងចែកចេញពីអំបូរផ្សេងៗទៀត។ អំបូររបស់ព្រះបាទដាវិឌនឹងត្រូវបែងចែកចេញពីគ្នា
ហើយប្រពន្ធរបស់ពួកគេនឹងត្រូវបែងចែកដោយឡែកពីបុរស។[13]អំបូររបស់កូនចៅលេវីនឹងត្រូវបែងចែកដោយឡែក
ហើយប្រពន្ធរបស់ពួកគេនឹងត្រូវចែកដោយឡែកពីបុរស។ អំបូររបស់ស៊ីម៉ែ នឹងត្រូវបែងចែកដោយឡែក ហើយប្រពន្ធរបស់ពួកគេនឹងត្រូវចែកដោយឡែកពីបុរស។
[14]គ្រប់អំបូរទាំងអស់ដែលសល់ពី អំបូរនីមួយៗនោះនឹងត្រូវបែងចែកដោយឡែក និងប្រពន្ធនឹងត្រូវចែកចេញដោយឡែកពីបុរសដែរ»។

Zechariah 12:1
ព័ត៌មានទូទៅ៖
ខគម្ពីរទាំងនេះចាប់ផ្តើមផ្នែកដែលប្រាប់អំពីការវាយប្រហារ
ដែលកំពុងកើតឡើងប្រឆាំងនឹងក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុង។
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
ដែលបានលាតស្ទឹងផ្ទៃមេឃ
«ព្រះអម្ចាស់ដែលបានបង្កើតផ្ទៃមេឃ»
ចាក់គ្រឹះផែនដី
របៀបផ្សេងទៀតនៃការបកប្រែ: «ដាក់ផែនដីទាំងមូល»
ដែលបង្កើតវិញ្ញាណនៅក្នុងខ្លួនមនុស្ស
របៀបផ្សេងទៀតនៃការបកប្រែ: «បង្កើតវិញ្ញាណមនុស្ស»
ពែង
«ពែងសម្រាប់ដាក់ផឹករបស់អ្វីមួយ»
បណ្តាលឲ្យប្រជាជនដែលនៅជុំវិញក្រុងភ្ញាក់ផ្អើល
នោះគឺភេសជ្ជៈមានជាតិអាល់កុល
ហើយនឹងធ្វើឲ្យកងទ័ពវាយប្រហារក្រុងយេរូសាឡឹមស្រវឹង
ហើយមិនអាចប្រយុទ្ធបាន។
ក្រុង
នោះគឺទីក្រុងយេរូសាឡិម។
ជារឿងធម្មតានៅក្នុងភាសាហេព្រើរក្នុងការនិយាយអំពីទីក្រុងឬប្រទេសមួយដូចជាស្ត្រី។
ថ្មដែលធ្ងន់ដល់ប្រជាជនគ្រប់គ្នា
«អ្វីដែលមិនអាចទៅរួចដើម្បីផ្លាស់ទី»
Zechariah 12:4
ព័ត៌មានទូទៅ៖
ខគម្ពីរទាំងនេះចាប់ផ្តើមផ្នែកដែលប្រាប់អំពីការវាប្រហារ
ដែលកំពុងកើតឡើងប្រឆាំងនឹងក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុង។
នៅក្នុងថ្ងៃនោះ
នេះសំដៅទៅលើថ្ងៃដែលកងទ័ពវាយលុកក្រុងយេរូសាឡិម។
ព្រះអម្ចាស់មានព្រះបន្ទូលថា
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
យើងនឹងពេញចិត្តលើ
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងការពារ»
កូនចៅយូដា
«ប្រជាជនយូដា»
និយាយនៅក្នុងចិត្តរបស់ពួកគេថា

generated on Wed Sep 10 16:16:32 2025

នេះមានន័យថាពួកគេនឹងគិត ហើយនិយាយទៅកាន់ខ្លួនឯង។
ព្រោះព្រះអម្ចាស់នៃពិភពទាំងមូល
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រោះពួកគេថ្វាយបង្គំព្រះអម្ចាស់នៃពិភពទាំងមូល»
Zechariah 12:6
ព័ត៌មានទូទៅ៖
ខគម្ពីរទាំងនេះចាប់ផ្តើមផ្នែកដែលប្រាប់អំពីការរាយប្រហារដែលកំពុងកើតឡើងប្រឆាំងនឹងក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុង។
នៅថ្ងៃនោះ
នេះសំដៅទៅលើពេលវេលាដែលក្រុងយេរូសាឡិមត្រូវបានវាយប្រហារ
ហើយព្រះបានកម្ចាត់សត្រូវរក្រុងនោះ។
ដូចជា ធើងភ្លើងនៅកណ្តាលឈើ...ស្រូវឈរ
«ដូចជាធើងភ្លើងក្នុងចំណោមអុស... គល់ឈើគ្មានគ្រាប់ដែលឈរនៅវាលស្រែ»
ធើងភ្លើង
ធើងដីឥដ្ឋដែលប្រជាជនពីបុរាណតែងតែដុតធ្យូង
ភ្លើងពិល
ដំបងឈើមួយដែលកំពុងឆេះនៅចុងម្ខាងដែលផ្តល់ពន្លឺនៅពេលអ្នកធ្វើដំណើរឬយកទៅដាក់ក្នុងភ្លើងដើម្បីដុត
នឹងប្រើប្រាស់ប្រជាជននៅជុំវិញទាំងអស់
«នឹងបំផ្លាញប្រជាជននៅជុំវិញទាំងអស់»
ក្រុងយេរូសាឡឹមនឹងរស់នៅក្នុងទីក្រុងរបស់ខ្លួនវិញ
ប្រជាជននៅក្រុងយេរូសាឡឹមនឹងរស់នៅក្នុងក្រុងរបស់ពួកគេវិញ។
Zechariah 12:7
ព័ត៌មានទូទៅ៖
ខគម្ពីរទាំងនេះចាប់ផ្តើមផ្នែកដែលប្រាប់អំពីការរាយប្រហារដែលកំពុងកើតឡើងប្រឆាំងនឹងក្រុងយេរូសាឡិម
ត្រសាលរបស់ពួកយូដា

ត្រង់ថា «ត្រសាល» តំណាងឲ្យផ្ទះ ហើយផ្ទះតំណាងឲ្យដែលរស់នៅក្នុងផ្ទះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជននៅស្រុកយូដា»។
កូនចៅរបស់ព្រះបាទដាវីឌ
អាចមានន័យថាទី ១) កូនចៅរបស់ដាវីឌ ឬ ទី២) ក្រុមមនុស្សដែលកំពុងគ្រប់គ្រង។
ទេវតានៃព្រះអម្ចាស់
នេះគឺជាទេវតាដែលព្រះអម្ចាស់បានចាត់មកដើម្បីការពារប្រជាជន។
ខគម្ពីរទាំងនេះចាប់ផ្តើមផ្នែកដែលប្រាប់អំពីការរាយប្រហារដែលកំពុងកើតឡើងប្រឆាំងនឹងក្រុងយេរូសាឡិម
យើងនឹងចាក់បង្ហូរវិញ្ញាណនៃសេចក្តីមេត្តា និងទូលអង្វរ
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំនឹងផ្តល់ឲ្យប្រជាជននូវស្មារតី
ដើម្បីអាណិតអាសូរអ្នកដទៃ និងអធិស្ឋានដល់ខ្ញុំសម្រាប់សេចក្តីមេត្តាករុណា»
ជាម្នាក់ដែលពួកគេបានចាក់ទំលុះ
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលគេចាក់សម្លាប់»
ទុក្ខសោកនៅក្រុងយេរូសាឡឹមនឹងបានដូចជាទុក្ខសោក ព្រះហាដាដ រីម៉ូន
ហាដាដរីម៉ូនប្រហែលជាកន្លែងដែលស្តេចយ៉ូសៀសបានស្លាប់ដោយសាររបួសក្នុងសមរភូមិបន្ទាប់ពីសង្គ្រា
ទំនៀមទម្លាប់បានកើតឡើង
ដើម្បីកាន់ទុក្ខជាទៀងទាត់នៅទីនោះចំពោះមរណភាពរបស់គាត់។
ដោយសារតែការយំសោកយ៉ាងខ្លាំងនៅទីនោះ ពួកគេបានដាក់ឈ្មោះកន្លែងនោះថា
បានស្លាប់ជារៀងរាល់ឆ្នាំជាព្រឹត្តិការណ៍មួយដែលអ្នកគោរពបូជារបស់គាត់នឹងកាន់ទុក្ខ។
មេគីដោ
នេះគឺជាឈ្មោះនៃវាលទំនាបនៅអ៊ីស្រាអែល។ .
Zechariah 12:12
ផែនដី
នេះសំដៅទៅលើប្រជាជនទាំងអស់កំពុងរស់នៅក្នុងទឹកដីយូដា។
នឹងក្រុងយេរូសាឡឹមនិងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុង។
កូនចៅរបស់ព្រះបាទដាវីឌ...ណាថាន...លេវី។

---

13 [1]«នៅថ្ងៃនោះប្រភពទឹកនឹងត្រូវបើកសម្រាប់ពូជពង្សរបស់ព្រះបាទដាវីឌ និងប្រជាជនក្រុងយេរូសាឡឹម សម្រាប់អំពើបាប និងអំពើសៅហ្មងរបស់ពួកគេ។[2]នៅថ្ងៃនោះ
យើងនឹងកាត់ផ្តាច់ឈ្មោះរបស់ព្រះក្លែងក្លាយចេញពីទឹកដី ដូច្នេះពួកគេនឹងមិនអាចចាំតទៅទៀតឡើយ នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។
យើងនឹងធ្វើឲ្យពួកព្យាការីក្លែងក្លាយ និងវិញ្ញាណមិនបរិសុទ្ធរបស់ពួកគេចេញពីទឹកដីផងដែរ។
[3]ប្រសិនបើអ្នកណាម្នាក់នៅតែបន្តទាយទៀត នោះឪពុក និងម្តាយដែលបង្កើតគេនឹងនិយាយប្រាប់គេថា «អ្នកនឹងមិនអាចរស់ទេ
ពីព្រោះអ្នកនិយាយកុហកនៅក្នុងព្រះនាមរបស់ព្រះអម្ចាស់! បន្ទាប់មកឪពុក និងម្តាយដែលបង្កើតលោកនឹងចាក់ទំលុះគេនៅពេលគាត់ប្រកាសព្រះបន្ទូលរបស់ព្រះ។
[4]នៅថ្ងៃនោះ ព្យាការីនីមួយៗនឹងត្រូវអាម៉ាសវិញ ព្រោះតែនិមិត្តរបស់ពួកគេពេលដែលប្រកាសព្រះបន្ទូលរបស់ព្រះ។ ពួកព្យាការីទាំងអស់នេះនឹងមិនអាចពាក់អាវរោមសត្វ
ដើម្បីបោកបញ្ឆោតមនុស្សបានទៀតទេ។[5]ដ្បិតម្នាក់ៗនឹងនិយាយថា «ខ្ញុំមិនជាព្យាការីទេ! ខ្ញុំគឺជាមនុស្សដែលអ្នកស្រែ
ធ្វើស្រែជាការងាររបស់ខ្ញុំតាំងពីខ្ញុំនៅកំលោះមកម្ល៉េះ![6]បុ៉ន្តែគេនឹងនិយាយមកគាត់ថា តើស្នាមរបួសនៅលើទ្រូងរបស់អ្នកគឺជាអ្វី៉? ហើយគាត់នឹងឆ្លើយថា
ខ្ញុំមានរបួសនៅក្នុងផ្ទះមិត្តភក្តិរបស់ខ្ញុំ»។
[7]«ដាវអើយ! ចូរភ្ញាក់ឡើងប្រឆាំងនឹងអ្នកគង្វាលរបស់យើង ជាមនុស្សដែលឈរនៅក្បែរយើង នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។ ចូរប្រហារអ្នកគង្វាល
ហើយហ្វូងចៀមនឹងខ្ចាត់ខ្ចាយ! ដ្បិតយើងនឹងបែរដៃរបស់យើងប្រហារចៀមតូចៗវិញ។
[8]បន្ទាប់មក នៅទឹកដីទាំងមូល មនុស្សពីរភាគបីនឹងត្រូវវិនាសអស់! ហើយមានមនុស្សតែមួយភាគបីដែលនឹងនៅសល់ នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[9]យើងនឹងនាំមនុស្សមួយភាគបីនោះទៅដាក់ក្នុងភ្លើង ហើយសម្រិតសម្រាំងពួកគេដូចជាប្រាក់ដែលស្លរហើយ
យើងនឹងសាកល្បងពួកគេដូចជាមាសដែលសាកល្បងហើយ។ ពួកគេនឹងហៅឈ្មោះរបស់យើង ហើយយើងនឹងឆ្លើយទៅកាន់ពួកគេថា «នេះគឺជាប្រជារាស្ត្ររបស់យើង!»
ហើយពួកគេនឹងនិយាយថា «ព្រះអម្ចាស់គឺជាព្រះរបស់ពួកយើងខ្ញុំ!»

Zechariah 13:1
ប្រភពទឹក
ជាកន្លែងដែលទឹកហូរចេញពីដី។
សម្រាប់អំពើបាប និងអំពើសៅហ្មងរបស់ពួកគេ
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីលាងសម្អាតអំពើបាប
និងអំពើសៅហ្មងរបស់ពួកគេ»
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
កាត់ផ្តាច់ឈ្មោះរបស់ព្រះក្លែងក្លាយចេញពីទឹកដី
របៀបផ្សេងទៀតនៃការបកប្រែ: «លុបការថ្វាយបង្គំរូបព្រះនៅពាសពេញស្រុក»
យើងនឹងធ្វើឲ្យពួកព្យាការីក្លែងក្លាយ និងវិញ្ញាណមិនបរិសុទ្ធរបស់ពួកគេចេញពីទឹកដីផងដែរ
របៀបផ្សេងទៀតនៃការបកប្រែ: «យើងក៏នឹងដកព្យាការីក្លែងក្លាយ
និងវិញ្ញាណអាក្រក់របស់គេចេញពីស្រុកដែរ»។
Zechariah 13:3
ឪពុក និងម្តាយដែលបង្កើតគេ
ឃ្លាថា «ដែលបង្កើតគេ» ពណ៌នាអំពី «ឪពុក និងម្តាយរបស់គេ»
ដើម្បីបង្ហាញពីការភ្ញាក់ផ្អើលដែលឪពុកម្តាយផ្ទាល់របស់នរណាម្នាក់នឹងប្រព្រឹត្តចំពោះគេតាមរបៀបនេះ។
អ្នកនឹងមិនអាចរស់ទេ
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកនឹងត្រូវស្លាប់»
នឹងចាក់ទំលុះ
«ចាក់សម្លាប់គាត់»។
Zechariah 13:4
ព្យាការីនីមួយៗ
នេះសំដៅទៅលើព្យាការីក្លែងក្លាយ គឺមិនមែនព្យាការីរបស់ព្រះអម្ចាស់ទេ។
មិនអាចពាក់អាវរោមសត្វ
រោមសត្វ សំដៅទៅលើសម្លៀកបំពាក់ខាងក្រៅធ្ងន់។
ធ្វើពីរោមសត្វដែលពួកព្យាការីតែងតែពាក់។
អ្នកស្រែ
នោះគឺ «កសិដ្ឋាន»។

generated on Wed Sep 10 16:16:32 2025

ធ្វើស្រែជាការងាររបស់ខ្ញុំតាំងពីខ្ញុំនៅកំលោះមកម្ល៉េះ
កំណែសម័យទំនើបខ្លះបកប្រែអត្ថបទភាសាហេព្រើរនេះថាជា
«បុរសម្នាក់ដែលទទួលខ្ញុំតាំងពីខ្ញុំនៅក្មេង»។ នោះគឺជាការទទួលគាត់ជាអ្នកបំរើ។
តើស្នាមរបួសនៅលើទ្រូងរបស់អ្នកគឺជាអ្វី?
របៀបផ្សេងទៀតនៃការបកប្រែ:
«តើអ្នកទទួលបានស្នាមរបួសនៅលើទ្រូងរបស់អ្នកយ៉ាងដូចម្តេច?»
នេះសំដៅទៅលើទំនៀមទម្លាប់ជាក់ស្តែងរបស់ព្យាការីក្លែងក្លាយ
ដែលធ្វើបាបខ្លួនឯងនៅក្នុងពិធីរបស់ពួកគេ។
គាត់នឹងឆ្លើយថា
នោះគឺ គាត់នឹងឆ្លើយដោយពាក្យកុហក។
Zechariah 13:7
ដាវអើយ! ចូរភ្ញាក់ឡើង
របៀបផ្សេងទៀតនៃការបកប្រែ: «ដាវអើយ! អ្នកត្រូវតែភ្ញាក់ឡើង»។
នេះជាបទបញ្ជារបស់ព្រះអម្ចាស់សំរាប់អោយអ្នកគង្វាលរបស់គេវាយប្រហារ
និងសម្លាប់ចោល។
ប្រឆាំងនឹងអ្នកគង្វាលរបស់យើង
នេះសំដៅទៅលើស្តេចមួយអង្គឬអ្នកបំរើណាម្នាក់របស់ព្រះអម្ចាស់។
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូល» នៅក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
ហ្វូងចៀម
«ហ្វូងចៀម» នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
ចៀមតូចៗ
នេះប្រហែលជាសំដៅទៅលើជនជាតិអ៊ីស្រាអែលទាំងអស់ដែលខ្សោយ
និងមិនចេះការពារ។
Zechariah 13:8
នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
ឃ្លានេះត្រូវបានបកប្រែជាញឹកញាប់ថា «ព្រះអម្ចាស់មានព្រះបន្ទូលថា» ក្នុង
UDB។
អ្នកអាចបកប្រែអត្ថន័យនេះតាមវិធីណាដែលល្អបំផុតនៅក្នុងភាសារបស់អ្នក។
ឃ្លានេះត្រូវបានប្រើជាច្រើនដងនៅក្នុងកាន់គម្ពីរសាការី។
យើងនឹងនាំមនុស្សមួយភាគបីនោះទៅដាក់ក្នុងភ្លើង
លោហៈធាតុត្រូវបានឆ្លងកាត់ភ្លើងដើម្បីបន្សុទ្ធ ឬរឹង។
ឃ្លានេះប្រើជាពាក្យប្រៀបធៀបសម្រាប់បង្ហាញឲ្យមនុស្សរងទុក្ខវេទនា
ដើម្បីឲ្យពួកគេកាន់តែស្មោះត្រង់នឹងព្រះ។
សម្រិតសម្រាំងពួកគេដូចជាប្រាក់ដែលស្រូរហើយ យើងនឹងសាកល្បងពួកគេដូចជាមាស
ការបន្សុតសំដៅទៅលើការធ្វើលោហៈដ៏មានតម្លៃដូចជាប្រាក់សុទ្ធ។
លោហៈធាតុដូចជាប្រាក់ និងមាសត្រូវបានសាកល្បង ដើម្បីដឹងថាតើវាសុទ្ធ
ឬរឹងមាំប៉ុណ្ណា។ ទាំងការចម្រាញ់
និងការសាកល្បងគឺជាឧទាហរណ៍នៃការធ្វើឲ្យប្រជាជនកាន់តែស្មោះត្រង់នឹងព្រះ។

14 [1]មើល៍! ថ្ងៃរបស់ព្រះអម្ចាស់នឹងមកដល់ នៅពេលដែលចោរប្លន់ដណ្តើមរបស់អ្នកនឹងចែកគ្នានៅកណ្តាលអ្នក។[2]ដ្បិតយើងនឹងប្រមូលគ្រប់ប្រជាជាតិ
ប្រឆាំងនឹងក្រុងយេរូសាឡិម ដើម្បីធ្វើសង្គ្រាម ហើយទីក្រុងនឹងត្រូវគេយកបាន។ ផ្ទះសំបែងជាច្រើននឹងត្រូវប្លន់ដណ្តើមយក ហើយស្រីៗនឹងត្រូវគេរំលោភ។
មនុស្សពាក់កណ្តាលក្រុងនឹងកៀរទៅជាឈ្លើយ ប៉ុន្តែប្រជាជនដែលនៅនៅសល់នឹងមិនបានបណ្តេញចេញពីទីក្រុងទេ។
[3]ប៉ុន្តែ ព្រះអម្ចាស់នឹងយាងចេញមក ហើយប្រកាសសង្គ្រាមប្រឆាំងនឹងប្រជាជាតិទាំងនោះ ដូចជាព្រះអង្គប្រកាសសង្គ្រាមនៅក្នុងថ្ងៃចម្បាំង។[4]នៅក្នុងថ្ងៃនោះ
ព្រះបាទនៃព្រះអម្ចាស់នឹងឈរនៅលើភ្នំអូលីវ ដែលនៅក្បែរក្រុងយេរូសាឡឹមនៅភាគខាងកើត។ ភ្នំអូលីវនឹងត្រូវពុះពាក់កណ្តាលនៅចន្លោះខាងកើត
និងលិចក្បែរជ្រលងភ្នំដ៏ធំ ហើយពាក់កណ្តាលទៀតនឹងត្រូវត្រលប់ឆ្ពោះទៅរកទិសខាងជើង និងម្ខាងទៀតទៅទិសខាងត្បូង។
[5]បន្ទាប់មក អ្នកនឹងរត់គេចខ្លួនទៅខាងក្រោមជ្រលងភ្នំនៅចន្លោះភ្នំរបស់ព្រះអម្ចាស់ ដ្បិតជ្រលងភ្នំនេះនៅចន្លោះភ្នំទាំងនោះនឹងលាតសន្ធឹងទៅដល់អាសែល។
អ្នកនឹងរត់គេចខ្លួនដូចជាអ្នកបានគេចខ្លួនចេញពីការញ្ជួយដីនៅជំនាន់អូសៀល ជាស្តេចរបស់យូដា។ បន្ទាប់មក ព្រះអម្ចាស់ជាព្រះរបស់យើងនឹងយាងមក
ហើយប្រជាជនដ៏វិសុទ្ធទាំងអស់នឹងមកជាមួយព្រះអង្គដែរ។
[6]នៅថ្ងៃនោះ នឹងលែងមានពន្លឺថ្ងៃ ប៉ុន្តែមិនត្រជាក់ ឬទឹកសន្សើមឡើយ។[7]នៅថ្ងៃនោះ ជាថ្ងៃដែលមានតែព្រះអម្ចាស់ទើបជ្រាប ពេលនោះនឹងលែងមានថ្ងៃ ឬយប់ទៀតហើយ
ដ្បិតពេលល្ងាចនឹងទៅជាម៉ោងពេលថ្ងៃវិញ។[8]នៅថ្ងៃនោះ ទឹករស់នឹងហូរចេញមកពីក្រុងយេរូសាឡឹម។ ពាក់កណ្តាលនៃទឹករស់នឹងហូរទៅសមុទ្រខាងកើត
និងពាក់កណ្តាលទៀតហូរទៅសមុទ្រខាងលិច នៅរដូវក្តៅ និងរដូវរងារ។
[9]ព្រះអម្ចាស់នឹងក្លាយទៅជាស្តេចលើផែនដីទាំងមូល។ នៅថ្ងៃនោះ ព្រះអម្ចាស់នឹងធ្វើជាព្រះតែមួយអង្គគត់ ហើយមានតែព្រះនាមរបស់ព្រះអង្គតែមួយដែរ។
[10]ទឹកដីទាំងមូលនឹងដូចជាតំបន់ អារ៉ាបា ចាប់ពីកេបារហូរដល់រីម៉ូនខាងត្បូងក្រុងយេរូសាឡឹម។ ក្រុងយេរូសាឡឹមនឹងនៅតែបន្តលើកឡើង
និងនៅតែនៅលើកន្លែងរបស់ខ្លួនដដែល ចាប់ពីទ្វារបេនយ៉ាមីនដល់កន្លែងដែលមានទ្វារកាលពីមុន រហូតដល់ជ្រុងទ្វារ ហើយចាប់ពីប៉មហាណានាល
ដល់កន្លែងជាន់ផ្លែនទំពាំងបាយជូររបស់ស្តេច។[11]ប្រជាជននឹងរស់នៅក្នុងក្រុងយេរូសាឡឹម
ហើយនឹងគ្មាននរណាអាចមកបំពេញការបំផ្លាញពីព្រះជាម្ចាស់ប្រឆាំងនឹងពួកគេឡើយ។ ក្រុងយេរូសាឡឹមនឹងរស់នៅដោយសុខសាន្ត។
[12]ការនេះនឹងទៅជាគ្រោះកាច ដែលព្រះអម្ចាស់នឹងវាយប្រហារដល់មនុស្សណាដែលបានប្រកាសសង្គ្រាមប្រឆាំងនឹងក្រុងយេរូសាឡឹម សាច់របស់គេនិងរលួយ
សូម្បីតែពួកគេកំពុងឈរដោយជើងរបស់ពួកគេក៏ដោយ។ ភ្នែករបស់ពួកគេនឹងរលួយនៅក្នុងរន្ធរបស់ពួកគេ ហើយអណ្តាតនឹងរលួយនៅក្នុងមាត់របស់គេពួកគេ។
[13]នៅថ្ងៃនោះ ភាពភ័យខ្លាចយ៉ាងខ្លាំងនៃព្រះអម្ចាស់នឹងមកនៅក្នុងចំណោមពួកគេ។ ម្នាក់ៗនឹងចាប់ដៃអ្នកផ្សេងទៀត
ហើយនឹងលើកដៃឡើងប្រឆាំងនឹងដៃរបស់ម្នាក់ផ្សេងដែរ។
[14]ពួកយូដានឹងវាយប្រឆាំងក្រុងយេរូសាឡឹមដែរ។ ពួកគេនឹងប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជាតិទាំងអស់ដែលនៅជុំវិញ ដូចជាមាស ប្រាក់
និងសម្លៀកបំពាក់ល្អៗយ៉ាងច្រើនក្រៃលែង។[15]គ្រោះកាចនឹងអាចកើតមានចំពោះសេះ លាកូនកាត់ អូដ្ឋ លា
និងគ្រប់ទាំងសត្វអស់ដែលនៅក្នុងជំរំនឹងអាចទទួលរងគ្រោះកាចដូចគ្នាដែរ។
[16]បន្ទាប់មក គ្រោះកាចនឹងកើតមានដល់ប្រជាជាតិណាដែលនៅតែមកប្រឆាំងក្រុងយេរូសាឡឹម ដែលនឹងទៅរាល់ឆ្នាំដើម្បីថ្វាយបង្គំព្រះមហាក្សត្រ
ព្រះអម្ចាស់នៃពិភពទាំងមូល ហើយនិងរក្សាទុកពិធីបុណ្យបារាំជំនួសវិញ។
[17]គ្រោះកាចនឹងកើតបើសិនមានអ្នកណាម្នាក់ពីគ្រប់ប្រជាជាតិទាំងអស់លើផែនដីទាំងមូលមិនឡើងទៅក្រុងយេរូសាឡឹមដើម្បីថ្វាយបង្គំព្រះមហាក្សត្រ
ព្រះអម្ចាស់នៃពិភពទាំងមូលនោះ ព្រះអម្ចាស់នឹងមិនបង្ហូរទឹកភ្លៀងដល់ពួកគេឡើយ។[18]បើសិនប្រជាជាតិនៃប្រទេសអេស៊ីបមិនឡើងទៅ
នោះពួកគេនឹងមិនទទួលបានទឹកភ្លៀងឡើយ។ គ្រោះកាចដែលមកពីព្រះអម្ចាស់នឹងប្រហារដល់ប្រជាជាតិណាដែលមិនឡើងទៅ បន្តរក្សារពីធីបុណ្យបារាំ។
[19]ការដាក់ទោសនេះគឺសម្រាប់ទឹកដីអេស៊ីប និងការដាក់ទោសចំពោះប្រជាជាតិទាំងអស់ណាដែលមិនឡើងទៅដើម្បីរក្សារពីធីបុណ្យបារាំ។
[20]ប៉ុន្តែនៅថ្ងៃនោះ កណ្តឹងនៃសេះនឹងស្រែកឡើងថា «ចូរញែកដោយឡែកថ្វាយព្រះអម្ចាស់»
ហើយថ្លាងទាំងប៉ុន្មានដែលនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់នឹងបានដូចជាចាននៅពីមុខអាសនៈដែរ។[21]គ្រប់ទាំងឆ្នាំងទាំងអស់ដែលនៅក្នុងក្រុងយេរូសាឡឹម
និងយូដានឹងត្រូវញែកជាចំណែកៗសម្រាប់ព្រះអម្ចាស់នៃពិភពទាំងមូល ហើយអស់អ្នកណាដែលនាំយញ្ញបូជានឹងបរិភោគពីថ្លាង និងស្ងោរសាច់នៅក្នុងឆ្នាំងនេះ។
នៅថ្ងៃនោះពួកអ្នកជំនួញនឹងលែងមាននៅក្នុងព្រះដំណាក់នៃព្រះអម្ចាស់នៃពិភពទាំងមូលទៀតហើយ។

Zechariah 14:1
ព័ត៌មានទូទៅ៖
ជំពូកនេះពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡឹម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។

generated on Wed Sep 10 16:16:32 2025

ចោរប្លន់ដណ្តើមរបស់អ្នកនឹងចែកគ្នានៅកណ្តាលអ្នក
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្មាំងសត្រូវរបស់អ្នកនឹងយកទ្រព្យសម្បត្តិទាំងអស់របស់អ្នក
ហើយចែកគ្នាខណៈពេលដែលអ្នកកំពុងមើលពួកគេ»
យើងនឹងប្រមូលគ្រប់ប្រជាជាតិ ប្រឆាំងនឹងក្រុងយេរូសាឡឹម ដើម្បីធ្វើសង្គ្រាម
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងធ្វើអោយប្រជាជាតិជាច្រើនវាយលុកក្រុងយេរូសាឡឹម»
ប្រជាជនដែលនៅនៅសល់នឹងមិនបានបណ្តេញចេញពីទីក្រុងទេ
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្មាំងសត្រូវរបស់អ្នកនឹងទុកអោយប្រជាជននៅសេសសល់ស្នាក់នៅក្នុងទីក្រុង»
Zechariah 14:3
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
ដូចជាព្រះអង្គប្រកាសសង្គ្រាមនៅក្នុងថ្ងៃចម្បាំង
របៀបផ្សេងទៀតនៃការបកប្រែ: «ដូចគាត់បានចម្បាំងពេលនៅអតីតកាល»
ព្រះបាទនៃព្រះអម្ចាស់នឹងឈរនៅលើភ្នំអូលីវ
«ព្រះបាទនៃព្រះអម្ចាស់» គឺសំដៅទៅលើព្រះអម្ចាស់ផ្ទាល់។
Zechariah 14:5
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
អាសែល
នេះជាឈ្មោះក្រុងឬភូមិមួយនៅខាងកើតក្រុងយេរូសាឡិម។
ប្រជាជនដ៏វិសុទ្ធ
នេះប្រហែលជាសំដៅទៅលើទេវតារបស់ព្រះ។
Zechariah 14:6
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
ទឹករស់
ជាធម្មតាមានន័យថាទឹកហូរ ឬហូរជាជាងទឹក ឬទឹកដែលនៅដដែល។
សមុទ្រខាងកើត
នេះសំដៅទៅលើសមុទ្រស្លាប់ដែលនៅខាងកើតក្រុងយេរូសាឡិម។
សមុទ្រខាងលិច
នេះសំដៅទៅលើសមុទ្រមេឌីទែរ៉ាណេ។
Zechariah 14:9
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
ព្រះអម្ចាស់នឹងធ្វើជាព្រះតែមួយអង្គគត់ ហើយមានតែព្រះនាមរបស់ព្រះអង្គតែមួយដែរ
មានតែព្រះជាអម្ចាស់ទេដែលជាព្រះតែមួយអង្គគត់ដែលត្រូវគោរពថ្វាយបង្គំ។
អារ៉ាបា ...កេបារ..រីម៉ូន
ទាំងនេះគឺជាឈ្មោះទីកន្លែង។
ក្រុងយេរូសាឡឹមនឹងនៅតែបន្តលើកឡើង
នេះសំដៅទៅលើនីរ៉ូទឹកនៃទីក្រុងយេរូសាឡិមដែលមានកំពស់ប្រហែល ៧៦០
ម៉ែត្រពីនីរ៉ូទឹកសមុទ្រ។
ចាប់ពីទ្វារបេនយ៉ាមីន...ទ្វារកាលពីមុន... ដល់ជ្រុងទ្វារ
ទាំងនេះគឺជាឈ្មោះនៃច្រកទ្វារផ្សេងៗនៅក្នុងជញ្ជាំងក្រុងយេរូសាឡិម។
ប៉មហាណានាល
នេះសំដៅទៅលើចំណុចរឹងមាំនៅក្នុងទីក្រុងការពារនៅលើកំផែង។
ប្រហែលជាត្រូវបានសាងសង់ដោយបុរសម្នាក់ឈ្មោះហាណានាល។
ដល់កន្លែងជាន់ផ្លែនទំពាំងបាយជូររបស់ស្តេច
នេះប្រហែលជាសំដៅទៅលើទីកន្លែងដែលស្រាត្រូវបានបង្កើតឡើងសម្រាប់គ្រួសាររាជវង្ស។
Zechariah 14:12
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
កំពុងឈរដោយជើងរបស់ពួកគេក៏ដោយ
របៀបផ្សេងទៀតនៃការបកប្រែ: «ការដើរជុំវិញ»
លើកដៃឡើងប្រឆាំងនឹងដៃរបស់ម្នាក់ផ្សេងដែរ
មនុស្សម្នាក់ៗនឹងវាយប្រហារអ្នកដទៃ។
Zechariah 14:14
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
ពួកយូដានឹងវាយប្រឆាំងក្រុងយេរូសាឡឹមដែរ
ខខ្លះអានថា «យូដាក៏នឹងប្រយុទ្ធដើម្បីក្រុងយេរូសាឡិមដែរ»។
អត្ថបទភាសាហេព្រើរមិនច្បាស់ទេ។
ពួកគេនឹងប្រមូលទ្រព្យសម្បត្តិ
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងចាប់យកទ្រព្យសម្បត្តិ»
យ៉ាងច្រើនក្រៃលែង
«ក្នុងបរិមាណដ៏អស្ចារ្យ»
Zechariah 14:16
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
មកប្រឆាំងក្រុងយេរូសាឡឹម
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងវាយប្រហារក្រុងយេរូសាឡិម»
នឹងប្រហារដល់ប្រជាជាតិ
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងដាក់ទោសប្រជាជាតិនានា»
Zechariah 14:19
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
Zechariah 14:20
ព័ត៌មានទូទៅ៖
ខទាំងនេះបន្តការពិពណ៌នាអំពីសង្គ្រាមចុងក្រោយសម្រាប់ទីក្រុងយេរូសាឡិម
និងរបៀបដែលព្រះនឹងជួយសង្គ្រោះទីក្រុងនោះ។
នឹងបានដូចជាចាននៅពីមុខអាសនៈដែរ
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងក្លាយទៅជាសក្ការៈបូជា
ដូចជាចានដែលប្រើនៅអាសនៈ»
គ្រប់ទាំងឆ្នាំងទាំងអស់ដែលនៅក្នុងក្រុងយេរូសាឡឹម
និងយូដានឹងត្រូវញែកជាចំណែកៗសម្រាប់ព្រះអម្ចាស់នៃពិភពទាំងមូល
ឆ្នាំងនិងប្រដាប់ប្រដាផ្សេងៗជាច្រើនត្រូវបានផលិតជាពិសេសសម្រាប់ប្រើប្រាស់ក្នុងព្រះវិហារសម្រាប់គោរ
និងយញ្ញបូជា។ វត្ថុទាំងនេះត្រូវបានគេចាត់ទុកថាពិសេសមិនមែន
ហើយក៏មិនប្រើទៅលើរបស់អ្វីផ្សេងទៀតដែរ។
អ្នកជំនួញនឹងលែងមាននៅក្នុងព្រះដំណាក់នៃព្រះអម្ចាស់នៃពិភពទាំងមូលទៀតហើយ
វាជាទម្លាប់សម្រាប់អាជីវករក្នុងការលក់របស់របរបស់ប្រជាជនដែលពួកគេត្រូវការ
ដើម្បីធ្វើពលិកម្មសម្រាប់ទីសក្ការៈថ្វាយព្រះអម្ចាស់នៅក្នុងព្រះវិហារ។
ការបកប្រែខ្លះបកប្រែថា «កាណាន»
ផ្ទុយទៅវិញពីព្រោះអត្ថបទភាសាហេព្រើរអាចមានអត្ថន័យពីរដង៖ «អ្នកជួញដូរ»
និង «កាណាន»។

ម៉ាឡាគី

1 [1]សេចក្តីប្រកាសនៃព្រះបន្ទូលរបស់ព្រះអម្ចាស់ ទៅកាន់កូនចៅអ៊ីស្រាអែល តាមរយៈការសរសេររបស់លោកម៉ាឡាគី។[2]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «យើងស្រឡាញ់
អ្នករាល់គ្នា»។ ប៉ុន្តែអ្នករាល់គ្នាបែរជាពោលថា «តើមានអ្វីបញ្ជាក់ថាព្រះអង្គស្រឡាញ់យើងខ្ញុំ?» នេះជាព្រះបន្ទូលនៃព្រះអម្ចាស់។ «តែយើងស្រឡាញ់យ៉ាកុប
[3]ប៉ុន្តែយើងស្អប់អេសាវវិញ។ យើងបានធ្វើឲ្យភ្នំនៅទឹកដីអេសាវ ក្លាយទៅជាទីបំផ្លិចបំផ្លាញ ហើយយើងបានធ្វើឲ្យកន្លែងពួកគេរស់នៅ សម្រាប់ឆ្កែព្រៃនៃវាលរហោស្ថាន»។

generated on Wed Sep 10 16:16:32 2025

[4]ប្រសិនបើអេដុមពោលថា «យើងនឹងកម្ទេចចោល តែយើងនឹងសាងសង់ទីកន្លែងត្រូវបំផ្លាញសាជាថ្មី។ ព្រះអម្ចាស់នៃពិភពទាំងមូលនឹងមានព្រះបន្ទូល «ពួកគេនឹងសង់ឡើងវិញ តែយើងនឹងបំផ្លាញម្តងទៀត ។ អ្នកផ្សេងនឹងហៅគេថា «ស្រុកនៃសេចក្តីអាក្រក់» ហើយ «មនុស្សដែលព្រះអម្ចាស់ដាក់បណ្តាសាជានិច្ច»។[5]ភ្នែករបស់អ្នកនឹងឃើញការទាំងនេះ ហើយអ្នកពោលថា៖ ព្រះអម្ចាស់គឺអស្ចារ្យ ហួសព្រំដែននៃអ៊ីស្រាអែល»។
[6]«កូនដែលគោរពឪពុក ហើយអ្នកបម្រើដែលគោរពម្ចាស់របស់គេ។ ហើយបើយើង ជាឪពុក តើការគោរពយើងនៅទី ណា? ប្រសិនបើយើងជាម្ចាស់ តើការគោរពសម្រាប់យើងនៅឯណា?» ព្រះ បន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល ដល់អ្នកជាព្យាការីដែលប្រមាថនាមរបស់យើង។ «តែអ្នករាល់គ្នាពោលថា៖ «តើយើងប្រមាថព្រះនាមព្រះអង្គត្រង់បែបណា?[7]ដោយថ្វាយតង្វាយម្ហូបអាហារកខ្វក់ ដាក់លើអាសនៈរបស់យើង។ តែអ្នករាល់គ្នាពោលថា «តើយើងខ្ញុំបានធ្វើឲ្យព្រះអង្គកខ្វក់បែបណា?» ដោយពោលថា តុនៃព្រះអម្ចាស់មិនសូវសំខាន់ទេ។
[8]ពេលអ្នករាល់ថ្វាយសត្វខ្វាក់ សម្រាប់យញ្ញបូជា នេះមិនមែនអាក្រក់ទេឬ? ពេលអ្នករាល់ថ្វាយសត្វបាក់ជើង និងសត្វមានជំងឺ តើមិនមែនអាក្រក់ទេឬ? បើបង្ហាញការនេះទៅជូនពួកមន្ត្រីវិញ! តើគេនឹងទទួលយកអ្នក ឬតើគេនឹងលើកមុខអ្នកឡើងទេ?» ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល។[9]ពេលនេះអ្នកបន្តទូលអង្វរកព្រះភក្ត្រនៃព្រះជាម្ចាស់ ដែលព្រះអង្គសន្តោសប្រណីដល់យើង។ ប៉ុន្តែព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ជាមួយតង្វាយអាក្រក់ក្នុងដៃអ្នក តើព្រះអង្គនឹងលើកមុខអ្នកឡើងទេ?
[10]«អូរ បើគ្រាន់តែមានម្នាក់ពីអ្នករាល់គ្នាដែលបានបិទទ្វារព្រះវិហារ ដូច្នេះដែលអ្នកនឹងមិនដុតភ្លើងនៅលើអាសនៈរបស់យើងដោយឥតបានការនោះទេ! យើងមិនពេញចិត្តនឹងអ្នកទេ» ព្រះបន្ទូលព្រះអម្ចាស់ នៃពិភពទាំងមូល «ហើយយើងមិនទទួលតង្វាយពីដៃរបស់អ្នកទេ។[11]ដ្បិត តាំងពីថ្ងៃរៈដល់ថ្ងៃលិច គឺនាមរបស់យើងបានឧតម្ត នៅក្នុងចំណោមប្រជាជាតិនានា ហើយនិងនៅគ្រប់ទីកន្លែងផង កំញានណនិងតង្វាយបរិសុទ្ធនឹងត្រូវថ្វាយក្នុងនាមយើង។ ដ្បិតនាមយើង នឹងលើកតម្កើងនៅក្នុងចំណោមប្រជាតិនានា» ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល។[12]«ប៉ុន្តែ អ្នករាល់គ្នាបប្រមាថនាមយើងដោយពោលថា តុនៃព្រះអម្ចាស់កខ្វក់ ហើយផលផ្លែ និងអាហារគឺត្រូវបានប្រមាថ។
[13]ប៉ុន្តែអ្នកក៏បានពោលថា «ការនេះធុញទ្រាន់ ហើយអ្នករាល់គ្នាបានមើលងាយយើង» ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល។ «អ្នកនាំអ្វីដែលត្រូវបានចាប់យកទៅដោយសត្វព្រៃ ឬសត្វបាក់ជើង និងសត្វឈឺផង ហើយអ្នករាល់គ្នានាំតង្វាយមកថ្វាយ។ តើគួរឲ្យយើងទទួលតង្វាយបែបនេះពីដៃអ្នករាល់គ្នាឬទេ? ព្រះបន្ទូលព្រះអម្ចាស់[14]«អ្នកបញ្ឆោតនឹងត្រូវបណ្តាសា ដែលមានសត្វឈ្មោលនៅក្នុងហ្វូង ហើយក៏ស្បថថានឹងថ្វាយដល់យើង ហើយនឹងថ្វាយយញ្ញបូជាដល់យើង ដែលជាព្រះអម្ចាស់នៅអ្វីដែលមិនល្អ! ដ្បិតយើងជាស្តេចដ៏ធំ» ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល «ហើយឈ្មោះយើង នឹងបានការគោរពក្នុងចំណោមប្រជាជាតិទាំងឡាយ»។

Malachi 1:1
សេចក្តីប្រកាសនៃព្រះបន្ទូលរបស់ព្រះអម្ចាស់ ទៅកាន់កូនចៅអ៊ីស្រាអែល
តាមរយៈការសរសេររបស់លោកម៉ាឡាគី
នេះអាចត្រូវបានបង្ហាញជាខ្លឹមសារភ្ជាប់។
«នេះជាការប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់ដល់ជនជាតិអ៊ីស្រាអែលដោយដៃរបស់[illegible]
ព្រះអម្ចាស់
នេះគឺជាព្រះនាមរបស់ព្រះជាម្ចាស់ ដែលព្រះអង្គ
បានបង្ហាញដល់ប្រជារាស្ត្ររបស់ព្រះអង្គ នៅក្នុងព្រះគម្ពីរសញ្ញាចាស់។
សូមមើលការបកប្រែនៅទំព័រ វ៉េដ អំពីព្រះអម្ចាស់
ទាក់ទងនឹងរបៀបការបកប្រែអត្ថបទនេះ។
តាមរយៈការសរសេររបស់លោកម៉ាឡាគី
ឃ្លាថា «ដៃ» នៅទីនេះតំណាងឱ្យការសម្តែង ឬការធ្វើ។
ការបកប្រែរបៀបផ្សេងទៀត: «តាមរយៈកិច្ចការងាររបស់ម៉ាឡាគី»
តើមានអ្វីបញ្ជាក់ថាព្រះអង្គស្រឡាញ់យើងខ្ញុំ?
សំណួរនេះបង្ហាញថា ប្រជារាស្ត្រមានការងឿងឆ្ងល់
ពីការពិតនៃអ្វីដែលព្រះអម្ចាស់មានព្រះបន្ទូល។ នេះអាចបង្ហាញជាខ្លឹមសារថា។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនបានបង្ហាញថា អ្នកស្រឡាញ់យើងទេ»
តើអេសាវមិនមែនជាបងប្រុសរបស់យ៉ាកុបទេឬអី?
សំណួរនេះ ជាការឆ្លើយតបរបស់ព្រះអម្ចាស់
ដែលរំលឹកដ៏ប្រជារាស្ត្រនៃប្រវត្តិសាស្ត្រប្រជាជាតិរបស់ពួកគេ
ក៏អាចត្រូវបានបង្ហាញជាខ្លឹមសារភ្ជាប់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នករាល់គ្នាដឹងថា អេសាវគឺជាបងប្រុសរបស់យ៉ាកុប» ។
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
«ព្រះអម្ចាស់មានព្រះបន្ទូលយ៉ាងម៉ឺងម៉ាត់ថា»
តែយើងស្រឡាញ់យ៉ាកុបជាង
ឃ្លាថា «សេចក្តីស្រឡាញ់»
នៅទីនេះការបង្ហាញពីទំនាក់ទំនងនៃភាពស្មោះត្រង់រវាងព្រះអម្ចាស់ និងយ៉ាកុប
ដែលក្នុងនោះជាកិច្ចព្រមព្រៀងរវាងពួកគេ។ នេះអាចធ្វើឱ្យយ៉ាងជាក់ច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដូចដែលអ្នកបានដឹងហើយ
យើងមានកាតព្វកិច្ចផ្ទាល់ខ្លួនជាមួយនឹងកិច្ចព្រមព្រៀងដើម្បីស្រឡាញ់យ៉ាកុប»
តែយើងស្រឡាញ់យ៉ាកុបជាង
ឈ្មោះនេះ «យ៉ាកុប» នៅទីនេះមិនត្រឹមតែសំដៅទៅលើយ៉ាកុបប៉ុណ្ណោះទេ
ប៉ុន្តែក៏សំដៅទៅលើកូនចៅទាំងអស់របស់គាត់ផងដែរ។
យើងស្អប់អេសាវវិញ
ឃ្លាថា «ស្អប់» នៅទីនេះបង្កប់ន័យថា គ្មានកិច្ចព្រមព្រៀងរវាងព្រះអម្ចាស់
និងអេសាវទេ។ ទោះយ៉ាងណា វាមិនមានន័យថា
ព្រះអម្ចាស់បានប្រឆាំងនឹងអេសាវនោះដែរ។
យើងស្អប់អេសាវវិញ
ឈ្មោះនេះ «អេសាវ» មិនត្រឹមតែសំដៅទៅលើអេសាវប៉ុណ្ណោះទេ
គឺសំដៅទៅលើកូនចៅរបស់គាត់ទាំងអស់ផងដែរ។
[illegible]
នេះសំដៅទៅលើតំបន់ភ្នំអេដុម។
ហើយយើងបានធ្វើឲ្យកន្លែងពួកគេរស់នៅ សម្រាប់ស្មៅព្រៃនៃវាលរហោស្ថាន
នៅក្នុងព្រះគម្ពីរសញ្ញាចាស់វត្តមាននៃសត្វព្រៃ
ដូចជាសត្វចចកគឺជាការពិពណ៌នាជាញឹកញាប់នៃទឹកដីដែលត្រូវបានបោះបង់ចោលដោយប្រជាជន
ដែលធ្លាប់រស់នៅទីនោះ។
ធ្វើឲ្យកន្លែងពួកគេរស់នៅ
ឃ្លាថា «មត៌ក»
នៅទីនេះតំណាងអោយតំបន់ដែលជាកូនចៅអេសាវជាជនជាតិអេដុមកាន់កាប់។
Malachi 1:4
ប្រសិនបើអេដុមពោលថា
ឃ្លាថា «អេដុម» នៅទីនេះតំណាងអោយប្រជាជនរបស់អេដុម។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើប្រជាជនរបស់អេដុមគេពោលថា»
យើងនឹងកម្ទេចចោល
ឃ្លាថា «កម្ទេច» នៅទីនេះតំណាងអោយ «បំផ្លាញចោល»។
ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងបំផ្លាញចោល»
ស្រុកនៃសេចក្តីអាក្រក់
ឃ្លាថា «ជនទុច្ចរិត» នៅទីនេះតំណាងអោយមនុស្សអាក្រក់ ឬអំពើអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត: «ជាព្រំស្រុកនៃសេចក្តីអាក្រក់»។
ភ្នែករបស់អ្នកនឹងឃើញការទាំងនេះ
ឃ្លាថា «ភ្នែកអ្នករាល់គ្នា» នៅទីនេះតំណាងអោយប្រជារាស្ត្ររបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នានឹងឃើញវា»
Malachi 1:6
ព័ត៌មានទូទៅ:
ព្រះអម្ចាស់បានបន្ទោសដល់ពួកបូជាចារ្យ
ដោយប្រើការសន្ទនាតាមបែបស្រមើស្រមៃ ដែលក្រុមបូជាចារ្យតវ៉ាថា
ពួកគេបានធ្វើត្រូវហើយ ព្រះអម្ចាស់ក៏ប្រាប់ពួកគេពីអ្វីដែលពួកគេបានធ្វើខុសឆ្គង។
ប្រមាថនាមរបស់យើង
ឃ្លាថា «ព្រះនាមរបស់យើង» នៅទីនេះតំណាងអោយព្រះអម្ចាស់ផ្ទាល់។
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើបាបយើង ដូចជាអ្នកស្អប់យើង»
តើយើងប្រមាថព្រះនាមព្រះអង្គត្រង់បែបណា ?
នៅទីនេះ ពួកបូជាចារ្យកំពុងសួរសំណួរដើម្បីបញ្ជាក់ថា

generated on Wed Sep 10 16:16:32 2025

ពួកគេពិតជាមិនបានមើលងាយដល់ព្រះអម្ចាស់ទេ។ នេះអាចបង្ហាញជាខ្លឹមសារ។
ការបកប្រែរបៀបផ្សេងទៀត:
«យើងពិតជាមិនបានមើលងាយដល់ព្រះនាមរបស់ព្រះអម្ចាស់ទេ» ។
ឬប្រាប់យើងពីរបៀប ដែលយើងមើលងាយព្រះនាមរបស់អ្នក
ពីព្រោះយើងមិនគិតថា យើងបានធ្វើដូច្នេះទេ។
មួបអាហារកខ្វក់
ឃ្លាថា «មិនបរិសុទ្ធ»
នៅទីនេះពិពណ៌នាអំពីអ្វីដែលមិនសមនឹងថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់។
តើយើងខ្ញុំបានធ្វើឲ្យព្រះអង្គកខ្វក់បែបណា?
នៅត្រង់នេះ ពួកបូជាចារ្យកំពុងសួរសំណួរ ដើម្បីបញ្ជាក់ថា
ពួកគេពិតជាមិនបានបរិសុទ្ធ ដល់ព្រះអម្ចាស់ទេ។ នេះអាចបង្ហាញជាខ្លឹមសារ។
ការបកប្រែរបៀបផ្សេងទៀត: «យើងមិនបានប្រមាថដល់ព្រះនាមព្រះអម្ចាស់ទេ»។
ឬ «ប្រាប់យើងពីរបៀបដែលយើងបានប្រមាថដល់ព្រះនាមព្រះអម្ចាស់ទេ
ពីព្រោះយើងមិនគិតថា យើងបានធ្វើដូច្នេះទេ» ។
ព្រះអង្គកខ្វក់បែបណា
ពាក្យនេះសំដៅទៅលើ
ការប្រមាថដល់ព្រះអម្ចាស់ដោយថ្វាយយញ្ញបូជាដែលមិនសមរម្យ។
តុ
នេះសំដៅទៅលើអាសនៈមួយ។
ដោយពោលថា តុនៃព្រះអម្ចាស់មិនសូវសំខាន់ទេ
នេះជាចម្លើយ ដែលព្រះអម្ចាស់ផ្តល់អោយពួកបូជាចារ្យ
ប៉ុន្តែចម្លើយពេញលេញគ្រាន់តែថ្លែងបញ្ជាក់។ នេះត្រូវបានធ្វើឱ្យយ៉ាងច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកស្មៅហ្មងនឹងយើង ដោយនិយាយថា
តុរបស់ព្រះអម្ចាស់គួរស្អប់ខ្ពើម»។
មិនសូវសំខាន់ទេ
ចាត់ទុកឥតប្រយោជន៍
Malachi 1:8
ពេលអ្នករាល់ថ្វាយសត្វខ្វាក់ សម្រាប់យញ្ញបូជា នេះមិនមែនអាក្រក់ទេឬ?
នៅទីនេះព្រះអម្ចាស់កំពុងសួរសំណួរដើម្បីធ្វើខ្លឹមសារ។
ការវិនិច្ឆ័យនេះជាការបន្ទោសដល់ប្រជាជន។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដឹងយ៉ាងច្បាស់ថា វាអាក្រក់សម្រាប់អ្នកយកសត្វដែលខ្វាក់ យកមកធ្វើជាយញ្ញបូជា!»
ពេលអ្នករាល់ថ្វាយសត្វបាក់ជើង និងសត្វមានជំងឺ តើមិនមែនអាក្រក់ទេឬ?
នៅទីនេះព្រះអម្ចាស់កំពុងសួរសំណួរដើម្បីធ្វើខ្លឹមសារ។
ការបកប្រែរបៀបផ្សេងទៀត: «ហើយអ្នកដឹងយ៉ាងច្បាស់ថា
វាអាក្រក់សម្រាប់អ្នកយកសត្វបាក់ជើង ឬសត្វមានជំងឺ!»
បង្ហាញការនេះទៅជូនពួកមន្ត្រី
នេះជាបទបញ្ជារបស់ព្រះអម្ចាស់ ដើម្បីបង្ហាញពីគំនិតដែលមានលក្ខខណ្ឌ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើអ្នកបង្ហាញវាទៅពួកមន្ត្រីរបស់អ្នកវិញ»
តើគេនឹងទទួលយកអ្នក ឬតើគេនឹងលើកមុខអ្នកឡើងទេ?
នៅទីនេះព្រះអម្ចាស់សួរសំណួរនេះ ដើម្បីការបន្ទោសដល់ប្រជាជន។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើអ្នកធ្វើរឿងទាំងនោះ
អ្នកដឹងថាពួកមន្ត្រីនឹងមិនទទួលយកពីអ្នកទេ។ គាត់នឹងមិនងើបមុខឡើងទេ» ។
នឹងលើកមុខអ្នកឡើងទេ
ការលើកមុខអ្នកណាម្នាក់
សំដៅទៅលើការព្រមទទួលយករបស់គាត់ដោយការពេញចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «គាត់នឹងព្រមទទួលយកពីអ្នកដោយការពេញចិត្ត
«ឬ» តើគាត់នឹងយល់ព្រមជួយអ្នកទេ»
បង្ហាញការនេះ
ផ្តល់ជាអំណាយដើម្បីបង្ហាញអំពីការគួរសម
ពេលនេះអ្នកបន្តទូលអង្វររកព្រះភក្ត្រនៃព្រះជាម្ចាស់ ដែលព្រះអង្គសន្តោសប្រណីដល់យើង
ម៉ាឡាគី គឺលែងនិយាយរកព្រះអម្ចាស់ទៀតហើយ។
គាត់កំពុងតែនិយាយដោយផ្ទាល់ទៅកាន់ជនជាតិអ៊ីស្រាអែល។
គាត់កំពុងរិះគន់ពួកគេ ចំពោះការហ៊ានគិតថា
ព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណាដល់ពួកគេ។
បន្តទូលអង្វររកព្រះភក្ត្រនៃព្រះជាម្ចាស់
ឃ្លាថា «ចំពោះមុខ» នៅទីនេះតំណាងឱ្យព្រះអម្ចាស់
ហើយក៏មានវត្តមានរបស់ព្រះអម្ចាស់ផងដែរ។ ការបកប្រែរបៀបផ្សេងទៀត:
«ចូរទូលអង្វរដល់ព្រះអម្ចាស់ នៅក្នុងព្រះវត្តមានទ្រង់»
ជាមួយតង្វាយអាក្រក់ក្នុងដៃអ្នក តើព្រះអង្គនឹងលើកមុខអ្នកឡើងទេ?
នៅទីនេះព្រះអម្ចាស់កំពុងសួរសំណួរ ដើម្បីនឹងធ្វើខ្លឹមសារអំពីការស្តីបន្ទោស។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើអ្នកផ្តល់ដង្វាយ
ដែលមិនអាចទទួលយកបាន ព្រះអម្ចាស់ប្រាកដជាមិនលើកមុខអ្នកឡើយ»។
ជាមួយតង្វាយអាក្រក់ក្នុងដៃអ្នក
ឃ្លាដ៏លំបាកនេះជាភាសាហេព្រើរ
ដែលត្រូវបានបកស្រាយតាមវិធីផ្សេងៗគ្នាជាច្រើនដោយជំនាន់ទំនើប។
ក្នុងដៃអ្នក
ឃ្លាថា «ដៃ» នៅទីនេះតំណាងអោយប្រជាជននាំយកដង្វាយមកថ្វាយ។
ការបកប្រែរបៀបផ្សេងទៀត: «ថ្វាយតាមរយៈអ្នករាល់គ្នា»
Malachi 1:10
អូរ បើគ្រាន់តែ
នេះបញ្ជាក់សេចក្តីប្រាថ្នាដ៏អស្ចារ្យ។
ដូច្នេះដែលអ្នកនឹងមិនដុតភ្លើងនៅលើអាសនៈរបស់យើងដោយឥតបានការនោះទេ
ឃ្លាថា «ភ្លើងដែលភ្លឺនៅលើអាសនៈរបស់យើង»
នៅទីនេះតំណាងអោយការថ្វាយយញ្ញបូជានៅលើអាសនៈរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះអ្នកប្រហែលជាមិនធ្វើឱ្យមានភ្លើងឆេះដង្វាយ
ដែលយើងនឹងមិនទទួលយក»
ពីដៃរបស់អ្នក
ឃ្លាថា «ដៃរបស់អ្នក» នៅទីនេះតំណាងអោយ «អ្នករាល់គ្នា»
ការបកប្រែរបៀបផ្សេងទៀត: «ពីអ្នក»
តាំងពីថ្ងៃរៈដល់ថ្ងៃលិច
ពាក្យពីរយ៉ាងនេះមានន័យថា «គ្រប់ទីកន្លែង» ។ វាស្របគ្នានឹង
«ក្នុងចំណោមប្រជាជាតិនានា» និង «នៅគ្រប់ទីកន្លែង»
នាមរបស់យើងបានឧតម្ត នៅក្នុងចំណោមប្រជាជាតិនានា
ឃ្លាថា «ព្រះនាមរបស់យើង» នៅទីនេះតំណាងឱ្យ «យើង»
ការបកប្រែរបៀបផ្សេងទៀត
«យើងនឹងទទួលបានកិត្តិយសនៅក្នុងប្រជាជាតិដទៃទៀត»
នាមរបស់យើង
ឃ្លាថា «ព្រះនាម» នៅទីនេះតំណាងឱ្យ «កេរ្តិ៍ឈ្មោះ» «កិត្តិយស»។
ហើយនិងនៅគ្រប់ទីកន្លែងផង កំញានិងតង្វាយបរិសុទ្ធនឹងត្រូវថ្វាយក្នុងនាមយើង
នេះបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងប្រជាជាតិទាំងនេះ ប្រជាជននឹងថ្វាយគ្រឿងក្រអូប
និងដង្វាយបរិសុទ្ធដល់យើង ដើម្បីថ្វាយបង្គំដល់យើង»
ក្នុងនាមយើង
ឃ្លាថា «ព្រះនាម» នៅទីនេះតំណាងអោយព្រះអម្ចាស់ ។
ការបកប្រែរបៀបផ្សេងទៀត: «ចំពោះយើង»
ហើយផលផ្លែ និងអាហារ
អាចមានន័យថា ១) «សាច់ដែលបានបូជានៅលើអាសនៈពីសត្វ
ដែលផ្នែកផ្សេងទៀតរបស់បូជាចារ្យត្រូវបរិភោគ» ឬ ២)
«សាច់ដែលបានបូជានៅលើអាសនៈ»។
Malachi 1:13
ធុញទ្រាន់មើលងាយ
បង្ហាញការមិនគោរពយ៉ាងខ្លាំង ដោយបង្កើតសំលេងរំខានតាមរយៈច្រមុះ
តើគួរឲ្យយើងទទួលតង្វាយបែបនេះពីដៃអ្នករាល់គ្នាឬទេ?
នៅទីនេះព្រះអម្ចាស់កំពុងសួរសំណួរដើម្បីធ្វើខ្លឹមសារអំពីការស្តីបន្ទោស។
ការបកប្រែរបៀបផ្សេងទៀត: «យើងពិតជាមិនគួរទទួលយករឿងនេះពីអ្នកទេ!»
ពីដៃអ្នករាល់គ្នា
ដ្បិត «ដៃរបស់យើង» តំណាងអោយ «យើង» ការបកប្រែរបៀបផ្សេងទៀត:
«ពីយើង»
ហើយឈ្មោះយើងនឹងបានការគោរពក្នុងចំណោមប្រជាជាតិទាំងឡាយ
នេះបង្ហាញជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជននៅប្រជាជាតិនានាដទៃផ្សេងទៀតបានគោរពដល់ព្រះនាមរបស់យើង»
ឈ្មោះយើងនឹងបានការគោរព
ឃ្លាថា «នាមរបស់យើង» នៅទីនេះតំណាងអោយព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «យើងជាទីស្ញែងខ្លាច»

generated on Wed Sep 10 16:16:32 2025

2 [1]ឥឡូវនេះ អ្នកជាបូជាចារ្យអើយ សេចក្ដីបង្គាប់នេះ គឺសម្រាប់អ្នករាល់គ្នា។[2]«បើសិនអ្នករាល់គ្នាមិនព្រមស្តាប់ទេ ហើយបើអ្នកមិនយកដាក់ក្នុងចិត្តនឹងថ្វាយសិរីល្អដល់
នាមយើងទេ» ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «យើងនឹងចាត់បណ្ដាសាមកលើអ្នករាល់គ្នា យើងនឹងដាក់បណ្ដាសាដល់ព្រះពរអ្នក។
ការពិតយើងដាក់បណ្ដាសារួចគេ ដោយអ្នកមិនបានយកការបង្គាប់យើងទុកដាក់នៅក្នុងចិត្តរបស់អ្នក។
[3]មើល៍! យើងនឹងបន្ទោសពូជពង្សរបស់អ្នករាល់គ្នា ហើយជះលាមកទៅលើមុខអ្នករាល់គ្នា គឺជាលាមកចេញពីពិធីបុណ្យរបស់អ្នក ហើយគេនឹងយកអ្នករាល់គ្នាចេញទៅ
ជាមួយនឹងលាមកនោះដែរ។[4]អ្នករាល់គ្នានឹងដឹងថា យើងបានបង្គាប់ដល់អ្នករាល់គ្នាហើយ ហើយសម្ពន្ធមេត្រីរបស់យើងអាចបន្តនៅជាមួយពួកលេវី» ព្រះបន្ទូលរបស់
ព្រះអម្ចាស់នៃពិភពទាំងមូល។
[5]«សម្ពន្ធមេត្រីជាមួយគេគឺជាជីវិត និងជាសេចក្ដីសុខសាន្ត ដែលយើងបានប្រទានដល់គេ យើងបានឲ្យភ័យខ្លាចដល់គេ ហើយគេក៏ភ័យខ្លាចយើង
ហើយងឈរស្ងប់ស្ងែងនាមរបស់យើង។[6]គេមានសេចក្ដីបង្រៀនពិតនៅក្នុងមាត់ ហើយមិនឃើញមានអំពើទុច្ចរិតនៅបបូរមាត់គេឡើយ។ គេបានដើរជាមួយយើង
ក្នុងសេចក្ដីសុខសាន្ត ហើយទៀងត្រង់ ក៏បាននាំមនុស្សជាច្រើនចេញពីអំពើទុច្ចរិតផង។[7]ដ្បិតគួរឲ្យបបូរមាត់របស់បូជាចារ្យរក្សាទុកនូវចំណេះដឹង ហើយគួរឲ្យមនុស្សស្វែង
រកការបង្រៀនពីមាត់គេ ដ្បិតគេជាអ្នកនាំសារនៃព្រះអម្ចាស់នៃពិភពទាំងមូល។
[8]តែអ្នករាល់គ្នាបានបែរចេញពីផ្លូវនៃសេចក្ដីពិត។ អ្នកបាននាំឲ្យមនុស្សជាច្រើនជំពប់ដួលក្នុងការគោរពដល់ក្រឹត្យវិន័យដែរ។ អ្នករាល់គ្នាបានផ្តាច់សម្ពន្ធមេត្រីរបស់លេវី
ហើយ» ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល។[9]«ដូច្នេះយើងក៏បានធ្វើឲ្យអ្នករាល់គ្នាជាទីមើលងាយ ហើយអប្រិយ នៅចំពោះមុខមនុស្សទាំងឡាយ ពី ព្រោះអ្នករាល់គ្នា
មិនបានកាន់តាមផ្លូវរបស់យើង តែផ្ទុយទៅវិញ បង្ហាញពីការចូលរួមជាមួយនឹងសេចក្ដីបង្រៀនទាំងនោះវិញ»។
[10]«តើយើងទាំងអស់គ្នាមិនមានឪពុកតែមួយទេឬ? ហេតុអ្វីបានជាយើងបានជាយើងក្បត់ ម្នាក់ៗទាស់ប្រឆាំងនឹងបងប្អូនខ្លួន ឯង
ហើយប្រមាថសម្ពន្ធមេត្រីនៃពួកដូនតារបស់យើងដូច្នេះ?[11]ពួកយូដាបានកំផិត។ ប្រព្រឹត្តអំពើគួរស្អប់ខ្ពើម នៅក្នុងពួកអ៊ីស្រាអែល ហើយនៅក្រុងយេរូសាឡិមដែរ។ ដ្បិត
យូដាបានប្រមាថទីបរិសុទ្ធរបស់ព្រះអម្ចាស់ ដែលព្រះអង្គស្រឡាញ់ ហើយបានរៀបការជាមួយកូនស្រីរបស់ព្រះជនជាតិដទៃ។[12]សូមព្រះអម្ចាស់កាត់ចេញពីត្រសាលនៃពួក
យ៉ាកុបទៅ ចំពោះមនុស្សដែលប្រព្រឹត្តអំពើដូច្នេះ ជាអ្នកដែលដែលដឹងខ្លួនហើយក៏បានឆ្លើយតប ទោះបីគេនាំយកតង្វាយមកថ្វាយដល់ព្រះអម្ចាស់នៃ
ពិភពទាំងមូលក៏ដោយ។
[13]អ្នករាល់គ្នាក៏បានធ្វើនេះដែរ គឺអ្នករាល់គ្នាបានបិតបាំងអាសនានៃព្រះអម្ចាស់ ដោយទឹកភ្នែក ដោយការយំសោក ហើយស្រែកថ្ងូរ ពីព្រោះព្រះអង្គមិនបានបែរមករកតង្វាយ
ឬទទួលតង្វាយនោះដោយព្រះគុណពីដៃអ្នករាល់គ្នាដោយ។
[14]ប៉ុន្តែអ្នកនិយាយថា «ហេតុអ្វីបានជាព្រះអង្គមិនទទួល?» ព្រោះព្រះអម្ចាស់ជាសាក្សីរវាងអ្នកនឹងប្រពន្ធអ្នក ដែលបានគ្នាកាលពីក្រមុំកំលោះមក
បានទាស់ប្រឆាំងដែលអ្នកបានក្បត់នឹងនាង ទោះបីនាងបានផ្តល់ក្តីមេត្តាដល់អ្នកហើយជាប្រពន្ធស្របតាមសម្ពន្ធមេត្រីដ៏ដោយ។[15]តើព្រះអង្គមិនបានធ្វើឲ្យអ្នកទាំងពីរក្លាយ
ជាតែមួយទេឬ? ហេតុអ្វីបានជាព្រះអង្គធ្វើមកតែមួយដូច្នេះ? ពីព្រោះព្រះអង្គចង់ស្វែងរកពូជបរិសុទ្ធមកពីព្រះជាម្ចាស់។ ដូច្នេះ ចូរប្រយ័ត្នចំពោះវិញ្ញាណរបស់អ្នក ហើយកុំ
ឲ្យមិនស្មោះត្រង់ចំពោះប្រពន្ធដែលបានគ្នាកាលពីក្មេងឡើយ។[16]«ដ្បិតយើងស្អប់ការលះលែងគ្នា» ព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល
«ហើយជាអ្នកបិតបាំងសម្លៀកបំពាក់ខ្លួន ដោយការឃោរឃៅ» ព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។ «ដូច្នេះ ចូរប្រយ័ត្នចំពោះវិញ្ញាណរបស់អ្នក ហើយកុំប្រព្រឹត្ត
ក្បត់ឡើយ»។
[17]ពាក្យសម្ដីរបស់អ្នករាល់គ្នា រំខានដល់ព្រះអម្ចាស់ណាស់។ ប៉ុន្តែអ្នករាល់គ្នានិយាយថា «ហេតុអ្វីបានជាយើងបានរំខានព្រះអង្គដូចម្តេច?» ដោយនិយាយថា «អស់អ្នក
ដែលធ្វើការអាក្រក់ គឺល្អនៅចំពោះព្រះនេត្រនៃព្រះអម្ចាស់ ហើយព្រះអង្គសព្វព្រះហឫទ័យក្នុងពួកគេ» ឬ «តើព្រះអម្ចាស់នៃសេចក្ដីយុត្តិធម៌នៅឯណា?»

Malachi 2:1

ទុកដាក់នៅក្នុងចិត្តរបស់អ្នក

នេះសំដៅទៅលើ ការពិចារណាអ្វីមួយគឺសំខាន់ណាស់។

ការបកប្រែរបៀបផ្សេងទៀត: «ការពិចារណាគឺសំខាន់ណាស់»

ថ្វាយសិរីល្អដល់នាមយើង

កិត្តិយសត្រូវបានគេនិយាយដូចជាពាក្យ ដែលអាចផ្តល់ឱ្យទៅអ្នកណាម្នាក់។

នាមយើង

នៅទីនេះ ពាក្យនេះសំដៅទៅលើព្រះអម្ចាស់។

យើងនឹងចាត់បណ្ដាសាមកលើអ្នករាល់គ្នា

បណ្ដាសាត្រូវបានពោលថា វាជាពាក្យដែលអាចធ្វើទៅលើនរណាម្នាក់។

ការបកប្រែរបៀបផ្សេងទៀត: «យើងនឹងដាក់បណ្ដាសាអ្នក»

អ្នកមិនបានយកការបង្គាប់យើងទុកដាក់នៅក្នុងចិត្តរបស់អ្នក

នេះសំដៅទៅលើការពិចារណាក្រោមការបង្គាប់របស់ព្រះអម្ចាស់ គឺសំខាន់ណាស់។

ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនបានពិចារណាដល់ការបង្គាប់របស់យើង
គឺសំខាន់ណាស់»

Malachi 2:3

ហើយជះលាមកទៅលើមុខអ្នករាល់គ្នា

ឃ្លាថា «លាមកនៅលើមុខរបស់អ្នករាល់គ្នា» នៅទីនេះតំណាងឱ្យភាពអាម៉ាស់។

ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំប្រាកដជាធ្វើអោយអ្នករាល់គ្នាអាម៉ាស់មុខ
វានឹងអាក្រក់ដូចយើងបានយកលាមកដាក់លើមុខអ្នករាល់គ្នា»

ជាលាមកចេញពីពិធីបុណ្យរបស់អ្នក

ឃ្លាថា «ពិធីបុណ្យ» នៅទីនេះតំណាងឱ្យសត្វ
ដែលពួកបូជាចារ្យថ្វាយយញ្ញបូជានៅឯពិធីបុណ្យរបស់ជនជាតិអ៊ីស្រាអែល។
«លាមក» ប្រហែលជាសំដៅលើលាមកដែលត្រូវបានផលិតដោយសត្វ
មុនពេលពួកគេត្រូវបានសំលាប់សម្រាប់ការបូជា និងលាមក
ដែលត្រូវបានគេរកឃើញនៅខាងក្នុងសត្វ
នៅពេលដែលសាកសពរបស់ពួកគេត្រូវបានកាត់ផ្តាច់មុនពេលបូជា។
អ្នកធ្វើការនៅព្រះវិហារត្រូវដឹកលាមកនេះទៅកន្លែងមួយនៅខាងក្រៅព្រះវិហារ
ហើយប្រហែលជានៅខាងក្រៅនៃក្រុងយេរូសាឡិម។

ហើយគេនឹងយកអ្នករាល់គ្នាចេញទៅជាមួយនឹងលាមកនោះ

ពាក្យដ៏លំបាកនេះ អាចត្រូវបានបកប្រែថា «ព្រះអម្ចាស់នឹងយកអ្នកទៅជាមួយ»
នោះគឺលាមក។

ពាក្យនេះនៅតែបន្តការប្រៀបធៀបនៃការសម្លាប់សត្វសម្រាប់ការលះបង់
ហើយវាអាចត្រូវបានដាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «
ហើយពួកគេនឹងបោះអ្នកទៅក្នុងគំនរលាមកសត្វ ព្រះអម្ចាស់នឹងធ្វើឱ្យប្រាកដថា
ពួកគេនឹងនាំអ្នកទៅឆ្ងាយ នៅពេលពួកគេយកលាមកទាំងអស់ចេញ»

គេនឹងយកអ្នករាល់គ្នាចេញទៅជាមួយនឹងលាមកនោះ

ឃ្លានេះអាចមានន័យថា ១) ព្រះអម្ចាស់នឹងដាក់ទណ្ឌកម្មពួកបូជាចារ្យ
ដែលមិនស្មោះត្រង់ដោយសម្លាប់ពួកគេ ហើយបណ្ដាលឱ្យសាកសពរបស់ពួកគេ
ត្រូវបានគេយកទៅដាក់លើគំនរលាមកសត្វឬ ២)
ព្រះអម្ចាស់នឹងដាក់ទោសបូជាចារ្យ
ដែលមិនស្មោះត្រង់តាមរបៀបដ៏គួរឱ្យរន្ធត់ដែលវានឹងក្លាយ
ដូចជាសាកសពរបស់ពួកគេត្រូវបានយកចេញទៅជាមួយលាមកសត្វ។

ពួកលេវី

ព្រះអម្ចាស់មានព្រះបន្ទូលអំពីពួកលេវី ដូចជាព្រះអម្ចាស់ដែរ
គឺដូចជាកុលសម្ព័ន្ធពួកលេវីដែរ។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះកិច្ចព្រមព្រៀងរបស់យើងនឹងនៅជាមួយអ្នក ដែលជាកូនចៅរបស់ពួកលេវី»

Malachi 2:5

ព័ត៌មានទូទៅ:

ព្រះអម្ចាស់មានព្រះបន្ទូលថា
កុលសម្ព័ន្ធរបស់ពួកលេវីដូចជាពួកគេជាមនុស្សតែមួយ។

សម្ពន្ធមេត្រីជាមួយគេគឺជាជីវិត និងជាសេចក្ដីសុខសាន្ត

នៅទីនេះលទ្ធផលដែលបានគ្រោងទុកនៃកិច្ចព្រមព្រៀងបាននិយាយថា
ដូចជាពួកគេបានចុះកិច្ចព្រមព្រៀងដោយខ្លួនឯង។ ការបកប្រែរបៀបផ្សេងទៀត:
«គោលបំណងនៃកិច្ចព្រមព្រៀងរបស់យើងជាមួយពួកលេវី
គឺដើម្បីឱ្យពួកបូជាចារ្យរស់នៅដោយភាពរុងរឿង និងសេចក្ដីសុខ»

ភ័យខ្លាចដល់គេ ហើយគេក៏ភ័យខ្លាចយើង

កន្សោមនេះនៅតែបន្តពាក្យប្រៀបធៀបគ្នា

generated on Wed Sep 10 16:16:32 2025

ប៉ុន្តែបន្សល់ទុកនូវគំនិតដែលត្រូវបានបង្កប់នៅក្នុងអត្ថបទ។
នេះអាចចាប់ផ្តើមប្រយោគថ្មី។ ការបកប្រែរបៀបផ្សេងទៀត:
«កិច្ចព្រមព្រៀងរបស់យើងជាមួយគេ ក៏មានការភ័យខ្លាចផងដែរ ហើយគេកោតខ្លាចយើង» ឬ «នៅក្នុងកិច្ចព្រមព្រៀងរបស់យើងជាមួយគេ
យើងបានតម្រូវឱ្យគេកោតខ្លាចយើង ហើយគេបានកោតខ្លាចយើង»
ហើយឯឈរស្ងប់ស្ងែងនាមរបស់យើង
ឃ្លាថា «ព្រះនាមរបស់យើង» នៅទីនេះតំណាងអោយព្រះអម្ចាស់ផ្ទាល់។
នៅក្នុងមាត់ ហើយមិនឃើញ
ការស្វែងរកអ្វីមួយនៅទីនេះ តំណាងឱ្យរឿងដែលមានស្រាប់។
ការបកប្រែរបៀបផ្សេងទៀត: «មិនមានការកុហកឡើយ»
នៅបបូរមាត់គេ
ឃ្លាថា «បបូរមាត់» នៅទីនេះតំណាងឱ្យសមត្ថភាពនិយាយរបស់មនុស្សម្នាក់។
គេបានដើរជាមួយយើង
ការដើរនៅទីនេះតំណាងឱ្យការរស់នៅ
រស់នៅក្នុងជីវិតរបស់មនុស្សម្នាក់តាមរបៀបជាក់លាក់។
ក្នុងសេចក្តីសុខសាន្ត ហើយទៀងត្រង់
តំបន់នៃគំនិតនៅទីនេះ តំណាងឱ្យលក្ខណៈដែលពួកលីវីរស់នៅ។
ការបកប្រែរបៀបផ្សេងទៀត: «ដោយសន្តិភាព និងទៀងត្រង់»
នាំមនុស្សជាច្រើនចេញពីអំពើទុច្ចរិត
នៅទីនេះការបញ្ចុះបញ្ចូលមនុស្ស ឱ្យឈប់ធ្វើអំពើទុច្ចរិត បានគេនិយាយថា
កំពុងបង្វែរពួកគេអោយចេញពីអំពើទុច្ចរិត។ ការបកប្រែរបៀបផ្សេងទៀត:
«គេបានបញ្ចុះបញ្ចូលមនុស្សជាច្រើនឱ្យឈប់ធ្វើអំពើទុច្ចរិត»
ដ្បិតគួរឲ្យបបូរមាត់របស់បូជាចារ្យរក្សាទុកនូវចំណេះដឹង
ចំណេះដឹងនៅទីនេះ គឺបាននិយាយថា វាជាពាក្យដែលេពួកបូជាចារ្យអាចរក្សាបាន។
នៅក្នុងអត្ថបទនេះគំនិតអំពី «រក្សាទុកនូវចំណេះដឹង»
បង្កប់ន័យការទាក់ទងចំណេះដឹងពិតអំពីព្រះអម្ចាស់។
បបូរមាត់
ឃ្លាថា «បបូរមាត់» នៅទីនេះតំណាងឱ្យសមត្ថភាពនិយាយរបស់មនុស្សម្នាក់។
ស្វែងរកការបង្រៀន
«ក្លាយជាក្រឹត្យវិន័យ»
ស្វែងរកការបង្រៀន
ក្រឹត្យវិន័យនៅទីនេះ គឺបាននិយាយថា វាជាពាក្យដែលមនុស្សអាចស្វែងរកបាន។
ការបកប្រែរបៀបផ្សេងទៀត: «ចង់បានពួកបូជាចារ្យពិត ដើម្បីបង្រៀនដល់ពួកគេ»
ពីមាត់គេ
ឃ្លាថា «មាត់» នៅទីនេះតំណាងអោយអ្វីដែលមនុស្សបាននិយាយ។
Malachi 2:8
អ្នករាល់គ្នាបានបែរចេញពីផ្លូវនៃសេចក្តីពិត
របៀបត្រឹមត្រូវក្នុងការប្រព្រឹត្ត គឺបានពោលដូចជា វាជាផ្លូវត្រឹមត្រូវក្នុងការដើរតាម
ហើយបោះបង់ចោលការប្រព្រឹត្តត្រឹមត្រូវ គឺបាននិយាយថា
ដូចជាពួកគេកំពុងងាកចេញពីផ្លូវនោះ។
អ្នកបាននាំឲ្យមនុស្សជាច្រើនជំពប់ដួល
ការមិនគោរព ព្រះអម្ចាស់មានព្រះបន្ទូលថា ដូចជាពួកគេកំពុងជំពប់ដួល។
អ្នកបាននាំឲ្យមនុស្សជាច្រើនជំពប់ដួលក្នុងការគោរពដល់ក្រឹត្យវិន័យ
កន្សោម «ក្នុងក្រឹត្យវិន័យ» ផ្តល់នូវបរិបទសម្រាប់ «ការជំពប់ដួល» ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាបានបណ្តាលឱ្យមនុស្សជាច្រើនមិនគោរពក្រឹត្យវិន័យ»
នៅចំពោះមុខមនុស្សទាំងឡាយ
គំនិតនេះមានទំហំធំទូលាយ
ដែលតំណាងឱ្យការយល់ដឹងរបស់ប្រជាជនអំពីអាកប្បកិរិយាអាក្រក់របស់ពួកបូជាចារ្យ
កាន់តាមផ្លូវរបស់យើង
ឃ្លាថា «ផ្លូវ» នៅទីនេះតំណាងឱ្យ «បំណងប្រាថ្នា» និង «អាកប្បកិរិយា» ។
របៀបទាំងនេះគឺបាននិយាយថា ពួកគេគឺជារបស់ដែលអាចរក្សាទុកដោយមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើតាមបំណងប្រាថ្នារបស់យើងក្នុងរបៀបដែលអ្នករាល់គ្នាគួររស់នៅ»
បង្ហាញពីការចូលរួមជាមួយនឹងសេចក្តីបង្រៀន
«កំណត់ស្តង់ដានៃឥរិយាបទគឺងាយស្រួល សម្រាប់មនុស្សដែលអ្នកចូលចិត្ត
និងស្តង់ដារនៃឥរិយាបទគឺលំបាកសម្រាប់មនុស្សដែលគេមិនចូលចិត្ត»
បង្ហាញពីការចូលរួម
ទំលាប់នៅទីនេះ ការអនុគ្រោះដល់មនុស្សមួយចំនួនច្រើនជាងអ្នកដទៃ
ត្រូវបានពោលដូចជា ពួគគេជារឿងមួយដែលអាចបង្ហាញដល់អ្នកដទៃផ្សេងទៀត។
ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឱ្យមនុស្សដឹងថាអ្នកពេញចិត្តមនុស្សមួយចំនួនច្រើនជាងអ្នកដទៃ។
Malachi 2:10
ព័ត៌មានទូទៅ៖
ពួកព្យាការីម៉ាឡាកីនៅទីនេះ
គឺចាប់ផ្តើមនិយាយទៅកាន់ពួកអ៊ីស្រាអែលជាបងប្អូនរបស់ពួកគេ។
តើយើងទាំងអស់គ្នាមិនមានឪពុកតែមួយទេឬ?
តើមិនមែនមានព្រះជាម្ចាស់តែមួយដែលបង្កើតពួកយើង?
ម៉ាឡាគីសួរសំនួរទាំងនេះ ដើម្បីរំលឹកដល់ប្រជាជនអ៊ីស្រាអែលរបស់ពួកគេ
អំពីអ្វីដែលពួកគេបានដឹង។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដឹងថាយើងទាំងអស់គ្នាមានឪពុកតែម្នាក់គត់
ដែលព្រះអម្ចាស់របស់យើងបានបង្កើតប្រជាជាតិមួយចេញពីយើង»។ ឬ
«អ្នកទាំងអស់គ្នាដឹងថាព្រះជាម្ចាស់ជាឪពុករបស់ជនជាតិអ៊ីស្រាអែលរបស់យើងទាំងអស់
ពីព្រោះព្រះអម្ចាស់ជាអ្នកបង្កើតប្រជាជាតិរបស់យើង»។
តើមិនមែនមានព្រះជាម្ចាស់តែមួយដែលបង្កើតពួកយើង?
សំណួរនេះមានគោលបំណងបង្ហាញពីខ្លឹមសារភ្ជាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រាកដជា ព្រះអម្ចាស់តែមួយដែលបានបង្កើតយើងរាល់គ្នាមក»។
បង្កើតពួកយើង
នេះប្រហែលជាសំដៅទៅលើព្រះអម្ចាស់
ដែលបង្កើតហេព្រើសទៅជាប្រជាជាតិមួយ។
ហេតុអ្វីបានជាយើងបានជាយើងក្បត់ ម្នាក់ៗទាស់ប្រឆាំងនឹងបងប្អូនខ្លួន ឯង
ហើយប្រមាថសម្ពន្ធមេត្រីនៃពួកដូនតារបស់យើងដូច្នេះ?
ម៉ាឡាគីសួរសំនួរនេះ ដើម្បីបន្ទោសដល់ជនរួមជាតិអ៊ីស្រាអែលរបស់គាត់។
សំណួរនេះអាចត្រូវបានបង្ហាញជាខ្លឹមសារ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនគួរធ្វើបាបបងប្អូនយើង និងមិនគោរពកិច្ចព្រមព្រៀងរបស់ព្រះអម្ចាស់
ដោយមិនគោរពតាមបញ្ញត្តិរបស់ព្រះអម្ចាស់ ដូចដែលអ្នកបានធ្វើនោះទេ»។
ពួកយូដាគ្មានជំនឿ
ឃ្លាថា «ទឹកដីយូដា» នៅទីនេះតំណាងអោយប្រជាជននៅទឹកដីយូដា
ហើយជាការពិត ដែលពួកគេមិនស្មោះត្រង់នឹងព្រះអម្ចាស់ គឺត្រូវបានគេពោលថា
ពួកគេជាបុរសតែម្នាក់ ដែលមានឈ្មោះថា «យូដា»។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនយូដាមិនស្មោះត្រង់»
ប្រព្រឹត្តអំពើគួរស្អប់ខ្ពើម នៅក្នុងពួកអ៊ីស្រាអែល ហើយនៅក្រុងយេរូសាឡិមដែរ
នេះអាចជាកន្សោមទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនបានធ្វើរឿងគួរស្អប់ខ្ពើមនៅទឹកដីអ៊ីស្រាអែល និងនៅទីក្រុងយេរូសាឡិម»
ដ្បិតយូដាបានប្រមាថទីបរិសុទ្ធរបស់ព្រះអម្ចាស់
ឃ្លាថា «យូដា» នៅទីនេះសំដៅទៅលើជនជាតិអ៊ីស្រាអែលម្តងទៀត។
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិត ប្រជាជនយូដាបានប្រមាថទីបរិសុទ្ធរបស់
ព្រះអម្ចាស់»
បានរៀបការជាមួយកូនស្រីរបស់ព្រះជនជាតិដទៃ
ប្រជាជនយូដា
ត្រូវបានគេហៅជាថ្មីម្តងទៀតថាពួកគេជាបុរសតែម្នាក់ដែលមានឈ្មោះថា
«យូដា»។ ការបកប្រែរបៀបផ្សេងទៀត:
«បានរៀបការជាមួយស្ត្រីមកពីជាតិសាសន៍ដទៃ ស្ត្រីដែលគោរពបូជារូបព្រះ»
សូមព្រះអម្ចាស់កាត់ចេញពីត្រសាលនៃពួកយ៉ាកុបទៅ ចំពោះមនុស្សដែល
ការបំផ្លាញអ្វីមួយ
ត្រូវបានគេពោលជាញឹកញាប់ដូចដែលពួកគេកំពុងតែកាត់វាចេញពីអ្វីមួយផ្សេងទៀត។
ការបកប្រែរបៀបផ្សេងទៀត: «សូមព្រះអម្ចាស់បំផ្លាញអ្នកណាម្នាក់
នៅក្នុងជំរំរបស់លោកយ៉ាកុបដែល» ឬ
«សូមអោយព្រះអម្ចាស់សម្លាប់នរណាម្នាក់នៅក្នុងសហគមន៍របស់អ៊ីស្រាអែលដែល»។
កាត់ចេញពីត្រសាលនៃពួកយ៉ាកុប
ឃ្លាថា «តង់របស់យ៉ាកុប» នៅទីនេះតំណាងអោយសហគមន៍អ៊ីស្រាអែល។
យ៉ាកុប
ឃ្លាថា «យ៉ាកុប» នៅទីនេះតំណាងអោយជនជាតិអ៊ីស្រាអែលទាំងអស់
ពីព្រោះយ៉ាកុបជាបុព្វបុរសម្នាក់ដែលជនជាតិអ៊ីស្រាអែលបានចុះមក។
ជាអ្នកដែលដែលដឹងខ្លួនហើយក៏បានឆ្លើយតប
ពាក្យនេះដូចជាមានន័យថា «ពិតជាមនុស្សគ្រប់គ្នា»។
Malachi 2:13
ព័ត៌មានទូទៅ៖

generated on Wed Sep 10 16:16:32 2025

ម៉ាឡាគីបានបន្តនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលជាបងប្អូនរបស់គាត់។
អ្នករាល់គ្នាបានបិតបាំងអាសនានៃព្រះអម្ចាស់ ដោយទឹកភ្នែក
នេះគឺជាវិធី ដែលនិយាយបំផ្លើសសម្រាប់អ្នកថ្វាយបង្គំដែលយំសោក
នៅពេលពួកគេបានអធិស្ឋានដល់ព្រះអម្ចាស់សុំជំនួយ។ ខ្លឹមសារនេះ
គឺមានន័យបង្ហាញពីការមិនពេញចិត្ត
ចំពោះការគោរពបូជាមិនពិតរបស់អ្នកថ្វាយបង្គំព្រះអម្ចាស់។
ដោយការយំសោក ហើយស្រែកថ្ងូរ
ឃ្លាថា «យំ» និង «ស្រែកថ្ងូរ»
មានអត្ថន័យស្រដៀងគ្នានិងបង្កើនគំនិតនៃការយំសោក។
ការបកប្រែរបៀបផ្សេងទៀត: «យំសោកយ៉ាងខ្លាំង»
ពីព្រោះព្រះអង្គមិនបានបែរមករកតង្វាយ
ទតមើលអំណោយនៅទីនេះ
តំណាងឱ្យការទទួលយកហើយបង្ហាញពីការពេញចិត្តដល់អ្នកផ្តល់។
ពីព្រោះព្រះអង្គមិនបានបែរមករកតង្វាយ
នេះបញ្ជាក់ថា អ្នកដែលកំពុងយំសោកនៅជិតអាសនៈរបស់ព្រះអម្ចាស់
បានថ្វាយយញ្ញបូជាដល់ព្រះអង្គ។
ពីដៃអ្នករាល់គ្នា
ឃ្លាថា «ដៃ» នៅទីនេះតំណាងឱ្យអ្នកដែលថ្វាយដង្វាយ។
ការបកប្រែរបៀបផ្សេងទៀត: «ពីអ្នករាល់គ្នា»
Malachi 2:14
ហេតុអ្វីបានជាព្រះអង្គមិនទទួល?
គំនិតពេញលេញគឺ «ហេតុអ្វីបានជាគាត់មិនទតមើលតង្វាយ
ឬទទួលយកការពេញចិត្តពីដៃរបស់យើង?»
ប្រពន្ធដែលអ្នកបានគ្នាពីកាលក្រមុំកំលោះនោះ
«ស្ត្រីដែលអ្នករៀបការ ពេលនៅវ័យក្មេង»
ព្រះអម្ចាស់ជាសាក្សីរវាងអ្នកនឹងប្រពន្ធដែលអ្នកបានគ្នាពីកាលក្រមុំកំលោះ
ខ្លឹមសារនេះសន្មតថា ស្ត្រីនេះកំពុងនៅរស់។
ជាសាក្សីរវាងអ្នកនឹងប្រពន្ធដែលអ្នកបានគ្នាពីកាលក្រមុំកំលោះ
នេះគឺជាសាក្សីនៃកិច្ចព្រមព្រៀងរវាងមនុស្សពីរនាក់
ដែលត្រូវបានគេគិតថាកំពុងឈរ
រវាងពួកគេដើម្បីធ្វើសក្ខីកម្មអំពីអ្វីដែលពួកគេបានយល់ព្រមក្នុងករណីមានជម្លោះកើតឡើង
ការកាត់ទោសនេះក៏មានគោលបំណងដើម្បីរំលឹកប្រជាជនថា
ព្រះអម្ចាស់នឹងដាក់ទោសជនជាតិអ៊ីស្រាអែលណាម្នាក់ដែលរំលោភលើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍
តើព្រះអង្គមិនបានធ្វើឲ្យអ្នកទាំងពីរក្លាយជាតែមួយទេឬ?
សំណួរនេះអាចត្រូវបានបង្ហាញជាខ្លឹមសារ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ពិតប្រាកដជាបានបង្កើតប្តីនិងប្រពន្ធតែមួយ
ទោះបីមានព្រះវិញ្ញាណនៅមួយចំណែកក៏ដោយ»។
ធ្វើឲ្យអ្នកទាំងពីរក្លាយជាតែមួយ
ការបង្ហាញនេះដែលធ្វើឱ្យស្វាមី និងភរិយាក្លាយជាសាច់ញាតិតែមួយ។
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើឱ្យប្តី និងប្រពន្ធក្លាយជាសាច់ញាតិតែមួយ»
ពូជបរិសុទ្ធមកពីព្រះជាម្ចាស់
កុមារ ដែលនឹងគោរព និងស្តាប់បង្គាប់ព្រះអម្ចាស់។
នាងបានផ្តល់ក្តីមេត្តាដល់អ្នកហើយជាប្រពន្ធស្របតាមសម្ពន្ធមេត្រី
ខ្លឹមសារនេះដែលជនជាតិអ៊ីស្រាអែលភាគច្រើនបានលែងលះជាមួយប្រពន្ធរបស់ពួកគេ។
តាមសម្ពន្ធមេត្រី
«ដោយកិច្ចព្រមព្រៀងនៃអាពាហ៍ពិពាហ៍ ដែលអ្នកបានយល់ព្រមជាមួយ»
យើងស្អប់ការលះលែង
ឃ្លាថា «ការលែងលះ» នៅទីនេះតំណាងឱ្យទង្វើនៃការលែងលះ
នៅពេលដែលបុរសម្នាក់បញ្ឆេះប្រពន្ធរបស់គាត់
ដើម្បីបញ្ចប់អាពាហ៍ពិពាហ៍របស់គាត់ទៅនាង។ ការបកប្រែរបៀបផ្សេងទៀត:
«យើងស្អប់ការលះលែងគ្នាណាស់នៅពេលបុរសម្នាក់លែងលះប្រពន្ធរបស់ខ្លួន»
ជាអ្នកបិតបាំងសម្លៀកបំពាក់ខ្លួន ដោយការឃោរឃៅ
ឃ្លានេះប្រហែលជាមានន័យថា បុរសណាដែលធ្វើបាបប្រពន្ធរបស់គាត់។
ដូច្នេះ ចូរប្រយ័ត្នចំពោះវិញ្ញាណរបស់អ្នក ហើយកុំប្រព្រឹត្តក្បត់
«ដូច្នេះ ត្រូវប្រយ័ត្នប្រយែងស្មោះត្រង់នឹងភរិយារបស់អ្នក»
Malachi 2:17
អ្នករាល់គ្នា រំខានដល់ព្រះអម្ចាស់
ព្រះអម្ចាស់ បានពោលថា ឥរិយាបទរបស់មនុស្សអាចធ្វើឱ្យគាត់នឿយហត់ ប៉ុន្តែ
ព្រះអម្ចាស់មិនអាចនឿយហត់ខាងកាយសម្បទា និងអារម្មណ៍បានទេ។
ខ្លឹមសារនេះ ប្រហែលជាមានន័យថាព្រះអម្ចាស់បានអាក់អន់ចិត្ត ឬហួសចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកបានអន់ចិត្តនឹងព្រះអម្ចាស់»
ហេតុអ្វីបានជាយើងបានរំខានព្រះអង្គដូចម្តេច?
សំណួរនេះមានន័យថា ដើម្បីបដិសេធថាប្រជាជនមិនបានធ្វើអ្វីខុសទេ។
នេះអាចត្រូវបានបង្ហាញជាខ្លឹមសារ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងពិតជាមិនអស់សង្ឃឹមនឹងព្រះអម្ចាស់ទេ» ។
ដោយនិយាយថា
គំនិតពេញលេញនៅទីនេះគឺ «អ្នកបានធុញទ្រាន់នឹងព្រះអម្ចាស់ដោយនិយាយថា»
។ នេះគឺជាចម្លើយរបស់ព្យាការីចំពោះសំណួរវោហាស័ព្ទ។
នៅចំពោះព្រះនេត្រនៃព្រះអម្ចាស់
ឃ្លាថា «នៅចំពោះព្រះនេត្រនៃព្រះអម្ចាស់» នៅទីនេះតំណាងអោយ
«យោបល់របស់ព្រះអម្ចាស់»។
តើព្រះអង្គគង់នៅឯណា? តើព្រះអង្គនៃសេចក្តីយុត្តិធម៌នៅឯណា?
ពួកបូជាចារ្យបានសួរសំណួរនេះ
ដើម្បីអះអាងថាព្រះអម្ចាស់មិនខ្វល់ថាមនុស្សប្រព្រឹត្តអំពើអាក្រក់ ឬមិនធ្វើ
ឬថាគាត់មិនដែលដាក់ទោសមនុស្សអាក្រក់ឡើយ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ពិតជាមិនដាក់ទណ្ឌកម្មមនុស្សអាក្រក់ទេ!»
ព្រះអម្ចាស់នៃសេចក្តីយុត្តិធម៌
ព្រះអម្ចាស់ ជាអ្នកដែលដាក់ទោសមនុស្សទុច្ចរិត

3 [1]«មើល៍! យើងចាត់អ្នកនាំសាររបស់យើងឲ្យទៅ ហើយគេនឹងរៀបចំផ្លូវនៅពីមុខយើង។ ហើយព្រះអម្ចាស់ដែលអ្នករាល់គ្នាស្វែងរក នឹងយាងចូលក្នុងព្រះវិហាររបស់
ព្រះអង្គភ្លាម។ អ្នកនាំសារនៃសម្ពន្ធមេត្រីដែលអ្នករាល់គ្នាប្រាថ្នានោះ មើល៍! ព្រះអង្គនឹងយាងមក» ព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពិភពទាំងមូល។[2]ប៉ុន្តែតើអ្នកណាអាច
ទ្រាំបាននៅថ្ងៃដែលព្រះអង្គយាងមកនោះ? តើអ្នកណានឹងឈរ ពេលដែលព្រះអង្គលេចមក? ដ្បិតព្រះអង្គប្រៀបដូចជាភ្លើងសម្រាំង ហើយដូចកន្លែងបោក សម្អាត។
[3]ព្រះអង្គនឹងគង់ចុះ ដូចជាជាងសម្រាំង ហើយសម្រង់ប្រាក់ ហើយព្រះអង្គនឹងសម្អាតពួកកូនចៅលេវី។ ព្រះអង្គនឹងសម្រាំងគេដូចជាមាស និងប្រាក់ ហើយគេនឹងនាំយក
តង្វាយនៃសេចក្តីសុចរិតមកថ្វាយព្រះអម្ចាស់។
[4]ហើយតង្វាយរបស់ពួកយូដា និងយេរូសាឡិមនឹងគាប់ដល់ព្រះហឫទ័យដល់ព្រះជាម្ចាស់ ដូចកាលពីដើម គឺដូចកាលពីចាស់បុរាណនោះ។[5]«ហើយយើងនឹងមកជិតអ្នក
រាល់គ្នាដោយការជំនុំជម្រះ។ យើងនឹងធ្វើជាសាក្សីយ៉ាងរហ័ស ទាស់នឹងពួកគ្រូអាបធ្មប់ ហើយនឹងពួកកំផិត ទាស់នឹងពួកសាក្សីក្លែងក្លាយ ហើយទាស់នឹងពួក
ជិះជាន់លើប្រាក់ជួលរបស់កម្មករក្នុងឈ្នួលរបស់គេ ហើយសង្កត់សង្កិនស្ត្រីមេម៉ាយ និងមនុស្សកំព្រាផង ហើយទាស់នឹងអ្នកដែលបែរទៅរកជនជាតិដទៃ
ហើយទាស់នឹងអ្នកដែលមិនគោរពយើង» ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល។
[6]«ដ្បិតយើង ព្រះអម្ចាស់ មិនប្រែប្រួលទេ ដូច្នេះហើយអ្នក ពួកកូនចៅយ៉ាកុបអើយ មិនទាន់មកដល់ទីបញ្ចប់ដោយ។[7]ចាប់តាំងពីជំនាន់ដូនតារបស់អ្នក
បានបែរចេញពីក្តីបរិសុទ្ធរបស់យើងហើយមិនរក្សាការទាំងនោះឡើយ។ ចូរត្រឡប់មកយើងវិញ ហើយយើងនឹងត្រឡប់មករកអ្នករាល់គ្នាដែរ»
ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល។ «តែអ្នកនិយាយថា តើយើងនឹងវិលទៅវិញយ៉ាងដូចម្តេច?"
[8]តើមនុស្សនឹងប្លន់ព្រះជាម្ចាស់ឬ? ប៉ុន្តែ អ្នករាល់គ្នាបានប្លន់យើង។ តែអ្នកនិយាយថា តើយើងបានយករបស់ព្រះអង្គដូចម្តេច? គឺក្នុងតង្វាយមួយភាគក្នុងដប់។[9]អ្នករាល់
គ្នាត្រូវបណ្តាសាជាមួយបណ្តាសា ដ្បិតអ្នកបានប្លន់យើង ប្រជាតិទាំងមូល។
[10]ចូរយកតង្វាយមួយភាគក្នុងដប់ទាំងអស់មកដាក់ក្នុងឃ្លាំង ដូច្នេះហើយនឹងមានអាហារនៅក្នុងដំណាក់របស់យើង ហើយល្បងលយើងឥឡូវក្នុងការនេះ» ព្រះបន្ទូលរបស់
ព្រះអម្ចាស់នៃពិភពទាំងមូល «បើយើងមិនបើកបង្ហាញដល់អ្នកនូវទ្វារនៃស្ថានសួគ៌ ហើយចាក់ព្រះពរដល់អ្នករហូតដល់គ្មានកន្លែងសម្រាប់នឹងដាក់ផង។[11]យើង
នឹងថ្កោលទាស់នឹងអ្នកដែលបំផ្លាញផលដំណាំ ដូច្នេះគេនឹងមិនបំផ្លាញការច្រូតកាត់នៃដីរបស់អ្នក។ ដើមទំពាំងបាយជូរនៅចម្ការ នឹងមិនជ្រុះផ្លែដែរ» ព្រះបន្ទូលព្រះអម្ចាស់
នៃពិភពទាំងមូល។[12]«ប្រជាតិទាំងមូលនឹងហៅអ្នករាល់គ្នាថាមានពរ ដ្បិតទឹកដីរបស់អ្នករាល់គ្នា នឹងបានជាទឹកដីអរសប្បាយ ព្រះបន្ទូលរបស់ព្រះអម្ចាស់នៃ
ពិភពទាំងមូល»។

generated on Wed Sep 10 16:16:32 2025

[13]ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ពាក្យសម្ដីរបស់អ្នករាល់គ្នាបានទាស់នឹងយើងយ៉ាងខ្លាំង ទោះបើយ៉ាងនោះក៏អ្នករាល់គ្នាថា យើងបាននិយាយអ្វីទាស់នឹងព្រះអង្គ[14]គឺអ្នករាល់គ្នាពោលថា ការដែលខំគោរពបម្រើព្រះជាម្ចាស់ នោះឥតអំពើទេ ហើយដែលយើងបានរក្សាបញ្ញើរបស់ព្រះអម្ចាស់នៃពិភពទាំងមូល ព្រមទាំងដើរនៅចំពោះព្រះអង្គដោយកាន់ទុក្ខដូច្នេះ តើមានប្រយោជន៍អ្វី?[15]ដ្បិត យើងរាប់មនុស្សឆ្មើងឆ្មៃ ទុកជាសប្បាយហើយ ពួកអ្នកដែលប្រព្រឹត្តការអាក្រក់បានតាំងឡើង គេល្បងលព្រះជាម្ចាស់ហើយក៏រួចខ្លួន»។
[16]ហើយពួកអ្នកដែលកោតខ្លាចដល់ព្រះអម្ចាស់ បាននិយាយគ្នាទៅវិញទៅមកថា។ ព្រះអម្ចាស់ប្រុងស្ដាប់ ហើយបានស្ដាប់ ហើយសៀវភៅនៃការចងចាំ បានសរសេរទុកនៅចំពោះព្រះអង្គ សម្រាប់ពួកអ្នកដែលកោតខ្លាចព្រះអម្ចាស់ ហើយតម្កើងព្រះនាមព្រះអង្គឡើង។
[17]«ពួកគេនឹងជារបស់យើង» ព្រះ បន្ទូលរបស់ព្រះអម្ចាស់នៃពួកពិភពទាំង មូល «សម្បត្តិដែលជាកម្មសិទ្ធិរបស់យើង នៅថ្ងៃដែលយើងបានប្រព្រឹត្ត។ យើងនឹងប្រណីដល់ពួកគេ ដូចជាមនុស្សអាណិតដល់កូនដែលបានបម្រើដល់ខ្លួនដែរ។[18]ហើយម្ដងទៀត អ្នករាល់គ្នានឹងបាន ញែកចេញ ពីមនុស្សសុចរិតនឹងមនុស្សអាក្រក់ រវាងអ្នកដែលថ្វាយបង្គំព្រះជាម្ចាស់នឹងអ្នកដែលមិនថ្វាយបង្គំព្រះអង្គ។

Malachi 3:1
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់ចាប់ផ្តើមនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលម្តងទៀតនៅក្នុងខ ១ ប៉ុន្តែព្យាការីម៉ាឡាគីចាប់ផ្តើមនិយាយនៅក្នុងខ ២ ។
មើល៍
«មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នក»
គេនឹងរៀបចំផ្លូវនៅពីមុខយើង
ការរៀបចំនៅទីនេះឱ្យប្រជាជនត្រៀមខ្លួន ដើម្បីទទួលយកព្រះអម្ចាស់
ត្រូវបានគេនិយាយដូចជា
ផ្លូវមួយត្រូវបានគេបោសសំអាតសម្រាប់ព្រះអម្ចាស់ដើម្បីធ្វើដំណើរ។
ហើយព្រះអម្ចាស់ដែលអ្នករាល់គ្នាស្វែងរក...អ្នកនាំសារនៃសម្ពន្ធមេត្រីដែលអ្នករាល់គ្នាប្រាថ្នានោះ
នៅសម័យទំនើបខ្លះ បកប្រែដើម្បីបញ្ជាក់ថាពាក្យទាំងពីរនេះ
សំដៅទៅលើមនុស្សតែមួយ។ នៅសម័យទំនើបដទៃទៀតបន្សល់ទុកនូវសំណួរនេះដែលមិនច្បាស់។
យើងសូមណែនាំថាការបកប្រែបន្សល់ទុកនូវភាពមិនច្បាស់លាស់ដូចជា ULB និង UDB ។
អ្នកនាំសារនៃសម្ពន្ធមេត្រី
ស្ទើរតែគ្រប់ជំនាន់ទាំងអស់ បន្សល់ទុកនូវអារម្មណ៍នៃការបញ្ចេញមតិនេះ។ ប៉ុន្តែអ្នកបកប្រែប្រហែលជាត្រូវបង្ហាញពីទំនាក់ទំនងរវាង «អ្នកនាំសារ» និង « សេចក្តីសញ្ញា»។ UDB បង្ហាញ «អ្នកនាំសារ»
ជាការសន្យាដែលបានសន្យាដោយកិច្ចព្រមព្រៀង
ដែលព្រះអម្ចាស់មានជាមួយអ៊ីស្រាអែល។ ជម្រើសមួយទៀតគឺ
បង្ហាញសារទូតដែលជាមនុស្សម្នាក់ដែលនឹងបញ្ជាក់សេចក្តីសញ្ញានោះ
ឬប្រកាសសេចក្តីសញ្ញាថ្មី។
ប៉ុន្តែតើអ្នកណាអាចទ្រាំបាននៅថ្ងៃដែលព្រះអង្គយាងមកនោះ? តើអ្នកណានឹងឈរ ពេលដែលព្រះអង្គលេចមក?
សំណួរវោហារទាំងនេះ
បង្ហាញថាគ្មាននរណាម្នាក់អាចតទល់នឹងព្រះអម្ចាស់បានឡើយ
នៅពេលដែលព្រះអម្ចាស់យាងមក។
ពួកវាអាចត្រូវបានបញ្ចូលគ្នាទៅក្នុងខ្លឹមសារមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ទោះយ៉ាងណាគ្មាននរណាម្នាក់នឹងអាចតទល់នឹងព្រះអម្ចាស់បានទេ
នៅពេលដែលព្រះអម្ចាស់បានមកវិនិច្ឆ័យពួកគេ។»
នៅថ្ងៃដែលព្រះអង្គយាងមក
ឃ្លាថា «ថ្ងៃ» នៅទីនេះតំណាងឱ្យ «ពេលវេលា»។ ការបកប្រែរបៀបផ្សេងទៀត:
«ពេលវេលាដែលព្រះអម្ចាស់បានយាងមកដល់»
អ្នកណានឹងឈរ
ការឈរនៅទីនេះតំណាងឱ្យការទប់ទល់នឹង ការវាយប្រហារ
ឬការចោទប្រកាន់របស់អ្នកណាម្នាក់។
ដ្បិតព្រះអង្គប្រៀបដូចជាងភ្លើងសម្រាំង ហើយដូចកន្លែងបោក សម្អាត
ការកាត់ទោសនេះផ្តល់មូលហេតុ ដែលគ្មានអ្នកណាម្នាក់អាចតតាំងនឹងព្រះអម្ចាស់
នៅពេលដែលព្រះអម្ចាស់យាងមក។
អំណាចរបស់ព្រះអម្ចាស់ក្នុងការថ្កោលទោសប្រជាជន
និងបញ្ឈប់ពួកគេពីអំពើបាបត្រូវបានគេនិយាយថា
វាជាអំណាចនៃសាប៊ូដ៏ខ្លាំងដើម្បីទៅសំអាតសម្លៀកបំពាក់ ឬអំណាចនៃភ្លើង
ដើម្បីរំលាយវត្ថុ។ ទាំងនេះជារបៀបនិយាយទៅកាន់
ព្រះចេស្តារបស់ព្រះអម្ចាស់ក្នុងការធ្វើអ្វីៗ ទាំងនេះមិនអាចបញ្ឈប់បានឡើយ។
ព្រះអង្គនឹងសម្អាតពួកកូនចៅលេវី
ការអភ័យទោសដល់កូនប្រុសរបស់លេវី
និងបញ្ចុះបញ្ចូលពួកគេមិនឱ្យធ្វើអំពើបាបទៀតទេគឺ
ដូចពួកគេបានសម្អាតលោហធាតុ។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយព្រះអម្ចាស់នឹងកែសំរួលកូនប្រុសរបស់លេវី
ហើយអត់ទោសឱ្យពួកគេដែលបានធ្វើបាប»
ពួកកូនចៅលេវី
ឃ្លាថា «កូនប្រុស» នៅទីនេះសំដៅទៅលើកូនចៅ។
កូនចៅប្រុសៗរបស់លេវីជាពួកបូជាចារ្យ និងជាកម្មករនៅក្នុងព្រះវិហារ។
ព្រះអង្គនឹងគង់ចុះ
ការអង្គុយនៅទីនេះ បង្កប់នូវសកម្មភាពរបស់ជាងសំណង់ម្នាក់
ដែលអង្គុយចុះដើម្បីនឹងសម្អាតមាស ឬប្រាក់បន្តិចបន្តួច។
វាក៏បង្ហាញពីសកម្មភាពរបស់ស្តេច ដែលអង្គុយចុះដើម្បីវិនិច្ឆ័យទោសប្រជាជន
និងផ្តល់ក្រឹត្យ។
ព្រះអង្គនឹងសម្រាំងគេដូចជាមាស និងប្រាក់
ការបញ្ចុះបញ្ចូលមនុស្សនៅទីនេះ មិនអោយធ្វើអំពើបាបទៀតទេ
គឺដូចជាជាងដែកម្នាក់កំពុងតែធ្វើមាស និងប្រាក់អោយបានស្អាត។ .
ហើយគេនឹងនាំយកតង្វាយនៃសេចក្តីសុចរិតមកថ្វាយព្រះអម្ចាស់
ឃ្លាថា «សេចក្តីសុចរិត» មានន័យថា «ការជម្រុញដោយបំណងប្រាថ្នាដ៏សុចរិត
ក្នុងការថ្វាយបង្គំព្រះអម្ចាស់» ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងថ្វាយតង្វាយ
ដែលគាប់ព្រះហឫទ័យដល់ព្រះអម្ចាស់ដើម្បីថ្វាយបង្គំព្រះអម្ចាស់»។
Malachi 3:4
ព័ត៌មានទូទៅ៖
ម៉ាឡាគីបន្តនិយាយនៅក្នុងខ ៤
ប៉ុន្តែព្រះអម្ចាស់ចាប់ផ្តើមនិយាយម្តងទៀតនៅក្នុងខ ៥ ។
តង្វាយរបស់ពួកយូដា និងយេរូសាឡិម
ឃ្លាថា «យូដា» និង «ក្រុងយេរូសាឡិម»
នៅទីនេះតំណាងអោយប្រជាជននៅកន្លែងទាំងនោះ។ ការបកប្រែរបៀបផ្សេងទៀត:
«តង្វាយដែលប្រជាជនយូដា និងក្រុងយេរូសាឡឹមយកមកថ្វាយ»
ដូចកាលពីដើម គឺដូចកាលពីចាស់បុរាណនោះ
ឃ្លាទាំងពីរនេះមានអត្ថន័យដូចៗគ្នា
ហើយសង្កត់ធ្ងន់ថាដង្វាយនោះត្រូវបានគាប់ព្រះហឫទ័យព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដូចដែលពួកគេមាននៅក្នុងអតីតកាលដ៏ឆ្ងាយ»
ហើយយើងនឹងមកជិតអ្នករាល់គ្នាដោយការជំនុំជម្រះ
ឃ្លាថា «ការវិនិច្ឆ័យ» នៅទីនេះសំដៅទៅលើសកម្មភាពនៃការវិនិច្ឆ័យ។
ការបកប្រែរបៀបផ្សេងទៀត: «បន្ទាប់មក យើងនឹងមកជិតអ្នករាល់គ្នា
ដើម្បីវិនិច្ឆ័យ»
ជិះជាន់លើប្រាក់ជួលរបស់កម្មករក្នុងឈ្នួលរបស់គេ
«បណ្តាលឱ្យកូនឈ្នួលនិយោជិត
ដែលបានរងទុក្ខដោយមិនបង់ថ្លៃឱ្យពួកគេដែលបានធ្វើការ»
បែរទៅរកជនជាតិដទៃ
នោះគឺការចូលមកស្នាក់អាស្រ័យ ពីការទទួលបានសិទ្ធិរបស់ពួកគេ។
ការដកហូតសិទ្ធិរបស់ប្រជាជនត្រូវបានគេនិយាយថា
ដូចជាពួកគេបង្វែររាងកាយពួកគេចេញពីខ្លួនឯង។ ប្រហែលជាគំនិតកំពុងតែចូលមកអ្នកណាម្នាក់ ដែលមករកអ្វីដែលខុសដើម្បីត្រូវបានកំណត់ត្រឹមត្រូវវិញ។
ការបកប្រែរបៀបផ្សេងទៀត: «ការបដិសេធជនបរទេស
ដែលរស់នៅក្នុងប្រទេសអ៊ីស្រាអែល ជាសិទ្ធិដែលពួកគេគួរតែមាន»
Malachi 3:6
ព័ត៌មានទូទៅ៖

generated on Wed Sep 10 16:16:32 2025

ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
មិនទាន់មកដល់ទីបញ្ចប់ដោយ
«មិនបានស្លាប់ទេ»
ចាប់តាំងពីជំនាន់ដូនតារបស់អ្នក
បានបែរចេញពីក្តីបរិសុទ្ធរបស់យើងហើយមិនរក្សាការទាំងនោះឡើយ
ការមិនគោរពពិធីបរិសុទ្ធរបស់ព្រះអម្ចាស់ ត្រូវបានគេនិយាយថា
ដូចជាពួកគេកំពុងងាកចេញពីព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នករាល់គ្នា មិនគោរពតាមវិន័យរបស់យើង
តាំងពីជំនាន់ដូនតារបស់អ្នករាល់គ្នាមកម្ល៉េះ»
ចូរត្រឡប់មកយើងវិញ ហើយយើងនឹងត្រឡប់មករកអ្នករាល់គ្នាដែរ
នៅទីនេះ ការស្រឡាញ់គ្នាទៅវិញទៅមក និងភាពស្មោះត្រង់ចំពោះគ្នា
ត្រូវបានគេនិយាយដូចជាកំពុងវិលត្រឡប់មករកគ្នាវិញ។
ការបកប្រែរបៀបផ្សេងទៀត: «ស្រឡាញ់យើង ហើយគោរពយើង
ហើយយើងនឹងជួយអ្នករាល់គ្នាជានិច្ច»
តើយើងនឹងវិលទៅវិញយ៉ាងដូចម្តេច?
ប្រជាជនសួរសំណួរនេះ
ដើម្បីអះអាងថាពួកគេមិនដែលឈប់គោរពព្រះអម្ចាស់ឡើយ។
នេះអាចត្រូវបានបង្ហាញជាខ្លឹមសារ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនដែលឃ្លាតឆ្ងាយពីអ្នកទេ ដូច្នេះយើងមិនអាចត្រឡប់មកអ្នកវិញទេ»។ ឬ
«យើងមិនដែលឃ្លាតឆ្ងាយពីអ្នកទេ
ដូច្នេះវាគ្មានន័យទេក្នុងការនិយាយពីពួកយើងថា
វិលត្រឡប់មករកអ្នករាល់គ្នាវិញ»។
Malachi 3:8
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់ នៅតែបន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
តើមនុស្សនឹងប្លន់ព្រះជាម្ចាស់ឬ?
សំណួរនេះបានបង្កប់ន័យថា គំនិតប្លន់របស់ព្រះអម្ចាស់គឺអាក្រក់ខ្លាំងណាស់។
នេះអាចត្រូវបានបង្ហាញជាខ្លឹមសារ។ ការបកប្រែរបៀបផ្សេងទៀត:
«បុរសមិនគួរណានឹងប្លន់ព្រះអម្ចាស់ទេ» ។ ឬ
«គ្មាននរណាម្នាក់អាចប្លន់យើងបានទេ» ។
តើយើងបានយករបស់ព្រះអង្គដូចម្តេច?
សំណួរនេះបានបង្កប់ន័យថា ប្រជាជនមិនគិតថាពួកគេបានប្លន់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «យើងពិតជាមិនបានប្លន់អ្នករាល់គ្នាទេ» ។
ក្នុងតង្វាយមួយភាគក្នុងដប់
ការឆ្លើយតបមកពីព្រះអម្ចាស់ នេះបង្កប់នូវចម្លើយយ៉ាងពេញលេញ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នករាល់គ្នាបានប្លន់យើង
ដោយដកយកពីដង្វាយមួយភាគដប់របស់អ្នករាល់គ្នាពីយើង»
អ្នករាល់គ្នាត្រូវបណ្តាសាជាមួយបណ្តាសា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងពិតជាបានដាក់បណ្តាសាអ្នករាល់គ្នាមែន!»
អ្នកបានប្លន់យើង ប្រជាតិទាំងមូល
ឃ្លាថា «ប្រជាជាតិ»
នៅទីនេះតំណាងឲ្យប្រជាជនដែលព្រះអម្ចាស់កំពុងតែមានបន្ទូលថា។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកទាំងអស់គ្នានៅក្នុងប្រទេសទាំងមូលកំពុងប្លន់យើង»
Malachi 3:10
ព័ត៌មានទូទៅ៖
ព្រះអម្ចាស់នៅតែបន្តមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
តង្វាយមួយភាគក្នុងដប់
«មួយភាគដប់ទាំងអស់»
ដំណាក់របស់យើង
ឃ្លាថា «ដំណាក់» នៅទីនេះតំណាងឱ្យព្រះវិហារ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះវិហាររបស់យើង»
ហើយល្បងលយើងឥឡូវ ...បើយើងមិនបើកបង្ហាញដល់អ្នកនូវទ្វារនៃស្ថានសួគ៌
ពាក្យបញ្ជា «សាកល្បងយើង» នៅទីនេះតំណាងឱ្យអ្វីមួយ
ដែលប្រជាជនអាចធ្វើបាន ហើយគួរធ្វើ: «ប្រសិនបើអ្នករាល់គ្នាសាកល្បងយើង»។
នេះអាចត្រូវបានបែងចែកជាពីរប្រយោគផងដែរ។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយប្រសិនបើអ្នករាល់គ្នាសាកល្បងយើង ... យើងនឹងបើកបង្ហួចនៅលើមេឃ « ឬ » ហើយអ្នករាល់គ្នាគួរតែសាកល្បងយើង ... ប្រសិនបើអ្នករាល់គ្នាធ្វើ
យើងនឹងបើកបង្ហួចស្ថានសួគ៌»
ប្រជាតិទាំងមូលនឹងហៅអ្នករាល់គ្នាថាមានពរ
នៅទីនេះត្រូវបានគេហៅថា ពរជ័យ តំណាងអោយបានពរ។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជាតិទាំងអស់នឹងដឹងថាអ្នករាល់គ្នាបានទទួលពរ»
ប្រជាតិទាំងមូល
ការបង្ហាញនេះ តំណាងអោយប្រជាជននៅគ្រប់ជនជាតិ។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៅគ្រប់ជាតិសាសន៏»
ជាទឹកដីអរសប្បាយ
ឃ្លាថា «សប្បាយណាស់» នៅទីនេះតំណាងឱ្យលក្ខខណ្ឌ
ដែលអ្នករស់នៅលើទឹកដីសប្បាយណាស់នឹងដីរបស់ពួកគេ។
Malachi 3:13
ព័ត៌មានទូទៅ៖
ខគម្ពីរទាំងនេះចាប់ផ្តើមផ្នែកថ្មីនៅក្នុងសៀវភៅ។ នៅទីនេះ
ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់ប្រជាជនអ៊ីស្រាអែល។
ពាក្យសម្តីរបស់អ្នករាល់គ្នាបានទាស់នឹងយើងយ៉ាងខ្លាំង
នៅទីនេះ «ខ្លាំង» តំណាងឱ្យ «អាក្រក់» ឬ «គួរឱ្យភ័យខ្លាច» ។ និង
«ពាក្យរបស់អ្នក» តំណាងឱ្យ «អ្វីដែលអ្នកបាននិយាយ» ។
ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលអ្នករាល់គ្នាបាននិយាយអំពីយើងគឺគួរឱ្យភ័យខ្លាច»
យើងបាននិយាយអ្វីទាស់នឹងព្រះអង្គ?
ប្រជាជនសួរសំណួរនេះ
ដើម្បីអះអាងថាពួកគេមិនបាននិយាយអ្វីប្រឆាំងនឹងព្រះអម្ចាស់ទេ។
នេះអាចត្រូវបានបង្ហាញជាខ្លឹមសារ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនបាននិយាយអ្វីក្នុងចំណោមយើងប្រឆាំងនឹងអ្នករាល់គ្នាទេ»។
ព្រះអម្ចាស់នៃពិភពទាំងមូល ព្រមទាំងដើរនៅចំពោះព្រះអង្គដោយកាន់ទុក្ខដូច្នេះ តើមានប្រយោជន៍
អ្វី?
ប្រជាជនសួរសំណួរនេះក្នុងចំណោមពួកគេដើម្បីធ្វើជាខ្លឹមសារភ្ជាប់។
ការបកប្រែរបៀបផ្សេងទៀត: «វាគ្មានប្រយោជន៍ទេ
ដែលយើងបានធ្វើតាមតម្រូវការរបស់គាត់
ហើយដើរដោយសោកសៅចំពោះព្រះអម្ចាស់នៃពិភពទាំងមូល»។
ព្រះអម្ចាស់នៃពិភពទាំងមូល ព្រមទាំងដើរនៅចំពោះព្រះអង្គ
ឃ្លាថា «ដើរដោយកាន់ទុក្ខ» នៅទីនេះតំណាងឱ្យ «មានអាកប្បកិរិយាកាន់ទុក្ខ»
ប្រហែលជាដើម្បីនឹងបង្ហាញពីភាពទុក្ខព្រួយចំពោះអំពើបាបរបស់ពួកគេ។
នៅចំពោះព្រះអង្គ
ការបង្ហាញនៅទីនេះសំដៅទៅលើព្រះអម្ចាស់ដែលដឹងអំពីអ្វីដែលប្រជាជនកំពុងធ្វើ។
ដ្បិត យើងរាប់មនុស្សឆ្មើងឆ្មៃ
ត្រូវបានគេហៅថា «ប្រទានពរ» នៅទីនេះតំណាងឱ្យការទទួលបានពរ។
ការបកប្រែរបៀបផ្សេងទៀត: «យើងនិយាយថាមនុស្សឆ្មើងឆ្មៃ ទុកជាសប្បាយ
ហើយ »
ដ្បិត យើងរាប់មនុស្សឆ្មើងឆ្មៃ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនិយាយថាមនុស្សឆ្មើងឆ្មៃគឺល្អ»
ក៏រួចខ្លួន
នោះគឺ «ពួកគេក៏រួចខ្លួនពីការដាក់ទណ្ឌកម្មរបស់ព្រះអម្ចាស់»។
Malachi 3:16
ព័ត៌មានទូទៅ៖
ព្រឹត្តិការណ៍ដែលបានពិពណ៌នា នៅទីនេះប្រហែលជាបានកើតឡើង
បន្ទាប់ពីមនុស្សដែលគោរពព្រះអម្ចាស់នៅអ៊ីស្រាអែលបានប្រែចិត្តពីអំពើបាបរបស់ពួកគេ។
(សូមចូលទៅមើល UDB)
ហើយសៀវភៅនៃការចងចាំ បានសរសេរទុកនៅចំពោះព្រះអង្គ សម្រាប់ពួកអ្នកដែលកោតខ្លាច
ព្រះអម្ចាស់
នេះអាចមានន័យថា ១) ជនជាតិអ៊ីស្រាអែលបានសរសេរសៀវភៅមួយក្បាល
ដូច្នេះពួកគេនឹងចងចាំនូវអ្វីដែលពួកគេបានសន្យា និងដាក់ឈ្មោះមនុស្ស
ដែលគោរពកោតខ្លាចព្រះអម្ចាស់ឬ ២) ព្រះអម្ចាស់បាន បណ្តាលឲ្យ
អ្នកណាម្នាក់នៅស្ថានសួគ៌សរសេរសៀវភៅមួយក្បាល
ដែលមានឈ្មោះមនុស្សដែលគោរពកោតខ្លាចព្រះអម្ចាស់។
សៀវភៅនៃការចងចាំ
ការបង្ហាញនេះសំដៅទៅលើសៀវភៅណាដែលជួយមនុស្សឱ្យចងចាំរឿងសំខាន់ៗដូចជា

generated on Wed Sep 10 16:16:32 2025

ព្រឹត្តិការណ៍ ឬមនុស្សដែលធ្លាប់រស់នៅកាលពីអតីតកាល។
តម្កើងព្រះនាមព្រះអង្គឡើង
ឃ្លាថា «ឈ្មោះរបស់យើង» នៅទីនេះតំណាងឱ្យព្រះអម្ចាស់ផ្ទាល់។
Malachi 3:17
ពួកគេនឹងជារបស់យើង
«ពួកគេនឹងធ្វើជាប្រជាជនរបស់យើង»
សម្បត្តិដែលជាកម្មសិទ្ធិរបស់យើង
ឃ្លាថា « ទ្រព្យ» នៅទីនេះសំដៅទៅលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់មនុស្សម្នាក់។ គំនិតនេះអាចត្រូវបានបង្ហាញដោយកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងជាកម្មសិទ្ធិរបស់យើងទាំងស្រុង»
យើងបានប្រព្រឹត្ត
ការបង្ហាញនេះសំដៅទៅលើពេលវេលា ដែលព្រះអម្ចាស់នឹងវិនិច្ឆ័យទោស និងដាក់ទណ្ឌកម្មជនជាតិអ៊ីស្រាអែល ដែលបះបោរដោយផ្តល់ជ័យជំនះដល់ជនជាតិអ៊ីស្រាអែលដោយភាពស្មោះត្រង់។ (សូមចូលទៅមើល 4:1)
មនុស្សអាក្រក់ រវាងអ្នក
«ឃើញភាពខុសគ្នារវាង» ឬ «ការប្រព្រឹត្តខុសគ្នា»

---

4 [1]ដ្បិតមើល៍! ថ្ងៃនោះកំពុងតែមកដល់ ឆេះដូចឡដុតនំ ពេលពួកអ្នកឆ្មើងឆ្មៃ ហើយពួកអ្នកប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាចំបើង។ ថ្ងៃដែលត្រូវមកដល់នោះ នឹងដុតពួកគេ» ព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពួកពិភពទាំងមូល «ដូច្នេះមិនទុកឲ្យគេសូម្បីតែឫសនិងមែក។[2]ប៉ុន្តែសម្រាប់អ្នកដែលកោតខ្លាចព្រះនាមរបស់យើង ព្រះអាទិត្យនៃសេចក្តីសុចរិតនឹងរះឡើង មានសស្លាបនៃការប្រោសឲ្យជាផង។ អ្នករាល់គ្នានឹងចេញទៅ លោតកញ្ឆោងដូចជាកូនគោដែលចេញពីក្រោល។[3]នៅថ្ងៃនោះអ្នករាល់គ្នានឹងជាន់ឈ្លីពួកមនុស្សអាក្រក់ ដ្បិតគេនឹងដូចជាផេះនៅក្រោមបាទជើងនៅថ្ងៃដែលយើងប្រព្រឹត្ត» ព្រះបន្ទូលព្រះអម្ចាស់នៃពិភពទាំងមូល។
[4]«ចូរនឹកចាំពីសេចក្តីបង្រៀនរបស់លោកម៉ូសេជាអ្នកបម្រើរបស់យើង ដែលយើងបានផ្តល់ដល់គាត់នៅលើភ្នំហោរែប សម្រាប់ជនជាតិអ៊ីស្រាអែលទាំងមូល គឺបញ្ញត្តិច្បាប់ ហើយសិទ្ធអំណាចទាំងឡាយ ។[5]មើល៍! យើងនឹងចាត់ព្យាការីអេលីយ៉ា មុនថ្ងៃដែលនឹងមកដល់នៃការអស្ចារ្យ ហើយនិងគួរឲ្យខ្លាច នៅថ្ងៃព្រះអម្ចាស់។[6]លោកនឹងបង្វែរចិត្តឪពុកមករកកូន ហើយដួងចិត្តរបស់កូនក៏មករកឪពុកដែរ ដូច្នេះយើងមិនមកប្រហារផែនដីជាមួយការបំផ្លាញទាំងមូលឡើយ»។

Malachi 4:1
មើល៍
ឃ្លាថា «មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលយើងរៀបនឹងប្រាប់អ្នករាល់គ្នា»
ថ្ងៃនោះកំពុងតែមកដល់ ឆេះដូចឡដុតនំ
គ្រោះមហន្តរាយដែលកើតឡើងនៅពេលនេះត្រូវបានគេនិយាយដូចជាថ្ងៃដែលវាកំពុងតែមកដល់ ការជំនុំជំរះរបស់ព្រះអម្ចាស់ត្រូវបានគេនិយាយជាញឹកញាប់ដូចជាភ្លើងឆេះ។
ពួកអ្នកឆ្មើងឆ្មៃ ... ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់
បកប្រែពាក្យទាំងនេះតាមរបៀបដែលអ្នកបានធ្វើនៅ 3:13។
ពួកអ្នកឆ្មើងឆ្មៃ ហើយពួកអ្នកប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាចំបើង
មនុស្សទាំងនេះត្រូវបានគេនិយាយថា ពួកគេនឹងក្លាយជារុក្ខជាតិស្ងួតហួតហែងសមនឹងឆេះ។ ព្រះគម្ពីរជារឿងធម្មតាដែលនិយាយអំពីមនុស្សដូចជា ពួកគេជារុក្ខជាតិ ឬដើមឈើ។ ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកឆ្មើងឆ្មៃ និងពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់ទាំងអស់នឹងឆេះដូចជារុក្ខជាតិស្ងួត»
ថ្ងៃដែលត្រូវមកដល់នោះ នឹងដុតពួកគេ
ឃ្លាថា «ថ្ងៃ» នៅទីនេះតំណាងឱ្យព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅថ្ងៃនោះ។ ការបកប្រែរបៀបផ្សេងទៀត: «នៅថ្ងៃនោះយើងនឹងដុតបំផ្លាញពួកគេទាំងអស់»
ដូច្នេះមិនទុកឲ្យគេសូម្បីតែឫសនិងមែក
ការបង្ហាញនេះបានបន្តនិយាយអំពីមនុស្សដូចជាពួកគេជារុក្ខជាតិ ឬដើមឈើ។ ដូច្នេះការត្រូវបានដកពីឫស និងមែកទាំងអស់គឺត្រូវបានសម្លាប់ចោលទាំងស្រុង។ ការបកប្រែរបៀបផ្សេងទៀត: «គ្មានអ្វីនឹងត្រូវទុក»
សម្រាប់អ្នកដែលកោតខ្លាចព្រះនាមរបស់យើង
ឃ្លាថា «ឈ្មោះយើង» នៅទីនេះតំណាងអោយព្រះអម្ចាស់ផ្ទាល់។
ព្រះអាទិត្យនៃសេចក្តីសុចរិតនឹងរះឡើង មានស្លាបនៃការប្រោសឲ្យជាផង
នេះអាចមានន័យថា ១) ព្រះអម្ចាស់ដែលតែងតែប្រព្រឹត្តដោយសេចក្តីសុចរិត ព្រះអម្ចាស់នឹងយាងមកប្រោសប្រជារាស្ត្ររបស់ព្រះអម្ចាស់នៅថ្ងៃនោះឬ ២) នៅថ្ងៃនោះព្រះអម្ចាស់នឹងសំដែងអោយមនុស្សសុចរិតឃើញហើយប្រោសពួកគេអោយជាផង
ស្លាបនៃការប្រោសឲ្យជា
អាចមានន័យថា ១) ទង្វើនៃការព្យាបាលមនុស្សម្នាក់ត្រូវបានគេនិយាយថា វាជាវត្ថុដែលព្រះអាទិត្យបានដឹកមនុស្សដោយចំអែងស្លាបឬ ២) ការព្យាបាលកើតឡើងនៅក្រោមចំអែងស្លាប នោះគឺនៅក្នុងសុវត្ថិភាពដែលព្រះអម្ចាស់បានប្រទានឲ្យប្រជាជន។
ស្លាប
វាជារឿងធម្មតានៅសម័យបុរាណនៅក្បែរខាងកើត ដើម្បីនិយាយពីព្រះអាទិត្យដូចជា វាមានចំអែង ស្លាបដែលបានធ្វើចលនានៅលើមេឃ។ អាចមានន័យថា ១) កាំរស្មីដែលផ្តល់ពន្លឺព្រះអាទិត្យត្រូវបានគេនិយាយថាជាចំអែងស្លាបរបស់វាឬ ២) ចំអែងស្លាបត្រូវបានគេនិយាយថាអាចគ្របបាំងប្រជាជនរបស់ព្រះអម្ចាស់ដើម្បីផ្តល់សេចក្តីសុវត្ថិភាព និងសុវត្ថិភាពដល់ពួកគេ។
អ្នករាល់គ្នានឹងចេញទៅ លោតកញ្ឆោងដូចជាកូនគោដែលចេញពីក្រោល
ប្រជាជនរបស់ព្រះអម្ចាស់នៅទីនេះ ដែលបានប្រោសលោះ ត្រូវគេនិយាយដូចជាពួកគេយកគោឈ្មោល ដែលត្រូវបានគេដោះលែងពីក្រោល ដែលត្រូវគេអនុញ្ញាតអោយចេញទៅស៊ីស្មៅ។
អ្នករាល់គ្នានឹងជាន់ឈ្លីពួកមនុស្សអាក្រក់ ដ្បិតគេនឹងដូចជាផេះនៅក្រោមបាទជើង
នៅទីនេះជ័យជំនះរបស់ប្រជាជនរបស់ព្រះអម្ចាស់ត្រូវបានគេនិយាយដូចជាកំពុងដើរលើសាកសព ដែលត្រូវបានដុតបំផ្លាញរបស់សត្រូវរបស់ពួកគេ។
គេនឹងដូចជាផេះ
សត្រូវរបស់ជនជាតិអ៊ីស្រាអែលត្រូវបានគេនិយាយថាត្រូវបានគេដុតទៅជាផេះ។ (សូមចូលទៅមើល 4:1)
Malachi 4:4
ចូរនឹកចាំពីសេចក្តីបង្រៀនរបស់លោកម៉ូសេជាអ្នកបម្រើរបស់យើង ដែលយើងបានផ្តល់ដល់គាត់
ខ្លឹមសារនៃការបង្រៀនរបស់ព្រះអម្ចាស់ ត្រូវបាននិយាយដូចជាពាក្យដែលព្រះអម្ចាស់បានប្រទានដល់លោកម៉ូសេ។
នឹកចាំ
ឃ្លាថា «ចងចាំ» នៅទីនេះតំណាងឱ្យ «គិតអំពី» ហើយក្នុងពេលតែមួយ «គោរព» ។
ភ្នំហោរែប
នេះគឺជាឈ្មោះមួយទៀតសម្រាប់ភ្នំស៊ីណាយ។
សម្រាប់ជនជាតិអ៊ីស្រាអែលទាំងមូល
«ដូចប្រជាជនអ៊ីស្រាអែលទាំងអស់កំពុងតែឈរនៅមុខភ្នំ»
ជនជាតិអ៊ីស្រាអែលទាំងមូល
ឃ្លាថា «អ៊ីស្រាអែលទាំងអស់» នៅទីនេះគឺជាឯកសារយោងមួយសម្រាប់ប្រជាជនទាំងអស់នៅក្នុងប្រទេសអ៊ីស្រាអែល។
បញ្ញត្តិច្បាប់
នេះជាក្រឹត្យវិន័យ ដែលព្រះអម្ចាស់ប្រទានអោយជនជាតិអ៊ីស្រាអែលគ្រប់ពេលវេលា។
ច្បាប់
ទាំងនេះគឺជាការសម្រេចចិត្តស្របច្បាប់ ដែលមានគោលបំណងដើម្បីបញ្ជាក់ឱ្យច្បាស់ពីរបៀបដែលក្រឹត្យក្រមទូទៅដើម្បីអនុវត្តចំពោះជីវិតប្រចាំថ្ងៃ
នឹងមកដល់នៃការអស្ចារ្យ ហើយនិងគួរឲ្យខ្លាច នៅថ្ងៃព្រះអម្ចាស់
ការកើតឡើងនៅទីនេះ ថ្ងៃនេះត្រូវបានគេនិយាយដូចជាវាកំពុងមកដល់។
ការបកប្រែរបៀផ្សេងទៀត: «មុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចរបស់ព្រះអម្ចាស់កើតឡើង»
ការអស្ចារ្យ ហើយនិងគួរឲ្យខ្លាច នៅថ្ងៃព្រះអម្ចាស់
ឃ្លានេះសំដៅទៅលើពេលវេលាណា ដែលព្រះអម្ចាស់ចាត់វិធានការយ៉ាងម៉ឺងម៉ាត់។
លោកនឹងបង្វែរចិត្តឪពុកមករកកូន ហើយដួងចិត្តរបស់កូនក៏មករកឪពុកដែរ
ការផ្លាស់ប្តូររបៀបនៅទីនេះ ចិត្តមនុស្សគិតត្រូវបានគេនិយាយដូចជាកំពុងតែបង្វែរចិត្តរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

កណ្ឌគម្ពីរម៉ាថាយ

1 [1]នេះជាសៀវភៅរាយនាមអំពីព្រះយេស៊ូគ្រិស្ត ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ ដែលត្រូវជាពូជពង្សរបស់លោកអប្រាហាំ។[2]លោកអប្រាហាំបង្កើតលោកអ៊ីសាក លោក
អ៊ីសាកបង្កើតលោកយ៉ាកុប លោកយ៉ាកុបបង្កើតលោកយូដា និងបងប្អូនរបស់គាត់។[3]លោកយូដា និងនាងតាម៉ារបង្កើតលោកពេរេស និងលោកសេរ៉ាស លោកពេរេស
បង្កើតលោកហេស្រុន លោកហេស្រុនបង្កើតលោកអើរ៉ាម
[4]លោកអើរ៉ាមបង្កើតលោកអមីណាដាប់ លោកអមីណាដាប់បង្កើតលោកណាសូន លោកណាសូនបង្កើតលោកសាលម៉ូន។[5]លោកសាលម៉ូន និងនាងរ៉ាហាបបង្កើតលោក
បូអូស លោកបូអូស និងនាងរស់បង្កើតលោកអូបេដ ហើយលោកអូបេដបង្កើតលោកអ៊ីសាយ។[6]លោកអ៊ីសាយបង្កើតស្តេចដាវីឌ ហើយស្តេចដាវីឌ និងភរិយារបស់អ៊ូរី
បង្កើតស្តេចសាឡូម៉ូន។
[7]សាឡូម៉ូនបង្កើតរេហូបោម រេហូបោមបង្កើតអប៊ីយ៉ា អប៊ីយ៉ាបង្កើតអេសា។[8]អេសាបង្កើតយ៉ូសាផាត យ៉ូសាផាតបង្កើតយ៉ូរ៉ាម យ៉ូរ៉ាមបង្កើតអូសៀស។
[9]អូសៀសបង្កើតយ៉ូថាម យ៉ូថាមបង្កើតអេហាស អេហាសបង្កើតអេសេគាស។[10]អេសេគាសបង្កើតម៉ាណាសេ ម៉ាណាសេបង្កើតអាំម៉ូន អាំម៉ូនបង្កើតយ៉ូសៀស។[11]យ៉ូសៀស
បង្កើតយេកូនាស និងប្អូនប្រុសរបស់គាត់ ក្នុងគ្រាដែលគេនិរទេស ទៅស្រុកបាប៊ីឡូន។
[12]ក្រោយពីនិរទេសទៅស្រុកបាប៊ីឡូន លោកយេកូនាសបង្កើតលោកសាលធាល លោកសាលធាលបង្កើតលោកសូរ៉ូបាបិល។[13]លោកសូរ៉ូបាបិលបង្កើតលោកអប៊ីយូដ លោក
អប៊ីយូដបង្កើតលោកអេលាគីម លោកអេលាគីមបង្កើតលោកអេសូរ។[14]លោកអេសូរបង្កើតលោកសាដុក លោកសាដុកបង្កើតលោកអេគីម លោកអេគីមបង្កើតលោក
អេលីយូដ។
[15]លោកអេលីយូដបង្កើតលោកអេឡាសារ លោកអេឡាសារបង្កើតលោកម៉ាថាន លោកម៉ាថាន បង្កើតលោកយ៉ាកុប។[16]លោកយ៉ាកុបបង្កើតលោកយ៉ូសែប ជាស្វាមីរបស់
នាងម៉ារី ដែលបង្កើតព្រះយេស៊ូ ដែលហៅថាព្រះគ្រិស្ត។[17]ពីជំនាន់លោកអប្រាហាំមកដល់ស្តេចដាវីឌ មានដប់បួនតំណ ពីស្តេចដាវីឌមកដល់នឹងគ្រា ដែលគេនិរទេសទៅ
ស្រុកបាប៊ីឡូន មានដប់បួនតំណ ហើយចាប់ពីគ្រាដែលគេនិរទេសទៅស្រុកបាប៊ីឡូនមកទល់ព្រះគ្រិស្ត ក៏មានដប់បួនតំណដែរ។
[18]នេះជាដំណើររឿងស្តីអំពីកំណើតរបស់ព្រះយេស៊ូគ្រិស្ត។ នាងម៉ារីជាមាតារបស់ព្រះអង្គ ត្រូវជាគូដណ្តឹងរបស់លោកយ៉ូសែប។ មុនពេលពួកគេរួមរស់ជាមួយគ្នា នាងម៉ារី
មានផ្ទៃពោះ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធរួចទៅហើយ។[19]លោកយ៉ូសែបដែលជាស្វាមីរបស់នាង ជាមនុស្សសុចរិត ហើយលោកមិនចង់បំបាក់មុខនាង
ជាសាធារណៈឡើយ។ ដូច្នេះ លោកបានសម្រេចចិត្តផ្តាច់ពាក្យជាមួយនាងដោយស្ងាត់ៗវិញ។
[20]ពេលដែលគាត់កំពុងគិតដូច្នេះ ស្រាប់តែមានទេវតារបស់ព្រះអម្ចាស់ លេចមកប្រាប់គាត់ក្នុងសុបិនថា៖ «យ៉ូសែប! ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌអើយ! សូមកុំខ្លាចនឹង
ទទួលយកនាងម៉ារីមកធ្វើជាភរិយាឡើយ ពីព្រោះបុត្រដែលនៅក្នុងផ្ទៃនាង កើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធទេ។[21]នាងនឹងសម្រាលបានបុត្រមួយ ហើយត្រូវថ្វាយព្រះនាមថា
យេស៊ូ ដ្បិតបុត្រនោះនឹងសង្គ្រោះប្រជារាស្ត្រព្រះអង្គ ឲ្យរួចពីបាបរបស់គេ»។
[22]ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្តីដែលព្រះអម្ចាស់មានព្រះបន្ទូល តាមរយៈព្យាការីថា៖[23]«មើល! ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះ ហើយនាងនឹងសម្រាលបានបុត្រ
មួយ គេនឹងថ្វាយព្រះនាមថា «អេម៉ាញូអែល» មានន័យថា «ព្រះជាម្ចាស់គង់ជាមួយយើង»។
[24]លុះលោកយ៉ូសែបភ្ញាក់ពីដំណេក លោកក៏ធ្វើតាមបង្គាប់ទេវតា គឺលោកទទួលនាងម៉ារីមកធ្វើជាភរិយា។[25]ប៉ុន្តែ លោកពុំបានរួមបវេណីជាមួយនាង រហូតដល់នាងសម្រាល
បានបុត្រ។ រួចលោកថ្វាយព្រះនាមថា «យេស៊ូ»។

Matthew 1:1

ពត៌មានទូទៅ៖

អ្នកនិពន្ធកណ្ឌគម្ពីរនេះចាប់ផ្តើមសរសេរដំបូងអំពីពង្សាវតារព្រះយេស៊ូ
ដើម្បីបង្ហាញថាព្រះអង្គជាកូនចៅរាជវង្សស្តេចដាវីឌ និងកូនចៅលោកអប្រាហាំ។
ពង្សាវតារមានបន្តនៅក្នុងជំពូក១ ខ១៥ ។

នេះជាសៀវភៅរាយនាមអំពីព្រះយេស៊ូគ្រិស្ត

អ្នកអាចបកប្រែវាជាប្រយោគពេញលេញថា៖
«នេះជាបញ្ជីបុព្វបុរសរបស់ព្រះយេស៊ូគ្រិស្ត» ។

ព្រះរាជវង្សរបស់ព្រះបាទដាវីឌ ដែលត្រូវជាពូជពង្សរបស់លោកអប្រាហាំ

មានជំនាន់ជាច្រើនរវាងព្រះយេស៊ូ ស្តេចដាវីឌនិងលោកអ័ប្រាហាំ។ នៅទីនេះ
"ព្រះរាជវង្ស ឬពូជពង្ស" មានន័យថា «កូនចៅ» គឺជា
«កូនចៅរបស់ស្តេចដាវីឌដែលជាកូនចៅរបស់លោកអ័ប្រាហាំ»។

ព្រះរាជវង្សរបស់ព្រះបាទដាវីឌ

ពេលខ្លះឃ្លាដែលថា «ព្រះរាជវង្សរបស់ព្រះបាទដាវីឌ»
ត្រូវបានប្រើជាចំណងជើងមួយ
ប៉ុន្តែនៅទីនេះសំដៅលើតែអំពីវង្សត្រកូលរបស់ព្រះយេស៊ូប៉ុណ្ណោះ។

លោកអប្រាហាំបង្កើតលោកអ៊ីសាក

«អប្រាហាំបានក្លាយជាឪពុកអ៊ីសាក» ឬ «អប្រាហាំមានកូនប្រុសអ៊ីសាក» ឬ
«អប្រាហាំមានកូនប្រុសម្នាក់ឈ្មោះអ៊ីសាក» ។
មានវិធីផ្សេងៗគ្នាដែលអ្នកអាចបកប្រែបាន។ វិធីដែលអ្នកបកប្រែល្អបំផុត
គឺត្រូវបកប្រែឲ្យដូចគ្នានឹងបញ្ជីនៃបុព្វបុរសរបស់ព្រះយេស៊ូ។

លោកអ៊ីសាកបង្កើត....លោកយ៉ាកុបបង្កើត

ពាក្យ «បង្កើត» នៅទីនេះ ត្រូវបានគេយល់ថា៖ «លោកអ៊ីសាកជាឪពុកបង្កើត ...
លោកយ៉ាកុបជាឪពុកបង្កើត»

ពេរេស និងសេរ៉ាស...ហេស្រុន...អើរ៉ាម

នេះជាឈ្មោះរបស់ពួកគេ។

ពេរេសបង្កើត...ហេស្រុនបង្កើត

ពាក្យ «បង្កើត» នៅទីនេះ ត្រូវបានយល់ថា៖ «ពេរេសជាឪពុក...ហេស្រុនជាឪពុក»

Matthew 1:4

លោកអមីណាដាប់បង្កើត...លោកណាសូនបង្កើត

ពាក្យ «បង្កើត» នៅទីនេះ ត្រូវបានយល់ថា៖ «លោកអមីណាដាប់ជាឪពុក ...
លោកណាហុនជាឪពុក»

លោកសាលម៉ូន និងនាងរ៉ាហាបបង្កើតលោកបូអូស

«លោកសាលម៉ូនជាឪពុករបស់បូអូស ហើយម្តាយរបស់បូអូសគឺរ៉ាហាប់» ឬ
«លោកសាលម៉ូន និងរ៉ាហាបជាឪពុកម្តាយរបស់បូអូស» ។

លោកបូអូសបង្កើត...លោកអូបេដបង្កើត

ពាក្យ «បង្កើត» នៅទីនេះ ត្រូវបានយល់ថា៖ «បូអូសគឺជាឪពុក ...
អូបេដគឺជាឪពុក»

លោកបូអូស និងនាងរស់បង្កើតលោកអូបេដ

«បូអូសជាឪពុករបស់អូបេដ ហើយម្តាយរបស់អូបេដគឺនាងរស់» ឬ «បូអូស
និងនាងរស់ជាឪពុកម្តាយរបស់អូបេដ» ។

ស្តេចដាវីឌ និងភរិយារបស់អ៊ូរី បង្កើតស្តេចសាឡូម៉ូន

ពាក្យ «បង្កើត» នៅទីនេះ ត្រូវបានយល់ថា៖ «ស្តេចដាវីឌជាឪពុករបស់សាឡូម៉ូន
ហើយម្តាយរបស់សាឡូម៉ូនជាភរិយារបស់អ៊ូរី»
ឬ«ដាវីឌនិងភរិយារបស់អ៊ូរីគឺជាឪពុកម្តាយរបស់សាឡូម៉ូន»

ភរិយារបស់អ៊ូរី

«ស្ត្រីមេម៉ាយអ៊ូរី» ។ សាឡូម៉ូនបានកើតក្រោយពីអ៊ូរីបានស្លាប់។

Matthew 1:7

រេហូបោមបង្កើតអប៊ីយ៉ា អប៊ីយ៉ាបង្កើតអេសា

ពាក្យ «បង្កើត» ត្រូវបានយល់នៅក្នុងឃ្លាទាំងពីរនេះថា៖ «
រេហូបោមជាឪពុករបស់អ័ប៊ីយ៉ា ហើយអ័ប៊ីយ៉ាជាឪពុករបស់អេសា»

Matthew 1:9

អាំម៉ូន

ពេលខ្លះឈ្មោះនេះត្រូវបានបកប្រែថា «អេម៉ុស» ។

យ៉ូសៀសបង្កើតយេកូនាស

មានពាក្យជាច្រើនទៀតសម្រាប់ពាក្យ «បង្កើត»” ដែលអាចត្រូវបានប្រើផងដែរ
ជាពិសេសប្រសិនបើពាក្យ «បង្កើត»
នឹងត្រូវបានប្រើសម្រាប់តែមនុស្សដែលរស់នៅមុនជីដូនជីតារបស់គេប៉ុណ្ណោះ គឺ
«យ៉ូសៀសគឺជាជីតារបស់យេកូនាស»

ក្នុងគ្រាដែលគេនិរទេស ទៅស្រុកបាប៊ីឡូន

generated on Wed Sep 10 16:16:32 2025

«នៅពេលដែលពួកគេត្រូវបានបង្ខំឲ្យផ្លាស់ទៅបាប៊ីឡូន» ឬ «ពេលពួកបាប៊ីឡូនបានច្បាំងនឹងពួកគេ ហើយបានធ្វើឲ្យពួកគេទៅរស់នៅក្នុងបាប៊ីឡូន» ។
ប្រសិនបើភាសារបស់អ្នកត្រូវការបញ្ជាក់ថា អ្នកណាទៅបាប៊ីឡូនអ្នកអាចនិយាយថា «ជនជាតិអ៊ីស្រាអែល» ឬ «ជនជាតិអ៊ីស្រាអែលដែលរស់នៅស្រុកយូដា» ។
ស្រុកបាប៊ីឡូន
ត្រង់នេះមានន័យថា ប្រទេសបាប៊ីឡូនមិនមែនត្រឹមតែទីក្រុងបាប៊ីឡូនទេ។
Matthew 1:12
ក្រោយពីនិរទេសទៅស្រុកបាប៊ីឡូន
សូមបកប្រែដូចនៅក្នុងជំពូក១ខ៩។
លោកសាលធាលបង្កើតលោកសូរ៉ូបាបិល
លោកសាលធាលគឺជាជីតារបស់លោកសូរ៉ូបាបិល។
Matthew 1:15
ប្រយោគតភ្ជាប់៖
អ្នកនិពន្ធអត្ថបទគម្ពីរនេះបានបញ្ចូលពង្សាវតារបស់ព្រះយេស៊ូ ដែលផ្តើមឡើងនៅក្នុងជំពូក១ ខ១។
នាងម៉ារី ដែលបង្កើតព្រះយេស៊ូ
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖ នាងម៉ារីបង្កើតព្រះយេស៊ូ។
ដែលហៅថាព្រះគ្រិស្ត
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖ បណ្តាជនហៅព្រះអង្គថា ព្រះគ្រិស្ត។
ដប់បួនតំណ
១៤
និរទេសទៅស្រុកបាប៊ីឡូន
សូមបកប្រើដូចនៅក្នុងជំពូក១ ខ៩។
Matthew 1:18
ព័ត៌មានទូទៅ៖
នេះចាប់ផ្តើមដោយផ្នែកថ្មីមួយនៃសាច់រឿង ដែលអ្នកនិពន្ធអត្ថបទគម្ពីរពិពណ៌នាអំពីព្រឹត្តិការណ៍ ដែលនាំទៅដល់ការប្រសូតរបស់ព្រះយេស៊ូ។
នាងម៉ារីជាមាតារបស់ព្រះអង្គ ត្រូវជាគូដណ្តឹងរបស់លោកយ៉ូសែប
មាតារបស់ព្រះអង្គឈ្មោះម៉ារីនឹងរៀបការជាមួយយ៉ូសែប។ ជាធម្មតា ឪពុកម្តាយជាអ្នករៀបចំអាពាហ៍ពិពាហ៍របស់កូនៗពួកគេ។
«ឪពុកម្តាយរបស់ម៉ារីដែលជាមាតារបស់ព្រះយេស៊ូ បានសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ឲ្យនាងជាមួយយ៉ូសែប»
នាងម៉ារីជាមាតារបស់ព្រះអង្គ ត្រូវជាគូដណ្តឹង
បកប្រែតាមរបៀបមួយដែលបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវមិនទាន់ប្រសូតនៅឡើយ នៅពេលដែលម៉ារីបានភ្ជាប់ពាក្យជាមួយយ៉ូសែប។
«ម៉ារីដែលនឹងក្លាយជាម្តាយរបស់ព្រះយេស៊ូ ដែលបានភ្ជាប់ពាក្យរួច»
មុនពេលពួកគេរួមរស់ជាមួយគ្នា
«មុនពេលពួកគេរៀបការ»។ ប្រហែលជាសំដៅទៅលើមុនពេលម៉ារី និងយ៉ូសែបគេងជាមួយគ្នា។ «មុនពេលពួកគេបានរួមរស់ជាមួយគ្នា»
នាងម៉ារីមានផ្ទៃពោះ
ប្រយោគនេះស្ថិតនៅក្នុងទម្រង់សកម្មដែលថា៖ «ពួកគេបានដឹងថានាងនឹងមានកូន» ឬ «នាងនឹងមានផ្ទៃពោះ»
ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ
ឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើឲ្យម៉ារីមានកូនមុនពេលនាងបានរួមរស់ជាមួយ
លោកយ៉ូសែបដែលជាស្វាមីរបស់នាង
យ៉ូសែបមិនទាន់រៀបការជាមួយម៉ារីនៅឡើយទេ ប៉ុន្តែនៅពេលដែលបុរសនិងស្ត្រីបានសន្យាថា នឹងរៀបការជាមួយគ្នាជនជាតិយូដា គេចាត់ទុកថាជាប្តីប្រពន្ធ ទោះបីជាពួកគេមិនបានរស់នៅជាមួយគ្នាក៏ដោយ។ «យ៉ូសែបសន្មតថា នឹងរៀបការជាមួយម៉ារី» ឬ «យ៉ូសែប»
ផ្តាច់ពាក្យជាមួយនាង
លុបចោលគម្រោងអាពាហ៍ពិពាហ៍របស់ពួកគេ
Matthew 1:20
ពេលដែលគាត់កំពុងគិត
ពេលដែលយ៉ូសែបបានគិត
លេចមកប្រាប់គាត់ក្នុងសុបិន
«បានលេចមកនៅពេលយ៉ូសែបកំពុងយល់សុបិន្ត»
ព្រះរាជវង្សរបស់ព្រះបាទដាវីឌ
នៅទីនេះ «ព្រះរាជវង្ស» មានន័យថា «ពូជពង្ស»។
បុត្រដែលនៅក្នុងផ្ទៃនាង កើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធ
ប្រយោគនេះប្រើនៅក្នុងទម្រង់កិរិយាសកម្មថា៖ « ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើឲ្យនាងមានផ្ទៃពោះ មានបុត្រនេះ»
នាងនឹងសម្រាលបានបុត្រមួយ
ដោយសារតែព្រះជាម្ចាស់បានបញ្ជូនទេវតា នោះទេវតាដឹងថាទារកនោះជាក្មេងប្រុស។
ត្រូវថ្វាយព្រះនាម
«អ្នកត្រូវថ្វាយព្រះនាមព្រះអង្គ» ឬ «អ្នកត្រូវតែថ្វាយព្រះនាមឲ្យព្រះអង្គ» ។ នេះគឺជាបទបញ្ជា។
បុត្រនោះនឹងសង្គ្រោះ
អ្នកបកប្រែអាចបន្ថែមលេខយោងដែលនិយាយថា "ព្រះនាម" ព្រះយេស៊ូមានន័យថា "ព្រះសង្គ្រោះ" ។
ប្រជារាស្ត្រព្រះអង្គ
ពាក្យនេះសំដៅទៅលើសាសន៍យូដា។
Matthew 1:22
ពត៌មានទូទៅ៖
អ្នកនិពន្ធអត្ថបទគម្ពីរនេះបញ្ជាក់ថា ព្យាការីអេសាយបង្ហាញអំពីកំណើតព្រះយេស៊ូស្របតាមអត្ថបទគម្ពីរ។
ហេតុការណ៍នេះកើតឡើង
ទេវតាមិននិយាយទៀតទេ។ ឥឡូវនេះម៉ាថាយកំពុងពន្យល់ពីសារសំខាន់នូវអ្វីដែលទេវតាបាននិយាយ។
ស្របតាមសេចក្តីដែលព្រះអម្ចាស់មានព្រះបន្ទូល តាមរយៈព្យាការី
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖ «អ្វីដែលព្រះអម្ចាស់បានប្រាប់ព្យាការីអេសាយឲ្យសរសេរជាយូរមកហើយ»។
មើល! អេម៉ាញូអែល
នៅទីនេះម៉ាថាយយកអត្ថបទគម្ពីរស្របតាមព្យាការីអេសាយ។
មើល!
"មើល" ឬ "ស្តាប់" ឬ "យកចិត្តទុកដាក់ចំពោះអ្វី ដែលខ្ញុំរៀបនឹងប្រាប់អ្នក។ " ពាក្យនេះបន្ថែមការសង្កត់ន័យទៅលើអ្វីដែលត្រូវនិយាយបន្ទាប់។
អេម៉ាញូអែល
ជាឈ្មោះប្រុស។
មានន័យថា «ព្រះជាម្ចាស់គង់ជាមួយយើង»
មិនមាននៅក្នុងកណ្ឌគម្ពីរអេសាយទេ។ ម៉ាថាយកំពុងពន្យល់អត្ថន័យឈ្មោះអេម៉ាញូអែល។ អ្នកអាចបកប្រែវាជាប្រយោគដាច់ដោយឡែកមួយ។ «ឈ្មោះនេះមានន័យថា ព្រះជាម្ចាស់គង់ជាមួយយើង»។
Matthew 1:24
ប្រយោគភ្ជាប់៖
អ្នកនិពន្ធអត្ថបទគម្ពីររួមបញ្ចូលការបកស្រាយរបស់លោកអំពីព្រឹត្តការណ៍ដែលនឹងនាំទៅដល់កំណើតព្រះយេស៊ូ។
ធ្វើតាមបង្គាប់ទេវតា
យេរ៉ូសាឡិមបានប្រាប់យ៉ូសែបឲ្យយកម៉ារីធ្វើជាភរិយា ហើយថ្វាយព្រះនាមព្រះអង្គថា យេស៊ូ។
លោកទទួលនាងម៉ារីមកធ្វើជាភរិយា
លោកបានរៀបការជាមួយម៉ារី។
សម្រាលបានបុត្រ
«សម្រាលទារកប្រុស» ឬ «កូនប្រុសរបស់នាង» ។ ត្រូវប្រាកដដោយមិនបង្ហាញថាយ៉ូសែបជាឪពុកពិតប្រាកដទេ។
រួចលោកថ្វាយព្រះនាមថា «យេស៊ូ»
លោកយ៉ូសែបថ្វាយព្រះនាមបុត្រនោះថា យេស៊ូ។

---

2 [1]បន្ទាប់ពីព្រះយេស៊ូប្រសូតនៅក្នុងភូមិបេថ្លេហិម ស្រុកយូដា ក្នុងរជ្ជកាលព្រះបាទហេរ៉ូដ មានពួកហោរាចារ្យធ្វើដំណើរពីទិសខាងកើតមកដល់យេរូសាឡឹមដោយសួរថា៖
[2]«តើព្រះអង្គដែលប្រសូតមកជាមហាក្សត្ររបស់ជនជាតិយូដាគង់នៅឯណា? យើងបានឃើញផ្កាយរបស់ព្រះអង្គពីទិសខាងកើត ហើយយើងមកថ្វាយបង្គំព្រះអង្គ»។
[3]កាលព្រះបាទហេរ៉ូដឮដំណឹងនេះ ព្រះអង្គមានព្រះហឫទ័យរន្ធត់យ៉ាងខ្លាំង ហើយអ្នករស់នៅយេរូសាឡឹមទាំងអស់ ក៏រន្ធត់ចិត្តជាមួយព្រះអង្គដែរ។

generated on Wed Sep 10 16:16:32 2025

[4]ព្រះបាទហេរ៉ូដកោះហៅពួកនាយកបូជាចារ្យ និងពួកអាចារ្យទាំងប៉ុន្មានរបស់ប្រជាជនមក ហើយសួរគេពីទីកន្លែងដែលព្រះគ្រិស្តបានប្រសូត។[5]ពួកគេទូលប្រាប់ស្តេចថា
ព្រះគ្រិស្តប្រសូតនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា ព្រោះមានសេចក្តីចែងទុកមកតាមរយៈព្យាការីថា៖[6]«បេថ្លេហិមជាដែនដីយូដាអើយ! អ្នកមិនមែនតូចជាងគេទេ ក្នុងក្រុង
សំខាន់ៗនៃស្រុកយូដា ដ្បិតនឹងមានមេដឹកនាំមួយរូបកើតចេញពីអ្នក លោកនឹងមើលថែជនជាតិអ៊ីស្រាអែលរបស់យើង»។
[7]ក្រោយមក ព្រះបាទហេរ៉ូដហៅពួកហោរាចារ្យមកជាសម្ងាត់ សួរបញ្ជាក់យ៉ាងហ្មត់ចត់ពីពេលដែលផ្កាយរះឡើង។[8]ព្រះអង្គចាត់ពួកគេទាំងនោះឲ្យទៅបេថ្លេហិម ដោយ
បង្គាប់ថា៖ «នាំគ្នាទៅចុះ! ហើយស៊ើបសួរដំណឹងអំពីព្រះបុត្រានោះអោយបានច្បាស់លាស់។ កាលបើបានឃើញបុត្រនោះហើយ សូមមកប្រាប់យើងវិញផង ដើម្បីឲ្យយើង
ទៅថ្វាយបង្គំព្រះអង្គដែរ»។
[9]បន្ទាប់ពីបានឮបញ្ជារបស់ស្តេចហើយ ពួកគេក៏នាំគ្នាចេញទៅ ហើយផ្កាយដែលគេបានឃើញនៅទិសខាងកើត ក៏នាំមុខគេជានិច្ចរហូតដល់កន្លែងដែលព្រះបុត្រគង់នៅ
ទើបឈប់។[10]កាលហោរាចារ្យទាំងនោះឃើញផ្កាយហើយ គេសប្បាយចិត្តយ៉ាងខ្លាំង។
[11]ពួកគេចូលទៅក្នុងផ្ទះ ហើយឃើញព្រះបុត្រានៅជាមួយនាងម៉ារី ជាមាតារបស់ព្រះអង្គ។ ពួកគេក៏នាំគ្នាថ្វាយបង្គំព្រះអង្គ រួចក៏បើកហិបយកទ្រព្យរបស់ខ្លួនមក គឺមាន មាស
គ្រឿងក្រអូប និងជ័រល្វីងទេសថ្វាយដល់ព្រះអង្គ។[12]ព្រះជាម្ចាស់មានព្រះបន្ទូលព្រមានគេ ក្នុងសុបិនមិនឲ្យវិលទៅជួបព្រះបាទហេរ៉ូដវិញឡើយ បន្ទាប់មក ពួកគេវិលត្រឡប់
ទៅស្រុករបស់ខ្លួនវិញ តាមផ្លូវមួយផ្សេងទៀត។
[13]បន្ទាប់ពីពួកហោរាចារ្យចាកចេញទៅ ទេវតារបស់ព្រះអម្ចាស់លេចមកប្រាប់លោកយ៉ូសែបក្នុងសុបិនថា៖ «ក្រោកឡើង! នាំព្រះបុត្រ និងមាតារបស់ព្រះអង្គ ភៀសខ្លួនទៅ
អេស៊ីបទៅ។ ត្រូវស្នាក់នៅកន្លែងនោះ រហូតដល់យើងប្រាប់ឲ្យវិលត្រឡប់មកវិញសឹមមក ពីព្រោះព្រះបាទហេរ៉ូដរកសម្លាប់ព្រះបុត្រ»។[14]យប់នោះលោកយ៉ូសែបក្រោកឡើង
ហើយនាំព្រះបុត្រ និងមាតារបស់ព្រះអង្គ រត់ភៀសខ្លួនទៅអេស៊ីបទាំងយប់។[15]គាត់នៅទីនោះរហូតដល់ព្រះបាទហេរ៉ូដសោយទិវង្គត ការនេះកើតឡើងស្របនឹងសេចក្តី
ដែលព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈព្យាការីថា៖ «យើងហៅបុត្រយើងចេញពីអេស៊ីបមក»។
[16]បន្ទាប់ពីព្រះបាទហេរ៉ូដយល់ថា ពួកហោរាចារ្យបានបំបាក់មុខព្រះអង្គ ព្រះអង្គព្រះពិរោធយ៉ាងខ្លាំង ហើយក៏ចេញបញ្ជាឲ្យគេសម្លាប់ក្មេងប្រុសៗទាំងអស់ក្នុងភូមិបេថ្លេហិម
និងភូមិជិតខាង ចាប់ពីអាយុយ៉ាងពីរឆ្នាំចុះក្រោម គឺតាមកំណត់ថ្ងៃដែលទ្រង់បានសួរបញ្ជាក់ពួកហោរាចារ្យ។
[17]ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្តីដែលបានចែងទុកតាមរយៈព្យាការី យេរេមាថា៖[18]«មានឮសំឡេងពីរ៉ាម៉ាមកជាទំនួញយំសោក និងកាន់ទុក្ខ គឺនាងរ៉ាជែលយំ
សោកអាណិតកូននាង ហើយនាងមិនព្រមអោយនរណាសម្រាលទុក្ខនាងឡើយ ព្រោះកូននាងបាត់បង់ជីវិតអស់ទៅហើយ»។
[19]ក្រោយពីព្រះបាទហេរ៉ូដសោយទិវង្គត ទេវតារបស់ព្រះអម្ចាស់បានលេចមកប្រាប់លោកយ៉ូសែប នៅអេស៊ីបក្នុងសុបិនថា៖[20]«ក្រោកឡើង! នាំព្រះបុត្រ និងមាតារបស់
ព្រះអង្គត្រឡប់ទៅអ៊ីស្រាអែលវិញទៅ ដ្បិតពួកអ្នកដែលប៉ុនប៉ងមកលើព្រះកុមារបានស្លាប់បាត់អស់ទៅហើយ»។[21]យ៉ូសែបក្រោកឡើង នាំព្រះបុត្រ និងមាតារបស់
ព្រះអង្គត្រឡប់ទៅអ៊ីស្រាអែលវិញ។
[22]ប៉ុន្តែ កាលលោកឮថា ព្រះបាទអើខេឡោសឡើងគ្រងរាជ្យនៅស្រុកយូដា ស្នងស្តេចហេរ៉ូដជាព្រះបិតា លោកភ័យខ្លាចមិនហ៊ានទៅស្រុកនោះទេ លោកភៀសខ្លួនទៅ
កាលីឡេ ដោយព្រោះព្រះជាម្ចាស់ប្រាប់លោកឲ្យដឹងក្នុងសុបិន។[23]លោកទៅរស់នៅ ក្នុងភូមិមួយឈ្មោះណាសារ៉ែត ការនេះកើតឡើងស្របតាមសេចក្តីដែលពួកព្យាការី បាន
ថ្លែងទុកថា៖ គេនឹងហៅព្រះអង្គថា ជាអ្នកភូមិណាសារ៉ែត។

Matthew 2:1

ព័ត៌មានទូទៅ៖

ផ្នែកថ្មីនៃរឿងចាប់ផ្តើមនៅទីនេះ ហើយបន្តរហូតដល់ចុងបញ្ចប់នៃជំពូក។
អ្នកនិពន្ធអត្ថបទគម្ពីរប្រាប់អំពីការប៉ុនប៉ងរបស់ស្តេចហេរ៉ូដ
ចង់សម្លាប់ស្តេចថ្មីរបស់សាសន៍យូដា។

ភូមិបេថ្លេហិម ស្រុកយូដា

«ក្រុងបេថ្លេហិមក្នុងខេត្តយូដា»។

ក្នុងរជ្ជកាលព្រះបាទហេរ៉ូដ

«នៅពេលព្រះបាទហេរ៉ូដជាស្តេចនៅទីនោះ»

ព្រះបាទហេរ៉ូដ

សំដៅទៅលើហេរ៉ូដដ៏ឧត្តម។

ពួកហោរាចារ្យ

«អ្នកដែលសិក្សាអំពីផ្កាយ»

ពីទិសខាងកើត

«ពីប្រទេសមួយនៅឆ្ងាយពីទិសខាងកើតនៃស្រុកយូដា»

តើព្រះអង្គដែលប្រសូតមកជាមហាក្សត្ររបស់ជនជាតិយូដាគង់នៅឯណា?

អ្នកទាំងនោះបានដឹងតាមការសិក្សាផ្កាយថា
មានព្រះមួយអង្គជាស្តេចដែលនឹងត្រូវចាប់កំណើតមក។ ពួកគេខិតខំសិក្សា
ថាតើព្រះអង្គនៅទីកន្លែងណា។ «ទារកដែលនឹងក្លាយជាស្តេចរបស់ជនជាតិយូដា
បានកើតមក។ តើព្រះអង្គគង់នៅឯណា?»

ផ្កាយរបស់ព្រះអង្គ

ពួកគេមិនបាននិយាយថា ទារកជាម្ចាស់ផ្កាយនោះទេ។

«ផ្កាយដែលប្រាប់អំពីព្រះអង្គ» ឬ «ផ្កាយដែលទាក់ទងនឹងកំណើតរបស់ព្រះអង្គ»

ពីទិសខាងកើត

«បានកើតឡើងនៅភាគខាងកើត» ឬ
«ក្នុងខណៈពេលដែលយើងនៅក្នុងប្រទេសរបស់យើង»

ថ្វាយបង្គំ

អាចមានន័យថា ១) ពួកគេមកថ្វាយបង្គំព្រះទារកជាអាទិទេព ឬ ២)
ពួកគេចង់គោរពព្រះអង្គជាស្តេចមួយអង្គ។ បើភាសារបស់អ្នកមានពាក្
យដែលមានអត្ថន័យទាំងពីរនេះ អ្នកគួរប្រើដូច្នេះ។

ព្រះអង្គមានព្រះហឫទ័យរន្ធត់យ៉ាងខ្លាំង

ព្រះអង្គមានព្រះហឫទ័យព្រួយ។ ស្តេចហេរ៉ូដព្រួយ
ព្រោះព្រះអង្គខ្លាចព្រះទារកនឹងក្លាយជាស្តេចជំនួសព្រះអង្គ។

អ្នករស់នៅយេរូសាឡឹមទាំងអស់

នៅទីនេះ«យេរូសាឡឹម»សំដៅលើប្រជាជន។ ដូចគ្នានេះផងដែរ «ទាំងអស់»
មានន័យថា «ជាច្រើន» ។ ម៉ាថាយកំពុងនិយាយបន្ថែមដើម្បីបញ្ជាក់ពីចំនួនមនុស្ស
ដែលមានការព្រួយបារម្ភ។ «មនុស្សជាច្រើននៅក្រុងយេរូសាឡឹម» (សូមមើល:|
Metonymy and|Hyperbole)

Matthew 2:4

ព័ត៌មានទូទៅ

នៅក្នុងខ ៦ ពួកនាយកបូជាចារ្យ
និងពួកអាចារ្យរបស់ប្រជាជនដកស្រង់សម្តីព្យាការីមីកាដែលបង្ហាញថា
ព្រះគ្រិស្តនឹងប្រសូតនៅភូមិបេថ្លេហិម។

នៅភូមិបេថ្លេហិម ក្នុងស្រុកយូដា

«នៅទីក្រុងនៃភូមិបេថ្លេហិមក្នុងស្រុកយូដា»

សេចក្តីចែងទុកមកតាមរយៈព្យាការី

ប្រយោគនេះសរសេរជាទម្រង់កិរិយាសកម្មថា៖
«នេះជាអ្វីដែលព្យាការីបានសរសេរទុកជាយូរមកហើយ»

បេថ្លេហិមជាដែនដីយូដាអើយ! អ្នកមិនមែនតូចជាងគេទេ ក្នុងក្រុងសំខាន់ៗនៃស្រុកយូដា

មីកាកំពុងនិយាយទៅកាន់ប្រជាជននៅភូមិបេថ្លេហិម
ដូចពួកគេកំពុងនៅជាមួយគាត់ ប៉ុន្តែពួកគេមិនបាននៅទេ។ ដូចគ្នានេះផងដែរ
«មិនមែនតូចជាងគេទេ» អាចត្រូវបានបកប្រែដោយឃ្លាវិជ្ជមាន។

«អ្នកក្រុងបេថ្លេហិម ...
ទីក្រុងរបស់អ្នកស្ថិតក្នុងចំណោមទីក្រុងសំខាន់បំផុតនៅស្រុកយូដា»

លោកនឹងមើលថែជនជាតិអ៊ីស្រាអែលរបស់យើង

ព្យាការីមីកានិយាយអំពីអ្នកគ្រប់គ្រងនេះថា អ្នកគង្វាល មានន័យថា
គាត់នឹងដឹកនាំនិងថែរក្សាប្រជាជន។
«តើអ្នកណានឹងនាំអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងដូចជាអ្នកគង្វាលនាំចៀមរបស់ខ្លួន»

Matthew 2:7

ព្រះបាទហេរ៉ូដហៅពួកហោរាចារ្យមកជាសម្ងាត់

មានន័យថា
ស្តេចហេរ៉ូដបាននិយាយជាមួយពួកហោរាចារ្យដោយមិនឲ្យនរណាម្នាក់ដឹងឡើយ។

សួរបញ្ជាក់យ៉ាងហ្មត់ចត់ពីពេលដែលផ្កាយរះឡើង

ប្រយោគនេះអាចប្រែជាប្រយោគដកស្រង់ផ្ទាល់។ ហើយព្រះអង្គបានសួរពួកគេថា៖

generated on Wed Sep 10 16:16:32 2025

តើផ្កាយរះឡើងនៅពេលណា?
ពេលដែលផ្កាយរះឡើង
បញ្ជាក់ថា ពួកហោរាចារ្យបានប្រាប់ព្រះអង្គអំពីពេលផ្កាយលេចចេញមក។
«ម៉ោងប៉ុន្មានផ្កាយបានបង្ហាញខ្លួន។
ពួកហោរាចារ្យបានប្រាប់ស្តេចហេរ៉ូដមុនគេអំពីពេលដែលផ្កាយបានបង្ហាញខ្លួន»
ព្រះបុត្រ
សំដៅទៅលើព្រះយេស៊ូ។
សូមមកប្រាប់យើងវិញផង
នៅទីនេះពាក្យ «ប្រាប់» ជាពាក្យបញ្ជាក់ថា «សារ» ឬ «ជាថ្មី»។
«សូមផ្តល់ដំណឹងមកខ្ញុំ» ឬ «ប្រាប់ខ្ញុំ» ឬ «រាយការណ៍មកខ្ញុំវិញ»
ថ្វាយបង្គំព្រះអង្គ
បកប្រែពាក្យនេះដូចដែលអ្នកបានធ្វើហើយនៅក្នុងជំពូក២ ខ១។
Matthew 2:9
បន្ទាប់ពីបាន
បន្ទាប់ពីពួកហោរាចារ្យបាន
គេបានឃើញនៅទិសខាងកើត
"«គេបានឃើញលេចមកនៅទិសខាងកើត» ឬ
«ពួកគេបានឃើញនៅក្នុងប្រទេសរបស់ពួកគេ»
នាំមុខគេ
«ដឹកនាំពួកគេ» ឬ «បាននាំផ្លូវពួកគេ»
ទើបឈប់
«ឈប់ដំណើរ»
កន្លែងដែលព្រះបុត្រគង់នៅ
«កន្លែងដែលព្រះបុត្រគង់ប្រថាប់»
Matthew 2:11
ប្រយោគក្ខាប់៖
នៅទីនេះ រឿងនេះផ្លាស់ប្តូរទៅជាផ្ទះ
ដែលម៉ារីយ៉ូសែបនិងព្រះយេស៊ូជាបុត្រតូចកំពុងស្នាក់នៅ។
ពួកគេចូលទៅ
«ពួកហោរាចារ្យបានចូលទៅ»
ទ្រព្យរបស់ខ្លួន
នៅទីនេះ «ទ្រព្យរបស់ខ្លួន» ផ្តោតទៅលើហិប
ឬកាតាបស្តាយដែលពួកគេប្រើប្រាស់សម្រាប់ទុកទ្រព្យរបស់ពួកគេ។
«ប្រអប់សម្រាប់ដាក់ទ្រព្យរបស់ពួកគេ»
ព្រះជាម្ចាស់មានព្រះបន្ទូលព្រមានគេ
«ក្រោយមក ព្រះជាម្ចាស់បានហាមប្រាមពួកហោរាចារ្យ»។ ព្រះជាម្ចាស់ជ្រាបថា
ស្តេចហេរ៉ូដចង់ធ្វើបាបបុត្រតូច។
មិនឲ្យវិលទៅជួបព្រះបាទហេរ៉ូដវិញឡើយ
អាចបកប្រែជាអត្ថបទដកស្រង់ផ្ទាល់។ «ព្រះអង្គមានព្រះបន្ទូលថា
មិនឲ្យពួកគេត្រឡប់ទៅស្តេចហេរ៉ូដឡើយ»
Matthew 2:13
ព័ត៌មានទូទៅ៖
នៅក្នុងខ ១៥ អ្នកនិពន្ធអត្ថបទគម្ពីរបានដកស្រង់អំពីព្យាការីហូសេថ្លែងថា
ព្រះគ្រិស្តនឹងចំណាយពេលរបស់ព្រះអង្គនៅស្រុកអេស៊ីប។
ពួកហោរាចារ្យចាកចេញទៅ
«ពួកហោរាចារ្យបានចាកចេញ»
លេចមកប្រាប់លោកយ៉ូសែបក្នុងសុបិន្ត
«បានលេចមកឯលោកយ៉ូសែបពេលលោកកំពុងយល់សុបិន្ត»
ក្រោកឡើងនាំយក... ភៀសខ្លួន... ស្នាក់... អ្នក
ព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកយ៉ូសែប
ដូច្នេះពាក្យទាំងនេះទម្រង់ឯកលក្ខណៈ។
រហូតដល់យើងប្រាប់
អត្ថន័យពេញនៃប្រយោគនេះបានបញ្ជាក់ច្បាស់។ «ទាល់តែខ្ញុំប្រាប់អ្នកថា
មានសុវត្ថិភាពក្នុងការត្រឡប់មកវិញ»
យើងប្រាប់
នៅទីនេះ «យើង» សំដៅលើព្រះជាម្ចាស់។
ទេវតាកំពុងតែនិយាយជំនួសព្រះជាម្ចាស់។
គាត់នៅទីនោះ
នេះបញ្ជាក់ថា លោកយ៉ូសែប
នាងម៉ារីនិងព្រះយេស៊ូបានស្នាក់នៅក្នុងស្រុកអេស៊ីប។ «ពួកគេស្នាក់នៅ»
រហូតដល់ព្រះបាទហេរ៉ូដសោយទិវង្គត
ស្តេចហេរ៉ូដមិនទាន់សោយទិវង្គត រហូតដល់ជំពូក២ ខ១៩។
ប្រយោគនេះពិពណ៌នាអំពីរយៈពេលនៃការស្នាក់នៅរបស់ពួកគេ
នៅក្នុងស្រុកអេស៊ីប ហើយមិនបានបញ្ជាក់ថា
ស្តេចហេរ៉ូដបានស្លាប់នៅពេលនោះទេ។
យើងហៅបុត្រយើងចេញពីអេស៊ីបមក
«យើងហៅបុត្រយើងចេញពីស្រុកអេស៊ីប»
បុត្រយើង
នៅក្នុងកណ្ឌគម្ពីរហូសេ នេះសំដៅទៅលើប្រជាជនអ៊ីស្រាអែល។
កណ្ឌគម្ពីរម៉ាថាយបានបញ្ជាក់ថា ការពិតអំពីព្រះបុត្រារបស់ព្រះជាម្ចាស់
គឺព្រះយេស៊ូ។ សូមបកប្រែដោយប្រើពាក្យបុត្រ
ដែលអាចសំដៅទៅលើកូនប្រុសតែមួយ ឬកូនប្រុសច្បង។
Matthew 2:16
ឃ្លាភ្ជាប់៖
រឿងនេះវិលត្រឡប់ទៅស្តេចហេរ៉ូដវិញ
ហើយប្រាប់ពីអ្វីដែលព្រះអង្គបានធ្វើនៅពេលព្រះអង្គដឹងថា
ពួកហោរាចារ្យបានបោកបញ្ឆោតព្រះអង្គ។
ព័ត៌មានទូទៅ៖
ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងមុនស្តេចហេរ៉ូដសោយទិវង្គត
អ្នកនិពន្ធអត្ថបទគម្ពីរបានបញ្ជាក់នៅក្នុងជំពូក២ ខ១៣។
ព្រះបាទហេរ៉ូដយល់ថា ពួកហោរាចារ្យបានបំបាក់មុខព្រះអង្គ
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្ម៖ "ពួកហោរាចារ្យបានធ្វើឲ្យព្រះអង្គខ្មាស
ដោយពួកគេបានបោកបញ្ឆោតព្រះអង្គ"
ចេញបញ្ជាឲ្យគេសម្លាប់ក្មេងប្រុសៗទាំងអស់
ស្តេចហេរ៉ូដមិនបានសម្លាប់កូនខ្លួនឯងទេ។ “
ព្រះអង្គបានចេញបញ្ជាឲ្យទាហានរបស់ព្រះអង្គ សម្លាប់ក្មេងប្រុសទាំងអស់” ឬ“
ព្រះអង្គបានបញ្ជូនទាហាននៅទីនោះ ទៅសម្លាប់ទារកប្រុសៗទាំងអស់”
អាយុពីរឆ្នាំចុះក្រោម
«ពីរឆ្នាំ និងក្មេងជាងពីរឆ្នាំ»
តាមកំណត់ថ្ងៃ
«ផ្អែកទៅលើពេលវេលា»
Matthew 2:17
ព័ត៌មានទូទៅ៖
អ្នកនិពន្ធរអត្ថបទគម្ពីរបានដកស្រង់ពីព្យាការីយេរេមាមក
បង្ហាញអំពីការស្លាប់របស់ក្មេងប្រុសទាំងអស់នៅតំបន់បេថ្លេហិម
ដែលយោងទៅតាមបទគម្ពីរ។
ហេតុការណ៍នេះកើតឡើង
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖ «ការនេះបានកើតឡើង» ឬ
«សកម្មភាពរបស់ស្តេចហេរ៉ូដបានកើតឡើង ស្របតាមអត្ថបទគម្ពីរ»
ស្របតាមសេចក្តីដែលបានចែងទុកតាមរយៈព្យាការី យេរេមា
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖ «អ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល
តាមរយៈព្យាការីយេរេមាជាយូរមកហើយ»
មានឮសំឡេង...កូននាងបាត់បង់ជីវិតអស់ទៅហើយ
លោកម៉ាថាយបានដកស្រង់ពាក្យសម្តីរបស់ព្យាការីយេរេមា។
មានឮសំឡេង
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖ «ប្រជារាស្ត្រឮសំឡេង» ឬ
«មានសំឡេងឮជាខ្លាំង»
នាងរ៉ាជែលយំសោកអាណិតកូននាង
នាងរ៉ាជែលរស់នៅជាច្រើនឆ្នាំមុនពេលនេះ។ ទំនាយនេះបង្ហាញពីនាងរ៉ាជែល
ដែលបានស្លាប់យំសោកចំពោះកូនចៅរបស់នាង។
នាងមិនព្រមអោយនរណាសម្រាលទុក្ខនាងឡើយ
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖
«គ្មាននរណាអាចសម្រាលបន្ទុកនាងឡើយ»
ព្រោះកូននាងបាត់បង់ជីវិតអស់ទៅហើយ
«ពីព្រោះក្មេងៗបានបាត់បង់ ហើយនឹងមិនត្រឡប់មកវិញទេ» ។ ឃ្លានេះ
«បាត់បង់ជីវិតអស់ហើយ» ជារបៀបដែលស្រាលក្នុងការនិយាយថា
ពួកគេបាត់បង់ជីវិតហើយ។ «ពីព្រោះពួកគេបានស្លាប់ទៅហើយ»
Matthew 2:19

generated on Wed Sep 10 16:16:32 2025

ឃ្លាភ្ជាប់៖
រឿងនេះផ្លាស់ទៅស្រុកអេស៊ីប ជាកន្លែងដែលលោកយ៉ូសែប នាងម៉ារី
និងព្រះយេស៊ូកំពុងតែរស់នៅ។
មើល
នេះជាការចាប់ផ្តើមនៃព្រឹត្តិការណ៍មួយទៀត នៅក្នុងរឿងដែលធំជាងមុន។
វាអាចពាក់ព័ន្ធនឹងមនុស្សផ្សេងគ្នាជាងព្រឹត្តិការណ៍មុន ៗ ។
ភាសារបស់អ្នកអាចមានរបៀបក្នុងការបកប្រែសាច់រឿងនេះ។
ដ្បិតពួកអ្នកដែលប៉ុនប៉ងមកលើព្រះកុមារ
«ប៉ុនប៉ងមកលើព្រះកុមារ» នៅត្រង់នេះ
គឺជារបៀបនិយាយមួយនៅពេលចង់សម្លាប់ព្រះកុមារ។
«អស់អ្នកដែលកំពុងស្វែងរកព្រះកុមារ ដើម្បីនឹងសម្លាប់ព្រះអង្គ»
អ្នកដែលប៉ុនប៉ង
សំដៅទៅលើស្តេចហេរ៉ូដ និងទីប្រឹក្សារបស់ព្រះអង្គ។
Matthew 2:22
ឃ្លាភ្ជាប់
នេះជាចុងបញ្ចប់នៃផ្នែកនៃរឿងរ៉ាវដែលបានចាប់ផ្តើមនៅជំពូក២ ខ១
អំពីការប៉ុនប៉ងរបស់ស្តេចហេរ៉ូដ ដើម្បីសម្លាប់ស្តេចថ្មីរបស់ជនជាតិយូដា។
ប៉ុន្តែ កាលលោកឮ
«ប៉ុន្តែ កាលលោកយ៉ូសែបបានឮ»
ព្រះបាទអើខេឡោស
នេះជាឈ្មោះបុត្រារបស់ព្រះបាទហេរ៉ូដ។
លោកភ័យខ្លាច
លោកយ៉ូសែបភ័យខ្លាច
ការនេះកើតឡើងស្របតាមសេចក្តីដែលពួកព្យាការី បានថ្លែងទុក
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖
«អ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈព្យាការី»
គេនឹងហៅព្រះអង្គថា ជាអ្នកភូមិណាសារ៉ែត
នៅទីនេះ «ព្រះអង្គ» សំដៅទៅលើព្រះយេស៊ូ។
ពួកព្យាការីមុនសម័យព្រះយេស៊ូបានហៅព្រះអង្គថា ជាព្រះមេស្ស៊ី ឬព្រះគ្រិស្ត។ «
មនុស្សអាចនិយាយបានថាព្រះគ្រិស្តជាអ្នកភូមិណាសារ៉ែត»

---

3 [1]នៅគ្រានោះ លោកយ៉ូហានបាទីស្តប្រកាសនៅវាលរហោស្ថាន ស្រុកយូដាថា៖[2]«ចូរប្រែចិត្តឡើង! ដ្បិតព្រះរាជ្យនៃស្ថានបរមសុខ ជិតមកដល់ហើយ!»។
[3]លោកនេះហើយដែលព្យាការីអេសាយបានថ្លែងទុកអំពីលោកថា៖ «មានសំឡេងមួយស្រែកឡើងនៅវាលរហោស្ថានថា៖ ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់ ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ!»។
[4]លោកយ៉ូហានស្លៀកសម្លៀកបំពាក់ធ្វើអំពីរោមអូដ្ឋ ហើយខ្សែក្រវាត់គាត់ធ្វើអំពីស្បែក។ លោកបរិភោគកណ្តូប និងទឹកឃ្មុំធ្វើជាអាហារ។[5]អ្នករស់នៅយេរូសាឡឹម ស្រុកយូដា និងអ្នកស្រុកនៅតំបន់ ទន្លេយ័រដាន់ទាំងមូលនាំគ្នាមករកលោក។[6]ពួកគេសារភាពអំពើបាបរបស់ខ្លួន ហើយលោកក៏ធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងទន្លេយ័រដាន់។
[7]ប៉ុន្តែកាលលោកឃើញពួកផារីស៊ី និងពួកសាឌូស៊ី មកទទួលពិធីជ្រមុជទឹកពីលោក លោកនិយាយទៅគេថា៖ «ឲ្យពូជពស់វែកអើយ! តើនរណាប្រាប់អ្នករាល់គ្នាឲ្យរត់គេចពីព្រះពិរោធ ដែលនឹងមកដល់ដូច្នេះ?។[8]ចូរបង្កើតផលផ្លែល្អ ដើម្បីបញ្ជាក់ពីការដែលអ្នករាល់គ្នាបានកែប្រែចិត្តគំនិតមែន។[9]កុំគិតថាថាខ្លួនមានលោកអប្រាហាំជាបុព្វបុរសនោះឡើយ ខ្ញុំសូមប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់អាចបង្កើតកូនចៅលោកអប្រាហាំចេញពីថ្មទាំងនេះក៏បានដែរ។
[10]ពូថៅដាក់នៅជិតគល់ឈើស្រេចហើយ ដើមឈើណាមិនផ្តល់ផ្លែល្អទេ នឹងត្រូវកាប់ ហើយបោះចោលទៅក្នុងភ្លើង។[11]ខ្ញុំធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាដោយទឹក ដើម្បីអ្នករាល់គ្នាកែប្រែចិត្តគំនិត ប៉ុន្តែលោកដែលមកក្រោយខ្ញុំ មានអំណាចលើសខ្ញុំទៅទៀត។ ខ្ញុំមិនសក្តិសមសូម្បីតែដោះស្បែកជើងជូនលោក។ លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាដោយព្រះវិញ្ញាណដ៏វិសុទ្ធនិងដោយភ្លើងវិញ។[12]លោកកាន់ចង្អេរ សម្អាតលានបោកស្រូវ អុំស្រូវប្រមូលយកគ្រាប់ដាក់ក្នុងជង្រុក រីឯសំដី លោកនឹងដុតក្នុងភ្លើង ដែលឆេះរហូត»។
[13]ពេលនោះ ព្រះយេស៊ូយាងពីកាលីឡេទៅទន្លេយ័រដាន់ដើម្បីឲ្យលោកយ៉ូហានធ្វើពិធីជ្រមុជទឹកឲ្យ។[14]ប៉ុន្តែ លោកយ៉ូហានព្យាយាមប្រកែកថា៖ «ខ្ញុំទេតើដែលត្រូវទទួលពិធីជ្រមុជទឹកពីលោក ម្តេចក៏លោកមករកខ្ញុំវិញ?»។[15]ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយតបទៅគាត់ថា៖ «ចូរធ្វើម្តងនេះសិនចុះ ដើម្បីឲ្យសម្រេចស្របតាមគ្រប់ទាំងសេចក្តីសុចរិតដែលព្រះជាម្ចាស់បានបង្គាប់»។ លោកយ៉ូហានក៏យល់ព្រម។
[16]ក្រោយពេលទទួលពិធីជ្រមុជទឹករួចហើយ ព្រះយេស៊ូយាងឡើងពីទឹកភ្លាម ស្រាប់តែផ្ទៃមេឃបើកចំហ ទ្រង់ឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ចុះមកដូចសត្វព្រាប និងសណ្ឋិតលើព្រះអង្គ។[17]មើល មានសំឡេងពីលើមេឃមកថា៖ «នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ព្រះទ័យនឹងព្រះអង្គខ្លាំងណាស់!»។

Matthew 3:1
ព័ត៌មានទូទៅ៖
នេះជាការចាប់ផ្តើមនៃផ្នែកថ្មីនៃរឿង ដែលអ្នកនិពន្ធអត្ថបទគម្ពីរ
បានប្រាប់អំពីព័ន្ធកិច្ចរបស់លោកយ៉ូហានបាទិស្ត។ នៅក្នុងខ ៣
អ្នកនិពន្ធអត្ថបទគម្ពីរបានដកស្រង់សម្តីរបស់ព្យាការីអេសាយ
ដែលបង្ហាញថាលោកយ៉ូហានបាទិស្ត ជាទូតរបស់ព្រះជាម្ចាស់
ដើម្បីរៀបចំព័ន្ធកិច្ចរបស់ព្រះយេស៊ូ។
នៅគ្រានោះ
ជាច្រើនឆ្នាំក្រោយមក
លោកយ៉ូសែបនិងក្រុមគ្រួសាររបស់គាត់បានចាកចេញពីស្រុកអេស៊ីប
ហើយបានធ្វើដំណើរឆ្ពោះទៅស្រុកណាសារ៉ែត។ ប្រហែលជាជិតដល់ពេល
ដែលព្រះយេស៊ូចាប់ផ្តើមព័ន្ធកិច្ចរបស់ព្រះអង្គ។ «ពេលខ្លះនៅពេលក្រោយ» ឬ
«ប៉ុន្មានឆ្នាំក្រោយ»
ចូរប្រែចិត្តឡើង
ប្រយោគនេះស្ថិតក្នុងទម្រង់ពហុវចន:។
លោកយ៉ូហានកំពុងនិយាយទៅកាន់បណ្តាជន។
ព្រះរាជ្យនៃស្ថានបរមសុខ ជិតមកដល់ហើយ
ប្រយោគថា «ព្រះរាជ្យនៃស្ថានបរមសុខ»
សំដៅដល់ព្រះអង្គកំពុងសោយរាជ្យជាស្តេច។
ឃ្លានេះមានតែនៅក្នុងកណ្ឌគម្ពីរម៉ាថាយប៉ុណ្ណោះ។ បើអាចសូមប្រើពាក្យ «ស្ថាន
បរមសុខ» ក្នុងការបកប្រែរបស់អ្នក។ «ព្រះនៃយើងដែលគង់នៅស្ថានបរមសុខ
នឹងបង្ហាញអង្គទ្រង់ជាស្តេច ឆាប់ៗនេះ»
លោកនេះហើយដែលព្យាការីអេសាយបានថ្លែងទុកអំពីលោក
ប្រយោគនេះប្រើជាទម្រង់កិរិយាសកម្មថា៖
«ព្យាការីអេសាយបាននិយាយអំពីលោកយ៉ូហានបាទិស្ត
ពេលលោកថ្លែងទំនាយ» (សូមមើល:|Active or Passive)
មានសំឡេងមួយស្រែកឡើងនៅវាលរហោស្ថាន
ពាក្យពេចន៍នេះអាចត្រូវបានបង្ហាញជាប្រយោគ។
«សំឡេងរបស់មនុស្សម្នាក់ដែលស្រែកនៅវាលរហោស្ថានត្រូវបានគេឮ» ឬ
«ពួកគេឮសំឡេងរបស់មនុស្សម្នាក់ ដែលស្រែកនៅវាលរហោស្ថាន »
ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់ ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ
ឃ្លាទាំងពីរមានន័យដូចគ្នា។
ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់
«រៀបចំផ្លូវសម្រាប់ព្រះអម្ចាស់» ។ ការធ្វើបែបនេះមានន័យថា
ឲ្យការត្រៀមខ្លួនដើម្បីស្តាប់ព្រះរាជសាររបស់ព្រះអម្ចាស់ ពេលព្រះអង្គយាងមក។
មនុស្សធ្វើដូច្នេះបានដោយការប្រែចិត្តពីអំពើបាបរបស់គេ។
«រៀបចំខ្លួនដើម្បីស្តាប់ព្រះរាជសាររបស់ព្រះអម្ចាស់ ពេលទ្រង់យាងមក» ឬ
«ប្រែចិត្តហើយត្រៀមខ្លួនទទួលព្រះអម្ចាស់យាងមក»
Matthew 3:4
ទឹកឃ្មុំ
នៅទីនេះ
កណ្ឌគម្ពីរម៉ាថាយបានប្រាប់អំពីព័ត៌មានប្រវត្តិរបស់លោកយ៉ូហានបាទិស្ត។
ស្លៀកសម្លៀកបំពាក់ធ្វើអំពីរោមអូដ្ឋ ហើយខ្សែក្រវាត់គាត់ធ្វើអំពីស្បែក
សម្លៀកបំពាក់នេះជានិមិត្តរូប ថាលោកយ៉ូហានជាព្យាការីម្នាក់
ដូចព្យាការីដែលមានតាំងពីយូរយារមកហើយ ជាពិសេសគឺព្យាការីអេលីយ៉ា។
អ្នករស់នៅយេរូសាឡឹម ស្រុកយូដា និងអ្នកស្រុកនៅតំបន់
សំដៅទៅលើប្រជាជនមកពីតំបន់ទាំងនោះ។ នៅទីនេះពាក្យ «ទាំងអស់»
មានន័យថា «ជាច្រើន» ។ លោកម៉ាថាយកំពុងសង្កត់ធ្ងន់ថា

generated on Wed Sep 10 16:16:32 2025

តើមានមនុស្សប៉ុន្មាននាក់បានទៅជួបយ៉ូហានបាទិស្ត។
លោកក៏ធ្វើពិធីជ្រមុជទឹកឲ្យគេ
ឃ្លានេះស្ថិតនៅក្នុងទម្រង់កិរិយាសកម្ម។
«លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកឲ្យពួកគេ»
ពួកគេ
សំដៅទៅលើប្រជាជន ដែលមកពីក្រុងយេរូសាឡឹម ស្រុកយូដា
និងតំបន់ជុំវិញទន្លេយ័រដាន់។
Matthew 3:7
ព័ត៌មានទូទៅ៖
លោកយ៉ូហានបាទិស្តចាប់ផ្តើមបន្ទោសពួកផារីស៊ី និងពួកសាឌូស៊ី។
ឲ្យពូជពស់វែកអើយ! តើនរណា
ជាពាក្យប្រៀបធៀប។ នៅទីនេះ «ពូជ» មានន័យថា «មានចរិតលក្ខណៈដូច» ។
ពស់វែកមានគ្រោះថ្នាក់ហើយតំណាងឲ្យការអាក្រក់។
អាចត្រូវបានបញ្ជាក់ជាប្រយោគដាច់ដោយឡែក។ «អ្នកជាពស់វែកនៃការអាក្រក់!
នរណា» ឬ «អ្នកអាក្រក់ដូចជាពស់វែក! អ្នកណា»
តើនរណាប្រាប់អ្នករាល់គ្នាឲ្យរត់គេចពីព្រះពិរោធ ដែលនឹងមកដល់ដូច្នេះ?
លោកយ៉ូហានប្រើសំណួរមួយដើម្បីស្តីបន្ទោសពួកផារីស៊ីនិងពួកសាឌូស៊ី
ព្រោះពួកគេបានសុំឲ្យលោកធ្វើពិធីជ្រមុជទឹកឲ្យគេ
ដើម្បីកុំឲ្យព្រះជាម្ចាស់ដាក់ទណ្ឌកម្មពួកគេ ប៉ុន្តែពួកគេមិនចង់ឈប់ធ្វើបាបឡើយ។
«អ្នកមិនអាចរត់ចេញពីព្រះពិរោធរបស់ព្រះជាម្ចាស់ដូចនេះទេ» ។ ឬ «កុំគិតថា
អ្នកអាចរត់គេចពីកំហឹងរបស់ព្រះបាន ព្រោះខ្ញុំធ្វើពិធីជ្រមុជទឹកឲ្យអ្នក»។
រត់គេចពីព្រះពិរោធ ដែលនឹងមកដល់
ពាក្យថា «ព្រះពិរោធ» ត្រូវបានគេប្រើដើម្បីសំដៅទៅលើ
ការដាក់ទណ្ឌកម្មរបស់ព្រះជាម្ចាស់
ពីព្រោះព្រះពិរោធរបស់ព្រះជាម្ចាស់បានកើតឡើងមុន។
«រត់គេចពីទណ្ឌកម្មដែលនឹងមកដល់» ឬ «រត់គេច
ព្រោះព្រះអង្គជិតដាក់ទណ្ឌកម្មអ្នក»
ចូរបង្កើតផលផ្លែល្អ ដើម្បីបញ្ជាក់ពីការដែលអ្នករាល់គ្នាបានកែប្រែចិត្តគំនិតមែន
ឃ្លា «បង្កើតផលផ្លែ» ជាពាក្យប្រៀបធៀប
ដែលសំដៅទៅលើសកម្មភាពរបស់មនុស្សម្នាក់។
«ចូរបង្ហាញសកម្មភាពរបស់អ្នកថា អ្នកបានប្រែចិត្តយ៉ាងពិតប្រាកដ»
ខ្លួនមានលោកអប្រាហាំជាបុព្វបុរស
«អប្រាហាំជាបុព្វបុរសរបស់យើង» ឬ «យើងជាកូនចៅរបស់លោកអប្រាហាំ» ។
អ្នកដឹកនាំជនជាតិយូដាគិតថា ព្រះជាម្ចាស់នឹងមិនដាក់ទណ្ឌកម្មពួកគេទេ
ព្រោះពួកគេជាកូនចៅរបស់អប្រាហាំ។
ខ្ញុំសូមប្រាប់អ្នករាល់គ្នា
បន្ថែមឲ្យច្បាស់ទៅលើអ្វី ដែលលោកយ៉ូហានកំពុងនិយាយ។
ព្រះជាម្ចាស់អាចបង្កើតកូនចៅលោកអប្រាហាំចេញពីថ្មទាំងនេះក៏បានដែរ
«ព្រះជាម្ចាស់អាចបង្កើតកូនចៅជារូបកាយចេញពីរូបថ្មទាំងនេះ
ហើយប្រគល់ពួកគេទៅលោកអប្រាហាំក៏បានដែរ»
Matthew 3:10
ឃ្លាភ្ជាប់៖
លោកយ៉ូហានបាទិស្តបន្តបន្ទោសពួកផារីស៊ី និងពួកសាឌូស៊ី។
ពូថៅដាក់នៅជិតគល់ឈើស្រេចហើយ ដើមឈើណាមិនផ្តល់ផ្លែល្អទេ នឹងត្រូវកាប់ ហើយបោះ
ចោលទៅក្នុងភ្លើង
ការប្រៀបធៀបនេះមានន័យថា ព្រះជាម្ចាស់ត្រៀមនឹងដាក់ទោសមនុស្សមានបាប។
ឃ្លានេះប្រើជាទម្រង់កិរិយាសកម្ម។ «ព្រះជាម្ចាស់មានពូថៅរបស់ព្រះអង្គ
ហើយព្រះអង្គត្រៀមនឹងកាប់ និងដុតដើមឈើណា ដែលមិនបង្កើតផលផ្លែល្អ» ឬ
«នៅពេលមនុស្សម្នាក់មានពូថៅរបស់គាត់ត្រៀមកាត់
និងដុតដើមឈើណាដែលមានផ្លែមិនល្អ
ព្រះជាម្ចាស់ត្រៀមនឹងដាក់ទណ្ឌកម្មអ្នកសម្រាប់អំពើបាបរបស់អ្នក»
កែប្រែចិត្តគំនិត
«ដើម្បីបង្ហាញថា អ្នកបានប្រែចិត្ត»
លោកដែលមកក្រោយខ្ញុំ
ព្រះយេស៊ូមកតាមក្រោយលោកយ៉ូហាន។
មានអំណាចលើសខ្ញុំ
«សំខាន់ជាងខ្ញុំ»
លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណដ៏វិសុទ្ធនិងដោយភ្លើងវិញ
ការប្រៀបធៀប រវាងពិធីជ្រមុជទឹករបស់លោកយ៉ូហា
និងពិធីជ្រមុជទឹកនាពេលអនាគត។
មានន័យថាពិធីជ្រមុជទឹករបស់លោកយ៉ូហានគ្រាន់តែជានិមិត្តរូប
នៃការសម្អាតមនុស្សពីអំពើបាបរបស់ពួកគេ។
ពិធីជ្រមុជទឹកដោយព្រះវិញ្ញាណដ៏វិសុទ្ធ
និងភ្លើងពិតជាអាចសម្អាតមនុស្សពីអំពើបាបរបស់គេបាន។ បើអាចសូមប្រើពាក្យ
"ជ្រមុជទឹក" នៅក្នុងការបកប្រែរបស់អ្នក
ដើម្បីរក្សាការប្រៀបធៀបទៅនឹងពិធីបជ្រមុជទឹករបស់លោកយ៉ូហាន។
លោកកាន់ចង្អេរ សម្អាតលានបោកស្រូវ អុំស្រូវ
ការប្រៀបធៀបដែលបង្ហាញថា ព្រះគ្រិស្តនឹងញែកមនុស្សសុចរិត
ចេញពីមនុស្សទុច្ចរិតទៅនឹងរបៀប ដែលបុរសម្នាក់ញែកគ្រាប់ស្រូវសាលីពីអង្កាម។
«ព្រះគ្រិស្តប្រៀបដូចជាមនុស្ស ដែលកាន់ចង្អេរនៅក្នុងព្រះហស្តរបស់ព្រះអង្គ»
លោកកាន់ចង្អេរ
«កាន់ចង្អេរ» នៅទីនេះមានន័យថា មនុស្សត្រៀមខ្លួនដើម្បីធ្វើសកម្មភាព។
«ព្រះគ្រិស្តកំពុងតែកាន់ចង្អេរ ព្រោះព្រះអង្គបានត្រៀមខ្លួនរួចរាល់ហើយ»
ចង្អេរ
នេះជាឧបករណ៍អុំស្រូវសាលី ដើម្បីញែកគ្រាប់ស្រូវសាលីចេញពីអង្កាម។
គ្រាប់ធញ្ញជាតិធ្ងន់ ៗ នឹងធ្លាក់ចុះមកវិញ
ហើយអង្កាមនឹងហើរធ្លាក់ចេញទៅតាមខ្យល់។
វាមានរាងប្រហាក់ប្រហែលនឹងស្លុងតែមានទំហំធំធ្វើពីឈើ។
សម្អាតលានបោកស្រូវ អុំស្រូវ
ព្រះគ្រិស្តកាន់ចង្អេររួចរាល់ ដើម្បីសម្អាតលានបោកស្រូវអុំស្រូវ។
លានបោកស្រូវអុំស្រូវ
«លានរបស់ព្រះអង្គ» ឬ «លានដែលព្រះអង្គញែកគ្រាប់ធញ្ញជាតិចេញពីអង្កាម»
ប្រមូលយកគ្រាប់ដាក់ក្នុងជង្រុក ...ដុតក្នុងភ្លើង ដែលឆេះរហូត
ជាពាក្យប្រៀបធៀប ដែលបង្ហាញពីរបៀបព្រះជាម្ចាស់ញែកមនុស្សសុចរិត
ចេញពីមនុស្សអាក្រក់។ មនុស្សសុចរិតនឹងឡើងទៅស្ថានបរមសុខ
ដូចជាស្រូវសាលីចូលទៅក្នុងឃ្លាំងរបស់កសិករ
ហើយព្រះជាម្ចាស់នឹងដុតមនុស្សក្នុងភ្លើងដែលឆេះរហូត។
ដែលឆេះរហូត
ឃ្លានេះស្ថិតនៅក្នុងទម្រង់កិរិយាសកម្ម។ «ដែលនឹងឆេះរហូត»
Matthew 3:13
ឃ្លាភ្ជាប់៖
រឿងនេះផ្លាស់ប្តូរទៅពេលក្រោយ
ពេលលោកយ៉ូហានបាទិស្តធ្វើពិធីជ្រមុជទឹកឲ្យព្រះយេស៊ូ។
ដើម្បីឲ្យលោកយ៉ូហានធ្វើពិធីជ្រមុជទឹកឲ្យ
ឃ្លានេះប្រើជាទម្រង់កិរិយាសកម្ម។
«ដូច្នេះលោកយ៉ូហានបាទិស្តទអាចធ្វើពិធីជ្រមុជទឹកឲ្យព្រះអង្គបាន»
ខ្ញុំទេតើដែលត្រូវទទួលពិធីជ្រមុជទឹកពីលោក ម្តេចក៏លោកមករកខ្ញុំវិញ?
លោកយ៉ូហានប្រើសំណួរដើម្បីបង្ហាញការភ្ញាក់ផ្អើលចំពោះសំណូមពររបស់ព្រះយេស៊ូ។
«ព្រះអង្គសំខាន់ជាងខ្ញុំ។ ខ្ញុំមិនគួរធ្វើពិធីជ្រមុជទឹកឲ្យព្រះអង្គទេ
ព្រះអង្គគួរតែធ្វើពិធីជ្រមុជទឹកឲ្យខ្ញុំ» ។
ម្តងនេះសិនចុះ
ការធ្វើនេះសំដៅលើព្រះយេស៊ូ និងលោកយ៉ូហាន។
Matthew 3:16
ឃ្លាភ្ជាប់៖
នេះជាចុងបញ្ចប់ផ្នែកនៃសាច់រឿងអំពីយ៉ូហានបាទិស្ត
ហើយពិពណ៌នាអំពីអ្វីដែលបានកើតឡើង
បន្ទាប់ពីលោកបានធ្វើពិធីជ្រមុជទឹកឲ្យព្រះយេស៊ូ។
ក្រោយពេលទទួលពិធីជ្រមុជទឹករួចហើយ
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«បន្ទាប់ពីលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកជូនព្រះយេស៊ូ»
ស្រាប់តែ
ពាក្យថា“ ស្រាប់តែ” នៅទីនេះដាស់តឿនយើង
ឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានគួរឱ្យភ្ញាក់ផ្អើល ដែលបានកើតឡើង។
ផ្ទៃមេឃបើកចំហ
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ព្រះយេស៊ូបានឃើញផ្ទៃមេឃបើកចំហ»
ឬ «ព្រះជាម្ចាស់បានបើកផ្ទៃមេឃឲ្យព្រះយេស៊ូ»
ចុះមកដូចសត្វព្រាប
អាចមានន័យថា ១) នេះគ្រាន់តែជាសេចក្តីថ្លែងថា

generated on Wed Sep 10 16:16:32 2025

ព្រះវិញ្ញាណមានទម្រង់ដូចជាសត្វព្រាប ឬ ២) នេះជាការប្រៀបធៀបមួយ
ដែលបង្ហាញថា ព្រះវិញ្ញាណយាងមកសណ្ឋិតលើព្រះយេស៊ូ
ដោយស្រទន់ដូចជាសត្វព្រាបកំពុងហើរចុះមក។
មានសំឡេងពីលើមេឃមក
«ព្រះយេស៊ូបានឮសំឡេងពីលើមេឃ» ។ «សំឡេង»
នៅទីនេះសំដៅទៅលើព្រះជាម្ចាស់ ដែលកំពុងតែមានបន្ទូល។
«ព្រះជាម្ចាស់មានព្រះបន្ទូលពីលើមេឃ»
បុត្រ
នេះជាឋានៈដ៏សំខាន់ចំពោះព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់។

---

4 [1]បន្ទាប់មក ព្រះវិញ្ញាណបាននាំព្រះយេស៊ូទៅវាលរហោស្ថានដើម្បីឲ្យមារសាតាំងល្បួង។[2]ពេលទ្រង់បានតមអាហារអស់ពេលសែសិបយប់ សែសិបថ្ងៃមក ព្រះអង្គ
ក៏ចាប់ផ្តើមឃ្លាន។[3]មេល្បួងបានចូលមករកព្រះអង្គ ទាំងនិយាយថា៖ «ប្រសិនបើលោកពិតជាបុត្រារបស់ព្រះជាម្ចាស់មែន សូមបញ្ជាឲ្យដុំថ្មទាំងនេះទៅជានំប៉ុង
មើល៍!»។[4]ប៉ុន្តែ ព្រះយេស៊ូឆ្លើយតបទៅមេល្បួងវិញថា៖ «ក្នុងគម្ពីរបានចែងថា មនុស្សមិនមែនរស់ដោយសារតែនំប៉ុង ប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែល
ចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ»។
[5]បន្ទាប់មក មារបាននាំព្រះអង្គទៅក្រុងដ៏វិសុទ្ធ ដាក់ព្រះអង្គលើកំពូលព្រះវិហារ[6]ហើយនិយាយថា៖ «ប្រសិនបើលោកពិតជាបុត្រារបស់ព្រះជាម្ចាស់មែន ចូរលោតទម្លាក់ខ្លួន
ចុះទៅក្រោមមើល៍ ដ្បិតក្នុងគម្ពីរបានចែងថា ព្រះជាម្ចាស់នឹងបញ្ជាឲ្យទេវតាថែរក្សាលោក ចាំទ្រលើកលោកឡើង មិនឲ្យជើងលោកប៉ះទង្គិចនឹងថ្មឡើយ»។
[7]ព្រះយេស៊ូឆ្លើយតបទៅមារវិញថា៖ «ក្នុងគម្ពីរបានចែងទៀតថា អ្នកមិនត្រូវល្បងលព្រះជាម្ចាស់ជាព្រះរបស់អ្នកឡើយ»។[8]លើកនេះមារក៏នាំព្រះអង្គទៅកន្លែងយ៉ាងខ្ពស់
មួយ ហើយបង្ហាញនគរទាំងប៉ុន្មានក្នុងពិភពលោក ព្រមទាំងបង្ហាញឲ្យឃើញភាពរុងរឿងរបស់នគរទាំងនោះផង។[9]មាននិយាយទៅកាន់ព្រះអង្គថា៖
«ខ្ញុំនឹងប្រគល់សម្បត្តិទាំងនេះឲ្យទៅលោកប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ!»។
[10]ក្រោយមកព្រះយេស៊ូនិយាយទៅកាន់មារថា៖ «ថយចេញពីទីនេះទៅសាតាំងអើយ! ដ្បិតក្នុងគម្ពីរបានចែងថា អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងបំរើតែ
ព្រះអង្គមួយប៉ុណ្ណោះ»។[11]ក្រោយមក មារក៏ចាកចេញពីព្រះអង្គទៅ រួចមានពួកទេវតានាំគ្នាចូលមក និងបម្រើព្រះអង្គ។
[12]កាលព្រះយេស៊ូឮដំណឹងថា គេបានចាប់លោកយ៉ូហានដាក់ឃុំឃាំងហើយ ព្រះអង្គក៏ភៀសចេញទៅស្រុកកាលីឡេ។[13]ព្រះអង្គចាកចេញពីភូមិណាសារ៉ែត ទៅរស់នៅក្រុង
កាពើណិមជិតមាត់សមុទ្រ ក្នុងតំបន់សាប់យូឡូន និងណែបថាលី។
[14]ការនេះកើតឡើងដើម្បីឲ្យបានស្របនឹងសេចក្តីដែលបានចែងទុកតាមរយៈព្យាការីអេសាយថា៖[15]«ដែនដីសាប់យូឡូន និងណែបថាលី ដែលជាផ្លូវឆ្ពោះទៅកាន់សមុទ្រ
អើយ! ខាងនាយទន្លេយ័រដាន់ ស្រុកកាលីឡេដែលជាកន្លែងសាសន៍ដទៃរស់នៅអើយ![16]ប្រជាជនដែលអង្គុយនៅក្នុងទីងងឹត បានឃើញពន្លឺមួយដ៏អស្ចារ្យ ហើយពួកអ្នករស់
ក្នុងស្រុកដែលស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ នឹងមានពន្លឺមួយលេចឡើងបំភ្លឺពួកគេ»។
[17]ចាប់តាំងពីគ្រានោះមក ព្រះយេស៊ូចាប់ផ្តើមប្រកាសនិងនិយាយថា៖ «ចូរកែប្រែចិត្តឡើង! ដ្បិតព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ»។
[18]កាលព្រះអង្គយាងតាមឆ្នេរសមុទ្រកាលីឡេ ទ្រង់បានឃើញបងប្អូនពីរនាក់គឺស៊ីម៉ូន ហៅពេត្រុស និងអនទ្រេ ជាប្អូនរបស់គាត់ ដែលកំពុងតែបង់សំណាញ់ ពួកគេជាអ្នក
នេសាទ។[19]ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេថា៖ «សូមអញ្ជើញមកតាមខ្ញុំចុះ ខ្ញុំនឹងតាំងអ្នកឲ្យនេសាទមនុស្សវិញ»។[20]ភ្លាមនោះអ្នកទាំងពីរក៏ទុកសំណាញ់ចោល រួច
ដើរតាមព្រះអង្គទៅ។
[21]កាលព្រះយេស៊ូយាងទៅមុខបន្តិច ព្រះអង្គឃើញបងប្អូនពីរនាក់ទៀត គឺយ៉ាកុប និងយ៉ូហានប្អូនរបស់គាត់ ពួកគេនៅក្នុងទូកជាមួយឪពុករបស់ពួកគេគឺលោកសេបេដេជា
ដែលកំពុងតែរៀបចំអួន។ ព្រះអង្គក៏ហៅអ្នកទាំងពីរ។[22]ហើយអ្នកទាំងពីរក៏ចាកចោលទូក និងឪពុកភ្លាម រួចដើរតាមព្រះអង្គទៅ។
[23]ព្រះយេស៊ូយាងកាត់ពេញស្រុកកាលីឡេទាំងមូល ទ្រង់បង្រៀនក្នុងគ្រប់សាលាប្រជុំ ប្រកាសដំណឹងល្អអំពីព្រះរាជ្យនៃព្រះជាម្ចាស់ ហើយប្រោសជំងឺគ្រប់យ៉ាង និងអ្នកជំងឺ
គ្រប់ប្រភេទ ក្នុងចំណោមប្រជាជនឲ្យបានជាសះស្បើយ។[24]ដំណឹងនេះក៏ល្បីឮពាសពេញស្រុកស៊ីរីទាំងមូល ហើយគេបាននាំអស់អ្នកជំងឺគ្រប់
ប្រភេទដែលមានជំងឺផ្សេងគ្នាៗ អ្នកអារក្សចូល មនុស្សឆ្កួតជ្រូក និងមនុស្សស្លាប់ដៃស្លាប់ជើង មករកព្រះអង្គ។ ព្រះអង្គក៏ប្រោសបានពួកគេឲ្យបានជាសះស្បើយទាំងអស់។
[25]មានមហាជនជាច្រើននាំគ្នាដើរតាមព្រះអង្គ ចាប់ពីស្រុកកាលីឡេ ស្រុកដេកាប៉ូល ក្រុងយេរូសាឡឹម ស្រុកយូដា និងពីតំបន់ខាងនាយទន្លេយ័រដាន់។

Matthew 4:1
ព័ត៌មានទូទៅ៖
នៅទីនេះ អ្នកនិពន្ធអត្ថបទគម្ពីរចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង
ដែលព្រះយេស៊ូចំណាយពេល៤០ថ្ងៃ នៅទីរហោស្ថាន
ជាកន្លែងដែលសាតាំងល្បួងព្រះអង្គ។ នៅក្នុងខ៤ ព្រះយេស៊ូបន្ទោសសាតាំង
ដោយដកស្រង់ចេញពីកណ្ឌគម្ពីរទុតិយកថា។
ព្រះវិញ្ញាណបាននាំព្រះយេស៊ូ
ឃ្លានេះប្រើជាទម្រង់កិរិយាសកម្ម។ «ព្រះវិញ្ញាណដឹកនាំព្រះយេស៊ូ»
ដើម្បីឲ្យមារសាតាំងល្បួង
ឃ្លានេះប្រើជាទម្រង់កិរិយាសកម្ម។ «ដូច្នេះអារក្សអាចល្បួងព្រះយេស៊ូ»
មារសាតាំង ... ល្បួង
សំដៅទៅលើលក្ខណៈគ្នា។
អ្នកប្រហែលជាត្រូវប្រើពាក្យតែមួយដើម្បីបកប្រែពាក្យទាំងពីរនេះ។
ទ្រង់បានតមអាហារ ... ព្រះអង្គក៏ចាប់ផ្តើមឃ្លាន
សំដៅទៅលើព្រះយេស៊ូ។
សែសិបយប់ សែសិបថ្ងៃ
«៤០ថ្ងៃ ៤០យប់»។ សំដៅលើរយៈពេល ២៤ ម៉ោង។ «៤០ថ្ងៃ»
ប្រសិនបើលោកពិតជាបុត្រារបស់ព្រះជាម្ចាស់មែន សូមបញ្ជា
ជាការល្បងបំផុតដែលថាសាតាំងដឹងថា ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។
អាចមានន័យថា ១) នេះជាការល្បួងព្រះយេស៊ូឲ្យធ្វើការអស្ចារ្យ
ជាប្រយោជន៍ផ្ទាល់ខ្លួនព្រះអង្គ។ «លោកពិតជាបុត្រារបស់ព្រះជាម្ចាស់មែន
សូមបញ្ជា» ឬ ២) នេះជាបញ្ហាប្រឈម ឬការចោទប្រកាន់។ «ដើម្បីបញ្ជាក់ថា
ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ដោយទ្រង់អាចបញ្ជាបាន»
ព្រះបុត្រារបស់ព្រះជាម្ចាស់
នេះជាឋានៈដ៏សំខាន់ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះយេស៊ូ
និងព្រះជាម្ចាស់។
ព្រះបុត្រារបស់ព្រះជាម្ចាស់
នេះជាឋានៈដ៏សំខាន់ចំពោះព្រះយេស៊ូ។
សូមបញ្ជាឲ្យដុំថ្មទាំងនេះទៅជានំប៉ុង
អ្នកអាចប្រែឃ្លានេះដោយដកស្រង់ផ្នាល់។ «និយាយទៅកាន់ថ្មទាំងនេះថា
ក្លាយជានំប៉ុង!»
នំប៉ុង
នៅទីនេះ «អាហារ» សំដៅទៅលើអាហារជាទូទៅ។ «ម្ហូប»
ក្នុងគម្ពីរបានចែងថា
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«លោកម៉ូសេបានសរសេរសេចក្តីនេះនៅក្នុងបទគម្ពីរជាយូរមកហើយ»
មនុស្សមិនមែនរស់ដោយសារតែនំប៉ុង ប៉ុណ្ណោះទេ
បញ្ជាក់ថាមានអ្វី ដែលសំខាន់ចំពោះជីវិតជាងអាហារ។
គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ
ពាក្យ «ព្រះបន្ទូល» និង «ព្រះឱស្ឋ» ត្រង់នេះ
សំដៅទៅលើអ្វីដែលព្រះជាម្ចាស់មានបន្ទូល។ «ដោយស្តាប់អ្វីគ្រប់យ៉ាង
ដែលព្រះអង្គមានបន្ទូល»
Matthew 4:5
ព័ត៌មានទូទៅ៖
នៅក្នុងខ ៦ សាតាំងនិយាយដូចក្នុងកណ្ឌគម្ពីរទំនុកតម្កើង ដើម្បីល្បួងព្រះយេស៊ូ។
ប្រសិនបើលោកពិតជាបុត្រារបស់ព្រះជាម្ចាស់មែន ចូរលោតទម្លាក់ខ្លួនចុះទៅក្រោម
យកល្អសន្មតថា សាតាំងដឹងថាព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។
អាចមានន័យថា ១) នេះជាការល្បួងព្រះយេស៊ូឲ្យធ្វើការអស្ចារ្យ
ជាប្រយោជន៍ផ្ទាល់ខ្លួនព្រះអង្គ។ «ដោយសារអ្នកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់
អ្នកអាចទម្លាក់ខ្លួនចុះទៅក្រោម» ឬ ២) នេះជាបញ្ហាប្រឈម ឬការចោទប្រកាន់។

generated on Wed Sep 10 16:16:32 2025

«បញ្ជាក់ថា អ្នកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន
ដោយទម្លាក់ខ្លួនអ្នកចុះទៅក្រោម»
បុត្រារបស់ព្រះជាម្ចាស់
នេះជាឋានៈដ៏សំខាន់ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់
និងព្រះយេស៊ូ។
ចូរលោតទម្លាក់ខ្លួនចុះទៅក្រោម
«ចូរទម្លាក់ខ្លួនអ្នកទៅដី» ឬ «លោតចុះ»
គម្ពីរបានចែងថា
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«ដោយអ្នកនិពន្ធអត្ថបទគម្ពីរបានសរសេរនៅក្នុងបទគម្ពីរ» ឬ
«ដោយបានបរិយាយនៅក្នុងបទគម្ពីរ»
ព្រះជាម្ចាស់នឹងបញ្ជាឲ្យទេវតាថែរក្សាលោក
«ព្រះជាម្ចាស់នឹងបញ្ជាពួកទេវតារបស់ព្រះអង្គ មើលថែរក្សាអ្នក»។
ឃ្លានេះអាចបកប្រែដោយដកស្រង់ផ្ទាល់។
«ព្រះជាម្ចាស់នឹងមានព្រះបន្ទូលទៅកាន់ពួកទេវតារបស់ព្រះអង្គថា
សូមថែរក្សាព្រះអង្គ»
ចាំទ្រលើកលោកឡើង
«ទេវតានឹងចាំទ្រអ្នក»
Matthew 4:7
ព័ត៌មានទូទៅ៖
នៅក្នុងខ៧ ព្រះយេស៊ូបានស្តីបន្ទោសសាតាំង
ដោយការដកស្រង់មួយទៀតចេញពីកណ្ឌគម្ពីរទុតិយកថា។
ក្នុងគម្ពីរបានចែងទៀតថា
គេយល់ថា ព្រះយេស៊ូកំពុងតែដកស្រង់បទគម្ពីរម្តងទៀត។
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ជាថ្មីម្តងទៀត
ខ្ញុំនឹងប្រាប់អ្នកពីអ្វីដែលម៉ូសេបានសរសេរនៅក្នុងបទគម្ពីរ»
អ្នកមិនត្រូវល្បងល
«អ្នក» នៅទីនេះ សំដៅទៅលើមនុស្សគ្រប់គ្នា។ «អ្នកមិនគួរសាកល្បង» ឬ
«គ្មាននរណាម្នាក់គួរល្បងល»
លើកនេះមារ
«បន្ទាប់មកមារ»
មារនិយាយទៅកាន់ព្រះអង្គ
«មារបាននិយាយទៅកាន់ព្រះយេស៊ូ»
«ខ្ញុំនឹងប្រគល់សម្បត្តិទាំងនេះឲ្យទៅលោក
«ខ្ញុំនឹងប្រគល់សម្បត្តិទាំងនេះឲ្យទៅលោក»។ មេល្បួងកំពុងសង្កត់ធ្ងន់នៅទីនេះ
ថាវានឹងផ្តល់ «របស់ទាំងអស់នេះ» មិនមែនគ្រាន់តែរបស់ខ្លះទេ។
Matthew 4:10
ឃ្លាភ្ជាប់៖
នេះជាចុងផ្នែកបញ្ចប់នៃសាច់រឿង ដែលសាតាំងល្បួងព្រះយេស៊ូ។
ព័ត៌មានទូទៅ៖
នៅក្នុងខ ១០
ព្រះយេស៊ូវបានស្តីបន្ទោសសាតាំងជាមួយនឹងការដកស្រង់មួយផ្សេងទៀត
ពីកណ្ឌគម្ពីរទុតិយកថា។
ដ្បិតក្នុងគម្ពីរបានចែងថា
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«ចំពោះលោកម៉ូសេក៏បានសរសេរក្នុងគម្ពីរដែរ»
អ្នកត្រូវ
«អ្នក» នៅទីនេះមានន័យថា មនុស្សគ្រប់គ្នា។
រួចមាន
ពាក្យថា «រួចមាន» នៅទីនេះដាស់តឿនយើង
ឲ្យយកចិត្តទុកដាក់លើព័ត៌មានថ្មីសំខាន់ៗ ដែលមាននៅខាងក្រោម។
Matthew 4:12
ព័ត៌មានទូទៅ៖
នេះជាការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង ដែលអ្នកនិពន្ធអត្ថបទគម្ពីរពិពណ៌នា
អំពីការចាប់ផ្តើមព័ន្ធកិច្ចបម្រើរបស់ព្រះយេស៊ូនៅស្រុកកាលីឡេ។
ខគម្ពីរទាំងនេះពន្យល់ពីរបៀប ដែលព្រះយេស៊ូបានយាងមកនៅស្រុកកាលីឡេ។
កាល
ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ការផ្អាកសាច់រឿងសំខាន់។ នៅទីនេះ
លោកម៉ាថាយចាប់ផ្តើមប្រាប់ផ្នែកថ្មីនៃសាច់រឿង។
គេបានចាប់លោកយ៉ូហានដាក់ឃុំឃាំង
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ស្តេចបានចាប់ខ្លួនលោកយ៉ូហាន»
ក្នុងតំបន់សាប់យូឡូន និងណែបថាលី
នេះជាឈ្មោះកុលសម្ព័ន្ធ
ដែលរស់នៅក្នុងតំបន់ទាំងនេះមុនពេលជនបរទេសចូលកាន់កាប់ទឹកដីអ៊ីស្រាអែលជាច្រើនឆ្នាំមុន។
Matthew 4:14
ព័ត៌មានទូទៅ៖
នៅក្នុងខ១៥ និង១៦
អ្នកនិពន្ធអត្ថបទគម្ពីរបានដកស្រង់ពាក្យរបស់ព្យាការីអេសាយ
ដើម្បីបង្ហាញថាព័ន្ធកិច្ចបម្រើរបស់ព្រះយេស៊ូ
នៅស្រុកកាលីឡេជាការសម្រេចតាមទំនាយ។
ការនេះកើតឡើង
សំដៅទៅលើព្រះយេស៊ូ ដែលនឹងរស់នៅក្នុងកាពើណិម។
ដើម្បីឲ្យបានស្របនឹងសេចក្តីដែលបានចែងទុក
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «អ្វីដែលព្រះជាម្ចាស់មានបន្ទូល»
ដែនដីសាប់យូឡូន និងណែបថាលី ដែលជាផ្លូវឆ្ពោះទៅកាន់សមុទ្រអើយ! ខាងនាយទន្លេយ័រដាន់
ស្រុកកាលីឡេដែលជាកន្លែងសាសន៍ដទៃរស់នៅអើយ!
ទឹកដីទាំងអស់នេះ ពិពណ៌នាអំពីតំបន់តែមួយ។
នេះអាចត្រូវបានបកប្រែជាប្រយោគពេញលេញ។
"នៅលើទឹកដីសាប់យូឡូននិងណាប៉ូធីលី ... នៅលើទឹកដីកាលីឡេ
ដែលជាតិសាសន៍ជាច្រើនរស់នៅ!"
ដែលជាផ្លូវឆ្ពោះទៅកាន់សមុទ្រអើយ
គឺសមុទ្រកាលីឡេ។
ប្រជាជនដែលអង្គុយនៅក្នុងទីងងឹត បានឃើញពន្លឺមួយដ៏អស្ចារ្យ
«ភាពងងឹត”ត្រង់នេះ សំដៅទៅលើភាពងងឹតខាងសីលធម៌ ឬអំពើបាប
ដែលបំបែកមនុស្សចេញពីព្រះជាម្ចាស់។ ហើយ «ពន្លឺ
»សំដៅទៅលើសារពិតរបស់ព្រះជាម្ចាស់ដែលជួយសង្គ្រោះមនុស្សពីអំពើបាបរបស់ពួកគេ។
នេះជារូបភាពរបស់មនុស្ស ដែលគ្មានសង្ឃឹមឥឡូវមានក្តីសង្ឃឹមមកពីព្រះជាម្ចាស់។
ពួកអ្នករស់ក្នុងស្រុកដែលស្ថិតនៅក្រោមអំណាចនៃសេចក្តីស្លាប់ នឹងមានពន្លឺមួយលេច
ឡើងបំភ្លឺពួកគេ
អាចមានន័យដូចគ្នានឹងផ្នែកដំបូងនៃការកាត់ទោស។ នៅទីនេះ «ស្រុកដែលស្ថិត
នៅក្រោមអំណាចសេចក្តីស្លាប់» សំដៅទៅលើសេចក្តីស្លាប់ខាងវិញ្ញាណ
ឬការឃ្លាតឆ្ងាយពីព្រះជាម្ចាស់។
Matthew 4:17
ចូរកែប្រែចិត្តឡើង! ដ្បិតព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ
ឃ្លាថា «ព្រះរាជ្យនៃស្ថានបរមសុខ» សំដៅទៅលើព្រះជាម្ចាស់
ដែលកំពុងសោយរាជ្យជាស្តេច។ ឃ្លានេះមានតែនៅក្នុងកណ្ឌគម្ពីរម៉ាថាយប៉ុណ្ណោះ។
បើអាចសូមប្រើពាក្យ“ ស្ថានបរមសុខ” ក្នុងការបកប្រែរបស់អ្នក។
«ព្រះជាម្ចាស់នៃយើងគង់នៅស្ថានបរមសុខ នឹងបង្ហាញអង្គទ្រង់ជាស្តេច» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក៣ ខ១ ។
Matthew 4:18
ព័ត៌មានទូទៅ៖
ចាប់ផ្តើមសាច់រឿងថ្មីអំពីព័ន្ធកិច្ចរបស់ព្រះយេស៊ូ នៅស្រុកកាលីឡេ។
នៅទីនេះព្រះអង្គចាប់ផ្តើមប្រមូលមនុស្ស ឲ្យធ្វើជាសិស្សរបស់ព្រះអង្គ។
ដែលកំពុងតែបង់សំណាញ់
អត្ថន័យពេញលេញនៃឃ្លានេះមានន័យច្បាស់។
«បោះសំណាញ់ទៅក្នុងទឹកដើម្បីចាប់ត្រី»
សូមអញ្ជើញមកតាមខ្ញុំចុះ
ព្រះយេស៊ូអញ្ជើញលោកស៊ីម៉ូន និងលោកអនទ្រេ ឲ្យមកតាមព្រះអង្គ
រស់នៅជាមួយនឹងព្រះអង្គ ហើយក្លាយជាសិស្សរបស់ព្រះអង្គ។
«ធ្វើជាសិស្សរបស់ខ្ញុំ»
ខ្ញុំនឹងតាំងអ្នកឲ្យនេសាទមនុស្សវិញ
ពាក្យប្រៀបធៀបនេះមានន័យថា
លោកស៊ីម៉ូននិងលោកអនទ្រេនឹងបង្រៀនមនុស្សអំពីព្រះរាជសារពិតរបស់ព្រះជាម្ចាស់
ដូច្នេះអ្នកផ្សេងទៀតក៏នឹងធ្វើតាមព្រះយេស៊ូដែរ។
«ខ្ញុំនឹងបង្រៀនអ្នកឲ្យប្រមូលមនុស្សមកខ្ញុំ ដូចអ្នកធ្លាប់ប្រមូលត្រី»
Matthew 4:21
ឃ្លាភ្ជាប់៖
ព្រះយេស៊ូត្រាស់ហៅមនុស្ស ឲ្យក្លាយជាសិស្សរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

ព្រះអង្គក៏ហៅអ្នកទាំងពីរ
«ព្រះយេស៊ូបានត្រាស់ហៅលោកយ៉ូហាន និងលោកយ៉ាកុប» ។
ឃ្លានេះក៏មានន័យថា ព្រះយេស៊ូបានអញ្ជើញពួកគេឲ្យដើរតាមព្រះអង្គ
រស់នៅជាមួយព្រះអង្គ ហើយក្លាយជាសិស្សរបស់ព្រះអង្គ។
ភ្លាម
«ខណៈនោះ»
ចាកចោលទូក...រួចដើរតាមព្រះអង្គទៅ
គួរតែច្បាស់ថា នេះការផ្លាស់ប្តូរជីវិត។ បុរសទាំងនេះលែងនេសាទត្រីទៀតហើយ
ពួកគេបានចាកចេញពីគ្រួសារ ដែលមានមុខជំនួញដើម្បីដើរតាមព្រះយេស៊ូ
អស់មួយជីវិត។
Matthew 4:23
ឃ្លាភ្ជាប់៖
នេះជាចុងបញ្ចប់នៃសាច់រឿងអំពីការចាប់ផ្តើម
នៃព័ន្ធកិច្ចរបស់ព្រះយេស៊ូវនៅស្រុកកាលីឡេ។
ខទាំងនេះសង្ខេបពីអ្វីដែលព្រះអង្គបានធ្វើ និងរបៀបដែលប្រជាជនឆ្លើយតប។
បង្រៀនក្នុងគ្រប់សាលាប្រជុំ
«បង្រៀននៅក្នុងសាលាប្រជុំនៅស្រុកកាលីឡេ»ឬ«បង្រៀននៅក្នុងសាលាប្រជុំរបស់មនុស្សនៃពាក្យ
ប្រកាសដំណឹងល្អអំពីព្រះរាជ្យនៃព្រះជាម្ចាស់

“ព្រះរាជ្យ”ត្រង់នេះ សំដៅលើការគ្រប់គ្រងរបស់ព្រះជាម្ចាស់ជាស្តេច។
«ផ្សាយដំណឹងល្អអំពីរបៀបដែលព្រះអង្គនឹងបង្ហាញខ្លួនជាស្តេច»
ជំងឺគ្រប់យ៉ាង និងអ្នកជំងឺគ្រប់ប្រភេទ
ពាក្យថា «ជំងឺគ្រប់យ៉ាង» និង «ជំងឺគ្រប់ប្រភេទ» មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ
ប៉ុន្តែគួរតែត្រូវបានបកប្រែជាពាក្យពីរផ្សេងគ្នា បើអាច។ «ជំងឺ»
គឺជាអ្វីដែលបណ្តាលឲ្យមនុស្សម្នាក់ឈឺ។
ជំងឺផ្សេងគ្នាៗ
គឺជាភាពទន់ខ្សោយ ឬការលំបាកខាងរាងកាយដែលបណ្តាលមកពីមានជំងឺ។
អ្នកអារក្សចូល
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «មនុស្សមានអារក្សចូល» ឬ
«អ្នកដែលអារក្សគ្រប់គ្រង»
មនុស្សឆ្កួតជ្រូក
«អ្នកដែលមានការប្រកាច់» ឬ «អ្នកដែលមានជំងឺដែលបណ្តាលឲ្យពួកគេត្រូវគ្នា»
មនុស្សស្លាប់ដៃស្លាប់ជើង
«អ្នកដែលមិនអាចដើរបាន»
ស្រុកដេកាប៉ូល
«ទីក្រុងទាំងដប់»។ នេះជាឈ្មោះតំបន់មួយនៅភាគអាគ្នេយ៍នៃសមុទ្រកាលីឡេ។

---

5 [1]ពេលព្រះយេស៊ូឃើញមហាជនទាំងនេះ ព្រះអង្គយាងឡើងទៅលើភ្នំ ហើយគង់នៅទីនោះ ពួកសិស្សនាំគ្នាចូលមកគាល់ព្រះអង្គ[2]ទ្រង់បង្រៀនពួកគេ
ដោយមានព្រះបន្ទូលថា៖[3]«មានពរហើយអ្នកណាក្រខ្សត់ខាងវិញ្ញាញ ដ្បិតអ្នកនោះនឹងបានទទួលព្រះរាជ្យនៃស្ថានបរមសុខ។[4]មានពរហើយអ្នកណាដែលសោកសៅ
ដ្បិតព្រះជាម្ចាស់នឹងសម្រាលទុក្ខពួកគេ។
[5]មានពរហើយអ្នកណាមានចិត្តស្លូតបូត ដ្បិតពួកគេនឹងទទួលផែនដីទុកជាមត៌ក។[6]មានពរហើយអ្នកណាស្រេកឃ្លានសេចក្តីសុចរិត ដ្បិតព្រះជាម្ចាស់នឹងប្រទានឲ្យពួកគេ
បានឆ្អែត។[7]មានពរហើយអ្នកណាមានចិត្តមេត្តាករុណា ដ្បិតគេនឹងទទួលបានក្តីមេត្តាករុណាត្រឡប់មកវិញ។[8]មានពរហើយអ្នកណាមានចិត្តបរិសុទ្ធ ដ្បិតគេនឹងឃើញ
ព្រះជាម្ចាស់។
[9]មានពរហើយអ្នកណាកសាងសន្តិភាព ដ្បិតពួកគេ នឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់។[10]មានពរហើយអ្នកណាត្រូវគេបៀតបៀន ព្រោះបានធ្វើតាមសេចក្តីសុចរិត
ដ្បិតពួកគេនឹងទទួលបានព្រះរាជ្យនៃស្ថានបរមសុខ។
[11]មានពរហើយអ្នកដែលត្រូវគេត្មះតិះដៀល បៀតបៀន និងមានគេនិយាយអាក្រក់គ្រប់យ៉ាង បង្ខូចឈ្មោះ ព្រោះតែខ្ញុំ។[12]ចូរមានអំណរ និងចិត្តរីករាយឡើង ព្រោះអ្នករាល់
គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ សូម្បីតែពួកព្យាការីដែលរស់នៅមុនអ្នករាល់គ្នា ក៏ត្រូវគេបៀតបៀនដែរ។
[13]អ្នកជាអំបិលនៃផែនដី ប៉ុន្តែ បើអំបិលបាត់ជាតិប្រៃហើយ តើគេនឹងយកអ្វីមកធ្វើឲ្យវាប្រៃឡើងវិញបាន? អំបិលនោះគ្មានប្រយោជន៍អ្វីទៀតឡើយ មានតែបោះចោលឲ្យ
មនុស្សដើរជាន់ប៉ុណ្ណោះ។[14]អ្នកជាពន្លឺ សម្រាប់បំភ្លឺពិភពលោក។ ទោះក្រុងនៅលើភ្នំក៏មិនអាចលាក់បំបាំងបានឡើយ។
[15]គ្មានអ្នកណាអុជចង្កៀងហើយ យកទៅដាក់ក្រោមល្អីលើនោះទេ គឺគេយកចង្កៀងនោះទៅដាក់លើជើងចង្កៀងវិញ ហើយចង្កៀងនោះនឹងបំភ្លឺមនុស្សនៅក្នុងផ្ទះ។
[16]ចូរឲ្យពន្លឺរបស់អ្នក បំភ្លឺដល់មនុស្សដូច្នោះដែរ គេនឹងឃើញអំពើល្អ ដែលអ្នកប្រព្រឹត្ត ហើយសរសើរតម្កើងដល់ព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ។
[17]កុំគិតថាខ្ញុំមកដើម្បីលុបបំបាត់គម្ពីរវិន័យ ឬគម្ពីរព្យាការីចោលឡើយ។ ខ្ញុំមិនមែនមកលុបបំបាត់ទេ ប៉ុន្តែខ្ញុំមកដើម្បីធ្វើឲ្យគម្ពីរនោះបានសម្រេចពេញលក្ខណៈទៅវិញទេ។
[18]ខ្ញុំប្រាប់អ្នករាល់គ្នាឲ្យបានដឹងច្បាស់ថា បើផ្ទៃមេឃ និងផែនដីនៅតែស្ថិតស្ថេរជាដរាប នោះគ្មានក្បៀស ឬបន្តក់ណាមួយក្នុងគម្ពីរវិន័យត្រូវរលុបចោលឡើយ គឺ
រហូតដល់ការទាំងនេះបានសម្រេចសព្វគ្រប់។
[19]អ្នកណាល្មើសបទបញ្ជាតូចបំផុតណាមួយ ហើយបង្រៀនអ្នកផ្សេងទៀតឲ្យធ្វើតាម អ្នកនោះនឹងមានឋានៈតូចបំផុតជាងគេ ក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ ប៉ុន្តែ អ្នកណា
ប្រព្រឹត្តតាមបទបញ្ជាទាំងនេះ ហើយបង្រៀនអ្នកផ្សេងទៀតឲ្យធ្វើតាម អ្នកនោះនឹងមានឋានៈធំក្នុងព្រះរាជ្យនៃស្ថានបរមសុខ។[20]ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា បើសេចក្តី
សុចរិតរបស់អ្នករាល់គ្នាមិនលើសសេចក្តីសុចរិតរបស់ពួកអាចារ្យ និងពួកខាងគណៈផារីស៊ីទេនោះ អ្នករាល់គ្នាគ្មានផ្លូវអាចចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខបាន
ឡើយ។
[21]អ្នកធ្លាប់ឮសេចក្តីដែលបាននិយាយពីជំនាន់ដើមថា៖ «កុំសម្លាប់មនុស្ស» ហើយ «អ្នកណាសម្លាប់មនុស្ស អ្នកនោះនឹងត្រូវគេផ្តន្ទាទោសវិញ»។[22]ប៉ុន្តែ ខ្ញុំសុំប្រាប់អ្នករាល់
គ្នាថា អ្នកណាខឹងបងប្អូនខ្លួន អ្នកនោះនឹងត្រូវគេផ្តន្ទាទោសដែរ។ ហើយអ្នកណាជេរបងប្អូនថាជាមនុស្សឥតប្រយោជន៍ អ្នកនោះនឹងត្រូវក្រុមប្រឹក្សាជាន់ខ្ពស់កាត់ទោស
ហើយអ្នកណាជេរគេថាមនុស្សឆ្កួត អ្នកនោះនឹងត្រូវផ្តន្ទាទោសធ្លាក់ក្នុងភ្លើងនរកអវិចី។
[23]ដូច្នេះ ប្រសិនបើអ្នកយកតង្វាយមកថ្វាយលើអាសនា ហើយស្រាប់តែនឹកឃើញថាអ្នកមានទំនាស់ជាមួយបងប្អូនណាមួយ[24]អ្នកត្រូវទុកតង្វាយរបស់អ្នក នៅលើ
អាសនាសិន ហើយទៅស្រុះស្រួលនឹងបងប្អូនរបស់អ្នកជាមុន រួចសូមវិលមកថ្វាយតង្វាយរបស់អ្នកវិញ។
[25]ត្រូវស្រុះស្រួលជាមួយគូវិវាទរបស់អ្នកសិន ពេលអ្នកធ្វើដំណើរទៅតុលាការជាមួយគ្នា ក្រែងលោគេបញ្ជូនអ្នកទៅចៅក្រម ហើយចៅក្រមបញ្ជូនអ្នកទៅនគរបាល ហើយ
អ្នកត្រូវជាប់គុក។[26]ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងថា បើអ្នកមិនបង់ប្រាក់ពិន័យគ្រប់ចំនួនឥតខ្វះមួយកាក់នោះទេ អ្នកនឹងមិនអាចរួចខ្លួនបានឡើយ»។
[27]អ្នកធ្លាប់ឮសេចក្តីថ្លែងទុកមកថា «កុំប្រព្រឹត្តអំពើផិតក្បត់»។[28]ប៉ុន្តែខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នកណាមើលស្ត្រីម្នាក់ ហើយមានចិត្តស្រើបស្រាលជាមួយនាង អ្នកនោះ
ដូចជាបានប្រព្រឹត្តអំពើផិតក្បត់នៅក្នុងចិត្ត រួចស្រេចទៅហើយ។
[29]ប្រសិនបើភ្នែកស្តាំអ្នក នាំអ្នកឲ្យជំពប់ដួល ចូរខ្វេះវាចេញ ហើយបោះចោលឲ្យឆ្ងាយពីអ្នកទៅ ដ្បិតបើបាត់ភ្នែកម្ខាងនោះនឹងប្រសើរជាងឲ្យរូបកាយទាំងមូលធ្លាក់ទៅក្នុង
នរក។[30]ប្រសិនបើដៃស្តាំអ្នក នាំអ្នកឲ្យជំពប់ដួល ចូរកាត់វា ហើយបោះចោលឲ្យឆ្ងាយពីអ្នកទៅ ដ្បិតបើបាត់អវយវៈមួយនេះ ប្រសើរជាងបណ្តោយឲ្យរូបកាយទាំងមូលធ្លាក់
ទៅក្នុងនរក»។
[31]មានសេចក្តីចែងទុកមកថា «អ្នកណាលែងភរិយាខ្លួន ត្រូវធ្វើលិខិតលែងលះឲ្យនាង»។[32]រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នកណាលែងភរិយារបស់ខ្លួន (លើកលែងតែ
អ្នកទាំងពីររស់នៅជាមួយគ្នា ដោយឥតបានរៀបការ) អ្នកនោះធ្វើឲ្យនាងទៅជាស្ត្រីផិតក្បត់ ប្រសិនបើនាងរៀបការម្តងទៀត។ រីឯបុរសណាមករៀបការជាមួយនឹងស្ត្រី
ដែលប្តីលែងនោះ អ្នកនោះក៏ប្រព្រឹត្តអំពើផិតក្បត់ដែរ»។
[33]អ្នករាល់គ្នាធ្លាប់ឮសេចក្តីដែលមានតែងទុកមកថា «កុំក្បត់ពាក្យសម្បថឡើយ ត្រូវធ្វើតាមគ្រប់ពាក្យដែលអ្នកបានស្បថនឹងព្រះអម្ចាស់»។[34]រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នា
ថា កុំស្បថឲ្យសោះ កុំយកមេឃមកស្បថឡើយ ព្រោះមេឃជាបល្ល័ង្ករបស់ព្រះជាម្ចាស់[35]ក៏កុំយកផែនដីមកស្បថដែរ ព្រោះផែនដីជាកំណល់កល់ព្រះបាទារបស់ព្រះអង្គ។ កុំ
យកក្រុងយេរូសាឡឹមមកស្បថឡើយ ព្រោះយេរូសាឡឹមជាក្រុងរបស់ព្រះមហាក្សត្រដ៏ឧត្តុង្គឧត្តម។

generated on Wed Sep 10 16:16:32 2025

[36]ក៏កុំស្បថដោយយកក្បាលអ្នកមកដាក់ឡើយ ព្រោះអ្នកពុំអាចធ្វើឲ្យសក់ទៅជាស ឬខ្មៅបានឡើយ។[37]ប៉ុន្តែត្រូវនិយាយឲ្យប្រាកដ បើ «មែន» ត្រូវនិយាយថា «មែន» បើ «ទេ» ត្រូវនិយាយថា «ទេ»។ រីឯពាក្យពន្លើស សុទ្ធតែមកពីមារទាំងអស់»។
[38]អ្នកធ្លាប់បានឮសេចក្តីចែងទុកមកថា «ភ្នែកទល់និងភ្នែក ធ្មេញទល់នឹងធ្មេញ»។[39]រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា កុំតបតនឹងមនុស្សអាក្រក់សោះឡើយ បើគេទះកំផ្លៀងស្តាំរបស់អ្នក ត្រូវបែរឲ្យគេទះម្ខាងទៀតទៅ។
[40]បើមានគេប្តឹងចង់យកអាវក្នុងអ្នក ចូរឲ្យគេយកអាវធំថែមទៀតទៅ។[41]បើមានគេបង្ខំអ្នកឲ្យធ្វើដំណើរមួយគីឡូដី ចូរដើរពីរគីឡូដីជាមួយគេចុះ។[42]អ្វីដែលគេសុំពីអ្នក ចូរឲ្យគេទៅ ហើយកុំគេចមុខចេញពីអ្នក ដែលចង់សុំខ្ចីពីអ្នកដែរឡើយ។
[43]អ្នករាល់គ្នាធ្លាប់បានឮសេចក្តីចែងទុកមកថា «ត្រូវស្រឡាញ់បងប្អូន តែត្រូវស្អប់ខ្មាំងសត្រូវរបស់អ្នក»។[44]រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ត្រូវស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក ព្រមទាំងអធិស្ឋានឲ្យអ្នកដែលបៀតបៀនដល់អ្នករាល់គ្នាផង។[45]ដូច្នោះ ទើបអ្នកសមជាបុត្ររបស់ព្រះបិតា ដែលគង់នៅស្ថានបរមសុខ ដ្បិតព្រះអង្គឲ្យព្រះអាទិត្យរបស់ព្រះអង្គរះបំភ្លឺ ទាំងមនុស្សអាក្រក់ ទាំងមនុស្សល្អ ហើយទ្រង់ឲ្យទឹកភ្លៀងធ្លាក់មកលើទាំងមនុស្សសុចរិត ទាំងមនុស្សទុច្ចរិតផងដែរ។
[46]ដ្បិត បើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នកណាដែលស្រឡាញ់ដល់អ្នក តើអ្នកនឹងទទួលបានរង្វាន់អ្វី? តើអ្នកទារពន្ធពួកគេមិនបានប្រព្រឹត្តដូច្នេះទេឬអី?[47]បើអ្នករាល់គ្នារាប់អានតែបងប្អូនខ្លួន តើមានអ្វីល្អជាងគេ? តើសាសន៍ដទៃមិនប្រព្រឹត្តដូច្នោះដែរឬ?។[48]ដូច្នេះសុំឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ ដែលព្រះអង្គគ្រប់លក្ខណ៍យ៉ាងនោះដែរ»។

Matthew 5:1
ឃ្លាភ្ជាប់៖
នេះជាការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង
ដែលព្រះយេស៊ូចាប់ផ្តើមបង្រៀនសិស្សរបស់ព្រះអង្គ។
ផ្នែកនេះបន្តរហូតដល់ចុងបញ្ចប់ជំពូកទី៧
ហើយត្រូវបានគេហៅថាសេចក្តីបង្រៀននៅលើភ្នំ។
ព័ត៌មានទូទៅ៖
នៅក្នុងខ ៣ ព្រះយេស៊ូចាប់ផ្តើមពិពណ៌នាអំពីលក្ខណៈរបស់មនុស្ស
ដែលបានទទួលពរ។
ទ្រង់បង្រៀន
នេះជាពាក្យសម្តាល់ថា ព្រះអង្គបានចាប់ផ្តើមមានព្រះបន្ទូល។
បង្រៀនពួកគេ
ពាក្យ «ពួកគេ» សំដៅទៅលើសាវ័ករបស់ព្រះយេស៊ូ។
អ្នកណាក្រខ្សត់ខាងវិញ្ញាញ
មានន័យថា អ្នកដែលបន្ទាបខ្លួន។ "អ្នកដែលដឹងថាពួកគេត្រូវការព្រះ"
ដ្បិតអ្នកនោះនឹងបានទទួលព្រះរាជ្យនៃស្ថានបរមសុខ
នៅទីនេះ«ស្ថានបរមសុខ»សំដៅលើការគ្រប់គ្រងរបស់ព្រះជាម្ចាស់ក្នុងនាមជាស្តេច។
ឃ្លានេះមានតែនៅក្នុងកណ្ឌគម្ពីរម៉ាថាយប៉ុណ្ណោះ។ បើអាចធ្វើបានសូមរក្សា“
ស្ថានបរមសុខ” នៅក្នុងការបកប្រែរបស់អ្នក។
"ចំពោះព្រះជាម្ចាស់គង់នៅស្ថានបរមសុខនឹងធ្វើជាស្តេចរបស់ពួកគេ"
អ្នកណាដែលសោកសៅ
ហេតុផលដែលអាចធ្វើឲ្យពួកគេសោកសៅគឺ ១) ភាពខុសឆ្គងនៃពិភពលោកឬ ២)
អំពើបាបរបស់ពួកគេឬ ៣) ការស្លាប់របស់នរណាម្នាក់។
កុំបញ្ជាក់ពីមូលហេតុនៃការកាន់ទុក្ខ លើកលែងតែភាសារបស់អ្នកត្រូវការវា។
ដ្បិតព្រះជាម្ចាស់នឹងសម្រាលទុក្ខពួកគេ
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ព្រះជាម្ចាស់នឹងកំសាន្តចិត្តពួកគេ"
Matthew 5:5
អ្នកណាមានចិត្តសូរបូត
"សុភាពរាបសា" ឬ "អ្នកដែលមិនពឹងផ្អែកលើអំណាចផ្ទាល់ខ្លួន"
ពួកគេនឹងទទួលផែនដីទុកជាមត៌ក
«ព្រះជាម្ចាស់នឹងឲ្យផែនដីទាំងមូលដល់ពួកគេ»
អ្នកណាស្រេកឃ្លានសេចក្តីសុចរិត
ការប្រៀបធៀបនេះមានន័យថា មនុស្សម្នាក់គួរតែមានចិត្តចង់ធ្វើអ្វីដែលត្រឹមត្រូវ។
"ចង់រស់នៅដោយត្រឹមត្រូវ ដូចដែលពួកគេត្រូវការអាហារនិងភេសជ្ជៈដែរ"
ពួកគេបានឆ្អែត
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ព្រះជាម្ចាស់នឹងបំពេញឲ្យពួកគេ" ឬ
"ព្រះអង្គនឹងបំពេញចិត្តពួកគេ"
អ្នកណាមានចិត្តបរិសុទ្ធ
"អ្នកណាមានចិត្តបរិសុទ្ធ" ។ នៅទីនេះ "ចិត្ត"
សំដៅទៅលើបំណងប្រាថ្នារបស់មនុស្សម្នាក់។
"អ្នកចង់បម្រើព្រះអង្គតែមួយប៉ុណ្ណោះ"
គេនឹងឃើញព្រះជាម្ចាស់
“ ឃើញ” ត្រង់នេះមានន័យថា
ពួកគេនឹងអាចរស់នៅក្នុងវត្តមានរបស់ព្រះអង្គ។"ព្រះជាម្ចាស់នឹងអនុញ្ញាតឲ្យពួកគេរស់នៅជិតស្និទ្ធនឹងព្រះអង្គ"
Matthew 5:9
អ្នកណាកសាងសន្តិភាព
ទាំងនេះជាមនុស្ស ដែលជួយអ្នកដទៃឲ្យមានសន្តិភាពជាមួយគ្នា។
ពួកគេ នឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ចំពោះព្រះជាម្ចាស់
គេនឹងហៅថាជាបុត្ររបស់ព្រះអង្គ" ឬ "ពួកគេនឹងក្លាយជាកូនរបស់ព្រះ"
បុត្ររបស់ព្រះជាម្ចាស់
វាជាការល្អបំផុតគួរបកប្រែ "បុត្រ" ជាមួយពាក្យតែមួយដែលភាសារបស់អ្នកនឹងប្រើ
សំដៅទៅលើកូនប្រុស ឬកូនរបស់មនុស្ស។
អ្នកណាត្រូវគេបៀតបៀន
ឃ្លានេះអាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"អស់អ្នកដែលមនុស្សដទៃធ្វើបាបដោយអយុត្តិធម៌"
ព្រោះបានធ្វើតាមសេចក្តីសុចរិត
"ពីព្រោះពួកគេធ្វើអ្វីដែលព្រះចង់អោយពួកគេធ្វើ"
ដ្បិតពួកគេនឹងទទួលបានព្រះរាជ្យនៃស្ថានបរមសុខ
«ស្ថានបរមសុខ»នៅទីនេះសំដៅលើការគ្រប់គ្រងរបស់ព្រះជាម្ចាស់ក្នុងនាមជាស្តេច។
ឃ្លានេះមានតែនៅក្នុងកណ្ឌគម្ពីរម៉ាថាយប៉ុណ្ណោះ។ បើអាចធ្វើបានសូមរក្សា“
ស្ថានបរមសុខ” នៅក្នុងការបកប្រែរបស់អ្នក។
"ចំពោះព្រះជាម្ចាស់គង់នៅស្ថានបរមសុខនឹងធ្វើជាស្តេចរបស់ពួកគេ" ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក៥ ខ ១ ។
Matthew 5:11
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានបញ្ចប់ការពិពណ៌នា អំពីលក្ខណៈរបស់មនុស្សមានពរ។
មានពរហើយអ្នក
ពាក្យថា "អ្នក" ជាពហុវចនៈ។
មានគេនិយាយអាក្រក់គ្រប់យ៉ាង បង្ខូចឈ្មោះ
"និយាយភូតកុហកគ្រប់យ៉ាងអំពីអ្នក" ឬ "និយាយអាក្រក់ពីអ្នកដែលមិនពិត"
ព្រោះតែខ្ញុំ
"ពីព្រោះអ្នកមកតាមខ្ញុំ" ឬដោយសារអ្នកជឿលើខ្ញុំ "
ចូរមានអំណរ និងចិត្តរីករាយឡើង
"ចូរមានអំណរ" និង "ចិត្តរីករាយឡើង" មានន័យស្ទើរតែដូចគ្នា។
ព្រះយេស៊ូចង់ឲ្យអ្នកស្តាប់មិនត្រាន់តែអរសប្បាយប៉ុណ្ណោះទេ
តែថែមទាំងធ្វើច្រើនជាងរីករាយទៀតផងបើអាច។
Matthew 5:13
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាប់ផ្តើមបង្រៀនអំពីរបៀប ដែលពួកសិស្សរបស់ទ្រង់ប្រៀបដូចជាអំបិល
និងពន្លឺ។
អ្នកជាអំបិលនៃផែនដី
អាចមានន័យថា ១) ដូចជាអំបិលធ្វើឲ្យអាហារមានរសជាតិឆ្ងាញ់
ហើយសិស្សរបស់ព្រះយេស៊ូត្រូវតែមានឥទ្ធិពលលើមនុស្សលោក
ដើម្បីឲ្យពួកគេបានល្អ។ “ អ្នកដូចជាអំបិលសម្រាប់ប្រជាជននៅលើពិភពលោក”
ឬទី ២) ដូចអំបិលថែរក្សាអាហារ
ហើយសិស្សរបស់ព្រះយេស៊ូត្រូវតែការពារមនុស្សពីភាពពុករលួយទាំងស្រុង។
"ដូចដែលអំបិលសម្រាប់អាហារអ្នក គឺដូចអ្នកសម្រាប់ពិភពលោកដែរ"
[illegible]
អាចមានន័យថា ១)

generated on Wed Sep 10 16:16:32 2025

"ប្រសិនបើអំបិលបាត់បង់អំណាចរបស់វាក្នុងការធ្វើអ្វីដែលអំបិលធ្វើបាន" ឬ ២) ប្រសិនបើអំបិលបាត់បង់រសជាតិ។
តើគេនឹងយកអ្វីមកធ្វើឲ្យវាប្រៃឡើងវិញបាន?
"តើវាអាចធ្វើឲ្យវាមានប្រយោជន៍ម្តងទៀតយ៉ាងដូចម្តេច?"
ព្រះយេស៊ូប្រើសំណួរនេះដើម្បីបង្រៀនពួកសិស្ស។
"គ្មានវិធីណាអាចធ្វើឲ្យវាមានប្រយោជន៍ម្តងទៀតទេ"
អំបិលនោះគ្មានប្រយោជន៍អ្វីទៀតឡើយ មានតែបោះចោលឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ
ឃ្លានេះអាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"លើកលែងតែមនុស្សបោះវាទៅតាមផ្លូវហើយដើរជាន់វា"
អ្នកជាពន្លឺ
មានន័យថា
អ្នកដើរតាមព្រះយេស៊ូនាំសារនៃសេចក្តីពិតរបស់ព្រះជាម្ចាស់ទៅដល់មនុស្សទាំងអស់ ដែលមិនទាន់ស្គាល់ព្រះអង្គនៅឡើយ។
"អ្នកដូចជាពន្លឺសម្រាប់ប្រជាជននៃពិភពលោក"
ក្រុងនៅលើភ្នំក៏មិនអាចលាក់បំបាំងបានឡើយ
ពេលយប់ងងឹត ប្រជាជនអាចមើលឃើញពន្លឺភ្លើងទីក្រុង។
ឃ្លានេះអាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"ពេលយប់គ្មាននរណាម្នាក់អាចលាក់ពន្លឺ ដែលចាំងពីទីក្រុងនៅលើភ្នំ" ឬ "មនុស្សគ្រប់គ្នាមើលឃើញពន្លឺនៃទីក្រុងនៅលើភ្នំ"
Matthew 5:15
គ្មានអ្នកណាអុជចង្កៀង
គ្មានអ្នកណាអុជបំភ្លឺចង្កៀង
យកទៅដាក់ក្រោមល្អី
"ដាក់អំពូលនៅក្រោមល្អី។ " នេះត្រូវបានគេនិយាយថា
វាជាការលួងខ្លៅក្នុងការបង្កើតពន្លឺ រួចលាក់វាទៅវិញ
ដូច្នេះមនុស្សមិនបានឃើញពន្លឺចង្កៀងទេ។
ចូរឲ្យពន្លឺរបស់អ្នក បំភ្លឺដល់មនុស្ស
មានន័យថា សិស្សរបស់ព្រះយេស៊ូគួរតែរស់នៅតាមរបៀបមួយ
ដែលអ្នកដទៃអាចរៀនអំពីសេចក្តីពិតរបស់ព្រះជាម្ចាស់។
"សូមឲ្យជីវិតរបស់អ្នកដូចជាពន្លឺ ដែលចាំងជះនៅចំពោះមុខមនុស្ស"
ព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ
ជាការល្អបំផុតក្នុងការបកប្រែ“ ព្រះបិតា”
ដោយប្រើពាក្យដូចគ្នាដែលភាសារបស់អ្នកប្រើ ដើម្បីសំដៅទៅឪពុករបស់មនុស្ស។
Matthew 5:17
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាប់ផ្តើមបង្រៀនអំពីរបៀប
ដែលព្រះអង្គយាងមកបំពេញក្រិត្យវិន័យគម្ពីរសញ្ញាចាស់។
គម្ពីរព្យាការី
សំដៅទៅលើអ្វីដែលពួកព្យាការីបានសរសេរនៅក្នុងបទគម្ពីរ។
ខ្ញុំប្រាប់អ្នករាល់គ្នាឲ្យបានដឹងច្បាស់ថា
"ខ្ញុំប្រាប់អ្នករាល់គ្នាឲ្យបានដឹងច្បាស់ថា" ។ ឃ្លានេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វីដែលព្រះយេស៊ូមានបន្ទូលបន្ទាប់។
បើផ្ទៃមេឃ និងផែនដីនៅតែស្ថិតស្ថេរជាដរាប
នៅទីនេះ "ផ្ទៃមេឃ" និង "ផែនដី" សំដៅទៅលើសកលលោកទាំងមូល។
"ដរាបណាសកលលោកនៅតែមាន"
គ្មានក្បៀស ឬបន្តក់ណាមួយ
"សូម្បីតែលិខិតសរសេរតូចបំផុត ឬផ្នែកតូចបំផុតនៃសំបុត្រ។
នេះជាពាក្យប្រៀបធៀប ដែលសំដៅទៅលើអ្វីមួយនៅក្នុងបទគម្ពីរ
ដែលមើលទៅហាក់ដូចជាមិនសំខាន់។ "
សូម្បីតែក្រឹត្យវិន័យដែលមើលទៅមិនសំខាន់ក៏ដោយ "
រហូតដល់ការទាំងនេះបានសម្រេចសព្វគ្រប់
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “ អ្វីៗទាំងអស់បានកើតឡើង” ឬ“ ព្រះជាម្ចាស់ធ្វើឲ្យអ្វីៗទាំងអស់កើតឡើង”
ការទាំងនេះ
ឃ្លា“ ការទាំងនេះ” សំដៅទៅលើអ្វីៗទាំងអស់នៅក្នុងក្រឹត្យវិន័យ។
"អ្វីគ្រប់យ៉ាងនៅក្នុងក្រឹត្យវិន័យ" ឬ "អ្វីទាំងអស់ ដែលត្រូវបានសរសេរនៅក្នុងក្រឹត្យវិន័យ"
Matthew 5:19
អ្នកណាល្មើសបទបញ្ជា
[4]ព្រះអង្គចាត់រាជបម្រើផ្សេង ឲ្យទៅជម្រាបភ្ញៀវម្តងទៀតថា៖ «សូមអញ្ជើញមកពិសាការ។ មើល! យើងបានរៀបចំភោជនាហារសម្រាប់ជប់លៀង។ ខ្ញុំបានសម្លាប់គោ និង
សម្លាប់សត្វដែលបានបំប៉ននោះរួចរាល់អស់ហើយ»។
[5]ប៉ុន្តែ ភ្ញៀវមិនរវីរវល់អើពើឡើយ ហើយដើរចេញ អ្នកខ្លះទៅចម្ការ អ្នកខ្លះទៅធ្វើជំនួញ។[6]អ្នកខ្លះទៀតចាប់ពួករាជបម្រើរបស់ស្តេចវាយធ្វើបាប ព្រមទាំងសម្លាប់ចោលថែម
ទៀត។[7]ព្រះរាជាទ្រង់ពិរោធយ៉ាងខ្លាំង ក៏ចាត់ទាហានឲ្យទៅប្រហារជីវិតឃាតកទាំងនោះ ហើយដុតស្រុកភូមិរបស់គេផង។
[8]បន្ទាប់មក ទ្រង់មានរាជឱង្ការទៅពួករាជបំរើថា៖ «ពិធីមង្គលការត្រូវបានរៀបចំរួចស្រេចហើយ ប៉ុន្តែ ភ្ញៀវទាំងនោះមិនសមនឹងមកចូលរួមទេ។[9]ហេតុនេះ ចូរនាំគ្នាចេញទៅ
តាមផ្លូវកែង ហើយអញ្ជើញមនុស្សទាំងអស់ដែលអ្នករាល់គ្នាជួប ឲ្យមកជប់លៀង»។[10]ពួករាជបម្រើក៏ចេញទៅតាមផ្លូវ ប្រមូលមនុស្សម្នា ដែលគេបានជួបទាំងប៉ុន្មានមក
ទាំងមនុស្សអាក្រក់ហើយនិងមនុស្សល្អផង។ ពេលនោះ មានភ្ញៀវពេញរោងការ។
[11]ប៉ុន្តែ ពេលព្រះរាជាយាងចូលមកមើលភ្ញៀវនៅក្នុងរោងការ ទតឃើញបុរសម្នាក់ស្លៀកពាក់មិនត្រូវនឹងរបៀបពិធីការ[12]ស្តេចក៏មានរាជឱង្ការទៅអ្នកនោះថា៖ «សម្លាញ់
អើយ! ហេតុអ្វីបានជាអ្នកចូលមកទីនេះ ដោយមិនស្លៀកសម្លៀកបំពាក់សម្រាប់មង្គលការដូច្នេះ?» ប៉ុន្តែបុរសនោះរកនិយាយអ្វីមិនចេញឡើយ។
[13]បន្ទាប់មកព្រះរាជាបង្គាប់ទៅពួករាជបម្រើថា៖ «ចូរចងដៃចងជើងអ្នកនេះ ហើយយកទៅចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោកខឹងសង្កៀតធ្មេញនោះទៅ»។
[14]មានមនុស្សជាច្រើនដែលព្រះត្រាស់ហៅ តែព្រះអង្គជ្រើសរើសយកបានចំនួនតិចទេ។

generated on Wed Sep 10 16:16:32 2025

[15]បន្ទាប់មកពួកខាងគណៈផារីស៊ី ចេញទៅពិគ្រោះគ្នា រិះរកមធ្យោបាយចាប់កំហុសព្រះយេស៊ូ[16]ក្រោយមកគេក៏ចាត់សិស្សរបស់ពួកគេ និងពួកខាងស្តេចហេរ៉ូដ ទៅទូលព្រះអង្គថា៖ «លោកគ្រូ! យើងខ្ញុំដឹងថា សេចក្តីពិតហើយពាក្យដែលលោកមានប្រសាសន៍សុទ្ធតែពិតទាំងអស់។ គឺលោកគ្រូពុំយោគយល់ ហើយក៏ពុំរើសមុខនរណាឡើយ។[17]ហេតុនេះ សូមលោកគ្រូប្រាប់យើងខ្ញុំមើល៍ថា បើតាមក្រឹត្យវិន័យ តើយើងត្រូវបង់ពន្ធ ថ្វាយសេសារឬទេ?»
[18]ប៉ុន្តែ ព្រះយេស៊ូឈ្វេងយល់គំនិតអាក្រក់របស់ពួកគេ ហើយព្រះអង្គមានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាចង់ចាប់កំហុសខ្ញុំដូច្នេះ មនុស្សមានពុតអើយ?[19]ចូរបង្ហាញប្រាក់សម្រាប់បង់ពន្ធនោះឲ្យខ្ញុំមើលមើល៍»។ គេក៏យកប្រាក់មួយកាក់មកថ្វាយព្រះអង្គ។
[20]ព្រះយេស៊ូមានព្រះបន្ទូលសួរគេថា៖ «តើលើកាក់នេះ មានរូបនរណា ឈ្មោះនរណា?»[21]គេទូលថា៖ «រូប និងឈ្មោះព្រះចៅអធិរាជ ព្រះយេស៊ូក៏មានព្រះបន្ទូលទៅគេថា៖ «អ្វីៗដែលជារបស់សេសារ ចូរថ្វាយទៅសេសារវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជាម្ចាស់វិញដែរ»។[22]ពួកគេងឿងឆ្ងល់នឹងចម្លើយរបស់ព្រះអង្គ ហើយនាំគ្នាចាកចេញពីព្រះអង្គទៅ។
[23]នៅថ្ងៃនោះ មានពួកខាងគណៈសាឌូស៊ីដែលមិនជឿថា មនុស្សស្លាប់នឹងរស់ឡើងវិញ ចូលមកគាល់ព្រះអង្គ។ ពួកគេទូលសួរព្រះអង្គថា៖[24]«លោកគ្រូ! លោកម៉ូសេមានប្រសាសន៍ថា បើបុរសណាស្លាប់ទៅ តែគ្មានកូនសោះ នោះប្អូនប្រុសរបស់បុរសនោះត្រូវរៀបការនឹងបង់ថ្លៃ ដើម្បីបន្តពូជឲ្យបងប្រុសរបស់ខ្លួន។
[25]ឧបមាថា មានបងប្អូនប្រុសប្រាំពីរនាក់ បងបង្អស់រៀបការ ហើយស្លាប់ទៅ តែគ្មានកូនសោះ ទុកប្រពន្ធឲ្យប្អូន។[26]បន្ទាប់មកប្អូនទីពីរ ប្អូនទីបី រហូតដល់ប្អូនទីប្រាំពីរ សុទ្ធតែបានរៀបការជាមួយនាង ហើយស្លាប់ទៅគ្មានកូនដូចគ្នា។[27]ហើយនៅទីបំផុត ស្ត្រីនោះក៏ស្លាប់ទៅដែរ។[28]ដល់ពេលមនុស្សស្លាប់នឹងរស់ឡើងវិញ តើនាងបានទៅជាប្រពន្ធនរណា បើបងប្អូនទាំងប្រាំពីរនាក់ សុទ្ធតែបានរៀបការជាមួយនាងគ្រប់គ្នាដូច្នេះ?
[29]ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «អ្នករាល់គ្នាយល់ខុសហើយ! ព្រោះអ្នករាល់គ្នាមិនយល់គម្ពីរ ទាំងមិនស្គាល់ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។[30]ដ្បិត ពេលមនុស្សស្លាប់នឹងរស់ឡើងវិញ គេមិនរៀបការប្តីប្រពន្ធទៀតឡើយ គឺគេនឹងបានដូចទេវតានៅស្ថានបរមសុខ។
[31]អំពីមនុស្សស្លាប់នឹងរស់ឡើងវិញ តើអ្នកមិនដែលអានដែលថាអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលថា៖[32]«យើងជាព្រះរបស់អប្រាហាំ ជាព្រះរបស់អ៊ីសាក និងជាព្រះរបស់យ៉ាកុប? ព្រះជាម្ចាស់មិនមែនជាព្រះបស់មនុស្សស្លាប់ទេ គឺជាព្រះអង្គរបស់មនុស្សដែលមានជីវិត»[33]កាលមហាជនបានឮសេចក្តី ដែលព្រះអង្គបង្រៀន ពួកគេងឿងឆ្ងល់ជាខ្លាំង។
[34]ពេលនោះ ពួកខាងគណៈផារីស៊ីប្រជុំគ្នា ព្រោះពួកគេឮថា ព្រះយេស៊ូបានធ្វើឲ្យពួកខាងគណៈសាឌូស៊ីទ័លប្រាជ្ញ។[35]ក្នុងចំណោមពួកគេមានម្នាក់ជាបណ្ឌិតខាងវិន័យ ទូលសួរព្រះអង្គក្នុងគោលបំណងល្បងលមើលព្រះអង្គថា៖[36]«លោកគ្រូ! ក្នុងក្រឹត្យវិន័យ តើមានបទបញ្ជាណាសំខាន់ជាងគេ?»។
[37]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា»។[38]នេះហើយជាបទបញ្ជាទីមួយ ដែលសំខាន់ជាងគេបំផុត។
[39]រីឯបទបញ្ជាទីពីរគឺដូច្នេះ គឺត្រូវស្រឡាញ់បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ។[40]បទបញ្ជាទាំងពីរនេះ ជាឫសគល់របស់គម្ពីរវិន័យ និងគម្ពីរពួកាវីទាំងអស់»។
[41]ពេលនោះ ពួកខាងគណៈផារីស៊ីនៅតែជុំគ្នា ព្រះយេស៊ូក៏សួរទៅពួកគេ។[42]ដោយព្រះបន្ទូលថា៖ «តើអ្នករាល់គ្នាយល់ថា ព្រះគ្រិស្តជាព្រះរាជវង្សរបស់អ្នកណាដែរ?» ពួកគេឆ្លើយថា៖ «ព្រះអង្គជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ»។
[43]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ចុះហេតុដូចម្តេចបានជាព្រះបាទដាវីឌ ដែលមានព្រះវិញ្ញាណបំភ្លឺហៅព្រះគ្រិស្តថា ព្រះអម្ចាស់ ទៅវិញដូច្នេះ គឺព្រះអង្គមានរាជឱង្ការថា[44]ព្រះអម្ចាស់មានបន្ទូលមកកាន់ព្រះអម្ចាស់របស់ខ្ញុំថា ចូរអង្គុយនៅខាងស្តាំយើង រហូតដល់យើងដាក់ខ្មាំងសត្រូវរបស់អ្នកនៅក្រោមជើងរបស់អ្នក?
[45]បើព្រះបាទដាវីឌហៅព្រះគ្រិស្តថា ជាព្រះអម្ចាស់ ដូច្នេះ តើឲ្យព្រះគ្រិស្តត្រូវជាព្រះរាជវង្សរបស់ព្រះអង្គដូចម្តេច?»[46]គ្មាននរណាម្នាក់អាចឆ្លើយទៅព្រះអង្គវិញ សូម្បីតែមួយម៉ាត់ក៏មិនបានផង ហើយចាប់តាំងពីពេលនោះមក គ្មាននរណាហ៊ានសួរព្រះអង្គទៀតឡើយ។

Matthew 22:1
ឃ្លាភ្ជាប់៖
ដើម្បីស្តីបន្ទោសមេដឹកនាំសាសនា និងបង្ហាញពីការមិនជឿរបស់ពួកគេ
ព្រះយេស៊ូប្រាប់ប្រស្នាអំពីពិធីមង្គលការ។
ទៅពួកគេ
"ទៅបណ្តា"
ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបាននឹង
នេះជាការចាប់ផ្តើមនៃរឿងប្រៀបប្រដូច។ សូមមើការបកប្រែនៅក្នុងជំពូក១៣ ខ២៤ ។
ឲ្យទៅអញ្ជើញភ្ញៀវមក
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “ ប្រជាជនដែលព្រះរាជាបានអញ្ជើញ”
Matthew 22:4
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានបន្តប្រើប្រស្នាមួយ។
រាជបម្រើផ្សេង ឲ្យទៅជម្រាបភ្ញៀវម្តងទៀត
សម្រង់ផ្ទាល់នេះអាចត្រូវបានបញ្ជាក់ ជាសម្រង់ដោយប្រយោល។
ដូចគ្នានេះផងដែរ អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"អ្នកបម្រើបញ្ជាឲ្យពួកគេប្រាប់អ្នកដែលទ្រង់បានអញ្ជើញ"
មើល!
"មើលទៅ" ឬ "ស្តាប់" ឬ "យកចិត្តទុកដាក់ចំពោះអ្វី ដែលខ្ញុំរៀបនឹងប្រាប់អ្នក"
ខ្ញុំបានសម្លាប់គោ និងសម្លាប់សត្វដែលបានបំប៉ននោះរួចរាល់អស់ហើយ
បញ្ជាក់ថា សត្វត្រូវបានចម្អិននិងត្រៀមខ្លួនបរិភោគ។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "អ្នកបម្រើរបស់ខ្ញុំបានសម្លាប់គោ
និងគោដែលបំប៉នរបស់ខ្ញុំ។
គោ...សត្វដែលបានបំប៉ន
"គោ និងកូនគោល្អបំផុតរបស់ខ្ញុំ សម្រាប់បរិភោគ"
Matthew 22:5
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានបន្តប្រើប្រស្នាមួយ។
ប៉ុន្តែ ភ្ញៀវមិនរវីរវល់អើពើឡើយ
"ប៉ុន្តែ ភ្ញៀវដែលព្រះរាជាបានអញ្ជើញ មិនអើពើនឹងការអញ្ជើញនេះទេ"
ប្រហារជីវិតឃាតកទាំងនោះ
បញ្ជាក់ថា ទាហានរបស់ស្តេចបានសម្លាប់ឃាតករ។
Matthew 22:8
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានបន្តប្រើប្រស្នាមួយ។
ភ្ញៀវ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "អ្នកដែលខ្ញុំបានអញ្ជើញ"
ផ្លូវកែង
"ដែលជាកន្លែងដែលផ្លូវធំនៃទីក្រុងឆ្លងកាត់។ "
ព្រះរាជាកំពុងចាត់អ្នកបម្រើទាំងនោះ ទៅកន្លែងដែលពួកគេអាចរកមនុស្សបាន។
ទាំងមនុស្សអាក្រក់ហើយនិងមនុស្សល្អផង
"ទាំងមនុស្សល្អ និងមនុស្សអាក្រក់"
ពេលនោះ មានភ្ញៀវពេញរោងការ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ដូច្នេះភ្ញៀវបានបំពេញសាលមង្គលការ"
រោង
បន្ទប់ធំ
Matthew 22:11
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានបន្តប្រើប្រស្នាមួយ។
ហេតុអ្វីបានជាអ្នកចូលមកទីនេះ ដោយមិនស្លៀកសម្លៀកបំពាក់សម្រាប់មង្គលការដូច្នេះ?
ស្តេចប្រើសំណួរដើម្បីស្តីបន្ទោសភ្ញៀវ។ "អ្នកមិនបានស្លៀកសម្លៀកបំពាក់ត្រឹមត្រូវ
ចូលរួមពិធីមង្គលការទេ។ អ្នកមិនគួរនៅទីនេះទេ"
បុរសនោះរកនិយាយអ្វីមិនចេញឡើយ

generated on Wed Sep 10 16:16:32 2025

"បុរសនោះនៅស្ងៀម"
Matthew 22:13
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានបញ្ចប់ប្រស្នារបស់ព្រះអង្គ អំពីពិធីមង្គលការ។
ចូរចងដៃចងជើងអ្នកនេះ
"ចងគាត់ឡើង ដើម្បីកុំឲ្យគាត់លើកដៃ ឬជើងគាត់"
យកទៅចោលនៅទីងងឹតខាងក្រៅ
ពាក្យនេះសំដៅទៅលើដំណើរជីវិតអស់កល្ប របស់អ្នកដែលបដិសេធព្រះអង្គ។
"កន្លែងងងឹតឆ្ងាយពីព្រះអង្គ" ។ សូមមើលការបកប្រែនៅក្នុងជំពូក៨ ខ១១ ។
កន្លែងយំសោកខឹងសង្កៀតធ្មេញ
តំណាងឲ្យភាពទុក្ខព្រួយ និងទុក្ខវេទនាយ៉ាងខ្លាំង។
សូមមើលការបកប្រែនៅក្នុងជំពូក៨ ខ១១ ។
មានមនុស្សជាច្រើនដែលព្រះត្រាស់ហៅ តែព្រះអង្គជ្រើសរើសយកបានចំនួនតិចទេ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "សម្រាប់ព្រះអង្គអញ្ជើញមនុស្សជាច្រើន
ប៉ុន្តែទ្រង់បានជ្រើសរើសតែពីរបីនាក់ប៉ុណ្ណោះ"
មាន
នេះជាការផ្លាស់ប្តូរមួយ។ ព្រះយេស៊ូបានបញ្ចប់រឿងប្រៀបប្រដូច
ហើយឥឡូវនេះនឹងពន្យល់ពីចំណុចសំខាន់នៃប្រស្នានេះ។
Matthew 22:15
ឃ្លាភ្ជាប់៖
ចាប់ផ្តើមដំណើររឿងរបស់អ្នកដឹកនាំសាសនា
ដែលព្យាយាមចាប់ព្រះយេស៊ូដោយសួរសំណួរពិបាកៗ ជាច្រើន។ នៅទីនេះ
ពួកផារីស៊ីសួរព្រះអង្គអំពីការបង់ពន្ធទៅសេសារ។
មធ្យោបាយចាប់កំហុសព្រះយេស៊ូ
"របៀបដែលពួកគេអាចនាំឲ្យព្រះយេស៊ូមានបន្ទូលខុស
ដូច្នេះពួកគេអាចចាប់ព្រះអង្គបាន"
សិស្សរបស់ពួកគេ...ពួកខាងស្តេចហេរ៉ូដ
ពួកសិស្សរបស់ពួកផារីស៊ីបានគាំទ្រការបង់ពន្ធ
តែទៅលើពួកអាជ្ញាធរយូដាប៉ុណ្ណោះ។ ពួកខាងស្តេច
ហេរ៉ូដបានគាំទ្រការបង់ពន្ធជូនអាជ្ញាធររ៉ូម។ បញ្ជាក់ថា ពួកផារីស៊ីជឿថា
មិនថាព្រះយេស៊ូមានបន្ទូលអ្វីក៏ដោយ
ព្រះអង្គនឹងធ្វើឲ្យក្រុមណាមួយក្នុងចំណោមក្រុមទាំងនេះរងទុក្ខ។
ពួកខាងស្តេចហេរ៉ូដ
ទាំងនេះជាមន្ត្រី និងជាអ្នកកាន់តាមស្តេចហេរ៉ូដ។ គាត់ជាមិត្តនឹងអាជ្ញាធររ៉ូម៉ាំង។
ហើយក៏ពុំរើសមុខនរណាឡើយ
"អ្នកមិនបង្ហាញកិត្តិយសពិសេសដល់មនុស្សមួយចំនួន"
ឬ"អ្នកមិនចាត់ទុកមនុស្សខ្ លះសំខាន់ជាងមនុស្សដទៃទៀត"
បង់ពន្ធ ថ្វាយសេសារ
ប្រជាជនមិនបានបង់ពន្ធដោយផ្ទាល់ទៅសេសារទេ
ប៉ុន្តែបង់ទៅអ្នកប្រមូលពន្ធម្នាក់របស់គាត់។ "បង់ពន្ធតាមសេសារតម្រូវឲ្យបង់"
Matthew 22:18
ហេតុអ្វីបានជាអ្នករាល់គ្នាចង់ចាប់កំហុសខ្ញុំដូច្នេះ មនុស្សមានពុតអើយ ?
ព្រះយេស៊ូប្រើសំណួរមួយ
ដើម្បីនឹងស្តីបន្ទោសអ្នកដែលកំពុងតែព្យាយាមចាប់ទ្រង់។ "កុំសាកល្បងខ្ញុំ
មនុស្សលាក់ពុត!" ឬ «ខ្ញុំដឹងថា អ្នកកំពុតលាក់ពុត កំពុងព្យាយាមធ្វើតេស្តខ្ញុំ!»
ប្រាក់មួយកាក់
ជាកាក់រ៉ូម៉ាំងដែលមានតម្លៃឈ្នួលមួយថ្ងៃ។
Matthew 22:20
គេ
នៅទីនេះ“ គេ” សំដៅទៅលើពួកខាងស្តេចហេរ៉ូដ និងសិស្សរបស់ពួកផារីស៊ី។
តើលើកាក់នេះ មានរូបនរណា ឈ្មោះនរណា?
ព្រះយេស៊ូប្រើសំណួរ ដើម្បីឲ្យមនុស្សគិតយ៉ាងជ្រាលជ្រៅ
អំពីអ្វីដែលព្រះអង្គកំពុងមានបន្ទូល។ "ប្រាប់ខ្ញុំតើរូប និងឈ្មោះរបស់អ្នកណា
ដែលអ្នកឃើញនៅលើកាក់នេះ"
របស់សេសារ
អ្នកអាចធ្វើឲ្យព័ត៌មានកាន់តែច្បាស់ងាយយល់។ "កាក់នេះមានរូបភាព
និងឈ្មោះរបស់សេសារនៅលើវា"
អ្វីៗដែលជារបស់សេសារ
«របស់ដែលសេសារជារបស់សេសារ»
អ្វីៗដែលជារបស់ព្រះជាម្ចាស់
«របស់ដែលជារបស់ព្រះជាម្ចាស់»
Matthew 22:23
ឃ្លាភ្ជាប់៖
ពួកសាឌូស៊ីព្យាយាមចាប់ព្រះយេស៊ូដោយសួរសំណួរដ៏ពិបាកមួយ
អំពីអាពាហ៍ពិពាហ៍ និងការរស់ឡើងវិញរបស់មនុស្សស្លាប់។
លោកគ្រូ! លោកម៉ូសេមានប្រសាសន៍ថា បើបុរសណាស្លាប់ទៅ
អ្នកដឹកនាំសាសនាបានសួរព្រះយេស៊ូអំពីអ្វី
ដែលម៉ូសេបានសរសេរនៅក្នុងបទគម្ពីរ។
បើភាសារបស់អ្នកមិនអនុញ្ញាតឲ្យដកស្រង់នៅក្នុងសម្រង់
ពាក្យនេះអាចបញ្ជាក់ជាការដកស្រង់ដោយប្រយោល: "លោកម៉ូសេបាននិយាយថា
បើបុរសម្នាក់ស្លាប់" ។
ប្អូនប្រុសរបស់បុរសនោះ...រៀបការ...បងប្រុសរបស់ខ្លួន
នៅទីនេះ "រប" សំដៅទៅលើបុរសដែលបានស្លាប់។
Matthew 22:25
ឃ្លាភ្ជាប់៖
ពួកសាឌូស៊ីបន្តសួរព្រះយេស៊ូអំពីសំណួរមួយ។
បងបង្កស់...ប្អូនទីពីរ... ប្អូនទីបី...ប្អូនទីប្រាំពីរ
សូមមើលការបកប្រែលំដាប់លំដោយ
ហើយនៅទីបំផុត
"បន្ទាប់ពីបងប្អូនទាំងអស់បានស្លាប់"
ដល់ពេល
នៅទីនេះ ពួកសាឌូស៊ីផ្លាស់ប្តូរពីរឿងអំពីបងប្អូនទាំងប្រាំពីរនាក់
ទៅជាសំណួរជាក់ស្តែង។
មនុស្សស្លាប់នឹងរស់ឡើងវិញ
"នៅពេលមនុស្សស្លាប់នឹងរស់ឡើងវិញ"
Matthew 22:29
អ្នករាល់គ្នាយល់ខុសហើយ
បញ្ជាក់ថា ព្រះយេស៊ូមានន័យថា
ពួកគេយល់ច្រឡំអំពីអ្វីដែលពួកគេគិតអំពីការរស់ឡើងវិញ។
"អ្នកយល់ច្រឡំអំពីការរស់ឡើងវិញ"
ឫទ្ធានុភាពរបស់ព្រះជាម្ចាស់
អ្វីដែលព្រះជាម្ចាស់អាចធ្វើបាន
អ្វីដែលព្រះអាចធ្វើបាន
"នៅពេលមនុស្សស្លាប់នឹងរស់ឡើងវិញ"
គេមិនរៀបការ
"មនុស្សនឹងមិនរៀបការ"
រៀបការប្តីប្រពន្ធទៀតឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"ហើយមនុស្សក៏នឹងមិនឲ្យកូនពួកគេរៀបអាពាហ៍ពិពាហ៍ដែរ"
Matthew 22:31
ព័ត៌មានទូទៅ៖
នៅជំពូក២២ ខ៣២ ព្រះយេស៊ូដកស្រង់ចេញពីកណ្ឌគម្ពីរនិក្ខមនំ
ដើម្បីបញ្ជាក់ថាមនុស្សរស់ឡើងវិញបន្ទាប់ពីពួកគេស្លាប់។
តើអ្នកមិនដែលអានដែលថាអ្វី...របស់យ៉ាកុប?
ព្រះយេស៊ូសួរសំណួរនេះ
ដើម្បីរំលឹកអ្នកដឹកនាំសាសនាអំពីអ្វីដែលពួកគេដឹងតាមរយៈបទគម្ពីរ។
"ខ្ញុំដឹងថាអ្នកបានអានវាហើយ ប៉ុន្តែអ្នកហាក់ដូចជាមិនយល់ពីអ្វីដែល ... យ៉ាកុប
'"
អ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "អ្វីដែលព្រះអង្គបានមានបន្ទូលមកកាន់អ្នក"
ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងជាព្រះ...របស់យ៉ាកុប?
អ្នកអាចបកប្រែសម្រង់ផ្ទាល់នេះជាសម្រង់ដោយប្រយោល។ “
ព្រះអង្គដែលមានបន្ទូលទៅកាន់លោកម៉ូសេថា
ព្រះអង្គជាព្រះជាម្ចាស់របស់អប្រាហាំ អ៊ីសាកនិងយ៉ាកុប”
មនុស្សស្លាប់ទេ គឺជាព្រះអង្គរបស់មនុស្សដែលមានជីវិត
គុណនាមបន្ទាប់បន្សំទាំងនេះ អាចត្រូវបានបញ្ជាក់ជាគុណនាម។ "នៃមនុស្សស្លាប់
ប៉ុន្តែព្រះអង្គគឺជាព្រះជាម្ចាស់របស់មនុស្សរស់"
Matthew 22:34

generated on Wed Sep 10 16:16:32 2025

ឃ្លាភ្ជាប់៖
អ្នកខាងគណៈផារីស៊ីម្នាក់
ដែលពូកែខាងវិន័យព្យាយាមចាប់ព្រះយេស៊ូដោយសួរសំនួរដ៏ពិបាក
អំពីបញ្ញត្តិដ៏សំខាន់បំផុត។
បណ្ឌិតខាងវិន័យ
«បណ្ឌិតខាងវិន័យ» ។ នេះជាផារីស៊ីម្នាក់
ដែលមានជំនាញពិសេសក្នុងការស្វែងយល់អំពីក្រិត្យវិន័យ របស់លោកម៉ូសេ។
Matthew 22:37
ព័ត៌មានទូទៅ៖
ព្រះយេស៊ូបានដកស្រង់ខគម្ពីរពីទុតិយកថាជាបទបញ្ញត្តិដ៏សំខាន់បំផុត។
អស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា
ឃ្លាទាំងបីនេះមានន័យដូចគ្នា។ ពួកគេមានន័យថា
មនុស្សម្នាក់ត្រូវតែស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្ត
និងដោយមានភក្តីភាពពេញលេញ។
បទបញ្ជាទីមួយ ដែលសំខាន់ជាងគេបំផុត
នៅទីនេះ "សំខាន់ជាងគេបំផុត" និង "ទីមួយ " មានន័យដូចគ្នា។
ពួកគេសង្កត់ធ្ងន់ថា នេះគឺជាបទបញ្ជាសំខាន់បំផុត។
Matthew 22:39
ព័ត៌មានទូទៅ៖
ព្រះយេស៊ូដកស្រង់ខគម្ពីរពីលេវីវិន័យថា ជាបញ្ញត្តិសំខាន់ទី២ ។
បទបញ្ជាទីពីរគឺដូច្នេះ
អាចមានន័យថា ១) "ហើយមានបញ្ញត្តិមួយទៀតដែលមានសារសំខាន់បន្ទាប់" ឬទី
២) "ហើយមានបញ្ញត្តិទី ២ ដែលសំខាន់ដូចគ្នានឹង" ។ តាមវិធីណាក៏ដោយ
ព្រះយេស៊ូមានន័យថា ព្រះបញ្ញត្តិទាំងពីរនេះសំខាន់ជាងបញ្ញត្តិទាំងអស់។
បទបញ្ជាទីពីរ
សូមមើលការបកប្រែលំដាប់លំដោយ
គឺដូច្នេះ
មានន័យថា ដូចជាបទបញ្ជាក្នុងជំពូក២២ ខ៣៧ ។
បងប្អូនឯទៀតៗ
នៅទីនេះ "អ្នកជិតខាង" មានន័យថា ច្រើនជាងអ្នកដែលរស់នៅក្បែរនោះ។
ព្រះយេស៊ូមានន័យថា មនុស្សម្នាក់ត្រូវស្រឡាញ់មនុស្សទាំងអស់។
បទបញ្ជាទាំងពីរនេះ ជាឫសគល់របស់គម្ពីរវិន័យ និងគម្ពីរព្យាការីទាំងអស់»។
នៅទីនេះ“គម្ពីរវិន័យ និងគម្ពីរព្យាការីទាំងអស់” សំដៅទៅលើបទគម្ពីរទាំងអស់។ “
អ្វីៗទាំងអស់ដែលលោកម៉ូសេ
និងពួកព្យាការីបានសរសេរនៅក្នុងបទគម្ពីរគឺផ្អែកលើបទបញ្ញត្តិទាំងពីរនេះ”
Matthew 22:41
ឃ្លាភ្ជាប់៖
ព្រះយេស៊ូសួរពួកផារីស៊ីនូវសំណួរដ៏ពិបាកមួយ បញ្ឈប់ការប៉ុនប៉ងរបស់ពួកគេ
ដើម្បីចាប់ទ្រង់។
ពេលនោះ
ពាក្យនេះត្រូវបានប្រើនៅទីនេះសម្គាល់ការផ្លាកនៅក្នុងសាច់រឿងសំខាន់។ នៅទីនេះ
កណ្ឌគម្ពីរម៉ាថាយចាប់ផ្តើមប្រាប់ពីផ្នែកថ្មីនៃរឿងនេះ
ពេលព្រះយេស៊ូសួរសំណួរដល់អ្នកដឹកនាំសាសនា។
ព្រះរាជវង្ស...ព្រះរាជវង្សរបស់ព្រះបាទដាវីឌ
នៅក្នុង“ កូនប្រុស” ទាំងពីរនេះមានន័យថា“ កូនចៅ” ។
Matthew 22:43
ព័ត៌មានទូទៅ៖
ព្រះយេស៊ូដកស្រង់ចេញពីទំនុកតម្កើង ដើម្បីបង្ហាញថាព្រះគ្រិស្តមិនត្រឹមតែជា“
ព្រះបុត្រារបស់ដាវីឌ” ឡើយ។
ចុះហេតុដូចម្តេចបានជាព្រះបាទដាវីឌ ដែលមានព្រះវិញ្ញាណបំភ្លឺហៅព្រះគ្រិស្តថា ព្រះអម្ចាស់ ទៅវិញ
ដូច្នេះ
ព្រះយេស៊ូប្រើសំណួរមួយ ដើម្បីធ្វើឲ្យអ្នកដឹកនាំសាសនាគិតយ៉ាងស៊ីជម្រៅ
អំពីកណ្ឌគម្ពីរទំនុកតម្កើង ដែលទ្រង់នឹងដកស្រង់។ "បន្ទាប់មកប្រាប់ខ្ញុំពីមូលហេតុ
ដែលដាវីឌនៅក្នុងព្រះវិញ្ញាណហៅព្រះអង្គថា ជាព្រះអម្ចាស់"
ព្រះបាទដាវីឌ ដែលមានព្រះវិញ្ញាណ
"ព្រះបាទដាវីឌដែលព្រះវិញ្ញាណដ៏វិសុទ្ធកំពុងតែបំផុសគំនិត" ។ មានន័យថា
ព្រះវិញ្ញាណដ៏វិសុទ្ធមានឥទ្ធិពលលើអ្វីដែលដាវីឌបាននិយាយ។
ហៅព្រះគ្រិស្ត
នៅទីនេះ "ព្រះគ្រិស្ត" សំដៅទៅលើព្រះគ្រីស្ទដែលជាព្រះរាជវង្សរបស់ដាវីឌផង។
ព្រះអង្គមានរាជឱង្ការថា
នៅទីនេះ "ព្រះអម្ចាស់" សំដៅទៅលើព្រះវរបិតា។
មកកាន់ព្រះអម្ចាស់របស់ខ្ញុំ
ត្រង់នេះ“ ព្រះអម្ចាស់” សំដៅទៅលើព្រះគ្រិស្ត។ ដូចគ្នានេះផងដែរ "របស់ខ្ញុំ"
សំដៅទៅលើព្រះបាទដាវីឌ។ នេះមានន័យថា ព្រះគ្រិស្តខ្ពស់ជាងព្រះបាទដាវីឌ។
នៅខាងស្តាំយើង
នៅទីនេះ "របស់ខ្ញុំ" សំដៅទៅលើព្រះបិតា។ ជារឿយៗ "ដៃស្តាំ"
ត្រូវបានប្រើដើម្បីចង្អុលបង្ហាញកន្លែងកិត្តិយស។
រហូតដល់យើងដាក់ខ្មាំងសត្រូវរបស់អ្នកនៅក្រោមជើងរបស់អ្នក
នេះជាពាក្យសម្គាល់។ "ទាល់តែខ្ញុំឈ្នះខ្មាំងសត្រូវរបស់អ្នក" ឬ
"រហូតដល់ខ្ញុំធ្វើឲ្យសត្រូវរបស់អ្នក ក្រាបនៅមុខអ្នក"
Matthew 22:45
ឃ្លាភ្ជាប់៖
នេះជាចុងបញ្ចប់នៃកំណត់ហេតុរបស់អ្នកដឹកនាំសាសនា
ដែលព្យាយាមចាប់ព្រះយេស៊ូដោយមានសំណួរពិបាកៗជាច្រើន។
ព័ត៌មានទូទៅ៖
នេះជាផ្នែកចុងបញ្ចប់នៃសាច់រឿង ដែលបានចាប់ផ្តើមនៅជំពូក១៩ ខ១
ប្រាប់ពីការដែលព្រះយេស៊ូកំពុងតែបម្រើនៅស្រុកយូដា។
បើព្រះបាទដាវីឌហៅព្រះគ្រិស្តថា ជាព្រះអម្ចាស់ ដូច្នេះ តើឲ្យព្រះគ្រិស្តត្រូវជាព្រះរាជវង្សរបស់ព្រះអង្គ
ដូចម្តេច?
ព្រះយេស៊ូប្រើសំណួរ ដើម្បីធ្វើឲ្យអ្នកដឹកនាំសាសនាគិតយ៉ាងជ្រាលជ្រៅអំពីអ្វី
ដែលទ្រង់កំពុងមានបន្ទូល។ "ព្រះបាទដាវីឌហៅព្រះអង្គថា"
ព្រះអម្ចាស់ដូច្នេះព្រះគ្រីស្តមិនត្រឹមតែជា ព្រះរាជវង្សរបស់ព្រះបាទដាវីឌប៉ុណ្ណោះទេ
"។
បើព្រះបាទដាវីឌហៅព្រះគ្រិស្ត
ព្រះបាទដាវីឌបានហៅព្រះយេស៊ូថា "ព្រះអម្ចាស់"
ព្រោះព្រះយេស៊ូមិនត្រឹមតែជាព្រះរាជវង្សរបស់ព្រះបាទដាវីឌប៉ុណ្ណោះទេ
ប៉ុន្តែព្រះអង្គក៏មានឋានៈខ្ពស់ជាងស្តេចដាវីឌដែរ។
ឆ្លើយទៅព្រះអង្គវិញ
នៅទីនេះ "ឆ្លើយ" សំដៅទៅលើអ្វីដែលមនុស្សនិយាយ។
"ដើម្បីឆ្លើយគាត់ពីអ្វីទាំងអស់" ឬ "ដើម្បីឆ្លើយគាត់"
សួរព្រះអង្គទៀតឡើយ
បញ្ជាក់ថា គ្មាននរណាម្នាក់សួរព្រះអង្គនូវសំណួរប្រភេទណា
ដែលមានបំណងធ្វើឲ្យព្រះអង្គមានបន្ទូលអ្វីដែលខុសទេ
ដូច្នេះអ្នកដឹកនាំសាសនាអាចចាប់ខ្លួនព្រះអង្គបាន។

---

23 [1]បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូល ទៅកាន់មហាជន និងពួកសិស្សរបស់ព្រះអង្គ។ ព្រះអង្គមានព្រះបន្ទូលថា៖[2]ពួកអាចារ្យ និងពួកផារីស៊ី មានភារកិច្ចបង្រៀនគម្ពីរ
វិន័យរបស់លោកម៉ូសេ។[3]អ្វីៗដែលគេបង្រៀនអ្នករាល់គ្នា ចូរស្តាប់ ហើយយកទៅប្រតិបត្តិតាមទៅ តែកុំយកតម្រាប់តាមអំពើដែលគេប្រព្រឹត្តឡើយ ពីព្រោះគេមិន
ប្រតិបត្តិតាមសេចក្តីដែលគេបង្រៀននោះឡើយ។
[4]ពិតមែន អ្នកទាំងនោះបានបង្កើតវិន័យយ៉ាងតឹងរ៉ឹង យកមកផ្ទុកលើស្មារបស់មនុស្ស ប៉ុន្តែគេមិនជួយសម្រាលបន្ទុកនោះទេ សូម្បីតែបន្តិចបន្តួចក៏មិនជួយផង។[5]ពួកគេធ្វើ
កិច្ចការទាំងនេះ គឺដើម្បីឲ្យមនុស្សម្នាកោតសរសើរ គឺគេធ្វើក្លាក់ កាន់តែធំឡើងៗ និងធ្វើខ្សែរំយោល នៅជាយអាវកាន់តែវែងទៅៗ។
[6]ពួកគេចូលចិត្តកន្លែងកិត្តិយសក្នុងពិធីជប់លៀង ហើយរើសកន្លែងអង្គុយនៅមុខគេក្នុងសាលាប្រជុំ។[7]ហើយពួកនេះជាពិសេសចូលចិត្តឲ្យគេអោនកាយគោរព នៅតាមផ្សារ
និងឲ្យគេហៅខ្លួនថា «លោកគ្រូ»។
[8]ប៉ុន្តែរីឯអ្នករាល់គ្នាវិញ កុំបង្គាប់គេឲ្យហៅខ្លួនថា «លោកគ្រូ» សោះឡើយ ដ្បិតអ្នករាល់គ្នាមានលោកគ្រូតែមួយគត់ ហើយអ្នករាល់គ្នាសុទ្ធតែជាបងប្អូននឹងគ្នា។[9]កុំហៅ
នរណាម្នាក់នៅលើផែនដីនេះថា «ព្រះបិតា» ឲ្យសោះ ដ្បិតអ្នករាល់គ្នាមាន ព្រះបិតា តែមួយគត់ប៉ុណ្ណោះ គឺទ្រង់គង់នៅស្ថានបរមសុខ។[10]កុំឲ្យគេហៅអ្នករាល់គ្នាថា គ្រូ
ឡើយ ដ្បិតមានតែព្រះគ្រិស្តមួយព្រះអង្គប៉ុណ្ណោះ ដែលជាគ្រូរបស់អ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

[11]ប៉ុន្តែបើអ្នកណាមានឋានៈធំជាងគេក្នុងចំណោមអ្នករាល់គ្នា ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់គ្នាវិញ។[12]អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួន នឹងត្រូវគេលើកតម្កើងវិញ។
[13]ប៉ុន្តែ ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ដ្បិតអ្នករាល់គ្នាបិទទ្វារព្រះរាជ្យនៃស្ថានបរមសុខ មិនឲ្យមនុស្សចូលទៅក្នុង អ្នករាល់គ្នាមិនត្រឹមតែមិនបានចូលខ្លួនឯងប៉ុណ្ណោះទេ គឺថែមទាំងរារាំងអ្នកដែលចង់ចូលមិនឲ្យគេចូលទៀតផង។[14]ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាឆក់បោកយកទ្រព្យសម្បត្តិរបស់ស្ត្រីមេម៉ាយ ដោយធ្វើឫកជាសូត្រធម៌យ៉ាងយូរ។ ហេតុនេះហើយបានជាអ្នករាល់គ្នាត្រូវទទួលទោសយ៉ាងធ្ងន់ជាមិនខាន។[15]ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាធ្វើដំណើរតាមផ្លូវទឹក និងតាមផ្លូវគោក ស្វែងរកបញ្ចុះបញ្ចូលគេ ឲ្យចូលសាសនារបស់អ្នករាល់គ្នា ។ លុះពួកគេចូលសាសនាហើយ អ្នករាល់គ្នាធ្វើឲ្យគេរឹតតែអាក្រក់ជួជាតិជាងអ្នករាល់គ្នាមួយទ្វេជាពីរ។
[16]ឱពួកអ្នកដឹកនាំកង្វាក់អើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន អ្នករាល់គ្នានិយាយថា បើអ្នកណាស្បថដោយយកព្រះវិហារមកធ្វើជាសាក្សី ពាក្យសម្បថនោះយកជាការពុំបានទេ។ ប៉ុន្តែ បើស្បថដោយយកមាសរបស់ព្រះវិហារធ្វើជាសាក្សី ទើបយកជាការបាន។[17]មនុស្សកង្វាក់លេលាអើយ! មាស និងព្រះវិហារដែលធ្វើឲ្យមាសទៅជាវត្ថុពិសិដ្ឋតើមួយណាសំខាន់ជាង?
[18]ហើយអ្នកណាស្បថដោយយកអាសនាធ្វើជាសាក្សី ពាក្យសម្បថនោះយកជាការពុំបានទេ ប៉ុន្តែបើស្បថដោយយកតង្វាយលើអាសនាធ្វើជាសាក្សី ទើបយកជាការបាន។
[19]ឱមនុស្សកង្វាក់អើយ! តង្វាយដែលគេថ្វាយលើអាសនា និងអាសនាដែលធ្វើឲ្យតង្វាយទៅជាតង្វាយពិសិដ្ឋ តើមួយណាសំខាន់ជាង?
[20]ដូច្នេះ អ្នកណាស្បថដោយយកអាសនាជាសាក្សី អ្នកនោះមានទាំងអាសនា និងមានទាំងអ្វីៗនៅលើអាសនាជាសាក្សី។[21]អ្នកណាស្បថដោយយកព្រះវិហារជាសាក្សី អ្នកនោះមានទាំងព្រះវិហារ និងមានទាំងព្រះជាម្ចាស់ដែលគង់នៅក្នុងព្រះវិហារជាសាក្សីដែរ។[22]ហើយអ្នកណាស្បថដោយយកស្ថានបរមសុខជាសាក្សី អ្នកនោះមានទាំងបល្ល័ង្ករបស់ព្រះជាម្ចាស់ មានទាំងព្រះជាម្ចាស់ដែលគង់នៅលើបល្ល័ង្កជាសាក្សី។
[23]ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ពីព្រោះអ្នករាល់គ្នាយកជីរអង្កាម ជីរនាងរង និងម្អមមួយភាគដប់មកថ្វាយព្រះជាម្ចាស់ ប៉ុន្តែអ្នករាល់គ្នាលះបង់ក្រឹត្យវិន័យសំខាន់ៗចោល គឺមានសេចក្តីសុចរិត មេត្តាករុណាធម៌ និងជំនឿស្មោះត្រង់ជាដើម។ ប៉ុន្តែវិន័យទាំងប៉ុន្មាននេះហើយ ដែលអ្នករាល់គ្នាត្រូវប្រតិបត្តិតាមដោយឥតលះបង់ចោលណាមួយឡើយ។[24]អ្នកដឹកនាំកង្វាក់អើយ! អ្នករាល់គ្នាត្រងយកមូសចេញពីទឹកផឹក តែអ្នករាល់គ្នាលេបអូដ្ឋវិញ។
[25]ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាសំអាតពែង និងចាន តែខាងក្រៅប៉ុណ្ណោះ ប៉ុន្តែ ផ្នែកខាងក្នុងពោរពេញទៅដោយផលដែលកើតមកពីការកេងប្រវ័ញ្ច និងការលោភលន់។[26]ពួកផារីស៊ីដ៏កង្វាក់អើយ! ចូរសម្អាតផ្នែកខាងក្នុងពែងជាមុនសិន ទើបអ្វីៗនៅខាងក្រៅបានស្អាតដែរ។
[27]ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាប្រៀបបាននឹងផ្នូរ ដែលលាបពណ៌ស មើលពីក្រៅឃើញហាក់ដូចជាស្អាត តែខាងក្នុងពោរពេញទៅដោយឆ្អឹងសាកសព និងអ្វីដែលមិនស្អាត់។[28]ដូចគ្នានោះដែរ អ្នករាល់គ្នាសំដែងឫកពារខាងក្រៅឲ្យមនុស្សម្នាឃើញថា ជាអ្នកសុចរិត តែចិត្តអ្នករាល់គ្នាពោរពេញដោយគំនិតលាក់ពុត និងគំនិតទុច្ចរិតទៅវិញ។
[29]ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាបានសង់ផ្នូរឲ្យពួកព្យាការី ព្រមទាំងតុបតែងផ្នូររបស់មនុស្សសុចរិត[30]ដោយខ្លួនពោលថា៖ «ប្រសិនបើយើងបានរស់នៅជំនាន់បុព្វបុរសរបស់យើង នោះយើងមុខជាមិនសមគំនិតជាមួយគេ ក្នុងការសម្លាប់ពួកព្យាការីឡើយ»។[31]ពោលដូច្នេះបានសេចក្តីថា អ្នករាល់គ្នាចោទខ្លួនឯងថាជាពូជពង្សរបស់ពួកអ្នកដែលបានសម្លាប់ព្យាការី។
[32]អ្នករាល់គ្នានៅតែបន្តកិច្ចការរបស់បុព្វបុរសអ្នករាល់គ្នា![33]ឱពូជពស់វែកអើយ! តើធ្វើម្តេចឲ្យអ្នករាល់គ្នាគេចផុតពីទោសធ្លាក់នរកបានទៅ?
[34]ហេតុនេះហើយ ខ្ញុំចាត់ព្យាការី អ្នកប្រាជ្ញ និងអាចារ្យឲ្យមករកអ្នករាល់គ្នា តែអ្នករាល់គ្នានឹងសម្លាប់ពួកគេខ្លះ ឆ្កាងខ្លះ និងវាយធ្វើបាបខ្លះក្នុងសាលាប្រជុំ ព្រមទាំងដេញពួកគេពីក្រុងមួយទៅក្រុងមួយផង។[35]ដូច្នេះ អ្នករាល់គ្នាត្រូវទទួលទោស ព្រោះអ្នករាល់គ្នាបានបង្ហូរឈាមជនសុចរិត ចាប់ពីលោកអេបិលជាមនុស្សសុចរិតរហូតដល់លោកសាការី ជាកូនរបស់លោកបារ៉ាគាដែលអ្នករាល់គ្នាបានសម្លាប់ នៅត្រង់ចន្លោះទីសក្ការៈ និងអាសនា។[36]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាបានដឹងថា ទោសទាំងនោះនឹងត្រូវធ្លាក់មកលើមនុស្សជំនាន់នេះជាមិនខាន។
[37]យេរូសាឡឹម យេរូសាឡឹមអើយ! អ្នករាល់គ្នាបានសម្លាប់ពួកព្យាការី និងយកដុំថ្មគប់សម្លាប់អស់អ្នកដែលព្រះជាម្ចាស់បានចាត់ឲ្យមករកអ្នករាល់គ្នា។ ច្រើនលើកច្រើនសារមកហើយដែលខ្ញុំប្រមូលផ្តុំអ្នករាល់គ្នា ដូចមេមាន់ក្រុងកូនវានៅក្រោមស្លាប តែអ្នករាល់គ្នាពុំព្រមសោះ។[38]ហេតុនេះ ផ្ទះរបស់អ្នករាល់គ្នា នឹងត្រូវបោះបង់ចោលអោយនៅស្ងាត់ជ្រងំ។[39]ដ្បិតខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀតហើយ រហូតដល់ពេលអ្នករាល់គ្នាពោលថា៖ «សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គដែលយាងមកក្នុងនាមព្រះអម្ចាស់»។

Matthew 23:1
ពត៌មានទូទៅ៖
នេះជាការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង ដែលកើតឡើងនៅជំពូក២៥ ខ៤៤ ដែលព្រះយេស៊ូបង្រៀនអំពីសេចក្តីសង្គ្រោះ និងការជំនុំជម្រះចុងក្រោយ។ នៅទីនេះព្រះអង្គចាប់ផ្តើមព្រមានប្រជាជនអំពីពួកអាចារ្យនិងពួកផារីស៊ី។
មានភារកិច្ចបង្រៀនគម្ពីរវិន័យរបស់លោកម៉ូសេ
នៅទីនេះ“ គម្ពីរវិន័យ” តំណាងឲ្យសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងវិនិច្ឆ័យ។ “ មានសិទ្ធិអំណាចដូចលោកម៉ូសេមាន” ឬ“ មានសិទ្ធិអំណាចដើម្បីនិយាយថាច្បាប់របស់លោកម៉ូសេមានន័យយ៉ាងដូចម្តេច”
អ្វីៗ
«អ្វីក៏ដោយ» ឬ «អ្វីៗទាំងអស់»
Matthew 23:4
អ្នកទាំងនោះបានបង្កើតវិន័យយ៉ាងតឹងរ៉ឹង យកមកផ្ទុកលើស្មារបស់មនុស្ស
នៅទីនេះ "ផ្ទុក" ជាច្បាប់ជាច្រើន ដែលអ្នកដឹកនាំសាសនាបង្កើត។
"ពួកគេធ្វើឲ្យអ្នកគោរពច្បាប់ជាច្រើន ពិបាកធ្វើតាម"
គេមិនជួយសម្រាលបន្ទុកនោះទេ
នៅទីនេះ "ជួយសម្រាលបន្ទុក" គឺជាពាក្យប្រៀបធៀបសម្រាប់ការផ្តល់ជំនួយ។
"ពួកគេនឹងមិនផ្តល់ជំនួយតិចបំផុតទេ"
ពួកគេធ្វើកិច្ចការទាំងនេះ គឺដើម្បីឲ្យមនុស្សម្នាកោតសរសើរ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “
ពួកគេធ្វើគ្រប់បែបយ៉ាងដើម្បីឲ្យមនុស្សអាចមើលឃើញនូវអ្វី ដែលពួកគេបានធ្វើ”
គេធ្វើភ្លាក់ កាន់តែធំឡើងៗ និងធ្វើខ្សែរំយោល នៅជាយអាវកាន់តែវែងទៅៗ
រឿងទាំងពីរនេះ គឺជាអ្វីដែលពួកផារីស៊ីធ្វើ ដើម្បីបង្ហាញថា ពួកគេគោរពព្រះជាម្ចាស់ច្រើនជាងមនុស្សដទៃទៀត។
ភ្លាក់
ប្រអប់ស្បែកតូចៗមានក្រដាស ដែលមានសរសេរអក្សរលើវា។
ធ្វើខ្សែរំយោល នៅជាយអាវកាន់តែវែងទៅៗ
ពួកផារីស៊ីដាក់រំយោលវែងនៅលើអាវផាយរបស់ពួកគេ
ដើម្បីបង្ហាញភក្តីភាពចំពោះព្រះជាម្ចាស់។
Matthew 23:6
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ហ្វូងមនុស្ស និងពួកសិស្ស អំពីពួកផារីស៊ី។
កន្លែងកិត្តិយស...កន្លែងអង្គុយនៅមុខគេ
កន្លែងទាំងពីរនេះ ជាកន្លែងដែលមនុស្សសំខាន់អង្គុយ។
ផ្សារ
តំបន់ធំទូលាយនិងបើកចំហ ដែលមនុស្សទិញនិងលក់របស់របរ។
ឲ្យគេហៅខ្លួនថា «លោកគ្រូ»
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "សម្រាប់មនុស្សហៅពួកគេថា" រ៉ាប៊ី ""
Matthew 23:8
ប៉ុន្តែរីឯអ្នករាល់គ្នាវិញ កុំបង្គាប់គេឲ្យហៅខ្លួន
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ប៉ុន្តែអ្នកមិនត្រូវឲ្យនរណាម្នាក់ហៅអ្នកទេ"
អ្នករាល់គ្នា
ពាក្យ "អ្នករាល់គ្នា" គឺជាពហុវចនៈ
ហើយសំដៅទៅលើអ្នកកដើរតាមព្រះយេស៊ូទាំងអស់។

generated on Wed Sep 10 16:16:32 2025

អ្នករាល់គ្នាសុទ្ធតែជាបងប្អូននឹងគ្នា
ត្រង់នេះ“ បងប្អូន” មានន័យថា“ អ្នកជឿគ្រប់គ្នា” ។
កុំហៅនរណាម្នាក់នៅលើផែនដីនេះថា «ព្រះបិតា» ឲ្យសោះ
"កុំហៅបុរសណាម្នាក់នៅលើផែនដីថា ឪពុកអ្នក" ឬ "កុំនិយាយថា
មនុស្សនៅលើផែនដីជាឪពុករបស់អ្នក"
អ្នករាល់គ្នាមាន ព្រះបិតា តែមួយគត់ប៉ុណ្ណោះ
"ព្រះបិតា" ជាឋានៈដ៏សំខាន់ចំពោះព្រះជាម្ចាស់។
កុំឲ្យគេហៅអ្នករាល់គ្នាថា
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "កុំឲ្យនរណាម្នាក់ហៅអ្នក"
មានតែព្រះគ្រិស្តមួយព្រះអង្គប៉ុណ្ណោះ ដែលជាគ្រូរបស់អ្នករាល់គ្នា
ពេលព្រះយេស៊ូវមានបន្ទូលថា“ ព្រះគ្រិស្ត”
ព្រះអង្គកំពុងតែមានបន្ទូលអំពីព្រះអង្គនៅក្នុងបុរសទីបី។ "ខ្ញុំជាព្រះគ្រិស្ត
ជាគ្រូតែម្នាក់គត់របស់អ្នក"
Matthew 23:11
អ្នកណាមានឋានៈធំជាងគេក្នុងចំណោមអ្នករាល់គ្នា
"មនុស្សដែលសំខាន់បំផុតក្នុងចំណោមអ្នក"
ក្នុងចំណោមអ្នករាល់គ្នា
នៅទីនេះ "អ្នក"ជាពហុវចនៈ និងសំដៅទៅលើអ្នកដើរតាមព្រះយេស៊ូ។
លើកតម្កើងខ្លួន
"ធ្វើឲ្យខ្លួនគាត់សំខាន់"
នោះនឹងត្រូវគេបន្ទាបចុះ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “ព្រះអង្គនឹងបន្ទាបខ្លួន”
ត្រូវគេលើកតម្កើងវិញ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “ ព្រះអង្គនឹងធ្វើឲ្យសំខាន់” ឬ“
ព្រះអង្គនឹងគោរព”។
Matthew 23:13
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាប់ផ្តើមស្តីបន្ទោសអ្នកដឹកនាំសាសនា
ដោយសារអំពើលាក់ពុតរបស់ពួកគេ។
ប៉ុន្តែ
"គួរឲ្យភ័យខ្លាចណាស់សម្រាប់អ្នក!" សូមមើលការបកប្រែនៅក្នុងជំពូក១១ ខ២០
។
អ្នករាល់គ្នាបិទទ្វារព្រះរាជ្យនៃស្ថានបរមសុខ មិនឲ្យមនុស្សចូលទៅក្នុង
នៅទីនេះ«ស្ថាន
បរមសុខ»សំដៅលើការគ្រប់គ្រងរបស់ព្រះជាម្ចាស់ក្នុងនាមជាស្តេច។
ឃ្លានេះមានតែនៅក្នុងកណ្ឌគម្ពីរម៉ាថាយប៉ុណ្ណោះ។ បើអាចធ្វើបានសូមរក្សា“ ស្ថាន
បរមសុខ” នៅក្នុងការបកប្រែរបស់អ្នក។
"អ្នករារាំងមនុស្សមិនឲ្យទទួលយកព្រះជាម្ចាស់របស់យើង នៅស្ថាន
បរមសុខជាស្តេចរបស់ពួកគេ"
អ្នករាល់គ្នាមិនត្រឹមតែមិនបានចូលខ្លួនឯង
"អ្នកមិនទទួលយកព្រះអង្គជាស្តេចរបស់អ្នក"
ថែមទាំងរារាំងអ្នកដែលចង់ចូលមិនឲ្យគេចូលទៀតផង។
"អ្នកមិនអនុញ្ញាតឲ្យអ្នក ដែលចង់ទទួលយកព្រះអង្គជាស្តេចរបស់ពួកគេ"
អ្នករាល់គ្នាធ្វើដំណើរតាមផ្លូវទឹក និងតាមផ្លូវគោក
នេះជាសំនួនវោហារដែលមានន័យថា ពួកគេទៅកន្លែងឆ្ងាយ។
"អ្នកធ្វើដំណើរទៅឆ្ងាយ"
ស្វែងរកបញ្ចុះបញ្ចូលគេ ឲ្យចូលសាសនារបស់អ្នករាល់គ្នា
"ដើម្បីធ្វើឲ្យមនុស្សម្នាក់ទទួលយកសាសនារបស់អ្នក"
អាក្រក់ជួជាតិ
នៅទីនេះ "អាក្រក់ជួជាតិ" គឺជាពាក្យសម្តាល់ដែលមានន័យថា
"មួយជាកម្មសិទ្ធិរបស់" ។ "មនុស្សដែលជាកម្មសិទ្ធិក្នុងស្ថាននរក" ឬ
"មនុស្សដែលគួរតែទៅស្ថាននរក"
ឆបោកយកទ្រព្យសម្បត្តិរបស់ស្ត្រីមេម៉ាយ
នៅក្នុងលេខយោង“ ឆបោកយក” ជាពាក្យសម្តាល់ដែលមានន័យថា
ត្រូវយកដោយកម្លាំង។ "លួចអ្វីៗគ្រប់យ៉ាងពីស្ត្រី
ដែលគ្មានបុរសដើម្បីការពារពួកគេ"
Matthew 23:16
ឱពួកអ្នកដឹកនាំកង្វាក់អើយ...មនុស្សកង្វាក់លេលាអើយ
អ្នកដឹកនាំជនជាតិយូដាងងឹតភ្នែកខាងវិញ្ញាណ។ ទោះបីពួកគេគិតថា
ខ្លួនឯងជាគ្រូបង្រៀនក៏ដោយ
ក៏ពួកគេមិនអាចយល់ពីសេចក្តីពិតរបស់ព្រះអង្គបានទេ។
សូមមើលពីរបៀបដែលអ្នកបកប្រែ“ មគ្គុទេសក៍ពិការភ្នែក” នៅក្នុងជំពូក១៥ ខ១២
។
ដោយយកព្រះវិហារមកធ្វើជាសាក្សី ពាក្យសម្បថនោះយកជាការពុំបានទេ
"ព្រោះព្រះវិហារមិនអាចរក្សាពាក្យស្បថរបស់អ្នកនោះទេ"
ទើបយកជាការបាន
"ត្រូវរក្សាពាក្យសម្បថរបស់គាត់" ។ ត្រូវបានគេតម្រូវឲ្យធ្វើអ្វី
ដែលនរណាម្នាក់បាននិយាយក្នុងសម្បថត្រូវរក្សាពាក្យសម្បថ។ “
ត្រូវតែធ្វើអ្វីដែលគាត់បានសន្យាថា នឹងធ្វើ”
មាស និងព្រះវិហារដែលធ្វើឲ្យមាសទៅជាវត្ថុពិសិដ្ឋ តើមួយណាសំខាន់ជាង?
ព្រះយេស៊ូប្រើសំណួរនេះ ដើម្បីស្តីបន្ទោសពួកផារីស៊ីព្រោះពួកគេចាត់ទុកមាស
ដូចជាសំខាន់ជាងព្រះវិហារ។ "ព្រះវិហារដែលបានថ្វាយមាសដល់ព្រះជាម្ចាស់
សំខាន់ជាងមាសទៅទៀត!"
ព្រះវិហារដែលធ្វើឲ្យមាសទៅជាវត្ថុពិសិដ្ឋ
"ព្រះវិហារដែលសង់ពីមាស ជារបស់ព្រះជាម្ចាស់តែមួយ"
Matthew 23:18
ហើយ
អាចបញ្ជាក់ព័ត៌មានឲ្យកាន់តែច្បាស់ងាយយល់។ "ហើយអ្នកក៏និយាយដែរ"
យកជាការពុំបានទេ
"គាត់មិនចាំបាច់ធ្វើអ្វី ដែលគាត់បានស្បថថា ត្រូវធ្វើ" ឬ "គាត់មិនចាំបាច់ស្បថទេ"
តង្វាយដែលគេថ្វាយលើអាសនា
នេះជាសត្វ ឬគ្រាប់ធញ្ញជាតិដែលមនុស្សម្នាក់នឹងថ្វាយព្រះជាម្ចាស់
ដោយដាក់វានៅលើអាសនៈរបស់ព្រះអង្គ។
ទើបយកជាការបាន
"ត្រូវរក្សាពាក្យសម្បថរបស់គាត់" ។ ត្រូវបានគេតម្រូវឲ្យធ្វើអ្វី
ដែលនរណាម្នាក់បាននិយាយក្នុងសម្បថត្រូវរក្សាពាក្យសម្បថ។ “
ត្រូវតែធ្វើអ្វីដែលគាត់បានសន្យាថា នឹងធ្វើ”
ឱមនុស្សកង្វាក់អើយ
អ្នកដឹកនាំជនជាតិយូដាងងឹតភ្នែកខាងវិញ្ញាណ។ ទោះបីពួកគេគិតថា
ខ្លួនឯងជាគ្រូបង្រៀនក៏ដោយ
ក៏ពួកគេមិនអាចយល់ពីសេចក្តីពិតរបស់ព្រះជាម្ចាស់។
តង្វាយដែលគេថ្វាយលើអាសនា និងអាសនាដែលធ្វើឲ្យតង្វាយទៅជាតង្វាយពិសិដ្ឋ តើមួយណា
សំខាន់ជាង?
ព្រះយេស៊ូប្រើសំណួរនេះ ដើម្បីស្តីបន្ទោសពួកផារីស៊ី
ដោយចាត់ទុកតង្វាយសំខាន់ជាងអាសនៈទៅទៀត។
"អាសនៈដែលធ្វើតង្វាយទៅជាពិសិដ្ឋ ហើយសំខាន់ជាងតង្វាយទៅទៀត!"
អាសនាដែលធ្វើឲ្យតង្វាយទៅជាតង្វាយពិសិដ្ឋ
"អាសនៈដែលធ្វើឲ្យតង្វាយពិសេសចំពោះព្រះជាម្ចាស់"
Matthew 23:20
មានទាំងអ្វីៗនៅលើអាសនាជាសាក្សី
"ដោយតង្វាយទាំងអស់ ដែលមនុស្សបានដាក់នៅលើវា"
មានទាំងព្រះជាម្ចាស់ដែលគង់នៅក្នុងព្រះវិហារជាសាក្សីដែរ...មានទាំងព្រះជាម្ចាស់ដែលគង់នៅលើ
បល្ល័ង្កជាសាក្សី
ទាំងពីរនេះសំដៅទៅលើព្រះបិតា។
Matthew 23:23
ពួក
"គួរឲ្យភ័យខ្លាចណាស់សម្រាប់អ្នក!" សូមមើលការបកប្រែនៅក្នុងជំពូក១១ ខ២០
។
ជីរអង្កាម ជីរនាងវង និងម្នាម
ទាំងនេះគឺជាស្លឹក និងគ្រាប់ផ្សេងៗ
ដែលមនុស្សប្រើដើម្បីធ្វើឲ្យម្ហូបមានរសជាតិឆ្ងាញ់។
អ្នករាល់គ្នាលះបង់
"អ្នកមិនបានគោរពតាម"
ក្រឹត្យវិន័យសំខាន់ៗ
"រឿងសំខាន់ជាង"
ប៉ុន្តែវិន័យទាំងប៉ុន្មាននេះហើយ ដែលអ្នករាល់គ្នាត្រូវប្រតិបត្តិតាម
"អ្នកគួរតែគោរពតាមច្បាប់ សំខាន់ជាងនេះ"
ដោយឥតលះបង់ចោលណាមួយឡើយ

generated on Wed Sep 10 16:16:32 2025

អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ "ខណៈពេលគោរពច្បាប់មិនសំខាន់ជាងច្បាប់"
អ្នកដឹកនាំកង្វាក់អើយ
ព្រះយេស៊ូប្រើពាក្យប្រៀបធៀបនេះ ដើម្បីពិពណ៌នាអំពីពួកផារីស៊ី។
ព្រះយេស៊ូមានន័យថា ពួកផារីស៊ីមិនយល់អំពីបញ្ញត្តិរបស់ព្រះអង្គ
ឬរបៀបដែលព្រះអង្គពេញព្រះទ័យ។
ដូច្នេះពួកគេមិនអាចបង្រៀនអ្នកដទៃអំពីរបៀបផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ។
សូមមើលការបកប្រែប្រៀបធៀបនៅក្នុងជំពូក១៥ ខ១២ ។
អ្នករាល់គ្នាត្រងយកមូសចេញពីទឹកផឹក តែអ្នករាល់គ្នាលេបអូដ្ឋវិញ
ការប្រុងប្រយ័ត្នធ្វើតាមច្បាប់មិនសូវសំខាន់ និងមិនអើពើនឹងច្បាប់សំខាន់
គឺល្ងីល្ងើដូចការប្រុងប្រយ័ត្ន មិនត្រូវលេបសត្វតូចបំផុត ដែលមិនស្អាត
ប៉ុន្តែបរិភោគសាច់សត្វធំជាងគេ មិនស្អាតដោយចេតនា ឬដោយមិនដឹងខ្លួន។ “
អ្នកជាមនុស្សល្ងីល្ងើដូចមនុស្ស ដែលត្រងយក មូសចេញពីទឹកផឹក
តែបែរជាលេបអូដ្ឋមួយចូលទៅវិញ”
ត្រងយកមូស
មានន័យថា ចាក់អង្គធាតុរាវតាមរយៈក្រណាត់មួយដើម្បីយកចេកចេញពីភេសជ្ជៈ។
មូស
សត្វល្អិតដែលចេះហើរតូចមួយ
Matthew 23:25
ពួក
"គួរឲ្យភ័យខ្លាចណាស់សម្រាប់អ្នក!" សូមមើលការបកប្រែនៅក្នុងជំពូក១១ ខ២០ ។
អ្នករាល់គ្នាសំអាតពែង និងចាន តែខាងក្រៅប៉ុណ្ណោះ ប៉ុន្តែ ផ្នែកខាងក្នុងពោរពេញទៅដោយផលដែលកើតមកពីការកេងប្រវ័ញ្ច និងការលោភលន់
ការកេងប្រវ័ញ្ច - ជាការប្រៀបធៀបដែលមានន័យថា ពួកអាចារ្យ
និងពួកផារីស៊ីមើលទៅស្អាតនៅខាងក្រៅ ចំពោះអ្នកដទៃ ប៉ុន្តែនៅខាងក្នុងពួកគេជាមនុស្សអាក្រក់។
ពោរពេញទៅដោយផលដែលកើតមកពីការកេងប្រវ័ញ្ច និងការលោភលន់
ការកេងប្រវ័ញ្ច - "ពួកគេចង់បានអ្វីដែលអ្នកដទៃមាន
ហើយពួកគេធ្វើដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន"
ពួកផារីស៊ីដ៏កង្វាក់អើយ
ពួកផារីស៊ីពិការភ្នែកខាងវិញ្ញាណ។
ទោះបីពួកគេគិតថាខ្លួនឯងជាគ្រូបង្រៀនក៏ដោយ
ក៏ពួកគេមិនអាចយល់ពីសេចក្តីពិតរបស់ព្រះជាម្ចាស់បានទេ។
ចូរសម្អាតផ្នែកខាងក្នុងពែងជាមុនសិន ទើបអ្វីៗនៅខាងក្រៅបានស្អាតដែរ
នេះជាការប្រៀបធៀបដែលមានន័យថា
បើពួកគេនឹងក្លាយជាមនុស្សបរិសុទ្ធនៅក្នុងខ្លួនរបស់ពួកគេ នោះលទ្ធផលគឺថា
ពួកគេនឹងមានភាពបរិសុទ្ធនៅខាងក្រៅផងដែរ។
Matthew 23:27
អ្នករាល់គ្នាប្រៀបបាននឹងផ្នូរ ដែលលាបពណ៌ស ...មិនស្អាត
នេះជាឧទាហរណ៍មួយដែលមានន័យថា
ពួកអាចារ្យនិងពួកផារីស៊ីអាចមើលទៅដូចជាស្អាតនៅខាងក្រៅ
តែពួកគេអាក្រក់នៅខាងក្នុង។
ផ្នូរ ដែលលាបពណ៌ស
"ផ្នូរដែលមនុស្សម្នាក់បានលាបពណ៌ស" ជនជាតិយូដាលាបផ្នូរពណ៌ស
ដើម្បីឲ្យមនុស្សងាយមើលឃើញហើយជៀសវាងប៉ះពួកគេ។
ការប៉ះផ្នូរនឹងធ្វើឲ្យមនុស្សមិនស្អាត។
Matthew 23:29
របស់មនុស្សសុចរិត
គុណនាមបន្ទាប់បន្សំនេះអាចត្រូវបានបញ្ជាក់ជាគុណនាម។ "នៃមនុស្សសុចរិត"
ជំនាន់បុព្វបុរសរបស់យើង
"ក្នុងអំឡុងពេលនៃបុព្វបុរសរបស់យើង"
យើងមុខជាមិនសមគំនិតជាមួយគេ
"យើងនឹងមិនចូលរួមជាមួយពួកគេទេ"
ការសម្លាប់ពួកព្យាការីឡើយ
នៅទីនេះ "ការសម្លាប់" សំដៅទៅលើជីវិត។ ការបង្ហូរឈាមមានន័យថា សម្លាប់។ “
សម្លាប់” ឬ“ ឃាតកម្ម”
ថាជាពូជពង្ស
នៅទីនេះ "កូនប្រុស" មានន័យថា "កូនចៅ" ។
Matthew 23:32
អ្នករាល់គ្នានៅតែបន្តកិច្ចការរបស់បុព្វបុរសអ្នករាល់គ្នា!
ព្រះយេស៊ូប្រើពាក្យនេះជាពាក្យប្រៀបធៀប
ដែលពួកផារីស៊ីនឹងបំពេញឥរិយាបទអាក្រក់ ដែលបុព្វបុរសរបស់គេបានចាប់ផ្តើម
នៅពេលគេសម្លាប់ព្យាការី។ "អ្នកក៏បញ្ចប់អំពើបាប
ដែលដូនតារបស់អ្នកបានចាប់ផ្តើម"
ពូជពស់វែកអើយ
ពស់និងពស់វែកគឺដូចគ្នា។ ពួកវាមានគ្រោះថ្នាក់
ហើយជារឿយៗជានិមិត្តរូបនៃអំពើអាក្រក់។
"អ្នកជាអាក្រក់ដូចពស់ដែលមានគ្រោះថ្នាក់ និងពុល"
ពូជពស់វែក
នៅទីនេះ "ពូជ" មានន័យថា "មានចរិតលក្ខណៈ" ។ សូមមើលពីរបៀប
ដែលអ្នកបានបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក៣ ខ៧ ។
តើធ្វើម្តេចឲ្យអ្នករាល់គ្នាគេចផុតពីទោសធ្លាក់នរកបានទៅ?
ព្រះយេស៊ូប្រើសំណួរនេះជាការស្តីបន្ទោស។ "គ្មានផ្លូវសម្រាប់ឲ្យអ្នករួចផុត
ពីការកាត់ទោសនរកទេ!"
Matthew 23:34
ខ្ញុំចាត់
"ខ្ញុំនឹងបញ្ជូនទៅ" ។ នៅទីនេះ "ខ្ញុំ" សំដៅទៅលើព្រះយេស៊ូ។
អ្នករាល់គ្នាត្រូវទទួលទោស ព្រោះអ្នករាល់គ្នាបានបង្ហូរឈាមជនសុចរិត
ឃ្លាថា "អ្នករាល់គ្នាត្រូវទទួលទោស" ជាពាក្យសម្ភាល់ដែលមានន័យថា
ត្រូវទទួលទណ្ឌកម្ម។ ហើយ“ ឈាម” សំដៅទៅលើជីវិតរបស់មនុស្សម្នាក់។
ការបង្ហូរឈាមមានន័យថា សម្លាប់។ «ព្រះជាម្ចាស់នឹងដាក់ទណ្ឌកម្មអ្នក
ព្រោះបានសម្លាប់មនុស្សសុចរិតទាំងអស់»
បង្ហូរឈាម...រហូតដល់
ពាក្យថាឈាមសំដៅទៅលើជីវិតរបស់មនុស្សម្នាក់។ ត្រង់នេះមានន័យថា“
ការបង្ហូរឈាម” ឬឃាតកម្ម។ "ពីឃាតកម្ម ... រហូតដល់អំពើឃាតកម្ម"
លោកអេបិល...លោកសាការី
លោកអេបិលជាជនរងគ្រោះដំបូង នៃអំពើឃាតកម្ម
ហើយលោកសាការីប្រហែលជាត្រូវបានគេគិតថា
ជាអ្នកចុងក្រោយដែលត្រូវបានសម្លាប់ដោយជនជាតិយូដា នៅក្នុងព្រះវិហារ។
បុរសទាំងពីរនាក់នេះតំណាងឲ្យមនុស្សសុចរិត ដែលត្រូវគេសម្លាប់។
លោកសាការី
លោកសាការីនេះមិនមែនជាឪពុករបស់យ៉ូហានបាទិស្តទេ។
ដែលអ្នករាល់គ្នាបានសម្លាប់
ព្រះយេស៊ូពុំមានន័យថា
មនុស្សដែលលោកកំពុងនិយាយពិតជាបានសម្លាប់លោកសាការីទេ។
ព្រះអង្គមានន័យថា បុព្វបុរសរបស់ពួកគេបានធ្វើ។
ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នា
ព្រះយេស៊ូពុំមានន័យថា
មនុស្សដែលលោកកំពុងនិយាយពិតជាបានសម្លាប់លោកសាការីទេ។
ព្រះអង្គមានន័យថា បុព្វបុរសរបស់ពួកគេបានធ្វើ។
Matthew 23:37
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានកាន់ទុក្ខប្រជាជននៅក្រុងយេរូសាឡឹម ព្រោះពួកគេបដិសេធរាល់សារ
ដែលព្រះអង្គចាត់ឲ្យមក។
យេរូសាឡឹម យេរូសាឡឹមអើយ
ព្រះយេស៊ូមានបន្ទូលទៅកាន់ប្រជាជននៅក្រុងយេរូសាឡឹម
ហាក់ដូចជាពួកគេជាទីក្រុងនោះ។
អស់អ្នកដែលព្រះជាម្ចាស់បានចាត់ឲ្យមករកអ្នករាល់គ្នា
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "អ្នកដែលព្រះជាម្ចាស់ចាត់ឲ្យមករកអ្នក"
អ្នករាល់គ្នា
ព្រះយេស៊ូកំពុងមានបន្ទូលទៅកាន់ក្រុងយេរូសាឡឹម ដូចជាស្ត្រី
ហើយប្រជាជនជាកូនៗរបស់នាង។ "មនុស្សរបស់អ្នក" ឬ"ប្រជាជនរបស់អ្នក"
ដូចមេមាន់ក្រុងកូនវានៅក្រោមស្លាប
នេះជាឧទាហរណ៍មួយ ដែលបញ្ជាក់ពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ
ចំពោះប្រជាជន និងរបៀបដែលទ្រង់ចង់ថែរក្សាពួកគេ។
មេមាន់
មាន់ញី។ អ្នកអាចបកប្រែជាមួយបក្សីណា
ដែលការពារកូនៗរបស់វានៅក្រោមស្លាបរបស់វា។

generated on Wed Sep 10 16:16:32 2025

ផ្ទះរបស់អ្នករាល់គ្នា នឹងត្រូវបោះបង់ចោលអោយនៅស្ងាត់ជ្រងំ
"ព្រះជាម្ចាស់នឹងចាកចេញពីផ្ទះរបស់អ្នក ហើយផ្ទះនឹងនៅទំនេរ"
ផ្ទះរបស់អ្នករាល់គ្នា
អាចមានន័យថា ១)“ ទីក្រុងយេរូសាឡឹម” ឬ ២)“ ព្រះវិហារ” ។
ខ្ញុំសុំប្រាប់អ្នករាល់គ្នា
បន្ថែមការសង្កត់ធ្ងន់ទៅលើអ្វី ដែលព្រះយេស៊ូមានបន្ទូលបន្ទាប់។

សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គដែលយាងមកក្នុងនាមព្រះអម្ចាស់
នៅទីនេះ "ក្នុងនាមព្រះអម្ចាស់" មានន័យថា "នៅក្នុងអំណាច" ឬ
"ក្នុងនាមជាអ្នកតំណាង" ។ "អ្នកណាដែលមកក្នុងអំណាចរបស់ព្រះអម្ចាស់
ត្រូវបានប្រទានពរ" ឬ "អ្នកដែលមកក្នុងនាមជាអ្នកតំណាងព្រះអម្ចាស់
នឹងត្រូវបានប្រទានពរ" ។ សូមមើលការបកប្រែនៅក្នុងជំពូក ២១ ខ៩ ។

---

24 [1]ព្រះយេស៊ូកំពុងយាងចេញពីព្រះវិហារ ពួកសិស្សចូលមកជិត ចង្អុលបង្ហាញវិមានផ្សេងៗក្នុងព្រះវិហារ ថ្វាយព្រះអង្គទត។[2]ប៉ុន្តែទ្រង់មានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នាមិនឃើញអ្វីៗនៅទីនេះទេឬ? ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា លែងមានថ្មត្រួតពីលើថ្មទៀតហើយ វានឹងត្រូវរលំបាក់បែកអស់»។
[3]កាលទ្រង់គង់នៅលើភ្នំដើមអូលីវ ពួកសិស្សនាំគ្នាចូលទៅគាល់ព្រះអង្គដាច់ឡែកពីគេ ហើយទូលថា៖ «សូមប្រាប់ឲ្យយើងខ្ញុំដឹងផង ហេតុការណ៍ទាំងនេះនឹងកើតឡើងនៅពេលណា? តើមានទីសំគាល់អ្វីឲ្យយើងខ្ញុំដឹងថាដល់ពេលព្រះអង្គយាងមក និងដល់អវសានកាលនៃពិភពលោក?»[4]ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «ចូរប្រុងប្រយ័ត្ន កុំឲ្យនរណាមកបញ្ឆោតអ្នករាល់គ្នាឲ្យវង្វេងបានឡើយ។[5]ដ្បិតនឹងមានមនុស្សជាច្រើន យកឈ្មោះខ្ញុំទៅប្រើដោយពោលថា៖ «ខ្ញុំនេះហើយជាព្រះគ្រិស្ត ហើយគេនឹងនាំមនុស្សជាច្រើនឲ្យវង្វេង។
[6]អ្នករាល់គ្នានឹងឮគេនិយាយអំពីសង្គ្រាម និងឮដំណឹងថា មានសង្គ្រាមផ្ទុះឡើង។ កុំជ្រួលច្របល់ឡើយ ដ្បិតហេតុការណ៍ទាំងនេះត្រូវតែកើតឡើង តែមិនទាន់ដល់អវសានកាលនៃពិភពលោកនៅឡើយទេ។[7]ប្រជាជាតិមួយនឹងតតាំងទល់នឹងប្រជាជាតិមួយទៀត ប្រទេសមួយតទល់នឹងប្រទេសមួយទៀត។ នៅតាមតំបន់ផ្សេងៗនឹងមានកើតទុរ្ភិក្ស និងរញ្ជួយផែនដី។[8]ប៉ុន្តែ ហេតុការណ៍ទាំងនេះប្រៀបបាននៅនឹងការឈឺចាប់ ដើមដំបូងរបស់ស្ត្រីដែលហៀបនឹងសម្រាលកូនប៉ុណ្ណោះ។
[9]គេនឹងបញ្ជូនអ្នករាល់គ្នាទៅធ្វើទុក្ខទោស ព្រមទាំងឲ្យគេសម្លាប់អ្នករាល់គ្នាថែមទៀតផង។ ជាតិសាសន៍ទាំងអស់នឹងស្អប់អ្នករាល់គ្នា ព្រោះតែនាមខ្ញុំ។[10]មានមនុស្សជាច្រើននឹងបែកចិត្តឃ្លាតចេញពីជំនឿ ក្បត់គ្នា និងស្អប់គ្នាផង។[11]នឹងមានព្យាការីក្លែងក្លាយជាច្រើនមកដល់ ហើយបញ្ឆោតមនុស្សជាច្រើនឲ្យវង្វេង។
[12]ដោយអំពើទុច្ចរិតនឹងរីកចម្រើនឡើងជាខ្លាំង បណ្តាលឲ្យការស្រឡាញ់របស់មនុស្សជាច្រើន ត្រូវធ្លាក់ចុះអន់ថយ។[13]ប៉ុន្តែ អ្នកណាស៊ូទ្រាំរហូតដល់ទីបញ្ចប់ ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ។[14]គេនឹងប្រកាសដំណឹងល្អអំពីព្រះរាជ្យនេះ ពាសពេញសកលលោកទាំងមូល ទុកជាសក្ខីភាពដល់ជាតិសាសន៍ទាំងអស់។ ពេលនោះ ទើបដល់អវសានកាលនៃពិភពលោក។
[15]កាលណាអ្នករាល់គ្នាឃើញ វត្ថុចង្រៃដ៏គួរស្អប់ខ្ពើម តាំងនៅក្នុងទីសក្ការៈ ដូចព្យាការីដានីយ៉ែលបានថ្លែងទុក» (សូមឲ្យអ្នកអានយល់ពាក្យនេះចុះ)[16]ពេលនោះ អ្នកដែលរស់ក្នុងស្រុកយូដា ត្រូវនាំគ្នារត់ទៅជ្រកនៅតាមភ្នំ។[17]រីឯអ្នកនៅលើដំបូលផ្ទះ មិនត្រូវចុះមកយកអ្វីៗនៅក្នុងផ្ទះឡើយ[18]ហើយអ្នកដែលនៅឯចម្ការ ក៏មិនត្រូវវិលទៅផ្ទះយកអាវធំរបស់ខ្លួនដែរ។
[19]ប៉ុន្តែគ្រានោះ ស្ត្រីដែលមានផ្ទៃពោះ និងស្ត្រីបំបៅកូនមុខជាត្រូវវេទនាជាពុំខាន។[20]ចូរទូលអង្វរព្រះជាម្ចាស់ សូមកុំឲ្យអ្នករាល់គ្នាត្រូវរត់ភៀសខ្លួននៅរដូវត្រជាក់ ឬនៅថ្ងៃសប្ប័ទឡើយ[21]ដ្បិតនៅគ្រានោះ ជាគ្រាដែលមានទុក្ខលំបាកយ៉ាងខ្លាំង តាំងពីដើមកំណើតពិភពលោក មកទល់សព្វថ្ងៃ ហើយទោះជាទៅថ្ងៃមុខទៀត ក៏ពុំដែលមានទុក្ខលំបាកខ្លាំងយ៉ាងនេះដែរ។[22]ប្រសិនបើព្រះជាម្ចាស់មិនបន្ថយចំនួនថ្ងៃទាំងនោះទេ មុខជាគ្មានមនុស្សណាមួយបានរួចជីវិតឡើយ ប៉ុន្តែដោយយោគយល់ដល់ពួកអ្នកដែលព្រះអង្គបានជ្រើសរើស ចំនួនថ្ងៃនឹងកាត់បន្ថយ។
[23]ប្រសិនបើមានគេប្រាប់អ្នករាល់គ្នាថា៖ «មើល៍! ព្រះគ្រិស្តគង់នៅទីនេះ» «ឬនៅទីនោះ» កុំជឿគេឡើយ។[24]ដ្បិតនឹងមានមនុស្សក្លែងខ្លួនធ្វើជាព្រះគ្រិស្ត ព្រមទាំងជាព្យាការីនាំគ្នាសម្តែងទីសម្គាល់ធំអស្ចារ្យ និងឫទ្ធិបាដិហារិយ៍ផ្សេងៗ ដើម្បីបញ្ឆោតមនុស្សរហូតដល់ទៅនាំពួកអ្នក ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យវង្វេងថែមទៀតផង ប្រសិនបើគេអាចធ្វើទៅបាន។[25]ខ្ញុំបាននិយាយប្រាប់ឲ្យអ្នករាល់គ្នាដឹងជាមុនឲ្យហើយ។
[26]បើមានគេប្រាប់អ្នករាល់គ្នាថា៖ «មើល៍! ព្រះអង្គនៅវាលរហោស្ថានឯណោះ» កុំចេញទៅតាមគេឡើយ ឬមួយបើគេថា៖ «ព្រះអង្គនៅក្នុងបន្ទប់ឯណេះ» ក៏កុំជឿពាក្យគេដែរ។[27]ដ្បិតបុត្រមនុស្សនឹងយាងមក ប្រៀបបីដូចជាផ្លេកបន្ទោរដ៏ភ្លឺ ឆូតកាត់ពីទិសខាងកើតទៅទិសខាងលិច។[28]សាកសពនៅទីណា ត្មាតក៏មកប្រមូលផ្តុំគ្នានៅទីនោះដែរ។
[29]ប៉ុន្តែលុះគ្រាដែលមានទុក្ខវេទនានេះ កន្លងផុតទៅភ្លាមនោះ ព្រះអាទិត្យនឹងបាត់រស្មី ព្រះច័ន្ទលែងមានពន្លឺទៀតហើយ រីឯផ្កាយទាំងឡាយនឹងធ្លាក់ចុះពីលើមេឃ ហើយអំណាចនានានៅលើមេឃ នឹងត្រូវកក្រើករំពើក។
[30]បន្ទាប់ ទីសម្គាល់របស់បុត្រមនុស្សនឹងលេចចេញពីផ្ទៃមេឃមក ហើយកុលសម្ព័ន្ធទាំងប៉ុន្មាននៅលើផែនដី នឹងនាំគ្នាយំគក់ទ្រូង ។ គេនឹងឃើញបុត្រមនុស្សយាងមកលើពពកក្នុងផ្ទៃមេឃ ប្រកបដោយឫទ្ធានុភាព និងសិរីរុងរឿងដ៏អស្ចារ្យ។[31]លោកក៏ចាត់ពួកទេវតារបស់លោក ជាមួយសំឡេងត្រែលាន់ឮរំពងឡើង ឲ្យទៅទិសទាំងបួន ដើម្បីប្រមូលពួកអ្នកដែលព្រះជាម្ចាស់បានជ្រើសរើស ចាប់ពីជើងមេឃម្ខាង ទៅជើងមេឃម្ខាង។
[32]ចូរអ្នករាល់គ្នាយកដើមឧទុម្ពរទៅរិះគិតចុះ។ កាលណាមែករបស់វាមានស្លឹកលាស់ខៀវខ្ចី អ្នករាល់គ្នាដឹងថា រដូវប្រាំងជិតមកដល់ហើយ។[33]ដូច្នេះ កាលណាអ្នករាល់គ្នាឃើញព្រឹត្តិការណ៍ទាំងអស់នោះកើតឡើងត្រូវដឹងថា បុត្រមនុស្សក៏ជិតមកដល់ហើយដែរ គឺលោកមកជិតបង្កើយហើយ។
[34]ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងប្រាកដថា ក្នុងពេលដែលមនុស្សជំនាន់នេះ នៅមានជីវិតនៅឡើយ ហេតុការណ៍ទាំងនោះនឹងកើតឡើង ។[35]ផ្ទៃមេឃ និងផែនដីនឹងរលាយបាត់ទៅ តែពាក្យដែលខ្ញុំនិយាយមិនរលាយបាត់ទេ។
[36]ប៉ុន្តែរីឯថ្ងៃកំណត់ និងពេលវេលា គ្មាននរណាដឹងឡើយ ទោះបីទេវតានៅស្ថានបរមសុខ ឬព្រះបុត្រាក៏ពុំជ្រាបដែរ មានតែព្រះបិតាមួយព្រះអង្គប៉ុណ្ណោះដែលជ្រាប។
[37]នៅគ្រាបុត្រមនុស្សយាងមក ក៏ដូចកាលនៅសម័យលោកណូអេដែរ។[38]ដ្បិតនៅមុនពេលទឹកជំនន់ធំ មនុស្សម្នាតែងតែនាំគ្នាស៊ីផឹក រៀបការប្តីប្រពន្ធរហូតដល់ថ្ងៃដែលលោកណូអេចូលក្នុងទូកធំ។[39]ហើយគេមិនបានចាប់អារម្មណ៍អ្វីសោះ ទាល់តែទឹកជំនន់ឡើងមកដល់បំផ្លាញគេអស់ទៅ ដូចគ្នានេះដែរនៅគ្រាដែលបុត្រមនុស្សយាងមក ក៏កើតមានដូច្នោះដែរ។
[40]បើមានមនុស្សពីរនាក់ធ្វើការក្នុងចំការជាមួយគ្នា ព្រះជាម្ចាស់នឹងយកម្នាក់ទៅ ទុកម្នាក់ទៀតឲ្យនៅ។[41]បើមានស្ត្រីពីរនាក់កិនស្រូវជាមួយគ្នា ព្រះជាម្ចាស់នឹងយកម្នាក់ទៅ ទុកម្នាក់ទៀតឲ្យនៅ។[42]ដូច្នេះ ចូរប្រុងស្មារតីឲ្យមែនទែន ព្រោះអ្នករាល់គ្នាពុំដឹងថា ព្រះអម្ចាស់របស់អ្នករាល់គ្នានឹងមកដល់នៅពេលណាឡើយ។
[43]ប៉ុន្តែអ្នករាល់គ្នាដឹងហើយថា បើម្ចាស់ផ្ទះដឹងចោរចូលមកប្លន់ថ្មើរណា គាត់មុខជាប្រុងស្មារតីពុំខាន មិនបណ្តោយឲ្យចោរចូលមកប្លន់ផ្ទះគាត់បានឡើយ។[44]ដូច្នេះ អ្នករាល់គ្នាត្រូវត្រៀមខ្លួនជានិច្ច ដ្បិតបុត្រមនុស្សនឹងមកដល់ នៅវេលាដែលអ្នករាល់គ្នាពុំបានគិត។
[45]បើអ្នកបម្រើណាមានចិត្តស្មោះត្រង់ ហើយឈ្លាសវៃ ម្ចាស់មុខជាផ្ទុកផ្តាក់ឲ្យអ្នកបម្រើនោះមើលខុសត្រូវលើអ្នកបំរើឯទៀតៗ ក្នុងការចែកម្ហូបអាហារឲ្យគេ តាមពេលដែលកំណត់ជាពុំខាន?[46]អ្នកបំរើនោះពិតជាមានពរហើយ ពេលម្ចាស់ត្រឡប់មកដល់ផ្ទះវិញ ឃើញអ្នកបម្រើកំពុងបំពេញកិច្ចការរបស់ខ្លួនដូច្នេះ។[47]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដថា ម្ចាស់មុខជាផ្ទុកផ្តាក់ឲ្យគាត់មើលខុសត្រូវ លើទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់លោកថែមទៀតផង។
[48]ប៉ុន្តែ បើអ្នកបម្រើអាក្រក់គិតក្នុងចិត្តថា៖ «ម្ចាស់អញក្រមកដល់ណាស់»[49]ហើយគាត់វាយអ្នកបម្រើឯទៀតៗព្រមទាំងទៅស៊ីផឹកជាមួយអ្នកប្រមឹកផងនោះ[50]ពេលម្ចាស់វិលត្រឡប់មកផ្ទះវិញ នៅថ្ងៃដែលអ្នកបម្រើនោះមិននឹកគិត ឬនៅពេលដែលគាត់មិនដឹងនោះ[51]លោកនឹងធ្វើទោសគាត់ជាទម្ងន់ ដោយឲ្យគាត់ទទួលទោសរួមជាមួយពួកមានពុតត្បុតដែរ គឺឲ្យទៅនៅកន្លែងយំសោកខឹងសង្កៀតធ្មេញ។

generated on Wed Sep 10 16:16:32 2025

Matthew 24:1
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាប់ផ្តើមពិពណ៌នាព្រឹត្តិការណ៍ ដែលនឹងកើតឡើង
មុនពេលទ្រង់យាងមកម្តងទៀតនៅគ្រាចុងក្រោយ។
ពីព្រះវិហារ
បញ្ជាក់ថា ព្រះយេស៊ូមិននៅក្នុងព្រះវិហារទេ។ គាត់នៅទីធ្លាជុំវិញព្រះវិហារ។
អ្នករាល់គ្នាមិនឃើញអ្វីៗនៅទីនេះទេឬ?
ព្រះយេស៊ូប្រើសំណួរមួយ ដើម្បីធ្វើឲ្យសិស្សគិតយ៉ាងជ្រាលជ្រៅអំពីអ្វី
ដែលទ្រង់នឹងប្រាប់ដល់ពួកគេ។ "ខ្ញុំសូមប្រាប់អ្នកអំពីអគារទាំងអស់នេះ" ។
ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់
"ខ្ញុំប្រាប់អ្នកពីការពិត" ។ នេះបន្ថែមការសង្កត់ធ្ងន់ទៅលើអ្វី
ដែលព្រះយេស៊ូមានបន្ទូលបន្ទាប់។
លែងមានថ្មត្រួតពីលើថ្មទៀតហើយ វានឹងត្រូវរលំបាក់បែកអស់
បញ្ជាក់ថាទាហានសត្រូវនឹងកម្ទេចថ្ម។ អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “
នៅពេលដែលទាហានសត្រូវមកពួកគេនឹងកម្ទេចថ្មទាំងអស់ នៅក្នុងអគារទាំងនេះ”
Matthew 24:3
តើមានទីសំគាល់អ្វីឲ្យយើងខ្ញុំដឹងថាដល់ពេលព្រះអង្គយាងមក និងដល់អវសានកាលនៃពិភព
លោក?
“ព្រះអង្គយាងមក” ត្រង់នេះ សំដៅទៅលើពេល
ដែលព្រះយេស៊ូនឹងឡើងកាន់អំណាច
ដោយបង្កើតរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដី និងធ្វើឲ្យគ្រាចុងក្រោយនេះចប់។
ចូរប្រុងប្រយ័ត្ន កុំឲ្យនរណាមកបញ្ឆោតអ្នករាល់គ្នាឲ្យវង្វេងបានឡើយ
"ប្រយ័ត្ន កុំជឿអ្នកណាកុហកអ្នកពីរឿងទាំងនេះ"
មនុស្សជាច្រើន យកឈ្មោះខ្ញុំ
នៅទីនេះ "ឈ្មោះ" សំដៅទៅលើ "នៅក្នុងសិទ្ធិអំណាច" ឬ
"ក្នុងនាមជាអ្នកតំណាង" របស់នរណាម្នាក់។ "មនុស្សជាច្រើននឹងអះអាងថា
ពួកគេបានមកក្នុងនាមជាអ្នកតំណាងរបស់ខ្ញុំ" ឬ
"មនុស្សជាច្រើននឹងនិយាយថាពួកគេនិយាយជំនួសខ្ញុំ"
Matthew 24:6
កុំជ្រួលច្របល់ឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "កុំឲ្យរឿងទាំងនេះបង្កបញ្ហាដល់អ្នក"
ប្រជាជាតិមួយនឹងតតាំងទល់នឹងប្រជាជាតិមួយទៀត ប្រទេសមួយតទល់នឹងប្រទេសមួយទៀត
ទាំងពីរនេះមានន័យដូចគ្នា។ ព្រះយេស៊ូកំពុងសង្កត់ធ្ងន់ថា
មនុស្សនៅគ្រប់ទីកន្លែងនឹងប្រយុទ្ធគ្នា។
ការឈឺចាប់ ដើមដំបូងរបស់ស្ត្រីដែលហៀបនឹងសម្រាលកូន
សំដៅទៅលើការឈឺចាប់ ដែលស្ត្រីមានអារម្មណ៍មុនពេលសម្រាលកូន។
ការប្រៀបធៀបនេះមានន័យថា សង្គ្រាមទុរភិក្ស
និងការរញ្ជួយដីទាំងនេះគ្រាន់តែជាការចាប់ផ្តើមនៃព្រឹត្តិការណ៍
ដែលនឹងនាំទៅដល់ចុងបញ្ចប់នៃសម័យកាលប៉ុណ្ណោះ។
Matthew 24:9
គេនឹងបញ្ជូនអ្នករាល់គ្នាទៅធ្វើទុក្ខទោស ព្រមទាំងឲ្យគេសម្លាប់អ្នករាល់គ្នាថែមទៀតផង
ប្រជាជននឹងប្រគល់អ្នកទៅអាជ្ញាធរ ដែលនឹងធ្វើឲ្យអ្នកឈឺចាប់
ហើយនឹងសម្លាប់អ្នក។
ជាតិសាសន៍ទាំងអស់នឹងស្អប់អ្នករាល់គ្នា
នៅទីនេះ“ ប្រជាជាតិនានា” សំដៅទៅលើប្រជាជននៃប្រជាជាតិនានា។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "មនុស្សមកពីគ្រប់ជាតិសាសន៍នឹងស្អប់អ្នក"
ព្រោះតែនាមខ្ញុំ
"ឈ្មោះ" នៅទីនេះសំដៅទៅលើមនុស្សពេញលេញ។ "ពីព្រោះអ្នកជឿលើខ្ញុំ"
ជាច្រើន
"នឹងមកដល់"
Matthew 24:12
អំពើទុច្ចរិតនឹងរីកចម្រើនឡើងជាខ្លាំង
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "មនុស្សនឹងធ្វើបាបកាន់តែច្រើនឡើង"
ការស្រឡាញ់របស់មនុស្សជាច្រើន ត្រូវធ្លាក់ចុះអន់ថយ
អាចមានន័យថា ១) "មនុស្សជាច្រើននឹងលែងស្រឡាញ់អ្នកដទៃ" ឬ ២)
"មនុស្សជាច្រើននឹងលែងស្រឡាញ់ព្រះជាម្ចាស់ទៀតហើយ" ។
អ្នកណាស៊ូទ្រាំ
"អ្នកណានៅស្មោះត្រង់"
ដល់អវសានកាលនៃពិភពលោក
មិនច្បាស់ទេថាតើ“ អវសានកាល” មានន័យថា
នៅពេលដែលមនុស្សម្នាក់បានស្លាប់ ឬនៅពេលការបៀតបៀនបានបញ្ចប់
ឬចុងបញ្ចប់នៃអាយុ ពេលព្រះជាម្ចាស់បង្ហាញអង្គទ្រង់ថាជាស្តេច។ ចំណុចសំខាន់
គឺថាពួកគេស៊ូទ្រាំបានយូរតាមភាពចាំបាច់។
នឹងសង្គ្រោះអ្នកនោះ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “ ព្រះអង្គនឹងរំដោះមនុស្សនោះ”
គេនឹងប្រកាសដំណឹងល្អអំពីព្រះរាជ្យនេះ
នៅទីនេះ«ព្រះរាជ្យ»សំដៅលើការគ្រប់គ្រងរបស់ព្រះជាម្ចាស់ក្នុងនាមជាស្តេច។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«មនុស្សនឹងនិយាយសារនេះអំពីការគ្រប់គ្រងរបស់ព្រះជាម្ចាស់»
ដល់ជាតិសាសន៍ទាំងអស់
នៅទីនេះ "ជាតិសាសន៍" តំណាងឲ្យប្រជាជន។ មនុស្សទាំងអស់នៅគ្រប់ទីកន្លែង"
អវសានកាលនៃពិភពលោក
“ ចុងបញ្ចប់នៃពិភពលោក” ឬ“ ចុងបញ្ចប់នៃអាយុ”
Matthew 24:15
វត្ថុចង្រៃដ៏គួរស្អប់ខ្ពើម
«មនុស្សអៀនខ្មាស ដែលធ្វើឲ្យរឿងរបស់ព្រះអង្គទៅជាស្មោកគ្រោក»
ដូចព្យាការីដានីយ៉ែលបានថ្លែងទុក
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "អំពីអ្វីដែលព្យាការីដានីយ៉ែលបានសរសេរ"។
សូមឲ្យអ្នកអានយល់ពាក្យនេះចុះ
មិនមែនជាព្រះយេស៊ូទេ ដែលកំពុងតែមានបន្ទូល។
កណ្ឌគម្ពីរម៉ាថាយបានបន្ថែមចំណុចនេះ ដើម្បីដាស់តឿនអ្នកអានថា
ព្រះយេស៊ូកំពុងប្រើពាក្យដែលពួកគេត្រូវគិតនិងបកស្រាយ។
អ្នកនៅលើដំបូលផ្ទះ
ដំបូលផ្ទះជាកន្លែង ដែលព្រះយេស៊ូគង់នៅមានរាងសំប៉ែត
ហើយមនុស្សអាចឈរនៅលើពួកគេបាន។
Matthew 24:19
ស្ត្រីដែលមានផ្ទៃពោះ
នេះជាវិធីគួរសមក្នុងការនិយាយថា "ស្ត្រីមានផ្ទៃពោះ" ។
គ្រានោះ
"ពេលនោះ"
សូមកុំឲ្យអ្នករាល់គ្នាត្រូវរត់ភៀសខ្លួន
"ដែលអ្នកមិនចាំបាច់រត់ភៀសខ្លួន" ឬ "ដែលអ្នកមិនចាំបាច់រត់ចេញ"
រដូវត្រជាក់
"រដូវរងា"
ប្រសិនបើព្រះជាម្ចាស់មិនបន្ថយចំនួនថ្ងៃទាំងនោះទេ មុខជាគ្មានមនុស្សណាមួយបានរួចជីវិតឡើយ
អាចបញ្ជាក់ជាទម្រង់វិជ្ជមាននិងកិរិយាសកម្ម។
"បើព្រះអង្គមិនបន្ថយពេលវេលានៃការរងទុក្ខទេ មនុស្សគ្រប់គ្នានឹងស្លាប់"
មនុស្ស
"មនុស្ស" ។ នៅទីនេះ“ សាច់ឈាម” ជាវិធីនិយាយបែបកំណាព្យ។
ចំនួនថ្ងៃនឹងកាត់បន្ថយ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “
ព្រះអង្គនឹងកាត់បន្ថយពេលវេលានៃការរងទុក្ខ”
Matthew 24:23
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ពួកសិស្ស។
កុំជឿគេឡើយ
"កុំជឿរឿងមិនពិត ដែលពួកគេបាននិយាយទៅកាន់អ្នក"
រហូតដល់ទៅនាំពួកអ្នក ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យវង្វេងថែមទៀតផង
នេះជាសំនួនវោហារ "បណ្តាលឲ្យមនុស្សមិនស្តាប់បង្គាប់ព្រះជាម្ចាស់"
ឲ្យវង្វេងថែមទៀតផង ប្រសិនបើគេអាចធ្វើទៅបាន
អាចបកប្រែជាប្រយោគដាច់ដោយឡែក។ "វង្វេងផ្លូវ។
បើអាចធ្វើបានពួកគេនឹងធ្វើឲ្យអ្នក
ដែលព្រះជាម្ចាស់បានជ្រើសរើសមិនគោរពព្រះជាម្ចាស់"
Matthew 24:26
បើមានគេប្រាប់អ្នករាល់គ្នាថា៖ «មើល៍! ព្រះអង្គនៅវាលរហោស្ថានឯណោះ
អាចបញ្ជាក់ជាសម្រង់ដោយប្រយោល។ "បើមាននរណាម្នាក់ប្រាប់អ្នកថា
ព្រះគ្រិស្តនៅទីរហោស្ថាន"
មួយបើគេថា៖ «ព្រះអង្គនៅក្នុងបន្ទប់ឯណេះ»

generated on Wed Sep 10 16:16:32 2025

អាចបញ្ជាក់ជាសម្រង់ដោយប្រយោល។ "ឬ បើនរណាម្នាក់ប្រាប់អ្នកថា
ព្រះគ្រិស្តស្ថិតនៅក្នុងបន្ទប់ខាងក្នុង"
នៅក្នុងបន្ទប់
"នៅក្នុងបន្ទប់សម្ងាត់" ឬ "នៅកន្លែងសម្ងាត់"
ដ្បិតបុត្រមនុស្សនឹងយាងមក...ប្រៀបបីដូចជាផ្លេកបន្ទោរដ៏ភ្លឺ
មានន័យថា កូនមនុស្សនឹងមកយ៉ាងលឿន
ហើយព្រះអង្គនឹងមើលឃើញយ៉ាងងាយស្រួល។
បុត្រមនុស្ស
ព្រះយេស៊ូកំពុងតែនិយាយអំពីអង្គទ្រង់ ជាបុរសទីបី។
សាកសពនៅទីណា ត្មាតក៏មកប្រមូលផ្តុំគ្នានៅទីនោះដែរ
ប្រហែលជាសុភាសិតមួយ ដែលមនុស្សនៅសម័យព្រះយេស៊ូបានយល់។
អាចមានន័យថា ១) នៅពេលកូនមនុស្សមកអ្នករាល់គ្នានឹងឃើញព្រះអង្គ
ហើយដឹងថាព្រះអង្គបានមកឬ ២) កន្លែងណាដែលមនុស្សស្លាប់ខាងវិញ្ញាណ
ព្យាការីក្លែងក្លាយនឹងនៅទីនោះ ដើម្បីនិយាយកុហកពួកគេ។
ត្មាត
បក្សីដែលស៊ីសាកសពមនុស្ស និងសត្វងាប់។
Matthew 24:29
ភ្លាមនោះ
"ភ្លាមៗ"
លុះគ្រាដែលមានទុក្ខវេទនានេះ
«គ្រាលំបាក»
ព្រះអាទិត្យនឹងបាត់រស្មី
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ព្រះអង្គនឹងធ្វើឲ្យព្រះអាទិត្យងងឹត"
អំណាចនានានៅលើមេឃ នឹងត្រូវកក្រើករំពើក
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ “ ព្រះជាម្ចាស់នឹងធ្វើឲ្យរញ្ជួយអ្វីៗនៅក្នុងមេឃ
និងលើមេឃ”
Matthew 24:30
បុត្រមនុស្ស...លោក...របស់លោក
ព្រះយេស៊ូកំពុងតែមានបន្ទូលអំពីអង្គទ្រង់ ជាបុរសទីបី។
កុលសម្ព័ន្ធទាំងប៉ុន្មាន
នៅទីនេះ "កុលសម្ព័ន្ធ" សំដៅទៅលើប្រជាជន។ "ប្រជាជនទាំងអស់នៃកុលសម្ព័ន្ធ"
ឬ "ប្រជាជនទាំងអស់"
លោកក៏ចាត់ពួកទេវតារបស់លោក ជាមួយសំឡេងត្រែលាន់ឮរំពងឡើង
ពេលសំឡេងត្រែបន្លឺឡើង ទ្រង់នឹងចាត់ពួកទេវតារបស់ទ្រង់ឲ្យមក»។
ប្រមូលពួកអ្នក
"ពួកទេវតារបស់គាត់នឹងប្រមូលផ្តុំ"
ដែលព្រះជាម្ចាស់បានជ្រើសរើស
អ្នកទាំងនេះជាមនុស្ស ដែលកូនមនុស្សបានជ្រើសរើស។
ចាប់ពីជើងមេឃម្ខាង ទៅជើងមេឃម្ខាង
ទាំងពីរនេះមានន័យដូចគ្នា។ ពួកគេគឺពាក្យសម្តាល់ដែលមានន័យថា
"មកពីគ្រប់ទិសទី" ។ "មកពីគ្រប់ទិសទីលើពិភពលោក"
Matthew 24:32
បុត្រមនុស្សក៏ជិតមកដល់ហើយដែរ
ព្រះយេស៊ូកំពុងតែមានបន្ទូលអំពីអង្គទ្រង់ ជាបុរសទីបី។
"ពេលវេលាសម្រាប់ខ្ញុំត្រូវមកជិតដល់ហើយ"
គឺលោកមកជិតបង្កើយហើយ
"ជិតនឹងទ្វារ។ " ព្រះយេស៊ូប្រើរូបភាពរបស់ស្តេច ឬមន្ត្រីសំខាន់ម្នាក់
ដែលចូលទៅជិតខ្លោងទ្វារក្រុង ដែលមានកំពែងព័ទ្ធជុំវិញ។
ជាពាក្យប្រៀបធៀបដែលមានន័យថា
ពេលវេលាសម្រាប់ព្រះយេស៊ូនឹងមកដល់ឆាប់ៗនេះ។
Matthew 24:34
ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងប្រាកដ
"ខ្ញុំប្រាប់អ្នកពីការពិត" ។
បន្ថែមការសង្កត់ន័យទៅលើអ្វីដែលព្រះយេស៊ូមានបន្ទូលបន្ទាប់។
ក្នុងពេលដែលមនុស្សជំនាន់នេះ នៅមានជីវិតនៅឡើយ
នៅទីនេះ“ ការចែកស្ថាន” ជាវិធីគួរសមក្នុងការសំដៅទៅលើសេចក្តីស្លាប់។
"ប្រជាជនដែលរស់នៅសព្វថ្ងៃនឹងមិនស្លាប់ទាំងអស់ទេ"
ហេតុការណ៍ទាំងនោះនឹងកើតឡើង
«ដរាបណាព្រះជាម្ចាស់បណ្តាលឲ្យរឿងទាំងអស់នេះ កើតឡើង»
ផ្ទៃមេឃ និងផែនដីនឹងរលាយបាត់ទៅ
"ផ្ទៃមេឃនិងផែនដីនឹងលែងមានទៀត"
តែពាក្យដែលខ្ញុំនិយាយមិនរលាយបាត់ទេ
«ពាក្យ»ត្រង់នេះសំដៅទៅលើអ្វី ដែលព្រះយេស៊ូបានមានបន្ទូល។
"អ្វីដែលខ្ញុំនិយាយនឹងក្លាយជាការពិត"
Matthew 24:36
ថ្ងៃកំណត់ និងពេលវេលា
ត្រង់នេះគឺ“ ថ្ងៃកំណត់” និង“ ពេលវេលា” សំដៅទៅលើពេលវេលាពិតប្រាកដ
ដែលកូនមនុស្សនឹងត្រឡប់មកវិញ។
ព្រះបុត្រាក៏ពុំជ្រាបដែរ
"សូម្បីតែព្រះបុត្រា"
ព្រះបុត្រា
នេះជាឋានៈដ៏សំខាន់ចំពោះព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់។
ព្រះបិតា
នេះជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
Matthew 24:37
នៅគ្រាបុត្រមនុស្សយាងមក ក៏ដូចកាលនៅសម័យលោកណូអេដែរ
នៅគ្រាដែលបុត្រមនុស្សយាងមក ក៏ដូចនៅជំនាន់លោកណូអេដែរ” ។
បុត្រមនុស្ស
ព្រះយេស៊ូកំពុងតែមានបន្ទូលអំពីអង្គទ្រង់ ជាបុរសទីបី។
ទូកធំ ហើយគេមិនបានចាប់អារម្មណ៍អ្វីសោះ
អាចបកប្រែជាប្រយោគដាច់ដោយឡែក។ "ទូកធំ ហើយប្រជាជនមិនបានដឹងថា
មានអ្វីកំពុងកើតឡើងទេ"
អស់ទៅ ដូចគ្នានេះដែរនៅគ្រាដែលបុត្រមនុស្សយាងមក
អាចបកប្រែជាប្រយោគដាច់ដោយឡែក។ «ទៅឆ្ងាយ។ នេះជារបៀបនៃពេលវេលា
ដែលកូនមនុស្សមក "
Matthew 24:40
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាប់ផ្តើមប្រាប់ពួកសិស្ស
ឲ្យត្រៀមខ្លួនសម្រាប់ការត្រឡប់មកវិញរបស់ទ្រង់។
បើមាន
នេះជាពេលដែលកូនមនុស្សមក។
ព្រះជាម្ចាស់នឹងយកម្នាក់ទៅ ទុកម្នាក់ទៀតឲ្យនៅ
អាចមានន័យថា ១) កូនមនុស្សនឹងយកម្នាក់ទៅស្ថានសួគ៌
ហើយទុកអ្នកផ្សេងនៅលើផែនដីទទួលទណ្ឌកម្មឬ ២)
ពួកទេវតានឹងយកម្នាក់ឲ្យទទួលទណ្ឌកម្ម ហើយទុកព្រះពរឲ្យអ្នកផ្សេងទៀត។
កិនស្រូវ
ឧបករណ៍សម្រាប់កិនស្រូវ
ដូច្នេះ
«ដោយសារតែអ្វីដែលខ្ញុំបានប្រាប់អ្នក»
ចូរប្រុងស្មារតីឲ្យមែនទែន
«ប្រុងប្រយ័ត្ន»
Matthew 24:43
បើម្ចាស់ផ្ទះ...ចូលមកប្លន់
ព្រះយេស៊ូប្រើរឿងប្រស្នាអំពីម្ចាស់ផ្ទះ និងអ្នកបម្រើដើម្បីបង្ហាញថា
សិស្សរបស់ទ្រង់គួរតែត្រៀមខ្លួនសម្រាប់ការត្រឡប់មកវិញរបស់ទ្រង់។
ចោរ
ព្រះយេស៊ូកំពុងតែមានបន្ទូលថា
ព្រះអង្គនឹងមកនៅពេលដែលមនុស្សមិននឹកស្មានដល់
ព្រះអង្គមិនមែនថាព្រះអង្គនឹងមកលួចនោះទេ។
គាត់មុខជាប្រុងស្មារតីពុំខាន
"គាត់នឹងបានយាមផ្ទះរបស់គាត់"
មិនបណ្តោយឲ្យចោរចូលមកប្លន់ផ្ទះគាត់បានឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"ហើយគាត់នឹងមិនអនុញ្ញាតឲ្យនរណាម្នាក់ចូលក្នុងផ្ទះរបស់គាត់
ហើយលួចរបស់របរផ្សេងៗទេ"
បុត្រមនុស្ស
ព្រះយេស៊ូកំពុងតែមានបន្ទូលអំពីអង្គទ្រង់ ជាបុរសទីបី។
Matthew 24:45

generated on Wed Sep 10 16:16:32 2025

ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តសុភាសិតរបស់ម្ចាស់ និងអ្នកបម្រើ ដើម្បីបង្ហាញថា
សិស្សរបស់ទ្រង់គួរតែត្រៀមខ្លួនសម្រាប់ការវិលត្រឡប់របស់ព្រះអង្គ។
បើអ្នកបម្រើណាមានចិត្តស្មោះត្រង់ ហើយឈ្លាសវៃ ម្ចាស់មុខជាផ្ទុកផ្តាក់ឲ្យអ្នកបម្រើនោះមើលខុសត្រូវលើអ្នកបំរើឯទៀតៗ ក្នុងការចែកម្ហូបអាហារឲ្យគេ តាមពេលដែលកំណត់ជាពុំខាន?
ព្រះយេស៊ូប្រើសំណួរនេះ ដើម្បីធ្វើឲ្យពួកសិស្សគិត។ "ដូច្នេះ
តើអ្នកណាជាអ្នកបម្រើស្មោះត្រង់ និងឈ្លាសវៃ? ព្រះអង្គជាអ្នកដែលម្ចាស់ផ្ទះ ... ពេលវេលា" ឬ "ធ្វើដូចអ្នកបម្រើស្មោះត្រង់ និងឈ្លាសវៃ ដែលម្ចាស់របស់គាត់ ... ពេលវេលា"
ចែកម្ហូបអាហារឲ្យគេ
"ផ្តល់អាហារឲ្យប្រជាជននៅក្នុងផ្ទះរបស់ម្ចាស់"
ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងប្រាកដ
"ខ្ញុំប្រាប់អ្នកពីការពិត"។ បន្ថែមការសង្កត់ន័យទៅលើអ្វី
ដែលព្រះយេស៊ូមានបន្ទូលបន្ទាប់។
Matthew 24:48
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានបញ្ចប់សុភាសិតរបស់ម្ចាស់ និងអ្នកបម្រើដើម្បីបង្ហាញថា
សិស្សរបស់ព្រះអង្គគួរតែត្រៀមខ្លួនសម្រាប់ការវិលត្រឡប់របស់ទ្រង់។
គិតក្នុងចិត្ត
ត្រង់នេះ“ ចិត្ត” សំដៅទៅលើចិត្ត។ "គិតនៅក្នុងគំនិតរបស់គាត់"
ម្ចាស់អញ្ជើញមកដល់ណាស់
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ម្ចាស់របស់ខ្ញុំយឺតនឹងវិលត្រឡប់មកវិញ" ឬ "ម្ចាស់របស់ខ្ញុំនឹងមិនវិលត្រឡប់មកវិញ ក្នុងរយៈពេលយូរ"
នៅថ្ងៃដែលអ្នកបម្រើនោះមិននឹកគិត ឬនៅពេលដែលគាត់មិនដឹងនោះ
សេចក្តីថ្លែងទាំងពីរនេះមានន័យដូចគ្នា។ ពួកគេសង្កត់ធ្ងន់ថា
ម្ចាស់នឹងមកពេលអ្នកបម្រើមិនរំពឹងចង់បានគាត់។
ឲ្យគាត់ទទួលទោស
"ចាត់ទុកគាត់"
ធ្វើទោសគាត់ជាទម្ងន់
នេះជាសម្មតិកម្មដែលមានន័យថា ធ្វើឲ្យមនុស្សរងគ្រោះយ៉ាងធ្ងន់ធ្ងរ។
កន្លែងយំសោកខឹងសង្កៀតធ្មេញ
តំណាងឲ្យភាពទុក្ខព្រួយ និងទុក្ខវេទនាយ៉ាងខ្លាំង។
សូមមើលការបកប្រែនៅក្នុងជំពូក៨ ខ១១ ។

---

25 [1]ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបានទៅនឹងស្ត្រីក្រមុំដប់នាក់ ដែលយកចង្កៀងហើយចេញទៅទទួលស្វាមី។[2]ពួកនាងប្រាំនាក់ជាស្ត្រីឥតគំនិត ហើយប្រាំនាក់ទៀតជាស្ត្រីឈ្លាសវៃ។[3]ស្ត្រីឥតគំនិតយកចង្កៀងទៅ តែមិនយកប្រេងទៅបង្ការជាមួយទេ។[4]រីឯស្ត្រីឈ្លាសវៃវិញ នាងបានយកចង្កៀងទៅ ទាំងមានប្រេងបង្ការផង។
[5]ដោយស្វាមីក្រមកដល់ នាងទាំងដប់នាក់ងោកងុយពេក ក៏ដេកលក់ទាំងអស់គ្នាទៅ។[6]ប៉ុន្តែលុះដល់ពាក់កណ្តាលអធ្រាត្រមានគេស្រែកឡើងថា៖ «មើល៍! ស្វាមីមកដល់ហើយ! ចូរនាំគ្នារត់ទៅទទួលលោក!»។
[7]ស្ត្រីក្រមុំទាំងនោះក៏ក្រោកឡើង ហើយរៀបចំអុជចង្កៀង។[8]ស្ត្រីឥតគំនិតនិយាយទៅកាន់ស្ត្រីឈ្លាសវៃថា សុំចែកប្រេងឲ្យយើងខ្លះផង ព្រោះចង្កៀងយើងចង់រលត់អស់ហើយ។[9]ប៉ុន្តែស្ត្រីឈ្លាសវៃឆ្លើយទៅវិញថា៖ «ទេមិនបានទេ! បើយើងចែកឲ្យពួកនាងក្រែងមិនគ្រាន់សម្រាប់យើងផង និងសម្រាប់ពួកនាងផង។ ចូរនាំគ្នាទៅទិញនៅផ្ទះលក់ប្រេងទៅ»។
[10]នៅពេលដែលស្ត្រីឥតគំនិតទាំងប្រាំចេញទៅរកទិញប្រេង ស្រាប់តែស្វាមីមកដល់ ឯស្ត្រីប្រាំនាក់ដែលត្រៀមខ្លួនជាស្រេច នាំគ្នាចូលទៅក្នុងរោងការជាមួយលោក ហើយគេបិទទ្វារជិត។[11]ក្រោយមក ស្ត្រីប្រាំនាក់ទៀតមកដល់ស្រែកហៅថា៖ «លោកម្ចាស់! លោកម្ចាស់! សូមបើកទ្វារឲ្យយើងខ្ញុំចូលផង»។[12]ស្វាមីឆ្លើយទៅវិញថា៖ «ខ្ញុំសុំប្រាប់ឲ្យនាងទាំងអស់គ្នាដឹងច្បាស់ថា ខ្ញុំមិនស្គាល់ពួកនាងទេ!»។[13]ចូរអ្នករាល់គ្នាប្រុងស្មារតី ដ្បិតអ្នករាល់គ្នាពុំដឹងថា ថ្ងៃណា ឬពេលណាដែលបុត្រមនុស្សមកនោះឡើយ។
[14]ប្រៀបបាននឹងបុរសម្នាក់ ដែលហៀបចេញដំណើរទៅស្រុកឆ្ងាយ គាត់ហៅពួកអ្នកបម្រើមកប្រគល់ទ្រព្យសម្បត្តិឲ្យ។[15]គឺឲ្យប្រាំណែនទៅអ្នកទីមួយ ពីរណែនទៅអ្នកទីពីរ និងមួយណែនទៅអ្នកទីបី តាមសមត្ថភាពរៀងៗខ្លួន រួចគាត់ចេញដំណើរទៅ។[16]អ្នកបម្រើដែលបានទទួលប្រាក់ប្រាំណែន យកប្រាក់ចេញទៅរកស៊ីភ្លាម ហើយចំណេញបានប្រាំណែនទៀត។
[17]ដូច្នោះដែរ អ្នកទីពីរដែលទទួលបានប្រាក់ពីរណែននោះក៏យកទៅរកស៊ី ចំណេញបានពីរណែនទៀត។[18]រីឯអ្នកដែលទទួលប្រាក់មួយណែន បានចេញទៅ ជីកដីកប់ប្រាក់ម្ចាស់របស់ខ្លួនទុក។
និងពីស្រុកយូដា[8]ហើយពីក្រុងយេរូសាឡឹម ស្រុកអេដុម ហើយពួកអ្នកជិតទន្លេយ័រដាន់ ព្រមទាំងតំបន់ជុំវិញក្រុងទីរ៉ូស និងក្រុងស៊ីដូនផងដែរ។
នៅពេលពួកគេបានឮអំពីអ្វីបានធ្វើ ដូច្នេះហើយ មានបណ្តាជនជាច្រើនមករកព្រះអង្គ។
[9]ព្រះអង្គបានប្រាប់ដល់ពួកសិស្សរបស់ព្រះអង្គរៀបចំទូកតូចមួយឲ្យហើយសម្រាប់ព្រះអង្គ ពីព្រោះបណ្តាជនច្រើនពេក ក្រែងពួកគេប្រជ្រៀតគ្នាចោមរោមព្រះអង្គ។[10]ដ្បិត
ព្រះអង្គបានប្រោសមនុស្សជាច្រើនឲ្យជា ដូច្នេះហើយ មានអ្នកជំងឺជាច្រើនខំប្រឹងសម្រុកចូលមកជិត ដើម្បីពាល់ព្រះអង្គ។
[11]ហើយនៅពេលវិញ្ញាណអាក្រក់ឃើញព្រះអង្គ ពួកវាក៏ដួលចុះនៅចំពោះព្រះអង្គ ហើយស្រែកឡើងថា៖ «ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់»។[12]ប៉ុន្តែ ព្រះយេស៊ូបាន
ហាមពួកវាយ៉ាងម៉ឺងម៉ាត់ មិនឲ្យនិយាយប្រាប់គេថាព្រះអង្គជានរណាឡើយ។
[13]ព្រះយេស៊ូបានយាងឡើងទៅលើភ្នំ ហើយព្រះអង្គបានត្រាស់ហៅអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យ ហើយពួកគេក៏បានចូលមករកព្រះអង្គ។[14]ព្រះអង្គ
ជ្រើសរើសដប់ពីរ (ជាអ្នកដែលព្រះអង្គហៅថាសាវ័ក) ដើម្បីឲ្យពួកគេនៅជាមួយព្រះអង្គ និងដើម្បីចាត់គេឲ្យទៅប្រកាសដំណឹងល្អ[15]ទាំងឲ្យពួកគេមានអំណាចដេញអារក្ស
ផងដែរ។[16]បន្ទាប់ពីនោះ ព្រះអង្គបានតែងតាំងអ្នកដប់ពីរនាក់នោះ គឺលោកស៊ីម៉ូនដែលព្រះអង្គដាក់ឈ្មោះថា៖ «ពេត្រុស»
[17]លោកយ៉ាកុបជាកូនរបស់លោកសេបេដេ និងលោកយ៉ូហានជាប្អូនរបស់គាត់ ដែលព្រះយេស៊ូដាក់ឈ្មោះថា «បោនអ៊ើកេ» ប្រែថា «អ្នកដែលមានកូននៃ
ផ្គរលាន់»[18]ហើយលោកអនទ្រេ លោកភីលីព លោកបារថូឡូមេ លោកម៉ាថាយ លោកថូម៉ាស លោកយ៉ាកុបជាកូនរបស់លោកអាល់ផាយ លោកថាដេ លោកស៊ីម៉ូនជាអ្នក
ជាតិនិយម[19]និងលោកយូដាសអ៊ីស្ការីយ៉ុតជាអ្នកក្បត់ព្រះអង្គ។
[20]កាលព្រះយេស៊ូយាងត្រឡប់មកផ្ទះវិញ បណ្តាជនបានមកជួបជុំគ្នាម្តងទៀត ជាហេតុធ្វើឲ្យព្រះអង្គ និងពួកសិស្សមិនអាចហូបនំប៉័ងបាន។[21]ពេលគ្រួសាររបស់ព្រះអង្គ
បានឮដំណឹងនេះ ក៏នាំគ្នាធ្វើដំណើរមក ដើម្បីចាប់ព្រះអង្គយកទៅវិញ ព្រោះពួកគេថា៖ «ព្រះអង្គវង្វេងស្មារតីហើយ»។[22]ពួកអាចារ្យដែលបានមកពីក្រុងយេរូសាឡឹម
និយាយថា៖ «អ្នកនេះមានបេលសេប៊ូលជាស្តេចអារក្សនៅក្នុងខ្លួន ទើបគាត់អាចដេញអារក្សបាន»។

generated on Wed Sep 10 16:16:32 2025

[23]ព្រះយេស៊ូបានហៅពួកគេមកឯព្រះអង្គ ហើយប្រាប់ពួកគេជាការប្រៀបធៀបថា «តើសាតាំងដេញសាតាំងបានដូចម្តេច?[24]ប្រសិនបើ នៅក្នុងនគរណាមួយបែកបាក់ទាស់ទែងគ្នាឯង នគរនោះពុំអាចស្ថិតស្ថេរបានឡើយ។[25]ប្រើសិនបើ នៅក្នុងផ្ទះមានការទាស់ទែងគ្នានោះ ផ្ទះនោះនឹងមិនអាចស្ថិតស្ថេរបានឡើយ។
[26]ប្រសិនបើ សាតាំងវាក្រោកឡើងប្រឆាំងនឹងខ្លួនឯង បែកបាក់ទាស់ទែងនឹងខ្លួនឯង វាមិនអាចនៅស្ថិតស្ថេរឡើយ គឺវាមុខជាដល់ពេលបញ្ចាប់មិនខាន។[27]គ្មាននរណាអាចចូលទៅក្នុងផ្ទះអ្នកខ្លាំងពូកែ ហើយប្លន់យកទ្រព្យសម្បត្តិរបស់គាត់បានឡើយ គឺត្រូវតែចងអ្នកខ្លាំងពូកែនោះជាមុនសិន ទើបអាចប្លន់យកទ្រព្យសម្បត្តិក្នុងផ្ទះគាត់របស់បាន។
[28]ខ្ញុំប្រាប់អ្នកជាប្រាកដថា បាបរបស់កូនមនុស្សទាំងអស់នឹងត្រូវអត់ទោសឲ្យ ព្រមទាំងពាក្យប្រមាថដែលពួកគេនិយាយផង[29]ប៉ុន្តែ
អ្នកណាដែលប្រមាថទាស់នឹងព្រះវិញ្ញាណបរិសុទ្ធនឹងមិនអាចលើកលែងទោសឲ្យឡើយ ដ្បិតជាកំហុសនៃបាបដ៏នូវអស់កល្បជានិច្ច»។[30]ព្រះយេស៊ូមានបន្ទូលបែបនេះ ដោយព្រោះពួកអាចារ្យបាននិយាយថា៖ «នៅក្នុងព្រះអង្គមានវិញ្ញាណអាក្រក់នៅក្នុងខ្លួន»។
[31]បន្ទាប់មក មាតា និងប្អូនៗប្រុសរបស់ព្រះអង្គ បានមកហើយឈរនៅខាងក្រៅផ្ទះ។ ហើយបានចាត់គេឲ្យចូលមកហៅព្រះអង្គ។[32]បណ្តាជនដែលអង្គុយជុំវិញព្រះអង្គ ពួកគេទូលព្រះអង្គថា៖ «មាតាហើយ និងប្អូនៗប្រុសរបស់ព្រះអង្គមករកព្រះអង្គ ពួកគេនៅខាងក្រៅផ្ទះឯណោះ»។
[33]ព្រះអង្គបានឆ្លើយទៅពួកគេថា៖ «តើនរណាទៅជាបងប្អូនរបស់ខ្ញុំពិត?»[34]ព្រះអង្គទតមើលអស់អ្នកដែលអង្គុយនៅជុំវិញហើយមានបន្ទូលថា៖ «ឃើញទេ
អ្នកទាំងអស់គ្នាហើយ គឺជាមាតា និងប្អូនៗប្រុសរបស់ខ្ញុំ![35]ដ្បិត អ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ អ្នកនោះហើយជាបងប្អូនប្រុសស្រី និងមាតារបស់ខ្ញុំ»។

Mark 3:1

ឃ្លាភ្ជាប់៖

ព្រះយេស៊ូប្រោសបុរសម្នាក់ឲ្យបានជា នៅថ្ងៃសប្ប័ទនៅក្នុងសាលាប្រជុំ
ហើយបង្ហាញពីអារម្មណ៍របស់គាត់ចំពោះអ្វីដែលពួកផារីស៊ីបានធ្វើទាក់ទងនឹងវិន័យថ្ងៃសប្ប័ទ។

ពួកផារីស៊ី និងស្តេចហេរ៉ូឌចាប់ផ្តើមរៀបចំផែនការធ្វើគុតព្រះយេស៊ូ។

មានអ្នកខ្លះ

«ពួកផារីស៊ីខ្លះ» ។ ក្រោយមកទៀតនៅក្នុងជំពូក៣ ខ៥
ប្រជាជនទាំងនេះត្រូវបានគេស្គាល់ថាជាពួកផារីស៊ី។

បុរសម្នាក់ស្ងិតដៃម្ខាង

«បុរសម្នាក់ពិការដៃ»

អ្នកខ្លះខំសម្លឹងមើលព្រះអង្គយ៉ាងយកចិត្តទុកដាក់ ថាតើព្រះយេស៊ូប្រោសគាត់ឲ្យជា

«ពួកផារីស៊ីបានឃ្លាំមើលព្រះយេស៊ូយ៉ាងយកចិត្តទុកដាក់ដើម្បីដឹងថា
ព្រះអង្គនឹងប្រោសបុរសស្ងិតដៃនោះទេ?»

ចោទប្រកាន់ព្រះអង្គ

ពួកផារីស៊ីចោទប្រកាន់ព្រះយេស៊ូថា បានបំពានច្បាប់ដោយធ្វើការនៅថ្ងៃសប្ប័ទ
តើព្រះអង្គគួរតែប្រោសបុរសនោះឬទេ។ «ចោទប្រកាន់ព្រះអង្គធ្វើខុស» ឬ
«ចោទប្រកាន់ព្រះអង្គបានរំលោភច្បាប់»

Mark 3:3

ឈរនៅទីនេះនៅក្នុងចំណោមមនុស្សគ្រប់គ្នា

«នៅកណ្តាលហ្វូងមនុស្សនេះ»

តើមានច្បាប់ក្នុងការធ្វើការល្អ ឬក៏ជាការអាក្រក់នៅថ្ងៃសាប្ប័ទ? ...ឬឲ្យសម្លាប់?

ព្រះយេស៊ូមានព្រះបន្ទូលដូច្នេះដើម្បីប្រឆាំងនឹងពួកគេ។
ព្រះអង្គចង់ឲ្យពួកគេទទួលស្គាល់ថា ជាការត្រឹមត្រូវប្រោសមនុស្សនៅថ្ងៃសប្ប័ទ។

ធ្វើការល្អ ឬក៏ជាការអាក្រក់...ត្រូវជួយសង្គ្រោះជីវិត ឬឲ្យសម្លាប់

ឃ្លាទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា
លើកលែងឃ្លាទី២សង្កត់ន័យធ្ងន់ជាង។

ត្រូវជួយសង្គ្រោះជីវិត ឬឲ្យសម្លាប់

ចាំបាច់ត្រូវនិយាយម្តងទៀតថា“ ត្រឹមត្រូវហើយ”
ដូចដែលព្រះយេស៊ូកំពុងតែសួរម្តងទៀត តាមរបៀបមួយផ្សេងទៀត។
តើមានសិទ្ធិក្នុងការជួយសង្គ្រោះអាយុជីវិត ឬសម្លាប់មនុស្សបានទេ»

ជីវិត

សំដៅទៅលើជីវិតខាងសាច់ឈាម និងជាពាក្យសម្តីសម្រាប់មនុស្សម្នាក់។
«នរណាម្នាក់ពីការស្លាប់» ឬ «ជីវិតរបស់នរណាម្នាក់»

ប៉ុន្តែអ្នកទាំងនោះបានស្ងៀម

«ប៉ុន្តែពួកគេបានបដិសេធមិនឆ្លើយនឹងព្រះអង្គ»

Mark 3:5

ព្រះយេស៊ូបានទតជុំវិញមើល

«ព្រះយេស៊ូទតមើលជុំវិញ»

ទាំងមានព្រះហឫទ័យពិរោធ

«មានការសោកស្តាយយ៉ាងខ្លាំង»

ពួកគេមានចិត្តរឹងរូស

ការប្រៀបធៀបនេះពិពណ៌នាពីពួកផារីស៊ីគ្មានចិត្តអាណិតបុរសស្ងិតដៃ។
«ពួកគេគ្មានចិត្តមេត្តាចំពោះបុរសនោះ»

ចូរលាតដៃមើល!

«លាតដល់ដៃរបស់អ្នក»

ដៃរបស់គាត់ក៏បានជា

អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ព្រះយេស៊ូបានលើកដៃរបស់គាត់ឡើង» ឬ
«ព្រះយេស៊ូបានធ្វើដៃរបស់គាត់ឲ្យបានជាដូចដើម»

ឃ្លាភ្ជាប់ទាក់ទងនឹងអ្នកមួយបក្សពួកស្តេចហេរ៉ូដភ្លាម

«ចាប់ផ្តើមរៀបចំផែនការ»

បក្សពួកស្តេចហេរ៉ូដ

ជាឈ្មោះរបស់គណបក្សនយោបាយក្រៅផ្លូវការមួយដែលបានគាំទ្រព្រះបាទហេរ៉ូឌអាន់ទីប៉ាស។

ដើម្បីរកមធ្យោបាយធ្វើគុតព្រះយេស៊ូ

របៀបដែលពួកគេអាចធ្វើគុតព្រះយេស៊ូ

Mark 3:7

ឃ្លាភ្ជាប់៖

ព្រះយេស៊ូបានបន្តប្រោសមនុស្សឲ្យជាសះស្បើយ
ពេលមនុស្សជាច្រើនបានទៅតាមព្រះអង្គ ពេលទ្រង់ចង់ចេញទៅ។

សមុទ្រ

សំដៅទៅលើសមុទ្រកាលីឡេ។

ស្រុកអេដុម

ជាតំបន់មួយដែលពីមុនគេស្គាល់ថា
អេដុមដែលគ្របដណ្តប់ភាគខាងត្បូងនៃខេត្តយូដា។

អ្វីបានធ្វើ

សំដៅទៅលើការអស្ចារ្យដែលព្រះយេស៊ូបានធ្វើ។

«ការអស្ចារ្យដែលព្រះយេស៊ូបានធ្វើ»

មករកព្រះអង្គ

«មកកន្លែងដែលព្រះយេស៊ូគង់នៅ»

Mark 3:9

ព្រះអង្គបានប្រាប់ដល់ពួកសិស្សរបស់ព្រះអង្គរៀបចំទូកតូចមួយ...ប្រជ្រៀតគ្នាចោមរោមព្រះអង្គ

ពេលហ្វូងមនុស្សកំពុងតែរុញច្រានគ្នាទៅរកព្រះយេស៊ូ
ព្រះអង្គស្ថិតនៅក្នុងគ្រោះថ្នាក់។ នៅក្នុងខ ៩-១០បញ្ជាក់ព័ត៌មានឲ្យច្បាស់ជាងនេះ។

ព្រះអង្គបានប្រាប់ដល់ពួកសិស្សរបស់ព្រះអង្គ

«ព្រះយេស៊ូមានបន្ទូលប្រាប់ពួកសិស្សរបស់ព្រះអង្គ»

ដ្បិត ព្រះអង្គបានប្រោសមនុស្សជាច្រើនឲ្យជា ដូច្នេះហើយ
ពាក្យថា «មនុស្សជាច្រើន» សំដៅទៅលើមនុស្សមួយចំនួនធំ
ដែលព្រះយេស៊ូបានប្រោសឲ្យជា។

«ដោយសារព្រះយេស៊ូបានប្រោសមនុស្សជាច្រើនឲ្យបានជា»

មានអ្នកជំងឺជាច្រើនខំប្រឹងសម្រុកចូលមកជិត ដើម្បីពាល់ព្រះអង្គ

«មនុស្សឈឺទាំងអស់បានរុញទៅមុខយ៉ាងខ្លាំងដោយព្យាយាមពាល់ព្រះអង្គ»

Mark 3:11

ឃើញព្រះអង្គ

បានឃើញព្រះយេស៊ូ

ពួកវាក៏ដួលចុះ...ស្រែកឡើងថា

ពាក្យ «ពួកវា» នៅទីនេះសំដៅទៅលើវិញ្ញាណអាក្រក់។
ពួកវាជាអ្នកដែលធ្វើឲ្យមនុស្សដែលវាកំពុងចូល។ អាចពន្យល់ឲ្យច្បាស់។
«ពួកវាបានធ្វើឲ្យមនុស្ស ដែលពួកគេមានកំពុងចូល
ត្រូវក្រាបនៅមុខព្រះអង្គហើយស្រែករកព្រះអង្គ»

ពួកវាក៏ដួលចុះនៅចំពោះព្រះអង្គ

generated on Wed Sep 10 16:16:32 2025

ពួកវិញ្ញាណអាក្រក់មិនបានក្រាបនៅចំពោះព្រះយេស៊ូទេ ដោយព្រោះវាស្រឡាញ់
ឬចង់ថ្វាយបង្គំព្រះអង្គទេ។ ពួកគេបានក្រាបនៅពីមុខព្រះអង្គ
ព្រោះពួកវាខ្លាចព្រះអង្គ។
ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់
ព្រះយេស៊ូមានអំណាចលើវិញ្ញាណអាក្រក់
ពីព្រោះព្រះអង្គជា«ព្រះរាជបុត្រារបស់ព្រះជាម្ចាស់»។
ព្រះបុត្រារបស់ព្រះជាម្ចាស់
ជាងារសំខាន់មួយសម្រាប់ព្រះយេស៊ូ។
ព្រះយេស៊ូបានហាមពួកវាយ៉ាងម៉ឺងម៉ាត់
«ព្រះយេស៊ូបានបញ្ជាយ៉ាងតឹងរឹងចំពោះវិញ្ញាណអាក្រក់»
មិនឲ្យនិយាយប្រាប់គេថាព្រះអង្គជានរណាឡើយ
«មិនឱ្យបង្ហាញថាព្រះអង្គជានរណា»
Mark 3:13
ព័ត៌មានទូទៅ៖
ព្រះយេស៊ូជ្រើសរើសបុរស ដែលព្រះអង្គហៅមកធ្វើជាសាវ័ក។
ដើម្បីឲ្យពួកគេនៅជាមួយព្រះអង្គ និងដើម្បីចាត់គេឲ្យទៅប្រកាសដំណឹងល្អ
«ដូច្នេះពួកគេនឹងនៅជាមួយព្រះអង្គ ហើយព្រះអង្គនឹងចាត់គេឲ្យប្រកាសរាជសារ»
លោកស៊ីម៉ូនដែលព្រះអង្គដាក់ឈ្មោះថា៖ «ពេត្រុស»
អ្នកនិពន្ធចាប់ផ្តើមចុះបញ្ជីឈ្មោះសាវ័កទាំង១២នាក់។
ស៊ីម៉ូនជាបុរសទីមួយដែលបានចុះបញ្ជី។
Mark 3:17
ដែលព្រះយេស៊ូដាក់ឈ្មោះ
ឃ្លាថា«ដែលព្រះយេស៊ូដាក់ឈ្មោះ»សំដៅទៅលើទាំងលោកយ៉ាកុបជាកូនរបស់សេបេដេ
និងបងប្រុសរបស់គាត់ឈ្មោះយ៉ូហាន។
ឈ្មោះថា «បោនអ៊ើកេ» ប្រែថា «អ្នកដែលមានកូននៃផ្គរលាន់»
«ឈ្មោះ បោនអ៊ើកេ ដែលមានន័យថាកូនប្រុសផ្គរលាន់» ។ អត្ថន័យនៃឈ្មោះ
«បោនអ៊ើកេ» អាចនឹងពន្យល់កាន់តែច្បាស់។ «ឈ្មោះថ្មី 'បុរសដែលដូចផ្គរលាន់»
លោកថាដេ
ជាឈ្មោះបុរសម្នាក់។
ជាអ្នកក្បត់ព្រះអង្គ
«អ្នកណានឹងក្បត់ព្រះយេស៊ូ» ពាក្យ «ដែល» សំដៅទៅលើយូដាសអ៊ីស្ការីយ៉ុត។
Mark 3:20
កាលព្រះយេស៊ូយាងត្រឡប់មកផ្ទះវិញ
«បន្ទាប់មកព្រះយេស៊ូយាងទៅផ្ទះដែលព្រះអង្គស្នាក់នៅ។»
ពួកសិស្សមិនអាចហូបនំប៉័ងបាន
ពាក្យថា នំប៉័ងតំណាងឲ្យអាហារ។ «ព្រះយេស៊ូ
និងពួកសិស្សរបស់ព្រះអង្គមិនអាចបរិភោគអ្វីទាំងអស់» ឬ
«ពួកគេមិនអាចបរិភោគអ្វីបានទេ»
នាំគ្នាធ្វើដំណើរមក ដើម្បីចាប់ព្រះអង្គយកទៅវិញ
សមាជិកគ្រួសាររបស់ព្រះយេស៊ូបានទៅផ្ទះ ដើម្បីចាប់ព្រះអង្គ
និងបង្ខំព្រះអង្គឲ្យទៅផ្ទះជាមួយពួកគេវិញ។
ព្រោះពួកគេថា
ពាក្យថា «ពួកគេ» អាចមានន័យថា ១) សាច់ញាតិរបស់គាត់ឬ ២)
មនុស្សមួយចំនួននៅក្នុងហ្វូងមនុស្ស។
វង្វេងស្មារតីហើយ
ក្រុមគ្រួសាររបស់ព្រះយេស៊ូប្រើក្រៀមភាសានេះ
ដើម្បីពិពណ៌នាអំពីរបៀបដែលព្រះអង្គកំពុងធ្វើការ។ «ឆ្កួត» ឬ «ហួសនិយាយ»
ស្តេចអារក្សនៅក្នុងខ្លួន ទើបគាត់អាចដេញអារក្សបាន
«ដោយអំណាចរបស់បេលសេប៊ូលដែលជាអ្នកគ្រប់គ្រងអារក្ស
ព្រះយេស៊ូបានដេញអារក្សចេញ»
Mark 3:23
ឃ្លាភ្ជាប់៖
ព្រះយេស៊ូពន្យល់ដោយប្រើរឿងប្រស្នា ហេតុអ្វីបានជាសាតាំងមិនអាចគ្រប់គ្រង
អស់អ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដូចជាបងប្អូនប្រុសស្រី
និងម្តាយរបស់ព្រះអង្គដែរ។
ព្រះយេស៊ូបានហៅពួកគេមកឯព្រះអង្គ
«ព្រះយេស៊ូបានហៅមនុស្សឲ្យមករកព្រះអង្គ»
តើសាតាំងដេញសាតាំងបានដូចម្តេច?
ព្រះយេស៊ូបានសួរសំណួរនេះដើម្បីឆ្លើយតបនឹងពួកអាចារ្យ
ដែលចោទថាទ្រង់ដេញអារក្សដោយបេលសេប៊ូល។
សំណួរនេះអាចត្រូវបានសរសេរជាឃ្លាថា
«សាតាំងមិនអាចបណ្តេញខ្លួនវាចេញទេ!» ឬ
«សាតាំងមិនប្រឆាំងនឹងវិញ្ញាណអាក្រក់របស់វាទេ!»
ប្រសិនបើ នៅក្នុងនគរណាមួយបែកបាក់ទាស់ទែងគ្នាឯង
ពាក្យថា «នគរ» គឺជាពាក្យសំដីសម្រាប់ប្រជាជនដែលរស់នៅក្នុងនគរ។
«ប្រសិនបើប្រជាជនដែលរស់នៅក្នុងនគរមួយត្រូវបែកបាក់គ្នា»
ពុំអាចស្ថិតស្ថេរបានឡើយ
ឃ្លានេះជាពាក្យប្រៀបធៀបមួយមានន័យថា ប្រជាជននឹងលែងរួបរួមគ្នាទៀត
ហើយពួកគេនឹងដួល។ «មិនអាចទ្រាំទ្របាន» ឬ «នឹងដួលរលំ»
ផ្ទះ
នេះជាឈ្មោះហៅក្រៅសម្រាប់ប្រជាជន ដែលរស់នៅក្នុងផ្ទះ។ «គ្រួសារ» ឬ
«គ្រួសារទាំងមូល»
Mark 3:26
ប្រសិនបើ សាតាំងវាក្រោកឡើងប្រឆាំងនឹងខ្លួនឯង បែកបាក់ទាស់ទែងនឹងខ្លួនឯង
ពាក្យថា «ខ្លួនឯង» គឺជាសព្វនាមឆ្លុះបញ្ចាំងសំដៅទៅលើសាតាំង
ហើយវាក៏ជាពាក្យប្រៀបធៀបសម្រាប់វិញ្ញាណអាក្រក់ដែរ។ «ប្រសិនបើសាតាំង
និងវិញ្ញាណអាក្រក់របស់វាបានងើបឡើងទាស់នឹងគ្នាហើយបែកបាក់គ្នា»
មិនអាចនៅស្ថិតស្ថេរឡើយ
ជាពាក្យប្រៀបធៀបដែលមានន័យថា វានឹងដួលហើយមិនអាចទ្រាំទ្របាន។
«នឹងឈប់រួបរួមគ្នា» ឬ «មិនអាចទ្រាំទ្របានហើយបានដល់ទីបញ្ចប់» ឬ
«នឹងដួលរលំហើយបានដល់ទីបញ្ចប់»
ប្លន់យកទ្រព្យសម្បត្តិ
ដើម្បីលួចទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិរបស់មនុស្ស។
Mark 3:28
ខ្ញុំប្រាប់អ្នកជាប្រាកដថា
បញ្ជាក់ថា ឃ្លាបន្តបន្ទាប់ពិតជាពិសេសនិងសំខាន់។
កូនមនុស្សទាំងអស់
"អ្នកដែលកើតពីមនុស្ស" ឃ្លានេះប្រើដើម្បីបញ្ជាក់ពីភាពជាមនុស្សរបស់ប្រជាជន។
"ប្រជាជន"
និយាយ
និយាយចេញជាសម្តី
ពួកអាចារ្យបាននិយាយ
ប្រជាជនកំពុងនិយាយ
មានវិញ្ញាណអាក្រក់
ជាលេខសម្គាល់ដែលមានន័យថា ត្រូវបានកាន់កាប់ដោយវិញ្ញាណអាក្រក់។
«ត្រូវបានកាន់កាប់ដោយវិញ្ញាណអាក្រក់»
Mark 3:31
បួនៗប្រុស
សំដៅទៅលើបងប្អូនរបស់ព្រះយេស៊ូ។
បានចាត់គេឲ្យចូលមកហៅព្រះអង្គ
«ពួកគេបានបញ្ជូននរណាម្នាក់នៅខាងក្នុង ដើម្បីប្រាប់គាត់ថា ពួកគេនៅខាងក្រៅ
ហើយឱ្យព្រះអង្គចេញមករកពួកគេ»
មករកព្រះអង្គ
«កំពុងសួររកអ្នក»
Mark 3:33
អ្នកនោះហើយជាបងប្អូនប្រុសស្រី និងមាតារបស់ខ្ញុំ
«មនុស្សទាំងនោះ ជាបងប្អូនប្រុសស្រី និងម្តាយរបស់ខ្ញុំ»

---

4 [1]ម្តងទៀត ព្រះយេស៊ូចាប់ផ្តើមបង្រៀននៅក្បែរសមុទ្រ ហើយបណ្តាជនយ៉ាងច្រើនកុះករនៅជុំវិញព្រះអង្គ។ ព្រះអង្គឈានទៅក្នុងទូកដែលនៅលើទឹកសមុទ្រ
ហើយព្រះអង្គក៏គង់ចុះនៅលើទូកនោះ។ បណ្តាជនទាំងអស់ក៏ឈរនៅលើឆ្នេរសមុទ្រ។[2]ព្រះយេស៊ូបានបង្រៀនដល់ពួកគេដោយពាក្យប្រៀបធៀបជាច្រើន
នៅក្នុងសេចក្តីបង្រៀនរបស់ព្រះអង្គ នេះគឺជាអ្វីដែលព្រះបានមានបន្ទូលដល់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[3]«ចូរស្តាប់ មានកសិករម្នាក់ចេញទៅព្រោះគ្រាប់ពូជរបស់គាត់។[4]នៅពេលគាត់បានព្រោះគ្រាប់ពូជនោះ មានគ្រាប់ពូជខ្លះធ្លាក់ទៅលើផ្លូវ
ហើយសត្វស្លាបមកចឹកស៊ីអស់ទៅ។[5]ហើយមានគ្រាប់ពូជខ្លះទៀតបានធ្លាក់ទៅលើថ្ម ជាកន្លែងដែលមិនសូវមានដី។ គ្រាប់ពូជទាំងនោះក៏ដុះឡើងភ្លាម
ដោយព្រោះតែគ្រាប់ពូជទាំងនោះមិនដីច្រើនទេ។
[6]ប៉ុន្តែ នៅពេលពន្លឺថ្ងៃរះឡើង គ្រាប់ពូជនោះក៏ក្រៀមស្វិតអស់ ដោយព្រោះវាគ្មានឫសជ្រៅនៅក្នុងដី។[7]និងគ្រាប់ពូជខ្លះទៀតធ្លាក់នៅក្នុងបន្លា។
ពេលបន្លាដុះឡើងខ្ទប់គ្រាប់ពូជទាំងនោះ ដែលធ្វើឲ្យគ្រាប់ពូជនោះមិនអាចបង្កើតផលបានឡើយ។
[8]មានគ្រាប់ពូជខ្លះទៀតបានធ្លាក់ទៅក្នុងដីល្អ ហើយវាក៏បង្កើតផលផ្លែដែលធំឡើង និងរីកចម្រើន គ្រាប់ពូជខ្លះបង្កើតបានពីមួយទៅជាសាមសិប
ខ្លះទៀតពីមួយទៅជាហុកសិប ហើយនិងខ្លះទៀតពីមួយទៅជាមួយរយ»។[9]បន្ទាប់មក ព្រះអង្គមានបន្ទូលថា៖ «អស់អ្នកណាដែលមានត្រចៀកស្តាប់ ចូលស្តាប់ចុះ!»
[10]នៅពេលព្រះយេស៊ូនៅតែម្នាក់ឯង ពួកអ្នកដែលជិតដិតជាមួយព្រះអង្គ ហើយនិងពួកសាវកបានទូលសួរព្រះអង្គអំពីរឿងប្រៀបធៀបទាំងនោះ។
[11]ព្រះអង្គបានមានបន្ទូលទៅពួកគេថា៖ «ព្រះអង្គប្រទានដល់អ្នករាល់គ្នាដឹងពីសេចក្តីលាក់កំបាំងនៃព្រះរាជ្យរបស់ព្រះអង្គ។ ប៉ុន្តែសម្រាប់អស់អ្នកដែលនៅខាងក្រៅវិញ
ព្រះអង្គនឹងមានបន្ទូលជាពាក្យប្រៀបធៀបវិញ[12]ទោះបីពួកគេមើល ពិតណាស់គឺមើល ប៉ុន្តែមើលមិនអាចឃើញទេ ហើយនៅពេលពួកគេស្តាប់ ពិតណាត់ពួកគេស្តាប់
ប៉ុន្តែពួកគេស្តាប់មិនអាចយល់ទេ ប៉ុន្តែ ប្រិសិនបើ ពួកគេប្រែចិត្តវិញ ព្រះជាម្ចាស់នឹងអត់ទោសឲ្យពួកគេ»។
[13]បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅពួកគេថា៖ «តើអ្នករាល់គ្នាមិនយល់ពាក្យប្រៀបធៀបនេះមែនទេ? បើដូច្នោះមែន ធ្វើម្តេចឲ្យអ្នករាល់គ្នាយល់ពីពាក្យប្រៀបធៀបឯ
ទៀតៗបាន?[14]កសិករដែលព្រោះគ្រាប់ពូជរបស់គាត់គឺជាអ្នកដែលព្រោះព្រះបន្ទូលដែរ។[15]មនុស្សខ្លះបៀបដូចជាផ្លូវ ដែលមានព្រះបន្ទូលបានព្រោះធ្លាក់ទៅលើផ្លូវ ប៉ុន្តែ
នៅពេលគាត់បានឮព្រះបន្ទូលហើយ សាតាំងក៏មកហើយឆក់យកព្រះបន្ទូលដែលបានព្រោះលើពួកគេទៅបាត់ភ្លាម។
[16]មនុស្សដែលបានទទួលគ្រាប់ពូជនៅលើដីមានថ្មក៏ដូច្នោះដែរ កាលបានឮព្រះបន្ទូលហើយ គេទទួលយកភ្លាមដោយអំណរ។[17]ប៉ុន្តែ គេពុំទុកឲ្យព្រះបន្ទូលឲ្យចាក់ឫសនៅ
ក្នុងខ្លួនគេទេ គឺគេជាប់នឹងគេតែមួយភ្លែតប៉ុណ្ណោះ។ នៅពេលមានទុក្ខវេទនា ឬការបៀតបៀនមកដល់ ដោយព្រោះតែព្រះបន្ទូល ពួកគេរវាតចិត្តភ្លាម។
[18]មនុស្សផ្សេងទៀត បានទទួលគ្រាប់ពូជនៅលើដីដែលមានបន្លា។ គេបានឮព្រះបន្ទូលដែរ[19]ប៉ុន្តែ ការខ្វល់ខ្វាយអំពីលោកីយ៍ ចិត្តមិនស្មោះត្រង់ហើយចង់បានទ្រព្យសម្បត្តិ
និងចិត្តប៉ងប្រាថ្នាលើអ្វីផ្សេងរឹបរួតព្រះបន្ទូលមិនឲ្យបង្កើតផលបាន។[20]រីឯអ្នកដែលបានទទួលគ្រាប់ពូជនៅលើដីដែលមានជីជាតិល្អ កាលបានឮព្រះបន្ទូលហើយ ក៏ទទួល
យក និងបង្កើតផលផ្លែ មួយជាសាមសិប មួយជាហុកសិប អ្នកខ្លះទៀតបានមួយជាមួយរយ»។
[21]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «តើអ្នកយកចង្កៀងនៅក្នុងផ្ទះហើយដាក់នៅក្រោមធុងមែនទេ? ឬយកទៅដាក់នៅក្រោមគ្រែមែនទេ? ប៉ុន្តែ
អ្នកនឹងយកវាទៅក្នុងផ្ទះហើយដាក់វានៅលើជើងចង្កៀងវិញ។[22]ដ្បិត គ្មានអ្វីបិតបាំង ដែលមិនអាចបើកឲ្យដឹងបាននោះទេ
ហើយក៏គ្មានអ្វីជាការសម្ងាត់ដែលមិនអាចបើកចំហបាននោះដែរ។[23]ប្រសិនបើ អ្នកណាមានត្រចៀកស្តាប់ សូមឲ្យអ្នកនោះស្តាប់ចុះ!»។
[24]ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «ចូរអ្នករាល់គ្នាប្រុងប្រយ័ត្នជាមួយនឹងសេចក្តី ដែលអ្នករាល់គ្នាបានឮនេះឲ្យមែនទែន ព្រះអង្គនឹងវាល់ឲ្យអ្នករាល់គ្នាតាមរង្វាល់ ដែលអ្នក
រាល់គ្នាវាល់ឲ្យអ្នកដទៃ ហើយព្រះអង្គនឹងបន្ថែមឲ្យអ្នករាល់គ្នាផង[25]ព្រោះអ្នកណាមានហើយ ព្រះជាម្ចាស់នឹងប្រទានឲ្យថែមទៀត តែអ្នកណាដែលគ្មាន ព្រះអង្គនឹងហូតយក
អ្វីៗដែលអ្នកនោះមានដែរ»។
[26]ហើយព្រះអង្គក៏បានមានបន្ទូលទៀតថា៖ «ព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺដូចបុរសម្នាក់ដែលព្រោះគ្រាប់ពូជទៅលើដី។[27]ហើយអ្នកនោះដេកនៅពេលយប់
និងក្រោកនៅពេលថ្ងៃក្តី គ្រាប់ពូជនៅតែមានពន្លកដុះឡើង ដោយគាត់ក៏មិនងងឹងថា គ្រាប់ពូជនោះដុះរបៀបណាដែរ។[28]ដ្បិត ដីធ្វើឲ្យពូជបង្កើតផលដោយខ្លួនឯង ដំបូង
មានពន្លកលេចឡើង បន្ទាប់មកក៏បែកជាកួរ ហើយចេញជាផ្លែ។[29]លុះផ្លែនោះទុំ ភ្លាមៗគេក៏យកកណ្តៀវមកច្រូត ដ្បិត ដល់រដូវចម្រូតហើយ»។
[30]ព្រះអង្គមានបន្ទូលម្តងទៀតថា៖ «តើយើងអាចប្រៀបធៀបព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅនឹងអ្វី ឬ តើយើងប្រៀបធៀបទៅនឹងអ្វី ដើម្បីអាចពន្យល់ពីការនេះ?[31]ព្រះរាជ្យ
របស់ព្រះជាម្ចាស់ប្រៀបបីដូចជាគ្រាប់ពូជម្យ៉ាង កាលគេព្រោះលើដី គ្រាប់ពូជនោះល្អិតជាងគេទាំងអស់ក្នុងលោក។[32]តែពេលព្រោះរួចហើយ គ្រាប់ពូជនោះក៏ដុះឡើងធំជាង
ដំណាំឯទៀតៗ ព្រមទាំងបែកមែកសាខា មានម្លប់ឲ្យបក្សាបក្សីមកពីអាកាស ធ្វើសំបុកជ្រកអាស្រ័យ»។
[33]ព្រះយេស៊ូមានព្រះបន្ទូលបៀបធៀបទាំងនេះទៅកាន់ពួកគេ ជាច្រើនគឺងាយឲ្យពួកគេយល់បាន។[34]ហើយព្រះអង្គតែងតែមាន
ព្រះបន្ទូលជាពាក្យប្រៀបធៀបទៅកាន់បណ្តាជន ប៉ុន្តែ ពេលនៅព្រះអង្គនៅដោយឡែកពីបណ្តាជន ព្រះអង្គពន្យល់ការទាំងអស់នោះដល់ពួកសិស្សរបស់ព្រះអង្គផ្ទាល់។
[35]នៅថ្ងៃនោះ ពេលរសៀលចូលមកដល់ ព្រះអង្គមានបន្ទូលទៅពួកគេថា៖ «ចូរយើងឆ្លងទៅត្រើយម្ខាងទៀត»។[36]ដូច្នេះ ពួកសិស្សបានចេញពីបណ្តាជន ហើយទៅជាមួយ
ព្រះយេស៊ូ ព្រះអង្គបានគង់នៅក្នុងទូកនោះជាមួយនឹងពួកគេ។ក៏មានទូកផ្សេងទៀតទៅជាមួយព្រះអង្គដែរ។[37]ស្រាប់តែមានខ្យល់ព្យុះបក់បោកមកយ៉ាងខ្លាំង ហើយរលកក៏
បោកប៉ះនឹងទូក ដូច្នេះហើយ បណ្តាលឲ្យទឹកចូលស្ទើរពេញ។
[38]ប៉ុន្តែ ព្រះយេស៊ូវិញ ព្រះអង្គផ្ទំលក់លើខ្នើយ នៅកន្សែងទូក។ ពួកសិស្សបានដាស់ព្រះអង្គ ហើយទូលទៅព្រះអង្គថា៖ «លោកគ្រូ យើងស្លាប់ឥឡូវហើយ លោកមិនបារម្ភទេ
ឬ?»។[39]ព្រះយេស៊ូតើនឡើង មានព្រះបន្ទូលបង្គាប់ទៅខ្យល់ព្យុះ និងមានបន្ទូលទៅកាន់សមុទ្រថា៖ «ស្ងប់ស្ងៀមទៅ!» ពេលនោះ ខ្យល់ព្យុះក៏ស្ងប់ ហើយផ្ទៃទឹកក៏រាបស្មើ
ដែរ។
[40]បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅពួកសិស្សថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាភ័យខ្លាចដូច្នេះ? អ្នករាល់គ្នាគ្មានជំនឿទេឬ?»។[41]ពួកគេកោតស្ញប់ស្ញែងជាខ្លាំង ហើយ
និយាយគ្នាទៅវិញទៅមកថា៖ «តើលោកនេះជានរណាបានជាខ្យល់ព្យុះ និងសមុទ្រស្តាប់បង្គាប់គាត់ដូច្នេះ?»។

Mark 4:1

ឃ្លាភ្ជាប់៖

ពេលព្រះយេស៊ូបង្រៀនពីទូកនៅមាត់សមុទ្រ
ព្រះអង្គបានប្រាប់ពួកគេជារឿងប្រស្នាស្តីអំពីដី។

ទឹកសមុទ្រ

ជាសមុទ្រកាលីឡេ។

ហើយព្រះអង្គក៏គង់ចុះ

«ហើយព្រះអង្គអង្គុយនៅលើទូក»

Mark 4:3

ចូរស្តាប់

ចូរយកចិត្តទុកដាក់

មានកសិករម្នាក់ចេញទៅព្រោះគ្រាប់ពូជ

«នៅពេលគាត់បោះគ្រាប់ពូជទៅលើដី» ។ តាមវប្បធម៌នីមួយៗ
មនុស្សសាបព្រោះគ្រាប់ពូជខុសគ្នាដែរ។ ក្នុងរឿងប្រស្នានេះ គេសាបព្រោះគ្រាប់ពូជ
ដោយបោះគ្រាប់ពូជទៅលើដី ដែលត្រូវបានរៀបចំជាស្រេច។

គ្រាប់ពូជទាំងនោះក៏ដុះឡើង

«គ្រាប់ពូជចាប់ផ្តើមដុះឡើងយ៉ាងឆាប់រហ័ស»

ដី

សំដៅទៅលើដីធូរ ដែលអ្នកអាចព្រោះគ្រាប់ពូជបាន។

Mark 4:6

គ្រាប់ពូជនោះក៏ក្រៀមស្វិតអស់

សំដៅទៅលើរុក្ខជាតិទើបនឹងដុះ។ គេអាចបើជាទម្រង់កិរិយាសកម្ម។

«វាបានបំផ្លាញរុក្ខជាតិទើបនឹងដុះ»

ដោយព្រោះវាគ្មានឫសជ្រៅនៅក្នុងដី

«ដោយសារតែរុក្ខជាតិទើបនឹងដុះគ្មានឫស វាឆាប់ងាប់ទៅវិញ»

ខ្ទប់គ្រាប់ពូជទាំងនោះ

ពាក្យថា“ គ្រាប់ពូជ” សំដៅទៅលើរុក្ខជាតិទើបនឹងដុះ។

Mark 4:8

គ្រាប់ពូជខ្លះបង្កើតបានពីមួយទៅជាសាមសិប

បរិមាណគ្រាប់ធញ្ញជាតិដែលទទួលបានពីរុក្ខជាតិនីមួយៗប្រៀបធៀបទៅនឹងគ្រាប់ពូជតែមួយដែលដុះចេញ

«រុក្ខជាតិខ្លះបង្កើតផលច្រើនជាងគ្រាប់ពូជដែលបុរសបានដាំសាមសិបដង»

សាមសិប...ហុកសិប ...មួយរយ

generated on Wed Sep 10 16:16:32 2025

«៣០ ... ៦០ ... ១០០ ។ «អាចសរសេរជាលេខ។
ខ្លះទៀតពីមួយទៅជាហុកសិប ហើយនិងខ្លះទៀតពីមួយទៅជាមួយរយ
ព្រះយេស៊ូបន្តរៀបរាប់អំពីបរិមាណគ្រាប់ធញ្ញជាតិទទួលផល។
ពាក្យនេះត្រូវបានប្រើដើម្បីបង្រួមឃ្លា ប៉ុន្តែគេអាចសរសេរចេញ។
«និងខ្លះផលិតបាន ៦០ ហុកសិបដងដូចគ្រាប់ច្រើនហើយខ្លះទៀតផលិតស្រូវបាន ១០០ ដង»
អស់អ្នកណាដែលមានត្រចៀកស្តាប់ ចូរស្តាប់ចុះ
នេះជាវិធីនិយាយសំដៅដល់មនុស្សគ្រប់គ្នាដែលស្តាប់។ «អ្នកដែលកំពុងស្តាប់ខ្ញុំ»
ចូរស្តាប់ចុះ
ពាក្យថា «ស្តាប់» ត្រង់នេះមានន័យថា ត្រូវយកចិត្តទុកដាក់។ «
ត្រូវយកចិត្តទុកដាក់លើអ្វីដែលខ្ញុំកំពុងនិយាយ»
Mark 4:10
នៅពេលព្រះយេស៊ូនៅតែម្នាក់ឯង
មិនមានន័យថា ព្រះយេស៊ូគង់នៅម្នាក់ឯងទាំងស្រុងនោះទេ។ ផ្ទុយទៅវិញ
ហ្វូងមនុស្សបានទៅបាត់ ហើយព្រះយេស៊ូគង់នៅជាមួយតែសិស្សទាំងដប់ពីរនាក់
និងសិស្សឯទៀតដែលនៅជាមួយព្រះអង្គប៉ុណ្ណោះ។
ព្រះអង្គប្រទាំងដល់អ្នករាល់គ្នា
អាចប្រើជាទម្រង់កិរិយាសកម្ម។ «ព្រះអង្គបានប្រទានដល់អ្នក» ឬ
«ខ្ញុំបានផ្តល់ឲ្យអ្នក»
សម្រាប់អស់អ្នកដែលនៅខាងក្រៅវិញ
«ប៉ុន្តែចំពោះអ្នកដែលមិននៅក្នុងចំណោមអ្នក» ។
សំដៅទៅលើមនុស្សទាំងអស់ផ្សេងទៀត
ដែលមិនស្ថិតនៅក្នុងចំណោមមនុស្សទាំងដប់ពីរនាក់
ឬអ្នកដើរតាមដ៏ជិតស្និទ្ធដទៃទៀតរបស់ព្រះយេស៊ូ។
ព្រះអង្គនឹងមានបន្ទូលជាពាក្យបៀបធៀបវិញ
អាចបញ្ជាក់ថាព្រះយេស៊ូបង្រៀនប្រជាជនដោយប្រើប្រស្នា។
«ខ្ញុំបាននិយាយអ្វីៗគ្រប់យ៉ាងដោយប្រើពាក្យប្រស្នា»
ទោះបីពួកគេមើល ពិតណាស់គឺមើល ...នៅពេលពួកគេស្តាប់
គេស្មានថា ព្រះយេស៊ូកំពុងតែមានបន្ទូលអំពីមនុស្សដែលក្រឡេកមើលអ្វី
ដែលទ្រង់បង្ហាញដល់ពួកគេនិង អំពីអ្វីដែលព្រះអង្គប្រាប់។
«នៅពេលពួកគេក្រឡេកមើលអ្វីដែលខ្ញុំកំពុងធ្វើ ...
នៅពេលពួកគេស្តាប់អ្វីដែលខ្ញុំកំពុងនិយាយ»
ពួកគេមើល ពិតណាស់គឺមើល ប៉ុន្តែមើលមិនអាចឃើញទេ
ព្រះយេស៊ូមានបន្ទូលអំពីមនុស្ស
ដែលយល់ពីអ្វីដែលពួកគេបានឃើញដូចជាបានឃើញជាក់ស្តែង។ «ពួកគេមើល
ហើយមិនយល់»
ប្រែចិត្ត
សំដៅទៅលើការងាកចេញពីអំពើបាប។
Mark 4:13
ឃ្លាភ្ជាប់៖
ព្រះយេស៊ូពន្យល់រឿងប្រស្នាអំពីដីប្រាប់ពួកសិស្ស បន្ទាប់មកប្រាប់ពួកគេអំពីចង្កៀង
ដើម្បីបង្ហាញថាការលាក់កំបាំងដែលគេត្រូវដឹង។
បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅពួកគេ
«ហើយព្រះយេស៊ូមានបន្ទូលទៅពួកសិស្សរបស់ទ្រង់»
តើអ្នករាល់គ្នាមិនយល់ពាក្យប្រៀបធៀបនេះមែនទេ? បើដូច្នោះមែន ធ្វើម្តេចឲ្យអ្នករាល់គ្នាយល់
ពីពាក្យប្រៀបធៀបឯទៀតៗបាន?
ព្រះយេស៊ូបានប្រើសំណួរទាំងនេះដើម្បីបង្ហាញការសោកស្តាយ
ដែលពួកសិស្សមិនអាចយល់ឧទាហរណ៍របស់ទ្រង់។
«ប្រសិនបើអ្នកមិនអាចយល់ពីរឿងប្រៀបប្រដូចនេះបានទេ អ្នកត្រូវគិតពីការលំបាក
ដែលអ្នកយល់ពីឧទាហរណ៍ផ្សេងទៀតទាំងអស់» ។
កសិករដែលព្រោះគ្រាប់ពូជរបស់គាត់គឺជា
«កសិករដែលសាបព្រោះពូជរបស់គាត់តំណាងឱ្យ»
អ្នកដែលព្រោះព្រះបន្ទូល
ពាក្យថា «តំណាងឲ្យសាររបស់ព្រះជាម្ចាស់» ។
ការសាបព្រោះសារតំណាងឲ្យការបង្រៀន។
«អ្នកដែលបង្រៀនមនុស្សអំពីសាររបស់ព្រះជាម្ចាស់»
មនុស្សខ្លះបៀបដូចជាផ្លូវ ដែលមានព្រះបន្ទូលបានព្រោះធ្លាក់ទៅលើផ្លូវ
«មនុស្សខ្លះដូចជាគ្រាប់ពូជដែលធ្លាក់ក្បែរផ្លូវ» ឬ
«មនុស្សខ្លះដូចជាផ្លូវដែលគ្រាប់ពូជខ្លះធ្លាក់»
ផ្លូវ
ផ្លូវ
នៅពេលគាត់បានឮព្រះបន្ទូលហើយ
ពាក្យ «ព្រះបន្ទូល» ត្រង់នេះសំដៅទៅលើ «ព្រះបន្ទូល» ឬ
«សាររបស់ព្រះជាម្ចាស់» ។
Mark 4:16
មនុស្សដែល
ហើយមនុស្សខ្លះដូចជាគ្រាប់ពូជ” ។
ព្រះយេស៊ូចាប់ផ្តើមពន្យល់ពីរបៀបដែលមនុស្សខ្លះដូចជាគ្រាប់ពូជ
ដែលបានធ្លាក់លើដីមានថ្ម។
ប៉ុន្តែ គេពុំទុកឲ្យព្រះបន្ទូលឲ្យចាក់ឫសនៅក្នុងខ្លួនគេទេ
នេះជាការប្រៀបធៀបទៅនឹងរុក្ខជាតិទើបនឹងដុះ ដែលមានឫសរាក់ណាស់។
ការប្រៀបធៀបនេះមានន័យថាប្រជាជនមានការរំភើបជាលើកដំបូង
ពេលពួកគេបានទទួលព្រះបន្ទូល ប៉ុន្តែពួកគេមិនបានបួរផ្តាច់ខ្លាំងនោះទេ។
«ហើយពួកគេប្រៀបដូចជារុក្ខជាតិទើបនឹងដុះ គ្មានឫសគល់»
ពុំទុកឲ្យព្រះបន្ទូលឲ្យចាក់ឫស
ជាការប្រៀបធៀបដ៏ជ្រាលជ្រៅដែលជាការបំផ្លើសមួយដោយសង្កត់ធ្ងន់ទៅលើរបៀបចាក់ឫសរាក់
ៗ ។
ជាប់នឹង
នៅក្នុងឧទាហរណ៍នេះ «ជាប់នឹង» មានន័យថា «ជឿ» ។ «បន្តជំនឿរបស់ពួកគេ»
ដោយព្រោះតែព្រះបន្ទូល
មានប្រយោជន៍ដើម្បីពន្យល់ពីមូលហេតុដែលមានទុក្ខវេទនា។
វាបានកើតឡើងដោយសារតែមនុស្សជឿពាក្យនេះ។
«ដោយសារពួកគេជឿព្រះបន្ទូល»
ពួកគេរភាតចិត្ត
នៅក្នុងរឿងប្រៀបប្រដូចនេះ «ការជំពប់ដួល» មានន័យថា
«ឈប់ជឿព្រះបន្ទូលរបស់ព្រះជាម្ចាស់»
Mark 4:18
មនុស្សផ្សេងទៀត បានទទួលគ្រាប់ពូជនៅលើដីដែលមានបន្លា
ព្រះយេស៊ូចាប់ផ្តើមពន្យល់ពីរបៀប
ដែលមនុស្សខ្លះប្រៀបដូចជាគ្រាប់ពូជដែលធ្លាក់លើដីមានបន្លា។
«ហើយមនុស្សផ្សេងទៀត ដូចជាគ្រាប់ពូជដែលត្រូវបានគេសាបព្រោះក្នុងគុម្ពបន្លា»
ការខ្វល់ខ្វាយអំពីលោកីយ៍
«ការព្រួយបារម្ភក្នុងជីវិតនេះ» ឬ «ការព្រួយបារម្ភអំពីជីវិតបច្ចុប្បន្ន»
ចិត្តមិនស្មោះត្រង់ហើយចង់បានទ្រព្យសម្បត្តិ
«បំណងប្រាថ្នាចង់បានទ្រព្យសម្បត្តិ»
ចិត្តប៉ងប្រាថ្នាលើអ្វីផ្សេងរឹបរួតព្រះបន្ទូល
នៅពេលព្រះយេស៊ូបន្តនិយាយអំពីមនុស្សដែលប្រៀបដូចជាគ្រាប់ពូជ
ដែលធ្លាក់លើដីមានបន្លា នោះព្រះអង្គពន្យល់អំពីសេចក្តីប៉ងប្រាថ្នា
និងកង្វល់ទាក់ទងនឹងជីវិតរបស់គេ។
«ចូលហើយរឹបរួតនឹងព្រះបន្ទូលនៅក្នុងជីវិតរបស់ពួកគេដូចជាបន្លាដែលដុះនៅលើរុក្ខជាតិទើបដុះ»
មិនឲ្យបង្កើតផលបាន
«ពាក្យនេះមិនបង្កើតផលអ្វីទេ»
អ្នកដែលបានទទួលគ្រាប់ពូជនៅលើដីដែលមានជីជាតិល្អ
ព្រះយេស៊ូចាប់ផ្តើមពន្យល់ពីរបៀប
ដែលមនុស្សខ្លះដូចជាគ្រាប់ពូជដែលត្រូវបានគេសាបព្រោះលើដីល្អ។
«ដូចជាគ្រាប់ពូជដែលត្រូវបានគេសាបព្រោះលើដីល្អ»
មួយជាសាមសិប មួយជាហុកសិប អ្នកខ្លះទៀតបានមួយជាមួយរយ
សំដៅទៅលើគ្រាប់ធញ្ញជាតិដែលរុក្ខជាតិឲ្យផល។
«អ្នកខ្លះឲ្យផលធញ្ញជាតិបានសាមសិប
គ្រាប់ហុកសិបខ្លះនិងធញ្ញជាតិមួយរយទៀត» ឬ «ខ្លះផលិតធុញ្ញជាតិ ៣០ គ្រាប់ខ្លះ
៦០ និងធញ្ញជាតិ ១០០»
Mark 4:21
ព្រះយេស៊ូមានបន្ទូលទៅពួកគេ
«ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកបណ្តាជន»
តើអ្នកយកចង្កៀងនៅក្នុងផ្ទះហើយដាក់នៅក្រោមធុងមែនទេ? ឬយកទៅដាក់នៅក្រោមគ្រែមែនទេ?
សំណួរនេះអាចសរសេរឃ្លា
«អ្នកប្រាកដជាមិនយកចង្កៀងចូលក្នុងផ្ទះដើម្បីដាក់វានៅក្រោមកន្ត្រក
ឬក្រោមគ្រែទេ!»

generated on Wed Sep 10 16:16:32 2025

ដ្បិត គ្មានអ្វីបិតបាំង
ដែលមិនអាចបើកឲ្យដឹងបាននោះទេ...ការសម្ងាត់ដែលមិនអាចបើកចំហបាននោះដែរ
អាចបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ «សម្រាប់អ្វីគ្រប់យ៉ាងដែលត្រូវបានគេលាក់
នឹងត្រូវគេដឹង ហើយអ្វីគ្រប់យ៉ាងដែលជាអាថ៌កំបាំង នឹងលេចចេញមកឲ្យគេដឹង»
គ្មានអ្វីបិតបាំង...គ្មានអ្វីជាការសម្ងាត់
"គ្មានអ្វីដែលត្រូវបានលាក់ ... មិនមានអ្វីដែលជាអាថ៌កំបាំងទេ"
ឃ្លាទាំងពីរមានអត្ថន័យដូចគ្នា។ ព្រះយេស៊ូកំពុងសង្កត់ធ្ងន់ថា
អ្វីៗទាំងអស់ដែលអាថ៌កំបាំងនឹងត្រូវគេដឹង។
ប្រសិនបើ អ្នកណាមានត្រចៀកស្តាប់ សូមឲ្យអ្នកនោះស្តាប់ចុះ
បកប្រែដូចដែលអ្ួកបានបកប្រែនៅក្នុងជំពូក៤ ខ៨ ។
Mark 4:24
ព្រះអង្គមានព្រះបន្ទូលទៀត
«ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកបណ្តាជន»
ព្រះអង្គនឹងវាល់ឲ្យអ្នករាល់គ្នាតាមរង្វាល់ ដែលអ្នករាល់គ្នាវាល់ឲ្យអ្នកដទៃ
អាចមានន័យថា ១) ព្រះយេស៊ូកំពុងតែនិយាយអំពីការវាស់វែងតាមព្យញ្ជនៈ
និងការផ្តល់អំណោយដល់អ្នកដទៃឬ ២)
ជាពាក្យប្រៀបធៀបដែលព្រះយេស៊ូមានបន្ទូលអំពី «ការយល់ដឹង »ដូចជា វាស់
ដែលអ្នករាល់គ្នាវាល់ឲ្យអ្នកដទៃ ហើយព្រះអង្គនឹងបន្ថែមឲ្យអ្នករាល់គ្នាផង
អាចប្រើជាទម្រង់កិរិយាសកម្ម។ «ព្រះជាម្ចាស់នឹងវាល់អ្នក
ហើយព្រះអង្គនឹងបន្ថែមឲ្យអ្នក»
ព្រះជាម្ចាស់នឹងប្រទានឲ្យថែមទៀត...ព្រះអង្គនឹងហូតយកអ្វីៗដែលអ្នកនោះមានដែរ
អាចប្រើជាទម្រង់កិរិយាសកម្ម។ «ទៅគាត់ព្រះជាម្ចាស់នឹងប្រទានច្រើនជាងនេះ ...
ពីគាត់ព្រះជាម្ចាស់នឹងដកហូតយក» ឬ «ព្រះនឹងប្រទានច្រើនជាងនេះទៅគាត់ ...
ព្រះនឹងដកហូតពីគាត់»
Mark 4:26
ឃ្លាភ្ជាប់៖
បន្ទាប់មកព្រះយេស៊ូមានបន្ទូលប្រាប់ប្រជាជន
ដោយប្រើរឿងប្រស្នាដើម្បីពន្យល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលក្រោយមកទ្រង់បានចូលទៅក្នុងស្ថានសួគ៌វិញ។
ដូចបុរសម្នាក់ដែលព្រោះគ្រាប់ពូជទៅលើដី
ព្រះយេស៊ូប្រៀបធៀបព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅនឹងកសិករម្នាក់ដែលសាបព្រោះគ្រាប់ពូជរបស់គាត់
«ដូចជាកសិករម្នាក់ដែលសាបព្រោះគ្រាប់ពូជរបស់គាត់»
ហើយអ្នកនោះដេកនៅពេលយប់ និងក្រោកនៅពេលថ្ងៃក្តី
«គាត់ក្រោកពីព្រលឹមហើយដេកពេលយប់»
ពន្លក
ត្រួយ ឬពន្លក
បែកជាកួរ
ក្បាលនៅលើទង ឬផ្នែកនៃរុក្ខជាតិដែលមានផ្លែ
ភ្លាមៗគេក៏យកកណ្តៀវមកច្រូត
ពាក្យ «កណ្តៀវ» នៅទីនេះជាឈ្មោះហៅក្រៅដែលតំណាងឲ្យកសិករ
ឬប្រជាជនដែលកសិករបញ្ជូនទៅដើម្បីប្រមូលផល។ «
គាត់ចេញទៅភ្លាមដោយប្រើកណ្តៀវដើម្បីច្រូតស្រូវ» ឬ
«គាត់ចាត់មនុស្សដែលមានកណ្តៀវចេញមកច្រូតស្រូវភ្លាម»
កណ្តៀវ
កាំបិតកោង ឬទំពក់មុតប្រើសម្រាប់កាត់គ្រាប់ធញ្ញជាតិ
ដ្បិត ដល់រដូវចម្រូតហើយ
ពាក្យ «ដល់»នៅទីនេះ
ជាពាក្យសម្តីសម្រាប់គ្រាប់ធញ្ញជាតិដែលទុំសម្រាប់ការប្រមូលផល។
«ពីព្រោះគ្រាប់បានត្រៀមរួចរាល់ហើយដើម្បីប្រមូលផល»
Mark 4:30
តើយើងអាចប្រៀបធៀបព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅនឹងអ្វី ឬ តើយើងប្រៀបធៀបទៅនឹងអ្វី
ដើម្បីអាចពន្យល់ពីការនេះ?
ព្រះយេស៊ូបានសួរសំណួរនេះដើម្បីធ្វើឲ្យអ្នកស្តាប់ព្រះអង្គគិតអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។
«ជាមួយនឹងរឿងប្រៀបប្រដូចនេះ
ខ្ញុំអាចពន្យល់បានថាតើព្រះរាជ្យព្រះជាម្ចាស់មានលក្ខណៈដូចម្តេច?»
កាលគេព្រោះលើដី
អាចប្រើជាទម្រង់កិរិយាសកម្ម។ «នៅពេលនរណាម្នាក់សាបព្រោះវា» ឬ
«នៅពេលនរណាម្នាក់ដាំវា»
ព្រមទាំងបែកមែកសាខា
ដើមម៉ៃសាក់ត្រូវបានគេពិពណ៌នាថា បានបែកមែកធំ។ «មានមែកសាខាធំ»
Mark 4:33
ព្រះយេស៊ូមានព្រះបន្ទូលបៀបធៀបទាំងនេះទៅកាន់ពួកគេ
ពាក្យថា «ពួកគេ» សំដៅទៅលើហ្វូងមនុស្ស។
ជាច្រើនគឺងាយឲ្យពួកគេយល់បាន
បើពួកគេអាចយល់ខ្លះ ព្រះអង្គនៅតែបន្តប្រាប់ពួកគេបន្ថែមទៀត។
ពេលនៅព្រះអង្គនៅដោយឡែកពីបណ្តាជន
មានន័យថា ព្រះអង្គនៅឆ្ងាយពីហ្វូងមនុស្ស
ប៉ុន្តែពួកសិស្សរបស់ព្រះអង្គនៅជាមួយព្រះអង្គ។
ព្រះអង្គពន្យល់ការទាំងអស់នោះ
ឃ្លា «ការទាំងអស់នោះ» នៅទីនេះជាការនិយាយបន្ថែម ឬនិយាយលើស។
ព្រះអង្គបានពន្យល់រឿងប្រៀបប្រដូចទាំងអស់របស់ព្រះអង្គ។
«ព្រះអង្គបានពន្យល់ពីរឿងប្រៀបប្រដូចទាំងអស់របស់ព្រះអង្គ»
Mark 4:35
ឃ្លាភ្ជាប់៖
នៅពេលដែលព្រះយេស៊ូ
និងពួកសិស្សរបស់ព្រះអង្គជិះទូកដើម្បីរួចផុតពីហ្វូងមនុស្ស
នោះស្រាប់តែមានខ្យល់ព្យុះយ៉ាងខ្លាំង។ ពួកសិស្សរបស់ទ្រង់ភ័យខ្លាច
ពេលឃើញខ្យល់ និងសមុទ្រស្តាប់បង្គាប់ព្រះយេស៊ូ។
ព្រះអង្គមានបន្ទូលទៅពួកគេ
ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកសិស្ស
ត្រើយម្ខាងទៀត
«ផ្នែកម្ខាងទៀតនៃសមុទ្រកាលីឡេ» ឬ «ផ្នែកម្ខាងទៀតនៃសមុទ្រ»
ខ្យល់ព្យុះបក់បោកមកយ៉ាងខ្លាំង
ពាក្យ «បក់បោកមក» នៅទីនេះជាពាក្យសម្តីសម្រាប់ «បានចាប់ផ្តើម» ។
«ខ្យល់ព្យុះដ៏សាហាវមួយបានចាប់ផ្តើម»
ដូច្នេះហើយ បណ្តាលឲ្យទឹកចូលស្ទើរពេញ
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា ទូកនោះពោពេញទៅដោយទឹក។
Mark 4:38
ព្រះយេស៊ូកំពុងដេក
ពាក្យ"ព្រះអង្គ"នៅទីនេះសង្កត់ធ្ងន់ថា ព្រះយេស៊ូនៅតែម្នាក់ឯង។
«ព្រះយេស៊ូផ្ទាល់តែម្នាក់ឯង»
កន្ទៃទូក
នៅខាងក្រោយទូក។ «កន្ទៃទូក»
ពួកសិស្សបានដាស់ព្រះអង្គ
ពាក្យថា «ពួកគេ» សំដៅទៅលើពួកសិស្ស។
យើងស្លាប់ឥឡូវហើយ លោកមិនបារម្ភទេឬ?
ពួកសិស្សបានសួរសំណួរនេះដើម្បីបង្ហាញពីការភ័យខ្លាចរបស់ពួកគេ។
សំណួរនេះអាចសរសេរជាឃ្លា
«អ្នកត្រូវយកចិត្តទុកដាក់ចំពោះអ្វីដែលកំពុងកើតឡើង។
យើងទាំងអស់គ្នាជិតស្លាប់ហើយ!»
យើងស្លាប់ឥឡូវហើយ
ពាក្យថា «យើង» រួមបញ្ចូលទាំងពួកសិស្ស និងព្រះយេស៊ូ។
«សូប់ស្ងៀមទៅ!»
ឃ្លាទាំងពីរនេះស្រដៀងគ្នា និងប្រើសម្រាប់ការសង្កត់ន័យ។
ក៏រាបស្មើដែរ
«ភាពអស្ចារ្យនៅលើសមុទ្រ» ឬ «ភាពសូប់ស្ងាត់ដ៏អស្ចារ្យលើសមុទ្រ»
Mark 4:40
បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅពួកសិស្ស
ហើយព្រះយេស៊ូមានបន្ទូលទៅកាន់ពួកសិស្ស
ហេតុអ្វីបានជាអ្នករាល់គ្នាភ័យខ្លាចដូច្នេះ? អ្នករាល់គ្នាគ្មានជំនឿទេឬ?
ព្រះយេស៊ូសួរសំណួរទាំងនេះដើម្បី
ធ្វើឲ្យអ្នកដើរតាមព្រះអង្គពិចារណាអំពីមូលហេតុដែលពួកគេខ្លាច
ពេលទ្រង់នៅជាមួយនឹងពួកគេ។ សំណួរទាំងនេះអាចសរសេរជាឃ្លា
«អ្នកមិនគួរភ័យខ្លាចទេអ្នកត្រូវមានជំនឿច្រើនជាងនេះ» ។
តើលោកនេះជានរណាបានជាខ្យល់ព្យុះ និងសមុទ្រស្តាប់បង្គាប់គាត់ដូច្នេះ?
ពួកសិស្សសួរសំណួរនេះដោយងឿងឆ្ងល់នឹងអ្វីដែលព្រះយេស៊ូបានធ្វើ។
សំណួរនេះអាចសរសេរជាឃ្លា «បុរសនេះមិនដូចបុរសធម្មតាទេ
សូម្បីតែខ្យល់និងសមុទ្រក៏ស្តាប់បង្គាប់គាត់ដែរ!»

generated on Wed Sep 10 16:16:32 2025

5 [1]ពួកគេបានឆ្លងទៅត្រើយម្ខាងនៃសមុទ្រ គឺដល់តំបន់របស់ពួកគេរ៉ាស៊ីន។[2]នៅពេលព្រះយេស៊ូកំពុងឈានជើងចេញពីទូក
រំពេចនោះស្រាប់តែមានបុរសម្នាក់ដែលមានវិញ្ញាណអាក្រក់ ដែលចេញពីផ្នូរបានមករកព្រះអង្គ។
[3]បុរសម្នាក់បានរស់ក្នុងផ្នូរខ្មោច គ្មានអ្នកណាអាចចាប់ចងគាត់បានឡើយ ទោះដាក់ច្រវាក់ក៏មិនជាប់ដែរ។[4]ពួកគេដាក់ខ្នោះជើង និងយកច្រវាក់ចងគាត់ច្រើនដង ប៉ុន្តែ គាត់
នៅតែកាច់បំបាក់ច្រវាក់ និងខ្នោះទាំងនោះជានិច្ច គ្មាននរណាអាចបង្ក្រាបគាត់ឡើយ។
[5]គាត់នៅតាមភ្នំ និងផ្នូរខ្មោច ជារៀងរាល់យប់ និងថ្ងៃ ហើយគាត់ចេះតែស្រែក ព្រមទាំងយកថ្មមកអារដៃរបស់ខ្លួនឯង។[6]នៅពេលដែលគាត់ឃើញព្រះយេស៊ូពីចម្ងាយ
ក៏រត់រកព្រះអង្គ ហើយក្រាបចុះនៅចំពោះព្រះអង្គ។
[7]គាត់បានស្រែកឡើងដោយសម្លេងយ៉ាងខ្លាំងថា៖ «ឱព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ តើឲ្យទូលបង្គំធ្វើអ្វីជាមួយព្រះអង្គ? ទូលបង្គំសុំព្រះអង្គ
ក្នុងព្រះនាមព្រះជាម្ចាស់ សូមមេត្តាកុំធ្វើទារុណកម្មទូលបង្គំអី»។[8]នោះ ព្រះអង្គក៏បានមានបន្ទូលទៅវាថា៖ «នែ៎ វិញ្ញាណអាក្រក់ ចេញពីបុរសនេះភ្លាម!»។
[9]ព្រះអង្គបានសួរវាថា «តើឯងឈ្មោះអី?» វាក៏ទូលឆ្លើយជាមួយព្រះអង្គថា៖ «ទូលបង្គំឈ្មោះកងទ័ព ដ្បិតយើងយើងមានគ្នាច្រើន»។[10]វាបានទទូចអង្វរ សូមកុំឲ្យព្រះអង្គ
បណ្តេញពួកវាចេញពីស្រុកនោះឡើយ។
[11]គ្រានោះ មានជ្រូកមួយហ្វូងធំដែលកំពុងរកស៊ីនៅតាមជម្រាលភ្នំ។[12]ហើយពួកវាបានអង្វរព្រះអង្គថា៖ «សូមបញ្ជូនពួកយើងទៅក្នុងហ្វូងជ្រូកទាំងនោះទៅ
សូមឲ្យពួកយើងចូលទៅក្នុងហ្វូងជ្រូកទៅ»។[13]ព្រះអង្គក៏អនុញ្ញាត ពេលនោះពួកវិញ្ញាណអាក្រក់ក៏ចេញ ហើយចូលទៅក្នុងហ្វូងជ្រូកនោះ ពួកវាក៏បោលចុះតាមជម្រាលភ្នំ
តម្រង់ទៅសមុទ្រ ហើយជ្រូកទាំងអស់នោះប្រហែលពីរពាន់ក្បាល បានលង់ទឹកអស់ទៅ។
[14]ក្រោយមក ពួកអ្នកចិញ្ចឹមជ្រូក ក៏យករឿងនេះរត់ទៅរកអ្នកនៅទីក្រុង និងអ្នកនៅស្រុកស្រែ ហើយរាយការណ៍ពីអ្វីដែលបានកើតឡើង មនុស្សម្នាក៏នាំគ្នាមកមើល
ហេតុការណ៍នោះ ដូច្នេះហើយ អ្នកទាំងនោះក៏នាំគ្នាទៅមើលអំពីអ្វីដែលបានកើតឡើង។[15]បន្ទាប់មក ពួកគេចូលមករកព្រះយេស៊ូ ឃើញបុរសដែលមានអារក្សចូលកាលពីមុន អង្គុយនៅទីនោះ ទាំងមានសម្លៀកបំពាក់ ហើយមានស្មារតីល្អ នោះពួកគេមានការភ័យខ្លាចជាខ្លាំង។
[16]អស់អ្នកដែលបានឃើញអ្វីដែលបានកើតឡើងជាមួយបុរសដែលមានអារក្សចូល បានប្រាប់គេអំពីហេតុការណ៍នោះយ៉ាងក្បោះក្បាយ
ហើយពួកគេក៏បានប្រាប់ពួកគេពីហ្វូងជ្រូកដែរ។[17]ក្រោយមកពួកគេក៏ចាប់ផ្តើមសុំឲ្យព្រះអង្គចាកចេញពីស្រុករបស់ពួកគេ។
[18]ពេលដែលព្រះយេស៊ូកំពុងចុះទូក បុរសដែលអារក្សចូលនោះក៏សុំរួមដំណើរជាមួយព្រះអង្គដែរ។ ប៉ុន្តែ
ព្រះអង្គមិនអនុញ្ញាតឲ្យគាត់ទៅទេ[19]តែព្រះអង្គមានបន្ទូលទៅគាត់ថា៖ «ចូរទៅផ្ទះ និងគ្រួសាររបស់អ្នក ហើយប្រាប់ពួកគេអំពីអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់អ្នក
និងពីសេចក្តីមេត្តាដែលព្រះអង្គផ្តល់ដល់អ្នកចុះ»។[20]ហើយបុរសនោះក៏ចេញទៅ ហើយចាប់ផ្តើមប្រកាសពីការអស្ចារ្យដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្លួន
នៅក្នុងស្រុកដេកាប៉ូល ហើយពួកគេគ្រប់គ្នាមានការកោតស្ងប់ស្ងែងជាខ្លាំង។
[21]លើកនេះ នៅពេលព្រះយេស៊ូឆ្លងតាមទូកទៅត្រើយម្ខាងវិញ មានបណ្តាលជនជាច្រើនកុះករបានជួបជុំគ្នានៅជុំវិញព្រះអង្គ ដូចពេលដែលព្រះអង្គនៅសមុទ្រកាលីឡេដែរ។
[22]បន្ទាប់មកមានអ្នកដឹកនាំម្នាក់នៃសាលាប្រជុំ លោកមានឈ្មោះថា យ៉ៃរុសបានឃើញព្រះអង្គ គាត់ក្រាបទៀបព្រះបាទាព្រះអង្គ។[23]គាត់បានទូលសូមម្តងហើយម្តងទៀត
ដោយនិយាយថា៖ «កូនស្រីតូចរបស់ទូលបង្គំជិតស្លាប់ហើយ។ ទូលបង្គំសូមអង្វរព្រះអង្គ សូមយាងទៅដាក់ព្រះហស្តលើនាង ដើម្បីឲ្យនាងមានជីវិត
ហើយបានជាសះស្បើយផងដែរ»។[24]ព្រះយេស៊ូយាងទៅជាមួយគាត់ ក៏មានបណ្តាជនជាច្រើនកុះករតាមព្រះអង្គទៅដែរ ទាំងប្រជ្រៀតគ្នាជុំវិញព្រះអង្គ។
[25]ខណៈនោះ មានម្នាក់ដែលធ្លាក់ឈាមអស់ដប់ពីរឆ្នាំ។[26]នាងបានរស់នៅក្នុងការឈឺចាប់ និងចំណាយអស់ទ្រព្យសម្បត្តិដែលនាងទៅលើគ្រូពេទ្យជាច្រើន ប៉ុន្តែ
ជំងឺនោះមិនបានប្រសើរឡើងឡើយ តែកាន់តែធ្ងន់ជាងមុនទៀត។[27]ពេលនាងបានឮគេនិយាយអំពីព្រះយេស៊ូ ក៏ចូលក្នុងចំណោមបណ្តាជន ហើយពាល់ព្រះពស្ត្ររបស់
ព្រះអង្គពីខាងក្រោយ។
[28]ដោយនាងបាននិយាយថា៖ «បើខ្ញុំគ្រាន់បានពាល់អាវរបស់លោក ខ្ញុំនឹងបានជា»។[29]ក្រោយពេលនាងបានពាល់ព្រះអង្គ ឈាមក៏ឈប់ធ្លាក់ភ្លាម
រំពេចនោះនាងដឹងមានអារម្មណ៍ថា រូបកាយរបស់នាងបានជាសះស្បើយរោគនោះ។
[30]ភ្លាមៗនោះ ព្រះយេស៊ូជ្រាបថា មានឫទ្ធានុភាពហូរចេញពីព្រះអង្គ។ ព្រះយេស៊ូ បែររកមើលជុំវិញក្នុងបណ្តាជនទាំងនោះដោយបន្ទូលថា៖
«តើអ្នកណាបានពាល់អាវរបស់ខ្ញុំ?»[31]ពួកសិស្សបានទូលតបទៅព្រះអង្គថា៖ «លោកគ្រូមានមនុស្សច្រើនណាស់ប្រជ្រៀតគ្នានៅជុំវិញលោកគ្រូ តែលោកគ្រូសួរថា៖
«តើនរណាពាល់ខ្ញុំ?»[32]ប៉ុន្តែ ព្រះយេស៊ូនៅតែទតមើលជុំវិញនោះថាតើនរណាបានពាល់ព្រះអង្គ។
[33]ស្ត្រីនោះ ដឹងពីអ្វីដែលបានកើតឡើងក្នុងនាង ហើយនាងក៏ភ័យរន្ធត់។ ស្ត្រីនោះក៏ចេញមកហើយក្រាបនៅចំពោះព្រះយេស៊ូ ដោយនិយាយប្រាប់ព្រះអង្គពីសេចក្តីពិត។
[34]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «កូនស្រីអើយ ជំនឿរបស់នាងបានឲ្យបានបានជាហើយ។ ចូរទៅដោយសុខសាន្ត ហើយបានជាពីជំងឺនេះចុះ»។
[35]កាលព្រះយេស៊ូកំពុងតែមានព្រះបន្ទូលនៅឡើយ មានគេមកពីផ្ទះលោកយ៉ៃរុស ជម្រាបគាត់ថា៖ «កូនស្រីរបស់លោកស្លាប់ហើយ។ ហេតុអីក៏នៅរំខានលោកគ្រូទៀត?»។
[36]ប៉ុន្តែ ព្រះយេស៊ូមិនយកព្រះហឫទ័យទុកដាក់នឹងពាក្យរបស់អ្នកទាំងនោះឡើយ តែព្រះអង្គមានព្រះបន្ទូលទៅលោកយ៉ៃរុសថា៖ «កុំខ្លាចអី! គ្រាន់តែជឿចុះបានហើយ!»។
[37]ព្រះអង្គមិនអនុញ្ញាតឲ្យអ្នកណាទៅតាមព្រះអង្គឡើយ លើកលែងតែលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហានដែលជាប្អូនរបស់លោកយ៉ាកុប។[38]កាលទៅដល់ផ្ទះ
លោកយ៉ៃរុសដែលជាអ្នកទទួលខុសត្រូវលើសាលាប្រជុំ ព្រះយេស៊ូទតឃើញមនុស្សម្នាជ្រួលច្របល់ ព្រមទាំងទ្រហោយំជាខ្លាំងផង។
[39]ក្រោយពេល ព្រះយេស៊ូចូលដល់ក្នុងផ្ទះ ព្រះអង្គមានបន្ទូលទៅពួកគេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាកើតទុក្ខ ហើយទ្រហោយំដូច្នេះ? នាងមិនស្លាប់ទេ
គ្រាន់តែដេកលក់ប៉ុណ្ណោះ»។[40]ពួកគេបានសើចចំអកដាក់ព្រះអង្គ។ ប៉ុន្តែព្រះយេស៊ូបានដេញពួកនោះទៅខាងក្រៅ ហើយយកឪពុកម្តាយ និងសិស្សនៅជាមួយព្រះអង្គ
ទ្រង់បានយាងទៅកន្លែងដែលក្មេងស្រីនោះដេក។
[41]ព្រះអង្គបានចាប់ដៃក្មេងស្រីនោះ ហើយមានព្រះបន្ទូលទៅនាងថា៖ «តាលីថាគូមី!» ដែលអាចបកប្រែថា «នាងតូចអើយ ខ្ញុំប្រាប់នាងថា ចូរក្រោកឡើង»។[42]រំពេចនោះ
ក្មេងស្រីក៏ក្រោកឡើងដើរ (ដ្បិតនាងមានអាយុដប់ពីរឆ្នាំហើយ)។ ខណៈនោះ ធ្វើឲ្យពួកគេងឿងឆ្ងល់ដ៏លើសលុប ទៅនឹងការអស្ចារ្យនោះ[43]ប៉ុន្តែ ព្រះយេស៊ូហាមពួកគេមិន
ត្រូវប្រាប់រឿងនេះដល់នរណាឡើយ។ បន្ទាប់មក ព្រះអង្គប្រាប់គេឲ្យយកចំណីអាហារមកឲ្យក្មេងស្រីនោះបរិភោគ។

Mark 5:1

ឃ្លាភ្ជាប់៖

បន្ទាប់ពីព្រះយេស៊ូបញ្ជាឲ្យខ្យល់ព្យុះស្ងាប់
ទ្រង់បានប្រោសបុរសម្នាក់មានអារក្សចូលជាច្រើន
ប៉ុន្តែប្រជាជនក្នុងតំបន់កេរ៉ាស៊ីនមិនសប្បាយចិត្តនឹងការជាសះស្បើយរបស់ពួកគេទេ
ហើយពួកគេបានអង្វរព្រះយេស៊ូឲ្យចាកចេញ។

ពួកគេបានឆ្លងទៅ

ពាក្យថា «ពួកគេ» សំដៅទៅលើព្រះយេស៊ូនិងសិស្សរបស់ទ្រង់។

សមុទ្រ

សំដៅទៅលើសមុទ្រកាលីឡេ។

ពួកគេរ៉ាស៊ីន

ឈ្មោះនេះសំដៅទៅលើមនុស្សដែលរស់នៅក្នុងតំបន់ គេរ៉ាស៊ីន ។

ដែលមានវិញ្ញាណអាក្រក់

ប្រើជាក្រៀមភាសា ដែលមានន័យថា គ្រប់គ្រង ឬកាន់កាប់ដោយវិញ្ញាណអាក្រក់។
«គ្រប់គ្រងដោយវិញ្ញាណអាក្រក់» ឬ «វិញ្ញាណអាក្រក់ចូល»

Mark 5:3

ចងគាត់ច្រើនដង

អាចប្រើជាទម្រង់កិរិយាសកម្ម។ «មនុស្សបានចងគាត់ច្រើនដងហើយ» ។

និងខ្នោះទាំងនោះជានិច្ច

អាចប្រើជាទម្រង់កិរិយាសកម្ម។ «បំបែកច្រវាក់របស់គាត់»

ខ្នោះ

«ចំណងនៅលើជើងរបស់គាត់» ឬ

generated on Wed Sep 10 16:16:32 2025

«ដែកផ្សារភ្ជាប់នៅនឹងកជើងរបស់គាត់ដើម្បីបង្ខាំងគាត់»
ច្រវាក់
«ខ្នោះដៃ» ឬ «ច្រវាក់ជាប់នឹងកដៃរបស់គាត់ដើម្បីបង្ខាំងគាត់»
គ្មាននរណាអាចបង្ក្រាបគាត់ឡើយ
បុរសនោះខ្លាំងណាស់ គ្មានអ្នកណាអាចបង្ក្រាបគាត់បានទេ។
«គាត់ខ្លាំងណាស់ដែលគ្មាននរណាម្នាក់មានកម្លាំងខ្លាំងអាចបង្ក្រាបគាត់បានទេ»
បង្ក្រាបគាត់
«គ្រប់គ្រងគាត់»
Mark 5:5
យកថ្មមកអារដៃរបស់ខ្លួនឯង
ជារឿយៗ នៅពេលដែលមនុស្សម្នាក់ត្រូវអារក្សចូល
នោះបណ្តាលឲ្យបុគ្គលនោះធ្វើអ្វីដែលបំផ្លាញខ្លួនឯង ដូចជាកាត់ខ្លួនឯង។
នៅពេលដែលគាត់ឃើញព្រះយេស៊ូពីចម្ងាយ
ពេលបុរសនោះបានឃើញព្រះយេស៊ូ នោះព្រះយេស៊ូនឹងចុះទូក។
ក្រាបចុះ
មានន័យថាគាត់បានលុតជង្គង់នៅចំពោះមុខព្រះយេស៊ូដោយការគោរព
និងការគោរពមិនមែនចេញពីការគោរពបូជាទេ។
Mark 5:7
ព័ត៌មានទូទៅ៖
យូឌីបឺ ប្រើស្ពានដើម្បីភ្ជាប់ខគម្ពីរទាំងពីរនេះ
សរសេរព្រឹត្តិការណ៍តាមលំដាប់លំដោយដែលបានកើតឡើង។
គាត់បានស្រែកឡើង
«វិញ្ញាណអាក្រក់បានស្រែក»
ឱព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ តើឲ្យទូលបង្គំធ្វើអ្វីជាមួយព្រះអង្គ?
វិញ្ញាណអាក្រក់សួរសំណួរនេះដោយភាពភ័យខ្លាច។ នេះអាចសរសេរជាឃ្លា
«ទុកឲ្យខ្ញុំតែម្នាក់ឯងចុះ ព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត!
គ្មានហេតុផលព្រះអង្គមកជ្រៀតជ្រែកខ្ញុំទេ» ។
ព្រះយេស៊ូ...សូមមេត្តាកុំធ្វើទារុណកម្មទូលបង្គំអី
ព្រះយេស៊ូមានអំណាចធ្វើទារុណកម្មវិញ្ញាណអាក្រក់។
ព្រះរាជបុត្រានៃព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ
ជាងារសំខាន់ចំពោះព្រះយេស៊ូ។
ទូលបង្គំសុំព្រះអង្គក្នុងព្រះនាមព្រះជាម្ចាស់
នៅទីនេះវិញ្ញាណអាក្រក់កំពុងតែស្បថចំពោះព្រះជាម្ចាស់ពេលវាស្នើសុំពីព្រះយេស៊ូ។
ពិចារណាអំពីសំណើរនេះសរសេរជាភាសារបស់អ្នក។
«ខ្ញុំសូមអង្វរអ្នកនៅចំពោះព្រះជាម្ចាស់» ឬ
«ខ្ញុំបានស្បថដោយព្រះអង្គផ្ទាល់ហើយអង្វរអ្នក»
Mark 5:9
ព្រះអង្គបានសួរ
ហើយព្រះយេស៊ូបានសួរវិញ្ញាណអាក្រក់
វាក៏ទូលឆ្លើយជាមួយព្រះអង្គថា៖ «ទូលបង្គំឈ្មោះកងទ័ព ដ្បិតយើងយើងមានគ្នាច្រើន»
វិញ្ញាណមួយនិយាយទៅកាន់មនុស្សជាច្រើននៅទីនេះ។
ព្រះអង្គមានបន្ទូលទៅកាន់ពួកគេ ដូចជាពួកគេជាកងពលរ៉ូម៉ាំង
ដែលមានទាហានប្រហែល៦០០០នាក់។
«ហើយវិញ្ញាណបាននិយាយទៅកាន់ព្រះអង្គថា
ហៅពួកយើងកងទ័ពមកព្រោះយើងភាគច្រើននៅខាងក្នុងបុរសនោះ›
Mark 5:11
ពួកវាបានអង្វរព្រះអង្គ
«វិញ្ញាណអាក្រក់បានអង្វរព្រះយេស៊ូ»
ព្រះអង្គក៏អនុញ្ញាត
ជារឿងសំខាន់បញ្ជាក់យ៉ាងច្បាស់នូវអ្វី ដែលព្រះយេស៊ូបានអនុញ្ញាតឲ្យពួកគេធ្វើ។
«ព្រះយេស៊ូអនុញ្ញាតឲ្យវិញ្ញាណអាក្រក់ធ្វើអ្វីដែលពួកគេបានស្នើសុំ»
ពួកវាក៏បោលចុះ
«ជ្រែកក៏បោលចុះ»
តាមជម្រាលភ្នំ តម្រង់ទៅសមុទ្រ ហើយជ្រែកទាំងអស់នោះប្រហែលពីរពាន់ក្បាល
បានលង់ទឹកអស់ទៅ
អ្នកអាចសរសេរឃ្លាដាច់ដោយឡែកមួយ៖
«ចូលទៅក្នុងសមុទ្រមានជ្រែកប្រហែលពីរពាន់ក្បាលហើយពួកគេបានលង់ទឹកស្លាប់នៅក្នុងទឹក»
ជ្រែកទាំងអស់នោះប្រហែលពីរពាន់ក្បាល
ប្រហែលជ្រែកពីរពាន់ក្បាល
Mark 5:14
អ្នកនៅទីក្រុង និងអ្នកនៅស្រុកស្រែ
អាចបញ្ជាក់យ៉ាងច្បាស់ថា
បុរសនេះបានរាយការណ៍ប្រាប់ប្រជាជនដែលរស់នៅក្នុងទីក្រុង និងជនបទ។
«ទៅកាន់ប្រជាជននៅទីក្រុង និងនៅជនបទ»
កាលពីមុន
ជាឈ្មោះរបស់អារក្សជាច្រើនដែលមាននៅក្នុងបុរសនោះ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក៥ ខ៩ ។
ហើយមានស្មារតីល្អ
ជាអត្ថន័យពិសេសដែលគាត់កំពុងគិតយ៉ាងច្បាស់។ «នៃគំនិតធម្មតា» ឬ
«គិតឲ្យច្បាស់»
ពួកគេមានការភ័យខ្លាចជាខ្លាំង
ពាក្យថា «ពួកគេ»
សំដៅទៅលើក្រុមមនុស្សដែលចេញទៅមើលអ្វីដែលបានកើតឡើង។
Mark 5:16
អស់អ្នកដែលបានឃើញអ្វីដែលបានកើតឡើង
«ប្រជាជនដែលបានឃើញហេតុការណ៍ដែលបានកើតឡើង»
Mark 5:18
បុរសដែលអារក្សចូល
បុរសម្នាក់ដែលមានអារក្សចូល - ទោះបីបុរសនោះលែងមានអារក្សចូលក៏ដោយ
គាត់នៅតែត្រូវបានគេពិពណ៌នាតាមរបៀបនេះ។ "បុរសដែលមានអារក្សចូល"
ប៉ុន្តែ ព្រះអង្គមិនអនុញ្ញាតឲ្យគាត់ទៅទេ
អ្វីដែលព្រះយេស៊ូមិនអនុញ្ញាតឲ្យបុរស ត្រូវបានបញ្ជាក់យ៉ាងច្បាស់។
«ប៉ុន្តែគាត់មិនបានអនុញ្ញាតិឲ្យបុរសនោះមកជាមួយពួកគេទេ»
ស្រុកដេកាប៉ូល
ជាឈ្មោះនៃតំបន់មួយដែលមានន័យថាទីក្រុងដប់។
វាមានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃសមុទ្រកាលីឡេ។
ពួកគេគ្រប់គ្នាមានការកោតស្ញប់ស្ញែងជាខ្លាំង
វាមានសារសំខាន់ណាស់ក្នុងការបញ្ជាក់ពីមូលហេតុដែលប្រជាជនមានការភ្ញាក់ផ្អើល។
«មនុស្សទាំងអស់ដែលបានឮអ្វីដែលបុរសនោះបាននិយាយ
មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង»
Mark 5:21
ឃ្លាភ្ជាប់៖
ក្រោយពីបានប្រោសបុរស ដែលមានអារក្សចូលក្នុងតំបន់គេរ៉ាស៊ីនមក
ព្រះយេស៊ូនិងពួកសិស្សរបស់ទ្រង់បានឆ្លងបឹងទៅក្រុងកាពើណិម
ជាកន្លែងដែលអ្នកគ្រប់គ្រងសាលាប្រជុំម្នាក់បានសុំព្រះយេស៊ូ
ប្រោសកូនស្រីរបស់គាត់ឲ្យជា។
ត្រើយម្ខាង
អាចមានប្រយោជន៍ក្នុងការបន្ថែមព័ត៌មានទៅឃ្លានេះ។
«ត្រើយម្ខាងទៀតនៃសមុទ្រ»
នៅសមុទ្រកាលីឡេដែរ
«នៅឆ្នេរសមុទ្រ» ឬ «នៅលើច្រាំងសមុទ្រ»
សមុទ្រ
ជាសមុទ្រកាលីឡេ។
យ៉ៃរូស
ជាឈ្មោះបុរសម្នាក់។
ព្រះយេស៊ូយាងទៅជាមួយគាត់
«ដូច្នេះព្រះយេស៊ូក៏ទៅជាមួយយ៉ៃរូស»។
សិស្សរបស់ព្រះយេស៊ូក៏ទៅតាមព្រះអង្គដែរ។
«ដូច្នេះព្រះយេស៊ូនិងពួកសិស្សបានទៅជាមួយយ៉ៃរូស»
ដាក់ព្រះហស្តលើនាង
«ការដាក់ដៃលើ» សំដៅទៅលើព្យាការី ឬគ្រូម្នាក់ដាក់ដៃលើនរណាម្នាក់
ហើយផ្តល់ការប្រោសឲ្យជា ឬពរជ័យ។
ក្នុងករណីនេះយ៉ៃរូសកំពុងស្នើសុំព្រះយេស៊ូឲ្យព្យាបាលកូនស្រីរបស់គាត់។
ដើម្បីឲ្យនាងមានជីវិត ហើយបានជាសះស្បើយផងដែរ
អាចប្រើជាទម្រង់កិរិយាសកម្ម។ «និងប្រោសនាង និងធ្វើឲ្យនាងរស់»
ឃ្លាភ្ជាប់
ជុំវិញព្រះអង្គ
មានន័យថាពួកគេបានប្រមូលផ្តុំគ្នានៅជុំវិញព្រះយេស៊ូ
ហើយបានបង្ខំពួកគេឲ្យនៅជិតព្រះយេស៊ូ។

generated on Wed Sep 10 16:16:32 2025

Mark 5:25

ឃ្លាភ្ជាប់៖

នៅពេលព្រះយេស៊ូកំពុងតែធ្វើដំណើរទៅប្រោសក្មេងស្រីតូចអាយុ ១២ ឆ្នាំ
ស្រាប់តែស្ត្រីម្នាក់ដែលឈឺអស់រយៈពេល១២ឆ្នាំមកហើយ
បានស្ទាក់ចាប់ដោយការពាល់ព្រះយេស៊ូដើម្បីប្រោសនាង។

ខណៈនោះ មានម្នាក់

«ឥឡូវនេះ» បង្ហាញថាស្ត្រីនេះកំពុងត្រូវបានណែនាំឱ្យដឹងពីរឿងរ៉ាវ។
ពិចារណាពីរបៀបដែលតួអក្សរថ្មីត្រូវបានណែនាំទៅជារឿងរ៉ាវនៅក្នុងភាសារបស់អ្នក។

ដែលធ្លាក់ឈាមអស់ដប់ពីរឆ្នាំ

ស្ត្រីនោះមិនមានរបួសបើកចំហទេ។
ផ្ទុយទៅវិញឈាមរដូវប្រចាំខែរបស់នាងនឹងមិនបញ្ឈប់ឡើយ។
ភាសារបស់អ្នកអាចមានរបៀបនិយាយបែបគួរសមទៅលើស្ថានភាពនេះ។

ដប់ពីរឆ្នាំ

១២ឆ្នាំ

តែកាន់តែធ្ងន់ជាងមុន

«ជំងឺរបស់នាងកាន់តែអាក្រក់ទៅៗ» ឬ «ការហូរឈាមរបស់នាងកើនឡើង»

គេនិយាយអំពីព្រះយេស៊ូ

នាងបានឮគេនិយាយអំពីព្រះយេស៊ូ អំពីរបៀបដែលទ្រង់បានប្រោសមនុស្ស។
«ដែលព្រះយេស៊ូបានប្រោសមនុស្ស»

ព្រះពស្ត្រ

សម្លៀកបំពាក់ ឬអាវក្រៅ

Mark 5:28

ខ្ញុំនឹងបានជា

អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «នឹងប្រោសខ្ញុំឲ្យជាសះស្បើយ» ឬ
«អំណាចរបស់ទ្រង់នឹងប្រោសខ្ញុំឲ្យជាសះស្បើយ»

រូបកាយរបស់នាងបានជាសះស្បើយភ្លាមនោះ

អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ជំងឺបានឃ្លាតឆ្ងាយពីនាង» ឬ
«នាងលែងមានជំងឺ»

Mark 5:30

ឫទ្ធានុភាពហូរចេញពីព្រះអង្គ

ពេលស្ត្រីនោះប៉ះព្រះយេស៊ូ
ព្រះយេស៊ូមានអារម្មណ៍ថាឫទ្ធានុភាពរបស់ព្រះអង្គបានធ្វើឲ្យនាងជា។
ព្រះយេស៊ូផ្ទាល់មិនបានបាត់បង់ឫទ្ធានុភាពណាមួយ
ក្នុងការប្រោសឲ្យមនុស្សជាសះស្បើយ
ពេលព្រះអង្គបានប្រោសឲ្យនាងជាសះស្បើយ។ "
ឫទ្ធានុភាពនៃការប្រោសរបស់ព្រះអង្គ បានធ្វើឲ្យស្ត្រីនោះជាសះស្បើយ"

មនុស្សច្រើនណាស់ប្រជ្រៀតគ្នានៅជុំវិញលោកគ្រូ

មានន័យថាពួកគេបានប្រមូលផ្តុំគ្នានៅជុំវិញព្រះយេស៊ូ
ហើយបានចូលទៅកៀកព្រះយេស៊ូ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក៥ ខ២១ ។

Mark 5:33

ក្រាបនៅចំពោះព្រះយេស៊ូ

“ លុតជង្គង់នៅចំពោះព្រះអង្គ” ។ នាងបានលុតជង្គង់នៅចំពោះព្រះយេស៊ូ
ជាការបង្ហាញការគោរពនិងការចុះចូល។

និយាយប្រាប់ព្រះអង្គពីសេចក្តីពិត

ឃ្លាថា «សេចក្តីពិត» សំដៅទៅលើរបៀបដែលនាងបានប៉ះព្រះអង្គ ហើយបានជា។
«បានប្រាប់ព្រះអង្គពីការពិតទាំងអស់ និងអំពីរបៀបដែលនាងបានប៉ះព្រះអង្គ»

កូនស្រីអើយ

ក្នុងន័យធៀប
ព្រះយេស៊ូប្រើពាក្យនេះជាន័យធៀបដើម្បីសំដៅទៅលើស្ត្រីដែលជាអ្នកជឿ។

ជំនឿរបស់នាង

ជំនឿរបស់នាងមើលព្រះអង្គ

Mark 5:35

កាលព្រះយេស៊ូកំពុងតែមានព្រះបន្ទូលនៅឡើយ

«កាលព្រះយេស៊ូកំពុងមានព្រះបន្ទូល

មានគេមកពីផ្ទះលោកយ៉ៃរូស ជម្រាបគាត់ថា

អាចមានន័យថា ១) មនុស្សទាំងនេះបានមកពីផ្ទះរបស់យ៉ៃរូស ឬ ២)
យ៉ៃរូសធ្លាប់បានបញ្ជាមនុស្សទាំងនេះ ឲ្យទៅជួបព្រះយេស៊ូ ឬ៣)
មនុស្សទាំងនេះត្រូវបានបញ្ជូនដោយបុរសដែលជាប្រធានសាលាប្រជុំ
ពេលលោកយ៉ៃរូសអវត្តមាន។

គេមកពីផ្ទះលោកយ៉ៃរូស

«មេដឹកនាំសាលាប្រជុំ»គឺយ៉ៃរូស។

ជម្រាបគាត់ថា

«និយាយទៅកាន់យ៉ៃរូស»

ហេតុអ៊ីក៏នៅរំខានលោកគ្រូទៀត?

សំណួរនេះអាចសរសេរជាឃ្លា «វាគ្មានប្រយោជន៍ទេក្នុងការរំខានដល់គ្រូទៀត» ។
ឬ «មិនចាំបាច់រំខានគ្រូទៀតទេ» ។

លោកគ្រូ

ពាក្យនេះសំដៅលើព្រះយេស៊ូ។

Mark 5:36

ព័ត៌មានទូទៅ៖

យូឌីប៊ីប្រើស្ពានខដើម្បីភ្ជាប់ខ៣៧ និង៣៨ ។ .

គ្រាន់តែជឿចុះបានហើយ!

បើចាំបាច់អ្នកអាចបញ្ជាក់ពីអ្វីដែលព្រះយេស៊ូកំពុងតែបញ្ជាដល់យ៉ៃរូសឲ្យជឿ។
«គ្រាន់តែជឿថា ខ្ញុំអាចប្រោសកូនស្រីអ្នកឲ្យរស់ឡើងវិញ»

ព្រះអង្គមិន... ព្រះយេស៊ូទតឃើញ

នៅក្នុងខទាំងនេះ និងពាក្យទាំងនេះ សំដៅទៅលើព្រះយេស៊ូ។

ទៅតាមព្រះអង្គឡើយ

ទៅជាមួយព្រះអង្គ។
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីកន្លែងដែលពួកគេត្រូវទៅ។
«ទៅជាមួយព្រះអង្គទៅផ្ទះរបស់យ៉ៃរូស»

Mark 5:39

ព្រះអង្គមានបន្ទូលទៅពួកគេ

«ព្រះយេស៊ូមានបន្ទូលទៅកាន់មនុស្សដែលកំពុងយំ»

ហេតុអ្វីបានជាអ្នករាល់គ្នាកើតទុក្ខ ហើយទ្រហោយំដូច្នេះ?

ព្រះយេស៊ូសួរសំណួរនេះដើម្បីជួយពួកគេឲ្យ ឃើញថាពួកគេគ្មានជំនឿ។
នេះអាចត្រូវបានសរសេរជាឃ្លា។
«នេះមិនមែនជាពេលវេលាដែលត្រូវកើតទុក្ខនិងយំទេ» ។

បានដេញពួកនោះទៅខាងក្រៅ

«បានបញ្ជូនមនុស្សផ្សេងទៀតទាំងអស់នៅខាងក្រៅផ្ទះ»

សិស្សនៅជាមួយព្រះអង្គ

សំដៅទៅលើលោកពេត្រុស យ៉ាកុប និងយ៉ូហាន។

បានយាងទៅកន្លែងដែលក្មេងស្រីនោះដេក

អាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីកន្លែងដែលកុមារនៅ។
«បានចូលទៅក្នុងបន្ទប់ដែលក្មេងកំពុងដេក»

Mark 5:41

តាលីថាគូមី

ជាប្រយោគអារ៉ាប់ដែលព្រះយេស៊ូមានបន្ទូលទៅកាន់ក្មេងស្រីតូចជាភាសារបស់នាង។
សរសេរពាក្យទាំងនេះដូចជាអក្ខរក្រមរបស់អ្នក។

នាងមានអាយុដប់ពីរឆ្នាំហើយ

នាងមានអាយុ១២ឆ្នាំ

ព្រះយេស៊ូហាមពួកគេមិនត្រូវប្រាប់រឿងនេះដល់នរណាឡើយ

អាចបញ្ជាក់ថាជាការដកស្រង់ផ្ទាល់។ "គាត់បានបញ្ជាពួកគេយ៉ាងតឹងរឹងថា
«គ្មាននរណាម្នាក់គួរតែដឹងអំពីរឿងនេះទេ!» ឬ
«គាត់បានបញ្ជាពួកគេយ៉ាងតឹងរឹងថាកុំប្រាប់នរណាម្នាក់អំពីអ្វីដែលខ្ញុំបានធ្វើ!»

ព្រះយេស៊ូហាមពួកគេ

"ព្រះអង្គបានហាមពួកគេយ៉ាងខ្លាំង"

បន្ទាប់មក ព្រះអង្គប្រាប់គេឲ្យយកចំណីអាហារមកឲ្យក្មេងស្រីនោះបរិភោគ

អាចបញ្ជាក់ថាជាការដកស្រង់ផ្ទាល់។
«ហើយព្រះអង្គបានប្រាប់ពួកគេថាសូមឲ្យនាងញ៉ាំអី»

---

6 [1]ព្រះយេស៊ូបានយាងចេញពីទីនោះត្រឡប់ទៅស្រុកកំណើតរបស់ព្រះអង្គវិញ ហើយពួកសាវកក៏បានទៅតាមព្រះអង្គដែរ។ [2]នៅថ្ងៃសប្ប័ទមកដល់ ព្រះអង្គបានបង្រៀន
បណ្តាជននៅក្នុងសាលាប្រជុំ។ មានមនុស្សជាច្រើនបានស្តាប់ព្រះអង្គបង្រៀន ហើយពួកគេមានការអស្ចារ្យក្នុងចិត្តជាខ្លាំង។ ពួកគេបាននិយាយថា៖
«តើគាត់បានសេចក្តីបង្រៀនទាំងនេះមកពីណា?» «តើប្រាជ្ញាអ្វីដែលបានប្រទានឲ្យគាត់?» «តើគាត់អាចធ្វើការអស្ចារ្យទាំងអស់នេះបានដោយរបៀបណា?»

generated on Wed Sep 10 16:16:32 2025

[3]«តើគាត់មិនមែនជាកូនជាងឈើ ដែលត្រូវជាកូនប្រុសរបស់នាងម៉ារី ហើយត្រូវជាបងប្រុសរបស់លោកយ៉ាកុប លោកយ៉ូសែប លោកយូដាស និងលោកស៊ីម៉ូនទេឬអី?» «តើបងប្អូនស្រីរបស់គាត់មិនបានរស់នៅក្នុងភូមិជាមួយយើងទេឬអី?» ពួកគេបានរវាតចិត្តដោយសារព្រះយេស៊ូ។
[4]បន្ទាប់មក ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ពួកគេថា៖ «ព្យាការីត្រូវបានគេគោរពនៅគ្រប់កន្លែង លើកលែងតែនៅក្នុងស្រុកកំណើត
នៅក្នុងចំណោមសាច់ញាតិបងប្អូន និងនៅក្នុងផ្ទះរបស់គាត់តែប៉ុណ្ណោះ»[5]ព្រះអង្គមិនអាចធ្វើកិច្ចការអស្ចារ្យអ្វីបានទេ ទ្រង់គ្រាន់តែអាចដាក់ដៃលើអ្នកឈឺមួយចំនួន
ហើយប្រោសគេឲ្យបានជាប៉ុណ្ណើ។[6]ព្រះអង្គពិតជាមានការងឿងឆ្ងល់ចំពោះការមិនជឿរបស់ពួកគេ។ ហើយទ្រង់ក៏បានយាងចេញទៅបង្រៀននៅទៅជុំវិញ តាមភូមិនានា។
[7]ហើយទ្រង់បានហៅពួកសិស្សទាំងដប់ពីរមក ហើយឱ្យពួកគេចេញទៅពីរៗនាក់ ព្រមទាំងប្រទានអំណាចដល់ពួកគេឲ្យឈ្នះលើវិញ្ញាណអាក្រក់នានា
[8]ហើយព្រះអង្គបានបង្គាប់ដល់ពួកគេ មិនឲ្យយកអ្វីទាំងអស់ទៅជាមួយសម្រាប់ការធ្វើដំណើររបស់ពួកគេឡើយ លើកលែងតែដំបង មិនត្រូវយកនំប៉័ង ថង់យាម
និងមិនត្រូវយកលុយកាក់ មាសប្រាក់ជាប់នឹងខ្លួនឡើយ។[9]ប៉ុន្តែ ត្រូវពាក់ស្បែកជើង និងមិនឲ្យពាក់អាវពីរបន្លាស់ឡើយ។
[10]ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេថា៖ «បើអ្នករាល់គ្នាចូលផ្ទះណា ចូរស្នាក់នៅទីនោះរហូតដល់អ្នកចេញពីទីនោះ។[11]ប្រសិនបើ នៅទីក្រុងណាមិនទទួល
ឬក៏មិនស្តាប់អ្នក ចូរចេញពីទីនោះ ហើយរលាស់ធូរលីដីចេញពីជើងរបស់អ្នកឲ្យអស់ដើម្បីជាបន្ទាល់ទាស់នឹងពួកគេវិញ»។
[12]ពួកសិស្សបានចេញទៅ ហើយប្រកាសឲ្យមនុស្សងាកបែរចេញពីបាបរបស់ពួកគេ។[13]ពួកគេដេញវិញ្ញាណអាក្រក់ជាច្រើន ព្រមទាំងចាក់ប្រេងលាបលើអ្នកជំងឺជាច្រើន
ហើយប្រោសពួកគេឲ្យបានជាសះស្បើយ។
[14]ព្រះបាទហេរ៉ូដបានឮពីកិច្ចការទាំងអស់នេះ ព្រោះព្រះនាមរបស់ព្រះយេស៊ូល្បីល្បាញ។ អ្នកខ្លះបាននិយាយថា៖ «លោកយូ ហានបាទីស្តបានរស់ឡើងវិញ
ហេតុនេះហើយបានជាគាត់អាចធ្វើការអស្ចារ្យបានយ៉ាងនេះ»[15]ហើយមានអ្នកខ្លះនិយាយថា៖ «លោកគឺជាព្យាការីអេលីយ៉ា» នៅមានអ្នកខ្លះនិយាយថា៖
«លោកដូចជាព្យាការីកាលពីជំនាន់ដើម»
[16]ប៉ុន្តែ នៅពេលស្តេចហេរ៉ូដបានឮពីរឿងនេះ ទ្រង់មានបន្ទូលថា៖ «លោកនេះគឺជាយ៉ូហានដែលយើងបានបញ្ជាឲ្យគេកាត់ក្បាល ពេលនេះគាត់បានរស់ឡើងវិញ»។
[17]ស្តេចហេរ៉ូដបានបញ្ជូនគេឲ្យចាប់លោកយ៉ូហានហើយឃុំឃាំងគាត់នៅក្នុងពន្ធនាគារ ដោយសារតែទ្រង់ជឿតាមព្រះនាងហេរ៉ូឌាស
(ដែលត្រូវជាមហេសីរបស់ស្តេចភីលីព) ដោយសារតែទ្រង់បានរៀបអភិសេកជាមួយនាង។
[18]លោកយ៉ូហានទូលទៅស្តេចហេរ៉ូដថា៖ «ទ្រង់គ្មានសិទ្ធិក្នុងការយកមហេសីរបស់អនុជទ្រង់ធ្វើជាមហេសីឡើយ»[19]ប៉ុន្តែ ព្រះនាងហេរ៉ូដាសបានខឹងនឹងលោក
ហើយចង់សម្លាប់លោក ប៉ុន្តែ ព្រះនាងសម្លាប់មិនកើត។[20]ព្រះបាទហេរ៉ូដកោតខ្លាចលោកយ៉ូហាន ព្រោះទ្រង់ជ្រាបថាលោកជាមនុស្សសុចរិត និងបរិសុទ្ធ
ហើយទ្រង់ចង់ការពារលោក។ ស្តេចសព្វព្រះហឫទ័យនឹងពាក្យលោកយ៉ូហានជាខ្លាំងតែទ្រង់ក៏ពិបាកព្រះហឫទ័យជាខ្លាំងដែរ។
[21]នៅក្នុងឱកាសបុណ្យចម្រើនព្រះជន្មរបស់ស្តេចហេរ៉ូដបានមកដល់ ទ្រង់ក៏បានរៀបចំពិធីជប់លៀងអាហារពេលល្ងាចជាមួយពួកមន្ត្រី ពួកមេទ័ព
និងពួកអ្នកដឹកនាំនៅក្នុងស្រុកកាលីឡេ។[22]បុត្រីរបស់ព្រះនាងហេរ៉ូដាសបានចេញមករាំ នៅមុខស្តេច និងភ្ញៀវរបស់គាត់ ស្តេច ព្រមទាំងភ្ញៀវទាំងអស់ពេញចិត្តជាខ្លាំង។
ស្តេចបានមានបន្ទូលទៅនាងថា៖ «ចូរសុំនូវអ្វីដែលនាងចង់បានចុះ យើងនឹងឲ្យទៅនាង»។
[23]ស្តេចបានស្បថនឹងនាងថា៖ «អ្វីក្តីដែលនាងសុំយើង យើងនឹងឲ្យនាង ទោះបីជាមួយនគរពាក់កណ្តាលក៏ដោយ»។[24]នាងបានចេញទៅក្រៅហើយសួរមាតានាងថា៖
«តើគួរឲ្យខ្ញុំម្ចាស់ទូលសុំអ្វីពីព្រះអង្គ?» មាតារបស់នាងបង្គាប់ថា៖ «ចូរសុំក្បាលរបស់យ៉ូហានបាទីស្តមក» ។[25]នាងក៏បានប្រញាប់ប្រញាល់ត្រឡប់ទៅកាន់ស្តេចវិញ
ហើយនាងក៏បានទូលទៅស្តេចថា៖ «ខ្ញុំម្ចាស់ចង់ឲ្យព្រះអង្គប្រទានក្បាលរបស់យ៉ូហានបាទីស្តដាក់នៅលើថាសឥឡូវនេះ។
[26]ស្តេចពិតជាព្រួយព្រះទ័យជាខ្លាំង តែព្រះអង្គមិនអាចបដិសេធនូវសំណើររបស់នាងបានឡើយ
ព្រោះព្រះអង្គបានស្បថនៅចំពោះមុខភ្ញៀវទាំងអស់ដែលបានចូលរួមរួចហើយ។[27]រួចស្តេចក៏បានបញ្ជូនទាហាន ហើយបញ្ជាឲ្យគេនាំយកក្បាលរបស់លោកយ៉ូហានមក។
ទាហានបានចេញទៅ ហើយកាត់ក្បាលរបស់លោកយ៉ូហាននៅក្នុងពន្ធនាគា។[28]ទាហានបាននាំយកក្បាលរបស់លោកយ៉ូហានដោយដាក់នៅលើថាស ហើយឲ្យនាង
ហើយនាងក៏យកទៅថ្វាយមាតារបស់នាង។[29]កាលពួកសិស្សរបស់លោកយ៉ូហានបានឮរឿងនេះ ពួកគេបាននាំគ្នាមកយកសពរបស់លោកទៅបញ្ចុះក្នុងផ្នូរ។
[30]ពួកសាវកបានមក ហើយប្រាប់ព្រះយេស៊ូអំពីកិច្ចការទាំងអស់ដែលគេបានធ្វើ និងបានបង្រៀន។[31]បន្ទាប់មកព្រះយេស៊ូបានមានបន្ទូលទៅកាន់ពួកគេថា៖
«ចូរនាំគ្នារកកន្លែងស្ងាត់សម្រាកសិនចុះ»។ មានមនុស្សបានធ្វើដំណើរចេញចូលច្រើនពេក ធ្វើឲ្យព្រះយេស៊ូ និងពួកសាវ័កពុំអាចរកពេល
សូម្បីតែហូបបាយក៏មិនបានផង។[32]ព្រះយេស៊ូ និងពួកសាវ័កបានយាងចុះទូកទៅរកកន្លែងស្ងាត់ដាច់ដោយឡែកពីបណ្តាជន ដើម្បីសម្រាក។
[33]ប៉ុន្តែ បណ្តាជនបានឃើញពួកគេ ហើយមានមនុស្សជាច្រើនបានចំណាំពួកសិស្ស ពួកគេបានរត់ទៅទីនោះទាំងអស់គ្នា ចេញពីទីក្រុងទៅដល់មុនពួកសិស្សផង។
[34]ពេលដែលព្រះយេស៊ូ និងពួកសិស្សបានចុះទូក ទ្រង់បានឃើញបណ្តាជនជាច្រើន
ហើយទ្រង់មានសេចក្តីអាណិតអាសូរពន់ពេកព្រោះពួកគេប្រៀបបាននឹងចៀមដែលគ្មានអ្នកគង្វាល។ ដូចនេះព្រះអង្គក៏បង្រៀនពួកគេពីរឿងជាច្រើន។
[35]នៅពេលនោះថ្ងៃកាន់តែជ្រេណាស់ទៅហើយ ពួកសាវកបាននាំគ្នាចូលមកគាល់ព្រះយេស៊ូ ហើយទូលព្រះអង្គថា៖ «ទីកន្លែងនេះស្ងាត់
ហើយថ្ងៃកាន់តែជ្រេណាស់ទៅហើយ»[36]ព្រះយេស៊ូមានបន្ទូលទៅកាន់គេថា៖ «សូមឲ្យពួកគេត្រឡប់ទៅវិញ
ហើយរកទិញអាហារនៅតាមភូមិជិតៗនេះសម្រាប់ពួកគេរៀងៗខ្លួន»។
[37]ប៉ុន្តែ ព្រះយេស៊ូបានឆ្លើយ ហើយមានព្រះបន្ទូលកាន់ទៅគេវិញថា៖ «ចូរ អ្នករាល់គ្នាកឲ្យអាហារពួកគេហូបផង»។ ពួកគេបានទូលព្រះអង្គថា៖
«តើយើងត្រូវយកប្រាក់ពីររយដួងទៅទិញនំប៉័ង ហើយឲ្យពួកគេហូបមែនទេ?»។[38]ព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «ទៅមើល មើល៍!
តើអ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?»។ កាលបានដឹងហើយពួកគេទូលទៅព្រះអង្គវិញថា៖ «យើងមាននំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយ»។
[39]ព្រះយេស៊ូបានបង្គាប់ឲ្យមនុស្សទាំងអស់អង្គុយចុះជាក្រុមនៅលើស្មៅ។[40]ពួកគេបានអង្គុយចុះជាក្រុម ក្រុមខ្លះមានមួយរយនាក់ ក្រុមខ្លះមានហាសិបនាក់។
[41]ព្រះយេស៊ូបានយកនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយមក ហើយព្រះអង្គងើបព្រះភ័ក្ត្រឡើង សសើរតម្កើងព្រះជាម្ចាស់
ហើយកាច់នំប៉័ងប្រទានឲ្យដល់ពួកសិស្សចែកបណ្តាជនហូប។ ព្រះអង្គក៏បានប្រទានត្រីពីរកន្ទុយដល់ពួកគេដែរ។
[42]ពួកគេគ្រប់គ្នាហូបរហូតដល់ពួកគេបានឆ្អែត។[43]ពួកសិស្សបានប្រមូលនំប៉័ង និងត្រីដែលនៅសល់ដាក់បានពេញដប់ពីរល្អី។
[44]មានមនុស្សប្រុសចំនួនប្រាំពាន់នាក់ដែលបានហូបនំប៉័ងនេះ។
[45]នៅរំពេចនោះព្រះយេស៊ូបានបង្គាប់ឲ្យពួកសិស្សចុះទូកឆ្លងទៅត្រើយម្ខាង ដើម្បីឆ្ពោះទៅភូមិបេតសៃដាមុនព្រះអង្គ
ខណៈនោះព្រះអង្គបានប្រាប់ឲ្យបណ្តាជនត្រឡប់ទៅវិញ។[46]កាលបណ្តាជនបានចេញទៅអស់ហើយ ព្រះយេស៊ូបានយាងទៅលើភ្នំ ដើម្បីអធិស្ឋាន។
[47]លុះពេលយប់មកដល់ទូកបានទៅដល់កណ្តាលសមុទ្រ រីឯព្រះយេស៊ូគង់នៅលើគោកតែមួយព្រះអង្គឯង។
[48]ព្រះអង្គទតឃើញពួកគេប្រឹងអុំទូកយ៉ាងលំបាក ព្រោះពួកគេអុំបញ្ច្រាសខ្យល់។ នៅពេលជិតភ្លឺព្រះអង្គបានយាងនៅលើទឹកឆ្ពោះទៅកាន់ពួកគេ
ហើយព្រះអង្គធ្វើដូចជាទៅហួសពួកគេ។[49]ប៉ុន្តែ កាលពួកសិស្សបានឃើញព្រះអង្គយាងនៅលើទឹកដូច្នេះ ពួកគេស្មានថាជាខ្មោចលង ហើយនាំគ្នាស្រែកជាខ្លាំង។[50]ដ្បិត
ពួកគេបានឃើញព្រះអង្គហើយពួកគេមានការភ័យរន្ធត់ជាខ្លាំង។ ពេលនោះព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកគេថា៖ «ចូរតាំងចិត្តក្លាហានឡើង ខ្ញុំទេតើ កុំខ្លាចអី!»
[51]បន្ទាប់មកព្រះយេស៊ូយាងទៅលើទូកជាមួយពួកគេ ហើយខ្យល់ក៏បានស្ងប់។[52]ពួកគេពិតជាឆ្ងល់ជាខ្លាំងពន់ពេកណាស់។ ដ្បិត
ពួកគេមិនទាន់បានយល់អំពីរឿងនំប៉័ងថាមានន័យយ៉ាងដូចម្តេចទេ មកពីពួកគេមានចិត្តរឹងរូស។
[53]កាលព្រះយេស៊ូ និងពួកសិស្សបានឆ្លងទៅដល់ទឹកដីនៃស្រុកគេនេសារ៉ែតហើយ ក៏ចតទូក។[54]ពេលពួកគេចេញពីទូកមក
មនុស្សម្នាបានស្គាល់ព្រះយេស៊ូភ្លាម[55]ហើយពួកគេបានរត់ទៅគ្រប់ច្រកល្ហកនៅក្នុងតំបន់ ហើយបានសែងអ្នកឈឺទៅកន្លែងដែលពួកគេឮថាព្រះអង្គគង់នៅ។

generated on Wed Sep 10 16:16:32 2025

[56]គ្រប់ទីកន្លែងដែលព្រះយេស៊ូយាងទៅ ទោះនៅក្នុងភូមិ ក្នុងទីក្រុង ឬក៏នៅតាមទីជនបទក្តី ពួកគេបាននាំអ្នកជំងឺមកតាមផ្សារ។
ពួកគេទទូចអង្វរសុំគ្រាន់តែអនុញ្ញាតឲ្យពួកគេបានប៉ះជាយព្រះពស្ត្រព្រះអង្គប៉ុណ្ណោះ ហើយនៅពេលដែលពួកគេបានពាល់ព្រះអង្គ សុទ្ធតែបានជាសះស្បើយគ្រប់គ្នា។

Mark 6:1
ឃ្លាភ្ជាប់៖
ព្រះយេស៊ូត្រឡប់ទៅស្រុកកំណើតរបស់ព្រះអង្គជាកន្លែងដែលព្រះអង្គមិនត្រូវបានគេទទួលស្គាល់
ស្រុកកំណើតរបស់ព្រះអង្គ
សំដៅទៅលើក្រុងណាសារ៉ែត ដែលព្រះយេស៊ូបានដឹងក្តី
និងជាកន្លែងដែលក្រុមគ្រួសាររបស់លោករស់នៅ។ មិនមានន័យថា
ព្រះអង្គជាម្ចាស់ដីនៅទីនោះទេ។
តើប្រាជ្ញាអ្វីដែលបានប្រទានឲ្យគាត់?
សំណួរនេះមានលក្ខណៈជាទម្រង់កិរិយាអកម្ម
ដែលយើងអាចប្រើជាទម្រង់កិរិយាសកម្មបាន។
«តើប្រាជ្ញាអ្វីដែលគាត់បានទទួល?»
បានដោយរបៀបណា?
ឃ្លានេះសង្កត់ធ្ងន់ថាព្រះយេស៊ូផ្ទាល់ធ្វើការអស្ចារ្យ។
"ព្រះអង្គផ្ទាល់បានធ្វើការអស្ចារ្យ"
«តើគាត់មិនមែនជាកូនជាងឈើ ដែលត្រូវជាកូនប្រុសរបស់នាងម៉ារី
ហើយត្រូវជាបងប្រុសរបស់លោកយ៉ាកុប លោកយ៉ូសែប លោកយូដាស និងលោកស៊ីម៉ូនទេឬអី?» «
តើបងប្អូនស្រីរបស់គាត់មិនបានរស់នៅក្នុងភូមិជាមួយយើងទេឬអី?»
សំណួរទាំងនេះអាចសរសេរជាឃ្លា "គាត់គ្រាន់តែជាជាងឈើធម្មតា!
«យើងស្គាល់គាត់ និងក្រុមគ្រួសាររបស់គាត់។ យើងស្គាល់ម៉ារីជាម្តាយរបស់គាត់។
យើងស្គាល់ប្អូនប្រុសរបស់គាត់ឈ្មោះយ៉ាកុប យ៉ូសេ
យូដាសនិងស៊ីម៉ូនហើយប្អូនស្រីរបស់គាត់ក៏រស់នៅទីនេះជាមួយយើងដែរ» ។
Mark 6:4
ទៅកាន់ពួកគេ
ទៅកាន់ពួកបណ្តាជន
ព្យាការីត្រូវបានគេគោរពនៅគ្រប់កន្លែង លើកលែងតែ
ប្រយោគនេះប្រើអវិជ្ជមានទ្វេដង ដើម្បីសង្កត់ន័យសមមូលវិជ្ជមាន។
«ព្យាការីតែងតែទទួលបានកិត្តិយសលើកលែងតែ» ឬ
«កន្លែងតែមួយគត់ដែលព្យាការីមិនត្រូវបានគេគោរព»
ដាក់ដៃលើអ្នកឈឺមួយចំនួន
«ការដាក់ដៃ» សំដៅទៅលើព្យាការី ឬគ្រូម្នាក់ដាក់ដៃលើនរណាម្នាក់
ហើយផ្តល់ការប្រោសឲ្យជា ឬការប្រទានពរ។
ក្នុងករណីនេះព្រះយេស៊ូកំពុងព្យាបាលមនុស្ស។
Mark 6:7
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាត់ពួកសិស្សឲ្យទៅជាពីរក្រុមឲ្យទៅប្រកាសដំណឹងល្អ និងប្រោសជំងឺ។
ព័ត៌មានទូទៅ៖
យូឌីប៊ី ប្រើស្ពានភ្ជាប់ខ៨ និង៩
ដើម្បីធ្វើឲ្យពាក្យណែនាំរបស់ព្រះយេស៊ូងាយស្រួលអាន។
ទ្រង់បានហៅពួកសិស្សទាំងដប់ពីរ
ត្រង់នេះពាក្យ«ហៅ»បានន័យថា
ព្រះអង្គបានត្រាស់ហៅមនុស្សទាំងដប់ពីរនាក់ឲ្យមកគាល់ព្រះអង្គ។
ពីរៗនាក់
«២ដោយ២» ឬ «ជាគូ»
មិនត្រូវយកនំបុ័ង
នៅទីនេះ «នំបុ័ង» ជាពាក្យប្រើសម្រាប់ម្ហូបអាហារជាទូទៅ។ «គ្មានអាហារ»
មិនត្រូវយកលុយកាក់ មាសប្រាក់ជាប់នឹងខ្លួនឡើយ
នៅក្នុងវប្បធម៌នោះ
បុរសបានយកប្រាក់របស់ពួកគេចងភ្ជាប់ទៅនឹងខ្សែក្រវ៉ាត់របស់ពួកគេ។
«គ្មានលុយនៅក្នុងកាបូបលុយរបស់ពួកគេ» ឬ «គ្មានលុយ»
Mark 6:10
ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេ
«ព្រះយេស៊ូមានបន្ទូលទៅពួកសិស្សទាំងដប់ពីរនាក់»
ចូរស្នាក់នៅទីនោះរហូតដល់អ្នកចេញពីទីនោះ
ឃ្លា «ស្នាក់នៅទីនោះ» ជាក្រៀមភាសាមានន័យថា“ បរិភោគនិងស្នាក់នៅ”
នៅក្នុងផ្ទះនោះ។ «បរិភោគ និងស្នាក់នៅក្នុងផ្ទះតែមួយនោះ
រហូតដល់អ្នកចាកចេញពីកន្លែងនោះ»
ជាបន្ទាល់ទាស់នឹងពួកគេវិញ
ជាសក្ខីកម្មប្រឆាំងនឹងពួកគេ។
អាចមានប្រយោជន៍ក្នុងការពន្យល់ពីរបៀបដែលសកម្មភាពនេះជាសក្ខីភាពមួយចំពោះពួកគេ។
តាមរយៈការធ្វើបែបនេះអ្នកនឹងផ្តល់សក្ខីកម្មថា ពួកគេមិនស្វាគមន៍អ្នកទេ។
Mark 6:12
ពួកសិស្សបានចេញទៅ
ពាក្យថា «ពួកគេ» សំដៅទៅលើពួកដប់ពីរនាក់ មិនរាប់បញ្ចូលព្រះយេស៊ូទេ។
គួរបញ្ជាក់ផងដែរថា អាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា
ពួកគេបានចេញទៅទីក្រុងផ្សេងៗ។
«ពួកគេបានធ្វើដំណើរទៅកាន់ទីប្រជុំជនផ្សេងៗគ្នា»
ងាកបែរចេញពីបាបរបស់ពួកគេ
«ប្រែចិត្តពីអំពើបាបរបស់គេ»
ពួកគេដេញវិញ្ញាណអាក្រក់ជាច្រើន
វាអាចមានប្រយោជន៍ក្នុងការថ្លែងថា ពួកគេបានដេញអារក្សចេញពីមនុស្ស។
«ពួកគេដេញអារក្សជាច្រើនចេញពីមនុស្ស»
Mark 6:14
ឃ្លាភ្ជាប់៖
ពេលស្តេចហេរ៉ូដបានលឺអំពីអព្ភូតហេតុរបស់ព្រះយេស៊ូគាត់មានការព្រួយបារម្ភ
ដោយគិតថាមានអ្នកណាម្នាក់បានប្រោសលោកយ៉ូហានបាទីស្តឲ្យរស់ឡើងវិញ។
(ហេរ៉ូដបានបញ្ជាគេឲ្យសម្លាប់លោកយ៉ូហានបាទីស្ត) ។
ព្រះបាទហេរ៉ូដបានឮពីកិច្ចការទាំងអស់នេះ
ពាក្យថា "នេះ" សំដៅទៅលើអ្វីៗទាំងអស់ដែលព្រះយេស៊ូ
និងសិស្សរបស់ទ្រង់បានធ្វើនៅតាមទីក្រុងផ្សេងៗរួមទាំងដេញអារក្ស
និងប្រោសមនុស្សផង។
អ្នកខ្លះបាននិយាយថា៖ «លោកយ៉ូហានបាទីស្តបាន
មនុស្សខ្លះនិយាយថា ព្រះយេស៊ូជាលោកយ៉ូហានបាទីស្ត។
អាចត្រូវបានបញ្ជាក់កាន់តែច្បាស់។ អ្នកខ្លះនិយាយថា «ព្រះអង្គជាយ៉ូហានបាទីស្ត»
លោកយ៉ូហានបាទីស្តបានរស់ឡើងវិញ
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«ព្រះជាម្ចាស់បានលើកលោកយ៉ូហានបាទីស្ត»
មានអ្នកខ្លះនិយាយថា៖ «លោកគឺជាព្យាការីអេលីយ៉ា»
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីមូលហេតុដែលមនុស្សមួយចំនួនគិតថាគាត់ជាអេលីយ៉ា។
«អ្នកខ្លះទៀតនិយាយថាគាត់ជាអេលីយ៉ាដែលព្រះបានសន្យាថានឹងបញ្ជូនមកម្តងទៀត»
។
Mark 6:16
ព័ត៌មានទូទៅ៖
នៅក្នុងខ១៧ អ្នកនិពន្ធចាប់ផ្តើមផ្តល់ព័ត៌មានអំពីស្តេចហេរ៉ូដ
និងមូលហេតុដែលគាត់កាត់ក្បាលលោកយ៉ូហានបាទីស្ត។ (សូមមើល:|
Background Information)
ដែលយើងបានបញ្ជាឲ្យគេកាត់ក្បាល
នៅទីនេះស្តេចហេរ៉ូដប្រើពាក្យ«យើង»សំដៅលើខ្លួនគាត់។ ពាក្យ «យើង»
ជាពាក្យប្រៀបធៀបសម្រាប់ទាហានរបស់ស្តេចហេរ៉ូដ។
«ដែលខ្ញុំបានបញ្ជាឲ្យទាហានរបស់ខ្ញុំកាត់ក្បាល»
បានរស់ឡើងវិញ
អាចប្រើជាទម្រង់កិរិយាសកម្ម។ «បានរស់ឡើងវិញ»
ស្តេចហេរ៉ូដបានបញ្ជូនគេឲ្យចាប់លោកយ៉ូហានហើយឃុំឃាំងគាត់នៅក្នុងពន្ធនាគារ
អាចប្រើជាទម្រង់កិរិយាសកម្ម។
«ស្តេចហេរ៉ូឌបានបញ្ជូនទាហានរបស់គាត់ឲ្យទៅចាប់ខ្លួនយ៉ូហាន
ហើយបានយកគាត់ទៅដាក់គុក»
បានបញ្ជូនគេឲ្យចាប់
«បញ្ជាឲ្យទៅ»
ដោយសារតែទ្រង់ជឿតាមព្រះនាងហេរ៉ូឌាស
«ដោយសារតែព្រះនាងហេរ៉ូឌាស»
ដែលត្រូវជាមហេសីរបស់ស្តេចភីលីព

generated on Wed Sep 10 16:16:32 2025

ភរិយារបស់ភីលីពជាបងប្អូនរបស់គាត់ ភីលីពបងប្រុសរបស់ហេរ៉ូដ
មិនមែនជាភីលីពដូចគ្នាដែលជាអ្នកប្រកាសដំណឹងល្អនៅក្នុងកណ្ឌគម្ពីរកិច្ចការ
ឬភីលីពដែលជាសិស្សម្នាក់ក្នុងចំណោមសិស្សទាំងដប់ពីររបស់ព្រះយេស៊ូ។ .
ដោយសារតែទ្រង់បានរៀបអភិសេកជាមួយនាង
«ពីព្រោះស្តេចហេរ៉ូដបានរៀបអភិសេកជាមួយនាង»
Mark 6:18
ហើយចង់សម្លាប់លោក ប៉ុន្តែ ព្រះនាងសម្លាប់មិនកើត
ព្រះនាងហេរ៉ូឌាស ជាប្រធានបទនៃឃ្លានេះហើយ «នាង»
ជាពាក្យសម្តីមួយដែលនាងចង់ឲ្យនរណាម្នាក់ផ្សេងទៀតប្រហារជីវិតលោកយ៉ូហាន។
«នាងចង់ឲ្យនរណាម្នាក់សម្លាប់គាត់ ប៉ុន្តែនាងមិនអាចឲ្យគេសម្លាប់គាត់បានទេ»
ព្រះបាទហេរ៉ូដកោតខ្លាចលោកយ៉ូហាន ព្រោះទ្រង់ជ្រាបថា
ឃ្លាទាំងពីរនេះអាចត្រូវបានផ្សាភ្ជាប់គ្នាខុសគ្នា
ដើម្បីបង្ហាញឲ្យកាន់តែច្បាស់នូវមូលហេតុស្តេចខ្លាចលោកយ៉ូហាន។
«ដោយស្តេចហេរ៉ូដខ្លាចលោក ព្រោះគាត់ដឹង»
ព្រោះទ្រង់ជ្រាបថាលោកជាមនុស្សសុចរិត
«ស្តេចហេរ៉ូដបានដឹងថា លោកយ៉ូហានជាមនុស្សសុចរិត»
ស្តេចសព្វព្រះហឫទ័យនឹងពាក្យលោកយ៉ូហានជាខ្លាំង
«ស្តាប់លោកយ៉ូហាន»
Mark 6:21
ឃ្លាភ្ជាប់៖
អ្នកនិពន្ធបន្តផ្តល់ព័ត៌មានអំពីស្តេចហេរ៉ូដ និងការកាត់ក្បាលរបស់យ៉ូហានបាទីស្ត។
ទ្រង់ក៏បានរៀបចំពិធីជប់លៀងអាហារពេលល្ងាចជាមួយពួកមន្ត្រី...នៅក្នុងស្រុកកាលីឡេ
ពាក្យថា «ទ្រង់» នៅទីនេះសំដៅទៅលើស្តេចហេរ៉ូដ
និងជាពាក្យធម្មតាសម្រាប់អ្នកបម្រើរបស់ទ្រង់ ដែលត្រូវទ្រង់បញ្ជាឲ្យរៀបចំអាហារ។
«គាត់បានរៀបចំអាហារពេលល្ងាចសម្រាប់មន្ត្រីរបស់ទ្រង់ ... ក្នុងស្រុកកាលីឡេ» ឬ
«ទ្រង់បានអញ្ជើញមន្ត្រី ... ក្នុងស្រុកកាលីឡេទៅបរិភោគ និងអបអរជាមួយទ្រង់»
ពិធីជប់លៀងអាហារពេលល្ងាច
អាហារផ្លូវការ ឬពិធីជប់លៀង
នាងហេរ៉ូដាស
ពាក្យថា «នាងហេរ៉ូដាស»
ជាសព្វនាមឆ្លុះបញ្ចាំងដែលត្រូវបានប្រើដើម្បីបញ្ជាក់កត់សម្គាល់ថា
នាងជាកូនស្រីផ្ទាល់ខ្លួនរបស់ហេរ៉ូឌាសដែលបានរាំនៅពេលល្ងាច។
បានចេញមក
«បានចូលមកក្នុងបន្ទប់»
Mark 6:23
អ្វីក្តីដែលនាងសុំយើង ...នគរ
អាចមានប្រយោជន៍ក្នុងការបន្ថែមព័ត៌មានដែលបាត់ខ្លះ។
«ខ្ញុំនឹងផ្តល់ឲ្យអ្នកនូវអ្វីដែលខ្ញុំកាន់កាប់និងគ្រប់គ្រងពាក់កណ្តាល
ប្រសិនបើអ្នកស្នើសុំវា»
បានចេញទៅក្រៅ
«បានចេញពីបន្ទប់»
ឥឡូវនេះ
ភ្លាមនេះ
ដាក់នៅលើថាស
នៅលើថាស
Mark 6:26
ព្រោះព្រះអង្គបានស្បថនៅចំពោះមុខភ្ញៀវទាំងអស់ដែលបានចូលរួមរួចហើយ
ខ្លឹមសារនៃសម្បថ និងទំនាក់ទំនងរវាងសម្បថ
និងភ្ញៀវពេលល្ងាចអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
«ដោយសារតែភ្ញៀវទទួលទានអាហារពេលល្ងាចរបស់ទ្រង់បានធ្វើឲ្យទ្រង់ស្បថថា
ទ្រង់នឹងឲ្យអ្វីៗដែលនាងសុំ»
ដាក់នៅលើថាស
នៅលើថាស
កាលពួកសិស្សរបស់លោកយ៉ូហាន
ហើយពួកសិស្សរបស់លោកយ៉ូហាន
Mark 6:30
ឃ្លាភ្ជាប់៖
បន្ទាប់ពីពួកសិស្សត្រឡប់មកពីប្រកាសដំណឹងល្អ និងប្រោសជំងឺ
ពួកគេបានទៅកន្លែងណាមួយតែម្នាក់ឯង
ប៉ុន្តែមានមនុស្សជាច្រើនមកស្តាប់ព្រះយេស៊ូបង្រៀន។
ពេលហួសម៉ោងអាហារទៅហើយ ព្រះអង្គបានប្រទានអាហារដល់ប្រជាជន
ហើយបន្ទាប់មកបញ្ជូនមនុស្សគ្រប់គ្នាទៅឆ្ងាយនៅពេលគាត់អធិស្ឋានតែម្នាក់ឯង។
កន្លែងស្ងាត់
កន្លែងដែលគ្មានមនុស្ស
មានមនុស្សបានធ្វើដំណើរចេញចូលច្រើនពេក
នេះមានន័យថា ប្រជាជនបានមករកពួកសាវ័កជាបន្តបន្ទាប់ ហើយចេញពីពួកគេ។
ពួកសាវ័កពុំអាចរកពេល
ពាក្យថា «ពួកសាវ័ក» សំដៅទៅលើពួកសិស្ស។
ព្រះយេស៊ូ និងពួកសាវ័កបានយាងចុះ
ត្រង់នេះពាក្យ «ពួកគេ» រួមបញ្ចូលទាំងសាវ័ក និងព្រះយេស៊ូ។
Mark 6:33
ពួកគេបានរត់ទៅទីនោះទាំងអស់គ្នា
«ប្រជាជនបានឃើញព្រះយេស៊ូ និងពួកសាវ័កចាកចេញទៅ»
បានរត់
ប្រជាជនធ្វើដំណើរដោយថ្មើរជើង
ដែលផ្ទុយពីរបៀបដែលពួកសិស្សបានធ្វើដំណើរតាមទូក។
ទ្រង់បានឃើញបណ្តាជនជាច្រើន
«ព្រះយេស៊ូទតឃើញមនុស្សមួយហ្វូងយ៉ាងធំ»
ពួកគេប្រៀបបាននឹងចៀមដែលគ្មានអ្នកគង្វាល
ព្រះយេស៊ូប្រៀបធៀបមនុស្សទៅនឹងចៀមដែលវង្វេង
នៅពេលពួកគេគ្មានគង្វាលដឹកនាំមើលថែពួកគេ។
Mark 6:35
នៅពេលនោះថ្ងៃកាន់តែជ្រេណាស់ទៅហើយ
មានន័យថា វាយឺតពេលហើយ។ «នៅពេលវាយឺតពេល» ឬ «ពេលរសៀល»
ទីកន្លែងនេះស្ងាត់
សំដៅទៅលើកន្លែងដែលគ្មានមនុស្ស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅជំពូក៦ ខ៣០ ។
Mark 6:37
ប៉ុន្តែ ព្រះយេស៊ូបានឆ្លើយ ហើយមានព្រះបន្ទូលកាន់ទៅគេវិញថា
ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សថា៖
តើយើងត្រូវយកប្រាក់ពីររយដួងទៅទិញនំបុ័ង ហើយឲ្យពួកគេហូបមែនទេ?
សិស្សសួរសំណួរនេះដើម្បីបញ្ជាក់ថា
គ្មានវិធីណាដែលពួកគេអាចមានលទ្ធភាពទិញអាហារគ្រប់គ្រាន់សម្រាប់ហ្វូងមនុស្សនេះទេ។
«យើងមិនអាចទិញនំបុ័ងគ្រប់គ្រាន់ដើម្បីចិញ្ចឹមហ្វូងមនុស្សនេះទេ
ទោះបីយើងមានពីររយឌីណារីក៏ដោយ!»
ប្រាក់ពីររយដួង
«២០០ ដួង»
ប្រាក់ដួងជាកាក់ប្រាក់រ៉ូម៉ាំងដែលមានតម្លៃស្មើនឹងប្រាក់ឈ្នួលមួយថ្ងៃ។
នំបុ័ង
«ដុំនំបុ័ង» នំបុ័ងមួយដុំជាម្សៅមួយដុំដែលមានរាង និងដុតនំ។
Mark 6:39
ស្មៅ
ពិពណ៌នាអំពីស្មៅទៅនឹងព័ណប្រើក្នុងភាសារបស់អ្នក ជាស្មៅក្រាស់
ឬមិនមែនជាពណ៌បៃតង។
ក្រុមខ្លះមានមួយរយនាក់ ក្រុមខ្លះមានហាសិបនាក់
សំដៅទៅលើចំនួនមនុស្សនៅក្នុងក្រុមនីមួយៗ។ «ប្រហែល៥០នាក់នៅក្នុងក្រុមខ្លះ
និងប្រហែល១០០ នាក់នៅក្នុងក្រុមផ្សេងទៀត»
ងើបព្រះភ័ក្ត្រឡើង
មានន័យថាគាត់បានសំឡឹងមើលទៅលើមេឃដែលជាប់ទាក់ទងនឹងកន្លែងដែលព្រះអង្គគង់នៅ
សសើរតម្កើងព្រះជាម្ចាស់
«ព្រះអង្គបានប្រទានពរ» ឬ «ព្រះអង្គបានអរព្រះគុណ»
ព្រះអង្គក៏បានប្រទានត្រីពីរកន្ទុយដល់ពួកគេដែរ
«គាត់បានបែងចែកត្រីទាំងពីរ ដូច្នេះអ្នកទាំងអស់គ្នាអាចមានខ្លះ»
Mark 6:42
ពួកសិស្សបានប្រមូល
អាចមានន័យថា ១) «ពួកសិស្សបានលើកយក» ឬ ២) «ប្រជាជនបានលើកយក»
។
នំបុ័ង និងត្រីដែលនៅសល់ដាក់បានពេញដប់ពីរល្អី

generated on Wed Sep 10 16:16:32 2025

«ដប់ពីរកន្ត្រកពេញដោយបំណែកនំប៉័ង»
ដប់ពីរល្អី
១២ល្អី
មនុស្សប្រុសចំនួនប្រាំពាន់នាក់
មនុស្ស៥០០០នាក់
មានមនុស្សប្រុសចំនួនប្រាំពាន់នាក់ដែលបានហូបនំប៉័ងនេះ
ចំនួនស្ត្រី និងកុមារមិនត្រូវបានរាប់បញ្ចូលទេ។ បើសិនគេយល់ថាស្ត្រី
និងកុមារពុំមានវត្តមាននោះ អាចបញ្ជាក់ឲ្យបានច្បាស់ជាងនេះ។
«ហើយមានបុរសប្រាំពាន់នាក់ដែលបានបរិភោគនំប៉័ងពួកគេមិនបានរាប់បញ្ចូលទាំងស្ត្រីនិងកុមារដែរ»
Mark 6:45
ត្រើយម្ខាង
សំដៅទៅលើសមុទ្រកាលីឡេ។ អាចបញ្ជាក់យ៉ាងច្បាស់។
«ទៅផ្នែកម្ខាងទៀតនៃសមុទ្រកាលីឡេ»
ភូមិបេតសៃដា
ជាទីក្រុងមួយនៅលើឆ្នេរសមុទ្រខាងជើងនៃសមុទ្រកាលីឡេ។
កាលបណ្តាជនបានចេញទៅអស់ហើយ
«ពេលប្រជាជនបានចាកចេញ»
Mark 6:48
ឃ្លាភ្ជាប់៖
ព្យុះមួយបានកើតឡើងខណៈដែលពួកសិស្សកំពុងព្យាយាមឆ្លងបឹង។
ពេលឃើញព្រះយេស៊ូកំពុងដើរលើទឹកធ្វើឲ្យពួកគេភ័យខ្លាច។
ពួកគេមិនយល់ពីរបៀប ដែលព្រះយេស៊ូអាចបញ្ជាឲ្យខ្យល់ព្យុះស្ងប់បានឡើយ។
នៅពេលជិតភ្លឺ
ពេលវេលារវាងម៉ោង ៣ និងថ្ងៃរះ។
ខ្មោច
ស្មារតីនៃមនុស្សស្លាប់ឬវិញ្ញាណប្រភេទផ្សេងទៀត
ចូរតាំងចិត្តក្លាហានឡើង... កុំខ្លាចអី!
ប្រយោគទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា
ដោយសង្កត់ធ្ងន់ទៅលើពួកសិស្សរបស់ព្រះអង្គ ពួកគេមិនចាំបាច់ខ្លាចឡើយ។
អាចបញ្ចូលគ្នាប្រសិនបើចាំបាច់។ «កុំខ្លាចខ្ញុំ!»
Mark 6:51
ពួកគេពិតជាឆ្ងល់ជាខ្លាំងពន់ពេកណាស់
បើអ្នកចង់ច្បាស់ជាងនេះ អ្នកអាចបញ្ជាក់ពីអ្វីដែលពួកគេភ្ញាក់ផ្អើល។
«ពួកភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះអ្វីដែលព្រះអង្គបានធ្វើ»
អំពីរឿងនំប៉័ងថាមានន័យយ៉ាងដូចម្តេចទេ
ឃ្លាដែលថា«នំប៉័ង»សំដៅទៅលើពេល ដែលព្រះយេស៊ូបានពហុគុណនំប៉័ង។
អាចត្រូវបានបញ្ជាក់កាន់តែច្បាស់។ តើវាមានន័យយ៉ាងដូចម្តេច
នៅពេលដែលព្រះអង្គបានពហុគុណនំប៉័ងនំប៉័ងនោះ
ពួកគេមានចិត្តរឹងរូស
ចិត្តមានៈជាចិត្តរឹងចចេសពិបាកយល់បាន។
«ពួកគេរឹងចចេសមិនអាចយល់បានទេ»
Mark 6:53
ឃ្លាភ្ជាប់៖
ពេលព្រះយេស៊ូ និងពួកសិស្សរបស់ព្រះអង្គមកដល់គេនេសារ៉ែត
នៅក្នុងទូករបស់ពួកគេមនុស្សបានឃើញទ្រង់
ហើយនាំមនុស្សមកឯទ្រង់ទទួលការប្រោសជំងឺ។
ស្រុកគេនេសារ៉ែត
ជាឈ្មោះតំបន់នៅភាគពាយព្យនៃសមុទ្រកាលីឡេ។
មនុស្សម្នាបានស្គាល់ព្រះយេស៊ូភ្លាម
«ប្រជាជននៅទីនោះបានទទួលស្គាល់ព្រះយេស៊ូ»
ពួកគេបានរត់ទៅគ្រប់ច្រកល្ហកនៅក្នុងតំបន់
មានប្រយោជន៍ក្នុងការបញ្ជាក់ពីមូលហេតុ ដែលពួកគេរត់កាត់តំបន់នេះ។
«ពួកគេបានរត់ពាសពេញស្រុកទាំងមូល ដើម្បីប្រាប់អ្នកផ្សេងថា
ព្រះយេស៊ូគង់នៅទីនោះ»
ពួកគេបានរត់ទៅ...ពួកគេឮ
ពាក្យថា «ពួកគេ»
សំដៅទៅលើមនុស្សដែលស្គាល់ព្រះយេស៊ូមិនមែនសំដៅទៅលើពួកសិស្សទេ។
អ្នកឈឺ
ឃ្លានេះសំដៅទៅលើមនុស្ស។ «មនុស្សឈឺ»
Mark 6:56
គ្រប់ទីកន្លែងដែលព្រះយេស៊ូយាងទៅ
«គ្រប់ទីកន្លែងដែលព្រះយេស៊ូបានចូល»
ពួកគេបាននាំ
ពាក្យ «ពួកគេ» នៅទីនេះសំដៅទៅលើប្រជាជន។
វាមិនសំដៅទៅលើពួកសិស្សរបស់ព្រះយេស៊ូទេ។
អ្នកជំងឺ
ឃ្លានេះសំដៅទៅលើមនុស្ស។ «មនុស្សឈឺ»
ពួកគេទទូចអង្វរសុំ
អាចមានន័យថា ១) «អ្នកជំងឺបានអង្វរព្រះអង្គ» ឬ ២)
«ប្រជាជនបានអង្វរព្រះអង្គ» ។
ពួកគេបានពាល់ព្រះអង្គ
ពាក្យថា «ពួកគេ» សំដៅទៅលើអ្នកឈឺ។
ជាយព្រះពស្ត្រព្រះអង្គប៉ុណ្ណោះ
«ជាយអាវរបស់ព្រះអង្គ» ឬ «សម្លៀកបំពាក់របស់ព្រះអង្គ»
គ្រប់គ្នា
«អស់អ្នកដែល»

---

7 [1]ពួកខាងគណៈផារីស៊ី និងពួកអាចារ្យដែលបានមកពីក្រុងយេរូសាឡឹម នាំគ្នាទៅជួបព្រះយេស៊ូ។
[2]ពួកគេបានឃើញពួកសិស្សរបស់ព្រះអង្គមួយចំនួនហូបអាហារដោយដៃមិនស្អាតដែលមិនបានលាងជាមុនឡើយ។[3]ដ្បិត ពួកផារីស៊ី និងសាសន៍យូដាមិនហូបឡើយ
ទាល់តែបានសម្អាតដៃជាមុនសិន ដោយសារពួកគេកាន់តាមទំនៀមទម្លាប់ពីចាស់បុរាណ។[4]នៅពេលដែលពួកផារីស៊ីត្រឡប់មកពីផ្សារវិញ ពួកគេមិនហូបទេ
ទាល់តែពួកគេបានងូតទឹកជាមុនសិន ពួកគេកាន់ខ្ជាប់នូវទំនៀមទម្លាប់ផ្សេងៗដូចជា ពិធីលាងពែង លាងឆ្នាំង លាងថូ និងតុជាដើម
ជាអ្វីៗដែលត្រូវប្រើសម្រាប់ហូបអាហារ។
[5]ពួកផារីស៊ី និងពួកអាចារ្យបានទូលសួរព្រះយេស៊ូថា៖ «តើហេតុអ្វីបានជាពួកសិស្សរបស់លោក មិនកាន់តាមទំនៀមទម្លាប់ចាស់បុរាណ
ដោយនាំគ្នាហូបអាហាររបស់ពួកគេដោយដៃមិនស្អាតយ៉ាងដូច្នេះ?»។
[6]ប៉ុន្តែ ព្រះយេស៊ូមានបន្ទូលតបទៅពួកគេវិញថា៖ «ព្យាការីអេសាយបានថ្លែងទុកថា៖ «អ្នករាល់គ្នាជាមនុស្សមានពុត»។[7]លោកបានថ្លែងថា៖
«ប្រជាជននេះគោរពយើងតែបបូរមាត់ប៉ុណ្ណោះ តែចិត្តគំនិតគេនៅឆ្ងាយពីយើងណាស់»។
[8]ដ្បិត អ្នករាល់គ្នាបានលះចោលបញ្ញត្តិរបស់ព្រះជាម្ចាស់ ទៅកាន់តាមទំនៀមទម្លាប់របស់មនុស្សវិញ។[9]ព្រះអង្គក៏មានបន្ទូលទៅកាន់ពួកគេថា៖
«អ្នករាល់គ្នាបោះបង់បទបញ្ញត្តិរបស់ព្រះជាម្ចាស់ចោល ហើយបែរទៅកាន់តាមទំនៀមទម្លាប់របស់អ្នករាល់គ្នាវិញ![10]ដ្បិត លោកម៉ូសេបានផ្តាំថា៖
«ចូរគោរពប្រតិបត្តិឪពុកម្តាយខ្លួន ហើយបើអស់អ្នកណាដែលនិយាយពាក្យអាក្រក់ពីឪពុកម្តាយខ្លួន អ្នកនោះនឹងត្រូវស្លាប់ជាមិនខាន»។
[11]ប៉ុន្តែ អ្នករាល់គ្នានិយាយថា៖ «បើអ្នករាល់គ្នានិយាយទៅកាន់ឪពុកម្តាយខ្លួននូវអ្វីៗដែលខ្ញុំអាចជួយឪពុកម្តាយបាន គឺពាក្យ គ័របាន់» «ដែលមានន័យថា
ជាតង្វាយថ្វាយទៅព្រះជាម្ចាស់។[12]នោះអ្នករាល់គ្នាមិនឲ្យគាត់ជួយឪពុកម្តាយ ក្នុងការធ្វើអ្វីទៀតសោះ។[13]ហើយអ្នករាល់គ្នាក៏លើកព្រះបន្ទូលព្រះជាម្ចាស់ចោល
ដោយសារទំនៀមទម្លាប់ដែលអ្នករាល់គ្នាបានបង្ហាត់បង្រៀនមក ហើយអ្នករាល់គ្នាក៏ធ្វើកិច្ចការផ្សេងៗទៀតដូចការនេះដែរ»។
[14]រួចព្រះអង្គបានហៅបណ្តាជនដោយមានបន្ទូលទៅកាន់ពួកគេថា៖ «អ្នករាល់គ្នាសូមស្តាប់ខ្ញុំ ហើយឲ្យយល់ចុះ!។[15]គ្មានអ្វីពីខាងក្រៅ
ដែលចូលទៅក្នុងខ្លួនមនុស្សអាចធ្វើឲ្យស្មោកគ្រោកទេ តែអ្វីដែលចេញមកពីខ្លួនមនុស្សទេតើដែលធ្វើឲ្យស្មោកគ្រោកវិញ»។[16]បើអ្នកណាមានត្រចៀកស្តាប់ ចូរឲ្យស្តាប់ចុះ។
[17]កាលព្រះយេស៊ូយាងចេញពីបណ្តាជន ហើយចូលទៅក្នុងផ្ទះ ពួកសិស្សរបស់ព្រះអង្គនាំគ្នាទូលសួរព្រះអង្គពីពាក្យប្រៀបធៀបនោះ។[18]ព្រះយេស៊ូមានបន្ទូលតបទៅគេថា៖
«អ្នករាល់គ្នាមិនទាន់យល់ទេឬអី? តើអ្នករាល់គ្នាមិនបានឃើញទេថា របស់អ្វីពីខាងក្រៅ ដែលចូលទៅក្នុងខ្លួនមនុស្សមិនបានធ្វើឲ្យស្មោកគ្រោកទេ[19]ដ្បិត

generated on Wed Sep 10 16:16:32 2025

អ្វីៗទាំងនោះមិនចូលដល់ក្នុងចិត្តទេ គឺវាចូលទៅក្នុងពោះហើយចេញមកវិញធ្លាក់ចូលទៅក្នុងបង្គន់»។ ព្រះយេស៊ូមានបន្ទូលបញ្ជាក់ប្រាប់គេថា
គ្រប់ទាំងអាហារទាំងអស់សុទ្ធតែជារបស់ស្អាត។
[20]ព្រះអង្គបានមានបន្ទូលថា៖ «គឺជាអ្វីដែលចេញពីខ្លួនមនុស្សទេតើ ដែលធ្វើឲ្យស្មោកគ្រោកវិញ។[21]ដ្បិត អ្វីដែលនៅខាងក្នុងមនុស្សគឺចេញពីចិត្តគេ
គឺមានគំនិតស្មោកគ្រោក ដែលនាំឲ្យប្រព្រឹត្តិអំពើអាក្រក់ផ្សេងៗដូចជា អាសអាភាស លួចប្លន់ កាប់សម្លាប់គ្នា[22]អំពើកំផិតសហាយស្មន់ លោភលន់ចង់បានទ្រព្យអ្នកដទៃ
កាចឃោឃៅ បោកបញ្ឆោតគេ កាមតុណ្ហា ច្រណែន មួលបង្កាច់ អំនួត និងសេចក្តីចម្កួត។[23]សេចក្តីអាក្រក់ទាំងនេះហើយចេញពីខាងក្នុង
ដែលធ្វើឲ្យមនុស្សស្មោកគ្រោកវិញ»។
[24]ព្រះអង្គក្រោកឡើង ហើយយាងចេញពីទីនោះឆ្ពោះទៅក្រុងទីរ៉ុស និងក្រុងស៊ីដូន។ រួចព្រះអង្គក៏យាងចូលទៅក្នុងផ្ទះមួយ
ដោយទ្រង់មិនចង់ឲ្យនណាម្នាក់ដឹងថាទ្រង់គង់នៅទីនោះឡើយ តែមិនអាចលាក់ជិតបានឡើយ។[25]ភ្លាមនោះ
មានស្ត្រីម្នាក់ដែលមានកូនស្រីត្រូវវិញ្ញាណអារក្សចូលបានឮគេនិយាយពីព្រះអង្គ ស្ត្រីនោះក៏មករកព្រះអង្គហើយលុតជង្គង់ក្រាមនៅទៀបព្រះបាទព្រះអង្គ។
[26]ស្ត្រីនោះជាសាសន៍ក្រិក កូនកាត់ស៊ីរ៉ុសភេនីស។ ស្ត្រីនោះទទូចអង្វរព្រះអង្គសុំឲ្យដេញវិញ្ញាណអាក្រក់នោះចេញពីកូនស្រីនាង។
[27]ព្រះអង្គមានបន្ទូលតបទៅនាងថា៖ «ចូរទុកឲ្យកូនៗហូបអាហារឆ្អែតជាមុនសិន ដ្បិត មិនគួរយកនំប៉័ងរបស់កូនទៅឲ្យឆ្កែស៊ីទេ»។[28]ប៉ុន្តែនាងទូលព្រះអង្គថា៖
«មែនហើយព្រះអម្ចាស់ ប៉ុន្តែ ឆ្កែដែលនៅក្រោមតុនោះវាស៊ីតែកម្ទេចដែលជ្រុះពីកូនក្មេងប៉ុណ្ណោះ»។
[29]នោះព្រះអង្គមានបន្ទូលទៅនាងថា៖ «ដោយនាងបាននិយាយដូច្នោះហើយ ចូរនាងទៅវិញចុះ អារក្សបានចេញពីកូនស្រីនាងហើយ»។
[30]ពេលនាងត្រឡប់ទៅផ្ទះវិញក៏បានដឹងថាកូននាងកំពុងតែដេកសម្រាកនៅលើគ្រែ ហើយអារក្សនោះក៏បានចេញពីកូនមែន។
[31]បន្ទាប់មក ព្រះអង្គក៏យាងចេញពីក្រុងទីរ៉ុសកាត់តាមក្រុងស៊ីដូន និងស្រុកដេកាប៉ូល ឆ្ពោះទៅកាន់សមុទ្រកាលីឡេ។[32]មានគេនាំមនុស្សថ្លង់ម្នាក់
ដែលពិបាកនិយាយមកឯព្រះអង្គ ហើយអង្វរឲ្យព្រះអង្គដាក់ព្រះហស្តលើគាត់។
[33]ព្រះអង្គក៏នាំគាត់ចេញពីបណ្តាជនទៅដោយឡែកពីពួកគេ ហើយព្រះអង្គក៏យកព្រះហស្តដាក់ក្នុងត្រចៀកគាត់ រួចបន្ទាប់ពីស្តោះទឹកព្រះឱស្ឋ ព្រះអង្គក៏ពាល់អណ្តាតគាត់។
[34]ព្រះអង្គបានងើបទតទៅលើមេឃ ហើយមានបន្ទូលថា៖ «អ៊ិបផាថា» ដែលមានន័យថា «ចូរបើកឡើង»![35]ភ្លាមនោះត្រចៀកគាត់ក៏បានបើក អណ្តាតក៏គ្រលាស់បាន
ហើយគាត់ក៏ចាប់ផ្តើមនិយាយយ៉ាងច្បាស់។
[36]ព្រះយេស៊ូមានព្រះបន្ទូលហាមពួកគេមិនឲ្យប្រាប់រឿងរ៉ាវដែលពួកគេបានដឹងដល់អ្នកណាម្នាក់ឡើយ ប៉ុន្តែ ពួកគេនៅតែប្រាប់រឿងរ៉ាវទាំងនោះដល់បណ្តាជនដដែរ។
[37]ពួកគេងឿងឆ្ងល់យ៉ាងខ្លាំងហើយ និយាយថា៖ «លោកធ្វើគ្រប់កិច្ចការបានយ៉ាងល្អ សូម្បីតែមនុស្សថ្លង់ក៏លោកធ្វើបានស្តាប់ឮ ហើយមនុស្សគក៏និយាយបាន»។

Mark 7:1
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្ទោសពួកផារីស៊ីនិងពួកអាចារ្យ។
នាំគ្នាទៅជួបព្រះយេស៊ូ
«បានប្រមូលផ្តុំគ្នានៅជុំវិញព្រះយេស៊ូ»
Mark 7:2
ព័ត៌មានទូទៅ:
ខ៣ និងខ៤ ផ្តល់ព័ត៌មានអំពីប្រពៃណីការលាងជម្រះរបស់ពួកផារីស៊ី។
យូឌីប៊ីប្រើជាស្ពានភ្ជាប់ព័ត៌មានក្នុងខ៣ និង៤ ដើម្បីងាយស្រួលយល់។
ពួកគេបានឃើញ
«ហើយពួកផារីស៊ីនិងពួកអាចារ្យបានឃើញ
មិនបានលាងជាមុនឡើយ។
អាចមានប្រយោជន៍ក្នុងការបន្ថែមព័ត៌មានដែលបាត់។
«ពួកគេបានបរិភោគដោយមិនលាងដៃ»
ពីចាស់បុរាណ
ព្រឹទ្ធាចារ្យយូដាជាអ្នកដឹកនាំនៅក្នុងសហគមន៍របស់ពួកគេហើយក៏ជាចៅក្រមកាត់ទោសលើបញ្ហាផ្សេងៗទៀតផងដែរ
លាងថូ
«ធុងដែក»
តុជាដើម ជាអ្វីៗដែលត្រូវប្រើសម្រាប់ហូបអាហារ
«កៅអីអង្គុយ» ឬ «គ្រែ» ។ ពេលនោះជនជាតិយូដានឹងអង្គុយចុះពេលបរិភោគ។
Mark 7:5
តើហេតុអ្វីបានជាពួកសិស្សរបស់លោក មិនកាន់តាមទំនៀមទម្លាប់ចាស់បុរាណ
ដោយនាំគ្នាហូបអាហាររបស់ពួកគេដោយដៃមិនស្អាតយ៉ាងដូច្នេះ?
ពួកផារីស៊ីនិងពួកអាចារ្យបានសួរសំណួរនេះដើម្បីតតាំងនឹងសិទ្ធិអំណាចរបស់ព្រះយេស៊ូ។
អាចសរសេរជាឃ្លាពីរ។
«សិស្សរបស់អ្នកមិនគោរពតាមទំនៀមទម្លាប់របស់ពួកព្រឹទ្ធាចារ្យរបស់យើងទេ។
ពួកគេគួរតែលាងដៃដោយប្រើប្រពៃណីរបស់យើង» ។
អាហារ
តំណាងឲ្យអាហារជាទូទៅ។ «ម្ហូប»
Mark 7:6
ព័ត៌មានទូទៅ:
នៅទីនេះព្រះយេស៊ូបានដកស្រង់ពាក្យរបស់ព្យាការីអេសាយដែលបានសរសេរបទគម្ពីរ
តែបបូរមាត់ប៉ុណ្ណោះ
ពាក្យ «បបូរមាត់» នៅទីនេះសំដៅទៅលើការនិយាយ។
«តាមអ្វីដែលពួកគេនិយាយ» (សូមមើល:
តែចិត្តគំនិតគេនៅឆ្ងាយពីយើងណាស់
ត្រង់នេះ «បេះដូង» សំដៅទៅលើគំនិតឬអារម្មណ៍របស់មនុស្សម្នាក់។
នេះជាវិធីនិយាយថា មនុស្សមិនស្មោះត្រង់ចំពោះព្រះជាម្ចាស់ទេ។
«ប៉ុន្តែពួកគេពិតជាមិនស្រឡាញ់ខ្ញុំទេ»
គោរពយើងតែបបូរមាត់ប៉ុណ្ណោះ
«ពួកគេថ្វាយបង្គំយើងដោយទទេ» ឬ «ពួកគេគោរពយើងដោយឥតប្រយោជន៍»
Mark 7:8
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តបន្ទោសពួកអាចារ្យនិងពួកផារិស៊ី។
លះចោល
«បដិសេធមិនព្រមធ្វើតាម»
ទៅកាន់តាម
«កាន់យ៉ាងខ្លាំង» ឬ «រក្សាទុក»
អ្នករាល់គ្នាបោះបង់បទបញ្ញត្តិរបស់ព្រះជាម្ចាស់ចោល
ហើយបែរទៅកាន់តាមទំនៀមទម្លាប់របស់អ្នករាល់គ្នាវិញ
ព្រះយេស៊ូប្រើពាក្យដ៏ហួសចិត្តនេះ ដើម្បីស្តីបន្ទោសដល់អ្នកស្តាប់ព្រះអង្គ
ដែលបានបដិសេធបទបញ្ញត្តិរបស់ព្រះជាម្ចាស់។
«អ្នកគិតថាអ្នកធ្វើបានល្អក្នុងរបៀបដែលអ្នកបដិសេធបទបញ្ជារបស់ព្រះជាម្ចាស់
ដូច្នេះអ្នកអាចរក្សាទំនៀមទំលាប់របស់អ្នក
តែអ្វីដែលអ្នកបានធ្វើមិនល្អទាល់តែសោះ!»
អ្នករាល់គ្នាបោះបង់
«អ្នកបដិសេធយ៉ាងប៉ិនប្រសប់»
និយាយពាក្យអាក្រក់
«ដែលដាក់បណ្តាសា»
នឹងត្រូវស្លាប់ជាមិនខាន
«ត្រូវតែសម្លាប់»
អស់អ្នកណាដែលនិយាយពាក្យអាក្រក់ពីឪពុកម្តាយខ្លួន អ្នកនោះនឹងត្រូវស្លាប់ជាមិនខាន
អ្នកណាដែលនិយាយអាក្រក់ពីឪពុកម្តាយគាត់ ច្បាស់ជាស្លាប់ហើយ។
«អាជ្ញាធរត្រូវតែប្រហារជីវិតមនុស្សដែលនិយាយអាក្រក់ពីឪពុកឬម្តាយ»
Mark 7:11
ព័ត៌មានទូទៅ:
យូឌីប៊ីប្រើស្ពានភ្ជាប់ពីខ១១ និង១២ ដើម្បីពន្យល់កាន់តែច្បាស់
ព្រះយេស៊ូកំពុងតែមានបន្ទូលទៅកាន់ពួកផារីស៊ី។
នូវអ្វីៗដែលខ្ញុំអាចជួយឪពុកម្តាយបាន គឺពាក្យ គ័របាន់
ទំនៀមទម្លាប់របស់ពួកអាចារ្យចែងថា
ពេលលុយឬវត្ថុផ្សេងទៀតត្រូវបានសន្យាសម្រាប់ព្រះវិហារ
ពួកគេមិនអាចប្រើសម្រាប់គោលបំណងផ្សេងទៀតបានទេ។

generated on Wed Sep 10 16:16:32 2025

គំរបាន់
នៅទីនេះអ្នកនិពន្ធសំដៅទៅលើអ្វីមួយដោយពាក្យហេប្រឺ។
ពាក្យនេះគួរតែត្រូវបានចម្លងដូចទៅនឹងភាសារបស់អ្នកដោយប្រើអក្ខរក្រមរបស់អ្នក។
ថ្វាយទៅព្រះជាម្ចាស់
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ខ្ញុំបានប្រគល់វាទៅព្រះជាម្ចាស់»
នោះអ្នករាល់គ្នាមិនឲ្យគាត់ជួយឪពុកម្តាយ ក្នុងការធ្វើអ្វីទៀតសោះ
ធ្វើដូចនេះពួកផារីស៊ីកំពុងអនុញ្ញាតឲ្យមនុស្សមិនផ្គត់ផ្គង់ឪពុកម្តាយរបស់ពួកគេ
ប្រសិនបើពួកគេសន្យាផ្តល់ដល់ព្រះជាម្ចាស់នូវអ្វីដែលពួកគេនឹងផ្តល់ឲ្យពួកគេ។
ចោល
លុបចោលឬធ្វើរួចជាមួយ
ធ្វើកិច្ចការផ្សេងៗទៀតដូចការនេះដែរ
«ហើយអ្នកកំពុងធ្វើរឿងផ្សេងទៀតដែលស្រដៀងនឹងរឿងនេះ»
Mark 7:14
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបានលើកឧទាហរណ៍មួយដល់បណ្តាជនដើម្បីជួយពួកគេឲ្យយល់អំពីអ្វី
ដែលទ្រង់បានមានបន្ទូលទៅកាន់ពួកអាចារ្យនិងផារីស៊ី។
ព្រះអង្គបានហៅ
«ព្រះយេស៊ូបានហៅ»
អ្នករាល់គ្នាសូមស្តាប់ខ្ញុំ ហើយឲ្យយល់ចុះ
ពាក្យ «ស្តាប់» និង "យល់" មានទំនាក់ទំនងគ្នា។
ព្រះយេស៊ូប្រើពាក្យជាមួយគ្នាដើម្បីបញ្ជាក់ថា
អ្នកស្តាប់ទ្រង់គួរយកចិត្តទុកដាក់នឹងអ្វី ដែលទ្រង់កំពុងមានបន្ទូល។
យល់
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីអ្វី
ដែលព្រះយេស៊ូកំពុងតែមានបន្ទូលប្រាប់ពួកគេឲ្យយល់។
«ព្យាយាមយល់ពីអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក»
គ្មានអ្វីពីខាងក្រៅ ដែលចូលទៅក្នុងខ្លួនមនុស្ស
ព្រះយេស៊ូកំពុងនិយាយអំពីអ្វីដែលមនុស្សបរិភោគ។ ផ្ទុយពី
«អ្វីដែលចេញមកពីមនុស្ស» ។ «គ្មានអ្វីដែលមកពីខាងក្រៅមនុស្ស
ដែលមនុស្សអាចបរិភោគបាន»
តែអ្វីដែលចេញមកពីខ្លួនមនុស្សទេតើ
សំដៅទៅលើអ្វីដែលមនុស្សធ្វើឬនិយាយ។ ផ្ទុយទៅនឹង
«អ្វីដែលនៅខាងក្រៅមនុស្ស ដែលចូលទៅក្នុងមនុស្ស» ។
«ជាអ្វីដែលចេញពីមនុស្ស ដោយការនិយាយឬធ្វើ»
Mark 7:17
ឃ្លាភ្ជាប់៖
ពួកសិស្សនៅតែមិនយល់ពីអ្វីដែលព្រះយេស៊ូមានបន្ទូលទៅកាន់ពួកអាចារ្យ
ពួកផារីស៊ីនិងហ្វូងមនុស្ស។ ព្រះយេស៊ូពន្យល់អត្ថន័យយ៉ាងច្បាស់ឲ្យពួកគេយល់។
ឥឡូវនេះ
ពាក្យនេះប្រើសម្រាប់សម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់។ ឥឡូវនេះ
ព្រះយេស៊ូឃ្លាតឆ្ងាយពីហ្វូងមនុស្សនៅក្នុងផ្ទះមួយជាមួយពួកសិស្ស។
អ្នករាល់គ្នាមិនទាន់យល់ទេឬអី?
ព្រះយេស៊ូប្រើសំណួរនេះដើម្បីបង្ហាញពីការខកចិត្តរបស់គេដែលពួកគេមិនយល់។
អាចបង្ហាញជាឃ្លាថា «បន្ទាប់ពីខ្ញុំបាននិយាយប្រាប់មករួចមក
ខ្ញុំរំពឹងថាអ្នករាល់គ្នានឹងយល់» ។
តើអ្នករាល់គ្នាមិនបានឃើញទេថា របស់អ្វីពីខាងក្រៅ ដែលចូលទៅក្នុង...ទៅក្នុងបង្គន់?
ព្រះយេស៊ូប្រើសំណួរនេះដើម្បីបង្រៀនសិស្សរបស់ព្រះអង្គនូវអ្វីដែលពួកគេគួរដឹង។
អាចបង្ហាញជាឃ្លា «អ្វីក៏ដោយចូល ... បង្គន់»។
ដ្បិត
នៅទីនេះ «វា» សំដៅទៅលើអ្វីដែលចូលទៅក្នុងមនុស្សម្នាក់;
ជាអ្វីដែលមនុស្សបរិភោគ។
ព្រះយេស៊ូមានបន្ទូលបញ្ជាក់ប្រាប់គេថា គ្រប់ទាំងអាហារទាំងអស់សុទ្ធ
«ព្រះយេស៊ូបានប្រកាស»
គ្រប់ទាំងអាហារទាំងអស់សុទ្ធតែជារបស់ស្អាត
អាចមានប្រយោជន៍ក្នុងការពន្យល់យ៉ាងច្បាស់ពីអត្ថន័យនៃឃ្លានេះ។
«អាហារទាំងអស់ស្អាតមានន័យថា
មនុស្សអាចបរិភោគអាហារណាមួយដោយពុំបានគិតថា ដល់ព្រះជាម្ចាស់
ចាត់ទុកជាអ្នកបរិភោគប្រមាថ» ។
Mark 7:20
ព្រះអង្គបានមានបន្ទូលថា
ព្រះអង្គបានមានបន្ទូលថា
គឺជាអ្វីដែលចេញពីខ្លួនមនុស្សទេតើ
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ឱ្យច្បាស់ថា «វា» សំដៅទៅលើអ្វី។
«ជាគំនិតនិងសកម្មភាពដែលចេញមកពី»
កាមតណ្ហា
មិនបានគ្រប់គ្រងបំណងប្រាថ្នាតណ្ហារបស់មនុស្សម្នាក់
ចេញពីខាងក្នុង
នៅទីនេះពាក្យ "ខាងក្នុង" ពិពណ៌នាអំពីចិត្តរបស់មនុស្សម្នាក់។
«មកពីបេះដូងរបស់មនុស្ស» ឬ «មកពីគំនិតរបស់មនុស្ស»
Mark 7:24
ឃ្លាភ្ជាប់៖
ពេលព្រះយេស៊ូទៅក្រុងទីរ៉ុស ទ្រង់បានប្រោសកូនស្រីរបស់ស្ត្រីសាសន៍ដទៃ
ដែលមានជំនឿមុតមាំម្នាក់ឲ្យជាសះស្បើយ។
វិញ្ញាណអារក្សចូល
ជាក្រៀមភាសា ដែលមានន័យថាត្រូវវិញ្ញាណអាក្រក់ចូល។
«ត្រូវបានចូលដោយវិញ្ញាណស្មោកគ្រោក»
លុតជង្គង់
«លុតជង្គង់» ។ នេះជាទង្វើលើកតម្កើងកិត្តិយសនិងការចុះចូល។
ស្ត្រីនោះជាសាសន៍ក្រិក កូនកាត់ស៊ីរ៉ុសភេនីស
ពាក្យថា «ឥឡូវនេះ» ជាការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់
ព្រោះថាប្រយោគនេះផ្តល់ឲ្យយើងនូវព័ត៌មានសំខាន់អំពីស្ត្រី។
កូនកាត់ស៊ីរ៉ុសភេនីស
ជាឈ្មោះសញ្ជាតិរបស់ស្ត្រី។ នាងកើតនៅតំបន់ភេនីនៀរក្នុងប្រទេសស៊ីរី។
Mark 7:27
ចូរទុកឲ្យកូនៗហូបអាហារឆ្អែតជាមុនសិន ដ្បិត មិនគួរយកនំប៉័ងរបស់កូនទៅឲ្យឆ្កែស៊ីទេ
នៅទីនេះព្រះយេស៊ូមានបន្ទូលអំពីពួកយូដា ពួកគេប្រៀបដូចជាកូនក្មេង
និងជាតិសាសន៍ដទៃដូចជាឆ្កែ។ «ទុកឲ្យកូនចៅអ៊ីស្រាអែលបរិភោគជាមុន។
មិនត្រឹមត្រូវទេ
ដែលយកនំប៉័ងរបស់កូនចៅបោះទៅឲ្យសាសន៍ដទៃដែលមានលក្ខណៈដូចឆ្កែ»
ចូរទុកឲ្យកូនៗហូបអាហារ
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «យើងត្រូវតែច
ម្ហែតកូនចៅអ៊ីស្រាអែលជាមុនសិន»
នំប៉័ង
សំដៅទៅលើអាហារជាទូទៅ។ «ម្ហូប»
ឆ្កែ
សំដៅទៅលើសត្វឆ្កែតូចៗ ដែលទុកជាសត្វចិញ្ចឹម។
Mark 7:29
ចូរនាងទៅវិញចុះ
«អ្នកអាចទៅឥឡូវ» ឬ «ទៅផ្ទះ»
អារក្សបានចេញពីកូនស្រីនាងហើយ
ព្រះយេស៊ូបានបណ្តេញវិញ្ញាណអាក្រក់ឲ្យចេញពីកូនស្រីរបស់ស្ត្រីនោះ។
អាចបញ្ជាក់យ៉ាងច្បាស់។
«ខ្ញុំបានបណ្តេញវិញ្ញាណអាក្រក់ឲ្យចេញពីកូនស្រីរបស់អ្នកហើយ»
Mark 7:31
ឃ្លាភ្ជាប់៖
ក្រោយពីបានប្រោសមនុស្សឲ្យជាសះស្បើយនៅក្រុងទីរ៉ុស
ព្រះយេស៊ូយាងទៅសមុទ្រកាលីឡេ។ នៅទីនោះទ្រង់បានប្រោសបុរសថ្លង់ម្នាក់
ធ្វើឱ្យមនុស្សភ្ញាក់ផ្អើល។
យាងចេញពីក្រុង
«ត្រឡប់មកពី»
ឆ្ពោះទៅកាន់
អាចមានន័យថា ១) «នៅក្នុងតំបន់»
ដូចជាព្រះយេស៊ូនៅឯសមុទ្រក្នុងតំបន់ដេប៉ូកាឬទី ២) «ឆ្លងតាមតំបន់»
នៅពេលដែលព្រះយេស៊ូបានឆ្លងកាត់តំបន់ដេកាប៉ូលទៅដល់សមុទ្រ។
ដេកាប៉ូល
ជាឈ្មោះនៃតំបន់មួយដែលមានន័យថាទីក្រុងដប់។
វាមានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃសមុទ្រកាលីឡេ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង៥:១៨ ។

generated on Wed Sep 10 16:16:32 2025

មានគេនាំ
«ហើយប្រជាជនបាននាំយកមក»
ពិបាកនិយាយ
«ដែលមិនអាចស្តាប់»
ព្រះអង្គដាក់ព្រះហស្តលើគាត់
ការដាក់ដៃលើសំដៅទៅលើព្យាការី
ឬគ្រូម្នាក់ដាក់ដៃលើនរណាម្នាក់ហើយផ្តល់ការប្រោសឲ្យជា ឬពរជ័យ។
ក្នុងករណីនេះប្រជាជនកំពុងអង្វរព្រះយេស៊ូ ឲ្យប្រោសបុរសម្នាក់នេះ។ «
ដាក់ដៃលើគាត់ដើម្បីប្រោសគាត់ឲ្យជា»
Mark 7:33
ព្រះអង្គក៏នាំគាត់ចេញ
«ព្រះយេស៊ូបានយកបុរសនោះ»
ព្រះអង្គក៏យកព្រះហស្តដាក់ក្នុងត្រចៀកគាត់
ព្រះយេស៊ូកំពុងតែដាក់ព្រះហស្តលើត្រចៀករបស់បុរសនោះ។
រួចបន្ទាប់ពីស្តោះទឹកព្រះឱស្ឋ ព្រះអង្គក៏ពាល់អណ្តាតគាត់
ព្រះយេស៊ូស្តោះទឹកមាត់ហើយប៉ះអណ្តាតរបស់បុរសនោះ។
បន្ទាប់ពីស្តោះទឹកព្រះឱស្ឋ
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា
ព្រះយេស៊ូបានស្តោះទឹកមាត់ដាក់ម្រាមដៃរបស់ទ្រង់។
«បន្ទាប់ពីស្តោះទឹកមាត់ដាក់ម្រាមដៃរបស់ទ្រង់»
បានងើបទតទៅលើមេឃ
មានន័យថា ទ្រង់បានសំឡឹងមើលទៅលើមេឃដែលជាកន្លែងដែលព្រះអង្គគង់នៅ។
អិបផាថា
នៅទីនេះអ្នកនិពន្ធសំដៅទៅលើពាក្យអារ៉ាម។
ពាក្យនេះគួរតែចម្លងដូចទៅនឹងភាសារបស់អ្នក ដោយប្រើអក្ខរក្រមរបស់អ្នក។
ងើបទតទៅ
ដកដង្ហើមចូល និងដកដង្ហើមចេញវែងៗ។
មានបន្ទូលថា
«បាននិយាយទៅកាន់បុរសនោះ»
ត្រចៀកគាត់ក៏បានបើក
មានន័យថាគាត់អាចស្តាប់បាន។ «ត្រចៀករបស់គាត់ត្រូវបានបើក
ហើយគាត់អាចស្តាប់បាន» ឬ «គាត់អាចស្តាប់បាន»
ហើយគាត់ក៏ចាប់ផ្តើមនិយាយយ៉ាងច្បាស់
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«ព្រះយេស៊ូបានដកយកអ្វីដែលរារាំងអណ្តាតរបស់គាត់
មិនឲ្យនិយាយបាននោះចេញ» ឬ «ព្រះយេស៊ូបានបន្ធូរអណ្តាត»
អ្វីដែលរារាំងអណ្តាតរបស់គាត់
«អ្វីដែលរារាំងគាត់មិនឲ្យនិយាយ» ឬ «រារាំងការនិយាយរបស់គាត់»
Mark 7:36
ទ្រង់បញ្ជាគេអោយកាន់តែច្រើន
អាចមានប្រយោជន៍ក្នុងការបន្ថែមព័ត៌មានដែលបាត់។
«ព្រះអង្គបានបញ្ជាមនុស្សកាន់តែច្រើនមិនឱ្យប្រាប់នរណាម្នាក់»
កាន់តែច្រើន
«កាន់តែទូលំទូលាយ» ឬ «កាន់តែច្រើន»
ពិតជា
«ទាំងស្រុង» ឬ «ខ្លាំង»
មនុស្សថ្លង់...មនុស្សគ
សំដៅទៅលើមនុស្ស។ «មនុស្សថ្លង់ ... មនុស្សគ» ឬ «មនុស្សដែលមិនអាចស្តាប់
មនុស្សដែលមិនចេះនិយាយ»

---

8 [1]នៅថ្ងៃនោះ បណ្តាជនបានមកជុំគ្នាយ៉ាងច្រើនកុះករជាថ្មីម្តងទៀត ហើយពួកគេមិនមានអ្វីហូបឡើយ។ ព្រះយេស៊ូបានហៅពួកសិស្ស ហើយមានបន្ទូលទៅគេថា៖
[2]«ខ្ញុំមានចិត្តអាណិតអាសូរចំពោះបណ្តាជនទាំងនេះណាស់ ពួកគេបាននៅជាមួយខ្ញុំអស់រយៈពេលបីថ្ងៃហើយ ហើយពេលនេះពួកគេគ្មានអ្វីសម្រាប់ហូបសោះ។
[3]បើខ្ញុំឲ្យពួកគេត្រឡប់ទៅផ្ទះវិញទាំងអត់អាហារដូច្នេះ ពួកគេប្រាកដជាហេវហត់តាមផ្លូវហើយ ដ្បិត មានមនុស្សខ្លះមកពីឆ្ងាយ»[4]ពួកសិស្សព្រះអង្គក៏ទូលទៅព្រះអង្គថា៖
«តើឲ្យយើងខ្ញុំទៅរកអាហារដើម្បីមកចម្អែតបណ្តាជននៅក្នុងទីរហោស្ថានយ៉ាងនេះដូចម្តេចទៅ»?
[5]ព្រះអង្គក៏តបទៅគេវិញថា៖ «តើអ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?» ពួកគេទូលថា៖ «មានប្រាំពីរដុំ»។[6]ព្រះអង្គក៏បង្គាប់ឲ្យបណ្តាជនអង្គុយនៅលើដី។
ព្រះអង្គយកនំប៉័ងទាំងប្រាំពីរនោះមកអរព្រះគុណហើយ កាច់ឲ្យពួកសិស្ស ហើយឲ្យចែកដល់បណ្តាជន។
[7]ពួកគេក៏មានត្រីតូចៗខ្លះដែរ ហើយកាលព្រះអង្គបានអរព្រះគុណហើយ ទ្រង់ក៏បង្គាប់ឲ្យលើកទៅឲ្យគេទៀត។[8]ពួកគេហូបឆ្អែតគ្រប់គ្នា រួចគេប្រមូលបាននំប៉័ង
និងត្រីដែលនៅសល់បានប្រាំពីរកន្ត្រក់។[9]នៅគ្រានោះបណ្តាជនទាំងអស់ប្រមាណជាបួនពាន់នាក់។ រួចព្រះអង្គបានឲ្យពួកគេត្រឡប់ទៅវិញ។
[10]រំពេចនោះស្រាប់តែព្រះអង្គយាងចុះទូកជាមួយពួកសិស្សឆ្ពោះទៅស្រុក ដាល់ម៉ានូថាទៅ។
[11]នោះពួកផារីស៊ីចេញមក ជជែកវែកញែកដើម្បីល្បងលព្រះអង្គ ដោយសុំឲ្យព្រះអង្គសម្តែងទីសម្គាល់ដ៏អស្ចារ្យពីស្ថានសួគ៌ឲ្យគេបានឃើញផង។
[12]ព្រះយេស៊ូដកដង្ហើមក្នុងវិញ្ញាណរបស់ព្រះអង្គ ទាំងមានបន្ទូលថា៖ «ហេតុអ្វីបានជាមនុស្សជំនាន់នេះចង់ឃើញតែទីសម្គាល់ដូច្នេះ?
ប្រាកដណាស់ខ្ញុំសូមប្រាប់អ្នករាល់គ្នាជាប្រាកដថានឹងគ្មានទីសម្គាល់ណាបានប្រទានមកមនុស្សជំនាន់នេះឡើយ»។[13]រួចព្រះអង្គក៏យាងចេញពីពួកគេ
ហើយចុះទូកឆ្លងទៅឯត្រើយម្ខាងទៀតវិញ។
[14]ឯពួកសិស្សភ្លេចយកនំប៉័ងទៅជាមួយ។ ពួកគេមាននំប៉័ងតែមួយដុំប៉ុណ្ណោះនៅលើទូក។[15]ព្រះយេស៊ូមានបន្ទូលរំលឹកដាស់តឿនពួកគេថា៖ «ចូរប្រុងប្រយ័ត្នមើល
ហើយក៏ប្រយ័ត្ននឹងមេដំបែររបស់ពួកផារីស៊ី និងស្តេចហេរ៉ូដឲ្យមែនទែន»។
[16]ពួកសិស្សនាំគ្នារិះគិតពិចារណាថា៖ «នេះមកពីយើងគ្មាននំប៉័ងទេដឹង»។[17]ព្រះយេស៊ូជ្រាបពីការនេះ នោះទ្រង់មានបន្ទូលទៅកាន់ពួកគេថា៖
«តើអ្នករាល់គ្នានៅរិះគិតពីការដែលគ្មាននំប៉័ង? តើអ្នករាល់គ្នាមិនទាន់គិតឃើញ? មិនទាន់យល់ទេឬអី? តើអ្នកមានចិត្តរឹងចចេសឬ?
[18]អ្នករាល់គ្នាមានភ្នែក តែមើលមិនឃើញឬ? អ្នករាល់គ្នាក៏មានត្រចៀកតែស្តាប់មិនឮឬ? អ្នកមិនចាំទេឬអី?[19]ពីកាលខ្ញុំបានកាច់នំប៉័ងប្រាំដុំ ចែកឲ្យមនុស្សប្រាំពាន់នាក់
ហើយពីរបៀបដែលអ្នករាល់គ្នាបានប្រមូលចំណិតដែលសល់បានប៉ុន្មានកន្ត្រក»? ពួកគេឆ្លើយថា៖ «បានដប់ពីរ»។
[20]ហើយកាលដែលខ្ញុំបានកាច់នំប៉័ង៧ដុំ ឲ្យទៅមនុស្សបួនពាន់នាក់ តើអ្នករាល់គ្នាប្រមូលទុកបានប៉ុន្មាន? ពួកគេឆ្លើយ៖ «បានប្រាំពីរ»[21]ព្រះអង្គទូលសួរថា៖
«តើអ្នកនៅមិនយល់ទៀតមែនទេ»?
[22]ព្រះយេស៊ូ និងពួកសិស្សក៏បានធ្វើដំណើរដល់ភូមិបេតសៃដា។ ពេលនោះមានគេនាំអ្នកពិការភ្នែកមកឯងព្រះអង្គហើយសុំឲ្យព្រះអង្គពាល់គាត់។
[23]ព្រះយេស៊ូបានដឹកដៃអ្នកពិការភ្នែកនោះចេញទៅក្រៅភូមិ។ រួចព្រះអង្គបានស្តោះព្រះឱស្ឋលើភ្នែកគាត់ ហើយដាក់ព្រះហស្តលើគាត់ ដោយសួរថា៖
«តើលោកបានឃើញអ្វីខ្លះ»?
[24]គាត់ក៏បើកភ្នែកឡើងហើយនិយាយថា៖ «ខ្ញុំឃើញមនុស្សដើរ មើលទៅដូចជាដើមឈើអ៊ីចឹង»។[25]រួចព្រះអង្គក៏ដាក់ព្រះហស្តលើភ្នែកគាត់ម្តងទៀត
ហើយពេលនោះបុរសនោះក៏បានបើកភ្នែកមើល ហើយស្រាប់តែ បានភ្លឺឡើង ហើយមើលឃើញអ្វីៗច្បាស់ទាំងអស់។[26]ព្រះយេស៊ូបានឲ្យគាត់ត្រឡប់ទៅផ្ទះវិញ
ហើយផ្តាំថា៖ «កុំចូលទៅក្នុងភូមិឲ្យសោះ»។
[27]ព្រះយេស៊ូ និងពួកសិស្សបានចេញពីទីនោះ ឆ្ពោះទៅភូមិទាំងប៉ុន្មាននៃក្រុងសេសារា-ភីលីព។ នៅតាមផ្លូវព្រះអង្គក៏មានបន្ទូលសួរពួកសិស្សរបស់ព្រះអង្គថា៖
«តើមនុស្សគ្រប់គ្នាគេនាំគ្នាថាខ្ញុំជានណា»?[28]ពួកគេក៏បានតូលទៅព្រះអង្គថា៖ «ព្រះអង្គជាលោកយ៉ូហានបាទីស្ត ខ្លះថា ជាព្យាការី អេលីយ៉ា ហើយខ្លះទៀតថា
ព្រះអង្គជាព្យាការីមួយរូបដែរ»។
[29]ព្រះអង្គក៏សួរពួកគេទៀតថា៖ «ចុះអ្នករាល់គ្នាវិញ តើគិតថាខ្ញុំជានណា»? នោះពេត្រុសក៏ឆ្លើយថា៖
«ព្រះអង្គជាព្រះគ្រិស្ត»[30]ព្រះយេស៊ូក៏ហាមពួកគេមិនឲ្យប្រាប់ការនេះទៅនណាម្នាក់ឡើយ។

generated on Wed Sep 10 16:16:32 2025

[31]រួចព្រះអង្គក៏ចាប់ផ្តើមបង្រៀនពួកគេពីកូនមនុស្សត្រូវរងទុក្ខជាច្រើន ហើយ ត្រូវពួកចាស់ទុំ នាយកបូជាចារ្យ និងពួកអាចារ្យបដិសេធ ហើយព្រះអង្គត្រូវគេធ្វើគុតទៀត
តែបីថ្ងៃក្រោយមក ព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិញ។ ព្រះអង្គក៏បានមានបន្ទូលបញ្ជាក់ពីការនេះយ៉ាងច្បាស់។[32]នោះលោកពេត្រុសក៏នាំព្រះអង្គទៅក្រៅបន្តិច
ហើយជំទាស់នឹងព្រះអង្គ។
[33]ប៉ុន្តែព្រះយេស៊ូក៏បែរមកទតពួកសិស្សរបស់ព្រះអង្គផ្សេងទៀត ហើយព្រះអង្គក៏បន្ទោសលោកពេត្រុសថា៖ «សាតាំងអើយ! ចេញទៅក្រោយអញទៅ ដ្បិត
គំនិតឯងមិនមែនជាគំនិតដែលមកពីព្រះជាម្ចាស់ទេ តែជាគំនិតរបស់មនុស្សលោកវិញ»។[34]រួចព្រះអង្គក៏ត្រាស់ហៅមនុស្សម្នា និងពួកសិស្សមកប្រជុំគ្នា
ហើយមានបន្ទូលថា៖ «ប្រសិនបើ អ្នកណាចង់មកតាមខ្ញុំ អ្នកនោះត្រូវលះកាត់ចិត្តខ្លួនចោល ហើយលីឈើឆ្កាងមកតាមខ្ញុំចុះ»។
[35]ដ្បិត អ្នកណាដែលចង់បានជីវិត នោះនឹងបាត់ជីវិតទៅ ហើយបើអ្នកណាដែលបាត់ជីវិតដោយព្រោះខ្ញុំ និងដំណឹងល្អនោះនឹងបានសង្គ្រោះវិញ។[36]ដ្បិត
បើអ្នកណាបានលោកីយ៍ទាំងមូល តែបាត់ជីវិតទៅ នោះមានប្រយោជន៍អ្វីដល់អ្នកនោះ?[37]តើឲ្យមនុស្សនឹងយកអ្វីទៅដូរ ដើម្បីឲ្យបានជីវិត?
[38]អស់អ្នកណាដែលមានភាពអាម៉ាស់ដោយសារខ្ញុំ និងពាក្យរបស់ខ្ញុំ នៅក្នុងជំនាន់មនុស្សផិតក្បត់ និងមនុស្សបាបនេះ
នោះកាលដែលបុត្រមនុស្សយាងមកនឹងមានសេចក្តីខ្មាសនឹងអ្នកនោះដូចគ្នាដែរ ដែលព្រះអង្គនឹងយាងមកប្រកបដោយសិរីរុងរឿងរបស់ព្រះបិតា
និងពួកទេវតាវិសុទ្ធផង»។

Mark 8:1
ឃ្លាភ្ជាប់៖
មានមនុស្សមួយក្រុមធំដែលកំពុងតែស្រេកឃ្លាននៅជាមួយព្រះយេស៊ូ។
ទ្រង់ចម្អែតពួកគេដោយប្រើតែនំបុ័ងប្រាំពីរដុំនិងត្រីពីរបីកន្ទុយ
មុនពេលដែលព្រះយេស៊ូនិងសិស្សរបស់ទ្រង់ចូលក្នុងទូកចេញដំណើរទៅកន្លែងផ្សេង។
នៅថ្ងៃនោះ
ឃ្លានេះប្រើសម្រាប់ណែនាំព្រឹត្តិការណ៍ថ្មីនៅក្នុងរឿង។
ពួកគេបាននៅជាមួយខ្ញុំអស់រយៈពេលបីថ្ងៃហើយ
«នេះជាថ្ងៃទីបីហើយ ដែលមនុស្សទាំងនេះបាននៅជាមួយខ្ញុំ»
ពួកគេប្រាកដជាហេវហត់
អាចមានន័យថា ១) «ពួកគេអាចបាត់បង់ស្មារតីជាបណ្តោះអាសន្ន» ឬ ២)
«ពួកគេអាចនឹងចុះខ្សោយ» ។
តើឲ្យយើងខ្ញុំទៅរកអាហារដើម្បីមកចម្អែតបណ្តាជននៅក្នុងទីរហោស្ថានយ៉ាងនេះដូចម្តេចទៅ»?
ពួកសិស្សកំពុងសម្តែងការភ្ញាក់ផ្អើលចំពោះព្រះយេស៊ូរំពឹងថាពួកគេនឹងអាចរកបានអាហារ
«កន្លែងនេះស្ងាត់ជ្រងំណាស់
ហើយគ្មានកន្លែងនៅទីនេះសម្រាប់ពួកយើងទិញនំបុ័ងគ្រប់គ្រាន់ចម្អែតប្រជាជនទាំងនេះ
រកអាហារ
នំបុ័ងមួយដុំជាម្សៅមួយដុំដែលគេដុតធ្វើជានំ។
Mark 8:5
ព្រះអង្គក៏តបទៅគេវិញថា
«ព្រះយេស៊ូសួរពួកសិស្សរបស់ព្រះអង្គ»
ព្រះអង្គក៏បង្គាប់ឲ្យបណ្តាជនអង្គុយនៅលើដី
សរសេរជាការដកស្រង់សម្តីផ្ទាល់។ «ព្រះយេស៊ូបញ្ជាទៅហ្វូងមនុស្សថា
អង្គុយចុះនៅលើដី»
អង្គុយ
ប្រើពាក្យក្នុងភាសារបស់អ្នកសម្រាប់របៀបដែលមនុស្សបរិភោគតាមទម្លាប់
នៅពេលមិនមានតុមិនថាអង្គុយឬដេក។
Mark 8:7
ពួកគេក៏មាន
ពាក្យ «ពួកគេ» ត្រង់នេះប្រើសំដៅទៅលើព្រះយេស៊ូនិងសិស្សរបស់ទ្រង់។
ព្រះអង្គបានអរព្រះគុណហើយ
«ព្រះយេស៊ូអរព្រះគុណព្រះជាម្ចាស់បានប្រទានត្រី»
ពួកគេហូប
"ប្រជាជនបរិភោគ"
គេប្រមូលបាននំបុ័ង
«ពួកសិស្សបានប្រមូល»
នំបុ័ង និងត្រីដែលនៅសល់បានប្រាំពីរកន្ត្រក់
អាចមានប្រយោជន៍ក្នុងការបន្ថែមព័ត៌មានដែលបាត់។
«ចំណិតនំបុ័ងនិងត្រីដែលនៅសេសសល់ ប្រមូលបានចំនួនប្រាំពីរកន្ត្រកពេញ»
រួចព្រះអង្គបានឲ្យពួកគេត្រឡប់ទៅវិញ
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ ពេលទ្រង់បញ្ជូនពួកគេទៅ។
«ហើយបន្ទាប់ពីពួកគេបរិភោគរួច ព្រះយេស៊ូក៏ឲ្យគេចេញទៅ»
ពួកសិស្សឆ្ពោះទៅស្រុក ដាល់ម៉ានូថាទៅ
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីរបៀបដែលពួកគេទៅដល់ដាល់ម៉ានូថា។
«ពួកគេបានធ្វើដំណើរជុំវិញសមុទ្រកាលីឡេទៅកាន់តំបន់ដាល់ម៉ានូថា»
ដាល់ម៉ានូថា
ជាឈ្មោះកន្លែងមួយនៅលើឆ្នេរពាយព្យនៃសមុទ្រកាលីឡេ។
Mark 8:11
ឃ្លាភ្ជាប់៖
នៅដាលីម៉ានុថា ព្រះយេស៊ូបដិសេធមិនធ្វើទីសម្គាល់ដល់ពួកផារីស៊ី
មុនពេលទ្រង់និងពួកសិស្សចូលក្នុងទូកហើយចាកចេញទៅ។
ដោយសុំឲ្យព្រះអង្គ
«ពួកគេបានទូលសុំព្រះអង្គ»
ពីស្ថានសួគ៌
នៅទីនេះ «ឋានសួគ៌» សំដៅទៅលើកន្លែងដែល ព្រះអង្គមានព្រះជន្មគង់នៅ
និងជានិមិត្តរូបរបស់ព្រះជាម្ចាស់។ «មកពីព្រះជាម្ចាស់»
ដើម្បីល្បងល
ពួកផារីស៊ីព្យាយាមល្បងព្រះយេស៊ូដើម្បីបញ្ជាក់ថា ទ្រង់មកពីព្រះជាម្ចាស់។
ព័ត៌មានខ្លះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ «ដើម្បីបង្ហាញថា
ព្រះអង្គបានបញ្ជូនមកជាបានបញ្ជូនព្រះអង្គមក»
ទីសម្គាល់ដ៏អស្ចារ្យ
ចង្អុលបង្ហាញ
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៧ ខ៣៣ ។
ក្នុងវិញ្ញាណរបស់ព្រះអង្គ
«នៅក្នុងខ្លួនព្រះអង្គ»
ហេតុអ្វីបានជាមនុស្សជំនាន់នេះចង់ឃើញតែទីសម្គាល់ដូច្នេះ?
ព្រះយេស៊ូកំពុងតែស្តីបន្ទោសពួកគេ។ សំណួរនេះអាចសរសេរជាឃ្លា
«ជំនាន់នេះមិនគួរស្វែងរកទីសម្គាល់ទេ» ។
មនុស្សជំនាន់នេះ
ពេលព្រះយេស៊ូមានបន្ទូលអំពី «ជំនាន់នេះ»
ទ្រង់កំពុងសំដៅទៅលើមនុស្សដែលរស់នៅគ្រានោះ។
មានពួកផារីស៊ីត្រូវបានរួមបញ្ចូលនៅក្នុងក្រុមនេះដែរ។
«អ្នកនិងប្រជាជននៅជំនាន់នេះ»
គ្មានទីសម្គាល់ណាបានប្រទានមក
អាចប្រើបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ខ្ញុំនឹងមិនធ្វើទីសម្គាល់ណាមួយនោះទេ»
រួចព្រះអង្គក៏យាងចេញពីពួកគេ ហើយចុះទូក
សិស្សរបស់ព្រះយេស៊ូក៏ទៅជាមួយព្រះអង្គដែរ។
ព័ត៌មានខ្លះអាចបង្ហាញឲ្យយកាន់តែច្បាស់។
«ព្រះអង្គទុកគេចោលហើយចុះទូកជាមួយសិស្សទ្រង់ម្តងទៀត»
ទៅឯត្រើយម្ខាងទៀត
នេះពិតណ៌នាអំពីសមុទ្រកាលីឡេដែលអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
«ទៅផ្នែកម្ខាងទៀតនៃសមុទ្រ»
Mark 8:14
ឃ្លាភ្ជាប់
ពេលព្រះយេស៊ូនិងពួកសិស្សរបស់ព្រះអង្គកំពុងនៅលើទូក ពួកគេពិភាក្សាគ្នា
កង្វះការយល់ដឹងក្នុងចំណោមពួកផារីស៊ីនិងហេរ៉ូដ
ទោះបីពួកគេបានឃើញទីសម្គាល់ជាច្រើនក៏ដោយ។
ឥឡូវនេះ
ពាក្យនេះប្រើសម្រាប់សម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់។
នៅទីនេះអ្នកនិពន្ធប្រាប់ព័ត៌មានសំខាន់អំពីពួកសិស្សភ្លេចយកនំបុ័ង។
មាននំបុ័ងតែមួយដុំប៉ុណ្ណោះ
ឃ្លាអវិជ្ជមាន «មិនមានទៀតទេ» ប្រើដើម្បីបញ្ជាក់ពីចំនួននំបុ័ងដែលពួកគេមាន។

generated on Wed Sep 10 16:16:32 2025

«នំប៉័ងមួយដុំប៉ុណ្ណោះ»
ចូរប្រុងប្រយ័ត្នមើល ហើយក៏ប្រយ័ត្ន
ឃ្លាទាំងពីរនេះមានន័យរួមហើយត្រូវបានប្រើម្តងទៀតនៅទីនេះដើម្បីបញ្ជាក់។
អាចបញ្ចូលគ្នាបាន។ «ចូរប្រុងប្រយ័ត្ន»
មេដំបែររបស់ពួកផារិស៊ី និងស្តេចហេរ៉ូដឲ្យមែនទែន
នៅទីនេះ
ព្រះយេស៊ូកំពុងមានបន្ទូលទៅកាន់សិស្សរបស់ទ្រង់ដោយប្រើពាក្យប្រៀបធៀបដែលពួកគេ**អាចមិនយល់**។
ព្រះយេស៊ូកំពុងតែប្រៀបធៀបការបង្រៀនរបស់ពួកផារិស៊ីនិងហេរ៉ូដទៅនឹងមេម្សៅ
ប៉ុន្តែអ្នកមិនគួរពន្យល់ពីរឿងនេះទេ នៅពេលដែលអ្នកបកប្រែវា
ព្រោះពួកសិស្សខ្លួនឯងមិនបានយល់ពីវាទេ។
Mark 8:16
នេះមកពីយើងគ្មាននំប៉័ងទេដឹង
ឃ្លានេះអាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា «វា»
សំដៅទៅលើអ្វីដែលព្រះយេស៊ូមានបន្ទូល។ «ទ្រង់ច្បាស់ជាមានបន្ទូលថា
ដោយសារតែយើងគ្មាននំប៉័ងហើយមើលទៅ»
គ្មាននំប៉័ង
ពួកសិស្សមាននំប៉័ងតែមួយដុំប៉ុណ្ណោះ មិនខុសគ្នាពីការគ្មាននំប៉័ងទាល់តែសោះ។
«នំប៉័ងតិចតួចណាស់»
តើអ្នករាល់គ្នានៅរិះគិតពីការដែលគ្មាននំប៉័ង?
នៅទីនេះ ព្រះយេស៊ូកំពុងតែស្តីបន្ទោសយ៉ាងខ្លាំងដល់សិស្សរបស់ទ្រង់
ព្រោះពួកគេគួរតែយល់ពីអ្វីដែលទ្រង់កំពុងតែមានបន្ទូល។ អាចសរសេរជាឃ្លាថា
«អ្នកមិនគួរគិតថាខ្ញុំកំពុងនិយាយអំពីនំប៉័ងពិតប្រាកដទេ» ។
តើអ្នករាល់គ្នាមិនទាន់គិតឃើញ? មិនទាន់យល់ទេឬអី?
សំណួរទាំងនេះមានន័យដូចគ្
នាហើយត្រូវប្រើជាមួយគ្នាដើម្បីបញ្ជាក់ថាពួកគេមិនយល់។
អាចសរសេរជាសំណួរមួយ ឬឃ្លា។ «អ្នកមិនទាន់យល់ទេ?» ឬ
«អ្នកគួរតែយល់និងយល់ពីអ្វីដែលខ្ញុំនិយាយនិងធ្វើ» ។
តើអ្នកមានចិត្តរឹងចចេសឬ?
ពាក្យប្រៀបធៀបនេះសំដៅលើពួកគេមិនទាន់បានបើកចិត្ត
ឬមិនយល់ពីអ្វីដែលព្រះយេស៊ូចង់មានន័យ។ អាចសរសេរជាឃ្លាថា
«តើចិត្តរបស់អ្នកមិនបើកចំហដើម្បីយល់ពីអ្វីដែលខ្ញុំនិយាយយ៉ាងដូចម្តេច?» ឬ
«បេះដូងរបស់អ្នកមិនមានឆន្ទៈក្នុងការយល់»។
Mark 8:18
អ្នករាល់គ្នាមានភ្នែក តែមើលមិនឃើញឬ? អ្នករាល់គ្នាក៏មានត្រចៀកតែស្តាប់មិនឮឬ?
អ្នកមិនចាំទេឬអី?
ព្រះយេស៊ូបន្តបន្ទោសពួកសិស្សរបស់ទ្រង់។ សំណួរទាំងនេះអាចសរសេរជាឃ្លាថា
"អ្នកមានភ្នែកតែអ្នកមិនយល់ពីអ្វីដែលអ្នកបានឃើញ។
អ្នកមានត្រចៀកប៉ុន្តែអ្នកមិនយល់ពីអ្វីដែលអ្នកឮទេ អ្នកគួរតែចងចាំ" ។
មនុស្សប្រាំពាន់នាក់
នេះសំដៅទៅលើមនុស្ស ៥០០០នាក់ ដែលព្រះយេស៊ូបានចម្អែត។ «ប្រជាជន
៥០០០ នាក់»
ពីរបៀបដែលអ្នករាល់គ្នាបានប្រមូលចំណិតដែលសល់បានប៉ុន្មានកន្ត្រក»? ពួកគេឆ្លើយថា៖
«បានដប់ពីរ»
មានប្រយោជន៍ក្នុងការថ្លែងបញ្ជាក់
ពេលពួកគេប្រមូលកន្ត្រកដែលមានចំណែកនំប៉័ង។
«តើអ្នកប្រមូលបានប៉ុន្មានកន្ត្រក ក្រោយពេលពួកគេរាល់គ្នាបានញ៉ាំរួច»
Mark 8:20
មនុស្សបួនពាន់នាក់
នេះសំដៅទៅលើមនុស្ស ៤០០០នាក់ ដែលព្រះយេស៊ូបានចម្អែត។ «ប្រជាជន
៤០០០ នាក់»
តើអ្នករាល់គ្នាប្រមូលទុកបានប៉ុន្មាន?
មានប្រយោជន៍ក្នុងការថ្លែងបញ្ជាក់
ពេលពួកគេប្រមូលកន្ត្រកដែលមានចំណែកនំប៉័ង។
«តើអ្នកប្រមូលបានប៉ុន្មានកន្ត្រក ក្រោយពេលពួកគេរាល់គ្នាបានញ៉ាំរួច»
«តើអ្នកនៅមិនយល់ទៀតមែនទេ»?
ព្រះយេស៊ូកំពុងតែស្តីបន្ទោសយ៉ាងខ្លាំងដល់សិស្សទ្រង់ដោយមិនយល់។
អាចសរសេរជាឃ្លាថា «អ្នកគួរតែយល់ពីអ្វីដែលខ្ញុំបាននិយាយនិងធ្វើ» ។
Mark 8:22
ឃ្លាភ្ជាប់៖
នៅពេលដែលព្រះយេស៊ូនិងពួកសិស្សរបស់ព្រះអង្គចុះពីទូកទៅភូមិបេតសៃដា
នោះព្រះយេស៊ូក៏ប្រោសបុរសខ្វាក់ម្នាក់ឲ្យជា។
ភូមិបេតសៃដា
ជាទីក្រុងមួយនៅលើឆ្នេរសមុទ្រកាលីឡេភាគខាងជើង។
មើលរបៀបដែលអ្នកបកប្រែឈ្មោះទីក្រុងនេះនៅ ៦:៤៥ ។
សុំឲ្យព្រះអង្គពាល់គាត់
អាចមិនចាំបាច់ប្រើការបញ្ជាក់ក្នុងការបញ្ជាក់ពីមូលហេតុដែលពួកគេចង់ឲ្យព្រះយេស៊ូវប៉ះពាល់បុរសនោះ។
«ប៉ះពាល់គាត់ គឺប្រោសគាត់»
រួចព្រះអង្គបានស្តោះព្រះឱស្ឋលើភ្នែកគាត់ ហើយដាក់ព្រះហស្តលើគាត់ ដោយសួរថា៖
«ពេលព្រះយេស៊ូស្តោះទឹកមាត់ដាក់ភ្នែកបុរសនោះ ...
ព្រះយេស៊ូបានសួរបុរសនោះ»
Mark 8:24
គាត់ក៏បើកភ្នែកឡើង
«បុរសនោះងើបមុខឡើង»
ខ្ញុំឃើញមនុស្សដើរ មើលទៅដូចជាដើមឈើអ៊ីចឹង
បុរសឃើញមនុស្សដើរជុំវិញ
គាត់មើលមិនទាន់ច្បាស់ទេដូច្នេះគាត់ប្រៀបធៀបពួកគេទៅនឹងដើមឈើ។
«មែនខ្ញុំឃើញមនុស្ស! ពួកគេកំពុងដើរជុំវិញ
ប៉ុន្តែខ្ញុំមិនអាចមើលឃើញពួកគេច្បាស់ទេ។ ពួកគេមើលទៅដូចជាដើមឈើ» ។
រួចព្រះអង្គក៏ដាក់ព្រះហស្តលើភ្នែកគាត់ម្តងទៀត
«បន្ទាប់មក ព្រះយេស៊ូ»
ហើយពេលនោះបុរសនោះក៏បានបើកភ្នែកមើល ហើយស្រាប់តែ បានភ្លឺឡើង
ឃ្លា «ភ្នែកគាត់មើលឃើញឡើងវិញ» អាចសរសេរជាទម្រង់កិរិយាសកម្ម។
»ភ្នែកគាត់មើលឃើញឡើងវិញហើយបន្ទាប់មកភ្នែកបុរសនោះក៏បើក»
Mark 8:27
ឃ្លាភ្ជាប់៖
ព្រះយេស៊ូនិងសិស្សរបស់ព្រះអង្គកំពុងជជែកគ្នា
ពេលធ្វើដំណើរនៅតាមផ្លូវទៅភូមិសេសារាភីលីព ថាតើព្រះយេស៊ូជាអ្នកណា
តើនឹងមានអ្វីកើតឡើងដល់ព្រះអង្គ?
ពួកគេក៏បានតួលទៅព្រះអង្គថា
គេឆ្លើយថា៖
ជាលោកយ៉ូហានបាទីស្ត
នេះជាចម្លើយរបស់ពួកសិស្សដែលមនុស្សខ្លះបាននិយាយថាព្រះយេស៊ូជានរណា។
អាចបង្ហាញកាន់តែច្បាស់។ «មានអ្នកខ្លះនិយាយថា
លោកជាលោកយ៉ូហានបាទីស្ត»
ខ្លះថា...ខ្លះទៀតថា
ពាក្យ «ខ្លះថា» សំដៅទៅលើមនុស្សផ្សេងទៀត។ ដូចគ្នានេះផងដែរ
វាអាចមានប្រយោជន៍ក្នុងការបន្ថែមព័ត៌មានដែលបាត់។
«មនុស្សផ្សេងទៀតនិយាយថាទ្រង់ជា ... មនុស្សផ្សេងទៀតនិយាយថា
ទ្រង់ជានរណាម្នាក់»
Mark 8:29
ព្រះអង្គក៏សួរពួកគេទៀតថា
«ព្រះយេស៊ូបានសួរពួកសិស្សរបស់ព្រះអង្គ»
ព្រះយេស៊ូក៏ហាមពួកគេមិនឲ្យប្រាប់ការនេះទៅនណាម្នាក់ឡើយ
ព្រះយេស៊ូមិនចង់ឲ្យពួកគេប្រាប់អ្នកណាម្នាក់ថា ទ្រង់ជាព្រះគ្រិស្តទេ។
អាចបញ្ជាក់ឲ្យកាន់តែច្បាស់។ មួយវិញទៀត
ក៏អាចសរសេរជាសម្តីដកស្រង់ផ្ទាល់ផងដែរ។
«ព្រះយេស៊ូបានព្រមានពួកគេកុំឲ្យប្រាប់អ្នកណាថា ទ្រង់ជាព្រះគ្រិស្ត» ឬ
«ព្រះយេស៊ូបានព្រមានពួកគេថាកុំប្រាប់នរណាម្នាក់ថា ខ្ញុំជាព្រះគ្រិស្ត»
Mark 8:31
កូនមនុស្ស
ជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូ។
ហើយ ត្រូវពួកចាស់ទុំ នាយកបូជាចារ្យ និងពួកអាចារ្យបដិសេធ ហើយព្រះអង្គត្រូវគេធ្វើគុតទៀត
តែបីថ្ងៃក្រោយមក ព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិញ។
ព្រះអង្គក៏បានមានបន្ទូលបញ្ជាក់ពីការនេះយ៉ាងច្បាស់
អាចសរសេរបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
«ហើយថាពួកព្រឹទ្ធាចារ្យនិងពួកនាយកបូជាចារ្យនិងពួកអាចារ្យនឹងបដិសេធព្រះអង្គ
ហើយឲ្យគេសម្លាប់ទ្រង់។ បីថ្ងៃក្រោយមកទ្រង់នឹងរស់ឡើងវិញ»
ព្រះអង្គក៏បានមានបន្ទូលបញ្ជាក់ពីការនេះយ៉ាងច្បាស់

generated on Wed Sep 10 16:16:32 2025

"ទ្រង់បាននិយាយបែបនេះតាមរបៀបដែលងាយយល់"
ជំទាស់នឹងព្រះអង្គ
ពេត្រុសបានស្តីបន្ទោសព្រះយេស៊ូ
ដោយព្រោះទ្រង់មានបន្ទូលអំពីអ្វីដែលទ្រង់បាននិយាយនឹងកើតឡើងចំពោះកូនមនុស្ស
អាចបញ្ជាក់ឲ្យកាន់តែច្បាស់។
«បានស្តីបន្ទោសទ្រង់ចំពោះការនិយាយពាក្យទាំងនេះ»
Mark 8:33
ឃ្លាភ្ជាប់៖
ក្រោយពីស្តីបន្ទោសពេត្រុសដោយសារគាត់មិនចង់ ឲ្យ ព្រះយេស៊ូសុគត
និងមានព្រះជន្មរស់ឡើងវិញនោះព្រះយេស៊ូបានមានបន្ទូលប្រាប់ទាំងសិស្ស
និងហ្វូងមនុស្សពីរបៀបដើរតាមទ្រង់។
សាតាំងអើយ! ថយទៅក្រោយអញទៅ គំនិតឯងមិនមែនជាគំនិត
ព្រះយេស៊ូមានន័យថា
ពេត្រុសកំពុងធ្វើដូចសាតាំងពីព្រោះពេត្រុសកំពុងព្យាយាមរារាំងព្រះយេស៊ូមិនឲ្យ
សម្រេចអ្វី ដែលព្រះជាម្ចាស់បានចាត់ឲ្យទ្រង់បំពេញ។ «ចូរទៅពីក្រោយខ្ញុំសាតាំង!
ខ្ញុំហៅអ្នកថាសាតាំងពីព្រោះ គំនិតឯងមិនមែនជាគំនិត» ឬ
«ថយក្រោយខ្ញុំពីព្រោះអ្នកកំពុងធ្វើដូចសាតាំង! អ្នកមិនបានអង្គុយទេ»
ថយទៅក្រោយអញទៅ
«ទៅឲ្យឆ្ងាយពីខ្ញុំទៅ»
មកតាមខ្ញុំ
ការដើរតាមព្រះយេស៊ូនៅទីនេះតំណាងឲ្យការធ្វើជាសិស្សម្នាក់របស់ព្រះអង្គ។
«ធ្វើជាសិស្សរបស់ខ្ញុំ» ឬ «ក្លាយជាសិស្សរបស់ខ្ញុំ»
ត្រូវលះកាត់ចិត្តខ្លួនចោល
«មិនត្រូវចុះចាញ់នឹងសេចក្តីប៉ងប្រាថ្នាផ្ទាល់ខ្លួនឡើយ» ឬ
«ត្រូវបោះបង់ចោលបំណងប្រាថ្នាផ្ទាល់ខ្លួន»
លីឈើឆ្កាងមកតាមខ្ញុំចុះ
"លីឈើឆ្កាងរបស់គាត់ហើយមកតាមខ្ញុំ" ។
ឈើឆ្កាងតំណាងឱ្យការរងទុក្ខនិងការស្លាប់។
ការលើកឈើឆ្កាងតំណាងឲ្យការសុខចិត្តរងទុក្ខនិងស្លាប់។
«ត្រូវតែស្តាប់បង្គាប់ខ្ញុំរហូតដល់ពេលរងទុក្ខនិងស្លាប់»
មកតាមខ្ញុំចុះ
ការដើរតាមព្រះយេស៊ូនៅទីនេះតំណាងឲ្យការស្តាប់បង្គាប់ទ្រង់។
«ហើយស្តាប់តាមខ្ញុំ»
Mark 8:35
ដ្បិត អ្នកណាដែលចង់បាន
«សម្រាប់អ្នកដែលចង់បាន»
ជីវិត
សំដៅទៅលើជីវិតខាងរូបកាយ និងជីវិតខាងវិញ្ញាណ។
ដោយព្រោះខ្ញុំ និងដំណឹងល្អ
«ដោយសារតែខ្ញុំនិងដោយសារតែដំណឹងល្អ» ។
ព្រះយេស៊ូកំពុងតែនិយាយអំពីមនុស្សដែលបាត់បង់ជីវិតដោយសារពួកគេធ្វើតាមព្រះយេស៊ូនិងដំណឹងល្អ
អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា
«ពីព្រោះគាត់ដើរតាមខ្ញុំហើយប្រាប់អ្នកដទៃអំពីដំណឹងល្អ»
ដ្បិត បើអ្នកណាបានលោកីយ៍ទាំងមូល តែបាត់ជីវិតទៅ នោះមានប្រយោជន៍អ្វីដល់អ្នកនោះ?
អាចសរសេរជាឃ្លាថា
«ទោះបីជាមនុស្សម្នាក់ទទួលបានពិភពលោកទាំងមូលក៏ដោយវានឹងមិនមានអត្ថប្រយោជន៍ដល់គេទេ
បើគេបាត់បង់ជីវិតរបស់គេ» ។
បានលោកីយ៍ទាំងមូល
ព្រះយេស៊ូប្រើពាក្យប្រៀបធៀបដើម្បីបញ្ជាក់ន័យថា
គ្មានអ្វីនៅក្នុងលោកដែលអ្នកបានទទួល
មានតម្លៃជាងការបាត់បង់ជីវិតរបស់អ្នកឡើយ។
«បើគាត់ទទួលបានអ្វីគ្រប់យ៉ាងនៅក្នុងលោកនេះ»
បាត់
«បាត់»
តើឲ្យមនុស្សនឹងយកអ្វីទៅដូរ ដើម្បីឲ្យបានជីវិត?
ត្រូវសរសេរជាឃ្លាថា
«គ្មានអ្វីដែលមនុស្សម្នាក់អាចផ្តល់ឲ្យជាថ្នូរនឹងជីវិតរបស់គាត់បានទេ» ។ ឬ
«គ្មាននរណាម្នាក់អាចផ្តល់ឲ្យអ្វីទាំងអស់នៅក្នុងការផ្លាស់ប្តូរជីវិតរបស់គាត់បានទេ»។
តើឲ្យមនុស្សនឹងយកអ្វីទៅដូរ
ប្រសិនបើនៅក្នុងភាសារបស់អ្នក «ការផ្តល់ឲ្យ»
តម្រូវឲ្យនរណាម្នាក់ទទួលបានអ្វីដែលត្រូវបានផ្តល់ឲ្យ "ព្រះជាម្ចាស់"
អាចជាអ្នកទទួល។ »តើមនុស្សម្នាក់អាចផ្តល់អ្វីដល់ព្រះជាម្ចាស់»
Mark 8:38
នៅក្នុងជំនាន់មនុស្សផិតក្បត់ និងមនុស្សបាបនេះ
ព្រះយេស៊ូមានព្រះបន្ទូលអំពីមនុស្សជំនាន់នេះ ថាជាមនុស្សផិតក្បត់មានន័យថា
ពួកគេជាមនុស្សមិនស្មោះត្រង់ក្នុងទំនាក់ទំនងរបស់ពួកគេជាមួយព្រះជាម្ចាស់។
«មនុស្សជំនាន់នេះដែលបានប្រព្រឹត្តអំពើផិតក្បត់ប្រឆាំងនឹងព្រះជាម្ចាស់ហើយមានបាប»
ឬ «មនុស្សជំនាន់នេះដែលមិនស្មោះត្រង់នឹងព្រះជាម្ចាស់
ហើយជាមនុស្សមានបាប»
បុត្រមនុស្ស
ជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូ។
នោះកាលដែលបុត្រមនុស្សយាងមក
«ពេលទ្រង់ត្រឡប់មកវិញ»
ប្រកបដោយសិរីរុងរឿងរបស់ព្រះបិតា
ពេលព្រះយេស៊ូត្រឡប់មកវិញ ទ្រង់នឹងមានសិរីរុងរឿងដូចបិតាទ្រង់ដែរ។
និងពួកទេវតាវិសុទ្ធផង
«អមដោយពួកទេវតាវិសុទ្ធ»

---

9 [1]ព្រះអង្គមានបន្ទូលទៅពួកគេថា៖ «ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាដកថា នឹងមានអ្នកខ្លះក្នុងចំណោមអ្នករាល់គ្នានឹងមិនដែរស្គាល់សេចក្តីស្លាប់ឡើយ
គេនឹងឃើញព្រះរាជ្យនៃព្រះជាម្ចាស់យាងចុះមកជាមួយនឹងអំណាចព្រះចេស្តា»។[2]ប្រាំមួយថ្ងៃក្រោយមក ព្រះយេស៊ូបានយកលោកពេត្រុស លោកយ៉ាកុប
និងលោកយ៉ូហានទៅលើភ្នំជាមួយព្រះអង្គ ដាច់ដោយឡែកតែពួកគេ។ ក្រោយមកព្រះអង្គក៏មានរូបរាងប្លែកនៅពីមុខពួកគេ។
[3]សម្លៀកបំពាក់របស់ព្រះអង្គប្រែជាសភ្លឺចាំងយ៉ាងអស្ចារ្យ គ្មានមនុស្សណានៅផែនដីនេះ អាចនឹងធ្វើឲ្យសដូចជាសម្លៀកបំពាក់នោះឡើយ។
[4]ក្រោយមក លោកអេលីយ៉ា និងលោកម៉ូសេបានលេចមកនៅចំពោះពួកគេ ហើយអ្នកទាំងពីរបានជជែកជាមួយព្រះយេស៊ូ។[5]លោកពេត្រុស
បានឆ្លើយដោយនិយាយទៅកាន់ព្រះយេស៊ូថា៖ «លោកគ្រូ គឺជាការល្អដែលយើងនៅទីនេះ ដូច្នេះ សូមឲ្យយើងសង់ផ្ទះបី មួយសម្រាប់លោកគ្រូ
និងមួយសម្រាប់លោកម៉ូសេ ហើយ និងមួយទៀតសម្រាប់លោកអេលីយ៉ា»។[6](ដ្បិត គាត់មិនដឹងជាត្រូវនិយាយអ្វីទេ ដោយព្រោះពួកគេកំពុងភ័យ)។
[7]មានពពកមួយលេចមកគ្របបាំងពួកគាត់ទាំងបី។ ក្រោយមកមានសំឡេងចេញពីពពកមកថា៖ «នេះគឺជាបុត្រជាទីស្រឡាញ់របស់យើង សូមស្តាប់តាមព្រះអង្គចុះ»។
[8]រំពេចនោះ ពេលដែលពួកគេមើលជុំវិញ គឺមិនឃើញមានអ្នកណានៅទីនោះទៀតហើយ ប៉ុន្តែគឺឃើញតែព្រះយេស៊ូមួយព្រះអង្គគត់។
[9]គ្រាដែលពួកគេចុះពីលើភ្នំមកវិញ ព្រះជាម្ចាស់បានបង្គាប់ហាមមិនឲ្យប្រាប់ការអ្វីដែលពួកគេបានឃើញដល់អ្នកណាឲ្យសោះ
ដរាបដល់កូនមនុស្សបានរស់ឡើងវិញពីសេចក្តីស្លាប់សិន។[10]ដូច្នេះ ហើយពួកគេក៏បានរក្សារឿងនោះ នៅក្នុងពួកគេ ប៉ុន្តែ ពួកគេបានជជែកគ្នានៅក្នុងចំណោមពួកគេអំពី
«រស់ចេញពីសេចក្តីស្លាប់ឡើងវិញ» មានន័យយ៉ាងម៉េច។
[11]ពួកគេទូលសួរព្រះអង្គថា៖ «ហេតុអ្វីពួកអាចារ្យនិយាយថាលោកអេលីយ៉ាត្រូវមកជាមុន»?[12]ព្រះអង្គតបទៅពួកគេថា៖ «លោកអេលីយ៉ាបានមកមុនមែន
គឺដើម្បីស្តារអ្វីទាំងគ្រប់យ៉ាងឡើងវិញ។ ហេតុអ្វី បានជាមានសេចក្តីចែងទុកមកថា កូនមនុស្ស ត្រូវតែរងទុក្ខលំបាកជាច្រើនដង និងត្រូវគេប្រព្រឹត្តិដូចអ្នកគ្មានតម្លៃ?[13]ប៉ុន្តែ
ខ្ញុំប្រាប់អ្នករាល់គ្នាថា លោកអេលីយ៉ាបានមក ហើយពួកគេបានប្រព្រឹត្តចំពោះគាត់តាមតែចិត្តគេចង់ ដូចដែលមានចែងទុកអំពីគាត់»។
[14]ពេលពួកគេមកដល់ពួកសិស្សវិញ នោះក៏ឃើញមនុស្សកុះករ ហើយពួកអាចារ្យនៅជុំវិញពួកសិស្ស កំពុងតែប្រកែកគ្នា។[15]ពេលពួកបណ្តាជនឃើញព្រះយេស៊ូភ្លាមក៏
អស្ចារ្យ ហើយពួកគេនាំគ្នារត់ទៅស្វាគមន៍ព្រះអង្គ។[16]ព្រះអង្គក៏សួរទៅពួកសិស្សថា៖ «តើអ្នកទាំងគ្នាកំពុងប្រកែកជាមួយពួកគេអំពីរឿងអ្វី»?
[17]មានម្នាក់ដែលនៅក្នុងបណ្តាជន បានទូលឆ្លើយទៅកាន់ព្រះអង្គថា៖ «លោកគ្រូ ខ្ញុំបាននាំយកកូនប្រុសមករកលោក។
គឺគាត់មានវិញ្ញាណនៅក្នុងខ្លួនដែលមិនអាចធ្វើឲ្យគាត់អាចនិយាយបាន។[18]នៅពេលវាចូលកូនខ្ញុំម្តងៗ ហើយវាផ្តួលកូនខ្ញុំឲ្យដួលចុះ ធ្វើឲ្យបែកពពុះមាត់ សង្កៀតធ្មេញ

generated on Wed Sep 10 16:16:32 2025

ហើយនិងរឹងខ្លួន។ ខ្ញុំបានសុំឲ្យពួកសិស្សលោកបណ្តេញវាចេញពីកូនរបស់ខ្ញុំដែរ ប៉ុន្តែពួកគេមិនអាចធ្វើបានទេ»។[19]ព្រះជាម្ចាស់មានបន្ទូលតបទៅពួកគេថា៖ «តំណមនុស្សដែលគ្មានជំនឿអើយ តើឲ្យខ្ញុំនៅជាមួយអ្នករាល់គ្នាដល់ពេលណាទៀត? តើឲ្យខ្ញុំអត់ទ្រាំជាមួយអ្នករាល់គ្នាដល់ពេលណាទៀត? ចូរនាំក្មេងនោះមកកាន់ខ្ញុំចុះ»។[20]ពួកគេក៏នាំយកក្មេងនោះទៅរកព្រះអង្គ។ ពេលវិញ្ញាណនោះឃើញព្រះយេស៊ូ វាក៏ធ្វើឲ្យក្មេងនោះដួលនៀលលើដី និងបែកពពុះមាត់ផងដែរ។[21]ព្រះយេស៊ូបានសួរទៅកាន់ឪពុករបស់កូនថា៖ «តើការនេះបានកើតឡើងក្មេងនេះយូរប៉ុណ្ណាហើយ?» ឪពុកបានឆ្លើយថា៖
«តាំងតែពីតូចមក»[22]វាជារឿយៗធ្វើឲ្យកូនខ្ញុំដួលទៅលើភ្លើងឬទៅក្នុងទឹក ដើម្បីនឹងសម្លាប់កូនរបស់ខ្ញុំ។ ប្រសិនបើ លោកគ្រូអាចធ្វើអ្វីម៉្យាង សូមមេត្តាអាណិតយើង និងជួយពួកយើងផង»។[23]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ប្រសិនបើ លោកអាចជួយបានឬ? អ្វីៗទាំងអស់នឹងកើតឡើងសម្រាប់អ្នកណាដែលជឿ»។[24]ភ្លាមនោះឪពុករបស់កូននោះក៏ស្រែកឡើងដោយនិយាយថា៖ «ខ្ញុំជឿហើយ សូមជួយការមិនមានជឿរបស់ខ្ញុំផង»![25]ពេលព្រះយេស៊ូបានឃើញបណ្តាលជនកំពុងរត់ទៅរកពួកគេ នោះព្រះអង្គក៏ដេញវិញ្ញាណអាក្រក់ ដោយបន្ទូលថា៖ «វិញ្ញាណគថ្កង់ យើងបង្គាប់ឯង ចូរចេញពីក្មេងនេះទៅ ហើយកុំចូលក្មេងនេះទៀត»។[26]វាបានស្រែកឡើង ហើយធ្វើឲ្យក្មេងនោះប្រកាច់យ៉ាងខ្លាំង រួចហើយក៏ចេញទៅ។ ក្មេងប្រុសនោះមើលទៅដូចជាមនុស្សស្លាប់ ដូច្នេះ មនុស្សជាច្រើនបាននិយាយថា៖ «គាត់ស្លាប់ហើយ»។[27]ប៉ុន្តែ ព្រះយេស៊ូបានលើកគាត់ឡើងដោយព្រះហស្ត ហើយក្មេងប្រុសក៏ឈរឡើង។[28]ពេលព្រះយេស៊ូយាងចូលទៅក្នុងផ្ទះ ពួកសិស្សបានសួរព្រះអង្គស្ងាត់ៗថា៖ «ហេតុអ្វីបានជាយើងមិនដេញវាចេញបាន»?[29]ព្រះអង្គមានបន្ទូលទៅពួកគេថា៖
«វិញ្ញាណប្រភេទនេះមិនអាចដេញបានទេ លើកលែងតែតាមរយៈពាក្យអធិស្ឋាន»។[30]ពួកគេធ្វើដំណើរចាកចេញពីទីនោះ ឆ្លងកាត់ស្រុកកាលីឡេ។ ព្រះអង្គមិនចង់ឲ្យអ្នកណាដឹង ថាពួកគេនៅទីណានោះទេ[31]ដោយសារព្រះអង្គកំពុងតែបង្រៀនពួកសិស្សរបស់ព្រះអង្គ។ ព្រះអង្គមានបន្ទូលទៅពួកគេថា៖ «កូនមនុស្សនឹងត្រូវបានបញ្ជូនទៅក្នុងដៃមនុស្ស ហើយពួកគេនឹងសម្លាប់លោក។ កាលគេបានសម្លាប់ហើយ បីថ្ងៃក្រោយមក លោកនឹងរស់ឡើងវិញម្តងទៀត»។[32]ប៉ុន្តែ ពួកគេមិនយល់ពីអ្វីដែលព្រះអង្គមានបន្ទូលឡើយ ហើយពួកគេក៏មិនហ៊ានសួរព្រះអង្គដែរ។[33]ពួកគេក៏មកដល់ក្រុងកាពើណិម។ បន្ទាប់ពីព្រះអង្គយាងចូលក្នុងផ្ទះ ព្រះអង្គសួរទៅពួកគេថា៖ «តើពួកអ្នកបានជជែកគ្នាពីអ្វីនៅតាមផ្លូវ»?[34]ប៉ុន្តែ ពួកគេនៅស្ងៀម។ ដ្បិតពួកគេបានប្រកែកគ្នានៅតាមផ្លូវ ក្នុងចំណោមពួកគេ អំពីអ្នកណានឹងក្លាយជាធំជាងគេ។[35]ព្រះអង្គក៏គង់ចុះ ព្រះជាម្ចាស់ក៏ហៅពួកសិស្សទាំងដប់ពីរមក និងមានបន្ទូលទៅគេថា៖ «ប្រសិនបើ អ្នកណាចង់ធ្វើជាទីមួយ អ្នកនោះនឹងទៅក្រោយគេបង្អស់ និងជាអ្នកបម្រើដល់មនុស្សគ្រប់គ្នាដែរ»។[36]ព្រះអង្គក៏យកក្មេងតូចម្នាក់មកដាក់នៅកណ្តាលពួកគេ។ ព្រះជាម្ចាស់បានលើកក្មេងឡើង ដោយបន្ទូលថា[37]«អ្នកណាដែលទទួលក្មេងតូចម្នាក់នេះ គឺក្នុងឈ្មោះខ្ញុំ នោះគឺបានទទួលខ្ញុំ ហើយបើមានអ្នកណាទទួលខ្ញុំ នោះមិនមែនទទួលតែខ្ញុំទេ គឺទទួលព្រះអង្គដែលបានចាត់ខ្ញុំឲ្យមកដែរ»។[38]លោកយ៉ូហានបានទូលព្រះអង្គថា៖ «លោកគ្រូ យើងបានឃើញមនុស្សម្នាក់កំពុងបណ្តេញអារក្សក្នុងនាមរបស់លោក ហើយយើងបានឃាត់គាត់ដែរ តែគាត់មិនតាមយើងសោះ»។[39]ប៉ុន្តែ ព្រះយេស៊ូមានបន្ទូលថា៖ «សូមកុំហាមគាត់អី ដ្បិត គ្មានអ្នកណាដែលនឹងធ្វើការដ៏អស្ចារ្យ នៅក្នុងឈ្មោះខ្ញុំ ហើយបន្ទាប់មកនិយាយអាក្រក់ពីខ្ញុំនោះទេ។[40]អស់អ្នកណាដែលមិនប្រឆាំងនឹងយើងគឺនៅជាមួយពួកយើងហើយ។[41]អ្នកណាដែលឲ្យទឹកអ្នករាល់គ្នាផឹក ទឹកមួយកែវដោយសារតែអ្នកជាកម្មសិទ្ធិរបស់ព្រះគ្រិស្ត ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា គាត់នោះនឹងមិនបាត់រង្វាន់របស់គាត់ឡើយ។[42]អ្នកណាធ្វើឲ្យអ្នកតូចម្នាក់ក្នុងចំណោមអ្នកដែលជឿក្នុងខ្ញុំ ទាំងឲ្យជំពប់ដួល វាគួរឲ្យអ្នកនោះចងកនឹងត្បាល់ថ្មកិន ហើយឲ្យគេទម្លាក់ក្នុងសមុទ្រនោះប្រសើរជាង។ ប្រសិនបើ ដៃរបស់អ្នកបានធ្វើឲ្យជំពប់ សូមកាត់វាចោលចុះ។[43]ប្រសើរជាងឲ្យអ្នកនោះចូលទៅក្នុងជីវិត ដោយពិការតែបើមានដៃទាំងពីរ បែបជាត្រូវធ្លាក់ទៅក្នុងស្ថាននរក ដែលមានភ្លើងមិនចេះរលត់។[44]ជាកន្លែងដែលមានដង្កូវមិនចេះងាប់ និងភ្លើងដែលឆេះមិនរលត់។[45]ប្រសិនបើ ជើងរបស់អ្នកធ្វើឲ្យអ្នកជំពប់ សូមកាត់វាចេញទៅ។ គួរឲ្យអ្នកចូលទៅក្នុងជីវិតទាំងពិការ ប្រសើរជាងមានជើងទាំងពីរ ហើយត្រូវបោះចូលទៅក្នុងស្ថាននរក។[46]ជាកន្លែងដែលមានដង្កូវមិនចេះងាប់ និងភ្លើងដែលឆេះមិនរលត់។[47]ប្រសិនបើភ្នែករបស់អ្នកធ្វើឲ្យអ្នកជំពប់ សូមខ្វេះវាចោលចុះ។ គួរឲ្យអ្នកចូលទៅក្នុងនគរព្រះជាម្ចាស់មានភ្នែកតែម្ខាង ប្រសើរជាងមានភ្នែកមួយគូ ហើយត្រូវបោះចូលទៅក្នុងស្ថាននរក។[48]គឺជាកន្លែងដែលមានដង្កូវមិនចេះងាប់ និងភ្លើងដែលឆេះមិនរលត់។[49]ដ្បិត មនុស្សគ្រប់ៗគ្នា នឹងមានជាតិប្រៃដោយសារភ្លើង។[50]អំបិលជារបស់ល្អ ប៉ុន្តែ បើអំបិលបាត់ជាតិប្រៃហើយ តើនឹងយកអ្វីមកធ្វើឲ្យប្រៃឡើងវិញបាន? សូមឲ្យមានជាតិប្រៃនៅក្នុងចំណោមអ្នករាល់គ្នា ហើយរស់នៅជាមួយគ្នាដោយសុខសាន្តចុះ។

Mark 9:1

ឃ្លាភ្ជាប់៖

ព្រះយេស៊ូបានមានបន្ទូលទៅបណ្តាជននិងសិស្សរបស់ព្រះអង្គអំពីការដើរតាមព្រះអង្គ។

ប្រាំមួយថ្ងៃក្រោយមកព្រះយេស៊ូបានឡើងទៅលើភ្នំជាមួយសិស្សបីនាក់

ជាកន្លែងដែលព្រះយេស៊ូផ្លាស់ប្រែព្រះភ័ក្ត្រ

ដូច្នេះព្រះភ័ក្ត្រទ្រង់មើលទៅដូចជាទ្រង់កំពុងតែនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។

ព្រះអង្គមានបន្ទូលទៅពួកគេថា

«ហើយព្រះយេស៊ូមានបន្ទូលទៅពួកសិស្សរបស់ទ្រង់»

ព្រះរាជ្យនៃព្រះជាម្ចាស់យាងចុះមកជាមួយនឹងអំណាចព្រះចេស្តា

ព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលយាងមកជាតំណាងព្រះជាម្ចាស់ដែលបង្ហាញថា

ព្រះអង្គជាស្តេច។

«ព្រះអង្គបង្ហាញអង្គទ្រង់ដោយឫទ្ធានុភាពដ៏អស្ចារ្យក្នុងនាមជាស្តេច»

ដាច់ដោយឡែកតែពួកគេ

អ្នកនិពន្ធប្រើសព្វនាមឆ្លុះបញ្ចាំងនៅទីនេះ

បញ្ជាក់ថាពួកគេនៅម្នាក់ឯងហើយមានតែព្រះយេស៊ូ ពេត្រុស យ៉ាកុប

និងយ៉ូហានប៉ុណ្ណោះដែលបានឡើងលើភ្នំ។

ព្រះអង្គក៏មានរូបរាងប្លែក

អាចសរសេរបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ «ទ្រង់បានបង្ហាញខ្លួនខុសគ្នាខ្លាំង»

នៅពីមុខពួកគេ

«នៅពីមុខពួកគេ»

ភ្លឺចាំងយ៉ាងអស្ចារ្យ

«ចាំងពន្លឺ» ឬ «បញ្ចេញពន្លឺ» ។ សម្លៀកបំពាក់របស់ព្រះយេស៊ូមានពណ៌ស ឬបញ្ចេញពន្លឺ។

យ៉ាងអស្ចារ្យ

«ខ្លាំងណាស់»

គ្មានមនុស្សណានៅផែនដីនេះ អាចនឹងធ្វើឲ្យសដូចជាសម្លៀកបំពាក់នោះឡើយ

អំពីដំណើរការនៃការធ្វើឲ្យរោមចៀមពណ៌សធម្មជាតិដោយប្រើសារធាតុគីមី ដូចជាសូលុយស្យុងឬអាម៉ូញាក់។

«ពណ៌សជាងមនុស្សទាំងអស់នៅលើផែនដីអាចធ្វើបាន»

Mark 9:4

លោកអេលីយ៉ា និងលោកម៉ូសេ

អាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា បុរសទាំងនេះជានរណា។

«ព្យាការីពីរនាក់ដែលបានរស់នៅជាយូរមកហើយ

គឺលោកម៉ូសេនិងលោកអេលីយ៉ា»

អ្នកទាំងពីរបានជជែក

ពាក្យថា“ ពួកគេ” សំដៅទៅលើអេលីយ៉ានិងលោកម៉ូសេ។

លោកពេត្រុស បានឆ្លើយដោយនិយាយទៅកាន់ព្រះយេស៊ូថា

លោកពេត្រុសទូលព្រះអង្គថា៖ «លោកម្ចាស់! នៅទីនេះពាក្យ "ឆ្លើយ" ត្រូវបានប្រើដើម្បីណែនាំពេត្រុសទៅក្នុងការសន្ទនានេះ។

ពេត្រុសមិនបានឆ្លើយសំណួរទេ។

យើង

ពាក្យនេះសំដៅទៅលើពេត្រុស យ៉ាកុប និងយ៉ូហាន។

ផ្ទះ
«តង់» ។ នេះសំដៅទៅលើលំនៅដ្ឋានបណ្តោះអាសន្នសាមញ្ញ។
ដ្បិត គាត់មិនដឹងជាត្រូវនិយាយអ្វីទេ ដោយព្រោះពួកគេកំពុងភ័យ
ប្រយោគនេះប្រាប់ព័ត៌មានសំខាន់អំពីពេត្រុសយ៉ាកុបនិងយ៉ូហាន។
ភ័យ
«ភ័យខ្លាច» ឬ «ភ័យខ្លាចខ្លាំងណាស់»
Mark 9:7
លេចមកគ្របបាំង
«បានលេចមកនិងគ្របដណ្តប់»
ក្រោយមកមានសំឡេងចេញពីពពកមកថា
«សំឡេង» ជាពាក្យប្រៀបធៀបសម្រាប់ព្រះជាម្ចាស់។ ដូចគ្នានេះផងដែរ «សំឡេង»
ត្រូវបានពិពណ៌នាថា «ចេញពីពពក»
មានន័យថាពួកគេបានឮព្រះជាម្ចាស់មានព្រះបន្ទូលចេញពីពពកមក។
«បន្ទាប់មកព្រះជាម្ចាស់មានព្រះបន្ទូលពីពពក»
នេះគឺជាបុត្រជាទីស្រឡាញ់របស់យើង សូមស្តាប់តាមព្រះអង្គចុះ»
ព្រះបិតាសម្តែងក្តីស្រឡាញ់ចំពោះ «ព្រះរាជបុត្រាជាទីស្រឡាញ់»
ជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។
បុត្រជាទីស្រឡាញ់
ជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូ ជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។
ពេលដែលពួកគេមើល
ពាក្យ «ពួកគេ» ត្រង់នេះ សំដៅទៅលើពេត្រុស យ៉ាកុបនិងយ៉ូហាន។
Mark 9:9
ព្រះជាម្ចាស់បានបង្គាប់ហាមមិនឲ្យប្រាប់ការអ្វីដែលពួកគេបានឃើញដល់អ្នកណាឲ្យសោះ
ដរាបដល់កូនមនុស្សបានរស់ឡើងវិញពីសេចក្តីស្លាប់សិន
មានន័យថា ទ្រង់បានអនុញ្ញាតឲ្យពួកគេប្រាប់មនុស្សអំពីអ្វីដែលពួកគេបានឃើញ
បន្ទាប់ពីទ្រង់បានរស់ពីស្លាប់ឡើងវិញសិន។
រស់ឡើងវិញពីសេចក្តីស្លាប់សិន
បានរស់ពីស្លាប់ឡើងវិញ ... ដើម្បីរស់ពីស្លាប់ឡើងវិញសិន «ឬ »
រស់ពីចំណោមមនុស្សស្លាប់ ... ដើម្បីរស់ពីចំណោមមនុស្សស្លាប់ឡើងវិញសិន" ។
មានន័យថារស់ឡើងវិញ។ ឃ្លា «អ្នកស្លាប់» សំដៅទៅលើ «មនុស្សស្លាប់»
និងជាពាក្យប្រៀបធៀបសម្រាប់ការស្លាប់។ «បានរស់ពីស្លាប់ឡើងវិញ ...
ដើម្បីរស់ពីស្លាប់ឡើងវិញសិន»
ដូច្នេះ ហើយពួកគេក៏បានរក្សារឿងនោះ នៅក្នុងពួកគេ
ឃ្លា «រក្សាទុករឿងនេះដោយខ្លួនឯង» ជាពាក្យសម្តីដែលមានន័យថា
ពួកគេមិនបានប្រាប់នរណាម្នាក់អំពីអ្វីដែលពួកគេបានឃើញទេ។
«ដូច្នេះពួកគេមិនបានប្រាប់នរណាម្នាក់អំពីអ្វីដែលពួកគេបានឃើញទេ»
Mark 9:11
ឃ្លាភ្ជាប់៖
ទោះបីពេត្រុស យ៉ាកុប និងយ៉ូហានឆ្ងល់ថាតើព្រះយេស៊ូចង់មានន័យយ៉ាងណា
«អំពីការរស់ពីស្លាប់ឡើងវិញ» ក៏ដោយ
ក៏ពួកគេបានសួរអំពីការមកដល់របស់អេលីយ៉ាទៅវិញ។
ព័ត៌មានទូទៅ:
យូឌីប៊ីប្រើជាស្ពានដើម្បីភ្ជាប់ខ១២ និង១៣ ដោយផ្តល់ព័ត៌មាន
ដែលព្រះយេស៊ូកំពុងប្រាប់ពួកគេតាមលំដាប់លំដោយងាយយល់ជាង។
ពួកគេទូលសួរព្រះអង្គថា
ពាក្យថា“ ពួកគេ” សំដៅទៅលើពេត្រុស យ៉ាកុបនិងយ៉ូហាន។
ហេតុអ្វីពួកអាចារ្យនិយាយថាលោកអេលីយ៉ាត្រូវមកជាមុន»?
ទំនាយថាអេលីយ៉ានឹងមកពីស្ថានសួគ៌ម្តងទៀត។
បន្ទាប់មកព្រះមេស្ស៊ីដែលជាកូនមនុស្សនឹងមកគ្រប់គ្រងនិងសោយរាជ្យ។
ទំនាយឯទៀតក៏បានទាយដែរថា កូនមនុស្សនឹងរងទុក្ខហើយត្រូវគេស្អប់។
ពួកសិស្សមានការភាន់ច្រឡំថាតើទាំងពីរអាចជាការពិតឬទេ។
លោកអេលីយ៉ាត្រូវមកជាមុន
ពួកអាចារ្យបានបង្រៀនថា
អេលីយ៉ានឹងត្រឡប់មកផែនដីវិញមុនពេលដែលព្រះមេស្ស៊ីយាងមក។
«អេលីយ៉ាត្រូវតែមកមុនព្រះមេស្ស៊ីយាងមក»
ហេតុអ្វី បានជាមានសេចក្តីចែងទុកមកថា ...អ្នកគ្មានតម្លៃ
ពេលព្រះយេស៊ូកំពុងបង្រៀនសិស្សរបស់ទ្រង់
នោះទ្រង់សួរសំណួរនេះរួចក៏ប្រាប់ចម្លើយដល់សិស្សទ្រង់។ អាចសរសេរជាឃ្លាថា
«ប៉ុន្តែខ្ញុំក៏ចង់ឲ្យអ្នកពិចារណានូវអ្វីដែលបានចែងអំពីកូនមនុស្សដែរ»។
ត្រូវគេប្រព្រឹត្តដូចអ្នកគ្មានតម្លៃ
អាចសរសេរជាទម្រង់កិរិយាសកម្ម។ «ហើយមនុស្សនឹងចាត់ទុកទ្រង់ថា
ជាមនុស្សដែលគ្មានតម្លៃ»
ហើយពួកគេបានប្រព្រឹត្តចំពោះគាត់តាមតែចិត្តគេចង់
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីអ្វី ដែលមនុស្សបានធ្វើចំពោះទ្រង់។
«និងមេដឹកនាំរបស់យើងបានធ្វើបាបទ្រង់យ៉ាងធ្ងន់ធ្ងរ តាមតែចិត្តពួកគេ»
Mark 9:14
ឃ្លាភ្ជាប់៖
ពេលពេត្រុស យ៉ាកុប យ៉ូហាន និងព្រះយេស៊ូចុះពីលើភ្នំមកវិញ
គេឃើញពួកអាចារ្យកំពុងតែឈ្លោះប្រកែកជាមួយសិស្សឯទៀត។
ពេលពួកគេមកដល់ពួកសិស្សវិញ
ព្រះយេស៊ូ ពេត្រុស យ៉ាកុប និងយ៉ូហានបានត្រឡប់ទៅពួកសិស្សផ្សេងទៀត
ដែលមិនបានឡើងទៅលើភ្នំជាមួយ។
ពួកអាចារ្យនៅជុំវិញពួកសិស្ស កំពុងតែប្រកែកគ្នា
ពួកអាចារ្យកំពុងតែប្រកែកគ្នាជាមួយពួកសិស្សដែលមិនទៅជាមួយព្រះយេស៊ូ។
ភ្លាមក៏អស្ចារ្យ
អាចមានប្រយោជន៍ក្នុងការបញ្ជាក់ពីមូលហេតុ ដែលពួកគេភ្ញាក់ផ្អើល។
«ភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលព្រះយេស៊ូបានយាងមក»
Mark 9:17
ឃ្លាភ្ជាប់៖
ដើម្បីពន្យល់ពីអ្វីដែលពួកអាចារ្យ និងសិស្សដទៃទៀតកំពុងឈ្លោះប្រកែកគ្នា
នោះឪពុករបស់បុរសដែលមានអារក្សចូលបានប្រាប់ព្រះយេស៊ូថា
គាត់បានស្នើសុំឲ្យយពួកសិស្សបណ្តេញអារក្សចេញពីកូនប្រុសរបស់គាត់
ប៉ុន្តែពួកគេមិនអាចធ្វើបានទេ។
បន្ទាប់មកព្រះយេស៊ូក៏ដេញអារក្សចេញពីក្មេងប្រុស។
ក្រោយមកពួកសិស្សសួរថាហេតុអ្វីបានជាពួកគេមិនអាចដេញអារក្សបាន?
គឺគាត់មានវិញ្ញាណ
មានន័យថា ក្មេងប្រុសនេះត្រូវបានវិញ្ញាណមិនល្អចូល។ «គាត់មានវិញ្ញាណមិនល្អ»
ឬ «គាត់ត្រូវបានវិញ្ញាណមិនល្អចូល»
ធ្វើឲ្យបែកពពុះមាត់
ពេលមនុស្សម្នាក់ប្រកាច់ពួកគេអាចមានបញ្ហាដកដង្ហើមឬការលេប។
នេះបណ្តាលឲ្យមានពពុះពណ៌សចេញពីមាត់។
ប្រសិនបើភាសារបស់អ្នកមានវិធីដើម្បីពិពណ៌នានោះអ្នកអាចប្រើវាបាន។
ហើយនិងរឹងខ្លួន
«ក្លាយជារឹង»។ អាចមានប្រយោជន៍ក្នុងការបញ្ជាក់ថា រាងកាយរបស់គាត់ដែលរឹង។
«រាងកាយរបស់គាត់រឹង»
ប៉ុន្តែពួកគេមិនអាចធ្វើបានទេ
អាចមានប្រយោជន៍ក្នុងការបន្ថែមព័ត៌មានដែលបាត់។
«ពួកគេមិនអាចបណ្តេញវាចេញពីគាត់បានទេ»
ព្រះជាម្ចាស់មានបន្ទូលតបទៅពួកគេថា
ទោះជាឪពុករបស់ក្មេងប្រុសនោះបានសុំព្រះយេស៊ូក៏ដោយ
មានតែព្រះអង្គជាព្រះជាម្ចាស់តែមួយប៉ុណ្ណោះដែលនៅជិតព្រះវរបិតា គឺព្រះអង្គបានសំដែងឲ្យស្គាល់ព្រះជាម្ចាស់។
[19]នេះគឺជាទីបន្ទាល់របស់លោកយ៉ូហាន នៅពេលពួកយូដាចាត់ពួកបូជាចារ្យ និងពួកលេវីទៅឯព្រះអង្គពីក្រុងយេរូសាឡិម ដើម្បីទូលសួរគាត់ថា៖
«តើគាត់ជានរណា?»[20]គាត់ថ្លែងយ៉ាងងាយ និងមិនបានបដិសេធទេ ប៉ុន្តែ ឆ្លើយថា៖ «ខ្ញុំមិនមែនជាព្រះគ្រិស្តទេ»។[21]ដូច្នេះ គេបានសួរគាត់ទៀតថា «អ៊ីចឹង
តើអ្នកជានរណា?» តើអ្នកជាលោកអេលីយ៉ា?» គាត់ឆ្លើយថា៖ «ខ្ញុំមិនមែនទេ»។ ពួកគេសួរថា៖ «តើអ្នកជាព្យាការី?» គាត់ឆ្លើយថា៖ «មិនមែនទេ»។
[22]បន្ទាប់មក ពួកគេបានសួរគាត់ទៀតថា៖ «តើអ្នកជានរណា អ៊ីចឹង ដើម្បីឲ្យយើងអាចឆ្លើយទៅអស់អ្នកដែលចាត់យើងឲ្យមក? តើអ្នកនិយាយពីខ្លួនអ្នកយ៉ាងដូចម្តេច»?
[23]គាត់ឆ្លើយថា៖ «ខ្ញុំជាសម្លេងមួយ ដែលស្រែកនៅក្នុងទីរហោស្ថានថា៖ «ចូររៀបចំផ្លូវត្រង់ថ្វាយព្រះអម្ចាស់ ដូចព្យាការីអេលីយ៉ាបានថ្លែង»។
[24]មានអ្នកខ្លះត្រូវបានពួកគណៈផារីស៊ីចាត់មក[25]ពួកគេសួរគាត់ ហើយនិយាយទៅកាន់គាត់ថា៖ «ម្តេចក៏អ្នកធ្វើពិធីជ្រមុជអ៊ីចឹង ប្រសិនបើ អ្នកមិនមែនជាព្រះគ្រិស្ត
ឬលោកអេលីយា ឬជាព្យាការី?»
[26]លោកយ៉ូហានបានឆ្លើយទៅកាន់ពួកគេថា៖ «ខ្ញុំជ្រមុជជាមួយនឹងទឹក។ ប៉ុន្តែ នៅក្នុងចំណោមអ្នករាល់គ្នាដែលឈរនេះ នឹងមានម្នាក់ដែលអ្នកមិនស្គាល់។
[27]លោកជាម្នាក់ដែលនឹងមកក្រោយខ្ញុំ ហើយខ្ញុំមិនស័ក្តិសមសូម្បីតែស្រាយខ្សែស្បែកជើងព្រះអង្គផង»។[28]ការទាំងនេះបានកើតឡើងនៅក្នុងភូមិបេតថានី
នៅផ្នែកម្ខាងទៀតនៃទន្លេយ័រដាន់ ជាកន្លែងដែលលោកយ៉ូហានធ្វើពិធីជ្រមុជ។
[29]នៅថ្ងៃបន្ទាប់ លោកយ៉ូហានបានឃើញព្រះយេស៊ូយាងមករកគាត់ ហើយគាត់មានប្រសាសន៍ថា «មើល! លោកជាកូនចៀមនៃព្រះដែលដកយកបាបរបស់មនុស្សលោក។
[30]លោកជាម្នាក់ដែលខ្ញុំបាននិយាយ «គឺជាម្នាក់ដែលមកក្រោយខ្ញុំ ធំជាងខ្ញុំ ដ្បិតព្រះអង្គគង់នៅមុនខ្ញុំ»។[31]ខ្ញុំមិនបានស្គាល់ព្រះអង្គទេ
ប៉ុន្តែគឺដូច្នេះហើយដែលព្រះអង្គបានបង្ហាញដល់អ៊ីស្រាអែលថាខ្ញុំបានមកធ្វើពិធីជ្រមុជដោយទឹកប៉ុណ្ណោះ»។
[32]លោកយ៉ូហានបានធ្វើបន្ទាល់ហើយមានប្រសាសន៍ថា៖ «ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីស្ថានសួគ៌មក ដូចជាសត្វព្រាប
ហើយសត្វព្រាបនោះបានសណ្ឋិតលើព្រះអង្គ។[33]ខ្ញុំមិនបានស្គាល់ព្រះអង្គទេ ប៉ុន្តែ ព្រះអង្គគឺជាព្រះដែលបានចាត់ខ្ញុំមកជ្រមុជដោយទឹក ទ្រង់មានបន្ទូលមកកាន់ខ្ញុំថា៖
«នៅពេលអ្នកឃើញព្រះវិញ្ញាណសណ្ឋិតលើនរណា ហើយស្ថិតនៅជាមួយអ្នកនោះ អ្នកនោះហើយជាអ្នកដែលធ្វើពិធីជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។
[34]ខ្ញុំបានឃើញទាំងពីរ ហើយបានធ្វើបន្ទាល់ថា នេះគឺជាបុត្ររបស់ព្រះជាម្ចាស់»។

generated on Wed Sep 10 16:16:32 2025

[35]នៅថ្ងៃបន្ទាប់ ជាថ្មីម្តងទៀត ក្នុងការដែលលោកយ៉ូហានឈរជាមួយសិស្សពីរនាក់របស់គាត់[36]ពួកគេបានឃើញព្រះយេស៊ូយាងមកជិត
ហើយលោកយ៉ូហានមានប្រសាសន៍ថា៖ «មើល! កូនចៀមនៃព្រះ»។
[37]សិស្សពីរនាក់របស់គាត់បានឮគាត់ដូច្នេះ ពួកគេក៏ដើរតាមព្រះយេស៊ូទៅ។[38]បន្ទាប់មកបានបែរមក ហើយឃើញពួកគេដើរតាមព្រះអង្គ
ហើយព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «តើអ្នកចង់បានអ្វី?» ពួកគេឆ្លើយថា៖ «រ៉ាប៊ី (ដែលប្រែមានន័យថា លោកគ្រូ)
តើលោកគ្រូស្នាក់នៅឯណា?»[39]ទ្រង់មានបន្ទូលទៅកាន់ពួកគេថា៖ «សូមមកតាមខ្ញុំ នោះអ្នកនឹងឃើញ»។ ដូច្នេះ ពួកគេក៏ទៅ ហើយឃើញកន្លែងដែលព្រះអង្គស្នាក់នៅ
ពួកគេបាននៅជាមួយព្រះអង្គនៅថ្ងៃនោះ ដ្បិតនៅពេលនោះប្រហែលជាម៉ោងដប់។
[40]សិស្សម្នាក់ក្នុងចំណោមសិស្សទាំងពីរបានឮលោកយ៉ូហាននិយាយ ហើយបន្ទាប់មកបានដើរតាមព្រះយេស៊ូ គាត់ឈ្មោះអនទ្រេ ជាបងប្រុសរបស់លោកស៊ីម៉ូនពេត្រុស។
[41]គាត់ជាមនុស្សដំបូងដែលរកបងប្រុសគាត់ផ្ទាល់គឺលោកស៊ីម៉ូន ហើយនិយាយទៅគាត់ថា «យើងបានរកព្រះមេស្ស៊ីឃើញហើយ» (ដែលប្រែថា: ព្រះគ្រិស្ត)។
[42]អនទ្រេបាននាំគាត់ទៅជួបព្រះយេស៊ូ ហើយព្រះយេស៊ូបានសម្លឹងមកឯគាត់ ហើយមានបន្ទូលថា «អ្នកជាស៊ីម៉ូនកូនរបស់លោកយ៉ូហាន គេនឹងហៅអ្នកថា៖ កៃផាស់»
(ដែលប្រែថាពេត្រុស)។
[43]នៅថ្ងៃបន្ទាប់ នៅពេលព្រះយេស៊ូចង់ចាកចេញ ដើម្បីទៅឯកាលីឡេវិញ ព្រះអង្គបានជួបលោកភីលីព ហើយមានបន្ទូលទៅគាត់ថា៖ «ចូរមកតាមខ្ញុំ»។
[44]លោកភីលីពមកពីបេតសៃដា ជាក្រុងរបស់លោកអនទ្រេ និងលោកពេត្រុស។[45]លោកភីលីពបានជួបលោកណាថាណែល ហើយនិយាយទៅគាត់ថា៖
«ព្រះដែលលោកម៉ូសេសរសេរនៅក្នុងគម្ពីរក្រឹត្យវិន័យ និងពួកព្យាការីបានសរសេរ យើងបានជួបព្រះអង្គហើយ
គឺព្រះយេស៊ូជាកូនរបស់លោកយ៉ូសែបមកពីស្រុកណាសារ៉ែត»។
[46]លោកណាថាណែលមានប្រសាសន៍ទៅកាន់គាត់ថា៖ «តើមានការល្អណាចេញពីណាសារ៉ែត?» លោកភីលីពឆ្លើយថា៖ «សូមមកតាមខ្ញុំនោះអ្នកនឹងឃើញ»។
[47]ព្រះយេស៊ូបានឃើញលោកណាថាណែលដើរចូលមករកព្រះអង្គ ហើយព្រះអង្គមានបន្ទូលពីគាត់ថា៖ «មើល ឱជនជាតិអ៊ីស្រាអែលដ៏ពិតអើយ
អ្នកគ្មានសេចក្តីកុហកក្នុងខ្លួនឡើយ»។[48]លោកណាថាណែលមានប្រសាសន៍ទៅព្រះអង្គវិញថា៖ «តើលោកអាចស្គាល់ខ្ញុំបានយ៉ាងដូចម្តេច?» ព្រះយេស៊ូឆ្លើយ
ហើយមានបន្ទូលថា៖ «មុនពេលភីលីពហៅអ្នក ខ្ញុំបានឃើញអ្នក នៅពេលដែលអ្នកនៅក្រោមដើមឧទុម្ពររួចហើយ។
[49]លោកណាថាណែលឆ្លើយថា៖ «រ៉ាប៊ី ព្រះអង្គគឺជាព្រះបុត្រានៃព្រះជាម្ចាស់ ព្រះអង្គគឺជាព្រះមហាក្សត្ររបស់អ៊ីស្រាអែល»។[50]ព្រះយេស៊ូឆ្លើយទៅគាត់វិញថា៖
«ដោយសារខ្ញុំបាននិយាយទៅកាន់អ្នកថា៖ «ខ្ញុំបានឃើញអ្នកនៅខាងក្រោមដើមឧទុម្ពរ ទើបអ្នកជឿខ្ញុំមែនទេ? អ្នកនឹងឃើញការដ៏អស្ចារ្យជាងនេះ»។[51]បន្ទាប់មក
ព្រះអង្គមានបន្ទូលថា ប្រាកដណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា អ្នកនឹងឃើញស្ថានសួគ៌បើកចំហ ហើយឃើញពួកទេវតារបស់ព្រះជាម្ចាស់ចុះឡើងពីលើបុត្រមនុស្ស»។

John 1:1
កាលដើមដំបូងឡើយ
សំដៅទៅលើពេលវេលាដំបូងបំផុតមុនពេល
ដែលព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃនិងផែនដី។
ព្រះបន្ទូល
សំដៅទៅលើព្រះយេស៊ូ។ បកប្រែថា "ព្រះបន្ទូល" ប្រសិនបើអាច។ បើ "ព្រះបន្ទូល"
មានលក្ខណៈជាភាសារបស់អ្នក វាអាចត្រូវបានបកប្រែថា
"អ្នកដែលត្រូវបានគេហៅថាព្រះបន្ទូល" ។
អ្វីៗទាំងអស់ត្រូវបានបង្កើតឡើងដោយសារព្រះអង្គ
អាចបកប្រែជាកិរិយាសកម្ម។
"ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់តាមរយៈព្រះយេស៊ូ"
គ្មានអ្វីដែលបានកើតមកដោយព្រះអង្គមិនបានបង្កើតឡើយ
អាចបកប្រែជាកិរិយាសកម្ម។ "ព្រះជាម្ចាស់មិនបានធ្វើអ្វីដោយគ្មានព្រះយេស៊ូទេ" ឬ
"ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ជាមួយព្រះយេស៊ូ"
John 1:4
ក្នុងព្រះអង្គមានជីវិត
នៅទីនេះ“ ជីវិត” ជាឧទាហរណ៍មួយ ដែលបណ្តាលឲ្យអ្វីៗមានជីវិត។
"ម្នាក់ដែលគេហៅថា ព្រះបន្ទូល ជាម្នាក់ដែលធ្វើឲ្យអ្វីៗទាំងអស់រស់នៅ"
ជីវិត
ពាក្យថា "ជីវិត"នៅទីនេះ បើអ្នកចង់ឲ្យច្បាស់លាស់ជាងនេះ ចូរបកប្រែថា“
ជីវិតខាងវិញ្ញាណ” ។
ជីវិតនោះគឺជាពន្លឺនៃមនុស្សលោកគ្រប់គ្នា
"ពន្លឺ" ជាពាក្យប្រៀបធៀបដែលមានន័យថា ជាការបើកសម្តែងរបស់ព្រះជាម្ចាស់។
"ទ្រង់បានបើកសម្តែងឲ្យយើងដឹងការពិតអំពីព្រះជាម្ចាស់
ដូចជាពន្លឺបង្ហាញពីអ្វីដែលស្ថិតនៅក្នុងភាពងងឹត"
ពន្លឺបំភ្លឺនៅក្នុងទីងងឹត ហើយទីងងឹតមិនអាចយកឈ្នះពន្លឺបានទេ
ដូចជាភាពងងឹតមិនអាចបញ្ចេញពន្លឺបានទេ
មនុស្សអាក្រក់មិនដែលរារាំងពន្លឺមិនឲ្យបង្ហាញពីសេចក្តីពិតរបស់ព្រះជាម្ចាស់បានឡើយ
John 1:6
ដើម្បីធ្វើបន្ទាល់អំពីពន្លឺ
ពាក្យ
"ពន្លឺ"នៅទីនេះជាពាក្យប្រៀបធៀបសម្រាប់ការបើកសម្តែងរបស់ព្រះជាម្ចាស់នៅក្នុងព្រះយេស៊ូ
"បង្ហាញពីរបៀប ដែលព្រះយេស៊ូប្រៀបដូចជាពន្លឺពិតរបស់ព្រះជាម្ចាស់"
John 1:9
ពន្លឺដ៏ពិត
ពាក្យ "ពន្លឺ"នៅទីនេះជាពាក្យប្រៀបធៀបដែលតំណាងឲ្យព្រះយេស៊ូ
ដែលជាការបើកសម្តែងដ៏ពិតរបស់ព្រះជាម្ចាស់។ "ដូចជាពន្លឺពិត"
John 1:10
ព្រះអង្គបានយាងមកនៅលោកីយ៍នេះ ហើយលោកីយ៍ត្រូវបានបង្កើតឡើងដោយសារព្រះអង្គ
ហើយលោកីយ៍មិនស្គាល់ព្រះអង្គទេ
"ទោះបីព្រះអង្គគង់នៅលើលោកនេះ
ហើយព្រះជាម្ចាស់បានបង្កើតអ្វីៗគ្រប់យ៉ាងតាមរយៈព្រះអង្គ
តែមនុស្សនៅតែមិនស្គាល់ព្រះអង្គ"
លោកីយ៍មិនស្គាល់ព្រះអង្គ
"លោកីយ៍" ជាពាក្យប្រៀបធៀបដែលតំណាងឲ្យប្រជាជនទាំងអស់
ដែលរស់នៅលើពិភពលោក។ "មនុស្សមិនបានដឹងថា ទ្រង់ជានរណាទេ"
ព្រះអង្គបានយាងមកលោកីយ៍នេះ ប៉ុន្តែ លោកីយ៍នេះ មិនទទួលព្រះអង្គទេ
"ទ្រង់មករកមិត្តរួមជាតិរបស់ព្រះអង្គ
ហើយមិត្តរបស់ព្រះអង្គផ្ទាល់ក៏មិនទទួលយកព្រះអង្គដែរ"
ទទួល
មានន័យថា ទទួលយកមនុស្សម្នាក់។ នៅពេលមនុស្សម្នាក់ទទួលភ្ញៀវ
ពួកគេស្វាគមន៍ហើយគោរពពួកគេ ដោយសង្ឃឹមថា
កសាងទំនាក់ទំនងជាមួយពួកគេ។
John 1:12
ជឿលើព្រះនាមព្រះអង្គ
មានន័យថា ជឿទុកចិត្តលើព្រះយេស៊ូជាព្រះសង្គ្រោះហើយរស់នៅតាមរបៀប
ដែលតម្កើងព្រះអង្គ។
នាមព្រះអង្គ
ពាក្យថា "ឈ្មោះ" ជាការប្រៀបធៀបដែលតំណាងឲ្យអត្តសញ្ញាណរបស់ព្រះយេស៊ូ
និងអ្វីៗទាំងអស់អំពីព្រះអង្គ។ "ព្រះយេស៊ូ"
ទ្រង់បានប្រទានសិទ្ធិ
"ទ្រង់បានផ្តល់សិទ្ធិអំណាចដល់ពួកគេ" ឬ "ឲ្យពួកគេអាចធ្វើបាន"
បុត្រារបស់ព្រះជាម្ចាស់
ពាក្យថា "កូនក្មេង"
ជាពាក្យប្រៀបធៀបដែលតំណាងឲ្យទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់
ដែលប្រៀបដូចជាកូនៗនឹងឪពុក។
John 1:14
ព្រះបន្ទូល
នេះជាពាក្យប្រៀបធៀប ដែលសំដៅលើព្រះយេស៊ូ។
ទ្រង់ជាអ្នកដែលបង្ហាញពីលក្ខណៈរបស់ព្រះជាម្ចាស់។
ព្រះបិតា
ជាងារសំខាន់សម្រាប់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

ពេញដោយព្រះគុណ
“ ពោរពេញទៅដោយព្រះទ័យសប្បុរសចំពោះយើង
ដែលយើងមិនសមនឹងទទួលបាន”
ព្រះអង្គដែលយាងមកក្រោយខ្ញុំ
យ៉ូហានកំពុងនិយាយអំពីព្រះយេស៊ូ។ ឃ្លាថា“ មកតាមក្រោយខ្ញុំ” មានន័យថា
ព័ន្ធកិច្ចរបស់លោកយ៉ូហានបានចាប់ផ្តើមរួចហើយ
ហើយព័ន្ធកិច្ចព្រះយេស៊ូនឹងចាប់ផ្តើមបន្ទាប់ពីលោកយ៉ូហាន។
ធំជាងខ្ញុំ
"ធំជាងខ្ញុំ" ឬ "សំខាន់ជាងខ្ញុំ"
ដ្បិតព្រះអង្គគង់នៅមុនខ្ញុំ
ប្រយ័ត្នកុំបកប្រែពាក្យនេះតាមរបៀប ដែលបង្ហាញថាព្រះយេស៊ូសំខាន់ជាង
ដោយសារទ្រង់មានអាយុច្រើនជាងលោកយ៉ូហាននៅលើផែនដីនេះ។
ព្រះយេស៊ូសំខាន់ជាងលោកយ៉ូហាន
ព្រោះព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ។
John 1:16
ភាពបរិបូរណ៌
ពាក្យនេះសំដៅទៅលើព្រះគុណរបស់ព្រះជាម្ចាស់ ដែលគ្មានទីបញ្ចប់។
ព្រះគុណថែមហើយថែមទៀត
"ព្រះពរលើព្រះពរ"
ព្រះបិតា
នេះជាងារសំខាន់ចំពោះព្រះជាម្ចាស់។
John 1:19
ពួកយូដាចាត់... ទៅឯព្រះអង្គពីក្រុងយេរូសាឡឹម
ពាក្យ "យូដា" នៅទីនេះតំណាងឲ្យ"មេដឹកនាំយូដា" ។
"មេដឹកនាំសាសន៍យូដាបានបញ្ជូន ... ពីទៅឯព្រះអង្គពីក្រុងយេរូសាឡឹម"
គាត់ថ្លែងយ៉ាងងាយ និងមិនបានបដិសេធទេ
ឃ្លាទីពីរនិយាយក្នុងន័យអវិជ្ជមាន ដូចគ្នានឹងឃ្លាទីមួយនិយាយក្នុងន័យវិជ្ជមាន។
បញ្ជាក់ថា លោកយ៉ូហាននិយាយការពិត។
"គាត់បានប្រាប់ការពិតដល់ពួកគេដោយសេរី"
អ៊ីចឹង តើអ្នកជានរណា
បើអ្នកពុំមែនជាព្រះសង្គ្រោះទេនោះ? ឬ "តើមានអ្វីកើតឡើង?" ឬ
"តើអ្នកកំពុងធ្វើអ្វី?"
John 1:22
ឃ្លាភ្ជាប់៖
លោកយ៉ូហានបន្តនិយាយជាមួយពួកបូជាចារ្យ និងពួកលេវី។
ពួកគេបានសួរគាត់ទៀតថា
"ពួកបូជាចារ្យនិងពួកលេវីនិយាយទៅកាន់លោកយ៉ូហាន"
យើង ពួកយើង
បូជាចារ្យនិងក្រុមលេវីមិនមែនលោកយ៉ូហានទេ
គាត់ឆ្លើយថា
លោកយ៉ូហាននិយាយថា
ខ្ញុំជាសម្លេងមួយ ដែលស្រែកនៅក្នុងទីរហោស្ថានថា
លោកយ៉ូហានកំពុងនិយាយថា ទំនាយរបស់អេសាយនិយាយអំពីខ្លួនគាត់។
ពាក្យថា“ សម្លេង” នៅទីនេះសំដៅទៅលើមនុស្ស
ដែលកំពុងតែស្រែកនៅទីរហោស្ថាន។ "ខ្ញុំអ្នកដែលស្រែកនៅវាលរហោស្ថាន"
ចូររៀបចំផ្លូវត្រង់ថ្វាយព្រះអម្ចាស់
ពាក្យ "ផ្លូវ"នៅទីនេះ ត្រូវបានប្រើជាពាក្យប្រៀបធៀប។
"រៀបចំខ្លួនសម្រាប់ការមកដល់របស់ព្រះអម្ចាស់
ដូចជាមនុស្សរៀបចំផ្លូវសម្រាប់មនុស្សសំខាន់"
John 1:24
អ្នកដែលគេចាត់អោយមកនោះជាពួកខាងគណៈផារីស៊ី
ជាព័ត៌មានខាងក្រោយអំពីមនុស្ស ដែលបានសួរលោកយ៉ូហាន។
John 1:26
ព័ត៌មានទូទៅ:
ខ២៨ ប្រាប់យើងអំពីសារនៃរឿង។
លោកជាម្នាក់ដែលនឹងមកក្រោយខ្ញុំ
«គាត់នឹងអធិប្បាយដល់អ្នកបន្ទាប់ពីខ្ញុំបានទៅ»
ខ្ញុំមិនស័ក្តិសមសូម្បីតែស្រាយខ្សែស្បែកជើងព្រះអង្គផង
ភារកិច្ច "ដោះស្បែកជើងរបស់គាត់" ដែលជាការងាររបស់ទាសករ ឬអ្នកបម្រើ។
លោកយ៉ូហានកំពុងនិយាយថាគាត់មិនសមនឹងធ្វើ
សូម្បីតែការងារមិនល្អរបស់អ្នកបម្រើសម្រាប់ព្រះយេស៊ូ។
John 1:29
កូនចៀមនៃព្រះ
នេះជាពាក្យប្រៀបធៀបដែលតំណាងឲ្យការលះបង់ដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់។
គេហៅព្រះយេស៊ូថា“ កូនចៀមនៃព្រះ”
ព្រោះទ្រង់បានបូជាព្រះជន្មសងថ្លៃលោះបាបរបស់មនុស្ស។
មនុស្សលោក
ពាក្យថា“ មនុស្សលោក”ជាពាក្យពិពណ៌
និងសំដៅទៅលើប្រជាជនទាំងអស់នៅលើពិភពលោក។
គឺជាម្នាក់ដែលមកក្រោយខ្ញុំ ធំជាងខ្ញុំ ដ្បិតព្រះអង្គគង់នៅមុនខ្ញុំ
បកប្រែដូចក្នុងជំពូក១ ខ១៤ ។
John 1:32
យាងចុះ
"ចុះមកក្រោម"
ដូចជាសត្វព្រាប
ឃ្លានេះជាពាក្យប្រៀបធៀបមួយ។ “ ព្រះវិញ្ញាណ”
ចុះមកដូចជាសត្វព្រាបចុះមកលើមនុស្សម្នាក់។
ស្ថានសួគ៌
ពាក្យថា ឋានសួគ៌សំដៅលើមេឃ។
បុត្រារបស់ព្រះជាម្ចាស់
ច្បាប់ចម្លងខ្លះនៃអត្ថបទនេះនិយាយថា“ ព្រះរាជបុត្រានៃព្រះជាម្ចាស់”
អ្នកផ្សេងទៀតនិយាយថា“ អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស”
បុត្រារបស់ព្រះជាម្ចាស់
នេះជាឋានៈសំខាន់ចំពោះព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះ។
John 1:35
នៅថ្ងៃបន្ទាប់ ជាថ្មីម្តងទៀត
នេះជាថ្ងៃមួយទៀត។ នេះជាថ្ងៃទីពីរ
ហើយដែលលោកយ៉ូហានបានឃើញព្រះយេស៊ូ។
កូនចៀមនៃព្រះ
នេះជាពាក្យប្រៀបធៀបដែលតំណាងឲ្យការលះបង់ដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់។
គេហៅព្រះយេស៊ូថា“ កូនចៀមនៃព្រះ”
ព្រោះទ្រង់ត្រូវបានបូជាព្រះជន្មសងថ្លៃលោះបាបរបស់មនុស្ស។ សូមមើលពីរបៀប
ដែលអ្នកបានបកប្រែឃ្លាដូចគ្នានេះនៅក្នុងជំពូក១ ខ២៩ ។
John 1:37
ម៉ោងដប់
"ម៉ោង១០" ឃ្លានេះចង្អុលបង្ហាញពេលវេលាមួយ ពេលរសៀលមុនពេលមេឃងងឹត
ប្រហែលជាយឺតពេលក្នុងការធ្វើដំណើរទៅកាន់ទីក្រុងមួយផ្សេងទៀត
គឺប្រហែលជាម៉ោង៤ល្ងាច។
John 1:40
ព័ត៌មានទូទៅ:
ខគម្ពីរទាំងនេះផ្តល់ឲ្យយើងនូវព័ត៌មានអំពីអនទ្រេនិងរបៀប
ដែលគាត់នាំបងប្រុសគាត់ទៅជួបព្រះយេស៊ូ។
រឿងនេះបានកើតឡើងមុនពេលពួកគេទៅ
និងបានឃើញកន្លែងព្រះយេស៊ូកំពុងគង់នៅក្នុង១:៣៧ ។
កូនរបស់លោកយ៉ូហាន
នេះមិនមែនជាយ៉ូហានបាទីស្តទេ។ "យ៉ូហាន"ជាឈ្មោះទូទៅមួយ។
John 1:43
លោកភីលីពមកពីបេតសៃដា ជាក្រុងរបស់លោកអនទ្រេ និងលោកពេត្រុស
នេះជាប្រវត្តិទូទៅរបស់លោកភីលីព។
John 1:46
លោកណាថាណែលមានប្រសាសន៍ទៅកាន់គាត់ថា
លោកណាថានិយាយទៅកាន់លោកភីលីព
តើមានការល្អណាចេញពីណាសារ៉ែត?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ធ្ងន់។
"គ្មានអ្វីល្អចេញពីណាសារ៉ែតទេ!"
អ្នកគ្មានសេចក្តីកុហកក្នុងខ្លួនឡើយ
អាចបញ្ជាក់តាមរបៀបវិជ្ជមាន។ "មនុស្សស្មោះត្រង់ទាំងស្រុង"
John 1:49

generated on Wed Sep 10 16:16:32 2025

រ៉ាប៊ី ព្រះអង្គគឺជាព្រះបុត្រានៃព្រះជាម្ចាស់ ព្រះអង្គគឺជាព្រះមហាក្សត្ររបស់អ៊ីស្រាអែល
ណាថាណែលនិយាយថា ព្រះយេស៊ូជា«ព្រះរាជបុត្រានៃព្រះជាម្ចាស់»
ព្រោះព្រះយេស៊ូស្គាល់ណាថាណែលដោយមិនបានជួបគាត់ពីមុន។
ព្រះបុត្រានៃព្រះជាម្ចាស់
នេះជាឋានៈសំខាន់ចំពោះព្រះយេស៊ូ។
ដោយសារខ្ញុំបាននិយាយទៅកាន់អ្នក.....អ្នកជឿខ្ញុំមែនទេ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីផ្តល់ការសង្កត់ធ្ងន់។
"អ្នកជឿព្រោះខ្ញុំនិយាយថា" ខ្ញុំបានឃើញអ្នកនៅក្រោមដើមឧទុម្ពរ '!
ប្រាកដណាស់
បកប្រែវិធីនេះជាភាសារបស់អ្នកសង្កត់ធ្ងន់ថា
អ្វីដែលនៅខាងក្រោមពិតជាសំខាន់ណាស់។

---

2 [1]បីថ្ងៃក្រោយមក មានពិធីមង្គលការមួយនៅភូមិកាណាក្នុងស្រុកកាលីឡេ ហើយមាតារបស់ព្រះយេស៊ូក៏នៅទីនោះដែរ។[2]ព្រះយេស៊ូ
និងពួកសិស្សរបស់ព្រះអង្គក៏ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងមង្គលការនោះដែរ។
[3]នៅពេលអស់ស្រា មាតារបស់ព្រះយេស៊ូទូលទៅកាន់ព្រះអង្គថា៖ «ពួកគេអស់ស្រាហើយ»។[4]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «អ្នកម្តាយអើយ
ហេតុអ្វីបានជាអ្នកម្តាយមកឯខ្ញុំ? មិនទាន់ដល់ពេលខ្ញុំនៅឡើយទេ»។[5]មាតារបស់ព្រះអង្គនិយាយទៅកាន់ពួកអ្នកបម្រើថា៖ «អ្វីដែលព្រះអង្គមានបន្ទូលទៅអ្នក
ចូរធ្វើវាចុះ!»។
[6]ឥឡូវនេះ មានពាងទឹកថ្មប្រាំមួយដែលប្រើសម្រាប់ពិធីជម្រះកាយរបស់សាសន៍យូដា ពាងនីមួយៗអាចផ្ទុកបានពីរទៅបីអម្រែក។[7]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖
«ចូរចាក់ទឹកបំពេញពាងទឹកទាំងអស់នេះទៅ»។ ដូច្នេះ ពួកគេក៏ចាក់ទឹកពេញមាត់ពាង។[8]បន្ទាប់មក ទ្រង់ប្រាប់ទៅពួកអ្នកបម្រើ «ឥឡូវ ចូរយកខ្លះចេញមក
ហើយយកវាទៅឲ្យមេការ»។ ពួកគេក៏ធ្វើតាម។
[9]មេការបានភ្លក់ទឹកដែលបានត្រឡប់ទៅជាស្រានោះ ប៉ុន្តែ គាត់មិនបានដឹងថាស្រានោះបានមកពីណាទេ (ប៉ុន្តែ អ្នកបម្រើដែលដងទឹកនោះទើបដឹង)។ បន្ទាប់មក
គាត់បានហៅកូនកម្លោះឲ្យមក[10]ហើយនិយាយទៅគាត់ថា «មនុស្សគ្រប់រូបគេដាក់ស្រាល្អមុន ហើយបន្ទាប់ពីស្រវឹងហើយ ទើបគេដាក់ស្រាមិនសូវល្អវិញ។ ប៉ុន្តែ អ្នកវិញ
អ្នកបានទុកស្រាល្អរហូតមកដល់ពេលនេះ»។
[11]នេះគឺជាការអស្ចារ្យទីមួយដែលព្រះយេស៊ូបានធ្វើនៅភូមិកាណាស្រុកកាលីឡេ ហើយព្រះអង្គបានបង្ហាញសិរីល្អរបស់ព្រះអង្គ
ហើយពួកសិស្សរបស់ព្រះអង្គបានជឿលើព្រះអង្គ។
[12]បន្ទាប់ពីនេះ ព្រះយេស៊ូ មាតា និងបងប្អូនរបស់ព្រះអង្គ ព្រមទាំងពួកសិស្សរបស់ព្រះអង្គបានធ្វើដំណើរចុះទៅភូមិកាពើណិម ហើយពួកគេក៏ស្នាក់នៅទីនោះពីរបីថ្ងៃ។
[13]ឥឡូវ ពិធីបុណ្យចម្លងរបស់សាសន៍យូដាក៏ជិតមកដល់ ហើយព្រះយេស៊ូបានយាងឡើងទៅក្រុងយេរូសាឡិម។[14]ព្រះអង្គបានជួបជាមួយនឹងពួកអ្នកលក់គោ ចៀម
និងព្រាប ព្រមទាំងពួកអ្នកប្តូរប្រាក់អង្គុយនៅទីនោះ។
[15]ដូច្នេះ ព្រះអង្គក៏ធ្វើខ្សែតី ហើយបានបណ្តេញពួកគេទាំងអស់ចេញពីព្រះវិហារ រួមទាំងចៀម និងគោផងដែរ។ ព្រះអង្គបានធ្វើឲ្យលុយកាក់របស់ពួកអ្នកប្តូរប្រាក់ខ្ចាត់ខ្ចាយ
ហើយបានក្រឡាប់តុរបស់ពួកគេចោល។[16]ចំពោះអ្នកលក់ព្រាបវិញ ព្រះអង្គមានបន្ទូលថា៖ «ចូរយករបស់ទាំងអស់នេះចេញពីទីនេះ។
ឈប់ធ្វើឲ្យដំណាក់របស់ព្រះបិតាយើងក្លាយជាកន្លែងលក់ដូរទៀត។
[17]ពួកសិស្សរបស់ព្រះអង្គបានចាំសេចក្តីដែលបានចែងថា៖ «ដោយសារតែខ្ញុំស្រឡាញ់ដំណាក់របស់ព្រះអង្គ ធ្វើឲ្យគេសម្លាប់ខ្ញុំ»។[18]ពេលនោះ
ពួកអាជ្ញាធររបស់យូដាបានឆ្លើយតបវិញ ហើយសួរទៅកាន់ព្រះអង្គថា៖ «តើអ្នកមានទីសម្គាល់អ្វីបង្ហាញយើង នៅពេលដែលអ្នកកំពុងធ្វើការទាំងនេះ?»
[19]ព្រះយេស៊ូបានឆ្លើយថា៖ «ខ្ញុំនឹងបំផ្លាញព្រះវិហារនេះ ហើយសង់វាឡើងវិញក្នុងរយៈពេលតែបីថ្ងៃប៉ុណ្ណោះ»។
[20]បន្ទាប់មក ពួកអាជ្ញាធររបស់យូដានិយាយថា៖ «ព្រះវិហារនេះ ត្រូវបានសង់ឡើងអស់រយៈពេលសែសិបប្រាំមួយឆ្នាំ ហើយអ្នកនឹងសង់ឡើងវិញ
ក្នុងរយៈពេលតែបីថ្ងៃ?»[21]ប៉ុន្តែ ព្រះអង្គកំពុងមានបន្ទូលអំពីព្រះវិហារនៃព្រះកាយរបស់ព្រះអង្គ។[22]ថាបន្ទាប់ពីព្រះអង្គសុគត ព្រះអង្គរស់ឡើងវិញ
ពួកសិស្សរបស់ព្រះអង្គចងចាំថាព្រះអង្គមានបន្ទូលពីការនេះ ហើយពួកគេជឿលើបទគម្ពីរ ហើយនឹងសេចក្តីដែលព្រះយេស៊ូបានថ្លែង។
[23]ឥឡូវនេះ នៅពេលព្រះអង្គចូលរួមពិធីបុណ្យរំលងនៅក្នុងក្រុងយេរូសាឡិម មានមនុស្សជាច្រើនបានជឿលើព្រះនាមព្រះអង្គ
នៅពេលដែលពួកគេបានឃើញទីសម្គាល់ដែលព្រះអង្គបានធ្វើ។[24]ប៉ុន្តែ ព្រះយេស៊ូមិនបានទុកចិត្តលើពួកគេឡើយ ដោយសារព្រះអង្គស្គាល់ពួកគេទាំងអស់គ្នា។
[25]ព្រោះព្រះអង្គមិនត្រូវការនរណាឲ្យធ្វើបន្ទាល់ពីព្រះអង្គនៅចំពោះមនុស្សឡើយ ដ្បិតព្រះអង្គជ្រាបពីគំនិតពួកគេ។

John 2:1
ព័ត៌មានទូទៅ:
ព្រះយេស៊ូនិងពួកសិស្សត្រូវបានអញ្ជើញឲ្យចូលរួមពិធីមង្គលការ។
ខគម្ពីរទាំងនេះផ្តល់នូវព័ត៌មានអំពីការកំណត់សាច់រឿង។
បីថ្ងៃក្រោយមក
អ្នកបកប្រែភាគច្រើនអានរឿងនេះ
នៅថ្ងៃទីបីបន្ទាប់ពីព្រះយេស៊ូបានហៅភីលីពនិងណាថាណែល ឲ្យទៅតាមព្រះអង្គ។
ថ្ងៃដំបូងកើតឡើងនៅក្នុងយ៉ូហាន១:៣៥ និងថ្ងៃទី២ នៅក្នុងយ៉ូហាន ១:៤៣ ។
ព្រះយេស៊ូ និងពួកសិស្សរបស់ព្រះអង្គក៏ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងមង្គលការនោះដែរ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"មានគេអញ្ជើញព្រះយេស៊ូនិងពួកសិស្សឲ្យចូលរួមពិធីមង្គលការ"
John 2:3
ស្ត្រី
សំដៅទៅលើម៉ារី។ បើកូនប្រុសហៅម្តាយខ្លួនឯងថា "ស្ត្រី" នៅក្នុងភាសារបស់អ្នក
សូមប្រើពាក្យផ្សេងទៀតដែលគួរសម ឬទុកវាចោល។
ហេតុអ្វីបានជាអ្នកម្តាយមកឯខ្ញុំ?
គេសួរសំណួរនេះដើម្បីសង្កត់ន័យ។ "ពុំមានជាប់ពាក់ព័ន្ធនឹងខ្ញុំទេ" ឬ
"មិនគួរប្រាប់ខ្ញុំពីអ្វីដែលត្រូវធ្វើទេ" ។
មិនទាន់ដល់ពេលខ្ញុំនៅឡើយទេ
ពាក្យ "ពេលវេលា" ជាឈ្មោះប្រៀបធៀបដែលតំណាងឲ្យឱកាសសមគួរ
សម្រាប់ព្រះយេស៊ូដើម្បីបង្ហាញថា ទ្រង់ជាព្រះមេស៊ីដោយធ្វើការអស្ចារ្យ។
"វាមិនទាន់ដល់ពេលដែលខ្ញុំត្រូវសម្តែងការអស្ចារ្យនោះទេ"
John 2:6
ពីរទៅបីអម្រែក
"៨០ ទៅ ១២០ លីត្រ។ " "អម្រែក" គឺជារង្វាស់នៃអង្គធាតុរាវប្រហែល៤០លីត្រ។
មាត់ពាង
មានន័យថា“ ដល់កំពូល” ឬ“ ពេញទាំងស្រុង” ។
មេការ
សំដៅទៅលើអ្នកទទួលខុសត្រូវលើអាហារនិងភេសជ្ជៈ។
John 2:9
ប៉ុន្តែ អ្នកបម្រើដែលដងទឹកនោះទើបដឹង
នេះជាព័ត៌មានផ្ទៃក្នុង។
ស្រវឹង
មិនអាចប្រាប់ពីភាពខុសគ្នារវាងស្រាថោកនិងស្រាថ្លៃៗ
ដោយសារតែផឹកគ្រឿងស្រវឹងច្រើនពេក
John 2:11
ឃ្លាភ្ជាប់៖
ខគម្ពីរនេះមិនមែនជាផ្នែកនៃសាច់រឿងសំខាន់ទេ
ផ្ទុយទៅវិញវាផ្តល់ជាយោបល់អំពីរឿងនេះ។
កាណា
ជាឈ្មោះទីកន្លែង
បង្ហាញសិរីល្អ
នៅទីនេះ «សិរីល្អ» សំដៅទៅលើអំណាចដ៏អស្ចារ្យរបស់ព្រះយេស៊ូ។
«បង្ហាញពីអំណាចរបស់ព្រះអង្គ»

generated on Wed Sep 10 16:16:32 2025

John 2:12
បានធ្វើដំណើរចុះទៅ
មានន័យថា ពួកគេបានធ្វើដំណើរពីកន្លែងខ្ពស់ទៅកន្លែងទាប។
កាណាស្ថិតនៅភាគនិរតីនៃក្រុងកាពើណិម ហើយស្ថិតនៅទីខ្ពស់ជាងគេ។
ប្អូនរបស់ព្រះអង្គ
ពាក្យថាបងប្អូន រួមមានទាំងបងប្អូនប្រុសស្រី។
បងប្អូនប្រុសស្រីរបស់ព្រះយេស៊ូទាំងអស់គឺក្មេងជាងព្រះអង្គ។
John 2:13
ព័ត៌មានទូទៅ:
ព្រះយេស៊ូនិងពួកសិស្សបានឡើងទៅព្រះវិហារក្រុងយេរូសាឡឹម។
ឡើងទៅក្រុងយេរូសាឡឹម
មានន័យថា ពួកគេបានធ្វើដំណើរពីកន្លែងទាបទៅកន្លែងខ្ពស់។
ក្រុងយេរូសាឡឹមត្រូវបានសាងសង់នៅលើភ្នំមួយ។
អង្គុយនៅទីនោះ
ខគម្ពីរបន្ទាប់បញ្ជាក់យ៉ាងច្បាស់ថា មនុស្សទាំងនេះស្ថិតនៅក្នុងទីធ្លាព្រះវិហារ។
កន្លែងនោះត្រូវបានបម្រុងទុកសម្រាប់ថ្វាយបង្គំ និងមិនមែនសម្រាប់លក់ដូរទេ។
ពួកអ្នកលក់គោ ចៀម និងព្រាប
ប្រជាជនបានទិញសត្វនៅក្នុងទីធ្លាព្រះវិហារ
ដើម្បីបូជាសត្វទាំងនោះថ្វាយព្រះជាម្ចាស់។
ពួកអ្នកប្តូរប្រាក់
អ្នកដឹកនាំជនជាតិជ្វីហ្វតម្រូវឲ្យមនុស្ស ដែលចង់ទិញសត្វសម្រាប់ការបូជា
ត្រូវប្តូរប្រាក់របស់ពួកគេសម្រាប់ប្រាក់ពិសេសពី "អ្នកប្តូរប្រាក់" ។
John 2:15
ដូច្នេះ
ពាក្យនេះសម្គាល់ព្រឹត្តិការណ៍ ដែលបានកើតឡើងដោយសារតែមានអ្វីផ្សេងទៀត
ដែលបានកើតឡើងមុន។
ក្នុងករណីនេះព្រះយេស៊ូបានឃើញអ្នកដូរលុយអង្គុយនៅក្នុងព្រះវិហារ។
ឈប់ធ្វើឲ្យដំណាក់របស់ព្រះបិតាយើងក្លាយជាកន្លែងលក់ដូរទៀត
"ឈប់ទិញនិងលក់របស់របរក្នុងដំណាក់ព្រះបិតាយើងទៅ"
ដំណាក់របស់ព្រះបិតាយើង
ជាឃ្លាដែលព្រះយេស៊ូប្រើដើម្បីសំដៅទៅលើព្រះវិហារ។
ព្រះបិតាយើង
ជាឋានៈសំខាន់ដែលព្រះយេស៊ូប្រើសម្រាប់ព្រះជាម្ចាស់។
John 2:17
បានចែងថា
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "មានគេសរសេរ"
ដំណាក់របស់ព្រះអង្គ
ពាក្យនេះសំដៅទៅលើព្រះវិហារ ដែលជាដំណាក់របស់ព្រះជាម្ចាស់។
សម្លាប់
ពាក្យថា“ សម្លាប់” ចង្អុលទៅពាក្យប្រៀបធៀប“ ភ្លើង” ។
សេចក្តីស្រឡាញ់របស់ព្រះយេស៊ូចំពោះព្រះវិហារ
ប្រៀបបីដូចជាភ្លើងដែលឆាបឆេះនៅក្នុងព្រះកាយព្រះអង្គ។
ទីសម្គាល់
សំដៅទៅលើព្រឹត្តិការណ៍មួយ ដែលបង្ហាញពីអ្វីដែលជាការពិត។
ការទាំងនេះ
សំដៅទៅលើសកម្មភាពរបស់ព្រះយេស៊ូប្រឆាំងនឹងអ្នកប្តូរប្រាក់នៅក្នុងព្រះវិហារ។
ខ្ញុំនឹងបំផ្លាញព្រះវិហារនេះ ហើយសង់វាឡើងវិញក្នុងរយៈពេលតែបីថ្ងៃប៉ុណ្ណោះ
ព្រះយេស៊ូចង់សំដៅទៅលើរូបកាយរបស់ព្រះអង្គផ្ទាល់
ជាព្រះវិហារដែលនឹងត្រូវស្លាប់ហើយនឹងរស់ឡើងវិញនៅបីថ្ងៃក្រោយ។
បកប្រែវាតាមរបៀបមួយដែលពិពណ៌នាអំពីការបំផ្លាញ
និងការកសាងអគារឡើងវិញ។ ព្រះយេស៊ូមិនបានបញ្ជាសិស្សរបស់ព្រះអង្គ
ឲ្យបំផ្លាញអគារព្រះវិហារនោះទេ។
សង់វាឡើងវិញ
មានន័យថា "កសាងឡើងវិញ" ឬ "ស្តារឡើងវិញ" ។
John 2:20
ព័ត៌មានទូទៅ:
ខ២១ និង២២ មិនមែនជាផ្នែកសំខាន់នៃសាច់រឿងទេ
ផ្ទុយទៅវិញពួកគេផ្តល់យោបល់លើរឿង
ហើយប្រាប់អំពីរឿងដែលកើតឡើងនៅពេលក្រោយ។
សែសិបប្រាំមួយឆ្នាំ ....បីថ្ងៃ
ប្រាំមួយឆ្នាំ ... បីថ្ងៃ - "៤៦ ឆ្នាំ ... ៣ ថ្ងៃ"
អ្នកនឹងសង់ឡើងវិញ ក្នុងរយៈពេលតែបីថ្ងៃ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបង្ហាញថាអ្នកដឹកនាំជ្វីហ្វយល់ថា
ព្រះយេស៊ូចង់បំផ្លាញព្រះវិហារហើយសាងសង់វាឡើងវិញក្នុងរយៈពេលបីថ្ងៃ។
"អ្នកមិនអាចកសាងវាឡើងវិញក្នុងរយៈពេលបីថ្ងៃទេ!"
ជឿ
ពាក្យ“ ជឿ” ត្រង់នេះមានន័យថា ទទួលយកអ្វីមួយ ឬជឿថាវាជាការពិត។
សេចក្តីដែល
សំដៅទៅលើសេចក្តីថ្លែងរបស់ព្រះយេស៊ូនៅ ២:១៧ ។
John 2:23
ឥឡូវនេះ នៅពេលព្រះអង្គនៅក្នុងក្រុងយេរូសាឡឹម
ពាក្យ“ ឥឡូវ” ណែនាំយើងអំពីព្រឹត្តិការណ៍ថ្មីមួយនៅក្នុងរឿង។
ជឿលើព្រះនាមព្រះអង្គ
ពាក្យ
"ឈ្មោះ"នៅទីនេះជាពាក្យប្រៀបធៀបដែលតំណាងឲ្យមនុស្សរបស់ព្រះយេស៊ូ។
"ជឿលើព្រះអង្គ" ឬ "ទុកចិត្តលើព្រះអង្គ"
ទីសម្គាល់ដែលព្រះអង្គបានធ្វើ
គេហៅការអស្ចារ្យថា "ទីសម្គាល់" ពីព្រោះពួកគេត្រូវបានប្រើជាភស្តុតាងបង្ហាញថា
ព្រះជាម្ចាស់មានអំណាចខ្លាំងបំផុត
ដែលមានសិទ្ធិអំណាចពេញលេញលើសកលលោក។

---

3 [1]ឥឡូវនេះ មានគណៈផារីស៊ីម្នាក់ មានឈ្មោះថាលោកនីកូដេម ជាអ្នកដឹកនាំរបស់យូដា។[2]បុរសនេះបានមករកព្រះយេស៊ូនៅពេលយប់ ហើយទូលទៅកាន់ព្រះអង្គថា៖
«រ៉ាប៊ី យើងដឹងថា លោកគឺជាគ្រូដែលបានមកពីព្រះជាម្ចាស់ ដ្បិតគ្មាននរណាអាចធ្វើទីសម្គាល់ដែលលោកបានធ្វើទាំងនេះទេ
លើកលែងតែព្រះជាម្ចាស់គង់នៅជាមួយគាត់»។
[3]ព្រះយេស៊ូបានឆ្លើយទៅគាត់វិញថា៖ «ពិតណាស់ ខ្ញុំសូមប្រាប់អ្នកជាប្រាកដថា ប្រសិនបើនរណាម្នាក់មិនបានកើតជាថ្មី
គាត់មិនអាចឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ»។[4]លោកនីកូដេមទូលទៅកាន់ព្រះអង្គថា៖ «តើមនុស្សអាចកើតម្តងទៀតបានដែរ បើគាត់ចាស់ហើយ?
គាត់មិនអាចចូលទៅក្នុងផ្ទៃម្តាយរបស់គាត់ជាលើកទីពីរ ហើយកើតជាថ្មីបានទេ តើអាចទេ?»
[5]ព្រះយេស៊ូឆ្លើយថា៖ «ពិតណាស់ ខ្ញុំសូមប្រាប់អ្នកជាប្រាកដថា ប្រសិនបើ អ្នកនោះមិនកើតចេញពីទឹក និងពីព្រះវិញ្ញាណទេ
គាត់មិនអាចចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ។[6]អ្វីដែលកើតចេញពីរូបកាយគឺជារូបកាយ ហើយអ្វីដែលកើតចេញពីព្រះវិញ្ញាណគឺព្រះវិញ្ញាណ។
[7]សូមកុំឆ្ងល់អ្វីដែលខ្ញុំនិយាយទៅកាន់អ្នកឡើយ «អ្នកត្រូវតែកើតជាថ្មី»។[8]ខ្យល់បក់ពីណាតាមតែវាចង់ អ្នកឮសម្លេងរបស់វា ប៉ុន្តែ អ្នកមិនដឹងថាវាមកពីណា ឬទៅណាទេ។
ដូចគ្នាជាមួយអ្នកដែលបានកើតពីព្រះវិញ្ញាណដែរ»។
[9]លោកនីកូដេមឆ្លើយ ហើយទូលទៅកាន់ព្រះអង្គថា៖ «តើការនេះអាចកើតឡើងបានយ៉ាងដូចម្តេច?»[10]ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលទៅកាន់គាត់ថា៖
«អ្នកគឺជាគ្រូរបស់អ៊ីស្រាអែល ហើយអ្នកនៅតែមិនយល់ពីការទាំងនេះទៀត?[11]ពិតណាស់ ខ្ញុំសូមប្រាប់អ្នកជាប្រាកដថា យើងនិយាយអ្វីដែលយើងដឹង
ហើយយើងធ្វើបន្ទាល់ពីអ្វីដែលយើងបានឃើញ។ តែអ្នកមិនទទួលទីបន្ទាល់របស់យើង។
[12]បើខ្ញុំគ្រាន់តែប្រាប់អ្នកពីកិច្ចការរបស់លោកីយ៍ ហើយអ្នកមិនជឿផង តើអ្នកនឹងជឿពីអ្វីដែលខ្ញុំប្រាប់អ្នកពីស្ថានសួគ៌ដូចម្តេចនឹងកើត?
[13]គ្មាននរណាម្នាក់បានឡើងទៅស្ថានសួគ៌ លើកលែងតែម្នាក់ដែលចុះពីស្ថានសួគ៌មក គឺបុត្រមនុស្ស។
[14]ដូចជាលោកម៉ូសេបានលើកសត្វពស់នៅទីរហោស្ថានយ៉ាងណា កូនមនុស្សនឹងត្រូវលើកឡើងយ៉ាងនោះដែរ[15]ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះអង្គ
នឹងមានជីវិតអស់កល្បជានិច្ច។

generated on Wed Sep 10 16:16:32 2025

[16]ដ្បិតព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ដូច្នេះហើយបានជាព្រះអង្គប្រទានព្រះបុត្រារបស់ព្រះអង្គតែមួយ ដើម្បីអស់អ្នកណាដែលជឿលើព្រះអង្គ
នឹងមិនស្លាប់ឡើយ តែនឹងមានជីវិតអស់កល្បជានិច្ចវិញ។[17]ដ្បិតព្រះជាម្ចាស់មិនបានចាត់ព្រះបុត្រាមកក្នុងលោកីយ៍ដើម្បីបំផ្លាញមនុស្សលោកទេ
ប៉ុន្តែដើម្បីនឹងសង្គ្រោះមនុស្សលោកតាមរយៈព្រះអង្គវិញ។[18]អស់អ្នកណាដែលជឿលើព្រះអង្គ នឹងមិនត្រូវមានទោសឡើយ ប៉ុន្តែអស់អ្នកណាដែលមិនជឿវិញ
ពួកគេមានទោសរួចស្រេចទៅហើយ ពួកគេមិនបានជឿលើព្រះនាមរបស់ព្រះ ហើយជាបុត្រារបស់ព្រះជាម្ចាស់តែមួយអង្គគត់។
[19]នេះគឺជាេហតុផលក្នុងការវិនិច្ឆ័យ ពន្លឺបានមកនៅក្នុងលោកីយ៍ហើយ ហើយមនុស្សស្រឡាញ់សេចក្តីងងឹតជាជាងពន្លឺ ព្រោះការប្រព្រឹត្តរបស់ពួកគេអាក្រក់។
[20]ព្រោះមនុស្សគ្រប់រូបដែលប្រព្រឹត្តការអាក្រក់ស្អប់ពន្លឺ ហើយមិនអាចចូលមកក្នុងពន្លឺទេ ដើម្បីកុំឲ្យការប្រព្រឹត្តរបស់ពួកគេនោះត្រូវបានបើកចំហឡើយ។[21]ប៉ុន្តែ
អស់អ្នកដែលប្រព្រឹត្តសេចក្តីពិត នឹងចូលមកឯពន្លឺ ដើម្បីឲ្យគេបានឃើញច្បាស់ថា ការប្រព្រឹត្តរបស់គាត់បានធ្វើនៅក្នុងព្រះជាម្ចាស់។
[22]បន្ទាប់ពីនេះ ព្រះយេស៊ូ និងពួកសិស្សរបស់ព្រះអង្គបានចេញទៅឯទឹកដីស្រុកយូដា។ ព្រះអង្គចំណាយពេលមួយរយៈនៅទីនោះជាមួយពួកគេ ហើយក៏ធ្វើពិធីជ្រមុជដែរ។
[23]ហើយលោកយ៉ូហានក៏ធ្វើពិធីជ្រមុជនៅអេណូន នៅជិតភូមិសាលីមដែរ ព្រោះនៅទីនោះមានទឹកច្រើន។ មនុស្សបានមករកគាត់
ហើយទទួលពិធីជ្រមុជជាមួយនឹងគាត់[24]នៅពេលនោះ លោកយ៉ូហានមិនទាន់ត្រូវបានចាប់ដាក់គុកនៅឡើយទេ។
[25]បន្ទាប់មកមានការប្រកែកគ្នាកើតឡើងរវាងពួកសិស្សរបស់លោកយ៉ូហាន និងសាសន៍យូដាម្នាក់ទាក់ទងរឿងពិធីលាងជម្រះ។[26]ពួកគេបានទៅជួបលោកយ៉ូហាន
ហើយនិយាយទៅកាន់គាត់ថា៖ «រ៉ាប៊ី មានម្នាក់នៅក្នុងចំណោមលោកគ្រូនៅឯទន្លេយ័រដាន់ម្ខាងទៀត ជាអ្នកដែលលោកបានធ្វើបន្ទាល់ មើល
គាត់កំពុងធ្វើពិធីជ្រមុជដល់មនុស្សគ្រប់គ្នាដែលមកឯគាត់។
[27]លោកយ៉ូហានឆ្លើយថា៖ «លោកយ៉ូហានមានប្រសាសន៍តបទៅគេថា៖ «បើព្រះជាម្ចាស់មិនប្រទានអោយទេ គ្មាននរណាម្នាក់អាចធ្វើអ្វីកើតឡើយ។
[28]អ្នកខ្លួនឯងក៏អាចធ្វើបន្ទាល់បានដែរ ពីអ្វីដែលខ្ញុំនិយាយថា៖ «ខ្ញុំមិនមែនជាព្រះគ្រិស្ត ប៉ុន្តែផ្ទុយទៅវិញខ្ញុំគ្រាន់តែត្រូវបានចាត់មកមុនព្រះអង្គប៉ុណ្ណោះ»។
[29]កូនក្រមុំជាកម្មសិទ្ធិរបស់កូនកម្លោះ។ ឥឡូវនេះ មិត្តសម្លាញ់របស់កូនកម្លោះ ដែលឈរ ហើយឮគាត់ មានអំណរជាខ្លាំងដោយសារសម្លេងរបស់កូនកម្លោះ។
ខ្ញុំពោរពេញដោយអំណរ។[30]សូមឲ្យព្រះអង្គបានចម្រើនឡើង តែសូមឲ្យទូលបង្គំបានថយចុះវិញ។
[31]ព្រះអង្គដែលយាងពីស្ថានលើមានអំណាចលើទាំងអស់។ អ្នកណាដែលមកពីផែនដីគឺមកពីផែនដី ហើយនិយាយតែពីរឿងលោកីយ៍។
អ្នកដែលមកពីស្ថានសួគ៌មានអំណាចលើទាំងអស់។[32]ព្រះអង្គបានធ្វើបន្ទាល់អំពីអ្វីដែលព្រះអង្គបានឃើញនិងឮ ប៉ុន្តែ គ្មាននរណាទទួលទីបន្ទាល់របស់ព្រះអង្គសោះ។
[33]អស់អ្នកណាដែលបានទទួលទីបន្ទាល់របស់ព្រះអង្គបានបញ្ជាក់ថាព្រះជាម្ចាស់បានសម្តែងសេចក្តីពិតមែន។
[34]ដ្បិតព្រះមួយអង្គដែលព្រះជាម្ចាស់បានចាត់មកឲ្យថ្លែងព្រះបន្ទូលរបស់ព្រះ ព្រោះព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកព្រះអង្គជាបរិបូរណ៌។[35]ព្រះបិតាស្រឡាញ់ព្រះបុត្រា
ហើយបានប្រទានអ្វីៗទាំងអស់ទៅក្នុងព្រះហស្តរបស់ព្រះអង្គ។[36]អ្នកណាដែលជឿលើព្រះបុត្រានឹងមានជីវិតអស់កល្បជានិច្ច
ប៉ុន្តែអ្នកណាដែលមិនស្តាប់បង្គាប់ដល់ព្រះបុត្រាវិញ នឹងមិនឃើញជីវិតឡើយ ប៉ុន្តែសេចក្តីក្រោធរបស់ព្រះនឹងស្ថិតនៅលើអ្នកនោះវិញ»។

John 3:1

ព័ត៌មានទូទៅ:

នីកូដេមបានមកជួបព្រះយេស៊ូ។

ឥឡូវនេះ

ពាក្យនេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ផ្នែកថ្មីនៃរឿងនិងណែនាំឲ្យស្គាល់នីកូដេម។

យើងដឹងថា

ពាក្យ "យើង" នៅទីនេះ
សំដៅទៅលើនីកូដេមនិងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាជ្វីហ្វប៉ុណ្ណោះ។

John 3:3

ឃ្លាភ្ជាប់៖

ព្រះយេស៊ូនិងនីកូដេមនៅតែបន្តនិយាយ។

ពិតណាស់

បកប្រែដូចនៅក្នុងជំពូក១ ខ៤៩។

កើតជាថ្មី

"កើតពីស្ថានលើ" ឬ "កើតពីព្រះជាម្ចាស់"

ព្រះរាជ្យរបស់ព្រះជាម្ចាស់

ពាក្យថា ព្រះរាជ្យ ជាពាក្យប្រៀបធៀបសម្រាប់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់។
"កន្លែងដែលព្រះជាម្ចាស់គ្រប់គ្រង"

តើមនុស្សអាចកើតម្តងទៀតបានដែរ បើគាត់ចាស់ហើយ?

នីកូដេមបានប្រើសំណួរនេះដើម្បីបញ្ជាក់ថា រឿងនេះមិនអាចកើតឡើងបានទេ។
"មនុស្សពិតជាមិនអាចកើតជាថ្មីបានទេពេលគាត់ចាស់ទៅ!"

គាត់មិនអាចចូលទៅក្នុងផ្ទៃម្តាយរបស់គាត់ជាលើកទីពីរ ហើយកើតជាថ្មីបានទេ តើអាចទេ?

នីកូដេមក៏បានប្រើសំណួរនេះបញ្ជាក់ពីជំនឿរបស់គាត់ថា
ការកើតជាលើកទីពីរមិនអាចទៅរួចទេ។ “
ប្រាកដណាស់គាត់មិនអាចចូលក្នុងផ្ទៃម្តាយជាលើកទីពីរបានទេ!

លើកទីពីរ

"ម្តងទៀត" ឬ "ពីរដង"

ផ្ទៃម្តាយ

ផ្នែកនៃរាងកាយរបស់ស្ត្រីដែលទារកលូតលាស់

John 3:5

ពិតណាស់

អ្នកអាចបកប្រែតាមជំពូក៣ ខ៣ ។

កើតចេញពីទឹក និងពីព្រះវិញ្ញាណ

មានន័យពីរយ៉ាង ១) «ទទួលពិធីជ្រមុជទឹកក្នុងទឹកនិងដោយវិញ្ញាណ»ឬ ២)
«កើតមកទាំងខាងរូបកាយនិងខាងវិញ្ញាណ»។

ព្រះរាជ្យរបស់ព្រះជាម្ចាស់

ពាក្យថាព្រះរាជ្យគឺជាពាក្យប្រៀបធៀបសម្រាប់ការគ្រប់គ្រងរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់មនុស្សម្នាក់

"គាត់មិនអាចពិសោធការគ្រប់គ្រងរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់គាត់ទេ"

John 3:7

សេចក្តីថ្លែងការណ៍ភ្ជាប់៖

ព្រះយេស៊ូបន្តនិយាយទៅកាន់នីកូដេម។

អ្នកត្រូវតែកើតជាថ្មី

"អ្នកត្រូវតែកើតពីខាងលើ"

ខ្យល់បក់ពីណាតាមតែវាចង់

នៅក្នុងភាសាដើមខ្យល់និងព្រះវិញ្ញាណ ជាពាក្យតែមួយ។
អ្នកនិយាយនៅទីនេះសំដៅទៅលើខ្យល់ដូចជាមនុស្ស។
«ព្រះវិញ្ញាណដ៏វិសុទ្ធប្រៀបដូចជាខ្យល់ ដែលបក់នៅគ្រប់ទីកន្លែងដែលវាចង់បក់»

John 3:9

តើការនេះអាចកើតឡើងបានយ៉ាងដូចម្តេច

សំណួរនេះបន្ថែមការសង្កត់ន័យទៅលើឃ្លា។ "នេះមិនអាចទេ!" ឬ
"នេះមិនអាចកើតឡើងបានទេ!"

អ្នកគឺជាគ្រូរបស់អ៊ីស្រាអែល ហើយអ្នកនៅតែមិនយល់ពីការទាំងនេះទៀត?

សំណួរនេះបន្ថែមការសង្កត់ន័យទៅលើឃ្លា។
"អ្នកជាគ្រូបង្រៀនជនជាតិអ៊ីស្រាអែល
ដូច្នេះខ្ញុំមានការភ្ញាក់ផ្អើលដែលអ្នកមិនយល់ពីរឿងទាំងនេះ!"

ពិតណាស់

បកប្រែដូចនៅក្នុងជំពូក១ ខ៤៩។

យើងនិយាយ

នៅពេលដែលព្រះយេស៊ូមានបន្ទូលថា“ យើង” ទ្រង់មិនរួមបញ្ចូលនីកូដេមទេ។

John 3:12

ឃ្លាភ្ជាប់៖

ព្រះយេស៊ូបន្តឆ្លើយតបទៅនីកូដេម។

តើអ្នកនឹងជឿពីអ្វីដែលខ្ញុំប្រាប់អ្នកពីស្ថានសួគ៌ដូចម្តេចនឹងកើត?

សំណួរនេះសង្កត់ន័យទៅលើការមិនជឿរបស់នីកូដេម។ "អ្នកប្រាកដជាមិនជឿទេ
បើខ្ញុំប្រាប់អ្នកអំពីរឿងនៅស្ថានសួគ៌!"

តើអ្នកនឹងជឿពីអ្វីដែលខ្ញុំប្រាប់អ្នក

នៅកន្លែងទាំងពីរ "អ្នក" មានលក្ខណៈឯកវចនៈ។

អ្វីពីស្ថានសួគ៌

generated on Wed Sep 10 16:16:32 2025

របស់ខាងវិញ្ញាណ
ស្ថានសួគ៌
មានន័យថា កន្លែងព្រះជាម្ចាស់គង់នៅ។
John 3:14
ដូចជាលោកម៉ូសេបានលើកសត្វពស់នៅទីរហោស្ថានយ៉ាងណា
កូនមនុស្សនឹងត្រូវលើកឡើងយ៉ាងនោះដែរ
លក្ខណៈនៃសម្តីនេះត្រូវគេហៅថា ពាក្យប្រៀបធៀប។
មនុស្សខ្លះនឹងលើកតម្កើងព្រះយេស៊ូឡើង
ដូចលោកម៉ូសេបាន«លើកពស់ឡើងលង្ហិន»នៅទីរហោស្ថាន។
ទីរហោស្ថាន
ទីរហោស្ថានជាកន្លែងវាលខ្សាច់ស្ងួត ប៉ុន្តែនៅទីនេះសំដៅទៅលើកន្លែង
ដែលលោកម៉ូសេនិងជនជាតិអ៊ីស្រាអែលដើរជុំវិញអស់រយៈពេលសែសិបឆ្នាំ។
John 3:16
ដ្បិតព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់
ពាក្យ "ពិភពលោក" នៅទីនេះជាពាក្យប្រៀបធៀប
សំដៅទៅលើមនុស្សគ្រប់គ្នានៅលើពិភពលោក។
ក្តីស្រឡាញ់
នេះជាសេចក្តីស្រឡាញ់កើតចេញពីព្រះជាម្ចាស់
ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
ទោះបីមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
ព្រះជាម្ចាស់ផ្ទាល់ជាសេចក្តីស្រឡាញ់ ហើយជាប្រភពនៃសេចក្តីស្រឡាញ់ពិត។
ដ្បិតព្រះជាម្ចាស់មិនបានចាត់ព្រះបុត្រាមកក្នុងលោកីយ៍ដើម្បីបំផ្លាញមនុស្សលោកទេ
ប៉ុន្តែដើម្បីនឹងសង្គ្រោះមនុស្សលោកតាមរយៈព្រះអង្គវិញ។
ឃ្លាទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា។ បានសង្កត់ន័យពីរដង
ទីមួយនៅក្នុងភាពអវិជ្ជមាន ហើយបន្ទាប់មកនៅក្នុងភាពវិជ្ជមាន។
នៅក្នុងភាសាខ្លះអាចបង្ហាញការសង្កត់ន័យតាមរបៀបផ្សេង។
ហេតុផលពិតប្រាកដរបស់ព្រះជាម្ចាស់
ក្នុងការបញ្ជូនព្រះបុត្រារបស់ព្រះអង្គមកក្នុងពិភពលោក គឺដើម្បីសង្គ្រោះមនុស្ស "
បំផ្លាញ
"ដាក់ទណ្ឌកម្ម"
មិនបំផ្លាញ
"ត្រូវបានវិនិច្ឆ័យដោយគ្មានកំហុស"
ព្រះបុត្រា
ជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូ។
John 3:19
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបញ្ចប់ការឆ្លើយតបនឹងនីកូដេម។
ពន្លឺបានមកនៅក្នុងលោកីយ៍ហើយ
ពាក្យ "ពន្លឺ" ជាពាក្យប្រៀបធៀបសម្រាប់សេចក្តីពិតរបស់ព្រះជាម្ចាស់
ដែលត្រូវបានបង្ហាញនៅក្នុងព្រះយេស៊ូ។ "ពិភពលោក"
ជាឈ្មោះហៅក្រៅសម្រាប់មនុស្សទាំងអស់ដែលរស់នៅក្នុង "ពិភពលោក" ។
ម្នាក់ដែលដូចជាពន្លឺបានបង្ហាញពីសេចក្តីពិតរបស់ព្រះជាម្ចាស់ ដល់ប្រជាជន "
មនុស្សស្រឡាញ់សេចក្តីងងឹត
ពាក្យ "ភាពងងឹត"នៅទីនេះជាពាក្យប្រៀបធៀបសម្រាប់កន្លែងដែលមិនបានទទួល
"ពន្លឺ" នៃការបើកសម្តែងរបស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រិស្ត។
ដើម្បីកុំឲ្យការប្រព្រឹត្តរបស់ពួកគេនោះត្រូវបានបើកចំហឡើយ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ដូច្នេះ ពន្លឺនឹងមិនបង្ហាញពីអ្វីដែលគាត់ធ្វើ" ឬ
"ដើម្បីឲ្យពន្លឺមិនបង្ហាញពីការប្រព្រឹត្តរបស់គាត់"
បានឃើញច្បាស់ថា ការប្រព្រឹត្តរបស់គាត់បានធ្វើ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។
"មនុស្សអាចនឹងឃើញការប្រព្រឹត្តរបស់គាត់យ៉ាងច្បាស់" ឬ
"អ្នករាល់គ្នាអាចមើលឃើញយ៉ាងច្បាស់នូវអ្វីដែលគាត់បានធ្វើ"
John 3:22
បន្ទាប់ពីនេះ
សំដៅទៅលើបន្ទាប់ពីព្រះយេស៊ូបាននិយាយជាមួយនីកូដេម។
មើលរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក២ ខ១២។
អេណូន
ពាក្យនេះមានន័យថា "ប្រភពទឹក" ។
ភូមិសាលីម
ភូមិឬក្រុងជាប់នឹងទន្លេយ័រដាន់
ព្រោះនៅទីនោះមានទឹកច្រើន
"ពីព្រោះមានប្រភពទឹកជាច្រើននៅក្នុងកន្លែងនោះ"
ទទួលពិធីជ្រមុជ
អ្នកអាចបកប្រែជាទម្រង់កិរិយាសកម្ម។ "យ៉ូហានកំពុងធ្វើពិធីជ្រមុជទឹកឲ្យពួកគេ"
ឬ "គាត់កំពុងធ្វើពិធីជ្រមុជទឹកឲ្យពួកគេ"
John 3:25
បន្ទាប់មកមានការប្រកែកគ្នាកើតឡើងរវាងពួកសិស្សរបស់លោកយ៉ូហាន និងសាសន៍យូដា
អាចបញ្ជាក់នៅក្នុងទម្រង់កិរិយាសកម្ម។ "ពេលនោះពួកសិស្សរបស់លោកយ៉ូហាន
និងជនជាតិយូដាម្នាក់ប្រកែកគ្នា"
ប្រកែកគ្នា
ការប្រយុទ្ធដោយប្រើពាក្យសម្តី
មើល គាត់កំពុងធ្វើពិធីជ្រមុជ
នៅក្នុងឃ្លានេះ "មើល" ជាពាក្យបញ្ជាដែលមានន័យថា "យកចិត្តទុកដាក់!" "មើល!
គាត់កំពុងធ្វើពិធីជ្រមុជទឹក" ឬ "មើលទៅ! គាត់កំពុងជ្រមុជទឹក"
John 3:27
គ្មាននរណាម្នាក់អាចធ្វើអ្វីកើតឡើយ
គ្មាននរណាម្នាក់មានអំណាចនោះទេ ដរាបណា
ព្រះជាម្ចាស់ប្រទានអោយ
នៅទីនេះ“ ឋានសួគ៌” ត្រូវបានប្រើជាពាក្យប្រៀបធៀបសំដៅទៅព្រះជាម្ចាស់។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ព្រះជាម្ចាស់បានប្រទានពរដល់គាត់"
អ្នកខ្លួនឯង
"អ្នក" ជាពហុវចនៈហើយសំដៅទៅលើមនុស្សទាំងអស់
ដែលយ៉ូហានកំពុងនិយាយជាមួយ។ "អ្នកទាំងអស់គ្នា" ឬ "អ្នកទាំងអស់គ្នា"
ខ្ញុំគ្រាន់តែត្រូវបានចាត់មកមុនព្រះអង្គ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ព្រះជាម្ចាស់បានចាត់ខ្ញុំឲ្យទៅមុនព្រះអង្គ"
John 3:29
ឃ្លាភ្ជាប់៖
យ៉ូហានបាទីស្តនិយាយបន្តទៀត។
កូនក្រមុំជាកម្មសិទ្ធិរបស់កូនកម្លោះ
នៅទីនេះ "កូនក្រមុំ" និង "កូនកំលោះ" ជាពាក្យប្រៀបធៀប។
ព្រះយេស៊ូប្រៀបដូចជា«កូនកម្លោះ»ហើយយ៉ូហានដូចជាមិត្តសំឡាញ់របស់«កូនកម្លោះ»។
ខ្ញុំពោរពេញដោយអំណរ
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "ដូច្នេះ ខ្ញុំរីករាយខ្លាំងណាស់" ឬ
"ដូច្នេះខ្ញុំរីករាយពន់ពេក"
អំណរ
ពាក្យថា "ខ្ញុំ" សំដៅទៅលើយ៉ូហានបាទីស្ត ដែលកំពុងនិយាយ។
សូមឲ្យព្រះអង្គបានចម្រើនឡើង
"គាត់" សំដៅទៅលើកូនកម្លោះ គឺព្រះយេស៊ូដែលនឹងបន្តរីកចម្រើនជាសំខាន់។
John 3:31
ព្រះអង្គដែលយាងពីស្ថានលើមានអំណាចលើទាំងអស់
"អ្នកណាដែលមកពីស្ថានបរមសុខ សំខាន់ជាងគ្រប់គ្នា"
អ្នកណាដែលមកពីផែនដីគឺមកពីផែនដី ហើយនិយាយតែពីរឿងលោកីយ៍
យ៉ូហានមានន័យថា ព្រះយេស៊ូធំជាងគាត់ទៅទៀត
ព្រោះព្រះយេស៊ូមកពីស្ថានបរមសុខ ហើយយ៉ូហានបានកើតនៅលើផែនដី។
"អ្នកដែលកើតក្នុងលោកនេះ ដូចជាមនុស្សគ្រប់គ្នាដែលរស់នៅលើពិភពលោក
ហើយគាត់និយាយអំពីអ្វីដែលកើតឡើងនៅក្នុងពិភពលោកនេះ"
អ្នកដែលមកពីស្ថានសួគ៌មានអំណាចលើទាំងអស់
មានន័យថា ដូចគ្នានឹងប្រយោគទីមួយដែរ។
យ៉ូហាននិយាយម្តងទៀតដើម្បីសង្កត់ន័យ។
ព្រះអង្គបានធ្វើបន្ទាល់អំពីអ្វីដែលព្រះអង្គបានឃើញនិងឮ
យ៉ូហានកំពុងនិយាយអំពីព្រះយេស៊ូ។ "អ្នកដែលមកពីស្ថានបរមសុខប្រាប់អំពីអ្វី
ដែលគាត់បានឃើញនិងនៅស្ថានបរមសុខ" ។
គ្មាននរណាទទួលទីបន្ទាល់របស់ព្រះអង្គសោះ
នៅទីនេះ យ៉ូហាននិយាយសង្កត់ន័យ
ដើម្បីបញ្ជាក់ថាមានតែមនុស្សពីរបីនាក់ប៉ុណ្ណោះ ដែលជឿលើព្រះយេស៊ូ។
"មានមនុស្សតិចណាស់ ដែលជឿលើព្រះអង្គ"
អស់អ្នកណាដែលបានទទួលទីបន្ទាល់
"អ្នកណាជឿអ្វី ដែលព្រះយេស៊ូមានបន្ទូល"

generated on Wed Sep 10 16:16:32 2025

បានបញ្ជាក់ថា
"បង្ហាញភស្តុតាង" ឬ "យល់ព្រម"
John 3:34
ឃ្លាភ្ជាប់៖
យ៉ូហានបាទីស្តបញ្ចប់ការនិយាយ។
ដ្បិតព្រះមួយអង្គដែលព្រះជាម្ចាស់បានចាត់មក
"ព្រះយេស៊ូជាអ្នក ដែលព្រះជាម្ចាស់បានចាត់ឲ្យមកធ្វើជាតំណាងព្រះអង្គ"
ព្រោះព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកព្រះអង្គជាបរិបូរណ៌
"ដ្បិតទ្រង់ជាអ្នក
ដែលព្រះជាម្ចាស់បានប្រគល់អំណាចទាំងអស់នៃព្រះវិញ្ញាណរបស់ព្រះអង្គ"
ព្រះបិតា....ព្រះបុត្រា
ទាំងនេះជាឋានៈសំខាន់ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់
និងព្រះយេស៊ូ។
ប្រទានអ្វី.....ក្នុងព្រះហស្តរបស់ព្រះអង្គ
មានន័យថា ត្រូវដាក់នៅក្នុងអំណាចឬការគ្រប់គ្រងរបស់ព្រះអង្គ។
អ្នកណាដែលជឿ
"មនុស្សដែលជឿ" ឬ "អ្នកណាជឿ"
សេចក្ដីក្រោធរបស់ព្រះនឹងស្ថិតនៅលើអ្នកនោះវិញ
នាមអរូបី "ក្រោធ" អាចត្រូវបានបកប្រែដោយកិរិយា "ដាក់ទណ្ឌកម្ម" ។
"ព្រះជាម្ចាស់នឹងបន្តដាក់ទណ្ឌកម្មព្រះអង្គ"

---

4 [1]នៅពេលព្រះយេស៊ូជ្រាបថា ពួកផារីស៊ីបានឮថា ព្រះអង្គបានបង្កើតសិស្ស
និងធ្វើពិធីជ្រមុជច្រើនជាងលោកយ៉ូហានទៅទៀត[2](សូម្បីតែព្រះអង្គផ្ទាល់មិនបានធ្វើពិធីជ្រមុជ ផ្ទុយទៅវិញពួកសិស្សរបស់ព្រះអង្គជាអ្នកធ្វើពិធីជ្រមុជ)។
[3]ព្រះអង្គបានចាកចេញពីស្រុកយូដា ហើយត្រឡប់ទៅកាលីឡេវិញ។
[4]គ្មានការចាំបាច់អ្វីដែលសម្រាប់ព្រះអង្គក្នុងការឆ្លងកាត់ស្រុកសាម៉ារីទេ។[5]ប៉ុន្តែ ព្រះអង្គបែរជាចូលទៅក្នុងក្រុងរបស់សាម៉ារី ដែលហៅថា ភូមិស៊ូខារ
នៅជិតដីមួយកន្លែងរបស់លោកយ៉ាកុបបានឲ្យទៅលោកយ៉ូសែបជាកូនរបស់គាត់។
[6]អណ្តូងរបស់លោកយ៉ាកុបនៅទីនោះ។ ព្រះយេស៊ូអស់កម្លាំងពីការធ្វើដំណើររបស់ព្រះអង្គ ហើយទ្រង់ក៏គង់នៅជិតអណ្តូងនោះ។ នៅពេលនោះម៉ោងប្រហែលជាប្រាំមួយ។
[7]ស្ត្រីសាសន៍សាម៉ារីម្នាក់បានមកដងទឹក ហើយព្រះយេស៊ូមានបន្ទូលទៅកាន់នាងថា៖ «ឲ្យខ្ញុំសូមទឹកផឹកបន្តិចផង»។[8]ដ្បិតពួកសិស្សរបស់ព្រះអង្គបានចូលទៅទីក្រុង
ដើម្បីទិញអាហារ។
[9]បន្ទាប់មក ស្ត្រីសាសន៍សាម៉ារីបានទូលទៅកាន់ព្រះអង្គថា៖ «លោកជាសាសន៍យូដា ម្តេចក៏លោកមកសុំទឹកពីខ្ញុំដែលជាសាសន៍សាម៉ារីដូច្នេះ?»
ដ្បិតសាសន៍យូដាមិនទាក់ទងជាមួយសាសន៍សាម៉ារីទេ។[10]ព្រះយេស៊ូបានឆ្លើយ ហើយមានបន្ទូលទៅកាន់នាងថា៖ «ប្រសិនបើ នាងបានស្គាល់អំណោយទានរបស់ព្រះ
ហើយស្គាល់ខ្ញុំជានរណាដែលនិយាយទៅកាន់នាងថា៖ “ខ្ញុំសុំទឹកទទួលទានបន្តិច”នោះនាងមុខជាសុំទឹកពីលោកវិញពុំខាន ហើយលោកនឹងអោយទឹកដល់នាង គឺជាទឹក
ដែលផ្តល់ជីវិត»។ ។
[11]ស្ត្រីនោះបានទូលទៅកាន់ព្រះអង្គថា៖ «លោកម្ចាស់អើយ លោកមិនមានធុងផង ហើយអណ្តូងក៏ជ្រៅទៀត។ តើលោកបានទឹករស់មកណា?
[12]លោកមិនធំជាងលោកយ៉ាកុប ជាឪពុករបស់យើង ដែលបានផ្តល់អណ្តូង និងទឹកពីអណ្តូងនេះ ឲ្យយើងនឹងកូនចៅ ព្រមទាំងហ្វូងសត្វរបស់គាត់ផឹកទេ។
[13]ព្រះយេស៊ូមានបន្ទូលទៅកាន់នាងថា៖
«មនុស្សគ្រប់គ្នាដែលផឹកពីទឹកនេះនឹងស្រេកម្តងទៀត[14]ប៉ុន្តែអស់អ្នកណាដែលផឹកទឹកដែលខ្ញុំនឹងផ្តល់ដល់អ្នកនោះនឹងមិនស្រេកទៀតទេ។ ផ្ទុយទៅវិញ
ទឹកដែលខ្ញុំឲ្យនោះនឹងផ្តល់ឲ្យអ្នកនោះក្លាយជាប្រភពទឹកនៅក្នុងអ្នកនោះ ផុសឡើង ដើម្បីឲ្យមានជីវិតអស់កល្បជានិច្ច»។
[15]ស្ត្រីនោះបានទូលទៅកាន់ព្រះអង្គថា៖ «លោកម្ចាស់ សូមឲ្យទឹកនេះខ្ញុំផង ដើម្បីឲ្យខ្ញុំលែងស្រេកទៀត ហើយខ្ញុំមិនបាច់មកដងទឹកនៅទីនេះទេ»។
[16]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «ចូរទៅ ហៅស្វាមីរបស់នាង ហើយត្រឡប់មកទីនេះវិញ»។
[17]ស្ត្រីនោះឆ្លើយ ហើយទូលទៅកាន់ព្រះអង្គថា៖ «ខ្ញុំគ្មានប្តីទេ»។ ព្រះយេស៊ូឆ្លើយថា៖ «នាងនិយាយថា៖ «ខ្ញុំគ្មានប្តីត្រូវហើយ»។[18]ដ្បិត នាងមានប្តីចំនួនប្រាំហើយ
ហើយម្នាក់ដែលនៅជាមួយនាងសព្វថ្ងៃ ក៏មិនមែនជាប្តីរបស់នាងដែរ។ អ្វីដែលនាងនិយាយគឺជាការពិត»។
[19]ស្ត្រីនោះទូលទៅកាន់ព្រះអង្គថា៖ «លោកម្ចាស់ ខ្ញុំឃើញថា លោកគឺជាព្យាការី។[20]ឪពុករបស់យើងថ្វាយបង្គំនៅលើភ្នំនេះ ប៉ុន្តែ តើលោកមានប្រសាសន៍ថា
ក្រុងយេរ៉ូសាឡិមគឺជាកន្លែងដែលមនុស្សត្រូវថ្វាយបង្គំ»។
[21]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «ស្ត្រីអើយ! ចូរជឿដល់ខ្ញុំចុះ ពេលនោះនឹងមកដល់នៅពេលអ្នកថ្វាយបង្គំព្រះបិតានៅលើភ្នំនេះ ឬនៅក្រុងយេរ៉ូសាឡិម។
[22]អ្នកថ្វាយបង្គំអ្វីដែលអ្នកមិនដឹង។ យើងថ្វាយបង្គំអ្វីដែលយើងដឹង ដើម្បីសេចក្តីសង្គ្រោះចេញពីសាសន៍យូដាមក។
[23]ប៉ុន្តែ ពេលវេលានឹងមកដល់ ឥឡូវនេះដល់ពេលហើយ នៅពេលអ្នកថ្វាយបង្គំពិត នឹងថ្វាយបង្គំព្រះបិតាដោយវិញ្ញាណ និងសេចក្តីពិត ដ្បិត
ព្រះបិតាស្វែងរកមនុស្សបែបនេះ ដើម្បីធ្វើជាអ្នកថ្វាយបង្គំព្រះអង្គ។[24]ព្រះជាម្ចាស់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំព្រះអង្គ ត្រូវតែថ្វាយបង្គំដោយវិញ្ញាណ
និងសេចក្តីពិត»។
[25]ស្ត្រីនោះទូលទៅកាន់ព្រះអង្គថា៖ «ខ្ញុំដឹងថាព្រះមេស្ស៊ីនឹងយាងមក (ជាព្រះដែលហៅថា ព្រះគ្រិស្ត)។ នៅពេលព្រះអង្គយាងមក
ព្រះអង្គនឹងពន្យល់គ្រប់យ៉ាងដល់យើង»។[26]ព្រះយេស៊ូឆ្លើយទៅនាងថា «ខ្ញុំគឺជាព្រះអង្គហើយ ជាព្រះដែលអ្នកកំពុងមានបន្ទូលទៅកាន់នាង»។
[27]នៅពេលនោះពួកសិស្សរបស់ព្រះអង្គក៏ត្រឡប់មកវិញ។ ពួកគេងឿងឆ្ងល់ថា ហេតុអ្វីបានជាព្រះអង្គមានបន្ទូលជាមួយស្ត្រីនោះ ប៉ុន្តែ គ្មាននរណាហ៊ាននិយាយថា៖
«តើព្រះអង្គចង់បានអ្វី?» ឬ «ហេតុអ្វីបានជាព្រះអង្គមានបន្ទូលជាមួយនាង?»
[28]ដូច្នេះ ស្ត្រីបានទុកក្អមទឹករបស់នាងចោល ត្រឡប់ទៅក្រុងវិញ ហើយនិយាយប្រាប់មនុស្ស[29]«មក ខ្ញុំឃើញបុរសម្នាក់ដែលបានប្រាប់អ្វីៗដែលខ្ញុំបានធ្វើគ្រប់យ៉ាង។
តើនេះមិនមែនជាព្រះគ្រិស្ត ទេឬអី?[30]ពួកគេបានចេញពីក្រុងទៅរកព្រះអង្គវិញ។
[31]នៅពេលជាមួយគ្នានោះ ពួកសិស្សបានអង្វរព្រះអង្គ ដោយនិយាយថា៖ «រ៉ាប៊ី សូមអញ្ជើញបរិភោគ!»។[32]ប៉ុន្តែ ព្រះអង្គមានបន្ទូលទៅពួកគេថា៖
«ខ្ញុំមានអាហារបរិភោគដែលអ្នកមិនស្គាល់ទេ»។[33]ដូច្នេះហើយ បានជាពួកសិស្សនិយាយទៅគ្នាទៅវិញទៅមកថា៖ «គ្មាននរណាយកអាហារឲ្យព្រះអង្គសោយទេ មែនទេ?»
[34]ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «អាហាររបស់ខ្ញុំគឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែលចាត់ខ្ញុំឲ្យមក ហើយធ្វើឲ្យកិច្ចការរបស់ព្រះអង្គបានសម្រេច។
[35]កុំនិយាយថា៖ «នៅសល់ពេលបួនខែទៀត ទើបរដូវចម្រូតមកដល់?» ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា សូមងើយឡើងមើលទៅវាល ដ្បិត ស្រូវទុំរួចរាល់ដើម្បីច្រូតហើយ!
[36]អស់អ្នកណាដែលច្រូតនឹងទទួលឈ្នួល ហើយប្រមូលផលនៃជីវិតអស់កល្បជានិច្ច ដូច្នេះហើយ អស់អ្នកណាដែលព្រោះ
ហើយអស់អ្នកដែលច្រូតអាចមានអំណរជាមួយគ្នា។
[37]ស្របតាមពាក្យចាស់លោកថា:“ម្នាក់ព្រោះ ម្នាក់ទៀតច្រូត”។[38]ខ្ញុំបានចាត់អ្នករាល់គ្នាអោយទៅច្រូត នៅក្នុងស្រែដែលអ្នករាល់គ្នាពុំបានធ្វើការនឿយហត់ គឺអ្នកផ្សេងទៀត
បានធ្វើការនឿយហត់ ហើយអ្នករាល់គ្នាទទួលផលពីការនឿយហត់របស់អ្នកទាំងនោះ»។
[39]មានសាសន៍សាម៉ារីជាច្រើននៅក្នុងក្រុងនោះបានជឿលើព្រះអង្គ ដោយសារការប្រាប់របស់ស្ត្រីដែលបានធ្វើបន្ទាល់ថា៖ «ព្រះអង្គបានប្រាប់អ្វីៗដែលខ្ញុំបានធ្វើគ្រប់យ៉ាង»។
[40]ដូច្នេះ នៅពេលសាសន៍សាម៉ារីមករកព្រះអង្គ ពួកគេសូមឲ្យព្រះអង្គគង់នៅជាមួយពួកគេ ហើយព្រះអង្គក៏គង់នៅទីនោះពីរថ្ងៃ។
[41]មានមនុស្សជាច្រើនថែមទៀតបានជឿដោយព្រោះព្រះបន្ទូលរបស់ព្រះអង្គ។[42]ពួកគេនិយាយទៅកាន់ស្ត្រីនោះថា៖
«យើងមិនបានជឿដោយសារអ្វីដែលនាងបាននិយាយទៀតទេ ដ្បិត យើងខ្លួនឯងផ្ទាល់បានឮពីព្រះអង្គ ហើយយើងបានដឹងថា
ព្រះអង្គគឺជាព្រះសង្គ្រោះពិភពលោកពិតប្រាកដមែន»។

generated on Wed Sep 10 16:16:32 2025

[43]បន្ទាប់ពីថ្ងៃនោះពីរថ្ងៃមក ព្រះអង្គបានចេញពីទីនោះទៅកាលីឡេវិញ។[44]ដ្បិត ព្រះយេស៊ូផ្ទាល់បានមានបន្ទូលថា គ្មានព្យាការីណាម្នាក់ត្រូវគេគោរពក្នុងស្រុកកំណើតរបស់ខ្លួនផ្ទាល់ឡើយ។[45]នៅពេលព្រះអង្គយាងទៅស្រុកកាលីឡេ អ្នកស្រុកកាលីឡេមិនស្វាគមន៍ព្រះអង្គទេ។
ពួកគេបានឃើញអ្វីៗទាំងអស់ដែលព្រះអង្គបានធ្វើនៅក្នុងក្រុងយេរូសាឡិមនៅថ្ងៃបុណ្យ ព្រោះពួកគេបានទៅចូលរួមបុណ្យនោះដែរ។
[46]ឥឡូវនេះ ព្រះអង្គបានយាងទៅកាណាក្នុងស្រុកកាលីឡេម្តងទៀត ជាកន្លែងដែលព្រះបានធ្វើទឹកឲ្យក្លាយជាស្រា។ នៅទីនោះមានមន្ត្រីម្នាក់
ដែលកូនរបស់គាត់ឈឺនៅកាពើណិម។[47]នៅពេលគាត់បានឮថាព្រះយេស៊ូមកពីស្រុកយូដាទៅកាលីឡេ គាត់បានទៅរកព្រះយេស៊ូ ហើយអង្វរព្រះអង្គឲ្យចុះទៅកាពើណិម
ហើយប្រោសកូនប្រុសគាត់ដែលជិតស្លាប់ហើយឲ្យជា។
[48]បន្ទាប់មក ព្រះយេស៊ូមានបន្ទូលទៅកាន់គាត់ថា៖ «បើអ្នកមិនឃើញទីសម្គាល់ និងការអស្ចារ្យ នោះអ្នកមិនជឿទេ»។[49]មន្ត្រីនោះមានប្រសាសន៍ទៅកាន់ព្រះអង្គថា៖
«លោកម្ចាស់អើយ សូមចុះទៅ មុនពេលកូនប្រុសខ្ញុំស្លាប់»។[50]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ទៅចុះ! កូនលោកនៅរស់ទេ»។
បុរសនោះជឿលើព្រះបន្ទូលដែលព្រះអង្គមានបន្ទូលទៅគាត់ ហើយគាត់ក៏ចេញទៅ។
[51]ក្នុងការដែលគាត់កំពុងចុះទៅ អ្នកបម្រើរបស់គាត់បានមកជួបគាត់ និយាយថា កូនរបស់គាត់នៅរស់ទេ។[52]ដូច្នេះ គាត់ក៏សួរទៅពួកគេ ពីពេលវេលា
ថាកូនគាត់ជាពេលណា។ ពួកគេប្រាប់គាត់ថា៖ «កាលពីម្សិលមិញម៉ោងប្រាំពីរ ជំងឺគ្រុនបានចេញពីគាត់»។
[53]នោះឪពុកបានដឹងថា គឺជាពេលដែលព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «កូនរបស់លោកនៅរស់ទេ»។ ដូច្នេះ គាត់ខ្លួនឯង
និងគ្រួសាររបស់គាត់ទាំងមូលបានជឿលើព្រះអង្គ។[54]នេះគឺជាទីសម្គាល់ទីពីរ ដែលព្រះយេស៊ូបានធ្វើ នៅពេលព្រះអង្គចេញពីស្រុកយូដាទៅកាលីឡេ។

John 4:1
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃរឿង ដែលនិយាយអំពីព្រះយេស៊ូនិងស្ត្រីសាសន៍សាម៉ារីម្នាក់។
ខគម្ពីរទាំងនេះផ្តល់នូវព័ត៌សំខាន់សម្រាប់ផ្នែកនៃរឿងនេះ។
នៅពេលព្រះយេស៊ូជ្រាបថា ពួកផារីស៊ីបានឮថា ព្រះអង្គបានបង្កើត....យ៉ូហាន
(ព្រះអង្គបានចាកចេញ...កាលីឡេ)
«ឥឡូវព្រះយេស៊ូកំពុងតែបង្កើត ... យ៉ូហាន (ទោះបីជា ...)
ហើយពួកផារីស៊ីបានឮអំពីជោគជ័យ ដែលព្រះអង្គកំពុងទទួលបាន។
ទ្រង់បានជ្រាបថា ពួកផារីស៊ីបានឮដូច្នេះទ្រង់ក៏ចាកចេញពី ... កាលីឡេ»
នៅពេលព្រះយេស៊ូជ្រាបថា
ពាក្យ "ឥឡូវនេះ" ត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការសម្រាកនៅក្នុងព្រឹត្តិការណ៍សំខាន់។ នៅទីនេះ
យ៉ូហានចាប់ផ្តើមប្រាប់ផ្នែកថ្មីនៃនិទានកថា។
ព្រះអង្គផ្ទាល់មិនបានធ្វើពិធីជ្រមុជ
សព្វនាមឆ្លុះបញ្ចាំងខ្លួនព្រះអង្គផ្ទាល់ និងបន្ថែមការសង្កត់ន័យថា
វាមិនមែនជាព្រះយេស៊ូដែលបានធ្វើពិធីជ្រមុជទឹកទេ តែជាសិស្សរបស់ព្រះអង្គវិញ។
John 4:4
ស្រុកសាម៉ារី សាសន៍សាម៉ារី
សាម៉ារីជាឈ្មោះទីក្រុងមួយ ស្ថិតនៅភាគខាងជើងប្រទេសអ៊ីស្រាអែល។
វាស្ថិតនៅចន្លោះតំបន់ទំនាបសារ៉ុនភាគខាងលិច និងទន្លេយ័រដាន់ភាគខាងកើត។
នៅក្នុងគ្រាសម័ន្ធមេត្រីចាស់
សាម៉ារីជារាជធានីរបស់រាជាណាចក្រអ៊ីស្រាអែលខាងជើង។ ក្រោយមក
តំបន់នៅជុំវិញនោះ ក៏ត្រូវគេហៅថាសាម៉ារីដែរ។
ពេលពួកអាស៊ីរីឈ្លានពានរាជាណាចក្រអ៊ីស្រាអែលខាងជើងរួចមក
ពួកគេចាប់យកទីក្រុងសាម៉ារី ហើយបង្ខំឲ្យពួកអ៊ីស្រាអែលភាគខាងជើង
ចាកចេញពីតំបន់នោះ ផ្លាស់ទីពួកគេឲ្យឆ្ងាយ ទៅនៅទីក្រុងផ្សេងៗនៅក្នុងអាស៊ីរី។
ពួកអាស៊ីរីក៏បាននាំជនបរទេសជាច្រើនមករស់នៅតំបន់សាម៉ារី
ជំនួសពួកអ៊ីស្រាអែលត្រូវបានរើចេញ។ មានពួកអ៊ីស្រាអែលខ្លះ
ដែលស្ថិតនៅក្នុងតំបន់នោះបានរៀបការជាមួយជនបរទេស ដែលផ្លាស់ទីលំនៅថ្មី
ហើយគេហៅកូនចៅរបស់ពួកគេថា សាសន៍សាម៉ារីដែរ។ -
ពួកយូដាមិនរាប់ពួកសាម៉ារីជាពូជសុទ្ធទេ
ព្រោះបុព្វបុរសរបស់ពួកគេថ្វាយបង្គំព្រះដទៃ។ នៅគ្រាសម័ន្ធមេត្រីថ្មី
តំបន់សាម៉ារីខណ្ឌគ្នាដោយតំបន់កាលីឡេនៅភាគខាងជើង
និងយូដាភាគខាងត្បូង។
យ៉ាកុប អ៊ីស្រាអែល
យ៉ាកុបជាកូនភ្លោះប្អូនរបស់លោកអ៊ីសាក និងនាងរ៉េបេកា។
ឈ្មោះយ៉ាកុបមានន័យថា «ចាប់កែងជើង» តាមន័យធៀបមានន័យថា
«អ្នកបោកបញ្ឆោត»។ កាលយ៉ាកុបកំពុងកើត
គាត់កាន់តកែងជើងបងប្រុសរបស់គាត់ឈ្មោះអេសាវជាប់។ ច្រើនឆ្នាំក្រោយមក
ព្រះជាម្ចាស់បានប្តូរឈ្មោះយ៉ាកុបទៅ«អ៊ីស្រាអែល»វិញ ដែលមានន័យថា
«បោកចំបាប់ជាមួយព្រះជាម្ចាស់»។ យ៉ាកុបជាមនុស្សឈ្លាសវៃ
និងពូកែបោកបញ្ឆោត។ គាត់រកមធ្យោបាយដើម្បីទទួលបានព្រះពរ
និងមរតក៌កូនច្បងពីបងរបស់គាត់ឈ្មោះអេសាវ។ អេសាវខឹងខ្លាំងណាស់
ហើយរៀបផែនការសម្លាប់គាត់ ដូច្នេះយ៉ាកុបរត់ភៀសខ្លួនពីស្រុកកំណើត។
ប៉ុន្មានឆ្នាំក្រោយមក យ៉ាកុបក៏ត្រឡប់មកស្រុកកាណានជាមួយប្រពន្ធ និងកូន
ជាកន្លែងអេសាវរស់នៅ
ហើយក្រុមគ្រួសារទាំងពីរក៏រស់នៅជាមួយគ្នាដោយសុខសាន្ត។
យ៉ាកុបមានកូនប្រុស១២នាក់
ហើយកូនចៅរបស់ពួកគេក្លាយជាកុលសម្ព័ន្ធទាំង១២របស់អ៊ីស្រាអែល។
មានឈ្មោះយ៉ាកុបផ្សេង ដែលជាឪពុករបស់លោកយ៉ូសែប
មាននៅក្នុងបញ្ជីរាយនាមក្នុងកណ្ឌគម្ពីរម៉ាថាយ។
យ៉ូសែប (សម័ន្ធមេត្រីចាស់)
យ៉ូសែបជាកូនប្រុសទី១១របស់លោកយ៉ាកុប
និងកូនប្រុសច្បងកើតចេញពីនាងរ៉ាជែល។
យ៉ូសែបជាកូនសំណព្វរបស់ឪពុក។ បងៗរបស់គាត់ច្រណែននឹងគាត់
រួចក៏លក់គាត់ឲ្យធ្វើជាទាសករ។ កាលនៅប្រទេសអេស៊ីប គេចោទប្រកាន់គាត់ខុស
និងដាក់គាត់ក្នុងមន្ទីរឃុំឃាំង។ ថ្វីដ្បិតតែជួបការលំបាក
តែយ៉ូសែបនៅតែស្មោះត្រង់ចំពោះព្រះជាម្ចាស់។
ព្រះជាម្ចាស់បានប្រទានឋានៈខ្ពង់ខ្ពស់លំដាប់ទី២ នៅក្នុងប្រទេសអេស៊ីប
និងប្រើប្រាស់គាត់សង្គ្រោះមនុស្សក្នុងគ្រាទុរ្ភិក្ស។ ប្រជាជនអេស៊ីប
ក៏ដូចជាក្រុមគ្រួសាររបស់គាត់ផ្ទាល់ មិនបានខ្វះខាតស្បៀងឡើយ។
John 4:6
សូមទឹកផឹកបន្តិចផង
នេះជាសំណើរគួរសមមិនមែនពាក្យបញ្ជាទេ។
រីឯពួកសិស្សរបស់ព្រះអង្គបានចូល
ព្រះអង្គមិនបានសុំឲ្យសិស្សរបស់ព្រះអង្គ ដងទឹកសម្រាប់ព្រះអង្គទេ
ព្រោះពួកគេបានចេញទៅក្រៅហើយ។
John 4:9
បន្ទាប់មក ស្ត្រីសាសន៍សាម៉ារីបានទូលទៅកាន់ព្រះអង្គថា
ពាក្យ "គាត់" សំដៅទៅលើព្រះយេស៊ូ។
លោកជាសាសន៍យូដា ម្តេចក៏លោកមកសុំទឹកពីខ្ញុំ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបង្ហាញពីការភ្ញាក់ផ្អើលរបស់ស្ត្រីសាសន៍សាម៉ារី
ដែលព្រះយេស៊ូបានសុំទឹកពីនាង។ "ខ្ញុំមិនជឿថា
អ្នកជាជនជាតិយូដាសុំទឹករបស់ជនជាតិសាម៉ារីនោះទេ!"
មិនទាក់ទងជាមួយ
"កុំសេពគប់ជាមួយ"
ទឹកដែលផ្តល់ជីវិត
ព្រះយេស៊ូប្រើពាក្យប្រៀបធៀបអំពី "ទឹករស់"
ដើម្បីសំដៅទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលធ្វើការនៅក្នុងមនុស្សម្នាក់ដើម្បីផ្លាស់ប្តូរជីវិត និងនាំមកជីវិតថ្មី។
John 4:11
លោកមិនធំជាងលោកយ៉ាកុប ជាឪពុករបស់យើង ...ហ្វូងសត្វ
ការកត់សម្គាល់នេះកើតឡើងក្នុងទម្រង់ជាសំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"អ្នកមិនធំជាងយ៉ាកុបឪពុករបស់យើងទេ ... ហ្វូងសត្វ!"
លោកយ៉ាកុប ជាឪពុករបស់យើង
"បុព្វបុរសរបស់យើង លោកយ៉ាកុប"
ផឹកពីអណ្តូង

generated on Wed Sep 10 16:16:32 2025

"ធីកទឹកដែលបានមកពីអណ្តូង"
John 4:13
នឹងស្រេកម្តងទៀត
"នឹងត្រូវការធីកទឹកម្តងទៀត"
ទឹកដែលខ្ញុំឲ្យនោះនឹងផ្តល់ឲ្យអ្នកនោះក្លាយជាប្រភពទឹកនៅក្នុងអ្នកនោះ
ពាក្យថា "ប្រភពទឹក" នៅទីនេះជាពាក្យប្រៀបធៀបសម្រាប់ទឹកផ្តល់ជីវិត។
"ទឹកដែលខ្ញុំនឹងផ្តល់ឲ្យគេនឹងក្លាយទៅជាប្រភពទឹករស់នៅក្នុងគាត់"
ជីវិតអស់កល្បជានិច្ច
ត្រង់នេះ" ជីវិត" សំដៅទៅលើ" ជីវិតខាងវិញ្ញាណ" ដែលមានតែព្រះជាម្ចាស់ទេ
ដែលអាចផ្តល់បាន។
John 4:15
លោកម្ចាស់
នៅក្នុងបរិបទនេះ ស្ត្រីជនជាតិសាម៉ារីកំពុងនិយាយទៅកាន់ព្រះយេស៊ូថា
"លោកម្ចាស់" ដែលជាពាក្យនៃការគោរព ឬភាពគួរសម។
ដងទឹក
"ដងទឹក" ឬ "ទាញទឹកឡើងពីអណ្តូង" ដោយប្រើធុងនិងខ្សែពួរ
John 4:17
ខ្ញុំគ្មានប្តីត្រូវហើយ....អ្វីដែលនាងនិយាយគឺជាការពិត
ព្រះយេស៊ូវរំលឹកសេចក្តីថ្លែងនេះឡើងវិញ ដើម្បីបញ្ជាក់ថា
ទ្រង់ជ្រាបពីអ្វីដែលស្ត្រីកំពុងតែនិយាយ។
John 4:19
លោកម្ចាស់
នៅក្នុងបរិបទនេះស្ត្រីជនជាតិសាម៉ារីកំពុងនិយាយទៅកាន់ព្រះយេស៊ូថា
"លោកម្ចាស់" ដែលជាពាក្យនៃការគោរព ឬភាពគួរសម។
ខ្ញុំឃើញថា លោកគឺជាព្យាការី
"ខ្ញុំអាចយល់ថា អ្នកគឺជាព្យាការី"
ឪពុក
"បុព្វបុរស"
John 4:21
ចូរជឿដល់ខ្ញុំចុះ
ការជឿនរណាម្នាក់ ត្រូវទទួលស្គាល់នូវអ្វីដែលម្នាក់នោះបាននិយាយថា ជាការពិត។
អ្នកថ្វាយបង្គំអ្វីដែលអ្នកមិនដឹង។ យើងថ្វាយបង្គំអ្វីដែលយើងដឹង
ព្រះយេស៊ូមានន័យថា ព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់និងបទបញ្ជារបស់ព្រះអង្គ
ដល់ប្រជាជនយូដាមិនមែនចំពោះជនជាតិសាម៉ារីទេ។
តាមរយៈបទគម្ពីរប្រជាជនយូដាដឹងថា ព្រះជាម្ចាស់ប្រសើរជាងជនជាតិសាម៉ារី។
អ្នកថ្វាយបង្គំព្រះបិតា.....សេចក្តីសង្គ្រោះចេញពីសាសន៍យូដាមក
ការសង្គ្រោះអស់កល្បជានិច្ចពីអំពើបាប បានមកពីព្រះបិតា ដែលជាព្រះយេហូវ៉ា
និងជាព្រះជាម្ចាស់របស់ជនជាតិយូដា។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
សេចក្តីសង្គ្រោះចេញពីសាសន៍យូដាមក
ពុំមានន័យថា
ប្រជាជនយូដានឹងជួយសង្គ្រោះអ្នកដទៃពីអំពើបាបរបស់ពួកគេឡើយ។
តែមានន័យថា ព្រះជាម្ចាស់បានជ្រើសរើសជនជាតិយូដា
ជាមនុស្សពិសេសរបស់ព្រះអង្គ
ដែលនឹងប្រាប់ប្រជាជនដទៃទៀតអំពីការសង្គ្រោះរបស់ព្រះអង្គ។
"សម្រាប់មនុស្សទាំងអស់នឹងដឹងអំពីការសង្គ្រោះរបស់ព្រះជាម្ចាស់
តាមរយៈជនជាតិយូដា" ។
John 4:23
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តនិយាយទៅកាន់ស្ត្រីសាសន៍សាម៉ារី។
ឥឡូវនេះដល់ពេលហើយ នៅពេលអ្នកថ្វាយបង្គំពិត នឹងថ្វាយបង្គំ
"ទោះយ៉ាងណា ឥឡូវនេះដល់ពេលហើយ សម្រាប់អ្នកថ្វាយបង្គំដ៏ពិត"
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិត
«ថ្វាយបង្គំព្រះអង្គតាមរបៀបត្រឹមត្រូវ»
John 4:25
ខ្ញុំដឹងថាព្រះមេស៊ី....ព្រះគ្រិស្ត
ពាក្យទាំងពីរនេះមានន័យថា“ ស្តេចដែលព្រះជាម្ចាស់បានសន្យា” ។
ព្រះអង្គនឹងពន្យល់គ្រប់យ៉ាងដល់យើង
ពាក្យ "ពន្យល់អ្វីៗគ្រប់យ៉ាង" មានន័យថា ការទាំងអស់ដែលប្រជាជនត្រូវដឹង។
"ទ្រង់នឹងប្រាប់យើងនូវអ្វីគ្រប់យ៉ាងដែលយើងត្រូវដឹង"
John 4:27
នៅពេលនោះពួកសិស្សរបស់ព្រះអង្គក៏ត្រឡប់មកវិញ
គ្រាន់តែព្រះយេស៊ូមានព្រះបន្ទូលដូច្នោះ
ហើយពួកសិស្សនាំគ្នាត្រឡប់មកពីក្រុងវិញ។
ពួកគេងឿងឆ្ងល់ថា ហេតុអ្វីបានជាព្រះអង្គមានបន្ទូលជាមួយស្ត្រីនោះ
វាជារឿងចម្លែក
ដែលជនជាតិយូដានិយាយជាមួយស្ត្រីដែលគាត់មិនស្គាល់ជាពិសេស
បើស្ត្រីនោះជាសាសន៍សាម៉ារី។
គ្មាននរណាហ៊ានិយាយថា...អ្វី?» ឬ «ហេតុអ្វី....នាង?»
អាចមានន័យពីរយ៉ាង ១) ពួកសិស្សសួរសំណួរទាំងពីរទៅព្រះយេស៊ូឬ ២)
"គ្មានអ្នកណាសួរស្ត្រីថា តើចង់បានអ្វីទេ? ' ឬសួរព្រះយេស៊ូថា "ហេតុអ្វីបានជា ...
នាង?"
John 4:28
មក ខ្ញុំឃើញបុរសម្នាក់ដែលបានប្រាប់អ្វីៗដែលខ្ញុំបានធ្វើគ្រប់យ៉ាង
នេះជាការបំផ្លើសមួយ។ ស្ត្រីសាសន៍សាម៉ារីមានការចាប់អារម្មណ៍យ៉ាងខ្លាំង
ចំពោះព្រះយេស៊ូដែលនាងជឿថាទ្រង់បានជ្រាបអ្វីៗទាំងអស់អំពីនាង។
"មកមើលបុរសម្នាក់ ដែលស្គាល់យ៉ាងច្បាស់
ទោះបីជាខ្ញុំមិនដែលជួបគាត់ពីមុនក៏ដោយ!"
តើនេះមិនមែនជាព្រះគ្រិស្ត ទេឬអី?
ស្ត្រីមិនប្រាកដថា ព្រះយេស៊ូជាព្រះគ្រិស្តនោះទេ
ដូច្នេះនាងសួរសំណួរដែលរំពឹងឆ្លើយថា "ទេ"
ប៉ុន្តែនាងក៏សួរសំណួរជំនួសដោយការបង្កើតជាឃ្លាមួយ
ព្រោះនាងចង់ឲ្យមនុស្សសម្រេចចិត្តដោយខ្លួនឯង។
John 4:31
នៅពេលជាមួយគ្នានោះ
"ខណៈពេលដែលស្ត្រីនេះចូលទៅក្នុងក្រុង"
ពួកសិស្សបានអង្វរព្រះអង្គ
“ ពួកសិស្សកំពុងប្រាប់ព្រះយេស៊ូ ” ឬ“ ពួកសិស្សកំពុងតែលើកទឹកចិត្តព្រះយេស៊ូ”
ខ្ញុំមានអាហារបរិភោគដែលអ្នកមិនស្គាល់ទេ
នៅទីនេះ ព្រះយេស៊ូពុំមានបន្ទូលអំពី“ អាហារ” ដែលយើងតែងតែញុំាទេ
ប៉ុន្តែទ្រង់កំពុងបង្រៀនសិស្សរបស់ព្រះអង្គអំពីមេរៀនខាងវិញ្ញាណ នៅក្នុងជំពូក៤
ខ៣៤។
គ្មាននរណាយកអាហារឲ្យព្រះអង្គសោយទេ មែនទេ?
ពួកសិស្សគិតថា ព្រះយេស៊ូកំពុងតែមានបន្ទូលអំពី“ អាហារ” ដែលគេតែងតែញុំា។
ពួកគេចាប់ផ្តើមសួរសំណួរនេះទៅវិញទៅមកដោយរំពឹងថា នឹងមានការឆ្លើយតប
"ទេ" ។ "ប្រាកដណាស់គ្មាននរណាម្នាក់នាំយកអាហារមកថ្វាយព្រះអង្គ
ពេលយើងនៅក្នុងក្រុងទេ!"
John 4:34
អាហាររបស់ខ្ញុំគឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដែលចាត់ខ្ញុំឲ្យមក
ហើយធ្វើឲ្យកិច្ចការរបស់ព្រះអង្គបានសម្រេច
ពាក្យ "អាហារ"នៅទីនេះ ជាពាក្យប្រៀបធៀប ដែលតំណាងឲ្យ
"ការស្តាប់បង្គាប់ព្រះជាម្ចាស់" ។ "ដូចជាអាហារចម្អែតមនុស្សឃ្លាន
ការធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺជាអ្វីដែលព្រះអង្គគាប់ព្រះទ័យ"
កុំនិយាយថា
"នេះមិនមែនជាសម្តីដ៏ពេញនិយមរបស់អ្នកទេ"
សូមងើយឡើងមើលទៅវាល ដ្បិត ស្រូវទុំរួចរាល់ដើម្បីច្រូតហើយ!
ពាក្យ "វាល" និង "ទុំសម្រាប់ការប្រមូលផល" គឺជាពាក្យប្រៀបធៀប។ "វាល"
តំណាងឲ្យប្រជាជន ដែលមិនមែនជាសាសន៍យូដាឬជាសាសន៍ដទៃ។ ពាក្យថា“
ទុំសម្រាប់ច្រូត” មានន័យថា
ពួកសាសន៍ដទៃបានត្រៀមខ្លួនទទួលព្រះបន្ទូលរបស់ព្រះយេស៊ូ
ដូចជាវាលត្រៀមបម្រុងនឹងច្រូតកាត់ដែរ។
"ក្រឡេកមើលហើយឃើញប្រជាជនមិនមែនជាជនជាតិយូដាទាំងនេះ
ពួកគេបានត្រៀមខ្លួនទទួលយកព្រះបន្ទូលរបស់ខ្ញុំ
ដូចជាដំណាំនៅតាមចម្ការបានត្រៀមសម្រាប់ប្រជាជនប្រមូលផល"
អស់អ្នកណាដែលច្រូតនឹងទទួលឈ្នួល ហើយប្រមូលផលនៃជីវិតអស់កល្បជានិច្ច

generated on Wed Sep 10 16:16:32 2025

ព្រះយេស៊ូបញ្ជាក់ថាអ្នកដែល«ធ្វើការក្នុងស្រែ
ហើយផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះ»នឹងទទួលរង្វាន់។
អ្នកដែលទទួលព្រះបន្ទូលរបស់ព្រះអង្គក៏នឹងទទួលបានជីវិតអស់កល្បជានិច្ច
ដែលព្រះអង្គបានប្រទាន។
John 4:37
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់សិស្សរបស់ព្រះអង្គ។
ម្នាក់ព្រោះ ម្នាក់ទៀតច្រូត”
ពាក្យ "ព្រោះ" និង "ច្រូត" គឺជាពាក្យប្រៀបធៀប។
អ្នកដែល«សាបព្រោះ»ចែកចាយព្រះបន្ទូលរបស់ព្រះយេស៊ូ។
អ្នកដែល«ច្រូតកាត់»ជួយប្រជាជនឲ្យទទួលព្រះបន្ទូលរបស់ព្រះយេស៊ូ។
"មនុស្សម្នាក់ដាំគ្រាប់ពូជហើយមនុស្សម្នាក់ទៀតច្រូតយកផល" ។
អ្នករាល់គ្នាទទួលផលពីការនឿយហត់របស់អ្នកទាំងនោះ
"ឥឡូវអ្នកកំពុងចូលរួមក្នុងការងាររបស់ពួកគេ"
John 4:39
ជឿលើព្រះអង្គ
ដើម្បី "ជឿលើ" នរណាម្នាក់មានន័យថា "ទុកចិត្តលើ" មនុស្សនោះ។
មានន័យថាពួកគេជឿថា ទ្រង់ជាព្រះបុត្រារបស់ព្រះជាម្ចាស់។
ព្រះអង្គបានប្រាប់អ្វីៗដែលខ្ញុំបានធ្វើគ្រប់យ៉ាង
នេះជាការបំផ្លើសមួយ។ ស្ត្រីនោះកោតស្ញប់ស្ញែងនឹងព្រះយេស៊ូណាស់
ហើយមានអារម្មណ៍ថា ព្រះអង្គច្បាស់ជាដឹងអ្វីៗទាំងអស់អំពីនាង។
"ទ្រង់បានប្រាប់ខ្ញុំរឿងជាច្រើនអំពីជីវិតរបស់ខ្ញុំ"
John 4:41
ព្រះបន្ទូលរបស់ព្រះអង្គ
នៅទីនេះ "ពាក្យ" ជាឈ្មោះប្រៀបធៀប
ដែលតំណាងឲ្យព្រះបន្ទូលដែលព្រះយេស៊ូបានប្រកាស។ "សាររបស់ព្រះអង្គ"
ពិភពលោក
"ពិភពលោក" ជាពាក្យពិពណ៌នា ដែលសំដៅទៅលើមនុស្សទាំងអស់
ដែលរស់នៅលើពិភពលោក។ "ប្រជាជនទាំងអស់នៃពិភពលោក"
John 4:43
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃសាច់រឿង ដែលព្រះយេស៊ូចុះទៅស្រុកកាលីឡេ
ហើយប្រោសក្មេងប្រុសម្នាក់។ ខ៤៤ ផ្តល់ឲ្យយើងនូវសាវតាប្រវត្តិអំពីហេតុការណ៍
ដែលព្រះយេស៊ូបានមានបន្ទូលពីមុន។
ពីទីនោះទៅ
ពីយូដា
ដ្បិត ព្រះយេស៊ូផ្ទាល់បានមានបន្ទូលថា
សព្វនាមឆ្លុះបញ្ចាំងខ្លួនឯង "ត្រូវបានបន្ថែមដើម្បីបញ្ជាក់ថាព្រះយេស៊ូបាន"
ប្រកាស "ឬបានមានបន្ទូលបែបនេះ។ អ្នកអាចបកប្រែភាសានេះជាភាសារបស់អ្នក
តាមរបៀបមួយដែលនឹងផ្តល់ការសង្កត់ន័យដល់មនុស្សម្នាក់។
គ្មានព្យាការីណាម្នាក់ត្រូវគេគោរពក្នុងស្រុកកំណើតរបស់ខ្លួនផ្ទាល់ឡើយ
"ប្រជាជនមិនបង្ហាញការគោរព ឬផ្តល់កិត្តិយសដល់ព្យាការីនៃប្រទេសរបស់ខ្លួន" ឬ
"ព្យាការីមិនត្រូវបានគេគោរពនៅក្នុងសហគមន៍ផ្ទាល់ខ្លួនរបស់គាត់ឡើយ"
បុណ្យនោះដែរ
ពិធីបុណ្យនេះគឺជាបុណ្យចម្លង។
John 4:46
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់សម្រាកនៅក្នុងសាច់រឿងសំខាន់
និងផ្លាស់ទៅផ្នែកថ្មីនៃសាច់រឿង។
បើអ្នកមានវិធីធ្វើបែបនេះជាភាសារបស់អ្នកអ្នកអាចពិចារណាប្រើវា។
មន្ត្រីម្នាក់
នរណាម្នាក់ដែលកំពុងបម្រើស្តេច
John 4:48
បើអ្នកមិនឃើញទីសម្គាល់ និងការអស្ចារ្យ នោះអ្នកមិនជឿទេ
"លើកលែងតែ ... មិនជឿ" ជាភាពអវិជ្ជមានទ្វេដង។ នៅក្នុងភាសាខ្លះ
វាជាការធម្មតាទេក្នុងការបកប្រែសេចក្តីថ្លែងនេះក្នុងទម្រង់វិជ្ជមាន។
"បើអ្នកឃើញការអស្ចារ្យ អ្នកនឹងជឿ"
ជឿលើព្រះបន្ទូល
នៅទីនេះ "ព្រះបន្ទូល" ជាការប្រៀបធៀប ដែលសំដៅទៅលើព្រះរាជសារ
ព្រះយេស៊ូមានបន្ទូល។ "ជឿលើព្រះរាជសារ"
John 4:51
ក្នុងការ
ពាក្យនេះត្រូវបានប្រើដើម្បីសម្គាល់ព្រឹត្តិការណ៍ពីរ
ដែលកំពុងកើតឡើងក្នុងពេលតែមួយ។ កាលមន្ត្រីនោះវិលត្រឡប់ទៅផ្ទះវិញ
អ្នកបម្រើរបស់លោកនាំគ្នាមកជួបលោកតាមផ្លូវ។
John 4:53
ដូច្នេះ គាត់ខ្លួនឯង និងគ្រួសាររបស់គាត់ទាំងមូលបានជឿលើព្រះអង្គ
សព្វនាមឆ្លុះបញ្ចាំង "ខ្លួនគាត់" ត្រូវបានប្រើនៅទីនេះដើម្បីបញ្ជាក់ពីពាក្យ "គាត់" ។
ប្រសិនបើអ្នកមានវិធីធ្វើបែបនេះជាភាសារបស់អ្នក អ្នកអាចពិចារណាប្រើបាន។
ទីសម្គាល់
ការអស្ចារ្យក៏អាចត្រូវបានគេហៅថា "ទីសម្គាល់"
ពីព្រោះពួកគេត្រូវបានប្រើជាសូចនាករ
ឬជាភស្តុតាងបង្ហាញថាព្រះជាម្ចាស់មានឫទ្ធានុភាព
ដែលមានឫទ្ធានុភាពពេញលើសកលលោក។

---

5 [1]បន្ទាប់ពីការនេះ មានបុណ្យរបស់សាសន៍យូដាមួយ ហើយព្រះយេស៊ូបានយាងឡើងទៅក្រុងយេរូសាឡិម។[2]ព្រះអង្គយាងចូលក្រុងយេរូសាឡិមតាមទ្វារចៀម
មានស្រះមួយ ដែលភាសាហេព្រើរហៅថា ស្រះបេថែសដា នៅជិតស្រះនោះមានថែវប្រាំ។[3]មានមនុស្សជាច្រើនដែលឈឺនៅទីនោះ មានអ្នកខ្វាក់ ខ្វិន
ឬស្វិតដៃជើងដេកនៅទីនោះ។[4]ទេវតារបស់ព្រះអម្ចាស់បានចុះមក ហើយកូរទឹកនោះយូរៗម្តង
អ្នកណាដែលចុះទៅក្នុងទឹកដែលកូរនោះមុនគេនឹងបានជាពីជំងឺរោគាដែលធ្វើឲ្យពួកគេឈឺចាប់។
[5]មានបុរសម្នាក់នៅទីនោះ មានជំងឺអស់រយៈពេលសាមសិបប្រាំបីឆ្នាំហើយ។[6]នៅពេលព្រះយេស៊ូឃើញគាត់ដេកនៅទីនោះ ហើយបន្ទាប់ពីព្រះអង្គជ្រាប់ថា
គាត់នៅទីនោះជាយូរមកហើយ ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «តើអ្នកចង់ជាទេ?»
[7]អ្នកឈឺនោះបានទូលឆ្លើយថា៖ «លោកម្ចាស់អើយ! ខ្ញុំគ្មាននរណាលើកខ្ញុំចូលទៅក្នុងស្រះទឹក នៅពេលទឹកកម្រើកឡើងទេ។ នៅពេលខ្ញុំមក
អ្នកផ្សេងបានចុះទៅមុនខ្ញុំរួចបាត់ទៅហើយ»។[8]ព្រះយេស៊ូឆ្លើយទៅគាត់ថា៖ «ក្រោកឡើង ចូរយកគ្រែអ្នកឡើង ហើយដើរទៅ!»។
[9]បុរសនោះបានជាមួយរំពេច ហើយគាត់បានយកគ្រែរបស់គាត់ឡើង ហើយដើរចេញទៅ។ ថ្ងៃនោះជាថ្ងៃសប្ប័ទ។
[10]ដូច្នេះ ពួកយូដាបានសួរគាត់ថា តើអ្នកណាធ្វើឲ្យអ្នកជា «ថ្ងៃនេះជាថ្ងៃសប្ប័ទ មិនអនុញ្ញាតឲ្យអ្នកលីគ្រែរបស់អ្នកឡើយ»។[11]គាត់ឆ្លើយថា៖ «អ្នកដែលធ្វើឲ្យខ្ញុំបានជា
គាត់ប្រាប់ខ្ញុំថា «ចូរយកកម្រាលរបស់អ្នកឡើង ហើយដើរទៅ»។
[12]ពួកគេសួរគាត់ថា៖ «តើបុរសដែលនិយាយមកកាន់អ្នកថា «ចូរយកវាឡើង ហើយដើរនោះ ជានរណា?»[13]ប៉ុន្តែ គ្មាននរណាដឹងថាម្នាក់ដែលធ្វើឲ្យគាត់ជានោះជានរណាទេ
ដោយសារព្រះយេស៊ូបានចេញពីទីនោះដោយអាថ៌កំបាំង ដ្បិតមានមនុស្សច្រើនកោះករនៅទីនោះ។
[14]បន្ទាប់ពីនោះមក ព្រះយេស៊ូបានជួបគាត់នៅក្នុងព្រះវិហារ ហើយមានបន្ទូលទៅកាន់គាត់ថា៖ «មើល អ្នកបានជាហើយ! កុំធ្វើបាបទៀតឡើយ
ដើម្បីកុំឲ្យមានអ្វីអាក្រក់ជាងនេះកើតឡើងចំពោះអ្នកទៀត»។[15]បុរសនោះបានចេញទៅ ហើយប្រាប់ទៅពួកយូដាថា គឺព្រះយេស៊ូដែលបានធ្វើឲ្យគាត់បានជា។
[16]ដោយសារការទាំងនេះ ពួកយូដាបានបៀតបៀនដល់ព្រះយេស៊ូ ដោយព្រោះព្រះអង្គធ្វើការទាំងនេះនៅថ្ងៃសប្ប័ទ។[17]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖
«ព្រះបិតារបស់ខ្ញុំធ្វើការសូម្បីតែពេលនេះ ហើយខ្ញុំក៏ធ្វើការដែរ»។[18]ដោយសារការនេះ បានធ្វើឲ្យពួកយូដាចង់សម្លាប់ព្រះអង្គកាន់តែខ្លាំង
ព្រោះព្រះអង្គមិនគ្រាន់តែប្រព្រឹត្តខុសថ្ងៃសប្ប័ទប៉ុណ្ណោះទេ ប៉ុន្តែ ព្រះអង្គបានហៅព្រះជាម្ចាស់ថា ជាព្រះបិតារបស់ព្រះអង្គផ្ទាល់ ព្រះអង្គលើកអង្គទ្រង់ស្មើព្រះជាម្ចាស់។
[19]ព្រះយេស៊ូមានបន្ទូលពួកគេថា៖ «ពិតណាស់ខ្ញុំប្រាប់អ្នកជាប្រាកដថា ព្រះបុត្រាមិនអាចធ្វើអ្វីដោយខ្លួនបានទេ លើកលែងតែអ្វីដែលព្រះអង្គបានឃើញព្រះបិតាធ្វើ
ព្រោះអ្វីក្តីដែលព្រះបិតាធ្វើ ព្រះបុត្រាក៏ធ្វើការទាំងនោះដូចព្រះអង្គដែរ។[20]ដ្បិតព្រះបិតាស្រឡាញ់ព្រះបុត្រា

generated on Wed Sep 10 16:16:32 2025

ហើយព្រះអង្គបង្ហាញអ្វីៗទាំងអស់ដែលព្រះអង្គផ្ទាល់បានធ្វើដល់ព្រះបុត្រា ហើយព្រះអង្គនឹងបង្ហាញដល់ព្រះបុត្រានូវការដ៏ធំជាងការទាំងនេះ
ដើម្បីឲ្យអ្នករាល់គ្នាមានការងឿងឆ្ងល់។
[21]ដ្បិតព្រះបិតាដែលប្រោសមនុស្សស្លាប់ ហើយប្រទានជីវិតដល់ពួកគេយ៉ាងណា ព្រះបុត្រានឹងប្រទានជីវិតដល់អស់អ្នកណាដែលព្រះអង្គគាប់ព្រះហឫទ័យយ៉ាងនោះដែរ។
[22]ដ្បិតព្រះបិតាមិនបានជំនុំជម្រះនរណាទេ ប៉ុន្តែព្រះអង្គប្រទានគ្រប់ទាំងការជំនុំជម្រះទាំងអស់ដល់ព្រះបុត្រា។
[23]ដើម្បីឲ្យមនុស្សគ្រប់គ្នាបានគោរពដល់ព្រះបុត្រាដូចដែលពួកគេបានគោរពដល់ព្រះបិតាដែរ។ អ្នកណាដែលមិនគោរពព្រះបុត្រា
ក៏មិនគោរពដល់ព្រះបិតាដែលចាត់ព្រះអង្គឲ្យមកដែរ។
[24]ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា អ្នកណាដែលឮពាក្យខ្ញុំ ហើយជឿលើព្រះអង្គដែលចាត់ខ្ញុំឲ្យមកនឹងមានជីវិតអស់កល្បជានិច្ច ហើយនិងមិនជាប់មានទោសឡើយ
ប៉ុន្តែឆ្លងផុតពីស្លាប់មកកាន់ជីវិតវិញ។
[25]ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា ពេលវេលានឹងមកដល់ ហើយឥឡូវនេះ ដល់ពេលហើយ នៅពេលដែលមនុស្សស្លាប់នឹងឮសម្លេងបុត្រារបស់ព្រះជាម្ចាស់
ហើយអស់អ្នកដែលឮនឹងបានរស់។
[26]ដ្បិតព្រះបិតាមានព្រះជន្មនៅក្នុងអង្គទ្រង់យ៉ាងណា ព្រះអង្គក៏ប្រទានដល់ព្រះបុត្រាយ៉ាងនោះដែរ ដើម្បីឲ្យព្រះអង្គមានព្រះជន្មនៅក្នុងអង្គទ្រង់ដែរ។
[27]ហើយព្រះបិតាបានប្រទានសិទ្ធិអំណាចដល់ព្រះបុត្រាក្នុងការវិនិច្ឆ័យដែរ ព្រោះព្រះអង្គគឺជាបុត្រមនុស្ស។
[28]កុំឲ្យងឿងឆ្ងល់ពីការនេះឡើយ ព្រោះនឹងមានពេលមកដល់ដែលមនុស្សគ្រប់រូបដែលនៅក្នុងផ្នូរនឹងឮព្រះសូរសៀងរបស់ព្រះអង្គ ហើយពួកគេ[29]នឹងចេញមក
អ្នកណាដែលធ្វើល្អនឹងរស់ឡើងដើម្បីទទួលជីវិត ហើយអស់អ្នកដែលបានធ្វើការអាក្រក់នឹងរស់ឡើងដើម្បីទទួលការជំនុំជម្រះ។
[30]ខ្ញុំមិនបានអាចធ្វើអ្វីដោយខ្លួនខ្ញុំទេ។ ខ្ញុំឮ ខ្ញុំជំនុំជម្រះ ហើយសេចក្តីវិនិច្ឆ័យរបស់ខ្ញុំគឺសុចរិត ព្រោះខ្ញុំមិនបានធ្វើតាមបំណងចិត្តរបស់ខ្ញុំផ្ទាល់ទេ
ប៉ុន្តែតាមបំណងព្រះហឫទ័យរបស់ព្រះដែលចាត់ខ្ញុំមកវិញ។[31]ប្រសិនបើខ្ញុំធ្វើបន្ទាល់ពីខ្លួនខ្ញុំ ទីបន្ទាល់របស់ខ្ញុំអាចមិនពិត។[32]មានអ្នកផ្សេងទៀតបានធ្វើបន្ទាល់ពីខ្ញុំ
ហើយខ្ញុំដឹងថាការធ្វើទីបន្ទាល់អំពីខ្ញុំជាសេចក្តីពិត។
[33]អ្នករាល់គ្នាបានចាត់មនុស្សឲ្យទៅរកលោកយ៉ូហាន ហើយគាត់បានធ្វើបន្ទាល់ពីសេចក្តីពិត។[34]ប៉ុន្តែទីបន្ទាល់ដែលខ្ញុំបានទទួលមិនមែនមកពីមនុស្សទេ។
ខ្ញុំនិយាយការទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបានសង្គ្រោះ។[35]លោកយ៉ូហានជាចង្កៀងដែលកំពុងឆេះ ហើយជះពន្លឺ
ហើយគាត់នឹងរីករាយជាមួយពន្លឺរបស់គាត់តែមួយរយៈប៉ុណ្ណោះ។
[36]ប៉ុន្តែទីបន្ទាល់ដែលខ្ញុំមានធំជាងលោកយ៉ូហានមាន ព្រោះកិច្ចការដែលព្រះបិតាបានប្រទានឲ្យខ្ញុំបំពេញ ហើយកិច្ចការសំខាន់ដែលខ្ញុំត្រូវធ្វើ
គឺធ្វើបន្ទាល់ពីខ្ញុំដែលព្រះបិតាបានចាត់ខ្ញុំឲ្យមក។[37]ព្រះបិតាបានចាត់ខ្ញុំមក ព្រះអង្គក៏ធ្វើបន្ទាល់អំពីខ្ញុំដែរ។ អ្នករាល់គ្នាមិនដែលបានឮព្រះសូរសៀង
ឬឃើញព្រះកាយរបស់ព្រះអង្គដែរ។[38]អ្នករាល់គ្នាគ្មានព្រះបន្ទូលរបស់ព្រះអង្គនៅជាមួយអ្នករាល់គ្នាទេ ព្រោះអ្នករាល់គ្នាមិនជឿលើព្រះដែលព្រះអង្គចាត់ឲ្យមកទេ។
[39]អ្នករាល់គ្នាស្វែងរកបទគម្ពីរដោយសារអ្នករាល់គ្នាគិតថា នៅក្នុងបទគម្ពីរនោះមានជីវិតអស់កល្បជានិច្ច
ហើយបទគម្ពីរដដែលនេះហើយធ្វើបន្ទាល់អំពីខ្ញុំ[40]ហើយអ្នករាល់គ្នាមិនចង់ចូលមករកខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាបានជីវិតសោះ។
[41]កុំទទួលការសរសើរពីមនុស្សឡើយ[42]ប៉ុន្តែ ខ្ញុំដឹងថា អ្នករាល់គ្នាមិនបានស្រឡាញ់ព្រះជាម្ចាស់នៅក្នុងខ្លួនរបស់អ្នករាល់គ្នាឡើយ។
[43]ខ្ញុំបានមកក្នុងព្រះនាមរបស់ព្រះបិតានៃខ្ញុំ ហើយអ្នករាល់គ្នាមិនទទួលខ្ញុំ។ ប្រសិនបើ អ្នកផ្សេងទៀតមកក្នុងនាមរបស់គេផ្ទាល់ អ្នកអាចនឹងទទួលអ្នកនោះ។
[44]តើអ្នកអាចជឿដូចម្តេចកើត អ្នកគឺជាមនុស្សដែលទទួលការសរសើរពីគ្នាទៅវិញទៅមក ប៉ុន្តែអ្នករាល់គ្នាមិនបានស្វែងរកការសរសើរដែលចេញពីព្រះជាម្ចាស់តែមួយផង?
[45]កុំគិតថា ខ្ញុំខ្លួនឯងនឹងចោទប្រកាន់អ្នករាល់គ្នានៅចំពោះព្រះបិតាឡើយ។ ម្នាក់ដែលចោទប្រកាន់អ្នករាល់គ្នាគឺលោកម៉ូសេ
គឺជាអ្នកដែលអ្នកបានដាក់សេចក្តីសង្ឃឹមរបស់អ្នកលើ។[46]ប្រសិនបើ អ្នករាល់អ្នកជឿលោកម៉ូសេ អ្នករាល់គ្នាជឿដល់ខ្ញុំដែរ ព្រោះគាត់សរសរពីខ្ញុំ។[47]ប្រសិនបើ
អ្នកមិនជឿលើការសរសេររបស់គាត់ទេ ធ្វើដូចម្តេចឲ្យអ្នករាល់គ្នាអាចជឿលើពាក្យរបស់ខ្ញុំបាន?»

John 5:1

ព័ត៌មានទូទៅ:

នេះជាព្រឹត្តិការណ៍បន្ទាប់នៅក្នុងរឿង
ដែលព្រះយេស៊ូបានយាងឡើងទៅក្រុងយេរូសាឡឹម ហើយប្រោសបុរសម្នាក់។
ខគម្ពីរទាំងនេះផ្តល់នូវព័ត៌មានសំខាន់ អំពីការកំណត់សាច់រឿង។

បន្ទាប់ពីការនេះ

សំដៅទៅលើបន្ទាប់ពីព្រះយេស៊ូបានប្រោសកូនប្រុសរបស់មន្ត្រីនោះ។

មើលរបៀបដែលអ្នកបកប្រែនេះ

មានបុណ្យរបស់សាសន៍យូដាមួយ

"ជនជាតិយូដាបានប្រារព្ធពិធីបុណ្យមួយ"

ឡើងទៅក្រុងយេរូសាឡឹម

ក្រុងយេរូសាឡឹមមានទីតាំងនៅលើកំពូលភ្នំ។ ផ្លូវទៅក្រុងយេរូសាឡឹម
ត្រូវឡើងចុះពីលើភ្នំតូចៗ។
ប្រសិនបើភាសារបស់អ្នកមានពាក្យផ្សេងសម្រាប់ការឡើងភ្នំ
ជាជាងការដើរនៅលើដី អ្នកអាចប្រើវានៅទីនេះ។

ស្រះ

ជារណ្តៅដីដែលមនុស្សចាក់បំពេញដោយទឹក។
ពេលខ្លះពួកគេក្រាលអាងទឹកដោយប្រើក្បឿង ឬដុំថ្មផ្សេងទៀត។

បេថែសដា

បេថែសដាមានន័យថា ផ្ទះនៃសេចក្តីមេត្តា។

ថែវ

ថែវជាដំបូលដែលគ្មានជញ្ជាំង និងភ្ជាប់ទៅនឹងអគារ

មានមនុស្សជាច្រើន

មនុស្សជាច្រើន

John 5:5

ព័ត៌មានទូទៅ:

ខ៥ ប្រាប់ពីបុរសដែលដេកនៅក្បែរស្រះទឹកទៅនឹងសាច់រឿង។

នៅទីនោះ

"នៅស្រះបេថែសដា (៥: ១)

សាមសិបប្រាំបីឆ្នាំ

ប្រាំបីឆ្នាំ - "៣៨ ឆ្នាំ"

ព្រះអង្គជ្រាប់ថា

"ព្រះអង្គបានជ្រាប" ឬ "ទ្រង់បានឃើញ"

ព្រះអង្គមានបន្ទូលទៅគាត់ថា

«ព្រះយេស៊ូមានបន្ទូលទៅបុរសខ្វិន»

John 5:7

លោកម្ចាស់អើយ! ខ្ញុំគ្មាន

នៅទីនេះពាក្យ "លោកម្ចាស់" បង្ហាញពីការគួរសម។

នៅពេលទឹកកម្រើកឡើង

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "នៅពេលទេវតាអង្រួនទីទឹក"

ក្នុងស្រះទឹក

ជារណ្តៅពីដីដែលមនុស្សចាក់ទឹកចូល។ ពេលខ្លះពួកក្រាលស្រះទឹកដោយប្រើក្បឿង
ឬដុំថ្មផ្សេងទៀត។ សូមមើលពីរបៀបដែលអ្នកបានបកប្រែ“ ស្រះ” នៅក្នុងជំពូក ៥
ខ ១ ។

អ្នកផ្សេងបានចុះទៅមុនខ្ញុំរួចបាត់ទៅហើយ

"មានអ្នកផ្សេងតែងតែចុះទៅក្នុងទឹកមុនខ្ញុំ"

ក្រោកឡើង

"ក្រោកឈរ!"

ចូរយកគ្រែអ្នកឡើង ហើយដើរទៅ

"សែងគ្រែដេករបស់អ្នក ហើយដើរទៅ!"

John 5:9

បុរសនោះបានជា

generated on Wed Sep 10 16:16:32 2025

"បុរសនោះមានសុខភាពល្អឡើងវិញ"
ថ្ងៃនោះជាថ្ងៃសប្ប័ទ
«ថ្ងៃនោះជាថ្ងៃសម្រាករបស់ព្រះជាម្ចាស់»
ឥឡូវ
"ឥឡូវនេះ" ត្រូវបានប្រើនៅទីនេះដើម្បីទាក់ទាញចំណាប់អារម្មណ៍
លើព័ត៌មានសំខាន់។ វាសង្កត់ន័យលើការពិតដែលថា
ព្រឹត្តិការណ៍នេះកើតឡើងនៅថ្ងៃសប្ប័ទ។
John 5:10
ដូច្នេះ ពួកយូដាបានសួរគាត់ថា
ជនជាតិយូដា (ជាពិសេសអ្នកដឹកនាំជនជាតិយូដា)
ខឹងនៅពេលដែលឃើញបុរសនោះ សែងគ្រែរបស់គាត់នៅថ្ងៃសប្ប័ទ។
ថ្ងៃនេះជាថ្ងៃសប្ប័ទ
"នេះជាថ្ងៃសម្រាករបស់ព្រះជាម្ចាស់"
អ្នកដែលធ្វើឲ្យខ្ញុំបានជា
"បុរសដែលធ្វើឲ្យខ្ញុំជា"
John 5:12
ពួកគេសួរគាត់ថា
"មេដឹកនាំសាសន៍យូដាបានសួរបុរស ដែលត្រូវបានប្រោសឲ្យជាថា"
John 5:14
ព្រះយេស៊ូបានជួបគាត់
"ព្រះយេស៊ូជួបបុរសដែលទ្រង់បានប្រោសឲ្យជា"
មើល
ពាក្យ "មើល" ត្រូវបានប្រើនៅទីនេះ
ដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះពាក្យដែលធ្វើតាម។
John 5:16
ឥឡូវ
"ឥឡូវនេះ"
សម្គាល់សេចក្តីថ្លែងសង្ខេបរបស់យ៉ូហានអំពីអាកប្បកិរិយារបស់មេដឹកនាំសាសន៍យូដា
ចំពោះព្រះយេស៊ូ។
ធ្វើការ
សំដៅទៅលើការធ្វើពលកម្មរួមទាំងអ្វីៗ
ដែលត្រូវបានធ្វើសម្រាប់បម្រើផលប្រយោជន៍មនុស្សផ្សេងទៀត។
ពួកយូដា
នៅទីនេះ "ពួកយូដា" ជានិមិត្តរូបដែលតំណាងឲ្យ "មេដឹកនាំយូដា" ។
"មេដឹកនាំសាសន៍យូដា"
លើកអង្គទ្រង់ស្មើព្រះជាម្ចាស់
"និយាយថា ទ្រង់ដូចព្រះជាម្ចាស់" ឬ "និយាយថា
ទ្រង់មានសិទ្ធិអំណាចដូចព្រះជាម្ចាស់"
ព្រះបិតារបស់ព្រះអង្គផ្ទាល់
នេះជាមុខងារសំខាន់ចំពោះព្រះជាម្ចាស់។
John 5:19
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់អ្នកដឹកនាំជនជាតិយូដា។
ពិតណាស់
បកប្រែដូចជំពូក១ ខ៤៩។
អ្នករាល់គ្នាមានការងឿងឆ្ងល់
"អ្នកនឹងភ្ញាក់ផ្អើល" ឬ "អ្នកនឹងរន្ធត់ចិត្ត"
ព្រោះអ្វីក្តីដែលព្រះបិតាធ្វើ ព្រះបុត្រាក៏ធ្វើការទាំងនោះដូចព្រះអង្គដែរ។
ដ្បិតព្រះបិតាស្រឡាញ់ព្រះបុត្រា
ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់
ដែលគោរពនិងស្តាប់បង្គាប់តាមការដឹកនាំរបស់ព្រះបិតានៅលើផែនដីព្រោះព្រះយេស៊ូ
ព្រះបិតាស្រឡាញ់ព្រះអង្គ។
ព្រះបិតា...ព្រះបុត្រា
ជាឋានៈសំខាន់ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះយេស៊ូនិងព្រះជាម្ចាស់។
ស្រឡាញ់
សេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់ផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
ទោះបីវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
ព្រះជាម្ចាស់ផ្ទាល់ជាសេចក្តីស្រឡាញ់ហើយជាប្រភពនៃសេចក្តីស្រឡាញ់ពិត។
John 5:21
ដ្បិតព្រះបិតាដែលប្រោសមនុស្សស្លាប់ ហើយប្រទានជីវិតដល់ពួកគេយ៉ាងណា
ព្រះបុត្រានឹងប្រទានជីវិតដល់អស់អ្នកណាដែលព្រះអង្គគាប់ព្រះហឫទ័យយ៉ាងនោះដែរ
ពាក្យ "សម្រាប់" បង្ហាញពីការប្រៀបធៀប។ ព្រះបុត្រារបស់ព្រះជាម្ចាស់
(ព្រះជាព្រះបុត្រា) ផ្តល់ជីវិតដូចព្រះបិតាប្រទានជីវិត។
ព្រះបិតា....ព្រះបុត្រា
ជាឋានៈសំខាន់ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់ និងព្រះយេស៊ូ។
ជីវិត
សំដៅទៅលើ "ជីវិតខាងវិញ្ញាណ" ។
ដ្បិតព្រះបិតាមិនបានជំនុំជម្រះនរណាទេ
ប៉ុន្តែព្រះអង្គប្រទានគ្រប់ទាំងការជំនុំជម្រះទាំងអស់ដល់ព្រះបុត្រា
ពាក្យ "សម្រាប់" បង្ហាញពីការប្រៀបធៀប។
ព្រះបុត្រារបស់ព្រះជាម្ចាស់អនុវត្តការជំនុំជម្រះសម្រាប់ព្រះបិតា។
គោរពដល់ព្រះបុត្រាដូចដែល...ព្រះបិតាដែរ។ អ្នកណាដែលមិនគោរពព្រះបុត្រា
ក៏មិនគោរពដល់ព្រះបិតា
ព្រះបុត្រាត្រូវតែគោរពនិងថ្វាយបង្គំដូចព្រះបិតា។ បើយើងមិនគោរពព្រះបុត្រាទេ
នោះយើងក៏មិនគោរពព្រះបិតាដែរ។
John 5:24
ពិតណាស់
បកប្រែដូចក្នុងជំពូក ១ ខ៤៩ ។
អ្នកណាដែលឮពាក្យខ្ញុំ
នៅទីនេះ"ពាក្យ" ជាការប្រៀបធៀប ដែលតំណាងឲ្យព្រះបន្ទូលរបស់ព្រះយេស៊ូ។
"អ្នកណាដែលស្តាប់ព្រះបន្ទូលរបស់ខ្ញុំ"
និងមិនជាប់មានទោសឡើយ
អាចបញ្ជាក់ជាទម្រង់វិជ្ជមាន។ "នឹងត្រូវបានវិនិច្ឆ័យថាគ្មានទោសពៃរ៍"
John 5:25
ពិតណាស់
បកប្រែពាក្យនេះតាមភាសារបស់អ្នក ដោយសង្កត់ន័យថា
ដែលអ្នកបានបកប្រែវានៅក្នុងជំពូក១ ខ៤៩ ។
មនុស្សស្លាប់នឹងឮសម្លេងបុត្រារបស់ព្រះជាម្ចាស់ ហើយអស់អ្នកដែលឮនឹងបានរស់
សំឡេងរបស់ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់នឹងប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ។
។
បុត្រារបស់ព្រះជាម្ចាស់
ជាឋានៈសំខាន់ចំពោះព្រះយេស៊ូ។
John 5:26
ដ្បិតព្រះបិតាមានព្រះជន្មនៅក្នុងអង្គទ្រង់យ៉ាងណា ព្រះអង្គក៏ប្រទានដល់ព្រះបុត្រាយ៉ាងនោះដែរ
ដើម្បីឲ្យព្រះអង្គមានព្រះជន្មនៅក្នុងអង្គទ្រង់ដែរ
ពាក្យ "សម្រាប់" ជាការប្រៀបធៀប។
ព្រះបុត្រារបស់ព្រះជាម្ចាស់មានអំណាចផ្តល់ជីវិតដូចព្រះបិតាដែរ។
ព្រះបិតា....បុត្រមនុស្ស
ទាំងនេះជាឋានៈសំខាន់ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់
និងព្រះយេស៊ូ។ ។
ជីវិត
មានន័យថាជីវិតខាងវិញ្ញាណ។
ព្រះបិតាបានប្រទានសិទ្ធិអំណាចដល់ព្រះបុត្រាក្នុងការវិនិច្ឆ័យ
ព្រះបុត្រារបស់ព្រះជាម្ចាស់មានសិទ្ធអំណាចរបស់ព្រះបិតា ក្នុងការជំនុំជម្រះ។
John 5:28
កុំឲ្យងឿងឆ្ងល់ពីការនេះឡើយ
"នេះ" សំដៅទៅលើការពិតដែលថា
ព្រះយេស៊ូជាបុត្រមនុស្សមានសិទ្ធិអំណាចផ្តល់ជីវិតអស់កល្បជានិច្ច
និងអនុវត្តការជំនុំជម្រះ។
នឹងឮព្រះសូរសៀងរបស់ព្រះអង្គ
"ឮសំឡេងរបស់ខ្ញុំ"
John 5:30
បំណងព្រះហឫទ័យរបស់ព្រះដែលចាត់ខ្ញុំមក
ពាក្យ "ព្រះអង្គ" សំដៅទៅលើព្រះបិតា។
មានអ្នកផ្សេងទៀតបានធ្វើបន្ទាល់ពីខ្ញុំ
"មានអ្នកផ្សេងដែលប្រាប់មនុស្សអំពីខ្ញុំ"
ផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

សំដៅទៅលើព្រះជាម្ចាស់
បន្ទាល់អំពីខ្ញុំជាសេចក្តីពិត
"អ្វីដែលទ្រង់ប្រាប់មនុស្សអំពីខ្ញុំ គឺជាការពិត"
John 5:33
បន្ទាល់ដែលខ្ញុំបានទទួលមិនមែនមកពីមនុស្សទេ
"ខ្ញុំមិនត្រូវការទីបន្ទាល់របស់មនុស្ស"
ដើម្បីឲ្យអ្នករាល់គ្នាបានសង្គ
អាចបកប្រែរាជាទម្រង់កិរិយាសកម្ម។ "ដូច្នេះព្រះជាម្ចាស់អាចជួយសង្គ្រោះអ្នក"
លោកយ៉ូហានជាចង្កៀងដែលកំពុងឆេះ ហើយជះពន្លឺ
ពាក្យ "ចង្កៀង"នៅទីនេះជាពាក្យប្រៀបធៀប។
យ៉ូហានបានបង្ហាញពីវិសុទ្ធភាពរបស់ព្រះជាម្ចាស់
តាមរបៀបមួយដែលចង្កៀងផ្តល់ពន្លឺ។
«យ៉ូហានប្រៀបដូចជាចង្កៀងដែលកំពុងឆេះនិងជះពន្លឺ»
John 5:36
កិច្ចការដែលព្រះបិតាបានប្រទានឲ្យខ្ញុំបំពេញ ...ដែលព្រះបិតាបានចាត់ខ្ញុំឲ្យមក
ព្រះជាម្ចាស់ជាព្រះបិតាបានចាត់ព្រះបុត្រា គឺព្រះយេស៊ូឲ្យមកផែនដី។
ព្រះយេស៊ូបានបំពេញអ្វី ដែលព្រះបិតាប្រគល់ឲ្យព្រះអង្គធ្វើ។
ព្រះបិតាបានចាត់ខ្ញុំមក ព្រះអង្គក៏ធ្វើបន្ទាល់អំពីខ្ញុំដែរ
សព្វនាមឆ្លុះបញ្ចាំងខ្លួនឯងថា "ព្រះអង្គផ្ទាល់" សង្កត់ន័យថា គឺព្រះបិតា
ពុំមែនមនុស្សណាម្នាក់មិនសូវសំខាន់ ដែលបានធ្វើបន្ទាល់អំពីខ្ញុំ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
កិច្ចការសំខាន់ដែលខ្ញុំត្រូវធ្វើ គឺធ្វើបន្ទាល់ពីខ្ញុំ
នៅទីនេះ ព្រះយេស៊ូមានបន្ទូលថា ការអស្ចារ្យ"ធ្វើទីបន្ទាល់" ឬ "ប្រាប់ប្រជាជន"
អំពីព្រះអង្គ។ " អ្វីដែលខ្ញុំធ្វើបង្ហាញដល់មនុស្សថា ព្រះជាម្ចាស់បានចាត់ខ្ញុំឲ្យមក"
អ្នករាល់គ្នាគ្មានព្រះបន្ទូលរបស់ព្រះអង្គនៅជាមួយអ្នករាល់គ្នាទេ
ព្រោះអ្នករាល់គ្នាមិនជឿលើព្រះដែលព្រះអង្គចាត់ឲ្យមកទេ
"អ្នកមិនជឿលើអ្នក ដែលព្រះអង្គបានចាត់ឲ្យមកទេ។ នេះជារបៀបដែលខ្ញុំដឹងថា
អ្នកមិនមានព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងអ្នកទេ"
នៅជាមួយអ្នករាល់គ
"រស់នៅក្នុងអ្នក"
John 5:39
ក្នុងបទគម្ពីរនោះមានជីវិតអស់កល្បជានិច្ច
"អ្នកនឹងរកឃើញជីវិតអស់កល្បជានិច្ច បើអ្នកអានព្រះបន្ទូល" ឬ
"ព្រះគម្ពីរនឹងប្រាប់អ្នកពីរបៀប ដែលអ្នកអាចមានជីវិតអស់កល្បជានិច្ច"
អ្នករាល់គ្នាមិនចង់ចូលមករកខ្
"អ្នកបដិសេធមិនជឿបន្ទូលរបស់ខ្ញុំ"
John 5:41
ទទួល
"ទទួលយក"
អ្នករាល់គ្នាមិនបានស្រឡាញ់ព្រះជាម្ចាស់នៅក្នុងខ្លួនរបស់អ្នករាល់គ្នាឡើយ
នេះអាចមានន័យថា ១)“ អ្នកពិតជាមិនស្រឡាញ់ព្រះ” ឬ ២)“
អ្នកពិតជាមិនបានទទួលសេចក្តីស្រឡាញ់ពីព្រះទេ” ។
John 5:43
ក្នុងព្រះនាមរបស់ព្រះបិតានៃខ្ញុំ
នៅទីនេះពាក្យ "ឈ្មោះ" ជាពាក្យប្រៀបធៀប ដែលតំណាងឲ្យឫទ្ធានុភាព
សិទ្ធិអំណាចរបស់ព្រះជាម្ចាស់។
"ខ្ញុំបានមកជាមួយសិទ្ធិអំណាចរបស់ព្រះបិតារបស់ខ្ញុំ"
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។ ។
ទទួល
ទទួលយក
ប្រសិនបើ អ្នកផ្សេងទៀតមកក្នុងនាមរបស់គេផ្ទាល់
ពាក្យ "ឈ្មោះ" ជាពាក្យប្រៀបធៀប ដែលតំណាងឲ្យសិទ្ធិអំណាច។
"ប្រសិនបើអ្នកផ្សេងទៀតគួរតែមកក្នុងអំណាចផ្ទាល់ខ្លួនរបស់គេ"
តើអ្នកអាចជឿដូចម្តេចកើត អ្នកគឺជាមនុស្សដែលទទួលការសរសើរ...ព្រះជាម្ចាស់
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"គ្មានវិធីណាដែលអ្នកអាចជឿបានទេ ព្រោះអ្នកទទួលយកការសរសើរ ...
ព្រះជាម្ចាស់!"
ជឿ
មានន័យថា ជឿទុកចិត្តលើព្រះយេស៊ូ។
John 5:45
ម្នាក់ដែលចោទប្រកាន់អ្នករាល់គ្នាគឺលោកម៉ូសេ ....សេចក្តីសង្ឃឹមរបស់អ្នក
"លោកម៉ូសេ" ជាពាក្យប្រៀបធៀប ដែលតំណាងឲ្យក្រឹត្យវិន័យខ្លួនឯង។
"លោកម៉ូសេចោទប្រកាន់អ្នកនៅក្នុងក្រឹត្យវិន័យ ជាច្បាប់ដែលអ្នកបានសង្ឃឹមលើ"
សេចក្តីសង្ឃឹមរបស់អ្នក
"ទំនុកចិត្តរបស់អ្នក" ឬ "ការទុកចិត្តរបស់អ្នក"
ប្រសិនបើ អ្នកមិនជឿលើការសរសេររបស់គាត់ទេ
ធ្វើដូចម្តេចឲ្យអ្នករាល់គ្នាអាចជឿលើពាក្យរបស់ខ្ញុំបាន?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីផ្តល់ការសង្កត់ន័យ។
"អ្នកមិនជឿការសរសេររបស់គាត់ទេ ដូច្នេះអ្នកនឹងមិនជឿពាក្យរបស់ខ្ញុំទេ!"
ពាក្យរបស់ខ្ញុំ
អ្វីដែលខ្ញុំនិយាយ

---

6 [1]បន្ទាប់ពីការនេះ ព្រះយេស៊ូបានយាងចេញទៅម្ខាងទៀតនៃសមុទ្រកាលីឡេ គេក៏ឈ្មោះមួយទៀតថាសមុទ្រទីបេរាស។
[2]មានបណ្តាជនយ៉ាងច្រើនកោះករដើរតាមព្រះអង្គ ព្រោះពួកគេបានឃើញទីសម្គាល់ដែលព្រះអង្គបានធ្វើជាមួយពួកអ្នកដែលឈឺ។[3]ព្រះយេស៊ូបានយាងឡើងភ្នំ
ហើយគង់នៅជាមួយពួកសិស្សនៅទីនោះ។
[4](ពិធីបុណ្យចម្លង ពិធីបុណ្យរបស់សាសន៍យូដាជិតមកដល់ហើយ)។[5]នៅពេលព្រះយេស៊ូងើបព្រះនេត្រឡើង ព្រះអង្គទតឃើញបណ្តាជនយ៉ាងច្រើនចូលមករកព្រះអង្គ
ទ្រង់មានបន្ទូលទៅលោកភីលីពថា៖ «តើយើងនឹងត្រូវទៅទិញនំបុ័ងពីណាមក ដើម្បីឲ្យអ្នកទាំងអស់នេះបរិភោគ?»[6](ព្រះយេស៊ូមានបន្ទូលបែបនេះ
ដើម្បីល្បងលលោកភីលីពទេ ដ្បិតព្រះអង្គផ្ទាល់ ទ្រង់ជ្រាបថាអ្វីដែលព្រះអង្គត្រូវធ្វើហើយ)។
[7]លោកភីលីពទូលព្រះអង្គថា៖ «ទោះបីជាយកលុយកាក់ពីររយឌេណារីទៅទិញនំបុ័ងក៏មិនគ្រប់ដែរ សូម្បីតែចែកម្នាក់បន្តិចក្តី»។[8]សិស្សម្នាក់ទៀតឈ្មោះ អនទ្រេ
ត្រូវជាបងប្រុសរបស់លោកស៊ីម៉ូនពេត្រុស ទូលទៅព្រះយេស៊ូថា៖[9]«មានក្មេងប្រុសម្នាក់ មាននំបុ័ងប្រាំដុំ និងត្រីពីរ ប៉ុន្តែ តើធ្វើដូចម្តេចឲ្យគ្រប់បាន
បើមនុស្សមានគ្នាច្រើនយ៉ាងនេះ?»។
[10]ព្រះយេស៊ូមានបន្ទូលថា៖ «សូមឲ្យមនុស្សអង្គុយចុះ»។ (នៅទីនោះមានស្មៅច្រើន)។ ដូច្នេះ បណ្តាជនក៏អង្គុយនៅទីនោះ មានគ្នាប្រហែលជាប្រាំពាន់អ្នក។[11]ដូច្នេះ
ព្រះយេស៊ូបានយកនំបុ័ង បន្ទាប់ពីព្រះអង្គបានអរព្រះគុណរួចហើយ ព្រះអង្គបានប្រទាននំបុ័ងទាំងនោះទៅដល់អស់អ្នកដែលបានអង្គុយ។ ចំណែកត្រីវិញ
ព្រះអង្គបានធ្វើដូចគ្នាដែរ[12]ចែកដល់ពួកគេតាមអ្វីដែលពួកគេត្រូវការ។ នៅពេលបណ្តាជនបានឆ្អែតហើយ ព្រះអង្គមានបន្ទូលទៅពួកសិស្សរបស់ព្រះអង្គថា៖
«ចូរប្រមូលនំបុ័ងដែលនៅសល់មកវិញ កុំឲ្យបាត់មួយដុំណាឡើយ»។
[13]ដូច្នេះ ពួកគេបានប្រមូលនំបុ័ងទាំងនោះមកវិញ ហើយបានដប់ពីរកន្ត្រកពេញពីមនុស្សជាច្រើនដែលបានបរិភោគ ជាដុំនំបុ័ងដែលបាក់បែក
ដែលកើតចេញពីនំបុ័ងប្រាំដុំនោះ។[14]បន្ទាប់ពីមនុស្សបានឃើញការអស្ចារ្យដែលព្រះអង្គបានធ្វើនេះ ពួកគេនិយាយថា៖
«នេះគឺជាព្យាការីដ៏ពិតដែលបានមកនៅក្នុងលោកីយ៍នេះ»។[15]នៅពេលព្រះយេស៊ូជ្រាបថា ពួកគេនាំគ្នា ហើយចង់បង្ខំព្រះអង្គឲ្យធ្វើជាស្តេច
ព្រះអង្គក៏ចាកចេញពីពួកគេឡើងទៅលើភ្នំម្តងទៀត។
[16]នៅពេលល្ងាចមកដល់ ពួកសិស្សរបស់ព្រះអង្គបានចុះទៅឯសមុទ្រ។[17]ពួកគេឡើងជិះទូក ហើយឆ្លងទៅសមុទ្រទៅកាពើណិម។ នៅពេលនេះងងឹតហើយ
ព្រះយេស៊ូមិនទាន់បានយាងទៅរកពួកគេនៅឡើយទេ។[18]មានខ្យល់បក់បោកយ៉ាងខ្លាំង ហើយទឹកសមុទ្រក៏កម្រើកឡើងដែរ។

generated on Wed Sep 10 16:16:32 2025

[19]នៅពេលដែលពួកគេចែវទូកបានចម្ងាយប្រហែលជាប្រាំ ឬប្រាំមួយគីឡូម៉ែត្រ ពួកគេបានឃើញព្រះយេស៊ូកំពុងយាងនៅលើទឹកសមុទ្រ ហើយចូលមកជិតទូក
ពួកគេមានការភ័យខ្លាច។[20]ប៉ុន្តែ ព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «ខ្ញុំទេ កុំខ្លាចអី»។[21]បន្ទាប់មក ពួកគេចង់ទទួលព្រះអង្គមកក្នុងទូកដែរ
ស្រាប់តែទូករបស់ពួកគេទៅដល់ច្រាំងជាកន្លែងដែលពួកគេចង់ទៅលួម។
[22]នៅថ្ងៃបន្ទាប់ បណ្តាជនដែលឈរនៅត្រើយម្ខាងនៃសមុទ្របានឃើញថា គ្មានទូកណាទៀតឡើយ លើកលែងតែមួយ
ហើយពេលនោះព្រះយេស៊ូមិនបានចូលទៅក្នុងទូកជាមួយពួកសិស្សរបស់ព្រះអង្គទេ ពួកសិស្សចេញទៅតែពួកគេទេ។[23]ក៏មានទូកមកពីក្រុងទីបេរាស
ចូលទៅជិតកន្លែងដែលពួកគេបានបរិភោគនំប៉័ងបន្ទាប់ពីព្រះអង្គអរព្រះគុណ។
[24]នៅពេលបណ្តាជនរកឃើញថា ព្រះយេស៊ូមិនបាននៅទីនោះជាមួយពួកសិស្សរបស់ព្រះអង្គ ពួកគេនាំគ្នាឡើងទូកទៅរកព្រះយេស៊ូនៅកាពើណិមខ្លួនគេ។
[25]បន្ទាប់ពីពួកគេបានរកព្រះអង្គឃើញនៅត្រើយម្ខាងនៃសមុទ្រហើយ ពួកគេនិយាយថាព្រះអង្គថា៖ «រ៉ាប៊ី ព្រះអង្គមកទីនេះពេលណា?»
[26]ព្រះយេស៊ូឆ្លើយទៅកាន់ពួកគេ ដោយបន្ទូលថា៖ «ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាស្វែងរកខ្ញុំ មិនមែនដោយចង់ឃើញទីសម្គាល់ទេ
ប៉ុន្តែដោយសារអ្នកចង់បរិភោគនំប៉័ង ហើយបានឆ្អែតប៉ុណ្ណោះ។[27]កុំធ្វើការដើម្បីឲ្យបានតែអាហារដែលពុករលួយ ប៉ុន្តែចូរធ្វើការដើម្បីឲ្យបានអាហារដែលស្ថិតស្ថេរ
ដើម្បីឲ្យបានជីវិតអស់កល្បជានិច្ច ដែលបុត្រមនុស្សនឹងផ្តល់ឲ្យ ដើម្បីព្រះជាម្ចាស់ជាព្រះវរបិតាបានបោះត្រារបស់ព្រះអង្គនៅលើគាត់។
[28]ពួកគេទូលតបទៅកាន់ព្រះអង្គវិញថា៖ «តើយើងត្រូវធ្វើអ្វី ដើម្បីឲ្យយើងអាចធ្វើការរបស់ព្រះជាម្ចាស់បាន?»[29]ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលទៅកាន់ពួកគេថា៖
«នេះគឺជាកិច្ចការរបស់ព្រះជាម្ចាស់៖ គឺថាអ្នករាល់គ្នាត្រូវជឿលើព្រះដែលព្រះអង្គបានចាត់មក»។
[30]ដូច្នេះ ពួកគេក៏ទូលទៅកាន់ព្រះអង្គថា៖ «តើលោកនឹងធ្វើទីសម្គាល់អ្វី ដើម្បីឲ្យយើងអាចឃើញ ហើយជឿលើលោកបាន?
[31]បុព្វបុរសរបស់យើងបានបរិភោគនំម៉ាណានៅឯទីរហោស្ថាន ដូចមានសេចក្តីចែងមកថា៖ «ព្រះអង្គបានប្រទាននំប៉័ងពីស្ថានសួគ៌មកដល់ពួកគេបរិភោគ»។
[32]បន្ទាប់មក ព្រះយេស៊ូមានបន្ទូលឆ្លើយទៅពួកគេថា៖ «ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មិនមែនលោកម៉ូសេទេ ដែលផ្តល់នំប៉័ងពីស្ថានសួគ៌ដល់អ្នករាល់គ្នា
ប៉ុន្តែ ព្រះបិតាខ្ញុំទៅវិញទេ ដែលបានប្រទាននំប៉័ងដ៏ពិតដែលមកពីស្ថានសួគ៌ដល់អ្នករាល់គ្នា។[33]ដ្បិត នំប៉័ងរបស់ព្រះជាម្ចាស់ដែលបានធ្លាក់ចុះពីស្ថានសួគ៌មកនោះ
នឹងផ្តល់ជីវិតដល់លោកីយ៍»។[34]ដូច្នេះ ពួកគេបានសួរព្រះអង្គថា «លោកម្ចាស់អើយ សូមឲ្យនំប៉័ងនេះដល់យើងរហូតមក»។
[35]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំនឹងមិនដែលស្រេកទៀតដែរ។[36]ប៉ុន្តែ
ខ្ញុំសូមប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាបានឃើញខ្ញុំ ហើយអ្នករាល់គ្នាមិនបានជឿដល់ខ្ញុំទេ។[37]អស់អ្នកណាដែលព្រះបិតាប្រទានដល់ខ្ញុំ នឹងមកឯខ្ញុំ
ហើយអស់អ្នកណាដែលមកឯខ្ញុំ ខ្ញុំនឹងមិនបោះបង់ចោលគេឡើយ។
[38]ដ្បិតខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែនដើម្បីធ្វើតាមចិត្តរបស់ខ្ញុំទេ ប៉ុន្តែធ្វើតាមព្រះហឫទ័យរបស់ព្រះដែលចាត់ខ្ញុំឲ្យមកវិញ។
[39]នេះគឺជាព្រះហឫទ័យរបស់ព្រះដែលចាត់ខ្ញុំឲ្យមក ដើម្បីកុំឲ្យខ្ញុំបាត់បង់នរណាម្នាក់ដែលព្រះអង្គបានប្រទានដល់ខ្ញុំឡើយ
ប៉ុន្តែនឹងប្រោសពួកគេឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ។[40]ដ្បិតនេះគឺជាព្រះហឫទ័យរបស់ព្រះបិតា ដែលថាមនុស្សគ្រប់គ្នាដែលបានឃើញព្រះបុត្រា
ហើយជឿលើព្រះអង្គនឹងមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំនឹងប្រោសឲ្យគាត់រស់ឡើងវិញនៅថ្ងៃចុងក្រោយ។
[41]ពួកយូដាបានរអ៊ូរទាំអំពីព្រះអង្គ ដោយសារទ្រង់មានបន្ទូលថា៖ «ខ្ញុំជានំប៉័ងដែលចុះពីស្ថានសួគ៌មក»។[42]ពួកគេនិយាយថា៖ «តើយេស៊ូនេះ
មិនមែនជាកូនរបស់លោកយ៉ូសែប យើងបានស្គាល់ឪពុកនិងម្តាយរបស់គាត់ទេឬអី? តើគាត់អាចនិយាយថា៖ «ខ្ញុំជានំប៉័ងដែលចុះមកពីស្ថានសួគ៌ដូចម្តេចនឹងកើត?»
[43]ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលទៅកាន់ពួកគេថា៖ «ឈប់រអ៊ូរទាំនៅក្នុងចំណោមអ្នករាល់គ្នាទៀតទៅ។[44]គ្មាននរណាអាចមកឯខ្ញុំបានទេ
លុះត្រាតែព្រះបិតាដែលបានចាត់ខ្ញុំមកឲ្យចូលទៅជិតគាត់ ហើយខ្ញុំនឹងប្រោសគាត់ឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ។[45]ដូចមានសេចក្តីចែងទុកក្នុងពួកព្យាការីថា៖
«ព្រះជាម្ចាស់នឹងបង្រៀនមនុស្សគ្រប់គ្នាដោយផ្ទាល់»។ មនុស្សគ្រប់គ្នាដែលបានឮ ហើយរៀនពីព្រះវរបិតានឹងមកឯខ្ញុំ។
[46]គ្មាននរណាម្នាក់បានឃើញព្រះបិតាឡើយ លើកលែងតែព្រះអង្គដែលមកពីព្រះជាម្ចាស់ ទ្រង់បានឃើញព្រះបិតា។[47]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
អស់អ្នកណាដែលជឿនឹងមានជីវិតអស់កល្ប។
[48]ខ្ញុំជានំប៉័ងជីវិត។[49]បុព្វបុរសរបស់អ្នករាល់គ្នាបានបរិភោគនំម៉ាណានៅក្នុងទីរហោស្ថាន ហើយពួកគេបានស្លាប់។
[50]នេះគឺជានំប៉័ងដែលមកពីស្ថានសួគ៌ ដើម្បីឲ្យអស់អ្នកដែលបានបរិភោគនំប៉័ងនេះ នឹងមិនស្លាប់ទេ។[51]ខ្ញុំជានំប៉័ងដ៏រស់ដែលមកពីស្ថានសួគ៌។ ប្រសិនបើ
អ្នកណាម្នាក់បរិភោគនំប៉័ងនេះ អ្នកនោះនឹងរស់នៅជារៀងរហូត។ នំប៉័ងដែលខ្ញុំនឹងឲ្យគឺជារូបកាយរបស់ខ្ញុំ សម្រាប់ជីវិតរបស់មនុស្សលោក។
[52]ពួកយូដាបានខឹងគ្នាទៅវិញទៅមក ហើយចាប់ផ្តើមឆ្លើយតប ដោយនិយាយថា៖
«តើបុរសនេះអាចឲ្យសាច់របស់ខ្ញុំមកយើងបរិភោគយ៉ាងដូចម្តេចកើត?»[53]បន្ទាប់មកព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
លុះត្រាតែអ្នកបរិភោគសាច់របស់កូនមនុស្ស ហើយផឹកឈាមរបស់គាត់ដែរ អ្នករាល់គ្នានឹងមិនអាចមានជីវិតនៅក្នុងអ្នករាល់គ្នាឡើយ។
[54]អស់អ្នកណាដែលបរិភោគសាច់ខ្ញុំ ហើយផឹកឈាមរបស់ខ្ញុំ នឹងមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំនឹងប្រោសអ្នកនោះឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ។
[55]ដ្បិតសាច់របស់ខ្ញុំគឺជាអាហារដ៏ពិត ហើយឈាមរបស់ខ្ញុំគឺជាភេសជ្ជៈដ៏ពិត។[56]អស់អ្នកណាដែលបរិភោគសាច់របស់ខ្ញុំ ហើយផឹកឈាមរបស់ខ្ញុំនឹងនៅជាប់ជាមួយខ្ញុំ
ហើយខ្ញុំនៅក្នុងអ្នកនោះ។
[57]ព្រះបិតាដែលចាត់ខ្ញុំមកមានព្រះជន្មរស់ ខ្ញុំក៏រស់ដោយសារព្រះបិតាដូចគ្នាដែរ ដូច្នេះអស់អ្នកណាដែលបរិភោគខ្ញុំ អ្នកនោះនឹងបានរស់ដោយសារខ្ញុំដែរ។
[58]នេះគឺជានំប៉័ងដែលចុះពីស្ថានសួគ៌មក មិនដូចជានំប៉័ងដែលបុព្វបុរសរបស់អ្នករាល់គ្នាដែលបរិភោគហើយស្លាប់នោះទេ។
អ្នកណាដែលបរិភោគនំប៉័ងនេះនឹងរស់នៅអស់កល្បជានិច្ច»។[59]ប៉ុន្តែព្រះយេស៊ូមានបន្ទូលការទាំងនេះនៅក្នុងសាលាប្រជុំ
អំឡុងពេលដែលព្រះអង្គបង្រៀននៅក្នុងកាពើណិម។
[60]បន្ទាប់មក ពួកសិស្សរបស់ព្រះអង្គជាច្រើនដែលបានឮព្រះអង្គមានបន្ទូលដូច្នេះ «នេះគឺជាសេចក្តីបង្រៀនដ៏ពិបាកមួយ
តើអ្នកណាអាចទទួលយកបាន?»[61]ដោយសារព្រះយេស៊ូជ្រាបនៅក្នុងអង្គទ្រង់ផ្ទាល់ថាពួកសិស្សទាំងនេះរអ៊ូរទាំពីការនេះ ទ្រង់មានបន្ទូលទៅកាន់ពួកគេថា៖
«តើការនេះធ្វើឲ្យអ្នករាល់គ្នារវាតចិត្តមែនទេ?
[62]ចុះទំរាំបើអ្នកឃើញបុត្រមនុស្សឡើងទៅកន្លែងដែលព្រះអង្គគង់នៅពីមុន?[63]គឺជាព្រះវិញ្ញាណដែលប្រទានជីវិត ហើយសាច់ឈាមគ្មានប្រយោជន៍អ្វីទាំងអស់។
ពាក្យដែលខ្ញុំបាននិយាយទៅកាន់អ្នករាល់គ្នាគឺជាវិញ្ញាណ ហើយពាក្យនោះគឺជាជីវិត។
[64]ប៉ុន្តែក្នុងចំណោមអ្នករាល់គ្នាមានអ្នកខ្លះមិនបានជឿទេ»។ ដ្បិតព្រះយេស៊ូជ្រាបតាំងពីដំបូងថា តើនរណាដែលអាចនឹងមិនជឿ ហើយអ្នកណាអាចនឹងក្បត់ព្រះអង្គ។
[65]ព្រះអង្គមានបន្ទូលថា៖ «ដោយសារការនេះហើយបានជាខ្ញុំនិយាយទៅកាន់អ្នករាល់គ្នាថា គ្មាននរណាម្នាក់មកឯខ្ញុំបានទេ លុះត្រាតែព្រះបិតាចាត់អ្នកនោះឲ្យមក»។
[66]ដោយសារហេតុនេះ ពួកសិស្សរបស់ព្រះអង្គជាច្រើនបានចាកចេញពីព្រះអង្គ ហើយលែងដើរតាមព្រះអង្គទៀត។[67]បន្ទាប់មក
ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកសិស្សទាំងដប់ពីរនាក់ថា៖ «អ្នករាល់គ្នាមិនចង់ចេញពីខ្ញុំដូចគេដែលទេឬ?»[68]លោកស៊ីម៉ូនពេត្រុសទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ
តើយើងគួរទៅតាមនរណា? ព្រះអង្គគឺជាព្រះបន្ទូលនៃជីវិតអស់កល្បជានិច្ច[69]ហើយយើងបានជឿ ហើយស្គាល់ថា ព្រះអង្គគឺជាព្រះដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។
[70]ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «តើមិនមែនខ្ញុំទេឬដែលជ្រើសរើសអ្នករាល់គ្នា ទាំងដប់ពីរនាក់នេះ
ហើយនឹងមានម្នាក់ក្នុងចំណោមអ្នករាល់គ្នាគឺជាមារ?»[71]ព្រះអង្គមានបន្ទូលពីលោកយូដាសកូនរបស់លោកស៊ីម៉ូន អ៊ីស្ការីយ៉ុត ដ្បិត
គាត់ហើយគឺជាម្នាក់ក្នុងចំណោមសិស្សទាំងដប់ពីរដែលក្បត់ព្រះយេស៊ូ។

generated on Wed Sep 10 16:16:32 2025

John 6:1
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃរឿង។
ព្រះយេស៊ូបានធ្វើដំណើរពីក្រុងយេរូសាឡឹមទៅកាលីឡេ។
ហ្វូងមនុស្សបានដើរតាមព្រះអង្គឡើងលើភ្នំ។
ខគម្ពីរទាំងនេះប្រាប់ពីការរៀបចំផ្នែកនៃរឿងនេះ។
បន្ទាប់ពីការនេះ
ឃ្លាថា“ របស់ទាំងនេះ” សំដៅទៅលើព្រឹត្តិការណ៍ក្នុងជំពូក៥ ខ១ ។
ព្រះយេស៊ូបានយាងចេញទៅ
វាបានបង្កប់ន័យនៅក្នុងអត្ថបទ ដែលព្រះយេស៊ូយាងតាមទូក
ហើយនាំសិស្សរបស់ព្រះអង្គទៅជាមួយ។
"ព្រះយេស៊ូបានធ្វើដំណើរតាមទូកជាមួយពួកសិស្សរបស់ព្រះអង្គ"
បណ្តាជនយ៉ាងច្រើនកោះករ
"មនុស្សមួយចំនួនធំ"
ទីសម្គាល់
សំដៅទៅលើការអស្ចារ្យ
ដែលត្រូវបានប្រើជាភស្តុតាងដែលបង្ហាញថាព្រះជាអ្នកមានឫទ្ធានុភាពខ្លាំងក្លាបំផុត
និងមានសិទ្ធិអំណាចពេញលេញលើអ្វីៗទាំងអស់។
John 6:4
ព័ត៌មានទូទៅ:
សកម្មភាពនៅក្នុងរឿងចាប់ផ្តើមនៅខ ៥ ។
ពិធីបុណ្យចម្លង ពិធីបុណ្យរបស់សាសន៍យូដាជិតមកដល់ហើយ
យ៉ូហាននិយាយខ្លីៗអំពីព្រឹត្តិការណ៍នៅក្នុងរឿងនេះ
ដើម្បីផ្តល់ព័ត៌មានអំពីសាវតាពេលព្រឹត្តិការណ៍កើតឡើង។
ព្រះយេស៊ូមានបន្ទូលបែបនេះ ដើម្បីល្បងលលោកភីលីពទេ ដ្បិតព្រះអង្គផ្ទាល់
ទ្រង់ជ្រាបថាអ្វីដែលព្រះអង្គត្រូវធ្វើហើយ
យ៉ូហាននិយាយខ្លីពីព្រឹត្តិការណ៍ក្នុងរឿងនេះ ដើម្បីពន្យល់ពីមូលហេតុ
ដែលព្រះយេស៊ូបានសួរភីលីពពីកន្លែងទិញនំបុ័ង។
ដ្បិតព្រះអង្គផ្ទាល់ ទ្រង់ជ្រាបថា
សព្វនាមឆ្លុះបញ្ចាំងថា "ខ្លួនគាត់" បញ្ជាក់យ៉ាងច្បាស់ថាពាក្យ "គាត់"
សំដៅទៅលើព្រះយេស៊ូ។ ព្រះយេស៊ូបានដឹងថាព្រះអង្គនឹងធ្វើអ្វី។
John 6:7
ទោះបីជាយកលុយកាក់ពីរយឧណារីទៅទិញនំបុ័ង
ពាក្យ "កាក់" គឺជាពហុវចនៈ។ "ចំនួននំបុ័ងដែលត្រូវចំណាយប្រាក់ឈ្នួលពីរយថ្ងៃ"
។
មាននំបុ័ងប្រាំដុំ
«នំបុ័ងប្រាំដុំ» ស្រូវបាលីជាគ្រាប់ធញ្ញជាតិធម្មតា។
ដុំ
នំបុ័ងមួយដុំ ធ្វើពីម្សៅមួយដុំ ដែលគេយកទៅដុតនំ។
តើធ្វើដូចម្តេចឲ្យគ្រប់បាន បើមនុស្សមានគ្នាច្រើនយ៉ាងនេះ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបញ្ជាក់ថាពួកគេពុំមានអាហារគ្រប់គ្រាន់សម្រាប់ចម្អែតមនុស្សគ្រប់គ្នាទេ។
"នំបុ័ងនិងត្រីនេះមិនគ្រប់គ្រាន់សម្រាប់ចម្អែតមនុស្សច្រើនទេ!"
John 6:10
អង្គុយចុះ
"ទម្រេតខ្លួន"
នៅទីនោះមានស្មៅច្រើន
យ៉ូហាននិយាយខ្លីៗអំពីព្រឹត្តិការណ៍នៅក្នុងរឿងនេះ
ដើម្បីផ្តល់ព័ត៌មានសំខាន់អំពីទីកន្លែង ដែលព្រឹត្តិការណ៍នេះកើតឡើង។
ដូច្នេះ បណ្តាជនក៏អង្គុយនៅទីនោះ មានគ្នាប្រហែលជាប្រាំពាន់អ្នក
ខណៈពេលហ្វូងមនុស្សប្រហែលជារាប់បញ្ចូលទាំងស្ត្រីនិងកុមារ (៦: ៤)
នៅទីនេះយ៉ូហានរាប់តែបុរសប៉ុណ្ណោះ។
អរព្រះគុណ
ព្រះយេស៊ូបានអធិស្ឋានទៅព្រះជាបិតា ហើយអរគុណព្រះអង្គចំពោះត្រីនិងនំបុ័ង។
ព្រះអង្គបានប្រទាន
"ព្រះអង្គ" នៅទីនេះតំណាងឲ្យ "ព្រះយេស៊ូនិងពួកសិស្សរបស់ព្រះអង្គ" ។
"ព្រះយេស៊ូនិងពួកសិស្សរបស់ព្រះអង្គបានឲ្យនំបុ័ង"
John 6:13
ព័ត៌មានទូទៅ:
ព្រះយេស៊ូដកខ្លួនចេញពីចំណោមបណ្តាជន។
នេះជាផ្នែកចុងបញ្ចប់នៃសាច់រឿងអំពីព្រះយេស៊ូ
ដែលប្រទានអាហារដល់ហ្វូងមនុស្សនៅលើភ្នំ។
ពួកគេបានប្រមូល
"ពួកសិស្សបានប្រមូលផ្តុំគ្នា"
នៅសល់
អាហារដែលគ្មាននរណាម្នាក់បានបរិភោគ
ការអស្ចារ្យ
ព្រះយេស៊ូបានចម្អែតមនុស្ស ៥.០០០ នាក់ដោយនំបុ័ងប្រាំដុំនិងត្រីពីរកន្ទុយ
គឺជាព្យាការី
ព្យាការីពិសេសដែលលោកម៉ូសេបាននិយាយនឹងចូលមកក្នុងពិភពលោកនេះ
John 6:16
ឃ្លាភ្ជាប់៖
នេះជាព្រឹត្តិការណ៍បន្ទាប់នៅក្នុងសាច់រឿង។
ពួកសិស្សរបស់ព្រះយេស៊ូចេញទៅឯបឹងតាមទូក។
នៅពេលនេះងងឹតហើយ ព្រះយេស៊ូមិនទាន់បានយាងទៅរកពួកគេនៅឡើយទេ
ប្រើពាក្យក្នុងភាសារបស់អ្នក ដើម្បីបង្ហាញថានេះជាព័ត៌មានសំខាន់។
John 6:19
ពួកគេចែវទូក
ជាធម្មតា ទូកមានមនុស្ស២ ៤ ឬ៦នាក់ចែវនៅសងខាងធ្វើការជាមួយគ្នា។
វប្បធម៌របស់អ្នកអាចមានវិធីផ្សេងៗគ្នាក្នុងការឲ្យទូកឆ្លងទឹកទៅកន្លែងមួយ។
ចម្ងាយប្រហែលជាប្រាំ ឬប្រាំមួយគីឡូម៉ែត្រ
ប្រហែលជាប្រាំ ឬប្រាំមួយគីឡូម៉ែត្រ - កីឡដ្ឋានមួយមានប្រវែង ១៨៥ ម៉ែត្រ។
"ប្រហែលប្រាំឬប្រាំមួយគីឡូម៉ែត្រ"
កុំខ្លាចអី
"កុំខ្លាចអី!"
ពួកគេចង់ទទួលព្រះអង្គមកក្នុងទូក
បញ្ជាក់ថា ព្រះយេស៊ូបានចូលទៅក្នុងទូក។
"ពួកគេបានទទួលព្រះអង្គចូលក្នុងទូកដោយរីករាយ"
John 6:22
សមុទ្រ
“ សមុទ្រកាលីឡេ”
ក៏មានទូកមក.....ព្រះអង្គអរព្រះគុណ
ប្រើវិធីភាសារបស់អ្នកដើម្បីបង្ហាញថានេះជាព័ត៌សំខាន់។
ទូកមកពីក្រុងទីបេរាស
នៅទីនេះ យ៉ូហានផ្តល់ជូននូវព័ត៌សំខាន់បន្ថែមទៀត។
នៅថ្ងៃបន្ទាប់ក្រោយពីព្រះយេយេស៊ូបាន ប្រទានអាហារដល់បណ្តាជន
មានទូកខ្លះរួមជាមួយប្រជាជនមកពីទីបេរៀសបានមកជួបព្រះយេស៊ូ។
ប៉ុន្តែព្រះយេស៊ូនិងសិស្សរបស់ព្រះអង្គបានចាកចេញពីយប់មុនទៅហើយ។
John 6:24
ព័ត៌មានទូទៅ:
ប្រជាជននាំគ្នាទៅក្រុងកាពើណិមដើម្បីរកព្រះយេស៊ូ។
នៅពេលពួកគេឃើញព្រះអង្គ ពួកគេចាប់ផ្តើមសួរសំណួរព្រះអង្គ។
John 6:26
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩។
ជីវិតអស់កល្បជានិច្ច ដែលបុត្រមនុស្សនឹងផ្តល់ឲ្យ
ដើម្បីព្រះជាម្ចាស់ជាព្រះវរបិតាបានបោះត្រារបស់ព្រះអង្គនៅលើគាត់
ព្រះជាម្ចាស់ជាព្រះបិតាបានយល់ព្រមជាមួយព្រះយេស៊ូជាបុត្រមនុស្ស
ដើម្បីប្រទានជីវិតអស់កល្បជានិច្ចដល់អស់អ្នកដែលជឿលើព្រះអង្គ។
បុត្រមនុស្ស.....ព្រះវរបិតា
ទាំងនេះគឺជាឋានៈសំខាន់ៗ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះយេស៊ូ
និងព្រះជាម្ចាស់ ។
បានបោះត្រារបស់ព្រះអង្គនៅលើគាត់
ដើម្បី "ដាក់ត្រា" លើអ្វីមួយមានន័យថាដាក់សញ្ញាសម្គាល់លើវា
ដើម្បីបង្ហាញថាវាជារបស់អ្នកណា។ មានន័យថា
ព្រះបុត្រាជាកម្មសិទ្ធិរបស់ព្រះបិតាហើយព្រះបិតាយល់ព្រមឲ្យគាត់តាមគ្រប់មធ្យោបាយ។
John 6:28
កិច្ចការ ការប្រព្រឹត្ត ធ្វើការ ការងារ

generated on Wed Sep 10 16:16:32 2025

នៅក្នុងព្រះគម្ពីរពាក្យ «កិច្ចការ» «ការប្រព្រឹត្ត» «ធ្វើការ» «ការងារ»
ប្រើជាទូទៅសំដៅទៅលើកិច្ចការ ដែលព្រះជាម្ចាស់ និងមនុស្សធ្វើ។
ពាក្យ «កិច្ចការ» សំដៅទៅលើការបំពេញការងារ
ឬធ្វើអ្វីមួយក្នុងគោលបំណងបម្រើប្រយោជន៍មនុស្សដ៏ទៃទៀត។
«កិច្ចការរបស់ព្រះជាម្ចាស់»
និង«ស្នាព្រះហស្តរបស់ព្រះជាម្ចាស់»សំដៅទៅលើការងារដែលព្រះជាម្ចាស់បានធ្វើរួមមាន
ការបង្កើតពិភពលោក សង្គ្រោះបាបជន
បំពេញសេចក្តីត្រូវការដល់របស់ដែលព្រះអង្គបានបង្កើត ថែរក្សាពិភពលោក។ ពាក្យ
«ការប្រព្រឹត្ត» និង«ការងារ»សំដៅទៅការអស្ចារ្យ ដែលព្រះជាម្ចាស់បានធ្វើ
ដូចជា«ការធ្វើការអស្ចារ្យរបស់ព្រះជាម្ចាស់»។ ការងារដែលមនុស្សម្នាក់បានធ្វើ
អាចជាការប្រព្រឹត្តល្អ និងមិនល្អ។ ព្រះវិញ្ញាណដ៏វិសុទ្ធចម្រើនកម្លាំងដល់អ្នកជឿ
ឲ្យធ្វើការងារល្អគ្រប់យ៉ាង ដែលយើងហៅថា «ផលផ្លែល្អ»។
មនុស្សពុំមែនបានសង្គ្រោះដោយការប្រព្រឹត្តល្អទេ
ប៉ុន្តែដោយសារជំនឿលើព្រះយេស៊ូវិញ។ «ការងារ»របស់បុគ្គលម្នាក់
អាចជាការងាររកប្រាក់ផ្គត់ផ្គង់គ្រួសារ ឬបម្រើព្រះជាម្ចាស់។
ព្រះគម្ពីរក៏សំដៅទៅលើព្រះជាម្ចាស់ថា ជាការបម្រើការងារដែរ។
ជឿ ជឿលើ ជំនឿ
ពាក្យ «ជឿ» «ជឿលើ» និង«ជំនឿ»មានទំនាក់ទំនងគ្នា តែមានន័យខុសគ្នាបន្តិច។
«ជឿ»ជាកិរិយាស័ព្ទអាចបកប្រែថា «ដឹងថាពិត» ឬ«ដឹងថាត្រឹមត្រូវ»។
ចំណែកឯពាក្យ«ជឿលើ»វិញ បកប្រែថា «ជឿទុកចិត្តទាំងស្រុង» ឬ«ទុកចិត្ត
និងស្តាប់បង្គាប់» ឬ«ពឹងផ្អែកទាំងស្រុង និងធ្វើតាម»។
ចាត់/ធ្វើ ចាត់បញ្ជូន បានចាត់
ពាក្យ«ចាត់»មានន័យថា បណ្តាលឲ្យនរណាម្នាក់ ឬអ្វីមួយទៅកន្លែងណាមួយ។
ពាក្យ«ចាត់បញ្ជូន»មានន័យថា នរណាម្នាក់ប្រាប់នរណាម្នាក់ទៀត
ឲ្យចេញទៅបំពេញការងារ ឬបេសកកម្ម។
ជាទូទៅ ម្នាក់ដែលត្រូវគេ«ចាត់បញ្ជូន»ទៅ
ទទួលការតែងតាំងឲ្យទៅបំពេញការងារជាក់ណាមួយ។
ឃ្លា«បង្អុរភ្លៀង»ឬ«បញ្ជូនគ្រោះមហន្តរាយ»
ជាទូទៅសំដៅលើព្រះជាម្ចាស់បណ្តាលឲ្យហេតុការណ៍នេះកើតឡើង។
ពាក្យ«ផ្ញើ»ប្រើសម្រាប់«ផ្ញើពាក្យ» ឬ«ផ្ញើសារ»
ដើម្បីប្រាប់ដំណឹងដល់នរណាម្នាក់។ ពាក្យ«ផ្ញើ»របស់អ្វីមួយតាមនរណាម្នាក់
មានន័យថា
«ឲ្យរបស់នោះទៅនរណាម្នាក់»ដើម្បីយកទៅឲ្យនរណាម្នាក់ផ្សេងទៀត។
ព្រះយេស៊ូតែងប្រើពាក្យ«ម្នាក់ដែលបានចាត់ខ្ញុំ»សំដៅទៅព្រះបិតា
ដែល«បានចាត់»ព្រះអង្គ ឲ្យយាងមកផែនដី ដើម្បីប្រោសលោះ
និងសង្គ្រោះមនុស្សលោក។ អាចបកប្រែថា «បញ្ជូនទៅបេសកកម្ម»មានន័យថា
«បណ្តាលឲ្យខ្ញុំចេញទៅ» ឬ«តែងតាំងខ្ញុំឲ្យចេញទៅ»។
John 6:30
បុព្វបុរស
"បុព្វបុរស" ឬ "ដូនតា"
ស្ថានសួគ៌
នេះសំដៅទៅលើកន្លែងដែលព្រះជាម្ចាស់គង់នៅ។
John 6:32
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩ ។
ព្រះបិតាខ្ញុំទៅវិញទេ ដែលបានប្រទាននំបុ័ងដ៏ពិតដែលមកពីស្ថានសួគ៌ដល់អ្នករាល់គ្
«នំបុ័ងពិត»គឺជាពាក្យប្រៀបធៀបទៅព្រះយេស៊ូ។ “ ព្រះបិតាប្រទានដល់អ្នក
នូវព្រះបុត្រាដែលជានំបុ័ងពិតពីលើស្ថានសួគ៌”
ព្រះបិតាខ្ញុំ
នេះជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ផ្តល់ជីវិតដល់លោកីយ៍
"ផ្តល់ជីវិតខាងវិញ្ញាណដល់លោកីយ៍"
លោកីយ៍
ពាក្យ “ លោកីយ”នៅទីនេះ
ជាពាក្យពិពណ៌នាសម្រាប់មនុស្សទាំងអស់នៅលើពិភពលោក
ដែលទុកចិត្តលើព្រះយេស៊ូ។
John 6:35
ខ្ញុំជានំបុ័ងជីវិត
តាមរយៈការប្រៀបធៀបនេះ ព្រះយេស៊ូប្រៀបដូចជានំបុ័ង។
ដូចជានំបុ័ងផ្តល់សារសំខាន់ដល់រូបកាយរបស់យើងយ៉ាងណា
ព្រះយេស៊ូក៏មានសារសំខាន់សម្រាប់ជីវិតខាងវិញ្ញាណរបស់យើងយ៉ាងនោះដែរ។
"ដូចជាម្ហូបអាហារជួយឲ្យអ្នកមានជីវិតរាងកាយយ៉ាងណា
ខ្ញុំអាចផ្តល់ជីវិតខាងវិញ្ញាណយ៉ាងនោះដែរ" ។
ជឿដល់
ឃ្លានេះមានន័យថា ជឿថាព្រះយេស៊ូជាព្រះបុត្រានៃព្រះ ទុកចិត្តព្រះអង្គជាព្រះអង្គសង្គ្រោះ
និងរស់នៅតាមរបៀបដែលគោរពព្រះអង្គ។
អស់អ្នកណាដែលព្រះបិតាប្រទានដល់ខ្ញុំ នឹងមកឯខ្
ព្រះជាម្ចាស់ដែលជាព្រះបិតា
និងព្រះបុត្រានឹងជួយសង្គ្រោះអស់អ្នកដែលជឿលើព្រះយេស៊ូ។ ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។ ។
អស់អ្នកណាដែលមកឯខ្ញុំ ខ្ញុំនឹងមិនបោះបង់ចោលគេឡើយ
ប្រយោគនេះនិយាយផ្ទុយពីអត្ថន័យ ដែលបានបញ្ជាក់ប្រាប់។
"ខ្ញុំនឹងរក្សាមនុស្សគ្រប់គ្នាដែលមករកខ្ញុំ"
John 6:38
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ហ្វូងមនុស្ស។
ព្រះដែលចាត់ខ្ញុំឲ្យមក
«ព្រះបិតាខ្ញុំដែលបានចាត់ខ្ញុំឲ្យមក»
ដើម្បីកុំឲ្យខ្ញុំបាត់បង់នរណាម្នាក់ដែលព្រះអង្គបានប្រទានដល់ខ្ញុំឡើយ
ប្រើនៅទីនេះបញ្ជាក់ថា
ព្រះយេស៊ូនឹងរក្សាមនុស្សទាំងអស់ដែលព្រះអង្គប្រទានមកឲ្យព្រះយេស៊ូ។
"ខ្ញុំគួរតែរក្សាទុកទាំងអស់"
John 6:41
ឃ្លាភ្ជាប់៖
អ្នកដឹកនាំជនជាតិយូដាបានបង្អាក់ព្រះយេស៊ូ
ពេលព្រះអង្គកំពុងមានបន្ទូលទៅកាន់បណ្តាជន។
រអ៊ូរទាំ
និយាយដោយមិនសប្បាយចិត្ត
ខ្ញុំជានំបុ័ង
ដូចជានំបុ័ងមានសារសំខាន់ចំពោះជីវិតខាងរូបកាយរបស់យើង
ព្រះយេស៊ូមានសារសំខាន់ចំពោះជីវិតខាងវិញ្ញាណរបស់យើង។ "ខ្ញុំជាជានំបុ័ងពិត"
។ សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក៦ ខ៣៥ ។
តើយេស៊ូនេះ ...យើងបានស្គាល់ឪពុកនិងម្តាយរបស់គាត់ទេឬអី?
ការកត់សម្គាល់នេះលេចចេញជាទម្រង់សំនួរ ដើម្បីបញ្ជាក់ថា
មេដឹកនាំយូដាជឿថាព្រះយេស៊ូមិនមែនជាមនុស្សពិសេសនោះទេ។ “
នេះគ្រាន់តែជាព្រះយេស៊ូជាកូនប្រុសរបស់យ៉ូសែប
ដែលយើងស្គាល់ឪពុកនិងម្តាយគាត់!
តើគាត់អាចនិយាយថា៖ «ខ្ញុំជានំបុ័ងដែលចុះមកពីស្ថានសួគ៌ដូចម្តេចនឹងកើត?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំនួរ ដើម្បីបញ្ជាក់ថា
មេដឹកនាំសាសន៍យូដាមិនជឿថាព្រះយេស៊ូយាងមកពីស្ថានបរមសុខទេ។
"ទ្រង់កំពុងនិយាយកុហក ពេលព្រះអង្គមានបន្ទូលថាខ្លួនមកពីស្ថានសួគ៌!"
John 6:43
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ហ្វូងមនុស្ស
ហើយឥឡូវនេះក៏មានបន្ទូលទៅកាន់ពួកមេដឹកនាំសាសន៍យូដាដែរ។
បានចាត់ខ្ញុំមក
អាចមានន័យថា ១) "ទាញ" ឬ ២) "ទាក់ទាញ" ។
ដូចមានសេចក្តីចែងទុកក្នុងពួកព្យាការីថា
ជាឃ្លាកិរិយាអកម្ម ដែលអាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ពួកព្យាការីបានសរសេរ"
មនុស្សគ្រប់គ្នាដែលបានឮ ហើយរៀនពីព្រះវរបិតានឹងមកឯខ្ញុំ
ជនជាតិយូដាគិតថា ព្រះយេស៊ូជា "កូនប្រុសរបស់យ៉ូសែប" (សូមមើលជំពូក៦
ខ៤១) ប៉ុន្តែទ្រង់ជាព្រះបុត្រានៃព្រះជាម្ចាស់ ព្រោះឪពុករបស់គាត់ជាព្រះជាម្ចាស់
ពុំមែនយ៉ូសែបទេ។ អ្នកដែលបានស្គាល់ព្រះបិតាជឿលើព្រះយេស៊ូ
ដែលជាព្រះបុត្រា។
ព្រះបិតា
ជាមុខងារសំខាន់ចំពោះព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

John 6:46
ឃ្លាភ្ជាប់៖
ឥឡូវនេះ
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ហ្វូងមនុស្សនិងពួកមេដឹកនាំសាសន៍យូដា។
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩។
គ្មាននរណាម្នាក់បានឃើញព្រះបិតាឡើយ លើកលែងតែព្រះអង្គដែលមកពីព្រះជាម្ចាស់
ទោះបីគ្មានមនុស្សណានៅលើផែនដីបានឃើញព្រះបិតា
តែព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់បានឃើញព្រះបិតា។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់ ។
អស់អ្នកណាដែលជឿនឹងមានជីវិតអស់កល្ប
ព្រះជាម្ចាស់ប្រទានជីវិតអស់កល្បជានិច្ច
ដល់អស់អ្នកដែលជឿលើព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។
John 6:48
ខ្ញុំជានំបុ័ងជីវិត
ដូចជានំបុ័ងផ្តល់សារសំខាន់ដល់រូបកាយរបស់យើង យ៉ាងណា
ព្រះយេស៊ូមានសារសំខាន់សម្រាប់ជីវិតខាងវិញ្ញាណរបស់យើងយ៉ាងនោះដែរ។
"ដូចជាម្ហូបអាហារជួយឲ្យអ្នកមានជីវិតរាងកាយយ៉ាងណា
ខ្ញុំអាចផ្តល់ជីវិតខាងវិញ្ញាណយ៉ាងនោះដែរ" ។ សូមមើលការបកប្រែនៅក្នុងជំពូក ៦ ខ៣៥ ។
បុព្វបុរស
"បុព្វបុរស" ឬ "ដូនតា"
ស្លាប់
សំដៅទៅលើការស្លាប់ខាងរូបកាយ។
John 6:50
គឺជានំបុ័ង
នៅទីនេះ“ នំបុ័ង” ជាពាក្យប្រៀបធៀប ដែលចង្អុលបង្ហាញថា
ព្រះយេស៊ូផ្តល់ជីវិតខាងវិញ្ញាណដូចជានំបុ័ងទ្រទ្រង់ជីវិតខាងរូបកាយដែរ។
"ខ្ញុំដូចជានំបុ័ងដ៏ពិត"
មិនស្លាប់ទេ
"រស់នៅជារៀងរហូត។" ត្រង់នេះពាក្យថាស្លាប់សំដៅទៅលើការស្លាប់ខាងវិញ្ញាណ។
នំបុ័ងដ៏រស់
មានន័យថា“ នំបុ័ងដែលធ្វើឲ្យមនុស្សមានជីវិត” (ជំពូក៦ ខ៣៥) ។
សម្រាប់ជីវិតរបស់មនុស្សលោក
នៅទីនេះ“ ពិភពលោក” ជាការប្រៀបធៀប
ដែលតំណាងឲ្យជីវិតរបស់ប្រជាជនទាំងអស់នៅលើពិភពលោក។
"ដែលនឹងផ្តល់ជីវិតដល់ប្រជាជនទាំងអស់នៅលើពិភពលោក"
John 6:52
ឃ្លាភ្ជាប់៖
ជនជាតិយូដាខ្លះ ដែលមានវត្តមានចាប់ផ្តើមឈ្លោះប្រកែកគ្នា ក្នុងចំណោមពួកគេ
ហើយព្រះយេស៊ូឆ្លើយតបសំណួររបស់ពួកគេ។
តើបុរសនេះអាចឲ្យសាច់របស់ខ្ញុំមកយើងបរិភោគយ៉ាងដូចម្តេចកើត?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំនួរ ដើម្បីបញ្ជាក់ថា
មេដឹកនាំសាសន៍យូដាកំពុងមានប្រតិកម្មអវិជ្ជមាន
ចំពោះអ្វីដែលព្រះយេស៊ូបានមានបន្ទូលអំពី“ សាច់ឈាមរបស់ព្រះអង្គ” ។
"គ្មានវិធីណាដែលបុរសនេះអាចឲ្យសាច់ឈាមរបស់គាត់មកបរិភោគបានទេ!"
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩ ។
បរិភោគសាច់របស់កូនមនុស្ស ហើយផឹកឈាមរបស់គាត់ដែរ
ឃ្លាថា“ បរិភោគសាច់” និង“ ផឹកឈាមរបស់គាត់” ជាពាក្យប្រៀបធៀប
ដែលបង្ហាញពីការជឿទុកចិត្តលើព្រះយេស៊ូជាកូនមនុស្ស
ពោលគឺដូចជាការទទួលអាហារនិងភេសជ្ជៈខាងវិញ្ញាណ។ ទទួលកូនមនុស្ស
ដូចដែលអ្នកបានទទួលម្ហូបនិងភេសជ្ជៈដែរ”
អ្នករាល់គ្នានឹងមិនអាចមានជីវិតនៅក្នុងអ្នករាល់គ្នាឡើយ
"អ្នកនឹងមិនទទួលបានជីវិតអស់កល្បជានិច្ចទេ"
John 6:54
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់អស់អ្នកដែលស្តាប់ព្រះអង្គ។
អស់អ្នកណាដែលបរិភោគសាច់ខ្ញុំ ហើយផឹកឈាមរបស់ខ្ញុំ នឹងមានជីវិតអស់កល្បជានិច្ច
ឃ្លា "បរិភោគសាច់របស់ខ្ញុំ" និង "ផឹកឈាមរបស់ខ្ញុំ" ជាពាក្យប្រៀបធៀប។
ដូចគ្នានឹងមនុស្សម្នាក់ត្រូវការអាហារនិងភេសជ្ជៈ ដើម្បីមានជីវិតយ៉ាងណា
អ្នកដែលជឿលើព្រះយេស៊ូនឹងមានជីវិតខាងវិញ្ញាណយ៉ាងនោះដែរ។
«អ្នកណាជឿលើខ្ញុំទទួលអាហារ
និងភេសជ្ជៈខាងវិញ្ញាណអ្នកនោះនឹងមានជីវិតអស់កល្បជានិច្ច»
នៅថ្ងៃចុងក្រោយ
"នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សទាំងអស់"
ដ្បិតសាច់របស់ខ្ញុំគឺជាអាហារដ៏ពិត ហើយឈាមរបស់ខ្ញុំគឺជាភេសជ្ជៈដ៏ពិត
ពាក្យថា «អាហារពិត» និង«ភេសជ្ជៈពិត» ជាពាក្យប្រៀបធៀប
ដែលមានន័យថាព្រះយេស៊ូផ្តល់អាហារខាងវិញ្ញាណនិងភេសជ្ជៈដល់អ្នកដែលទុកចិត្តលើព្រះអង្គ។
ការទទួលព្រះយេស៊ូដោយជំនឿ ផ្តល់ជីវិតអស់កល្បជានិច្ច
ដូចគ្នានឹងអាហារនិងភេសជ្ជៈ ដែលចិញ្ចឹមរាងកាយ។
"ខ្ញុំពិតជាអាហារនិងភេសជ្ជៈខាងវិញ្ញាណ"
នៅជាប់ជាមួយខ្ញុំ ហើយខ្ញុំនៅក្នុងអ្នកនោះ
"មានទំនាក់ទំនងជិតស្និទ្ធជាមួយខ្ញុំ"
John 6:57
ដូច្នេះអស់អ្នកណាដែលបរិភោគខ្ញុំ
"អ្នកដែលទុកចិត្តលើខ្ញុំ"
ព្រះបិតា
អាចមានន័យថា ១)“ ព្រះបិតាដែលប្រទានជីវិត” ឬ ២)“
ព្រះបិតាដែលមានព្រះជន្មគង់នៅ” ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
នេះគឺជានំបុ័ងដែលចុះពីស្ថានសួគ៌មក
"នំបុ័ង" ជាពាក្យប្រៀបធៀប សម្រាប់ព្រះយេស៊ូដែលយាងមកពីស្ថានសួគ៌។
"ខ្ញុំដូចជានំបុ័ងមកពីស្ថានសួគ៌"
អ្នកណាដែលបរិភោគនំបុ័ងនេះ
នេះជាពាក្យប្រៀបធៀប។ អ្នកដែលជឿជាក់លើព្រះយេស៊ូទទួលជីវិតខាងវិញ្ញាណ
ប្រៀបដូចអ្នកដែលពឹងផ្អែកលើនំបុ័ង ជាអាហារខាងរាងកាយរបស់ពួកគេ។
"អ្នកណាជឿទុកចិត្តលើខ្ញុំ"
បុព្វបុរស
"បុព្វបុរស" ឬ "ដូនតា"
ព្រះយេស៊ូមានបន្ទូលការទាំងនេះនៅក្នុងសាលាប្រជុំ
អំឡុងពេលដែលព្រះអង្គបង្រៀននៅក្នុងកាពើណិម
នៅទីនេះយ៉ូហានផ្តល់ព័ត៌មានអំពីប្រវត្តិ ពេលព្រឹត្តិការណ៍នេះកើតឡើង។
John 6:60
ឃ្លាភ្ជាប់៖
សិស្សខ្លះសួរសំណួរ ហើយព្រះយេស៊ូតបឆ្លើយ
ពេលព្រះអង្គកំពុងមានបន្ទូលទៅកាន់បណ្តាជន។
តើអ្នកណាអាចទទួលយកបាន?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំនួរ
ដើម្បីបញ្ជាក់ថាពួកសិស្សពិបាកយល់ពីអ្វី ដែលព្រះយេស៊ូមានបន្ទូល។
"គ្មាននរណាម្នាក់អាចទទួលយកបាន" ឬ "វាពិបាកយល់ណាស់!"
តើការនេះធ្វើឲ្យអ្នករាល់គ្នារវាតចិត្តមែនទេ?
"តើការនេះធ្វើឲ្យអ្នកភ្ញាក់ផ្អើលទេ?" ឬ "តើនេះធ្វើឲ្យអ្នកខកចិត្ត?"
John 6:62
ចុះទំរាំបើអ្នកឃើញបុត្រមនុស្សឡើងទៅកន្លែងដែលព្រះអង្គគង់នៅពីមុន?
ព្រះយេស៊ូផ្តល់នូវការកត់សម្គាល់នេះជាទម្រង់សំណួរដើម្បីបញ្ជាក់ថា
សិស្សរបស់ទ្រង់នឹងឃើញរឿងផ្សេងទៀតពិបាកយល់ដែរ។
"ពេលនោះអ្នកនឹងមិនដឹងថា ត្រូវគិតយ៉ាងម៉េច
ពេលអ្នកឃើញខ្ញុំជាកូនមនុស្សឡើងទៅស្ថានបរមសុខ!"
ប្រយោជន៍
ពាក្យថា“ ប្រយោជន៍” មានន័យថាធ្វើឲ្យមានរឿងល្អកើតឡើង។
ពាក្យ
"ពាក្យ" ជាឈ្មោះហៅក្រៅដែលអាចមានន័យថា៖ ១)
ពាក្យរបស់ព្រះយេស៊ូនៅក្នុង៦:៣២ ឬ ២)
អ្វីគ្រប់យ៉ាងដែលព្រះយេស៊ូបានបង្រៀន។
ពាក្យដែលខ្ញុំបាននិយាយទៅកាន់អ្នករាល់គ្នា

generated on Wed Sep 10 16:16:32 2025

"អ្វីដែលខ្ញុំបានប្រាប់អ្នក"
គឺជាវិញ្ញាណ ហើយពាក្យនោះគឺជាជីវិត
អាចមានន័យថា ១) "គឺអំពីព្រះវិញ្ញាណនិងជីវិតអស់កល្បជានិច្ច" ឬ ២)
"មកពីព្រះវិញ្ញាណហើយផ្តល់ជីវិតអស់កល្បជានិច្ច" ឬ ៣)
"គឺនិយាយអំពីរឿងខាងវិញ្ញាណនិងជីវិត" ។
John 6:64
ឃ្លាភ្ជាប់៖
ព្រះយេស៊ូឈប់មានបន្ទូលទៅកាន់ហ្វូងមនុស្ស។
ដ្បិតព្រះយេស៊ូជ្រាបតាំងពីដំបូងថា តើនរណាដែលអាចនឹងមិនជឿ
ហើយអ្នកណាអាចនឹងក្បត់ព្រះអង្គ
នៅទីនេះយ៉ូហានផ្តល់ព័ត៌មានអំពីអ្វី ដែលព្រះយេស៊ូជ្រាបថានឹងកើតឡើង។
គ្មាននរណាម្នាក់មកឯខ្ញុំបានទេ លុះត្រាតែព្រះបិតាចាត់អ្នកនោះឲ្យមក»
អ្នកណាជឿត្រូវចូលមកជិតព្រះជាម្ចាស់ តាមរយៈព្រះបុត្រា។
មានតែព្រះបិតាតែមួយគត់ ដែលអនុញ្ញាតឲ្យមនុស្សមករកព្រះយេស៊ូ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។ ។
មកឯខ្ញុំ
"មកតាមខ្ញុំនឹងទទួលបានជីវិតអស់កល្បជានិច្ច"
John 6:66
ព្រះអម្ចាស់អើយ តើយើងគួរទៅតាមនរណា?
ស៊ីម៉ូនពេត្រុសផ្តល់នូវការកត់សម្គាល់នេះជាទម្រង់សំណួរដើម្បីបញ្ជាក់ថា
គាត់ចង់ដើរតាមព្រះយេស៊ូតែប៉ុណ្ណោះ។ "ព្រះអម្ចាស់
យើងមិនអាចដើរតាមនរណាម្នាក់បានទេលើកលែងតែព្រះអង្គ!
សិស្សរបស់ព្រះអង្គ
ត្រង់នេះ«ពួកសិស្សរបស់ទ្រង់»សំដៅទៅលើក្រុមមនុស្សទូទៅដែលបានដើរតាមព្រះយេស៊ូ។
សិស្សទាំងដប់
"ពួកសិស្សទាំងដប់ពីរនាក់" ជាក្រុមជាក់លាក់មានបុរសដប់ពីរនាក់
ដែលបានដើរតាមព្រះយេស៊ូបម្រើព័ន្ធកិច្ចទាំងមូលរបស់ព្រះអង្គ។
"សិស្សទាំងដប់ពីរនាក់"
John 6:70
ព័ត៌មានទូទៅ:
ខគម្ពីរ ៧១
មិនមែនជាផ្នែកនៃសាច់រឿងសំខាន់ដូចដែលយ៉ូហានបានលើកឡើងអំពីអ្វី
ដែលព្រះយេស៊ូមានបន្ទូលនោះទេ។
តើមិនមែនខ្ញុំទេឬដែលជ្រើសរើសអ្នករាល់គ្នា ទាំងដប់ពីរនាក់នេះ
ហើយនឹងមានម្នាក់ក្នុងចំណោមអ្នករាល់គ្នាគឺជាមារ?
ព្រះយេស៊ូមានបន្ទូលជាទម្រង់សំណួរ ដើម្បីទាក់ទាញការចាប់អារម្មណ៍ថា
សិស្សម្នាក់នឹងក្បត់ព្រះអង្គ។ "ខ្ញុំបានជ្រើសរើសអ្នកទាំងអស់គ្នាដោយខ្លួនឯង
ប៉ុន្តែម្នាក់ក្នុងចំណោមអ្នក ជាអ្នកបម្រើរបស់សាតាំង!"

---

7 [1]បន្ទាប់ពីការទាំងនេះហើយ ព្រះយេស៊ូបានធ្វើដំណើរទៅកាលីឡេ ព្រោះព្រះអង្គមិនចង់ចូលទៅក្នុងស្រុកយូដា ដោយសារពួកយូដាកំពុងស្វែងរកធ្វើឃាតព្រះអង្គ។
[2]ឥឡូវនេះ ពិធីបុណ្យជម្រកបានជិតមកដល់ហើយ។
[3]ដូច្នេះ ប្អូនប្រុសៗរបស់ព្រះអង្គនិយាយទៅកាន់ព្រះអង្គថា៖ «ចូរចេញពីទីនេះ ហើយទៅស្រុកយូដាទៅ ដើម្បីឲ្យពួកសិស្សរបស់បងបានឃើញពីកិច្ចការដែលបងឯងធ្វើ។
[4]គ្មាននរណាអាចធ្វើអ្វីអាថ៌កំបាំងបានទេ ប្រសិនបើ គេចង់បើកឲ្យអ្នកដទៃដឹងជាសាធារណៈនោះ។ ប្រសិនបើ បងឯងធ្វើការទាំងនេះ
ចូរបងខ្លួនឯងបង្ហាញឲ្យមនុស្សលោកបានឃើញទៅ»។
[5]ដ្បិត សូម្បីតែប្អូនៗប្រុសរបស់ព្រះអង្គមិនបានជឿលើព្រះអង្គទេ។[6]ដូច្នេះហើយ បានជាព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «មិនទាន់ដល់ពេលបងនៅឡើយទេ ប៉ុន្តែ
ពេលវេលាប្អូនៗវិញរួចរាល់ជានិច្ច។[7]មនុស្សលោកមិនស្អប់ប្អូនៗទេ ប៉ុន្តែ មនុស្សលោកស្អប់បងដោយសារ បងធ្វើបន្ទាល់ពីមនុស្សលោកថា
កិច្ចការរបស់មនុស្សលោកអាក្រក់។
[8]អ្នករាល់គ្នាចូលទៅចូលរួមបុណ្យទៅ បងមិនទៅបុណ្យនេះទេ ព្រោះពេលវេលារបស់បងមិនទាន់បានសម្រេចនៅឡើយទេ»។
[9]បន្ទាប់ពីព្រះអង្គមានបន្ទូលទៅកាន់ពួកគេពីការទាំងនេះហើយ ព្រះអង្គស្នាក់នៅក្នុងកាលីឡេដែរ។
[10]ប៉ុន្តែ នៅពេលប្អូនៗរបស់ព្រះអង្គបានទៅចូលរួមពិធីបុណ្យហើយ ព្រះអង្គក៏ឡើងទៅដែរ ប៉ុន្តែព្រះអង្គទៅដោយសម្ងាត់វិញ មិនទៅដោយបើកចំហទេ។
[11]ពួកយូដាស្វែងរកព្រះអង្គនៅថ្ងៃបុណ្យនោះ ហើយនិយាយថា៖ «តើលោកនោះនៅឯណា?»។
[12]មានការពិភាក្សាជាច្រើនអំពីព្រះអង្គនៅក្នុងចំណោមហ្វូងមនុស្ស។ អ្នកខ្លះនិយាយថា៖ «ព្រះអង្គជាមនុស្សល្អ»។ ហើយអ្នកខ្លះទៀតនិយាយថា៖ «អត់ទេ
ព្រះអង្គនាំហ្វូងមនុស្សឲ្យវង្វេង»។[13]យ៉ាងណាក្តី គ្មាននរណាហ៊ាននិយាយពីព្រះអង្គនៅក្នុងទីសាធារណៈឡើយ ព្រោះខ្លាចពួកយូដា។
[14]ពេលពិធីបុណ្យចប់បានពាក់កណ្តាលហើយ ព្រះយេស៊ូបានឡើងទៅហើយចូលទៅក្នុងព្រះវិហារ រួចក៏បង្រៀន។[15]បន្ទាប់មក ពួកយូដាមានការងឿងឆ្ងល់យ៉ាងខ្លាំង
ហើយនិយាយថា «លោកនេះ មិនដែលបានរៀនផង ម្តេចក៏គាត់ដឹងច្រើនម្ល៉េះ?»។[16]ព្រះយេស៊ូឆ្លើយទៅពួកគេ ហើយមានបន្ទូលថា៖
«សេចក្តីបង្រៀនរបស់ខ្ញុំមិនមែនមកពីខ្ញុំទេ ប៉ុន្តែ មកពីព្រះអង្គដែលចាត់ខ្ញុំឲ្យមក។
[17]ប្រសិនបើនរណាម្នាក់ចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ អ្នកនោះនឹងដឹងអំពីសេចក្តីបង្រៀននេះ ថាតើមកពីព្រះជាម្ចាស់ ឬខ្ញុំនិយាយចេញពីខ្លួនឯង។
[18]អ្នកណាដែលនិយាយពីខ្លួនឯង អ្នកនោះស្វែងរកសិរីល្អសម្រាប់ខ្លួនឯងហើយ ប៉ុន្តែអ្នកណាដែលស្វែងរកសិរីល្អរបស់ព្រះអង្គដែលចាត់ខ្លួនឲ្យមក
អ្នកនោះជាមនុស្សពិតត្រង់ ហើយគ្មានសេចក្តីទុច្ចរិតនៅក្នុងគាត់ឡើយ។
[19]តើមិនមែនជាលោកម៉ូសេទេឬអីដែលឲ្យក្រឹត្យវិន័យដល់អ្នករាល់គ្នា? ប៉ុន្តែ គ្មាននរណាម្នាក់នៅក្នុងចំណោមអ្នករាល់គ្នាធ្វើតាមទេ។
ហេតុអ្វីបានជាអ្នករាល់គ្នាស្វែងរកសម្លាប់ខ្ញុំ?[20]ហ្វូងមនុស្សឆ្លើយថា៖ «ឯងមានវិញ្ញាណអាក្រក់។ តើអ្នកណាស្វែងរកសម្លាប់ឯង?
[21]ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ «ខ្ញុំបានធ្វើការមួយ ហើយអ្នកទាំងអស់គ្នាបែរជាងឿងឆ្ងល់ដោយសារការនោះទៅវិញ។
[22]លោកម៉ូសេបានឲ្យអ្នករាល់គ្នាកាត់ស្បែក (មិនមែនមកពីលោកម៉ូសេទេ ប៉ុន្តែមកពីដូនតារបស់អ្នករាល់គ្នាទេតើ) ហើយនៅថ្ងៃសប្ប័ទអ្នករាល់គ្នាក៏កាត់ស្បែកមនុស្សដែរ។
[23]ប្រសិនបើបុរសម្នាក់ទទួលការកាត់ស្បែកនៅថ្ងៃសប្ប័ទ ដូច្នេះគាត់បានធ្វើខុសនឹងក្រឹត្យវិន័យរបស់លោកម៉ូសេហើយ ហេតុអ្វីបានជាអ្នករាល់គ្នាខឹងនឹងខ្ញុំ
ដោយសារខ្ញុំធ្វើឲ្យបុរសម្នាក់បានជានៅថ្ងៃសប្ប័ទដូច្នេះ?[24]កុំវិនិច្ឆ័យតាមលក្ខណៈខាងក្រៅ ប៉ុន្តែចូរវិនិច្ឆ័យដោយសុចរិតវិញ»។
[25]មានអ្នកខ្លះនៅក្នុងចំណោមពួកគេមកពីក្រុងយេរូសាឡិមនិយាយថា៖ «តើលោកម្នាក់នេះមែនទេ ដែលគេស្វែងរកចង់សម្លាប់នោះ?[26]មើល គាត់និយាយនៅទីសាធារណៈ
ហើយពួកគេមិនបាននិយាយអ្វីទៅកាន់គាត់ឡើយ។ វាមិនអាចទៅជាបែបនឹងបានទេ អ្នកគ្រប់គ្រងប្រាកដជាដឹងថា លោកនេះគឺជាព្រះគ្រិស្តហើយ តើអាចទេ?[27]ប៉ុន្តែ
យើងដឹងថាលោកនេះមកពីណា។ ប៉ុន្តែ នៅពេលព្រះគ្រិស្តយាងមក គ្មាននរណាដឹងថាព្រះអង្គមកពីណាទេ»។
[28]ពេលនោះ ព្រះយេស៊ូស្រែកបង្រៀននៅក្នុងព្រះវិហារខ្លាំងៗ ដោយមានបន្ទូលថា៖ «អ្នករាល់គ្នាស្គាល់ខ្ញុំ ហើយដឹងថាខ្ញុំមកពីណា។ ខ្ញុំមិនបានមកដោយខ្លួនឯងទេ ប៉ុន្តែ
ព្រះអង្គទេដែលចាត់ខ្ញុំឲ្យមកពិតត្រង់ ហើយអ្នករាល់គ្នាមិនស្គាល់ព្រះអង្គទេ។[29]ខ្ញុំស្គាល់ព្រះអង្គ ដោយសារខ្ញុំមកពីព្រះអង្គ ហើយព្រះអង្គចាត់ខ្ញុំមក»។
[30]ពួកគេព្យាយាមចង់ចាប់ព្រះអង្គ ប៉ុន្តែគ្មាននរណាអាចចាប់ព្រះអង្គបានទេ ដោយសារពេលកំណត់របស់ព្រះអង្គមិនទាន់មកដល់នៅឡើយទេ។[31]ប៉ុន្តែ
មានមនុស្សជាច្រើននៅក្នុងហ្វូងមនុស្សបានជឿលើព្រះអង្គ ហើយនិយាយថា៖ «នៅពេលព្រះគ្រិស្តយាងមក ព្រះអង្គនឹងធ្វើទីសម្គាល់ច្រើនជាងបុរសម្នាក់នេះបានធ្វើ?
[32]ពួកផារីស៊ីបានឮហ្វូងមនុស្សនិយាយខ្សិបខ្សួរគ្នាការទាំងនេះអំពីព្រះយេស៊ូ ហើយនាយកបូជាចារ្យ និងពួកផារីស៊ីបានចាត់មន្ត្រីទៅចាប់ព្រះអង្គ។
[33]បន្ទាប់មកព្រះយេស៊ូមានបន្ទូលថា៖ «ខ្ញុំនៅជាមួយអ្នករាល់គ្នាតែបន្តិចទៀតទេ ហើយបន្ទាប់មកខ្ញុំនឹងត្រឡប់ទៅឯព្រះអង្គដែលចាត់ខ្ញុំឲ្យមកវិញ។
[34]អ្នករាល់គ្នានឹងស្វែងរកខ្ញុំ តែអ្នករាល់គ្នារកខ្ញុំមិនឃើញទេ កន្លែងដែលខ្ញុំទៅ អ្នកមិនអាចទៅបានទេ»។

generated on Wed Sep 10 16:16:32 2025

[35]ដូច្នេះ ពួកយូដាបាននិយាយក្នុងចំណោមពួកគេថា៖ «តើបុរសម្នាក់នេះនឹងទៅណា ដែលយើងមិនអាចទៅរកគាត់ឃើញ? តើគាត់នឹងខ្ចាត់ខ្ចាយនៅក្នុងចំណោមពួកក្រិក
ហើយបង្រៀនដល់ពួកក្រិកដែរ?[36]តើពាក្យដែលគាត់និយាយថា៖ «អ្នកនឹងស្វែងរកខ្ញុំ តែរកកន្លែងដែលខ្ញុំទៅ មិនឃើញ
ហើយអ្នករាល់គ្នាមិនអាចទៅកន្លែងដែលខ្ញុំទៅបានទេ»។
[37]ឥឡូវនេះ ដល់ថ្ងៃចុងក្រោយ នៃពិធីបុណ្យដ៏ធំហើយ ព្រះយេស៊ូបានឈរឡើង ហើយស្រែកឮៗ ថា៖ «ប្រសិនបើ អ្នកណាម្នាក់ស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ។
[38]អ្នកណាដែលជឿលើខ្ញុំ ដូចដែលបទគម្ពីរបានចែងថា ទន្លេទឹករស់នឹងហូរចេញពីពោះរបស់គាត់មក»។
[39]ប៉ុន្តែព្រះអង្គមានបន្ទូលការនេះអំពីព្រះវិញ្ញាណទេ ដែលអស់អ្នកណាដែលបានជឿលើព្រះអង្គហើយ នឹងបានទទួលព្រះវិញ្ញាណដែលមិនទាន់បានប្រទានមកនៅឡើយទេ
ដោយសារព្រះយេស៊ូមិនទាន់បានទទួលការលើកតម្កើងនៅឡើយ។
[40]មានខ្លះនៅក្នុងចំណោមហ្វូងមនុស្ស នៅពេលពួកគេឮពាក្យទាំងនេះ ពួកគេនិយាយថា៖ «លោកនេះគឺជាព្យាការីពិតប្រាកដមែន»។[41]ហើយអ្នកខ្លះទៀតនិយាយថា៖
«អ្នកនេះគឺជាព្រះគ្រិស្ត»។ ប៉ុន្តែ អ្នកខ្លះនិយាយថា៖ «តើព្រះគ្រិស្តមកពីកាលីឡេ?[42]តើបទគម្ពីរមិនបានចែងថា៖ «ព្រះគ្រិស្តនឹងមកពីបេថ្លេហិម
តាមពូជពង្សរបស់ព្រះបាទដាវីឌ ជាភូមិដែលព្រះបាទដាវីឌបានកើតមកទេឬអី?»។
[43]ដូច្នេះក៏កើតមានការបែកបាក់នៅក្នុងចំណោមហ្វូងមនុស្សដោយសារព្រះអង្គ។[44]អ្នកខ្លះនៅក្នុងចំណោមពួកគេចង់ចាប់ព្រះអង្គ ប៉ុន្តែគ្មានអ្នកណាអាចចាប់ព្រះអង្គបានទេ។
[45]បន្ទាប់មកពួកមន្ត្រីបានត្រឡប់ទៅឯនាយកបូជាចារ្យ និងពួកផារីស៊ីវិញ ជាអ្នកដែលនិយាយទៅកាន់ពួកគេថា៖ «ហេតុអ្វីបានជាមិនចាប់គាត់មក?»[46]ពួកមន្ត្រីឆ្លើយថា៖
«គ្មាននរណាអាចនិយាយដូចគាត់ទេ»។
[47]ដូច្នេះ ពួកផារីស៊ីឆ្លើយទៅពួកគេថា៖ «អ្នករាល់គ្នាក៏ត្រូវបានគេបោកប្រាសដែរមែនទេ?[48]តើមានមេដឹកនាំឬពួកផារីស៊ីណាបានជឿដល់គាត់ទេ?
[49]ប៉ុន្តែហ្វូងមនុស្សដែលមិនស្គាល់ក្រឹត្យវិន័យនេះ ពួកគេត្រូវបណ្តាសារហើយ។
[50]លោកនីកូដេម (ម្នាក់ក្នុងចំណោមពួកផារីស៊ី ដែលបានមករកព្រះអង្គកាលពីមុន) មានប្រសាសន៍ទៅពួកគេថា៖
[51]«តើក្រឹត្យវិន័យរបស់អ្នករាល់គ្នាវិនិច្ឆ័យមនុស្សមុនពេលអ្នកបានឮលោក និងបានដឹងនូវអ្វីដែលលោកបានធ្វើឬ?[52]ពួកគេឆ្លើយ ហើយនិយាយទៅកាន់ព្រះអង្គថា៖
«តើអ្នកក៏មកពីកាលីឡេដែរមែនទេ? ចូរស្វែងរកហើយមើល គ្មានព្យាការីណាមកពីកាលីឡេទេ»។
[53]បន្ទាប់មក មនុស្សគ្រប់គ្នាបានត្រឡប់ទៅផ្ទះរៀងៗខ្លួន។

John 7:1

ព័ត៌មានទូទៅ:

នេះជាផ្នែកបន្ទាប់នៃសាច់រឿង។ ព្រះយេស៊ូកំពុងគង់នៅស្រុកកាលីឡេ
មានបន្ទូលទៅកាន់បងប្អូនរបស់ព្រះអង្គ។ ខគម្ពីរទាំងនេះប្រាប់អំពីពេលវេលា
ដែលព្រឹត្តិការណ៍នេះបានកើតឡើង។

បន្ទាប់ពីការទាំងនេះហើយ

«បន្ទាប់ពីព្រះអង្គមានបន្ទូលចប់ទៅជាមួយពួកសិស្ស» (សូមមើលជំពូក៦ ខ៦៦)
ឬ«មួយរយៈក្រោយមក»

ធ្វើដំណើរ

ដើរ

ពួកយូដាកំពុងស្វែងរកធ្វើឃាតព្រះអង្គ

"ជនជាតិយូដា" នៅទីនេះ ជាការផ្តោតអារម្មណ៍សម្រាប់ "មេដឹកនាំយូដា" ។
មេដឹកនាំរបស់ជនជាតិយូដាបានរៀបផែនការធ្វើគុតព្រះអង្គ

ឥឡូវនេះ ពិធីបុណ្យជម្រកបានជិតមកដល់ហើយ

«ពេលវេលារៀបចំពិធីបុណ្យរបស់ជនជាតិយូដា ជិតមកដល់ហើយ
ឬឥឡូវនេះជិតដល់ពេលពិធីជប់លៀងរបស់ជនជាតិយូដា។

John 7:3

បងប្អូនប្រុស

សំដៅទៅលើបងប្អូនប្រុសរបស់ព្រះយេស៊ូ ដែលជាកូនរបស់ម៉ារីនិងយ៉ូសែប។

កិច្ចការដែលបងឯងធ្វើ

ពាក្យ«កិច្ចការ»សំដៅទៅលើការអស្ចារ្យ ដែលព្រះយេស៊ូបានធ្វើ។

បងឯង

ពាក្យថា“ បងឯង” ជាសព្វនាមឆ្លុះបញ្ចាំង ដែលសង្កត់ន័យលើពាក្យ“ គាត់” ។

លោក

“ ពិភពលោក”នៅទីនេះ
ជាឈ្មោះហៅក្រៅសម្រាប់ប្រជាជនទាំងអស់នៅលើពិភពលោក។
"មនុស្សទាំងអស់" ឬ "មនុស្សគ្រប់គ្នា"

John 7:5

ដ្បិត សូម្បីតែបងប្អូនៗប្រុសរបស់ព្រះអង្គមិនបានជឿលើព្រះអង្គទេ

ប្រយោគនេះជាការដកស្រង់ចេញពីសាច់រឿងសំខាន់ពេលយ៉ូហានប្រាប់យើងអំពីប្រវត្តិខ្លះៗអំពីប្អូនប្រុសរបស់ព្រះយេស៊ូ។

បងប្អូនៗប្រុសរបស់ព្រះអង្គ

"បងប្អូនប្រុសរបស់ព្រះអង្គ"

មិនទាន់ដល់ពេលបងនៅឡើយទេ

ពាក្យថា "ពេល" គឺជាពាក្យប្រៀបធៀប។ ព្រះយេស៊ូកំពុងបញ្ជាក់ថា
នេះមិនទាន់ដល់ពេលព្រះអង្គបំពេញពន្ធកិច្ចរបស់ព្រះអង្គចប់ឡើយ។
"មិនមែនជាពេលវេលាដ៏ត្រឹមត្រូវសម្រាប់ខ្ញុំបញ្ចប់ការងាររបស់ខ្ញុំទេ"

ពេលវេលាបងប្អូនៗវិញរួចរាល់ជានិច្ច

"ពេលណាក៏ល្អសម្រាប់អ្នក"

មនុស្សលោកមិនស្អប់បងប្អូនៗទេ

“ ពិភពលោក”នៅទីនេះពាក្យប្រៀបធៀបសម្រាប់ប្រជាជនដែលរស់នៅលើពិភពលោក។
“ មនុស្សទាំងអស់នៅលើពិភពលោកមិនអាចស្អប់អ្នកបានទេ”

បងធ្វើបន្ទាល់ពីមនុស្សលោកថា កិច្ចការរបស់មនុស្សលោកអាក្រក់

"ខ្ញុំប្រាប់ពួកគេថា អ្វីពួកគេកំពុងធ្វើគឺអាក្រក់"

John 7:8

សេចក្តីថ្លែងការណ៍ភ្ជាប់៖

ព្រះយេស៊ូបន្តមានបន្ទូលទៅបងប្អូនរបស់ព្រះអង្គ។

ពេលវេលារបស់បងមិនទាន់បានសម្រេចនៅឡើយទេ

នៅទីនេះព្រះយេស៊ូកំពុងបញ្ជាក់ថា បើទ្រង់ទៅក្រុងយេរូសាឡឹម
ព្រះអង្គនឹងបញ្ចប់កិច្ចការរបស់ព្រះអង្គហើយ។
"មិនមែនជាពេលវេលាដ៏ត្រឹមត្រូវសម្រាប់ខ្ញុំដែលត្រូវទៅក្រុងយេរូសាឡឹមទេ"

John 7:10

ព័ត៌មានទូទៅ:

ការកំណត់សាច់រឿងបានផ្លាស់ប្តូរហើយ ឥឡូវនេះព្រះយេស៊ូ
និងបងប្អូនរបស់ព្រះអង្គកំពុងតែចូលរួមក្នុងពិធីបុណ្យនេះ។

នៅពេលបងប្អូនៗរបស់ព្រះអង្គបានទៅចូលរួមពិធីបុណ្យហើយ

បងប្អូនទាំងនេះគឺជាប្អូនប្រុសរបស់ព្រះយេស៊ូ។

ព្រះអង្គក៏ឡើងទៅដែរ

ក្រុងយេរូសាឡឹមស្ថិតនៅកម្ពស់ខ្ពស់ជាងស្រុកកាលីឡេដែលព្រះយេស៊ូ
និងប្អូនប្រុសរបស់ព្រះអង្គធ្លាប់រស់នៅពីមុន។

ប៉ុន្តែព្រះអង្គទៅដោយសម្ងាត់វិញ មិនទៅដោយបើកចំហទេ

ឃ្លាទាំងពីរនេះមានន័យដូចគ្នា។ គំនិតនេះត្រូវបាននិយាយម្តងទៀតបញ្ជាក់ន័យ។
"ជាការសម្ងាត់បំផុត"

ពួកយូដាស្វែងរកព្រះអង្គ

ពាក្យ "យូដា"នៅទីនេះជាពាក្យសំដៅទៅលើ "មេដឹកនាំយូដា" ។ ពាក្យ "គាត់"
សំដៅទៅលើព្រះយេស៊ូ។ “ មេដឹកនាំសាសន៍យូដាបានតាមរកព្រះយេស៊ូ”

John 7:12

សំដៅទៅលើអារម្មណ៍មិនល្អ ដែលមនុស្សម្នាក់មាន
ពេលមានការគំរាមកំហែងបង្កគ្រោះថ្នាក់ដល់ខ្លួន និងអ្នកដទៃ។

យូដា

ពាក្យ "យូដា" សំដៅទៅលើអ្នកដឹកនាំជនជាតិយូដា ដែលប្រឆាំងនឹងព្រះយេស៊ូ។
"មេដឹកនាំជនជាតិយូដា"

John 7:14

ព័ត៌មានទូទៅ:

ឥឡូវនេះ ព្រះយេស៊ូកំពុងតែបង្រៀនជនជាតិយូដានៅក្នុងព្រះវិហារ។

generated on Wed Sep 10 16:16:32 2025

លោកនេះ មិនដែលបានរៀនផង ម្តេចក៏គាត់ដឹងច្រើនម្ល៉េះ?
ការកត់សម្គាល់នេះមានទម្រង់ជាសំណួរ
ដើម្បីបញ្ជាក់ពីការភ្ញាក់ផ្អើលរបស់អ្នកដឹកនាំជនជាតិយូដាថា
ព្រះយេស៊ូមានចំណេះដឹងច្រើន។ "គាត់មិនអាចដឹងច្រើនអំពីបទគម្ពីរទេ!"
ប៉ុន្តែ មកពីព្រះអង្គដែលចាត់ខ្ញុំឲ្យមក
"តែមកពីព្រះជាម្ចាស់ ដែលបានចាត់ខ្ញុំឲ្យមក"
John 7:17
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ជនជាតិយូដា។
ប៉ុន្តែអ្នកណាដែលស្វែងរកសិរីល្អរបស់ព្រះអង្គដែលចាត់ខ្លួនឲ្យមក អ្នកនោះជាមនុស្សពិតត្រង់
ហើយគ្មានសេចក្តីទុច្ចរិតនៅក្នុងគាត់ឡើយ
"នៅពេលមនុស្សម្នាក់ស្វះស្វែងរកអ្នក ដែលបានចាត់គាត់ឲ្យមក ដើម្បីលើកតម្កើង
អ្នកនោះនិយាយការពិតហើយគេមិនកុហកទេ"
John 7:19
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ជនជាតិយូដា។
តើមិនមែនជាលោកម៉ូសេទេឬអីដែលឲ្យក្រឹត្យវិន័យដល់អ្នករាល់គ្នា?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"គឺលោកម៉ូសេដែលបានឲ្យក្រឹត្យវិន័យដល់អ្នក"
ធ្វើតាមទេ
"គោរពក្រឹត្យវិន័យ"
ហេតុអ្វីបានជាអ្នករាល់គ្នាស្វែងរកសម្លាប់ខ្ញុំ?
ព្រះយេស៊ូសួរអំពីបំណងចិត្តរបស់មេដឹកនាំសាសន៍យូដា ដែលចង់សម្លាប់ព្រះអង្គ
ដោយព្រោះការរំលងច្បាប់របស់ម៉ូសេ។ ទ្រង់បញ្ជាក់ថា
មេដឹកនាំខ្លួនឯងមិនរក្សាច្បាប់នោះទេ។ "អ្នកបំពានច្បាប់ដោយខ្លួនឯង
ហើយអ្នកនៅតែចង់សម្លាប់ខ្ញុំ!" ។
ឯងមានវិញ្ញាណអាក្រក់
"បង្ហាញថា អ្នកឆ្កួតហើយ ឬប្រហែលជាបិសាចកំពុងគ្រប់គ្រងអ្នក!"
តើអ្នកណាស្វែងរកសម្លាប់ឯង?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"គ្មាននរណាម្នាក់ព្យាយាមសម្លាប់អ្នកទេ!"
John 7:21
ការមួយ
"ការអស្ចារ្យមួយ" ឬ "ទីសម្គាល់មួយ"
អ្នកទាំងអស់គ្នាបែរជាងឿងឆ្ងល់
"អ្នកទាំងអស់គ្នាមានការភ្ញាក់ផ្អើល"
មិនមែនមកពីលោកម៉ូសេទេ ប៉ុន្តែមកពីដូនតារបស់អ្នករាល់គ្នាទេតើ
នៅទីនេះយ៉ូហានផ្តល់ព័ត៌មានបន្ថែមអំពីការកាត់ស្បែក។
នៅថ្ងៃសប្ប័ទអ្នករាល់គ្នាក៏កាត់ស្បែកមនុស្សដែរ
ព្រះយេស៊ូបញ្ជាក់ថា ការកាត់ស្បែកក៏រួមបញ្ចូលការងារដែរ។
"អ្នកកាត់ស្បែកទារកនៅថ្ងៃសប្ប័ទ។ វាក៏ជាការងារដែរ!"
នៅថ្ងៃសប្ប័ទ
"នៅថ្ងៃឈប់សម្រាករបស់ជនជាតិយូដា"
John 7:23
ប្រសិនបើបុរសម្នាក់ទទួលការកាត់ស្បែកនៅថ្ងៃសប្ប័ទ
ដូច្នេះគាត់បានធ្វើខុសនឹងក្រឹត្យវិន័យរបស់លោកម៉ូសេហើយ
បើអ្នកធ្វើពិធីកាត់ស្បែកឲ្យទារកប្រុសនៅថ្ងៃសប្ប័ទ
ដូច្នេះអ្នកមិនបំពានលើវិន័យរបស់លោកម៉ូសេទេ។
ហេតុអ្វីបានជាអ្នករាល់គ្នាខឹងនឹងខ្ញុំ ដោយសារខ្ញុំធ្វើឲ្យបុរសម្នាក់បានជានៅថ្ងៃសប្ប័ទដូច្នេះ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"អ្នកមិនគួរខឹងនឹងខ្ញុំទេ ព្រោះខ្ញុំបានធ្វើឲ្យបុរសម្នាក់បានជាសះស្បើយទាំងស្រុង
នៅថ្ងៃសប្ប័ទ!"
នៅថ្ងៃសប្ប័ទ
"នៅថ្ងៃឈប់សម្រាករបស់ជនជាតិយូដា?"
កុំវិនិច្ឆ័យតាមលក្ខណៈខាងក្រៅ ប៉ុន្តែចូរវិនិច្ឆ័យដោយសុចរិតវិញ
ព្រះយេស៊ូបានមានបន្ទូលថា
ប្រជាជនមិនគួរសម្រេចចិត្តថាត្រូវធ្វើអ្វីដោយផ្អែកលើអ្វី
ដែលពួកគេអាចមើលឃើញនឹងភ្នែកទេ។ នៅពីក្រោយសកម្មភាពនេះ
ជាហេតុផលដែលមិនអាចមើលឃើញ។
ឈប់វិនិច្ឆ័យមនុស្សតាមអ្វីដែលអ្នកឃើញ!
ត្រូវយកចិត្តទុកដាក់នឹងអ្វីដែលត្រូវចំពោះព្រះជាម្ចាស់»
John 7:25
តើលោកម្នាក់នេះមែនទេ ដែលគេស្វែងរកចង់សម្លាប់នោះ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"នេះជាព្រះយេស៊ូដែលពួកគេចង់សម្លាប់!"
ពួកគេមិនបាននិយាយអ្វីទៅកាន់គាត់ឡើយ
បញ្ជាក់ថា មេដឹកនាំសាសន៍យូដាមិនប្រឆាំងនឹងព្រះយេស៊ូទេ។
"ពួកគេមិននិយាយអ្វីដើម្បីប្រឆាំងនឹងព្រះអង្គឡើយ"
វាមិនអាចទៅជាបែបនឹងបានទេ អ្នកគ្រប់គ្រងប្រាកដជាដឹងថា លោកនេះគឺជាព្រះគ្រិស្តហើយ
តើអាចទេ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"ប្រហែលជាពួកគេបានសម្រេចថា ទ្រង់ពិតជាព្រះមេស្ស៊ី!"
John 7:28
ស្រែកបង្រៀន
"និយាយដោយសំឡេងខ្លាំងៗ"
ក្នុងព្រះវិហារ
តាមពិតព្រះយេស៊ូ និងប្រជាជននៅទីធ្លាព្រះវិហារ។ "នៅក្នុងទីធ្លាព្រះវិហារ"
អ្នករាល់គ្នាស្គាល់ខ្ញុំ ហើយដឹងថាខ្ញុំមកពីណា
យ៉ូហានប្រើិពាក្យចំអកនៅក្នុងឃ្លានេះ។ ប្រជាជនជឿថា
ព្រះយេស៊ូមកពីណាសារ៉ែត។ ពួកគេមិនដឹងថា
ព្រះជាម្ចាស់បានបញ្ជូនទ្រង់ពីស្ថានសួគ៌
ហើយទ្រង់បានចាប់កំណើតនៅភូមិបេថ្លេហិម។ "អ្នកទាំងអស់គ្នាស្គាល់ខ្ញុំហើយ
អ្នកគិតថាអ្នកដឹងថាខ្ញុំមកពីណា"
ដោយខ្លួនឯង
"ដោយអំណាចខ្លួនឯង" ។ សូមមើលពីរបៀប ដែលអ្នកបានបកប្រែ“
ដោយខ្លួនព្រះអង្គ” នៅក្នុងជំពូក៥ ខ១៩ ។
ព្រះអង្គទេដែលចាត់ខ្ញុំឲ្យមកពិតត្រង់
«ព្រះជាអ្នកដែលចាត់ខ្ញុំឲ្យមក ហើយព្រះអង្គគឺពិតត្រង់»
John 7:30
ពេលកំណត់របស់ព្រះអង្គមិនទាន់មកដល់នៅឡើយទេ
ពាក្យថា“ ពេលកំណត់” ជាពាក្យប្រៀបធៀប ដែលតំណាងឲ្យពេលវេលាត្រឹមត្រូវ
សម្រាប់ការចាប់ខ្លួនព្រះយេស៊ូ នេះបើយោងតាមផែនការរបស់ព្រះជាម្ចាស់។
"មិនមែនជាពេលវេលាត្រឹមត្រូវទេ ក្នុងការចាប់ខ្លួនព្រះអង្គ"
នៅពេលព្រះគ្រិស្តយាងមក ព្រះអង្គនឹងធ្វើទីសម្គាល់ច្រើនជាងបុរសម្នាក់នេះបានធ្វើ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"នៅពេលដែលព្រះគ្រិស្តយាងមកច្បាស់ជា
ទ្រង់នឹងមិនអាចធ្វើទីសម្គាល់ច្រើនជាងបុរសនេះបានធ្វើនោះទេ!"
ទីសម្គាល់
ផែនការអស់កល្បរបស់ព្រះជាម្ចាស់សម្រាប់ព្រះបុត្រ
គឺត្រូវថ្វាយជីវិតរបស់ព្រះអង្គជាថ្លៃលោះបាបរបស់មនុស្សលោក។
ការសោយទិវង្គតរបស់ព្រះយេស៊ូ
នៅលើឈើឆ្កាងបង្ហាញពីសេចក្តីស្រឡាញ់យ៉ាងខ្លាំងរបស់ព្រះបុត្រាចំពោះព្រះបិតានិងព្រះបិតាចំពោះព្រះ
ព្រះបិតា
ជាងារសំខាន់របស់ព្រះជាម្ចាស់។ ។
ក្តីស្រឡាញ់
សេចក្តីស្រឡាញ់នេះកើតចេញពីព្រះជាម្ចាស់ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
សូម្បីតែវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។ សេចក្តីស្រឡាញ់បែបនេះ
យកចិត្តទុកដាក់ចំពោះអ្នកដទៃ ទោះពួកគេធ្វើអ្វីក៏ដោយ។
ខ្ញុំលះបង់ជីវិតរបស់ខ្ញុំ ដើម្បីឲ្យខ្ញុំបានវាត្រឡប់មកវិញម្តងទៀត
នេះជាវិធីដ៏ស្លួតបូតរបស់ព្រះយេស៊ូ ដោយមានព្រះបន្ទូលថា
ទ្រង់នឹងស្លាប់ហើយបន្ទាប់មកទ្រង់នឹងរស់ឡើងវិញ។ "ខ្ញុំអនុញ្ញាតឲ្យខ្លួនខ្ញុំស្លាប់
ដើម្បីឲ្យខ្ញុំអាចរស់ឡើងវិញ"
ខ្ញុំលះបង់ជីវិតខ្ញុំដោយខ្លួនឯង
សព្វនាមដែលឆ្លុះបញ្ចាំង "ពីខ្លួនខ្ញុំផ្ទាល់" ត្រូវបានប្រើនៅទីនេះដើម្បីបញ្ជាក់ថា
ព្រះយេស៊ូបានលះបង់ជីវិតរបស់ព្រះអង្គ។ គ្មាននរណាម្នាក់យកវាពីព្រះអង្គទេ។
"ខ្ញុំខ្លួនឯងបានដាក់វាចុះ"
ខ្ញុំបានទទួលសេចក្តីបង្គាប់នេះ ពីព្រះបិតាខ្ញុំមក
“ នេះជាអ្វីដែលព្រះបិតាខ្ញុំបានបង្គាប់ឲ្យខ្ញុំធ្វើ” ។ ពាក្យថា“ ព្រះបិតា”
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។ ។
John 10:19
ឃ្លាភ្ជាប់៖
ខគម្ពីរទាំងនេះប្រាប់ពីរបៀប ដែលពួកយូដាបានឆ្លើយតបនឹងអ្វី
ដែលព្រះយេស៊ូបានមានបន្ទូល។
ហេតុអ្វីបានជាអ្នករាល់គ្នាស្តាប់វា?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ ដើម្បីបញ្ជាក់ពីចំណុច
ដែលប្រជាជនមិនគួរស្តាប់ព្រះយេស៊ូ។ "កុំស្តាប់គាត់!"
តើអារក្សអាចធ្វើឲ្យភ្នែកពិការភ្លឺដែរទេ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យថា
"ប្រាកដណាស់អារក្សមិនអាចបណ្តាលឲ្យមនុស្សខ្វាក់មើលឃើញនោះទេ!" ឬ
"ពិតប្រាកដមែនអារក្ស មិនអាចឲ្យមនុស្សខ្វាក់មើលឃើញបានទេ!"
John 10:22
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃរឿង។ ឥឡូវនេះ ជាពេលបុណ្យចម្លង
ហើយជនជាតិយូដាខ្លះចាប់ផ្តើមសួរព្រះយេស៊ូ។ ខ ២២ និង ២៣
ផ្តល់ព័ត៌មានសំខាន់អំពីការរៀបចំសាច់រឿង។
ពិធីបុណ្យចម្លង
នេះជាថ្ងៃឈប់សម្រាកប្រាំបីថ្ងៃនៃរដូវរងារ ដែលរបស់ជនជាតិយូដា

generated on Wed Sep 10 16:16:32 2025

ដើម្បីចងចាំការអស្ចារ្យមួយ ដែលព្រះជាម្ចាស់បានធ្វើឲ្យប្រេងតិចតួច
នៅតែមាននៅលើជើងចង្កៀងអស់រយៈពេលប្រាំបីថ្ងៃ។
ពួកគេបានអុជចង្កៀងដើម្បីឧទ្ទិសព្រះវិហាររបស់ជនជាតិយូដា។ ដើម្បីឧទ្ទិសអ្វីមួយ
គឺសន្យាថានឹងប្រើវាសម្រាប់គោលបំណងពិសេស។
ព្រះយេស៊ូបានយាងឡើងចូលទៅក្នុងព្រះវិហារ
កន្លែងដែលព្រះយេស៊ូកំពុងដើរ គឺពិតជាទីធ្លាដែលនៅអគារខាងក្រៅព្រះវិហារ។ “
ព្រះយេស៊ូកំពុងតែដើរនៅក្នុងទីធ្លាព្រះវិហារ”
សាលាដំណាក់
នេះជារចនាសម្ព័ន្ធ ដែលភ្ជាប់ទៅនឹងច្រកចូលអគារ; វាមានដំបូលហើយវាអាច
ឬប្រហែលមិនមានជញ្ជាំង។
ពួកសាសន៍យូដាបានមកជុំវិញព្រះអង្គ
នៅទីនេះ "ជនជាតិយូដា" ជាមេដឹកនាំជនជាតិយូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។
"បន្ទាប់មកមេដឹកនាំជនជាតិយូដាបានឡោមព័ទ្ធព្រះអង្គ"
មានការសង្ស័យ
ជាពាក្យក្រៀមភាសាមួយ។ "ធ្វើឲ្យយើងឆ្ងល់" ឬ "មិនឲ្យយើងដឹងពីការពិត?"
John 10:25
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាប់ផ្តើមឆ្លើយតបនឹងពួកយូដា។
នៅក្នុងនាមព្រះបិតាខ្ញុំ
"ឈ្មោះ"នៅត្រង់នេះ ជាពាក្យប្រៀបធៀបសម្រាប់អំណាចរបស់ព្រះជាម្ចាស់។
នៅទីនេះ "ព្រះបិតា" ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ព្រះយេស៊ូបានធ្វើការអស្ចារ្យតាមរយៈព្រះចេស្ដ ដានិងសិទ្ធិអំណាចរបស់ព្រះបិតា។ “
តាមរយៈព្រះចេស្ដារបស់ព្រះបិតាខ្ញុំ” ឬ“ ដោយអំណាចចេស្ដារបស់ព្រះបិតាខ្ញុំ”
បានធ្វើបន្ទាល់ពីខ្ញុំហើយ
ការអស្ចារ្យរបស់ព្រះអង្គផ្តល់ភស្តុតាងអំពីទ្រង់
ដូចជាមនុស្សម្នាក់ដែលផ្តល់សក្ខីកម្មនឹងផ្តល់ភស្តុតាងនៅក្នុងតុលាការ។
"ផ្តល់ភស្តុតាងទាក់ទងនឹងខ្ញុំ"
មិនមែនជាចៀមខ្ញុំ
ពាក្យ "ចៀម" ជាពាក្យប្រៀបធៀបសម្រាប់អ្នកដើរតាមព្រះយេស៊ូ។
"មិនមែនជាអ្នកកាន់តាមខ្ញុំ" ឬ "មិនមែនជាសិស្សរបស់ខ្ញុំ"
John 10:27
ចៀមខ្ញុំស្តាប់សម្លេងខ្ញុំ
ពាក្យ "ចៀម" ជាពាក្យប្រៀបធៀបសម្រាប់អ្នកដើរតាមព្រះយេស៊ូ។
ពាក្យប្រៀបធៀបរបស់ព្រះយេស៊ូជា«អ្នកគង្វាល»ក៏ត្រូវបានបញ្ជាក់ផងដែរ។
"ដូចជាចៀមស្តាប់តាមសំឡេងរបស់អ្នកគង្វាលពិតរបស់ពួកគេ
អ្នកដើរតាមខ្ញុំឮសំឡេងខ្ញុំ"
គ្មាននរណាឆក់យកពួកវាចេញពីដៃខ្ញុំបានដែរ
ពាក្យថា“ ដៃ” នៅទីនេះជាពាក្យប្រៀបធៀប
ដែលតំណាងឲ្យការការពាររបស់ព្រះយេស៊ូ។
"គ្មាននរណាម្នាក់នឹងលួចពួកគេចេញពីខ្ញុំទេ" ឬ
"ពួកគេនឹងនៅតែមានសុវត្ថិភាពជារៀងរហូត ដោយខ្ញុំការពារគេ"
John 10:29
ព្រះបិតាខ្ញុំ ជាអ្នកប្រទានពួកវាមកខ្ញុំ
ពាក្យថា“ ព្រះបិតា” ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់ ។
ព្រះហស្តរបស់ព្រះបិតា
ពាក្យថា“ ព្រះហស្ត” ជាពាក្យប្រៀបធៀប ដែលសំដៅទៅលើកម្មសិទ្ធិ
និងការពាររបស់ព្រះជាម្ចាស់។ "គ្មានអ្នកណាអាចលួចយកពួកគេ
ពីព្រះបិតាខ្ញុំបានទេ"
ខ្ញុំ និងព្រះបិតាគឺតែមួយ
ព្រះយេស៊ូជាព្រះបុត្រា និងព្រះជាម្ចាស់ជាព្រះបិតាគឺតែមួយ។ ពាក្យថា“ ព្រះបិតា”
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ក្រោយមក ពួកយូដាបានយកដុំថ្ម
ពាក្យ "យូដា" ជានិមិត្តរូបមួយ
សម្រាប់មេដឹកនាំសាសន៍យូដាដែលបានប្រឆាំងនឹងព្រះយេស៊ូ។ “
មេដឹកនាំជនជាតិយូដាបានរើសដុំថ្មម្តងទៀត”
John 10:32
ព្រះយេស៊ូបានឆ្លើយទៅពួកគេថា៖ «ខ្ញុំបានបង្ហាញការល្អជាច្រើន ពីព្រះបិតាដល់អ្នករាល់គ្នា
ព្រះយេស៊ូបានធ្វើការអស្ចារ្យ ដោយព្រះចេស្ដារបស់ព្រះអង្គ។ ពាក្យថា“
ព្រះបិតា”ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់ ។
ដោយសារការទាំងនោះ អ្នករាល់គ្នាចោលខ្ញុំនឹងដុំថ្មមែនទេ?
សំណួរនេះប្រើភាពមិនត្រឹមត្រូវ។
ព្រះយេស៊ូដឹងថាអ្នកដឹកនាំជនជាតិយូដាមិនចង់គប់ដុំថ្មព្រះទេ
ព្រោះព្រះអង្គបានធ្វើការល្អ។
ពួកយូដាឆ្លើយទៅកាន់ព្រះអង្គថា
ពាក្យ "យូដា" ជានិមិត្តរូបមួយ ដែលតំណាងឲ្យមេដឹកនាំសាសន៍យូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។ "គូប្រជែងដែលជាជនជាតិយូដាបានឆ្លើយតប"
ឬ "មេដឹកនាំជនជាតិយូដាបានឆ្លើយទៅព្រះអង្គ"
តាំងខ្លួនឯងជាព្រះជាម្ចាស់
"អះអាងថាជាព្រះជាម្ចាស់"
John 10:34
តើមិនបានសរសេរ....ព្រះ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"អ្នកគួរតែដឹងរួចហើយថា ត្រូវសរសេរនៅក្នុងច្បាប់របស់អ្នក
ដែលខ្ញុំបាននិយាយថា" អ្នកគឺជាព្រះជាម្ចាស់ "។
អ្នករាល់គ្នាគឺជាព្រះ
នៅទីនេះ ព្រះយេស៊ូដកស្រង់ខគម្ពីរមួយ ដែលព្រះជាម្ចាស់បានត្រាស់ហៅអ្នក
ដើរតាមព្រះអង្គថា «ព្រះជាម្ចាស់»
ប្រហែលជាដោយសារព្រះអង្គបានជ្រើសរើសពួកគេ
ឲ្យធ្វើជាអ្នកតំណាងព្រះនៅលើផែនដីនេះ។
ទទួលព្រះបន្ទូល
"ព្រះអង្គមានព្រះបន្ទូល"
បទគម្ពីរមិនអាផ្លាស់ប្តូរបានទេ
អាចមានន័យថា ១) "គ្មាននរណាម្នាក់អាចផ្លាស់ប្តូរខគម្ពីរឬ ២)"
ខគម្ពីរនឹងក្លាយជាការពិតបានទេ "។
ចុះហេតុដូចម្តេចបានជាពេលខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំជាបុត្រារបស់ព្រះជាម្ចាស់ អ្នករាល់គ្នាបែរជា
ពោលថា ខ្ញុំប្រមាថព្រះអង្គទៅវិញ? ព្រះបិតាបានប្រោសខ្ញុំអោយវិសុទ្ធ ហើយចាត់ខ្ញុំអោយមកក្នុង
ពិភពលោកនេះទៀតផង។
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
អ្នកប្រឆាំងព្រះយេស៊ូជឿថា ព្រះយេស៊ូកំពុងតែប្រមាថព្រះជាម្ចាស់
ដោយហៅខ្លួនឯងថា“ ព្រះបុត្រាព្រះជាម្ចាស់” ។
ពួកគេដឹងថាគាត់កំពុងអះអាងថាខ្លួនស្មើនឹងព្រះ។ "អ្នកមិនគួរនិយាយទៅកាន់អ្នក
ដែលព្រះបិតាបានចាត់ឲ្យមកក្នុងពិភពលោកនេះថា"
ជាអ្នកកំពុងប្រមាថព្រះជម្ចាស់នៅពេលខ្ញុំនិយាយថាខ្ញុំជាព្រះរាជបុត្រារបស់ព្រះអង្គឡើយ!
"
ព្រះបិតា....ព្រះបុត្រា
ទាំងនេះជាងារ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់ និងព្រះយេស៊ូ។ ។
John 10:37
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបញ្ចប់ការឆ្លើយតបនឹងពួកយូដា។
ព្រះបិតា
ជាងារសំខាន់ថ្វាយព្រះជាម្ចាស់។ ។
ជឿខ្ញុំ
ត្រង់នេះពាក្យថា“ ជឿ” មានន័យថាទទួលយក ឬជឿជាក់លើអ្វី
ដែលព្រះយេស៊ូមានបន្ទូល។
ជឿលើកិច្ចការ
ត្រង់នេះ“ ជឿលើ” ត្រូវទទួលស្គាល់ថាកិច្ចការដែលព្រះយេស៊ូបានធ្វើ
គឺមកពីព្រះបិតា។
ព្រះបិតានៅក្នុងខ្ញុំ ហើយដឹងថា ខ្ញុំនៅក្នុងព្រះបិតានោះ
ទាំងនេះ ជាពាក្យប្រៀបភាសា ដែលបង្ហាញពីទំនាក់ទំនងផ្ទាល់ខ្លួនដ៏ជិតស្និទ្ធ
រវាងព្រះជាម្ចាស់និងព្រះយេស៊ូ។ “ ព្រះបិតាខ្ញុំនិងខ្ញុំគឺរួមគ្នាតែមួយ”
បានចេញទៅក្រៅពីការចាប់របស់ពួកគេ
ពាក្យថា“ ដៃ” ជាពាក្យប្រៀបធៀបតំណាងឲ្យ ការកាន់កាប់
ឬការកាន់កាប់របស់មេដឹកនាំយូដា។ "បានចេញឆ្ងាយពីពួកគេម្តងទៀត"
John 10:40
ឆ្ងាយពីទន្លេយ័រដាន់
ព្រះយេស៊ូឆ្ងាប់នៅខាងលិចទន្លេយ័រដាន់។ "នៅប៉ែកខាងកើតនៃទន្លេយ័រដាន់"
ព្រះអង្គស្នាក់នៅទីនោះ

generated on Wed Sep 10 16:16:32 2025

ព្រះយេស៊ូបានស្នាក់នៅត្រើយខាងកើតទន្លេយ័រដាន់ក្នុងរយៈពេលខ្លី។
"ព្រះយេស៊ូបានស្នាក់នៅទីនោះអស់រយៈពេលជាច្រើនថ្ងៃ"
លោកយ៉ូហានមិនបានធ្វើទីសម្គាល់អ្វីទេ ប៉ុន្តែ
អ្វីគ្រប់យ៉ាងដែលលោកយ៉ូហានបាននិយាយអំពីបុរសម្នាក់នេះគឺជាសេចក្តីពិត
"វាជាការពិត ដែលយ៉ូហានមិនបានធ្វើទីសម្គាល់ទេ
ប៉ុន្តែគាត់បាននិយាយការពិតអំពីបុរសនេះ ដែលធ្វើទីសម្គាល់។ "

ទីសម្គាល់
ទាំងនេះជាការអស្ចារ្យ ដែលបង្ហាញថាមានអ្វីមួយ
ឬជាការពិតដែលផ្តល់ភាពជឿជាក់ដល់នរណាម្នាក់។
បានជឿ
ត្រង់នេះ“ ជឿលើ”
មានន័យថាទទួលយកឬជឿជាក់លើអ្វីដែលព្រះយេស៊ូបានមានបន្ទូលគឺពិត។

---

11 [1]មានបុរសម្នាក់ឈ្មោះឡាសាមានជំងឺ។ គាត់នៅភូមិបេតថានី នៅក្នុងភូមិដែលនាងម៉ារី និងបងស្រីរបស់នាងម៉ាថា។
[2]នាងម៉ារីគឺជាអ្នកដែលបានចាក់ប្រេងក្រអូបលាបលើព្រះអម្ចាស់ ហើយយកសក់របស់នាងជូតជើងរបស់ព្រះអង្គ រីឯ ឡាសាដែលឈឺនោះជាប្អូនរបស់នាង។
[3]នោះបងស្រីទាំងពីរបានចាត់គេឲ្យទៅឯព្រះយេស៊ូ និយាយថា៖ «ព្រះអម្ចាស់អើយ មើល អ្នកដែលព្រះស្រឡាញ់ឈឺហើយ»។[4]នៅពេលព្រះយេស៊ូឮដូច្នេះ
ព្រះអង្គមានបន្ទូលថា៖ «ជំងឺនេះមិនស្លាប់ទេ ប៉ុន្តែផ្ទុយទៅវិញ ជំងឺនេះដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់វិញ ដើម្បីឲ្យបុត្រារបស់ព្រះបានទទួលសិរីល្អដោយសារវាដែរ»។
[5]ព្រះយេស៊ូស្រឡាញ់នាងម៉ាថា និងប្អូនស្រីរបស់នាង ព្រមទាំងឡាសាផង។[6]ដូច្នេះ នៅពេលព្រះអង្គឮថា ឡាសាឈឺ
ព្រះយេស៊ូស្នាក់នៅកន្លែងដែលព្រះអង្គនៅនោះពីរយប់ថែមទៀត។[7]បន្ទាប់មក ព្រះអង្គមានបន្ទូលទៅកាន់ពួកសិស្សថា៖ «តោះ យើងទៅស្រុកយូដាម្តងទៀត»។
[8]ពួកសិស្សនិយាយទៅកាន់ព្រះអង្គថា៖ «រ៉ាប៊ី ពួកយូដាកំពុងតែចង់ចោលព្រះអង្គនឹងដុំថ្ម តើព្រះអង្គនៅតែចង់ត្រឡប់ទៅវិញម្តងទៀត?»[9]ព្រះយេស៊ូឆ្លើយថា៖
«តើមួយថ្ងៃមិនមានដប់ពីរម៉ោងទេឬអី? ប្រសិនបើ អ្នកណាម្នាក់ដើរនៅពេលថ្ងៃ គាត់នឹងមិនជំពប់ទេ ព្រោះគាត់មើលឃើញ ដោយសារពន្លឺរបស់លោកីយ៍នេះ។
[10]ប៉ុន្តែ ប្រសិនបើ គាត់ដើរពេលយប់វិញ គាត់នឹងជំពប់មិនខាន ព្រោះពន្លឺមិននៅក្នុងគាត់ទេ»។[11]ព្រះអង្គមានបន្ទូលពីការទាំងនេះ
ហើយបន្ទាប់ពីមានបន្ទូលពីការទាំងនេះហើយ ទ្រង់មានបន្ទូលទៅពួកគេថា៖ «មិត្តសម្លាញ់របស់យើងឡាសាបានដេកលក់ហើយ ប៉ុន្តែ ខ្ញុំនឹងទៅ
ដើម្បីខ្ញុំដាស់គាត់ឲ្យក្រោកពីគេវិញ»។
[12]ដូច្នេះហើយ បានជាពួកសិស្សទូលទៅកាន់ព្រះអង្គថា៖ «ព្រះអម្ចាស់អើយ ប្រសិនបើ គាត់ដេកលក់មែន គាត់នឹងភ្ញាក់ឡើងវិញ»។
[13]ព្រះយេស៊ូមានបន្ទូលពីការស្លាប់របស់គាត់ ប៉ុន្តែ ពួកគេគិតថា ព្រះអង្គកំពុងមានបន្ទូលពីការដេកសម្រាក។[14]បន្ទាប់មក ព្រះយេស៊ូមានបន្ទូលទៅពួកគេយ៉ាងច្បាស់ថា៖
«ឡាសាស្លាប់ហើយ»។
[15]ដោយព្រោះអ្នករាល់គ្នា ខ្ញុំសប្បាយចិត្តណាស់ ដែលខ្ញុំមិននៅទីនោះដើម្បីឲ្យអ្នករាល់គ្នាអាចជឿ។ តោះ ចូរយើងទៅជួបគាត់»។[16]លោកថូម៉ាស ដែលហៅថា ឌីឌីម
និយាយទៅពួកសិស្សទាំងអស់ថា៖ «តោះ យើងទៅ ដើម្បីឲ្យយើងអាចស្លាប់ជាមួយព្រះយេស៊ូ»។
[17]នៅពេលព្រះយេស៊ូយាងមកដល់ ព្រះអង្គបានឃើញថា ឡាសាត្រូវបានដាក់ទៅក្នុងផ្នូរបួនថ្ងៃរួចស្រេចទៅហើយ។[18]ភូមិបេថានីនៅជិតយេរូសាឡិម
ប្រហែលជាបីគីឡូម៉ែត្រ។[19]ពួកយូដាជាច្រើនបានចូលទៅឯនាងម៉ាថា និងម៉ារី ដើម្បីកម្សាន្តចិត្តពួកនាងពីប្អូនរបស់របស់ពួកគេ។[20]បន្ទាប់មក នាងម៉ាថា
នៅពេលដែលនាងបានឮថាព្រះយេស៊ូយាងមក នាងបានទៅជួបព្រះអង្គ ប៉ុន្តែនាងម៉ារីកំពុងអង្គុយនៅក្នុងផ្ទះ។
[21]បន្ទាប់មក នាងម៉ាថាបាននិយាយទៅកាន់ព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ ប្រសិនបើ ព្រះអង្គនៅទីនេះ ប្អូនប្រុសរបស់ខ្ញុំម្ចាស់មិនស្លាប់ទេ។[22]ខ្ញុំម្ចាស់ដឹងថា
អ្វីក្តីដែលព្រះអង្គទូលសូមដល់ព្រះជាម្ចាស់ ទ្រង់នឹងប្រទានដល់ព្រះអង្គមិនខាន»។[23]ព្រះយេស៊ូឆ្លើយទៅនាងថា៖ «ប្អូនប្រុសរបស់នាងនឹងរស់ឡើងវិញម្តងទៀត»។
[24]នាងម៉ាថាឆ្លើយទៅកាន់ព្រះអង្គថា៖ «ខ្ញុំម្ចាស់ដឹងថា ព្រះអង្គនឹងប្រោសគាត់ឲ្យរស់ឡើងវិញនៅថ្ងៃចុងក្រោយ»។[25]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖
«ខ្ញុំជាសេចក្តីរស់ឡើងវិញ និងជាជីវិត អស់អ្នកណាដែលជឿដល់ខ្ញុំ ទោះបើស្លាប់ក៏ដោយ នឹងរស់ឡើងវិញជាមិនខាន។[26]ហើយអស់អ្នកដែលរស់នៅនៅឡើយ
ដែលជឿដល់ខ្ញុំ នឹងមិនស្លាប់ឡើយ។ តើអ្នករាល់គ្នាជឿការនេះទេ?»។
[27]នាងនិយាយទៅកាន់ព្រះអង្គថា៖ «ចាស់ ព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿថា ព្រះអង្គគឺជាព្រះគ្រិស្ត ជាព្រះបុត្រានៃព្រះជាម្ចាស់ ដែលបានយាងមកនៅលើផែនដីនេះ»។
[28]នៅពេលដែលនាងនិយាយការនេះរួចហើយ នាងបានចេញទៅហៅនាងម៉ារីជាប្អូនស្រីរបស់នាងដោយសម្ងាត់។ នាងនិយាយថា៖ «លោកគ្រូមកដល់ហើយ
ហើយសួររកអ្នកឯង»។[29]នៅពេលនាងឮដូច្នេះ នាងបានក្រោកឡើងយ៉ាងលឿន ហើយទៅរកព្រះអង្គ។
[30]ព្រះយេស៊ូមិនទាន់បានចូលទៅក្នុងភូមិនៅឡើយទេ ប៉ុន្តែ ព្រះអង្គនៅកន្លែងដែលនាងម៉ាថាបានជួបព្រះអង្គ។[31]ដូច្នេះ នៅពេលពួកយូដា ដែលនៅក្នុងផ្ទះជាមួយនាង
និងអ្នកដែលមកកម្សាន្តចិត្តនាង ឃើញនាងម៉ារីក្រោកឡើងយ៉ាងលឿន ហើយចេញក្រៅយ៉ាងដូច្នេះ ពួកគេក៏ដើរតាមនាង គិតថានាងទៅឯផ្នូរ ដើម្បីយំនៅទីនោះ។
[32]នៅពេលនាងម៉ារីមកដល់កន្លែងដែលព្រះយេស៊ូគង់នៅ ហើយបានឃើញព្រះអង្គ។ នាងបានលុតជង្គង់ចុះនៅជិតព្រះបាទាព្រះអង្គ ហើយនិយាយទៅកាន់ព្រះអង្គថា៖
«ព្រះអម្ចាស់អើយ ប្រសិនបើ ព្រះអង្គនៅទីនេះ ប្អូនប្រុសរបស់ខ្ញុំម្ចាស់ មិនស្លាប់ទេ»។
[33]នៅពេលព្រះយេស៊ូឃើញនាងយំ ហើយពួកយូដាដែលមកជាមួយនាងកំពុងយំផងដែរ ព្រះអង្គមានព្រះទ័យក្តុកក្តួលជាខ្លាំងនៅខាងក្នុងវិញ្ញាណរបស់ព្រះអង្គ
ហើយអន្ទះសារជាខ្លាំង។[34]ទ្រង់មានបន្ទូលថា៖ «តើអ្នកបានគាត់នៅឯណា?» ពួកគេនិយាយទៅកាន់ព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមយាងមក ព្រះអង្គនឹងឃើញ»។
[35]ព្រះយេស៊ូទ្រង់ព្រះកន្សែង។
[36]បន្ទាប់មក ពួកយូដានិយាយថា៖ «មើល ព្រះអង្គស្រឡាញ់ឡាសាប៉ុណ្ណា!»[37]ប៉ុន្តែ មានអ្នកខ្លះនៅក្នុងចំណោមពួកគេនិយាយថា៖ «តើបុរសម្នាក់នេះ
ដែលអាចធ្វើឲ្យមនុស្សខ្វាក់ភ្លឺបាន តើគាត់អាចធ្វើឲ្យបុរសនេះមិនស្លាប់បានទេ?»
[38]បន្ទាប់មក ព្រះយេស៊ូមានព្រះទ័យក្តុកក្តួលម្តងទៀតនៅក្នុងព្រះអង្គ ទ្រង់បានយាងទៅឯផ្នូរ។ នៅឯផ្នូរ មានថ្មបិទជិត។[39]ព្រះយេស៊ូមានបន្ទូលថា៖ «ចូរយកថ្មនេះចេញ!»។
នាងម៉ាថា បងស្រីរបស់ឡាសាទូលទៅកាន់ព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ មកដល់ពេលនេះរូបកាយរលួយហើយដ្បិតគាត់បានស្លាប់បួនថ្ងៃហើយ»។
[40]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «តើខ្ញុំមិនបាននិយាយទេឬអីថា ប្រសិនបើអ្នកជឿ អ្នកនឹងបានឃើញសិរីល្អរបស់ព្រះជាម្ចាស់?»។
[41]ដូច្នេះ ពួកគេបានយកថ្មចេញ។ ព្រះយេស៊ូបានសម្លឹងមើល ហើយ មានបន្ទូលថា៖ «ព្រះបិតាអើយ ទូលបង្គំដឹងថា ព្រះអង្គស្តាប់ទូលបង្គំ។[42]ទូលបង្គំដឹងថា
ព្រះអង្គស្តាប់ទូលបង្គំជានិច្ច ប៉ុន្តែ ដោយព្រោះហ្វូងមនុស្សដែលកំពុងឈរនៅជុំវិញទូលបង្គំ បានជឿថាព្រះអង្គបានចាត់ទូលបង្គំឲ្យមក»។
[43]បន្ទាប់ពីព្រះអង្គមានបន្ទូលរួចហើយ ព្រះអង្គក៏ស្រែកសម្លេងយ៉ាងខ្លាំងថា៖ «ឡាសា ចេញមក!»[44]បុគ្គលដែលស្លាប់នោះបានចេញមក ជើង
និងដៃរបស់គាត់ត្រូវបានចងដោយក្រណាត់ ហើយមុខរបស់គាត់ក៏ត្រូវបានចងដោយក្រណាត់ដែរ។ ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ចូរស្រាយគាត់
ហើយឲ្យគាត់ចេញទៅ»។
[45]បន្ទាប់មក មានពួកយូដាជាច្រើនដែលមកជាមួយនាងម៉ារី បានឃើញអ្វីដែលព្រះយេស៊ូបានធ្វើ ហើយបានជឿលើព្រះអង្គ។[46]ប៉ុន្តែ
មានអ្នកខ្លះក្នុងចំណោមពួកគេបានចេញទៅឯពួកផារីស៊ី ហើយប្រាប់ពួកគេពីអ្វីដែលព្រះយេស៊ូបានធ្វើ។
[47]នាយកបូជាចារ្យ និងពួកផារីស៊ីបានជួបជុំគ្នា ប្រឹក្សាជាមួយគ្នា ហើយនិយាយថា «តើយើងត្រូវធ្វើអ្វី?»។ បុរសម្នាក់នេះ បានធ្វើទីសម្គាល់ជាច្រើន។[48]ប្រសិនបើ
យើងទុកគាត់ឲ្យធ្វើដូច្នេះ មនុស្សគ្រប់គ្នាមុខជាជឿលើគាត់មិនខាន។ ពួករ៉ូមនឹងមក ហើយនឹងគ្រប់គ្រងលើយើង និងប្រទេសយើងផង»។
[49]ប៉ុន្តែ មានបុរសម្នាក់នៅក្នុងចំណោមពួកគេឈ្មោះ កៃផាស ដែលជាមហាបូជាចារ្យនៅឆ្នាំនោះ មានប្រសាសន៍ទៅពួកគេថា៖ «អ្នករាល់គ្នាគ្មានដឹងអ្វីទាំងអស់។
[50]អ្នករាល់គ្នាមិនគិតទេថា ប្រសិនបើ មនុស្សម្នាក់ស្លាប់ ជំនួសប្រជាជន ប្រសើរជាងមនុស្សមួយប្រទេសត្រូវវិនាស»។
[51]គាត់មានប្រសាសន៍ការនេះ មិនមែនដោយខ្លួនគាត់ទេ។ ផ្ទុយទៅវិញ ក្នុងនាមជាមហាបូជាចារ្យនៅក្នុងឆ្នាំនោះ គាត់បានថ្លែងទំនាយថា
ព្រះយេស៊ូត្រូវសុគតដើម្បីប្រទេសជាតិ។[52]ហើយមិនគ្រាន់តែសម្រាប់ប្រទេសជាតិប៉ុណ្ណឹងទេ ប៉ុន្តែ

generated on Wed Sep 10 16:16:32 2025

ដើម្បីឲ្យបុត្រធីតារបស់ព្រះជាម្ចាស់ដែលបានខ្ចាត់ខ្ចាយអាចប្រមូលមូលរួមតែមួយវិញ។[53]ដូច្នេះ ចាត់តាំងពីថ្ងៃនោះមក
ពួកគេបានរៀបគម្រោងពីរបៀបនៃការសម្លាប់ព្រះយេស៊ូ។
[54]ព្រះយេស៊ូលែងយាងនៅក្នុងចំណោមពួកគេជាសាធារណៈទៀតហើយ ប៉ុន្តែ
ព្រះអង្គបានចេញពីទីនោះទៅតំបន់ដែលនៅជិតនឹងទីរហោស្ថានគឺនៅក្នុងក្រុងមួយដែលហៅថា អេប្រាអ៊ីម។ ព្រះអង្គគង់នៅទីនោះជាមួយពួកសិស្ស។
[55]ហើយពិធីបុណ្យរំលងរបស់សាសន៍យូដាជិតមកដល់ ហើយមានមនុស្សជាច្រើនមកពីប្រទេសផ្សេងបានឡើងទៅក្រុងយេរូសាឡិម មុនថ្ងៃបុណ្យចម្លង
ដើម្បីធ្វើឲ្យពួកគេវិសុទ្ធ។
[56]ពួកគេស្វែងរកព្រះយេស៊ូ ហើយបាននិយាយទៅកាន់គ្នាទៅវិញទៅមក នៅពេលដែលពួកគេនៅក្នុងព្រះវិហារថា៖ «តើអ្នកគិតយ៉ាងដូចម្តេច?
ថាតើគាត់នឹងមិនមកចូលរួមពិធីបុណ្យទេឬអី?»។[57]នាយកបូជាចារ្យ និងពួកផារីស៊ីបានដាក់សេចក្តីបង្គាប់ថា ប្រសិនបើអ្នកណាម្នាក់ដឹងថាព្រះយេស៊ូនៅទីណា
អ្នកនោះត្រូវរាយការណ៍ ដើម្បីឲ្យពួកគេបានចាប់ព្រះអង្គ។

John 11:1
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃរឿង ដែលនិយាយអំពីឡាសា។
ខគម្ពីរទាំងនេះណែនាំឲ្យដឹងពីរឿងរ៉ាវ
និងផ្តល់ព័ត៌មានអំពីគាត់និងប្អូនស្រីរបស់គាត់ឈ្មោះម៉ារី។
នាងម៉ារីគឺជាអ្នកដែលបានចាក់ប្រេងក្រអូបលាបលើព្រះអម្ចាស់ ....យកសក់របស់នាងជូត
ពេលយ៉ូហានណែនាំម៉ារីជាប្អូនស្រីរបស់ម៉ាថា
គាត់ក៏ចែកចាយព័ត៌មានទាក់ទងនឹងអ្វី
ដែលនឹងកើតឡើងនៅពេលក្រោយនៃសាច់រឿងនេះ។
John 11:3
ចាត់គេឲ្យទៅឯព្រះយេស៊ូ
"សុំឲ្យព្រះយេស៊ូយាងមក"
សេចក្តីស្រឡាញ់
នៅទីនេះ“ សេចក្តីស្រឡាញ់” សំដៅទៅលើសេចក្តីស្រឡាញ់ជាបងប្អូន
ដែលជាសេចក្តីស្រឡាញ់ធម្មជាតិរបស់មនុស្សរវាងមិត្តភក្តិ ឬសាច់ញាតិ។
ជំងឺនេះមិនស្លាប់ទេ
ព្រះយេស៊ូបានបញ្ជាក់ថា ទ្រង់ជ្រាបអំពីអ្វីដែលនឹងកើតឡើងទាក់ទងនឹងឡាសា
និងជំងឺរបស់គាត់។ “ សេចក្តីស្លាប់នឹងមិនមែនជាលទ្ធផលចុងក្រោយនៃជំងឺនេះទេ”
ស្លាប់
នេះសំដៅទៅលើការស្លាប់ខាងរូបកាយ។
ជំងឺនេះដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់វិញ
ដើម្បីឲ្យបុត្រារបស់ព្រះបានទទួលសិរីល្អដោយសារវាដែរ
ព្រះយេស៊ូបានបញ្ជាក់ថា ទ្រង់ជ្រាបតើនឹងមានលទ្ធផលយ៉ាងណា។ “
ប៉ុន្តែគោលបំណងគឺ ប្រជាជនអាចនឹងមើលឃើញ
តើព្រះជាម្ចាស់អស្ចារ្យយ៉ាងណាទៅ គឺដោយសារព្រះចេស្តារបស់ព្រះអង្គ
ដែលនឹងអនុញ្ញាតឲ្យខ្ញុំធ្វើការនេះ”
ព្រះបុត្រា
ជាឋានៈសំខាន់របស់ព្រះយេស៊ូ។ ។
John 11:5
ព្រះយេស៊ូស្រឡាញ់នាងម៉ាថា និងប្អូនស្រីរបស់នាង ព្រមទាំងឡាសាផង
នេះជាប្រវត្តិពត៌មាន។
John 11:8
រ៉ាប៊ី ពួកយូដាកំពុងតែចង់ចោលព្រះអង្គនឹងដុំថ្ម តើព្រះអង្គនៅតែចង់ត្រឡប់ទៅវិញម្តងទៀត?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ ដើម្បីបញ្ជាក់ថា
ពួកសិស្សមិនចង់ឲ្យព្រះយេស៊ូយាងទៅក្រុងយេរូសាឡឹមទេ។ "លោកគ្រូ
ប្រាកដជាមិនចង់វិលត្រឡប់ទៅទីនោះទេ!
ជនជាតិយូដាបានព្យាយាមគប់ដុំថ្មសម្លាប់លោកគ្រូ ពេលទៅទីនោះចុងក្រោយ!"
យូដា
នេះគឺជាការផ្តោតអារម្មណ៍មួយទៅលើមេដឹកនាំសាសន៍យូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។ "មេដឹកនាំសាសន៍យូដា"
តើមួយថ្ងៃមិនមានដប់ពីរម៉ោងទេឬអី?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"អ្នកដឹងថានៅពេលថ្ងៃមានពន្លឺដប់ពីរម៉ោង!"
ប្រសិនបើ អ្នកណាម្នាក់ដើរនៅពេលថ្ងៃ គាត់នឹងមិនជំពប់ទេ ព្រោះគាត់មើលឃើញ
ដោយសារពន្លឺរបស់លោកីយ៍នេះ
មនុស្សដែលដើរក្នុងពន្លឺថ្ងៃអាចមើលឃើញល្អ ហើយមិនជំពប់ដួល។ "ពន្លឺ"
ជាពាក្យប្រៀបធៀបសម្រាប់ "សេចក្តីពិត" ។ ព្រះយេស៊ូកំពុងតែមានបន្ទូលថា
មនុស្សដែលរស់នៅស្របតាមសេចក្តីពិត នឹងអាចទទួលបានជោគជ័យនូវអ្វី
ដែលព្រះអង្គសព្វព្រះហឫទ័យឲ្យពួកគេធ្វើ។
John 11:10
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានប្រសាសន៍ទៅកាន់សិស្សរបស់ព្រះអង្គ។
ប្រសិនបើ គាត់ដើរពេលយប់វិញ
នៅទីនេះ "យប់" គឺជាពាក្យប្រៀបធៀប ដែលសំដៅទៅលើការដើររបស់មនុស្សម្នាក់
ដោយគ្មានពន្លឺរបស់ព្រះអង្គ។
ពន្លឺមិននៅក្នុងគាត់ទេ
អាចមានន័យថា ១) "គាត់មិនអាចមើលឃើញ" ឬ
"គាត់មិនមានពន្លឺរបស់ព្រះជាម្ចាស់" ។
មិត្តសម្លាញ់របស់យើងឡាសាបានដេកលក់ហើយ
“ ដេកលក់” នៅទីនេះមានន័យថាឡាសារបានស្លាប់ហើយ។
ប្រសិនបើអ្នកមានវិធីនិយាយបែបនេះជាភាសារបស់អ្នក
អ្នកអាចប្រើវានៅទីនេះបាន។
ប៉ុន្តែ ខ្ញុំនឹងទៅ ដើម្បីខ្ញុំដាស់គាត់ឲ្យក្រោកពីគេវិញ
ពាក្យថា "ដាស់គាត់ឲ្យភ្ញាក់ពីដំណេក" គឺថា
ព្រះយេស៊ូកំពុងបង្ហាញផែនការរបស់ព្រះអង្គ
ដើម្បីធ្វើឲ្យឡាសារមានជីវិតរស់ឡើងវិញ។
ប្រសិនបើអ្នកមានពាក្យផ្សេងក្នុងភាសារបស់អ្នក អ្នកអាចប្រើវាបាននៅទីនេះ។
John 11:12
ព័ត៌មានទូទៅ:
នៅក្នុងខ ១៣ មានការផ្អាកនៅក្នុងដំណើររឿង
ពេលយ៉ូហាននិយាយអំពីការយល់ច្រឡំរបស់ពួកសិស្សនូវអ្វី
ដែលព្រះយេស៊ូចង់មានន័យ ពេលទ្រង់មានបន្ទូលថាឡាសារកំពុងតែដេកលក់។
ប្រសិនបើ គាត់ដេកលក់មែន
ពួកសិស្សយល់ច្រលំនឹងន័យ ដែលព្រះយេស៊ូថាឡាសារកំពុងតែសម្រាក
ហើយនឹងបានជាឡើងវិញ។
បន្ទាប់មក ព្រះយេស៊ូមានបន្ទូលទៅពួកគេយ៉ាងច្បាស់ថា
«ដូច្នេះព្រះយេស៊ូបានប្រាប់ពួកគេនូវពាក្យ ដែលពួកគេអាចយល់បាន»
John 11:15
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានប្រសាសន៍ទៅកាន់សិស្សរបស់ព្រះអង្គ។
ដោយព្រោះអ្នករាល់គ្នា
"ដើម្បីផលប្រយោជន៍របស់អ្នក"
ដែលខ្ញុំមិននៅទីនោះដើម្បីឲ្យអ្នករាល់គ្នាអាចជឿ
"ខ្ញុំមិននៅទីនេះទៀតទេ។ ដោយសារតែបញ្ហានេះអ្នកនឹងរៀនទុកចិត្តខ្ញុំកាន់តែខ្លាំង" ។
ដែលហៅថា ឌីឌីម
អ្នកអាចបកប្រែជាទម្រង់កិរិយាសកម្ម។ "អ្នកដែលពួកគេហៅថាឌីឌីម"
ឌីឌីម
គឺជាឈ្មោះបុរសដែលមានន័យថា "ភ្លោះ" ។
John 11:17
ព័ត៌មានទូទៅ:
ឥឡូវនេះព្រះយេស៊ូនៅភូមិបេថានី។
ខគម្ពីរទាំងនេះផ្តល់នូវព័ត៌មានសំខាន់អំពីការរៀបចំ
និងអំពីអ្វីដែលបានកើតឡើងមុនពេលព្រះយេស៊ូមកដល់។
ព្រះអង្គបានឃើញថា ឡាសាត្រូវបានដាក់ទៅក្នុងផ្នូរបួនថ្ងៃរួចស្រេចទៅហើយ
អ្នកអាចបកប្រែជាទម្រង់កិរិយាសកម្ម។

generated on Wed Sep 10 16:16:32 2025

"ទ្រង់បានដឹងថាគេបានដាក់ឡាសារនៅក្នុងផ្នូរបួនថ្ងៃមុនហើយ"
បីគីឡូម៉ែត្រ
"ចម្ងាយប្រហែលបីគីឡូម៉ែត្រ។ " កីឡដ្ឋានមួយមានប្រវែង ១៨៥ ម៉ែត្រ។
បួនរបស់របស់ពួកគេ
ឡាសារជាប្អូនប្រុសរបស់ពួកគេ។ "អំពីប្អូនប្រុសរបស់ពួកគេ"
John 11:21
ប្អូនប្រុសរបស់ខ្ញុំម្ចាស់មិនស្លាប់ទេ
ឡាសារជាប្អូនប្រុស។: "ប្អូនប្រុសរបស់ខ្ញុំនឹងនៅរស់"
ប្អូនប្រុសរបស់នាងនឹងរស់ឡើងវិញម្តងទៀត
ឡាសារជាប្អូនប្រុស។ "ប្អូនប្រុសរបស់អ្នកនឹងមានជីវិតរស់ឡើងវិញ"
John 11:24
គាត់ឲ្យរស់ឡើងវិញ
"គាត់នឹងមានជីវិតឡើងវិញ"
ទោះបើស្លាប់ក៏ដោយ
នៅទីនេះ "ស្លាប់" សំដៅទៅលើការស្លាប់ខាងរូបកាយ។
នឹងរស់ឡើងវិញជាមិនខាន
នៅទីនេះ "រស់" សំដៅទៅលើជីវិតខាងវិញ្ញាណ។
ហើយអស់អ្នកដែលរស់នៅនៅឡើយ ដែលជឿដល់ខ្ញុំ នឹងមិនស្លាប់ឡើយ
"អ្នកដែលរស់នៅហើយទុកចិត្តលើខ្ញុំ នឹងមិនដែលឃ្លាតឆ្ងាយពីព្រះជាម្ចាស់ឡើយ"
ឬ "អ្នកដែលរស់នៅនិងទុកចិត្តខ្ញុំនឹងរស់នៅជាមួយព្រះជាម្ចាស់ជារៀងរហូត"
នឹងមិនស្លាប់ឡើយ
នៅទីនេះ "ស្លាប់" សំដៅទៅលើការស្លាប់ខាងវិញ្ញាណ។
John 11:27
នាងនិយាយទៅកាន់ព្រះអង្គថា
"ម៉ាថាបាននិយាយទៅកាន់ព្រះយេស៊ូ"
ចាស៎ ព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿថា ព្រះអង្គគឺជាព្រះគ្រិស្ត ជាព្រះបុត្រានៃព្រះជាម្ចាស់
ដែលបានយាងមកនៅលើផែនដីនេះ
ម៉ាថាជឿជាក់ថា ព្រះយេស៊ូជាព្រះអម្ចាស់ ព្រះគ្រិស្តជា (ព្រះមេស្ស៊ី) ជាព្រះបុត្រា។
ព្រះបុត្រា
ជាឋានៈសំខាន់របស់ព្រះយេស៊ូ។ ។
នាងបានចេញទៅហៅនាងម៉ារីជាប្អូនស្រីរបស់នាង
ម៉ារីជាប្អូនស្រីរបស់ម៉ាថា។ "នាងបានទៅឆ្ងាយហើយបានហៅប្អូនស្រីគឺនាងម៉ារី"
លោកគ្រូម
ជាងារសំដៅទៅលើព្រះយេស៊ូ។
សួររកអូនឯង
"កំពុងសួរថាអ្នកមក"
John 11:30
ព្រះយេស៊ូមិនទាន់បានចូលទៅក្នុងភូមិនៅឡើយទេ
នៅទីនេះយ៉ូហានឈប់សម្រាកខ្លីនៅក្នុងរឿង
ដើម្បីផ្តល់ព័ត៌មានសំខាន់ទាក់ទងនឹងទីកន្លែងរបស់ព្រះយេស៊ូ។
លុតជង្គង់ចុះនៅជិតព្រះបាទាព្រះអង្គ
ម៉ារីបានក្រាបចុះ ឬលុតជង្គង់នៅព្រះបាទាព្រះយេស៊ូដើម្បីបង្ហាញការគោរព។
បួនប្រុសរបស់ខ្ញុំម្ចាស់ មិនស្លាប់ទេ
ឡាសារជាប្អូនប្រុសរបស់ម៉ារី។ សូមមើលពីរបៀប ដែលអ្នកបានបកប្រែវានៅក្នុង
១១:២១ ។ "ប្អូនប្រុសរបស់ខ្ញុំនឹងនៅតែមានជីវិត" ។
John 11:33
ព្រះអង្គមានព្រះទ័យក្តុកក្តួលជាខ្លាំងនៅខាងក្នុងវិញ្ញាណរបស់ព្រះអង្គ ហើយអន្ទះសារជាខ្លាំង
យ៉ូហានបញ្ចូលឃ្លាទាំងនេះជាមួយគ្នា ធ្វើឲ្យមានអត្ថន័យស្រដៀងគ្នា
ដើម្បីបង្ហាញពីអារម្មណ៍តានតឹងយ៉ាងខ្លាំង និងកំហឹងដែលអាចកើតមានឡើង
ទោះបីព្រះយេស៊ូក៏បានឆ្លងកាត់ផ្ទាល់។ "ព្រះអង្គពីជាមិនសប្បាយចិត្តទេ"
តើអ្នកបានគាត់នៅឯណា
ជារបៀបដ៏សាមញ្ញសួរថា "តើអ្នកបានបញ្ចុះគាត់នៅឯណា?"
ព្រះយេស៊ូព្រះកន្សែង
"ព្រះយេស៊ូចាប់ផ្តើមយំ" ឬ "ព្រះយេស៊ូព្រះកន្សែង"
John 11:36
ស្រឡាញ់
សំដៅទៅលើសេចក្តីស្រឡាញ់ជាបងប្អូន
ឬសេចក្តីស្រឡាញ់របស់មនុស្សចំពោះមិត្តភក្តិ ឬសមាជិកគ្រួសារ។
តើបុរសម្នាក់នេះ ដែលអាចធ្វើឲ្យមនុស្សខ្វាក់ភ្លឺបាន តើគាត់អាចធ្វើឲ្យបុរសនេះមិនស្លាប់បានទេ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបង្ហាញការភ្ញាក់ផ្អើលរបស់ជនជាតិយូដា
ដែលព្រះយេស៊ូមិនបានប្រោសឡាសារ។ "ទ្រង់អាចប្រោសបុរសពិការភ្នែក
ដូច្នេះទ្រង់គួរតែប្រោសបុរសម្នាក់នេះ ដើម្បីកុំឲ្យគាត់ស្លាប់" ឬ
""ដោយសារទ្រង់មិនបានការពារបុរសនេះពីការស្លាប់
ដូច្នេះប្រហែលជាទ្រង់មិនបានប្រោសបុរសដែលខ្វាក់ពីកំណើតនោះទេ
ដូចពួកគេនិយាយថា ព្រះអង្គបានធ្វើនោះ!"
ធ្វើឲ្យមនុស្សខ្វាក់ភ្លឺ
ជាពាក្យក្រៀមភាសា។ "ប្រោសភ្នែកឲ្យភ្លឺ"
John 11:38
នៅឯផ្នូរ មានថ្មបិទជិត
យ៉ូហានផ្អាកដំណើររឿង
ដើម្បីពិពណ៌នាអំពីផ្នូរដែលប្រជាជនបានបញ្ចុះសពឡាសារ។
នាងម៉ាថា បងស្រីរបស់ឡាសា
ម៉ាថានិ ងម៉ារីជាបងស្រីរបស់ឡាសារ។ “ ម៉ាថាដែលជាបងស្រីច្បងរបស់ឡាសា”
មកដល់ពេលនេះរូបកាយរលួយហើយ
"នៅពេលនេះនឹងមានក្លិនមិនល្អ" ឬ "រាងកាយមានក្លិនស្អុយរួចហើយ"
តើខ្ញុំមិនបាននិយាយទេឬអីថា ប្រសិនបើអ្នកជឿ អ្នកនឹងបានឃើញសិរីល្អរបស់ព្រះជាម្ចាស់?
ការកត់សម្គាល់នេះលេចចេញជាទម្រង់សំណួរ
ដើម្បីបន្ថែមការសង្កត់ន័យទៅលើចំណុច
ដែលព្រះជាម្ចាស់ប្រហែលនឹងធ្វើការអស្ចារ្យ។ "ខ្ញុំបានប្រាប់អ្នកថា បើអ្នកទុកចិត្តខ្ញុំ
អ្នកនឹងឃើញអ្វីដែលព្រះជាម្ចាស់អាចធ្វើបាន!"
John 11:41
ព្រះយេស៊ូបានសម្លឹងមើល
ជាពាក្យមានន័យថារកមើល។ "ព្រះយេស៊ូទតមើលទៅលើឋានសួគ៌"
ព្រះបិតាអើយ ទូលបង្គំដឹងថា ព្រះអង្គស្តាប់ទូលបង្គំ
ព្រះយេស៊ូអធិដ្ឋានទៅព្រះបិតាដោយផ្ទាល់
ដើម្បីឲ្យអ្នកឯទៀតដែលនៅជុំវិញព្រះអង្គ ឮសេចក្តីអធិស្ឋានរបស់ព្រះអង្គ។
"ព្រះបិតា ខ្ញុំសូមអរគុណដែលព្រះអង្គបានឮទូលបង្គំ" ឬ
"ព្រះបិតាខ្ញុំសូមអរគុណព្រះអង្គដែលបានឮការអធិស្ឋានរបស់ទូលបង្គំ" ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ជឿថាព្រះអង្គបានចាត់ទូលបង្គំឲ្យមក
"ខ្ញុំចង់ឲ្យពួកគេជឿថា ព្រះអង្គបានបញ្ជូនទូលបង្គំមក"
John 11:43
បន្ទាប់ពីព្រះអង្គមានបន្ទូលរួចហើយ
"បន្ទាប់ពីព្រះយេស៊ូបានអធិស្ឋាន"
ព្រះអង្គក៏ស្រែកសម្លេងយ៉ាងខ្លាំងថា
"ទ្រង់បានស្រែក"
ជើង និងដៃរបស់គាត់ត្រូវបានចងដោយក្រណាត់
ហើយមុខរបស់គាត់ក៏ត្រូវបានចងដោយក្រណាត់ដែរ
តាមទំនៀមទម្លាប់បញ្ចុះសព គេរុំសពនឹងក្រណាត់ទេសឯកវែង។
អាចបញ្ជាក់ជាទម្រង់កិរិយាសកម្ម។ "មានគេយកក្រណាត់រុំដៃ និងជើងរបស់គាត់។
ពួកគេក៏បានចងក្រណាត់រុំមុខគាត់ដែរ"
ព្រះយេស៊ូមានបន្ទូលទៅពួកគេថា
ពាក្យថា“ ពួកគេ”
សំដៅទៅលើមនុស្សដែលនៅទីនោះហើយបានឃើញការអស្ចារ្យ។
John 11:45
ព័តមានទូទៅ:
ខគម្ពីរទាំងនេះប្រាប់យើងពីអ្វី
ដែលបានកើតឡើងបន្ទាប់ព្រះយេស៊ូបានប្រោសឡាសាឲ្យរស់ឡើងវិញ។
John 11:47
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃសាច់រឿង។
ពួកនាយកបូជាចារ្យនិងពួកខាងគណៈផារីស៊ីប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់របស់ជនជាតិយូដា។
នាយកបូជាចារ្យ
"បន្ទាប់មកមេដឹកនាំក្នុងចំណោមបូជាចារ្យ"
តើយើងត្រូវធ្វើអ្វី?
បានបញ្ជាក់នៅទីនេះថា សមាជិកក្រុមប្រឹក្សាកំពុងនិយាយអំពីព្រះយេស៊ូ។

generated on Wed Sep 10 16:16:32 2025

"តើយើងនឹងធ្វើអ្វីចំពោះព្រះយេស៊ូ?"
មនុស្សគ្រប់គ្នាមុខជាជឿលើគាត់មិនខាន
អ្នកដឹកនាំជនជាតិយូដាភ័យខ្លាចថា
ប្រជាជននឹងព្យាយាមតែងតាំងព្រះយេស៊ូជាស្តេចរបស់ពួកគេ។
"មនុស្សគ្រប់គ្នានឹងជឿជាក់លើគាត់ ហើយបះបោរប្រឆាំងនឹងរ៉ូម" ។
ពួករ៉ូមនឹងមក
នេះជាការរួមបញ្ចូលគ្នាជាមួយកងទ័ពរ៉ូម៉ាំង។ "កងទ័ពរ៉ូម៉ាំងនឹងមក" ។
នឹងគ្រប់គ្រងលើយើង និងប្រទេសយើងផង
"បំផ្លាញទាំងព្រះវិហារ និងប្រទេសជាតិយើង"
John 11:49
មានបុរសម្នាក់នៅក្នុងចំណោមពួកគេ
ជាវិធីណែនាំតួអង្គថ្មីក្នុងសាច់រឿង។
បើអ្នកមានវិធីដើម្បីធ្វើវាជារបៀបភាសារបស់អ្នក អ្នកអាចប្រើវានៅទីនេះបាន។
អ្នករាល់គ្នាគ្មានដឹងអ្វីទាំងអស់
ជាពាក្យដែលលោកកៃផាប្រើ ដើម្បីបន្ថែមការសង្កត់ន័យទៅលើចំណុចរបស់គាត់។
"អ្នកមិនយល់ពីអ្វីដែលកំពុងកើតឡើងទេ!" ឬ
"អ្នកនិយាយដូចជាអ្នកមិនដឹងរឿងអ្វីទាំងអស់!"
មនុស្សមួយប្រទេសត្រូវវិនាស
កៃផាសបង្កប់ន័យថា កងទ័ពរ៉ូម៉ាំងនឹងសម្លាប់ប្រជាជនយូដាទាំងអស់
បើព្រះយេស៊ូនៅរស់និងបង្កឲ្យមានការបះបោរ។ ពាក្យថា“ ជាតិ”
នៅទីនេះជានិមិត្តរូបមួយ ដែលតំណាឲ្យប្រជាជនយូដាទាំងអស់។ “
រ៉ូម៉ាំងបានសម្លាប់ប្រជាជនទាំងអស់ នៅក្នុងប្រទេសជាតិយើង”
John 11:51
ព័ត៌មានទូទៅ:
នៅក្នុងខ៥១ និង៥២ យ៉ូហានពន្យល់ថា
កៃផាកំពុងថ្លែងទំនាយទោះបីគាត់មិនបានដឹងពេលវេលាក៏ដោយ។
នេះជាព័ត៌មានសំខាន់។
សុគតដើម្បីប្រទេសជាតិ
ពាក្យថា“ ប្រជាជាតិ” ជានិមិត្តរូបមួយសំដៅទៅលើប្រជាជន
ក្នុងប្រទេសអ៊ីស្រាអែល។
ប្រមូលមូលរួមតែមួយវិញ
ពាក្យ "ប្រជាជន" បង្កប់ន័យតាមបរិបទ។ “ នឹងត្រូវប្រមូលផ្តុំគ្នាជាប្រជាជនតែមួយ”
បុត្រធីតារបស់ព្រះជាម្ចាស់
សំដៅទៅលើមនុស្សដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់
ដោយសារជំនឿលើព្រះយេស៊ូ និងជាកូនខាងវិញ្ញាណរបស់ព្រះជាម្ចាស់។
John 11:54
ព័ត៌មានទូទៅ:
ព្រះយេស៊ូចាកចេញពីភូមិបេថានីហើយទៅអេប្រាអ៊ីម។ នៅក្នុងខ៥៥
រឿងបង្វែរទៅប្រាប់អំពីអ្វី ដែលជនជាតិយូដាជាច្រើនកំពុងធ្វើនៅពេលនេះ
ថាបុណ្យចម្លងជិតមកដល់ហើយ។
យាងនៅក្នុងចំណោមពួកគេជាសាធារណៈ
"យូដា"នៅត្រង់នេះ ជាភាពស៊ីចង្វាក់គ្នារវាងមេដឹកនាំយូដា។ “
ដើរដោយបើកចំហក្នុងចំណោមមេដឹកនាំជនជាតិយូដា ដែលប្រឆាំងនឹងព្រះអង្គ”
តំបន់
តំបន់ជនបទក្រៅទីក្រុង ដែលពុំសូវមានមនុស្សរស់នៅ។
ព្រះអង្គគង់នៅទីនោះជាមួយពួកសិស្ស
ព្រះយេស៊ូ និងពួកសិស្សរបស់ព្រះអង្គបានស្នាក់នៅអេប្រាអ៊ីមមួយរយៈ។ “
នៅទីនោះទ្រង់បានស្នាក់នៅជាមួយពួកសិស្សក្នុងរយៈពេលខ្លី”
បានឡើងទៅក្រុងយេរូសាឡឹម
ឃ្លាថា "បានកើនឡើង" ប្រើនៅទីនេះ
ព្រោះក្រុងយេរូសាឡឹមមានកំពស់ខ្ពស់ជាងតំបន់ជុំវិញនោះ។
John 11:56
ព័ត៌មានទូទៅ:
ខ្លឹមសារនៃខ៥៧ កើតឡើងមុនខ៥៦។ បើបទបញ្ជានេះធ្វើឲ្យអ្នកអានច្របូកច្របល់
អ្នកអាចបញ្ចូលខគម្ពីរទាំងនេះ ហើយដាក់អត្ថបទនៃខ ៥៧ មុនអត្ថបទនៃខ ៥៦ ។
ពួកគេស្វែងរកព្រះយេស៊ូ
ពាក្យថា“ ពួកគេ” សំដៅទៅលើប្រជាជនយូដា
ដែលបានធ្វើដំណើរទៅក្រុងយេរូសាឡឹម។
តើអ្នកគិតយ៉ាងដូចម្តេច? ថាតើគាត់នឹងមិនមកចូលរួមពិធីបុណ្យទេឬអី?
ទាំងនេះជាសំនួនវោហាស័ព្ទ ដែលបង្ហាញពីការសង្ស័យយ៉ាងខ្លាំងថា
ព្រះយេស៊ូនឹងយាងមកបុណ្យចម្លង។ សំណួរទីពីរគឺថា "តើអ្នកគិតទេ?"
វាគ្មិននៅទីនេះមានការងឿងឆ្ងល់ថា
តើព្រះយេស៊ូនឹងមកចូលរួមពិធីបុណ្យនេះដែរឬទេ?
ព្រោះអាចមានគ្រោះថ្នាក់ដល់ការចាប់ខ្លួនព្រះអង្គ។
"ព្រះយេស៊ូប្រហែលជាមិនមកចូលរួមពិធីបុណ្យទេ។
ទ្រង់ប្រហែលជាខ្លាចការចាប់ខ្លួន!"
នាយកបូជាចារ្យ
នេះជាព័ត៌មានសំខាន់ពន្យល់ពីមូលហេតុ ដែលអ្នកថ្វាយបង្គំជនជាតិយូដាឆ្ងល់ថា
តើព្រះយេស៊ូនឹងមកពិធីបុណ្យនេះឬអត់។
បើភាសារបស់អ្នកមានវិធីសម្គាល់ព័ត៌មានសំខាន់ សូមប្រើនៅទីនេះចុះ។

---

12 [1]ប្រាំមួយថ្ងៃមុនថ្ងៃបុណ្យរំលង ព្រះយេស៊ូបានយាងចូលភូមិបេថានី ជាកន្លែងដែល ព្រះយេស៊ូបានប្រោសឡាសា ពីស្លាប់ឡើងវិញ។[2]ដូច្នេះ
ពួកគេបានចម្អិនអាហារល្ងាចសម្រាប់ព្រះអង្គនៅទីនោះ ហើយនាងម៉ាថាជាអ្នកធ្វើម្ហូប ប៉ុន្តែ ឡាសាគឺជាម្នាក់ដែលអង្គុយរួមតុជាមួយព្រះយេស៊ូ។[3]បន្ទាប់មក
នាងម៉ារីបានយកទឹកអប់ដែលធ្វើឡើងចេញពីទេព្វិរូបរិសុទ្ធដ៏មានតម្លៃបំផុត ចាក់លាបព្រះបាទារបស់ព្រះយេស៊ូជាមួយទឹកអប់នោះ
ហើយបានជូតជើងព្រះអង្គជាមួយនឹងសក់របស់នាង។ នៅក្នុងផ្ទះពេញដោយក្លិនក្រអូបរបស់ទឹកអប់នោះ។
[4]លោកយូដាសអ៊ីស្ការីយ៉ុត ជាសិស្សម្នាក់ក្នុងចំណោមសិស្សរបស់ព្រះអង្គ ជាម្នាក់ដែលក្បត់ព្រះអង្គ បាននិយាយថា៖[5]«ម្តេចមិនយកទឹកអប់ទៅលក់បីរយឌេណារី
រួចចែកដល់អ្នកក្រទៅ?»។[6]គាត់និយាយដូច្នេះ មិនមែនដោយសារគាត់យកទុកដាក់ជាមួយអ្នកក្រទេ ប៉ុន្តែ ដោយសារគាត់ជាចោរ គាត់ជាអ្នកកាន់ថង់លុយ
ហើយគាត់បានលួចពីអ្វីដែលដាក់ទៅក្នុងថង់នោះ។
[7]ព្រះយេស៊ូមានបន្ទូលថា៖ «ឲ្យនាងបន្តធ្វើអ្វីដែលនាងមានសម្រាប់ថ្ងៃបញ្ចុះសពរបស់ខ្ញុំចុះ។ អ្នករាល់គ្នាតែងតែមានអ្នកក្រនៅជាមួយអ្នករាល់គ្នាជានិច្ច។[8]ប៉ុន្តែ
ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតទេ»។
[9]មានសាសន៍ជាច្រើនបានដឹងថា ព្រះយេស៊ូនៅទីនោះ ហើយពួកគេក៏មករក មិនគ្រាន់តែមករកព្រះយេស៊ូទេ ប៉ុន្តែ ពួកគេក៏ចង់ឃើញឡាសា
ដែលព្រះយេស៊ូបានប្រោសគាត់ពីសេចក្តីស្លាប់ឡើងវិញដែរ។[10]នាយកបូជាចារ្យបានរួមគំនិតគ្នាធ្វើដូច្នោះ ដើម្បីចង់សម្លាប់ឡាសាដែរ។[11]ដោយសារតែគាត់
សាសន៍យូដាជាច្រើនចេញពីពួកគេ ហើយបានជឿលើព្រះយេស៊ូ។
[12]នៅថ្ងៃបន្ទាប់មានហ្វូងមនុស្សយ៉ាងច្រើនកោះករទៅចូលរួមបុណ្យ។ នៅពេលពួកគេឮថាព្រះយេស៊ូមកក្រុងយេរូសាឡិមដែរ[13]ពួកគេបានយកស្លឹកត្នោត
ហើយចេញទៅជួបព្រះអង្គ ហើយស្រែកឡើងថា «ហូសាណា! មានពរហើយ អ្នកដែលមកក្នុងព្រះនាមព្រះអម្ចាស់ ជាព្រះមហាក្សត្រនៃអ៊ីស្រាអែល»។
[14]ព្រះយេស៊ូបានជួបជាមួយនឹងសត្វលាស្ទាវមួយ ហើយក៏គង់នៅលើវា ដូចមានសេចក្តីចែងទុកមកថា៖[15]«កុំខ្លាចអី កូនស្រីស៊ីយ៉ូនអើយ ព្រះមហាក្សត្ររបស់អ្នកមកហើយ
ព្រះអង្គគង់នៅលើខ្នងលា។
[16]ដំបូង ពួកសិស្សរបស់ព្រះអង្គមិនយល់ពីការទាំងនេះទេ ប៉ុន្តែ នៅពេលព្រះយេស៊ូបានទទួលសិរីល្អ ពួកគេបាននឹកចាំ ការទាំងនេះដែលបានចែងអំពីព្រះអង្គ
ហើយពួកគេបានធ្វើការទាំងនេះចំពោះព្រះអង្គ។
[17]បណ្តាជនបានធ្វើបន្ទាល់ថា ពួកគេបាននៅជាមួយព្រះអង្គ នៅពេលទ្រង់ហៅឡាសាចេញពីផ្នូរ ហើយប្រោសគាត់ឲ្យរស់ពីស្លាប់មកវិញ។[18]ដោយសារហេតុផលនេះហើយ
បានជាបណ្តាជនចេញទៅជួបព្រះអង្គ ព្រោះពួកគេបានឮថាព្រះអង្គបានធ្វើទីសម្គាល់នេះ។[19]ដូច្នេះ ពួកផារីស៊ីបាននិយាយនៅក្នុងចំណោមពួកគេថា៖
«អ្នករាល់គ្នាមិនអាចធ្វើអ្វីបានទាល់តែសោះ មើល! មនុស្សបានទៅតាមអ្នកនោះអស់ហើយ»។

generated on Wed Sep 10 16:16:32 2025

[20]សាសន៍ក្រិកមួយចំនួននៅក្នុងចំណោមអស់អ្នកដែលឡើងទៅថ្វាយបង្គំនៅថ្ងៃបុណ្យនោះ។[21]ពួកគេបានទៅជួបលោកភីលីព ជាអ្នកដែលមកពីភូមិបេតសៃដា ក្នុងស្រុកកាលីឡេ បានសួរគាត់ ហើយនិយាយថា៖ «លោក ពួកយើងចង់ជួបព្រះយេស៊ូ»។[22]លោកភីលីពបានទៅជួប ហើយប្រាប់លោកអនទ្រេ ហើយលោកអនទ្រេ និងលោកភីលីពបានទៅជួប ហើយពួកគេបានប្រាប់ព្រះយេស៊ូ។
[23]ព្រះយេស៊ូឆ្លើយទៅពួកគេ ហើយមានបន្ទូលថា៖ «ពេលកំណត់មកដល់ហើយ ដែលកូនមនុស្សនឹងទទួលសិរីល្អ។[24]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវមិនកប់ទៅក្នុងដី ហើយស្លាប់ទេ វានៅតែជាគ្រាប់ស្រូវដដែល ប៉ុន្តែ ប្រសិនបើវាស្លាប់ វានឹងបង្កើតផលជាច្រើន។
[25]អ្នកណាដែលស្រឡាញ់ជីវិតរបស់ខ្លួន នឹងបាត់ជីវិតនោះ ប៉ុន្តែ អ្នកណាដែលស្អប់ជីវិតរបស់ខ្លួននៅក្នុងលោកីយ៍នេះ នឹងរក្សាវាដើម្បីជីវិតអស់កល្បជានិច្ច។[26]ប្រសិនបើអ្នកណាម្នាក់បម្រើខ្ញុំ ឲ្យគេបម្រើខ្ញុំចុះ ហើយបើខ្ញុំនៅទីណា អ្នកបម្រើខ្ញុំនឹងនៅទីនោះដែរ។ ប្រសិនបើ អ្នកណាម្នាក់បម្រើខ្ញុំព្រះបិតាខ្ញុំនឹងផ្តល់កិត្តិយសដល់អ្នកនោះ។
[27]ឥឡូវនេះ ព្រលឹងខ្ញុំខ្វល់ខ្វាយ ហើយខ្ញុំនឹងនិយាយយ៉ាងដូចម្តេច? ឱព្រះបិតាអើយ សូមសង្គ្រោះទូលបង្គំនៅក្នុងវេលានេះ ប៉ុន្តែ ហេតុផលដែលទូលបង្គំមក គឺដើម្បីវេលានេះឯង។[28]ឱព្រះបិតាអើយ សូមថ្វាយសិរីរុងរឿងដល់ព្រះនាមព្រះអង្គ»។ បន្ទាប់មក មានសម្លេងពីស្ថានសួគ៌មក ហើយមានបន្ទូលថា៖ «យើងបានទទួលសិរីរុងរឿង ហើយនឹងទទួលសិរីរុងរឿងម្តងទៀត»។[29]នោះ បណ្តាជនដែលឈរនៅជិត បានឮ ហើយនិយាយថា «មានសម្លេងផ្គរលាន់»។ ហើយអ្នកខ្លះទៀតនិយាយថា៖ «ទេវតាបាននិយាយជាមួយគាត់»។
[30]ព្រះយេស៊ូឆ្លើយ ហើយមានបន្ទូលថា៖ «សម្លេងដែលឮនេះមិនមែនសម្រាប់ខ្ញុំទេ ប៉ុន្តែ សម្រាប់អ្នករាល់គ្នាវិញ។
[31]សេចក្តីជំនុំជម្រះរបស់លោកីយ៍នេះមកដល់ហើយនៅពេលនេះ ហើយដល់ពេលដែលពួកគ្រប់គ្រងលោកីយ៍នេះ ត្រូវបោះទៅក្រៅហើយ។
[32]នៅពេលដែលខ្ញុំត្រូវបានលើកឡើងពីលោកីយ៍ ខ្ញុំនឹងនាំអ្នករាល់គ្នាមកជិតខ្លួនខ្ញុំផ្ទាល់។[33]ព្រះអង្គមានបន្ទូលដូច្នេះ ដើម្បីបង្ហាញពីបែបបទនៃសេចក្តីស្លាប់ដែលព្រះអង្គត្រូវសុគត។
[34]បណ្តាជនបានទូលឆ្លើយទៅកាន់ព្រះអង្គថា៖ «យើងបានឮពីក្រឹត្យវិន័យថា ព្រះគ្រិស្តនឹងគង់នៅអស់កល្បជានិច្ច។ តើយើងអាចនិយាយយ៉ាងដូចម្តេច «បុត្រមនុស្សត្រូវតម្កើងឡើង? តើអ្នកណាជាបុត្ររបស់មនុស្ស?»[35]បន្ទាប់មកព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ពន្លឺនឹងនៅជាមួយអ្នករាល់គ្នាក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ចូរដើរក្នុងការដែលអ្នករាល់គ្នានៅក្នុងពន្លឺនៅឡើយ ធ្វើដូច្នេះ ដើម្បីកុំឲ្យសេចក្តីងងឹតយកឈ្នះអ្នករាល់គ្នាឡើយ។ អស់អ្នកណាដែលដើរក្នុងសេចក្តីងងឹត មិនដឹងថាពួកគេកំពុងទៅណាទេ។[36]ក្នុងការដែលអ្នករាល់គ្នាមានពន្លឺ ចូរជឿលើពន្លឺ ដើម្បីឲ្យអ្នករាល់គ្នាបានក្លាយជាកូននៃពន្លឺ»។
ព្រះយេស៊ូមានបន្ទូលការទាំងនេះរួចហើយ ព្រះអង្គក៏ចាកចេញទៅ ហើយលាក់ខ្លួនពីពួកគេ។
[37]ទោះបីជាព្រះយេស៊ូបានធ្វើទីសម្គាល់ជាច្រើននៅចំពោះពួកគេ ប៉ុន្តែ ពួកគេនៅតែមិនជឿលើព្រះអង្គទៀត[38]ដូច្នេះ
ដើម្បីឲ្យពាក្យរបស់ព្យាការីអេសាយបានមានប្រសាសន៍ថា៖ «ព្រះអម្ចាស់អើយ តើអ្នកណាជឿលើការរាយការណ៍របស់យើង
ហើយព្រះអម្ចាស់ចង់ឲ្យអ្នកណាឃើញព្រះហស្តរបស់ព្រះអង្គ?»
[39]ដ្បិត ហេតុផលដែលពួកគេមិនអាចជឿ ព្រោះលោកអេសាយក៏បានមានប្រសាសន៍ដូច្នេះដែរថា[40]«ព្រះអង្គបានធ្វើឲ្យភ្នែករបស់ពួកគេខ្វាក់
ហើយព្រះអង្គក៏ធ្វើឲ្យចិត្តរបស់ពួកគេរឹងរូសដែរ បើមិនដូច្នោះទេ ពួកគេអាចមើលឃើញដោយភ្នែករបស់ពួកគេ ហើយយល់នៅក្នុងចិត្តរបស់ពួកគេរឹង ហើយអាចប្រែចិត្ត ហើយយើងអាចប្រោសពួកគេឲ្យជា»។
[41]លោកអេសាយមានប្រសាសន៍ការទាំងនេះ ដោយសារគាត់ឃើញសិរីរុងរឿងរបស់ព្រះយេស៊ូ ហើយក៏មានប្រសាសន៍ពីព្រះអង្គ។[42]ប៉ុន្តែ សូម្បីតែអ្នកដឹកនាំជាច្រើនបានជឿលើព្រះយេស៊ូ ប៉ុន្តែដោយសារពួកផារីស៊ី ពួកគេមិនទទួលស្គាល់វាទេ ដើម្បីកុំឲ្យពួកគេត្រូវបណ្តេញចេញពីសាលាប្រជុំ។
[43]ពួកគេស្រឡាញ់ការសរសើរដែលមកពីមនុស្សច្រើនជាការសរសើរដែលមកពីព្រះជាម្ចាស់។
[44]ព្រះយេស៊ូបានបន្លឺសម្លេង ហើយមានបន្ទូលថា៖ «អ្នកណាដែលជឿដល់ខ្ញុំ មិនគ្រាន់តែជឿលើខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែ
អ្នកនោះបានជឿដល់ព្រះអង្គដែលចាត់ខ្ញុំឲ្យមកដែរ[45]ហើយអ្នកណាដែលឃើញខ្ញុំ អ្នកនោះក៏ឃើញព្រះដែលចាត់ខ្ញុំឲ្យមកដែរ។
[46]ខ្ញុំបានមកធ្វើជាពន្លឺនៃលោកីយ៍ ដូច្នេះ អស់អ្នកណាដែលជឿលើខ្ញុំ មិនស្ថិតនៅក្នុងសេចក្តីងងឹតឡើយ។[47]ប្រសិនបើ អ្នកណាម្នាក់ឮពាក្យខ្ញុំ ប៉ុន្តែ
មិនប្រព្រឹត្តតាមពាក្យនោះទេ ខ្ញុំមិនជំនុំជម្រះគាត់ទេ ដ្បិត ខ្ញុំមិនបានមកដើម្បីជំនុំជម្រះលោកីយ៍ ប៉ុន្តែ ដើម្បីសង្គ្រោះលោកីយ៍វិញ។
[48]អ្នកណាដែលបដិសេធខ្ញុំ ហើយអ្នកណាដែលមិនទទួលពាក្យរបស់ខ្ញុំ មានម្នាក់នឹងជំនុំជម្រះអ្នកនោះ។ ពាក្យដែលខ្ញុំបាននិយាយនឹងជំនុំជម្រះអ្នកនោះនៅថ្ងៃចុងក្រោយ។
[49]ដ្បិត ខ្ញុំមិនបាននិយាយដើម្បីខ្លួនខ្ញុំទេ ប៉ុន្តែ ព្រះបិតាដែលចាត់ខ្ញុំឲ្យមក ជាអ្នកប្រទានសេចក្តីបង្គាប់ដល់ខ្ញុំ ពីអ្វីដែលខ្ញុំត្រូវនិយាយ និងពីអ្វីដែលត្រូវប្រាប់។[50]ខ្ញុំដឹងថា សេចក្តីបង្គាប់របស់ព្រះអង្គគឺជាជីវិតអស់កល្បជានិច្ច នោះជាអ្វីដែលខ្ញុំនិយាយ ដូចដែលព្រះបិតាបានមានបន្ទូលមកកាន់ខ្ញុំ ដូច្នេះ ខ្ញុំក៏ប្រាប់»។

John 12:1
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃសាច់រឿង។
ពេលព្រះយេស៊ូកំពុងសោយព្រះស្ងោយនៅភូមិបេថានី
នាងម៉ារីក៏ចាក់ប្រេងក្រអូបលើព្រះបាទារបស់ព្រះអង្គ។
ទេព្វិរូប
"ទេព្វិរូប" ជារង្វាស់នៃទម្ងន់។ ប្រហែលមួយភាគបីនៃគីឡូក្រាម (0.3 គីឡូក្រាម) ។
ទឹកអប់
ជាអង្គធាតុរាវដែលមានក្លិនឈ្ងុយក្រអូប ផលិតដោយប្រើប្រេងរុក្ខជាតិនិងផ្កា។
ថ្លៃបំផុត
ជាទឹកអប់ដែលធ្វើពីផ្កាកណ្តឹងពំណផ្កាឈូក ដុះនៅលើភ្នំប្រទេសនេប៉ាល់ ចិន និងឥណ្ឌា។
នៅក្នុងផ្ទះពេញដោយក្លិនក្រអូបរបស់ទឹកអប់នោះ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ក្លិនក្រអូបនៃទឹកអប់របស់នាងមានក្លិនភាយពាសពេញផ្ទះ"
John 12:4
ម្នាក់ដែលក្បត់ព្រះអង្គ
«ម្នាក់ដែលក្រោយមកបានជួយសត្រូវរបស់ព្រះយេស៊ូ ឲ្យ ចាប់ព្រះអង្គ»
ម្តេចមិនយកទឹកអប់ទៅលក់បីរយឌេណារី រួចចែកដល់អ្នកក្រទៅ?
នេះជាសំនួរវោហាស័ព្ទ។ អ្នកអាចបកប្រែវាជាសេចក្តីថ្លែងដ៏រឹងមាំ។
"ទឹកអប់នេះអាចលក់ក្នុងតម្លៃ ៣០០ ឌីណារី
ហើយអាចយកប្រាក់នោះទៅជួយជនក្រីក្រ!"
បីរយឌេណារី
អ្នកអាចបកប្រែនេះជាលេខ។ ការបកប្រែផ្សេងទៀត "៣០០ឌេណារី»
ឌេណារី
មួយឌីណារីស្មើចំនួនប្រាក់ ដែលកម្មករធម្មតាអាចរកបានក្នុងមួយថ្ងៃ។
គាត់និយាយដូច្នេះ ....លួចពីអ្វីដែលដាក់ទៅក្នុងថង់នោះ
យ៉ូហានពន្យល់ពីមូលហេតុដែលយូដាសសួរសំណួរអំពីអ្នកក្រ។
បើភាសារបស់អ្នកមានវិធីបង្ហាញព័ត៌មានឲ្យមានសារៈសំខាន់ជាងនេះ
អ្នកអាចប្រើវានៅទីនេះបាន។
គាត់និយាយដូច្នេះ មិនមែនដោយសារគាត់យកទុកដាក់ជាមួយអ្នកក្រទេ ប៉ុន្តែ ដោយសារគាត់ជាចោរ
"គាត់និយាយបែបនេះពីព្រោះគាត់ជាចោរ។ គាត់មិនខ្វល់ពីអ្នកក្រ"
John 12:7
ឲ្យនាងបន្តធ្វើអ្វីដែលនាងមានសម្រាប់ថ្ងៃបញ្ចុះសពរបស់ខ្ញុំចុះ
ព្រះយេស៊ូបានបញ្ជាក់ថា សកម្មភាពរបស់ស្ត្រីជាការទន្ទឹងរង់ចាំមរណភាព
និងការបញ្ចុះសពរបស់ព្រះអង្គ។ "អនុញ្ញាតឲ្យនាងបង្ហាញថា នាងឲ្យតម្លៃដល់ខ្ញុំចុះ!
តាមរបៀបនេះ នាងបានរៀបចំរាងកាយរបស់ខ្ញុំសម្រាប់យកទៅបញ្ចុះ»
អ្នករាល់គ្នាតែងតែមានអ្នកក្រនៅជាមួយអ្នករាល់គ្នាជានិច្ច
ព្រះយេស៊ូបានបញ្ជាក់ថា អ្នករាល់គ្នាមានឱកាសជួយមនុស្សក្រីក្រ។
"នឹងមានមនុស្សក្រីក្រក្នុងចំណោមអ្នកជានិច្ច
ហើយអ្នកអាចជួយពួកគេពេលណាអ្នកចង់ជួយក៏បាន"
ប៉ុន្តែ ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតទេ

generated on Wed Sep 10 16:16:32 2025

តាមរបៀបនេះ ព្រះយេស៊ូបានបញ្ជាក់ថា ទ្រង់នឹងត្រូវសុគត។
"ប៉ុន្តែខ្ញុំនឹងមិននៅជាមួយអ្នកជានិច្ចទេ"
John 12:9
ឥឡូវនេះ
ពាក្យនេះត្រូវប្រើនៅទីនេះ ដើម្បីសម្គាល់ការផ្អាកនៅក្នុងសាច់រឿងសំខាន់។
នៅទីនេះយ៉ូហានប្រាប់អំពីក្រុមមនុស្សថ្មី
ដែលបានមកដល់ភូមិបេថានីពីក្រុងយេរូសាឡឹម។
ដោយសារតែគាត់
ហេតុការណ៍ដែលថា ឡាសាបានរស់ឡើងវិញ
បានធ្វើឲ្យជនជាតិយូដាជាច្រើនជឿលើព្រះយេស៊ូ។
ជឿលើព្រះយេស៊ូ
បញ្ជាក់ថា ជនជាតិយូដាជាច្រើនបានជឿទុកចិត្តលើព្រះយេស៊ូ
ជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ពួកគេបានជឿទុកចិត្តលើព្រះយេស៊ូ” ។
John 12:12
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃសាច់រឿង។ ព្រះយេស៊ូចូលក្រុងយេរូសាឡឹម
ហើយប្រជាជនលើកតម្កើងព្រះអង្គជាស្តេចមួយអង្គ។
ហ្វូងមនុស្សយ៉ាងច្រើនកុះករ
«មនុស្សមួយក្រុមធំ»
ហូសាណា
មានន័យថា "ព្រះជាម្ចាស់អាចជួយសង្គ្រោះយើងឥឡូវនេះ!"
មានពរហើយ
បង្ហាញពីបំណងប្រាថ្នារបស់ព្រះជាម្ចាស់
ដើម្បីធ្វើឲ្យរឿងល្អកើតឡើងចំពោះមនុស្សម្នាក់។
មកក្នុងព្រះនាមព្រះអម្ចាស់
ពាក្យ "ឈ្មោះ"នៅទីនេះ ជាពាក្យប្រៀបធៀបដែលមានន័យថា សិទ្ធិអំណាច
និងឫទ្ធានុភាព។ "មកក្នុងនាមជាអ្នកតំណាងរបស់ព្រះអម្ចាស់" ឬ
"មកក្នុងឫទ្ធានុភាពរបស់ព្រះអម្ចាស់"
John 12:14
ព្រះយេស៊ូបានជួបជាមួយនឹងសត្វលាស្ទាវមួយ ហើយក៏គង់នៅលើវា
នៅទីនេះ យ៉ូហានផ្តល់ព័ត៌មានសំខាន់ថា ព្រះយេស៊ូការពារសត្វលា។
គាត់បញ្ជាក់ថា ព្រះយេស៊ូនឹងជិះលាទៅក្រុងយេរូសាឡឹម។
"ព្រះអង្គឃើញសត្វលាមួយក្បាល ហើយជិះវាចូលទៅក្នុងទីក្រុង"
ដូចមានសេចក្តីចែងទុកមកថា
អាចបកប្រែវាជាទម្រង់កិរិយាសកម្ម។ "ដូចពួកព្យាការីបានសរសេរនៅក្នុងបទគម្ពីរ"
កូនស្រីស៊ីយ៉ូនអើយ
"កូនស្រីស៊ីយ៉ូន" គឺជាពាក្យប្រៀបធៀប សំដៅទៅលើប្រជាជនក្រុងយេរូសាឡឹម។
"អ្នកជាប្រជាជនក្រុងយេរូសាឡឹម"
John 12:16
ព័ត៌មានទូទៅ:
យ៉ូហានដែលជាអ្នកនិពន្ធបានបង្ហាក់ ដើម្បីផ្តល់ព័ត៌មានខ្លះជូនអ្នកអាន
អំពីអ្វីដែលពួកសិស្សបានយល់នៅពេលក្រោយ។
ពួកសិស្សរបស់ព្រះអង្គមិនយល់ពីការទាំងនេះទេ
ពាក្យ“ ការទាំងនេះ”ត្រង់នេះសំដៅទៅលើពាក្យ
ដែលព្យាការីបានសរសេរទុកអំពីព្រះយេស៊ូ។
ពេលព្រះយេស៊ូបានទទួលសិរីល្អ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ពេលព្រះជាម្ចាស់បានលើកតម្កើងសិរីរុងរឿងរបស់ព្រះយេស៊ូ"
ពួកគេបានធ្វើការទាំងនេះចំពោះព្រះអង្គ
ពាក្យថា "ការទាំងនេះ" សំដៅទៅលើអ្វី ដែលប្រជាជនបានធ្វើ
ពេលព្រះយេស៊ូបានជិះសត្វលាចូលទៅក្នុងក្រុងយេរូសាឡឹម ។
(សរសើរព្រះអង្គហើយគ្រវីមែកឈើ) ។
John 12:17
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ការផ្អាកនៅក្នុងនិទានកថាដ៏សំខាន់។
នៅទីនេះយ៉ូហានពន្យល់ថា មនុស្សជាច្រើនបានមកជួបព្រះយេស៊ូ
ព្រោះពួកគេបានឮអ្នកផ្សេងទៀតនិយាយថា
ទ្រង់បានប្រោសឡាសាឲ្យរស់ឡើងវិញ។
ពួកគេបានឮថាព្រះអង្គបានធ្វើទីសម្គាល់នេះ
"ពួកគេបានឮអ្នកផ្សេងទៀតនិយាយថា ទ្រង់បានធ្វើទីសម្គាល់"
ទីសម្គាល់
"ទីសម្គាល់" ជាព្រឹត្តិការណ៍ ឬការកើតឡើងដែលបង្ហាញថាអ្វីមួយជាការពិត។
ក្នុងករណីនេះ "ទីសម្គាល់" នៃការប្រោសឡាសាបង្ហាញថា ព្រះយេស៊ូជាព្រះមេស្ស៊ី។
អ្នករាល់គ្នាមិនអាចធ្វើអ្វីបានទាល់តែសោះ
ពួកផារីស៊ីបញ្ជាក់ថា មិនអាចបញ្ឈប់ព្រះយេស៊ូបានទេ។
"ហាក់ដូចជាយើងមិនអាចធ្វើអ្វី ដើម្បីបញ្ឈប់ទ្រង់បានទេ!"
មើល! មនុស្សបានទៅតាមអ្នកនោះអស់ហើយ
នេះជាការបំផ្លើសមួយ ដែលពួកផារីស៊ីធ្លាប់សម្តែងការភ្ញាក់ផ្អើល
ពេលមនុស្សជាច្រើនបានចេញមកជួបព្រះយេស៊ូ។
"មើលទៅដូចជាមនុស្សគ្រប់គ្នាកំពុងក្លាយជាសិស្សរបស់គាត់!"
មនុស្ស
“ ពិភពលោក”នៅទីនេះ ជាពាក្យប្រៀបធៀប ដែលតំណាង (និយាយលំអៀង)
ប្រជាជនទាំងអស់នៅលើពិភពលោក។
John 12:20
សាសន៍ក្រិក
ឃ្លា "ឥឡូវនេះ" សម្គាល់ការបញ្ចូលតួអក្សរថ្មីទៅក្នុងរឿង។
ថ្វាយបង្គំនៅថ្ងៃបុណ្យនោះ
យ៉ូហានបញ្ជាក់ថា“ ជនជាតិក្រិក” ទាំងនេះនឹងថ្វាយបង្គំព្រះជាម្ចាស់
អំឡុងពេលបុណ្យចម្លង។ ដើម្បីថ្វាយបង្គំព្រះជាម្ចាស់នៅបុណ្យចម្លង។
បេតសៃដា
ជាក្រុងមួយក្នុងស្រុកកាលីឡេ។
ពួកគេបានប្រាប់ព្រះយេស៊ូ
ភីលីពនិងអនទ្រេប្រាប់ព្រះយេស៊ូ អំពីសំណូមពររបស់ជនជាតិក្រិក
ដែលចង់ជួបព្រះអង្គ។ អ្នកអាចបកប្រែដោយបន្ថែមពាក្យដែលបង្កប់ន័យបាន។ “
ពួកគេបានប្រាប់ព្រះយេស៊ូ នូវអ្វីដែលពួកក្រិកបាននិយាយ”
John 12:23
ព័ត៌មានទូទៅ:
ព្រះយេស៊ូចាប់ផ្តើមឆ្លើយតបនឹងភីលីពនិងអនទ្រេ។
ពេលកំណត់មកដល់ហើយ ដែលកូនមនុស្សនឹងទទួលសិរីល្អ
ព្រះយេស៊ូបានបញ្ជាក់ថា
ឥឡូវនេះដល់ពេលព្រះជាម្ចាស់ត្រូវលើកកិត្តិយសបុត្រមនុស្ស តាមរយៈការរងទុក្ខ
សេចក្តីស្លាប់ និងការរស់ឡើងវិញ។ “
ព្រះជាម្ចាស់នឹងលើកកិត្តិយសខ្ញុំក្នុងពេលឆាប់ៗ
ពេលខ្ញុំស្លាប់ហើយនិងរស់ឡើងវិញ”
ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
បកប្រែតាមវិធីនេះក្នុងភាសារបស់អ្នក ដើម្បីសង្កត់ន័យថា
អ្វីដែលនៅខាងក្រោមគឺសំខាន់ និងពិតប្រាកដ។ សូមមើលពីរបៀបដែលអ្នកបកប្រែ
"ពិតណាស់" នៅក្នុងជំពូក ១ ខ៤៩ ។
បើគ្រាប់ស្រូវមិនកប់ទៅក្នុងដី ហើយស្លាប់ទេ .... វានឹងបង្កើតផលជាច្រើន
“ គ្រាប់ស្រូវ” ឬ“ គ្រាប់ពូជ” នៅទីនេះ ជាពាក្យប្រៀបធៀបមួយសម្រាប់ការសុគត
បញ្ចុះក្នុងផ្នូរ និងការរស់ឡើងវិញរបស់ព្រះយេស៊ូ។ ដូចជាគ្រាប់ពូជមួយគ្រាប់
ដែលត្រូវបានគេដាំ ហើយដុះម្តងទៀតក្លាយជារុក្ខជាតិ
ដែលនឹងបង្កើតផលបានច្រើន ដូច្នេះមនុស្សជាច្រើននឹងជឿទុកចិត្តលើព្រះយេស៊ូ
បន្ទាប់ពីទ្រង់ត្រូវបានគេសម្លាប់ បញ្ចុះក្នុងផ្នូរ និងរស់ឡើងវិញ។
John 12:25
អ្នកណាដែលស្រឡាញ់ជីវិតរបស់ខ្លួន នឹងបាត់ជីវិតនោះ
“ ស្រឡាញ់ជីវិតរបស់ខ្លួន”នៅត្រង់នេះ
មានន័យថាពិចារណាលើជីវិតរូបកាយរបស់មនុស្សម្នាក់
ដែលមានតម្លៃជាងជីវិតអ្នកដទៃ។ “
អ្នកណាឲ្យតម្លៃលើជីវិតរបស់ខ្លួនច្រើនជាងអ្នកដទៃ
នឹងមិនសមទទួលជីវិតអស់កល្បជានិច្ចទេ”
អ្នកណាដែលស្អប់ជីវិតរបស់ខ្លួននៅក្នុងលោកីយ៍នេះ នឹងរក្សាវាដើម្បីជីវិតអស់កល្បជានិច្ច
នៅទីនេះ អ្នកដែលស្អប់ជីវិតរបស់ខ្លួន
សំដៅទៅលើអ្នកដែលស្រឡាញ់ជីវិតផ្ទាល់ខ្លួនតិចជាងការ
ដែលគាត់ស្រឡាញ់ជីវិតអ្នកដទៃ។ «អ្នកណាចាត់ទុកជីវិតអ្នកដទៃថា
សំខាន់ជាងជីវិតខ្លួនឯង នោះនឹងរស់នៅជាមួយព្រះជាម្ចាស់ជារៀងរហូត»
បើខ្ញុំនៅទីណា អ្នកបម្រើខ្ញុំនឹងនៅទីនោះដែរ
ព្រះយេស៊ូបានបញ្ជាក់ថា

generated on Wed Sep 10 16:16:32 2025

អ្នកដែលបម្រើព្រះអង្គនឹងនៅជាមួយនឹងទ្រង់នៅស្ថានសួគ៌។
"នៅពេលដែលខ្ញុំនៅស្ថានសួគ៌ អ្នកបម្រើរបស់ខ្ញុំក៏នឹងនៅទីនោះ ជាមួយខ្ញុំដែរ"
បិតាខ្ញុំនឹងផ្តល់កិត្តិយសដល់អ្នកនោះ
"ព្រះបិតា" នៅទីនេះជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
John 12:27
ខ្ញុំនឹងនិយាយយ៉ាងដូចម្តេច? ឱព្រះបិតាអើយ សូមសង្គ្រោះទូលបង្គំនៅក្នុងវេលានេះ
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំនួនវោហារ។
ទោះបីព្រះយេស៊ូចង់ជៀសវាងពីការជាប់ឆ្កាងក៏ដោយ
ក៏ព្រះអង្គនៅតែជ្រើសរើសយកការគោរពប្រតិបត្តិចំពោះព្រះជាម្ចាស់
និងត្រូវគេសម្លាប់។ "ខ្ញុំនឹងមិនអធិស្ឋានថា"
ព្រះបិតាជួយសង្គ្រោះខ្ញុំចាប់ពីម៉ោងនេះទេ! "
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
វេលានេះ
នៅទីនេះ "ម៉ោងនេះ" ជាពាក្យប្រៀបធៀប ដែលតំណាងពេលព្រះយេស៊ូរងទុក្ខ
និងសុគតនៅលើឈើឆ្កាង។
សូមថ្វាយសិរីរុងរឿងដល់ព្រះនាមព្រះអង្គ
នៅទីនេះពាក្យ "នាម" ជាពាក្យប្រៀបជៀប ដែលសំដៅទៅលើព្រះជាម្ចាស់។
"ឲ្យសិរីរុងរឿងរបស់អ្នកគេស្គាល់" ឬ "បង្ហាញពីសិរីរុងរឿងរបស់អ្នក"
មានសំឡេងពីស្ថានសួគ៌មក
នេះតំណាងឲ្យព្រះជាម្ចាស់មានព្រះបន្ទូល។
ពេលខ្លះមនុស្សជៀសវាងពីការសំដៅទៅព្រះជាម្ចាស់ដោយផ្ទាល់ពីព្រោះពួកគេគោរពព្រះអង្គ
“ ព្រះជាម្ចាស់មានបន្ទូលពីឋានសួគ៌មក”
John 12:30
ព័ត៌មានទូទៅ:
ព្រះយេស៊ូពន្យល់ពីមូលហេតុ ដែលសំឡេងនោះបន្លឺចេញពីលើឋានសួគ៌មក។
សេចក្តីជំនុំជម្រះរបស់លោកីយ៍នេះ
“ លោកីយ៍នេះ”នៅទីនេះជាពាក្យប្រៀបធៀប
ដែលសំដៅទៅលើប្រជាជនទាំងអស់នៅលើពិភពលោក។ "ឥឡូវនេះ
ដល់ពេលព្រះជាម្ចាស់វិនិច្ឆ័យមនុស្សទាំងអស់" ។
ដល់ពេលដែលពួកគ្រប់គ្រងលោកីយ៍នេះ ត្រូវបោះទៅក្រៅហើយ
“ អ្នកគ្រប់គ្រង” ត្រង់នេះសំដៅទៅលើសាតាំង។
អ្នកអាចបកប្រែវាជាទម្រង់កិរិយាសកម្ម។ “ ឥឡូវនេះ ជាពេលវេលា
ដែលខ្ញុំនឹងបំផ្លាញអំណាចរបស់សាតាំងដែលគ្រប់គ្រងពិភពលោកនេះ”
John 12:32
ព័ត៌មានទូទៅ:
នៅក្នុងខទី ៣៣
យ៉ូហានប្រាប់យើងអំពីព័ត៌មានសំខាន់អ្វីដែលព្រះយេស៊ូបានមានបន្ទូលអំពីការ
«លើកឡើងទៅលើ»
នៅពេលដែលខ្ញុំត្រូវបានលើកឡើងពីលោកីយ៍
នៅទីនេះព្រះយេស៊ូសំដៅទៅលើការជាប់ឆ្កាងរបស់ព្រះអង្គ។
អ្នកអាចបកប្រែវាជាទម្រង់សកម្ម។
"នៅពេលមនុស្សលើកខ្ញុំឡើងខ្ពស់នៅលើឈើឆ្កាង"
ខ្ញុំនឹងនាំអ្នករាល់គ្នាមកជិតខ្លួនខ្ញុំផ្ទាល់
តាមរយៈការជាប់ឆ្កាងរបស់ព្រះយេស៊ូ
ទ្រង់នឹងផ្តល់ផ្លូវឱ្យមនុស្សគ្រប់គ្នាជឿជាក់លើព្រះអង្គ។
ព្រះអង្គមានបន្ទូលដូច្នេះ ដើម្បីបង្ហាញពីបែបបទនៃសេចក្តីស្លាប់ ដែលព្រះអង្គត្រូវសុគត
យ៉ូហានបកស្រាយពាក្យរបស់ព្រះយេស៊ូមានន័យថា មនុស្សនឹងឆ្កាងព្រះអង្គ។
"គាត់បាននិយាយបែបនេះដើម្បីឲ្យប្រជាជនដឹងពីរបៀប ដែលទ្រង់នឹងសុគត"
John 12:34
បុត្រមនុស្សត្រូវតម្កើងឡើង
ឃ្លាថា“ លើកតម្កើងឡើង” មានន័យថាជាប់ឆ្កាង។ អ្នកអាចបកប្រែវាតាមរបៀបមួយ
ដែលរួមបញ្ចូលទាំងពាក្យបង្កប់ន័យថា "នៅលើឈើឆ្កាង" ។
"កូនមនុស្សត្រូវតែលើកឡើងលើឈើឆ្កាងឬ?"
តើអ្នកណាជាបុត្រារបស់មនុស្ស?
អាចមានន័យថា ១) "តើអត្តសញ្ញាណរបស់បុត្រានេះជាអ្វី? ឬ ២)"
តើកូនមនុស្សនិយាយអំពីអ្វី? "
ពន្លឺនឹងនៅជាមួយអ្នករាល់គ្នាក្នុងរយៈពេលខ្លីប៉ុណ្ណោះ។
ចូរដើរក្នុងការដែលអ្នករាល់គ្នានៅក្នុងពន្លឺនៅឡើយ ធ្វើដូច្នេះ
ដើម្បីកុំឲ្យសេចក្តីងងឹតយកឈ្នះអ្នករាល់គ្នាឡើយ។ អស់អ្នកណាដែលដើរក្នុងសេចក្តីងងឹត
មិនដឹងថាពួកគេកំពុងទៅណាទេ
"ពន្លឺ" នៅទីនេះជាពាក្យប្រៀបធៀបមួយ សម្រាប់ការបង្រៀនរបស់ព្រះយេស៊ូ
ដែលបង្ហាញពីសេចក្តីពិតរបស់ព្រះជាម្ចាស់។ “ ដើរក្នុងភាពងងឹត”
គឺជាពាក្យប្រៀបធៀបដែលមានន័យថា
រស់នៅដោយគ្មានសេចក្តីពិតរបស់ព្រះជាម្ចាស់។ “ សម្តីខ្ញុំដូចជាពន្លឺដល់អ្នក
ដើម្បីជួយអ្នកឲ្យយល់ពីរបៀបរស់នៅ ដែលព្រះសព្វព្រះហឫទ័យ។
ខ្ញុំនឹងមិននៅជាមួយអ្នកយូរទៀតទេ។ អ្នកត្រូវធ្វើតាមការណែនាំរបស់ខ្ញុំ
ពេលខ្ញុំនៅជាមួយអ្នក ប្រសិនបើអ្នកបដិសេធ
ពាក្យរបស់ខ្ញុំនឹងដូចជាដើរក្នុងភាពងងឹត ហើយអ្នកមិនអាចមើលឃើញកន្លែង
ដែលអ្នកកំពុងចង់ទៅបាននោះទេ។
ក្នុងការដែលអ្នករាល់គ្នាមានពន្លឺ ចូរជឿលើពន្លឺ ដើម្បីឲ្យអ្នករាល់គ្នាបានក្លាយជាកូននៃពន្លឺ
"ពន្លឺ" ជាពាក្យប្រៀបធៀបមួយ សម្រាប់ការបង្រៀនរបស់ព្រះយេស៊ូ
ដែលបង្ហាញពីសេចក្តីពិតរបស់ព្រះជាម្ចាស់។ "កូននៃពន្លឺ" ជាពាក្យប្រៀបធៀប
សម្រាប់អ្នកដែលទទួលយកសាររបស់ព្រះយេស៊ូ
ហើយរស់នៅស្របតាមសេចក្តីពិតរបស់ព្រះជាម្ចាស់។
"ពេលខ្ញុំនៅជាមួយអ្នកសូមទទួលយកពាក្យរបស់ខ្ញុំ
ដើម្បីឲ្យសេចក្តីពិតរបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងអ្នក"
John 12:37
ព័ត៌មានទូទៅ:
នេះជាការផ្អាកនៅក្នុងសាច់រឿងសំខាន់
ដែលយ៉ូហានចាប់ផ្តើមពន្យល់អំពីការសម្រេចតាមទំនាយ ដែលបាន
ទាយទុកដោយព្យាការីអេសាយ។
ដូច្នេះ ដើម្បីឲ្យពាក្យរបស់ព្យាការីអេសាយបានមានប្រសាសន៍ថា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ ដើម្បីបំពេញសាររបស់ព្យាការីអេសាយ”
ព្រះអម្ចាស់អើយ តើអ្នកណាជឿលើការរាយការណ៍របស់យើង
ហើយព្រះអម្ចាស់ចង់ឲ្យអ្នកណាឃើញព្រះហស្តរបស់ព្រះអង្គ?
រឿងនេះលេចចេញជាទម្រង់សំណួរ ដើម្បីបង្ហាញពីភាពស្រងាកចិត្តរបស់ព្យាការី
ដែលប្រជាជនមិនជឿសាររបស់គាត់។
"ស្ទើរតែគ្មាននរណាម្នាក់ជឿលើសាររបស់ព្រះអង្គ ទោះបីជាពួកគេបានឃើញថា
ទ្រង់អាចជួយសង្គ្រោះពួកគេក៏ដោយ!"
ព្រះហស្តរបស់ព្រះអង្គ
នេះជាពាក្យប្រៀបធៀប ដែលសំដៅទៅលើសមត្ថភាពរបស់ព្រះអម្ចាស់
ក្នុងការជួយសង្គ្រោះដោយឫទ្ធានុភាព។
John 12:39
ព្រះអង្គក៏ធ្វើឲ្យចិត្តរបស់ពួកគេរឹងរូស
នេះជាក្រៀមភាសាមានន័យថា ព្រះជាម្ចាស់បណ្តាលឲ្យពួកគេរឹងចចេស។
"ទ្រង់បានធ្វើឲ្យពួកគេរឹងចចេស"
យល់នៅក្នុងចិត្តរបស់ពួក
ជនជាតិយូដាចាត់ទុកបេះដូងជាសរីរាង្គ ដែលបណ្តាលឲ្យមានការយល់ដឹង។
John 12:41
ដើម្បីកុំឲ្យពួកគេត្រូវបណ្តេញចេញពីសាលាប្រជុំ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដូច្នេះមនុស្សនឹងមិនបញ្ឈប់ពួកគេ
ពីការទៅសាលាប្រជុំទេ"
ពួកគេស្រឡាញ់ការសរសើរដែលមកពីមនុស្សច្រើនជាការសរសើរដែលមកពីព្រះជាម្ចាស់
«ពួកគេចង់ឲ្យមនុស្សសរសើរពួកគេ ច្រើនជាងពួកគេចង់
ឲ្យព្រះជាម្ចាស់សរសើរពួកគេ»
John 12:44
ព័ត៌មានទូទៅ:
ឥឡូវយ៉ូហានវិលត្រឡប់ទៅរករឿងសំខាន់វិញ។ នេះជាពេលមួយទៀត
ដែលព្រះយេស៊ូចាប់ផ្តើមមានបន្ទូលទៅកាន់ហ្វូងមនុស្ស។
ព្រះយេស៊ូបានបន្លឺសំឡេង
នៅទីនេះ យ៉ូហានបញ្ជាក់ថា
ហ្វូងមនុស្សបានប្រមូលផ្តុំគ្នាស្តាប់ព្រះយេស៊ូមានព្រះបន្ទូល។
"ព្រះយេស៊ូបានស្រែកទៅកាន់ហ្វូងមនុស្ស ដែលបានប្រមូលផ្តុំគ្នា" ។
អ្នកណាដែលឃើញខ្ញុំ អ្នកនោះក៏ឃើញព្រះដែលចាត់ខ្ញុំឲ្យមកដែរ
ពាក្យ“ គាត់” ត្រង់នេះសំដៅទៅលើព្រះជាម្ចាស់។ "អ្នកដែលឃើញខ្ញុំ
ក៏បានឃើញព្រះជាម្ចាស់ ដែលបានចាត់ខ្ញុំឲ្យមកដែរ" ។
John 12:46

generated on Wed Sep 10 16:16:32 2025

ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់ហ្វូងមនុស្ស។
ខ្ញុំបានមកធ្វើជាពន្លឺ
"ពន្លឺ" នៅទីនេះជាពាក្យប្រៀបធៀបមួយ ជាឧទាហរណ៍របស់ព្រះយេស៊ូ។
"ខ្ញុំបានមកដើម្បីបង្ហាញការពិត"
មិនស្ថិតនៅក្នុងសេចក្តីងងឹតឡើយ
“ ភាពងងឹត” នៅទីនេះជាពាក្យប្រៀបធៀបមួយ
សម្រាប់ការរស់នៅដោយមិនស្គាល់ព្រះជាម្ចាស់។
"ប្រហែលជាមិនបន្តងងឹតភ្នែកខាងវិញ្ញាណទេ" ។
ប្រសិនបើ អ្នកណាម្នាក់ឮពាក្យខ្ញុំ ប៉ុន្តែ មិនប្រព្រឹត្តតាមពាក្យនោះទេ ខ្ញុំមិនជំនុំជម្រះគាត់ទេ ដ្បិត
ខ្ញុំមិនបានមកដើម្បីជំនុំជម្រះលោកីយ៍ ប៉ុន្តែ ដើម្បីសង្គ្រោះលោកីយ៍វិញ
នៅទីនេះ "ដើម្បីវិនិច្ឆ័យលោកីយ៍ " បង្កប់ន័យថ្កោលទោស។
ព្រះយេស៊ូមិនបានមកដើម្បីថ្កោលទោសមនុស្សទេ។
"បើអ្នកណាឮការបង្រៀនរបស់ខ្ញុំ ហើយបដិសេធ ខ្ញុំមិនថ្កោលទោសអ្នកទេ។
ខ្ញុំមិនបានមកដើម្បីថ្កោលទោសមនុស្សទេ
ផ្ទុយទៅវិញខ្ញុំបានមកជួយសង្គ្រោះអ្នកដែលទុកចិត្តលើខ្ញុំ"
លោកីយ៍
"លោកីយ៍ " នៅទីនេះ ជាពាក្យប្រៀបធៀប
ដែលតំណាងឲ្យប្រជាជនទាំងអស់នៅលើពិភពលោក។
John 12:48
នៅថ្ងៃចុងក្រោយ
"ពេលព្រះជាម្ចាស់វិនិច្ឆ័យបាបមនុស្ស"
ខ្ញុំដឹងថា សេចក្តីបង្គាប់របស់ព្រះអង្គគឺជាជីវិតអស់កល្បជានិច្ច
"ខ្ញុំដឹងថា ពាក្យដែលទ្រង់បញ្ជាឲ្យខ្ញុំនិយាយ គឺជាពាក្យផ្តល់ជីវិតអស់កល្បជានិច្ច"
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។ ។

---

13 [1]ឥឡូវនេះ ជាថ្ងៃមុនពេលពិធីបុណ្យរំលង។ ព្រះយេស៊ូជ្រាបថា ពេលកំណត់របស់ព្រះអង្គបានមកដល់ហើយ ក្នុងការចាកចេញពីលោកីយ៍
ហើយត្រឡប់ទៅព្រះបិតាវិញ។ ព្រះអង្គស្រឡាញ់អស់អ្នកដែលនៅជាមួយព្រះអង្គនៅក្នុងលោកីយ៍ណាស់ ហើយទ្រង់ស្រឡាញ់ពួកគេរហូតដល់ទីបំផុត។[2]ឥឡូវនេះ
មារបានដាក់វានៅក្នុងចិត្តរបស់លោកយូដាសអ៊ីស្ការីយ៉ុតជាកូនលោកស៊ីម៉ូនរួចហើយ ដើម្បីក្បត់ព្រះយេស៊ូ។
[3]ព្រះអង្គជ្រាបថា ព្រះបិតាបានប្រទានអ្វីៗទាំងអស់ក្នុងព្រះហស្តរបស់ព្រះអង្គ ហើយជ្រាបថា ព្រះអង្គបានយាងមកពីព្រះជាម្ចាស់
ហើយព្រះអង្គនឹងត្រឡប់ទៅឯព្រះជាម្ចាស់វិញ។[4]ព្រះអង្គបានក្រោកឡើងពីអាហារល្ងាច ហើយបានយកសម្លៀកបំពាក់ខាងក្រៅរបស់ព្រះអង្គ។
បន្ទាប់មកព្រះអង្គបានយកកន្សែង ហើយយកវាមកក្រវាត់ខ្លួនរបស់ព្រះអង្គ។[5]បន្ទាប់មក ព្រះអង្គបានចាក់ទឹកចូលទៅក្នុងផើងមួយ
ហើយបានចាប់ផ្តើមលាងជើងពួកសិស្ស ហើយយកកន្សែងដែលចងនៅនឹងខ្លួនរបស់ព្រះអង្គមកជូត។
[6]ព្រះអង្គបានមកឯលោកស៊ីម៉ូនពេត្រុស ហើយលោកពេត្រុសបានទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គនឹងលាងជើងទូលបង្គំឬអី?»[7]ព្រះយេស៊ូឆ្លើយ
ហើយមានបន្ទូលទៅគាត់ថា៖ «អ្វីដែលខ្ញុំកំពុងធ្វើ អ្នកមិនយល់ទេនៅពេលនេះ ប៉ុន្តែ អ្នកនឹងយល់ការនេះនៅពេលក្រោយ»។[8]លោកពេត្រុសទូលទៅព្រះអង្គថា៖
«ព្រះអង្គមិនត្រូវលាងជើងទូលបង្គំទេ»។ ព្រះយេស៊ូឆ្លើយទៅគាត់ថា៖ «ប្រសិនបើ ខ្ញុំមិនលាងជើងអ្នក អ្នកគ្មានចំណែកអ្វីជាមួយខ្ញុំទេ»។
[9]លោកស៊ីម៉ូនពេត្រុសទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមកុំគ្រាន់តែលាងជើងទូលបង្គំឡើយ ប៉ុន្តែ សូមលាងដៃ និងក្បាលរបស់ទូលបង្គំផង»។
[10]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «អ្នកដែលងូតទឹករួចហើយមិនចាំបាច់ទេ លាងតែជើងរបស់អ្នកនោះទៅបានហើយ អ្នកនោះបានស្អាតទាំងស្រុងហើយ។
អ្នកស្អាតហើយ ប៉ុន្តែ អ្នកផ្សេងទេដែលមិនស្អាត»។[11](ដើម្បីព្រះយេស៊ូជ្រាបថា អ្នកណានឹងក្បត់ព្រះអង្គ ហេតុដូច្នេះ ហើយបានជាព្រះអង្គមានបន្ទូលថា៖
«អ្នករាល់គ្នាមិនស្អាតទាំងអស់គ្នាទេ»)។
[12]នៅពេលព្រះយេស៊ូបានលាងជើងពួកគេដូច្នេះ ហើយបានយកសម្លៀកបំពាក់របស់ព្រះអង្គមកពាក់ ហើយគង់នៅតុអាហារវិញ ព្រះអង្គមានបន្ទូលទៅពួកគេថា៖
«តើអ្នកដឹងអ្វីដែលខ្ញុំកំពុងធ្វើជាមួយអ្នករាល់គ្នាទេ?[13]អ្នករាល់គ្នាហៅខ្ញុំថា៖ «លោកគ្រូ» ឬ «ព្រះអម្ចាស់» អ្នករាល់គ្នានិយាយនោះត្រូវហើយ ខ្ញុំអ៊ីចឹងមែន។[14]ប្រសិនបើខ្ញុំ
ជាព្រះអម្ចាស់ និងជាគ្រូ បានលាងជើងអ្នករាល់គ្នា អ្នកក៏ត្រូវលាងជើងដល់គ្នាទៅវិញទៅមកដែរ។[15]ដ្បិត ខ្ញុំបានធ្វើជាគំរូដល់អ្នករាល់គ្នាហើយ អ្នករាល់គ្នាត្រូវធ្វើដូច្នេះ
បានធ្វើដល់អ្នករាល់គ្នាដែរ។
[16]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកបម្រើមិនធំជាម្ចាស់របស់ខ្លួនឡើយ ឬអ្នកនាំសារក៏មិនធំជាងអ្នកដែលចាត់គាត់ឲ្យមកនោះទេ។[17]ប្រសិនបើ
អ្នករាល់គ្នាស្គាល់ការទាំងនេះ អ្នកនឹងមានពរ ប្រសិនបើ អ្នករាល់គ្នាធ្វើការទាំងនោះ។[18]ខ្ញុំមិននិយាយពីអ្នករាល់គ្នាទេ ខ្ញុំដឹងអស់អ្នកដែលខ្ញុំបានជ្រើសរើស ប៉ុន្តែ
ការនេះអាចកើតឡើងដូច្នេះ ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរថា៖ «អ្នកដែលបរិភោគនំប៉័ងខ្ញុំ បានលើកកែងជើងរបស់គាត់ទាស់នឹងខ្ញុំ»។
[19]ខ្ញុំប្រាប់អ្នករាល់គ្នានៅពេលនេះ មុនពេលវាកើតឡើង ដើម្បីនៅពេលវាកើតឡើង អ្នកអាចជឿថា ខ្ញុំជាព្រះ។[20]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
អស់អ្នកណាដែលទទួលអ្នកដែលខ្ញុំចាត់ឲ្យទៅ ទទួលខ្ញុំដែរ ហើយអស់អ្នកណាដែលទទួលខ្ញុំ ទទួលព្រះអង្គដែលចាត់ខ្ញុំឲ្យមកដែរ។
[21]នៅពេលព្រះយេស៊ូមានបន្ទូលការនេះរួចហើយ ព្រះអង្គមានការខ្វល់ខ្វាយក្នុងវិញ្ញាណ។ ព្រះអង្គបានធ្វើបន្ទាល់ ហើយមានបន្ទូលថា៖ «ពិតណាស់
ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មានម្នាក់ក្នុងចំណោមអ្នករាល់គ្នាក្បត់ខ្ញុំ»។[22]ពួកសិស្សមើលគ្នាទៅវិញទៅមក ងឿងឆ្ងល់ថាព្រះអង្គកំពុងមានបន្ទូលពីអ្នកណា។
[23]សិស្សម្នាក់នៃពួកសិស្សរបស់ព្រះអង្គ ជាអ្នកដែលព្រះអង្គស្រឡាញ់ កំពុងតែអង្គុយតុនៅជិតព្រះយេស៊ូ។[24]លោកស៊ីម៉ូនពេត្រុស បានធ្វើសញ្ញាទៅសិស្សនោះ
ហើយនិយាយថា៖ «សួរព្រះអង្គមើល ព្រះអង្គកំពុងនិយាយអំពីអ្នកណា?»។[25]ដូច្នេះ គាត់បានផ្អែកទៅជិតព្រះយេស៊ូហើយនិយាយទៅកាន់ព្រះអង្គថា «ព្រះអង្គម្ចាស់អើយ
តើអ្នកនោះជាអ្នកណា?»
[26]បន្ទាប់មក ព្រះយេស៊ូឆ្លើយថា៖ «គឺជាម្នាក់ដែលខ្ញុំនឹងជ្រលក់នំប៉័ងមួយដុំ ហើយឲ្យទៅអ្នកនោះ»។ ដូច្នេះ នៅពេលព្រះអង្គបានជ្រលក់នំប៉័ងរួចហើយ
ព្រះអង្គបានប្រទានទៅលោកយូដាសជាកូនរបស់លោកស៊ីម៉ូនអ៊ីស្ការីយ៉ុត។[27]បន្ទាប់ពីបានទទួលនំប៉័ងហើយ សាតាំងបានចូលទៅក្នុងគាត់ ដូច្នេះ
ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «តើអ្នកកំពុងធ្វើអ្វី ចូរធ្វើវាឲ្យលឿនទៅ»។
[28]អស់អ្នកដែលអង្គុយនៅតុ គ្មាននរណាម្នាក់ដឹងថា ហេតុអ្វីបានជាព្រះអង្គមានបន្ទូលការនេះទៅគាត់។[29]អ្នកខ្លះគិតថា ដោយសារលោកយូដាសជាអ្នកកាន់ថង់ប្រាក់
ព្រះយេស៊ូមានបន្ទូលទៅគាត់ «ឲ្យទិញអ្វីដែលយើងត្រូវការ សម្រាប់ពិធីបុណ្យ»។ ឬ អាចឲ្យគាត់ឲ្យអ្វីមួយដល់អ្នកក្រ។[30]បន្ទាប់ពីលោកយូដាសបានទទួលនំប៉័ងហើយ
គាត់ក៏ចេញទៅភ្លាម។ ពេលនោះយប់ហើយ។
[31]នៅពេលលោកយូដាសចេញផុតទៅ ព្រះយេស៊ូមានបន្ទូលថា៖ «ឥឡូវនេះ បុត្ររបស់មនុស្សត្រូវទទួលសិរីរុងរឿង
ហើយព្រះជាម្ចាស់បានទទួលសិរីរុងរឿងបានតាមរយៈព្រះអង្គដែរ។[32]ព្រះជាម្ចាស់នឹងតម្កើងព្រះអង្គនៅក្នុងអង្គទ្រង់ផ្ទាល់ ហើយទ្រង់នឹងតម្កើងព្រះអង្គភ្លាម។[33]កូនតូចអើយ
ខ្ញុំនៅជាមួយអ្នករាល់គ្នាតែមួយរយៈខ្លីទៀតតែប៉ុណ្ណោះ។ អ្នករាល់គ្នានឹងស្វែងរកខ្ញុំ ដូចដែលខ្ញុំបាននិយាយទៅពួកយូដាដែរថា៖ «កន្លែងដែលខ្ញុំទៅ
អ្នករាល់គ្នាមិនអាចទៅបានទៅបានទេ»។ ពេលនេះ ខ្ញុំក៏និយាយទៅកាន់អ្នករាល់គ្នាដែរ។
[34]ខ្ញុំឲ្យដល់អ្នករាល់គ្នានូវក្រឹត្យវិន័យមួយថ្មី គឺថាអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នាដែរ ដូច្នេះ
អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមកដែរ។[35]មនុស្សទាំងអស់នឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំដោយសារការនេះ
គឺដោយសារអ្នករាល់គ្នាស្រឡាញ់អ្នកទៅវិញទៅមក»។
[36]លោកស៊ីម៉ូនពេត្រុសទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គយាងទៅណា?» ព្រះយេស៊ូឆ្លើយថា៖ «កន្លែងដែលខ្ញុំទៅ
អ្នកមិនអាចទៅតាមខ្ញុំបានទេនៅពេលនេះ ប៉ុន្តែ អ្នកនឹងទៅតាមខ្ញុំនៅពេលក្រោយ»។[37]លោកពេត្រុសទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ
ហេតុអ្វីបានជាទូលបង្គំមិនអាចទៅតាមព្រះអង្គនៅពេលនេះ? ទូលបង្គំនឹងលះបង់ជីវិតរបស់ទូលបង្គំដើម្បីព្រះអង្គ»។[38]ព្រះយេស៊ូឆ្លើយថា៖
«តើអ្នកនឹងលះបង់ជីវិតដើម្បីខ្ញុំ? ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា មាន់នឹងមិនរងាវទេ ប្រសិនបើអ្នកមិនបដិសេធខ្ញុំបីដង»។

generated on Wed Sep 10 16:16:32 2025

John 13:1
ព័ត៌មានទូទៅ:
មិនទាន់ដល់ពេលបុណ្យចម្លងទេ
ហើយព្រះយេស៊ូគង់នៅជាមួយសិស្សរបស់ព្រះអង្គ បរិភោគអាហារជាមួយគ្នា។
ខគម្ពីរទាំងនេះពន្យល់ពីសាច់រឿង ដែលផ្តល់ព័ត៌មានអំពីព្រះយេស៊ូ និងយូដាស។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ស្រឡាញ់
ជាសេចក្តីស្រឡាញ់ដែលកើតចេញពីព្រះជាម្ចាស់
ដែលផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
ទោះបីមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។ សេចក្តីស្រឡាញ់បែបនេះ
យកចិត្តទុកដាក់ចំពោះអ្នកដទៃ ទោះជាពួកគេធ្វើអ្វីក៏ដោយ។
មារបានដាក់វានៅក្នុងចិត្តរបស់លោកយូដាសអ៊ីស្ការីយ៉ុតជាកូនលោកស៊ីម៉ូនរួចហើយ
ដើម្បីក្បត់ព្រះយេស៊ូ
ឃ្លា "ដាក់វាចូលទៅក្នុងចិត្តថា" ជាពាក្យដែលមានន័យថា
បណ្តាលឲ្យនរណាម្នាក់គិតអំពីអ្វីមួយ។
"អារក្សបានធ្វើឲ្យយូដាសអ៊ីស្ការីយ៉ុតជាកូនរបស់ស៊ីម៉ូន
គិតរួចជាស្រេចក្នុងគំនិតអំពីការក្បត់ព្រះយេស៊ូ" ។
John 13:3
ឃ្លាភ្ជាប់៖
ខ៣ បន្តប្រាប់យើងអំពីព័ត៌មានសំខាន់ ដែលព្រះយេស៊ូបានជ្រាប។
សកម្មភាពនៅក្នុងរឿងចាប់ផ្តើមនៅខ ៤។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
បានប្រទានអ្វីៗទាំងអស់ក្នុងព្រះហស្តរបស់ព្រះអង្គ
"ព្រះហស្តរបស់ព្រះអង្គ"នៅទីនេះ ជាពាក្យប្រៀបធៀបទៅនឹងឫទ្ធានុភាព
និងសិទ្ធិអំណាច។ "បានប្រគល់ឫទ្ធានុ្ភាព
និងសិទ្ធិអំណាចពេញលេញដល់ព្រះអង្គលើអ្វីៗទាំងអស់"
ព្រះអង្គបានយាងមកពីព្រះជាម្ចាស់ ហើយព្រះអង្គនឹងត្រឡប់ទៅឯព្រះជាម្ចាស់វិញ
ព្រះយេស៊ូតែងគង់នៅជាមួយព្រះបិតា ហើយទ្រង់នឹងយាងត្រឡប់មកទីនោះវិញ
បន្ទាប់ពីកិច្ចការរបស់ព្រះអង្គនៅលើផែនដី ត្រូវបានបញ្ចប់។
ព្រះអង្គបានក្រោកឡើងពីអាហារល្ងាច
ហើយបានយកសម្លៀកបំពាក់ខាងក្រៅរបស់ព្រះអង្គ។..ចាប់ផ្តើមលាងជើងពួកសិស្ស
ដោយសារតំបន់នេះមានធូលីច្រើន
ដូច្នេះជាទម្លាប់របស់ម្ចាស់ផ្ទះទទួលទានអាហារពេលល្ងាច
ដោយឲ្យអ្នកបម្រើលាងជើងឲ្យភ្ញៀវ។
John 13:6
ព្រះអម្ចាស់អើយ តើព្រះអង្គនឹងលាងជើងទូលបង្គំឬអី?
សំណួររបស់ពេត្រុសបង្ហាញថា
គាត់មិនមានឆន្ទៈឲ្យព្រះយេស៊ូលាងជើងរបស់គាត់ទេ។ "ព្រះអម្ចាស់
មិនសមទេដែលព្រះអង្គលាងជើងខ្ញុំ ជាមនុស្សមានបាប!"
ប្រសិនបើ ខ្ញុំមិនលាងជើងអ្នក អ្នកគ្មានចំណែកអ្វីជាមួយខ្ញុំទេ
នៅទីនេះ
ព្រះយេស៊ូមានបន្ទូលពីភាពអវិជ្ជមានពីរយ៉ាងដើម្បីបញ្ចុះបញ្ចូលពេត្រុសឲ្យគាត់លាងជើង។
ព្រះយេស៊ូបានបញ្ជាក់ថា ពេត្រុសត្រូវតែឲ្យព្រះអង្គលាងជើង
បើគាត់ចង់បន្តធ្វើជាសិស្ស។ "ប្រសិនបើខ្ញុំលាងជើងអ្នក
អ្នកជាកម្មសិទ្ធិរបស់ខ្ញុំជានិច្ច"
John 13:10
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលជាមួយស៊ីម៉ូនពេត្រុស។
ព័ត៌មានទូទៅ:
ព្រះយេស៊ូប្រើពាក្យ «អ្នក» ដើម្បីសំដៅលើសិស្សទាំងអស់របស់ព្រះអង្គ។
អ្នកដែលងូតទឹករួចហើយមិនចាំបាច់ទេ លាងតែជើងរបស់អ្នកនោះទៅបានហើយ
"ងូតទឹក"នៅទីនេះ ជាពាក្យប្រៀបធៀប មានន័យថា
ព្រះជាម្ចាស់បានសម្អាតមនុស្សខាងវិញ្ញាណម្នាក់។
"បើនរណាម្នាក់បានទទួលការអភ័យទោស ពីព្រះជាម្ចាស់រួចហើយ
នោះគាត់គ្រាន់តែត្រូវការការសម្អាតពីអំពើបាបប្រចាំថ្ងៃរបស់គាត់ប៉ុណ្ណោះ"
អ្នករាល់គ្នាមិនស្អាតទាំងអស់គ្នាទេ
ព្រះយេស៊ូបានបញ្ជាក់ថា អ្នកដែលក្បត់លោកគឺយូដាសមិនបានទុកចិត្តព្រះអង្គទេ។
ដូច្នេះព្រះជាម្ចាស់មិនលើកលែងទោសឲ្យគាត់ទេ។ “ មិនមែនទាំងអស់គ្នាទេ
ដែលបានទទួលការអត់ទោសពីព្រះជាម្ចាស់”
John 13:12
តើអ្នកដឹងអ្វីដែលខ្ញុំកំពុងធ្វើជាមួយអ្នករាល់គ្នាទេ?
ការកត់សម្គាល់នេះលេចចេញជាសំណួរ
ដូច្នេះព្រះយេស៊ូអាចបញ្ជាក់ពីសារសំខាន់នៃមេរៀន
ដែលទ្រង់កំពុងបង្រៀនសិស្សរបស់ព្រះអង្គ។
"អ្នកត្រូវយល់ពីអ្វីដែលខ្ញុំបានធ្វើសម្រាប់អ្នក!"
អ្នករាល់ហៅខ្ញុំថា៖ «លោកគ្រូ» ឬ «ព្រះអម្ចាស់
នៅទីនេះ ព្រះយេស៊ូចង់បញ្ជាក់ថា
អ្នកកាន់តាមព្រះអង្គមានការគោរពយ៉ាងខ្លាំងចំពោះព្រះអង្គ។
"អ្នកបង្ហាញការគោរពដល់ខ្ញុំនៅពេលអ្នកហៅខ្ញុំថា" គ្រូ "និង" ព្រះអម្ចាស់ "។
អ្នករាល់គ្នាត្រូវធ្វើដូច្នេះបានធ្វើដល់អ្នករាល់គ្នាដែរ
ព្រះយេស៊ូបានបញ្ជាក់ប្រាប់សិស្សរបស់ព្រះអង្គ គួរធ្វើតាមគំរូរបស់ព្រះអង្គ
ហើយបម្រើគ្នាទៅវិញទៅមក។ “ អ្នកគួរតែបម្រើគ្នាដោយរាបសារ”
John 13:16
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តនិយាយទៅកាន់សិស្សរបស់ព្រះអង្គ។
ពិតណាស់
បកប្រែដូចនៅក្នុង ១:៤៩ ។
ធំជាង
"សំខាន់ជាង"
អ្នកនឹងមានពរ
ពាក្យថា“ មានពរ”ត្រង់នេះ មានន័យថា បង្កឲ្យមានរឿងល្អ
និងមានប្រយោជន៍កើតឡើងចំពោះមនុស្សម្នាក់។
អ្នកអាចបកប្រែវាជាទម្រង់កិរិយាសកម្ម។ “ ព្រះជាម្ចាស់នឹងប្រទានពរដល់អ្នក”
ការនេះអាចកើតឡើងដូច្នេះ ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរថា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដើម្បីឲ្យសម្រេចតាមបទគម្ពីរ"
អ្នកដែលបរិភោគនំប៉័ងខ្ញុំ បានលើកកែងជើងរបស់គាត់ទាស់នឹងខ្ញុំ
ឃ្លា "បរិភោគនំប៉័ងរបស់ខ្ញុំ"នៅទីនេះ សំដៅទៅលើអ្នកដែលធ្វើពុតជាមិត្ត។ ឃ្លាថា“
លើកកែងជើងឡើងលើ” ក៏មានន័យថា អ្នកដែលក្លាយជាសត្រូវ។
ប្រសិនបើអ្នកមានពាក្យផ្សេងក្រៅពីនេះនៅក្នុងភាសារបស់អ្នក
ដែលមានអត្ថន័យដូចនេះ អ្នកអាចប្រើវានៅទីនេះ។
"អ្នកដែលធ្វើពុតជាមិត្តរបស់ខ្ញុំបានប្រែក្លាយជាសត្រូវ"
John 13:19
ខ្ញុំប្រាប់អ្នករាល់គ្នានៅពេលនេះ មុនពេលវាកើតឡើង
"ខ្ញុំកំពុងប្រាប់អ្នកពេលនេះនូវអ្វី ដែលនឹងកើតឡើង មុនពេលវានឹងកើតឡើង"
អ្នកអាចជឿថា ខ្ញុំជាព្រះ
"អ្នកអាចជឿថាខ្ញុំជាព្រះជាម្ចាស់" ឬ "អ្នកអាចជឿថាខ្ញុំជាព្រះមេស្ស៊ី"
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩។
John 13:21
ខ្វល់ខ្វាយ
ព្រួយបារម្ភ តូចចិត្ត
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩។
ពួកសិស្សមើលគ្នាទៅវិញទៅមក ងឿងឆ្ងល់ថាព្រះអង្គកំពុងមានបន្ទូលពីអ្នកណា
"ពួកសិស្សមើលមុខគ្នា ហើយងឿងឆ្ងល់ថា «តើអ្នកណានឹងក្បត់ព្រះយេស៊ូ?"
John 13:23
សិស្សម្នាក់នៃពួកសិស្សរបស់ព្រះអង្គ ជាអ្នកដែលព្រះអង្គស្រឡាញ់
សំដៅទៅលើយ៉ូហាន។
កំពុងតែអង្គុយតុ
អំឡុងពេលព្រះគ្រិស្តគង់នៅលើផែនដី ជនជាតិយូដាច្រើនតែបរិភោគអាហាររួមគ្នា
តាមរបៀបរបស់ជនជាតិក្រិក ដែលពួកគេអង្គុយនៅលើគ្រែទាប។
នៅជិតព្រះយេស៊ូ

generated on Wed Sep 10 16:16:32 2025

ទម្រេតនឹងក្បាលរបស់មនុស្សម្នាក់ទល់នឹងចំហៀងតុអាហារពេលល្ងាច
តាមរបៀបរបស់ជនជាតិក្រិក គេចាត់ទុកថាជាកន្លែងនៃមិត្តភាពដ៏អស្ចារ្យបំផុត
ជាមួយព្រះអង្គ។
ស្រឡាញ់
សេចក្តីស្រឡាញ់ប្រភេទនេះកើតចេញពីព្រះជាម្ចាស់
ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
ទោះបីវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់
ចំពោះអ្នកដទៃទោះជាពួកគេធ្វើអ្វីក៏ដោយ។
John 13:26
អ៊ីស្ការីយ៉ុត
បង្ហាញថាយូដាសមកពីភូមិខេរីត។
បន្ទាប់ពីបានទទួលនំប៉ុងហើយ
ឃ្លានេះ អ្នកអាចបញ្ចូលពាក្យដែលបង្កប់ន័យ។
"ភ្លាមៗនៅពេលយូដាសយកដុំនំប៉ុង"
សាតាំងបានចូលទៅក្នុងគាត់
នេះជាពាក្យមួយដែលមានន័យថា សាតាំងបានគ្រប់គ្រងយូដាសទាំងស្រុង។ “
សាតាំងបានគ្រប់គ្រងលើគាត់” ឬ“ សាតាំងបានចាប់ផ្តើមបញ្ជាគាត់”
ព្រះយេស៊ូមានបន្ទូលទៅគាត់ថា
នៅទីនេះ ព្រះយេស៊ូកំពុងតែមានបន្ទូលទៅកាន់យូដាស។
តើអ្នកកំពុងធ្វើអ្វី ចូរធ្វើវាឲ្យលឿនទៅ
"ធ្វើយ៉ាងឆាប់រហ័សនូវអ្វី ដែលអ្នកគ្រោងនឹងធ្វើទៅ!"
John 13:28
អាចឲ្យគាត់ឲ្យអ្វីមួយដល់អ្នកក្រ
អ្នកអាចបកប្រែវាជាការដកស្រង់ដោយផ្ទាល់៖
"ទៅហើយឲ្យលុយខ្លះដល់អ្នកក្រីក្រ" ។
គាត់ក៏ចេញទៅភ្លាម។ ពេលនោះយប់ហើយ
យ៉ូហានហាក់ដូចជាចំណាប់អារម្មណ៍នៅទីនេះ
ចំពោះការដែលថាយូដាសនឹងធ្វើអំពើអាក្រក់ ឬ
អំពើអាក្រក់របស់គាត់នៅក្នុងទីងងឹតនៃពេលយប់។
"គាត់បានចេញទៅក្រៅភ្លាមនៅពេលយប់ងងឹត"
John 13:31
ឥឡូវនេះ បុត្រារបស់មនុស្សត្រូវទទួលសិរីរុងរឿង
ហើយព្រះជាម្ចាស់បានទទួលសិរីរុងរឿងបានតាមរយៈព្រះអង្គដែរ
អ្នកអាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ឥឡូវនេះមនុស្សហៀបនឹងមើលឃើញពីកូនមនុស្ស នឹងទទួលកិត្តិយស
និងការដែលព្រះអង្គនឹងទទួលកិត្តិយសតាមរយៈអ្វី ដែលកូនមនុស្សកំពុងធ្វើ»
ព្រះជាម្ចាស់នឹងតម្កើងព្រះអង្គនៅក្នុងអង្គទ្រង់ផ្ទាល់ ហើយទ្រង់នឹងតម្កើងព្រះអង្គភ្លាម
ពាក្យថា“ គាត់” សំដៅទៅលើកូនមនុស្ស។ ពាក្យ "ខ្លួនគាត់"
គឺជាសព្វនាមឆ្លុះបញ្ចាំង ដែលសំដៅទៅលើព្រះជាម្ចាស់។ “
ព្រះអង្គនឹងផ្តល់កិត្តិយសដល់បុត្រមនុស្សភ្លាមៗ”
កូនតូចអើយ
ព្រះយេស៊ូប្រើពាក្យ «កូនតូច» ដើម្បីប្រាស្រ័យទាក់ទងថា
ទ្រង់ស្រឡាញ់ពួកសិស្សដូចជាពួកគេជាកូនរបស់ព្រះអង្គ។
ដូចដែលខ្ញុំបាននិយាយទៅពួកយូដាដែរថា
នៅទីនេះ "ជនជាតិយូដា" តំណាងឲ្យមេដឹកនាំជនជាតិយូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។
"ដូចដែលខ្ញុំបាននិយាយទៅកាន់មេដឹកនាំសាសន៍យូដា"
John 13:34
សេចក្តីថ្លែងការណ៍ភ្ជាប់៖
ព្រះយេស៊ូបន្តមានប្រសាសន៍ទៅកាន់សិស្សរបស់ព្រះអង្គ។
ស្រឡាញ់
នេះជាសេចក្តីស្រឡាញ់
ដែលកើតចេញពីព្រះជាម្ចាស់ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
ទោះបីវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់
ចំពោះអ្នកដទៃទោះជាពួកគេធ្វើអ្វីក៏ដោយ។
អ្នករាល់គ្នា
នេះគឺជាការបន្ថែមការសង្កត់ន័យទៅលើឃ្លារបស់ព្រះយេស៊ូ។
សំដៅទៅលើមនុស្សទាំងនោះ ដែលបានឃើញសេចក្តីស្រឡាញ់របស់ពួកសិស្ស
ចំពោះគ្នាទៅវិញទៅមក។ "មនុស្សគ្រប់គ្នាដែលដឹងពីសេចក្តីស្រឡាញ់របស់អ្នក
ចំពោះគ្នាទៅវិញទៅមក"
John 13:36
លះបង់ជីវិតរបស់ទូលបង្គំ
"លះបង់ជីវិតខ្ញុំ" ឬ "ស្លាប់"
តើអ្នកនឹងលះបង់ជីវិតដើម្បីខ្ញុំ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបន្ថែមការសង្កត់ន័យទៅលើសេចក្តីថ្លែងរបស់ព្រះយេស៊ូ។ "អ្នកនិយាយថា
អ្នកនឹងស្លាប់ជំនួសខ្ញុំ ប៉ុន្តែការពិតគឺថាអ្នកនឹងមិនធ្វើវាទេ!"
មាន់នឹងមិនរងាវទេ ប្រសិនបើអ្នកមិនបដិសេធខ្ញុំបីដង
"អ្នកនឹងនិយាយថា អ្នកមិនស្គាល់ខ្ញុំបីដងមុនពេលមាន់រងាវ"

---

14 [1]កុំឲ្យរបស់អ្នករាល់គ្នាខ្វល់ខ្វាយឡើយ។ អ្នកជឿដល់ព្រះជាម្ចាស់ហើយ ក៏ជឿដល់ខ្ញុំដែរ។[2]នៅក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានបន្ទប់ជាច្រើន។
ប្រសិនបើមិនដូច្នោះទេ ខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងទៅដើម្បីរៀបចំកន្លែងសម្រាប់អ្នករាល់គ្នា។[3]ប្រសិនបើខ្ញុំទៅ ហើយរៀបចំកន្លែងសម្រាប់អ្នករាល់គ្នា
ខ្ញុំនឹងត្រឡប់មកវិញម្តងទៀត ហើយយកអ្នករាល់គ្នាទៅឯខ្ញុំ ដូច្នេះ អ្នករាល់គ្នានឹងបាននៅកន្លែងដែលខ្ញុំនៅដែរ។
[4]អ្នករាល់គ្នាបានស្គាល់ផ្លូវដែលខ្ញុំកំពុងទៅ។[5]លោកថូម៉ាសទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ យើងមិនដឹងថាព្រះអង្គទៅណាផង
ធ្វើដូចម្តេចឲ្យយើងស្គាល់ផ្លូវបានទៅ?»[6]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ខ្ញុំជាផ្លូវ ជាសេចក្តីពិត និងជាជីវិត គ្មាននរណាអាចទៅឯព្រះបិតាបានទេ
លើកលែងតែចូលតាមរយៈខ្ញុំ។[7]ប្រសិនបើ អ្នករាល់គ្នាបានស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ ចាប់ពីពេលនេះតទៅ អ្នករាល់គ្នាស្គាល់ព្រះអង្គ
ហើយក៏បានឃើញព្រះអង្គដែរ»។
[8]លោកភីលីពទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមបង្ហាញព្រះបិតាដល់យើងខ្ញុំផង នោះយើងខ្ញុំស្កប់ចិត្តហើយ»។[9]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖
«ខ្ញុំបាននៅជាមួយអ្នកអស់រយៈពេលយ៉ាងយូរ ហើយអ្នកនៅតែមិនស្គាល់ខ្ញុំទៀត ភីលីព? អស់អ្នកណាដែលឃើញខ្ញុំ ឃើញព្រះបិតាដែរ។ តើអ្នកអាចនិយាយថា៖
«សូមបង្ហាញព្រះបិតាឲ្យយើងខ្ញុំឃើញផងដូចម្តេចកើត?
[10]តើអ្នករាល់គ្នាមិនជឿថា ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតានៅក្នុងខ្ញុំទេឬអី? ពាក្យដែលខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា
ខ្ញុំមិនបាននិយាយចេញដោយសិទ្ធិអំណាចខ្លួនរបស់ខ្ញុំផ្ទាល់ទេ ប៉ុន្តែ ព្រះបិតារស់នៅក្នុងខ្ញុំកំពុងធ្វើការងាររបស់ព្រះអង្គ។[11]ចូរជឿដល់ខ្ញុំថា ខ្ញុំនៅក្នុងព្រះបិតា
ហើយព្រះបិតានៅក្នុងខ្ញុំ ឬជឿដោយសារកិច្ចការទាំងនោះចុះ។
[12]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នឹងធ្វើការដូចដែលខ្ញុំធ្វើដែរ ហើយអ្នកនោះនឹងធ្វើការលើសជាងការទាំងនេះផង ដ្បិត
ខ្ញុំបានទៅឯព្រះបិតាខ្ញុំវិញហើយ។[13]អ្វីក្តីដែលអ្នករាល់គ្នាសុំដោយនូវឈ្មោះខ្ញុំ ខ្ញុំនឹងសម្រេចឲ្យ ដើម្បីឲ្យព្រះបិតាបានទទួលសិរីរុងរឿងនៅក្នុងព្រះបុត្រា។[14]ប្រសិនបើ
អ្នករាល់គ្នាសុំអ្វីៗដោយនូវឈ្មោះខ្ញុំ ហើយខ្ញុំនឹងធ្វើវា។
[15]ប្រសិនបើ អ្នករាល់គ្នាស្រឡាញ់ខ្ញុំ នឹងប្រព្រឹត្តតាមបញ្ញាតិរបស់ខ្ញុំ[16]ហើយខ្ញុំនឹងអធិស្ឋានទៅព្រះបិតា ហើយព្រះអង្គនឹងប្រទានអ្នកកម្សាន្តចិត្តដល់អ្នករាល់គ្នា
ដើម្បីឲ្យព្រះអង្គបានគង់នៅជាមួយអ្នករាល់គ្នាជារៀងរហូតតទៅ[17]ជាព្រះវិញ្ញាណនៃសេចក្តីពិត។ លោកីយ៍មិនអាចទទួលព្រះអង្គបានទេ
ដោយសារលោកីយ៍មិនឃើញព្រះអង្គ ឬស្គាល់ព្រះអង្គ។ ប៉ុន្តែ អ្នករាល់គ្នាវិញ ស្គាល់ព្រះអង្គ ដើម្បីព្រះអង្គមានព្រះជន្មរស់នៅជាមួយអ្នករាល់គ្នា
ហើយគង់នៅជាមួយអ្នករាល់គ្នា។
[18]ខ្ញុំនឹងមិនបោះបង់អ្នករាល់គ្នាចោលឡើយ ខ្ញុំនឹងត្រឡប់មករកអ្នករាល់គ្នាវិញ។[19]នៅក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ លោកីយ៍នឹងលែងឃើញខ្ញុំទៀតហើយ ប៉ុន្តែ
អ្នករាល់គ្នាឃើញខ្ញុំ។ ព្រោះខ្ញុំរស់ អ្នករាល់គ្នាក៏រស់ដែរ។[20]នៅថ្ងៃនោះ អ្នកនឹងដឹងថា ខ្ញុំនៅក្នុងព្រះបិតា ហើយថាអ្នករាល់គ្នានៅក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

[21]អស់អ្នកណាដែលមានក្រឹត្យវិន័យរបស់ខ្ញុំ ហើយប្រព្រឹត្តតាម គឺជាអ្នកដែលស្រឡាញ់ខ្ញុំ ហើយអ្នកណាដែលស្រឡាញ់ខ្ញុំ ព្រះបិតារបស់ខ្ញុំក៏ស្រឡាញ់អ្នកនោះដែរ
ហើយខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយខ្ញុំនឹងបង្ហាញខ្លួនខ្ញុំដល់អ្នកនោះ»។[22]លោកយូដា (មិនមែនអ៊ីស្ការីយ៉ុត) បានទូលទៅព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ
ហេតុអ្វីបានជាព្រះអង្គបង្ហាញអង្គទ្រង់ដល់យើង ហើយមិនបង្ហាញដល់លោកីយ៍?»
[23]ព្រះយេស៊ូបានឆ្លើយ ហើយមានបន្ទូលទៅគាត់ថា៖ «ប្រសិនបើ អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រព្រឹត្តតាមពាក្យរបស់ខ្ញុំ។ ព្រះបិតារបស់ខ្ញុំនឹងស្រឡាញ់អ្នកនោះ
ហើយយើងនឹងមករកអ្នកនោះ ហើយយើងនឹងតាំងទីលំនៅរបស់យើងជាមួយអ្នកនោះ។[24]អ្នកណាដែលមិនស្រឡាញ់ខ្ញុំ មិនប្រព្រឹត្តតាមពាក្យរបស់ខ្ញុំទេ។
ពាក្យដែលអ្នករាល់គ្នាបានឮមិនមែនជាពាក្យរបស់ខ្ញុំទេ ប៉ុន្តែ មកពីព្រះបិតាដែលចាត់ខ្ញុំឲ្យមក។
[25]ខ្ញុំបាននិយាយការទាំងនេះដល់អ្នករាល់គ្នា ក្នុងពេលដែលខ្ញុំនៅជាមួយនឹងអ្នករាល់គ្នា។[26]ប៉ុន្តែ អ្នកកម្សាន្តចិត្ត គឺព្រះវិញ្ញាណដ៏វិសុទ្ធ
ជាព្រះដែលព្រះបិតាបានចាត់មកដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងបង្រៀនអ្នករាល់គ្នាគ្រប់យ៉ាង
ហើយព្រះអង្គនឹងរំលឹកអ្នករាល់គ្នាពីអ្វីៗគ្រប់យ៉ាងដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នា។[27]ខ្ញុំទុកសេចក្តីសុខសាន្តដល់អ្នករាល់គ្នា
ខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំឲ្យ មិនដូចជាសេចក្តីសុខសាន្តដែលលោកីយ៍ឲ្យទេ។ កុំឲ្យចិត្តរបស់អ្នករាល់គ្នាខ្វល់ខ្វាយឡើយ
ហើយក៏កុំឲ្យភ័យខ្លាចដែរ។
[28]អ្នករាល់គ្នាបានឮអ្វីដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាថា៖ «ខ្ញុំនឹងចេញទៅឆ្ងាយ ហើយខ្ញុំនឹងត្រឡប់មកឯអ្នករាល់គ្នាវិញ។ ប្រសិនបើ អ្នករាល់គ្នាស្រឡាញ់ខ្ញុំ
អ្នកនឹងមានអំណរ ព្រោះខ្ញុំកំពុងតែទៅឯព្រះបិតា ដ្បិតព្រះបិតាធំជាងខ្ញុំ។[29]ខ្ញុំបានប្រាប់អ្នករាល់គ្នារួចហើយ វានឹងកើតឡើងយ៉ាងដូច្នេះ ដើម្បីនៅពេលវាកើតឡើង
អ្នករាល់គ្នានឹងជឿ។[30]ខ្ញុំនឹងឈប់និយាយច្រើនជាមួយនឹងអ្នករាល់គ្នាទៀតហើយ ដ្បិតមេគ្រប់គ្រងលោកីយ៍នេះមកដល់ហើយ។ វាគ្មានអំណាចអ្វីមកលើខ្ញុំទេ[31]ប៉ុន្តែ
ដើម្បីលោកីយ៍បានដឹងថា ខ្ញុំស្រឡាញ់ព្រះបិតា ហើយខ្ញុំធ្វើអ្វីៗតាមសេចក្តីបង្គាប់របស់ព្រះបិតាខ្ញុំ តែប៉ុណ្ណោះ។ ចូរយើងក្រោកឡើង ហើយចេញពីទីនេះទៅ»។

John 14:1
ឃ្លាភ្ជាប់៖
ផ្នែករបស់រឿងនៅជំពូកមុនបន្ត។
ព្រះយេស៊ូអង្គុយនៅតុជាមួយនឹងពួកសិស្សរបស់ព្រះអង្គ
ហើយបន្តមានបន្ទូលជាមួយពួកគេ។
កុំឲ្យរបស់អ្នករាល់គ្នាខ្វល់ខ្វាយឡើយ
មានបញ្ហាក្នុងការគិតមានន័យថា ការខ្វល់ខ្វាយ ឬការថប់បារម្ភ។ “
ឈប់ខ្វល់ខ្វាយនិងព្រួយបារម្ភ”
នៅក្នុងដំណាក់របស់ព្រះបិតាខ្ញុំ មានបន្ទប់ជាច្រើន
"មានកន្លែងជាច្រើនណាស់ សម្រាប់រស់នៅក្នុងដំណាក់របស់ព្រះបិតាខ្ញុំ"
នៅក្នុងដំណាក់របស់ព្រះបិតាខ្ញុំ
សំដៅទៅលើឋានសួគ៌ជាកន្លែង ដែលព្រះជាម្ចាស់គង់នៅ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
មានបន្ទប់ជាច្រើន
ពាក្យថា“ បន្ទប់” អាចសំដៅទៅលើបន្ទប់តែមួយ ឬជាលំនៅដ្ឋានធំជាង។
ខ្ញុំទៅ ហើយរៀបចំកន្លែងសម្រាប់អ្នករាល់គ្នា
ព្រះយេស៊ូនឹងរៀបចំកន្លែងមួយនៅស្ថានសួគ៌សម្រាប់មនុស្សគ្រប់គ្នា
ដែលទុកចិត្តលើព្រះយេស៊ូ។ "អ្នក" គឺជាពហុវចន:
ហើយសំដៅទៅលើសិស្សទាំងអស់របស់ព្រះអង្គ។
John 14:4
ធ្វើដូចម្តេចឲ្យយើងស្គាល់ផ្លូវបានទៅ?
តើយើងអាចដឹងយ៉ាងដូចម្តេចដើម្បីទៅដល់ទីនោះ?
ផ្លូវ
ជាពាក្យប្រៀបធៀប ដែលអាចមានន័យថា ១)“ ផ្លូវទៅព្រះជាម្ចាស់” ឬ ២)“
អ្នកដែលនាំមនុស្សទៅរកព្រះជាម្ចាស់” ។
សេចក្តីពិត
ជាពាក្យប្រៀបធៀប ដែលអាចមានន័យថា ១)“ មនុស្សពិត” ឬ ២)“
អ្នកដែលនិយាយពាក្យពិតអំពីព្រះជាម្ចាស់” ។
ជីវិត
ជាពាក្យប្រៀបធៀប ដែលមានន័យថា ព្រះយេស៊ូអាចផ្តល់ជីវិតដល់មនុស្ស។ “
អ្នកដែលអាចធ្វើឲ្យមនុស្សរស់បាន”
គ្មាននរណាអាចទៅឯព្រះបិតាបានទេ លើកលែងតែចូលតាមរយៈខ្ញុំ
មនុស្សអាចមករកព្រះជាម្ចាស់ ហើយរស់នៅជាមួយព្រះអង្គបាន
ដោយគ្រាន់តែជឿទុកចិត្តលើព្រះយេស៊ូ។ "គ្មាននរណាម្នាក់អាចទៅរកព្រះបិតា
ហើយរស់នៅជាមួយព្រះអង្គបានទេ លើកលែងតែគេមកតាមរយៈខ្ញុំ" ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
John 14:8
ព្រះអម្ចាស់អើយ សូមបង្ហាញព្រះបិតាដល់យើងខ្ញុំផង
“ ព្រះបិតា” ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ខ្ញុំបាននៅជាមួយអ្នកអស់រយៈពេលយ៉ាងយូរ ហើយអ្នកនៅតែមិនស្គាល់ខ្ញុំទៀត ភីលីព?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបន្ថែមការសង្កត់ន័យទៅលើពាក្យរបស់ព្រះយេស៊ូ។ "ភីលីព
ខ្ញុំបាននៅជាមួយអ្នកអស់រយៈពេលជាយូរមកហើយ។ អ្នកគួរតែស្គាល់ខ្ញុំឥឡូវនេះ!"
អស់អ្នកណាដែលឃើញខ្ញុំ ឃើញព្រះបិតាដែរ
ឃើញព្រះយេស៊ូជាព្រះបុត្រា គឺឃើញព្រះបិតា។ “ ព្រះបិតា”
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
តើអ្នកអាចនិយាយថា៖ «សូមបង្ហាញព្រះបិតាឲ្យយើងខ្ញុំឃើញផងដូចម្តេចកើត?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់នៃសំណួរ
ដើម្បីបញ្ជាក់ពីពាក្យរបស់ព្រះយេស៊ូទៅកាន់ភីលីព។
"ដូច្នេះអ្នកពិតជាមិនគួរនិយាយថា" បង្ហាញព្រះបិតាដល់យើងទេ! "
John 14:10
ឃ្លាភ្ជាប់៖
ព្រះយេស៊ូសួរភីលីពនូវសំណួរមួយ
បន្ទាប់មកទ្រង់បន្តនិយាយទៅកាន់សិស្សទាំងអស់របស់ព្រះអង្គ។
តើអ្នករាល់គ្នាមិនជឿថា ...ក្នុងខ្ញុំទេឬអី?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់នៃសំណួរ
ដើម្បីបញ្ជាក់ពីពាក្យរបស់ព្រះយេស៊ូទៅកាន់ភីលីព។ "អ្នកពិតជាគួរជឿ ... លើខ្ញុំ" ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ពាក្យដែលខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា
ខ្ញុំមិនបាននិយាយចេញដោយសិទ្ធិអំណាចខ្លួនរបស់ខ្ញុំផ្ទាល់ទេ
"អ្វីដែលខ្ញុំកំពុងប្រាប់អ្នកមិនមែនមកពីខ្ញុំទេ" ឬ
"ពាក្យដែលខ្ញុំប្រាប់អ្នកមិនមែនមកតាមរយៈខ្ញុំទេ"
ពាក្យដែលខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា
"អ្នក"នៅទីនេះ ជាពហុវចន:។ ឥឡូវនេះ
ព្រះយេស៊ូកំពុងមានបន្ទូលទៅកាន់សិស្សរបស់ព្រះអង្គទាំងអស់។
ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតានៅក្នុងខ្ញុំ
ពាក្យនេះមានន័យថា ព្រះបិតានិងព្រះយេស៊ូមានទំនាក់ទំនងពិសេស។
"ខ្ញុំនៅជាមួយព្រះបិតា ហើយព្រះបិតាក៏នៅជាមួយខ្ញុំដែរ" ឬ
"ព្រះបិតាខ្ញុំនិងខ្ញុំគឺយើងតែមួយ"
John 14:12
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩ ។
ជឿដល់ខ្ញុំ
មានន័យថា ជឿលើព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។
អ្វីក្តីដែលអ្នករាល់គ្នាសុំដោយនូវឈ្មោះខ្ញុំ
នៅទីនេះ "ឈ្មោះ" ជាពាក្យប្រៀបធៀបតំណាងឲ្យសិទ្ធិអំណាចរបស់ព្រះយេស៊ូ។
"អ្វីក៏ដោយដែលអ្នកសុំ សូមប្រើសិទ្ធិអំណាចរបស់ខ្ញុំ"
ដើម្បីឲ្យព្រះបិតាបានទទួលសិរីរុងរឿងនៅក្នុងព្រះបុត្រា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដូច្នេះខ្ញុំអាចបង្ហាញដល់មនុស្សគ្រប់គ្នាថា
ព្រះបិតាខ្ញុំអស្ចារ្យប៉ុណ្ណា"
ព្រះបិតា...ព្រះបុត្រា

generated on Wed Sep 10 16:16:32 2025

ទាំងនេះគឺជាងារសំខាន់ៗដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់និងព្រះយេស៊ូ
ប្រសិនបើ អ្នករាល់គ្នាសុំអ្វីៗដោយនូវឈ្មោះខ្ញុំ ហើយខ្ញុំនឹងធ្វើវា
នៅទីនេះ "ឈ្មោះ" គឺតំណាងឲ្យសិទ្ធិអំណាចរបស់ព្រះយេស៊ូ។
"ប្រសិនបើអ្នកសុំខ្ញុំនូវអ្វីមួយ ក្នុងនាមជាអ្នកដើរតាមខ្ញុំ ខ្ញុំនឹងឲ្យវាដល់អ្នក" ឬ
"អ្វីក៏ដោយដែលអ្នកសុំពីខ្ញុំ ខ្ញុំនឹងឲ្យ ព្រោះអ្នកជាកម្មសិទ្ធិរបស់ខ្ញុំ"
John 14:15
អ្នកកម្សាន្តចិត្ត
សំដៅទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ។
ព្រះវិញ្ញាណនៃសេចក្តីពិត
សំដៅទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលបង្រៀនមនុស្សអំពីសេចក្តីពិតរបស់ព្រះជាម្ចាស់។
លោកីយ៍មិនអាចទទួលព្រះអង្គបានទេ
“ លោកីយ”នៅទីនេះ ជាពាក្យប្រៀបធៀប សំដៅទៅលើមនុស្ស
ដែលប្រឆាំងនឹងព្រះជាម្ចាស់។ “ មនុស្សដែលមិនជឿលើព្រះអង្គ
និងមិនស្វាគមន៍ព្រះអង្គទេ” ឬ“ អ្នកដែលប្រឆាំងនឹងព្រះជាម្ចាស់
នឹងមិនទទួលព្រះអង្គឡើយ”
John 14:18
បោះបង់អ្នករាល់គ្នាចោល
នៅទីនេះ ព្រះយេស៊ូបានបញ្ជាក់ថា ទ្រង់នឹងមិនទុកសិស្សរបស់ព្រះអង្គចោល
ដោយមិនមានអ្នកណាមើលថែពួកគេឡើយ។
"ទុកអ្នកចោលដោយគ្មានអ្នកមើលថែ"
លោកីយ៍
«លោកីយ» នៅទីនេះ ជាពាក្យប្រៀបធៀប តំណាងឲ្យមនុស្ស
ដែលមិនមែនជារបស់ព្រះជាម្ចាស់។ «អ្នកមិនជឿ»
អ្នកនឹងដឹងថា ខ្ញុំនៅក្នុងព្រះបិតា
ព្រះបិតា និងព្រះយេស៊ូជាមនុស្សតែម្នាក់។ «អ្នកនឹងដឹងថា
ព្រះបិតាខ្ញុំនិងខ្ញុំពិតជាមនុស្សតែម្នាក់» ។
ព្រះបិតារបស់ខ្ញុំ
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
អ្នករាល់គ្នានៅក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នករាល់គ្នា
«អ្នកនិងខ្ញុំគឺជាមនុស្សតែម្នាក់»
John 14:21
ស្រឡាញ់
សេចក្តីស្រឡាញ់ប្រភេទនេះកើតចេញពីព្រះជាម្ចាស់
ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
ទោះបីវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះជាពួកគេធ្វើអ្វីក៏ដោយ។
អ្នកណាដែលស្រឡាញ់ខ្ញុំ ព្រះបិតារបស់ខ្ញុំក៏ស្រឡាញ់អ្នកនោះដែរ
អ្នកអាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ ព្រះបិតាខ្ញុំនឹងស្រឡាញ់អ្នកណា
ដែលស្រឡាញ់ខ្ញុំ”
ព្រះបិតារបស់ខ្ញុំ
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
លោកយូដា (មិនមែនអ៊ីស្ការីយ៉ុត)
សំដៅទៅលើសិស្សម្នាក់ទៀត ដែលមានឈ្មោះយូដាសមិនមែនសំដៅទៅលើសិស្ស
ដែលមកពីភូមិខេរ័ត្នដែលបានក្បត់ព្រះយេស៊ូទេ។
ហេតុអ្វីបានជាព្រះអង្គបង្ហាញអង្គទ្រង់ដល់យើង
ពាក្យថា“ បង្ហាញ”ត្រង់នេះ សំដៅទៅលើការបង្ហាញពីការអស្ចារ្យរបស់ព្រះយេស៊ូ។
"ហេតុអ្វីបានជាទ្រង់នឹងបង្ហាញអង្គទ្រង់ដល់យើង " ឬ
"ហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យយើងមើលថា ទ្រង់អស្ចារ្យប៉ុណ្ណា?"
មិនបង្ហាញដល់លោកីយ៍
នៅទីនេះ "លោកីយ" ជាពាក្យប្រៀបធៀ
តំណាងឲ្យមនុស្សដែលប្រឆាំងនឹងព្រះជាម្ចាស់។
"មិនមែនចំពោះអ្នកដែលមិនមែនជារបស់ព្រះជាម្ចាស់ទេ"
John 14:23
ឃ្លាភ្ជាប់៖
ព្រះយេស៊ូឆ្លើយតបនឹងយូដាស (មិនមែនអ៊ីស្ការីយ៉ុតទេ) ។
"អ្នកដែលស្រឡាញ់ខ្ញុំ នឹងធ្វើអ្វីដែលខ្ញុំបានប្រាប់ឲ្យធ្វើ"
ស្រឡាញ់
សេចក្តីស្រឡាញ់ប្រភេទនេះកើតចេញពីព្រះជាម្ចាស់
ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
សូម្បីតែវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះបីជាពួកគេធ្វើអ្វីក៏ដោយ។
ព្រះបិតារបស់ខ្ញុំ
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
យើងនឹងមករកអ្នកនោះ ហើយយើងនឹងតាំងទីលំនៅរបស់យើងជាមួយអ្នកនោះ
ព្រះបិតានិងព្រះបុត្រានឹងចែករំលែកជីវិតជាមួយអ្នក
ដែលគោរពតាមអ្វីព្រះយេស៊ូបានបញ្ជា។ "យើងនឹងមករស់នៅជាមួយគេ
ហើយនឹងមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយគេ"
ពាក្យដែលអ្នករាល់គ្នាបានឮមិនមែនជាពាក្យរបស់ខ្ញុំទេ ប៉ុន្តែ មកពីព្រះបិតាដែលចាត់ខ្ញុំឲ្យមក
"រឿងដែលខ្ញុំបានប្រាប់អ្នកមិនមែនជារឿង
ដែលខ្ញុំសម្រេចចិត្តនិយាយដោយខ្លួនឯងទេ"
ពាក្យ
"ពាក្យ" នៅទីនេះជាពាក្យប្រៀបធៀបសម្រាប់សារ
ដែលព្រះយេស៊ូបាននាំមកពីព្រះជាម្ចាស់។
ដែលអ្នករាល់គ្នាបានឮ
នៅទីនេះ ពេលព្រះយេស៊ូមានបន្ទូលថា "អ្នក"
ទ្រង់កំពុងនិយាយទៅកាន់សិស្សទាំងអស់របស់ព្រះអង្គ។
John 14:25
អ្នកកម្សាន្តចិត្ត
សំដៅទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមមើលពីរបៀប
ដែលអ្នកបានបកប្រែនៅក្នុងជំពូក ១៤ ខ១៥ ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
នូវឈ្មោះខ្ញុំ
ពាក្យ "ឈ្មោះ"នៅទីនេះ ជាពាក្យប្រៀបធៀប ដែលតំណាងឲ្យឫទ្ធានុភាព
និងសិទ្ធិអំណាចរបស់ព្រះយេស៊ូ។ "ដោយសារតែខ្ញុំ" ឬ
"សម្រាប់ជាប្រយោជន៍របស់ខ្ញុំ"
លោកីយ៍
«លោកីយ»ជាពាក្យប្រៀបធៀប
ដែលតំណាងឲ្យមនុស្សដែលមិនស្រឡាញ់ព្រះជាម្ចាស់។
កុំឲ្យចិត្តរបស់អ្នករាល់គ្នាខ្វល់ខ្វាយឡើយ ហើយក៏កុំឲ្យភ័យខ្លាចដែរ
«មានចិត្តច្របូកច្របល់» ជាពាក្យមានន័យថា មានការថប់បារម្ភ ឬភ័យខ្លាចខ្លាំង។
នៅទីនេះ ព្រះយេស៊ូមានបន្ទូលអំពីដួងចិត្ត ប្រៀបដូចជាមនុស្ស។
«ដូច្នេះឈប់បារម្ភហើយកុំភ័យខ្លាច»
John 14:28
ស្រឡាញ់
សេចក្តីស្រឡាញ់ប្រភេទនេះកើតចេញពីព្រះជាម្ចាស់
ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
សូម្បីតែវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះបីជាពួកគេធ្វើអ្វីក៏ដោយ។
ខ្ញុំកំពុងតែទៅឯព្រះបិតា
នៅទីនេះ ព្រះយេស៊ូបានបញ្ជាក់ថា ព្រះអង្គនឹងត្រឡប់ទៅបិតារបស់ព្រះអង្គវិញ។
"ខ្ញុំនឹងត្រឡប់ទៅព្រះបិតាវិញ"
ដ្បិតព្រះបិតាធំជាងខ្ញុំ
នៅទីនេះ ព្រះយេស៊ូបញ្ជាក់ថា ព្រះបិតាមានសិទ្ធិអំណាចខ្លាំងជាងព្រះបុត្រា
ពេលព្រះបុត្រានៅលើផែនដី។ "ព្រះបិតាមានសិទ្ធិអំណាចខ្លាំងជាងខ្ញុំមាន
នៅទីនេះ" ។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

15 [1]ខ្ញុំជាដើមទំពាំងបាយជូរពិត ហើយព្រះបិតាខ្ញុំជាអ្នកដាំ។[2]ព្រះអង្គកាត់មែកទាំងឡាយណាដែលមិនបង្កើតផលនៅក្នុងខ្ញុំចោល
ហើយព្រះអង្គកាត់លោះមែកទាំងឡាយណាដែលបង្កើតផល ដើម្បីឲ្យមែកនោះបានបង្កើតផលកាន់តែច្រើនឡើងថែមទៀត។
[3]អ្នករាល់គ្នាបានស្អាតហើយ ដោយសារព្រះបន្ទូលដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នា។[4]ចូរនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នករាល់គ្នា។ ដូចជាមែកមួយ
មិនអាចបង្កើតផលដោយខ្លួនវាបានទេ លុះត្រាតែវានៅជាប់នឹងដើមទំពាំងបាយជូរ អ្នករាល់គ្នាក៏ដូចគ្នាដែរ លុះត្រាតែនៅជាប់នឹងខ្ញុំ។
[5]ខ្ញុំជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក។ អ្នកណាដែលនៅជាប់ក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នកនោះ អ្នកនោះនឹងបង្កើតផលជាច្រើន ដ្បិត បើគ្មានខ្ញុំទេ
អ្នកមិនអាចធ្វើអ្វីបានទាំងអស់។[6]ប្រសិនបើ អ្នកណាមិននៅជាប់នឹងខ្ញុំ អ្នកនោះនឹងត្រូវបោះចោលទៅក្រៅ ដូចជាមែក ហើយវានឹងស្ងួត
ហើយពួកគេនឹងប្រមូលមែកទាំងនោះ ហើយបោះមែកទាំងនោះចោលទៅក្នុងភ្លើង មែកទាំងនោះនឹងត្រូវឆេះអស់។[7]ប្រសិនបើ អ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយប្រសិនបើ
ពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា ចូរសុំអ្វីៗតាមតែអ្នកប្រាថ្នាចុះ វានឹងបានសម្រេចដល់អ្នករាល់គ្នា។
[8]ព្រះបិតាខ្ញុំបានទទួលសិរីល្អ ដោយសារអ្នករាល់គ្នាបង្កើតផលជាច្រើន ហើយបញ្ជាក់ថាអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន។[9]ព្រះបិតាស្រឡាញ់ខ្ញុំយ៉ាងណា
ខ្ញុំក៏ស្រឡាញ់អ្នករាល់គ្នាយ៉ាងនោះដែរ។ ចូរនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ។
[10]ប្រសិនបើ អ្នករាល់គ្នា ប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ខ្ញុំ អ្នករាល់គ្នានឹងនៅជាប់នឹងសេចក្តីស្រឡាញ់របស់ខ្ញុំ ដូចខ្ញុំ បានប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ព្រះបិតាខ្ញុំដែរ
ហើយខ្ញុំបាននៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គដែរ។[11]ខ្ញុំបានប្រាប់ការទាំងនេះដល់អ្នករាល់គ្នា ដើម្បីឲ្យអំណររបស់ខ្ញុំបាននៅជាមួយអ្នករាល់គ្នា
និងដើម្បីឲ្យអំណររបស់អ្នករាល់គ្នាបានពេញលក្ខណៈ។
[12]នេះគឺជាក្រឹត្យវិន័យរបស់ខ្ញុំ គឺថាអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នាដែរ។[13]គ្មាននរណាមានក្តីស្រឡាញ់ធំជាងនេះទេ
ដោយព្រះអង្គហ៊ានលះបង់ជីវិតដើម្បីមិត្តសម្លាញ់។
[14]អ្នករាល់គ្នាជាមិត្តសម្លាញ់របស់ខ្ញុំ ប្រសិនបើ អ្នករាល់គ្នាធ្វើការដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា។[15]ខ្ញុំលែងហៅអ្នករាល់គ្នាថាជាអ្នកបម្រើទៀតហើយ
ដ្បិតអ្នកបម្រើមិនដឹងថាម្ចាស់របស់គាត់កំពុងធ្វើអ្វីនោះទេ។ ខ្ញុំបានហៅអ្នករាល់គ្នាថាមិត្តសម្លាញ់ ដើម្បីអ្វីៗគ្រប់យ៉ាងដែលខ្ញុំបានឮពីព្រះបិតាខ្ញុំ
ហើយខ្ញុំបានប្រាប់ដល់អ្នករាល់គ្នារួចហើយ។
[16]អ្នករាល់គ្នាមិនបានជ្រើសរើសខ្ញុំទេ ប៉ុន្តែ ខ្ញុំបានជ្រើសរើសអ្នករាល់គ្នា ហើយបានរើសតាំងអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានចេញទៅហើយបង្កើតផល
ហើយផលរបស់អ្នករាល់គ្នាបាននៅជាប់ផង។ ដូច្នេះហើយ អ្វីដែលអ្នករាល់គ្នាទូលសុំពីព្រះបិតាដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងប្រទានមកអ្នករាល់គ្នា។
[17]ខ្ញុំបង្គាប់ការទាំងនេះមកអ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក។
[18]ប្រសិនបើ លោកីយ៍ស្អប់អ្នករាល់គ្នា ចូរដឹងថា ពួកគេស្អប់ខ្ញុំមុនពេលពួកគេស្អប់អ្នករាល់ទៅទៀត។[19]ប្រសិនបើ អ្នករាល់គ្នាមកពីលោកីយ៍
លោកីយ៍នឹងស្រឡាញ់អ្នករាល់គ្នា ព្រោះអ្នករាល់គ្នាជារបស់លោកីយ៍។ ប៉ុន្តែ ដោយព្រោះអ្នករាល់គ្នាមិនមែនជារបស់លោកីយ៍
ហើយដោយសារខ្ញុំបានជ្រើសរើសអ្នករាល់គ្នាចេញពីលោកីយ៍ ដូច្នេះហើយ បានជាលោកីយ៍ស្អប់អ្នករាល់គ្នា។
[20]ចាំសម្តីដែលខ្ញុំបាននិយាយជាមួយអ្នករាល់គ្នាទេ ថា៖ «អ្នកបម្រើមិនធំជាងចៅហ្វាយរបស់គាត់ទេ»។ ប្រសិនបើ ពួកគេបៀតបៀនខ្ញុំ
ពួកគេក៏បៀតបៀនដល់អ្នករាល់គ្នាដែរ។ ប្រសិនបើ អ្នករាល់គ្នាប្រព្រឹត្តតាមពាក្យខ្ញុំ ពួកគេនឹងប្រព្រឹត្តពាក្យរបស់អ្នករាល់គ្នាដែរ។
[21]ពួកគេនឹងធ្វើការទាំងអស់នេះដល់អ្នករាល់គ្នា ដោយព្រោះឈ្មោះខ្ញុំ ព្រោះពួកគេមិនស្គាល់ព្រះអង្គដែលចាត់ខ្ញុំឲ្យមកទេ។[22]ប្រសិនបើ ខ្ញុំមិនបានមក
ហើយប្រាប់ដល់ពួកគេទេ នោះពួកគេអាចនឹងគ្មានបាបទេ ប៉ុន្តែ ឥឡូវនេះ ពួកគេលែងមានការដោះសារពីបាបរបស់ពួកគេហើយ។
[23]អ្នកណាដែលស្អប់ខ្ញុំ ក៏ស្អប់ព្រះបិតាខ្ញុំដែរ។[24]ប្រសិនបើ ខ្ញុំមិនបានធ្វើការ ដែលគ្មាននរណានៅក្នុងចំណោមពួកគេអាចធ្វើការនោះបាន ពួកគេអាចនឹងមិនមានបាបទេ
ប៉ុន្តែ ឥឡូវនេះ ពួកគេបានឃើញ ហើយស្អប់ទាំងខ្ញុំ និងព្រះបិតាខ្ញុំ។[25]ប៉ុន្តែ ការនេះកើតឡើង ដើម្បីឲ្យបានសម្រេចតាមពាក្យដែលចែងនៅក្នុងក្រឹត្យវិន័យរបស់ពួកគេថា៖
«ពួកគេស្អប់ខ្ញុំ ឥតហេតុផលឡើយ»។
[26]នៅពេលដែលចាត់អ្នកកម្សាន្តចិត្តមកឯអ្នករាល់គ្នាពីព្រះបិតាខ្ញុំមក ព្រះអង្គជា ព្រះវិញ្ញាណនៃសេចក្តីពិត ដែលយាងពីព្រះបិតាខ្ញុំមក ព្រះអង្គនឹងធ្វើបន្ទាល់ពីខ្ញុំ។
[27]អ្នករាល់គ្នាដ៏កំពុងធ្វើបន្ទាល់ពីខ្ញុំដែរ ព្រោះអ្នករាល់គ្នាបាននៅជាមួយខ្ញុំតាំងពីដំបូង។

John 15:1

ឃ្លាភ្ជាប់៖

ផ្នែកនៃសាច់រឿងតពីជំពូកមុន។

ព្រះយេស៊ូគង់នៅតុជាមួយនឹងពួកសិស្សរបស់ព្រះអង្គ
ហើយបន្តមានបន្ទូលជាមួយពួកគេ។

ខ្ញុំជាដើមទំពាំងបាយជូរពិត

នៅទីនេះ“ ទំពាំងបាយជូរពិត” ជាពាក្យប្រៀបធៀប។

ព្រះយេស៊ូប្រៀបធៀបអង្គទ្រង់ទៅនឹងដើមទំពាំងបាយជូរ។ ទ្រង់ជាប្រភពនៃជីវិត
ធ្វើឲ្យមនុស្សរស់នៅតាមរបៀប ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់។

"ខ្ញុំប្រៀបដូចជាដើមទំពាំងបាយជូរ ដែលបង្កើតផលល្អ"

ព្រះបិតាខ្ញុំជាអ្នកដាំ

"អ្នកដាំ" ជាពាក្យប្រៀបធៀប។ "អ្នកដាំ" ជាមនុស្សម្នាក់ដែលថែរក្សាទំពាំងបាយជូរ
ដើម្បីធានាថាវាមានផ្លែផ្កាតាមដែលអាចធ្វើទៅបាន។ "ព្រះបិតាខ្ញុំគឺជាអ្នកដាំ"

ព្រះបិតារបស់ខ្ញុំ

ជាងារសំខាន់ចំពោះព្រះជាម្ចាស់។

ព្រះអង្គកាត់មែកទាំងឡាយណាដែលមិនបង្កើតផលនៅក្នុងខ្ញុំចោល

ហើយព្រះអង្គកាត់លោះមែកទាំងឡាយណាដែលបង្កើតផល

ដើម្បីឲ្យមែកនោះបានបង្កើតផលកាន់តែច្រើនឡើងថែមទៀត

នៅទីនេះ "មែក" ជាពាក្យប្រៀបធៀប តំណាងឲ្យមនុស្សម្នាក់ៗ
ដែលជាកម្មសិទ្ធិរបស់ព្រះយេស៊ូ។ ព្រះជាម្ចាស់យកចិត្តទុកដាក់ចំពោះពួកគេ
ដើម្បីឲ្យពួកគេនឹងអាចរស់នៅតាមរបៀបគាប់ព្រះទ័យព្រះអង្គ។

កាត់មែក

"កាត់ផ្តាច់និងយកទៅឆ្ងាយ"

លួសមែកទាំងឡាយណា

"កាត់លួសមែកណា"

John 15:3

អ្នករាល់គ្នាបានស្អាតហើយ ដោយសារព្រះបន្ទូលដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នា

ការប្រៀបធៀបដែលបង្កប់ន័យនៅទីនេះ ជា "សម្អាតមែក" ដែលលួស។
"ដូចជាអ្នកបានលួសចេញហើយធ្វើឲ្យមែកនោះស្អាត
ព្រោះអ្នកបានធ្វើតាមអ្វីដែលខ្ញុំបានបង្រៀនអ្នក"

អ្នក

ពាក្យ "អ្នក" នៅទូទាំងអត្ថបទនេះជាពហុវចន:
ហើយសំដៅទៅលើពួកសិស្សរបស់ព្រះយេស៊ូ។

រនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នករាល់គ្នា

"បើអ្នកនៅជាប់នឹងខ្ញុំ ខ្ញុំនឹងនៅជាប់នឹងអ្នកនោះ" ឬ "នៅជាប់នឹងខ្ញុំ
ហើយខ្ញុំនឹងនៅជាប់នឹងអ្នក"

លុះត្រាតែនៅជាប់នឹងខ្ញុំ

ដោយស្ថិតនៅជាប់នឹងព្រះគ្រិស្ត អ្នកជាកម្មសិទ្ធិរបស់ព្រះអង្គ ។
"លុះត្រាតែអ្នកនៅជាប់នឹងខ្ញុំ ហើយពឹងផ្អែកលើខ្ញុំគ្រប់យ៉ាង" ។

John 15:5

ខ្ញុំជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក

ដើមទំពាំងបាយជូរ ជាពាក្យប្រៀបធៀបតំណាងឲ្យព្រះយេស៊ូ។ "មែក"
ជាពាក្យប្រៀបធៀប តំណាងឲ្យអ្នកដែលទុកចិត្តលើព្រះយេស៊ូ
ហើយជាកម្មសិទ្ធិរបស់ព្រះអង្គ។ "ខ្ញុំប្រៀបដូចជាដើមទំពាំងបាយជូរ
ហើយអ្នកប្រៀបដូចជាមែក ដែលជាប់នឹងដើមទំពាំងបាយជូរ" ។

អ្នកណាដែលនៅជាប់ក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នកនោះ

នៅទីនេះ ព្រះយេស៊ូបានបញ្ជាក់ថា អ្នកកាន់តាមព្រះអង្គបានចូលរួមជាមួយព្រះអង្គ
ពេលទ្រង់ចូលរួមជាមួយព្រះជាម្ចាស់។ “ អ្នកណានៅជាប់នឹងខ្ញុំ

generated on Wed Sep 10 16:16:32 2025

ដូចខ្ញុំនៅជាប់នឹងព្រះបិតាខ្ញុំដែរ”
បង្កើតផលជាច្រើន
ពាក្យប្រៀបធៀបនៅទីនេះគឺជាមែកប្រកបដោយផ្លែផ្កា តំណាងឲ្យអ្នកជឿ
ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់។ ដូចគ្នានឹងមែក
ដែលជាប់នឹងដើមទំពាំងបាយជូរដែរ នឹងបង្កើតផលជាច្រើន
អ្នកនៅជាប់នឹងព្រះយេស៊ូ នឹងធ្វើអ្វីៗជាច្រើនដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់។
"អ្នកនឹងបង្កើតផ្លែច្រើន"
អ្នកនោះនឹងត្រូវបោះចោលទៅក្រៅ ដូចជាមែក
ជាពាក្យប្រៀបធៀបនៅទីនេះគឺជាមែក មិនបង្កើតផលតំណាងឲ្យអ្នក
ដែលមិននៅជាប់នឹងព្រះយេស៊ូ។ អ្នកអាចបកប្រែជាទម្រង់កិរិយាសកម្ម។ “
អ្នកថែចម្ការបោះគាត់ចោល ដូចបោះចោលមែកឈើដែរ”
មែកទាំងនោះនឹងត្រូវឆេះអស់
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ភ្លើងឆេះពួកគេ"
ចូរសុំអ្វីៗតាមតែអ្នកប្រាថ្នាចុះ
ព្រះយេស៊ូបានបញ្ជាក់ថា
អ្នកជឿត្រូវតែសុំឲ្យព្រះអង្គឆ្លើយតបការអធិស្ឋានរបស់ពួកគេ។
"សុំព្រះអង្គនូវអ្វីដែលអ្នកចង់បាន"
វានឹងបានសម្រេចដល់អ្នករាល់គ្នា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ទ្រង់នឹងធ្វើវាសម្រាប់អ្នក"
John 15:8
ព្រះបិតាខ្ញុំបានទទួលសិរីល្អ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "វាធ្វើឲ្យមនុស្សគោរពដល់ព្រះបិតាខ្ញុំ"
ព្រះបិតារបស់ខ្ញុំ
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ដោយសារអ្នករាល់គ្នាបង្កើតផលជាច្រើន
នៅទីនេះ“ ផលផ្លែ” ជាពាក្យប្រៀបធៀបមួយ
សម្រាប់ការរស់នៅគាប់ព្រះហឫទ័យព្រះជាម្ចាស់។ "នៅពេលអ្នករស់នៅតាមរបៀប
ដែលគាប់ព្រះហឫទ័យព្រះអង្គ"
អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ
"បង្ហាញអ្នកជាសិស្សរបស់ខ្ញុំ" ឬ "បង្ហាញថា អ្នកជាសិស្សរបស់ខ្ញុំ"
ព្រះបិតាស្រឡាញ់ខ្ញុំយ៉ាងណា ខ្ញុំក៏ស្រឡាញ់អ្នករាល់គ្នាយ៉ាងនោះដែរ
ព្រះយេស៊ូចែកសេចក្ដីស្រឡាញ់ ដែលព្រះបិតាមានចំពោះព្រះអង្គជាមួយអស់អ្នក
ដែលទុកចិត្តលើព្រះអង្គ។ នៅទីនេះ "ព្រះបិតា" ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ចូរនៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់ខ្ញុំ
"បន្តទទួលយកក្ដីស្រឡាញ់របស់ខ្ញុំ"
John 15:10
ប្រសិនបើ អ្នករាល់គ្នា ប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ខ្ញុំ
អ្នករាល់គ្នានឹងនៅជាប់នឹងសេចក្ដីស្រឡាញ់របស់ខ្ញុំ ដូចខ្ញុំ
បានប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ព្រះបិតាខ្ញុំដែរ
ហើយខ្ញុំបាននៅជាប់ក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គដែរ
ពេលអ្នកដើរតាមព្រះយេស៊ូ ស្តាប់បង្គាប់ព្រះអង្គ
ពួកគេបង្ហាញសេចក្ដីស្រឡាញ់ចំពោះព្រះអង្គ។ "នៅពេលអ្នកធ្វើអ្វីៗ
ដែលខ្ញុំបានប្រាប់អ្នកឲ្យធ្វើ អ្នកកំពុងរស់នៅក្នុងសេចក្ដីស្រឡាញ់របស់ខ្ញុំ
ដូចខ្ញុំបានស្តាប់បង្គាប់ព្រះបិតាខ្ញុំ ហើយរស់នៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ"
ព្រះបិតាខ្ញុំ
នៅទីនេះ "ព្រះបិតា" ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ខ្ញុំបានប្រាប់ការទាំងនេះដល់អ្នករាល់គ្នា ដើម្បីឲ្យអំណររបស់ខ្ញុំបាននៅជាមួយអ្នករាល់គ្នា
"ខ្ញុំបានប្រាប់អ្នកអំពីរឿងទាំងនេះ ដើម្បីឲ្យអ្នកមានអំណរដូចគ្នានឹងអំណរ
ដែលខ្ញុំមានដែរ"
ដើម្បីឲ្យអំណររបស់អ្នករាល់គ្នាបានពេញលក្ខណៈ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដើម្បីឲ្យអ្នកមានអំណរពេញលេញ" ឬ
"ដើម្បីឲ្យអំណររបស់អ្នកមិនមានអ្វីដែលបាត់"
John 15:12
គ្មាននរណាមានក្ដីស្រឡាញ់ធំជាងនេះ
សេចក្ដីស្រឡាញ់ប្រភេទនេះកើតចេញពីព្រះជាម្ចាស់ហើយចង់ឲ្យអ្នកដទៃមានសេចក្ដីស្រ
សូម្បីវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្ដីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះជាពួកគេធ្វើអ្វីក៏ដោយ។ "អ្នកមិនអាចមានក្ដីស្រឡាញ់ណាធំជាងនេះទេ" ។
ជីវិត
សំដៅទៅលើជីវិតខាងរូបកាយ។
John 15:14
អ្នករាល់គ្នាជាមិត្តសម្លាញ់របស់ខ្ញុំ ប្រសិនបើ អ្នករាល់គ្នាធ្វើការដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា
"បង្ហាញថា អ្នកជាមិត្តរបស់ខ្ញុំ
ប្រសិនបើអ្នកនៅតែធ្វើអ្វីៗដែលខ្ញុំបានបង្គាប់អ្នកឲ្យធ្វើ"
គ្រប់យ៉ាងដែលខ្ញុំបានឮពីព្រះបិតាខ្ញុំ ហើយខ្ញុំបានប្រាប់ដល់អ្នករាល់គ្នារួចហើយ
"ខ្ញុំបានប្រាប់អ្នកនូវអ្វីៗគ្រប់យ៉ាង ដែលព្រះបិតាខ្ញុំបានប្រាប់ខ្ញុំ"
ព្រះបិតាខ្ញុំ
នៅទីនេះ "ព្រះបិតា" ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
John 15:16
អ្នករាល់គ្នាមិនបានជ្រើសរើសខ្ញុំទេ
ព្រះយេស៊ូបានបញ្ជាក់ថា អ្នកដើរតាមព្រះអង្គមិនបានសម្រេចចិត្តដោយខ្លួនឯង
ដើម្បីក្លាយជាសិស្សរបស់ព្រះអង្គទេ។
"អ្នកមិនបានសម្រេចចិត្តក្លាយជាសិស្សរបស់ខ្ញុំឡើយ"
ចេញទៅហើយបង្កើតផល
នៅទីនេះ "ផល" ជាពាក្យប្រៀបធៀប
តំណាងឲ្យជីវិតដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់។ “
ជីវិតដែលរស់នៅគាប់ព្រះហឫទ័យព្រះជាម្ចាស់”
ហើយផលរបស់អ្នករាល់គ្នាបាននៅជាប់ផង
"លទ្ធផលនៃអ្វីៗ ដែលអ្នកធ្វើគួរតែស្ថិតស្ថេរជារៀងរហូត"
អ្វីដែលអ្នករាល់គ្នាទូលសុំពីព្រះបិតាដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងប្រទានមកអ្នករាល់គ្នា
នៅទីនេះ "ឈ្មោះ" ជាពាក្យប្រៀបធៀប តំណាងឲ្យសិទ្ធិអំណាចរបស់ព្រះយេស៊ូ។
"ដោយសារអ្នកជាកម្មសិទ្ធិរបស់ខ្ញុំ អ្វីៗក៏ដោយដែលអ្នកសុំពីព្រះបិតា
នោះទ្រង់នឹងប្រទានឲ្យអ្នកជាមិនខាន"
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់
ខ្ញុំបង្គាប់ការទាំងនេះមកអ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក
សេចក្ដីស្រឡាញ់ប្រភេទនេះកើតចេញពីព្រះជាម្ចាស់ហើយគឺចង់អ្នកដទៃបានសេចក្ដីសុខ
សូម្បីតែវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្ដីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះជាពួកគេធ្វើអ្វីក៏ដោយ។
"ខ្ញុំនិយាយម្តងទៀតនូវអ្វីដែលខ្ញុំបានបង្គាប់បញ្ជាអ្នករួចហើយ
ចូរស្រឡាញ់គ្នាទៅវិញទៅមក" ។
John 15:18
ប្រសិនបើ លោកីយ៍ស្អប់អ្នករាល់គ្នា ...ពួកគេស្អប់អ្នករាល់ទៅទៀត
ព្រះយេស៊ូប្រើពាក្យ«លោកីយ៍»ក្នុងខគម្ពីរទាំងនេះជាពាក្យប្រៀបធៀប
សំដៅទៅលើមនុស្ស ដែលមិនមែនជារបស់ព្រះជាម្ចាស់ ហើយប្រឆាំងនឹងព្រះអង្គ។
ក្ដីស្រឡាញ់
សំដៅទៅលើមនុស្សដែលស្រឡាញ់បងប្អូន ឬស្រឡាញ់មិត្តភក្តិ
ឬសមាជិកគ្រួសារខ្លួន។
John 15:20
ចាំសម្តីដែលខ្ញុំបាននិយាយជាមួយអ្នករាល់គ្នាទេ
"សម្តី"នៅទីនេះ ជាពាក្យប្រៀបធៀប ចំពោះសាររបស់ព្រះយេស៊ូ។ "ចងចាំសារ
ដែលខ្ញុំបាននិយាយទៅកាន់អ្នក"
ដោយព្រោះឈ្មោះខ្ញុំ
នៅទីនេះ "ដោយសារតែឈ្មោះរបស់ខ្ញុំ" ជាពាក្យប្រៀបធៀប
ដែលតំណាងឲ្យព្រះយេស៊ូ។ មនុស្សនឹងធ្វើឲ្យអ្នកដើរតាមព្រះអង្គ
រងទុក្ខដោយសារតែពួកគេជាកម្មសិទ្ធិរបស់ព្រះអង្គ។ "ព្រោះអ្នកជាកម្មសិទ្ធិរបស់ខ្ញុំ"
ប្រសិនបើ ខ្ញុំមិនបានមក ហើយប្រាប់ដល់ពួកគេទេ នោះពួកគេអាចនឹងគ្មានបាបទេ ប៉ុន្តែ ឥឡូវនេះ
ពួកគេលែងមានការដោះសារពីបាបរបស់ពួកគេហើយ
ព្រះយេស៊ូមានបន្ទូលនៅត្រង់នេះថា ទ្រង់បានចែកចាយសាររបស់ព្រះជាម្ចាស់
ដល់អ្នកដែលមិនជឿលើព្រះអង្គ។ “
ព្រោះខ្ញុំបានមកហើយប្រាប់សាររបស់ព្រះជាម្ចាស់ដល់ពួកគេ ពួកគេគ្មានលេសអ្វី
ប្រកែកពេលព្រះជាម្ចាស់វិនិច្ឆ័យអំពើបាបរបស់ពួកគេ”
John 15:23
អ្នកណាដែលស្អប់ខ្ញុំ ក៏ស្អប់ព្រះបិតាខ្ញុំដែរ...ពួកគេបានឃើញ ហើយស្អប់ទាំងខ្ញុំ និងព្រះបិតាខ្ញុំ
ការស្អប់ព្រះបុត្រា ជាការស្អប់ព្រះជាម្ចាស់ជាព្រះបិតា។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់

generated on Wed Sep 10 16:16:32 2025

ប្រសិនបើ ខ្ញុំមិនបានធ្វើការ ដែលគ្មាននរណានៅក្នុងចំណោមពួកគេអាចធ្វើការនោះបាន
ពួកគេអាចនឹងមិនមានបាបទេ ប៉ុន្តែ
អ្នកអាចបកប្រែជាអវិជ្ជមានទ្វេដងនៅត្រង់នេះ ជាទម្រង់វិជ្ជមាន។ “
ព្រោះខ្ញុំបានធ្វើការក្នុងចំណោមពួកគេ នូវការងារដែលគ្មាននរណាម្នាក់បានធ្វើ
ពួកគេមានបាបហើយ”
ពួកគេអាចនឹងមិនមានបាបទេ
ពួកគេនឹងមិនមានបាបអ្វីឡើយ។ សូមមើលពីរបៀប
ដែលអ្នកបានបកប្រែនៅក្នុងជំពូក១៥ ខ២០ ។
ដើម្បីឲ្យបានសម្រេចតាមពាក្យដែលចែងនៅក្នុងក្រឹត្យវិន័យ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ដើម្បីសម្រេចទំនាយនៅក្នុងច្បាប់របស់ពួកគេ"
ក្រឹត្យវិន័យ
ជាទូទៅ នៅត្រង់នេះសំដៅទៅលើគម្ពីរសម្ព័ន្ធមេត្រីចាស់ទាំងមូល
ដែលមានការណែនាំទាំងអស់របស់ព្រះជាម្ចាស់ ចំពោះប្រជារាស្ត្ររបស់ព្រះអង្គ។
John 15:26
អ្នកកម្សាន្តចិត្ត
សំដៅទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមមើលពីរបៀប
ដែលអ្នកបានបកប្រែនៅក្នុងជំពូក១៤ ខ១៥ ។
ចាត់...ពីព្រះបិតា...ព្រះវិញ្ញាណនៃសេចក្ដីពិត ...ព្រះអង្គនឹងធ្វើបន្ទាល់ពីខ្ញុំ
ព្រះបិតាបានចាត់ព្រះវិញ្ញាណមកបង្ហាញពិភពលោកថា ព្រះយេស៊ូជាព្រះបុត្រា។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
ព្រះវិញ្ញាណនៃសេចក្ដីពិត
នេះជាងារដ៏សំខាន់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
"ព្រះវិញ្ញាណដែលប្រាប់សេចក្ដីពិតអំពីព្រះជាម្ចាស់ និងខ្ញុំ"
អ្នករាល់គ្នាដ៏កំពុងធ្វើបន្ទាល់ពីខ្ញុំដែរ
នេះជាទីបន្ទាល់ដែលមានន័យថា ដើម្បីប្រាប់អ្នកដទៃអំពីព្រះយេស៊ូ។
"អ្នកក៏ត្រូវតែប្រាប់មនុស្សគ្រប់គ្នា នូវអ្វីដែលអ្នកដឹងអំពីខ្ញុំដែរ" ។
តាំងពីដំបូង
“តាំងពីដំបូង” នៅទីនេះជាពាក្យប្រៀបធៀប ដែលមានន័យថា
ថ្ងៃដំបូងនៃព័ន្ធកិច្ចបម្រើរបស់ព្រះយេស៊ូ។ "តាំងពីថ្ងៃដំបូង
ពេលខ្ញុំចាប់ផ្តើមបង្រៀនប្រជាជននិងធ្វើការអស្ចារ្យ"

---

16 [1]ខ្ញុំបានប្រាប់សេចក្ដីទាំងនេះដល់អ្នករាល់គ្នា ដេើម្បីកុំឲ្យអ្នករាល់គ្នារវាតចិត្ត។[2]ពួកគេនឹងបណ្តេញអ្នករាល់គ្នាពីសាលាប្រជុំ។ ប៉ុន្តែ នៅពេលកំណត់មកដល់
នៅពេលមនុស្សគ្រប់គ្នាដែលរកសម្លាប់អ្នករាល់គ្នា ពួកគេនឹងគិតថា ដើម្បីធ្វើជាយញ្ញបូជាថ្វាយព្រះជាម្ចាស់។
[3]ពួកគេធ្វើការទាំងនេះ ដោយសារពួកគេមិនបានស្គាល់ព្រះបិតាខ្ញុំ ឬស្គាល់ខ្ញុំទេ។[4]ខ្ញុំបានប្រាប់ការទាំងនេះដល់អ្នករាល់គ្នា ដើម្បីនៅពេលកំណត់មកដល់ អ្នកនឹងចាំថា
ខ្ញុំនិយាយពួកគេប្រាប់អ្នករាល់គ្នាហើយ។ ខ្ញុំមិនបានប្រាប់ការនេះដល់អ្នករាល់គ្នាតាំងពីដំបូងមកទេ ដោយសារខ្ញុំនៅជាមួយអ្នករាល់គ្នា។
[5]ប៉ុន្តែ ឥឡូវនេះ ខ្ញុំត្រឡប់ទៅព្រះអង្គដែលចាត់ខ្ញុំឲ្យមកវិញ ប៉ុន្តែ គ្មាននរណានៅក្នុងចំណោមអ្នករាល់គ្នាសួរខ្ញុំថា៖ «តើព្រះអង្គកំពុងទៅណា?»[6]ប៉ុន្តែ
ដោយសារខ្ញុំបាននិយាយការនេះដល់អ្នករាល់គ្នា ធ្វើឲ្យចិត្តរបស់អ្នករាល់គ្នាពេញដោយសេចក្ដីព្រួយ។ ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើខ្ញុំទៅ
វាប្រសើរដល់អ្នករាល់គ្នា។[7]ដ្បិត ប្រសិនបើ ខ្ញុំមិនទៅទេ ព្រះដ៏កម្សាន្តចិត្តនឹងមិនមកទេ ប៉ុន្តែ ប្រសិនបើ ខ្ញុំទៅ ខ្ញុំនឹងចាត់ព្រះអង្គឲ្យមកសម្រាប់អ្នករាល់គ្នា។
[8]នៅពេលព្រះដ៏កម្សាន្តចិត្តយាងមក ព្រះអង្គបង្ហាញដល់លោកីយ៍កំហុសទាក់ទងនឹងបាប ទាក់ទងនឹងសេចក្ដីសុចរិត និងទាក់ទងនឹងការជំនុំជម្រះ។[9]ទាក់ទងនឹងបាប
ដោយសារពួកគេមិនជឿលើខ្ញុំ[10]ទាក់ទងនឹងសេចក្ដីសុចរិត ដោយសារខ្ញុំត្រឡប់ទៅព្រះបិតាវិញ[11]ហើយទាក់ទងនឹងការជំនុំជម្រះ
ដោយសារអ្នកគ្រប់គ្រងរបស់លោកីយ៍នេះនឹងត្រូវជំនុំជម្រះ។
[12]ខ្ញុំមានការជាច្រើនប្រាប់ដល់អ្នករាល់គ្នា ប៉ុន្តែឥឡូវនេះ អ្នករាល់គ្នាមិនយល់ពីវាទេ។[13]ប៉ុន្តែ នៅពេលព្រះវិញ្ញាណនៃសេចក្ដីពិតយាងមក
ព្រះអង្គនឹងនាំអ្នករាល់គ្នាទៅក្នុងសេចក្ដីពិតគ្រប់យ៉ាង ដ្បិតព្រះអង្គមិនបានមានបន្ទូលពីអង្គទ្រង់ផ្ទាល់ទេ។ ប៉ុន្តែ ព្រះអង្គនឹងមានបន្ទូលពីអ្វីដែលព្រះអង្គបានឮ
ហើយព្រះអង្គនឹងប្រាប់អ្នករាល់គ្នាពីអ្វីៗដែលនឹងមកដល់។[14]ព្រះអង្គនឹងថ្វាយសិរីល្អដល់ខ្ញុំ ព្រោះព្រះអង្គនឹងយកអ្វីដែលជារបស់ខ្ញុំ
ហើយព្រះអង្គនឹងប្រាប់ពីការនោះដល់អ្នករាល់គ្នា។
[15]អ្វីៗទាំងអស់ដែលព្រះបិតាមានជារបស់ខ្ញុំ។ ដូច្នេះ ខ្ញុំនិយាយថា ព្រះវិញ្ញាណនឹងទទួលអ្វីដែលជារបស់ខ្ញុំ និងព្រះអង្គនឹងប្រាប់ដល់អ្នករាល់គ្នា។
[16]ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀតហើយ ហើយនៅក្នុងរយៈពេលដ៏ខ្លីខាងមុខ អ្នករាល់គ្នានឹងបានឃើញខ្ញុំម្តងទៀត។
[17]បន្ទាប់មក មានពួកសិស្សរបស់ព្រះអង្គខ្លះនិយាយទៅកាន់គ្នាទៅវិញទៅមកថា៖ «តើមានន័យយ៉ាងដូចម្តេច ដែលព្រះអង្គមានបន្ទូលមកហើយថា៖ «ក្នុងរយៈពេលដ៏ខ្លី
អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀត ហើយនៅក្នុងរយៈពេលដ៏ខ្លះខាងមុន អ្នករាល់គ្នានឹងបានឃើញខ្ញុំម្តងទៀត?» ហើយ «ដោយសារខ្ញុំទៅឯព្រះបិតាខ្ញុំវិញ?»[18]ដូច្នេះហើយ
បានជាពួកគេនិយាយថា៖ «តើអ្វីទៅដែលព្រះអង្គមានបន្ទូលថា៖ «ក្នុងរយៈពេលដ៏ខ្លី?» យើងមិនដឹងថា ព្រះអង្គមានបន្ទូលអំពីអ្វីទេ»។
[19]ព្រះយេស៊ូឃើញថា ពួកគេចង់សួរព្រះអង្គ ហើយព្រះអង្គក៏មានបន្ទូលទៅកាន់ពួកគេថា៖ «តើនេះគឺជាអ្វីដែលអ្នករាល់គ្នាកំពុងតែសួរនៅក្នុងចំណោមអ្នករាល់គ្នា
តើអ្វីដែលខ្ញុំនិយាយនោះ មានន័យយ៉ាងដូចម្តេចថា៖ «ក្នុងរយៈពេលដ៏ខ្លី ហើយអ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀត ហើយក្នុងរយៈពេលដ៏ខ្លី
អ្នករាល់គ្នាបានឃើញខ្ញុំម្តងទៀត?[20]ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នានឹងយំ ហើយកាន់ទុក្ខ ប៉ុន្តែ លោកីយ៍នឹងសប្បាយរីករាយ។
អ្នករាល់គ្នានឹងមានទុក្ខព្រួយយ៉ាងខ្លាំង ប៉ុន្តែ ទុក្ខព្រួយរបស់អ្នករាល់គ្នានឹងត្រឡប់ទៅជាអំណរវិញ។[21]នៅពេលស្ត្រីបង្កើតកូន នាងមានទុក្ខព្រួយជាខ្លាំង
ព្រោះពេលកំណត់របស់នាងមកដល់ហើយ ប៉ុន្តែ នៅពេលនាងបង្កើតកូនរួចហើយ នាងលែងនឹកចាំពីការឈឺចាប់របស់នាងទៀតហើយ
ព្រោះតែអំណររដែលនមនុស្សម្នាក់បានកើតមកក្នុងលោកីយ៍នេះ។
[22]ដូច្នេះ នៅពេលនេះ អ្នករាល់គ្នាមានទុក្ខព្រួយមែន ប៉ុន្តែ ខ្ញុំនឹងជួបអ្នកសារជាថ្មីម្តងទៀត ហើយដួងចិត្តរបស់អ្នកនឹងមានអំណរ
ហើយគ្មានអ្នកណាអាចយកអំណររបស់អ្នកចេញពីអ្នករាល់គ្នាឡើយ។[23]នៅថ្ងៃនោះ អ្នករាល់គ្នានឹងមិនសួរខ្ញុំទៀតទេ។ ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
ប្រសិនបើ អ្នករាល់គ្នាសុំអ្វីពីព្រះបិតាដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងប្រទានវាមកអ្នករាល់គ្នា។[24]រហូតមកទល់ពេលនេះ អ្នករាល់គ្នាមិនបានសុំអ្វីដោយនូវឈ្មោះខ្ញុំទេ។ ចូរសុំ
ហើយអ្នករាល់គ្នានឹងទទួល ដូច្នេះ អំណររបស់អ្នកនឹងបានគ្រប់លក្ខណៈ។
[25]ខ្ញុំបានប្រាប់ការទាំងនេះដល់អ្នករាល់គ្នា ក្នុងពាក្យនៃការប្រៀបធៀប ប៉ុន្តែ នៅពេលកំណត់មកដល់ ខ្ញុំនឹងលែងនិយាយជាពាក្យនៃការប្រៀបធៀបទៀតហើយ ប៉ុន្តែ
ផ្ទុយទៅវិញ ខ្ញុំប្រាប់អ្នករាល់គ្នាយ៉ាងច្បាស់អំពីព្រះបិតា។
[26]នៅថ្ងៃនោះ ខ្ញុំនឹងសុំដោយនូវឈ្មោះខ្ញុំ ហើយខ្ញុំនឹងមិននិយាយទៅកាន់អ្នកថា ខ្ញុំនឹងអធិស្ឋានដល់ព្រះបិតាសម្រាប់អ្នករាល់គ្នាសិនទេ[27]ដ្បិត
ព្រះបិតាផ្ទាល់ស្រឡាញ់អ្នករាល់គ្នា ដោយសារ អ្នករាល់គ្នាបានស្រឡាញ់ខ្ញុំ ហើយដោយសារអ្នករាល់គ្នាបានជឿថា ខ្ញុំបានមកពីព្រះបិតា។[28]ខ្ញុំបានមកពីព្រះបិតា
ហើយខ្ញុំបានមកក្នុងលោកីយ៍នេះ។ ខ្ញុំកំពុងតែចាកចេញពីលោកីយ៍នេះ ហើយខ្ញុំនឹងទៅឯព្រះបិតាវិញ។
[29]ពួកសិស្សរបស់ព្រះអង្គទូលថា៖ «មើល ឥឡូវនេះ ព្រះអង្គបានមានបន្ទូលយ៉ាងច្បាស់ ហើយព្រះអង្គមិនបានប្រើពាក្យនៃការប្រៀបធៀបទេ។[30]ឥឡូវនេះ
យើងដឹងហើយថា ព្រះអង្គជ្រាបទាំងអស់ ហើយព្រះអង្គមិនត្រូវការឲ្យនរណាសួរព្រះអង្គឡើយ។ ដោយហេតុនេះ យើងខ្ញុំជឿថា ព្រះអង្គបានមកពីព្រះជាម្ចាស់មែន»។
[31]ព្រះយេស៊ូវឆ្លើយទៅកាន់ពួកគេថា៖ «តើអ្នករាល់គ្នាជឿហើយមែនទេ?»
[32]មើល៍ ពេលកំណត់បានមកដល់ហើយ ពិតណាស់ បានមកដល់ពិតប្រាកដមែន នៅពេលដែលអ្នករាល់គ្នាត្រូវខ្ចាត់ខ្ចាយ មនុស្សគ្រប់គ្នានឹងទៅផ្ទះរបស់គេរៀងៗខ្លួន
ហើយអ្នករាល់គ្នាក៏នឹងបោះបង់ខ្ញុំចោលដែរ។ ប៉ុន្តែ ខ្ញុំមិននៅម្នាក់ឯងទេ ព្រោះព្រះបិតានៅជាមួយខ្ញុំ។[33]ខ្ញុំនិយាយការទាំងនេះដល់អ្នករាល់គ្នា
ដើម្បីឲ្យអ្នករាល់គ្នាមានសន្តិភាពនៅក្នុងខ្ញុំ។ នៅក្នុងលោកីយ៍អ្នកមានទុក្ខលំបាកជាច្រើន ប៉ុន្តែ ចូលមានសេចក្ដីក្លាហាន ខ្ញុំបានឈ្នះលោកីយ៍ហើយ»។

generated on Wed Sep 10 16:16:32 2025

John 16:1
ឃ្លាភ្ជាប់៖
បន្តផ្នែកនៃសាច់រឿងពីជំពូកមុន។ ព្រះយេស៊ូអង្គុយនៅតុជាមួយនឹងពួកសិស្ស
ហើយបន្តមានបន្ទូលជាមួយពួកគេ។
ដេីម្បីកុំឲ្យអ្នករាល់គ្នារវាតចិត្ត
នៅទីនេះឃ្លា «រវាតចិត្ត» បង្កប់ន័យថា ឈប់ទុកចិត្តលើព្រះយេស៊ូ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដូច្នេះអ្នកនឹងមិនឈប់ជឿទុកចិត្តលើខ្ញុំ
ព្រោះតែការលំបាកដែលអ្នកត្រូវតែប្រឈមមុខឡើយ" ។
ពេលកំណត់មកដល់ នៅពេលមនុស្សគ្រប់គ្នាដែលរកសម្លាប់អ្នករាល់គ្នា ពួកគេនឹងគិតថា
ដើម្បីធ្វើជាយញ្ញបូជាថ្វាយព្រះជាម្ចាស់
ថ្ងៃណាមួយ វានឹងកើតឡើងដែលមនុស្សម្នាក់នឹងសម្លាប់អ្នក
ហើយគិតថាគេកំពុងធ្វើអ្វី ដែលល្អសម្រាប់ព្រះជាម្ចាស់” ។
John 16:3
ពួកគេធ្វើការទាំងនេះ ដោយសារពួកគេមិនបានស្គាល់ព្រះបិតាខ្ញុំ ឬស្គាល់ខ្ញុំទេ
ពួកគេនឹងសម្លាប់អ្នកជឿខ្លះ ព្រោះពួកគេមិនស្គាល់ព្រះបិតា ឬព្រះយេស៊ូ។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
នៅពេលកំណត់មកដល់
នៅទីនេះ "ពេលកំណត់" ជាពាក្យប្រៀបធៀប សំដៅទៅលើពេលវេលា
ដែលមនុស្សនឹងត្រូវគេធ្វើទុក្ខបុកម្នេញអ្នកដើរតាមតាមព្រះយេស៊ូ។
"ពេលពួកគេបណ្តាលឲ្យអ្នកទទួលការឈឺចាប់"
តាំងពីដំបូងមក
នេះជាពាក្យប្រៀបធៀប
ដែលសំដៅទៅលើថ្ងៃដំបូងនៃព័ន្ធកិច្ចបម្រើរបស់ព្រះយេស៊ូ។
"នៅពេលដែលអ្នកចាប់ផ្តើមដើរតាមខ្ញុំដំបូង"
John 16:5
ចិត្តរបស់អ្នករាល់គ្នាពេញដោយសេចក្តីព្រួយ
នេះជាពាក្យមានន័យថា ពួកសិស្សមានចិត្តក្រៀមក្រំណាស់។
"ឥឡូវនេះអ្នកក្រៀមក្រំណាស់"
ប្រសិនបើ ខ្ញុំមិនទៅទេ ព្រះដ៏កម្សាន្តចិត្តនឹងមិនមកទេ
អ្នកអាចបកប្រែជាទម្រង់វិជ្ជមាន។ "ព្រះអង្គដែលជួយកម្សាន្តចិត្តនឹងមករកអ្នក
លុះត្រាតែខ្ញុំទៅឆ្ងាយ"
ព្រះដ៏កម្សាន្តចិត្ត
នេះជាងាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនឹងនៅជាមួយពួកសិស្ស
បន្ទាប់ពីព្រះយេស៊ូបានចេញទៅ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក១៤ ខ២៥ ។
John 16:8
ព្រះដ៏កម្សាន្តចិត្តយាងមក
ព្រះអង្គបង្ហាញដល់លោកីយ៍កំហុសទាក់ទងនឹងបាប...សេចក្តីសុចរិត..ខ្ញុំត្រឡប់ទៅព្រះបិតាវិញ
នៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ទ្រង់ចាប់ផ្តើមបង្ហាញមនុស្សថា
ពួកគេជាមនុស្សមានបាប។
ព្រះដ៏កម្សាន្តចិត្ត
សំដៅទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក១៤ ខ១៥ ។
លោកីយ៍
នេះជាពាក្យប្រៀបធៀប ដែលសំដៅទៅលើប្រជាជននៅលើពិភពលោកនេះ។
ទាក់ទងនឹងបាប ដោយសារពួកគេមិនជឿលើខ្ញុំ
"ពួកគេមានបាបដោយសារពួកគេមិនទុកចិត្តខ្ញុំ"
ទាក់ទងនឹងសេចក្តីសុចរិត ដោយសារខ្ញុំត្រឡប់ទៅព្រះបិតាវិញ
"ពេលខ្ញុំត្រឡប់ទៅរកព្រះជាម្ចាស់ ហើយពួកគេនឹងលែងឃើញខ្ញុំទៀត គេនឹងដឹងថា
ខ្ញុំបានធ្វើអ្វីៗដែលត្រឹមត្រូវ"
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ហើយទាក់ទងនឹងការជំនុំជម្រះ ដោយសារអ្នកគ្រប់គ្រងរបស់លោកីយ៍នេះនឹងត្រូវជំនុំជម្រះ
«ព្រះជាម្ចាស់នឹងទទួលខុសត្រូវចំពោះពួកគេ ហើយនឹងដាក់ទណ្ឌកម្មពួកគេ
ចំពោះអំពើបាបរបស់ពួកគេ ដូចទ្រង់នឹងដាក់ទណ្ឌកម្មសាតាំង
ដែលគ្រប់គ្រងពិភពលោកនេះដែរ»
អ្នកគ្រប់គ្រងរបស់លោកីយ៍នេះ
ត្រង់នេះ“ អ្នកគ្រប់គ្រង” សំដៅទៅលើសាតាំង។
"សាតាំងដែលគ្រប់គ្រងពិភពលោកនេះ" ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក១២ ខ៣០ ។
John 16:12
ការជាច្រើនប្រាប់ដល់អ្នករាល់គ្នា
"សារសម្រាប់អ្នក" ឬ "ពាក្យសម្រាប់អ្នក"
ព្រះវិញ្ញាណនៃសេចក្តីពិត
នេះជាឈ្មោះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលនឹងប្រាប់ប្រជាជនអំពីសេចក្តីពិតអំពីព្រះជាម្ចាស់។
ព្រះអង្គនឹងនាំអ្នករាល់គ្នាទៅក្នុងសេចក្តី
"សេចក្តីពិត" សំដៅទៅលើសេចក្តីពិតខាងវិញ្ញាណ។ “
ទ្រង់នឹងបង្រៀនអ្នកនូវសេចក្តីពិតខាងវិញ្ញាណ ដែលអ្នកត្រូវដឹង”
ព្រះអង្គនឹងមានបន្ទូលពីអ្វីដែលព្រះអង្គបានឮ
ព្រះយេស៊ូបានបញ្ជាក់ថា ព្រះបិតានឹងមានបន្ទូលទៅកាន់ព្រះវិញ្ញាណ។ “
ទ្រង់នឹងមានបន្ទូលអ្វី ដែលព្រះជាម្ចាស់ប្រាប់ព្រះអង្គឲ្យមានបន្ទូល”
ព្រះអង្គនឹងយកអ្វីដែលជារបស់ខ្ញុំ ហើយព្រះអង្គនឹងប្រាប់ពីការនោះដល់អ្នករាល់គ្នា
នៅទីនេះ“ របស់ខ្ញុំ” សំដៅទៅលើការបង្រៀន និងការអស្ចារ្យរបស់ព្រះយេស៊ូ។
"ទ្រង់នឹងបង្ហាញដល់អ្នកថា អ្វីដែលខ្ញុំបាននិយាយនិងធ្វើ គឺជាការពិត"
John 16:15
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ព្រះវិញ្ញាណនឹងទទួលអ្វីដែលជារបស់ខ្ញុំ និងព្រះអង្គនឹងប្រាប់ដល់អ្នករាល់គ្នា
ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រាប់ប្រជាជនថា
ពាក្យនិងកិច្ចការរបស់ព្រះយេស៊ូជាការពិត។ “
ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រាប់ដល់អ្នករាល់គ្នាថា ពាក្យនិងកិច្ចការរបស់ខ្ញុំគឺពិត”
ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ
"ឆាប់ៗនេះ" ឬ "មុនពេលវេលាជាច្រើនកន្លងផុតទៅ"
នៅក្នុងរយៈពេលដ៏ខ្លីខាងមុខ
"ម្តងទៀតមុនពេលវេលាជាច្រើនកន្លងផុតទៅ"
John 16:17
ព័ត៌មានទូទៅ:
មានការផ្អាកនៅក្នុងការនិទានរបស់ព្រះយេស៊ូ ពេលសិស្សរបស់ព្រះអង្គសួរគ្នាអំពីអ្វី
ដែលព្រះយេស៊ូចង់មានន័យ។
ក្នុងរយៈពេលដ៏ខ្លី អ្នករាល់គ្នានឹងលែងឃើញខ្ញុំទៀត
ពួកសិស្សមិនបានយល់ថា
នេះសំដៅទៅលើការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាងទេ។
ក្នុងរយៈពេលដ៏ខ្លះខាងមុន អ្នករាល់គ្នានឹងបានឃើញខ្ញុំ
អាចមានន័យថា ១) អាចសំដៅទៅលើការរស់ឡើងវិញរបស់ព្រះយេស៊ូឬ ២)
អាចសំដៅទៅលើការយាងមករបស់ព្រះយេស៊ូ នៅចុងបញ្ចប់នៃពេលវេលា។
ព្រះបិតា
ជាងារសំខាន់ចំពោះព្រះជាម្ចាស់។
John 16:19
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់សិស្សរបស់ព្រះអង្គ។
តើនេះគឺជាអ្វីដែលអ្នករាល់កំពុងតែសួរនៅក្នុងចំណោមអ្នករាល់គ្នា តើអ្វីដែលខ្ញុំនិយាយនោះ
មានន័យយ៉ាងដូចម្តេចថា៖ ...ឃើញខ្ញុំ?
ព្រះយេស៊ូប្រើសំនួរនេះ ដូច្នេះសិស្សរបស់ព្រះអង្គនឹងផ្តោតលើអ្វី
ដែលទ្រង់ទើបតែបានប្រាប់ដល់ពួកគេ ដូច្នេះទ្រង់អាចពន្យល់ថែមទៀត។
"អ្នកសួរខ្លួនឯងថាតើខ្ញុំចង់និយាយអ្វីពេលខ្ញុំនិយាយ ... ឃើញខ្ញុំ។ "
ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
បកប្រែវិធីនេះជាភាសារបស់អ្នក ដោយសង្កត់ន័យថាអ្វីដែលនៅខាងក្រោម
គឺសំខាន់និងពិត។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក១ ខ៤៩ ។
ប៉ុន្តែ លោកីយ៍នឹងសប្បាយរីករាយ
នៅទីនេះ“ លោកីយ”
ជាការពិពណ៌នាសម្រាប់មនុស្សដែលប្រឆាំងនឹងព្រះជាម្ចាស់។ “
តែមនុស្សដែលប្រឆាំងនឹងព្រះជាម្ចាស់នឹងរីករាយ”
ប៉ុន្តែ ទុក្ខព្រួយរបស់អ្នករាល់គ្នានឹងត្រឡប់ទៅជាអំណរវិញ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ តែទុក្ខព្រួយរបស់អ្នកនឹងប្រែទៅជាអំណរ”
John 16:22
ដួងចិត្តរបស់អ្នកនឹងមានអំណរ

generated on Wed Sep 10 16:16:32 2025

នេះជាពាក្យ ដែលនិយាយពីដួងចិត្តដូចជាមនុស្ស។ “ អ្នកនឹងសប្បាយចិត្ត” ឬ“ អ្នកនឹងមានអំណរ”
ពិតណាស់ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
បកប្រែវិធីនេះជាភាសារបស់អ្នក ដោយសង្កត់ន័យថា អ្វីៗដែលនៅខាងក្រោម
គឺសំខាន់និងពិត។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក១ ខ៤៩ ។
ប្រសិនបើ អ្នករាល់គ្នាសុំអ្វីពីព្រះបិតាដោយនូវឈ្មោះខ្ញុំ ព្រះអង្គនឹងប្រទានវាមកអ្នករាល់គ្
នៅទីនេះពាក្យ "ឈ្មោះ" ជាពាក្យប្រៀបធៀប ដែលសំដៅទៅលើបុគ្គល
និងសិទ្ធិអំណាចរបស់ព្រះយេស៊ូ។ “ បើអ្នកសូមអ្វីៗពីព្រះបិតា
នោះទ្រង់នឹងប្រទានដល់អ្នក ព្រោះអ្នកជាកម្មសិទ្ធិរបស់ខ្ញុំ”
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
នូវឈ្មោះខ្ញុំ
នៅទីនេះ "ឈ្មោះ" ជាពាក្យប្រៀបធៀប ដែលសំដៅទៅលើបុគ្គល
និងសិទ្ធិអំណាចរបស់ព្រះយេស៊ូ។ ព្រះបិតានឹងធ្វើតាមសំណូមពររបស់អ្នកជឿ
ដោយសារតែទំនាក់ទំនងរបស់ពួកគេជាមួយព្រះយេស៊ូ។ :
"ព្រោះអ្នកគឺជាអ្នកដើរតាមខ្ញុំ" ឬ "លើសិទ្ធិអំណាចរបស់ខ្ញុំ"
អំណររបស់អ្នកនឹងបានគ្រប់លក្ខណៈ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ព្រះជាម្ចាស់នឹងផ្តល់ឲ្យអ្នកនូវអំណរដ៏អស្ចារ្យ"
John 16:25
ក្នុងពាក្យនៃការប្រៀបធៀប
"នៅក្នុងភាសាដែលមិនច្បាស់"
ពេលកំណត់មកដល់
"វានឹងកើតឡើងឆាប់ៗ"
ប្រាប់អ្នករាល់គ្នាយ៉ាងច្បាស់អំពីព្រះបិតា
"ប្រាប់អ្នកអំពីព្រះបិតាតាមរបៀបមួយ ដែលអ្នកនឹងយល់ច្បាស់" ។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
John 16:26
ខ្ញុំនឹងសុំដោយនូវឈ្មោះខ្ញុំ
នៅទីនេះ "ឈ្មោះ" ជាពាក្យប្រៀបធៀប
សម្រាប់បុគ្គលនិងសិទ្ធិអំណាចរបស់ព្រះយេស៊ូ។ "អ្នកនឹងសុំ
ព្រោះអ្នកជាកម្មសិទ្ធិរបស់ខ្ញុំ"
ព្រះបិតាផ្ទាល់ស្រឡាញ់អ្នករាល់គ្នា ដោយសារ អ្នករាល់គ្នាបានស្រឡាញ់ខ្ញុំ
នៅពេលមនុស្សម្នាក់ស្រឡាញ់ព្រះយេស៊ូ ដែលជាព្រះបុត្រា
ពួកគេក៏ស្រឡាញ់ព្រះបិតាដែរ ព្រោះព្រះបិតានិងព្រះបុត្រាគឺតែមួយ។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ខ្ញុំបានមកពីព្រះបិតា ... ខ្ញុំកំពុងតែចាកចេញពីលោកីយ៍នេះ ហើយខ្ញុំនឹងទៅឯព្រះបិតាវិញ
បន្ទាប់ពីព្រះយេស៊ូសោយទិវង្គត និងការរស់ឡើងវិញ
ទ្រង់នឹងត្រឡប់ទៅព្រះបិតាវិញ។
ខ្ញុំបានមកពីព្រះបិតា...ទៅឯព្រះបិតាវិញ
នៅទីនេះ "ព្រះបិតា" ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
លោកីយ៍
"លោកីយ៍" ជាឈ្មោះពិពណ៌នាសំដៅទៅលើមនុស្ស ដែលរស់នៅលើពិភពលោក។
John 16:29
ឃ្លាភ្ជាប់៖
ពួកសិស្សឆ្លើយតបនឹងព្រះយេស៊ូ។
តើអ្នករាល់គ្នាជឿហើយមែនទេ?
ការកត់សម្គាល់នេះលេចចេញជាសំណួរ ដើម្បីបង្ហាញថាព្រះយេស៊ូកំពុងឆ្ងល់ថា
ពួកសិស្សរបស់ព្រះអង្គទើបតែបានទុកចិត្តលើព្រះអង្គ។ "ដូច្នេះ
ឥឡូវនេះអ្នកបានទុកចិត្តលើខ្ញុំហើយ!
John 16:32
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបន្តមានបន្ទូលទៅកាន់សិស្សរបស់ព្រះអង្គ។
អ្នករាល់គ្នាត្រូវខ្ចាត់ខ្ចាយ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "អ្នកផ្សេងទៀតនឹងធ្វើឲ្យអ្នកខ្ចាត់ខ្ចាយ"
ព្រះបិតានៅជាមួយខ្ញុំ
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
អ្នករាល់គ្នាមានសន្តិភាពនៅក្នុងខ្ញុំ
នៅទីនេះ "សន្តិភាព" សំដៅទៅលើសេចក្តីសុខសាន្តខាងក្នុង។
"ដើម្បីឲ្យអ្នកមានសន្តិភាពខាងក្នុង អ្នកត្រូវមានទំនាក់ទំនងជាមួយខ្ញុំ"
ខ្ញុំបានឈ្នះលោកីយ៍ហើយ
នៅទីនេះ“ លោកីយ៍” សំដៅទៅលើបញ្ហា និងការបៀតបៀន
ដែលអ្នកជឿនឹងស៊ូទ្រាំពីអ្នកប្រឆាំងនឹងព្រះជាម្ចាស់។
"ខ្ញុំបានឈ្នះលើបញ្ហានៃពិភពលោកនេះ"

---

17 [1]បន្ទាប់ពីព្រះេ◌ួយស៊ូមានបន្ទូលពីសេចក្តីទាំងនោះរួចហើយ ព្រះអង្គបានទតព្រះនេត្រឡើងទៅលើ ឯស្ថានសួគ៌ ហើយមានបន្ទូលថា៖ «ព្រះបិតាអើយ
ពេលកំណត់បានមកដល់ហើយ សូមលើកតម្កើងព្រះបុត្រារបស់ព្រះអង្គ
ដើម្បីឲ្យព្រះបុត្រាបានលើកតម្កើងព្រះអង្គវិញ[2]ដូចដែលព្រះអង្គបានប្រទានសិទ្ធិអំណាចដល់ព្រះបុត្រាលើមនុស្សលោកទាំងអស់
ដើម្បីឲ្យទ្រង់បានប្រទានជីវិតអស់កល្បជានិច្ចដល់មនុស្សគ្រប់គ្នាដែលព្រះអង្គបានប្រទានដល់ព្រះបុត្រាដែរ។
[3]នេះជាជីវិតអស់កល្បជានិច្ច៖ គឺថាពួកគេស្គាល់ព្រះអង្គ ជាព្រះពិតតែមួយគត់ និងជឿព្រះដែលចាត់ព្រះអង្គឲ្យមក គឺព្រះយេស៊ូគ្រិស្ត។
[4]ទូលបង្គំថ្វាយសិរីល្អដល់ព្រះអង្គនៅលើផែនដីនេះ។ ទូលបង្គំបានបញ្ចប់ការងារដែលព្រះអង្គបានប្រទានឲ្យទូលបង្គំធ្វើហើយ។[5]ឥឡូវនេះ បិតាអើយ
សូមលើកតម្កើងទូលបង្គំឡើងជាមួយនឹងសិរីល្អដែលទូលបង្គំមាន នៅចំពោះមុខលោកីយ៍ដែលទ្រង់បានបង្កើត។
[6]ទូលបង្គំបានបង្ហាញព្រះនាមព្រះអង្គ ដល់អស់អ្នកដែលព្រះអង្គបានប្រទានមកទូលបង្គំនៅក្នុងលោកីយ៍នេះ។ ពួកគេជាកម្មសិទ្ធិរបស់ព្រះអង្គ
ហើយព្រះអង្គបានប្រទានទូលបង្គំឲ្យទៅពួកគេ ហើយពួកគេបានប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។[7]ឥឡូវនេះ ពួកគេដឹងថា អ្វីៗដែលព្រះអង្គប្រទានមកទូលបង្គំ
គឺមកពីព្រះអង្គ[8]ដ្បិត ទូលបង្គំបានឲ្យដល់ពួកគេគ្រប់គ្នានូវព្រះបន្ទូលដែលព្រះអង្គបានប្រទានមកទូលបង្គំ។ ពួកគេបានទទួលព្រះបន្ទូល ហើយបានស្គាល់យ៉ាងប្រាកដថា
ទូលបង្គំមកពីព្រះអង្គ ហើយពួកគេបានជឿថា ព្រះអង្គជាអ្នកចាត់ទូលបង្គំឲ្យមក។
[9]ទូលបង្គំអធិស្ឋានឲ្យពួកគេ។ ទូលបង្គំមិនអធិស្ឋានឲ្យលោកីយ៍ទេ ប៉ុន្តែ អធិស្ឋានដល់អស់អ្នកដែលព្រះអង្គប្រទានដល់ទូលបង្គំ ដ្បិត ពួកគេជាកម្មសិទ្ធិរបស់ព្រះអង្គ។
[10]អ្វីៗគ្រប់យ៉ាងដែលជារបស់ទូលបង្គំ ជារបស់ព្រះអង្គ ហើយអ្វីៗគ្រប់យ៉ាងដែលជារបស់ព្រះអង្គ ក៏ជារបស់ទូលបង្គំដែរ ហើយទូលបង្គំបានទទួលសិរីល្អនៅក្នុងពួកគេ។
[11]ទូលបង្គំលែងនៅក្នុងលោកីយ៍ទៀតហើយ ប៉ុន្តែ អ្នកទាំងអស់នេះ នៅក្នុងលោកីយ៍ ហើយទូលបង្គំនឹងត្រឡប់ទៅឯព្រះអង្គវិញ។ ឱបិតាដ៏វិសុទ្ធអើយ
សូមការពារពួកគេនៅក្នុងព្រះនាមព្រះអង្គ ដែលព្រះអង្គបានប្រទានមកទូលបង្គំ ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូចយើងបានរួមគ្នាតែមួយដែរ។
[12]អំឡុងពេល ដែលទូលបង្គំនៅជាមួយពួកគេ ទូលបង្គំបានការពារពួកគេនៅក្នុងព្រះនាមរបស់ព្រះអង្គ ដែលព្រះអង្គបានប្រទានមកទូលបង្គំ។ ទូលបង្គំការពារពួកគេ
ហើយមិនឲ្យនរណាម្នាក់ត្រូវវិនាសឡើយ លើកលែងតែកូននៃសេចក្តីវិនាសតែប៉ុណ្ណោះ ដើម្បីឲ្យបទគម្ពីរបានសម្រេច។[13]ឥឡូវនេះ ទូលបង្គំនឹងទៅឯព្រះអង្គ ប៉ុន្តែ
ទូលបង្គំប្រាប់ការទាំងអស់នេះនៅក្នុងលោកីយ៍ ដើម្បីឲ្យអំណររបស់ទូលបង្គំបានបំពេញនៅក្នុងពួកគេ។[14]ទូលបង្គំបានប្រគល់ព្រះបន្ទូលរបស់ព្រះអង្គដល់ពួកគេ
ហើយលោកីយ៍បានស្អប់ពួកគេ ដោយសារពួកគេមិនមែនចេញពីលោកីយ៍មក ដូចជាទូលបង្គំដែរ មិនបានចេញពីលោកីយ៍មកទេ។
[15]ទូលបង្គំមិនបានសុំឲ្យព្រះអង្គដកពួកគេចេញពីលោកីយ៍ទេ ប៉ុន្តែ សុំឲ្យព្រះអង្គការពារពួកគេពីការអាក្រក់គ្រប់យ៉ាង។[16]ពួកគេមិនមែនមកពីលោកីយ៍នេះទេ
ដូចជាទូលបង្គំដែរ មិនមែនមកពីលោកីយ៍នេះទេ។[17]សូមញែកពួកគេ ដោយសារសេចក្តីពិត។ ព្រះបន្ទូលរបស់ព្រះអង្គគឺជាសេចក្តីពិត។
[18]ដូចដែលព្រះអង្គបានចាត់ទូលបង្គំមកក្នុងលោកីយ៍នេះ ដើម្បីទូលបង្គំបានចាត់ពួកគេឲ្យទៅក្នុងលោកីយ៍វិញដែរ។[19]ដ្បិត ទូលបង្គំបានញែកខ្លួនឯង ដោយសារពួកគេ
ដើម្បីឲ្យពួកគេអាចត្រូវបានញែកនៅក្នុងសេចក្តីពិតដែរ។

generated on Wed Sep 10 16:16:32 2025

[20]ទូលបង្គំមិនគ្រាន់តែអធិស្ឋានសម្រាប់ពួកគេទេ ប៉ុន្តែ
អធិស្ឋានដល់អស់អ្នកដែលនឹងជឿដល់ទូលបង្គំតាមរយៈពាក្យរបស់ពួកគេដែរ[21]ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូចជាព្រះអង្គ ព្រះបិតា នៅក្នុងទូលបង្គំ
ហើយទូលបង្គំនៅក្នុងព្រះអង្គ។ ទូលបង្គំអធិស្ឋានថា សូមឲ្យពួកគេបាននៅក្នុងយើង ដើម្បីឲ្យលោកីយ៍ជឿថា ព្រះអង្គបានចាត់ទូលបង្គំឲ្យមក។
[22]សិរីល្អដែលព្រះអង្គប្រទានដល់ទូលបង្គំ នោះទូលបង្គំបានឲ្យដល់ពួកគេហើយ ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូច យើងដែរ។[23]ទូលបង្គំនៅក្នុងពួកគេ
ហើយព្រះអង្គនៅក្នុងទូលបង្គំ ដើម្បីឲ្យពួកគេអាចនាំភាពរួបរួមទាំងស្រុង ដើម្បីឲ្យលោកីយ៍ដឹងថា ព្រះអង្គបានចាត់ទូលបង្គំឲ្យមក ហើយព្រះអង្គបានស្រឡាញ់ពួកគេ
ដូចព្រះអង្គបានស្រឡាញ់ទូលបង្គំដែរ។
[24]ឱព្រះបិតាអើយ ទូលបង្គំចង់ឲ្យអស់អ្នកដែលព្រះអង្គប្រទានមកទូលបង្គំ បាននៅកន្លែងដែលទូលបង្គំនៅដែរ ហើយនឹងឃើញសិរីល្អរបស់ទូលបង្គំ
គឺជាសិរីល្អរបស់ព្រះអង្គដែលបានប្រទានដល់ទូលបង្គំ ព្រោះព្រះអង្គស្រឡាញ់ទូលបង្គំ មុនលោកីយ៍បានបង្កើតមកម៉្លេះ។
[25]ឱព្រះបិតាដ៏សុចរិតអើយ លោកីយ៍មិនស្គាល់ព្រះអង្គទេ ប៉ុន្តែ ទូលបង្គំស្គាល់ព្រះអង្គ ហើយពួកគេបានដឹងថាព្រះអង្គចាត់ទូលបង្គំឲ្យមក។
[26]ទូលបង្គំបានធ្វើឲ្យគេស្គាល់ព្រះនាមព្រះអង្គ ហើយទូលបង្គំនឹងធ្វើឲ្យគេស្គាល់ ដើម្បីឲ្យសេចក្តីស្រឡាញ់ដែលព្រះអង្គបានស្រឡាញ់ទូលបង្គំនឹងនៅក្នុងពួកគេ
ហើយទូលបង្គំនឹងនៅក្នុងពួកគេដែរ។

John 17:1
ឃ្លាភ្ជាប់៖
ភ្ជាប់ផ្នែកនៃសាច់រឿងពីជំពូកមុន។
ព្រះយេស៊ូមានបន្ទូលទៅអ្នកកាន់សិស្សរបស់ព្រះអង្គ
ប៉ុន្តែឥឡូវនេះទ្រង់ចាប់ផ្តើមអធិស្ឋានទៅព្រះជាម្ចាស់។
ព្រះអង្គបានទតព្រះនេត្រឡើងទៅលើ ឯស្ថានសួគ៌
នេះជាពាក្យដែលមានន័យថាមើលទៅខាងលើ។ "ទ្រង់មើលទៅលើមេឃ" ។
ស្ថានសួគ៌
សំដៅទៅលើមេឃ។
ព្រះបិតាអើយ ...លើកតម្កើងព្រះបុត្រារបស់ព្រះអង្គ ដើម្បីឲ្យព្រះបុត្រាបានលើកតម្កើងព្រះអង្គវិញ
ព្រះយេស៊ូសុំឲ្យព្រះបិតាលើកតម្កើងព្រះអង្គ
ដើម្បីទ្រង់អាចលើកកិត្តិយសព្រះជាម្ចាស់។
ព្រះបិតា...ព្រះបុត្រា
ទាំងនេះជាងារសំខាន់ៗ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់
និងព្រះយេស៊ូ។
ពេលកំណត់បានមកដល់ហើយ
ពាក្យថា“ ពេលកំណត់”នៅទីនេះ ជាពាក្យប្រៀបធៀប សំដៅទៅលើពេលវេលា
ដែលព្រះយេស៊ូត្រូវរងទុក្ខនិងសុគត។ “
ដល់ពេលដែលខ្ញុំត្រូវរងទុក្ខនិងសុគតហើយ”
លើមនុស្សលោក
សំដៅទៅលើមនុស្សទាំងអស់។
John 17:3
នេះជាជីវិតអស់កល្បជានិច្ច....ស្គាល់ព្រះអង្គ ជាព្រះពិតតែមួយគត់ និង...ព្រះយេស៊ូគ្រិស្ត
ជីវិតអស់កល្បគឺការស្គាល់ព្រះពិតតែមួយ គឺព្រះបិតានិងព្រះបុត្រា។
គឺថាពួកគេស្គាល់ព្រះអង្គ
នេះជាពាក្យមានន័យថា ទទួលបានបទពិសោធន៍ជាមួយព្រះជាម្ចាស់
ជាជាងគ្រាន់តែស្គាល់ពីព្រះជាម្ចាស់។
ការងារដែលព្រះអង្គបានប្រទានឲ្យទូលបង្គំធ្វើ
"ការងារ" នៅទីនេះជាពាក្យប្រៀបធៀប
ដែលសំដៅទៅលើព័ន្ធកិច្ចទាំងមូលរបស់ព្រះយេស៊ូ នៅលើផែនដី។
បិតាអើយ សូមលើកតម្កើងទូលបង្គំឡើងជាមួយនឹងសិរីល្អដែលទូលបង្គំមាន
នៅចំពោះមុខលោកីយ៍ដែលទ្រង់បានបង្កើត
ព្រះយេស៊ូមានសិរីរុងរឿងជាមួយនឹងព្រះជាម្ចាស់ ដែលជាបិតានៅ
«មុនពិភពលោកបានត្រូវបង្កើត» ព្រោះព្រះយេស៊ូជាព្រះបុត្រា។ "ឱព្រះបិតាអើយ
សូមលើកតម្កើងទូលបង្គំ ដោយនាំទូលបង្គំទៅឯវត្តមានរបស់ព្រះអង្គ
ដូចយើងនៅពីមុន ពេលយើងបានបង្កើតលោកីយនេះ" ។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
John 17:6
ឃ្លាភ្ជាប់៖
ព្រះយេស៊ូចាប់ផ្តើមអធិស្ឋានឲ្យពួកសិស្សរបស់ព្រះអង្គ។
ទូលបង្គំបានបង្ហាញព្រះនាមព្រះអង្គ
"ឈ្មោះ"នៅទីនេះ ជាពាក្យប្រៀបធៀប
ដែលសំដៅទៅលើមនុស្សរបស់ព្រះជាម្ចាស់។ "ខ្ញុំបានបង្រៀនពួកគេថា
អ្នកជានរណា ហើយអ្នកជាមនុស្សបែបណា" ។
នៅក្នុងលោកីយ៍នេះ
“លោកីយ” នៅទីនេះ ជាពាក្យប្រៀបធៀប សំដៅទៅលើប្រជាជនក្នុងពិភពលោក
ដែលប្រឆាំងនឹងព្រះជាម្ចាស់។ មានន័យថា
ព្រះជាម្ចាស់បានបំបែកអ្នកជឿខាងវិញ្ញាណ
ចេញពីមនុស្សដែលមិនជឿលើព្រះអង្គ។
ប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ
ជាពាក្យមានន័យថាគោរពតាម។ "បានស្តាប់តាមការបង្រៀនរបស់ព្រះអង្គ"
John 17:9
ទូលបង្គំមិនអធិស្ឋានឲ្យលោកីយ៍ទេ
ពាក្យ «លោកីយ»ត្រង់នេះ ជាពាក្យប្រៀបធៀប សំដៅទៅលើមនុស្ស
ដែលប្រឆាំងនឹងព្រះជាម្ចាស់។ "ខ្ញុំមិនអធិស្ឋានជូនអ្នក
ដែលមិនមែនជារបស់ព្រះអង្គទេ"
នៅក្នុងលោកីយ៍
ជាពាក្យប្រៀបធៀប ដែលសំដៅទៅលើការនៅលើផែនដី
និងស្ថិតក្នុងចំណោមមនុស្ស ដែលប្រឆាំងនឹងព្រះជាម្ចាស់។ "ក្នុងចំណោមមនុស្ស
ដែលមិនមែនជាកម្មសិទ្ធិរបស់ព្រះអង្គ"
ឱបិតាដ៏វិសុទ្ធអើយ សូមការពារពួកគេ.. ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ
ដូចយើងបានរួមគ្នាតែមួយដែរ
ព្រះយេស៊ូសុំឲ្យព្រះបិតាថែរក្សាអស់អ្នក ដែលទុកចិត្តលើព្រះអង្គ
ដើម្បីឲ្យពួកគេអាចមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
សូមការពារពួកគេនៅក្នុងព្រះនាមព្រះអង្គ ដែលព្រះអង្គបានប្រទានមកទូលបង្គំ
ពាក្យ "នាម" នៅទីនេះ ជាការប្រៀបធៀប ដែលសំដៅទៅលើការការពារ
និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់។
"រក្សាពួកគេនៅក្រោមការការពារនៃនាមរបស់ព្រះអង្គ ដូចទ្រង់បានការពារទូលបង្គំ"
ឬ "ការពារពួកគេដោយអំណាចនៃនាមរបស់ព្រះអង្គ
ដែលទ្រង់បានផ្តល់ឲ្យទូលបង្គំ"
John 17:12
ទូលបង្គំនៅជាមួយពួកគេ ទូលបង្គំបានការពារពួកគេនៅក្នុងព្រះនាមរបស់ព្រះអង្គ
"នាម"នៅទីនេះ ជាការប្រៀបធៀប ដែលសំដៅទៅលើឫទ្ធានុភាព
និងការការពាររបស់ព្រះជាម្ចាស់។ "ខ្ញុំបានការពារគេ ដោយការការពាររបស់ព្រះអង្គ"
មិនឲ្យនរណាម្នាក់ត្រូវវិនាសឡើយ លើកលែងតែកូននៃសេចក្តីវិនាសតែប៉ុណ្ណោះ
"មានតែមនុស្សម្នាក់ក្នុងចំណោមពួកគេ ដែលនឹងត្រូវវិនាស
គឺកូនប្រុសនៃសេចក្តីវិនាស"
កូននៃសេចក្តីវិនាស
សំដៅទៅលើយូដាស ដែលក្បត់ព្រះយេស៊ូ។ "អ្នកដែលទ្រង់បានសម្រេចថា
ជាអ្នកនឹងត្រូវវិនាស"
ដើម្បីឲ្យបទគម្ពីរបានសម្រេច
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ដើម្បីសម្រេចតាមទំនាយពីព្រះអង្គនៅក្នុងបទគម្ពីរ"
នៅក្នុងលោកីយ៍
“លោកីយ”នៅទីនេះ ជាការប្រៀបធៀប
សម្រាប់ប្រជាជនដែលរស់នៅលើពិភពលោក។
ដើម្បីឲ្យអំណររបស់ទូលបង្គំបានបំពេញនៅក្នុងពួកគេ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “
ដើម្បីព្រះអង្គផ្តល់អំណរដល់ពួកគេពេញលេញ”

generated on Wed Sep 10 16:16:32 2025

លោកីយ៍...ដោយសារពួកគេមិនមែនចេញពីលោកីយ៍មក ...ទូលបង្គំដែរ
មិនបានចេញពីលោកីយ៍មកទេ
“លោកីយ៍” នៅទីនេះ ជាការប្រៀបធៀប សំដៅទៅលើមនុស្ស
ដែលប្រឆាំងនឹងព្រះជាម្ចាស់។ “ ប្រជាជនដែលប្រឆាំងព្រះអង្គ
បានស្អប់អ្នកដើរតាមទូលបង្គំ ព្រោះពួកគេមិនមែនជារបស់អ្នកដែលមិនជឿ
ដូចទូលបង្គំមិនមែនជាកម្មសិទ្ធិរបស់ពួកគេ។ "
John 17:15
លោកីយ៍
"លោកីយ៍" នៅក្នុងអត្ថបទនេះ
ជាពាក្យប្រៀបធៀបសម្រាប់មនុស្សដែលប្រឆាំងនឹងព្រះជាម្ចាស់។
សុំឲ្យព្រះអង្គការពារពួកគេពីការអាក្រក់គ្រប់យ៉ាង
សំដៅទៅលើសាតាំង។ “ ការពារពួកគេ ពីសាតាំងដែលជាមារកំណាច”
សូមញែកពួកគេ ដោយសារសេចក្តីពិត
គោលបំណងសម្រាប់ការញែកពួកគេ អាចបញ្ជាក់យ៉ាងច្បាស់។ នៅឃ្លា“
ដោយសេចក្តីពិត” នៅទីនេះតំណាងដោយការបង្រៀនពីសេចក្តីពិត។
"ធ្វើឲ្យពួកគេក្លាយជាមនុស្សរបស់ព្រះអង្គ ដោយបង្រៀនពួកគេពីសេចក្តីពិត"
ព្រះបន្ទូលរបស់ព្រះអង្គគឺជាសេចក្តីពិត
"ព្រះបន្ទូលរបស់ព្រះអង្គជាសេចក្តីពិត" ឬ "អ្វីដែលទ្រង់មានបន្ទូល
គឺជាសេចក្តីពិត"
John 17:18
ក្នុងលោកីយ៍នេះ
"លោកីយ៍" នៅទីនេះ ជាការប្រៀបធៀប
ដែលមានន័យប្រជាជនរស់នៅលើពិភពលោក។
"ទៅកាន់ប្រជាជននៅលើពិភពលោក"
ដើម្បីឲ្យពួកគេអាចត្រូវបានញែកនៅក្នុងសេចក្តីពិតដែរ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ ដើម្បីឲ្យពួកគេអាចញែកខ្លួនគេចេញ
សម្រាប់ព្រះអង្គពិតប្រាកដ”
John 17:20
ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូចជាព្រះអង្គ ព្រះបិតា នៅក្នុងទូលបង្គំ
អ្នកដែលទុកចិត្តលើព្រះយេស៊ូបានរួបរួមជាមួយព្រះបិតា និងព្រះបុត្រា
ពេលដែលគេជឿ។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
លោកីយ៍
“លោកីយ”នៅទីណេះ ជាពាក្យពិពណ៌ន សំដៅទៅលើមនុស្ស
ដែលមិនទាន់បានស្គាល់ព្រះជាម្ចាស់នៅឡើយ “
ប្រជាជនដែលមិនទាន់ស្គាល់ព្រះជាម្ចាស់។
John 17:22
សិរីល្អដែលព្រះអង្គប្រទានដល់ទូលបង្គំ នោះទូលបង្គំបានឲ្យដល់ពួកគេហើយ
"ទូលបង្្គបានផ្តល់កិត្តិយស ដល់អ្នកដើរតាមទូលបង្គំ
ដូចព្រះអង្គបានផ្តល់កិត្តិយសដល់ទូលបង្គំដែរ"
ដើម្បីឲ្យពួកគេបានត្រឡប់ទៅជាតែមួយ ដូច យើងដែរ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដូច្នេះអ្នកទ្រង់បង្រួបបង្រួមពួកគេ
ដូចទ្រង់បានបង្រួបបង្រួមយើងដែរ"
ដើម្បីឲ្យពួកគេអាចនាំភាពរួបរួមទាំងស្រុង
"ដើម្បីឲ្យពួកគេអាចរួបរួមគ្នាបាន"
ដើម្បីឲ្យលោកីយ៍ដឹងថា
“លោកីយ” នៅទីនេះ ជាពាក្យពិពណ៌នា សំដៅទៅលើមនុស្ស
ដែលមិនទាន់ស្គាល់ព្រះជាម្ចាស់នៅឡើយ។ "ប្រជាជនទាំងអស់នឹងស្គាល់"
ស្រឡាញ់
សេចក្តីស្រឡាញ់ប្រភេទនេះ កើតចេញពីព្រះជាម្ចាស់
ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
សូម្បីតែវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់
ចំពោះអ្នកដទៃទោះជាពួកគេធ្វើអ្វីក៏ដោយ។
John 17:24
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
កន្លែងដែលទូលបង្គំនៅ
“ កន្លែងដែលខ្ញុំនៅ”នៅទីនេះ សំដៅទៅលើស្ថានសួគ៌។
"នៅជាមួយខ្ញុំនៅស្ថានសួគ៌"
ឃើញសិរីល្អរបស់ទូលបង្គំ
មើលឃើញភាពអស្ចារ្យរបស់ខ្ញុំ "
មុនលោកីយ៍បានបង្កើតមកម៉្លេះ
នៅទីនេះ ព្រះយេស៊ូសំដៅទៅលើពេលវេលា មុនពេលការបង្កើតអ្វីៗទាំងអស់។
"មុនពេលយើងបានបង្កើតពិភពលោក"
John 17:25
ឃ្លាភ្ជាប់៖
ព្រះយេស៊ូបញ្ចប់ការអធិស្ឋានរបស់ព្រះអង្គ។
ឱព្រះបិតាដ៏សុចរិតអើយ
នៅទីនេះ "ព្រះបិតា" ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
លោកីយ៍មិនស្គាល់ព្រះអង្គទេ
"លោកិយ៍" ជាពាក្យសំដៅទៅលើមនុស្ស ដែលមិនមែនជារបស់ព្រះជាម្ចាស់។ “
អ្នកដែលមិនមែនជារបស់ព្រះអង្គ មិនដឹងថាទ្រង់ជាមនុស្សបែបណាទេ”
ទូលបង្គំបានធ្វើឲ្យគេស្គាល់ព្រះនាមព្រះអង្គ
ពាក្យ "នាម" សំដៅទៅលើព្រះជាម្ចាស់។
"ខ្ញុំបានបង្ហាញដល់ពួកគេនូវលក្ខណៈរបស់ព្រះអង្គ"
សេចក្តីស្រឡាញ់..ស្រឡាញ់
សេចក្តីស្រឡាញ់ប្រភេទនេះកើតចេញពីព្រះជាម្ចាស់ហើយផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
សូម្បីតែវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះជាពួកគេធ្វើអ្វីក៏ដោយ។

---

18 [1]បន្ទាប់ពីព្រះយេស៊ូមានបន្ទូលសេចក្តីទាំងនោះហើយ ព្រះអង្គបានចេញទៅជ្រលងក្រដូនម្ខាងទៀតជាមួយពួកសិស្ស
ព្រះអង្គបានចូលទៅក្នុងសួនមួយនៅទីនោះជាមួយពួកសិស្ស។[2]លោកយូដាស ជាអ្នកដែលក្បត់ព្រះអង្គ ក៏ដឹងពីកន្លែងនោះដែរ ដ្បិត
ព្រះយេស៊ូបានយាងទៅទីនោះជាញឹកញាប់ជាមួយពួកសិស្ស។[3]បន្ទាប់មក លោកយូដាស បាននាំទាហានមួយក្រុម ហើយនិងពួកអាជ្ញាធរពីនាយកបូជាចារ្យ និងពួកផារីស៊ី
ទៅទីនោះជាមួយនឹងគោម ចន្លុះ ហើយនិងអាវុធផង។
[4]បន្ទាប់មក ព្រះយេស៊ូបានជ្រាបក្នុងគ្រប់ការទាំងអស់ថាអ្វីនឹងកើតឡើងចំពោះព្រះអង្គ ទ្រង់បានយាងទៅជួបពួកគេ ហើយមានបន្ទូលសួរថា៖
«តើអ្នករាល់គ្នាកំពុងស្វែងរកនរណា?»[5]ពួកគេទូលទៅព្រះអង្គវិញថា៖ «រកយេស៊ូ អ្នកស្រុកណាសារ៉ែត»។ ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ខ្ញុំហ្នឹងហើយ»។
លោកយូដាស ជាអ្នកដែលក្បត់ព្រះអង្គ ក៏ឈរនៅជាមួយទាហានដែរ។
[6]នៅពេលព្រះអង្គមានបន្ទូលទៅពួកគេថា៖ «ខ្ញុំហ្នឹងហើយ» ដូច្នេះ ពួកគេក៏ថ្ងាក្រោយ ហើយដួលទៅនឹងដី។[7]បន្ទាប់មក ទ្រង់មានបន្ទូលទៅកាន់ពួកគេម្តងទៀតថា៖
«តើអ្នករាល់គ្នាស្វែងរកនរណា?» ពួកគេទូលឆ្លើយម្តងទៀតថា៖ «យេស៊ូ អ្នកស្រុកណាសារ៉ែត»។
[8]ព្រះយេស៊ូមានបន្ទូលឆ្លើយថា៖ «ខ្ញុំប្រាប់អ្នករាល់គ្នាហើយថា៖ «គឺខ្ញុំហ្នឹងហើយ។ ប្រសិនបើ អ្នករាល់គ្នាស្វែងរកខ្ញុំ ដូច្នេះ សូមឲ្យអ្នកទាំងអស់នេះចេញទៅ»។
[9]ការនេះកើតឡើង ដើម្បីឲ្យបានសម្រេចតាមព្រះបន្ទូលដែលព្រះអង្គមានបន្ទូលថា៖ «អស់អ្នកណាដែលព្រះអង្គបានប្រទានមកទូលបង្គំ គ្មានអ្នកណាបាត់បង់ឡើយ»។
[10]បន្ទាប់មក លោកស៊ីម៉ូនពេត្រុស ជាអ្នកដែលមានដាវ បានដក ហើយកាប់អ្នកបម្រើរបស់មហាបូជាចារ្យ ហើយបានកាត់ត្រចៀកខាងស្តាំរបស់គាត់។
អ្នកបម្រើនោះឈ្មោះម៉ាលកុស។[11]ព្រះយេស៊ូទៅលោកពេត្រុសថា៖ «ដាក់ដាវទៅក្នុងស្រោមរបស់វាវិញទៅ។ តើខ្ញុំមិនផឹកពែងដែលព្រះបិតាបានប្រទានដល់ខ្ញុំទេឬអី?»
[12]ដូច្នេះ ក្រុមទាហាន និងមេបញ្ជាការ ព្រមទាំងអាជ្ញាធររបស់សាសន៍យូដា បានចាប់ព្រះយេស៊ូ ហើយចងព្រះអង្គ។[13]ពួកគេបាននាំព្រះអង្គទៅជួបលោកអេណា
ដ្បិតគាត់គឺជាឪពុកក្មេករបស់លោកកៃផាស ដែលជាមហាបូជាចារ្យនៅឆ្នាំនោះ។[14]លោកកៃផាសជាម្នាក់ដែលបានផ្តល់យោបល់ទៅសាសន៍យូដាដែលគឺជាល្អ ប្រសិនបើ
ម្នាក់នេះស្លាប់ជំនួសមនុស្ស។

generated on Wed Sep 10 16:16:32 2025

[15]លោកស៊ីម៉ូនពេត្រុសបានដើរតាមព្រះយេស៊ូ ជាមួយនឹងពួកសិស្សផ្សេងទៀតដែរ។ មានសិស្សម្នាក់នោះបានស្គាល់មហាបូជាចារ្យ
ហើយគាត់បានចូលទៅឯព្រះយេស៊ូនៅទៅទីធ្លាខាងក្នុងដំណាក់របស់មហាបូជាចារ្យ ប៉ុន្តែ លោកពេត្រុសឈរនៅខាងក្រៅទ្វារ។[16]ដូច្នេះ សិស្សម្នាក់ទៀត
ដែលស្គាល់មហាបូជាចារ្យ បានចូលទៅ ហើយនិយាយជាមួយស្ត្រីអ្នកយាមទ្វារ ហើយគាត់បាននាំលោកពេត្រុសចូលក្នុង។
[17]បន្ទាប់មក ស្ត្រីបម្រើ ដែលជាអ្នកយាមទ្វារ និយាយទៅកាន់លោកពេត្រុសថា៖ «តើអ្នកក៏ជាសិស្សម្នាក់របស់បុរសនោះមែនទេ?» គាត់ឆ្លើយថា៖ «មិនមែនទេ»។
[18]ពួកអ្នកបម្រើ និងពួកអាជ្ញាធរកំពុងឈរនៅទីនោះ ពួកគេបង្កាត់ភ្លើងអាំង ដ្បិតពេលនោះរងារណាស់ ពួកគេបានអាំងកម្តៅរូបកាយរបស់ពួកគេ។
លោកពេត្រុសក៏នៅជាមួយពួកគេ អាំងភ្លើង និងកម្តៅខ្លួនពួកគេនៅទីនោះដែរ។
[19]បន្ទាប់មក មហាបូជាចារ្យបានសួរព្រះយេស៊ូអំពីសេចក្តីបង្រៀនរបស់ពួកសិស្ស និងសេចក្តីបង្រៀនរបស់ព្រះអង្គ។[20]ព្រះយេស៊ូបានមានបន្ទូលឆ្លើយទៅគាត់ថា៖
«ខ្ញុំបានប្រាប់ជាសាធារណៈដល់លោកីយ៍ហើយ។ ខ្ញុំតែងតែបង្រៀននៅក្នុងសាលាប្រជុំ និងនៅក្នុងព្រះវិហារ ជាកន្លែងដែលសាសន៍យូដាមកប្រជុំគ្នា។
ខ្ញុំមិនបាននិយាយអ្វីអាថ៌កំបាំងឡើយ។[21]ហេតុអ្វីបានជាលោកសួរខ្ញុំ? ចូរសួរអស់អ្នកដែលបានស្តាប់ខ្ញុំពីអ្វីដែលខ្ញុំបានបង្រៀន។ មើល
អ្នកទាំងអស់នេះដឹងអ្វីដែលខ្ញុំបាននិយាយ»។
[22]នៅពេលព្រះយេស៊ូមានបន្ទូលការនេះហើយ អាជ្ញាធរម្នាក់ដែលឈរនៅទីនោះបានវាយព្រះយេស៊ូ ហើយនិយាយថា៖ «ឯងឆ្លើយបែបនេះ
ទៅកាន់មហាបូជាចារ្យមែនទេ?»[23]ព្រះយេស៊ូមានបន្ទូលឆ្លើយទៅអ្នកនោះថា៖ «ប្រសិនបើ ខ្ញុំនិយាយខុសមែន ចូរគិតពីកំហុសខ្ញុំចុះ ប៉ុន្តែ ប្រសិនបើខ្ញុំត្រូវ
ហេតុអ្វីបានជាលោកវាយខ្ញុំ?»[24]បន្ទាប់មកលោកអេណាបានចាត់ព្រះអង្គឲ្យទៅឯកៃផាសជាមហាបូជាចារ្យទាំងជាប់ចំណង។
[25]លោកស៊ីម៉ូនពេត្រុសកំពុងតែឈរ ហើយកំពុងអាំងភ្លើង។ នោះ បណ្តាជនបានមកហើយនិយាយទៅគាត់ថា៖
«តើអ្នកមិនមែនជាសិស្សម្នាក់ក្នុងចំណោមពួកសិស្សរបស់អ្នកនោះទេឬអី?» គាត់បដិសេធ ហើយនិយាយថា៖ «ខ្ញុំមិនមែនទេ»។[26]អ្នកបម្រើម្នាក់របស់មហាបូជាចារ្យ
ជាញាតិរបស់បុរសម្នាក់ដែលលោកពេត្រុសបានកាត់ដាច់ត្រចៀក និយាយថា៖ «តើខ្ញុំមិនបានឃើញអ្នកនៅជាមួយអ្នកនោះនៅក្នុងសួនទេឬអី?»[27]បន្ទាប់មក
លោកពេត្រុសបដិសេធម្តងទៀត ហើយរំពេចនោះមាន់ក៏រងាវ។
[28]បន្ទាប់មក ពួកគេបាននាំព្រះយេស៊ូពីលោកកៃផាសទៅទីស្នាក់ការកណ្តាលរដ្ឋាភិបាល។ ពេលនោះគឺជាពេលព្រឹកព្រលឹម
ហើយពួកគេមិនបានចូលទៅទីស្នាក់ការកណ្តាលរដ្ឋាភិបាល ព្រោះបើធ្វើដូច្នោះ ពួកគេនឹងរាប់ជាមិនស្អាត ព្រោះពួកគេបរិភោគក្នុងពិធីបុណ្យរំលង។[29]ដូច្នេះ
លោកពីឡាតបានចេញមកជួបពួកគេ ហើយមានប្រសាសន៍ថា៖ «តើអ្នកចោទប្រកាន់បុរសនេះរឿងអ្វី?»[30]ពួកគេឆ្លើយ ដោយនិយាយទៅកាន់គាត់ថា៖ «ប្រសិនបើ
បុរសនេះ មិនបានធ្វើការអាក្រក់ទេ យើងនឹងមិននាំគាត់មកប្រគល់ឲ្យលោកទេ»។
[31]ដូច្នេះ លោកពីឡាតមានប្រសាសន៍ទៅពួកគេថា៖ «ចូរយកគាត់ទៅខ្លួនឯងទៅ ហើយកាត់ក្តីគាត់ស្របទៅតាមក្រឹត្យវិន័យរបស់អ្នករាល់គ្នាចុះ»។
ពួកយូដានិយាយទៅកាន់គាត់ថា៖ «វាមិនត្រឹមត្រូវតាមច្បាប់សម្រាប់យើងទេ ក្នុងការសម្លាប់អ្នកណាម្នាក់នោះ»។[32]ពួកគេនិយាយដូច្នេះ
ដើម្បីឲ្យព្រះបន្ទូលដែលព្រះយេស៊ូបានថ្លែងបានសម្រេច តាមសេចក្តីដែលព្រះអង្គបានមានបន្ទូលពីការដែលព្រះអង្គត្រូវសុគតយ៉ាងណា។
[33]បន្ទាប់មកលោកពីឡាតបានចូលទៅក្នុងទីស្នាក់ការកណ្តាលរដ្ឋាភិបាលម្តងទៀត ហើយបានហៅព្រះយេស៊ូ ព្រមទាំងនិយាយទៅកាន់ព្រះអង្គថា៖
«តើលោកគឺជាមហាក្សត្ររបស់សាសន៍យូដាមែនទេ?»[34]ព្រះយេស៊ូឆ្លើយថា៖ «តើលោកនិយាយខ្លួនឯង ឬ អ្នកផ្សេងប្រាប់លោកពីខ្ញុំ?»[35]លោកពីឡាតឆ្លើយថា៖
«ខ្ញុំមិនមែនជាសាសន៍យូដាទេ តើមែនទេ? សាសន៍របស់អ្នកផ្ទាល់ ហើយនាយកបូជាចារ្យបានប្រគល់អ្នកមកខ្ញុំ។ តើអ្នកបានធ្វើអ្វី?»
[36]ព្រះយេស៊ូឆ្លើយថា៖ «ព្រះរាជ្យរបស់ខ្ញុំមិនមែនមកពីលោកីយ៍នេះទេ។ ប្រសិនបើរាជ្យរបស់ខ្ញុំមកពីលោកីយ៍នេះមែន នោះពួកអ្នកបម្រើរបស់ខ្ញុំមុខជាតយុទ្ធមិនខាន
ដើម្បីកុំឲ្យខ្ញុំត្រូវចាប់ប្រគល់ទៅឲ្យសាសន៍យូដាឡើយ។ ប៉ុន្តែ រាជ្យរបស់ខ្ញុំមិនមែនមកពីនេះទេ»។[37]បន្ទាប់ លោកពីឡាតមានប្រសាសន៍ទៅព្រះអង្គថា៖ «អ៊ីចឹង
តើលោកជាមហាក្សត្រមែនទេ?» ព្រះយេស៊ូបានឆ្លើយថា៖ «លោកនិយាយថា ខ្ញុំជាមហាក្សត្រ។ ដ្បិត ខ្ញុំកើតមកក្នុងគោលបំណងនេះឯង
ហើយគោលបំណងដែលខ្ញុំបានមកក្នុងលោកីយ៍នេះ ដើម្បីឲ្យខ្ញុំបានធ្វើបន្ទាល់ចំពោះសេចក្តីពិតនេះ។ មនុស្សគ្រប់រូបដែលជាកម្មសិទ្ធិសេចក្តីពិតនឹងស្តាប់សម្លេងរបស់ខ្ញុំ។
[38]លោកពីឡាតមានប្រសាសន៍ទៅព្រះអង្គថា៖ «តើសេចក្តីពិតជាអ្វី?» នៅពេលដែលគាត់បាននិយាយដូច្នេះរួចហើយ គាត់បានចេញទៅជួបពួកយូដាខាងក្រៅម្តងទៀត
ហើយមានប្រសាសន៍ទៅពួកគេថា៖ «ខ្ញុំរកកំហុសមិនឃើញនៅក្នុងបុរសនេះទេ។[39]ប៉ុន្តែ អ្នករាល់គ្នាមានទម្លាប់
ខ្ញុំនឹងដោះលែងមនុស្សម្នាក់ដល់អ្នករាល់គ្នានៅថ្ងៃបុណ្យរំលងនេះ។ ដូច្នេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងស្តេចរបស់សាសន៍យូដាដល់អ្នករាល់គ្នាឬយ៉ាងណា?»[40]នោះ
ពួកគេបានស្រែកឡើង ហើយនិយាយថា៖ «មិនមែនបុរសនេះទេ ប៉ុន្តែសូមដោះលែងបារ៉ាបាសវិញ»។ លោកបារ៉ាបាសជាចោរប្លន់។

John 18:1
ព័ត៌មានទូទៅ:
នេះជាផ្នែកបន្ទាប់នៃសាច់រឿងនេះ ដែលរួមមានការចាប់ខ្លួនព្រះយេស៊ូ។ ខ១ ប្រាប់យើងពីការរៀបចំសាច់រឿងនិងខទី ២ ប្រាប់យើងនូវចំណេះដឹងពីយូដាស។
ជ្រលងក្រេដូន
ជ្រលងភ្នំនៅក្រុងយេរូសាឡឹម បែងចែកព្រះវិហារនៅលើភ្នំ ពីភ្នំដើមអូលីវ។
ចូលទៅក្នុងសួន
ជាព្រៃដើមអូលីវ។ “ កន្លែងដែលមានដើមអូលីវ”
John 18:4
ព័ត៌មានទូទៅ:
ព្រះយេស៊ូចាប់ផ្តើមនិយាយជាមួយពួកទាហាន ពួកមន្ត្រី និងពួកផារីស៊ី។
ព្រះយេស៊ូបានជ្រាបក្នុងគ្រប់ការទាំងអស់ថាអ្វីនឹងកើតឡើងចំពោះព្រះអង្គ
"បន្ទាប់មកព្រះយេស៊ូ ទ្រង់ជ្រាបអ្វីៗទាំងអស់ ដែលនឹងកើតឡើងចំពោះព្រះអង្គ"
យេស៊ូ អ្នកស្រុកណាសារ៉ែត
"ព្រះយេស៊ូជាអ្នកមកពីណាសារ៉ែត"
ខ្ញុំហ្នឹងហើយ
ពាក្យ "គាត់" ត្រូវបានបង្កប់នៅក្នុងអត្ថបទ។ "ខ្ញុំគឺគាត់"
អ្នកដែលក្បត់ព្រះអង្គ
អ្នកណាប្រគល់ព្រះអង្គឲ្យទៅ
John 18:6
ខ្ញុំហ្នឹងហើយ
ពាក្យ "គាត់" នៅទីនេះមិនមាននៅក្នុងអត្ថបទដើមទេ ប៉ុន្តែវាត្រូវបានបង្កប់ន័យ។
"ខ្ញុំគឺគាត់"
ដួលទៅនឹងដី
បុរសទាំងនោះបានដួលទៅនឹងដី ដោយសារតែបារមីរបស់ព្រះយេស៊ូ។ “ ដួលដោយសារបារមីរបស់ព្រះយេស៊ូ”
យេស៊ូ អ្នកស្រុកណាសារ៉ែត
"ព្រះយេស៊ូជាអ្នកមកពីណាសារ៉ែត"
John 18:8
ព័ត៌មានទូទៅ:
នៅក្នុងខ៩ មានការផ្ទាកពីដំណើររឿងសំខាន់
ពេលយ៉ូហានប្រាប់យើងពីប្រវត្តិអំពីព្រះយេស៊ូ
ដែលបានធ្វើឲ្យបទគម្ពីរពេញលេញ។
ខ្ញុំហ្នឹងហើយ
ពាក្យ "គាត់" នៅទីនេះមិនមាននៅក្នុងអត្ថបទដើមទេ ប៉ុន្តែវាត្រូវបានបង្កប់ន័យ។
"ខ្ញុំគឺគាត់"
ការនេះកើតឡើង ដើម្បីឲ្យបានសម្រេចតាមព្រះបន្ទូលដែលព្រះអង្គមានបន្ទូលថា
ត្រង់នេះពាក្យនេះសំដៅទៅលើពាក្យ ដែលព្រះយេស៊ូបានអធិស្ឋាន។
អ្នកអាចបកប្រែជាទម្រង់កិរិយាសកម្ម។ "រឿងនេះបានកើតឡើង
ដើម្បីបំពេញនូវពាក្យទំនាយ ដែលព្រះអង្គមានបន្ទូល
ពេលទ្រង់កំពុងអធិស្ឋានដល់ព្រះបិតា។
John 18:10
ម៉ាលកុស
ម៉ាលកុសជាអ្នកបម្រើប្រុសរបស់មហាបូជាចារ្យ។

generated on Wed Sep 10 16:16:32 2025

ក្នុងស្រោម
ស្រោមដាក់កំបិត ឬដាវមុតមួយ ដូច្នេះកាំបិតនឹងមិនកាត់ម្ចាស់ឡើយ។
តើខ្ញុំមិនផឹកពែងដែលព្រះបិតាបានប្រទានដល់ខ្ញុំទេឬអី?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបន្ថែមការសង្កត់ន័យទៅលើសេចក្តីថ្លែងរបស់ព្រះយេស៊ូ។
"ខ្ញុំប្រាកដជាផឹកពែង ដែលព្រះបិតាប្រទានមកខ្ញុំ!"
ពែង
“ពែង” នៅទីនេះជាពាក្យប្រៀបធៀប សំដៅទៅលើការរងទុក្ខ
ដែលព្រះយេស៊ូត្រូវតែស៊ូទ្រាំ។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់
John 18:12
ព័ត៌មានទូទៅ:
ខ ១៤ ប្រាប់យើងអំពីសាវតារបស់កៃផា។
សាសន៍យូដា
នៅទីនេះ "ពួកយូដា" សំដៅទៅលើមេដឹកនាំសាសន៍យូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។ "មេដឹកនាំសាសន៍យូដា"
បានចាប់ព្រះយេស៊ូ ហើយចងព្រះអង្គ
ពួកទាហានបានចងដៃព្រះយេស៊ូ ដើម្បីការពារមិនឲ្យព្រះអង្គរត់។
"បានចាប់ព្រះយេស៊ូ ហើយបានចងព្រះអង្គកុំឲ្យរត់គេចខ្លួន"
John 18:15
មានសិស្សម្នាក់នោះបានស្គាល់មហាបូជាចារ្យ ហើយគាត់បានចូលទៅឯព្រះយេស៊ូ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “មហាបូជាចារ្យបានស្គាល់សិស្សនោះ
ដូច្នេះគាត់អាចចូលមកជាមួយព្រះយេស៊ូបាន” ។
ដូច្នេះ សិស្សម្នាក់ទៀត ដែលស្គាល់មហាបូជាចារ្យ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដូច្នេះសិស្សផ្សេងទៀត
ដែលលោកមហាបូជាចារ្យស្គាល់"
John 18:17
តើអ្នកក៏ជាសិស្សម្នាក់របស់បុរសនោះមែនទេ?
នេះបង្ហាញជាទម្រង់សំណួរ ដើម្បីឲ្យអ្នកបម្រើអាចសម្តែងការកត់សម្គាល់របស់នាង
ដោយប្រុងប្រយ័ត្ន។ "អ្នកក៏ជាសិស្សម្នាក់ក្នុងចំណោមសិស្សរបស់បុរស
ដែលត្រូវបានចាប់ខ្លួន ដែរមែនទេ?"
ពួកអ្នកបម្រើ និងពួកអាជ្ញាធរកំពុងឈរនៅទីនោះ ពួកគេបង្កាត់ភ្លើងអាំង ដ្បិតពេលនោះរងារណាស់
ពួកគេបានអាំងកម្តៅរូបកាយរបស់ពួកគេ
អ្នកទាំងនេះជាអ្នកបម្រើរបស់មហាបូជាចារ្យ និងឆ្មាំយាមព្រះវិហារ។ “
ត្រជាក់ណាស់ ដូច្នេះពួកអ្នកបម្រើរបស់មហាបូជាចារ្យ
និងឆ្មាំយាមព្រះវិហារបានធ្វើអុសធ្យូងហើយកំពុងឈរកំដៅខ្លួន”
ឥឡូវនេះ
ពាក្យនេះប្រើនៅទីនេះ ដើម្បីសម្គាល់ការផ្អាកនៅក្នុងសាច់រឿងសំខាន់
ដូច្នេះយ៉ូហានអាចបន្ថែមព័ត៌មានអំពីមនុស្សដែលកំពុងកំដៅខ្លួនជុំវិញភ្លើង។
John 18:19
ព័ត៌មានទូទៅ:
នៅទីនេះដំណើររឿងវិលត្រឡប់ទៅរកព្រះយេស៊ូវិញ។
មហាបូជាចារ្យ
គឺជាកៃផាស។ (សូមមើលជំពូក ១៨ ខ១២)
អំពីសេចក្តីបង្រៀនរបស់ពួកសិស្ស និងសេចក្តីបង្រៀនរបស់ព្រះអង្គ
ត្រង់នេះ «ការបង្រៀនរបស់ព្រះអង្គ»
សំដៅទៅលើអ្វីដែលព្រះយេស៊ូបានបង្រៀនប្រជាជន។ "អំពីពួកសិស្សរបស់ព្រះអង្គ
និងអ្វីដែលទ្រង់បានបង្រៀនប្រជាជន"
ខ្ញុំបានប្រាប់ជាសាធារណៈដល់លោកីយ៍ហើយ
«លោកីយ៍»
គឺជាពាក្យពិពណ៌សម្រាប់មនុស្សទាំងនោះដែលបានឮព្រះយេស៊ូបង្រៀន។
នៅទីនេះមានពាក្យបន្ថែម "លោកីយ"
បន្ថែមការសង្កត់ន័យទៅលើឃ្លារបស់ព្រះយេស៊ូ។
ជាកន្លែងដែលសាសន៍យូដាមកប្រជុំគ្នា
នៅទីនេះ "ជនជាតិយូដាទាំងអស់" ជាពាក្យបន្ថែមមួយ
ដែលបន្ថែមការសង្កត់ន័យលើឃ្លារបស់ព្រះយេស៊ូ។ "ជនជាតិយូដាជាច្រើន"
ហេតុអ្វីបានជាលោកសួរខ្ញុំ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យទៅលើអ្វី
ដែលព្រះយេស៊ូកំពុងតែមានបន្ទូល។ "អ្នកមិនគួរសួរខ្ញុំនូវសំណួរទាំងនេះទេ!"
John 18:22
ឯងឆ្លើយបែបនេះ ទៅកាន់មហាបូជាចារ្យមែនទេ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"នោះមិនមែនជារបៀប ដែលអ្នកគួរឆ្លើយតបនឹងមហាបូជាចារ្យទេ!"
គិតពីកំហុស
"ប្រាប់ខ្ញុំនូវអ្វីដែលខ្ញុំបាននិយាយគឺខុស"
ប្រសិនបើខ្ញុំត្រូវ ហេតុអ្វីបានជាលោកវាយខ្ញុំ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យទៅលើអ្វី
ដែលព្រះយេស៊ូកំពុងតែមានបន្ទូល។ "បើខ្ញុំនិយាយតែអ្វីដែលត្រឹមត្រូវ
អ្នកមិនគួរវាយខ្ញុំទេ!"
John 18:25
ព័ត៌មានទូទៅ:
នៅទីនេះដំណើររឿងវិលត្រឡប់ទៅពេត្រុសវិញ។
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើដើម្បីសម្គាល់ការផ្អាកនៅក្នុងដំណើររឿង
ដូច្នេះយ៉ូហានអាចផ្តល់ព័ត៌មានអំពីពេត្រុស។
តើអ្នកមិនមែនជាសិស្សម្នាក់ក្នុងចំណោមពួកសិស្សរបស់អ្នកនោះទេឬអី?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"អ្នកក៏ជាសិស្សម្នាក់របស់គាត់ដែរ!"
តើខ្ញុំមិនបានឃើញអ្នកនៅជាមួយអ្នកនោះនៅក្នុងសួនទេឬអី?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។ ពាក្យ“
គាត់”ត្រង់នេះ សំដៅទៅលើព្រះយេស៊ូ។ "ខ្ញុំបានឃើញអ្នកនៅក្នុងព្រៃអូលីវ
ជាមួយបុរសដែលពួកគេបានចាប់ខ្លួន! តើខ្ញុំមែនឬទេ?"
លោកពេត្រុសបដិសេធម្តងទៀត
ត្រង់នេះ បញ្ជាក់ថាពេត្រុសបានបដិសេធមិនស្គាល់ និងនៅជាមួយព្រះយេស៊ូទេ។ “
ក្រោយមកពេត្រុសបានបដិសេធម្តងទៀតថា គាត់មិនស្គាល់ព្រះយេស៊ូ
ឬថាគាត់បាននៅជាមួយព្រះយេស៊ូទេ”
ហើយរំពេចនោះមាន់ក៏រងាវ
នៅទីនេះ អ្នកអាននឹងចងចាំថា ព្រះយេស៊ូបានមានបន្ទូលថា
ពេត្រុសនឹងបដិសេធព្រះអង្គមុនពេលមាន់រងាវ។ “ ហើយមាន់រងាវឡើងភ្លាម
ដូចព្រះយេស៊ូបានមានបន្ទូលថា នឹងកើតឡើង”
John 18:28
ព័ត៌មានទូទៅ:
នៅទីនេះ ដំណើររឿងវិលត្រឡប់មករកព្រះយេស៊ូវិញ។ ពួកទាហាន
និងពួកអ្នកចោទប្រកាន់ព្រះយេស៊ូនាំព្រះអង្គទៅឯកៃផា។ ខ២៨
ផ្តល់ឲ្យយើងនូវព័ត៌មានសំខាន់អំពីមូលហេតុ
ដែលពួកគេមិនបានចូលក្នុងបន្ទាយ។
បន្ទាប់មក ពួកគេបាននាំព្រះយេស៊ូពីលោកកៃផាស
បញ្ជាក់ថា ពួកគេកំពុងនាំព្រះយេស៊ូចេញពីផ្ទះរបស់កៃផា។ “ បន្ទាប់មក
ពួកគេបាននាំព្រះយេស៊ូចេញពីផ្ទះរបស់កៃផាស”
ពួកគេមិនបានចូលទៅទីស្នាក់ការកណ្តាលរដ្ឋាភិបាល ព្រោះបើធ្វើដូច្នោះ ពួកគេនឹងរាប់ជាមិនស្អាត
លោកពីឡាតមិនមែនជាជនជាតិយូដាទេ ដូច្នេះ
បើមេដឹកនាំសាសន៍យូដាចូលក្នុងទីស្នាក់ការរបស់គាត់ គេមុខជាមិនស្អាត។
អាចរារាំងពួកគេមិនឲ្យ ធ្វើបុណ្យចម្លងបាន។
អ្នកអាចបកប្រែអវិជ្ជមានទ្វេដងក្នុងទម្រង់វិជ្ជមាន។ “
ពួកគេបាននៅខាងក្រៅទីស្នាក់ការរបស់លោកពីឡាតព្រោះពីឡាតជាសាសន៍ដទៃ។
ពួកគេមិនចង់ធ្វើឲ្យមិនស្អាតឡើយ”
ប្រសិនបើ បុរសនេះ មិនបានធ្វើការអាក្រក់ទេ យើងនឹងមិននាំគាត់មកប្រគល់ឲ្យលោកទេ
អ្នកអាចបកប្រែជាអវិជ្ជមានទ្វេដងនេះក្នុងទម្រង់វិជ្ជមាន។
"បុរសនេះជាមនុស្សអាក្រក់ ហើយយើងត្រូវនាំគាត់មករកអ្នកឲ្យទទួលទណ្ឌកម្ម"
នាំគាត់មកប្រគល់ឲ្យ
ឃ្លានៅទីនេះមានន័យថា ប្រគល់ទៅឲ្យសត្រូវ។
John 18:31
ព័ត៌មានទូទៅ:
នៅក្នុងខ៣២ មានការផ្អាកពីដំណើររឿងសំខាន់
នៅពេលអ្នកនិពន្ធប្រាប់យើងនូវប្រវត្តិអំពីរបៀប ដែលព្រះយេស៊ូបានទាយថា
ទ្រង់នឹងត្រូវគេសម្លាប់។
ពួកយូដានិយាយទៅកាន់គាត់ថា

generated on Wed Sep 10 16:16:32 2025

នៅទីនេះ "ពួកយូដា" ជាពាក្យប្រៀបធៀប សម្រាប់មេដឹកនាំសាសន៍យូដា ដែលបានប្រឆាំងនឹងព្រះយេស៊ូ ហើយបានចាប់ខ្លួនព្រះអង្គ។
"មេដឹកនាំសាសន៍យូដាបាននិយាយទៅកាន់ព្រះអង្គ"
វាមិនត្រឹមត្រូវតាមច្បាប់សម្រាប់យើងទេ ក្នុងការសម្លាប់អ្នកណាម្នាក់នោះ
យោងទៅតាមច្បាប់រ៉ូម៉ាំង ជនជាតិយូដាមិនអាចសម្លាប់បុរសម្នាក់បានទេ។ “ យោងទៅតាមច្បាប់រ៉ូម៉ាំងយើងមិនអាចសម្លាប់មនុស្សម្នាក់បានទេ”
ដើម្បីឲ្យព្រះបន្ទូលដែលព្រះយេស៊ូបានថ្លែងបានសម្រេច
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដើម្បីឲ្យសម្រេចតាមទំនាយ ដែលព្រះយេស៊ូមានបន្ទូលប្រាប់ជាមុន"
តាមសេចក្តីដែលព្រះអង្គបានមានបន្ទូលពីការ ដែលព្រះអង្គត្រូវសុគតយ៉ាងណា
"ទាក់ទងនឹងរបៀប ដែលព្រះអង្គនឹងសុគត"
John 18:33
ខ្ញុំមិនមែនជាសាសន៍យូដាទេ តើមែនទេ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ ដូច្នេះលោកពីឡាត់អាចបញ្ជាក់ពីការមិនចាប់អារម្មណ៍ទាំងស្រុងរបស់គាត់ ចំពោះវប្បធម៌របស់ជនជាតិយូដា។ "មែនហើយ ខ្ញុំពិតជាមិនមែនជាជនជាតិយូដាទេ ហើយខ្ញុំមិនចាប់អារម្មណ៍នឹងបញ្ហាទាំងនេះទេ!"
សាសន៍របស់អ្នកផ្ទាល់
"ជនជាតិយូដារបស់អ្នក"
John 18:36
ព្រះរាជ្យរបស់ខ្ញុំមិនមែនមកពីលោកីយ៍នេះទេ
នៅទីនេះ "លោកីយ" ជាពាក្យប្រៀបធៀប សម្រាប់មនុស្សដែលប្រឆាំងនឹងព្រះយេស៊ូ។ អាចមានន័យថា ១)“ នគររបស់ខ្ញុំមិនមែនជាពិភពលោកនេះទេ” ឬ ២)“ ខ្ញុំមិនត្រូវការការអនុញ្ញាតពីលោកនេះ ដើម្បីគ្រប់គ្រងជាស្តេចរបស់ពួកគេទេ” ឬ“ មិនមែនមកពីពិភពលោកនេះទេ ដែលខ្ញុំមានសិទ្ធិអំណាចធ្វើជាស្តេច” ។
ដើម្បីកុំឲ្យខ្ញុំត្រូវចាប់ប្រគល់ទៅឲ្យសាសន៍យូដាឡើយ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ហើយនឹងរារាំងមេដឹកនាំយូដាពីការចាប់ខ្លួនខ្ញុំ"
យូដា
នៅទីនេះ "ពួកយូដា" ជាការប្រៀបធៀប សំដៅទៅលើអ្នកដឹកនាំជនជាតិយូដា ដែលបានប្រឆាំងនឹងព្រះយេស៊ូ។
ខ្ញុំបានមកក្នុងលោកីយ៍នេះ
នៅទីនេះ“ លោកិយ” សំដៅទៅលើប្រជាជន ដែលរស់នៅលើពិភពលោក។
ធ្វើបន្ទាល់ចំពោះសេចក្តីពិត
ត្រង់នេះ“ សេចក្តីពិត” សំដៅទៅលើសេចក្តីពិតអំពីព្រះជាម្ចាស់។ ប្រាប់មនុស្សអំពីសេចក្តីពិតរបស់ព្រះជាម្ចាស់›
គ្រប់រូបដែលជាកម្មសិទ្ធិសេចក្តីពិត
នៅត្រង់នេះ សំដៅទៅលើអ្នកដែលស្រឡាញ់សេចក្តីពិតអំពីព្រះជាម្ចាស់។
សំឡេងរបស់ខ្ញុំ
នៅទីនេះ“ សំឡេង” សំដៅទៅលើពាក្យ ដែលព្រះយេស៊ូមានបន្ទូល។ “ អ្វីដែលខ្ញុំនិយាយ” ឬ“ ខ្ញុំ”
John 18:38
តើសេចក្តីពិតជាអ្វី?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ ដើម្បីឆ្លុះបញ្ចាំងពីជំនឿរបស់លោកពីឡាតថា គ្មាននរណាម្នាក់ដឹងថាសេចក្តីពិតជាអ្វីទេ។ រឿងគួរឲ្យអស់សំណើចនៅទីនេះ គឺថាព្រះយេស៊ូជាសេចក្តីពិត។ "គ្មាននរណាម្នាក់អាចដឹងថាអ្វីដែលជាការពិតទេ!"
យូដា
នៅទីនេះ "ពួកយូដា" សំដៅទៅលើអ្នកដឹកនាំជនជាតិយូដា ដែលប្រឆាំងនឹងព្រះយេស៊ូ។
មិនមែនបុរសនេះទេ ប៉ុន្តែសូមដោះលែងបារ៉ាបាសវិញ
អ្នកអាចបន្ថែមពាក្យដែលបង្កប់ន័យ។ "ទេ! កុំដោះលែងបុរសនេះ។ ដោះលែងបារ៉ាបាសជំនួសវិញ!"
លោកបារ៉ាបាសជាចោរប្លន់
នៅទីនេះយ៉ូហានប្រាប់ព័ត៌មានអំពីបារ៉ាបាស។

---

19 [1]បន្ទាប់មក លោកពីឡាតបានយកព្រះយេស៊ូហើយវាយព្រះអង្គនឹងខ្សែតី។[2]ទាហានបានពាក់មកុដបន្លា។ ពួកគេពាក់វានៅលើព្រះសិរសារបស់ព្រះយេស៊ូ
ហើយពាក់អាវពណ៌ស្វាយឲ្យព្រះអង្គ។[3]ពួកគេបានមករកព្រះអង្គ ហើយនិយាយថា៖ «សូមថ្វាយបង្គំ មហាក្សត្ររបស់យូដា!»។
[4]បន្ទាប់មក លោកពីឡាតបានចេញទៅក្រៅម្តងទៀត ហើយមានប្រសាសន៍ទៅពួកគេថា៖ «មើល ខ្ញុំបាននាំគាត់មកឲ្យអ្នករាល់គ្នាហើយ ដើម្បីឲ្យអ្នករាល់គ្នាដឹងថា
ខ្ញុំមិនឃើញថាគាត់មានកំហុសអ្វីទេ»។[5]ដូច្នេះ ព្រះយេស៊ូបានចេញមក ពាក់មកុដបន្លា និងអាវផាយពណ៌ស្វាយ។ លោកពីឡាតមានប្រសាសន៍ទៅពួកគេថា៖ «មើល
នេះណែ បុរសនេះហើយ!»[6]នៅពេលនាយកបូជាចារ្យ និងពួកអាជ្ញាធរបានឃើញព្រះយេស៊ូ ពួកគេស្រែកឡើង ហើយនិយាយថា៖ «ឆ្កាងវាទៅ ឆ្កាងវាទៅ!»
លោកពីឡាតមានប្រសាសន៍ទៅពួកគេថា៖ «យកគាត់ទៅឆ្កាងខ្លួនឯងទៅ ដ្បិត ខ្ញុំមិនឃើញថាគាត់មានកំហុសអ្វីទេ»។
[7]ពួកយូដាឆ្លើយទៅគាត់ថា៖ «យើងមានច្បាប់មួយ ហើយស្របតាមច្បាប់ដែលវាត្រូវស្លាប់ ដោយសារវាបានប្រកាសថា ជាបុត្រារបស់ព្រះជាម្ចាស់»។
[8]នៅពេលលោកពីឡាតបានឮប្រយោគនេះ គាត់រឹតតែខ្លាចខ្លាំងឡើងថែមទៀត[9]ហើយគាត់បានចូលទៅក្នុងទីស្នាក់ការកណ្តាលរដ្ឋាភិបាលវិញ
ហើយមានប្រសាសន៍ទៅព្រះយេស៊ូថា៖ «តើលោកមកពីណា?» ប៉ុន្តែ ព្រះយេស៊ូមិនបានឆ្លើយទៅគាត់ទេ។
[10]បន្ទាប់មក លោកពីឡាតមានប្រសាសន៍ទៅព្រះអង្គថា៖ «លោកមិននិយាយអ្វីជាមួយខ្ញុំទេឬអី? តើលោកដឹងទេថា ខ្ញុំមានអំណាចនឹងដោះលែងលោក
ហើយមានអំណាចនឹងឆ្កាងលោក?»[11]ព្រះយេស៊ូមានបន្ទូលឆ្លើយទៅគាត់ថា៖ «លោកគ្មានអំណាចអ្វីលើខ្ញុំទេ
លើកលែងតែអំណាចដែលបានប្រទានដល់លោកពីស្ថានសួគ៌។ ដូច្នេះហើយ អ្នកដែលប្រគល់ខ្ញុំមកឲ្យលោកជាមនុស្សមានបាបយ៉ាងធំ»។
[12]ពេលព្រះអង្គមានបន្ទូលឆ្លើយដូច្នេះ លោកពីឡាតចង់ដោះលែងព្រះអង្គ ប៉ុន្តែ ពួកយូដាស្រែកឡើង ហើយនិយាយថា៖ «ប្រសិនបើ លោកដោះលែងបុរសនេះ
លោកមិនមែនជាមិត្តសម្លាញ់របស់ស្តេចសេសាឡើយ»។[13]អស់អ្នកណាដែលតាំងខ្លួនឯងជាស្តេច និយាយទាស់នឹងស្តេចសេសាហើយ»។
នៅពេលលោកពីឡាតឮពាក្យទាំងនេះ គាត់បាននាំព្រះយេស៊ូចេញក្រៅ ហើយអង្គុយចុះនៅលើកៅអីជំនុំជម្រះ ដែលហៅថា៖ «ទៅលានក្រាលថ្ម» ប៉ុន្តែ
នៅក្នុងភាសាហេព្រើរហៅថា៖ «កាបាថា»។
[14]ពេលនេះ គឺជាពេលនៃការរៀបចំសម្រាប់ថ្ងៃបុណ្យរំលង ប្រហែលជាម៉ោងដប់ពីរថ្ងៃត្រង់។ លោកពីឡាតមានប្រសាសន៍ទៅកាន់ពួកយូដាថា៖ «មើល៍ នេះគឺជា
ស្តេចរបស់អ្នករាល់គ្នា»។[15]ពួកគេស្រែកឡើងថា៖ «ឆ្កាងវាទៅ! ឆ្កាងវាទៅ! ឆ្កាងវាទៅ!» លោកពីឡាតមានប្រសាសន៍ទៅពួកគេថា៖
«តើឲ្យខ្ញុំឆ្កាងស្តេចរបស់អ្នករាល់គ្នាមែនទេ?» នាយកបូជាចារ្យបានឆ្លើយថា៖ «យើងគ្មានស្តេចទេ មានតែស្តេចសេសាតែមួយគត់»។[16]នោះ
លោកពីឡាតបានប្រគល់ព្រះយេស៊ូទៅឲ្យពួកគេ ដើម្បីឆ្កាង។
[17]បន្ទាប់មក ពួកគេបាននាំព្រះយេស៊ូ ហើយព្រះអង្គបានចេញទៅក្រៅ ព្រះអង្គបានលីឈើឆ្កាងដោយព្រះអង្គផ្ទាល់ ទៅកន្លែងដែលហៅថា៖ «តំបន់លលាក្បាល» ដែល
នៅក្នុងភាសាហេព្រើរហៅថា៖ «គាល់កូថា»។[18]ពួកគេឆ្កាងព្រះយេស៊ូនៅទីនោះ ជាមួយបុរសពីរនាក់ទៀត ម្នាក់ម្ខាង ហើយព្រះយេស៊ូនៅចំកណ្តាល។
[19]លោកពីឡាតក៏សរសេរសញ្ញា ហើយដាក់នៅលើឈើឆ្កាង។ សញ្ញានោះសរសេរថា៖ «ព្រះយេស៊ូ អ្នកស្រុកណាសារ៉ែត ស្តេចរបស់សាសន៍យូដា»។
[20]សាសន៍យូដាជាច្រើនបានអានសញ្ញានេះ ដោយសារកន្លែងដែលព្រះយេស៊ូត្រូវឆ្កាងនោះ នៅជិតទីក្រុង។ សញ្ញានោះសរសេរជាភាសាហេព្រើរ ឡាទីន និងក្រិក។
[21]នោះ នាយកបូជាចារ្យរបស់សាសន៍យូដាមានប្រសាសន៍ទៅកាន់លោកពីឡាតថា៖ «សូមកុំសរសេរថា «ស្តេចរបស់សាសន៍យូដាអី» ផ្ទុយទៅវិញ
ចូរសរសេរដូច្នេះវិញថា៖ «អ្នកនេះនិយាយថា៖ «ខ្ញុំគឺជាស្តេចរបស់សាសន៍យូដា»។[22]លោកពីឡាតឆ្លើយថា៖ «ខ្ញុំសរសេរយ៉ាងម៉េច សរសេរអ៊ីចឹងហើយ!»។
[23]នៅពេលពួកទាហានឆ្កាងព្រះយេស៊ូ ពួកគេបានយកសម្លៀកបំពាក់របស់ព្រះយេស៊ូ បែងចែកជាបួនចំណែក ចែកគ្នាម្នាក់មួយចំណែកសម្រាប់ពួកគេ
រួមទាំងអាវផងដែរ។ ហើយអាវនោះ គ្មានថ្នេរ ជាក្រណាត់មួយដុំ តាំងពីលើដល់ក្រោម។[24]បន្ទាប់មក ពួកគេនិយាយទៅកាន់គ្នាទៅវិញទៅមកថា៖ «សូមយើងកុំហែកវាអី

generated on Wed Sep 10 16:16:32 2025

ប៉ុន្តែ ចូរយើងចាប់ឆ្នោតវិញ ដើម្បីសម្រេចថា តើអាវនេះនឹងបានទៅលើនរណា!»។ ការនេះកើតឡើង ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរដែលចែងថា៖
«ពួកគេបានបែងចែកសម្លៀកបំពាក់ទូលបង្គំនៅក្នុងចំណោមពួកគេ ហើយចាប់ឆ្នោត ដើម្បីយកសម្លៀកបំពាក់របស់ទូលបង្គំ»។ នេះគឺជាអ្វីដែលពួកទាហានបានធ្វើ។
[25]ព្រះមាតារបស់ព្រះយេស៊ូ ប្អូនស្រីមាតារបស់ព្រះអង្គ នាងម៉ារីភរិយារបស់លោកក្លូប៉ាស និងម៉ារីជាអ្នកក្រុងម៉ាក់ដាឡាកំពុងឈរនៅជិតឈើឆ្កាងរបស់ព្រះយេស៊ូ។
[26]នៅពេលព្រះយេស៊ូទតឃើញមាតារបស់ព្រះអង្គ ហើយសិស្សម្នាក់ដែលព្រះអង្គស្រឡាញ់កំពុងឈរនៅជិតនោះ ព្រះអង្គមានបន្ទូលទៅមាតារបស់ព្រះអង្គថា៖
«អ្នកម្តាយអើយ! មើល៍ នោះជាកូនរបស់អ្នកម្តាយហើយ»[27]បន្ទាប់មក ព្រះអង្គមានបន្ទូលទៅសិស្សថា៖ «មើល៍! នេះជាអ្នកម្តាយរបស់អ្នកហើយ» ចាត់ពីម៉ោងនោះមក
សិស្សរបស់ព្រះអង្គបានយកនាងទៅនៅផ្ទះរបស់គាត់ផ្ទាល់។
[28]បន្ទាប់ពីនេះ ទើបបានដឹងថាអ្វីៗបានសម្រេចហើយ ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរ ព្រះយេស៊ូមានបន្ទូលថា៖ «ខ្ញុំស្រេកទឹក»។
[29]មានក្រឡមួយពេញដោយទឹកខ្មេះបានដាក់នៅទីនោះ ដូច្នេះ ពួកគេបានយកសារាយស្ងួតរុំនឹងមែកហ៊ីសុបជ្រលក់ទឹកខ្មេះជោក រួចហុចដល់ព្រះឱស្ឋរបស់ព្រះអង្គ។
[30]នៅពេលយេស៊ូផឹកទឹកខ្មេះនោះហើយ ព្រះអង្គមានបន្ទូលថា៖ «សម្រេចហើយ»។
[31]បន្ទាប់មក សាសន៍យូដា ដោយព្រោះថ្ងៃនោះគឺជាថ្ងៃនៃការរៀបចំ ដូច្នេះ ពួកគេបានទុកឲ្យព្រះកាយរបស់ព្រះយេស៊ូនៅលើឈើឆ្កាងនៅក្នុងថ្ងៃសប្ប័ទទេ
(ដ្បិតថ្ងៃសប្ប័ទគឺជាថ្ងៃបុណ្យធំ) ពួកគេបានសូមលោកពីឡាត ដើម្បីបំបាក់ជើងរបស់ពួកគេ ហើយយកសាកសពរបស់ពួកគេចុះមក។[32]បន្ទាប់មក ពួកទាហានបានមកដល់
ហើយបំបាក់ជើងរបស់បុរសទីមួយ និងបំពាក់ជើងបុរសទីពីរ ដែលបានឆ្កាងជាមួយព្រះយេស៊ូ។[33]នៅពេលពួកគេមកដល់ព្រះយេស៊ូ ពួកគេឃើញថា
ព្រះអង្គសុគតរួចស្រេចបាត់ទៅហើយ ដូច្នេះ ពួកគេមិនបានបំបាក់ជើងរបស់ព្រះអង្គទេ។
[34]ប៉ុន្តែ មានទាហានម្នាក់បានចាក់ចំហៀងខ្លួនរបស់ព្រះអង្គជាមួយនឹងលំពែង ហើយរំពេចនោះឈាម និងទឹកបានហូរចេញមក។[35]ម្នាក់ដែលបានឃើញការនេះ
បានធ្វើបន្ទាល់ ហើយទីបន្ទាល់របស់គាត់គឺជាការពិត។ គាត់ដឹងថា អ្វីដែលគាត់និយាយគឺជាការពិត ដើម្បីឲ្យអ្នករាល់គ្នាអាចជឿដែរ។
[36]ដ្បិត ការទាំងអស់នេះ បានកើតឡើង ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរថា៖ «គ្មានឆ្អឹងណាមួយរបស់ព្រះអង្គត្រូវបានបាក់ឡើយ»។
[37]ក៏មានបទគម្ពីរផ្សេងទៀតបានចែងថា៖ «ពួកគេសម្លឹងមើលព្រះអង្គដែលត្រូវគេចាក់ទម្លុះ»។
[38]បន្ទាប់ពីការទាំងនេះហើយ លោកយ៉ូសែប អ្នកស្រុកអើរីម៉ាថេ គាត់ក៏ជាសិស្សម្នាក់របស់ព្រះយេស៊ូដែរ (ដោយសារខ្លាចពួកយូដា
គាត់មិនបង្ហាញថាជាសិស្សរបស់ព្រះអង្គទេ) បានសូមលោកពីឡាត ដើម្បីគាត់អាចនឹងយកព្រះសពរបស់ព្រះយេស៊ូបានឬអត់។
[39]លោកពីឡាតបានផ្តល់ការអនុញ្ញាតឲ្យគាត់។ ដូច្នេះ លោកយ៉ូសែបបានមក ហើយយកព្រះសពរបស់ព្រះអង្គទៅ។ លោកនីកូដេមក៏បានមកដែរ
គាត់គឺជាម្នាក់ដែលបានមករកព្រះយេស៊ូនៅពេលយប់មុនគេ។ គាត់បានយកជ័រល្វីងទេសលាយជាមួយគ្រឿងក្រអូប ប្រហែលជាហាសិបគីឡូក្រាម។
[40]ដូច្នេះ ពួកគេបានយកព្រះកាយរបស់ព្រះយេស៊ូ ហើយបានរុំព្រះកាយនោះនឹងក្រណាត់សរមួយដុំ ដូចទម្លាប់របស់សាសន៍យូដា ដើម្បីបញ្ចុះសព។
[41]នៅកន្លែងដែលគេឆ្កាងព្រះអង្គនោះ មានសួនមួយ ហើយនៅក្នុងសួននោះមានផ្នូរថ្មីមួយដែលគ្មាននរណាយកសពមកដាក់នៅឡើយទេ។
[42]ដោយសារថ្ងៃនោះជាថ្ងៃរៀបចំរបស់សាសន៍យូដា ហើយដោយសារផ្នូរនោះនៅជិតផង ពួកគេបានបញ្ចុះព្រះយេស៊ូនៅទីនោះទៅ។

John 19:1
ឃ្លាភ្ជាប់៖
បន្តផ្នែកនៃសាច់រឿងពីជំពូកមុន។ ព្រះយេស៊ូកំពុងតែឈរនៅមុខលោកពីឡាត់
ពេលទ្រង់ត្រូវពួកយូដាចោទប្រកាន់។
បន្ទាប់មក លោកពីឡាតបានយកព្រះយេស៊ូហើយវាយព្រះអង្គនឹងខ្សែតី
ពីឡាតពុំបានវាយព្រះយេស៊ូទេ។ នៅទីនេះ "លោកពីឡាត់" តំណាងឲ្យទាហាន
ដែលលោកពីឡាត់បានបញ្ជាឲ្យវាយព្រះយេស៊ូ។ “
លោកពីឡាតបានបញ្ជាឲ្យទាហានរបស់លោកវាយព្រះយេស៊ូ”
សូមថ្វាយបង្គំ មហាក្សត្ររបស់យូដា
ការសួរសុខទុក្ខ «ហារ» ដោយលើកដៃគេ ដើម្បីស្វាគមន៍សេសារ។
ពេលទាហានប្រើមកុដបន្លា និងអាវពណ៌ស្វាយចំអកដល់ព្រះយេស៊ូ
វាជារឿងគួរឲ្យហួសចិត្តដែលពួកគេមិនទទួលស្គាល់ថា
ទ្រង់ពិតជាស្តេចមួយអង្គទេ។
John 19:4
ខ្ញុំមិនឃើញថាគាត់មានកំហុសអ្វីទេ
លោកពីឡាតថ្លែងបែបនេះពីរដងដោយពោលថា
លោកមិនជឿថាព្រះយេស៊ូមានទោសអ្វីទេ។ គាត់មិនចង់ដាក់ទណ្ឌកម្មគាត់ទេ។
"ខ្ញុំមិនមានហេតុផលដាក់ទណ្ឌកម្មគាត់ទេ"
មកុដបន្លា និងអាវផាយពណ៌ស្វាយ
មកុដនិងអាវពណ៌ស្វាយជារបស់ ដែលមានតែស្តេចប៉ុណ្ណោះអាចពាក់។
ពួកទាហានស្លៀកពាក់របៀបនេះដើម្បីចំអកឲ្យព្រះយេស៊ូ។ សូមមើលជំពូក១៩ ខ១
។
John 19:7
ពួកយូដាឆ្លើយទៅគាត់ថា
នៅទីនេះ "ជនជាតិយូដា" សំដៅទៅលើមេដឹកនាំជនជាតិយូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។
"មេដឹកនាំជនជាតិយូដាបានឆ្លើយទៅលោកពីឡាត"
យើងមានច្បាប់មួយ ហើយស្របតាមច្បាប់ដែលវាត្រូវស្លាប់ ដោយសារវាបានប្រកាសថា
ជាបុត្រារបស់ព្រះជាម្ចាស់
ព្រះយេស៊ូត្រូវបានគេកាត់ទោសប្រហារជីវិត ដោយជាប់ឆ្កាង
ព្រោះទ្រង់បានអះអាងថា ទ្រង់ជា«ព្រះបុត្រារបស់ព្រះជាម្ចាស់»។
បុត្រារបស់ព្រះជាម្ចាស់
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់
John 19:10
លោកមិននិយាយអ្វីជាមួយខ្ញុំទេឬអី?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ។
នៅទីនេះលោកពីឡាតសម្តែងការភ្ញាក់ផ្អើល
ដែលថាព្រះយេស៊ូមិនឆ្លៀតឱកាសការពារខ្លួនទេ។ "ខ្ញុំមិនចង់ជឿថា
អ្នកបដិសេធមិននិយាយជាមួយខ្ញុំ" ឬ "ឆ្លើយខ្ញុំ!"
តើលោកដឹងទេថា ខ្ញុំមានអំណាចនឹងដោះលែងលោក ហើយមានអំណាចនឹងឆ្កាងលោក?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរ ដើម្បីបន្ថែមការសង្កត់ន័យ។
"អ្នកគួរតែដឹងថា ខ្ញុំអាចដោះលែងអ្នកឬបញ្ជាទាហានរបស់ខ្ញុំឆ្កាងអ្នក!"
អំណាច
នៅទីនេះ“ អំណាច” សំដៅទៅលើសមត្ថភាព ដែលអាចធ្វើអ្វីមួយ
ឬបង្កឲ្យមានអ្វីមួយកើតឡើង។
លោកគ្មានអំណាចអ្វីលើខ្ញុំទេ លើកលែងតែអំណាចដែលបានប្រទានដល់លោកពីស្ថានសួគ៌
អ្នកអាចបកប្រែអវិជ្ជមានទ្វេដងក្នុងទម្រង់វិជ្ជមាន និងកិរិយាសកម្ម។ “
អ្នកអាចធ្វើបាបខ្ញុំបាន ព្រោះព្រះជាម្ចាស់បានធ្វើឲ្យអ្នកមានអំណាចនេះ”
ពីស្ថានសួគ៌
នេះជាវិធីគួរឲ្យគោរព ដែលសំដៅទៅព្រះជាម្ចាស់។
ប្រគល់ខ្ញុំមកឲ្យ
ឃ្លានេះមានន័យថា ប្រគល់ទៅឲ្យសត្រូវ។
John 19:12
ពេលព្រះអង្គមានបន្ទូលឆ្លើយដូច្នេះ
ត្រង់នេះ“ ចម្លើយនេះ” សំដៅទៅលើចម្លើយរបស់ព្រះយេស៊ូ។
"ពេលពីឡាតឮចម្លើយរបស់ព្រះយេស៊ូ"
លោកពីឡាតចង់ដោះលែងព្រះអង្គ
ទម្រង់នៃការ«ព្យាយាម»នៅក្នុងឯកសារដើមបង្ហាញថា ពីឡាតបានព្យាយាម «ខំ»
ឬ «ដដែលៗ» ដើម្បីដោះលែងព្រះយេស៊ូ។ "គាត់បានព្យាយាមយ៉ាងខ្លាំង
ដើម្បីដោះលែងព្រះយេស៊ូ" ឬ "គាត់បានព្យាយាមម្តងហើយម្តងទៀត
ដើម្បីដោះលែងព្រះយេស៊ូ"
ប៉ុន្តែ ពួកយូដាស្រែកឡើង
នៅទីនេះ "យូដា" សំដៅទៅលើអ្នកដឹកនាំជនជាតិយូដា
ដែលប្រឆាំងនឹងព្រះយេស៊ូ។ នៅក្នុងច្បាប់ដើមទម្រង់នៃការ "ស្រែក" បង្ហាញថា
ពួកគេស្រែក ឬស្រែកម្តងហើយម្តងទៀត។ “
តែពួកមេដឹកនាំសាសន៍យូដានៅតែបន្តស្រែក”

generated on Wed Sep 10 16:16:32 2025

លោកមិនមែនជាមិត្តសម្លាញ់របស់ស្តេចសេសាឡើយ
"អ្នកកំពុងប្រឆាំងសេសារ" ឬ "អ្នកកំពុងប្រឆាំងនឹងអធិរាជ"
តាំងខ្លួនឯងជាស្តេច
"អះអាងថាគាត់ជាស្តេច"
គាត់បាននាំព្រះយេស៊ូចេញក្រៅ
នៅទីនេះ "គាត់" សំដៅទៅលើលោកពីឡាត និងជាអ្នករួមគំនិត
"លោកពីឡាត់បានបញ្ជាទាហាន" ។ “
គាត់បានបញ្ជាឲ្យទាហាននាំព្រះយេស៊ូចេញមក”
អង្គុយចុះ
មនុស្សសំខាន់ដូចជាលោកពីឡាតបានអង្គុយ
នៅពេលពួកគេបំពេញភារកិច្ចជាផ្លូវការ រឺមនុស្សដែលមិនសូវសំខាន់ក្រោកឈរ។
នៅលើកៅអីជំនុំជម្រះ
នេះជាកៅអីពិសេស ដែលមនុស្សសំខាន់ដូចជាលោកពីឡាត់អង្គុយ
ពេលគាត់ធ្វើការកាត់ទោសជាផ្លូវការ។ បើភាសារបស់អ្នកមានវិធីពិសេសជាងនេះ
ដើម្បីពិពណ៌នាអំពីសកម្មភាពនេះ អ្នកអាចប្រើវានៅទីនេះបាន។
ហៅថា៖ «ទៅលានក្រាលថ្ម»
នេះជាវេទិកាដែលមានថ្មពិសេសមួយ ដែលមានតែមនុស្សសំខាន់ប៉ុណ្ណោះ
ដែលត្រូវបានអនុញ្ញាតឲ្យទៅ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។"នៅកន្លែងមួយដែលប្រជាជនហៅថា
លានក្រាលថ្ម"
ភាសាហេប្រឺ
សំដៅទៅលើភាសា ដែលប្រជាជនអ៊ីស្រាអែលបាននិយាយ។
John 19:14
ឃ្លាភ្ជាប់៖
ពេលវេលាបានកន្លងផុតទៅហើយ ឥឡូវនេះម៉ោងដប់ពីរថ្ងៃត្រង់
ហើយពីឡាតបញ្ជាឲ្យទាហានរបស់គាត់ឆ្កាងព្រះយេស៊ូ។
ពេលនេះ
ពាក្យនេះសម្គាល់ការផ្អាកនៅក្នុងដំណើររឿង
ដូច្នេះយ៉ូហាអាចផ្តល់ព័ត៌មានអំពីបុណ្យចម្លង ដែលនឹងមកដល់
និងពេលវេលាថ្ងៃនេះ។
ម៉ោងដប់ពីរថ្ងៃត្រង់
"អំពីពេលថ្ងៃត្រង់"
លោកពីឡាតមានប្រសាសន៍ទៅកាន់ពួកយូដាថា
នៅទីនេះ "យូដា" សំដៅទៅលើអ្នកដឹកនាំជនជាតិយូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។
"ពីឡាតបាននិយាយទៅកាន់មេដឹកនាំជនជាតិយូដា"
តើឲ្យខ្ញុំឆ្កាងស្តេចរបស់អ្នករាល់គ្នាមែនទេ?
នៅទីនេះ "ខ្ញុំ" សំដៅទៅលើទាហានរបស់លោកពីឡាត ដែលនឹងឆ្កាងព្រះអង្គ។
"តើអ្នកពិតជាចង់ឲ្យខ្ញុំប្រាប់ទាហានរបស់ខ្ញុំ
ឲ្យឆ្កាងស្តេចរបស់អ្នកនៅលើឈើឆ្កាងឬ?"
នោះ លោកពីឡាតបានប្រគល់ព្រះយេស៊ូទៅឲ្យពួកគេ ដើម្បីឆ្កាង
នៅទីនេះ លោកពីឡាតចេញបញ្ជាឲ្យទាហានឆ្កាងព្រះយេស៊ូ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ដូច្នេះលោកពីឡាតបានបញ្ជាទាហានឲ្យឆ្កាងព្រះយេស៊ូ"
John 19:17
ទៅកន្លែងដែលហៅថា៖ «តំបន់លលាក្បាល»
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ទៅកាន់កន្លែងដែលប្រជាជនហៅថា
«តំបន់លលាដ៏ក្បាល»
ដែលនៅក្នុងភាសាហេព្រើរហៅថា៖ «គាល់កូថា»
ហេប្រឺជាភាសារបស់ប្រជាជនអ៊ីស្រាអែល។ អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"តាមភាសាហេប្រឺ ពួកគេហៅថា 'គាល់កូថា" ។
ជាមួយបុរសពីរនាក់ទៀត
អាចបកប្រែពាក្យនេះបន្ថែមពាក្យដែលបង្កប់ន័យ។
"ពួកគេក៏បានឆ្កាងឧក្រិដ្ឋជនពីរនាក់ទៀត នៅលើឈើឆ្កាង។
John 19:19
លោកពីឡាតក៏សរសេរសញ្ញា ហើយដាក់នៅលើឈើឆ្កាង
នៅទីនេះ "លោកពីឡាត" ជាមនុស្សឲ្យគេសរសេរនៅលើសញ្ញានេះ។ នៅទីនេះ
"នៅលើឈើឆ្កាង" សំដៅទៅលើឈើឆ្កាងរបស់ព្រះយេស៊ូ។
«ពីឡាតក៏បានបញ្ជាឲ្យមនុស្សម្នាក់ សរសេរលើសញ្ញាសម្គាល់មួយ
ហើយភ្ជាប់វានៅលើឈើឆ្កាងរបស់ព្រះយេស៊ូផងដែរ»
សញ្ញានោះសរសេរថា៖ «ព្រះយេស៊ូ អ្នកស្រុកណាសារ៉ែត ស្តេចរបស់សាសន៍យូដា»
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដូច្នេះ មនុស្សនោះបានសរសេរពាក្យថា:
ព្រះយេស៊ូ អ្នកស្រុកណាសារ៉ែតជាស្តេចរបស់ជនជាតិយូដា"
កន្លែងដែលព្រះយេស៊ូត្រូវឆ្កាង
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ កន្លែងដែលពួកទាហានបានឆ្កាងព្រះយេស៊ូ”
សញ្ញានោះសរសេរជាភាសាហេប្រឺ ឡាទីន និងក្រិក
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ អ្នកដែលបានរៀបចំសញ្ញាសម្គាល់នេះ
បានសរសេរពាក្យនេះជា ៣ ភាសាគឺហេប្រឺ ឡាតាំង និងក្រិក”
ឡាតាំង
នេះជាភាសារបស់រដ្ឋាភិបាលរ៉ូម៉ាំង។
John 19:21
នោះ នាយកបូជាចារ្យរបស់សាសន៍យូដាមានប្រសាសន៍ទៅកាន់លោកពីឡាតថា
ពួកនាយកបូជាចារ្យត្រឡប់ទៅទីស្នាក់ការរបស់លោកពីឡាត
ដើម្បីតវ៉ានឹងលោកអំពីពាក្យ ដែលមាននៅលើស្លាកសម្គាល់នោះ។
"ពួកនាយកបូជាចារ្យបានត្រឡប់ទៅជួបលោកពីឡាតវិញ
ហើយមានប្រសាសន៍ថា"
ខ្ញុំសរសេរយ៉ាងម៉េច សរសេរអ៊ីចឹងហើយ!»
លោកពីឡាត់បានបញ្ជាក់ថា
គាត់នឹងមិនផ្លាស់ប្តូរពាក្យនៅលើសញ្ញាសម្គាល់នោះទេ។
"ខ្ញុំបានសរសេរអ្វីដែលខ្ញុំចង់សរសេរហើយ ខ្ញុំនឹងមិនផ្លាស់ប្តូរទេ!"
John 19:23
ព័ត៌មានទូទៅ:
នៅចុងបញ្ចប់នៃខ២៤
មានការផ្អាកពីដំណើររឿងសំខាន់ពេលយ៉ូហានប្រាប់យើងពីរបៀប
ដែលព្រឹត្តិការណ៍នេះបានធ្វើឲ្យព្រះគម្ពីរបានសម្រេច ។
រួមទាំងអាវផងដែរ
ហើយពួកគេក៏បានយកអាវធំរបស់ព្រះអង្គ ទៅជាមួយផងដែរ។
ពួកទាហានបានទុកអាវយឺតនេះ ដាច់ដោយឡែកពីគ្នា ហើយមិនបែងចែកវាឡើយ។
"ហើយពួកគេបានរក្សាអាវរបស់ព្រះអង្គដាច់ដោយឡែកពីគ្នា"
ចូរយើងចាប់ឆ្នោតវិញ ដើម្បីសម្រេចថា តើអាវនេះនឹងបានទៅលើនរណា
ទាហាននឹងលេងល្បែង ហើយអ្នកឈ្នះនឹងទទួលបានអាវ។
"សូមឲ្យយើងលេងល្បែងចាប់អាវយឺត
ហើយអ្នកឈ្នះនឹងទទួលបានដើម្បីរក្សាវាទុក"
ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរដែលចែងថា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ការនេះបានសម្រេចតាមបទគម្ពីរដែលចែងថា" ឬ "រឿងនេះបានកើតឡើង
ដើម្បីឲ្យសម្រេចតាមបទគម្ពីរដែលបានចែងទុក"
ចាប់ឆ្នោត
ជារបៀបដែលពួកទាហានចែកសម្លៀកបំពាក់របស់ព្រះយេស៊ូ ក្នុងចំណោមពួកគេ។
"ពួកគេបានលេងល្បែង"
John 19:25
សិស្សម្នាក់ដែលព្រះអង្គស្រឡាញ់
គឺយ៉ូហានដែលជាអ្នកនិពន្ធសៀវភៅដំណឹងល្អនេះ។
មើល៍ នោះជាកូនរបស់អ្នកម្តាយហើយ
ពាក្យថា "កូន" ជាពាក្យប្រៀបធៀប។ ព្រះយេស៊ូចង់ឲ្យ សិស្សរបស់ព្រះអង្គ
គឺយ៉ូហានធ្វើជាកូនប្រុសរបស់ម្តាយព្រះអង្គ។ “ នាងអើយ នេះគឺជាបុរស
ដែលនឹងធ្វើដូចជាកូនប្រុសរបស់អ្នក”
មើល៍! នេះជាអ្នកម្តាយរបស់អ្នកហើយ
ពាក្យថា "ម្តាយ" ជាពាក្យប្រៀបធៀប។ ព្រះយេស៊ូចង់ឲ្យ ម្តាយរបស់ព្រះអង្គ
ធ្វើដូចជាម្តាយរបស់យ៉ូហាន ដែលជាសិស្សរបស់ព្រះអង្គ។ "គិតពីស្ត្រីម្នាក់នេះ
ដូចជានាងជាម្តាយរបស់អ្នកផ្ទាល់"
ចាត់ពីម៉ោងនោះមក
"ចាប់ពីពេលនោះមក"
John 19:28
ទើបបានដឹងថាអ្វីៗបានសម្រេចហើយ ដើម្បីឲ្យបានសម្រេច
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ ទ្រង់ជ្រាបថា ព្រះអង្គបានធ្វើអ្វីគ្រប់យ៉ាង
ដែលព្រះបិតាបានចាត់ឲ្យព្រះអង្គធ្វើ”
មានក្រឡមួយពេញដោយទឹកខ្មេះបានដាក់នៅទីនោះ

generated on Wed Sep 10 16:16:32 2025

អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "មានគេដាក់ទឹកខ្មេះពេញមួយក្រឡនៅទីនោះ"
ទឹកខ្មេះ
"ស្រាជូរចត់"
ពួកគេបានយក
នៅទីនេះ "ពួកគេ" សំដៅទៅលើឆ្មាំរ៉ូម៉ាំង។
សារាយសួត
វត្ថុតូចមួយដែលអាចត្រាំនិងទប់ទឹកបានច្រើន
មែកហ៊ីសុប
"នៅលើមែករបស់រុក្ខជាតិ ដែលគេហៅថាហ៊ីបសុប"
ព្រះអង្គមានបន្ទូលថា៖ «សម្រេចហើយ»
យ៉ូហានបញ្ជាក់ត្រង់នេះថា ព្រះយេស៊ូបានប្រគល់វិញ្ញាណទៅព្រះជាម្ចាស់វិញ។ “
ទ្រង់បានឱនក្បាលហើយថ្វាយវិញ្ញាណដល់ព្រះជាម្ចាស់” ឬ“
ទ្រង់បានឱនក្បាលចុះហើយសុគត”
John 19:31
សាសន៍យូដា
នៅទីនេះ "ជនជាតិយូដា" សំដៅទៅលើមេដឹកនាំជនជាតិយូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។ "មេដឹកនាំសាសន៍យូដា"
ថ្ងៃនៃការរៀបចំ
ជាពេលវេលាមុនបុណ្យចម្លង ពេលមនុស្សរៀបចំម្ហូបសម្រាប់បុណ្យចម្លង។
ដើម្បីបំបាក់ជើងរបស់ពួកគេ ហើយយកសាកសពរបស់ពួកគេចុះមក
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ បំបាក់ជើងបុរសដែលត្រូវគេប្រហារជីវិត
ហើយយកសាកសពរបស់ពួកគេចុះពីឈើឆ្កាង›
បុរសទីពីរ ដែលបានឆ្កាងជាមួយព្រះយេស៊ូ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "អ្នកដែលគេបានឆ្កាងនៅក្បែរព្រះយេស៊ូ"
John 19:34
ម្នាក់ដែលបានឃើញការនេះ
ប្រយោគនេះផ្តល់ព័ត៌មានសំខាន់ក្នុងសាច់រឿង។ យ៉ូហានកំពុងប្រាប់អ្នកអានថា
គាត់នៅទីនោះ ហើយយើងអាចជឿជាក់លើអ្វីដែលគាត់បានសរសេរ។
បានធ្វើបន្ទាល់ ហើយទីបន្ទាល់របស់គាត់គឺជាការពិត
ដើម្បី "ផ្តល់សក្ខីកម្ម" មានន័យថា ត្រូវប្រាប់អំពីអ្វីមួយដែលអ្នកបានឃើញ។
"បានប្រាប់ការពិតអំពីអ្វីដែលគាត់បានឃើញ"
ដើម្បីឲ្យអ្នករាល់គ្នាអាចជឿដែរ
ត្រង់នេះ“ ជឿ” មានន័យថាការដាក់សេចក្តីទុកចិត្តរបស់មនុស្សម្នាក់លើព្រះយេស៊ូ។
"ដូច្នេះអ្នកក៏នឹងដាក់ជំនឿចិត្តលើព្រះយេស៊ូ"
John 19:36
ព័ត៌មានទូទៅ:
នៅក្នុងខទាំងនេះមានការផ្អាកពីដំណើររឿងសំខាន់
ដូចយ៉ូហានប្រាប់យើងអំពីរបៀប
ដែលព្រឹត្តិការណ៍ទាំងនេះបានធ្វើឲ្យព្រះគម្ពីរបានសម្រេច។
ដើម្បីឲ្យបានសម្រេចតាមបទគម្ពីរថា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ដើម្បីធ្វើឲ្យបានសម្រេចពាក្យ
ដែលមាននរណាម្នាក់បានសរសេរនៅក្នុងបទគម្ពីរ"
គ្មានឆ្អឹងណាមួយរបស់ព្រះអង្គត្រូវបានបាក់ឡើយ
នេះជាការដកស្រង់ពីកណ្ឌគម្ពីរទំនុកតម្កើងជំពូក៣៤
អ្នកអាចបកប្រែក្នុងទម្រង់កិរិយាសកម្ម។
"គ្មាននរណាម្នាក់នឹងបំបាក់ឆ្អឹងណាមួយរបស់ព្រះអង្គទេ"
ពួកគេសម្លឹងមើលព្រះអង្គដែលត្រូវគេចាក់ទម្លុះ
នេះជាការដកស្រង់ចេញពីកណ្ឌគម្ពីរសាការីជំពូក១២ ។
John 19:38
លោកយ៉ូសែប អ្នកស្រុកអើរីម៉ាថេ
អើរីម៉ាថេ ជាទីក្រុងតូចមួយ។ "យ៉ូសែបមកពីទីក្រុងអារីម៉ាថេ"
ដោយសារខ្លាចពួកយូដា
នៅទីនេះ "ជនជាតិយូដា" ជាមេដឹកនាំជនជាតិយូដា
ដែលបានប្រឆាំងនឹងព្រះយេស៊ូ។ "ដោយខ្លាចមេដឹកនាំយូដា"
បានសូមលោកពីឡាត ដើម្បីគាត់អាចនឹងយកព្រះសពរបស់ព្រះយេស៊ូ
យ៉ូហានបញ្ជាក់ថា យ៉ូសែបអារីម៉ាថេចង់បញ្ចុះព្រះសពរបស់ព្រះយេស៊ូ។ “
ដើម្បីទទួលបានការអនុញ្ញាតឲ្យយកព្រះសពរបស់ព្រះយេស៊ូ
ចុះពីឈើឆ្កាងដើម្បីបញ្ចុះ”
លោកនីកូដេម
នីកូដេមជាពួកផារីស៊ីម្នាក់ ដែលបានជឿលើព្រះយេស៊ូ។ សូមមើលពីររបៀប
ដែលអ្នកបានបកប្រែនៅក្នុងជំពូក៣ ខ ១។
ជ័រល្វីងទេសលាយជាមួយគ្រឿងក្រអូប
ទាំងនេះជាគ្រឿងក្រអូប ដែលមនុស្សប្រើដើម្បីរៀបចំសាកសពទៅបញ្ចុះ។
ហាសិបគីឡូក្រាម
"១០០"
គីឡូក្រាម
"គីឡូក្រាម" ជារង្វាស់នៃទំងន់ស្មើនឹង៣១ក្រាម។ សូមមើលពីររបៀប
ដែលអ្នកបានបកប្រែនៅក្នុងជំពូក១២ ខ១ ។
John 19:40
នៅកន្លែងដែលគេឆ្កាងព្រះអង្គនោះ មានសួនមួយ
ហើយនៅក្នុងសួននោះមានផ្នូរថ្មីមួយដែលគ្មាននរណាយកសពមកដាក់នៅឡើយទេ
នៅទីនេះយ៉ូហានកំណត់ការផ្អាកនៅក្នុងដំណើររឿង
ដើម្បីផ្តល់ព័ត៌សំខាន់ពីទីតាំងទីបញ្ចុះសព ដែលពួកគេនឹងបញ្ចុះសពព្រះយេស៊ូ។
នៅកន្លែងដែលគេឆ្កាងព្រះអង្គនោះ មានសួនមួយ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ នៅកន្លែងដែលគេឆ្កាងព្រះយេស៊ូនោះ
មានសួនច្បារមួយ”
ដែលគ្មាននរណាយកសពមកដាក់នៅឡើយទេ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"មិនដែលបានបញ្ចុះសពនរណាម្នាក់នៅទីនោះឡើយ"
ដោយសារថ្ងៃនោះជាថ្ងៃរៀបចំរបស់សាសន៍យូដា
យោងទៅតាមច្បាប់យ៉ូដា គ្មាននរណាម្នាក់អាចធ្វើការបានទេ
បន្ទាប់ពីថ្ងៃលិចនៅថ្ងៃសុក្រ។ នោះជាថ្ងៃចាប់ផ្តើមនៃថ្ងៃសប្ប័ទ និងបុណ្យចម្លង “
បុណ្យចម្លងនឹងមកដល់ពេលល្ងាច”

---

20 [1]នៅព្រឹកព្រលឹមនៅថ្ងៃទីមួយនៃសប្តាហ៍ កាលនៅងងឹតនៅឡើយ នាងម៉ារី អ្នកស្រុកម៉ាដាឡា បានមកឯផ្នូរ ហើយឃើញថ្មដែលបិទផ្នូរចំហរពីផ្នូរ។[2]ដូច្នេះ នាងក៏រត់
ហើយទៅរកលោកស៊ីម៉ូនពេត្រុស ហើយទៅរកសិស្សម្នាក់ទៀតដែលស្រឡាញ់ព្រះអង្គ ហើយនាងនិយាយទៅកាន់ពួកគេថា៖
«ពួកគេយកព្រះអម្ចាស់ពីផ្នូរទៅបាត់ហើយ យើងមិនដឹងថាពួកគេយកព្រះអង្គទៅដាក់នៅទីណាទេ»។
[3]នោះ លោកពេត្រុស និងសិស្សម្នាក់ទៀតបានចេញទៅ ហើយពួកគេបានទៅដល់ផ្នូរ។[4]ពួកគេទាំងពីរបានរត់ជាមួយគ្នា
ហើយសិស្សម្នាក់ទៀតរត់លឿនជាងទៅមុខលោកពេត្រុស ហើយបាននៅដល់ផ្នូរមុន។[5]បន្ទាប់មក ឱនមើល គាត់បានឃើញក្រណាត់សរនៅទីនោះ ប៉ុន្តែ
គាត់មិនបានចូលទៅខាងក្នុងទេ។
[6]បន្ទាប់មកលោកស៊ីម៉ូនពេត្រុសក៏មកដល់ ហើយបានចូលទៅក្នុងផ្នូរ។ គាត់ក៏បានឃើញក្រណាត់សរនៅទីនោះដែរ។
និងជាក្រណាត់ដែលនៅលើព្រះសិរសារបស់ព្រះអង្គ។[7]ក្រណាត់នោះបាននៅជាមួយនឹងក្រណាត់សម្លៀកបំពាក់ ប៉ុន្តែ រមូរនៅកន្លែងមួយដោយឡែក។
[8]បន្ទាប់មក សិស្សម្នាក់ទៀត ម្នាក់ដែលមកដល់ផ្នូរមុនគេ ក៏ចូលទៅក្នុងដែរ ហើយគាត់បានឃើញ ហើយក៏ជឿ។[9]ដ្បិត រហូតមកដល់ពេលនេះ ពួកគេនៅតែមិនដឹងបទគ
ម្ពីរដែលថា ព្រះអង្គនឹងរស់ពីស្លាប់ឡើងវិញ។[10]ដូច្នេះ ពួកសិស្សក៏ត្រឡប់ទៅផ្ទះវិញ។
[11]ប៉ុន្តែ នាងម៉ារីដែលកំពុងឈរយំនៅខាងក្រៅផ្នូរ។ ក្នុងកាលដែលនាងកំពុងនៅយំនៅឡើយ នាងបានឈ្ងោកមើលទៅក្នុងផ្នូរ។
[12]នាងបានឃើញទេវតាពីរនាក់ក្នុងសម្លៀកបំពាក់សអង្គុយនៅទីនោះ ម្នាក់អង្គុយនៅខាងក្បាល ម្នាក់ទៀតអង្គុយនៅខាងចុងជើង នៅកន្លែងដែលគេបានដាក់ព្រះយេស៊ូ។
[13]ពួកគេបាននិយាយទៅនាងថា៖ «នាងអើយ ហេតុអ្វីបានជានាងយំ?» នាងឆ្លើយទៅពួកគេថា៖ «ដោយសារគេយកព្រះជាម្ចាស់របស់ខ្ញុំម្ចាស់ទៅបាត់ហើយ
ហើយខ្ញុំមិនដឹងថា ពួកគេយកព្រះអង្គទៅដាក់នៅទីណាទេ»។

generated on Wed Sep 10 16:16:32 2025

[14]នៅពេលនាងឃើញការនេះ នាងបានបែរក្រោយ ហើយឃើញព្រះយេស៊ូកំពុងឈរនៅទីនោះ ប៉ុន្តែ នាងមិនស្គាល់ថា ជាព្រះយេស៊ូទេ។[15]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «នាងអើយ ហេតុអ្វីបានជានាងយំដូច្នេះ? តើនាងកំពុងស្វែងរកនរណា?» នាងស្មានថា ព្រះអង្គជាអ្នកថែសួន ដូច្នេះ នាងបានទូលឆ្លើយទៅព្រះអង្គថា៖ «លោកអើយ ប្រសិនបើ លោកបានយកព្រះអង្គទៅ សូមប្រាប់ខ្ញុំផងថា លោកទុកព្រះអង្គនៅទីណា ខ្ញុំនឹងទៅយកព្រះអង្គ»។
[16]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «ម៉ារីអើយ»។ នាងបានបែរមករក ហើយឆ្លើយទៅព្រះអង្គវិញជាភាសាហេព្រើរថា៖ «រ៉ាប៊ូនី» ប្រែថា (លោកគ្រូ)។
[17]ព្រះយេស៊ូមានបន្ទូលទៅនាងថា៖ «កុំប៉ះខ្ញុំអី ដើម្បីខ្ញុំមិនទាន់ឡើងទៅព្រះបិតាខ្ញុំនៅឡើយទេ ប៉ុន្តែ ខ្ញុំនឹងទៅបងប្អូនខ្ញុំ ហើយនិយាយទៅកាន់ពួកគេថា ខ្ញុំនឹងឡើងទៅឯព្រះបិតារបស់ខ្ញុំ និងជាបិតារបស់អ្នក ហើយព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់អ្នកដែរ»។[18]នាងម៉ារីអ្នកស្រុកម៉ាដាឡាបានមក ហើយប្រាប់ដល់ពួកសិស្សថា៖ «ខ្ញុំបានឃើញព្រះអម្ចាស់» ហើយប្រាប់ថា ព្រះអង្គមានបន្ទូលសេចក្តីទាំងនេះមកនាង។
[19]នៅពេលល្ងាច ថ្ងៃនោះ គឺជាថ្ងៃទីមួយនៃសប្តាហ៍ ទ្វារផ្ទះដែលពួកសិស្សនៅបានបិទ ព្រោះខ្លាចពួកយូដា ព្រះយេស៊ូបានយាងចូល ហើយឈរនៅក្នុងចំកណ្តាលពួកគេ ហើយមានបន្ទូលទៅពួកគេថា៖ «សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្តីសុខសាន្ត»។[20]បន្ទាប់ពីព្រះអង្គមានបន្ទូលរួចហើយ ព្រះអង្គបានបង្ហាញព្រះហស្តរបស់ព្រះអង្គដល់ពួកគេ និងចំហៀងខ្លួនរបស់ព្រះអង្គដែរ។ ពួកសិស្សមានអំណរ នៅពេលពួកគេបានឃើញព្រះអម្ចាស់។
[21]បន្ទាប់មក ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត។ ព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំក៏ចាត់អ្នករាល់ឲ្យចេញទៅយ៉ាងនោះដែរ»។[22]នៅពេលព្រះយេស៊ូមានបន្ទូលរួចហើយ ព្រះអង្គបានផ្លុំខ្យល់ដង្ហើមលើពួកគេ ហើយមានបន្ទូលទៅពួកគេថា៖ «ចូរទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។[23]ប្រសិនបើ អ្នករាល់គ្នាអត់ទោសឲ្យអ្នកណា ពួកគេនឹងបានទទួលការអត់ទោស តែប្រសិនបើ អ្នករាល់គ្នាមិនអត់ទោសទេ ពួកគេក៏មិនអាចទទួលការអត់ទោសដែរ»។
[24]លោកថូម៉ាស ជាម្នាក់នៃសិស្សទាំងដប់ពីរ ហៅថា ឌីឌីមមិនបាននៅជាមួយពួកគេ នៅពេលព្រះយេស៊ូយាងមក។[25]ក្រោយមក មានសិស្សម្នាក់ទៀតទូលទៅកាន់ព្រះអង្គថា៖ «យើងបានឃើញព្រះអម្ចាស់»។ គាត់និយាយទៅកាន់ពួកគេថា៖ «ប្រសិនបើ ខ្ញុំមិនឃើញព្រះហស្តដែលដំដោយដែកគោល ហើយដាក់ម្រាមដៃទៅប៉ះចំហៀងខ្លួនរបស់ព្រះអង្គនោះទេ ខ្ញុំនឹងមិនជឿទេ»។
[26]ប្រាំបីថ្ងៃក្រោយមក ពួកសិស្សរបស់ព្រះអង្គនៅខាងក្នុងផ្ទះម្តងទៀត ហើយលោកថូមាសបាននៅជាមួយពួកគេដែរ។ ព្រះយេស៊ូបានយាងមក ក្នុងពេលដែលទ្វារបានបិទនៅឡើយ ហើយគង់នៅក្នុងកណ្តាលចំណោមពួកគេ ហើយមានបន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្តីសុខសាន្ត»។[27]បន្ទាប់មក ព្រះអង្គមានបន្ទូលទៅលោកថូម៉ាសថា៖ «ចូរយកម្រាមដៃរបស់អ្នកមកដាក់នៅត្រង់នេះ ហើយមើលដៃខ្ញុំចុះ។ ចូរហុចដៃរបស់អ្នកមកត្រង់នេះ ហើយដាក់វាចូរមកក្នុងចំហៀងខ្លួនរបស់ខ្ញុំចុះ។ ចូរជឿ កុំធ្វើជាអ្នកមិនជឿឡើយ»។
[28]លោកថូម៉ាសបានឆ្លើយ ហើយទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់របស់ខ្ញុំ ព្រះជាម្ចាស់របស់ខ្ញុំ»។[29]ព្រះយេស៊ូមានបន្ទូលទៅកាន់គាត់ថា៖ «អ្នកជឿ ដោយសារអ្នកបានឃើញខ្ញុំ។ មានពរហើយ អស់អ្នកណាដែលជឿ ដោយមើលមិនឃើញ»។
[30]ព្រះយេស៊ូបានធ្វើទីសម្គាល់ជាច្រើន នៅក្នុងចំណោមពួកសិស្ស ទីសម្គាល់ជាច្រើនទៀតដែលបានសរសេរនៅក្នុងសៀវភៅនេះ[31]ប៉ុន្តែ ទីសម្គាល់ដែលបានកត់ត្រាទាំងនោះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូគឺជាព្រះគ្រិស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងដើម្បីឲ្យអ្នករាល់គ្នាបានជឿ ហើយដើម្បីឲ្យអ្នកមានជីវិតនៅក្នុងព្រះនាមព្រះអង្គ។

John 20:1
ព័ត៌មានទូទៅ:
នេះជាថ្ងៃទីបី បន្ទាប់ពីព្រះយេស៊ូត្រូវគេបញ្ចុះ។
នៅថ្ងៃទីមួយនៃសប្តាហ៍
"ថ្ងៃអាទិត្យ"
ឃើញថ្មដែលបិទផ្នូរចំហរពីផ្នូរ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ " នាងបានឃើញមានគេបានប្រមៀលថ្មចេញ"
សិស្សម្នាក់ទៀតដែលស្រឡាញ់ព្រះអង្គ
ឃ្លានេះហាក់ដូចជាយ៉ូហានសំដៅទៅលើខ្លួនគាត់ ក្នុងកណ្ឌគម្ពីរនេះ។
ត្រង់នេះពាក្យថា ស្រឡាញ់គឺសំដៅទៅលើការស្រឡាញ់គ្នាជាបងប្អូន
ឬសេចក្តីស្រឡាញ់ចំពោះមិត្តភក្តិ ឬសមាជិកគ្រួសារ។
ពួកគេយកព្រះអម្ចាស់ពីផ្នូរទៅបាត់ហើយ
ម៉ារីម៉ាក់ដាឡាគិតថា មាននរណាម្នាក់លួចយកសពរបស់ព្រះអម្ចាស់។ "
មានគេយកសពរបស់ព្រះអម្ចាស់ចេញពីផ្នូរ"
John 20:3
សិស្សម្នាក់ទៀត
យ៉ូហានទំនងជាបង្ហាញលក្ខណៈបន្ទាយខ្លួន
ដោយសំដៅទៅលើខ្លួនគាត់នៅទីនេះថាជា" សិស្សម្នាក់"
ជាជាងរាប់បញ្ចូលឈ្មោះរបស់គាត់។
ចេញទៅ
យ៉ូហានបញ្ជាក់ថា ពួកសិស្សទាំងនេះបានទៅផ្នូរ។ " ប្រញាប់ប្រញាល់ចេញទៅផ្នូរ"
ក្រណាត់សរ
ទាំងនេះគឺជាក្រណាត់បញ្ចុះសព
ដែលមនុស្សបានប្រើដើម្បីរុំព្រះសពរបស់ព្រះយេស៊ូ។
John 20:6
ក្រណាត់សរ
ទាំងនេះគឺជាសំពត់បញ្ចុះសព ដែលមនុស្សបានប្រើដើម្បីរុំព្រះសពរបស់ព្រះយេស៊ូ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក២០ ខ៣ ។
ក្រណាត់ដែលនៅលើព្រះសិរសារបស់ព្រះអង្គ
ត្រង់នេះ" ព្រះសិរសារបស់ព្រះ" សំដៅទៅលើ" សិរសារបស់ព្រះយេស៊ូ" ។
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ក្រណាត់ដែលមាននរណាម្នាក់ធ្លាប់ប្រើ
ដើម្បីបិទមុខព្រះយេស៊ូ"
ប៉ុន្តែ រមូរនៅកន្លែងមួយដោយឡែក
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ប៉ុន្តែមាននរណាម្នាក់បានបត់វា
ហើយដាក់វាមួយឡែកពីក្រណាត់ស"
John 20:8
សិស្សម្នាក់ទៀត
យ៉ូហានទំនងជាបង្ហាញ
និងសំដៅទៅលើខ្លួនគាត់ជា«សិស្សម្នាក»ជាជាងរាប់បញ្ចូលឈ្មោះរបស់គាត់នៅក្នុងកណ្ឌគម្ពីរនេះ។
គាត់បានឃើញ ហើយក៏ជឿ
ពេលគាត់ឃើញថា ផ្នូរនោះនៅទទេ
គាត់ជឿថាព្រះយេស៊ូបានរស់ពីសុគតឡើងវិញ។ " គាត់បានឃើញរឿងទាំងនេះ
ហើយចាប់ផ្តើមជឿថា ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ"
ពួកគេនៅតែមិនដឹងបទគម្ពីរ
ត្រង់នេះពាក្យ" ពួកគេ" សំដៅទៅលើពួកសិស្ស ដែលមិនយល់ពីបទគម្ពីរថា
ព្រះយេស៊ូនឹងរស់ឡើងវិញ។ "ពួកសិស្សនៅតែមិនទាន់យល់បទគម្ពីរ"
ដែលថា ព្រះអង្គនឹងរស់ពីស្លាប់ឡើងវិញ
"ដែលបាននិយាយថា ព្រះយេស៊ូត្រូវតែមានព្រះជន្មរស់ឡើងវិញ"
ត្រឡប់ទៅផ្ទះវិញ
សិស្សនាំគ្នាបន្តស្នាក់នៅក្រុងយេរូសាឡឹម។ " បានត្រឡប់ទៅកន្លែង
ដែលពួកគេកំពុងស្នាក់នៅក្នុងក្រុងយេរូសាឡឹម"
John 20:11
នាងបានឃើញទេវតាពីរនាក់ក្នុងសម្លៀកបំពាក់ស
ពួកទេវតាស្លៀកពាក់ស។ " នាងបានឃើញទេវតាពីររូបស្លៀកពាក់ស"
ពួកគេបាននិយាយទៅនាងថា
"ពួកគេបានសួរនាងថា"
ដោយសារគេយកព្រះជាម្ចាស់របស់ខ្ញុំម្ចាស់ទៅបាត់ហើយ
"ព្រោះពួកគេបានយករូបកាយរបស់ព្រះអម្ចាស់ខ្ញុំទៅហើយ" ។
ខ្ញុំមិនដឹងថា ពួកគេយកព្រះអង្គទៅដាក់នៅទីណាទេ
"ខ្ញុំមិនដឹងថា គេដាក់នៅទីណាទេ"
John 20:14
ព្រះយេស៊ូមានបន្ទូលទៅនាងថា
"ព្រះយេស៊ូបានសួរនាងថា"
លោកអើយ ប្រសិនបើ លោកបានយកព្រះអង្គទៅ

generated on Wed Sep 10 16:16:32 2025

ត្រង់នេះពាក្យ“ ព្រះអង្គ” សំដៅទៅលើព្រះយេស៊ូ។
"ប្រសិនបើអ្នកបានយកសពរបស់ព្រះយេស៊ូទៅ"
សូមប្រាប់ខ្ញុំផងថា លោកទុកព្រះអង្គនៅទីណា
"ប្រាប់ខ្ញុំពីកន្លែងដែលទុកព្រះអង្គ"
ខ្ញុំនឹងទៅយកព្រះអង្គ
ម៉ារីម៉ាក់ដាឡាចង់យកសពព្រះយេស៊ូទៅបញ្ចុះម្តងទៀត។
"ហើយខ្ញុំនឹងយកព្រះសព ហើយបញ្ចុះម្តងទៀត"
John 20:16
រ៉ាប៊ូនី
ពាក្យថារ៉ាប៊ូនីមានន័យថា រ៉ប៊ី ឬគ្រូជាភាសាអារ៉ាប់
ដែលព្រះយេស៊ូនិងសិស្សរបស់ព្រះអង្គបាននិយាយ។
បងប្អូន
ព្រះយេស៊ូបានប្រើពាក្យ «បងប្អូន»ដើម្បីសំដៅលើសិស្សរបស់ព្រះអង្គ។
ខ្ញុំនឹងឡើងទៅឯព្រះបិតារបស់ខ្ញុំ និងជាបិតារបស់អ្នក ហើយព្រះជាម្ចាស់របស់ខ្ញុំ
និងជាព្រះជាម្ចាស់របស់អ្នកដែរ
ព្រះយេស៊ូបានរស់ពីសុគតឡើងវិញហើយ ទ្រង់បានទាយថា
ទ្រង់នឹងឡើងទៅស្ថានសួគ៌ ត្រឡប់ទៅឯព្រះបិតារបស់ព្រះអង្គ
ដែលជាព្រះជាម្ចាស់។ “ ខ្ញុំហៀបនឹងត្រឡប់ទៅស្ថានសួគ៌
ដើម្បីនៅជាមួយព្រះបិតាខ្ញុំ និងជាព្រះបិតារបស់អ្នកទាំងអស់គ្នា
ទៅឯព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់អ្នករាល់គ្នា”
ព្រះបិតារបស់ខ្ញុំ និងជាបិតារបស់អ្នក
ទាំងនេះជាងារសំខាន់ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះយេស៊ូ
និងព្រះជាម្ចាស់ និងរវាងអ្នកជឿនិងព្រះជាម្ចាស់។
នាងម៉ារីអ្នកស្រុកម៉ាដាឡាបានមក ហើយប្រាប់ដល់ពួកសិស្សថា
ម៉ារីម៉ាក់ដាឡាបានទៅកន្លែង ដែលពួកសិស្សកំពុងស្នាក់នៅហើយប្រាប់ពួកគេពីអ្វី
ដែលនាងបានឃើញនិងបាន ឮ។ ”ម៉ារីម៉ាក់ដាឡាបានទៅកន្លែង
ដែលពួកសិស្សនៅទីនោះហើយប្រាប់ពួកគេ”
John 20:19
ព័ត៌មានទូទៅ:
ឥឡូវនេះគឺល្ងាចហើយ ព្រះយេស៊ូបានលេចមកឯពួកសិស្ស។
ថ្ងៃនោះ គឺជាថ្ងៃទីមួយនៃសប្តាហ៍
នេះសំដៅទៅលើថ្ងៃអាទិត្យ។
ទ្វារផ្ទះដែលពួកសិស្សនៅបានបិទ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ពួកសិស្សបានចាក់សោទ្វារផ្ទះ
ដែលពួកគេស្នាក់នៅ"
ព្រោះខ្លាចពួកយូដា
នៅទីនេះ "ជនជាតិយូដា" គឺសំដៅទៅលើមេដឹកនាំជនជាតិយូដា
ដែលអាចចាប់ខ្លួនពួកសិស្ស។“ ដោយសារពួកគេខ្លាចមេដឹកនាំយូដា
អាចចាប់ខ្លួនពួកគេ”
សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្តីសុខសាន្ត
នេះគឺជាការស្វាគមន៍ជាទូទៅ ដែលមានន័យថា
"សូមឲ្យព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដល់អ្នក" ។
ព្រះអង្គបានបង្ហាញព្រះហស្តរបស់ព្រះអង្គដល់ពួកគេ និងចំហៀងខ្លួនរបស់ព្រះអង្គដែរ
ព្រះយេស៊ូបានបង្ហាញស្នាមរបួសរបស់ព្រះអង្គដល់ពួកសិស្ស។
"ទ្រង់បង្ហាញស្នាមរបួសនៅលើដៃ និងចំហៀងខ្លួន"
John 20:21
សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត
នេះគឺជាការស្វាគមន៍ជាទូទៅ ដែលមានន័យថា
"សូមឲ្យព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដល់អ្នក" ។
ព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា
ខ្ញុំក៏ចាត់អ្នករាល់ឲ្យចេញទៅយ៉ាងនោះដែរ..ព្រះអង្គ...មានបន្ទូលទៅពួកគេថា៖
«ចូរទទួលព្រះវិញ្ញាណដ៏វិសុទ្ធ
ព្រះជាម្ចាស់ជាព្រះបិតាបានចាត់ព្រះបុត្រា
ឥឡូវបញ្ជូនអ្នកជឿក្នុងអំណាចព្រះចេស្តានៃព្រះវិញ្ញាណដ៏វិសុទ្ធ។
ព្រះបិតា
ជាងារដ៏សំខាន់ចំពោះព្រះជាម្ចាស់។
ពួកគេនឹងបានទទួលការអត់ទោស
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ “ ព្រះជាម្ចាស់នឹងអត់ទោសឲ្យពួកគេ”
បើ អ្នករាល់គ្នាមិនអត់ទោសទេ
"បើអ្នកមិនអត់ទោសអំពើបាបរបស់អ្នកដទៃ"
ពួកគេក៏មិនអាចទទួលការអត់ទោសដែរ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ព្រះជាម្ចាស់នឹងមិនអត់ទោសឲ្យពួកគេទេ"
John 20:24
ឌីឌីម
នេះគឺជាឈ្មោះបុរសដែលមានន័យថា "ភ្លោះ" ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅជំពូក១១ ខ១៥ ។
ក្រោយមក មានសិស្សម្នាក់ទៀតទូលទៅកាន់ព្រះអង្គថា
ពាក្យថា“ គាត់” សំដៅទៅលើថូម៉ាស។
ប្រសិនបើ ខ្ញុំមិនឃើញ..ចំហៀងខ្លួនរបស់ព្រះអង្គនោះទេ ខ្ញុំនឹងមិនជឿទេ»។
អ្នកអាចបកប្រែអវិជ្ជមានទ្វេដងនេះក្នុងទម្រង់វិជ្ជមានបាន។
"ខ្ញុំនឹងជឿប្រសិនបើខ្ញុំឃើញ ... ចំហៀងខ្លួនរបស់ព្រះអង្គ"
ព្រះហស្ត..ចំហៀងខ្លួនរបស់ព្រះអង្គ
ពាក្យ "របស់គាត់" សំដៅទៅលើព្រះយេស៊ូ។
John 20:26
ពួកសិស្សរបស់ព្រះអង្គ
ពាក្យ "របស់គាត់" សំដៅទៅលើព្រះយេស៊ូ។
ក្នុងពេលដែលទ្វារបានបិទនៅឡើយ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "នៅពេលដែលពួកគេបានចាក់សោទ្វារ"
សូមឲ្យអ្នករាល់គ្នាប្រកបដោយសេចក្តីសុខសាន្ត
នេះគឺជាការស្វាគមន៍ជាទូទៅ ដែលមានន័យថា
"សូមឱ្យព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដល់អ្នក" ។
មិនជឿ
"ដោយគ្មានជំនឿ" ឬ "អត់ជំនឿ"
ចូរជឿ
ត្រង់នេះ“ ជឿ” មានន័យថាទុកចិត្តលើព្រះយេស៊ូ។ “ ទុកចិត្តលើខ្ញុំ”
John 20:28
អ្នកជឿ
ថូម៉ាសជឿថា ព្រះយេស៊ូមានព្រះជន្មរស់ដោយសារគាត់បានឃើញគាត់។
"អ្នកបានជឿថា ខ្ញុំមានជីវិតរស់"
មានពរហើយ អស់អ្នកណា
មានន័យថា“ ព្រះជាម្ចាស់ប្រទានសុភមង្គលដល់អ្នកទាំងឡាយណា”
អស់អ្នកណាដែលជឿ ដោយមើលមិនឃើញ
មានន័យថា អ្នកដែលមិនបានឃើញព្រះយេស៊ូ។
"អ្នកដែលមិនបានឃើញខ្ញុំមាននៅជីវិត"
John 20:30
ព័ត៌មានទូទៅ:
នៅពេលរឿងនេះជិតដល់ទីបញ្ចប់
អ្នកនិពន្ធនិយាយអំពីរឿងជាច្រើនដែលព្រះយេស៊ូបានធ្វើ។
ទីសម្គាល់
ពាក្យថា“ ទីសម្គាល់” សំដៅទៅលើការអស្ចារ្យដែលបង្ហាញថា
ព្រះជាម្ចាស់មានឫទ្ធានុភាពបំផុត
ដែលមានសិទ្ធិអំណាចពេញលេញលើសកលលោក។
ទីសម្គាល់ជាច្រើនទៀតដែលបានសរសេរនៅក្នុងសៀវភៅនេះ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ទីសម្គាល់ដែលអ្នកនិពន្ធមិនបានសរសេរនៅក្នុងកណ្ឌគម្ពីរនេះ"
ប៉ុន្តែ ទីសម្គាល់ដែលបានកត់ត្រា
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
"ប៉ុន្តែអ្នកនិពន្ធបានសរសេរអំពីទីសម្គាល់ទាំងនេះ"
ព្រះបុត្រា
ជាងារដ៏សំខាន់ចំពោះព្រះយេស៊ូ
មានជីវិតនៅក្នុងព្រះនាមព្រះអង្គ
នៅទីនេះ "ជីវិត" មានន័យថា ព្រះយេស៊ូបានផ្តល់ជីវិត។
"អ្នកអាចមានជីវិតដោយសារព្រះយេស៊ូ"
ជីវិត
សំដៅទៅលើជីវិតខាងឯវិញ្ញាណ

generated on Wed Sep 10 16:16:32 2025

21 [1]បន្ទាប់ពីការទាំងនេះមក ព្រះយេស៊ូបានបង្ហាញអង្គទ្រង់ម្តងទៀតដល់ពួកសិស្សនៅសមុទ្រទីបេរាស ។
នេះគឺជារបៀបដែលព្រះអង្គបង្ហាញអង្គទ្រង់:[2]លោកស៊ីម៉ូនពេត្រុសបាននៅជាមួយនឹងលោកថូម៉ាស ដែលហៅថា ឌីឌីម លោកណាថានណែលជាអ្នកភូមិកាណា
ស្រុកកាលីឡេ ត្រូវជាកូនប្រុសរបស់លោកបេសេដេ និងសិស្សរបស់ព្រះយេស៊ូពីរនាក់ទៀត។[3]លោកស៊ីម៉ូនពេត្រុសនិយាយទៅកាន់ពួកគេថា៖ «ខ្ញុំទៅរកត្រីហើយ»។
ពួកគេនិយាយទៅកាន់គាត់ថា៖ «យើងក៏ទៅរកត្រីជាមួយអ្នកដែរ»។ ពួកគេក៏ចេញទៅ ហើយឡើងទៅលើទូក ប៉ុន្តែ ពួកគេរកត្រីពេញមួយយប់មិនបានត្រីសោះ។
[4]នៅពេលព្រឹកព្រលឹម ព្រះយេស៊ូបានគង់នៅមាត់សមុទ្រ ប៉ុន្តែ ពួកសិស្សមិនបានដឹងថា ជាព្រះយេស៊ូទេ។[5]ដូច្នេះ ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «អ្នកកម្លោះអើយ
តើមានអ្វីបរិភោគទេ?» ពួកគេបានទូលឆ្លើយទៅកាន់ព្រះអង្គថា៖ «អត់មានទេ»។[6]ទ្រង់មានបន្ទូលទៅពួកគេថា៖ «ចូរទំលាក់អួននៅខាងស្តាំទូកវិញ ហើយនឹងរកត្រីបាន»។
ដូច្នេះ ពួកគេក៏ទំលាក់អួនរបស់ពួកគេ ហើយមិនអាចទាញអួនមកវិញបានទេ ដោយសារតែជាប់ត្រីច្រើនពេក។
[7]បន្ទាប់មក សិស្សដែលព្រះអង្គស្រឡាញ់បាននិយាយទៅកាន់លោកពេត្រុសថា៖ «គាត់ជាព្រះអម្ចាស់»។ ពេលលោកស៊ីម៉ូនពេត្រុសឮថា ជាព្រះអម្ចាស់ដូច្នោះ
គាត់បានដោះអាវខាងក្រៅរបស់គាត់ចេញ (គាត់មិនបានស្លៀកពាក់ទេ) ហើយក៏លោតចូលទៅក្នុងសមុទ្រ។[8]មានពួកសិស្សផ្សេងទៀតបានមកឯទូក (ដ្បិត
ពួកគេនៅមិនឆ្ងាយពីច្រាំងប៉ុន្មានទេ ប្រហែលជាពីររយម៉ែត្រប៉ុណ្ណោះ ហើយពួកគេបានទាញអួនដែលមានសុទ្ធតែត្រី។[9]នៅពេលពួកគេមកដល់ច្រាំងហើយ
ពួកគេបានឃើញរងើកភ្លើង មានត្រីអាំងនៅពីលើ ជាមួយនឹងនំប៉័ងផង។
[10]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «ចូរយកត្រីដែលអ្នករាល់គ្នាចាប់បានខ្លះមក!»។[11]លោកស៊ីម៉ូនពេត្រុសក្រោកឡើង ហើយទៅទាញអួនមកលើដីដែលមានត្រីជាច្រើន
១៥៣។ មានត្រីជាច្រើន ប៉ុន្តែ អួនមិនបានរហែកទេ។
[12]ព្រះយេស៊ូមានបន្ទូលទៅពួកគេថា៖ «មក បរិភោគអាហារពេលព្រឹក»។ គ្មាននរណាម្នាក់ហ៊ានសួរព្រះអង្គថា៖ «តើលោកជានរណា?»។ ពួកគេដឹងថា
ព្រះអង្គជាព្រះអម្ចាស់។[13]ព្រះយេស៊ូមកដល់ ហើយកាច់នំប៉័ង ហើយប្រទានទៅពួកគេ ព្រមទាំងត្រីផង។[14]នេះគឺជាលើកទីបីហើយ
ដែលព្រះយេស៊ូបានបង្ហាញអង្គទ្រង់ដល់ពួកសិស្ស បន្ទាប់ពីទ្រង់រស់ពីស្លាប់ឡើងវិញ។
[15]បន្ទាប់ពីពួកគេបានបរិភោគអាហារពេលព្រឹករួចហើយ ព្រះយេស៊ូមានបន្ទូលទៅលោកស៊ីម៉ូនពេត្រុសថា៖ «ស៊ីម៉ូនកូនលោកយ៉ូហានអើយ
តើអ្នកស្រឡាញ់ខ្ញុំច្រើនជាងរបស់ទាំងនេះឬទេ?» លោកពេត្រុសទូលឆ្លើយទៅព្រះអង្គថា៖ «ក្រាបទូលព្រះអម្ចាស់ ព្រះអង្គជ្រាបហើយថា
ទូលបង្គំស្រឡាញ់ព្រះអង្គហើយ»។[16]ព្រះយេស៊ូមានបន្ទូលទៅគាត់ជាលើកទីពីរទៀតថា៖ «ស៊ីម៉ូន កូនលោកយ៉ូហានអើយ តើអ្នកស្រឡាញ់ខ្ញុំឬទេ?»
លោកពេត្រុសទូលឆ្លើយទៅព្រះអង្គថា៖ «ក្រាបទូល ព្រះអម្ចាស់ ព្រះអង្គជ្រាបហើយថា ទូលបង្គំស្រឡាញ់ព្រះអង្គ»។ ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖
«ចូរមើលថែចៀមខ្ញុំ»។
[17]ព្រះអង្គមានបន្ទូលទៅគាត់ជាលើកទីបីថា៖ «ស៊ីម៉ូន កូនលោកយ៉ូហានអើយ តើអ្នកស្រឡាញ់ខ្ញុំឬទេ?» លោកពេត្រុសព្រួយចិត្ត
ដោយសារព្រះយេស៊ូបានសួរគាត់ជាលើកទីបីថា៖ «តើអ្នកស្រឡាញ់ខ្ញុំឬទេ?» គាត់ទូលទៅព្រះអង្គថា៖ «ព្រះអម្ចាស់ ព្រះអង្គជ្រាបគ្រប់យ៉ាង ព្រះអង្គជ្រាបថា
ទូលបង្គំស្រឡាញ់ព្រះអង្គហើយ»។ ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ចូរឲ្យចំណីចៀមខ្ញុំផង»។[18]ពិតណាស់ ខ្ញុំប្រាប់អ្នកជាប្រាកដថា នៅពេលអ្នកនៅក្មេង
អ្នកស្លៀកពាក់ខ្លួនអ្នក ហើយដើរតាមតែចិត្តអ្នកចង់ ប៉ុន្តែ នៅពេលអ្នកចាស់ អ្នកនឹងបោះដៃរបស់អ្នក ហើយអ្នកម្នាក់ផ្សេងទៀតនឹងស្លៀកពាក់ឲ្យអ្នក
ហើយនាំអ្នកទៅកន្លែងដែលអ្នកមិនចង់ទៅ»។
[19]ព្រះយេស៊ូមានបន្ទូលដូច្នេះ ដើម្បីបង្ហាញពីការដែលលោកពេត្រុសត្រូវស្លាប់ជាយ៉ាងណា ក្នុងការថ្វាយសិរីល្អដល់ព្រះ។ បន្ទាប់មក ព្រះអង្គមានបន្ទូលការនេះរួចហើយ
ព្រះអង្គមានបន្ទូលទៅលោកពេត្រុសថា៖ «ចូរដើរតាមខ្ញុំ!»។
[20]លោកពេត្រុសមើលជុំវិញ ហើយឃើញសិស្សម្នាក់ដែលព្រះយេស៊ូស្រឡាញ់ ដើរតាមពួកគេ ម្នាក់ដែលគាត់ផ្តេកខ្លួននៅលើព្រះយេស៊ូនៅអាហារពេលល្ងាច
និងជាអ្នកដែលសួរព្រះអង្គថា៖ «ព្រះអម្ចាស់អើយ តើនរណានឹងក្បត់ព្រះអង្គ?»[21]ពេត្រុសឃើញគាត់ ហើយបន្ទាប់មកទូលទៅព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ
តើបុរសនេះនឹងធ្វើអ្វី?»
[22]ព្រះយេស៊ូមានបន្ទូលទៅគាត់ថា៖ «ប្រសិនបើ ខ្ញុំចង់ឲ្យគាត់នៅ រហូតទាល់តែខ្ញុំមកវិញ គ្មានអ្វីទាក់ទងជាមួយអ្នកទេ? ចូរតាមខ្ញុំមក!»។[23]ប្រយោគនេះ
បានរីកសាយភាយនៅក្នុងចំណោមបងប្អូន ថាសិស្សម្នាក់នោះនឹងមិនស្លាប់ទេ។ លើសពីនេះទៀត ព្រះយេស៊ូមិនបានមានបន្ទូលទៅលោកពេត្រុសថា សិស្សផ្សេងៗទៀត
មិនស្លាប់ទេ ប៉ុន្តែ «ប្រសិនបើ ព្រះអង្គចង់ឲ្យគាត់នៅ រហូតទាល់តែព្រះអង្គយាងមក គ្មានអ្វីទាក់ទងជាមួយគាត់ទេ»។
[24]ពួកសិស្សរបស់ព្រះអង្គបានធ្វើបន្ទាល់សេចក្តីទាំងនេះឯង ហើយបានកត់ត្រាសេចក្តីទាំងនេះ ហើយយើងដឹងថា ទីបន្ទាល់របស់ពួកគេគឺជាសេចក្តីពិត។
[25]មានការជាច្រើនទៀតផងដែរ ដែលព្រះយេស៊ូបានធ្វើ។ ប្រសិនបើ កត់ត្រាសេចក្តីទាំងអស់ តាមដែលបានឃើញនោះ
សូម្បីតែលោកីយ៍ទាំងមូលក៏មានអាចទុកសៀវភៅនោះបានផង។

John 21:1
ព័ត៌មានទូទៅ:
ព្រះយេស៊ូបានបង្ហាញខ្លួនឲ្យពួកសិស្សឃើញម្តងទៀតនៅឯសមុទ្រទីបេរាស។ ខ២ និង៣ ប្រាប់យើងពីអ្វីដែលកើតឡើងនៅក្នុងរឿងមុនពេលព្រះយេស៊ូលេចមក។
បន្ទាប់ពីការទាំងនេះមក
"ពេលក្រោយ"
ជាមួយនឹងលោកថូម៉ាស ដែលហៅថា ឌីឌីម
អាចបកប្រែជាទម្រង់កិរិយាសកម្ម។ "ជាមួយថូម៉ាសដែលយើងហៅថាឌីឌីម"
ឌីឌីម
នេះជាឈ្មោះបុរសដែលមានន័យថា "ភ្លោះ" ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក១១ ខ១៥ ។
John 21:4
អ្នកកម្លោះអើយ
នេះជាពាក្យនៃសេចក្តីស្រឡាញ់ ដែលមានន័យថា "មិត្តជាទីស្រឡាញ់អើយ" ។
នឹងរកត្រីបាន
នៅទីនេះ "ខ្លះ" សំដៅទៅលើត្រី។
"អ្នកនឹងចាប់បានត្រីខ្លះនៅក្នុងសំណាញ់របស់អ្នក"
ទាញអួនមក
"ទាញសំណាញ់ចូល"
John 21:7
ស្រឡាញ់
គឺជាសេចក្តីស្រឡាញ់ ដែលមកពីព្រះជាម្ចាស់ និងផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
សូម្បីតែវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះជាពួកគេធ្វើអ្វីក៏ដោយ។
គាត់មិនបានស្លៀកពាក់ទេ
នេះជាពត៌មានសំខាន់។
ហើយក៏លោតចូលទៅក្នុងសមុទ្រ
ពេត្រុសបានលោតចូលទៅក្នុងទឹកហើយហែលទៅច្រាំង។
"ហើយលោតចូលសមុទ្រហើយហែលទៅច្រាំង"
លោតចូល
មានន័យថា ពេត្រុសលោតចូលទៅក្នុងទឹកយ៉ាងលឿន។
ដ្បិត ពួកគេនៅមិនឆ្ងាយពីច្រាំងប៉ុន្មានទេ ប្រហែលជាពីររយម៉ែត្រប៉ុណ្ណោះ
នេះជាព័ត៌មានសំខាន់
ពីររយម៉ែត្រប៉ុណ្ណោះ
"៩០ ម៉ែត្រ។ " មួយហត្ថគឺតិចជាងកន្លះម៉ែត្រ។
John 21:10
លោកស៊ីម៉ូនពេត្រុសក្រោកឡើង
ត្រង់នេះ“ បានឡើងទៅ” មានន័យថា ស៊ីម៉ូនពេត្រុសត្រូវតែត្រឡប់ទៅទូកវិញ។
"ដូច្នេះស៊ីម៉ូនពេត្រុសបានត្រឡប់ទៅទូកវិញ"
ទាញអួនមកលើដី
"ហើយទាញសំណាញ់ទៅច្រាំង"

generated on Wed Sep 10 16:16:32 2025

អ្នកមិនបានរហែកទេ
អាចបកប្រែជាទម្រង់កិរិយាសកម្ម។"សំណាញ់មិនបានរហែកទេ"
John 21:12
បរិភោគអាហារពេលព្រឹក
អាហារពេលព្រឹក
ជាលើកទីបី
អាចបកប្រែពាក្យធម្មតា "ទីបី" ជា "ពេលវេលា ៣" ។
John 21:15
ព័ត៌មានទូទៅ:
ព្រះយេស៊ូចាប់ផ្តើមមានការសន្ទនាជាមួយស៊ីម៉ូនពេត្រុស។
តើអ្នកស្រឡាញ់ខ្ញុំឬទេ
ត្រង់នេះ“ សេចក្តីស្រឡាញ់” សំដៅទៅលើសេចក្តីស្រឡាញ់
ដែលមកពីព្រះជាម្ចាស់ដែលផ្តោតលើសេចក្តីល្អរបស់អ្នកដទៃ
ទោះបីវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
ព្រះអង្គជ្រាបហើយថា ទូលបង្គំស្រឡាញ់ព្រះអង្គហើយ
ពេលពេត្រុសឆ្លើយគាត់ប្រើពាក្យថា "ស្រឡាញ់"
ដែលសំដៅទៅលើសេចក្តីស្រឡាញ់ជាបងប្អូន ឬសេចក្តីស្រឡាញ់ចំពោះមិត្តភក្តិ
ឬសមាជិកគ្រួសារ។
ចម្អែតកូនចៀមខ្ញុំផង
នៅទីនេះ "កូនចៀម"
ជាពាក្យប្រៀបធៀបមនុស្សទាំងអស់ដែលស្រឡាញ់ព្រះយេស៊ូ
ហើយធ្វើតាមព្រះអង្គ។ "ផ្តល់អាហារដល់មនុស្សដែលខ្ញុំយកចិត្តទុកដាក់"
ចូរមើលថែចៀមខ្ញុំ
នៅទីនេះ "ចៀម" ជាពាក្យប្រៀបធៀប
សម្រាប់អ្នកដែលស្រឡាញ់និងធ្វើតាមព្រះយេស៊ូ។
"យកចិត្តទុកដាក់ចំពោះមនុស្សដែលខ្ញុំយកចិត្តទុកដាក់"
John 21:17
ព្រះអង្គមានបន្ទូលទៅគាត់ជាលើកទីបីថា
សព្វនាម "គាត់" សំដៅទៅលើព្រះយេស៊ូ។ នៅទីនេះ "លើកទីបី" មានន័យថា
"ពេលវេលានៃលេខ ៣" ។ "ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ជាលើកទីបី"
តើអ្នកស្រឡាញ់ខ្ញុំឬទេ
លើកនេះ ពេលព្រះយេស៊ូសួរសំណួរនេះ ទ្រង់ប្រើពាក្យថា“ សេចក្តីស្រឡាញ់”
ដែលសំដៅទៅលើសេចក្តីស្រឡាញ់ជាបងប្អូន ឬសេចក្តីស្រឡាញ់ចំពោះមិត្តភក្តិ
ឬសមាជិកគ្រួសារ។
ចូរឲ្យចំណីចៀមខ្ញុំផង
នៅទីនេះ "ចៀម" ជាពាក្យប្រៀបធៀប
តំណាងឲ្យអ្នកដែលជាកម្មសិទ្ធិរបស់ព្រះយេស៊ូ ហើយដើរតាមព្រះអង្គ។
"យកចិត្តទុកដាក់ចំពោះមនុស្ស ដែលខ្ញុំយកចិត្តទុកដាក់"
ពិតណាស់
បកប្រែដូចនៅក្នុងជំពូក១ ខ៤៩ ។
John 21:19
ពេលនេះ
យ៉ូហានប្រើពាក្យនេះដើម្បីបង្ហាញថា
គាត់កំពុងផ្តល់ព័ត៌មានសំខាន់មុនពេលគាត់បន្តសាច់រឿង។
ដើម្បីបង្ហាញពីការដែលលោកពេត្រុសត្រូវស្លាប់ជាយ៉ាងណា ក្នុងការថ្វាយសិរីល្អដល់ព្រះ
នៅទីនេះ យ៉ូហានបញ្ជាក់ថា ពេត្រុសនឹងស្លាប់នៅលើឈើឆ្កាង។ “
ដើម្បីបង្ហាញថាពេត្រុសនឹងត្រូវស្លាប់នៅលើឈើឆ្កាងជាការគោរពដល់ព្រះជាម្ចាស់”
ចូរដើរតាមខ្ញុំ
ត្រង់នេះពាក្យថា“ ដើរតាម” មានន័យថា“ ធ្វើជាសិស្ស” ។ “
បន្តធ្វើជាសិស្សរបស់ខ្ញុំ”
John 21:20
សិស្សម្នាក់ដែលព្រះយេស៊ូស្រឡាញ់
យ៉ូហានសំដៅលើខ្លួនឯង ពេញមួយកណ្ឌគម្ពីរជាងនិយាយពីឈ្មោះរបស់គាត់។
ស្រឡាញ់
នេះជាសេចក្តីស្រឡាញ់
ដែលកើតចេញពីព្រះជាម្ចាស់ហើយតែងតែប្រាថ្នាចង់ឲ្យអ្នកដទៃបានសេចក្តីសុខ
ទោះបីវាមិនផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងក៏ដោយ។
សេចក្តីស្រឡាញ់បែបនេះយកចិត្តទុកដាក់ចំពោះអ្នកដទៃ
ទោះជាពួកគេធ្វើអ្វីក៏ដោយ។
នៅអាហារពេលល្ងាច
នេះសំដៅទៅលើអាហារចុងក្រោយ។ (សូមមើល៖ ជំពូក១៣ ខ១)
ពេត្រុសឃើញគាត់
នៅទីនេះ "គាត់" សំដៅទៅលើ "សិស្សដែលព្រះយេស៊ូស្រឡាញ់" ។
ព្រះអម្ចាស់អើយ តើបុរសនេះនឹងធ្វើអ្វី?
ពេត្រុសចង់ដឹងថា តើនឹងមានអ្វីកើតឡើងចំពោះយ៉ូហាន។ "ព្រះអម្ចាស់
តើនឹងមានអ្វីកើតឡើងចំពោះបុរសនេះ?"
John 21:22
ព្រះយេស៊ូមានបន្ទូលទៅគាត់ថា
"ព្រះយេស៊ូមានព្រះបន្ទូលទៅលោកពេត្រុសថា"
ប្រសិនបើ ខ្ញុំចង់ឲ្យគាត់នៅ
ត្រង់នេះ“ គាត់” សំដៅទៅលើ“ សិស្សដែលព្រះយេស៊ូស្រឡាញ់” ជំពូក២១ ខ២០
។
ខ្ញុំមកវិញ
សំដៅទៅលើការយាងមកជាលើកទីពីររបស់ព្រះយេស៊ូដែលជាការវិលត្រឡប់របស់ព្រះអង្គមកផែនដីវិញ។
គ្មានអ្វីទាក់ទងជាមួយអ្នកទេ?
ការកត់សម្គាល់នេះលេចឡើងជាទម្រង់សំណួរ
ដើម្បីបង្ហាញការស្តីបន្ទោសបន្តិចបន្តួច។ "នោះមិនមែនជាការដែលអ្នកត្រូវបារម្ភទេ"
ឬ "អ្នកមិនគួរព្រួយបារម្ភអំពីរឿងនោះទេ"
នៅក្នុងចំណោមបងប្អូន
នៅទីនេះ“ បងប្អូន” សំដៅទៅលើដើរតាមព្រះយេស៊ូទាំងអស់។
John 21:24
ព័ត៌មានទូទៅ:
នេះជាចុងបញ្ចប់នៃដំណឹងល្អរបស់យ៉ូហាន។ នៅទីនេះអ្នកនិពន្ធគឺសាវ័កយ៉ូហាន
ដែលនិយាយពីសេចក្តីបញ្ចប់របស់ខ្លួនគាត់
និងអ្វីដែលគាត់បានសរសេរនៅក្នុងកណ្ឌគម្ពីរនេះ។
ពួកសិស្ស
«សិស្សរបស់យ៉ូហាន»
ធ្វើបន្ទាល់សេចក្តីទាំងនេះ
នៅទីនេះ «ធ្វើបន្ទាល់» មានន័យថា គាត់បានឃើញអ្វីមួយដោយខ្លួនឯង។
«អ្នកដែលបានឃើញរឿងទាំងអស់នេះ»
យើងដឹងថា
នៅទីនេះ «យើង» សំដៅទៅលើអ្នកដែលទុកចិត្តលើព្រះយេស៊ូ។
«យើងដែលជឿលើព្រះយេស៊ូដឹងថា»
ប្រសិនបើ កត់ត្រាសេចក្តីទាំងអស់
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
«ប្រសិនបើមាននរណាម្នាក់សរសេរការណ៍នេះទាំងអស់»
សូម្បីតែលោកីយ៍ទាំងមូលក៏មិនអាចទុកសៀវភៅនោះបានផង
ព្រះយេស៊ូបានធ្វើអស្ចារ្យជាច្រើនទៀត
ជាជាងអ្វីដែលមនុស្សអាចសរសេរនៅក្នុងកណ្ឌគម្ពីរនេះ។ នៅទីនេះ
យ៉ូហានប្រើពាក្យបន្ថែមសម្រាប់ការសង្កត់ន័យ។
អាចទុកសៀវភៅនោះបានផង
អាចបកប្រែជាទម្រង់កិរិយាសកម្ម។
«សៀវភៅដែលមនុស្សអាចសរសេរអំពីអ្វីដែលព្រះអង្គបានធ្វើ»

កណ្ឌគម្ពីរកិច្ចការ

1 [1]សូមជម្រាបមកលោកថេវភីល សូមជ្រាប! ក្នុងសៀវភៅទីមួយដែលខ្ញុំបានរៀបរាប់អំពីកិច្ចការទាំងប៉ុន្មាន ដែលព្រះយេស៊ូបានធ្វើ ហើយបានបង្រៀនកន្លងមក[2]រហូត
ដល់ថ្ងៃដែលព្រះអង្គឡើងទៅស្ថានបរមសុខ បន្ទាប់ពីព្រះអង្គបានផ្តែផ្តាំដល់ក្រុមសាវ័ក ដែលព្រះអង្គបានជ្រើសរើសតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។[3]ក្រោយពេលរងទុក្ខ
លំបាករួចហើយ ព្រះយេស៊ូបានបង្ហាញព្រះអង្គតាមរបៀបផ្សេងៗឲ្យសាវ័កទាំងនោះឃើញថា ព្រះអង្គមានព្រះជន្មរស់ពិតមែន។ ព្រះអង្គឲ្យគេឃើញអស់រយៈពេលសែសិប
ថ្ងៃ ព្រមទាំងមានព្រះបន្ទូលអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ផង។

generated on Wed Sep 10 16:16:32 2025

[4]ព្រះអង្គហាមគេមិនឲ្យចេញទៅណាឆ្ងាយពីក្រុងយេរូសាឡឹមឡើយ គឺពួកគេត្រូវរង់ចាំតាមព្រះបន្ទូលសន្យារបស់ព្រះបិតា ហើយព្រះអង្គក៏មានបន្ទូលថា៖ «អ្នករាល់គ្នាបានឮពីខ្ញុំហើយ[5]ថាលោកយ៉ូហានបានធ្វើពិធីជ្រមុជឲ្យពួកគេក្នុងទឹក ប៉ុន្តែនៅប៉ុន្មានថ្ងៃទៀត អ្នករាល់គ្នានឹងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ»។
[6]ពួកគេទូលសួរព្រះយេស៊ូថា៖ «ព្រះអម្ចាស់ តើព្រះអង្គនឹងស្តារឫទ្ធានុភាពរបស់ស្តេចដាវីឌឡើងវិញនៅពេលនេះឬ?»។[7]ព្រះអង្គមានព្រះបន្ទូលតបថា៖ «ត្រង់ឯពេលវេលាដែលព្រះបិតាបានកំណត់ទុកដោយអំណាចព្រះអង្គផ្ទាល់នោះ អ្នករាល់គ្នាមិនបាច់ដឹងទេ។[8]ប៉ុន្តែអ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំនៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី»។
[9]ពេលព្រះអម្ចាស់ព្រះយេស៊ូមានព្រះបន្ទូលរួចហើយ ព្រះជាម្ចាស់ក៏លើកព្រះអង្គឡើងទៅលើមេឃ ព្រមទាំងមានពពកមកបាំងព្រះអង្គបាត់ពីភ្នែកគេទៅ ក្នុងពេលពួកសាវ័កកំពុងតែសម្លឹងមើលព្រះអង្គ។[10]កាលពួកគេកំពុងតែសម្លឹងមើលទៅស្ថានបរមសុខ ពេលដែលព្រះអង្គយាងឡើងទៅនោះ ស្រាប់តែមានបុរសពីរនាក់ស្លៀកពាក់សចូលមកជិតគេ[11]ពោលថា៖ «អ្នកស្រុកកាលីឡេអើយ! ហេតុម្តេចបានជាអ្នករាល់គ្នានៅតែឈរសម្លឹងមើលទៅស្ថានបរមសុខដូច្នេះ? ព្រះយេស៊ូនោះហើយដែលព្រះជាម្ចាស់បានលើកពីកណ្តាលចំណោមអ្នករាល់គ្នា ឡើងទៅស្ថានបរមសុខហើយ ព្រះអង្គនឹងយាងត្រឡប់មកវិញតាមរបៀប ដូចដែលអ្នករាល់គ្នាបានឃើញទ្រង់យាងឡើងទៅស្ថានបរមសុខដូច្នេះដែរ»។
[12]បន្ទាប់មកពួកសាវ័កនាំគ្នាវិលត្រឡប់ពីភ្នំដើមអូលីវ ទៅក្រុងយេរូសាឡឹមវិញ ជាដំណើរថ្ងៃសប្ប័ទ។[13]លុះបានមកដល់ផ្ទះ ពួកគេឡើងទៅបន្ទប់ខាងលើជាកន្លែងដែលគេធ្លាប់ស្នាក់នៅ។ ក្នុងចំណោមពួកគេ មានលោកពេត្រុស លោកយ៉ូហាន លោកយ៉ាកុប លោកអនទ្រេ លោកភីលីព លោកថូម៉ាស លោកបារថូឡូមេ លោកម៉ាថាយ លោកយ៉ាកុបជាកូនលោកអាល់ផាយ លោកស៊ីម៉ូនហៅអ្នកជាតិនិយម និងលោកយូដាសជាកូនរបស់លោកយ៉ាកុប។[14]ពួកគេរួមចិត្តគំនិតគ្នាព្យាយាមអធិស្ឋាន ក្នុងនោះក៏មានស្ត្រីឯទៀតៗ មាននាងម៉ារីជាមាតារបស់ព្រះយេស៊ូ និងមានបងប្អូនរបស់ព្រះអង្គផងដែរ។
[15]លោកពេត្រុសក្រោកឈរឡើង នៅកណ្តាលចំណោមបងប្អូនប្រមាណមួយរយម្ភៃនាក់ហើយនិយាយថា៖[16]«បងប្អូនអើយ! ពិតជាសំខាន់ណាស់ដែលអត្ថបទគម្ពីរនឹងពេញលេញ ដូចព្រះវិញ្ញាណបានថ្លែងទុកជាមុន តាមរយៈព្រះបាទដាវីឌអំពីយូដាសជាអ្នកនាំគេមកចាប់ព្រះយេស៊ូ។
[17]យូដាសជាសមាជិកមួយរូបក្នុងក្រុមរបស់យើង ហើយបានទទួលចំណែកមុខងាររួមជាមួយយើងដែរ។[18](ឥឡូវបុរសម្នាក់នេះបានទិញដីចំការមួយកន្លែងដោយប្រើប្រាក់ដែលគាត់បានមកពីអំពើទុច្ចរិតរបស់គាត់ ក្រោយមក គាត់ដួលផ្កាប់មុខធ្លាយពោះ ចេញពោះវៀនមកក្រៅ។[19]អ្នកក្រុងយេរូសាឡឹមដឹងរឿងនេះគ្រប់ៗគ្នា ដូច្នេះបានជាគេហៅចម្ការនោះតាមភាសារបស់គេថា “អាកិលដាម៉ា”មានន័យថា «ចម្ការឈាម»)។
[20]ក្នុងគម្ពីរទំនុកតម្កើងមានចែងទុកអំពីហេតុការណ៍នេះថា៖ «ចូរឲ្យចម្ការរបស់អ្នកនោះក្លាយទៅជាទីស្ងាត់ជ្រងំ កុំឲ្យមាននរណារស់នៅទីនោះឡើយ។ និង«ត្រូវឲ្យម្នាក់ទៀតទទួលយកតំណែងរបស់គាត់»។
[21]ហេតុនេះ ជាការសំខាន់ណាស់ ព្រះអង្គនោះហើយដែលបានគង់នៅជាមួួយយើងគ្រប់ពេល គឺជាព្រះអម្ចាស់យេស៊ូដែលបានយាងមក
និងយាងឡើងទៅក្នុងចំណោមពួកយើង[22]ចាប់តាំងពីលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកឲ្យព្រះអង្គ រហូតដល់ពេលព្រះជាម្ចាស់លើកយកព្រះអង្គចេញពីយើងទៅ នេះជាបន្ទាល់អំពីការរស់ឡើងវិញរបស់ព្រះអង្គ»។[23]គេបាននាំសិស្សពីររូបមក ម្នាក់ឈ្មោះយ៉ូសែប ហៅបារសាបាស យូស្ទុស និងម្នាក់ទៀតឈ្មោះម៉ាត់ធាស។
[24]ពួកគេក៏នាំគ្នាអធិស្ឋានថា៖ «បពិត្រព្រះអម្ចាស់! ព្រះអង្គជ្រាបចិត្តគំនិតរបស់មនុស្សទាំងអស់ ហេតុនេះ សូមបង្ហាញឲ្យយើងខ្ញុំដឹងផងថា ក្នុងចំណោមបងប្អូនទាំងពីររូបនេះ តើព្រះអង្គសព្វព្រះហឫទ័យជ្រើសរើសអ្នកណា[25]ឲ្យបំពេញមុខងារជាសាវ័កជំនួសយូដាស ដ្បិតយូដាសបានបោះបង់មុខងារនេះ ទៅឯកន្លែងរបស់គាត់»។[26]សិស្សនាំគ្នាចាប់ឆ្នោតត្រូវលើលោកម៉ាត់ធាស ហើយលោកម៉ាត់ធាសក៏បានចូលរួមក្នុងក្រុមសាវកដប់មួយរូបទៀត។

Acts 1:1
ប្រយោគភ្ជាប់
លោកលូកាពន្យល់ ពីហេតុដែលលោកសរសេរមកកាន់លោកថេវភីល។
សៀវភៅទីមួយដែលខ្ញុំបានសរសេរ
សៀវភៅទីមួយគឺដំណឹងល្អរបស់លោកលូកា។
លោកថេវភីល
លោកលូកាបានសរសេរសៀវភៅនេះទៅកាន់បុរសម្នាក់ដែលឈ្មោះថាលោកថេវភីល។ ការបកប្រែខ្លះ បានធ្វើតាមវប្បធម៌របស់ពួកគេនៅការបញ្ជាក់ពីសំបុត្រ
ហើយសរសេរថា៖ «ជូនចំពោះលោកថេវភីល» គឺជាការចាប់ផ្តើមនៃប្រយោគ។
លោកថេវភីលមានន័យថា «មិត្តសម្លាញ់របស់ព្រះជាម្ចាស់»។
រហូតដល់ថ្ងៃដែលព្រះអង្គឡើងទៅស្ថានបរមសុខ
ឃ្លានេះសំដៅលើការយាងឡើងទៅស្ថានសួគ៌វិញរបស់ព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «រហូតដល់ថ្ងៃ
ដែលព្រះជាម្ចាស់បានលើកព្រះអង្គឡើងទៅស្ថានបរមសុខវិញ»
ព្រះអង្គបានផ្តែផ្តាំតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ
ព្រះវិញ្ញាណដ៏វិសុទ្ធបាននាំព្រះយេស៊ូឲ្យណែនាំដល់សាវករបស់ព្រះអង្គទាក់ទងនឹងកិច្ចការដែលទ្រង់ត្រូវធ្វើ
ក្រោយពេលរងទុក្ខលំបាករួចហើយ
ការនេះសំដៅលើការរងទុក្ខរបស់ព្រះយេស៊ូ និងការសុគតលើឈើឆ្កាង។
ព្រះអង្គបានបង្ហាញអង្គទ្រង់ដល់ពួកគេថាព្រះអង្គមានព្រះជន្មរស់ពិតមែន
ព្រះយេស៊ូបានយាងមករកពួកសាវក និងពួកសិស្សជាច្រើនទៀតរបស់ព្រះអង្គ។
Acts 1:4
ប្រយោគភ្ជាប់
ព្រឹកការណ៍នេះបានកើតឡើងនៅក្នុងអំឡុងពេលសែបសិបថ្ងៃ
ដែលព្រះយេស៊ូបានយាងមកជួបអ្នកដើរតាមព្រះអង្គ
បន្ទាប់ពីព្រះអង្គមានព្រះជន្មរស់ឡើងវិញ។
ព័ត៌មានទូទៅ
ពាក្យថា «គាត់» សំដៅលើ ព្រះយេស៊ូ។ លើកលែងតែកន្លែងសម្គាល់ផ្សេងទៀត
ពាក្យ «អ្នក» នៅក្នុងកណ្ឌកិច្ចការជាពហុសវចនៈ។
កាលព្រះអង្គបានជួបជុំជាមួយពួកគេហើយ
«កាលព្រះយេស៊ូបានជួបជុំជាមួយពួកសាវករបស់ព្រះអង្គ»។
ព្រះបន្ទូលសន្យារបស់ព្រះបិតា
ការនេះសំដៅលើព្រះវិញ្ញាណដ៏វិសុទ្ធ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះបិតាសន្យាថានឹងចាត់មក»។
ហើយព្រះអង្គក៏មានបន្ទូល
ប្រសិនបើ អ្នកបកប្រែឃ្លាមុនដើម្បីបូកពាក្យ «ព្រះវិញ្ញាណដ៏វិសុទ្ធ»
អ្នកអាចប្តូរពាក្យ «ដែល» ទៅ «អ្នក»។ របៀបផ្សេងទៀតនៃការបកប្រែ:
«អំពីអ្នកដែលព្រះយេស៊ូមានបន្ទូល»។
លោកយ៉ូហានបានធ្វើពិធីជ្រមុជឲ្យពួកគេក្នុងទឹក...ជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ
ព្រះយេស៊ូបានបង្ហាញពីភាពខុសគ្នា
ពីរបៀបនៃការជ្រមុជរបស់លោកយ៉ូហានដល់មនុស្ស ដោយទឹក
និងជាមួយរបៀបដែលព្រះអង្គជ្រមុជអ្នកជឿដោយព្រះវិញ្ញាណដ៏វិសុទ្ធ។
លោកយ៉ូហានបានធ្វើពិធីជ្រមុជឲ្យពួកគេក្នុងទឹក
«លោកយ៉ូហានពិតជាបានធ្វើពិធីជ្រមុជឲ្យពួកគេក្នុងទឹកមែន»។
អ្នករាល់គ្នានឹងទទួលពិធីជ្រមុជ
[illegible]យ៉ាង បែបបទ ឬទម្រង់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងជ្រមុជអ្នករាល់គ្នា»
Acts 1:6
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅត្រង់នេះ សំដៅលើពួកសាវក។
តើព្រះអង្គនឹងស្តាររាជាណាចក្រអ៊ីស្រាអែលឡើងវិញនៅពេលនេះឬ?
«តើព្រះអង្គនឹងធ្វើឲ្យអ៊ីស្រាអែលទៅជាអាណាចក្រដ៏អស្ចារ្យម្តងទៀតឬ?»
ពេលវេលា ឬរដូវកាល
ប្រហែលជាមានន័យថា៖ ទី១ ពាក្យថា៖ «ពេលវេលា» និង «រដូវកាល»
សំដៅទៅលើប្រភេទនៃពេលវេលាផ្សេងគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«កំឡុងនៃពេលវេលាទូទៅ ឬ ថ្ងៃជាក់លាក់ណាមួយ» ឬទី ២ ពាក្យទាំងពីរនេះ
ជាទូទៅមានន័យដូចគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលវេលាពិតប្រាកដ»។
អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ
ពួកសាវកនឹងទទួលឫទ្ធានុភាពដែលនឹងជួយឲ្យពួកគេឲ្យធ្វើបន្ទាល់ពីព្រះយេស៊ូ។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់នឹងប្រទានអំណាចដល់អ្នក...ធ្វើជាបន្ទាល់របស់ខ្ញុំ»។
រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី
ទំនងជាមានន័យថា ទីមួយ «ពេញទូទាំងពិភពលោក» ឬទីពីរ «ទៅកន្លែងនៅលើផែនដីដាច់ស្រយាល»។
Acts 1:9
កាលពួកគេកំពុងតែសម្លឹងមើលទៅ
«ពេលពួកគេសម្លឹងមើល»។ ពួកសាវក «បានសម្លឹងមើលឡើងលើ» ទៅឯព្រះយេស៊ូ ដោយសារព្រះយេស៊ូបានលើកឡើងទៅលើមេឃ។ របៀបផ្សេងទៀតនៃការបកប្រែ: «កាលពួកគេកំពុងតែសម្លឹងមើលទៅ»។
អ្នកស្រុកកាលីឡេអើយ!
ទេវតាបញ្ជាក់ដល់ពួកសាវក ក្នុងនាមជាអ្នកស្រុកកាលីឡេ។
នឹងយាងត្រឡប់មកវិញតាមរបៀបដូចគ្នា
ព្រះយេស៊ូនឹងយាងត្រឡប់មកវិញពីលើមេឃ ដូចដែលពពកបានគ្របបាំងព្រះអង្គ នៅពេលព្រះអង្គយាងឡើងទៅស្ថានសួគ៌។
Acts 1:12
បន្ទាប់មកពួកគេក៏ត្រឡប់ទៅវិញ
ពួកសាវកបានប្រឡប់ទៅវិញ
ធ្វើដំណើរនៅថ្ងៃសប្ប័ទ
ពាក្យនេះ សំដៅលើចម្ងាយ សម្របតាមប្រពៃណីរបស់រ៉ាប៊ីមនុស្សដែលអនុញ្ញាតឲ្យដើរនៅថ្ងៃសប្ប័ទ។ របៀបផ្សេងទៀតនៃការបកប្រែ: «ចម្ងាយប្រហែលជាមួយគីឡូម៉ែត្រ»។
ពេលពួកគេបានទៅដល់
«ពេលពួកគេទៅដល់គោលដៅរបស់ពួកគេ»។ ខ ១២ ចែងថា ពួកគេបានត្រឡប់ទៅដល់យេរូសាឡិម។
បន្ទប់ខាងលើ
«នៅក្នុងផ្ទះដែលមានបន្ទប់ខាងលើ»។
ពួកគេរួមចិត្តគំនិតគ្នា
ពាក្យនេះមានន័យថា ពួកសាវក និងពួកអ្នកជឿបានរួមគ្នា និងប្តូរផ្តាច់ជាមួយគ្នាក្នុងគោលបំណងតែមួយ ហើយគ្មានជម្លោះនៅក្នុងចំណោមពួកគេឡើយ។
ព្យាយាមអធិស្ឋាន
ពាក្យនេះមានន័យថា ពួកសិស្សបានអធិស្ឋានជាមួយគ្នាជាប្រចាំ និងញឹកញាប់។
Acts 1:15
ប្រយោគភ្ជាប់
ព្រឹកការណ៍នេះបានកើតឡើង នៅអំឡុងពេលដែលលោកពេត្រុស និងអ្នកជឿផ្សេងៗទៀតនៅជាមួយគ្នានៅបន្ទប់ខាងលើ។
នៅគ្រានោះ
ពាក្យនេះសម្គាល់ពីចំណុចចាប់ផ្តើមនៃសាច់រឿងថ្មី។ ពួកគេសំដៅលើអំឡុងពេលបន្ទាប់ពីព្រះយេស៊ូយាងឡើងទៅស្ថានសួគ៌ ចំណែកពួកសិស្សជួបជុំគ្នានៅបន្ទប់ជាន់លើ។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅអំឡុងពេលនោះ»។
នៅកណ្តាលចំណោមបងប្អូន
ពាក្យ «បងប្អូន» នៅទីនេះ សំដៅលើបងប្អូនអ្នកជឿ ហើយបូករួមទាំងបុរស និងស្ត្រីផង។
ពិតជាសំខាន់ណាស់ដែលអត្ថបទគម្ពីរនឹងពេញលេញ
ពាក្យនេះ អាចនៅក្នុងទម្រង់ដែលមានសកម្មភាព។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលយើងបានអានអំពីបទគម្ពីរ ត្រូវតែបានសម្រេច»។
តាមរយៈព្រះបាទដាវីឌ
ពាក្យ «មាត់» សំដៅលើពាក្យដែលព្រះបាទដាវីឌសរសេរ។ របៀបផ្សេងទៀតនៃការបកប្រែ: «តាមរយៈព្រះបាទដាវីឌ»។
Acts 1:17
ប្រយោគភ្ជាប់
នៅក្នុងខ ១៧
លោកពេត្រុសបានបន្តសុន្ទរកថារបស់គាត់ទៅកាន់អ្នកដែលគាត់បានចាប់ផ្តើមនៅក្នុង ១:១៥។
ព័ត៌មានទូទៅ
នៅក្នុងខ ១៨-១៩
អ្នកនិពន្ធបានប្រាប់អ្នកអានពីព័ត៌មាននៃសាវតាអំពីការដែលលោកយូដា និងកន្លែងដែលគាត់ស្លាប់។
នេះមិនមែនជាផ្នែកនៃសុន្ទរកថារបស់លោកពេត្រុសទេ។
ព័ត៌មានទូទៅ
ទោះបីជា លោកពេត្រុសគឺបញ្ជាក់នៅក្នុងក្រុមមនុស្ស ពាក្យ «យើង» នៅទីនេះ សំដៅទៅលើតែពួកសាវកទេ។
ឥឡូវបុរសម្នាក់នេះ
ពាក្យថា «បុរសនេះ» សំដៅលើ លោកយូដាសអ៊ីស្ការីយ៉ុត។
បានយកប្រាក់ទុច្ចរិតរបស់ខ្លួន
«ប្រាក់ដែលគាត់បានមក ពីអំពើអាក្រក់ដែលគាត់បានធ្វើ»។ ពាក្យថា: «អំពើអាក្រក់របស់ខ្លួន» សំដៅលើលោកយូដាសអ៊ីស្ការីយ៉ុតក្បត់ព្រះយេស៊ូ ដើម្បីឲ្យមនុស្សធ្វើឃាតព្រះអង្គ។
គាត់ដួលផ្តាប់មុខធ្លាយពោះ ចេញពោះវៀនមកក្រៅ
ការនេះប្រហែលជា លោកយូដាធ្លាក់ពីទីខ្ពស់ ឬប្រហែលជាគ្រាន់តែរអិលដួល។ ការដួលនេះធ្ងន់ធ្ងរ ព្រោះធ្វើឲ្យគាត់ធ្លាយពោះវៀន។ បទគម្ពីរផ្សេងទៀតបានចែងថា គាត់ចងករសម្លាប់ខ្លួន។
ចម្ការឈាម
ពេលមនុស្សរស់នៅក្នុងក្រុងយេរូសាឡិមបានឮពីការដែលលោកយូដាសស្លាប់ ពួកគេបានដូរឈ្មោះចម្ការនោះ។
Acts 1:20
ប្រយោគភ្ជាប់
លោកពេត្រុសបន្តសុន្ទរកថារបស់គាត់ជាមួយអ្នកជឿដែលគាត់បានចាប់ផ្តើមនៅក្នុងជំពូក ១:១៥
ព័ត៌មានទូទៅ
ផ្អែកទៅលើស្ថានភាពរបស់លោកយូដា នោះលោកពេត្រុសបានប្រកាស ហើយគាត់បានដកស្រងពីទំនុកតម្កើងរបស់ព្រះបាទដាវីឌពីរខដែលទាក់ទងនឹងរឿងនេះ។ គាត់ដកស្រងនៅខាងចុងខនេះ។
ក្នុងគម្ពីរទំនុកតម្កើងមានចែងទុក
ការនេះអាចចាប់ផ្តើមនៅទម្រង់សកម្មភាព។ របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត ព្រះបាទដាវីឌបានសរសេរនៅក្នុងកណ្ឌទំនុកតម្កើង»។
ចូរឲ្យចម្ការរបស់អ្នកនោះក្លាយទៅជាទីស្ងាត់ជ្រងំ កុំឲ្យមាននរណារស់នៅទីនោះឡើយ
នៅក្នុងឃ្លាទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា។ សេចក្តីបញ្ជាក់ទីពីរមានគំនិតតែមួយតែពាក្យផ្សេងគ្នា។
ក្លាយទៅជាទីស្ងាត់ជ្រងំ
«ក្លាយជាទទេ»។
Acts 1:21
ប្រយោគភ្ជាប់
លោកពេត្រុសបានបញ្ចប់សុន្ទរកថារបស់គាត់ជាមួយអ្នកជឿដែលគាត់បានចាប់ផ្តើមនៅក្នុងជំពូក ១:១៥
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើពួកសាវក មិនបូករួមអ្នកស្តាប់លោកពេត្រុសនិយាយជាមួយទេ។
ហេតុនេះ ជាការសំខាន់ណាស់
ផ្អែកទៅលើបទគម្ពីរដែលគាត់បានដកស្រង់ និងលើអ្វីដែលលោកយូដាបានធ្វើ លោកពេត្រុសបានប្រាប់ក្រុម ពីអ្វីដែលពួកគេត្រូវធ្វើ។
រហូតដល់ពេលព្រះជាម្ចាស់លើកយកព្រះអង្គចេញពីយើងទៅ នេះជាបន្ទាល់អំពីការរស់ឡើងវិញរបស់ព្រះអង្គ
លោកពេត្រុសបានរៀបរាប់ពីគុណសម្បត្តិរបស់មនុស្សដែលជំនួសលោកយូដាស ដើម្បីធ្វើជាសាវក។
ព្រះអម្ចាស់យេស៊ូដែលបានយាងមក និងយាងឡើងទៅក្នុងចំណោមពួកយើង
«ព្រះអម្ចាស់យេស៊ូគង់នៅកណ្តាលចំណោមយើង»។
ចាប់តាំងពីលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹក
អាចមានន័យថា៖ ទីមួយ) «ចាប់តាំងពីលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកឲ្យព្រះយេស៊ូ» ឬ «ចាប់តាំងពីលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកឲ្យប្រជាជន»។ ។
រហូតដល់ពេលព្រះជាម្ចាស់លើកយកព្រះអង្គចេញពីយើងទៅ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «រហូតដល់ពេលព្រះជាម្ចាស់លើកយកព្រះអង្គចេញពីយើងទៅស្ថានសួគ៌»
គេបាននាំសិស្សពីររូបមក

generated on Wed Sep 10 16:16:32 2025

ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើអ្នកជឿទាំងអស់ដែលមានវត្តមាននៅទីនោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេអាចជាបុរសពីរនាក់ដែលអាចបំពេញតម្រូវការដែលលោកពេត្រុសបានរៀបរាប់
ម្នាក់ឈ្មោះយ៉ូសែប ហៅបារសាបាស យូស្ទុស និងម្នាក់ទៀតឈ្មោះម៉ាត់ធាស។
បារសាបាសគឺជាត្រកូលរបស់លោកយ៉ូសែប ឬនាមខ្លួន ប៉ុន្តែ
មនុស្សក៏បានហៅពួកគេផងដែរថា យូស្ទុស។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកយ៉ូសែប បារសាបាស ដែលគេហៅគាត់ថា យូស្ទុស»។
Acts 1:24
ពួកគេក៏នាំគ្នាអធិស្ឋានថា
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើអ្នកជឿទាំងអស់ ប៉ុន្តែ
វាប្រហែលជាសិស្សម្នាក់នៅក្នុងចំណោមពួកសាវកដែលបាននិយាយពាក្យទាំងនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកជឿបានអធិស្ឋានជាមួយគ្នា
ហើយសាវកម្នាក់មានប្រសាសន៍ថា»។
បពិត្រព្រះអម្ចាស់! ព្រះអង្គជ្រាបចិត្តគំនិតរបស់មនុស្សទាំងអស់
ពាក្យ «ចិត្តគំនិត» នៅទីនេះ សំដៅទៅលើគំនិត និងការជំរុញ។
របៀបផ្សេងទៀតនៃការបកប្រែ: «បពិត្រព្រះអម្ចាស់! ព្រះអង្គជ្រាបគំនិត
និងការជម្រុញរបស់មនុស្សទាំងអស់»។
ព្រះអង្គសព្វព្រះហឫទ័យជ្រើសរើសអ្នកណាឲ្យបំពេញមុខងារជាសាវក
ពាក្យ «សាវក» នៅទីនេះ បង្ហាញអ្វីទៅជា «ព័ន្ធកិច្ច»។ ឬ «ជំនួសយូដាស
ក្នុងការបម្រើជាសាវក។
យូដាសបានបោះបង់មុខងារនេះ
ពាក្យ «បោះបង់ចោល» នៅទីនេះ សំដៅលើលោកយូដាសបានបែរចេញពី
ឬឈប់ធ្វើការ នៅក្នុងព័ន្ធកិច្ចនេះ។ របៀបផ្សេងទៀតនៃការបកប្រែ: «យូដាសបាន
បោះបង់មុខងារនេះ»។
សិស្សនាំគ្នាចាប់ឆ្នោត
ពួកសាវកបោះឆ្នោតជ្រើសរើសរវាងលោកយ៉ូសែប និងលោកម៉ាត់ធាស។
ចាប់ឆ្នោតត្រូវលើលោកម៉ាត់ធាស
ឆ្នោតបានបង្ហាញថា លោកម៉ាត់ធាសជាម្នាក់ដែលជំនួសលោកយូដាស។
លោកម៉ាត់ធាសក៏បានចូលរួមក្នុងក្រុមសាវកដប់មួយរូបទៀត
នេះអាចជាទម្រង់សកម្មភាព។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជឿបានរាប់ថាគាត់គឺជាម្នាក់ក្នុងចំណោមពួកសាវកដប់មួយផ្សេងទៀត»។

---

2 [1]នៅបុណ្យថ្ងៃទីហាសិបបានមកដល់ ពួកសិស្សទាំងអស់បានជួបជុំគ្នានៅកន្លែងតែមួយ។[2]រំពេចនោះ ស្រាប់តែមានឮស្នូរសន្ធឹកពីលើមេឃដូចជាខ្យល់បក់បោកយ៉ាង
ខ្លាំង ហើយវាក៏ចូលមកពេញក្នុងផ្ទះទាំងអស់ជាកន្លែងដែលគេកំពុងអង្គុយ។[3]មានអណ្តាតភ្លើងបែកជាចំណែកចេញពីគ្នា ចុះមកសណ្ឋិតលើពួកគេម្នាក់ៗ។[4]អ្នក
ទាំងអស់នោះក៏បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្តើមនិយាយភាសាផ្សេងៗពីគ្នាតាមព្រះវិញ្ញាណប្រោសប្រទានឲ្យ។
[5]នៅសម័យកាលនោះ មានជនជាតិយូដា គឺជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់មកពីប្រជាជាតិនានាក្នុងពិភពលោកទាំងមូលចូលមកស្នាក់នៅក្រុងយេរូសាឡឹម។[6]ពេល
ស្នូរសន្ធឹកលាន់ឮយ៉ាងខ្លាំងនោះ មហាជននាំគ្នាមកមើល ហើយភាន់ភាំង ពីព្រោះពួកគេបានឮពួកសិស្សនិយាយភាសាផ្សេងៗពីគ្នា។[7]បណ្តាជនសូប់ស្ងែងនិងស្ងើច
សរសើរជាខ្លាំងទាំងពោលថា៖ «អ្នកទាំងនេះសុទ្ធតែជាអ្នកស្រុកកាលីឡេមែនទេ?
[8]ហេតុដូចម្តេចបានជាយើងឮគេនិយាយភាសារបស់យើងរៀងៗខ្លួនទៅវិញដូច្នេះ?[9]គឺទាំងអ្នកស្រុកផាថុស ស្រុកមេឌី ស្រុកអេឡាំ ទាំងអ្នកស្រុកមេសូប៉ូតាមា ស្រុកយូដា
ស្រុកកាប៉ាដូគា ស្រុកប៉ុនតុស ស្រុកអាស៊ី[10]ស្រុកព្រីគា ស្រុកប៉ាមភីលា ស្រុកអេស៊ីប ស្រុកលីប៊ីដែលនៅក្បែរស្រុកគីរេន និងអស់អ្នកមកពីក្រុងរ៉ូម[11]ទាំងជនជាតិយូដា ទាំង
អ្នកចូលសាសនាយូដា ទាំងអ្នកមកពីកោះក្រែត ទាំងជនជាតិអារ៉ាប់ យើងបានឮគេថ្លែងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ជាភាសាយើងទាំងអស់គ្នាផ្ទាល់!»។
[12]បណ្តាជនសូប់ស្ងែងនិង មិនដឹងគិតយ៉ាងណា គេសួរគ្នាទៅវិញទៅមកថា៖ «តើហេតុការណ៍នេះ មានន័យដូចម្តេច?»។[13]ប៉ុន្តែ មានអ្នកខ្លះទៀតបែរជានិយាយចំអកថា៖
«ពួកអស់ហ្នឹងសុទ្ធតែស្រវឹងស្រាទេតើ»។
[14]លោកពេត្រុសក៏ក្រោកឈរឡើងជាមួយសាវកដប់មួយរូបទៀត ហើយមានប្រសាសន៍ទៅកាន់បណ្តាជនថា៖ «បងប្អូនយូដា និងបងប្អូនទាំងអស់ដែលស្នាក់នៅក្រុង
យេរូសាឡឹមអើយ! សូមបងប្អូនជ្រាប ហើយផ្ទៀងត្រចៀកស្តាប់ពាក្យរបស់ខ្ញុំ។[15]អ្នកទាំងនេះមិនមែនស្រវឹងស្រាដូចបងប្អូនស្មាននោះទេ ព្រោះទើបតែម៉ោងបីប៉ុណ្ណោះ។
[16]ហេតុការណ៍នេះជាទំនាយ ដែលព្យាការីយ៉ូអែលបានថ្លែងទុកមកថា៖[17]«ព្រះជាម្ចាស់មានព្រះបន្ទូលថា នៅគ្រាចុងក្រោយបង្អស់ ព្រះអង្គនឹងយកវិញ្ញាណព្រះអង្គមកចាក់
បង្ហូរលើមនុស្សលោក។ កូនប្រុសកូនស្រីរបស់អ្នកនឹងថ្លែងព្រះបន្ទូលពួកយុវជននឹងនិមិត្តឃើញការអស្ចារ្យ ហើយពួកចាស់ទុំរបស់អ្នករាល់គ្នានឹងយល់សុបិននិមិត្ត។
[18]ក្នុងថ្ងៃនោះ ព្រះអង្គនឹងផ្តល់ព្រះវិញ្ញាណ បង្ហូរលើអ្នកបម្រើទាំងប្រុសទាំងស្រីរបស់ព្រះអង្គ ហើយពួកគេនឹងថ្លែងព្រះបន្ទូល។[19]ព្រះអង្គនឹងសម្តែងឫទ្ធិបាដិហារិយ៍នៅលើ
មេឃ និងទីសម្គាល់ផ្សេងៗនៅលើផែនដី គឺមានឈាម មានភ្លើង និងមានកំសួលផ្សែង។
[20]ព្រះអាទិត្យនឹងប្រែទៅជាងងឹតបាត់រស្មី ព្រះចន្ទនឹងប្រែទៅជាឈាមនៅមុនថ្ងៃដ៏អស្ចារ្យ និងរុងរឿងឧត្តុង្គឧត្តមពេលព្រះអង្គយាងមក[21]ពេលនោះ អ្នកណាអង្វររកព្រះនាម
ព្រះអម្ចាស់ អ្នកនោះនឹងទទួលការសង្គ្រោះ»។
[22]បងប្អូនអ៊ីស្រាអែលអើយ សូមស្តាប់ពាក្យនេះចុះ! ព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត ព្រះជាម្ចាស់បានបង្ហាញព្រះយេស៊ូដល់អ្នក ដោយព្រះអង្គបានសម្តែងការអស្ចារ្យ
ឫទ្ធិបាដិហារិយ៍ និងទីសម្គាល់ផ្សេងៗ នៅកណ្តាលចំណោមបងប្អូនដូចបងប្អូនបានដឹងហើយ។[23]បងប្អូនបានចាប់បញ្ជូនលោកយេស៊ូនេះ ទៅឲ្យពួកជនពាលឥតសាសនា
ឆ្កាងលោក ដូចព្រះជាម្ចាស់បានកំណត់ទុក ដោយព្រះអង្គជ្រាបជាមុនថា ព្រះអង្គត្រូវសុគតដោយការជាប់ឆ្កាង។[24]ប៉ុន្តែ ព្រះជាម្ចាស់បានប្រោសលោកឲ្យរស់ឡើងវិញ និង
ដោះលែងលោកឲ្យរួចពីទុក្ខលំបាកនៃសេចក្តីស្លាប់ ព្រោះសេចក្តីស្លាប់មិនអាចឃុំលោកទុកបានឡើយ។
[25]ព្រះបាទដាវីឌ មានរាជឱង្ការអំពី លោកយេស៊ូនេះថា៖ ទូលបង្គំបានឃើញព្រះអម្ចាស់នៅមុខទូលបង្គំជានិច្ច ព្រោះព្រះអង្គគង់នៅខាងស្តាំទូលបង្គំមិនឲ្យទូលបង្គំត្រូវ
ញាប់ញ័រឡើយ។[26]ហេតុនេះហើយបានជាចិត្តទូលបង្គំរីករាយទូលបង្គំពោលពាក្យដោយអំណរ ហើយសូម្បីតែរូបកាយរបស់ទូលបង្គំក៏នឹងសម្រាកដោយសេចក្តីសង្ឃឹម
ដែរ។
[27]ដ្បិត ព្រះអង្គនឹងមិនបោះបង់ព្រលឹងទូលបង្គំ ចោលនៅក្នុងស្ថានមនុស្សស្លាប់ឡើយ ហើយព្រះអង្គក៏មិនបណ្តោយឲ្យសពអ្នកបម្រើរបស់ព្រះអង្គត្រូវរលួយដែរ។ ព្រះអង្គ
បានបង្ហាញអោយទូលបង្គំស្គាល់ផ្លូវនៃជីវិត។[28]ព្រះអង្គនឹងប្រទានឲ្យទូលបង្គំមានសុភមង្គលដ៏ពេញលេញដោយព្រះអង្គគង់ជាមួយទូលបង្គំ»។
[29]«បងប្អូនអើយ! ខ្ញុំសូមជម្រាបបងប្អូនឲ្យបានច្បាស់អំពីព្រះបាទដាវីឌ ជាបុព្វបុរសរបស់យើងនោះថា ព្រះអង្គបានសោយទិវង្គតផុតទៅហើយ គេបានបញ្ចុះព្រះសពរបស់
ព្រះអង្គ រីឯផ្នូររបស់ព្រះអង្គក៏ស្ថិតនៅជាមួយយើងរហូតដល់សព្វថ្ងៃដែរ។[30]ដោយព្រះបាទដាវីឌជាព្យាការីមួយរូបទ្រង់ជ្រាបថា ព្រះជាម្ចាស់បានសន្យាយ៉ាងម៉ឺងម៉ាត់ជាមួយ
ព្រះអង្គថា នឹងប្រទានឲ្យព្រះរាជវង្សរបស់ទ្រង់មួយអង្គ ឡើងស្នងរាជ្យ។[31]ព្រះបាទដាវីឌបានឈ្វេងយល់ជាមុនអំពីការរស់ឡើងវិញរបស់ព្រះគ្រិស្ត គឺទ្រង់មានរាជឱង្ការថា
ព្រះជាម្ចាស់ពុំទុកព្រះគ្រិស្តចោលនៅក្នុងស្ថានមនុស្សស្លាប់ទេ ហើយក៏មិនទុកឲ្យសពព្រះអង្គត្រូវរលួយដែរ។
[32]ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឲ្យរស់ឡើងវិញ ដោយយើងខ្ញុំទាំងអស់គ្នាជាសាក្សី។[33]ព្រះជាម្ចាស់បានលើកលោកយេស៊ូឡើងគង់នៅខាងស្តាំព្រះវរបិតា
ហើយបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះបិតាតាមព្រះបន្ទូលសន្យា ហើយព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណនេះមកលើយើងខ្ញុំ ដូចបងប្អូនបានឃើញនិងឮស្រាប់។
[34]ព្រះបាទដាវីឌ មិនបានយាងឡើងទៅស្ថានបរមសុខទេ តែព្រះអង្គមានរាជឱង្ការថា៖ «ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ព្រះអម្ចាស់របស់ខ្ញុំថា សូមគង់ខាងស្តាំយើង។
[35]ទំរាំដល់យើងបង្ក្រាបខ្មាំងសត្រូវរបស់ព្រះអង្គ មកដាក់ក្រោមព្រះបាទារបស់ព្រះអង្គ»។[36]ហេតុនេះ សូមឲ្យជនជាតិអ៊ីស្រាអែលទាំងមូលដឹងជាក់ច្បាស់ថា លោកយេស៊ូនេះ
ដែលបងប្អូនបានឆ្កាង ព្រះជាម្ចាស់បានតែងតាំងលោកឡើងជាព្រះអម្ចាស់ និងជាព្រះគ្រិស្តហើយ»។
[37]នៅពេលបណ្តាជនបានឮសេចក្តីទាំងនេះ ពួកគេរំជួលចិត្តជាខ្លាំង ហើយសួរលោកពេត្រុស និងសាវកឯទៀតៗថា៖ «បងប្អូនអើយ! តើឲ្យយើងខ្ញុំធ្វើដូចម្តេច?»។[38]លោក
ពេត្រុសមានប្រសាសន៍ទៅគេថា៖ «សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូគ្រិស្តទៅ ដើម្បីព្រះជាម្ចាស់លើកលែងទោស
បងប្អូនអោយរួចពីបាប ហើយបងប្អូននឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធជាអំណោយទានរបស់ព្រះជាម្ចាស់[39]ដ្បិតព្រះអង្គមានព្រះបន្ទូលសន្យា ចំពោះបងប្អូនទាំងអស់គ្នា ចំពោះ
កូនចៅរបស់បងប្អូន និងចំពោះអស់អ្នកដែលនៅឆ្ងាយៗទាំងប៉ុន្មានដែរ តាមតែព្រះអម្ចាស់ជាព្រះរបស់យើងត្រាស់ហៅ»។

generated on Wed Sep 10 16:16:32 2025

[40]លោកពេត្រុសបានពន្យល់បញ្ជាក់ និងដាស់តឿនពួកគេ ដោយពាក្យពេចន៍ជាច្រើនទៀត គឺលោកមានប្រសាសន៍ថា៖ «សូមបងប្អូនទទួលការសង្គ្រោះឲ្យរួចផុតពីមនុស្ស
អាក្រក់សម័យនេះ»។[41]បន្ទាប់មកពួកគេបានទទួលពាក្យរបស់លោក និងទទួលពិធីជ្រមុជទឹក ហើយនៅថ្ងៃនោះ មានមនុស្សប្រមាណបីពាន់នាក់ចូលមករួម
ជាមួយពួកសាវក។[42]សិស្សទាំងនោះព្យាយាមស្ដាប់សេចក្ដីបង្រៀនរបស់ក្រុមសាវក និងប្រកបគ្នាជាបងប្អូនដោយធ្វើពិធីកាច់នំប៉័ង និងអធិស្ឋាន។
[43]មនុស្សម្នាកោតស្ញប់ស្ញែងគ្រប់ៗគ្នា ដ្បិតក្រុមសាវកបានសម្តែងឫទ្ធិបាដិហារិយ៍ និងធ្វើទីសម្គាល់ផ្សេងៗជាច្រើន។[44]អស់អ្នកដែលបានជឿលើព្រះអម្ចាស់ មានចិត្តគំនិតតែ
មួយ ហើយយករបស់របរដែលខ្លួនមានមកដាក់រួមគ្នាទាំងអស់។[45]គេលក់ទ្រព្យសម្បត្តិ និងអ្វីៗជារបស់ខ្លួនយកប្រាក់មកចែកគ្នាតាមសេចក្ដីត្រូវការរបស់ពួកគេម្នាក់ៗ។
[46]ជារៀងរាល់ថ្ងៃ គេបន្តរួមចិត្តគំនិតគ្នាធ្វើនៅព្រះវិហារនិងធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរ
ផង។[47]ពួកគេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា។ ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែលព្រះអង្គបានសង្គ្រោះ មកក្នុង
ក្រុមរបស់គេជារៀងរាល់ថ្ងៃ។

Acts 2:1
ព័ត៌មានទូទៅ
នេះគឺជាព្រឹត្តការណ៍ថ្មី នៅពេលនេះគឺជាថ្ងៃទីហាសិប
ហាសិបថ្ងៃបន្ទាប់ពីពិធីបុណ្យចម្លង។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើពួកសាវក និងអ្នកជឿ១២០នាក់ផ្សេងទៀត
ដែលលោកលូកាបាននិយាយនៅក្នុងកណ្ឌលូកា ១:១៥។
រំពេចនោះ
ពាក្យនេះ សំដៅលើព្រឹត្តការណ៍ដែលបានកើតឡើងដោយមិនបានរំពឹងទុក។
ស្រាប់តែមានឮស្នូរសន្ធឹកពីលើមេឃ
ន័យទី១ អាច «ស្ថានសួគ៌» សំដៅទៅកាន់ទីកន្លែងដែលព្រះគង់នៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្រាប់តែមានឮស្នូរសន្ធឹកពីលើមេឃ» ឬ ២
«ស្ថានសួគ៌» សំដៅលើមេឃ។ របៀបផ្សេងទៀតនៃការបកប្រែ: «ស្រាប់តែមានឮ
ស្នូរសន្ធឹកពីលើមេឃ»។
ដូចជាខ្យល់បក់បោកយ៉ាងខ្លាំង
«មានឮស្នូរសន្ធឹកពីលើមេឃដូចជាខ្យល់បក់បោកយ៉ាងខ្លាំង»
ពេញក្នុងផ្ទះទាំងអស់
នេះអាចជាផ្ទះ ឬអាចជាអគារដែលធំជាងផ្ទះ។
មានអណ្ដាតភ្លើងបែកជាចំណែកចេញពីគ្នា
ទាំនអាចមិនមែនជាអណ្ដាតឬភ្លើងពិតប្រាកដទេ ប៉ុន្តែ
ជាអ្វីមួយដែលស្រដៀងនឹងវា។ ន័យទី១) អណ្ដាតដែលមើលទៅដូចជាអណ្ដាតភ្លើង
ឬទី២) អាចជាអណ្ដាតភ្លើងតូចមួយដែលមើលទៅដូជាអណ្ដាត។
នៅពេលភ្លើងឆេះនៅកន្លែងតូចមួយ ដូចជាអំពូលភ្លើងមួយ
អំពូលភ្លើងអាចមានសណ្ឋានដូចជាអណ្ដាតមួយ។
ចុះមកសណ្ឋិតលើពួកគេម្នាក់ៗ
ឃ្លានេះមានន័យថា៖ «អណ្ដាតដូចជាភ្លើង» បែងខ្ញែកទៅលើមនុស្សម្នាក់ៗ។
អ្នកទាំងអស់នោះក៏បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ
នេះអាចជាទម្រង់សកម្ម។ ប្រែម្យ៉ាងទៀតថា:
«ព្រះវិញ្ញាណដ៏វិសុទ្ធបានបំពេញអស់អ្នកដែលនៅទីនោះ ហើយពួកគេ»។
ចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា
ភាសាទាំងនេះគឺជាភាសាដែលពួកគេមិនដឹងពីមុន។
Acts 2:5
ព័ត៌មានទូទៅ
ខ៥ផ្ដល់ព័ត៌មានទូទៅអំពីចំនួនជនជាតិយូដាជាច្រើនដែលរស់នៅក្នុងក្រុងយេរូសាឡិម
មានជនជាតិយូដាជាច្រើនដែលមានវត្តមាននៅក្នុងក្រុងយេរូសាឡិម
នៅក្នុងអំឡុងពេលព្រឹត្តការណ៍នោះ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើពួកអ្នកជឿ។ ពាក្យថា: «គាត់»
សំដៅលើមនុស្សម្នាក់ៗនៅក្នុងហ្វូងមនុស្ស។
អ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់
ពាក្យ៖ «អ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់»
សំដៅលើមនុស្សដែលជឿព្រះដែលពួកគេថ្វាយបង្គំ
ហើយព្យាយាមក្នុងការស្ដាប់បង្គាប់តាមច្បាប់របស់ជនជាតិយូដាទាំងអស់។
ប្រជាជាតិនានាក្នុងពិភពលោកទាំងមូល
«ប្រជាជាតិនានាក្នុងពិភពលោកទាំងមូល»។ នេះគឺជាការនិយាយបំផ្លើស
ក្នុងការបញ្ជាក់ថាមនុស្សមានពីប្រជាជាតិជាច្រើនផ្សេងគ្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជាតិផ្សេងៗជាច្រើន»។
ពេលស្នូរសន្ធឹកលាន់ឮយ៉ាងខ្លាំងនោះ
នេះសំដៅលើសម្លេងដែលប្រហាក់ប្រហែលជាសម្លេងខ្យល់បក់ខ្លាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលពួកគេឮសម្លេងនេះ»។
មហាជន
«ហ្វូងមនុស្សយ៉ាងធំ»
ពួកគេស្ងប់ស្ងែងនិងស្ញើចសរសើរ
ពាក្យពីរនេះ ប្រហាក់ប្រហែលគ្នា។ ពាក្យទាំងពីរនេះបង្ហាញពីការភ្ញាក់ផ្អើល។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេភ្ញាក់ផ្អើលយ៉ាងខ្លាំង»។
អ្នកដែលនិយាយទាំងនេះសុទ្ធតែជាអ្នកស្រុកកាលីឡេមែនទេ?
មនុស្សបានសួរសំណួរនេះ ដើម្បីបង្ហាញពីការភ្ញាក់ផ្អើលរបស់ពួកគេ។
សំណួរអាចប្ដូរទៅជាការលាន់មាត់។ ប្រែម្យ៉ាងទៀតថា: «អ្នកស្រុកកាលីឡេទាំងនេះ
មិនអាចចេះភាសារបស់យើងទេ»។
Acts 2:8
ហេតុដូចម្តេចបានជាយើងឮគេនិយាយភាសារបស់យើងរៀងៗខ្លួនទៅវិញដូច្នេះ?
អត្ថន័យទី១ អាច ១) នេះគឺជាសំណួរដែលមិនទាមទារចម្លើយ
ដែលបង្ហាញថាពួកគេភ្ញាក់ផ្អើលយ៉ាងណា ឬ ទី២) នេះគឺជាសំណួរពិត
សម្រាប់មនុស្សដែលចង់បានចម្លើយ។
ជាភាសាកំណើតរបស់យើងទាំងអស់គ្នាផ្ទាល់
«ជាភាសាកំណើតរបស់យើង ដែលយើងទាំងអស់គ្នាបានរៀនតាំងពីកើតមក»
អ្នកស្រុកផាថុស...ជនជាតិអារ៉ាប់
បញ្ជីនេះ មានប្រទេស សាសនា និងទីក្រុងមួយចំនួន ដែលពួកគេបានមក។
អ្នកចូលសាសនាយូដា
«អ្នកជឿលើសាសនាយូដា»។
Acts 2:12
ស្ងប់ស្ងែងនិង មិនដឹងគិតយ៉ាងណា
ពាក្យពីរនេះមានន័យប្រហែលគ្នា។
ពាក្យទាំងពីរនេះបញ្ជាក់ថាមនុស្សមិនយល់ពីអ្វីដែលកំពុងកើតឡើងទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ភ្ញាក់ផ្អើល ហើយវង្វេង»។
ពួកអស់ហ្នឹងសុទ្ធតែស្រវឹងស្រាទេតើ
អ្នកខ្លះចោទប្រកាន់ថា អ្នកជឿបានស្រវឹងដោយសារផឹកស្រាច្រើនពេក។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេស្រវឹង»។
ស្រាថ្មី
នេះសំដៅលើស្រាដែលស្ថិតនៅក្នុងដំណើរការនៃការធ្វើឲ្យក្លាយជាស្រា។
Acts 2:14
ប្រយោគភ្ជាប់
លោកពេត្រុសបានចាប់ផ្ដើមសុន្ទរកថារបស់គាត់ទៅកាន់ជនជាតិយូដា
ដែលមកចូលរួមបុណ្យថ្ងៃទីហាសិប។
ឈរឡើងជាមួយសាវកដប់មួយរូប
សាវកទាំងអស់បានឈរជាមួយដើម្បីគាំទ្រប្រសាសន៍របស់លោកពេត្រុស។
សូមបងប្អូនជ្រាប
នេះមានន័យថា
លោកពេត្រុសកំពុងពន្យល់ពីអត្ថន័យនៃអ្វីដែលមនុស្សបានធ្វើបន្ទាល់។
នេះអាចជាទម្រង់នៃសកម្មភាព។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមដឹងពីការនេះ» ឬ «សូមឲ្យខ្ញុំជម្រាបដល់បងប្អូនពីការនេះ»។
សូមផ្ទៀងត្រចៀកស្ដាប់ពាក្យរបស់ខ្ញុំ
លោកពេត្រុសកំពុងសំដៅលើអ្វីដែលគាត់កំពុងនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមស្ដាប់ដោយយកចិត្តទុកដាក់នូវអ្វីដែលខ្ញុំកំពុងនិយាយនេះ»។
ព្រោះទើបតែម៉ោងទីបីប៉ុណ្ណោះ
«ទើបតែម៉ោងប្រាំបួនព្រឹកប៉ុណ្ណោះ»
Acts 2:16

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ

នៅទីនេះ
លោកពេត្រុសប្រាប់ពួកគេពីបទគម្ពីរដែលព្យាការីយ៉ូអែលសរសេរនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់
ដែលទាក់ទងអ្វីដែលបានកើតឡើងជាមួយនឹងភាសាដែលអ្នកជឿកំពុងនិយាយ។
ពាក្យនេះ ត្រូវបានសរសេរឡើងនៅក្នុងទម្រង់កំណាព្យ
ហើយគាត់បានដកស្រង់វាមក។

នេះជាទំនាយ ដែលព្យាការីយ៉ូអែលបានថ្លែងទុកមក

នេះអាចជាទម្រង់សកម្ម។ ប្រែម្យ៉ាងទៀតថា:
«នេះគឺជាអ្វីដែលព្រះជាម្ចាស់បានប្រាប់ដល់ព្យាការីយ៉ូអែលឲ្យសរសេរ» ឬ
«នេះគឺជាអ្វីដែលព្យាការីយ៉ូអែលបានថ្លែង»។

នឹងមាន

«នេះគឺជាអ្វីដែលនឹងកើតឡើង» ឬ «នេះគឺជាអ្វីដែលយើងនឹងធ្វើ»

យើងនឹងយកវិញ្ញាណព្រះអង្គមកចាក់បង្ហូរលើមនុស្សលោក

ពាក្យនៅទីនេះ «ចាក់បង្ហូរ» មានន័យថា នឹងប្រទានដោយសទ្ធានិងបរិបូរ។
ប្រែម្យ៉ាងទៀតថា:
«យើងនឹងប្រទានព្រះវិញ្ញាណរបស់យើងជាបរិបូរដល់មនុស្សលោកគ្រប់គ្នា»។
Acts 2:18

ប្រយោគភ្ជាប់

លោកពេត្រុសបន្តដកស្រង់ពីព្យាការីយ៉ូអែល។

អ្នកបម្រើទាំងប្រុសទាំងស្រីរបស់យើង

«ទាំងអ្នកបម្រើទាំងប្រុសទាំងស្រីរបស់យើង»។ ពាក្យនេះ បញ្ជាក់ថា
ព្រះជាម្ចាស់នឹងចាក់បង្ហូរព្រះវិញ្ញាណរបស់ទ្រង់ទៅលើអ្នកបម្រើរបស់ព្រះអង្គ
ទាំងបុរស និងស្ត្រី។

យើងនឹងចាក់ព្រះវិញ្ញាណរបស់យើង

ពាក្យ «ចាក់បង្ហូរ» នៅទីនេះ មានន័យថា នឹងប្រទានដោយសទ្ធា និងជាបរិបូរ។
ប្រែម្យ៉ាងទៀតថា:
«យើងនឹងប្រទានព្រះវិញ្ញាណរបស់យើងជាបរិបូរដល់មនុស្សគ្រប់រូប»។
មើលពីរបៀបដែលអ្នកត្រូវបកប្រែនៅក្នុង ២:១៦។

កំសួលផ្សែង

«ផ្សែងយ៉ាងក្រាស់» ឬ «ផ្សែងពពក»។
Acts 2:20

ប្រយោគភ្ជាប់

លោកពេត្រុសបានបញ្ចប់ការដកស្រង់ពីព្យាការីយ៉ូអែល។

ព្រះអាទិត្យនឹងប្រែទៅជាងងឹតបាត់រស្មី

នេះមានន័យថា ព្រះអាទិត្យនឹងប្រែជាងងឹតលែងភ្លឺទៀតហើយ។ ប្រែម្យ៉ាងទៀតថា:
«ព្រះអាទិត្យនឹងត្រឡប់ទៅជាងងឹត»។

ព្រះចន្ទនឹងប្រែទៅជាឈាម

នេះមានន័យថា ព្រះចន្ទនឹងប្រែជាក្រហមដូចជាឈាម។ ប្រែម្យ៉ាងទៀតថា:
«ហើយព្រះចន្ទនឹងប្រែជាក្រហម»។

ថ្ងៃដ៏អស្ចារ្យ និងរុងរឿងឧត្តុង្គឧត្តម

ពាក្យ «អស្ចារ្យ» និង «គួរឲ្យកត់សម្គាល់» មានន័យប្រហាក់ប្រហែលគ្នា
ហើយបញ្ជាក់ន័យពីភាពអស្ចារ្យ។ ប្រែម្យ៉ាងទៀតថា: «ជាថ្ងៃដ៏អស្ចារ្យណាស់»។

អ្នកណាអង្វររកព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងទទួលការសង្គ្រោះ

នេះអាចជាទម្រង់សកម្ម។ ប្រែម្យ៉ាងទៀតថា:
«ព្រះអម្ចាស់នឹងសង្គ្រោះមនុស្សគ្រប់គ្នា ដែលអំពាវនាវរកព្រះអង្គ»។
Acts 2:22

ប្រយោគភ្ជាប់

លោកពេត្រុសបន្តសន្ទរកថារបស់គាត់ទៅកាន់ជនជាតិយូដាដែលគាត់បានមានប្រសាសន៍ទៅកាន់ក្នុង
១:១៥

សូមស្តាប់ពាក្យនេះចុះ

«សូមស្តាប់អ្វីដែលខ្ញុំនឹងនិយាយចុះ»

ព្រះជាម្ចាស់បានបង្ហាញ... ដោយសម្តែងការអស្ចារ្យ ឫទ្ធិបាដិហារិយ៍ និងទីសម្គាល់ផ្សេងៗ។

នេះមានន័យថា ព្រះជាម្ចាស់បានបង្ហាញថា
ព្រះជាម្ចាស់បានជ្រើសរើសព្រះយេស៊ូបំពេញបេសកកម្មរបស់ព្រះអង្គ
ដោយប្រទានឲ្យព្រះយេស៊ូសម្តែងការអស្ចារ្យជាច្រើន។

ជាម្ចាក់ដែលព្រះជាម្ចាស់បានកំណត់មកសម្រាប់អ្នក

ជាម្ចាក់ដែលត្រូវបានកំណត់ដោយព្រះជាម្ចាស់សម្រាប់អ្នក»។

ព្រោះព្រះជាម្ចាស់មានផែនការកំណត់ ហើយទ្រង់បានជ្រាបជាមុន

នេះមានន័យថា ព្រះជាម្ចាស់បានមានផែនការ
ហើយជ្រាបជាមុននូវអ្វីដែលអាចនឹងកើតឡើងចំពោះព្រះយេស៊ូ។ ប្រែម្យ៉ាងទៀតថា:
«ព្រោះព្រះជាម្ចាស់មានផែនការ
ហើយជ្រាបជាមុនអ្វីៗគ្រប់យ៉ាងដែលអាចនឹងកើតឡើង»។

ព្រះអង្គនឹងត្រូវបានគេចាប់បញ្ជូន

អត្ថន័យទី១) «អ្នកបានចាប់បញ្ជូនព្រះយេស៊ូទៅក្នុងដៃរបស់ខ្មាំងសត្រូវ»

អ្នកនឹងបញ្ជូនទ្រង់ទៅឲ្យពួកជនពាលឆ្កាង និងសម្លាប់លោក

ពិតណាស់ ទោះបីជា «ពួកជនពាល»ឆ្កាងព្រះយេស៊ូ
លោកពេត្រុសបានចោទប្រកាន់ទៅលើបណ្តាជន ដោយសារពួកគេបានសម្លាប់
ព្រោះពួកគេចង់ឲ្យព្រះអង្គសុគត។

ដោយសារហេតុនេះ បានជាពួកគេចង ហើយធ្វើទុក្ខដល់សុគត។

លោកពេត្រុសមានប្រសាសន៍ពីការសុគត
ព្រោះពួកគេបានធ្វើជាមួយទ្រង់ដូចជាអ្នកទោស ហើយធ្វើឲ្យអ្នកនោះរងទុក្ខ។

ត្រូវបានដោះរួចពីការឈឺចាប់នៃសេចក្តីស្លាប់... ដោយសារការនោះ

លោកពេត្រុសមានប្រសាសន៍ពីសេចក្តីស្លាប់
ប្រៀបដូចជាមនុស្សម្នាក់ដែលជាអ្នកទោស ហើយធ្វើឲ្យគេរងទុក្ខ។

ដោះលែងលោកឲ្យរួចពីទុក្ខលំបាកនៃសេចក្តីស្លាប់

លោកពេត្រុសមានប្រសាសន៍អំពីសេចក្តីស្លាប់
ប្រៀបដូចជាចំណងដែលចងមនុស្សជាមួយចំណងនៃភាពឈឺចាប់។
ប្រែម្យ៉ាងទៀតថា:
«មានសេរីភាពពីការឈឺចាប់ដែលតកើតឡើងដោយសេចក្តីស្លាប់»។

សេចក្តីស្លាប់មិនអាចឃុំលោកទុកបានឡើយ

«នោះសេចក្តីស្លាប់មិនអាចឃុំព្រះអង្គបានឡើយ»។ នេះអាចជាទម្រង់សកម្ម។
ប្រែម្យ៉ាងទៀតថា: «នោះសេចក្តីស្លាប់នឹងកាន់ទ្រង់ជាប់»។ ឬ
«សេចក្តីស្លាប់នោះនឹងមិនអាចយកឈ្នះអំណាចរបស់ព្រះអង្គបានឡើយ»។
Acts 2:25

ព័ត៌មានទូទៅ

នៅទីនេះ
លោកពេត្រុសបានដកស្រង់បទគម្ពីរដែលព្រះបាទដាវីឌសរសេរនៅក្នុងកណ្ឌទំនុកតម្កើង
ដែលទាក់ទងនឹងការជាប់ឆ្កាង និងការរស់ឡើងវិញរបស់ព្រះយេស៊ូ។

ព័ត៌មានទូទៅ

នៅពេលលោកពេត្រុសមានប្រសាសន៍ថា៖
ព្រះបាទដាវីឌមានរាជឱង្ការសេចក្តីទាំងនេះទាក់ទងនឹងព្រះយេស៊ូ ពាក្យ «ខ្ញុំ» និង
«របស់ខ្ញុំ» សំដៅលើព្រះយេស៊ូ និងពាក្យ «ព្រះអម្ចាស់» និង «ទ្រង់»
សំដៅលើព្រះជាម្ចាស់។

នៅមុខទូលបង្គំ

«នៅចំពោះមុខខ្ញុំ»។ ប្រែម្យ៉ាងទៀតថា: «នៅក្នុងវត្តមានខ្ញុំ» ឬ «ជាមួយខ្ញុំ»

នៅខាងស្តាំទូលបង្គំ

ការនៅ «ខាងស្តាំដៃ» នរណាម្នាក់ ជាញឹកញាប់សំដៅលើ តួនាទីក្នុងការជួយ
និងទ្រទ្រង់។ ប្រែម្យ៉ាងទៀតថា: «នៅជាមួយខ្ញុំ ដើម្បីជួយខ្ញុំ»។

មិនឲ្យទូលបង្គំត្រូវញាប់ញ័រឡើយ

ពាក្យ «ញាប់ញ័រ» នៅទីនេះមានន័យថា ចប់បារម្ភ ។ នេះគឺជាទម្រង់សកម្ម។
ប្រែម្យ៉ាងទៀតថា: «មនុស្សមិនអាចធ្វើឲ្យខ្ញុំចប់បារម្ភឡើង» ឬ
គ្មានអ្វីអាចធ្វើឲ្យខ្ញុំចប់បារម្ភឡើយ»។

ចិត្តទូលបង្គំរីករាយ ហើយអណ្តាត ទូលបង្គំពោលពាក្យដោយអំណរ

មនុស្សគិតថា «ដួងចិត្ត» ចំណុចកណ្តាលនៃអារម្មណ៍ ហើយ «អណ្តាត»
គឺជាសម្តែងនៃអារម្មណ៍។ អាចប្រែម្យ៉ាងទៀតថា: «ខ្ញុំមានអំណរ
ហើយអរសប្បាយ»។

រូបកាយទូលបង្គំក៏នឹងសម្រាកដោយសេចក្តីសង្ឃឹមដែរ។

ពាក្យ «រូបកាយ» អាចមានន័យ ទី១) គាត់ជាមនុស្ស ដែលនឹងស្លាប់។
ប្រែម្យ៉ាងទៀតថា: «ទោះបីទូលបង្គំគ្រាន់តែជាមនុស្សក្តី
ទូលបង្គំទុកចិត្តលើព្រះជាម្ចាស់»។ ឬ ទី២) វាគឺជារូបកាយរបស់គាត់ទាំងមូល។
ប្រែម្យ៉ាងទៀតថា: «ខ្ញុំនឹងរស់នៅដោយទុកចិត្តនៅក្នុងព្រះជាម្ចាស់»។
Acts 2:27

ប្រយោគភ្ជាប់

លោកពេត្រុសបានបញ្ចប់ការដកស្រង់ពីព្រះបាទដាវីឌ។

ព័ត៌មានទូទៅ

នៅពេលលោកពេត្រុសមានប្រសាសន៍ថា
ព្រះបាទដាវីឌមានរាជឱង្ការសេចក្តីទាំងនេះទាក់ទងនឹងព្រះយេស៊ូ ពាក្យថា: «ខ្ញុំ»
«ព្រះដ៏វិសុទ្ធ»។ ហើយ «ខ្ញុំ» សំដៅលើព្រះយេស៊ូ និងពាក្យថា: «អ្នក» និង

generated on Wed Sep 10 16:16:32 2025

«របស់អ្នក» សំដៅលើព្រះជាម្ចាស់។
ព្រះអង្គក៏មិនបណ្តោយឲ្យសពអ្នកបម្រើរបស់ព្រះអង្គត្រូវរលួយដែរ
ព្រះមេស្ស៊ី ព្រះយេស៊ូ សំដៅលើអង្គទ្រង់ជាមួយនឹងពាក្យថា៖ «អ្នកបរិសុទ្ធរបស់ព្រះអង្គ»។ ប្រែម្យ៉ាងទៀតថា: «ព្រះអង្គមិនបណ្តោយទូលបង្គំ ជាអ្នកបរិសុទ្ធត្រូវពុករលួយឡើយ»។
ឃើញនឹងភាពពុករលួយ
ពាក្យ «ឃើញ» មានន័យថាមានបទពិសោធន៍ជាមួយអ្វីមួយ។ ពាក្យថា: «ពុករលួយ» សំដៅលើការស្អុយរលួយនៃរូបកាយរបស់គាត់បន្ទាប់ពីស្លាប់។ អាចប្រែម្យ៉ាងទៀតថា: «ពុករលួយ»
ផ្លូវនៃជីវិត
«ផ្លូវដែលនាំទៅកាន់ជីវិត»។
មានទឹកមុខពេញដោយអំណរ
ពាក្យ «មុខ» នៅទីនេះ សំដៅលើវត្តមានរបស់ព្រះជាម្ចាស់។ អាចប្រែម្យ៉ាងទៀតថា: «សប្បាយចិត្តខ្លាំងណាស់ពេលបានជួបអ្នក» ឬ សប្បាយចិត្តណាស់ពេលខ្ញុំបាននៅក្នុងវត្តមានរបស់អ្នក»។
អំណរ
«អំណរ» ឬ «សុភមង្គល»
Acts 2:29
ប្រយោគភ្ជាប់
លោកពេត្រុសបានបន្តសុន្ទរកថាដែលគាត់បានថ្លែងនៅក្នុង ១:១៥ ទៅកាន់ជនជាតិយូដា ដែលនៅជុំវិញគាត់ ហើយអ្នកជឿផ្សេងទៀតនៅក្នុងយេរូសាឡិម។
ព័ត៌មានទូទៅ
នៅក្នុងខ ២៩&៣០ ពាក្យថា គាត់ «របស់គាត់» និង «គាត់» សំដៅលើព្រះបាទដាវីឌ។ នៅក្នុងខ ៣១ ទី១ «គាត់» សំដៅលើព្រះបាទដាវីឌ និងពាក្យនៅក្នុងការដែលគាត់បានដកស្រង់ «គាត់» និង «របស់គាត់» សំដៅលើព្រះគ្រិស្ត។
បងប្អូនអើយ
«បងប្អូនជនជាតិយូដា»
អ្នកទាំងពីរបានស្លាប់ ហើយត្រូវបានបញ្ចុះក្នុងផ្នូរ
ឃ្លានិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតក្នុងការបកប្រែ: «គាត់បានស្លាប់ ហើយមនុស្សបានបញ្ចុះសពគាត់ ។
ទ្រង់គឺជាផលដំបូងនៃរូបកាយរបស់គាត់នៅលើបល្ល័ង្ករបស់ទ្រង់។
«ព្រះជាម្ចាស់បានតាំងពូជពង្សរបស់ព្រះបាទដាវីឌឲ្យសោយរាជ្យ។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«ព្រះជាម្ចាស់នឹងតាំងពូជពង្សរបស់ដាវីឌឲ្យធ្វើជាស្តេចលើរាជបល្ល័ង្ករបស់ដាវីឌ»។
ព្រះរាជវង្សរបស់ទ្រង់មួយអង្គ
ពាក្យ «ផលផ្លែ» នៅត្រង់នេះ សំដៅលើអ្វីដែល «រូបកាយរបស់ទ្រង់» បានបង្កើត។ របៀបផ្សេងទៀតក្នុងការបកប្រែ: «ព្រះរាជវង្សរបស់ទ្រង់មួយអង្គ»
ព្រះបាទដាវីឌបានឈ្វេងយល់ជាមុន
«ទ្រង់ជ្រាបការនេះ មុនពេលវាកើតឡើង»។
លោកពេត្រុសប្រើភាសានេះដើម្បីនិយាយពីអ្វីមួយដែលបានដឹងមុន ដូចជាបានឃើញមុនពេលវាកើតឡើង។
ទ្រង់បានឈ្វេងយល់
នៅក្នុងករណីនេះ ព្រះជាម្ចាស់បានធ្វើឲ្យព្រះបាទដាវីឌមានរាជឱង្ការអំពីការរស់ឡើងវិញរបស់ព្រះមេស្ស៊ី។
ព្រះជាម្ចាស់ពុំទុកព្រះគ្រិស្តចោលនៅក្នុងស្ថានមនុស្សស្លាប់ទេ
ឃានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«ព្រះជាម្ចាស់មិនបានទុកឲ្យទ្រង់នៅក្នុងស្ថានមនុស្សស្លាប់ឡើយ»។
មិនទុកឲ្យសពព្រះអង្គត្រូវរលួយ
ពាក្យ «ជួប» នៅទីនេះ មានន័យថា មានបទពិសោធន៍ជាមួយអ្វីមួយ។ ពាក្យថា៖ «រលួយ» សំដៅលើរូបកាយរបស់ទ្រង់បន្ទាប់ពីសុគត។ របៀបផ្សេងទៀតក្នុងការបកប្រែ: «រូបកាយរបស់ទ្រង់នឹងជួបនឹងភាពពុករលួយ»។ ឬ «រូបកាយរបស់ទ្រង់នៅតែស្លាប់រហូតដល់រូបកាយពុករលួយឡើយ»
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ២:២៧។ ។
Acts 2:32
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើ ពួកសិស្ស និងអស់អ្នកដែលបានធ្វើបន្ទាល់ពីការរស់ឡើងវិញរបស់ព្រះយេស៊ូ បន្ទាប់ពីព្រះអង្គសុគត។
ព្រះជាម្ចាស់បានលើកទ្រង់ឡើង
ពាក្យ «លើកឡើង» សំដៅលើ ព្រះជាម្ចាស់បានលើកព្រះយេស៊ូពីសុគតឡើងវិញ។
បានលើកឡើងគង់នៅខាងស្តាំព្រះជាម្ចាស់
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបមួយទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានលើកព្រះយេស៊ូឡើង ដើម្បីឲ្យគង់នៅខាងស្តាំព្រះហស្តព្រះអង្គ។
បានលើកឡើងគង់នៅខាងស្តាំព្រះហស្ត
ឃ្លានេះសំដៅលើ ព្រះជាម្ចាស់បានលើកតម្កើងព្រះយេស៊ូ ទៅក្នុងតំណែងនៃកិត្តិយស និងសិទ្ធិអំណាច។
ព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណនេះ
ពាក្យ «ចាក់បង្ហូរ» មានន័យថា ព្រះយេស៊ូជាព្រះជាម្ចាស់ដែលធ្វើឲ្យការនេះកើតឡើង។ វាគឺជាការចាក់បំពេញដែលព្រះអង្គបានធ្វើការនេះ ដោយព្រះវិញ្ញាណដ៏វិសុទ្ធដល់អ្នកជឿ។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«ព្រះអង្គបានធ្វើឲ្យការទាំងនេះបានកើតឡើង»។
Acts 2:34
ប្រយោគភ្ជាប់
លោកពេត្រុសបានបញ្ចប់សុន្ទរកថារបស់គាត់ទៅកាន់ជនជាតិយូដាដែលលោកបានចាប់ផ្តើមនៅក្នុង ១:១៥
ព័ត៌មានទូទៅ
លោកពេត្រុសបានដកស្រង់ទំនុកតម្កើងមួយរបស់ព្រះបាទដាវីឌ។ ព្រះបាទដាវីឌមិនបានមានរាជឱង្ការពីអង្គទ្រង់ទេ នៅក្នុងទំនុកតម្កើងនេះ។ «ព្រះអម្ចាស់» និង «របស់ខ្ញុំ» សំដៅលើព្រះជាម្ចាស់ «ព្រះអម្ចាស់របស់ខ្ញុំ» និង «របស់អ្នក» សំដៅលើព្រះយេស៊ូ ជាព្រះមេស្ស៊ី។
ទំរាំដល់យើងបង្ក្រាបខ្មាំងសត្រូវរបស់ព្រះអង្គ មកដាក់ក្រោមព្រះបាទារបស់ព្រះអង្គ
ឃ្លានេះ មានន័យថា ព្រះជាម្ចាស់នឹងយកឈ្នះលើខ្មាំងសត្រូវរបស់ព្រះមេស្ស៊ី ហើយធ្វើឲ្យពួកគេចុះចូលជាមួយព្រះអង្គសិន។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«ទំរាំ យើងបានធ្វើឲ្យអ្នកឈ្នះលើខ្មាំងសត្រូវទាំងអស់របស់អ្នកសិន»។
ជនជាតិអ៊ីស្រាអែលទាំងមូល
ឃ្លានេះសំដៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។ បៀបផ្សេងទៀតក្នុងការបកប្រែ:
«ជនជាតិអ៊ីស្រាអែលគ្រប់រូប»
Acts 2:37
ប្រយោគភ្ជាប់
ជនជាតិយូដាបានឆ្លើយតបទៅកាន់សុន្ទរកថារបស់លោកពេត្រុស ហើយលោកពេត្រុសបានឆ្លើយទៅកាន់ពួកគេ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើមនុស្សនៅក្នុងហ្វូងមនុស្ស ដែលលោកពេត្រុសបាននិយាយជាមួយ។
នៅពេលបណ្តាជនបានឮសេចក្តីទាំងនេះ
«នៅពេលប្រជាជនបានឮអ្វីដែលលោកពេត្រុសមានប្រសាសន៍»។
ពួកគេរំជួលចិត្តជាខ្លាំង
ឃ្លានេះនិយាយជាទម្រង់សកម្ម។ បៀបផ្សេងទៀតក្នុងការបកប្រែ:
«ពាក្យរបស់លោកពេត្រុសបានចាក់ចុចចិត្តរបស់ពួកគេ»។
ពួកគេរំជួលចិត្តជាខ្លាំង
ឃ្លានេះមានន័យថា មនុស្សមានអារម្មណ៍ថាគេមានកំហុស ហើយពួកគេមានការសោកស្តាយជាខ្លាំង។ បៀបផ្សេងទៀតក្នុងការបកប្រែ:
«មានការព្រួយចិត្តជាខ្លាំង»។
ត្រូវទទួលពិធីជ្រមុជទឹក
ឃ្លានេះ នៅក្នុងទម្រង់សកម្ម។ បៀបផ្សេងទៀតក្នុងការបកប្រែ:
«សូមឲ្យយើងជ្រមុជទឹកឲ្យអ្នករាល់គ្នា»
ព្រះអង្គមានព្រះបន្ទូលសន្យា ចំពោះបងប្អូនទាំងអស់គ្នា
«ព្រោះព្រះបន្ទូលសន្យានេះសម្រាប់បងប្អូន»។
ចំពោះអស់អ្នកដែលនៅឆ្ងាយៗទាំងប៉ុន្មានដែរ
ឃ្លានេះអាចមានន័យថា ទី១) «មនុស្សទាំងអស់ដែលរស់នៅទីឆ្ងាយៗ» ឬ ទី២) «មនុស្សគ្រប់គ្នាដែលរស់នៅឆ្ងាយពីព្រះជាម្ចាស់»។
Acts 2:40
ប្រយោគភ្ជាប់
នេះគឺជាចុងបញ្ចប់នៃសាច់រឿង ដែលបានកើតឡើងនៅថ្ងៃទីហាសិប។ នៅក្នុង ខ ៤២

generated on Wed Sep 10 16:16:32 2025

បានចាប់ផ្តើមនៅក្នុងវគ្គដែលពន្យល់ពីរបៀបរបស់អ្នកជឿបន្តរស់នៅបន្ទាប់ពីថ្ងៃទីហាសិប។ សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ២:២២។

លោកពេត្រុសបានពន្យល់បញ្ជាក់ និងដាស់តឿនពួកគេ

«លោកបានប្រាប់ពួកគេយ៉ាងច្បាស់ ហើយអង្វរពួកគេផង»។ ពាក្យ «ធ្វើបន្ទាល់នៅទីនេះ» និង «អង្វរ» មានន័យប្រហាក់ប្រហែលគ្នា ហើយបានបញ្ជាក់ថា លោកពេត្រុសបានដាស់តឿនពួកគេយ៉ាងខ្លាំង ក្នុងការឆ្លើយតបចំពោះអ្វីដែលគាត់បាននិយាយ។ បៀបផ្សេងទៀតក្នុងការបកប្រែ: «គាត់បានទូន្មានយ៉ាងខ្លាំងដល់ពួកគេ»។

សូមបងប្អូនទទួលការសង្គ្រោះឲ្យរួចផុតពីមនុស្សអាក្រក់សម័យនេះ

ការប៉ះពាល់គឺថា ព្រះជាម្ចាស់នឹងដាក់ទោស «មនុស្សអាក្រក់នៅក្នុងជំនាន់នេះ»។ បៀបផ្សេងទៀតក្នុងការបកប្រែ: «ចូរសង្គ្រោះខ្លួនអ្នកពីការដាក់ទោសដែលមនុស្សអាក្រក់នឹងទទួលរង»។

ពួកគេបានទទួលពាក្យរបស់លោក

ពាក្យ «ទទួល» នៅទីនេះ មានន័យថា ពួកគេទទួលអ្វីដែលលោកពេត្រុសមានប្រសាសន៍ថាជាសេចក្តីពិត។ បៀបផ្សេងទៀតក្នុងការបកប្រែ: «ពួកគេជឿលើអ្វីដែលលោកពេត្រុសនិយាយ»។

ទទួលពិធីជ្រមុជទឹក

ឃ្លានេះនិយាយជាទម្រង់សកម្ម។ បៀបផ្សេងទៀតក្នុងការបកប្រែ: «ពួកគេធ្វើពិធីជ្រមុជដល់ពួកគេ»។

នៅថ្ងៃនោះមានមនុស្សប្រមាណបីពាន់នាក់បានរាប់បញ្ចូល

ឃ្លានេះនិយាយជាទម្រង់សកម្ម។ បៀបផ្សេងទៀតក្នុងការបកប្រែ: «មានព្រលឹងមនុស្សប្រហែលជាបីពាន់នាក់ទៀតបានចូលរួមជាមួយពួកអ្នកជឿនៅថ្ងៃនោះ»។

ធ្វើពិធីកាច់នំប៉័ង

ឃ្លានេះមានន័យថា ពួកគេបានចែករំលែកអាហារ និងបរិភោគជាមួយគ្នា។

Acts 2:43

មនុស្សម្នាកោតស្ញប់ស្ញែងគ្រប់ៗគ្នា

ពាក្យ «កោតស្ញប់ស្ញែង» នៅទីនេះ សំដៅលើការគោរពយ៉ាងខ្លាំង ហើយស្ញែងខ្លាចចំពោះព្រះជាម្ចាស់។ ពាក្យថា «ព្រលឹង» សំដៅលើមនុស្សទាំងស្រុង។ របៀបផ្សេងទៀតក្នុងការបកប្រែ: «មនុស្សម្នាក់ៗមានការកោតខ្លាច ហើយស្ញប់ស្ញែងចំពោះព្រះជាម្ចាស់»។

ក្រុមសាវកបានសម្តែងឫទ្ធិបាដិហារិយ៍ និងធ្វើទីសម្គាល់ផ្សេងៗជាច្រើន។

អាចមានន័យថា ទី១) «ពួកសាវកធ្វើទីសម្គាល់ និងការអស្ចារ្យជាច្រើន» ឬ ទី២) «ព្រះជាម្ចាស់បានធ្វើទីសម្គាល់ និងការអស្ចារ្យជាច្រើនតាមរយៈពួកសាវក ។

សម្តែងឫទ្ធិបាដិហារិយ៍ និងធ្វើទីសម្គាល់ផ្សេងៗ

«ធ្វើការអស្ចារ្យ និងព្រឹត្តការណ៍អធិធម្មជាតិ»។

សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ២:២២។

អស់អ្នកដែលបានជឿលើព្រះអម្ចាស់ មានចិត្តគំនិតតែមួយ

អាចមានន័យថា ទី១) «ពួកគេជឿលើរឿងតែមួយទាំងអស់គ្នា» ឬទី២) «អ្នកជឿទាំងអស់បានរួមជាមួយគ្នានៅកន្លែងតែមួយ»។

យករបស់របរដែលខ្លួនមានមកដាក់រួមគ្នាទាំងអស់

«បានចែករបស់របររបស់ពួកគេដល់គ្នាទៅវិញទៅមក»។

គេលក់ទ្រព្យសម្បត្តិ និងអ្វីៗជារបស់ខ្លួន

«ដី និងអ្វីៗដែលពួកគេមាន»។

ចែកដល់ពួកគេគ្រប់គ្នា

ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើ ផលចំណេញដែលពួកគេធ្វើបានពីការលើទ្រព្យសម្បត្តិ និងកេរអាកររបស់ពួកគេ។ របៀបផ្សេងទៀតក្នុងការបកប្រែ: «បានចែករំលែកអ្វីដែលមានដល់មនុស្សគ្រប់គ្នា» ។

តាមសេចក្តីត្រូវការរបស់ពួកគេម្នាក់ៗ

ពួកគេចែកប្រាក់ដែលពួកគេសន្សំបានពីការលក់ ទ្រព្យសម្បត្តិ និងកេរអាករ ដល់អ្នកជឿដែលខ្វះខាត។

Acts 2:46

គេបន្តរួមចិត្តគំនិតគ្នា

ទី១) អាចមានន័យថា: «ពួកគេបន្តជួបជុំជាមួយគ្នា» (UDB)។ ទី ២ «ពួកគេទាំងអស់គ្នាបន្តក្នុងការមានចិត្តគំនិតតែមួយ»។

ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ

ទី១) អាចមានន័យថា៖ «ពួកគេបានចែករំលែកអាហារ ហើយបរិភោគអាហារនៅផ្ទះជាមួយគ្នា» ទី២) «ពួកគេ ធ្វើពិធីជប់លៀងអាហារពេលល្ងាចជាមួយគ្នានៅផ្ទះរបស់ពួកគេ»។

សូមមើលពីរបៀបនៃការបកប្រែឃ្លានៅក្នុង ២:៤០។

យ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។

ពាក្យ «ចិត្តស្មោះសរ» នៅទីនេះ អាចសំដៅទៅលើចិត្តជ្រះថ្លា។ ពាក្យ «ចិត្ត» សំដៅលើមនុស្សទាំងមូល។ របៀបនៃការបកប្រែមួយទៀត: «ពេញដោយអំណរ និងមានចិត្តជ្រះថ្លា»។

រាប់អានជាមួយមនុស្សគ្រប់គ្នា

«មនុស្សទាំងអស់ទទួលស្គាល់គ្នាទៅវិញទៅមក»

អ្នកដែលព្រះអង្គបានសង្គ្រោះ

នេះអាចជាប្រយោគនៅក្នុងទម្រង់សកម្ម។ របៀបនៃការបកប្រែផ្សេងទៀត: «អស់អ្នកដែលព្រះអម្ចាស់បានសង្គ្រោះ»។

---

3 [1]ឥឡូវលោកពេត្រុស និងលោកយ៉ូហានបានឡើងទៅព្រះវិហារជាមួយគ្នានៅម៉ោងប្រាំបួន។[2]អ្នកពិការជើង ពីកំណើតម្នាក់ត្រូវបានគេសែងមកដាក់នៅខ្លោងទ្វារព្រះវិហារ ឈ្មោះ «ទ្វារលំអ» រៀងរាល់ថ្ងៃដើម្បីសុំទានអស់អ្នកដែលចូលទៅក្នុងព្រះវិហារ។[3]ពេលគាត់ឃើញលោកពេត្រុស និងលោកយ៉ូហានកំពុងដើរចូលព្រះវិហារ គាត់ក៏សុំទានពីលោកទាំងពីរ។

[4]លោកពេត្រុស និងលោកយ៉ូហានសម្លឹងមើលមុខគាត់ រួចនិយាយថា៖ «សូមមើលមកយើង!»។[5]គាត់ក៏ក្រឡេកមើលទៅលោកទាំងពីរ ដោយសង្ឃឹមថានឹងទទួលរបស់អ្វីមួយពីពួកលោក។[6]ប៉ុន្តែ លោកពេត្រុសមានប្រសាសន៍ទៅគាត់ថា៖ «ខ្ញុំគ្មានប្រាក់ គ្មានមាសទេ តែអ្វីៗដែលខ្ញុំមាន ខ្ញុំសុំជូនអ្នក។ ក្នុងព្រះនាមព្រះយេស៊ូគ្រិស្តជាអ្នកភូមិណាសារ៉ែត សូមអ្នកក្រោកដើរចុះ»។

[7]លោកចាប់ដៃស្តាំគាត់ឲ្យក្រោកឈរឡើង។ រំពេចនោះជើងរបស់គាត់ និងសន្លាក់ឆ្អឹងរឹងមាំ[8]គាត់ក៏ស្ទុះឈរឡើង ហើយដើរបាន។ គាត់ចូលក្នុងព្រះវិហារជាមួយសាវកទាំងពីររូប ទាំងដើរផង លោតផង និងសរសើរតម្កើងព្រះជាម្ចាស់ផង។

[9]ប្រជាជនទាំងអស់បានឃើញគាត់ដើរ និងឮគាត់សរសើរតម្កើងព្រះជាម្ចាស់[10]គេបានដឹងថាអ្នកនោះហើយដែលតែងតែ អង្គុយសុំទាននៅខ្លោងទ្វារព្រះវិហារឈ្មោះ «ទ្វារលំអ» គេក៏ទទួលការអស្ចារ្យ និងស្ងើចសរសើរអំពីហេតុការណ៍ដែលកើតមានដល់គាត់។

[11]នៅពេលបុរសនោះដើរតាមលោកពេត្រុស និងលោកយ៉ូហាន ប្រជាជនទាំងអស់បានរត់មកជុំគ្នានៅថែវសាឡូម៉ូនដោយស្ញប់ស្ញែងជាខ្លាំង។[12]កាលលោកពេត្រុសឃើញដូច្នោះ ក៏មានប្រសាសន៍ទៅកាន់ប្រជាជនថា៖ «បងប្អូនអ៊ីស្រាអែលអើយ! ហេតុដូចម្តេចបានជាបងប្អូនស្ញប់ស្ញែងអំពីហេតុការណ៍នេះ? ហេតុដូចម្តេចបានជាបងប្អូនសម្លឹងមើលមកយើងមិនដាក់ភ្នែកដូច្នេះ? តើបងប្អូនស្មានថា យើងខ្ញុំបានប្រោសបុរសនេះឲ្យដើររួច មកពីឫទ្ធានុភាពរបស់យើងខ្ញុំផ្ទាល់ ឬមកពីយើងខ្ញុំចេះគោរពប្រណិប័តន៍ព្រះជាម្ចាស់មែនទេ?

[13]ព្រះជាម្ចាស់របស់លោកអប្រាហាំ របស់លោកអ៊ីសាក និងរបស់លោកយ៉ាកុប ជាព្រះនៃបុព្វបុរសរបស់យើងទាំងអស់គ្នា ទ្រង់បានប្រទានសិរីរុងរឿងមកលើព្រះយេស៊ូ ជាអ្នកបម្រើព្រះជាម្ចាស់។ ព្រះយេស៊ូត្រូវបានគេបញ្ជូនទៅឲ្យគេកាត់ទោស និងត្រូវបានគេបដិសេធមិនទទួលស្គាល់ព្រះអង្គនៅចំពោះមុខលោកពីឡាត នៅពេលដែលលោកពីឡាតចង់ដោះលែងព្រះអង្គទៀតផង។[14]បណ្តាជនបានបដិសេធមិនទទួលស្គាល់ព្រះដ៏វិសុទ្ធ ជាព្រះដ៏សុចរិត ហើយបានទាមទារសុំអគេដោះលែងឃាតករជំនួសព្រះអង្គទៅវិញ។

[15]បងប្អូនបានធ្វើគុតម្ចាស់ប្រភពនៃជីវិត ដែលព្រះជាម្ចាស់បានប្រោសឲ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ ហើយយើងខ្ញុំជាសាក្សីអំពីហេតុការណ៍នេះ។[16]ឥឡូវនេះដោយសារជំនឿលើព្រះនាមព្រះយេស៊ូ បុរសដែលបងប្អូនឃើញនិងស្គាល់នេះមានកម្លាំងឡើងវិញ។
ដោយលោកបានជឿនោះហើយបានជាព្រះយេស៊ូគ្រិស្តផ្តល់មកលោកនូវសុខភាពពេញលេញដូចដែលបងប្អូនបានឃើញស្រាប់។

[17]បងប្អូនអើយ ខ្ញុំដឹងថាបងប្អូនទាំងអស់គ្នា និងពួកនាម៉ឺនរបស់បងប្អូនបានប្រព្រឹត្តដូច្នោះ ទាំងមិនដឹងខ្លួន។[18]ប៉ុន្តែ ព្រះជាម្ចាស់បានធ្វើឲ្យហេតុការណ៍នេះកើតឡើង ស្របតាមសេចក្តីដែលព្រះអង្គប្រកាសទុកជាមុន តាមរយៈព្យាការីទាំងអស់ គឺថាព្រះគ្រិស្តរបស់ព្រះអង្គនឹងត្រូវតែរងទុក្ខលំបាក
ហើយព្រះអង្គឥឡូវនេះបានបំពេញកិច្ចការនោះមែន។

generated on Wed Sep 10 16:16:32 2025

[19]ហេតុនេះ សូមកែប្រែចិត្តគំនិត ហើយវិលមករកព្រះជាម្ចាស់ដើម្បីឲ្យព្រះអង្គលុបអំពើបាបរបស់បងប្អូន។ ព្រះអម្ចាស់នឹងប្រទានឲ្យបងប្អូន
បានទទួលព្រះវត្តមានរបស់ព្រះអង្គ[20]ព្រមទាំងប្រទានព្រះគ្រិស្តយេស៊ូមកបងប្អូន ដូចព្រះអង្គបានគ្រោងទុកជាមុន។
[21]ឥឡូវនេះ ព្រះយេស៊ូគ្រិស្តគង់នៅឯស្ថានបរមសុខ រហូតដល់ព្រះជាម្ចាស់រៀបចំអ្វីៗទាំងអស់ឡើងវិញ ដូចព្រះអង្គមានព្រះបន្ទូលទុក តាមរយៈពួកព្យាការីដ៏វិសុទ្ធរបស់
ព្រះអង្គ នៅជំនាន់ដើមស្រាប់។[22]លោកម៉ូសេមានប្រសាសន៍ថា៖ «ព្រះអម្ចាស់គឺជាព្រះរបស់អ្នករាល់គ្នានឹងធ្វើឲ្យមានព្យាការីម្នាក់ដូចខ្ញុំ ងើបឡើងពីចំណោមបងប្អូនអ្នករាល់
គ្នា។ អ្នករាល់គ្នាត្រូវស្តាប់តាមសេចក្តីទាំងប៉ុន្មាន ដែលលោកមានប្រសាសន៍ប្រាប់។[23]រីឯអស់អ្នកដែលមិនព្រមស្តាប់ព្យាការីនេះ នឹងត្រូវដកចេញពីចំណោមប្រជារាស្ត្រ។
[24]ពិតមែន ព្យាការីទាំងប៉ុន្មានដែលបានថ្លែងព្រះបន្ទូលចាប់តាំងពីលោកសាំយូអែលមកសុទ្ធតែបានថ្លែងទុកអំពីសម័យកាលនេះ។[25]បងប្អូនហ្នឹងហើយជាកូនចៅរបស់
ព្យាការី ហើយបងប្អូនក៏ចូលរួមក្នុងសម្ពន្ធមេត្រីដែលព្រះជាម្ចាស់បានធ្វើជាមួយបុព្វបុរសដែរ ដូចព្រះអង្គមានព្រះបន្ទូលទៅកាន់លោកអ្រាហាំថា៖ «ក្រុមគ្រួសារទាំងអស់
នៅផែនដីនឹងទទួលពរ តាមរយៈពូជពង្សរបស់អ្នក។[26]ព្រះជាម្ចាស់បានឲ្យអ្នកបម្រើរបស់ព្រះអង្គងើបឡើង ហើយចាត់លោកឲ្យមករកបងប្អូនទាំងអស់គ្នាមុនគេបង្អស់ ដើម្បី
ប្រទានពរដល់បងប្អូន ដោយណែនាំម្នាក់ៗឲ្យងាកចេញពីអំពើទុច្ចរិត»។

Acts 3:1

ប្រយោគភ្ជាប់

ថ្ងៃមួយលោកពេត្រុស និងលោកយ៉ូហានបានឡើងទៅព្រះវិហារ។

ព័ត៌មានទូទៅ

ខ ២ បានប្រាប់ពីព័ត៌មានទូទៅអំពីអ្នកពិការជើង។

ឡើងទៅព្រះវិហារ

ពួកគេមិនបានឡើងចូលទៅក្នុងអគារព្រះវិហារ
ជាកន្លែងដែលអនុញ្ញាតឲ្យមានតែបូជាចារ្យទេ។ របៀបបកប្រែផ្សេងទៀត:
«ឡើងទីធ្លាព្រះវិហារ» (UDB) ឬ «ទៅបរិវេណព្រះវិហារ»។

អ្នកពិការជើង ពីកំណើតម្នាក់ត្រូវបានគេសែងមកដាក់

ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបបកប្រែផ្សេងទៀត: «ជារៀងរាល់ថ្ងៃ
គេបានសែងបុរសម្នាក់ ដែលពិការជើងពីកំណើតនេះ
ហើយបានដាក់គាត់នៅទីនោះ»។

ពិការជើង

មិនអាចដើរបាន

នៅខ្លោងទ្វារព្រះវិហារឈ្មោះ «ទ្វារលម្អ»

នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបបកប្រែផ្សេងទៀត:
«នៅខ្លោងទ្វារព្រះវិហារ ដែលមនុស្សហៅថា «លម្អ»

ទ្វារ

«ខ្លោងទ្វារ»

Acts 3:4

លោកពេត្រុស និងលោកយ៉ូហានសម្លឹងមើលមុខគាត់ រួចនិយាយថា៖

ទាំងលោកពេត្រុស និងលោកយ៉ូហានសម្លឹងមើលបុរសនោះ ប៉ុន្តែលោកពេត្រុស
និយាយ។

សម្លឹងមើលមុខគាត់

ទី ១ អាចមានន័យថា៖ «សម្លឹងទៅគាត់ចំតែម្តង»

អ្នកពិការជើងក៏ក្រឡេកមើលទៅលោកទាំងពីរ

ពាក្យ «មើល» នៅទីនេះ មានន័យថា យកចិត្តទុកដាក់លើអ្វីមួយ។
របៀបបកប្រែផ្សេងទៀត:
«អ្នកពិការជើងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅកាន់ពួកគេ»។

ខ្ញុំគ្មានប្រាក់ គ្មានមាសទេ

ពាក្យនេះ សំដៅលើលុយកាក់។

អ្វីៗដែលខ្ញុំមាន

យើងយល់ថា លោកពេត្រុសមានសមត្ថភាពក្នុងការប្រោសបុរសនោះឲ្យជា។

ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត

ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើអំណាច និងសិទ្ធិអំណាច។
របៀបបកប្រែផ្សេងទៀត: «ដោយសារសិទ្ធិអំណាចរបស់ព្រះយេស៊ូគ្រិស្ត»។

Acts 3:7

គាត់ចូលក្នុងព្រះវិហារ

គាត់មិនបានចូលទៅខាងក្នុងព្រះវិហារ ដែលអនុញ្ញាតឲ្យតែបូជាចារ្យនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គាត់បានចូលទៅក្នុង...
បរិវេណព្រះវិហារ» (UDB) ឬ «គាត់បានចូលទៅក្នុង...ទីធ្លាព្រះវិហារ»។

Acts 3:9

គេបានដឹងថាអ្នកនោះ

«បានដឹងថាគឺបុរសនោះហើយ» ឬ «បានដឹងថាគាត់គឺជាបុរសនោះ»។

«ទ្វារលំអ»

នេះគឺជាឈ្មោះនៃច្រកចូលមួយរបស់ព្រះវិហារ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅឃ្លាប្រហាក់ប្រហែលនេះ នៅក្នុង ៣:១

ពួកគេមានការការអស្ចារ្យ និងស្ងើចសរសើរជាខ្លាំង

ពាក្យ «អស្ចារ្យ» និង «ស្ងើចសរសើរ» មានន័យប្រហាក់ប្រហែលគ្នា
ហើយសង្កត់ន័យទៅលើការស្ងើចសរសើររបស់មនុស្ស។ របៀបបកប្រែផ្សេងទៀត:
«ពួកគេកើតមានការភ្ញាក់ផ្អើលជាខ្លាំង»។

Acts 3:11

ប្រយោគភ្ជាប់

បន្ទាប់ពីប្រោសបុរសដែលមិនអាចដើរបានឲ្យជាហើយ
លោកពេត្រុសនិយាយទៅកាន់មនុស្ស។

ព័ត៌មានទូទៅ

ឃ្លា «នៅថែវដែលហៅថា ថែវសាឡូម៉ូន» បានបង្ហាញយ៉ាងច្បាស់ថា
ពួកគេមិនបាននៅក្នុងព្រះវិហារ
ជាកន្លែងដែលអនុញ្ញាតឲ្យចូលបានតែពួកបូជាចារ្យទេ។

ព័ត៌មានទូទៅ

ពាក្យ «ពួកយើង» និង «យើង» នៅទីនេះ សំដៅលើ លោកពេត្រុស
និងលោកយ៉ូហាន ប៉ុន្តែ
មិនមែនបណ្តាជនដែលលោកពេត្រុសកំពុងនិយាយជាមួយទេ។

ថែវដែលគេហៅថាថែវសាឡូម៉ូន

«ថែវសាឡូម៉ូន»។ នេះគឺជាកន្លែងដើរ ដែលមានសរសេរសង្ឃខាង
និងមានដំបូលពីលើ ដែលគេដាក់ឈ្មោះវាតាមព្រះនាមរបស់ព្រះបាទសាឡូម៉ូន។

ស្ងប់ស្ងែងជាខ្លាំង

«ភ្ញាក់ផ្អើលយ៉ាងខ្លាំង»

កាលលោកពេត្រុសឃើញដូច្នោះ

ពាក្យ «ដូច្នោះ» នៅទីនេះ សំដៅលើ ការភ្ញាក់ផ្អើលរបស់មនុស្ស។

បងប្អូនអ៊ីស្រាអែលអើយ!

«បងប្អូនអ៊ីស្រាអែលអើយ» (UDB)។ លោកពេត្រុសបានបញ្ជាក់ដល់បណ្តាជន។

ហេតុដូចម្តេចបានជាបងប្អូនស្ងប់ស្ងែងអំពីហេតុការណ៍នេះ?

លោកពេត្រុសសួរសំណួរដើម្បីបញ្ជាក់ថា
ពួកគេមិនគួរភ្ញាក់ផ្អើលដោយសារអ្វីដែលបានកើតឡើងទេ។
របៀបបកប្រែផ្សេងទៀត: «អ្នករាល់គ្នាមិនគួរភ្ញាក់ផ្អើលទេ» ។

ហេតុដូចម្តេចបានជាបងប្អូនសម្លឹងមើលមកយើងមិនដាក់ភ្នែកដូច្នេះ? តើបងប្អូនស្មានថា យើងខ្ញុំ
បានប្រោសបុរសនេះឲ្យដើររួច មកពីឫទ្ធានុភាពរបស់យើងខ្ញុំផ្ទាល់ ឬមកពីយើងខ្ញុំចេះគោរព
ប្រណិប័តន៍ព្រះជាម្ចាស់មែនទេ?

លោកពេត្រុសសួរសំណួរដើម្បីបញ្ជាក់ថា បណ្តាជនមិនគួរគិតថា គាត់
និងលោកយ៉ូហានជាអ្នកធ្វើឲ្យបុរសនោះជាដោយសមត្ថភាពរបស់ពួកគេទេ។
ពាក្យនេះ អាចសរសេរជាពីប្រយោគ។ របៀបបកប្រែផ្សេងទៀត:
«សូមកុំសម្លឹងមកយើងដូច្នេះ យើងមិនបានធ្វើឲ្យគាត់ដើរបានដោយអំណាច
ឬអំពើល្អរបស់យើងទេ»។

បងប្អូនសម្លឹងមើលមកយើង

ឃ្លានេះមានន័យថា ពួកគេសម្លឹងមិនដាក់ភ្នែកលើពួកគេ។ របៀបបកប្រែផ្សេងទៀត:
«សម្លឹងមើលមកយើង» ឬ «មើលមកយើង»។

Acts 3:13

ប្រយោគភ្ជាប់

លោកពេត្រុសបន្តមានប្រសាសន៍ទៅកាន់ជនជាតិយូដាដែលគាត់បានមានប្រសាសន៍នៅក្នុង
ជំពូក ៣:១១

ត្រូវបានគេបញ្ជូន

«អ្នកដែលអ្នកបានបញ្ជូនឲ្យទៅលោកពីឡាត់» ឬ
«ជាអ្នកដែលអ្នកបានប្រគល់ទៅលោកពីឡាត់»។

ត្រូវបានគេបដិសេធមិនទទួលស្គាល់នៅចំពោះមុខលោកពីឡាត

ពាក្យ «ចំពោះមុខ» មានន័យថា «នៅចំពោះវត្តមាន»។ របៀបបកប្រែផ្សេងទៀត:
«បដិសេធនៅចំពោះវត្តមានរបស់លោកពីឡាត់»
នៅពេលដែលលោកពីឡាតចង់ដោះលែងព្រះអង្គ
«នៅពេលដែលលោកពីឡាតចង់ដោះលែងព្រះយេស៊ូ»
ដូច្នេះ យើងនឹងដោះលែងឃាតករដល់អ្នករាល់គ្នា
នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបបកប្រែផ្សេងទៀត:
«ព្រោះលោកពីឡាត់បានដោះលែងឃាតករ»។
Acts 3:15
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ បូករួមទាំងលោកពេត្រុស និងលោកយ៉ូហាន។
ម្ចាស់ប្រភពនៃជីវិត
ឃ្លានេះសំដៅលើព្រះយេស៊ូ។ ទី១ អាចមានន័យថា:
«ម្នាក់ដែលផ្តល់ឲ្យមនុស្សមានជីវិតអស់កល្ប» (UDB) ឬ ទី២)
«អ្នកត្រួតត្រាជីវិត»។
ព្រះអង្គម្ចាស់
«ព្រះអង្គម្ចាស់» «អ្នកនិពន្ធ» ឬ «មេបញ្ជាការ»
ឥឡូវ
ពាក្យ «ឥឡូវ»
ជាមធ្យោបាយក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់អ្នកស្តាប់ទៅកាន់អ្នកពិការជើង។
ដោយសារជំនឿលើព្រះនាម
ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើព្រះយេស៊ូ។ ទី ១ អាចមានន័យថា:
«ដោយសារបុរសនេះជឿលើព្រះនាមព្រះយេស៊ូ» ឬទី២) ដោយសារលោកយ៉ូហាន
និងខ្ញុំជឿលើព្រះនាមព្រះយេស៊ូ»។
ធ្វើឲ្យគាត់មានកម្លាំងឡើងវិញ
«ធ្វើឲ្យគាត់បានជា»
Acts 3:17
ឥឡូវនេះ
លោកពេត្រុសទាញចំណាប់អារម្មណ៍អ្នកស្តាប់ពីអ្នកពិការជើង
ហើយបន្តនិយាយជាមួយពួកគេដោយផ្ទាល់។
បងប្អូនបានប្រព្រឹត្តដូច្នោះ ទាំងមិនដឹងខ្លួន
ទី១ អាចមានន័យថា: «មនុស្សមិនបានដឹងថាព្រះយេស៊ូជាព្រះមេស្ស៊ី (UDB) ឬ
ទី២) មនុស្សមិនបានយល់ពីភាពសំខាន់នូវអ្វីដែលពួកគេកំពុងធ្វើ។
ព្រះជាម្ចាស់បានធ្វើឲ្យហេតុការណ៍នេះកើតឡើង ស្របតាមសេចក្តីដែលព្រះអង្គប្រកាសទុកជាមុន
តាមរយៈព្យាការីទាំងអស់
នៅពេលព្យាការីថ្លែង វាដូចជាអ្វីដែលព្រះអង្គមានបន្ទូលចេញពីព្រះអង្គផ្ទាល់
ព្រោះព្រះអ្នកប្រាប់ពួកគេនូវអ្វីដែលពួកគេត្រូវថ្លែង។ របៀបបកប្រែផ្សេងទៀតថា:
«ព្រះជាម្ចាស់បានប្រាប់ជាមុន
ដោយប្រាប់ដល់ព្យាការីទាំងអស់នូវអ្វីដែលពួកគេត្រូវថ្លែង»។
ប្រកាសទុកជាមុន
«ប្រាប់មុនពេល» ឬ «ប្រាប់មុនវាកើតឡើង»។
នៅក្នុងបបូរមាត់របស់ព្យាការីទាំងអស់
ពាក្យ «បបូរមាត់» នៅទីនេះ សំដៅលើពាក្យដែលព្យាការីនិយាយ និងសរសេរចុះ។
របៀបបកប្រែផ្សេងទៀត: «ពាក្យរបស់ព្យាការីទាំងអស់»
Acts 3:19
ចូរកែប្រែចិត្តគំនិត ហើយវិលមករក
ពាក្យ «ប្រែចិត្ត» និង «វិលមករក» សំដៅលើការប្តូរផ្លូវនៃការគិតរបស់មនុស្សម្នាក់
បែរចេញពីផ្លូវនៃអំពើបាប ហើយបែរទៅរកព្រះជាម្ចាស់វិញ។
ដើម្បីឲ្យព្រះអង្គលុបអំពើបាបរបស់បងប្អូន
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបបកប្រែផ្សេងទៀតថា:
«ដើម្បីឲ្យព្រះជាម្ចាស់បានលុបអំពើបាបរបស់អ្នកចេញ»។
ព្រះអម្ចាស់នឹងប្រទានឲ្យបងប្អូនបានទទួលព្រះវត្តមានរបស់ព្រះអង្គ
«ពេលវេលាដែលបងប្អូនអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់»។ ទី១
អាចមានន័យថា៖
«ជាពេលដែលនៅពេលព្រះជាម្ចាស់នឹងចម្រើនកម្លាំងខាងវិញ្ញាណរបស់អ្នក» ឬ
ទី២) ជាពេលវេលា នៅពេលព្រះជាម្ចាស់ស្តារអ្នកឡើងវិញ»។
ពីព្រះវត្តមានរបស់ព្រះអម្ចាស់
ពាក្យ «ព្រះវត្តមានរបស់ព្រះអម្ចាស់» នៅទីនេះ
គឺជាពាក្យប្រៀបធៀបមួយសម្រាប់ព្រះអម្ចាស់ទ្រង់ផ្ទាល់។ របៀបបកប្រែផ្សេងទៀត:
«ពីព្រះអម្ចាស់»
ដើម្បីឲ្យព្រះអង្គប្រទានព្រះគ្រិស្ត
«ដើម្បីឲ្យព្រះអង្គបានព្រះប្រទានព្រះគ្រិស្ត»។ ឃ្លានេះ
សំដៅលើការយាងត្រឡប់មកវិញជាថ្មីម្តងទៀតរបស់ព្រះគ្រិស្ត។
ដូចព្រះអង្គបានគ្រោងទុកជាមុនសម្រាប់អ្នករាល់គ្នា
ឃ្លានេះ អាចនិយាយជាទម្រង់សកម្ម។ របៀបបកប្រែផ្សេងទៀត:
«ជាអ្នកដែលព្រះអង្គបានគ្រោងទុកសម្រាប់អ្នករាល់គ្នា»។
Acts 3:21
ប្រយោគភ្ជាប់
លោកពេត្រុសបន្តសន្ទរកថារបស់គាត់ដែលគាត់បានចាប់ផ្តើមនៅក្នុង ជំពូក ៣:១១
ទៅកាន់ជនជាតិយូដានៅក្នុងបរិវេណព្រះវិហារ។
ព័ត៌មានទូទៅ
នៅក្នុង ខ ២២-២៣ លោកពេត្រុសបានដកស្រងអ្វីមួយដែលលោកម៉ូសេបានប្រាប់
មុនពេលព្រះមេស្ស៊ីមក។
ព្រះអង្គគឺជាព្រះមួយអង្គដែលគង់នៅស្ថានសួគ៌ត្រូវទទួល។
«ព្រះអង្គគឺជាព្រះដែលស្ថានសួគ៌ស្វាគមន៍»។
លោកពេត្រុសមានប្រសាសន៍អំពីស្ថានសួគ៌ថា
ស្ថានសួគ៌នឹងស្វាគមន៍អស់អ្នកដែលដែលស្វាគមន៍ព្រះយេស៊ូមកក្នុងផ្ទះរបស់ពួកគេ។
ស្ថានសួគ៌អាចទទួលបាន ទាល់តែ
ឃ្លានេះមានន័យថា វាគឺជាការចាំបាច់សម្រាប់ព្រះយេស៊ូក្នុងការគង់នៅស្ថានសួគ៌
ព្រោះនោះគឺជាផែនការរបស់ព្រះជាម្ចាស់។
រហូតដល់ព្រះជាម្ចាស់រៀបចំអ្វីៗទាំងអស់ឡើងវិញ
ទី១ អាចមានន័យថា: «រហូតទាល់តែ ព្រះជាម្ចាស់បានស្តារអ្វីៗទាំងអស់ឡើងវិញ»
ឬ ទី២ «រហូតទាល់តែ
ព្រះជាម្ចាស់នឹងបំពេញអ្វីៗទាំងអស់ដែលព្រះអង្គបានមានបន្ទូលប្រាប់ពីមុន»។
ដូចព្រះអង្គមានព្រះបន្ទូលទុក តាមរយៈពួកព្យាការីដ៏វិសុទ្ធរបស់ព្រះអង្គ នៅជំនាន់ដើមស្រាប់។
តាមរយៈពួកព្យាការីដ៏វិសុទ្ធរបស់ព្រះអង្គ នៅជំនាន់ដើមស្រាប់
វាជាអ្វីដែលព្រះជាម្ចាស់ផ្ទាល់បានមានបន្ទូល
ព្រោះព្រះអង្គបានប្រាប់ឲ្យពួកគេនិយាយ។ របៀបបកប្រែផ្សេងទៀត:
«ពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលយូរណាស់មកហើយ
ដោយប្រាប់ដល់ពួកព្យាការីដ៏បរិសុទ្ធរបស់ព្រះអង្គថ្លែងពីពួកគេ»។
តាមរយៈបបូរមាត់របស់ពួកព្យាការីដ៏វិសុទ្ធរបស់ព្រះអង្គ
ពាក្យ «បបូរមាត់» សំដៅលើពាក្យដែលពួកព្យាការីបានថ្លែង និងកត់ទុក។
របៀបបកប្រែផ្សេងទៀត:«ពាក្យរបស់ព្យាការីដ៏វិសុទ្ធរបស់ព្រះអង្គ» ។
នឹងធ្វើឲ្យមានព្យាការីម្នាក់ដូចខ្ញុំ ងើបឡើង
«នឹងតែងតាំងឲ្យមានព្យាការីម្នាក់ឡើង»
គេនឹងបំផ្លាញព្យាការីនោះទាំងស្រុង
ឃ្លានេះអាចស្ថិតក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្យាការីនោះ
ព្រះជាម្ចាស់នឹងបំផ្លាញទាំងស្រុង»។
Acts 3:24
ប្រយោគភ្ជាប់
លោកពេត្រុសបានបញ្ចប់សុន្ទរកថារបស់គាត់ទៅកាន់ជនជាតិយូដាដែលគាត់បានចាប់ផ្តើមនៅក្នុងជំពូក
៣:១១
ពិតមែន ព្យាការីទាំងអស់
«ពិតមែន ព្យាការីទាំងអស់»។ ពាក្យ «ពិតមែន» នៅទីនេះ
ដាក់មកដើម្បីបញ្ជាក់អ្វីដែលនឹងមកតាមក្រោយ។
ចាប់តាំងពីលោកសាំយូអែលមកសុទ្ធតែបានថ្លែងទុកអំពីសម័យកាលនេះ
«ចាប់តាំងពីលោកសាំយូអែល ហើយបន្តមកជាមួយព្យាការីផ្សេងៗទៀត
ដែលរស់នៅតាមក្រោយគាត់»។
សម័យកាលនេះ
«សម័យកាលនេះ» ឬ «អ្វីៗដែលកើតឡើងនៅពេលនេះ»។
បងប្អូនហ្នឹងហើយជាកូនចៅរបស់ព្យាការី
ពាក្យ «កូនចៅ» សំដៅលើអ្នកទទួលមរតក ដែលនឹងបានទទួលអ្វីដែលពួកព្យាការី
និងសេចក្តីសន្យានៃសម្ពន្ធមេត្រី។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកគឺជាអ្នកទទួលមរតកពីព្យាការី និងទទួលមរតពីសម្ពន្ធមេត្រី»។
ពូជពង្សរបស់អ្នក
«ដោយព្រោះពូជពង្សរបស់អ្នក»។
ក្រុមគ្រួសារទាំងអស់នៅផែនដីនឹងទទួលពរ
ពាក្យ «ក្រុមគ្រួសារ» នៅទីនេះ សំដៅលើ ក្រុមមនុស្ស ឬប្រជាជាតិ។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«យើងនឹងឲ្យពរដល់ក្រុមមនុស្សនៅក្នុងពិភពលោកទាំងមូល»។

4 [1]នៅពេលលោកពេត្រុស និងលោកយ៉ូហានកំពុងតែមានប្រសាសន៍ទៅកាន់ប្រជាជន ស្រាប់តែពួកបូជាចារ្យ មេកងរក្សាព្រះវិហារ និងពួកខាងគណៈសាឌូស៊ីមកដល់។
[2]ពួកគេទាស់ចិត្តដោយព្រោះលោកពេត្រុស និងលោកយ៉ូហានកំពុងបង្រៀនប្រជាជន ហើយប្រកាសអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូ។[3]ពួកគេបានចាប់សាវកទាំងពីរយកទៅឃុំទុករហូតដល់ព្រឹកស្អែក ដ្បិតពេលនោះល្ងាចណាស់ហើយ។[4]ប៉ុន្តែ បណ្តាជនភាគច្រើនដែលបានឮព្រះបន្ទូលបានជឿ ហើយចំនួនអ្នកជឿមានប្រមាណប្រាំពាន់នាក់។
[5]លុះស្អែកឡើង ពួកមេដឹកនាំ ពួកព្រឹទ្ធាចារ្យ និងពួកអាចារ្យបានជួបជុំគ្នានៅក្រុងយេរូសាឡឹម។[6]មានលោកមហាបូជាចារ្យអាណ លោកកៃផា លោកយ៉ូហាន លោកអលេក្សានត្រុស និងក្រុមគ្រួសាររបស់នាយកបូជាចារ្យទាំងអស់។[7]លោកទាំងនោះបានបញ្ជាឲ្យគេនាំលោកពេត្រុស និងលោកយ៉ូហានមកឈរនៅមុខអង្គប្រជុំ រួចសួរថា៖ «អ្នកបានធ្វើការនេះសម្អាងលើអំណាចអ្វី? ក្នុងនាមនរណា?»
[8]ពេលនោះ លោកពេត្រុសបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ លោកមានប្រសាសន៍ទៅគេថា៖ «សូមជម្រាបអស់លោកជាអ្នកដឹកនាំប្រជាជន និងអស់លោកព្រឹទ្ធាចារ្យ។[9]ថ្ងៃនេះ អស់លោកសួរចម្លើយយើងខ្ញុំ ពីអំពើល្អដែលយើងខ្ញុំសង្គ្រោះអ្នកពិការឲ្យបានជាតាមរបៀបណា?[10]សូមអស់លោក និងប្រជារាស្ត្រអ៊ីស្រាអែលទាំងមូលជ្រាបថា បុរសដែលឈរនៅមុខអស់លោកទាំងមានសុខភាពល្អនេះ បានជាដោយសារព្រះនាមព្រះយេស៊ូគ្រិស្តជាអ្នកភូមិណាសារ៉ែត ដែលអស់លោកបានឆ្កាង ហើយព្រះជាម្ចាស់បានប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ។
[11]ព្រះយេស៊ូ គឺជាថ្មដែលលោកទាំងអស់គ្នា ជាជាងសំណង់បានបោះចោល ប៉ុន្តែព្រះអង្គបានត្រឡប់មកជាថ្មគ្រឹះដ៏សំខាន់បំផុត។[12]ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សបានទាល់តែសោះ ដ្បិតនៅក្រោមមេឃនេះ ព្រះជាម្ចាស់ពុំបានប្រទាននាមណាមួយផ្សេងទៀតមកមនុស្ស ដើម្បីសង្គ្រោះយើងបានឡើយ»។
[13]កាលក្រុមប្រឹក្សាជាន់ខ្ពស់ឃើញទឹកចិត្តក្លាហានរបស់លោកពេត្រុស និងលោកយ៉ូហានដូច្នេះ គេងឿងឆ្ងល់ណាស់ថា លោកទាំងពីរជាមនុស្សសាមញ្ញ ពុំដែលបានរៀនសូត្រជ្រៅជ្រះទេ គ្រាន់តែដឹងថាលោកទាំងពីរធ្លាប់នៅជាមួយព្រះយេស៊ូ។[14]ពួកគេក៏រកពាក្យឆ្លើយតបវិញពុំបានសោះ ដោយព្រោះបុរសដែលបានជា ក៏កំពុងឈរនៅទីនោះដែរ។
[15]ពួកគេក៏បញ្ជាឲ្យលោកទាំងពីរចេញពីអង្គប្រជុំ[16]ហើយពិគ្រោះគ្នាថា៖ «តើយើងគួរធ្វើអ្វីដល់អ្នកទាំងពីរនេះ? ដ្បិតអ្នកក្រុងយេរូសាឡឹមទាំងមូលដឹងច្បាស់ថា គេធ្វើទីសម្គាល់អស្ចារ្យមួយដ៏វិសេស ដែលយើងមិនអាចបដិសេធបាន។[17]ដូច្នេះ ដើម្បីកុំឲ្យរឿងនេះលេចឮខ្ទរខ្ចាយដល់ប្រជាជនបន្ថែមទៀត យើងត្រូវហាមប្រាម និងគំរាមអ្នកទាំងពីរនេះ កុំឲ្យប្រកាសប្រាប់នរណាអំពីនាមនោះតទៅទៀតឡើយ»។[18]ក្រុមប្រឹក្សាក៏ហៅសាវកទាំងពីរមក ហើយហាមប្រាមមិនឲ្យនិយាយ និងបង្រៀនអំពីព្រះនាមព្រះយេស៊ូទៀតជាដាច់ខាត។
[19]លោកពេត្រុស និងលោកយ៉ូហាន មានប្រសាសន៍តបទៅគេវិញថា៖ «សូមអស់លោកពិចារណាមើល នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ គួរឲ្យយើងខ្ញុំធ្វើតាមបង្គាប់អស់លោក ឬធ្វើតាមបង្គាប់របស់ព្រះអង្គ?[20]យើងខ្ញុំឈប់និយាយអំពីហេតុការណ៍ដែលយើងខ្ញុំបានឃើញ បានឮនោះពុំកើតទេ»។
[21]បន្ទាប់ពីគំរាមសាជាថ្មីទៀត ពួកគេក៏ដោះលែងលោកពេត្រុស និងលោកយ៉ូហាន។ ក្រុមប្រឹក្សាជាន់ខ្ពស់រកហេតុ ដើម្បីដាក់ទោសលោកទាំងពីរមិនបាន ដ្បិតប្រជាជនគ្រប់ៗគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ចំពោះហេតុការណ៍ដែលកើតមាននោះ។[22]រីឯបុរសដែលបានជាដោយការអស្ចារ្យនោះ មានអាយុជាងសែសិបឆ្នាំហើយ។
[23]ក្រោយ ពីបានរួចខ្លួនហើយ លោកពេត្រុស និងលោកយ៉ូហាននាំគ្នាទៅជួបពួកបងប្អូន ហើយរៀបរាប់អំពីសេចក្តីទាំងប៉ុន្មានដែលពួកមហាបូជាចារ្យ និងពួកព្រឹទ្ធាចារ្យបាននិយាយទៅពួកគេ។[24]កាលពួកគេឮដូច្នោះ គេរួមចិត្តគំនិតគ្នា ហើយបន្លឺសំឡេងទូលព្រះជាម្ចាស់ថា៖ «បពិត្រព្រះដ៏ជាចៅហ្វាយ ព្រះអង្គបានបង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងអ្វីៗសព្វសារពើនៅទីនោះ[25]ព្រះអង្គមានព្រះបន្ទូលតាមព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈអ្នកបម្រើរបស់ព្រះអង្គ គឺព្រះបាទដាវីឌ ជាបុព្វបុរសយើងខ្ញុំថា៖ «ហេតុអ្វីបានជាជាតិសាសន៍ទាំងឡាយនាំគ្នាបង្កើតកោលាហលដូច្នេះ? ហេតុអ្វីបានជាប្រជារាស្ត្រនានាមានគំនិតឥតខ្លឹមសារដូច្នេះ?
[26]ព្រះអង្គមានព្រះបន្ទូលថា៖ «ពួកស្តេចនៅលើផែនដី និងពួកមេដឹកនាំពួតដៃ រួមគំនិតគ្នាប្រឆាំងនឹងព្រះអម្ចាស់ ហើយប្រឆាំងនឹងព្រះគ្រិស្តរបស់ព្រះអង្គ»។
[27]ប្រាកដមែន នៅក្នុងក្រុងនេះ ស្តេចហេរ៉ូដ និងលោកប៉ុនទាស-ពីឡាត រួមមានសាសន៍ដទៃទៀត និងប្រជារាស្ត្រអ៊ីស្រាអែលសមគំនិតផង បានរួមគ្នាប្រឆាំងនឹងព្រះយេស៊ូជាអ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គ ដែលទ្រង់បានចាក់ប្រេងអភិសេក ។[28]គេនាំគ្នាប្រព្រឹត្តដូចព្រះអង្គបានកំណត់ទុកជាមុនដោយព្រះហស្តទ្រង់ និងដោយព្រះតម្រិះរបស់ព្រះអង្គ។
[29]ឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមជ្រាបសេចក្តីគំរាមរបស់ពួកគេ ហើយសូមប្រោសប្រទានអោយពួកអ្នកបម្រើព្រះអង្គ ថ្លែងព្រះបន្ទូលដោយចិត្តអង់អាចផង[30]សូមសម្តែងបារមីឲ្យអ្នកជំងឺបានជា និងប្រទានទីសម្គាល់ និងការអស្ចារ្យតាមរយៈព្រះនាមព្រះយេស៊ូជាអ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គ»។[31]កាលពួកគេទូលអង្វរព្រះជាម្ចាស់ដូច្នោះរួចហើយ កន្លែងដែលគេជួបជុំគ្នានោះក៏រញ្ជួយ គេបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធទាំងអស់គ្នា ហើយនាំគ្នាថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយចិត្តក្លាហាន។
[32]អ្នកជឿទាំងអំបាលម៉ានមានចិត្តថ្លើមតែមួយ គ្មានអ្នកណាម្នាក់នឹកគិតថា ទ្រព្យសម្បត្តិដែលខ្លួនមានជារបស់ខ្លួនផ្ទាល់នោះឡើយ គឺគេយកមកដាក់ជាសម្បត្តិរួមទាំងអស់។[33]ក្រុមសាវកបានប្រកបដោយឫទ្ធានុភាពដ៏ខ្លាំងក្លា ហើយនាំគ្នាផ្តល់សក្ខីភាពអំពីព្រះអម្ចាស់យេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយព្រះជាម្ចាស់ទ្រង់សម្តែងព្រះហឫទ័យប្រណីសន្តោសដ៏លើសលប់ដល់ពួកគេទាំងអស់គ្នា។
[34]ក្នុងចំណោមពួកគេគ្មាននរណាខ្វះខាតអ្វីឡើយ ព្រោះអស់អ្នកដែលមានដីធ្លី ឬផ្ទះសម្បែងនាំគ្នាលក់ដីធ្លី និងផ្ទះនោះ[35]យកប្រាក់ មកជូនក្រុមសាវក។ បន្ទាប់មក អ្នកជឿទាំងអស់គ្នាទទួលចំណែកតាមសេចក្តីត្រូវការរៀងៗខ្លួន។
[36]មានបុរសម្នាក់ឈ្មោះយ៉ូសេ ជាពួកលេវី ស្រុកកំណើតនៅកោះគីប្រុស ក្រុមសាវកបានដាក់ឈ្មោះគាត់ថា បារណាបាស (ដែលមានន័យថា ជាអ្នកលើកទឹកចិត្តគេ)[37]ហើយគាត់បានលក់ចម្ការមួយរបស់គាត់ ហើយយកប្រាក់មកជូនក្រុមសាវកដែរ។

Acts 4:1

ប្រយោគភ្ជាប់

អ្នកដឹកនាំសាសនាបានចាប់លោកពេត្រុស និងលោកយ៉ូហាន បន្ទាប់ពីលោកពេត្រុសបានធ្វើឲ្យបុរសដែលពិការតាំងពីកំណើតឲ្យបានជា។

បានមកដល់ពួកគេ

«បានមកដល់ពួកគេ» ឬ «មកដល់ពួកគេ»

ពួកគេទាស់ចិត្តជាខ្លាំង

«ពួកគេខឹងសម្បាជាខ្លាំង»។ ជាពិសេសពួកសាឌូស៊ី

បានខឹងសម្បាជាមួយនឹងអ្វីដែលលោកពេត្រុស និងលោកយ៉ូហានបាននិយាយ ព្រោះពួកគេមិនជឿលើការរស់ឡើងវិញទេ។

ប្រកាសអំពីការរស់ពីស្លាប់ឡើងវិញអំពីព្រះយេស៊ូ

លោកពេត្រុស និងលោកយ៉ូហានមានប្រសាសន៍ថា ព្រះជាម្ចាស់បានប្រោសមនុស្សពីស្លាប់ឡើងវិញដូចគ្នានឹងការដែលព្រះអង្គបានប្រោសព្រះយេស៊ូពីស្លាប់ដែរ។

បកប្រែបែបនេះថា: អនុញ្ញាត «ឲ្យមានការរស់ឡើងវិញ»

ដើម្បីសំដៅលើទាំងការរស់ឡើងវិញរបស់ព្រះយេស៊ូ និងការរស់ឡើងវិញជាទូទៅរបស់អ្នកផ្សេង។

ពីចំណោមមនុស្សស្លាប់

«ពីចំណោមមនុស្សស្លាប់»

ពួកគេបានចាប់សាវកទាំងពីរ

«ពួកបូជាចារ្យ មេកងរក្សាព្រះវិហារ និងពួកខាង គណៈសាឌូស៊ីបានចាប់លោកពេត្រុស និងលោកយ៉ូហាន»។

ដ្បិត ពេលនោះល្ងាចណាស់ហើយ

វាគឺជាទម្លាប់ មិនត្រូវសួរសំណួរនៅពេលយប់ឡើយ។

បណ្តាជនភាគច្រើនដែលបានឮព្រះបន្ទូលបានជឿ

ឃ្លានេះសំដៅលើតែបុរសទេ មិនបានបូករួមជាមួយស្ត្រីនិងកុមារដែលជឿទេ។

ព្រះយេស៊ូពីចំណោមមនុស្សស្លាប់

generated on Wed Sep 10 16:16:32 2025

«រីកចម្រើនទៅដល់ចំនួនប្រាំពាន់អ្នក»។
Acts 4:5
ប្រយោគភ្ជាប់
ពួកមេដឹកនាំបានសួរលោកពេត្រុសនិងលោកយ៉ូហាន
ដែលឆ្លើយដោយគ្មានការភ័យខ្លាច។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើជនជាតិយូដាទាំងមូល។
លុះស្អែកឡើង
ឃ្លាដែលត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ពីសកម្មភាពចាប់ផ្តើមនៅទីណា។
ប្រសិនបើ ភាសារបស់អ្នកមានរបៀបដូចនេះ អ្នកអាចប្រើវានៅទីនេះ។
ពួកមេដឹកនាំ ពួកព្រឹទ្ធាចារ្យ និងពួកអាចារ្យរបស់ពួកគេ
ឃ្លានេះ អំណះអំណាងទៅលើក្រុមប្រឹក្សាជាន់ខ្ពស់ អ្នកគ្រប់គ្រងលើផ្នែកតុលាការ
ដែលមានមនុស្សបីក្រុមនៅក្នុងនោះ។
លោកយ៉ូហាន លោកអលេក្សានត្រុស
បុរសពីរនាក់នេះ គឺជាសមាជិកគ្រួសាររបស់មហាបូជាចារ្យ។
នេះមិនមែនជាលោកយ៉ូហាន ដែលជាសាវកទេ។
សម្អាងលើអំណាចអ្វី
«តើនរណាប្រគល់អំណាចដល់អ្នក» (UDB)
ក្នុងនាមនរណា
ពាក្យ «នាមនរណា» នៅទីនេះ សំដៅលើសិទ្ធិអំណាច។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្អាងលើអំណាចនរណា»
Acts 4:8
លោកពេត្រុសបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណដ៏វិសុទ្ធបានចាក់បំពេញលោកពេត្រុស ហើយនិងព្រះអង្គ»។
សូមមើលពីរបៀបនៃការដែលអ្នកបកប្រែនៅក្នុងជំពូក ២:១
ថ្ងៃនេះ អស់លោកសួរចម្លើយយើងខ្ញុំ ពីអំពើល្អដែលយើងខ្ញុំសង្គ្រោះអ្នកពិការឲ្យបានជាតាមរបៀប
ណា?
លោកពេត្រុសសួរសំណួរនេះ ដើម្បីបញ្ជាក់ថា
នេះគឺជាហេតុផលជាក់លាក់ដែលពួកគេត្រូវគេចោទប្រកាន់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកបានសួរយើងនៅថ្ងៃនេះ...តើអំពើល្អដែល
យើងខ្ញុំធ្វើឲ្យអ្នកពិការឲ្យបានជា»
សូមអស់លោក និងប្រជារាស្ត្រអ៊ីស្រាអែលទាំងមូលជ្រាបថា
ឃ្លានេះ អាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបនៃការបកប្រែផ្សេងទៀត:
«សូមឲ្យអ្នកទាំងអស់គ្នា និងប្រជាជនអ៊ីស្រាអែលទាំងអស់ដឹងពីការនេះ»
ចំពោះអស់លោក និងប្រជាជនអ៊ីស្រាអែលទាំងអស់គ្នា
«ចំពោះអស់អ្នករាល់គ្នាដែលសួរយើងខ្ញុំ
និងប្រជាជនអ៊ីស្រាអែលទាំងអស់ផ្សេងទៀត»។
ដោយសារព្រះនាមព្រះយេស៊ូគ្រិស្តជាអ្នកភូមិណាសារ៉ែត
ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើអំណាច និងសិទ្ធិអំណាច។
របៀបនៃការបកប្រែផ្សេងទៀត: «ដោយសារអំណាចរបស់ព្រះយេស៊ូគ្រិស្ត
ជាអ្នកភូមិណាសារ៉ែត ។
Acts 4:11
ប្រយោគភ្ជាប់
លោកពេត្រុសបានបញ្ចប់សុន្ទរកថារបស់គាត់ទៅកាន់អ្នកកាន់អ្នកដឹកនាំសាសនាយូដា ដែលបានចាប់ផ្តើមនៅក្នុងជំពូក
៤:៨។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកពេត្រុស
និងអស់អ្នកដែលគាត់និយាយទៅកាន់។
ព្រះយេស៊ូគ្រិស្ត គឺជាថ្ម...ប៉ុន្តែ ព្រះអង្គបានត្រឡប់មកជាថ្មគ្រឹះដ៏សំខាន់បំផុត
លោកពេត្រុសបានដកស្រង់ពីទំនុកតម្កើង។
នេះគឺជាពាក្យប្រៀបធៀបដែលសំដៅលើអ្នកដឹកនាំសាសនា ប្រៀបដូចជាអ្នកសង់
បានបដិសេធព្រះយេស៊ូ ប៉ុន្តែ
ព្រះជាម្ចាស់នឹងធ្វើឲ្យព្រះអង្គទៅជាសំខាន់បំផុតនៅក្នុងព្រះរាជរបស់ព្រះ
ប្រៀបដូចជាថ្មគ្រឹះដ៏សំខាន់ នៅក្នុងការសាងសង់។ ។
ដ៏សំខាន់បំផុត (ក្បាល/សិរសា)
ពាក្យ «ក្បាល» នៅទីនេះ មានន័យថា: «សំខាន់បំផុត» ឬ «សំខាន់ណាស់»។
លោកទាំងអស់គ្នា ជាជាងសំណង់បានបោះចោល
«លោកទាំងអស់គ្នា ជាជាងសំណង់បានបដិសេធ» ឬ
«អ្នករាល់គ្នាជាជាងសំណង់បដិសេធថាគ្មានប្រយោជន៍»
ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សបានទាល់តែសោះ
ឃ្លានេះ នៅក្នុងទម្រង់អសកម្ម។ របៀបបកប្រែផ្សេងទៀត:
«ព្រះអង្គគឺជាព្រះតែមួយអង្គគត់ដែលអាចសង្គ្រោះបាន» ។
ដ្បិត នៅក្រោមមេឃនេះ ព្រះជាម្ចាស់ពុំបានប្រទាននាមណាមួយផ្សេងទៀតមកមនុស្ស
នេះអាចជាទម្រង់សកម្ម។ របៀបនៃការបកប្រែផ្សេងទៀត:
«គ្មាននាមណាទៀតនៅក្រោមមេឃ
ដែលព្រះជាម្ចាស់បានប្រទានដល់មនុស្សឡើយ» ។
ដ្បិត នៅក្រោមមេឃនេះ ព្រះជាម្ចាស់ពុំបានប្រទាននាមណាមួយផ្សេងទៀតមកមនុស្ស ដើម្បី
សង្គ្រោះយើងបានឡើយ
ឃ្លា «នាម...ដែលបានប្រទានដល់មនុស្ស» សំដៅលើព្រះយេស៊ូ។
របៀបនៃការបកប្រែផ្សេងទៀត: «គ្មាននរណាផ្សេងទៀតនៅក្រោមមេឃ
ដែលបានប្រគល់ដល់មនុស្សដើម្បីឲ្យបានសង្គ្រោះឡើយ»
ដើម្បីសង្គ្រោះយើងបានឡើយ
ពាក្យនេះ អាចជាទម្រង់សកម្ម។ របៀបនៃការបកប្រែផ្សេងទៀត:
«ដែលអាចសង្គ្រោះយើង» ឬ «ដែលសង្គ្រោះយើង» ។
Acts 4:13
ព័ត៌មានទូទៅ
នេះគឺជាឧទាហរណ៍ទីពីរនៃពាក្យ «ពួកគេ» សំដៅលើ លោកពេត្រុស
និងលោកយ៉ូហាន។ ពាក្យ «ពួកគេ» នៅដែលមានផ្សេងៗទៀតនៅក្នុងវគ្គនេះ
សំដៅលើអ្នកដឹកនាំរបស់ជនជាតិយូដា។
ទឹកចិត្តក្លាហានរបស់លោកពេត្រុស និងលោកយ៉ូហាន
ពាក្យ «ទឹកចិត្តក្លាយហាន» សំដៅលើរបៀបដែលលោកពេត្រុស
និងលោកយ៉ូហានឆ្លើយតបចំពោះអ្នកដឹកនាំរបស់ជនជាតិយូដា។
របៀបនៃការបកប្រែផ្សេងទៀត: «លោកពេត្រុស
និងលោកយ៉ូហានមានទឹកចិត្តក្លាហានក្នុងការនិយាយ» ។
ភាពក្លាយហាន
«អង់អាច» ឬ «ចិត្តក្លាហាន»
គេងឿងឆ្ងល់ណាស់ថា លោកទាំងពីរជាមនុស្សសាមញ្ញ
អ្នកដឹកនាំជនជាតិយូដា «ដឹងថា»
ដោយព្រោះតែការនិយាយស្តីរបស់លោកពេត្រុស និងលោកយ៉ូហាន។
បានដឹង
«បានយល់»
ជាមនុស្សសាមញ្ញ ពុំដែលបានរៀនសូត្រជ្រៅជ្រះទេ
ពាក្យ «សាមញ្ញ» និង «មិនបានរៀនសូត្រជ្រៅជ្រះ» មានន័យប្រហែលគ្នា។
ពួកគេសង្កត់ន័យថា លោកពេត្រុស
និងលោកយ៉ូហានបានទទួលការហឺកហឺនជាផ្លូវការតាមច្បាប់របស់ជនជាតិយូដាទេ។
បុរសដែលបានជា
នេះជាទម្រង់សកម្ម។ របៀបបកប្រែផ្សេងទៀត: «បុរសម្នាក់ដែលលោកពេត្រុស
និងលោកយ៉ូហានបានធ្វើឲ្យជា»
ពួកគេក៏រកពាក្យឆ្លើយតបវិញពុំបានសោះ
«គ្មានអ្វីនិយាយទាស់នឹងលោកពេត្រុស
និងលោកយ៉ូហានដែលធ្វើឲ្យអ្នកនោះជាទេ»។ ពាក្យ «នេះ»
សំដៅលើអ្វីដែលលោកពេត្រុស និងលោកយ៉ូហានបានធ្វើ។
ដែលបានចាប់ផ្តើមនៅក្នុងជំពូក
ពួកសាវក
ឃ្លានេះ សំដៅលើលោកពេត្រុស និងលោកយ៉ូហាន។
តើយើងគួរធ្វើអ្វីដល់អ្នកទាំងពីរនេះ?
អ្នកដឹកនាំជនជាតិយូដា សួរសំណួរនេះចេញពីការខកចិត្ត
ពីព្រោះពួកគេគិតមិនឃើញថាត្រូវធ្វើអ្វីជាមួយលោកពេត្រុស និងលោកយ៉ូហាន។
របៀបនៃការបកប្រែផ្សេងទៀត:
«គ្មានអ្វីដែលយើងអាចធ្វើជាមួយបុរសទាំងពីរនាក់នេះទេ!»
ដ្បិត អ្នកក្រុងយេរូសាឡិមទាំងមូលដឹងច្បាស់ថា គេធ្វើទីសម្គាល់អស្ចារ្យមួយដ៏វិសេស ដែលយើងមិន
អាចបដិសេធបាន។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត
គ្មានអ្នករស់នៅក្នុងយេរូសាឡិមមួយណាមិនដឹងថា
ពួកគេបានធ្វើទីសម្គាល់អស្ចារ្យមួយដ៏វិសេសដែលមិនអាចបដិសេធបាននោះទេ» ។
អ្នករស់នៅក្រុងយេរូសាឡិមគ្រប់គ្នា
នេះអាចជាពាក្យបំផ្លើស។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«មនុស្សដែលរស់នៅក្នុងក្រុងយេរូសាឡិមស្ទើរតែទាំងអស់គ្នា» ។
ដើម្បីកុំឲ្យរឿងនេះលេចឮខ្ជរខ្ជាយដល់ប្រជាជនបន្ថែមទៀត
ពាក្យ «វា» សំដៅលើការអស្ចារ្យ ឬសេចក្តីបង្រៀនផ្សេងៗរបស់លោកពេត្រុស
និងលោកយ៉ូហានអាចបន្តទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីកុំឲ្យមានអ្នកផ្សេងទៀតបានឮអំពីការអស្ចារ្យនេះទៀត»
«ដើម្បីកុំឲ្យដំណឹងនៃការអស្ចារ្យនេះឮខ្ជរខ្ជាយទៀត»
កុំឲ្យប្រកាសប្រាប់នរណាអំពីនាមនោះតទៅទៀតឡើយ
ពាក្យ «ព្រះនាម» សំដៅលើ បុគ្គលយេស៊ូ។ របៀបផ្សេងទៀតនៃការបកប្រែ:
«លែងឲ្យនិយាយទៅនរណាម្នាក់ទៀតអំពីមនុស្សម្នាក់ហ្នឹង គឺព្រះេយស៊ូ»
Acts 4:19
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើលោកពេត្រុស និងលោកយ៉ូហាន ប៉ុន្តែ
មិនសំដៅលើអ្នកដែលគាត់និយាយទៅកាន់ទេ។
សូមអស់លោកពិចារណាមើល នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់
ឃ្លា «នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់» សំដៅលើព្រះតម្រិះរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បើព្រះអង្គព្រះតម្រិះថាត្រឹមត្រូវ»
យើងឈប់និយាយមិនបានទេ
«យើងត្រូវតែបន្តនិយាយ» ឬ «យើងមិនអាចឈប់និយាយបានទេ»
Acts 4:21
ព័ត៌មានទូទៅ
នៅក្ុង ខ២២បានផ្តល់ព័ត៌មានពីប្រវត្តិនៃបុរសពិការដែលបានជា។
បន្ទាប់ពី គំរាមសាជាថ្មីទៀត
អ្នកដឹកនាំជនជាតិយូដាបានគំរាមកំហែងសាជាថ្មី ក្នុងការដាក់ទោសលោកពេត្រុស
និងលោកយ៉ូហាន។
ពួកគេមិនអាចរកឃើញកំហុសណាមួយ ដើម្បីដាក់ទោសដល់ពួកគេបានឡើយ
ទោះបីជា អ្នកដឹកនាំជនជាតិយូដាគំរាមកំហែងលោកពេត្រុស និងលោកយ៉ូហានក្តី
ក៏ពួកគេមានអាចរកហេតុនឹងដាក់ទោសពួកគេបានដែរ
ព្រោះពួកគេមិនបាននាំឲ្យមនុស្សមានការបះបោរទេ។
ចំពោះហេតុការណ៍ដែលកើតមាននោះ
នេះអាចជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយព្រោះអ្វីដែលលោកពេត្រុស និងលោកយ៉ូហានបានធ្វើ»
បុរសដែលបានជាដោយការអស្ចារ្យនោះ
«បុរសដែលលោកពេត្រុស និងលោកយ៉ូហានបានធ្វើឲ្យជាដោយសារការអស្ចារ្យ»។
Acts 4:23
ព័ត៌មានទូទៅ
ថ្លែងរួមគ្នា គេបានដកស្រង់ទំនុកតម្កើងរបស់ព្រះបាទដាវីឌ
ពីព្រះគម្ពីរសម្ពន្ធមេត្រីចាស់។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើអ្នកជឿទាំងអស់ ប៉ុន្តែ
មិនមែនសំដៅលើលោកពេត្រុស និងលោកយ៉ូហានទេ។
លោកពេត្រុស និងលោកយ៉ូហាននាំគ្នាទៅជួបពួកបងប្អូន
ឃ្លា «បងប្អូនរបស់ពួកគេ» សំដៅលើអ្នកជឿទាំងអស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បានទៅជួបអ្នកជឿផ្សេងទៀត»
ព្រះអង្គមានព្រះបន្ទូលតាមព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈអ្នកបម្រើរបស់ព្រះអង្គ គឺព្រះបាទដាវីឌ ជាបុព្វបុរសយើងខ្ញុំថា៖
នេះមានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធ ធ្វើឲ្យព្រះបាទដាវីឌមានរាជឱង្ការ
ឬសរសេរចុះនូវអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល។
តាមរយៈព្រះបាទដាវីឌ ជាបុព្វបុរសយើងខ្ញុំ
ពាក្យ «មាត់» នៅទីនេះ សំដៅលើពាក្យដែលព្រះបាទដាវីឌមានរាជឱង្ការ
ឬសរសេរចុះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«តាមរយៈព្រះរាជឱង្ការរបស់ព្រះបាទដាវីឌ ជាបុព្វបុរសរបស់យើង»។
«ហេតុអ្វីបានជាជាតិសាសន៍ទាំងឡាយនាំគ្នាបង្កើតកោលាហលដូច្នេះ? ហេតុអ្វីបានជាប្រជារាស្ត្រនានាមានគំនិតឥតខ្លឹមសារដូច្នេះ?
នេះគឺជាសំណួរដែលមិនទាមទារចម្លើយ
ដែលបញ្ជាក់ពីភាពឥតប្រយោជន៍នៃការប្រឆាំងជាមួយព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជាតិសាសន៍ដទៃមិនគួរមានកំហឹង
ហើយប្រជាជនទាំងឡាយក៏មិនគួរមានគំនិតឥតប្រយោជន៍ដែរ»
ប្រជារាស្ត្រនានាមានគំនិតឥតខ្លឹមសារ
«ឥតខ្លឹមសារ» នៅទីនេះ មានមកជាមួយនូវផែនការទាស់ជាមួយព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សមានគំនិតឥតខ្លឹមសារ
ក្នុងការទាស់ជាមួយព្រះជាម្ចាស់»។
ប្រជារាស្ត្រ
«ក្រុមមនុស្ស» ឬ «កុលសម្ព័ន្ធ»
Acts 4:26
ប្រយោគភ្ជាប់
ពួកអ្នកជឿបាននិយាយពីការដកស្រង់នៅក្នុងទំនុកតម្កើងរបស់ព្រះបាទដាវីឌ
ដែលពួកគេបាននិយាយនៅក្នុងជំពូក ៤:២៣
ពួកស្តេចនៅលើផែនដី និងពួកមេដឹកនាំពួតដៃ រួមគំនិតគ្នាប្រឆាំងនឹងព្រះអម្ចាស់ ហើយប្រឆាំងនឹងព្រះគ្រិស្តរបស់ព្រះអង្គ
ប្រយោគពីរនេះ មានន័យដូចគ្នា។ ប្រយោគពីរនេះ
បញ្ជាក់ពីការខំប្រឹងរួបរួមគ្នារបស់មេដឹកនាំនៅលើផែនដី
ដើម្បីប្រឆាំងជាមួយព្រះជាម្ចាស់»។
ពួតដៃ រួមគំនិតគ្នា
ឃ្លាពីរនេះ មានន័យថា
ពួកគេបង្រួបបង្រួមទាហានរបស់ពួកគេជាមួយគ្នាដើម្បីធ្វើសង្គ្រាម។
របៀបផ្សេងទៀតនៃការបកប្រែ: «បានបង្រួបបង្រួមទាហានរបស់ពួកគេជាមួយគ្នា...
ប្រមូលកងទ័ពរបស់ពួកគេជាមួយគ្នា»
ប្រឆាំងនឹងព្រះគ្រិស្តរបស់ព្រះអង្គ
ពាក្យ «ព្រះអម្ចាស់» នៅទីនេះ សំដៅលើព្រះជាម្ចាស់។ នៅក្នុងទំនុកតម្កើង ពាក្យ
«ព្រះគ្រិស្ត» សំដៅលើព្រះមេស្ស៊ី ឬ ព្រះដែលព្រះជាម្ចាស់បានចាក់ប្រេងតាំង។
Acts 4:27
ប្រយោគភ្ជាប់
អ្នកជឿបន្តក្នុងការអធិស្ឋាន
នៅក្នុងក្រុងនេះ
«ក្រុងនេះ» សំដៅលើក្រុងយេរូសាឡិម»
អ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គ
«ព្រះេយស៊ូដែលបម្រើព្រះអង្គដោយស្មោះត្រង់»
ប្រព្រឹត្តដូចព្រះអង្គបានកំណត់ទុកជាមុនដោយព្រះហស្តទ្រង់ និងដោយព្រះតម្រិះរបស់ព្រះអង្គ
ពាក្យ «ព្រះហស្ត» នៅទីនេះ ប្រើក្នុងន័យ ព្រះចេស្តារបស់ព្រះជាម្ចាស់។
លើសពីនេះទៀត ឃ្លា «ព្រះហស្ត និងព្រះតម្រិះរបស់ព្រះអង្គ»
Acts 4:29
ប្រយោគភ្ជាប់
អ្នកជឿបានបញ្ចប់សេចក្តីអធិស្ឋានរបស់ពួកគេ
ដែលពួកគេបានចាប់ផ្តើមនៅក្នុងជំពូក ៤:២៣
សូមទតមើល សេចក្តីគំរាមរបស់ពួកគេ
ពាក្យ «សូមទតមើល» នេះ
គឺជាសំណើថ្វាយដល់ព្រះជាម្ចាស់ឲ្យកត់សម្គាល់ពីរបៀបដែលអ្នកដឹកនាំជនជាតិយូដាបានគំរាមកំហែងដ
របៀបផ្សេងទៀតនៃការបកប្រែ: «សូមចំណាំមើល
ពីការដែលពួកគេគំរាមនឹងដាក់ទោសពួកយើង»។
សូមសម្តែងបារមីឲ្យអ្នកជំងឺបានជា
ពាក្យ «ព្រះហស្ត» នៅទីនេះ សំដៅលើ អំណាចចេស្តារបស់ព្រះ។
នេះគឺជាការស្នើសុំចំពោះព្រះជាម្ចាស់ សូមឲ្យព្រះអង្គសម្តែងពីព្រះចេស្តារបស់ទ្រង់។
របៀបផ្សេងទៀតនៃការបកប្រែ: «សូមសម្តែងបារមីនៃការប្រោសឲ្យអ្នកជំងឺបាន
ជារបស់ព្រះអង្គ»
តាមរយៈព្រះនាមព្រះយេស៊ូជាអ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គ
ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើអំណាច និងសិទ្ធិអំណាច។
របៀបផ្សេងទៀតនៃការបកប្រែ:
«តាមរយៈអំណាចរបស់ព្រះយេស៊ូជាអ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គ»។
អ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គ
«ព្រះយេស៊ូជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះអង្គ»។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៤:២៧
កន្លែងនោះ...ក៏រញ្ជួយ
នេះអាចជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
គេបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ
នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណដ៏វិសុទ្ធបានចាក់បំពេញគេគ្រប់គ្នា»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះ នៅក្នុងជំពូក ២:១។
Acts 4:32

generated on Wed Sep 10 16:16:32 2025

ពួកគេមានចិត្តថ្លើមតែមួយ
ពាក្យ «ចិត្ត» នៅទីនេះ សំដៅលើគំនិត និងពាក្យ «គំនិត» សំដៅលើអារម្មណ៍ ជាមួយគ្នាពួកគេសំដៅលើមនុស្សទាំង អស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេគិតដូចគ្នា ហើយចង់បានអ្វីដូចគ្នា»
ពួកគេបានដាក់របស់ទាំងអស់រួមគ្នា
«ពួកគេបានចែករំលែកអ្វីដែលគេមានដល់គ្នាទៅវិញទៅមក»
សូមមើលរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុង ជំពូក ២:៤៣
ទ្រង់សម្តែងព្រះហឫទ័យប្រណីសន្តោសដ៏លើសលប់ដល់ពួកគេទាំងអស់គ្នា។
ទី ១) អាចមានន័យថា: ព្រះជាម្ចាស់បានប្រទានពរដល់អ្នកជឿគ្រប់គ្នាដ៏លើសលប់ ឬ ២) អ្នកក្រុងយេរូសាឡិម មានការស្ញើចសរសើរដល់អ្នកជឿយ៉ាងខ្លាំង។
Acts 4:34
អស់អ្នកដែលមានដីធ្លី ឬផ្ទះសម្បែងនាំគ្នាលក់ដីធ្លី និងផ្ទះ
ឃ្លានេះមានន័យថា ពួកគេសរសេរ ដើម្បីបង្ហាញថាពួកគេដែលមានដីផ្ទះផ្ទាល់ខ្លួន។
មានដីធ្លី
«បានចែករំលែក» ឬ «បានកត់ត្រាទុក»
លុយដែលបានមកពីលក់របស់របរ
ឃ្លានេះ អាចជាស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លុយដែលពួកគេទទួលបានពីអ្វីដែលគេលក់ឥវាន់»
យកប្រាក់ មកជូនក្រុមសាវក
«នេះមានន័យថា ពួកគេបានយកលុយទៅជូនពួកសាវក។ របៀបផ្សេងទៀតនៃការបកប្រែ: «បាននាំវាមកជូនពួកសាវក»
អ្នកជឿទាំងអស់គ្នាទទួលចំណែកតាមសេចក្តីត្រូវការរៀងៗខ្លួន
ឃ្លានេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានបែងចែកលុយដល់អ្នកជឿម្នាក់ៗតាមដែលពួកគេត្រូវការ»។
Acts 4:36
ព័ត៌មានទូទៅ
លោកលូកាបានណែនាំលោកបារណាបាស មកក្នុងសាច់រឿងនេះ។
យ៉ូសែប ជាពួកលេវី ...ក្រុមសាវកបានដាក់ឈ្មោះគាត់ថា បារណាបាស
ឃ្លានេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកសាវកបានហៅលោកយ៉ូសែប...ថាបារណាបាស»
ដែលមានន័យថា
ឃ្លានេះនិយាយនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដែលអាចប្រែថា» ឬ «ដែលមានន័យថា»
កូននៃការលើកទឹកចិត្ត
ពួកសាវកបានប្រើពាក្យនេះ ដើម្បីបង្ហាញថា លោកយ៉ូសែបជាមនុស្សម្នាក់ដែលលើកទឹកចិត្តអ្នកដទៃ។ គេប្រើពាក្យនេះ ហាក់បីដូចគាត់ជាមនុស្សម្នាក់ដែលជាអ្នកលើកទឹកចិត្ត ឪពុករបស់លោកយ៉ូសែប។ របៀបផ្សេងទៀតនៃការបកប្រែ: «ជាមនុស្សម្នាក់ដែលតែងតែលើកទឹកចិត្តអ្នកដទៃជានិច្ច» ។
យកប្រាក់មកជូនក្រុមសាវក
ឃ្លានេះ មានន័យថាពួកគេបានយកប្រាក់មកជូនពួកសាវក។ របៀបផ្សេងទៀតនៃការបកប្រែ: «បានយកវាមកជូនពួកសាវក» ឬ «បានឲ្យវាទៅពួកសាវក»។ សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៤:៣៤។

---

5 [1]ឥឡូវនេះមានបុរសម្នាក់ឈ្មោះ អាណាណាស និងភរិយាលោកឈ្មោះសាភីរ៉ាបានលក់ដីរបស់គាត់មួយចំណែក[2]ហើយសមគំនិតជាមួយភរិយាទុកប្រាក់មួយចំណែក
សម្រាប់ខ្លួនឯង រួចយកប្រាក់ដែលនៅសល់ទៅជូនក្រុមសាវក។
[3]ប៉ុន្តែលោកពេត្រុសមានប្រសាសន៍ទៅគាត់ថា៖ «អាណាណាសអើយ! ហេតុដូចម្តេចបានជាមារសាតាំងនៅពេញក្នុងចិត្តអ្នក រហូតដល់ទៅកុហកព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយទុកប្រាក់ដែលលក់ដីបាននោះមួយចំណែកដូច្នេះ?[4]កាលដើមឡើយ ដីនោះជាកម្មសិទ្ធិរបស់អ្នក លុះអ្នកបានលក់ហើយ ប្រាក់ដែលបានមកនោះអ្នកអាចប្រើប្រាស់
តាមចិត្ត! ចុះហេតុដូចម្តេចបានជាអ្នកមានគំនិតប្រព្រឹត្តយ៉ាងហ្នឹង? អ្នកបានកុហកព្រះជាម្ចាស់ មិនមែនកុហកមនុស្សទេ»។[5]កាលអាណាណាសបានឮពាក្យនេះ ក៏ដួល
ដាច់ខ្យល់ស្លាប់ទៅ។ រីឯអស់អ្នកដែលបានឮដំណឹងនេះ ក៏ស្ញែងខ្លាចជាខ្លាំង។[6]ពួកយុវជននាំគ្នាមករុំសពអាណាណាស ហើយសែងយកទៅកប់។
[7]ប្រមាណជាបីម៉ោងក្រោយមក ភរិយារបស់អាណាណាសចូលមកដល់ ដោយមិនបានដឹងហេតុការណ៍ដែលកើតមាននោះឡើយ។[8]លោកពេត្រុសសួរនាងថា៖ «សូមប្រាប់
ខ្ញុំមកមើល៍ តើប្តីនាង និងនាងលក់ដីបានប្រាក់ប៉ុណ្ណេះមែនឬ?»។ នាងឆ្លើយថា៖ «ចាំស! បានប្រាក់ប៉ុណ្ណឹងមែន»។
[9]បន្ទាប់មក លោកពេត្រុសក៏មានប្រសាសន៍ទៅនាងទៀតថា៖ «ហេតុដូចម្តេចបានជាអ្នករួមគំនិតគ្នាល្បងលព្រះវិញ្ញាណរបស់ព្រះអម្ចាស់ដូច្នេះ? មើល៍! ពួកអ្នកដែលបាន
បញ្ចុះសពប្តីនាងមកដល់នៅមាត់ទ្វារហើយ គេនឹងសែងនាងយកទៅដែរ»។[10]រំពេចនោះ នាងក៏ដួលនៅទៀបជើងរបស់លោក ហើយដាច់ខ្យល់ស្លាប់ទៅ។ ពេលពួកយុវជន
ចូលមក ឃើញនាងស្លាប់ទៅហើយ គេក៏នាំគ្នាយកសពនាងទៅបញ្ចុះនៅក្បែរសពប្តីរបស់នាង។[11]ក្រុមជំនុំទាំងមូល និងអស់អ្នកដែលបានឮដំណឹងនេះ ស្ញែងខ្លាចជាខ្លាំង។
[12]សាវកបាននាំគ្នាបានធ្វើទីសម្គាល់ដ៏អស្ចារ្យ និងឫទ្ធិបាដិហារិយ៍ជាច្រើននៅក្នុងចំណោមប្រជាជន។ អ្នកជឿទាំងអស់រួមចិត្តគំនិតគ្នា គេឈរនៅតាមថែវសាឡូម៉ូន។[13]ប៉ុន្តែ
គ្មាននរណាហ៊ានមកចូលរួមជាមួយក្រុមសាវកឡើយ ទោះយ៉ាងណាប្រជាជនកោតសរសើរពួកគេគ្រប់ៗគ្នា។
[14]មានបណ្តាជនទាំងប្រុសទាំងស្រីកាន់តែច្រើនឡើងបានជឿលើព្រះអម្ចាស់។[15]មនុស្សម្នាបានសែងអ្នកជំងឺមកដាក់នៅតាមផ្លូវ ឲ្យដេកលើគ្រែស្នែង លើកន្ទេល ប្រាថ្នាយ៉ាង
ហោចណាស់ គ្រាន់តែឲ្យស្រមោលលោកពេត្រុសបាំងលើអ្នកជំងឺណាម្នាក់ នៅពេលដែលលោកដើរកាត់តាមនោះ។[16]មានមនុស្សជាច្រើននាំគ្នាធ្វើដំណើរមកពីភូមិនានានៅ
ជិតក្រុងយេរូសាឡឹមទាំងសែងអ្នកជំងឺ និងអ្នកដែលមានវិញ្ញាណអាក្រក់ចូលមកជាមួយផង អ្នកទាំងនោះបានជាគ្រប់ៗគ្នា។
[17]ប៉ុន្តែ មានលោកមហាបូជាចារ្យ និងអស់អ្នកដែលនៅជាមួយលោកទាំងប៉ុន្មាន គឺពួកខាងគណៈសាឌូស៊ីមានចិត្តច្រណែនជាខ្លាំង។[18]គេលើកគ្នាមកចាប់ក្រុមសាវកយកទៅ
ឃុំឃាំងនៅពន្ធនាគារសាធារណៈ។
[19]លុះដល់យប់ មានទេវតារបស់ព្រះអម្ចាស់មកបើកទ្វារពន្ធនាគារឲ្យក្រុមសាវកចេញទាំងពោលថា៖[20]«សូមអញ្ជើញទៅឈរក្នុងព្រះវិហារ ហើយប្រកាសព្រះបន្ទូល
ទាំងឡាយណា ដែលផ្តល់ជីវិតនេះឲ្យប្រជាជនស្តាប់ចុះ»។[21]កាលបានឮពាក្យទេវតា ក្រុមសាវកនាំគ្នាចូលទៅក្នុងព្រះវិហារតាំងពីព្រលឹម ហើយបង្រៀនប្រជាជន។
ប៉ុន្តែលោកមហាបូជាចារ្យ និងអស់អ្នកដែលនៅជាមួយលោកបានកោះហៅក្រុមប្រឹក្សាជាន់ខ្ពស់ និងក្រុមចាស់ទុំនៃប្រជាជនអ៊ីស្រាអែលមកជួបជុំគ្នា រួចចាត់អ្នកយាមឲ្យទៅ
នាំក្រុមសាវកពីពន្ធនាគារមក។
[22]ប៉ុន្តែ ពេលទៅដល់ទីឃុំឃាំង គេពុំឃើញក្រុមសាវកនោះទេ គេនាំគ្នាវិលមកវិញជម្រាបថា៖[23]«យើងខ្ញុំឃើញទីឃុំឃាំងនៅបិទជិតល្អណាស់ ហើយពួកអ្នកយាមក៏ឈរ
យាមនៅខាងមុខទ្វារដែរ តែពេលយើងខ្ញុំបើកទ្វារ ពុំឃើញមាននរណាម្នាក់នៅក្នុងទីនោះសោះ»។
[24]កាលមេកងរក្សាព្រះវិហារ និងពួកនាយកបូជាចារ្យឮដូច្នោះ ពួកគេមិនដឹងជាត្រូវគិតយ៉ាងណាអំពីក្រុមសាវក និងអំពីហេតុការណ៍ដែលនឹងកើតឡើងនោះឡើយ។[25]ពេល
នោះ មានម្នាក់ចូលមកជម្រាបអង្គប្រជុំថា៖ «ពួកអ្នកដែលអស់លោកបានចាប់ឃុំឃាំង កំពុងតែឈរបង្រៀនប្រជាជន ក្នុងព្រះវិហារឯណោះ»។
[26]មេកងរក្សាព្រះវិហារ ក៏នាំទាហានចេញទៅចាប់ក្រុមសាវកបណ្តើរមក តែឥតមានធ្វើបាបអ្វីទេ ព្រោះគេខ្លាចប្រជាជនយកដុំថ្មគប់។[27]លុះនាំក្រុមសាវកមកដល់ហើយ
ពួកគេក៏ឲ្យឈរនៅមុខក្រុមប្រឹក្សាជាន់ខ្ពស់ លោកមហាបូជាចារ្យសួរក្រុមសាវកថា៖[28]«យើងបានហាមប្រាមអ្នករាល់គ្នាជាដាច់ខាត ថាមិនឲ្យបង្រៀនប្រជាជនក្នុងនាមនេះ
ជាដាច់ខាត តែឥឡូវនេះ អ្នករាល់គ្នាបែរជាបង្រៀនគេពាសពេញក្រុងយេរូសាឡឹមទាំងមូលទៅវិញ ហើយចង់ទម្លាក់កំហុសនៃការប្រហារជីវិតបុរសនោះមកលើយើងថែម
ទៀតផង»។
[29]ប៉ុន្តែលោកពេត្រុស និងសាវកឯទៀតៗឆ្លើយឡើងថា៖ «យើងខ្ញុំត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ជាជាងស្តាប់បង្គាប់មនុស្ស។[30]ព្រះជាម្ចាស់នៃបុព្វបុរសរបស់យើងបានប្រោស
លោកយេស៊ូ ដែលអស់លោកបានសម្លាប់ដោយព្យួរនៅលើឈើនោះឲ្យមានជីវិតរស់ឡើងវិញ។[31]ព្រះជាម្ចាស់បានលើកតម្កើងលោកយេស៊ូឡើងទៅគង់នៅខាងស្តាំព្រះបិតា
ហើយតែងតាំងលោកជាព្រះរាជបុត្រា និងជាព្រះសង្គ្រោះមួយអង្គ ដើម្បីឲ្យប្រជារាស្ត្រអ៊ីស្រាអែលកែប្រែចិត្តគំនិត ហើយព្រះជាម្ចាស់លើកលែងទោសឲ្យពួកគេរួចពីបាប។
[32]យើងខ្ញុំជាសាក្សីអំពីហេតុការណ៍ទាំងនេះ ហើយព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះជាម្ចាស់ប្រទានដល់អស់អ្នកស្តាប់បង្គាប់ព្រះអង្គ ក៏ធ្វើជាសាក្សីបានដែរ»។

generated on Wed Sep 10 16:16:32 2025

[33]កាលក្រុមប្រឹក្សាជាន់ខ្ពស់ឮដូច្នេះ ពួកគេក្រេវក្រោធជាខ្លាំង ហើយចង់សម្លាប់ក្រុមសាវក។[34]ប៉ុន្តែមានបុរសម្នាក់ខាងគណៈផារីស៊ីឈ្មោះកាម៉ាលាលជាអ្នកប្រាជ្ញខាងវិន័យ ដែលប្រជាជនគោរពគ្រប់ៗគ្នាក្រោកឈរឡើងនៅមុខក្រុមប្រឹក្សាជាន់ខ្ពស់ ហើយសុំឲ្យគេនាំក្រុមសាវកចេញពីទីនោះមួយស្របក់។
[35]បន្ទាប់មក លោកមានប្រសាសន៍ទៅកាន់អង្គប្រជុំថា៖ «អស់លោកជាជនជាតិអ៊ីស្រាអែលអើយ សូមប្រយ័ត្នចំពោះអំពើដែលអស់លោកប៉ុនប៉ងនឹងធ្វើដល់អ្នកទាំងនេះ។[36]ក្នុងពេលថ្មីៗកន្លងទៅ មានម្នាក់ឈ្មោះថីដាស បានតាំងខ្លួនឡើងជាវីរជន ហើយប្រមូលបានមនុស្សប្រមាណជាបួនរយនាក់។ ថីដាសត្រូវគេប្រហារជីវិត រីឯពួកអ្នកដែលចូលដៃជាមួយគាត់ក៏ត្រូវបែកខ្ញែកគ្នាអស់គ្មានសល់។[37]បន្ទាប់ពីបុរសម្នាក់នោះ នៅជំនាន់ដែលគេជំរឿនប្រជាជន មានយូដាសជាអ្នកស្រុកកាលីឡេ បានលើកខ្លួនឡើងបញ្ចុះបញ្ចូលមនុស្សជាច្រើនឲ្យទៅតាមគាត់។ យូដាសក៏ត្រូវគេប្រហារជីវិតដែរ ហើយអស់អ្នកដែលចូលដៃជាមួយគាត់ក៏បែកខ្ញែកគ្នាអស់ទៅ។
[38]ឥឡូវនេះ ខ្ញុំសូមជម្រាបអស់លោកថា សូមកុំរវីរវល់នឹងអ្នកទាំងនេះទៀតធ្វើអ្វី លែងគេទៅវិញទៅ។ ប្រសិនបើគម្រោងការ និងកិច្ចការដែលគេចាប់ផ្តើមធ្វើមានប្រភពចេញមកពីមនុស្ស នោះមុខជារលាយសាបសូន្យមិនខាន[39]ផ្ទុយទៅវិញ បើកិច្ចការទាំងនោះមានប្រភពចេញមកពីព្រះជាម្ចាស់ អស់លោកពុំអាចរំលាយបានឡើយ។ ហេតុនេះ សូមប្រុងប្រយ័ត្ន ក្រែងលោអស់លោកបែរជាប្រឆាំងទាស់នឹងព្រះជាម្ចាស់ទៅវិញ»។ ពួកគេយល់ស្របតាមយោបល់របស់លោកកាម៉ាលាលទាំងអស់គ្នា។
[40]បន្ទាប់មក គេក៏ហៅក្រុមសាវកមកវិញ ហើយបញ្ជាឲ្យវាយនឹងរំពាត់ទាំងហាមប្រាមមិនឲ្យប្រកាសអំពីព្រះនាមព្រះយេស៊ូទៀត រួចលែងឲ្យត្រឡប់ទៅវិញ។[41]ក្រុមសាវកចាកចេញពីក្រុមប្រឹក្សាជាន់ខ្ពស់ទាំងអរសប្បាយ ដ្បិតព្រះជាម្ចាស់បានប្រទានឲ្យគេមានកិត្តិយស រងទុក្ខទោសព្រោះតែព្រះនាមព្រះយេស៊ូ។[42]ជារៀងរាល់ថ្ងៃ គេតែងតែបង្រៀនប្រជាជន និងផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្តនៅក្នុងព្រះវិហារ និងនៅតាមផ្ទះឥតឈប់ឈរឡើយ។

Acts 5:1
ប្រយោគភ្ជាប់
បន្តពីរឿងរ៉ាវដែលគ្រិស្តបរិស័ទដំបូងបានចែករំលែកអ្វីដែលគេមានដល់អ្នកជឿផ្សេងទៀត
លោកលូកាបានប្រាប់អំពីអ្នកជឿពីរនាក់ លោកអាណាណាស និងនាងសាភីរ៉ា។
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើដើម្បីបង្ហាញពីការ សម្រាកពីរឿងចាស់
ហើយចាប់ផ្តើមសាច់រឿងថ្មី។
ប្រពន្ធរបស់គាត់ក៏ដឹងឮដែរ
«ប្រពន្ធរបស់គាត់ក៏បានដឹងថាគាត់បានទុកប្រាក់មួយចំណែក»
យកប្រាក់ដែលនៅសល់ទៅជូនក្រុមសាវក
ឃ្លានេះមានន័យថា ពួកគបានយកប្រាក់ទៅជូនពួកសាវក។
របៀបផ្សេងទៀតនៃការបកប្រែ: «បានយកវាមកដាក់ឲ្យពួកសាវក»។
សូមមើលពីរបៀបនៃការដែលអ្នកបកប្រែពាក្យនេះនៅក្នុងជំពូក ៤:៣៤
Acts 5:3
ព័ត៌មានទូទៅ
ប្រសិនបើ ភាសារបស់អ្នកមិនប្រើសំណួរដែលមិនទាមទារចម្លើយទេ
អ្នកអាចត្រឡប់ប្រយោគនេះបាន។
ហេតុដូចម្តេចបានជាមារសាតាំងនៅពេញក្នុងចិត្តអ្នក រហូតដល់ទៅកុហក...ដីដូច្នេះ?
លោកពេត្រុសប្រើសំណួរនេះ ដើម្បីស្តីបន្ទោសលោកអាណាណាស។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនត្រូវអនុញ្ញាតឲ្យសាតាំងបញ្ចុះបញ្ចូលអ្នកឲ្យកុហក...ដីដូច្នេះ» ។
មារសាតាំងនៅពេញក្នុងចិត្តអ្នក
ពាក្យ «ចិត្ត» នៅទីនេះ សំដៅលើ បំណងចិត្ត និងអារម្មណ៍។ ទី ១
អាចមានន័យថា: «សាតាំងគ្រប់គ្រងអ្នកទាំងស្រុង»
រហូតដល់ទៅកុហកព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទុកប្រាក់ដែលលក់ដីបាននោះមួយចំណែកដូច្នេះ?
ឃ្លានេះមានន័យថា លោកអាណាណាសបានប្រាប់ពួកសាវកថា
លោកបានថ្វាយអ្វីៗគ្រប់យ៉ាងដែលបានទទួលពីការលក់ដីរបស់លោក។
កាលវាមិនទាន់លក់នៅឡើយ តើវាមិនមែនជារបស់អ្នកទេឬអី?
លោកពេត្រុសប្រើសំណួរនេះដើម្បីស្តីបន្ទោសលោកអាណាណាស។
របៀបផ្សេងទៀតនៃការបកប្រែ: «កាលវាមិនទាន់លក់នៅឡើយ
វាគឺជាទ្រព្យសម្បត្តិរបស់អ្នក»។
កាលវាមិនទាន់លក់នៅឡើយ
«កាលអ្នកមិនបានលក់វានៅឡើយ»
ម្តេចបានជាអ្នកមានចិត្តប្រព្រឹត្តយ៉ាងហ្នឹង?
លោកពេត្រុសប្រើសំណួរនេះ ដើម្បីស្តីបន្ទោសដល់លោកអាណាណាស។ ពាក្យ
«ចិត្ត» នៅទីនេះ សំដៅលើបំណងចិត្ត និងអារម្មណ៍។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកមិនគួរមានគំនិតធ្វើការបែបនេះទេ»
ដួលដាច់ខ្យល់ស្លាប់ទៅ
លោកអាណាណាសបានដួលចុះ ព្រោះគាត់ស្លាប់
គាត់មិនបានស្លាប់ដោយសារគាត់ដួលទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានស្លាប់ ហើយដួលទៅនឹងដី»
Acts 5:7
ភរិយារបស់គាត់បានចូលមកដល់
«ភរិយារបស់លោកអាណាណាសបានចូលមកខាងក្នុង» ឬ
«នាងសាភីរ៉ាបានចូលមកដល់»
អ្វីដែលបានកើតឡើង
«ដែលស្វាមីរបស់នាងបានស្លាប់»
តាមច្រើនប៉ុណ្ណឹង
«បានច្រើនប៉ុណ្ណឹង»។
ឃ្លានេះសំដៅលើចំនួនប្រាក់ដែលលោកអាណាណាសបានប្រគល់ឲ្យពួកសាវក។
Acts 5:9
ប្រយោគភ្ជាប់
នេះគឺជាចុងបញ្ចប់នៃសាច់រឿងអំពីលោកអាណាណាស និងនាងសាភីរ៉ា។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ ជាពហុវចន: សំដៅទៅលើទាំងលោកអាណាណាស និង
នាងសាភីរ៉ា។
ហេតុដូចម្តេចបានជាអ្នករួមគំនិតគ្នា ដើម្បីល្បងលព្រះវិញ្ញាណរបស់ព្រះអម្ចាស់ដូច្នេះ?
លោកពេត្រុសសួរសំណួរនេះដើម្បីស្តីបន្ទោសនាងសាភីរ៉ា។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនគួររួមគំនិតគ្នាដើម្បីល្បងលវិញ្ញាណរបស់ព្រះអម្ចាស់ដូច្នេះទេ»
អ្នករួមគំនិតគ្នា
«អ្នកទាំងពីរនាក់បានរួមគំនិតជាមួយគ្នា»
ដើម្បីល្បងលព្រះវិញ្ញាណរបស់ព្រះអម្ចាស់
ពាក្យ «ល្បងល» នៅទីនេះ មានន័យថា រករឿងឈ្លោះ ឬបង្ហាញភស្តុតាង។
ពួកគេព្យាយាមកំហែងព្រះជាម្ចាស់
ហើយចង់ឃើញថាព្រះជាម្ចាស់នឹងដាក់ទោសគេឬយ៉ាងណា។
ជើងនៃពួកអ្នកដែលបានបញ្ចុះសពប្តីនាងមកដល់នៅមាត់ទ្វារហើយ
ឃ្លា «ជើង» នៅទីនេះ សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ
«ពួកអ្នកដែលកប់ស្វាមីនាង»
ហើយនាងក៏ដាច់ខ្យល់ស្លាប់ទៅ
«ស្លាប់» សូមមើលរបៀបដែលអ្នកបកប្រែឃ្លានេះនៅក្នុងគំរូនៅក្នុង កិច្ចការ ៥:៣។
Acts 5:12
ប្រយោគភ្ជាប់
លោកលូកាបន្តប្រាប់ពីអ្វីដែលបានកើតឡើងនៅក្នុងក្រុមជំនុំសម័យដើម។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅទៅលើពួកអ្នកជឿ។
មានទីសម្គាល់ និងការអស្ចារ្យ ជាច្រើននៅក្នុងចំណោមប្រជាជនតាមរយៈដៃរបស់ពួកសាវក
«មានទីសម្គាល់ និងការអស្ចារ្យ ជាច្រើននៅក្នុងចំណោម
ប្រជាជនតាមរយៈដៃរបស់ពួកសាវក»។ ឃ្លានេះនិយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកសាវកបានធ្វើទីសម្គាល់
និងការអស្ចារ្យជាច្រើននៅក្នុងចំណោមប្រជាជន» ។
ទីសម្គាល់ និងការអស្ចារ្យ ជាច្រើន
«ព្រឹត្តិការណ៍អធិឆម្មជាតិ និងការសម្តែងការអស្ចារ្យ»។
សូមមើលពីការរបៀបនៃការបកប្រែរបស់អ្នកនៅក្នុងជំពូក ២:២២
តាមរយៈដៃរបស់ពួកសាវក
ពាក្យ «ដៃ» នៅទីនេះ សំដៅលើពួកសាវក។ របៀបផ្សេងទៀតនៃការបកប្រែ:
«តាមរយៈដៃរបស់ពួកសាវក»
បាំងសាចសាឡូម៉ូន
នេះគឺផ្លូវដើរដែលមានដំបូល ដែលមានសរសេរសង្ខាង ដើម្បីទ្រដំបូល
ហើយគេបានហៅឈ្មោះតាមព្រះនាមរបស់ព្រះបាទសាឡូម៉ូន។

generated on Wed Sep 10 16:16:32 2025

សូមមើលពីរបៀបនៃការបកប្រែរបស់អ្នកនៅក្នុងជំពូក ៣:១១ ដែលថា៖ «បាំងសាចសាឡូម៉ូន»។
ពួកគេបានទទួលការកោតសរសើរពីប្រជាជនគ្រប់ៗគ្នា។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជនបានកោតសរសើរដល់ពួកអ្នកជឿជាខ្លាំង» ។
Acts 5:14
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើមនុស្សដែលរស់នៅក្នុងក្រុងយេរូសាឡិម។
មានអ្នកជឿជាច្រើនបានបូកបន្ថែមមកក្នុងព្រះអម្ចាស់
ឃ្លានេះស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «មានមនុស្សជាច្រើនថែមទៀតបានជឿដល់ព្រះអម្ចាស់»។ សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២:៤០ «បានបន្ថែម»។
ស្រមោលរបស់លោកបាំងលើអ្នកណាម្នាក់
មានន័យថា ព្រះជាម្ចាស់បានប្រោសពួកគេ ដោយសារស្រមោលរបស់លោកពេត្រុសប៉ះពួកគេ។
អ្នកដែលមានវិញ្ញាណអាក្រក់ចូល
«អស់អ្នកដែលមានវិញ្ញាណអាក្រក់ចូល»
ពួកគេបានជាគ្រប់ៗគ្នា
ឃ្លានេះ ស្ថិតក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកសាវកបានប្រោសពួកគឲ្យបានជាគ្រប់គ្នា» ។
Acts 5:17
ប្រយោគភ្ជាប់
ពួកអ្នកដឹកនាំសាសនាបានចាប់ផ្តើមបៀតបៀនដល់ពួកអ្នកជឿ។
ប៉ុន្តែ
នៅទីចាប់ផ្តើមដោយសាច់រឿងផ្ទុយគ្នា។ អ្នកអាចបកប្រែឃ្លានេះនៅក្នុងភាសារបស់អ្នកណែនាំក្នុងន័យផ្ទុយគ្នា។
លោកមហាបូជាចារ្យបានក្រោកឡើង
ឃ្លា «ក្រោកឡើង» នៅទីនេះ មានន័យថា មហាបូជាចារ្យសម្រេចក្នុងការចាត់វិធានការ មិនមែនក្រោកពីកន្លែងអង្គុយរបស់លោកទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកមហាបូជាចារ្យបានចាត់វិធានការ»
ពួកគេមានចិត្តច្រណែនជាខ្លាំង
នេះអាចស្ថិតក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេមានចិត្តច្រណែនជាខ្លាំង»
បានមកចាប់ពួកសាវក
នេះមានន័យថា ពួកគេបានចាប់ពួកសាវកដោយប្រើកម្លាំង។
ពួកគអាចអាចបញ្ជាឲ្យអ្នកយាមធ្វើការនេះ។ របៀបផ្សេងទៀតនៃការបកប្រែ: «បានឲ្យអ្នកយាមចាប់ខ្លួនពួកសាវក»
Acts 5:19
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ និង «ពួកគេ» សំដៅលើពួកសាវក។
ក្នុងព្រះវិហារ...ចូលទៅក្នុងព្រះវិហារ
ពួកគេមិនបានចូលទៅក្នុងអគារព្រះវិហារ ជាកន្លែងដែលអនុញ្ញាតឲ្យតែបូជាចារ្យទេចូលបាន។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងទីលានព្រះវិហារ... ចូលទៅក្នុងទីលានរបស់ព្រះវិហារ» ។
ព្រះបន្ទូលនៃជីវិត
ឃ្លានេះសំដៅលើដំណឹងល្អដែលពួកសាវកបានប្រកាសរួចហើយ។ ន័យទី ១) អាចមានន័យថា «គ្រប់ទាំងព្រះបន្ទូលនៃជីវិត» ឬ ទី២) ព្រះបន្ទូលនៃការរស់នៅបែបថ្មីទាំងមូល»។
តាំងពីមុនថ្ងៃរះ
«មុនពេលថ្ងៃចាប់ផ្តើមរះ» ទោះបីជាទេវតាបាននាំពួកគេចញពីគុកនៅពេលយប់ថ្ងៃមិនទាន់រះក្តី ពួកសាវកបានចូលទៅដល់ទីលានព្រះវិហារបាត់ទៅហើយ។
ចាត់គេឲ្យទៅនាំពួកសាវកពីគុកមក
នេះមានន័យថាចាប់នរណាម្នាក់ដាក់គុក។ របៀបផ្សេងទៀតនៃការបកប្រែ: «ចាត់នរណាម្នាក់ទៅគុក ដើម្បីនាំពួកសាវកចេញពីគុក» ។
Acts 5:22
យើងខ្ញុំពុំឃើញមាននរណាម្នាក់នៅក្នុងទីនោះទេ
ពាក្យ «នរណាម្នាក់» សំដៅលើពួកសាវក។ នេះមានន័យថា គ្មានអ្នកផ្សេងណាទៀតនៅក្នុងគុកក្រៅពីពួកសាវកឡើយ»។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងមិនបានឃើញពួកគេនៅខាងក្នុងឡើយ»
Acts 5:24
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ ជាពហុវចន: ហើយសំដៅលើមេឆ្មាំព្រះវិហារ និងនាយកបូជាចារ្យ។
ពួកគេងឿងឆ្ងល់ជាខ្លាំង
«ពួកគេងឿងឆ្ងល់ជាខ្លាំង» ឬ «ពួកគេភណ្ឌភាំងជាខ្លាំង»
ទាក់ទងនឹងពួកគេ
«ទាក់ទងនឹងពាក្យ ដែលពួកគេបានឮ» ឬ «ទាក់ទងនឹងការទាំងនេះ»។
អំពីអ្វីៗដែលបានកើតឡើងនោះ
«ហើយអ្វីដែលនឹងកើតឡើង ចេញជាលទ្ធផល»។
ឈរនៅក្នុងព្រះវិហារ
ពួកគេមិនបានចូលទៅក្នុងអគារព្រះវិហារ ជាកន្លែងដែលអនុញ្ញាតឲ្យតែបូជាចារ្យទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «ឈរនៅក្នុងទៅលានព្រះវិហារ» ។
Acts 5:26
ប្រយោគភ្ជាប់
មេឆ្មាំ
និងពួកអជ្ញាធរបាននាំពួកសាវកមកចំណោះក្រុមព្រឹក្សាជាន់ខ្ពស់របស់ជនជាតិយូដា។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅក្នុងវគ្គនេះ សំដៅលើមេឆ្មាំ និងពួកអជ្ញាធ។ នៅក្នុងឃ្លាថា «ពួកគេខ្លាចបណ្តាជនចោលពួកគេនឹងដុំថ្ម» ពាក្យ «ពួកគេ» សំដៅលើមេឆ្មាំ និងពួកអជ្ញាធ។ គ្រប់យ៉ាងដែលបានកើតឡើងដោយសារ «ពួកគេ» នៅក្នុងកំណាត់នេះ សំដៅលើ ពួកសាវក។
ពួកគេខ្លាច
«ពួកគេភ័យខ្លាច»
ក្នុងនាមនេះ
ពាក្យ «ឈ្មោះ» សំដៅលើ ព្រះយេស៊ូ។ របៀបផ្សេងទៀតនៃការបកប្រែ: «កុំនិយាយពីឈ្មោះបុរសឈ្មោះថាយេស៊ូនេះទៀត»។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១៥
អ្នករាល់គ្នាបែរជាបង្រៀនគេពាសពេញក្រុងយេរូសាឡិមទៅវិញ
ឃ្លាប្រៀបធៀបនេះមានន័យថា ពួកគេបានបង្រៀនដល់មនុស្សគ្រប់គ្នានៅក្នុងក្រុងយេរូសាឡិម។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកបានបង្រៀនដល់មនុស្សគ្រប់គ្នានៅក្នុងក្រុងយេរូសាឡិមពីព្រះអង្គ»។
ចង់នាំឈាមរបស់បុរសនេះមកលើយើង
ពាក្យ «ឈាម» នៅទីនេះ សំដៅលើការស្លាប់របស់ព្រះយេស៊ូ។ នេះគឺជាពាក្យប្រៀបធៀបនៃការនិយាយថា ពួកគេនឹងទទួលខុសត្រូវសម្រាប់ការធ្វើគត់ព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ: «មានបំណងចង់ឲ្យយើងទទួលខុសត្រូវលើការស្លាប់របស់បុរសម្នាក់នេះ» ។
Acts 5:29
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើពួកសាវក មិនមែនសំដៅលើអ្នកស្តាប់ទេ។
លោកពេត្រុស និងពួកសាវកបានឆ្លើយឡើងថា
លោកពេត្រុសមានប្រសាសន៍នៅក្នុងនាមពួកសាវក នៅពេលគាត់មានប្រសាសន៍សេចក្តីដូចខាងក្រោមនេះ។
ដោយព្យួរនៅលើឈើ
ពាក្យ «ឈើ» នៅទីនេះ លោកពេត្រុសចង់សំដៅទៅលើឈើឆ្កាងដែលធ្វើពីឈើ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដោយព្យួរព្រះអង្គលើឈើឆ្កាង»
ដើម្បីឲ្យប្រជារាស្ត្រអ៊ីស្រាអែលបានប្រែចិត្ត ហើយអស់ទោសឲ្យរួចពីបាប
ពាក្យ «ប្រែចិត្ត» និង «ការអត់ទោស» អាចប្រែជាកិរិយាសព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីប្រទានឲ្យអ៊ីស្រាអែលមានឱកាសដើម្បីប្រែចិត្ត និងបានទទួលការអត់ទោសពីព្រះជាម្ចាស់ចំពោះបាបរបស់ពួកគេ» ។
អ៊ីស្រាអែល
ពាក្យ «អ៊ីស្រាអែល» សំដៅលើជនជាតិយូដា»។
អស់អ្នកស្តាប់បង្គាប់ព្រះអង្គ
«អស់អ្នកដែលចុះចូលចំពោះសិទ្ធិអំណាចរបស់ព្រះជាម្ចាស់»។

generated on Wed Sep 10 16:16:32 2025

Acts 5:33
ប្រយោគភ្ជាប់
លោកកាម៉ាលាលបានឆ្លើយទៅសមាជិកក្រុមព្រឹក្សាជាន់ខ្ពស់។
លោកកាម៉ាលាល ជាគ្រូបង្រៀនខាងវិន័យ ជាម្នាក់ដែលប្រជាជនគោរពគ្រប់ៗគ្នា
លោកលូកាបានណែនាំលោកកាម៉ាលាល និងប្រាប់ពីជីវប្រវត្តិរបស់លោក។
ជាម្នាក់ដែលប្រជាជនគោរពគ្រប់ៗគ្នា
នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបបកប្រែផ្សេងទៀត:
«ជាម្នាក់ដែលមនុស្សទាំងអស់គោរព»
បានបង្គាប់ឲ្យគេយកពួកសាវកចេញពីទីនោះ
នេះស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បង្គាប់ឲ្យអ្នកយាមនាំពួកសាវកចេញក្រៅ» ។
Acts 5:35
សូមប្រយ័ត្នចំពោះអ្វី
«សូមរិះគិតដោយប្រុងប្រយ័ត្ន» (UDB) ឬ «ចូរប្រយ័ត្នអំពី»។
លោកកាម៉ាលាលបានដាស់តឿនពួកគេមិនឲ្យធ្វើអ្វីដែលពួកគេអាចនឹងសោកស្តាយនៅពេលក្រោយ
លោកថីដាសបានក្រោកឡើង
អាចមានន័យពីរ ១) «លោកថីដាស់ប្រឆាំង» (UDB) ឬ ២)
«លោកថីដាសបានបង្ហាញខ្លួន»។
ប្រកាសថាខ្លួនជាអ្នកក្លាហាន
«ប្រកាសថាខ្លួនជាមនុស្សសំខាន់»
លោកត្រូវគេប្រហារជីវិត
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គេបានសម្លាប់គាត់»
ពួកអ្នកដែលបានចូលរួមជាមួយគាត់ក៏ត្រូវបែកខ្ញែកគ្នាអស់
នេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលបានស្តាប់តាមគាត់ បានបានបែកខ្ញែកគ្នា
ហើយទៅតាមកន្លែងផ្សេងៗគ្នា»
លែងធ្វើអ្វីទៀតបាន
នេះមានន័យថា ពួកគេធ្វើអ្វីដែលពួកគេគ្រោងនឹងធ្វើមិនកើត។
បន្ទាប់ពីបុរសម្នាក់នោះ
«បន្ទាប់ពីលោកថីដាស»
នៅថ្ងៃដែលគេជំរឿនប្រជាជន
«អំឡុងពេលនៃការជំរឿន»
នាំមនុស្សជាច្រើនឲ្យទៅតាមគាត់
នេះមានន័យថា
គាត់បានបញ្ចុះបញ្ចូលអ្នកខ្លះឲ្យបះបោរជាមួយគាត់ទាស់នឹងអាណាចក្ររ៉ូម។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើឲ្យមានមនុស្សជាច្រើនដើរតាមគាត់» ឬ
«ធ្វើឲ្យមានមនុស្សជាច្រើនចូលរួមប៉ះបោរជាមួយគាត់» ។
Acts 5:38
ប្រយោគភ្ជាប់
លោកកាម៉ាលាលបានឆ្លើយទៅកាន់ពួកសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់។
ទោះបីជាពួកគេវាយពួកសាវក
ហើយបង្គាប់ពួកគេមិនឲ្យបង្រៀនអំពីព្រះយេស៊ូទៀត ហើយឲ្យពួកគេចេញទៅ
តែពួកសិស្សនៅតែបន្តបង្រៀន និងប្រកាសព្រះបន្ទូលទៀត។
សូមដកខ្លួនពីអ្នកទាំងនេះ ហើយដោះលែងគេទៅ
លោកកាម៉ាលាលប្រាប់ដល់អ្នកដឹកនាំជនជាតិយូដាមិនឲ្យដាក់ទោសពួកសាវក
ឬចាប់ពួកគេដាក់គុកឡើយ។
ប្រសិនបើគម្រោង ឬកិច្ចការនេះមកពីមនុស្ស
«ប្រសិនបើមនុស្សបង្កើតគម្រោងនេះ ឬធ្វើការនេះ»។
វានឹងត្រូវវិនាសមិនខាន
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងមាននរណាម្នាក់បំផ្លាញវាមិនខាន» ។
ប៉ុន្តែប្រសិនបើ មកពីព្រះជាម្ចាស់វិញ
ពាក្យ «វា» សំដៅលើ «គម្រោង ឬកិច្ចការនេះ» របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រសិនបើ ព្រះជាម្ចាស់បង្កើតគម្រោងនេះ ឬបង្គាប់អ្នកទាំងអស់នេះឲ្យធ្វើការនេះ»
។
ដូច្នេះ ពួកគេយល់ស្របតាម
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកកាម៉ាលាលបានបញ្ចុះបញ្ចូលពួកគេយ៉ាងដូច្នេះ» ។
Acts 5:40
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើកសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់។ ពាក្យ
«ពួកគេ» ទាំងអស់ សំដៅលើពួកសាវក។
ពួកគេក៏ហៅពួកសាវកមកក្នុងវិញ ហើយវាយពួកគេ
សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់បានបញ្ជាឲ្យអ្នកយាមព្រះវិហារធ្វើការទាំងនេះ។
ប្រកាសអំពីព្រះនាមព្រះយេស៊ូ
ពាក្យ «ឈ្មោះ» នៅទីនេះ សំដៅលើសិទ្ធិអំណាចរបស់ព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនឲ្យនិយាយអំពីសិទ្ធិអំណាចរបស់ព្រះយេស៊ូទៀត» សូមមើល
ពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ៤:១៥
ពួកគេបានរាប់ថាមានកិត្តិយស ដោយសារគេមើលងាយព្រោះតែព្រះនាម
ពួកសាវកមានអំណរ ដោយសារព្រះជាម្ចាស់បានលើកតម្កើងពួកគេ
ដោយអនុញ្ញាតឲ្យអ្នកដឹកនាំរបស់ជនជាតិយូដាកោតសរសើរពួកគេ។
ឃ្លានេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានរបស់ពួកគេថាសមនឹងទទួលការមើលងាយដោយព្រោះព្រះនាមរបស់ព្រះអង្គ»។
ព្រោះតែព្រះនាម
ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើព្រះយេស៊ូ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រោះតែព្រះយេស៊ូ»
បន្ទាប់ពីនោះមក
«បន្ទាប់ពីនោះមក ជារៀងរាល់ថ្ងៃ» ឃ្លានេះសំដៅលើ
អ្វីដែលពួកសាវកបានធ្វើជារៀងរាល់ថ្ងៃ។
នៅក្នុងព្រះវិហារ និងពីផ្ទះមួយទៅផ្ទះមួយ
ពួកគេមិនបានចូលទៅក្នុងអគារព្រះវិហារជាកន្លែងដែលពួកបូជាចារ្យទៅទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងទីលានព្រះវិហារ
និងនៅតាមផ្ទះរបស់មនុស្សផ្សេងៗ» ។

---

6 [1]រហូតមកដល់ពេលនោះ ចំនួនសិស្សចេះតែកើនឡើងជាលំដាប់។ ជនជាតិយូដាដែលនិយាយភាសាក្រិកនាំគ្នារអ៊ូរទាំទាស់នឹងជនជាតិយូដាដែលនិយាយភាសាហេប្រឺ
ថា នៅពេលចែកម្ហូបអាហារប្រចាំថ្ងៃ ពួកហេប្រឺបានមើលរំលងស្ត្រីមេម៉ាយ។
[2]សាវកទាំងដប់ពីររូបក៏កោះហៅពួកសិស្សទាំងអស់មក ហើយមានប្រសាសន៍ថា៖ «មិនគួរឲ្យយើងខ្ញុំបោះបង់ចោលការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីទៅ
បម្រើនៅតុអាហារឡើយ។[3]ហេតុនេះ បងប្អូនអើយ សូមជ្រើសរើសយកបុរសប្រាំពីររូបក្នុងចំណោមបងប្អូន ដែលមានកេរ្តិ៍ឈ្មោះល្អ ហើយពោរពេញដោយព្រះវិញ្ញាណ និង
ប្រាជ្ញាឈ្លាសវៃ យើងខ្ញុំនឹងតែងតាំងគេឲ្យបំពេញមុខងារនេះ។[4]រីឯយើងខ្ញុំវិញ យើងខ្ញុំនឹងគិតតែពីអធិស្ឋាន និងបម្រើព័ន្ធកិច្ចនៃព្រះបន្ទូលប៉ុណ្ណោះ»។
[5]ពួកសិស្សទាំងប៉ុន្មានពេញចិត្តនឹងសេចក្តីស្នើនេះណាស់ ដូច្នេះគេក៏ជ្រើសយកលោកស្តេផានដែលពោរពេញដោយជំនឿ និងព្រះវិញ្ញាណដ៏វិសុទ្ធ លោកភីលីព លោក
ប្រូខូរ៉ុស លោកនីកាន័រ លោកទីម៉ូន លោកប៉ាមេណា និងលោកនីកូឡាសជាអ្នកស្រុកអន់ទីយ៉ូកដែលចូលសាសនាយូដា។[6]ពួកអ្នកជឿនាំអ្នកទាំងនោះមកជួបក្រុមសាវក
ក្រុមសាវកក៏នាំគ្នាអធិស្ឋាន ហើយដាក់ដៃពីលើអ្នកទាំងនោះ។
[7]ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏ឮសុសសាយកាន់តែខ្លាំងឡើងៗ ចំនួនសិស្សនៅក្រុងយេរូសាឡឹមបានកើនឡើងយ៉ាងច្រើនឥតគណនា ហើយមានពួកបូជាចារ្យដ៏ច្រើន
លើសលប់ សុខចិត្តប្រតិបត្តិតាមជំនឿដែរ។
[8]ឥឡូវលោកស្តេផានបានពោរពេញដោយព្រះគុណ និងឫទ្ធានុភាពហើយសម្តែងឫទ្ធិបាដិហារិយ៍ និងទីសម្គាល់ធំៗក្នុងចំណោមប្រជាជន។[9]តែមានអ្នកខ្លះជាសមាជិក
សាលាប្រជុំដែលគេហៅថា «សាលាប្រជុំពួកអ្នកងារពីដើម» និងអ្នកខ្លះពីចំណោមអ្នកស្រុកគីរេន អ្នកស្រុកអលេក្សានទ្រា និងអ្នកខ្លះទៀតពីចំណោមអ្នកស្រុកគីលីគា និង
អ្នកស្រុកអាស៊ី នាំគ្នាជជែកតវ៉ាជាមួយលោកស្តេផាន។
[10]ប៉ុន្តែ ពួកគេពុំអាចជជែកឈ្នះលោកស្តេផានឡើយ ព្រោះលោកមានប្រសាសន៍ប្រកបដោយប្រាជ្ញាមកពីព្រះវិញ្ញាណ។[11]ដូច្នេះ អ្នកទាំងនេះនាំគ្នាសូកមនុស្សខ្លះឲ្យនិយាយ
ថា៖ «យើងខ្ញុំបានឮអ្នកនេះ ពោលពាក្យប្រមាថលោកម៉ូសេ និងប្រមាថព្រះជាម្ចាស់»។

generated on Wed Sep 10 16:16:32 2025

[12]ពួកគេបានធ្វើឲ្យមានការបះបោរក្នុងប្រជាជន និងពួកព្រឹទ្ធាចារ្យ ហើយពួកអាចារ្យ រួចមកចាប់លោកស្ទេផានបញ្ជូនទៅក្រុមប្រឹក្សាជាន់ខ្ពស់។[13]ពួកគេនាំសាក្សីក្លែងក្លាយ
មកចោទប្រកាន់លោកថា៖ «ជននេះចេះតែនិយាយប្រឆាំងនឹងព្រះវិហារ ប្រឆាំងនឹងក្រឹត្យវិន័យឥតឈប់ឈរ។[14]ដ្បិតយើងខ្ញុំបានឮគាត់និយាយថា ឈ្មោះយេស៊ូជាអ្នកភូមិ
ណាសារ៉ែត នោះនឹងរុះព្រះវិហារចោល ព្រមទាំងប្តូរប្រពៃណីដែលលោកម៉ូសេបានទុកឲ្យយើងខ្ញុំថែមទៀតផង»។[15]អស់អ្នកដែលអង្គុយនៅក្នុងក្រុមប្រឹក្សាជាន់ខ្ពស់ទាំង
ប៉ុន្មាន សម្លឹងមើលមកលោកស្ទេផានគ្រប់ៗគ្នា ហើយឃើញមុខរបស់លោកមានទ្រង់ទ្រាយដូចមុខរបស់ទេវតា។

Acts 6:1
ព័ត៌មានទូទៅ
នេះគឺជាការចាប់ផ្តើមសាច់រឿងថ្មី។
លោកលូកាបានផ្តល់ប្រវត្តិសំខាន់ដើម្បីយល់ពីសាច់រឿង។
នៅគ្រានោះ
ចូរពិចារណាពីសាច់រឿងថ្មី ដែលណែនាំនៅក្នុងភាសារបស់អ្នក។
ចេះតែកើនចម្រើនឡើង
«រីកចម្រើនជាខ្លាំង»
ជនជាតិយូដាដែលនិយាយភាសាក្រិក
អ្នកទាំងនេះគឺជាជនជាតិយូដាដែលរស់នៅក្នុងអាណាចក្ររ៉ូមស្ទើរតែមួយជីវិតរបស់ពួកគេ
ហើយបានលូតលាស់ឡើងដោយនិយាយជាភាសាក្រិក។ ភាសា
និងវប្បធម៌របស់ពួកគេគឺខុសពីអស់អ្នកដែលលូតលាស់នៅអ៊ីស្រាអែល។
ជនជាតិយូដាដែលនិយាយភាសាហេព្រើរ
ជនជាតិយូដាទាំងនេះគឺជាអ្នកដែលរស់នៅក្នុងអ៊ីស្រាអែល និយាយភាសាហេព្រើរ
ឬអារ៉ាម។ ក្រុមជំនុំដែលមានតែជនជាតិយូដា
និងអ្នកដែលប្តូរទៅកាន់សាសនាយូដាកន្លងមក។
ស្រីមេម៉ាយ
ស្ត្រីដែលមានប្តីស្លាប់
ពួកគេបានមើលរំលងស្រីមេម៉ាយរបស់ពួកគេ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអ្នកជឿជនជាតិហេព្រើរបានមើលរំលងស្ត្រីមេម៉ាយជាជនជាតិក្រិក» ។
មើលរំលង
«ត្រូវបានគេមើលរំលង» ឬ «ត្រូវបានគេបំភ្លេចចោល»។
មានសេចក្តីត្រូវការជាច្រើនដែលពួកគេមិនបានបំពេញ។
នៅពេលចែកម្ហូបអាហារប្រចាំថ្ងៃ
ប្រាក់ដែលបានប្រគល់ឲ្យពួកសាវកប្រើដើម្បីទិញអាហារសម្រាប់ស្ត្រីមេម៉ាយនៅក្នុងក្រុម
Acts 6:2
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ សំដៅលើពួកអ្នកជឿ។
ព័ត៌មានទូទៅ
ពាក្យ «យើង» និង «ពួកយើង» នៅទីនេះ សំដៅលើពួកសាវកទាំងដប់ពីរ។
ដែលអាចប្រើបាន ជាពិសេសនៅក្នុងភាសារបស់អ្នក។
សិស្សទាំងដប់ពីររូប
សំដៅលើពួកសាវកដប់មួយនាក់ បូករួមទាំងម៉ាធាស
ដែលបានជ្រើសរើសនៅក្នុងជំពូក ១:២៤
ពួកសិស្សទាំងអស់
«ពួកសិស្សទាំងអស់» ឬ «ពួកអ្នកជឿទាំងអស់»។
មិនគួរឲ្យយើងខ្ញុំបោះបង់ព្រះបន្ទូលរបស់ព្រះជាម្ចាស់
និយាយបំផ្លើសដើម្បីបញ្ជាក់ពីភាពសំខាន់នៃភារកិច្ចបង្រៀនព្រះបន្ទូលព្រះជាម្ចាស់របស់ពួកគេ
របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់ប្រកាស
និងឈប់បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់» ។
បម្រើនៅតុ
ឃ្លានេះមានន័យថា បម្រើអាហារដល់បណ្តាជន។
ជាអ្នកដែលមានកេរ្តិ៍ឈ្មោះល្អ ពេញដោយព្រះវិញ្ញាណ និងមានប្រាជ្ញា
អាចមានន័យពីរយ៉ាង ទី១) មនុស្សដែលមានគុណសម្បត្តិបី កេរ្តិ៍ឈ្មោះល្អ
ពេញដោយព្រះវិញ្ញាណ និងមានប្រាជ្ញា។ ឬ ទី២) មនុស្សដេលមានកេរ្តិ៍ឈ្មោះល្អ
ដោយសារមានគុណសម្បត្តិពីរ គឺពេញដោយព្រះវិញ្ញាណ
និងប្រកបដោយប្រាជ្ញា(UDB)។
អ្នកដែលមានកេរ្តិ៍ឈ្មោះល្អ
«អ្នកដែលមនុស្សស្គាល់ថាជាមនុស្សល្អ» ឬ «ជាមនុស្សដែលគេទុកចិត្ត»
តែងតាំងពួកគេឲ្យធ្វើការងារនេះ
«ឲ្យទទួលខុសត្រូវក្នុងការបំពេញភារកិច្ចនេះ»។
ក្នុងព័ន្ធកិច្ចបម្រើព្រះបន្ទូល
អាចជាប្រយោជន៍ជាច្រើនក្នុងការបន្ថែមពណ៌មានថែមទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ព័ន្ធកិច្ចនៃការបង្រៀន
និងប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់»។
Acts 6:5
សំដីរបស់ពួកគេបានពេញចិត្តនឹងអ្នកទាំងអស់នោះណាស់
«ពួកសិស្សទាំងអស់ពេញចិត្តនឹងសំណើរបស់ពួកគេ»។
លោកស្ទេផាន...និងលោកនីកូឡាស
ទាំងពីរនេះគឺជាឈ្មោះរបស់ក្រិក
ហើយអ្នកដែលបានជ្រើសរើសគឺមកពីពួកអ្នកជឿជនជាតិយូដានិយាយភាសាក្រិក។
[illegible]
សាសន៍ដទៃដែលបានចូលសាសនាយូដា
ដាក់ដៃពីលើបុរសទាំងនោះ
ស្តែងអំពីការឲ្យពរ និងផ្ទុកផ្តាក់ទំនួលខុសត្រូវ
ព្រមទាំងប្រគល់សិទ្ធិអំណាចដើម្បីធ្វើការដល់អ្នកទាំងប្រាំពីរនាក់នោះ។
Acts 6:7
ព័ត៌មានទូទៅ
នៅខគម្ពីរនេះ បានបង្ហាញពីព័ត៌មាននៃការរីកចម្រើនរបស់ក្រុមជំនុំ។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបន្តផ្សាយ
និយាយអំពីការរីកចម្រើននៃចំនួនមនុស្សដែលជឿលើព្រះបន្ទូល
គឺប្រៀបដូចជាព្រះបន្ទូលបានបន្តផ្សាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចំនួនមនុស្សដែលបានជឿលើព្រះបន្ទូលដែលបានផ្សាយ»។
បានស្តាប់បង្គាប់ចំពោះជំនឿនេះ
«ដើរតាមសេចក្តីបង្រៀននៃជំនឿថ្មីនេះ»
ជំនឿ
អាចមានន័យបី ទី១) សាររបស់ដំណឹងល្អនៃសេចក្តីពិតនៅក្នុងព្រះយេស៊ូ ឬទី២)
[illegible]
Acts 6:8
ប្រយោគភ្ជាប់
នេះគឺជាការចាប់ផ្តើមនៃសាច់រឿងមួយថ្មី
ព័ត៌មានទូទៅ
ខនេះបានផ្តល់ពីជីវប្រវត្តិរបស់លោកស្ទេផាន
និងអ្នកផ្សេងទៀតដើម្បីងាយយល់នៅក្នុងសាច់រឿងនេះ។
ពេលនោះ លោកស្ទេផាន
នេះគឺជាការណែនាំអំពីតួអង្គរបស់លោកស្ទេផាននៅក្នុងសាច់រឿងត្រង់នេះ។
លោកស្ទេផានបានពេញព្រះគុណ និងអំណាច បានធ្វើការការអស្ចារ្យ និងទីសម្គាល់ធំៗជាច្រើន
ពាក្យ «ព្រះគុណ» និង «អំណាច» នៅទីនេះ
សំដៅលើការទទួលអំណាចពីព្រះជាម្ចាស់។
ពាក្យនេះបកប្រែនៅក្នុងទម្រង់ជាក់លាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
[illegible]
សាលាប្រជុំរបស់អ្នកដែលមានសេរីភាព
«សេរីភាព» ប្រហែលជា អតីតជាបាវបម្រើដែលមកពីតំបន់ផ្សេងៗ។ មិនប្រាកដថា
អ្នកទាំងនេះមានឈ្មោះក្នុងបញ្ជីនៅក្នុងសាលាប្រជុំ
ឬគ្រាន់តែចូលរួមតវ៉ាជាមួយលោកស្ទេផានតែប៉ុណ្ណឹង។
ជជែកតវ៉ាជាមួយលោកស្ទេផាន
«ជជែកវែកញែកជាមួយលោកស្ទេផាន» (UDB)
Acts 6:10
ប្រយោគភ្ជាប់
ព័ត៌មានពីសាវតាដែលបានចាប់ផ្តើមនៅក្នុងជំពូក ៦:៨ បន្តរហូតដល់ ខ១០។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅតែបុរសៗដែលពួកគេបញ្ចុះបញ្ចូលឲ្យកុហកទេ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ»
សំដៅលើមនុស្សដែលមកពីសាលាប្រជុំនៃពួកអ្នកដែលមានសេរីភាពក្នុងជំពូក

generated on Wed Sep 10 16:16:32 2025

៦:៨។
ពុំអាចឈរទាស់នឹង
ឃ្លានេះមានន័យថា
ពួកគេមិនអាចបង្ហាញពីអ្វីដែលគាត់មានប្រសាសន៍ថាមិនត្រឹមត្រូវឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនអាចប្រឆាំងទាស់»។
ព្រះវិញ្ញាណ
«ព្រះវិញ្ញាណដ៏វិសុទ្ធ»
មនុស្សខ្លះឲ្យនិយាយ
ដោយសារការនេះបានធ្វើដោយអាថ៌កំបាំង មានន័យថា
ទីបន្ទាល់របស់ពួកគេគឺកុហក។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកខ្លះដើម្បីកុហក ដោយនិយាយថា»
និយាយពាក្យប្រមាថ
«និយាយការអាក្រក់អំពី» (UDB)
Acts 6:12
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ដែលប្រើ
ភាគច្រើនសំដៅលើមនុស្សដែលមកពីសាលាប្រជុំសេរីភាព នៅក្នុងជំពូក ៦:៨។
ពួកគេទទួលខុសត្រូវលើទីបន្ទាល់ក្លែងក្លាយ
និងការចាក់រុកដល់ក្រុមទីប្រឹក្សាជាន់ខ្ពស់ ពួកចាស់ទុំ និងពួកអាចារ្យ
ព្រមទាំងមនុស្សផ្សេងៗទៀតផង។
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើទីបន្ទាប់ក្លែងក្លាយដែលពួកគេបាននាំមកធ្វើជាសាក្សី។
ចាក់រុកប្រជាជន
«ញុះញង់ប្រជាជនឲ្យខឹង»
ពួកគេបានមកឯ
នេះអាចជាប្រយោគថ្មី។ របៀបផ្សេងទៀតនៃការបកប្រែ: «នោះ
ពួកគេទាំងគ្នាបានតទល់នឹង»
បានចាប់
«បានចាប់ទាញ»
មិនព្រមឈប់និយាយ
«បន្តនិយាយ»
បានប្រគល់មកឲ្យយើង
ឃ្លា «បានប្រគល់» មានន័យថា «ហុចបន្ត»។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបង្រៀនដល់បុព្វបុរសរបស់យើង»
បានសម្លឹងមើលមុខលោកគ្រប់ៗគ្នា
«បានសម្លឹងមើលទៅគាត់» ឬ «បានសម្លក់គាត់»
មុខរបស់លោកមានលក្ខណដូចមុខរបស់ទេវតា
ឃ្លានេះ ប្រៀបធបៀបមុខរបស់គាត់ថា ដូចជាទេវតា ប៉ុន្តែ
មិនបាននិយាយជាក់លាក់នូវអ្វីដែលជារួមទេ។

---

7 [1]លោកមហាបូជាចារ្យមានប្រសាសន៍សួរថា៖ «តើពិតជាដូច្នេះមែនឬ?»[2]លោកស្តេផានឆ្លើយឡើងថា៖ «សូមជម្រាបអស់លោកជាបងប្អូន និងជាឪពុក សូមជ្រាប!
កាលព្រះជាម្ចាស់ប្រកបដោយសិរីរុងរឿង បានបង្ហាញលោកអប្រាហាំជាបុព្វបុរសរបស់យើង ពេលលោករស់នៅឯស្រុកមេសូប៉ូតាមា គឺមុនពេលលោកទៅនៅស្រុក
ខារ៉ាន[3]ព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកថា៖ «ចូរចាកចេញពីស្រុកកំណើតរបស់អ្នក និងញាតិសន្តានរបស់អ្នក រួចធ្វើដំណើរទៅកាន់ស្រុកមួយដែលយើងនឹងបង្ហាញ
អ្នក»។
[4]បន្ទាប់មក លោកអប្រាហាំក៏ចាកចេញពីស្រុកខាល់ដេ ទៅរស់នៅក្នុងស្រុកខារ៉ាន។ ក្រោយពេលឪពុករបស់លោកទទួលមរណភាពផុតទៅ ព្រះជាម្ចាស់បាននាំលោកចេញ
ពីស្រុកនោះ មកនៅស្រុកដែលអស់លោករស់នៅសព្វថ្ងៃ។[5]ព្រះជាម្ចាស់ពុំបានប្រទានដីធ្លីឲ្យលោកឡើយ គឺសូម្បីតែដីល្មមនឹងដាក់បាតជើង ក៏ព្រះអង្គមិនប្រទានឲ្យដែរ។
ប៉ុន្តែ ព្រះអង្គបានសន្យាថា នឹងប្រគល់ស្រុកនេះទាំងមូលមកឲ្យលោក និងឲ្យពូជពង្សរបស់លោកដល់ជំនាន់ក្រោយៗផង ទោះបីពេលនោះ លោកអប្រាហាំពុំទាន់មាន
កូននៅឡើយក្តី។
[6]ព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកថា ពូជពង្សរបស់លោកនឹងអាស្រ័យនៅលើទឹកដីបរទេសមួយរយៈ ហើយអ្នកស្រុកនោះនឹងយកពូជពង្សរបស់លោក ធ្វើជាខ្ញុំបម្រើ
ព្រមទាំងធ្វើទុក្ខទោសគេអស់រយៈពេលបួនរយឆ្នាំ។[7]ព្រះជាម្ចាស់មានព្រះបន្ទូលទៀតថា៖ «ប៉ុន្តែ យើងនឹងដាក់ទោសជាតិសាសន៍ណា ដែលយកពូជពង្សរបស់អ្នកធ្វើជាខ្ញុំ
បម្រើ។ ក្រោយមក ពូជពង្សរបស់អ្នកនឹងចាកចេញពីស្រុកនោះ មកគោរពថ្វាយបង្គំយើងនៅទីកន្លែងនេះ»។[8]បន្ទាប់មក ព្រះជាម្ចាស់បានប្រោសប្រទានសម្ពន្ធមេត្រីឲ្យ
លោកអប្រាហាំ ដោយយកពិធីកាត់ស្បែកធ្វើជាសញ្ញា។ ហេតុនេះហើយបានជាលោកអ៊ីសាកកើតបានប្រាំបីថ្ងៃ លោកអប្រាហាំជាឪពុក បានធ្វើពិធីកាត់ស្បែកឲ្យ។ លោក
អ៊ីសាកក៏បានធ្វើពិធីកាត់ស្បែកឲ្យលោកយ៉ាកុប ហើយលោកយ៉ាកុបក៏បានធ្វើពិធីកាត់ស្បែកឲ្យបុព្វបុរសទាំងដប់ពីររូប។
[9]ពួកបុព្វបុរសមានចិត្តច្រណែនឈ្នានីសនឹងលោកយ៉ូសែប ក៏លក់លោកឲ្យគេនាំយកទៅធ្វើជាខ្ញុំបម្រើនៅស្រុកអេស៊ីប។ ប៉ុន្តែ ព្រះជាម្ចាស់គង់ជាមួយនិងលោក[10]ហើយ
រំដោះលោកឲ្យរួចផុតពីទុក្ខវេទនាទាំងប៉ុន្មាន។ ព្រះអង្គប្រទានឲ្យលោកមានប្រាជ្ញាវាងវៃ និងគាប់ព្រះហឫទ័យព្រះចៅផារ៉ោនជាស្តេចនៃស្រុកអេស៊ីប។ ព្រះចៅផារ៉ោនបាន
តែងតាំងលោក ឲ្យគ្រប់គ្រងលើស្រុកអេស៊ីប និងត្រួតត្រាព្រះរាជវាំងទាំងមូលផង។
[11]ពេលនោះ មានកើតទុរ្ភិក្សពេញទាំងស្រុកអេស៊ីប និងស្រុកកាណាន បណ្តាលឲ្យមានទុក្ខវេទនាជាខ្លាំង បុព្វបុរសរបស់យើងរកអ្វីបរិភោគពុំបានឡើយ។[12]ពេលលោក
យ៉ាកុបឮដំណឹងថា នៅស្រុកអេស៊ីបមានស្រូវ លោកក៏ចាត់ពួកបុព្វបុរសរបស់យើងឲ្យទៅស្រុកនោះជាលើកទីមួយ។[13]នៅលើកទីពីរ លោកយ៉ូសែបបានប្រាប់ឲ្យបងប្អូន
របស់លោក ឲ្យបានស្គាល់លោក ហើយព្រះចៅផារ៉ោនក៏បានជ្រាបអំពីដើមកំណើតរបស់លោកយ៉ូសែបដែរ។
[14]បន្ទាប់មក លោកយ៉ូសែបបានចាត់គេឲ្យទៅអញ្ជើញលោកយ៉ាកុបជាឪពុក និងញាតិសន្តានទាំងអស់ ដែលមានគ្នាចិតសិបប្រាំនាក់នោះមកស្រុកអេស៊ីប។[15]លោកយ៉ាកុប
ក៏ចុះទៅស្រុកអេស៊ីប ហើយលោកទទួលមរណភាពនៅទីនោះ ព្រមទាំងពួកបុព្វបុរសយើងក៏ទទួលមរណភាពនៅស្រុកនោះដែរ។[16]គេបានដឹកសពលោកយ៉ាកុប និងសព
ពួកបុព្វបុរសមកបញ្ចុះនៅភូមិស៊ីគែមក្នុងផ្នូរ ដែលលោកអប្រាហាំបានទិញពីកូនរបស់លោកហេម៉ូរនៅភូមិស៊ីគែមនោះ។
[17]លុះជិតដល់ពេលព្រះជាម្ចាស់ត្រូវបំពេញតាមព្រះបន្ទូលដែលព្រះអង្គសន្យាជាមួយលោកអប្រាហាំ នោះជនជាតិរបស់យើងបានកើនចំនួនកាន់តែច្រើនឡើងៗនៅស្រុក
អេស៊ីប។[18]រហូតដល់មានស្តេចថ្មីឡើងគ្រងរាជ្យនៅស្រុកអេស៊ីប ប៉ុន្តែស្តេចនោះមិនស្គាល់លោកយ៉ូសែបទេ។[19]ស្តេចថ្មីនោះបានប្រើល្បិចអាក្រក់បោកបញ្ឆោតបុព្វបុរសយើង
គឺបានធ្វើបាបបុព្វបុរសរបស់យើង រហូតដល់ថ្នាក់បង្ខំពួកគាត់ឲ្យយកទារកតូចៗរបស់ខ្លួនយកទៅចោល ដើម្បីកុំឲ្យមានជីវិតរស់តទៅមុខទៀត។
[20]នៅជំនាន់ លោកម៉ូសេចាប់កំណើត ហើយលោកជាទារកមួយដ៏ស្អាតជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់។ ឪពុកម្តាយបានចិញ្ចឹមលោកនៅក្នុងផ្ទះអស់រយៈពេលបីខែ។
[21]កាលគេយកលោកទៅចោល បុត្រីរបស់ស្តេចផារ៉ោនបានរើសលោកយកមកចិញ្ចឹមបីបាច់ថែរក្សា ធ្វើជាកូន។
[22]លោកម៉ូសេបានទទួលការអប់រំតាមចំណេះវិជ្ជាទាំងប៉ុន្មាន របស់ជនជាតិអេស៊ីប លោកមានសំនួនវោហារពូកែ ហើយប៊ិនប្រសប់ធ្វើកិច្ចការផ្សេងៗផង។[23]ប៉ុន្តែពេលលោក
អាយុប្រហែលសែសិបឆ្នាំ លោកក៏បានសម្រេចចិត្តទៅសួរសុខទុក្ខជនជាតិអ៊ីស្រាអែលជាបងប្អូនរួមជាតិរបស់លោក។[24]លោកបានឃើញជនរួមជាតិរបស់លោកម្នាក់ត្រូវគេ
ធ្វើបាប លោកក៏ចេញមុខការពារ ហើយសងសឹកជំនួសអ្នកដែលត្រូវគេធ្វើបាប ដោយវាយសម្លាប់ជនជាតិអេស៊ីបនោះទៅ។[25]លោកបានគិតថា បងប្អូនរួមជាតិរបស់លោក
នឹងយល់ថា ព្រះជាម្ចាស់នឹងប្រើលោកមកសង្គ្រោះពួកគេ ប៉ុន្តែពួកគេពុំបានយល់ដូច្នោះឡើយ។
[26]នៅថ្ងៃបន្ទាប់ លោកម៉ូសេបានប្រទះឃើញជនជាតិអ៊ីស្រាអែលខ្លះកំពុងវាយគ្នា លោកក៏មានប្រសាសន៍សម្រុះសម្រួលគេថា៖ «អ្នករាល់គ្នាជាបងប្អូននឹងគ្នា ហេតុដូចម្តេច
បានជាធ្វើបាបគ្នាឯងដូច្នេះ?»[27]ប៉ុន្តែម្នាក់ដែលធ្វើបាបបងប្អូនខ្លួន បានច្រានលោកម៉ូសេចេញទាំងពោលថា៖ «នរណាបានតាំងអ្នកឲ្យធ្វើជាមេដឹកនាំ និងជាចៅក្រមពីលើ
យើង?[28]តើអ្នកចង់សម្លាប់ខ្ញុំដូចអ្នកបានសម្លាប់អេស៊ីបម្នាក់ពីម្សិលមិញនោះដែរឬ?»។
[29]លោកម៉ូសេក៏ភៀសខ្លួនទៅនៅស្រុកម៉ាឌាន ក្រោយពេលបានឮដូច្នេះ ហើយនៅស្រុកនោះលោកបានកូនប្រុសពីរនាក់។[30]សែសិបឆ្នាំកន្លងមកទៀត មានទេវតាមួយរូប
បានបង្ហាញខ្លួនឲ្យលោកឃើញ នៅវាលរហោស្ថានភ្នំស៊ីណៃ ក្នុងអណ្តាតភ្លើងដែលកំពុងឆេះក្នុងគុម្ពោតមួយ។

generated on Wed Sep 10 16:16:32 2025

[31]ពេលលោកបានឃើញអណ្ដាតភ្លើងនោះ លោកងឿងឆ្ងល់ចំពោះហេតុដ៏អស្ចារ្យនោះណាស់។ ពេលលោកចូលទៅជិតវាដើម្បីពិនិត្យមើល លោកក៏បានឮព្រះសូរសៀង
របស់ព្រះអម្ចាស់មានព្រះបន្ទូលថា៖[32]«យើងជាព្រះជាម្ចាស់នៃបុព្វបុរសរបស់អ្នក គឺជាព្រះរបស់អប្រាហាំ ព្រះរបស់អ៊ីសាក និងព្រះរបស់យ៉ាកុប»។ លោកម៉ូសេភ័យញ័រជា
ខ្លាំង ពុំហ៊ានសម្លឹងមើលទេ។
[33]ព្រះអម្ចាស់មានព្រះបន្ទូលមកលោកថា៖ «ចូរដោះស្បែកជើងចេញ ដ្បិតកន្លែងដែលអ្នកឈរនេះជាកន្លែងដ៏វិសុទ្ធ។[34]យើងបានឃើញប្រជារាស្ត្ររបស់យើងរងទុក្ខលំបាក
នៅស្រុកអេស៊ីប យើងក៏បានឮសម្រែកសោកសៅរបស់គេដែរ យើងចុះមកដើម្បីរំដោះពួកគេ។ ចូរមក! យើងនឹងចាត់អ្នកឲ្យទៅស្រុកអេស៊ីបឥឡូវនេះ»។
[35]ជនជាតិអ៊ីស្រាអែល បានបដិសេធមិនទទួលស្គាល់លោកម៉ូសេនេះទេ ដោយពោលថា៖ «នរណាបានតាំងអ្នកឲ្យធ្វើជាមេដឹកនាំ និងជាចៅក្រមលើយើង?»។ ក៏ប៉ុន្តែ
ព្រះជាម្ចាស់បានចាត់លោកឲ្យទៅក្នុងឋានៈជាមេដឹកនាំ និងជាអ្នករំដោះ។ ព្រះជាម្ចាស់បានបញ្ជូនលោកដោយមានជំនួយពីទេវតា ដែលបានបង្ហាញខ្លួនឲ្យលោកឃើញក្នុង
គុម្ពោត។[36]លោកម៉ូសេនេះបានដឹកនាំជនជាតិអ៊ីស្រាអែលចេញពីអេស៊ីប បន្ទាប់ពីបានធ្វើការអស្ចារ្យ និងទីសម្គាល់ដ៏អស្ចារ្យក្នុងស្រុកអេស៊ីប នៅសមុទ្រក្រហម និងនៅវាល
រហោស្ថាន អស់រយៈពេលសែសិបឆ្នាំផង។[37]លោកម៉ូសេនេះហើយ ដែលមានប្រសាសន៍ទៅកាន់ជនជាតិអ៊ីស្រាអែលថា៖ «ព្រះជាម្ចាស់នឹងធ្វើឲ្យមានព្យាការីម្នាក់ដូចខ្ញុំ ងើប
ឡើងពីចំណោមបងប្អូនរបស់អ្នករាល់គ្នា»។
[38]លោកម៉ូសេនេះហើយ ដែលបានជួបជាមួយទេវតាក្នុងវាលរហោស្ថាន បានថ្លែងព្រះបន្ទូលមកលោកនៅលើភ្នំស៊ីណៃដែរ។
លោកម៉ូសេនេះហើយដែលបាននៅជាមួយបុព្វបុរសយើង ហើយលោកបានទទួលព្រះបន្ទូលដែលផ្ដល់ជីវិតយកមកប្រគល់ឲ្យយើងទាំងអស់គ្នា។
[39]លោកនេះហើយជាបុព្វបុរសរបស់យើង ដែលបណ្ដាជនបដិសេធមិនព្រមធ្វើតាម ហើយគេបែរជានាំគ្នាជំទាស់នឹងលោក ហើយមានចិត្តចង់វិលត្រឡប់ទៅស្រុកអេស៊ីប
វិញ។[40]ពេលនោះ ពួកគេបាននិយាយទៅកាន់លោកអើរ៉ុនថា៖ «សូមលោកឆ្លាក់រូបចម្លាក់ផ្សេងៗធ្វើជាព្រះដឹកនាំយើង ដ្បិតលោកម៉ូសេដែលបាននាំយើងចេញពីស្រុក
អេស៊ីបមកនោះ យើងមិនដឹងលោកទៅជាយ៉ាងណាហើយទេ»។
[41]ដូច្នេះ ពេលនោះពួកគេក៏បានឆ្លាក់រូបកូនគោមួយ ហើយយកយញ្ញបូជាមកថ្វាយរូបចម្លាក់នោះ រួចនាំគ្នាសប្បាយរីករាយចំពោះវត្ថុដែលជាស្នាដៃរបស់ខ្លួន។
[42]ប៉ុន្តែព្រះជាម្ចាស់ឈប់រវីរវល់នឹងពួកគេ ព្រះអង្គបណ្ដោយឲ្យគេគោរពថ្វាយបង្គំផ្កាយទាំងឡាយនៅលើមេឃ ស្របនឹងសេចក្ដីដែលមានចែងទុកក្នុងគម្ពីរព្យាការីថា៖
«ប្រជារាស្ត្រអ៊ីស្រាអែលអើយ! ក្នុងអំឡុងពេលសែសិបឆ្នាំនៅវាលរហោស្ថាន តើអ្នករាល់គ្នាដែលបានយកសត្វ ឬយញ្ញបូជាអ្វីមកឲ្យយើងឬទេ?
[43]អ្នករាល់គ្នាបានសែងខ្ទមរបស់ព្រះម៉ូឡុក និងសែងរូបផ្កាយតំណាងព្រះរេមផាន់របស់អ្នករាល់គ្នា និងរូបសំណាក់អស់ទាំងនោះ អ្នករាល់គ្នាបានឆ្លាក់ដើម្បីយកមក
ថ្វាយបង្គំ ហើយយើងនឹងកៀរអ្នករាល់គ្នាយកទៅឆ្ងាយ ហួសស្រុកបាប៊ីឡូនទៅទៀត»។
[44]នៅវាលរហោស្ថាន បុព្វបុរសរបស់យើងមានព្រះពន្លារបស់ព្រះជាម្ចាស់ សង់ឡើងស្របតាមព្រះបន្ទូល ដែលព្រះជាម្ចាស់បានបង្គាប់មកលោកម៉ូសេ គឺលោកត្រូវយកតាម
គំរូដែលលោកបានឃើញ។[45]បុព្វបុរសរបស់យើងបានទទួលព្រះពន្លា ដាក់តៗគ្នា ហើយសែងចូលទៅក្នុងទឹកដី ដែលរឹបយកពីជាតិសាសន៍នានា ក្រោមការដឹកនាំរបស់
លោកយ៉ូស្វេ គឺជាជាតិសាសន៍ដែលព្រះជាម្ចាស់បានដេញចេញពីមុខពួកគេ។ ព្រះពន្លានេះនៅគង់វង្សរហូតដល់ជំនាន់ព្រះបាទដាវីឌ។[46]ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹង
ព្រះបាទដាវីឌ ព្រះបាទដាវីឌក៏បានទូលសូមអនុញ្ញាតពីព្រះអង្គ រកព្រះដំណាក់មួយថ្វាយព្រះជាម្ចាស់របស់លោកយ៉ាកុប។
[47]ប៉ុន្តែ ព្រះបាទសាឡូម៉ូនឯណោះវិញទេ ដែលបានសង់ព្រះដំណាក់នោះ។[48]ទោះយ៉ាងណាក្តី ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតមិនគង់នៅក្នុងដំណាក់ ដែលសង់ឡើងដោយដៃ
មនុស្សឡើយ ដូចព្យាការីបានថ្លែងទុកមកស្រាប់ថា៖[49]«ផ្ទៃមេឃជាបល្ល័ង្ករបស់យើង ហើយផែនដីក៏ជាកំណល់ទ្រជើងយើងដែរ»។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «តើអ្នក
រាល់គ្នានឹងសង់ដំណាក់បែបណាឲ្យយើងបាន? តើកន្លែងដែលយើងនឹងសម្រាកនោះនៅឯណា?[50]តើមិនមែនយើងទេឬដែលបានបង្កើតអ្វីៗទាំងនោះមក?»
[51]អស់លោកមានចិត្តរឹងរូសអើយ! អស់លោកមានចិត្ត មានត្រចៀកដូចសាសន៍ដទៃ ចេះតែជំទាស់ប្រឆាំងនឹងព្រះវិញ្ញាណដ៏វិសុទ្ធជានិច្ច គឺមិនខុសពីបុព្វបុរសរបស់អស់
លោកទេ។[52]គ្មានព្យាការីណាម្នាក់ដែលបុព្វបុរសរបស់អស់លោកមិនបានបៀតបៀននោះឡើយ។ បុព្វបុរសរបស់អស់លោកបានសម្លាប់ អស់អ្នកដែលប្រកាសទុកជាមុនថា
ព្រះជាម្ចាស់ដ៏សុចរិតនឹងយាងមក។ ឥឡូវនេះ អស់លោកបានចាប់ព្រះអង្គនោះបញ្ជូនទៅឲ្យគេ ហើយអស់លោកធ្វើគុតព្រះអង្គថែមទៀតផង។[53]អស់លោកបានទទួល
ក្រឹត្យវិន័យតាមរយៈទេវតា តែអស់លោកពុំបានប្រព្រឹត្តតាមសោះ»។
[54]កាលសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ឮដូច្នោះ គេក្រេវក្រោធជាខ្លាំងគេសង្កៀតធ្មេញដាក់លោកស្ទេផាន។[55]រីឯលោកស្ទេផានវិញ លោកបានពោរពេញដោយព្រះវិញ្ញាណ
ដ៏វិសុទ្ធ លោកសម្លឹងមើលទៅលើមេឃឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងឃើញព្រះយេស៊ូឈរនៅខាងស្ដាំព្រះអង្គ។[56]លោកមានប្រសាសន៍ថា៖ «មើលហ្ន៎! ខ្ញុំឃើញផ្ទៃ
មេឃបើកចំហ និងឃើញបុត្រមនុស្ស ឈរនៅខាងស្ដាំព្រះជាម្ចាស់»។
[57]ពួកគេស្រែកឡើងយ៉ាងខ្លាំងទាំងយកដៃខ្ទប់ត្រចៀក ហើយនាំគ្នាស្ទុះទៅសង្ក្រប់ពីលើលោក។[58]គេបណ្ដេញលោកចេញពីទីក្រុង រួចយកដុំថ្មគប់សម្លាប់លោក។ អ្នកដែល
បានឃើញក៏យកសម្លៀកបំពាក់របស់ខ្លួនដាក់នៅក្បែរជើងយុវជនម្នាក់ឈ្មោះ សូល។
[59]នៅពេលគេគប់ដុំថ្មសម្លាប់នោះ លោកស្ទេផានទូលអង្វរថា៖ «ព្រះអម្ចាស់យេស៊ូអើយសូមទទួលវិញ្ញាណរបស់ទូលបង្គំផង»។[60]បន្ទាប់មក លោកលុតជង្គង់ចុះ ហើយបន្លឺ
សំឡេងខ្លាំងៗថា៖ «ព្រះអម្ចាស់អើយ! សូមកុំប្រកាន់ទោសគេ ព្រោះតែអំពើបាបនេះអី»។ កាលបានទូលដូច្នោះហើយ លោកក៏ផុតដង្ហើមទៅ។

Acts 7:1
ប្រយោគភ្ជាប់
ផ្នែកមួយនៃសាច់រឿងរបស់លោកស្ទេផាន ដែលបានចាប់ផ្តើមនៅក្នុង ជំពូក ៦:៨ នៅតែបន្ត។
លោកស្ទេផានបានចាប់ផ្តើមការឆ្លើយតបរបស់គាត់ទៅកាន់មហាបូជាចារ្យ និងក្រុមទីប្រឹក្សាជាន់ខ្ពស់
ដោយនិយាយអំពីអ្វីៗដែលបានកើតឡើងចំពោះប្រវត្តិរបស់អ៊ីស្រាអែល។ ភាគច្រើននៃសាច់រឿងនេះបានមកពីការសរសេររបស់លោកម៉ូសេ។
ព័ត៌មានទូទៅ
ពាក្យ «យើង» បូករួមទាំងលោកស្ទេផាន និងក្រុមប្រឹក្សាជាន់ខ្ពស់របស់យូដាដែលលោកនិយាយជាមួយ ហើយនិងអ្នកស្តាប់គាត់ទាំងអស់ផង។ ពាក្យ «របស់អ្នក» ជាឯកវចន: សំដៅលើលោកអប្រាហាំ។
ឱបងប្អូន និងលោកឪពុកអើយ សូមស្តាប់ខ្ញុំសិន
លោកស្ទេផាន ចាប់ផ្តើមដោយការគោរពដល់ក្រុមប្រឹក្សាជាន់ខ្ពស់នៅក្នុងការស្វាគមន៍របស់គាត់ដល់ពួកគេ ដែលប្រៀបដូចជាគ្រួសារ។
Acts 7:4
ព័ត៌មានទូទៅ
នៅក្នុងខ ៤ ពាក្យ «គាត់» ឬ «របស់គាត់» សំដៅលើ លោកអប្រាហាំ។ នៅក្នុងខ ៥ ពាក្យ He «គាត់» សំដៅលើព្រះជាម្ចាស់ ប៉ុន្តែ ពាក្យ «គាត់» ជាអក្សរតូច សំដៅលើលោកអប្រាហាំ។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ សំដៅលើក្រុមប្រឹក្សារបស់យូដា និងអ្នកស្តាប់។
ព្រះជាម្ចាស់មិនបានប្រទានទឹកដីឲ្យលោកឡើយ
«ព្រះអង្គមិនបានប្រទានទឹកដីណាឲ្យទេ»
សូម្បីតែដីដើម្បីដាក់បាតជើងក៏គ្មានផង
អាចមានន័យពីរ ទី១) ដីសម្រាប់ឈរក៏គ្មានផង ឬទី២) ដីដាក់ជើងក៏គ្មានផង។ របៀបផ្សេងទៀតនៃការបកប្រែ: «សូម្បីដីតូចមួយ»
ទៅជំនាន់ក្រោយគាត់ទុកជាកេរអាករ
«ព្រោះលោកអប្រាហាំមានដី ហើយប្រគល់ឲ្យកូនចៅរបស់គាត់»
Acts 7:6
ព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកយ៉ាងដូច្នេះថា
នេះអាចជាប្រយោជន៍ក្នុងការបញ្ជាក់ ពាក្យនេះ ដែលមាននៅពេលក្រោយទៀត ក៏ប្រយោគក្នុងខមុន។ របៀបផ្សេងទៀតនៃការបកប្រែ: «ក្រោយមក ព្រះជាម្ចាស់បានប្រាប់ដល់លោកអប្រាហាំ»
អស់រយៈពេលបួនរយឆ្នាំ
«៤០០ឆ្នាំ»

generated on Wed Sep 10 16:16:32 2025

យើងនឹងជំនុំជម្រះប្រជាជាតិ
«ប្រជាជាតិ» សំដៅលើមនុស្សដែលរស់នៅក្នុងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងជំនុំជម្រះប្រជាជនរបស់ប្រជាជាតិនេះ» ។
ដែលពួកគេបម្រើ
«ដែលពូជពង្សរបស់អ្នកធ្វើជាទាសករ»
ប្រទានសម្ពន្ធមេត្រីនៃការកាត់ស្បែកឲ្យលោកអប្រាហាំ
ជនជាតិយូដាអាចយល់ថា
សម្ពន្ធមេត្រីនេះគឺតម្រូវឲ្យលោកអប្រាហាំកាត់ស្បែកពួកប្រុសៗនៅក្នុងគ្រួសាររបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ចងសម្ពន្ធមេត្រីជាមួយលោកអប្រាហាំ
គឺកាត់ស្បែកពួកប្រុសៗនៅក្នុងគ្រួសាររបស់គាត់»
ដូច្នេះ លោកអប្រាហាំជាឪពុករបស់លោកអ៊ីសាក
សាច់រឿងបានប្តូរមកកូនចៅរបស់គាត់វិញ។
ហើយលោកយ៉ាកុបជាឪពុក
«ហើយលោកយ៉ាកុបបានក្លាយជាឪពុក»
លោកស្ទេផានបានសង្ខេបមកដល់ត្រង់នេះ។
Acts 7:9
ពួកបុព្វបុរស
«កូនប្រុសច្បងរបស់លោកយ៉ាកុប» ឬ «បងប្រុសច្បងរបស់លោកយ៉ូសែប»
មានចិត្តច្រណែន
«មានចិត្តច្រណែន»។ ឃ្លានេះ និយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ភាពច្រណែនបានធ្វើឲ្យបុព្វបុរសប្រឆាំងទាស់»
លក់លោកឲ្យអ្នកស្រុកអេស៊ីប
ជនជាតិយូដាដឹងពីបុព្វបុរសរបស់ពួកគេបានលក់លោកយ៉ូសែបឲ្យទៅធ្វើជាទាសកនៅក្នុងអេស៊ីប។
របៀបផ្សេងទៀតនៃការបកប្រែ: «លក់គាត់ឲ្យធ្វើជាទាសកនៅក្នុងអេស៊ីប»
ប៉ុន្តែ ព្រះជាម្ចាស់
បើនិយាយឲ្យងាយស្តាប់សម្រាប់អ្នកស្តាប់គឺ «ប៉ុន្តែ ព្រះជាម្ចាស់»។
គង់ជាមួយលោក
ពាក្យប្រៀបធៀបនេះសម្រាប់ជួយនរណាម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជួយគាត់»
ឲ្យគ្រប់គ្រងស្រុកអេស៊ីប
នេះសំដៅលើមនុស្សនៅអេស៊ីប។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រប់គ្រងលើប្រជាជនអេស៊ីប»
ត្រួតត្រាដំណាក់របស់ស្តេចទាំងមូលផង
ឃ្លានេះសំដៅលើរាជ្យទ្រព្យរបស់ស្តេចទាំងមូលផង។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីៗគ្រប់យ៉ាងដែលស្តេចមាន» ។
Acts 7:11
មានគ្រោះទុរ្ភិក្ស
«មានគ្រោះទុរ្ភិក្សបានកើតឡើង»។ ដីលែងបង្កើតផល។
បុព្វបុរសរបស់យើង
សំដៅលើលោកយ៉ាកុប
និងកូនប្រុសៗរបស់គាត់ដែលជាបុព្វបុរសរបស់ជនជាតិយូដា។
ស្រូវ
«ស្រូវ» ជាអាហារចំបាច់សម្រាប់មនុស្សគ្រប់គ្នានៅពេលនោះ។
ពួកបុព្វបុរសរបស់យើង...បងប្អូនរបស់លោក
ឃ្លាទាំងពីរនេះសំដៅលើបងប្រុសច្បងរបស់លោកយ៉ូសែប។ នៅក្នុងគម្ពីរ UDB
និយាយយ៉ាងច្បាស់។
លើកទីពីរ
«គ្រាបន្ទាប់មក»
បង្ហាញបងប្អូនរបស់លោកឲ្យស្គាល់លោក
លោកយ៉ូសែបបានបង្ហាញខ្លួនដល់បងប្អូនរបស់គាត់
ថាគាត់ជាបងប្អូនរបស់ពួកគេ។
ព្រះបាទផារោនក៏ស្គាល់ក្រុមគ្រួសាររបស់លោកយ៉ូសែបដែរ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ស្តេចផារោនបានដឹងថា ពួគគេជាក្រុមគ្រួសាររបស់លោកយ៉ូសែប»។
Acts 7:14
បានចាត់បងប្អូនរបស់លោកឲ្យត្រឡប់ទៅវិញ
«បានចាត់បងប្អូនរបស់លោកឲ្យត្រឡប់ទៅវិញ» ឬ
«ចាត់បងប្អូនរបស់គាត់ឲ្យត្រឡប់ទៅផ្ទះវិញ»។
ហើយលោកស្លាប់ទៅ
សូមឲ្យប្រាកដថា គាត់ស្លាប់នេះមិនមែនគាត់មកដល់អេស៊ីបភ្លាមស្លាប់ទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្រោយមកគាត់បានស្លាប់ទៅ»។
លោកស្លាប់ទៅ ព្រមទាំងពួកបុព្វបុរសយើងផងដែរ
«យ៉ាកុបនិងកូនៗប្រុសរបស់គាត់ដែលជាបុព្វបុរសរបស់យើង»
ពួកគេបានដឹកសពលោកទៅស៊ីគែម ហើយបានបញ្ចុះក្នុងផ្នូរ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«កូនចៅរបស់លោកយ៉ាកុបបានដឹកសពរបស់លោកយ៉ាកុប ហើយបានបញ្ចុះ» ។
Acts 7:17
ព័ត៌មានទូទៅ
ពាក្យ «របស់យើង» បូករួមទាំងលោកស្ទេផាន និងអ្នកស្តាប់លោកដែរ។
នៅពេលសន្យាជិតមកដល់... ប្រជាជនរបស់យើងបានចម្រើនកាន់តែចម្រើនឡើង
នៅក្នុងភាសាខ្លះអាចជួយក្នុងការនិយាយថា មនុស្សរឹកចម្រើនជាច្រើនឡើង
មុនពេលសេចក្តីសន្យានោះបានសម្រេច។ (សូមមើល: UDB)
នៅពេលសន្យាជិតមកដល់
វាជិតដល់ពេលដែលព្រះជាម្ចាស់សម្រេចសេចក្តីសន្យារបស់ព្រះអង្គដល់លោកអប្រាហាំ។
មានស្តេចអេស៊ីបថ្មីឡើងគ្រងរាជ្យ
«ស្តេចផ្សេងទៀតបានចាប់ផ្តើមគ្រប់គ្រង»។
លើអេស៊ីប
«អេស៊ីប» សំដៅលើប្រជាជនរបស់អេស៊ីប។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រជាជនអេស៊ីប» ។
ស្តេចនោះមិនស្គាល់លោកយ៉ូសែបទេ
«យ៉ូសែប» សំដៅលើកេរ្តិ៍ឈ្មោះរបស់លោកយ៉ូសែប»
ឯអេស៊ីប របៀបផ្សេងទៀតនៃការបកប្រែ:
«ស្តេចមិនបានស្គាល់ថាលោកយ៉ូសែបបានជួយដល់អេស៊ីបឡើយ»។
បានប្រើល្បិចអាក្រក់ ហើយបោកបញ្ឆោត
«ប្រព្រឹត្តនឹងបុព្វបុរសរបស់យើងមិនល្អ» ឬ
«កេងចំណេញលើបុព្វបុរសរបស់យើង»។
ឲ្យដាក់កូនងែតនៅកន្លែងគ្រោះថ្នាក់
ធ្វើទុក្ខដល់កូនងែតរបស់ពួកគេ ដើម្បីឲ្យកូនងែតនោះស្លាប់។
Acts 7:20
នៅសម័យ លោកម៉ូសេកើតមក
នេះគឺជាការណែនាំលោកម៉ូសេមកក្នុងសាច់រឿង។
ដ៏ស្អាតនៅចំពោះព្រះជាម្ចាស់
ឃ្លានេះគឺជាពាក្យប្រៀបធៀបដែលមានន័យថាលោកម៉ូសេស្អាតណាស់។
បានចិញ្ចឹម
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឪពុកម្តាយរបស់គាត់បានចិញ្ចឹមគាត់» ឬ
«ឪពុកម្តាយរបស់គាត់បានមើលថែគាត់»។
នៅពេលគេដាក់លោកចោលនៅខាងក្រៅ
លោកម៉ូសេ «ត្រូវបានដាក់នៅខាងក្រៅ» ដោយសារស្តេចផារោនបានបង្គាប់។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលឪពុកម្តាយគាត់បានទុកគាត់ចោលនៅខាងក្រៅ» ឬ
«ពេលឪពុកម្តាយរបស់គាត់បោះបង់គាត់ចោលនៅខាងក្រៅ»។
ធ្វើជាបុត្ររបស់ព្រះនាងផ្ទាល់
«ធ្វើដូចជាបុត្ររបស់ព្រះនាងផ្ទាល់»
Acts 7:22
លោកម៉ូសេបានទទួលការអប់រំ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជនជាតិអេស៊ីបបានផ្តល់ការអប់រំដល់លោកម៉ូសេ»។
អប់រំតាមចំណេះវិជ្ជាទាំងប៉ុន្មាន
នេះគឺជាជានិយាយបំផ្លើស ដើម្បីបញ្ជាក់ថា គាត់បានទទួលការអប់រំយ៉ាងជ្រៅជ្រះ។
លោកពូកែវោហារ ហើយប៉ិនប្រសប់ធ្វើកិច្ចការផ្សេងៗផង
«លោកមានឥទ្ធិពលក្នុងការនិយាយ និងការប្រព្រឹត្ត» ឬ
«មានឥទ្ធិពលក្នុងអ្វីដែលគាត់និយាយ និងធ្វើ»។
លោកមានដួងចិត្ត
«លោកបានគិត ហើយបានសម្រេចចិត្ត»។
នេះគឺជាការពាក្យប្រៀបធៀបដែលមានន័យថា «លោកបានសម្រេចចិត្ត» ។
ការសួរសុខទុក្ខបងប្អូនរួមជាតិរបស់លោកដែលជាកូនចៅអ៊ីស្រាអែល

generated on Wed Sep 10 16:16:32 2025

នេះសំដៅលើប្រជាជនរបស់គាត់ និងមិនគ្រាន់តែក្រុមគ្រួសាររបស់គាត់ប៉ុណ្ណោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទៅមើលឲ្យដឹងថាប្រជាជនរបស់លោកសុខទុក្ខយ៉ាងណា
ហើយកូនចៅអ៊ីស្រាអែល ធ្វើអ្វីខ្លះ» ។
លោកបានឃើញជនជាតិអ៊ីស្រាអែលម្នាក់ត្រូវគេធ្វើបាប...ជនជាតិអេស៊ីប
ឃ្លានេះនិយាយជាទម្រង់សកម្ម ដោយគ្រាន់តែប្តូរលេខរៀង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយឃើញជនជាតិអេស៊ីបធ្វើបានជនជាតិអ៊ីស្រាអែលដូច្នេះ
លោកម៉ូសេបានការពារពួកគេ
ហើយបានសងសឹកជំនួសជនជាតិអ៊ីស្រាអែលដោយវាយជនជាតិអេស៊ីបដែលបានសង្កត់សង្កិនគាត់»
វាយសម្លាប់ជនជាតិអេស៊ីប
លោកម៉ូសេបានវាយជនជាតិអេស៊ីបយ៉ាងខ្លាំងរហូតដល់ស្លាប់។
លោកបានគិតថា
«គាត់បានគិតក្នុងចិត្តថា»
ប្រើដៃលោកសង្គ្រោះពួកគេ
«សង្គ្រោះពួកគេតាមរយៈលោកម៉ូសេ» ឬ «ប្រើលោកម៉ូសេដើម្បីសង្គ្រោះពួកគេ» ។
Acts 7:26
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើជនជាតិអ៊ីស្រាអែល ប៉ុន្តែ
មិនបានបូករួមលោកម៉ូសេ។
ជនជាតិអ៊ីស្រាអែលខ្លះ
អ្នកស្តាប់អាចនឹងស្គាល់ពីកំណត់ហេតុនៅក្នុងនិក្ខមនំ គឺបុរសពីរនាក់នេះ ប៉ុន្តែ
លោកស្ទេផានមិនបានបញ្ជាក់ច្បាស់លាស់ទេ។
ព្យាយាមសម្រុះសម្រួលពួកគេឲ្យត្រូវគ្នាវិញ
«ធ្វើឲ្យពួកគេឈប់ឈ្លោះគ្នា» (UDB)
អ្នករាល់គ្នាជាបងប្អូននឹងគ្នា
លោកម៉ូសេបានបញ្ជាក់ថាជនជាតិអ៊ីស្រាអែលគឺជាអ្នកឈ្លោះគ្នា។
ហេតុអ្វីបានជាធ្វើបាបគ្នាឯងដូច្នេះ?
លោកម៉ូសេបានសួរសំណួរនេះ ដើម្បីលើកទឹកចិត្តពួកគេ ឲ្យឈប់ឈ្លោះគ្នា។
របៀបមួយផ្សេងទៀតនៃការបកប្រែ: «បងប្អូនមិនធ្វើបាបគ្នាឯងនោះទេ!»
តើអ្នកណាបានតាំងលោកឲ្យធ្វើជាមេដឹកនាំ និងជាចៅក្រមលើយើង?
បុរសដែលប្រើសំណួរនេះ ដើម្បីដាស់តឿនលោកម៉ូសេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកគ្មានសិទ្ធិអំណាចលើយើងទេ» ។
តើលោកចង់សម្លាប់ខ្ញុំ ដូចលោកបានសម្លាប់ជនជាតិអេស៊ីបម្នាក់ពីម្សិលមិញដែរឬ
បុរសនេះប្រើសំនួរនេះ ដើម្បីដាស់តឿនលោកម៉ូសេថា
គាត់និងអ្នកផ្សេងទៀតបានដឹងថាលោកម៉ូសេបានសម្លាប់ជនជាតិអេស៊ីប។
Acts 7:29
ព័ត៌មានទូទៅ
អ្នកស្តាប់របស់លោកស្ទេផានបានដឹងរួចហើយថា
លោកម៉ូសេបានរៀបការជាមួយស្ត្រីជនជាតិម៉ាឌាន ពេលគាត់រត់គេចពីអេស៊ីប។
បន្ទាប់ពីបានឮការនេះ
បង្កប់ន័យថា
លោកម៉ូសេយល់ថាជនជាតិអ៊ីស្រាអែលដឹងថាគាត់បានសម្លាប់ជនជាតិអេស៊ីបពីម្សិលមិញ
នៅក្នុងជំពូក ៧:២៦។
នៅពេលសែសិបឆ្នាំបានកន្លងផុតទៅ
«បន្ទាប់ពី៤០សិបឆ្នាំក្រោយមក»។
នេះគឺជាចំនួនឆ្នាំដែលលោកម៉ូសេបានរស់នៅក្នុងស្រុកម៉ាឌាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«សែបសិបឆ្នាំបន្ទាប់ពីលោកម៉ូសេរត់គេចពីអេស៊ីប»។
ទេវតាមួយរូបបានបង្ហាញខ្លួន
អ្នកស្តាប់របស់លោកស្ទេផានដឹងថា ព្រះជាម្ចាស់មានបន្ទូលតាមរយៈទេវតា។
កណ្ឌគម្ពីរ UDB បានបញ្ជាក់យ៉ាងច្បាស់។
Acts 7:31
លោកងឿងឆ្ងល់នឹងអ្វីដែលបានឃើញនោះ
លោកម៉ូសេភ្ញាក់ផ្អើលនឹងគម្ពោតព្រៃដែលឆេះមិនសុស។
នេះប្រហែលជាអ្នកស្តាប់របស់លោកស្ទេផានយល់។
របៀបផ្សេងទៀតនៃការបកប្រែ:ដោយសារគម្ពោតព្រៃឆេះមិនសុស»
លោកចូលទៅជិតវា ដើម្បីមើលវា ...លោកម៉ូសេភ័យញ័រជាខ្លាំង ហើយមិនហ៊ានទាំងមើលផង
ឃ្លានេះអាចមានន័យថា លោកម៉ូសេបានចាប់ផ្តើមចូលទៅជិតគុម្ពោតព្រៃ
ដើម្បីពិនិត្យមើល ប៉ុន្តែ គាត់បានត្រឡប់ក្រោយដោយភាពភ័យខ្លាច
ពេលគាត់ឮសម្លេង។
យើងជាព្រះជាម្ចាស់នៃបុព្វបុរសរបស់អ្នករាល់គ្នា
«យើងគឺជាព្រះជាម្ចាស់ដែលដូនតារបស់អ្នកថ្វាយបង្គំ» (UDB)។
លោកម៉ូសេភ័យញ័រជាខ្លាំង
លោកម៉ូសេញ័រដោយសារភ័យខ្លាច។ នេះបានបង្ហាញយ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកម៉ូសេញ័រដោយសាខ្លាច»។
Acts 7:33
ចូរដោះស្បែកជើងរបស់អ្នកចេញ
ព្រះជាម្ចាស់បានបន្ទូលជាមួយលោកម៉ូសេបែបនេះ
ដើម្បីឲ្យគាត់បានគោរពកោតខ្លាចដល់ព្រះអង្គ។
ដ្បិត កន្លែងដែលអ្នកឈរជាកន្លែងដ៏វិសុទ្ធ
បញ្ជាក់ថាកន្លែងនោះជាកន្លែងដែលព្រះជាម្ចាស់គង់នៅ
ជាកន្លែងដែលព្រះជាម្ចាស់រាប់ថាជាកន្លែងបរិសុទ្ធសម្រាប់ព្រះអង្គ។
យើងបានឃើញ
«បានឃើញយ៉ាងច្បាស់» ពាក្យច្បាស់នៅត្រង់នេះ បន្ថែមដើម្បីបញ្ជាក់ពាក្យ
ឃើញ។
ប្រជារាស្ត្ររបស់យើង
ពាក្យ «របស់យើង» បញ្ជាក់ថា ប្រជាជនទាំងនេះ ជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ពូជពង្សរបស់លោកអាប្រាហាំ អ៊ីសាក
និងយ៉ាកុប»
យើងចុះមកដើម្បីសង្គ្រោះពួកគេ
យើងខ្លួនឯងនឹងធ្វើពួកគេមានសេរីភាព»
ឥឡូវនេះ ចូរមក
«ចូររួចរាល់»។ ព្រះជាម្ចាស់ប្រើសេចក្តីបង្គាប់នៅត្រង់នេះ។
Acts 7:35
ព័ត៌មានទូទៅ
នៅក្នុងខ ៣៥-៣៨ បង្កប់សេរីនៃការភ្ជាប់ពីឃ្លាសំដៅលើលោកម៉ូសេ។
ឃ្លានីមួយៗ បញ្ជាកពីលោកម៉ូសេ ដូចជា «លោកម៉ូសេនេះ» ឬ
«លោកម៉ូសេនេះហើយ» ឬ «នេះគឺជាបុរស» ឬ «គឺលោកម៉ូសេនេះហើយ»
ប្រសិនបើអាច ប្រើប្រយោគដើម្បីបញ្ជាក់លោកម៉ូសេ។
ព័ត៌មានទូទៅ
បន្ទាប់ពីជនជាតិអ៊ីស្រាអែលចេញពីអេស៊ីប ពួកគចំណាយ៤០ឆ្នាំ
វង្វេងនៅក្នុងទីរហោស្ថាន មុនពេលព្រះជាម្ចាស់នាំពួកគេមកចូលក្នុងទឹកដី
ដែលព្រះអង្គបានសន្យាជាមួយពួកគេ។
គឺលោកម៉ូសេនេះហើយ ដែលពួកគេបានបដិសេធ
នេះសំដៅលើព្រឹត្តការណ៍ដែលបានកត់ត្រានៅក្នុងជំពូក ៧:២៦
តើអ្នកណាបានតាំងលោកឲ្យធ្វើជាមេដឹកនាំ និងជាចៅក្រម?
សំណួរនេះប្រើដើម្បីដាស់តឿនលោកម៉ូសេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកគ្មានសិទ្ធិអំណាចលើយើងទេ!»
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងសំណួរដែលមិនទាមទារចម្លើយនៅក្នុងជំពូក
៧:២៦
មេដឹកនាំ និងជាអ្នកសង្គ្រោះ
«ដើម្បីដឹកនាំលើពួកគេ និងរំដោះពួកគេពីភាពជាទាសភាព»។
ដោយមានជំនួយពីទេវតា
«ទេវតាជាអ្នកជួយ»
អស់រយៈពេលសែសិបឆ្នាំ
អ្នកស្តាប់របស់លោកស្ទេផានដឹងអំពីរឿង ៤០ឆ្នាំ
ដែលជនជាតិអ៊ីស្រាអែលរស់នៅក្នុងទីរហោស្ថាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អំឡុងពេល ៤០ឆ្នាំដែលជនជាតិអ៊ីស្រាអែលរស់នៅក្នុងទីរហោស្ថាន» ។
ធ្វើឲ្យមានព្យាការីម្នាក់
«ធ្វើឲ្យអ្នកផ្សេងទៀតក្លាយជាព្យាការី»។
ពីចំណោមបងប្អូនអ្នករាល់គ្នា
«ពីចំណោមប្រជាជនរបស់អ្នកផ្ទាល់» (UDB)។
Acts 7:38
ព័ត៌មានទូទៅ
នៅក្នុងការដកស្រង់នៅក្នុងខ ៤០ យកចេញពីការសរសេររបស់លោកម៉ូសេ។
នេះគឺជាបុរសម្នាក់ដែលនៅជួបជុំគ្នា
«បុរសនេះគឺលោកម៉ូសេដែលបាននៅក្នុងចំណោមជនជាតិអ៊ីស្រាអែល» (UDB)

generated on Wed Sep 10 16:16:32 2025

នេះគឺជាបុរសម្នាក់
ឃ្លា «នេះគឺជាបុរសម្នាក់» នេះ
នៅក្នុងព្រះបន្ទូលដែលនិយាយទាក់ទងនឹងលោកម៉ូសេទាំងអស់។
នេះគឺជាបុរសម្នាក់ដែលបានទទួលព្រះបន្ទូលដែលផ្តល់ដ៏រស់យកមកប្រគល់ឲ្យយើង
ព្រះជាម្ចាស់ជាព្រះដែលបានប្រទានព្រះបន្ទូលទាំងនោះមកយើង។
របៀបផ្សេងទៀតនៃការបកប្រែ:
«នេះគឺជាបុរសម្នាក់ដែលព្រះជាម្ចាស់មានបន្ទូលពីព្រះបន្ទូលដ៏រស់ដល់យើង»។
ព្រះបន្ទូលដ៏រស់
អាចមានន័យពីរ ទី១) «ព្រះបន្ទូលដែលអត់ធ្មត់» ទី២)
«ព្រះបន្ទូលដែលផ្តល់ជីវិត»។
ពួកគេបានច្រានលោកចោលចេញពីពួកគេ
ពាក្យប្រៀបធៀបនេះ បង្ហាញពីការដែលពួកគេបដិសេធលោកម៉ូសេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានបដិសេធលោកឲ្យធ្វើជាអ្នកដឹកនាំ»
នៅក្នុងចិត្តរបស់ពួកគេ ពួកគេចង់ត្រឡប់ទៅស្រុកអេស៊ីបវិញ។
ពួកគេប្រាថ្នាចង់ត្រឡប់ទៅអេស៊ីបវិញ»
ពេលនោះ
«នៅពេលពួកគេសម្រេចចិត្តប្រឡប់ទៅអេស៊ីបវិញ»
Acts 7:41
ព័ត៌មានទូទៅ
ការដកស្រង់របស់លោកស្ទេផាននៅទីនេះ មកពីព្យាការីអេម៉ុស។
ពួកគេបានធ្វើរូបកូនគោមួយ
អ្នកស្តាប់របស់លោកស្ទេផានបានដឹងពីកូនគោ ដែលពួកគេបានធ្វើជារូបចម្លាក់
មើលទៅដូចជាសត្វគោ»។
ធ្វើរូបកូនគោមួយ... រូបព្រះ...ដោយ សារស្នាដៃរបស់ពួកគេ
ឃ្លាទាំងអស់នេះសំដៅលើរូបចម្លាក់កូនគោ។
ព្រះជាម្ចាស់បានបែរចេញ
«ព្រះជាម្ចាស់បានបែរចេញ»។ សម្មភាពនេះបង្ហាញថា
ព្រះជាម្ចាស់មិនគាត់ព្រះទ័យនឹងប្រជាជន ហើយព្រះអង្គលែងជួយគេទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់ឈប់កែតម្រង់ពួកគេ»
ប្រគល់ពួកគេឲ្យ
«បោះបង់ពួកគេចោល» (UDB)។
ផ្កាយទាំងឡាយនៅលើមេឃ
អាចមានន័យថាពីរ ទី១) តែផ្កាយទេ ឬ ទី២) មានព្រះអាទិត្យ ព្រះចន្ទ និងផ្កាយ។
គម្ពីរពួកព្យាការី
នេះគឺជាការប្រមូលការសរសេររបស់ព្យាការីមួយចំនួននៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់
មកដាក់នៅក្នុងក្រាំងមួយ។ អាចបូកបញ្ចូលជាមួយកណ្ឌគម្ពីរអេម៉ូសដែរ។
តើអ្នករាល់គ្នាបានសម្លាប់សត្វ និងយកយញ្ញបូជា...អ៊ីស្រាអែល?
ព្រះជាម្ចាស់សួរសំនួរនេះដើម្បីបង្ហាជនជាតិអ៊ីស្រាអែល
ពួកគេមិនបានថ្វាយបង្គំព្រះអង្គដោយយញ្ញបូជារបស់ពួកគេដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: អ្នករាល់គ្នាមកបានគោរពយើង
ពេលអ្នករាល់គ្នាសម្លាប់សត្វ និងថ្វាយយញ្ញបូជា...អ៊ីស្រាអែល។
វង្ស អ៊ីស្រាអែល
នេះសំដៅលើប្រជាជាតិអ៊ីស្រាអែលទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
អ្នករាល់គ្នាជាវង្ស អ៊ីស្រាអែលអើយ»។
Acts 7:43
ប្រយោគភ្ជាប់
លោកស្ទេផានបន្តការឆ្លើយតបរបស់គាត់ចំពោះមហាបូជាចារ្យ
និងក្រុមប្រឹក្សាជាន់ខ្ពស់ ដែលគាត់បានចាប់ផ្តើមនៅក្នុង ជំពូក ៧:១។
ព័ត៌មានទូទៅ
ដកស្រង់ចេញពីព្យាការីអេម៉ូស បន្តនៅត្រង់នេះ។
អ្នករាល់គ្នាបានទទួល
មានន័យថា ពួកគេបានយករូបព្រះនេះមកជាមួយពួកគេ
នៅពេលពួកគេធ្វើដំណើរនៅក្នុងទីរហោស្ថាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នករាល់គ្នាបានយកមកជាមួយអ្នករាល់គ្នាពីកន្លែងមួយទៅកន្លែងមួយ»
ពន្លារបស់ព្រះម៉ូឡុក
ពន្លាគឺជាផ្ទះរបស់ព្រះក្លែងក្លាយរបស់ម៉ូឡុក
ផ្កាយរបស់ព្រះរេមផាន់
ផ្កាយគឺបញ្ជាក់ពីព្រះក្លែងក្លាយរបស់រេមផាន់
រូបសំណាក់ដែលអ្នករាល់គ្នាបានធ្វើ
ពួកគេបានធ្វើរូបចម្លាក់ ឬរូបរបស់ព្រះម៉ូឡុក
និងព្រះរេមផាន់ដើម្បីថ្វាយបង្គំរូបព្រះទាំងនោះ។
យើងនឹងនាំអ្នករាល់គ្នាយកទៅហួសស្រុកបាប៊ីឡូនទៅទៀត
«យើងនឹងនាំអ្នករាល់គ្នាទៅឆ្ងាយជាដូនតារបស់អ្នករាល់គ្នាទៀតគឺទៅឆ្ងាយជាងបាប៊ីឡូនទៀត»។
នេះគឺជាការជំនុំជម្រះរបស់ព្រះជាម្ចាស់។
Acts 7:44
ព្រះពន្លានៃទីបន្ទាល់
ព្រះពន្លាគឺជាផ្ទះរបស់ហឹប (ប្រអប់) ជាមួយនឹងបញ្ញត្តិទាំងដប់ប្រការ
ដែលបានឆ្លាក់នៅលើថ្មដាក់ក្នុងនោះ។
ព្រះពន្លានៃទីបន្ទាល់...ព្រះបន្លា
ទាំងពីឃ្លានេះសំដៅលើរបស់ដូចគ្នា។
ជាមរតករបស់បុព្វបុរស
«មកជាមរតករបស់ប្រជាជាតិ»។ បូកបញ្ចូលជាមួយ ទឹកដី អគារ ស្រូវ សត្វពាហនៈ
ព្រមទាំងមរតករបស់ប្រជាជាតិដែលជនជាតិអ៊ីស្រាអែលវាយយកបាន។
ប្រជាជាតិផ្សេងៗ
សំដៅលើមនុស្សដែលរស់នៅក្នុងទឹកដីនោះមុនជនជាតិអ៊ីស្រាអែល។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជនដែលរស់នៅមុនជនជាតិអ៊ីស្រាអែល» ។
ព្រះពន្លានេះនៅគង់វង្សនៅក្នុងទឹកដីរហូតដល់ជំនាន់ព្រះបាទដាវីឌ។
ហឹបនៅគង់វង្សក្នុងព្រះពន្លារហូតដល់សម័យរបស់ព្រះបាទដាវីឌ
ស្តេចរបស់អ៊ីស្រាអែល។
ជាព្រះដំណាក់មួយថ្វាយព្រះជាម្ចាស់របស់លោកយ៉ាកុប
«ផ្ទះសម្រាប់ហឹប ជាកន្លែងដែលព្រះជាម្ចាស់របស់លោកយ៉ាកុបគង់នៅ»។
ព្រះបាទដាវីឌចង់ដាក់ហឹបនៅក្នុងក្រុងយេរូសាឡិមរហូត
មិនមែននៅក្នុងព្រះពន្លាទេ។
Acts 7:47
ព័ត៌មានទូទៅ
នៅក្នុងខ ៤៩-៥០ លោកស្ទេផានដកស្រង់ចេញពីព្យាការីអេសាយ។
នៅក្នុងការដកស្រង់នេះ ព្រះជាម្ចាស់មានបន្ទូលថាពីអង្គទ្រង់ផ្ទាល់។
ធ្វើដោយដៃ
«មនុស្សជាអ្នកធ្វើ»
ស្ថានសួគ៌ជាបល្ល័ង្ករបស់យើង ហើយផែនដីគឺជាកំណល់ទ្រជើងយើង
ព្យាការីកំពុងតែប្រៀបធៀបពីភាពធំឧត្តមរបស់ព្រះវត្តមានរបស់ព្រះជាម្ចាស់
ថាការដែលមនុស្សសង់កន្លែងសម្រាប់ព្រះអង្គ
ទោះបីជាពេញផែនដីទាំងមូលក៏គ្មានប្រយោជន៍ដែរ ប៉ុន្តែ
វាជាកន្លែងដែលព្រះអង្គដាក់ព្រះបាទារបស់ទ្រង់។
តើដំណាក់បែបណាដែលអ្នកអាចសង់ឲ្យយើង?
ព្រះជាម្ចាស់សួរសំណួរដើម្បីបង្ហាញពីការខំប្រឹងរបស់មនុស្សឥតប្រយោជន៍
ក្នុងការមើលថែព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចសង់ផ្ទះដែលធំល្មមសម្រាប់យើងទេ» ។
តើកន្លែងណាសម្រាប់ឲ្យយើងសម្រាក?
ព្រះជាម្ចាស់សួរសំណួរនេះដើម្បីបង្ហាញដល់មនុស្សថា
ពួកគេមិនអាចផ្តល់កន្លែងណាមួយដើម្បីឲ្យព្រះអង្គបានសម្រាកនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានកន្លែងសម្រាកណាដែលល្អល្មមសម្រាប់យើងបានទេ!»
តើមិនមែនដៃរបស់យើងទេឬដែលបានបង្កើតអ្វីៗទាំងនោះមក?
ព្រះជាម្ចាស់សួរសំណួរនេះ ដើម្បីបង្ហាញថា មនុស្សមិនអាចបង្កើតអ្វីមួយបានទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដៃរបស់យើងបង្កើតរបស់ទាំងអស់នេះ»
Acts 7:51
ប្រយោគភ្ជាប់
លោកស្ទេផានបានបញ្ចប់ដោយការដាស់តឿនធ្ងន់ៗ ចំពោះមហាបូជាចារ្យ
និងក្រុមប្រឹក្សាជាន់ខ្ពស់ ដែលបានចាប់ផ្តើមនៅក្នុងជំពូក ៧:១
អស់លោកជាមនុស្សរឹងចចេស
ក្បាលរឹង លោកស្ទេផានបូរដោយបង្ហាញអ្នកដឹងនាំរបស់យូដា
ដើម្បីដាស់តឿនពួកគេ។
មនុស្សរឹងចចេស
មនុស្សរឹងចចេស មិនមែនមានន័យថាករបស់ពួកគេរឹងទេ ប៉ុន្តែ សំដៅលើ
«ចិត្តរឹងរូស» របស់ពួកគេ។
មានចិត្ត និងត្រចៀកមិនកាត់ស្បែក
ជនជាតិយូដារាប់ការមិនកាត់ស្បែកថាជាមនុស្សមិនស្តាប់បង្គាប់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

លោកស្ទេផានប្រើពាក្យ «ចិត្ត និងត្រចៀក»
ដើម្បីបង្ហាញដល់អ្នកដឹកនាំរបស់យូដាដែលបានប្រព្រឹត្តជាមួយសាសន៍ដទៃ
ពេលពួកគេមិនស្តាប់បង្គាប់ ឬមិនស្តាប់តាមព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នាបដិសេធក្នុងការស្តាប់បង្គាប់
និងស្តាប់»
តើមានព្យាការីណាម្នាក់ដែលបុព្វបុរសរបស់អស់លោកមិនបានបៀតបៀន?
លោកស្ទេផានសួរសំនួរនេះ ដើម្បីបង្ហាញពួកគេថា
ពួកគេមិនដឹងអ្វីពីកំហុសរបស់បុព្វបុរសរបស់ពួកគេឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«បុព្វបុរសរបស់អ្នករាល់គ្នាបានបៀតបៀនដល់ព្យាការីគ្រប់គ្នា»។
ព្រះជាម្ចាស់ដ៏សុចរិត
សំដៅលើព្រះគ្រិស្ត ព្រះមេស្ស៊ី។
ឥឡូវនេះ អស់លោកបានជាអ្នកក្បត់ ហើយក៏បានសម្លាប់ព្រះអង្គ
«អ្នករាល់គ្នាក៏ជាអ្នកក្បត់ និងធ្វើឃាតព្រះអង្គដែរ»។
អ្នកធ្វើឃាតព្រះអង្គ
«អ្នកធ្វើឃាតដល់ព្រះជាម្ចាស់ដ៏សុចរតិ» ឬ «អ្នកធ្វើឃាតដល់ព្រះគ្រិស្ត»។
ក្រឹត្យវិន័យដែលទេវតាបានបង្កើត
«ក្រឹត្យវិន័យដែលព្រះជាម្ចាស់បានធ្វើឲ្យទេវតាផ្តល់ឲ្យបុព្វបុរសរបស់យើង» (UDB)។
Acts 7:54
ប្រយោគភ្ជាប់
ក្រុមប្រឹក្សាជាន់ខ្ពស់ឆ្លើយតបចំពោះពាក្យសំដីរបស់លោកស្ទេផាន។
ឥឡូវនេះ នៅពេលសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់បានឮសេចក្តីទាំងនេះ
នេះជាចំណុចសំខាន់ ពេលបញ្ចប់ការចែកចាយ
ហើយសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់មានព្រឹត្តកម្ម។
មានចិត្តក្តៅក្រហាយ
«ខឹងជាខ្លាំង»
ពួកគេបានសង្កៀតធ្មេញរបស់ពួកគេដាក់លោកស្ទេផាន
សកម្មភាពនេះបង្ហាញពីកំហឹងយ៉ាងខ្លាំងរបស់ពួកគេចំពោះលោកស្ទេផាន
ឬស្អប់ដល់លោកស្ទេផាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេខឹងជាខ្លាំង
ហើយពួកគេបានសង្កៀតធ្មេញរបស់ពួកគេទាំងអស់គ្នា»។ ឬ
«សង្កៀតធ្មេញទៅមុខទៅក្រោយ ពេលពួកគេមើលលោកស្ទេផាន»។
លោកសម្លឹងមើលទៅលើស្ថានសួគ៌
«លោកសម្លឹងមើលទៅលើស្ថានសួគ៌ » បង្ហាញថា មានតែលោកស្ទេផានទេ
ដែលមើលឃើញនិមិត្ត ហើយពួកបណ្តាជនផ្សេងទៀតមិនបានឃើញទេ។
ឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់
ជាទូទៅមនុស្សមានបទពិសោធជាមួយសិរីល្អរបស់ព្រះជាម្ចាស់
ជាពន្លឺភ្លឺពីព្រះជាម្ចាស់»។
គង់នៅខាងស្តាំព្រះជាម្ចាស់
ឃ្លា «គង់នៅខាងស្តាំ» គឺជាពាក្យប្រៀបធៀបដែលសំដៅលើកន្លែងកិតិយស។
របៀបផ្សេងទៀតនៃការបកប្រែ: «គង់នៅកន្លែងកិតិយសក្បែរព្រះជាម្ចាស់» ។
បុត្រមនុស្ស
ស្ទេផានសំដៅមុខតំណែងព្រះយេស៊ូ ជា «បុត្រមនុស្ស»
Acts 7:57
បិទត្រចៀករបស់ពួកគេ
បិទត្រចៀករបស់ពួកគេ បង្ហាញថា
ពួកគេមិនចង់ឮអ្វីដែលលោកស្ទេផានមានប្រសាសន៍ទៀត។
ពួកគេបានអូសលោកចេញពីទីក្រុង
«ពួកគេចាប់លោកស្ទេផាន ហើយអូសកាត់ចេញក្រៅក្រុង»។
ដាក់អាវធំ
អាវធំនេះ ឬរ៉ូបគឺសម្រាប់ពាក់នៅខាងក្រៅ ដើម្បីឲ្យកក់ក្តៅ ប្រហែលនឹងអាវរងា
ឬអាវស្បែក។
នៅក្បែរជើង
«នៅខាងមុខ»។ ពួកគេដាក់នៅទីនោះ ដើម្បីលោកសូលអាចមើលពួកគេ។
យុវជនម្នាក់
លោកសូលប្រហែលជាអាយុ៣០ឆ្នាំនៅពេលនោះ។
Acts 7:59
ប្រយោគភ្ជាប់
នេះគឺជាចំណុចបញ្ចប់របស់លោកស្ទេផាន។
សូមទទួលវិញ្ញាណរបស់ទូលបង្គំផង
«សូមទទួលវិញ្ញាណរបស់ទូលបង្គំ» អាចបន្ថែមពាក្យ «សូម»
ដើម្បីបង្ហាញពីការស្នើសុំ។ របៀបផ្សេងទៀតនៃការបកប្រែ: «សូមទទួលវិញ្ញាណ
របស់ទូលបង្គំផង»
លោកបានលុតជង្គង់ចុះ
នេះគឺជាសកម្មភាពនៃការចុះចូលចំពោះព្រះជាម្ចាស់។
សូមកុំប្រកាន់ពួកគេជាមួយនឹងបាបនេះឡើយ
ឃ្លានេះអាចស្ថិតនៅក្នុងទម្រង់វិជ្ជាមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមអត់ទោសដល់ពួកគេ សម្រាប់បាបនេះផង»
លោកក៏ស្លាប់ទៅ
នេះជាភាសាសុភាព បង្ហាញថាគាត់បាន «ស្លាប់» ហើយ។

---

8 [1]លោកសូលបានយល់ស្របនឹងការសម្លាប់លោកស្ទេផានដែរ។ ក្រោយពីថ្ងៃនោះមក ចាប់ផ្តើមមានការបៀតបៀនជាខ្លាំង មកលើក្រុមជំនុំនៅក្រុងយេរូសាឡឹម
ហើយពួកអ្នកជឿទាំងប៉ុន្មានបានបែកខ្ញែកគ្នាពាសពេញស្រុកយូដា និងស្រុកសាម៉ារី លើកលែងតែក្រុមសាវក។[2]អស់អ្នកដែលគោរពប្រណិប័តន៍ព្រះជាម្ចាស់ បាននាំគ្នា
បញ្ចុះសពលោកស្ទេផាន និងយំសោកយ៉ាងខ្លាំងចំពោះលោក។[3]រីឯលោកសូលវិញ លោកខំប្រឹងរំលាយក្រុមជំនុំ លោកបានចូលពីផ្ទះមួយទៅផ្ទះមួយ ចាប់ពួកអ្នកជឿទាំង
ប្រុសទាំងស្រីយកទៅឃុំឃាំង។
[4]ប៉ុន្តែ ពួកសិស្សដែលបែកខ្ញែកគ្នានោះ ពួកគេធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទាំងប្រកាសពីព្រះបន្ទូលផងដែរ។[5]លោកភីលីពបានធ្វើដំណើរទៅឯក្រុងមួយនៅស្រុក
សាម៉ារី ហើយប្រកាសប្រាប់អ្នកក្រុងអំពីព្រះគ្រិស្ត។
[6]នៅពេលបណ្តាជនជាច្រើនបានឮ និងឃើញពីទីសម្គាល់ដែលលោកភីលីពបានធ្វើ ពួកគេនាំគ្នាមកស្តាប់លោកដែលមានប្រសាសន៍។[7]មានវិញ្ញាណអាក្រក់ចេញពីមនុស្ស
ជាច្រើនទាំងស្រែកខ្លាំងៗ និងមានមនុស្សខ្វិន មនុស្សស្លាប់ដៃជើងជាច្រើនបានជា។[8]ប្រជាជននៅក្រុងនោះមានអំណរសប្បាយដ៏លើសលប់។
[9]មានបុរសម្នាក់ ឈ្មោះស៊ីម៉ូនរស់នៅក្នុងក្រុងនោះ តាំងពីមុនលោកភីលីពមកដល់ម៉្លេះ។ គាត់ជាគ្រូមន្តអាគម ធ្វើឲ្យប្រជាជននៅស្រុកសាម៉ារីស្ងើចសរសើរគាត់ជាខ្លាំង
ហើយគាត់អួតខ្លួនថាគាត់ជាមនុស្សសំខាន់មួយរូប។[10]ប្រជាជនសាសន៍សាម៉ារីទាំងអស់ ទាំងអ្នកតូចអ្នកធំស្តាប់គាត់គ្រប់ៗគ្នា គេពោលថា៖ «លោកនេះហើយជា
ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលជាឫទ្ធានុភាពដ៏ឧត្តុង្គឧត្តម»។[11]ប្រជាជនបានស្តាប់គាត់ ព្រោះគាត់បានសម្តែងមន្តអាគមឲ្យគេស្ងើចសរសើរអស់រយៈពេលជាច្រើនឆ្នាំ
មកហើយ។
[12]ប៉ុន្តែ ពេលពួកគេបានជឿដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងអំពីព្រះនាមព្រះយេស៊ូគ្រិស្ត ដែលលោកភីលីពបានប្រកាសប្រាប់ ពួកគេក៏ទទួលពិធីជ្រមុជទឹកទាំង
ប្រុសទាំងស្រី។[13]សូម្បីតែលោកស៊ីម៉ូនក៏បានជឿដែរ ថែមទាំងបានទទួលពិធីជ្រមុជទឹក ហើយគាត់នៅជាមួយនឹងលោកភីលីពជានិច្ច។ ពេលគាត់បានឃើញទីសម្គាល់ និង
ការអស្ចារ្យធំៗដែលកើតមាននៅពេលនោះ គាត់បានស្ងើចសរសើរយ៉ាងខ្លាំង។
[14]ក្រុមសាវកនៅក្រុងយេរូសាឡឹមបានឮដំណឹងថា អ្នកស្រុកសាម៉ារីនាំគ្នាទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ លោកក៏ចាត់លោកពេត្រុស និងលោកយ៉ូហានឲ្យទៅជួបអ្នក
ទាំងនោះ។[15]ពេលទៅដល់ស្រុកសាម៉ារី សាវកទាំងពីរបានអធិស្ឋានឲ្យពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ[16]ដ្បិតព្រះវិញ្ញាណពុំទាន់យាងចុះមកសណ្ឋិតលើអ្នកណាម្នាក់
ក្នុងចំណោមពួកគេនៅឡើយទេ គឺពួកគេគ្រាន់តែបានទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូប៉ុណ្ណោះ។[17]បន្ទាប់មក លោកពេត្រុស និងលោកយ៉ូហានបានដាក់
ដៃលើគេ ហើយពួកគេក៏បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។
[18]ពេលលោកស៊ីម៉ូនឃើញថា ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកអ្នកជឿដោយសាវកដាក់ដៃលើដូច្នោះ គាត់ក៏យកប្រាក់មកជូនសាវកទាំងពីរ[19]ហើយពោលថា៖ «សូម
លោកប្រគល់ឲ្យខ្ញុំមានអំណាចនេះផង ដើម្បីឲ្យខ្ញុំដាក់ដៃលើអ្នកណា អ្នកនោះនឹងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែរ»។
[20]តែលោកពេត្រុសតបទៅគាត់វិញថា៖ «ចូរឲ្យប្រាក់របស់អ្នកវិនាសអន្តរាយជាមួយអ្នកទៅ ព្រោះអ្នកនឹកស្មានថាអាចយកប្រាក់មកទិញព្រះអំណោយទានរបស់
ព្រះជាម្ចាស់បាន![21]អ្នកគ្មានចំណែក គ្មានសិទ្ធិអ្វីក្នុងកិច្ចការនេះឡើយ ដ្បិតចិត្តរបស់អ្នកមិនទៀងត្រង់ចំពោះព្រះជាម្ចាស់។[22]ដូច្នេះ សូមអ្នកលះបង់ចិត្តគំនិតអាក្រក់នេះ

generated on Wed Sep 10 16:16:32 2025

ចោលទៅ ហើយទូលសូមព្រះអម្ចាស់ ក្រែងលោព្រះអង្គលើកលែងទោសឲ្យអ្នកដែលមានចិត្តបែបនេះ[23]ដ្បិតខ្ញុំឃើញថាអ្នកមានចិត្តពិសពល់ ហើយក៏នៅជាប់ចំណងអំពើទុច្ចរិតដែរ»។
[24]លោកស៊ីម៉ូនតបទៅវិញថា៖ «សូមលោកទូលអង្វរព្រះអម្ចាស់ឲ្យខ្ញុំផង ដើម្បីកុំឲ្យមានហេតុអាក្រក់ណាមួយកើតឡើងចំពោះរូបខ្ញុំ ដូចលោកបានមានប្រសាសន៍នោះឡើយ»។
[25]ក្រោយពីបានផ្តល់សក្ខីភាព និងប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់រួចហើយ សាវកទាំងពីររូបក៏វិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញ ទាំងប្រកាសដំណឹងល្អក្នុងភូមិជាច្រើននៅស្រុកសាម៉ារី។
[26]ទេវតារបស់ព្រះអម្ចាស់ពោលមកកាន់លោកភីលីពថា៖ «សូមក្រោកឡើង ធ្វើដំណើរឆ្ពោះទៅទិសខាងត្បូង គឺតាមផ្លូវចុះពីក្រុងយេរូសាឡឹមទៅក្រុងកាសាជាផ្លូវស្ងាត់នោះទៅ»។[27]លោកភីលីពក៏ក្រោកឡើងចេញដំណើរទៅ។ នៅតាមផ្លូវ មានជនជាតិអេត្យូពីមួយរូបជាមនុស្សកម្រៀវ លោកជាមន្ត្រីជាន់ខ្ពស់របស់មហាក្សត្រិយានីកានដេស ដែលគ្រងរាជ្យនៅស្រុកអេត្យូពី ហើយលោកជាអ្នកកាន់កាប់ព្រះរាជទ្រព្យទាំងប៉ុន្មាន។ លោកបានមកថ្វាយបង្គំព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម[28]ហើយលោកធ្វើដំណើរវិលត្រឡប់ទៅវិញ ដោយជិះរទេះសេះទាំងអានគម្ពីរព្យាការីអេសាយ។
[29]ព្រះវិញ្ញាណមានព្រះបន្ទូលមកលោកភីលីពថា៖ «ចូរទៅមុខ រួចចូលទៅជិតរទេះសេះនោះទៅ»។[30]ដូច្នេះលោកភីលីពក៏រត់ទៅមុខ ហើយឮមន្ត្រីអេត្យូពីអានគម្ពីរព្យាការីអេសាយ លោកភីលីពសួរមន្ត្រីនោះថា៖ «តើលោកយល់សេចក្តីដែលលោកកំពុងតែអាននេះឬទេ?»។[31]លោកមន្ត្រីតបមកវិញថា៖ «ធ្វើម្តេចឲ្យខ្ញុំយល់បាន បើគ្មាននរណាពន្យល់ណែនាំសោះនោះ?»។ លោកក៏អញ្ជើញលោកភីលីពឡើងជិះរទេះសេះជាមួយ។
[32]រីឯអត្ថបទគម្ពីរដែលលោកកំពុងអាននោះ គឺថាលោកត្រូវគេនាំយកទៅដូចជាចៀមដែលគេនាំទៅសម្លាប់ លោកពុំបានហើបមាត់ទាល់តែសោះ ប្រៀបដូចជាកូនចៀមដែលស្ងៀមស្ងាត់នៅមុខអ្នកកាត់រោម។[33]លោកត្រូវគេបន្ទាបបន្ថោកហើយគេមិនរកយុត្តិធម៌ជូនលោកឡើយ។ គ្មាននរណាអាចតំណាលអំពីពូជពង្ស របស់លោកបានទេ ព្រោះគេបានដកជីវិតរបស់លោក ចេញពីផែនដីនេះបាត់ទៅហើយ»។
[34]មន្ត្រីនោះសួរលោកភីលីពថា៖ «សូមប្រាប់ខ្ញុំផង តើព្យាការីមានប្រសាសន៍ដូច្នេះ សំដៅលើអ្នកណា? តើលោកមានប្រសាសន៍អំពីខ្លួនលោកផ្ទាល់ ឬមានប្រសាសន៍អំពីអ្នកណាម្នាក់ផ្សេងទៀត?»។[35]លោកភីលីពក៏ជំរាបជូនដំណឹងល្អអំពីព្រះយេស៊ូប្រាប់លោក ដោយចាប់ផ្តើមពីអត្ថបទគម្ពីរនោះទៅ។
[36]លោកទាំងពីរចេះតែបន្តដំណើរទៅមុខ។ លុះដល់កន្លែងមួយមានទឹក លោកមន្ត្រីមានប្រសាសន៍ថា៖ «ទីនេះមានទឹក តើមានអ្វីឃាត់ខ្ញុំ មិនឲ្យទទួលពិធីជ្រមុជទឹក»។
[37]លោកភីលីពមានប្រសាសន៍ទៅលោកមន្ត្រីថា៖ «បើលោកជឿយ៉ាងស្មោះអស់ពីចិត្តនោះ លោកអាចទទួលពិធីជ្រមុជទឹកបាន»។ លោកមន្ត្រីឆ្លើយវិញថា៖ «ខ្ញុំជឿហើយថាព្រះយេស៊ូគ្រិស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់»។[38]លោកបញ្ជាឲ្យគេបញ្ឈប់រទេះសេះ។ លោកមន្ត្រី និងលោកភីលីពចុះទៅក្នុងទឹកទាំងពីរនាក់ ហើយលោកភីលីពក៏ជ្រមុជទឹកជូនមន្ត្រីនោះ។
[39]កាលលោកទាំងពីរឡើងពីទឹកមកវិញ ព្រះវិញ្ញាណនៃព្រះអម្ចាស់បានលើកលោកភីលីពយកចេញបាត់ទៅ លោកមន្ត្រីលែងឃើញលោកភីលីពទៀតហើយ។ លោកមន្ត្រីបន្តដំណើរទៅមុខដោយចិត្តត្រេកអរសប្បាយ។[40]រីឯលោកភីលីព គេបែរជាឃើញលោកនៅឯក្រុងអាសូត ហើយលោកធ្វើដំណើរពីក្រុងមួយទៅក្រុងមួយទាំងផ្សព្វផ្សាយដំណឹងល្អរហូតទៅដល់ក្រុងសេសារ។

Acts 8:1

ប្រយោគភ្ជាប់

ប្លុរសាច់រឿងពីលោកស្ទេផានមកលោកសូលវិញ នៅក្នុងខគម្ពីរទាំងនេះ។

ព័ត៌មានទូទៅ

វាអាចជាប្រយោជន៍ជាខ្លាំងដល់អ្នកស្តាប់របស់អ្នក
ក្នុងការប្តូរពីរឿងរបស់លោកស្ទេផានដោយប្រើមួយខភ្ជាប់ដូចនៅក្នុង
កំណែកណ្ឌគម្ពីរ UDB បានធ្វើ។

ដូច្នេះ មានការចាប់ផ្តើម...លើកលែងតែពួកសាវកប៉ុណ្ណោះ

នៅក្នុងខមួយនេះគឺជាប្រវត្តិអំពីការបៀតបៀនដែលបានចាប់ផ្តើមបន្ទាប់ពីការស្លាប់របស់លោកស្តេផាន។
នៅក្នុងខបី ពន្យល់ពីហេតុដែលលោកសូលបៀតបៀនដល់ពួកអ្នកជឿ។

នៅថ្ងៃនោះ

ឃ្លានេះសំដៅលើថ្ងៃដែលលោកស្ទេផានស្លាប់។ (សូមមើល: ៧:៥៩)

ពួកអ្នកជឿគ្រប់រូបបានបែកខ្ញែកគ្នា

ឃ្លានេះគឺជាទិដ្ឋភាពជាក់ស្តែង ដើម្បីបញ្ជាក់ថា
ពួកអ្នកជឿជាច្រើននាក់បានចាកចេញពីក្រុងយេរូសាឡិម ដោយការបៀតបៀន។

លើកលែងតែពួកសាវកប៉ុណ្ណោះ

ប្រយោគនេះ បញ្ជាក់ថា ពួកសាវកនៅក្នុងយេរូសាឡិម
ទោះបីជាមានការបៀតបៀនខ្លាំងយ៉ាងណាក៏ដោយ។

ពួកអ្នកដែលគោរពកោតខ្លាចព្រះជាម្ចាស់

«មនុស្សដែលកោតខ្លាចព្រះជាម្ចាស់» ឬ «បុរសដែលគោតខ្លាចព្រះជាម្ចាស់»។

ទួញសោកជាខ្លាំងចំពោះលោក

«បានយំសោកជាខ្លាំងចំពោះការស្លាប់របស់លោក»។

ចាប់ទាំងប្រុសទាំងស្រី

លោកសូលបានចាប់បង្ខំពួកអ្នកជឿជនជាតិយូដាចេញពីផ្ទះរបស់ពួកគេ
ហើយយកពួកគេទៅដាក់គុក។

ពីផ្ទះមួយទៅផ្ទះមួយ

«ពីមួយផ្ទះម្តងៗ» (UDB)

ចាប់ទាំងប្រុសទាំងស្រី

«ចាប់ទាំងប្រុសទាំងស្រីដោយប្រើកម្លាំង»

ចាប់ទាំងប្រុសទាំងស្រី

ឃ្លានេះសំដៅលើអ្នកជឿលើព្រះយេស៊ូទាំងប្រុសទាំងស្រី។

Acts 8:4

ប្រយោគភ្ជាប់

ឃ្លានេះចាប់ផ្តើមដោយរឿងរបស់លោកភីលីព
ជាម្នាក់ដែលគេបានជ្រើសរើសឲ្យធ្វើជាអ្នកបម្រើ។ (សូមមើល: ៦:៥)

ដែលបែកខ្ញែកគ្នា

ការបៀតបៀនបានធ្វើឲ្យមានការបែកខ្ញែកគ្នា បានចាប់ផ្តើមពីមុន។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបានរត់គេចពីការបៀតបៀនយ៉ាងខ្លាំង ហើយបានចេញពីផុតពីនោះ»។

បានធ្វើដំណើរចុះទៅក្រុងរបស់សាម៉ារី

ឃ្លានេះចាប់ផ្តើមដោយរឿងរបស់លោកភីលីព
ប្រើនៅទីនេះដោយសារសាម៉ារីមានកំពស់ទាបជាងក្រុងយេរូសាឡិម។

ទីក្រុងសាម៉ារី

មិនច្បាស់ ថាវាជាទីក្រុងរបស់សាសន៍សាម៉ារី ដែលហៅថា «ក្រុងសាម៉ារី» (ULB)
ឬ ទៅ «ទីក្រុងមួយនៅក្នុងសាម៉ារី» (UDB)។

ប្រកាសប្រាប់ពួកគេអំពីព្រះគ្រិស្ត

ឈ្មោះ «ព្រះគ្រិស្ត» សំដៅលើព្រះយេស៊ូ ព្រះមេស្ស៊ី។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាប់ពួកគេថា ព្រះយេស៊ូជាព្រះមេស្ស៊ី»

Acts 8:6

នៅពេលបណ្តាជនជាច្រើន

«នៅពេលមនុស្សជាច្រើននៅទីក្រុងសាម៉ារី» ទីកន្លែងបានប្រាប់ពីមុនរួចហើយ។
(សូមមើល: ៨:៤)

ពួកគេបានយកចិត្តទុកដាក់ស្តាប់

ហេតុផលដែលប្រជាជនយកចិត្តទុកដាក់ស្តាប់ដោយសារលោកភីលីបបានប្រោសមនុស្សឲ្យជា។

មានវិញ្ញាណអាក្រក់ចេញពីមនុស្សដែលវាបានចូល ដោយស្រែកឮជាខ្លាំង

«វិញ្ញាណអាក្រក់ស្រែកឡើងជាខ្លាំង នៅពេលពួកវាចេញពីមនុស្សជាច្រើន
ដែលពួកវាបានចូល»។

មានអំណរសប្បាយជាខ្លាំងនៅក្នុងក្រុងនោះ

ឃ្លា «ទីក្រុងនោះ» សំដៅលើមនុស្សដែលមានអំណរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ មនុស្សនៅទីក្រុងនោះ មានអំណរ»

Acts 8:9

ព័ត៌មានទូទៅ

មានការណែនាំលោកស៊ីម៉ូនមកក្នុងរឿងរបស់លោកភីលីព។ ខ ៩-១១
គឺជាប្រវត្តិអំពីលោកស៊ីម៉ូន និងអស់អ្នកដែលនៅក្នុងចំណោមសាសន៍សាម៉ារី។

generated on Wed Sep 10 16:16:32 2025

ប៉ុន្តែ មានបុរសម្នាក់... ឈ្មោះស៊ីម៉ូន
នេះគឺជាការណែនាំមនុស្សថ្មីមកក្នុងសាច់រឿង។
ភាសារបស់អ្នកអាចប្រើពាក្យខុសគ្នា ក្នុងការណែនាំមនុស្សថ្មីមកក្នុងសាច់រឿង។
ទីក្រុង
«ទីក្រុងនៅក្នុងសាម៉ារី» (សូមមើល: ៨:៥)
សាសន៍សាម៉ារីទាំងអស់
នេះគឺជាការនិយាយបំផ្លើស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានសាសន៍សាម៉ារីជាច្រើននៅក្នុងទីក្រុង» ។
ទាំងអ្នកតូចដល់អ្នកធំ
ឃ្លាទាំងពីរនេះ សំដៅលើមនុស្សគ្រប់គ្នា ពីអ្នកធំម្នាក់ ទៅអ្នកផ្សេងទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនសំខាន់ថាពួកគេជានរណាឡើយ» ។
លោកនេះហើយជាអំណាចរបស់ព្រះជាម្ចាស់ ដែលហៅថាមហិមា
មនុស្សនិយាយថា លោកស៊ីម៉ូនជាអំណាចមកពីព្រះ ដែលពួកគេស្គាល់ថា
«អំណាចមហិមា»
ហើយជាអំណាចរបស់ព្រះជាម្ចាស់ ដែលហៅថាមហិមា
អាចមានន័យបួនយ៉ាង ទី១) អំណាចដែលតំណាងឲ្យព្រះជាម្ចាស់។ ទី២) ព្រះជាម្ចាស់ ឬទី៣) មនុស្សដែលមានអំណាចខ្លាំងក្លា ឬទី៤) ជាទេវតា។ ពាក្យគេប្រើមិនច្បាស់ការបកប្រែដែលល្អបំផុត គឺគ្រាន់តែប្រែថា
«អំណាចដ៏មហិមារបស់ព្រះជាម្ចាស់» (UDB)។
Acts 8:12
ប្រយោគភ្ជាប់
ខគម្ពីរទាំងនេះបានផ្តល់ព័ត៌មានអំពីលោកស៊ីម៉ូន
និងសាសន៍សាម៉ារីមួយចំនួនដែលបានចូលមកជឿលើព្រះយេស៊ូ។
ទទួលពិធីជ្រមុជទឹក
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកភីលីពបានធ្វើពិធីជ្រមុជទឹកឲ្យគេ»។
លោកស៊ីម៉ូនខ្លួនឯងក៏បានជឿដែរ
ពាក្យ «ខ្លួនឯង» នៅទីនេះ ប្រើដើម្បីបញ្ជាក់ថា លោកស៊ីម៉ូនបានជឿ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកស៊ីម៉ូនក៏ជាម្នាក់នៃអស់អ្នកដេលបានជឿដែរ» ។
លោកបានទទួលពិធីជ្រមុជទឹក
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកភីលីពបានជ្រមុជទឹកឲ្យលោកស៊ីម៉ូន»
គាត់បានឃើញទីសម្គាល់
ឃ្លានេះចាប់ផ្តើមដោយប្រយោគមួយថ្មី។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលគាត់ឃើញ»
ពេលគាត់បានឃើញទីសម្គាល់ និងការអស្ចារ្យធំៗដែលកើតឡើង គាត់បានការភ្ញាក់ផ្អើលជាខ្លាំង
«លោកស៊ីម៉ូនភ្ញាក់ផ្អើលជាខ្លាំង ពេលគាត់ឃើញលោកភីលីពធ្វើការទីសម្គាល់
និងការអស្ចារ្យធំៗជាច្រើន» ។
Acts 8:14
ប្រយោគភ្ជាប់
លោកលូកាបន្តរឿងថ្មី ជាមួយនឹងអ្វីដែលបានកើតឡើងនៅស្រុកសាម៉ារី។
ឥឡូវនេះ នៅពេលពួកសាវកនៅក្រុងយេរូសាឡិមបានឮ
នៅក្នុងផ្នែកនេះ បានចាប់ផ្តើមរឿងថ្មីអំពីសាសន៍សាម៉ារីបានទទួលជឿ។
សាម៉ារី
ឃ្លានេះ សំដៅលើមនុស្សជាច្រើនដែលបានជឿ នៅក្នុងស្រុកសាម៉ារី។
បានទទួល
«បានជឿ» ឬ «បានទទួលស្គាល់»
ពេលពួកគេបានចុះទៅដល់
«នៅពេលលោកពេត្រុស និងលោកយ៉ូហានបានចុះទៅ»
ចុះទៅ
ឃ្លាដែលប្រើនៅទីនេះ
ដោយសារស្រុកសាម៉ារីមានកំពស់ទាបជាងក្រុងយេរូសាឡិម។
បានអធិស្ឋានឲ្យពួកគេ
«លោកពេត្រុស និងលោកយ៉ូហានបានអធិស្ឋានឲ្យពួកអ្នកជឿសាសន៍សាម៉ារី»។
ដើម្បីឲ្យពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ
«ដើម្បីឲ្យពួកអ្នកជឿសាសន៍សាម៉ារីបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ»។
ពួកគេបានត្រឹមតែបានទទួលពិធីជ្រមុជទឹក
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកភីលីពគ្រាន់ជ្រមុជឲ្យពួកអ្នកជឿនៅស្រុកសាម៉ារីតែប៉ុណ្ណោះ» ។
ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូប៉ុណ្ណោះ
«ព្រះនាម» នៅទីនេះ សំដៅលើព្រះយេស៊ូ ដែលសាសន៍សាម៉ារីបានជឿ។
លោកពេត្រុស និងលោកយ៉ូហានបានដាក់ដៃលើពួកគេ
ពាក្យ «ពួកគេ» សំដៅលើ សាសន៍សាម៉ារី
ដែលបានជឿលើព្រះបន្ទូលដែលលោកស្ទេផានបានប្រកាសដំណឹងល្អ។
បានដាក់ដៃលើពួកគេ
ជានិមិត្តរូបដែលបង្ហាញថា លោកពេត្រុស
និងលោកយ៉ូហានចង់ឲ្យព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់ពួកអ្នកជឿ។
Acts 8:18
ព្រះវិញ្ញាណត្រូវបានប្រទានមកអ្នកជឿដោយសារការដាក់ដៃលើរបស់ពួកសាវក
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកសាវកបានប្រគល់ព្រះវិញ្ញាណដ៏វិសុទ្ធ
ដោយការដាក់ដៃរបស់ពួកគេលើបងប្អូន។
ដើម្បីឲ្យអ្នកណាដែលខ្ញុំដាក់ដៃលើ អ្នកនោះនឹងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ
«ដើម្បីឲ្យខ្ញុំអាចប្រគល់ព្រះវិញ្ញាណដ៏វិសុទ្ធដល់អ្នកណាដែលខ្ញុំបានដាក់របស់ខ្ញុំលើគេ»។
Acts 8:20
ព័ត៌មានទូទៅ
ពាក្យ គាត់ របស់អ្នក អ្នក និងរបស់អ្នក សំដៅលើលោកស៊ីម៉ូន។
ចូរឲ្យប្រាក់របស់អ្នកវិនាសជាមួយអ្នកទៅ
«ចូរឲ្យអ្នក និងប្រាក់របស់អ្នកត្រូវវិនាសទៅ» (UDB)
អំណោយទានរបស់ព្រះជាម្ចាស់
ឃ្លានេះ
សំដៅលើលទ្ធភាពនៃការប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដោយការដាក់ដៃលើមនុស្សណាម្នាក់។
អ្នកគ្មានចំណែក ឬមិនអាចចូលរួមក្នុងកិច្ចការនេះឡើយ
ពាក្យ «ចំណែក» និង «រួមចំណែក» នៅទីនេះ មានន័យដូចគ្នា
ហើយប្រើដើម្បីបញ្ជាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនអាចចូលរួមក្នុងការងារនេះទេ» ។
ចិត្តរបស់អ្នកមិនត្រឹមត្រូវ
ពាក្យ «ចិត្ត» នៅទីនេះ សំដៅលើការគិតរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ការគិតរបស់អ្នកមិនត្រឹមត្រូវទេ»
ចំពោះបំណងចិត្តរបស់អ្នក
«ដោយសារចង់ទិញសមត្ថភាពនៃការប្រគល់ព្រះវិញ្ញាណដ៏វិសុទ្ធដល់អ្នកដទៃ»។
គំនិតអាក្រក់
«ទាំងនេះគឺជាគំនិតអាក្រក់»
ដើម្បីឲ្យព្រះអង្គអត់ទោសឲ្យអ្នក
«ព្រះអង្គអាចនឹងអត់ទោស»
មានជាតិពុលនៃភាពជូរល្វីង
ពាក្យបៀបធៀបនេះមានន័យថា «មានចិត្តច្រណែនជាខ្លាំង»
នៅក្នុងចំណងនៃអំពើបាប
ពាក្យ «បាប» នៅទីនេះ ក្នុងន័យថាវាអាចទាញគាត់ឲ្យក្លាយជាអ្នកជាប់ចំណង។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកទោសនៃអំពើបាប» ឬ
«អាចធ្វើបានតែបាបប៉ុណ្ណោះ»
Acts 8:24
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ សំដៅលើ លោកពេត្រុស និងលោកយ៉ូហាន។
កុំឲ្យអ្វីដែលលោកមានប្រសាសន៍បានកើតឡើងចំពោះខ្ញុំឡើយ
ឃ្លានេះស្ថិតនៅក្នុងដំណាក់មួយផ្សេងទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការទាំងនេះ...សូមកុំឲ្យកើតឡើងចំពោះខ្ញុំឡើយ»។
ដើម្បីកុំឲ្យអ្វីដែលលោកមានប្រសាសន៍
ឃ្លានេះសំដៅលើការដែលលោកពេត្រុសស្តីបន្ទោសអំពីប្រាក់របស់លោកស៊ីម៉ូន
នឹងត្រូវវិនាសតាមគាត់ដែរ។
Acts 8:25
ប្រយោគភ្ជាប់
រឿងនេះទាក់ទងជាមួយនឹងសាច់រឿងរបស់លោកស៊ីម៉ូន និងសាសន៍សាម៉ារី។
ធ្វើបន្ទាល់
លោកពេត្រុស
និងលោកយ៉ូហានប្រាប់ពីអ្វីដែលពួកគេបានស្គាល់ព្រះយេស៊ូដោយផ្ទាល់ដល់សាសន៍សាម៉ារី។
ថ្លែងព្រះបន្ទូលរបស់ព្រះអម្ចាស់

generated on Wed Sep 10 16:16:32 2025

លោកពេត្រុស និងលោកយ៉ូហាន
ពន្យល់ព្រះបន្ទូលរបស់ព្រះយេស៊ូដល់សាសន៍សាម៉ារី។
វិលត្រឡប់ទៅ
ឃ្លានេះ អាចជាប្រយោគថ្មី។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅតាមផ្លូវ» ឬ «នៅពេលពួកគេទៅ»
ក្នុងភូមិនានារបស់ សាសន៍សាម៉ារី
«ភូមិនានា» នៅទីនេះ សំដៅលើមនុស្សដែលរស់នៅក្នុងភូមិនោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទៅកាន់ប្រជាជនដែលរស់នៅតាមភូមិនានានៅក្នុងស្រុកសាម៉ារី»
Acts 8:26
ប្រយោគភ្ជាប់
នៅទីនេះចាប់ផ្តើមនិយាយផ្នែកមួយទៀតដែលលោកភីលីព
និងបុរសដែលមកពីអេត្យូពី។
ព័ត៌មានទូទៅ
នៅក្នុងខ ២៧ បានផ្តល់ព័ត៌មានពីប្រវត្តិរបស់បុរសដែលមកពីស្រុកអេត្យូពី។
ឥឡូវនេះ
ដើម្បីបង្កើតដំណើរផ្លាស់ប្តូរនៃសាច់រឿង។
សូមក្រោកឡើង ហើយធ្វើដំណើរឆ្ពោះទៅ
កិរិយាទាំងនេះ ធ្វើការជាមួយគ្នា ដើម្បីបញ្ជាក់ថា
លោករួចរាល់ក្នុងការចាប់ផ្តើមចេញដំណើរ ដែលនឹងចំណាយពេលមួយរយៈ។
របៀបផ្សេងទៀតនៃការបកប្រែ: «រួចរាល់ក្នុងការធ្វើដំណើរ»។
តាមផ្លូវចុះពីក្រុងយេរូសាឡិមទៅក្រុងកាសា
ឃ្លា «ចុះពី» ប្រើនៅទីនេះ ដោយសារក្រុងយេរូសាឡិមខ្ពស់ជាក្រុងកាសា។
ផ្លូវនេះស្ងាត់ណាស់
អ្នកប្រាជ្ញភាគច្រើនជឿថា លោកលូកាបន្ថែមនៅត្រង់នេះ
ដើម្បីពណ៌នាតំបន់ដែលលោកភីលីពធ្វើដំណើរ។
មើល៍
ពាក្យ «មើល៍» នៅទីនេះ រំលឹកយើងពីមនុស្សថ្មីម្នាក់នៅក្នុងសាច់រឿងនេះ។
នៅក្នុងភាសារបស់អ្នក អ្នកអាចរបៀបក្នុងការប្រើពាក្យនេះ។
មនុស្សកម្រៀវ
ការបញ្ជាក់ «មនុស្សកម្រៀវ» នៅទីនេះ
គឺនិយាយអំពីជនជាតិអេត្យូពីដែលមានឋានៈខ្ពស់នៅក្នុងរដ្ឋាភិបាល
មិនមែនលក្ខណៈនៃភេទផ្ទុយគ្នាឡើយ។
មហាក្សត្រិយានី
នេះគឺជាបរមងារសម្រាប់ម្ចាស់ក្សត្រីអេត្យូពី។
វាប្រហែលនឹងរាជឱង្ការរបស់ព្រះបាទផារោន ប្រើសម្រាប់ស្តេចនៅអេស៊ីប។
លោកបានមកក្រុងយេរូសាឡិម ដើម្បីថ្វាយបង្គំព្រះជាម្ចាស់
នេះបង្ហាញថាគាត់ជាសាសន៍ដទៃ ដែលជឿលើព្រះជាម្ចាស់
ហើយបានមកថ្វាយបង្គំព្រះនៅព្រះវិហាររបស់ជនជាតិយូដា។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានមកថ្វាយបង្គំនៅព្រះវិហារក្រុងយេរូសាឡិម»។
រទេះសេះ
អាចជា «រទេះមានកង់បួន» ឬ «រទេះសេះកង់បួន» ស៊ីចង្វាក់នៅក្នុងបរិបទនេះ។
រទេះសេះជាទូទៅនិយាយប្រៀបដូចជាយានយន្តសម្រាប់ធ្វើសង្គ្រាម
មិនមែនជារថយន្តសម្រាប់ធ្វើដំណើរផ្លូវឆ្ងាយទេ។
ហើយមនុស្សឈរបររានៅលើរទេះសេះនោះ។
ព្រមទាំងអានគម្ពីរព្យាការីអេសាយផង
នេះគឺជាកណ្ឌគម្ពីរអេសាយ នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «កំពុងអានចេញពីកណ្ឌគម្ពីរព្យាការីអេសាយ»។
Acts 8:29
ចូលទៅជិតរទេះសេះ
លោកភីលីពយល់ថា គាត់ត្រូវទៅឈរនៅជិតអ្នកដែលជិះរទេះសេះនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទៅរួមដំណើរជាមួយអ្នកនោះនៅលើរទេះសេះ»។
តើលោកយល់អ្វីដែលលោកកំពុងតែអាននេះទេ?
ជនជាតិអេត្យូពីជាមនុស្សឆ្លាត ហើយអាចអាន ប៉ុន្តែ ខ្វះការយល់ដឹខាងវិញ្ញាណ។
របៀបផ្សេងទៀតនៃការបកប្រែ: «តើលោកយល់អត្ថន័យដែលលោកបានអានទេ?»
តើខ្ញុំអាចយល់ដូចម្តេចបាន ទាល់តែមាននរណាម្នាក់ណែនាំខ្ញុំ?
សំណួរនេះត្រូវបានសួរដើម្បីបញ្ជាក់ថា គាត់មិនយល់ទេ ទាល់តែមានអ្នកជួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនអាចយល់បានទេ
ទាល់តែមាននរណាម្នាក់ណែនាំខ្ញុំ»
លោកក៏សូមឲ្យលោកភីលីពឡើងជិះរទេះសេះ...អង្គុយជាមួយគាត់
ឃ្លានៅទីនេះ បញ្ជាក់ថា លោកភីលីពយល់ព្រមធ្វើដំណើរជាមួយលោក
ដើម្បីពន្យល់ពីបទគម្ពីរ។
Acts 8:32
ព័ត៌មានទូទៅ
អត្ថបទគម្ពីរនេះ ដកស្រង់ចេញពីកណ្ឌគម្ពីរអេសាយ។
ព័ត៌មានទូទៅ
ពាក្យ «លោក» និង «របស់លោក» នៅទីនេះ សំដៅលើព្រះមេស្ស៊ី។
ដូចជាចៀមដែលគេនាំទៅសម្លាប់ និងដូចជាកូនចៀមដែលស្ងៀមនៅមុខអ្នកកាត់រោមដែរ
អ្នកកាត់រោមគឺជាមនុស្សដែលកាត់រោមរបស់ចៀម ដើម្បីយកទៅប្រើ។
នៅពេលគេបន្ទាបបន្ថោកលោក គេមិនបានរកយុត្តិធម៌ជូនលោកទេ។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកត្រូវគេបន្ទាបបន្ថោក ហើយពួកគេមិនបានកាត់ក្តីឲ្យលោកដោយសុចរិតទេ»
។
តើនរណាអាចតំណាលអំពីពូជពង្សរបស់លោកបាន?
សំណួរនេះប្រើដើម្បីបញ្ជាក់ថា លោកគ្មានពូជពង្សទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាអាចនិយាយទៅកាន់ពូជពង្សរបស់លោកឡើយ ដ្បិត
គ្មាននរណាសោឡើយ» ។
ជីវិតរបស់លោកបានដកចេញពីផែនដីហើយ
នេះសំដៅលើការសុគតរបស់លោក។ ឃ្លានេះអាចស្ថិតនៅក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «គេសម្លាប់លោក» ឬ
«គេនឹងយកជីវិតលោកពីផែនដីទៅ»
Acts 8:34
សូមប្រាប់ខ្ញុំផង
«សូមមេត្តាប្រាប់ខ្ញុំផង»
ពីខ្លួនលោកផ្ទាល់ ឬពីអ្នកណាម្នាក់ផ្សេងទៀត
នេះអាចជាប្រយោជន៍ដល់អ្នកស្តាប់របស់អ្នកក្នុងបន្ថែមពណ៌មានដែលបានបាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «តើនេះ ព្យាការីនិយាយពីខ្លួនគាត់
ឬគាត់និយាយពីមនុស្សផ្សេងទៀត»
នៅក្នុងអេសាយ
ឃ្លានេះសំដៅលើការសរសេររបស់កណ្ឌគម្ពីរអេសាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងសំណេររបស់លោកអេសាយ» ។
ប្រកាស់ពីដំណឹងល្អព្រះយេស៊ូដល់លោក
«ដើម្បីបង្រៀនពីដំណឹងល្អអំពីព្រះយេស៊ូដល់មនុស្សកម្រៀវនោះ»។
Acts 8:36
ពួកគេធ្វើដំណើរតាមផ្លូវ
«ពួកគេបានបន្តដំណើរតាមផ្លូវនោះ»
កន្លែងមួយមានទឹក
«ទឹក» ជាគឺអូរ ឬជាថ្លុកទឹក ឬជាស្ទឹងធំមួយ។
យើងមិនដឹងថាវាជ្រៅល្មមឲ្យពួកគេអាចចុះងូតទឹកនោះទេ។
ចូរជ្រើសរើសពាក្យដែលត្រូវជាមួយនឹងភាសារបស់អ្នក។
តើមានអ្វីឃាត់ខ្ញុំ មិនឲ្យទទួលពិធីជ្រមុជទឹកបាន?
អ្នកកម្រៀវប្រើសំណួរនេះ ជាវិធីក្នុងការសួរលោកភីលីព
ដើម្បីសុំឲ្យគាត់ជ្រមុជទឹកឲ្យ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមអនុញ្ញាតឲ្យខ្ញុំជ្រមុជទឹកផង»
បានបញ្ជារទេះសេះឲ្យឈប់
«ប្រាប់អ្នកបររទេះសេះឲ្យឈប់»
Acts 8:39
ប្រយោគភ្ជាប់
នេះគឺជាចំណុចបញ្ចប់សាច់រឿងអំពីលោកភីលីព
និងបុរសម្នាក់ដែលមកពីស្រុកអេត្យូពីហើយ។
សាច់រឿងរបស់លោកភីលីពបញ្ចប់នៅក្រុងសេសារ។
មនុស្សកម្រៀវក៏លែងឃើញលោកទៀត
«អ្នកកម្រៀវលែងឃើញលោកភីលីពទៀត»
លោកភីលីពបានបង្ហាញខ្លួននៅឯក្រុងអាសូតវិញ
មិនមានការបញ្ជាក់ថា
លោកភីលីពធ្វើដំណើរបន្ទាប់ពីជ្រមុជទឹកឲ្យសាសន៍អេត្យូពីហើយ

generated on Wed Sep 10 16:16:32 2025

និងទៅក្រុងអាសូត។ គាត់គ្រាន់តែបង្ហាញខ្លួននៅតាមផ្លូវទៅកាសា
និងបង្ហាញខ្លួនម្តងទៀតនៅក្រុងអាសូត។
តំបន់នោះ

ឃ្លានេះ សំដៅលើតំបន់ដែលនៅជុំវិញក្រុងអាសូត។
គ្រប់ទីក្រុងទាំងអស់
«ទៅគ្រប់ទីក្រុងទាំងអស់នៅក្នុងតំបន់នោះ»។

---

9 [1]ប៉ុន្តែ លោកសូលគិតតែពីគំរាមកំហែង និងសម្លាប់សិស្សរបស់ព្រះអម្ចាស់ជានិច្ច ហើយគាត់ទៅជួបលោកមហាបូជាចារ្យ[2]រួចសុំលិខិតអនុញ្ញាតចូលទៅក្នុងសាលាប្រជុំ
នានានៅក្រុងដាម៉ាស ក្រែងរកឃើញអ្នកខ្លះនៅទីនោះ ដែលដើរតាមមាគ៌ារបស់ព្រះអម្ចាស់ ទោះជាប្រុស ឬស្ត្រីក្តី គាត់នឹងចាប់ចងនាំយកមកក្រុងយេរូសាឡឹម។
[3]ពេលគាត់ធ្វើដំណើរទៅជិតដល់ក្រុងដាម៉ាសហើយ ស្រាប់តែមានពន្លឺមួយចាំងពីផ្ទៃមេឃមកជុំវិញគាត់[4]រួចគាត់ក៏ដួលហើយឮសូរសំឡេងមួយពោលមកគាត់ថា៖ «សូល
អើយសូល! ហេតុដូចម្តេចបានជាអ្នកបៀតបៀនខ្ញុំ?»។
[5]លោកសូលសួរវិញថា៖ «លោកម្ចាស់អើយ! តើលោកជានរណា?»។ សំឡេងនោះក៏ឆ្លើយឡើងថា៖ «ខ្ញុំជាយេស៊ូដែលអ្នកកំពុងតែបៀតបៀន។[6]ចូរក្រោកឡើង ហើយចូល
ទៅក្នុងទីក្រុង នៅទីនោះនឹងមានគេប្រាប់អ្នកថា ត្រូវធ្វើអ្វីខ្លះ»។[7]រីឯអស់អ្នកដែលបានធ្វើដំណើរជាមួយលោកសូល នាំគ្នាឈរស្ងៀមរកនិយាយអ្វីមិនកើត ព្រោះគេបានឮ
សំឡេង តែពុំឃើញមាននរណាឡើយ។
[8]លោកសូលក្រោកឡើង ហើយនៅពេលគាត់បើកភ្នែក ស្រាប់តែគាត់មើលអ្វីមិនឃើញសោះ។ គេដឹកដៃគាត់នាំចូលទៅក្នុងក្រុងដាម៉ាស។[9]ក្នុងរយៈពេលបីថ្ងៃ គាត់មិនអាច
មើលឃើញ ហើយក៏មិនបានពិសាបាយពិសាទឹកដែរ។
[10]នៅក្រុងដាម៉ាស មានសិស្សម្នាក់ឈ្មោះអាណាណាស។ ព្រះអម្ចាស់មានព្រះបន្ទូលមកគាត់ក្នុងនិមិត្តមួយថា៖ «អាណាណាស!»។ គាត់ទូលតបថា៖ «ក្រាបទូល
ព្រះអម្ចាស់!»។[11]ព្រះអម្ចាស់មានព្រះបន្ទូលមកគាត់ថា៖ «ចូរក្រោកឡើង ទៅឯផ្លូវមួយឈ្មោះ «ផ្លូវត្រង់» សួររកឈ្មោះសូល ជាអ្នកស្រុកតើសុសនៅក្នុងផ្ទះយូដាស
នៅទីនោះគាត់កំពុងតែអធិស្ឋាន។[12]សូលបាននិមិត្តឃើញបុរសម្នាក់ ឈ្មោះអាណាណាសចូលមកដាក់ដៃលើគាត់ ដើម្បីឲ្យគាត់មើលឃើញឡើងវិញ»។
[13]តែលោកអាណាណាសទូលព្រះអង្គវិញថា៖ «បពិត្រព្រះអម្ចាស់! ទូលបង្គំបានឮមនុស្សជាច្រើននិយាយថា បុរសនេះបានធ្វើបាបប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គនៅក្រុង
យេរូសាឡឹមជាខ្លាំង។[14]គាត់បានទទួលការអនុញ្ញាតពីលោកមហាបូជាចារ្យឲ្យមកទីនេះ ដើម្បីចាប់ចងអស់អ្នកដែលអង្វររកព្រះនាមព្រះអង្គ»។[15]ប៉ុន្តែ ព្រះអម្ចាស់មាន
ព្រះបន្ទូលមកគាត់វិញថា៖ «អញ្ជើញទៅចុះ! ដ្បិតខ្ញុំជ្រើសរើសបុរសនេះ ដើម្បីប្រើគាត់ឲ្យទៅប្រាប់ប្រជាជាតិ និងស្តេចនានា ព្រមទាំងប្រាប់ជនជាតិអ៊ីស្រាអែលឲ្យស្គាល់
ឈ្មោះខ្ញុំ។[16]ខ្ញុំនឹងបង្ហាញប្រាប់គាត់ឲ្យដឹងថា គាត់ត្រូវរងទុក្ខលំបាកជាច្រើន ព្រោះតែឈ្មោះរបស់ខ្ញុំ»។
[17]ដូច្នេះ លោកអាណាណាសក៏ចេញទៅ ហើយបានចូលទៅក្នុងផ្ទះនោះ។ គាត់ដាក់ដៃលើលោកសូល ហើយមានប្រសាសន៍ថា៖ «បងសូលអើយ! ព្រះអម្ចាស់យេស៊ូដែល
បងបានឃើញនៅតាមផ្លូវបងធ្វើដំណើរមកនោះ ទ្រង់បានចាត់ខ្ញុំមក ដើម្បីអោយបងអាចមើលឃើញឡើងវិញ និងអោយបងបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ»។
[18]រំពេចនោះ មានអ្វីមួយដូចស្រកាត្រីជ្រុះពីភ្នែកលោកសូល លោកក៏មើលឃើញឡើងវិញ លោកក្រោកឡើង ហើយបានទទួលពិធីជ្រមុជទឹក។[19]បន្ទាប់មក លោកបរិភោគ
ម្ហូបអាហារ ហើយមានកម្លាំងឡើងវិញ។ លោកបានស្នាក់នៅជាមួយពួកសិស្សនៅក្រុងដាម៉ាសអស់ពេលបួនដប់ថ្ងៃ។
[20]លោកចាប់ផ្តើមប្រកាសនៅក្នុងសាលាប្រជុំនានាភ្លាមថា ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។[21]អស់អ្នកដែលបានឮលោកមានប្រសាសន៍ នឹកស្ងើច គេពោលថា៖
«លោកនេះហើយមែនទេដែលបានធ្វើទុក្ខបៀតបៀន អស់អ្នកដែលអង្វររកឈ្មោះយេស៊ូនៅក្រុងយេរូសាឡឹម? គាត់មកទីនេះរកចាប់ចងគេនាំទៅជូន នាយកបូជាចារ្យទេ
តើ»។[22]រីឯលោកសូលវិញ លោកមានកម្លាំងចិត្តកាន់តែខ្លាំងឡើងៗ ហើយលោកវែកញែកប្រាប់សាសន៍យូដា នៅក្រុងដាម៉ាសដោយអះអាងច្បាស់ថា ព្រះយេស៊ូពិតជា
ព្រះគ្រិស្ត។
[23]ប៉ុន្មានថ្ងៃក្រោយមក ជនជាតិយូដាបានសមគំនិតគ្នារកសម្លាប់លោកសូល[24]តែលោកបានជ្រាបគម្រោងការរបស់គេ។ ពួកគេបាននាំគ្នាទៅចាំនៅទ្វារក្រុងទាំងយប់ទាំង
ថ្ងៃដើម្បីសម្លាប់លោក។[25]ប៉ុន្តែ នៅពេលយប់ ពួកសិស្សរបស់លោកបានដាក់លោកក្នុងជាលមួយ សម្រូតលោកចុះទៅខាងក្រៅកំពែងក្រុង។
[26]កាលលោកសូលមកដល់ក្រុងយេរូសាឡឹម លោកចង់ចូលរួមជាមួយពួកសិស្ស តែពួកគេខ្លាចលោកទាំងអស់គ្នា ព្រោះគេពុំជឿថាលោកជាសិស្សនោះឡើយ។[27]តែលោក
បារណាបាសបានទទួលលោក ហើយនាំទៅជួបក្រុមសាវកទាំងរៀបរាប់អំពីលោកសូលបានឃើញព្រះអម្ចាស់នៅតាមផ្លូវ អំពីព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោក
ហើយនឹងរៀបរាប់អំពីលោកសូលមានប្រសាសន៍ដោយចិត្តអង់អាចក្នុងព្រះនាមព្រះយេស៊ូនៅក្រុងដាម៉ាសផងដែរ។
[28]ចាប់តាំងពីពេលនោះមក លោកសូលតែងតែជួបក្រុមសាវក នៅពេលពួកគេចុះឡើងក្រុងយេរូសាឡឹម។ លោកបានមានប្រសាសន៍ដោយចិត្តអង់អាចក្នុងព្រះនាម
ព្រះអម្ចាស់ថែមទៀតផង[29]ហើយលោកបានជជែកវែកញែកជាមួយសាសន៍យូដាដែលនិយាយភាសាក្រិក តែពួកគេបែរជានាំគ្នាប៉ុនប៉ងសម្លាប់លោកទៅវិញ។[30]កាលពួក
បងប្អូនបានជ្រាបដំណឹងនេះ គេនាំលោកទៅក្រុងសេសារា ហើយបន្ទាប់មកបញ្ជូនលោកទៅក្រុងតើសុស។
[31]ក្រុមជំនុំក្នុងស្រុកយូដា ស្រុកកាលីឡេ និងស្រុកសាម៉ារីបានប្រកបដោយសេចក្តីសុខសាន្ត។ ក្រុមជំនុំមានជំហរកាន់តែមាំមួនឡើងៗ ហើយពួកគេរស់នៅដោយគោរព
កោតខ្លាចព្រះអម្ចាស់ ព្រមទាំងមានចំនួនកើនឡើងជាលំដាប់ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជួយលើកទឹកចិត្តគេផង។[32]កាលលោកពេត្រុសបានធ្វើដំណើរទៅគ្រប់ទី
កន្លែង។ លោកបានចុះទៅសួរសុខទុក្ខប្រជាជនដ៏វិសុទ្ធនៅក្រុងលីដា។
[33]នៅក្រុងនោះ លោកឃើញបុរសម្នាក់ឈ្មោះអេណាស ឈឺក្រោកមិនរួច គាត់ដេកជាប់នឹងគ្រែជ្រាំបីឆ្នាំមកហើយ។[34]លោកពេត្រុសមានប្រសាសន៍ទៅគាត់ថា៖ «អេណាស
អើយ! ព្រះយេស៊ូគ្រិស្តប្រោសអ្នកឲ្យបានជាហើយ។ ចូរក្រោកឡើង រៀបចំគ្រែអ្នកទៅ!» ហើយលោកអេណាសក៏ក្រោកឡើងភ្លាម។[35]អ្នកក្រុងលីដាទាំងអស់ និងអ្នកស្រុក
នៅតំបន់សារ៉ូនបានឃើញគាត់ជាដូច្នេះ ពួកគេក៏បែរចិត្តគំនិតមករកព្រះអម្ចាស់។
[36]នៅក្រុងយ៉ុបប៉េ មានស្ត្រីម្នាក់ ឈ្មោះតេប៊ីថា ភាសាក្រិកថា «ឌ័រកាស» នាងជាសិស្សដែរ នាងតែងប្រព្រឹត្តអំពើល្អ និងធ្វើទានជាច្រើន។[37]នៅគ្រានោះ នាងមានជំងឺ ហើយ
ស្លាប់ទៅ។ គេបានលាងសពរបស់នាងតម្កល់ទុកនៅបន្ទប់ខាងលើ។
[38]ដោយសារក្រុងលីដានៅជិតក្រុងយ៉ុបប៉េ ដូច្នេះពួកសិស្សឮដំណឹងថា លោកពេត្រុសស្ថិតនៅឯក្រុងលីដានោះ គេចាត់បុរសពីរនាក់ឲ្យទៅអញ្ជើញលោកថា៖ «សូមលោក
មេត្តាប្រញាប់ធ្វើដំណើរបង្ហួសទៅកន្លែងយើងខ្ញុំផង»។[39]លោកពេត្រុសក៏ចេញដំណើរមកជាមួយអ្នកទាំងពីរនោះភ្លាម។ ពេលលោកមកដល់ គេបានអញ្ជើញលោកឡើងទៅ
បន្ទប់ខាងលើ ស្ត្រីមេម៉ាយទាំងប៉ុន្មានបាននាំគ្នាចូលមកជិតលោកទាំងយំសោក និងបង្ហាញអាវវែង និងអាវក្រៅដែលនាងឌ័រកាសបានដេរ កាលនាងរស់នៅជាមួយគេនៅ
ឡើយ។
[40]លោកពេត្រុសសុំឲ្យគេចេញទៅក្រៅបន្ទប់ទាំងអស់គ្នា រួចលោកលុតជង្គង់អធិស្ឋាន។ បន្ទាប់មក លោកបែរទៅរកសព មានប្រសាសន៍ថា៖ «តេប៊ីថាអើយ ក្រោកឡើង!»។
ពេលនោះ នាងក៏បើកភ្នែក ហើយកាលនាងបានឃើញលោកពេត្រុស នាងក្រោកអង្គុយ។[41]លោកចាប់ដៃនាងឲ្យក្រោកឈរ ហើយហៅពួកអ្នកជឿ និងស្ត្រីមេម៉ាយឲ្យចូល
មកបង្ហាញនាងឌ័រកាស ដែលមានជីវិតរស់ឲ្យគេឃើញ។[42]អ្នកក្រុងយ៉ុបប៉េទាំងប៉ុន្មានបានដឹងរឿងនេះ ហើយច្រើននាក់ជឿលើព្រះអម្ចាស់។[43]លោកពេត្រុសស្នាក់នៅក្រុង
យ៉ុបប៉េជាយូរថ្ងៃទៅទៀត ក្នុងផ្ទះបុរសម្នាក់ឈ្មោះស៊ីម៉ូនជាអ្នកសម្លាប់ស្បែក។

Acts 9:1
ប្រយោគភ្ជាប់
សាច់រឿងបានប្តូរមករកលោកសូល ហើយនិងសេចក្តីសង្គ្រោះរបស់លោកវិញ។
ព័ត៌មានទូទៅ
នៅក្នុងខទាំងនេះ

ផ្តល់ព័ត៌មានពីប្រវត្តិដែលប្រាប់ពីយើងពីអ្វីដែលលោកប៉ូលបានធ្វើតាំងពីគាត់បានចោលលោកស្ទេផាននឹង
ព័ត៌មានទូទៅ
ពាក្យ «លោក» សំដៅលើមហាបូជាចារ្យ និង «លោក» នេះ
សំដៅលើលោកសូល។
រហូតដល់សម្លាប់ពួកសិស្សរបស់ព្រះអម្ចាស់ទៀតផង

generated on Wed Sep 10 16:16:32 2025

ពាក្យ «សម្លាប់» អាចបកប្រែជាកិរិយាសព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅតែនិយាយគំរាមកំហែង រហូតដល់សម្លាប់ពួកសិស្សផង»។
ចូលទៅក្នុងសាលាប្រជុំ
ឃ្លានេះ សំដៅលើមនុស្សនៅក្នុងសាលាប្រជុំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីចាប់មនុស្សនៅក្នុងសាលាប្រជុំ» ឬ
«ដើម្បីចាប់អ្នកដឹកនាំនៅក្នុងសាលាប្រជុំ» ។
ដើម្បីរកឃើញអ្នកខ្លះនៅទីនោះ
«ពេលលោកឃើញនរណាម្នាក់» ឬ «ប្រសិនបើលោកឃើញនរណាម្នាក់»
ដែលដើរតាមផ្លូវរបស់ព្រះអម្ចាស់
«ដែលដើរតាមសេចក្តីបង្រៀនរបស់ព្រះយេស៊ូគ្រិស្ត»។
ផ្លូវ
ពាក្យនេះ លេចឡើង ជាងារសម្រាប់គ្រិស្តបរិសទនៅសម័យនោះ។
គាត់នឹងចាប់ចងពួកគេនាំយកមកក្រុងយេរូសាឡិម
«លោកនឹងចាប់ពួកគេទៅដាក់គុកនៅក្រុងយេរូសាឡិម»។ គោលបំណងលោកប៉ូល
អាចច្បាស់ថែមទៀតដោយបន្ថែម «ដើម្បីឲ្យអ្នកដឹកនាំជនជាតិយូដាអាចកាត់ក្តី
ហើយដាក់ទោសពួកគេ» ។
Acts 9:3
ប្រយោគភ្ជាប់
បន្ទាប់ពី មហាបូជាចារ្យប្រគល់សំបុត្រដល់លោកសូល
លោកសូលបានចេញទៅក្រុងដាម៉ាស។
ពេលគាត់ចូលទៅជិតក្រុងដាម៉ាស
លោកសូលបានចេញពីក្រុងយេរូសាឡិម
ហើយឥឡូវនេះគាត់បានធ្វើដំណើរទៅក្រុងដាម៉ាស។
រំពេចនោះ
ឃ្លានេះបញ្ជាក់ថា ជាចំណុចផ្លាស់ប្តូរនៅក្នុងសាច់រឿង
ដើម្បីបង្ហាញពីអ្វីដែលបានកើតឡើងផ្សេងទៀត ។
មានពន្លឺមួយចាំងមកជុំវិញលោក ពីស្ថានសួគ៌មក
«ពន្លឺមួយពីស្ថានសួគ៌បានចាំងនៅជុំវិញគាត់»។
ពីស្ថានសួគ៌មក
មានន័យពីរ ទី១) ស្ថានសួគ៌ជាកន្លែងដែលព្រះជាម្ចាស់គង់នៅ ឬទី២) ជាមេឃ។
ន័យទីមួយគឺល្អជាង។ សូមប្រើន័យនេះ
ប្រសិនបើភាសារបស់អ្នកមានពាក្យដោយឡែកទៀត។
លោកក៏ដួលនៅលើដី
អាចមានន័យបីយ៉ាង ទី១) «លោកសូលផ្តួលខ្លួនឯងទៅនឹងដី» ឬទី២)
«ពន្លឺបានធ្វើឲ្យគាត់ដួលទៅដី» ឬទី៣)
«លោកសូលដួលទៅដីដោយសារដួលសន្លប់»។
លោកសូលមិនបានដួលដោយចៃដន្យទេ។
ហេតុអ្វីបានជាអ្នកបៀតបៀនខ្ញុំ?
នេះជាសំណួរដែលមិនទាមទារចម្លើយ ដើម្បីនិយាយដាស់តឿនដល់លោកសូល។
នៅក្នុងភាសាខ្លះ ប្រើប្រយោគសាមញ្ញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើអ្នកបៀតបៀនខ្ញុំ!» ឬ ជាការបង្គាប់។ របៀបបកប្រែខ្លះទៀតថា:
«ឈប់បៀតបៀនខ្ញុំទៅ!»
Acts 9:5
ប្រយោគភ្ជាប់
គ្រប់ទាំងពាក្យដែលនិយាយថា «អ្នក» នៅទីនេះ ជាឯកវចន:
លោកម្ចាស់អើយ! តើលោកជានរណា?
លោកសូលមិនទទួលស្គាល់ថា ព្រះយេស៊ូជាព្រះអម្ចាស់ទេ។
លោកប្រើងារនេះដោយសារលោកយល់ថា
លោកនិយាយជាមួយនរណាម្នាក់ដែលមានអំណាចខាងវិញ្ញាណ។
ប៉ុន្តែ ចូរក្រោកឡើង ចូលទៅក្នុងទីក្រុង
«ក្រោកឡើង ហើយចូលទៅក្នុងទីក្រុងដាម៉ាសទៅ»
គេនឹងប្រាប់អ្នកថា
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងមានគេប្រាប់អ្នក»
ឮសម្លេង ប៉ុន្តែ គ្មានឃើញមាននរណាឡើយ
«ពួកគេឮសម្លេង ប៉ុន្តែ ពួកគេមិនឃើញនរណាម្នាក់ឡើយ»។
ប៉ុន្តែ គ្មានឃើញមាននរណាឡើយ
«ប៉ុន្តែ មិនឃើញនរណាម្នាក់ឡើយ»។
មានតែលោកសូលទេដែលមានបទពិសោធន៍ជាមួយពន្លឺនោះ។
Acts 9:8
ពេលលោកបើកភ្នែករបស់លោក
ឃ្លានេះបញ្ជាក់ថា លោកបានបិទភ្នែករបស់លោក ដោយសារពន្លឺភ្លឺខ្លាំងពេក។
លោកមើលអ្វីមិនឃើញសោះ
«លោកមិនអាចមើលអ្វីឃើញទេ»។ លោកសូលខ្វាក់ភ្នែក។
មិនអាចមើលឃើញ
«បានខ្វាក់ភ្នែក» ឬ «មិនអាចមើលអ្វីឃើញទេ» (UDB)
លោកក៏មិនបានហូបបាយ ឬក៏ពិសាទឹកដែរ
នេះមិនមែនជាស្ថានភាពនៃការមិនផឹកឬមិនហូប
នៅក្នុងទម្រង់ជាការថ្វាយបង្គំព្រះឡើយ ឬ លោកមិនបានទូលអង្វរអ្វីដែរ
ព្រោះលោកតានតឹងខ្លាំងពេក ពីហេតុការណ៍ដែលលោកបានជួប។ ជាការល្អ
បើយើងមិនបញ្ជាក់ពីហេតុផល។
Acts 9:10
ព័ត៌មានទូទៅ
សាច់រឿងរបស់លោកសូលនៅតែបន្តប៉ុន្តែ
លោកលូកាបានណែនាំបុរសម្នាក់ទៀតឈ្មោះលោកអាណាណាស។
នេះមិនមែនជាអាណាណាសដែលស្លាប់នៅក្នុងកិច្ចការ ៥:៣ ទេ។
អ្នកអាចប្រែវាដូចអ្នកប្រែនៅក្នុងកិច្ចការ ៥:៣ដែរ។
ព័ត៌មានទូទៅ
នៅទីនេះ ទោះបីលោកយូដាសបាននិយាយលើសពីម្នាក់នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី
នៅទីនេះនិយាយតែលោកយូដាតែមួយទេ។
ឥឡូវនេះ មានសិស្សម្នាក់
ឃ្លានេះកំពុងណែនាំលោកអាណាណាស ជាតួអង្គមួយថ្មី។
គាត់ទូលតបថា
«លោកអាណាណាសទូលតបថា»
ចូរក្រោកឡើង ហើយទៅតាមផ្លូវមួយឈ្មោះ ផ្លូវត្រង់
«ទៅតាមផ្លូវត្រង់» (UDB)
ផ្ទះយូដាស
លោកយូដាសនេះ មិនជាសិស្សដែលក្បត់ព្រះយេស៊ូទេ។
លោកយូដាសនេះជាម្ចាស់ផ្ទះនៅក្នុងក្រុងដាម៉ាស
ជាកន្លែងដែលលោកប៉ូលស្នាក់នៅ។
បុរសម្នាក់មកពីស្រុកតើសុស ឈ្មោះសូល
«មានបុរសម្នាក់មកពីក្រុងតើសុស ឈ្មោះសូល» ឬ «លោកសូល
អ្នកក្រុងតើសុ ុស»
ចូលមកដាក់ដៃលើលោក
នេះគឺជានិមិត្តរូបនៃការឲ្យពរខាងវិញ្ញាណដល់លោកសូល។
លោកមើលឃើញឡើងវិញ
«អាចមើលឃើញសារជាថ្មី»
Acts 9:13
ប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ
«ប្រជារាស្ត្រដ៏វិសុទ្ធ» នៅទីនេះ សំដៅលើគ្រិស្តបរិស័ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សនៅក្នុងក្រុងយេរូសាឡិម
ដែលជឿលើព្រះអង្គ» (UDB)។
បានទទួលសិទ្ធិអំណាច...ដើម្បីចាប់ចងអស់អ្នកដែលអង្វររកព្រះនាមព្រះអង្គនៅទីនេះ
ឃ្លានេះបង្ហាញ
ពីសិទ្ធិអំណាចដែលលោកសូលទទួលបានមានដែនកំណត់ចំពោះជនជាតិយូដានៅត្រង់ចំណុចនេះ។
អង្វររកព្រះនាមព្រះអង្គ
ពាក្យ «ព្រះនាមព្រះអង្គ» នៅទីនេះ សំដៅលើព្រះយេស៊ូ។
លោកគឺជាភាជន:ដែលខ្ញុំបានជ្រើសរើស
«ជាភាជន:ដែលបានជ្រើសរើស»
សំដៅលើអ្វីមួយដែលបានញែកដោយឡែកសម្រាប់ការបម្រើ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានជ្រើសរើសគាត់ដើម្បីបម្រើយើង» ។
នាំឈ្មោះខ្ញុំ
ឃ្លានេះសម្រាប់បញ្ជាក់ ឬនិយាយពីព្រះនាមព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីឲ្យគាត់អាចនិយាយពីខ្ញុំ» (UDB) ។
ដោយព្រោះតែឈ្មោះរបស់ខ្ញុំ
ឃ្លាមួយនេះមានន័យថា «សម្រាប់ប្រាប់មនុស្សអំពីខ្ញុំ»
Acts 9:17
ប្រយោគភ្ជាប់

generated on Wed Sep 10 16:16:32 2025

លោកអាណាណាសបានទៅផ្ទះដែលលោកសូលស្នាក់នៅ។ បន្ទាប់មក
លោកសូលបានជា សាច់រឿងបានប្តូរពីលោកអាណាណាសមកលោកសូលវិញ។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ ជាឯកវចន: និងសំដៅលើលោកសូល។ (សូមមើល: formsofyou-singular)
ដូច្នេះ លោកអាណាណាសបានចេញទៅ ហើយបានចូលទៅក្នុងផ្ទះនោះ
វាអាចជួយបានច្រើនក្នុងការនិយាយថា លោកអាណាណាសទៅផ្ទះ
មុនពេលគាត់ចូលទៅក្នុងផ្ទះនោះ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
លោកអាណាណាសបានចេញទៅ
ហើយបន្ទាប់មកបានឃើញផ្ទះដែលលោកសូលស្នាក់នៅនោះ
លោកក៏ចូលទៅ» (UDB)។
ដាក់ដៃរបស់លោកលើលោក
លោកអាណាណាសបានដាក់ដៃលើលោកសូល។
នេះជានិមិត្តរូបនៃការឲ្យពរដល់លោកសូល។
ដើម្បីឲ្យបងអាចមើលឃើញឡើងវិញ និងឲ្យបងបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «បានចាត់ខ្ញុំមក
ដើម្បីឲ្យបងអាចមើលឃើញជាថ្មី
ហើយបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធក្នុងបង» ។
មានអ្វីមួយដូចស្រកាត្រី
«អ្វីមួយដែលលេចមកដូចជាស្រកាត្រី»
លោកក៏មើលឃើញឡើងវិញ
«លោកអាចមើលឃើញវិញម្តងទៀត»
លោកបានក្រោកឡើង ហើយបានទទួលពិធីជ្រមុជទឹក
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានក្រោកឡើង ហើយលោកអាណាណាសបានជ្រមុជទឹកឲ្យគាត់»
Acts 9:20
ព័ត៌មានទូទៅ
នៅទីនេះមានពាក្យ «គាត់» លើកទីពីរ សំដៅលើព្រះយេស៊ូ បុត្ររបស់ព្រះជាម្ចាស់។
ហើយពាក្យ «គាត់» ទីមួយ និងផ្សេងទៀតសំដៅលើលោកសូល។
បុត្ររបស់ព្រះជាម្ចាស់
នេះគឺជាងារយ៉ាងសំខាន់សម្រាប់ព្រះយេស៊ូ
អស់អ្នកដែលបានឮលោក
ឃ្លានេះ ទិដ្ឋភាពជាក់ស្តែងគឺ «មនុស្សជាច្រើនបានឮ»។ ប្រសិនបើ
អ្នកពន្យល់បំផ្លើសផ្សេងទៀត ដូច្នេះ ចូរប្រើតាមទម្រង់របស់អ្នកចុះ។
តើមិនមែនជាលោកនេះទេឬដែលបានបំផ្លាញ អស់អ្នកដែលនៅក្រុងយេរូសាឡិម ដែលអង្វររក
ព្រះនាមយេស៊ូនោះ
ឃ្លាប្រៀបធៀប និងសំណួរអវិជ្ជាមាននេះ បញ្ជាក់ថា
លោកសូលគឺជាមនុស្សដែលបៀតបៀនពួកអ្នកជឿ។
របៀបផ្សេងទៀតនៃការបកប្រែ:
«នេះគឺជាអ្នកដែលបំផ្លាញបងប្អូននៅក្នុងយេរូសាឡិម
ដែលអង្វររកព្រះនាមព្រះយេស៊ូ»។
ព្រះនាមយេស៊ូនោះ
ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើព្រះយេស៊ូ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នាមរបស់ព្រះយេស៊ូ»
លោកបានផ្ចាញ់ផ្ចាល់ក្នុងចំណោមសាសន៍យូដា
ពួកគេភ្ញាក់ផ្អើលក្នុងន័យថា
ពួកគេមិនអាចរកអ្វីមកឆ្លើយបដិសេធជម្លោះរបស់លោកសូល
ដែលថាព្រះយេស៊ូគឺជាព្រះគ្រិស្ត។
Acts 9:23
ព័ត៌មានទូទៅ
ពាក្យ «គាត់» នៅក្នុងវគ្គនេះ សំដៅលើលោកសូល។
ជនជាតិយូដា
ឃ្លានេះ សំដៅលើអ្នកដឹកនាំរបស់ជនជាតិយូដា។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដឹកនាំសាសន៍យូដា»
ប៉ុន្តែ ផែនការរបស់ពួកគេ បានដឹងដល់លោកសូល
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
មានមនុស្សមកប្រាប់ពីផែនការរបស់ពួកគេដល់លោកសូល» ឬ «ប៉ុន្តែ
លោកសូលបានដឹងអំពីផែនការរបស់ពួកគេ»។
ពួកគេបានឃ្លាំមើលនៅទ្វារក្រុង
ទីក្រុងនេះមានជញ្ជាំងព័ទ្ធជុំវិញ។
ជាទូលទៅមនុស្សអាចចេញចូលទីក្រុងបានតាមទ្វារនេះ។
ពួកសិស្សរបស់លោក
មនុស្សដែលជឿនៅព្រះបន្ទូលដែលលោកសូលប្រកាសអំពីព្រះយេស៊ូ
ហើយដើរតាមសេចក្តីបង្រៀនរបស់លោក។
បានដាក់លោកក្នុងជាលមួយ សម្រួតលោកចុះតាមកំពែងក្រុង
«ប្រើខ្សែសម្រួតលោកដោយដាក់នៅក្នុងជាលមួយយ៉ាងធំ
ចុះតាមជញ្ជាំង» (UDB)
Acts 9:26
ព័ត៌មានទូទៅ
ពាក្យ «គាត់» និង «របស់គាត់» នៅទីនេះ សំដៅលើលោកសូលទាំងអស់ ប៉ុន្តែ
មានតែមួយទេ ដែលមិននិយាយពីលោក។ «ហើយពាក្យ «គាត់»
ប្រាប់ពួកគេយ៉ាងណានោះ» ក្នុងខ ២៧ សំដៅលើលោកបារណាបាស។
តែពួកគេទាំងអស់គ្នាខ្លាចលោក
«ពួកគេទាំងអស់គ្នា» គឺនិយាយបំផ្លើស ដ្បិត តាមពិតពួកគេជាច្រើន ឬភាគច្រើន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេស្ទើរតែទាំងអស់» ។
ប្រកាសដោយចិត្តក្លាហាននៅក្រុងដាម៉ាសផង ក្នុងព្រះនាមព្រះយេស៊ូ
ការនិយាយថាប្រកាស
ឬបង្រៀនពីដំណឹងល្អអំពីព្រះយេស៊ូគ្រិស្តដោយគ្មានការភ័យខ្លាច។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេប្រកាសពីព្រះបន្ទូលអំពីព្រះយេស៊ូ»
Acts 9:28
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើពួកយូដា
និងមនុស្សដែលបានប្តូរសាសនាមកកាន់សាសន៍យូដាវិញ។
ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ
ពាក្យ «ព្រះនាម» គឺជាន័យប្រៀបធៀបសម្រាប់ដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្ត។
បានជជែកវែកញែកជាមួយសាសន៍យូដាដែលនិយាយភាសាក្រិក
លោកសូលព្យាយាមជជែកវែកញែកជាមួយជនជាតិយូដាដែលនិយាយភាសាក្រិក។
ពួកបងប្អូន
ពាក្យ «ពួកបងប្អូន» សំដៅលើពួកអ្នកជឿនៅក្នុងក្រុងយេរូសាឡិម។
នាំលោកចុះទៅក្រុងសេសារា
ឃ្លា «នាំលោកចុះ» ប្រើនៅទីនេះ
ដោយសារសេសារាមានកម្ពស់ទាបជាងក្រុងយេរូសាឡិម។
បានបញ្ជូនលោកទៅក្រុងតើសុស
សេសារាជាកំពង់ផែ។ ពួកគេប្រហែលជាជូនដំណើរលោកសូលទៅក្រុងតើសុស
ធ្វើដំណើរតាមសំពៅ។
Acts 9:31
ប្រយោគភ្ជាប់
នៅក្នុងខ ៣២ សាច់រឿងបានប្តូរពីលោកសូលទៅសាច់រឿងមួយថ្មី
អំពីលោកពេត្រុសវិញ។
ព័ត៌មានទូទៅ
ខ ៣១ គឺជាប្រយោគដែលផ្តល់ដំណឹងពីការលូតលាស់ក្រុមជំនុំដើម។
ក្រុមជំនុំក្នុងស្រុកយូដា ស្រុកកាលីឡេ និងស្រុកសាម៉ារីទាំងមូល
នេះគឺជាលើកទីមួយហើយដែលប្រើ «ក្រុមជំនុំ» ជាឯកវចន:
សំដៅលើក្រុមជំនុំច្រើនកន្លែងជាក្រុមជំនុំមួយកន្លែង។ នៅទីនេះ
សំដៅលើអ្នកជឿទាំងអស់នៅក្នុងក្រុមអ៊ីស្រាអែលទាំងមូល។
បានប្រកបដោយសេចក្តីសុខសាន្ត
«រស់នៅដោយសុខសាន្ត» (UDB)។ នេះមានន័យថា
ការបៀតបៀនដែលបានសម្លាប់លោកស្ទេផានត្រូវចប់ហើយ។
បានរឹងមាំឡើង
អ្នកដែលធ្វើឲ្យរឹងមាំ គឺព្រះជាម្ចាស់ ឬព្រះវិញ្ញាណដ៏វិសុទ្ធ។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ជួយឲ្យពួកគេរីកចម្រើន» ឬ
«ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើឲ្យពួកគេរឹងមាំ» ។
ដើរដោយកោតខ្លាចព្រះអម្ចាស់
«បន្តគោរពកោតខ្លាចព្រះអម្ចាស់»
បានទទួលការលួងលោមចិត្តដោយព្រះវិញ្ញាណដ៏វិសុទ្ធផង
«ព្រះវិញ្ញាណដ៏វិសុទ្ធបានចម្រើនកម្លាំង និងលើកទឹកចិត្តពួកគេ»
គ្រានោះ

generated on Wed Sep 10 16:16:32 2025

នៅក្នុងឃ្លានេះ ប្រើដើម្បីបង្ហាញពីផ្នែកថ្មីនៃសាច់រឿង។
បានធ្វើដំណើរទៅតាមតំបន់គ្រប់ទីកន្លែង
នេះគឺជាពាក្យបំផ្លើសសម្រាប់លោកពេត្រុស
ក្នុងការសួរសុខទុក្ខដល់ពួកអ្នកជឿពេញទាំងស្រុកយូដា កាលីឡេ និងសាម៉ារី។
លោកក៏បានចុះទៅរក
ឃ្លា «ចុះ» ប្រើនៅទីនេះ ដោយសារក្រុង
លីដាមានកម្ពស់ទាបជាងក្រុងផ្សេងៗទៀតដែលគាត់ធ្វើដំណើរទៅ។
ក្រុងលីដា
ក្រុងលីដាជាទីក្រុងមួយដែលមានទីតាំងមួយដែលនៅឆ្ងាយពីក្រុងយ៉ុបប៉ែ
១៨គីឡូម៉ែត្រ។ ទីក្រុងនេះហៅថាទីក្រុងឡុតនៅក្នុងសម្ពន្ធមេត្រីចាស់
និងនៅក្នុងអ៊ីស្រាអែលបច្ចុប្បន្ន។
Acts 9:33
នៅទីនោះ លោកឃើញបុរសម្នាក់
លោកពេត្រុសបានបំណងចិត្តក្នុងការស្វែងរកជនពិការឡើយ ប៉ុន្តែ
វាបានកើតឡើងចំពោះលោក។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅទីនោះ
លោកពេត្រុសបានជួបបុរសម្នាក់»។
បុរសម្នាក់ឈ្មោះអេណាស
នៅទីនេះ គឺជាការណែនាំតួអង្គថ្មីនៅក្នុងសាច់រឿងគឺលោកអេណាស។
ដែលឈឺដេកលើគ្រែ...គាត់ជាមនុស្សខ្វិន
នេះគឺជាប្រវត្តិរបស់លោកអេណាស។
ខ្វិន
មិនអាចដើរបាន ប្រហែលជាមិនអាចធ្វើចលនានៅត្រង់ចង្កេះបាន។
រៀបចំគ្រែអ្នកចុះ
«បត់គ្រែរបស់អ្នកចុះ» (UDB)
មនុស្សគ្រប់គ្នាដែលរស់នៅ
នេះគឺជាពាក្យបំផ្លើស «មនុស្សជាច្រើនដែលរស់នៅ»
ក្រុងលីដា និងស្រុកសារ៉ូន
ក្រុងលីដា ស្ថិតនៅក្នុងតំបន់វាលទំនាបស្រុកសារ៉ូន។
ឃើញបុរសនោះ
វាអាចជួយបានច្រើនក្នុងការនិយាយថា ពួកគេបានឃើញថា គាត់បានជា។
របៀបផ្សេងទៀតនៃការបកប្រែ:
«គេបានឃើញបុរសដែលលោកពេត្រុសបានប្រោសឲ្យជា»។
Acts 9:36
ប្រយោគភ្ជាប់
លោកលូកាបន្តសាច់រឿងជាមួយនឹងព្រឹត្តការណ៍មួយថ្មីអំពីលោកពេត្រុស។
ព័ត៌មានទូទៅ
នៅក្នុងខនេះបានផ្តល់ព័ត៌មានអំពីស្រីម្នាក់ឈ្មោះ តេប៊ីថា។
ឥឡូវនេះ មាន
នេះគឺជាការណែនាំសាច់រឿងមួយថ្មី។
ឈ្មោះតេប៊ីថា ភាសាក្រិកថា «ឌ័រកាស»
តេប៊ីថា គឺជាឈ្មោះរបស់នាងជាភាសាអារ៉ាម ហើយឌ័រកាស
គឺជាឈ្មោះរបស់នាងជាភាសាក្រិក។ ទាំងពីរនេះមានន័យថា: «ក្តាន់ញី»។
របៀបផ្សេងទៀតនៃការបកប្រែ: «ឈ្មោះរបស់នាងជាភាសាក្រិកគឺ «ឌ័រកាស»
តែងតែប្រព្រឹត្តអំពើល្អ
«បានធ្វើការល្អជាច្រើន»
នៅគ្រានោះ
ឃ្លានេះ សំដៅលើពេលដែលលោកពេត្រុសនៅក្នុងក្រុងយ៉ុបប៉ែ។
អាចនិយាយបែបនេះ។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅគ្រានោះ
ខណៈពេលដែលលោកពេត្រុសនៅជិត»
បានលាងសាកសពនាង
នេះគឺជាការលាងដើម្បីរៀបចំបញ្ចុះសព។
ពួកគេបាននាងនៅបន្ទប់ខាងលើ។
ពួកគេដាក់នៅបន្ទប់ខាងលើបណ្តោះអាសន្ន នៅក្នុងអំឡុងពេលធ្វើពិធីបុណ្យ។
Acts 9:38
ពួកគេបានចាត់បុរសពីរនាក់ឲ្យទៅរកលោក
«ពួកសិស្សបានចាត់មនុស្សពីរនាក់ទៅរកលោកពេត្រុស»។
ទៅបន្ទប់ខាងលើ
«ទៅបន្ទប់ជាន់លើ ជាកន្លែងដែលគេដាក់សពនាងឌ័រកាស» (UDB)
ពួកស្ត្រីមេម៉ាយទាំងឡាយ
អាចនិយាយពីពួកស្ត្រីមេម៉ាយនៅក្នុងទីក្រុង ព្រោះទីក្រុងនោះមិនធំប៉ុន្មានទេ។
ស្ត្រីមេម៉ាយ
ស្ត្រីដែលប្តីស្លាប់ ហើយពួកគេត្រូវការជំនួយ។
កាលនាងរស់នៅជាមួយពួកគេនៅឡើយ
«កាលនាងនៅរស់ នាងបាននៅជាមួយពួកសិស្ស» (UDB)
Acts 9:40
ប្រយោគភ្ជាប់
សាច់រឿងរបស់នាងតេប៊ីថាបានចប់នៅក្នុងខ ៤២។ ខ ៤៣
ប្រាប់យើងអំពីអ្វីដែលបានកើតឡើងជាមួយលោកពេត្រុសបន្ទាប់ពីសាច់រឿងចប់។
បានឲ្យពួកគេទាំងអស់គ្នាចេញទៅក្រៅបន្ទប់
«ប្រាប់ពួកគេទាំងអស់ឲ្យចេញពីបន្ទប់»។
លោកពេត្រុសបានឲ្យមនុស្សគ្រប់គ្នាចេញពីបន្ទប់ ដើម្បីគាត់អាចនៅម្នាក់ឯង
រួចអធិស្ឋានឲ្យនាងតេប៊ីថា។
ចាប់ដៃនាង ហើយលើកនាងឲ្យក្រោកឈរឡើង
លោកពេត្រុសបានចាប់ដៃនាង ហើយជួយនាងឲ្យក្រោកឡើង។
ពួកអ្នកជឿ និងពួកស្ត្រីមេម៉ាយ
ស្ត្រីមេម៉ាយ ប្រហែលជាបានជឿង ប៉ុន្តែនិយាយច្បាស់លាស់ដោយសារ
នាងតេប៊ីថាសំខាន់សម្រាប់ពួកគេ។
រឿងនេះបានដឹងដល់អ្នកក្រុងយ៉ុបប៉ែទាំងមូល
ឃ្លានេះសំដៅលើការអស្ចារ្យដែលលោកពេត្រុសបានប្រោសនាងតេប៊ីថាឲ្យរស់ពីស្លាប់ឡើងវិញ។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សនៅក្រុងយ៉ុបប៉ែទាំងមូលបានឮអំពីរឿងនេះ»។
បានជឿលើព្រះអម្ចាស់
«បានជឿលើដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូ»។
នៅគ្រានោះ
«នៅគ្រានោះ»។ នេះគឺជាការណែនាំនៃការចាប់ផ្តើមសាច់រឿងថ្មី។
ស៊ីម៉ូនជាអ្នកសម្លាប់ស្បែក
«បុរសម្នាក់ឈ្មោះស៊ីម៉ូន ដែលធ្វើស្បែកពីស្បែកសត្វ» (UDB)

---

10 [1]នៅក្រុងសេសារា មានបុរសម្នាក់ឈ្មោះកូនេលាស ជានាយទាហានក្នុងកងវរសេនាតូចរ៉ូម៉ាំងមួយឈ្មោះ «កងវរសេនាតូចអ៊ីតាលី»។[2]គាត់ និងក្រុមគ្រួសាររបស់គាត់
ទាំងមូល ជាអ្នកគោរពប្រណិប័តន៍ និងកោតខ្លាចព្រះជាម្ចាស់។ គាត់តែងចែកទានជាច្រើនអោយប្រជាជន ព្រមទាំងទូលអង្វរព្រះជាម្ចាស់គ្រប់ពេលវេលា។
[3]ថ្ងៃមួយ ប្រមាណជាម៉ោងប្រាំបួន គាត់បាននិមិត្តឃើញទេវតាមួយរូបរបស់ព្រះជាម្ចាស់យ៉ាងច្បាស់។ ទេវតានោះពោលមកកាន់គាត់ថា៖ «លោកកូនេលាសអើយ!»។
[4]លោកកូនេលាសសម្លឹងមើលទៅទេវតា ហើយមានប្រសាសន៍ទៅវិញទាំងភ័យខ្លាចថា៖ «លោកម្ចាស់អើយ! តើលោកមានការអ្វី?»។ ទេវតាពោលមកគាត់ថា៖
«ព្រះជាម្ចាស់ស្តាប់ពាក្យទូលអង្វររបស់លោក ហើយព្រះអង្គក៏មិនភ្លេចអំពីទានដែលលោកបានធ្វើចំពោះជនក្រីក្រ ជាតង្វាយនៅចំពោះព្រះវត្តមានព្រះជាម្ចាស់។
[5]សូមលោកចាត់គេឲ្យទៅក្រុងយ៉ុបប៉ែ ឥឡូវនេះ អញ្ជើញបុរសម្នាក់ឈ្មោះស៊ីម៉ូន ហៅពេត្រុសមក។[6]គាត់ស្នាក់នៅផ្ទះអ្នកសម្លាប់ស្បែកម្នាក់ឈ្មោះស៊ីម៉ូន ផ្ទះនោះនៅក្បែរ
មាត់សមុទ្រ»។
[7]កាលទេវតាដែលបាននិយាយជាមួយគាត់ចេញផុតទៅ លោកកូនេលាសក៏ហៅអ្នកបម្រើពីរនាក់ និងទាហានម្នាក់គោរពប្រណិប័តន៍ព្រះជាម្ចាស់ ដែលនៅក្រោមបញ្ជា
របស់គាត់ជាយូរហើយឲ្យចូលមក។[8]លោកបានរៀបរាប់ហេតុការណ៍ទាំងអស់ប្រាប់ពួកគេ រួចចាត់ពួកគេឲ្យទៅក្រុងយ៉ុបប៉ែ។
[9]នៅថ្ងៃបន្ទាប់ អ្នកទាំងនោះធ្វើដំណើរទៅជិតដល់ក្រុងយ៉ុបប៉ែ។ ប្រមាណជាម៉ោងប្រាំមួយ លោកពេត្រុសឡើងទៅអធិស្ឋាននៅលើដំបូលផ្ទះ។[10]ពេលនោះ លោក
ឃ្លានចង់រកអ្វីមកពិសា ប៉ុន្តែ កាលគេកំពុងតែរៀបចំម្ហូបចំណីជូនលោកពិសា លោកបានទទួលនូវនិមិត្តមួយ[11]ហើយលោកបានលង់ស្មារតីនិមិត្តឃើញផ្ទៃមេឃបើកចំហ
ឃើញវត្ថុម្យ៉ាងចុះមកដូចកម្រាលតុមួយយ៉ាងធំ ដែលមានចងចុងជាយទាំងបួនជ្រុងចុះពីលើមកដល់ដី។[12]នៅលើកម្រាលនោះ មានសត្វចតុប្បាទគ្រប់ប្រភេទ មានសត្វ
លូនវារ និងបក្សាបក្សី។

generated on Wed Sep 10 16:16:32 2025

[13]បន្ទាប់មក មានព្រះសូរសៀងមកគាត់ថា៖ «ពេត្រុសអើយ! ចូរក្រោយឡើង រួចសម្លាប់សត្វទាំងនេះបរិភោគទៅ!»។[14]ប៉ុន្តែ លោកពេត្រុសទូលទៅវិញថា៖ «ទេ ព្រះអម្ចាស់ ទូលបង្គំពុំដែលទទួលទានអ្វីដែលវិន័យហាមឃាត់ ឬមិនបរិសុទ្ធឡើយ»។[15]ប៉ុន្តែព្រះសូរសៀងនោះជាលើកទីពីរមកកាន់លោកថា៖ «អ្វីៗដែលព្រះជាម្ចាស់បានប្រោសឲ្យ បរិសុទ្ធហើយ ចូរកុំចាត់ទុកថាជាវិន័យហាមឃាត់នោះឡើយ»។[16]ហេតុការណ៍នេះកើតមានដល់ទៅបីដង នៅទីបំផុត វត្ថុនោះក៏ឡើងទៅលើមេឃវិញភ្លាមបាត់ទៅ។
[17]ខណៈពេលដែលលោកពេត្រុសកំពុងភាន់ភាំងអំពីអត្ថន័យនៃនិមិត្ត ដែលលោកបានឃើញនោះ ស្រាប់តែពួកអ្នកដែលលោកកូនេលាសចាត់ឲ្យមក បានមកដល់មាត់ទ្វារ ទាំងសាកសួររកផ្ទះរបស់លោកស៊ីម៉ូន។[18]ពួកគេស្រែកសួរថា៖ «លោកស៊ីម៉ូនហៅពេត្រុសស្នាក់ក្នុងផ្ទះនេះឬទេ?»។
[19]ពេលលោកពេត្រុសកំពុងរិះគិតអំពីនិមិត្តនោះ ព្រះវិញ្ញាណមានព្រះបន្ទូលមកគាត់ថា៖ «មានបុរសបីនាក់កំពុងសួររកអ្នក[20]ចូរចុះទៅក្រោម រួចចេញដំណើរទៅជាមួយគេ ភ្លាម កុំរារែកឡើយ ដ្បិតយើងនេះហើយដែលបានចាត់គេឲ្យមក»។[21]លោកពេត្រុសក៏ចុះទៅក្រោម មានប្រសាសន៍ទៅបុរសទាំងនោះថា៖ «ខ្ញុំនេះហើយដែលអ្នករាល់គ្នា កំពុងតែរក! តើអ្នកមកមានការអ្វី?»។
[22]ពួកគេឆ្លើយថា៖ «លោកកូនេលាស ជានាយទាហាន បានចាត់យើងឲ្យមក គាត់ជាមនុស្សសុចរិត គោរពកោតខ្លាចព្រះជាម្ចាស់ ហើយជាមនុស្សម្នាក់ដែលប្រជាជាតិ យូដាសរសើរគ្រប់ៗគ្នា។ ទេវតាដ៏វិសុទ្ធមួយរូបបានមកប្រាប់គាត់ឲ្យអញ្ជើញលោកទៅផ្ទះគាត់ ដើម្បីស្តាប់លោកមានប្រសាសន៍»។[23]លោកពេត្រុសក៏អញ្ជើញអ្នកទាំងនោះ ចូលក្នុងផ្ទះឲ្យស្នាក់នៅជាមួយ។ ព្រឹកឡើង លោកក៏ចេញដំណើរទៅជាមួយគេទាំងមានបងប្អូនខ្លះនៅក្រុងយ៉ុបប៉េជូនដំណើរផងដែរ។
[24]នៅថ្ងៃបន្ទាប់មកទៀត ពួកគេបានទៅដល់ក្រុងសេសារា។ លោកកូនេលាសកំពុងរង់ចាំពួកគេ ហើយពេលនោះគាត់ក៏បានអញ្ជើញញាតិសន្តាន និងមិត្តជិតដិតមកផ្ទះ របស់គាត់ផងដែរ។
[25]ពេលលោកពេត្រុសមកដល់ លោកកូនេលាសចេញទៅទទួល ក្រាបចុះទៀបជើងលោក។[26]ប៉ុន្តែ លោកពេត្រុសចាប់គាត់ឲ្យក្រោកឡើងទាំងពោលថា៖ «អញ្ជើញក្រោកឡើង ខ្ញុំក៏ជាមនុស្សដែរទេតើ!»។
[27]ខណៈពេលលោកសន្ទនាជាមួយលោកកូនេលាសបណ្តើរ ដើរចូលទៅក្នុងបណ្តើរ លោកបានឃើញមនុស្សជាច្រើននៅជុំគ្នា[28]លោកមានប្រសាសន៍ទៅគេថា៖ «បងប្អូន ជ្រាបឬទេ វិន័យរបស់សាសនាយូដា ហាមមិនឲ្យសាសន៍យូដាទាក់ទងជាមួយជនបរទេស ឬក៏ចូលទៅក្នុងផ្ទះរបស់គេឡើយ។ ប៉ុន្តែ ព្រះជាម្ចាស់បានបង្ហាញខ្ញុំឲ្យដឹងថា មិនត្រូវប្រកាន់នរណាម្នាក់ថា ជាមនុស្សដែលវិន័យហាមឃាត់មិនឲ្យទាក់ទង ឬជាមនុស្សមិនបរិសុទ្ធនោះឡើយ។[29]ហេតុនេះហើយ បានជាខ្ញុំមកភ្លាម ឥតមានជំទាស់អ្វីសោះ នៅពេលដែលបងប្អូនហៅខ្ញុំមក។ ឥឡូវនេះ សុំប្រាប់ខ្ញុំមើល៍ បងប្អូនហៅខ្ញុំមកមានការអ្វី?»។
[30]លោកកូនេលាសមានប្រសាសន៍ថា៖ «កាលបួនថ្ងៃមុន ក្នុងពេលដដែលនេះ ខ្ញុំកំពុងអធិស្ឋានក្នុងផ្ទះខ្ញុំ នៅម៉ោងប្រាំបួន មានបុរសម្នាក់ស្លៀកសម្លៀកបំពាក់ភ្លឺត្រចះត្រចង់ មកឈរនៅមុខខ្ញុំ[31]ហើយពោលថា៖ «លោកកូនេលាសអើយ ព្រះជាម្ចាស់ស្តាប់ពាក្យទូលអង្វររបស់លោកហើយ រីឯទានរបស់លោកក៏ព្រះអង្គមិនភ្លេចដែរ។[32]ឥឡូវនេះ ចូរចាត់គេឲ្យទៅហៅបុរសម្នាក់ឈ្មោះស៊ីម៉ូនហៅពេត្រុសនៅក្រុងយ៉ុបប៉េមក។ គាត់ស្នាក់នៅផ្ទះរបស់លោកស៊ីម៉ូនជាអ្នកសម្លាប់ស្បែក ផ្ទះនោះស្ថិតនៅមាត់សមុទ្រ”។[33]ខ្ញុំក៏បានចាត់គេឲ្យទៅអញ្ជើញលោកភ្លាម លោកមកដូច្នេះជាការប្រពៃណាស់។ ឥឡូវនេះ យើងខ្ញុំទាំងអស់គ្នាស្ថិតនៅទីនេះ ចំពោះព្រះភក្ត្រព្រះជាម្ចាស់រង់ចាំស្តាប់សេចក្តីទាំងប៉ុន្មាន ដែលព្រះអម្ចាស់បានបង្គាប់មកលោក»។
[34]ពេលនោះ លោកពេត្រុសចាប់ផ្តើមមានប្រសាសន៍ថា៖ «ឥឡូវនេះ ខ្ញុំបានយល់យ៉ាងច្បាស់ហើយថា ព្រះជាម្ចាស់រាប់រកមនុស្សទូទៅឥតរើសមុខឡើយ។[35]ជាតិសាសន៍ទាំងប៉ុន្មាន អ្នកណាក៏ដោយឲ្យតែគោរពកោតខ្លាចព្រះអង្គ ហើយប្រព្រឹត្តអំពើសុចរិត ព្រះអង្គមុខជាគាប់ព្រះហឫទ័យនឹងអ្នកនោះមិនខាន។
[36]អ្នកដឹងហើយថា ព្រះអង្គបានប្រទានព្រះបន្ទូលមកឲ្យជនជាតិអ៊ីស្រាអែលនៅពេលព្រះអង្គបានប្រកាសដំណឹងល្អ អំពីសេចក្តីសុខសាន្តតាមរយៈព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់ លើមនុស្សទាំងអស់ដល់ពួកគេ។[37]បងប្អូនជ្រាបហេតុការណ៍ដែលកើតឡើងនៅស្រុកយូដាទាំងមូលស្រាប់ហើយ ជាហេតុការណ៍ដែលបានចាប់ផ្តើមនៅស្រុកកាលីឡេ ក្រោយពេលលោកយ៉ូហានបានប្រកាសឲ្យបណ្តាជនទទួលពិធីជ្រមុជទឹក[38]ដែលព្រះជាម្ចាស់បានចាក់ព្រះវិញ្ញាណដ៏វិសុទ្ធនិងឫទ្ធានុភាពដោយបានអភិសេកព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត។ បងប្អូនក៏ជ្រាបដែរថា ព្រះយេស៊ូបានយាងពីកន្លែងមួយទៅកន្លែងមួយ ទាំងប្រព្រឹត្តអំពើល្អ និងប្រោសអស់អ្នកដែលត្រូវមារសង្កត់សង្កិនឲ្យបានជា ដ្បិតព្រះជាម្ចាស់គង់ជាមួយព្រះអង្គ។
[39]យើងជាបន្ទាល់អំពីកិច្ចការទាំងអស់ ដែលព្រះអង្គបានធ្វើនៅក្នុងដែនដីរបស់ជនជាតិយូដា និងនៅក្រុងយេរូសាឡឹម។ ពួកគេបាននាំគ្នាធ្វើគុតព្រះអង្គដោយព្យួរនៅលើឈើ។[40]ព្រះជាម្ចាស់បានប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី និងប្រោសប្រទានឲ្យព្រះអង្គបង្ហាញខ្លួន[41]ដល់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើសជាមុន ឲ្យធ្វើជាបន្ទាល់ប៉ុណ្ណោះ គឺយើងហ្នឹងហើយជាបន្ទាល់ ដែលបានបរិភោគជាមួយព្រះអង្គ ក្រោយពេលព្រះអង្គមានព្រះជន្មរស់ឡើងវិញ។
[42]ព្រះយេស៊ូបានបញ្ជាឲ្យយើងធ្វើជាបន្ទាល់ ប្រកាសប្រាប់ប្រជាជនថា ព្រះជាម្ចាស់បានតែងតាំងព្រះអង្គឲ្យវិនិច្ឆ័យទោសទាំងមនុស្សរស់ និងមនុស្សស្លាប់។[43]ព្យាការីទាំងប៉ុន្មានសុទ្ធតែបានផ្តល់សក្ខីភាពអំពីព្រះយេស៊ូថា អស់អ្នកដែលជឿលើព្រះអង្គ នឹងទទួលការលើកលែងទោសឲ្យរួចពីបាបដោយសារព្រះនាមព្រះអង្គ»។
[44]ពេលលោកពេត្រុសកំពុងមានប្រសាសន៍នៅឡើយ ស្រាប់តែព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមកសណ្ឋិតលើអស់អ្នកដែលស្តាប់លោក។[45]ពួកអ្នកដែលស្ថិតក្នុងក្រុមអ្នកជឿដែលបានកាត់ស្បែកក៏មកជាមួយលោកពេត្រុសដែរ ពួកគេស្ងើចសរសើរ ព្រោះជាម្ចាស់បានចាក់បង្ហូរអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យមកសាសន៍ដទៃផងដែរ។
[46]ដ្បិតគេបានឮសាសន៍ដទៃទាំងនោះនិយាយភាសាចំឡែកអស្ចារ្យ ព្រមទាំងលើកតម្កើងព្រះជាម្ចាស់ផង។ ពេលនោះ លោកពេត្រុសមានប្រសាសន៍ថា៖[47]«គ្មាននរណាអាចឃាត់យើង មិនឲ្យធ្វើពិធីជ្រមុជទឹកជូនអស់អ្នក ដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដូចជាយើងបានទទួលដែរនោះទេ»។[48]បន្ទាប់មក លោកក៏បញ្ជាឲ្យគេធ្វើពិធីជ្រមុជទឹកជូនអ្នកទាំងនោះ ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ បន្ទាប់មក ពួកគេសុំឲ្យលោកស្នាក់នៅជាមួយគេ បានយូរថ្ងៃបន្តិចទៀត។

Acts 10:1
ប្រយោគភ្ជាប់
នេះគឺជាការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿងរបស់លោកកូនេលាស។
ព័ត៌មានទូទៅ
នៅក្នុងទាំងនេះ បានផ្តល់ប្រវត្តិរបស់លោកកូនេលាស។
ឥឡូវ មានបុរសម្នាក់
នេះគឺជារបៀបនៃការណែនាំមនុស្សថ្មីនៅក្នុងចំណែកនៃកំណត់ហេតុប្រវត្តិសាស្ត្រ។
ឈ្មោះកូនេលាស ជានាយទាហាននៃកងវរសេនាធំមួយហៅថា «កងវរសេនាធំអ៊ីតាលី
«ឈ្មោះរបស់គាត់គឺកូនេលាស។ គាត់ជាមេទាហានដែលគ្រប់គ្រងលើទាហាន
១០០នាក់ មកពីប្រទេសអ៊ីតាលី ជាតំណែងរបស់កងទ័ពរ៉ូម»
លោកជាមនុស្សដែលគោរពកោតខ្លាចព្រះ ហើយជាម្នាក់ដែលថ្វាយបង្គំព្រះជាម្ចាស់
«លោកបានជឿលើព្រះជាម្ចាស់ ហើយបានគោរព
និងថ្វាយបង្គំព្រះជាម្ចាស់នៅក្នុងជីវិតរបស់លោក»។
ថ្វាយបង្គំព្រះជាម្ចាស់
ពាក្យថា «ថ្វាយបង្គំព្រះជាម្ចាស់»
នៅទីនេះគឺនៅក្នុងបរិបទនៃការគោរពកោតខ្លាចព្រះ និងស្ងប់ស្ងែងដល់ព្រះ។
ជាមួយក្រុមគ្រួសាររបស់គាត់ទាំងមូល
ពាក្យ «ជាមួយក្រុមគ្រួសារ»
សំដៅលើមនុស្សទាំងអស់ដែលនៅក្នុងផ្ទះរបស់លោក។
សមាជិកផ្សេងទៀតនៅក្នុងផ្ទះរបស់លោកប្រហែលជាសាសន៍ដទៃ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ជាមួយនឹងសមាជិកនៅក្នុងផ្ទះរបស់លោកទាំងមូល»
អធិស្ឋានទៅព្រះជាម្ចាស់ឥតឈប់ឈរ
«លោកបានអធិស្ឋានទៅព្រះជាម្ចាស់ជាប្រចាំ» (UDB)
Acts 10:3
ម៉ោងប្រហែលជាប្រាំបួន
«ម៉ោងបីរសៀល»
នេះគឺជាពេលវេលាអធិស្ឋានសម្រាប់សម្រាប់សាសន៍យូដានៅពេលរសៀល។
លោកបានឃើញក្នុងនិមិត្តយ៉ាងច្បាស់
«លោកកូនេលាសបានឃើញយ៉ាងច្បាស់»
សេចក្តីអធិស្ឋាន និងអំណោយ...ជាតង្វាយនៃការចងចាំនៅចំពោះព្រះវត្តមានរបស់ព្រះជាម្ចាស់
ឃ្លានេះមានន័យថា អំណោយ និងសេចក្តីអធិស្ឋានរបស់លោក

generated on Wed Sep 10 16:16:32 2025

ព្រះជាម្ចាស់បានទទួលហើយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់គាប់ព្រះទ័យនឹងសេចក្តីអធិស្ឋាន
និងអំណោយរបស់លោក...ជាតង្វាយនៃការចងចាំនៅចំពោះព្រះវត្តមានរបស់ព្រះអង្គ»
។
អ្នកសម្លាប់ស្បែក
ជាមនុស្សម្នាក់ដែលស្បែកចេញពីស្បែកសត្វ។
Acts 10:7
ពេលលទេវតាដែលបាននិយាយជាមួយលោកចេញផុតទៅ
«ពេលនិមិត្តរបស់លោកកូនេលាសអំពីទេវតាចប់ហើយ»
ទាហានដែលគោរពកោតខ្លាចព្រះម្នាក់ ពីចំណោមអស់អ្នកដែលបម្រើលោក
«មានទាហានម្នាក់ដែលបម្រើលោក គាត់ជាមនុស្សកោតខ្លាចព្រះជាម្ចាស់។
កម្រមានទាហានរ៉ូមកោតខ្លាចព្រះជាម្ចាស់ណាស់ ដូច្នេះ
ប្រហែលជាទាហានផ្សេងទៀតរបស់លោកកូនេលាសមិនបានកោតខ្លាចព្រះជាម្ចាស់ទេ។
បានប្រាប់អ្វីដែលបានកើតឡើងដល់ពួកគេទាំងអស់
លោកកូនេលាសបានប្រាប់ពួកគេពីនិមិត្តរបស់គាត់ដល់អ្នកបម្រើទាំងពីរនោះទាំងអស់
ហើយដល់ម្នាក់ទៀតដែលជាទាហានរបស់លោក។
បានចាត់ពួកគេឲ្យទៅក្រុងយ៉ុបប៉េ
«បានចាត់អ្នកបម្រើរបស់លោកពីរនាក់ ហើយទាហានម្នាក់ទៅក្រុងយ៉ុបប៉េ»
Acts 10:9
ប្រយោគភ្ជាប់
សាច់រឿងបានប្តូរពីលោកកូនេលាស
ហើយប្រាប់យើងពីអ្វីដែលព្រះជាម្ចាស់បានធ្វើជាមួយលោកពេត្រុសទៅវិញ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើអ្នកបម្រើពីរនាក់របស់លោកកូនេលាស
និងទាហានម្នាក់ដែលនៅក្នុងការបង្គាប់របស់លោកកូនេលាស។ (សូមមើល:
១០:៧)
ប្រមាណជាម៉ោងប្រាំមួយ
«ប្រហែលជាថ្ងៃត្រង់»
ឡើងទៅលើដំបូលផ្ទះ
នៅលើដំបូលផ្ទះមានផ្ទៃរាបស្មើ ហើយជារឿយៗគេធ្វើកិច្ចការផ្សេងៗនៅលើនោះ។
ក្នុងកាលដែលគេកំពុងតែចម្អិនម្ហូបចំណីនោះ
«មុនពេលគេធ្វើម្ហូបរួច»
លោកបានទទួលនូវនិមិត្តមួយ
«ព្រះជាម្ចាស់បានប្រទាននិមិត្តមួយឲ្យលោក» ឬ «លោកបានឃើញនិមិត្តមួយ»
លោកបានឃើញផ្ទៃមេឃបើកចំហ
នេះគឺជាការចាប់ផ្តើមនិមិត្តរបស់លោកពេត្រុស។ វាអាចជាប្រយោគថ្មី។
ឃើញអ្វីមួយសម្រាប់ដាក់វត្ថុចុះមកដូចកម្រាលតុមួយផ្ទាំងយ៉ាងធំ ដែលមានចងចុងជាយទាំងបួន
ជ្រុង
មានវត្ថុមួយផ្ទុកដោយសត្វដែលមានលក្ខណជាកម្រាលដែលមានបួនជ្រុងស្មើរ។
មានចងចុងជាយទាំងបួនជ្រុងចុះពីលើមកដល់ដី
«លាតដល់បួនជ្រុង» ឬ «ជាមួយនឹងជ្រុងទាំងបួនរបស់វា ខ្ពស់ផុតពីដី»។
មានសត្វចតុប្បាទគ្រប់ប្រភេទ និងមានសត្វលូនវារ និងបក្សាបក្សីដែលហើរនៅលើមេឃផង
សត្វចតុប្បាទគ្រប់ប្រភេទ...បក្សាបក្សីដែលហើរនៅលើមេឃផង
តាមរយៈការឆ្លើយតបរបស់លោកពេត្រុសនៅក្នុងខបន្ទាប់
អាចបង្ហាញពីច្បាប់របស់លោកម៉ូសេ
ដែលបានបង្គាប់ដល់ជនជាតិយូដាមិនឲ្យបរិភោគសត្វទាំងនោះឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «មានសត្វពាហនៈ និងសត្វស្លាប
ដែលលោកម៉ូសេបានហាមជនជាតិយូដាមិនឲ្យបរិភោគ» ។
Acts 10:13
ឮព្រះសូរសៀងមានបន្ទូលមកលោក
អ្នកនិយាយមិនបានបញ្ជាក់ច្បាស់ទេ។ «សម្លេង» ប្រហែលជាព្រះជាម្ចាស់
ហើយអាចជាសម្លេងរបស់ទេវតាដែលមកព្រះជាម្ចាស់ដែរ។
ទេ
«ទូលបង្គំមិនធ្វើបែបនោះទេ»
ទូលបង្គំពុំដែលហូបអ្វីដែលស្មោកគ្រោក និងមិនស្អាតឡើយ
ឃ្លានេះបង្ហាញថាមានសត្វខ្លះនៅក្នុងវត្ថុនោះមិនស្អាត
តាមសេចក្តីបង្គាប់របស់ក្រឹត្យវិន័យរបស់លោកម៉ូសេឡើយហើយអ្នកជឿមិនត្រូវបរិភោគ
គឺមុនពេលព្រះគ្រិស្តសុគត។
អ្វីៗដែលព្រះជាម្ចាស់បានសម្អាតហើយ
ប្រសិនបើ ព្រះជាម្ចាស់មានបន្ទូលហើយ ព្រះអង្គ គឺសំដៅលើអង្គទ្រង់ ជាបុរសទីបី។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលខ្ញុំ ព្រះជាម្ចាស់ បានសម្អាតហើយ»។
ការនេះកើតមានបីដង
មើលទៅដូចជាមិនមែនជាអ្វីដែលលោកពេត្រុសឃើញបីដងទេ។
នេះប្រហែលមានន័យថា: «អ្វីដែលព្រះជាម្ចាស់មានបន្ទូលថាស្អាត
មិនអាចថាមិនស្អាតបានទេ» និយាយបីដង។ ប៉ុន្តែ
នេះអាចជាវិធីដ៏ល្អបំផុតក្នុងការនិយាយថា «ការនេះបានកើតឡើងបីដង» ជំនួសឲ្យ
ពន្យល់វែងឆ្ងាយ។
Acts 10:17
លោកពេត្រុសកំពុងភាន់ភាំង
នេះមានន័យថាលោកពេត្រុសកំពុងតែពិបាកក្នុងការយល់ថានិមិត្តនោះមានន័យយ៉ាងដូចម្តេច។
មើល៍
ពាក្យ «មើល៍» នៅទីនេះ
រំលឹកដាស់តឿនយើងឲ្យយកចិត្តទុកដាក់នឹងព័ត៌មានដ៏ភ្ញាក់ផ្អើលដែលត្រូវធ្វើតាម
នៅក្នុងករណីនេះ មានមនុស្សពីរនាក់ឈរនៅមាត់ទ្វារ។
បានមកឈរនៅមាត់ទ្វារ
«បានមកឈរនៅមាត់ទ្វារ នៅមុខផ្ទះ» នេះមានន័យថា
ផ្ទះមានជញ្ជាំងនិងទ្វារដើម្បីចូលទៅក្នុងបាន។
ឈរនៅមាត់ទ្វារ
«ឈរនៅខាងមុខទ្វារផ្ទះ» មានន័យថាថា
ផ្ទះនេះមានជញ្ជាំងជាមួយនឹងទ្វារនៅក្នុងនោះ ដើម្បីចូលទៅក្នុងផ្ទះបាន។
បន្ទាប់មក ពួកកេបានសាកសួររកផ្លូវទៅផ្ទះនោះ
ការនេះកើតឡើងមុនពេលពួកគេមកដល់ផ្ទះ។ ឃ្លានេះនិយាយនៅក្នុងខមុននេះ
ដូចនៅក្នុងUDB ដែរ។
ពួកគេស្រែកសួរថា
អ្នកបម្រើលោកកូនេលាសនៅខាងក្រៅទ្វារ ពេលពួកគេសួររកលោកពេត្រុស។
Acts 10:19
កំពុងតែគិតអំពីនិមិត្តនោះ
«កំពុងឆ្ងល់អំពីអត្ថន័យរបស់និមិត្តនោះ»
ព្រះវិញ្ញាណ
«ព្រះវិញ្ញាណដ៏វិសុទ្ធ»
មើល៍
«ចូរប្រយ័ត្ន» ឬ «ចូរភ្ញាក់ឡើង»
មានបុរសបីនាក់កំពុងរកអ្នក
អត្ថបទបុរាណមានចំនួនខុសគ្នារបស់មនុស្ស។
ចុះទៅក្រោម
«ចុះទៅក្រោមពីដំបូលផ្ទះ»
កុំរារែកក្នុងការទៅជាមួយពួកគេឡើយ
ជាទូទៅសម្រាប់លោកពេត្រុសមិនចង់ទៅជួបពួកគេទេ។ ទី១)
ពួកគេជាមនុស្សមិនដែលស្គាល់ ហើយ ទី២) ពួកគេជាសាសន៍ដទៃ
សម្រាប់ជនជាតិយូដាមិនទាក់ទងជាមួយពួកគេឡើយ។
ខ្ញុំនេះហើយដែលអស់លោកកំពុងរក
«ខ្ញុំគឺជាអ្នកដែលអ្នករាល់គ្នាកំពុងស្វែងរក» (UDB)
Acts 10:22
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «ពួកគាត់» នៅទីនេះ សំដៅលើអ្នកបម្រើទាំងពីរនាក់
និងទាហានម្នាក់មកពីលោកកូនេលាស។ (សូមមើល: ១០:៧)
នាយទាហានម្នាក់ លោកកូនេលាស...ស្តាប់ព្រះបន្ទូលពីលោក
ឃ្លានេះអាចបែងចែកជាប្រយោគផ្សេងៗ ហើយនិយាយនៅក្នុងទម្រង់សកម្ម
ដូច្នេះនៅក្នុង UDB ដែរ។
គោរពកោតខ្លាចព្រះជាម្ចាស់
ពាក្យ «គោរពកោតខ្លាច» នៅទីនេះ នៅការគោរពជាខ្លាំង និងកោតស្ញប់ស្ញែង។
ជនជាតិយូដាសរសើរគ្រប់ៗគ្នា
ឃ្លានេះបំផ្លើស ដើម្បីបញ្ជាក់ថា គេស្គាល់ច្រើន។
ដូច្នេះ លោកពេត្រុសបានអញ្ជើញពួកគេចូលក្នុងផ្ទះ ហើយឲ្យស្នាក់នៅជាមួយលោក
ដំណើរពីសេសារាជាដំណើរវែងឆ្ងាយណាស់សម្រាប់ពួកគេ
ស្នាក់នៅជាមួយលោក
«ធ្វើជាភ្ញៀវរបស់លោក»

generated on Wed Sep 10 16:16:32 2025

មានបងប្អូនខ្លះនៅក្រុងយ៉ុបប៉េ
ឃ្លានេះសំដៅលើពួកអ្នកជឿដែលរស់នៅក្នុងក្រុងយ៉ុបប៉េ។
Acts 10:24
មួយថ្ងៃក្រោយមក
ឃ្លានេះគឺជាថ្ងៃបន្ទាប់ ពួកគេបានចាកចេញពីក្រុងយ៉ុបប៉េ។
ធ្វើដំណើរទៅសេសារាវិញ ដោយចំណាយពេលជាងមួយថ្ងៃ។
លោកកូនេលាសកំពុងរង់ចាំពួកគេ
«លោកកូនេលាសរំពឹងរង់ចាំពួកគេ»
Acts 10:25
ពេលលោកពេត្រុសមកដល់
«ពេលលោកពេត្រុសចូលមកដល់ក្នុងផ្ទះ»
លុតជង្គង់ចុះទៀបជើងលោក ដើម្បីថ្វាយបង្គំ
ទោះបីជាការលុតជង្គង់គឺជារឿងសាមញ្ញនៅក្នុងវប្បធម៌នោះ នៅទីនេះ
លោកកូនេលាសបានលុតជង្គង់ចំពោះលោកពេត្រុស
ជាសកម្មភាពនៃការថ្វាយបង្គំ។
ចូរក្រោកឡើង! ខ្ញុំក៏ជាមនុស្សដែរ
នេះគឺជាការដាស់តឿន ឬកែតម្រង់ស្រាលៗដល់លោកកូនេលាស
មិនត្រូវថ្វាយបង្គំលោកពេត្រុសទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឈប់ធ្វើបែបនេះទៅ! ខ្ញុំក៏ជាមនុស្សដូចលោកដែរ»។
Acts 10:27
ប្រយោគភ្ជាប់
លោកពេត្រុសបានបញ្ជាក់ដល់មនុស្សដែលមកជុំគ្នានៅផ្ទះរបស់លោកកូនេលាស។
ព័ត៌មានទូទៅ
ពាក្យ «គាត់» នៅទីនេះ សំដៅលើលោកកូនេលាស។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» (អក្សរធំ) និង «អ្នក» (អក្សរតូច) ជាពហុវចន:
ហើយបូករួមទាំងលោកកូនេលាសផងដែរ
ដែលជាសាសន៍ដទៃនៅមានវត្តមាននៅទីនោះ។
មនុស្សជាច្រើននៅជុំគ្នា
«មានសាសន៍ដទៃជាច្រើនប្រជុំគ្នា»។ ឃ្លានេះ មានន័យថា
អ្នកដែលលោកកូនេលាសបានអញ្ជើញមកទាំងអស់នេះ គឺជាសាសន៍ដទៃ។
បងប្អូនដឹងទេ
លោកពេត្រុសកំពុងប្រាប់លោកកូនេលាស ហើយភ្ញៀវដែលលោកបានអញ្ជើញ។
វិន័យរបស់សាសនាយូដា ហាមមិនឲ្យសាសន៍យូដាទាក់ទងជាមួយ ឬសួរសុខទុក្ខជនជាតិផ្សេង
«វិន័យរបស់សាសន៍យូដាបានហាមសាសន៍យូដា»។
នេះសំដៅលើវិន័យរបស់សាសនាយូដា។
ជនជាតិផ្សេង
ឃ្លានេះសំដៅលើមនុស្សដែលមិនមែនជាជនជាតិយូដា
និងមិនសំខាន់ថាពួកគេរស់នៅទីណាទេ។
Acts 10:30
ប្រយោគភ្ជាប់
លោកកូនេលាសឆ្លើយទៅសំណួរលោកពេត្រុសវិញ។
ព័ត៌មានទូទៅ
នៅក្នុងខ ៣១ និង៣២
លោកកូនេលាសបានស្រង់សម្តីដែលទេវតាបានប្រាប់លោក
នៅពេលទេវតាលេចមកជួបលោកនៅម៉ោងប្រាំបួននោះ។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» និង «របស់អ្នក» ជាឯកវចន:ទាំងអស់។ ពាក្យ «យើង» នៅទីនេះ
មិនបូករួមលោកពេត្រុសទេ។
កាលពីបួនថ្ងៃមុន
លោកកូនេលាសសំដៅលើថ្ងៃមុនយប់ទីបីមុនពេលគាត់និយាយជាមួយលោកពេត្រុស។
នៅក្នុងវប្បធម៌របស់ព្រះគម្ពីររាប់ពីថ្ងៃបច្ចុប្បន្ន ដូច្នេះ ថ្ងៃមុនពេលបីថ្ងៃមុនគឺ
«បួនថ្ងៃមុន»។ បច្ចុប្បន្ននេះ នៅវប្បធម៌លោកខាងលិចមិនបានរាប់ថ្ងៃបច្ចុប្បន្នទេ
ដូច្នេះ នៅក្នុងការបកប្រែរបស់ពួកលោកខាងលិចសរសេរថា៖ «កាលពីបីថ្ងៃមុន»។
កំពុងអធិស្ឋាន
អជ្ញាធរពីបុរាណនិយាយថា៖ «ការតមអត់ និងការអធិស្ឋាន»
ជំនួសឲ្យគ្រាន់តែនិយាយថា «ការអធិស្ឋាន»។
ម៉ោងប្រាំបួន
ជាទូទៅគឺពេលរសៀល ដែលជនជាតិយូដាអធិស្ឋានទៅព្រះជាម្ចាស់។
ព្រះជាម្ចាស់បានឮសេចក្តីអធិស្ឋានរបស់លោកហើយ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានឮសេចក្តីអធិស្ឋានរបស់អ្នកហើយ»
ព្រះជាម្ចាស់ចងចាំ
«អ្នកបានធ្វើឲ្យព្រះជាម្ចាស់យកព្រះទ័យទុកដាក់ហើយ»។ នេះមិនមែនមានន័យថា
ព្រះជាម្ចាស់បានបោះបង់ចោលទេ។
ហៅបុរសម្នាក់ឈ្មោះស៊ីម៉ូន ហៅថាពេត្រុសឲ្យមករកលោកចុះ
«ប្រាប់លោកស៊ីម៉ូន ដែលគេហៅថាពេត្រុសឲ្យមករកអ្នក»។
ភ្លាមនោះ
«រំពេចនោះ»
លោកបានមកល្អហើយ
ឃ្លានេះបង្ហាញពីការគួរសមនៃការអរគុណដល់លោកពេត្រុសដែលបានមក។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំពិតជាអរគុណដល់លោកដែលបានមក» (UDB)
នៅចំពោះព្រះភក្ត្រព្រះជាម្ចាស់
ឃ្លានេះ សំដៅលើព្រះវត្តមានរបស់ព្រះជាម្ចាស់។
ព្រះអម្ចាស់បានបង្គាប់មកលោកមានប្រសាសន៍ហើយ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ថាព្រះអម្ចាស់បានប្រាប់លោកឲ្យមានប្រសាសន៍»
Acts 10:34
ប្រយោគភ្ជាប់
លោកពេត្រុសបានចាប់ផ្តើមមានប្រសាសន៍ទៅកាន់មនុស្សគ្រប់គ្នានៅក្នុងផ្ទះរបស់លោកកូនេលាស។
លោកពេត្រុសបើកមាត់របស់លោក ហើយមានប្រសាសន៍ថា
«លោកពេត្រុសបានចាប់ផ្តើមនិយាយជាមួយពួកគេ» (UDB)
ពិតណាស់
ឃ្លានេះមានន័យថា
អ្វីដែលលោកនឹងមានប្រសាសន៍នេះគឺសំខាន់ណាស់ដែលត្រូវដឹង។
ព្រះជាម្ចាស់មិនរើសមុខនរណាឡើយ
«ព្រះជាម្ចាស់មិនរើសមុខនរណាឡើយ»។
អ្នកណាក៏ដោយដែលថ្វាយបង្គំព្រះអង្គ ហើយប្រព្រឹត្តសុចរិត ព្រះអង្គទទួលអ្នកនោះមិនខាន
«ព្រះអង្គទទួលមនុស្សគ្រប់គ្នា ដែលគោរពកោតខ្លាចព្រះអង្គ
ហើយធ្វើអ្វីដែលសុចរិត»
ថ្វាយបង្គំព្រះអង្គ
ពាក្យ «ថ្វាយបង្គំព្រះអង្គ» នៅទីនេះ មានន័យថា គោរពកោតខ្លាច
និងស្វប់ស្វែងព្រះអង្គយ៉ាងខ្លាំង។
Acts 10:36
ប្រយោគភ្ជាប់
លោកពេត្រុសបន្តប្រាប់ដល់លោកកូនេលាស និងភ្ញៀវរបស់លោកទៀត។
ព័ត៌មានទូទៅ
ពាក្យថា «គាត់» នៅទីនេះ សំដៅលើព្រះយេស៊ូ។
បងប្អូនដឹងហើយថា ព្រះបន្ទូលដែលព្រះអង្គបានប្រទាន និងជាមួយនឹងអំណាច
ប្រយោគដ៏វែងនេះអាចធ្វើឲ្យខ្លីដូចនៅក្នុងគម្ពីរ UDB ដែរ។
ជាព្រះអម្ចាស់ លើមនុស្សទាំងអស់
ពាក្យ «លើទាំងអស់» នៅទីនេះ មានន័យថា «លើមនុស្សទាំងអស់»
នៅក្នុងស្រុកយូដាទាំងមូល
ឃ្លានេះជាឃ្លាបំផ្លើស។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅតាមកន្លែងជាច្រើនក្នុងស្រុងយូដា»
លោកយ៉ូហានបានប្រកាសពីពិធីជ្រមុជទឹក
«បន្ទាប់ពីលោកយ៉ូហានប្រកាសដល់មនុស្សឲ្យប្រែចិត្ត
និងបន្ទាប់ធ្វើពិធីជ្រមុជទឹកឲ្យពួកគេ»។
ព្រះជាម្ចាស់បានចាក់ព្រះវិញ្ញាណដ៏វិសុទ្ធ និងអំណាចលើព្រះអង្គ។
ព្រះវិញ្ញាណដ៏វិសុទ្ធ និងអំណាចរបស់ព្រះជាម្ចាស់
និយាយដូចជាអ្វីមួយដែលអាចចាក់លើមនុស្ស។
អស់អ្នកដែលត្រូវមារសង្កត់សង្កិនឲ្យបានជា
ឃ្លានេះបំផ្លើស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានមនុស្សជាច្រើនដែលត្រូវមារសង្កត់សង្កិន» ។
ព្រះជាម្ចាស់គង់ជាមួយព្រះអង្គ
ឃ្លាប្រៀបធៀបនេះគឺ «ព្រះអង្គគង់ជាមួយគាត់» មានន័យថា «ជួយគាត់»។
Acts 10:39

generated on Wed Sep 10 16:16:32 2025

ប្រយោគភ្ជាប់
ពាក្យ «យើង»
ព័ត៌មានទូទៅ
ពាក្យ «ព្រះអង្គ» និង «ទ្រង់»នៅទីនេះ សំដៅលើព្រះយេស៊ូ។
នៅក្នុងស្រុករបស់ជនជាតិយូដា
ឃ្លានេះ សំដៅលើស្រុកយូដាទាំងមូលនៅសម័យនោះ។
ពួកគេបានសម្លាប់ព្រះអង្គ
«អស់អ្នកដែលជាអ្នកដឹកនាំជនជាតិយូដាបានសម្លាប់ព្រះអង្គ»
ដោយព្យួរព្រះអង្គនៅលើឈើ
ឃ្លានេះ គឺជាការបញ្ជាក់មួយទៀតដែលសំដៅលើការឆ្កាង។
របៀបផ្សេងទៀតនៃការបកប្រែ: «ឆ្កាងព្រះអង្គនៅលើឈើឆ្កាង» (UDB)
បុរសនេះ
«បុរសនេះគឺព្រះយេស៊ូ»
ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យរស់ឡើងវិញ
«ព្រះជាម្ចាស់បានធ្វើឲ្យរស់ឡើងវិញម្តងទៀត»
នៅថ្ងៃទីបី
«នៅថ្ងៃទីបី បន្ទាប់ពីព្រះអង្គសុគត»
ធ្វើឲ្យគេឃើញព្រះអង្គ
«ធ្វើឲ្យគេបានឃើញព្រះអង្គ»
ក្រោយពេលព្រះអង្គរស់ពីស្លាប់ឡើងវិញ
«ក្រោយពេលព្រះអង្គរស់ពីស្លាប់ឡើងវិញ»។ ពាក្យថា «អ្នកស្លាប់» សំដៅលើវិញ្ញាណរបស់មនុស្សដែលបានស្លាប់ទៅ។ បានត្រឡប់មកវិញពីចំណោមពួកគេ មានន័យថាបានរស់ឡើងវិញម្តងទៀត។
Acts 10:42
ប្រយោគភ្ជាប់
លោកពេត្រុសបញ្ចប់សុន្ទរកថារបស់លោកចំពោះមនុស្សគ្រប់គ្នានៅក្នុងផ្ទះរបស់លោកកូនេលាស ដែលបានចាប់ផ្តើមនៅក្នុងជំពូក ១០:៣៤
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ បូករួមទាំងលោកពេត្រុស និងពួកអ្នកជឿ។ មិនបានបូករួមជាមួយអ្នកស្តាប់គាត់ទេ។
ព្រះអង្គគឺជាព្រះ ដែលព្រះជាម្ចាស់បានជ្រើសរើស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «នោះព្រះជាម្ចាស់បានជ្រើសរើសព្រះយេស៊ូនេះ»
ទាំងមនុស្សរស់ និងមនុស្សស្លាប់
ឃ្លានេះ សំដៅលើមនុស្សដែលនៅរស់ និងមនុស្សដែលស្លាប់។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សដែលរស់ និងមនុស្សដែលស្លាប់» ។
គឺព្រះអង្គហើយ ដែលពួកព្យាការីទាំងប៉ុន្មានបានធ្វើបន្ទាល់នោះ
«ដែលពួកព្យាការីទាំងអស់ធ្វើបន្ទាល់ពីព្រះយេស៊ូ»។
អស់អ្នកណាដែលជឿលើព្រះអង្គ នឹងទទួលការអត់ទោសឲ្យរួចពីបាប
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់នឹងអត់ទោសបាបដល់អស់អ្នកដែលជឿលើព្រះយេស៊ូ ដោយសារតែអ្វីដែលព្រះអង្គបានធ្វើ។
តាមរយៈព្រះនាមព្រះអង្គ
ពាក្យ «ព្រះនាមព្រះអង្គ» នៅទីនេះ សំដៅលើកិច្ចការរបស់ព្រះយេស៊ូ។ ព្រះនាមព្រះអង្គមានន័យថា ព្រះជាម្ចាស់សង្គ្រោះ។ របៀបផ្សេងទៀតនៃការបកប្រែ: «តាមរយៈអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ពួកគេ» ។
Acts 10:44
ព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមក
ពាក្យ «យាងចុះមក» នៅទីនេះ សំដៅលើការ «យាងចុះមកភ្លាមៗ»។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកភ្លាម»
អស់អ្នកដែលស្តាប់ព្រះបន្ទូលដែលលោកថ្លែង
ពាក្យ «អស់អ្នក» សំដៅលើសាសន៍ដទៃគ្រប់គ្នា
នៅផ្ទះដែលពួកគេបានស្តាប់លោកពេត្រុស។
ពួកអ្នកដែលជាសមាជិកពួកអ្នកជឿ ដែលបានកាត់ស្បែក
ឃ្លានេះគឺជាវិធីមួយទៀតក្នុងការសំដៅលើពួកអ្នកជឿសាសន៍យូដា។
អំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ
ឃ្លានេះ សំដៅលើព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់ ដែលបានប្រទានមកដល់ពួកគេ។
ព្រះវិញ្ញាណដ៏វិសុទ្ធ បានចាក់បង្ហូរ
ឃ្លានេះស្ថិតនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ»
បានចាក់បង្ហូរ
និយាយពីព្រះវិញ្ញាណដ៏វិសុទ្ធប្រៀបដូចជាអ្វីមួយដែលអាចចាក់បង្ហូរមកលើមនុស្សបាន។ នៅក្នុងន័យបង្ហូរមកដោយចិត្តសប្បុរស។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រទានមកដោយសប្បុរស» ។
អំណោយទាន
«អំណោយដោយឥតគិតថ្លៃ»
មកសាសន៍ដទៃដែរ
ពាក្យ «ផងដែរ» នៅទីនេះ
សំដៅលើសេចក្តីពិតដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានដល់ពួកអ្នកជឿសាសន៍យូដារួចហើយ។
Acts 10:46
ប្រយោគភ្ជាប់
ឃ្លានេះបញ្ចប់សាច់រឿងរបស់លោកកូនេលាស។
ពាក្យ «លោក» និង «គាត់» សំដៅលោកពេត្រុស។
ពួកគេបានឮសាសន៍ដទៃទាំងនេះនិយាយភាសាផ្សេងៗ ហើយសរសើរដល់ព្រះជាម្ចាស់ផង
ការទាំងនេះភាសាដែលគេដឹងថា
បានធ្វើឲ្យជនជាតិយូដាទទួលស្គាល់ថាសាសន៍ដទៃក៏សរសើរព្រះជាម្ចាស់ដែរ។
តើនរណាអាចរារាំងយើង មិនឲ្យបងប្អូនទាំងនេះធ្វើពិធីជ្រមុជទឹកបាន និងបងប្អូនទាំងនេះដែលបានទទួល... ដូចជាយើងដែរឬទេ?»
លោកពេត្រុសប្រើសំណួរនេះដើម្បីបញ្ចុះបញ្ចូលដល់គ្រិស្តបរិស័ទសាសន៍យូដាថា ពួកអ្នកជឿសាសន៍ដទៃក៏អាចទទួលបុណ្យជ្រមុជទឹកដែរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាអាចរារាំងអ្នកទាំងនេះមិនឲ្យជ្រមុជទឹកឡើយ! យើងត្រូវជ្រមុជទឹកឲ្យពួកគេដោយសារពួកគេបានទទួល...ដូចយើងដែរ!»
លោកក៏បង្គាប់ឲ្យគេធ្វើពិធីជ្រមុជទឹក
ឃ្លានេះ បានបង្ហាញដល់គ្រិស្តបរិស័ទសាសន៍យូដាគឺជាអ្នកដែលជ្រមុជទឹកឲ្យគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកពេត្រុសបង្គាប់ឲ្យគ្រិស្តបរិស័ទសាសន៍យូដាជ្រមុជទឹកឲ្យពួកគេ»
ធ្វើពិធីជ្រមុជទឹកដល់ពួកគេ ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត
ពាក្យ «ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត» នៅទីនេះ
បង្ហាញពីហេតុដែលពួកគេត្រូវជ្រមុជទឹកថា ពួកគេជឿលើព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរទទួលពិធីជ្រមុជ ក្នុងនាមជាអ្នកជឿលើព្រះយេស៊ូគ្រិស្ត»

---

11 [1]ក្រុមសាវក និងបងប្អូននៅស្រុកយូដាឮដំណឹងថា សាសន៍ដទៃបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។[2]កាលលោកពេត្រុសឡើងទៅដល់ក្រុងយេរូសាឡឹមវិញ
អ្នកជឿដែលជាសាសន៍យូដានាំគ្នារិះគន់លោកថា៖[3]«លោកបានចូលក្នុងផ្ទះសាសន៍ដទៃ ហើយក៏បានបរិភោគជាមួយពួកគេថែមទៀតផង!»។
[4]ប៉ុន្តែ លោកពេត្រុសក៏បានពន្យល់ក្បោះក្បាយប្រាប់គេថា៖[5]«កាលខ្ញុំកំពុងតែអធិស្ឋាននៅក្រុងយ៉ុបប៉េ ខ្ញុំក៏លង់ស្មារតីនិមិត្តឃើញវត្ថុម្យ៉ាងដូចកំរាលតូមួយយ៉ាងធំដែល
មានចងចុងជាយទាំងបួនជ្រុង ចុះពីលើមកដល់ខ្ញុំ។[6]ពេលខ្ញុំពិនិត្យយ៉ាងជិតដល់ទៅ។ ខ្ញុំឃើញមានសត្វចតុប្បាទ សត្វព្រៃ សត្វលូនវារ និងបក្សាបក្សី។
[7]បន្ទាប់មក ខ្ញុំក៏បានឮព្រះសូរសៀងបញ្ជាមកខ្ញុំថា៖ «ពេត្រុសអើយ! ចូរក្រោកឡើង ហើយសម្លាប់សត្វទាំងនេះបរិភោគទៅ!»។[8]ខ្ញុំទូលទៅវិញថា៖ «ទេ ព្រះអម្ចាស់ ទូលបង្គំ
ពុំដែលទទួលទានអ្វី ដែលវិន័យហាមឃាត់ ឬមិនបរិសុទ្ធនោះឡើយ។[9]ព្រះសូរសៀងនោះក៏បន្លឺចុះពីលើមេឃមក ជាលើកទីពីរថា៖ «អ្វីៗដែលព្រះជាម្ចាស់ប្រោសឲ្យបាន
បរិសុទ្ធហើយ ចូរកុំចាត់ទុកថាជាវិន័យហាមឃាត់នោះឡើយ»។[10]ហេតុការណ៍នេះបានកើតមានដល់ទៅបីដង ទើបវត្ថុនោះឡើងទៅលើមេឃវិញអស់។
[11]ពេលនោះ ស្រាប់តែមានបុរសបីនាក់ ដែលគេចាត់ពីក្រុងសេសារាឲ្យមករកខ្ញុំ បានឈរនៅមុខផ្ទះ ដែលយើងស្នាក់នៅ។[12]ព្រះវិញ្ញាណមានព្រះបន្ទូលប្រាប់ខ្ញុំឲ្យចេញ
ដំណើរទៅជាមួយគេ កុំរារែកឡើយ។ ពេលនោះ មានបងប្អូនប្រាំមួយនាក់បានរួមដំណើរជាមួយខ្ញុំ ហើយយើងបានទៅដល់ផ្ទះលោកកូនេលាស។[13]លោកបានរៀបរាប់ប្រាប់
យើងថា លោកបានឃើញទេវតាឈរនៅក្នុងផ្ទះលោក ទាំងពោលថា៖ «សុំលោកចាត់មនុស្សឲ្យទៅក្រុងយ៉ុបប៉េ រកម្នាក់ឈ្មោះស៊ីម៉ូនហៅពេត្រុស។[14]គាត់នឹងប្រកាស
ព្រះបន្ទូល ដែលផ្តល់ការសង្គ្រោះដល់លោក និងក្រុមគ្រួសាររបស់លោកទាំងមូល»។

generated on Wed Sep 10 16:16:32 2025

[15]នៅពេលខ្ញុំចាប់ផ្តើមនិយាយ ព្រះវិញ្ញាណដ៏វិសុទ្ធក៏យាងចុះមកសណ្ឋិតលើពួកគេ ដូចព្រះអង្គបានយាងចុះមកសណ្ឋិតលើយើងកាលពីដើមដំបូងនោះដែរ។[16]ខ្ញុំក៏នឹកឃើញព្រះបន្ទូលរបស់ព្រះអម្ចាស់ថា៖ «លោកយ៉ូហានបានធ្វើពិធីជ្រមុជឲ្យគេក្នុងទឹក រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នានឹងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ»។
[17]បើព្រះជាម្ចាស់ប្រទានព្រះអំណោយទានដល់គេ ដូចព្រះអង្គប្រទានមកយើងដែលជឿលើព្រះអម្ចាស់យេស៊ូគ្រិស្តដែរនោះ តើរូបខ្ញុំនេះមានអំណាចអ្វីនឹងឃាត់ឃាំងព្រះជាម្ចាស់បាន?»[18]កាលពួកអ្នកជឿបានឮសេចក្តីទាំងនេះ គេក៏ធូរចិត្ត ហើយនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ទាំងពោលថា៖ «សូម្បីតែសាសន៍ដទៃ ក៏ព្រះជាម្ចាស់ប្រោសប្រទានឲ្យគេកែប្រែចិត្តគំនិត ដើម្បីទទួលជីវិតដែរ»។
[19]ក្រោយពីជនជាតិយូដាបានសម្លាប់លោកស្តេផានហើយ ពួកគេក៏បៀតបៀនអ្នកជឿ ធ្វើឲ្យអ្នកទាំងនោះខ្ចាត់ខ្ចាយ អ្នកខ្លះទៅដល់ស្រុកភេនីស អ្នកខ្លះទៅដល់កោះគីប្រុស និងអ្នកខ្លះទៀតទៅដល់ក្រុងអន់ទីយ៉ូក។ អ្នកជឿទាំងនោះបានប្រកាសព្រះបន្ទូលដល់សាសន៍យូដាតែប៉ុណ្ណោះ។[20]ប៉ុន្តែ មានអ្នកជឿខ្លះពីកោះគីប្រុស និងពីស្រុកគីរេនមកដល់ក្រុងអន់ទីយ៉ូក ក៏បានប្រកាសដំណឹងល្អអំពីព្រះអម្ចាស់យេស៊ូ ដល់ពួកអ្នកដែលនិយាយភាសាក្រិកផងដែរ។[21]ព្រះអម្ចាស់បានជួយជ្រោមជ្រែងគេ ហើយមានមនុស្សដ៏ច្រើនលើសលប់បានជឿ ព្រមទាំងបែរចិត្តគំនិតមករកព្រះអម្ចាស់។
[22]ក្រុមជំនុំនៅក្រុងយេរូសាឡឹមបានឮដំណឹងនេះ ក៏ចាត់លោកបារណាបាសឲ្យទៅក្រុងអន់ទីយ៉ូក។[23]ពេលគាត់ទៅដល់ ហើយឃើញព្រះគុណរបស់ព្រះជាម្ចាស់ដូច្នេះ គាត់ត្រេកអរសប្បាយ។ គាត់បានទូន្មានពួកគេគ្រប់គ្នានៅតែឲ្យនៅតែប្តេជ្ញាចិត្តជាមួយព្រះអម្ចាស់ជានិច្ច។[24]លោកបារណាបាសជាមនុស្សម្នាក់មានចិត្តសប្បុរសពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយជំនឿ ហើយបណ្តាជនជាច្រើនបានទទួលជឿព្រះជាម្ចាស់។
[25]បន្ទាប់មកទៀត លោកបារណាបាសចេញដំណើរទៅរកលោកសូលនៅក្រុងតើសុស។[26]កាលបានជួបហើយ គាត់ក៏នាំលោកមកក្រុងអន់ទីយ៉ូក។ លោកទាំងពីរបានរស់នៅជាមួយក្រុមជំនុំអស់រយៈពេលមួយឆ្នាំ ហើយបង្រៀនបណ្តាជនជាច្រើនផង។ នៅក្រុងអន់ទីយ៉ូកនោះហើយ ដែលគេហៅពួកសាវក «គ្រិស្តបរិស័ទ» ដំបូងគេបង្អស់។
[27]នៅគ្រានោះ មានពួកព្យាការីធ្វើដំណើរចុះពីក្រុងយេរូសាឡឹម មកដល់ក្រុងអន់ទីយ៉ូក។[28]ក្នុងចំណោមព្យាការីទាំងនោះ មានម្នាក់ឈ្មោះអកាប៊ូស។ ដោយព្រះវិញ្ញាណបានបំភ្លឺ គាត់ក្រោកឡើងប្រាប់ពួកអ្នកជឿឲ្យដឹងថា បន្តិចទៀតនឹងមានកើតទុរ្ភិក្សនៅលើផែនដីទាំងមូល។ ទុរ្ភិក្សនោះក៏កើតមានមែន គឺនៅក្នុងរជ្ជកាលព្រះចៅអធិរាជក្លូឌាស។
[29]ពួកសិស្សនាំគ្នាសម្រេចចិត្តផ្ញើជំនួយតាមសមត្ថភាពរៀងៗខ្លួន ជូនបងប្អូននៅស្រុកយូដា។[30]ពួកគេបានប្រមូលប្រាក់ ហើយផ្ញើយកទៅជូនពួកព្រឹទ្ធាចារ្យតាមលោកបារណាបាស និងលោកសូល។

Acts 11:1

ប្រយោគភ្ជាប់

លោកពេត្រុសបានមកដល់ក្រុងយេរូសាឡិម
ហើយបានចាប់ផ្តើមនិយាយជាមួយជនជាតិយូដានៅទីនោះ។

ព័ត៌មានទូទៅ

នេះគឺជាការចាប់ផ្តើមព្រឹត្តការណ៍ថ្មីនៅក្នុងសាច់រឿង។

ឥឡូវនេះ

ឃ្លានេះ បញ្ជាក់ពីផ្នែកថ្មីនៃសាច់រឿង។

ពួកបងប្អូន

ឃ្លាថា «ពួកបងប្អូន» នៅទីនេះ សំដៅលើពួកអ្នកជឿនៅក្នុងស្រុកយូដា។

ដែលនៅស្រុកយូដា

«អ្នកដែលរស់នៅក្នុងស្រុកយូដា»

បានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ

ឃ្លានេះសំដៅលើសេចក្តីពិតដែលសាសន៍ដទៃដែលបានជឿលើដំណឹងល្អអំពីព្រះយេស៊ូវ
របៀបផ្សេងទៀតនៃការបកប្រែ:
«បានជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់អំពីព្រះយេស៊ូ»

ឡើងទៅដល់ក្រុងយេរូសាឡិមវិញ

ក្រុងយេរូសាឡិមមានកម្ពស់ខ្ពស់ជាងកន្លែងផ្សេងៗទៀតជាច្រើននៅក្នុងអ៊ីស្រាអែល។
ដូច្នេះ
វាជារឿងសាមញ្ញដែលជនជាតិអ៊ីស្រាអែលនិយាយថាឡើងទៅក្រុងយេរូសាឡិម
និងចុះពីក្រុង។

ពួកអ្នកដែលជាសមាជិកកាត់ស្បែក

ឃ្លានេះ ជាអំណះអំណាងចំពោះជនជាតិយូដាខ្លះដែលបានជឿថា
អ្នកជឿទាំងអស់ត្រូវតែកាត់ស្បែក។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអ្នកជឿជនជាតិយូដាខ្លះនៅក្នុងក្រុងយេរូសាឡិម
ដែលចង់ឲ្យពួកអ្នកដែលដើរតាមព្រះយេស៊ូទាំងអស់ត្រូវកាត់ស្បែក។

ពួកអ្នកដែលមិនកាត់ស្បែក

ពាក្យថា «ពួកអ្នកដែលមិនកាត់ស្បែក» សំដៅលើសាសន៍ដទៃ»

បានបរិភោគជាមួយពួកគេ

វាគឺជាប្រឆាំងនឹងទម្លាប់របស់ជនជាតិយូដាក្នុងការបរិភោគជាមួយសាសន៍ដទៃ។

Acts 11:4

ប្រយោគភ្ជាប់

លោកពេត្រុសបានឆ្លើយតបទៅជនជាតិយូដាដោយប្រាប់ពួកគេពីនិមិត្តរបស់លោក
និងពីអ្វីដែលបានកើតឡើងនៅក្នុងផ្ទះរបស់លោកកូនេលាស។

លោកពេត្រុសបានចាប់ផ្តើមពន្យល់

លោកពេត្រុសមិនបានរិះគន់ពួកអ្នកជឿជនជាតិយូដាទេ ប៉ុន្តែ លោកបានឆ្លើយតប
និងពន្យល់យ៉ាងសុភាព។

យ៉ាងល្អិតល្អន់

«យ៉ាងជាក់លាក់នូវអ្វីដែលបានកើតឡើង» (UDB)

ដូចកម្រាលតុមួយផ្ទាំងយ៉ាងធំ

វត្ថុដែលផ្ទុកសត្វទាំងឡាយមានរាងបួនជ្រុង ជាក្រណាត់មួយផ្ទាំងយ៉ាងធំ។
សូមមើលពីរបៀបនៃការបកប្រែនេះ នៅក្នុងជំពូក ១០:៩។

មានចងចុងជាយទាំងបួនជ្រុង

«មានចងចុងជាយទាំងបួនជ្រុង» ឬ «ទាំងបួនជ្រុងចុះពីលើមកដល់ដី»
សូមមើលពីការបកប្រែនៅក្នុង ១០:៩

មានសត្វចតុប្បាទនៅលើផែនដី

មានសត្វចតុប្បាទនៅលើផែនដី ការដែលលោកពេត្រុសឆ្លើយយ៉ាងដូច្នេះ
អាចបញ្ជាក់ថា
វិន័យរបស់លោកម៉ូសេបង្គាប់មិនឲ្យសាសន៍យូដាបរិភោគសាច់ខ្លះក្នុងចំណោមសត្វទាំងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «សត្វចតុបាទ
និងសត្វស្លាបដែលច្បាប់របស់លោកម៉ូសេបានហាមសាសន៍យូដាមិនឲ្យបរិភោគ»។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ១០:៩

សត្វព្រៃ

ប្រហែលជាសំដៅលើសត្វដែលមនុស្សមិនអាចចិញ្ចឹម ឬផ្សាំ ឬគ្រប់គ្រងបាន។

សត្វលូនវារ

ទាំងនេះគឺជាពពួកសត្វល្អួន។

Acts 11:7

ខ្ញុំបានឮព្រះសូរសៀង

មិនបានបញ្ជាក់ថានរណាអ្នកនិយាយ។ «សម្លេង» ប្រហែលជាព្រះជាម្ចាស់
ឬអាចជាទេវតារបស់ព្រះជាម្ចាស់។ សូមមើលពីរបៀបដែលអ្នកបកប្រែ: «សម្លេង»
នៅក្នុង១០:១៣.

ទេ

«ទូលបង្គំមិនធ្វើដូច្នេះទេ» សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក
១០:១៣

មិនដែលមានអ្វី ដែលស្មោកគ្រោក ឬមិនស្អាតចូលមកក្នុងមាត់ទូលបង្គំឡើយ

លក្ខណៈរបស់សត្វនៅក្នុងផ្ទាំងក្រណាត់នោះ
គឺជាអ្វីដែលវិន័យរបស់ជនជាតិយូដានៅក្នុងសម្ពន្ធមេត្រីចាស់ហាមជនជាតិយូដាមិនឲ្យបរិភោគ។
ឃ្លានេះនិយាយក្នុងន័យវិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំបរិភោគតែសាច់ណាដែលស្អាត ហើយបរិសុទ្ធប៉ុណ្ណោះ» ។

មិនស្អាត

នៅក្នុងសម្ពន្ធមេត្រីចាស់ ច្បាប់របស់ជនជាតិយូដា
មនុស្សនិងក្លាយជាមិនស្អាតដោយសារ ការផ្សេងៗ ដូចជា
បរិភោគសត្វដែលបានហាមជាដើម។

អ្វីៗដែលព្រះជាម្ចាស់ប្រកាសថាស្អាតហើយ មិនត្រូវហៅថាមិនស្អាតឡើយ

ឃ្លានេះសំដៅលើសត្វនៅក្នុងផ្ទាំងក្រណាត់។

ការនេះបានកើតឡើងបីដង

វាមិនធម្មតាទេ នៅពេលអ្វីមួយនិយាយម្តងទៀតម្តងទៀតរហូតដល់ទៅបីដង។
នេះប្រហែលជាមានន័យថា: «អ្វីដែលព្រះជាម្ចាស់សម្អាតហើយ

generated on Wed Sep 10 16:16:32 2025

កុំហៅថាមិនស្អាតឡើយ» បាននិយាយដដែលៗរហូតដល់បីដង។ ប៉ុន្តែ
វិធីងាយក្នុងការនិយាយគឺ «ការនេះបានកើតឡើងបីដង»
ជំនួសឲ្យនិយាយពន្យល់លម្អិត។ សូមមើលពីការដែលអ្នកបកប្រែនៅក្នុង ជំពូក
១០:១៣ «ការនេះបានកើតឡើងបីដង»
Acts 11:11
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកពេត្រុស
និងពួកអ្នកជឿនៅក្នុងក្រុងយ៉ុបប៉េ។
មិនបានបូកបញ្ចូលជាមួយអ្នកស្តាប់នៅក្រុងយេរូសាឡិម។
មើល៍
ពាក្យនេះរំលឹកយើងចំពោះមនុស្សថ្មីនៅក្នុងសាច់រឿង។
ភាសារបស់អ្នកអាចមានវិធីក្នុងការប្រើពាក្យនេះ។
រំពេចនោះ
«ភ្លាមនោះ» ឬ «ពេលខណៈនោះ» (UDB)
ពួកគេត្រូវបានគេចាត់
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នរណាម្នាក់បានចាត់គេឲ្យមក»
ដោយមិនមានការបារម្ភទាក់ទងនឹងពួកគេឡើយ
«ថា ខ្ញុំមិនត្រូវបារម្ភថា ពួកគេជាសាសន៍ដទៃឡើយ»
បងប្អូនទាំងប្រាំមួយនាក់នេះបានរួមដំណើរជាមួយខ្ញុំ
«បងប្អូនទាំងប្រាំមួយនាក់នេះបានរួមដំណើរជាមួយខ្ញុំទៅសេសារា»
បងប្អូនទាំងប្រាំមួយនាក់
«បងប្អូនទាំងប្រាំមួយនាក់ជាអ្នកជឿជនជាតិយូដា»
ទៅដល់ផ្ទះរបស់ម្នាក់នោះ
ឃ្លានេះសំដៅលើផ្ទះរបស់លោកកូនេលាស។
ឈ្មោះស៊ីម៉ូនដែលហៅថាពេត្រុសមក
«ឈ្មោះស៊ីម៉ូនដែលហៅថាពេត្រុសមក» សូមមើលពីការដែលអ្នកបកប្រែនៅក្នុង
ជំពូក ១០:៣០
នឹងធ្វើឲ្យបានសង្គ្រោះ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងសង្គ្រោះអ្នក»
ក្រុមគ្រួសាររបស់លោកគ្រប់គ្នាផង
ឃ្លានេះសំដៅលើមនុស្សទាំងអស់នៅក្នុងផ្ទះ។ របៀបផ្សេងទៀតក្នុងការបកប្រែ:
«មនុស្សគ្រប់គ្នាដែលរស់នៅនៅក្នុងផ្ទះរបស់អ្នក» (សូមមើល:figs-metonymy)
Acts 11:15
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះសំដៅលើ លោកពេត្រុស ពួកសាវក
និងពួកអ្នកជឿជនជាតិយូដាផ្សេងៗទៀតដែលទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៅថ្ងៃទីហាសិប
ក្នុងកាលដែលខ្ញុំចាប់ផ្តើមនិយាយទៅកាន់ពួកគេ ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកលើពួកគេ
ឃ្លានេះបង្ហាញថា លោកពេត្រុសមិនទាន់បញ្ចប់ការនិយាយរបស់គាត់ទេ ប៉ុន្តែ
លោកចង់និយាយច្រើនថែមទៀត។
ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកលើពួកគេ ដូចព្រះអង្គបានយាងចុះមកលើយើងតាំងពីដើមដំបូង
ដែរ
លោកពេត្រុសបានចាកចេញ ហើយបានយកមកនិយាយរឿងនេះខ្លីៗវិញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកលើពួកអ្នកជឿសាសន៍ដទៃ
ដូចដែលព្រះវិញ្ញាណបានសណ្ឋិតលើពួកអ្នកជឿជនជាតិយូដានៅថ្ងៃទីហាសិប» ។
តាំងពីដើមដំបូង
លោកពេត្រុសកំពុងសំដៅលើថ្ងៃទីហាសិប។
នឹងត្រូវជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងជ្រមុជដល់អ្នកនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ»
Acts 11:17
ប្រយោគភ្ជាប់
លោកប៉ូលបានបញ្ចប់សុន្ទរកថារបស់គាត់ (ដែលបានចាប់ផ្តើមនៅក្នុងជំពូក ១១:៤
ទៅកាន់ជនជាតិយូដាអំពីនិមិត្ត
និងអំពីអ្វីដែលបានកើតឡើងនៅផ្ទះរបស់លោកកូនេលាស។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើលោកកូនេលាស និងភ្ញៀវរបស់លោក
និងអ្នកផ្ទះរបស់គាត់។
លោកពេត្រុសមិនបានហៅពួកគេថាសាសន៍ដទៃនៅក្នុងទំនួលខុសត្រូវរបស់លោកចំពោះអ្នកជឿសាសន៍
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ»
សំដៅលើអ្នកជឿជនជាតិយូដាដែលលោកពេត្រុសនិយាយទៅកាន់។ ពាក្យ
«យើង» បូករួមទាំងអ្នកជឿសាសន៍យូដាទាំងអស់។
ព្រះជាម្ចាស់បានប្រទានអំណោយទានខ្លះដល់ពួកគេ...តើខ្ញុំជាអ្វីដែលខ្ញុំអាចប្រឆាំងជាមួយ
ព្រះជាម្ចាស់នោះ?
លោកពេត្រុសប្រើសំណួរនេះដើម្បីបញ្ជាក់ថា
លោកគ្រាន់តែស្តាប់បញ្ជាព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«បើព្រះជាម្ចាស់ប្រទានដល់ពួកគេ...ខ្ញុំសម្រេចថា
ខ្ញុំមិនប្រឆាំងជាមួយនឹងព្រះជាម្ចាស់ឡើយ»
អំណោយទានដូចគ្នា
លោកពេត្រុសសំដៅលើអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
ពួកគេមិនបានឆ្លើយតបអ្វីឡើយ
«ពួកគេឈប់រិះគន់លោកពេត្រុសទៀត»
ប្រទានឲ្យគេកែប្រែចិត្ត ដើម្បីទទួលជីវិត
«ប្រទានឲ្យគេកែប្រែចិត្ត ដើម្បីទទួលជីវិត»។
ប្រហែលជាសំដៅលើជីវិតអស់កល្បជានិច្ច។
Acts 11:19
ប្រយោគភ្ជាប់
លោកលូកាប្រាប់អំពីអ្វីដែលបានកើតឡើងដល់ពួកអ្នកជឿដែលរត់គេចបន្ទាប់ពីគេចោលលោកស្តេផាននឹង
ឥឡូវនេះ
នេះគឺជាការណែនាំផ្នែកថ្មីនៃសាច់រឿង។
អស់អ្នកដែលបានបែកខ្ចាត់ខ្ចាយ ដោយសារការបៀតបៀន
ដែលបានចាប់ផ្តើមដោយសម្លាប់លោកស្តេផាន
នេះគឺជាការនិយាយសារជាថ្មី នៅក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ការបៀតបៀនដែលបានចាប់ផ្តើមសម្លាប់លោកស្តេផាន ពួកអ្នកជឿបានខ្ចាត់ខ្ចាយ
ហើយពួកគេបានប្រកាស» ឬ
«ការរងទុក្ខដែលបានចាប់ផ្តើមបន្ទាប់ពីអ្នកដឹកនាំសាសន៍យូដាបានសម្លាប់លោកស្តេផាន
ដោយសារមានអ្នកជឿជាច្រើនចាកចេញពីក្រុងយេរូសាឡិម
ហើយពួកគេបានបែកខ្ញែកគ្នា»
តែសាសន៍យូដាប៉ុណ្ណោះ
ពួកអ្នកជឿគិតថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្រាប់សាសន៍យូដា
មិនមែនសម្រាប់សាសន៍ដទៃទេ។
បានប្រាប់ដល់ពួកអ្នកក្រិក
ប្រសិនបើអ្នកដែលនិយាយភាសាក្រិកក៏រាប់ជាសាសន៍ដទៃដែរឬ មិនមែនជនជាតិយូដា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ក៏បានប្រាប់ដល់សាសន៍ដទៃដែលនិយាយភាសាក្រិកដែរ» ។
ព្រះហស្តរបស់ព្រះអម្ចាស់បានជួយពួកគេ
ព្រះហស្តព្រះជាម្ចាស់បញ្ជាក់ពីកម្លាំងរបស់ព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ពេញដោយព្រះចេស្តាអាចធ្វើឲ្យពួកអ្នកជឿប្រកាសប្រកបដោយឥទ្ធិពល»
។
បានបែរមករកព្រះអម្ចាស់វិញ
ឃ្លានេះមានន័យថា ពួកគឈប់ជឿលើព្រះរបស់ពួកគេពីមុន
ហើយចាប់ផ្តើមជឿលើព្រះយេស៊ូ។
Acts 11:22
ព័ត៌មានទូទៅ
នៅក្នុងខទាំងនេះ ពាក្យ «គាត់» សំដៅលើ «លោកបារណាបាស»។ ពាក្យ
«ពួកគេ» សំដៅលើពួកអ្នកជឿរបស់ក្រុមជំនុំក្រុងយេរូសាឡិម។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «របស់ពួកគេ» សំដៅលើពួកអ្នកជឿថ្មី។ (សូមមើល: ១១:១៩)
បានឮមកដល់ក្រុមជំនុំ
ពាក្យ «ត្រចៀក» នៅទីនេះ សំដៅលើ «ពួកអ្នកជឿបានឮអំពីព្រឹត្តការណ៍នោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកអ្នកជឿនៅក្នុងក្រុងយេរូសាឡិម» ។
ឃើញអំណោយទានរបស់ព្រះជាម្ចាស់
«ឃើញព្រះគុណរបស់ព្រះជាម្ចាស់» ឬ

generated on Wed Sep 10 16:16:32 2025

«ព្រះជាម្ចាស់បានប្រព្រឹត្តដោយសប្បុរសចំពោះពួកអ្នកជឿ» (UDB)
លោកបានលើកទឹកចិត្តពួកគេ
«លោកបានបន្តក្នុងការលើកទឹកចិត្តដល់ពួកគេ»
ឲ្យនៅជាប់ជាមួយព្រះអម្ចាស់
«ឲ្យនៅតែស្មោះត្រង់ចំពោះព្រះអម្ចាស់» ឬ «ឲ្យបន្តទុកចិត្តលើព្រះអម្ចាស់»។
អស់ពីចិត្តជានិច្ច
«ទាំងស្រុង» ឬ «គ្រប់យ៉ាង»
ពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ
ព្រះវិញ្ញាណដ៏វិសុទ្ធបានគ្រប់គ្រងលើលោកបារណាបាស
នៅពេលលោកស្តាប់បង្គាប់ព្រះវិញ្ញាណដ៏វិសុទ្ធ។
មានមនុស្សជាច្រើនបានបន្ថែមមកក្នុងព្រះអម្ចាស់ថែមទៀត
ពាក្យ «បានបន្ថែម» នៅទីនេះ មានន័យថាពួកគេបានជឿដូចអ្នកដទៃជឿដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «មានមនុស្សជាច្រើនទៀត
ក៏ជឿលើព្រះអម្ចាស់ដែរ» ។
Acts 11:25
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកបារណាបាស និង «របស់គាត់»
សំដៅលើលោកសូល។
ទៅក្រុងតើសុស
«ចេញទៅទីក្រុងតើសុស»
ដើម្បីស្វែងរកលោកសូលនៅ... ពេលរកលោកឃើញហើយ
ឃ្លានេះបង្ហាញថា លោកបារណាបាសបានចំណាយពេល
និងកម្លាំងដើម្បីស្វែងរកទីតាំងលោកប៉ុល។
គ្រានោះ
ឃ្លានេះចាប់ផ្តើមព្រឹត្តការណ៍ថ្មីនៅក្នុងសាច់រឿង។
ពួកគេបានរស់នៅជាមួយក្រុមជំនុំ
«លោកបារណាបាស និងលោកសូលបានរស់នៅជាមួយក្រុមជំនុំជាមួយគ្នា»
ពួកសិស្សនៅក្រុងអន់ទីយ៉ូកត្រូវបានគេហៅថា «គ្រិស្តបរិស័ទ»
ឃ្លានេះបង្ហាញថា អ្នកដទៃហៅពួកអ្នកជឿតាមឈ្មោះនេះឯង។
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកក្រុងអន់ទីយ៉ូកហៅពួកសិស្សថា គ្រិស្តបរិស័ទ» ។
ជំបូងនៅក្រុងអន់ទីយ៉ូក
«លើកទីមួយនៅក្នុងក្រុងអន់ទីយ៉ូក។
Acts 11:27
ព័ត៌មានទូទៅ
នៅទីនេះ លោកលូកាប្រាប់ពីប្រវត្តិអំពីសេចក្តីទំនាយនៅក្នុងក្រុងអន់ទីយ៉ូក។
ឥឡូវនេះ
ពាក្យដែលប្រើនៅទីនេះ ដើម្បីសម្គាល់ពីការសម្រាកនៅក្នុងរឿងចម្បង។
ចុះពីក្រុងយេរូសាឡិម ទៅឯក្រុងអន់ទីយ៉ូក
ក្រុងយេរូសាឡិមមានកម្ពស់ខ្ពស់ជាងក្រុងអន់ទីយ៉ូក ដូច្នេះ
វាគឺជាការសាមញ្ញក្នុងការឡើង និងចុះពីក្រុងយេរូសាឡិម។
ម្នាក់ក្នុងចំណោមពួកគេ ឈ្មោះអកាប៊ូស
«លោកឈ្មោះអកាប៊ូស» (UDB)
មានការបង្ហាញពីព្រះវិញ្ញាណ
«ព្រះវិញ្ញាណដ៏វិសុទ្ធបានបណ្តាលឲ្យគាត់អាចថ្លែងទំនាយ» (UDB)
នឹងមានកើតទុរ្ភិក្ស
«នឹងមានខ្វះអាហារកើតឡើង»
នៅលើផែនដីទាំងមូល
នេះគឺជាការបំផ្លើសសំដៅទៅលើអាណាចក្ររ៉ូមទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេញទូទាំងអាណាចក្ររ៉ូម»
នៅក្នុងរជ្ជកាលព្រះចៅក្លូឌាស
អ្នកស្តាប់របស់លោកលូកាអាចដឹងថា
ព្រះចៅក្លូឌាសជាអ្នកគ្រប់គ្រងនៅក្នុងអាណាចក្ររ៉ូម» ។
Acts 11:29
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «ពួកគេ» សំដៅលើពួកអ្នកជឿនៅក្នុងក្រុមជំនុំអន់ទីយ៉ូក។
(សូមមើល: ២២:២៧)
ដូច្នេះ
ពាក្យនេះ មានន័យថា
ជាទីសម្គាល់អំពីអ្វីដែលបានកើតឡើងដោយសាររឿងអ្វីមួយបានកើតឡើងមុន។
នៅក្នុងករណីនេះ ពួកគេបានផ្ញើប្រាក់ដោយសារលោកអកាប៊ូសថ្លែងទំនាយ
ឬប្រកាសពីគ្រោះអត់ឃ្លាន។
តាមលទ្ធភាពរៀងៗខ្លួន
អ្នកមានផ្ញើច្រើន អ្នកក្រជាងផ្ញើតិច។
បងប្អូននៅក្នុងស្រុកយូដា
«ដល់ពួកអ្នកជឿនៅក្នុងស្រុកយូដា»
តាមរយៈ
«នៅក្រោមការមើលថែរបស់»

---

12 [1]ឥឡូវនេះដល់ពេលដែលព្រះបាទហេរ៉ូដបានលូកព្រះហស្ថ លើសមាជិកខ្លះនៃក្រុមជំនុំ ធ្វើដូច្នេះដើម្បីធ្វើបាបពួកគេ។[2]ស្តេចបានឲ្យគេប្រហារជីវិតលោកយ៉ាកុបជាបងរបស់លោកយ៉ូហានដោយដាវ។
[3]ដោយយល់ឃើញថាជនជាតិយូដាពេញចិត្ត ទ្រង់ក៏ចាត់គេឲ្យទៅចាប់លោកពេត្រុសថែមទៀត។ ពេលនោះ ជាពេលបុណ្យនំប៉័ងឥតមេ។[4]បន្ទាប់ពីចាប់លោកពេត្រុសយកទៅឃុំឃាំងហើយ ស្តេចក៏បញ្ជាឲ្យទាហានបួនក្រុមនៅយាមលោក ក្នុងក្រុមនីមួយៗមានគ្នាបួននាក់ រួចព្រះបាទហេរ៉ូដមានបំណងនឹងកាត់ទោសលោកនៅមុខប្រជាជនក្រោយបុណ្យចម្លង។
[5]ដូច្នេះ លោកពេត្រុសក៏ជាប់នៅក្នុងមន្ទីរឃុំឃាំង តែក្រុមជំនុំបាននាំគ្នាទូលអង្វរព្រះជាម្ចាស់ឥតស្រាកស្រាន្ត សូមព្រះអង្គជួយលោក។[6]នៅយប់មុនពេលដែលព្រះបាទហេរ៉ូដយកលោកពេត្រុសទៅកាត់ទោស លោកសម្រាន្តទាំងជាប់ច្រវាក់ពីរខ្សែផង មានទាហានពីរនាក់នៅអមសងខាង ហើយក៏មានទាហានយាមនៅមាត់ទ្វារពន្ធនាគារដែរ។
[7]ពេលនោះ ទេវតារបស់ព្រះអម្ចាស់មកដល់ ហើយមានពន្លឺភ្លឺក្នុងទីឃុំឃាំង។ ទេវតាដាស់លោកពេត្រុស ដោយកេះលោកពីចំហៀង ទាំងពោលថា៖ «សូមក្រោកឡើងជាប្រញាប់!» ហើយច្រវាក់ក៏របូតធ្លាក់ពីដៃលោក។[8]ទេវតាពោលមកកាន់លោកថា៖ «សូមស្លៀកសម្លៀកបំពាក់ហើយពាក់ស្បែកជើងទៅ!» លោកក៏ធ្វើតាម។ ទេវតាពោលមកលោកទៀតថា៖ «សូមពាក់អាវក្រៅ ហើយអញ្ជើញមកតាមខ្ញុំ»។
[9]លោកពេត្រុសក៏ចេញពីទីឃុំឃាំងដើរតាមក្រោយទេវតាទៅ។ លោកពុំនឹកស្មានថា ការដែលទេវតាកំពុងធ្វើនេះ ជាការពិតទេ។ លោកស្មានថាលោកកំពុងយល់សប្តិ។
[10]ទេវតា និងលោកពេត្រុសបានឆ្លងផុតកន្លែងយាមទីពីរ ហើយមកដល់ទ្វារដែក ដែលបែរទៅរកទីក្រុង ទ្វារនោះបើកដោយខ្លួនវានៅមុខអ្នកទាំងពីរ។ អ្នកទាំងពីរដើរចេញក្រៅទ្វារក្រុង ហើយបានដើរទៅតាមដងផ្លូវមួយ រួចស្រាប់តែទេវតាចេញបាត់ពីលោកពេត្រុសទៅ។
[11]លោកពេត្រុសបានដឹងខ្លួនក៏ពោលថា៖ «ឥឡូវនេះ ខ្ញុំដឹងថាហេតុការណ៍នេះជាការពិតមែន ព្រះអម្ចាស់បានចាត់ទេវតារបស់ព្រះអង្គមកដោះលែងខ្ញុំ ឲ្យរួចពីកណ្តាប់ដៃរបស់ស្តេចហេរ៉ូដ និងរួចពីបំណងដែលប្រជាជនយូដាបម្រុងធ្វើមកលើរូបខ្ញុំ»។[12]ពេលលោកបានដឹងដូច្នោះ លោកក៏ទៅផ្ទះនាងម៉ារីជាម្តាយយ៉ូហានហៅម៉ាកុស ជាកន្លែងមានបងប្អូនជាច្រើនកំពុងជួបជុំគ្នាអធិស្ឋាន។
[13]នៅពេលលោកគោះទ្វារ មានស្ត្រីបម្រើម្នាក់ ឈ្មោះនាងរ៉ូដាចេញ។[14]នាងស្គាល់ថាជាសំឡេងរបស់លោកពេត្រុស។ ដោយនាងត្រេកអរខ្លាំងពេក នាងពុំបានបើកទ្វារឲ្យទេ នាងបែរជារត់ចូលទៅជូនដំណឹងប្រាប់ពួកបងប្អូនថា៖ «លោកពេត្រុសមកដល់ហើយ លោកឈរនៅមាត់ទ្វារ»។[15]គេនាំគ្នានិយាយមកកាន់នាងថា៖ «នាងឆ្កួតហើយ!» ប៉ុន្តែ នាងបានប្រកែកវិញថា៖ «លោកពិតជាមកដល់មែន»។ ពួកគេនិយាយថា៖ «អ្នកនោះជាទេវតារបស់លោកពេត្រុសទេដឹង»។
[16]លោកពេត្រុសនៅតែគោះទ្វារដដែល គេក៏ចេញទៅបើកទ្វារឲ្យ ហើយពេលឃើញលោក គេក៏ស្ញើចជាខ្លាំង។[17]លោកពេត្រុសធ្វើសញ្ញាឲ្យគេនៅស្ងៀម រួចរៀបរាប់អំពីរបៀបដែលព្រះអម្ចាស់បានជួយលោក ឲ្យចេញរួចពីទីឃុំឃាំង។ លោកមានប្រសាសន៍ទៅគេថា៖ «សូមយកដំណឹងនេះទៅជម្រាបលោកយ៉ាកុប និងពួកបងប្អូនផង»។ បន្ទាប់មក លោកបានចេញពីទីនោះ ធ្វើដំណើរឆ្ពោះទៅកន្លែងមួយផ្សេងទៀត។

generated on Wed Sep 10 16:16:32 2025

[18]លុះភ្លឺឡើង ពួកទាហាននាំគ្នាជ្រួលច្របល់យ៉ាងខ្លាំង ព្រោះមិនដឹងជាលោកពេត្រុសទៅណាបាត់។[19]ព្រះបាទហេរ៉ូដបញ្ជាឲ្យគេរកលោក តែរកមិនឃើញសោះ ស្តេចក៏ឲ្យគេកាត់ទោសពួកអ្នកយាម រួចនាំយកទៅសម្លាប់។ បន្ទាប់មក ស្តេចយាងចុះពីស្រុកយូដាទៅគង់ប្រថាប់នៅក្រុងសេសារា។
[20]ព្រះបាទហេរ៉ូដក្រោតនឹងអ្នកក្រុងទីរ៉ុស និងអ្នកក្រុងស៊ីដូន។ អ្នកទាំងនោះបាននាំគ្នាចូលទៅគាល់ស្តេច។ គេបានបញ្ចុះបញ្ចូលលោកប្លាសតុសជាមហាតលិកឲ្យជួយពួកគេ។ រួចគេទូលសូមសន្តិភាពពីស្តេច ដ្បិតស្រុករបស់គេទទួលស្បៀងអាហារពីនគរព្រះបាទហេរ៉ូដ។[21]លុះដល់ថ្ងៃកំណត់ ព្រះបាទហេរ៉ូដទ្រង់គ្រឿងគង់លើបល្ល័ង្ក ហើយមានព្រះរាជឱង្ការទៅពួកគេ។
[22]ប្រជាជននាំគ្នាស្រែកឡើងថា៖ «នេះជាព្រះសូរសៀងរបស់ព្រះ មិនមែនសំឡេងរបស់មនុស្សទេ!»។[23]រំពេចនោះ ស្រាប់តែមានទេវតារបស់ព្រះជាម្ចាស់មកប្រហារស្តេចហេរ៉ូដ ព្រោះទ្រង់ពុំបានថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់។ ស្តេចត្រូវដង្កូវចោះ ហើយក៏ផុតដង្ហើមទៅ។
[24]មនុស្សម្នាបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយចំនួនអ្នកជឿបានកើនឡើងជាលំដាប់។[25]រីឯលោកបារណាបាស និងលោកសូល ក្រោយពីបានបំពេញបេសកកម្មរបស់ខ្លួនចប់សព្វគ្រប់ហើយ លោកវិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញដោយយកលោកយ៉ូហានហៅម៉ាកុសទៅជាមួយផង។

Acts 12:1

ប្រយោគភ្ជាប់

ឃ្លានេះចាប់ផ្តើមការប៉ៀតប៉ៀនជាថ្មី ទីមួយការស្លាប់របស់លោកយ៉ាកុប ហើយបន្ទាប់មក គេដាក់លោកពេត្រុសនៅក្នុងគុក ហើយក្រោមមកដោះវិញ។

ព័ត៌មានទូទៅ

ឃ្លានេះប្រាប់ពីការដែលស្តេចហេរ៉ូឌសម្លាប់លោកយ៉ាកុប។

ឥឡូវនេះ

ការនេះចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង។

ដល់ពេលដែល

ឃ្លានេះសំដៅលើពេលគ្រោះអត់ឃ្លាន។

បានលូកព្រះហស្តលើ

នេះមានន័យថា ស្តេចហេរ៉ូឌបានចាប់ចងពួកអ្នកជឿ។ សូមមើលពីការប្រែរបស់អ្នកនៅក្នុងជំពូក ៥:១៧។ របៀបផ្សេងទៀតនៃការបកប្រែ: «បានចាត់ពួកទាហានមកចាប់»

លើសមាជិកខ្លះនៃក្រុមជំនុំ

មានតែលោកយ៉ាកុបនិងលោកពេត្រុសទេដែលបាននិយាយច្បាស់ ដែលបង្ហាញថាជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំក្រុងយេរូសាឡិម។

ដើម្បីធ្វើបាបដល់ពួកគេ

«ដើម្បីធ្វើឲ្យអ្នកជឿរងទុក្ខលំបាក»

ស្តេចបានសម្លាប់លោកយ៉ាកុប...ដោយដាវ។

ឃ្លានេះប្រាប់ពីរបៀបដែលលោកយ៉ាកុបត្រូវគេសម្លាប់។

ស្តេចបានសម្លាប់

ឃ្លានេះមានន័យថា «ស្តេចហេរ៉ូឌជាអ្នកសម្លាប់» ឬ «ស្តេចហេរ៉ូឌបង្គាប់ឲ្យគេសម្លាប់»។

Acts 12:3

ព័ត៌មានទូទៅ

ពាក្យ «គាត់» នៅទីនេះ សំដៅលើស្តេចហេរ៉ូឌ។ (សូមមើល: ១២:១)

បន្ទាប់ពីទ្រង់ទតឃើញថា ការនេះបានធ្វើឲ្យជនជាតិយូដាពេញចិត្ត

«នៅពេលស្តេចហេរ៉ូឌជ្រាប់ថាការសម្លាប់លោកយ៉ាកុប គឺជាការពេញចិត្តរបស់អ្នកដឹកនាំសាសន៍យូដា»

ជនជាតិយូដាពេញចិត្ត

«ធ្វើឲ្យជនជាតិយូដាសប្បាយចិត្ត»

ពេលនោះ

«ស្តេចហេរ៉ូឌបានធ្វើការនេះ» ឬ «ការនេះបានកើតឡើង» (UDB)

នៅក្នុងអំឡុងពេលបុណ្យនំបុ័ងឥតមេ

នេះគឺសំដៅលើពេលវេលាដែលសាសនាយូដាធ្វើពិធីបុណ្យក្នុងអំឡុងពេលបុណ្យនំបុ័ងឥតមេ។ របៀបផ្សេងទៀតការបកប្រែ: «ពិធីបុណ្យនៅពេលប្រជាជនយូដាបរិភោគនំបុ័ងឥតមេ» (UDB)។

បានចាត់ទាហានបួនក្រុម

«បានចាត់ទាហានបួនក្រុម» (UDB)។ ក្រុមនីមួយៗមានទាហានបួននាក់យាមលោកពេត្រុស យាមមួយក្រុមម្តង។ ក្រុមនីមួយៗបែងចែកគ្នានៅក្នុងពេលម្តៃបួនម៉ោង ប្តូរគ្នាជាបួនក្រុម។ មួយពេលមានទាហានពីររូប យាមនៅសងខាងលោក ហើយពីរនាក់ទៀតយាមនៅច្រកចូល។

ស្តេចមានបំណងនឹងនាំលោកមកចំពោះមុខប្រជាជន

«ស្តេចហេរ៉ូឌបានគ្រោងនឹងកាត់ក្តីលោកពេត្រុសនៅក្នុងចំណោមប្រជាជន» ឬ «ស្តេចហេរ៉ូឌគ្រោងកាត់ក្តីលោកពេត្រុសនៅចំពោះមុខជនជាតិយូដា»។

Acts 12:5

ដូច្នេះ លោកពេត្រុសក៏ជាប់នៅក្នុងគុក

ឃ្លានេះបង្ហាញថា ពួកទាហានបន្តយាមលោកពេត្រុសនៅក្នុងគុក។ ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះពួកទាហានបានយាមលោកពេត្រុសនៅក្នុងគុក»។

អស់អ្នកដែលនៅក្រុមជំនុំបានអធិស្ឋានយ៉ាងអស់ពីចិត្តដល់ព្រះជាម្ចាស់សម្រាប់លោក

ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ក្រុមអ្នកជឿនៅក្នុងយេរូសាឡឹមបានអធិស្ឋានយ៉ាងអស់ពីចិត្តដល់ព្រះសម្រាប់គាត់» ។

យ៉ាងអស់ពីចិត្ត

«បន្តអធិស្ឋានយ៉ាងអស់ពីចិត្ត» ឬ «បួរផ្តាច់អធិស្ឋានយ៉ាងអស់ពីចិត្ត»។

ព្រះបាទហេរ៉ូដយកលោកទៅកាត់ទោស

ស្តេចហេរ៉ូឌគ្រោងនឹងសម្លាប់គាត់អាចឃើញយ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការប្រែ: «ស្តេចហេរ៉ូឌនឹងនាំលោកពេត្រុសចេញពីគុកដើម្បីសម្លាប់គាត់»

ជាប់ច្រវាក់ពីរខ្សែផង

«ជាប់ច្រវាក់ពីរខ្សែផង» ឬ «ចង់ជាមួយខ្សែរពីរ»។ ខ្សែនីមួយៗចងជាមួយអ្នកយាមមួយ នៅយាមនៅខាងក្នុងជាមួយលោកពេត្រុស។

យាមនៅខាងមុខ

«យាមកាម»

Acts 12:7

ព័ត៌មានទូទៅ

ពាក្យ «គាត់» និង «របស់គាត់» សំដៅលើលោកពេត្រុស។

មើល៍

គឺជាពាក្យដាស់តឿនដល់យើងឲ្យយកចិត្តទុកដាក់ចំពោះព័ត៌មានដែលនៅខាងក្រោម។

ដល់គាត់

«ក្បែរលោក» ឬ «នៅជិតលោក»

បន្ទប់ក្នុងគុក

«នៅបន្ទប់ក្នុងគុក»

លោកប៉ះលោកពេត្រុស

«ទេវតាបានប៉ះលោកពេត្រុស» ឬ «ទេវតាបានចាក់លោកពេត្រុស» លោកពេត្រុសបានគេងលក់យ៉ាងស្កប់ស្កល់ ដែលត្រូវឲ្យគេដាស់គាត់។

ច្រវាក់របស់គាត់ធ្លាក់ចេញពីដៃរបស់លោក

ទេវតាធ្វើឲ្យច្រវាក់ធ្លាក់ចេញពីលោកពេត្រុសដោយមិនបានប៉ះច្រវាក់នោះ។

លោកពេត្រុសក៏ធ្វើតាម

«លោកពេត្រុសបានធ្វើតាមអ្វីដែលទេវតាប្រាប់លោកឲ្យធ្វើ» ឬ «លោកពេត្រុសបានស្តាប់បង្គាប់»

Acts 12:9

ព័ត៌មានទូទៅ

ពាក្យ «លោក» នៅត្រង់នេះ សំដៅលើលោកពេត្រុស។ ពាក្យ «ពួកគេ» និង «ពួកគេ» សំដៅលើលោកពេត្រុស និងទេវតា។

លោកមិនបានដឹង

«លោកមិនយល់»

អ្វីដែលទេវតាបានធ្វើនោះគឺជាការពិតឡើយ

ឃ្លានេះអាចប្តូរជាទម្រង់សកម្មវិញ។ របៀបផ្សេងទៀតនៃការបកប្រែ: «សកម្មភាពរបស់ទេវតាគឺជាការពិត» ឬ «អ្វីដែលទេវតាបានធ្វើពិតជាបានកើតឡើងមែន»

បន្ទាប់ពី ពួកគេបានឆ្លងផុតកន្លែងយាមទីមួយ និងទីពីរហើយ

បង្ហាញថា ពួកទាហានមិនអាចឃើញលោកពេត្រុស និងទេវតាទេ

generated on Wed Sep 10 16:16:32 2025

នៅពេលពួកកេដើរកាត់នោះ។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកយាមទីមួយ និងទីពីរមិនបានឃើញពួកគេទេ នៅពេលពួកគេដើរកាត់នោះ»
បានឆ្លងផុត
«បានដើរកាត់»
ទីពីរ
«អ្នកយាមទីពីរ»
ពួកគេបានមកដល់
«ពួកគេបានមកដល់ឯ»
ចេញទៅរកទីក្រុង
«ទ្វារបានបើកចំហទៅរកទីក្រុង» ឬ «បានចេញពីគុកទៅរកទីក្រុង»
បានបើកដោយឯកឯង
ពាក្យ «ឯកឯង» វាមើលឲ្យលោកពេត្រុស និងទេវតាដោយឯកឯង។ របៀបផ្សេងទៀតនៃការបកប្រែ: «ទ្វារបានបើកចំហឲ្យពួកគេ» ឬ «ទ្វារបើកចំហដោយឯកឯងដល់ពួកគេ»
បានដើរទៅតាមផ្លូវនោះទៅ
«បានដើរតាមផ្លូវនោះ»
ទេវតាក៏បានចាកចេញបាត់ពីលោកបាត់ទៅ
«ទេវតាបានចេញពីលោកពេត្រុសភ្លាម» ឬ «បានបាត់ខ្លួនមួយរំពេច»
Acts 12:11
នៅពេល លោកពេត្រុសបានដឹងខ្លួន
«នៅពេលលោកពេត្រុសភ្ញាក់ ហើយដឹងខ្លួន» ឬ «នៅពេលលោកពេត្រុសបានដឹងថាអ្វីដែលកើតឡើងគឺជាការពិត»
បានរំដោះខ្ញុំចេញពីដៃរបស់ស្តេចហេរ៉ូដ
ពាក្យ «ដៃរបស់ស្តេចហេរ៉ូដ» សំដៅលើ «ការចាប់ខ្លួនរបស់ស្តេចហេរ៉ូដ» ឬ «គម្រោងការរបស់ស្តេចហេរ៉ូដ»។ របៀបផ្សេងទៀតនៃការបកប្រែ: «បានសង្គ្រោះខ្ញុំពីការធ្វើទុក្ខដែលស្តេចហេរ៉ូដបានគ្រោងទុក»
ចេញពីអ្វីៗគ្រប់យ៉ាងដែលប្រជាជនយូដាចង់ធ្វើ
ពាក្យ «ប្រជាជនយូដា» ប្រហែលជាសំដៅលើអ្នកដឹកនាំរបស់យូដា។ របៀបផ្សេងទៀតនៅការបកប្រែ: «ពីអ្វីដែលអ្នកដឹកនាំជនជាតិគិតថាកើតឡើងមកលើខ្ញុំ»
បានយល់ច្បាស់ហើយ
លោកបានដឹងថាព្រះជាម្ចាស់បានរំដោះលោក។
យ៉ូហានដែលហៅម៉ាកុស
«យ៉ូហានដែលហៅថាម៉ាកុសផងដែរ»
Acts 12:13
ព័ត៌មានទូទៅ
ពាក្យ «នាង» ឬ «របស់នាង» ទាំងនេះសំដៅលើស្រីបម្រើឈ្មោះ នាងរ៉ូដា។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើមនុស្សដែលនៅខាងក្នុងហើយអធិស្ឋាន។ (សូមមើល: ១២:១១)
លោកគោះទ្វារ
«លោកពេត្រុសគោះទ្វារ» គោះទ្វារគឺជាវប្បធម៌របស់ជនជាតិយូដា ដើម្បីឲ្យពួកគេដឹងថាអ្នកចង់សួរសុខទុក្ខដល់ពួកគេ។ អ្នកអាចប្តូរការនេះដើម្បីឲ្យត្រូវនឹងវប្បធម៌របស់អ្នក។
កំពុងឈរនៅមាត់ទ្វារ
«នៅមាត់ទ្វារខាងក្រៅ» ឬ «នៅច្រក់ទ្វារចូលពីផ្លូវទៅទីលាន»។
មកបើកឲ្យ
«បានមកឯទ្វារដើម្បីសួរថានរណាគោះទ្វារ»
រំភើបខ្លាំងពេក
«ដោយសារនាងមានអំណរពេក» ឬ «ដោយសារនាងរំភើបពេក»
នាងពុំបានបើកទ្វារឲ្យទេ
«នាងពុំបានបើកទ្វារ» ឬ «នាងភ្លេចដើកទ្វារ»
នាងបានរត់ចូលទៅក្នុងបន្ទប់វិញ
អ្នកអាចនិយាយថា «រត់ឡើងទៅក្នុងបន្ទប់នៅក្នុងផ្ទះ»
នាងបានរាយការណ៍ថា
«នាងបានប្រាប់ពួកគេ» ឬ «នាងនិយាយ»
កំពុងឈរនៅមាត់ទ្វារ
«កំពុងឈរនៅមាត់ទ្វារខាងក្រៅ» លោកពេត្រុសកំពុងឈរនៅខាងក្រៅ។
នាងរង្វេងស្មារតីហើយ
គេមិនបានជឿដល់នាងទេ ប៉ុន្តែ បានដាស់តឿននាថដោយនិយាយថា នាងឆ្កួតហើយ។ របៀបផ្សេងទៀតនៃការបកប្រែ: «នាងឆ្កួតហើយ»
ប៉ុន្តែ នាងបានប្រកែកថារាជាការពិត
«នាងនៅតែប្រកែកថា អ្វីដែលនាងនិយាយគឺជាការពិត»។
ពួកគេប្រាប់
«ពួកគេបានឆ្លើយ»
ជាទេវតារបស់លោកទេ
«អ្វីដែលនាងឃើញគឺជាទេវតារបស់លោកពេត្រុសទេ»។ ជនជាតិយូដាខ្លះជឿថាមានទេវតាការពារ ហើយគិតថាជាទេវតារបស់លោកពេត្រុសដែលបានមករកពួកគេ។
Acts 12:16
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «របស់ពួកគេ» នៅទីនេះ សំដៅលើមនុស្សដែលនៅក្នុងផ្ទះ។
ពាក្យ «លោក» ឬ «គាត់» សំដៅលើលោកពេត្រុស។
ព័ត៌មានទូទៅ
ទោះបីជាស្តេចហេរ៉ូដបានសម្លាប់លោកយ៉ាកុបនៅក្នុង ជំពូក ១២:១ ក៏មានយ៉ាកុបលើសពីមួយដែរ។
ប៉ុន្តែ លោកពេត្រុសនៅតែបន្តគោះទ្វារ
ពាក្យ «បានបន្ត» មានន័យថា លោកពេត្រុសបន្តគោះទ្វាររហូត ទោះបីជាអ្នកនៅខាងក្នុងកំពុងជជែកគ្នាក្តី។
សូមរាយការណ៍ទាំងនេះ
«ប្រាប់ពីការទាំងនេះ»
ពួកបងប្អូន
«ពួកអ្នកជឿផ្សេងទៀត»
Acts 12:18
ព័ត៌មានទូទៅ
ពាក្យ «គាត់» នៅទីនេះ សំដៅលើលោកពេត្រុស។ ពាក្យ «ទ្រង់» សំដៅលើស្តេចហេរ៉ូដ។
ឥឡូវនេះ
ពាក្យនេះប្រើដើម្បីសម្គាល់ចំណុចសម្រាកនៃសាច់រឿង។ ពេលវេលាបានកន្លងផុតទៅ ប៉ុន្តែ ឥឡូវគឺជាថ្ងៃបន្ទាប់។
ពេលថ្ងៃរះឡើង
«នៅពេលព្រឹក»
មានការភ្ញាក់ផ្អើលជាខ្លាំង
ឃ្លានេះប្រើដើម្បីបញ្ជាក់ពីអ្វីដែលបានកើតឡើង។ ឃ្លានេះអាចនិយាយក្នុងន័យវិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ: «មានការភ្ញាក់ផ្អើលជាខ្លាំង» ឬ «មានការរំភើពជាខ្លាំង»
ភ្ញាក់ផ្អើល
ឃ្លានេះសំដៅលើការភ្ញាក់ផ្អើលបែបអវិជ្ជមានដូចជាភាពតានតឹង នឿយព្រួយជាខ្លាំង ភ័យខ្លាច ឬវិលវល់ជាដើម។
ទាក់ទងនឹង
«ទាក់ទងនឹង» ឬ «អំពី»
បន្ទាប់មក ព្រះបាទហេរ៉ូដបានរកលោក តែរកលោកមិនឃើញ
«បន្ទាប់មក ព្រះបាទហេរ៉ូដបានរកលោកពេត្រុស ហើយរកលោកមិនឃើញ»
បន្ទាប់មក ព្រះបាទហេរ៉ូដបានរកលោក
មានន័យពីរ ទី១) «ពេលស្តេចហេរ៉ូដឮថាបាត់ខ្លួនលោកពេត្រុស ស្តេចទៅរកលោកនៅក្នុងគុកដោយអង្គទ្រង់ផ្ទាល់» ឬ ទី២) ពេលស្តេចហេរ៉ូដឮថាបាត់លោកពេត្រុស ស្តេចបានចាត់ទាហានឲ្យទៅស្វែករកនៅក្នុងគុក»។
ស្តេចសាកសួរពួកអ្នកយាម ហើយបានបង្គាប់គេឲ្យសម្លាប់ពួកគេ
គឺជាការដាក់ទៅបែបសាមញ្ញសម្រាប់រដ្ឋាភិបាលរ៉ូម ក្នុងការសម្លាប់អ្នកយាម ប្រសិនបើអ្នកទោសរត់បាត់។
បន្ទាប់មក ស្តេចយាងពីស្រុកយូដាចុះ
ឃ្លា «យាងចុះ» ប្រើនៅទីនេះ ដោយសេសារានៅទាបជាងយូដា។
Acts 12:20
ប្រយោគភ្ជាប់
លោកលូកាបន្តជាមួយនឹងព្រឹត្តការណ៍មួយទៀតពីជីវិតរបស់ស្តេចហេរ៉ូដ។
ឥឡូវនេះ
ពាក្យដែលប្រើនៅទីនេះ ដើម្បីសម្គាល់ពីព្រឹត្តការណ៍បន្ទាប់នៅក្នុងសាច់រឿង។

generated on Wed Sep 10 16:16:32 2025

ពួកគេបាននាំគ្នាចូលទៅគាល់ស្តេច
វាមិនទំនងទេ ដែលពួកគេទាំងអស់គ្នាទៅគាល់ស្តេចហេរ៉ូដនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: ពួកអ្នកដែលតំណាងឲ្យអ្នកក្រុងទីរ៉ុស និងអ្នកក្រុងស៊ីដូនបាននាំគ្នាទៅទូលព្រះបាទហេរ៉ូដ»។
ពួកគេបានបញ្ចុះបញ្ចូលលោកប្លាសតុស
«អ្នកទាំងនោះបានបញ្ចុះបញ្ចូលលោកប្លាសតុស»
លោកប្លាសតុស
លោកប្លាសតុសគឺជាជំនួយការ ឬជាមន្ត្រីរបស់ស្តេចហេរ៉ូដ។
ពួកគេបានទូលសូមសន្តិភាព
«អ្នកទាំងនោះបានសូមសន្តិភាព»
ប្រទេសរបស់ពួកគេបានទទួលស្បៀងអាហារពីនគរព្រះបាទហេរ៉ូដ
ពួកគេប្រហែលជាទិញអាហារទាំងនេះ។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកក្រុងទីរ៉ុស និងអ្នកក្រុង
ស៊ីដូនបានទិញស្បៀងរបស់ពួកគេពីអ្នកដែលស្តេចហេរ៉ូដគ្រប់គ្រង» ។
ទទួលស្បៀងអាហារ
បង្ហាញថា
ព្រះបាទហេរ៉ូដដាក់កម្រិតការផ្គត់ផ្គង់ស្បៀងដោយសារទ្រង់ក្រោធជាមួយនឹងអ្នកក្រុងទីរ៉ុស និងអ្នកក្រុងស៊ីដូន។
លុះដល់ថ្ងៃកំណត់
នេះប្រហែលជាថ្ងៃដែលព្រះបាទហេរ៉ូដយល់ព្រមជួបជាមួយអ្នកតំណាង។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅថ្ងៃដែលព្រះបាទហេរ៉ូដយល់ព្រមជួបជាមួយពួកគេ»
បានស្លៀកសម្លៀកបំពាក់របស់ស្តេច
ជាសម្លៀកបំពាក់ដ៏មានតម្លៃដែលបង្ហាញថាទ្រង់ជាស្តេច។
គង់លើបល្ល័ង្ក
នេះគឺជាកន្លែងដែលព្រះបាទហេរ៉ូដមានរាជឱង្ការទៅកាន់ប្រជារាស្ត្រដែលចូលមកគាល់ទ្រង់
Acts 12:22
ប្រយោគភ្ជាប់
នេះគឺជាសាច់រឿងចុងក្រោយរបស់ស្តេចហេរ៉ូដ។
ភ្លាមនោះ
«រំពេចនោះ» ឬ «នៅពេលប្រជារាស្ត្រសរសើរព្រះបាទហេរ៉ូដ»។
បានប្រហារស្តេច
«ស្តេចហេរ៉ូដមានជំងឺ» ឬ «ធ្វើឲ្យស្តេចហេរ៉ូដប្រឈួនជាខ្លាំង»
ទ្រង់ពុំបានថ្វាយសិរីដល់ព្រះជាម្ចាស់
ព្រះបាទហេរ៉ូឌអនុញ្ញាតឲ្យប្រជារាស្ត្រទាំងអស់នោះសរសើរទ្រង់
ជំនួសឲ្យពួកគេថ្វាយបង្គំព្រះជាម្ចាស់វិញ។
ស្តេចត្រូវដង្កូវស៊ី ហើយសុគតទៅ
ពាក្យ «ដង្កូវ» សំដៅលើដង្កូវដែលនៅក្នុងសាច់របស់មនុស្ស
ប្រហែលជាដង្កូវក្នុងពោះវៀន។ ឃ្លានេះនិយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ដង្កូវបានស៊ីគ្រឿងក្នុងរបស់ស្តេចហេរ៉ូដ
ហើយទ្រង់ក៏សុគត»
Acts 12:24
ព័ត៌មានទូទៅ
នេះគឺជាព័ត៌មានដែលផ្តល់ការជូនដំណឹងទាក់ទងនឹងការរីកសាយភាយរបស់ព្រះបន្ទូលព្រះជាម្ចាស់
ហើយលើ អ្វីដែលលោកបារណាបាស និងលោកសូលកំពុងធ្វើ។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចម្រើនឡើង និងកើនឡើងជាលំដាប់
ព្រះបន្ទូលរបស់ព្រះជាម្ចាស់និយាយដូចជាដើមឈើដែលរស់ ដែលលូតលាស់
និងបង្កើតផល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានរីកសាយភាយទៅដល់កន្លែងផ្សេងៗ
និងមានមនុស្សជាច្រើនបានជឿលើលោក»។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
មានមនុស្សជាច្រើនបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់។
ឃ្លានេះសំដៅលើព្រះបន្ទូលនៃសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះបន្ទូលរបស់ព្រះជាម្ចាស់អំពីព្រះយេស៊ូ»
បានបញ្ចប់បេសកកម្មរបស់ពួកគេហើយ ពួកគេបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ
ឃ្លានេះសំដៅលើ
កាលដែលពួកគេបាននាំប្រាក់ពីពួកអ្នកជឿនៅក្រុងអន់ទីយ៉ូកនៅក្នុងជំពូក
១១:២៩។ របៀបផ្សេងទៀតនៃការបកប្រែ:
«បាននាំយកប្រាក់មកប្រគល់ឲ្យអ្នកដឹកនាំក្រុមជំនុំក្រុងយេរូសាឡិម»
ពួកគេបានត្រឡប់ពីទីនោះ
ពួកគេត្រឡប់ទៅក្រុងអន់ទីយ៉ូកវិញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបារណាបាស និងលោកសូលបានត្រឡប់ទៅក្រុងអន់ទីយ៉ូកវិញ»
បានយកលោកយ៉ូហាន
«ពួកគេបានយកលោកយ៉ូហានទៅជាមួយពួកគេ»។
ដែលហៅថាម៉ាកុស
«ដែលហៅថាម៉ាកុសផងដែរ»

---

13 [1]ក្នុងក្រុមជំនុំនៅក្រុងអន់ទីយ៉ូក មានព្យាការី និងគ្រូអាចារ្យខ្លះ។ រួមមានលោកបារណាបាស លោកស៊ីម្មានហៅនីគើរ លោកលូគាសជាអ្នកស្រុកគីរេន លោក
ម៉ាណាអេន ដែលត្រូវគេចិញ្ចឹមជាមួយព្រះបាទហេរ៉ូដជាស្តេចអនុរាជ កាលនៅពីក្មេង និងលោកសូល។[2]នៅពេលដែលអ្នកទាំងនោះកំពុងតែធ្វើពិធីថ្វាយបង្គំ
ព្រះអម្ចាស់ និងតមអាហារ ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលថា៖ «ចូរញែកបារណាបាស និងសូលចេញដោយឡែក ដ្បិតយើងបានហៅអ្នកទាំងពីរឲ្យមកបំពេញកិច្ចការ
ដែលយើងនឹងដាក់ឲ្យគេធ្វើ»។[3]ក្រោយពីបាននាំគ្នាតមអាហារ និងអធិស្ឋានរួចហើយ គេបានដាក់ដៃលើលោកទាំងពីរ ហើយលោកក៏ចេញទៅ។
[4]លោកបារណាបាស និងលោកសូលបានធ្វើតាមព្រះវិញ្ញាណដ៏វិសុទ្ធ លោកក៏បានធ្វើដំណើរទៅដល់ក្រុងសេលើស៊ា ហើយចុះសំពៅទៅកោះគីប្រុស។[5]ពេលទៅដល់ក្រុង
សាឡាមីន លោកទាំងពីរបានប្រកាសព្រះបន្ទូលព្រះជាម្ចាស់ នៅក្នុងសាលាប្រជុំរបស់ជនជាតិយូដា ដោយមានលោកយ៉ូហានហៅម៉ាកុសបានជួយផង។
[6]បន្ទាប់មក លោកបាននាំគ្នាធ្វើដំណើរកាត់តាមកោះនោះ រហូតទៅដល់ក្រុងប៉ាផូស។ នៅក្រុងនោះ លោកបានជួបគ្រូមន្តអាគមជនជាតិយូដាម្នាក់ ឈ្មោះបារយេស៊ូជា
ព្យាការីក្លែងក្លាយ[7]គាត់រស់នៅជាមួយលោកស៊ើគាស-ប៉ូឡូស ដែលជារាជប្រតិភូរបស់ព្រះចៅអធិរាជរ៉ូម៉ាំង ដែលជាមនុស្សមានប្រាជ្ញា។ លោកប្រតិភូចាត់គេឲ្យទៅអញ្ជើញ
លោកបារណាបាស និងលោកសូលមក ព្រោះលោកមានបំណងចង់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។[8]ប៉ុន្តែ អេលីម៉ាស (ភាសាក្រិក ប្រែថាគ្រូមន្តអាគម) ចេះតែប្រឆាំង
នឹងលោកទាំងពីរ ហើយរកមធ្យោបាយពង្វាងលោកប្រតិភូឲ្យងាកចេញពីជំនឿ។
[9]រីឯលោកសូល ដែលហៅថាប៉ូលបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ លោកសម្លឹងមើលទៅអេលីម៉ាស[10]ហើយមានប្រសាសន៍ថា៖ «ន៎ែ! ជនពោរពេញទៅដោយ
ពុតត្បុត និងល្បិចកិច្ចកលអើយ! អ្នកជាកូនរបស់មារ អ្នកជាសត្រូវនឹងអំពើសុចរិតគ្រប់យ៉ាង។ តើអ្នកនៅតែពង្វាងគេអោយងាកចេញពីមាគ៌ាដ៏ត្រឹមត្រូវរបស់ព្រះអម្ចាស់
ដល់ណាទៀត?
[11]ឥឡូវនេះ ព្រះបារមីរបស់ព្រះអម្ចាស់នឹងធ្វើឲ្យអ្នកខ្វាក់ភ្នែក លែងឃើញពន្លឺថ្ងៃអស់មួយរយៈ»។ រំពេចនោះ ស្រាប់តែភ្នែករបស់គាត់ក៏ដូចជាមានបាំង ហើយងងឹតមើលអ្វីពុំ
ឃើញ។ គាត់ដើរវិលវល់ រកគេជួយដឹកដៃ។[12]កាលលោកប្រតិភូឃើញហេតុការណ៍កើតឡើងដូច្នេះ លោកក៏ជឿដោយស្ងប់ស្ងែងនឹងសេចក្តីដែលគេបង្រៀនអំពីព្រះអម្ចាស់
ជាខ្លាំង។
[13]ឥឡូវនេះលោកប៉ូល និងមិត្តភក្តិរបស់លោកបានចុះសំពៅពីក្រុងប៉ាផូស ឆ្ពោះទៅក្រុងពើកា ក្នុងស្រុកប៉ាមភីលា។ រីឯលោកយ៉ូហានបានបែកចេញពីពួកគេ វិលត្រឡប់ទៅ
ក្រុងយេរូសាឡឹមវិញ។[14]លោកប៉ូល និងមិត្តភក្តិរបស់លោក បានបន្តដំណើរពីក្រុងពើកា រហូតទៅដល់ក្រុងអន់ទីយ៉ូកក្នុងស្រុកពីស៊ីឌា។ នៅថ្ងៃសប្ប័ទ លោកទាំងពីរចូល
ទៅអង្គុយក្នុងសាលាប្រជុំ។[15]បន្ទាប់ពីបានអានគម្ពីរវិន័យនិងគម្ពីរព្យាការីរួចហើយ ពួកអ្នកទទួលខុសត្រូវលើសាលាប្រជុំ សុំឲ្យគេជម្រាបពួកលោកប៉ូលថា៖ «បងប្អូនអើយ!
បើបងប្អូនមានពាក្យអ្វីលើកទឹកចិត្តប្រជាជន សូមមានប្រសាសន៍មកចុះ»។
[16]លោកប៉ូលក្រោកឡើងលើកដៃធ្វើសញ្ញា ហើយមានប្រសាសន៍ថា៖ «សូមជម្រាបបងប្អូនជនជាតិអ៊ីស្រាអែល និងបងប្អូនដែលជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់ សូម
ជ្រាប![17]ព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលបានជ្រើសរើសបុព្វបុរសរបស់យើង និងប្រទានឲ្យប្រជារាស្ត្រនេះបានកើនឡើង នៅពេលគេស្នាក់នៅក្នុងប្រទេសអេស៊ីប
លោកបានលើកដៃជាសញ្ញា។ បន្ទាប់មក ព្រះអង្គបាននាំគេចេញពីប្រទេសនោះ ដោយឫទ្ធិបារមីរបស់ព្រះអង្គ។[18]ព្រះអង្គបានផ្គត់ផ្គង់គេអស់រយៈពេលប្រមាណសែសិប
ឆ្នាំនៅវាលរហោស្ថាន។

generated on Wed Sep 10 16:16:32 2025

[19]ក្រោយពីព្រះអង្គរំលាយជាតិសាសន៍ទាំងប្រាំពីរនៅស្រុកកាណានរួចហើយ ព្រះអង្គបានប្រទានទឹកដីនោះឲ្យប្រជារាស្ត្ររបស់ព្រះអង្គធ្វើជាកម្មសិទ្ធិ។[20]ហេតុការណ៍ទាំងនោះកើតមានក្នុងអំឡុងពេលប្រមាណបួនរយហាសិបឆ្នាំមុន។ ក្រោយមក ព្រះអង្គប្រទានឲ្យមានអ្នកគ្រប់គ្រងរហូតដល់ជំនាន់ព្យាការីសាំយូអែល។
[21]បន្ទាប់មកទៀត គេបាននាំគ្នាទូលសូមស្តេចមួយអង្គ ព្រះជាម្ចាស់ក៏ប្រទានព្រះបាទសូល ជាបុត្ររបស់លោកគីស ក្នុងកុលសម្ព័ន្ធបេនយ៉ាមីនឲ្យគ្រងរាជ្យអស់រយៈពេលសែសិបឆ្នាំ។[22]ក្រោយពីបានដករាជ្យពីព្រះបាទសូល ព្រះជាម្ចាស់ប្រទានអោយព្រះបាទដាវីឌឡើងគ្រងរាជ្យ។ ព្រះអង្គប្រទានសក្ខីភាពអំពីព្រះបាទដាវីឌនេះថា៖ «យើងរកបានមនុស្សម្នាក់ជាទីគាប់ចិត្តយើងណាស់ គឺដាវីឌជាបុត្ររបស់អ៊ីសាយ ដ្បិតដាវីឌនឹងបំពេញតាមបំណងទាំងប៉ុន្មានរបស់យើង»។
[23]ចាប់តាំងពីព្រះរាជវង្សរបស់ព្រះបាទដាវីឌនេះហើយ ដែលព្រះជាម្ចាស់ប្រទានឲ្យព្រះយេស៊ូកើតមក និងធ្វើជាព្រះសង្គ្រោះរបស់ជនជាតិអ៊ីស្រាអែល ស្របតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ។[24]ហេតុការណ៍នេះបានចាប់ផ្តើមមុនពេលព្រះយេស៊ូកើតមក នៅពេលលោកយ៉ូហានបានប្រកាសឲ្យជនជាតិអ៊ីស្រាអែលទាំងមូលកែប្រែចិត្តគំនិត រួចទទួលពិធីជ្រមុជទឹក។[25]ពេលលោកយ៉ូហានបំពេញមុខងាររបស់លោកចប់សព្វគ្រប់ហើយ លោកមានប្រសាសន៍ថា៖ «ខ្ញុំនេះមិនមែនជាអ្នក ដែលបងប្អូនទន្ទឹងរង់ចាំនោះទេ។ ប៉ុន្តែសូមស្តាប់ មានលោកម្នាក់មកតាមក្រោយខ្ញុំ ទោះបើខ្ញុំស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង»។
[26]បងប្អូនជាពូជពង្សលោកអប្រាហាំ និងបងប្អូនដែលគោរពកោតខ្លាចព្រះជាម្ចាស់អើយ! នេះហើយជាព្រះបន្ទូលស្តីអំពីការសង្គ្រោះ ដែលបានផ្ញើមកឲ្យយើងទាំងអស់គ្នា
[27]ដ្បិតអ្នកក្រុងយេរូសាឡឹម និងពួកមេដឹកនាំរបស់គេពុំបានដឹងថាព្រះយេស៊ូជានរណាឡើយ ហើយគេបានកាត់ទោសព្រះអង្គ ស្របនឹងសេចក្តីដែលព្យាការីថ្លែងទុកមកដែលគេអានៅរៀងរាល់ថ្ងៃសប្ប័ទ។
[28]ទោះបីគេរកកំហុសអ្វីមកកាត់ទោសលោកមិនឃើញក៏ដោយ ក៏គេនៅតែសុំឲ្យលោកពីឡាតប្រហារជីវិតព្រះអង្គដែរ។[29]កាលគេបានធ្វើស្របនឹងសេចក្តីដែលមានចែងទុកអំពីព្រះអង្គចប់សព្វគ្រប់ហើយ គេក៏យកព្រះសពព្រះអង្គចុះពីឈើឆ្កាងទៅបញ្ចុះក្នុងផ្នូរ។
[30]ប៉ុន្តែ ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យរស់ឡើងវិញ។[31]ព្រះយេស៊ូបានបង្ហាញខ្លួនឲ្យគេឃើញអស់រយៈពេលជាច្រើនថ្ងៃ ហើយឲ្យអស់អ្នកដែលបានរួមដំណើរជាមួយព្រះអង្គ ពីស្រុកកាលីឡេ ទៅក្រុងយេរូសាឡឹមបានឃើញ ។ ឥឡូវនេះ អ្នកទាំងនោះធ្វើជាបន្ទាល់របស់ព្រះអង្គនៅចំពោះមុខប្រជាជន។
[32]ដូច្នេះយើងខ្ញុំប្រាប់បងប្អូនអំពីដំណឹងល្អ ដែលព្រះជាម្ចាស់បានសន្យាជាមួយបុព្វបុរសរបស់យើង។[33]ព្រះអង្គបានបំពេញសព្វគ្រប់សម្រាប់យើង ដែលជាពូជពង្សរបស់បុព្វបុរសយើង ដោយព្រះអង្គបានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញ។ ដូចមានចែងទុកក្នុងទំនុកតម្កើងទីពីរថា៖ «ព្រះអង្គជាបុត្ររបស់យើង
ហើយថ្ងៃនេះយើងជាព្រះបិតារបស់ឯង។[34]ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញពិត ដើម្បីកុំឲ្យព្រះសពព្រះអង្គត្រូវរលួយឡើយ
ហើយព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងនឹងឲ្យឯងបានវិសុទ្ធ និងទទួលព្រះពរគ្រប់យ៉ាងដូចដែលយើងបានសន្យាជាមួយដាវីឌ»។
[35]ហេតុនេះហើយព្រះជាម្ចាស់មានព្រះបន្ទូល ចែងទុកក្នុងអត្ថបទគម្ពីរមួយទៀតថា៖ «ព្រះអង្គមិនបណ្តោយឲ្យសពអ្នកបម្រើ ដ៏វិសុទ្ធរបស់ព្រះអង្គរលួយឡើយ។[36]ព្រះបាទដាវីឌបានបម្រើព្រះជាម្ចាស់តាមគម្រោងព្រះអង្គនៅជំនាន់នោះ រួចក៏សោយទិវង្គតទៅ។ គេបានបញ្ចុះសពព្រះបាទដាវីឌក្នុងផ្នូរ ជាមួយព្រះអយ្យកោ ហើយសពរបស់ទ្រង់ក៏បានរលួយអស់ដែរ។[37]ចំណែកឯ ព្រះយេស៊ូដែលព្រះជាម្ចាស់បានប្រោសឲ្យមានព្រះជន្មរស់ឡើងវិញនោះ ព្រះសពរបស់ព្រះអង្គពុំបានរលួយទេ។
[38]ដូច្នេះ បងប្អូនអើយ! សូមបងប្អូនជ្រាបឲ្យច្បាស់ថា ព្រះជាម្ចាស់លើកលែងទោសឲ្យបងប្អូនរួចពីបាប តាមរយៈព្រះយេស៊ូ។[39]បងប្អូនពុំអាចទៅជាមនុស្សសុចរិត រួចផុតអំពើបាបទាំងប៉ុន្មានដោយ គោរពតាមវិន័យរបស់លោកម៉ូសេបានឡើយ។ បងប្អូនបានសុចរិតតាមរយៈព្រះយេស៊ូប៉ុណ្ណោះ។
[40]ហេតុនេះ សូមបងប្អូនប្រយ័ត្នក្រែងអ្វី ដែលព្យាការីថ្លែងទុកមកមិនបានកើតមានដល់អ្នក។[41]«មើល៍ មនុស្សដែលចេះតែមើលងាយគេអើយ! ចូរនាំគ្នាមើល ហើយអ្នកនឹងងឿងឆ្ងល់ ហើយត្រូវវិនាសបាត់ទៅចុះ! ដ្បិតយើងនឹងធ្វើកិច្ចការមួយនៅជំនាន់របស់អ្នករាល់គ្នាជាកិច្ចការ ដែលអ្នករាល់គ្នាមិនជឿ ទោះបីជាគេរៀបរាប់ប្រាប់អ្នករាល់គ្នាក៏ដោយ»។
[42]ពេលលោកប៉ូល និងលោកបារណាបាសចេញពីសាលាប្រជុំ ពួកគេបានអញ្ជើញលោកឲ្យមានប្រសាសន៍អំពីសេចក្តីទាំងនេះ ម្តងទៀតនៅថ្ងៃសប្ប័ទខាងមុខ។[43]លុះអង្គប្រជុំចប់ហើយ មានសាសន៍យូដា និងអ្នកចូលសាសនាយូដាជាច្រើននាក់ ដែលគោរពប្រណិប័តន៍ព្រះជាម្ចាស់ នាំគ្នាទៅតាមលោកប៉ូល និងលោកបារណាបាស។ លោកទាំងពីរបានសន្ទនាជាមួយពួកគេ ហើយក្រើនរំលឹកគេឲ្យនៅខ្ជាប់ខ្ជួននឹងព្រះគុណរបស់ព្រះជាម្ចាស់ជានិច្ច។
[44]នៅថ្ងៃសប្ប័ទបន្ទាប់មកទៀត ប្រជាជននៅក្រុងនោះបានមកជួបជុំស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ស្ទើរតែទាំងអស់គ្នា។[45]ពេលជនជាតិយូដាឃើញមហាជនដូច្នោះ គេមានចិត្តច្រណែនជាខ្លាំង ក៏នាំគ្នានិយាយជំទាស់នឹងពាក្យ ដែលលោកប៉ូលមានប្រសាសន៍ ហើយថែមទាំងជេរប្រមាថលោកទៀតផង។
[46]លោកប៉ូល និងលោកបារណាបាសក៏មានប្រសាសន៍ទៅគេ ដោយចិត្តអង់អាចថា៖ «សំខាន់ណាស់ដែលយើងខ្ញុំត្រូវតែប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់បងប្អូនជាមុនសិន។ ប៉ុន្តែដោយបងប្អូនបដិសេធមិនព្រមទទួលព្រះបន្ទូលនេះ ហើយបងប្អូនយល់ឃើញថា ខ្លួនមិនសមនឹងទទួលជីវិតអស់កល្បជានិច្ចទេនោះ យើងខ្ញុំនឹងងាកទៅប្រកាសដល់សាសន៍ដទៃវិញ[47]ដ្បិតព្រះអម្ចាស់បានបង្គាប់មកយើងខ្ញុំថា៖ «យើងបានតែងតាំងអ្នកឲ្យធ្វើជាពន្លឺបំភ្លឺជាតិសាសន៍នានា និងឲ្យនាំការសង្គ្រោះរហូតទៅដល់ស្រុកដាច់ស្រយាលនៃផែនដី»។
[48]កាលសាសន៍ដទៃឮដូច្នោះ គេមានអំណររីករាយ ហើយនាំគ្នាសរសើរតម្កើងព្រះបន្ទូលរបស់ព្រះអម្ចាស់។ អស់អ្នកដែលព្រះជាម្ចាស់តម្រូវឲ្យទទួលជីវិតអស់កល្បជានិច្ច ក៏នាំគ្នាជឿដែរ។[49]ព្រះបន្ទូលរបស់ព្រះអម្ចាស់បានឮសុសសាយ ក្នុងស្រុកនោះទាំងមូល។
[50]ប៉ុន្តែ សាសន៍យូដាបានញុះញង់ស្ត្រីៗមានឋានៈខ្ពង់ខ្ពស់ ដែលគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងញុះញង់ពួកនាម៉ឺននៅក្រុងនោះ ឲ្យលើកគ្នាទៅបៀតបៀនលោកប៉ូល និងលោកបារណាបាស ហើយដេញលោកទាំងពីរចេញពីដែនដីរបស់គេ។[51]លោកប៉ូល និងលោកបារណាបាស ក៏រលាស់ធូលីដីចេញពីជើងរបស់លោក រួចធ្វើដំណើរទៅក្រុងអ៊ីកូនាម។[52]ឯពួកសិស្សនៅអន់ទីយ៉ូកវិញ គេបានពោរពេញដោយអំណរ និងពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

Acts 13:1

ប្រយោគភ្ជាប់

លោកលូកាចាប់ផ្តើមប្រាប់អំពីដំណើរបេសកកម្មដែលក្រុមជំនុំនៅអន់ទីយ៉ូកចាត់លោកប៉ូល
និងលោកសូល។

ព័ត៌មានទូទៅ

ខ១ ផ្តល់ប្រវិត្តអំពីមនុស្សនៅក្នុងក្រុមជំនុំអន់ទីយ៉ូក។

ព័ត៌មានទូទៅ

ពាក្យ «ពួកគេ» ទីមួយនៅទីនេះ គឺប្រហែលជាសំដៅលើអ្នកដឹកនាំទាំងប្រាំ ប៉ុន្តែប្រហែលជារួមបញ្ចូលជាមួយអ្នកជឿផ្សេងទៀតដែរ។ ពាក្យ «ពួកគេ» បន្ទាប់ និង «របស់ពួកគេ» ប្រហែលជាសំដៅលើអ្នកដឹកនាំបីនាក់ទៀត
រួមទាំងលោកបារណាបាស និងលោកសូល ប៉ុន្តែ អាចរួមទាំងអ្នកជឿផ្សេងៗទៀត។

ឥឡូវនេះ ក្រុមជំនុំនៅក្រុងអន់ទីយ៉ូក

«នៅពេលនោះ នៅក្នុងក្រុមជំនុំអន់ទីយ៉ូក»

លោកស៊ីម្មាន...លោកម៉ាណាអេន

ជាបងប្អូនចិញ្ចឹមរបស់ហេរ៉ូដជាស្តេចអនុរាជ

លោកម៉ាណាអេនប្រហែលជាអ្នក លេងជាមួយ
ឬមិនភ័ក្ត្រជិតស្និទធំធាត់ជាមួយគ្នា។

ចាត្តាធិបតេយ្យ

គ្រប់គ្រងលើមួយភាគបួន ឬ មួយភាគបួននៃប្រទេស។

នៅពេល

ពាក្យនេះប្រើដើម្បីសម្គាល់ពីព្រឹត្តការណ៍ពីរដែលកំពុងកើតឡើងក្នុងពេលតែមួយ។

ញែកដោយឡែកសម្រាប់យើង

«ជ្រើសតាំងដើម្បីបម្រើយើង»

យើងហៅឲ្យពួកគេ

កិរិយាសព្ទនៅទីនេះមានន័យថា ព្រះជាម្ចាស់បានជ្រើសរើសពួកគេឲ្យធ្វើការនេះ។

បានដាក់ដៃលើលោកទាំងពីរ

«បានដាក់ដៃលើលោកទាំងពីរ
ដែលព្រះជាម្ចាស់បានញែកដោយឡែកសម្រាប់ការងារនេះ»។
សកម្មភាពនេះបានបង្ហាញថា ពួកអ្នកដឹកនាំបានយល់ស្របថា
ព្រះវិញ្ញាណដ៏វិសុទ្ធបានត្រាស់ហៅលោកបារណាបាស

generated on Wed Sep 10 16:16:32 2025

និងលោកសូលឲ្យធ្វើការងារនេះ។
ចាត់ពួកលោកឲ្យចេញទៅ
«ចាត់ពួកលោកឲ្យចេញទៅ» ឬ
«ចាត់អ្នកទាំងពីរឲ្យទៅធ្វើការងារដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រាប់ពួកគេឲ្យធ្វើ»
Acts 13:4
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ និង «របស់ពួកគេ» សំដៅលើលោកបារណាបាស
និងលោកស៊ីឡាស។
ដូច្នេះ
ពាក្យនេះសម្គាល់ពីព្រឹត្តការណ៍ដែលបានកើតឡើងដោយព្រោះព្រឹត្តការណ៍ពីមុន។
នៅក្នុងករណីនេះ កាលពីព្រឹត្តការណ៍លើកមុនគឺលោកបារណាបាស
និងលោកសូល ត្រូវបានញែកដោយឡែកដោយព្រះវិញ្ញាណដ៏វិសុទ្ធ។
បានធ្វើដំណើរចុះទៅ
ការដែលប្រើឃ្លា «ចុះទៅ» នៅទីនេះ ដោយសារ ក្រុង
សេលើស៊ាមានកម្ពស់ទាបជាងក្រុងអន់ទីយ៉ូក។
ក្រុងសេលើស៊ា
ជាទីក្រុងមួយនៅជិតសមុទ្រ
ក្រុងសាឡាមីន
ក្រុងសាឡាមីន ស្ថិតនៅលើកោះគីប្រុស។
នៅក្នុងសាលាប្រជុំរបស់ជនជាតិយូដា
មានន័យពីរ ទី១) «មានសាលាប្រជុំរបស់ជនជាតិយូដាជាច្រើននៅក្រុងសាឡាមីន
ជាកន្លែងដែលលោកបារណាបាស និងលោកសូលប្រកាស»។ ឬទី២)
«លោកបារណាបាស និងលោកសូលបានចាប់ផ្តើមនៅសាលាប្រជុំសាឡាមីន
ហើយបន្តប្រកាសនៅគ្រប់សាលាប្រជុំទាំងអស់ នៅពេលពួកគេរកឃើញ
នៅពេលពួកគេធ្វើដំណើរជុំវិញកោះគីប្រុស»។
ពួកគេក៏មានលោកយ៉ូហានម៉ាកុសធ្វើជាជំនួយការរបស់ពួកគេផងដែរ
«លោកយ៉ូហានម៉ាកុសបានធ្វើដំណើរជាមួយពួកគេ
ហើយបានជួយដល់ពួកគេ» (UDB)។
Acts 13:6
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល លោកស៊ីឡាស
និងលោកយ៉ូហានម៉ាកុស។
ព័ត៌មានទូទៅ
ពាក្យ «បុរសនេះ» សំដៅលើ «លោកស៊ើគាស-ប៉ូឡូស»។ ពាក្យ «គាត់»
លើកទីមួយ សំដៅលើលោកស៊ើគាស-ប៉ូឡូស ជាអភិបាលខេត្ត ពាក្យ «គាត់»
លើកទីពីរសំដៅលើលោកអេលីម៉ាស (គេហៅគាត់ថាបារយេស៊ូ) ជាគ្រូមន្តអាគម។
តាមកោះនោះ
ពួកគេឆ្លងកាត់ពីកោះម្ខាងទៅកោះម្ខាងទៀត ហើយចែកចាយដំណឹងល្អ
នៅតាមក្រុងនីមួយៗ ដែលពួកគេឆ្លងកាត់។
ក្រុងប៉ាផូស
ជាទីក្រុងធំមួយនៅលើកោះគីប្រុស ជាកន្លែងដែលលោកអភិបាលខេត្តរស់នៅ។
ជាមនុស្សមានប្រាជ្ញា
នេះគឺជាប្រវត្តិរបស់លោកស៊ើគាស-ប៉ូឡូស។
អេលីម៉ាស (ឈ្មោះគាត់ប្រែថាគ្រូមន្តអាគម)
នេះគឺជាបារយេស៊ូ ដែលហៅថា គ្រូមន្តអាគមផងដែរ»។
(ឈ្មោះគាត់ប្រែថាគ្រូមន្តអាគម)
«នោះគឺជាអ្វីដែលគេហៅគាត់ជាភាសាក្រិក»។
បានប្រឆាំងនឹងពួកគេ ហើយគាត់បានព្យាយាមបង្វែរ
«តតាំងជាមួយពួកគេ ដោយព្យាយាមបង្វែរ» ឬ
«ព្យាយាមក្នុងការបញ្ឈប់ពួកគេដោយព្យាយាមបង្វែរ»។
ព្យាយាមបង្វែរលោកអភិបាលខេត្ត ចេញពីជំនឿ
«ព្យាយាមបញ្ចុះបញ្ចូលលោកអភិបាលមិនឲ្យជឿសារនៃដំណឹងល្អ»។
Acts 13:9
ប្រយោគភ្ជាប់
នៅពេលទៅដល់កោះប៉ាផូស លោកប៉ូលបានចាប់ផ្តើមនិយាយជាមួយអេលីម៉ាស។
ព័ត៌មានទូទៅ
ពាក្យ «គាត់» «អ្នក» សំដៅលើអេលីមាសជាក្រូមន្តអាគម
(គេហៅគាត់ថាបារយេស៊ូផងដែរ» (សូមមើល: ១៣:៦)។
លោកសូល ដែលហៅថាប៉ូល
«សូល» ជាឈ្មោះរបស់ជនជាតិយូដា ហើយ «ប៉ូល» ជាឈ្មោះរបស់រ៉ូម។
ចាប់តាំងពីលោកមានប្រសាសន៍ទៅកាន់មន្ត្រីម្នាក់របស់រ៉ូម
លោកបានប្រើឈ្មោះរ៉ូម។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកសូល ឥឡូវនេះ
ហៅខ្លួនឯងថាប៉ូល»
បានសម្លឹងមើលទៅគាត់
បានមើលទៅគាត់យ៉ាងខ្លាំង»
នែ៎! កូនរបស់មារ
លោកប៉ូលកំពុងនិយាយទៅកាន់បុរសម្នាក់នេះ ដោយធ្វើដូចជាមារ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកបៀបដូចជាមារ» ឬ «អ្នកធ្វើដូចជាមារ»
ឯងពេញដោយល្បិចកិច្ចកល និងអាក្រក់គ្រប់យ៉ាង
អ្នកតែងតែបំណងចិត្តធ្វើឲ្យអ្នកដទៃជឿលើអ្វីដែលមិនពិត ដោយប្រើភាពកុហក
និងធ្វើអ្វីដែលខុស។
អាក្រក់
នៅក្នុងបរិបទនេះ មានន័យថាខ្ជិលប្រអូស
ហើយមិនឧស្សាហ៍នៅក្នុងការដើរតាមបញ្ញត្តិរបស់ព្រះជាម្ចាស់។
ឯងជាសត្រូវនឹងអំពើសុចរិតគ្រប់យ៉ាង
លោកប៉ូលបានរួមបញ្ចូលលោកអេលីម៉ាសជាមួយនឹងមារ។
ដែលមារគឺជាខ្មាំងសត្រូវរបស់ព្រះជាម្ចាស់ និងទាស់ជាមួយនឹងសេចក្តីសុចរិត
ដូចជាលោកអេលីម៉ាសដែរ។
តើឯងនៅតែមិនឈប់បង្វែរគេឲ្យងាកចេញពីផ្លូវត្រឹមត្រូវរបស់ព្រះអម្ចាស់ដល់ណាទៀត?
លោកប៉ូលប្រើសំនួរនេះដើម្បីស្តីបន្ទោសដល់អេលីមាស
ព្រោះគាត់ប្រឆាំងជាមួយព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកតែងតែនិយាយថា សេចក្តីពិតពីព្រះជាអម្ចាស់គឺកុហក»
ផ្លូវត្រឹមត្រូវរបស់ព្រះអម្ចាស់
នៅទីនេះ «ផ្លូវត្រង់» សំដៅលើផ្លូវដែលជាសេចក្តីពិត។
របៀបផ្សេងទៀតនៃការបកប្រែ: «ផ្លូវនៃសេចក្តីពិតរបស់ព្រះអម្ចាស់»
Acts 13:11
ប្រយោគភ្ជាប់
លោកប៉ូលបញ្ចាប់និយាយជាមួយអេលីម៉ាស។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» និង «គាត់» សំដៅលើ អេលីម៉ាស ជាគ្រូមន្តអាគម។
ព័ត៌មានទូទៅ
ពាក្យ «គាត់» សំដៅលើលោកស៊ើគាស-ប៉ូឡូស អភិបាលខេត្ត (ជាអ្នកគ្រប់គ្រងលើ
ក្រុងប៉ាផូស)
ព្រះហស្តរបស់ព្រះអម្ចាស់មកលើអ្នកហើយ
ពាក្យ «ព្រះហស្ត» តំណាងឲ្យអំណាចរបស់ព្រះជាម្ចាស់ និង «លើអ្នក»
បង្ហាញពីការដាក់ទោស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងដាក់ទោសអ្នក»
អ្នកនឹងត្រូវខ្វាក់ភ្នែក
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងធ្វើឲ្យអ្នកខ្វាក់ភ្នែក»។
អ្នកនឹងលែងឃើញពន្លឺថ្ងៃ
អេលីម៉ាសនឹងខ្វាក់ភ្នែកទាំងស្រុង សូម្បីតែមើលព្រះអាទិត្យក៏មើលមិនឃើញដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកនឹងខ្វាក់ភ្នែក
សូម្បីមើលថ្ងៃក៏មើលមិនឃើញដែរ»។
មួយរយៈ
«មួយរយៈពេលខ្លី» ឬ «រហូតដល់ព្រះជាម្ចាស់បានកំណត់ទុក»
ភ្នែករបស់អេលីម៉ាសក៏ដូចជាអព្ធ ហើយងងឹត
«ភ្នែករបស់អេលីម៉ាសបានស្រវាំង ហើយបន្ទាប់មកងងឹតតែម្តង» ឬ
«ភ្នែករបស់អេលីម៉ាសបានចាប់ផ្តើមមើលឃើញលែងច្បាស់
ហើយបន្ទាប់មកលោកមើលអ្វីលែងឃើញតែម្តង»។
គាត់ដើរជុំវិញ
«អេលីម៉ាសបានដើរជុំវិញ» ឬ «អេលីម៉ាសបានចាប់ផ្តើមដើរជុំវិញ»
លោកអភិបាលខេត្ត
នេះគឺជាអភិបាលខេត្តដែលទទួលខុសត្រូវលើខេត្តរបស់រ៉ូម។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកគ្រប់គ្រង»
លោកបានជឿ
«លោកបានជឿលើព្រះយេស៊ូ»
លោកមានការស្ងប់ស្ងែងនឹងសេចក្តីបង្រៀនអំពីព្រះអម្ចាស់ជាខ្លាំង

generated on Wed Sep 10 16:16:32 2025

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«សេចក្តីបង្រៀនអំពីព្រះអម្ចាស់ធ្វើឲ្យគាត់ភ្ញាក់ផ្អើល»។
Acts 13:13
ប្រយោគភ្ជាប់
នៅក្នុងសាច់រឿងថ្មីនេះ និយាយអំពីលោកប៉ូលនៅក្នុងក្រុងអន់ទីយ៉ូកក្នុងស្រុកពីស៊ីឌា។
ព័ត៌មានទូទៅ
ខ ១៣ និង១៤ ប្រាប់ពីប្រវត្តិនៅក្នុងសាច់រឿងនេះ។
ព័ត៌មានទូទៅ
«លោកប៉ូល និងមិត្រភក្តិរបស់លោក» គឺបារណាបាស និងលោកយ៉ូហានម៉ាកុស (ដែលហៅថាយ៉ូហាន)។ ពីចំណុចនេះ
លោកសូលហៅថាប៉ូលវិញនៅក្នុងកណ្ឌគម្ពីរកិច្ចការ។
ឈ្មោះរបស់លោកប៉ូលត្រូវបានសរសេរមុនគេ ដោយសារលោកជាអ្នកដឹកនាំក្រុម។
ការដាក់ជាលំដាប់លំដោយងាយក្នុងការបកប្រែ។
ឥឡូវនេះ
ឃ្លានេះសម្គាល់អំពីការចាប់ផ្តើមនៃវគ្គថ្មីរបស់សាច់រឿង។
បានចុះសំពៅពីក្រុងប៉ាផូស
«បានធ្វើដំណើរតាមសំពៅពីប៉ាផូស»
ទៅក្រុងពើកា ក្នុងស្រុកប៉ាមភីលា
«បានមកដល់ក្រុងពើកា ដែលនៅក្នុងស្រុកប៉ាមភីលា»
ប៉ុន្តែ លោកយ៉ូហានបានបែកចេញពីពួកគេ
«ប៉ុន្តែ លោកយ៉ូហានម៉ាកុសបានបែកចេញពីលោកប៉ូល និងលោកបារណាបាស»
ក្រុងអន់ទីយ៉ូក ស្រុកពីស៊ីឌា
«ក្រុងអន់ទីយ៉ូក នៅក្នុងស្រុកពីស៊ីឌា» (UDB)
បន្ទាប់ពី បានអានគម្ពីរវិន័យ និងគម្ពីរព្យាការីរួចហើយ
«គម្ពីរវិន័យ និងគម្ពីរព្យាការី»
សំដៅលើផ្នែកនៃបទគម្ពីររបស់សាសន៍យូដាដែលបានអាន។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពីគេបានអានពីគម្ពីរវិន័យ និងគម្ពីរព្យាការី»
បានប្រាប់គេឲ្យទៅប្រាប់ពួកគេ ដោយនិយាយថា
«ប្រាប់នរណាម្នាក់ឲ្យនិយាយ» ឬ «សូមនរណាម្នាក់ឲ្យនិយាយ»
បងប្អូនអើយ
ពាក្យ «បងប្អូនអើយ» អ្នកនៅក្នុងសាលាប្រជុំប្រើ ដើម្បីសំដៅលើលោកប៉ូល
និងលោកបារបាស ជាបងប្អូនជនរួមជាតិ។
ប្រសិនបើ បងប្អូនមានព្រះបន្ទូលលើកទឹកចិត្ត
«បើ បងប្អូនមានអ្វីចង់និយាយលើកទឹកចិត្តយើង»
សូមមានប្រសាសន៍មកចុះ
«សូមនិយាយចុះ» ឬ «សូមប្រាប់យើងមកចុះ»
Acts 13:16
ប្រយោគភ្ជាប់
លោកប៉ូលចាប់ផ្តើមសុន្ទរកថារបស់កាត់ដល់អស់អ្នកដែលនៅក្នុងសាលាប្រជុំ
នៅក្នុងស្រុកពីស៊ីឌា ក្រុងអន់ទីយ៉ូក។
លោកបានចាប់ផ្តើមដោយនិយាយពីប្រវត្តិរបស់អ៊ីស្រាអែល។
ព័ត៌មានទូទៅ
ពាក្យ «គាត់» លើកទីមួយសំដៅលើលោកប៉ូល។ ពាក្យ «គាត់»
លើទីពីរសំដៅលើព្រះជាម្ចាស់។
ពត៌មានទូទៅ
ពាក្យ «របស់យើង» សំដៅលើលោកប៉ូល និងបងប្អូនជនជាតិយូដារបស់លោក។
ពត៌មានទូទៅ
ពាក្យ «ពួកគេ» និង «របស់ពួកគេ» សំដៅលើជនជាតិអ៊ីស្រាអែល។
លើកដៃរបស់គាត់ជាសញ្ញា
ឃ្លានេះ សំដៅលើការលើកដៃរបស់គាត់ជាសញ្ញាថាគាត់រួចរាល់ក្នុងការនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «បក់ដៃរបស់គាត់
ដើម្បីបង្ហាញថាគាត់ចង់និយាយ»
បងប្អូនដែលជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់អើយ
ឃ្លានេះសំដៅលើសាសន៍ដទៃដែលបានប្តូរមកកាន់សាសនាយូដាវិញ។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនដែលមិនមែនជាជនជាតិអ៊ីស្រាអែល ប៉ុន្តែ
ថ្វាយបង្គំព្រះជាម្ចាស់»
សូមស្តាប់
«សូមស្តាប់ខ្ញុំ» ឬ «សូមស្តាប់អ្វីដែលខ្ញុំនឹងនិយាយ»
ព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលនេះហើយ
«ព្រះជាម្ចាស់របស់ជនជាតិអ៊ីស្រាអែលថ្វាយបង្គំ»
បុព្វបុរសរបស់យើង
«បុព្វបុរសរបស់យើងជាជនជាតិ»
ធ្វើឲ្យប្រជាជនមានគ្នាជាច្រើន
«បានធ្វើឲ្យពួកគេមានគ្នាជាច្រើន» (UDB)
ដោយព្រះចេស្តារបស់ព្រះអង្គ
ឃ្លានេះសំដៅលើព្រះចេស្តាដ៏ខ្លាំងពូកែរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រកបដោយអំណាចចេស្តា»
ចេញពីប្រទេសនោះ
«ចេញពីទឹកដីអេស៊ីប»
ព្រះអង្គបានផ្គត់ផ្គង់ពួកគេ
ឃ្លានេះមានន័យថា: «ព្រះអង្គអត់ឱនដល់ពួកគេ»។
នៅក្នុងកំណែខ្លះប្រើពាក្យផ្សេងទៀត ដែលមានន័យថា «ព្រះអង្គមើលថែពួកគេ»។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់អត់ធ្មត់ជាមួយនឹងការមិនស្តាប់បង្គាប់របស់ពួកគេ» ឬ
«ព្រះជាម្ចាស់មើលថាពួកគេ»
Acts 13:19
ព័ត៌មានទូទៅ
ពាក្យ «គាត់» នៅទីនេះ សំដៅលើព្រះជាម្ចាស់។
ព័ត៌មានទូទៅ
ពាក្យ «ទឹកដីរបស់ពួកគេ» សំដៅលើទឹកដីរបស់ប្រជជាតិទាំងប្រាំពីរ
ដែលពួកគេចាប់យកបាន។
ព័ត៌មានទូទៅ
ពាក្យ «យើង» និង «ពួកគេ» សំដៅលើប្រជាជនអ៊ីស្រាអែល។
អ្នកស្តាប់ជនជាតិយូដារបស់លោកប៉ូល គឺបូករួមទាំង «យើង» គឺលោកប៉ូល
និងលោកបារណាបាស។
ប្រជាជាតិ
ពាក្យ «ប្រជាជាតិ» នៅទីនេះ សំដៅលើមនុស្សក្រុមផ្សេងៗ
និងមិនមែនភូមិសាស្ត្រដែលមានព្រំដែនទេ។
បានកើតមានក្នុងអំឡុងពេលប្រមាណបួនរយហាសិបឆ្នាំមុន
«បានចំណាយពេលជាងបួនរយហាសិបឆ្នាំដើម្បីបានសម្រេច»
រហូតដល់ព្យាការីសាំយូអែល
«រហូតដល់សម័យរបស់ព្យាការីសាំយូអែល»
Acts 13:21
ព័ត៌មានទូទៅ
ការដកស្រង់នៅទីនេះ មកពីប្រវត្តិរបស់លោកសាំយ៉ូអែល
និងពីទំនុកតម្កើងរបស់លោកអថាន នៅក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីចាស់។
អស់រយៈពេលសែសិបឆ្នាំ
«ធ្វើជាស្តេចរបស់ពួកគេអស់រយៈពេលសែសិបឆ្នាំ»
ព្រះជាម្ចាស់បានដកទ្រង់ចេញពីភាពជាស្តេច
ពាក្យនេះ មានន័យថាព្រះជាម្ចាស់បានធ្វើឲ្យស្តេចសូលលែងធ្វើជាស្តេចទៀត។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានបដិសេធស្តេចសូលពីភាពជាស្តេចទៀត» (UDB)។
ព្រះអង្គបានលើកព្រះបាទដាវីឌឲ្យធ្វើជាស្តេចរបស់ពួកគេ
«ព្រះជាម្ចាស់បានលើកព្រះបាទដាវីឌឲ្យធ្វើជាស្តេចរបស់ពួកគេ» ពាក្យ «លើក»
គឺជាពាក្យរបៀបធៀបដែលមានន័យថា ព្រះជាម្ចាស់ធ្វើឲ្យព្រះបាទដាវីឌធ្វើជាស្តេច។
ធ្វើជាស្តេចរបស់ពួកគេ
«ស្តេចរបស់អ៊ីស្រាអែល» ឬ «ស្តេចនៅលើអ៊ីស្រាអែល»
ព្រះអង្គបានមានបន្ទូលអំពីព្រះបាទដាវីឌថា
«ព្រះជាម្ចាស់បានមានបន្ទូលអំពីព្រះបាទដាវីឌ»
យើងរកបាន
«យើងសង្កេតឃើញថា»
ជាមនុស្សម្នាក់ជាទីគាប់ចិត្តយើងណាស់
ពាក្យនេះមានន័យថា «លោកជាមនុស្សម្នាក់ដែលចង់ធ្វើអ្វីដែលខ្ញុំចង់ធ្វើ»
Acts 13:23
ព័ត៌មានទូទៅ
ការដកស្រង់នៅទីនេះគឺដកស្រង់មកពីដំណឹងល្អ។
មកតាមព្រះរាជវង្សរបស់ព្រះបាទដាវីឌនេះហើយ

generated on Wed Sep 10 16:16:32 2025

«តាមរយៈព្រះរាជវង្សរបស់ព្រះបាទដាវីឌ» ឃ្លានេះបានដាក់តាំងពីប្រយោគដំបូង
ដើម្បីបញ្ជាក់ថា ព្រះសង្គ្រោះត្រូវតែជាម្នាក់ដែលមកពីពូជពង្សរបស់ព្រះបាទដាវីឌ។
(សូមមើល: ១៣:២១)
នាំព្រះសង្គ្រោះមួយអង្គដល់អ៊ីស្រាអែល
ឃ្លានេះសំដៅលើប្រជាជនអ៊ីស្រាអែល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រទានដល់ជនជាតិអ៊ីស្រាអែល។
ដូចព្រះអង្គបានសន្យា
«ដូចដែលព្រះជាម្ចាស់បានសន្យាថា ព្រះអង្គនឹងធ្វើ»
អំពីពិធីជ្រមុជទឹកនៃការប្រែចិត្ត
អ្នកអាចបកប្រែពាក្យ «ការប្រែចិត្ត» ជាកិរិយាសព្ទ «ប្រែចិត្ត» ក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អំពីពិធីជ្រមុជទឹកនៃការប្រែចិត្ត» ឬ
«ពិធីជ្រមុជដែលពួកគេចង់ធ្វើ ពេលពួកគេចង់ប្រែចិត្តចេញពីបាបរបស់ពួកគេ»។
តើអ្នករាល់គ្នាគិតថាខ្ញុំជានរណា?
លោកយ៉ូហានបានសួរសំណួរនេះទៅកាន់មនុស្សដើម្បីបង្ខំឲ្យគេគិតថាគាត់ជានរណា។
របៀបផ្សេងទៀតនៃការបកប្រែ: «គិតមើល ថាខ្ញុំជានរណា»
ខ្ញុំនេះមិនមែនជាព្រះអង្គទេ
លោកយ៉ូហានកំពុងសំដៅលើព្រះមេស្ស៊ី ដែលពួកគេរំពឹងថានឹងយាងមក។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនមែនជាព្រះមេស្ស៊ីទេ»
ប៉ុន្តែ សូមស្តាប់
ឃ្លានេះបញ្ជាក់ពីភាពសំខាន់នូវអ្វីដែលលោកនឹងមានប្រសាសន៍បន្ទាប់។
ព្រះអង្គដែលមកតាមក្រោយខ្ញុំ
ឃ្លានេះសំដៅលើព្រះមេស្ស៊ី។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះមេស្ស៊ីនឹងយាងមកជាឆាប់» (UDB)
សូម្បីតែស្រាយខ្សែស្បែកជើង ក៏ខ្ញុំមិនសមនឹងនឹងស្រាយផង
«ខ្ញុំមិនសម សូម្បីតែស្រាយខ្សែស្បែកជើងរបស់ព្រះអង្គផង»។
ព្រះមេស្ស៊ីធំអស្ចារ្យជាលោកយ៉ូហានឆ្ងាយណាស់ ដែលលោកមានអារម្មណ៍ថា
មិនសមឲ្យលោកបានស្រាយស្បែកជើងឲ្យព្រះអង្គ។
Acts 13:26
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ បូករួមទាំងលោកប៉ូល
និងអ្នកស្តាប់របស់លោកនៅក្នុងសាលាប្រជុំទាំងអស់គ្នា។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ឬ «របស់ពួកគេ» សំដៅលើ
ជនជាតិយូដាដែលរស់នៅក្នុងក្រុងយេរូសាឡិម។
បងប្អូន ដែលជាខ្សែស្រឡាយរបស់លោកអប្រាហាំ និងអស់អ្នកដែល...គោរពកោតខ្លាចព្រះជាម្ចាស់
អើយ!
លោកប៉ូលបញ្ជាក់ដល់អ្នកស្តាប់របស់លោកអំពីសាសន៍យូដា
និងសាសន៍ដទៃដែលប្តូរមកកាន់សាសនាយូដាវិញ
ដោយរំលឹកពួកគេពីឋានៈពិសេសក្នុងការថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិត។
ព្រះបន្ទូលដែលថ្លែងអំពីការសង្គ្រោះនេះ បានប្រទានមកដល់យើង
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលអំពីសេចក្តីសង្គ្រោះនេះហើយ»
អំពីការសង្គ្រោះនេះ
ពាក្យ «ការសង្គ្រោះ» អាចបកប្រែជាកិរិយាសព្ទ «សង្គ្រោះ»
របៀបផ្សេងទៀតនៃការបកប្រែ: «ថាព្រះជាម្ចាស់នឹងសង្គ្រោះមនុស្ស»
មិនបានស្គាល់ព្រះអង្គឡើយ
«មិនបានដឹងថាព្រះយេស៊ូនេះហើយ
ជាព្រះដែលព្រះជាម្ចាស់បានចាត់មកសង្គ្រោះពួកគេ» (UDB)
ពួកគេធ្វើតាមព្រះបន្ទូលរបស់ពួកព្យាការី
ពាក្យ «ព្រះបន្ទូល» តំណាងឲ្យព្រះបន្ទូលដែលពួកព្យាការីបានថ្លែង។
របៀបផ្សេងទៀតនៃការបកប្រែ: «គម្ពីររបស់ពួកព្យាការី» ឬ
«ព្រះបន្ទូលរបស់ពួកព្យាការី» ។
ដែលបានអាន
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដែលគេអាន»
ពួកគេធ្វើតាមព្រះបន្ទូលរបស់ព្យាការី
«ពួកគេធ្វើតាមព្រះបន្ទូលរបស់ព្យាការីបាននិយាយ
ពួកគេធ្វើតាមសេចក្តីដែលមាននៅក្នុងគម្ពីររបស់ពួកព្យាការី»។
Acts 13:28
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើជនជាតិយូដា
និងអ្នកដឹកនាំសាសនារបស់ពួកគេនៅក្នុងក្រុងយេរូសាឡិម។ ពាក្យ «គាត់»
នៅទីនេះ សំដៅលើព្រះយេស៊ូ។
ពួកគេរកហេតុអ្វី ដើម្បីកាត់ទោសព្រះអង្គដល់ស្លាប់ក្តី
«ពួកគេមិនបានរកហេតុផលអ្វីដើម្បីសម្លាប់ព្រះយេស៊ូបានទេ»។
ពួកគេនៅតែសុំឲ្យលោកពីឡាត
ពាក្យ «សុំ» នៅទីនេះ ពាក្យធ្ងន់ ក្នុងន័យតម្រូវ អង្វរ ឬទូលអង្វរ។
នៅពេលពួកគេបានធ្វើតាមសេចក្តីដែលមានចែងទុកអំពីព្រះអង្គហើយ
«នៅពេលពួកគេបានធ្វើដល់ព្រះយេស៊ូតាមសេចក្តីគ្រប់យ៉ាងដែល
ពួកព្យាការីបានចែងថា នឹងកើតឡើងជាមួយព្រះអង្គ»
ពួកគេបានយកសពព្រះអង្គចុះពីឈើឆ្កាង
វាអាចងាយយល់ក្នុងការនិយាយជាក់លាក់ថា
ព្រះយេស៊ូសុគតមិនពេលការនេះកើតឡើង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេសម្លាប់ព្រះយេស៊ូ ហើយយកព្រះអង្គចុះពីឈើឆ្កាង បន្ទាប់ពីព្រះអង្គសុគត»
ចុះពីឈើឆ្កាង
«ចុះពីឈើឆ្កាង»។
នេះគឺជារបៀបមួយផ្សេងទៀតដែលមនុស្សនៅសម័យនោះនិយាយទាក់ទងនឹងឈើឆ្កាង។
Acts 13:30
ប៉ុន្តែ ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យរស់ពីស្លាប់ឡើងវិញ
«ប៉ុន្តែ» បង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំងរវាងអ្វីដែលមនុស្សធ្វើ
និងអ្វីដែលព្រះជាម្ចាស់ធ្វើ។
បានប្រោសព្រះអង្គឲ្យរស់ពីស្លាប់ឡើងវិញ
«បានប្រោសព្រះអង្គឲ្យរស់ពីស្លាប់ឡើងវិញពីមនុស្សស្លាប់»។ ការនៅជាមួយ
«មនុស្សស្លាប់» មានន័យថា ព្រះយេស៊ូបានសុគត។
បានប្រោស
«ធ្វើឲ្យរស់ឡើងវិញ»
គេឃើញព្រះអង្គ...ពីស្រុកកាលីឡេ ទៅក្រុងយេរូសាឡិម
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកសិស្សដែលមកពីស្រុកកាលីឡេទៅក្រុងយេរូសាឡិមបានឃើញព្រះអង្គជាច្រើនថ្ងៃ»
ជាច្រើនថ្ងៃ
យើងដឹងពីអ្នកសរសេរផ្សេងទៀតថារយៈពេលនេះគឺសែសិបថ្ងៃ។ បកប្រែថា
«ជាច្រើនថ្ងៃ» ជាមួយនឹងឃ្លាដែលអាចជាក់លាក់នៃចំនួនថ្ងៃ។
បានធ្វើបន្ទាល់ពីព្រះអង្គដល់ប្រជាជន
«បានធ្វើបន្ទាល់ពីព្រះអង្គដល់ប្រជាជនអំពីព្រះយេស៊ូ» ឬ
«បានប្រាប់ប្រជាជនអំពីព្រះយេស៊ូ»
Acts 13:32
ព័ត៌មានទូទៅ
ការដក់ស្រង់ទីពីរនៅទីនេះគឺចេញពីព្យាការីអេសាយ។
ដូច្នេះ
ពាក្យនេះសង្កត់ពីព្រឹត្តការណ៍ដែលបានកើតឡើងដោយសារព្រឹត្តការណ៍ពីមុន។
នៅក្នុងករណីនេះ
ព្រឹត្តការណ៍មុនគឺព្រះជាម្ចាស់បានប្រោសព្រះយេស៊ូពីស្លាប់ឡើងវិញ។
បុព្វបុរសរបស់យើង
«បុព្វបុរសរបស់យើង» លោកប៉ូលនៅតែបន្តពីជនជាតិយូដា
និងសាសន៍ដទៃដែលនៅក្នុងសាលាប្រជុំអន់ទីយ៉ូក នៅស្រុកពីស៊ីឌា
ដែលបានប្តូរមកកាន់សាសនាយូដាវិញ។
ទាំងនេះគឺជាបុព្វបុរសខាងសាច់ឈាមរបស់ជនជាតិយូដា
និងបុព្វបុរសខាងវិញ្ញាណរបស់ពួកអ្នកដែលប្តូរសាសនា។
ព្រះជាម្ចាស់បានរក្សាសេចក្តីសន្យា
«ព្រះជាម្ចាស់បានធ្វើឲ្យសេចក្តីសន្យាបានសម្រេច»
សម្រាប់យើង និងកូនចៅរបស់ពួកគេ។
«សម្រាប់យើង ដែលជាកូនចៅរបស់បុព្វបុរសរបស់យើង»។
លោកប៉ូលនៅតែបន្តនិយាយទៅកាន់ជនជាតិយូដា
និងសាសន៍ដទៃដែលប្តូរមកកាន់សាសនាយូដា
ដែលនៅក្នុងសាលាប្រជុំអន់ទីយ៉ូកនៅស្រុកពីស៊ីឌា ។
ទាំងនេះគឺជាបុព្វបុរសខាងសាច់ឈាមរបស់ជនជាតិយូដា
និងបុព្វបុរសខាងវិញ្ញាណរបស់ពួកអ្នកដែលប្តូរសាសនា។
ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឲ្យមានរស់ឡើងវិញ
«ដោយធ្វើឲ្យព្រះយេស៊ូរស់ឡើងវិញ»

generated on Wed Sep 10 16:16:32 2025

ដូចមានសេចក្តីចែងទុកក្នុងទំនុកតម្កើងទីពីរថា
«ដូចមានសេចក្តីចែងទុកក្នុងទំនុកតម្កើងទីពីរគឺជាការពិត»។
ទំនុកតម្កើងទីពីរ
«ទំនុកតម្កើង២»
បុត្រ...បិតា
នេះគឺជាងារដ៏សំខាន់ដែលពណ៌នាអំពីទំនាក់ទំនងរវាងព្រះយេស៊ូ និងព្រះជាម្ចាស់។
ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឲ្យមានរស់ឡើងវិញ ដើម្បីកុំឲ្យសពព្រះអង្គត្រូវរលួយឡើយ
ព្រះជាម្ចាស់បានមានព្រះបន្ទូលបែបនេះថា
«ព្រះជាម្ចាស់មានបន្ទូលពាក្យទាំងនេះអំពីការដែលព្រះអង្គធ្វើឲ្យព្រះយេស៊ូរស់ឡើងវិញ
ដើម្បីកុំឲ្យព្រះអង្គសុគតទៀត»។
ពីមនុស្សស្លាប់
ឃ្លា «មនុស្សស្លាប់» សំដៅលើមនុស្សដែលបានស្លាប់។
ដើម្បីឲ្យបានរស់ឡើងវិញក្នុងចំណោមពួកគេ
មានន័យថាបានរស់ឡើងវិញសារជាថ្មី។
បានពរជាប្រាកដ
«ប្រាកដជាបានពរ»
Acts 13:35
នេះជាហេតុ បានជាព្រះអង្គមានព្រះបន្ទូលនៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងផ្សេងទៀតថា
អ្នកស្តាប់របស់លោកប៉ូលអាចយល់ថា កណ្ឌគម្ពីរទំនុកតម្កើងសំដៅលើព្រះមេស្ស៊ី។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងទំនុកតម្កើងរបស់ស្តេចដាវីឌផ្សេងទៀត
ទ្រង់ក៏មានបន្ទូលពីព្រះមេស្ស៊ីដែរ» ។
ព្រះអង្គក៏មានព្រះបន្ទូល
«ព្រះបាទដាវីឌក៏មានរាជឱង្ការដែរ»។
ព្រះបាទដាវីឌជាអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើង ១៦
ពីសេចក្តីដែលបានដកស្រង់ដែរ។
ព្រះអង្គមិនអនុញ្ញាតឲ្យអ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គត្រូវរលួយឡើយ
ឃ្លា «ត្រូវរលួយឡើយ» គឺជាពាក្យប្រៀបធៀបសម្រាប់ «ពុករលួយ»។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គមិនអនុញ្ញាតឲ្យរូបកាយអ្នកបម្រើដ៏វិសុទ្ធរបស់ព្រះអង្គត្រូវរលួយឡើង»
ព្រះអង្គមិនអនុញ្ញាតឲ្យ
នៅទីនេះ ព្រះបាទដាវីឌទូលទៅព្រះជាម្ចាស់។
ក្នុងជំនាន់របស់ទ្រង់នោះ
«ក្នុងជំនាន់ដែលទ្រង់គង់នៅ»
បានបម្រើព្រះជាម្ចាស់តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់
«បានធ្វើអ្វីដែលព្រះជាម្ចាស់ចង់ឲ្យទ្រង់ធ្វើ» ឬ
«បានធ្វើឲ្យព្រះជាម្ចាស់គាប់ព្រះទ័យ»។
ទ្រង់ក៏គេងលក់ទៅ
នេះគឺជារបៀបនិយាយគួរសម សំដៅលើការស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទ្រង់សុគត»
គេបានបញ្ចុះសពទ្រង់ក្នុងផ្នូរ ជាមួយបុព្វបុរសរបស់ទ្រង់
«បានបញ្ចុះជាមួយបុព្វបុរសរបស់ទ្រង់ ដែលបានសុគតទៅ»
បានរលួយអស់
ឃ្លា «បានរលួយអស់» គឺជានិមិត្តរូបសម្រាប់ «រូបកាយដែលរលួយ»។
របៀបផ្សេងទៀតនៃការបកប្រែ: «រូបកាយរបស់ទ្រង់ត្រូវរលួយ»
ប៉ុន្តែ ព្រះអង្គដែល
«ប៉ុន្តែ ព្រះយេស៊ូដែល»
មិនបានរលួយទេ
ឃ្លា «មិនបានរលួយទេ» គឺជាវិធីក្នុងការនិយាយថា «មិនបានរលួយទេ»។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនត្រូវរលួយ»
Acts 13:38
ព័ត៌មានទូទៅ
ពាក្យ «ព្រះអង្គ» នៅទីនេះ សំដៅលើព្រះយេស៊ូ។
សូមបងប្អូនដឹងច្បាស់ថា
«ចូរដឹងពីការនេះ» ឬ «ការនេះសំខាន់សម្រាប់បងប្អូនក្នុងការដឹង»
បងប្អូន
លោកប៉ូលប្រើប្រយោគនេះដោយសារពួកគេជាជនជាតិយូដា
និងជាអ្នកដើរតាមសាសនាយូដាដែរ។ នៅត្រង់ចំណុចនេះ
ពួកគេមិនមែនជាអ្នកជឿដែលជាគ្រិស្តបរិស័ទឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនអ៊ីស្រាអែល
និងមិត្រភក្តិផ្សេងៗទៀតអើយ» (UDB)
ដោយសារបុរសនេះហើយ យើងបានប្រកាសពីការអត់ទោសបាបដល់បងប្អូន
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងប្រកាសដល់បងប្អូនថា
បាបរបស់បងប្អូនអាចទទួលការអត់ទោសតាមរយៈព្រះយេស៊ូ»
ការអត់ទោសបាប
«ការអត់ទោសបាប» ជានាមអរូបី អាចបកប្រែជាកិរិយាសព្ទ «អត់ទោស»។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់អាចអត់ទោសបាបរបស់អ្នករាល់គ្នា»
តាមរយៈព្រះអង្គ អស់អ្នកណាដែលជឿ
«តាមរយៈព្រះអង្គ អស់អ្នកណាដែលជឿ» ឬ «មនុស្សគ្រប់គ្នាដែលជឿលើព្រះអង្គ»
តាមរយៈព្រះអង្គ អស់អ្នកណាដែលជឿនិងបានសុចរិតពីការគ្រប់យ៉ាង
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះយេស៊ូនឹងធ្វើឲ្យអ្នកជឿគ្រប់គ្នាបានសុចរិត»។
ពីការគ្រប់យ៉ាង
«ពីអំពើបាបទាំងអស់»
Acts 13:40
ប្រយោគភ្ជាប់
លោកប៉ូលបានបញ្ចប់សន្ទរកថារបស់លោកនៅក្នុងសាលាប្រជុំនៅស្រុកពីស៊ីឌា
ក្រុងអន់ទីយ៉ូក ដែលបានចាប់ផ្តើមនៅក្នុងជំពូក ១៣:១៦
ព័ត៌មានទូទៅ
នៅក្នុងសាររបស់គាត់ទៅកាន់ប្រជាជននៅក្នុងសាលាប្រជុំ
លោកប៉ូលបានដកស្រង់ចេញពីព្យាការីហាបាគុក។
ព័ត៌មានទូទៅ
ពាក្យ «ខ្ញុំ» នៅទីនេះ សំដៅលើព្រះជាម្ចាស់។
ចូរប្រយ័ត្ន
ឃ្លានេះបញ្ជាក់ថាអ្វីដែលពួកគេស្តាប់សារពីលោកប៉ូលនោះ ពួកគេត្រូវប្រយ័ត្ន។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរយកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំនិយាយ»
អ្វីដែលពួកព្យាការីបានថ្លែង
«ដើម្បីស្តាប់អ្វីដែលពួកព្យាការីបានថ្លែង»
មើល៍ មនុស្សដែលមើលងាយអ្នក
«អ្នកដែលមានអារម្មណ៍ថាគេមើលងាយ» ឬ «អ្នកដែលត្រូវញ្ជេរញ្ជែង»
នឹងងឿងឆ្ងល់
«ភ្ញាក់ផ្អើល» ឬ «តក់ស្លុត»
ហើយនឹងត្រូវវិនាសបាត់ទៅ
«ហើយនឹងស្លាប់»
ខ្ញុំកំពុងធ្វើកិច្ចការមួយ
«ខ្ញុំកំពុងធ្វើអ្វីមួយ» ឬ «ខ្ញុំកំពុងធ្វើការមួយ»
នៅជំនាន់របស់បងប្អូន
«នៅក្នុងសម័យរបស់បងប្អូន»
ជាកិច្ចការ ដែល
«ខ្ញុំកំពុងធ្វើការអ្វីមួយដែល»
ទោះបីជាមានគេប្រកាសអ្នករាល់គ្នាក៏ដោយ
«ទោះបីជាមានគេប្រាប់អ្នករាល់គ្នាក៏ដោយ»
Acts 13:42
ពេលលោកប៉ូល និងលោកបារណាបាសចាកចេញ
«ក្នុងកាលដែលលោកប៉ូល និងលោកបារណាបាសកំពុងតែចាកចេញ»
ប្រជាជនបានអង្វរពួកគេឲ្យ
«បានអង្វរពួកគេឲ្យ»
មានប្រសាសន៍អំពីសេចក្តីទាំងនេះ ម្តងទៀត
ពាក្យ «សេចក្តីនេះ» សំដៅលើព្រះបន្ទូលដែលលោកប៉ូលបាននិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រកាសព្រះបន្ទូលម្តងទៀត»
ពេលប្រជុំនៅសាលាប្រជុំចប់ហើយ
អាចមានន័យថា ទី១) និយាយម្តងទៀត «ពេលលោកប៉ូល និងលោកបារណាបាស
ចាកចេញ» នៅក្នុងខ៤២ ឬ ទី២) ពេលលោកប៉ូល និងលោកបារណាបាស
ចាកចេញពីការប្រជុំ មុនពេលចប់ ហើយការនេះបានកើតឡើងនៅពេលក្រោយ។
ពួកអ្នកកោតខ្លាចព្រះចូលសាសនាយូដាជាច្រើន
អ្នកទាំងនេះមិនមែនជាជនជាតិយូដាទេ ដែលបានប្តូរមកកាន់សាសនាយូដា។
ដែលបាននិយាយមួយពួកគេ ហើយដាស់តឿនពួកគេ
«លោកប៉ូល និងលោកបារណាបាសបាននិយាយជាមួយ

generated on Wed Sep 10 16:16:32 2025

អ្នកទាំងនោះហើយបានលើកទឹកចិត្តពួកគេ»
ឲ្យបន្តនៅក្នុងព្រះគុណរបស់ព្រះជាម្ចាស់
ឃ្លានេះបង្ហាញថា ពួកគបានជឿព្រះបន្ទូលរបស់លោកប៉ូល ដែលប្រកាសថា
ព្រះយេស៊ូជាព្រះមេស្ស៊ី។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឲ្យបន្តក្នុងការទុកចិត្តថាព្រះជាម្ចាស់នឹងអត់ទោសបាបរបស់មនុស្សដោយសារអ្វីដែលព្រះយេស៊ូបានធ្វើ»
Acts 13:44
ព័ត៌មានទូទៅ
ពាក្យ «គាត់» នៅទីនេះ សំដៅលើលោកប៉ូល។
ស្ទើរតែនៅក្រុងទាំងមូល
«ទីក្រុង» តំណាងឲ្យមនុស្សនៅក្នុងទីក្រុង។
ឃ្លានេះប្រើដើម្បីបង្ហាញពីការឆ្លើយតបចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងខ្លាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សភាគច្រើននៅក្នុងទីក្រុង»
ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់
ឃ្លានេះបញ្ជាក់ថា លោកប៉ូល និងលោកបារណាបាស
គឺជាអ្នកប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីស្តាប់លោកប៉ូល និងលោកបារណាបាសប្រកាសអំពីព្រះអម្ចាស់យេស៊ូ»
ជនជាតិយូដា
ពាក្យ «ជនជាតិយូដា» តំណាងឲ្យអ្នកដឹកនាំរបស់ជនជាតិយូដា។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកអ្នកដឹកនាំជនជាតិយូដា»
មានចិត្តច្រណែនជាខ្លាំង
ពាក្យ ចិត្តច្រណែននៅទីនេះ និយាយអំពីអ្វីមួយដែលមាននៅក្នុងចិត្តរបស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «មានចិត្តច្រណែនជាខ្លាំង»
និយាយទាស់នឹង
«និយាយប្រឆាំង» ឬ«ជំទាស់»
អ្វីៗដែលលោកប៉ូលបានមានប្រសាសន៍
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីៗដែលលោកប៉ូលមានប្រសាសន៍»
Acts 13:46
ព័ត៌មានទូទៅ
ឧទាហរណ៍ពីរដំបូងរបស់ពាក្យ «អ្នក» ជាពហុវចន:
ហើយសំដៅលើជនជាតិយូដាដែលលោកប៉ូលនិយាយជាមួយ។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកប៉ូល និងលោកបារណាបាស ប៉ុន្តែ
មិនមែនបណ្តាជនដែលមានវត្តមាននៅទីនេះទេ។
ព័ត៌មានទូទៅ
ការដកស្រង់របស់លោកប៉ូលគឺចេញពីព្យាការីអេសាយនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់។
នៅក្នុងព្រះបន្ទូលដើម ពាក្យ «ខ្ញុំ» សំដៅលើព្រះជាម្ចាស់ ហើយពាក្យ «អ្នក»
ជាឯកវចន: និងសំដៅលើព្រះមេស្ស៊ី។ នៅទីនេះ លោកប៉ូល
និងលោកបារណាបាសនិយាយពាក្យដកស្រង់នេះសំដៅលើកិច្ចការបម្រើរបស់ពួកគេដែរ
សំខាន់ណាស់
ឃ្លានេះ បញ្ជាក់ថាព្រះជាម្ចាស់បានបង្គាប់ថាត្រូវតែធ្វើការនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់បានបង្គាប់»
ដែលយើងខ្ញុំត្រូវតែប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់បងប្អូនជាមុនសិន។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់បងប្អូនជាមុនសិន»
ប៉ុន្តែដោយបងប្អូនបដិសេធ
ការបដិសេធព្រះបន្ទូលព្រះជាម្ចាស់របស់ពួកគេគឺនិយាយអំពីអ្វីមួយដែលពួកគេច្រានចោល
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលបងប្អូនបដិសេធព្រះបន្ទូលរបស់ព្រះជាម្ចាស់»។
គិតថា ខ្លួនមិនសមនឹងទទួលជីវិតអស់កល្បជានិច្ចទេ
«បានបង្ហាញថា បងប្អូនមិនសមនឹងជីវិតអស់កល្បជានិច្ចទេ» (UDB) ឬ
«ធ្វើដូចជាគិតថាបងប្អូនមិនសមនឹងជីវិតអស់កល្បជានិច្ចទេ»
យើងខ្ញុំនឹងងាកទៅសាសន៍ដទៃវិញ
ពាក្យ «ងាក» សំដៅទៅលើបួរទៅរកអ្នកដែលពួកគេអាចបង្រៀនបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ឥឡូវនេះ
យើងនឹងប្រកាសព្រះបន្ទូលដល់សាសន៍ដទៃ»
ព្រះអម្ចាស់យេស៊ូបានធ្វើ
នៅទីនេះ សេចក្តីពិតអំពីព្រះយេស៊ូនោះលោកប៉ូលកំពុងតែប្រកាស
ប្រៀបដូចជាពន្លឺមួយដែលអនុញ្ញាតឲ្យមនុស្សមើលឃើញ។
នាំការសង្គ្រោះទៅដល់ចុងបំផុតនៃផែនដី
«សេចក្តីសង្គ្រោះ» ជាពាក្យអរូបនាម អាចប្រែជាកិរិយាសព្ទ «សង្គ្រោះ» ឃ្លា
«ចុងបំផុត» សំដៅលើគ្រប់កន្លែង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាប់មនុស្សគ្រប់ទីកន្លែងនៅក្នុងពិភពលោកនេះថា ខ្ញុំចង់សង្គ្រោះពួកគេ»
Acts 13:48
សរសើរតម្កើងព្រះបន្ទូលរបស់ព្រះអម្ចាស់
ពាក្យ «ព្រះបន្ទូល» នៅទីនេះ
សំដៅលើព្រះបន្ទូលអំពីព្រះយេស៊ូដែលពួកគេបានជឿ»។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេសរសើរព្រះជាម្ចាស់ដោយសារព្រះបន្ទូលអំពីព្រះអម្ចាស់យេស៊ូ»
អស់អ្នកដែលព្រះជាម្ចាស់តម្រូវឲ្យទទួលជីវិតអស់កល្បជានិច្ច
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានអ្នកដែលព្រះជាម្ចាស់បានតម្រូវឲ្យទទួលជីវិតអស់កល្បជាចិត្តជាច្រើនបានជឿ»
ឬ «មនុស្សគ្រប់គ្នា
ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យទទួលជីវិតអស់កល្បជានិច្ច»
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានផ្សាយសុសសាយទូទាំងតំបន់នោះទាំងមូល
«ព្រះបន្ទូល» នៅទីនេះ សំដៅលើព្រះបន្ទូលអំពីព្រះយេស៊ូ។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលបានជឿបានប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់នៅគ្រប់តំបន់ទាំងអស់»
ឬ «អស់អ្នកដែលបានជឿបានចេញទៅគ្រប់កន្លែងនៅក្នុងតំបន់
ហើយប្រាប់អ្នកដទៃអំពីព្រះបន្ទូលរបស់ព្រះយេស៊ូ» ។
Acts 13:50
ប្រយោគភ្ជាប់
នេះគឺជាពេលចុងក្រោយរបស់លោកប៉ូលនិងលោកបារណាបាសនៅក្រុងអន់ទីយ៉ូក
ក្នុងស្រុកពីស៊ីឌា ហើយពួកគេបានចេញទៅអ៊ីកូនាម។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះសំដៅលើលោកប៉ូល និងលោកបារណាបាស។
សាសន៍យូដា
ប្រហែលជាសំដៅលើអ្នកដឹកនាំរបស់សាសន៍យូដា។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹកនាំរបស់សាសន៍យូដា»
បានជំរុញ
«បញ្ចុះបញ្ចូល» ឬ «លើកទឹកចិត្ត»
មានមុខមាត់
«ជាអ្នកមានមុខមានមាត់»
ឲ្យលើកគ្នាទៅបៀតបៀនលោកប៉ូល និងលោកបារណាបាស
«ពួកគេបញ្ចុះបញ្ចូលពួកអ្នកមានមុខមានមាត់
និងពួកស្រីៗឲ្យបៀតបៀនលោកប៉ូល និងលោកបារណាបាស»
ដេញពួកគេចេញពីដែនដីក្រុងរបស់ពួកគេ
«យកលោកប៉ូល និងលោកបារណាបាសចេញពីទីក្រុងរបស់ពួកគេ»
ធាន
ដាស់ធូលីដីចេញពីជើងរបស់ពួកគេទាស់នឹងពួកគេ
នេះគឺជាសញ្ញាដែលបង្ហាញដល់ពួកអ្នកមិនជឿថា ព្រះជាម្ចាស់នឹងបដិសេធពួកគេ
ហើយនិងដាក់ទោសពួកគេ»
ពួកសិស្ស
ឃ្លានេះប្រហែលជាសំដៅលើពួកអ្នកជឿថ្មីនៅក្នុងក្រុងអន់ទីយ៉ូក ស្រុកពីស៊ីឌា
ដែលលោកប៉ូលនិងលោកស៊ីឡាសទើបតែចាកចេញ។

---

14 [1]នៅក្រុងអ៊ីកូនាម លោកប៉ូល និងលោកបារណាបាសបានចូលទៅក្នុងសាលាប្រជុំរបស់ជនជាតិយូដា ហើយមានប្រសាសន៍រហូតដល់ជនជាតិយូដា និងជនជាតិក្រិក
ដ៏ច្រើនលើសលប់នាំគ្នាជឿ។[2]ប៉ុន្តែ ជនជាតិយូដាដែលមិនព្រមជឿ បានញុះញង់សាសន៍ដទៃ និងធ្វើឲ្យគេមានចិត្តទាស់នឹងពួកបងប្អូន។
[3]លោកប៉ូល និងលោកបារណាបាសស្នាក់នៅក្នុងក្រុងអ៊ីកូនាមជាយូរថ្ងៃពោរពេញដោយឫទ្ធានុភាពមកពីព្រះជាម្ចាស់ ខណៈពេលព្រះអង្គបានបញ្ជាក់ព្រះបន្ទូលអំពី
ព្រះគុណរបស់ព្រះអង្គ។ ព្រះអង្គបានឲ្យលោកទាំងពីរសម្តែងទីសម្គាល់ដ៏អស្ចារ្យ និងឫទ្ធិបាដិហារិយ៍ផ្សេងៗ។[4]មនុស្សជាច្រើននៅក្រុងនោះបានបាក់បែកគ្នា អ្នកខ្លះកាន់ខាង
សាសន៍យូដា អ្នកខ្លះទៀតកាន់ខាងក្រុមសាវក។

generated on Wed Sep 10 16:16:32 2025

[5]នៅពេលសាសន៍ដទៃ និងសាសន៍យូដាបានសមគំនិតគ្នាជាមួយពួកមេដឹកនាំរបស់គេ ចង់ធ្វើបាប និងចង់យកដុំថ្មគប់សម្លាប់លោកទាំងពីរ[6]លោកប៉ូល និងលោកបារណាបាសដឹងមុនពីសភាពការណ៍មិនស្រួល ក៏រត់ភៀសខ្លួនទៅស្រុកលូកៅនា គឺទៅក្រុងលីស្ត្រា និងក្រុងឌើបេ ព្រមទាំងតំបន់ដែលនៅជុំវិញ[7]ហើយប្រកាសដំណឹងល្អនៅទីនោះ។
[8]នៅក្រុងលីស្ត្រា មានបុរសម្នាក់ពិការជើងតាំងពីកំណើតមក ហើយគាត់មិនអាចដើរបានឡើយ។[9]គាត់អង្គុយស្តាប់លោកប៉ូលមានប្រសាសន៍។ លោកប៉ូលសម្លឹងមើលគាត់ ហើយយល់ឃើញថា គាត់មានជំនឿគួរនឹងជា។[10]លោកក៏មានប្រសាសន៍ទៅគាត់ខ្លាំងៗថា៖ «សុំក្រោកឡើង ឈរឲ្យត្រង់!»។ បុរសនោះស្ទុះក្រោកឈរដោយអាចលោតបាន និងដើរបានផង។
[11]ពេលមហាជនឃើញការអស្ចារ្យដែលលោកប៉ូលបានធ្វើ គេក៏នាំគ្នាស្រែកហ៊ោជាភាសាលូកៅនាថា៖ «ព្រះបាននិមិត្តជាមនុស្ស ចុះមកគង់ជាមួយយើងហើយ!»។[12]គេហៅលោកបារណាបាសថា «ព្រះសេយូស» និងហៅលោកប៉ូលថា «ព្រះហ៊ើមេស» ព្រោះលោកជាអ្នកនាំពាក្យ។[13]បូជាចារ្យរបស់ព្រះសេយូសដែលមានវិហារនៅក្រៅទីក្រុង បានដឹកគោឈ្មោលតុបតែងលំអដោយភួងផ្កា មកមាត់ទ្វារក្រុង ព្រោះគាត់ចង់ធ្វើបូជាយញ្ញរួមជាមួយមហាជន។
[14]កាលសាវកបារណាបាស និងប៉ូលបានឮដំណឹងនេះ លោកក៏ហែកសម្លៀកបំពាក់ ហើយស្ទុះរត់ទៅរកប្រជាជន ទាំងស្រែកយំ[15]ហើយពោលថា៖ «ហេតុអ្វីបានជាបងប្អូននាំគ្នាធ្វើដូច្នេះ? យើងខ្ញុំក៏ជាមនុស្សធម្មតាដូចបងប្អូនដែរ។ យើងខ្ញុំនាំដំណឹងល្អមកជម្រាបជូនបងប្អូន ដើម្បីបងប្អូនងាកចេញពីការថ្វាយបង្គំរូបសំណាក់ឥតប្រយោជន៍នេះ ហើយបែរមករកព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ ជាព្រះដែលបានបង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងអ្វីៗសព្វសារពើដែលមាននៅទីទាំងនោះផង។[16]នៅជំនាន់មុនៗ ព្រះអង្គបានបណ្តោយឲ្យជាតិសាសន៍នានាដើរតាមមាគ៌ារបស់គេរៀងៗខ្លួន។
[17]ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គនៅតែបង្ហាញទីសម្គាល់ ដោយព្រះអង្គបានផ្តល់ក្តីសប្បុរសមកយើង ហើយទ្រង់បានប្រទានទឹកភ្លៀងពីលើមេឃ និងប្រទានភោគផលមកបងប្អូនតាមរដូវកាល ធ្វើឲ្យបងប្អូនមានមួបអាហារដ៏បរិបូណ៌ និងមានអំណរសប្បាយក្នុងចិត្តផង»។[18]ទោះបីលោកទាំងពីរមានប្រសាសន៍ដូច្នេះ ក៏លោករកឃាត់មហាជនមិនឲ្យធ្វើបូជាយញ្ញជូនលោកសឹងតែពុំបាន។
[19]ប៉ុន្តែ មានជនជាតិយូដាមកពីក្រុងអន់ទីយ៉ូក និងក្រុងអ៊ីកូនាម បានទាក់ទាញចិត្តមហាជនឲ្យចូលទៅខាងគេ។ ពួកគេយកដុំថ្មគប់សម្លាប់លោកប៉ូល រួចអូសយកទៅចោលនៅខាងក្រៅទីក្រុង ព្រោះគេនឹកស្មានថា លោកស្លាប់បាត់ទៅហើយ។[20]ប៉ុន្តែ ក្រុមសិស្សនាំគ្នាមកឈរជុំវិញលោក លោកក៏ក្រោកឡើង វិលចូលទៅទីក្រុងវិញ។ លុះស្អែកឡើង លោកចេញដំណើរទៅក្រុងឌើបេជាមួយលោកបារណាបាស។
[21]លោកប៉ូល និងលោកបារណាបាសបានផ្សព្វផ្សាយដំណឹងល្អនៅក្រុងឌើបេ ហើយណែនាំមនុស្សជាច្រើនឲ្យក្លាយជាសិស្ស។ បន្ទាប់មក លោកវិលទៅក្រុងលីស្ត្រា ក្រុងអ៊ីកូនាម និងក្រុងអន់ទីយ៉ូកវិញ។[22]លោកដាស់តឿនពួកសិស្សឲ្យតាំងចិត្តមាំមួន និងលើកទឹកចិត្តគេឲ្យមានជំនឿខ្ជាប់ខ្ជួន ដោយមានប្រសាសន៍ថា៖ «យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីឲ្យបានចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់»។
[23]លោកបានតែងតាំងពួកព្រឹទ្ធាចារ្យនៅតាមក្រុមជំនុំនីមួយៗ ហើយបានអធិស្ឋាន និងតមអាហាររួចហើយ លោកទាំងពីរក៏ផ្ញើពួកសិស្សទុកនៅនឹងព្រះអម្ចាស់ដែលគេបានជឿ។[24]បន្ទាប់មកទៀត លោកទាំងពីរធ្វើដំណើរឆ្លងកាត់ស្រុកពីស៊ីឌាមកដល់ស្រុកប៉ាមភីលា។[25]លោកបានប្រកាសព្រះបន្ទូលនៅក្រុងពើកា រួចលោកនាំគ្នាចុះទៅក្រុងអាតាលា។[26]នៅទីនោះ លោកនាំគ្នាចុះសំពៅវិលត្រឡប់មកក្រុងអន់ទីយ៉ូកវិញ គឺនៅក្រុងអន់ទីយ៉ូកនេះហើយ ដែលក្រុមជំនុំបានផ្ញើលោកទាំងពីរទៅលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដើម្បីបំពេញកិច្ចការដែលលោកទើបនឹងបានសម្រេចនេះ។
[27]កាលលោកទាំងពីរមកដល់ លោកប្រមូលក្រុមជំនុំឲ្យមកជួបជុំគ្នា ហើយរៀបរាប់អំពីកិច្ចការទាំងប៉ុន្មាន ដែលព្រះជាម្ចាស់បានធ្វើជាមួយពួកលោក និងរៀបរាប់អំពីរបៀបដែលព្រះអង្គបើកផ្លូវឲ្យសាសន៍ដទៃបានជឿ។[28]លោកទាំងពីរក៏ស្នាក់នៅទីនោះជាមួយពួកសិស្សអស់រយៈពេលជាយូរ។

Acts 14:1
ព័ត៌មានទូទៅ
សាច់រឿងរបស់លោកប៉ូល និងលោកបារណាបាស បន្តនៅក្នុងក្រុងអ៊ីកូនាម។
កាលបានទៅដល់ក្រុងអ៊ីកូនាមហើយ
អាចមានន័យ ទី១) «បានកើតឡើងនៅក្រុងអ៊ីកូនាម» ឬ ទី២)
នៅក្រុងអ៊ីកូននាមដូចធម្មតា»។
បានប្រកាសរហូតដល់
«ប្រកាសប្រកបដោយអានុភាព»។ និយាយឲ្យងាយយល់គឺថា
ពួកគប្រកាសព្រះបន្ទូលអំពីព្រះយេស៊ូ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រកាសព្រះបន្ទូលអំពីព្រះយេស៊ូប្រកបដោយអានុភាពជាខ្លាំង»
ជនជាតិយូដាដែលមិនស្តាប់បង្គាប់
ឃ្លានេះសំដៅលើជនជាតិយូដាមួយចំនួនដែលមានបានជឿព្រះបន្ទូលអំពីព្រះយេស៊ូ។
បានចាក់រុកដល់គំនិតសាសន៍ដទៃ
ធ្វើឲ្យសាសន៍ដទៃខឹងជាខ្លាំង របៀបដូចជាទឹកបាក់ត្រនប់។
គំនិត
ពាក្យ «គំនិត» នៅទីនេះ សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«សាសន៍ដទៃ»
ពួកបងប្អូន
ពាក្យ «ពួកបងប្អូន» នៅទីនេះ សំដៅលើលោកប៉ូល និងលោកបារណាបាស
និងពួកអ្នកជឿថ្មី។
Acts 14:3
ព័ត៌មានទូទៅ
ពាក្យ «ព្រះអង្គ» នៅទីនេះ សំដៅលើព្រះអម្ចាស់។
ដូច្នេះ ពួកគេបានស្នាក់នៅទីនោះ
«ទោះជាយ៉ាងណាក៏ដោយ ពួកគេបានស្នាក់នៅទីនោះ»។ លោកប៉ូល
និងលោកបារណាបាសបានស្នាក់នៅក្រុងអ៊ីកូនាម សម្រាប់នុស្សជាច្រើនដែលជឿ
នៅក្នុងជំពូក ១៤:១។ «ដូច្នេះ»
អាចលុបចោលប្រសិនបើធ្វើឲ្យមានការយល់ច្រឡំនៅក្នុងបរិបទនេះ។
បានបញ្ជាក់ព្រះបន្ទូលអំពីព្រះគុណរបស់ព្រះអង្គ
«បានបង្ហាញពីព្រះបន្ទូលនៃព្រះគុណរបស់ទ្រង់ថាជាសេចក្តី»។
ដោយប្រទានឲ្យមានទីសម្គាល់ និងការអស្ចារ្យដោយរយៈដៃរបស់លោកប៉ូល និងលោកបារណាបាស
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយធ្វើឲ្យលោកប៉ូល និងលោកបារណាបាស ក្នុងការធ្វើការអស្ចារ្យ
និងទីសម្គាល់ផ្សេងៗ។
តាមរយៈដៃរបស់លោកប៉ូល និងលោកបារណាបាស
ពាក្យ «ដៃ» នៅទីនេះ សំដៅលើបំណងចិត្ត និងការខំប្រឹងប្រែងរបស់អ្នកទាំងពីរ
ដែលនាំដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ របៀបផ្សេងទៀតនៃការបកប្រែ:
«តាមរយៈព័ន្ធកិច្ចរបស់លោកប៉ូល និងលោកបារណាបាស»
មនុស្សភាគច្រើននៅក្រុងនោះបានបាក់បែកគ្នា
ពាក្យ «ទីក្រុង» នៅទីនេះ សំដៅលើមនុស្សដែលរស់នៅក្នុងទីក្រុងនោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សភាគច្រើននៅក្នុងទីក្រុងមិនបានយល់ស្របជាមួយគ្នាឡើយ»
អ្នកខ្លះនៅខាងសាសន៍យូដា
«បានគាំទ្រសាសន៍យូដា» ឬ «យល់ស្របជាមួយជាមួយសាសន៍យូដា»។
ក្រុមទីមួយមិនបានយល់ស្របជាមួយនឹងព្រះបន្ទូលនៃព្រះគុណទេ។
អ្នកខ្លះទៀតនៅខាងពួកសាវក
ក្រុមទីពីរយល់ស្របជាមួយនឹងព្រះបន្ទូលនៃព្រះគុណ។
វាងាយយល់ក្នុងការនិយាយជាថ្មីដោយកិរិយាសព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅខាងពួកសាវក» ។
ពួកសាវក
លូកាសំដៅលើលោកប៉ូល និងលោកបារណាបាស។ ពាក្យ «សាវក» នៅទីនេះ
អាចត្រូវបានប្រើជាទូទៅក្នុងន័យ «ម្នាក់ដែលបានចាត់ឲ្យទៅ»។
Acts 14:5
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល និងលោកបារណាបាស។
បានរួមគំនិតគ្នាដើម្បីបញ្ចុះបញ្ចូលមេដឹកនាំរបស់គេ
«បានព្យាយាមបញ្ចុះបញ្ចូលពួកអ្នកដឹកនាំរបស់ក្រុងអ៊ីកូនាម»។ នៅទីនេះ
«រួមគំនិតគ្នា» បង្ហាញថា

generated on Wed Sep 10 16:16:32 2025

ពួកគេមិនអាចបញ្ចុះបញ្ចូលពួកគេមុនពេលពួកសាវកចាកចេញពីទីក្រុង។
ដើម្បីធ្វើបាប និងចង់ចោលនឹងដុំថ្មសម្លាប់លោកប៉ូល និងបារណាបាស
«វាយលោកប៉ូល និងលោកបារណាបាស ហើយសម្លាប់ពួកគេដោយចោលនឹងដុំថ្ម»
ស្រុកលូកៅនា
ជាស្រុកមួយនៅក្នុងស្រុកអាស៊ីមីន័រ ។
ក្រុងលីស្ត្រា
ជាទីក្រុងមួយនៅក្នុងអាស៊ីមីន័រ ភាគខាងត្បូងក្រុងអ៊ីកូនាម និងភាគខាងជើងក្រុងឌើបេ
ក្រុងឌើបេ
ជាទីក្រុងមួយនៅក្នុងអាស៊ីមីន័រ ភាគខាងត្បូងក្រុងអ៊ីកូនាម និងក្រុងលីស្ត្រា
ពួកគេប្រកាសដំណឹងល្អនៅទីនោះ
«លោកប៉ូល និងលោកបារណាបាសប្រកាសដំណឹងល្អនៅទីនោះ»
Acts 14:8
ប្រយោគភ្ជាប់
លោកប៉ូល និងលោកបារណាបាសនៅលីស្ត្រានៅពេលនេះ។
ព័ត៌មានទូទៅ
ពាក្យ «លោក» ទីមួយ សំដៅលើបុរសស្ងិតជើង ហើយពាក្យ «លោក» លើកទីពីរ សំដៅលើលោកប៉ូល។ ពាក្យ «គាត់» សំដៅលើបុរសស្ងិតជើង។
មានបុរសម្នាក់អង្គុយ
នេះគឺជាការណែនាំមនុស្សថ្មីនៅក្នុងសាច់រឿង។
ជើងរបស់គាត់គ្មានកម្លាំងទេ
«មិនអាចធ្វើចលនាជើងរបស់គាត់ទេ» ឬ «មិនអាចដើរដោយជើងគាត់បានទេ»។
ពិការជើង
«ខ្វិន»
ស្ងិតជើង តាំងពីក្នុងផ្ទៃរបស់ម្តាយរបស់គាត់មកម្ល៉ះ
«ស្ងិតជើងតាំងពីកំណើត»
លោកប៉ូលសម្លឹងមើលគាត់
«លោកប៉ូលបានមើលទៅរកគាត់»
ឃើញថា គាត់មានជំនឿអាចនឹងជាបាន
«ជំនឿ» គឺជាអរូបនាម អាចប្រែជាមួយនិងកិរិយាសព្ទ «ជឿ» បានជឿថាព្រះយេស៊ូអាចប្រោសគាត់ឲ្យជា» ឬ «បានជឿថាព្រះយេស៊ូអាចធ្វើឲ្យគាត់ជា»
បានលោតឡើង
«បានលោតឡើងទៅលើ»។ នេះបង្ហាញថា ជើងរបស់គាត់បានជាទាំងស្រុង។
Acts 14:11
អ្វីដែលលោកប៉ូលបានធ្វើ
ឃ្លានេះសំដៅលើការដែលលោកប៉ូលប្រោសបុរសខ្វិនឲ្យជា។
ព្រះបានយាងចុះមករកយើង
មានមនុស្សយ៉ាងច្រើនកោះករជឿលើលោកប៉ូល និងលោកបារណាបាសថាជាព្រះរបស់ពួកគេដែលបានចុះពីស្ថានសួគ៌មក។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះបានចុះពីស្ថានសួគ៌មានរកយើង»
និយាយជាភាសាលូកៅនា
«នៅក្នុងភាសាលូកៅនារបស់ពួកគេផ្ទាល់» (UDB)។ អ្នកស្រុកលីស្ត្រា និយាយភាសាលូកៅនា និងក្រិកផងដែរ។
ក្នុងទម្រង់ជាមនុស្ស
ប្រជាជនទាំងនេះបានជឿថាព្រះរបស់ពួកគេប្តូរលក្ខណៈដើម្បីឲ្យមើលទៅដូចជាមនុស្ស។
ពួកគេហៅលោកបារណាបាសថា៖ «ព្រះសេយូស»
ព្រះសេយូសគឺជាស្តេចលើព្រះរបស់សាសន៍ដទៃ។
ហៅលោកប៉ូលថា: «ព្រះហ៊ើមេស» ព្រោះលោកគឺជាអ្នកនាំក្នុងការនិយាយ
ព្រះហ៊ើមេសជាព្រះរបស់សាសន៍ដទៃ ដែលនាំសារមកឲ្យមនុស្សព្រះព្រះសេយូស និងព្រះផ្សេងៗទៀត។
បូជាចារ្យរបស់ព្រះសេយូស ដែលមានវិហារនៅក្រៅទីក្រុង បានដឹក
ងាយយល់ប្រសិនបើ បន្ថែមព័ត៌មានពីបូជាចារ្យ។ របៀបផ្សេងទៀតនៃការបកប្រែ: «មានវិហារមួយនៅក្រៅក្រុង ជាកន្លែងមនុស្សមកថ្វាយបង្គំព្រះសេយូស។ នៅពេលបូជាចារ្យដែលបម្រើនៅក្នុងព្រះវិហារបានឮពីអ្វីដែលលោកប៉ូល និងលោកបារណាបាសបានធ្វើ គាត់បាននាំ»
គោឈ្មោលនិងកម្រងផ្កា
នាំគោឈ្មោលមកថ្វាយយញ្ញបូជា។ យកកម្រងផ្កាមកពាក់ឲ្យលោកប៉ូល និងលោកបារណាបាស ឬដាក់នៅលើគោឈ្មោលដើម្បីថ្វាយជាយញ្ញបូជា។
នៅមាត់ទ្វារក្រុង
ទ្វាររបស់ទីក្រុង ជាកន្លែងដែលប្រើ ដើម្បីជួបជុំគ្នារបស់ដែលនៅក្នុងក្រុងនោះ។
ចង់ធ្វើបូជាយញ្ញ
«ចង់ថ្វាយយញ្ញបូជាចំពោះលោកប៉ូល និងលោកបារណាបាស ជាព្រះសេយូស និងព្រះហ៊ើមេស»
Acts 14:14
ពួកសាវក គឺលោកបារណាបាស និងប៉ូល
នៅទីនេះ លោកលូកាប្រើពាក្យ «សាវក» ក្នុងន័យធម្មតាដែលមានន័យថា «ត្រូវបានចាត់ឲ្យទៅ»
ពួកគេបានហែកសម្លៀកបំពាក់
នេះជានិមិត្តរូបនៃការបង្ហាញថាពួកគេព្រួយចិត្ត និងមិនសប្បាយចិត្តជាខ្លាំង ដែលបណ្តាជនចង់ថ្វាយយញ្ញបូជាដល់ពួកគេ។
បងប្អូនអើយ ហេតុអ្វីបានជាបងប្អូនធ្វើការទាំងនេះ?
លោកបារណាបាស
និងលោកប៉ូលស្តីបន្ទោសដល់មនុស្សដែលព្យាយាមថ្វាយយញ្ញបូជាដល់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូន មិនត្រូវថ្វាយបង្គំពួកយើងឡើយ!»
យើងខ្ញុំក៏ជាមនុស្ស ដែលមានអារម្មណ៍ដូចបងប្អូនដែរ។
ដោយសារប្រយោគនេះ លោកបារណាបាស និងលោកប៉ូលប្រាប់ថា ពួកគេមិនមែនជាព្រះទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «យើងក៏ជាមនុស្សដូចបងប្អូនដែរ។ យើងមិនមែនជាព្រះទេ!»
មានអារម្មណ៍ដូចបងប្អូនដែរ
«ដូចបងប្អូនគ្រប់យ៉ាង»
ងាកចេញពីរបស់ឥតប្រយោជន៍នេះ ទៅរកព្រះជាម្ចាស់ដ៏មានព្រះជន្មរស់
«ឈប់ថ្វាយបង្គំព្រះក្លែងក្លាយទាំងអស់នេះ ដែលមិនអាចជួយបងប្អូនបាន ផ្ទុយទៅវិញចាប់ផ្តើមថ្វាយបង្គំព្រះដ៏មានព្រះជន្មរស់»។
ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់
«ព្រះជាម្ចាស់ដែលមាននៅពិតប្រាកដ» ឬ «ព្រះជាម្ចាស់ដែលមានព្រះជន្មរស់»។
នៅជំនាន់មុនៗ
«សម័យមុនៗ» ឬ «រហូតមកដល់សព្វថ្ងៃនេះ»
ដើរតាមផ្លូវ
«រស់នៅតាម»
Acts 14:17
ប្រយោគភ្ជាប់
លោកប៉ូល
និងលោកបារណាបាសបន្តនិយាយទៅកាន់បណ្តាជនដែលនៅក្រៅក្រុងលីស្ត្រា។ (សូមមើល: ១៤:៨)
ព្រះអង្គមិនមែនមិនបានទុកអង្គទ្រង់ដោយគ្មានសាក្សីឡើយ
ឃ្លានេះនិយាយក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់បានសន្យល់ទុកសាក្សីម្នាក់» ឬ «ព្រះជាម្ចាស់បានឲ្យមានអ្នកធ្វើបន្ទាល់»
គឺ
«បង្ហាញសេចក្តីពិតថា»
ប្រទានឲ្យរដូវកាលបង្កើតផល ប្រទានឲ្យមានអាហារ និងមានអំណរក្នុងចិត្តផង
«ក្នុងចិត្ត» នៅទីនេះ សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ: «ប្រទានឲ្យអ្នកមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគ និងអ្វីៗដែលធ្វើឲ្យអ្នករីករាយ»
លោកប៉ូល និងលោកបារណាបាសមានប្រសាសន៍ទាំងនេះក្តី
ក៏ពិបាកក្នុងការទប់បណ្តាជនពីការថ្វាយយញ្ញបូជាដល់ពួកគេដែរ
លោកប៉ូល
និងលោកបារណាបាសបានបញ្ឈប់បណ្តាជនពីការថ្វាយយញ្ញបូជាដល់ពួកគេ ប៉ុន្តែធ្វើមិនបានទេ។
ពិបាកក្នុងការទប់
«ពិបាកក្នុងការទប់ណាស់»
Acts 14:19
ព័ត៌មានទូទៅ
ពាក្យ «លោក» និង «គាត់» នៅទីនេះ សំដៅលើលោកប៉ូល។
បានបញ្ចុះបញ្ចូលបណ្តាជន
ងាយយល់ប្រសិនបើនិយាយថា អ្វីដែលពួកគេបញ្ចុះបញ្ចូលបណ្តាជនឲ្យធ្វើ។ របៀបផ្សេងទៀតនៃការបកប្រែ: បានបញ្ចុះបញ្ចូលប្រជាជនមិនឲ្យជឿលោកប៉ូល

generated on Wed Sep 10 16:16:32 2025

និងលោកបារណាបាស ហើយបែរជាទាស់ជាមួយពួកគេវិញ»។
បណ្ដាជន
នេះអាចមិនមែនក្រុមមនុស្សពីមុន ដូចជា «ហ្វូងមនុស្ស» នៅក្នុងខមុនឡើយ។ មួយរយៈកន្លងផុតទៅ ហើយនេះអាចជាក្រុមផ្សេងដែលប្រជុំគ្នា។
គិតថា លោកស្លាប់ហើយ
«ពីព្រោះពួកគេគិតថាលោកបានស្លាប់បាត់ទៅហើយ»។
ពួកសិស្ស
នេះគឺជាអ្នកជឿថ្មីដែលនៅក្នុងក្រុងលីស្ត្រា។
ចូលទៅទីក្រុងវិញ
«លោកប៉ូលបានចូលក្រុងលីស្ត្រាម្ដងទៀតជាមួយពួកអ្នកជឿ»។
លោកបានទៅក្រុងឌើបេជាមួយលោកបារណាបាស
«លោកប៉ូល និងលោកបារណាបាសបានធ្វើដំណើរទៅក្រុងឌើបេ»
Acts 14:21
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះសំដៅលើលោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ បូករួមទាំងលោកប៉ូល និងលោកបារណាបាស ព្រមទាំងពួកអ្នកជឿផងដែរ។
នៅក្នុងទីក្រុងនោះ
«ក្រុងឌើបេ» (សូមមើល: ១៤:១៩)
ពួកគេបន្តកម្លាចិត្តរបស់ពួកសិស្ស និងលើកទឹកចិត្តពួកគេឲ្យបន្តក្នុងជំនឿ
ពាក្យ «ព្រលឹង» នៅទីនេះ សំដៅលើពួកសិស្ស។ ឃ្លានេះ បញ្ជាក់ពីខាងក្នុងគំនិត និងជំនឿ។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកប៉ូល និងលោកបារណាបាស បានដាស់តឿនពួកគអ្នកជឿឲ្យបន្តលូតលាស់នៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយព្រះអម្ចាស់។
និងលើកទឹកចិត្តពួកគេឲ្យបន្តក្នុងជំនឿ
«លើកទឹកចិត្តពួកអ្នកជឿឲ្យបន្តទុកចិត្តលើព្រះយេស៊ូ»។
Acts 14:23
ព័ត៌មានទូទៅ
លើកលែងតែលើកទីបីទេ ដែលពាក្យ«ពួកគេ» សំដៅលើមនុស្សដែលលោកប៉ូល និងលោកបារណាបាសបាននាំឲ្យស្គាល់ព្រះអម្ចាស់ ក្រៅពីនោះ ពាក្យ «ពួកគេ» នៅទីនេះសំដៅលើលោកប៉ូល និងលោកបារណាបាស។
ពួកគេបានតែងតាំងពួកចាស់ទុំនៅតាមក្រុមជំនុំនីមួយៗ
«នៅពេលលោកប៉ូល និងលោកបារណាបាសបានតែងតាំងពួកចាស់ទុំនៅតាមក្រុមពួកអ្នកជឿថ្មីហើយ។
ពួកគេបានធ្វើពួកសិស្ស
អានមានន័យពីរ ទី១) «លោកប៉ូល និងលោកបារណាបាសបានផ្ទុកផ្ដាក់ពួកចាស់ទុំដែលពួកគេបានតែងតាំង» ឬទី២ «លោកប៉ូល និងលោកបារណាបាសបានធ្វើពួកចាស់ទុំ និងពួកអ្នកជឿផ្សេងទៀត» (UDB)
នឹងព្រះអម្ចាស់ជាព្រះដែលពួកគេបានជឿ
«ពួកគេ» សំដៅលើ អាស្រ័យលើការជ្រើសរើសន័យរបស់ពាក្យ «ពួកគេ» នៅក្នុងសំណេរពីមុន ថា សំដៅលើ (ពួកចាស់ទុំ ឬ ពួកអ្នកដឹកនាំ និងពួកអ្នកជឿផ្សេងៗទៀត)។
ចុះទៅក្រុងអាតាលា
ឃ្លា «ចុះទៅ» នៅទីនេះ ដោយសារក្រុងអាតាលាមានកំពស់ទាបជាងក្រុងពើកា។
ជាកន្លែងដែលគេបានប្រគល់ពួកគេទៅក្នុងព្រះគុណរបស់ព្រះជាម្ចាស់
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ជាកន្លែងដែលពួកអ្នកជឿ និងអ្នកដឹងនាំនៅក្រុងអន់ទីយ៉ូកបានថ្វាយលោកប៉ូល និងលោកបារណាបាសទៅក្នុងព្រះគុណរបស់ព្រះជាម្ចាស់» ឬ «ជាកន្លែងដែលមនុស្សដែលនៅក្នុងក្រុងអន់ទីយ៉ូកអធិស្ឋាន សូមឲ្យព្រះជាម្ចាស់មើលថែ និងការពារលោកប៉ូល និងលោកបារណាបាស»។
Acts 14:27
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «របស់ពួកគេ» សំដៅលើលោកប៉ូល និងលោកបារណាបាស។ ពាក្យ «ព្រះអង្គ» សំដៅលើព្រះជាម្ចាស់។
បានប្រមូលក្រុមជំនុំឲ្យមកជួបជុំគ្នា
«បានហៅពួកអ្នកជឿនៅតាមតំបន់មកជួបជុំគ្នា»
ព្រះអង្គបើកទ្វារនៃជំនឿដល់សាសន៍ដទៃ
ព្រះជាម្ចាស់បានអនុញ្ញាតឲ្យសាសន៍ដទៃបានជឿ គឺនិយាយដូចជា ព្រះអង្គបានបើកទ្វារដែលបានរារាំងពួកគេពីការចូលមកកាន់ជំនឿដូច្នោះដែរ។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់បានបានធ្វើឲ្យសាសន៍ដទៃអាចជឿ»។

---

15 [1]មានអ្នកខ្លះមកពីស្រុកយូដានាំគ្នាប្រៀនប្រដៅពួកបងប្អូនថា៖ «ប្រសិនបើបងប្អូនមិនទទួលពិធីកាត់ស្បែកតាមទំនៀមទម្លាប់របស់លោកម៉ូសេទេ នោះបងប្អូនមិនអាចទទួលការសង្គ្រោះបានឡើយ»។[2]ដោយហេតុនេះ លោកប៉ូល និងលោកបារណាបាសបានប្រកែកជំទាស់ និងជជែកវែកញែកជាមួយពួកគេយ៉ាងខ្លាំង។ ពួកបងប្អូនបានសម្រេចចិត្តចាត់លោកប៉ូល លោកបារណាបាស និងបងប្អូនខ្លះទៀតឲ្យទៅក្រុងយេរូសាឡឹម ដើម្បីទៅជម្រាបពួកសាវក និងក្រុមព្រឹទ្ធាចារ្យអំពីរឿងនេះ។
[3]ដូច្នេះ ក្រុមជំនុំបានបញ្ជូនលោកទាំងពីរធ្វើដំណើរឆ្លងកាត់ស្រុកភេនីស ស្រុកសាម៉ារីទាំងប្រកាសប្រាប់ពួកបងប្អូនថា សាសន៍ដទៃបានបែរចិត្ត មករកព្រះជាម្ចាស់។ ដំណឹងនេះធ្វើឲ្យបងប្អូនគ្រប់ៗគ្នា មានអំណរសប្បាយយ៉ាងខ្លាំង។[4]កាលមកដល់ក្រុងយេរូសាឡឹមហើយ ក្រុមជំនុំ ក្រុមសាវក និងក្រុមព្រឹទ្ធាចារ្យនាំគ្នាទទួលពួកលោក ហើយពួកលោកក៏ជម្រាបអំពីកិច្ចការទាំងប៉ុន្មាន ដែលព្រះជាម្ចាស់បានធ្វើជាមួយពួកលោក។
[5]ពេលនោះ មានបងប្អូនខ្លះខាងគណៈផារីស៊ី ដែលជឿព្រះអម្ចាស់ក្រោកឈរឡើងពោលថា ត្រូវតែធ្វើពិធីកាត់ស្បែកឲ្យសាសន៍ដទៃ ហើយត្រូវបង្គាប់គេឲ្យប្រតិបត្តិតាមវិន័យរបស់លោកម៉ូសេដែរ។[6]ដូច្នេះក្រុមសាវក និងក្រុមព្រឹទ្ធាចារ្យក៏ប្រជុំគ្នាដើម្បីពិចារណាសំណុំរឿងនេះ។
[7]បន្ទាប់ពីមានការជជែកវែកញែកគ្នាយ៉ាងខ្លាំង លោកពេត្រុសក្រោកឈរឡើង ហើយមានប្រសាសន៍ថា៖ «បងប្អូនអើយ! បងប្អូនជ្រាបស្រាប់ហើយថា ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ក្នុងចំណោមបងប្អូនតាំងតែពីថ្ងៃដំបូងមកម្ល៉េះ ដើម្បីឲ្យខ្ញុំប្រកាសដំណឹងល្អដល់សាសន៍ដទៃ ឲ្យគេបានឮ និងបានជឿ។[8]ព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តគំនិតមនុស្ស ព្រះអង្គជាបន្ទាល់សម្រាប់ពួកគេ ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យគេ ដូចព្រះអង្គបានប្រទានមកយើងដែរ។[9]ព្រះអង្គមិនចាត់ទុកពួកគេផ្សេងពីពួកយើងឡើយ គឺព្រះអង្គបានសម្អាតចិត្តគេឲ្យបានបរិសុទ្ធដោយជំនឿ។
[10]ហេតុដូចម្ដេចបានជាបងប្អូនល្បងលនឹងព្រះជាម្ចាស់ដូច្នេះ? នឹមដែលបុព្វបុរសរបស់យើង និងខ្លួនយើងផ្ទាល់មិនអាចទ្រាំទ្របានផងនោះ ម្ដេចក៏បងប្អូនចង់យកនឹមមកដាក់លើពួកសិស្ស?[11]ផ្ទុយទៅវិញ យើងជឿថា ទាំងសាសន៍យើងទាំងសាសន៍គេ បានទទួលការសង្គ្រោះដោយសារព្រះគុណរបស់ព្រះអម្ចាស់យេស៊ូ»។
[12]ពេលនោះ អង្គប្រជុំទាំងមូលនៅស្ងៀមស្ងាត់ ស្ដាប់លោកប៉ូល និងលោកបារណាបាស មានប្រសាសន៍រៀបរាប់អំពីទីសម្គាល់ដ៏អស្ចារ្យ និងឫទ្ធិបាដិហារិយ៍ ដែលព្រះជាម្ចាស់បានសម្ដែងនៅកណ្ដាលចំណោមសាសន៍ដទៃតាមរយៈលោក។
[13]លុះលោកទាំងពីរមានប្រសាសន៍ចប់ហើយ លោកយ៉ាកុបក៏មានប្រសាសន៍ឡើងថា៖ «បងប្អូនអើយ សូមស្ដាប់ខ្ញុំ។[14]លោកស៊ីម៉ូនបានរៀបរាប់ថា កាលពីដើមដំបូង ព្រះជាម្ចាស់បានជួយសាសន៍ដទៃដោយសារព្រះគុណ ដើម្បីញែកពួកគេពីចំណោមមនុស្ស ឲ្យក្លាយជាប្រជារាស្ត្ររបស់ព្រះអង្គ។
[15]រីឯព្រះបន្ទូលដែលពួកព្យាការីបានថ្លែង ក៏ស្របនឹងសេចក្ដីនេះដែរ ដូចមានចែងទុកមកថា៖[16]«បន្ទាប់ពីជាតិសាសន៍នានាបានឮដំណឹងល្អហើយ យើងនឹងវិលត្រឡប់មកវិញ យើងនឹងសង់ពន្លារបស់ដាវីឌ ដែលរលំទៅនោះឡើងវិញ យើងនឹងសង់ដំណាក់ដែលបាក់បែកខ្ទេចខ្ទីឡើងវិញ[17]ពេលនោះ មនុស្សម្នាដែលនៅសល់នឹងស្វែងរកព្រះអម្ចាស់ រួមទាំងជាតិសាសន៍នានាផង។[18]នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលបានសម្ដែងឲ្យមនុស្សលោកស្គាល់តាំងពីដើមមក។
[19]ហេតុនេះហើយបានជាខ្ញុំយល់ឃើញថា មិនគួរធ្វើឲ្យមានឧបសគ្គដល់សាសន៍ដទៃ ដែលបានបែរចិត្តវិលមករកព្រះជាម្ចាស់វិញនោះឡើយ។[20]ប៉ុន្តែ គួរយើងសរសេរសំបុត្រទៅប្រាប់គេ កុំឲ្យបរិភោគម្ហូបអាហារដែលបានសែនរូបសំណាក់ កុំឲ្យរួមរស់ជាមួយគ្នាដោយឥតបានរៀបការ កុំឲ្យបរិភោគសាច់សត្វដែលគេសម្លាប់ដោយច្របាច់កនិងកុំឲ្យបរិភោគឈាម។[21]ដ្បិតតាំងពីសម័យដើមរៀងមក នៅតាមក្រុងនីមួយៗ គេតែងប្រកាសវិន័យរបស់លោកម៉ូសេដោយអានគម្ពីររបស់លោក រៀងរាល់ថ្ងៃសប្ប័ទនៅក្នុងសាលាប្រជុំ»។

generated on Wed Sep 10 16:16:32 2025

[22]ពេលនោះ ក្រុមសាវក ក្រុមព្រឹទ្ធាចារ្យ និងក្រុមជំនុំទាំងមូលយល់ឃើញថា គួរតែជ្រើសយកយូដាស ហៅបារសាបាស និងលោកស៊ីឡាសដែលជាអ្នកដឹកនាំក្នុងក្រុមជំនុំ
ហើយចាត់ឲ្យទៅក្រុងអន់ទីយ៉ូកជាមួយលោកប៉ូល និងលោកបារណាបាស។[23]ក្រុមជំនុំបានសរសេរសំបុត្រមួយ មានសេចក្ដីដូចតទៅនេះ៖ «យើងខ្ញុំជាសាវក ជាព្រឹទ្ធាចារ្យ
និងជាបងប្អូន សូមជម្រាបសួរមកបងប្អូនជាសាសន៍ដទៃ ដែលរស់នៅក្រុងអន់ទីយ៉ូក ស្រុកស៊ីរី និងស្រុកគីលីគា!។
[24]យើងខ្ញុំបានទទួលដំណឹងថា មានពួកអ្នកខ្លះបានចេញពីយើង ដោយមិនបានប្រាប់យើងឲ្យដឹង និងបានរំខានដល់ការបង្រៀន ពួកគេបានធ្វើឲ្យអ្នកព្រួយចិត្ត។[25]យើងខ្ញុំ
ទាំងអស់គ្នាបានសម្រេចចិត្ត ជ្រើសរើសយកគ្នាយើងខ្លះ ដោយចាត់ឲ្យមកជួបបងប្អូនជាមួយលោកប៉ូល និងលោកបារណាបាសដ៏ជាទីស្រឡាញ់របស់យើង[26]ជាអ្នកដែល
បានសុខចិត្តបូជាជីវិតរបស់ខ្លួន បម្រើព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់របស់យើង។
[27]ហេតុនេះ យើងខ្ញុំសុំចាត់លោកយូដាស និងលោកស៊ីឡាសឲ្យនាំពាក្យដដែលនេះ យកមកជម្រាបបងប្អូនដោយផ្ទាល់។[28]ព្រះវិញ្ញាណដ៏វិសុទ្ធ និងយើងខ្ញុំយល់ឃើញថា
មិនគួរយកវិន័យណាផ្សេងទៀត ដែលមិនចាំបាច់មកបង្ខំបងប្អូនឲ្យប្រតិបត្តិតាមក្រៅពីនេះឡើយ យើងគ្រាន់តែសុំឲ្យបងប្អូនចៀសវាង កុំប្រព្រឹត្តដូចតទៅនេះ[29]គឺកុំបរិភោគ
ម្ហូបអាហារដែលសែនរូបសំណាក កុំបរិភោគឈាម កុំបរិភោគសាច់សត្វដែលគេសម្លាប់ដោយច្របាច់ក និងកុំរួមរស់ជាមួយគ្នាដោយមិនរៀបការ។ ប្រសិនបើបងប្អូន
ប្រតិបត្តិដូច្នេះបាន នោះប្រពៃហើយ។ សូមឲ្យបងប្អូនបានប្រកបដោយសេចក្ដីសុខ»។
[30]ពួកអ្នកតំណាងក៏លាគេចេញដំណើរទៅដល់ក្រុងអន់ទីយ៉ូក ហើយប្រមូលអង្គប្រជុំ រួចប្រគល់សំបុត្រជូន។[31]នៅពេលគេបានអានសំបុត្ររួចហើយ ពួកគេមានអំណរ
សប្បាយគ្រប់ៗគ្នាចំពោះការលើកទឹកចិត្តនេះ។[32]លោកយូដាស និងលោកស៊ីឡាស និងព្យាការីមានប្រសាសន៍ជាច្រើន បានលើកទឹកចិត្ត និងពង្រឹងជំនឿរបស់បងប្អូន។
[33]បន្តិចក្រោយមក ពួកបងប្អូនសុខចិត្តឲ្យលោកទាំងពីរ វិលត្រឡប់ទៅឯក្រុមជំនុំ ដែលបានចាត់គេឲ្យមកនោះវិញ ទាំងជូនពរឲ្យលោកធ្វើដំណើរប្រកបដោយសុខសាន្ត។
[34]ប៉ុន្តែ លោកស៊ីឡាសសម្រេចចិត្តស្នាក់នៅទីនោះបន្តទៅទៀត។[35]រីឯលោកប៉ូល និងលោកបារណាបាស រួមទាំងបងប្អូនឯទៀត ក៏បានស្នាក់នៅក្នុងក្រុងអន់ទីយ៉ូក ទាំង
បង្រៀន និងផ្សព្វផ្សាយដំណឹងល្អអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
[36]ប៉ុន្មានថ្ងៃកន្លងមកទៀត លោកប៉ូលមានប្រសាសន៍ទៅកាន់លោកបារណាបាសថា៖ «យើងត្រូវត្រឡប់ទៅសួរសុខទុក្ខបងប្អូននៅតាមក្រុងទាំងប៉ុន្មាន ដែលយើងបាន
ផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះអម្ចាស់»។[37]លោកបារណាបាសមានបំណងនាំលោកយ៉ូហាន ហៅម៉ាកុសទៅជាមួយដែរ[38]ប៉ុន្តែ លោកប៉ូលយល់ឃើញថាមិនគួរនាំគាត់ទៅ
ជាមួយឡើយ ព្រោះគាត់បានរត់ចោលពួកលោក កាលពីនៅក្រុងប៉ាមភីលា គឺគាត់មិនបានបន្តដំណើរជាមួយពួកលោកឡើយ។
[39]បន្ទាប់មកលោកទាំងពីរក៏ខ្វែងគំនិតគ្នាយ៉ាងខ្លាំង រហូតដល់ទៅបែកផ្លូវគ្នា។ លោកបារណាបាស បាននាំលោកម៉ាកុសទៅជាមួយ រួចចុះសំពៅឆ្ពោះទៅកោះគីប្រុស។[40]រីឯ
លោកប៉ូល លោកនាំលោកស៊ីឡាសទៅជាមួយ ដោយពួកបងប្អូនបានផ្ញើលោកទៅលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអម្ចាស់។[41]លោកធ្វើដំណើរឆ្លងកាត់ស្រុកស៊ីរី
និងស្រុកគីលីគាទាំងពង្រឹងជំនឿក្រុមជំនុំនានាផង។

Acts 15:1
ប្រយោគភ្ជាប់
លោកប៉ូល និងលោកបារណាបាសនៅតែស្ថិតក្នុងទីក្រុងអន់ទីយ៉ូកដដែល
ពេលមានជម្លោះអំពីសាសន៍ដទៃ និងការមិនកាត់ស្បែក។
មានអ្នកខ្លះ
«មានអ្នកខ្លះ»។ អ្នកអាចបញ្ជាក់ឲ្យច្បាស់ទៀតថា
បុរសទាំងនេះគឺជាជនជាតិយូដាដែលបានជឿលើព្រះយេស៊ូគ្រិស្ត។
ចុះពីស្រុកយូដា
ឃ្លា «ចុះពី» ប្រើនៅទីនេះ ដោយសារយូដាមានកម្ពស់ខ្ពស់ជាងក្រុងអន់ទីយ៉ូក។
បង្រៀនដល់បងប្អូន
ពាក្យ «បងប្អូន» នៅទីនេះ សំដៅលើ ពួកអ្នកជឿលើព្រះគ្រិស្ត។
បង្ហាញថាពួកគេនៅក្នុងក្រុងអន់ទីយ៉ូក។ របៀបផ្សេងទៀតនៃការបកប្រែ:
«បង្រៀនដល់ពួកអ្នកជឿនៅក្នុងក្រុងអន់ទីយ៉ូក» ឬ
«កំពុងបង្រៀងបងប្អូននៅក្នុងក្រុងអន់ទីយ៉ូក»
ប្រសិនបើ បងប្អូនមិនទទួលពិធីកាត់ស្បែកតាមទំនៀមទម្លាប់របស់លោកម៉ូសេទេ នោះបងប្អូនមិន
អាចទទួលការសង្គ្រោះបានទេ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លុះត្រាតែ
នរណាម្នាក់កាត់ស្បែកឲ្យបងប្អូន តាមទម្លាប់របស់លោកម៉ូសេ
ព្រះជាម្ចាស់មិនអាចសង្គ្រោះបងប្អូនឡើយ» ឬ
«ព្រះជាម្ចាស់មិនអាចសង្គ្រោះបងប្អូនឡើយ លុះត្រាតែ
បងប្អូនទទួលពីធីកាត់ស្បែកស្របតាមក្រឹត្យវិន័យរបស់លោកម៉ូសេ»
តាមទំនៀមទម្លាប់
«ស្របតាមទំនៀមទម្លាប់» ឬ «ដើរតាមសេចក្ដីបង្រៀន»
បានជំទាស់ និងជជែកតវ៉ាជាមួយពួកគេយ៉ាងខ្លាំង
ពាក្យ «ប្រឈម» និង «ជជែកតវ៉ា» ជានាមអរូប អាចនិយាយជាកិរិយាសព្ទ
ហើយពីកន្លែងដែលមនុស្សបានមក អាចបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បានមកជំទាស់
និងជជែកតវ៉ាជាមួយបុរសដែលមកពីយូដា»
ទៅក្រុងយេរូសាឡិម
ក្រុងយេរូសាឡិមស្ថើរតែខ្ពស់ជាងកន្លែងផ្សេងៗនៅក្នុងអ៊ីស្រាអែល ដូច្នេះ
ជាទូទៅជនជាតិអ៊ីស្រាអែលនិយាយថាឡើងទៅក្រុងយេរូសាឡិម។
ទាក់ទងនឹងរឿងនេះ
«បញ្ហានេះ»
Acts 15:3
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «របស់ពួកគេ» នៅទីនេះ សំដៅលើ លោកប៉ូល
និងលោកបារណាបាស ព្រមទាំងអ្នកផ្សេងទៀត។ (សូមមើល: ១៥:១)
ដូច្នេះ ក្រុមជំនុំបានបញ្ជូនពួកគេ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
សហគមន៍របស់ពួកអ្នកជឿបានចាត់ពួកគេពីអន់ទីយ៉ូកទៅក្នុងយេរូសាឡិម»
ក្រុមជំនុំបានបញ្ជូន
«ក្រុមជំនុះ» នៅទីនេះ សំដៅលើមនុស្សដែលមានចំណែកនៅក្នុងក្រុមជំនុំ។
ធ្វើដំណើរឆ្លងកាត់...ព្រមទាំងប្រាប់ពី
ពាក្យ «ធ្វើដំណើរឆ្លងកាត់» និង «ព្រមទាំងប្រាប់ពី»
បញ្ជាក់ពីការដែលពួកគេចំណាយពេលនៅតាមកន្លែងផ្សេងៗ
ចែកចាយព័ត៌មានលម្អិតអំពីអ្វីដែលព្រះជាម្ចាស់បានធ្វើ។
ព្រមទាំងប្រាប់ពី ការប្រែចិត្តរបស់សាសន៍ដទៃ
ពាក្យ «ការប្រែចិត្ត» ជានាមអរូប
មានន័យថាសាសន៍ដទៃបានបដិសេធព្រះក្លែងក្លាយសាសន៍ដទៃ
ហើយបានជឿលើព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រកាសដល់សហគមន៍ពួកអ្នកជឿនៅតាមកន្លែងទាំងនោះថា
សាសន៍ដទៃបានជឿលើព្រះជាម្ចាស់»។
ពួកគេបាននាំអំណរដ៏លើសលប់ដល់បងប្អូនគ្រប់ៗគ្នា
ព្រះបន្ទូលដែលពួកគេប្រកាស ធ្វើឲ្យបងប្អូនមានអំណរ
គឺនិយាយជាអំណរជារឿងដែលនាំឲ្យពួកគេនាំទៅកាន់បងប្អូន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលពួកគេនិយាយ
ធ្វើឲ្យបងប្អូនអ្នកជឿមានអំណរ»
បងប្អូន
ពាក្យ «បងប្អូន» នៅទីនេះ សំដៅលើបងប្អូនអ្នកជឿ។
ក្រុមជំនុំ និងពួកសាវក ព្រមទាំងចាស់ទុំផងបានទទួលស្វាគមន៍ពួកលោក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកសាវក
ពួកចាស់ទុំ និងបងប្អូនអ្នកជឿទាំងអស់បានស្វាគមន៍ដល់ពួកគេ»
ជាមួយពួកគេ
«តាមរយៈពួកគេ»
Acts 15:5
ប្រយោគភ្ជាប់
លោកប៉ូល និងលោកបារណាបាស ឥឡូវនេះ នៅក្នុងក្រុងយេរូសាឡិម
ដើម្បីជួបពួកសាវក និងពួកចាស់ទុំនៅទីនោះ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើ ពួកអ្នកជឿដែលមិនមែនជាជនជាតិយូដា
ដែលមិនបានកាត់ស្បែក
និងមិនបានកាន់តាមច្បាប់នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់របស់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

ប៉ុន្តែ មានបងប្អូនខ្លះ
នៅទីនេះ លោកលូកាគិតផ្ទួយពីអ្នកដែលជឿថា
សេចក្តីសង្គ្រោះមាននៅលើតែព្រះយេស៊ូតែមួយគត់
ហើយត្រូវធ្វើពិធីកាត់ស្បែកដើម្បីបានទទួលសេចក្តីសង្គ្រោះ។
កាន់តាមវិន័យរបស់លោកម៉ូសេដែរ
«ស្តាប់បង្គាប់តាមវិន័យរបស់លោកម៉ូសេ»
ដើម្បីពិចារណាអំពីបញ្ហានេះ
អ្នកដឹកនាំក្រុមជំនុំបានសម្រេចចិត្តពិភ្សាថាតើ សាសន៍ដទៃ ចាំបាច់ត្រូវកាត់ស្បែ
ឬត្រូវប្រព្រឹត្តតាមច្បាស់របស់លោកម៉ូសេ
ដើម្បីឲ្យព្រះជាម្ចាស់បានសង្គ្រោះពួកគេពីបាបរបស់ពួកគេឬយ៉ាងណា។
Acts 15:7
ប្រយោគភ្ជាប់
លោកពេត្រុសចាប់ផ្តើមនិយាយប្រាប់ពួកសាវក និងពួកចាស់ទុំ ដែលបានជួប
ដើម្បីពិភាក្សាថាតើ សាសន៍ដទៃត្រូវកាត់ស្បែក
និងកាន់តាមច្បាប់របស់លោកម៉ូសេ។ (សូមមើល: ១៥:៥)
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ដំបូង សំដៅលើពួកសាវក និងពួកចាស់ទុំ (១៥:៥)។ ហើយពាក្យ
«ពួកគេ» ផ្សេងទៀត សំដៅលើពួកអ្នកជឿសាសន៍ដទៃ។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ ជាពហុវចន: សំដៅលើពួកសាវក និងពួកចាស់ទុំ។
ព័ត៌មានទូទៅ
ពាក្យ «ព្រះអង្គ» សំដៅលើព្រះជាម្ចាស់។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ ជាពហុវចន: ហើយសំដៅលើលោកពេត្រុស ពួកសាវក
និងពួកចាស់ទុំ ព្រមទាំងពួកអ្នកជឿជនជាតិយូដាទូទៅ។
បងប្អូន
លោកពេត្រុសបានបញ្ជាក់ដល់ពួកអ្នកជឿទាំងអស់ដែលមានវត្តនាមនៅទីនោះ។
តាមរយៈមាត់ខ្ញុំ
ពាក្យ «មាត់ខ្ញុំ» សំដៅលើលោកពេត្រុស។ របៀបផ្សេងទៀតនៃការបកប្រែ: «ពីខ្ញុំ»
ឬ «តាមរយៈខ្ញុំ»
ពួកសាសន៍ដទៃនឹងបានឮ
«ពួកសាសន៍ដទៃអាចបានឮ»
ព្រះបន្ទូលនៃដំណឹងល្អ
ពាក្យ «ព្រះបន្ទូល» នៅទីនេះ សំដៅលើ សារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សារអំពីព្រះយេស៊ូ»
ដែលស្គាល់ចិត្ត
ពាក្យ «ចិត្ត» នៅទីនេះ សំដៅលើ «គំនិត» ឬ «សភាវខាងក្នុង»។
របៀបផ្សេងទៀតនៃការបកប្រែ: «ដែលស្គាល់ចិត្តរបស់មនុស្ស» ឬ
«ស្គាល់អ្វីដែលមនុស្សគិត»
បានធ្វើបន្ទាល់ដល់ពួកគេ
«បានធ្វើបន្ទាល់ដល់សាសន៍ដទៃ»
ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យគេ
«ធ្វើឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមើលពួកគេ»
មិនប្រកាន់
ព្រះជាម្ចាស់មិនបានប្រព្រឹត្តចំពោះពួកអ្នកជឿជនជាតិយូដាខុសពីពួកអ្នកជឿសាសន៍ដទៃ
បានធ្វើឲ្យចិត្តរបស់ពួកគេស្អាតដោយសារជំនឿ
ព្រះជាម្ចាស់អត់ទោសបាបដល់ពួកអ្នកជឿសាសន៍ដទៃ
លោកនិយាយនៅក្នុងន័យត្រង់គឺសម្អាតចិត្តរបស់ពួកគេ។ «ចិត្ត» នៅទីនេះ
សំដៅលើ សភាវខាងក្នុងរបស់មនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«អត់ទោសបាបរបស់ពួកគេ ដោយសារពួកគេបានជឿលើព្រះយេស៊ូ»
Acts 15:10
ប្រយោគភ្ជាប់
លោកពេត្រុសបានបញ្ចប់សម្តីរបស់គាត់ទៅកាន់ពួកសាវក និងពួកចាស់ទុំ។
ព័ត៌មានទូទៅ
លោកពេត្រុសបូករួមអ្នកស្តាប់របស់លោកដោយប្រើពាក្យ «របស់យើង» និង
«យើង»។
ឥឡូវនេះ
ឃ្លានេះមិនមែនមានន័យថា «ខណៈនេះទេ» ប៉ុន្តែ
ប្រើដើម្បីទាញចំណាប់អារម្មណ៍មកកាន់ចំណុចសំខាន់ខាងក្រោម។
ចុះហេតុអ្វីបានជាបងប្អូនល្បងលនឹងព្រះជាម្ចាស់ដូច្នេះ? តើបងប្អូនគួរដាក់នឹមលើកររបស់ពួកសិស្ស
ដែលសូម្បីបុព្វបុរសរបស់យើង ឬយើងខ្លួនឯងផ្ទាល់មិនអាចទទួលបានផងយ៉ាងដូច្នេះ?
លោកពេត្រុសប្រើសំនួរមួយជាមួយនឹងរូបភាព
ដើម្បីប្រាប់ដល់ពួកអ្នកជឿជនជាតិយូដាថា
ពួកគេមិនគួរតម្រូវឲ្យពួកអ្នកជឿដែលមិនមែនជាសាសន៍យូដាកាត់ស្បែកដើម្បីឲ្យបានសង្គ្រោះឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំល្បងលព្រះជាម្ចាស់
ដោយដាក់បន្ទុកលើពួកអ្នកជឿដែលមិនមែនជាជនជាតិយូដាឡើយ
សូម្បីតែយើងជាសាសន៍យូដាក៏មិនអាចធ្វើបាន!»
បុព្វបុរសរបស់យើង
ឃ្លានេះសំដៅលើសាសន៍យូដាជាដូនតារបស់ពួកគេ។
ប៉ុន្តែ យើងជឿថា យើងបានទទួលការសង្គ្រោះតាមរយៈព្រះគុណរបស់ព្រះអម្ចាស់យេស៊ូ
ដូចជាពួកគេដែរ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
យើងជឿលើព្រះអម្ចាស់យេស៊ូនឹងសង្គ្រោះយើង ដោយសារព្រះគុណរបស់ព្រះអង្គ
ដូចព្រះអង្គបានសង្គ្រោះពួកអ្នកជឿដែលមិនមែនជាជនជាតិយូដាដែរ»។
Acts 15:12
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល និងលោកបារណាបាស។
អង្គប្រជុំទាំងមូល
«មនុស្សគ្រប់គ្នា» ឬ «នៅក្នុងក្រុមទាំងមូល» (សូមមើល: ១៥:៥)
ព្រះជាម្ចាស់បានធ្វើការ
«ព្រះជាម្ចាស់បានធ្វើការ» ឬ «ព្រះជាម្ចាស់បានធ្វើឲ្យកើតឡើង»
Acts 15:13
ប្រយោគភ្ជាប់
លោកយ៉ាកុបបានចាប់ផ្តើមនិយាយទៅកាន់ពួកសាវក និងពួកចាស់ទុំ។ (សូមមើល:
១៥:៥)
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល និងលោកបារណាបាស។
(សូមមើល: ១៥:៥)
បងប្អូន
«បងប្អូនអ្នកជឿ»
ដើម្បីញែកពួកគេពីចំណោមមនុស្ស
«ដើម្បីឲ្យគាត់អាចជ្រើសរើសពួកគេពីចំណោមមនុស្ស»
ឲ្យធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គ
«សម្រាប់ព្រះនាមរបស់ព្រះអង្គ»។ ពាក្យ «ព្រះនាម» នៅទីនេះ
សំដៅលើព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ: សម្រាប់ព្រះអង្គផ្ទាល់»
Acts 15:15
ប្រយោគភ្ជាប់
លោកយ៉ាកុបបានដកស្រង់ពីព្យាការីអេម៉ុសនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់។
ព័ត៌មានទូទៅ
ពាក្យ «ខ្ញុំ» នៅទីនេះ
សំដៅលើព្រះជាម្ចាស់ដែលមានបន្ទូលចេញពីពាក្យរបស់ព្យាការី។
ពួកព្យាការីបានថ្លែងក៏ស្របនឹងនេះដែរ
ពាក្យ «ព្រះបន្ទូល» នៅត្រង់នេះសំដៅលើសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការនេះត្រូវបានសរសេរ» ឬ «ត្រូវស្របជាមួយអ្វីដែលព្យាការីបានថ្លែង» ។
ស្របនឹងនេះដែរ
«បញ្ជាក់ថាជាសេចក្តីពិត»
ដូចមានសេចក្តីចែងទុកមកថា
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចព្យាការីអេម៉ុសបានសរសេរជាយូរមកហើយ» ។
ហើយយើងនឹងសង់ពន្លារបស់ដាវីឌដែលរលំជាថ្មី ...បាក់បែកខ្ទេចខ្ទីឡើងវិញ
ឃ្លានេះនិយាយម្តងទៀតពីពូជពង្សដែលព្រះបានជ្រើសរើសនៅក្នុងពូជពង្សស្តេចដាវីឌឲ្យសោយរាជ្យលើ
ទោះបីជាទ្រង់សង់ព្រះពន្លាជាថ្មីក្តី បន្ទាប់ពីវាបានដួលចុះ» ។
ព្រះបន្លា
ពាក្យ «ព្រះពន្លា» នៅទីនេះ សំដៅលើគ្រួសាររបស់ព្រះបាទដាវីឌ។
ពួកអ្នកដែលដែលនៅសល់ ស្វែងរកព្រះអម្ចាស់
ឃ្លានេះនិយាយអំពីមនុស្សដែលចង់ស្តាប់បង្គាប់ព្រះជាម្ចាស់
ហើយរៀនពីព្រះអង្គច្រើនថែមទៀត និយាយក្នុងន័យត្រង់ពួកគេស្វែងរកព្រះអង្គ។
ពួកអ្នកដែលដែលនៅសល់

generated on Wed Sep 10 16:16:32 2025

ពាក្យ «បុរស» នៅទីនេះ សំដៅលើទាំងមនុស្សប្រុស និងមនុស្សស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកអ្នកដែលនៅសល់»
អាចស្វែងរកព្រះអម្ចាស់
ព្រះជាម្ចាស់មានបន្ទូលពីអង្គទ្រង់ជាបុរសទីបី។ របៀបផ្សេងទៀតនៃការបកប្រែ:
«អាចស្វែកយើង ព្រះអម្ចាស់»
រួមជាមួយជាតិសាសន៍ដទៃដែលស្រែករកឈ្មោះយើងផង
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បូករួមទាំងសាសន៍ដទៃទាំងអស់ដែលជាកម្មសិទ្ធិរបស់ខ្ញុំ»
ឈ្មោះយើង
ពាក្យ «ឈ្មោះយើង» សំដៅលើ ព្រះជាម្ចាស់។
ពួកគេបានដឹង
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ថាមនុស្សទាំងអស់បានដឹង»
Acts 15:19
ប្រយោគភ្ជាប់
លោកយ៉ាកុបបញ្ចប់ការនិយាយរបស់គាត់ទៅកាន់ពួកសាវក និងពួកចាស់ទុំ។
(សូមមើល: ១៥:៣ និង ១៥:១៣)
ព័ត៌មានទូទៅ
ពាក្យ «យើង» បូករួមទាំងលោកយ៉ាកុប ពួកសាវក និងពួកចាស់ទុំ។
យើងមិនគួរធ្វើឲ្យមានការខ្វាយខ្វល់ដល់សាសន៍ដទៃ
អ្នកអាចធ្វើឲ្យកាន់តែច្បាស់នៅក្នុងអ្វីដែលលោកយ៉ាកុបមិនចង់ធ្វើឲ្យសាសន៍ដទៃខ្វល់ខ្វាយ
របៀបផ្សេងទៀតនៃការបកប្រែ: «យើងមិនគួរតម្រូវឲ្យសាសន៍ដទៃកាត់ស្បែក
និងធ្វើតាមក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ» ។
ដែលបានបែរមករកព្រះជាម្ចាស់
មនុស្សដែលចាប់ផ្តើមស្តាប់បង្គាប់ព្រះជាម្ចាស់
បើនិយាយឲ្យងាយយល់គឺបែរខាងសាច់ឈាមមករកព្រះជាម្ចាស់។
ពួកគេ ជៀសចេញពីអំពើសៅហ្មងនៃរូបព្រះ...ប្រាសចាកសីលធម៌ខាងផ្លូវភេទ...បរិភោគសាច់សត្វ
ដែលសម្លាប់ដោយច្របាច់ក...ការបរិភោគឈាម
ប្រាសចាកសីលធម៌ខាងផ្លូវភេទ បរិភោគសាច់សត្វដែលសម្លាប់ដោយច្របាច់ក
និងបរិភោគឈាម ជាញឹកញាប់នៅក្នុងផ្នែកនៃការថ្វាយបង្គំរូបព្រះ
និងព្រះក្លែងក្លាយ។
ជៀសចេញពីអំពើសៅហ្មង
នេះប្រហែលជាសំដៅការបរិភោគសត្វដែលនរណាម្នាក់ដែលថ្វាយយញ្ញបូជាទៅរូបព្រះ
ឬទៅអ្វីផ្សេងទៀតដូចជាការថ្វាយបង្គំរូបព្រះ។
បានប្រកាសគ្រប់ទីក្រុងទាំងអស់តាំងពីដើម ហើយលោកអាននៅនៅក្នុងសាលាប្រជុំ រៀងរាល់ថ្ងៃ
សប្ប័ទ
លោកយ៉ាកុបកំពុងបង្ហាញថាសាសន៍ដទៃដឹងពីច្បាប់ដ៏សំខាន់នេះ
ព្រោះជនជាតិយូដាបានបង្រៀនដល់ពួកគេនៅគ្រប់កន្លែងដែលមានសាលាប្រជុំ។
បង្ហាញថា សាសន៍ដទៃ។
អានគម្ពីរលោកម៉ូសេ
ពាក្យ «លោកម៉ូសេ» នៅទីនេះ សំដៅលើក្រឹត្យវិន័យ។
របៀបផ្សេងទៀតនៃការបកប្រែ: «អានក្រឹត្យវិន័យរបស់លោកម៉ូសេ»
Acts 15:22
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកយូដាស និងលោកស៊ីឡាស។ ពាក្យ
«ពួកគេ» សំដៅលើ ពួកសាវក ពួកចាស់ទុំ
និងពួកអ្នកជឿរបស់ក្រុមជំនុំនៅក្នុងក្រុងយេរូសាឡិម។
ក្រុមជំនុំទាំងមូល
ពាក្យ «ក្រុមជំនុំ» នៅទីនេះ
សំដៅលើមនុស្សដែលមានចំណែកនៅក្នុងក្រុមជំនុំនៅក្រុងយេរូសាឡិម។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្រុមជំនុំនៅក្នុងក្រុងយេរូសាឡិម ឬ
នៅក្នុងសហគមន៍ពួកអ្នកជឿនៅក្នុងក្រុងយេរូសាឡិមទាំងមូល»
យូដាស ហៅបារសាបាស
នេះគឺជាឈ្មោះរបស់បុរសម្នាក់។ «បារណាបាស»
គឺជាឈ្មោះទីពីរដែលគេហៅលោក។
យើងខ្ញុំជាសាវក ជាចាស់ទុំ និងជាបងប្អូន សូមជម្រាបសួរបងប្អូនជាសាសន៍ដទៃ នៅក្រុងអន់ទីយ៉ូក
ស្រុកស៊ីរី និងស្រុកគីលីគា!
នេះគឺជាការណែនាំនៅក្នុងសំបុត្រ។
ភាសារបស់អ្នកអាចមានវិធីផ្សេងទៀតក្នុងការណែនាំអ្នកនិពន្ធសំបុត្រ
ហើយផ្ញើដល់អ្នកដែលអ្នកនិពន្ធសរសេរទៅកាន់។ របៀបផ្សេងទៀតនៃការបកប្រែ:
«សំបុត្រនេះបានមកពីពួកសាវក ពួកចាស់ទុំ
និងបងប្អូនអ្នកជឿនៅក្នុងក្រុងយេរូសាឡិម។
យើងខ្ញុំសរសេរសំបុត្រនេះមកកាន់បងប្អូនអ្នកជឿសាសន៍ដទៃនៅក្រុងអន់ទីយ៉ូក
ស្រុកស៊ីរី និងស្រុកគីលីគា។
ស្រុកគីលីគា
នេះគឺជាឈ្មោះរបស់ខេត្តមួយ នៅលើឈូងសមុទ្រអាស៊ីមីន័រនៅក្នុងកោះគីប្រុស
Acts 15:24
ព័ត៌មានទូទៅ
ពាក្យ «យើង» និង «ពួកយើង»
សំដៅលើពួកអ្នកជឿនៅក្នុងក្រុមជំនុំក្រុងយេរូសាឡិម។ (សូមមើល: និង ១៥:២២)
ព័ត៌មានទូទៅ
ពាក្យ «របស់យើង» នៅទីនេះ សំដៅលើពួកអ្នកជឿនៅក្នុងក្រុងយេរូសាឡិម
បូករួមទាំងពួកអ្នកជឿទាំងអស់ ទាំងពួកអ្នកជឿសាសន៍ដទៃ
និងអស់អ្នកដែលគេសរសេរសំបុត្រផ្ញើទៅ។
មានពួកអ្នកខ្លះ
«មានអ្នកខ្លះ»
មានពួកអ្នកខ្លះបានចេញពីយើង ដោយមិនបានទទួលបញ្ជាពីយើង
«ពួកអ្នកខ្លះដែលយើងមិនបានបង្គាប់ដល់ពួកគេឡើយ»
បានរំខានដល់បងប្អូនដោយការបង្រៀនដែលធ្វើឲ្យបងប្អូនព្រួយចិត្ត
ពាក្យ «ចិត្ត» នៅទីនេះ សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបង្រៀងការខ្លះដែលនាំឲ្យបងប្អូនព្រួយចិត្ត»។
ដោយហេតុនេះហើយ យើងខ្ញុំទាំងអស់គ្នាបានព្រមព្រៀង
«ដូច្នេះ យើងទាំងអស់គ្នាបានព្រមព្រៀងគ្នា»
ជ្រើសរើសអ្នកខ្លះ
បុរសដែលពួកគេចាត់ឲ្យទៅនោះគឺលោកយូដាស ដែលហៅថាបារណាបាស
និងលោកស៊ីឡាស។ (សូមមើល:១៥:២២)
ដើម្បីព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើង
ពាក្យ «ព្រះនាម» សំដៅលើមនុស្សតាំងស្រុង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រោះពួកគេបានជឿលើព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង» ឬ
«ដោយសារពួកគេបម្រើព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង»។
Acts 15:27
ប្រយោគភ្ជាប់
នេះបូករួមសំបុត្រមកពីក្រុមជំនុំក្រុងយេរូសាឡិម
ផ្ញើទៅកាន់ពួកអ្នកជឿសាសន៍ដទៃនៅក្នុងក្រុងអន់ទីយ៉ូក។
ព័ត៌មានទូទៅ
ពាក្យ «យើង» និង «ពួកយើង» នៅទីនេះ សំដៅលើអ្នកដឹកនាំ
និងពួកអ្នកជឿនៅក្នុងក្រុមជំនុំក្រុងយេរូសាឡិម។ (សូមមើល: និង ១៥:២២)
ដូច្នេះ យើងខ្ញុំចាត់
«ដូច្នេះហើយ យើងខ្ញុំបានចាត់» ឬ «ដោយហេតុនេះ
យើងខ្ញុំបានចាត់» (សូមមើល: ១៥:២៤)
ដែលនឹងជម្រាបបងប្អូនចេញពីពាក្យរបស់ពួកគេផ្ទាល់
«ពួកគេនឹងប្រាប់បងប្អូននូវអ្វីៗដែលយើងខ្ញុំបានសរសេរ»
មិនគួរដាក់បន្ទុកលើបងប្អូន ក្រៅពីសេចក្តីដែលចាំបាច់ទាំងនេះឡើយ
ឃ្លានេះ និយាយពីច្បាប់ដែលមនុស្សត្រូវធ្វើតាម
ប្រៀបដូចជាវត្ថុមួយដែលមនុស្សលីនៅលើស្មារបស់ពួកគេដូច្នោះដែរ។
គឺបងប្អូនជៀសវាងពីអ្វីៗដែល
ឃ្លានេះ និយាយពីការដែលពួកគេមិនត្រូវចូលរួមជាមួយនិងការប្រព្រឹត្តមួយចំនួន
សំដៅលើការបែរចេញពីពួកគេ។
បានថ្វាយដល់រូបព្រះ
មានន័យថា
ពួកគេមិនត្រូវបរិភោគសាច់សត្វដែលនរណាម្នាក់បានថ្វាយទៅរូបព្រះឡើយ។
ឈាម
នេះសំដៅលើធាតុឈាម ឬបរិភោគសាច់សត្វដែលមិនបានបង្ហូរឈាម។
អ្វីៗដែលសម្លាប់ដោយច្របាច់ក
សត្វដែលសម្លាប់ដោយច្របាច់ក ប៉ុន្តែ ឈាមរបស់វាមិនបានហូរចេញមក។
សូមជម្រាបលា
នេះគឺជាចុងបញ្ចប់នៃសំបុត្រ។ របៀបផ្សេងទៀតនៃការបកប្រែ: «លាសិនហើយ»។
Acts 15:30

generated on Wed Sep 10 16:16:32 2025

ប្រយោគភ្ជាប់
លោកប៉ូល លោកបារណាបាស លោកយូដាស
និងលោកស៊ីឡាសបានធ្វើដំណើរទៅក្រុងអន់ទីយ៉ូក។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ពីរដំបូង សំដៅលើលោកប៉ូល លោកបារណាបាស លោកយូដាស
និងលោកស៊ីឡាស។ ហើយពាក្យ «ពួកគេ» ពីរចុងក្រោយ រួមទាំងពាក្យ
«របស់ពួកគេ» សំដៅលើពួកអ្នកជឿសាសន៍ដទៃនៅក្នុងក្រុងអន់ទីយ៉ូក។
ពួកគេបានបែកខ្ញែកគ្នា
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលពួកសាវក និងពួកចាស់ទុំចាត់ពួកគេឲ្យទៅ» ឬ
«នៅពេលពួកអ្នកជឿនៅក្នុងក្រុងយេរូសាឡិមបានបែកគ្នាជាមួយពួកគេ»
ធ្វើដំណើរទៅដល់ក្រុងអន់ទីយ៉ូក
ឃ្លា «ចុះទៅ» នៅទីនេះ
ដោយសារក្រុងអន់ទីយ៉ូកមានកំពស់ទាបជាងក្រុងយេរូសាឡិម។
និងពួកព្យាការី
ពួកព្យាការីគឺជាគ្រូបង្រៀនដែលបានទទួលសិទ្ធិអំណាចមកព្រះជាម្ចាស់ដើម្បីនិយាយ
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយសារពួកគេជាពួកព្យាការី» ឬ
«ពួកគេជាព្យាការីផងដែរ»
បងប្អូន
«បងប្អូនអ្នកជឿ»
បានកម្លាចិត្តដល់ពួកគេ
ជួយនរណាម្នាក់ឲ្យទុកចិត្តលើព្រះយេស៊ូថែមទៀត
ប្រៀបដូចជាអ្នកដែលចម្រើនកម្លាំងខាងសាច់ឈាមដែរ។
Acts 15:33
ប្រយោគភ្ជាប់
លោកយូដាស និងលោកស៊ីឡាសបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ ប៉ុន្តែ
លោកប៉ូល និងលោកស៊ីឡាសបន្តនៅក្នុងក្រុងអន់ទីយ៉ូកដដែល។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ប្រើពីរដងដំបូង សំដៅលើលោកយូដាស និងលោកស៊ីឡាស។
ប៉ុន្តែ ពាក្យ «ពួកគេ» លើកទីបី ប្រើថា «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល
និងលោកបារណាបាស។
បន្ទាប់ពីបានចំណាយពេលនៅទីនោះមួយរយៈមក
និយាយពីពេលវេលា ប្រៀបដូចអ្នកនោះចំណាយទិញទំនិញដូច្នោះដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពីពួកគេស្នាក់នៅទីនោះមួយរយៈ»
ពួកបងប្អូនបានចាត់ពួកគេឲ្យត្រឡប់ទៅឯអ្នកដែលបានចាត់គេឲ្យមក ដោយសុខសាន្ត
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអ្នកជឿនៅក្នុងក្រុងអន់ទីយ៉ូកបានចាត់ពួកគេឲ្យទៅពីក្រុងអន់ទីយ៉ូកប្រកបដោយ
ពួកបងប្អូនបានចាត់ពួកគេឲ្យត្រឡប់ទៅឯអ្នកដែលបានចាត់គេឲ្យមក ដោយសុខសាន្ត
«ដូចជាមិត្តសម្លាញ់ពីក្រុមជំនុំនៅក្នុងក្រុងអន់ទីយ៉ូក»
ឲ្យត្រឡប់ទៅឯអ្នកដែលបានចាត់គេឲ្យមក
«ចាត់ឲ្យទៅរកបងប្អូននៅក្នុងក្រុងយេរូសាឡិម ដែលបានចាត់លោកយូដាស
និងលោកស៊ីឡាសមក» (សូមមើល: ១៥:២២)
ចំណែក លោកប៉ូល និងលោកបារណាបាស់ស្នាក់នៅ
«ប៉ុន្តែ លោកប៉ូល និងលោកបារណាបាស់ស្នាក់នៅបន្ត»
ប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់
ពាក្យ «ព្រះបន្ទូល» សំដៅលើព្រះរាជសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះរាជ្យសារអំពីព្រះអម្ចាស់»
Acts 15:36
ប្រយោគភ្ជាប់
លោកប៉ូល និងលោកបារណាបាសបានបែកផ្លូវគ្នា។
ឥឡូវនេះ ចូរយើងត្រូវត្រឡប់ទៅ
«ខ្ញុំស្នើ ថាយើងត្រូវត្រឡប់ទៅ ឥឡូវនេះ»
សួរសុខទុក្ខបងប្អូន
«ខ្វល់ខ្វាយពីបងប្អូន» ឬ «ផ្តល់ជំនួយដល់ពួកអ្នកជឿ»
ប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់
ពាក្យ «ព្រះបន្ទូល» នៅទីនេះ សំដៅលើព្រះរាជសារ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះរាជសារអំពីព្រះអម្ចាស់»
ដើម្បីឲ្យដឹងពីសុខទុក្ខយ៉ាងណា
«ដើម្បីឲ្យដឹងថាបងប្អូនសុខទុក្ខយ៉ាងណា»
ពួកគេចង់ដឹងពីស្ថានភាពបច្ចុប្បន្នរបស់បងប្អូន
និងពីការដែលពួកគេកាត់ខ្ជាប់សេចក្តីពិតរបស់ព្រះអម្ចាស់។
ចង់នាំលោកយ៉ូហាន ហៅម៉ាកុសទៅជាមួយពួកគេដែរ
«យកលោកយ៉ូហាន ដែលហៅថាម៉ាកុសទៅជាមួយដែរ»
លោកប៉ូលយល់ឃើញថា យកលោកម៉ាកុសទៅជាមួយមិនល្អទេ
ការប្រកាន់ខ្លួន
របៀបផ្សេងទៀតនៃការបកប្រែ: «លោកប៉ូលគិតថា
យកលោកម៉ាកុសទៅជាមួយមិនល្អទេ»។ (សូមមើល: |Litotes)
ក្រុងប៉ាមភីលា
នេះគឺជាខេត្តមួយនៅក្នុងអាស៊ីមីន័រ។ សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង
ជំពូក ២:៨
មិនបានបន្តធ្វើការជាមួយពួកគេទៀតឡើយ
«មិនបន្តធ្វើការជាមួយពួកគេទៀតឡើយ» ឬ
«មិនបន្តបម្រើជាមួយពួកគេទៀតឡើយ»។
Acts 15:39
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកបារណាបាស និងលោកប៉ូល។
បន្ទាប់មក មានខ្វែងគំនិតគ្នាយ៉ាងខ្លាំង
«ខ្វែងគំនិតគ្នា» ជានាមអរូប អាចនិយាយជាកិរិយាឬក៏បាន «ខ្វែងគំនិតគ្នា»។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេខ្វែងគំនិងគ្នាជាខ្លាំង»
បន្ទាប់មក ពួកបងប្អូនបានថ្វាយលោកទៅក្នុងព្រះគុណរបស់ព្រះអម្ចាស់
ផ្ទុកផ្តាក់លើនរណាម្នាក់ មានន័យថា ដាក់ការមើលថែ
និងទំនួលខុសត្រូវលើអ្នកនោះ ឬលើអ្វីមួយដល់អ្នកណាម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មក
បងប្អូនអ្នកជឿនៅក្នុងក្រុងអន់ទីយ៉ូកបានថ្វាយលោកប៉ូល
ទៅក្នុងព្រះគុណរបស់ព្រះអម្ចាស់» ឬ «បន្ទាប់មក
បងប្អូនអ្នកជឿនៅក្នុងក្រុងអន់ទីយ៉ូកបានអធិស្ឋានដល់ព្រះអម្ចាស់ដើម្បីថ្វាយលោកប៉ូល
និងសូមព្រះជាម្ចាស់មេត្តាដល់លោក» ។
លោកក៏ចេញដំណើរ
នៅក្នុងប្រយោគមុន បញ្ជាក់ថា លោកស៊ីឡាសនៅជាមួយលោកប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយពួកគេក៏ចេញដំណើរទៅ» ។
ឆ្លងកាត់ស្រុកស៊ីរី និងស្រុកគីលីគា
ទាំងពីរនេះគឺជាខេត្តនៅក្នុង អាស៊ីមីន័រ ជិតកោះគីប្រុស។
ដោយបានកម្លាចិត្តដល់ក្រុមជំនុំនានាផង
លើកទឹកចិត្តដល់ពួកអ្នកជឿនៅតាមក្រុមជំនុំ គឺលោកប៉ូល
និងលោកស៊ីឡាសជាអ្នកកម្លាទឹកចិត្តបងប្អូនក្រុមជំនុំឲ្យរឹងមាំឡើង។ ពាក្យ
«ក្រុមជំនុំនានា» សំដៅលើក្រុមអ្នកជឿនៅក្នុងស្រុកស៊ីរី និងស្រុកគីលីគា។
របៀបផ្សេងទៀតនៃការបកប្រែ: «លើកទឹកចិត្តពួកអ្នកជឿនៅតាមក្រុមជំនុំនានា» ឬ
«ជួយសហគមន៍អ្នកជឿឲ្យទុកចិត្តលើព្រះយេស៊ូកាន់តែខ្លាំងឡើង» ។

---

16 [1]លោកប៉ូលធ្វើដំណើរទៅដល់ក្រុងឌើបេ រួចទៅដល់ក្រុងលីស្ត្រា។ នៅក្រុងលីស្ត្រានោះ មានសិស្សមួយឈ្មោះធីម៉ូថេនៅទីនោះ គាត់ជាកូនរបស់ស្ត្រីសាសន៍យូដាម្នាក់
ជាអ្នកជឿ ឪពុកគាត់ជាសាសន៍ក្រិក។[2]គាត់មានកេរ្តិ៍ឈ្មោះល្អ ក្នុងចំណោមបងប្អូននៅក្រុងលីស្ត្រា និងបងប្អូននៅក្រុងអ៊ីកូនាម។[3]លោកប៉ូលមានបំណងនាំគាត់រួម
ដំណើរទៅជាមួយលោក ដូច្នេះលោកក៏យកគាត់មកធ្វើពិធីកាត់ស្បែកឲ្យ ព្រោះយោគយល់ដល់សាសន៍យូដានៅស្រុកនោះ ដ្បិតគេដឹងគ្រប់គ្នាថាឪពុកគាត់ជាសាសន៍
ក្រិក។
[4]ពេលពួកលោកធ្វើដំណើរតាមក្រុងនានា លោកបានប្រាប់អ្នកជឿឲ្យដឹងអំពីការណែនាំរបស់ក្រុមសាវក និងក្រុមព្រឹទ្ធាចារ្យដែលបានសរសេរនៅក្រុងយេរូសាឡឹម ហើយសុំ
ឲ្យគេអនុវត្តតាម។[5]ដូច្នេះហើយបានជាក្រុមជំនុំនានាក៏មានជំនឿកាន់តែមាំមួនរៀងរាល់ថ្ងៃ ហើយមានគ្នាកាន់តែច្រើនជាលំដាប់។
[6]ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រាមលោកប៉ូល និងគ្នារបស់លោក មិនឲ្យទៅប្រកាសព្រះបន្ទូលនៅស្រុកអាស៊ីទេ ហេតុនេះហើយបានជាលោកនាំគ្នាធ្វើដំណើរកាត់ស្រុកព្រីគា
និងដែនដីកាឡាទី។[7]ពេលទៅដល់ជិតស្រុកមីស៊ា ពួកគេមានបំណងទៅស្រុកប៊ីធូនា ប៉ុន្តែព្រះវិញ្ញាណរបស់ព្រះយេស៊ូពុំអនុញ្ញាតឲ្យទៅទេ។[8]ដូច្នេះ លោកក៏នាំគ្នាឆ្លងកាត់
ស្រុកមីស៊ា ទៅដល់ក្រុងត្រូអាស។

generated on Wed Sep 10 16:16:32 2025

[9]នៅពេលយប់ លោកប៉ូលបាននិមិត្តឃើញអ្នកស្រុកម៉ាសេដូនម្នាក់ឈរនៅទីនោះហៅលោក ហើយពោលថា៖ «សូមលោកឆ្លងមកស្រុកម៉ាសេដូនជួយយើងខ្ញុំផង!»។[10]
ពេលលោកបានឃើញនិមិត្តហេតុអស្ចារ្យនេះហើយ យើងក៏រួតរះចេញដំណើរទៅស្រុកម៉ាសេដូន ព្រោះយើងជឿជាក់ថា ព្រះជាម្ចាស់ត្រាស់ហៅយើងទៅផ្សព្វផ្សាយដំណឹងល្អដល់អ្នកស្រុកនោះ។
[11]នៅក្រុងត្រូអាស យើងបានចុះសំពៅធ្វើដំណើរតម្រង់ឆ្ពោះទៅកោះសាម៉ូត្រាស។ ស្អែកឡើងយើងបានទៅដល់ក្រុងនាប៉ូល។[12]បន្ទាប់មក យើងចេញដំណើរពីក្រុងនោះឆ្ពោះទៅក្រុងភីលីពជាក្រុងសំខាន់ជាងគេក្នុងស្រុកម៉ាសេដូន ហើយជាក្រុងដែលស្ថិតនៅក្នុងចក្រភពរ៉ូម៉ាំង រួចយើងបានស្នាក់នៅក្រុងនោះជាច្រើនថ្ងៃ។[13]នៅថ្ងៃសប្ប័ទ
យើងបានចេញទៅខាងក្រៅទ្វារក្រុង សំដៅទៅមាត់ស្ទឹងមួយ យើងគិតថាកន្លែងនោះ យើងអាចអធិស្ឋាននៅទីនោះបាន។ យើងក៏នាំគ្នាអង្គុយ ហើយនិយាយជាមួយពួកស្ត្រី ដែលមកជួបជុំគ្នានៅទីនោះ។
[14]មានស្ត្រីម្នាក់ដែលគោរពកោតខ្លាចព្រះជាម្ចាស់ឈ្មោះលីឌា ជាអ្នកស្រុកធាទេរ៉ា និងជាឈ្មួញក្រណាត់ពណ៌ក្រហមដ៏មានតម្លៃ។ ព្រះអម្ចាស់បានបើកចិត្តនាង ឲ្យយកចិត្តទុកដាក់នឹងសេចក្តីដែលលោកប៉ូលមានប្រសាសន៍។[15]បន្ទាប់ពីនាងបានទទួលពិធីជ្រមុជទឹក ជាមួយក្រុមគ្រួសារនៅផ្ទះរបស់នាងរួចហើយ នាងបានអញ្ជើញយើងទៅស្នាក់នៅផ្ទះនាងដោយពោលថា៖ «បើលោកយល់ឃើញថា នាងខ្ញុំពិតជាជឿលើព្រះអម្ចាស់មែន សូមអញ្ជើញទៅស្នាក់នៅផ្ទះរបស់នាងខ្ញុំទៅ»។ នាងបានទទូចសុំឲ្យយើងយល់ព្រម តាមសេចក្តីអញ្ជើញរបស់នាង។
[16]មានថ្ងៃមួយ ពេលយើងធ្វើដំណើរទៅកន្លែងអធិស្ឋាន មានស្រីបម្រើម្នាក់មកជួបយើង។ នាងមានអារក្សភីថង់ចូល នាំឲ្យនាងចេះទាយ ធ្វើឲ្យពួកម្ចាស់របស់នាងបានទទួលកំរៃយ៉ាងច្រើន ពីការទាយ។[17]នាងដើរតាមក្រោយលោកប៉ូល និងតាមយើង ទាំងស្រែកថា៖ «លោកទាំងនេះជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត។ លោកនាំដំណឹងអំពីមាគ៌ានៃការសង្គ្រោះ មកប្រាប់អ្នករាល់គ្នា»។[18]នាងតែងតែធ្វើដូច្នេះជាយូរថ្ងៃហើយ។ ដោយលោកប៉ូលទាស់ចិត្តជាខ្លាំងនឹងនាង ក៏ងាកទៅក្រោយបញ្ជាវិញ្ញាណអាក្រក់ថា៖ «ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត ចូរចេញពីនាងទៅ!»។ វិញ្ញាណអាក្រក់ក៏ចេញពីនាងភ្លាម។
[19]កាលពួកម្ចាស់របស់ស្រីបម្រើនោះឃើញថា លែងមានសង្ឃឹមនឹងបានកំរៃអ្វីទៀត គេក៏នាំគ្នាចាប់លោកប៉ូល និងលោកស៊ីឡាស អូសយកទៅជូនចៅក្រមនៅទីសាធារណៈ។[20]ចៅក្រមនាំលោកទាំងពីរទៅជួបពួកអាជ្ញាធរ ពោលថា៖ «ជនជាតិយូដាទាំងនេះបង្កឲ្យមានចលាចល នៅក្នុងក្រុងយើង។[21]គេនាំទំនៀមទម្លាប់ផ្សេងៗមកផ្សាយប្រាប់យើង ដែលមិនស្របច្បាប់សម្រាប់ជនជាតិរ៉ូម៉ាំង ក្នុងការទទួល ឬអនុវត្តតាមបានឡើយ»។
[22]បណ្តាជនក៏លើកគ្នាមកប្រឆាំងនឹងលោកទាំងពីរដែរ។ ពួកអាជ្ញាធរបានបញ្ជាឲ្យគេដោះសម្លៀកបំពាក់លោកប៉ូល និងលោកស៊ីឡាសចេញ រួចបញ្ជាឲ្យវាយនឹងរំពាត់។
[23]ក្រោយពីបានវាយលោកទាំងពីរច្រើនរំពាត់រួចហើយ គេក៏យកលោកទៅដាក់ក្នុងទីឃុំឃាំង ទាំងបញ្ជាឲ្យយាមកាមយ៉ាងម៉ឺងម៉ាត់ផង។[24]បន្ទាប់ពីឆ្មាំគុកបានឮបញ្ជានេះ គេក៏យកលោកទាំងពីរទៅឃុំក្នុងគុកងងឹត និងដាក់ខ្នោះជើង។
[25]ប្រមាណជាពាក់កណ្តាលអធ្រាត្រ លោកប៉ូល និងលោកស៊ីឡាសនាំគ្នាអធិស្ឋាន និងច្រៀងសរសើរតម្កើងព្រះជាម្ចាស់ រួចអ្នកទោសឯទៀតៗស្តាប់លោកទាំងពីរដែរ។
[26]រំពេចនោះ ស្រាប់តែមានរញ្ជួយផែនដីយ៉ាងខ្លាំង បណ្តាលឲ្យកក្រើកដល់គ្រឹះនៅទីឃុំឃាំង រំពេចនោះ ទ្វារគុកទាំងប៉ុន្មានក៏របើកឡើងភ្លាម រីឯច្រវាក់ដែលគេដាក់អ្នកទោសក៏របូតចេញអស់ដែរ។
[27]ពេលនោះ ឆ្មាំគុកភ្ញាក់ឡើង ហើយបានឃើញទ្វារគុករបើក គាត់ក៏ហូតដាវបម្រុងនឹងសម្លាប់ខ្លួន ព្រោះនឹកស្មានថាអ្នកទោសរត់បាត់អស់ហើយ។[28]ប៉ុន្តែ លោកប៉ូលបានស្រែកឡើងយ៉ាងខ្លាំងៗថា៖ «កុំធ្វើបាបខ្លួនឯងអី ព្រោះយើងទាំងអស់គ្នានៅទីនេះទេ!»។
[29]ឆ្មាំគុកសុំឲ្យគេយកភ្លើងមក រួចប្រញាប់ប្រញាល់ចូលទៅក្នុងគុក ហើយគាត់ក្រាបចុះនៅមុខលោកប៉ូល និងលោកស៊ីឡាសទាំងញាប់ញ័រ[30]គាត់នាំលោកទាំងពីរចេញមកក្រៅ ពោលថា៖ «លោកម្ចាស់! តើខ្ញុំប្របាទត្រូវធ្វើយ៉ាងណា ដើម្បីឲ្យបានទទួលការសង្គ្រោះ?»។[31]លោកតបទៅគាត់វិញថា៖ «សូមជឿលើព្រះអម្ចាស់យេស៊ូទៅ នោះព្រះជាម្ចាស់នឹងសង្គ្រោះលោក ព្រមទាំងសង្គ្រោះក្រុមគ្រួសាររបស់លោកផងដែរ»។
[32]លោកទាំងពីរបានប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់គាត់ រួមជាមួយអ្នកទាំងប៉ុន្មានដែលនៅក្នុងផ្ទះគាត់។[33]ពេលនោះ ឆ្មាំគុកនាំលោកទាំងពីរមកលាងស្នាមរបួសទាំងយប់ ហើយគាត់ និងក្រុមគ្រួសាររបស់គាត់ក៏បានទទួលពិធីជ្រមុជទឹកភ្លាម។[34]គាត់បាននាំលោកប៉ូល និងលោកស៊ីឡាសឡើងទៅផ្ទះគាត់ រៀបចំម្ហូបអាហារជូន រួចគាត់ និងក្រុមគ្រួសាររបស់គាត់មានអំណរយ៉ាងខ្លាំង ដោយបានជឿលើព្រះជាម្ចាស់។
[35]លុះភ្លឺឡើង ពួកអាជ្ញាធរបានចាត់តម្រួតឲ្យទៅប្រាប់ឆ្មាំគុកថា៖ «ចូរដោះលែងអ្នកទាំងនោះទៅ!»។[36]ឆ្មាំគុកបាននាំដំណឹងនេះទៅជម្រាបលោកប៉ូលថា៖ «ពួកអាជ្ញាធរបានចាត់គេមកប្រាប់ឲ្យដោះលែងលោកហើយ ដូច្នេះសូមលោកចេញទៅឲ្យបានសុខសាន្តចុះ»។
[37]ប៉ុន្តែ លោកប៉ូលមានប្រសាសន៍ទៅតម្រួតទាំងនោះថា៖ «យើងជាជនជាតិរ៉ូម៉ាំង គេបានវាយយើងនឹងរំពាត់នៅមុខប្រជុំជន ដោយពុំបានជំនុំជម្រះជាមុន ហើយក៏យកយើងមកដាក់គុកទៀត។ តើពួកគេចង់ដោះលែងយើងដោយស្ងាត់ៗឬ? ទេ មិនបានទេ! លោកទាំងនោះត្រូវតែមកដោះលែងយើងផ្ទាល់តែម្តងទើបបាន»។[38]ពួកតម្រួតនាំពាក្យនេះទៅជម្រាបពួកអាជ្ញាធរ។ កាលដឹងថា លោកប៉ូល និងលោកស៊ីឡាសមានសញ្ជាតិរ៉ូម៉ាំងដូច្នេះ ពួកអាជ្ញាធរភ័យខ្លាចជាខ្លាំង។[39]ពួកអាជ្ញាធរសុំទោសលោកទាំងពីរ រួចដោះលែងលោក និងអង្វរឲ្យលោកចាកចេញពីក្រុងនោះផង។
[40]លោកប៉ូល និងលោកស៊ីឡាសចេញពីទីឃុំឃាំងចូលទៅផ្ទះរបស់នាងលីឌា។ នៅពេលប៉ូល និងស៊ីឡាសបានជួបពួកបងប្អូន ពួកលោកក៏លើកទឹកចិត្តគេ រួចលោកទាំងពីរនាំគ្នាធ្វើដំណើរចេញទៅ។

Acts 16:1
ប្រយោគភ្ជាប់
ដំណើរបេសកកម្មរបស់លោកប៉ូល និងលោកស៊ីឡាសនៅតែបន្ត។
ព័ត៌មានទូទៅ
លោកធីម៉ូថេត្រូវបានណែនាំមកក្នុងសាច់រឿង ក្នុងការចូលរួមលោកប៉ូល
និងលោកស៊ីឡាស។ នៅក្នុងខ ១ និង ២
បាននិយាយពីជីវប្រវត្តិរបស់លោកធីម៉ូថេ។
ព័ត៌មានទូទៅ
ទីមួយ ទីបី និងទីបួន មានករណីនៃពាក្យ «គាត់» សំដៅលើលោកធីម៉ូថែ។
ចំណែកពាក្យ «គាត់» ទីពីរ សំដៅលើលោកប៉ូល។
លោកប៉ូលបានទៅដល់
ពាក្យ «មកដល់» នៅទីនេះ អាចប្រែថា «បានមកដល់»។
ក្រុងឌើបេ
នេះគឺជាឈ្មោះរបស់ទីក្រុងនៅអាស៊ីមីន័រ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ជំពូក ១៤:៥
មើល៍
ពាក្យ «មើល៍» តឿនឲ្យយើងដឹងថាមានមនុស្សថ្មីនៅក្នុងសាច់រឿង។
ភាសារបស់អ្នកអាចធ្វើបែបនេះដែរ។
ដែលបានជឿម្នាក់
ពាក្យ «នៅក្នុងព្រះគ្រិស្ត» ងាយយល់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបានជឿលើព្រះគ្រិស្ត»
គាត់មានកេរ្តិ៍ឈ្មោះល្អ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកធីម៉ូថេមានកេរ្តិ៍ឈ្មោះល្អនៅក្នុងចំណោមបងប្អូន» ឬ
«បងប្អូននិយាយល្អពីគាត់»
ក្នុងចំណោមបងប្អូន
ពាក្យ «បងប្អូន» នៅទីនេះ សំដៅលើពួកអ្នកជឿ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីសំណាក់ពួកអ្នកជឿ»។
បានធ្វើពិធីកាត់ស្បែកឲ្យគាត់
អាចទៅរួច ដែលលោកប៉ូលខ្លួនឯងជាអ្នកកាត់ស្បែកឲ្យលោកធីម៉ូថេ ប៉ុន្តែ
ហាក់បីដូចជាមានអ្នកផ្សេងទៀតកាត់ស្បែកឲ្យលោកធីម៉ូថេ។
ដោយយល់ដល់ជនជាតិយូដានៅស្រុកទាំងនោះ
«ដោយសារជនជាតិយូដារស់នៅស្រុកនោះ ជាកន្លែងដែលលោកប៉ូល
និងលោកធីម៉ូថេធ្វើដំណើរទៅ»

generated on Wed Sep 10 16:16:32 2025

ដ្បិត ពួកគេបានដឹងថាឪពុកគាត់ជាជនជាតិក្រិកគ្រប់គ្នា
ព្រោះសាសន៍ក្រិកមិនដែលឲ្យកូនរបស់ពួកគេកាត់ស្បែកឡើយ
ជនជាតិយូដាអាចដឹងថាលោកធីម៉ូថេមិនបានកាត់ស្បែក
ហើយពួកគេនឹងបដិសេធលោកប៉ូល និងលោកធីម៉ូថេ
មុនពេលពួកគេបានឮព្រះបន្ទូលអំពីព្រះយេស៊ូ។
Acts 16:4
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល លោកស៊ីឡាស (១៥:៣៩)
និងលោកធីម៉ូថេ (១៦:១)។
នៅពេលពួកគេធ្វើដំណើរតាមក្រុងនានា
«ពួកគេបានប្រាប់ដល់ក្រុមជំនុំនានានៅទីនោះ»
ដើម្បីឲ្យពួកគេអនុវត្តតាម
«ដើម្បីឲ្យក្រុមជំនុំបានអនុវត្តតាម» ឬ «ដើម្បីឲ្យពួកអ្នកជឿបានអនុវត្តតាម»
ពីការណែនាំរបស់ពួកសាវក និងពួកចាស់ទុំដែលបានសរសេរនៅក្រុងយេរូសាឡិម
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលពួកសាវក និងពួកចាស់ទុំនៅក្នុងក្រុងយេរូសាឡិមបានសរសេរ» ។
បានជាក្រុមជំនុំនានាបានទទួលការកម្លាចិត្តក្នុងជំនឿ និងមានចំនួនច្រើនឡើងជារៀងរាល់ថ្ងៃ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកអ្នកជឿបានរឹងមាំឡើងនៅក្នុងជំនឿរបស់ពួកគេ
ហើយមានអ្នកជឿច្រើនឡើងថែមទៀតជារៀងរាល់ថ្ងៃ» ។
ក្រុមជំនុំនានា
សំដៅលើពួកអ្នកជឿនៅក្នុងក្រុមជំនុំនានា។
Acts 16:6
ស្រុកព្រីគា
ស្រុកព្រីគាគឺជាតំបន់នៅក្នុងអាស៊ី។ សូមមើលពីរបៀបបកប្រែឈ្មោះនេះ
នៅក្នុងជំពូក ២:៨។
ព្រះវិញ្ញាណដ៏វិសុទ្ធបានហាមមិនឲ្យទៅប្រកាសព្រះបន្ទូលនៅស្រុកអាស៊ីទេ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណដ៏វិសុទ្ធបានហាមពួកគេ» ឬ
«ព្រះវិញ្ញាណដ៏វិសុទ្ធមិនបានអនុញ្ញាតដល់ពួកគេ» (សូមមើល:|Active or Passive)
ព្រះបន្ទូល
ពាក្យ «ព្រះបន្ទូល» នៅទីនេះ សំដៅលើ «ព្រះរាជសារ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះរាជសារអំពីព្រះយេស៊ូ»
ពេលពួកគេទៅដល់
ពាក្យ «មកដល់» នៅទីនេះ អាចប្រែជាកិរិយាសព្ទ «បានទៅដល់» ឬ
«បានមកដល់»
ស្រុកមីស៊ា...ស្រុកប៊ីធូនា
នេះគឺជាតំបន់ពីរផ្សេងទៀតនៅក្នុងអាស៊ី។ (សូមមើល:|How to Translate Names)
ព្រះវិញ្ញាណរបស់ព្រះយេស៊ូ
«ព្រះវិញ្ញាណដ៏វិសុទ្ធ»
ពួកគេបានចុះទៅទៅក្រុងរបស់ត្រូអាសវិញ
ឃ្លា «ចុះទៅ» ប្រើនៅទីនេះ ដោយសារក្រុងត្រូអាសមានកម្ពស់ទាបជាងមីស៊ា។
ពួកគេបានចុះទៅ
ពាក្យ «មក» អាចប្រែជា «បានទៅ»។
Acts 16:9
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ រាប់បញ្ចូល និងសំដៅលើលោកប៉ូល
និងបូករួមអ្នកធ្វើដំណើរជាមួយលោកលូកា និងលោកលូកាជាអ្នកនិពន្ធដែរ។
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើមនុស្សនៅក្នុងស្រុកម៉ាសេដូន។ ពាក្យ «យើង» លើកទីពីរ
ប្រើសំដៅលើលោកប៉ូល និងអ្នករួមដំណើរជាមួយលោក។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើមនុស្សនៅក្នុងស្រុកម៉ាសេដូន។
លោកបានឃើញនិមិត្តហើយ
«លោកប៉ូលមាននិមិត្តពីព្រះជាម្ចាស់» ឬ
«លោកប៉ូលបានទទួលនិមិត្តពីព្រះជាម្ចាស់»។
ហៅលោក
«សូមលោក» ឬ «អញ្ជើញលោក»
សូមលោកឆ្លងមកស្រុកម៉ាសេដូន
ឃ្លា «ឆ្លងមក» នៅទីនេះ ព្រោះស្រុកម៉ាសេដូនត្រូវឆ្លងសមុទ្រចេញពីត្រូអាសទៅ។
Acts 16:11
ប្រយោគភ្ជាប់
លោកប៉ូល និងអ្នករួមដំណើរជាមួយលោក នៅពេលនេះគឺនៅក្រុងភីលីព
នៅក្នុងដំណើររបស់ពួកគេ។ ខ ១៣ ចាប់ផ្តើមសាច់រឿងលីឌា។ មានរឿងខ្លីនៅទីនេះ
ក្នុងដំណើររបស់លោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «យើង» រួមបញ្ចូល និងសំដៅលើលោកប៉ូល និងអ្នករួមដំណើរជាមួយលោក
ព្រមទាំងលោកលូកា ដែលជាអ្នកនិពន្ធកណ្ឌកិច្ចការនេះផងដែរ។ (សូមមើល:|Inclusive "យើង")
កោះសាម៉ូត្រាស...ក្រុងនាប៉ូល
នេះគឺជាកោះនៅតាមទីក្រុងនានាជិតក្រុងភីលីព នៅក្នុងស្រុងម៉ាសេដូន។
(សូមមើល:translate-names|How to Translate Names)
យើងបានទៅដល់ក្រុងនាប៉ូល
ពាក្យ «ទៅដល់» នៅទីនេះ អាចប្រែថា «មកដល់» ឬ «បានមកដល់»
នៅក្រោមអាណានិគមរ៉ូម
នេះគឺជាទីក្រុងនៅខាងក្រៅប្រទេសអ៊ីតាលី
នៅទីនោះមានជនជាតិរ៉ូមជាច្រើនរស់នៅ។ ពួកគេមានសិទ្ធិ និងសេរីភាពមួយចំនួន
ក្នុងនាមជាអ្នកក្រុងម្នាក់នៅអ៊ីតាលី។ ពួកគេអាចគ្រប់គ្រងខ្លួនឯង
ហើយពួកគេមិនចាំបាច់បង់ពន្ធទេ។
Acts 16:14
ប្រយោគភ្ជាប់
ចុងបញ្ចប់នៃសាច់រឿងរបស់នាងលីឌា។
មានស្ត្រីម្នាក់ ឈ្មោះលីឌា
ពាក្យ «មានស្ត្រីម្នាក់» គឺជាការណែនាំមនុស្សថ្មីមកក្នុងសាច់រឿង។
របៀបផ្សេងទៀតនៃការបកប្រែ: «មានស្រីម្នាក់ ឈ្មោះនាងលីឌា» ។
ជាអ្នកលក់ក្រណាត់ពណ៌ស្វាយ
ពាក្យ «ក្រណាត់» គេយល់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជំនួញដែលលក់ក្រណាត់ពណ៌ស្វាយ»
ជាអ្នកស្រុកធាទេរ៉ា
នេះគឺជាឈ្មោះរបស់ក្រុងមួយ។
ជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់
ជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់ និងដើរតាមព្រះអង្គ ប៉ុន្តែ
មិនបានស្តាប់បង្គាប់តាមច្បាប់របស់លោកម៉ូសេទាំងអស់ទេ។
ព្រះអម្ចាស់បានបើកចិត្តនាង ឲ្យយកចិត្តទុកដាក់នឹងអ្វីដែលលោកប៉ូលមានប្រសាសន៍
ដ្បិត ព្រះអម្ចាស់ធ្វើឲ្យនរណាម្នាក់បានយកចិត្តទុកដាក់ស្តាប់
ហើយទទួលសារដែលលោកប៉ូលបាននិយាយ
គឺបៀបដូចជាព្រះអង្គជាអ្នកបើកចិត្តមនុស្សចំហ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់បានធ្វើឲ្យនាងយល់ និងយកចិត្តទុកដាក់ជាមួយនឹងការនោះ ។
បានបើកចិត្តនាង
ពាក្យ «ចិត្ត» នៅទីនេះ សំដៅលើគំនិតរបស់មនុស្សម្នាក់។
បូករួមទាំងអ្នកនិយាយផងដែរ និយាយពី «ចិត្ត» ឬ «គំនិត»
ប្រៀបដូចជាប្រអប់មួយដែលគេបើកចំហ ងាយឲ្យនរណាម្នាក់ដាក់ឥវ៉ានចូល។
ឲ្យយកចិត្តទុកដាក់នឹងអ្វីដែលលោកប៉ូលមានប្រសាសន៍
ឃ្លានេះ និយាយនៅក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីៗដែលលោកប៉ូនបានមានប្រសាសន៍» (សូមមើល:|Active ឬ Passive)
ពេលនាង និងក្រុមគ្រួសារនាងបានទទួលពិធីជ្រមុជទឹករួចហើយ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបធៀបផ្សេងទៀតនៃការបកប្រែ:
«ពេលពួកគេជ្រមុជទឹកឲ្យលីឌា និងអ្នកនៅក្នុងគ្រួសាររបស់នាង» (សូមមើល:|Active ឬ Passive)។
Acts 16:16
ប្រយោគភ្ជាប់
ឃ្លានេះចាប់ផ្តើមពីព្រឹត្តការណ៍ដំបូង និងឆ្លងទៅព្រឹត្តការណ៍មួយទៀត
នៅក្នុងដំណើររបស់លោកប៉ូល។ គឺនិយាយពីគ្រូទាយស្រីវ័យក្មេង។
ព័ត៌មានទូទៅ

generated on Wed Sep 10 16:16:32 2025

ព័ត៌មានពីប្រវត្តិដែលបានផ្តល់នៅទីនេះ ដើម្បីពន្យល់ថា ស្ត្រីគ្រូទាយវ័យក្មេងនេះ
រកប្រាក់បានច្រើនណាស់សម្រាប់ម្ចាស់របស់នាង
ដោយទាយពីអនាគតរបស់មនុស្ស។
មានថ្ងៃមួយ
ឃ្លានេះ សម្គាល់ពីការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង។ ប្រសិនបើ
ភាសារបស់អ្នកធ្វើបែបនេះ អ្នកអាចប្រើវាបាន។
មានស្រីម្នាក់
ឃ្លា «មានស្រីម្នាក់» ណែនាំពីមនុស្សថ្មីមកក្នុងសាច់រឿង។
របៀបផ្សេងទៀតនៃការបកប្រែ: «មានក្មេងស្រីម្នាក់»
ដែលមានវិញ្ញាណភីថង់ចូលមកជួបយើង
មានវិញ្ញាណអាក្រក់និយាយប្រាប់នាង
ជាញឹកញាប់ទាក់ទងនឹងរឿងនាពេលអនាគតរបស់មនុស្ស។
ផ្លូវនៃការសង្គ្រោះ
ពីការដែលមនុស្សអាចបានសង្គ្រោះ ត្រូវបាននិយាយនៅទីនេះ ប្រៀបដូចជាផ្លូវ ឬ
មាគ៌ាដែលមនុស្សដើរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីរបៀបដែលព្រះជាម្ចាស់សង្គ្រោះមនុស្ស»
ប៉ុន្តែ នាងរំខានដល់លោកប៉ូលជាខ្លាំង ក៏ងាកទៅក្រោយ
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
នាងបានរំខានដល់លោកប៉ូលជាខ្លាំង ដូច្នេះលោកក៏បែរទៅក្រោយ»។
ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត
ពាក្យ «ព្រះនាម» តំណាងឲ្យការនិយាយអាងលើសិទ្ធិអំណាច
ឬជាអ្នកតំណាងឲ្យព្រះយេស៊ូគ្រិស្ត។
ហើយវាក៏ចេញពីនាងភ្លាម
«ហើយវិញ្ញាណនោះបានចេញភ្លាម»
Acts 16:19
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើលោកប៉ូល និងលោកស៊ីឡាស ប៉ុន្តែ
មិនមែនលោកធីម៉ូថេ និងលោកលូកាទេ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ពីរដំបូង
សំដៅលើចៅហ្វាយរបស់ក្មេងស្រីដែលជាទាយឲ្យគេនោះ។ ពាក្យ «ពួកគេ»
លើកទីបី សំដៅលើលោកប៉ូល និងលោកស៊ីឡាស។
ព័ត៌មានទូទៅ
នៅត្រង់នេះចៅហ្វាយនិយាយពាក្យ ពាក្យ «យើង» បូករួមទាំងពួកអាជ្ញាធរ
ដែលពួកគេប្រកាសថាពួកគេជារ៉ូម។ (សូមមើល: |Inclusive "យើង")
ពួកម្ចាស់របស់នាង
«ម្ចាស់របស់ទាសករស្រី»
លែងមានសង្ឃឹមនឹងបានកម្រៃអ្វីទៀត
ឃ្លានេះសំដៅលើសមត្ថភាពរបស់ក្មេងស្រីដែលចេញមន្តអាគម
ឬចេះទាយពីអនាគត ហើយធ្វើឲ្យមនុស្សចាប់អារម្មណ៍ថានាងជាព្យាការី។
តាមផ្សារ
«ចូលទៅតាមទីសាធារណៈ» ទីសាធារណៈនេះគឺជាកន្លែងជំនួញ
ដែលមនុស្សម្នាទិញលក់ឥវ៉ាន គោ ឬ កន្លែងធ្វើការ។
ទៅជួបពួកអាជ្ញាធរ
«មកចំពោះពួកអាជ្ញាធរ» ឬ «ដើម្បីឲ្យពួកអាជ្ញាធរកាត់ក្តីឲ្យពួកគេ»។
នៅពេលពួកគេបាននាំពួកលោកជួបចៅក្រមហើយ
«ពេលគេបាននាំពួកគេទៅដល់ចៅក្រមហើយ»
ពួកចៅក្រម
«អ្នកគ្រប់គ្រង» ឬ «អ្នកកាត់ក្តី»
ទទួល ឬ កាន់តាម
«ជឿ ឬស្តាប់បង្គាប់» ឬ «ទទួល ឬ ធ្វើ»
Acts 16:22
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «ពួកគេ» សំដៅលើលោកប៉ូល និងលោកស៊ីឡាស។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើពួកទាហាន។
បញ្ជាឲ្យវាយពួកគេនឹងរំពាត់
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបង្គាប់ឲ្យពួកទាហានវាយពួកគេ ជាមួយនឹងរំពាត់» (សូមមើល: |Active ឬ
Passive)
បានបញ្ជាឲ្យអ្នកយាមគុកយាមពួកគេដោយប្រុងប្រយ័ត្ន។
«បានបង្គាប់អ្នកយាមគុក
យកពួកគេទៅដាក់គុកដោយយាមឲ្យប្រុងប្រយ័ត្ន» (UDB)
បានវាយពួកគេច្រើនរំពាត់រួចហើយ
«បានវាយពួកគេជាច្រើនរំពាត់»
អ្នកយាមគុក
មនុស្សម្នាក់ដែលទទួលខុសត្រូវ មនុស្សដែលជាប់គុក និងមើលខុសត្រូវគុក។
អ្នកយាមគុកបានទទួលបញ្ជានេះហើយ
«គាត់បានទទួលបញ្ជានេះ»
ដាក់ខ្នោះនៅនឹងជើងរបស់ពួកគេ
«បានដាក់ខ្នោះជើងរបស់ពួកគេទាំងពីរ»
ខ្នោះ
ឈើមួយដុំ ជាមួយនឹងរន្ធសម្រាប់ការពារជើងរបស់គេមិនឲ្យរើរួច។
Acts 16:25
ប្រយោគភ្ជាប់
ឃ្លានេះ បន្តនិយាយពីរឿងរបស់លោកប៉ូល និងលោកស៊ីឡាសនៅក្នុងគុក
នៅក្រុងភីលីព ហើយបានប្រាប់ពីអ្វីដែលបានកើតឡើងដល់អ្នកយាមគុក។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើ លោកប៉ូល និងលោកស៊ីឡាស។
ក៏មានការរញ្ជួយផែនដីយ៉ាងខ្លាំង ធ្វើឲ្យកក្រើកដល់គ្រឹះនៅក្នុងគុក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានការរញ្ជួយដី ធ្វើឲ្យកក្រើកដល់គ្រឹះនៅក្នុងគុក» ។
ធ្វើឲ្យកក្រើកដល់គ្រឹះនៅក្នុងគុក
នៅពេលកក្រើកដល់គ្រឹះនៅក្នុងគុក ធ្វើឲ្យគុកទាំងមូលរញ្ជួយ។
ទ្វារគុកទាំងអស់បានបើកឡើង
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទ្វារទាំងអស់បានបើកចំហ»
ហើយច្រវាក់របស់មនុស្សគ្រប់គ្នាក៏របូតចេញអស់ដែរ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្នោះរបស់ពួកគេបានរបូតចេញ»
Acts 16:27
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើលោកប៉ូល លោកស៊ីឡាស និងអ្នកទោសផ្សេងៗទៀត
ប៉ុន្តែ មិនបូករួមអ្នកយាមគុកទេ។
អ្នកយាមគុកបានភ្ញាក់ពីគេងឡើង
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកយាមគុកបានក្រោកពីគេងឡើង»
រៀបនឹងសម្លាប់ខ្លួន
«ប្រុងនឹងសម្លាប់ខ្លួនគាត់»។ អ្នកយាមគុកចង់សម្លាប់ខ្លួនឯង
ជាជាងរងទុក្ខដោយសារឃើញពីលទ្ធផលនៃការដែលអ្នកទោសគេចផុត។
Acts 16:29
ហៅឲ្យគេយកភ្លើងមក
ហេតុផលដែលអ្នកយាមគុកត្រូវការភ្លើងគឺដើម្បីបង្ហាញឲ្យច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បានហៅនរណាម្នាក់យកភ្លើងឲ្យគាត់
ដើម្បីកាត់អាចមើលថាតើនរណានៅក្នុងគុកខ្លះ» ។
យកភ្លើងមក
ពាក្យ «យកភ្លើងមក» សំដៅលើអ្វីមួយដែលធ្វើឲ្យមានភ្លើង។
របៀបផ្សេងទៀតនៃការបកប្រែ: «ចន្លុះ» ឬ «ចង្កៀង»
ចូលទៅក្នុងគុកជាប្រញាប់ប្រញាប់
«បានចូលទៅក្នុងគុកជាប្រញាប់ប្រញាប់»
ក្រាបចុះនៅមុខលោកប៉ូល និងលោកស៊ីឡាស
អ្នកយាមគុកបានបន្ទាបខ្លួនដោយលុតជង្គង់នៅចំពោះលោកប៉ូល
និងលោកស៊ីឡាស។
បាននាំពួកគេចេញមកក្រៅ
«បាននាំពួកគេចេញមកក្រៅគុក»
តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីឲ្យបានសង្គ្រោះ?
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«តើយើងខ្ញុំត្រូវធ្វើអ្វី ដើម្បីឲ្យព្រះជាម្ចាស់សង្គ្រោះខ្ញុំចេញពីបាប»

generated on Wed Sep 10 16:16:32 2025

នឹងបានសង្គ្រោះ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នឹងសង្គ្រោះអ្នក» ឬ «ព្រះជាម្ចាស់សង្គ្រោះអ្នក ពីបាបរបស់អ្នក»
ក្រុមគ្រួសាររបស់លោក
ពាក្យ «ផ្ទះ» នៅទីនេះ តំណាងឲ្យអ្នករស់នៅក្នុងផ្ទះទាំងអស់គ្នា។
របៀបផ្សេងទៀតនៃការបកប្រែ: «សមាជិកនៅក្នុងផ្ទះរបស់លោក» ឬ
«នៅក្នុងគ្រួសាររបស់លោក»
Acts 16:32
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ប្រើលើកទីមួយ បូករួមទាំង «ពួកគេ» និង «ពួកគេ»
សំដៅលើលោកប៉ូល និងលោកស៊ីឡាស។ ប្រៀបធៀបនៅក្នុង ជំពូក ១៦:២៥។
ព័ត៌មានទូទៅ
ពាក្យ «គាត់» «របស់គាត់» និង «គាត់» សំដៅលើ អ្នកគុក។
ពួកគេបានប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់គាត់
ពាក្យ «ព្រះបន្ទូល» តំណាងឲ្យព្រះរាជសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេប្រាប់គាត់ពីព្រះបន្ទូលអំពីព្រះអម្ចាស់យេស៊ូ»។
ហើយគាត់ និងក្រុមគ្រួសាររបស់គាត់ក៏បានទទួលពិធីជ្រមុជទឹក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកប៉ូល
និងលោកស៊ីឡាសបានជ្រមុជទឹកឲ្យអ្នកយាមគុក
និងសមាជិកគ្រួសាររបស់គាត់ទាំងអស់» (សូមមើល:|Active ឬ Passive)។
Acts 16:35
ព័ត៌មានទូទៅ
នេះគឺជាព្រឹត្តការណ៍ចុងក្រោយនៃរឿងរបស់លោកប៉ូល និងលោកស៊ីឡាស
នៅក្នុងភីលីព។ (សូមមើល: ១៦:១១)
ឥឡូវនេះ
ពាក្យនេះ ប្រើដើម្បីបញ្ជាក់ថា សម្រាកនៅក្នុងសាច់រឿងធំ។
លោកលូកាប្រាប់នៅទីនេះ គឺជាព្រឹត្តការណ៍ចុងក្រោយដែលចាប់ផ្តើមនៅក្នុងជំពូក
១៦:១៦។
ចាត់គេឲ្យប្រាប់ពួកអ្នកយាមគុក
ពាក្យ «ព្រះបន្ទូល» នៅទីនេះ តំណាងឲ្យ «ព្រះរាជសារ» ឬ «បង្គាប់»
របៀបផ្សេងទៀតនៃការបកប្រែ: «បានចាត់គេឲ្យទៅប្រាប់អ្នកយាមគុក» ឬ
«បានបង្គាប់គេឲ្យប្រាប់អ្នកយាមគុក»
ចាត់ព្រះបន្ទូល
ពាក្យ «ចាត់» នៅទីនេះ
មានន័យថាក្រុមអ្នកកាត់ក្តីប្រាប់គេឲ្យទៅប្រាប់អ្នកយាមគុកតាមសាររបស់គេ។
ឲ្យដោះលែងលោក
«ដោះលែងពួកគេ» ឬ «អនុញ្ញាតឲ្យពួកគេចេញទៅ»
ចេញទៅ
«ចេញពីគុក»
Acts 16:37
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» គ្រប់ពេលវេលាទាំងអស់ លើកលែងតែម្តងទេ ប្រើពាក្យ «ពួកគេ»។
ពាក្យទាំងនេះ សំដៅលើពួកចៅក្រម។ ពាក្យ «ពួកគេខ្លួនឯង»
សំដៅលើពួកចៅក្រម»។ ពាក្យ «ពួកគេ» លើកទីពីរ សំដៅលើលោកប៉ូល
និងលោកស៊ីឡាស។
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើតែ លោកប៉ូល និងលោកស៊ីឡាសទេ។ (សូមមើល:|
Exclusive "យើង")
មានប្រសាសន៍ទៅពួកគេ
ប្រហែលជាលោកប៉ូលមានប្រសាសន៍ទៅកាន់អ្នកយាមគុក ប៉ុន្តែ
គាត់ប្រាប់អ្នកយាមគុក ឲ្យប្រាប់ទៅពួកចៅក្រមដែលលោកមានប្រសាសន៍។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រាប់ដល់អ្នកយាមគុក»
ពួកគេមានសិទ្ធិអ្វីក្នុងការវាយយើងនៅកន្លែងសាធារណៈ
ពាក្យ «ពួកគេ» សំដៅលើក្រុមចៅក្រម ដែលបានបង្គាប់ពួកទាហានឲ្យវាយពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកចៅក្រមបានបង្គាប់ពួកទាហានឲ្យវាយយើងនៅទីសាធារណៈ»
ដោយមិនបានជំនុំជម្រះដូច្នេះ ហើយក៏យកយើងមកដាក់គុកទៀត ទាំងយើងជាជនជាតិរ៉ូម
«អ្នកដែលមានសញ្ជាតិរ៉ូម
ហើយពួកគេបានឲ្យពួកទាហានរបស់ពួកគេចាប់យើងដាក់គុក
ដោយមិនបានជំនុំជម្រះ ថាយើងមានកំហុស»
ឥឡូវនេះ តើពួកគេចង់ដោះលែងយើងដោយស្ងាត់ៗឬ? ទេ!
លោកប៉ូលប្រើសំនួរមួយនេះ ដើម្បីបញ្ជាក់ថា
គាត់មិនអនុញ្ញាតឲ្យពួកចៅក្រមដោះលែងពួកគេដោយសម្ងាត់ឡើង
បន្ទាប់ពីពួកគេបានធ្វើបាបលោកប៉ូល និងលោកស៊ីឡាស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិនអនុញ្ញាតឲ្យគេដោះលែងយើងចេញពីទីក្រុងនេះដោយសម្ងាត់ឡើយ»។
ចូរឲ្យពួកគេមកដោយខ្លួនឯង
ពាក្យ «ដោយខ្លួនឯង» នៅទីនេះ ប្រើដើម្បីបញ្ជាក់។
ពួកចៅក្រម ហើយនៅពេលពួកគេបានឮថា លោកប៉ូល និងលោកស៊ីឡាសមានសញ្ជាតិរ៉ូម៉ាំងដូច្នេះ
ក្នុងនាមជាសញ្ជាតិរ៉ូម ជាសិទ្ធិស្របច្បាប់នៅអាណាចក្ររ៉ូម។
សញ្ជាតិរ៉ូមដល់សេរីភាពមិនឲ្យនរណាធ្វើទោសដោយមមិនបានជំនុំជម្រះឡើយ។
អ្នកដឹកនាំក្រុងភ័យខ្លាចជាពិសេសខ្លាចអជ្ញាធររ៉ូមដឹងថាអ្នកដឹកនាំក្រុងធ្វើបាបលោកប៉ូល
និងលោកស៊ីឡាស។ (សូមមើល:|Assumed Knowledge និង Implicit
Information)
Acts 16:40
ប្រយោគភ្ជាប់
នេះគឺជាសាច់រឿងចុងក្រោយរបស់លោកប៉ូល
និងលោកបារណាបាសចំណាយពេលនៅក្រុងភីលីព។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល និងលោកស៊ីឡាស។ ពាក្យ
«ពួកគេ» សំដៅលើលពួកអ្នកជឿនៅភីលីព។
ចូលទៅផ្ទះ
ពាក្យ «ចូលទៅ» អាចប្រែថា «បានចូល»
ចូលទៅផ្ទះរបស់នាងលីឌា
«ផ្ទះរបស់នាងលីឌា»
បានឃើញពួកបងប្អូន
ពាក្យ «បងប្អូន» នៅទីនេះ សំដៅលើអ្នកជឿ ទាំងប្រុសទាំងស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «បានឃើញអ្នកជឿ»

17 [1]លោកប៉ូល និងលោកស៊ីឡាសធ្វើដំណើរកាត់ក្រុងអាំភីប៉ូលី និងក្រុងអប៉ុឡូនា ហើយទៅដល់ក្រុងថេស្សាឡូនិក ដែលជាក្រុងមួយមានសាលាប្រជុំរបស់សាសន៍
យូដា។[2]លោកប៉ូលបានចូលទៅសាលាប្រជុំតាមទម្លាប់របស់លោក ព្រមទាំងវែកញែកគម្ពីរជាមួយពួកគេរាល់ថ្ងៃសប្ប័ទក្នុងអំឡុងបីសប្តាហ៍។
[3]លោកបានបើកអត្ថបទគម្ពីរ ហើយបរិយាយពន្យល់ប្រាប់គេថា ជាការសំខាន់ណាស់ដែលព្រះគ្រិស្តត្រូវតែរងទុក្ខវេទនា និងមានព្រះជន្មរស់ឡើងវិញ។ លោកមាន
ប្រសាសន៍ថា៖ «ព្រះយេស៊ូនេះហើយ ដែលខ្ញុំបានជម្រាបប្រាប់បងប្អូនថាជាព្រះគ្រិស្ត»។[4]ជនជាតិយូដាខ្លះយល់ស្របតាម ហើយចូលមករួបរួមជាមួយលោកប៉ូល និង
លោកស៊ីឡាស មានទាំងជនជាតិក្រិក ដែលគោរពកោតខ្លាចព្រះជាម្ចាស់ជាច្រើនអ្នក និងមានស្ត្រីៗជាច្រើនក្នុងចំណោមអ្នកធំក៏ចូលមករួបរួមដែរ។
[5]រីឯជនជាតិយូដាដែលមិនទាន់ជឿ គេមានចិត្តច្រណែន ហើយប្រមូលពួកពាលដែលនៅតាមផ្លូវមកបំបះបំបោរប្រជាជន ឲ្យកើតចលាចលក្នុងក្រុង។ គេបានទៅផ្ទះលោក
យ៉ាសូន ក្នុងគោលបំណងចាប់លោកប៉ូល និងលោកស៊ីឡាស យកទៅឲ្យប្រជាជនកាត់ទោស។[6]តែដោយគេរកលោកទាំងពីរមិនឃើញ គេក៏ចាប់លោកយ៉ាសូន និងបងប្អូន
ខ្លះទៀត អូសយកទៅជូនលោកអភិបាលក្រុង ទាំងស្រែកឡើងថា៖ «ពួកដែលបង្កការជ្រួលច្របល់ពេញពិភពលោកទាំងមូល បានមកដល់ទីនេះហើយ!។[7]យ៉ាសូនបាន
ទទួលពួកគេឲ្យស្នាក់នៅផ្ទះគាត់ ហើយអ្នកទាំងនោះបានប្រព្រឹត្តខុសនឹងព្រះរាជក្រឹត្យរបស់ព្រះចៅអធិរាជសេសារ ដ្បិតពួកគេប្រកាសថា មានស្តេចមួយអង្គទៀត នាម
យេស៊ូ»។
[8]ពាក្យនេះបានធ្វើឲ្យបណ្តាជន និងលោកអភិបាលក្រុងខ្វល់ចិត្ត។[9]គេបានសុំឲ្យលោកយ៉ាសូន និងអ្នកឯទៀតៗបង់ប្រាក់ធានា ទើបគេសុខចិត្តដោះលែងឲ្យទៅវិញ។
[10]នៅយប់នោះ ពួកបងប្អូនបានបណ្តោះលោកប៉ូល និងលោកស៊ីឡាសឲ្យចេញដំណើរទៅក្រុងបេរាភ្លាម។ លុះទៅដល់ហើយ លោកទាំងពីរក៏ចូលទៅក្នុងសាលាប្រជុំរបស់
សាសន៍យូដា។[11]សាសន៍យូដានៅក្រុងនេះ មានសន្តានចិត្តល្អជាងសាសន៍យូដានៅក្រុងថេស្សាឡូនិក ដ្បិតគេបានទទួលព្រះបន្ទូលដោយចិត្តស្មោះសរ ហើយពិនិត្យពិច័យ

generated on Wed Sep 10 16:16:32 2025

មើលគម្ពីរជារៀងរាល់ថ្ងៃ ដើម្បីឲ្យដឹងថា សេចក្ដីដែលលោកប៉ូល និងលោកស៊ីឡាសមានប្រសាសន៍ប្រាប់គេ ពិតជាត្រឹមត្រូវមែន ឬយ៉ាងណា។[12]ក្នុងចំណោមពួកគេមានច្រើននាក់បានជឿ ហើយមានស្ត្រីៗអ្នកមុខអ្នកការជាតិក្រិក និងមានបុរសជាច្រើនបានជឿដែរ។
[13]ប៉ុន្តែ កាលសាសន៍យូដានៅក្រុងថេស្សាឡូនិកដឹងថា លោកប៉ូលផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្រុងបេរាដែរនោះ គេក៏នាំគ្នាមកបំបះបំបោរមហាជនឲ្យជ្រួលច្របល់ឡើង។[14]ឃើញដូច្នោះ ពួកបងប្អូនបាននាំលោកប៉ូលឆ្ពោះទៅមាត់សមុទ្រភ្លាម រីឯលោកស៊ីឡាស និងលោកធីម៉ូថេវិញ ស្នាក់នៅទីនោះដដែល។[15]ពួកអ្នកជូនដំណើរលោកប៉ូល បានមកជាមួយលោករហូតដល់ក្រុងអាថែន។ នៅពេលពួកគេត្រឡប់ទៅវិញ គេនាំពាក្យផ្តែផ្តាំពីលោកប៉ូល ទៅជម្រាបលោកស៊ីឡាស និងលោកធីម៉ូថេឲ្យមកតាមលោកយ៉ាងប្រញាប់បំផុត។
[16]ពេលលោកប៉ូលរង់ចាំលោកស៊ីឡាស និងលោកធីម៉ូថេ នៅក្រុងអាថែន លោកតឹងទ្រូងជាខ្លាំង ដោយឃើញមានរូបសំណាក់ពាសពេញក្នុងក្រុងនេះ។[17]ដូច្នេះលោកបានជជែកសន្ទនាជាមួយសាសន៍យូដា និងជាមួយអ្នកដែលគោរពកោតខ្លាចព្រះជាម្ចាស់នៅក្នុងសាលាប្រជុំ ហើយរៀងរាល់ថ្ងៃ លោកសន្ទនាជាមួយអស់អ្នកដែលលោកជួបនៅតាមទីសាធារណៈក្នុងក្រុងនោះ។
[18]មានទស្សនវិទូខ្លះខាងអេពីគួរ និងខាងស្តូអ៊ីក ក៏បានជួបលោកដែរ។ អ្នកខ្លះពោលថា៖ «តើអ្នកព្រោកប្រាជ្ញនេះចង់និយាយអំពីរឿងអ្វី?» ខ្លះទៀតពោលថា៖ «គាត់មើលទៅដូចជាអ្នកដែលប្រកាសប្រាប់មនុស្សពីព្រះចម្លែក»។ គេពោលដូច្នេះ មកពីឮលោកប៉ូលប្រកាសអំពីព្រះយេស៊ូ និងអំពីការរស់ឡើងវិញ។
[19]គេក៏នាំលោកយកទៅមុខសភាក្រុង នៅទួលអើរីយ៉ូស ហើយពោលមកលោកថា៖ «តើលោកអាចប្រាប់យើងឲ្យដឹង អំពីលទ្ធិថ្មីដែលលោកបង្រៀននោះបានទេ?[20]ដ្បិតយើងបានឮលោកថ្លែងរឿងចំឡែកៗ ដូច្នេះយើងពិតជាចង់ដឹងអត្ថន័យណាស់។[21]អ្នកក្រុងអាថែន និងជនបរទេសឯទៀតៗ ដែលរស់នៅក្នុងក្រុងនោះ មិនធ្វើអ្វីផ្សេងទៀតក្រៅពីនិយាយ ឬស្តាប់រឿងថ្មីៗ។
[22]ដូច្នេះលោកប៉ូលក្រោកឈរនៅកណ្ដាលអង្គប្រជុំនៅទួលអើរីយ៉ូស ហើយមានប្រសាសន៍ថា៖ «អស់លោកជាអ្នកក្រុងអាថែនអើយ! ខ្ញុំសង្កេតឃើញអ្នកថាអស់លោកជាអ្នកកាន់សាសនាខ្ជាប់ខ្ជួនណាស់។[23]ពេលខ្ញុំដើរក្នុងទីក្រុង ខ្ញុំឃើញមានបូជនីយដ្ឋានទាំងប៉ុន្មាន ដែលអស់លោកគោរពបូជា ហើយខ្ញុំក៏បានឃើញអាសន: មួយដែលមានចារឹកអក្សរថា៖ «សូមឧទ្ទិសដល់ព្រះដែលយើងពុំស្គាល់»។ ខ្ញុំចង់ប្រកាសប្រាប់ថា អស់លោកថ្វាយបង្គំព្រះដែលអស់លោកពុំស្គាល់។
[24]ព្រះជាម្ចាស់ដែលបានបង្កើតពិភពលោក និងបង្កើតអ្វីៗសព្វសារពើនៅក្នុងពិភពលោកនេះ ព្រះអង្គជាព្រះអម្ចាស់នៃស្ថានបរមសុខ និងផែនដី ព្រះអង្គមិនគង់នៅក្នុងព្រះវិហារ ដែលមនុស្សសង់នោះឡើយ។[25]ព្រះអង្គក៏មិនត្រូវការឲ្យមនុស្សបីបាច់ថែរក្សាព្រះអង្គដែរ ព្រោះព្រះអង្គទេតើដែលបានប្រទានជីវិត ប្រទានដង្ហើម និងប្រទានរបស់សព្វសារពើដល់មនុស្ស។
[26]ព្រះអង្គប្រទានឲ្យប្រជាជាតិនានា កើតចេញមកពីមនុស្សតែម្នាក់ ហើយឲ្យគេរស់នៅពាសពេញលើផែនដីទាំងមូល ទាំងកំណត់រដូវកាល និងកំណត់ព្រំដែនឲ្យមនុស្សរស់នៅ[27]ហេតុដូច្នេះបានជាគេគួរស្វែងរកព្រះជាម្ចាស់ ប្រហែលជាគេនឹងរកព្រះអង្គឃើញ។ តាមពិត ព្រះជាម្ចាស់មិនគង់នៅឆ្ងាយពីយើងម្នាក់ៗទេ។
[28]ដ្បិតយើងមានជីវិត មានចលនា និងមានភាវៈជាមនុស្សក្នុងព្រះអង្គ ដូចអ្នកកវីម្នាក់របស់អស់លោកតែងពោលថា៖ “យើងក៏ជាពូជរបស់ព្រះអង្គដែរ”។[29]ហេតុនេះ ប្រសិនបើយើងពិតជាពូជរបស់ព្រះជាម្ចាស់មែន យើងមិនត្រូវគិតថា ព្រះអង្គមានសណ្ឋានដូចរូបសំណាក់ ធ្វើពីមាស ប្រាក់ ឬថ្មដែលជាក្បាច់រចនាតាមការនឹកឃើញរបស់មនុស្សនោះឡើយ។
[30]ដូច្នេះ ព្រះជាម្ចាស់មិនប្រកាន់ទោសមនុស្សលោក ដែលប្រព្រឹត្តអំពើមិនគប្បីនោះឡើយ តែឥឡូវនេះ ព្រះអង្គបង្គាប់ឲ្យមនុស្សទាំងអស់រស់នៅគ្រប់ទីកន្លែង បានកែប្រែចិត្ត។[31]ដ្បិតព្រះអង្គបានកំណត់ថ្ងៃមួយទុក ដើម្បីវិនិច្ឆ័យទោសមនុស្ស តាមសេចក្ដីសុចរិត ដោយសារបុរសម្នាក់ដែលព្រះអង្គបានតែងតាំង។ ព្រះអង្គបានប្រោសបុរសនោះឲ្យរស់ឡើងវិញទុកជាភស្តុតាងសម្រាប់មនុស្សទាំងអស់»។
[32]កាលពួកគេបានឮសូរពាក្យ “រស់ឡើងវិញ” ដូច្នេះ អ្នកខ្លះក៏ចំអកអោយលោកប៉ូល អ្នកខ្លះទៀតពោលថា៖ «ចាំលើកក្រោយ យើងនឹងស្តាប់លោកមានប្រសាសន៍អំពីរឿងនេះទៀត»។[33]បន្ទាប់មក លោកប៉ូលក៏ចាកចេញពីចំណោមពួកគេ។[34]ប៉ុន្តែ មានអ្នកខ្លះបានមកចូលរួមជាមួយលោកហើយជឿ រួមទាំងលោកឌេរនីស ជាសមាជិកសភាក្រុងនៅទួលអើរីយ៉ូស និងមានស្ត្រីម្នាក់ឈ្មោះនាងដាម៉ារីស ព្រមទាំងអ្នកឯទៀតៗផង។

Acts 17:1
ប្រយោគភ្ជាប់
សាច់រឿងរបស់លោកប៉ូល និងលោកស៊ីឡាស
ព្រមទាំងលោកធីម៉ូថេដំណើរបេសកកម្ម។ ពួកគេបានមកដល់ក្រុងថេស្សាឡូនិក
នៅទីនេះ គ្មានលោកលូកាទេ លោកមានប្រសាសន៍ថា «ពួកគេ» មិនមែន «យើង» ទេ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើលោកប៉ូល និងលោកស៊ីឡាស។
ប្រៀបធៀបនៅក្នុងជំពូក ១៦:៤០។ពាក្យ «ពួកគេ»
សំដៅលើជនជាតិយូដានៅក្នុងសាលាប្រជុំនៅក្នុងក្រុងថេស្សាឡូនិក។
ឥឡូវនេះ
ពាក្យនេះប្រើដើម្បីសម្គាល់ពីការសម្រាកពីសាច់រឿងធំ។ នៅទីនេះ លោកលូកា
ជាអ្នកនិពន្ធចាប់ផ្តើមប្រាប់ពីសាច់រឿងថ្មី។
ធ្វើដំណើរកាត់
«បានធ្វើដំណើរឆ្លងកាត់»
ក្រុងអាំភីប៉ូលី និងក្រុងអប៉ុឡូនា
ទីក្រុងទាំងនេះនៅតាមឈូងសមុទ្រនៅក្នុងស្រុកម៉ាសេដូន។ (សូមមើល: | How to Translate Names)
ពួកគេបានទៅដល់ក្រុង
ពាក្យ «មកដល់» នៅទីនេះ ប្រែថា «បានទៅ» ឬ «បានមកដល់»
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានមកដល់ទីក្រុង» ឬ
«ពួកគេបានមកដល់ទីក្រុង»
តាមទម្លាប់របស់លោក
«តាមទម្លាប់របស់លោក» ឬ «នៅក្នុងការប្រតិបត្តរបស់លោក»។
លោកប៉ូលជាទូទៅបានចូលទៅតាមសាលាប្រជុំរៀងរាល់ថ្ងៃសប្ប័ទ
នៅពេលជនជាតិយូដាប្រជុំគ្នា។
បីថ្ងៃសប្ប័ទ
«នៅថ្ងៃសប្ប័ទ បីសប្តាហ៍»
ព្រមទាំងជជែកវែកញែកពីបទគម្ពីរ
លោកប៉ូលពន្យល់អ្វីអត្ថន័យនៅក្នុងបទគម្ពីរ
ដើម្បីបង្ហាញដល់ជនជាតិយូដាថាព្រះយេស៊ូជាព្រះមេស្ស៊ី។
ជជែកវែកញែកពីបទគម្ពីរជាមួយពួកគេ
«ឲ្យហេតុផលដល់ពួកគេ» ឬ «ជជែកតវ៉ាជាមួយពួកគេ» ឬ
«ពិភាក្សាជាមួយពួកគេ»។
Acts 17:3
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកប៉ូល។ (សូមមើល: ១៧:១)
លោកបានបើកបទគម្ពីរ
ឃ្លានេះអាចមានន័យពីរ ទី១)
ដើម្បីពន្យល់ពីបទគម្ពីរឲ្យមនុស្សបានយល់ពីអ្វីដែលលោកបានមានប្រសាសន៍ដូចជាលោកបើកអ្វីមួយឲ្យ
ឬទី២) លោកប៉ូលបើកសៀវភៅ ឬក្រាំងគម្ពីរហើយអានពីគម្ពីរនោះ។ (សូមមើល:
ជាការសំខាន់ណាស់
«ជាផ្នែកមួយនៃផែនការរបស់ព្រះជាម្ចាស់»
រស់ពីស្លាប់ឡើងវិញ
«មានព្រះជន្មរស់ឡើងវិញ»
រស់ពីស្លាប់ឡើងវិញ
«រស់ពីស្លាប់ឡើងវិញ» ឃ្លានេះ «របស់ពីមនុស្សស្លាប់»
សំដៅលើវិញ្ញាណរបស់មនុស្សដែលបានស្លាប់។ រស់ពីស្លាប់ឡើងវិញ
មានន័យថាមានជីវិតរស់ឡើងវិញ។
ជនជាតិយូដាខ្លះបានជឿ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជឿជនជាតិយូដា» ឬ «ជនជាតិយូដាបានយល់»

generated on Wed Sep 10 16:16:32 2025

ហើយចូលមករួមជាមួយលោកប៉ូល
«បានចូលរួមជាមួយលោកប៉ូល»
ជនជាតិក្រិកដែលកោតខ្លាចព្រះ
ឃ្លានេះមានន័យថា អ្នកដែលថ្វាយបង្គំព្រះជាម្ចាស់ ប៉ុន្តែ
មិនមែនអ្នកដែលប្តូរមកកាន់សាសនាយូដាតាមរយៈការកាត់ស្បែកទេ។
បណ្តាជនជាច្រើន
«មានហ្វូងមនុស្សជាច្រើន»
Acts 17:5
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើសាសន៍យូដាដែលមិនជឿ
និងមនុស្សអាក្រក់ពីផ្សារ។
គេមានចិត្តច្រណែន
មានអារម្មណ៍ច្រណែន និយាយដូចជាច្រណែនបានធ្វើឲ្យមនុស្សខឹងសម្បា។
របៀបផ្សេងទៀតនៃការបកប្រែ: «មានអារម្មណ៍ច្រណែន» ឬ
«មានអារម្មណ៍ខឹងយ៉ាងខ្លាំង»
មានចិត្តច្រណែន
ឃ្លានេះបញ្ជាក់ថាជនជាតិយូដាបានច្រណែនជាមួយនឹងជនជាតិយូដា
និងជនជាតិក្រិកខ្លះ ដែលបានជឿលើព្រះបន្ទូលរបស់លោកប៉ូល។
ប្រមូលជនពាល
ពាក្យ «ប្រមូល» មិនមែនមានន័យថា ប្រមូលមនុស្សដោយបង្ខំទេ។
មានន័យថាជនជាតិយូដាបានបញ្ចុះបញ្ចូលជនពាលឲ្យជួយពួកគេ។
ប្រមូលជនពាល
«មនុស្សអាក្រក់ខ្លះ» ពាក្យ «មនុស្ស» នៅទីនេះ សំដៅលើតែមនុស្ស
ប្រុសជាពិសេស។
ដែលនៅតាមផ្សារ
«នៅតាមទីសាធារណៈ» គឺនៅកន្លែងជំនួញនៅតាមសាធារណៈ
ជាកន្លែងដែលគេទិញ និងលក់ឥវ៉ាន គោឬ កន្លែងសេវាកម្មផ្សេងទៀត។
បង្ករឲ្យការប៉ះបោរនៅក្នុងក្រុង
ពាក្យ «ទីក្រុង» តំណាងឲ្យមនុស្សដែលនៅក្នុងទីក្រុង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើឲ្យមនុស្សនៅក្នុងទីក្រុងមានការបះបោរកើតឡើង» ឬ
«ធ្វើឲ្យមនុស្សនៅក្នុងទីក្រុងបះបោរ»
បានវាយសម្រុកចូលផ្ទះ
«បានវាយលុកផ្ទះ»។ ឃ្លានេះ មានន័យថាមនុស្សដែលចោលដុំថ្មលើផ្ទះ
និងព្យាយាមក្នុងការបំបាក់ទ្វារផ្ទះ។
លោកយ៉ាសូន
នេះគឺជាឈ្មោះរបស់បុរសម្នាក់។
យកទៅឲ្យបណ្តាជន
អាចមានន័យថា «មនុស្ស» ទី១) ក្រុមមនុស្សដែលមានអំណាច
ឬអ្នកច្បាប់នៅក្នុងជាតិសាសន៍នោះបានជួបជុំគ្នាដើម្បីសម្រេចចិត្ត។ ឬ ទី២)
ហ្វូងមហាជន
បងប្អូនខ្លះទៀត
ពាក្យ «បងប្អូន» សំដៅលើពួកអ្នកជឿ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានបងប្អូនផ្សេងទៀត»
ទៅប្រគល់ឲ្យអាជ្ញាធរក្រុង
«នៅចំពោះវត្តមានរបស់អាជ្ញាធរ»
«ពួកអ្នកទាំងនេះបាននាំ»
អ្នកដឹកនាំជនជាតិយូដាបាននិយាយ ហើយឃ្លាថា «បុរសទាំងនេះ»
សំដៅលើលោកប៉ូល និងលោកស៊ីឡាស។
ធ្វើឲ្យពិភពលោកទាំងមូលក្រឡាប់ចាក់
ឃ្លានេះ គឺជារបៀបមួយទៀតក្នុងការនិយាយពីលោកប៉ូល និងលោកស៊ីឡាស
ជាអ្នកធ្វើឲ្យមានបញ្ហានៅគ្រប់កន្លែងដែលពួកគេទៅ។
អ្នកដឹកនាំជនជាតិយូដាបាននិយាយបំផ្លើសពីឥទ្ធិពលរបស់លោកប៉ូល
និងលោកស៊ីឡាស ដោយសារសេចក្តីបង្រៀនរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើឲ្យមានបញ្ហាគ្រប់កន្លែងដែលពួកគេបានទៅ»
យ៉ាសូនបានទទួល
ឃ្លានេះជាសញ្ញាដែលលោកយ៉ាសូនបានយល់ស្របជាមួយនឹងសារដែលនាំឲ្យវឹកវរ
Acts 17:8
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើពួកអាជ្ញាធរនៅក្នុងទីក្រុង។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើលោកយ៉ាសូន និងអ្នកជឿផ្សេងៗទៀត
ពួកគេត្រូវបានគេនាំមកជួបពួកអាជ្ញាធរក្រុង។
ខឹង
«បារម្ភ» ឬ «ខ្វល់ខ្វាយ»
ពួកអាជ្ញាធរបានសុំឲ្យលោកយ៉ាសូន និងអ្នកឯទៀតៗ
ប្រាក់នេះ ត្រូវបានសន្យាដោយបំណងល្អ ប្រាក់នេះអាចនឹងធ្វើត្រឡប់ទៅវិញ
ប្រសិនបើ វាដំណើរការធម្មតាឡើងវិញ ឬ អាចប្រើដើម្បីជួសជុលអ្វីៗដែលខូច
ដោយសារប្រព្រឹត្តមិនគួរសម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានទទួលចំណង» ឬ «បានទទួលប្រាក់»
អ្នកឯទៀតៗ
ពាក្យ «អ្នកឯទៀតៗ»
សំដៅលើអ្នកជឿផ្សេងទៀតដែលជនជាតិយូដាបាននាំមកចំពោះអាជ្ញាធរ។
Acts 17:10
ព័ត៌មានទូទៅ
លោកប៉ូល និងលោកស៊ីឡាសបានធ្វើដំណើរបន្តទៅក្រុងបេរាទៀត។
ពួកបងប្អូន
ពាក្យ «ពួកបងប្អូន» នៅទីនេះ សំដៅលើបុរស និងស្ត្រីអ្នកជឿ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកអ្នកជឿ»
ឥឡូវ
ពាក្យ «ឥឡូវ» ប្រើនៅទីនេះ ដើម្បីសម្រាកពីសាច់រឿងធំ។ នៅទីនេះ
លោកលូកាប្រាប់ពីប្រវត្តិអំពីមនុស្សនៅក្នុងក្រុងបេរា។
ពីរបៀបដែលពួកគេចង់ស្តាប់លោកប៉ូល និងពិភាក្សាពីអ្វីដែលលោកបាននិយាយ។
ប្រជាជននៅក្រុងនេះ មានចិត្តល្អជាងជនជាតិយូដា
ពាក្យនេះ «មានចិត្តល្អ» មនុស្សមានចិត្តក្នុងការគិតពីគំនិតថ្មីៗជាងអ្នកដទៃទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ចិត្តចិត្តទូលាយជាង» ឬ
«មានចិត្តចង់ស្តាប់ច្រើនជាង»
បានទទួលព្រះបន្ទូល
ពាក្យ «ព្រះបន្ទូល» នៅទីនេះ សំដៅលើការបង្រៀន។
របៀបផ្សេងទៀតនៃការបកប្រែ: «បានស្តាប់សេចក្តីបង្រៀន»
ដោយយកចិត្តទុកដាក់
ីអ្នកស្រុកបេរារួចរាល់ក្នុងការពិនិត្យពិចៃសេចក្តីបង្រៀនរបស់លោកប៉ូលអំពីបទគម្ពីរ។
សេចក្តីពិតជាត្រឹមត្រូវមែន
«អ្វីដែលលោកប៉ូលមានប្រសាសន៍គឺជាសេចក្តីពិត»
Acts 17:13
ព័ត៌មានទូទៅ
ក្រុងអាថែនជាឈូងសមុទ្រនៅទាបជាងបេរា ដែលនៅក្នុងស្រុកម៉ាសេដូន។ ក្រុង
អាថែនជាក្រុងមួយដ៏សំខាន់នៅក្នុងប្រទេសក្រិក។
ដឹងថា
«រកឃើញ» ឬ «បានដឹង» (UDB)
ក៏ទៅទីនោះនាំឲ្យមានបញ្ហាឡើង
ឃ្លានេះនិយាយអំពីភាពវឹកវរ ដោយសារគំនិតរបស់ពួកគេនាំឲ្យមានការវឹកវរ
ដូចជាការកូរវត្ថុរាវ ឲ្យវាឡើងមកលើ» របៀបផ្សេងទៀតនៃការបកប្រែ:
«បានទៅទីនោះ ហើយនាំឲ្យមានបញ្ហា» ឬ «បានទៅទីនោះ ហើយរំខាន»
ហើយមានបញ្ហាជាមួយបណ្តាជន
«ហើយធ្វើឲ្យបណ្តាជនបារម្ភ» ឬ «ធ្វើឲ្យញាញើត និងខ្លាចនៅក្នុងចំណោមមនុស្ស»
ពួកបងប្អូន
ពាក្យ «ពួកបងប្អូន» នៅទីនេះ សំដៅលើមនុស្សប្រុស និងមនុស្សស្រីដែលជឿ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកអ្នកជឿ»
ទៅមាត់សមុទ្រ
«ទៅតាមមាត់សមុទ្រ» ពីទីនេះ លោកប៉ូលប្រហែលជានិយាយពីទីក្រុងផ្សេង។
ដែលជូនដំណើរលោកប៉ូល
«ដែលបានរួមដំណើរលោកប៉ូល» ឬ «ដែលធ្វើដំណើរជាមួយលោកប៉ូល»
លោកប៉ូលបានផ្តាំឲ្យលោកស៊ីឡាស និងលោកធីម៉ូថេ
«លោកបានប្រាប់ពួកគេដោយប្រាប់ដល់លោកស៊ីឡាស និងលោកធីម៉ូថេ»។
ឃ្លានេះជាដោយដោយត្រង់នៅក្នុង UDB
Acts 17:16
ព័ត៌មានទូទៅ

generated on Wed Sep 10 16:16:32 2025

នេះគឺជាផ្នែកមួយទៀតនៃសាច់រឿងនៃដំណើររបស់លោកប៉ូល និងលោកស៊ីឡាស។ លោកប៉ូលនៅក្នុងក្រុងអាថែននៅពេលនេះ ជាកន្លែងដែលគាត់រងចាំលោកស៊ីឡាស និងធីម៉ូថេដើម្បីចូលរួមជាមួយលោក។

ឥឡូវនេះ

ពាក្យនេះ ប្រើនៅទីនេះដើម្បីបញ្ជាក់ពីការសម្រាកពីសាច់រឿងធំ។ នៅទីនេះ លោកលូកាចាប់ផ្តើមប្រាប់យើងពីផ្នែកថ្មីនៃសាច់រឿង។

វិញ្ញាណរបស់លោកមានកំហឹងជាខ្លាំង ពេលគាត់ឃើញទីក្រុងពេញដោយរូបព្រះ

ពាក្យ «វិញ្ញាណ» នៅទីនេះ តំណាងឲ្យលោកប៉ូលខ្លួនឯង។ ឃ្លានេះ អាចនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកមិនសប្បាយចិត្តសោះ ដោយសារលោកឃើញថាមានរូបព្រះនៅគ្រប់កន្លែងនៅក្នុងទីក្រុង» ឬ «ឃើញរូបព្រះនៅក្នុងទីក្រុងគ្រប់កន្លែងដូច្នេះ ធ្វើឲ្យលោកមិនសប្បាយចិត្តសោះ»

លោកបានជជែកតវ៉ា

«លោកបានតវ៉ា» ឬ «លោកបានពិភាក្សា»។ នេះមានន័យថាមានការឆ្លើយឆ្លងពីអ្នកស្តាប់ជាជាងលោកតែម្នាក់ឯង។ ពួកគេក៏និយាយមករកលោកដែរ។

អ្នកផ្សេងទៀតដែលកោតខ្លាចព្រះ

ឃ្លានេះ សំដៅលើសាសន៍ដទៃដែលបានសរសើរដល់ព្រះជាម្ចាស់ និងអ្នកដើរតាមព្រះអង្គ ប៉ុន្តែ មិនបានស្តាប់បង្គាប់តាមច្បាប់របស់ជនជាតិយូដាឡើយ។

នៅតាមផ្សារ

«នៅតាមទីលានសាធារណៈ» គឺជាកន្លែងសម្រាប់ធ្វើជំនួញ កន្លែងដែលគេទិញ និងលក់ឥវ៉ាន គោ ឬ បម្រើសេវាកម្មផ្សេងៗ។

Acts 17:18

ព័ត៌មានទូទៅ

ពាក្យ «លោក» «គាត់» នៅទីនេះ សំដៅលើលោកប៉ូល។

មានអ្នកទស្សនវិទូខ្លះខាងអេពីគួរ និងខាងស្តូអ៊ីក

អ្នកទាំងនេះ ជឿលើអ្វីៗគ្រប់យ៉ាង ដែលបានកើតឡើងដោយចៃដន្យ និងថាព្រះរវល់នឹងរីករាយជាមួយការគ្រប់គ្រងសកលលោកទាំងមូល។ ពួកគេបដិសេធការរស់ឡើងវិញ និងចង់មានតែភាពរីករាយតែប៉ុណ្ណោះ។ (សូមមើល: |How to Translate Names)

ទស្សនខាងស្តូអ៊ីក

អ្នកទាំងនេះជឿលើសេរីភាពបានមកដោយសារការលះចោលខ្លួនឯងមករកព្រហ្មលិខិតវិញ្ញា ពួកគេបដិសេធការស្រឡាប់ព្រះជាម្ចាស់ផ្ទាល់ខ្លួន និងការរស់ឡើងវិញ។ (សូមមើល: |How to Translate Names)

បានជួបលោក

«បានកើតឡើងចំពោះលោក»

អ្នកខ្លះទៀតពោលថា

«ហើយអ្នកទស្សនវិទូខ្លះពោលថា»

អ្នកដែលនិយាយផ្តេសផ្តាសនេះចង់និយាយអំពីរឿងអ្វី

ពាក្យ «ផ្តេសផ្តាស» ប្រើសំដៅលើសត្វស្លាបដែលចឹកគ្រាប់ស្រូវជាអាហារ។ សំដៅលើភាពអវិជ្ជាមានរបស់មនុស្ស ដែលដឹងព័ត៌មានបន្តិចបន្តួច។ អ្នកទស្សនវិទូមានប្រសាសន៍ថា លោកប៉ូលមានព័ត៌មានតិចតួច គ្មានតម្លៃនឹងស្តាប់លោកទេ។ របៀបផ្សេងទៀតនៃការបកប្រែ: «តើមនុស្សល្ងង់ម្នាក់នេះចង់និយាយពីអ្វី?»

អ្នកខ្លះទៀតពោលថា

«អ្នកទស្សនវិទូខ្លះពោលថា»

មើលទៅគាត់ដូចជាអ្នកដែលប្រកាស

«មើលទៅគាត់ដូចជាអ្នកដែលប្រកាស» ឬ «លោកប្រៀបដូចជាបេសកកជនប្រកាសព្រះបន្ទូល»

ព្រះសាសន៍ដទៃ

ឃ្លានេះ មិនមែនក្នុងន័យ «ប្លែក» ទេ ប៉ុន្តែ ក្នុងន័យ «ព្រះសាសន៍ដទៃ» ជាព្រះដែលសាសន៍ក្រិក និងរ៉ូមមិនបានថ្វាយបង្គំ ឬស្គាល់ឡើយ។

Acts 17:19

ព័ត៌មានទូទៅ

ពាក្យ «ពួកគេ» និង «យើង» នៅទីនេះ សំដៅលើអ្នកទស្សនវិទូខ្លះខាងអេពីគួរ និងខាងស្តូអ៊ីក។ (សូមមើល: |Exclusive "យើង" និង ១៧:១៨)

ព័ត៌មានទូទៅ

ពាក្យ «គាត់» «លោក» និង «អ្នក» សំដៅលើលោកប៉ូល (សូមមើល: ១៧:១៨)

ពួកគេបានយក...នាំគាត់

ឃ្លានេះមិនបានមានន័យថា ពួកគេចាប់ខ្លួនលោកប៉ូលទេ។ ប៉ុន្តែ ពួកទស្សនវិទូបានអញ្ជើញលោកប៉ូល មកនិយាយជាផ្លូវការជាមួយអ្នកដឹកនាំរបស់ពួកគេ។

នៅទួលអើរីយ៉ូស

«នៅទួលអើរីយ៉ូស» ជាកន្លែងដែលពួកអ្នកដឹកនាំជួបជុំគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ: «ទៅរកអ្នកដឹកនាំដែលជួបគ្នានៅទួលអើរីយ៉ូស»

ហើយនាំគាត់នៅទួលអើរីយ៉ូស ហើយពោលថា

នៅទីនេះ អ្នកដឹកនាំនៅទួលអើរីយ៉ូសកំពុងនិយាយ។ ឃ្លានេះអាចនិយាយនៅក្នុងប្រយោគថ្មី។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅទួលអើរីយ៉ូស អ្នកដឹកនាំនិយាយទៅកាន់លោកប៉ូល»

ទួលអើរីយ៉ូស

នេះគឺជាថ្មមួយដុំយ៉ាងធំ លេចចេញមកក្រៅ ឬជាភ្នំនៅក្នុងអាថែននៅចំកន្លែងតុលាកំពូលរបស់ក្រុងអាថែន ដែលជួបជុំនៅទីនោះ។ (សូមមើល: |How to Translate Names)

ដ្បិត លោកបាននាំអ្វីមួយដែលប្លែកមកដល់ត្រចៀករបស់យើង

សេចក្តីបង្រៀនរបស់លោកប៉ូលអំពីព្រះយេស៊ូ និងអំពីការរស់ឡើងវិញ ប្រៀបដូចជាដែលវត្ថុម្យ៉ាងដែលមនុស្សម្នាក់អាចនាំយកមកឲ្យម្នាក់ទៀតបាន។ ពាក្យ «ច្រចៀក» នៅត្រង់នេះ សំដៅលើអ្វីដែលពួកគេបានឮ។ របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត អ្នកបានបង្រៀនអ្វីមួយដែលយើងមិនដែលឮពីមុន» ។

ឥឡូវ...អ្វីថ្មីៗ

ពាក្យនេះប្រើ ដើម្បីសម្គាល់ពីការសម្រាកនៅក្នុងសាច់រឿងធំ។ នៅទីនេះ លោកលូកាប្រាប់ពីប្រវត្តិអំពីមនុស្សដែលរស់នៅក្រុងអាថែន និងចំណាប់អារម្មណ៍នៃសេចក្តីបង្រៀនថ្មី។

អ្នកក្រុងអាថែនទាំងអស់

«អ្នកក្រុងអាថែន» ជាអ្នករស់នៅក្រុងអាថែន ទីក្រុងនៅជិតសមុទ្រនៅខាងក្រោមម៉ាសេដូន (បច្ចុប្បន្នក្រិក) (សូមមើល: |How to Translate Names)

និងជនបរទេសឯទៀតៗ

«និងសាសន៍ដទៃផ្សេងទៀត»

មិនចំណាយពេលរបស់ពួកគេ ក្រៅពីនិយាយ

ពាក្យ «ពេលវេលា» នៅទីនេះ សំដៅលើ ប្រៀបដូចវត្ថុមួយដែលអាចចំណាយពេល។ របៀបផ្សេងទៀតនៃការបកប្រែ: «ចូលចិត្តតែ»

ក្រៅពីនិយាយ ឬស្តាប់រឿងអ្វីថ្មីៗឡើយ

«ពីការពិភាក្សាទស្សនៈថ្មី» ឬ និយាយអំពីអ្វីដែលថ្មីចំពោះពួកគ» (UDB)

Acts 17:22

ព័ត៌មានទូទៅ

លោកប៉ូលចាប់ផ្តើមសុន្ទរកថារបស់លោកទៅកាន់អ្នកទស្សនានៅក្នុងអើរីយ៉ូស។

អស់លោកជាអ្នកកាន់សាសនាគ្រប់របៀបតែម្តង

លោកប៉ូលសំដៅលើរូបព្រះដែលបានឃើញនៅទីសាធារណៈនៅក្រុងអាថែនដែលពួកគេគោរពអធិស្ឋាន សង់កន្លែងថ្វាយយញ្ញបូជា និងថ្វាយយញ្ញបូជាថែមទៀតផង។

ពេលខ្ញុំដើរក្នុងទីក្រុង

«ដោយសារ ពេលខ្ញុំដើរកាត់» ឬ «កាលខ្ញុំដើរកាត់»

សូមឧទ្ទិសដល់ព្រះដែលយើងពុំស្គាល់

អាចមានន័យពីរ ទី១) ទៅកាន់ព្រះមួយអង្គដែលមិនស្គាល់» ឬ២) «ទៅព្រះដែលមិនស្គាល់»។ នេះគឺជាការសរសេរចំៗ ឬជាការចារនៅលើកន្លែងថ្វាយយញ្ញបូជានោះ។

Acts 17:24

ផែនដី

នៅក្នុងន័យទូទៅ ពាក្យ «ផែនដី» សំដៅលើស្ថានសួគ៌ និងផែនដី ព្រមទាំងអ្វីៗនៅក្នុងនោះ។

ព្រោះព្រះអង្គជាព្រះអម្ចាស់

«ព្រោះព្រះអង្គជាព្រះអម្ចាស់»។ ពាក្យ «ទ្រង់» នៅទីនេះ សំដៅលើព្រះដែលមិនស្គាល់ ដែលនិយាយក្នុងជំពូក ១៧:២២ ដែលលោកប៉ូលបានពន្យល់ថាព្រះអម្ចាស់គឺជាព្រះជាម្ចាស់។

នៃស្ថានសួគ៌ និងផែនដី

ពាក្យ «ស្ថានសួគ៌» និង «ផែនដី» ប្រើជាមួយគ្នា សំដៅលើសត្តនិករ

generated on Wed Sep 10 16:16:32 2025

និងអ្វីៗនៅស្ថានសួគ៌និងផែនដី
ដែលសង់ដោយដៃមនុស្ស
ពាក្យ «ដៃមនុស្ស» នៅទីនេះ តំណាងឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ: «សង់ដោយដៃរបស់មនុស្ស» ឬ «ដែលមនុស្សបានសង់»
ព្រះអង្គក៏មិនត្រូវការឲ្យដៃមនុស្សបម្រើព្រះអង្គដែរ
ពាក្យ «បម្រើ» មានន័យដូចជាគ្រូពេទ្យដែលព្យាបាលអ្នកជំងឺ ដើម្បីឲ្យអ្នកជំងឺបានជា។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គក៏មិនត្រូវការឲ្យដៃមនុស្សដើម្បីមើលថែព្រះអង្គឡើយ»
ដោយដៃមនុស្ស
ពាក្យ «ដៃមនុស្ស» តំណាងឲ្យមនុស្សទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ: «ដោយដៃមនុស្សលោក»
ព្រោះព្រះអង្គទ្រង់ផ្ទាល់
«ដោយសារព្រះអង្គទ្រង់ផ្ទាល់» ពាក្យ «អង់ទ្រង់» គឺបន្ថែមសម្រាប់បញ្ជាក់។
Acts 17:26
ព័ត៌មានទូទៅ
ពាក្យ «ព្រះអង្គ» និង «ទ្រង់» នៅទីនេះ សំដៅលើព្រះពិតតែមួយ ព្រះអទិករ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» ឬ «របស់ពួកគេ» សំដៅលើប្រជាជាតិទាំងអស់ដែលរស់នៅលើផែនដី។
ព័ត៌មានទូទៅ
ការប្រើពាក្យ «យើង» នៅទីនេះ លោកប៉ូលបានរួមបញ្ចូលខ្លួនលោក និងអ្នកស្តាប់ ព្រមទាំងប្រជាជាតិទាំងអស់ដែរ។ (សូមមើល: | Inclusive "យើង")
ដូច្នេះហើយ
ពាក្យនេះ សម្គាល់អំពីប្រយោគដែលបាននិយាយហើយ ដោយសារអ្វីដែលលោកប៉ូលបានមានប្រសាសន៍កាលពីមុន។
ចេញពីមនុស្សម្នាក់
ឃ្លានេះមានន័យថាលោកអាដាម គឺជាមនុស្សដំបូងដែលព្រះជាម្ចាស់បានបង្កើត។ នេះអាចនិយាយរួមបញ្ចូលនាងអេវាដែរ។ គឺតាមរយៈលោកអាដាម និងនាងអេវានោះព្រះជាម្ចាស់បានបង្កើតមនុស្សទាំងអស់។
របៀបផ្សេងទៀតនៃការកប្រែ: «គូស្វាមីភរិយា» (UDB)
ទាំងកំណត់រដូវកាល និងកំណត់ព្រំដែននៃការរស់នៅរបស់ពួកគេ
នេះអាចនិយាយនៅក្នុងប្រយោគថ្មី។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយព្រះអង្គបានកំណត់ពេលវេលា និងកន្លែងដែលពួកគេរស់នៅ»
ដូច្នេះហើយ
ពាក្យនេះ សម្គាល់អំពីប្រយោគដែលបាននិយាយហើយ ដោយសារអ្វីដែលលោកប៉ូលបានមានប្រសាសន៍កាលពីមុន។
ដើម្បីឲ្យពួកគេអាចស្វែងរកព្រះជាម្ចាស់ ប្រសិនបើ ពួកគេស្វែងរកព្រះជាម្ចាស់ ប្រហែលជាពួកគេអាចនឹងរកព្រះអង្គឃើញ។
មានដួងចិត្តក្នុងការរៀនពីព្រះជាម្ចាស់ និងមានទំនាក់ទំនងជាមួយព្រះអង្គ
គឺប្រៀបដូចជាមនុស្សម្នាក់ ដែលស្វែងរកមនុស្សម្នាក់ទៀត ហើយបានឈោងចាប់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេរៀនពីព្រះអង្គ ដើម្បីពួកគេអាចយល់ថាពួកគេត្រូវការព្រះអង្គ ហើយបានក្លាយជាម្នាក់នៅក្នុងចំណោមប្រជារាស្ត្រព្រះអង្គ»។
ព្រះអង្គមិនគង់នៅឆ្ងាយពីយើងម្នាក់ៗឡើយ
នេះអាចនិយាយក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គគង់នៅជិតយើងគ្រប់គ្នា»។
Acts 17:28
ព័ត៌មានទូទៅ
ពាក្យ «ទ្រង់» ឬ «របស់ព្រះអង្គ» សំដៅលើព្រះជាម្ចាស់។ (សូមមើល: ១៧:២៤)
ព័ត៌មានទូទៅ
នៅពេលលោកប៉ូលមានប្រសាសន៍ថា «យើង» នៅទីនេះ លោករួមបញ្ចូលខ្លួនលោក ជាមួយនឹងអ្នកស្តាប់របស់លោកដែរ។ (សូមមើល: | Inclusive "We")
នៅក្នុងព្រះអង្គ
«ដោយសារព្រះអង្គ»
យើងពិតជាពូជរបស់ព្រះជាម្ចាស់
ដោយសារព្រះអង្គបង្កើតមនុស្សគ្រប់គ្នា ដូច្នេះ ពួកគេគឺជាបុត្រធីតារបស់ព្រះជាម្ចាស់។
ព្រះអង្គមានលក្ខណៈ
ពាក្យ «ព្រះអង្គមានលក្ខណៈ» សំដៅលើលក្ខណៈរបស់ព្រះ ឬ លក្ខណៈសម្បត្តិ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាព្រះជាម្ចាស់»
ដូចរូបសំណាក់ ធ្វើពីមាស ប្រាក់ ឬថ្មដែលជាការរចនាតាមការនឹកឃើញរបស់មនុស្សនោះឡើយ
ឃ្លានេះ និយាយជាទម្រង់សកម្ម។
«ដែលមនុស្សម្នាក់ប្រើទេពកោសល់របស់ខ្លួនបង្កើតទៅជាអ្វីមួយដែលគាត់តាក់តែ» ឬ «ធ្វើវាជាមួយនឹងសិល្បៈនិងគំនិតរបស់មនុស្ស»។
Acts 17:30
ប្រយោគភ្ជាប់
លោកប៉ូលបញ្ចប់សុន្ទរកថាទៅកាន់អ្នកទស្សនវិទូ នៅអ៊ីរីយ៉ូស ដែលលោកបានចាប់ផ្តើមនៅក្នុងជំពូក ១៧:២២
ព័ត៌មានទូទៅ
ពាក្យ «ព្រះអង្គ» សំដៅលើព្រះជាម្ចាស់។
ដូច្នេះ
ពាក្យនេះ សម្គាល់អំពីប្រយោគដែលបាននិយាយហើយ ដោយសារអ្វីដែលលោកប៉ូលបានមានប្រសាសន៍កាលពីមុន។
ព្រះជាម្ចាស់បានទតរំលងនៅក្នុងសម័យកាលនៃភាពល្ងង់ខ្លៅ
«ព្រះជាម្ចាស់បានសម្រេចចិត្តមិនដាក់ទោសមនុស្ស នៅក្នុងអំឡុងពេលនៃភាពល្ងង់ខ្លៅឡើយ»
ក្នុងសម័យកាលនៃភាពល្ងង់ខ្លៅ
ឃ្លានេះ
សំដៅលើសម័យមុនពេលព្រះអង្គបើកសម្តែងអង្គទ្រង់តាមរយៈព្រះយេស៊ូគ្រិស្ត និងមុនពេលមនុស្សមិនទាន់ដឹងពីរបៀបនៃការស្តាប់បង្គាប់ព្រះជាម្ចាស់។
មនុស្សទាំងអស់
ឃ្លានេះមានន័យថាមនុស្សទាំងអស់ មិនថាប្រុសឬស្រីឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សគ្រប់គ្នា»
នៅពេលព្រះអង្គជំនុំជម្រះផែនដីដោយសុចរិត តាមសេចក្តីសុចរិត ដោយសារបុរសម្នាក់ដែលព្រះអង្គបានជ្រើសរើស
«នៅពេលដែលព្រះអង្គជំនុំជម្រះមនុស្សដែលព្រះអង្គបានជ្រើសរើស ព្រះអង្គនឹងជំនុំជម្រះពិភពលោកដោយសុចរិត»។
ព្រះអង្គជំនុំជម្រះផែនដី
ពាក្យ «ផែនដី» សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គនឹងជំនុំជម្រះមនុស្ស» ។
ដោយសុចរិត
«ទៀតត្រង់» ឬ «ត្រឹមត្រូវ»
ព្រះជាម្ចាស់បានបង្ហាញភ័ស្តុតាងពីបុរសម្នាក់នោះ
«ព្រះជាម្ចាស់បានបង្ហាញការសម្រេចចិត្តរបស់ព្រះអង្គនៅលើបុរសម្នាក់នោះ»
ដោយប្រោសលោកឲ្យរស់ពីស្លាប់ឡើងវិញ
«ពីក្នុងចំណោមមនុស្សស្លាប់» ឃ្លា «មនុស្សស្លាប់» សំដៅលើវិញ្ញាណរបស់មនុស្សដែលបានស្លាប់ទៅ។
ឲ្យត្រឡប់ពីចំណោមពួកគេមានន័យថាឲ្យបានរស់ឡើងវិញម្តងទៀត។
Acts 17:32
ប្រយោគភ្ជាប់
នេះគឺជាផ្នែកចុងក្រោយនៃសាច់រឿងរបស់លោកប៉ូលនៅក្នុងក្រុងអាថែន។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើអ្នកក្រុងអាថែន។
ពួកគេនិយាយទៅរកលោកប៉ូលដោយផ្ទាល់ ប៉ុន្តែ មិនបានរួមជាមួយលោកប៉ូលនៅក្នុងក្រុមរបស់ពួកគេឡើយ។
ប្រហែលជាពួកគេគ្រាន់តែគួរសម ហើយគិតថាពួកគេចង់ស្តាប់លោកប៉ូលម្តងទៀត។ (សូមមើល: | Exclusive "យើង")
ឥឡូវ
ពាក្យនេះប្រើនៅទីនេះ ដើម្បីសម្គាល់ពីការសម្រាកពីសាច់រឿងធំ។ នៅទីនេះ លោកលូកាបង្ហូរពីការបង្រៀនរបស់លោកប៉ូលទៅពីព្រឹត្តកម្មរបស់ប្រជាជនអាថែនវិញ។
អ្នកក្រុងអាថែន
អ្នកទាំងនេះ គឺមានវត្តមាននៅអារីយ៉ូស ស្តាប់លោកប៉ូល។
មានអ្នកខ្លះក៏ចំអកលោកប៉ូល
«មានអ្នកខ្លះសើចចំអកឲ្យលោកប៉ូល» ឬ «អ្នកខ្លះសើចដាក់លោកប៉ូល»។
ពួកគេមិនបានជឿថាមនុស្សម្នាក់ស្លាប់ហើយបន្ទាប់មករស់ឡើងវិញបានទេ។
លោកឌេរនីសនៅទួលអ៊ីរីយ៉ូស

generated on Wed Sep 10 16:16:32 2025

លោកឌេរនីសគឺជាឈ្មោះរបស់បុរសម្នាក់។ ហើយទួលអើរីយ៉ូសបង្ហាញថា ដេរនីសជាចៅក្រមនៅក្រុមប្រឹក្សារបស់អើរីយ៉ូស។ (សូមមើល: | How to Translate Names)

ដាម៉ារីស
នេះគឺជាឈ្មោះរបស់មនុស្សស្រីម្នាក់។

---

18 [1]ក្រោយមក លោកប៉ូលបានចាកចេញពីក្រុងអាថែន ហើយធ្វើដំណើរឆ្ពោះទៅក្រុងកូរិនថូស។[2]នៅក្រុងនោះ លោកបានជួបជនជាតិយូដាម្នាក់ ឈ្មោះអគីឡា ជាអ្នកស្រុកប៉ុនតុស និងនាងព្រីស៊ីលជាភរិយា អ្នកទាំងពីរទើបនឹងមកពីស្រុកអ៊ីតាលី ព្រោះព្រះចៅអធិរាជក្លូឌាស បានចេញបញ្ជាអោយជនជាតិយូដាទាំងអស់ចាកចេញពីក្រុងរ៉ូម។ លោកប៉ូលបានទៅជួបអ្នកទាំងពីរ[3]ហើយស្នាក់នៅ និងធ្វើការជាមួយគេ ព្រោះលោកមានមុខរបរដូចគ្នា គឺត្បាញក្រណាត់សសម្រាប់បោះជំរំ។
[4]ដូច្នេះ រៀងរាល់ថ្ងៃសប្ប័ទ លោកប៉ូលតែងតែមានប្រសាសន៍ក្នុងសាលាប្រជុំ។ លោកណែនាំទាំងសាសន៍យូដា ទាំងសាសន៍ក្រិកឲ្យជឿ។[5]កាលលោកស៊ីឡាស និងលោកធីម៉ូថេធ្វើដំណើរពីស្រុកម៉ាសេដូនមកដល់ហើយ លោកប៉ូលក៏ចំណាយពេលទាំងអស់របស់លោក ដើម្បីប្រកាសព្រះបន្ទូល។ លោកបានបញ្ជាក់ប្រាប់សាសន៍យូដាថា ព្រះយេស៊ូពិតជាព្រះគ្រិស្ត។[6]ពេលសាសន៍យូដាបានប្រឆាំង និងជេរប្រមាថលោក លោកក៏រលាស់ធូលីដីពីអាវរបស់លោកទាំងមានប្រសាសន៍ថា៖ «បើអ្នករាល់គ្នាវិនាសបាត់បង់នោះ គឺមកតែពីកំហុសរបស់អ្នករាល់គ្នាផ្ទាល់ប៉ុណ្ណោះ គ្មានជាប់ជំពាក់អ្វីជាមួយខ្ញុំទេ។ ចាប់ពីពេលនេះ ខ្ញុំនឹងទៅរកសាសន៍ដទៃវិញ»។
[7]ដូច្នេះ លោកក៏ចាកចេញពីទីនោះឆ្ពោះទៅផ្ទះបុរសម្នាក់ ឈ្មោះយូស្ទុសជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់។ ផ្ទះគាត់នៅជាប់នឹងសាលាប្រជុំ។[8]លោកគ្រីសប៉ុស ដែលជាអ្នកទទួលខុសត្រូវលើសាលាប្រជុំ និងក្រុមគ្រួសាររបស់លោកវិញ ក៏ជឿលើព្រះអម្ចាស់ដែរ។ មានអ្នកក្រុងកូរិនថូសជាច្រើនទៀត បានស្តាប់លោកប៉ូលហើយជឿ ព្រមទាំងទទួលពិធីជ្រមុជទឹកផងដែរ។
[9]យប់មួយ លោកប៉ូលនិមិត្តឃើញព្រះអម្ចាស់មានព្រះបន្ទូលមកលោកថា៖ «កុំខ្លាចអី! ត្រូវនិយាយតទៅទៀត កុំនៅស្ងៀមឡើយ។[10]ដ្បិតយើងស្ថិតនៅជាមួយអ្នកហើយ ពុំមាននរណាអាចធ្វើបាបអ្នកបានទេ ព្រោះនៅក្រុងនេះ មានមនុស្សជាច្រើនជាប្រជារាស្ត្ររបស់យើង»។[11]លោកប៉ូលស្នាក់នៅក្រុងកូរិនថូស អស់រយៈពេលមួយឆ្នាំប្រាំមួយខែ លោកបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់អ្នកក្រុងនោះ។
[12]នៅគ្រាដែលលោកកាលីយ៉ូកាន់តំណែងជារាជប្រតិភូរបស់ព្រះចៅអធិរាជរ៉ូម៉ាំងនៅស្រុកអាខៃ សាសន៍យូដាបានសមគំនិតគ្នាប្រឆាំងនឹងលោកប៉ូល ហើយនាំលោកយកទៅសាលាកាត់ក្តី[13]ទាំងចោទថា៖ «ជននេះបញ្ចុះបញ្ចូលមនុស្សម្នាឲ្យគោរពថ្វាយបង្គំព្រះជាម្ចាស់ តាមរបៀបមួយខុសច្បាប់»។
[14]ពេលលោកប៉ូលបម្រុងនឹងហាមាត់និយាយ លោកកាលីយ៉ូមានប្រសាសន៍ទៅកាន់ជនជាតិយូដាថា៖ «ជនជាតិយូដាអើយ ប្រសិនបើរឿងនេះទាក់ទងនឹងបទឧក្រិដ្ឋ ឬបទល្មើសណាមួយនោះ ខ្ញុំមុខជាសុខចិត្តស្តាប់អ្នករាល់គ្នាមិនខាន។[15]តែបើជារឿងជជែកវែកញែកស្តីអំពីពាក្យពេចន៍ អំពីឈ្មោះ ឬអំពីធម៌វិន័យរបស់អ្នករាល់គ្នាទេនោះ ចូរដោះស្រាយខ្លួនឯងទៅ។ ខ្ញុំមិនព្រមកាត់ក្តីឲ្យអ្នករាល់គ្នាអំពីរឿងនេះឡើយ»។
[16]លោកក៏ដេញពួកគេចេញពីសាលាកាត់ក្តី។[17]ពេលនោះ ពួកគេនាំគ្នាចាប់លោកសូស្ថែនជាអ្នកទទួលខុសត្រូវលើសាលាប្រជុំ មកវាយនៅមុខសាលាកាត់ក្តី តែលោកកាលីយ៉ូមិនអើពើទេ។
[18]បន្ទាប់ពីលោកប៉ូលបានស្នាក់នៅក្រុងកូរិនថូសជាយូរថ្ងៃក្រោយមក លោកក៏ជម្រាបលាពួកបងប្អូន រួចចុះសំពៅឆ្ពោះទៅស្រុកស៊ីរី ដោយមាននាងព្រីស៊ីល និងលោកអគីឡាជូនដំណើរទៅជាមួយដែរ។ លោកបានកោរសក់លាបំណន់មុនពេលលោកចាកចេញ នៅកំពង់ផែកេងគ្រា។[19]លុះមកដល់ក្រុងអេភេសូ លោកប៉ូលក៏ជម្រាបលានាងព្រីស៊ីល និងលោកអគីឡា។ លោកបានចូលទៅសាលាប្រជុំ ហើយសន្ទនាជាមួយសាសន៍យូដា។
[20]ពួកគេបានអង្វរសុំឲ្យលោកប៉ូលស្នាក់នៅទីនោះមួយរយៈទៀត តែលោកមិនព្រមទេ។[21]លោកជម្រាបលាគេទាំងពោលថា៖ «ប្រសិនបើព្រះជាម្ចាស់សព្វព្រះហឫទ័យ ខ្ញុំនឹងវិលមករកបងប្អូនវិញ» រួចលោកចុះសំពៅចេញពីក្រុងអេភេសូ។
[22]កាលធ្វើដំណើរមកដល់ក្រុងសេសារា លោកបានឡើងទៅសួរសុខទុក្ខក្រុមជំនុំយេរូសាឡឹម ហើយលោកបន្តដំណើរទៅដល់ក្រុងអន់ទីយ៉ូក។[23]ក្រោយពីបានស្នាក់នៅក្រុងអន់ទីយ៉ូកយូរបន្តិចមក លោកក៏ចេញដំណើរបន្តទៀត ដោយឆ្លងកាត់ស្រុកកាឡាទី និងស្រុកព្រីគា ហើយបានលើកទឹកចិត្តពួកសិស្សនៅទីនោះផង។
[24]ឥឡូវមានជនជាតិយូដាម្នាក់ ឈ្មោះអប៉ូឡូស មានកំណើតជាអ្នកស្រុកអលេក្សានទ្រា បានមកនៅក្រុងអេភេសូ។ គាត់ជាមនុស្សមានវោហារ ហើយស្គាល់គម្ពីរយ៉ាងល្អិតល្អន់។[25]គាត់បានទទួលការអប់រំអំពីមាគ៌ារបស់ព្រះអម្ចាស់។ គាត់ប្រកាសព្រះបន្ទូល ហើយប៉ិនប្រសប់បង្រៀនគេយ៉ាងច្បាស់លាស់ អំពីព្រះយេស៊ូដោយចិត្តឧស្សាហ៍មោះមុត ប៉ុន្តែគាត់ដឹងត្រឹមតែពិធីជ្រមុជទឹករបស់លោកយ៉ូហានប៉ុណ្ណោះ។[26]គាត់បានបង្រៀនគេក្នុងសាលាប្រជុំដោយចិត្តអង់អាច។ កាលនាងព្រីស៊ីល និងលោកអគីឡាបានឮគាត់បង្រៀនដូច្នេះ ក៏អញ្ជើញគាត់ទៅជាមួយ ព្រមទាំងពន្យល់គាត់ឲ្យរឹតតែស្គាល់មាគ៌ារបស់ព្រះជាម្ចាស់ថែមទៀត។
[27]ដោយលោកអប៉ូឡូសមានបំណងធ្វើដំណើរទៅកាន់ស្រុកអាខៃ ពួកបងប្អូនក៏នាំគ្នាលើកទឹកចិត្តគាត់អោយទៅ ថែមទាំងសរសេរសំបុត្រទៅជំរាបពួកសិស្សនៅស្រុកនោះអោយទទួលស្វាគមន៍គាត់ផង។ លុះទៅដល់ គាត់បានខ្នះខ្នែងជួយអស់អ្នកនៅទីនោះដែលបានទទួលជឿ ដោយសារព្រះគុណរបស់ព្រះជាម្ចាស់។[28]ដ្បិតគាត់ចេះផ្ដាច់សាសន៍យូដានៅមុខប្រជុំជនទាំងអស់ និងវែកញែកគម្ពីរ បញ្ជាក់ប្រាប់គេថា ព្រះយេស៊ូពិតជាព្រះគ្រិស្តមែន។

Acts 18:1
ប្រយោគភ្ជាប់
នេះគឺជាផ្នែកផ្សេងទៀតរបស់សាច់រឿងដំណើររបស់លោកប៉ូល
ពេលគាត់ទៅក្រុងកូរិសថូស។
ព័ត៌មានទូទៅ
លោកអគីឡា និងនាងព្រីស៊ីល ត្រូវបានណែនាំមកក្នុងសាច់រឿងនេះ នៅក្នុងខ ២ និងខ៣ បានប្រាប់ពីប្រវត្តិអំពីពួកគេ។
បន្ទាប់ពីការទាំងនេះមក
«បន្ទាប់ពីព្រឹត្តការណ៍ការទាំងនេះបានកើតឡើងនៅក្រុងអាថែន»
ក្រុងអាថែន
ក្រុងអាថែនជាទីក្រុងមួយដ៏សំខាន់របស់ប្រទេសក្រិក។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ជំពូក ១៧:១៣។
នៅទីនោះ លោកបានជួប
អាចមានន័យពីរយ៉ាង ទី១) លោកប៉ូលបានជួបដោយចៃដន្យ ឬទី២) លោកប៉ូលបានជួបដោយការតាំងចិត្ត។
ជនជាតិយូដាម្នាក់ ឈ្មោះអគីឡា
«បុរសម្នាក់» នៅទីនេះ បង្ហាញពីការណែនាំមនុស្សថ្មីនៅក្នុងសាច់រឿង។
ជាអ្នកស្រុកប៉ុនតុស
ស្រុកប៉ុនតុសជាខេត្តមួយនៅភាគខាងត្បូងឈូងសមុទ្រខ្មៅ។
លោកទើបតែមក
នេះប្រហែលជាទើបនឹងមកកាលពីឆ្នាំមុន។
អ៊ីតាលី
នេះគឺជាឈ្មោះរបស់ប្រទេស។ រ៉ូមជាទីក្រុងរបស់ប្រទេសអ៊ីតាលី។
ព្រះចៅក្លូឌាស បានចេញបញ្ជា
នៅពេលនេះ ព្រះចៅក្លូឌាស ជាព្រះចៅអធិរាជរបស់រ៉ូម។
សូមមើលពីរបៀបដែលអ្នកបកប្រែក្នុងជំពូក ១១:២៧។
លោកប្រកបរបរដូចគ្នា
«លោកធ្វើការដូចពួកគេធ្វើដែរ»
Acts 18:4
ព័ត៌មានទូទៅ
លោកស៊ីឡាស និងលោកធីម៉ូថេ បានមកចូលរួមជាមួយលោកប៉ូលជាថ្មី។
ដូច្នេះ លោកប៉ូលបានជជែកតវ៉ា
«ដូច្នេះ លោកប៉ូលបានជជែកវែកញែក» ឬ «ដូច្នេះ លោកប៉ូលបានពិភាក្សា»។ លោកបានឲ្យហេតុផល។ នេះមានន័យថា មិនគ្រាន់តែបង្រៀនប៉ុណ្ណោះទេ លោកប៉ូលបាននិយាយ ហើយឆ្លើយឆ្លងជាមួយនឹងប្រជាជនដែរ។
លោកបញ្ចុះបញ្ចូលទាំងជនជាតិយូដា និងជនជាតិក្រិកឲ្យជឿ
អាចមានន័យពីរ ទី១) លោកធ្វើឲ្យទាំងសាសន៍យូដា និងសាសន៍ក្រិកជឿ» ឬទី២) «លោកបានព្យាយាមបញ្ចុះបញ្ចូលសាសន៍យូដា និងសាសន៍ក្រិក»។

generated on Wed Sep 10 16:16:32 2025

ព្រះវិញ្ញាណបានជំរុញលោកប៉ូល
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «
លោកប៉ូលត្រូវបានជំរុញដោយព្រះវិញ្ញាណ» (សូមមើល: |Active ឬ Passive)
លោកប៉ូលបានរលាស់អាវរបស់លោក
នេះគឺជានិមិត្តរូបនៃការបញ្ជាក់ថាលោកប៉ូលលែងព្យាយាមបង្រៀនដល់សាសន៍យូដានៅទីនោះទៀតហើយ។
លោកបានប្រគល់ពួកគេឲ្យព្រះជាម្ចាស់ជំនុំជម្រះពួកគេចុះ»។
សូមឲ្យឈាមរបស់អ្នករាល់គ្នាបានធ្លាក់នៅលើក្បាលរបស់អ្នករាល់គ្នាចុះ
ពាក្យ «ឈាម» នៅទីនេះ តំណាងឲ្យកំហុសនៃការប្រព្រឹត្តរបស់ពួកគេ។ ពាក្យ
«ក្បាល» នៅទីនេះសំដៅលើមនុស្សទាំងស្រុង។ លោកប៉ូលប្រាប់ជនជាតិយូដាថា
ពួកគេនឹងប្រឈមនឹងភាពរឹងរូសរបស់ពួកគេ ប្រសិនបើពួកគេមិនព្រមប្រែចិត្ត។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នករាល់គ្នានឹងទទួលខុសត្រូវដោយខ្លួនឯង
ពេលអ្នកត្រូវបានដាក់ទោសដោយសារបាបរបស់អ្នករាល់គ្នា»។
Acts 18:7
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «លោក» ទីមួយ សំដៅលើលោកទីទិយុសយូស្ទុស។ ហើយលោកទីពីរ
សំដៅលើលោកគ្រីសប៉ុស ុ។
លោកទីទិយុសយូស្ទុស...លោកគ្រីសប៉ុស
នេះគឺជាឈ្មោះរបស់មនុស្សប្រុស។ (សូមមើល: |How to Translate
Names)
អ្នកគោរពកោតខ្លាចព្រះជាម្ចាស់
អ្នកថ្វាយបង្គំព្រះជាម្ចាស់គឺជាសាសន៍ដទៃម្នាក់
ដែលបានថ្វាយការសរសើរដល់ព្រះជាម្ចាស់ និងដើរតាមព្រះអង្គ ប៉ុន្តែ
មិនចំបាច់ត្រូវធ្វើតាមក្រឹត្យវិន័យគ្រប់យ៉ាងរបស់ជនជាតិយូដាឡើយ។
អ្នកដឹកនាំនៅក្នុងសាលាប្រជុំ
ជាឧបាសកដែលគាំទ្រ និងជាអ្នកគ្រប់គ្រងនៅក្នុងសាលាប្រជុំ
មិនចាំបាច់ត្រូវបង្រៀនទេ។
នៅក្នុងផ្ទះរបស់គាត់ទាំងអស់គ្នា
ពាក្យ «ផ្ទះ» សំដៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សដែលរស់នៅក្នុងផ្ទះជាមួយគាត់»
បានជ្រមុជទឹក
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានទទួលវិធីជ្រមុជទឹក»
Acts 18:9
កុំខ្លាចអី! ប៉ុន្តែ ចូរប្រកាស ហើយមិនត្រូវនៅស្ងៀមឡើយ
ព្រះអម្ចាស់បានប្រទានសេចក្តីបង្គាប់មួយតាមរបៀបពីរយ៉ាង ដើម្បីបញ្ជាក់ថា
លោកប៉ូលត្រូវបន្តប្រកាស។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនត្រូវភ័យខ្លាចឡើយ ផ្ទុយទៅវិញ អ្នកត្រូវបន្តនិយាយ
ហើយមិនត្រូវស្ងាត់ឡើយ» (សូមមើល: |Parallelism)
ចូរប្រកាស ហើយមិនត្រូវនៅស្ងៀមឡើយ
ព្រះអម្ចាស់បានប្រទានសេចក្តីបង្គាប់មួយតាមរបៀបពីរយ៉ាង
ដើម្បីបង្គាប់យ៉ាងខ្លាំងដល់លោកប៉ូលឲ្យនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកត្រូវបន្តនិយាយ ហើយមិនត្រូវស្ងាត់ឡើយ» (សូមមើល: |Doublet)
ហើយមិនត្រូវនៅស្ងៀមឡើយ
ឃ្លានេះអាចនិយាយបញ្ជាក់នូវអ្វីដែលព្រះអម្ចាស់ចង់ឲ្យលោកប៉ូលនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «និងមិនត្រូវឈប់ក្នុងការប្រកាសដំណឹងល្អឡើយ»
ដ្បិតយើងមានមនុស្សជាច្រើននៅក្នុងទីក្រុងនេះ
«មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះ ដែលបានដាក់ជំនឿរបស់ពួកគេលើខ្ញុំ» ឬ
«មានមនុស្សជាច្រើននៅក្នុងទីក្រុងនេះ នឹងដាក់ជំនឿរបស់ពួកគេលើខ្ញុំ»
លោកប៉ូលរស់នៅទីនោះ...បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងចំណោមពួកគេ
ឃ្លានេះ រួមបញ្ចូលទាំងប្រសាសន៍ដែលមាននៅក្នុងសាច់រឿងនេះផងដែរ។
Acts 18:12
ប្រយោគភ្ជាប់
សាសន៍យូដាដែលមិនជឿបាននាំលោកប៉ូលទៅកន្លែងកាត់ក្តីនៅចំពោះ លោក
កាលីយ៉ូ។
ព័ត៌មានទូទៅ
ស្រុកអាខៃ ជាខេត្តរបស់រ៉ូម ដែលមានទីតាំងនៅក្នុងក្រុងកូរិនថូស។
ជាទីក្រុងដ៏ធំបំផុតនៅក្នុងភាគខាងត្បូងនៃប្រទេសក្រិក
និងជាទីក្រុងរបស់ខេត្តនោះ។ (សូមមើល: |How to Translate Names)
លោកកាលីយ៉ូ
នេះគឺជាឈ្មោះរបស់បុរសម្នាក់។
ជនជាតិយូដា
នៅទីនោះនាំគ្នាមកឈរនៅមុខតុលាការ ដើម្បីចាប់យកប៉ូលនិងនាំគាត់ទៅសាលាក្តីសាសន៍យូដា ដែលមិនបានជឿលើព្រះយេស៊ូ។
បានរួមគ្នាប្រឆាំង
«បានមករួមគ្នា» ឬ «បានចូលរួមជាមួយគ្នា»
នាំលោកយកទៅកន្លែងកាត់ក្តី
ជនជាតិយូដាបាននាំលោកប៉ូលដោយប្រើកម្លាំង យកលោកប៉ូលមកកាត់ក្តី។ ពាក្យ
«កន្លែងកាត់ក្តី» នៅទីនេះ សំដៅលើកន្លែងដែលលោកកាលីយ៉ូអង្គុយ
ពេលលោកសម្រេចក្តីនៅក្នុងតុលាការ។ របៀបផ្សេងទៀតនៃការបកប្រែ: «នាំលោក
ដើម្បីឲ្យមន្ត្រីអាចជំនុំជម្រះលោក នៅកន្លែងកាត់ក្តី»។
Acts 18:14
លោកកាលីយ៉ូបានមានប្រសាសន៍
លោកកាលីយ៉ូជាអភិបាលខេត្តរ៉ូម។
បញ្ញត្តិរបស់អ្នកផ្ទាល់
ពាក្យ «បញ្ញត្តិ» សំដៅលើច្បាប់របស់លោកម៉ូសេ
និងទំនៀមទម្លាប់របស់សាសន៍យូដានៅសម័យរបស់ប៉ូល។
ខ្ញុំមិនកាត់ក្តីឲ្យអ្នករាល់គ្នាអំពីរឿងទាំងនេះទេ
«ខ្ញុំបដិសេធមិនជំនុំជម្រះបញ្ហានេះទេ»។
Acts 18:16
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើសាសន៍ដទៃនៅក្នុងតុលាការ។
ពួកគេបានប្រព្រឹត្តទាស់នឹងជនជាតិយូដាដែលបាននាំលោកប៉ូលមកកន្លែងជំនុំជម្រះ។
(សូមមើល: ១៨:១២)
លោកកាលីយ៉ូបានឲ្យពួកគេចេញពីកន្លែងកាត់ក្តី
«លោកកាលីយ៉ូបានឲ្យពួកគេចេញពីកន្លែងកាត់ក្តី»។ ពាក្យ «កន្លែងកាត់ក្តី»
សំដៅលើកន្លែងដែលលោកកាលីយ៉ូអង្គុយសម្រេចក្តីនៅក្នុងតុលាការ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកកាលីយ៉ូបានធ្វើឲ្យពួកគេចេញពីវត្តមាននៅក្នុងតុលាការ» ឬ
«លោកកាលីយ៉ូបានធ្វើឲ្យពួកគេចេញពីតុលាការ»
ពួកគេទាំងអស់គ្នាបានចាប់
ឃ្លានេះអាចនិយាយបំផ្លើស ដើម្បីបញ្ជាក់ពីអារម្មណ៍ដ៏ខ្លាំងដែលមនុស្សមាន។
របៀបផ្សេងទៀតនៃការបកប្រែ: «មានមនុស្សជាច្រើនបានចាប់» ឬ
«មានពួកគេជាច្រើនបានចាប់» (សូមមើល: |Hyperbole)
ដូច្នេះ ពួកគេទាំងអស់គ្នាបានចាប់លោកសូស្ថែន ជាអ្នកដឹកនាំនៅក្នុងសាលាប្រជុំ ហើយបានមក
វាយគាត់នៅមុខកន្លែងកាត់ក្តី
អាចមានន័យពីរ ទី១) សាសន៍ដទៃបានវាយលោកសូស្ថែននៅក្នុងតុលាការ
នៅកន្លែងកាត់ក្តី ព្រោះលោកជាអ្នកដឹកនាំសាសន៍យូដា ឬ ទី២)
អាចទៅរួចដែលលោកសូស្ថែនជាអ្នកជឿលើព្រះគ្រិស្ត ដូច្នេះ
ជនជាតិយូដាវាយគាត់នៅចំពោះមុខតុលាការ។
លោកសូស្ថែន ជាអ្នកដឹកនាំនៅក្នុងសាលាប្រជុំ
«លោកសូស្ថែន» ជាអ្នកគ្រប់គ្រងលើសាលាប្រជុំនៅក្នុងក្រុងកូរិនថូស។
(សូមមើល: |How to Translate Names)
វាយគាត់
«វាយគាត់ជាច្រើនរំពាត់» ឬ «វាយជាច្រើនដៃ»
Acts 18:18
ប្រយោគភ្ជាប់
នេះជាដំណើរបេសកកម្មរបស់លោកប៉ូល នៅពេលលោកប៉ូល និងនាងព្រីស៊ីល និង
លោកអគីឡាចាកចេញពីក្រុងកូរិនថូស។ នៅទីនេះ ហាក់បីដូចជាបង្ហាញថា
លោកស៊ីឡាស និងធីម៉ូថេនៅក្នុងក្រុងកូរិនថូសដដែល ព្រោះបាននិយាយថា
«លោក» នៅទីនេះ មិនមែនជា «យើង» ទេ។
ព័ត៌មានទូទៅ
កេងគ្រាជាកំពង់ផែដែលជាចំណែកមួយនៅក្នុងទីក្រុងដ៏ធំនេះ
នៅក្នុងតំបន់ក្រុងកូរិនថូស។ (សូមមើល: |How to Translate Names)
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកប៉ូល។
ប្រយោគភ្ជាប់
ពាក្យ «ពួកគេ» សំដៅលើលោកប៉ូល នាងព្រីស៊ីល និងលោកអគីឡា ុ។

generated on Wed Sep 10 16:16:32 2025

បានចាកចេញបងប្អូន
ពាក្យ «បងប្អូន» សំដៅលើមនុស្សប្រុស និងស្រីដែលជាអ្នកជឿ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានចាកចេញពីបងប្អូនអ្នកជឿ»
ចុះសំពៅទៅស្រុកស៊ីរី ដោយមាននាងព្រីស៊ីល និងលោកអគីឡា
លោកប៉ូលបានឡើងសំពៅនោះ ហើយធ្វើដំណើរទៅស្រុកស៊ីរី។ នាងព្រីស៊ីល និងលោកអគីឡាបានធ្វើដំណើរជាមួយគាត់ដែរ។
លោកបានកោរសក់របស់លោក
នេះគឺជានិមិត្តរូបដែលបង្ហាញពីការបំពេញតាមសម្បថ។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានរកគេកោរសក់នៅលើក្បាលរបស់លោក»
បានជជែកវែកញែក
«ពិភាក្សាជាមួយ» ឬ «បានតវ៉ាជាមួយ»
Acts 18:20
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើជនជាតិយូដានៅអេភេសូរ។
ចេញពីពួកគេ
«និយាយពាក្យជម្រាបលាទៅកាន់ពួកគេ»
Acts 18:22
ប្រយោគភ្ជាប់
លោកប៉ូលបន្តដំណើរបេសកកម្មរបស់លោក។
ព័ត៌មានទូទៅ
ស្រុកព្រីគាគឺជាខេត្តមួយនៅអាស៊ីដែលឥឡូវនេះជាប្រទេសទួរគី។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២:៨។
ទៅដល់ក្រុងសេសារ
«បានមកដល់ក្រុងសេសារា» ពាក្យ «មកដល់» ប្រើដើម្បីបង្ហាញថា
លោកបានមកដល់ដោយសារសំពៅ។
លោកបានឡើងទៅ
លោកបានធ្វើដំណើរទៅទីក្រុងយេរូសាឡិម។ ឃ្លា «ឡើងទៅ» ដែលប្រើនៅទីនេះ
គឺដោយសារទីក្រុងយេរូសាឡិមមានកម្ពស់ខ្ពស់ជាងក្រុងសេសារា។
សួរសុខទុក្ខក្រុមជំនុំនៅយេរូសាឡិម
ពាក្យ «ក្រុមជំនុំ» នៅទីនេះ សំដៅលើអ្នកជឿនៅក្នុងក្រុងយេរូសាឡិម»
របៀបផ្សេងទៀតនៃការបកប្រែ: «សួរសុខទុក្ខសមាជិកក្រុមជំនុំក្រុងយេរូសាឡិម»
បន្ទាប់មក ចុះទៅ
ឃ្លា «ចុះទៅ» ប្រើនៅទីនេះ
ដោយសារក្រុងអន់ទីយ៉ូកមានកម្ពស់ទាបជាងក្រុងយេរូសាឡិម។
លោកប៉ូលបានចេញដំណើរ
«លោកប៉ូលបានចេញទៅ» ឬ «លោកប៉ូលបានចាកចេញ»
បន្ទាប់ពីបានស្នាក់នៅទីនោះមួយរយៈមក
ឃ្លានេះនិយាយពី «ពេលវេលា» ប៉ៅដូចជាមនុស្សម្នាក់ដែលចំណាយពេល។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពី ស្នាក់នៅទីនោះមួយរយៈ»
Acts 18:24
ប្រយោគភ្ជាប់
លោកលូកាប្រាប់អ្វីដែលបានកើតឡើងនៅក្នុងអេភេសូរ ជាមួយនាងព្រីស៊ីល និងលោកអគីឡា។
ព័ត៌មានទូទៅ
លោកអប៉ូឡូស ត្រូវបានណែនាំមកក្នុងសាច់រឿងនេះ។ ខ ២៤ និង ២៥
ប្រាប់ពីប្រវត្តិគាត់។
ឥឡូវនេះ
ពាក្យនេះ ប្រើនៅទីនេះដើម្បីសម្គាល់ការសម្រាកនៅក្នុងសាច់រឿងធំ។
មានជនជាតិយូដាម្នាក់ ឈ្មោះអប៉ូឡូស
ឃ្លា «បុរសម្នាក់» នេះ បញ្ជាក់ថា
លោកលូកាកំពុងណែនាំមនុស្សថ្មីចូលមកក្នុងសាច់រឿង។
មានកំណើតជាអ្នកស្រុកអលេក្សានទ្រា
«ជាអ្នកស្រុកអលេក្សានទ្រា» អាចមានន័យពីរ ទី១)
អលេក្សានទ្រានៅក្នុងស្រុកអេស៊ីប នៅភាគខាងជើងនៃឈូងសមុទ្ររបស់អាហ្វិក។
ឬទី២) អលេក្សានទ្រា ស្ថិតនៅភាគខាលិចនៃឈូងសមុទ្រអាស៊ី។
គាត់ជាមនុស្សមានវោហារ
«ពូកែនិយាយ»
ហើយស្គាល់បទគម្ពីរយ៉ាងល្អិតល្អន់
«ហើយស្គាល់បទគម្ពីរយ៉ាងពិស្តារ»
លោកយល់សេចក្តីដែលសរសេរនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់យ៉ាងល្អ។
លោកអប៉ូឡូសបានទទួលការអប់រំអំពីសេចក្តីបង្រៀនរបស់ព្រះអម្ចាស់
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជឿផ្សេងទៀតបានបង្រៀនលោកអប៉ូឡូសពីរបៀបដែលព្រះជាម្ចាស់ចង់ឲ្យមនុស្សរស់នៅ»
មានចិត្តភ្លៀវក្លាខាងវិញ្ញាណ
ពាក្យ «វិញ្ញាណ» នៅទីនេះសំដៅលើជីវិតរបស់លោកអប៉ូឡូសទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «មានចិត្តភ្លៀវក្លាជាខ្លាំង»
ពិធីជ្រមុជទឹករបស់លោកយ៉ូហាន
«ជាពិធីជ្រមុជដែលលោកយ៉ូហានបានធ្វើ»។
នេះគឺជាការប្រៀបធៀបពិធីជ្រមុជរបស់លោកយ៉ូហាន ដែលជ្រមុជដោយទឹក
ដល់ព្រះយេស៊ូ ជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ។
ស្គាល់ផ្លូវរបស់ព្រះជាម្ចាស់
ពីរបៀបដែលព្រះជាម្ចាស់ចង់ឲ្យមនុស្សរស់នៅ
គឺប្រៀបដូចជាផ្លូវរបស់មនុស្សដើរដែរ។
រឹតតែស្គាល់ច្បាស់ថែមទៀត
«ត្រឹមត្រូវ» ឬ «ពេញលេញ»
Acts 18:27
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកអប៉ូឡូស។ (សូមមើល: ១៨:២៤)
ព័ត៌មានទូទៅ
ស្រុកអាខៃជាខេត្តរបស់រ៉ូមនៅភាគខាងត្បូងរបស់ក្រិក។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ១៨:១២។
ធ្វើដំណើរទៅកាន់ស្រុកអាខៃ
«ធ្វើដំណើរទៅកាន់តំបន់អាខៃ» ឃ្លា «ឆ្លងកាត់» ប្រើនៅទីនេះ
ដោយសារលោកអប៉ូឡូសត្រូវឆ្លងកាត់សមុទ្រប៉ាត់ម៉ុសដើម្បីចូលទៅស្រុកអាខៃ
ដោយចេញពីក្រុងអេភេសូរ។
ពួកបងប្អូន
ពាក្យ «ពួកបងប្អូន» នៅទីនេះ សំដៅលើប្រុស និងស្រីដែលជាអ្នកជឿ។
អ្នកអាចធ្វើឲ្យវាច្បាស់គឺថាពួកគេជាពួកអ្នកជឿនៅក្នុងក្រុងអេភេសូរ។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនអ្នកជឿនៅក្នុងអេភេសូរ»
បានសរសេរសំបុត្រផ្ញើទៅពួកសិស្ស
«បានសរសេរសំបុត្រផ្ញើទៅកាន់គ្រិស្តបរិស័ទនៅស្រុកអាខៃ»
អ្នកដែលបានជឿ ដោយសារព្រះគុណ
«អ្នកដែលបានជឿនៅលើសេចក្តីសង្គ្រោះ ដោយសារព្រះគុណ» ឬ
«អស់អ្នកដែលដោយសារព្រះគុណរបស់ព្រះជាម្ចាស់
ពួកគេបានជឿលើព្រះយេស៊ូ»។
លោកអប៉ូឡូសឆ្លើយបដិសេធជនជាតិយូដានៅតាមទីសាធារណៈ
លោកអប៉ូឡូសបានឆ្លើយការពារជនជាតិយូដា
នៅចំពោះមុខមនុស្សដែលឈ្លោះជាមួយលោក។
ដោយអំណាច និងជំនាញរបស់លោក
«ជាមួយនឹងកម្លាំងនៃការតវ៉ា និងជំនាញរបស់គាត់ក្នុងនាមជាវាគ្មិន»។

---

19 [1]ពេលដែលលោកអប៉ូឡូសនៅក្រុងកូរិនថូស លោកប៉ូលបានឆ្លងកាត់តំបន់ខ្ពង់រាប ហើយធ្វើដំណើរមកដល់ក្រុងអេភេសូ លោកបានជួបសិស្សខ្លះ[2]ហើយសួរថា៖
«កាលបងប្អូនចាប់ផ្តើមជឿនោះ តើបងប្អូនទទួលព្រះវិញ្ញាណដ៏វិសុទ្ធហើយឬនៅ?»។ គេតបមកលោកវិញថា៖ «យើងខ្ញុំមិនដែលទាំងឮថា មានព្រះវិញ្ញាណដ៏វិសុទ្ធផង»។
[3]លោកប៉ូលសួរគេទៀតថា៖ «ដូច្នេះ តើបងប្អូនបានទទួលពិធីជ្រមុជទឹកណា?»។ គេតបថា៖ «ពិធីជ្រមុជទឹករបស់លោកយ៉ូហាន»។[4]លោកប៉ូលក៏មានប្រសាសន៍ថា៖
«លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកឲ្យអស់អ្នកដែលកែប្រែចិត្តគំនិត ទាំងមានប្រសាសន៍ប្រាប់ប្រជាជនឲ្យជឿលើព្រះអង្គ ដែលយាងមកក្រោយលោក គឺព្រះយេស៊ូនេះហើយ»។

generated on Wed Sep 10 16:16:32 2025

[5]ក្រោយបានឮលោកប៉ូលមានប្រសាសន៍ដូច្នោះ ពួកសិស្សក៏ទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ។[6]លោកប៉ូលបានដាក់ដៃលើគេ ព្រះវិញ្ញាណដ៏វិសុទ្ធក៏យាងមកសណ្ឋិតលើគេ ហើយគេនាំគ្នានិយាយភាសាចំឡែកអស្ចារ្យ និងថ្លែងព្រះបន្ទូលផង។[7]អ្នកទាំងនោះមានគ្នាទាំងអស់ប្រមាណដប់ពីរនាក់។
[8]លោកប៉ូលបានចូលទៅសាលាប្រជុំ ហើយមានប្រសាសន៍ដោយចិត្តអង់អាចអស់ពេលបីខែ ទាំងសន្ទនាជាមួយពួកគេ និងខិតខំណែនាំពួកគេឲ្យជឿលើព្រះរាជ្យរបស់ព្រះជាម្ចាស់។[9]ប៉ុន្តែ ដោយសាសន៍យូដាខ្លះនៅតែមានចិត្តមានះមិនព្រមជឿ ថែមទាំងប្រមាថមាគ៌ារបស់ព្រះអម្ចាស់នៅមុខប្រជុំជនផង។ ដូច្នេះលោកប៉ូលក៏ចាកចេញពីពួកគេ រួចនាំសិស្សទៅដាច់ឡែក ហើយបង្រៀនគេជារៀងរាល់ថ្ងៃនៅក្នុងសាលាទីរ៉ាណុស។[10]លោកបានបង្រៀនគេអស់ពេលពីរឆ្នាំ គឺរហូតទាល់តែអ្នកស្រុកអាស៊ីទាំងអស់ ទាំងសាសន៍យូដា ទាំងសាសន៍ក្រិក បានឮព្រះបន្ទូលរបស់ព្រះអម្ចាស់។
[11]ព្រះជាម្ចាស់បានធ្វើការអស្ចារ្យដ៏ធំៗជាច្រើនតាមរយៈលោកប៉ូល[12]ហើយសូម្បីតែគេយកក្រណាត់ ឬកន្សែងដែលបានប៉ះលោកប៉ូលមកដាក់ពីលើអ្នកជំងឺ អ្នកជំងឺនឹងបានជា ហើយវិញ្ញាណអាក្រក់ក៏នឹងចេញពីគេទៅដែរ។
[13]មានគ្រូដេញវិញ្ញាណអាក្រក់ជាតិយូដាខ្លះ តែងធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ។ ពួកគេចង់ដេញវិញ្ញាណអាក្រក់ចេញពីមនុស្សដោយប្រើព្រះនាមព្រះអម្ចាស់យេស៊ូ គឺគេនិយាយទៅវិញ្ញាណអាក្រក់ថា៖ «យើងបញ្ជាពួកឯង ក្នុងព្រះនាមព្រះយេស៊ូដែលលោកប៉ូលប្រកាស ចូរចេញទៅ»។[14]កូនប្រុសទាំងប្រាំពីររបស់លោកស្កេវ៉ាដែលជានាយកបូជាចារ្យរបស់សាសន៍យូដា ក៏បានធ្វើដូច្នេះដែរ។
[15]វិញ្ញាណអាក្រក់បានតបមកអ្នកទាំងនោះវិញថា៖ «យើងស្គាល់ព្រះយេស៊ូ ហើយក៏ស្គាល់លោកប៉ូលដែរ ចុះឯងរាល់គ្នាវិញជានរណា?»។[16]អ្នកដែលមានវិញ្ញាណអាក្រក់ចូលបានស្ទុះមកសង្កត់ពួកគេជាប់ ហើយវិញ្ញាណអាក្រក់មានកម្លាំងជាង រហូតទាល់តែធ្វើឲ្យអ្នកទាំងនោះរត់ចេញពីផ្ទះ របួតខោ របួតអាវ និងត្រូវរបួសទៀតផង។
[17]មនុស្សម្នានៅក្រុងអេភេសូ ទាំងសាសន៍យូដា ទាំងសាសន៍ក្រិក បានដឹងរឿងនេះ ហើយខ្លាចគ្រប់ៗគ្នា ដូច្នេះគេនាំគ្នាលើកតម្កើងព្រះនាមព្រះអម្ចាស់យេស៊ូ។
[18]មានអ្នកជឿជាច្រើននាក់ បាននាំគ្នាមកទទួលសារភាពជាសាធារណៈនូវអំពើដែលខ្លួនធ្លាប់ប្រព្រឹត្ត។[19]អស់អ្នកដែលធ្លាប់ប្រព្រឹត្តអំពើអាបធ្មប់ ក៏បានយកក្បួនតម្រារបស់ខ្លួនមកដុតចោល នៅមុខគេឯងទាំងអស់គ្នាផង។ គេបានគិតគូររបស់ទាំងនោះ ឃើញថាមានតម្លៃប្រាំម៉ឺនដួង។[20]ដូច្នេះព្រះបន្ទូលរីកចំរើន និងមានប្រសិទ្ធភាពកាន់តែខ្លាំងឡើងៗ។
[21]ក្រោយលោកប៉ូលបានបំពេញព័ន្ធកិច្ចរបស់លោកហើយ ព្រះវិញ្ញាណណែនាំលោកប៉ូលឲ្យសំរេចចិត្តទៅក្រុងយេរូសាឡឹម ដោយធ្វើដំណើរឆ្លងកាត់ស្រុកម៉ាសេដូន និងស្រុកអាខៃ។ លោកមានប្រសាសន៍ថា៖ «កាលណាទៅដល់ស្រុកនោះខ្ញុំត្រូវតែទៅក្រុងរ៉ូមទៀត»។[22]លោកបានចាត់សហការីរបស់លោកពីររូប គឺលោកធីម៉ូថេ និងលោកអេរ៉ាស្ទុសឲ្យទៅស្រុកម៉ាសេដូនមុន។ ប៉ុន្តែលោកស្នាក់នៅក្នុងស្រុកអាស៊ីមួយរយៈពេលសិន។
[23]នៅគ្រានោះ មានកើតការបះបោរមួយយ៉ាងខ្លាំងព្រោះតែមាគ៌ារបស់ព្រះអម្ចាស់។[24]មានជាងចម្លាក់ម្នាក់ឈ្មោះដេមេទ្រាស ដែលបានធ្វើរូបវិហាររបស់ព្រះនាងឌីអានពីប្រាក់ ហើយគាត់បានផ្តល់កំរៃជាច្រើនដល់ពួកកូនជាង។[25]គាត់បានប្រមូលកូនជាងរបស់គាត់ និងអស់អ្នកដែលមានមុខជំនួញដូចគ្នាមក រួចពោលថា៖ «បងប្អូនអើយ បងប្អូនជ្រាបស្រាប់ហើយថា យើងបានរកកំរៃបានច្រើនក៏ដោយសារតែមុខជំនួញនេះ។
[26]បងប្អូនក៏បានឃើញបានឮដែរថា ឈ្មោះប៉ូលនោះបញ្ចុះបញ្ចូលនាំមហាជនឲ្យទៅតាមគាត់ មិនត្រឹមតែនៅក្រុងអេភេសូនេះប៉ុណ្ណោះទេ គឺសឹងតែពេញស្រុកអាស៊ីទាំងមូលថែមទៀតផង។ លោកពោលថា រូបព្រះដែលធ្វើដោយដៃមនុស្ស មិនមែនជាព្រះឡើយ។[27]វាមិនត្រឹមតែជាគ្រោះថ្នាក់នោះទេ
តែវានឹងធ្វើឲ្យមុខជំនួញរបស់យើងគ្មានគេត្រូវការ ថែមទាំងធ្វើឲ្យព្រះវិហារនៃព្រះនាងឌីអាន គ្មានតម្លៃទៀតទេ។ បន្ទាប់មក កិត្តិនាមរបស់ព្រះនាងដែលអ្នកស្រុកអាស៊ី និងសកលលោកទាំងមូលធ្លាប់ថ្វាយបង្គំ មុខជាអន់ថយទៀត»។
[28]កាលបានឮពាក្យនេះហើយ គេខឹងយ៉ាងខ្លាំង ក៏នាំគ្នាស្រែកឡើងថា៖ «ព្រះនាងឌីអានជាព្រះរបស់អ្នកក្រុងអេភេសូ ទ្រង់ប្រសើរឧត្តម!»។[29]ទីក្រុងទាំងមូលកើតវឹកវរ ហើយគេនាំគ្នាស្រូតដើរតម្រង់ទៅលានមហោស្រព។ ពួកគេអូសទាញអ្នកមកជាមួយលោកប៉ូល គឺលោកកៃយុស និងលោកអើរីស្តាកជាអ្នកស្រុក
ម៉ាសេដូនឲ្យទៅជាមួយដែរ។
[30]លោកប៉ូលមានបំណងទៅជួបប្រជាជន ប៉ុន្តែពួកសិស្សបានឃាត់លោកមិនឲ្យទៅ។[31]សូម្បីតែមន្ត្រីក្រុងខ្លះដែលជាមិត្តភក្តិរបស់លោក ក៏បានចាត់គេឲ្យទៅជម្រាបលោកមិនឲ្យទៅលានមហោស្រពដែរ។[32]អ្នកខ្លះស្រែកយ៉ាងនេះ អ្នកខ្លះស្រែកយ៉ាងនោះ ដ្បិតមានកើតច្របូកច្របល់ពេញអង្គប្រជុំទាំងមូល ហើយមានអ្នកខ្លះមិនដឹងថា គេមកប្រជុំគ្នារឿងអ្វីផង។
[33]ពេលនោះ ជនជាតិយូដាបានរុញបុរសម្នាក់ ឈ្មោះអលេក្សានត្រុសឲ្យចេញពីក្នុងចំណោមបណ្តាជន ឡើងទៅឈរនៅខាងមុខ។ អលេក្សានត្រុសក៏លើកដៃធ្វើសញ្ញាព្រោះគាត់ចង់ឆ្លើយនៅមុខប្រជាជន។[34]ប៉ុន្តែកាលប្រជាជនឃើញថា គាត់ជាជនជាតិយូដា គេក៏ស្រែកឡើងដោយសម្លេងតែមួយព្រមគ្នាអស់រយៈពេលជិតពីរម៉ោងថា៖ «ព្រះនាងឌីអានជាព្រះរបស់អ្នកក្រុងអេភេសូ ទ្រង់ប្រសើរឧត្តម!»។
[35]នៅពេលលោកលេខាធិការក្រុងបានឃាត់បណ្តាជន ឲ្យនៅស្ងៀមដោយពោលថា៖ «បងប្អូនជាអ្នកក្រុងអេភេសូអើយ! តើនរណាមិនដឹងថា ក្រុងអេភេសូជាក្រុងរបស់ព្រះនាងឌីអានជាព្រះដ៏ប្រសើរឧត្តម និងជាក្រុងដែលមានរូបសំណាក់ធ្លាក់ចុះពីស្ថានសួគ៌មកនោះ?[36]ត្រង់នេះគ្មាននរណាអាចជំទាស់បានទេ សូមបងប្អូននៅស្ងៀមទៅ កុំប្រព្រឹត្តដោយឥតពិចារណាដូច្នេះ។[37]បងប្អូនបាននាំអ្នកទាំងនេះមកទីនេះ ដែលពួកគេមិនបានប្លន់ព្រះវិហារ ឬក៏ពោលពាក្យអ្វីប្រមាថព្រះនាងរបស់យើងទេ។
[38]ប្រសិនបើលោកដេមេទ្រាស និងពួកជាងដែលនៅជាមួយគាត់មានរឿងអ្វីទាស់នឹងនរណា ត្រូវនាំពាក្យបណ្តឹងមកជូនអស់លោកជារាជប្រតិភូ រកយុត្តិធម៌ឲ្យនៅថ្ងៃជំនុំជម្រះទៅ។[39]ប្រសិនបើបងប្អូនចង់តវ៉ាអំពីរឿងអ្វីទៀតនោះ ចាំដល់ពេលមានអង្គប្រជុំពេញច្បាប់ គេនឹងដោះស្រាយជូន។[40]បើមិនដូច្នោះទេ សុំប្រយ័ត្ន ក្រែងយើងត្រូវជាប់ចោទថាជាអ្នកបះបោរ ព្រោះតែរឿងរ៉ាវដែលកើតមានឡើងនៅថ្ងៃនេះ។ គ្មានមូលហេតុណាសម្រាប់ការប្រជុំនេះទេ ហើយយើងក៏មិនអាចពន្យល់បាន»។[41]គាត់មានប្រសាសន៍ដូច្នេះរួចហើយ ក៏ប្រាប់អង្គប្រជុំឲ្យបញ្ចប់។

Acts 19:1

ប្រយោគភ្ជាប់

លោកប៉ូលធ្វើដំណើរទៅក្រុងអេភេសូរ។

ព័ត៌មានទូទៅ

«តំបន់ខ្ពង់រាប» ជាតំបន មួយនៅអាស៊ី ដែលសព្វថ្ងៃនេះនៅក្នុងប្រទេសទួរគី ទៅភាគខាងជើងនៃក្រុងអេភេសូរ។

លោកប៉ូលត្រូវធ្វើដំណើរដោយថ្មើជើងនៅខាងលើសមុទ្របាតម៉ុស ដើម្បីឲ្យអាចចូលទៅក្រុងអេភេសូរបាន (សព្វថ្ងៃនេះ នៅក្នុងប្រទេសតួគី) ចេញពីនេះទៅក្រុងកូរិនថូសដោយត្រង់តាមសមុទ្រ។

នៅគ្រាដែល

ឃ្លានេះប្រើទៅទីនេះ ដើម្បីសម្គាល់ពីចាប់ផ្តើមសាច់រឿងថ្មី។ ប្រសិនបើភាសារបស់អ្នកចាប់ផ្តើមដោយវិធីនេះ អ្នកអាចប្រើវានៅទីនេះបាន។

ឆ្លងកាត់

«ធ្វើដំណើរឆ្លងកាត់»

ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ

ឃ្លានេះមានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកលើពួកគេ។

សូម្បីតែឮអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ក៏យើងមិនធ្លាប់ឮដែរ

«សូម្បីតែឮអំពីព្រះវិញ្ញាណដ៏វិសុទ្ធក៏យើងមិនធ្លាប់ឮផង»

Acts 19:3

ព័ត៌មានទូទៅ

ពាក្យ «ពួកគេ» «អ្នក» និង «ពួកគេ» សំដៅលើពួកសិស្សនៅក្នុងក្រុងអេភេសូរ។ (សូមមើល: ៩:៣)

ព័ត៌មានទូទៅ

ពាក្យ «គាត់» សំដៅលើលោកយ៉ូហាន។

ដូច្នេះ តើបងប្អូនបានទទួលពិធីជ្រមុជទឹកបែបណា?

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «តើបងប្អូនបានទទួលពិធីជ្រមុជទឹកបែបណា?»

ពិធីជ្រមុជទឹកដោយពិធីជ្រមុជនៃការប្រែចិត្ត

generated on Wed Sep 10 16:16:32 2025

អ្នកអាចបកប្រែជានាមអរូប «ការប្រែចិត្ត» ជាកិរិយាសព្ទ «ប្រែចិត្ត»។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាពិធីជ្រមុជដែលមនុស្សសុំ
នៅពេលពួកគេចង់ប្រែចិត្ត»
ពិធីជ្រមុជទឹករបស់លោកយ៉ូហាន
អាចប្រែប្រយោគនេះជាមួយប្រយោគតែម្តងក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងទទួលពិធីជ្រមុជទឹកដែលបង្រៀនដោយលោកយ៉ូហាន»
ពិធីជ្រមុជនៃការប្រែចិត្ត
អ្នកអាចបកប្រែជានាមអរូប «ការប្រែចិត្ត» ជាកិរិយាសព្ទ «ប្រែចិត្ត»។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាពិធីជ្រមុជដែលមនុស្សសុំ
នៅពេលពួកគេចង់ប្រែចិត្ត»
លើព្រះអង្គ ដែលយាងមក
ពាក្យ «លើព្រះអង្គ» សំដៅលើព្រះយេស៊ូ។
ក្រោយលោក
ឃ្លានេះ មានន័យថា មកក្រោយសម័យលោកយ៉ូហានបាទិស្ត
និងមែនក្រោយខាងសាច់ឈាមរបស់លោកទេ។
Acts 19:5
ប្រយោគភ្ជាប់
លោកប៉ូលបន្តនិយាយនៅក្នុងអេភេសូរ។
ពេលប្រជាជន
ពាក្យ «ប្រជាជន» សំដៅលើពួកសិស្សនៅអេភេសូរ
ដែលនិយាយជាមួយលោកប៉ូល» (សូមមើល: ១៩:៣)
ពួកគេបានទទួលពិធីជ្រមុជទឹក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេបានទទួលពិធីជ្រមុជទឹក»
ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ
ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើអំណាច និងសិទ្ធិអំណាចរបស់ព្រះេយស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្នុងនាមជាអ្នកជឿក្នុងព្រះអម្ចាស់យេស៊ូ។
បានដាក់ដៃលើគេ
«បានដាក់ដៃលើពួកគេ»។ លោកប្រហែលជាដាក់ដៃរបស់លោកនៅលើស្មារ
ឬលើក្បាល។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានដាក់ដៃរបស់លោកនៅលើក្បាលរបស់ពួកគេ
ហើយលោកអធិស្ឋានឲ្យ» (UDB)
ពួកគេបាននិយាយភាសាផ្សេងៗ និងថ្លែងទំនាយផង
មិនដូចនៅក្នុងជំពូក ២:១ ទេ
នៅទីនេះគ្មានព័ត៌មានលម្អិតពីអ្នកដែលយល់ពីព្រះបន្ទូលហើយ។
ពួកគេមានគ្នាទាំងអស់ប្រហែលជាដប់ពីរនាក់
ឃ្លានេះ ប្រាប់ពីចំនួនមនុស្សប៉ុន្មានអ្នកដែលបានទទួលពិធីជ្រមុជ។
ដប់ពីរនាក់
«១២ នាក់»
Acts 19:8
លោកប៉ូលបានចូលទៅសាលាប្រជុំ ហើយមានប្រសាសន៍ដោយចិត្តក្លាហានអស់រយៈពេលបីខែ
«លោកប៉ូលបានចូលរួមប្រជុំនៅក្នុងសាលប្រជុំជាប្រចាំអស់រយៈពេលបីខែ
ហើយប្រកាសដោយចិត្តក្លាហាន»
បញ្ចុះបញ្ចូលពួកគេ
«ជំរុញមនុស្សពីសេចក្តីពិត»
អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់
ពាក្យ «ព្រះរាជ» នៅទីនេះ តំណាងឲ្យ
ការសោយរាជរបស់ព្រះជាម្ចាស់ក្នុងនាមជាស្តេច។ របៀបផ្សេងទៀតនៃការបកប្រែ:
«អំពីការសោយរាជរបស់ព្រះជាម្ចាស់ ក្នុងនាមជាស្តេច» ឬ
«ទាក់ទងនឹងរបៀបដែលព្រះជាម្ចាស់បង្ហាញអង្គទ្រង់ក្នុងនាមជាស្តេច»។
មានជនជាតិយូដាខ្លះមានចិត្តរឹង ហើយមិនស្តាប់បង្គាប់
មានចិត្តរឹងក្នុងការជឿ គឺប្រៀបដូចជាមនុស្សដែលដូចជាថ្ម
ហើយធ្វើចលនាមិនបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានជនជាតិយូដាខ្លះមានចិត្តរឹងមិនព្រមជឿ» ឬ
«មានជនជាតិយូដាខ្លះមានចិត្តរឹងបដិសេធមិនទទួល
និងមិនស្តាប់បង្គាប់ព្រះបន្ទូល»
និយាយអាក្រក់ពីផ្លូវរបស់ព្រះអម្ចាស់នៅមុខបណ្តាជនផង
អ្វីដែលព្រះគ្រិស្តចង់ឲ្យមនុស្សជឿ ប្រៀបដូចជាផ្លូវដែលមនុស្សដើរ។ ឃ្លា «ផ្លូវ»
ហាក់បីដូចជាងារសម្រាប់គ្រិស្តបរិស័ទនៅសម័យនោះ» ឬ
«និយាយអាក្រក់ទៅប្រាប់បណ្តាជនអំពីព្រះគ្រិស្ត
និងអំពីអ្វីដែលលោកបង្រៀនអំពីព្រះជាម្ចាស់»។ (សូមមើល: និង ៩:១)
និយាយអាក្រក់ពី
«និយាយការមិនល្អអំពី»
នៅក្នុងសាលប្រជុំរបស់ទីរ៉ាណុស
«នៅក្នុងបន្ទាប់ដ៏ធំ ដែលបង្រៀនមនុស្សនៅទីរ៉ាណុស»
ទីរ៉ាណុស
នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។
អ្នកស្រុកអាស៊ីទាំងអស់បានឮព្រះបន្ទូល
អានមានន័យពីរយ៉ាង។ ទី១)
លោកប៉ូលចែកចាយពីដំណឹងល្អនៅពេញអាស៊ីទាំងមូល ឬ ទី២)
ព្រះបន្ទូលរបស់លោកប៉ូលបានទៅលើមនុស្សទាំងអស់នៅអាស៊ី ពីក្រុងអេភេសូរ
ដោយអ្នកក្រុងអេភេសូរ និងអ្នកដែលមកលេងក្រុងអេភេសូរ
និងមកពីគ្រប់ទិសទីនៅក្នុងអេភេសូរ។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
ពាក្យ «ព្រះបន្ទូល» តំណាងឲ្យព្រះបន្ទូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបន្ទូលរបស់ព្រះអម្ចាស់»
Acts 19:11
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «ពួកគេ» សំដៅលើអស់អ្នកដែលមានជំងឺ។
ព្រះជាម្ចាស់បានធ្វើការអស្ចារ្យជាច្រើនតាមរយៈដៃលោកប៉ូល
ពាក្យ «ដៃ» តំណាងឲ្យខ្លួនលោកប៉ូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានធ្វើឲ្យលោកប៉ូលអាចធ្វើការអស្ចារ្យបាន» ឬ
«ព្រះជាម្ចាស់ធ្វើការអស្ចារ្យតាមរយៈលោកប៉ូល»
ហើយសូម្បីតែគេយកកន្សែង និងអៀមដែលបានប៉ះលោកប៉ូលមកដាក់ពីលើអ្នកជំងឺ ហើយជំងឺ
របស់គេនឹងបានជា
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីឲ្យលោកបានប្រោសអ្នកឈឺឲ្យជា» ឬ «សូម្បីតែអ្នកឈឺក៏បានជាដែរ»
អ្នកជំងឺ
ពាក្យ «អ្នកជំងឺ» បញ្ជាក់យ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកជំងឺ»
ឬ «អស់អ្នកដែលឈឺ»
គេយកកន្សែង និងអៀមដែលបានប៉ះលោកប៉ូលមកដាក់ពីលើអ្នកជំងឺ ជំងឺរបស់គេនឹងបានជា
នេះប្រហែលជាអាវដែលលោកប៉ូលពាក់ ឬប្រើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលពួកគេប៉ះកន្សែង និងអៀមដែលលោកប៉ូលពាក់ពេលគាត់ធ្វើការ»។
កន្សែង
កន្លែងដែលពាក្យនៅជុំវិញក្បាល
អៀម
អាវដែលពាក់នៅខាងមុខខ្លួន ដើម្បីការពារមិនឲ្យប្រឡាក់។
Acts 19:13
ព័ត៌មានទូទៅ
ឃ្លានេះចាប់ផ្តើមព្រឹត្តការមួយទៀតដែលបានកើតឡើងពេលលោកប៉ូលនៅក្រុងអេភេសូរ។
គឺទាក់ទងនឹងគ្រូដេញអារក្សរបស់សាសន៍យូដា។
គ្រូដេញអារក្ស
មនុស្សដែលដេញវិញ្ញាណអាក្រក់ពីមនុស្ស ឬពីកន្លែងផ្សេងៗ។
អំពាវនាវរកព្រះនាមព្រះអម្ចាស់យេស៊ូ ដើម្បីឲ្យពួកគេអាចមានអំណាច
ទោះបីជាពួកគេមិនបានទទួលជឿព្រះយេស៊ូក្តី
ពួកគេព្យាយាមប្រើព្រះនាមព្រះអង្គជាគ្រូមន្តអាគមរបស់ពួកគេម្នាក់។
អស់អ្នកដែលមានវិញ្ញាណអាក្រក់ចូល
«អស់អ្នកដែលនៅក្រោមការគ្រប់គ្រងរបស់វិញ្ញាណអាក្រក់»
ក្នុងព្រះនាមព្រះយេស៊ូដែលលោកប៉ូលប្រកាស
«ព្រះយេស៊ូ» គឺជាឈ្មោះមួយដ៏សំខាន់នៅសម័យនោះ
ដូច្នេះហើយពួកគ្រូដេញអាក្សចង់ឲ្យមនុស្សបានដឹងថា
គេកំពុងតែនិយាយពីឈ្មោះនរណា។
ក្នុងព្រះនាមព្រះយេស៊ូ
ឃ្លានេះ តំណាងឲ្យអំណាច និងសិទ្ធិអំណាចរបស់ព្រះយេស៊ូ។
របៀបផ្សេងទៀតនៅក្នុងការបកប្រែ: «ដោយសារអំណាច
និងសិទ្ធិអំណាចរបស់ព្រះយេស៊ូ» ឬ «ដោយសារអំណាចរបស់ព្រះយេស៊ូ»
កូនប្រុសទាំងប្រាំពីររបស់លោកស្កេវ៉ាដែលជាមហាបូជាចារ្យរបស់ជនជាតិយូដាបានធ្វើការនេះ

generated on Wed Sep 10 16:16:32 2025

នេះគឺប្រវត្តិអំពីពួកគ្រូដេញអារក្ស។

លោកស្កេវ៉ា

នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។

Acts 19:15

យើងស្គាល់ព្រះយេស៊ូ ហើយលោកប៉ូលក៏យើងស្គាល់ដែរ

«យើងស្គាល់ព្រះយេស៊ូ និងលោកប៉ូល» ឬ «យើងស្គាល់ព្រះយេស៊ូ ហើយយើងស្គាល់ប៉ូល»

ចុះពួកឯងវិញជានរណា?

វិញ្ញាណអាក្រក់បានសួរសំនួរនេះដើម្បីបញ្ជាក់ថា ពួកគ្រូទាយគ្មានសិទ្ធិអំណាចលើវិញ្ញាណអាក្រក់ឡើយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ យើងមិនស្គាល់អ្នកទេ!» ឬ «ប៉ុន្តែ អ្នកគ្មានសិទ្ធិអំណាចអ្វីលើយើងទេ!» (សូមមើល: | Rhetorical Question)

វិញ្ញាណអាក្រក់ដែលនៅក្នុងនោះបានស្ទុះមកសង្កត់

ពាក្យនេះមានន័យថា វិញ្ញាណអាក្រក់ធ្វើឲ្យមនុស្សដែលអារក្សគ្រប់គ្រងបានស្ទុះមើលលើពួកគ្រូដេញអារក្ស។

ពួកគ្រូដេញអារក្ស

សំដៅលើមនុស្សដែលដេញវិញ្ញាណអាក្រក់ពីមនុស្ស ឬពីទីកន្លែងផ្សេងៗ។ សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ជំពូក ១៩:១៣។

ពួកគេរត់ចេញ...ទាំងអាក្រាត

ពួកគ្រូដេញអារក្សបានរត់ជ្រុះខោអាវពីពួកគេអស់។

ព្រះនាមរបស់ព្រះអម្ចាស់យេស៊ូត្រូវបានលើកតម្កើង

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានលើកតម្កើងព្រះនាមព្រះអម្ចាស់យេស៊ូ» ឬ «ពួកគេគិតថា ព្រះនាមរបស់ព្រះអម្ចាស់យេស៊ូពិតជាអស្ចារ្យណាស់»

ព្រះនាម

តំណាងឲ្យអំណាច និងសិទ្ធិអំណាចរបស់ព្រះយេស៊ូ។

Acts 19:18

ប្រយោគភ្ជាប់

នេះគឺជាចុងបញ្ចប់នៃសាច់រឿងអំពីពួកគ្រូដេញអារក្ស។

បានយកក្បួនតម្រារបស់ពួកគេ

«បានប្រមូលក្បួនតម្រារបស់ពួកគេ»។ ពាក្យ «សៀវភៅ» សំដៅលើក្រាំដែលពួកគ្រូមន្តអាគមធ្វើ និងសរសេរជារូបមន្ត។

បានធ្វើជាសាធារណៈ

«នៅចំពោះមនុស្សគ្រប់គ្នា»

បានរាប់ពីតម្លៃរបស់ទាំងនោះ

«តម្លៃរបស់ក្បួនតម្រាទាំងនោះ» ឬ «តម្លៃរបស់ក្រាំងទាំងនោះ»

ប្រាំម៉ឺន

«៥០០០០»

កាក់ប្រាក់

«កាក់ប្រាក់» មួយកាក់ប្រាក់ស្មើនឹងថ្លៃឈ្នួលកម្លាំងធ្វើការមួយថ្ងៃ។

ដូច្នេះ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានឮយ៉ាងទូលំទូលាយ និងប្រកបដោយអំណាចផង

«ដូច្នេះ ដោយសារអំណាចនៃការធ្វើការអស្ចារ្យទាំងនេះ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានឮយ៉ាងទូលំទូលាយ»

Acts 19:21

ប្រយោគភ្ជាប់

លោកប៉ូលមានប្រសាសន៍អំពីការចេញទៅក្រុងយេរូសាឡិម ប៉ុន្តែ មិនទាន់ចេញពីក្រុងអេភេសូរនៅឡើយទេ។

ឥឡូវនេះ

ការប្រើពាក្យនេះនៅទីនេះដើម្បីសម្គាល់ពីការសម្រាកពីសាច់រឿងចម្បង។ នៅទីនេះ លោកលូកាចាប់ផ្តើមប្រាប់ពីផ្នែកថ្មីនៃសាច់រឿង។

លោកប៉ូលបានបំពេញព័ន្ធកិច្ចរបស់លោកនៅអេភេសូរហើយ

«លោកប៉ូលបានបំពេញកិច្ចការដែលព្រះជាម្ចាស់ប្រទានឲ្យលោកនៅអេភេសូររួចហើយ»

លោកបានសម្រេចចិត្តនៅក្នុងវិញ្ញាណ

អាចមានន័យពីរ។ ទី១) លោកប៉ូលបានសម្រេចចិត្តដោយព្រះវិញ្ញាណជួយ។ ទី២) លោកប៉ូលបានសម្រេចនៅខាងក្នុងវិញ្ញាណរបស់លោកផ្ទាល់ ដែលមានន័យថាលោកបានសម្រេចចិត្តរួចស្រេចហើយ។

ស្រុកអាខៃ

ស្រុកអាខៃជាខេត្តរបស់រ៉ូម ដែលក្រុងកូនរិនថូសក៏នៅទីនោះដែរ។ ស្រុកអាខៃជាទីក្រុងដ៏ធំបំផុតនៅភាគខាងត្បូងរបស់ប្រទេសក្រិក និងទីក្រុងរបស់ខេត្តនោះតែម្តង។ សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ១៨:១២។

ខ្ញុំនឹងទៅក្រុងរ៉ូមទៀត

«ខ្ញុំត្រូវទៅក្រុងរ៉ូមទៀត»

លោកអេរ៉ាស្ទុស

នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។

ប៉ុន្តែ លោកខ្លួនឯងស្នាក់នៅក្នុងស្រុកអាស៊ីមួយរយៈសិន

ឃ្លានេះបញ្ជាក់នៅក្នុងពីរបីបន្ទាប់ដែលលោកប៉ូលនៅក្រុងអេភេសូរដដែល។

លោកខ្លួនឯង

ឃ្លានេះសម្រាប់បញ្ជាក់។

Acts 19:23

ប្រយោគភ្ជាប់

លោកលូកាប្រាប់ពីកុប្បកម្មដែលបានកើតឡើងពេលលោកប៉ូលនៅក្រុងអេភេសូរ។

ព័ត៌មានទូទៅ

ដេមេទ្រាសត្រូវបានណែនាំមកក្នុងសាច់រឿង។ ខ ២៤ ប្រាប់ពីប្រវត្តិអំពីដេមេទ្រាស។

ព័ត៌មានទូទៅ

ក្រុងអេភេសូរមានព្រះវិហារដ៏ធំមួយដែលឧទ្ទិស ថ្វាយព្រះនាងឌីអាន ពេលខ្លះប្រែឈ្មោះជាភាសាក្រិក «អរតេមីស»។

ព្រះនាងឌីអានជាព្រះក្លែងក្លាយដែលសាយកូន។ (សូមមើល: | How to Translate Names)

មានការរំខានជាខ្លាំងនៅអេភេសូរ ដោយព្រោះមាគ៌ានេះ

នេះគឺជាការសង្ខេបនៃការចាប់ផ្តើមបើកសេចក្តីថ្លែងការណ៍។

មានការរំខានជាខ្លាំង

«ប្រជាជននាំគ្នាខឹងជាខ្លាំង»

ផ្លូវ

នេះគឺជាពាក្យដែលប្រើសំដៅលើគ្រិស្តបរិស័ទ។ សូមមើលពីរបៀបដែលអ្នកបកប្រែងារនេះ នៅក្នុងជំពូក ៩:១។

មានជាងប្រាក់ម្នាក់ឈ្មោះដេមេទ្រាស

ការប្រើពាក្យ «មានបុរសម្នាក់» ដើម្បីណែនាំបុគ្គលថ្មីនៅក្នុងសាច់រឿង។

ជាងប្រាក់

ជាងប្រាក់ដែលធ្វើការជាមួយប្រាក់ ដើម្បីធ្វើជារូបសំណាក ឬគ្រឿងអលង្ការ។

ឈ្មោះដេមេទ្រាស

នេះគឺជាឈ្មោះរបស់បុរសម្នាក់។ ដេមេទ្រាសជាជាងប្រាក់នៅក្នុងក្រុងអេភេសូរ ដែលប្រឆាំងទាស់ជាមួយលោកប៉ូល និងក្រុមជំនុំនៅក្នុងតំបន់នោះ។ (សូមមើល: | How to Translate Names)

មានជាងប្រាក់ម្នាក់ឈ្មោះដេមេទ្រាស

ការប្រើពាក្យ «មានបុរសម្នាក់» ដើម្បីណែនាំបុគ្គលថ្មីនៅក្នុងសាច់រឿង។

Acts 19:26

ប្រយោគភ្ជាប់

លោកដេមេទ្រាសបន្តនិយាយជាមួយពួកជាង។

សូមបងប្អូនមកមើល ហើយស្តាប់ចុះ

«សូមបងប្អូនមក ដើម្បីដឹងហើយយល់ថា»

បង្វែរមនុស្សជាច្រើន

លោកប៉ូលបានបញ្ឈប់មនុស្សជាច្រើនពីការថ្វាយបង្គំរូបព្រះ បើនិយាយទៅលោកប៉ូលបានបង្វែរមនុស្សឲ្យដើរតាមផ្លូវផ្សេង។ របៀបផ្សេងទៀតនៃការបកប្រែ: «បានធ្វើឲ្យមនុស្សជាច្រើនឈប់លែងថ្វាយបង្គំរូបព្រះនៅតាមតំបន់»

គាត់ពោលថា គ្មានព្រះណាដែលធ្វើដោយដៃមនុស្សទេ

ពាក្យ «ដៃ» នៅទីនេះ អាចសំដៅលើមនុស្សទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកមានប្រសាសន៍ថា គ្មានព្រះដែលបង្កើតដោយមនុស្សទេ»។ ឬ «លោកកំពុងនិយាយថា រូបព្រះដែលមនុស្សបានធ្វើមិនមែនជាព្រះពិតទេ»

មុខរបរបស់យើងគ្មានគេត្រូវការ

ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សលែងចង់ទិញរូបព្រះពីយើងហើយ»

ព្រះវិហារនៃព្រះនាងឌីអាន គ្មានតម្លៃទៀតផង

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សនឹងគិតថាលែងមានប្រយោជន៍ក្នុងការទៅព្រះវិហារ

generated on Wed Sep 10 16:16:32 2025

ដើម្បីថ្វាយបង្គំព្រះនាងឌីអានទៀតហើយ»
ព្រះនាងនឹងបាត់ភាព មហិមារបស់ព្រះនាង
ភាពធំឧត្តមរបស់ព្រះនាងឌីអានកើតចេញពីការគិតរបស់មនុស្សតែប៉ុណ្ណោះ។
អ្នកស្រុកអាស៊ី និងពិភពលោកទាំងមូលថ្វាយបង្គំ
ឃ្លានេះ និយាយបំផ្លើស ដើម្បីបង្ហាញពីប្រជាប្រិយ៍ភាពរបស់ព្រះនាងឌីអាន។ ពាក្យ «អាស៊ី» និងផែនដី» នៅទីនេះ សំដៅលើមនុស្សនៅក្នុងអាស៊ី និងពិភពលោក។
របៀបផ្សេងទៀតនៃការបកប្រែ: «មានមនុស្សនៅអាស៊ីជាច្រើន
និងអ្នកនៅកន្លែងផ្សេងទៀតនៃផែនដីថ្វាយបង្គំ»
Acts 19:28
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ ដំបូងគេសំដៅលើជាងប្រាក់ ដែលធ្វើរូបព្រះ (១៩:២៣)។ ពាក្យ «ពួកគេ» លើកទីពីរ
សំដៅលើមនុស្សដែលប្រមូលគ្នាមកស្តាប់ជាងប្រាក់ដែលស្រែក។
ព័ត៌មានទូទៅ
លោកកៃយុស និងលោកអើរីស្ទាកបានមកពីម៉ាសេដូន ប៉ុន្តែ
បានមកធ្វើការជាមួយលោកប៉ូលនៅក្នុងក្រុងអេភេសូរ។
ពួកគេខឹងយ៉ាងខ្លាំង
ឃ្លានេះនិយាយពីជាងប្រាក់ ពួកគេប្រៀបដូចជាប្រអប់មួយ។ ពាក្យ «ខឹង» និយាយពីការចាក់ពេញ ដូចជាពេញប្រអប់ដូច្នោះដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានខឹងជាខ្លាំង»
ហើយបានស្រែកឡើង
«ស្រែកជាខ្លាំង» ឬ «ស្រែកឮៗ»
ទីក្រុងទាំងមូលកើតការច្របូកច្របល់
ពាក្យ «ទីក្រុង» នៅទីនេះ សំដៅលើមនុស្ស។ ទីក្រុងប្រៀបដូចជាប្រអប់។ ហើយ «ការច្របូកច្របល់»
និយាយប្រៀបដូចជាវាបានពេញដូចដែលគេចាក់ពេញក្នុងប្រអប់ដូច្នោះដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មក ប្រជាជននៅក្នុងទីក្រុង មានការខឹង ហើយចាប់ផ្តើមស្រែកឡើយ»
បណ្តាជនបានដើរជាមួយគ្នា
ឃ្លានេះសំដៅលើហ្វូងមនុស្ស ឬស្ថានភាពកុប្បកម្ម។
ឆ្ពោះទៅមហោស្រព
សាលមហោស្របនៅក្រុងអេភេសូរត្រូវបានប្រើជាសាធារណៈ ដើម្បីប្រជុំ
និងសម្រាប់កម្សាន្តដូចជាលែង និងតន្ត្រីជាដើម។
នៅទីនោះគឺហាលវាលមានកន្លែងអង្គុយ ដេលដាក់មនុស្សបានរាប់ពាន់នាក់។
អ្នករួមដំណើរជាមួយលោកប៉ូល
អ្នកដែលបាននៅជាមួយលោកប៉ូល។
លោកកៃយុស និងលោកអើរីស្ទាក
នេះគឺជាឈ្មោះរបស់មនុស្ស។ (សូមមើល: |How to Translate Names)
Acts 19:30
ព័ត៌មានទូទៅ
ក្រុងអេភេសូរជាផ្នែកមួយនៃអាណាចក្ររ៉ូម និងនៅក្នុងខេត្តរបស់អាស៊ី។
ចូលទៅក្នុងសាលមហោស្រព
សាលមហោស្របនៅក្រុងអេភេសូរត្រូវបានប្រើជាសាធារណៈ ដើម្បីប្រជុំ
និងសម្រាប់កម្សាន្តដូចជាលែង និងតន្ត្រីជាដើម។
នៅទីនោះគឺហាលវាលមានកន្លែងអង្គុយ ដែលដាក់មនុស្សបានរាប់ពាន់នាក់។
សូមមើលពីរបៀបនៃការបកប្រែរបស់អ្នកនៅក្នុង ជំពូក ១៩:២៨។
Acts 19:33
លោកអលេក្សានត្រុស
នេះគឺជាឈ្មោះរបស់បុរសម្នាក់។
បានលើកដៃរបស់គាត់ធ្វើសញ្ញា ចង់ពន្យល់
អ្នកអាចបង្ហាញថា លោកអលេក្សានត្រុសព្យាយាមធ្វើឲ្យបណ្តាជនស្ងាត់។
«របៀបផ្សេងទៀតនៃការបកប្រែ: «បានធ្វើជាសញ្ញាដល់បណ្តាជនឲ្យស្ងាត់ ដើម្បីលោកអាចពន្យាល់បាន» ។
ចង់ពន្យល់ដល់
លោកចង់និយាយ ប៉ុន្តែ មិនច្បាស់ថាលោកចង់និយាយពីអ្វី។
ដោយសម្លេងតែមួយ
មនុស្សបានស្រែកឡើងជាមួយនៅក្នុងពេលតែមួយ និយាយទៅ
ពួកគេមានសម្លេងតែមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ឯកភាពគ្នា» ឬ «ជាមួយគ្នា»
Acts 19:35
ប្រយោគភ្ជាប់
លេខាធិការរបស់ក្រុងអេភេសូរនិយាយឲ្យបណ្តាជននៅស្ងៀម។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» និង «អ្នក» សំដៅលើមនុស្សដែលមានវត្តមាន
គឺអ្នកដែលមកពីអេភេសូរ។ (សូមមើល: |Forms of You)
លេខាធិការក្រុង
ឃ្លានេះ សំដៅលើ «អ្នកសរសេរ» ឬ «ជាលេខាធិការ» ទីក្រុង។
តើនរណាមិនដឹងថា ក្រុងអេភេសូរជាអ្នកថែរក្សាព្រះវិហារដែលមានរូបសំណាក់...ស្ថានសួគ៌មក នោះ?
លេខាធិការបានសួរសំនួរនេះដើម្បីបញ្ជាក់ដល់បណ្តាជនថា ពួកគេត្រឹមត្រូវ
និងដើម្បីកម្លាចិត្តពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់គ្នាដឹងពីទីក្រុងអេភេសូរជាព្រះវិហារដែលទុក...
ស្ថានសួគ៌» (សូមមើល: |Rhetorical Question)។
តើនរណាមិនដឹង
ស្ងៀនក្រុងប្រើពាក្យ «មិន» ដើម្បីបញ្ជាក់ថាមនុស្សគ្រប់គ្នាដឹងពីការនេះ។
អ្នកថែរក្សាព្រះវិហារ
អ្នកក្រុងអេភេសូរមើលថែ និងការពារព្រះវិហាររបស់ព្រះនាងឌីអាន។
រូបសំណាក់ធ្លាក់ចុះពីស្ថានសួគ៌មក
នៅក្នុងព្រះវិហារព្រះនាងឌីអានជារូបសំណាកមួយដែលបានបង្ហាញពីអាចម៍ផ្កាយដែលធ្លាក់ពីលើមេឃមក
នេះគឺជាថ្មមួយដុំ ដែលបានធ្លាក់ចុះមកពីព្រះសេយូស
ជាអ្នកគ្រប់គ្រងព្រះរបស់ក្រិក (រូបព្រះ)។
ការទាំងអស់នេះមិនអាចបដិសេធបានទេ
«បងប្អូនបានដឹងពីការនេះទាំងអស់គ្នាហើយ»
កុំធ្វើអ្វីប្រញាប់ប្រញាលពេក
«កុំទាន់ធ្វើអ្វីមុនពេលអ្នកមានពេលគិតពីវាសិន»។
ប្រញាប់ប្រញាល
«សាហាវ» ឬ «កាច» ឬ «មិនបានគិតគូរ»
អ្នកទាំងនេះ
ពាក្យ «អ្នកទាំងនេះ» សំដៅលើលោក «លោកកៃយុស និងលោកអើរីស្ទាក
ដែលបានរួមដំណើរជាមួយលោកប៉ូល។ (សូមមើល: ១៩:២៨)
Acts 19:38
ប្រយោគភ្ជាប់
ស្ងៀនក្រុងបានបញ្ចប់ការនិយាយរបស់គាត់ជាមួយបណ្តាជន។
ដូច្នេះ
ពាក្យនេះ ដើម្បីសម្គាល់ប្រយោគដែលបាននិយាយ
ដោយសារអ្វីដែលបាននិយាយពីមុន។ ស្ងៀនក្រុងបាននិយាយនៅក្នុង ជំពូក ១៩:៣៥ ថា លោកកៃយុស និងលោកអើរីស្ទាក មិនមែនជាចោរ
ឬជាអ្នកប្រមាថអ្វីឡើយ។
ចូរឲ្យពួកគេប្តឹងផ្តល់គ្នាចុះ
ពាក្យ «ប្តឹងផ្តល់» អាចប្រែជាកិរិយាសព្ទ «ប្តឹង»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចង់ប្តឹងនរណាម្នាក់»
អភិបាល
«ជាតំណាង» ឃ្លានេះ សំដៅលើអ្នកតំណាងរបស់ព្រះចៅអធិរាជរ៉ូម
ដែលមានសិទ្ធិកាត់ក្នុងនៅក្នុងតុលាការ។ (សូមមើល: |Translate Unknowns)
ចូរឲ្យពួកគេប្តឹងផ្តល់គ្នាចុះ
មិនគ្រាន់តែលោកដេមេទ្រាស
និងអស់អ្នកដែលនៅជាមួយគាត់តវ៉ាដល់គ្នាទៅវិញទៅមក។ នេះមានន័យថា
នេះគឺជាកន្លែងដែលមនុស្សអាចនិយាយប្តឹងផ្តល់គ្នាបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សអ្នកប្តឹងផ្តល់រវាងគ្នានិងគ្នា»។
ប៉ុន្តែ ប្រសិនបើបងប្អូនចង់តវ៉ាអំពីរឿងអ្វីទៀតនោះ
«ប៉ុន្តែ ប្រសិនបើបងប្អូនមានរឿងចង់ពិភាក្សា»
គួរតែដោះស្រាយពេលមានអង្គប្រជុំពេញច្បាប់ទៅ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរយើងដោះស្រាយគ្នានៅតាមអង្គប្រជុំតាមធម្មតាទៅ» ។
មានអង្គប្រជុំ
ឃ្លានេះ
សំដៅលើការប្រជុំរបស់ជាតិសាសន៍មួយដែលនៅក្រោមអធិបតីភាពរបស់ស្ងៀន។

generated on Wed Sep 10 16:16:32 2025

គេអាចនឹងប្តឹងយើងទាក់ទងនឹងការបះបោរដែលបានកើតឡើងនៅថ្ងៃនេះ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«មានការគ្រោះថ្នាក់ដោយព្រោះការប្តឹងផ្តល់របស់អាជ្ញាធររ៉ូម
ប្តឹងយើងនាំឲ្យមានកុប្បកម្មនៅថ្ងៃនេះ»

---

20 [1]បន្ទាប់ពីចលាចលនោះបានបញ្ចប់ លោកប៉ូលក៏ហៅពួកសិស្សមកលើកទឹកចិត្ត រួចជំរាបលាពួកគេ ធ្វើដំណើរទៅស្រុកម៉ាសេដូន។[2]លោកធ្វើដំណើរកាត់ស្រុកនោះ
ទាំងមានប្រសាសន៍លើកទឹកចិត្តអ្នកជឿយ៉ាងច្រើនផង។ បន្ទាប់មក លោកក៏បានទៅដល់ស្រុកក្រិក។[3]លោកស្នាក់នៅស្រុកនោះអស់រយៈពេលបីខែ។ ពេលលោក
ហៀបនឹងចុះសំពៅធ្វើដំណើរទៅស្រុកស៊ីរី ជនជាតិយូដាបានឃុបឃិតគ្នាប៉ុនប៉ងធ្វើបាបលោក។ លោកជ្រាបដូច្នេះ ក៏សម្រេចចិត្តវិលត្រឡប់ទៅវិញ កាត់តាមស្រុក
ម៉ាសេដូន។
[4]អ្នកដែលបានរួមដំណើរជាមួយលោកនៅពេលនោះ មានលោកសូប៉ាត្រុស កូនរបស់លោកពីរូស ជាអ្នកស្រុកបេរា លោកអើរីស្តាក និងលោកសេគុនដុស ជាអ្នកស្រុក
ថេស្សាឡូនិក លោកកៃយុសជាអ្នកស្រុកឌើបេ លោកធីម៉ូថេ ព្រមទាំងលោកទីឃីកុស និងលោកត្រូភីម ជាអ្នកស្រុកអាស៊ីផង។[5]បងប្អូនទាំងនេះបានចេញដំណើរទៅមុន
ហើយរង់ចាំយើងនៅក្រុងត្រូអាស។[6]ចំណែកឯយើងវិញ ក្រោយថ្ងៃបុណ្យនំបុ័ងឥតមេ យើងចេញពីក្រុងភីលីពទៅតាមសំពៅ ហើយប្រាំថ្ងៃក្រោយមក យើងក៏បានទៅដល់
ក្រុងត្រូអាស ជួបជុំនឹងពួកគេ រួចស្នាក់នៅទីនោះប្រាំពីរថ្ងៃ។
[7]នៅថ្ងៃទីមួយក្នុងសប្តាហ៍នោះយើងបានជួបជុំគ្នាដើម្បីធ្វើពិធីកាច់នំបុ័ង លោកមានប្រសាសន៍ទៅកាន់អង្គប្រជុំ។ លោកប៉ូលត្រូវចេញដំណើរនៅថ្ងៃបន្ទាប់ ហើយអធិប្បាយ
រហូតដល់ពាក់កណ្តាលអធ្រាត្រ។[8]ក្នុងបន្ទប់ដែលយើងប្រជុំគ្នានៅជាន់ខាងលើ មានចង្កៀងជាច្រើន។
[9]ពេលលោកប៉ូល កំពុងតែមានប្រសាសន៍ យ៉ាងយូរនោះ យុវជនម្នាក់ឈ្មោះ អ៊ើទីកុស អង្គុយនៅលើមាត់បង្អួច ហើយលង់លក់ ក៏ដាច់ផ្ងារធ្លាក់ពីជាន់ទីបីមកក្រោម។ ពេល
គេលើកគាត់ឡើង គាត់ស្លាប់បានទៅហើយ។[10]លោកប៉ូលក៏ចុះទៅខាងក្រោម ឱនពីលើអ៊ើទីកុស ត្រកងគាត់លើកឡើងទាំងពោលថា៖ «សូមបងប្អូនកុំបារម្ភឲ្យសោះ គាត់
នៅរស់ទេ!»។
[11]ពេលលោកឡើងទៅខាងលើវិញ ក៏ធ្វើពិធីកាច់នំបុ័ង និងបរិភោគ។ បន្ទាប់មក លោកមានប្រសាសន៍បន្តទៅទៀតយ៉ាងយូរ រហូតដល់ភ្លឺ ទើបលោកចេញដំណើរទៅ។
[12]ពួកគេបាននាំយកយុវជនដែលនៅរស់មានជីវិតនោះត្រឡប់ទៅវិញ ហើយពួកគេធូរបានស្រាលក្នុងចិត្តឥតឧបមា។
[13]រីឯយើងវិញ យើងបានចុះសំពៅទៅមុនធ្វើដំណើរដល់ក្រុងអាសុស ដើម្បីចាំលោកប៉ូលនៅទីនោះ ដូចលោកបានគ្រោងទុក ព្រោះលោកចង់ធ្វើដំណើរដោយថ្មើរជើង។
[14]កាលលោកបានមកជួបជុំជាមួយពួកយើងនៅក្រុងអាសុសហើយ យើងក៏ទទួលលោកមកក្នុងសំពៅ រួចធ្វើដំណើរឆ្ពោះទៅក្រុងមីទូឡែន។
[15]យើងបានចេញពីទីនោះ បន្តដំណើរតាមសមុទ្រ ទៅដល់ទន្លឹមនឹងកោះឃីយ៉ូសនៅថ្ងៃបន្ទាប់។ នៅថ្ងៃបន្ទាប់មកទៀត យើងទៅដល់កោះសាម៉ូស ហើយនៅថ្ងៃទីបីយើងក៏
បានទៅដល់ក្រុងមីលេត។[16]លោកប៉ូលសម្រេចចិត្តមិនចូលក្រុងអេភេសូទេ ដើម្បីកុំឲ្យយឺតដំណើរនៅស្រុកអាស៊ី ដ្បិតលោកប្រញាប់ចង់ទៅដល់ក្រុងយេរូសាឡឹម
ដើម្បីឲ្យទាន់បុណ្យថ្ងៃទីហាសិប ប្រសិនបើអាចធ្វើទៅបាន។
[17]លោកប៉ូលបានចាត់គេពីក្រុងមីលេត ឲ្យទៅអញ្ជើញពួកព្រឹទ្ធាចារ្យនៃក្រុមជំនុំនៅក្រុងអេភេសូ។[18]លុះគេបានមកដល់ហើយ លោកមានប្រសាសន៍ទៅគេថា៖ «បងប្អូន
ជ្រាបស្រាប់ហើយតាំងពីថ្ងៃដំបូង ដែលខ្ញុំបានទៅដល់ស្រុកអាស៊ីអំពីពេលវេលាដែលខ្ញុំមានជាមួយអ្នក។[19]ខ្ញុំបានបម្រើព្រះអម្ចាស់ ដោយចិត្តសុភាពរាបសា ទាំងទឹកភ្នែក
ទាំងលំបាកដោយសារជនជាតិយូដាបានឃុបឃិតគ្នាប៉ុនប៉ងធ្វើបាបខ្ញុំ។[20]ខ្ញុំបានជម្រាប និងបង្រៀនបងប្អូន តាមទីសាធារណៈ និងតាមផ្ទះ នូវសេចក្តីទាំងប៉ុន្មានដែលមាន
សារប្រយោជន៍ដល់បងប្អូន ឥតមានលាក់លៀមត្រង់ណាសោះឡើយ[21]ខ្ញុំបានធ្វើជាបន្ទាល់ឲ្យទាំងសាសន៍យូដាទាំងសាសន៍ក្រិក កែប្រែចិត្តគំនិតមករកព្រះជាម្ចាស់ និង
មានជំនឿលើព្រះយេស៊ូជាព្រះអម្ចាស់របស់យើងផង។
[22]ឥឡូវនេះ ព្រះវិញ្ញាណបានទាក់ទាញចិត្តខ្ញុំឲ្យធ្វើដំណើរទៅក្រុងយេរូសាឡឹម ហើយខ្ញុំមិនដឹងថា នឹងមានហេតុការណ៍អ្វីកើតមានដល់ខ្ញុំ នៅក្រុងនោះឡើយ[23]គឺខ្ញុំគ្រាន់តែ
ដឹង តាមព្រះវិញ្ញាណដ៏វិសុទ្ធបញ្ជាក់ប្រាប់ ពីក្រុងមួយទៅក្រុងមួយថា ខ្ញុំនឹងត្រូវគេចាប់ចង ហើយនឹងត្រូវរងទុក្ខវេទនា។[24]ប៉ុន្តែខ្ញុំមិនខ្វល់នឹងជីវិតរបស់ខ្ញុំទេ ឲ្យតែខ្ញុំបាន
បង្ហើយមុខងារ និងសម្រេចកិច្ចការដែលព្រះអម្ចាស់យេស៊ូបានប្រទានឲ្យខ្ញុំធ្វើ គឺផ្តល់សក្ខីភាព អំពីដំណឹងល្អនៃព្រះគុណរបស់ព្រះជាម្ចាស់។
[25]ឥឡូវនេះ ខ្ញុំដឹងថាខ្ញុំស្ថិតនៅក្នុងចំណោមបងប្អូនទាំងអស់គ្នា ទាំងប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ប៉ុន្តែ បងប្អូននឹងលែងឃើញមុខខ្ញុំទៀតហើយ។[26]ហេតុ
នេះបានជាខ្ញុំផ្តល់សក្ខីភាពឲ្យបងប្អូនដឹងនៅថ្ងៃនេះថា ប្រសិនបើមានម្នាក់ក្នុងចំណោមបងប្អូនត្រូវវិនាស មិនមែនមកពីកំហុសរបស់ខ្ញុំទេ។[27]ដ្បិតខ្ញុំបានជម្រាបបង
ប្អូនអំពីគម្រោងការទាំងមូល របស់ព្រះជាម្ចាស់រួចហើយ ឥតមានលាក់លៀមត្រង់ណាសោះ។
[28]ដូច្នេះ សូមបងប្អូនថែរក្សាខ្លួនឯង និងថែរក្សាក្រុមអ្នកជឿទាំងមូលផង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្ដាក់ឲ្យបងប្អូន ធ្វើជាអ្នកទទួលខុសត្រូវនេះ ដើម្បីឲ្យបងប្អូន
ថែរក្សាក្រុមជំនុំរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានលោះមក ដោយសារព្រះលោហិតរបស់ព្រះអង្គផ្ទាល់។[29]ខ្ញុំដឹងច្បាស់ថា ពេលខ្ញុំចេញផុតទៅ នឹងមានមនុស្សចិត្តសាហាវ
ដូចចចក នាំគ្នាចូលមកក្នុងចំណោមបងប្អូន គេនឹងធ្វើបាបក្រុមអ្នកជឿឥតត្រាប្រណីឡើយ[30]ថែមទាំងមានអ្នកខ្លះក្នុងចំណោមបងប្អូននាំគ្នាពោលពាក្យបញ្ឆោតដើម្បី
ទាក់ទាញពួកសិស្សឲ្យទៅតាមគេទៀតផង។
[31]ហេតុនេះ សូមបងប្អូនប្រុងស្មារតីឲ្យមែនទែន ដោយនឹកចាំថា ខ្ញុំបានដាស់តឿនបងប្អូនគ្រប់ៗរូប ទាំងទឹកភ្នែកក្នុងរវាងបីឆ្នាំ ទាំងយប់ ទាំងថ្ងៃ ឥតមានឈប់ឡើយ។
[32]ឥឡូវនេះ ខ្ញុំសូមផ្ញើបងប្អូននឹងព្រះជាម្ចាស់ ហើយផ្ញើនឹងព្រះបន្ទូលនៃព្រះគុណរបស់ព្រះអង្គ។ មានតែព្រះអង្គទេ ដែលអាចកសាងបងប្អូនឡើងជាក្រុមជំនុំ ព្រមទាំង
ឲ្យបងប្អូនទទួលមត៌ក រួមជាមួយប្រជាជនដ៏វិសុទ្ធ។
[33]ខ្ញុំមិនដែលចង់បានមាស ប្រាក់ ឬសម្លៀកបំពាក់អ្វីពីនរណាឡើយ។[34]បងប្អូនជ្រាបស្រាប់ហើយថា ខ្ញុំបានធ្វើការដោយផ្ទាល់ដៃ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់ខ្ញុំ និង
សេចក្តីត្រូវការរបស់អស់អ្នកដែលនៅជាមួយខ្ញុំ។[35]ក្នុងគ្រប់កិច្ចការទាំងអស់ខ្ញុំតែងតែប្រាប់អោយបងប្អូនដឹងថា ត្រូវតែធ្វើការនឿយហត់បែបនេះឯង ដើម្បីជួយទំនុកបម្រុង
អស់អ្នកដែលក្រខ្សត់ ហើយត្រូវចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូថា៖ «បើឲ្យ នោះនឹងបានពរច្រើនជាងទទួល»។
[36]បន្ទាប់ពី លោកមានប្រសាសន៍ដូច្នេះរួចហើយ ក៏លុតជង្គង់ចុះអធិស្ឋានជាមួយពួកគេទាំងអស់គ្នា។[37]ពួកព្រឹទ្ធាចារ្យទាំងនោះ នាំគ្នាទ្រហោយំឱបកលោកប៉ូល ហើយថើប
គាត់ទៀតផង។[38]ជាពិសេស ពួកគេព្រួយចិត្តមកពីលោកប៉ូលមានប្រសាសន៍ថា ពួកគេនឹងលែងឃើញមុខលោកទៀតហើយ។ បន្ទាប់មក ពួកគេក៏ជូនដំណើរលោករហូត
ដល់សំពៅ។

Acts 20:1
ប្រយោគភ្ជាប់
លោកប៉ូលចាកចេញពីក្រុងអេភេសូរ និងបន្តដំណើររបស់លោកទៀត។
បន្ទាប់ពី ភាពចលាចលនេះបានបញ្ចប់
«បន្ទាប់ពីកុប្បកម្ម» ឬ «ក្រោយពីកុប្បកម្ម»
លោកបានលា
«លោកបានជម្រាបលា»
បានលើកទឹកចិត្តដល់ពួកគេជាច្រើន
«បានលើកទឹកចិត្តបងប្អូនអ្នកជឿជាច្រើន» ឬ
«បាននិយាយការជាច្រើនលើកទឹកចិត្តបងប្អូនអ្នកជឿ»
បន្ទាប់មក លោកស្នាក់នៅទីនោះអស់រយៈពេលបីខែ
«បន្ទាប់មក លោកស្នាក់នៅទីនោះអស់រយៈពេលបីខែ»។
ឃ្លានេះនិយាយពីពេលវេលា ប្រៀបដូចជាការចំណាយ។
ជនជាតិយូដារៀបចំផែនការទាស់នឹងលោក
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជនជាតិយូដាបានរៀបគម្រោងទាស់នឹងលោក» ឬ
«ជនជាតិយូដាបានរៀបគម្រោងដោយសម្ងាត់ដើម្បីធ្វើទុក្ខដល់លោក» (សូមមើល: | Active or Passive)
ជាតិយូដា
ពាក្យនេះ មានន័យថា តែជនជាតិយូដាទេ។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«ជនជាតិយូដាខ្លះ»
ពេលលោករៀបនឹងចុះសំពៅទៅស្រុកស៊ីរី
«ពេលលោករៀបចំចុះសំពៅទៅស្រុកស៊ីរី»
Acts 20:4
ព័ត៌មានទូទៅ
ពាក្យ «គាត់» នៅទីនេះ សំដៅលើលោកប៉ូល។ (សូមមើល: ២០:១)
ព័ត៌មានទូទៅ
លោកលូកា ជាអ្នកនិពន្ធសៀវភៅកិច្ចការ បានចូលរួមក្រុង។ នៅទីនេះ
លោកប្រើពាក្យ «យើង» សំដៅលើ លោកលូកា និងលោកប៉ូល។
អ្នកដែលបានរួមដំណើរជាមួយលោក
«ធ្វើដំណើរជាមួយលោក»
លោកសូប៉ាត្រុស...លោកពីរូស ...លោកសេគុនដុស...ទីយីកុស... លោកត្រូភីម
នេះគឺជាឈ្មោះរបស់មនុស្ស។
ស្រុកបេរា...ស្រុកឌើបេ...ក្រុងត្រូអាស
នេះគឺជាឈ្មោះទីកន្លែងផ្សេងៗ។
លោកអើរីស្តាក...លោកកៃយុស
នេះគឺជាឈ្មោះរបស់មនុស្ស។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនៅក្នុងជំពូក ១៩:២៨។
អ្នកទាំងនេះបានចេញដំណើរទៅមុនយើង
«អ្នកទាំងនេះបានចេញដំណើរទៅមុនយើង»
Acts 20:7
ប្រយោគភ្ជាប់
លោកលូកាប្រាប់ពីការដែលលោកប៉ូលបង្រៀននៅក្រុងត្រូអាស
និងអំពីអ្វីដែលបានកើតឡើងជាមួយនឹងអ៊ើទីកុស។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកលូកា លោកប៉ូល
និងអ្នករួមដំណើរជាមួយពួកគេ។ (សូមមើល: និង ២០:៤)
កាច់នំបុ័ង
នំបុ័ងជាការអាហារសំខាន់សម្រាប់គ្រប់ពេល។ ពាក្យ «កាច់នំបុ័ង» នៅទីនេះ
ប្រហែលជាមានន័យថាពួកគេប្រកបអាហារជាមួយគ្នា។
បន្ទប់ជាន់លើ
ឃ្លានេះអាចនៅផ្ទះជាន់ទីបី។
Acts 20:9
ព័ត៌មានទូទៅ
ពាក្យ «ខ្លួនឯង» សំដៅលើលោកប៉ូល។ ពាក្យ «លោក»
លើកទីមួយសំដៅលើលោកប៉ូល។ ពាក្យ «លោក» លើកទីពីរសំដៅលើយុវជន
អ៊ើទីកុស។ ពាក្យ «គាត់» សំដៅលើ អ៊ើទីកុស។
នៅលើមាត់បង្អួច
បង្អួចបានបើកមានជើងដែលធំល្មមឲ្យមនុស្សម្នាក់អាចអង្គុយបាន។
អ៊ើទីកុស
នេះគឺជាឈ្មោះរបស់មនុស្សម្នាក់។
បានលង់លក់យ៉ាងស្កប់ស្កល់
និយាយពីគេងលក់ យ៉ាងស្កប់ស្កល់ ដែលធ្វើឲ្យមនុស្សធ្លាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «គេងលក់ស្រួល» ឬ «គាត់បានងោកងុយខ្លាំងៗ
រហូតដល់ទីបំផុងគេងលក់ស្រួលតែម្តង» ។
បានធ្លាក់ពីជាន់ទីបីនោះមក ហើយពេលគេលើកឡើង គាត់បានស្លាប់បាត់ទៅហើយ
ពេលពួកគេចុះមក ពិនិត្យមើលស្ថានភាពរបស់គាត់
ពួកគេឃើញថាគាត់បានស្លាប់បាត់ទៅហើយ។ ឃ្លានេះ និយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅជាន់ទីបី
ហើយនៅពេលពួកគេចុះទៅលើកគាត់ឡើង
ពួកគេឃើញថាគាត់ស្លាប់បាត់ទៅហើយ»
ជាន់ទីបី
ឃ្លានេះ មានន័យថាពីរជាន់នៅពីលើជាន់ទីមួយ។ ប្រសិនបើ
ទម្លាប់របស់អ្នកមិនរាប់ជាន់ក្រោម អ្នកអាចនិយាយឃ្លានេះថា «ជាន់ទីពីរ»។
Acts 20:11
ប្រយោគភ្ជាប់
នេះគឺជាចុងបញ្ចប់នៃសាច់រឿង ពីសេចក្តីបង្រៀនរបស់លោកប៉ូលនៅក្រុងត្រូអាស
និង ពីអ៊ើទីកុស។
ព័ត៌មានទូទៅ
ពាក្យ «គាត់» សំដៅលើលោកប៉ូល។
កាច់នំបុ័ង
នំបុ័ងជាអាហារសំខាន់សម្រាប់គ្រប់ពេល។ ពាក្យ «កាច់នំបុ័ង» នៅទីនេះ
ប្រហែលជាមានន័យថា
ពួកគេប្រកបអាហារជាមួយនឹងអាចផ្សេងទៀតមិនគ្រាន់តែនំបុ័ងប៉ុណ្ណោះទេ។
លោកក៏ចេញដំណើរទៅ
«លោកបានចាកចេញទៅ»
យុវជន
ពាក្យនេះ សំដៅលើអ៊ើទីកុស(២០:៩)។ អាចមានន័យបី: ទី១)
គាត់ជាក្មេងដែលមានអាយុលើពី១៤ឆ្នាំ (UDB) ទី២) គាត់អាចមានអាយុពីចន្លោះ
៩ដល់១៤ឆ្នាំ។ ទីបី) ពាក្យ «យុវជន» សំដៅលើ គាត់ជាអ្នកបម្រើ ឬជាទាសករ។
Acts 20:13
ប្រយោគភ្ជាប់
លោកលូកា ជាអ្នកនិពន្ធ លោកប៉ូល
និងអ្នករួមដំណើរជាមួយលោកបានបន្តដំណើររបស់ពួកគេបន្តទៀត។ ប៉ុន្តែ
លោកប៉ូល បានចែកផ្លូវដែរ។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកលូកា និងអស់អ្នកដែលនៅជាមួយគាត់
ប៉ុន្តែ មិនរួមបញ្ចូលលោកប៉ូលទេ។ (សូមមើល:|Exclusive "We")
ព័ត៌មានទូទៅ
ពាក្យ «លោក» «លោកខ្លួនឯង» និង «គាត់» សំដៅលើលោកប៉ូល។
ពួកយើងផ្ទាល់ យើងចង់ចុះសំពៅ
ពាក្យ «ពួកយើងផ្ទាល់» បន្ថែមដើម្បីបញ្ជាក់ និងការញែកចេញពីលោកលូកា
ហើយនិងអ្នករួមដំណើរជាមួយលោកចេញពីលោកប៉ូល
ដែលមិនបានរួមសំពៅជាមួយគ្នា។ (សូមមើល:|Reflexive Pronouns និង|
Exclusive "We")
ចុះសំពៅទៅក្រុងអាសុស
អាសុសគឺជាក្រុងមួយដែលមានទីតាំងបច្ចុប្បន្ននៅប៊ឺរាម ក្នុងប្រទេសទួរគី
នៅឈូងសមុទ្រប៉ាត់ម៉ុស។ (សូមមើល:|How to Translate Names)
លោកខ្លួនឯងផ្ទាល់ចង់
លោកខ្លួនឯងប្រើដើម្បីបញ្ជាក់ថា នេះគឺជាអ្វីដែលលោកប៉ូលចង់ធ្វើ។ (សូមមើល:|
Reflexive Pronouns)
ធ្វើដំណើរតាមផ្លូវគោក
«ធ្វើដំណើរតាមផ្លូវគោក»
ឆ្ពោះទៅក្រុងមីទូឡែន
ក្រុងមីទូឡែនគឺជាទីក្រុងមួយ ដែលបច្ចុប្បន្ននេះនៅក្នុងប្រទេសទួរគី
នៅឈូងសមុទ្រប៉ាត់ម៉ុស។ (សូមមើល:|How to Translate Names)
Acts 20:15
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកប៉ូល អ្នកនិពន្ធលោកលូកា
ហើយនិងអ្នកធ្វើដំណើរជាមួយពួកគេ។
ទៅដល់ទន្លឹមនឹងកោះ
«នៅជិតកោះ» ឬ «ឆ្លងពីកោះ»
កោះឃីយ៉ូស
កោះឃីយ៉ូសគឺជាកោះដែលនៅឈូងសមុទ្រតួគីបច្ចុប្បន្ន
នៅឈូងសមុទ្រប៉ាត់ម៉ុស។ (សូមមើល:|How to Translate Names)
យើងទៅដល់កោះសាម៉ូស
«យើងបានទៅដល់លើកោះសាម៉ូស»។
កោះសាម៉ូស
កោះសាម៉ូសគឺជាកោះនៅភាគខាងត្បូងនៃកោះឃីយ៉ូស
ដែលបច្ចុប្បន្ននេះនៅឈូងសមុទ្រប៉ាត់ម៉ុស ប្រទេសតួគី។ (សូមមើល:|How to
Translate Names)
យើងក៏បានទៅដល់ក្រុងមីលេត
ក្រុងមីលេតជាទីក្រុងកំពង់ផែ នៅភាគខាងជើងនៃមាត់ទន្លេមេហ្គាន។ (សូមមើល:|
How to Translate Names)
លោកប៉ូលសម្រេចចិត្តមិនចូលក្រុងអេភេសូរទេ
លោកប៉ូលធ្វើដំណើរពីភាគខាងត្បូងកំពង់ផែអេភេសូរ
ហួសទៅភាគខាងត្បូងនៃក្រុងមីលេត។ (សូមមើល:|How to Translate
Names)

generated on Wed Sep 10 16:16:32 2025

ដើម្បីកុំឲ្យយឺតដំណើរ
ឃ្លានេះនិយាយពី «ពេលវេលា»
ប្រៀបដូចជាចំណាយទិញទំនិញដែលមនុស្សម្នាក់អាចចំណាយ ឬប្រើប្រាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ
លោកមិនបានចំណាយពេលនៅទីនោះឡើយ» ឬ «ដូច្នេះ
លោកមិនបានពន្យាពេលឡើយ»
Acts 20:17
ប្រយោគភ្ជាប់
លោកប៉ូលបានហៅពួកអ្នកដឹកនាំពីក្រុមជំនុំអេភេសូរ
ហើយចាប់ផ្តើមនិយាយទៅពួកគេ។
ព័ត៌មានទូទៅ
ពាក្យ «លោក» សំដៅលើលោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើលោកប៉ូល និងអ្នកដឹកនាំ
ដែលគាត់គាត់កំពុងនិយាយជាមួយ។
ក្រុងមីលេត
ក្រុងមីលេត ជាកំពង់ផែក្រុងភាគខាងលិចនៃអាស៊ីកណ្តាល ជិតមានទន្លេមេហ្គាន។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុង ២០:១៥។ (សូមមើល: |How to Translate Names)
បងប្អូនដឹងស្រាប់ហើយ
ពាក្យ «អ្នកខ្លួនឯង» ប្រើដើម្បីបញ្ជាក់ន័យ។
ខ្ញុំជាន់ជើងលើទឹកដីស្រុកអាស៊ី
ពាក្យ «ជើង» នៅទីនេះ តំណាងឲ្យមនុស្សទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានចូលដល់អាស៊ី»
ពីការដែលខ្ញុំបានចំណាយពេលវេលាជាមួយបងប្អូន
ឃ្លានេះ និយាយពីពេលវេលា របៀបដូចជាអ្វីមួយដែលត្រូវចំណាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំតែងតែធ្វើឲ្យខ្លួនខ្ញុំ មានពេលសម្រាប់បងប្អូន»
ដោយចិត្តទន់ទាប
ឃ្លានេះ និយាយពីអ្វីមួយដែលបន្ទាបខ្លួន របៀបដូចជាការបន្ទាបដល់ដី។ ពាក្យ «គំនិត» តំណាងឲ្យឥរិយាបថខាងក្នុងរបស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាបខ្លួន» ឬ «ភាពទន់ទាប»
ទាំងទឹកភ្នែក
ពាក្យ «ទឹកភ្នែក» តំណាងឲ្យអារម្មណ៍កើតទុក្ខ និងយំសោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំយំ នៅពេលខ្ញុំបម្រើព្រះអម្ចាស់»
របស់ជនជាតិយូដា
នេះមិនមែនសំដៅលើជនជាតិយូដាទាំងអស់។
ឃ្លានេះបានឲ្យយើងដឹងថានរណាជាអ្នកមានគម្រោងអាក្រក់។
របៀបផ្សេងទៀតនៃការបកប្រែ: «របស់ជនជាតិយូដាខ្លះ» ។
បងប្អូនដឹងហើយថា ខ្ញុំមិនបានឈប់ពីការប្រកាសដល់បងប្អូន
«បងប្អូនដឹងហើយថា ខ្ញុំមិនដែលនៅស្ងៀមឡើយ ប៉ុន្តែ
ខ្ញុំតែងតែប្រកាសដល់បងប្អូនជានិច្ច»
និងតាមផ្ទះមួយទៅផ្ទះមួយ
លោកប៉ូលបានបង្រៀនដល់បងប្អូននៅតាមផ្ទះផ្សេងៗដោយឡែក។ ពាក្យ «ខ្ញុំបង្រៀន» ងាយយល់។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយខ្ញុំក៏បង្រៀនពេលខ្ញុំនៅតាមផ្ទះដែរ» ។
អំពីការប្រែចិត្តមករកព្រះជាម្ចាស់ និងមានជំនឿលើព្រះអម្ចាស់ព្រះយេស៊ូរបស់យើង
ជានាមអរូប «ការប្រែចិត្ត» ឬ «ជំនឿ» អាចនិយាយជាកិរិយាសព្ទក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេត្រូវប្រែចិត្តនៅចំពោះព្រះជាម្ចាស់
និងជឿលើព្រះអម្ចាស់យេស៊ូគ្រិស្ត»
Acts 20:22
ព័ត៌មានទូទៅ
ពាក្យ «ខ្ញុំ» សំដៅលើលោកប៉ូល។
ខ្ញុំនឹងធ្វើដំណើរទៅក្រុងយេរូសាឡិម ដោយព្រះវិញ្ញាណបានបណ្តាល ខ្ញុំមិនដឹងថា នឹងមានអ្វីកើតឡើងដល់ខ្ញុំនៅទីនោះទេ
ព្រះវិញ្ញាណដ៏វិសុទ្ធបានជំរុញលោកប៉ូលឲ្យធ្វើដំណើរទៅក្រុងយេរូសាឡិម
និយាយប្រៀបដូចជាព្រះវិញ្ញាណចងកាត់ដូចជាទាសករ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះវិញ្ញាណដ៏វិសុទ្ធ
បានជំរុញខ្ញុំឲ្យទៅក្រុងយេរូសាឡិម
ហើយខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះខ្ញុំនៅទីនោះទេ»
ព្រះវិញ្ញាណដ៏វិសុទ្ធដាស់តឿនដល់ខ្ញុំ
«ព្រះវិញ្ញាណដ៏វិសុទ្ធបានមានបន្ទូលដាស់តឿនដល់ខ្ញុំ»
ច្រវាក់ និងការឈឺចាប់រងចាំខ្ញុំ
«ច្រវាក់» សំដៅលើ លោកប៉ូលត្រូវបានចាប់ខ្លួន និងដាក់គុក។
របៀបផ្សេងទៀតនៃការបកប្រែ: «គេចាប់ខ្ញុំដាក់គុក ហើយធ្វើឲ្យខ្ញុំឈឺចាប់»។
ប្រសិនបើខ្ញុំបញ្ចប់ការប្រណាំង និងបញ្ចប់ព័ន្ធកិច្ចដែលខ្ញុំបានទទួលពីព្រះអម្ចាស់យេស៊ូ
ឃ្លានេះ និយាយពី «ការរត់ប្រណាំង» និង «ព័ន្ធកិច្ច» របស់លោកប៉ូល។
ឃ្លានេះប្រសិនបើពួកគេជាវត្ថុដែលព្រះយេស៊ូប្រទាន
ហើយលោកប៉ូលជាអ្នកទទួល។ «ការប្រណាំង» និង «ព័ន្ធកិច្ច» នៅទីនេះ
មានន័យដូចគ្នា។ លោកប៉ូលនិយាយការនេះម្តងទៀតដើម្បីបញ្ជាក់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីឲ្យខ្ញុំអាចបំពេញការងារដែលព្រះអម្ចាស់យេស៊ូបានបង្គាប់ឲ្យខ្ញុំធ្វើ»
ខ្ញុំបញ្ចប់ការប្រណាំង
លោកប៉ូលនិយាយអំពីបញ្ចប់ការងារដែលព្រះយេស៊ូបង្គាប់លោកឲ្យធ្វើ
របៀបដូចជាការរត់ប្រណាំង។ (សូមមើល: |Metaphor)
ដើម្បីឲ្យខ្ញុំធ្វើបន្ទាល់អំពីដំណឹងល្អនៃព្រះគុណរបស់ព្រះជាម្ចាស់
«ដើម្បីប្រាប់មនុស្សពីដំណឹងល្អអំពីព្រះគុណរបស់ព្រះជម្ចាស់»។
នេះគឺជាព័ន្ធកិច្ចដែលលោកប៉ូលទទួលពីព្រះយេស៊ូ។
Acts 20:25
ប្រយោគភ្ជាប់
លោកប៉ូលបន្តនិយាយទៅកាន់ពួកចាស់ទុំនៅក្រុងអេភេសូរ។ (សូមមើល: ២០:១៧)
ឥឡូវនេះ មើល៍ ខ្ញុំដឹងថា
«ហើយឥឡូវនេះ សូមយកចិត្តទុកដាក់ ព្រោះខ្ញុំដឹង»
ខ្ញុំដឹងថា ក្នុងចំណោមបងប្អូនទាំងអស់គ្នា
«ខ្ញុំដឹងថាបងប្អូនទាំងអស់គ្នា»
ក្នុងចំណោមបងប្អូនទាំងអស់គ្នា ទាំងប្រកាសដំណឹងល្អអំពីព្រះរាជ្យ
ពាក្យ «ព្រះរាជ្យ» តំណាងឲ្យការគ្រប់គ្រងជាស្តេច។
របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានប្រកាសទៅដល់អស់អ្នកដែលខ្ញុំបង្រៀនពីព្រះបន្ទូលអំពីព្រះជាម្ចាស់សោយរាជ្យជាស្តេច»
ឬ «ទៅអ្នកដែលខ្ញុំប្រកាសពីការដែលព្រះជាម្ចាស់បង្ហាញអង្គទ្រង់ជាស្តេច»
បងប្អូននឹងលែងឃើញមុខខ្ញុំទៀតហើយ
ពាក្យ «មុខ» នៅទីនេះ សំដៅលើវត្តមានរបស់លោកប៉ូលខាងរូបសាច់របស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងលែងឃើញខ្ញុំនៅលើផែនដីទៀតហើយ» (សូមមើល: |Synecdoche)
ខ្ញុំជាមនុស្សគ្មានកំហុសពីឈាមរបស់នរណាម្នាក់ឡើយ
ពាក្យ «ឈាម» នៅទីនេះ តំណាងឲ្យមនុស្សម្នាក់ស្លាប់ ដែលនៅក្នុងករណីនេះ
មិនស្លាប់ខាងរូបសាច់នេះទេ ប៉ុន្តែ
ស្លាប់ខាងវិញ្ញាណនៅពេលព្រះជាម្ចាស់ប្រកាសពីកំហុសរបស់មនុស្សម្នាក់។
លោកប៉ូលបានប្រាប់ពួកគេពីសេចក្តីពិតរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនទទួលខុសត្រូវសម្រាប់នរណាឡើយ
នៅពេលព្រះជាម្ចាស់ជំនុំជម្រះកំហុសនៃអំពើបាប
ដោយសារពួកគេមិនបានទុកចិត្តលើព្រះយេស៊ូ» ។
នរណាម្នាក់ឡើយ
នរណាម្នាក់ នៅទីនេះមានន័យថាទាំងប្រុសទាំងស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «នរណាក៏ដោយ»
ដ្បិត ខ្ញុំមិនបានលាក់លៀមក្នុងការប្រកាសដល់បងប្អូន
«ដ្បិត ខ្ញុំមិននៅស្ងៀម ហើយមិនប្រាប់ដល់បងប្អូនឡើយ»។ ឃ្លានេះ
និយាយក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត
ខ្ញុំបានប្រកាសយ៉ាងច្បាស់ហើយដល់បងប្អូន»
Acts 20:28
ដូច្នេះ
ពាក្យនេះសម្គាល់ពីប្រយោគ ដែលបាននិយាយ ដោយអ្វីដែលបាននិយាយពីមុន។
នៅក្នុងករណីនេះ
វាបានត្រឡប់ទៅរកអ្វីដែលលោកបានមានប្រសាសន៍កន្លងមកនៅក្នុងសុន្ទរកថារបស់លោក
អំពីការដែលលោកចាកចេញពីពួកគេ។
ចូរថែរក្សាខ្លួនឯង និងថែរក្សាក្រុមអ្នកជឿទាំងមូលផង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្តាក់ឲ្យបងប្អូន ធ្វើជាអ្នកទទួលខុសត្រូវនេះ ដើម្បីឲ្យបងប្អូនថែរក្សាហ្វូងចៀមនៅក្នុងក្រុមជំនុំរបស់ព្រះជាម្ចាស់នៅទីនេះ អ្នកជឿបៀបដូចជា «ហ្វូងចៀម»។

generated on Wed Sep 10 16:16:32 2025

ព្រះជាម្ចាស់បានផ្ទុកផ្តាក់ដល់អ្នកដឹកនាំក្រុមជំនុំឲ្យមើលថែសហគមន៍អ្នកជឿដូចជាមើលថែអ្នកគង្វាលមើលថែហ្វូងចៀម ហើយការពារពួកគេពីឆ្កែចចក។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្តាក់ក្រុមអ្នកជឿដល់បងប្អូន។ ចូរប្រាកដថាបងប្អូនមើលថែក្រុមជំនុំរបស់ព្រះជាម្ចាស់» (សូមមើល:|Metaphor)
ក្រុមជំនុំរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានទិញ ដោយសារព្រះលោហិតរបស់ព្រះអង្គផ្ទាល់
បានបង្ហូរ «ឈាម» របស់ព្រះគ្រិស្ត នៅទីនេះ
ប្រៀបដូចជាការបង់ថ្លៃទៅព្រះជាម្ចាស់សម្រាប់បាបរបស់យើង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះគ្រិស្តបានសង្គ្រោះមនុស្សពីបាបរបស់ពួកគេដោយបង្ហូរព្រះលោហិតនៅលើឈើឆ្កាង» (សូមមើល: Metaphor)
ព្រះលោហិតរបស់ព្រះអង្គផ្ទាល់
ពាក្យ «លោហិត» តំណាងឲ្យការសុគតរបស់ព្រះគ្រិស្ត។
នឹងមានចចកដ៏សាហាវចូលមកក្នុងចំណោមបងប្អូន ហើយវានឹងមិនប្រណីដល់ហ្វូងចៀមឡើយ
រូបភាពរបស់មនុស្សដែលបង្រៀនគោលលទ្ធិខុសឆ្គង
និងអ្នកដែលធ្វើទុក្ខដល់សហគមន៍របស់អ្នកជឿ គិតថាពួកគេជាពួកចចក
ដែលស៊ីចៀមនៅក្នុងហ្វូង។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានខ្មាំងសត្រូវជាច្រើននឹងមកក្នុងចំណោមអ្នករាល់
ហើយព្យាយាមធ្វើទុក្ខដល់សហគមន៍គ្រិស្តបរិស័ទ» ។
ដើម្បីទាក់ទាញពួកសិស្សឲ្យទៅតាមពួកគេទៀតផង
គ្រូបង្រៀនខុសឆ្គងបញ្ចុះបញ្ចូលអ្នកជឿឲ្យចាប់ផ្តើមជឿលើសេចក្តីបង្រៀនខុសឆ្គងរបស់ពួកគេ
និយាយដូចជាពួកគេនាំចៀមឲ្យវង្វេងពីហ្វូងចៀម ហើយដើរតាមព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីបញ្ចុះបញ្ចូលមនុស្សដែលជាសិស្សរបស់ព្រះគ្រិស្ត
ឲ្យក្លាយជាសិស្សរបស់គេវិញ» ។
Acts 20:31
ដូច្នេះ ចូរប្រយ័ត្ន ដោយនឹកចាំថា
«ចូរប្រយ័ត្ន ហើយនឹកចាំថា» ឬ «ចូរប្រយ័ត្ន ហើយអ្នកត្រូវចាំ»
ដូច្នេះ ចូរប្រយ័ត្ន
«ចូរប្រយ័ត្ន និងភ្ញាក់រលឹកឡើង» ឬ «ប្រយ័ត្ន»
នឹកចាំ
«បន្តនឹកចាំ» ឬ «កុំភ្លេច»
ក្នុងរយៈពេលបីឆ្នាំ ខ្ញុំមិនបានឈប់ក្នុងការដាស់តឿនបងប្អូនគ្រប់គ្នា...ទាំងយប់ ទាំងថ្ងៃ
លោកប៉ូលមិនបង្រៀនពួកគេរហូតដល់បីឆ្នាំ ប៉ុន្តែ លើសជាងបីឆ្នាំ។ (សូមមើល:|Hyperbole)
ខ្ញុំមិនបានឈប់ក្នុងការដាស់តឿន
«ខ្ញុំមិនបានឈប់ក្នុងការដាស់តឿន»
ដោយទឹកភ្នែក
ពាក្យ «ទឹកភ្នែក» សំដៅលើលោកប៉ូលយំដោយសារអារម្មណ៍បារម្ភ
ពេលគាត់ចាកចេញ ហើយលោកបានដាស់តឿនពួកគេផងដែរ។
ខ្ញុំសូមផ្ទុកផ្តាក់បងប្អូនដល់ព្រះជាម្ចាស់ ហើយផ្ញើនឹងព្រះបន្ទូលនៃព្រះគុណរបស់ព្រះអង្គ
ពាក្យ «ព្រះបន្ទូល» តំណាងឲ្យព្រះរាជសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំទូលទៅព្រះជាម្ចាស់ឲ្យមើលថែបងប្អូន
ហើយឲ្យព្រះអង្គជួយបងប្អូននៅតែបន្តជឿលើព្រះបន្ទូលដែលខ្ញុំបានប្រាប់ជាមួយបងប្អូន»
ផ្ទុកផ្តាក់
ប្រគល់នរណាម្នាក់ទៅអ្នកម្នាក់ទៀតទទួលខុសត្រូវមើលថែអ្នកនោះ ឬរបស់នោះ។
ដែលអាចនឹងសាងបងប្អូនឡើង
ជំនឿរបស់អ្នកនោះបានរឹងមាំឡើង បៀបដូចអ្នកនោះជាជញ្ជាំង
ដែលនរណាម្នាក់កំពុងសង់គាត់ឲ្យខ្ពស់ និងរឹងមាំឡើង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលអាចធ្វើឲ្យអ្នកបានរឹងមាំកាន់តែខ្លាំងឡើងៗនៅក្នុងជំនឿ» ។
ព្រមទាំងប្រទានមរតកដល់បងប្អូន
នេះគឺនិយាយអំពី «ព្រះបន្ទូលនៃព្រះគុណរបស់ព្រះអង្គ» ដែលអាចប្រទានមរតកដល់អ្នកជឿ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយព្រះជាម្ចាស់នឹងប្រទានមរតកដល់បងប្អូន»
មរតក
ព្រះពរដែលព្រះជាម្ចាស់ប្រទានដល់អ្នកជឿ គឺនិយាយប្រៀបដូចជាប្រាក់កាស ឬទ្រព្យសម្បត្តិដែលកូនបានទទួលកេរពីឪពុករបស់ខ្លួន។
Acts 20:33
ប្រយោគភ្ជាប់
លោកប៉ូលបានបញ្ចាប់សុន្ទរកថាទៅកាន់ពួកចាស់ទុំរបស់ក្រុមជំនុំនៅក្នុងអេភេសូរ ដែលជាការចាប់ផ្តើមនិយាយនៅក្នុងជំពូក ២០:១៧។
ខ្ញុំមិនចង់បានប្រាក់ មាសឬសម្លៀកបំពាក់អ្វីរបស់នរណាឡើយ
«ខ្ញុំមិនប្រាថ្នាចង់បានប្រាក់របស់អ្នកណាឡើយ» ឬ
«ខ្ញុំមិនចង់បានប្រាក់របស់អ្នកណា មាសឬសម្លៀកបំពាក់អ្វីរបស់នរណាឡើយ»។
ប្រាក់ មាសឬសម្លៀកបំពាក់អ្វីរបស់នរណាឡើយ
សម្លៀកបំពាក់សំដៅលើទ្រព្យសម្បត្តិ បើអ្នកមានសម្លៀកបំពាក់ច្រើនប៉ុណ្ណា
អ្នកជាអ្នកមានខ្លាំងប៉ុណ្ណោះដែរ។
បងប្អូនខ្លួនឯង
ពាក្យ «បងប្អូនខ្លួនឯង» ដែលប្រើនៅទីនេះ គឺដើម្បីបញ្ជាក់ន័យ។ (សូមមើល:|Reflexive Pronouns)
ដៃទាំងពីររបស់ខ្ញុំនេះ បានធ្វើការ ដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្ញុំ
ពាក្យ «ដៃ» នៅទីនេះ តំណាងឲ្យខ្លួនមនុស្សទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំធ្វើការសន្សំប្រាក់
ហើយបង់ថ្លៃចំណាយផ្សេងៗរបស់ខ្ញុំ»
បងប្អូនត្រូវជួយដល់អ្នកដែលខ្សោយ
បងប្អូនត្រូវធ្វើការ
ដើម្បីបងប្អូនមានប្រាក់ជួយដល់អ្នកដែលគ្មានប្រាក់សម្រាប់ខ្លួនគេ»។
អ្នកដែលខ្សោយ
អ្នកអាចនិយាយពាក្យនេះជាគុណនាមធម្មតា គឺជាគុណនាម។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សទន់ខ្សោយ» ឬ «អ្នកដែលទន់ខ្សោយ»
ខ្សោយ
«ឈឺ»
ព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូ
ពាក្យ «ព្រះបន្ទូល» សំដៅលើអ្វីដែលព្រះយេស៊ូមានបន្ទូល»
ដែលឲ្យនោះ មានពរច្រើនជាងទទួល
នេះមានន័យថាមនុស្សម្នាក់ដែលទទួលមេត្តាពីព្រះជាម្ចាស់
ហើយមានបទពិសោធជាមួយអំណរថែមទៀត នៅពេលគេឲ្យទៅអ្នកដទៃ
ជាជាងអ្នកដែលតែងតែទទួលពីអ្នកដទៃ។
Acts 20:36
ប្រយោគភ្ជាប់
លោកប៉ូលបានបញ្ចប់ពេលវេលារបស់គាត់ជាមួយពួកចាស់ទុំនៅក្នុងក្រុមជំនុំអេភេសូរ ដោយអធិស្ឋានជាមួយពួកគេ។
លោកបានលុតជង្គង់ចុះហើយបានអធិស្ឋាន
វាគឺជាទម្លាប់សាមញ្ញក្នុងការលុតជង្គង់ក្នុងពេលអធិស្ឋាន។
បង្ហាញការគោរព
ការបង្ហាញពីការបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់។
ឱបកលោកប៉ូល
«ឱបលោកយ៉ាងខ្លាំង» ឬ «ដាក់ដៃរបស់ពួកគេនៅជុំវិញលោក»
ថើបលោក
ថើបថ្ពាល់នរណាម្នាក់បង្ហាញពីភាពជាបងប្អូន ឬស្រឡាញ់ជាមិត្តសម្លាញ់
នៅក្នុងទម្លាប់របស់ពួកមជ្ឈិមបូព៌ា។
គេនឹងលែងឃើញមុខលោកទៀតហើយ
ពាក្យ «មុខ» នៅទីនេះ តំណាងឲ្យរូបសាច់របស់លោកប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងលែងឃើញខ្ញុំនៅលើផែនដីនេះទៀត» (សូមមើល:|Synecdoche)

---

21 [1]ក្រោយពីបានលាពួកគេហើយ យើងបានចេញសំពៅតម្រង់ឆ្ពោះទៅកោះកូស។ នៅថ្ងៃបន្ទាប់ យើងបានទៅដល់ទីក្រុងកោះរ៉ូដូស ហើយចេញពីកោះរ៉ូដូស ទៅដល់ក្រុងប៉ាតារ៉ា។[2]នៅពេលយើងឃើញមានសំពៅមួយត្រូវទៅស្រុកភេនីស យើងក៏ចុះសំពៅនោះបន្តដំណើរទៀត។
[3]ពេលមកជិតដល់កោះគីប្រុស យើងវាងតាមខាងត្បូង បន្តដំណើរឆ្ពោះទៅស្រុកស៊ីរី និងបានចូលចតកំពង់ផែក្រុងទីរ៉ុសដើម្បីយកទំនិញចេញពីសំពៅ។[4]យើងបានជួបពួកសិស្សនៅទីនោះ ហើយស្នាក់នៅជាមួយពួកគេអស់រយៈពេលប្រាំពីរថ្ងៃ។ ដោយព្រះវិញ្ញាណសម្តែងឲ្យគេដឹង គេបានឃាត់លោកប៉ូល មិនឲ្យឡើងទៅក្រុងយេរូសាឡឹមឡើយ។

generated on Wed Sep 10 16:16:32 2025

[5]លុះប្រាំពីរថ្ងៃនោះកន្លងផុតទៅ យើងត្រូវចេញដំណើរទៅមុខទៀត ហើយបងប្អូនទាំងអស់ ព្រមទាំងភរិយា និងកូនចៅរបស់គេជូនដំណើរយើងរហូតដល់ក្រៅទីក្រុង។ យើងនាំគ្នាលុតជង្គង់ អធិស្ឋាននៅមាត់សមុទ្រ។[6]បន្ទាប់មក យើងបានជម្រាបលាគ្នា រួចចុះសំពៅ។ រីឯពួកគេវិញ ពួកគេវិលត្រឡប់ទៅផ្ទះរៀងៗខ្លួន។
[7]ពេលយើងបានចាកចេញពីក្រុងទីរ៉ុសមក យើងក៏មកដល់ក្រុងផ្ទោឡេម៉ៃស៍។ យើងបានចូលទៅជម្រាបសួរពួកបងប្អូននៅក្រុងផ្ទោឡេម៉ៃស៍ និងស្នាក់នៅជាមួយពួកគេមួយថ្ងៃ។[8]នៅថ្ងៃបន្ទាប់ យើងបន្តដំណើរដល់ក្រុងសេសារា។ យើងបានចូលផ្ទះលោកភីលីព ជាអ្នកផ្សាយដំណឹងល្អ និងជាម្នាក់នៅក្នុងចំណោមក្រុមប្រាំពីររូប ហើយយើងក៏ស្នាក់នៅផ្ទះគាត់។[9]លោកភីលីពមានកូនក្រមុំបួននាក់ដែលថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់។
[10]យើងស្នាក់នៅទីនោះជាច្រើនថ្ងៃ រួចពេលនោះមានព្យាការីមួយរូបឈ្មោះអកាប៊ូសបានធ្វើដំណើរមកពីស្រុកយូដា។[11]គាត់មកជួបយើង ហើយយកខ្សែក្រវាត់លោកប៉ូលមកចងជើងចងដៃរបស់ខ្លួនទាំងពោលថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលថា នៅក្រុងយេរូសាឡឹមសាសន៍យូដានឹងចងដៃចងជើងម្ចាស់ខ្សែក្រវាត់នេះដូច្នេះដែរ ហើយថែមទាំងបញ្ជូនលោកទៅក្នុងកណ្តាប់ដៃរបស់សាសន៍ដទៃផង»។
[12]កាលបានឮពាក្យនេះហើយ ទាំងយើង ទាំងបងប្អូនដែលនៅក្រុងនោះ ក៏អង្វរលោកប៉ូលមិនឲ្យឡើងទៅក្រុងយេរូសាឡឹមឡើយ។[13]ប៉ុន្តែ លោកប៉ូលតបមកវិញថា៖ «ហេតុអ្វីបានជាបងប្អូននាំគ្នាយំ ព្រមទាំងធ្វើឲ្យខ្ញុំពិបាកចិត្តដូច្នេះ? ខ្ញុំបានប្រុងប្រៀបខ្លួនរួចស្រេចហើយ មិនត្រឹមតែឲ្យគេចងប៉ុណ្ណោះទេ គឺថែមទាំងឲ្យគេសម្លាប់នៅក្រុងយេរូសាឡឹម ព្រោះតែព្រះនាមរបស់ព្រះអម្ចាស់យេស៊ូទៀតផង»។[14]ដោយយើងពុំអាចឃាត់លោកបានទេនោះ យើងក៏ឈប់អង្វរលោក ហើយពោលថា៖ «សូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ចុះ»។
[15]ក្រោយពីបានស្នាក់នៅទីនោះយូរបន្តិចមក យើងរៀបចំខ្លួនទៅក្រុងយេរូសាឡឹម។[16]ពួកសិស្សនៅក្រុងសេសារាខ្លះ បានរួមដំណើរជាមួយយើង។ ហើយនាំយើងទៅស្នាក់នៅផ្ទះបុរសម្នាក់ឈ្មោះម៉្នាសុន ជាអ្នកកោះគីប្រុស និងជាសិស្សតាំងដើមដំបូងមក។
[17]ពេលទៅដល់ក្រុងយេរូសាឡឹម ពួកបងប្អូនបានទទួលយើងដោយរីករាយ។[18]នៅថ្ងៃបន្ទាប់ លោកប៉ូលបានធ្វើដំណើរជាមួយយើងទៅផ្ទះលោកយ៉ាកុប ហើយពួកព្រឹទ្ធាចារ្យទាំងអស់ក៏ជួបជុំគ្នានៅទីនោះដែរ។[19]លោកបានជម្រាបសួរពួកបងប្អូនហើយ លោកប៉ូលរៀបរាប់យ៉ាងល្អិតល្អន់អំពីកិច្ចការ ដែលព្រះអម្ចាស់បានធ្វើក្នុងចំណោមសាសន៍ដទៃតាមរយៈព័ន្ធកិច្ចរបស់លោក។
[20]ពេលបានឮលោកប៉ូលមានប្រសាសន៍ដូច្នេះ គេនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ហើយពោលមកកាន់លោកថា៖ «បងអើយ! បងឃើញទេ មានជនជាតិយូដារាប់ម៉ឺននាក់បានជឿ។ បងប្អូនទាំងនោះរក្សាក្រឹត្យវិន័យខ្លាំងណាស់។[21]ប៉ុន្តែ គេបានឮដំណឹងថា បងបានបង្រៀនជនជាតិយូដាទាំងអស់ ដែលរស់នៅក្នុងចំណោមសាសន៍ដទៃ មិនឲ្យប្រតិបត្តិតាមគម្ពីរវិន័យរបស់លោកម៉ូសេទេ គឺបងប្រាប់គេមិនឲ្យធ្វើពិធីកាត់ស្បែកកូនចៅ និងមិនឲ្យកាន់តាមទំនៀមទម្លាប់ចាស់ឡើយ។
[22]តើយើងត្រូវធ្វើដូចម្តេចវិញ? គេមុខជាដឹងថាបងនៅទីនេះមិនខាន។[23]សូមធ្វើតាមយោបល់យើងចុះ ដ្បិតគ្នាយើងបួននាក់មានជាប់បំណន់។[24]សូមបងនាំគេទៅ ហើយធ្វើពិធីជម្រះកាយឲ្យបានវិសុទ្ធជាមួយគេ ព្រមទាំងចេញប្រាក់ឲ្យគេកោរសក់ផង ដើម្បីឲ្យមនុស្សម្នាដឹងគ្រប់គ្នាថា ដំណឹងដែលគេបានឮអំពីបងនោះមិនពិតទេ ផ្ទុយទៅវិញ បងក៏ប្រព្រឹត្តតាមក្រឹត្យវិន័យដែរ។
[25]រីឯសាសន៍ដទៃដែលបានជឿនោះ យើងបានសរសេរសេចក្តីដែលយើងបានសម្រេចជូនទៅគេរួចហើយ ថាកុំឲ្យបរិភោគសាច់ដែលបានសែនរូបសំណាក់ កុំបរិភោគឈាម កុំបរិភោគសាច់សត្វដែលសម្លាប់ដោយច្របាច់ក និងកុំរួមរស់ជាមួយគ្នាដោយឥតរៀបការ»។[26]នៅថ្ងៃបន្ទាប់ លោកប៉ូលបាននាំបងប្អូនទាំងបួននាក់នោះទៅធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធជាមួយលោក។ លោកក៏ចូលទៅក្នុងព្រះវិហារ ប្រាប់គេអំពីពេលកំណត់ដែលពិធីជម្រះកាយឲ្យបានវិសុទ្ធនេះនឹងត្រូវចប់ និងពេលកំណត់ដែលម្នាក់ៗត្រូវថ្វាយតង្វាយ។
[27]លុះរយៈពេលមួយសប្តាហ៍នោះជិតផុត មានជនជាតិយូដាមកពីស្រុកអាស៊ី បានឃើញលោកនៅក្នុងព្រះវិហារ ក៏បះបោរបណ្តាជនទាំងមូលឲ្យនាំគ្នាចាប់លោក។[28]ពួកគេស្រែកឡើងថា៖ «បងប្អូនជនជាតិអ៊ីស្រាអែលអើយ សូមជួយផង! ជននេះហើយដែលបានប្រៀនប្រដៅមនុស្សម្នា នៅគ្រប់ទីកន្លែងឲ្យប្រឆាំងនឹងប្រជារាស្ត្រអ៊ីស្រាអែល ប្រឆាំងនឹងក្រឹត្យវិន័យ ហើយប្រឆាំងនឹងព្រះវិហារ។ គាត់ថែមទាំងបាននាំសាសន៍ក្រិកចូលមកក្នុងព្រះវិហារ គឺបង្អាប់បង្អោនទីកន្លែងដ៏វិសុទ្ធនេះ»។[29]គេថាដូច្នេះ មកពីគេបានឃើញលោកត្រូភីម ជាអ្នកក្រុងអេភេសូរ នៅជាមួយលោកប៉ូលក្នុងទីក្រុង ហើយគេស្មានថា លោកបាននាំគាត់ចូលក្នុងព្រះវិហារដែរ។
[30]ពេលនោះ មានកើតចលាចលពេញទីក្រុង ប្រជាជននាំគ្នារត់មកពីគ្រប់ទិសទី ហើយពួកគេបានចាប់លោកប៉ូលអូសចេញពីព្រះវិហារ រួចបិទទ្វារភ្លាម។[31]នៅពេលដែលពួកគេបម្រុងនឹងសម្លាប់លោកប៉ូល ដំណឹងអំពីចលាចលនៅក្រុងយេរូសាឡឹមក៏បានឮទៅដល់មេបញ្ជាការកងទាហានរ៉ូម។
[32]ភ្លាមនោះ គាត់នាំកូនទាហាន និងនាយទាហាន រត់ទៅកាន់បណ្តាជន។ កាលប្រជាជនបានឃើញមេបញ្ជាការ និងពួកទាហាន គេឈប់វាយលោកប៉ូល។[33]បន្ទាប់មក មេបញ្ជាការបានចូលទៅជិត ហើយចាប់លោក ព្រមទាំងបញ្ជាគេឲ្យដាក់ច្រវាក់ពីរថែមទៀតផង រួចទើបសាកសួរថា លោកប៉ូលនេះជានរណា ហើយបានធ្វើអ្វីខ្លះ។
[34]ក្នុងចំណោមបណ្តាជនមានអ្នកខ្លះស្រែកយ៉ាងនេះ អ្នកខ្លះស្រែកយ៉ាងនោះ។ ដោយមានសំឡេងអឺងកងពេក លោកមេបញ្ជាការពុំអាចដឹងរឿងហេតុច្បាស់លាស់ឡើយ គាត់ក៏បញ្ជាគេឲ្យនាំលោកប៉ូលទៅបន្ទាយ។[35]ពេលលោកប៉ូលមកដល់ជណ្តើរបន្ទាយ ពួកទាហាននាំគ្នាសែងលោក ព្រោះបណ្តាជនចង់វាយលោក។[36]បណ្តាជនមកតាមទាំងកម្រោល និងស្រែកថា៖ «សម្លាប់គាត់ចោលទៅ!»។
[37]នៅពេលគេហៀបនឹងនាំលោកប៉ូលចូលទៅក្នុងបន្ទាយ លោកមានប្រសាសន៍ទៅមេបញ្ជាការថា៖ «តើខ្ញុំមានសិទ្ធិនិយាយជាមួយលោកបន្តិចបានឬទេ?»។ មេបញ្ជាការពោលមកលោកថា៖ «តើអ្នកចេះនិយាយភាសាក្រិកដែរមែនទេ?[38]ដូច្នេះ អ្នកមិនមែនជាជនជាតិអេស៊ីប ដែលបាននាំការបះបោរប្រជាជនប៉ុន្មានថ្ងៃមុននេះ ហើយនាំពួកឧទ្ទាមបួនពាន់នាក់ ចូលព្រៃនោះទេឬ?»។
[39]លោកប៉ូលមានប្រសាសន៍ទៅគាត់ថា៖ «ខ្ញុំជាជនជាតិយូដា កើតនៅក្រុងតើសុស ជាក្រុងដ៏ល្បីល្បាញក្នុងស្រុកគីលីគា! សូមលោកមេត្តាអនុញ្ញាតឲ្យខ្ញុំនិយាយទៅកាន់ប្រជាជននេះផង»។[40]លោកមេបញ្ជាការក៏អនុញ្ញាតឲ្យ រួចលោកប៉ូលឈរនៅលើកាំជណ្តើរ ហើយលើកដៃធ្វើសញ្ញាទៅប្រជាជន។ នៅពេលនោះបណ្តាជនក៏ស្ងប់ស្ងាត់ ហើយលោកមានប្រសាសន៍ទៅគេជាភាសាហេប្រឺថា៖

Acts 21:1

ប្រយោគភ្ជាប់

លោកលូកាជាអ្នកនិពន្ធ លោកប៉ូល
និងអ្នករួមដំណើរជាមួយលោកបន្តដំណើរទៅមុខទៀត។

ព័ត៌មានទូទៅ

ពាក្យ «យើង» នៅទីនេះ សំដៅលើអ្នកនិពន្ធ លោកលូកា លោកប៉ូល
និងអ្នករួមដំណើរជាមួយលោកបន្តដំណើរជាមួយពួកគេ។ (សូមមើល: | Exclusive "We")

យើងបានធ្វើដំណើរតម្រង់ឆ្ពោះទៅក្រុងកូស

«យើងបានធ្វើដំណើរតម្រង់ឆ្ពោះទៅក្រុងកូស» ឬ
«យើងទៅទីក្រុងកូសត្រង់តែម្តង»

ក្រុងកូស

ក្រុងកូស នៅក្នុងកោះរបស់ក្រិក នៅខាងត្បូងឈូងសមុទ្រប៉ាតម៉ូស។ (សូមមើល: | How to Translate Names)

ក្រុងកោះរ៉ូដូស

កោះរ៉ូដូសគឺជាកោះរបស់ក្រុងនៅក្នុងប្រទេសតួគីបច្ចុប្បន្ន
ដែលស្ថិតតំបន់ឈូងសមុទ្រប៉ាតម៉ូស នៅភាគខាងត្បូងនៃកោះកូស
និងភាគខាងជើងកោះក្រែត។ (សូមមើល: | How to Translate Names)

ក្រុងប៉ាតារ៉ា

ក្រុងប៉ាតារ៉ាគឺជាទីក្រុងនៅភាគខាងត្បូងនៃឈូងសមុទ្ររបស់តួគីបច្ចុប្បន្ន
នៅខាងត្បូងកោះប៉ាតម៉ូស នៅក្នុងសមុទ្រមេឌីទែរ៉ាណេ។ (សូមមើល: | How to Translate Names)

នៅពេលយើងឃើញសំពៅមួយជិះឆ្លងទៅស្រុកភេនីស

ពាក្យ «ជិះសំពៅឆ្លង» តំណាងឲ្យអ្នកសំពៅដែលជិះសំពៅជាមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលយើងឃើញសំពៅមួយ
ជាមួយនឹងអ្នកសំពៅឆ្លងទៅស្រុកភេនីស»

generated on Wed Sep 10 16:16:32 2025

សំពៅនោះហើយចេញដំណើរទៅទៀត
ពាក្យ «ឆ្លង» មិនមែនមានន័យថាភ្លាមៗនោះទេ ប៉ុន្តែ
វាអាចឆ្លងក្នុងពេលឆាប់ៗទៅស្រុកភេនីស។ របៀបផ្សេងទៀតនៃការបកប្រែ:
«សំពៅបន្តឆ្លងកាត់តាមសមុទ្រ» ឬ «សំពៅដែលអាចនឹងឆ្លងទៅ»
Acts 21:3
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកលូកា លោកប៉ូល
និងពួកអ្នកដែលរួមដំណើរជាមួយពួកគេ។
បានងាកទៅខាងឆ្វេង
«ឆ្លងកោះនៅខាងឆ្វេងដៃ»
យកទំនិញចេញពីសំពៅ
ពាក្យ «សំពៅ» តំណាងឲ្យអ្នកសំពៅដែលជិះសំពៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកនាវិកយកទំនិញចេញពីសំពៅ»
តាមរយៈព្រះវិញ្ញាណ ពួកគេបានឃាត់លោកប៉ូល
«ពួកអ្នកជឿបានប្រាប់លោកប៉ូល នូវអ្វីដែលព្រះវិញ្ញាណបានបើកសម្តែងពួកគេ»។
មិនឲ្យទៅក្រុងយេរូសាឡិមឡើយ
ពាក្យ «ជើង» តំណាងឲ្យរូបកាយរបស់មនុស្សទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ថា លោកមិនគួរទៅក្រុងយេរូសាឡិមឡើយ»
Acts 21:5
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើពួកអ្នកជឿដែលមកក្រុងទីរ៉ុស។
ពេលយើងនៅទីនោះបានប្រាំពីរថ្ងៃហើយ
ឃ្លានេះសំដៅលើថ្ងៃ ថ្ងៃរបៀបដូចជាអ្វីមួយដែលមនុស្សចំណាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលប្រាំពីរថ្ងៃកន្លងផុតទៅ» ឬ
«នៅពេលដល់ពេលដែលត្រូវចាកចេញ»។
នៅពេលយើងបានចំណាយពេលជាច្រើនថ្ងៃ
និយាយពីថ្ងៃ បៀបដូចជាអ្វីមួយដែលពួកគេចំណាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលប្រាំពីរថ្ងៃកន្លងផុតទៅ» ឬ
«នៅពេលដល់ពេលដែលត្រូវចាកចេញ»
លុតជង្គង់នៅមាត់សមុទ្រ អធិស្ឋាន
ជាទម្លាប់ធម្មតាក្នុងការលុតជង្គង់ ពេលអធិស្ឋាន។
នេះគឺជាសញ្ញានៃការបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់។
ហើយបាននិយាយលាគ្នាទៅវិញទៅមក
«និយាយលាគ្នាទៅវិញទៅមក»
Acts 21:7
ប្រយោគភ្ជាប់
នៅទីនេះចាប់ផ្តើមពីពេលលោកប៉ូលនៅសេសារា។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកលូកា លោកប៉ូល
និងអ្នករួមដំណើរជាមួយពួកគេ។ (សូមមើល: |Exclusive "We")
យើងក៏មកដល់ក្រុងផ្ទោឡេម៉ៃស៍
ក្រុងផ្ទោឡេម៉ៃស៍ជាទីក្រុងមួយនៃក្រុងទីរ៉ុស ប្រទេសលីបង់។ ក្រុង
ផ្ទោឡេម៉ៃស៍បច្ចុប្បន្នស្ថិតនៅអាយើ (Acre) ប្រទេសអ៊ីស្រាអែល។ (សូមមើល: |
How to Translate Names)
ពួកបងប្អូន
«បងប្អូនអ្នកជឿ»
ជាម្ចាស់នៅក្នុងចំណោមក្រុមប្រាំពីររូប
«ប្រាំពីរ» សំដៅលើមនុស្សដែលបានជ្រើសរើសដើម្បីចែកអាហារ
និងជួយដល់ស្ត្រីមេម៉ាយនៅក្នុងជំពូក ៦:៥។
លោកភីលីព
«បុរសនេះ» នៅក្នុង ខ៨។
ឥឡូវនេះ
ពាក្យប្រើដើម្បីបង្ហាញពីការសម្រាកនៅក្នុងសាច់រឿងចម្បង។ នៅទីនេះ
លោកលូកាបានប្រាប់ពីប្រវត្តិរបស់លោកភីលីព និងកូនស្រីរបស់លោក។
កូនក្រមុំបួននាក់ដែលថ្លែងព្រះបន្ទូល
«កូនក្រមុំបួននាក់ដែលបានទទួល
និងប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រចាំ»
Acts 21:10
ប្រយោគភ្ជាប់
នៅត្រង់នេះប្រាប់អំពីទំនាយមួយដែលទាយអំពីលោកប៉ូលនៅក្នុងសេសារា
ថ្លែងដោយព្យាការីអកាប៊ូស។
ព័ត៌មានទូទៅ
ពាក្យ «យើង» និង «ពួកយើង» សំដៅលើលោកលូកា លោកប៉ូល
និងអ្នករួមដំណើរជាមួយពួកគេ។
មានព្យាការីមួយរូបបានធ្វើដំណើរមកពីស្រុកយូដាឈ្មោះអកាប៊ូស
ឃ្លានេះ បានណែនាំមនុស្សថ្មីមកក្នុងសាច់រឿង។
ឈ្មោះអកាប៊ូស
អកាប៊ូសគឺជាបុរសម្នាក់មកពីស្រុកយូដា។ (សូមមើល: |How to Translate
Names)
ដកយកខ្សែក្រវាត់លោកប៉ូល
«បានដោះខ្សែក្រវាត់របស់លោកប៉ូលចេញពីចង្កេះរបស់លោកប៉ូល»
ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលដូច្នេះថា ជនជាតិយូដានៅក្រុងយេរូសាឡិមនឹងចងដៃម្ចាស់ខ្សែ
ក្រវាត់នេះដូច្នេះដែរ...របស់ជនជាតិដទៃផងដែរ។
ការដកស្រង់សំដីនៅក្នុងការដកស្រង់។
នៅខាងក្នុងការដកស្រង់សម្តីអាចនិយាយការស្រង់សម្តីដោយត្រង់តែម្តង។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលថា
នេះគឺជាអ្វីដែលជនជាតិយូដានៅយេរូសាឡិមចងលោក ...របស់ជនជាតិដទៃ
ផងដែរ។
ជនជាតិយូដា
នេះមិនមែនមានន័យថាជនជាតិយូដាទាំងអស់នោះទេ ប៉ុន្តែ
ប្រជាជននេះដែលនឹងធ្វើការនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដឹកនាំសាសន៍យូដា» ឬ «ជនជាតិយូដាខ្លះ»
បញ្ជូនលោកទៅក្នុង
«ប្រគល់លោក»
ទៅក្នុងកណ្តាប់ដៃរបស់ជនជាតិដទៃ
ពាក្យ «ដៃ» នៅទីនេះ តំណាងឲ្យការគ្រប់គ្រង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រគល់ទៅឲ្យសាសន៍ដទៃចាប់ឃុំ» ឬ «ទៅឲ្យសាសន៍ដទៃ» (សូមមើល: |
Metonymy)
សាសន៍ដទៃ
តំណាងឲ្យសិទ្ធិអំណាចនៅក្នុងចំណោមសាសន៍ដទៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «សិទ្ធិអំណាចរបស់សាសន៍ដទៃ»
Acts 21:12
ប្រយោគភ្ជាប់
ពាក្យ «យើង» នៅទីនេះ សំដៅលើលលោកលូកា និងអ្នកជឿផ្សេងៗទៀត ប៉ុន្តែ
មិនបានរួមបញ្ចូលលោកប៉ូលទេ។
ហេតុអ្វីបានជាបងប្អូនយំហើយបំបាក់ទឹកចិត្តខ្ញុំដូច្នេះ
លោកប៉ូលសួរសំនួរនេះ ដើម្បីបង្ហាញអ្នកជឿ
ឲ្យពួកគេឈប់ព្យាយាមបញ្ចុះបញ្ចូលលោកទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឈប់ធ្វើអ្វីដែលអ្នករាល់គ្នាធ្វើទៅ។
ការយំសោករបស់បងប្អូនធ្វើឲ្យខ្ញុំបាក់ទឹកចិត្តទេ» (សូមមើល: |Rhetorical
Question)
បំបាក់ទឹកចិត្តខ្ញុំ
ធ្វើឲ្យនរណាម្នាក់មិនសប្បាយចិត្ត
ឬបំបាក់ទឹកចិត្តរបស់នរណាម្នាក់ដោយនិយាយបំបាក់ទឹកចិត្ត។ ពាក្យ «ចិត្ត»
តំណាងឲ្យអារម្មណ៍របស់មនុស្សម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«បំបាក់ទឹកចិត្តខ្ញុំ» ឬ ធ្វើឲ្យខ្ញុំមិនសប្បាយចិត្តសោះ»
មិនគ្រាន់តែឲ្យគេចងប៉ុណ្ណោះទេ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនគ្រាប់តែឲ្យពួកគេចងខ្ញុំទេ»
ព្រោះតែព្រះនាមរបស់ព្រះអម្ចាស់យេស៊ូ
ពាក្យ «ព្រះនាម» នៅទីនេះ សំដៅលើបុគ្គលរបស់ព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិតដោយព្រះអម្ចាស់យេស៊ូ» ឬ
«ដោយសារខ្ញុំជឿនៅលើព្រះអម្ចាស់យេស៊ូ»
មិនចង់ឲ្យគេបញ្ចុះបញ្ចូល
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនចង់ឲ្យយើងព្យាយាមបញ្ចុះបញ្ចូលគាត់មិនឲ្យទៅក្រុងយេរូសាឡិមឡើយ។
សូមឲ្យព្រះហឫទ័យរបស់ព្រះអម្ចាស់បានសម្រេចចុះ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«សូមឲ្យគ្រប់យ៉ាងបានកើតឡើងតាមព្រះអម្ចាស់មានផែនការចុះ»
Acts 21:15
ប្រយោគភ្ជាប់
នេះគឺជាពេលចុងក្រោយរបស់លោកប៉ូលនៅសេសារាហើយ។
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើលោកលូកា លោកប៉ូល
និងអស់អ្នកដែលធ្វើដំណើរជាមួយពួកគេ។ (សូមមើល:|Exclusive "We")
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើពួកសិស្សខ្លះមកពីសេសារា។
ពួកគេបាននាំបុរសម្នាក់ឈ្មោះម៉្នាសុនមកជាមួយពួកគេ
«នៅក្នុងចំណោមពួកគេមានបុរសម្នាក់»
សិស្សតាំងដើមដំបូងមក
ឃ្លានេះមានន័យថាម្នាសុន ជាម្នាក់ដែលជាអ្នកជឿព្រះយេស៊ូដំបូងគេ។
Acts 21:17
ប្រយោគភ្ជាប់
លោកប៉ូឡនិងអ្នករួមដំណើរជាមួយលោកបានមកដល់ក្រុងយេរូសាឡិម។
ព័ត៌មានទូទៅ
ពាក្យ «លោក» ឬ «គាត់» សំដៅលើលោកប៉ូល។ ពាក្យ «ពួកគេ»
សំដៅលើពួកចាស់ទុំ។
ពួកបងប្អូនបានទទួលយើងដោយអំណរ។
ពាក្យ «បងប្អូន»
នៅទីនេះសំដៅលើអ្នកជឿក្នុងក្រុងយេរូសាឡិមមិនប្រុសឬស្រីឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ: បងប្អូនអ្នកជឿបានស្វាយគមន៍យើង»
លោកបានរាយការណ៍ម្តងមួយៗ
«លោកផ្តល់ការលម្អិតទាក់ទងនឹងមនុស្សគ្រប់គ្នា»
Acts 21:20
ប្រយោគភ្ជាប់
ពួកចាស់ទុំនៅក្នុងក្រុងយេរូសាឡិម ចាប់ផ្តើមឆ្លើយតបទៅកាន់លោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើលោកយ៉ាកុប និងពួកចាស់ទុំ។
ព័ត៌មានទូទៅ
ពាក្យ «លោក» សំដៅលើលោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើអ្នកជឿសាសន៍យូដា
ដែលចង់ឲ្យអ្នកជឿសាសន៍យូដាទាំងអស់កាន់តាមច្បាប់
និងទំនៀមទម្លាប់របស់ជនជាតិយូដា។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» និង «របស់ពួកគេ» នៅទីនេះ
សំដៅលើជនជាតិយូដាដែលជឿលើព្រះយេស៊ូ។
បងប្អូន
ពាក្យ «បងប្អូន» មានន័យថា «បងប្អូនអ្នកជឿ»។
ពួកគេបានដឹងឮពីបងថា...ឲ្យបោះបង់ចោលគម្ពីរវិន័យ
នៅទីនេះ មានជនជាតិយូដាខ្លះបានបង្ខូចអ្វីដែលលោកប៉ូលបានបង្រៀន។
លោកមិនបានបំបាក់ទឹកចិត្តរបស់ជនជាតិយូដា
មិនឲ្យពួកគេស្តាប់បង្គាប់ក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ។
សាររបស់លោកគឺការកាត់ស្បែក និង
ទំនៀមទម្លាប់មួយចំនួនមិនចំបាច់ដើម្បីឲ្យព្រះយេស៊ូសង្គ្រោះពួកគេឡើយ។
អ្នកអាចបញ្ជាក់ថា
ពួកអ្នកដឹកនាំសាសន៍យូដាដែលជឿនៅក្នុងក្រុងយេរូសាឡិមដឹងថា
លោកប៉ូលបង្រៀនព្រះបន្ទូលនៃសេចក្តីពិតរបស់ព្រះជាម្ចាស់។
ពួកគេបានដឹងឮពីបងថា
ឃ្លានេះនិយាយជាប្រយោគសកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានគេប្រាប់ដល់អ្នកជឿសាសន៍យូដា» (សូមមើល:|Active ឬ Passive)
ឲ្យបោះបង់ចោលគម្ពីរវិន័យរបស់លោកម៉ូសេ
ពាក្យ «លោកម៉ូសេ» នៅទីនេះ តំណាងឲ្យច្បាប់របស់លោកម៉ូសេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ឲ្យឈប់ប្រព្រឹត្តតាមច្បាប់ដែលលោកម៉ូសេបានប្រគល់ដល់យើង» ។
មិនឲ្យកាន់តាមទំនៀមទម្លាប់ចាស់
មិនឲ្យស្តាប់បង្គាប់តាមទម្លាប់ចាស់ និយាយសំដៅលើការនាំពួកគេ
ហើយមនុស្សដែលដើរតាមលោក។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនឲ្យប្រព្រឹត្តតាមទំនៀមទម្លាប់ចាស់»
តាមទំនៀមទម្លាប់ចាស់
«ទំនៀមទម្លាប់ដែលជនជាតិយូដាប្រព្រឹត្តតាមជាធម្មតា»។
Acts 21:22
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើលោកយ៉ាកុប និងពួកចាស់ទុំ។ (សូមមើល: ២១:១៧
និង|Exclusive "We")
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើអ្នកជឿជនជាតិយូដានៅក្នុងក្រុងយេរូសាឡិម
ដែលចង់បង្រៀនអ្នកជឿជនជាតិយូដាថា
ពួកគេតែប្រព្រឹត្តតាមច្បាប់របស់លោកម៉ូសេ។ (សូមមើល: ២១:២០
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» «របស់ពួកគេ» ហើយពាក្យ «ពួកគេ» លើកទីមួយ
សំដៅលើមនុស្សបួននាក់ដែលបានស្បថ។ ពាក្យ «ពួកគេ» លើកទីពីរ
សំដៅលើអ្នកជឿជនជាតិយូដានៅក្នុងក្រុងយេរូសាឡិម
ដែលចង់បង្រៀនអ្នកជឿជនជាតិយូដាថា
ពួកគេនៅតែកាន់តាមច្បាប់របស់លោកម៉ូសេ។
បួននាក់ដែលជាប់បំណន់
«បួននាក់ដែលបានសន្យាជាមួយព្រះជាម្ចាស់»។ សម្បថប្រភេទនេះ
គឺមនុស្សមិនអាចផឹកស្រា ឬកាត់សក់របស់ពួកគេទេ
រហូតទាល់តែចប់ពេលកំណត់។
នាំប្រុសៗទាំងនេះទៅ ហើយធ្វើពិធីជម្រះកាយឲ្យខ្លួនឯងបានបរិសុទ្ធជាមួយគេ
ពួកគេបានធ្វើពិធីជម្រះកាយ
ដើម្បីឲ្យពួកគេអាចថ្វាយបង្គំព្រះជាម្ចាស់នៅក្នុងព្រះវិហារបាន។
បង់ថ្លៃសម្រាប់ពួកគេផង
«បង់ថ្លៃសម្រាប់អ្វីដែលពួកគេត្រូវការផង»។ ចំណាយលផ្សេងៗត្រូវទៅទិញចៀមញី
ចៀមឈ្មោល និងគ្រាប់ស្រូវ ព្រមទាំងតង្វាយច្រូចផង។
ពួកគេបានកោរសក់របស់ពួកគេ
នេះជាសញ្ញាដែលមនុស្សម្នាក់បានបំពេញអ្វីដែលពួកគេបានសន្យាជាមួយព្រះជាម្ចាស់ឲ្យពួកគេធ្វើ។
មនុស្សគ្នានឹងដឹងថា អ្វីៗដែលពួកគេបាននិយាយពីបង
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលគេនិយាយពីបង»
ប្រព្រឹត្តតាមក្រឹត្យវិន័យ
ឃ្លានេះនិយាយពីការស្តាប់បង្គាប់ច្បាប់ ប្រៀបដូចជាច្បាប់របស់អ្នកដឹកនាំម្នាក់
និងមនុស្សដែលដើរតាមពីក្រោយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ស្តាប់តាមច្បាប់» ឬ «រស់ក្នុងជីវិតដែលកាន់តាមច្បាប់របស់លោកម៉ូសេ
និងទំនៀមទម្លាប់ផ្សេងៗទៀតរបស់លោកម៉ូសេ។
Acts 21:25
ប្រយោគភ្ជាប់
លោកយ៉ាកុប
និងពួកចាស់ទុំនៅក្នុងក្រុងយេរូសាឡិមបានបញ្ចប់សំណើរបស់ពួកគេចំពោះលោកប៉ូល។
(សូមមើល: ២១:១៧)
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើលោកយ៉ាកុប និងពួកគេចាស់ទុំ។ (សូមមើល:|
Exclusive "We")
ពួកគេត្រូវជៀសវាងពីអ្វីដែលបានថ្វាយដល់រូបព្រះ ពីឈាម ពីសត្វដែលសម្លាប់ដោយច្របាច់ក
ច្បាប់ទាំងអស់នេះ គឺមិនឲ្យពួកគេបរិភោគ។
ពួកគេត្រូវបានហាមមិនឲ្យបរិភោគសត្វដែលថ្វាយទៅរូបព្រះ
បរិភោគសាច់ដែលមានឈាម និងសាច់សត្វដែលស្លាប់ដោយច្របាច់ក
ព្រោះវាមានឈាមនៅក្នុងសាច់។
សូមមើលពីរបៀបដែលអ្នកបកប្រែប្រហាក់ប្រហែលនិងឃ្លានៅក្នុងជំពូក ១៥:១៩។
ពួកគេត្រូវជៀសវាងពីអ្វីដែលបានថ្វាយដល់រូបព្រះ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេត្រូវនៅឆ្ងាយពីសាច់របស់សត្វដែលនរណាម្នាក់បានថ្វាយដល់រូបព្រះ» ។
ពីសត្វដែលសម្លាប់ដោយច្របាច់ក
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។
អ្នកអាចនិយាយបញ្ជាក់សង្ខេបព័ត៌មានអំពីសត្វ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីសត្វដែលមនុស្សម្នាក់បានសម្លាប់ដោយច្របាច់ក» ឬ

generated on Wed Sep 10 16:16:32 2025

«ពីសត្វដែលមនុស្សបានសម្លាប់សម្រាប់ជាអាហារ ប៉ុន្តែ មិនបានបង្ហូរឈាម»។
នាំបុរសទាំងនោះ
អ្នកទាំងបួននេះគឺជាអ្នកដែលបានស្បថ។
ទៅធ្វើពិធីជម្រះកាយខ្លួនលោកឲ្យបានបរិសុទ្ធជាមួយពួកគេ
មុនពេលចូលទៅក្នុងទីតាំងរបស់ព្រះវិហារ ជនជាតិយូដាតម្រូវឲ្យធ្វើពិធីជម្រះកាយ។
ពាក្យសម្អាតនេះគឺសម្រាប់ជនជាតិយូដាដែលបានទៅពាក់ព័ន្ធជាមួយសាសន៍ដទៃ។
ចូលទៅក្នុងព្រះវិហារ
ពួកគេមិនបានចូលទៅក្នុងព្រះវិហារ
ជាកន្លែងដែលមានតែមហាបូជាចារ្យតែមួយគត់ដែលអនុញ្ញាតឲ្យចូល។
ពួកគេបានចូលទៅក្នុងទីធ្លារបស់ព្រះវិហារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានចូលទៅក្នុងទីធ្លារបស់ព្រះវិហារ»
ពេលកំណត់នៃថ្ងៃជម្រះកាយឲ្យបានបរិសុទ្ធ
នេះគឺជាការជម្រះកាយដែលជាដំណើរការ
ខុសពីការជម្រះកាយដែលតម្រូវឲ្យពួកគេបំពេញ
ដើម្បីពួកគេអាចចូលទៅក្នុងទីលានរបស់ព្រះវិហារបាន។
រហូតទាល់តែ ពួកគេបានថ្វាយតង្វាយ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«រហូតដល់ពួកគេបានថ្វាយសត្វសម្រាប់ជាតង្វាយ»។
Acts 21:27
ប្រយោគភ្ជាប់
នេះគឺជាចាប់ផ្តើមការចាប់ខ្លួនលោកប៉ូល។
ព័ត៌មានទូទៅ
ខ ២៩ ផ្តល់ប្រវត្តិអំពីជនជាតិយូដាពីស្រុកអេស៊ី។
លុះរយៈពេលមួយសប្តាហ៍
នេះគឺជារយៈពេលនៃការជម្រះកាយឲ្យបរិសុទ្ធក្នុងរយៈពេលប្រាំពីរថ្ងៃ។
នៅក្នុងព្រះវិហារ
លោកប៉ូលមិនបាននៅក្នុងព្រះវិហារ។ លោកនៅក្នុងទីធ្លាព្រះវិហារ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅក្នុងទីធ្លាព្រះវិហារ» ។
បំបះបំបោរបណ្តាជនទាំងមូល
«បណ្តាលឲ្យមានមនុស្សជាច្រើនចាប់ផ្តើមបះបោរ»
នាំគ្នាចាប់លោក
ពាក្យ «នាំគ្នាចាប់» មានន័យថា «ចាប់ខ្លួន» ឬ «ចាប់»។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ជំពូក ៥:១៧។
របៀបផ្សេងទៀតនៃការបកប្រែ: «បានចាប់លោកប៉ូល»
ប្រឆាំងនឹងប្រជារាស្ត្រ ប្រឆាំងនឹងក្រឹត្យវិន័យ ហើយប្រឆាំងនឹងព្រះវិហារ
«ប្រឆាំងនឹងប្រជារាស្ត្រអ៊ីស្រាអែល ប្រឆាំងនឹងក្រឹត្យវិន័យ ហើយប្រឆាំងនឹងព្រះវិហារ»
គាត់ថែមទាំងបាននាំសាសន៍ក្រិកចូលមកក្នុងព្រះវិហារ
មានតែប្រុសៗជនជាតិយូដាទេ
ដែលអនុញ្ញាតឲ្យចូលទៅក្នុងបរិវេណព្រះវិហារក្រុងយេរូសាឡិម។
មកពីគេបានឃើញលោក...ចូលក្នុងព្រះវិហារដែរ
នេះគឺជាប្រវត្តិ។ លោកលូកាពន្យល់ពីហេតុផលដែលជនជាតិយូដាមកពីអាស៊ីគិតថាលោកប៉ូលបាននាំជនជាតិក្រិកចូលទៅក្នុងព្រះវិហារ។
លោកត្រូភីម
លោកគឺជាបុរសជនជាតិក្រិកម្នាក់ ដែលពួកគេចោទប្រកាន់លោកប៉ូល
អំពីការដែលបាននាំមនុស្សចូលទៅក្នុងទីលានព្រះវិហារដែលមានតែជនជាតិយូដាទេដែលអាចចូលបាន។
សូមមើលពីរបៀបដែលអ្នកប្រែឈ្មោះនេះនៅក្នុងជំពូក ២០:៤។
Acts 21:30
មានការភ្ញាក់ផ្អើលពេញទីក្រុងទាំងមូល
ពាក្យ «ទាំងមូល» នៅទីនេះ គឺជាពាក្យបំផ្លើសដើម្បីបញ្ជាក់។ ពាក្យ «ទីក្រុង» សំដៅលើមនុស្សនៅក្នុងក្រុងយេរូសាឡិម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានមនុស្សជាច្រើននៅក្នុងទីក្រុងបានខឹងលោកប៉ូល» (សូមមើល: | Hyperbole និង | Metonymy)
បានចាប់លោកប៉ូល
«បានចាប់ខ្លួនលោកប៉ូល» ឬ «ចាប់លោកប៉ូល»
បានបិទទ្វារភ្លាម
ពួកគេបានបិទទ្វារ ដើម្បីកុំឲ្យមានកុប្បកម្មនៅក្នុងទីធ្លារបស់ព្រះវិហារ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកជនជាតិយូដាខ្លះបានបិទទ្វារព្រះវិហារភ្លាម»
ឬ «អ្នកយាមព្រះវិហារបានបិទទ្វារ» (សូមមើល: និង | Active ឬ Passive)
ដំណឹងបានឮទៅដល់មេបញ្ជាការនៃកងទាហាន
ពាក្យ «ដំណឹង» សំដៅលើអ្នកនាំសារដែលបានទៅប្រាប់ដំណឹង។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សម្នាក់បានផ្តល់ដំណឹងដល់មេបញ្ជាការនៃកងទាហាន។
មេបញ្ជាការនៃកងទាហាន
មន្ត្រីយោធារបស់រ៉ូម ឬ មេទាហានលើទាហាន ៦០០នាក់។
ក្រុងយេរូសាឡិមទាំងមូលអំពីការចលាចលនេះ
ពាក្យ «ក្រុងយេរូសាឡិម» នៅទីនេះ សំដៅលើអ្នកក្រុងយេរូសាឡិម។ ពាក្យ «ទាំងមូល»
គឺជាពាក្យបំផ្លើសដើម្បីបង្ហាញថាមានបណ្តាជនជាច្រើនមិនសប្បាយចិត្ត។
របៀបផ្សេងទៀតនៃការបកប្រែ:
«មានមនុស្សជាច្រើននៅក្នុងក្រុងយេរូសាឡិមបានប៉ះបោរឡើង» (សូមមើល: | Hyperbole និង | Metonymy)
Acts 21:32
ព័ត៌មានទូទៅ
ពាក្យ «លោក» និងពាក្យ «គាត់»
សំដៅលើនាយទាហានរបស់អ្នកយាមដែលនិយាយនៅក្នុងជំពូក ២១:៣០។
រត់ចុះ
ពីបន្ទាយ មានកាំជណ្តើរចុះមកក្នុងតុលាការ។
មេបញ្ជាការ
មន្ត្រីយោធារបស់រ៉ូម ឬ មេទាហានលើទាហាន ៦០០នាក់។
បានចាប់លោកប៉ូល
«បានចាប់លោកប៉ូល» ឬ «គេចាប់ខ្លួនលោកប៉ូល»
បញ្ជាឲ្យគេដាក់ច្រវាក់ពីរថែមទៀតផង
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបង្គាប់ទាហានឲ្យចាប់ចងគាត់»
ច្រវាក់ពីរ
ឃ្លានេះមានន័យថា ពួកគេបានចងលោកប៉ូលដោយទាហានពីរនាក់របស់រ៉ូមម្នាក់ម្ខាង។
លោកបានសួរថា លោកជានរណា ហើយលោកបានធ្វើអ្វីខ្លះ
ឃ្លានេះនិយាយដូចជាការដកស្រង់ដោយផ្ទាល់។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានសួរថា: «តើបុរសនេះជានរណា? តើគាត់បានធ្វើអ្វីខ្លះ?»
លោកបានសួរថា លោកជានរណា
លោកមេបញ្ជាការនិយាយទៅកាន់បណ្តាជន មិនមែនទៅកាន់លោកប៉ូល។
Acts 21:34
មេបញ្ជាការ
មន្ត្រីយោធារបស់រ៉ូម ឬ មេទាហានលើទាហាន ៦០០នាក់។
លោកបានបញ្ជាឲ្យគេនាំលោកប៉ូល
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានបង្គាប់ទាហានរបស់លោកឲ្យនាំលោកប៉ូល»
ទៅបន្ទាយ
បន្ទាយនេះមានរបងជាប់នឹងទីធ្លាខាងក្រៅរបស់ព្រះវិហារ។
នៅពេលលោកមកដល់ជណ្តើរបន្ទាយ ពួកទាហានបានសែងលោក
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលលោកប៉ូលមកដល់កាំជណ្តើរបន្ទាយ ពួកទាហានបានសែងលោក»
សម្លាប់ចោល
បណ្តាជនប្រើពាក្យប្រហាក់ប្រហែលនឹងភាសាដែលសូមឲ្យសម្លាប់លោកប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្លាប់គាត់» ឬ «សម្លាប់លោក»
Acts 21:37
នៅពេលពួកគេរៀបនឹងយកលោកប៉ូល
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកទាហានរួចរាល់នឹងនាំលោកប៉ូល»
ចូលទៅក្នុងបន្ទាយ
បន្ទាយនេះមានរបងជាប់នឹងទីធ្លាខាងក្រៅរបស់ព្រះវិហារ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ២១:៣៤។
មេបញ្ជាការ
មន្ត្រីយោធារបស់រ៉ូម ឬ មេទាហានលើទាហាន ៦០០នាក់។
តើលោកចេះនិយាយភាសាក្រិកដែរមែនទេ? តើលោកមិនមែនជាជនជាតិអេស៊ីប ដែលបាន

generated on Wed Sep 10 16:16:32 2025

បំបះបំបោរ ហើយនាំអ្នកធ្វើឃាតបួនពាន់នាក់ចេញទៅទីរហោស្ថានទេឬ?»
មេបញ្ជាការប្រើសំណួរទាំងនេះ ដើម្បីបញ្ជាក់ពីការភ្ញាក់ផ្អើលដែលថា
លោកមិនដូចជាមនុស្សដែលលោកបានគិតនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ តើអ្នកនិយាយភាសាក្រិក។
ខ្ញុំគិតថាអ្នកជាជនជាតិអស៊ីប
ដែលនាំការបះបោរនៅទីរហោស្ថានជាមួយពួកអ្នកចំណាលស្រុកបួនពាន់នាក់»
Status:
តើលោកមិនមែនជាជនជាតិអេស៊ីប
មុនពេលលោកប៉ូលបានមកដល់ មានបុរសម្នាក់ដែលគ្មានឈ្មោះ
មកពីស្រុកអេស៊ីប បាននាំឲ្យមានប៉ះបោរប្រឆាំងជាមួយរ៉ូម
នៅក្នុងក្រុងយេរូសាឡិម។ ក្រោយមក លោកបានរត់ «ទៅក្នុងទីរហោស្ថាន»
និងមេទ័ពដែលឆ្ងល់ថា លោកប៉ូលគឺជាម្នាក់នោះ។
ដែលបានបំបះបំបោ
ពាក្យ «បះបោរ» អាចប្រើជាកិរិយាសព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើឲ្យមនុស្សបះបោរទាស់នឹងរដ្ឋាភិបាលរ៉ូម»
អ្នកធ្វើឃាតបួនពាន់នាក់
«អ្នកធ្វើឃាត ៤០០០នាក់»
ពួកអ្នកធ្វើឃាត
«ពួកឃាតករ» នៅទីនេះ សំដៅលើជនជាតិយូដាដែលបានសម្លាប់ជនជាតិរ៉ូម
និងនរណាម្នាក់ដែលបានគ្រាំទ្រជនជាតិរ៉ូម។

Acts 21:39
ប្រយោគភ្ជាប់
លោកប៉ូលចាប់ផ្តើមការពារអ្វីដែលលោកបានធ្វើ។
សូមលោក
«សូមលោកមេត្តា» ឬ «ខ្ញុំសូមអង្វរលោក»
អនុញ្ញាតឲ្យខ្ញុំ
«សូមអនុញ្ញាតឲ្យខ្ញុំ» ឬ សូមអនុញ្ញាតឲ្យខ្ញុំ។
ពេលលោកមេបញ្ជាការអនុញ្ញាតឲ្យលោកហើយ
ពាក្យ «អនុញ្ញាត» អាចនិយាយជាកិរិយាសព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ:
«មេបញ្ជាការបានអនុញ្ញាតឲ្យលោកប៉ូលមានប្រសាសន៍» ឬ
«មេបញ្ជាការអនុញ្ញាតឲ្យលោកប៉ូលមានប្រសាសន៍»
លោកប៉ូលបានឈរនៅលើកាំជណ្តើរ
ពាក្យ «កាំជណ្តើរ» នៅទីនេះសំដៅលើកាំជណ្តើរឡើងទៅបន្ទាយ។
លើកដៃធ្វើសញ្ញាទៅប្រជាជន
នេះគឺជាការបញ្ជាក់ ហេតុអ្វីលោកប៉ូលនិយាយជាមួយនឹងការលើកដៃជាសញ្ញា។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើសញ្ញាដោយដៃរបស់គាត់
ដើម្បីឲ្យមនុស្សស្ងាត់ស្ងៀម»។
នៅពេលស្ងៀមស្ងាត់ហើយ
«នៅពេលមនុស្សបានស្ងប់ស្ងាត់អស់ហើយ»

22 [1]«បងប្អូន និងចាស់ទុំទាំងអស់គ្នាអើយ សូមស្តាប់ពាក្យដោះសារបស់ខ្ញុំសិន!»។[2]កាលពួកគេឮលោកប៉ូលមានប្រសាសន៍ជាភាសាហេប្រឺដូច្នេះ គេរឹតតែស្ងៀមស្ងាត់
ថែមទៀត។ លោកប៉ូលមានប្រសាសន៍ថា៖
[3]«ខ្ញុំជាជនជាតិយូដាម្នាក់កើតនៅក្រុងតើសុសក្នុងស្រុកគីលីគា ប៉ុន្តែ ខ្ញុំបានមករស់នៅក្រុងយេរូសាឡឹមនេះតាំងពីកុមារ ខ្ញុំបានទទួលការអប់រំតាមក្រឹត្យវិន័យនៃបុព្វបុរស
របស់យើងយ៉ាងតឹងរ៉ឹងពីសំណាក់លោកកាម៉ាលាល។ ខ្ញុំបានខ្នះខ្នែងបម្រើព្រះជាម្ចាស់ ដូចបងប្អូនទាំងអស់គ្នានៅថ្ងៃនេះដែរ។[4]ខ្ញុំធ្លាប់បៀតបៀនអស់អ្នកដែលដើរតាមមាគ៌ា
របស់ព្រះអម្ចាស់ រហូតដល់សម្លាប់គេ ហើយចាប់ចងមនុស្សប្រុសស្រីយកទៅឃុំឃាំងទៀតផង[5]ដូចមានមហាបូជាចារ្យ និងក្រុមព្រឹទ្ធាចារ្យជាសាក្សីស្រាប់។ ខ្ញុំបានទទួល
លិខិតពីលោកទាំងនោះយកទៅជូនបងប្អូននៅក្រុងដាម៉ាស ដ្បិត ខ្ញុំទៅទីនោះដើម្បីចាប់ចងពួកអ្នកដែលដើរតាមមាគ៌ានេះ យកមកធ្វើទោសនៅក្រុងយេរូសាឡឹម។
[6]ពេលខ្ញុំកំពុងតែធ្វើដំណើរទៅជិតដល់ក្រុងដាម៉ាសប្រមាណជាថ្ងៃត្រង់ ស្រាប់តែមានពន្លឺមួយដ៏ភ្លឺត្រចះត្រចង់ ចាំងពីផ្ទៃមេឃមកជុំវិញខ្ញុំ។[7]ខ្ញុំក៏ដួល ហើយឮសំឡេងមួយ
ពោលមកខ្ញុំថា៖ «សូលអើយ សូល! ហេតុដូចម្តេចបានជាអ្នកបៀតបៀនខ្ញុំដូច្នេះ?»។[8]ខ្ញុំបានសួរវិញថា៖ «លោកម្ចាស់អើយ តើលោកជានរណា?»។ សំឡេងនោះឆ្លើយមក
ខ្ញុំថា៖ «ខ្ញុំជាយេស៊ូ អ្នកស្រុកណាសារ៉ែត ដែលអ្នកកំពុងតែបៀតបៀន»។
[9]រីឯអស់អ្នកដែលធ្វើដំណើរជាមួយខ្ញុំ ក៏បានឃើញពន្លឺនោះដែរ តែមិនបានឮព្រះសូរសៀងទេ។[10]ខ្ញុំក៏សួរថា៖ «ព្រះអម្ចាស់អើយ តើទូលបង្គំត្រូវធ្វើដូចម្តេច?»។ ព្រះអម្ចាស់
មានព្រះបន្ទូលមកខ្ញុំថា៖ «ចូរក្រោកឡើង ទៅក្រុងដាម៉ាសទៅ នៅទីនោះ គេនឹងប្រាប់អ្នកអំពីកិច្ចការទាំងប៉ុន្មាន ដែលព្រះជាម្ចាស់បង្គាប់អោយអ្នកធ្វើ»។[11]ដោយខ្ញុំពុំអាច
មើលអ្វីឃើញ ព្រោះតែពន្លឺរស្មីដ៏រុងរឿងនោះ អស់អ្នកដែលនៅជាមួយខ្ញុំបានដឹកដៃនាំខ្ញុំទៅក្រុងដាម៉ាស។
[12]នៅក្រុងនោះ មានបុរសម្នាក់ឈ្មោះអណាណាស ជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ស្របតាមក្រឹត្យវិន័យ ហើយជនជាតិយូដានៅក្រុងដាម៉ាសគោរពរាប់អានគាត់
គ្រប់ៗគ្នា។[13]គាត់មកឈរជិតខ្ញុំ ហើយពោលថា៖ «បងសូលអើយ! សូមឲ្យបងមើលឃើញវិញចុះ!»។ រំពេចនោះ ភ្នែកខ្ញុំក៏ភ្លឺឡើង ហើយខ្ញុំមើលឃើញគាត់។
[14]គាត់មានប្រសាសន៍ថា «ព្រះនៃបុព្វបុរសរបស់យើង បានជ្រើសរើសបង ដើម្បីឲ្យបងស្គាល់ព្រះហឫទ័យរបស់ព្រះអង្គ ឲ្យបងបានឃើញព្រះដ៏សុចរិត និងឲ្យបងបានឮ
ព្រះបន្ទូលរបស់ព្រះអង្គផ្ទាល់តែម្តង។[15]បងនឹងធ្វើជាបន្ទាល់របស់ព្រះអង្គនៅមុខមនុស្សទាំងអស់ អំពីហេតុការណ៍ដែលបងបានឃើញ និងសេចក្តីដែលបងបានឮ។
[16]ឥឡូវនេះ តើបងនៅបង្អែបង្អង់ដល់កាលណាទៀត? សូមក្រោកឡើង ទទួលពិធីជ្រមុជទឹក ហើយហៅរកព្រះនាមព្រះអង្គទៅ ដើម្បីព្រះអង្គលាងបាបឲ្យ»។
[17]ខ្ញុំវិលមកដល់ក្រុងយេរូសាឡឹមវិញ ហើយនៅពេលខ្ញុំកំពុងអធិស្ឋានក្នុងព្រះវិហារ ខ្ញុំលង់ស្មារតីឃើញនិមិត្តមួយ។[18]ខ្ញុំឃើញព្រះអង្គម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ «ចូរ
ប្រញាប់ចាកចេញពីក្រុងយេរូសាឡឹមភ្លាមទៅ ដ្បិត អ្នកក្រុងនេះមិនព្រមទទួលសក្ខីភាពដែលអ្នកនិយាយអំពីយើងទេ»។
[19]ខ្ញុំទូលថា៖ «បពិត្រព្រះអម្ចាស់ អ្នកទាំងនោះបានដឹងស្រាប់ហើយថា ទូលបង្គំធ្លាប់ចូលទៅសាលាប្រជុំនានា ចាប់អស់អ្នកដែលជឿព្រះអង្គយកទៅឃុំឃាំង និងវាយដំ
ឡៃផង។[20]នៅពេលគេសម្លាប់លោកស្ទេផាន ដែលជាបន្ទាល់របស់ព្រះអង្គ ទូលបង្គំក៏នៅទីនោះ ហើយបានយល់ស្របជាមួយពួកគេ ទាំងនៅយាមសម្លៀកបំពាក់របស់
ពួកអ្នក ដែលប្រហារជីវិតលោកផងដែរ»។[21]ពេលនោះ ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា៖ «ទៅចុះ ដ្បិត យើងនឹងចាត់អ្នកឲ្យទៅរកសាសន៍ដទៃដែលនៅឆ្ងាយៗ»។
[22]បណ្តាជនបានស្តាប់លោកប៉ូលមានប្រសាសន៍មកដល់ត្រឹមនេះ ក៏ស្រែកឡើងថា៖ «សូមសម្លាប់មនុស្សបែបនេះចោលទៅ កុំទុកឲ្យនៅរស់ឡើយ!»។[23]នៅពេលគេនាំគ្នា
ស្រែក ទាំងបោះអាវរបស់ខ្លួន និងបាចធូលីដីឡើងលើទៀតផងនោះ[24]លោកមេបញ្ជាការបង្គាប់ឲ្យគេនាំលោកប៉ូល ចូលទៅក្នុងបន្ទាយ និងឲ្យគេវាយសួរចម្លើយ ចង់ដឹងមូល
ហេតុដែលនាំឲ្យបណ្តាជនស្រែកប្រឆាំងនឹងលោកបែបនេះ។
[25]នៅពេលគេកំពុងយកខ្សែចងលោក លោកប៉ូលមានប្រសាសន៍ទៅកាន់នាយទាហានម្នាក់នៅជិតនោះថា៖ «តើអស់លោកមានសិទ្ធិវាយអ្នកដែលមានសញ្ជាតិរ៉ូម ដោយ
មិនកាត់ទោសជាមុនឬ!»។[26]នាយទាហានឮពាក្យនេះ ក៏ទៅជម្រាបលោកមេបញ្ជាការថា៖ «តើលោកគិតធ្វើអីហ្នឹង បុរសនោះជាជនជាតិរ៉ូមទេតើ»។
[27]លោកមេបញ្ជាការមកសួរលោកប៉ូលថា៖ «សុំប្រាប់ខ្ញុំមើល៍ តើអ្នកជាជនជាតិរ៉ូមមែនឬ?»។ លោកឆ្លើយថា៖ «បាទ ខ្ញុំជាជនជាតិរ៉ូមាំងមែន»។[28]លោកមេបញ្ជាការក៏មាន
ប្រសាសន៍ទៀតថា៖ «ខ្ញុំបានចំណាយប្រាក់ជាច្រើន ដើម្បីឲ្យបានសញ្ជាតិរ៉ូម»។ លោកប៉ូលតបថា៖ «រីឯខ្ញុំវិញ ខ្ញុំមានសញ្ជាតិរ៉ូម តាំងពីកំណើតមកម៉្លេះ»។[29]ពួកអ្នកដែល
បម្រុងនឹងសួរចម្លើយលោក នាំគ្នាដកខ្លួនថយពីទីនោះភ្លាម រីឯលោកមេបញ្ជាការក៏ភិតភ័យដែរ នៅពេលដឹងថាលោកប៉ូលមានសញ្ជាតិរ៉ូមដូច្នេះ ព្រោះគាត់បានឲ្យគេដាក់
ច្រវាក់លោក។
[30]នៅថ្ងៃបន្ទាប់ ដោយលោកមេបញ្ជាការចង់ដឹងច្បាស់នូវមូលហេតុ ដែលនាំឲ្យជនជាតិយូដាចោទប្រកាន់លោកប៉ូល គាត់ក៏ឲ្យគេដោះច្រវាក់ចេញពីលោក។ គាត់បញ្ជាឲ្យ
នាយកបូជាចារ្យ និងក្រុមប្រឹក្សាជាន់ខ្ពស់ទាំងមូលជួបជុំគ្នា ហើយឲ្យនាំលោកប៉ូលចុះមកឈរនៅមុខអង្គប្រជុំ។

Acts 22:1
ប្រយោគភ្ជាប់
លោកប៉ូលមានប្រសាសន៍ទៅកាន់បណ្តាជនជនជាតិយូដានៅក្នុងក្រុងយេរូសាឡឹម។

ព័ត៌មានទូទៅ
ខ ២ បានប្រាប់ពីសាវតាដែលបានកើតឡើង។
បងប្អូន និងឪពុកទាំងអស់គ្នាអើយ

generated on Wed Sep 10 16:16:32 2025

នេះគឺជារបៀបនិយាយដោយសុភាពទៅកាន់បងប្អូន ទាំងចាស់ ទាំងក្មេង ដែលជាអ្នកស្តាប់។
នឹងនិយាយជាមួយបងប្អូននៅពេលនេះសិន
«ខ្ញុំនឹងពន្យល់ដល់បងប្អូន» ឬ «ខ្ញុំនឹងប្រាប់ដល់បងប្អូននៅពេលនេះ»
ភាសាហេព្រើរ
ភាសាហេព្រើរជាភាសារបស់ជនជាតិយូដា។
Acts 22:3
ប៉ុន្តែ ខ្ញុំបានមកទទួលការអប់រំនៅក្នុងទីក្រុងនេះ អង្គុយរៀនជាមួយលោកកាម៉ាលាល
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ ខ្ញុំជាសិស្សរបស់រ៉ាប៊ីកាម៉ាលាស នៅក្នុងក្រុងយេរូសាឡិមនេះ»
អង្គុយរៀនជាមួយលោកកាម៉ាលាល
ពាក្យ «ជើង» តំណាងឲ្យកន្លែងដែលសិស្សម្នាក់ អង្គុយក្នុងពេលដែលពួកគេរៀនពីគ្រូម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ: «ពីលោកកាម៉ាលាល»
លោកកាម៉ាលាល
លោកកាម៉ាលាលគឺជាគ្រូក្រឹត្យវិន័យរបស់ជនជាតិយូដាដែលមានមុខមាត់បំផុត។ សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនេះនៅក្នុងជំពូក ៥:៣៤។
ខ្ញុំបានទទួលការយ៉ាងតឹងរ៉ឹងអំពីក្រឹត្យវិន័យនៃបុព្វបុរសរបស់យើង
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានបង្រៀនដល់ខ្ញុំ ពីរបៀបនៃការប្រព្រឹត្តតាមច្បាប់របស់បុព្វបុរសរបស់យើងយ៉ាងយកចិត្តទុកដាក់» ឬ «ខ្ញុំបានទទួលការណែនាំឲ្យដើរតាមច្បាប់របស់បុព្វបុរសរបស់យើងយ៉ាងល្អិតល្អន់»
អំពីក្រឹត្យវិន័យនៃបុព្វបុរសរបស់យើង
នេះគឺជារបៀបមួយទៀត «នៃការក្រឹត្យវិន័យរបស់លោកម៉ូសេ»។
ខ្ញុំបានខ្នះខ្នែងចំពោះព្រះជាម្ចាស់
«ខ្ញុំបានឧទ្ទិសខ្លួនទាំងស្រុងក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់» ឬ «ខ្ញុំមានចិត្តឆេះឆួលចំពោះកិច្ចការបម្រើរបស់ខ្ញុំចំពោះព្រះជាម្ចាស់»។
ដូចបងប្អូនទាំងអស់គ្នានៅថ្ងៃនេះដែរ
«ដូចគ្នាជាមួយបងប្អូនទាំងអស់គ្នា នៅថ្ងៃនេះដែរ»
លោកប៉ូលបានប្រៀបខ្លួនរបស់លោកជាមួយបណ្តាជន។
តាមផ្លូវនេះ
នេះគឺជាពាក្យដែលប្រើសំដៅលើគ្រិស្តបរិស័ទ។ សូមមើលពីរបៀបដែលអ្នកបកប្រែ «តាមផ្លូវនេះ» នៅក្នុងជំពូក ៩:១។
ដល់សម្លាប់ពួកគេ
ពាក្យ «ស្លាប់» អាចប្រែជាកិរិយាសព្ទ «ស្លាប់» ឬ «សម្លាប់»។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយខ្ញុំបានស្វែងរកវិធីដើម្បីសម្លាប់ពួកគេ»
ចាប់យកពួកគេទៅដាក់គុក
«ចាប់ពួកគេដាក់គុក» ឬ ដាក់ពួកគេទៅក្នុងគុក»។
ធ្វើជាសាក្សីបាន
«អាចប្រាប់បាន» ឬ «បញ្ជាក់បាន» ឬ «ធ្វើបន្ទាល់បាន»
ខ្ញុំបានទទួលលិខិតពីលោកទាំងនោះ
«មហាបូជាចារ្យ និងពួកចាស់ទុំបានប្រគល់សំបុត្រដល់ខ្ញុំ»
ទៅជូនបងប្អូននៅក្រុងដាម៉ាស
ពាក្យ «បងប្អូន» នៅទីនេះ សំដៅលើ «បងប្អូនជនជាតិយូដា»។
ខ្ញុំបានទៅទីនោះដើម្បីចាប់ចងពួកគេយកមកក្រុងយេរូសាឡិម
«ពួកគេបានបង្គាប់ដល់ខ្ញុំ ឲ្យចាប់ចងអស់អ្នកដែលដើរតាមផ្លូវនេះ ហើយបញ្ជូលពួកគេប្រឡប់ទៅក្រុងយេរូសាឡិមវិញ»។
ដើម្បីដាក់ទោស
ឃ្លានេះអាចនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីចាប់ពួកគេឲ្យទទួលទោស» ឬ «ដើម្បីជនជាតិយូដាដែលមានសិទ្ធិអំណាចដាក់ទោសពួកគេ»
Acts 22:6
ប្រយោគភ្ជាប់
លោកប៉ូលពណ៌នាពីការដែលលោកបានជួបព្រះយេស៊ូ។
ការនេះបានកើតឡើង
ឃ្លានេះ ប្រើដើម្បីបញ្ជាក់ សកម្មភាពដែលគេចាប់ផ្តើមនៅទីណា។ ប្រសិនបើភាសារបស់អ្នកមានរបៀបក្នុងការធ្វើការនេះ អ្នកអាចប្រើវានៅទីនេះបាន។
បានឮសម្លេងមួយពោលមកខ្ញុំ
ពាក្យ «សម្លេង» តំណាងឲ្យមនុស្សកំពុងនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានឮមនុស្សម្នាក់និយាយមកខ្ញុំ»
Acts 22:9
ពួកគេមិនបានឮព្រះសូរសៀងរបស់ព្រះអង្គដែលមានបន្ទូលមកខ្ញុំទេ
ពាក្យ «សម្លេង» តំណាងឲ្យមនុស្សម្នាក់កំពុងនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេមិនយល់ពីអ្វីដែលអ្នកនោះនិយាយមកខ្ញុំទេ»
គេនឹងប្រាប់អ្នកគ្រប់យ៉ាង
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅទីនោះនឹងមានគេប្រាប់អ្នកហើយ» ឬ «នៅទីនោះ អ្នកនឹងដឹងហើយ»
ខ្ញុំពុំអាចមើលអ្វីឃើញសោះ
«ខ្ញុំបានខ្វាក់ភ្នែកដោយសារពន្លឺដ៏ភ្លឺ»
ហើយអស់អ្នកដែលនៅជាមួយខ្ញុំបានដឹកដៃខ្ញុំចូលទៅក្រុងដាម៉ាស
ពាក្យ «ដៃ» តំណាងឲ្យអ្នកដែលដឹកដៃលោកប៉ូល។
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលនៅជាមួយខ្ញុំបានដឹកដៃខ្ញុំចូលទៅក្នុងក្រុងដាម៉ាស» ។
Acts 22:12
ព័ត៌មានទូទៅ
ពាក្យ «លោក» និង «គាត់» សំដៅលើលោកអណាណាស។
លោកអណាណាស
នេះមិនមែនជាលោកអណាណាសដែលស្លាប់នៅក្នុងកិច្ចការ ៥:៣ នោះទេ
អ្នកអាចប្រែវាដូចគ្នា ដូចអ្នកបានធ្វើនៅក្នុងកិច្ចការ ៥:១
ជាអ្នកគោរពកោតខ្លាចព្រះស្របតាមក្រឹត្យវិន័យ
លោកអណាណាសជាមនុស្សដែលច្បាស់លាស់ជាមួយនឹងការដើរតាមច្បាប់របស់ព្រះជាម្ចាស់។
ហើយមានកេរ្តិ៍ឈ្មោះល្អនៅក្នុងចំណោមជនជាតិយូដាគ្រប់ៗគ្នាដែលរស់នៅទីនោះ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ជនជាតិយូដាដែលរស់នៅក្នុងទីនោះ ស្គាល់ពីកេរ្តិ៍ឈ្មោះរបស់គាត់»
បងសូល
ពាក្យ «បង» នៅទីនេះ ជារបៀបគួរសមនៃការនិយាយជាមួយនរណាម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ: «សម្លាញ់សូលអើយ» (UDB)
សូមឲ្យបងមើលឃើញវិញចុះ
ពាក្យ «មើលឃើញ» អាចប្រែជាកិរិយាសព្ទ «ឃើញ»។ របៀបផ្សេងទៀតនៃការបកប្រែ: «ឃើញជាថ្មី»
រំពេចនោះ
នេះគឺជាទម្លាប់នៃការនិយាយពីអ្វីដែលបានកើតឡើងភ្លាមៗ។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលនោះ» «ភ្លាមនោះ»
Acts 22:14
ប្រយោគភ្ជាប់
លោកប៉ូលបានបញ្ចប់ប្រាប់ពីអ្វីដែលបានកើតឡើងជាមួយលោកនៅក្រុងដាម៉ាស។ លោកបានដកស្រង់អ្វីដែលលោកអណាណាសនិយាយជាមួយគាត់។ នេះគឺជាចំណែកមួយនៃសុន្ទរកថារបស់លោកទៅកាន់បណ្តាជននៅក្នុងក្រុងយេរូសាឡិម។
ព័ត៌មានទូទៅ
ពាក្យ «លោក» សំដៅលើ លោកអណាណាស។ (សូមមើល: ២២:១២)
ព្រះហឫទ័យរបស់ព្រះអង្គ
«អ្វីដែលព្រះជាម្ចាស់មានផែនការ ហើយនឹងធ្វើឲ្យកើតឡើង»
បានឮព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះអង្គផ្ទាល់
ទាំង «សម្លេង» និង «មាត់» សំដៅលើនរណាម្នាក់និយាយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ស្តាប់ព្រះអង្គមានបន្ទូលមកកាន់លោកដោយផ្ទាល់ទៅ»
ពោះមុខមនុស្សទាំងអស់
«មនុស្ស» មានន័យថា មនុស្សទាំងអស់មិនថាប្រុស ឬស្រី។ របៀបផ្សេងទៀតនៃការបកប្រែ: «ចំពោះមនុស្សគ្រប់គ្នា» ។
ឥឡូវនេះ
ពាក្យ «ឥឡូវនេះ» មិនមែនមានន័យថា «នៅពេលនេះទេ» ប៉ុន្តែ វាត្រូវបានប្រើដើម្បីទាញចំណាប់អារម្មណ៍ទៅកាត់ចំណុចសំខាន់ដែលនឹងមកដល់។
តើបងនៅចាំដល់កាលណាទៀត?
នេះជាសំណួរដែលបានសួរទៅលោកប៉ូល ដើម្បីឲ្យទទួលពិធីជ្រមុជទឹក។ របៀបផ្សេងទៀតនៃការបកប្រែ: «កុំចាំអី» ឬ «កុំពន្យាអី»
ទទួលពិធីជ្រមុជទឹក
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

generated on Wed Sep 10 16:16:32 2025

«សូមឲ្យខ្ញុំធ្វើពិធីជ្រមុជទឹកឲ្យបង» ឬ «ចូរទទួលពិធីជ្រមុជទឹក»
លាងបាបរបស់បងចេញ
ប្រៀបដូចជាលាងសម្អាតដីពីនរណាម្នាក់
អំពាវនាវរកព្រះនាមព្រះយេស៊ូដើម្បីឲ្យព្រះអង្គអត់ទោស
និងសម្អាតបាបដែលនៅខាងក្នុង។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមអត់ទោសបាបសម្រាប់បាបរបស់អ្នក»
ព្រមទាំងអំពាវនាវរកព្រះនាមទ្រង់ផង
ពាក្យ «ព្រះនាម» សំដៅលើព្រះអម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អំពាវនាវរកព្រះអម្ចាស់» ឬ «ទុកចិត្តលើព្រះអម្ចាស់»។
Acts 22:17
ប្រយោគភ្ជាប់
លោកប៉ូលចាប់ផ្តើមដោយប្រាប់បណ្តាជនពីនិមិត្តរបស់គាត់អំពីព្រះយេស៊ូ។
ការនេះបានកើតឡើងដូច្នេះ
ឃ្លានេះ ប្រើដើម្បីបង្ហាញកន្លែងដែលត្រូវចាប់ផ្តើម។ ប្រសិនបើ
ភាសារបស់អ្នកមានរបៀបនេះដែរ អ្នកអាចប្រើវានៅទីនេះ។
ខ្ញុំបានទទួលនិមិត្តមួយ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានឃើញនិមិត្តមួយ» ឬ «ព្រះជាម្ចាស់បានប្រទាននិមិត្តមួយឲ្យខ្ញុំ»
ខ្ញុំបានឃើញព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា
«ខ្ញុំបានឃើញ ព្រះយេស៊ូ មានបន្ទូលមកខ្ញុំ»
ពួកគេមិនព្រមទទួលទីបន្ទាល់ដែលអ្នកនិយាយអំពីខ្ញុំទេ
«អស់អ្នកដែលរស់នៅក្នុងក្រុងយេរូសាឡិមមិន
ជឿអ្វីដែលអ្នកប្រាប់ពួកគេអំពីខ្ញុំទេ»។
Acts 22:19
ប្រយោគភ្ជាប់
នេះគឺជាចុងបញ្ចប់នូវអ្វីដែលលោកប៉ូលអាចនិយាយបានទៅកាន់បណ្តាជនជនជាតិយូដា
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ»
នៅទីនេះសំដៅលើអ្នកជឿដែលមិនមែនជាជនជាតិយូដានៅក្នុងក្រុងយេរូសាឡិម។
ពួកគេបានដឹងហើយថា
ពាក្យ «ពួកគេខ្លួនឯង» ប្រើនៅទីនេះ ដើម្បីបញ្ជាក់។
នៅតាមសាលាប្រជុំទាំងអស់
លោកប៉ូលបានចូលទៅតាមសាលាប្រជុំដើម្បីជួបអ្នកជឿព្រះយេស៊ូជនជាតិយូដា។
នៅពេលគេបង្ហូរឈាមលោកស្ទេផាន ដែលជាបន្ទាល់របស់ព្រះអង្គ
ពាក្យ «ឈាម» តំណាងឲ្យជីវិតរបស់លោកស្ទេផាន។
កម្ចាយឈាមមានន័យថាសម្លាប់។ ឃ្លានេះ និយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបានសម្លាប់លោកស្ទេផាន
ដែលបានធ្វើបន្ទាល់ពីព្រះអង្គ»
Acts 22:22
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ និងពាក្យ «លោក» លើកទីមួយ និងទីពីរ
សំដៅលើលោកប៉ូល។ ពាក្យ «លោក»និង «លោក»
ចុងក្រោយសំដៅលើមេបញ្ជាការ។
សូមកម្ចាត់មនុស្សបែបនេះចេញពីផែនដីចោលទៅ
ឃ្លា «ចេញពីផែនដី» បន្ថែមមកដើម្បីបញ្ជាក់ទៅនឹងពាក្យ
«កម្ចាត់មនុស្សបែបនេះចោលទៅ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«សម្លាប់គាត់ចោលទៅ»
កាលដែលពួកគេកំពុងតែ
«កាលដែលពួកគេកំពុងតែ» (UDB)។ ឃ្លា «កាលពួកគេកំពុងតែ» ប្រើនៅទីនេះ
ដើម្បីបង្ហាញពីព្រឹត្តិការណ៍ពីរ ដែលបានកើតឡើងនៅក្នុងពេលតែមួយ។
បោះអាវរបស់ពួកគេ និងបាចធូលីដីឡើងលើទៀតផងនោះ
នៅក្នុងសកម្មភាពទាំងនេះបង្ហាញថា ជនជាតិយូដានៅទីនោះបានតវ៉ា
ដោយសារពួកគេមានអារម្មណ៍ថាលោកប៉ូលនិយាយទាស់នឹងព្រះជាម្ចាស់។
មេបញ្ជាការ
មន្ត្រីយោធារបស់រ៉ូម ឬ មេទាហានលើទាហាន ៦០០នាក់។
បានបញ្ជាគេឲ្យនាំលោកប៉ូល
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបង្គាប់ទាហានរបស់លោកឲ្យទៅនាំលោកប៉ូល»។
បន្ទាយ
បន្ទាយនេះ នៅជាប់ទីលានខាងក្រៅព្រះវិហារ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២១:៣៤។
លោកបានបញ្ជាឲ្យគេវាយសួរចម្លើយ
មេបញ្ជាការបានឲ្យគេធ្វើទារុណកម្មលោកប៉ូលដោយវាយលោក
ដើម្បីឲ្យលោកប្រាប់ពីការពិត។ ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបានបង្គាប់ទាហានរបស់លោកឲ្យវាយលោកប៉ូលដើម្បីបង្ខំលោកឲ្យប្រាប់សេចក្តីពិត»
Acts 22:25
ព័ត៌មានទូទៅ
ពាក្យ «ពួកគេនៅទីនេះ» សំដៅលើទាហាន»។
ខ្សែ
នេះគឺជាខ្សែស្បែក ឬខ្សែស្បែកសត្វ។
តើអស់លោកមានសិទ្ធិវាយអ្នកដែលមានសញ្ជាតិរ៉ូម ដោយមិនកាត់ទោសជាមុនឬ?
លោកប៉ូលប្រើសំណួរនេះដើម្បីធ្វើឲ្យមេទាហានពិនិត្យថាពួកទាហានវាយលោកប៉ូលនោះតើត្រឹមត្រូវ
ឬយ៉ាងណា។ របៀបផ្សេងទៀតនៃការបកប្រែ: «តើត្រូវច្បាប់ទេ
ដែលអ្នកវាយមនុស្សម្នាក់ដែលជាសញ្ជាតិរ៉ូមដោយមិនបានកាត់ក្តី» (សូមមើល: |
Rhetorical Question)
កាត់ទោស
ឃ្លានេះមានន័យថា គ្មាននរណារកឃើញថាលោកមានកំហុសទេ នៅក្នុងតុលាការ។
តើលោកនឹងធ្វើអ្វីជាមួយរបស់នេះ?
[illegible]
ឲ្យគិតសារជាថ្មីពីផែនការរបស់គាត់ក្នុងការវាយលោកប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកមិនត្រូវធ្វើដូច្នេះទេ!» (សូមមើល: |
Rhetorical Question)
Acts 22:27
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើលោកប៉ូល។
លោកមេបញ្ជាការបានមក
ពាក្យ «បានមក» អាចបកប្រែថា «បានទៅ»
ខ្ញុំបានចាយប្រាក់ជាច្រើន ដើម្បីឲ្យបានសញ្ជាតិរ៉ូមនេះ
«ដើម្បីឲ្យបានសញ្ជាតិរ៉ូមនេះ ខ្ញុំបានចាយប្រាក់ជាច្រើនទៅឲ្យអាជ្ញធរ»
លោកមេបញ្ជាការបានមានប្រសាសន៍បែបនេះ ដោយសារលោកដឹងថា
វាលំបាកយ៉ាងណាដើម្បីឲ្យបានសញ្ជាតិរ៉ូម
ហើយលោកសង្ស័យថាលោកប៉ូលប្រាប់មិនពិត។
ខ្ញុំបានកើតមកមានសញ្ជាតិរ៉ូមតែម្តង
ខ្ញុំបានទទួលសញ្ជាតិរ៉ូមតែម្តង» ឬ «ខ្ញុំក្លាយជាសញ្ជាតិរ៉ូម»
អ្នកដែលរៀបនឹងសួរចម្លើយលោក
«អ្នកដែលគ្រោងនឹងសួរចម្លើយ» ឬ «បុរសដែលរៀបនឹងសួរសំណួរ»
Acts 22:30
ព័ត៌មានទូទៅ
ពាក្យ «លោក» សំដៅលើមេបញ្ជាការ។
មេបញ្ជាការ
មន្ត្រីយោធារបស់រ៉ូម ឬ មេទាហានលើទាហាន ៦០០នាក់។
ដូច្នេះ លោកបានឲ្យគេស្រាយចំណងចេញពីលោក
អាចជា «មេបញ្ជាការ» តំណាងឲ្យ «មេបញ្ជាការរបស់ទាហាន»។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះ មេបញ្ជាការ
បានបង្គាប់ទាហាររបស់លោកឲ្យស្រាយចំណងលោកប៉ូល»
បាននាំលោកប៉ូលចុះមក
ពីបន្ទាយ ដែលមានកាំជណ្តើរចុះទៅកាន់ទីលានរបស់ព្រះវិហារ។

---

23 [1]លោកប៉ូល សម្លឹងមើលទៅក្រុមប្រឹក្សាជាន់ខ្ពស់ ហើយមានប្រសាសន៍ថា៖ «បងប្អូនអើយ ខ្ញុំបានរស់នៅនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់រហូតមកទល់ថ្ងៃនេះ
មនសិកាត្រឹមត្រូវទាំងអស់»។[2]លោកមហាបូជាចារ្យអណានាសបង្គាប់ឲ្យអស់អ្នកដែលឈរក្បែរលោកប៉ូល ទះមាត់លោក។[3]លោកប៉ូលមានប្រសាសន៍ទៅលោក
មហាបូជាចារ្យថា៖ «ព្រះជាម្ចាស់នឹងវាយកំពែងទ្រុឌទ្រោមលាបពណ៌សជាមិនខាន។ តើលោកអង្គុយកាត់ក្តីខ្ញុំតាមក្រឹត្យវិន័យ តែលោកបែរជាបង្គាប់ឲ្យគេទះខ្ញុំ ខុសនឹង
ក្រឹត្យវិន័យទៅវិញមែនទេ?»។

generated on Wed Sep 10 16:16:32 2025

[4]ពួកអ្នកដែលនៅទីនោះពោលថា៖ «អ្នកហ៊ានប្រមាថលោកមហាបូជាចារ្យរបស់ព្រះជាម្ចាស់ផងឬ?»។[5]លោកប៉ូលតបវិញថា៖ «បងប្អូនអើយខ្ញុំនិយាយដូច្នេះ មកពីខ្ញុំមិនបានដឹងថា លោកជាមហាបូជាចារ្យទេ។ ដ្បិត មានសេចក្តីចែងទុកមកថា៖ «អ្នកមិនត្រូវនិយាយអាក្រក់ពីអ្នកដឹកនាំប្រជាជាតិរបស់អ្នកឡើយ»។
[6]លោកប៉ូលជ្រាបថា នៅក្នុងអង្គប្រជុំ មានមួយផ្នែកជាអ្នកខាងគណៈសាឌូស៊ី និងមួយផ្នែកទៀតខាងគណៈផារីស៊ី លោកក៏មានប្រសាសន៍ខ្លាំងៗនៅកណ្តាលក្រុមប្រឹក្សាជាន់ខ្ពស់ថា៖ «បងប្អូនអើយ ខ្ញុំជាអ្នកខាងគណៈផារីស៊ី ហើយខ្ញុំក៏ជាកូនរបស់អ្នកខាងគណៈផារីស៊ីដែរ ដោយព្រោះខ្ញុំសង្ឃឹមចង់បានការរស់ឡើងវិញពីសេចក្តីស្លាប់ដែលខ្ញុំកំពុងទទួលបានវិនិច្ឆ័យទោសនេះ»។[7]លោកប៉ូលមានប្រសាសន៍ដូច្នេះហើយ ពួកខាងគណៈផារីស៊ី និងពួកខាងគណៈសាឌូស៊ី ឈ្លោះប្រកែកគ្នាធ្វើឲ្យបែកខ្ញែកអង្គប្រជុំ។[8]ពួកខាងគណៈសាឌូស៊ីពុំជឿថា មនុស្សស្លាប់នឹងរស់ឡើងវិញ និងពុំជឿថាមានទេវតា ឬមានអារក្សទេ រីឯពួកខាងគណៈផារីស៊ីវិញគេជឿថាមានទាំងអស់។
[9]ពេលនោះ គេនាំគ្នាស្រែកឡូឡា ហើយអាចារ្យខ្លះពីខាងគណៈផារីស៊ីក្រោកឡើងប្រកែកតវ៉ាយ៉ាងខ្លាំងថា៖ «យើងពុំឃើញបុរសនេះមានកំហុសអ្វីឡើយ ប្រហែលជាមានអារក្ស ឬទេវតាណាមួយបាននិយាយមកកាន់គាត់ទេ មើលទៅ?»។[10]ដោយឃើញអង្គប្រជុំឈ្លោះប្រកែកគ្នាកាន់តែខ្លាំងឡើងៗ លោកមេបញ្ជាការក៏បញ្ជាឲ្យកងទាហានចុះមក នាំលោកប៉ូលចេញពីកណ្តាលចំណោមពួកគេ ចូលទៅក្នុងបន្ទាយ ព្រោះគាត់ខ្លាចគេហែកហួរសម្លាប់លោក។
[11]នៅយប់បន្ទាប់ ព្រះអម្ចាស់យាងចូលមកជិតលោកប៉ូល រួចមានព្រះបន្ទូលថា៖ «កុំខ្លាចអ្វីឡើយ! អ្នកត្រូវតែផ្តល់សក្ខីភាពនៅក្រុងរ៉ូម ដូចអ្នកបានផ្តល់សក្ខីភាពអំពីខ្ញុំនៅក្រុងយេរូសាឡឹមនេះដែរ»។
[12]នៅថ្ងៃបន្ទាប់មកទៀត ជនជាតិយូដាបានឃុបឃិតគ្នា ហើយស្បថស្បែថានឹងមិនបរិភោគ ឬផឹកអ្វីឡើយ ដរាបណាមិនបានសម្លាប់លោកប៉ូលសិនទេនោះ។[13]អស់អ្នកដែលបានឃុបឃិតគ្នានេះ មានចំនួនជាងសែសិបនាក់។
[14]គេបាននាំគ្នាទៅជួបពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យជំរាបថា៖ «យើងខ្ញុំបានស្បថស្បែថា នឹងមិនប៉ះពាល់ម្ហូបអាហារអ្វីឡើយ ដរាបណាមិនបានសម្លាប់ប៉ូលសិន។[15]ដូច្នេះ ឥឡូវនេះសូមចុះសម្រុងជាមួយក្រុមប្រឹក្សាជាន់ខ្ពស់ ហើយសុំឲ្យលោកមេបញ្ជាការនាំប៉ូលមក ធ្វើហាក់ដូចជាអស់លោកចង់ពិនិត្យពិច័យមើលសំណុំរឿងរបស់គាត់ឲ្យបានដិតដល់ថែមទៀត។ រីឯយើងខ្ញុំវិញ យើងខ្ញុំបានប្រុងប្រៀបខ្លួនរួចស្រេចហើយ ដើម្បីសម្លាប់គាត់ មុននឹងគាត់មកជិតដល់»។
[16]ប៉ុន្តែ ក្មួយប្រុសរបស់លោកប៉ូលបានដឹងកលល្បិចនេះ ក៏ចូលទៅក្នុងបន្ទាយជម្រាបលោកប៉ូលឲ្យបានជ្រាប។[17]លោកប៉ូលហៅនាយទាហានម្នាក់មកប្រាប់ថា៖ «សូមនាំយុវជននេះទៅជួបលោកមេបញ្ជាការទៅ ដ្បិត គេមានរឿងមួយជម្រាបលោក»។
[18]ដូច្នេះ នាយទាហានក៏នាំយុវជននោះទៅជួបលោកមេបញ្ជាការ រួចជម្រាបថា៖ «អ្នកទោសឈ្មោះ ប៉ូលបានហៅខ្ញុំបាទ ហើយសុំឲ្យខ្ញុំបាទនាំយុវជននេះមកជួបលោក ព្រោះគេមានរឿងមួយជម្រាបប្រាប់លោក»។[19]លោកមេបញ្ជាការដឹកដៃយុវជននោះ នាំចេញទៅដាច់ឡែកពីគេ សួរថា៖ «តើក្មួយមានរឿងអ្វីចង់ប្រាប់ខ្ញុំ?»។
[20]យុវជននោះជម្រាបថា៖ «ជនជាតិយូដាបានព្រមព្រៀងគ្នាថា នឹងមកសុំលោកឲ្យបញ្ជូនលោកប៉ូលទៅជួបក្រុមប្រឹក្សាជាន់ខ្ពស់នៅថ្ងៃស្អែក ដោយយកលេសថា ក្រុមប្រឹក្សាចង់ពិនិត្យមើលសំណុំរឿងរបស់គាត់ ឲ្យបានដិតដល់ថែមទៀត។[21]សូមលោកកុំជឿអ្នកទាំងនោះឡើយ ព្រោះមានពួកគេជាងសែសិបនាក់ ពួនស្ទាក់ចាំចាប់គាត់។ គេបានស្បថស្បែថានឹងមិនបរិភោគ ឬផឹកអ្វីឡើយ ដរាបណាមិនបានសម្លាប់លោកប៉ូលសិនទេនោះ។ ឥឡូវនេះ គេប្រុងប្រៀបរួចរាល់អស់ហើយ គេនៅចាំតែការយល់ស្របពីលោកប៉ុណ្ណោះ»។
[22]លោកមេបញ្ជាការបានប្រាប់យុវជននោះត្រឡប់ទៅវិញ ទាំងផ្តែផ្តាំមិនឲ្យនិយាយប្រាប់នរណាថា ខ្លួនបានជម្រាបគាត់អំពីរឿងនេះឡើយ។[23]បន្ទាប់មក លោកបានហៅនាយទាហានរបស់លោកពីររូបមកប្រាប់ថា៖ «សុំលោករៀបចំពលថ្មើរជើងពីររយនាក់ ពលសេះចិតសិបនាក់ និងពលកាន់លំពែងពីររយនាក់ ដើម្បីចេញដំណើរទៅក្រុងសេសារ។ អ្នកនឹងចេញដំណើរ នៅវេលាម៉ោងបីយប់»។[24]សុំរៀបចំសេះជាជំនិះ សម្រាប់លោកប៉ូលផង ដើម្បីនាំគាត់ទៅជួបលោកទេសាភិបាលភេលិចដោយសុខសាន្ត»។
[25]លោកមេបញ្ជាការបានសរសេរសំបុត្រមួយ ដូចតទៅនេះ៖[26]«ខ្ញុំបាទឈ្មោះក្លូឌាស លូស៊ា សូមជម្រាបមកឯកឧត្តមភេលិច ជាទេសាភិបាល សូមទានជ្រាប។[27]ជនជាតិយូដាបាននាំគ្នាចាប់បុរសនេះ បម្រុងនឹងសម្លាប់ចោល។ កាលខ្ញុំបាទដឹងថា គាត់ជាជនជាតិរ៉ូម ខ្ញុំបាទឲ្យទាហានទៅធ្វើអន្តរាគមន៍រំដោះគាត់មក។
[28]ខ្ញុំបាទចង់ដឹងមូលហេតុ ដែលនាំឲ្យគេចោទប្រកាន់គាត់ ដូច្នេះខ្ញុំបាទក៏នាំគាត់ទៅជួបក្រុមប្រឹក្សាជាន់ខ្ពស់របស់ពួកគេ។[29]ខ្ញុំបាទបានឃើញថា ពួកគេគ្រាន់តែចោទប្រកាន់គាត់ អំពីបញ្ហាទាក់ទងទៅនឹងធម៌វិន័យរបស់គេប៉ុណ្ណោះ គាត់មិនបានធ្វើអ្វីខុសដែលត្រូវមានទោសដល់ជីវិត ឬត្រូវជាប់ឃុំឃាំងឡើយ។[30]បន្ទាប់មក មានគេប្រាប់ខ្ញុំបាទថា ជនជាតិយូដាបានឃុបឃិតគ្នាប៉ុនប៉ងសម្លាប់គាត់ ហេតុនេះហើយបានជាខ្ញុំបាទបញ្ជូនគាត់មកឯកឧត្តមភ្លាម ហើយខ្ញុំបាទបានប្រាប់អស់អ្នកដែលចោទប្រកាន់គាត់ ឲ្យនាំពាក្យបណ្តឹងមកជូនឯកឧត្តមតែម្តង»។
[31]ពួកទាហានយកលោកប៉ូលមក ហើយនាំទៅក្រុងអាន់ទីប៉ាទ្រីសទាំងយប់តាមបញ្ជាដែលគេបានទទួល។[32]នៅថ្ងៃបន្ទាប់ គេបានវិលត្រឡប់មកបន្ទាយវិញដោយទុកតែពលសេះឲ្យបន្តដំណើរជាមួយលោកប៉ូល។[33]លុះទៅដល់ក្រុងសេសារ ពួកពលសេះបានយកសំបុត្រទៅជូនលោកទេសាភិបាល និងប្រគល់លោកប៉ូលជូនផងដែរ។
[34]ពេលលោកទេសាភិបាលអានសំបុត្ររួចហើយ គាត់ក៏សួរលោកប៉ូលថាមកពីស្រុកណា។ កាលលោកជ្រាបថា លោកប៉ូលជាអ្នកស្រុកគីលីគា[35]ហើយលោកមានប្រសាសន៍ថា៖ «ចាំពួកចោទប្រកាន់អ្នកមកដល់សិន ទើបយើងសួរចម្លើយ»។ បន្ទាប់មក លោកបង្គាប់ឲ្យគេយកលោកប៉ូលទៅឃុំទុក ក្នុងវិមានរបស់ព្រះបាទហេរ៉ូដ។

Acts 23:1

ប្រយោគភ្ជាប់

លោកប៉ូលឈរនៅចំពោះនាយកបូជាចារ្យ និងសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់។ (សូមមើល: ២២:៣០)

បងប្អូនអើយ

ពាក្យនេះមានន័យថា «បងប្អូនជនជាតិយូដាអើយ»។

ខ្ញុំបានរស់នៅនៅចំពោះព្រះជាម្ចាស់ មនសិការត្រឹមត្រូវគ្រប់យ៉ាងរហូតមកដល់សព្វថ្ងៃ

«ខ្ញុំដឹងថា ទោះបីជាសព្វថ្ងៃនេះក្តី ខ្ញុំបានធ្វើអ្វីដែលព្រះជាម្ចាស់ចង់ឲ្យខ្ញុំធ្វើ»។

លោកអណាណាស

នេះគឺជាឈ្មោះរបស់បុរសម្នាក់។ ទោះបីជាឈ្មោះនេះដូចឈ្មោះអណាណាសនៅក្នុងជំពូក ៥:១ ឬ ដូចជាអណាណាស នៅក្នុងជំពូក ៩:១០ ក្តី។

ឱកំពែងលាបពណ៌សអើយ

ឃ្លានេះ សំដៅលើជញ្ជាំងមួយដែលលាបពណ៌ស ដើម្បីឲ្យមើលទៅឃើញស្អាត។ លោកប៉ូលប្រាប់លោកអណាណាសថាលោកដូចជាជញ្ជាំងលាបពណ៌សដែលមើលទៅស្អាត ដូច្នេះហើយបានជាលោកអណាណាសមើលទៅដូចជាមនុស្សដែលស្អាតស្អំ ប៉ុន្តែលោកពេញដោយការអាក្រក់នៅខាងក្នុង។ របៀបផ្សេងទៀតនៃការបកប្រែ: «ឱកំពែងលាបពណ៌សអើយ»

តើលោកអង្គុយកាត់ក្តី...តាមក្រឹត្យវិន័យមែនទេ?

លោកប៉ូលប្រើសំណួរនេះដើម្បីបង្ហាញពីភាពលាក់ពុតរបស់លោកអណានាស។ របៀបផ្សេងទៀតនៃការបកប្រែ:

«លោកអង្គុយកាត់ក្តីនៅទីនោះ...ទាស់នឹងក្រឹត្យវិន័យ»

បានបង្គាប់ឲ្យអស់អ្នកដែលឈរជិតលោក វាយមាត់លោក

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ អ្នកអាចប្រើពាក្យ «វាយ» ដូចអ្នកប្រើនៅក្នុងឃ្លា «ព្រះជាម្ចាស់នឹងប្រហារអ្នក»។ របៀបផ្សេងទៀតនៃការបកប្រែ: «បានបង្គាប់ដល់មនុស្សឲ្យវាយខ្ញុំ»

Acts 23:4

តើអ្នកហ៊ានមើលងាយមហាបូជាចារ្យរបស់ព្រះជាម្ចាស់ផងឬ?

មនុស្សប្រើសំណួរនេះ

ដើម្បីស្តីបន្ទោសលោកប៉ូលចំពោះអ្វីដែលលោកបាននិយាយនៅក្នុងជំពូក ២៣:១។ របៀបផ្សេងទៀតនៃការបកប្រែ: «កុំប្រមាថមហាបូជាចារ្យរបស់ព្រះជាម្ចាស់ឡើយ»

ដ្បិត មានចែងទុកមកថា

លោកប៉ូលបម្រុងនឹងដកស្រង់អ្វីដែលលោកម៉ូសេបានសរសេរនៅក្នុងក្រឹត្យវិន័យ។ ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិតលោកម៉ូសេបានសរសេរនៅក្នុងក្រឹត្យវិន័យ»

Acts 23:6

បងប្អូនអើយ

ពាក្យ «បងប្អូនអើយ» សំដៅលើ «បងប្អូនជនជាតិយូដា»

ជាកូនរបស់គណៈផារីស៊ី

ពាក្យ «កូន» មានន័យថាលោកពិតជាកូនរបស់ផារីស៊ី និងជាពូជពង្សរបស់ផារីស៊ី។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «ហើយឪពុកខ្ញុំ
និងដូនតារបស់ខ្ញុំក៏ជាផារីស៊ីដែរ»
ដោយព្រោះខ្ញុំបានជឿលើការរស់ពីស្លាប់ឡើងវិញ ដែលខ្ញុំ
ពាក្យ «រស់ឡើងវិញ» អាចនិយាយថា «មានជីវិតរស់ឡើងវិញ»។ ពាក្យ «ស្លាប់»
អាចប្រែថា «អស់អ្នកដែលបានស្លាប់»។ របៀបផ្សេងទៀតនាំការបកប្រែ:
«អស់ងួកដែលបានស្លាប់ទៅហើយ នឹងមានជីវិតរស់ឡើងវិញ។ ហើយខ្ញុំ»
ខ្ញុំកំពុងកាត់ទោសនៅពេលនេះ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកកំពុងកាត់ក្តីខ្ញុំ»
បណ្តាជនក៏បាក់បែកគ្នា
«មនុស្សនៅក្នុងហ្វូងមនុស្សមានការខ្វែងគំនិតគ្នាជាខ្លាំង»
រវាងពួកខាងគណៈផារីស៊ី...និងពួកខាងគណៈសាឌូស៊ី
នេះគឺជាប្រវត្តិអំពី...ពួកខាងគណៈផារីស៊ី និងពួកខាងគណៈសាឌូស៊ី។
Acts 23:9
ដូច្នេះ ក៏កើតមានសម្រែកឡូឡា
«ដូច្នេះ ពួកគេបានចាប់ផ្តើមសម្រែកឡូឡា ដាក់គ្នាទៅវិញទៅមក»។ ពាក្យ «ដូច្នេះ»
សម្គាល់ពីព្រឹត្តិការណ៍ដែលបានកើតឡើង
ដោយសារអ្វីមួយផ្សេងទៀតដែលបានកើតឡើងពីមុន។ នៅក្នុងករណីនេះ
ព្រឹត្តិការណ៍មុនគឺលោកប៉ូលចាប់ពីសេចក្តីជំនឿរបស់លោកនៅក្នុងការរស់ឡើងវិញ។
ប្រហែលជាមានវិញ្ញាណ ឬទេវតាណាមួយបាននិយាយមកកាន់គាត់ទេដឹង?
ផារីស៊ីបានស្តីបន្ទោសដល់សាឌូស៊ីដោយបញ្ជាក់ថា ព្រះវិញ្ញាណ និងទេវតាមាននៅ
ហើយអាចនិយាយទៅកាន់មនុស្សបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រហែលជាព្រះវិញ្ញាណ ឬទេវតាបាននិយាយមកកាន់គាត់»
នៅពេលមានការឈ្លោះប្រកែកគ្នាកាន់តែខ្លាំងឡើងៗ
ពាក្យ «ការឈ្លោះប្រកែកគ្នាកាន់តែខ្លាំងឡើង» អាចនិយាយសារឡើងវិញ
«ឈ្លោះគ្នាដោយហឹង្សា»។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលពួកគេចាប់ផ្តើមឈ្លោះគ្នាជាខ្លាំង»
មេបញ្ជាការ
មន្ត្រីយោធារបស់រ៉ូម ឬ មេទាហានលើទាហាន ៦០០នាក់។
ពួកគេហែកហួរសម្លាប់លោកប៉ូល
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេអាចហែកលោកប៉ូលជាបំណែកតូចៗ» ឬ «ពួកគេនឹងធ្វើឲ្យលោកប៉ូល
គ្រោះថ្នាក់ដល់រូបកាយជាខ្លាំង»
គាត់ក៏បញ្ជាឲ្យទាហាននាំលោកដោយប្រើកម្លាំង
«ដោយប្រើកម្លាំងដើម្បីយកលោកចេញ»
ទៅបន្ទាយវិញ
បន្ទាយនៅជិតទីលានខាងក្រៅរបស់ព្រះវិហារ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២១:៣៤។
Acts 23:11
នៅយប់បន្ទាប់
នេះមានន័យថានៅយប់បន្ទាប់
បន្ទាប់ពីលោកប៉ូលបានឈរនៅចំពោះក្រុមប្រឹក្សាជាន់ខ្ពស់។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅយប់នោះ» (UDB)
ត្រូវធ្វើទីបន្ទាល់ពីខ្ញុំនៅក្រុងរ៉ូម
ពាក្យ «ពីខ្ញុំ» យល់។ របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើបន្ទាប់ពីខ្ញុំនៅក្រុងរ៉ូម» ឬ
«ធ្វើសាក្សីពីខ្ញុំនៅក្រុងរ៉ូម»
Acts 23:12
ប្រយោគភ្ជាប់
ពេលលោកប៉ូលនៅក្នុងគុកនៅក្នុងបន្ទាយ
ពួកយូដាដែលមិនជឿបានស្បថថានឹងសម្លាប់គាត់។
ស្បថ
«បានស្បថ» ឬ «បានស្បថនៅចំពោះព្រះជាម្ចាស់»
ស្បថ
ជាការព្រមព្រៀងក្នុងការធ្វើអ្វីមួយ
ស្បថឲ្យត្រូវបណ្តាសាលើពួកគេ
ពាក្យ «បណ្តាសា» និយាយសាឡើងវិញ។
ក៏អាចបញ្ជាក់អ្វីដែលធ្វើឲ្យពួកគេត្រូវបណ្តាសា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលទៅព្រះជាម្ចាស់ឲ្យត្រូវបណ្តាសាដល់ពួកគេ ប្រសិនបើ
ពួកគេមិនបានធ្វើតាមសេចក្តីសន្យា»
សែសិបនាក់
«៤០នាក់»
ដែលបានផ្សំគំនិតគ្នានេះ
«ដែលបង្កើតផែនការនេះ» ឬ «អ្នកដែលគ្រោងសម្លាប់លោកប៉ូល»
Acts 23:14
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើជនជាតិយូដាទាំងសែសិបនាក់ នៅក្នុងជំពូក ២៣:១២។
ព័ត៌មានទូទៅ
ពាក្យ «លោក» ប្រើជាពហុវចន: និងសំដៅលើនាយកបូជាចារ្យ និងចាស់ទុំ។
ព័ត៌មានទូទៅ
ពាក្យ «យើង» និង «ពួកយើង» ទាំងពីរ នៅទីនេះ
សំដៅលើជនជាតិយូដាទាំងសែសិបនាក់ ដែលគ្រោងសម្លាប់លោកប៉ូល។
យើងខ្ញុំបានស្បថថា នឹងមិនបរិភោគអាហារអ្វីឡើយ លុះត្រាតែយើងបានបានសម្លាប់ប៉ូលសិន
ស្បថ ហើយសូមព្រះជាម្ចាស់ឲ្យពួកគេត្រូវបណ្តាសា
ប្រសិនបើពួកគេស្បថហើយមិនធ្វើតាម។
បណ្តាសាប្រៀបដូចជាវត្ថុមួយដែលពួកគេអាចលឺនៅលើស្មាររបស់ពួកគេបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានស្បថឲ្យត្រូវបណ្តាសាលើយើង
ប្រសិនបើ យើងមិនបានស្លាប់លោកប៉ូលទេ។
យើងសូមព្រះជាម្ចាស់ឲ្យត្រូវបណ្តាសាលើយើង
ប្រសិនបើយើងមិនធ្វើអ្វីដែលយើងបានសន្យាថានឹងធ្វើ»។
ឥឡូវនេះ
ឥឡូវនេះ មិនមែនមានន័យថា «នៅពេលនេះទេ» ប៉ុន្តែ
ប្រើដើម្បីទាញចំណាប់អារម្មណ៍ទៅរកចំណុចសំខាន់ដែលត្រូវដើរតាម។
ដូច្នេះ
ពាក្យនេះគឺឃ្លាដែលត្រូវនិយាយ ដោយសារអ្វីដែលបាននិយាយកាលពីមុខ។
នៅក្នុងករណីនេះ ជនជាតិយូដាប្រាប់ក្រុមប្រឹក្សាអំពីសម្បថរបស់ពួកគេ។
នាំលោកមកជួប
«នាំលោកប៉ូលចុះពីបន្ទាយមកជួបជាមួយលោក»
ធ្វើដូចជាអស់លោកចង់ពិនិត្យពិច័យមើលសំណុំរឿងរបស់គាត់ឲ្យបានច្បាស់លាស់ថែមទៀត
«ក្រែងលោលោកចង់សិក្សាបន្ថែមទៀតអំពីអ្វីដែលលោកប៉ូលបានធ្វើ»
Acts 23:16
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើក្មួយលោកប៉ូល។ ពាក្យ «គាត់»
សំដៅលើមេបញ្ជាការ។
ពួកគេចង់សម្លាប់
«ពួកគេរួចរាល់នឹងពួនស្ទាក់វាយលោកប៉ូល» ឬ
«ពួកគេរងចាំស្ទាក់សម្លាប់លោកប៉ូល»។
បន្ទាយ
បន្ទាយនេះនៅជាប់នឹងទីលានខាងក្រៅរបស់ព្រះវិហារ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២១:៣៤។
Acts 23:18
ប៉ូលជាអ្នកទោសបានហៅខ្ញុំបាទទៅជួបគាត់
«ប៉ូលជាអ្នកទោសបានហៅខ្ញុំបាទឲ្យមកនិយាយជាមួយគាត់»
នាំយុវជននេះមក...ជួបលោកមេបញ្ជាការបានដឹកដៃគាត់
ពេលលោកមេបញ្ជាការបានដឹកដៃនាំយុវជន
ក្មួយរបស់លោកប៉ូលមានអាយុប្រហែលជា ១២ដល់ ១៥ឆ្នាំ។
Acts 23:20
ជនជាតិយូដាបានព្រមព្រៀងគ្នាថា
ឃ្លានេះ មិនមានន័យថាជនជាតិយូដាទាំងអស់នោះទេ ប៉ុន្តែ
ក្រុមមនុស្សទាំងអស់ដែលនៅទីនោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជនជាតិយូដាខ្លះបានយល់ស្រប»
ឲ្យបញ្ជូនលោកប៉ូលចុះទៅ
«ឲ្យបញ្ជូនលោកប៉ូលចុះពីបន្ទាយ»
ពួកគេចង់សាកសួរសំណុំរឿងរបស់គាត់ឲ្យកាន់តែច្បាស់ថែមទៀត
«ពួកគេចង់សិក្សាបន្ថែមទៀតនូវអ្វីដែលលោកប៉ូលបានធ្វើ»
សែសិបនាក់
«៤០នាក់»
ពួនស្ទាក់ចង់សម្លាប់លោក
«បានពួនស្ទាក់រួចរាល់រងចាំសម្លាប់លោក» ឬ «រួចរាល់ក្នុងការសម្លាប់លោកប៉ូល»

generated on Wed Sep 10 16:16:32 2025

ពួកគេបានស្បថមិនបរិភោគ ឬផឹកអ្វីឡើយ លុះត្រាណាតែពួកគេបានសម្លាប់លោកសិន
«ពួកគេបានស្បថមិនបរិភោគ ឬផឹកអ្វីឡើយ
លុះត្រាតែពួកគេបានស្លាប់លោកប៉ូលសិន។
ហើយពួកគេបានទូលដល់ព្រះជាម្ចាស់ឲ្យដាក់បណ្តាសាលើពួកគេ
ប្រសិនបើពួកគេមិនបានធ្វើអ្វីដែលពួកគេបានសន្យានឹងធ្វើ»។
Acts 23:22
ព័ត៌មានទូទៅ
ពាក្យ «លោក» នៅទីនេះ សំដៅលើមេបញ្ជាការ។
ព័ត៌មានទូទៅ
លោកភេលិចបានរស់នៅក្រុងសេសារា ជាទេសាភិបាលរបស់រ៉ូមនៅក្នុងតំបន់នោះ។
លោកបានហៅនាយទាហានពីររូបមក
លោកបានហៅគេមកឯលោក»
នាយទាហានពីររូប
«នាយទាហាន២នាក់»
ទ័ពសេះចិតសិបនាក់
«ទ័ពសេះ៧០»
ទ័ពលំពែងពីរយនាក់
«ទាហាន២០០នាក់ ដែលមានលំពែងជាមួយផង»
ម៉ោងទីបីយប់នេះ
នៅម៉ោងប្រាំបួនយប់នេះ
Acts 23:25
ព័ត៌មានទូទៅ
លោកមេបញ្ជាការ
បានសរសេរសំបុត្រទៅជូនលោកទេសាភិបាលភេលិចអំពីការចាប់ខ្លួនលោកប៉ូល។
ព័ត៌មានទូទៅ
ក្លូឌាសលូស៊ាគឺជាឈ្មោះរបស់មេបញ្ជាការ។
លោកទេសាភិបាលរ៉ូមដែលគ្រប់គ្រងលើតំបន់នោះទាំងមូល។
ខ្ញុំបាទឈ្មោះក្លូឌាស លូស៊ា សូមជម្រាបមកឯកឧត្តមភេលិច ជាទេសាភិបាល សូមទានជ្រាប
នេះគឺជាការណែនាំជាផ្លូវការនៅក្នុងសំបុត្រ។
លោកមេបញ្ជាការបានចាប់ផ្តើមណែនាំខ្លួនលោក។ អ្នកអាចបកប្រែជាបុរសទីមួយ។
ពាក្យ «ខ្ញុំសរសេរ» អាចយល់បាន។ របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបាទ
ជាក្លូឌាស លូស៊ា ខ្ញុំបាទសរសេរសំបុត្រនេះជូនលោកឯកឧត្តមភេលិច ជា
ទេសាភិបាល។ សូមជម្រាបសួរ»។
សូមជម្រាបមកឯកឧត្តមភេលិច ជាទេសាភិបាល សូមទានជ្រាប
«សូមជម្រាបមកលោកទេសាភិបាលភេលិច ជាទីគោរពដ៏ខ្ពង់ខ្ពស់»។
បុរសនេះត្រូវបានជនជាតិយូដាចាប់ខ្លួន
ពាក្យ «ជនជាតិយូដា» មានន័យថា មានជនជាតិយូដាខ្លះ»។
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានជនជាតិយូដាខ្លះបានចាប់ខ្លួនបុរសនេះ»
ពួកគេបម្រុងនឹងសម្លាប់
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេរួចរាល់ក្នុងការសម្លាប់លោកប៉ូល»
ខ្ញុំបាទបានទៅជាមួយនឹងទាហានហើយជួយគាត់
«ខ្ញុំ និងទាហានបានទៅដល់កន្លែងនោះ ជាកន្លែងដែលលោកប៉ូល
និងជនជាតិយូដានោះ»
Acts 23:28
ព័ត៌មានទូទៅ
លោកមេបញ្ជាការបានបញ្ចប់សំបុត្ររបស់លោកជាមួយលោកទេសាភិបាលភេលិច។
ព័ត៌មានទូទៅ
ពាក្យ «ខ្ញុំ» នៅទីនេះ សំដៅលើ លោកក្លូឌាសលីស៊ា ជាមេបញ្ជាការ។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើក្រុមរបស់ជនជាតិយូដាដែលចោទប្រកាន់លោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «អ្នក» គឺជាឯកវចន: ហើយសំដៅទៅលើលោកទេសាភិបាលភេលិច។
កគេគ្រាន់តែចោទប្រកាន់គាត់ អំពីបញ្ហាទាក់ទងទៅ
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេចោទប្រកាន់លោកដោយសារបញ្ហាដែលទាក់ទងនឹង»
ប៉ុន្តែ ការចោទប្រកាន់ដែលទាស់នឹងគាត់នោះ មិនសមនឹងមានទោសដល់ជីវិត ឬត្រូវជាប់ឃុំឃាំង
ឡើយ
«ស្លាប់» ជាពាក្យអរូប ហើយ «ជាប់ឃុំឃាំង» អាចនិយាយជាកិរិយាសព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ គ្មានអ្វីអាចនិយាយទាល់នឹងលោក
ដល់ថ្នាក់អជ្ញាធររ៉ូមសម្លាប់លោកទេ ឬ បញ្ជូលគាត់ទៅឃុំឃាំងឡើយ»
បន្ទាប់មក មានគេប្រាប់ខ្ញុំបាទថា
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ក្រោយមក
ខ្ញុំបាទបានដឹងថា»
Acts 23:31
ប្រយោគភ្ជាប់
នេះគឺជាពេលចុងក្រោយរបស់លោកប៉ូលនៅក្រោមការចាប់ខ្លួននៅក្នុងយេរូសាឡិម
ហើយចាប់ផ្តើមបញ្ជូនលោកទេសាភិបាលទៅក្រុងសេសារ។
ព័ត៌មានទូទៅ
ក្រុងអាន់ទីប៉ាទ្រីស
ជាទីក្រុងមួយដែលស្តេចហេរ៉ូដបានសង់ដើម្បីឧទ្ទិសថ្វាយទៅព្រះបាទ អាន់តីប៉ាធើ
ជាព្រះបិតារបស់ទ្រង់។ វាមានទីតាំងនៅចំកណ្តាលអ៊ីស្រាអែលបច្ចុប្បន្ន។
ព័ត៌មានទូទៅ
ពាក្យ «គាត់» លើកដំបូង សំដៅលើលោកប៉ូល។ ពាក្យ «គាត់»
ទីពីរសំដៅលើលោកទេសាភិបាលភេលិច។
ដូច្នេះ ពួកទាហានក៏ធ្វើតាមបញ្ជារបស់ពួកគេ
ពាក្យ «ដូច្នេះ» សម្គាល់ពីព្រឹត្តការដែលបានកើតឡើង
ដោយសារអ្វីមួយបានកើតឡើងពីមុន។ នៅក្នុងករណីនេះ
ព្រឹត្តការណ៍លើកមុនគឺលោកមេបញ្ជាការបានបញ្ជាឲ្យគេការពារលោកប៉ូល។
ពួកគេបានយកលោកប៉ូល ហើយនាំគាត់ទៅក្រុងអាន់ទីប៉ាទ្រីសទាំងយប់
ពាក្យ «នាំ» អាចប្រែជា «យក»។ របៀបផ្សេងទៀតនៃការបកប្រែ:
ពួកគេបាននាំលោកប៉ូល ហើយយកលោកទៅទាំងយប់»។
Acts 23:34
ព័ត៌មានទូទៅ
ពាក្យ «លោក» ទីមួយ និងទីពីរសំដៅលើលោកទេសាភិបាលភេលិច ហើយពាក្យ
«លោក» ទីបីសំដៅលើលោកប៉ូល ហើយពាក្យ «លោក»
ចុងក្រោយសំដៅលើលោកទេសាភិបាលភេលិច។
គាត់បានសួរលោកប៉ូលថាមកពីស្រុកណា
ឃ្លានេះ និយាយដកស្រង់ដោយផ្ទាល់តែម្តង។ របៀបផ្សេងទៀតនៃការបកប្រែ:
«គាត់បានសួរលោកប៉ូលថា «តើលោកមកពីខេត្តណា?»
ពេលលោកជ្រាបថា គាត់មកពីស្រុកគីលីគា នោះលោកមានប្រសាសន៍ថា
ឃ្លានេះ និយាយដកស្រង់សំដីផ្ទាល់តែម្តង។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកប៉ូលមានប្រសាសន៍ថា «ខ្ញុំមកពីស្រុកគីលីគា»។ បន្ទាប់មក
លោកទេសាភិបាលមានប្រសាសន៍ថា»
ខ្ញុំនឹងស្តាប់លោកទាំងស្រុង
«ខ្ញុំនឹងស្តាប់លោកទាំងស្រុង នូវអ្វីដែលលោកមានប្រសាសន៍» ឬ
«លោកបានបង្គាប់ពួកទាហានឲ្យការពារគាត់»

---

24 [1]ប្រាំថ្ងៃក្រោយមក លោកមហាបូជាចារ្យអាណាណាស និងពួកព្រឹទ្ធាចារ្យមួយចំនួនបានធ្វើដំណើរមកដល់ មានទាំងមេធាវីម្នាក់ឈ្មោះទើទូលុសមកជាមួយផង។ ពួក
គេបានប្តឹងទៅលោកទេសាភិបាល ចោទប្រកាន់លោកប៉ូល។[2]គេហៅលោកប៉ូលមក ហើយលោកទើទូលុសចោទប្រកាន់លោក ដូចតទៅនេះ៖ «សូមគោរពឯកឧត្តម
ភេលិចសូមទានជ្រាប ដោយសារតែឯកឧត្តម និងដោយការកែទម្រង់ផ្សេងៗ ដែលឯកឧត្តមបានធ្វើជាប្រយោជន៍ដល់ប្រជាជាតិនេះ យើងខ្ញុំបានប្រកបដោយសេចក្តីសុខ
គ្រប់យ៉ាង ក្រោមការគ្រប់គ្រងដ៏ប៉ិនប្រសប់របស់ឯកឧត្តម[3]ដូច្នេះ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តមភេលិច ដែលបានប្រទានអ្វីៗនៅគ្រប់ទីកន្លែង
និងគ្រប់ពេលវេលាមកយើងខ្ញុំ។
[4]ដូច្នេះ ខ្ញុំបាទមិនចង់រំខានឯកឧត្តមវែងឆ្ងាយទៀតទេ ខ្ញុំបាទគ្រាន់តែអង្វរឯកឧត្តម សូមមេត្តាស្តាប់យើងខ្ញុំតែបន្តិចប៉ុណ្ណោះ។[5]យើងខ្ញុំយល់ឃើញថាជននេះជាមនុស្សចង្រៃ
ឧត្បាត បង្កចលាចលក្នុងចំណោមជនជាតិយូដាទាំងអស់ នៅលើពិភពលោកទាំងមូល។ គាត់ជាមេដឹកនាំពួកខាងគណៈណាសារ៉ែត។[6]គាត់ថែមទាំងបានបន្ទុះបង្អាប់
ព្រះវិហារទៀតផង ហេតុនេះបានជាយើងខ្ញុំចាប់គាត់ យើងខ្ញុំចង់កាត់ទោសគាត់តាមក្រឹត្យវិន័យរបស់យើងខ្ញុំ។

generated on Wed Sep 10 16:16:32 2025

[7]ប៉ុន្តែ លោកមេបញ្ជាការលូស៊ាបានប្រើកម្លាំង ធ្វើអន្តរាគមន៍យ៉ាងខ្លាំងដណ្តើមយកគាត់ពីយើងខ្ញុំ ហើយបានបង្គាប់ឲ្យអស់អ្នកដែលចោទប្រកាន់ជននេះ មកជួបឯកឧត្តម។
[8]សូមឯកឧត្តមសួរគាត់ផ្ទាល់តែម្តងទៅ ឯកឧត្តមមុខជាជ្រាបមូលហេតុទាំងអស់ ដែលយើងខ្ញុំចោទប្រកាន់គាត់នោះមិនខាន»។[9]ជនជាតិយូដាបានគាំទ្រពាក្យចោទប្រកាន់នេះ និងបញ្ជាក់ថា ពិតជាត្រឹមត្រូវមែន។
[10]ពេលនោះ លោកទេសាភិបាលបានធ្វើសញ្ញាប្រាប់លោកប៉ូលឲ្យមានប្រសាសន៍ លោកប៉ូលក៏មានប្រសាសន៍ថា៖ «ខ្ញុំបានដឹងថា ឯកឧត្តមជាអ្នកគ្រប់គ្រងលើប្រជាជាតិនេះ ច្រើនឆ្នាំមកហើយ ដូច្នេះ ខ្ញុំបានសូមឆ្លើយការពារខ្លួន ទាំងទុកចិត្ត។[11]ខ្ញុំបានបានធ្វើដំណើរទៅថ្វាយបង្គំព្រះជាម្ចាស់នៅក្រុងយេរូសាឡឹមកាលដប់ពីរថ្ងៃកន្លងទៅនេះ សូមឯកឧត្តមស៊ើបសួរមើលចុះ។[12]ទោះបីនៅក្នុងព្រះវិហារក្តី នៅក្នុងសាលាប្រជុំ ឬនៅក្នុងទីក្រុងក្តី គ្មាននរណាម្នាក់បានឃើញខ្ញុំបានជជែកវែកញែកជាមួយគេ ឬក៏បង្កចលាចលក្នុងចំណោមបណ្តាជនឡើយ។[13]អស់លោកទាំងនេះគ្មានភស្តុតាងអ្វី មកបញ្ជាក់ពាក្យចោទប្រកាន់របស់ខ្លួន ជូនឯកឧត្តមទាល់តែសោះ។
[14]ប៉ុន្តែ ខ្ញុំបានសូមជម្រាបឯកឧត្តមថា ខ្ញុំបានគោរពប្រណិប័តន៍ព្រះនៃបុព្វបុរស ខ្ញុំបានដើរតាមមាគ៌ាមួយ ដែលលោកទាំងនេះចោទថាជាគណៈខុសឆ្គង។ ខ្ញុំបានជឿសេចក្តីទាំងប៉ុន្មាន ដែលមានចែងទុកក្នុងគម្ពីរវិន័យ និងគម្ពីរព្យាការី។[15]ខ្ញុំបានសង្ឃឹមទុកចិត្តព្រះជាម្ចាស់ ដូចលោកទាំងនេះដែរថា ព្រះអង្គនឹងប្រោសទាំងមនុស្សសុចរិត ទាំងមនុស្សទុច្ចរិតឲ្យរស់ឡើងវិញ។[16]ហេតុនេះហើយបានជាខ្ញុំបានខំប្រឹងធ្វើយ៉ាងណា ឲ្យមានចិត្តស្អាតបរិសុទ្ធគ្រប់ចំពូកចំពោះព្រះជាម្ចាស់ និងចំពោះមនុស្សលោក។
[17]ខ្ញុំបានបានចាកចេញពីក្រុងយេរូសាឡឹមជាច្រើនឆ្នាំ ហើយខ្ញុំបានវិលត្រឡប់មកវិញ ដើម្បីជួយជនរួមជាតិរបស់ខ្ញុំបាន និងថ្វាយតង្វាយទៅព្រះជាម្ចាស់ផង។[18]នៅពេលពួកគេឃើញខ្ញុំបានធ្វើពិធីជម្រះកាយឲ្យបានបរិសុទ្ធនៅក្នុងព្រះវិហារ មានសាសន៍យូដាខ្លះមកពីស្រុកអាស៊ីដែរ តែឥតមានការប្រជុំបណ្តាជន ឬកើតវឹកវរអ្វីឡើយ។
[19]ពួកអ្នកទាំងនោះគួរតែនៅចំពោះលោកឥឡូវនេះ ហើយចោទប្រកាន់ខ្ញុំបាន ប្រសិនបើគេមានរឿងហេតុណាមួយទាស់នឹងខ្ញុំបានមែន។
[20]ខ្ញុំបានឈរមុខក្រុមប្រឹក្សាជាន់ខ្ពស់ស្រាប់ហើយ បើអស់លោកដែលនៅទីនេះ បានឃើញខ្ញុំបានមានទោសអ្វី សូមថាមកចុះ[21]លើកលែងតែពាក្យដែលខ្ញុំបានបាននិយាយយ៉ាងខ្លាំងៗនៅកណ្តាលចំណោមពួកគេថា៖ «បងប្អូនយកខ្ញុំមកកាត់ទោសនៅថ្ងៃនេះ ព្រោះតែខ្ញុំជឿថា មនុស្សស្លាប់នឹងរស់ឡើងវិញ»។
[22]បន្ទាប់មក លោកភេលិចក៏បានជ្រាបច្បាស់លាស់ អំពីមាគ៌ារបស់ព្រះអម្ចាស់ដែរ។ លោកប្រាប់ពួកគេឲ្យត្រឡប់ទៅវិញ ដោយពោលថា៖ «ពេលលោកមេបញ្ជាការលូស៊ាមកដល់ ខ្ញុំនឹងវិនិច្ឆ័យសំណុំរឿងរបស់លោក»។[23]លោកបញ្ជាឲ្យគេយកលោកប៉ូលទៅឃុំ តែលោកទុកឲ្យលោកប៉ូលមានសេរីភាពខ្លះៗដែរ ព្រមទាំងបើកឲ្យអ្នកជិតដិតនឹងលោកប៉ូល ចូលទៅជួយទំនុកបម្រុងលោកថែមទៀតផង។
[24]ប៉ុន្មានថ្ងៃក្រោយមក លោកភេលិចបានមកជាមួយភរិយារបស់លោក គឺម្ចាស់ក្សត្រីយ៍ទ្រូស៊ីលជាជនជាតិយូដា លោកឲ្យគេទៅហៅលោកប៉ូលមក ហើយស្តាប់លោកប៉ូលមានប្រសាសន៍អំពីជំនឿលើព្រះគ្រិស្តយេស៊ូ។[25]ប៉ុន្តែ កាលលោកប៉ូលវែកញែកអំពីសេចក្តីសុចរិត អំពីការទប់ចិត្តនឹងតណ្ហា និងអំពីការវិនិច្ឆ័យទោសនៅអនាគតកាល លោកភេលិចភិតភ័យ ហើយពោលទៅលោកប៉ូលថា៖ «ឥឡូវនេះ ចូរអ្នកត្រឡប់ទៅវិញសិនចុះ។ កាលណាខ្ញុំមានពេល ខ្ញុំនឹងហៅអ្នកមកទៀត»។
[26]ក្នុងពេលដដែលនោះ លោកភេលិចសង្ឃឹមថានឹងបានទទួលប្រាក់ពីលោកប៉ូល ហេតុនេះហើយបានជាលោកចាត់គេឲ្យទៅហៅលោកប៉ូល មកសន្ទនាជាមួយលោកជារឿយៗ។[27]ពីរឆ្នាំក្រោយមក លោកពរគាស-ភេស្ទុស ចូលកាន់តំណែងជំនួសលោកភេលិច។ ដោយលោកភេលិចចង់យកចិត្តសាសន៍យូដា លោកបានទុកលោកប៉ូលឲ្យនៅជាប់ឃុំឃាំងដដែល។

Acts 24:1

ប្រយោគភ្ជាប់

លោកប៉ូលកាត់ក្តីនៅសេសារ។

ទើទូលុសគឺជាអ្នកប្តឹងនឹងលោកទេសាភិបាលភេលិច ទាស់នឹងលោកប៉ូល។

ព័ត៌មានទូទៅ

ពាក្យ «លោក» នៅទីនេះ សំដៅលើលោកទេសាភិបាលភេលិច។

ព័ត៌មានទូទៅ

ពាក្យ «យើង» សំដៅលើសញ្ជាតិដែលនៅក្រោមការគ្រប់គ្រងលោកភេលិច។

ប្រាំថ្ងៃក្រោយមក

«ប្រាំថ្ងៃ បន្ទាប់ពីទាហានរ៉ូមយកលោកប៉ូទៅក្រុងសេសារ»

លោកអណាណាស

នេះគឺជាឈ្មោះរបស់បុរសម្នាក់។ នេះមិនមែនជាលោកអណាណាសនៅក្នុងជំពូក ៥:១ ឬ លោកអណាណាស នៅក្នុងជំពូក ៩:១០ ទេ។

សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ២៣:១។

មេធាវីម្នាក់

«ជាមេធាវី»។ លោកទើទូលុសគឺជាអ្នកជំនាញច្បាប់នៅក្នុងក្រុងរ៉ូម ដែលមកប្តឹងលោកប៉ូលឡើងតុលាការ។

លោកទើទូលុស

គឺជាឈ្មោះរបស់បុរសម្នាក់។

បានទៅដល់ទីនោះ

«បានទៅដល់សេសារា កន្លែងដែលលោកប៉ូលនៅ»

ឈរនៅចំពោះលោកទេសាភិបាល

«នៅចំពោះវត្តមានរបស់លោកទេសាភិបាល ដែលជំនុំជម្រះនៅក្នុងតុលាការ»

បានចោទប្រកាន់លោក

«បានចោទប្រកាន់លោកពីការធ្វើខុសច្បាប់» ដល់លោកទេសាភិបាល។

យើងខ្ញុំបានប្រកបដោយសេចក្តីសុខសាន្ត

ពាក្យ «យើង» នៅទីនេះ
សំដៅលើប្រជាជនដែលនៅក្រោកការគ្រប់គ្រងរបស់លោកភេលិច។
របៀបផ្សេងទៀតនៃការបកប្រែ: «យើង
ជាប្រជាជនដែលនៅក្រោមការគ្រប់គ្រងរបស់លោក
យើងខ្ញុំរស់នៅដោយសុខសាន្តណាស់»

ដោយសារតែឯកឧត្តមមានចក្ខុវិស័យ នាំការកែទម្រង់ដល់ប្រជាជាតិរបស់យើងខ្ញុំ

«ដោយសារគម្រោងការរបស់លោក មានការអភិវឌ្ឍប្រជាជនយើងខ្ញុំជាខ្លាំង»។

ឯកឧត្តមភេលិចជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

«ឯកឧត្តមភេលិចស័ក្តិសមនឹងទទួលការគោរពដ៏ខ្ពស់បំផុត» ឯកឧត្តមភេលិចជាទេសាភិបាលជនជាតិរ៉ូម ដែលគ្រប់គ្រងនៅក្នុងតំបន់នោះទាំងមូល។

សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងឃ្លាដែលប្រហាក់ប្រែនៅក្នុងជំពូក ២៣:២៥។

Acts 24:4

ព័ត៌មានទូទៅ

ពាក្យ «យើង» សំដៅលើលោកអណាណាស ពួកចាស់ទុំ និងលោកទើទូលុស។

ខ្ញុំបានមិនចង់រំខានឯកឧត្តមច្រើនទេ

អាចមានន័យពីរយ៉ាង។ ទី១) «ដូច្នេះ ខ្ញុំនឹងមិនចំណាយពេលឯកឧត្តមច្រើនទេ (UDB)។ ទី២) ដូច្នេះ ខ្ញុំបានមិនរំខានឯកឧត្តមច្រើនទេ»។

ខ្ញុំបានគ្រាន់សូមឲ្យឯកឧត្តមមេត្តាស្តាប់ខ្ញុំសង្ខេបខ្លីៗតែប៉ុណ្ណោះ

«សូមមេត្តាស្តាប់ខ្ញុំបានិយាយខ្លីៗ»

ជននេះជាមនុស្សចង្រៃ

ឃ្លានេះនិយាយពីលោកប៉ូល
ប្រៀបដូចជាលោកជាមនុស្សដែលនាំគ្រោះកាចពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «បុរសនេះ ជាមនុស្សនាំឲ្យមានបញ្ហាកើតឡើង»

ជនជាតិយូដាទាំងអស់ នៅលើពិភពលោកទាំងមូល

ពាក្យ «ទាំងមូល» នៅទីនេះ ប្រើដើម្បីបំផ្លើសការចោទប្រកាន់ទាស់នឹងលោកប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ:
«មានជនជាតិយូដាពេញទូទាំងពីភពលោកទាំងមូល»

គាត់ជាមេដឹកនាំម្នាក់នៅក្នុងនិកាយណាសារ៉ែត

ឃ្លា «និកាយណាសារ៉ែត» ឈ្មោះមួយទៀតគឺគ្រិស្តបរិស័ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«លោកបាននាំក្រុមមនុស្សទាំងអស់ដែលហៅខ្លួនឯងថាជាអ្នកដើរតាមនិកាយណាសារ៉ែត»

និកាយ

នេះគឺជាក្រុមដែលតូចជាពួកមនុស្សដែលនៅក្នុងក្រុមធំ។ លោក
ទើទូលុសគិតថាគ្រិស្តបរិស័ទគឺជាក្រុមតូចមួយនៅក្នុងសាសនាយូដា។

Acts 24:7

ប្រយោគភ្ជាប់

លោក

ទើទូលុសបានបញ្ចប់ការប្តឹងទាស់នឹងលោកប៉ូលនៅចំពោះលោកទេសាភិបាលភេលិច។

ព័ត៌មានទូទៅ

generated on Wed Sep 10 16:16:32 2025

ពាក្យ «អ្នក» ជាឯវចន: ហើយសំដៅទៅលើលោកទេសាភិបាលភេលិច។
ចោទប្រកាន់លោក
«ចោទប្រកាន់លោកប៉ូលពីការប្រព្រឹត្ត» ឬ
«ចោទប្រកាន់លោកប៉ូលពីកំហុសរបស់លោក»
ជនជាតិយូដា
ឃ្លានេះ សំដៅលើអ្នកដឹកនាំជនជាតិយូដា
ដែលនៅកន្លែងកាត់ក្តីលោកប៉ូលនៅទីនោះ។
Acts 24:10
ប្រយោគភ្ជាប់
លោកប៉ូលឆ្លើយទៅលោកទេសាភិបាលភេលិចអំពីការដែលពួកគេចោទប្រកាន់ទាស់នឹងលោក
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើជនជាតិយូដាដែលចោទប្រកាន់លោកប៉ូល។
លោកទេសាភិបាលបានធ្វើសញ្ញា
«លោកទេសាភិបាលបានធ្វើកាយវិការ»
អ្នកកាត់ក្តីដល់ប្រជាជាតិនេះ
ពាក្យ «ប្រជាជាតិ» សំដៅលើមនុស្សដែលជាជនជាតិយូដា។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកកាត់ក្តីប្រជាជនជនជាតិយូដា»
នឹងពន្យល់ពីខ្លួនខ្ញុំបាទ
«នឹងពន្យល់ពីស្ថានភាពរបស់ខ្ញុំ»
ឯកឧត្តមនឹងជ្រាបថា
«ឯកឧត្តមនឹងឃើញភ័ស្តុតាង»
ពីដប់ពីរថ្ងៃ
«១២ថ្ងៃ»
ខ្ញុំបាទក៏មិនបាបង្ករចលាចលនៅក្នុងបណ្តាជន
«បង្ករចលាចល» គឺជាពាក្យប្រៀបធៀបនឹងការចាក់ចុចមនុស្សមិនឲ្យសម្រាកបាន
ដូចជាការអង្រួនវត្ថុរាវឲ្យក្រឡក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិនបានធ្វើឲ្យបណ្តាជនខឹងទេ»
ការចោទប្រកាន់
«ស្តីបន្ទោសចំពោះការធ្វើខុស» ឬ «ចោទប្រកាន់ពីបទល្មើស»
Acts 24:14
ខ្ញុំបាទទទួលស្គាល់ចំពោះឯកឧត្តមថា
«ខ្ញុំបាទទទួលស្គាល់ចំពោះឯកឧត្តម» ឬ «ខ្ញុំសារភាពការនេះជាមួយឯកឧត្តម»
យោងទៅតាមមាគ៌ា
ឃ្លា «ផ្លូវ» គឺជាងារប្រើសម្រាប់គ្រិស្តបរិស័ទ នៅក្នុងសម័យរបស់លោកប៉ូល។
ពួកគេហៅថានិកាយខុសឆ្គង
នេះគឺជាក្រុមមនុស្សដែលក្នុងក្រុមតូច នៅក្នុងក្រុមធំ។ លោកទើទូលុស
គិតថាគ្រិស្តបរិស័ទគឺជាក្រុមតូចមួយនៅក្នុងសាសនាយូដា។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យ «និកាយ» នៅក្នុងជំពូក ២៤:៤។
ខ្ញុំបាទបានបម្រើព្រះជាម្ចាស់របស់បុព្វបុរសរបស់យើង
លោកប៉ូលប្រើឃ្លា «ដូចគ្នា» មានន័យថាលោកជាអ្នកជឿលើព្រះយេស៊ូ
សម្រាប់ព្រះជាម្ចាស់ដូចជាជាមួយនឹងបុព្វបុរសរបស់យើងបានធ្វើដែរ។
លោកមិនមែនជាអ្នកដឹកនាំ «និកាយ» ឬ
បង្រៀនអ្វីមួយថ្មីដែលផ្ទុយនឹងសាសនាបុរាណរបស់ពួកគេឡើយ។
ដូចលោកទាំងនេះដែរ
ពាក្យ «លោកទាំងនេះ»
សំដៅលើជនជាតិយូដាដែលចោទប្រកាន់លោកប៉ូលនៅក្នុងតុលាការ។
ទាំងមនុស្សទុច្ចរិតនឹងរស់ឡើងវិញ
«ការរស់ឡើងវិញ» នេះគឺជានាមអរូប អាចនិយាយបានថា:
«ព្រះជាម្ចាស់នឹងធ្វើឲ្យពួកគេរស់ឡើងវិញ»។ បើជាគុណនាមវិញ «ស្លាប់»
អាចនិយាយថា: «អស់អ្នកដែលស្លាប់»។
នៅពេលព្រះជាម្ចាស់ប្រោសមនុស្សទាំងអស់ឲ្យរស់ឡើងវិញ ទាំងមនុស្សសុចរិត
និងទុច្ចរិត»
ទាំងមនុស្សសុចរិត
«អស់អ្នកដែលបានធ្វើអ្វីដែលត្រឹមត្រូវ»
ទាំងមនុស្សទុច្ចរិតនឹងរស់ឡើងវិញ
«អស់អ្នកដែលបានប្រព្រឹត្តអ្វីដែលអាក្រក់»
ខ្ញុំបាទតែងតែខិតខំជាខ្លាំង
«ខ្ញុំព្យាយាមអស់ពីសមត្ថភាព»
ដើម្បីឲ្យមានមនសិការស្អាតនៅចំពោះ
ពាក្យ «មនសិការល្អ» សំដៅលើមនុស្សខាងក្នុង
ជាសីលធម៌នៃការជ្រើសរើសរវាងត្រឹមត្រូវ និងខុសឆ្គង។
របៀបផ្សេងទៀតនៃការបកប្រែ: «រកកន្លែងបន្ទោសមិនបាន» ឬ
«ធ្វើអ្វីដែលត្រឹមត្រូវជានិច្ច»។
នៅចំពោះព្រះជាម្ចាស់
«នៅចំពោះព្រះវត្តមានរបស់ព្រះជាម្ចាស់»
Acts 24:17
ឥឡូវនេះ
ពាក្យនេះ បង្ហាញពីការប្តូររឿងជម្លោះរបស់លោកប៉ូល។ នៅទីនេះ
លោកប៉ូលបានពន្យល់ពីស្ថានភាពនៅក្នុងក្រុងយេរូសាឡិម
ពេលជនជាតិយូដាខ្លះបានចាប់ខ្លួនលោក។
បន្ទាប់ពីបានចាកចេញច្រើនឆ្នាំ
«បន្ទាប់ពីបានចាកចេញពីក្រុងយេរូសាឡិមច្រើនឆ្នាំ»
ខ្ញុំបាទបានត្រឡប់មកជួយប្រជាជាតិខ្ញុំវិញ ហើយបាននាំយកប្រាក់ជាច្រើន
ពាក្យ «ខ្ញុំបានមក» អាចប្រែថា «ខ្ញុំបានទៅ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានទៅជួយបងប្អូនរបស់ខ្ញុំដោយនាំយកប្រាក់ជាអំណោយដល់ពួកគេ»។
ខ្ញុំបាទធ្វើពិធីជម្រះកាយនៅក្នុងព្រះវិហារ
«នៅក្នុងព្រះវិហារ
បន្ទាប់ពីខ្ញុំបានបញ្ចប់ពិធីជម្រះកាយឲ្យបានបរិសុទ្ធដល់ខ្ញុំខ្លួនឯងរួចហើយ»។
គ្មានការប្រជុំបណ្តាជន ឬកើតចលាចលឡើយ
ឃ្លានេះអាចបំបែកជាប្រយោគពីរផ្សេងគ្នា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំមិនបានជួបជុំបណ្តាជន ឬ ខ្ញុំព្យាយាមឲ្យមានការធ្វើកុប្បកម្មឡើយ»
ពួកអ្នកទាំងនោះ
«ជនជាតិយូដាមកពីអាស៊ី»
ប្រសិនបើពួកគេមានរឿងអ្វីទាស់នឹងខ្ញុំបាទមែន
«ប្រសិនបើ ពួកគេគ្មានអ្វីនិយាយទេ»
Acts 24:20
ប្រយោគភ្ជាប់
លោកប៉ូលបានបញ្ចប់ការឆ្លើយតបរបស់គាត់ទៅកាន់លោកទេសាភិបាលភេលិចអំពីការដែលគេចោទប្រក
អ្នកទាំងនេះ
ឃ្លានេះ
សំដៅលើសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ដែលមានវត្តមាននៅក្នុងក្រុងយេរូសាឡិម
កាត់ក្តីលោកប៉ូល។
អ្នកទាំងនេះ ដែលបានឃើញខ្ញុំបាទមានទោសអ្វី
«អាចនិយាយកំហុសឆ្គងដែលខ្ញុំបានធ្វើដែលពួកគេអាចចាប់កំហុសបាន»
កាត់ទោសនៅថ្ងៃនេះ ដោយសារតែមនុស្សស្លាប់នឹងរស់ឡើងវិញ
«ការរស់ឡើងវិញ» ជានាមអរូប អាចនិយាយថា
«ព្រះជាម្ចាស់ធ្វើឲ្យមានជីវិតរស់ឡើងវិញ»។ ប៉ុន្តែ «ស្លាប់» គុណនាម
អាចនិយាយថា: «អស់អ្នកដែលស្លាប់»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយសារខ្ញុំជឿថា ព្រះជាម្ចាស់បានប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ»
បងប្អូនយកខ្ញុំមកកាត់ទោសនៅថ្ងៃនេះ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បងប្អូនកាត់ក្តីខ្ញុំនៅថ្ងៃនេះ»
Acts 24:22
ព័ត៌មានទូទៅ
លោកភេលិចជាទេសាភិបាលរបស់រ៉ូមនៅក្នុងតំបន់ដែលលោកគ្រប់គ្រងនៅក្នុងក្រុងសេសារា។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៣:២២។
អំពីមាគ៌ា
គឺជាងាររបស់គ្រិស្តបរិស័ទ។ សូមមើលពីរបៀបបកប្រែនៅក្នុងជំពូក ៩:១។
ពេលលោកមេបញ្ជាការលូស៊ាចុះពីយេរូសាឡិមមកដល់
«ពេលលោកលូស៊ា មេបញ្ជាការចុះពីមកដល់» ឬ «នៅពេលលោកសូស៊ា
ជាមេបញ្ជាការចុះមកដល់»
លោកលូស៊ា
នេះគឺជាឈ្មោះរបស់មេបញ្ជាការ។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនៅក្នុងជំពូក ២៣:២៥។
ចុះពីយេរូសាឡិមមកដល់
ក្រុងយេរូសាឡិមខ្ពស់ជាងក្រុងសេសារា ដូច្នេះ
ជាទូទៅពួកគេនិយាយថាចុះពីក្រុងយេរូសាឡិម។
ខ្ញុំនឹងសម្រេចក្តីរបស់លោក

generated on Wed Sep 10 16:16:32 2025

«ខ្ញុំនឹងសម្រេចចិត្តទាក់ទងនឹងរឿងក្តីទាស់នឹងលោកនេះ» ឬ «ខ្ញុំមិនកាត់ក្តី ថាតើលោកមានកំហុសឬយ៉ាងណា»
មានសេរីភាព
«លោកប៉ូលបានទទួលសេរីភាពខ្លះ បើមិនដូច្នោះទេ លោកជាប់គុកបាត់ទៅហើយ»
Acts 24:24
ប៉ុន្មានថ្ងៃក្រោយមក
«ពីរបីថ្ងៃក្រោយមក»
ទ្រូស៊ីល ជាមួយភរិយារបស់លោក
ទ្រូស៊ីលគឺជាឈ្មោះរបស់ស្ត្រីម្នាក់។
ជាស្ត្រីជនជាតិយូដា
មានន័យថា ស្ត្រីជនជាតិយូដា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជាជនជាតិយូដា»
លោកភេលិចមានការភ័យខ្លាច
លោកភេលិចមានអារម្មណ៍ប៉ះពាល់ចំពោះបាបរបស់លោក។
ឥឡូវនេះ
«សម្រាប់ពេលឥឡូវនេះ»
Acts 24:26
លោកសង្ឃឹមថាលោកប៉ូលនឹងជូនប្រាក់ដល់លោក
លោកភេលិចសង្ឃឹមថាលោកប៉ូលឲ្យអំណោយអ្វីមួយដល់លោក។
ហេតុនេះហើយបានជាលោកចាត់គេឲ្យទៅហៅលោកប៉ូលមក ហើយជជែកជាមួយលោកជារឿយៗ
«ហេតុនេះហើយបានជាលោកភេលិចចាត់គេឲ្យទៅហៅលោកប៉ូលមក ហើយជជែកជាមួយលោកប៉ូលជារឿយៗ»
លោកពរគាស-ភេស្ទុស
នេះគឺជាទេសាភិបាលថ្មីជំនួសលោកភេលិច។
លោកភេលិចចង់យកចិត្តសាសន៍យូដា
ពាក្យ «ជនជាតិយូដា» សំដៅលើអ្នកដឹកនាំជនជាតិយូដា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ចង់យកចិត្តអ្នកដឹកនាំជនជាតិយូដាឲ្យចូលចិត្តលោក»
លោកបានទុកលោកប៉ូលឲ្យបន្តនៅជាប់គុកដដែល
«លោកបានទុកលោកប៉ូលនៅជាប់គុកដដែល»

---

25 [1]បន្ទាប់ពីបានទៅដល់ស្រុកនោះបីថ្ងៃ លោកភេស្ទុសធ្វើដំណើរពីក្រុងសេសារាឆ្ពោះទៅក្រុងយេរូសាឡឹម។[2]នាយកបូជាចារ្យ និងពួកអ្នកធំនៃជនជាតិយូដាបាននាំគ្នាទៅជួបលោក ដើម្បីប្តឹងពីលោកប៉ូល។ ពួកគេបានទទូច[3]និងសុំឲ្យលោកភេស្ទុស មេត្តាអនុគ្រោះបញ្ជូនលោកប៉ូលមកក្រុងយេរូសាឡឹម ព្រោះពួកគេបានឃុបឃិតគ្នាថានឹងពួនស្នាក់ចាំសម្លាប់លោកតាមផ្លូវ។
[4]ប៉ុន្តែ លោកភេស្ទុសតបទៅវិញថា លោកប៉ូលជាប់ឃុំឃាំងនៅក្រុងសេសារាឯណោះ រីឯខ្លួនលោកផ្ទាល់ លោកក៏ត្រូវត្រឡប់ទៅវិញក្នុងពេលបន្តិចទៀតដែរ។[5]លោកមានប្រសាសន៍ថា៖ «សុំឲ្យអ្នកដែលមានសមត្ថភាពក្នុងចំណោមអស់លោក អញ្ជើញទៅជាមួយខ្ញុំ ហើយបើឃើញថាបុរសនោះមានកំហុសអ្វី សុំចោទប្រកាន់គាត់ទៅ»។
[6]លោកភេស្ទុសស្នាក់នៅជាមួយពួកគេបួនដប់ថ្ងៃ រួចលោកចុះទៅក្រុងសេសារាវិញ។ នៅថ្ងៃបន្ទាប់ លោកបានអង្គុយនៅទីកាត់ក្តី ហើយបង្គាប់ឲ្យគេនាំលោកប៉ូលមក។
[7]ពេលលោកប៉ូលមកដល់ ជនជាតិយូដាដែលមកពីក្រុងយេរូសាឡឹមបាននាំគ្នាចោមរោមលោក ហើយចោទប្រកាន់យ៉ាងធ្ងន់ៗជាច្រើន តែគេពុំអាចបង្ហាញភស្តុតាងអ្វីទេ។
[8]លោកប៉ូលមានប្រសាសន៍ការពារខ្លួនថា៖ «ខ្ញុំពុំបានប្រព្រឹត្តអ្វីខុសនឹងវិន័យរបស់សាសន៍យូដា ខុសនឹងព្រះវិហារ ឬក៏ខុសនឹងព្រះចៅអធិរាជឡើយ»។
[9]ដោយលោកភេស្ទុសចង់យកចិត្តជនជាតិយូដា លោកមានប្រសាសន៍មកកាន់លោកប៉ូលថា៖ «តើអ្នកចង់ឡើងទៅក្រុងយេរូសាឡឹមឲ្យគេកាត់ក្តីអ្នក អំពីរឿងទាំងនេះនៅចំពោះមុខខ្ញុំឬទេ?»។[10]លោកប៉ូលតបថា៖ «ខ្ញុំបានឈរនៅមុខតុលាការរបស់ព្រះចៅអធិរាជដូច្នេះ គឺទីនេះហើយដែលឯកឧត្តមត្រូវកាត់ក្តីឲ្យខ្ញុំបាទ។ ខ្ញុំបាទពុំបានធ្វើអ្វីខុសនឹងសាសន៍យូដាទេ ដូចឯកឧត្តមជ្រាបច្បាស់ហើយ។
[11]ប្រសិនបើ ខ្ញុំបាទមានទោសអ្វី ឬបានប្រព្រឹត្តអ្វីខុស សមនឹងមានទោសដល់ជីវិតនោះ ខ្ញុំបាទមិនរួញរានឹងស្លាប់ទេ។ ប៉ុន្តែ ប្រសិនបើពាក្យដែលលោកទាំងនេះចោទខ្ញុំបាទមិនពិតទេ គ្មាននរណាម្នាក់មានសិទ្ធិប្រគល់ខ្ញុំបាទទៅឲ្យគេឡើយ។ ខ្ញុំបាទសូមឡើងទៅព្រះចៅអធិរាជវិញ»។[12]បន្ទាប់ពីលោកភេស្ទុសពិភាក្សាជាមួយក្រុមប្រឹក្សា លោកមានប្រសាសន៍ថា៖ «អ្នកបានសុំឡើងទៅព្រះចៅអធិរាជ ដូច្នេះ អ្នកនឹងទៅជួបព្រះចៅអធិរាជ!»។
[13]ប៉ុន្មានថ្ងៃក្រោយមកទៀត ព្រះបាទអគ្រីប៉ា និងម្ចាស់ក្សត្រីយ៍បេរេនីស យាងមកដល់ក្រុងសេសារាដើម្បីសួរសុខទុក្ខលោកភេស្ទុស។[14]ដោយស្តេចគង់នៅទីនោះជាច្រើនថ្ងៃ លោកភេស្ទុសក៏ទូលស្តេចពីរឿងលោកប៉ូលថា៖ «លោកភេលិចបានទុកបុរសម្នាក់នៅក្នុងទីឃុំឃាំង។[15]កាលទូលបង្គំទៅក្រុងយេរូសាឡឹម ពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យនៃសាសន៍យូដា បាននាំគ្នាប្តឹងពីគាត់ដោយសុំឲ្យទូលបង្គំកាត់ទោសគាត់។[16]ទូលបង្គំបានប្រាប់លោកទាំងនោះវិញថា ជនជាតិរ៉ូមមិនមានទំនៀមទម្លាប់បញ្ជូនរណាម្នាក់ ទៅឲ្យគេសម្លាប់ ដោយមិនបានជួបជាមួយអ្នកដើមចោទ និងមិនមានឱកាសឆ្លើយការពារខ្លួនចំពោះពាក្យចោទជាមុនសិននោះឡើយ។
[17]ដូច្នេះ លោកទាំងនោះនាំគ្នាមកទីនេះ ហើយនៅថ្ងៃបន្ទាប់ ទូលបង្គំមិនរង់ចាំអ្វីទេ ហើយបានអង្គុយនៅទីកាត់ក្តី និងឲ្យគេនាំបុរសនោះមក។[18]ពួកដើមចោទក៏ឈរនៅទីកាត់ក្តីដែរ រួចចោទគាត់ តែទូលបង្គំគិតថាគេពុំបានចោទគាត់ពីអំពើអាក្រក់ណាមួយឡើយ។[19]ពួកគេមានតែជជែកវែកញែកអំពីរឿងសាសនារបស់គេ និងអំពីបុរសម្នាក់ឈ្មោះយេស៊ូដែលបានស្លាប់ ដោយលោកប៉ូលអះអាងថាលោកយេស៊ូរស់ឡើងវិញហើយ។[20]ចំណែកឯទូលបង្គំវិញ ទូលបង្គំមិនដឹងជាត្រូវគិតដូចម្តេច ចំពោះការជជែកវែកញែកបែបនេះ ទូលបង្គំបានសួរគាត់ថាតើ គាត់ចង់ទៅក្រុងយេរូសាឡឹមឲ្យគេកាត់ក្តីអំពីរឿងទាំងនេះឬទេ។
[21]តែលោកប៉ូលបានសុំឡើងទៅព្រះចៅអធិរាជ ដើម្បីសុំឲ្យព្រះអង្គកាត់ក្តី។ ទូលបង្គំចេញបញ្ជាឲ្យគេឃុំគាត់ទុក រហូតដល់ពេលទូលបង្គំនឹងបញ្ជូនគាត់ទៅព្រះចៅអធិរាជ»។
[22]ព្រះបាទអគ្រីប៉ា មានរាជឱង្ការទៅលោកភេស្ទុសថា៖ «ខ្ញុំក៏ចង់ស្តាប់បុរសនោះនិយាយដែរ»។ លោកតបវិញថា៖ «ព្រះករុណាអាចស្តាប់គាត់នៅថ្ងៃស្អែក»។
[23]លុះស្អែកឡើង ព្រះបាទអគ្រីប៉ា និងម្ចាស់ក្សត្រីយ៍បេរេនីស បានយាងចូលក្នុងសាលសវនាការយ៉ាងអធិកអធម ដោយមានពួកនាយទាហានជាន់ខ្ពស់ និងពួកនាម៉ឺនធំៗនៅក្រុងនោះហែហមមកជាមួយផង។ គេនាំលោកប៉ូលមកតាមបញ្ជារបស់លោកភេស្ទុស។[24]លោកភេស្ទុសមានប្រសាសន៍ថា៖ «សូមទូលព្រះរាជា និងជម្រាបអស់លោកដែលនៅទីនេះ។ បុរសដែលព្រះរាជា និងអស់លោកឃើញនេះ ជាអ្នកដែលជនជាតិយូដាទាំងមូល ទាំងនៅក្រុងយេរូសាឡឹម ទាំងនៅក្រុងនេះ បាននាំគ្នាមកជួបខ្ញុំ ហើយស្រែកថា គាត់មិនត្រូវរស់តទៅទៀតទេ។
[25]ចំពោះខ្ញុំវិញ ខ្ញុំយល់ឃើញថាគាត់ពុំបានប្រព្រឹត្តអ្វីខុស ដែលត្រូវមានទោសដល់ជីវិតនោះឡើយ ប៉ុន្តែ ដោយខ្លួនគាត់ផ្ទាល់បានសុំឡើងទៅព្រះចៅអធិរាជ ខ្ញុំក៏សម្រេចចិត្តបញ្ជូនគាត់ទៅព្រះអង្គ។[26]តែខ្ញុំគ្មានមូលហេតុអ្វីច្បាស់លាស់ ដើម្បីសរសេរសេចក្តីរាយការណ៍ថ្វាយព្រះចៅអធិរាជ អំពីសំណុំរឿងគាត់ទាល់តែសោះ។ ហេតុនេះហើយ បានជាខ្ញុំឲ្យគេនាំគាត់មកជួបអស់លោក ជាពិសេស ជួបព្រះចៅអគ្រីប៉ាផ្ទាល់ ហេតុនេះខ្ញុំនឹងមានមូលហេតុ សរសេរសេចក្តីរាយការណ៍បាន។
[27]គ្មានមូលហេតុណាដែលខ្ញុំត្រូវបញ្ជូន ហើយមិនបានបញ្ជាក់អំពីពាក្យចោទទៅជាមួយផងនោះដែរ»។

Acts 25:1
ប្រយោគភ្ជាប់
លោកប៉ូលបន្តធ្វើជាអ្នកទោសនៅក្នុងក្រុងសេសារា។
ព័ត៌មានទូទៅ
លោកភេស្ទុសក្លាយជាទេសាភិបាលនៅក្រុងសេសារា។
សូមមើលពីរបៀបនៃការបកប្រែឈ្មោះនៅក្នុងជំពូក ២៤:២៦។
ឥឡូវនេះ
ពាក្យនេះ ដើម្បីសម្គាល់ពីការចាប់ផ្តើមព្រឹត្តការណ៍ថ្មីនៅក្នុងសាច់រឿង។
លោកភេស្ទុសចូលមកដល់ស្រុកនោះ
អាចមានន័យពីរ។ ទី១) លោកផេស្ទុសមកដល់កន្លែងនោះដើម្បីគ្រប់គ្រង (UDB)។ ទី២) លោកភេស្ទុសបានមកដល់តំបន់នោះ។
លោកបានចេញពីក្រុងសេសារាឡើងទៅក្រុងយេរូសាឡិម
ឃ្លា «ឡើងទៅ» ប្រើនៅទីនេះ
ដោយសារក្រុងយេរូសាឡិមមានកម្ពស់ខ្ពស់ជាងក្រុងសេសារា។
ពួកអ្នកធំរបស់ជនជាតិយូដាបានទៅប្តឹងពីលោកប៉ូលជាមួយលោកភេស្ទុស
ឃ្លានេះ និយាយពីការប្តឹង និយាយដូចជាមនុស្សម្នាក់នាំមនុស្សម្នាក់ទៀត។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកអ្នកធំរបស់ជនជាតិយូដា បានប្តឹងលោកប៉ូលជាមួយនឹងលោកភេស្ទុស»។

generated on Wed Sep 10 16:16:32 2025

ពួកគេបានទទូចលោកភេស្ទុស
«ពួកគេអង្វរលោកភេស្ទុស»
សុំឲ្យលោកមេត្តាអនុគ្រោះបញ្ជូនលោកប៉ូល...ព្រោះពួកគេបានផ្សំគំនិតគ្នា ស្មាក់ចាំសម្លាប់លោកតាមផ្លូវ
«សូមលោកភេស្ទុសឲ្យហៅលោកប៉ូល...ដើម្បីពួកជនជាតិយូដាអាចសម្លាប់លោកប៉ូលតាមផ្លូវ»
សុំឲ្យលោកមេត្តាអនុគ្រោះបញ្ជូនលោក
ឃ្លានេះ
មានន័យថាលោកភេលិចបង្គាប់ទាហានរបស់លោកឲ្យនាំលោកប៉ូលឡើងទៅក្រុងយេរូសាឡិម
រៀបផ្សេងទៀតនៃការបកប្រែ:
«ឲ្យលោកបញ្ជាទាហានរបស់លោកឲ្យនាំលោកប៉ូល»
ពួកគេបានផ្សំគំនិតគ្នា ស្មាក់ចាំសម្លាប់លោកតាមផ្លូវ
ពួកគេនឹងស្មាក់សម្លាប់លោកប៉ូលតាមផ្លូវ។
Acts 25:4
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកភេស្ទុស
និងជនជាតិរ៉ូមដែលធ្វើដំណើរជាមួយលោក។
ប៉ុន្តែ លោកភេស្ទុសបានឆ្លើយថា លោកប៉ូលជាអ្នកទោសនៅក្រុងសេសារាចំណែកខ្លួនលោកផ្ទាល់
នឹងត្រូវត្រឡប់ទៅទីនោះវិញឆាប់ៗនេះហើយ
ឃ្លានេះគឺនិយាយដកស្រង់ទាំងស្រុង។ រៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែ
លោកភេស្ទុសមានប្រសាសន៍ថា៖ «លោកប៉ូលជាអ្នកទោសនៅក្នុងក្រុងសេសារា
ហើយខ្ញុំនឹងត្រឡប់ទៅទីនោះវិញជាប្រញាប់»។
ដូច្នេះ លោកមានប្រសាសន៍ថា៖ «អស់អ្នកដែលអាច សូមអញ្ជើញទៅទីនោះជាមួយយើង
ឃ្លា «លោកមានប្រសាសន៍» អាចនិយាយនៅដើមប្រយោគក៏បាន។
រៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មកលោកមានប្រសាសន៍ថា៖ «ដូច្នេះ
អស់អ្នកដែលអាចចុះទៅក្រុងសេសារា ចូរទៅទីនោះជាមួយយើង»
បើបុរសនោះមានកំហុសអ្វី
«ប្រសិនបើ លោកប៉ូលបានធ្វើអ្វីខុស»
អ្នករាល់គ្នាចោទប្រកាន់គាត់ទៅ
«អ្នករាល់គ្នាអាចចោទប្រកាន់លោកតាមច្បាប់» ឬ
«អ្នកអាចប្តឹងទាស់នឹងលោកបាន»
Acts 25:6
ព័ត៌មានទូទៅ
ពាក្យ «លោក» បីដំបូង ជាមួយនឹងពាក្យ «គាត់» សំដៅលើលោកភេស្ទុស។ ពាក្យ
«លោក» លើកទីបួន សំដៅលើលោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» សំដៅលើជនជាតិយូដា ដែលមកពីក្រុងយេរូសាឡិម។
ចុះទៅក្រុងសេសារា
ក្រុងយេរូសាឡិមមានកម្ពស់ខ្ពស់ជាងក្រុងសេសារា។
វាគឺជារឿងសាមញ្ញក្នុងការនិយាយថាចុះពីក្រុងយេរូសាឡិម។
បានអង្គុយនៅទីកាត់ក្តី
ពាក្យ «បានអង្គុយនៅទីកាត់ក្តី» សំដៅលើលើការគ្រប់គ្រងរបស់លោកភេស្ទុស
ក្នុងនាមជាចៅក្រមកាត់ក្តីលោកប៉ូល។ រៀបផ្សេងទៀតនៃការបកប្រែ:
«អង្គុយនៅលើកៅអី ជាកន្លែងដែលលោកជំនុំជម្រះក្តី» ឬ
«លោកអង្គុយកាត់ក្តីក្នុងនាមជាចៅក្រម»
បង្គាប់ឲ្យគេនាំលោកប៉ូលមកជួបលោក
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ រៀបផ្សេងទៀតនៃការបកប្រែ:
«ទាហានរបស់លោកបាននាំលោកប៉ូលមកជួបលោក»
ពេលគាត់មកដល់
«នៅពេលលោកមានដល់ ហើយឈរនៅចំពោះលោកភេស្ទុស»
ពួកគេបាននាំបណ្តឹងធ្ងន់ៗជាច្រើន
ចោទប្រកាន់មនុស្សម្នាក់ពីបទល្មើស
និយាយប្រៀបដូចជាវត្ថុមួយដែលមនុស្សនាំទៅកាត់ក្នុងនៅតុលាការ។
រៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនិយាយទាស់នឹងលោកប៉ូលរឿងអាក្រក់ៗជាច្រើន»
ទាស់នឹងព្រះវិហារ
លោកប៉ូលមានប្រសាសន៍ថា លោកមិនបានធ្វើខុសច្បាប់
នៃការចូលទៅក្នុងព្រះវិហារក្រុងយេរូសាឡិមឡើយ។
រៀបផ្សេងទៀតនៃការបកប្រែ: «ទាស់នឹងច្បាប់នៃការចូលក្នុងព្រះវិហារ»
Acts 25:9
ប្រយោគភ្ជាប់
លោកប៉ូលសូមប្តឹងឡើងទៅចំពោះព្រះចៅអធិរាជ ដើម្បីកាត់ក្តី។
លោកភេស្ទុសចង់យកចិត្តជនជាតិយូដា
ពាក្យ «ជនជាតិយូដា» មានន័យថាអ្នកដឹកនាំជនជាតិយូដា។
រៀបផ្សេងទៀតនៃការបកប្រែ: «ចង់យកចិត្តអ្នកដឹកនាំជនជាតិយូដា»
ឡើងទៅក្រុងយេរូសាឡិម
ក្រុងយេរូសាឡិមមានកម្ពស់ខ្ពស់ជាងក្រុងសេសារា។
វាគឺជារឿងសាមញ្ញក្នុងការនិយាយថាឡើងទៅក្រុងយេរូសាឡិមគឺជារឿងធម្មតា។
ខ្ញុំនឹងកាត់ក្តីឲ្យអ្នក អំពីរឿងទាំងនេះនៅទីនោះ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ រៀបផ្សេងទៀតនៃការបកប្រែ:
«ជាកន្លែងដែលខ្ញុំនឹងជំនុំជម្រះជាមួយនឹងរឿងក្តីទាំងនេះ»
ខ្ញុំបានឈរនៅចំពោះមុខទីកាត់ក្តីរបស់សេសារហើយ ជាកន្លែងដែលត្រូវកាត់ក្តីឲ្យខ្ញុំបាទ
«វេទិកាជំនុំជម្រះ»
សំដៅលើសិទ្ធិអំណាចរបស់ព្រះចៅអធិរាជដើម្បីកាត់ក្តីលោកប៉ូល។ ឃ្លានេះ
និយាយជាទម្រង់សកម្ម។ រៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំសូមលោកទៅរកព្រះចៅអធិរាជ ដើម្បីឲ្យទ្រង់បានជំនុំជម្រះខ្ញុំ»
Acts 25:11
ប្រសិនបើ ការចោទប្រកាន់របស់ពួកគេមិនពិតទេ គ្មាននរណាម្នាក់មានសិទ្ធិប្រគល់ខ្ញុំបាទទៅ
ឲ្យពួកគេឡើយ
លោកប៉ូលមានប្រសាសន៍អំពីស្ថានភាពប្រឌិត។ ប្រសិនបើ លោកមានកំហុស
លោកនឹងទទួលទោស ប៉ុន្តែ លោកដឹងថា លោកគ្មានកំហុសទេ។
ខ្ញុំបានបានធ្វើអ្វីខុស សមនឹងមានទោសដល់ស្លាប់នោះ
«ប្រសិនបើខ្ញុំបានធ្វើអ្វីខុសដែលសមឲ្យមានទោសដល់ស្លាប់»
ប្រសិនបើ ការចោទប្រកាន់របស់ពួកគេមិនពិតទេ
«ប្រសិនបើ ការចោទប្រកាន់ទាស់នឹងខ្ញុំមិនពិត»
គ្មាននរណាម្នាក់មានសិទ្ធិប្រគល់ខ្ញុំបាទទៅឲ្យពួកគេឡើយ
អាចមានន័យពីរ។ ទី១)
លោកភេស្ទុសមិនមានសិទ្ធិប្រគល់លោកប៉ូលទៅក្នុងកណ្តាប់ដៃរបស់អ្នកដែលចោទប្រកាន់លោកទេ។
ទី២) លោកប៉ូលមានប្រសាសន៍ថា ប្រសិនបើ លោកមិនបានធ្វើអ្វីខុស
លោកទេសាភិបាលមិនអាចធ្វើតាមសំណើរបស់ជនជាតិយូដាទេ។
ខ្ញុំបាទសូមប្តឹងឡើងទៅសេសារវិញ
«ខ្ញុំសូម បន្តទៅព្រះចៅអធិរាជ ដើម្បីឲ្យទ្រង់បានកាត់ក្តីឲ្យខ្ញុំ»។
ជាមួយក្រុមប្រឹក្សាជាន់ខ្ពស់
នេះមិនមែនជាតុលាការជាន់ខ្ពស់នៃ សាសន៍យូដាទេ។ ពាក្យ
«ក្រុមប្រឹក្សាជាន់ខ្ពស់» នៅក្នុងកិច្ចការទាំងមូល។
នេះគឺជាក្រុមប្រឹក្សាជាន់ខ្ពស់នៅក្នុងអាណាចក្ររ៉ូម។
រៀបផ្សេងទៀតនៃការបកប្រែ:
«ជាមួយនឹងមន្ត្រីប្រឹក្សាយោបលរបស់លោកផ្ទាល់»។
Acts 25:13
ប្រយោគភ្ជាប់
លោកភេស្ទុសពន្យល់រឿងក្តីលោកប៉ូលដល់ព្រះបាទអគ្រីប៉ា។
ព័ត៌មានទូទៅ
ព្រះបាទអគ្រីប៉ា និងម្ចាស់ក្សត្រីយ៍បេរេនីសជាបុគ្គលថ្មីនៅក្នុងសាច់រឿង។
ទ្រង់គ្រប់គ្រងតំបន់មួយចំនួនប៉ុណ្ណោះ ព្រះបាទអគ្រីប៉ា
ជាស្តេចដែលសោយរាជ្យនៅប៉ាឡេស្ទីន។
ម្ចាស់ក្សត្រីយ៍បេរេនីសជាប្អូនស្រីរបស់ព្រះបាទអគ្រីប៉ា។
ឥឡូវនេះ
ពាក្យនេះ សម្គាល់អំពីការចាប់ផ្តើមព្រឹត្តការណ៍ថ្មីនៅក្នុងសាច់រឿង។
ដើម្បីសួរសុខទុក្ខលោកភេស្ទុសជាផ្លូវការ
«ដើម្បីសួរសុខទុក្ខលោកភេស្ទុសជាផ្លូវការដើម្បីដោះស្រាយបញ្ហាមួយចំនួន»
លោកភេលិចបានទុកបុរសម្នាក់នៅទីនេះជាអ្នកទោស
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ រៀបផ្សេងទៀតនៃការបកប្រែ:
«ពេលលោកភេលិចចេញពីមុខតំណែងរបស់លោក
លោកបានបន្សល់អ្នកទោសម្នាក់នៅទីនេះ»
លោកភេលិច
លោកភេលិចជាទេសាភិបាលរបស់រ៉ូម លោកគ្រប់គ្រងនៅតំបន់ក្រុងសេសារា។
សូមមើលពីរបៀបនៃការដែលអ្នកបកប្រែឈ្មោះនៅក្នុងជំពូក ២៣:២២។
បាននាំពាក្យបណ្តឹងមកទូលបង្គំ ឲ្យកាត់ទោសគាត់
ដើម្បីប្តឹងមនុស្សម្នាក់នៅក្នុងតុលាការ នៅទីនេះ និយាយប្រៀបដូចកម្មបទ

generated on Wed Sep 10 16:16:32 2025

ដែលមនុស្សម្នាក់បាននាំទៅតុលាការ។ របៀបផ្សេងទៀតនៃការបកប្រែ:
«និយាយប្រាប់ទូលបង្គំទាស់នឹងបុរសនេះ»
និងពួកចាស់ទុំនៃសាសន៍យូដាបាននាំពាក្យបណ្តឹងមកទូលបង្គំ ឲ្យកាត់ទោសគាត់
ពាក្យ «កាត់ទោស» ជានាមអរូបី អាចប្រែជាកិរិយាសព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេសូមឲ្យទូលបង្គំកាត់ទោសកាត់ដល់ស្លាប់»
ទៅឲ្យគេសម្លាប់
«ដើម្បីកាត់ទោសបុរសម្នាក់ដល់ស្លាប់»
បានជួបជាមួយអ្នកដើមចោទនោះទេ
«ដើម្បីជួបអ្នកដែលចោទប្រកាន់គាត់ដោយផ្ទាល់»
Acts 25:17
ដូច្នេះ
ពាក្យនេះសម្គាល់ពីប្រយោគ ដែលបាននិយាយពីមុន។ នៅក្នុងករណីនេះ
លោកភេស្ទុសគ្រាន់តែនិយាយថា បុរសដែលគេចោទប្រកាន់
ត្រូវតែមានឱកាសជួបអ្នកដែលចោទប្រកាន់លោក ហើយត្រូវមានការឆ្លើយការពារ។
ពេលពួកគេមកជាមួយគ្នានៅទីនេះ
«ពេលអ្នកដឹកនាំជនជាតិយូដាមកជួបទូលបង្គំនៅទីនេះ»
ទូលបង្គំបានអង្គុយនៅទីកាត់ក្តី
ពាក្យ «អង្គុយនៅទីកាត់ក្តី»
សំដៅលើលោកភេស្ទុសគ្រប់គ្រងលើការជំនុំជម្រះក្តីលោកប៉ូល
ក្នុងនាមជាចៅក្រម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំបានអង្គុយដើម្បីកាត់ក្តី» ឬ «ទូលបង្គំអង្គុយកាត់ក្តីក្នុងនាមជាចៅក្រម»
ទូលបង្គំបានឲ្យគេនាំបុរសនោះមក
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំបានបង្គាប់ពួកទាហានឲ្យនាំលោកប៉ូលមករកទូលបង្គំ»
សាសនារបស់គេផ្ទាល់
ពាក្យ «សាសន៍» មានន័យថា ជាប្រព័ន្ធជំនឿរបស់មនុស្សចំពោះជីវិត
និងខាងវិញ្ញាណ។
ឲ្យគេកាត់ក្តីអំពីរឿងទាំងនេះ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជាកន្លែងដែលក្រុមប្រឹក្សាជាន់ខ្ពស់របស់ជនជាតិយូដាអាចសម្រេចថា
គាត់មានកំហុសចំពោះការចោទប្រកាន់ទាំងនេះ»
Acts 25:21
ប្រយោគភ្ជាប់
ឯឧត្តមភេស្ទុសបានបញ្ចប់ពន្យល់រឿងក្តីរបស់លោកប៉ូលថ្វាយព្រះបាទអគ្រីប៉ា។
ប៉ុន្តែ ពេលលោកប៉ូលបានសុំឲ្យឃុំគាត់សិន ក្នុងការដែលរងចាំឲ្យព្រះចៅអធិរាជសម្រេច
ឃ្លានេះនិយាយជាប្រយោគសកម្ម។ របៀបផ្សេងទៀតការបកប្រែ:
«ប៉ុន្តែពេលលោកប៉ូលទទួចថា លោករស់នៅក្រោមការគ្រប់គ្រងរបស់អ្នកយាម
ពេលព្រះចៅអធិរាជ អាចសម្រេចក្តីនេះ» ។
ទូលបង្គំបានចេញបញ្ជាឲ្យឃុំគាត់ទុក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំប្រាប់ទាហានឲ្យរក្សាលោកក្នុងគុក»
លោកភេស្ទុសទូលថា៖ «នៅថ្ងៃស្អែកព្រះករុណានឹងបានស្តាប់គាត់ហើយ»
ឃ្លា «លោកភេស្ទុសទូលថា៖» អាចយកមកដាក់នៅដើមប្រយោគក៏បាន។
របៀបផ្សេងទៀតនៃការបកប្រែ: «លោកភេស្ទុសទូលថា៖
«ទូលបង្គំនឹងរៀបចំថ្វាយទ្រង់ស្តាប់លោកប៉ូលថ្ងៃស្អែក»
Acts 25:23
ប្រយោគភ្ជាប់
លោកភេស្ទុសបានផ្តល់ព័ត៌មានអំពីរឿងក្តីលោកប៉ូលថ្វាយព្រះបាទអគ្រីប៉ា។
ព័ត៌មានទូទៅ
ទ្រង់គ្រប់គ្រងតែពីរបីតំបន់ប៉ុណ្ណោះ ព្រះបាទអគ្រីប៉ាសោយរាជនៅស្រុកប៉ាលីស្ទីន។
ម្ចាស់ក្សត្រីយ៍បេរេនីជាប្អូនស្រីរបស់ទ្រង់។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនេះនៅក្នុងជំពូក ២៥:១៣។
កម្មវិធីយ៉ាងអធិកអធម
«ធ្វើកម្មវិធីយ៉ាងអធិកអធមដើម្បីថ្វាយកិត្តិយសដល់ពួកគេ»
សាល
នេះគឺជាបន្ទប់យ៉ាងធំ ជាកន្លែងដែលមនុស្សប្រមូលផ្តុំធ្វើពិធី និងជំនុំជម្រះក្តី
និងព្រឹត្តការណ៍ផ្សេងៗ។
គេក៏នាំលោកប៉ូលមកឯពួកគេ
ឃ្លានេះនិយាយជាប្រយោគសកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកទាហានបាននាំលោកប៉ូលមកចំពោះពួកគេ»
ជាអ្នកដែលជនជាតិយូដាគ្រប់រូប
នេះគឺជាការនិយាយបំផ្លើស ប្រើដើម្បីបញ្ជាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានជនជាតិយូដាជាច្រើន» ឬ «ពួកអ្នកដឹកនាំជនជាតិយូដា»
ពួកគេបានស្រែកមកខ្ញុំថា
«ពួកគេបានស្រែកមកខ្ញុំ»
គាត់មិនត្រូវរស់តទៅទៀតទេ
ឃ្លានេះនិយាយក្នុងភាពអវិជមានដើម្បីបញ្ជាក់ពីភាពវិជ្ជមានវិញ។
របៀបផ្សេងទៀតនៃការបកប្រែ: «គាត់គួរតែស្លាប់ភ្លាម»
Acts 25:25
ព័ត៌មានទូទៅ
ពាក្យ «អ្នក» ជាពហុវចន:ទីមួយ។ ពាក្យ «អ្នក» ទីពីរជាឯកវចន:។
ដោយសារគាត់បានសុំឡើងទៅព្រះចៅអធិរាជ
«ដោយសារលោកបានសូមព្រះចៅអធិរាជដើម្បីកាត់ក្តីឲ្យលោក»
ហេតុនេះហើយបានជាខ្ញុំឲ្យគេនាំគាត់មកជួបអស់លោក ជាពិសេស ជួបព្រះបាទអគ្រីប៉ាផ្ទាល់
«ខ្ញុំបាននាំលោកប៉ូលមកជួបអស់លោកទាំងអស់គ្នា ប៉ុន្តែជាពិសេស
ព្រះបាទអគ្រីប៉ា»។
ប៉ុន្តែ ខ្ញុំគ្មានមូលហេតុអ្វីច្បាស់លាស់ ដើម្បីសរសើរ
«ដើម្បីឲ្យទូលបង្គំមានអ្វីមួយផ្សេងទៀតដើម្បីសរសេរ» ឬ
«ដើម្បីឲ្យទូលបបង្គំដឹងអ្វីដែលទូលបង្គំគួរសរសេរ»។
ដ្បិត មិនសមឲ្យខ្ញុំត្រូវបញ្ជូនអ្នកទោស ហើយមិនបានបញ្ជាក់ពីការចោទប្រកាន់ទាស់នឹងគាត់នោះ
ជាពាក្យអវិជ្ជាមាន «គ្មានហេតុផល» និង «មិនសម»
អាចប្រែជាប្រយោគវិជ្ជាមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«វាសមហេតុផលសម្រាប់ទូលបង្គំក្នុងការចាត់បញ្ជូលអ្នកទៅ
ហើយទូលបង្គំមានអ្វីនិយាយនោះ»
ការចោទប្រកាន់ទាស់នឹងគាត់នោះ
អាចមានន័យពីរ។ ទី១)
ការចោទប្រកាន់ដែលអ្នកដឹកនាំជនជាតិយូដាបាននាំមកទាស់នឹងលោក។ ទី២)
ចោទប្រកាន់នៅក្រោមច្បាប់ដែលអនុវត្តនៅក្នុងរឿងក្តីរបស់លោកប៉ូល។

---

26 [1]ព្រះចៅអគ្រីប៉ាមានរាជឱង្ការទៅលោកប៉ូលថា៖ «អ្នកមានសិទ្ធិនិយាយការពារខ្លួននៅពេលនេះបាន»។ បន្ទាប់មក លោកប៉ូលលើកដៃឡើងមានប្រសាសន៍ថា៖
[2]«បពិត្រព្រះរាជា ទូលបង្គំមានកិត្តិយសធំណាស់ អាចឆ្លើយការពារខ្លួននៅចំពោះព្រះភក្ត្រព្រះករុណាថ្ងៃនេះ អំពីពាក្យបណ្តឹងទាំងប៉ុន្មានដែលសាសន៍យូដាចោទ
ទូលបង្គំ[3]ដ្បិត ព្រះករុណាជ្រាបយ៉ាងច្បាស់ អំពីទំនៀមទម្លាប់ផ្សេងៗរបស់សាសន៍យូដា និងអំពីសេចក្តីដែលគេនិយមជជែកវែកញែក។ ហេតុនេះ សូមព្រះអង្គមេត្តា
ព្រះសណ្តាប់ទូលបង្គំ ដោយអនុគ្រោះផង។
[4]ជនជាតិយូដាទាំងមូលស្គាល់ប្រវត្តិរបស់ទូលបង្គំ តាំងពីក្មេងមកស្រាប់ហើយ។[5]ពួកគេក៏ដឹងថាតាំងពីដើមមក ទូលបង្គំរស់នៅកណ្តាលចំណោមជនជាតិរបស់ទូលបង្គំ និង
នៅក្រុងយេរូសាឡឹមរបៀបណាដែរ។ គេបានស្គាល់ទូលបង្គំតាំងពីយូរមកហើយ ពីដើមទូលបង្គំជាអ្នកខាងគណៈផារីស៊ី ដែលជាគណៈតឹងរ៉ឹងជាងគេក្នុងសាសនារបស់
យើង។
[6]ប៉ុន្តែ ឥឡូវនេះ គេយកទូលបង្គំមកវិនិច្ឆ័យទោស ព្រោះតែសេចក្តីសង្ឃឹមលើព្រះបន្ទូល ដែលព្រះជាម្ចាស់បានសន្យាជាមួយបុព្វបុរសរបស់យើង។[7]កុលសម្ព័ន្ធទាំងដប់ពីរ
របស់យើង នាំគ្នាគោរពបម្រើព្រះជាម្ចាស់ទាំងយប់ទាំងថ្ងៃ ឥតឈប់ឈរ ដោយសង្ឃឹមថា ព្រះបន្ទូលសន្យានេះនឹងបានសម្រេច។ បពិត្រព្រះរាជា ជនជាតិយូដាបានចោទ
ប្រកាន់ទូលបង្គំ ព្រោះតែសេចក្តីសង្ឃឹមនេះហើយ។[8]ចុះហេតុដូចម្តេចបានជាអស់លោកយល់ថា ការដែលព្រះជាម្ចាស់ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ជាការមួយមិនគួរ
ឲ្យជឿដូច្នេះ?
[9]ចំណែកឯទូលបង្គំផ្ទាល់ ពីដើមទូលបង្គំយល់ឃើញថា ត្រូវតែប្រឆាំងនឹងព្រះនាមព្រះយេស៊ូ ជាអ្នកភូមិណាសារ៉ែតគ្រប់យ៉ាងទាំងអស់។[10]ទូលបង្គំបានប្រព្រឹត្តដូច្នេះ នៅ
ក្រុងយេរូសាឡឹមមែន គឺទូលបង្គំបានទទួលច្បាប់អនុញ្ញាតពីក្រុមនាយកបូជាចារ្យ ដើម្បីចាប់អស់អ្នកដែលជឿលើព្រះអម្ចាស់ជាច្រើននាក់ យកទៅឃុំឃាំង។ នៅពេលគេ

generated on Wed Sep 10 16:16:32 2025

សម្លាប់អ្នកទាំងនោះ ទូលបង្គំក៏យល់ស្របជាមួយដែរ។[11]ទូលបង្គំតែងចូលទៅក្នុងសាលាប្រជុំនានាជាញឹកញាប់ ដើម្បីធ្វើទុក្ខទោសអ្នកទាំងនោះ បង្ខំឲ្យគេលះបង់ចោលជំនឿរបស់ខ្លួន។ ទូលបង្គំខឹងគេជាខ្លាំងពន់ពេក រហូតដល់ទៅតាមបៀតបៀនគេក្នុងក្រុងនានានៅបរទេសផង។
[12]ហេតុនេះហើយបានជាទូលបង្គំធ្វើដំណើរទៅក្រុងដាម៉ាស ទាំងទទួលអំណាច និងការអនុញ្ញាតពីក្រុមនាយកបូជាចារ្យ។[13]បពិត្រព្រះរាជា នៅតាមផ្លូវ ប្រមាណជាថ្ងៃត្រង់ ទូលបង្គំបានឃើញពន្លឺមួយភ្លឺជាងពន្លឺថ្ងៃទៅទៀត ចាំងពីលើមេឃមកលើទូលបង្គំ និងលើអ្នកដែលរួមដំណើរជាមួយទូលបង្គំ។[14]ពេលនោះ យើងខ្ញុំដួលទាំងអស់គ្នា ហើយទូលបង្គំបានឮសំឡេងពោលមកកាន់ទូលបង្គំជាភាសាហេប្រឺថា៖ «សូល! សូលអើយ! ហេតុដូចម្តេចបានជាអ្នកបៀតបៀនខ្ញុំ? អ្នកខំប្រឹងតយុទ្ធនឹងខ្ញុំ ដូចគោជល់នឹងជន្លួញដូច្នេះមិនកើតទេ»។
[15]ទូលបង្គំបានតបទៅវិញថា៖ «លោកម្ចាស់អើយ! តើលោកជានរណា?»។ ព្រះអម្ចាស់មានព្រះបន្ទូលមកទូលបង្គំវិញថា៖ «ខ្ញុំជាយេស៊ូដែលអ្នកកំពុងតែបៀតបៀន។[16]ចូរក្រោកឈរឡើង ខ្ញុំបង្ហាញខ្លួនឲ្យអ្នកឃើញ មកពីខ្ញុំបានជ្រើសរើសអ្នកឲ្យបម្រើ ព្រមទាំងធ្វើជាបន្ទាល់អំពីហេតុការណ៍ ដែលខ្ញុំបង្ហាញឲ្យអ្នកឃើញនៅពេលនេះ និងហេតុការណ៍ឯទៀតៗ ដែលខ្ញុំនឹងបង្ហាញឲ្យអ្នកឃើញនៅពេលខាងមុខ។[17]ខ្ញុំបានរំដោះអ្នកឲ្យរួចពីសាសន៍អ៊ីស្រាអែល និងសាសន៍ដទៃ។ ខ្ញុំចាត់អ្នកឲ្យទៅរកសាសន៍ទាំងនោះ[18]ដើម្បីបើកភ្នែកគេឲ្យភ្លឺ ឲ្យគេងាកចេញពីសេចក្តីងងឹតបែរមករកពន្លឺ និងងាកចេញពីអំណាចរបស់សាតាំង បែរមករកព្រះជាម្ចាស់វិញ ព្រមទាំងទទួលការអត់ទោសឲ្យរួចពីបាប និងទទួលមរតករួមជាមួយអស់អ្នក ដែលព្រះជាម្ចាស់ប្រោសឲ្យបានវិសុទ្ធដោយមានជំនឿលើខ្ញុំ»។
[19]បពិត្រព្រះរាជា ទូលបង្គំពុំបានជំទាស់នឹងការអស្ចារ្យ ដែលទូលបង្គំនិមិត្តឃើញនោះឡើយ។[20]ទូលបង្គំបានប្រាប់ប្រជាជននៅក្រុងដាម៉ាសមុនគេបង្អស់ បន្ទាប់មក ប្រាប់ប្រជាជននៅក្រុងយេរូសាឡឹម នៅស្រុកយូដាទាំងមូល ហើយប្រាប់សាសន៍ដទៃឲ្យកែប្រែចិត្តគំនិត និងបែរមករកព្រះជាម្ចាស់ ដោយប្រព្រឹត្តអំពើផ្សេងៗបញ្ជាក់ថា គេពិតជាកែប្រែចិត្តគំនិតមែន។[21]ហេតុនេះហើយបានជាសាសន៍យូដានាំគ្នាចាប់ទូលបង្គំនៅក្នុងព្រះវិហារ ព្រមទាំងប៉ុនប៉ងប្រហារជីវិតទូលបង្គំផង។
[22]ប៉ុន្តែ ដោយព្រះជាម្ចាស់ជួយទូលបង្គំរហូតមកទល់ថ្ងៃនេះ បានជាទូលបង្គំនៅតែផ្តល់សក្ខីភាពអំពីព្រះអង្គនៅចំពោះមុខអ្នកតូច និងអ្នកធំ។ ទូលបង្គំពុំបាននិយាយអ្វីក្រៅពីសេចក្តីដែលពួកព្យាការី និងលោកម៉ូសេបានថ្លែងទុកអំពីហេតុការណ៍ ដែលត្រូវតែកើតមាននោះឡើយ[23]ពោលគឺព្រះគ្រិស្តបានរងទុក្ខលំបាក ហើយមានព្រះជន្មរស់ឡើងវិញមុនគេបង្អស់ ទ្រង់នឹងប្រទានដំណឹងអំពីពន្លឺនៃការសង្គ្រោះ ប្រាប់សាសន៍យូដា និងសាសន៍ដទៃ»។
[24]កាលលោកប៉ូលកំពុងមានប្រសាសន៍ការពារខ្លួនដូច្នេះ លោកភេស្ទុសក៏បន្លឺសំឡេងឡើងយ៉ាងខ្លាំងថា៖ «ប៉ូលអើយ! អ្នកវង្វេងស្មារតីហើយ! គឺអ្នករៀនសូត្រច្រើនពេកបានជាត្រឡប់ទៅជាវង្វេងស្មារតីដូច្នេះ»។[25]លោកប៉ូលតបវិញថា៖ «សូមជម្រាបឯកឧត្តមភេស្ទុស ខ្ញុំបាទមិនមែនវង្វេងស្មារតីទេ ផ្ទុយទៅវិញ ខ្ញុំបាទនិយាយតែពាក្យពិតមានន័យត្រឹមត្រូវ។[26]ព្រះរាជាក៏ជ្រាបអំពីហេតុការណ៍ទាំងនេះ រួចស្រេចទៅហើយដែរ ខ្ញុំបាទហ៊ាននិយាយនៅចំពោះមុខព្រះអង្គ ដោយឥតភ័យខ្លាចឡើយ ដ្បិតខ្ញុំបាទជឿជាក់ថា ព្រះរាជាជ្រាបទាំងអស់ ព្រោះហេតុការណ៍នេះមិនមែនកើតឡើងស្ងាត់ៗ នៅកៀនកោះណាមួយឡើយ។
[27]បពិត្រព្រះរាជា តើព្រះអង្គជឿពួកព្យាការីឬទេ? ទូលបង្គំដឹងថា ព្រះអង្គពិតជាជឿមែន»។[28]ព្រះបាទអគ្រីប៉ាមានរាជឱង្ការទៅលោកប៉ូលថា៖ «នៅតែបន្តិចទៀត អ្នកមុខជាធ្វើឲ្យខ្ញុំទៅជាគ្រិស្តបរិស័ទហើយ!»។[29]លោកប៉ូលទូលតបវិញថា៖ «ទោះបីនៅតែបន្តិចទៀត ឬយូរទៀតក្តី ទូលបង្គំអង្វរព្រះជាម្ចាស់ សូមទ្រង់ប្រោសប្រណី មិនត្រឹមតែដល់ព្រះរាជាប៉ុណ្ណោះទេ គឺដល់អស់លោកដែលកំពុងស្តាប់ទូលបង្គំនៅថ្ងៃនេះ សូមឲ្យព្រះរាជា និងអស់លោកបានដូចទូលបង្គំដែរ លើកលែងតែការជាប់ច្រវាក់នេះចេញ»។
[30]បន្ទាប់មកព្រះរាជា លោកទេសាភិបាល ព្រមទាំងម្ចាស់ក្សត្រីយ៍បេរេនីស និងអ្នកឯទៀតៗដែលអង្គុយនៅទីនោះ បាននាំគ្នាក្រោកឡើង[31]ហើយចាកចេញទៅទាំងនិយាយគ្នាថា៖ «បុរសនេះពុំបានធ្វើអ្វីខុសត្រូវមានទោសដល់ជីវិត ឬត្រូវជាប់ច្រវាក់ឡើយ»។[32]ព្រះបាទអគ្រីប៉ាមានរាជឱង្ការទៅកាន់ លោកភេស្ទុសថា៖ «ប្រសិនបើបុរសនេះមិនបានសុំឡើងទៅដល់ព្រះចៅអធិរាជទេនោះ យើងអាចដោះលែងគាត់បាន»។

Acts 26:1
ប្រយោគភ្ជាប់
ឯកឧត្តមភេស្ទុសបាននាំលោកប៉ូលមកចំពោះព្រះបាទអគ្រីប៉ា។ នៅក្នុងខ ២ លោកប៉ូលបានការពារខ្លួនរបស់លោកចំពោះព្រះបាទអគ្រីប៉ា។
ព្រះបាទអគ្រីប៉ា
ព្រះបាទអគ្រីប៉ាបច្ចុប្បន្នសោយរាជ្យនៅប៉ាលីស្ទីន
ទ្រង់បានសោយរាជ្យលើទឹកដីមួយចំនួន។
សូមមើលពីរបៀបដែលអ្នកបកប្រែឈ្មោះនៅក្នុងជម្ពូក ២៥:១៣។
លោកប៉ូលលើកដៃឡើង
«បានលើកដៃធ្វើសញ្ញាទៅរកបណ្តាជន ដើម្បីទាញចំណាប់អារម្មណ៍របស់ពួកគេ»
មានប្រសាសន៍ការពារខ្លួន
«ការពារខ្លួន» ជានាមអរូប អាចនិយាយជាកិរិយាសព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានចាប់ផ្តើមការពារខ្លួនលោកទាស់នឹងអ្នកដែលចោទប្រកាន់លោក»
ទូលបង្គំមានរីករាយណាស់
លោកប៉ូលរីករាយ ដោយសារលោកអាចឈរនៅចំពោះព្រះបាទអគ្រីប៉ា ដើម្បីមានឱកាសប្រកាសដំណឹងល្អ។
អាចឆ្លើយការពារខ្លួន
ឃ្លានេះ មានន័យថា លោកពណ៌នាពីស្ថានភាពរបស់គាត់ ដើម្បីឲ្យអស់អ្នកដែលនៅក្នុងតុលាការអាចពិភាក្សា និងសម្រេចចិត្តពីរឿងក្តីនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីការពារខ្លួនរបស់ទូលបង្គំ»
ចំពោះសេចក្តីទាំងប៉ុន្មានដែលសាសន៍យូដាចោទទូលបង្គំ
«ការចោទប្រកាន់» គឺជានាមអរូប អាចនិយាយជាកិរិយាសព្ទ «ចោទប្រកាន់»។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទាស់នឹងពួកយូដាទាំងអស់ដែលចោទប្រកាន់នឹងទូលបង្គំ»
ពួកយូដា
ពាក្យនេះមានន័យថាពួកយូដាទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដឹកនាំជនជាតិយូដា»
បញ្ហាផ្សេងៗ
អ្នកអាចបញ្ជាក់ថាបញ្ហាប្រភេទណា មានន័យយ៉ាងដូចម្តេច។
របៀបផ្សេងទៀតនៃការបកប្រែ: «និងសំណួរទាក់ទងនឹងបញ្ហាសាសនា។

Acts 26:4
ជនជាតិយូដាគ្រប់រូបស្គាល់ពីរបៀបរស់នៅរបស់ទូលបង្គំ...នៅក្នុងក្រុងយេរូសាឡិម
អាចមានន័យពីរ។ ទី១) ផារីស៊ីដែលបានធំធាត់ជាមនុស្សលោកប៉ូល ហើយគេនឹងស្គាល់លោកថាជាផារីស៊ី។ ទី២) លោកប៉ូលមានឈ្មោះល្បីនៅក្នុងចំណោមជនជាតិយូដា ដែលមានចិត្តឆេះឆួលក្នុងនាមជាផារីស៊ី ហើយឥឡូវនេះបានត្រឡប់ទៅជាអ្នកជឿ។
ជនជាតិយូដាគ្រប់រូប
ឃ្លានេះនិយាយបំផ្លាស់ ដើម្បីបញ្ជាក់ថា មានជនជាតិយូដាជាច្រើនបានស្គាល់លោកប៉ូល។ របៀបផ្សេងទៀតនៃការបកប្រែ: «មានជនជាតិយូដាជាច្រើន»
នៅក្នុងប្រទេសជាតិរបស់ទូលបង្គំផ្ទាល់
អាចមានន័យពីរ។ ទី១) ក្នុងចំណោមប្រជាជនរបស់លោកផ្ទាល់ មិនសំខាន់លើតែទឹកដីអ៊ីស្រាអែលទេ។ ទី២) នៅក្នុងទឹកដីអ៊ីស្រាអែល។
ជាគណៈតឹងរ៉ឹងជាងគេក្នុងសាសនារបស់យើង
«ក្រុមនៅក្នុងសាសនាយូដា ជាមនុស្សដែលរស់នៅកាន់ច្បាប់តឹងរ៉ឹងជាងគេ»

Acts 26:6
ព័ត៌មានទូទៅ
ពាក្យ «លោក» ជាពហុវចន:និងសំដៅទៅលើមនុស្សដែលកំពុងស្តាប់លោកប៉ូល។
ឥឡូវនេះ
ពាក្យនេះ ដើម្បីគម្លាល់ពីការផ្លាស់ប្តូរពីការពិភាក្សារឿងពីអតីតរបស់លោកប៉ូល មកនិយាយជាមួយនឹងរឿងបច្ចុប្បន្នម្តង។
ទូលបង្គំឈរនៅទីនេះ ដើម្បីឲ្យគេកាត់ក្តី
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំនៅទីនេះ ជាកន្លែងដែលគេយកទូលបង្គំមកកាត់ក្តី»
ទូលបង្គំចង់បានសេចក្តីសន្យាដែលព្រះជាម្ចាស់បានសន្យាជាមួយបុព្វបុរសរបស់យើង
ឃ្លានេះ និយាយពីសេចក្តីសន្យា ប្រៀបដូចជាអ្វីមួយដែលពួកគេស្វែងរក និងចង់ឃើញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំរង់ចាំដោយសង្ឃឹមចំពោះព្រះជាម្ចាស់ឲ្យព្រះអង្គធ្វើអ្វីដែលព្រះអង្គបានសន្យាជាមួយបុព្វបុរសរប
ដ្បិត នេះគឺជាសេចក្តីសង្ឃឹមរបស់កុលសម្ព័ន្ធទាំងដប់ពីររបស់យើង នឹងបានទទួល

generated on Wed Sep 10 16:16:32 2025

ឃ្លា «កុលសម្ព័ន្ធទាំងដប់ពីររបស់យើង»
តំណាងឲ្យប្រជាជននៅក្នុងកុលសម្ពន្ធទាំងនោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះក៏ជាអ្វីដែលបងប្អូនជនជាតិយូដានៅក្នុងកុលសម្ពន្ធទាំងដប់ពីរដែលកំពុងរង់ចាំ។
សេចក្ដីសន្យាជាសេចក្ដីសង្ឃឹម...នឹងបានទទួល
ឃ្លានេះនិយាយពីសេចក្ដីសន្យា ដែលដូចជាវត្ថុមួយដេលអាចទទួលបាន។
ថ្វាយបង្គំព្រះជាម្ចាស់ទាំងយប់ទាំងថ្ងៃ
ពាក្យ «ទាំងយប់» និង «ថ្ងៃ» មានន័យថាពួកគេ «ថ្វាយបង្គំព្រះជាម្ចាស់រហូត»។
ជនជាតិយូដា
ឃ្លានេះ មិនមានន័យថាជនជាតិយូដាទាំងអស់នោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹកនាំជនជាតិយូដា»
ហេតុអ្វីបានជាអស់លោកគិតថា ការដែលព្រះជាម្ចាស់ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ គឺជាការដែលមិនគួរឲ្យជឿដូច្នេះ?
លោកប៉ូលប្រើសំណួរមួយដើម្បីសួរជនជាតិយូដាដែលមានវត្តមាននៅទីនេះ។
ពួកគេជឿព្រះម្ចាស់ថា ប្រោសមនុស្សឲ្យរស់ឡើងវិញ ប៉ុន្តែ មិនបានមិនជឿថា
ព្រះជាម្ចាស់អាចប្រោសព្រះយេស៊ូឲ្យរស់ឡើងវិញទេ។
នេះគឺជាឃ្លាដែលអាចបញ្ជាក់នៅក្នុងប្រយោគ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនជឿទេឬថា ព្រះជាម្ចាស់អាចប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ»
Acts 26:9
ពេលមួយ
លោកប៉ូលប្រើឃ្លានេះ ដើម្បីបញ្ជាក់ពីការប្តូរនៅរកការការពារខ្លួនរបស់គាត់វិញ។
លោកកំពុងទទួលខុសត្រូវពីការដែលគាត់ធ្លាប់បៀតបៀនពួកបរិសុទ្ធ។
ទាស់នឹងព្រះនាមព្រះយេស៊ូ
ពាក្យ «ព្រះនាម» នៅទីនេះ តំណាងឲ្យព្រះយេស៊ូផ្ទាល់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដើម្បីបញ្ឈប់មនុស្សលែងឲ្យជឿលើព្រះយេស៊ូ»
ពេលគេសម្លាប់អ្នកទាំងនោះ ទូលបង្គំបោះឆ្នោតទាស់នឹងពួកគេដែរ។
ឃ្លា «បានសម្លាប់» អាចនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយខ្ញុំក៏បោះឆ្នោតយល់ស្របជាមួយអ្នកដឹកនាំជនជាតិយូដាផ្សេងទៀត
ឲ្យកាត់ទោសពួកអ្នកជឿដល់ស្លាប់ដែរ»
ទូលបង្គំបានធ្វើទុក្ខដល់ពួកគេជាច្រើនដង
អាចមានន័យពីរ។ ទី១) លោកប៉ូលដាក់ទោសអ្នកជឿខ្លះជាច្រើនដង ឬទី២)
លោកប៉ូលបានដាក់ទោសពួកអ្នកជឿជាច្រើនអ្នក។
Acts 26:12
ប្រយោគភ្ជាប់
អំឡុងពេលទូលទៅព្រះបាទអគ្រីប៉ា
លោកប៉ូលបានទូលពីការដែលលោកបានទូលទៅព្រះជាអម្ចាស់។
អំឡុងពេលទូលបង្គំធ្វើការនេះ
លោកប៉ូលប្រើឃ្លានេះ
ដើម្បីសម្គាល់ថាលោកបានប្តូរទៅរកការការពារខ្លួនរបស់លោកវិញ។
លោកទូលអំពីការដែលលោកបានឃើញព្រះយេស៊ូ
ហើយបានត្រឡប់ទៅជាសិស្សរបស់ព្រះអង្គ។
អំឡុងពេល
ពាក្យនេះ ប្រើដើម្បីសម្គាល់ពីព្រឹត្តការណ៍ពីរ ដេលបានកើតឡើងក្នុងពេលតែមួយ។
នៅក្នុងករណីនេះ លោកប៉ូលបានធ្វើដំណើរទៅក្រុងដាម៉ាស
ក្នុងពេលដែលលោកបៀតបៀនគ្រិស្តបរិស័ទ។
បានទទួលសិទ្ធិអំណាច និងសេចក្ដីបង្គាប់
លោកប៉ូលមានសំបុត្រពីពួកអ្នកដឹកនាំយូដា
បានប្រគល់អំណាចឲ្យបៀតបៀនពួកអ្នកជឿជនជាតិយូដា។
ទូលបង្គំបានឮសម្លេងមួយពោលមកទូលបង្គំ
ពាក្យ «សម្លេង» តំណាងឲ្យមនុស្សម្នាក់កំពុងនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទូលបង្គំបានឮសម្លេងមនុស្សម្នាក់និយាយមកកាន់ទូលបង្គំ និយាយថា»
វាពិបាកសម្រាប់អ្នកក្នុងការទាត់ជន្លួញដូច្នេះ
ដ្បិត លោកប៉ូលបានបដិសេធព្រះយេស៊ូ ហើយទៅបៀតបៀនដល់ពួកអ្នកជឿ
បៀបដូចជាលោកទៅនឹងសត្វគោ
ហើយយកខ្លួនទៅទល់នឹងជន្លួញដ៏មុតដែលគេប្រើដើម្បីចាក់សត្វ។ មានន័យថា
លោកប៉ូលធ្វើទុក្ខដល់ខ្លួនឯងទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកធ្វើទុកដល់ខ្លួនឯងទេ ដូចជាគោទាត់ជន្លួញដូច្នោះដែរ»
Acts 26:15
ប្រយោគភ្ជាប់
លោកប៉ូលបន្តធ្វើការការពារខ្លួននៅចំពោះព្រះបាទអគ្រីប៉ា។ នៅក្នុងទាំងនេះ
លោកបន្តដកស្រង់ការសន្ទនារបស់លោកជាមួយព្រះអម្ចាស់។
ដើម្បីបើកភ្នែករបស់ពួកគេ
ដើម្បីជួយមនុស្សឲ្យយល់សេចក្ដីពិត
នៅក្នុងន័យត្រង់គឺជួយមនុស្សឲ្យបើកភ្នែករបស់ពួកគេ។
ឲ្យពួកគេបែរចេញពីសេចក្ដីងងឹតមករកពន្លឺ
ជួយនរណាម្នាក់ឲ្យឈប់ធ្វើអ្វីដែលអាក្រក់ ហើយចាប់ផ្តើមស្តាប់បង្គាប់ព្រះជាម្ចាស់
និយាយក្នុងន័យត្រង់គឺនាំមនុស្សចេញពីទីងងឹតមកដាក់នៅកន្លែងភ្លឺ។
បែរចេញពីអំណាចរបស់មារសាតាំង មករកព្រះជាម្ចាស់វិញ
ជួយនរណាម្នាក់ឲ្យឈប់ស្តាប់បង្គាប់សាតាំង
ហើយចាប់ផ្តើមស្តាប់បង្គាប់ដល់ព្រះជាម្ចាស់វិញ និយាយក្នុងន័យត្រង់
គឺបែរនរណាម្នាក់ពីកន្លែងដែលសាតាំងគ្រប់គ្រង
ហើយនាំអ្នកនោះទៅដាក់នៅកន្លែងដែលព្រះជាម្ចាស់ជាអ្នកគ្រប់គ្រងវិញ។
ដើម្បីឲ្យពួកគេអាចទទួលពីព្រះជាម្ចាស់នៅការអត់ទោសឲ្យរួចពីបាប
«ការអត់ទោស» ជានាមអរូប អាចនិយាយជាកិរិយាសព្ទក៏បាន «អត់ទោស»។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់អាចអត់ទោសបាបរបស់ពួកគេ»
ទទួលមរតកដែលខ្ញុំឲ្យដល់
«មរតក» ជានាមអរូប អាចនិយាយជាកិរិយាសព្ទក៏បាន «ទទួលមរតក»។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេអាចនឹងទទួលមរតកដែលខ្ញុំនឹងឲ្យ»
ទទួលមរតក
ជាព្រះពរដែលព្រះយេស៊ូប្រទានដល់អ្នកជឿលើព្រះអង្គ
របៀបដូចជាមរតកដែលពួកគេបានទទួលពីឪពុករបស់ពួកគេដែរ។
ដែលបានញែកដោយឡែកសម្រាប់ខ្ញុំ
ព្រះយេស៊ូបានជ្រើសរើសមនុស្សខ្លះ ដើម្បីធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គ
និយាយន័យត្រង់គឺញែកពួកគេដោយឡែកពីមនុស្សផ្សេងទៀត។
ដោយជំនឿលើខ្ញុំ
«ដោយសារពួកគេបានជឿដល់ខ្ញុំ»
លោកប៉ូលបានបញ្ចប់ដោយដកស្រង់ព្រះបន្ទូលពីព្រះអម្ចាស់។
Acts 26:19
ដូច្នេះ
ពាក្យនេះ ដើម្បីសម្គាល់ពីសេចក្ដីថ្លែង ដោយសារអ្វីដែលបាននិយាយពីមុន។
នៅក្នុងករណីនេះ
លោកប៉ូលបានពន្យល់ពីអ្វីដែលព្រះជាម្ចាស់បានបង្គាប់ដល់លោកនៅក្នុងនិមិត្តរបស់លោក។
ទូលបង្គំត្រូវស្តាប់បង្គាប់
ឃ្លានេះនិយាយក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំបានស្តាប់បង្គាប់»
និមិត្តពីស្ថានសួគ៌
សំដៅលើអ្វីដែលមនុស្សម្នាក់នៅក្នុងនិមិត្តប្រាប់លោកប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលមនុស្សម្នាក់មកពីស្ថានសួគ៌ប្រាប់ខ្ញុំនៅក្នុងនិមិត្ត»
បែរមករកព្រះជាម្ចាស់
ចាប់ផ្តើមទុកចិត្តលើព្រះជាម្ចាស់
និយាយប្រៀបដូចជាមនុស្សម្នាក់ចាប់ផ្តើមដើរទៅរកព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ទុកចិត្តលើព្រះជាម្ចាស់»
ដោយប្រព្រឹត្តអំពើដែលសមនឹងការកែប្រែចិត្តមែន
«ការប្រែចិត្ត» ជានាមអរូប អាចនិយាយជាកិរិយាសព្ទក៏បាន «ប្រែចិត្ត»។
របៀបផ្សេងទៀតនៃការបកប្រែ: «ចាប់ផ្តើមធ្វើអ្វីល្អ
ដើម្បីបង្ហាញថាពួកគេពិតជាប្រែចិត្តមែន»
ជនជាតិយូដា
ពាក្យនេះ មិនសំដៅលើជនជាតិយូដាទាំងអស់នោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ជនជាតិយូដាខ្លះ»
Acts 26:22
ប្រយោគភ្ជាប់
លោកប៉ូលបញ្ចប់ការការពារខ្លួនរបស់គាត់ចំពោះព្រះបាទអគ្រីប៉ា។
មិនបាននិយាយក្រៅពីអ្វី
ឃ្លានេះ និយាយក្នុងទម្រង់វិជ្ជាមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អំពីអ្វីដែលច្បាស់លាស់»
អ្វីដែលពួកព្យាការី
លោកប៉ូលសំដៅលើការចងក្រងសំណេររបស់ពួកព្យាការីនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់។

generated on Wed Sep 10 16:16:32 2025

គឺថាព្រះគ្រិស្តបានរងទុក្ខ
អ្នកអាចបញ្ជាក់ច្បាស់នៅត្រង់នេះថា ព្រះគ្រិស្តត្រូវសុគត។
របៀបផ្សេងទៀតនៃការបកប្រែ: «ថាព្រះគ្រិស្តត្រូវរងទុក្ខ ហើយសុគត» ។
ព្រះអង្គនឹងរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីក្រោកឡើង
ពាក្យ «រស់ឡើងវិញ» ជានាមអរូប អាចនិយាយថា
«ប្រោសមនុស្សឲ្យមានជីវិតរស់ឡើងវិញ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គគឺជាមនុស្សដំបូងដែលបានរស់ពីចំណោមមនុស្សស្លាប់
នៅពេលព្រះជាម្ចាស់ចាប់ផ្តើមធ្វើឲ្យមនុស្សស្លាប់រស់ឡើងវិញ»
រស់ពីស្លាប់
ពាក្យ «រស់ពីស្លាប់» សំដៅលើ វិញ្ញាណរបស់មនុស្សដែលបានស្លាប់ទៅហើយ។
ឲ្យមានជីវិតរស់ឡើងវិញពីចំណោមពួកគេ មានន័យថា រស់ឡើងវិញម្តងទៀត។
ប្រកាសពីពន្លឺ
«ប្រកាសពីព្រះបន្ទូលនៃពន្លឺ»។
ប្រាប់មនុស្សអំពីការដែលព្រះជាម្ចាស់សង្គ្រោះមនុស្ស
និយាយពីមនុស្សបៀបដូចជាពន្លឺ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីប្រកាសពីព្រះបន្ទូលពីការដែលព្រះជាម្ចាស់សង្គ្រោះមនុស្ស» ។
Acts 26:24
ប្រយោគភ្ជាប់
លោកប៉ូល និងព្រះបាទអគ្រីប៉ាបន្តនិយាយជាមួយគ្នា។
អ្នកឆួតហើយ
«អ្នកកំពុងនិយាយរឿងឥតប្រយោគហើយ» ឬ «អ្នកឆួតហើយ»
អ្នករៀនសូត្រច្រើនពេក បានជាធ្វើឲ្យអ្នកឆួតដូច្នេះ
«អ្នករៀនសូត្រច្រើនពេក បានជាធ្វើឲ្យអ្នកឆួតដូច្នេះ»
ខ្ញុំបាទមិនឆួតទេ ប៉ុន្តែ
ឃ្លានេះនិយាយក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំឆួត...ហើយ» ឬ «ខ្ញុំគិតត្រឹមត្រូវទេ... ហើយ»
ឯកឧត្តមភេស្ទុសអើយ
«ឯកឧត្តមភេស្ទុស ដែលស័ក្តិសមនឹងទទួលការគោរពអើយ»
ខ្ញុំបាទនិយាយតែពាក្យពិត មានន័យត្រឹមត្រូវតែប៉ុណ្ណោះ
«ពាក្យ» តំណាងឲ្យ សាររបស់លោកប៉ូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនិយាយពីសេចក្តីពិត និងច្បាស់លាស់»
ដ្បិត ព្រះរាជា...ចំពោះព្រះអង្គ...ពីទ្រង់
លោកប៉ូលនៅតែទូលទៅព្រះបាទអគ្រីប៉ា ប៉ុន្តែ
លោកកំពុងតែសំដៅលើខ្លួនលោកជាបុរសទីបី។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដ្បិត ព្រះរាជា...ចំពោះព្រះអង្គ...ពីទ្រង់»
ខ្ញុំបាទជឿជាក់ថា
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំប្រាកដណាស់»
គ្មានអ្វីអាចលាក់កំបាំងពីទ្រង់ឡើយ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម និងវិជ្ជា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ថាលោកដឹងការនេះ» ឬ «ថាអ្នកបានដឹងពីការនេះហើយ»
មិនបានកើតឡើងនៅទីសម្ងាត់ឡើយ
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនបានកើតឡើងនៅទីសម្ងាត់ឡើយ»។
Acts 26:27
ឱព្រះបាទអគ្រីប៉ាអើយ តើព្រះអង្គជឿពួកព្យាការីឬទេ?
លោកប៉ូលទូលសួរសំនួរនេះ ដើម្បីរំលឹកព្រះបាទអគ្រីប៉ាថា
ព្រះបាទអគ្រីប៉ាបានជឿរួចមកហើយនូវអ្វីដែលព្យាការីបានថ្លែងពីព្រះយេស៊ូ។
ឃ្លានេះនិយាយដូចជាសេចក្តីថ្លែងដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឱព្រះបាទអគ្រីប៉ា! ព្រះអង្គជ្រាប់នូវអ្វីដែលព្យាការីបានថ្លែងហើយ»
នៅតែបន្តិចទៀត អ្នកអាចនឹងធ្វើឲ្យខ្ញុំទៅជាគ្រិស្តបរិស័ទហើយ
ព្រះបាទអគ្រីប៉ាបានសួរសំនួរនេះដើម្បីបង្ហាញលោកប៉ូលថា
លោកមិនអាចបញ្ចុះបញ្ចូលព្រះបាទអគ្រីប៉ាបានទេ
ប្រសិនបើគ្មានភ័ស្តុតាងផ្សេងទៀតបញ្ជាក់នោះ។
ឃ្លានេះនិយាយដូចជាសេចក្តីថ្លែងដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាកដណាស់ សូមកុំគិតថា អ្នកអាចបញ្ចុះបញ្ចូលយើង
ដើម្បីឲ្យយើងបានជឿលើព្រះយេស៊ូដោយងាយដូច្នេះ»
មិនមែនដោយជាប់ច្រវាក់ទាំងនេះឡើយ
ពាក្យ «ជាប់ច្រវាក់» តំណាងឲ្យភាពជាអ្នកទោស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែ ប្រាកដណាស់ ខ្ញុំមិនចង់ឲ្យអ្នក ក្លាយជាអ្នកទោសដូចខ្ញុំទេ»
Acts 26:30
ប្រយោគភ្ជាប់
នេះគឺជាចុងបញ្ចប់នៃពេលវេលារបស់លោកប៉ូលជាមួយព្រះបាទអគ្រីប៉ា។
ព័ត៌មានទូទៅ
ម្ចាស់ក្សត្រីយ៍បេរេនីស ជាប្អូនស្រីរបស់ព្រះបាទអគ្រីប៉ា។ (សូមមើល: ២៥:១៣)
បន្ទាប់មក ព្រះរាជា លោកទេសាភិបាល
«បន្ទាប់មក ព្រះបាទអគ្រីប៉ា លោកទេសាភិបាលភេស្ទុសបានក្រោកឡើង»
សាលប្រជុំ
នេះគឺជាបន្ទប់ប្រជុំដ៏ធំមួយ សម្រាប់ពិធីបុណ្យ ជំនុំជម្រះក្តី
និងព្រឹត្តការណ៍ផ្សេងៗទៀត។
បុរសនេះមិនបានធ្វើអ្វីឲ្យសមដល់ស្លាប់ ឬជាប់ច្រវាក់ឡើយ
«ស្លាប់» ជានាមអរូបី អាចនិយាយជាកិរិយាសព្ទ «ស្លាប់»។ ពាក្យ «ជាប់ច្រវាក់»
នៅទីនេះ តំណាងឲ្យដាក់គុក។ របៀបផ្សេងទៀតនៃការបកប្រែ: «បុរសនេះ
មិនសមស្លាប់ ឬជាប់គុកឡើយ»
គាត់អាចមានសេរីភាពបាន
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំអាចដោះលែងបុរសនេះបាន»

---

27 [1]នៅពេលនោះ គេសម្រេចថាយើងគួរចុះសំពៅចេញដំណើរទៅស្រុកអ៊ីតាលី គេប្រគល់លោកប៉ូល និងអ្នកទោសខ្លះទៀតទៅនាយទាហានម្នាក់ឈ្មោះលោកយូលាស
ក្នុងកងទ័ពរបស់ព្រះមហាក្សត្រាធិរាជ។[2]យើងបានចុះសំពៅដែលមកពីក្រុងអាដ្រាមីត រួចចេញដំណើរទៅ។ សំពៅនោះត្រូវចូលចតនៅស្រុកអាស៊ី។ លោកអើរីស្ទាក
ជាអ្នកស្រុកម៉ាសេដូន ដែលរស់នៅក្រុងថេស្សាឡូនិក ក៏បានរួមដំណើរជាមួយយើងដែរ។
[3]នៅថ្ងៃបន្ទាប់ យើងបានមកដល់ក្រុងស៊ីដូន ហើយលោកយូលាសមានចិត្តសប្បុរសចំពោះលោកប៉ូលណាស់ គាត់អនុញ្ញាតឲ្យលោកប៉ូលទៅផ្ទះមិត្តភក្តិ ដើម្បីឲ្យគេ
មើលថែលោក។[4]បន្ទាប់មកទៀត យើងបានចេញសំពៅពីក្រុងនោះ សសៀរតាមបណ្តោយកោះគីប្រុស ព្រោះបញ្ហាសខ្យល់។[5]បន្ទាប់មកយើងបានឆ្លងសមុទ្រជិតស្រុក
គីលីគា និងស្រុកប៉ាមភីលា ហើយមកដល់ក្រុងមីរ៉ា ក្នុងស្រុកលូគា។[6]នៅក្រុងនោះ លោកនាយទាហានរកបានសំពៅមួយ មកពីស្រុកអលេក្សានទ្រា ហើយត្រូវចេញទៅ
ស្រុកអ៊ីតាលី។ គាត់ក៏នាំយើងចុះសំពៅនោះ។
[7]សំពៅទៅមុខសន្សឹមៗអស់រយៈពេលជាច្រើនថ្ងៃ ហើយបានមកដល់ទន្ទឹមនឹងក្រុងគ្នីដូសដោយលំបាកបំផុត ដោយខ្យល់បក់មកពីមុខ យើងក៏បត់សំពៅទៅរកជ្រោយ
សាលម៉ូន សសៀរតាមបណ្តោយកោះក្រែតវិញ។[8]យើងបន្តដំណើរយ៉ាងលំបាកតាមបណ្តោយកោះនោះ ហើយក៏បានមកដល់កន្លែងមួយឈ្មោះ «កំពង់ស្អាត» ដែលនៅ
ជិតក្រុងឡាសេ។
[9]យើងបានប្រើពេលជាច្រើនថ្ងៃ ហើយឥឡូវជាដំណើរមួយដែលពេញដោយគ្រោះថ្នាក់ ដ្បិតថ្ងៃពិធីបុណ្យតមអាហារក៏ហួសហើយដែរ។ ដូច្នេះ លោកប៉ូលជូនយោបល់គេ
ថា៖[10]«ខ្ញុំយល់ថាបើយើងបន្តដំណើរទៅមុខទៀតនោះ គ្រោះថ្នាក់ណាស់ មិនត្រឹមតែធ្វើឲ្យខូចខាតទំនិញ និងសំពៅប៉ុណ្ណោះទេ គឺថែមទាំងមានគ្រោះថ្នាក់ដល់ជីវិតយើង
ទៀតផង»។[11]ប៉ុន្តែ លោកនាយទាហានបានទុកចិត្តអ្នកបើកសំពៅ និងនាយសំពៅជាងពាក្យរបស់លោកប៉ូលបានប្រាប់។
[12]ដោយសារកំពង់ផែនោះ ពុំមែនជាកន្លែងស្រួលស្នាក់អាស្រ័យនៅរដូវរងា អ្នកសំពៅភាគច្រើន បានសម្រេចចិត្តចេញសំពៅទៅមុខទៀត។ ប្រសិនបើ អាចធ្វើបាន គេចង់
ទៅដល់ក្រុងភេនីច ជាកំពង់ផែមួយនៅកោះក្រែត ដែលបែរទៅរកទិសនិរតី និងទិសពាយ័ព្យ ដើម្បីស្នាក់នៅទីនោះក្នុងរដូវរងា។[13]ពេលនោះ មានខ្យល់បក់មកតិចៗពីទិស
ខាងត្បូង ពួកគេយល់ឃើញថាជាឱកាសល្អសម្រាប់គម្រោងការរបស់គេ គេក៏នាំគ្នាស្រាវយុថ្កា ហើយចេញសំពៅសសៀរៗកោះក្រែតទៅ។
[14]ប៉ុន្តែ បន្តិចក្រោយមក មានខ្យល់ព្យុះមួយយ៉ាងខ្លាំងឈ្មោះ «ខ្យល់ព្យុះអ៊ើរ៉ាគ្លីដូន» បក់បោកនៅកោះនោះ[15]នាំទាំងសំពៅទៅតាមខ្យល់ព្យុះ ហើយដោយយើងពុំអាចធ្វើ
ឲ្យសំពៅបើកបញ្ច្រាសខ្យល់វិញបាន យើងក៏បណ្តោយសំពៅឲ្យរសាត់ទៅតាមខ្យល់ទៅ។[16]ពេលមកដល់ខាងត្បូងកោះតូចមួយឈ្មោះកោះក្លូដេ យើងបានលើកសំប៉ាន
ឡើងទាំងពិបាក។

generated on Wed Sep 10 16:16:32 2025

[17]បន្ទាប់មក យើងយកខ្សែពួរសម្រាប់ប្រើនៅគ្រាមានអាសន្ន មកចងព័ទ្ធជុំវិញសំពៅ ការពារកុំឲ្យធ្លាយ។ យើងក៏បានទម្លាក់ឈើបណ្តែតចុះដែរ ក្រែងលោសំពៅទៅកៀងនៅឈូងសមុទ្រសៀរទីស រួចហើយទុកឲ្យសំពៅរសាត់ទៅតាមខ្យល់។[18]នៅថ្ងៃបន្ទាប់ ដោយខ្យល់ព្យុះបក់បោកមកខ្លាំងពេក គេបានទម្លាក់ទំនិញចោល។
[19]នៅថ្ងៃទីបី ពួកអ្នកសំពៅក៏បោះគ្រឿងប្រដាប់សំពៅចោលដែរ។[20]នៅពេលមិនអាចមើលឃើញព្រះអាទិត្យ ឬផ្កាយ អស់រយៈពេលជាច្រើនថ្ងៃ ហើយដោយខ្យល់ព្យុះនៅតែមានសន្ទុះខ្លាំងដដែល នៅទីបំផុត យើងក៏លែងមានសង្ឃឹមថានឹងបានរួចជីវិត។
[21]ពេលពួកគេពុំបានបរិភោគអ្វីជាយូរថ្ងៃមក លោកប៉ូលក៏ក្រោកឈរនៅកណ្តាលចំណោមអស់អ្នកដែលនៅក្នុងសំពៅ ហើយមានប្រសាសន៍ថា៖ «បើបងប្អូនស្តាប់ខ្ញុំ ហើយមិនចាកចេញពីកោះក្រែតមកទេនោះ បងប្អូនពិតជាមិនត្រូវអន្តរាយខូចខាតដូច្នេះឡើយ។[22]ប៉ុន្តែ ខ្ញុំសូមលើកទឹកចិត្តបងប្អូន សូមមានចិត្តក្លាហានឡើងព្រោះ គ្មាននរណាម្នាក់ក្នុងចំណោមបងប្អូនត្រូវបាត់បង់ជីវិតឡើយ គឺមានតែសំពៅប៉ុណ្ណោះទេ ដែលត្រូវអន្តរាយ។
[23]ដ្បិតយប់មិញ មានទេវតារបស់ព្រះជាម្ចាស់ដែលខ្ញុំជឿ និងគោរពបម្រើបានមកជិតខ្ញុំ[24]ប្រាប់ថា៖ «ប៉ូលអើយកុំខ្លាចអី! ដ្បិត អ្នកត្រូវតែបានទៅឈរនៅមុខព្រះចៅអធិរាជ ហើយដោយព្រះជាម្ចាស់ប្រោសប្រណីអ្នក ព្រះអង្គនឹងសង្គ្រោះអស់អ្នកដែលរួមដំណើរជាមួយអ្នក ឲ្យបានរួចជីវិតផងដែរ»។[25]ហេតុនេះបងប្អូនអើយ ចូរមានចិត្តក្លាហានឡើង ដ្បិត ខ្ញុំជឿទុកចិត្តលើព្រះជាម្ចាស់ថា នឹងបានសម្រេចដូចព្រះអង្គមានព្រះបន្ទូលមែន។[26]សំពៅយើងនឹងត្រូវទៅកៀងនៅកោះណាមួយជាក់ជាពុំខាន»។
[27]សំពៅយើងបានរសាត់អណ្តែតលើផ្ទៃសមុទ្រអាដ្រា អស់រយៈពេលដប់បួនថ្ងៃមកហើយ។ ពេលនោះ ប្រមាណជាពាក់កណ្តាលអធ្រាត្រ ពួកអ្នកសំពៅនឹកសង្ស័យថា ប្រហែលជាមកជិតដល់ដីគោកហើយ។[28]គេបោះខ្សែសម្ទង់ទៅក្នុងទឹកឃើញថា មានជម្រៅសាមសិបប្រាំពីរម៉ែត្រ។ លុះទៅមុខបន្តិច គេបោះខ្សែសម្ទង់ទៅក្នុងទឹកម្តងទៀត ឃើញថាមានជម្រៅម្ភៃប្រាំបីម៉ែត្រ។[29]ដោយខ្លាចក្រែងសំពៅរសាត់ទៅប៉ះនឹងថ្ម ពួកគេទម្លាក់យុថ្កាបួន នៅខាងកន្ទៃ ហើយអធិស្ឋានទន្ទឹងរង់ចាំភ្លឺឆាប់។
[30]ពួកអ្នកសំពៅចង់រត់ចោលសំពៅ គេក៏នាំគ្នាសម្រួតសំប៉ានចុះទៅក្នុងសមុទ្រ ដោយយកលេសថា គេចង់ទាញយុថ្កាទៅដាក់នៅខាងក្បាលសំពៅវិញ។[31]លោកប៉ូលមានប្រសាសន៍ទៅនាយទាហាន និងកូនទាហានថា៖ «ប្រសិនបើ អ្នកទាំងនេះមិននៅក្នុងសំពៅទេ អស់លោកប្រាកដជាពុំអាចរួចជីវិតបានឡើយ»។[32]ពួកទាហានក៏កាប់ផ្តាច់ខ្សែ ទម្លាក់សំប៉ាននោះទៅក្នុងសមុទ្របាត់ទៅ។
[33]លុះទៀបភ្លឺ លោកប៉ូលអញ្ជើញគេទាំងអស់គ្នាឲ្យបរិភោគអាហារ ដោយមានប្រសាសន៍ថា៖ «បងប្អូនបានទ្រាំតមអាហារអស់រយៈពេលដប់បួនថ្ងៃមកហើយ បងប្អូនពុំបានពិសាអ្វីសោះ។[34]ដូច្នេះ សូមបងប្អូនអញ្ជើញពិសាទៅដើម្បីឲ្យបានរួចជីវិត ដ្បិតនៅក្នុងចំណោមបងប្អូន សូម្បីតែសក់មួយសរសៃរបស់បងប្អូ ក៏មិនបាត់ផង»។[35]លោកមានប្រសាសន៍ដូច្នោះហើយ ក៏យកនំប៉័ងមកអរព្រះគុណព្រះជាម្ចាស់នៅមុខពួកគេទាំងអស់គ្នា រួចលោកកាច់បរិភោគ។
[36]ពេលនោះ អ្នកដែលនៅក្នុងសំពៅមានកម្លាំងចិត្តឡើងវិញ គេក៏បរិភោគទាំងអស់គ្នា។[37]នៅក្នុងសំពៅនោះ យើងមានគ្នាទាំងអស់ពីររយចិតសិបប្រាំមួយនាក់។[38]កាលបរិភោគឆ្អែតហើយ គេក៏លើកបាវស្រូវទម្លាក់ទៅក្នុងសមុទ្រដើម្បីឲ្យស្រាលសំពៅ។
[39]លុះភ្លឺឡើង អ្នកសំពៅមើលស្រុកនោះមិនស្គាល់ទេ គេឃើញតែឆកសមុទ្រដែលមានវាលខ្សាច់ រួចគេបានសម្រេចចិត្តចូលសំពៅទៅបង្កៀងនៅទីនោះ ប្រសិនបើ អាចចូលទៅបាន។[40]ដូច្នេះគេក៏ស្រាយខ្សែយុថ្កាទម្លាក់ចោលទៅក្នុងសមុទ្រ ព្រមទាំងស្រាយខ្សែចង្កូតចោលផងដែរ រួចគេលើកក្តោងខាងមុខឡើងឲ្យត្រូវខ្យល់សំពៅចូលទៅរកច្រាំង។[41]ប៉ុន្តែ សំពៅបានបុកខ្សាច់ ដែលនៅចន្លោះខ្សែទឹកពីរបណ្តាលឲ្យសំពៅកៀងនៅទីនោះ។ ក្បាលសំពៅនៅជាប់នឹងថ្កល់ រីឯកន្ទៃវិញបានត្រូវបាក់បែក ដោយទឹករលកបក់បោកផ្ទប់មកយ៉ាងខ្លាំង។
[42]ពួកទាហានមានបំណងសម្លាប់អ្នកទោសទាំងអស់ចោល ដើម្បីកុំឲ្យនរណាម្នាក់ហែលទឹកគេចខ្លួនបានឡើយ។[43]ប៉ុន្តែ ដោយនាយទាហានចង់សង្គ្រោះជីវិតលោកប៉ូល គាត់ក៏ជំទាស់នឹងគោលបំណងរបស់កូនទាហានទាំងនោះ។ គាត់បានបញ្ជាឲ្យអស់អ្នកដែលចេះហែលទឹក លោតទៅក្នុងទឹកហែលទៅរកគោកមុន។[44]រីឯអ្នកមិនចេះហែលទឹក ត្រូវតោងបន្ទះក្តារ ឬតោងបំណែកសំពៅហែលទៅតាមក្រោយ។ ធ្វើដូច្នេះ គេបានទៅដល់ដីគោកដោយសុខសាន្តគ្រប់ៗគ្នា។

Acts 27:1
ប្រយោគភ្ជាប់
លោកប៉ូល ជាអ្នកទោស ចាប់ផ្តើមធ្វើដំណើរទៅរ៉ូម។
ព័ត៌មានទូទៅ
ពាក្យ «យើង» រួមបញ្ចូលលោកលូកា ជាអ្នកនិពន្ធកណ្ឌគម្ពីរកិច្ចការ
និងអ្នកផ្សេងទៀតដែលធ្វើដំណើរជាមួយលោកប៉ូល។
ព័ត៌មានទូទៅ
ក្រុងអាត្រាមីត
គឺជាទីក្រុងមួយដែលមានទីតាំងនៅប៉ែកខាងលិចប្រទេសតួគីបច្ចុប្បន្ន។
នៅពេល ពួកគេសម្រេច
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលលោកទេសាភិបាលបានសម្រេច»
ចុះសំពៅចេញទៅស្រុកអ៊ីតាលី
ស្រុកអ៊ីតាលីគឺជាឈ្មោះរបស់ខេត្តរ៉ូម។ សូមមើលពីរបៀបដែលអ្នកបកប្រែ
«អ៊ីតាលី» នៅក្នុងជំពូក ១៨:១។
ពួកគេបានដាក់លោកប៉ូល និងអ្នកទោសខ្លះទៀតនៅក្រោមការទទួលខុសត្រូវរបស់នាយទាហានម្នាក់
ឈ្មោះលោកយូលាស ជាកងទាហានរបស់ព្រះចៅអធិរាជ
«ទាហានរបស់រ៉ូម បានដាក់មេទាហានម្នាក់ឈ្មោះ លោកយូលាស ជាកងទាហាន
របស់ព្រះចៅអធិរាជ ជាអ្នកទទួលខុសត្រូវលើលោកប៉ូល
និងអ្នកទោសផ្សេងៗទៀត»
នាយទាហានម្នាក់ឈ្មោះលោកយូលាស
លោកយូលាសគឺជាឈ្មោះរបស់បុរសម្នាក់។
ជាកងទាហានរបស់ព្រះចៅអធិរាជអូហ្គូស្ទីន
នេះគឺជាឈ្មោះរបស់កងវរសេនាតូច ឬទាហានដែលលោកយូលាសចេញមក។
យើងបានចុះសំពៅ...កាត់តាមបណ្តោយឆ្នេរ
ពាក្យ «សំពៅ...ដែលបានចុះសំពៅ» តំណាងឲ្យអ្នកសំពៅដែលជិះសំពៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានចុះ
សំពៅ...ជាមួយនឹងអ្នកសំពៅដើម្បីធ្វើដំណើរ»
សំពៅពីក្រុងអាត្រាមីត
អាចមានន័យពីរ។ ទី១) ជាសំពៅដែលមកពីក្រុងអាត្រាមីត។ ឬទី២)
ជាសំពៅដែលចុះឈ្មោះ ឬមានសិទ្ធិនៅក្នុងអាត្រាមីត។
បានចុះសំពៅ
«យើងបម្រុងនឹងចុះសំពៅ» ឬ «ចេញដំណើរជាឆាប់»
បានទៅតាមសមុទ្រ
«ចាប់ផ្តើមធ្វើដំណើរតាមសមុទ្រ»
លោកអើរីស្តាក
លោកអើរីស្តាកមកពីម៉ាសេដូន ប៉ុន្តែធ្លាប់ធ្វើការជាមួយលោកប៉ូលនៅក្នុងអេភេសូរ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុងជំពូក ១៩:២៨។
Acts 27:3
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅទីនេះ សំដៅលើលោកលូកា លោកប៉ូល
និងអ្នករួមដំណើរជាមួយពួកគេ។
លោកយូលាសបានប្រព្រឹត្តនឹងលោកប៉ូលដោយចិត្តមេត្តា
«លោកយូលាសបានប្រព្រឹត្តនឹងលោកប៉ូលដោយក្តីសប្បុរស»។
សូមមើលពីរបៀបដែលអ្នកបកប្រែ «យូលាស» នៅក្នុងជំពូក ២៧:១។
ទៅផ្ទះមិត្រភក្តិ ដើម្បីឲ្យគេមើលថែលោក
«មើលថែ» ជានាមអរូប អាចនិយាយជាកិរិយាសព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ទៅរកមិត្តសម្លាញ់របស់លោកដើម្បីពួកគេអាចជួយលោក» ឬ
«ទៅរកមិត្តសម្លាញ់របស់លោក
ដើម្បីពួកគេអាចជួយលោកនូវអ្វីដែលលោកត្រូវការ» ។
យើងបានចុះសំពៅ ហើយចេញទៅ
«យើងបានចាប់ផ្តើមចុះសំពៅ ហើយចេញទៅ»
ដោយសសៀរតាមបណ្តោយកោះគីប្រុស នៅជិតកោះ ហើយក៏មានខ្យល់បកជាខ្លាំងផងដែរ
ជាឃ្លាអកម្ម «មានខ្យល់បក» និយាយក្នុងទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «បានសសៀរតាមឈូងសមុទ្រគីប្រុស
ដើម្បីគេចពីខ្យល់ ហើយនាំសំពៅទៅខុសផ្លូវ» (UDB)
ស្រុកប៉ាមភីលា

generated on Wed Sep 10 16:16:32 2025

ស្រុកប៉ាមភីលាជាខេត្តមួយនៅក្នុងស្រុកអាស៊ីមីន័រ។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅជំពូក ២:៨។
បានមកដល់ក្រុងមីរ៉ា ជាក្រុងមួយនៅក្នុងស្រុកលូគា
អ្នកអាចបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតថា ពួកគេបានចេញពីសំពៅនៅក្រុងមីរ៉ា
ជាទីក្រុងមួយរបស់ស្រុកលូគា។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានមកដល់ក្រុងមីរ៉ា ជាស្រុកលូគា ជាកន្លែងដែលពួកគេចុះសំពៅមក។
ជាក្រុងមួយនៅក្នុងស្រុកលូគា
ស្រុកលូគា ជាខេត្តរបស់រ៉ូម
មានទីតាំងនៅភាគខាងត្បូងឈៀងខ្លាលេចឈូងសមុទ្ររបស់ប្រទេសទួរគីបច្ចុប្បន្ន។
បានសំពៅមួយ មកពីស្រុកអលេក្សានទ្រាដែលត្រូវចេញទៅស្រុកអ៊ីតាលី
ឃ្លានេះបញ្ជាក់ថា អ្នកសំពៅបានចុះសំពៅទៅអ៊ីតាលី។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានឃើញសំពៅមួយដែលអ្នកសំពៅនោះមកពីស្រុកអលេក្សានទ្រា
ហើយរៀបនឹងចេញដំណើរទៅអ៊ីតាលី» ។
ស្រុកអលេក្សានទ្រា
នេះគឺជាឈ្មោះរបស់ទីក្រុងមួយ។
Acts 27:7
ពេលយើងជិះសំពៅទៅមុខយឺតៗអស់រយៈពេលជាច្រើនថ្ងៃ ហើយបានមកដល់ជិតក្រុង
គ្នីដូសដោយលំបាក
អ្នកអាចបញ្ជាក់ថា ហេតុដែលពួកគេធ្វើដំណើរយឺត
និងលំបាកគឺដោយសារខ្យល់ព្យុះបក់បោកលើពួកគេខ្លាំងពេក។
ក្រុងគ្នីដូស
នេះគឺជាទីក្រុងបុរាណ ដែលមានទីតាំងនៅប្រទេសទួរគីបច្ចុប្បន្ន។
ខ្យល់បក់ខ្លាំងពេកមិនឲ្យយើងអាចទៅតាមផ្លូវនោះបានទេ
«យើងមិនអាចទៅតាមផ្លូវនោះបានទេ ដោយសារខ្យល់បង់ខ្លាំងពេក»
ដូច្នេះ យើងក៏បត់សំពៅសៀរទៅរកតាមបណ្តោយកោះក្រែតវិញ
«ដូច្នេះ យើងបានធ្វើដំណើរសៀរទៅរកតាមបណ្តោយកោះក្រែតវិញ
ជាកន្លែងដែលមិនសូវមានខ្យល់»
ទល់មុខនឹងជ្រោយសាលម៉ូន
នេះគឺជាឈូងសមុទ្ររបស់ទីក្រុងក្រែត។
យើងបន្តដំណើរតាមឆ្នេរយ៉ាងលំបាក
អ្នកអាចបញ្ជាក់ឲ្យកាន់តែច្បាស់ទៀតថា ទោះបីជាខ្យល់ខ្លាំង
តែមិនសូវខ្លាំងដូចមុនទេ ប៉ុន្តែ នៅតែលំបាកក្នុងការធ្វើដំណើរ។
កំពង់ស្អាត
ជាកំពង់ផែដែលនៅជិតក្រុងឡាសេ
មានទីតាំងនៅជិតភាគខាងត្បូងរបស់កោះក្រែត។
នៅជិតក្រុងឡាសេ
នេះគឺជាឈូងសមុទ្ររបស់ទីក្រុងកោះក្រែត។
Acts 27:9
ព័ត៌មានទូទៅ
ពាក្យ «យើង» «ពួកយើង» នៅទីនេះ សំដៅលើលោកប៉ូល
និងមនុស្សគ្រប់គ្នាដែលនៅលើសំពៅ។
យើងបានប្រើពេលជាច្រើនថ្ងៃ
ដោយសារទៅដៅនោះខ្យល់បក់ខ្លាំងពេក ដំណើរពីសេសារា ទៅកាន់កំពង់
ស្អាតត្រូវចំណាយពេលច្រើនជាងការគ្រោងទុក។
ឥឡូវជាដំណើរមួយដែលពេញដោយគ្រោះថ្នាក់ ដ្បិតថ្ងៃពិធីបុណ្យតមអាហារក៏ហួសហើយដែរ
ពិធីបុណ្យតមអាហារនេះ កើតឡើងនៅថ្ងៃបុណ្យថ្ងៃរំដោះបាប
ដែលជាទូទៅគេធ្វើឡើងនៅចុងខែកញ្ញា ឬដើមខែតុលា យោងទៅតាមប្រតិទិន
របស់ពួកលោកខាងលិច។ បន្ទាប់ពីនេះ
មានគឺជាដំណើរដ៏គ្រោះថ្នាក់ដោយសារព្យុះ។
ខ្ញុំយល់ថាបើយើងបន្តដំណើរទៅមុខទៀតនោះ គ្រោះថ្នាក់ណាស់ មិនត្រឹមតែធ្វើឲ្យខូចខាតទំនិញ និង
សំពៅប៉ុណ្ណោះទេ គឺថែមទាំងមានគ្រោះថ្នាក់ដល់ជីវិតយើងទៀតផង
«ប្រសិនបើ យើងធ្វើដំណើរនៅពេលនេះ យើងនឹងគ្រោះថ្នាក់ជាខ្លាំង
និងមានការបាត់បង់ផង»។
គ្រោះថ្នាក់ណាស់ មិនត្រឹមតែធ្វើឲ្យខូចខាតទំនិញ និងសំពៅប៉ុណ្ណោះទេ គឺថែមទាំងមានគ្រោះថ្នាក់
ដល់ជីវិតយើងទៀតផង
ពាក្យ «គ្រោះថ្នាក់» មានន័យថា ត្រូវបំផ្លាញ ពេលសំដៅលើរបស់ផ្សេងៗ
និងសេចក្តីស្លាប់ នៅពេលសំដៅលើមនុស្ស។
មិនត្រឹមតែធ្វើឲ្យខូចខាតទំនិញ និងសំពៅប៉ុណ្ណោះទេ
ទំនិញគឺជាអ្វីមួយដែលមនុស្សដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀតតាមសំពៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនគ្រាន់តែសំពៅ និងទំនិញនៅក្នុងសំពៅទេ»។
ពាក្យរបស់លោកប៉ូលបានប្រាប់
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលលោកប៉ូលបានមានប្រសាសន៍»
Acts 27:12
ដោយសារកំពង់ផែនោះ ពិបាកក្នុងការចតនៅក្នុងរដូវរងា
អ្នកអាចបញ្ជាក់ពីហេតុដែលពិបាកក្នុងការចងនៅកំពង់ផែ។
របៀបផ្សេងទៀតនៃការបកប្រែ: «កំពង់ផែមិនធំគ្រប់គ្រាន់ក្នុងការឲ្យសំពៅបានចត
នៅអំឡុងពេលព្យុះនៅក្នុងរដូវរងារឡើយ។
កំពង់ផែ
ជាកន្លែងមួយនៅជិតដីគោក ដែលមានសុវត្ថិភាពសម្រាប់សំពៅ។
ក្រុងភេនីច
ក្រុងភេនីចជាទីក្រុងកំពង់ផែនៅលើឈូងសមុទ្រក្រែត។
ដើម្បីស្នាក់នៅទីនោះនៅក្នុងរដូវរងា
ឃ្លានេះ និយាយពីរដូវកាលរដូវរងា ប្រៀបដូចជាប្រាក់ដែលគេអាចចំណាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ស្នាក់នៅទីនោះនៅក្នុងរដូវរងារ»
បែរទៅរកទិសនិរតី និងទិសពាយ័ព្យ
ឃ្លានេះមានន័យថាទីក្រុងនេះបែរចេញពីទិសខ្យល់បប់។ ដូច្នេះ
ខ្យល់បក់លើទីក្រុងពីខាងជើងឈៀងខាងលិច
និងភាគខាងត្បូងឈៀងខាងលិចដែរ។
ស្រាវយុថ្កា
ពាក្យ «ស្រាវ» មានន័យថាទាញចេញពីទឹក។
យុថ្កាជាវត្ថុមួយធ្ងន់ដែលចងភ្ជាប់នឹងខ្សែពួរ ដេលធ្វើឲ្យសំពៅមានសុវត្ថិភាព។
យុថ្កាគឺជាជើងរបស់សំពៅដែលលេចចូលទៅក្នុងទឹក
ហើយលេចទៅដល់បាតសមុទ្រ ការពារសំពៅមិនឲ្យរសាត់ទៅឆ្ងាយ។
Acts 27:14
ប្រយោគភ្ជាប់
លោកប៉ូល និងអស់អ្នកដែលបានធ្វើដំណើរនៅលើសំពៅ
បានជួបនឹងព្យុះដ៏កំណាច។
ប៉ុន្តែ បន្តិចក្រោយមក
«បន្តិចក្រោយមក»
មានខ្យល់ព្យុះមួយយ៉ាងខ្លាំង
«ជាខ្យល់យ៉ាងខ្លាំង និងគ្រោះថ្នាក់»
ឈ្មោះ «ខ្យល់ព្យុះភាគឦសាន្ត»
«បានហៅថា ខ្យល់បក់ពីទិសភាគឦសាន្ត»។ ពាក្យសម្រាប់ «ខ្យល់ព្យុះ
ភាគឦសាន្ត» នៅក្នុងភាសាដើមគឺ «ខ្យល់ព្យុះភាគឦសាន្ត»។
អ្នកអាចបកប្រែពាក្យនេះ តាមភាសារបស់អ្នក។
បានចាប់ផ្តើមបក់បោកពីកោះនោះមក
«បានមកពីកោះក្រែត ហើយវាបានបក់យ៉ាងខ្លាំងប៉ះនឹងសំពៅរបស់យើង»
នៅពេលសំពៅបានប៉ះនឹងព្យុះនោះ សំពៅមិនអាចបែរក្បាលទល់នឹងខ្យល់បានទេ
«នៅពេលខ្យល់បក់យ៉ាងខ្លាំងប៉ះនឹងមុខសំពៅ
នោះយើងមិនអាចបណ្តែតសំពៅទល់នឹងវាបានទេ»
យើងក៏បណ្តោយសំពៅឲ្យរសាត់ទៅតាមខ្យល់ទៅ ហើយខ្យល់នោះបាននាំយើងទៅ។
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានឈប់ព្យាយាមជិះសំពៅទៅមុខទៀត
ហើយយើងបានអនុញ្ញាតឲ្យខ្យល់រុញយើងតាមទិសដែលវាបក់»។
ពេលយើងមកដល់ខាងត្បូងកោះតូចមួយ
«យើងបានជិះទៅដល់កន្លែងមួយជាកន្លែងដែលមិនសូវមានខ្យល់បក់ខ្លាំង»
កោះតូចមួយឈ្មោះកោះក្លូដេ
នេះគឺជាកោះមួយដែលមានទីតាំងនៅខាងត្បូងឈូងសមុទ្រក្រែត។
សំប៉ាន
ជាទូកតូចដែលដាក់នៅខាងក្រោយសំពៅ
ហើយជាអ្វីមួយដែលអាចដឹកមនុស្សទៅរកសំពៅ និងចុះពីសំពៅ។
ទូកតូចប្រើនៅក្នុងបុព្វហេតុផ្សេងរួមបញ្ចូលទាំងការគេចផុតពីការលេចសំពៅផងដែរ។
Acts 27:17
ពួកគេបានលើងសំពានឡើងអស់ហើយ
«ពួកគេបានលើកសំពានឡើង» ឬ «ពួកគេបានរុញសំពានឡើងលើសំពៅ»
ពួកគេបានប្រើខ្សែពួរដើម្បីចងព័ទ្ធជុំវិញសំពៅ

generated on Wed Sep 10 16:16:32 2025

«គ្រោង» សំដៅលើតួសំពៅ។ ពួកគេចងខ្សែជុំវិញ
ដើម្បីសំពៅអាចយកឈ្នះក្នុងពេលមានព្យុះ។
ឈូងសមុទ្រសៀរទីស
សៀរទីសជាកន្លែងមួយដែលរាក់នៅតំបន់សមុទ្រនៅក្នុងកោះ។ ឈូងសមុទ្រ
សៀរទីសបានជាប់គាំងនៅលើដីខ្សាច់។ ឈូងសមុទ្រ
សៀរទីសមានទីតាំងនៅឈូងសមុទ្ររបស់លីយា អាហ្វិកខាងជើង។
ពួកគេក៏ទម្លាក់យុថ្កាសមុទ្រ
ពួកគេបានទម្លាក់យុថ្កាចូលទៅក្នុងទឹក ដើម្បីទប់សំពៅឲ្យឈប់
ព្រោះខ្យល់បក់សំពៅរបស់ពួកគេ។
យុថ្កា
យុថ្កាជាវត្ថុមួយធ្ងន់ ចង់ភ្ជាប់ជាមួយខ្សែ ដើម្បីធ្វើឲ្យសំពៅមានសុវត្ថិភាព។
យុថ្កាត្រូវបានទម្លាក់ទៅក្នុងទឹក ហើយលិចទៅក្នុងសមុទ្រដល់បាតសមុទ្រ
ដើម្បីទប់សំពៅពីការរសាត់។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះនៅក្នុងជំពូក ២៧:១២។
ហើយទុកឲ្យសំពៅរសាត់ទៅតាមខ្យល់
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឲ្យសំពៅទៅទិសណាតាមតែខ្យល់បក់យើង» ។
យើងបានជួបជាមួយនឹងខ្យល់ព្យុះបក់បោកមកយ៉ាងខ្លាំង
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្យល់បក់មកលើយើងជាខ្លាំង បក់ទៅមក» ។
ពួកគេក៏ចាប់ផ្តើមទម្លាក់ទំនិញចោល
ធ្វើបែបនេះដើម្បីឲ្យសំពៅបានស្រាលឡើង ដើម្បីការពារកុំឲ្យសំពៅលិច។
ទំនិញ
ទំនិញ
គឺជាអ្វីមួយដែលមនុស្សបានដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀតតាមរយៈសំពៅ
របៀបផ្សេងទៀតនៃការបកប្រែ: «ទំនិញលើសំពៅ»
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះ នៅក្នុងជំពូក ២៧:៩។
Acts 27:19
ពួកអ្នកសំពៅក៏បោះគ្រឿងសម្ភាររបស់សំពៅចោលដោយដៃរបស់ពួកគេផ្ទាល់
ពាក្យ «សម្ភារ» សំដៅលើឧបករណ៍របស់អ្នកសំពៅត្រូវការដើម្បីធ្វើជាក្តោង។
ការនេះបង្ហាញពីស្ថានភាពលំបាកខ្លាំងយ៉ាងណា។
នៅពេលព្រះអាទិត្យ និងផ្កាយអត់រះលើយើងអស់រយៈពេលជាច្រើនថ្ងៃ
ពួកគេមិនអាចមើលឃើញថ្ងៃ និងផ្កាយទេដោយសារខ្យល់ព្យុះពពកងងឹត។
អ្នកសំពៅ ចង់ឃើញព្រះអាទិត្យ និងផ្កាយដើម្បីដឹងថាពួកគេទៅណា
ឬនៅកន្លែងណា ថាតើពួកគេកំពុងទៅណា។
ដោយខ្យល់ព្យុះនៅតែវាយលុកលើយើងដដែលនោះ
«ខ្យល់ព្យុសាហាវពេក នៅតែបក់មកលើយើងទៅវិញទៅមកយ៉ាងខ្លាំង»។
យើងក៏លែងមានសង្ឃឹមថាយើងនឹងបានរួចជីវិត
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់គ្នាលែងមានសង្ឃឹម ថាយើងអាចរួចជីវិត»
Acts 27:21
ប្រយោគភ្ជាប់
លោកប៉ូលមានប្រសាសន៍ទៅអ្នកសំពៅនៅលើសំពៅ។
ពេលពួកគេមិនបានបរិភោគអាហារជាយូរថ្ងៃមក
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើអ្នកសំពៅ។ សំដៅលើលោកលូកា លោកប៉ូល
និងអស់អ្នកដែលនៅជាមួយពួកគេក៏មិនបានបរិភោគអាហារដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានអត់អាហារជាច្រើនថ្ងៃ»
នៅកណ្តាលចំណោមពួកអ្នកសំពៅ
«ក្នុងចំណោមពួកប្រុសៗ»
បងប្អូននឹងមិនរងរបួស ហើយខូចខាតដូច្នេះឡើយ
«ជាលទ្ធផលបងប្អូននឹងរងរបួស ហើយខូចខាតមិនខាន»
ដ្បិតគ្មាននរណាម្នាក់ក្នុងចំណោមបងប្អូនត្រូវបាត់បង់ជីវិតឡើយ
លោកប៉ូលមានប្រសាសន៍ទៅកាន់អ្នកសំពៅ។ បង្ហាញថា
លោកប៉ូលចង់មានន័យថា លោក និងអ្នកដែលនៅជាមួយលោកមិនស្លាប់ទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្នុងចំណោមយើងនៅទីនេះគ្មាននរណាស្លាប់ទេ»
មានតែសំពៅប៉ុណ្ណោះទេ ដែលត្រូវខូចបង់
ពាក្យ «ខូចបង់» ប្រើនៅទីនេះក្នុងន័យបំផ្លាញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែ ខ្យល់ព្យុះនឹងបំផ្លាញតែសំពៅទេ»។
Acts 27:23
អ្នកត្រូវតែបានទៅឈរនៅមុខសេសារ
ឃ្លា «ឈរនៅមុខសេសារ» សំដៅលើលោកប៉ូលនឹងឡើងតុលាការ
ហើយព្រះអធិរាជសេសារនឹងកាត់ក្តីលោក។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនឹងឈរនៅចំពោះព្រះចៅអធិរាជសេសារ ដូច្នេះ ទ្រង់នឹងជំនុំជម្រះក្តីឲ្យលោក»
។
ព្រះជាម្ចាស់ប្រោសប្រណីអ្នក និងអស់អ្នកដែលរួមដំណើរជាមួយអ្នកផងដែរ
«ព្រះជាម្ចាស់បានសម្រេចព្រះទ័យ
អនុញ្ញាតឲ្យអស់អ្នកដែលជិះសំពៅជាមួយអ្នកមានជីវិតរស់នៅ»
ដូចព្រះអង្គមានព្រះបន្ទូលមកខ្ញុំមែន
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចដែលទេវតាបានប្រាប់ខ្ញុំ»
យើងនឹងត្រូវទើរនៅលើកោះណាមួយមិនខាន
«ខ្យល់នឹងបក់យើងឡើងដីគោកមិនខាង»
Acts 27:27
ប្រយោគភ្ជាប់
ខ្យល់ព្យុះយ៉ាងខ្លាំងនៅតែបន្ត។
នៅពេលដល់យប់ទីដប់បួន
ពាក្យ «ទីដប់បួន» ជាលេខទី អាចប្រែថា «ដប់បួន» ឬ «១៤»។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពី១៤ថ្ងៃ
តាំងពីព្យុះបានចាប់ផ្តើមនៅពេលយប់នោះ»
កាលដែលយើងបានរសាត់អណ្តែត
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលខ្យល់បន្តបក់មកលើយើងទៅវិញទៅមក»
នៅលើផ្ទៃសមុទ្រអាឌ្រា
ជាសមុទ្រដែលនៅចន្លោះប្រទេសអ៊ីតាលី និងប្រទេសក្រិក។
ពួកគេបានបោះខ្សែសម្ងួនក្នុងទឹក
«ពួកគេវាស់ជម្រៅទឹកសមុទ្រ» (UDB)។
ពួកគេវាស់ជម្រៅទឹកដោយទម្លាក់ខ្សែចង់ជាមួយរបស់ធ្ងន់ដាក់ចូលទៅក្នុងទឹក។
បានឃើញថាមានជម្រៅម្ភៃព្យាម
«ឃើញថាមានជម្រៅ២០ព្យាម»។ ពាក្យ «ព្យាម»
គឺជារង្វាស់សម្រាប់វាស់ជម្រៅទឹក។ មួយព្យាមប្រហែលជាពីរម៉ែត្រ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឃើញថាមានជម្រៅ ៤០ម៉ែត្រ»
ឃើញថាមានជម្រៅដប់ប្រាំព្យាម
«ឃើញថាមានជម្រៅ១៥ព្យាម»។ ពាក្យ «ព្យាម»
គឺជារង្វាស់សម្រាប់វាស់ជម្រៅទឹក។ មួយព្យាមប្រហែលជាពីរម៉ែត្រ។
របៀបផ្សេងទៀតនៃការបកប្រែ: «ឃើញថាមានជម្រៅ ៣០ម៉ែត្រ»
យុថ្កា
យុថ្កាជាវត្ថុមួយធ្ងន់ ចង់ភ្ជាប់ជាមួយខ្សែ ដើម្បីធ្វើឲ្យសំពៅមានសុវត្ថិភាព។
យុថ្កាត្រូវបានទម្លាក់ទៅក្នុងទឹក ហើយលិចទៅក្នុងសមុទ្រដល់បាតសមុទ្រ
ដើម្បីទប់សំពៅពីការរសាត។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យនេះនៅក្នុងជំពូក ២៧:១២។
កន្ទៃសំពៅ
«ពីខាងក្រោយសំពៅ»
Acts 27:30
ព័ត៌មានទូទៅ
ពាក្យ «អ្នក» នៅទីនេះ ជាពហុវចន: សំដៅលើមេទាហាន និងទាហានរបស់រ៉ូម។
សំប៉ាន
សំប៉ានជាទូកតូចដែលពេលខ្លះគេដាក់នៅខាងក្រោយសំពៅ
ហើយពេលខ្លះគេដាក់នៅខាងក្នុងសំពៅ ហើយចង់ភ្ជាប់។ ជាទូកតូច
គេប្រើវាក្នុងករណីមួយចំនួន។ រួមបញ្ចូលទាំងគេចពេលសំពៅលិច។
សូមមើលពីរបៀបដែលអ្នកបកប្រែនៅក្នុង ជំពូក ២៧:១៤។
ពីក្បាលសំពៅ
«ពីក្បាលសំពៅ»
ប្រសិនបើ អ្នកទាំងនេះមិននៅក្នុងសំពៅទេ អស់លោកមិនអាចរួចជីវិតបានឡើយ
ពាក្យ «ប្រសិនបើ» និង «មិនអាច» អាចនិយាយជាប្រយោគភ្ជាប់។
ជាប្រយោគអកម្ម ឃ្លា «បានសង្គ្រោះ» អាចនិយាយជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «បុរសទាំងអស់នេះត្រូវនៅក្នុងសំពៅ
ដើម្បីឲ្អកទាំងអស់គ្នាបានរួចជីវិត»
Acts 27:33

generated on Wed Sep 10 16:16:32 2025

លុះថ្ងៃរៀបនឹងរះឡើង
«នៅពេលថ្ងៃរៀបនឹងរះឡើង»
នេះគឺជាថ្ងៃទីដប់បួនហើយ
លេខ «ទីដប់បួន» អាចនិយាយ «ដប់បួន» ឬ «១៤ថ្ងៃ»
ដ្បិត គ្មាននរណាម្នាក់ក្នុងចំណោមបងប្អូនបាត់សក់មួយសរសៃពីក្បាលរបស់គេឡើយ
នេះគឺជាទម្លាប់នៃការនិយាយថា គ្មានគ្រោះថ្នាក់អ្វីកើតឡើងដល់ពួកគេឡើយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់គ្នានឹងរួចជីវិតនៅក្នុងគ្រោះមហន្តរាយនេះ»
កាច់នំបុ័ង
«ហែកនំបុ័ង» ឬ «កាច់នំបុ័ងជាបំណែក»
Acts 27:36
បន្ទាប់មក ពួកគេគ្រប់គ្នាបានទទួលការលើកទឹកចិត្ត
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការនេះបានលើកទឹកចិត្តដល់ពួកគេទាំងអស់គ្នា»
យើងមានគ្នាទាំងអស់២៧៦នាក់ នៅក្នុងសំពៅនោះ
នេះគឺជាព័ត៌មានពីប្រវត្តិ។
Acts 27:39
ឆកសមុទ្រ
ជាតំបន់ទឹកមួយយ៉ាងធំ ព័ទ្ធទៅដោយដីគោក។
ពួកគេមិនស្គាល់ទឹកដីនោះទេ
«ឃើញទឹកដី ប៉ុន្តែ មិនស្គាល់កន្លែងដែលពួកគេទៅដល់នោះទេ»។
កាត់ខ្សែយុថ្កា ហើយទម្លាក់វាចូលទៅក្នុងសមុទ្រ
«កាត់ខ្សែ និងទម្លាក់យុថ្កាចោល»
ក្តោង
ជាក្តោង ឬឈើដេលនៅខាងក្រោយសំពៅ ប្រើសម្រាប់កាច់បង្កូត។
ក្តោងមុខ
«ជាក្តោងនៅខាងមុខសំពៅ» ក្តោងមានក្រណាត់មួយយ៉ាងធំ
ដើម្បីចាប់ខ្យល់ឲ្យបក់សំពៅ។
ពួកគេក៏តម្រង់ទៅរកឆ្នេរ។
«ពួកគេបានកាច់បង្កូតទៅរកឆ្នេរ»
ពួកគេបានទៅកន្លែងមួយដែលមានខ្សែទឹកពីរប្រសបគ្នា
នៅទីនេះ ទឹកហូរនៅក្នុងទិសដៅមួយ។ ពេលខ្លះទឹកហូរលើសពីមួយ
ទៅទិសដៅផ្សេងគ្នា។ នេះអាចធ្វើឲ្យខ្សាច់នៅក្រោមទឹក
មូលគ្នាធ្វើឲ្យទឹកហូរកាន់តែខ្លាំង។
ក្បាលសំពៅ
«នៅខាងមុខសំពៅ»
កន្សែសំពៅ
«កន្ទុយសំពៅ»
Acts 27:42
គម្រោងរបស់ពួកទាហាននោះ
«ពួកទាហានបានរៀបគម្រោង»
ដូច្នេះ គាត់បញ្ឈប់គម្រោងរបស់ពួកគេ
«ដូច្នេះ លោកបានបញ្ឈប់ពួកគេពីធ្វើអ្វីដែលពួកគេបានរៀបគម្រោងនឹងធ្វើ»
លោតពីសំពៅមុន
«លោតចេញពីសំពៅនៅក្នុងទឹក»
ខ្លះតោងលើបន្ទះក្តារ
«អ្នកខ្លះតោងបន្ទះក្តារ»

---

28 [1]កាល ពួកយើងបានរួចជីវិតហើយ យើងដឹងថា កោះនោះឈ្មោះ កោះម៉ាល់ត៍។[2]អ្នកកោះនោះបានទទួលយើងដោយចិត្តសប្បុរសរកអ្វីប្រៀបផ្ទឹមពុំបាន ដោយអញ្ជើញ
យើងទាំងអស់គ្នា មកជុំវិញភ្នក់ភ្លើងមួយយ៉ាងធំដែលគេបានដុត ដ្បិតពេលនោះមានភ្លៀងធ្លាក់ ហើយធាតុអាកាសក៏ត្រជាក់ណាស់ផង។
[3]លោកប៉ូលរើសមែកឈើមួយកងមកបោះក្នុងភ្លើង ស្រាប់តែមានពស់វែកមួយលូនចេញមក ដោយកំដៅភ្លើង ហើយខាំដៃលោកជាប់។[4]កាលអ្នកកោះនោះឃើញពស់ខាំដៃ
លោកជាប់ដូច្នេះ ក៏និយាយគ្នាថា៖ «អ្នកនេះពិតជាបានសម្លាប់គេហើយ ទោះបីគាត់ទើបនឹងរួចខ្លួនពីសមុទ្រនោះក៏ដោយ ក៏ព្រះអង្គយុត្តិធម៌មិនទុកឲ្យគាត់នៅរស់រានមាន
ជីវិតដែរ»។
[5]លោកប៉ូលបានរលាស់ពស់នោះទម្លាក់ទៅក្នុងភ្លើង តែលោកពុំឈឺចុកចាប់អ្វីទេ។[6]អ្នកកោះនោះរង់ចាំមើលលោកប៉ូល ហើមខ្លួន ឬក៏ត្រូវដាច់ខ្យល់ស្លាប់។ ប៉ុន្តែ ក្រោយពីចាំ
មើលអស់រយៈពេលយ៉ាងយូរមក គេឃើញថាគ្មានហេតុអាក្រក់កើតដល់លោកសោះ ពួកគេក៏ផ្លូរគំនិត ហើយបែរជាពោលថា លោកប៉ូលជាព្រះជាម្ចាស់វិញ។
[7]នៅជិតនោះ មានដីមួយកន្លែង ដែលជាកម្មសិទ្ធិរបស់មេកន្ត្រាញកោះ ឈ្មោះពូព្លាស។ គាត់បានទទួលយើងឲ្យស្នាក់នៅ យ៉ាងរាក់ទាក់ចំនួនបីថ្ងៃ។[8]ឪពុករបស់លោក
ពូព្លាស សម្រាន្តនៅលើគ្រែ ព្រោះគាត់គ្រុនផង និងរាកមូលផង។ លោកប៉ូលបានចូលទៅក្នុងផ្ទះគាត់ ហើយអធិស្ឋានដាក់ដៃពីលើ និងប្រោសគាត់ឲ្យបានជា។[9]អ្នកជំងឺឯ
ទៀតៗនៅលើកោះឃើញគាត់ជាដូច្នេះ គេក៏នាំគ្នាមកដែរ ហើយបានជាទាំងអស់គ្នា។[10]ពួកគេបានសម្តែងការគោរពគ្រប់យ៉ាងចំពោះយើង។ នៅពេលយើងរៀបចំចេញ
ដំណើរ ពួកគេបានជួយឧបត្ថម្ភនូវអ្វីៗដែលយើងត្រូវការ។
[11]បីខែក្រោយមក យើងចុះសំពៅមួយឈ្មោះ «ឌីអូស្គួរ» ជាសំពៅមកពីក្រុងអលេក្សានទ្រា ដែលបានចតនៅកោះនោះក្នុងអំឡុងពេលរដូវរងា។[12]លុះមកដល់ក្រុងស៊ីរ៉ាគូស
យើងបានស្នាក់នៅទីនោះបីថ្ងៃ។
[13]បន្ទាប់មក យើងបានសសៀរតាមឆ្នេរសមុទ្រទៅដល់ក្រុងរេគាម។ ស្អែកឡើង មានខ្យល់បក់មកពីទិសខាងត្បូង ហើយក្នុងរវាងតែពីរថ្ងៃ យើងមកដល់ក្រុងពូទីយ៉ូលី។
[14]នៅក្រុងនោះ យើងបានជួបពួកបងប្អូន គេអញ្ជើញយើងឲ្យស្នាក់នៅជាមួយអស់រយៈពេលប្រាំពីរថ្ងៃ។ យើងក៏បន្តដំណើរទៅកាន់ក្រុងរ៉ូម។[15]ពួកបងប្អូននៅក្រុងរ៉ូមដឹង
ដំណឹងអំពីយើង ក៏នាំគ្នាធ្វើដំណើររហូតទៅដល់ផ្សារអាប់ភាស និងភូមិផ្ទះសំណាកបីខ្នង ដើម្បីទទួលយើង។ កាលលោកប៉ូលឃើញបងប្អូនទាំងនោះ លោកបានអរ
ព្រះគុណព្រះជាម្ចាស់ដោយចិត្តក្លាហាន។
[16]លុះយើងមកដល់ក្រុងរ៉ូមហើយ អាជ្ញាធរអនុញ្ញាតឲ្យលោកប៉ូលស្នាក់នៅផ្ទះមួយតាមបំណងចិត្តរបស់លោក តែពួកគេដាក់ទាហានម្នាក់ឲ្យនៅយាមលោក។[17]បីថ្ងៃក្រោយ
មក លោកប៉ូលអញ្ជើញអ្នកមុខអ្នកការក្នុងចំណោមជនជាតិយូដា ឲ្យមកជួបលោក។ លុះគេមកជួបជុំគ្នាហើយ លោកមានប្រសាសន៍ទៅគេថា៖ «បងប្អូនអើយ ខ្ញុំពុំបានធ្វើ
អ្វីប្រឆាំងនឹងប្រជាជាតិយើង ឬក៏ទាស់នឹងប្រពៃណីបុព្វបុរសយើងទេ តែគេបានចាប់ខ្ញុំឃុំឃាំងនៅក្រុងយេរូសាឡឹម និងបញ្ជូនខ្ញុំមកក្នុងកណ្តាប់ដៃរបស់ជនជាតិរ៉ូម។
[18]កាលពួករ៉ូមសួរចម្លើយខ្ញុំរួចរាល់ហើយ គេចង់ដោះលែងខ្ញុំវិញ ព្រោះគេពុំឃើញខ្ញុំមានកំហុសអ្វី គួរនឹងមានទោសដល់ជីវិតនោះឡើយ។
[19]ប៉ុន្តែ ជនជាតិយូដាបាននាំគ្នាជំទាស់ ជាហេតុបង្ខំឲ្យខ្ញុំសុំឡើងមកដល់ព្រះចៅអធិរាជ។ រីឯខ្ញុំវិញ ខ្ញុំគ្មានគោលបំណងនឹងចោទប្រកាន់ប្រជាជាតិរបស់ខ្ញុំទេ។[20]ហេតុនេះ
ហើយបានជាខ្ញុំសុំជួប និងសុំនិយាយជាមួយបងប្អូន ដ្បិតខ្ញុំជាប់ចំណងព្រោះតែសេចក្តីសង្ឃឹមរបស់ជនជាតិអ៊ីស្រាអែល»។
[21]អ្នកទាំងនោះតបវិញថា៖ «យើងពុំបានទទួលសំបុត្រអ្វីពីស្រុកយូដាស្តីអំពីលោកឡើយ ហើយក៏គ្មានបងប្អូនណាម្នាក់មករាយការណ៍ ឬនិយាយអាក្រក់ពីលោកដែរ។
[22]យើងចង់ស្តាប់លោកមានប្រសាសន៍អំពីគំនិតរបស់លោក ព្រោះយើងដឹងថាមានគេជំទាស់នឹងគណៈរបស់លោកនៅគ្រប់ទីកន្លែង»។
[23]ពួកគេបានណាត់ពេលជួបលោកប៉ូលម្តងទៀតនៅថ្ងៃមួយ ហើយមានមនុស្សច្រើនជាងមុនមកផ្ទះលោកប៉ូល។ លោកបានវែកញែក និងធ្វើជាបន្ទាល់អំពីព្រះរាជ្យរបស់
ព្រះជាម្ចាស់ប្រាប់គេតាំងពីព្រឹក រហូតដល់ល្ងាច ដោយលើកយកគម្ពីរវិន័យរបស់លោកម៉ូសេ និងគម្ពីរព្យាការីមកពន្យល់បញ្ជាក់ប្រាប់គេអំពីព្រះយេស៊ូ។[24]មានពួកគេមួយ
ផ្នែក បានជឿពាក្យដែលលោកមានប្រសាសន៍ តែមួយផ្នែកទៀតពុំព្រមជឿទេ។
[25]ដោយពួកគេចាកចេញពីទីនោះទៅទាំងខ្វែងគំនិតគ្នា លោកប៉ូលក៏មានប្រសាសន៍ទៅគេថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកកាន់បុព្វបុរសយើង តាមរយៈព្យាការី
អេសាយពិតជាត្រូវមែន។[26]ព្រះអង្គមានព្រះបន្ទូលថា៖ «ចូរទៅរកប្រជារាស្ត្រនោះ ហើយប្រាប់ពួកគេថា អ្នករាល់គ្នាស្តាប់ឮមែន តែពុំយល់ទេ អ្នករាល់គ្នាមើលមែន តែពុំ
ឃើញដែរ។
[27]ដ្បិតចិត្តរបស់ប្រជារាស្ត្រនេះរឹងណាស់ គេបាននាំគ្នាខ្ទប់ត្រចៀក ហើយបិទភ្នែក។ ពួកគេមើលឃើញនឹងភ្នែក ហើយឮនឹងត្រចៀក តែមិនយល់ ហើយក៏មិនចង់កែប្រែចិត្ត
គំនិតដែរ ក្រែងលោយើងប្រោសគេឲ្យបានជា»។

generated on Wed Sep 10 16:16:32 2025

[28]ហេតុនេះ សូមបងប្អូនជ្រាបថា ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលនិយាយពីការសង្គ្រោះរបស់ព្រះអង្គ ឲ្យសាសន៍ដទៃវិញ ព្រោះគេមុខជាស្តាប់មិនខាន។[29]កាលលោកប៉ូលមានប្រសាសន៍ដូច្នេះហើយ ជនជាតិយូដាក៏ចេញទៅ ទាំងជជែកគ្នាយ៉ាងខ្លាំងផង។
[30]លោកប៉ូលបានស្នាក់នៅផ្ទះ ដែលលោកបានជួលនោះអស់រយៈពេលពីរឆ្នាំ ហើយលោកតែងទទួលអស់អ្នកដែលមកជួបលោក។[31]លោកបានប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ និងបង្រៀនគេអំពីព្រះយេស៊ូគ្រិស្តដោយចិត្តអង់អាច ហើយគ្មានអ្វីមកររាំងលោកឡើយ។

Acts 28:1

ប្រយោគភ្ជាប់

បន្ទាប់ពីការលិចសំពៅ មនុស្សនៅលើ កោះម៉ាល់ត៍បានជួយលោកប៉ូល
ហើយនិងមនុស្សគ្រប់គ្នាដែលនៅក្នុងសំពៅ។ ពួកគេស្នាក់នៅទីនោះបីខែ។

ព័ត៌មានទូទៅ

ពាក្យ «យើង» សំដៅលើលោកប៉ូល
និងលោកលូកាដែលជាអ្នកនិពន្ធកណ្ឌគម្ពីរកិច្ចការ
ដែលបានធ្វើដំណើរជាមួយលោកប៉ូលនៅក្នុងដំណើរនេះ»។

នៅពេលយើងបានមកដល់ដោយសុវត្ថិភាពហើយ

ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលយើងមកដល់ដោយសុវត្ថិភាពហើយ»

ទើបយើងស្គាល់ថា

លោកប៉ូល និងលោកលូកាបានស្គាល់ឈ្មោះកោះនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងបានដឹងពីប្រជាជន» ឬ
«យើងបានដឹងពីអ្នកដែលរស់នៅទីនោះ»

កោះនោះឈ្មោះ កោះម៉ាល់ត៍

កោះម៉ាល់ត៍ជាកោះមួយដែលមានទីតាំងនៅភាគខាងត្បូងកោះស៊ីលីសព្វថ្ងៃ។

អ្នកកោះនោះ

«ប្រជាជននៅក្នុងតំបន់»

មិនគ្រាន់តែទទួលយើងដោយចិត្តសប្បុរសដ៏លើសលប់ប៉ុណ្ណោះទេ

មានចិត្តសប្បុរសដល់មនុស្សគ្រប់គ្នា របៀបដូចជាឲ្យរបស់ទៅនរណាម្នាក់។
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនគ្រាន់តែទទួលយើងដោយចិត្តល្អលើសលប់ប៉ុណ្ណោះទេ»

មិនគ្រាន់តែទទួលយើងដោយចិត្តសប្បុរសដ៏លើសលប់ប៉ុណ្ណោះទេ

ឃ្លានេះត្រូវបានប្រើដើម្បីបញ្ជាក់ពីការនិយាយផ្ទុយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រព្រឹត្តដោយក្តីសប្បុរស»

ពួកគេបានបង្កាត់ភ្លើង

«ពួកគេបានបង្កាត់ភ្លើង និងផ្គុំមែកឈើជាមួយគ្នា ហើយដុតមែកឈើទាំងនោះ»

បានស្វាគមន៍យើងទាំងអស់គ្នា

អាចមានន័យពីរ។ ទី១) ស្វាគមន៍មនុស្សគ្រប់គ្នាដែលមកពីសំពៅ» ឬ ទី២)
បានស្វាគមន៍លោកប៉ូល ហើយនិងអ្នករួមដំណើរជាមួយលោក»។

Acts 28:3

មានពស់វែកមួយលួនចេញមក

«ពស់វែងមួយបានលូនចេញពីកំដៅភ្លើង»

បានចឹកដៃរបស់លោកជាប់

«បានចឹកលោកប៉ូល ហើយមិនរបូតសោះ»

អ្នកនេះពិតជាឃាតកមែន

«ប្រាកដណាស់ អ្នកនេះពិតជាឃាតកវិមែន» ឬ «បុរសនេះ ពិតជាឃាតកវិមែន»

សេចក្តីយុត្តិធម៌

ពាក្យ «សេចក្តីយុត្តិធម៌» សំដៅលើឈ្មោះរបស់ព្រះមួយអង្គដែលពួកគេថ្វាយបង្គំ។
របៀបបកប្រែ: «ព្រះរបស់គេហៅថាសេចក្តីយុត្តិធម៌»

Acts 28:5

លោកបានរលាស់ពស់នោះទម្លាក់ទៅក្នុងភ្លើង

«លោកបានរលាស់ដៃរបស់លោក ដើម្បីឲ្យពស់នោះធ្លាក់ពីដៃរបស់គាត់ចូលទៅក្នុងភ្លើង»

លោកគ្មានការឈឺចាប់អ្វីឡើយ

«លោកប៉ូលគ្មានការឈឺចាប់អ្វីឡើយ»

ហើមនិងក្តៅខ្លួន

អាចមានន័យពីរ។ ទី១) រូបកាយរបស់លោកហើម ដោយសារពិសរបស់ពស់។
ឬទី២) លោកក្តៅខ្លួនជាខ្លាំង។

គ្មានអ្វីខុសពីធម្មតាកើតឡើងដល់លោកសោះ

ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្រប់យ៉ាងធម្មតា គ្មានអ្វីកើតឡើងឡើយ»

ពួកគេបានដូរគំនិតរបស់ពួកគេ
គិតខុសពីស្ថានភាព ប្រៀបដូចជាមនុស្សម្នាក់ប្តូរគំនិតរបស់គេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេគិតជាថ្មី»

ហើយនិយាយថា លោកប៉ូលជាព្រះ

ឃ្លានេះអាចនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយនិយាយថា៖ «បុរសគឺជាព្រះហើយ»

និយាយថា លោកជាព្រះ

ប្រហែលនៅទីនោះពួកគេជឿថានរណាម្នាក់ដែលនៅមានជីវិតបន្ទាប់ពីពិសពស់ចឹកហើយ
គឺជាព្រះ ឬ មកពីព្រះ។

Acts 28:7

ព័ត៌មានទូទៅ

ពាក្យ «យើង» និង «យើង» នៅទីនេះ សំដៅលើលោកប៉ូល លោកលូកា
និងអស់អ្នកដែលធ្វើដំណើរជាមួយពួកគេ។

ឥឡូវនេះ នៅជិតនោះ មានដីមួយកន្លែង

«ឥឡូវនេះ» ប្រើដើម្បីណែនាំមនុស្សថ្មី
ឬព្រឹត្តការណ៍ថ្មីនៅក្នុងសាច់រឿងដែលពាក់ព័ន្ធ។

ដែលជាកម្មសិទ្ធិរបស់មេកន្ត្រាញកោះ

អាចមានន័យពីរ។ ទី១) ជាអ្នកដឹកនាំដែលធំជាងគេ ឬទី២)
ជាមនុស្សម្នាក់ដែលសំខាន់នៅលើកោះនោះ ប្រហែលជាគាត់ជាអ្នកមាន។

ឈ្មោះពូព្លាស

នេះគឺជាឈ្មោះរបស់បុរសម្នាក់

នៅពេលនោះ ឪពុករបស់លោកពូព្លាសមានជំងឺ គ្រុនក្តៅ និងរោគមួល

នេះគឺជាព័ត៌មានពីសាវតារឪពុករបស់លោកពូព្លាសដែលសំខាន់ដើម្បីយល់ពីសាច់រឿងនេះ។

មានជំងឺ

ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ឈឺ»

មានជំងឺ គ្រុនក្តៅ និងរោគមួល

ជំងឺមួលគឺមេរោគដែលរលាក់ខាងក្នុង។

លោកបានអធិស្ឋាន ដាក់ដៃរបស់លោកពីលើគាត់

«បានយកដៃទៅប៉ះគាត់»

បានប្រោសគាត់ឲ្យជា

ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយលោកបានប្រោសឲ្យពួកគេបានជាដែរ» (UDB)

ប្រជាជនគោរពរាប់អានយើងជាខ្លាំង

ប្រហែលជាពួកគេគោរពរាប់លោកប៉ូល
និងអ្នកដែលនៅជាមួយគាត់ដោយឲ្យជាអំណោយផ្សេងៗ។

Acts 28:11

ប្រយោគភ្ជាប់

ដំណើររបស់លោកប៉ូលបន្តទៅក្រុងរ៉ូម។

ព័ត៌មានទូទៅ

បងប្អូនភ្លោះពីរនាក់សំដៅលើខាស្ទើ និងផូលលុច ជាកូនភ្លោះរបស់ព្រះសេយូស
ព្រះរបស់ក្រិក។ ពួកគេគិតថាលោកជាអ្នកការពារសំពៅ។

ជាសំពៅមកពីក្រុងអលេក្សានទ្រា

អាចមានន័យពីរ។ ទី១) «ជាសំពៅដែលមកពីអលេក្សានទ្រា» ទី២)
«ជាសំពៅដែលបានចុះឈ្មោះ ឬមានសិទ្ធិនៅក្នុងអលេក្សានទ្រា»។
សូមមើលពីរបៀបដែលអ្នកបកប្រែពាក្យ«អលេក្សានទ្រា» នៅក្នុងជំពូក ៦:៨។

ហើយបានចំណាយពេលនៅលើកោះនោះនៅក្នុងរដូវរងា

«គេបានទុកអ្នកសំពៅកោះនោះនៅក្នុងរដូវរងារ»។

ក្រុងស៊ីរ៉ាគូស

ក្រុង

ស៊ីរ៉ាគូសជាក្រុងមួយនៅទិសខាងត្បូងឆៀងខាងកើតឈូងសមុទ្រស៊ីលីបច្ចុប្បន្ន
ដូចនៅទិសខាងត្បូងឆៀងខាងកើតរបស់អ៊ីតាលីដែរ។

Acts 28:13

ព័ត៌មានទូទៅ

ផ្សារអាប់ភាស និងដល់ផ្ទះសំណាក់បីខ្នងជាផ្សារមានឈ្មោះល្បី ហើយផ្ទះសំណាក់
នៅលើផ្លូវធំហៅថាផ្លូវអាប់ភាស ប្រហែលជា៥០គីឡូម៉ែត្រខាងត្បូងក្រុងរ៉ូម។

generated on Wed Sep 10 16:16:32 2025

ក្រុងរេគាម
នេះគឺជាទីក្រុងកំពង់ផែ ដែលមានទីតាំងនៅនិរតីប្រទេសអ៊ីតាលី។
មានខ្យល់បក់មកពីទិសខាងត្បូង
«ខ្យល់ចាប់ផ្តើមបក់មកពីទិសខាងត្បូង»
ក្រុងពូទីយ៉ូលី
ក្រុងពូទីយ៉ូលីមានទីតាំងនៅឈូងសមុទ្រភាគខាលិចអ៊ីតាលី។
នៅទីនោះ យើងបានជួប
«នៅទីនោះយើងបានជួប»
ពួកបងប្អូន
អ្នកទាំងនេះគឺជាអ្នកដើរតាមព្រះយេស៊ូ រួមបញ្ចូលទាំងប្រុស ទាំងស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនអ្នកជឿ»
ពួកគេបានអញ្ជើញយើង
ឃ្លានេះនិយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកគេបានអញ្ជើញយើង»
យើងបានទៅដល់ក្រុងរ៉ូមបែបនេះឯង
នៅពេលលោកប៉ូលបានទៅដល់ក្រុងពូទីយ៉ូលី
នោះគឺជាដំណើរចុងក្រោយរបស់លោកទៅរ៉ូមតាមដីគោក។
របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់ពីយើងស្នាក់នៅជាមួយពួកគេបានប្រាំពីរថ្ងៃ យើងបានចេញទៅរ៉ូម»។
បន្ទាប់ពីបងប្អូននៅទីនោះបានដឹងដំណឹងអំពីយើង
«បន្ទាប់ពី ពួកគេបានឮថាយើងមក»
លោកបានអរព្រះគុណព្រះជាម្ចាស់ ហើយមានចិត្តក្លាហានឡើងវិញ
មានចិត្តក្លាហានគឺនិយាយប្រៀបដូចជាវត្ថុដែលមនុស្សម្នាក់យក។
របៀបផ្សេងទៀតនៃការបកប្រែ: «ការនេះបានលើកទឹកចិត្តដល់គាត់
ហើយគាត់បានអរគុណដល់ព្រះជាម្ចាស់»
Acts 28:16
ប្រយោគភ្ជាប់
លោកប៉ូលបានមកដល់ក្រុងរ៉ូម ក្នុងនាមជាអ្នកទោស ប៉ុន្តែ មានសេរីភាព
អាចស្នាក់នៅផ្ទះរបស់គាត់ខ្លួនឯង។
លោកបានហៅជនជាតិយូដាដែលនៅក្នុងតំបន់មកជុំគ្នា
ដើម្បីពន្យល់ពីអ្វីដែលបានកើតឡើងជាមួយលោក។
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើលោកលូកា ដែលសរសរសរកណ្ឌគម្ពីរកិច្ចការ
ក៏ដូចជាលោកប៉ូល និងអ្នកឯទៀតដែលធ្វើដំណើរជាមួយលោកដែរ។
នៅពេលយើងបានចូលដល់ក្រុងរ៉ូមហើយ គេបានអនុញ្ញាតឲ្យលោកប៉ូលនៅម្នាក់ឯង
ឃ្លានេះនិយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពី
យើងបានមកដល់ក្រុងរ៉ូម ពួកអាជ្ញាធរបានអនុញ្ញាតឲ្យលោកប៉ូលមាន»
បីថ្ងៃក្រោយមក
ឃ្លាប្រើនៅទីនេះ ដើម្បីសម្គាល់ពីការចាប់ផ្តើមផ្នែកថ្មីនៃសាច់រឿង។ ប្រសិនបើ
ភាសារបស់អ្នក មានរបៀបនិយាយពីការនេះ អាចអាចប្រើវានៅទីនេះ។
ពួកអ្នកដឹកនាំក្នុងចំណោមជនជាតិយូដា
អ្នកទាំងនេះគឺជាជនជាតិយូដាធម្មតា ឬ
ជាអ្នកដឹកនាំសាសនាយូដាដែលរស់នៅក្រុងរ៉ូម។
បងប្អូនអើយ
ពាក្យនេះមានន័យថា «បងប្អូនយូដាអើយ»
ទាស់នឹងប្រជាជាតិយើង
«ទាស់នឹងប្រជាជាតិយើង» ឬ «ទាស់នឹងជនជាតិយូដា»
តែគេបានចាប់ខ្ញុំបញ្ជូនខ្ញុំពីក្រុងយេរូសាឡិម មកក្នុងកណ្តាប់ដៃរបស់ជនជាតិរ៉ូម
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានជនជាតិយូដាខ្លះបានចាប់ខ្ញុំនៅក្នុងក្រុងយេរូសាឡិម
ហើយបានយកខ្ញុំទៅដាក់ក្នុងមន្ទីឃុំឃាំងរបស់អាជ្ញាធររ៉ូម»
មកក្នុងកណ្តាប់ដៃរបស់ជនជាតិរ៉ូម
ពាក្យ «ដៃ» នៅទីនេះ តំណាងឲ្យអំណាច ឬការគ្រប់គ្រង។
ពួកគេរកហេតុនឹងដាក់ទោសខ្ញុំដល់ស្លាប់ឡើយ។
«ខ្ញុំមិនបានធ្វើអ្វីដែលធ្វើឲ្យពួកគេសម្លាប់ខ្ញុំឡើយ»
Acts 28:19
ជនជាតិយូដា
នេះមិនមែនមានន័យថាជនជាតិយូដាទាំងអស់នោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដឹកនាំជនជាតិយូដា»
ជំទាស់បំណងរបស់ពួកគេ
«បានប្តឹងផ្តល់អំពីអ្វីដែលអាជ្ញាធររ៉ូមចង់ធ្វើ»
ខ្ញុំបានបង្ខំចិត្តសុំឡើងមកដល់សេសារ
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំសូមប្តឹងទៅដល់សេសារឲ្យកាត់ក្តីខ្ញុំ»
ទោះបីខ្ញុំគ្មានបំណងចោទប្រកាន់ទាស់នឹងប្រជាជាតិរបស់ខ្ញុំក៏ដោយ
ពាក្យ «ចោទប្រកាន់» គឺជានាមអរូប អាចនិយាយជាកិរិយាសព្ទ «ចោទប្រកាន់»។
ពាក្យ «ប្រជាជាតិ» នៅទីនេះ តំណាងឲ្យមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែមិនមែនដោយសារខ្ញុំចង់ចោទប្រកាន់ជនជាតិខ្ញុំ នៅចំពោះសេសារទេ»
ជនជាតិអ៊ីស្រាអែលជឿ
អាចមានន័យពីរ។ ១) ប្រជាជនអ៊ីស្រាអែលជឿលើព្រះមេស៊ីនឹងយាងមក។ ទី២)
ប្រជាជនអ៊ីស្រាអែលជឿថាព្រះជាម្ចាស់នឹងប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ។
អ្វីដែលជនជាតិអ៊ីស្រាអែល
ពាក្យ «អ៊ីស្រាអែល» នៅទីនេះ តំណាងឲ្យប្រជាជាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្វីដែលជនជាតិអ៊ីស្រាអែលជឿគឺ» ឬ
«អ្វីដែលជនជាតិយូដាជឿគឺ»
បានជាខ្ញុំជាប់ចំណងនេះដូច្នេះ
ពាក្យ «បានជាខ្ញុំជាប់ចំណងនេះ» តំណាងឲ្យភាពជាអ្នកទោស។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំជាអ្នកទោស»
Acts 28:21
ប្រយោគភ្ជាប់
អ្នកដឹកនាំជនជាតិយូដាបានឆ្លើយទៅលោកប៉ូល។
ព័ត៌មានទូទៅ
ពាក្យ «យើង» សំដៅលើអ្នកដឹកនាំជនជាតិយូដានៅក្នុងក្រុងរ៉ូម។
ក៏គ្មានបងប្អូនណាម្នាក់មក
ពាក្យ «បងប្អូន» តំណាងឲ្យបងប្អូនជនជាតិយូដា។ របៀបផ្សេងទៀតនៃការបកប្រែ:
«ក៏គ្មានបងប្អូនជនជាតិយូដាណាដែរ»
ពីអ្វីដែលលោកគិតអំពីនិកាយនេះ
និកាយនេះ ជាក្រុមតូចមួយនៅក្នុងក្រុមធំ។
នៅទីនេះសំដៅលើអស់អ្នកដែលជឿលើព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកគិតថា អ្នកនៅក្រុមនេះ»
ព្រោះយើងដឹងថាមានគេជំទាស់នឹងនិកាយរបស់លោក
ឃ្លានេះ និយាយជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយសារយើងដឹង»
គេជំទាស់នឹងនិកាយរបស់លោកនៅគ្រប់ទីកន្លែង
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មានជនជាតិយូដាជាច្រើននៅក្នុងអាណាចក្ររ៉ូមនិយាយអាក្រក់ពីការនេះ»
Acts 28:23
ព័ត៌មានទូទៅ
ពាក្យ «ពួកគេ» នៅទីនេះ សំដៅលើអ្នកដឹកនាំជនជាតិយូដានៅក្នុងក្រុងរ៉ូម
(សូមមើល: ២៨:១៦)
ព័ត៌មានទូទៅ
ពាក្យ «គាត់» «លោក» និង «គាត់» សំដៅលើលោកប៉ូល។
បានណាត់ពេលជួបលោកម្តងទៀត
«បានជ្រើសរើសពេលវេលាសម្រាប់លោកដើម្បីនិយាយជាមួយពួកគេ»។
បានធ្វើបន្ទាល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់
ពាក្យ «ព្រះរាជ្យរបស់ព្រះជាម្ចាស់» តំណាងឲ្យ
ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ក្នុងនាមជាស្តេច» ឬ
«ប្រាប់ពួកគេពីព្រះជាម្ចាស់បង្ហាញអង្គទ្រង់ជាស្តេច» ។
ពីគម្ពីរព្យាការី
ពាក្យ «ពួកព្យាការី» សំដៅលើអ្វីដែលពួកគេបានសរសេរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីអ្វីដែលពួកព្យាការីបានសរសេរ» ។
មានពួកគេខ្លះបានជឿពាក្យដែលលោកមានប្រសាសន៍
ឃ្លានេះ និយាយក្នុងទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកប៉ូលអាចបញ្ចុះបញ្ចូលពួកគេខ្លះឲ្យជឿ»
Acts 28:25
ប្រយោគភ្ជាប់
ពេលជនជាតិយូដារៀបនឹងចេញហើយ
លោកប៉ូលបានដក់ស្រង់បទគម្ពីរសម្ពន្ធមេត្រីចាស់ដែលត្រូវនឹងពេលបច្ចុប្បន្ន។

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ

ពាក្យ «ពួកគេ» សំដៅលើអ្នកដឹកនាំជនជាតិយូដានៅក្នុងក្រុងរ៉ូម។ (សូមមើល: ២៨:១៦)

ព័ត៌មានទូទៅ

ពាក្យ «របស់អ្នក» សំដៅលើមនុស្សដែលលោកប៉ូលនិយាយជាមួយ។ នៅក្នុង ខ២៦ លោកប៉ូលបានចាប់ផ្តើមដោយដកស្រង់ពីព្យាការីអេសាយ។

បន្ទាប់ពីលោកមានប្រសាសន៍ពាក្យមួយនេះ

ពាក្យ «ពាក្យ» តំណាងឲ្យ សារ ឬជាសេចក្តីថ្លែង។ របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់ពីលោកប៉ូលមានប្រសាសន៍ម្តងទៀត» ឬ «បន្ទាប់មក លោកប៉ូលបានថ្លែងការនេះម្តងទៀត»

ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកកាន់បុព្វបុរសយើង តាមរយៈព្យាការីអេសាយពិតជាត្រូវមែន ព្រះអង្គមានព្រះបន្ទូលថា៖ «ចូរទៅរកប្រជារាស្ត្រនោះ ហើយប្រាប់ថា៖ «អ្នករាល់គ្នាស្តាប់ឮមែន ប៉ុន្តែមិនយល់ទេ ហើយអ្នករាល់គ្នាមើលមែន ប៉ុន្តែ មើលមិនឃើញទេ

ការដកស្រង់សម្តីរនៅក្នុងសម្រង់សម្តី។

អ្នកអាចប្រែការដកស្រង់ដោយផ្ទាល់ដូចនៅក្នុង UDB ឬ អ្នកអាចបកប្រែទាំងពីរនេះនៅក្នុងការដកស្រង់នៅក្នុងសម្រង់សម្តីបានដែរ។

របៀបផ្សេងទៀតនៃការបកប្រែ:

«ព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលតាមរយៈព្យាការីអេសាយទៅកាន់បុព្វបុរសរបស់អ្នករាល់គ្នា ពេលព្រះវិញ្ញាណប្រាប់លោកអេសាយឲ្យប្រាប់ពួកគេថា ពួកគេនឹងឮ ហើយមិនយល់ ហើយពួកគេឃើញ តែពួកគេមិនយល់»

អ្នករាល់គ្នាស្តាប់ឮមែន ប៉ុន្តែ មិនយល់ទេ ហើយអ្នករាល់គ្នាមើលមែន ប៉ុន្តែមើលមិនឃើញទេ

ពាក្យ «ឮ» និង «ឃើញ» និយាយម្តងហើយម្តងទៀតដើម្បីបញ្ជាក់។

«អ្នកស្តាប់ដោយយកចិត្តទុកដាក់...ហើយអ្នកមើលដោយយកចិត្តទុកដាក់ដែរ»។

ប៉ុន្តែមិនយល់ទេ...ប៉ុន្តែ មើលមិនឃើញទេ។

ឃ្លាទាំងពីរនេះមានន័យថាដូចគ្នា។ ពួគគេបញ្ជាក់ថា ជនជាតិយូដានឹងមិនយល់ពីផែនការរបស់ព្រះជាម្ចាស់ឡើយ»

Acts 28:27

ប្រយោគភ្ជាប់

លោកប៉ូលបានបញ្ចប់ការដកស្រង់ពីព្យាការីអេសាយ។

ព័ត៌មានទូទៅ

ការបកប្រែការដកស្រង់របស់លោកប៉ូលពីលោកអេសាយ ឲ្យដូចនឹងការដកស្រង់ដែលអ្នកបានបកប្រែនៅក្នុង ជំពូក ២៨:២៥។

ដ្បិត ចិត្តរបស់ប្រជាជននេះបានស្អីកស្រពន់អស់ហើយ មនុស្សដែលមានចិត្តរឹងរូសបដិសេធក្នុងការយល់ពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល ឬធ្វើ គឺបៀបដូចជាមនុស្សថ្លង់។ ពាក្យ «ចិត្ត» នៅទីនេះ តំណាងឲ្យគំនិត។

ត្រចៀករបស់ពួកគេក៏ពួកគេស្តាប់លែងឮ ហើយពួកគេក៏បិទភ្នែកដែរ

មនុស្សដែលមានចិត្តរឹងរូស បដិសេធក្នុងការយល់ពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល ឬធ្វើ ប្រៀបដូចជាមនុស្សថ្លង់បានបិទភ្នែក ដើម្បីពួកគេមើលឃើញ។

ក៏យល់នៅក្នុងចិត្តរបស់ពួកគេដែរ

ពាក្យ «ចិត្ត» តំណាងឲ្យគំនិត។

ហើយបែរមកវិញ

ដើម្បីស្តាប់បង្គាប់ព្រះជាម្ចាស់ គឺបែរទាំងរូបកាយមករកព្រះជាម្ចាស់វិញ។

យើងប្រោសពួកគេឲ្យបានជា

នេះមិនមែនមានន័យថា ព្រះជាម្ចាស់ព្យាបាលគ្រាន់តែរូបសាច់របស់ពួកគេទេ។ ព្រះអង្គថែមទាំងព្យាបាលខាងវិញ្ញាណដែរ ដោយអត់ទោសបាបរបស់ពួកគេដែរ។

Acts 28:28

ប្រយោគភ្ជាប់

លោកប៉ូលបានបញ្ចប់និយាយជាមួយអ្នកដឹកនាំជនជាតិយូដានៅក្នុងក្រុងរ៉ូម។

សេចក្តីសង្គ្រោះរបស់ព្រះអង្គដែលបានប្រទានឲ្យដល់សាសន៍ដទៃ

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីរបៀបដែលព្រះអង្គសង្គ្រោះមនុស្ស ឬ[illegible]

ត្រូវបានបកប្រែតាមមួយដែលអាចធ្វើបាន។ ឃ្លានេះនិយាយជាទម្រង់សកម្ម។

របៀបផ្សេងទៀតនៃការបកប្រែ:

«ព្រះជាម្ចាស់បានចាត់អ្នកនាំសាររបស់ព្រះអង្គទៅកាន់សាសន៍ដទៃ ដើម្បីប្រាប់ពួកគេអំពីរបៀបដែលព្រះអង្គសង្គ្រោះពួកគេ»

ពួកគេព្រមស្តាប់

«នឹងមានអ្នកខ្លះក្នុងចំណោមពួកគេស្តាប់អ្នក»។ ការឆ្លើយតបរបស់សាសន៍ដទៃផ្ទុយពីការឆ្លើយតបរបស់ជនជាតិយូដានៅពេលនោះ។

Acts 28:30

ប្រយោគភ្ជាប់

លោកលូកាបានបញ្ចប់សាច់រឿងរបស់លោកប៉ូលនៅក្នុងកណ្ឌគម្ពីរកិច្ចការ។

លោកបានប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់

ពាក្យ «ព្រះរាជ្យរបស់ព្រះជាម្ចាស់» សំដៅលើព្រះជាម្ចាស់គ្រប់គ្រងក្នុងនាមជាស្តេច។ របៀបផ្សេងទៀតនៃការបកប្រែ: «លោកបានប្រកាសអំពីការសោយរាជ្យរបស់ព្រះជាម្ចាស់ក្នុងនាមជាស្តេច» ឬ «លោកប្រកាសអំពីរបៀបដែលព្រះជាម្ចាស់បង្ហាញអង្គទ្រង់ជាស្តេច»

រ៉ូម

1 [1]ខ្ញុំ ប៉ូល ជាអ្នកបម្រើរបស់ព្រះយេស៊ូគ្រិស្ត បានហៅឲ្យធ្វើជាសាវ័ក ហើយបានញែកខ្ញុំដោយឡែកសម្រាប់ដំណឹងល្អរបស់ព្រះជាម្ចាស់។[2]នេះគឺជាដំណឹងល្អ
ដែលព្រះបានសន្យាតាមរយៈព្យាការីរបស់ព្រះអង្គនៅក្នុងបទគម្ពីរដ៏វិសុទ្ធ។[3]អំពីព្រះបុត្រារបស់ព្រះអង្គ ដែលបានប្រសូតពីពូជពង្សរបស់ព្រះបាទដាវីឌ។
[4]ដោយសារការរស់ពីសុគតឡើងវិញ ព្រះអង្គបានប្រកាសថា ជាព្រះបុត្រានៃព្រះ ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ថាព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង។[5]ដោយសារព្រះអង្គ
យើងបានទទួលព្រះគុណ និងភាពជាសិស្សសម្រាប់អ្នកដែលស្តាប់បង្គាប់ដោយជំនឿនៅក្នុងចំណោមប្រជាជាតិ ដោយសារព្រះនាមព្រះអង្គ។
[6]នៅក្នុងចំណោមប្រជាជាតិទាំងនោះ បងប្អូនក៏បានត្រាស់ហៅដើម្បីឲ្យបានធ្វើជាកម្មសិទ្ធិរបស់ព្រះយេស៊ូគ្រិស្ត។
[7]ខ្ញុំធ្វើសំបុត្រនេះទៅកាន់បងប្អូនទាំងអស់ដែលនៅក្នុងក្រុងរ៉ូម ដែលជាទីស្រឡាញ់របស់ព្រះជាម្ចាស់
ជាអ្នកដែលព្រះជាម្ចាស់បានហៅឲ្យបានត្រឡប់ជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ។ សូមព្រះគុណ និងសេចក្តីសុខសាន្តមកពីព្រះជាម្ចាស់ជាព្រះបិតា
និងពីព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង ស្ថិតនៅជាប់ជាមួយអ្នករាល់គ្នា។
[8]ជាដំបូង ខ្ញុំអរគុណដល់ព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូគ្រិស្តសម្រាប់អ្នកទាំងអស់គ្នា ដោយសារជំនឿរបស់អ្នករាល់គ្នាបានប្រកាសពេញពិភពលោកទាំងមូល។
[9]ដោយសារព្រះអង្គជាទីបន្ទាល់របស់ខ្ញុំ ដែលខ្ញុំបម្រើខាងវិញ្ញាណ នៅក្នុងដំណឹងល្អនៃបុត្រារបស់ព្រះអង្គ ដែលខ្ញុំបានដំណាលប្រាប់អ្នករាល់គ្នាជាបន្តបន្ទាប់។
[10]ខ្ញុំតែងតែទូលសូមដល់ព្រះអង្គជានិច្ចនៅក្នុងសេចក្តីអធិស្ឋានរបស់ខ្ញុំ តាមវិធីណាក៏ដោយ យ៉ាងហោចណាស់ គឺខ្ញុំចង់ទៅជួបអ្នករាល់គ្នា ប្រសិនបើ
ព្រះសព្វព្រះហឫទ័យ។
[11]ខ្ញុំចង់ជួបអ្នករាល់គ្នា ដើម្បីឲ្យខ្ញុំអាចផ្តល់អំណោយទានខាងវិញ្ញាណខ្លះចម្រើនកម្លាំងដល់អ្នករាល់គ្នា។
[12]ខ្ញុំចង់ឲ្យអ្នករាល់គ្នាបានទទួលការលើកទឹកចិត្តនៅក្នុងចំណោមអ្នករាល់គ្នា តាមរយៈជំនឿរវាងគ្នានឹងគ្នា ជំនឿរបស់អ្នករាល់គ្នា និងខ្ញុំដែរ។
[13]ឥឡូវនេះ បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាដឹង ថា ខ្ញុំតែងតែមានបំណងចិត្តចង់មករកអ្នករាល់គ្នា (ប៉ុន្តែ មានអ្វីមួយរារាំងខ្ញុំរហូតមកដល់ពេលនេះ)
ដើម្បីកុំឲ្យខ្ញុំអាចប្រមូលផលនៅក្នុងចំណោមអ្នករាល់គ្នាបាន ដូចដែលខ្ញុំធ្លាប់ធ្វើនៅក្នុងចំណោមសាសន៍ដទៃ។[14]ខ្ញុំជាប់ជំពាក់ទាំងសាសន៍ក្រិក និងសាសន៍ដទៃ
ទាំងអ្នកប្រាជ្ញ និងអ្នកល្ងង់។[15]ដូច្នេះ សម្រាប់ខ្ញុំ គឺខ្ញុំត្រៀមរួចរាល់នឹងប្រកាសដំណឹងល្អដល់អ្នករាល់គ្នាទាំងអ្នកនៅក្រុងរ៉ូមដែរ។
[16]ដ្បិតខ្ញុំមិនខ្មាសដោយព្រោះដំណឹងល្អឡើយ ព្រោះដំណឹងល្អគឺជាព្រះចេស្តានៃព្រះជាម្ចាស់ ដើម្បីសង្គ្រោះមនុស្សគ្រប់គ្នាដែលជឿ ដំបូងសាសន៍យូដា
ហើយនិងសាសន៍ក្រិក។[17]នៅក្នុងដំណឹងល្អនោះ គឺសេចក្តីសុចរិតរបស់ព្រះជាម្ចាស់បានបើកសម្តែងពីជំនឿទៅកាន់ជឿ ដូចជាសេចក្តីដែលបានចែងទុកថា៖
«មនុស្សសុចរិតនឹងរស់នៅដោយជំនឿ»។
[18]ពីព្រោះព្រះពិរោធរបស់ព្រះជាម្ចាស់បានបង្ហាញពីស្ថានសួគ៌ទាស់នឹងមនុស្សដែលមិនគោរពប្រតិបត្តិដល់ព្រះអង្គ និងមនុស្សទុច្ចរិត ដោយសារអំពើអាក្រក់
ហើយបានលាក់សេចក្តីពិត។[19]នេះគឺដោយសារព្រះជាម្ចាស់បានបើកសម្តែងឲ្យពួកគេបានដឹង។

generated on Wed Sep 10 16:16:32 2025

[20]គុណសម្បត្តិរបស់ព្រះអង្គដែលយើងមើលមិនឃើញ ដូចជាអំណាច និងសណ្ឋានជាព្រះរបស់ព្រះអង្គដែលបានឃើញតាំងពីដំបូងមក គឺតាំងពីកំណើតលោកីយ៍
និងនៅក្នុងអ្វីៗទាំងអស់ដែលបានបង្កើតមកម៉្លេះ។ ដូច្នេះពួកគេមិនអាចដោះសារបានទេ។[21]សូម្បីតែពួកគេបានស្គាល់ព្រះជាម្ចាស់ហើយក្តី ប៉ុន្តែ
ពួកគេមិនបានថ្វាយសិរីល្អដល់ព្រះអង្គឲ្យដូចជាព្រះទេ ឬពួកគេមិនបានអរព្រះគុណដល់ព្រះអង្គទេ។ ផ្ទុយទៅវិញ
ពួកគេបានត្រឡប់ទៅជាល្ងង់ខ្លៅនៅក្នុងគំនិតរបស់ពួកគេ និងមនសិការនៅក្នុងចិត្តរបស់ពួកគេបានងងឹតទៅ។
[22]ពួកគេគិតថាពួកគេជាមនុស្សឆ្លាត ប៉ុន្តែ ពួកគេគឺជាមនុស្សល្ងង់វិញ។[23]ពួកគេបានប្តូរសិរីល្អនៃព្រះដែលមិនចេះពុករលួយទៅដូចជារូបចម្លាក់មនុស្ស បក្សាបក្សី
សត្វជើងបួន និងសត្វលូនវាដែលពុករលួយទៅវិញ។
[24]ហេតុដូច្នេះហើយ ព្រះជាម្ចាស់បានប្រគល់ពួកគេទៅក្នុងចិត្តស្រើបស្រាលដែលស្រែកឃ្លានភាពមិនស្អាត
ហើយរូបកាយរបស់ពួកគេត្រូវបានទទួលការមើលងាយនៅក្នុងចំណោមពួកគេទៅវិញ។[25]ពួកគេបានដូរសេចក្តីពិតរបស់ព្រះជាម្ចាស់ យកសេចក្តីភូតភរ ហើយបាន
ថ្វាយបង្គំ និងបម្រើអ្វីៗដែលត្រូវបានបង្កើតឡើង ជាជាងព្រះដែលបានបង្កើត និងជាព្រះដែលប្រកបដោយព្រះពរអស់កល្បជានិច្ច អាម៉ែន។
[26]ដោយហេតុនេះហើយ បានជាព្រះជាម្ចាស់ប្រគល់ពួកគេឲ្យទៅតាមតណ្ហាថោកទាប ពួកគេបានប្តូរទំនាក់ទំនងបែបធម្មជាតិ
ទៅរបៀបដែលខុសពីធម្មជាតិវិញគឺស្រីស្រឡាញ់ស្រី។[27]ដូចគ្នាដែរ បុរសក៏បោះបង់ចោលទំនាក់ទំនងបែបធម្មជាតិចោលដែរ លែងស្រឡាញ់ស្រី
បែរជាមានការស្រើបស្រាលជាមួយប្រុសគ្នាឯងទៅវិញ។ ពួកគេបានប្រព្រឹត្តបែបនេះ ដោយគ្មានអាម៉ាស់
ហើយពួកគេនឹងបានទទួលការដាក់ទោសសមនឹងអំពើដែលពួកគេបានប្រព្រឹត្តដែរ។
[28]ដោយសារតែពួកគេមិនបានបង្ហាញថាមានព្រះជាម្ចាស់ នៅក្នុងការយល់ដឹងរបស់ពួកគេ ពួកគេបានបណ្តោយខ្លួនទៅតាមគំនិតអាក្រក់របស់ពួកគេ
ព្រោះពួកគេធ្វើអ្វីដែលមិនត្រឹមត្រូវ។
[29]ពួកគេបានពោពេញទៅដោយអំពើទុច្ចរិត អំពើអាក្រក់ និងការលោភលន់ និងព្យាបាទគ្រប់យ៉ាង។ ពួកគេពេញដោយការច្រណែន សម្លាប់ ឈ្លោះប្រកែក
និងបោកប្រាស ហើយមានដួងចិត្តក្នុងការធ្វើការអាក្រក់។[30]ពួកគេនិយាយដើមគ្នា និយាយមួលបង្កាច់គ្នា ហើយជាអ្នកស្អប់ព្រះជាម្ចាស់ថែមទៀតផង។
ពួកគេប្រើអំពើហិង្សា មានភាពក្រអឺតក្រទម និងពេញដោយអំនួត។ ពួកគេបង្កើតឲ្យមានការអាក្រក់ផ្សេងៗ ហើយពួកគេមិនស្តាប់បង្គាប់ឪពុកម្តាយ។
[31]ពួកគេគ្មានការយល់ដឹង ពួកគេជាមនុស្សដែលមិនអាចទុកចិត្តបាន គ្មានសេចក្តីស្រឡាញ់ដូចមនុស្សធម្មតា ហើយគ្មានមេត្តាថែមទៀតផង។
[32]ពួកគេដឹងអំពីការដាក់ទោសរបស់ព្រះជាម្ចាស់ថា អស់អ្នកដែលប្រព្រឹត្តអំពើបែបនេះសមនឹងស្លាប់ ហើយពួកគេមិនត្រឹមតែប្រព្រឹត្តខ្លួនឯងប៉ុណ្ណោះទេ ថែមទាំងពេញចិត្ត
នឹងពួកអ្នកដែលប្រព្រឹត្តអំពើទាំងនោះទៀតផង។

Romans 1:1

ប៉ូល
នៅក្នុងភាសារបស់អ្នក
អាចនឹងមានរបៀបជាក់លាក់ក្នុងការណែនាំអ្នកនិពន្ធសំបុត្រ។
អ្នកក៏ត្រូវតែបរិយាយផងដែរនៅក្នុងខដូចគ្នានេះ
ពីមនុស្សដែលលោកប៉ូលបានសរសេរសំបុត្រទៅកាន់ពួកគេ
បានហៅឲ្យធ្វើជាសាវក ហើយបានញែកខ្ញុំដោយឡែកសម្រាប់ដំណឹងល្អរបស់ព្រះជាម្ចាស់
អ្នកអាចបកប្រែឃ្លានេះនៅក្នុងទម្រង់សកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានហៅខ្ញុំឲ្យធ្វើជាសាវក
ហើយជ្រើសខ្ញុំដើម្បីនាំដំណឹងល្អប្រាប់មនុស្សទាំងអស់»។
បានហៅ
ពាក្យនេះ មានន័យថា ព្រះជាម្ចាស់បានកំណត់ ឬ
បានជ្រើសរើសមនុស្សឲ្យធ្វើជាកូនស្ងួនភ្ងារបស់ទ្រង់ ឲ្យធ្វើជាអ្នកបម្រើរបស់ទ្រង់
ហើយជាអ្នកប្រកាសរាជសាររបស់ទ្រង់អំពីសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូគ្រិស្ត។
នេះគឺជាដំណឹងល្អ ដែលព្រះបានសន្យាតាមរយៈព្យាការីរបស់ព្រះអង្គនៅក្នុងបទគម្ពីរដ៏វិសុទ្ធ
ព្រះជាម្ចាស់បានសន្យាជាមួយរាស្ត្ររបស់ព្រះ
ថាទ្រង់នឹងតាំងព្រះរាជ្យរបស់ទ្រង់ឡើង។
ព្រះអង្គបានប្រាប់ពួកព្យាការីឲ្យសរសេរពាក្យសន្យាទាំងនេះនៅក្នុងព្រះគម្ពីរ។
អំពីព្រះបុត្រារបស់ព្រះអង្គ
ឃ្លានេះសំដៅលើ «ដំណឹងល្អរបស់ព្រះជាម្ចាស់» ដំណឹងល្អដែល
ព្រះជាម្ចាស់បានសន្យាចាត់ព្រះរាជបុត្រារបស់ទ្រង់មកក្នុងពិភពលោកនេះ។
ព្រះបុត្រា
នេះគឺជាឋាន: យ៉ាងសំខាន់របស់ព្រះយេស៊ូ ជាព្រះរាបុត្រារបស់ព្រះជាម្ចាស់។
ដែលបានប្រសូតពីពូជពង្សរបស់ព្រះបាទដាវីឌ
នៅទីនេះពាក្យថា «សាច់ឈាម» សំដៅទៅដល់ រាងកាយធម្មជាតិ។
ការបកប្រែរបៀបផ្សេងទៀត «ដែលជាពូជពង្សរបស់ព្រះបាទដាវីឌ
ផ្នែកសាច់ឈាម» ឬ «អ្នកដែលបានកើតក្នុងគ្រួសាររបស់ព្រះបាទដាវីឌ»។

Romans 1:4

ប្រយោគភ្ជាប់
នៅទីនេះលោកប៉ូលមានប្រសាសន៍អំពីកាតព្វកិច្ចរបស់គាត់ក្នុងការថ្លែងព្រះបន្ទូល។
ដោយសារការរស់ពីសុគតឡើងវិញ
«ដោយការប្រោសទ្រង់ឲ្យរស់ឡើងវិញ ពីក្នុងចំណោមមនុស្ស ដែលបានស្លាប់»។
ព្រះអង្គបានប្រកាសថា ជាព្រះបុត្រានៃព្រះ
ពាក្យថា «ព្រះអង្គ» សំដៅដល់ព្រះយេស៊ូគ្រិស្ត។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត
«ព្រះជាម្ចាស់បានប្រកាសថាព្រះអង្គជាព្រះបុត្រានៃព្រះ»។
ព្រះបុត្រានៃព្រះ
ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ បានបង្ហាញជាភស្តុតាងថា ទ្រង់ពីមុន
និងពេលឥឡូវនេះ «ជាព្រះបុត្រានៃព្រះ» នេះគឺជាឋាន:ដ៏សំខាន់របស់ព្រះយេស៊ូ។
ព្រះវិញ្ញាណដ៏វិសុទ្ធ
អង្គនេះសំដៅទៅដល់ព្រះវិញ្ញាណដ៏វិសុទ្ធ។
យើងបានទទួលព្រះគុណ និងភាពជាសាវក
ព្រះជាម្ចាស់បានប្រទានអំណោយដល់លោកប៉ូល ជាសាវក។
អ្នកក៏អាចបកប្រែឃ្លានេះជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានធ្វើអោយខ្ញុំក្លាយជាសាវ័ក។ នេះគឺជាឯកសិទ្ធិដ៏វិសេសមួយ»
យើង
នៅទីនេះពាក្យ «យើង» សំដៅដល់ លោកប៉ូល និងដល់សាវកដទៃទៀត
ដែលដើរតាមព្រះយេស៊ូ ប៉ុន្តែ មិនរាប់បញ្ចូលអ្នកជឿក្នុងក្រុមជំនុំ
ក្នុងក្រុងរ៉ូមនេ ះទេ។
សម្រាប់អ្នកដែលស្តាប់បង្គាប់ដោយជំនឿនៅក្នុងចំណោមប្រជាជាតិ ដោយសារព្រះនាមព្រះអង្គ
ប៉ូល ប្រើពាក្យថា «នាម ឬ ឈ្មោះ» ជាន័យធៀប ដែលសំដៅដល់ព្រះយេស៊ូ។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីបង្រៀនគ្រប់ជាតិសាសន៍
ទាំងអស់ឲ្យស្តាប់បង្គាប់ ព្រោះក្តីជំនឿរបស់ពួកគេនៅក្នុងទ្រង់» ។

Romans 1:7

ខ្ញុំធ្វើសំបុត្រនេះទៅកាន់បងប្អូនទាំងអស់ដែលនៅក្នុងក្រុងរ៉ូម ដែលជាទីស្រឡាញ់របស់ព្រះជាម្ចាស់
ជាអ្នកដែលព្រះជាម្ចាស់បានហៅឲ្យបានត្រឡប់ជាប្រជារាស្ត្រដ៏វិសុទ្ធ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំសរសេរសំបុត្រនេះ មកកាន់អ្នករាល់គ្នានៅក្នុងក្រុងរ៉ូម
ដែលព្រះជាម្ចាស់ស្រលាញ់ ហើយបានជ្រើសរើសមកជាប្រជារាស្ត្ររបស់ព្រះអង្គ»។
សូមព្រះគុណ និងសេចក្តីសុខសាន្តស្ថិតនៅជាប់ជាមួយអ្នករាល់គ្នា
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មបែបនេះ «សូមព្រះអម្ចាស់ប្រទានព្រះគុណ
និងសេចក្តីសុខសាន្ត» ឬ «សូមព្រះអម្ចាស់ប្រទានពរដល់អ្នក
និងប្រទានសេចក្តីសុខសាន្តដល់អ្នក»។
ព្រះជាម្ចាស់ជាព្រះបិតានៃយើង
ពាក្យថា «ព្រះបិតា» គឺជាឋាន:ដ៏សំខាន់របស់ព្រះជាម្ចាស់។

Romans 1:8

ពេញពិភពលោកទាំងមូល
ឃ្លានេះមានអត្ថន័យសំដៅដល់ពិភពលោកដែលពួកគេបានស្គាល់រួចមកហើយ
ដែលក្នុងករណីរបស់ពួកវាគឺមានន័យដល់ចក្រភពរ៉ូម។
ដោយសារព្រះអង្គជាទីបន្ទាល់របស់ខ្ញុំ
លោកប៉ូល សង្កត់ធ្ងន់ថា គាត់អធិស្ឋានយ៉ាងអស់ពីចិត្តសម្រាប់ពួកគេ
ហើយព្រះជាម្ចាស់បានព្រះជាម្ចាស់បានស្តាប់ការអធិស្ឋានរបស់លោក។ ពាក្យថា

generated on Wed Sep 10 16:16:32 2025

«ដោយសារ» ជាញឹកញាប់មិនត្រូវបានបកប្រែទេ។
ខ្ញុំបម្រើខាងវិញ្ញាណ
វិញ្ញាណរបស់មនុស្ស គឺជាផ្នែកមួយរបស់គេ ដែលគេអាចស្គាល់ព្រះអម្ចាស់
និងជឿក្នុងទ្រង់។
ដំណឹងល្អនៃបុត្រារបស់ព្រះអង្គ
ដំណឹងល្អនៃព្រះគម្ពីរ គឺថា ព្រះបុត្រារបស់ព្រះជាម្ចាស់បានប្រទានអង្គទ្រង់
ជាព្រះសង្គ្រោះរបស់ពិភពលោកនេះ។
បុត្រា
នេះគឺជាឋាន: ដ៏សំខាន់របស់ព្រះយេស៊ូ ព្រះបុត្រារបស់ព្រះជាម្ចាស់។
(សូមមើល:guidelines-sonofgodprinciples)
ខ្ញុំបានដំណាលប្រាប់
«ខ្ញុំទូលព្រះជាម្ចាស់អំពីអ្នករាល់គ្នា»។
ខ្ញុំតែងតែទូលសូមក្នុងសេចក្តីអធិស្ឋានរបស់ខ្ញុំ... តាមវិធីណាក៏ដោយ យ៉ាងហោចណាស់
គឺខ្ញុំចង់ទៅជួបអ្នករាល់គ្នា ប្រសិនបើ ព្រះសព្វព្រះហឫទ័យ
«គ្រប់ពេលដែលខ្ញុំអធិស្ឋាន
ខ្ញុំទូលសូមព្រះអម្ចាស់ថា...នៅទីបំផុត...សូមឲ្យខ្ញុំបានមកជួបសួរសុខទុក្ខអ្នករាល់គ្នា»។
តាមវិធីណាក៏ដោយ
«តាមគ្រប់មធ្យោបាយដែលព្រះជាម្ចាស់អនុញ្ញាត»។
ជាចុងក្រោយ
«តាមយថាហេតុ» ឬ «ជាចុងបញ្ចប់»។
ដោយព្រះហឫទ័យរបស់ព្រះ
«ព្រោះព្រះជាម្ចាស់សម្រេចការនោះ»។
Romans 1:11
ប្រយោគភ្ជាប់
លោកប៉ូលបន្តការប្រកាសរបស់លោក ទៅកាន់មនុស្សនៅក្រុងរ៉ូម
ដោយបញ្ជាក់ពីគោលបំណងរបស់គាត់ដែលចង់ឃើញពួកគេផ្ទាល់នឹងភ្នែក។
ខ្ញុំចង់ជួបអ្នករាល់គ្នា
«ពីព្រោះខ្ញុំពិតជាចង់ឃើញអ្នករាល់គ្នា»។
អំណោយទានខាងវិញ្ញាណខ្លះចម្រើនកម្លាំងដល់អ្នករាល់គ្នា
លោកប៉ូល ចង់ចម្រើនកម្លាំងខាងវិញ្ញាណរបស់អ្នកជឿនៅក្រុងរ៉ូម។
ការបកប្រែរបៀបផ្សេងទៀត: «អំណោយទាននឹងជួយអ្នកឲ្យលូតលាស់វិញ្ញាណ»។
(សូមមើល:)
ខ្ញុំចង់ឲ្យអ្នករាល់គ្នាបានទទួលការលើកទឹកចិត្តនៅក្នុងចំណោមអ្នករាល់គ្នា
តាមរយៈជំនឿរវាងគ្នានឹងគ្នា ជំនឿរបស់អ្នករាល់គ្នា និងខ្ញុំដែរ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំមានន័យថា ខ្ញុំចង់ឲ្យយើងទាំងអស់គ្នាលើកទឹកចិត្តគ្នាទៅវិញទៅមក
ដោយចែករំលែកបទពិសោធន៍របស់យើង អំពីជំនឿក្នុងព្រះយេស៊ូ»។ (សូមមើល:)
Romans 1:13
ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាមិនដឹង
លោកប៉ូល សង្កត់ធ្ងន់ថា លោកចង់ឲ្យពួកគេបានទទួលដំណឹងនេះ។
អ្នកអាចបកប្រែតាមទម្រង់ដែលប្រើ
ប្រយោគបដិសេធស្នូននៅក្នុងទម្រង់ប្រយោគស្របវិញ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំចង់អោយអ្នករាល់គ្នាដឹង»។ (សូមមើល:figs-doublenegatives)
បងប្អូន
នៅទីនេះមានន័យសំដៅដល់គ្រិស្តបរិស័ទ រួមទាំងបុរស និងស្ត្រី។
ប៉ុន្តែ មានអ្វីមួយរារាំងខ្ញុំរហូតមកដល់ពេលនេះ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត
«អ្វីមួយដែលតែងតែរារាំងខ្ញុំ»។ (សូមមើល:)
ដើម្បីកុំឲ្យខ្ញុំអាចប្រមូលផលនៅក្នុងចំណោមអ្នករាល់គ្នាបាន
ពាក្យ «ផល» គឺជាការប្រៀបធៀបដែលតំណាងឲ្យមនុស្សដែលនៅក្រុងរ៉ូម
ដែលលោកប៉ូលចង់ឲ្យគេបានទទួលដំណឹងល្អ។
«ដែលមានមនុស្សជាច្រើនក្នុងចំណោមអ្នករាល់គ្នាអាចនឹងមានជំនឿក្នុងព្រះយេស៊ូ»។
ដូចដែលខ្ញុំធ្លាប់ធ្វើនៅក្នុងចំណោមសាសន៍ដទៃ
នៅទីនេះលោកប៉ូល បានប្រើការបញ្ជាក់បន្ថែមដើម្បីធ្វើការសង្កត់ធ្ងន់។
ការបកប្រែរបៀបផ្សេងទៀត:
«គឺមានមនុស្សជាច្រើនក្នុងសាសន៍ដទៃដែលបានចូលមកទទួលជឿដំណឹងល្អ»។
(សូមមើល:)
ខ្ញុំជាប់ជំពាក់ទាំងពីរ
ការប្រើពាក្យប្រៀបធៀប «ទាំងពីរ» លោកប៉ូល និយាយអំពីកិច្ចការបម្រើព្រះ
ដូចជាព្រះជាម្ចាស់ជាម្ចាស់បំណុលរបស់លោក។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំត្រូវតែនាំដំណឹងល្អទៅ...» (សូមមើល:)
Romans 1:16
ដ្បិត ខ្ញុំមិនខ្មាសដោយព្រោះដំណឹងល្អឡើយ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់វិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំជឿជាក់ទាំងស្រុងក្នុងដំណឹងល្អ»។ (សូមមើល:)
គឺជាព្រះចេស្តានៃព្រះជាម្ចាស់ ដើម្បីសង្គ្រោះមនុស្សគ្រប់គ្នាដែលជឿ
នៅទីនេះពាក្យ «អ្នកជឿ»
មានន័យថាអ្នកដែលដាក់សេចក្តីជំនឿរបស់គេលើព្រះគ្រិស្ត។
ការបកប្រែរបៀបផ្សេងទៀត: «គឺតាមរយៈដំណឹងល្អ ដែលព្រះចេស្តានៃព្រះ
សង្គ្រោះមនុស្សគ្រប់គ្នាដែលដាក់សេចក្តីជំនឿរបស់ពួកគេលើព្រះគ្រិស្ត»។
ជំបូងសាសន៍យូដា ហើយនិងសាសន៍ក្រិក
«គឺសម្រាប់ទាំងសាសន៍យូដា និងសម្រាស់សាសន៍ក្រិក»។
ជំបូង
នៅទីនេះពាក្យ «ជំបូង» មានន័យថាការមកដល់មុនគេ នៅក្នុងពេលវេលាកំណត់។
នៅក្នុងនោះ
នៅទីនេះពាក្យ «នោះ» សំដៅទៅដល់ ដំណឹងល្អ។
លោកប៉ូលពន្យល់ពីមូលហេតុដែលលោកទុកចិត្តទាំងស្រុងក្នុងដំណឹងល្អ។
គឺសេចក្តីសុចរិតរបស់ព្រះជាម្ចាស់បានបើកសម្តែងពីជំនឿទៅកាន់ជំនឿ
លោកប៉ូលមានប្រសាសន៍អំពីសារនៃដំណឹងល្អ
ដែលព្រះជាម្ចាស់អាចនឹងបង្ហាញដល់មនុស្សក្នុងភាពជាសាច់ឈាម។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានមានព្រះបន្ទូលមកយើងថា គឺដោយសារសេចក្តីជំនឿ
ពីដើមរហូតដល់ទីបញ្ចប់ ដែលមនុស្សបានមកជាសុចរិត»។ (សូមមើល:)
ដូចជាសេចក្តីដែលបានចែងទុក
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត
«ដូចជាអ្នកណាម្នាក់ដែលបានសរសេរក្នុងព្រះគម្ពីរ»។ (សូមមើល:)
មនុស្សសុចរិតនឹងរស់នៅដោយជំនឿ
នៅទីនេះពាក្យ «សុចរិត» សំដៅដល់អ្នកណាដែលទុកចិត្តលើេព្រះជាម្ចាស់។
ក្នុងឃ្លាថាការបកប្រែរបៀបផ្សេងទៀត: «គឺអស់អ្នកដែលទុកចិត្តលើព្រះជាម្ចាស់
ថាគេរំពឹងទុកយ៉ាងត្រឹមត្រូវជាមួយនឹងទ្រង់
ហើយពួកគេនឹងមានជីវិតដ៏អស់កល្ប»។ (សូមមើល:)
Romans 1:18
ប្រយោគភ្ជាប់
លោកប៉ូលបង្ហាញព្រះពិរោធដ៏ខ្លាំងក្លារបស់ព្រះជាម្ចាស់ ទាស់នឹងមនុស្សបាប។
ព្រះពិរោធរបស់ព្រះជាម្ចាស់បានបង្ហាញ
លោកប៉ូល ពន្យល់អំពីមូលហេតុដែលមនុស្សត្រូវការឮដំណឹងល្អ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម ។ ការបកប្រែរបៀបផ្សេងទៀត:
«ពីព្រោះព្រះជាម្ចាស់ទ្រង់ បង្ហាញព្រះពិរោធរបស់ទ្រង់»។ (សូមមើល:)
ប្រឆាំង
«ទាស់ ជំទាស់»។
មនុស្សដែលមិនគោរពប្រតិបត្តិដល់ព្រះអង្គ និងមនុស្សទុច្ចរិត
«មនុស្សទាំងអស់ដែលគ្មានព្រះ
ហើយនិងអំពើទុច្ចរិតទាំងឡាយដែលមនុស្សប្រព្រឹត្ត»។
លាក់សេចក្តីពិត
នៅទីនេះពាក្យ «សេចក្តីពិត» សំដៅដល់ព័ត៌មានពិតអំពីព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ការលាក់ព័ត៌មានពិតអំពីព្រះជាម្ចាស់»។
(សូមមើល:)
គឺដោយសារព្រះជាម្ចាស់បានបើកសម្តែងឲ្យពួកគេបានដឹង
ឺអ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត
«ពួកគេអាចដឹងអំពីព្រះជាម្ចាស់ ពីព្រោះតែអ្វីដែលពួកគេអាចមើលឃើញ»។
(សូមមើល:)
ដោយសារព្រះជាម្ចាស់បានបំភ្លឺពួកគេ
នៅទីនេះពាក្យ «បានបំភ្លឺពួកគេ»
មានន័យថាព្រះជាម្ចាស់បានបង្ហាញពួកគេពីសេចក្តីពិតអំពីទ្រង់។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រោះព្រះជាម្ចាស់បានបង្ហាញគ្រប់គ្នានូវអ្វីដែលទ្រង់សព្វព្រះទ័យឲ្យគេដឹង»។
Romans 1:20

សណ្ឋានដែលមិនអាចមើលឃើញរបស់ទ្រង់បានបង្ហាញមកយ៉ាងច្បាស់
លោកប៉ូល ពន្យល់ពីរបៀបដែលព្រះជាម្ចាស់បរិយាយពីព្រះអង្គទ្រង់
ទៅដល់មនុស្សជាតិ។
នៅពេលដែលយើងក្រឡេកទៅមើលកិច្ចការដែលព្រះជាម្ចាស់បានបង្កើត
នោះយើងអាចយល់បានអំពីព្រះជាម្ចាស់។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់បែបនេះថា
«ពីព្រោះពេលដែលយើងឃើញកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងធម្មជាតិ
យើងចាប់ផ្តើមយល់ពីអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យ»។ (សូមមើល:)
លោកីយ៍
ពាក្យនេះសំដៅដល់មេឃ និង ផែនដី និងរបស់ផ្សេងទៀតដែលមាននៅក្នុងនោះ។
ពួកគេបានស្គាល់ព្រះជាម្ចាស់តាមរយៈអ្វីៗដែលទ្រង់បានបង្កើត
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មរបៀបនេះថា
«មនុស្សអាចដឹងពីព្រះជាម្ចាស់តាមរយៈការមើលទៅលើអ្វីៗដែលទ្រង់បានបង្កើត»។
សណ្ឋានតាំងពីដំបូង
«គុណសម្បត្តិ និងលក្ខណសម្បត្តិទាំងអស់របស់ព្រះជាម្ចាស់» ឬ
«អ្វីៗទាំងអស់អំពីព្រះជាម្ចាស់ដែលធ្វើអោយទ្រង់គឺជាព្រះ»។
មនុស្សទាំងនេះមិនមានការអភ័យទោសទេ
«មនុស្សទាំងនេះមិនអាចនឹងនិយាយថា ពួកគេមិនបានដឹងនោះទេ»។
ពីព្រោះភាពល្ងង់ខ្លៅនៅក្នុងគំនិតរបស់ពួកគេ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានចាប់ផ្តើមដោយគិតរឿងល្ងីល្ងើ»។ (សូមមើល:)
មនសិការនៅក្នុងចិត្តរបស់ពួកគេបានងងឹត
នៅទីនេះពាក្យ «ងងឹត» គឺជាការប្រៀបធៀប
ដែលសំដៅដល់ការខ្វះការយល់ដឹងរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមិនអាចទទួលយល់នូវអ្វីដែលព្រះចង់អោយពួកគេយល់នោះទេ»។
Romans 1:22
ពួកគេគិតថាពួកគេជាមនុស្សឆ្លាត ប៉ុន្តែ ពួកគេគឺជាមនុស្សល្ងង់វិញ
«ពេលដែលពួកគេគិតថាពួកគេមានប្រាជ្ញា
ពួកគេត្រឡប់មកជាមនុស្សល្ងង់ទៅវិញ»។
ពួកគេ...ពួកគេ
គឺពួកមនុស្សដែលនៅក្នុង ១:១៨
បូរសិរីល្អនៃព្រះដែលមិនចេះពុករលួយ
«ប្តូរសេចក្តីពិត ដែលថាព្រះជាម្ចាស់ពេញដោយសិរីល្អ និងមិនដែលស្លាប់» ឬ
«ឈប់ជឿថាព្រះជាម្ចាស់ពេញដោយសិរីល្អ និងមិនដែលស្លាប់»។
ទៅដូចជារូបចម្លាក់នៃ
«ហើយផ្ទុយមកវិញពួកគេជ្រើសរើសយកការថ្វាយបង្គំរូបចំលាក់នានា ដូចជា»។
មនុស្សដែលតែងតែពុករលួយ
«ភាពជាមនុស្សដែលតែងតែស្លាប់»។
បក្សាបក្សី សត្វជើងបួន និងសត្វលូនវា
សត្វចតុបាតដែលដើរនិងជើងនិងសត្វលូនវា «ឬ ដូចជាបក្សាបក្សី
ពពួកសត្វដែលមានជើងបួន ឬ ពពួកសត្វលូនវា»។
Romans 1:24
ហេតុដូច្នេះហើយ
«ពីព្រោះការនេះ»
ព្រះជាម្ចាស់បានប្រគល់ពួកគេទៅក្នុង
«ព្រះជាម្ចាស់អនុញ្ញាតឲ្យពួកគេធ្លាក់ទៅក្នុង..»
ពួកគេ... របស់ពួកគេ...ខ្លួនរបស់ពួកគេ...ពួកគេ
ជា «ប្រភេទមនុស្ស» នៅក្នុង ១:១៨
ចិត្តស្រើបស្រាលដែលស្រែកឃ្លានភាពមិនស្អាត
នៅទីនេះពាក្យ «ចិត្តស្រើបស្រាល» គឺន័យដូចគ្នា
ដែលបង្ហាញការអាក្រក់ដែលពួកគេចង់ធ្វើ។ ការបកប្រែរបៀបផ្សេងទៀត:
«ភាពមិនបរិសុទ្ធខាងសីលធម៌ដែលពួកគេចង់បានយ៉ាងខ្លាំង»។
រូបកាយរបស់ពួកគេត្រូវបានទទួលការមើលងាយនៅក្នុងចំណោមពួកគេទៅវិញ
នេះគឺជាការសម្រាលពាក្យ ដែលមានន័យថា
ពួកគេបានពាក់ពន្ធ័នឹងការប្រព្រឹត្តអំពើអសីលធម៌ផ្នែកភេទ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយពួកគេបានប្រព្រឹត្តអំពើអសីលធម៌ខាងផ្លូវភេទ»។
ដែលថ្វាយបង្គំ និងបម្រើអ្វីៗដែលត្រូវបានបង្កើតឡើង
នៅទីនេះពាក្យ «អ្វីៗដែលបានបង្កើតឡើង»
សំដៅដល់អ្វីៗដែលជាការបង្កើតរបស់ព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានថ្វាយបង្គំរបស់នានាដែលព្រះជាម្ចាស់បានបង្កើតឡើង»។ (សូមមើល:)
ជាជាង
«ជាជាង»
Romans 1:26
នេះ
«អំពើបាបនៃការថ្វាយបង្គំរូបព្រះ និងអំពើបាបនៃទំនាក់ទំនងផ្លូវភេទ»។
ព្រះជាម្ចាស់ប្រគល់ពួកគេឲ្យទៅ
«ព្រះជាម្ចាស់អនុញ្ញាតឲ្យពួកគេធ្លាក់ទៅក្នុង...»
តាមតុណ្ហាថោកទាប
«ចំណង់ផ្លូវភេទដែលគួរឲ្យខ្មាសអៀន»។
សម្រាប់មនុស្សស្រីរបស់ពួកគេ
«ដោយសារតែមនុស្សស្រីរបស់ពួកគេ»។
ពួកគេបានប្តូរទំនាក់ទំនងបែបធម្មជាតិ ទៅរបៀបដែលខុសពីធម្មជាតិវិញ
ឃ្លា «ពួកគេបានប្តូរទំនាក់ទំនងបែបធម្មជាតិ»
នេះជាការសម្រាលពាក្យសម្រាប់ភាពអសីលធ៌មខាងផ្លូវភេទ។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេចាប់អនុវត្តការមានទំនាក់ទំនងផ្លូវភេទក្នុងរបៀបដែលព្រះជាម្ចាស់មិនបានអនុញ្ញាត»។
(សូមមើល:)
បុរសក៏បោះបង់ចោលទំនាក់ទំនងបែបធម្មជាតិចោលដែរ
នៅទីនេះឃ្លា «ទំនាក់ទំនងបែបធម្មជាតិ» ជាការសម្រាលពាក្យ
សំដៅទៅដល់មនុស្ស ហើយនឹងទំនាក់ទំនងផ្លូវភេទ។ ការបកប្រែរបៀបផ្សេងទៀត:
«បុរសជាច្រើនបានឈប់មានទំនាក់ទំនងផ្លូវភេទតាមបែបធម្មជាតិជាមួយមនុស្សស្រី»។
(សូមមើល:)
បែរជាមានការស្រើបស្រាលជាមួយប្រុសគ្នាឯងទៅវិញ
«ការមានចំណង់ផ្លូវភេទខ្លាំង»។
មិនសមរម្យ
«ដែលអាប់កេរ្តិ៍ឈ្មោះ» ឬ «ដែលពេញដោយអំពើបាប»។
ដែលនឹងបានទទួលការដាក់ទោសនៅក្នុងពួកគេសមនឹងអំពើដែលពួកគេបានប្រព្រឹត្ត
នៅទីនេះ «នៅក្នុងពួកគេ» សំដៅដល់ «នៅក្នុងរាងកាយរបស់ពួកគេ»
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានដាក់ទោសពួកគេដោយជំងឺនានាក្នុងរាងកាយរបស់ពួកគេ»។
(សូមមើល:)
ការប្រព្រឹត្តអាក្រក់
អាកប្បកិយាដែលអាក្រក់ និង គួរអោយខ្ពើមរអើម។
Romans 1:28
ដោយសារតែពួកគេមិនបានបង្ហាញថាមានព្រះជាម្ចាស់ នៅក្នុងការយល់ដឹងរបស់ពួកគេ
«ពួកគេមិនបានគិតថា ជាការចាំបាច់ក្នុងការស្គាល់ព្រះជាម្ចាស់នោះទេ»។
ពួកគេ... របស់ពួកគេ... ពួកគេ
ពាក្យទាំងអស់នេះសំដៅដល់ «ប្រភេទមនុស្ស» នៅក្នុងខគម្ពីរ ១:១៨។
ពួកគេបានបណ្តោយខ្លួនទៅតាមគំនិតអាក្រក់របស់ពួកគេ
នៅទីនេះ «គំនិតអាក្រក់» មានន័យថា ការគិតតែអំពីរឿងអសីលធម៌។
ការបកប្រែរបៀបផ្សេងទៀត «ព្រះជាម្ចាស់អនុញ្ញាតឲ្យគំនិតរបស់ពួកគេ
ដែលពួកគេបានបំពេញវាដោយភាពមិនសមរម្យ និងគំនិតអសីលធម៌
ឲ្យត្រួតត្រាលើពួកគេទាំងស្រង់»។
ដែលមិនត្រឹមត្រូវ
«ដែលអាប់អោនកេរ្តិ៍ឈ្មោះ» ឬ «ដែលពេញដោយអំពើបាប»។
Romans 1:29
ពួកគេបានពោរពេញទៅដោយ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមានចំណង់យ៉ាងខ្លាំងទៅលើ...» ឬ
«ពួកគេមានចំណង់យ៉ាងខ្លាំងនៅក្នុង...» (សូមមើល:)
ពួកគេពេញដោយការច្រណែន សម្លាប់ ឈ្លោះប្រកែក និងបោកប្រាស
ហើយមានដួងចិត្តក្នុងការធ្វើការអាក្រក់
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សជាច្រើន ជានិច្ចកាលមានការច្រណែនចំពោះនាក់ដទៃ...
ជានិច្ចកាលមានបំណងសម្លាប់មនុស្ស ...
បង្កជម្លោះនិងឈ្លោះប្រកែកក្នុងចំណោមមនុស្ស ...
បោកប្រាស់អ្នកដទៃ ...ការនិយាយដែលពេញដោយការស្អប់ខ្ពើមអ្នកដទៃ»។

generated on Wed Sep 10 16:16:32 2025

និយាយមួលបង្កាច់គ្នា
ការនិយាយបង្កាច់បង្ខូច គឺការនិយាយរឿងមិនពិតពីអ្នកដទៃ
ក្នុងបំណងបង្ខូចកិត្តិយសរបស់គេ។
ពួកគេបង្កើតឲ្យមានការអាក្រក់ផ្សេងៗ
«ពួកគេព្យាយាមគិតរកវិធីថ្មីដើម្បីធ្វើការអាក្រក់ ទៅលើអ្នកដទៃ»។
Romans 1:32
ពួកគេដឹងអំពីការដាក់ទោសរបស់ព្រះជាម្ចាស់
«ពួកគេដឹង ពីរបៀបដែលព្រះជាម្ចាស់ចង់អោយពួកគេរស់នៅ»។
អស់អ្នកដែលប្រព្រឹត្តអំពើបែបនេះ
នៅទីនេះពាក្យ «អនុវត្ត» សំដៅដល់ការបន្ត ឬ
ចំណង់ចំណូលចិត្តដែលមានទៅលើកិច្ចការនានា ដែលជាអំពើអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត «ហើយមនុស្សទាំងនោះ
ដែលរក្សាការប្រព្រឹត្តអំពើដ៏ឃោរឃៅ»។ (សូមមើល:)
សមនឹងស្លាប់
«ស័ក្តសមនឹងស្លាប់»
អំពើបែបនេះ
«ប្រភេទនៃអំពើអាក្រក់ទាំងឡាយ»។
ពួកអ្នកដែលប្រព្រឹត្តអំពើទាំងនោះ
កិរិយាស័ព្ទ «ធ្វើ» សំដៅដល់ការបន្តការអនុវត្តន៍កិច្ចការដែលអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត: «ពួកអ្នកនៅតែរក្សាការប្រព្រឹត្តអំពើអាក្រក់»។
(សូមមើល:)

---

2 [1]ដូច្នេះហើយ អ្នកមិនអាចដោះសារបានទេ អ្នកគឺជាអ្នកដែលនឹងត្រូវជំនុំជម្រះ ចំពោះអ្វីដែលអ្នកបានថ្កោលទោសអ្នកដទៃ អ្នកបានថ្កោលទោសខ្លួនឯងដែរ។
ពីព្រោះអ្នកបានចោទប្រកាន់គេ តែអ្នកបានធ្វើការនោះដូចគេដែរ។[2]ប៉ុន្តែ យើងដឹងថា សេចក្តីជំនុំជម្រះរបស់ព្រះជាម្ចាស់ស្របតាមសេចក្តីពិត
ហើយវានឹងធ្លាក់ទៅលើអ្នកដែលប្រព្រឹត្តបែបនេះដែរ។
[3]ប៉ុន្តែ ចូរពិចារណាការនេះ អ្នកគឺជាអ្នកដែលជំនុំជម្រះអស់អ្នកដែលប្រព្រឹត្តការណាមួយ ហើយអ្នកក៏ធ្វើដូចគេដែរ។
តើអ្នកអាចគេចពីការជំនុំជម្រះរបស់ព្រះជាម្ចាស់បានទេ?[4]ឬ តើអ្នកគិតថា ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ កាលពន្យារការដាក់ទោសរបស់ព្រះអង្គ
ហើយនិងការអត់ធ្មត់របស់ព្រះជាម្ចាស់តិចពេក? តើអ្នកមិនដឹងទេថា សេចក្តីសប្បុរសរបស់ព្រះអង្គគឺដើម្បីឲ្យអ្នកឲ្យប្រែចិត្ត?
[5]ប៉ុន្តែ ដោយសារតែចិត្តរឹងរូសរបស់អ្នក និងចិត្តដែលមិនព្រមប្រែចិត្តរបស់អ្នក ដែលអ្នកបានរក្សាទុកនៅក្នុងអ្នក សម្រាប់ថ្ងៃនៃព្រះពិរោធហើយ
នោះគឺជាថ្ងៃនៃការជំនុំជម្រះដ៏សុចរិតរបស់ព្រះជាម្ចាស់បានបង្ហាញ។[6]ព្រះអង្គនឹងតបស្នងដល់មនុស្សគ្រប់គ្នាតាមរង្វាល់នៃការប្រព្រឹត្តរបស់ពួកគេ។
[7]ចំពោះអស់អ្នកដែលបន្តក្នុងការប្រព្រឹត្តអំពើល្អ គេនឹងបានទទួលការសរសើរ កិត្តិយស និងសេចក្តីមិនពុករលួយ ទ្រង់នឹងប្រទានជីវិតអស់កល្បជានិច្ច។
[8]ប៉ុន្តែ អស់អ្នកណាដែលអាត្មានិយម អ្នកដែលមិនស្តាប់បង្គាប់តាមសេចក្តីពិត ប៉ុន្តែ បែរជាស្តាប់តាមសេចក្តីទុច្ចរិតវិញ សេចក្តីក្រោធ និង ព្រះពិរោធដ៏ខ្លាំងនឹងមកដល់។
[9]ព្រះជាម្ចាស់នឹងនាំទុក្ខលំបាក និងក្តីវេទនាយ៉ាងខ្លាំង មកលើមនុស្សគ្រប់រូប ដែលប្រព្រឹត្តអំពើអាក្រក់ ព្រះអង្គនឹងដាក់ទោសសាសន៍យូដាជំបូង
បន្ទាប់មកសាសន៍ក្រិកផងដែរ។
[10]ប៉ុន្តែ ពាក្យសរសើរ កិត្តិយស និងសេចក្តីសុខសាន្តនឹងមកដល់អស់អ្នកដែលប្រព្រឹត្តអំពើល្អ ទៅកាន់សាសន៍យូដាជំបូង ហើយបន្ទាប់មកសាសន៍ក្រិកផងដែរ។
[11]ព្រោះគ្មានការរើសអើងជាមួយព្រះជាម្ចាស់ឡើយ។[12]អស់អ្នកណាដែលបានធ្វើបាបក្រៅពីក្រឹត្យវិន័យ នឹងត្រូវទោសក្រៅក្រឹត្យវិន័យ
ហើយអស់អ្នកណាដែលធ្វើបាបក្នុងក្រឹត្យវិន័យ នឹងត្រូវទោសនៅក្នុងក្រឹត្យវិន័យដែរ។
[13]ដ្បិត មិនមែនអ្នកដែលឮក្រឹត្យវិន័យទបានសុចរិតនៅចំពោះព្រះជាម្ចាស់ទេ ប៉ុន្តែ អ្នកដែលធ្វើតាមក្រឹត្យវិន័យទេតើ ដែលនឹងបានសុចរិតនោះ។
[14]ព្រោះនៅពេលសាសន៍ដទៃ ពួកគេគ្មានក្រឹត្យវិន័យទេ ពួកគេធ្វើតាមក្រឹត្យវិន័យ តាមច្បាប់ធម្មជាតិ ពួកគេមានក្រឹត្យវិន័យនៅនឹងខ្លួនឯងស្រាប់ហើយ
ទោះបីជាពួកគេគ្មានក្រឹត្យវិន័យក៏ដោយ។
[15]ដោយសារការនេះហើយ បានជាតម្រូវឲ្យពួកគេធ្វើដូច្នេះ ព្រោះក្រឹត្យវិន័យបានសរសេរទុកនៅក្នុងចិត្តរបស់ពួកគេរួចហើយ។
មនសិការរបស់ពួកគេក៏ធ្វើបន្ទាល់ដល់ពួកគេដែរ ហើយគំនិតរបស់គេក៏ចោទប្រកាន់ ឬការពារពួកគេដោយខ្លួនឯង[16]ហើយចំពោះព្រះជាម្ចាស់ផងដែរ។
ការនោះនឹងកើតឡើងនៅថ្ងៃមួយ នៅពេលព្រះជាម្ចាស់នឹងជំនុំជម្រះការសម្ងាត់របស់មនុស្ស អាស្រ័យទៅលើដំណឹងល្អ តាមរយៈព្រះយេស៊ូគ្រិស្ត។
[17]ប៉ុន្តែ ប្រសិនបើ អ្នកហៅខ្លួនឯងថា យូដា ហើយទុកចិត្តលើក្រឹត្យវិន័យ និងអួតនៅក្នុងព្រះជាម្ចាស់[18]ហើយស្គាល់ព្រះហឫទ័យរបស់ព្រះអង្គ និងស្គាល់អ្វីដែលល្អឥតខ្ចោះ
ដោយសារអ្នកបានទទួលសេចក្តីបង្រៀនពីក្រឹត្យវិន័យ[19]ហើយប្រសិនបើ អ្នកជឿជាក់ថាអ្នកខ្លួនឯងជាអ្នកនាំមនុស្សខ្វាក់
ហើយជាពន្លឺដល់អស់អ្នកដែលនៅក្នុងទីងងឹតនោះ[20]ជាអ្នកកែតម្រូវមនុស្សល្ងង់ ឬជាគ្រូដល់កូនតូចៗ ហើយថាអ្នកនៅក្នុងក្រឹត្យវិន័យ បង្កើតឲ្យមានចំណេះដឹង
និងសេចក្តីពិត បើអ៊ីចឹងមែន តើការអាក្រក់អាចកើតមកលើជីវិតរស់នៅរបស់អ្នកយ៉ាងដូចម្តេចកើត?
[21]អ្នកគឺជាអ្នកដែលបង្រៀនអ្នកដទៃ តើអ្នកមិនបង្រៀនខ្លួនឯងទេឬអី? អ្នកគឺជាអ្នកបង្រៀនឲ្យទាស់នឹងការលួច តើអ្នកលួចទេ?[22]អ្នកគឺជាអ្នកដែលនិយាយថា
កុំប្រព្រឹត្តអំពើផិតក្បត់ឲ្យសោះ តើអ្នកប្រព្រឹត្តអំពើផិតក្បត់ទេ? អ្នកគឺជាដែលស្អប់រូបព្រះ តើអ្នកបានលួចពីព្រះវិហារដែរឬទេ?
[23]អ្នកគឺជាអ្នកដែលមានអំនួតនៅក្នុងក្រឹត្យវិន័យ តើអ្នកគោរពកោតខ្លាចព្រះជាម្ចាស់ តាមរយៈការដែលអ្នកធ្វើខុសនឹងក្រឹត្យវិន័យឬអី?[24]ដ្បិត
ដូចសេចក្តីដែលបានចែងទុកមកថា៖ «ព្រះនាមរបស់ព្រះជាម្ចាស់ត្រូវគេមើលងាយនៅក្នុងចំណោមសាសន៍ដទៃ ដោយសារអ្នករាល់គ្នា»។
[25]ការកាត់ស្បែកពិតជាមានប្រយោជន៍ដល់អ្នករាល់គ្នា ប្រសិនបើ អ្នកស្តាប់បង្គាប់តាមក្រឹត្យវិន័យ ប៉ុន្តែ ប្រសិនបើ អ្នកបានធ្វើខុសនឹងក្រឹត្យវិន័យ
នោះការកាត់ស្បែករបស់អ្នកនឹងត្រឡប់ទៅជាមិនកាត់ស្បែកវិញ។[26]ប្រសិនបើ មនុស្សមិនកាត់ស្បែកធ្វើតាមការទាមទាររបស់ក្រឹត្យវិន័យ
តើមិនគួរឲ្យពិចារណាថាគាត់ជាមនុស្សដែលមិនកាត់ស្បែកទៅជាអ្នកកាត់ស្បែកវិញទេឬអី?[27]ហើយតើអ្នកដែលមិនបានកាត់ស្បែកតាំងពីកំណើត គេថ្កោលទោសអ្នក
ដោយសារអ្នកមិនធ្វើតាមក្រឹត្យវិន័យទេឬអី? នេះគឺដោយសារ អ្នកមានក្រឹត្យវិន័យដែលសរសេរ និងមានទាំងការកាត់ស្បែក ប៉ុន្តែ អ្នកនៅតែធ្វើខុសនឹងក្រឹត្យវិន័យ។
[28]គាត់មិនមែនជាសាសន៍យូដា ដែលគ្រាន់តែសំបកក្រៅ ឬកាត់ស្បែកគ្រាន់តែកាត់ស្បែកខាងសាច់ឈាមតែប៉ុណ្ណោះទេ[29]ប៉ុន្តែ គាត់គឺជាសាសន៍យូដាទាំងខាងក្នុង
និងកាត់ស្បែកដែលចេញពីក្នុងចិត្ត និងខាងវិញ្ញាណ មិនមែនដោយតួអក្សរឡើយ។ មនុស្សបែបនេះទើបសមនឹងសរសើរ មិនមែនមកពីមនុស្សទេ
តែមកពីព្រះជាម្ចាស់វិញ។

Romans 2:1
ប្រយោគភ្ជាប់
លោកប៉ូលបានបញ្ជាក់ថា មនុស្សទាំងអស់ជាមនុស្សបាប ហើយបន្តរំលឹកពួកគេថា
មនុស្សទាំងអស់គឺអាក្រក់។
ដូច្នេះហើយ អ្នកមិនអាចដោះសារបានទេ
ពាក្យ «ដូច្នេះហើយ» កំណត់សម្គាល់ពីផ្នែកថ្មីនៃសំបុត្រ។
វាក៏ជាការបង្ហាញប្រយោគបញ្ចប់ ដែលលោកប៉ូលបាននិយាយនៅក្នុងជំពូក
១:៣២។ ការបកប្រែរបៀបផ្សេងទៀត: «ចាប់តាំងពីព្រះជាម្ចាស់នឹងដាក់ទោស
ពួកអ្នកដែលនៅតែប្រព្រឹត្តអំពើបាប
គេមិនអាចដោះសារពីអំពើបាបរបស់គេបានទេ»។ (សូមមើល:)
អ្នកគឺជា
លោកប៉ូលសរសេរនៅទីនេះ លោកបានសំដៅដល់ជនជាតិយូដា
ដែលមានការជជែកតវ៉ាគ្នាជាមួយលោក។ លោកប៉ូលធ្វើដូច្នេះ
ដើម្បីបង្រៀនស្មរបន្ទាល់របស់លោកថាព្រះជាម្ចាស់នឹងដាក់ទោសមនុស្សគ្រប់គ្នាដែលនៅតែបន្តធ្វើបាប
ទោះជាសាសន៍យូដាក្តី ឬសាសន៍ដទៃក្តី។
អ្នក
នៅទីនេះសព្វនាម «អ្នក» គឺជាឯកវចន។
អ្នកគឺជាអ្នកដែលនឹងត្រូវជំនុំជម្រះ

generated on Wed Sep 10 16:16:32 2025

លោកប៉ូលបានប្រើពាក្យ «អ្នក» នៅទីនេះ ដើម្បីស្តីបន្ទោសដល់អ្នកដែលគិតថា
គេអាចធ្វើដូចជាព្រះជាម្ចាស់ ហើយនិងការថ្កោលទោសអ្នកដទៃ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកគ្រាន់តែជាមនុស្ស
ហេតុអ្វីបានជាអ្នកថ្កោលទោសអ្នកដទៃ ហើយនិយាយថា
ពួកគេស័ក្តិសមនឹងសេចក្តីជំនុំជម្រះរបស់ព្រះជាម្ចាស់!»។
ចំពោះអ្វីដែលអ្នកបានថ្កោលទោសអ្នកដទៃ អ្នកបានថ្កោលទោសខ្លួនឯងដែរ
«ប៉ុន្តែ អ្នកបានត្រឹមតែថ្កោលទោសខ្លួនឯងតែប៉ុណ្ណោះ
ពីព្រោះអ្នកបានថ្កោលទោសគេ តែអ្នកបានធ្វើការអាក្រក់នោះដូចគេដែរ»។
ប៉ុន្តែ យើងដឹងថា
នៅទីនេះសព្វនាម «យើង» អាចរួមបញ្ចូលគ្រិស្តបរិស័ទ ជាអ្នកជឿ
និងរួមទាំងសាសន៍យូដា ដែលមិនមែនជាគ្រិស្តបរិស័ទដែរ។
សេចក្តីជំនុំជម្រះរបស់ព្រះជាម្ចាស់ស្របតាមសេចក្តីពិត
នៅទីនេះលោកប៉ូល និយាយអំពី «សេចក្តីជំនុំជម្រះរបស់ព្រះជាម្ចាស់» គឺនៅតែបន្ត
ហើយអាចនឹង «ធ្លាក់» ទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត
«ព្រះជាម្ចាស់នឹងថ្កោលទោសមនុស្សទាំងអស់ដោយសេចក្តីពិត
និងភាពយុត្តិធម៌»។
អ្នកដែលប្រព្រឹត្តបែបនេះដែរ
«មនុស្សដែលធ្វើការដ៏គួរអោយស្អប់ខ្ពើមទាំងនោះ»។
Romans 2:3
ប៉ុន្តែ
«ដូច្នេះ»
ចូរពិចារណាការនេះ
«ចូរគិតពីអ្វីដែលខ្ញុំនឹងប្រាប់ទៅអ្នក»។
អ្នក
ប្រើពាក្យធម្មតាសម្រាប់មនុស្សញាតិ «អ្នកគឺជាអ្នកណា»។
អ្នកគឺជាអ្នកដែលជំនុំជម្រះអស់អ្នកដែលប្រព្រឹត្តិការណ៍ណាមួយ ហើយអ្នកក៏ធ្វើដូចគេដែរ
«អ្នក ជាអ្នកដែលនិយាយ
ថាអ្នកណាម្នាក់ថាស័ក្តិសមនឹងទទួលការជំនុំជម្រះរបស់ព្រះជាម្ចាស់
នៅខណៈពេលដែលអ្នកខ្លួនឯងក៏ប្រព្រឹត្តអំពើដូចគេដែរ»។
តើអ្នកអាចគេចពីការជំនុំជម្រះរបស់ព្រះជាម្ចាស់បានទេ?
ឃ្លានេះគឺការកំណត់សម្គាល់បង្ហាញពីទម្រង់សំណួរដែលបន្ថែមលើការសង្កត់ធ្ងន់លើអត្ថន័យ
អ្នកក៏អាចបកប្រែ ប្រយោគសំណួរនេះ ជាប្រយោគបដិសេធ។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នកពិតជាមិនអាចគេចផុតពីការជំនុំជម្រះរបស់ព្រះជាម្ចាស់បានទេ!»
ឬ តើអ្នកគិតថា ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ កាលពន្យារការដាក់ទោសរបស់ព្រះអង្គ
ហើយនិងការអត់ធ្មត់របស់ព្រះជាម្ចាស់តិចពេក?
នេះគឺកំណត់សម្គាល់បង្ហាញពីទម្រង់សំណួរដែលបន្ថែមលើការសង្កត់ធ្ងន់។
អ្នកក៏អាចបកប្រែប្រយោគសំណួរនេះ ទៅជាប្រយោគបដិសេធ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកមិនគួរធ្វើដូចជាមិនមានបញ្ហាអ្វី
ដែលព្រះជាម្ចាស់សុចរិត ហើយទ្រង់អត់ធ្មត់រងចាំជាយូរ
មុនពេលដែលទ្រង់ដាក់ទោសមនុស្សនោះទេ ដូច្នេះ សេចក្តីសុចរិតរបស់ទ្រង់
នឹងធ្វើឲ្យពួកគេប្រែចិត្ត!»
គិតថា ព្រះហឫទ័យសប្បុរស.... ការអត់ធ្មត់ តិចពេក
«ពិចារណាថាព្រះហឫទ័យសប្បុរស ....ការអត់ធ្មត់មិនសំខាន់» ឬ
«ពិចារណា....មិនល្អ»
តើអ្នកមិនដឹងទេថា សេចក្តីសប្បុរសរបស់ព្រះអង្គគឺដើម្បីឲ្យអ្នកឲ្យប្រែចិត្ត?
នេះគឺកំណត់សម្គាល់បង្ហាញពីទម្រង់សំណួរដែលបន្ថែមលើការសង្កត់ធ្ងន់។
អ្នកក៏អាចបកប្រែប្រយោគនេះ ទៅជារបាយការណ៍ដ៏រឹងមាំមួយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកត្រូវដឹងថា ព្រះជាម្ចាស់បង្ហាញអ្នកថាទ្រង់ល្អ
ដូច្នេះ អ្នកអាចប្រែចិត្ត!»
Romans 2:5
ប្រយោគភ្ជាប់
លោកប៉ូលបន្ត ដើម្បីរំលឹកថាមនុស្សទាំងអស់សុទ្ធតែអាក្រក់។
ប៉ុន្តែ ដោយសារតែចិត្តរឹងរូសរបស់អ្នក និងចិត្តដែលមិនព្រមប្រែចិត្តរបស់អ្នក
លោកប៉ូល បានប្រើការប្រៀបធៀប
ដើម្បីប្រៀបធៀបមនុស្សដែលបដិសេធការស្តាប់បង្គាប់ព្រះជាម្ចាស់
ទៅនឹងអ្វីមួយដែលរឹង ដូចជាដុំថ្ម។ លោកក៏ប្រើការប្រៀបធៀប «ចិត្ត»
ដើម្បីពណ៌នាអំពីមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត: «ព្រោះតែ
អ្នករាល់គ្នាបដិសេធការស្តាប់បង្គាប់ និងការប្រែចិត្ត»។
ចិត្តរឹងរូស និងចិត្តដែលមិនព្រមប្រែចិត្តរបស់អ្នក
នេះជាការសួនដែលអាចយករួមវាបញ្ចូលគ្នាបានដូចជា «ការដែលមិនព្រមប្រែចិត្ត»
អ្នកបានរក្សាទុកនៅក្នុងអ្នក សម្រាប់ថ្ងៃនៃព្រះពិរោធហើយ
ឃ្លា «រក្សាទុក» ជាការប្រៀបប្រដូច
ដែលជាធម្មតាសំដៅដល់មនុស្សដែលប្រមូលទ្រព្យសម្បត្តិរបស់គេ
ហើយទុកដាក់នៅទីកន្លែងដែលមានសុវត្ថិភាព។ លោកប៉ូលមានប្រសាសន៍ថា
ជំនួសពីការប្រមូលទ្រព្យសម្បត្តិទុក
មនុស្សបែរជាប្រមូលការវិនិច្ឆ័យទោសរបស់ព្រះជាម្ចាស់ទុក។
ពួកគេរស់នៅយ៉ាងយូរដោយមិនប្រែចិត្ត ដែលបម្រើការវិនិច្ឆ័យទោស។
ការបកប្រែរបៀបផ្សេងទៀត:
«អ្នករាល់គ្នាកំពុងបង្កើតការដាក់ទាន់កម្មលើការអាក្រក់របស់អ្នករាល់គ្នា»។
សម្រាប់ថ្ងៃនៃព្រះពិរោធហើយ នោះគឺជាថ្ងៃនៃការជំនុំជម្រះដ៏សុចរិតរបស់ព្រះជាម្ចាស់បានបង្ហាញ
ឃ្លាទាំងពីរនេះ សំដៅដល់ថ្ងៃដូចគ្នា។ ការបកប្រែតាមរបៀបផ្សេងទៀត :
«នៅពេលដែលព្រះជាម្ចាស់បង្ហាញគ្រប់គ្នាថា ព្រះអង្គព្រះពិរោធ
ហើយថាព្រះអង្គវិនិច្ឆ័យទោសមនុស្សទាំងអស់យ៉ាងយុត្តិធម៌»។
តបស្នង
«ផ្តល់ឲ្យយ៉ាងយុត្តិធម៌ជារង្វាន់ ឬជាការធ្វើទណ្ឌកម្ម»។
ដល់មនុស្សគ្រប់គ្នាតាមរង្វាល់នៃការប្រព្រឹត្តរបស់ពួកគេ
«យោងទៅតាមអ្វីដែលម្នាក់ៗបានប្រព្រឹត្ត»។
គេនឹងបានទទួល
មានន័យថា
ពួកគេប្រព្រឹត្តក្នុងផ្លូវមួយដែលនាំទៅរកការសម្រេចចិត្តវិជ្ជមានពីព្រះជាម្ចាស់នៅថ្ងៃវិនិច្ឆ័យទោស។
ការសរសើរ កិត្តិយស និងសេចក្តីមិនពុករលួយ
ពួកគេចង់ឲ្យព្រះជាម្ចាស់សរសើរ និងផ្តល់កិត្តិយសដល់ពួកគេ
ហើយពួកគេមិនចង់ស្លាប់នោះទេ។
សេចក្តីមិនពុករលួយ
ពាក្យនេះសំដៅដល់ការពុករលួយរូបកាយ ដែលមិនមែនខាងសីលធម៌ទេ។
Romans 2:8
ប្រយោគភ្ជាប់
ផ្នែកនេះ និយាយអំពីមនុស្សអាក្រក់ដែលមិនមានសាសន៍
ដែលលោកប៉ូលសំដៅសរុបទាំងអ្នកដែលមិនមែនជាសាសន៍យូដា ទាំងសាសន៍យូដា
គឺមានបាបនៅចំពោះព្រះជាម្ចាស់។
អាត្មានិយម
ស្វែងរក «ភាពអាត្មានិយម» (UDB) ឬ
«ខ្វល់ខ្វាយតែជាមួយនឹងអ្វីដែលធ្វើឲ្យពួកគេសប្បាយរីករាយ»។
អ្នកដែលមិនស្តាប់បង្គាប់តាមសេចក្តីពិត ប៉ុន្តែ បែរជាស្តាប់តាមសេចក្តីទុច្ចរិតវិញ
ឃ្លាទាំងពីរនេះ មានន័យដូចគ្នា។ ឃ្លាទីពីរបញ្ជាក់ន័យឲ្យឃ្លាទីមួយ។
សេចក្តីក្រោធ និង ព្រះពិរោធដ៏ខ្លាំងនឹងមកដល់
ពាក្យ «សេចក្តីក្រោធ» និង «ព្រះពិរោធដ៏ខ្លាំង» ឃ្លាទាំងពីរមានអត្ថន័យដូចគ្នា
ហើយបញ្ជាក់អំពីព្រះពិរោធរបស់ព្រះជាម្ចាស់។
សេចក្តីក្រោធ
ទីនេះពាក្យ «សេចក្តីក្រោធ»
គឺជាការប្រៀបធៀបដែលសំដៅលើការវិនិច្ឆ័យទោសដ៏តឹងតែងរបស់ព្រះជាម្ចាស់ចំពោះមនុស្សអាក្រក់។
ទុក្ខលំបាក និងក្តីវេទនាយ៉ាងខ្លាំង
ពាក្យថា «ទុក្ខលំបាក» និង «ក្តីវេទនា» នៅទីនេះ
ពាក្យទាំងពីរនេះមានអត្ថន័យដូចគ្នា ហើយបង្ហាញថា
តើការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ដែលនឹងមកដល់នោះអាក្រក់បែបណា។
ការបកប្រែតាមរបៀបផ្សេងទៀត: «ការវិនិច្ឆ័យទោសដ៏គួរឲ្យខ្លាចនឹងកើតឡើង»។
មកលើមនុស្សគ្រប់រូប
នៅទីនេះ លោកប៉ូល ប្រើពាក្យ «ព្រលឹង» ជាវេចនៈសព្ទ ដែលសំដៅដល់មនុស្ស។
ការបកប្រែតាមរបៀបផ្សេងទៀត: «លើមនុស្សគ្រប់គ្នា»។
ដែលប្រព្រឹត្តអំពើអាក្រក់
«ដែលនៅតែបន្តប្រព្រឹត្តការអាក្រក់»។
សាសន៍យូដាដំបូង បន្ទាប់មកសាសន៍ក្រិកផងដែរ
«ព្រះជាម្ចាស់នឹងកាត់ទោសសាសន៍យូដា ជាមនុស្សដំបូង ហើយបន្ទាប់មក
គឺមនុស្សទាំងអស់ដែលមិនមែនជាសាសន៍យូដា»។
ដំបូង
អាចមានអត្ថន័យថា ទី១) «ជាដំបូងនៅក្នុងពេលវេលាដែលបានកំណត់» ឬ ទី២)
«ភ្លាមៗ»។

generated on Wed Sep 10 16:16:32 2025

Romans 2:10
ប៉ុន្តែ ពាក្យសរសើរ កិត្តិយស និងសេចក្តីសុខសាន្តនឹងមកដល់
«ប៉ុន្តែ ព្រះជាម្ចាស់នឹងប្រទានពាក្យសរសើរ កិត្តិយស និងសេចក្តីសុខសាន្ត»។
អស់អ្នកដែលប្រព្រឹត្តអំពើល្អ
«ការនៅតែបន្តធ្វើអ្វីដែលល្អ»។
ទៅកាន់សាសន៍យូដាដំបូង ហើយបន្ទាប់មកសាសន៍ក្រិកផងដែរ
«ដំបូងព្រះជាម្ចាស់នឹងផ្តល់រង្វាន់ដល់សាសន៍យូដា
ហើយបន្ទាប់មកដល់អស់អ្នកដែលមិនមែនជាសាសន៍យូដា»។
ដំបូង
អាចមានអត្ថន័យ ទី១) «ជាដំបូងនៅក្នុងពេលវេលាដែលបានកំណត់» ឬ ទី២) «ភ្លាមៗ»
ព្រោះគ្មានការរើសអើងជាមួយព្រះជាម្ចាស់ឡើយ
អ្នកអាចបកប្រែឃ្លានេះ ក្នុងទម្រង់វិជ្ជមាន។ ការបកប្រែតាមរបៀបផ្សេងទៀត:
«សម្រាប់ព្រះជាម្ចាស់ ទ្រង់ប្រព្រឹត្តចំពោះមនុស្សទាំងអស់ដូចគ្នា»។
អស់អ្នកណាដែលបានធ្វើបាប
«សម្រាប់អស់អ្នកដែលបានប្រព្រឹត្តបាប»។
ក្រៅពីក្រឹត្យវិន័យ នឹងត្រូវទោសក្រៅក្រឹត្យវិន័យ
លោកប៉ូលនិយាយឡើងវិញ «ដោយមិនមានក្រឹត្យវិន័យ» ដើម្បីបញ្ជាក់ថា
វាមិនមានបញ្ហាអ្វីទេ ប្រសិនបើ មនុស្សមិនស្គាល់ក្រឹត្យវិន័យរបស់លោកម៉ូសេ។
ប្រសិនបើ ពួកគេមានបាប ព្រះជាម្ចាស់នឹងវិនិច្ឆ័យពួកគេ។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកដែលមិនស្គាល់ក្រឹត្យវិន័យរបស់លោកម៉ូសេ
ប្រាកដណាស់ថាគេស្លាប់ខាងវិញ្ញាណ»។
ហើយអស់អ្នកណាដែលធ្វើបាប
«ហើយមនុស្សទាំងអស់ដែលប្រព្រឹត្តអំពើបាប»។
ក្នុងក្រឹត្យវិន័យ នឹងត្រូវទោសនៅក្នុងក្រឹត្យវិន័យដែរ
ព្រះជាម្ចាស់នឹងវិនិច្ឆ័យមនុស្សបាប ដោយយោងទៅតាមក្រឹត្យវិន័យរបស់ទ្រង់។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយអ្នកណាដែលស្គាល់ក្រឹត្យវិន័យរបស់លោកម៉ូសេ
ព្រះជាម្ចាស់នឹងវិនិច្ឆ័យពួកគេដោយយោងទៅតាមក្រឹត្យវិន័យ»។
Romans 2:13
ប្រយោគភ្ជាប់
លោកប៉ូលបន្តឲ្យអ្នកអានដឹងថា
ការគោរពក្រឹត្យវិន័យរបស់ព្រះជាម្ចាស់យ៉ាងល្អឥតខ្ចោះ គឺជាការតម្រូវ
ទោះបីជាមនុស្សទាំងនោះមិនធ្លាប់បានស្គាល់ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ក្តី។
ដ្បិត
ក្នុងខទី ១៤ និង ១៥ កាត់ផ្តាច់សេចក្តីអះអាងដ៏សំខាន់របស់លោកប៉ូល
ដើម្បីផ្តល់ព័ត៌មានបន្ថែមឲ្យអ្នកអាន។ ប្រសិនបើ
អ្នកមានរបៀបដើម្បីសម្គាល់ការអះអាងដូចនេះ នៅក្នុងភាសារបស់អ្នក
អ្នកអាចប្រើវានៅទីនេះបាន។
មិនមែនអ្នកដែលឮក្រឹត្យវិន័យទេ
នៅទីនេះ «ក្រឹត្យវិន័យ» សំដៅដល់ក្រឹត្យវិន័យរបស់លោកម៉ូសេ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមែនអស់អ្នកដែលគ្រាន់តែបានឮក្រឹត្យវិន័យរបស់លោកម៉ូសេទេ»។
ដែលបានសុចរិតនៅចំពោះព្រះជាម្ចាស់
«អ្នកដែលព្រះជាម្ចាស់ចាត់ទុកថាសុចរិត»។
ប៉ុន្តែ អ្នកដែលធ្វើតាមក្រឹត្យវិន័យទេតើ
«ប៉ុន្តែ គឺជាអស់អ្នកដែលគោរពតាមក្រឹត្យវិន័យរបស់លោកម៉ូសេ»។
ដែលនឹងបានសុចរិតនោះ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកដែលព្រះជាម្ចាស់ទទួលយក»។
ព្រោះនៅពេលសាសន៍ដទៃ
ពួកគេគ្មានក្រឹត្យវិន័យទេ...ពួកគេមានក្រឹត្យវិន័យនៅនឹងខ្លួនឯងស្រាប់ហើយ
ឃ្លាថា «ពួកគេមានក្រឹត្យវិន័យនៅនឹងខ្លួនឯងស្រាប់ហើយ» គឺជាភាសានិយាយ
ដែលមានន័យថា ធម្មជាតិនៃមនុស្សទាំងនេះគឺគោរពច្បាប់របស់ព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត:
«នៅក្នុងពួកគេមានច្បាប់របស់ព្រះជាម្ចាស់រួចស្រេចហើយ»។
ទោះបីជាពួកគេគ្មានក្រឹត្យវិន័យក៏ដោយ
នៅទីនេះ «ក្រឹត្យវិន័យ» សំដៅដល់ក្រឹត្យវិន័យរបស់លោកម៉ូសេ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនប្រាកដថាពួកគេមានក្រឹត្យវិន័យដែលព្រះជាម្ចាស់បានផ្តល់ឲ្យលោកម៉ូសេនោះទេ»។
Romans 2:15
ដោយសារការនេះហើយ
«ដោយសារពួកគេបង្ហាញ ការស្តាប់បង្គាប់ពីធម្មជាតិ»។
ជាតម្រូវឲ្យពួកគេធ្វើដូច្នេះ ព្រោះក្រឹត្យវិន័យបានសរសេរទុកនៅក្នុងចិត្តរបស់ពួកគេរួចហើយ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មភាព។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានចារ នៅក្នុងចិត្តរបស់ពួកគេ នូវអ្វីដែលច្បាប់តម្រូវ ឲ្យពួកគេធ្វើ»
ឬ «ព្រះជាម្ចាស់បានបង្ហាញពួកគេ នូវអ្វីដែលច្បាប់តម្រូវ»។
មនសិការរបស់ពួកគេក៏ធ្វើបន្ទាល់ដល់ពួកគេដែរ ហើយគំនិតរបស់គេក៏ចោទប្រកាន់
ឬការពារពួកគេដោយខ្លួនឯង
នៅទីនេះពាក្យ «ធ្វើបន្ទាល់»
សំដៅលើការយល់ដឹងដែលពួកគេបានទទួលពីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ដែលបានចារឹកក្នុងចិត្តរបស់ពួ
ការបកប្រែតាមរបៀបផ្សេងទៀត: «ចូរប្រាប់ពួកគេថា ប្រសិនបើ ពួកគេមិនគោរព
ឬគោរពក្រឹត្យវិន័យរបស់ព្រះជាម្ចាស់»។
នៅពេលព្រះជាម្ចាស់នឹងជំនុំជម្រះ
នេះគឺជាការបញ្ចប់គំនិតរបស់លោកប៉ូល ពី ២:១៣។
ការបកប្រែតាមរបៀបផ្សេងទៀត:
«វានឹងកើតឡើងនៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោស»។
Romans 2:17
ប្រយោគភ្ជាប់
នៅទីនេះចាប់ផ្តើម ការពិភាក្សារបស់លោកប៉ូល
អំពីច្បាប់ដែលនឹងថ្កោលទោសសាសន៍យូដាដែលជាម្ចាស់
ដោយសារតែពួកគមិនបានគោរពប្រតិបត្តិ។
ប្រសិនបើ អ្នកហៅខ្លួនឯងថា យូដា
លោកប៉ូលនិយាយនៅទីនេះ ហាក់ដូចជាលោកសំដៅលើមនុស្សតែម្នាក់។
អ្វីដែលពិតសម្រាប់មនុស្សម្នាក់ គឺពិតសម្រាប់មនុស្សទាំងអស់។ «ឥឡូវនេះ
អ្នកគិតថាខ្លួនរបស់អ្នកថា អ្នកជាសមាជិកនៃសាសន៍យូដា»។
ហើយទុកចិត្តលើក្រឹត្យវិន័យ និងអួតនៅក្នុងព្រះជាម្ចាស់
ឃ្លា «ទុកចិត្តលើក្រឹត្យវិន័យ» គឺជាភាសានិយាយ។
លោកប៉ូលនិយាយអំពីការជឿទុកចិត្តលើក្រឹត្យវិន័យ គឺប្រសិនបើ
អ្នកណាម្នាក់ពិតជាអាចផ្អែកខ្លួនទាំងស្រុងលើច្បាប់។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយអ្នកពឹងផ្អែកទាំងស្រុងទៅលើច្បាប់របស់លោកម៉ូសេ
ហើយមានអំនួតដោយសារព្រះជាម្ចាស់»។
ហើយស្គាល់ព្រះហឫទ័យរបស់ព្រះអង្គ
«ហើយអ្នកស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់»។
បានទទួលសេចក្តីបង្រៀនពីក្រឹត្យវិន័យ
«ព្រោះអ្នករាល់គ្នាបានទទួលការសិក្សានូវអ្វីដែលក្រឹត្យវិន័យរបស់លោកម៉ូសេបានបង្រៀន»។
ហើយប្រសិនបើ អ្នកជឿជាក់ថាអ្នកខ្លួនឯង.... និងសេចក្តីពិត
ប្រសិនបើ ក្នុងភាសារបស់អ្នកមានរបៀបក្នុងការកំណត់ថា ២:១៩-២០
កាត់ផ្តាច់ការអះអាងរបស់លោកប៉ូល ក្នុង ២:១៧ និង ២:២១
អ្នកក៏អាចប្រើវានៅទីនោះបានដែរ។ អ្នកអាចដាក់ ២:១៩-២០ ពីមុខ ២:១៧។
ថាអ្នកខ្លួនឯងជាអ្នកនាំមនុស្សខ្វាក់ ហើយជាពន្លឺដល់អស់អ្នកដែលនៅក្នុងទីងងឹតនោះ
នៅទីនេះ «ជាអ្នកនាំមនុស្សខ្វាក់» និង «ជាពន្លឺ»
ជាការប្រៀបធៀបសម្រាប់មធ្យោបាយក្នុងការជួយមនុស្សដែលមិនអាចមើលឃើញ។
ឃ្លាទាំងពីរនេះ មានអត្ថន័យជាមូលដ្ឋានប្រហាក់ប្រហែលគ្នាខ្លាំងណាស់។
ការប្រើប្រាស់ឃ្លាទាំងពីរនេះ លោកប៉ូលប្រៀបធៀបពីការបង្រៀនអ្នកណាម្នាក់
របស់សាសន៍យូដាអំពីក្រឹត្យវិន័យដើម្បីជួយគេដែលមិនអាចមើលឃើញ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ថាអ្នកខ្លួនឯងដូចជាអ្នកនាំមនុស្សខ្វាក់
ហើយអ្នកដូចជាពន្លឺសម្រាប់អ្នកណាម្នាក់ដែលវង្វងនៅក្នុងភាពងងឹត»។
ជាអ្នកកែតម្រូវមនុស្សល្ងង់
«អ្នកកែតម្រូវអស់អ្នកដែលប្រព្រឹត្តខុស»។
ជាគ្រូដល់កូនតូចៗ
លោកប៉ូល ប្រៀបធៀបមនុស្សទាំងអស់ដែលមិនដឹងអ្វីសោះពីក្រឹត្យវិន័យ
ទៅនឹងក្មេងតូចៗ។ ការបកប្រែតាមរបៀបផ្សេងទៀត: «ហើយអ្នកបង្រៀន
មនុស្សទាំងអស់ដែលមិនស្គាល់ក្រឹត្យវិន័យ»។ (សូមមើល:
ហើយថាអ្នកនៅក្នុងក្រឹត្យវិន័យ បង្កើតឲ្យមានចំណេះដឹង និងសេចក្តីពិត
ការយល់ដឹងនៃសេចក្តីពិត គឺនៅក្នុងច្បាប់ដែលមកពីព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត «ដ្បិតអ្នកពិតប្រាកដថា

generated on Wed Sep 10 16:16:32 2025

អ្នកយល់ពីសេចក្តីពិតដែលព្រះជាម្ចាស់បានប្រទានមកក្នុងក្រឹត្យវិន័យ។
Romans 2:21
អ្នកគឺជាអ្នកដែលបង្រៀនអ្នកដទៃ តើអ្នកមិនបង្រៀនខ្លួនឯងទេឬអី?
លោកប៉ូលប្រើប្រយោគសំណួរ ដើម្បីស្តីបន្ទោសអ្នកស្តាប់របស់លោក។
អ្នកអាចបកប្រែឃ្លានេះនុងទម្រង់ជាប្រយោគអវិជ្ជមាន។
ការបកប្រែតាមរបៀបផ្សេងទៀត: «នៅពេលដែលអ្នកបង្រៀនអ្នកដទៃ
អ្នកមិនបានបង្រៀនខ្លួនឯងនោះទេ!»
អ្នកគឺជាអ្នកបង្រៀនឲ្យទាស់នឹងការលួច តើអ្នកលួចទេ?
លោកប៉ូលប្រើសំណួរ ដើម្បីស្តីបន្ទោសអ្នកស្តាប់របស់លោក។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់ជាប្រយោគដែលសង្កត់ធ្ងន់។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកប្រាប់អ្នកដទៃថាកុំលួច ប៉ុន្តែ
អ្នកបែរជាលួច!»
អ្នកគឺជាអ្នកដែលនិយាយថា កុំប្រព្រឹត្តអំពើផិតក្បត់ឲ្យសោះ តើអ្នកប្រព្រឹត្តអំពើផិតក្បត់ទេ?
លោកប៉ូលប្រើសំណួរ ដើម្បីស្តីបន្ទោសអ្នកស្តាប់របស់លោក។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់ជាប្រយោគដែលសង្កត់ធ្ងន់។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកប្រាប់អ្នកដទៃថា
កុំប្រព្រឹត្តអំពើផិតក្បត់ឲ្យសោះ ប៉ុន្តែ អ្នកប្រព្រឹត្តអំពើផិតក្បត់!»
អ្នកគឺជាអ្នកដែលស្អប់រូបព្រះ តើអ្នកបានលួចពីព្រះវិហារដែរឬទេ?
លោកប៉ូលប្រើសំណួរ ដើម្បីស្តីបន្ទោសអ្នកស្តាប់របស់លោក។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់ជាប្រយោគដែលសង្កត់ធ្ងន់។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកនិយាយថា អ្នកស្អប់រូបព្រះ
ប៉ុន្តែអ្នកលួចពីព្រះវិហារទាំងនោះ!»
លួចពីព្រះវិហារដែរឬទេ
អាចមានអត្ថន័យពីរ ទី១) «លួចរបស់របរពីបរិវេនវិហារទាំងអស់
ដើម្បីលក់ហើយបង្កើតផលប្រយោជន៍» ឬ ទី២)
«មិនធ្វើប្រាក់ទាំងអស់ដែលជារបស់ព្រះជាម្ចាស់ ទៅព្រះវិហារក្រុងយេរូសាឡិម»។
Romans 2:23
អ្នកគឺជាអ្នកដែលមានអំនួតនៅក្នុងក្រឹត្យវិន័យ តើអ្នកគោរពកោតខ្លាចព្រះជាម្ចាស់
តាមរយៈការដែលអ្នកធ្វើខុសនឹងក្រឹត្យវិន័យឬអី?
លោកប៉ូលប្រើសំណួរ ដើម្បីស្តីបន្ទោសអ្នកស្តាប់របស់លោក។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់ជាប្រយោគដែលសង្កត់ធ្ងន់។
ការបកប្រែតាមរបៀបផ្សេងទៀត:
«វាជាអំពើអាក្រក់ដែលអ្នកមានអំនួតចំពោះក្រឹត្យវិន័យ
ដែលក្នុងពេលតែមួយអ្នកមិនបានគោរពក្រឹត្យវិន័យ
និងនាំយកក្តីអាម៉ាស់ដល់ព្រះជាម្ចាស់!»
ព្រះនាមរបស់ព្រះជាម្ចាស់ត្រូវគេមើលងាយនៅក្នុងចំណោមសាសន៍ដទៃ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អំពើអាក្រក់របស់អ្នក នាំភាពអាម៉ាស់ដល់ព្រះជាម្ចាស់
ក្នុងគំនិតរបស់សាសន៍ដទៃ»។
ព្រះនាមរបស់ព្រះជាម្ចាស់
ពាក្យ «ព្រះនាម» គឺជាការប្រៀបធៀបដែលសំដៅដល់អង្គព្រះជាម្ចាស់ទាំងមូល
មិនមែនត្រឹមតែជាព្រះនាមរបស់ទ្រង់នោះទេ។
Romans 2:25
ប្រយោគភ្ជាប់
លោកប៉ូលបន្តបង្ហាញថាព្រះជាម្ចាស់
ទ្រង់វិនិច្ឆ័យសូម្បីតែសាសន៍យូដាដែលមានក្រឹត្យវិន័យ
ដោយសារក្រឹត្យវិន័យរបស់ទ្រង់។
ការកាត់ស្បែកពិតជាមានប្រយោជន៍ដល់អ្នករាល់គ្នា
«ខ្ញុំនិយាយទាំងអស់នេះ ពីព្រោះការកាត់ស្បែកពិតជាប្រយោជន៍ដល់អ្នករាល់គ្នា»។
ប្រសិនបើ អ្នកប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យ
«ប្រសិនបើអ្នកមិនគោរពបទបញ្ជា ដែលបានរកឃើញក្នុងក្រឹត្យវិន័យទេនោះ»។
នោះការកាត់ស្បែករបស់អ្នកនឹងត្រឡប់ទៅជាមិនកាត់ស្បែកវិញ
«វាហាក់ដូច អ្នកមិនបានកាត់ស្បែក»។
មនុស្សមិនកាត់ស្បែក
«មនុស្សដែលមិនបានទទួលពិធីកាត់ស្បែក»។
ធ្វើតាមការទាមទាររបស់ក្រឹត្យវិន័យ
«គោរពនៅអ្វីដែលព្រះជាម្ចាស់បានបញ្ជាក្នុងក្រឹត្យវិន័យ»។
តើមិនគួរឲ្យពិចារណាថាគាត់ជាមនុស្សដែលមិនកាត់ស្បែកទៅជាអ្នកកាត់ស្បែកវិញទេឬអី?
ហើយតើអ្នកដែលមិនបានកាត់ស្បែកតាំងពីកំណើត គេថ្កោលទោសអ្នក
ដោយសារអ្នកមិនធ្វើតាមក្រឹត្យវិន័យទេឬអី?
លោកប៉ូលសួរពីរសំណួរ នៅទីនេះ ដើម្បីបញ្ជាក់ថា
ការកាត់ស្បែកមិនមែនជាអ្វីដែលធ្វើអោយមនុស្សម្នាក់បានសុចរិតនៅចំពោះមុខព្រះជាម្ចាស់នោះទេ។
មិនមែនដោយសារការកាត់ស្បែកខាងរូបកាយនោះទេ...ដែលនឹងវិនិច្ឆ័យអ្នក...គឺក្រឹត្យវិន័យ»។
Romans 2:28
សំបកក្រៅ
ពាក្យនេះសំដៅដល់ ក្បួនច្បាប់របស់សាសន៍យូដា ដូចជាការកាត់ស្បែក
ដែលមនុស្សអាចឃើញ។
សំបកក្រៅខាងសាច់ឈាម
ឃ្លានេះសំដៅដល់ការផ្លាស់ប្តូររាងកាយ ទៅជារូបកាយមនុស្សប្រុស
នៅពេលអ្នកណាម្នាក់ធ្វើការកាត់ស្បែកគាត់។
ខាងសាច់ឈាម
ពាក្យនេះជាវេវចនៈសព្ទ សម្រាប់រូបកាយទាំងមូល ដូចជា «រាងកាយ»
គាត់គឺជាសាសន៍យូដាទាំងខាងក្នុង និងកាត់ស្បែកដែលចេញពីក្នុងចិត្ត
ឃ្លាទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា។ ឃ្លាទីមួយ
«គាត់គឺជាសាសន៍យូដា ទាំងខាងក្នុង» ពន្យល់នៅឃ្លាទីពីរ «ការកាត់ស្បែក
ដែលចេញពីក្នុងចិត្ត»។
ខាងក្នុង
នេះសំដៅដល់ការឲ្យតម្លៃនិងការលើកទឹកចិត្តដល់អ្នកដែលព្រះជាម្ចាស់បានផ្លាស់ប្តូរពួកគេ។
ចេញពីក្នុងចិត្ត
ទីនេះពាក្យ «ចិត្ត» គឺជាការប្រៀបធៀបសម្រាប់មនុស្សខាងក្នុង។
ខាងវិញ្ញាណ មិនមែនដោយតួអក្សរឡើយ
នៅទីនេះពាក្យ «តួអក្សរ» គឺសំដៅដល់ខព្រះគម្ពីរ។
ការបកប្រែតាមរបៀបផ្សេងទៀត: «តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណ
មិនមែនដោយសារអ្នកបានស្គាល់ព្រះគម្ពីរនោះទេ»។
ខាងវិញ្ញាណ
សំដៅដល់ភាពខាងក្នុង ខាងវិញ្ញាណជាផ្នែកមួយរបស់មនុស្សដែល
«ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់» ធ្វើការផ្លាស់ប្តូរ។

---

3 [1]បើដូច្នេះ តើសាសន៍យូដាមានអត្ថប្រយោជន៍អ្វីខ្លះ? ហើយការកាត់ស្បែកមានអត្ថប្រយោជន៍អ្វីខ្លះដែរ?[2]ពួកគេអស្ចារ្យនៅក្នុងគ្រប់ទាំងផ្លូវ។
សាសន៍យូដាជាអ្នកដែលបានប្រទានការបើកសម្តែងមុនគេបង្អស់។
[3]ចុះបើ សាសន៍យូដាខ្លះដែលគ្មានជំនឿយ៉ាងម៉េចដែរ? តើការមិនជឿរបស់ពួកគេធ្វើឲ្យសេចក្តីស្មោះត្រង់របស់ព្រះលែងមានសុពលភាពឬអី?[4]ប្រហែលជាមិនអាចទេ។
ផ្ទុយទៅវិញ ព្រះជាម្ចាស់នៅក្នុងសេចក្តីពិតជានិច្ច ទោះបីជាមនុស្សគ្រប់រូបជាមនុស្សកុហកក៏ដោយ។ ដូចជាមានសេចក្តីចែងទុកមកថា៖
«គេនឹងបានឃើញថាព្រះអង្គសុចរិតនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ ហើយព្រះអង្គនឹងឈ្នះនៅពេលព្រះអង្គចូលទៅក្នុងការកាត់ក្តី។
[5]ប៉ុន្តែ ប្រសិនបើសេចក្តីទុច្ចរិតរបស់យើងបង្ហាញសេចក្តីសុចរិតរបស់ព្រះ តើយើងអាចនិយាយបានយ៉ាងដូចម្តេច? តើយើងអាចនិយាយថា ព្រះជាម្ចាស់ទុច្ចរិត
ក្នុងការនាំយកព្រះពិរោធមកលើយើង? (ខ្ញុំកំពុងប្រើសេចក្តីសំអាងរបស់មនុស្ស)។[6]ប្រហែលជាមិនអាចកើតឡើងបានទេ បើអ៊ីចឹងមែន
តើព្រះជាម្ចាស់ជំនុំជម្រះលោកីយ៍យ៉ាងម៉េចនឹងកើត?
[7]ប៉ុន្តែ ប្រសិនបើ សេចក្តីពិតរបស់ព្រះជាម្ចាស់តាមរយៈការកុហករបស់ខ្ញុំផ្តល់ការសរសើរដល់ព្រះអង្គជាបរិបូរណ៌នោះ ហេតុអ្វីបានជាខ្ញុំត្រូវទទួលរងការកាត់ក្តី
ថាជាមនុស្សមានបាប?[8]ហើយហេតុអ្វីយើងមិននិយាយថា ចូរយើងធ្វើការអាក្រក់ដើម្បីឲ្យការល្អកើតចេញមក? ដូចជាមនុស្សមួយចំនួនបាននិយាយបង្ខូចយើងថាយើង
និយាយដូច្នេះ។ អ្នកទាំងនោះដែលនិយាយដូច្នេះសមតែទទួលការជំនុំជម្រះ។
[9]បើដូច្នេះ តើយើងកំពុងតែដោះសារខ្លួនយើងឬអី? អត់ទេ។ គឺសម្រាប់ទាំងសាសន៍យូដា និងសាសន៍ក្រិក និងពួកគេគ្រប់គ្នា ស្ថិតនៅក្រោមអំពើបាប។
[10]ដូចដែលមានសេចក្តីចែងទុកមកថា៖ «គ្មាននរណាម្នាក់សុចរិតឡើយ សូម្បីតែម្នាក់»។

generated on Wed Sep 10 16:16:32 2025

[11]គ្មាននរណាម្នាក់យល់បានទេ ក៏គ្មាននរណាម្នាក់ដែលស្វែងរកព្រះជាម្ចាស់ដែរ។[12]ពួកគេគ្រប់គ្នាបានបែរចេញពីព្រះ។ ពួកគេបានត្រឡប់ទៅជាឥតបានការ។
គ្មាននរណាម្នាក់ធ្វើល្អឡើយ គ្មានសូម្បីតែម្នាក់។
[13]បំពង់ករបស់ពួកគេបើកចេញពីផ្នូរ។ អណ្តាតរបស់ពួកគេបោកបញ្ឆោត។ ពិសរបស់សត្វពោះស្ថិតនៅក្រោមបបូរមាត់របស់ពួកគេ។
[14]មាត់របស់ពួកគេពេញទៅដោយបណ្តាសារ និងភាពជូរល្វីង។
[15]ជើងរបស់ពួកគេរហ័សនឹងបង្ហូរឈាម។[16]ការបំផ្លាញ និងការឈឺចាប់ស្ថិតនៅលើផ្លូវរបស់ពួកគេ។[17]មនុស្សទាំងនេះ មិនបានស្គាល់ផ្លូវនៃសេចក្តីសុខសាន្តឡើយ។
[18]គ្មានការកោតខ្លាចព្រះជាម្ចាស់នៅក្នុងក្រសែភ្នែករបស់ពួកគេឡើយ។
[19]ឥឡូវនេះ យើងដឹងហើយថា អ្វីដែលក្រឹត្យវិន័យបានចែង គឺនិយាយទៅកាន់មនុស្សដែលនៅក្រោមក្រឹត្យវិន័យ។ ការនេះគឺដើម្បីឲ្យគ្រប់មាត់ទាំងអស់បានបិត
ហើយពិភពលោកទាំងមូលទទួលខុសត្រូវនៅចំពោះព្រះជាម្ចាស់។[20]ការនេះ មិនមែនដោយសារសាច់ឈាមនឹងធ្វើឲ្យយើងបានសុចរិតទេ
គឺដោយធ្វើតាមក្រឹត្យវិន័យនៅក្នុងក្រសែភ្នែករបស់ពួកគេ។ តាមរយៈក្រឹត្យវិន័យ ធ្វើឲ្យមនុស្សស្គាល់អំពើបាប។
[21]ប៉ុន្តែឥឡូវនេះ ក្រៅពីគម្ពីរវិន័យ សេចក្តីសុចរិតរបស់ព្រះជាម្ចាស់បានសំដែងឲ្យឃើញហើយ ដោយមានគម្ពីរវិន័យ និងពួកអ្នកនាំព្រះបន្ទូលធ្វើបន្ទាល់ទៀតផង។[22]គឺថា
សេចក្តីសុចរិតរបស់ព្រះជាម្ចាស់ គឺតាមរយៈជំនឿនៅលើព្រះយេស៊ូគ្រិស្ត សម្រាប់អស់អ្នកដែលជឿព្រោះគ្មានភាពខុសគ្នាទេ។
[23]ព្រោះមនុស្សគ្រប់គ្នាមានបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះជាម្ចាស់[24]ហើយពួកគេបានសុចរិតដោយឥតបង់ថ្លៃ ដោយសារព្រះគុណរបស់ព្រះអង្គ
តាមរយៈការប្រោសលោះ ដែលនៅក្នុងព្រះយេស៊ូគ្រិស្ត។
[25]ព្រោះ ព្រះជាម្ចាស់បានប្រទានព្រះគ្រិស្តយេស៊ូ ធ្វើជាតង្វាយលោះបាប តាមរយៈជំនឿនៅលើព្រះលោហិតរបស់ព្រះអង្គ។ ព្រះអង្គបានប្រទានព្រះគ្រិស្ត
ដើម្បីបង្ហាញពីសេចក្តីយុត្តិធម៌របស់ព្រះអង្គ ដោយសារតែព្រះអង្គបានបំភ្លេចចោលបាបកាលពីកន្លងទៅ[26]នៅក្នុងសេចក្តីអត់ធ្មត់របស់ព្រះអង្គ។ ការទាំងអស់នេះ កើតឡើង
ដើម្បីបង្ហាញពីសេចក្តីសុចរិតរបស់ព្រះអង្គ នៅក្នុងពេលបច្ចុប្បន្នយើងនេះ។ ការនេះ ដើម្បីឲ្យព្រះអង្គអាចបង្ហាញថា ព្រះអង្គផ្ទាល់សច្ចៈ ហើយដើម្បីបង្ហាញថា
ព្រះអង្គប្រទានសេចក្តីសុចរិតដល់នរណាម្នាក់ ដោយសារជំនឿនៅក្នុងព្រះយេស៊ូ។
[27]តើយើងបានអ្វីមកអួត? គ្មានទាល់តែសោះ។ អួតអំពីអ្វី? ពីការប្រព្រឹត្ត? អត់ទេ ប៉ុន្តែ អួតពីជំនឿវិញ។[28]ដូច្នេះ យើងសរុបសេចក្តីយ៉ាងដូច្នេះថា
មនុស្សបានសុចរិតដោយសារជំនឿ មិនមែនដោយសារការប្រព្រឹត្តតាមក្រឹត្យវិន័យទេ។
[29]អ៊ីចឹង តើព្រះជាម្ចាស់ គឺជាព្រះរបស់សាសន៍យូដាតែមួយនោះទេ? ប្រសិនបើ ព្រះអង្គមិនមែនជាព្រះរបស់សាសន៍តែមួយទេ អ៊ីចឹង
តើព្រះអង្គជាព្រះជាម្ចាស់របស់សាសន៍ដទៃដែរ? មែន ព្រះអង្គគឺជាព្រះរបស់សាសន៍ដទៃដែរ។[30]បើដូច្នេះមែន ព្រះអង្គគឺជាព្រះតែមួយ
ព្រះអង្គនឹងធ្វើឲ្យអ្នកកាត់ស្បែកបានសុចរិតដោយសារជំនឿ និងអ្នកដែលមិនកាត់ស្បែកបានសុចរិតដោយសារជំនឿដែរ។
[31]តើយើងចាត់ទុកក្រឹត្យវិន័យជាមោឃៈដោយសារជំនឿ? មិនមែនទេ ផ្ទុយទៅវិញ យើងត្រូវកាន់តាមក្រឹត្យវិន័យដែរ។

Romans 3:1

ប្រយោគភ្ជាប់

លោកប៉ូលប្រកាសពីអត្ថប្រយោជន៍ដែលសាសន៍យូដាមាន
ដ្បិតព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យរបស់ទ្រង់ដល់ពួកគេ។

បើដូច្នេះ តើសាសន៍យូដាមានអត្ថប្រយោជន៍អ្វីខ្លះ?

ហើយការកាត់ស្បែកមានអត្ថប្រយោជន៍អ្វីខ្លះដែរ?

លោកប៉ូលប្រើសំណួរទាំងនេះ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអាន។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«បើដូច្នេះ
សាសន៍យូដានឹងមិនបានទទួលផលអ្វីទាំងអស់ពីសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់
ទោះបីជា ព្រះជាម្ចាស់បានសន្យាជាមួយពួកគេ
ថាពួកគេគួរនឹងបានទទួលវាក៏ដោយ!»

ពួកគេអស្ចារ្យនៅក្នុងគ្រប់ទាំងផ្លូវ

ពាក្យ «ពួកគេ» សំដៅដល់ការចូលរួមជាសមាជិកនៃសាសន៍យូដា។
ការបកប្រែតាមរបៀបផ្សេងទៀត: «ពួកគេមានអត្ថប្រយោជន៍ខ្លាំងណាស់!»

មុនគេបង្អស់

អាចមានន័យថា ទី១) «ដំបូងក្នុងពេលវេលាដែលកំណត់» ឬ ទី២) «ឥឡូវនេះ» ឬ
ទី៣) «ដែលសំខាន់បំផុត»។

សាសន៍យូដាជាអ្នកដែលបានប្រទានការបើកសម្តែងពីព្រះជាម្ចាស់

ពាក្យ «ការបើកសម្តែង» សំដៅដល់ព្រះបន្ទូល
និងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលដែលបានសន្យាជាមួយសាសន៍យូដា»។

Romans 3:3

ចុះបើ សាសន៍យូដាខ្លះដែលគ្មានជំនឿយ៉ាងម៉េចដែរ?

តើការមិនជឿរបស់ពួកគេធ្វើឲ្យសេចក្តីស្មោះត្រង់របស់ព្រះលែងមានសុពលភាពឬអី?

លោកប៉ូលប្រើសំណួរទាំងនេះ ដើម្បីធ្វើឲ្យមនុស្សគិត ថា
«មានសាសន៍យូដាមួយចំនួន ដែលមិនមានជំនឿលើព្រះជាម្ចាស់។
តើយើងគួរសន្និដ្ឋានពីការនេះ
ថាព្រះជាម្ចាស់នឹងមិនបំពេញតាមសេចក្តីសន្យារបស់ទ្រង់ឬ?»

ប្រហែលជាមិនអាចទេ

ឃ្លានេះបដិសេធយ៉ាងដាច់ខាត ថាវាអាចកើតឡើង។ អ្នកក៏អាចប្រើឃ្លានេះ
នៅក្នុងភាសារបស់អ្នកដែរ គឺអ្នកអាចប្រើថា: «ការនេះគឺមិនអាចទៅរួចទេ» ឬ
«ពិតប្រាកដណាស់ថា វាមិនអាច!»

ផ្ទុយទៅវិញ

«យើងគួរនិយាយផ្ទុយពីនេះ»។

ព្រះជាម្ចាស់នៅក្នុងសេចក្តីពិតជានិច្ច

ព្រះជាម្ចាស់គឺស្ថិតក្នុងសេចក្តីពិតជានិច្ច ហើយទ្រង់នឹងរក្សាការសន្យារបស់ទ្រង់។
ក្នុងឃ្លាថា «ព្រះជាម្ចាស់តែងតែបំពេញនូវអ្វីដែលទ្រង់បានសន្យា»។

ទោះបីជាមនុស្សគ្រប់រូបជាមនុស្សកុហកក៏ដោយ

នៅទីនេះលោកប៉ូលបញ្ជាក់បន្ថែមថា
ព្រះជាម្ចាស់តែងតែពិតប្រាកដនឹងព្រះបន្ទូលសន្យារបស់ទ្រង់ គឺថា
«ទោះបីជាមនុស្សគ្រប់គ្នា កុហកក៏ដោយ»។

ដូចជាមានសេចក្តីចែងទុកមកថា

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះគម្ពីរបានសម្រេច ជាមួយនឹងអ្វីដែលខ្ញុំបាននិយាយ»។

គេនឹងបានឃើញថាព្រះអង្គសុចរិតនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ
ហើយព្រះអង្គនឹងឈ្នះនៅពេលព្រះអង្គចូលទៅក្នុងការកាត់ក្តី

ឃ្លាទាំងពីរនេះមានន័យប្រហាក់ប្រហែលគ្នា។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មនុស្សគ្រប់គ្នាត្រូវដឹងថា អ្វីដែលអ្នកនិយាយគឺពិត
ហើយអ្នកត្រូវតែមានជ័យជម្នះក្នុងករណីរបស់អ្នក
នៅពេលដែលមានអ្នកណាម្នាក់ចោទប្រកាន់អ្នក»។

Romans 3:5

ប៉ុន្តែ ប្រសិនបើសេចក្តីទុច្ចរិតរបស់យើងបង្ហាញសេចក្តីសុចរិតរបស់ព្រះ

តើយើងអាចនិយាយបានយ៉ាងដូចម្តេច?

ឃ្លានេះកំណត់បង្ហាញនៅក្នុងទម្រង់សំណួរដើម្បីបន្ថែមអត្ថន័យ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែមនុស្សមួយចំនួនបានប្រឆាំងថា
ពេលដែលយើងធ្វើខុស មនុស្សអាចមើលឃើញបានយ៉ាងងាយ
ពីរបៀបដែលព្រះជាម្ចាស់បានធ្វើយ៉ាងត្រឹមត្រូវ។
តើយើងអាចនិយាយបានយ៉ាងដូចម្តេច?»

តើយើងអាចនិយាយថា ព្រះជាម្ចាស់ទុច្ចរិត ក្នុងការនាំយកព្រះពិរោធមកលើយើង?

ឃ្លានេះកំណត់បង្ហាញនៅក្នុងទម្រង់សំណួរ ដើម្បីសង្កត់ធ្ងន់ថា
«យើងមិនអាចនិយាយថា ព្រះជាម្ចាស់ទុចរិត
នៅពេលដែលទ្រង់ផ្តោលទោសមនុស្ស នោះទេ» ឬ
«ទោះបីជាក្នុងពេលដែលព្រះជាម្ចាស់ ផ្តោលទោសមនុស្សក្តី
ក៏យើងត្រូវតែនិយាយថា ព្រះអង្គសុចរិតដែរ»។

ព្រះពិរោធរបស់ទ្រង់

ពាក្យ «ព្រះពិរោធរបស់ទ្រង់» គឺជាការប្រៀបធៀប

generated on Wed Sep 10 16:16:32 2025

ដែលបញ្ជាក់ពីការថ្កោលទោសរបស់ព្រះជាម្ចាស់។
ខ្ញុំកំពុងនិយាយដោយយោង តាមសេចក្ដីសម្អាងរបស់មនុស្ស
ពាក្យថា «សេចក្ដីសម្អាងរបស់មនុស្ស»
នៅទីនេះសំដៅដល់របៀបដែលមនុស្សនិយាយជាធម្មតា។
ការបកប្រែតាមរបៀបផ្សេងទៀត: «ខ្ញុំកំពុងនិយាយនៅទីនេះ
នូវអ្វីដែលមនុស្សអាចនិយាយជាទូទៅ»។ (សូមមើល:figs-explicit)
តើព្រះជាម្ចាស់ជំនុំជម្រះលោកីយ៍យ៉ាងម៉េចនឹងកើត?
លោកប៉ូលប្រើសំណួរនេះ ដើម្បីបង្ហាញថា ការប្រែកែកប្រឆាំងនឹងដំណឹងល្អ
មិនមែនជាការត្រឹមត្រូវនោះទេ ចាប់តាំងពីសាសន៍យូដា
ជឿថាព្រះជាម្ចាស់នឹងវិនិច្ឆ័យមនុស្សទាំងអស់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«យើងទាំងអស់គ្នាដឹងថា ព្រះជាម្ចាស់នឹងវិនិច្ឆ័យលោកីយ៍ យ៉ាងប្រាកដណាស់!»
លោកីយ៍
ពាក្យ «លោកីយ៍» គឺជាន័យធៀបដែលសំដៅលើមនុស្សដែលរស់លើផែនដីនេះ។
ការបកប្រែតាមរបៀបផ្សេងទៀត: «មនុស្សគ្រប់គ្នានៅលើលោកនេះ»។
Romans 3:7
ប៉ុន្តែ ប្រសិនបើ
សេចក្ដីពិតរបស់ព្រះជាម្ចាស់តាមរយៈការកុហករបស់ខ្ញុំផ្ដល់ការសរសើរដល់ព្រះអង្គជាបរិបូរណ៌នោះ
ហេតុអ្វីបានជាខ្ញុំត្រូវទទួលរងការកាត់ក្តី ថាជាមនុស្សមានបាប?
នៅទីនេះ
លោកប៉ូលប្រមើលមើលពីអ្នកម្នាក់ដែលបន្តបដិសេធដំណឹងល្អរបស់គ្រិស្តបរិស័ទ។
ដែលជាសត្រូវនៃការប្រកែកគ្នា ព្រោះអំពើបាបរបស់គេ
បង្ហាញសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់
នោះព្រះជាម្ចាស់អាចនឹងមិនប្រកាសថាគាត់ជាមនុស្សបាបនៅថ្ងៃវិនិច្ឆ័យទោស
ប្រសិនបើ ឧទាហរណ៍ថា គាត់និយាយកុហក។
ហើយហេតុអ្វីយើងមិននិយាយថា ...ចេញមក?
លោកប៉ូលលើកសំណួរនៃរឿងផ្ទាល់ខ្លួនរបស់លោក
ដើម្បីបង្ហាញពីរបៀបជជែកអះអាងដ៏គួរឲ្យអស់សំណើច
នៃការប្រមើលមើលពីគូបដិបក្សរបស់លោក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ខ្ញុំក៏អាចនិយាយបានដែរ...ចេញមក!»
ដូចជាមនុស្សមួយចំនួនបាននិយាយបង្ខូចយើងថាយើងនិយាយ
«អ្នកខ្លះនិយាយកុហកដោយប្រាប់អ្នកដទៃថា នេះជាអ្វីដែលយើងនិយាយ»។
អ្នកទាំងនោះដែលនិយាយដូច្នេះសមតែទទួលការជំនុំជម្រះ
សេចក្ដីយុត្តិធម៌នឹងមកដល់
នៅពេលដែលព្រះជាម្ចាស់វិនិច្ឆ័យទោសពួកខ្មាំងសត្រូវរបស់លោកប៉ូល
ដែលបាននិយាយកុហកអំពីអ្វីដែលលោកប៉ូលបានបង្រៀន។
Romans 3:9
ប្រយោគភ្ជាប់
លោកប៉ូលសរុបឡើងថា កំហុសទាំងអស់នៃអំពើបាប
គឺមិនមានអ្នកណាម្នាក់សុចរិត ហើយគ្រប់គ្នាមិនអាចស្វែងរកព្រះជាម្ចាស់ឃើញទេ។
បើដូច្នេះ តើយើងកំពុងតែដោះសារខ្លួនយើងឬអី?
លោកប៉ូលសួរសំណួរទាំងនេះ ដើម្បីបញ្ជាក់គោលបំណងរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត «យើងជាសាសន៍យូដា
មិនគួរព្យាយាមរំពឹងទុកថា យើងនឹងគេចចេញពីការថ្កោលទោសរបស់ព្រះជាម្ចាស់
ដោយព្រោះតែយើងជាសាសន៍យូដានោះទេ!»
មិនទាំងអស់ទេ
ពាក្យទាំងនេះមានកម្លាំងជាងពាក្យ «ទេ» ដែលប្រើជាធម្មតា ប៉ុន្តែ
វាមិនខ្លាំងដូចជាឃ្លាថា «ពិតជាមិនដូច្នេះទេ!»
ដូចដែលមានសេចក្ដីចែងទុកមក
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«នេះជាពាក្យទំនាយ ដែលបានចារទុកក្នុងបទគម្ពីរ»។
Romans 3:11
គ្មាននរណាម្នាក់យល់បានទេ
មិនមាននរណាម្នាក់យល់ នូវអ្វីដែលជាត្រឹមត្រូវនោះទេ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមានអ្នកណាដែលយល់យ៉ាងច្បាស់ពីអ្វីដែលត្រឹមត្រូវនោះទេ»។
ក៏គ្មាននរណាម្នាក់ដែលស្វែងរកព្រះជាម្ចាស់ដែរ
នៅទីនេះឃ្លា «ស្វែងរកព្រះជាម្ចាស់» មានន័យថា
ការមានទំនក់ទំនងជាមួយព្រះជាម្ចាស់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមានអ្នកណាម្នាក់ព្យាយាមដោយភាពស្មោះត្រង់
ដើម្បីមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះជាម្ចាស់ទេ»។
ពួកគេគ្រប់គ្នាបានបែរចេញពីព្រះ
ប្រយោគនេះមានន័យថា មនុស្សមិនចង់បន្តគិតអំពីព្រះជាម្ចាស់ទេ។
ពួកគេចង់គេចវេសចេញពីទ្រង់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ពួកគេបានបែរចេញទាំងស្រុងពីព្រះជាម្ចាស»។
ពួកគេបានត្រឡប់ទៅជាឥតបានការ
ចាប់តាំងពីមិនមានអ្នកណាម្នាក់ធ្វើការល្អ
ពួកគេបានទៅជាគ្មានប្រយោជន៍សម្រាប់ព្រះជាម្ចាស់ទៀតទេ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ពួកគេគ្រប់គ្នាបានក្លាយជាគ្មានប្រយោជន៍សម្រាប់ព្រះជាម្ចាស់»។
Romans 3:13
ពួកគេ...ពួកគេ
ពាក្យ «ពួកគេ» សំដៅដល់សាសន៍យូដា និងសាសន៍ក្រិក ក្នុង ៣:៩ ។
បំពង់ករបស់ពួកគេបើកចេញពីផ្នូរ
ពាក្យ «បំពង់ក» គឺជាការប្រៀបធៀបសម្រាប់អ្វីៗដែលមនុស្សនិយាយ
ដែលជាការមិនត្រឹមត្រូវ និង គួរស្អប់ខ្ពើម។ ឃ្លា «ផ្នូរដែលបើកចំហ» នៅទីនេះ
ជាការប្រៀបធៀបដែលសំដៅដល់ក្លិនស្អុយនៃពាក្យសម្ដីអាក្រក់របស់មនុស្ស។
អណ្ដាតរបស់ពួកគេបោកបញ្ឆោត
ពាក្យ «អណ្ដាត»
គឺជាការប្រៀបធៀបសម្រាប់ពាក្យសម្ដីខុសឆ្គងដែលមនុស្សនិយាយ។
ការបកប្រែតាមរបៀបផ្សេងទៀត: «មនុស្សនិយាយកុហក»។
ពិសរបស់សត្វពស់ស្ថិតនៅក្រោមបបូរមាត់របស់ពួកគេ
ឃ្លា «ពិសរបស់សត្វពស់» នៅទីនេះ
គឺជាការប្រៀបធៀបដែលបានប្រើបរិយាយអំពីមហន្តរាយនៃពាក្យសម្ដីអាក្រក់ៗ
ដែលមនុស្សនិយាយ។ ពាក្យ «បបូរមាត់» សំដៅដល់ពាក្យសម្ដីរបស់មនុស្ស។
ការបកប្រែតាមរបៀបផ្សេងទៀត «ពាក្យរបស់ពួកគេធ្វើអោយមនុស្សអន្តរាយ
ដូចជាពិសរបស់សត្វពស់ពិស»។
មាត់របស់ពួកគេពេញទៅដោយបណ្ដាសារ និងភាពជូរល្វីង
«មាត់» នៅទីនេះ គឺជាការប្រៀបធៀប
ដែលនិយាយពីពាក្យសម្ដីអាក្រក់របស់មនុស្ស។ ពាក្យ «ពេញ»
គឺជាការបន្ថែមដែលបានប្រើដើម្បីសង្កត់បន្ថែមលើអត្ថន័យរបស់ពាក្យ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ពួកគេនិយាយយ៉ាងមុឺងម៉ាត់ដោយដាក់បណ្ដាសា និងពាក្យដែលល្វីងជូរចត់»។
Romans 3:15
របស់ពួកគេ...របស់ពួកគេ...មនុស្សទាំងនេះ...របស់ពួកគេ
ពាក្យទាំងនេះសំដៅទៅលើពួកសាសន៍យូដា និងសាសន៍ក្រិក ក្នុង ៣:៩។
ជើងរបស់ពួកគេរហ័សនឹងបង្ហូរឈាម
នៅទីនេះ «ជើង» គឺជាវេវចនសព្ទ ដែលបរិយាយអំពីមនុស្ស។ ពាក្យ «ឈាម»
គឺជាការប្រៀបធៀប ដែលសំដៅដល់មនុស្សស្លាប់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ពួកគេប្រញាប់ប្រញាល់ប្រព្រឹត្តការអាក្រក់
និងសម្លាប់មនុស្ស»។
ការបំផ្លាញ និងការឈឺចាប់ស្ថិតនៅលើផ្លូវរបស់ពួកគេ
ឃ្លា «ការបំផ្លាញ និងការឈឺចាប់» នៅទីនេះ ជាពាក្យប្រៀបធៀប
ដែលបរិយាយការឈឺចាប់ ដែលមនុស្សទាំងនេះធ្វើឲ្យអ្នកដទៃឈឺចាប់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ពួកគេព្យាយាមបំផ្លាញអ្នកដទៃ
ហើយធ្វើអោយពួកគេឈឺចាប់»។
ផ្លូវនៃសេចក្ដីសុខសាន្ត
«របៀបរស់នៅដោយសុខសាន្តជាមួយអ្នកដទៃ»។ «របៀប» គឺជាផ្លូវ ឬ ជាផ្នែក។
គ្មានការកោតខ្លាចព្រះជាម្ចាស់នៅក្នុងក្រសែភ្នែករបស់ពួកគេឡើយ
ពាក្យ «ការកោតខ្លាច» នៅទីនេះគឺជាពាក្យប្រៀបធៀប
ដែលបរិយាយការគោរពព្រះជាម្ចាស់
ហើយនិងឆន្ទៈក្នុងការលើកកិត្តិយសព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «គ្រប់គ្នាបដិសេធការគោរពព្រះជាម្ចាស់
ដែលទ្រង់សមនឹងទទួល»។
Romans 3:19
អ្វីដែលក្រឹត្យវិន័យបានចែង គឺនិយាយទៅកាន់
នៅទីនេះ លោកប៉ូលនិយាយអំពីក្រឹត្យវិន័យ ដែលហាក់ដូចជាមានជីវិតរស់
ហើយមានសូរសម្លេងរបស់ខ្លួន។ ការបកប្រែតាមរបៀបផ្សេងទៀត
«អ្វីៗដែលក្រឹត្យវិន័យនិយាយ មនុស្សអាចនឹងធ្វើការនោះបាន» ឬ

generated on Wed Sep 10 16:16:32 2025

«គ្រប់ទាំងពាក្យបញ្ជាដែលលោកម៉ូសេបានសរសេរនៅក្នុងក្រឹត្យវិន័យ
គឺសម្រាប់មនុស្ស»។
មនុស្សដែលនៅក្រោមក្រឹត្យវិន័យ
«អស់អ្នកដែលត្រូវស្តាប់បង្គាប់ក្រឹត្យវិន័យ»។
គឺដើម្បីឲ្យគ្រប់មាត់ទាំងអស់បានបិទ
«មាត់» នៅទីនេះ ជាវេវចនសព្ទ ដែលមានន័យថា
ជាពាក្យសម្តីដែលមនុស្សនិយាយ។ អ្នកអាចពាក្យឃ្លានេះនៅក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ដូច្នេះមិនមានមនុស្សណាម្នាក់ដែលអាចនឹងនិយាយការពារខ្លួនរបស់ពួកគេបានទេ»។
ហើយពិភពលោកទាំងមូលទទួលខុសត្រូវនៅចំពោះព្រះជាម្ចាស់
ពាក្យ «លោកីយ៍»
នៅទីនេះជាវេវចនសព្ទដែលពណ៌នាអំពីមនុស្សទាំងអស់ដែលរស់នៅក្នុងលោកីយ៍នេះ។
ការបកប្រែតាមរបៀបផ្សេងទៀត: «
ព្រះជាម្ចាស់ប្រកាសគ្រប់គ្នានៅក្នុងលោកីយ៍ដែលពេញដោយកំហុស។
សាច់ឈាម
នៅទីនេះពាក្យ «សាច់ឈាម» សំដៅដល់មនុស្សទាំងអស់។
សម្រាប់
អាចមានអត្ថន័យពីរ ទី១) «ហេតុដូច្នេះ» ឬ ទី២) «ដោយព្រោះហេតុនេះ»។
តាមរយៈក្រឹត្យវិន័យ ធ្វើឲ្យមនុស្សស្គាល់អំពើបាប
«នៅពេលដែលអ្នកណាម្នាក់ស្គាល់ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ គេទទួលស្គាល់ថា
គេមានបាប»។
Romans 3:21
ប្រយោគភ្ជាប់
ពាក្យ «ប៉ុន្តែ» នៅទីនេះបង្ហាញថា
លោកប៉ូលបានបញ្ចប់ការណែនាំរបស់លោកទាំងស្រុង
ហើយឥឡូវនេះលោកចាប់ផ្តើមធ្វើការបើកបង្ហាញចំនុចសំខាន់របស់លោក។
ឥឡូវនេះ
ពាក្យ «ឥឡូវនេះ» សំដៅដល់ពេលវេលាដែល
ចាប់តាំងពីព្រះគ្រិស្តបានយាងមកលើផែនដីនេះ។
ក្រៅពីគម្ពីរវិន័យ សេចក្តីសុចរិតរបស់ព្រះជាម្ចាស់បានសំដែងឲ្យឃើញហើយ
អ្នកអាចបកប្រែក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«ព្រះជាម្ចាស់បានធ្វើអោយយើងស្គាល់របៀបដែលត្រឹមត្រូវជាមួយទ្រង់
ដោយមិនមានការគោរពក្រឹត្យវិន័យនោះទេ»។
ដោយមានគម្ពីរវិន័យ និងពួកអ្នកនាំព្រះបន្ទូលធ្វើបន្ទាល់
ពាក្យ «ដោយមានគម្ពីរវិន័យ និងពួកអ្នកនាំព្រះបន្ទូល»
សំដៅទៅដល់ផ្នែកនៃព្រះគម្ពីរដែលលោកម៉ូសេ
និងពួកព្យាការីបានកត់ត្រាទុកក្នុងព្រះគម្ពីររបស់សាសន៍យូដា។
លោកប៉ូលបរិយាយនៅទីនេះ
ដូចជាពួកគេជាមនុស្សដែលធ្វើបន្ទាល់នៅក្នុងទីកាត់ក្តី។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្វីដែលលោកម៉ូសេ និងពួកហោរាបានសរសេរគឺប្រាប់អំពីការនេះ»។
សេចក្តីសុចរិតរបស់ព្រះជាម្ចាស់ គឺតាមរយៈជំនឿនៅលើព្រះយេស៊ូគ្រិស្ត
នៅទីនេះពាក្យ «សេចក្តីសុចរិត»
មានន័យថាការចាប់ផ្តើមត្រឹមត្រូវជាមួយព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ការចាប់ផ្តើមត្រឹមត្រូវជាមួយព្រះជាម្ចាស់
តាមរយៈសេចក្តីជំនឿលើព្រះគ្រិស្តយេស៊ូ»។
ព្រោះគ្មានភាពខុសគ្នាទេ
លោកប៉ូលបញ្ជាក់ថា ព្រះជាម្ចាស់ទទួលយកមនុស្សទាំងអស់ក្នុងរបៀបដូចគ្នា។
ការបកប្រែតាមរបៀបផ្សេងទៀត: «គឺមិនមានភាពខុសគ្នាអ្វីទេ រវាងសាសន៍យូដា
និងសាសន៍ក្រិក»។
Romans 3:23
ហើយខ្វះមិនដល់សិរីល្អនៃព្រះជាម្ចាស់
នៅទីនេះឃ្លា «សិរីល្អនៃព្រះជាម្ចាស់» គឺជាជាការប្រៀបធៀប
ដែលសំដៅដល់រូបភាពរបស់ព្រះជាម្ចាស់ និងភាពជាព្រះរបស់ទ្រង់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ហើយបរាជ័យក្នុងការធ្វើឲ្យដូចជាព្រះ»។
ពួកគេបានសុចរិតដោយឥតបង់ថ្លៃ ដោយសារព្រះគុណរបស់ព្រះអង្គ តាមរយៈការប្រោសលោះ
ដែលនៅក្នុងព្រះយេស៊ូគ្រិស្ត
នៅទីនេះពាក្យ «សុចរិត»
សំដៅដល់ការចាប់ផ្តើមធ្វើឲ្យត្រឹមត្រូវជាមួយព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានធ្វើឲ្យពួកគេត្រឹមត្រូវជាមួយអង្គទ្រង់
ជាអំណោយដែលមិនបាច់បង់ថ្លៃ
ព្រោះព្រះគ្រិស្តយេស៊ូបានរំដោះពួកគេអោយមានសេរីភាព»។
Romans 3:25
លើព្រះលោហិតរបស់ព្រះអង្គ
នេះជាពាក្យប្រៀបធៀប សម្រាប់ការសុគតរបស់ព្រះយេស៊ូ
ជាយញ្ញបូជាសម្រាប់អំពើបាប។ របៀបនៃការបកប្រែផ្សេងទៀត:
«ក្នុងការសុគតរបស់ទ្រង់ គឺជាតង្វាយសម្រាប់អំពើបាប»។
បំភ្លេចចោល
អាចអត្ថន័យថា ទី១)ការបដិសេធ ឬ ទី២)ការអត់ទោស
ការទាំងអស់នេះ កើតឡើង ដើម្បីបង្ហាញពីសេចក្តីសុចរិតរបស់ព្រះអង្គ
នៅក្នុងពេលបច្ចុប្បន្នយើងនេះ
«ទ្រង់បានធ្វើការអស់ទាំងនេះ
ដើម្បីបង្ហាញពីរបៀបដែលព្រះជាម្ចាស់ធ្វើអោយមនុស្សត្រឹមត្រូវជាមួយព្រះអង្គផ្ទាល់»។
ការនេះ ដើម្បីឲ្យព្រះអង្គអាចបង្ហាញថា ព្រះអង្គផ្ទាល់សច្ចៈ ហើយដើម្បីបង្ហាញថា
ព្រះអង្គប្រទានសេចក្តីសុចរិតដល់នរណាម្នាក់ ដោយសារជំនឿនៅក្នុងព្រះយេស៊ូ
«ដោយការអស់ទាំងនេះ ទ្រង់បង្ហាញថាទ្រង់សច្ចៈ យុត្តិធម៌
ហើយទ្រង់ជានាក់ដែលប្រកាសថា មនុស្សគ្រប់គ្នាដែលជឿលើព្រះគ្រិស្ត
ជាមនុស្សសុច្ចរិត»។
Romans 3:27
តើយើងបានអ្វីមកអួត? គ្មានទាល់តែសោះ
លោកប៉ូលសួរសំណួរទាំងនេះ
ដើម្បីបង្ហាញថាទាំងនេះមិនមានហេតុផលសម្រាប់មនុស្សអួតអំពីការគោរពក្រឹត្យវិន័យនោះទេ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ដូច្នេះមិនមានវិធីណាដែលយើងអាចអួតថាព្រះជាម្ចាស់អត់ទោសយើង
ដោយសារតែយើងបានគោរពក្រឹត្យវិន័យនោះទេ»។
អួតអំពីអ្វី? ពីការប្រព្រឹត្ត? អត់ទេ ប៉ុន្តែ អួតពីជំនឿវិញ
លោកប៉ូលសួរ
និងឆ្លើយសំណួរដែលមិនទាមទារចម្លើយទាំងនេះដើម្បីបញ្ជាក់បន្ថែមថា
ចំនុចនីមួយៗដែលលោកកំពុងធ្វើគឺសុទ្ធតែជាការពិត។
អ្នកអាចបកប្រែចំនុចនេះដោយផ្អែកលើពាក្យដែល លោកប៉ូលបញ្ជាក់
និងដោយប្រើទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«តើយើងបានអ្វីមកជាទីអួត? តើយើងគួរដកវាចេញ
ដោយសារការប្រព្រឹត្តល្អរបស់យើងឬ? ទេ, គឺយើងគួរនឹងអួត
ដោយសារសេចក្តីជំនឿវិញ»។ (សូមមើល: និង និង
មិនមែនដោយសារ
«ដោយឡែកពី» ឬ «ដោយមិនមានការពិចារណាសម្រាប់»។
Romans 3:29
តើព្រះជាម្ចាស់ គឺជាព្រះរបស់សាសន៍យូដាតែមួយនោះទេ
លោកប៉ូលសួរសំណួរនេះដើម្បីបញ្ជាក់បន្ថែម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នករាល់គ្នាជាសាសន៍យូដា មិនត្រូវគិតថា
មានតែអ្នករាល់គ្នាដែលព្រះជាម្ចាស់នឹងទទួលយកនោះឡើយ!»
តើព្រះអង្គជាព្រះជាម្ចាស់របស់សាសន៍ដទៃដែរ? មែន ព្រះអង្គគឺជាព្រះរបស់សាសន៍ដទៃដែរ
លោកប៉ូលសួរសំណួរនេះដើម្បីបញ្ជាក់ពីគោលបំណងរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះអង្គនឹងទទួលមិនត្រឹមតែសាសន៍យូដាប៉ុណ្ណោះទេ
គឺទាំងសាសន៍ដទៃផងដែរ»។
ព្រះអង្គនឹងធ្វើឲ្យអ្នកកាត់ស្បែកបានសុចរិតដោយសារជំនឿ
និងអ្នកដែលមិនកាត់ស្បែកបានសុចរិតដោយសារជំនឿដែរ
នៅទីនេះពាក្យ «អ្នកកាត់ស្បែក» គឺជាពាក្យធៀបដែលសំដៅដល់សាសន៍យូដា និង
«អ្នកដែលមិនកាត់ស្បែក»
គឺជាពាក្យធៀបដែលសម្តៅដល់អ្នកមិនមែនជាសាសន៍យូដា។
ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះជាម្ចាស់នឹងធ្វើឲ្យទាំងសាសន៍យូដា
និងមិនមែនសាសន៍យូដា សុចរិតចំពោះព្រះអង្គផ្ទាល់
តាមរយៈសេចក្តីជំនឿរបស់ពួកគេលើព្រះគ្រិស្ត»។
Romans 3:31
ប្រយោគភ្ជាប់
លោកប៉ូលបញ្ជាក់បន្ថែមពីក្រឹត្យវិន័យទោះបីមានជំនឿក៏ដោយ។

generated on Wed Sep 10 16:16:32 2025

តើយើងចាត់ទុកក្រឹត្យវិន័យជាមោឃៈដោយសារជំនឿ?
លោកប៉ូលសួរសំណួរនេះ ដើម្បីបញ្ជាក់បន្ថែម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«តើយើងគួរបដិសេធក្រឹត្យវិន័យ ដោយសារយើងមានសេចក្តីជំនឿឬ?»
មិនមែនទេ
ការបញ្ចេញយោបល់នេះ
ផ្តល់នូវចម្លើយអវិជ្ជមានយ៉ាងខ្លាំងសម្រាប់សំណួរគ្រាមភាសានេះ។
អ្នកអាចសរសេរន័យប្រហាក់ប្រហែលគ្នាក្នុងភាសារបស់អ្នក
ដែលអ្នកអាចប្រើនៅទីកន្លែងនេះ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«វាពិតប្រាកដណាស់ថាមិនពិត!» ឬ «ប្រាកដណាស់ថា ទេ!»
យើងត្រូវកាន់តាមក្រឹត្យវិន័យ
«យើងគោរពក្រឹត្យវិន័យ»។
យើង
សព្វនាមនេះសំដៅដល់លោកប៉ូល អ្នកជឿដទៃទៀត និងសំដៅដល់អ្នកអានដែរ។

---

4 [1]ដូច្នេះ តើយើងនឹងនិយាយថា លោកអប្រាហាំជាបុព្វបុរសរបស់យើង ក្នុងសាច់ឈាមមែនទេ?[2]ព្រោះប្រសិនបើ លោកអប្រាហាំបានសុចរិតដោយសារការប្រព្រឹត្តមែន
គាត់នឹងមានហេតុក្នុងការអួត ប៉ុន្តែ មិនមែននៅចំពោះព្រះជាម្ចាស់ទេ។[3]តើបទគម្ពីរបានចែងយ៉ាងដូចម្តេច? «លោកអប្រាហាំបានជឿដល់ព្រះជាម្ចាស់
ហើយបានរាប់គាត់ថាជាសុចរិត»។
[4]ឥឡូវនេះ សម្រាប់អ្នកដែលធ្វើការ តើគាត់នឹងបានទទួលអ្វីដែលគាត់បានធ្វើ គឺមិនមែនជាអំណោយទេ ប៉ុន្តែ ជាតម្លៃឈ្នួលវិញ។[5]ប៉ុន្តែ សម្រាប់អ្នកដែលមិនបានធ្វើការវិញ
ផ្ទុយទៅវិញគាត់ជឿនៅលើព្រះជាម្ចាស់ដែលធ្វើឲ្យមនុស្សអាក្រក់បានសុចរិត ដោយសារជំនឿរបស់គាត់បានរាប់ថាជាសុចរិត។
[6]ព្រះបាទដាវីឌបានប្រកាសពីព្រះពរចំពោះបុរសម្នាក់ដែលព្រះជាម្ចាស់បានរាប់ថាជាសុចរិតមិនមែនដោយការប្រព្រឹត្តឡើយទេ។[7]ព្រះជាម្ចាស់មានបន្ទូលថា៖
«មានពរហើយអស់អ្នកដែលបាបរបស់ខ្លួនបានអត់ទោស និងបាបរបស់ខ្លួនបានគ្របបាំង។[8]មានពរហើយអ្នកដែលព្រះអម្ចាស់មិនបានរាប់បាបរបស់ពួកគេ។
[9]ដូច្នេះ ព្រះពរនេះបានប្រកាសតែអស់អ្នកដែលកាត់ស្បែក ឬ ក៏ប្រកាសដល់អស់អ្នកដែលមិនកាត់ស្បែកដែរ? ព្រោះយើងនិយាយថា៖
«លោកអប្រាហាំបានរាប់ជាសុចរិតដោយសារជំនឿ»។[10]ដូច្នេះ តើរាប់យ៉ាងដូចម្តេច? គឺនៅពេលលោកអប្រាហាំស្ថិតនៅក្នុងការកាត់ស្បែក ឬមិនកាត់ស្បែក?
វាមិនមែនមកពីការកាត់ស្បែកទេ ប៉ុន្តែ នៅពេលក្នុងការមិនកាត់ស្បែកវិញ។
[11]លោកអប្រាហាំបានទទួលទីសម្គាល់នៃការកាត់ស្បែក។ នេះគឺជាត្រានៃសេចក្តីសុចរិតរបស់ជំនឿដែលគាត់បានទទួល
នៅពេលគាត់ស្ថិតនៅក្នុងការមិនកាត់ស្បែកនៅឡើយ។ លទ្ធផលនៃសញ្ញានេះគឺថាគាត់បានក្លាយជាឪពុកនៃអស់អ្នកដែលជឿទាំងអស់
ទោះបីជាពួកគេមិនបានកាត់ស្បែកក្តី។ នេះមានន័យថា សេចក្តីសុចរិតបានរាប់ជាមួយពួកគេដែរ។[12]នេះក៏មានន័យផងដែរ
ថាលោកអប្រាហាំបានក្លាយជាឪពុកនៃអស់អ្នកដែលបានកាត់ស្បែកប៉ុណ្ណោះទេ ប៉ុន្តែ
លោកក៏ជាឪពុកសម្រាប់អស់អ្នកដែលដើរតាមជំហ៊ាននៃជំនឿរបស់ឪពុកយើងគឺលោកអប្រាហាំ មុនពេលគាត់បានកាត់ស្បែកទៅទៀត។
[13]ព្រោះសេចក្តីសន្យាចំពោះលោកអប្រាហាំ និងចំពោះពូជពង្សរបស់គាត់ដែលគាត់នឹងទទួលលោកីយ៍ជាមរតក មិនមែនបានមកដោយសារក្រឹត្យវិន័យទេ ប៉ុន្តែ
តាមរយៈសេចក្តីសុចរិតនៃជំនឿវិញ។[14]ប្រសិនបើ អស់អ្នកដែលរស់នៅដោយក្រឹត្យវិន័យ បានទទួលមរតក ដូច្នេះ ជំនឿក្លាយជារបស់ឥតប្រយោជន៍
ហើយសេចក្តីសន្យាក៏គ្មានតម្លៃដែរ។[15]ព្រោះក្រឹត្យវិន័យនាំឲ្យមានសេចក្តីក្រោធ ប៉ុន្តែ ប្រសិនបើគ្មានក្រឹត្យវិន័យ ក៏គ្មានការរំលងដែរ។
[16]ដោយហេតុនេះ ដោយសារជំនឿ ដើម្បីឲ្យសេចក្តីសន្យាបានស្ថិតនៅលើព្រះគុណ ហើយអាចរាប់រងចំពោះពូជពង្សរបស់លោកអប្រាហាំទាំងអស់
មិនគ្រាន់តែចំពោះអស់អ្នកដែលនៅក្រោមក្រឹត្យវិន័យប៉ុណ្ណោះទេ ប៉ុន្តែ សម្រាប់អស់អ្នកដែលមានចំណែកនៅក្នុងជំនឿរបស់លោកអប្រាហាំដែរ។
គាត់ជាឪពុករបស់យើងគ្រប់គ្នា[17]ដូចមានសេចក្តីចែងទុកមកថា៖ «ខ្ញុំបានធ្វើឲ្យអ្នកបានត្រឡប់ទៅជាឪពុកលើប្រជាជាតិជាច្រើន»។
លោកអប្រាហាំស្ថិតនៅក្នុងព្រះវត្តមាននៃព្រះអង្គ ជាអ្នកដែលព្រះបានទុកចិត្ត គឺព្រះអង្គហើយ ដែលប្រទានជីវិតដល់អ្នកស្លាប់
ហើយបានហៅអ្វីៗដែលគ្មានមកកាន់អ្វីដែលមានវិញ។
[18]ក្រៅពីការកាត់ស្បែកក្នុងរូបភាពខាងក្រៅ លោកអប្រាហាំបានទុកចិត្តដល់ព្រះជាម្ចាស់ទាំងស្រុងសម្រាប់ពេលអនាគត។ ដូច្នេះហើយ
គាត់បានត្រឡប់ទៅជាឪពុកនៃប្រជាជាតិជាច្រើន ស្របទៅតាមអ្វីដែលបានចែងថា៖ «អ្នកនឹងមានពូជពង្សជាច្រើន»។[19]គាត់មិនបានខ្សោយនៅក្នុងជំនឿរបស់គាត់ទេ។
លោកអប្រាហាំយល់ថា រូបកាយរបស់គាត់ផ្ទាល់មិនអាចមានកូនបានទេ (ដោយសារគាត់មានអាយុមួយរយឆ្នាំទៅហើយ)។ គាត់ក៏ទទួលស្គាល់ផងដែរថា
ផ្ទៃរបស់នាងសារ៉ាក៏មិនអាចមានកូនបានដែរ។
[20]ប៉ុន្តែ ដោយសារសេចក្តីសន្យារបស់ព្រះជាម្ចាស់ លោកអប្រាហាំគ្មានការសង្ស័យនៅក្នុងជំនឿរបស់គាត់ឡើយ ផ្ទុយទៅវិញ គាត់ត្រូវបានចម្រើនកម្លាំងដោយជំនឿ
ហើយបានសរសើរតម្កើងដល់ព្រះជាម្ចាស់។[21]គាត់ពិតជាជឿជាក់ទាំងស្រុងថា អ្វីដែលព្រះជាម្ចាស់បានសន្យាហើយ ព្រះអង្គក៏អាចធ្វើវាឲ្យបានសម្រេចដែរ។
[22]ដោយសារហេតុនេះ ហើយបានជាគាត់ត្រូវបានរាប់ជាសុចរិត។
[23]ឥឡូវនេះ សេចក្តីដែលបានសរសេរមកនោះ មិនត្រឹមតែជាប្រយោជន៍របស់គាត់ទេ[24]ប៉ុន្តែ
វាត្រូវបានរាប់ជាសុចរិតចំពោះអស់អ្នកដែលជឿលើព្រះអង្គដែលបានប្រោសព្រះយេស៊ូ ជាព្រះអម្ចាស់នៃយើងពីសេចក្តីស្លាប់។
[25]ព្រះអង្គនេះហើយគឺជាអ្នកដែលត្រូវបានគេបញ្ជូនទៅសម្លាប់ដោយសារអំពើរំលងរបស់យើង ហើយបានប្រោសព្រះអង្គឲ្យរស់ឡើងវិញ គឺឲ្យយើងបានសុចរិត។

Romans 4:1
ប្រយោគភ្ជាប់
លោកប៉ូលបញ្ជាក់ថា ទោះបីជាក្នុងអតីតកាល
អ្នកជឿដែលបានសុចរិតដោយសារជំនឿ
ហើយមិនមែនដោយសារការប្រព្រឹត្តតាមក្រឹត្យវិន័យទេ។
តើយើងនឹងនិយាយថា លោកអប្រាហាំជាបុព្វបុរសរបស់យើង ក្នុងសាច់ឈាមមែនទេ?
លោកប៉ូលប្រើសំណួរនេះ ដើម្បីទាញចំណាប់អារម្មណ៍របស់អ្នកអាន
និងដើម្បីចាប់ផ្តើមការនិយាយអំពីកិច្ចការថ្មី។ ការបកប្រែតាមបរៀបផ្សេងទៀត
«នេះជាអ្វីដែលលោកអប្រាហាំ
ជាបុព្វបុរសក្នុងសាច់ឈាមរបស់យើងបានរកឃើញ»។
តើបទគម្ពីរបានចែងយ៉ាងដូចម្តេច?
លោកប៉ូលប្រើសំណួរនេះ ដើម្បីបន្ថែមអត្ថន័យ។ លោកនិយាយអំពីបទគម្ពីរ
ហាក់ដូចជាមានជីវិតនិងអាចនិយាយបាន។ ការបកប្រែតាមរបៀបផ្សេងទៀត
«គឺយើងអាចអាននៅក្នុងព្រះគម្ពីរ»។
ហើយបានរាប់គាត់ជាសុចរិត
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«ហើយព្រះជាម្ចាស់បានចាត់ទុកលោកអប្រាហាំជាមនុស្សសុចរិត»។
Romans 4:4
ការទូទាត់
«ថ្លៃឈ្នួល» ឬ «បង់ថ្លៃ» ឬ «អ្វីដែលគេបានទទួលពីការធ្វើការងារ»។
អ្វីជារបស់ខ្លួន
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមបរៀបផ្សេងទៀត:
«អ្វីដែលនិយោជករបស់គាត់ជំពាក់គាត់»។
នៅលើព្រះជាម្ចាស់ដែលសុចរិត
«នៅលើព្រះជាម្ចាស់ ដែលសុចរិត»។
ដោយសារជំនឿរបស់គាត់បានរាប់ថាជាសុចរិត
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមបរៀបផ្សេងទៀត
«ព្រះជាម្ចាស់ចាត់ទុកថាជំនឿរបស់មនុស្ស ដូចជាសេចក្តីសុចរិត» ឬ
«ព្រះជាម្ចាស់ចាត់ទុកថាមនុស្សសុចរិត ដោយសារជំនឿរបស់គេ»។
Romans 4:6
ព្រះបាទដាវីឌបានប្រកាសពីព្រះពរចំពោះបុរសម្នាក់ដែលព្រះជាម្ចាស់បានរាប់ថាជាសុចរិតមិនមែនដោយការប្រព្រឹត្តឡើយទេ
«ព្រះបាទដាវីឌក៏បានសរសេរផងដែរអំពីរបៀបដែលព្រះជាម្ចាស់ប្រទានពរ

generated on Wed Sep 10 16:16:32 2025

មនុស្សដែលព្រះអង្គប្រទានឲ្យបានសុចរិតដោយមិនមានការប្រព្រឹត្តតាមក្រឹត្យវិន័យ»។
អស់អ្នកដែលបាបរបស់ខ្លួនបានអត់ទោស...បាបរបស់ខ្លួនបានគ្របបាំង...ហើយអ្នកដែលព្រះអម្ចាស់មិនប
ទស្សនៈតែមួយ ត្រូវបានបញ្ជាក់ក្នុងវិធីបីផ្សេងគ្នា។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមបរៀបផ្សេងទៀត:
«អស់អ្នកដែលព្រះអម្ចាស់បានអត់ទោសបាបរបស់ខ្លួន...
អស់អ្នកដែលអំពើបាបរបស់ខ្លួនបានគ្របបាំង...ហើយអស់អ្នកដែលព្រះអម្ចាស់មិនបាន
Romans 4:9
ដូច្នេះ ព្រះពរនេះបានប្រកាសតែអស់អ្នកដែលកាត់ស្បែក ឬ
ក៏ប្រកាសដល់អស់អ្នកដែលមិនកាត់ស្បែកដែរ?
ការកត់សម្គាល់នេះបង្ហាញជាទម្រង់សំណួរដើម្បីបន្ថែមការសង្កត់ធ្ងន់។
ការបកប្រែក្នុងរបៀបផ្សេងទៀត:
«តើព្រះជាម្ចាស់ប្រទានពរដល់តែអស់អ្នកដែលកាត់ស្បែក
ឬក៏ដល់អស់អ្នកដែលមិនកាត់ស្បែកដែរ?»
អស់អ្នកដែលកាត់ស្បែក
នេះជាការប្រៀបធៀប ដែលសំដៅដល់ប្រជាជនយូដា។
ការបកប្រែក្នុងរបៀបផ្សេងទៀត: «សាសន៍យូដា»
អស់អ្នកដែលមិនកាត់ស្បែក
នេះជាពាក្យប្រៀបធៀប ដែលសំដៅដល់អ្នកមិនមែនប្រជាជនយូដា។
ការបកប្រែក្នុងរបៀបផ្សេងទៀត «សាសន៍ដទៃ»។
លោកអប្រាហាំបានរាប់ជាសុចរិតដោយសារជំនឿ
អ្នកអាចបកប្រែតាមទម្រង់សកម្ម។ ការបកប្រែក្នុងរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់រាប់ទុកលោកអប្រាហាំជាមនុស្សសុចរិត
ដោយសារសេចក្តីជំនឿរបស់លោក»។
ដូច្នេះ តើគិតយ៉ាងដូចម្តេច? តើនៅពេលលោកអប្រាហាំស្ថិតនៅក្នុងការកាត់ស្បែក
ឬពេលមិនកាត់ស្បែក?
លោកប៉ូលសួរសំណួរទាំងនេះ ដើម្បីសង្កត់ធ្ងន់លើកំណត់សម្គាល់របស់គាត់។
ការបកប្រែក្នុងរបៀបផ្សេងទៀត:
«តើព្រះជាម្ចាស់រាប់លោកអប្រាហាំជាមនុស្សសុចរិតនៅពេលណា?
តើនៅមុនពេលលោកទទួលការកាត់ស្បែក ឬនៅក្រោយនោះ?» (សូមមើល:figs-rquestion)
វាមិនមែនមកពីការកាត់ស្បែកទេ ប៉ុន្តែ នៅពេលដែលមិនកាត់ស្បែកវិញ។
«គឺវាកើតឡើងមុនពេលលោកទទួលការកាត់ស្បែក
មិនមែនបន្ទាប់ពីលោកកាត់ស្បែកនោះទេ»។
Romans 4:11
នេះគឺជាត្រានៃសេចក្តីសុចរិតរបស់ជំនឿដែលគាត់បានទទួល
នៅពេលគាត់ស្ថិតនៅក្នុងការមិនកាត់ស្បែកនៅឡើយ
នៅទីនេះឃ្លា «សេចក្តីសុចរិតរបស់ជំនឿ» មានន័យថា
ព្រះជាម្ចាស់រាប់គាត់ថាបានសុចរិត។ ការបកប្រែក្នុងរបៀបផ្សេងទៀត:
«សញ្ញាជាក់ស្តែង គឺថាព្រះជាម្ចាស់រាប់ថាគាត់ជាមនុស្សសុចរិត
ព្រោះគាត់មានជំនឿលើព្រះជាម្ចាស់មុនពេលដែលគាត់បានទទួលការកាត់ស្បែក។
ទោះបីជាពួកគេមិនបានកាត់ស្បែកក្តី
«ទោះបីជាពួកគេមិនបានទទួលការកាត់ស្បែកក្តី»។
នេះមានន័យថា សេចក្តីសុចរិតបានរាប់ជាមួយពួកគេដែរ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែក្នុងរបៀបផ្សេងទៀត:
«នេះមានន័យថា ព្រះជាម្ចាស់នឹងរាប់ពួកគេជាមនុស្សសុចរិត»។
លោកអប្រាហាំបានក្លាយជាឪពុកនៃអស់អ្នកដែលបានកាត់ស្បែក
ពាក្យ «ការកាត់ស្បែក» នៅទីនេះ
សំដៅដល់អស់អ្នកដែលជឿពិតប្រាកដលើព្រះជាម្ចាស់ គឺទាំងសាសន៍យូដា
ទាំងសាសន៍ក្រិក។
ដើរតាមជំហាននៃជំនឿរបស់ឪពុកយើងគឺលោកអប្រាហាំ
នៅទីនេះឃ្លា «ដើរតាមជំហាន» គឺជាការបញ្ជាក់ដែលមានន័យថា
ដើរតាមឧទាហរណ៍របស់អ្នកណាម្នាក់។ ការបកប្រែក្នុងរបៀបផ្សេងទៀត:
«ដើរតាមឧទាហរណ៍លោកអប្រាហាំ ជាឪពុករបស់យើង»។
Romans 4:13
ដែលសេចក្តីសន្យាបានផ្តល់លោកអប្រាហាំ និងចំពោះពូជពង្សរបស់គាត់
ដែលគាត់នឹងទទួលលោកីយ៍ជាមរតក
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែក្នុងរបៀបផ្សេងទៀត
«ព្រះជាម្ចាស់បានប្រទានសេចក្តីសន្យាដល់លោកអប្រាហាំ និងពូជពង្សរបស់លោក
ដែលពួកគេនឹងទទួលបានផែនដីនេះ»។
អ្នកទទួលមរតក
មនុស្សដែលព្រះជាម្ចាស់បានប្រទានសេចក្តីសន្យាដោយបានមានព្រះបន្ទូល
ពួកគេនឹងទទួលទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។
ជំនួសមកវិញ គឺតាមរយៈសេចក្តីសុចរិតនៃសេចក្តីជំនឿ
ពាក្យ «ព្រះជាម្ចាស់ប្រទានសេចក្តីសន្យា» ត្រូវបានលុបចេញពីឃ្លានេះ
ប៉ុន្តែ ឃ្លានេះនៅតែមានន័យអាចយល់បាន។
អ្នកអាចបងកប្រែឃ្លានេះដោយបន្ថែមពាក្យទាំងនោះ។
ការបកប្រែក្នុងរបៀបផ្សេងទៀត: «ជំនួសមកវិញ
ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលសន្យា តាមរយៈសេចក្តីជំនឿ
ដែលទ្រង់រាប់ទុកជាមនុស្សសុចរិត»។
ប្រសិនបើពួកគេរស់នៅដោយក្រឹត្យវិន័យ គឺជាអ្នកទទួលមរតក
ឃ្លា «រស់នៅដោយក្រឹត្យវិន័យ»
នៅទីនេះមានន័យសំដៅដល់អស់អ្នកដែលគោរពក្រឹត្យវិន័យ។
ការបកប្រែក្នុងរបៀបផ្សេងទៀត «គឺអស់អ្នកណាដែលគោរពក្រឹត្យវិន័យ
ពួកគេនឹងបានត្រងផែនដីនេះជាមរតក»។
ជំនឿក្លាយជារបស់ឥតប្រយោជន៍ ហើយសេចក្តីសន្យាក៏គ្មានតម្លៃ
«សេចក្តីជំនឿទៅជាគ្មានតម្លៃ ហើយ សេចក្តីសន្យាគឺមិនមានអត្ថន័យ»។
ប៉ុន្តែ ទីណាដែលមិនមានក្រឹត្យវិន័យ ទីនោះក៏គ្មានការគោរពប្រតិបត្តិដែរ
អ្នកអាចបកប្រែឃ្លាបដិសេធស្នួន មកជាទម្រង់ស្របៗ
ការបកប្រែក្នុងរបៀបផ្សេងទៀត: «ប៉ុន្តែ តែនៅទីកន្លែងណាមិនមានក្រឹត្យវិន័យ
គឺមិនមានការគោរពទេ» ឬ
«ដោយសារមានរបស់ខ្លះសម្រាប់មនុស្សដែលមិនគោរព
នៅកន្លែងដែលមានក្រឹត្យវិន័យ»។
Romans 4:16
ដោយហេតុនេះ ដោយសារជំនឿ ដើម្បីឲ្យសេចក្តីសន្យាបានស្ថិតនៅលើព្រះគុណ
ពាក្យ «ព្រះគុណ»
នៅទីនេះសំដៅដល់អំណោយដែលឥតគិតថ្លៃរបស់ព្រះជាម្ចាស់។
ការបកប្រែក្នុងរបៀបផ្សេងទៀត:
«នៅទីនេះហេតុផលដែលយើងបានទទួលសេចក្តីសន្យា
នៅពេលដែលយើងទុកចិត្តលើព្រះជាម្ចាស់ វាគឺជាអំណោយដែលឥតគិតថ្លៃ»។
ជាលទ្ធផល សេចក្តីសន្យាគឺប្រកដសម្រាប់ពូជពង្សទាំងអស់
ុ«ដូច្នេះពូជពង្សទាំងអស់របស់លោកអប្រាហាំ
គឺពិតជាបានទទួលសេចក្តីសន្យា»។
អស់អ្នកដែលស្គាល់ក្រឹត្យវិន័យ
ឃ្លានេះគឺសំដៅដល់ប្រជាជនយូដា ដែលដើរតាមក្រឹត្យវិន័យរបស់លោកម៉ូសេ។
អស់អ្នកដែលមានចំណែកនៅក្នុងជំនឿរបស់លោកអប្រាហាំ
ឃ្លានេះគឺសំដៅលើអស់អ្នកដែលមានជំនឿដូចលោកអប្រាហាំ
ដែលបានធ្វើមុនពេលលោកទទួលពិធីកាត់ស្បែក។
ឪពុករបស់យើងគ្រប់គ្នា
ពាក្យ «យើង» នៅទីនេះសំដៅដល់លោកប៉ូល និងរាប់ទាំងសាសន៍យូដាទាំងអស់
រួមទាំងសាសន៍ដទៃដែលជឿលើព្រះគ្រិស្ត។
លោកអប្រាហាំគឺជាបុព្វបុរសរបស់សាសន៍យូដាខាងសាច់ឈាម ប៉ុន្តែ
លោកជាឪពុកខាងវិញ្ញាណរបស់អស់អ្នកដែលមានជំនឿ។
ដូចមានសេចក្តីចែងទុក
នៅទីកន្លែងដែលមានសរសេរទុកនោះ អាចធ្វើអោយកាន់តែច្បាស់លាស់។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់។ ការបកប្រែក្នុងរបៀបផ្សេងទៀត:
«ដូចដែលអ្នកណាម្នាក់បានសរសេរក្នុងគម្ពីរ»។
ខ្ញុំបានធ្វើឲ្យអ្នក
ពាក្យ «អ្នក» នៅទីនេះ គឺជាឯកវចន និងសំដៅដល់លោកអប្រាហាំ។
លោកអប្រាហាំស្ថិតនៅក្នុងព្រះវត្តមាននៃព្រះអង្គ ជាអ្នកដែលព្រះបានទុកចិត្ត គឺព្រះអង្គហើយ
ដែលប្រទានជីវិតដល់អ្នកស្លាប់
នៅទីនេះ ឃ្លា «ជាអ្នកដែលព្រះបានទុកចិត្ត» សំដៅលើព្រះជាម្ចាស់។
ការបកប្រែក្នុងរបៀបផ្សេងទៀត «លោកអប្រាហាំស្ថិតនៅក្នុងព្រះវត្តមាននៃព្រះ
ដែលលោកទុកចិត្ត គឺព្រះអង្គដែលប្រទានជីវិតដល់អស់អ្នកដែលបានស្លាប់»។
បានហៅអ្វីៗដែលគ្មានមកកាន់អ្វីដែលមានវិញ
«បានបង្កើតអ្វីៗគ្រង់យ៉ាងពីភាពទទេស្អាត»។
Romans 4:18
ក្រៅពីការកាត់ស្បែកក្នុងរូបភាពខាងក្រៅ
អត្ថន័យពេញលេញឃ្លា «ការកាត់ស្បែករូបភាពខាងក្រៅ»

generated on Wed Sep 10 16:16:32 2025

អាចបង្កើតភាពជាក់លាក់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ទោះបីវាហាក់ដូចជាមិនអាចទៅរួចសម្រាប់គាត់ ដើម្បីមានកូនចៅ»។
ដូច្នេះហើយ គាត់បានត្រឡប់ទៅជាឪពុកនៃប្រជាជាតិជាច្រើន
«ហើយជាលទ្ធផល នៃសេចក្តីជំនឿរបស់លោកអប្រាហាំ
គឺថាលោកបានក្លាយមកជាឪពុកនៃប្រជាជាតិជាច្រើន»។
ស្របទៅតាមអ្វីដែលបានចែង
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដូចដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកអប្រាហាំ»។
អ្នកនឹងមានពូជពង្សជាច្រើន
សេចក្តីសន្យាទាំងស្រុង ដែលព្រះជាម្ចាស់បានប្រទានឲ្យលោកអប្រាហាំ
អាចធ្វើឲ្យមានភាពជាក់ស្តែង។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកនឹងមានកូនចៅជាច្រើន លើសពីការដែលអ្នកអាចរាប់បាន»។
គាត់មិនបានខ្សោយនៅក្នុងជំនឿរបស់គាត់ទេ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់វិជ្ជមាន។ ការបកប្រែតាមរបៀបផ្សេងទៀត:
«គាត់នៅតែខ្លាំងក្នុងសេចក្តីជំនឿរបស់គាត់»។
Romans 4:20
គ្មានការសង្ស័យនៅក្នុងជំនឿ
អ្នកអាចបកប្រែឃ្លាអវិជ្ជមានស្នូននេះ ជាទម្រង់វិជ្ជមានវិញ។
ការបកប្រែតាមរបៀបផ្សេងទៀត: «នៅតែរក្សាការសេចក្តីជំនឿដដែរ»។
គាត់ត្រូវបានចម្រើនកម្លាំងដោយជំនឿ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«លោកកាន់តែចម្រើនឡើងក្នុងសេចក្តីជំនឿរបស់លោក»។
គាត់ពិតជាជឿជាក់ទាំងស្រុង
«លោកអប្រាហាំពិតប្រាកដមួយរយភាគរយ»។
ព្រះអង្គក៏អាចធ្វើវាឲ្យបានសម្រេចដែរ
«ព្រះជាម្ចាស់ពិតជាធ្វើបាន»។
ដោយសារហេតុនេះ ហើយបានជាគាត់ត្រូវបានរាប់ជាសុចរិត
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដោយហេតុនេះ ព្រះជាម្ចាស់រាប់សេចក្តីជំនឿរបស់លោកអប្រាហាំជាសុចរិត» ឬ
«ដោយហេតុនេះព្រះជាម្ចាស់ចាត់ទុកលោកអប្រាហាំសុចរិត
ដ្បិតលោកអប្រាហាំជឿលើទ្រង់»។
Romans 4:23
ឥឡូវនេះ
ពាក្យ «ឥឡូវនេះ» ត្រូវបានប្រើនៅទីនេះ
ដើម្បីភ្ជាប់ការប្រព្រឹត្តត្រឹមត្រូវរបស់លោកអប្រាហាំដោយសេចក្តីជំនឿ
ទៅកាន់ការប្រព្រឹត្តត្រឹមត្រូវរបស់អ្នកជឿសព្វថ្ងៃ ដោយសារសេចក្តីជំនឿ
ក្នុងការសុគតនិងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត។
ត្រឹមតែជាប្រយោជន៍របស់គាត់
«សម្រាប់តែលោកអប្រាហាំប៉ុណ្ណោះ»។
វាត្រូវបានរាប់សម្រាប់គាត់
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«គឺព្រះជាម្ចាស់រាប់លោកជាមនុស្សសុចរិត» ឬ
«ព្រះជាម្ចាស់ចាត់ទុកលោកជាមនុស្សសុចរិត»។
សម្រាប់យើង
ពាក្យ «យើង» សំដៅដល់លោកប៉ូល
និងរួមទាំងអ្នកដែលជឿលើព្រះគ្រិស្តទាំងអស់ផង។
សេចក្តីដែលបានសរសេរមកនោះ សម្រាប់អស់អ្នកដែលនឹងរាប់ជាសុចរិត យើងដែលជាអ្នកជឿ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«វាក៏សម្រាប់ប្រយោជន៍របស់យើងដែរ ដ្បិត
ព្រះជាម្ចាស់ក៏នឹងចាត់ទុកយើងថាសុចរិតដែរ ប្រសិនបើ យើងជំនឿ»។
ព្រះអង្គដែលបានប្រោស
«ព្រះជាម្ចាស់ ព្រះអង្គដែលបានប្រោស»។
ព្រះអង្គនេះហើយគឺជាអ្នកដែលត្រូវបានគេបញ្ជូនទៅសម្លាប់ដោយសារអំពើរំលងរបស់យើង
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះអង្គនេះហើយគឺជាអ្នកដែលព្រះជាម្ចាស់បានប្រគល់ទៅឲ្យពួកអ្នកដែលបានធ្វើគត់ទ្រង់»។
ហើយបានប្រោសព្រះអង្គឲ្យរស់ឡើងវិញ គឺឲ្យយើងបានសុចរិត
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ហើយជាអ្នកដែលព្រះជាម្ចាស់បាននាំមកឯជីវិតវិញ ដូច្នេះ
ព្រះជាម្ចាស់អាចធ្វើឲ្យយើងសុចរិតជាមួយទ្រង់»។

---

5 [1]ដូច្នេះ យើងបានសុចរិតដោយសារជំនឿ យើងមានសន្តិភាពជាមួយព្រះជាម្ចាស់ តាមរយៈព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើង។[2]ដោយសារព្រះអង្គ
យើងក៏មានផ្លូវចូលទៅកាន់ព្រះគុណដោយជំនឿ ដែលយើងឈរ។ យើងមានអំណរនៅក្នុងទំនុកចិត្តលើព្រះជាម្ចាស់ដែលប្រទានឲ្យយើងសម្រាប់ពេលអនាគត
យើងមានទំនុកចិត្តថា យើងនឹងមានចំណែកនៅក្នុងសិរីល្អរបស់ព្រះជាម្ចាស់។
[3]មិនគ្រាន់តែប៉ុណ្ណោះទេ ប៉ុន្តែ យើងក៏មានអំណរនៅក្នុងទុក្ខលំបាករបស់យើងផងដែរ។[4]យើងដឹងថា ទុក្ខលំបាកនាំឲ្យយើងអត់ធន់។
ហើយការអត់ធន់ធ្វើឲ្យយើងគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ ហើយការគាប់ព្រះឫទ័យដល់ព្រះអង្គ នាំឲ្យយើងមានទំនុកចិត្តនាពេលអនាគត។[5]ទំនុកចិត្តនេះ
មិនធ្វើឲ្យយើងខកចិត្តឡើយ ដោយសារសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានចាក់បំពេញនៅក្នុងដួងចិត្តរបស់យើងតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ
ដែលបានប្រទានមកយើង។
[6]កាលដែលយើងនៅខ្សោយនៅឡើយ នៅពេលកំណត់ ព្រះគ្រិស្តបានសុគតសម្រាប់មនុស្សទុច្ចរិត។[7]កម្រមានអ្នកព្រមស្លាប់ជំនួសមនុស្សសុចរិតណាស់។
ហើយក៏ប្រហែលជាមានអ្នកដែលហ៊ានស្លាប់សម្រាប់មនុស្សល្អដែរ។
[8]ប៉ុន្តែ ព្រះជាម្ចាស់បានបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គផ្ទាល់ចំពោះយើង ព្រោះនៅពេលដែលយើងស្ថិតនៅក្នុងភាពជាមនុស្សមានបាបនៅឡើយ
ព្រះគ្រិស្តបានសុគតសម្រាប់យើងរួចហើយ។[9]លើសពីនេះ យើងបានសុចរិតដោយសារព្រះលោហិតរបស់ព្រះអង្គ យើងនឹងបានសង្គ្រោះឲ្យរួចផុតពីសេចក្តីក្រោធ
នៃព្រះជាម្ចាស់ដោយសារព្រះលោហិតនេះ។
[10]ប្រសិនបើ យើងស្ថិតនៅក្នុងភាពជាសត្រូវ ហើយយើងបានផ្សះផ្សាជាមួយព្រះជាម្ចាស់តាមរយៈការសុគតរបស់ព្រះបុត្រាព្រះអង្គ
បន្ទាប់ពីយើងបានផ្សះផ្សាជាមួយព្រះអង្គហើយ លើសពីនេះ យើងនឹងបានសង្គ្រោះដោយសារព្រះជន្មរបស់ព្រះអង្គផងដែរ។[11]មិនគ្រាន់តែប៉ុណ្ណោះ
យើងក៏មានអំណរនៅក្នុងព្រះជាម្ចាស់តាមរយៈព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង ដោយសារព្រះអង្គ នៅពេលនេះ យើងបានទទួលការផ្សះផ្សារឡើងវិញ។
[12]ដូច្នេះ តាមរយៈមនុស្សបាបម្នាក់បានចូលមកក្នុងលោកីយ៍នេះ ដូចគ្នានេះដែរ សេចក្តីស្លាប់បានចូលមកក្នុងលោកីយ៍ដោយសារបាបនោះដែរ។
ហើយសេចក្តីស្លាប់បានរីកសាយទៅដល់មនុស្សគ្រប់រូប ព្រោះមនុស្សទាំងអស់បានធ្វើបាប។[13]រហូតដល់មានក្រឹត្យវិន័យ បាបបានចូលមកក្នុងលោកីយ៍ហើយ ប៉ុន្តែ
បាបមិនត្រូវបានស្គាល់នៅឡើយទេ ដោយសារមិនទាន់មានក្រឹត្យវិន័យនៅឡើយ។
[14]យ៉ាងណាក៏ដោយ សេចក្តីស្លាប់បានគ្រប់គ្រងលើលោកអដាំរហូតដល់លោកម៉ូសេ
ថែមទាំងគ្រប់គ្រងលើអស់អ្នកដែលមិនបានធ្វើបាបនៃការមិនស្តាប់បង្គាប់ដូចជាលោកអដាំដែរ ក៏មានម្នាក់ដែលមានលក្ខណៈដូចជាគាត់ដែរ នឹងមក។ ប៉ុន្តែ
ទោះជាយ៉ាងនេះក្តី អំណោយទានមិនដូចជាការរំលងទេ។[15]ដូច្នេះ ប្រសិនបើការរំលងរបស់មនុស្សម្នាក់ធ្វើឲ្យមនុស្សជាច្រើនបានស្លាប់ តើព្រះគុណរបស់ព្រះជាម្ចាស់
និងអំណោយទាន ដោយសារព្រះជាម្ចាស់នៃមនុស្សម្នាក់ គឺព្រះយេស៊ូគ្រិស្ត នឹងមានលើសជាយ៉ាងណាទៅទៀត។
[16]អំណោយទាននេះ មិនដូចជាលទ្ធផលនៃម្នាក់ដែលបានធ្វើបាបទេ។ ផ្ទុយទៅវិញ ការជំនុំជម្រះនៃការកាត់ទោសបានមក ដោយសារការរំលងនៃមនុស្សម្នាក់។ ក៏ប៉ុន្តែ
អំណោយទានបានធ្វើឲ្យមានសេចក្តីសុចរិត មកដល់បន្ទាប់ពីមានការរំលងជាច្រើន។[17]ដូច្នេះ ដោយសារការរំលងរបស់មនុស្សម្នាក់
សេចក្តីស្លាប់បានគ្រប់គ្រងតាមរយៈម្នាក់នោះ តើព្រះគុណដ៏បរិបូរណ៌ និងអំណោយទាននៃសេចក្តីសុចរិតនឹងគ្រង់គ្រងលើម្នាក់ដែលមានព្រះនាមថា យេស៊ូគ្រិស្តទេឬអី?
[18]ដូច្នេះ ដោយសារម្នាក់បានប្រព្រឹត្តរំលង មនុស្សគ្រប់រូបត្រូវទទួលការជំនុំជម្រះ ដូចគ្នាដែរ ដោយសារមនុស្សម្នាក់ដែលប្រព្រឹត្តអំពើសុចរិត
នឹងធ្វើឲ្យមនុស្សគ្រប់គ្នាមានសេចក្តីសុចរិតនៅក្នុងជីវិតយ៉ាងនោះដែរ។[19]ដូច្នេះ ដោយសារមនុស្សម្នាក់ដែលមិនស្តាប់បង្គាប់ ធ្វើឲ្យមនុស្សជាច្រើនត្រូវមានបាបយ៉ាងណា
ដូចគ្នាដែរ តាមរយៈការស្តាប់បង្គាប់របស់មនុស្សម្នាក់ នឹងធ្វើឲ្យមនុស្សជាច្រើនបានសុចរិតយ៉ាងនោះដែរ។

generated on Wed Sep 10 16:16:32 2025

[20]ប៉ុន្តែ ក្រឹត្យវិន័យបានមក ដើម្បីឲ្យអំពើរំលងកាន់តែច្រើនឡើង។ ប៉ុន្តែ ទីណាមានបាបច្រើន នៅទីនោះក៏មានព្រះគុណច្រើនដែរ។[21]ការនេះបានកើតឡើង
ដូចដែលបាបបានគ្រប់គ្រងធ្វើឲ្យមនុស្សស្លាប់ ដូច្នេះ ព្រះគុណគ្រប់គ្រងក៏ធ្វើឲ្យបានសុចរិត សម្រាប់ជីវិតអស់កល្បជានិច្ច តាមរយៈព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង។

Romans 5:1
ការភ្ជាប់សេចក្តីថ្លែងការណ៍
លោកប៉ូលចាប់ផ្តើមនិយាយពីកិច្ចការខុសគ្នាជាច្រើន
ដែលកើតឡើងនៅពេលដែលព្រះជាម្ចាស់ធ្វើអោយអ្នកជឿមានសន្តិភាពជាមួយទ្រង់។
ដូច្នេះ
«ព្រោះ»
យើង...របស់យើង
ការជួបប្រទះទាំងអស់នៃពាក្យ «យើង» ឬ «របស់យើង»
សំដៅដល់អ្នកជឿទាំងអស់ និងគួរតែរាប់បញ្ចូល។
តាមរយៈព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើង
«ដោយសារព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើង»។
ព្រះអម្ចាស់
ពាក្យ «ព្រះអម្ចាស់» នៅទីនេះមានន័យថា ព្រះយេស៊ូ គឺជាព្រះ។
ដោយសារព្រះអង្គ យើងក៏មានផ្លូវចូលទៅកាន់ព្រះគុណដោយជំនឿ ដែលយើងឈរ
នៅទីនេះពាក្យ «ដោយជំនឿ» សំដៅលើជំនឿរបស់យើងលើព្រះយេស៊ូ
ដែលអនុញ្ញាតអោយយើងឈរនៅចំពោះព្រះភក្ត្រទ្រង់។
ការបកប្រែតាមរបៀបផ្សេងទៀត «ពីព្រោះយើងទុកចិត្តលើព្រះយេស៊ូ
ព្រះអង្គអនុញ្ញាតឲ្យយើងចូលមកក្នុងព្រះវត្តមានទ្រង់»។
Romans 5:3
មិនគ្រាន់តែប៉ុណ្ណោះទេ
ពាក្យ «ប៉ុណ្ណោះ» សំដៅលើការពណ៌នាគំនិតនៅក្នុងជំពូក ៥:១ ។
យើង...របស់យើង...យើង
ពាក្យដែលជួបទាំងអស់នៃពាក្យ «យើង» «របស់យើង» ហើយនិង «យើង»
គឺសំដៅដល់អ្នកជឿ និងគួរតែរាប់បញ្ចូល។
ការយល់ព្រម
ពាក្យ «ការយល់ព្រម» សំដៅដល់ការទទួលស្គាល់យើង របស់ព្រះជាម្ចាស់។
ទំនុកចិត្តនាពេលអនាគត
នេះគឺជាភាពពិតប្រាកដ
ដែលព្រះជាម្ចាស់នឹងសម្រេចសេចក្តីសន្យារបស់ទ្រង់សម្រាប់អស់អ្នកដែលទុកចិត្តលើទ្រង់។
ទំនុកចិត្តនេះ មិនធ្វើឲ្យយើងខកចិត្តឡើយ
លោកប៉ូលប្រើបដិរូបកម្មនៅទីនេះ ដែលលោកនិយាយពី «ទំនុកចិត្ត»
ដែលហាក់ដូចជាមានជីវិតរស់។ ការបកប្រែផ្សេងទៀត:
«យើងពិតជាមានទំនុកចិត្តខ្លាំងណាស់ ថាយើងនឹងទទួលអ្វីៗដែលយើងបានរង់ចាំ
Romans 5:6
យើង
ពាក្យ «យើង» នៅទីនេះ សំដៅដល់អ្នកជឿទាំងអស់
ហើយដែលគួររាប់បញ្ចូលដែរ។
កម្រមានអ្នកព្រមស្លាប់ជំនួសមនុស្សសុចរិតណាស់
«វាពិបាកស្វែងរកមនុស្សណាម្នាក់ដែលសុខចិត្តស្លាប់
ទោះជាសម្រាប់មនុស្សល្អក្តី»។
ហើយប្រហែលជាមានអ្នកដែលហ៊ានស្លាប់សម្រាប់មនុស្សល្អដែរ
«ប៉ុន្តែ អ្នកអាចស្វែងរកមនុស្ស ដែលសុខចិត្តស្លាប់សម្រាប់មនុស្សល្អដែរ»។
Romans 5:8
បានបង្ហាញ
អ្នកអាចបកប្រែកិរិយាសព្ទនេះក្នុង ទម្រង់អតីតកាល « បានធ្វើទស្សនីយ៍ភាព» ឬ
«បានបង្ហាញ» ។
យើង...យើង
រាល់ការជួបពាក្យ «យើង» និង «យើង» សំដៅដល់អ្នកជឿទាំងអស់
និងគួរតែរាប់បញ្ចូល។
លើសពីនេះ យើងបានសុចរិតដោយសារព្រះលោហិតរបស់ព្រះអង្គ
នៅទីនេះពាក្យ «សុចរិត» មានន័យថា
ព្រះជាម្ចាស់ដាក់យើងទៅក្នុងទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះអង្គផ្ទាល់។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមបែបផ្សេងទៀត:
«ឥឡូវនេះ តើព្រះជាម្ចាស់បានធ្វើអ្វីខ្លះសម្រាប់យើងរាល់គ្នា
ដែលទ្រង់បានធ្វើឲ្យយើងបានត្រឹមត្រូវជាមួយអង្គទ្រង់
ដោយសារព្រះគ្រិស្តបានសុគតនៅលើឈើឆ្កាង»។
ព្រះលោហិត
នេះជាការប្រៀបធៀបសម្រាប់យញ្ញបូជាស្លាប់របស់ព្រះយេស៊ូនៅលើឈើឆ្កាង។
បានសង្គ្រោះ
ពាក្យនេះមានន័យថា តាមរយៈយញ្ញបូជាស្លាប់របស់ព្រះយេស៊ូនៅលើឈើឆ្កាង
ព្រះជាម្ចាស់បានអត់ទោសដល់យើងរាល់គ្នា
និងសង្គ្រោះយើងពីថ្កោលទោសនៅក្នុងបឹងភ្លើងសម្រាប់អំពើបាបរបស់យើង។
សេចក្តីក្រោធ នៃព្រះជាម្ចាស់
ពាក្យ «សេចក្តីក្រោធ» នៅទីនេះ ជាពាក្យប្រៀបធៀប
ដែលសំដៅដល់ការថ្កោលទោសរបស់ព្រះជាម្ចាស់ ចំពោះអស់អ្
នកដែលបានធ្វើអំពើបាបទាស់នឹងទ្រង់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ការថ្កោលទោសរបស់ព្រះជាម្ចាស់»។
Romans 5:10
យើងបាន
រាល់ការជួបពាក្យ «យើង» សំដៅលើអ្នកជឿទាំងអស់
ហើយដែលគួរនឹងរាប់បញ្ចូល។)
បុត្រាព្រះអង្គ...ព្រះជន្មរបស់ព្រះអង្គ
«ព្រះរាជ្យបុត្រារបស់ព្រះ...ព្រះជន្មរបស់ព្រះរាជបុត្រារបស់ព្រះ»។
ហើយយើងបានផ្សះផ្សាជាមួយព្រះជាម្ចាស់តាមរយៈការសុគតរបស់ព្រះបុត្រាព្រះអង្គ
ការសុគតរបស់ព្រះបុត្រារបស់ព្រះជាម្ចាស់បានបង្ហាញការអត់ទោសជាសកល
ហើយធ្វើឲ្យយើងក្លាយជាមិត្តនឹងព្រះជាម្ចាស់
សម្រាប់អស់អ្នកដែលជឿលើព្រះយេស៊ូ។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់អនុញ្ញាតឲ្យយើងមានទំនាក់ទំនងសន្តិភាពជាមួយទ្រង់
ដោយសារព្រះបុត្រារបស់ព្រះអង្គបានសុគតជួសយើង»។
ព្រះបុត្រា
នេះគឺជា ឋានៈដ៏សំខាន់របស់ព្រះគ្រិស្ត ព្រះបុត្រារបស់ព្រះជាម្ចាស់។
បន្ទាប់ពីយើងបានផ្សះផ្សា
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ឥឡូវនេះ ដែលព្រះជាម្ចាស់បានផ្សះផ្សាយើងជាមិត្តរបស់ទ្រង់ម្តងទៀត»។
Romans 5:12
ប្រយោគភ្ជាប់
លោកប៉ូលពន្យល់ ហេតុអ្វីសេចក្តីស្លាប់កើតឡើង
ទោះបីមុនពេលប្រទានក្រឹត្យវិន័យទៅលោកម៉ូសេ។
តាមរយៈមនុស្សបាបម្នាក់បានចូលមក...
សេចក្តីស្លាប់បានចូលមកក្នុងលោកីយ៍ដោយសារបាបនោះដែរ
លោកប៉ូលបរិយាយថា
បាបគឺដូចជាជម្ងឺដែលបានមកក្នុងពិភពលោកតាមរយៈសកម្មភាពរបស់
«មនុស្សម្នាក់» គឺ អ័ដាម។ បាបនេះបានបើកមុខតាមរយៈសេចក្តីស្លាប់
ដែលរូបភាពនៅទីនេះ ហាក់ដូចជាជម្ងឺមួយផ្សេងទៀត
ដែលបានមកក្នុងពិភពលោកដែល។
រហូតដល់មានក្រឹត្យវិន័យ បាបបានចូលមកក្នុងលោកីយ៍ហើយ
ឃ្លានេះមានន័យថា
មនុស្សបានធ្វើបាបតាំងពីមុនពេលព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យមកម្ល៉ៈ។
ការបកប្រែផ្សេងទៀត: «មនុស្សក្នុងពិភពលោកទាំងអស់បានប្រព្រឹត្យអំពើបាប
មុនពេលដែលព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យទៅលោកម៉ូសេ»
ប៉ុន្តែ បាបមិនត្រូវបានស្គាល់នៅឡើយទេ ដោយសារមិនទាន់មានក្រឹត្យវិន័យនៅឡើយ
ឃ្លានេះមានន័យថា ព្រះជាម្ចាស់មិនចោទប្រកាន់មនុស្សជាមួយអំពើបាប
មុនគេពេលទ្រង់ប្រទានក្រឹត្យវិន័យនោះទេ។ ការបកប្រែផ្សេងទៀត: «ប៉ុន្តែ
ព្រះជាម្ចាស់បានកត់ចំណាំថាមិនមានបាបប្រឆាំងនឹងក្រឹត្យវិន័យទេ
មុនពេលព្រះអង្គប្រទានក្រឹត្យវិន័យមក»។
Romans 5:14
យ៉ាងណាក៏ដោយ
ឃ្លា «នៅឡើយ» ឬ «ប៉ុន្តែ ចាប់តាំងពីជំនាន់អដាំ រហូតដល់លោកម៉ូសេ
គឺនៅមិនទាន់មានក្រឹត្យវិន័យដែលបានចារឹកនោះទេ»។ ពាក្យ «យ៉ាងណាក៏ដោយ»

generated on Wed Sep 10 16:16:32 2025

ភ្ជាប់វគ្គនេះជាមួយនឹងខដែល ទើបនឹងរំលងមកខាងមុខនោះ។ (សូមមើល: ៥:១២)
សេចក្តីស្លាប់បានគ្រប់គ្រងលើលោកអដាំរហូតដល់លោកម៉ូសេ
លោកប៉ូលកំពុងមានប្រសាសន៍អំពីសេចក្តីស្លាប់
ដែលបីដូចជាស្តេចដែលគ្រប់គ្រង។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មនុស្សបានបន្តស្លាប់ពីជំនាន់អដាំ រហូតដល់ជំនាន់លោកម៉ូសេ
ជាផលនៃអំពើបាបរបស់ពួកគេ»។
ថែមទាំងគ្រប់គ្រងលើអស់អ្នកដែលមិនបានធ្វើបាបនៃការមិនស្តាប់បង្គាប់ដូចជាលោកអដាំដែរ
«ទោះបីមនុស្សបានធ្វើបាបខុសគ្នាពីបាបរបស់លោកអដាំ
ក៏ពួកគេនៅតែបន្តស្លាប់»។
ក៏មានម្នាក់ដែលមានលក្ខណៈដូចជាគាត់ដែល នឹងមក
លោកអាដាំគឺជារូបដំណាងរបស់ព្រះគ្រិស្ត
ដែលបានបង្ហាញជាច្រើនលើកនៅពេលក្រោយ។
លោកមានទំនាក់ទំនងជាច្រើនជាមួយនឹងទ្រង់។
ដូច្នេះ ប្រសិនបើការរំលងរបស់មនុស្សម្នាក់ធ្វើឲ្យមនុស្សជាច្រើនបានស្លាប់
នៅទីនេះពាក្យ «ម្នាក់» សំដៅដល់លោកអាដាំ។ ការបកប្រែផ្សេងទៀត:
«ដោយសារតែអំពើបាបរបស់មនុស្សម្នាក់ មនុស្សជាច្រើនបានស្លាប់។»។
តើព្រះគុណរបស់ព្រះជាម្ចាស់ និងអំណោយទាន ដោយសារព្រះជាម្ចាស់នៃមនុស្សម្នាក់
គឺព្រះយេស៊ូគ្រិស្ត នឹងមានលើសជាយ៉ាងណាទៅទៀត។
នៅទីនេះពាក្យ «ព្រះគុណ»
សំដៅដល់អំណោយដែលមិនមានលក្ខណៈរបស់ព្រះជាម្ចាស់
ដែលទ្រង់បានធ្វើសម្រាប់មនុស្សគ្រប់គ្នាទាំងអស់តាមរយៈព្រះយេស៊ូគ្រិស្ត។
ការបកប្រែផ្សេងទៀត: «ទោះបីជាយើងមិនស័ក្តិសមនឹងទទួលយ៉ាងណាក៏ដោយ
ព្រះជាម្ចាស់ដែលពេញដោយសេចក្តីសប្បុរសបានប្រទានជីវិតដ៏អស់កល្បជាអំណោយទាន
តាមរយៈព្រះយេស៊ូគ្រិស្ត ដែលបានសុគតសម្រាប់យើងរាល់គ្នា»។
Romans 5:16
អំណោយទាននេះ មិនដូចជាលទ្ធផលនៃម្នាក់ដែលបានធ្វើបាបទេ
ពាក្យ «អំណោយទាន» នៅទីនេះ សំដៅដល់ការលុបចោលអំពើបាបរបស់យើង
របស់ព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត: «អំណោយទានដ៏បរិបូរ
គឺមិនដូចជាលទ្ធផលនៃអំពើបាបរបស់អដាំនោះទេ»។
ផ្ទុយទៅវិញ ការជំនុំជម្រះនៃការកាត់ទោសបានមក ដោយសារការរំលងនៃមនុស្សម្នាក់។ ក៏ប៉ុន្តែ
អំណោយទានបានធ្វើឲ្យមានសេចក្តីសុចរិត
នៅទីនេះលោកប៉ូលបានផ្តល់នូវហេតុផលពីរ ថា: «អំណោយទាន
គឺមិនដូចជាផលនៃអំពើបាបរបស់អដាំឡើយ»។ ឃ្លា «សម្រាប់ការជំនុំជម្រះ» ឬ
«ប៉ុន្តែការជំនុំជម្រះ» ណែនាំពីវិធីខុសគ្នាពីរយ៉ាងអំពីរឿងអ្វីមួយ។
«ការជំនុំជម្រះនៃការវិនិច្ឆ័យទោស»
បញ្ជាក់ថាយើងរាល់គ្នាសុទ្ធតែសមគួរនឹងការកាត់ទោសរបស់ព្រះជាម្ចាស់សម្រាប់អំពើបាបរបស់យើង
ការបកប្រែផ្សេងទៀត: «ដ្បិតការជំនុំជម្រះ
ព្រះជាម្ចាស់បានប្រកាសថាមនុស្សទាំងអស់សមនឹងទទួលការថ្កោលទោស
ព្រោះតែអំពើបាបរបស់មនុស្សម្នាក់ ប៉ុន្តែជាអំណោយទាន»។
អំណោយទានបានធ្វើឲ្យមានសេចក្តីសុចរិត
ឃ្លានេះសំដៅដល់របៀបដែលព្រះជាម្ចាស់ ធ្វើអោយយើងបានជានាជាមួយទ្រង់
ទោះបីជាយើងមិនស័ក្តិសមនឹងទទួលក៏ដោយ។ ការបកប្រែផ្សេងទៀត
«អំណោយទានរបស់ព្រះជាម្ចាស់ ដើម្បីដាក់ឲ្យយើងជានាជាមួយព្រះអង្គផ្ទាល់»។
បន្ទាប់ពីមានការរំលងជាច្រើន
«បន្ទាប់ពីអំពើបាបជាច្រើន»។
ការរំលងរបស់មនុស្សម្នាក់
ឃ្លានេះសំដៅលើអំពើបាបរបស់លោកអដាំ
សេចក្តីស្លាប់បានគ្រប់គ្រង
លោកប៉ូលនិយាយពី «សេចក្តីស្លាប់» នៅទីនេះ ដូចជាស្តេចដែលគ្រប់គ្រង។
«ការគ្រប់គ្រង» របស់សេចក្តីស្លាប់បណ្តាលឲ្យគ្រប់គ្នាស្លាប់។
ការបកប្រែផ្សេងទៀត: «គ្រប់គ្នាស្លាប់»។
ជីវិតគ្រប់គ្រងលើម្នាក់
ឃ្លានេះសំដៅដល់ជីវិតរបស់ព្រះយេស៊ូគ្រិស្ត។
Romans 5:18
ដោយសារម្នាក់បានប្រព្រឹត្តរំលង
«តាមរយៈមនុស្សធ្វើបាបដែលបានភ្ជាប់ដោយអដាំ» ឬ
«ព្រោះអំពើបាបរបស់អាដាំ»។
មនុស្សគ្រប់រូបត្រូវទទួលការជំនុំជម្រះ
ពាក្យ «ការជំនុំជម្រះ» នៅទីនេះ សំដៅដល់ការវិនិច្ឆ័យទោសរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត
«មនុស្សទាំងអស់ស័ក្តិសមនឹងទទួលការកាត់ទោសសម្រាប់អំពើបាប»។
មនុស្សម្នាក់ដែលប្រព្រឹត្ត
យញ្ញបូជារបស់ព្រះយេស៊ូគ្រិស្ត
មនុស្សគ្រប់គ្នាមានសេចក្តីសុចរិតនៅក្នុងជីវិត
ពាក្យ «សេចក្តីសុចរិត» នៅទីនេះ
សំដៅដល់អំណាចរបស់ព្រះជាម្ចាស់ដែលធ្វើឲ្យមនុស្សបានជានាជាមួយនឹងទ្រង់។
ការបកប្រែផ្សេងទៀត: «អំណោយរបស់ព្រះជាម្ចាស់
ដើម្បីធ្វើឲ្យមនុស្សទាំងអស់បានជានាជាមួយនឹងទ្រង់»។ (មើល:figs-explicit)
មនុស្សម្នាក់ដែលមិនស្តាប់បង្គាប់
ការមិនស្តាប់បង្គាប់របស់លោកអដាំ
ធ្វើឲ្យមនុស្សជាច្រើនត្រូវមានបាប
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«មនុស្សជាច្រើនបានប្រព្រឹត្តបាប»។
ការស្តាប់បង្គាប់របស់មនុស្សម្នាក់
ការស្តាប់បង្គាប់របស់ព្រះយេស៊ូ
នឹងធ្វើឲ្យមនុស្សជាច្រើនបានសុចរិត
អ្នកអាចបកប្រែតាមទម្រង់បែបនេះថា
«ព្រះជាម្ចាស់នឹងធ្វើអោយមនុស្សជាច្រើនជានាជាមួយព្រះជាម្ចាស់»។
Romans 5:20
ក្រឹត្យវិន័យបានមក
នៅទីនេះលោកប៉ូលក្រឹត្យវិន័យ ដែលដូចជាមនុស្សម្នាក់។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យមកលោកម៉ូសេ»
អំពើរំលងកាន់តែច្រើនឡើង
លោកប៉ូលនិយាយពី «អំពើរំលង» ឬបាបដែលហាក់ដូចជាមានជីវិត។
ការបកប្រែផ្សេងទៀត: «ដែលមនុស្សអាចដឹង ថាតើពួកគេមានបាបយ៉ាងណា»
កាន់តែច្រើនឡើង
«បានកើនឡើន»
ព្រះគុណក៏កាន់តែច្រើនឡើងដែរ
នៅទីនេះពាក្យ «ព្រះគុណ» សំដៅដល់ព្រះគុណដ៏លើសលុបរបស់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់នៅតែបន្តធ្វើការដោយសេចក្តីសប្បុរសទៅរកពួកគេ
ក្នុងរបៀបដែលពួកគេមិនស័ក្តិសមនឹងទទួល»
ដូចដែលបាបបានគ្រប់គ្រងធ្វើឲ្យមនុស្សស្លាប់
នៅទីនេះលោកប៉ូលបានមានប្រសាសន៍អំពី «បាប»
ដែលប្រៀបបាននឹងស្តេចដែលគ្រងរាជ្យ។ ការបកប្រែផ្សេងទៀត:
«ផលនៃអំពើបាបគឺសេចក្តីស្លាប់»។
ដូច្នេះ ព្រះគុណគ្រប់គ្រងក៏ធ្វើឲ្យបានសុចរិត សម្រាប់ជីវិតអស់កល្បជានិច្ច
តាមរយៈព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង
លោកប៉ូលបានមានប្រសាសន៍អំពី «ព្រះគុណ» នៅទីនេះ
ដែលប្រៀបបាននឹងស្តេចដែលគ្រងរាជ្យ។ ការបកប្រែផ្សេងទៀត:
«ព្រះគុណបានប្រទានឲ្យមនុស្សមានជីវិតអស់កល្បតាមរយៈសេចក្តីសុចរិតរបស់ព្រះយេស៊ូ
ជាព្រះអម្ចាស់របស់យើង»។
ដូច្នេះ ព្រះគុណគ្រប់គ្រងក៏ធ្វើឲ្យបានសុចរិត
លោកប៉ូលបាននិយាយអំពី «ព្រះគុណ» នៅទីនេះ
ដែលប្រៀបបាននឹងស្តេចដែលគ្រងរាជ្យ។ ពាក្យ «សេចក្តីសុចរិត»
សំដៅដល់អំណាចរបស់ព្រះជាម្ចាស់ដែលធ្វើអោយមនុស្សជានាជាមួយទ្រង់។
ការបកប្រែផ្សេងទៀត: «ដូច្នេះ
ព្រះជាម្ចាស់ប្រទានអំណោយដែលមិនគិតថ្លៃដល់មនុស្ស
ដើម្បីឲ្យពួកគេបានត្រឹមត្រូវជាមួយទ្រង់»។
ព្រះអម្ចាស់នៃយើង
លោកប៉ូលរាប់បញ្ចូលទាំងរូបលោកផ្ទាល់ អ្នកអានរបស់លោក និង
អ្នកជឿទាំងអស់។

[1]ដូច្នេះ តើយើងនឹងនិយាយយ៉ាងដូចម្តេច? តើគួរឲ្យយើងបន្តនៅក្នុងបាបទៀត ដើម្បីឲ្យព្រះគុណបានចម្រើនឡើង?[2]មិនអាចធ្វើដូច្នេះបានទេ។
យើងដែលបានស្លាប់ខាងឯបាបហើយ តើយើងអាចរស់នៅក្នុងបាបដូចម្តេចទៀតបាន?[3]តើអ្នកមិនដឹងទេឬអីថា មានមនុស្សជាច្រើនបានជ្រមុជនៅក្នុងព្រះគ្រិស្តយេស៊ូ
គឺបានជ្រមុជទៅក្នុងសេចក្តីស្លាប់របស់ព្រះអង្គ?
[4]យើងត្រូវបានកប់ ដូច្នេះ តាមរយៈព្រះអង្គ យើងបានជ្រមុជទៅក្នុងសេចក្តីស្លាប់ជាមួយព្រះអង្គ។ ការនេះ បានកើតឡើង
ដើម្បីឲ្យបានដូចជាព្រះគ្រិស្តបានរស់ឡើងវិញពីស្លាប់តែម្តង ដោយសារសិរីល្អព្រះបិតា ដូច្នេះ យើងត្រូវតែដើរនៅក្នុងជីវិតថ្មីនេះ។[5]ប្រសិនបើ
យើងបានរួមតែមួយជាមួយព្រះអង្គនៅក្នុងសេចក្តីស្លាប់ យើងក៏នឹងរួមជាមួយការរស់ឡើងវិញរបស់ព្រះអង្គដែរ។
[6]យើងដឹងការនេះ ថាមនុស្សចាស់របស់យើងត្រូវបានឆ្កាងជាមួយព្រះអង្គ ដើម្បីឲ្យរូបកាយនៃបាបអាចបំផ្លាញ។ ការនេះបានកើតឡើង
ដើម្បីយើងលែងស្ថិតនៅក្នុងភាពជាទាសកររបស់បាបទៀត។[7]អស់អ្នកដែលបានស្លាប់ហើយគឺប្រកាសពីសេចក្តីសុចរិត លែងពាក់ព័ន្ធជាមួយបាបទៀតហើយ។
[8]ប៉ុន្តែ ប្រសិនបើ យើងបានស្លាប់ជាមួយព្រះគ្រិស្តហើយ យើងជឿថា យើងនឹងរស់នៅជាមួយព្រះអង្គ។[9]យើងដឹងថា ព្រះគ្រិស្តបានរស់ពីសុគតឡើងវិញតែម្តង
ហើយទ្រង់ក៏លែងស្លាប់ទៀតហើយ។ សេចក្តីស្លាប់លែងគ្រប់គ្រងលើព្រះអង្គទៀតហើយ។
[10]ទាក់ទងទៅនឹងការសុគតគឺព្រះអង្គសុគតចំពោះបាប ទ្រង់បានសុគតតែម្តងសម្រាប់មនុស្សគ្រប់គ្នា។ ប៉ុន្តែ ជីវិតដែលព្រះអង្គរស់នៅ ទ្រង់រស់នៅសម្រាប់ព្រះជាម្ចាស់។
[11]ដូចគ្នាដែរ អ្នកត្រូវតែគិតថាខ្លួនអ្នកក៏ត្រូវតែស្លាប់ចំពោះបាបដែរ ប៉ុន្តែ រស់នៅគឺរស់នៅថ្វាយព្រះជាម្ចាស់នៅក្នុងព្រះគ្រិស្តយេស៊ូ។
[12]ដូច្នេះហើយ មិនត្រូវអនុញ្ញាតបាបគ្រប់គ្រងនៅក្នុងរូបកាយដែលពុករលួយ ដើម្បីឲ្យអ្នកអាចនឹងធ្វើតាមតណ្ហារបស់រូបកាយនោះ។
[13]កុំប្រគល់ចំណែកណាមួយនៅក្នុងរូបកាយរបស់អ្នកទៅកាន់បាប ដើម្បីធ្វើជាឧបករណ៍សម្រាប់សេចក្តីទុច្ចរិតឡើយ។ ប៉ុន្តែ ចូរថ្វាយខ្លួនរបស់អ្នកទៅកាន់ព្រះជាម្ចាស់
ពីមុនយើងស្លាប់ តែឥឡូវយើងរស់។ ហើយថ្វាយផ្នែកនៃរូបកាយរបស់អ្នកទៅព្រះជាម្ចាស់ ជាឧបរណ៍សម្រាប់ប្រើក្នុងសេចក្តីសុចរិតវិញ។
[14]កុំអនុញ្ញាតឲ្យបាបបានគ្រប់គ្រងលើអ្នកឡើយ។ ព្រោះអ្នកមិនស្ថិតនៅក្រោមក្រឹត្យវិន័យឡើយ ប៉ុន្តែ នៅក្នុងព្រះគុណវិញ។
[15]បើដូច្នេះ តើយើងគួរធ្វើបាប ដោយព្រោះយើងមិនស្ថិតនៅក្រោមក្រឹត្យវិន័យមែន ហើយនៅក្រោមព្រះគុណមែនទេ? មិនអាចធ្វើដូច្នោះទេ។[16]តើអ្នកមិនដឹងទេឬអីថា
អ្នកដែលអ្នកថ្វាយខ្លួនរបស់អ្នកដូចជាអ្នកបម្រើគឺជាម្ចាស់ដែលត្រូវស្តាប់បង្គាប់ តើអ្នកត្រូវស្តាប់នរណា? ការនេះគឺជាសេចក្តីពិត
មិនថាអ្នកជាអ្នកបម្រើនៃអំពើបាបដែលនាំអ្នកទៅក្នុងសេចក្តីស្លាប់ ឬជាអ្នកបម្រើដែលស្តាប់បង្គាប់ ដែលនាំទៅរកសេចក្តីសុចរិត។
[17]ប៉ុន្តែ សូមអរគុណដល់ព្រះជាម្ចាស់! ព្រោះអ្នកធ្លាប់ជាអ្នកបម្រើរបស់បាប ប៉ុន្តែ អ្នកបានស្តាប់បង្គាប់ពីចិត្តតាមគំរូនៃសេចក្តីបង្រៀនដែលបានប្រគល់ដល់អ្នក។
[18]អ្នកបានមានសេរីភាពពីបាបហើយ ហើយអ្នកបានធ្វើឲ្យក្លាយជាអ្នកបម្រើនៃសេចក្តីសុចរិតវិញ។
[19]ខ្ញុំនិយាយដូចជាមនុស្សទូទៅ ដោយសារសេចក្តីកម្សោយនៃសាច់ឈាមរបស់អ្នក។ ដោយព្រោះអ្នកបានថ្វាយខ្លួនរបស់អ្នកឲ្យធ្វើជាទាសកររំចំពោះសេចក្តីដែលមិនស្អាត
ហើយចំពោះការអាក្រក់ ដូច្នេះនេះដែរ នៅពេលនេះ ចូរថ្វាយខ្លួនរបស់អ្នកដូចជាទាសករនៃសេចក្តីសុចរិតវិញ ដើម្បីឲ្យបានសុចរិត។[20]ព្រោះ
នៅពេលអ្នកធ្លាប់ជាទាសករនៃបាប អ្នកមានសេរីភាពពីសេចក្តីសុចរិត។[21]នៅពេលនោះ តើផលផ្លែអ្វីដែលយើងមានពីការអ្វីដែលអ្នកមានសព្វថ្ងៃនេះគឺភាពអាម៉ាស់? ដ្បិត
លទ្ធផលនៃការទាំងអស់នោះគឺជាសេចក្តីស្លាប់។
[22]ប៉ុន្តែ នៅពេលនេះ អ្នកត្រូវបានដោះឲ្យមានសេរីភាពពីបាប ហើយគឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់វិញ អ្នកបានទទួលផលរបស់អ្នកសម្រាប់សេចក្តីសុចរិតផងដែរ។
ជាលទ្ធផលគឺបានជីវិតអស់កល្បជានិច្ច។[23]ព្រោះឈ្នួលនៃបាបគឺជាសេចក្តីស្លាប់ ប៉ុន្តែ
អំណោយទាននៃព្រះជាម្ចាស់វិញគឺជាជីវិតអស់កល្បជានិច្ចនៅក្នុងព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើង។

Romans 6:1

ប្រយោគភ្ជាប់

នៅក្រោមព្រះគុណ លោកប៉ូលប្រាប់ថា អស់អ្នកដែលជឿលើព្រះយេស៊ូ
រស់នៅក្នុងជីវិតថ្មី គឺដូចជាគំនិតដែលស្លាប់សម្រាប់បាប
ហើយរស់សម្រាប់ព្រះជាម្ចាស់វិញ។

ដូច្នេះ តើយើងនឹងនិយាយយ៉ាងដូចម្តេច? តើគួរឲ្យយើងបន្តនៅក្នុងបាបទៀត
ដើម្បីឲ្យព្រះគុណបានចម្រើនឡើង?

លោកប៉ូលសួរសំណួរទាំងនេះ
ដើម្បីទាក់ទាញចំណាប់អារម្មណ៍អ្នកអានរបស់លោក។ ការបកប្រែផ្សេងទៀត:
«ដូច្នេះ តើយើងគួរនិយាយយ៉ាងដូចម្តេចអំពីរឿងទាំងនេះ? ពិតណាស់
យើងត្រូវបញ្ឈប់ការធ្វើបាប ដូច្នេះព្រះជាម្ចាស់នឹងប្រទានព្រះគុណបន្ថែម
ហើយបន្ថែមទៀតមកយើង»។

យើងនិយាយ
សព្វនាម «យើង» សំដៅដល់លោកប៉ូល អ្នកអានរបស់លោក
និងមនុស្សដទៃទៀត។

យើងដែលបានស្លាប់ខាងឯបាបហើយ តើយើងអាចរស់នៅក្នុងបាបដូចម្តេចទៀតបាន?
នៅទីនេះឃ្លា «បានស្លាប់ខាងឯបាប» មានន័យថាអស់អ្នកដែលតាមព្រះគ្រិស្ត
ឥឡូវនេះ គឺដូចជាមនុស្សស្លាប់ ដែលអំពើបាបគ្មានអំណាចលើគេទៀតទេ។
លោកប៉ូលប្រើសំណួរដែលមិនទាមទារចម្លើយនេះ ដើម្បីបន្ថែមអត្ថន័យ។
ការបកប្រែផ្សេងទៀត: «យើងរាល់គ្នា ឥឡូវនេះ ដូចជាមនុស្សស្លាប់
ដែលអំពើបាបមិនមានអំណាចលើយើងទៀតទេ»។ ដូច្នេះពិតណាស់
យើងមិនត្រូវបន្តការប្រព្រឹត្តបាបទៀតនោះទេ!»

យើងដែលបានស្លាប់ខាងឯបាបហើយ តើយើងអាចរស់នៅក្នុងបាបដូចម្តេចទៀតបាន?
លោកប៉ូលប្រើសំណួរនេះ ដើម្បីបន្ថែមអត្ថន័យ។ ការបកប្រែផ្សេងទៀត: «ចូរចាំថា
នៅពេលដែលអ្នកណាម្នាក់បានទទួលពិធីជ្រមុជ
យើងបង្ហាញថាយើងមានទំនាក់ទំនងជាមួយព្រះគ្រិស្ត ការនេះក៏បង្ហាញថា
យើងបានស្លាប់ជាមួយព្រះគ្រិស្តនៅលើឈើឆ្កាង»។

Romans 6:4

យើងត្រូវបានកប់ ដូច្នេះ តាមរយៈព្រះអង្គ យើងបានជ្រមុជទៅក្នុងសេចក្តីស្លាប់
នៅទីនេះលោកប៉ូលនិយាយពីការជ្រមុជក្នុងទឹករបស់អ្នកជឿដែលហាក់វាដូចជាការស្លាប់និងកប់ក្នុងផ្នូរ។
ការបកប្រែតាមរបៀបផ្សេងទៀត «ពេលដែលអ្នកណាម្នាក់ជ្រមុជយើង
គឺដូចជាមនុស្សម្នាក់នោះបានកប់យើងជាមួយព្រះគ្រិស្តក្នុងផ្នូរ។ (មើលៈfigs-metaphor)

ដើម្បីឲ្យបានដូចជាព្រះគ្រិស្តបានរស់ឡើងវិញពីស្លាប់តែម្តង ដោយសារសិរីល្អព្រះបិតា ដូច្នេះ
យើងត្រូវតែដើរនៅក្នុងជីវិតថ្មីនេះ
ឃ្លានេះប្រៀបធៀបជីវិតថ្មីខាងវិញ្ញាណរបស់អ្នកជឿ
ទៅនឹងការត្រឡប់មកវិញរបស់ព្រះយេស៊ូក្នុងជីវិតបែបសាច់ឈាម។
ជីវិតថ្មីខាងវិញ្ញាណរបស់អ្នកជឿ ធ្វើឲ្យគេមានសមត្ថភាពស្តាប់បង្គាប់ព្រះជាម្ចាស់។
អ្នកអាចបកប្រែក្នុងទម្រង់បែបនេះថា
«ដូចដែលព្រះបិតាបាននាំព្រះយេស៊ូត្រឡប់ទៅកាន់ជីវិតបន្ទាប់ពីទ្រង់បានសុគត
យើងអាចមានជីវិតខាងវិញ្ញាណ និងគោរពព្រះជាម្ចាស់»។

បានរួមតែមួយជាមួយព្រះអង្គនៅក្នុងសេចក្តីស្លាប់
យើងក៏នឹងរួមជាមួយការរស់ឡើងវិញរបស់ព្រះអង្គដែរ
លោកប៉ូលប្រៀបធៀបការរួមគ្នាមកតែមួយរបស់យើងជាមួយព្រះគ្រិស្តទៅក្នុងសេចក្តីស្លាប់។
អស់អ្នកដែលរួមគ្នាជាមួយព្រះគ្រិស្តក្នុងសេចក្តីស្លាប់នឹងរួមចំណែកជាមួយការរស់ឡើងវិញរបស់ព្រះអង្គដែ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«បានស្លាប់ជាមួយទ្រង់...បានរស់ឡើងវិញជាមួយទ្រង់»។

Romans 6:6

មនុស្សចាស់របស់យើងត្រូវបានឆ្កាងជាមួយព្រះអង្គ
ពាក្យថា «មនុស្សចាស់»
ជាការប្រៀបធៀបដែលសំដៅដល់មនុស្សមុនពេលដែលគាត់ជឿលើព្រះយេស៊ូ។
លោកប៉ូលពណ៌នាថា
នៅពេលដែលយើងជឿលើព្រះយេស៊ូមនុស្សចាស់ដែលពេញដោយអំពើបាបរបស់យើង
ដូចជាបានស្លាប់នៅលើឈើឆ្កាងជាមួយទ្រង់។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«មនុស្សដែលពេញដោយអំពើបាបរបស់យើងបានស្លាប់នៅលើឈើឆ្កាងជាមួយព្រះយេស៊ូ»។

មនុស្សចាស់
ពាក្យនេះមានន័យថា មនុស្សម្នាក់ដែលធ្លាប់មាន ប៉ុន្តែ ឥឡូវនេះមិនមានទៀតទេ។

generated on Wed Sep 10 16:16:32 2025

រូបកាយនៃបាប
ឃ្លានេះជាការប្រៀបធៀបដែលសំដៅដល់មនុស្សម្នាក់ដែលពេញដោយអំពើបាប។
ការបកប្រែផ្សេងទៀត: «ធម្មជាតិនៃអំពើបាបរបស់យើង»។
អាចបំផ្លាញ
អ្នកអាចបកប្រែថា «អាចស្លាប់»។
ដើម្បីយើងលែងស្ថិតនៅក្នុងភាពជាទាសកររបស់បាបទៀត
លោកប៉ូលប្រៀបធៀបអំណាចនៃអំពើបាបដែលមានលើមនុស្ស
ទៅនឹងចៅហ្វាយដែលត្រួតត្រាលើទាសករ។
មនុស្សដែលមិនមានព្រះវិញ្ញាណបរិសុទ្ធ
មិនមានសេរីភាពនឹងធ្វើការអ្វីដែលសព្វព្រះទ័យព្រះជាម្ចាស់នោះទេ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«យើងមិនគួរបន្តជ្រើសរើសការប្រព្រឹត្តអំពើបាបទៀតនោះទេ»។
អស់អ្នកដែលបានស្លាប់ហើយគឺប្រកាសពីសេចក្តីសុចរិត លែងពាក់ព័ន្ធជាមួយបាបទៀតហើយ។
នៅទីនេះពាក្យ «សេចក្តីសុចរិត» សំដៅដល់អំណាចព្រះជាម្ចាស់
ដែលធ្វើឲ្យមនុស្សបានត្រឹមត្រូវជាមួយទ្រង់។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ពេលដែលព្រះជាម្ចាស់ប្រកាសថាមនុស្សម្នាក់បានជានាជាមួយទ្រង់
នោះមានន័យថា បានមិនមានអំណាចត្រួតត្រាលើគេទៀតនោះទេ»។
Romans 6:8
យើងបានស្លាប់ជាមួយព្រះគ្រិស្ត
ុពាក្យ «បានស្លាប់» នៅទីនេះ
សំដៅដល់កត្តាដែលបាបមិនអាចគ្រប់គ្រងលើអ្នកជឿទៀតទេ។
យើងដឹងថា ព្រះគ្រិស្តបានរស់ពីសុគតឡើងវិញតែម្តង
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«យើងដឹងថាបន្ទាប់ពីចូលទីវង្គត ព្រះជាម្ចាស់បាននាំព្រះគ្រិស្តមកកាន់ជីវិតវិញ»។
សេចក្តីស្លាប់លែងគ្រប់គ្រងលើព្រះអង្គទៀតហើយ
ពាក្យ «សេចក្តីស្លាប់» នៅទីនេះពណ៌នាដូចជាស្តេច
ឬអ្នកគ្រប់គ្រងដែលមានអំណាចលើមនុស្ស។ ការបកប្រែផ្សេងទៀត:
«ទ្រង់នឹងមិនសុគតទៀតទេ»។
Romans 6:10
ទាក់ទងទៅនឹងការសុគតគឺព្រះអង្គសុគតចំពោះបាប ទ្រង់បានសុគតតែម្តងសម្រាប់មនុស្សគ្រប់គ្នា
ក្នុងឃ្លា «តែម្តងសម្រាប់មនុស្សគ្រប់គ្នា» មានន័យថាបានបញ្ចប់អ្វីមួយទាំងស្រុង។
អ្នកអាចធ្វើឲ្យឃ្លានេះមានអត្ថន័យពេញលេញនៅក្នុងការបកប្រែរបស់អ្នក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ទ្រង់បានបំផ្លាញអំណាចរបស់អំពើបាបទាំងស្រុង នៅពេលដែលទ្រង់សុគត»។
ដូចគ្នាដែរ អ្នកត្រូវតែគិត
«ពិចារណាសម្រាប់ហេតុផលនេះ»។
គិតថាខ្លួនអ្នក
«គិតថាខ្លួនរបស់អ្នកជា» ឬ «ឃើញខ្លួនរបស់អ្នកជា»។
ស្លាប់ចំពោះបាប
ដូចជាសាកសពដែលមិនមានកម្លាំងនឹងធ្វើអ្វីមួយ
បាបមិនមានអំណាចធ្វើឲ្យអ្នកជឿមានកម្លាំងប្រឆាំងនឹងព្រះជាម្ចាស់ទេ។
ការបកប្រែផ្សេងទៀត: «អ្នកបានស្លាប់ពីអំណាចនៃអំពើបាប»។
ស្លាប់ចំពោះបាបដែរ ប៉ុន្តែ រស់នៅគឺរស់នៅថ្វាយព្រះជាម្ចាស់
«បានស្លាប់ពីអំណាចនៃអំពើបាប ប៉ុន្តែរស់នៅដើម្បីថ្វាយបង្គំព្រះជាម្ចាស់»។
រស់នៅថ្វាយព្រះជាម្ចាស់នៅក្នុងព្រះគ្រិស្តយេស៊ូ
«រស់នៅថ្វាយព្រះជាម្ចាស់
តាមរយៈអំណាចដែលព្រះគ្រិស្តយេស៊ូប្រទានអោយអ្នក»។
Romans 6:12
ប្រយោគភ្ជាប់
លោកប៉ូលរំលឹកយើងថា ព្រះគុណគ្រប់គ្រងលើយើង មិនមែនជាក្រឹត្យវិន័យទេ
យើងមិនមែនជាទាសកររបស់អំពើបាបឡើយ ប៉ុន្តែ ជាអ្នកបម្រើរបស់ព្រះជាម្ចាស់។
មិនត្រូវអនុញ្ញាតបាបគ្រប់គ្រង...កុំអនុញ្ញាតឲ្យបាបបានគ្រប់គ្រង
លោកប៉ូលពំណាអំពីបាប ដែលដូចជាស្តេច ឬជាចៅហ្វាយរបស់មនុស្សម្នាក់។
រូបកាយដែលពុករលួយរបស់អ្នក
ឃ្លានេះសំដៅលើផ្នែកនៃរូបកាយរបស់មនុស្ស ដែលនិងស្លាប់។
ការបកប្រែផ្សេងទៀត: «អ្នក»
ដើម្បីឲ្យអ្នកអាចនឹងធ្វើតាមតណ្ហារបស់រូបកាយនោះ
ជាចៅហ្វាយ «បាប» ចង់ឲ្យអ្នកប្រព្រឹត្តបាប
គោរពបទបញ្ជារបស់វាដើម្បីធ្វើការអាក្រក់។
កុំប្រគល់ចំណែកណាមួយនៅក្នុងរូបកាយរបស់អ្នកទៅកាន់បាប
ដើម្បីធ្វើជាឧបករណ៍សម្រាប់សេចក្តីទុច្ចរិតឡើយ
នេះជារូបភាពរបស់អ្នកប្រព្រឹត្តអំពើបាប ដែលថ្វាយ «ផ្នែកនៃរូបការរបស់គេ»
ទៅចៅហ្វាយឬ ស្តេចរបស់ពួកគេ។ ឃ្លាថា «ផ្នែកនៃរាងកាយ» របស់មនុស្សម្នាក់
ជាវេចនសព្ទសម្រាប់ដល់រូបមនុស្សទាំងមនុស្ស។ ការបកប្រែផ្សេងទៀត:
«កុំប្រគល់រូបកាយរបស់អ្នកទៅឲ្យអំពើបាបឡើយ ដូច្នេះ
អ្នកនឹងមិនប្រព្រឹត្តការដែលមិនត្រឹមត្រូវទេ»។
ប៉ុន្តែ ចូរថ្វាយខ្លួនរបស់អ្នកទៅកាន់ព្រះជាម្ចាស់ ពីមុនយើងស្លាប់ តែឥឡូវយើងរស់
នៅទីនេះឃ្លា «ឥឡូវយើងរស់នៅ» សំដៅដល់ជីវិតថ្មីខាងវិញ្ញាណរបស់អ្នកជឿ។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែ ថ្វាយខ្លួនរបស់អ្នកទៅព្រះជាម្ចាស់
ពីព្រោះទ្រង់បានប្រទានឲ្យអ្នកនូវជីវិតថ្មីខាងវិញ្ញាណ។
ថ្វាយផ្នែកនៃរូបកាយរបស់អ្នកទៅព្រះជាម្ចាស់ ជាឧបករណ៍សម្រាប់ប្រើក្នុងសេចក្តីសុចរិតវិញ
នៅទីនេះឃ្លា «ផ្នែកនៃរូបកាយរបស់អ្នក» ជាវេចនៈសព្ទ
ដែលសំដៅទៅដល់មនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត:
«អនុញ្ញាតឲ្យព្រះជាម្ចាស់ប្រើអ្នកសម្រាប់អ្វីដែលទ្រង់សព្វព្រះហឫទ័យ»។
កុំអនុញ្ញាតឲ្យបាបបានគ្រប់គ្រងលើអ្នកឡើយ
លោកប៉ូលនិយាយអំពី «បាប» នៅទីនេះដូចជាស្តេចដែលគ្រប់គ្រងលើមនុស្ស។
ការបកប្រែផ្សេងទៀត:
«កុំុអនុញ្ញាតឲ្យអំពើបាបត្រួតត្រាការសម្រេចចិត្តអ្វីដែលអ្នកធ្វើឡើយ» ឬ
«មិនត្រូវអនុញ្ញាតឲ្យខ្លួនរបស់អ្នកធ្វើអំពើបាបដែលអ្នកចង់ធ្វើឡើយ»
ព្រោះអ្នកមិនស្ថិតនៅក្រោមក្រឹត្យវិន័យឡើយ
ឃ្លា «នៅក្រោមក្រឹត្យវិន័យ»
មានន័យថាប្រធានបទមានដែនកំណត់និងភាពខ្សោយរបស់វា។
អ្នកអាចធ្វើឲ្យឃ្លានេះមានអត្ថន័យពេញលេញ ក្នុងការបកប្រែរបស់អ្នក។
ការបកប្រែផ្សេងទៀត:
«អ្នករាល់គ្នាមិនស្ថិតនៅក្នុងដែនកំណត់នៃក្រឹត្យវិន័យរបស់លោកម៉ូសេ
ដែលមិនអាចផ្តល់ឲ្យអ្នកនូវអំណាចក្នុងការបញ្ឈប់អំពើបាបបានទេ»។
ប៉ុន្តែ នៅក្នុងព្រះគុណវិញ
ឃ្លា «នៅក្នុងព្រះគុណ»
មានន័យថាអំណោយទានដែលមិនគិតថ្លៃរបស់ព្រះជាម្ចាស់
ប្រទាននូវអំណាចដែលបង្ខាំងចេញពីការប្រព្រឹត្តអំពើបាប។
អ្នកអាចធ្វើឲ្យឃ្លានេះមានអត្ថន័យពេញលេញក្នុងការបកប្រែរបស់អ្នក។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែ អ្នករាល់គ្នាស្ថិតក្នុងព្រះគុណរបស់ព្រះជាម្ចាស់
ដែលប្រទានឲ្យអ្នកនូវអំណាចដើម្បីបញ្ឈប់ការប្រព្រឹត្តអំពើបាប»។
Romans 6:15
បើដូច្នេះ តើយើងគួរធ្វើបាប ដោយព្រោះយើងមិនស្ថិតនៅក្រោមក្រឹត្យវិន័យមែន
ហើយនៅក្រោមព្រះគុណមែនទេ? មិនអាចធ្វើដូច្នោះទេ
លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ថា ការរស់នៅក្រោមព្រះគុណរបស់ព្រះ
គឺមិនមានហេតុផលសម្រាប់បាបនោះទេ។ ការបកប្រែផ្សេងទៀត:
«ទោះបីយ៉ាងណាក្តី
ពិតប្រាកដណាស់មិនមានន័យថាយើងអនុញ្ញាតឲ្យអំពើបានទៀតទេ
ព្រោះយើងរស់នៅដោយព្រះគុណ ជំនួសឲ្យក្រឹត្យវិន័យរបស់លោកម៉ូសេ»។
មិនអាចធ្វើដូច្នោះទេ
«អ្នកមិនគួរចង់ឲ្យវាកើតឡើងនោះទេ!» ឬ
«សូមព្រះជាម្ចាស់ជួយកុំអោយយើងប្រព្រឹត្តការណ៍នោះឡើយ!»
ឃ្លានេះបង្ហាញការសម្រេចចិត្តខ្លាំងបំផុត ដែលមិនអាចជំនួសបាន។ នៅទីនេះ
អ្នកក៏អាចប្រើឃ្លាផ្សេងទៀតក្នុងភាសាររបស់អ្នកដែលមានន័យដូចគ្នា។
មើលការបកប្រែរបស់អ្នកក្នុង ៣:៣១។
តើអ្នកមិនដឹងទេឬអីថា អ្នកដែលអ្នកថ្វាយខ្លួនរបស់អ្នកដូចជាអ្នកបម្រើគឺជាម្ចាក់ដែលត្រូវស្តាប់បង្គាប់
តើអ្នកត្រូវស្តាប់នរណា?
លោកប៉ូលប្រើភាសារនេះដើម្បីសង្កត់ធ្ងន់អ្នកណា ដែលគិតថាព្រះគុណរបស់ព្រះ
ជាហេតុផលរក្សាការប្រព្រឹត្តអំពើបាប។
អ្នកអាចមកប្រែឃ្លានេះក្នុងការសង្កត់ន័យបន្ថែម។ ការបកប្រែផ្សេងទៀត:
«អ្នកត្រូវដឹងថា អ្នកជាអ្នកបម្រើរបស់ចៅហ្វាយដែលអ្នកត្រូវគោរព!»
ការនេះគឺជាសេចក្តីពិត មិនថាអ្នកជាអ្នកបម្រើនៃអំពើបាបដែលនាំអ្នកទៅក្នុងសេចក្តីស្លាប់
ឬជាអ្នកបម្រើដែលស្តាប់បង្គាប់ ដែលនាំទៅរកសេចក្តីសុចរិត។
លោកប៉ូលពណ៌នា «អំពើបាប» ឬ «ការគោរព ស្តាប់បង្គាប់» ដូចជាចៅហ្វាយ
ដែលអ្នកបម្រើគួរបម្រើ។ ការបកប្រែផ្សេងទៀត: «អ្នកក៏ជាអ្នកបម្រើអំពើបាប

generated on Wed Sep 10 16:16:32 2025

ដែលជាផលក្នុងការស្លាប់ខាងវិញ្ញាណ ឬអ្នកជាអ្នកបម្រើការគោរពស្តាប់បង្គាប់
ដែលជាផលក្នុងប្រព្រឹត្តអ្វីដែលព្រះជាម្ចាស់ចង់ឲ្យយើងធ្វើ។
Romans 6:17
ប៉ុន្តែ សូមអរគុណដល់ព្រះជាម្ចាស់!
«ប៉ុន្តែខ្ញុំអរព្រះគុណព្រះជាម្ចាស់!»
ព្រោះអ្នកធ្លាប់ជាអ្នកបម្រើរបស់បាប
នៅទីនេះពាក្យ «បាប» ដូចជាចៅហ្វាយដែលអ្នកបម្រើគួរបម្រើ។ «បាប»
ក៏សំដៅដល់អំណាចដែលរស់នៅក្នុងយើងដែលធ្វើឲ្យយើងជ្រើសរើសការប្រព្រឹត្តបាប។
ការបកប្រែផ្សេងទៀត: «អ្នកធ្លាប់ជាអ្នកបម្រើរបស់អំណាចអំពើបាប»។
ប៉ុន្តែ អ្នកបានស្តាប់បង្គាប់ពីចិត្ត
នៅទីនេះពាក្យ «ចិត្ត» សំដៅដល់ការមានសេចក្តីត្រង់ក្នុងចំណង់ដែលធ្វើអ្វីមួយ។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែ អ្នកពិតជាបានគោរព»។
តាមគំរូនៃសេចក្តីបង្រៀនដែលបានប្រគល់ដល់អ្នក
នៅទីនេះពាក្យ «គំរូ» សំដៅដល់ផ្លូវនៃជីវិតដែលដឹកនាំទៅកាន់សេចក្តីសុចរិត។
អ្នកជឿត្រូវផ្លាស់ប្តូរផ្លូវជីវិតចាស់របស់ពួកគេ
ដើម្បីភ្ជាប់ផ្លូវថ្មីនៃជីវិតដែលអ្នកដឹកនាំគ្រិស្តបរិស័ទបានបង្រៀនពួកគេនោះ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ការបង្រៀនដែលអ្នកដឹកនាំគ្រិស្តបរិស័ទបានផ្តល់ឲ្យអ្នក»។
អ្នកបានមានសេរីភាពពីបាបហើយ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«ព្រះគ្រិស្តបានរំដោះអ្នកពីអំណាចនៃអំពើបាប»។
ជាអ្នកបម្រើនៃសេចក្តីសុចរិតវិញ
«ឥឡូវនេះអ្នកជាអ្នកបម្រើសម្រាប់អ្វីដែលត្រឹមត្រូវ»។
Romans 6:19
ខ្ញុំនិយាយដូចជាមនុស្សទូទៅ៖
«នៅទីនេះខ្ញុំប្រើឧទាហរណ៍ពីជីវិតប្រចាំថ្ងៃ»។
ដោយសារសេចក្តីកំសោយនៃសាច់ឈាមរបស់អ្នក
ជាញឹកញាប់លោកប៉ូលប្រើពាក្យ «សាច់ឈាម» ដែលផ្ទុយពី «វិញ្ញាណ»។
ការបកប្រែផ្សេងទៀត
«ព្រោះអ្នករាល់គ្នាមិនបានយល់គ្រប់យ៉ាងពីកិច្ចការខាងវិញ្ញាណនោះទេ»។
ដោយព្រោះអ្នកបានថ្វាយខ្លួនរបស់អ្នកឲ្យធ្វើជាទាសករចំពោះសេចក្តីដែលមិនស្អាត
ហើយចំពោះការអាក្រក់
នៅទីនេះពាក្យ «ខ្លួន» សំដៅដល់ខ្លួនមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត:
«ថ្វាយខ្លួនរបស់អ្នកទៅជាអ្នកបម្រើគ្រប់អ្វីដែលជាការអាក្រក់
និងមិនសព្វព្រះទ័យព្រះជាម្ចាស់»។
ចូរថ្វាយខ្លួនរបស់អ្នកដូចជាទាសកររនៃសេចក្តីសុចរិតវិញ ដើម្បីឲ្យបានសុចរិត
នៅទីនេះពាក្យ «ខ្លួន» សំដៅដល់ខ្លួនមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត:
«ថ្វាយខ្លួនរបស់អ្នកទៅជាអ្នកបម្រើនៃគ្រប់អ្វីដែលជាការត្រឹមត្រូវ
ចំពោះព្រះជាម្ចាស់ដែលទ្រង់នឹងញែកយើង
ហើយប្រទានឲ្យយើងនូវអំណាចបម្រើទ្រង់»។
នៅពេលនោះ តើផលផ្លែអ្វីដែលយើងមានពីការអ្វីដែលអ្នកមានសព្វថ្ងៃនេះគឺភាពអាម៉ាស់?
លោកប៉ូលប្រើសំណួរដើម្បីបញ្ជាក់ថា
លទ្ធផលនៃការប្រព្រឹត្តអំពើបាបមិនមានអ្វីល្អទេ។ ការបកប្រែផ្សេងទៀត:
«អ្នកមិនបានប្រកែកចំពោះការប្រព្រឹត្តការទាំងអស់នោះ
ដែលនាំឲ្យអ្នកមានសេចក្តីខ្មាស»។
Romans 6:22
ប៉ុន្តែ នៅពេលនេះ អ្នកត្រូវបានដោះឲ្យមានសេរីភាពពីបាប ហើយគឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់វិញ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ប៉ុន្តែ
ឥឡូវនេះព្រះគ្រិស្តបានរំដោះអ្នកពីបាប និងបានផ្សារភ្ជាប់អ្នកនឹងព្រះជាម្ចាស់»។
ជាលទ្ធផលគឺបានជីវិតអស់កល្បជានិច្ច
«ហើយលទ្ធផលនៃការទាំងអស់គឺអ្នកនឹងមានជីវិតដ៏អស់កល្បជាមួយនឹងព្រះជាម្ចាស់»។
ឈ្នួលនៃបាបគឺជាសេចក្តីស្លាប់
ពាក្យ «ឈ្នួល»
សំដៅដល់ការចំណាយឲ្យអ្នកណាម្នាក់សម្រាប់ការងាររបស់ពួកគេ។ «ប្រសិនបើ
អ្នកបម្រើអំពើបាប អ្នកនឹងបានទទួលថ្លៃឈ្នួលជាសេចក្តីស្លាប់ខាងវិញ្ញាណ» ឬ
«ប្រសិនបើ
អ្នកនៅតែបន្តប្រព្រឹត្តអំពើបាបព្រះជាម្ចាស់នឹងដាក់ទោសអ្នកដោយសេចក្តីស្លាប់ខាងវិញ្ញាណ»។
ប៉ុន្តែ
អំណោយទាននៃព្រះជាម្ចាស់វិញគឺជាជីវិតអស់កល្បជានិច្ចនៅក្នុងព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើង
«ប៉ុន្តែ
ព្រះជាម្ចាស់ប្រទានអំណោយទានជាជីវិតអស់កល្បជានិច្ចដល់អស់អ្នកដែលនៅក្នុងព្រះគ្រិស្តយេស៊ូ
ជាអម្ចាស់នៃយើង»។

---

7 [1]បងប្អូនអើយ តើអ្នកមិនដឹងទេឬអីថា (ខ្ញុំកំពុងនិយាយជាមួយអ្នកដែលស្គាល់ក្រឹត្យវិន័យ) ក្រឹត្យវិន័យគ្រប់គ្រងលើមនុស្សរហូតអស់មួយជីវិតរបស់ពួកគេ?
[2]ស្ត្រីដែលបានរៀបការគឺជាប់ចំណងដោយសារច្បាប់ ជាមួយនឹងស្វាមីរបស់នាងក្នុងការដែលគាត់នៅរស់ ប៉ុន្តែ ប្រសិនបើ ស្វាមីរបស់នាងស្លាប់
នាងនឹងរួចពីចំណងនៃច្បាប់របស់អាពាហ៍ពិពាហ៍នោះហើយ។[3]ដូច្នេះ នៅក្នុងពេលដែលស្វាមីរបស់នាងនៅរស់នៅឡើយ ប្រសិនបើ នាងរួមរស់ជាមួយបុរសផ្សេង
គេនឹងហៅនាងថា ស្រីផិតប្តី។ ប៉ុន្តែ ប្រសិនបើ ស្វាមីរបស់នាងស្លាប់វិញ នាងមានសេរីភាពពីច្បាប់ហើយ ដូច្នេះ នាងមិនមែនជាស្រីផិតប្តីទេ
ប្រសិនបើនាងរួមរស់នៅជាមួយបុរសផ្សេងទៀត។
[4]ដូច្នេះ បងប្អូនរបស់ខ្ញុំអើយ អ្នកក៏បានធ្វើឲ្យស្លាប់នៅក្នុងក្រឹត្យវិន័យដែរ តាមរយៈព្រះកាយរបស់ព្រះគ្រិស្ត។ ការនេះ កើតឡើងដូច្នេះ ដើម្បីឲ្យអ្នកអាចចូលរួមជាមួយគ្នា
គឺចូលរួមជាមួយព្រះអង្គ ដែលបានរស់ពីសុគតឡើងវិញ ដើម្បីឲ្យយើងអាចបង្កើតផលផ្លែថ្វាយព្រះជាម្ចាស់។[5]ព្រោះ នៅពេលយើងនៅក្នុងសាច់ឈាម
មានដួងចិត្តពេញដោយអំពើបាប ក្រឹត្យវិន័យជាអ្នកជំរុញ ធ្វើការនៅក្នុងសរីរាង្គរបស់យើង ដើម្បីបង្កើតផលជាសេចក្តីស្លាប់។
[6]ប៉ុន្តែ ឥឡូវនេះ យើងមានសេរីភាពពីក្រឹត្យវិន័យហើយ។ យើងបានស្លាប់ចំពោះក្រឹត្យវិន័យដែលបានចងយើងរួចហើយ។
នេះគឺជាអ្វីដែលយើងអាចបម្រើនៅក្នុងរូបភាពថ្មីខាងវិញ្ញាណ ហើយមិនស្ថិតនៅក្នុងភាពចាស់នៃតួអក្សរពីមុនទៀតទេ។
[7]តើយើងនឹងនិយាយយ៉ាងដូចម្តេចអ៊ីចឹង? តើក្រឹត្យវិន័យជាអំពើបាបមែនទេ? គឺមិនមែនទេ។ ប៉ុន្តែ យើងអាចនឹងមិនស្គាល់បាបទេ ប្រសិនបើអត់មានក្រឹត្យវិន័យ។
យើងមិនអាចស្គាល់ថាការលោភលន់ជាអំពើបាបទេ លុះត្រាតែក្រឹត្យវិន័យនិយាយចែងថា៖ «មិនត្រូវលោភលន់ឡើយ»។[8]ប៉ុន្តែ បាបមានឱកាសតាមរយៈមនសិកា
ហើយបាននាំឲ្យមានការលោភលន់គ្រប់យ៉ាងនៅក្នុងខ្ញុំ។ ព្រោះបើគ្មានក្រឹត្យវិន័យទេ អំពើបាបគឺជាសេចក្តីស្លាប់។
[9]នៅពេលមួយខ្ញុំបានរស់នៅដោយគ្មានក្រឹត្យវិន័យ ប៉ុន្តែ នៅពេលបញ្ញត្តិបានមកដល់ បាបបានរស់ឡើងវិញ ហើយខ្ញុំក៏ស្លាប់។[10]បញ្ញត្តិដែលគួរតែនាំឲ្យមានជីវិត
បែរជានាំឲ្យស្លាប់សម្រាប់ខ្ញុំទៅវិញ។
[11]នៅពេលបាបមានឱកាសតាមរយៈបញ្ញត្តិ ហើយបានបោកបញ្ឆោតខ្ញុំ។ តាមរយៈបញ្ញត្តិនោះបានសម្លាប់ខ្ញុំ។[12]ដូច្នេះ ក្រឹត្យវិន័យបរិសុទ្ធ ហើយបញ្ញត្តិក៏បរិសុទ្ធ សុចរិត
និងល្អដែរ។
[13]តើអ្វីៗដ៏ល្អនេះបែរជានាំអោយខ្ញុំស្លាប់ឬ? ទេ មិនមែនទេ! គឺបាបវិញទេតើដែលនាំអោយខ្ញុំស្លាប់។ បាបបានប្រើវិន័យដែលល្អធ្វើអោយខ្ញុំស្លាប់ ដើម្បីបង្ហាញអោយឃើញ
ថា បាបពិតជាបាបមែន ហើយតាមរយៈបញ្ញត្តិ បាបលេចចេញមករឹតតែអាក្រក់ហួសហេតុទៅទៀត។[14]ព្រោះយើងដឹងថា ក្រឹត្យវិន័យគឺខាងវិញ្ញាណ ប៉ុន្តែ
ខ្ញុំកើតចេញពីសាច់ឈាម។ ខ្ញុំត្រូវបានលក់នៅក្រោមទាសកររនៃអំពើបាប។
[15]ដ្បិត អ្វីដែលខ្ញុំធ្វើ ខ្ញុំពិតជាមិនយល់ទេ។ ព្រោះអ្វីដែលខ្ញុំចង់ធ្វើ ខ្ញុំបែរជាមិនធ្វើ ហើយអ្វីដែលខ្ញុំស្អប់ ខ្ញុំបែរជាធ្វើវាវិញ។[16]ប៉ុន្តែ ប្រសិនបើ ខ្ញុំធ្វើអ្វីដែលខ្ញុំមិនចង់ធ្វើ
គឺខ្ញុំយល់ព្រមជាមួយក្រឹត្យវិន័យហើយ ថាក្រឹត្យវិន័យល្អ។
[17]ដូច្នេះ មិនមែនខ្ញុំទេដែលប្រព្រឹត្តកិច្ចការនោះ គឺបាបនៅក្នុងខ្ញុំវិញទេតើដែលប្រព្រឹត្ត[18]ដ្បិតខ្ញុំដឹងថា អ្វីៗដែលល្អមិនស្ថិតនៅក្នុងខ្ញុំទេ ពោលគឺមិនស្ថិតនៅក្នុងខ្ញុំដែលមាន
និស្ស័យលោកីយ៍ទេ។ ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ។
[19]ខ្ញុំមិនប្រព្រឹត្តអំពើល្អ ដែលខ្ញុំចង់ធ្វើនោះទេ តែបែរជាប្រព្រឹត្តអំពើអាក្រក់ដែលខ្ញុំមិនចង់ធ្វើទៅវិញ។[20]ប្រសិនបើខ្ញុំប្រព្រឹត្តអំពើណាដែលខ្ញុំមិនចង់ធ្វើ បានសេចក្តីថាមិនមែន
ខ្ញុំទៀតទេដែលប្រព្រឹត្តដូច្នេះ គឺបាបស្ថិតនៅក្នុងខ្ញុំវិញទេតើ ដែលប្រព្រឹត្ត។[21]ដូច្នេះ ចំពោះខ្ញុំដែលចង់ធ្វើអំពើល្អ ខ្ញុំសង្កេតឃើញមានគោលការណ៍មួយនេះថា ខ្ញុំមាន
សមត្ថភាពធ្វើបានតែអំពើអាក្រក់ប៉ុណ្ណោះ។

generated on Wed Sep 10 16:16:32 2025

[22]ក្នុងជម្រៅចិត្តខ្ញុំ ខ្ញុំមានអំណរនៅក្នុងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ណាស់។[23]ប៉ុន្តែ ខ្ញុំឃើញមានគោលការណ៍ផ្សេងនៅក្នុងផ្នែកនៃរូបកាយរបស់ខ្ញុំ។
វាបានតយុទ្ធទាស់ទទឹងជាមួយអ្វីដែលជាគោលការណ៍ថ្មីនៅក្នុងគំនិតរបស់ខ្ញុំ។ វាបានធ្វើឲ្យខ្ញុំជាប់ចំណងដែលជាគោលការណ៍នៃអំពើបាប
ដែលស្ថិតក្នុងផ្នែកនៃរូបកាយរបស់ខ្ញុំ។
[24]ខ្ញុំជាមនុស្សវេទនាហើយ! តើអ្នកណារំដោះខ្ញុំចេញពីរូបកាយដែលស្លាប់នេះបាន?[25]ប៉ុន្តែ អរគុណដល់ព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូគ្រិស្ត ជាព្រះអម្ចាស់នៃយើង! ដូច្នេះ
ខ្ញុំខ្លួនឯងបម្រើក្រឹត្យវិន័យរបស់ព្រះជាម្ចាស់នៅក្នុងគំនិតរបស់ខ្ញុំហើយសាច់ឈាមរបស់ខ្ញុំវិញបែរជាបម្រើគោលការណ៍បាបវិញ។

Romans 7:1
ប្រយោគភ្ជាប់
លោកប៉ូលពន្យល់ពីរបៀបដែលក្រឹត្យវិន័យត្រួតត្រាអស់អ្នកដែលចង់រស់នៅក្រោមក្រឹត្យវិន័យ
បងប្អូនអើយ
តើអ្នកមិនដឹងទេឬអីថា ...ក្រឹត្យវិន័យគ្រប់គ្រងលើមនុស្សរហូតអស់មួយជីវិតរបស់ពួកគេ?
លោកប៉ូលសួរសំណួរទាំងនេះដើម្បីបន្ថែមអត្ថន័យ។ ការបកប្រែផ្សេងទៀត: «ដូច្នេះ
អ្នកពិតជាដឹងថាមនុស្សត្រូវស្តាប់បង្គាប់ក្រឹត្យវិន័យ
តែនៅពេលដែលគេមានជីវិតរស់នៅតែប៉ុណ្ណោះ»។
បងប្អូន
សំដៅដល់គ្រិស្តបរិស័ទទាំងអស់ ដែលរួមទាំងបុរស និងស្ត្រី។
ក្រឹត្យវិន័យគ្រប់គ្រងលើមនុស្សរហូតអស់មួយជីវិតរបស់ពួកគេ
លោកប៉ូលលើកឧទាហរណ៍នៃខនេះ ក្នុង ៧:២។
Romans 7:2
ស្ត្រីដែលបានរៀបការ
សំដៅដល់ស្ត្រីៗ ដែលបានរៀបការរួចហើយ។
គេនឹងហៅនាងថា ស្រីផិតប្តី
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ព្រះជាម្ចាស់នឹងរាប់នាងទុកជាស្ត្រីក្បត់» ឬ
«មនុស្សនឹងហៅនាងថាជាមនុស្សផិតក្បត់»។
Romans 7:4
ដូច្នេះ
វាមានទំនាក់ទំនងទៅនឹង ៧:១។
បងប្អូន
សំដៅដល់គ្រិស្តបរិស័ទទាំងអស់ ដែលរួមទាំងបុរស និងស្ត្រី។
អ្នកក៏បានធ្វើឲ្យស្លាប់នៅក្នុងក្រឹត្យវិន័យដែរ តាមរយៈព្រះកាយរបស់ព្រះគ្រិស្ត
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«អ្នកក៏បានស្លាប់ក្នុងក្រឹត្យវិន័យ
ហើយតាមរយៈព្រះគ្រិស្តនៅពេលទ្រង់បានសុគតនោះលើឈើឆ្កាង»។
ដើម្បីឲ្យយើងអាចបង្កើតផលផ្លែថ្វាយព្រះជាម្ចាស់
ពាក្យ «ផលផ្លែ» នៅទីនេះជាការប្រៀបធៀប
ដែលបញ្ជាក់ពីសកម្មភាពដែលគាប់ព្រះទ័យព្រះជាម្ចាស់។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«យើងអាចធ្វើកិច្ចការទាំងឡាយដែលគាប់ព្រះទ័យព្រះជាម្ចាស់»។
ដើម្បីបង្កើតផលជាសេចក្តីស្លាប់
ពាក្យ «ផលផ្លែ» នៅទីនេះគឺជាពាក្យប្រៀបធៀបដែលសំដៅដល់
ការរស់នៅក្នុងជីវិតដែលពេញដោយអំពើបាប។
Romans 7:6
ប្រយោគភ្ជាប់
លោកប៉ូលបានរំលឹកយើង
ថាព្រះជាម្ចាស់មិនបានធ្វើឲ្យយើងបរិសុទ្ធដោយសារក្រឹត្យវិន័យនោះទេ។
យើងមានសេរីភាពពីក្រឹត្យវិន័យហើយ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ដើម្បីបង្កើតផលជាសេចក្តីស្លាប់
«ព្រះជាម្ចាស់បានរំដោះយើងឲ្យមានសេរីភាពពីក្រឹត្យវិន័យ»។
យើង
សព្វនាមនេះ សំដៅដល់លោកប៉ូល និងអ្នកជឿ។
ចំពោះក្រឹត្យវិន័យដែលបានចងយើង
ឃ្លានេះគឺសំដៅដល់ក្រឹត្យវិន័យ។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ដើម្បីបង្កើតផលជាសេចក្តីស្លាប់ «ចំពោះក្រឹត្យវិន័យដែលបានចងយើង»។
តួអក្សរ
ពាក្យនេះសំដៅដល់ ក្រឹត្យវិន័យរបស់លោកម៉ូសេ។ ដើម្បីបង្កើតផលជាសេចក្តីស្លាប់
«ក្រឹត្យវិន័យរបស់លោកម៉ូសេ»។
Romans 7:7
តើយើងនឹងនិយាយយ៉ាងដូចម្តេចអ៊ីចឹង?
លោកប៉ូលចាប់ផ្តើមណែនាំប្រធានបទថ្មី។
ទេ
«ពិតណាស់វាមិនមែនជាការពិតនោះទេ!»
ឃ្លានេះផ្តល់នូវចម្លើយបដិសេធដែលអាចទៅរួចខ្លាំងជាង
ទៅនឹងសំណួរដែលមិនទាមទារចម្លើយពីមុន។ នៅទីនេះ
អ្នកអាចប្រើឃ្លាស្រដៀងគ្នាក្នុងភាសារបស់អ្នក។
មើលពីការបកប្រែរបស់អ្នកនៅក្នុង ៩:១៤។
យើងអាចនឹងមិនស្គាល់បាបទេ ប្រសិនបើ អត់មានក្រឹត្យវិន័យ...ប៉ុន្តែ
បាបមានឱកាស...នាំឲ្យមានការលោភលន់គ្រប់យ៉ាង
លោកប៉ូលធ្វើការប្រៀបធៀបអំពើបាប ទៅនឹងអ្នកអាចធ្វើការនោះ។
បាប
«បំណងចិត្តរបស់ខ្ញុំចំពោះបាប»។
លោភលន់
ពាក្យនេះសំដៅដល់ទាំងពីរ គឺទាំងបំណងចិត្តចង់បានអ្វីដែលជារបស់អ្នកដទៃ
ទាំងបំណងផ្នែកភេទដែលមិនត្រឹមត្រូវ។
បើគ្មានក្រឹត្យវិន័យទេ អំពើបាបគឺជាសេចក្តីស្លាប់
«ប្រសិនបើមិនមានក្រឹត្យវិន័យទេ ក៏នឹងមិនមានការទាស់នឹងក្រឹត្យវិន័យដែល
ដូច្នេះ ក៏នឹងមិនមានអំពើបាបដែរ»។
Romans 7:9
បាបបានរស់ឡើងវិញ
ឃ្លានេះអាចមានអត្ថន័យពីរ ទី១) «ខ្ញុំបានដឹងថា ខ្ញុំធ្លាប់មានបាប»
បញ្ញត្តិដែលគួរតែនាំឲ្យមានជីវិត បែរជានាំឲ្យស្លាប់សម្រាប់ខ្ញុំទៅវិញ
លោកប៉ូលនិយាយអំពីបញ្ញត្តិរបស់ព្រះជាម្ចាស់ ដែលហាលទ្ធផលដំបូង
វាជាសេចក្តីស្លាប់ខាងរូបកាយ។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានប្រទានបទបញ្ញត្តិ ដើម្បីខ្ញុំអាចរស់បាន ប៉ុន្តែ
ជំនួសមកវិញវាបានសម្លាប់ខ្ញុំ»។
Romans 7:11
នៅពេលបាបមានឱកាសតាមរយៈបញ្ញត្តិ ហើយបានបោកបញ្ឆោតខ្ញុំ។
តាមរយៈបញ្ញត្តិនោះបានសម្លាប់ខ្ញុំ
ដូចជានៅក្នុង ៧:៧ លោកប៉ូលរៀបរាប់អំពើបាបដូចជា
មនុស្សម្នាក់ដែលអាចធ្វើកិច្ចការបី: ឆក់ឱកាស បោកបញ្ឆោត និងសម្លាប់។
ការបកប្រែផ្សេងទៀត: «ដោយសារខ្ញុំចង់ប្រព្រឹត្តអំពើបាប
ខ្ញុំបានប្រគល់ខ្លួនរបស់ខ្ញុំទៅក្នុងអ្វីដែលខ្ញុំអាចមានបាប
ហើយក៏គោរពបទបញ្ញត្តិក្នុងពេលតែមួយ ប៉ុន្តែ
ព្រះជាម្ចាស់បានដាក់ទោសខ្ញុំសម្រាប់ការមិនគោរពបទបញ្ញត្តិដោយបំបែកខ្ញុំចេញពីទ្រង់»។
បាប
«បំណងចិត្តរបស់ខ្ញុំចំពោះបាប»។
មានឱកាសតាមរយៈបញ្ញត្តិ
លោកប៉ូលធ្វើការប្រៀបធៀបអំពើបាប ទៅនឹងអ្នកអាចធ្វើការនោះ។
មើលពីរបៀបបកប្រែក្នុងខ ៧:៧
វាបានសម្លាប់ខ្ញុំ
លោកប៉ូលនិយាយអំពីបញ្ញត្តិរបស់ព្រះជាម្ចាស់ លើមនុស្សបាប
ដែលជាលទ្ធផលដំបូង វាជាសេចក្តីស្លាប់ខាងរូបកាយ។ ការបកប្រែផ្សេងទៀត: «
វាបានញែកខ្ញុំពីព្រះជាម្ចាស់»។
បរិសុទ្ធ
«សីលធម៌ដ៏ឥតខ្ចោះ មិនមានបាប»។
Romans 7:13
ប្រយោគភ្ជាប់
លោកប៉ូលនិយាយអំពីការតយុទ្ធគ្នាខាងក្នុងរវាងមនុស្សបាប
និងគំនិតរួមនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ដែលនៅក្នុងលោក
គឺរវាងបាបនិងការល្អ។

generated on Wed Sep 10 16:16:32 2025

ដូច្នេះ
លោកប៉ូលណែនាំអំពីប្រធានបទថ្មី។
តើអ្វីៗដ៏ល្អនេះបែរជានាំឲ្យខ្ញុំស្លាប់ឬ?
លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់បន្ថែម។
អ្វីៗដ៏ល្អ
គឺសំដៅដល់ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។
នាំឲ្យខ្ញុំស្លាប់
«ធ្វើឲ្យខ្ញុំស្លាប់»
ទេ មិនមែនទេ!
ឃ្លានេះផ្តល់នូវចម្លើយបដិសេធដែលអាចទៅរួចខ្លាំងជាង
ទៅនឹងសំណួរដែលមិនទាមទារពីមុន។ នៅទីនេះ
អ្នកអាចប្រើឃ្លាស្រដៀងគ្នាក្នុងភាសារបស់អ្នក។ការបកប្រែផ្សេងទៀត:
«ជាការពិតណាស់ ថាវាមិនពិត!»
បាប...ដែលល្អធ្វើអោយខ្ញុំស្លាប់
លោកប៉ូលរំលឹកឡើងវិញ បាបដូចជាមនុស្សម្នាក់ដែលអាចមានសកម្មភាព។
ធ្វើឲ្យខ្ញុំស្លាប់
«បំបែកខ្ញុំចេញពីព្រះជាម្ចាស់»។
តាមរយៈបញ្ញត្តិ
«ដោយសារខ្ញុំមិនបានគោរពបទបញ្ជាតិ»។
Romans 7:15
ប្រយោគភ្ជាប់
លោកប៉ូលនិយាយពីការតយុទ្ធគ្នានៅខាងក្នុងលោក រវាងសាច់ឈាមរបស់លោក
និងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ និង រវាងអំពើបាបនិងការល្អ។
ដ្បិត អ្វីដែលខ្ញុំធ្វើ ខ្ញុំពិតជាមិនយល់ទេ
នៅទីនេះលោកប៉ូលនិយាយបន្ថែមទៅលើឃ្លារបស់លោក។ ការបកប្រែផ្សេងទៀត:
«ខ្ញុំមិនប្រាកដទេ ថាហេតុអ្វីបានជាខ្ញុំធ្វើកិច្ចការមួយចំនួនដែលខ្ញុំធ្វើ»។
ដ្បិត
«ពីព្រោះ»
ព្រោះអ្វីដែលខ្ញុំចង់ធ្វើ ខ្ញុំបែរជាមិនធ្វើ
នៅទីនេះលោកប៉ូលនិយាយបន្ថែមទៅលើឃ្លារបស់លោក។ ការបកប្រែផ្សេងទៀត:
«មិនមែនគ្រប់ពេល ខ្ញុំធ្វើនូវអ្វីដែលខ្ញុំចង់ធ្វើនោះទេ»។
អ្វីដែលខ្ញុំស្អប់ ខ្ញុំបែរជាធ្វើវា
នៅទីនេះលោកប៉ូលនិយាយបន្ថែមទៅលើឃ្លារបស់លោក។ ការបកប្រែផ្សេងទៀត:
«កិច្ចការមួយចំនួនដែលខ្ញុំដឹងថាមិនល្អ បែរជាកិច្ចការដែលខ្ញុំធ្វើវានៅពេលខ្លះ»។
ប៉ុន្តែ
«ទោះបីជា»
ខ្ញុំយល់ព្រមជាមួយក្រឹត្យវិន័យហើយ
«ខ្ញុំដឹងថាក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ គឺល្អ»។
Romans 7:17
បាបនៅក្នុងខ្ញុំ
លោកប៉ូលបរិយាយពីបាប
ដែលដូចជាមនុស្សដែលមានអំណាចមានឥទ្ធិពលលើលោក។
ខ្ញុំដែលមាននិស្ស័យលោកីយ៍
នៅទីនេះពាក្យ «និស្ស័យលោកីយ៍» ជាការប្រៀបធៀប
បញ្ជាក់ដល់ធម្មជាតិនៃអំពើបាប។ ការបកប្រែផ្សេងទៀត:
«ធម្មជាតិនៃអំពើបាបរបស់ខ្ញុំ»។
Romans 7:19
អំពើល្អ
«អំពើល្អ» ឬ «ការធ្វើល្អ»
អំពើអាក្រក់
«អំពើអាក្រក់» ឬ «ការធ្វើអាក្រក់»។
គឺបាបស្ថិតនៅក្នុងខ្ញុំវិញទេតើ
លោកប៉ូលនិយាយអំពី «បាប» ដូចជាមានជីវិត និងកំពុងរស់នៅក្នុងលោក។
ខ្ញុំមានសមត្ថភាពធ្វើបានតែអំពើអាក្រក់ប៉ុណ្ណោះ
លោកប៉ូលនិយាយអំពី «អំពើបាប» ដូចជាមានជីវិត និងកំពុងរស់នៅក្នុងលោក។
Romans 7:22
ក្នុងជម្រៅចិត្តខ្ញុំ
នេះជាវិញ្ញាណថ្មីដែលរស់ឡើងវិញ របស់មនុស្សអ្នកដែលទុកចិត្តលើព្រះគ្រិស្ត។
ប៉ុន្តែ ខ្ញុំឃើញមានគោលការណ៍ផ្សេងនៅក្នុងផ្នែកនៃរូបកាយរបស់ខ្ញុំ។
វាបានតយុទ្ធទាស់ទទឹងជាមួយអ្វីដែលជាគោលការណ៍ថ្មីនៅក្នុងគំនិតរបស់ខ្ញុំ។
វាបានធ្វើឲ្យខ្ញុំជាប់ចំណងដែលជាគោលការណ៍
«ខ្ញុំមានសមត្ថភាពធ្វើតែអ្វីដែលមនុស្សចាស់របស់ខ្ញុំប្រាប់ឲ្យខ្ញុំធ្វើតែប៉ុណ្ណោះ
គឺខ្ញុំមិនរស់នៅតាមរបៀបថ្មីដែលខាងវិញ្ញាណបង្ហាញខ្ញុំនោះទេ»។
គោលការណ៍ថ្មី
នេះគឺជាធម្មជាតិនៃការរស់នៅថ្មីខាងវិញ្ញាណ។
គោលការណ៍ផ្សេងនៅក្នុងផ្នែកនៃរូបកាយរបស់ខ្ញុំ
នេះជាធម្មជាតិចាស់
ជារបៀបដែលមនុស្សមានតាំងពីពេលដែលពួកគេចាប់កំណើតមក។
ជាគោលការណ៍នៃអំពើបាប ដែលស្ថិតក្នុងផ្នែកនៃរូបកាយរបស់ខ្ញុំ
«ធម្មជាតិនៃបាបរបស់ខ្ញុំ»។
Romans 7:24
តើអ្នកណារំដោះខ្ញុំចេញពីរូបកាយដែលស្លាប់នេះបាន?
លោកប៉ូលប្រើសំណួរនេះដើម្បីបង្ហាញការរំភើបចិត្តយ៉ាងខ្លាំង។
អ្នកក៏អាចប្រើជាសញ្ញាឧទាន ឬជាសំណួរដើម្បីបង្ហាញការរំភើបចិត្ត
តាមភាសារបស់អ្នកនៅទីនេះ។ ការបកប្រែផ្សេងទៀត:
«ខ្ញុំចង់ឲ្យមានអ្នកណាម្នាក់រំដោះខ្ញុំ ចេញពីការគ្រប់គ្រងនៃចំណង់របស់រូបកាយខ្ញុំ!»
រូបកាយដែលស្លាប់នេះ
នេះជាការប្រៀបធៀបដែលបញ្ជាក់ថា រូបកាយដែលនឹងជួបប្រទះសេចក្តីស្លាប់។
ប៉ុន្តែ អរគុណដល់ព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូគ្រិស្ត ជាព្រះអម្ចាស់នៃយើង
នេះជាចម្លើយនៃសំណួរ ដែលនៅក្នុងខ ៧:២៤។
ដូច្នេះ
ខ្ញុំខ្លួនឯងបម្រើក្រឹត្យវិន័យរបស់ព្រះជាម្ចាស់នៅក្នុងគំនិតរបស់ខ្ញុំហើយសាច់ឈាមរបស់ខ្ញុំវិញបែរជាបម្រើគោលការណ៍បាបវិញ។
គំនិត និងសាច់ឈាម ត្រូវបានប្រើនៅទីនេះ
ដើម្បីបង្ហាញការប្រៀបធៀបរវាងការបម្រើក្រឹត្យវិន័យរបស់ព្រះជាម្ចាស់
ឬគោលការណ៍របស់អំពើបាប។ ជាមួយគំនិត ឬការយល់ដឹង
មនុស្សអាចជ្រើសរើសការគោរពព្រះជាម្ចាស់ជាមួយសាច់ឈាម ឬ
ធម្មជាតិជាមនុស្សដើម្បីបម្រើអំពើបាប។ ការបកប្រែផ្សេងទៀត:
«គំនិតរបស់ខ្ញុំជ្រើសរើសការបម្រើព្រះជាម្ចាស់ ប៉ុន្តែ
សាច់ឈាមរបស់ខ្ញុំបែរជាជ្រើសរើសគោរពបាបទៅវិញ»។

---

8 [1]ដូច្នេះ គ្មានការកាត់ទោសដល់អស់អ្នកដែលនៅក្នុងព្រះគ្រិស្តយេស៊ូទេ។
[2]ព្រោះគោលការណ៍របស់ព្រះវិញ្ញាណនៃជីវិតក្នុងព្រះគ្រិស្តយេស៊ូបានធ្វើឲ្យខ្ញុំមានសេរីភាពពីគោលការណ៍នៃអំពើបាប និងសេចក្តីស្លាប់។
[3]ដ្បិត អ្វីដែលក្រឹត្យវិន័យមិនអាចធ្វើបាន គឺដោយសារភាពខ្សោយនៃសាច់ឈាម ប៉ុន្តែព្រះជាម្ចាស់អាចធ្វើបាន។
ព្រះអង្គបានចាត់ព្រះបុត្រារបស់ព្រះអង្គផ្ទាល់នៅក្នុងនិស្ស័យជាមនុស្សមានបាបខាងសាច់ឈាម ឲ្យធ្វើជាយញ្ញបូជាលោះបាប
ហើយព្រះអង្គត្រូវបានកាត់ទោសចំពោះបាបនៅក្នុងសាច់ឈាមនេះឯង។[4]ព្រះអង្គធ្វើការនេះ ដើម្បីឲ្យតម្រូវតាមក្រឹត្យវិន័យ អាចបានសម្រេចនៅក្នុងយើង
យើងគឺជាអ្នកដែលដើរមិនមែនដោយសាច់ឈាមទេ ប៉ុន្តែដោយវិញ្ញាណវិញ។[5]អស់អ្នកដែលរស់នៅក្នុងសាច់ឈាម នឹងយកចិត្តទុកដាក់ជាមួយអ្វីៗដែលជាសាច់ឈាម
ប៉ុន្តែ អ្នកណាដែលរស់នៅខាងវិញ្ញាណវិញ នឹងយកចិត្តទុកដាក់អ្វីៗខាងវិញ្ញាណវិញដែរ។
[6]ដ្បិតគំនិតខាងសាច់ឈាមគឺជាសេចក្តីស្លាប់ ប៉ុន្តែ គំនិតខាងវិញ្ញាណគឺជាជីវិត និងសេចក្តីសុខសាន្ត។[7]ការគិតខាងសាច់ឈាមគឺទាស់ចំពោះព្រះជាម្ចាស់
ព្រោះសាច់ឈាមមិនបានចុះចូលចំពោះច្បាប់របស់ព្រះ ឬមិនអាចធ្វើតាមច្បាប់របស់ព្រះជាម្ចាស់ដែរ។[8]អស់អ្នកដែលនៅក្នុងសាច់ឈាម
មិនអាចគាប់ព្រះហឫទ័យព្រះជាម្ចាស់ឡើយ។
[9]ទោះជាយ៉ាងណា អ្នកមិនបានស្ថិតនៅក្នុងសាច់ឈាមទេ ប៉ុន្តែនៅខាងវិញ្ញាណវិញ ប្រសិនបើអ្នកនៅខាងវិញ្ញាណមែន
នោះព្រះវិញ្ញាណនៃព្រះជាម្ចាស់នឹងរស់នៅក្នុងអ្នក។ ប៉ុន្តែបើអ្នកណាម្នាក់គ្មានវិញ្ញាណរបស់ព្រះគ្រិស្តទេ អ្នកនោះមិនមែនជាកម្មសិទ្ធិរបស់ព្រះអង្គឡើយ។
[10]ប្រសិនបើព្រះគ្រិស្តនៅក្នុងអ្នក រូបកាយត្រូវស្លាប់ខាងឯអំពើបាប ប៉ុន្តែវិញ្ញាណនឹងរស់នៅខាងឯសេចក្តីសុចរិតវិញ។

generated on Wed Sep 10 16:16:32 2025

[11]ប្រសិនបើព្រះវិញ្ញាណរបស់ព្រះដែលបានប្រោសព្រះយេស៊ូពីស្លាប់មកវិញ ហើយរស់នៅក្នុងអ្នក
ព្រះអង្គដែលប្រោសព្រះគ្រិស្តពីសេចក្តីស្លាប់នឹងប្រទានជីវិតដល់រូបកាយពុករលួយរបស់អ្នកតាមរយៈព្រះវិញ្ញាណរបស់ព្រះអង្គ ដែលរស់នៅក្នុងអ្នក។
[12]ដូច្នេះ បងប្អូនអើយ យើងគឺជាកូនបំណុល ប៉ុន្តែ មិនមែនកូនបំណុលខាងសាច់ឈាម គឺរស់នៅតាមសាច់ឈាមឡើយ។[13]ព្រោះប្រសិនបើអ្នករស់តាមសាច់ឈាម
អ្នកនឹងស្លាប់ ប៉ុន្តែប្រសិនបើអ្នករស់នៅខាងវិញ្ញាណវិញ អ្នកនឹងស្លាប់ខាងឯការប្រព្រឹត្តខាងរូបកាយ ហើយអ្នកនឹងបានរស់វិញ។
[14]ដ្បិតអស់អ្នកណាដែលដឹកនាំដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ អ្នកនោះគឺជាកូនរបស់ព្រះជាម្ចាស់។
[15]ព្រោះអ្នកមិនបានទទួលវិញ្ញាណនៃចំណងដែលធ្វើឲ្យភ័យខ្លាចឡើយ។ ផ្ទុយទៅវិញ អ្នកបានទទួលវិញ្ញាណនៃកូនចិញ្ចឹម ដូច្នេះ ហើយអាចស្រែកថា «អ័ប្បា បិតា!»។
[16]ព្រះវិញ្ញាណរបស់ព្រះអង្គផ្ទាល់ធ្វើបន្ទាល់ជាមួយវិញ្ញាណរបស់យើងថា យើងគឺជាកូនរបស់ព្រះជាម្ចាស់។[17]ប្រសិនបើ យើងជាកូនរបស់ព្រះជាម្ចាស់មែន ដូច្នេះ
យើងក៏នឹងទទួលមរតក របស់ព្រះអង្គដែរ។ ហើយយើងនឹងរួមទទួលមរតកជាមួយព្រះគ្រិស្ត ប្រសិនបើយើងពិតជារងទុក្ខជាមួយព្រះអង្គ
ដើម្បីឲ្យយើងអាចទទួលសិរីល្អជាមួយព្រះអង្គ។
[18]ដ្បិតខ្ញុំគិតថា ការឈឺចាប់នៅក្នុងពេលបច្ចុប្បន្ននេះ មិនស័ក្តិសមនឹងប្រៀបធៀបជាមួយនឹងសិរីល្អដែលនឹងបង្ហាញមកយើងឡើយ។[19]ដ្បិតអ្វីៗដែលព្រះជាម្ចាស់បានបង្កើត
មកកំពុងទន្ទឹងរង់ចាំការបង្ហាញខ្លួននៃបុត្ររបស់ព្រះជាម្ចាស់ដោយអន្ទះសារ។
[20]ព្រោះអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក បានប្រគល់ទៅក្នុងភាពឥតប្រយោជន៍ តែមិនមែនដោយស្ម័គ្រចិត្តទេ គឺព្រះជាម្ចាស់បានតម្រូវដូច្នេះ ដោយសង្ឃឹមថា។[21]អ្វីៗ
ដែលព្រះជាម្ចាស់បានបង្កើតមកនឹងបានដោះឲ្យរួចពីភាពជាបាវបម្រើរបស់សេចក្តីពុករលួយទៅឯសេរីភាពនៃសេចក្តីរុងរឿងជាបុត្រព្រះជាម្ចាស់។[22]យើងដឹងហើយថា មក
ទល់ថ្ងៃនេះ ពិភពលោកទាំងមូលកំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ដូចជាស្ត្រីដែលហៀបនឹងសំរាលកូន។
[23]មិនត្រឹមតែប៉ុណ្ណោះទេ សូម្បីតែយើងខ្លួនឯងដែលជាផលដំបូងរបស់ព្រះវិញ្ញាណ សូម្បីតែយើងខ្លួនឯងថ្ងូរនៅក្នុងខ្លួនយើង
រងចាំការទទួលយកភាពជាកូនគឺជាការប្រោសលោះរូបកាយរបស់យើង។[24]ដោយទុកចិត្ត យើងបានសង្គ្រោះ។ ប៉ុន្តែ អ្វីដែលយើងទុកចិត្តមិនទាន់ឃើញនៅឡើយ
សម្រាប់អស់អ្នកដែលមានទំនុកចិត្តចំពោះអ្វីដែលខ្លួនបានឃើញហើយ តើមានប្រយោជន៍អ្វី?[25]ប៉ុន្តែ ប្រសិនបើយើង
មានទំនុកចិត្តអំពីអ្វីដែលយើងមិនទាន់ឃើញនៅឡើយ ដូច្នេះ យើងរង់ចាំដោយភាពអត់ធ្មត់ជាមួយវា។
[26]ដូចគ្នានេះដែរ ព្រះវិញ្ញាណក៏ជួយយើងនៅក្នុងភាពកម្សោយរបស់យើងដែរ។ ព្រោះយើងមិនដឹងថា យើងត្រូវអធិស្ឋានដោយរបៀបណាទេ ប៉ុន្តែ
ព្រះវិញ្ញាណដែលនៅក្នុងយើង បានអធិស្ឋានទូលអង្វរសម្រាប់យើង ជាមួយនឹងការថ្ងូរដែលមិនអាចរៀបរាប់បាន។[27]ព្រះអង្គជាព្រះជាម្ចាស់ដែលស្គាល់ចិត្ត
និងស្គាល់គំនិតរបស់ព្រះវិញ្ញាណ ព្រោះ ព្រះអង្គទូលអង្វរក្នុងនាមអ្នកជឿស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។
[28]យើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នាឡើងសម្រាប់ជាសេចក្តីល្អដល់អស់អ្នកដែលស្រឡាញ់ព្រះជាម្ចាស់ គឺដល់អស់អ្នកដែលព្រះអង្គបានត្រាស់ហៅស្របតាមបំណងរបស់
ព្រះអង្គ។[29]ដ្បិតអស់អ្នកដែលព្រះអង្គបានស្គាល់ជាមុន ព្រះអង្គបានតម្រូវពួកគេទុកជាស្រេចឲ្យមានលក្ខណៈដូចព្រះរាជបុត្រារបស់ព្រះអង្គ ដើម្បីឲ្យព្រះរាជបុត្រាត្រលប់ជា
កូនច្បងនៅក្នុងចំណោមបងប្អូនជាច្រើន។[30]អស់អ្នកដែលបានតម្រូវទុកជាមុន អ្នកទាំងនេះ ត្រូវបានព្រះអង្គត្រាស់ហៅផងដែរ។ អស់អ្នកដែលព្រះអង្គបានហៅ
អ្នកទាំងនោះនឹងបានសុចរិត។ អស់អ្នកដែលព្រះអង្គបានធ្វើឲ្យសុចរិត អ្នកទាំងនោះនឹងបានទទួលសិរីល្អផងដែរ។
[31]ដូច្នេះ តើយើងគួរនិយាយអំពីរឿងនេះយ៉ាងដូចម្តេច? ប្រសិនបើ ព្រះជាម្ចាស់នៅខាងយើងហើយ តើអ្នកណាប្រឆាំងនឹងយើងបាន?
[32]ព្រះអង្គមិនបានសំចៃព្រះបុត្រារបស់ព្រះអង្គផ្ទាល់ ទ្រង់បានចាត់ព្រះអង្គមកសម្រាប់យើងទាំងអស់គ្នាទៅហើយ ដូច្នេះ
ព្រះអង្គនឹងប្រទានអ្វីៗទាំងអស់ដល់យើងបានរួមជាមួយព្រះអង្គដែរ។
[33]តើអ្នកណាអាចប្រឆាំងទាស់ជាមួយនឹងអ្នកដែលព្រះជាម្ចាស់បានរើសតាំងបាន? ព្រះអង្គគឺជាព្រះជាម្ចាស់នៃយុត្តិធម៌។[34]តើអ្នកណានឹងត្រូវកាត់ទោស?
ព្រះគ្រិស្តគឺជាព្រះដែលបានសុគតសម្រាប់យើង លើសពីនោះ ទ្រង់ក៏បានរស់ឡើងវិញ។ ព្រះកំពុងសោយរាជ្យជាមួយព្រះជាម្ចាស់នៅទីកិត្តិយស
ហើយព្រះអង្គក៏ជាព្រះជាម្ចាស់ដែលទូលអង្វរសម្រាប់យើងដែរ។
[35]តើអ្នកណានឹងពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តបាន? តើជាសេចក្តីវេទនា សេចក្តីលំបាក ការបៀតបៀន សេចក្តីអត់ឃ្លាន សេចក្តីអាក្រាត សេចក្តី
អន្តរាយ ឬក៏ដាវ?[36]ដូចជាសេចក្តីដែលបានចែងទុកមកថា៖ «ដោយសារតែព្រះអង្គ យើងត្រូវបានគេចង់ស្លាប់ពីព្រឹកដល់ល្ងាច។
គេបានរាប់យើងថាជាចៀមដែលត្រូវគេសម្លាប់»។
[37]ក្នុងគ្រប់ការទាំងអស់នេះ យើងវិសេសជាងមនុស្សមានជ័យជម្នះទៅទៀត តាមរយៈព្រះអង្គដែលស្រឡាញ់យើង។[38]ព្រោះយើងមានការជឿជាក់ហើយថា ទោះបើ ស្លាប់ ឬ
ឬរស់ ទេវតា ឬការគ្រប់គ្រង ឬអ្វីៗនៅក្នុងពេលបច្ចុប្បន្ននេះ ឬ អ្វីៗដែលត្រូវមក ឬអំណាច[39]ឬកំពស់ ឬក៏ជម្រៅ ឬក៏អ្វីៗដែលបានបង្កើតផ្សេងទៀត
មិនអាចបំបែកយើងចេញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានទេ ដែលនៅក្នុងព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើង។

Romans 8:1
ប្រយោគភ្ជាប់
លោកប៉ូលផ្តល់ចម្លើយសម្រាប់ការតយុទ្ធដែលោកមានជាមួយ បាប និងអំពើល្អ។
ដូច្នេះ គ្មានការកាត់ទោសដល់អស់អ្នកដែលនៅក្នុងព្រះគ្រិស្តយេស៊ូទេ
នៅទីនេះពាក្យ «ការកាត់ទោស» សំដៅដល់ការដាក់ទោសមនុស្ស។
ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់នឹងមិនកាត់ទោស
និងមិនដាក់ទោសអស់អ្នកដែលរួមជាមួយព្រះគ្រិស្តយេស៊ូឡើយ» (UDB)។
(សូមមើល:
ដូច្នេះ
«សម្រាប់ហេតុផល» ឬ «ព្រោះអ្វីដែលខ្ញុំប្រាប់អ្នករាល់គ្នាជាសេចក្តីពិត»។
គោលការណ៍របស់ព្រះវិញ្ញាណនៃជីវិតក្នុងព្រះគ្រិស្តយេស៊ូ
ឃ្លានេះសំដៅដល់ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត
«ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រិស្តយេស៊ូ»។
គោលការណ៍នៃអំពើបាប និងសេចក្តីស្លាប់
ឃ្លានេះសំដៅដល់ធម្មជាតិបាបរបស់យើង ដែលបង្ខំយើងឲ្យធ្វើបាប។
Romans 8:3
ដ្បិត អ្វីដែលក្រឹត្យវិន័យមិនអាចធ្វើបាន គឺដោយសារភាពខ្សោយនៃសាច់ឈាម ប៉ុន្តែ
ព្រះជាម្ចាស់អាចធ្វើបាន
នៅទីនេះ ក្រឹត្យវិន័យបានពណ៌នាដូចជាមនុស្សម្នាក់
ដែលមិនអាចបំបែកអំណាចអំពើបាបបាន។ ការបកប្រែផ្សេងទៀត:
«ក្រឹត្យវិន័យមិនមានអំណាចបញ្ឈប់យើងពីការប្រព្រឹត្តបាបបានទេ
ព្រោះអំណាចនៃអំពើបាបដែលមានក្នុងយើងនោះខ្លាំង។
ប៉ុន្តែព្រះជាម្ចាស់មិនបានបញ្ឈប់យើងពីការប្រព្រឹត្តបាបនោះទេ។
ដោយសារសាច់ឈាម
«ដោយសារធម្មជាតិបាបរបស់មនុស្ស»។
ព្រះអង្គបានចាត់ព្រះបុត្រារបស់ព្រះអង្គផ្ទាល់នៅក្នុងនិស្ស័យជាមនុស្សមានបាបខាងសាច់ឈាម...
ជាយញ្ញបូជាលោះបាប ហើយព្រះអង្គត្រូវបានកាត់ទោសចំពោះបាប
ព្រះបុត្រារបស់ព្រះជាម្ចាស់ជាយញ្ញបូជាអស់កល្ប
ធួននឹងព្រះពិរោធន៍របស់ព្រះជាម្ចាស់សម្រាប់អំពើបាបរបស់យើង
ដោយថ្វាយព្រះអង្គទ្រង់និងព្រះជន្មជាមនុស្សជាយញ្ញបូជាអស់កល្បសម្រាប់បាប។
ព្រះបុត្រា
នេះជាឋានៈដ៏សំខាន់បំផុតសម្រាប់ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះ។
នៅក្នុងនិស្ស័យជាមនុស្សមានបាបខាងសាច់ឈាម
«ដែលមើលទៅដូចជាមនុស្សដទៃទៀតដែលជាមនុស្សបាប»។
ឲ្យធ្វើជាយញ្ញបូជាលោះបាប
«ដូច្នេះ ទ្រង់អាចសុគតជាយញ្ញបូជាសម្រាប់បាបរបស់យើង»។
ហើយព្រះអង្គត្រូវបានកាត់ទោសចំពោះបាបនៅក្នុងសាច់ឈាម
«ហើយព្រះជាម្ចាស់បំផ្លាញអំណាចបាបតាមរយៈព្រះកាយរបស់ព្រះរាជបុត្រារបស់ទ្រង់»។
ដើម្បីឲ្យតម្រូវតាមក្រឹត្យវិន័យ អាចបានសម្រេចនៅក្នុងយើង
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

«យើងអាចសម្រេចនូវអ្វីដែលក្រឹត្យវិន័យតម្រូវ»។
យើងគឺជាអ្នកដែលដើរមិនមែនដោយសាច់ឈាមទេ
«យើងគឺជាអ្នកដែលមិនគោរពតាមចំណង់បាបរបស់យើង»។
ប៉ុន្តែ ដោយវិញ្ញាណវិញ
«ប៉ុន្តែ ជាអ្នកដែលគោរពព្រះវិញ្ញាណបរិសុទ្ធ»។
Romans 8:6
ប្រយោគភ្ជាប់
លោកប៉ូលបន្តបង្ហាញភាពខុសគ្នារវាងសាច់ឈាម
និងវិញ្ញាណដែលយើងមានឥឡូវនេះ។
គំនិតខាងសាច់ឈាម...គំនិតខាងវិញ្ញាណ
នៅទីនេះលោកប៉ូលនិយាយអំពីទាំង «ខាងសាច់ឈាម» និង «ខាងវិញ្ញាណ»
ដែលហាក់ដូចជាមនុស្សដែលមានជីវិតរស់នៅ។ ការបកប្រែផ្សេងទៀត:
«របៀបដែលមនុស្សបាបគិត...របៀបដែលមនុស្សស្តាប់ព្រះវិញ្ញាណបរិសុទ្ធគិត»
សេចក្តីស្លាប់
ពាក្យនេះមានន័យសំដៅដល់ការញែកមនុស្សចេញពីព្រះជាម្ចាស់។
អស់អ្នកដែលនៅក្នុងសាច់ឈាម
ឃ្លានេះសំដៅដល់មនុស្សដែលធ្វើអ្វីៗតាមធម្មជាតិជាមនុស្សបាបរបស់គេប្រាប់ពួកគេ។
Romans 8:9
ក្នុងសាច់ឈាម
«ការប្រព្រឹត្តតាមធម្មជាតិអំពើបាបរបស់អ្នក» មើលការបកប្រែ «សាច់ឈាម»
ដែលបកប្រែក្នុង ៨:៣។
នៅខាងវិញ្ញាណ
«ការប្រព្រឹត្តតាមព្រះវិញ្ញាណបរិសុទ្ធ»។
ព្រះវិញ្ញាណ...ព្រះវិញ្ញាណនៃព្រះជាម្ចាស់...វិញ្ញាណរបស់ព្រះគ្រិស្ត
ទាំងអស់ គឺសំដៅដល់ព្រះវិញ្ញាណបរិសុទ្ធ។
ប្រសិនបើពិតមែន
ឃ្លានេះមិនមែនមានន័យថា លោកប៉ូលសង្ស័យថាពួកគេតែមួយចំនួន
ដែលមានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះទេ។ លោកចង់អោយពួកគេដឹងថា
ពួកគេគ្រប់គ្នាទាំងអស់ មានព្រះវិញ្ញាណរបស់ព្រះ។ ការបកប្រែផ្សេងទៀត:
«ចាប់តាំងពី» ឬ «ពីព្រោះ»។
រូបកាយត្រូវស្លាប់ខាងឯអំពើបាប
ឃ្លានេះអាចមានន័យថា ទី១) មនុស្សគឺស្លាប់ខាងឯវិញ្ញាណ
ដោយសារអំណាចនៃបាប ឬ ទី២) រូបកាយដែលត្រូវស្លាប់នឹងនៅតែស្លាប់
ព្រោះតែបាប។
ប៉ុន្តែ វិញ្ញាណនឹងរស់នៅខាងឯសេចក្តីសុចរិតវិញ
ឃ្លានេះអាចមានន័យថា ទី១) មនុស្សរស់ខាងឯវិញ្ញាណ
ដោយសារព្រះជាម្ចាស់បានប្រទានឲ្យគេមានអំណាចធ្វើអ្វីដែលត្រឹមត្រូវ ឬ ទី២)
ព្រះជាម្ចាស់នឹងនាំមនុស្សមកកាន់ជីវិតវិញ បន្ទាប់ពីគេស្លាប់
ព្រោះព្រះជាម្ចាស់សុចរិត និងប្រទានជីវិតអស់កល្បដល់អ្នកជឿ។
Romans 8:11
ប្រសិនបើព្រះវិញ្ញាណ...រស់នៅក្នុងអ្នក
លោកប៉ូលសរុបថា ព្រះវិញ្ញាណបរិសុទ្ធគង់ក្នុងអ្នកអានរបស់លោក។
ការបកប្រែផ្សេងទៀត: «ចាប់តាំងពីព្រះវិញ្ញាណ...គង់នៅក្នុងអ្នក»។
របស់ព្រះដែលបានប្រោស
«របស់ព្រះជាម្ចាស់ ដែលបានប្រោស»។
ប្រោស
ពាក្យ «ប្រោស» នៅទីនេះ
មានន័យថាការធ្វើឲ្យមនុស្សដែលស្លាប់មានជីវិតរស់ឡើងវិញម្តងទៀត។
រូបកាយពុករលួយ
«រូបកាយ» ឬ «ខ្លួនប្រាណ» ដែលនឹងស្លាប់នៅថ្ងៃណាមួយ»។
Romans 8:12
ដូច្នេះ
«ព្រោះ អ្វីដែលខ្ញុំទើបនឹងប្រាប់អ្នករាល់គ្នាជាការពិត»។
បងប្អូន
ពាក្យនេះសំដៅដល់អ្នកដើរតាមព្រះគ្រិស្ត រួមទាំងបុរស និងស្ត្រី។
យើងគឺជាកូនបំណុល
លោកប៉ូលកំពុងនិយាយអំពីការគោរពស្តាប់បង្គាប់ ដែលដូចជាការសងបំណុល។
ការបកប្រែផ្សេងទៀត «យើងត្រូវគោរព»។
ប៉ុន្តែ មិនមែនកូនបំណុលខាងសាច់ឈាម គឺរស់នៅតាមសាច់ឈាមឡើយ
លោកប៉ូលកំពុងនិយាយអំពីការគោរពស្តាប់បង្គាប់ ដែលដូចជាការសងបំណុល។
ការបកប្រែផ្សេងទៀត «យើងត្រូវគោរព»។
ព្រោះប្រសិនបើអ្នករស់តាមសាច់ឈាម
លោកប៉ូលនិយាយម្តងទៀតអំពីការគោរព ដែលដូចជាការសងបំណុល។
អ្នកអាចរាប់បញ្ចូលទាំងសង្កត់ធ្ងន់លើពាក្យ «កូនបំណុល»។ ការបកប្រែផ្សេងទៀត
«ប៉ុន្តែ យើងមិនមែនជាកូនបំណុលខាងសាច់ឈាមនោះទេ
ហើយយើងក៏មិនត្រូវគោរពបំណងនៃអំពើបាបរបស់យើងដែរ»។
អ្នកនឹងស្លាប់
«អ្នកពិតជាត្រូវញែកចេញពីព្រះជាម្ចាស់»។
ប៉ុន្តែ ប្រសិនបើអ្នករស់នៅខាងវិញ្ញាណវិញ អ្នកនឹងស្លាប់ខាងឯការប្រព្រឹត្តខាងរូបកាយ
លោកប៉ូលមានប្រសាសន៍អំពី «មនុស្សចាស់» ត្រូវឆ្កាងជាមួយព្រះគ្រិស្ត
ជាមនុស្សដែលទទួលខុសត្រូវលើចំណង់បាបរបស់គាត់។ ការបកប្រែផ្សេងទៀត:
«ប៉ុន្តែ ដោយសារអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ
អ្នកលែងគោរពចំណង់នៃអំពើបាបរបស់អ្នកទៀត»។
Romans 8:14
ដ្បិតអស់អ្នកណាដែលដឹកនាំដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់
អ្នកអាចបកប្រែក្នុងទម្រង់បែបនេះថា
«សម្រាប់អស់អ្នកដែលព្រះវិញ្ញាណរបស់ព្រះដឹកនាំ»។
កូនរបស់ព្រះជាម្ចាស់
ឃ្លានេះមានន័យដល់អ្នកជឿទាំងអស់លើព្រះយេស៊ូ
ហើយជាញឹកញាប់ត្រូវបានបកប្រែថា «កូនស្ងួនភ្ងារបស់ព្រះជាម្ចាស់»។
ព្រោះអ្នកមិនបានទទួលវិញ្ញាណនៃចំណងដែលធ្វើឲ្យភ័យខ្លាចឡើយ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់មិនបានប្រទានឲ្យអ្នករាល់គ្នានូវវិញ្ញាណដែលនាំឲ្យជាទាសករនៃអំណាចបាប
និងភាពភ័យខ្លាចចំពោះការវិនិច្ឆ័យទោសរបស់ព្រះជាម្ចាស់នោះទេ។
ហើយអាចស្រែកថា
«ដែលជាហេតុឲ្យយើងស្រែកចេញមក»។
អ័ប្បា បិតា
«អ័ប្បា» គឺ «បិតា» ក្នុងភាសារអារ៉ាម។
Romans 8:16
ទទួលមរតក របស់ព្រះអង្គ
លោកប៉ូលនិយាយពីគ្រិស្តបរិស័ទ ដែលពួកគេដូចជាអ្នកទទួលមរតក
និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។ ការបកប្រែផ្សេងទៀត:
«នៅថ្ងៃមួយយើងក៏នឹងបានទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យា»។
យើងនឹងរួមទទួលមរតកជាមួយព្រះគ្រិស្ត
លោកប៉ូលនិយាយពីគ្រិស្តបរិស័ទ ដែលពួកគេដូចជាអ្នកទទួលមរតក
និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។
ព្រះជាម្ចាស់នឹងប្រទានអ្វីដែលទ្រង់ប្រទានឲ្យព្រះគ្រិស្ត។
ការបកប្រែតាមរបៀបផ្សេងទៀត:
«យើងនឹងបានទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យាជាមួយយើង
និងព្រះគ្រិស្តជាមួយគ្នា» (UDB)។
យើងអាចទទួលសិរីល្អជាមួយព្រះអង្គ
ព្រះជាម្ចាស់នឹងលើកតម្កើងគ្រិស្តបរិស័ទអ្នកជឿ
ពេលដែលទ្រង់លើកតម្កើងព្រះគ្រិស្ត។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត: «យើងអាចទទួលសិរីរុងរឿងជាមួយទ្រង់»។
Romans 8:18
ប្រយោគភ្ជាប់
លោកប៉ូលរំលឹកយើងជាអ្នកជឿថា រូបកាយរបស់យើងនឹងផ្លាស់ប្តូរ
នៅពេលការឆក់យករូបកាយរបស់យើងនៅវគ្គនេះ ដែលបញ្ចប់ក្នុង ៨:២៣។
ដ្បិត
ពាក្យនេះជាការសង្កត់ន័យ «ខ្ញុំគិតថា»។ វាមិនមានន័យថា «ពីព្រោះ» នោះទេ។
ខ្ញុំគិតថា...មិនស័ក្តិសមនឹងប្រៀបធៀបជាមួយ
អ្នកបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ខ្ញុំមិនអាចប្រៀបធៀបការឈឺចាប់ក្នុងពេលបច្ចុប្បន្ននេះជាមួយ...»។
នឹងបង្ហាញ
អ្នកបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់នឹងបង្ហាញ» ឬ «ព្រះជាម្ចាស់នឹងធ្វើឲ្យយើងដឹង»។
ព្រះជាម្ចាស់បានបង្កើតមកកំពុងទន្ទឹងរង់ចាំយ៉ាងអន្ទះសារ
លោកប៉ូលអធិប្បាយថា អ្វីៗគ្រប់បែបយ៉ាងដែលព្រះជាម្ចាស់បានបង្កើតមក

generated on Wed Sep 10 16:16:32 2025

ដូចជាមនុស្ស ដែលរង់ចាំយ៉ាងអន្ទះសារសម្រាប់អ្វីមួយ។
ការបង្ហាញខ្លួននៃបុត្ររបស់ព្រះជាម្ចាស់
អ្នកបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«សម្រាប់ពេលដែលព្រះជាម្ចាស់នឹងបង្ហាញបុត្ររបស់ទ្រង់»។
បុត្ររបស់ព្រះជាម្ចាស់
នៅទីនេះគឺសំដៅដល់អ្នកជឿលើព្រះយេស៊ូទាំងអស់។ អ្នកក៏អាចបកប្រែថា «បុត្រាបុត្រី របស់ព្រះជាម្ចាស់»។
Romans 8:20
ព្រោះអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក បានប្រគល់ទៅក្នុងភាពឥតប្រយោជន៍
អ្នកបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់ធ្វើឲ្យអ្វីៗដែលព្រះអង្គបានបង្កើត ទៅជាឥតបានការ
តាមការគ្រោងទុក»
តែមិនមែនដោយស្ម័គ្រចិត្តទេ គឺព្រះជាម្ចាស់បានតម្រូវដូច្នេះ
នៅទីនេះលោកប៉ូលអធិប្បាយពី «ការបង្កើត» ដូចជាមនុស្ស អាចមានចំណង់។ ការបកប្រែផ្សេងទៀត:
«ពីព្រោះនេះមិនមែនជាអ្វីដែលជាស្នាព្រះហស្តទ្រង់បង្កើតចង់បានទេ
ប៉ុន្តែព្រោះជាអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យ»។
ដោយសង្ឃឹមថា អ្វីៗដែលព្រះជាម្ចាស់បានបង្កើតមកនឹងបានដោះឲ្យរួច
អ្នកអាចបកប្រែឃ្លានេះ ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រោះព្រះជាម្ចាស់បានដឹងថា ទ្រង់នឹងសង្គ្រោះអ្វីដែលជាស្នារព្រះហស្តរបស់ទ្រង់។
ពីភាពជាបាវបម្រើ
លោកប៉ូលនិយាយពីភាពឥតប្រយោជន៍នៃអ្វីៗទាំងអស់ដែល រងឥទ្ធិពលមកពីបាប ដូចជារូបកាយដែលស្លាប់ ហើយរលួយទៅ។ បន្ទាប់មក
លោកនិយាយអំពីអ្វីៗទាំងអស់ដែលមានបទពិសោធន៍ដូចគ្នា
ប្រសិនបើពួកគេធ្លាប់បម្រើចៅហ្វាយនោះ។ ការបកប្រែផ្សេងទៀត:
«ពីភាពស្មុយរលួយ និងសេចក្តីស្លាប់»។
ទៅឯសេរីភាពនៃសេចក្តីរុងរឿងជាបុត្រព្រះជាម្ចាស់
«ហើយទ្រង់នឹងរំដោះពួកគេ
ពេលដែលទ្រង់ប្រទានសិរីរុងរឿងទៅក្នុងរាជ្យបុត្រារបស់ទ្រង់»។
យើងដឹងហើយថា មកទល់ថ្ងៃនេះ ពិភពលោកទាំងមូលកំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់
ការបង្កើតគឺប្រៀបបាននឹងមនុស្សស្រីដែលឈឺចាប់ កំឡុងពេលដែលហៀបនឹងសម្រាលកូន។ ការបកប្រែផ្សេងទៀត: «យើងដឹងហើយថា
អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក ត្រូវការសេរីភាព
ហើយឈឺចុកចាប់ដូចជាស្ត្រីហៀបនឹងសម្រាលបុត្រ។
Romans 8:23
ដែលជាផលដំបូងរបស់ព្រះវិញ្ញាណ
លោកប៉ូលប្រៀបធៀបការទទួលព្រះវិញ្ញាណរបស់អ្នកជឿទៅនឹងផលប្រៃដំបូង និងបន្លែបង្កានៃរដូវដាំដុះ។ ប្រយោគនេះគូសបញ្ជាក់ថាព្រះវិញ្ញាណបរិសុទ្ធ
ជារបស់ដំបូងគេដែលព្រះជាម្ចាស់នឹងប្រទានឲ្យអ្នកជឿ។
រង់ចាំការទទួលយកភាពជាកូនគឺជាការប្រោសលោះរូបកាយរបស់យើង
ឃ្លា «ភាពជាកូនរបស់យើង» នៅទីនេះមានន័យថា
ពេលដែលយើងក្លាយជាសមាជិកពេញសិទ្ធក្នុងគ្រួសារព្រះជាម្ចាស់
គឺយើងដូចជាកូនចិញ្ចឹម។ ពាក្យ «សេចក្តីសង្គ្រោះ» មានន័យថា
នៅពេលដែលព្រះជាម្ចាស់សង្គ្រោះយើង។ ការបកប្រែផ្សេងទៀត:
«រង់ចាំការក្លាយជាសមាជិកពេញសិទ្ធិក្នុងគ្រួសារព្រះជាម្ចាស់
ហើយទ្រង់សង្គ្រោះរូបកាយរបស់យើងពីភាពពុករលួយ និងសេចក្តីស្លាប់។
ដោយទុកចិត្ត យើងបានសង្គ្រោះ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ដោយព្រះជាម្ចាស់បានសង្គ្រោះយើង ដ្បិត យើងបានទុកចិត្តលើទ្រង់»។
ប៉ុន្តែ អ្វីដែលយើងទុកចិត្តមិនទាន់ឃើញនៅឡើយ
សម្រាប់អស់អ្នកដែលមានទំនុកចិត្តចំពោះអ្វីដែលខ្លួនបានឃើញហើយ តើមានប្រយោជន៍អ្វី?
លោកប៉ូលប្រើសំណួរនេះ ដើម្បីជួយអ្នកស្តាប់របស់លោក ឲ្យយល់ថា អ្វីទៅជា «ការទុកចិត្ត»។ ការបកប្រែផ្សេងទៀត: «ប៉ុន្តែ
ប្រសិនបើយើងរង់ចាំដោយភាពជឿជាក់ នោះមានន័យថា
យើងមិនទាន់មានអ្វីដែលយើងចង់បាននោះទេ។
មិនមានអ្នកណាម្នាក់រង់ចាំដោយទុកចិត្តនោះទេ ប្រសិនបើ
គេមានអ្វីដែលគេចង់បានហើយនោះ»។
Romans 8:26
ប្រយោគភ្ជាប់
ទោះបីជាលោកប៉ូលបានបញ្ជាក់ថា មានការតយុទ្ធគ្នារវាងសាច់ឈាម
និងវិញ្ញាណក្នុងអ្នកជឿក៏ដោយ តែលោកក៏បញ្ជាក់ថាព្រះវិញ្ញាណកំពុងជួយយើង។
ការថ្ងូរដែលមិនអាចរៀបរាប់បាន
«ការថ្ងូរដែលយើងមិនអាច ពណ៌នាជាពាក្យសម្តីបាន»។
ព្រះអង្គជាព្រះជាម្ចាស់ដែលស្គាល់ចិត្ត
ឃ្លានេះសំដៅដល់ព្រះជាម្ចាស់។ ពាក្យ «ស្គាល់ចិត្ត» នៅទីនេះ
មានន័យបញ្ជាក់ពីការ «ពិនិត្យមើលគំនិត និងអារម្មណ៍របស់យើង»។
ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់
ដែលស្គាល់ចិត្តនិងគំនិតរបស់យើងទាំងអស់»
Romans 8:28
ប្រយោគភ្ជាប់
លោកប៉ូលរំលឹកអ្នកជឿថា
គ្មានអ្វីអាចញែកពួកគេចេញពីក្តីស្រលាញ់របស់ព្រះជាម្ចាស់បានទេ។
ដល់អស់អ្នកដែលព្រះអង្គបានត្រាស់ហៅ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«សម្រាប់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស»។
អស់អ្នកដែលព្រះអង្គបានស្គាល់ជាមុន
«អស់អ្នកដែលព្រះជាម្ចាស់បានស្គាល់ មុនពេលដែលទ្រង់បង្កើតពួកគេ»។
ព្រះអង្គបានតម្រូវពួកគេ
«ទ្រង់ក៏បានបង្កើតជោគវាសនារបស់ពួកគេ» ឬ «ទ្រង់ក៏បានរៀបចំផែនការណ៍
ដែលជាប្រយោជន៍»
បានតម្រូវពួកគេទុកជាស្រេចឲ្យមានលក្ខណដូចព្រះរាជបុត្រារបស់ព្រះអង្គ
ព្រះជាម្ចាស់បានគ្រោងទុកតាំងពីចាប់ផ្តើមការបង្កើត
ដើម្បីដាំអស់អ្នកដែលជឿលើព្រះយេស៊ូ ជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់
នៅក្នុងមនុស្សដែលដូចជាព្រះអង្គ។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ទ្រង់អាចផ្លាស់ប្តូរពួកគេឲ្យដូចជាព្រះបុត្រារបស់ទ្រង់»
ព្រះរាជបុត្រា
នេះជាឋានៈដ៏សំខាន់បំផុតសម្រាប់ព្រះយេស៊ូ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់។
ដើម្បីឲ្យព្រះរាជបុត្រាត្រលប់ជាកូនច្បង
«ដូច្នេះ ព្រះរាជបុត្រារបស់ទ្រង់អាចជាបុត្រច្បង»
ក្នុងចំណោមបងប្អូនជាច្រើន
នៅទីនេះពាក្យ «បងប្អូន» សំដៅលើអ្នកជឿទាំងអស់ ទាំងស្រី និងប្រុស។
ការបកប្រែតាមរបៀបផ្សេងទៀត: «ក្នុងចំណោមបងប្អូនប្រុសស្រី
ដែលជាគ្រួសាររបស់ព្រះជាម្ចាស់។
អស់អ្នកដែលបានតម្រូវទុក
«អស់អ្នកដែលព្រះជាម្ចាស់បានបង្កើតគ្រោងការសម្រាប់ជាប្រយោជន៍»
អ្នកទាំងនោះនឹងបានសុចរិត
នៅទីនេះពាក្យ «បានសេចក្តីសុចរិត» គឺជាទម្រង់អតីតកាល ដើម្បីបញ្ជាក់ថា
វាពិតជានឹងកើតឡើង។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ទ្រង់ក៏ធ្វើអោយសុចរិតជាមួយទ្រង់»
អ្នកទាំងនោះនឹងបានទទួលសិរីល្អផងដែរ
ពាក្យ «បានទទួលសិរីល្អ» គឺជាទម្រង់អតីតកាល
ដែលបញ្ជាក់ថាការនេះនឹងពិតជាបានកើតឡើង។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ទាំងនេះទ្រង់នឹងប្រទានសិរីរុងរឿង»។
Romans 8:31
ដូច្នេះ តើយើងគួរនិយាយអំពីរឿងនេះយ៉ាងដូចម្តេច? ប្រសិនបើ ព្រះជាម្ចាស់នៅខាងយើងហើយ
តើអ្នកណាប្រឆាំងនឹងយើងបាន?
លោកប៉ូលប្រើសំណួរដើម្បីបញ្ជាក់ចំនុចសំខាន់ពីអ្វីដែលលោកនិយាយយ៉ាងញឹកញាប់។
ការបកប្រែតាមរបៀបផ្សេងទៀត: «នេះជាអ្វីដែលយើងគួរតែដឹងពីការណ៍នេះ គឺថា:
គ្មានអ្នកណាអាចប្រឆាំងនឹងយើងបានទេ ចាប់តាំងពីព្រះជាម្ចាស់ជួយយើង»។
ព្រះអង្គមិនបានសំចៃយព្រះបុត្រារបស់ព្រះអង្គផ្ទាល់
ព្រះជាម្ចាស់ ព្រះបិតាបានចាត់ព្រះបុត្រារបស់ទ្រង់ ព្រះយេស៊ូគ្រិស្ត
ឲ្យមកជាប់ឆ្កាងដោយគ្មានបាបសោះ ជាយញ្ញបូជាបរិសុទ្ធដ៏អស់កល្ប
ជាការលះបង់គ្មានដែនកំណត់ដើម្បីបំពេញភាពវិសុទ្ធដ៏អស់កល្បរបស់ព្រះជាម្ចាស់
ប្រឆាំងនឹងអំពើបាបរបស់មនុស្សជាតិ។ ពាក្យ «ព្រះរាជបុត្រា» នៅទីនេះ
ជាឋានៈដ៏សំខាន់សម្រាប់ព្រះយេស៊ូ បុត្រារបស់ព្រះជាម្ចាស់។
ទ្រង់បានចាត់ព្រះអង្គមក
«ប៉ុន្តែ បានលើកទ្រង់ឡើងលើអស់ទាំងខ្មាំងសត្រូវរបស់ទ្រង់»

generated on Wed Sep 10 16:16:32 2025

ដូច្នេះ ព្រះអង្គនឹងប្រទានអ្វីៗទាំងអស់ដល់យើងបានរួមជាមួយព្រះអង្គដែរ
លោកប៉ូលប្រើសំណួរសម្រាប់បញ្ជាក់ថា:
«ទ្រង់ពិតជានឹងប្រទានអ្វីៗទាំងអស់ដល់យើង»
Romans 8:33
តើអ្នកណាអាចប្រឆាំងទាស់ជាមួយនឹងអ្នកដែលព្រះជាម្ចាស់បានរើសតាំងបាន?
ព្រះអង្គគឺជាព្រះជាម្ចាស់នៃយុត្តិធម៌
លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់អត្ថន័យ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមានអ្នកណាអាចប្រឆាំងទាស់នឹងយើង នៅចំពោះព្រះជាម្ចាស់បានទេ
ពីព្រោះទ្រង់គឺជាអ្នកដែលធ្វើឲ្យយើងត្រឹមត្រូវជាមួយទ្រង់»។
តើអ្នកណានឹងត្រូវកាត់ទោស?
លោកប៉ូលប្រើសំណួរនេះសម្រាប់បញ្ជាក់បន្ថែម។
លោកមិនបានរំពឹងលើចម្លើយទេ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមានអ្នកណាម្នាក់នឹងកាត់ទោសយើងនោះទេ!»
លើសពីនោះ ទ្រង់ក៏បានរស់ឡើងវិញ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«អ្នកដែលមានសារសំខាន់ជាងនេះទៅទៀត ព្រះជាម្ចាស់បានប្រោសពីស្លាប់» ឬ
«អ្នកដែលមានសារសំខាន់ជាងនេះទៅទៀត បានរស់ឡើងវិញ។
Romans 8:35
តើអ្នកណានឹងពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តបាន?
សំណួរនេះហាក់ដូចជាសួរអំពីមនុស្ស ប៉ុន្តែ តាមរយៈចម្លើយដែលបានរៀបរាប់
គឺមិនមែនទេ។ ដូច្នេះ លោកប៉ូលប្រហែលជាកំពុងនិយាយអំពីព្រឹត្តិការណ៍
ដែលពួកវាដូចជាមនុស្ស។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមានអ្នកណាម្នាក់អាចពង្រាត់យើងពីក្តីស្រលាញ់របស់ព្រះគ្រិស្តបានទេ» ឬ
«មិនមានអ្វីមួយដែលនឹងអាចពង្រាត់យើងពីក្តីស្រលាញ់របស់ព្រះគ្រិស្តបានទេ»។
តើជាសេចក្តីវេទនា សេចក្តីលំបាក ការបៀតបៀន សេចក្តីអត់ឃ្លាន សេចក្តីអាក្រាត សេចក្តីអន្តរាយ ឬក៏ដាវ?
ពាក្យ «ដាវ» នៅទីនេះជាការប្រៀបធៀបដែលបញ្ជាក់ពីអ្នកណាម្នាក់ដែលសម្លាប់។
ពាក្យ «វាមិនអាចទៅបានទេដែលមានអ្នកណាម្នាក់បង្កបញ្ហាឲ្យយើង
ធ្វើឲ្យយើងឈឺចាប់ យកសម្លៀកបំពាក់និងអាហាររបស់យើង
ឬសូម្បីតែសម្លាប់យើង»។
សេចក្តីវេទនា ឬសេចក្តីលំបាក
ពាក្យទាំងពីរនេះគឺមានអត្ថន័យដូចគ្នា។
ដោយសារតែព្រះអង្គ
ពាក្យ «ដោយសារ» គឺឯកវចន ហើយសំដៅដល់ព្រះជាម្ចាស់។ ពាក្យ
«សម្រាប់អ្នក»
យើងត្រូវបានគេចង់ស្លាប់ពីព្រឹកដល់ល្ងាច
ពាក្យ «យើង» នៅទីនេះសំដៅដល់អ្នកដែលសរសេរ ខគម្ពីរនេះ
និងរាប់បញ្ចូលទាំងអស់អ្នកដែលស្មោះត្រង់នឹងព្រះជាម្ចាស់ផងដែរ។ ឃ្លា
«ពីព្រឹកដល់ល្ងាច»
គឺជាការបន្ថែមដើម្បីបញ្ជាក់ថាតើពួកគេស្ថិតនៅក្នុងគ្រោះថ្នាក់កំរិតណា។
លោកប៉ូលប្រើផ្នែកនេះក្នុងខគម្ពីរដើម្បីបង្ហាញថា
មនុស្សទាំងអស់ដែលដើរតាមព្រះជាម្ចាស់គួររំពឹងទុកដល់ពេលវេលាលំបាក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ខ្មាំងសត្រូវរបស់យើងតាមសម្លាប់យើងមិនឈប់មិនឈរ»។
គេបានរាប់យើងថាជាចៀមដែលត្រូវគេសម្លាប់
លោកប៉ូលប្រៀបធៀបមនុស្សដែលគេសម្លាប់ដោយសារតាមព្រះជាម្ចាស់ទៅនឹងរបស់សត្វ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ជីវិតរបស់យើងគឺមិនមានតម្លៃលើសជាងចៀមដែលពួកគេសម្លាប់នោះទេ»។
Romans 8:37
យើងវិសេសជាងមនុស្សមានជ័យជម្នះទៅទៀត
«យើងមានជ័យជម្នះមួយរយភាគរយ»
តាមរយៈព្រះអង្គដែលស្រឡាញ់យើង
អ្នកអាចធ្វើការបញ្ជាក់ប្រភេទក្តីស្រលាញ់ដែលព្រះយេស៊ូបានបង្ហាញ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដោយព្រះយេស៊ូ
ដែលបានស្រលាញ់យើងដល់ម្លេះ ទ្រង់សុខចិត្តសុគតដើម្បីយើង»។
យើងមានការជឿជាក់
«ខ្ញុំមានការជឿទុកចិត្ត» ឬ «ខ្ញុំមានភាពជឿជាក់»។
ការគ្រប់គ្រង
ពាក្យនេះអាចមានន័យថា ទី១) ពួកវិញ្ញាណគ្រប់គ្រងឬវិញ្ញាណអាក្រក់ ឬ ទី២)
ពួកស្តេច ឬ ពួកអ្នកគ្រប់គ្រង។
ឬអំណាច
ពាក្យនេះអាចមានន័យថា ទី១)ខាងវិញ្ញាណជាមួយអំណាច ឬ
ទី២)ខាងសាច់ឈាម និងអំណាច។

---

9 [1]ខ្ញុំប្រាប់ពីសេចក្តីពិតនៅក្នុងព្រះគ្រិស្ត។ ខ្ញុំមិនកុហកទេ ហើយមនសិការរបស់ខ្ញុំធ្វើបន្ទាល់ជាមួយនឹងខ្ញុំ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ[2]សម្រាប់ខ្ញុំ
គឺខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង ហើយក៏មានការឈឺចាប់ឥតឈប់ឈរនៅក្នុងចិត្តរបស់ខ្ញុំដែរ។
[3]ព្រោះខ្ញុំចង់ឲ្យខ្លួនខ្ញុំត្រូវបណ្តាសា ហើយត្រូវបានញែកចេញពីព្រះគ្រិស្តដោយព្រោះបងប្អូនរបស់ខ្ញុំ គឺអស់អ្នកដែលជាសាសន៍របស់ខ្ញុំ ខាងឯសាច់ឈាម។[4]គឺជាជនជាតិ
អ៊ីស្រាអែលដែលជាកូនចិញ្ចឹមរបស់ព្រះជាម្ចាស់ ហើយមានសិរីរុងរឿង កិច្ចព្រមព្រៀង គម្ពីរវិន័យ ការបម្រើព្រះ និងសេចក្តីសន្យាផ្សេងៗ។[5]ដោយសារដូនតារបស់គេ
ព្រះយេស៊ូបានប្រសូតជាសាច់ឈាម ព្រះអង្គគឺជាព្រះជាម្ចាស់លើទាំងអស់។ សូមឲ្យព្រះអង្គបានសរសើរជារៀងរហូត។ អាម៉ែន។
[6]ប៉ុន្តែ នោះមិនមែនមានន័យថាសេចក្តីសន្យារបស់ព្រះជាម្ចាស់ត្រូវបានបរាជ័យនោះឡើយ។ ព្រោះមិនមែនមនុស្សគ្រប់គ្នានៅក្នុងអ៊ីស្រាអែល
ដែលពិតជាកម្មសិទ្ធិរបស់អ៊ីស្រាអែលនោះទេ។[7]មិនប្រាកថា ពូជពង្សរបស់លោកអប្រាហាំទាំងអស់ ពិតជាកូនចៅគាត់នោះទេ។ ប៉ុន្តែ «តាមរយៈលោកអ៊ីសាកវិញទេតើ
ជាពូជពង្សដែលព្រះជាម្ចាស់បានហៅ»។
[8]កូនចៅខាងសាច់ឈាមមិនមែនជាកូនរបស់ព្រះជាម្ចាស់ទេ។ ប៉ុន្តែ មានតែកូនចៅនៃសេចក្តីសន្យាទេ ដែលបានរាប់ថាជាមួយពូជពង្សដែលព្រះជាម្ចាស់បានរើស។
[9]ព្រោះនេះគឺជាព្រះបន្ទូលសន្យា៖ «នៅពេលនេះ ឆ្នាំក្រោយ យើងនឹងមកវិញ នោះ សារ៉ានឹងមានកូនប្រុសមួយ»។
[10]មិនគ្រាន់តែប៉ុណ្ណោះ នាងរេបេកាមានផ្ទៃពោះជាមួយបុរសម្នាក់ គឺលោកអ៊ីសាកជាឪពុករបស់យើង[11]ព្រោះកូនដែលមិនទាន់បានកើត ក៏មិនអាចធ្វើល្អ ឬអាក្រក់ដែរ
ដូច្នេះគោលបំណងរបស់ព្រះជាម្ចាស់ដែលជ្រើសរើសនៅតែបាននៅជាប់ មិនមែនដោយសារការប្រព្រឹត្តឡើយ ប៉ុន្តែ ដោយសារព្រះអង្គដែលបានត្រាស់ហៅវិញ។
[12]ព្រះអង្គមានបន្ទូលទៅនាងថា៖ «កូនច្បងនឹងបម្រើកូនប្អូន»។[13]ដូចមានសេចក្តីដែលបានចែងទុកមកថា៖ «យើងស្រឡាញ់យ៉ាកុប ប៉ុន្តែយើងស្អប់អេសាវវិញ»។
[14]ដូច្នេះ តើយើងនឹងនិយាយយ៉ាងដូចម្តេច? តើមនុស្សទុច្ចរិតអាចនៅជាមួយព្រះជាម្ចាស់បាន? ទេ អត់ទេ។[15]ព្រោះ ទ្រង់មានបន្ទូលទៅកាន់លោកម៉ូសេថា៖
«យើងនឹងផ្តល់មេត្តាដល់អ្នកដែលដែលយើងនឹងផ្តល់មេត្តា ហើយយើងនឹងផ្តល់អាណិតអាសូរដល់អ្នកណាដែលយើងអាណិតអាសូរ»។[16]ដូច្នេះ
មិនមែនដោយសារគាត់ខំប្រឹងប្រែង ឬមិនដោយសារគាត់ខំរត់ទេ ប៉ុន្តែ ដោយសារព្រះជាម្ចាស់ ដែលផ្តល់មេត្តាវិញ។
[17]ដ្បិត បទគម្ពីរបានថ្លែងទៅកាន់ស្តេចផារោនថា៖ «ហេតុផលដែលយើងបានតាំងអ្នកឡើង គឺដើម្បីយើងអាចបង្ហាញអំណាចរបស់យើងនៅក្នុងអ្នក
និងដើម្បីឲ្យមនុស្សបានឃើញពីព្រះនាមដ៏មានឫទ្ធិរបស់យើងបានប្រកាសពេញផែនដី»។[18]ដូច្នេះ ព្រះជាម្ចាស់ផ្តល់មេត្តាដល់អ្នកដែលព្រះអង្គគាប់ព្រះហឫទ័យ
ហើយអ្នកដែលព្រះអង្គគាប់ព្រះហឫទ័យធ្វើឲ្យមានចិត្តរឹងរូស ក៏ស្រេចតែព្រះហឫទ័យរបស់ព្រះអង្គ។
[19]ដូច្នេះ អ្នកនឹងនិយាយមកខ្ញុំថា៖ «ហេតុអ្វីបានជាព្រះអង្គនៅតែស្វែងរកកំហុសរបស់អ្នកដែលប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះអង្គទៀត?[20]មិនមែនទេ ឱមនុស្សអើយ
តើអ្នកជានរណា ដែលហ៊ានតវ៉ាទាស់ជាមួយព្រះជាម្ចាស់ដូច្នេះ? តើដីឥដ្ឋនឹងនិយាយទៅកាន់ អ្នកដែលសូនខ្លួនថា៖ «ហេតុអ្វីបានជាអ្នកសូនខ្ញុំមានរាងបែបនេះ?»[21]គឺដី
ឥដ្ឋដដែល គាត់អាចយកទៅសូនធ្វើជារបស់ថ្លៃថ្នូរផង ហើយសូនធ្វើជារបស់ធម្មតាផង។
[22]ចុះបើព្រះជាម្ចាស់ គាប់ព្រះហឫទ័យនឹងសម្តែងព្រះពិរោធរបស់ព្រះអង្គ ហើយធ្វើឲ្យគេស្គាល់ពីឫទ្ធានុភាពរបស់ព្រះអង្គ
ទ្រង់បានស៊ូទ្រាំអត់ធ្មត់យ៉ាងខ្លាំងជាមួយនឹងរបស់ដែលនឹងត្រូវរងព្រះពិរោធ និងបានរៀបចំសម្រាប់ការបំផ្លាញឬទេ?[23]ចុះបើ ព្រះអង្គធ្វើការនេះ
ដើម្បីឲ្យគេបានស្គាល់ពីសិរីល្អដ៏លើសលប់របស់ព្រះចំពោះរបស់ដែលព្រះអង្គផ្តល់ក្តីមេត្តា ដែលព្រះអង្គបានរៀបចំរួចមកហើយសម្រាប់សិរីល្អរបស់ព្រះអង្គមែនទេ?[24]ចុះបើ
ព្រះអង្គធ្វើការនេះ សម្រាប់យើងទាំងអស់គ្នា ដែលព្រះបានហៅផងដែរ មិនគ្រាន់តែបានហៅតែក្នុងចំណោមពួកយូដាប៉ុណ្ណោះទេ ប៉ុន្តែ ក្នុងចំណោមសាសន៍ដទៃដែរនោះ?

generated on Wed Sep 10 16:16:32 2025

[25]ដូចដែលទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរហូសេថា៖ «យើងនឹងហៅអ្នកដែលមិនមែនជាប្រជារាស្ត្ររបស់យើង ថាជាប្រជារាស្ត្ររបស់យើង
យើងនឹងហៅអ្នកដែលមិនគួរឲ្យស្រឡាញ់ថា គួរឲ្យស្រឡាញ់។[26]វានឹងកើតឡើងដូច្នេះ ដូចដែលព្រះអង្គមានបន្ទូលទៅកាន់ពួកគេថា៖ «អ្នកមិនមែនជារាស្ត្ររបស់យើងទេ
ពួកគេនឹងត្រូវបានហៅថា បុត្ររបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ»។
[27]លោកអេសាយបានស្រែកឡើងទាក់ទងនឹងអ៊ីស្រាអែលថា៖ «ទោះបើចំនួនកូនចៅអ៊ីស្រាអែលមានគ្នាដូចជាខ្សាច់សមុទ្រក្តី មានតែអ្នកដែលនៅសល់តែប៉ុណ្ណោះ
នឹងបានសង្គ្រោះ។[28]ព្រោះព្រះអម្ចាស់នឹងធ្វើឲ្យព្រះបន្ទូលរបស់ព្រះអង្គបានសម្រេចនៅលើផែនដី ជាឆាប់។[29]ដូច្នេះ លោកអេសាយបានមានប្រសាសន៍រួចមកហើយថា៖
«ប្រសិនបើ ព្រះអម្ចាស់នៃពួកពលបរិវារមិនរក្សាកូនចៅរបស់យើងទេ នោះយើងនឹងបានដូចជាក្រុងសូដុម ឬយើងនឹងបានដូចជាក្រុងកូម៉ូរ៉ាហើយ។
[30]ដូច្នេះ តើយើងនឹងនិយាយយ៉ាងដូចម្តេច? សាសន៍ដទៃ ដែលមិនស្វែងរកសេចក្តីសុចរិត បែរជាបានសុចរិត ហើយបានសុចរិតដោយសារជំនឿ។[31]ប៉ុន្តែ អ៊ីស្រាអែល
ដែលខំធ្វើតាមក្រឹត្យវិន័យនៃសេចក្តីសុចរិត ប៉ុន្តែ ពួកគេមិនអាចធ្វើបានទេ។
[32]ហេតុអ្វីបានជាមិនបាន? ព្រោះពួកគេមិនបានខំស្វែងសេចក្តីសុចរិតដោយសារជំនឿឡើយ ប៉ុន្តែ តាមរយៈការប្រព្រឹត្តវិញ។
ពួកគេជំពប់ដួលនឹងថ្មនៃការជំពប់[33]ដូចដែលមានសេចក្តីចែងទុកមកថា៖ «មើល យើងកំពុងតែចាក់គ្រឹះនៅលើស៊ីយ៉ូននូវថ្មនៃការជំពប់ ហើយថ្មនៃការរវាតចិត្ត។
អស់អ្នកណាដែលជឿនៅថ្មនោះ នឹងមិនត្រូវអាម៉ាស់ឡើយ។

Romans 9:1

ការភ្ជាប់សេចក្តីថ្លែងការណ៍៖

លោកប៉ូលប្រាប់អំពីបំណងប្រាថ្នាផ្ទាល់ខ្លួនរបស់លោក
ថាប្រជាជនអ៊ីុស្រាអែលនឹងបានសង្គ្រោះ។ បន្ទាប់មក លោកបញ្ជាក់ពីរបៀបផ្សេង
ដែលព្រះជាម្ចាស់បានរៀបចំដើម្បីអោយពួកគេជឿ។

ខ្ញុំប្រាប់ពីសេចក្តីពិតនៅក្នុងព្រះគ្រិស្ត។ ខ្ញុំមិនកុហកទេ

ក្នុងឃ្លាទាំងពីរនេះមានអត្ថន័យជាមូលដ្ឋានដូចគ្នា។
លោកប៉ូលប្រើឃ្លាទាំងនោះដើម្បីបញ្ជាក់ថា លោកកំពុងប្រាប់សេចក្តីពិត។

ហើយមនសិការរបស់ខ្ញុំធ្វើបន្ទាល់ជាមួយនឹងខ្ញុំ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ

«ព្រះវិញ្ញាណដ៏វិសុទ្ធត្រួតត្រាលើមនសិការរបស់ខ្ញុំ
ហើយបញ្ជាក់អ្វីដែលខ្ញុំនិយាយ»។

សម្រាប់ខ្ញុំ គឺខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង

ហើយក៏មានការឈឺចាប់ឥតឈប់ឈរនៅក្នុងចិត្តរបស់ខ្ញុំដែរ

ឃ្លា «ការឈឺចាប់ឥតឈប់ឈរនៅក្នុងចិត្តរបស់ខ្ញុំ»
គឺជាសំនួនដែលលោកប៉ូលប្រើដើម្បីចែករំលែកការពិបាករបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត: «ខ្ញុំប្រាប់អ្នកថា
ខ្ញុំពិតជាសោកសង្រេងយ៉ាងខ្លាំង»។

ការសោកស្តាយយ៉ាងខ្លាំង ហើយក៏មានការឈឺចាប់ឥតឈប់ឈរ

ក្នុងឃ្លាទាំងពីរនេះមានអត្ថន័យមូលដ្ឋានដូចគ្នា។
លោកប៉ូលប្រើឃ្លាទាំងនោះដើម្បីបញ្ជាក់ ពីការរំជួលចិត្តដែលលោកមាន។

Romans 9:3

ព្រោះខ្ញុំចង់ឲ្យខ្លួនខ្ញុំត្រូវបណ្តាសា ហើយត្រូវបានញែកចេញពីព្រះគ្រិស្តដោយព្រោះបងប្អូនរបស់ខ្ញុំ

គឺអស់អ្នកដែលជាសាសន៍របស់ខ្ញុំ ខាងឯសាច់ឈាម

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ខ្លួនខ្ញុំផ្ទាល់ចង់ឲ្យព្រះជាម្ចាស់ ដាក់បណ្តាសាខ្ញុំ
ហើយញែកខ្ញុំចេញពីព្រះគ្រិស្តជារាងរហូត
ប្រសិនបើនោះអាចជួយសាសន៍អ៊ីុស្រាអែលជាមនុស្សរបស់ខ្ញុំ ជឿលើព្រះគ្រិស្ត»។

បងប្អូន

នៅទីនេះសំដៅដល់គ្រិស្តបរិស័ទ រាប់ទាំងបុរស និងស្ត្រី។

ជាជនជាតិអ៊ីស្រាអែល

«ពួកគេ ដូចខ្ញុំ ជាសាសន៍អ៊ីុស្រាអែល។
ព្រះជាម្ចាស់បានជ្រើសរើសពួកគេជាពូជពង្សរបស់លោកយ៉ាកុប» (UDB)។

ជាកូនចិញ្ចឹម

លោកប៉ូលប្រើពាក្យប្រៀបធៀបនៅទីនេះ «កូនចិញ្ចឹម» ដើម្បីចង្អុលបង្ហាញថា
អ៊ីុស្រាអែលដូចជាកូនរបស់ព្រះជាម្ចាស់។ ការបកប្រែតាមរបៀបផ្សេងទៀត
«ពួកគេមានព្រះជាម្ចាស់ជាព្រះបិតារបស់ពួកគេ»។

ដោយសារដូនតារបស់គេ ព្រះយេស៊ូបានប្រសូតជាសាច់ឈាម

«ព្រះយេស៊ូបានប្រសូតជាសាច់ឈាម»
មានន័យថាព្រះគ្រិស្តគឺជាពូជជង្សនៃដូនតាអ៊ីុស្រាអែល។
ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះយេស៊ូបានប្រសូតជាសាច់ឈាម
ជាពូជពង្ស ពីដូចតារបស់ពួកគេ»។

Romans 9:6

ប្រយោគភ្ជាប់

លោកប៉ូលបញ្ជាក់ថា អស់អ្នកដែលកើតក្នុងគ្រួសាររបស់អ៊ីស្រាអែល
អាចក្លាយជាផ្នែកពិតរបស់អ៊ីស្រាអែលគឺតាមរយៈសេចក្តីជំនឿតែប៉ុណ្ណោះ។

ប៉ុន្តែ នោះមិនមែនមានន័យថាសេចក្តីសន្យារបស់ព្រះជាម្ចាស់ត្រូវបានបរាជ័យនោះឡើយ
«ប៉ុន្តែ ព្រះជាម្ចាស់នឹងមិនបរាជ័យក្នុងការរក្សាសន្យារបស់ទ្រង់ឡើយ» ឬ
«ព្រះជាម្ចាស់បានរក្សាព្រះបន្ទូលសន្យារបស់ទ្រង់»។

ព្រោះមិនមែនមនុស្សគ្រប់គ្នានៅក្នុងអ៊ីស្រាអែល ដែលពិតជាកម្មសិទ្ធិរបស់អ៊ីស្រាអែលនោះទេ

ព្រះជាម្ចាស់មិនបានប្រទានព្រះបន្ទូលសន្យាដល់គ្រប់គ្នាដែលជាពូជពង្សរបស់អ៊ីស្រាអែលខាងសាច់ឈាម
ប៉ុន្តែ គឺដល់ពូជពង្សខាងវិញ្ញាណរបស់ទ្រង់ នោះគឺ
អស់អ្នកដែលទុកចិត្តលើព្រះយេស៊ូ។

មិនប្រាកដថា ពូជពង្សរបស់លោកអប្រាហាំទាំងអស់ ពិតជាកូនចៅគាត់នោះទេ

«មិនមែនពួកគេទាំងអស់ជាកូនរបស់ព្រះជាម្ចាស់
ដោយព្រោះតែពួកគេជាកូនចៅរបស់លោកអប្រាហាំនោះទេ»។

Romans 9:8

កូនចៅខាងសាច់ឈាមមិនមែនជា

«កូនចៅខាងសាច់ឈាម» ទីនេះជានិយមធៀបដែលសំដៅ
ពូជពង្សរបស់អាប្រាហាំខាងសាច់ឈាម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមែនកូនចៅរបស់អប្រាហាំទាំងអស់»

កូនរបស់ព្រះជាម្ចាស់

ជាពាក្យប្រៀបធៀបដែលសំដៅដល់មនុស្សដែលជាពូជពង្សខាងវិញ្ញាណ
គឺអស់អ្នកដែលមានជំនឿលើព្រះយេស៊ូ។

កូនចៅនៃសេចក្តីសន្យា

សំដៅដល់មនុស្សដែលនឹងទទួលសេចក្តីសន្យាដែលព្រះជាម្ចាស់បានប្រទានឲ្យលោកអប្រាហាំ។

សារ៉ានឹងមានកូនប្រុសមួយ

អ្នកអាចបកប្រែឃ្លានេះ ក្នុងទម្រង់សកម្មដើម្បីបញ្ជាក់ថា
ព្រះជាម្ចាស់នឹងប្រទានកូនប្រុសមួយដល់សារ៉ា។ ការបកប្រែតាមរបៀបផ្សេងទៀត:
« យើងនឹងអោយកូនប្រុសមួយដល់សារ៉ា»។

Romans 9:10

នាងរេបេកា

«នាងរេបេកា» ក្នុងសមន្ធមេត្រីថ្មី គេសរសេរថា «នាងរេបិកា»។

លោកអ៊ីសាកជាឪពុករបស់យើង...ដូចមានសេចក្តី

ក្នុងវប្បធម៌របស់អ្នក អ្នកអាចត្រូវប្តូរ ៩:១១ បន្ទាប់ ៩:១២
ដែលធ្វើឲ្យពួកគេងាយស្រួលយល់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«គឺលោកអ៊ីសាកជាឪពុករបស់យើង ព្រះអង្គមានបន្ទូលទៅនាងថា៖
«កូនច្បងនឹងបម្រើកូនប្អូន»
ព្រោះកូនដែលមិនទាន់បានកើត...ដោយសារព្រះអង្គដែលបានត្រាស់ហៅវិញ។

ដូចមានសេចក្តី

ឪពុករបស់យើង

លោកប៉ូលសំដៅដល់លោកអ៊ីសាកជា «ឪពុករបស់យើង»
ព្រោះលោកអ៊ីសាកជាដូនតារបស់លោក និងអ្នកជឿសាសន៍យូដាក្នុងក្រុងរ៉ូម។

មានផ្ទៃពោះ

«មានគំត»

ព្រោះកូនដែលមិនទាន់បានកើត ក៏មិនអាចធ្វើល្អ ឬអាក្រក់ដែរ

«មុនពេលក្មេងកើតមក និងមុនពេលគេធ្វើអ្វីមួយ
ទោះជាការល្អឬការអាក្រក់ក្តី...»។

ដូច្នេះ គោលបំណងរបស់ព្រះជាម្ចាស់ដែលជ្រើសរើសនៅតែបាននៅជាប់

«ដូច្នេះអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យឲ្យកើតឡើង តាមការជ្រើសរើសរបស់ទ្រង់
នឹងកើតឡើង»។

ព្រោះកូនដែលមិនទាន់បានកើត

«មុនពេលក្មេងបានកើតមក»។

generated on Wed Sep 10 16:16:32 2025

ក៏មិនអាចធ្វើល្អ ឬអាក្រក់ដែរ
«មិនមែនដោយសារតែអ្វីដែលពួកគេធ្វើនោះទេ»។
ដោយសារព្រះអង្គ
ព្រោះព្រះជាម្ចាស់
ព្រះអង្គមានបន្ទូលទៅនាងថា៖ «កូនច្បងនឹងបម្រើកូនប្អូន»
«ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់នាងរេបេកា
កូនប្រុសច្បងនឹងបម្រើកូនប្រុសប្អូន»។
យើងស្រឡាញ់យ៉ាកុប ប៉ុន្តែ យើងស្អប់អេសាវវិញ
ព្រះជាម្ចាស់មិនបានស្អប់អេសាវ តាមសម័យរបស់ពាក្យទេ ប៉ុន្តែ
ទ្រង់ស្រលាញ់លោកយ៉ាកុបច្រើនជាងស្រលាញ់លោកអេសាវ។
Romans 9:14
តើយើងនឹងនិយាយយ៉ាងដូចម្តេច?
លោកប៉ូលប្រើសំណួរនេះដើម្បីទាញចំណាប់អារម្មណ៍អ្នកអានរបស់លោក។
ទេ អត់ទេ
«វាមិនអាចទៅរួចទេ!» ឬ «ពិតណាស់មិនអាច!» ឃ្លានេះបដិសេធយ៉ាងដាច់ខាត
ថាការណ៍នេះអាចនឹងកើតឡើង។
នៅទីនេះអ្នកក៏អាចប្រើឃ្លាដែលមានន័យដូចគ្នាក្នុងភាសារបស់អ្នក។
ទ្រង់មានបន្ទូលទៅកាន់លោកម៉ូសេថា
លោកប៉ូលនិយាយពីការសន្ទនារបស់ព្រះជាម្ចាស់ជាមួយលោកម៉ូសេ
ដូចជាកំពុងមានបន្ទូលក្នុងពេលបច្ចុប្បន្ននេះ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេ»។
មិនមែនដោយសារគាត់ខំប្រឹងប្រែង ឬមិនដោយសារគាត់ខំរត់ទេ
«វាមិនមែនដោយសារអ្វីដែលមនុស្សចង់ ឬដោយសារពួកគេព្យាយាមធ្វើនោះទេ»។
ឬមិនដោយសារគាត់ខំរត់ទេ
លោកប៉ូលនិយាយពីមនុស្សដែលធ្វើការល្អ ដើម្បីឲ្យគាប់ព្រះទ័យព្រះជាម្ចាស់
ដូចដែលមនុស្សបានរត់ប្រណាំង។
Romans 9:17
ដ្បិត បទគម្ពីរបានថ្លែង
នៅទីនេះបទគម្ពីរគឺដូចជាតួអង្គដែលព្រះជាម្ចាស់បានមានព្រះបន្ទូលមកកាន់ស្តេចផារោនៅក្នុង
ការបកប្រែតាមរបៀបផ្សេងទៀត:
«បទគម្ពីរកត់ត្រាអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល»។
ខ្ញុំ...របស់ខ្ញុំ
ព្រះជាម្ចាស់ សំដៅដល់ព្រះអង្គទ្រង់ផ្ទាល់។
អ្នក
ពាក្យនេះជា ឯកវចន
និងដើម្បីឲ្យមនុស្សបានឃើញពីព្រះនាមដ៏មានឫទ្ធិរបស់យើងបានប្រកាសពេញផែនដី
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយមនុស្សអាចប្រកាសពីព្រះនាមរបស់យើងនៅពេញផែនដីទាំងមូល»។
នាមរបស់យើង
ជាពាក្យសំដៅដល់ព្រះជាម្ចាស់ ក្នុងភាពជាអង្គទ្រង់ទាំងអស់។
ហើយអ្នកដែលព្រះអង្គគាប់ព្រះហឫទ័យ
ហើយអ្នកដែលព្រះអង្គគាប់ព្រះហឫទ័យធ្វើឲ្យមានចិត្តរឹងរូស ធ្វើឲ្យមានចិត្តរឹងរូស
ព្រះជាម្ចាស់ធ្វើឲ្យគេមានចិត្តរឹងរូស
ដល់អស់អ្នកណាដែលទ្រង់គាប់ព្រះទ័យធ្វើឲ្យគេរឹងរូស។
Romans 9:19
អ្នកនឹងនិយាយមកខ្ញុំថា
លោកប៉ូលកំពុងនិយាយរិះគន់ការបង្រៀនរបស់លោក
ដូចជាលោកកំពុងតែនិយាយទៅកាន់មនុស្សតែម្នាក់។
អ្នកអាចត្រូវប្រើពហុវចននៅទីនេះ។
«ហេតុអ្វីបានជាព្រះអង្គនៅតែស្វែងរកកំហុសរបស់អ្នកដែលប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះអង្គទៀត?
នេះជាសំណួរដែលមិនទាមទារចម្លើយ ដែលលោកប៉ូលប្រើដើម្បីបន្ថែមអត្ថន័យ។
អ្នកអាចបកប្រែសំណួរទាំងនេះជាប្រយោគដើម្បីបញ្ជាក់ន័យក៏បាន។
ព្រះអង្គ...របស់ព្រះអង្គ
ពាក្យ «ព្រះអង្គ» និង «របស់ព្រះអង្គ» នៅទីនេះសំដៅលើព្រះជាម្ចាស់។
តើដីឥដ្ឋនឹងនិយាយទៅកាន់... របស់ធម្មតាផង?
លោកប៉ូលប្រើប្រាស់សិទ្ធិរបស់ជាងស្មូនក្នុងការសូនប្រភេទផ្សេងៗនៃភាជន:ដែលទ្រង់ចង់សូនសើ
ជាន័យធៀបសម្រាប់សិទ្ធិរបស់អ្នកបង្កើត
ក្នុងការធ្វើអ្វីមួយដែលគាត់ចង់ជាមួយនឹងការបង្កើតរបស់គាត់។
លោកប៉ូលសួរសំណួរទាំងនេះដើម្បីបញ្ជាក់ប្រធានបទរបស់លោក។
ហេតុអ្វីបានជាអ្នកសូនខ្ញុំមានរាងបែបនេះ?
ពាក្យ «អ្នក» នៅទីនេះសំដៅលើព្រះជាម្ចាស់។
លោកប៉ូលប្រើសំណួរនេះដើម្បីបន្ថែមអត្ថន័យ។
អ្នកអាចបកប្រែសំណួរទាំងនេះជាការថ្លែងការណ៍ដោយសង្កត់ធ្ងន់។
ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់អើយ!
ព្រះអង្គមិនគួរបង្កើតទូលបង្គំក្នុងលក្ខណៈបែបនេះទេ!»
Romans 9:22
ព្រះជាម្ចាស់...របស់ព្រះអង្គ
ពាក្យ «ព្រះជាម្ចាស់» និង «របស់ព្រះអង្គ» នៅទីនេះសំដៅដល់ព្រះជាម្ចាស់។
របស់ដែលនឹងត្រូវរងព្រះពិរោធ...របស់ដែលព្រះអង្គផ្តល់ក្តីមេត្តា
លោកប៉ូលប្រៀបធៀបមនុស្សទៅនឹងរបស់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មនុស្សដែលសមនឹងទទួលព្រះពិរោធន...មនុស្សដែលសមនឹងទទួលព្រះគុណ»។
សិរីល្អដ៏លើសលប់របស់ព្រះ
លោកប៉ូលប្រៀបធៀបកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ទៅនឹង
«ភាពលើសលប់»។ ការបកប្រែតាមរបៀបផ្សេងទៀត: «សិរីរុងរឿងរបស់ទ្រង់
ដែលមានតម្លៃដ៏អស្ចារ្យ»។
ដែលព្រះអង្គបានរៀបចំរួចមកហើយសម្រាប់សិរីល្អរបស់ព្រះអង្គមែនទេ?
ពាក្យ «សិរីល្អ» នៅទីនេះសំដៅដល់ជីវិតនៅស្ថានសួគ៌ជាមួយនឹងព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «អស់អ្នកដែលព្រះជាម្ចាស់បានរៀបចំជាមុន
ដើម្បីអោយពួកគេអោចរស់នៅជាមួយទ្រង់»។
សម្រាប់យើងទាំងអស់គ្នា
ពាក្យ «យើង» ទីនេះសំដៅដល់លោកប៉ូលនិងអ្នកជឿទាំងឡាយ។
បានហៅ
នៅទីនេះពាក្យ «បានហៅ» មានន័យថាព្រះជាម្ចាស់បានកំណត់
ឬបានជ្រើសរើសមនុស្សឲ្យក្លាយមកជាកូន ជាអ្នកបម្រើ
និងជាអ្នកប្រកាសព្រះបន្ទូលនៃសេចក្តីសង្គ្រោះរបស់ទ្រង់តាមរយៈព្រះយេស៊ូ។
Romans 9:25
ប្រយោគភ្ជាប់
នៅក្នុងវគ្គនេះលោកប៉ូលពន្យល់ ពីការមិនជឿរបស់សាសន៍អ៊ីស្រាអែល
ដូចជាជាតិសាសន៍ដែលព្យាការីហូសេបានថ្លែងទុកពីមុន។
ដូចដែលទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរហូសេ
ពាក្យ «ទ្រង់» នៅទីនេះសំដៅលើព្រះជាម្ចាស់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដូចដែលព្រះជាម្ចាស់មានព្រះបន្ទូល
ដែលមាននៅក្នុងសៀវភៅដែលលោកហូសេបានសរសេរ»។
ហូសេ
លោកហូសេជាព្យាការី។
យើងនឹងហៅអ្នកដែលមិនមែនជាប្រជារាស្ត្ររបស់យើង
«យើងនឹងជ្រើសរើសមនុស្សដែលមិនមែនជាមនុស្សរបស់យើង
មកធ្វើជាមនុស្សរបស់យើង»។
អ្នកដែលមិនគួរឲ្យស្រឡាញ់ថា គួរឲ្យស្រឡាញ់
ពាក្យ «អ្នក» នៅទីនេះសំដៅដល់នាងកូមើ ភរិយារបស់លោកហូសេ
ដែលដំណាងឲ្យសាសន៍អ៊ីស្រាអែល។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត:
«យើងនឹងជ្រើសរើសអ្នកដែលយើងមិនស្រលាញ់
មកធ្វើជាអ្នកដែលយើងស្រលាញ់»។
បុត្ររបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ
ឃ្លា «ព្រះជន្មគង់នៅ» អាចសំដៅលើការពិតដែលថា ព្រះជាម្ចាស់ គឺជាព្រះ «ពិត»
ហើយមិនដូចជាព្រះក្លែងក្លាយទាំងឡាយនោះដែរ។
ការបកប្រែតាមរបៀបផ្សេងទៀត: «បុត្រនៃព្រះដ៏ពិត» (UDB)។
Romans 9:27
ស្រែកឡើង
«ស្រែកហៅ»
ដូចជាខ្សាច់សមុទ្រ
លោកប៉ូលប្រៀបធៀបចំនួនប្រជាជនអ៊ីស្រាអែលទៅនឹងចំនួនគ្រាប់ខ្សាច់នៃសមុទ្រ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដែលច្រើនឥតគណនា»។
ដើម្បីសង្គ្រោះដ
លោកប៉ូលប្រើពាក្យ «បានសង្គ្រោះ» នៅក្នុងផ្នែកវិញ្ញាណ។ ប្រសិនបើ
ព្រះជាម្ចាស់សង្គ្រោះមនុស្ស គឺមានន័យថា
តាមរយៈការជឿលើការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាង

generated on Wed Sep 10 16:16:32 2025

ព្រះជាម្ចាស់បានអត់ទោស
និងសង្គ្រោះគេពីការដាក់ទោសសម្រាប់អំពើបាបរបស់គេ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងសង្គ្រោះ» ។
ពាក្យ
សំដៅដល់គ្រប់យ៉ាងដែលព្រះជាម្ចាស់មានព្រះបន្ទូល ឬបញ្ជា។
យើង...យើង
ពាក្យ «យើង» នៅទីនេះ សំដៅដល់លោកអ៊ីសាយ
និងរួមបញ្ចូលទាំងជនជាតិអ៊ីស្រាអែល។
យើងនឹងបានដូចជាក្រុងសូដុម ឬយើងនឹងបានដូចជាក្រុងកូម៉ូរ៉ា
អ្នកអាចធ្វើឲ្យជាក់លាក់ជាងនេះ ពីរបៀបដែលជនជាតិអ៊ីស្រាអែលអាចដូចជាសូដុម
មិងកូម៉ូរ៉ា។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានបំផ្លាញយើងទាំងអស់គ្នា
ដូចជាទ្រង់បានបំផ្លាញក្រុងសូដុម និងក្រុងកូម៉ូរ៉ា»។
Romans 9:30
តើយើងនឹងនិយាយយ៉ាងដូចម្តេច?
លោកប៉ូលប្រើសំណួរនេះដើម្បីទាញការផ្តង់ស្មារតីរបស់អ្នកអានរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត: «នេះជាអ្វីដែលយើងត្រូវនិយាយ»។
សាសន៍ដទៃ
«យើងនឹងនិយាយថា សាសន៍ដទៃ»។
ដែលមិនស្វែងរកសេចក្តីសុចរិត
«អ្នកដែលមិនព្យាយាមតម្រូវព្រះទ័យព្រះជាម្ចាស់»។
បានសុចរិតដោយសារជំនឿ
ឃ្លា «ដោយសារជំនឿ» នៅទីនេះ
សំដៅដល់ការដាក់សេចក្តីទុកចិត្តរបស់អ្នកណាម្នាក់លើព្រះគ្រិស្ត។
អ្នកអាចធ្វើការបញ្ជាក់បន្ថែមក្នុងភាសារបស់អ្នក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រោះព្រះជាម្ចាស់បានធ្វើឲ្យពួកគេត្រឹមត្រូវជាមួយទ្រង់
ពេលដែលេពួកគេទុកចិត្តលើព្រះគ្រិស្ត»។
ពួកគេមិនអាចធ្វើបានទេ
ឃ្លានេះមានន័យថាជនជាតិអ៊ីស្រាអែល អាចមិនសព្វព្រះទ័យព្រះជាម្ចាស់
ដោយការព្យាយាមប្រកាន់ក្រឹត្យវិន័យ។
អ្នកអាចធ្វើការបញ្ជាក់បន្ថែមក្នុងភាសារបស់អ្នក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនបានទទួលការសព្វព្រះទ័យពីព្រះជាម្ចាស់ដោយការរក្សាក្រឹត្យវិន័យទេ
ព្រោះពួកគេមិនអាចរក្សាបាន»។
Romans 9:32
ហេតុអ្វីបានជាមិនបាន?
នេះជាការឃ្លាបិត។
អ្នកអាចរាប់បញ្ចូលទាំងការបញ្ជាក់ពាក្យក្នុងការបកប្រែរបស់អ្នក។
លោកប៉ូលសួរសំណួរនេះដើម្បីទាញចំណាប់អារម្មណ៍របស់អ្នកអានរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ហេតុអ្វីបានជាពួកគេមិនបានទទួលសេចក្តីសុចរិត?»
តាមរយៈការប្រព្រឹត្ត
ឃ្លានេះសំដៅដល់អ្វីៗដែលមនុស្សព្យាយាមធ្វើឲ្យព្រះជាម្ចាស់សព្វព្រះទ័យ។
អ្នកអាចធ្វើការបញ្ជាក់បន្ថែមពាក្យនេះក្នុងការបកប្រែរបស់អ្នក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ដោយការព្យាយាមធ្វើអ្វីដែលអាចឲ្យព្រះជាម្ចាស់សព្វព្រះទ័យ» ឬ
«ដោយប្រកាន់ភ្ជាប់ក្រឹត្យវិន័យ»។
ដូចដែលមានសេចក្តីចែងទុកមក
អ្នកអាចបង្ហាញប្រាប់ថាលោកអេសាយបានសសេរពាក្យនេះ។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«គឺព្យាការីអេសាយបានសសេរ»។
លើស៊ីយ៉ូន
នៅទីនេះ ស៊ីយ៉ូន ជាការប្រៀបធៀបដែលបញ្ជាក់ពី អ៊ីស្រាអែល។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ៊ីស្រាអែល»។
ថ្មនៃការជំពប់ ហើយថ្មនៃការរារាតចិត្ត
ឃ្លាទាំងពីរនេះមានអត្ថន័យមូលដ្ឋានដូចគ្នា
ហើយជាការធៀបដែលសំដៅដល់ព្រះយេស៊ូហើយនិងការសុគតនៅលើឈើឆ្កាងរបស់ទ្រង់។
វាបានធ្វើឲ្យមនុស្សជំពប់ដួលនៅលើថ្ម
ព្រោះពួកគេមានការខ្ជើមរអើងនៅពេលដែលព្រះយេស៊ូសុគតនៅលើឈើឆ្កាង។
ជឿនៅថ្មនោះ
ពីព្រោះថ្មស្ថិតនៅសម្រាប់មនុស្ស អ្នកអាចត្រូវបកប្រែថា «ជឿនៅលើទ្រង់»។

---

10 [1]បងប្អូនអើយ ដួងចិត្តខ្ញុំ ហើយសេចក្តីអធិស្ឋានរបស់ខ្ញុំចំពោះព្រះជាម្ចាស់គឺសម្រាប់ពួកគេ និងសម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេដែរ។[2]ដ្បិត ខ្ញុំធ្វើបន្ទាល់ពីពួកគេថា
ពួកគេមានដួងចិត្តឆេះឆួលចំពោះព្រះជាម្ចាស់ ប៉ុន្តែ មិនធ្វើឲ្យមានប្រាជ្ញាទេ។[3]ព្រោះពួកគេមិនដឹងពីសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ ហើយពួកគេស្វែងរកសេចក្តី
សុចរិតដោយពឹងលើកម្លាំងខ្លួនឯង។ ពួកគេមិនព្រមគោរពតាមសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ឡើយ។
[4]ដ្បិតព្រះគ្រិស្តបានធ្វើឲ្យក្រឹត្យវិន័យសម្រេចសម្រាប់ពួកអ្នកសុចរិត ហើយពួកអ្នកដែលជឿ។
[5]ព្រោះលោកម៉ូសេបានសរសេរអំពីសេចក្តីសុចរិតបានមកដោយសារក្រឹត្យវិន័យ៖ «អ្នកណាដែលធ្វើតាមសេចក្តីសុចរិតរបស់ក្រឹត្យវិន័យ
នឹងរស់នៅតាមសេចក្តីសុចរិតរបស់ក្រឹត្យវិន័យនោះ»។
[6]ប៉ុន្តែ សេចក្តីសុចរិតដែលបានមកដោយសារជំនឿិវិញគឺបែបនេះ «កុំនិយាយនៅក្នុងចិត្តរបស់អ្នកថា តើអ្នកណានឹងឡើងទៅស្ថានសួគ៌?
(ហើយនាំព្រះគ្រិស្តចុះពីស្ថានសួគ៌មក)[7]ហើយកុំនិយាយថា តើអ្នកណានឹងចុះទៅក្នុងស្ថាននរក?» (ហើយនាំព្រះគ្រិស្តឡើងពីសេចក្តីស្លាប់មកវិញ)។
[8]ប៉ុន្តែ តើបទគម្ពីរបានចែងយ៉ាងដូចម្តេច? «ព្រះបន្ទូលនៅជិតអ្នក នៅក្នុងមាត់ និងនៅក្នុងចិត្តរបស់អ្នក»។ នោះគឺជាព្រះបន្ទូលនៃជំនឿ ដែលយើងប្រកាស។[9]ដ្បិត
ប្រសិនបើ មាត់របស់អ្នកទទួលស្គាល់ថា ព្រះយេស៊ូជាព្រះអម្ចាស់ ហើយជឿនៅក្នុងចិត្តរបស់អ្នកថា ព្រះជាម្ចាស់បានប្រោសព្រះអង្គពីសេចក្តីស្លាប់ អ្នកនឹងបានសង្គ្រោះ។
[10]ព្រោះបើចិត្តរបស់មនុស្សជឿ គេនឹងបានសុចរិត ហើយដោយមាត់ គាត់ទទួលស្គាល់ នោះគាត់នឹងបានសង្គ្រោះ។
[11]ព្រោះ បទគម្ពីរបានចែងថា៖ «អស់អ្នកណាដែលជឿលើព្រះអង្គ នឹងមិនត្រូវអាម៉ាស់ឡើយ។[12]ព្រោះគ្មានភាពខុសគ្នារវាងសាសន៍ក្រិក និងសាសន៍យូដាឡើយ។
ព្រោះព្រះអម្ចាស់តែមួយ ជាព្រះអម្ចាស់លើទាំងអស់ ហើយព្រះអង្គមានព្រះហឫទ័យទូលាយដល់មនុស្សទាំងអស់ ដែលអំពាវនាវរកព្រះអង្គ។
[13]ព្រោះអស់អ្នកណាដែលអំពាវនាវរកព្រះនាមព្រះអម្ចាស់នឹងបានសង្គ្រោះ។
[14]ដូច្នេះ តើពួកគេអាចអំពាវនាវរកព្រះអង្គ ដែលពួកគេមិនជឿបានយ៉ាងដូចម្តេច? តើពួកគេអាចជឿ ដោយគ្មានអ្នកប្រកាសបានយ៉ាងដូចម្តេច?[15]ដូច្នេះ
តើពួកគេអាចប្រកាស បានយ៉ាងដូចម្តេច ទាល់តែមានអ្នកដែលចាត់ពួកគេឲ្យទៅ? ដូចមានសេចក្តីចែងទុកមកថា៖ «មើលល្អណាស់ហ្ន៎
ជើងរបស់អ្នកដែលប្រកាសពីដំណឹងល្អពីដំណើរដែលធ្វើឲ្យចិត្តរីករាយ!»។
[16]ប៉ុន្តែ មិនមែនពួកគេទាំងអស់គ្នាស្តាប់ដំណឹងល្អនោះទេ។ ព្រោះលោកអេសាយមានប្រសាសន៍ថា៖ «ព្រះអម្ចាស់អើយ តើអ្នកណានឹងជឿសាររបស់យើង?»[17]ដូច្នេះ
ជំនឿកើតឡើងដោយសារឮ ហើយការឮដោយសារព្រះបន្ទូលរបស់ព្រះគ្រិស្ត។
[18]ប៉ុន្តែ ខ្ញុំនិយាយដូច្នេះ «តើពួកគេមិនបានឮមែនទេ? មិនមែនទេ ពួកគេភាគច្រើនបានឮ។ «សម្លេងរបស់ពួកគេបានចេញទៅពេញទូទាំងពិភពលោក
ហើយពាក្យរបស់ពួកគេក៏ទៅដល់ចុងបំផុតនៃផែនដីដែរ»។
[19]លើសពីនេះទៅទៀត ខ្ញុំសួរថា៖ «តើជនជាតិអ៊ីស្រាលមិនដឹងមែនទេ?» លោកម៉ូសេបាននិយាយមុនគេថា៖ «ខ្ញុំនឹងធ្វើឲ្យអ្នកច្រណែនជាមួយប្រជាជាតិនានា។
ព្រោះប្រជាជាតិដែលមិនយល់ ខ្ញុំនឹងធ្វើឲ្យកំហឹងរបស់អ្នកឆាបឆេះឡើង»។
[20]ហើយលោកអេសាយមានសេចក្តីក្លាហាន នៅពេលគាត់និយាយថា៖ «អ្នកដែលមិនស្វែងរកខ្ញុំ គេបែររកខ្ញុំឃើញ។ ខ្ញុំបានលេចមកឲ្យអ្នកដែលមិនអំពាវនាវរកខ្ញុំ។[21]ចំពោះ
ជនជាតិអ៊ីស្រាអែលវិញ លោកបានថ្លែងថា: «មួយថ្ងៃវាល់ល្ងាច យើងបានលូកដៃទៅរកប្រជារាស្ត្រដែលមិនស្តាប់បង្គាប់ហើយចេះតែប្រកែកជំទាស់»។

---

generated on Wed Sep 10 16:16:32 2025

Romans 10:1

ប្រយោគភ្ជាប់

លោកប៉ូលបន្តបញ្ជាក់ពីបំណងប្រាថ្នារបស់លោកចំពោះជនជាតិអ៊ីស្រាអែលដើម្បីឲ្យគេជឿ
ប៉ុន្តែ លោកក៏បញ្ជាក់ថាទាំងសាសន៍យូដា
និងអ្នកដទៃទៀតនឹងទទួលបានការសង្គ្រោះដោយការជឿលើព្រះគ្រិស្ត។

បងប្អូន

ពាក្យនេះសំដៅដល់គ្រិស្តបរិស័ទ ដែលរួមបញ្ចូលទាំងបុរសនិងស្ត្រី។

ដួងចិត្តខ្ញុំ

«បំណងប្រាថ្នាដ៏ធំបំផុតរបស់ខ្ញុំ»។

គឺសម្រាប់ពួកគេ និងសម្រាប់សេចក្តីសង្គ្រោះ

«គឺថាព្រះជាម្ចាស់នឹងសង្គ្រោះជនជាតិយូដា»។

ខ្ញុំធ្វើបន្ទាល់ពីពួកគេ

«យើងប្រកាសដោយទៀងត្រង់អំពីពួកគេ»។ (UDB)

ព្រោះពួកគេមិនដឹងពីសេចក្តីសុចរិតរបស់ព្រះជាម្ចាស់

«គឺថាព្រះជាម្ចាស់នឹងសង្គ្រោះជនជាតិយូដា»។

ពួកគេមិនព្រមគោរពតាមសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ឡើយ

«ពួកគេមិនព្រមទទួលផ្លូវរបស់ព្រះជាម្ចាស់ដែលដាក់ឲ្យគេត្រឹមត្រូវជាមួយទ្រង់។

Romans 10:4

ដ្បិត ព្រះគ្រិស្តបានធ្វើឲ្យក្រឹត្យវិន័យសម្រេច

«ដ្បិត ព្រះគ្រិស្តបានធ្វើឲ្យក្រឹត្យវិន័យសម្រេចទាំងស្រុង»។

សម្រាប់ពួកអ្នកសុចរិត ហើយពួកអ្នកដែលជឿ

ពាក្យ «ជឿ» នៅទីនេះមានន័យថា «ទុកចិត្ត»។ ការបកប្រែតាមរបៀបផ្សេងទៀត:
«គឺថាទ្រង់អាចធ្វើឲ្យគ្រប់គ្នាដែលទុកចិត្តលើទ្រង់ត្រឹមត្រូវនៅចំពោះព្រះជាម្ចាស់»។

អំពីសេចក្តីសុចរិតបានមកដោយសារក្រឹត្យវិន័យ

លោកប៉ូលនិយាយពី «សេចក្តីសុចរិត» ហាក់ដូចជាមានជីវិត និងអាចផ្លាស់ទីបាន។
ការបកប្រែតាមរបៀបផ្សេងទៀត:
«របៀបដែលក្រឹត្យវិន័យធ្វើអោយមនុស្សបានត្រឹមត្រូវនៅចំពោះព្រះជាម្ចាស់»។

អ្នកណាដែលធ្វើតាមសេចក្តីសុចរិតរបស់ក្រឹត្យវិន័យ
នឹងរស់នៅតាមសេចក្តីសុចរិតរបស់ក្រឹត្យវិន័យនោះ

ដើម្បីឲ្យបានសុចរិតជាមួយព្រះជាម្ចាស់តាមរយៈក្រឹត្យវិន័យ
ដែលវាមិនអាចទៅរួចទេ ដែលមនុស្សអាចរក្សាក្រឹត្យវិន័យបានល្អឥតខ្ចោះនោះ។
ការបកប្រែតាមរបៀបផ្សេងទៀត: «មនុស្សដែលគោរពក្រឹត្យវិន័យបានយ៉ាងល្អ
នឹងមានជីវិតរស់ ព្រោះក្រឹត្យវិន័យនឹងធ្វើអោយគេសុចរិតនៅចំពោះព្រះជាម្ចាស់»។

នឹងរស់

ពាក្យ «នឹងរស់» អាចមានអត្ថន័យពីរ ទី១) ជីវិតដ៏អស់កល្ប ឬ
ទី២)ជីវិតដែលតែងតែស្លាប់ ដែលប្រកបជាមួយព្រះជាមួយព្រះជាម្ចាស់។

Romans 10:6

ប៉ុន្តែ សេចក្តីសុចរិតដែលបានមកដោយសារជំនឿវិញគឺបែបនេះ

ពាក្យ «សេចក្តីសុចរិត» នៅទីនេះ ពណ៌នា
ដូចជាមនុស្សម្នាក់ដែលអាចនិយាយបាន។ ការបកប្រែតាមរបៀបផ្សេងទៀត «ប៉ុន្តែ
លោកម៉ូសេសរសេរបៀបដែលសេចក្តីជំនឿធ្វើឲ្យមនុស្សបានសុចរិតនៅចំពោះព្រះជាម្ចាស់»។

កុំនិយាយនៅក្នុងចិត្តរបស់អ្នក

លោកម៉ូសេកំពុងនិយាយទៅកាន់ប្រជាជន
ហាក់ដូចជាលោកកំពុងនិយាយទៅកាន់មនុស្សតែម្នាក់។
ការបកប្រែតាមរបៀបផ្សេងទៀត «កុំនិយាយទៅកាន់ខ្លួនរបស់អ្នក»។

តើអ្នកណានឹងឡើងទៅស្ថានសួគ៌?

លោកម៉ូសេប្រើសំណួរនេះ ដើម្បីបង្រៀនអ្នកស្តាប់របស់លោក។
ការណែនាំពីមុនរបស់លោកអំពី «កុំនិយាយ»
តម្រូវចម្លើយអវិជ្ជមានសម្រាប់សំណួរនេះ។
អ្នកអាចបកប្រែសំណួរនេះទៅកាន់ទម្រង់ថា
«មិនមានអ្នកណាម្នាក់អាចឡើងទៅស្ថានសួគ៌បានទេ»។

ហើយនាំព្រះគ្រិស្តចុះពីស្ថានសួគ៌មក

«គឺថាពួកគេអាចមានព្រះគ្រិស្តចុះមកលើផែនដី» ។

តើអ្នកណានឹងចុះទៅក្នុងស្ថាននរក?

លោកម៉ូសេប្រើសំណួរនេះ ដើម្បីបង្រៀនអ្នកស្តាប់របស់លោក។
ការណែនាំពីមុនរបស់លោកអំពីឃ្លា «កុំនិយាយ»
តម្រូវចម្លើយអវិជ្ជមានសម្រាប់សំណួរនេះ។
អ្នកអាចបកប្រែឃ្លានេះទៅក្នុងកាន់ទម្រង់ថា:
«មិនមានអ្នកណាម្នាក់អាចចុះទៅក្រោមហើយជាកន្លែងសម្រាប់វិញ្ញាណមនុស្សស្លាប់នៅ

ហើយនាំព្រះគ្រិស្តឡើងពីសេចក្តីស្លាប់មកវិញ

«គឺថាពួកគេអាចនាំព្រះគ្រិស្តត្រឡប់ពីសេចក្តីស្លាប់»។

ពីសេចក្តីស្លាប់

ឃ្លា «សេចក្តីស្លាប់» សំដៅដល់ការស្លាប់ខាងរាងកាយ។

Romans 10:8

ប៉ុន្តែ តើបទគម្ពីរបានចែងយ៉ាងដូចម្តេច?

ពាក្យ «បទគម្ពីរ» សំដៅដល់ «សេចក្តីសុចរិត» ក្នុង ១០:៦។
នៅទីនេះលោកប៉ូលពណ៌នាពី «សេចក្តីសុចរិត»
ដែលដូចជាមនុស្សម្នាក់ដែលអាចនិយាយបាន។ លោកប្រើសំណួរនេះ
ដើម្បីបញ្ជាក់ចម្លើយ ដែលលោកនឹងឆ្លើយ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ប៉ុន្តែ នេះជាអ្វីដែលលោកម៉ូសេនិយាយ»។

ព្រះបន្ទូលនៅជិតអ្នក

លោកប៉ូលនិយាយពី «រាជសារ» របស់ព្រះជាម្ចាស់
ដែលដូចជាមនុស្សម្នាក់ដែលអាចផ្លាស់ទីបាន។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះរាជសារគឺត្រឹមត្រូវនៅទីនេះ» ។

នៅក្នុងមាត់

ពាក្យ «មាត់» ជានិយមធៀប ដែលសំដៅដល់អ្វីដែលមនុស្សនិយាយ។
ការបកប្រែតាមរបៀបផ្សេងទៀត: «គឺនៅក្នុងអ្វីដែលអ្នកនិយាយ»។

និងនៅក្នុងចិត្តរបស់អ្នក

ឃ្លា «នៅក្នុងចិត្តរបស់អ្នក» គឺជាឃ្លាដែលសំដៅដល់ អ្វីដែលមនុស្សគិតនិងជឿ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ហើយវាជាអ្វីដែលអ្នកគិតនិងជឿ»។

ប្រសិនបើ មាត់របស់អ្នកទទួលស្គាល់ថា ព្រះយេស៊ូជាព្រះអម្ចាស់

«ប្រសិនបើអ្នកសារភាពថា ព្រះយេស៊ូជាព្រះអម្ចាស់»។

ហើយជឿនៅក្នុងចិត្តរបស់អ្នក

«ទទួលយកការពិត»។

ព្រះជាម្ចាស់បានប្រោសព្រះអង្គពីសេចក្តីស្លាប់

ទីនេះមានន័យថា
ព្រះជាម្ចាស់ធ្វើអោយព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញម្តងទៀត។

អ្នកនឹងបានសង្គ្រោះ

អ្នកអាចបកប្រែឃ្លានេះថា: «ព្រះជាម្ចាស់នឹងសង្គ្រោះអ្នក»។

ព្រោះបើចិត្តរបស់មនុស្សជឿ គេនឹងបានសុចរិត ហើយដោយមាត់ គាត់ទទួលស្គាល់
នោះគាត់នឹងបានសង្គ្រោះ

នៅទីនេះពាក្យ «ចិត្ត» គឺជាការប្រៀបធៀប ដែលនិយាយពីគំនិត ឬអារម្មណ៍។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដ្បិត បើគំនិតរបស់គេជឿ
ហើយគេបានសុចរិតនៅចំពោះព្រះ មាត់របស់គេសារភាព
នោះព្រះជាម្ចាស់នឹងសង្គ្រោះទេ»។

ហើយដោយមាត់

ពាក្យ «មាត់» ជានិយមធៀប
ដែលនិយាយពីសមត្ថភាពរបស់មនុស្សក្នុងការនិយាយ។

Romans 10:11

បទគម្ពីរបានចែងថា

លោកប៉ូលនិយាយពីបទគម្ពីរដែលហាក់ដូចជាមានជីវិតនិងមានសម្លេង។
អ្នកអាចបញ្ជាក់អ្នកដែលបានសរសេរបទគម្ពីរដែលលោកប៉ូលប្រើនៅទីនេះ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដ្បិត លោកអ៊ីសាយបានសរសេរក្នុងបទគម្ពីរ»។

អស់អ្នកណាដែលជឿលើព្រះអង្គ នឹងមិនត្រូវអាម៉ាស់ឡើយ

ឃ្លានេះមានន័យដូចគ្នាទៅនឹង «អស់អ្នកដែលមិនជឿ នឹងត្រូវអាម៉ាស់»។
ការបដិសេធត្រូវបានប្រើសម្រាប់ឃ្លានេះ។ អ្នកអាចបកប្រែក្នុងទម្រង់បែបនេះថា:
«ព្រះជាម្ចាស់នឹងលើកតម្កើងអស់អ្នកដែលជឿលើទ្រង់»។

ព្រោះគ្មានភាពខុសគ្នារវាងសាសន៍ក្រិក និងសាសន៍យូដាឡើយ

លោកប៉ូលបញ្ជាក់ថា ព្រះជាម្ចាស់នឹងវិនិច្ឆ័យមនុស្សទាំងអស់ដូចគ្នា។
អ្នកក៏អាចធ្វើការបញ្ជាក់ក្នុងភាសារបស់អ្នកដូចគ្នា។
ការបកប្រែតាមរបៀបផ្សេងទៀត: «ក្នុងរបៀបនេះ ព្រះជាម្ចាស់វិនិច្ឆ័យសាសន៍យូដា
និងមិនមែនយូដា ដូចគ្នា»។

ហើយព្រះអង្គមានព្រះហឫទ័យទូលាយដល់មនុស្សទាំងអស់ ដែលអំពាវនាវរកព្រះអង្គ

ឃ្លា «ព្រះអង្គមានព្រះហឫទ័យទូលាយ» នៅទីនេះ
មានន័យថាព្រះជាម្ចាស់ប្រទានពរដោយព្រះហឫទ័យទូលាយ។
អ្នកក៏អាចធ្វើការបញ្ជាក់ក្នុងភាសារបស់អ្នកដូចគ្នា។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយព្រះអង្គប្រទានពរ ព្រះហឫទ័យទូលាយប្រទានពរដល់មនុស្សទាំងអស់ដែលទុកចិត្តលើព្រះអង្គ»។

generated on Wed Sep 10 16:16:32 2025

(សូមមើល:figs-explicit)
ព្រោះអស់អ្នកណាដែលអំពាវនាវរកព្រះនាមព្រះអម្ចាស់នឹងបានសង្គ្រោះ
នៅទីនេះ ពាក្រ «ព្រះនាម» គឺការប្រៀបធៀបដល់ព្រះយេស៊ូ។
អ្នកអាចបកប្រែក្នុងភាសារបស់អ្នកក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះអម្ចាស់នឹងសង្គ្រោះមនុស្សគ្រប់គ្នាដែលទុកចិត្តលើទ្រង់»។
Romans 10:14
ដូច្នេះ តើពួកគេអាចអំពាវនាវរកព្រះអង្គ ដែលពួកគេមិនជឿបានយ៉ាងដូចម្តេច?
លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់សារសំខាន់នៃការប្រកាសដំណឹងល្អនៃព្រះគ្រិស្ត
ពាក្យ «ពួកគេ» សំដៅដល់អស់អ្នកដែលមិនទាន់បានថ្វាយខ្លួនទៅព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត
«អស់អ្នកដែលមិនជឿលើព្រះជាម្ចាស់មិនអាចអំពាវនាវរកព្រះអង្គបានទេ»។
តើពួកគេអាចជឿលើទ្រង់ម្តេចបាន បើពួកគេមិនឮអំពីទ្រង់ផងនោះ?
លោកប៉ូលប្រើសំណួរផ្សេងទៀតសម្រាប់ហេតុផលដូចគ្នា។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយប្រសិនបើពួកគេមិនបានឮរាជសាររបស់ទ្រង់ទេ
ពួកគេគឺមិនអាចជឿលើទ្រង់បានឡើយ» ឬ
«ហើយពួកគេមិនអាចជឿលើទ្រង់បានទេ
ប្រសិនបើពួកគេមិនបានឮរាជសារអំពីទ្រង់»។
ជឿដោយ
មានន័យថាដើម្បីយល់ដឹងថាអ្វីដែលមនុស្សនិយាយគឺពិតមែន។
តើពួកគេអាចជឿ ដោយគ្មានអ្នកប្រកាសបានយ៉ាងដូចម្តេច?
លោកប៉ូលប្រើសំណួរដ៏ទៀតសម្រាប់ហេតុផលផ្សេងទៀត។
ការបកប្រែតាមរបៀបផ្សេងទៀត: «ហើយពួកគេមិនអាចឮព្រះរាជសារបានទេ
ប្រសិនបើ មិនមានអ្នកណាម្នាក់ប្រាប់គេ»។
ដូច្នេះ តើពួកគេអាចប្រកាស បានយ៉ាងដូចម្តេច ទាល់តែមានអ្នកដែលចាត់ពួកគេឲ្យទៅ?
លោកប៉ូលប្រើសំណួរដ៏ទៀតសម្រាប់ហេតុផលដូចគ្នា។ ពាក្យ «ពួកគេ»
សំដៅដល់អស់អ្នកដែលជារបស់ព្រះជាម្ចាស់។ ការបកប្រែតាមរបៀបផ្សេងទៀត
`«ហើយពួកគេមិនអាចប្រកាសរាជសារដល់មនុស្សដទៃបានទេ
លុះណាតែមានអ្នកចាត់គេទៅ»។
មើលល្អណាស់ហ្ន៎ ជើងរបស់អ្នកដែលប្រកាសពីដំណឹងល្អពីដំណើរដែលធ្វើឲ្យចិត្តរីករាយ!
លោកប៉ូលប្រើពាក្យ «ជើង»
ដើម្បីជាសញ្ញាសំដៅដល់អស់អ្នកដែលធ្វើដំណើរនិងនាំរាជសារទៅដល់អ្នកដែលមិនទាន់បានឮ
ការបកប្រែតាមរបៀបផ្សេងទៀត: «ពិតជាអស្ចារ្យណាស់
នៅពេលដែលអ្នកនាំសារមកហើយប្រាប់យើងអំពីដំណឹងល្អ!»
Romans 10:16
ប៉ុន្តែ មិនមែនពួកគេទាំងអស់គ្នាស្តាប់
ទីនេះ «ពួកគេ» សំដៅដល់សាសន៍យូដា។ «ប៉ុន្តែ
មិនមែនសាសន៍យូដាទាំងអស់ស្តាប់នោះទេ!»
ព្រះអម្ចាស់អើយ តើអ្នកណានឹងជឿសាររបស់យើង?
លោកប៉ូលកំពុងប្រើសំណួរនេះដើម្បីបញ្ជាក់ថាលោកអ៊ីសាយបានទាយទុកជាមុននៅក្នុងសៀវភៅ
ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះជាម្ចាស់អើយ!
ពួកគេជាច្រើនណាស់មិនជឿលើសាររបស់យើងទេ!» ជឿ - ទទួលយក ឬ ទុកចិត្ត
ថាអ្វីមួយគឺពិត
សាររបស់យើង
ទីនេះពាក្យ «របស់យើង» សំដៅដល់ព្រះជាម្ចាស់ និងលោកអ៊ីសាយ។
ជំនឿកើតឡើងដោយសារឮ
ទីនេះពាក្យ «ជំនឿ» សំដៅដល់ «ការជឿលើព្រះគ្រិស្ត» (UDB)។
Romans 10:18
ប៉ុន្តែ ខ្ញុំនិយាយដូច្នេះ «តើពួកគេមិនបានឮមែនទេ? មិនមែនទេ ពួកគេភាគច្រើនបានឮ
លោកប៉ូលប្រើសំណួរនេះដើម្បីបន្ថែមអត្ថន័យ។
អ្នកអាចបកប្រែឃ្លានេះដូចជាការរាយការណ៍។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ប៉ុន្តែ ខ្ញុំនិយាយដូច្នេះ សាសន៍យូដាពិតជាបានឮសារអំពីព្រះគ្រិស្ត»។ (សូមមើល:
and
សម្លេងរបស់ពួកគេបានចេញទៅពេញទូទាំងពិភពលោក
ហើយពាក្យរបស់ពួកគេក៏ទៅដល់ចុងបំផុតនៃផែនដីដែរ
ប្រយោគទាំងពីរនេះមានន័យជាគោលដូចគ្នា
ហើយលោកប៉ូលប្រើពួកវាសម្រាប់បន្ថែមអត្ថន័យ។ ពាក្យ «ពួកគេ»
សំដៅដល់ព្រះអាទិត្យ ព្រះច័ន្ទ និងពួកផ្កាយ។
នៅទីនេះពួកវាត្រូវបានបរិយាយដូចជាអ្នកនាំសារ
ដែលប្រាប់មនុស្សលោកអំពីព្រះជាម្ចាស់។
នេះសំដៅពីរបៀបដែលពួកគេបង្ហាញមនុស្សអំពីអំណាច
និងសិរីរុងរឿងរបស់ព្រះជាម្ចាស់។
នៅទីនេះអ្នកអាចធ្វើការបញ្ជាក់ថាលោកប៉ូលបានស្រង់បទគម្ពីរ
ដោយអត្ថន័យ
ជាភ័ស្តុតាងនៃអំណាច និងសិរីរុងរឿងរបស់ព្រះជាម្ចាស់
ហើយមនុស្សនៅលើផែនដីទាំងមូលដែលឃើញពួកគេ
ហើយបានស្គាល់សេចក្តីពិតអំពីព្រះជាម្ចាស់»។
Romans 10:19
លើសពីនេះទៅទៀត ខ្ញុំសួរថា៖ «តើជនជាតិអ៊ីស្រាលមិនដឹងមែនទេ?»
លោកប៉ូលប្រើសំណួរដើម្បីបន្ថែមអត្ថន័យ។ ពាក្យ «អ៊ីស្រាអែល»
ជាការប្រៀបធៀបអំពីមនុស្សដែលបានរស់នៅក្នុងជាតិសាសន៍អ៊ីស្រាអែល។
ការបកប្រែតាមរបៀបដទៃទៀត: «ខ្ញុំសូមប្រាប់អ្នករាល់គ្នាម្តងទៀត ថា
អ៊ីស្រាអែលបានដឹងអំពី រាជសារ»។
លោកម៉ូសេបាននិយាយមុនគេថា៖
«ខ្ញុំនឹងធ្វើឲ្យអ្នកច្រណែន...ខ្ញុំនឹងធ្វើឲ្យកំហឹងរបស់អ្នកឆាបឆេះឡើង»។
មានន័យថា លោកម៉ូសេបានសរសេរនូវអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល។ ពាក្យ
«យើង» សំដៅដល់ព្រះជាម្ចាស់ ហើយ «អ្នក» សំដៅដល់ជនជាតិអ៊ីស្រាអែល។
ការបកប្រែតាមរបៀបផ្សេងទៀត: «លោកម៉ូសេបាននិយាយមុន
ថាព្រះជាម្ចាស់នឹងធ្វើអោយអ្នកច្រណែន...ព្រះជាម្ចាស់នឹងបញ្ឆេះកំហឹងអ្នកឡើង»។
ជាមួយប្រជាជាតិនានា
«ដោយអស់អ្នកដែលមិនបានគិតទុកជាជនជាតិអ៊ីស្រាអែល» (UDB) ឬ
«ដោយមនុស្សដែលមិនមែនជាជនជាតិណាមួយ»។
ព្រោះប្រជាជាតិដែលមិនយល់
ពាក្យ «ដែលមិនយល់» នៅទីនេះ មានន័យថាមនុស្សដែលមិនស្គាល់ព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ដោយជាតិសាសន៍ដែលប្រជាជនមិនស្គាល់យើង និងបទបញ្ញតិរបស់យើង»។
ខ្ញុំនឹងធ្វើឲ្យកំហឹងរបស់អ្នកឆាបឆេះឡើង
«យើងនឹងធ្វើឲ្យអ្នកខឹង» ឬ «យើងនឹងធ្វើអោយអ្នកមានកំហឹង»។
អ្នក
សំដៅដល់ជនជាតិអ៊ីស្រាអែល។
Romans 10:20
ព័ត៌មានទូទៅ
ពាក្យ «ខ្ញុំ» «ខ្ញុំ» និង «របស់ខ្ញុំ» សំដៅដល់ព្រះជាម្ចាស់។
ហើយលោកអេសាយមានសេចក្តីក្លាហាន នៅពេលគាត់និយាយ
អត្ថន័យនេះ លោកអ៊ីសាយបានសរសេរអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូល។
ទំនាយជាញឹកញាប់និយាយពីអ្វីដែលនៅក្នុងអនាគត
ដែលវាហាក់ដូចជាបានកើតឡើងរួចហើយ។
ការបញ្ជាក់នេះថាទំនាយពិតជានឹងក្លាយជាការពិត។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ទោះបីជាសាសន៍ដទៃមិនស្វែងរកយើង ក៏ពួកគេនឹងឃើញយើងដែរ»។
ខ្ញុំបានលេចមក
«យើងធ្វើឲ្យគេស្គាល់យើង»
លោកបានថ្លែងថា៖
«លោក» សំដៅដល់ព្រះជាម្ចាស់
ដែលកំពុងមានព្រះបន្ទូលតាមរយៈលោកអេសាយ។
មួយថ្ងៃរាលល្ងាច
ឃ្លានេះគឺត្រូវបានប្រើដើម្បីបញ្ជាក់ការប្រឹងប្រែងបន្តរបស់ព្រះជាម្ចាស់។ «ជានិច្ច»
យើងបានលូកដៃទៅរកប្រជារាស្ត្រដែលមិនស្តាប់បង្គាប់ហើយចេះតែប្រកែកជំទាស់
«ខ្ញុំបានព្យាយាមស្វាគមន៍នាក់ ហើយជួយនាក់ ប៉ុន្តែ
អ្នកបានបដិសេធការជួយរបស់យើង ហើយបន្តមិនស្តាប់បង្គាប់»។

11 [1]ដូច្នេះ តើព្រះជាម្ចាស់បដិសេធប្រជារាស្ត្ររបស់ព្រះអង្គមែនទេ? មិនមែនទេ។ ព្រោះខ្ញុំក៏ជាជនជាតិអ៊ីស្រាអែលដែរ ហើយក៏ជាពូជពង្សរបស់លោកអប្រាហាំដែរ
ចេញពីអំបូរបេនយ៉ាមីន។[2]ព្រះជាម្ចាស់មិនបានបដិសេធប្រជារាស្ត្ររបស់ព្រះអង្គទេ ព្រោះព្រះអង្គបានជ្រាបជាមុនហើយ។

generated on Wed Sep 10 16:16:32 2025

តើអ្នកមិនដឹងទេឬអីថាបទគម្ពីរចែងពីលោកអេលីយ៉ា ហើយគាត់បានទូលអង្វរព្រះជាម្ចាស់ ឲ្យទាស់នឹងអ៊ីស្រាអែលយ៉ាងដូចម្តេច?[3]«ព្រះអម្ចាស់អើយ
ពួកគេបានសម្លាប់ព្យាការីរបស់ព្រះអង្គ ពួកគេបានបំផ្លាញកន្លែងថ្វាយយញ្ញបូជារបស់ព្រះអង្គ។ មានតែទូលបង្គំតែម្នាក់គត់ដែលនៅសល់
ហើយពួកគេក៏កំពុងតែតាមសម្លាប់ដែរ»។
[4]ប៉ុន្តែ តើព្រះជាម្ចាស់បានឆ្លើយទៅគាត់ ហើយមានបន្ទូលទៅគាត់វិញយ៉ាងដូចម្តេច? «ខ្ញុំបានរៀបចំសម្រាប់ខ្លួនខ្ញុំនូវមនុស្សប្រាំពីរពាន់ទៀត
គឺជាអ្នកដែលមិនបានលុតជង្គង់ថ្វាយបង្គំព្រះបាល»។[5]ទោះបីជាដូច្នោះក្តី នៅក្នុងពេលបច្ចុប្បន្ននេះ ក៏មានអ្នកនៅសេសសល់ ដោយព្រោះតែជម្រើសនៃព្រះគុណ។
[6]ប៉ុន្តែ ប្រសិនបើ ព្រះអង្គជ្រើសរើសដោយសារព្រះគុណមែន គឺមានន័យថាមិនមែនដោយសារការប្រព្រឹត្តទៀតទេ។[7]បើមិនដូច្នោះទេ
ព្រះគុណលែងជាព្រះគុណទៀតហើយ។ ដូច្នេះ តើយើងនិយាយយ៉ាងដូចម្តេច? អ្វីៗដែលជនជាតិអ៊ីស្រាអែលស្វែងរក គេមិនបានទទួលទេ ប៉ុន្តែ
អ្នកដែលព្រះអង្គជ្រើសរើស ទើបបានទទួលវិញ ហើយពួកអ្នកផ្សេងទៀតនៅតែមានចិត្តរឹងរូសដដែល។[8]ដូចដែលមានសេចក្តីចែងទុកមកថា៖
«ព្រះជាម្ចាស់ប្រទានឲ្យពួកគេមានវិញ្ញាណនៃស្ពឹក ហើយក៏ធ្វើភ្នែករបស់គេមើលលែងឃើញ ព្រមទាំងត្រចៀករបស់គេក៏ស្តាប់លែងឮដែរ រហូតមកដល់សព្វថ្ងៃនេះ»។
[9]ស្តេចដាវីឌមានបន្ទូលថា៖ «សូមឲ្យតុបានក្លាយជាអួន និងអន្ទាក់ដែលធ្វើឲ្យជំពប់ដួល និងនាំឲ្យគេមានទោស។[10]សូមឲ្យភ្នែករបស់ពួកគេបានងងឹត
ដើម្បីកុំឲ្យពួកគេអាចមើលឃើញទៀត ហើយចងពួកគេឲ្យជាប់ជារៀងរហូតតទៅ»។
[11]ដូច្នេះ ខ្ញុំសូមសួរថា «តើពួកគេជំពប់ដួលរហូតមែនទេ? ទេ មិនរហូតទេ។ ផ្ទុយទៅវិញ ដោយសារកំហុសរបស់ពួកគេ សេចក្តីសង្គ្រោះបានមកដល់សាសន៍ដទៃ
ដើម្បីធ្វើឲ្យពួកគេមានសេចក្តីច្រណែន។[12]ឥឡូវនេះ ប្រសិនបើកំហុសរបស់ពួកគេនាំឲ្យពិភពលោកបានទទួលព្រះពរ
ហើយដោយសារការរង្វេងរបស់ពួកគេបានធ្វើឲ្យសាសន៍ដទៃទទួលព្រះពរដែរនោះ ដូច្នេះ តើពួកគេនឹងទទួលព្រះពរយ៉ាងច្រើនលើសលប់ប៉ុណ្ណា?
[13]ប៉ុន្តែ នៅពេលនេះ ខ្ញុំកំពុងតែនិយាយមកកាន់អ្នកដែលជាសាសន៍ដទៃ ហើយដរាបណាខ្ញុំជាសាវកសម្រាប់សាសន៍ដទៃ ខ្ញុំមានមោទនភាពនៅក្នុងព័ន្ធកិច្ចរបស់ខ្ញុំ។
[14]ប្រហែលជាខ្ញុំអាចនឹងធ្វើឲ្យអស់អ្នកដែលបងប្អូនខាងសាច់ឈាមរបស់ខ្ញុំច្រណែន។ ប្រហែលជាយើងអាចជួយសង្គ្រោះពួកគេបានខ្លះ។
[15]ប្រសិនបើ ការបដិសេធរបស់ពួកគេ ធ្វើឲ្យមានការផ្សះផ្សានៃពិភពលោក តើពួកគេនឹងបានទទួលយ៉ាងណា? គឺបានទទួលជីវិតពីសេចក្តីស្លាប់។[16]ប្រសិនបើ
ផលដំបូងត្រូវបានរក្សាទុក ដូច្នេះ ម្សៅរបស់ទុំប៉ុងក៏ត្រូវបានរក្សាទុកដែរ ប្រសិនបើ ឫសត្រូវបានរក្សាទុក ដូច្នេះ មែកក៏ត្រូវបានរក្សាទុកដែរ។
[17]ប៉ុន្តែ ប្រសិនបើ មែកខ្លះត្រូវបានកាត់ចេញ ហើយអ្នកគឺជាមែកដើមអូលីវព្រៃ ហើយបានផ្សាំក្នុងចំណោមដើមអូលីវផ្សេងទៀត[18]ហើយប្រសិនបើ
អ្នកមានចំណែកជាមួយពួកគេនៅក្នុងឫសនៃដើមអូលីវដែរ ដូច្នេះ កុំអួតពីមែកឡើយ។ ប៉ុន្តែ ប្រសិនបើ អ្នកអួត មិនមែនអ្នកទេដែលចិញ្ចឹមឫស ប៉ុន្តែ ឫសទេ
តើដែលចិញ្ចឹមអ្នក។
[19]ដូច្នេះ តើអ្នកនឹងនិយាយថា «មែកត្រូវបានកាត់ចោល ដើម្បីឲ្យខ្ញុំបានផ្សាំវិញ?»[20]ពិតមែនហើយ។ ដោយសារពួកគេគ្មានជំនឿ ពួកគេបានកាត់ចេញមែន ប៉ុន្តែ
អ្នកអាចឈរមាំបានដោយសារជំនឿរបស់អ្នក។ កុំមានមោទនភាពលើខ្លួនឯងខ្ពស់ពេក ផ្ទុយទៅវិញ ចូរកោតខ្លាចវិញ។[21]ពីព្រោះ
បើព្រះជាម្ចាស់មិនសំចៃមែកពីធម្មជាតិផង ដូច្នេះ ព្រះអង្គក៏មិនសំចៃអ្នកដែរ។
[22]ដូច្នេះ ចូលមើល! ពីអំពើសប្បុរស និងភាពប្រិតប្រៀនរបស់ព្រះជាម្ចាស់។ ម្យ៉ាងវិញទៀត ភាពប្រិតប្រៀបដែលមានចំពោះសាសន៍យូដាដែលដួលចុះ។ ប៉ុន្តែ មួយវិញទៀត
សេចក្តីសប្បុរសព្រះជាម្ចាស់បានធ្លាក់មកលើអ្នក ប្រសិនបើអ្នក បន្តនៅក្នុងសេចក្តីសប្បុរសព្រះអង្គ។ បើមិនដូច្នោះទេ អ្នកនឹងត្រូវកាត់ចោលដែរ។
[23]ចំពោះពួកគេវិញ ប្រសិនបើ ពួកគេបោះបង់ចោលភាពមិនជឿរបស់ពួកគេចេញ ពួកគេនឹងបានផ្សាំឡើងវិញ។ ព្រោះព្រះជាម្ចាស់អាចផ្សាំពួកគេម្តងទៀត។[24]ព្រោះ
ប្រសិនបើ អ្នកត្រូវបានកាត់ចេញពីដើមអូលីវព្រៃអាចផ្សាំបានប៉ុណ្ណឹងទៅហើយ ចុះទំរាំបើ សាសន៍យូដា ពួកគេជាមែកពីធម្មជាតិ
តើពួកគេមិនងាយក្នុងការផ្សាំនឹងដើមអូលីវរបស់ពួកគេផ្ទាល់ទេឬអី?
[25]បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នក មិនដឹងអំពីអាថ៌កំបាំង ដើម្បីកុំឲ្យអ្នកឆ្លាតនៅក្នុងការគិតរបស់ខ្លួនឡើយ។
អាថ៌កំបាំងនេះគឺនៅក្នុងផ្នែកនៃការមានចិត្តរឹងរូសដែលកើតឡើងនៅក្នុងអ៊ីស្រាអែល រហូតទាល់តែសាសន៍ដទៃបានចូលមកគ្រប់ចំនួន។
[26]ដូច្នេះ ជនជាតិអ៊ីស្រាអែលទាំងអស់នឹងបានសង្គ្រោះ ដូចមានសេចក្តីចែងទុកមកថា «ព្រះនៃការប្រោសលោះចេញពីក្រុងស៊ីយ៉ូនមក។
ព្រះអង្គនឹងលុបបំបាត់អំពើទុច្ចរិតរបស់លោកយ៉ាកុប[27]ហើយនេះគឺជាសម្ពន្ធមេត្រីរបស់យើងជាមួយពួកគេ នៅពេលដែលយើងនឹងដកយកអំពើបាបរបស់ពួកគេចេញ»។
[28]មួយវិញទៀត ទាក់ទងនឹងដំណឹងល្អ ពួកគេជាសត្រូវជំនួសអ្នករាល់គ្នា។ ហើយម្យ៉ាងវិញទៀត ស្របទៅតាមការជ្រើសរើសរបស់ព្រះអង្គ
ពួកគេបានទទួលសេចក្តីស្រឡាញ់ដោយសារដូនតារបស់ពួកគេ។[29]ព្រោះអំណោយទាន និងការត្រាស់ហៅរបស់ព្រះមិនផ្លាស់ប្រែឡើយ។
[30]ពីមុនអ្នកក៏ធ្លាប់មិនស្តាប់បង្គាប់ព្រះជាម្ចាស់ដែរ ប៉ុន្តែ ឥឡូវនេះ អ្នកបានទទួលព្រះគុណ ដោយសារការមិនស្តាប់បង្គាប់របស់ពួកគេ។[31]ដូចគ្នានេះដែរ
ឥឡូវនេះសាសន៍យូដាទាំងនេះក៏ធ្លាប់មិនស្តាប់បង្គាប់ព្រះដែរ។ ជាលទ្ធផល ដោយសារព្រះគុណបានបង្ហាញដល់អ្នក ពួកគេក៏អាចទទួលបានព្រះគុណដូចគ្នាដែរ។[32]ដ្បិត
ព្រះជាម្ចាស់បានបង្ខាំងមនុស្សទាំងអស់ទៅក្នុងការមិនស្តាប់បង្គាប់ ដើម្បីព្រះអង្គអាចបង្ហាញព្រះគុណដល់មនុស្សទាំងអស់ដែរ។
[33]ទាំងប្រាជ្ញា និងព្រះតម្រិះរបស់ព្រះជាម្ចាស់ជ្រៅហើយធំទូលាយណាស់! គ្មាននរណាអាចដឹងពីការជំនុំជម្រះរបស់ព្រះជាម្ចាស់យ៉ាងណានោះទេ
ហើយស្វែងរកផ្លូវរបស់ព្រះជាម្ចាស់យ៉ាងណាឡើយ![34]«តើអ្នកណាអាចស្គាល់ព្រះតម្រិះរបស់ព្រះអម្ចាស់បាន ឬតើអ្នកណាអាចធ្វើជាអ្នកប្រឹក្សាយោបល់របស់ព្រះអង្គបាន?
[35]តើអ្នកណាថ្វាយអ្វីទៅព្រះជាម្ចាស់មុនគេ ដែលព្រះជាម្ចាស់អាចសងគាត់វិញ?[36]ព្រោះអ្វីៗទាំងអស់មកពីព្រះអង្គ តាមរយៈព្រះអង្គ និងសម្រាប់ព្រះអង្គវិញ។
សូមថ្វាយសិរីល្អដល់ព្រះជារៀងរហូតតទៅ។ អាម៉ែន។

Romans 11:1

ប្រយោគភ្ជាប់

ដោយជនជាតិអ៊ីស្រាអែលជាសាសន៍ដែលបដិសេធព្រះជាម្ចាស់
ព្រះជាម្ចាស់ចង់អោយពួកគេយល់ ថាការសង្គ្រោះបានមកដោយព្រះគុណ
មិនដោយការប្រព្រឹត្ត។

ដូច្នេះ

«ខ្ញុំ ប៉ូល និយាយ» ។

តើព្រះជាម្ចាស់បដិសេធប្រជារាស្ត្ររបស់ព្រះអង្គមែនទេ?

លោកប៉ូលសួរសំណួរនេះ ដូច្នេះលោកអាចឆ្លើយសំណួរអំពីសាសន៍យូដាដទៃទៀត
ដែលអន់ចិត្ត ដោយព្រះជាម្ចាស់រាប់បញ្ចូលសាសន៍ដទៃក្នុងប្រជាជាតិរបស់ទ្រង់
នៅពេលដែលសាសន៍យូដាមានចិត្តរឹងរូសនោះ។

មិនមែនទេ

«គឺវាមិនអាចទៅរួចទេ!» ឬ «ពិតជាមិនអាចទេ!» ឃ្លានេះសង្កត់ធ្ងន់ថា
វាអាចកើតឡើង។
នៅទីនេះអ្នកអាចប្រើឃ្លាដែលមានន័យស្រដៀងគ្នាក្នុងភាសារបស់អ្នក។

មើលពីការបកប្រែរបស់អ្នក ក្នុងជំពូក ៩:១៤

អំបូរបេនយ៉ាមីន

សំដៅដល់ពូជពង្សដែលកើតពីអំបូរបេនយ៉ាមីន ជាអំបូរមួយក្នុងចំណោមដប់ពីរ
ដែលព្រះជាម្ចាស់បានចែងក្នុងប្រជាជាតិអ៊ីស្រាអែល។

ព្រោះព្រះអង្គបានជ្រាបមុនហើយ

«អស់អ្នកដែលព្រះជាម្ចាស់បានស្គាល់តាំងពីមុនពេល»។

តើអ្នកមិនដឹងទេឬអីថាបទគម្ពីរចែងពីលោកអេលីយ៉ា ហើយគាត់បានទូលអង្វរព្រះជាម្ចាស់
ឲ្យទាស់នឹងអ៊ីស្រាអែលយ៉ាងដូចម្តេច?

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ពិតណាស់ អ្នកអាចដឹងពីអ្វីដែលបទគម្ពីរបានចែង
អំពីពេលដែលលោកអេលីយ៉ាបានទូលអង្វរព្រះជាម្ចាស់
ឲ្យទាស់ប្រឆាំងនឹងអ៊ីស្រាអែល»។

តើអ្វីដែលបទគម្ពីរចែង

លោកប៉ូលកំពុងសំដៅដល់បទគម្ពីរដែលពួកគេហាក់ដូចជាអាចនិយាយបាន។

ពួកគេបានសម្លាប់

generated on Wed Sep 10 16:16:32 2025

«ពួកគេ» សំដៅដល់សាសន៍អ៊ីស្រាអែល។
មានតែទូលបង្គំតែម្នាក់គត់
ពាក្យ «ខ្ញុំ» ជាឯកវចន នៅទីនេះសំដៅលើលោកអេលីយ៉ា។
កំពុងតែតាមសម្លាប់
«មានបំណងដើម្បីសម្លាប់ខ្ញុំ»។
Romans 11:4
ប៉ុន្តែ តើព្រះជាម្ចាស់បានឆ្លើយទៅគាត់ ហើយមានបន្ទូលទៅគាត់វិញយ៉ាងដូចម្តេច?
លោកប៉ូលប្រើសំណួរនេះ
ដើម្បីនាំអ្នកអានរបស់លោកឲ្យចូលកាន់តែជិតចំនុចសំខាន់របស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត «តើព្រះជាម្ចាស់ឆ្លើយទៅគាត់ដូចម្តេច?»
គាត់
សព្វនាម «គាត់» សំដៅលោកអេលីយ៉ា។
មនុស្សប្រាំពីរពាន់
«ប្រាំពីរពាន់នាក់»។
សេសសល់
នៅទីនេះមានន័យថា មានមនុស្សចំនួនតិចទេ
ដែលព្រះជាម្ចាស់ជ្រើសរើសដើម្បីទទួលសេចក្តីសង្គ្រោះ។
Romans 11:6
ប៉ុន្តែ ប្រសិនបើ ព្រះអង្គជ្រើសរើសដោយសារព្រះគុណមែន
លោកប៉ូលបន្តពន្យល់ពីការប្រព្រឹត្តទៅនៃសេចក្តីមេត្តារបស់ព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ សេចក្តីមេត្តាករុណា
របស់ព្រះជាម្ចាស់ប្រព្រឹត្តទៅដោយព្រះគុណ»។
បើមិនដូច្នោះទេ
«តើយើងគួរសម្រេចយ៉ាងដូចម្តេច?» លោកប៉ូលសួរសំណួរនេះ
ដើម្បីនាំអ្នកអានរបស់លោកទៅកាន់ចំនុចបន្ទាប់។
អ្នកអាចបកប្រែឃ្លានេះជារបាយការណ៍។ ការបកប្រែតាមរបៀបផ្សេងទៀត:
«នេះជាអ្វីដែលយើងត្រូវចងចាំ»។
ព្រះជាម្ចាស់ប្រទានឲ្យពួកគេមានវិញ្ញាណស្ពឹកស្រពន់ ហើយក៏ធ្វើភ្នែករបស់គេមើលលែងឃើញ
ព្រមទាំងត្រចៀករបស់គេក៏ស្តាប់លែងឮដែរ រហូតមកដល់សព្វថ្ងៃនេះ
នេះជាការប្រៀបធៀបអំពីការពិតថា មនុស្សមានវិញ្ញាណដែលស្ពឹកស្រពន់។
ពួកគេមិនអាចស្តាប់ឮ ឬទទួលវិញ្ញាណនៃសេចក្តីពិតនោះទេ។
វិញ្ញាណនៃ
នៅទីនេះមានន័យថា «ដែលមានចរិតលក្ខណៈនៃ» ដូចជា «វិញ្ញាណនៃប្រាជ្ញា»។
ភ្នែករបស់គេមើលលែងឃើញ
ឹទស្សនៈនៃការមើលជាមួយនឹងភ្នែករបស់អ្នកណាម្នាក់ដែលបានពិចារណាអោយបាន
ត្រចៀករបស់គេក៏ស្តាប់លែងឮ
ទស្សនៃការស្តាប់ឮ ជាមួយនឹងត្រចៀក
ដែលបានពិចារណាឲ្យបានសមស្របទៅនឹងការស្តាប់បង្គាប់។
Romans 11:9
សូមឲ្យតុបានក្លាយជាអួន និងអន្ទាក់
«តុ» ជាន័យធៀបដែលអធិប្បាយពីពិធីជប់លៀង ហើយ «អួន» និង «អន្ទាក់»
ជាន័យធៀបដែលនិយាយពីការថ្កោលទោស។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ឱព្រះអម្ចាស់អើយ! សូមធ្វើឲ្យពិធីបុណ្យរបស់ពួកគេជាអន្ទាក់ដែលទាក់ពួកគេ»។
ដែលធ្វើឲ្យជំពប់ដួល
លោកប៉ូលនិយាយពីអ្នកណាម្នាក់ដែលធ្វើអំពើបាប ដូចជាកំពុងធ្លាក់ចុះ។
«ធ្វើឲ្យជំពប់ដួល » គឺអ្វីមួយដែលបណ្តាលឲ្យមនុស្សជំពប់ជើង ដូច្នេះគេធ្លាក់ចុះ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្វីមួយដែលបញ្ឆោតអ្នកណាម្នាក់ឲ្យប្រព្រឹត្តអំពើបាប»។
និងនាំឲ្យគេមានទោស
«អ្វីមួយដែលអនុញ្ញាតឲ្យអ្នក ធ្វើការសងសឹកទៅលើគេ»។
ហើយចងពួកគេឲ្យជាប់ជារៀងរហូតទៅ
ព្រះបាទដាវីឌទូលសូមឲ្យព្រះជាម្ចាស់
ត្រឡប់សត្រូវរបស់ស្តេចទៅក្នុងភាពជាអ្នកបម្រើ
គឺអ្នកដែលតែងតែស្ពាយបន្ទុកលើខ្នងរបស់ពួកគេ។
Romans 11:11
ប្រយោគភ្ជាប់
ជាមួយជនជាតិអ៊ីស្រាអែល ជាជាតិសាសន៍ដែលបដិសេធព្រះជាម្ចាស់
លោកប៉ូលប្រមានសាសន៍ដទៃត្រូវប្រយ័ត្ន មិនត្រូវប្រព្រឹត្តកំហុសដូចគ្នានេះទេ។
តើពួកគេជំពប់ដួលរហូតមែនទេ?
លោកប៉ូលប្រើសំណួរនេះ ដើម្បីបន្ថែមអត្ថន័យ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«តើព្រះជាម្ចាស់បដិសេធពួកគេរហូត ដោយសារតែពួកគេបានប្រព្រឹត្តបាបឬ?»
ទេ មិនរហូតទេ
«គឺមិនអាចទៅរួចទេ» ឬ «ពិតជាមិនអាចទេ!»
ឃ្លានេះបានសង្កត់ធ្ងន់ថាអាចនឹងកើតឡើង។
នៅទីនេះអ្នកអាចប្រើឃ្លាដែលមានន័យប្រហាក់ប្រហែលគ្នាក្នុងភាសារបស់អ្នក។
មើលរបៀបដែលអ្នកបកប្រែក្នុង ៩:១៤ ។
ធ្វើឲ្យពួកគេមានសេចក្តីច្រណែន
ការបកប្រែឃ្លានេះដូចគ្នានឹងការបកប្រែក្នុងជំពូក ១០:១៩។
ប្រសិនបើកំហុសរបស់ពួកគេនាំឲ្យពិភពលោកបានទទួលព្រះពរ
ហើយដោយសារការរង្វេងរបស់ពួកគេបានធ្វើឲ្យសាសន៍ដទៃទទួលព្រះពរដែរ
ឃ្លាទាំងពីរនេះមានអត្ថន័យគោលដូចគ្នា។ ប្រសិនបើ អ្នកត្រូវការ
អ្នកអាចបង្រួមឃ្លាទាំងពីរនេះក្នុងការបកប្រែរបស់អ្នក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«នៅពេលដែលសាសន៍អ៊ីស្រាអែលធ្លាក់ចុះខាងវិញ្ញាណ
ជាលទ្ធផលគឺព្រះជាម្ចាស់បានប្រទានពរយ៉ាងមហាសាលដល់អ្នកមិនមែនជាយូដា»។
នាំឲ្យពិភពលោក
ដោយសារតែសាសន៍យូដាបដិសេធព្រះគ្រិស្តព្រះជាម្ចាស់បានប្រទានពរដល់សាសន៍ដទៃ
ដោយប្រទានឲ្យពួកគេនូវឱកាសទទួលព្រះយេស៊ូ។
ពិភពលោក
ពាក្យ «ពិភពលោក»
នៅទីនេះជាការប្រៀបធៀបដែលសំដៅដល់មនុស្សដែលរស់នៅលើផែនដី
ជាពិសេសគឺសាសន៍ដទៃ។
Romans 11:13
ធ្វើឲ្យច្រណែន
មានន័យថា លោកម៉ូសេបានសរសេរនូវអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល។
«យើង» សំដៅដល់ព្រះជាម្ចាស់ ហើយ «អ្នក» សំដៅដល់ជនជាតិអ៊ីស្រាអែល។
របៀបបកប្រែផ្សេងទៀត: «លោកម៉ូសេបាននិយាយមុន
ថាព្រះជាម្ចាស់នឹងធ្វើអោយអ្នកច្រណែន...ព្រះជាម្ចាស់នឹងបញ្ឆេះកំហឹងអ្នកឡើង»។
អស់អ្នកដែលបងប្អូនខាងសាច់ឈាមរបស់ខ្ញុំច្រណែន
នេះសំដៅដល់ «អ្នកដើរតាមសាសន៍យូដារបស់ខ្ញុំ»។
ប្រហែលជាយើងអាចជួយសង្គ្រោះពួកគេបានខ្លះ
ព្រះជាម្ចាស់នឹងសង្គ្រោះអស់អ្នកដែលជឿ។ របៀបបកប្រែផ្សេងទៀត:
សម្រេចនៅពីក្រោយ
ព្រះជាម្ចាស់នឹងសង្គ្រោះពួកគេ»។
Romans 11:15
ពួកគេ
ពហុវចននេះ សំដៅដល់សាសន៍យូដាដែលមិនមែនជាអ្នកជឿ។
ពិភពលោក
ពាក្យ «ពិភពលោក»
នៅទីនេះគឺជាន័យធៀបសម្រាប់មនុស្សដែលរស់នៅលើផែនដី។
ការបកប្រែតាមរបៀបផ្សេងទៀត: «មនុស្សនៅលើផែនដី»
តើពួកគេនឹងបានទទួលយ៉ាងណា? គឺបានទទួលជីវិតពីសេចក្តីស្លាប់
លោកប៉ូលសួរសំណួរនេះ ដើម្បីបន្ថែមពាក្យ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«តើព្រះជាម្ចាស់នឹងទទួលពួកគេយ៉ាងដូចម្តេច ពេលដែលពួកគេជឿលើព្រះគ្រិស្ត?
វានឹងដូចជាពួកគេត្រឡប់មកពីសេចក្តីស្លាប់ទៅកាន់ជីវិត!»
ប្រសិនបើ ផលដំបូងត្រូវបានរក្សាទុក ដូច្នេះ ម្សៅរបស់នំប៉័ងក៏ត្រូវបានរក្សាទុកដែរ
លោកប៉ូលកំពុងនិយាយពីលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប
ជាបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែល ដូចជាធញ្ញាជាតិដំបូង ឬ «ផលដំបូង»
ដែលបានច្រូតកាត់។ លោកក៏កំពុងនិយាយពីជនជាតិអ៊ីស្រាអែល
ដែលជាពូជពង្សរបស់លោកទាំងនោះ ដែលពួកគេដូចជា « ម្សៅរបស់នំប៉័ង»
ដែលពួកគេបានធ្វើពីគ្រាប់ធញ្ញជាតិ។
ប្រសិនបើ ឫសត្រូវបានរក្សាទុក ដូច្នេះ មែកក៏ត្រូវបានរក្សាទុកដែរ
លោកប៉ូលកំពុងនិយាយពីលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប
ជាបុព្វបុរសរបស់ជនជាតិអ៊ីស្រាអែល ដូចជាឫសរបស់ដើមឈើ
ហើយជនជាតិអ៊ីស្រាអែល ដែលជាពូជពង្សរបស់លោកទាំងនោះ ដែលពួកគេដូចជា
«មែក» នៃដើមឈើ។
ត្រូវបានរក្សាទុក

generated on Wed Sep 10 16:16:32 2025

មនុស្សតែងតែថ្វាយព្រះជាម្ចាស់នូវកណ្តាប់ដំបូងដែលពួកគេបានច្រូត។ ទីនេះ «ផលដំបូង» តំណាងឲ្យមនុស្សដំបូងដែលជឿលើព្រះគ្រិស្ត។
Romans 11:17
ហើយអ្នកគឺជាមែកដើមអូលីវព្រៃ
សព្វនាម «អ្នក» និងឃ្លា «គឺជាមែកដើមអូលីវព្រៃ» សម្តៅដល់សាសន៍ដទៃ ដែលទទួលសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូ។
ប៉ុន្តែ ប្រសិនបើ មែកខ្លះត្រូវបានកាត់ចេញ
នៅទីនេះលោកប៉ូលសំដៅដល់សាសន៍យូដាដែលបដិសេធ ព្រះយេស៊ូ គឺជា «មែកដែលកាត់ចោល»។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ
ប្រសិនបើអ្នកណាម្នាក់ត្រូវកាត់ចេញពីមែក»។
ហើយបានផ្សាំក្នុងចំណោមដើមអូលីវផ្សេងទៀត
នៅទីនេះលោកប៉ូល សំដៅដល់គ្រិស្តបរិស័ទសាសន៍ដទៃពួកគេគឺជា «មែកដែលផ្សាំ»។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានផ្សាំអ្នកទៅនឹងដើម
ក្នុងចំណោមមែកទាំងនោះ»។
ជាឫសដើមអូលីវ
ពាក្យ «ជាឫស» នៅទីនេះ ជាន័យធៀប
ដែលសំដៅដល់ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។
កុំអួតពីមែកឡើយ
ពាក្យ «មែក» នៅទីនេះ ជាការប្រៀបធៀបដែលបញ្ជាក់ពីជនជាតិយូដា។ ការបកប្រែតាមរបៀបផ្សេងទៀត: «កុំនិយាយថាអ្នកប្រសើរជាងសាសន៍យូដា ដែលព្រះជាម្ចាស់បានបដិសេធនោះឡើយ»។
មិនមែនអ្នកទេដែលចិញ្ចឹមឫស ប៉ុន្តែ ឫសទេតើ ដែលចិញ្ចឹមអ្នក
លោកប៉ូលបញ្ជាក់ថាអ្នកជឿសាសន៍ដទៃ គឺជាមែក។ ព្រះជាម្ចាស់សង្គ្រោះពួកគេ គឺដោយសារតែសម្ព័ន្ធមេត្រីសន្យាដែលព្រះអង្គបានសន្យានឹងសាសន៍យូដាប៉ុណ្ណោះ។
Romans 11:19
មែកត្រូវបានកាត់ចោល
ពាក្យ «មែក» នៅទីនេះ សំដៅដល់សាសន៍យូដាដែលបដិសេធព្រះយេស៊ូ និងអស់អ្នកដែលព្រះជាម្ចាស់បានបដិសេធពួកគេ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះជាម្ចាស់បានកាត់មែកចោល»។
ដើម្បីឲ្យខ្ញុំបានផ្សាំវិញ
លោកប៉ូលប្រើឃ្លានេះសំដៅដល់អ្នកជឿសាសន៍ដទៃ ដែលព្រះជាម្ចាស់បានទទួលពួកគេ។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះអង្គនឹងផ្សាំខ្ញុំវិញ»។
របស់ពួកគេ...ពួកគេ
សព្វនាម «របស់ពួកគេ» និង «ពួកគេ» សំដៅដល់ប្រជាជនយូដា ដែលមិនជឿ។
ប៉ុន្តែ អ្នកអាចឈរមាំបានដោយសារជំនឿរបស់អ្នក
លោកប៉ូលនិយាយពីអ្នកជឿសាសន៍ដទៃ ដែលដោយសារសេចក្តីជំនឿ ពួកគេឈរមាំ ហើយមិនមានអ្នកណាអាចធ្វើឲ្យគេរង្គើបានទេ។ ការបកប្រែតាមរបៀបផ្សេងទៀត: « ប៉ុន្តែ អ្នកទ្រាំទ្របាន
ដោយសារសេចក្តីជំនឿរបស់អ្នក»។
ពីព្រោះ បើព្រះជាម្ចាស់មិនសំចៃមែកពីធម្មជាតិផង ដូច្នេះ ព្រះអង្គក៏មិនសំចៃអ្នកដែរ
ឃ្លា «មែកពីធម្មជាតិ» នៅទីនេះ សំដៅដល់សាសន៍យូដា ដែលបដិសេធព្រះយេស៊ូ។ ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រោះថា ព្រះជាម្ចាស់មិនសំចៃពួកសាសន៍យូដាដែលមិនជឿ ដែលលូតលាស់ឡើងដូចជាមែកធម្មជាតិដែលមកពីឫសមក នោះត្រូវដឹងថា ប្រសិនបើអ្នកមិនជឿ នោះទ្រង់ក៏នឹងមិនសំចៃអ្នកដូចគ្នា (UDB)។
Romans 11:22
អំពើសប្បុរស និងភាពប្រិតប្រៀនរបស់ព្រះជាម្ចាស់
លោកប៉ូលរំលឹកអ្នកជឿសាសន៍ដទៃថា
ទោះបីជាព្រះជាម្ចាស់មានព្រះហឫទ័យដ៏សប្បុរសចំពោះពួកគេក្តី ក៏ទ្រង់មិនញញើតក្នុងការវិនិច្ឆ័យ និងដាក់ទោសពួកគេដែរ។
ភាពប្រិតប្រៀងដែលមានចំពោះសាសន៍យូដា
លោកប៉ូលនិយាយពី «ភាពប្រិតប្រៀន» ដែលហាក់ដូចជាមានជីវិត និងមានចលនា។ អ្នកអាចបញ្ជាក់បន្ថែមថា
ព្រះជាម្ចាស់បានប្រព្រឹត្តចំពោះសាសន៍យូដា យ៉ាងហាក់គ្មានធម៌មេត្តា។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានគ្មានសេចក្តីធម៌មេត្តាជាមួយសាសន៍យូដា»។
បើមិនដូច្នោះទេ អ្នកនឹងត្រូវកាត់ចោលដែរ
លោកប៉ូលប្រើន័យធៀបជាថ្មីអំពី មែក ដែលព្រះជាម្ចាស់អាច «កាត់ចោល» ប្រសិនបើត្រូវធ្វើ។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «មិនដូចច្នោះ ព្រះជាម្ចាស់នឹងកាត់អ្នកចោល»។
Romans 11:23
ប្រសិនបើ ពួកគេបោះបង់ចោលភាពមិនជឿរបស់ពួកគេចេញ
ឃ្លា «បោះបង់ចោលភាពមិនជឿរបស់ពួកគេ» គឺស្នូនអរិជ្ជមាន។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់វិជ្ជមាន។ ការបកប្រែតាមរបៀបផ្សេងទៀត: «ប្រសិនបើជនជាតិយូដា ចាប់ផ្តើមជឿលើព្រះគ្រិស្ត»។
ពួកគេនឹងបានផ្សាំឡើងវិញ
លោកប៉ូលនិយាយពីជនជាតិយូដាដូចជាមែកដែលអាចនឹងត្រូវបានផ្សាំចូលទៅដើមវិញ ប្រសិនបើ ពួកគេចាប់ផ្តើមជឿលើព្រះយេស៊ូ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត «ព្រះជាម្ចាស់នឹងផ្សាំពួកគេត្រឡប់ទៅវិញ»។
ផ្សាំ
នេះជាសញ្ញាប្រតិបត្តិការដែលបញ្ចប់នៃមែកដែលរស់របស់ដើមឈើមួយដើម ដាក់ចូលទៅក្នុងដើមឈើមួយផ្សេងទៀត
ដូច្នេះមែកថ្មីនឹងបន្តលូតលាស់ក្នុងដើមឈើនោះ។
ប្រសិនបើ អ្នកត្រូវបានកាត់ចេញពីដើមអូលីវព្រៃអាចផ្សាំបានប៉ុណ្ណឹងទៅហើយ ចុះទំរាំបើ
សាសន៍យូដា ពួកគេជាមែកពីធម្មជាតិ
តើពួកគេមិនងាយក្នុងការផ្សាំនឹងដើមអូលីវរបស់ពួកគេផ្ទាល់ទេឬអី?
លោកប៉ូលបន្តនិយាយពីសាសន៍ដទៃ និងសាសន៍យូដាដែលពួកគេជាមែកឈើ។ អ្នកអាចបកប្រែឃ្លានេះក្នុងសកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«ព្រោះប្រសិនបើព្រះជាម្ចាស់បានកាត់អ្នកចេញពី ដើមអូលីវព្រៃ ដែលជាធម្មជាតិ ហើយផ្សាំអ្នកទៅក្នុងដើមអូលីវល្អដែលផ្ទុយពីធម្មជាតិយ៉ាងនេះទៅហើយ
ចុះទំរាំបើសាសន៍យូដា ដែលជាមែកធម្មជាតិ
តើព្រះអង្គនឹងផ្សាំពួកគេទៅក្នុងដើមរបស់ពួកគេយ៉ាងណាទៅ?»
មែក
លោកប៉ូលបន្តនិយាយពីសាសន៍ដទៃ និងសាសន៍យូដាដែលពួកគេជាមែកឈើ។ «មែកធម្មជាតិ» និយាយពីសាសន៍យូដា ហើយ «មែកផ្សាំ» និយាយពីអ្នកជឿសាសន៍ដទៃ។
ពួកគេ...ពួកគេ
គ្រប់កន្លែងដែលជួបពាក្យ «ពួកគេ» គឺសំដៅដល់សាសន៍យូដា។
Romans 11:25
ខ្ញុំមិនចង់ឲ្យអ្នក មិនដឹងអំពីអាថ៌កំបាំង
លោកប៉ូលប្រើទម្រង់អវិជ្ជមានស្នួន។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់វិជ្ជមាន។ ការបកប្រែតាមរបៀបផ្សេងទៀត: «ខ្ញុំពិតជាចង់ឲ្យអ្នករាល់គ្នាដឹង»។
បងប្អូនអើយ
ពាក្យ «បងប្អូន» នៅទីនេះ សំដៅដល់ គ្រិស្តបរិស័ទ រាប់ទាំងបុរស ទាំងស្ត្រី។
ខ្ញុំ
សព្វនាម «ខ្ញុំ» សំដៅដល់លោកប៉ូល។
អ្នក...អ្នក...របស់អ្នក
សព្វនាម «អ្នក» និង «របស់អ្នក» សំដៅដល់អ្នកជឿសាសន៍ដទៃ។
កុំឲ្យអ្នកឆ្លាតនៅក្នុងការគិតរបស់ខ្លួនឡើយ
លោកប៉ូលមិនចង់អោយអ្នកជឿ
គិតថាពួកគេមានប្រាជ្ញាជាងសាសន៍យូដាដែលមិនជឿនោះទេ។ ការបកប្រែតាមរបៀបផ្សេងទៀត: «ដូច្នេះ អ្នកមិនត្រូវគិតថា អ្នកមានប្រាជ្ញា ជាងអ្វីដែលជាខ្លួនរបស់អ្នកនោះទេ»។
ក្នុងផ្នែកនៃការមានចិត្តរឹងរូសដែលកើតឡើងនៅក្នុងអ៊ីស្រាអែល
លោកប៉ូលនិយាយពី «ភាពរឹងរូស» ឬ
ភាពចចេសដែលជាការរឹងរូសនៃសរីរាង្គកាយក្នុងរូបកាយ។
សាសន៍យូដាមួយចំនួនបានបដិសេធមិនទទួលការសង្គ្រោះតាមរយៈព្រះយេស៊ូ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ប្រជាជនអ៊ីស្រាអែលជាច្រើននៅតែបន្តមានចិត្តចចេស»។
រហូតទាល់តែសាសន៍ដទៃបានចូលមកគ្រប់ចំនួន
ពាក្យ « រហូតទាល់តែ» នៅទីនេះ
បញ្ជាក់ថាយូដាមួយចំនួននឹងជឿបន្ទាប់ពីព្រះជាម្ចាស់បានបញ្ចប់ការនាំសាសន៍ដទៃទៅក្នុងក្រុមជំនុំ។
Romans 11:26

generated on Wed Sep 10 16:16:32 2025

ការភ្ជាប់សេចក្តីថ្លែងការណ៍៖
លោកប៉ូលនិយាយថា ព្រះនៃសេចក្តីប្រោសលោះនឹងចេញពីអ៊ីស្រាអែល
ទៅកាន់សិរីរុងរឿងរបស់ព្រះជាម្ចាស់។
ដូច្នេះ ជនជាតិអ៊ីស្រាអែលទាំងអស់នឹងបានសង្គ្រោះ
នៅទីនេះលោកប៉ូលនិយាយយ៉ាងសាមញ្ញ។ គាត់មិនបានមានន័យថា
គ្រប់មនុស្សទាំងអស់ក្នុងអ៊ីស្រាអែលនឹងបានសង្គ្រោះនោះទេ។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រោះព្រះជាម្ចាស់នឹងសង្គ្រោះសាសន៍អ៊ីស្រាអែលជាច្រើន។
ដូចមានសេចក្តីចែងទុកមកថា
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត
«ដូចដែលបទគម្ពីរបានចែងទុកមក»។
ចេញពីក្រុងស៊ីយ៉ូនមក
ពាក្យ «ស៊ីយ៉ូន» នៅទីនេះ
គឺបានប្រើជាការប្រៀបធៀបបញ្ជាក់ពីទីកន្លែងដែលព្រះជាម្ចាស់គង់នៅ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ពីកន្លែងដែលព្រះជាម្ចាស់អង្គក្នុងចំណោមជនជាតិយូដា»
ព្រះនៃការប្រោសលោះ
«ព្រះដែលរំដោះរាស្ត្ររបស់ទ្រង់អោយមានសេរីភាព» ។(UDB)
នឹងលុបបំបាត់អំពើទុច្ចរិត
លោកប៉ូលមានប្រសាសន៍អំពើអំពើទុច្ចរិត
ដូចជាកម្មបទដែលអ្នកណាម្នាក់អាចផ្លាស់ប្តូរវាបាន
ប្រហែលជាដូចអ្នកម្នាក់ផ្លាស់សម្លៀកបំពាក់។
ចេញពីលោកយ៉ាកុប
ឃ្លា «យ៉ាកុប» នៅទីនេះ ត្រូវបានប្រើជាការប្រៀបធៀប
បញ្ជាក់ពីជនជាតិអ៊ីស្រាអែល។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ចេញពីជនជាតិអ៊ីស្រាអែល»
យើងនឹងដកយកអំពើបាបរបស់ពួកគេចេញ
លោកប៉ូលនិយាយពីអំពើបាប
ដូចជាកម្មបទដែលអ្នកណាម្នាក់អាចយកវាចេញបាន។
ការបកប្រែតាមរបៀបផ្សេងទៀត: «យើងនឹងយក
បន្ទុកនៃអំពើបាបចេញពីពួកគេ»។
Romans 11:28
មួយវិញទៀត...ហើយម្យ៉ាងវិញទៀត
នេះជាឃ្លាគូរដែលត្រូវបានប្រើដើម្បីប្រៀបធៀបការពិតខុសគ្នាពីអំពីប្រធាន។
លោកប៉ូលប្រើឃ្លាទាំងនេះដើម្បីពន្យល់ថា
ទោះបីព្រះជាម្ចាស់បានបដិសេធជនជាតិយូដាក្តី ប៉ុន្តែទ្រង់នៅតែស្រលាញ់ពួកគេ។
ទាក់ទងនឹងដំណឹងល្អ
អ្នកអាចបញ្ជាក់ថា ព្រះជាម្ចាស់ប្រព្រឹត្តចំពោះសាសន៍យូដាដូចជាចំពោះសត្រូវ
ព្រោះពួកគេបានបដិសេធព្រះយេស៊ូ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ពីព្រោះសាសន៍យូដាបានបដិសេធដំណឹងល្អអំពីព្រះគ្រិស្ត»
ពួកគេជាសត្រូវជំនួសអ្នករាល់គ្នា
ក្តីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះសាសន៍ដទៃ គឺអស្ចារ្យណាស់
ដែលក្តីស្រលាញ់របស់ទ្រង់ចំពោះសាសន៍យូដា ធៀបមើលទៅ
ដូចជាបានស្អប់ទៅវិញ។
ពួកគេបានទទួលសេចក្តីស្រឡាញ់ដោយសារដូនតារបស់ពួកគេ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នៅតែស្រលាញ់ពួកគេ
ព្រោះតែអ្វីដែលព្រះអង្គបានសន្យាសម្រាប់ដូនតារបស់ពួកគេ។
ព្រោះអំណោយទាន និងការត្រាស់ហៅរបស់ព្រះមិនផ្លាស់ប្រែឡើយ
លោកប៉ូលមានប្រសាសន៍អំពីព្រះពរខាងវិញ្ញាណ និងសម្ភារ
ដែលព្រះជាម្ចាស់បានសន្យាប្រទានឲ្យរាស្ត្ររបស់ទ្រង់ជាអំណោយ។
ការត្រាស់ហៅរបស់ព្រះជាម្ចាស់
សំដៅដល់ការពិតដែលព្រះជាម្ចាស់បានត្រាស់ហៅសាសន៍យូដាឲ្យមកជារាស្ត្ររបស់ព្រះអង្គ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រោះព្រះជាម្ចាស់មិនដែលផ្លាស់ប្តូរព្រះទ័យរបស់ទ្រង់
ពីអ្វីដែលទ្រង់បានសន្យាថាប្រទានឲ្យពួកគេ
និងការត្រាស់ហៅដែលទ្រង់បានហៅពួកគេឲ្យធ្វើជារាស្ត្ររបស់ទ្រង់នោះឡើយ»។
Romans 11:30
ពីមុនអ្នកក៏ធ្លាប់មិនស្តាប់បង្គាប់
«នៅក្នុងអតីតកាលអ្នកក៏មិនបានស្តាប់បង្គាប់ដែរ»។
អ្នកបានទទួលព្រះគុណ ដោយសារការមិនស្តាប់បង្គាប់របស់ពួកគេ
ព្រះគុណនៅទីនេះ គឺមានន័យដល់ ព្រះពររបស់ព្រះជាម្ចាស់
ដែលមនុស្សមិនស័ក្តិសមនឹងទទួល។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកបានទទួលព្រះពរដែលមិនស័ក្តិសមនឹងទទួល ដ្បិត
សាសន៍យូដាបានបដិសេធព្រះយេស៊ូ»។
អ្នក
ពាក្យនេះ សំដៅដល់អ្នកជឿសាសន៍ដទៃទាំងឡាយ។
ព្រះជាម្ចាស់បានបង្ខាំងមនុស្សទាំងអស់ទៅក្នុងការមិនស្តាប់បង្គាប់
ព្រះជាម្ចាស់បានប្រព្រឹត្តចំពោះមនុស្សដែលមិនស្តាប់បង្គាប់ព្រះអង្គ ដូចជាអ្នកទោស
ដែលមិនអាចទទួលបានការដោះលែងចេញពីមន្ទីរឃុំឃាំង។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានដាក់អស់អ្នកដែលមិនស្តាប់បង្គាប់ទ្រង់ ឲ្យក្លាយជាអ្នកទោស។
ឥឡូវនេះ ពួកគេនៅតែបន្តការមិនស្តាប់ព្រះជាម្ចាស់»។
Romans 11:33
ទាំងប្រាជ្ញា និងព្រះតម្រិះរបស់ព្រះជាម្ចាស់ជ្រៅហើយធំទូលាយណាស់!
នៅទីនេះពាក្យ «ប្រាជ្ញា» និង «តម្រិះ» មានអត្ថន័យជាគោលដូចគ្នា។
ការបកប្រែតាមរបៀបផ្សេងទៀត: «តើទាំងប្រាជ្ញា និងតម្រិះរបស់ព្រះជាម្ចាស់
មានប្រយោជន៍យ៉ាងណាទៅហ្ន៎!»
គ្មាននរណាអាចដឹងពីការជំនុំជម្រះរបស់ព្រះជាម្ចាស់យ៉ាងណានោះទេ
ហើយស្វែងរកផ្លូវរបស់ព្រះជាម្ចាស់យ៉ាងណាឡើយ!
«យើងពិតជាមិនអាចយល់អំពីអ្វីដែលព្រះជាម្ចាស់បានសម្រេចព្រះទ័យនោះទេ
ហើយក៏មិនអាចស្វែងរករបៀបរបស់ព្រះជាម្ចាស់ដែលធ្វើចំពោះយើងយ៉ាងណាឡើយ»។
តើអ្នកណាអាចស្គាល់ព្រះតម្រិះរបស់ព្រះអម្ចាស់បាន ?
លោកប៉ូលប្រើសំណួរនេះ ដើម្បីបញ្ជាក់អត្ថន័យគោលដៅរបស់លោក។
អ្នកអាចបកប្រែឃ្លានេះជាការរាយការណ៍។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមានអ្នកណាម្នាក់អាចដឹងពីអ្វីដែលព្រះអម្ចាស់គិតឡើយ»
ឬតើអ្នកណាអាចធ្វើជាអ្នកប្រឹក្សាយោបល់របស់ព្រះអង្គបាន?
លោកប៉ូលប្រើសំណួរនេះ ដើម្បីបញ្ជាក់អត្ថន័យគោលដៅរបស់លោក។
អ្នកអាចបកប្រែក្នុងឃ្លានេះជាការរាយការណ៍។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះអង្គមិនត្រូវការអោយអ្នកណាម្នាក់ផ្តល់យោបល់ដល់ទ្រង់នោះឡើយ»។
Romans 11:35
តើអ្នកណាថ្វាយអ្វីទៅព្រះជាម្ចាស់មុនគេ ដែលព្រះជាម្ចាស់អាចសងគាត់វិញ?
លោកប៉ូលប្រើសំណួរនេះ ដើម្បីបញ្ជាក់អត្ថន័យគោលដៅរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«មិនមានអ្នកណាអាចថ្វាយអ្វីមួយទៅព្រះជាម្ចាស់
ទាំងដែលគេមិនបានទទួលពីព្រះជាម្ចាស់ជាមុននោះឡើយ»។ ពីទ្រង់...
តាមរយៈទ្រង់.... ទៅទ្រង់ រាល់ការជួបប្រទះនឹងពាក្យ «ទ្រង់» គឺសំដៅដល់
ព្រះជាម្ចាស់។
សូមថ្វាយសិរីល្អដល់ព្រះជារៀងរហូតតទៅ
ឃ្លានេះជាបំណងប្រាថ្នារបស់លោកប៉ូល
ចង់ឲ្យមនុស្សទាំងអស់ថ្វាយសិរីល្អព្រះជាម្ចាស់។ អ្នកអាចធ្វើការបញ្ជាក់ឃ្លានេះ
ក្នុងការបកប្រែរបស់អ្នក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«សូមមនុស្សទាំងអស់ថ្វាយសិរីល្អព្រះជាម្ចាស់ជារាងរហូតតទៅ!»

---

12 [1]ដូច្នេះ បងប្អូនអើយ ខ្ញុំសូមដាស់តឿនបងប្អូន ដោយសារព្រះគុណនៃព្រះ ចូរថ្វាយរូបកាយរបស់អ្នកជាយញ្ញបូជារស់ បរិសុទ្ធ
ហើយអាចទទួលយកបាននៅចំពោះព្រះជាម្ចាស់។ នេះគឺជាការបម្រើព្រះដ៏ត្រឹមត្រូវ។ កុំត្រាប់តាមលោកីយ៍ឡើយ ប៉ុន្តែ ចូរផ្លាស់ប្រែ ដោយកែប្រែគំនិតរបស់អ្នកជាថ្មី។
[2]ចូរធ្វើបែបនេះ ដើម្បីឲ្យដឹងថា អ្វីជាការល្អ អ្វីដែលអាចទទួលយកបាន និងគ្រប់លក្ខណ៍នៅចំពោះព្រះជាម្ចាស់។
[3]ដ្បិត ខ្ញុំនិយាយដូច្នេះ ដោយសារព្រះគុណ ដែលបានប្រទានមកខ្ញុំសូមនិយាយទៅកាន់មនុស្សគ្រប់គ្នា ដែលនៅក្នុងចំណោមអ្នករាល់គ្នា
សូមកុំគិតពីខ្លួនឯងខ្ពស់ហួសពីការដែលគួរគិតឡើយ។ ផ្ទុយទៅវិញ ពួកគេត្រូវគិតដែលប្រកបដោយប្រាជ្ញាវិញ ដូច
ជាព្រះបានប្រទានដល់មនុស្សម្នាក់ៗតាមជំនឿរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

[4]ព្រោះនៅក្នុងរូបកាយមួយមានអវៈយវៈជាច្រើន ប៉ុន្តែ មិនមែនគ្រប់ទាំងអវៈយវៈនោះមានមុខងារតែមួយនោះទេ។[5]ដូចគ្នា
នៅក្នុងព្រះកាយរបស់ព្រះគ្រិស្តក៏មានអវយវៈជាច្រើនដែរ ហើយអវយវៈនីមួយៗមានមុខងាររៀងៗខ្លួន។
[6]យើងមានអំណោយទានផ្សេងៗ តាមព្រះគុណដែលបានប្រទានមកយើង។ ប្រសិនបើ អ្នកណាម្នាក់មានអំណោយទានជាព្យាការី
ចូរឲ្យធ្វើការតាមកម្រិតនៃជំនឿរបស់គាត់។[7]ប្រសិនបើ អ្នកណាម្នាក់មានអំណោយទាននៃការបម្រើ ចូរឲ្យគាត់បម្រើចុះ។ ប្រសិនបើ អ្នកណាម្នាក់មានអំណោយទានបង្រៀន
ចូរឲ្យគាត់បង្រៀនចុះ។[8]ប្រសិនបើ អ្នកណាម្នាក់មានអំណោយទាននៃការថ្វាយ ចូរឲ្យគាត់ថ្វាយដោយសទ្ធាចុះ។ ប្រសិនបើ អ្នកណាមានអំណោយទាននៃការដឹកនាំ
ចូរឲ្យគាត់ធ្វើឲ្យយកចិត្តទុកដាក់។ ប្រសិនបើ អ្នកណាម្នាក់មានអំណោយទាននៃការបង្ហាញមេត្តា ចូរឲ្យគាត់ធ្វើដោយចិត្តរីករាយចុះ។
[9]ចូរស្រឡាញ់ដោយឥតពុតមាយាឡើយ។ ចូរស្អប់ខ្ពើមអ្វីដែលអាក្រក់ ហើយកាន់ខ្ជាប់អ្វីដែលល្អវិញ។[10]ទាក់ទងនឹងការស្រឡាញ់បងប្អូន ចូរស្រឡាញ់គ្នាទៅវិញទៅមក។
ទាក់ទងនឹងការគោរព ចូរគោរពគ្នាទៅវិញទៅមកដែរ។
[11]ទាក់ទងនឹងសេចក្តីឧស្សាហ៍ ចូរកុំខ្ជិលច្រអូសឡើយ។ ទាក់ទងខាងវិញ្ញាណ ចូរស្រេកឃ្លាន។ ទាក់ទងនឹងព្រះអម្ចាស់ ចូរបម្រើព្រះអង្គ។[12]ចូរមានអំណរ
នៅក្នុងទំនុកចិត្តដែលអ្នកមានអំពីអនាគត។ ចូរអត់ធ្មត់នៅក្នុងទុក្ខលំបាករបស់អ្នក។ ចូរបន្តក្នុងការអធិស្ឋាន។[13]ចូរចែករំលែកដល់បងប្អូនរួមជំនឿដែលខ្វះខាត។
ចូរស្វែងរកវិធីក្នុងការបង្ហាញភាពចៅរ៉ៅរាក់ទាក់។
[14]ចូរឲ្យពរដល់អស់អ្នកដែលបៀតបៀនដល់អ្នក ចូរឲ្យពរ កុំដាក់បណ្តាសាឡើយ។[15]ចូរមានអំណរជាមួយអស់អ្នកដែលមានអំណរ ចូរយំជាមួយអស់អ្នកដែលយំ
ចូរមានគំនិតតែមួយចំពោះគ្នាទៅវិញទៅមក។[16]កុំគិតក្នុងបែបមានអំនួតឡើយ ប៉ុន្តែ ចូរទទួលមនុស្សដែលទន់ទាប។ សូមកុំគិតថាខ្លួនឯងមានប្រាជ្ញាឡើយ។
[17]កុំធ្វើអាក្រក់ ស្នងនឹងការអាក្រក់ឡើយ។ ចូរធ្វើល្អនៅក្នុងក្រសែភ្នែករបស់មនុស្សគ្រប់គ្នា។[18]ប្រសិនបើអាច វាអាស្រ័យលើអ្នកទេ
ចូររស់នៅដោយសុខសាន្តជាមួយមនុស្សទាំងអស់។
[19]បងប្អូនជាទីស្រឡាញ់អើយ មិនត្រូវសងសឹកដោយខ្លួនអ្នកឡើយ ប៉ុន្តែ ចូរថ្វាយទៅព្រះជាម្ចាស់ ឲ្យព្រះអង្គបញ្ចេញសេចក្តីក្រោធវិញ។ ព្រោះមានសេចក្តីចែងទុកមកថា
«ការសងសឹកស្រេចនៅលើយើង យើងនឹងសងសឹក» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។[20]«ប៉ុន្តែ ប្រសិនបើ សត្រូវរបស់អ្នកឃ្លាន ចូរឲ្យគេបរិភោគផង។ ប្រសិនបើ
គាត់ស្រេក ចូរឲ្យទឹកទៅគាត់ផឹក។ ប្រសិនបើ អ្នកធ្វើដូច្នេះ ប្រៀបបីដូចជាអ្នកយកធ្យូងភ្លើងយ៉ាងច្រើនទៅដុតនៅលើក្បាលគាត់ដូច្នោះដែរ។
[21]កុំយកឈ្នះដោយធ្វើការអាក្រក់ឡើយ ប៉ុន្តែ ចូរយកឈ្នះការអាក្រក់ដោយការល្អវិញ។

Romans 12:1

ប្រយោគភ្ជាប់

លោកប៉ូលប្រាប់ពីអ្វីដែលជីវិតអ្នកជឿត្រូវមាន និងរបៀបដែលអ្នកជឿត្រូវបម្រើ។

ដូច្នេះ បងប្អូនអើយ ខ្ញុំសូមដាស់តឿនបងប្អូន ដោយសារព្រះគុណនៃព្រះ

នៅទីនេះពាក្យ «បងប្អូន» សំដៅដល់អ្នកជឿ ទាំងបុរស ទាំងស្ត្រី។

ការបកប្រែតាមរបៀបផ្សេងទៀត: «បងប្អូនជាអ្នកជឿអើយ!
ខ្ញុំពិតជាចង់ដាស់តឿនបងប្អូន
ដោយសារព្រះគុណដ៏មហិមាដែលព្រះជាម្ចាស់ប្រទានឲ្យ»។

ចូរថ្វាយរូបកាយរបស់អ្នកជាយញ្ញបូជារស់

លោកប៉ូលប្រើពាក្យ «រូបកាយ» នៅទីនេះ សំដៅដល់ខ្លួនមនុស្សទាំងមូល។

លោកក៏ប្រៀបធៀប អ្នកជឿនៅក្នុងព្រះគ្រិស្ត
ដែលស្តាប់បង្គាប់ព្រះជាម្ចាស់ពិតប្រាកដ ទៅនឹងសត្វដែលសាសន៍យូដាសម្លាប់
ថ្វាយជាយញ្ញបូជាទៅព្រះជាម្ចាស់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ត្រូវថ្វាយខ្លួនរបស់អ្នកទាំងស្រុងទៅព្រះជាម្ចាស់ ដែលអ្នកនៅមានជីវិតនៅឡើង
ដូចជាយញ្ញបូជាដែលស្លាប់នៅលើអាសនានៃព្រះវិហារ»។

បរិសុទ្ធ ហើយអាចទទួលយកបាននៅចំពោះព្រះជាម្ចាស់

ឃ្លានេះអាចមានន័យថា ទី១) «ដង្វាយដែលអ្នកថ្វាយព្រះជាម្ចាស់តែមួយអង្គគត់
ហើយសព្វព្រះទ័យទ្រង់»។

នេះគឺជាការបម្រើព្រះដ៏ត្រឹមត្រូវ

«នេះជារបៀបដ៏ត្រឹមត្រូវដើម្បីថ្វាយបង្គំព្រះជាម្ចាស់»។

កុំត្រាប់តាមលោកីយ៍ឡើយ

ឃ្លានេះអាចមានន័យពីរថា ទី១) «កុំមានអាកប្បកិរិយាដូចដែលលោកីយ៍នេះមាន»
ឬ ទី២) «កុំគិតតាមរៀបដែលលោកីយ៍នេះគិត»

កុំត្រាប់តាម

ឃ្លានេះអាចមានន័យពីរគឺ ទី១) «កុំអនុញ្ញាតឲ្យលោកីយ៍ប្រាប់អ្នកពីអ្វីដែលត្រូវធ្វើ
ឬអ្វីដែលត្រូវគិតនោះឡើយ» ឬ ទី២) កុំអនុញ្ញាតឲ្យខ្លួនរបស់អ្នកធ្វើឬគិត
អ្វីដែលលោកីយ៍នេះគិតនិងធ្វើឡើយ»។

លោកីយ៍នេះ

សំដៅលើមនុស្សដែលរស់នៅលើផែនដីដែលមិនមែនជាអ្នកជឿ។

ប៉ុន្តែ ចូរផ្លាស់ប្រែ ដោយកែប្រែគំនិតរបស់អ្នកជាថ្មី

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ
ចូលឲ្យព្រះជាម្ចាស់ផ្លាស់ប្តូរការគិត និងអាកប្បកិរិយារបស់អ្នក»។

Romans 12:3

ដោយសារព្រះគុណ ដែលបានប្រទានមកខ្ញុំ

នៅទីនេះពាក្យ «ព្រះគុណ»
សំដៅដល់ការជ្រើសរើសលោកប៉ូលរបស់ព្រះជាម្ចាស់ឲ្យជាសាវកនិងជាអ្នកដឹកនាំក្រុមជំនុំ
អ្នកអាចធ្វើការបញ្ជាក់ក្នុងការបកប្រែក្នុងភាសារបស់អ្នក។
អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រោះព្រះជាម្ចាស់បានជ្រើសរើសខ្ញុំឲ្យមកជាសាវក»។

ដែលនៅក្នុងចំណោមអ្នករាល់គ្នា សូមកុំគិតពីខ្លួនឯងខ្ពស់ហួសពីការដែលគួរគិតឡើយ

«ដែលក្នុងចំណោមអ្នករាល់គ្នា
មិនគួរអោយមានអ្នកណាម្នាក់គិតថាពួកគេប្រសើរជាងអ្នកដទៃឡើយ»។

ផ្ទុយទៅវិញ ពួកគេត្រូវគិតដែលប្រកបដោយប្រាជ្ញាវិញ

«ប៉ុន្តែ អ្នកគួរមានប្រាជ្ញាក្នុងរបៀបដែលអ្នកគិតអំពីខ្លួនរបស់អ្នក»។

ដូច ជាព្រះបានប្រទានដល់មនុស្សម្នាក់ៗតាមជំនឿរបស់ពួកគេ

លោកប៉ូលបញ្ជាក់នៅទីនេះថា
អ្នកជឿមានសមត្ថភាពខុសៗគ្នាដែលឆ្លើយតបទៅនឹងសេចក្តីជំនឿរបស់ពួកគេលើព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «គឺព្រះជាម្ចាស់បានប្រទានសមត្ថភាពខុសគ្នា
ឲ្យអ្នករាល់គ្នាម្នាក់ៗទៅតាមការទុកចិត្តរបស់ពួកគេលើព្រះអង្គ»។

Romans 12:4

ព្រោះ

លោកប៉ូលប្រើពាក្យនេះដើម្បីបង្ហាញថា លោកនឹងពន្យល់ឥឡូវនេះ
ថាហេតុអ្វីបានជាអ្នកជឿមិនគួរគិតថា ពួកគេប្រសើរជាងអ្នកដទៃ។

នៅក្នុងរូបកាយមួយមានអវៈយវៈជាច្រើន

លោកប៉ូលសំដៅដល់អ្នកជឿក្នុងព្រះគ្រិស្តទាំងអស់ដែលពួកគេដូចជាផ្នែកនីមួយៗនៃរាងកាយមនុស្ស។
លោកធ្វើបែបនេះដើម្បីបង្ហាញថា
ទោះបីជាអ្នកជឿអាចបម្រើព្រះជាម្ចាស់នៅក្នុងរបៀបផ្សេងគ្នា
ម្នាក់ៗជារបស់ព្រះគ្រិស្ត ហើយបម្រើក្នុងផ្នែកដ៏សំខាន់។

អវៈយវៈជាច្រើន

អវៈយវៈទាំងនេះដូចជា៖ ភ្នែក ពោះ និង ដៃ។

អវយវៈនីមួយៗមានមុខងាររៀងៗខ្លួន

លោកប៉ូលនិយាយពីអ្នកជឿ
ដូចជាព្រះជាម្ចាស់បានផ្គុំពួកគេចូលគ្នាជាផ្នែកនៃរូបកាយមនុស្ស។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានបង្រួបបង្រួមអ្នកជឿទាំងអស់ឲ្យរួមគ្នាមកតែមួយ»។

Romans 12:6

យើងមានអំណោយទានផ្សេងៗ តាមព្រះគុណដែលបានប្រទានមកយើង

លោកប៉ូលនិយាយអំពីសមត្ថភាពខុសៗគ្នារបស់អ្នកជឿ
ដែលជាអំណោយទានពីព្រះជាម្ចាស់។ អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត
«ព្រះជាម្ចាស់ប្រទានព្រះអំណោយទាននីមួយៗសម្រាប់យើងអោយមានសមត្ថភាពធ្វើកិច្ចការខុសៗគ្នាស

ចូរឲ្យធ្វើការតាមកម្រិតនៃជំនឿរបស់គាត់

ឃ្លានេះអាចមានអត្ថន័យពីរ ទី១) «ចូរអោយគាត់និយាយពាក្យទំនាយ
តាមកម្រិតនៃអំណោយទាននៃក្តីជំនឿដែលព្រះប្រទានឲ្យយើង» ឬ
ទី២)ចូរឲ្យគាត់និយាយពាក្យទំនាយដែលយល់ព្រមតាមការបង្រៀននៃសេចក្តីជំនឿរបស់យើង»។

អ្នកណាម្នាក់មានអំណោយទាននៃការថ្វាយ

generated on Wed Sep 10 16:16:32 2025

នៅទីនេះពាក្យ «ការថ្វាយ» សំដៅដល់ការថ្វាយប្រាក់ឬរបស់ដទៃទៀតទៅមនុស្ស។
អ្នកអាចធ្វើការបញ្ជាក់បន្ថែមអត្ថន័យក្នុងការបកប្រែរបស់អ្នក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ប្រសិនបើអ្នកណាម្នាក់មានអំណោយទានក្នុងការឲ្យប្រាក់ឬ
របស់អ្វីមួយទៅមនុស្សដែលមានតម្រូវការ»។
Romans 12:9
ចូរស្រឡាញ់ដោយឥតពុតមាយាឡើយ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកត្រូវស្រលាញ់មនុស្សទាំងអស់ដោយស្មោះត្រង់ និងពិតប្រាកដ»។
ស្រឡាញ់
ពាក្យដែលលោកប៉ូលប្រើនៅទីនេះសំដៅដល់ប្រភេទនៃក្តីស្រលាញ់ដែលមកពីព្រះជាម្ចាស់
និងការរំពឹងល្អសម្រាប់អ្នកដទៃ
ទោះបីជាការនោះមិនមានបានទទួលប្រយោជន៍អ្វីក៏ដោយ។
ទាក់ទងនឹងការស្រឡាញ់បងប្អូន ចូរស្រឡាញ់គ្នាទៅវិញទៅមក
នៅទីនេះលោកប៉ូលចាប់ផ្តើមរៀបរាប់ប្រាំបួនចំនុច ដែលជាទម្រង់
«ទាក់ទងនឹង...ចូរ» ប្រាប់ដល់អ្នកជឿ ថា
តើពួកគេគួរជាមនុស្សប្រភេទយ៉ាងដូចម្តេច។ ក្នុងចំនុចខ្លះ អ្នកអាចត្រូវបកប្រែថា
«ទាក់ទងនឹង...ត្រូវ»។ ការរៀបរាប់បន្តនៅក្នុងជំពូក ១២:១១ ។
ទាក់ទងនឹងការស្រឡាញ់បងប្អូន
«ដូចជាការដែលអ្នកស្រលាញ់អ្នកជឿរបស់អ្នក»។
ស្រឡាញ់
នេះជាប្រភេទក្តីស្រលាញ់ផ្សេងទៀត ជាក្តីស្រលាញ់ចំពោះបងប្អូន
ឬការស្រលាញ់មិត្តភក្តិ ឬសមាជិកគ្រួសារ។
នេះជាធម្មជាតិក្តីស្រលាញ់របស់មនុស្សរវាងមិត្ត ឬសាច់ញាតិ។
ចូរស្រឡាញ់គ្នាទៅវិញទៅមក
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ចូរបង្ហាញក្តីស្រលាញ់»
ទាក់ទងនឹងការគោរព ចូរគោរពគ្នាទៅវិញទៅមកដែរ
«ការលើកកិត្តិយសនិងគោរពអ្នកដទៃ» ឬ
«ការលើកកិត្តិយសអ្នកជឿរបស់អ្នកដោយការគោរពពួកគេ»។
Romans 12:11
ទាក់ទងនឹងសេចក្តីឧស្សាហ៍ ចូរកុំខ្ជិលច្រអូសឡើយ។ ទាក់ទងខាងវិញ្ញាណ ចូរស្រែកឃ្លាន។
ទាក់ទងនឹងព្រះអម្ចាស់ ចូរបម្រើព្រះអង្គ
«កុំខ្ជិលច្រអូស ក្នុងការឫកិច្ចរបស់អ្នក ប៉ុន្តែ ត្រូវអន្ទះសារដើរតាមព្រះវិញ្ញាណ
និងបម្រើព្រះអម្ចាស់»។
ចូរមានអំណរ នៅក្នុងទំនុកចិត្តដែលអ្នកមានអំពីអនាគត
លោកប៉ូលបញ្ជាក់នៅទីនេះថា អ្នកជឿអាចមានទំនុកចិត្តថា
ព្រះជាម្ចាស់នឹងជួយពួកគេ។ ការបកប្រែតាមរបៀបផ្សេងទៀត: «ចូរអរសប្បាយ
ពីព្រោះអ្នកមានទំនុកចិត្តថាព្រះជាម្ចាស់នឹងតែងតែជួយអ្នក»។
ចូរអត់ធ្មត់នៅក្នុងទុក្ខលំបាករបស់អ្នក
«រង់ចាំដោយការអត់ធ្មត់ រាល់ពេលដែលអ្នកមានទុក្ខលំបាក»។
ចូរចែករំលែកដល់បងប្អូនរួមជំនឿដែលខ្វះខាត
នេះជាឃ្លាចុងក្រោយក្នុងការរៀបរាប់ ដែលបានចាប់ផ្តើមក្នុង ១២:៩។
«ពេលដែលគ្រិស្តបរិស័ទ ស្ថិតនៅក្នុងទុក្ខលំបាក
ចូរជួយពួកគេក្នុងការណ៍ដែលពួកគេត្រូវការ»។
ចូរស្វែងរកវិធីក្នុងការបង្ហាញភាពចៅរ៉ៅរាក់ទាក់
«ត្រូវស្វាគមន៍ពួកគេគ្រប់ពេលវេលា
នៅក្នុងផ្ទះរបស់អ្នករាល់ពេលដែលពួកគេត្រូវការទីកន្លែងស្នាក់»។
Romans 12:14
ចូរមានគំនិតតែមួយចំពោះគ្នាទៅវិញទៅមក
នេះជាគ្រាមភាសាដែលមានន័យដល់ជីវិតនៅក្នុងសាមគ្គីភាព។
ការបកប្រែតាមរបៀបផ្សេងទៀត: «ចូរយល់ព្រមជាមួយអ្នកដទៃ» ឬ
«ចូររស់នៅក្នុងសាមគ្គីភាពជាមួយអ្នកដទៃទៀត»។
កុំគិតក្នុងបែបមានអំនួតឡើយ
«កុំគិតថាអ្នកមានសារសំខាន់ជាងអ្នកដទៃឡើយ»។
ចូរទទួលមនុស្សដែលទន់ទាប
«ស្វាគមន៍មនុស្សដែលមិនសំខាន់»។
សូមកុំគិតថាខ្លួនឯងមានប្រាជ្ញាឡើយ
«កុំគិតថាខ្លួនរបស់អ្នកមានប្រាជ្ញាជាងអ្នកដទៃផ្សេងទៀតឡើយ»។
Romans 12:17
កុំធ្វើអាក្រក់ ស្មុគនឹងការអាក្រក់ឡើយ
«កុំធ្វើការអាក្រក់ទៅកាន់អ្នកណា ដែលបានធ្វើការអាក្រក់មកកាន់អ្នកឡើយ»។
ចូរធ្វើល្អនៅក្នុងក្រសែភ្នែករបស់មនុស្សគ្រប់គ្នា
«ធ្វើកិច្ចការអ្វីដែលគ្រប់ៗគ្នារាប់ទុកថាជាការល្អ»។
វាអាស្រ័យលើអ្នកទេ ចូររស់នៅដោយសុខសាន្តជាមួយមនុស្សទាំងអស់
«ធ្វើអ្វីក៏ដោយ ដែលអ្នកអាចរស់នៅក្នុងក្តីសុខសាន្តជាមួយអ្នកដទៃ»។
Romans 12:19
ចូរថ្វាយទៅព្រះជាម្ចាស់ ឲ្យព្រះអង្គបញ្ចេញសេចក្តីក្រោធវិញ
នៅទីនេះឃ្លា «សេចក្តីក្រោធ» ជាពាក្យសំដៅដល់ការផ្តន្ទាទោសរបស់ព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «សូមទុកឲ្យព្រះជាម្ចាស់
ដាក់ទោសពួកគេទៅចុះ»។
ព្រោះមានសេចក្តីចែងទុកមកថា
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដ្បិតមានការចែងទុកមក»។
ការសងសឹកស្រេចនៅលើយើង យើងនឹងសងសឹក
ប្រយោគទាំងពីរនេះ មានន័យជាគោលដូចគ្នា
ហើយបញ្ជាក់ថាព្រះជាម្ចាស់នឹងសងសឹកជួសប្រជាជនរបស់ទ្រង់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ព្រះជាម្ចាស់ពិតជានឹងសងសឹកជួសអ្នក»។
«...សត្រូវរបស់...ចូរឲ្យគេបរិភោគ... ចូរឲ្យទឹកទៅគាត់ផឹក។ ប្រសិនបើ អ្នកធ្វើដូច្នេះ
ប្រៀបបីដូចជាអ្នកយកធ្យូងភ្លើង...កុំយកឈ្នះដោយធ្វើការអាក្រក់ឡើយ ប៉ុន្តែ
ចូរយកឈ្នះការអាក្រក់ដោយការល្អវិញ។
ពាក្យ «អ្នក» និង «របស់អ្នក» ទាំងអស់ គឺហៅសម្រាប់ដូចជាមួយមនុស្សម្នាក់។
ប្រសិនបើ សត្រូវរបស់អ្នកឃ្លាន ចូរឲ្យគេបរិភោគ...លើក្បាលគាត់ដូច្នោះដែរ
នៅក្នុងខគម្ពីរ ១២:២០ លោកប៉ូលបានស្រង់ផ្នែកផ្សេងទៀតនៃបទគម្ពីរ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែបទគម្ពីរបានដែលទុកមកថា៖ ប្រសិនបើ
សត្រូវរបស់អ្នកឃ្លាន... លើក្បាលរបស់គេ»។
ចូរឲ្យគេបរិភោគផង
«អោយអាហារគេខ្លះផង»។
យកធ្យូងភ្លើងយ៉ាងច្រើនទៅដុតនៅលើក្បាលគាត់
លោកប៉ូលនិយាយអំពីព្រះពរដែលខ្មាំងសត្រូវនឹងទទួល
ដូចជាពេលដែលអ្នកណាម្នាក់ចាក់រងើកភ្លើងលើក្បាលរបស់ពួកគេ។
ឃ្លានេះអាចមានអត្ថន័យពីរគឺ ទី១)
«ធ្វើឲ្យអ្នកដែលបានធ្វើឲ្យអ្នកឈើចាប់ទទួលអារម្មណ៍មិនល្អ
អំពីអ្វីដែលគេបានធ្វើមិនល្អចំពោះអ្នក» ឬ ទី២)
«ថ្វាយព្រះជាម្ចាស់ក្នុងការកាត់ទោសសត្រូវរបស់ ដែលកាន់តែគួរអោយខ្លាច។
កុំយកឈ្នះដោយធ្វើការអាក្រក់ឡើយ ប៉ុន្តែ ចូរយកឈ្នះការអាក្រក់ដោយការល្អវិញ
លោកប៉ូលបរិយាយអំពីពាក្យ «ការអាក្រក់» ដែលហាក់ដូចជាមនុស្ស។
អ្នកអាចបកប្រែក្នុងន័យបែបនេះថា
«កុំអនុញ្ញាតឲ្យមនុស្សអាក្រក់យកឈ្នះអ្នកឡើយ ប៉ុន្តែ
អ្នកត្រូវយកឈ្នះមនុស្សអាក្រក់ដោយការធ្វើអ្វីល្អវិញ»។

---

13 [1]ចូរឲ្យគ្រប់ទាំងព្រលឹងបានស្តាប់បង្គាប់ដល់អ្នកដែលមានសិទ្ធិអំណាចជាងខ្លួន ព្រោះគ្មានសិទ្ធិអំណាចណាបានមក ក្រៅពីព្រះជាម្ចាស់ឡើយ។
សិទ្ធិអំណាចដែលមានគឺព្រះជាម្ចាស់ចាត់តាំងឲ្យមាន។[2]ដូច្នេះហើយ អស់អ្នកណាដែលតទល់នឹងសិទ្ធិអំណាច
អ្នកនោះប្រឆាំងជាមួយនឹងបទបញ្ជារបស់ព្រះជាម្ចាស់ហើយ។ ហើយអស់អ្នកដែលប្រឆាំងនឹងបទបញ្ជារបស់ព្រះជាម្ចាស់
អ្នកនោះនឹងទទួលការកាត់ទោសលើខ្លួនឯងហើយ។
[3]ដ្បិត អ្នកគ្រប់គ្រងគ្មានអ្វីធ្វើឲ្យអ្នកដែលប្រព្រឹត្តល្អភ័យខ្លាចនោះឡើយ ប៉ុន្តែមានតែមនុស្សដែលប្រព្រឹត្តអាក្រក់ទេតើដែលភ័យខ្លាចពួកអាជ្ញាធរនោះ។
តើអ្នកចង់ក្លាយជាម្នាក់ដែលមិនខ្លាចពួកគេមែនទេ? ចូរធ្វើអ្វីដែលល្អទៅ! នោះពួកគេនឹងទទួលស្គាល់អ្នក។[4]ព្រោះពួកគេក៏ជាអ្នកបម្រើរបស់ព្រះជាម្ចាស់
ធ្វើការដើម្បីឲ្យអ្នកបានល្អដែរ។ ប៉ុន្តែ ប្រសិនបើ អ្នកធ្វើអ្វីដែលអាក្រក់ ចូរភ័យខ្លាច ព្រោះអ្នកគ្រប់គ្រងកាន់ដាវមិនមែនកាន់ដោយឥតហេតុផលឡើយ។

generated on Wed Sep 10 16:16:32 2025

ព្រោះពួកគេគឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ជាអ្នកបញ្ចេញកំហឹងសងសឹកដល់អស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់។[5]ដូច្នេះ អ្នកត្រូវតែស្តាប់បង្គាប់
មិនមែនដោយសារតែកំហឹងប៉ុណ្ណឹងទេ ប៉ុន្តែ ដោយសារមនសិការផងដែរ។
[6]ដោយហេតុនេះហើយ បានជាអ្នកត្រូវបង់ពន្ធដែរ។ ព្រោះពួកអាជ្ញាធរជាអ្នកបម្រើព្រះជាម្ចាស់ ដែលកំពុងទទួលខុសត្រូវលើការទាំងនេះ។
[7]ត្រូវបង់ដល់អស់អ្នកដែលអ្នកជំពាក់ពួកគេ ចូរបង់ពន្ធទៅអ្នកដែលយកពន្ធ ត្រូវបង់ថ្លៃចំពោះអ្នកដែលត្រូវបង់ថ្លៃ ខ្លាចអ្នកណាដែលគួរខ្លាច គោរពអ្នកណាដែលគួរគោរព។
[8]សូមកុំជំពាក់អ្វីអ្នកណាឡើយ ផ្ទុយទៅវិញត្រូវអោយស្រឡាញ់ដល់គ្នាទៅវិញទៅមក។
ព្រោះអស់អ្នកណាដែលស្រឡាញ់អ្នកជិតខាងរបស់ខ្លួនបានធ្វើតាមក្រឹត្យវិន័យរបស់ព្រះហើយ។[9]បទបញ្ជារបស់ព្រះអង្គគឺ «កុំប្រព្រឹត្តអំពើផិតក្បត់ឡើយ កុំសម្លាប់ កុំលួច
កុំលោភលន់»។ ហើយបទបញ្ជាផ្សេងៗទៀតក៏បង្គាប់ផងដែរ ហើយបានសរុបនៅក្នុងប្រយោគនេះ «ចូរស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង»។
[10]សេចក្តីស្រឡាញ់មិនធ្វើទុក្ខដល់អ្នកជិតខាងឡើយ ដូច្នេះ សេចក្តីស្រឡាញ់គឺជាការធ្វើឲ្យក្រឹត្យវិន័យបានសម្រេច។
[11]ដោយហេតុនេះហើយ អ្នកដឹងពេលវេលាហើយ ថានេះគឺជាពេលសម្រាប់អ្នកក្នុងការភ្ញាក់ពីគេងហើយ។ ដ្បិត ឥឡូវនេះ
សេចក្តីសង្គ្រោះនៅជិតជាងនៅពេលយើងបានជឿតាំងពីមុន។[12]ពេលយប់បានចប់ហើយ ហើយថ្ងៃក៏បានចូលមកជិតដែរ។ ដូច្នេះ
ចូរយើងបោះបង់កិច្ចការខាងសេចក្តីងងឹតចោល ហើយពាក់គ្រឿងសស្ត្រាវុធនៃពន្លឺវិញ។
[13]ចូរយើងដើរឲ្យបានត្រឹមត្រូវ ដូចនៅក្នុងពេលថ្ងៃដែរ មិនប្រមឹក ឬស៊ីផឹកឡូឡាឡើយ ហើយក៏មិនត្រូវដើរក្នុងផ្លូវប្រាស ចាកសីលធម៌ខាងផ្លូវភេទ ឬល្មោភកាម
និងឈ្លោះប្រកែក ឬច្រណែនឡើយ។[14]ប៉ុន្តែ ប្រដាប់ខ្លួនដោយព្រះអម្ចាស់យេស៊ូគ្រិស្ត ហើយកុំបំពេញចំណង់តណ្ហាខាងសាច់ឈាមឡើយ។

Romans 13:1

ប្រយោគភ្ជាប់

លោកប៉ូលប្រាប់អ្នកជឿ
ពីរបៀបដើម្បីរស់នៅក្រោមការដឹកនាំរបស់ពួកគេអ្នកដឹកនាំ។

ចូរឲ្យគ្រប់ទាំងព្រលឹងបានស្តាប់បង្គាប់ដល់

ពាក្យ «ព្រលឹង» នៅទីនេះជាការប្រៀបធៀបបញ្ជាក់ពីខ្លួនមនុស្សទាំងមូល។
«គ្រប់គ្រិស្តបរិស័ទទាំងអស់គួរតែស្តាប់បង្គាប់» ឬ «គ្រប់គ្នាគួរតែស្តាប់បង្គាប់»។

អ្នកដែលមានសិទ្ធិអំណាច

«មន្ត្រីរាជការ» (UDB)

ព្រោះ

«ពីព្រោះ»

គ្មានសិទ្ធិអំណាចណាបានមក ក្រៅពីព្រះជាម្ចាស់ឡើយ

«គ្រប់ទាំងសិទ្ធអំណាចទាំងអស់សុទ្ធតែមកពីព្រះជាម្ចាស់»។

ហើយសិទ្ធិអំណាចដែលមានគឺព្រះជាម្ចាស់ចាត់តាំងឲ្យមាន

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយមនុស្សដែលនៅក្នុងអំណាចទាំងនេះ
ព្រោះព្រះជាម្ចាស់ដាក់ពួកគេនៅទីនោះ»។

សិទ្ធិអំណាច

«នោះជាសិទ្ធិអំណាចរដ្ឋាភិបាល» ឬ
«សិទ្ធិអំណាចដែលព្រះជាម្ចាស់ដាក់ក្នុងអំណាច»។

អស់អ្នកដែលប្រឆាំងនឹងបទបញ្ជារបស់ព្រះជាម្ចាស់

អ្នកនោះនឹងទទួលការកាត់ទោសលើខ្លួនឯងហើយ

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងកាត់ទោសអស់អ្នកដែលប្រឆាំងនឹងសិទ្ធិអំណាចរដ្ឋាភិបាល»។

Romans 13:3

ដ្បិត

លោកប៉ូលប្រើពាក្យនេះ ដើម្បីការពន្យល់របស់លោកអំពីខគម្ពីរ ១៣:១
ហើយដើម្បីប្រាប់អំពីអ្វីទៅជាលទ្ធផល
ប្រសិនបើរដ្ឋាភិបាលកាត់ទោសមនុស្សណាម្នាក់។

អ្នកគ្រប់គ្រងគ្មានអ្វីធ្វើអោយភ័យខ្លាចនោះទេ

អ្នកគ្រប់គ្រងមិនធ្វើឲ្យមនុស្សល្អភ័យខ្លាចនោះទេ។

ធ្វើអ្វីដែលល្អទៅ...ធ្វើអ្វីដែលអាក្រក់

អត្តសញ្ញាណរបស់មនុស្សគឺបង្ហាញជាមួយ «ការប្រព្រឹត្តល្អ» ឬ
«ការប្រព្រឹត្តអាក្រក់» របស់គេ។

តើអ្នកចង់ក្លាយជាម្នាក់ដែលមិនកោតខ្លាចពួកគេមែនទេ?

លោកប៉ូលប្រើសំណួរនេះ ដើម្បីបញ្ជាក់គោលបំណងរបស់លោក។
អ្នកអាចបកប្រែឃ្លានេះក្នុងការរាយការណ៍។ ការបកប្រែតាមរបៀបផ្សេងទៀត:
«សូមឲ្យខ្ញុំប្រាប់អ្នកថា តើអ្នកគួរភ័យខ្លាចរដ្ឋាភិបាលនៅពេលណា!»

អ្នកនឹងទទួលការសរសើរពីវា

រដ្ឋាភិបាលនឹងនិយាយថា ជាការល្អ ពីមនុស្សដែលធ្វើកិច្ចការអ្វីដែលល្អ។

ព្រោះអ្នកគ្រប់គ្រងកាន់ដាវមិនមែនកាន់ដោយឥតហេតុផលឡើយ

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់វិជ្ជមាន។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ពួកលោកកាន់ដាវសម្រាប់ហេតុផលដែលល្អ» ឬ
«ពួកលោកមានអំណាចដើម្បីដាក់ទោស និងដាក់ទោសមនុស្ស។

កាន់ដាវ

ពួកមេដឹកនាំរ៉ូម៉ាំងកាន់ដាវខ្លី ជាសញ្ញាសម្គាល់នៃសិទ្ធិអំណាចរបស់ពួកគេ។

បញ្ចេញកំហឹងសងសឹក

ពាក្យ «កំហឹង» នៅទីនេះ
និយាយពីការកាត់ទោសដែលមនុស្សត្រូវទទួលពេលដែលពួកគេធ្វើការអាក្រក់។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកដាក់ទោសមនុស្ស
ដូចជាការបង្ហាញពីកំហឹងរបស់រដ្ឋាភិបាលប្រឆាំងនឹងការអាក្រក់»។

មិនមែនដោយសារតែកំហឹងប៉ុណ្ណឹងទេ ប៉ុន្តែ ដោយសារមនសិការផងដែរ

«មិនមែនដោយសារតែរដ្ឋាភិបាលដែលនឹងដាក់ទោសអ្នកប៉ុណ្ណោះទេ ប៉ុន្តែ
អ្នកក៏ត្រូវតែសម្អាតមនសិការនៅចំពោះព្រះជាម្ចាស់ដែរ»។

Romans 13:6

ដោយហេតុនេះហើយ

«ព្រោះរដ្ឋអំណាចដាក់ទោសមនុស្សដែលប្រព្រឹត្តអាក្រក់»។

អ្នក...ត្រូវបង់ដល់អស់អ្នក

នៅទីនេះលោកប៉ូលនិយាយសំដៅដល់អ្នកជឿ។

ព្រោះ

«នេះគឺជាហេតុផលដែលអ្នកត្រូវបង់ពន្ធ»។

ទទួលខុសត្រូវលើ

«ចាត់ការលើ» ឬ «ធ្វើការលើ»។

ចូរបង់ពន្ធទៅអ្នកដែលយកពន្ធ ត្រូវបង់ថ្លៃចំពោះអ្នកដែលត្រូវបង់ថ្លៃ ខ្លាចអ្នកណាដែលគួរខ្លាច
គោរពអ្នកណាដែលគួរគោរព

អនុប្រយោគទាំងនេះជាប្រយោគបិត។
អ្នកអាចបញ្ចូលពាក្យដែលបាត់ទៅក្នុងការបកប្រែរបស់អ្នកបាន។
ការបកប្រែតាមរបៀបផ្សេងទៀត: «ចូរបង់ពន្ធទៅអស់អ្នកដែលអ្នកត្រូវបង់។
ចូរបង់ថ្លៃទំនិញទៅអស់អ្នកដែលអ្នកត្រូវបង់ថ្លៃ។
ចូរគោរពអស់អ្នកដែលអ្នកត្រូវគោរព។
ចូរលើកកិត្តិយសអស់អ្នកដែលអ្នកត្រូវលើកកិត្តិយស»

ត្រូវបង់ថ្លៃ

ពាក្យនេះសំដៅទៅលើករណីកិច្ច ឬកាតព្វកិច្ច។

Romans 13:8

ប្រយោគភ្ជាប់

លោកប៉ូលប្រាប់អ្នកជឿពីរបៀបនៃការប្រព្រឹត្តចំពោះអ្នកជិតខាង។

សូមកុំជំពាក់អ្វីអ្នកណាឡើយ ផ្ទុយទៅវិញត្រូវអោយស្រឡាញ់ដល់គ្នាទៅវិញទៅមក

នេះជាប្រយោគដែលស្ទួនអវិជ្ជមាន។ អ្នកអាចប្រែវានៅក្នុងទម្រង់វិជ្ជមានថា
«ចូរសងបំណុលទាំងអស់ទៅគ្រប់គ្នាដែលអ្នកជំពាក់
ហើយត្រូវអោយក្តីស្រលាញ់ដល់គ្នាវិញទៅមក»។

ជំពាក់

កិរិយាសព្ទនេះជាពហុវចន ហើយសំដៅដល់គ្រិស្តបរិស័ទសាសន៍រ៉ូមទាំងអស់។

ត្រូវឲ្យស្រឡាញ់ដល់គ្នាទៅវិញទៅមក

នេះគឺបំណុលមួយដែលអាចលើកមកបង្ហាញក្នុងការកត់សម្គាល់ខាងលើ។

ស្រឡាញ់

គឺសំដៅដល់ប្រភេទនៃក្តីស្រលាញ់ដែលមកពីព្រះជាម្ចាស់
ហើយរំពឹងការល្អសម្រាប់អ្នកដទៃ ទោះបីវាមិនមានផលប្រយោជន៍ក្តី។

អ្នកនឹង

generated on Wed Sep 10 16:16:32 2025

រាល់ការជួបប្រទះពាក្យ «អ្នក» ក្នុង ១៣:៩ ជាឯកវចន ប៉ុន្តែ
អ្នកសរសេរបានសំដៅដល់មនុស្សមួយក្រុម
ដែលហាក់ដូចជាពួកគេជាមនុស្សតែម្នាក់។
លោភលន់
ជាបំណងប្រាថ្នាបង់បាន ឬកាន់កាប់ របស់អ្វីមួយដែលជាកម្មសិទ្ធិរបស់អ្នកដទៃ។
សេចក្តីស្រឡាញ់មិនធ្វើទុក្ខដល់អ្នកជិតខាងឡើយ
ប្រយោគនេះពណ៌នាអំពីរូបភាពក្តីស្រលាញ់
ដូចជាមនុស្សដែលមានបំណងល្អដល់អ្នកដទៃ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មនុស្សដែលស្រលាញ់អ្នកជិតខាងរបស់ពួកគេ គឺមិនធ្វើទុក្ខអ្នកជិតខាងឡើយ»។
Romans 13:11
អ្នកដឹងពេលវេលាហើយ ថានេះគឺជាពេលសម្រាប់អ្នកក្នុងការភ្ញាក់ពីគេងហើយ
លោកប៉ូលនិយាយពីតម្រូវការសម្រាប់អ្នកជឿសាសន៍រ៉ូម៉ាំង
ដើម្បីផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ
ប្រសិនបើពួកគេត្រូវការភ្ញាក់ពីការដេកលក់នោះ។
ពេលយប់បានចប់ហើយ
លោកប៉ូលនិយាយអំពីពេលវេលាដែលមនុស្សប្រព្រឹត្តការអាក្រក់នោះ
គឺដូចជាពេលយប់។ ការបកប្រែតាមរបៀបផ្សេងទៀត
«ពេលវេលានៃអំពើបាបឥឡូវនេះ គឺបានមកជិតដល់ទីបញ្ចប់ហើយ»។
ហើយថ្ងៃក៏បានចូលមកជិតដែរ
លោកប៉ូលនិយាយអំពីពេលវេលាដែលមនុស្សឈប់ប្រព្រឹត្តការអាក្រក់នោះ
គឺដូចជាពេលថ្ងៃ។ ការបកប្រែតាមរបៀបផ្សេងទៀត «ព្រះគ្រិស្តនឹងត្រឡប់មក
ក្នុងពេលដ៏ឆាប់»។
កិច្ចការខាងសេចក្តីងងឹត
ទាំងនេះជាការអាក្រក់ដែលមនុស្សចូលចិត្តធ្វើនៅពេលយប់
គឺជាពេលងងឹតហើយមិនមានអ្នកណាម្នាក់អាចឃើញពួកគេ។
ហើយពាក់គ្រឿងសស្ត្រាវុធនៃពន្លឺវិញ
លោកប៉ូលនិយាយពីការធ្វើអ្វីៗតទល់ជាមួយសាតាំង
ដូចជាមនុស្សពាក់គ្រឿងសឹករបស់គេក្នុងការរៀបចំសម្រាប់សង្គ្រាម។
ការបកប្រែតាមរបៀបផ្សេងទៀត: «យើងគួរអនុញ្ញាតឲ្យព្រះជាម្ចាស់ការពារយើង
ដោយធ្វើតែកិច្ចការទាំងឡាយណា ដែលយើងចង់ឲ្យមនុស្សឃើញយើងធ្វើ»។
Romans 13:13
ចូរយើង
លោកប៉ូលរាប់បញ្ចូលទាំងអ្នកអានរបស់លោក អ្នកជឿដទៃទៀត
រួមទាំងរូបលោកផង។
ចូរយើងដើរឲ្យបានត្រឹមត្រូវ ដូចនៅក្នុងពេលថ្ងៃដែរ
លោកប៉ូលនិយាយពីការរស់នៅរបស់អ្នកដែលជឿពិតប្រាកដ
គឺប្រសិនបើគេដើរក្នុងពន្លឺថ្ងៃ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ចូរយើងដើរនៅក្នុងផ្លូវដែលអាចមើលឃើញ
ដែលដឹងថាគ្រប់គ្នាអាចឃើញយើង»។
ក្នុងផ្លូវប្រាស ចាកសីលធម៌ខាងផ្លូវភេទ ឬល្មោភកាម
ទស្សនៈទាំងនេះមានន័យជាគោលដូចគ្នា។
អ្នកអាចបញ្ចូលពួកវាក្នុងការបកប្រែរបស់អ្នក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ការប្រព្រឹត្តប្រាសចាកសីលធម៌»។
ឈ្លោះប្រកែក
ពាក្យនេះសំដៅដល់ការធ្វើអាក្រក់ប្រឆាំង ហើយឈ្លោះប្រកែកជាមួយមនុស្សដទៃ។
ច្រណែន
សំដៅដល់អារម្មណ៍អវិជ្ជមានទាស់នឹងជោគជ័យ
ឬគុណសម្បត្តិដែលអ្នកដទៃទទួល។
ប្រដាប់ខ្លួនដោយព្រះអម្ចាស់យេស៊ូគ្រិស្ត
លោកប៉ូលនិយាយពីការទទួលធម្មជាតិពុករលួយរបស់ព្រះគ្រិស្ត
ដូចជាទ្រង់បានទទួលសម្លៀកបំពាក់ក្រៅរបស់យើង ដែលមនុស្សអាចមើលឃើញ។
ប្រដាប់ខ្លួន
អ្នកអាចប្រើទម្រង់ពហុវចន នៅទីនេះ ប្រសិនបើ មាននៅក្នុងភាសារបស់អ្នក។
កុំបំពេញចំណង់តណ្ហាខាងសាច់ឈាម
ពាក្យ «សាច់ឈាម» នៅទីនេះ សំដៅដល់ធម្មជាតិដឹកនាំខ្លួនឯង របស់មនុស្ស
ដែលខុសពីព្រះជាម្ចាស់។ នេះគឺជាធម្មជាតិនៃអំពើបាបរបស់មនុស្ស។
ការបកប្រែតាមរបៀបផ្សេងទៀត:
«កុំអនុញ្ញាតឲ្យមនុស្សចាស់ដែលមានចិត្តអាក្រក់របស់អ្នក
មានឱកាសធ្វើការអាក្រក់ទាំងអស់នោះឡើយ»។

---

14 [1]ចូរទទួលអស់អ្នកដែលខ្សោយខាងជំនឿ ដោយគ្មានការជំនុំជម្រះអំពីគំនិតរបស់ពួកគេឡើយ។[2]ម្នាក់មានជំនឿថា អាចបរិភោគអ្វីក៏បាន
ហើយម្នាក់ទៀតដែលខ្សោយថាបរិភោគតែបន្លែទេ។
[3]នោះចូរកុំឲ្យអ្នកដែលបរិភោគមើលងាយអ្នកដែលមិនបរិភោគ ហើយអ្នកដែលមិនបរិភោគក៏មិនត្រូវថ្កោលទោសអ្នកដែលបរិភោគដែរ ដ្បិតព្រះជាម្ចាស់បានទទួលអ្នកនោះ
។[4]តើអ្នកជាអ្វី បានជាហ៊ានថ្កោលទោសបាវបម្រើរបស់គេ? ទោះជាអ្នកបម្រើនោះឈរក្តី ដួលក្តី ស្រេចលើចៅហ្វាយរបស់គេទេតើ តែគេនឹងឈរបាន ព្រោះព្រះអម្ចាស់មាន
អំណាចជួយគេឲ្យឈរបាន។
[5]ដ្បិតម្នាក់គិតថា ថ្ងៃមួយប្រសើរជាងថ្ងៃមួយទៀត ម្នាក់ទៀតបែរជាគិតថា ថ្ងៃណាក៏ដូចជាថ្ងៃណាដែរ ដូច្នេះ ចូរម្នាក់ៗជឿជាក់នៅក្នុងគំនិតរបស់ខ្លួនចុះ។
[6]អ្នកណាដែលប្រតិបត្តិតាមថ្ងៃណា ចូរប្រតិបត្តិថ្ងៃនោះសម្រាប់ព្រះអម្ចាស់ចុះ ហើយអ្នកណាបរិភោគ ចូរបរិភោគសម្រាប់ព្រះជាម្ចាស់ចុះ
ព្រោះអ្នកនោះបានអរគុណដល់ព្រះជាម្ចាស់ហើយ។ ហើយអស់អ្នកណាដែលមិនបរិភោគ ចូរចៀសវាងពីការបរិភោគនោះ សម្រាប់ព្រះជាម្ចាស់
ព្រោះអ្នកនោះក៏បានអរព្រះគុណដល់ព្រះជាម្ចាស់ផងដែរ។
[7]ដ្បិត យើងម្នាក់ៗមិនបានរស់នៅសម្រាប់ខ្លួនឯងទេ ហើយក៏គ្មាននរណាស្លាប់សម្រាប់ខ្លួនឯងដែរ។[8]ដ្បិត បើយើងរស់នៅ យើងរស់នៅសម្រាប់ព្រះអម្ចាស់
ហើយបើយើងស្លាប់ ក៏ស្លាប់សម្រាប់ព្រះជាម្ចាស់ដែរ។ ដូច្នេះ មិនថាយើងរស់ ឬក៏ស្លាប់ទេ យើងជាកម្មសិទ្ធិរបស់ព្រះអម្ចាស់។[9]ដ្បិត ដោយព្រោះការនេះ
ព្រះគ្រិស្តបានសុគត ហើយរស់ឡើងវិញ ដើម្បីឲ្យព្រះអង្គអាចធ្វើជាព្រះអម្ចាស់សម្រាប់អ្នកដែលស្លាប់ និងសម្រាប់អស់អ្នកដែលរស់ផង។
[10]ប៉ុន្តែ សម្រាប់អ្នកវិញ ហេតុអ្វីបានជាអ្នកថ្កោលទោសបងប្អូនរបស់អ្នកយ៉ាងដូច្នេះ? ហើយហេតុអ្វីបានជាអ្នកបដិសេធបងប្អូនរបស់អ្នកយ៉ាងដូចម្តេច?
[11]ដ្បិតយើងទាំងអស់គ្នានឹងឈរនៅចំពោះបល្ល័ង្កនៃការជំនុំជម្រះរបស់ព្រះជាម្ចាស់។ ដូចមានសេចក្តីចែងទុកមកថា «ក្នុងការដែលយើងរស់» ព្រះជាម្ចាស់មានបន្ទូល
«គ្រប់ជង្គង់នឹងលុតចុះចំពោះយើង ហើយគ្រប់ទាំងអណ្តាតនឹងថ្វាយសិរីល្អដល់ព្រះជាម្ចាស់»។
[12]ដូច្នេះ យើងម្នាក់ៗនឹងទទួលខុសត្រូវនៅចំពោះកិច្ចការខ្លួនឯងនៅចំពោះព្រះជាម្ចាស់។[13]ដូច្នេះហើយ សូមយើងកុំថ្កោលទោសដល់គ្នាទៅវិញទៅមកឡើយ ផ្ទុយទៅវិញ
ចូរធ្វើដូច្នេះវិញ សូមកុំធ្វើឲ្យអ្នកណាម្នាក់ជំពប់ដួល ឬធ្វើជាអន្ទាក់ដល់បងប្អូនរបស់ខ្លួនឡើយ។
[14]ខ្ញុំដឹង ហើយខ្ញុំមានការជឿជាក់នៅក្នុងព្រះអម្ចាស់យេស៊ូថា គ្មានអ្វីមិនស្អាតដោយឯកឯងទេ។ មិនស្អាតគឺដោយសារមនុស្សគិតថាការនោះមិនស្អាតទេ
ហើយសម្រាប់គាត់គឺមិនស្អាត។[15]ប្រសិនបើ អ្នកធ្វើឲ្យបងប្អូនរបស់អ្នកឈឺចាប់ដោយសារតែអាហារ អ្នកលែងដើរនៅក្នុងសេចក្តីស្រឡាញ់ទៀតហើយ។
កុំបំផ្លាញបងប្អូនរបស់អ្នកដោយសារតែអាហាររបស់អ្នកឡើយ ព្រោះព្រះគ្រិស្តបានសុគតសម្រាប់អ្នកនោះហើយ។
[16]ដូច្នេះ សូមកុំអនុញ្ញាតឲ្យអ្វីដែលអ្នកគិតថាល្អ ហើយបែរជាគេនិយាយអាក្រក់វិញឡើយ។[17]ដ្បិត នរគរបស់ព្រះជាម្ចាស់មិនមែនជារឿងអាហារ និងផឹកឡើយ ប៉ុន្តែ
គឺជារឿងសេចក្តីសុចរិត សេចក្តីសុខសាន្ត និងសេចក្តីអំណរនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ។
[18]ដ្បិត អស់អ្នកណាដែលបម្រើព្រះគ្រិស្តបែបនេះ គឺអាចទទួលយកបាននៅចំពោះព្រះជាម្ចាស់ ហើយមនុស្សក៏ទទួលស្គាល់ដែរ។[19]ដូច្នេះ
ចូរយើងដេញតាមអ្វីៗដែលមេត្រីភាព និងអ្វីៗដែលកសាងគ្នាទៅវិញទៅមក។
[20]សូមកុំបំផ្លាញកិច្ចការរបស់ព្រះជាម្ចាស់ដោយព្រោះអាហារឡើយ។ អាហារស្អាតទាំងអស់ ប៉ុន្តែ មិនស្អាតនៅពេលដែលមនុស្សដែលបរិភោគ
ហើយធ្វើឲ្យបងប្អូនរវាតចិត្តវិញ។[21]គឺជាការល្អ ប្រសិនបើមិនបរិភោគសាច់ ឬ ផឹកស្រា ឬបរិភោគអ្វីផ្សេងទៀត ដោយហេតុចង់ធ្វើឲ្យបងប្អូនរវាតចិត្តឡើយ។
[22]ជំនឿដែលអ្នកមាន ចូររក្សាវារវាងខ្លួនអ្នក និងព្រះជាម្ចាស់។ មានពរហើយអស់អ្នកណាដែលមិនថ្កោលទោសខ្លួនឯងដោយសារអ្វីដែលខ្លួនឯងគិតថាល្អឡើយ។
[23]អស់អ្នកណាដែលសង្ស័យនឹងត្រូវទោស ប្រសិនបើ វាមិនកើតចេញពីជំនឿ។ ហើយអ្វីក្តីដែលមិនមែនកើតចេញពីជំនឿគឺជាអំពើបាបទាំងអស់។

generated on Wed Sep 10 16:16:32 2025

Romans 14:1
ប្រយោគភ្ជាប់
លោកកប៉ូលជំរុញលើកទឹកចិត្តអ្នកជឿអោយចងចាំថា
ពួកគេអាចឆ្លើយតបទៅព្រះជាម្ចាស់បាន។
ខ្សោយខាងជំនឿ
ប្រយោគនេះសំដៅដល់អស់អ្នកដែលមានអារម្មណ៍មានកំហុសចំពោះការទទួលទាន
ឬធឹករបស់អ្វីមួយ។
ដោយគ្មានការជំនុំជម្រះអំពីគំនិតរបស់ពួកគេឡើយ
«ហើយមិនមានការជំនុំជម្រះពួកគេ សម្រាប់ការយល់ឃើញរបស់ពួកគេទេ»។
ម្នាក់មានជំនឿថា អាចបរិភោគអ្វីក៏បាន
ពាក្យ «ជំនឿ» នៅទីនេះ សំដៅដល់ការធ្វើអ្វីមួយ មនុស្សជឿ
លើអ្វីដែលព្រះជាម្ចាស់ប្រាប់ឲ្យគេធ្វើ។
ហើយម្នាក់ទៀតដែលខ្សោយថាបរិភោគតែបន្លែទេ
និយាយពីមនុស្សដែលជឿថាព្រះជាម្ចាស់មិនសព្វព្រះទ័យឲ្យគេបរិភោគសាច់។
Romans 14:3
តើអ្នកជាអ្វី បានជាហ៊ានថ្កោលទោសបាវបម្រើរបស់គេ?
លោកប៉ូលប្រើសំណួរនេះ ដើម្បីស្តីបន្ទោសអស់អ្នកដែលថ្កោលទោសអ្នកដទៃ។
អ្នកអាចបកប្រែឃ្លានេះតាមរបៀបផ្សេងទៀត «អ្នកមិនមែនជាព្រះជាម្ចាស់នោះទេ
អ្នកមិនមានសិទ្ធិនឹងថ្កោលទោសអ្នកបម្រើរបស់គេនោះទេ!»
អ្នក របស់អ្នក
ពាក្យ «អ្នក» ជាទម្រង់ឯកវចន។
ទោះជាអ្នកបម្រើនោះឈរក្តី ដួលក្តី ស្រេចលើចៅហ្វាយរបស់គេទេតើ
លោកប៉ូលនិយាយពីព្រះជាម្ចាស់ ទ្រង់គឺជាចៅហ្វាយរបស់អ្នកបម្រើទ្រង់។
ការបកប្រែតាមរបៀបផ្សេងទៀត: «មានតែចៅហ្វាយប៉ុណ្ណោះ
ដែលសម្រេចចិត្តថាគាត់ទទួលឬមិនទទួលអ្នកបម្រើនោះ»។
តែគេនឹងឈរបាន ព្រោះព្រះអម្ចាស់មានអំណាចជួយគេឲ្យឈរបាន
លោកប៉ូលនិយាយពីអ្នកបម្រើដែលទទួលព្រះជាម្ចាស់ គឺពួកគេចាប់ផ្តើម
«ឈរបាន» ជំនួសការដួលចុះ។ អ្នកអាចបកប្រែឃ្លានេះថាក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ ព្រះជាម្ចាស់នឹងទទួលគាត់
ដោយសារគាត់ធ្វើជាអ្នកបម្រើដែលអាចទទួលយកបាន»។
Romans 14:5
ដ្បិត ម្នាក់គិតថា ថ្ងៃមួយប្រសើរជាងថ្ងៃមួយទៀត ម្នាក់ទៀតបែរជាគិតថា ថ្ងៃណាក៏ដូចជាថ្ងៃណាដែរ
«មនុស្សម្នាក់គិតថា ថ្ងៃមួយមានសារសំខាន់ជាងថ្ងៃដទៃ ប៉ុន្តែ ម្នាក់ទៀតគិតថា
ថ្ងៃទាំងអស់គឺដូចគ្នា»។
ដូច្នេះ ចូរម្នាក់ៗជឿជាក់នៅក្នុងគំនិតរបស់ខ្លួនចុះ
អ្នកអាចបំពេញអត្ថន័យបន្ថែម។ អ្នកក៏អាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដូច្នេះ
ត្រូវឲ្យមនុស្សម្នាក់ៗប្រាកដនូវអ្វីដែលគេកំពុងធ្វើ ដើម្បីថ្វាយសិរីល្អព្រះអម្ចាស់ចុះ»។
អ្នកណាដែលប្រតិបត្តិតាមថ្ងៃណា ចូរប្រតិបត្តិថ្ងៃនោះសម្រាប់ព្រះអម្ចាស់ចុះ
ពាក្យ «ប្រតិបត្តិ» នៅទីនេះ សំដៅដល់ការថ្វាយបង្គំ។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកដែលថ្វាយបង្គំក្នុងថ្ងៃជាក់ស្តែងណាមួយ
ដើម្បីថ្វាយសិរីល្អព្រះអម្ចាស់»។
ហើយអ្នកណាបរិភោគ ចូរបរិភោគសម្រាប់ព្រះជាម្ចាស់ចុះ
នេះជាប្រយោគបិត។ អ្នកក៏អាចបន្ថែមពាក្យដែលខ្វះ។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកណាដែលបរិភោគគ្រប់ប្រភេទអាហារ
ចូរបរិភោគវាដើម្បីថ្វាយសិរីល្អព្រះជាម្ចាស់»។
ហើយអស់អ្នកណាដែលមិនបរិភោគ ចូរចៀសវាងពីការបរិភោគនោះ សម្រាប់ព្រះជាម្ចាស់
នេះជាប្រយោគបិត។ អ្នកអាចបន្ថែមពាក្យដែលខ្វះ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកណាដែលមិនបរិភោគប្រភេទអាហារជាក់លាក់ណាមួយ
ដើម្បីថ្វាយសិរីល្អព្រះជាម្ចាស់»។
Romans 14:7
ដ្បិត យើងម្នាក់ៗមិនបានរស់នៅសម្រាប់ខ្លួនឯងទេ
ឃ្លា «រស់នៅសម្រាប់ខ្លួនឯង» នៅទីនេះមានន័យថា
ការរស់នៅដើម្បីបំពេញតែខ្លួនឯង។ ការបកប្រែតាមរបៀបផ្សេងទៀត:
«យើងម្នាក់ៗមិនគួររស់នៅគ្រាន់តែបំពេញខ្លួនយើងនោះទេ»។
ហើយក៏គ្មាននរណាស្លាប់សម្រាប់ខ្លួនឯងដែរ
នេះមានន័យថា ការស្លាប់របស់អ្នកណាម្នាក់មានឥទ្ធិពលលើមនុស្សផ្សេងទៀត។
ការបកប្រែតាមរបៀបផ្សេងទៀត: «យើងម្នាក់ៗមិនគួរគិតថា ពេលដែលយើងស្លាប់
វានឹងមានឥទ្ធិពលមកលើខ្លួនយើងតែម្នាក់នោះទេ»។
យើង...យើង
លោកប៉ូលរាប់បញ្ចូល អ្នកអានរបស់លោក។
ស្លាប់ និង រស់
«អស់អ្នកដែលស្លាប់ និងអស់អ្នកនៅរស់»។
Romans 14:10
ហេតុអ្វីបានជាអ្នកថ្កោលទោសបងប្អូនរបស់អ្នកយ៉ាងដូច្នេះ?
ហើយហេតុអ្វីបានជាអ្នកបដិសេធបងប្អូនរបស់អ្នកយ៉ាងដូចម្តេច?
ដោយការប្រើសំណួរនេះ គឺលោកប៉ូលធ្វើការពន្យល់
ហេតុអ្វីលោកត្រូវស្តីបន្ទោសចំពោះបុគ្គលម្នាក់ៗក្នុងចំណោមអ្នកអានរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត:
«វាមិនត្រឹមត្រូវនោះទេដែលអ្នកថ្កោលទោសបងប្អូនរបស់អ្នក
ហើយក៏មិនត្រឹមត្រូវដែរ ក្នុងការដែលអ្នកបដិសេធបងប្អូនរបស់អ្នក!» ឬ
«ចូរឈប់ថ្កោលទោស និងបដិសេធបងប្អូនរបស់អ្នកទៅ!»
បងប្អូន
នៅទីនេះ មានន័យសំដៅដល់គ្រិស្តបរិស័ទ ទាំងបុរស និងស្ត្រី។
ដ្បិត យើងទាំងអស់គ្នានឹងឈរនៅចំពោះបល្ល័ង្កនៃការជំនុំជម្រះរបស់ព្រះជាម្ចាស់
ឃ្លា «ចំពោះបល្ល័ង្កនៃការជំនុំជម្រះ»
សំដៅដល់សិទ្ធិអំណាចរបស់ព្រះជាម្ចាស់ក្នុងការជំនុំជម្រះ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដ្បិត ព្រះជាម្ចាស់នឹង
ជំនុំជម្រះយើងទាំងអស់គ្នា»។
ដូចមានសេចក្តីចែងទុកមកថា
អ្នកអាចបកប្រែក្នុងន័យបែបនេះថា «ដ្បិត មានអ្នកបានសរសេរក្នុងបទគម្ពីរ»។
ក្នុងការដែលយើងរស់
ប្រយោគនេះត្រូវបានប្រើដើម្បីចាប់ផ្តើមការស្បថស្បែ ឬការសន្យា។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកអាចប្រាកដចិត្ត ថានេះគឺពិត»។
គ្រប់ជង្គង់នឹងលុតចុះចំពោះយើង ហើយគ្រប់ទាំងអណ្តាតនឹងថ្វាយសិរីល្អដល់ព្រះជាម្ចាស់
លោកប៉ូលប្រើពាក្យទាំងនេះ «ជង្គង់» និង «អណ្តាត»
សំដៅដល់តួអង្គមនុស្សទាំងមូល។ ព្រះអម្ចាស់ក៏ប្រើពាក្យ «ព្រះអង្គ»
សំដៅដល់ព្រះអង្គទ្រង់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មនុស្សទាំងអស់នឹងក្រាបចុះ ហើយសរសើរតម្កើងយើង»។
Romans 14:12
នឹងទទួលខុសត្រូវនៅចំពោះកិច្ចការខ្លួនឯងនៅចំពោះព្រះជាម្ចាស់
«នឹងត្រូវពន្យល់ពីកិច្ចការរបស់យើងចំពោះព្រះជាម្ចាស់»។
ផ្ទុយទៅវិញ ចូរធ្វើដូច្នេះវិញ សូមកុំធ្វើឲ្យអ្នកណាម្នាក់ជំពប់ដួល
ឬធ្វើជាអន្ទាក់ដល់បងប្អូនរបស់ខ្លួនឡើយ
ពាក្យ «ជំពប់ដួល» និង «អន្ទាក់» នៅទីនេះ មានន័យជាគោលដូចគ្នា។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ ជំនួសមកវិញត្រូវធ្វើយ៉ាងដូច្នេះ
គឺមិនត្រូវធ្វើ ឬ និយាយអ្វីដែលជាហេតុបណ្តាលឲ្យអ្នកជឿធ្វើបាបនោះឡើយ»។
បងប្អូន
គឺសំដៅដល់គ្រិស្តបរិស័ទ ទាំងបុរស ទាំងស្ត្រី។
Romans 14:14
ខ្ញុំដឹង ហើយខ្ញុំមានការជឿជាក់នៅក្នុងព្រះអម្ចាស់យេស៊ូ
ពាក្យ «ដឹង» និង «ខ្ញុំមានការជឿជាក់» នៅទីនេះ មានន័យជាគោលដូចគ្នា
លោកប៉ូលបានប្រើពួកវាដើម្បីបញ្ជាក់ភាពជឿជាក់របស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត: «ខ្ញុំជឿជាក់
ដោយសារបងប្អូនរបស់ខ្ញុំនៅក្នុងព្រះអម្ចាស់ព្រះយេស៊ូ»។
គ្មានអ្វីមិនស្អាតដោយឯកឯងទេ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់វិជ្ជមាន។ ការបកប្រែតាមរបៀបផ្សេងទៀត
«អ្វីៗទាំងអស់វាស្អាតដោយខ្លួនរបស់វា»។
ដោយឯកឯងទេ
«ដោយធម្មជាតិរបស់វា» ឬ «ពីព្រោះវាគឺជាខ្លួនរបស់វា»។
មិនស្អាតគឺដោយសារមនុស្សគិតថាការនោះមិនស្អាតទេ ហើយសម្រាប់គាត់គឺមិនស្អាត
លោកប៉ូលបញ្ជាក់នៅទីនេះថា មនុស្សគួរតែនៅឲ្យឆ្ងាយពីអ្វីដែលគេគិតថា
របស់នោះជារបស់មិនស្អាត។ អ្នកអាចបញ្ជាក់បន្ថែមក្នុងការបកប្រែរបស់អ្នក។

generated on Wed Sep 10 16:16:32 2025

ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ ប្រសិនបើគេគិតថារបស់អ្វីមួយមិនស្អាត
នោះវានឹងមិនស្អាតសម្រាប់គេ ហើយគេគួរតែនៅឲ្យឆ្ងាយពីវា»។
ប្រសិនបើ អ្នកធ្វើឲ្យបងប្អូនរបស់អ្នកឈឺចាប់ដោយសារតែអាហារ
«ប្រសិនបើអ្នកធ្វើឲ្យជំនឿរបស់បងប្អូនរបស់អ្នក មានបញ្ហាដោយសារអាហារ»។
នៅទីនេះ ពាក្យ «របស់អ្នក»
សំដៅដល់អស់អ្នកដែលមានភាពរឹងមាំក្នុងសេចក្តីជំនឿ ហើយ «បងប្អូន»
សំដៅដល់អស់អ្នកដែលខ្សោយក្នុងសេចក្តីជំនឿ។
បងប្អូន
មានន័យសំដៅដល់គ្រិស្តបរិស័ទ ទាំងបុរស និងស្ត្រី។
អ្នកលែងដើរនៅក្នុងសេចក្តីស្រឡាញ់ទៀតហើយ
លោកប៉ូលនិយាយអំពីអាកប្បកិរិយារបស់អ្នកជឿ ដូចជាការដើរ។
ការបកប្រែតាមរបៀបផ្សេងទៀត «នោះអ្នកលែងបង្ហាញក្តីស្រលាញ់ទៀតហើយ»។
Romans 14:16
សូមកុំអនុញ្ញាតឲ្យអ្វីដែលអ្នកគិតថាល្អ ហើយបែរជាគេនិយាយអាក្រក់វិញឡើយ
«ទោះបីជាអ្នកគិតថា ទាំងនោះជាការល្អដ៏ដោយ កុំធ្វើវា
ប្រសិនបើមនុស្សដទៃនិយាយវាជាការអាក្រក់»។
កិច្ចការល្អរបស់អ្នក
សំដៅដល់កិច្ចការរបស់មនុស្សដែលមានភាពរឹងមាំក្នុងសេចក្តីជំនឿ។
មនុស្ស
ពាក្យនេះអាចមានន័យថា: ទី១) អ្នកជឿដទៃទៀត ឬ ទី២) មិនមែនគ្រិស្តបរិស័ទ។
ដ្បិត នរគរបស់ព្រះជាម្ចាស់មិនមែនជារឿងអាហារ និងផឹកឡើយ ប៉ុន្តែ គឺជារឿងសេចក្តីសុចរិត
សេចក្តីសុខសាន្ត និងសេចក្តីអំណរនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ
លោកប៉ូលវែកញែកថា ព្រះជាម្ចាស់បានបង្កើតព្រះរាជាណាចក្ររបស់ទ្រង់មក
ដូច្នេះ ព្រះអង្គនឹងប្រទានឲ្យយើងនូវទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយទ្រង់
ហើយប្រទានសេចក្តីសុខសាន្ត និងអំណរដល់យើង។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដ្បិត
ព្រះជាម្ចាស់មិនបានបង្កើតរាជាណាចក្ររបស់ទ្រង់សម្រាប់ការបរិភោគ
ឬផឹកនោះទេ ដូច្នេះ ទ្រង់អាចត្រួតត្រាលើអ្វីដែលយើងបរិភោគ
ឬលើអ្វីដែលយើងផឹក។ ព្រះអង្គបង្កើតរាជាណាចក្ររបស់ព្រះអង្គមក ដូច្នេះ
យើងអាចមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះអង្គ ហើយប្រទានសេចក្តីសុខសាន្ត
និងអំណរដល់យើង»។
Romans 14:18
ហើយមនុស្សក៏ទទួលស្គាល់ដែរ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«មនុស្សនឹងទទួលស្គាល់គាត់»ឬ «មនុស្សនឹងគោរពគាត់»។
ចូរយើងដេញតាមអ្វីៗដែលមេត្រីភាព និងអ្វីៗដែលកសាងគ្នាទៅវិញទៅមក
ឃ្លា «កសាងគ្នាទៅវិញទៅមក» នៅទីនេះ
សំដៅលើការជួយគ្នាឲ្យលូតលាស់ក្នុងសេចក្តីជំនឿ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ចូរយើងស្វែងរករស់នៅជាមួយគ្នាដោយសេចក្តីសុខសាន្ត
ហើយជួយគ្នាទៅវិញទៅមក លូតលាស់កាន់តែខ្លាំងឡើងក្នុងសេចក្តីជំនឿ»។
Romans 14:20
សូមកុំបំផ្លាញកិច្ចការរបស់ព្រះជាម្ចាស់ដោយព្រោះអាហារឡើយ
អ្នកអាចបញ្ជាក់ឲ្យមានអត្ថន័យពេញលេញ សម្រាប់ប្រយោគនេះ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«កុំកែប្រែអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់អ្នកជឿ
ព្រោះតែអ្នកចង់បរិភោគអាហារប្រភេទណាមួយនោះឡើយ»។
ប៉ុន្តែ មិនស្អាតនៅពេលដែលមនុស្សដែលបរិភោគ ហើយធ្វើឲ្យបងប្អូនរវាតចិត្តវិញ
នៅទីនេះឃ្លា «ធ្វើឲ្យបងប្អូនរវាតចិត្ត» មានន័យថា
វាធ្វើឲ្យបងប្អូនដែលខ្សោយធ្វើកិច្ចការដែលប្រឆាំងនឹងមនសិការរបស់គាត់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ
វានឹងទៅជាបាបសម្រាប់អ្នកណាម្នាក់ដែលបរិភោគអាហារ
ដែលបងប្អូនដទៃទៀតគិតថាវាខុសបើបរិភោគ ប្រសិនបើដោយសារការបរិភោគនេះ
ធ្វើឲ្យបងប្អូនដែលខ្សោយធ្វើអ្វីដែលប្រឆាំងនឹងមនសិការរបស់គាត់»។
គឺជាការល្អ ប្រសិនបើមិនបរិភោគសាច់ ឬ ផឹកស្រា ឬបរិភោគអ្វីផ្សេងទៀត
ដោយហេតុចង់ធ្វើឲ្យបងប្អូនរវាតចិត្តឡើយ
«វាជាការប្រសើរ បើមិនបរិភោគសាច់ ឬផឹកស្រាទំពាំងបាយជូរ
ឬធ្វើអ្វីផ្សេងទៀតដែលអាចនាំឲ្យបងប្អូនរបស់អ្នកមានប្រព្រឹត្តបាប»។
បងប្អូន
ពាក្យនេះមានន័យសំដៅដល់គ្រិស្តបរិស័ទ ទាំងបុរស និងស្ត្រី។
របស់អ្នក
សំដៅដល់អ្នកដែលរឹងមាំក្នុងសេចក្តីជំនឿ ហើយ «បងប្អូន»
សំដៅដល់អ្នកដែលខ្សោយក្នុងសេចក្តីជំនឿ។
Romans 14:22
ជំនឿដ៏ពិសេសទាំងនេះដែលអ្នកមាន
ប្រយោគនេះនិយាយពីជំនឿលើអាហារ និងសុរា ឬភេសជ្ជៈ:
អ្នក...ខ្លួនរបស់អ្នក
ជាឯកវចន។ ព្រោះលោកប៉ូលសំដៅលើអ្នកជឿទាំងអស់
អ្នកអាចត្រូវប្រែឃ្លានេះដោយប្រើពហុវចន។
មានពរហើយអស់អ្នកណាដែលមិនថ្កោលទោសខ្លួនឯងដោយសារអ្វីដែលខ្លួនឯងគិតថាល្អឡើយ
«មានពរហើយអ្នកដែលមិនមានអារម្មណ៍ថាមានកុំហុស
សម្រាប់អ្វីដែលពួកគេសម្រេចចិត្តធ្វើ»។
អស់អ្នកណាដែលសង្ស័យនឹងត្រូវទោស ប្រសិនបើគេបរិភោគ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងមានព្រះបន្ទូលថា ប្រសិនបើ មនុស្សមិនប្រាកដថា
នោះជាប្រភេទអាហារដែលអាចបរិភោគបាន ប៉ុន្តែ គេបរិភោគវា
នោះគេនឹងមានកំហុស» ឬ
«មនុស្សដែលមិនប្រាកដថាវាត្រឹមត្រូវសម្រាប់បរិភោគអាហារជាក់លាក់
ប៉ុន្តែបន្ទាប់មកគេបរិភោគ យ៉ាងណាក៏ដោយ នឹងមានបញ្ហាមនសិការ»។
ប្រសិនបើ វាមិនកើតចេញពីជំនឿ
អ្វីដែល «មិនមកពីជំនឿ» គឺជាអ្វីដែលព្រះជាម្ចាស់មិនចង់ឲ្យធ្វើ។
អ្នកអាចបញ្ចាក់បន្ថែមអត្ថន័យនៅទីនេះ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងមានព្រះបន្ទូលថា គេខុស ព្រោះគេបរិភោគអាហារដែលគេជឿថា
ព្រះជាម្ចាស់មិនចង់អោយគេបរិភោគ»។
អ្វីក្តីដែលមិនមែនកើតចេញពីជំនឿគឺជាអំពើបាបទាំងអស់
អ្វីដែល «មិនមកពីជំនឿ» គឺជាអ្វីដែលព្រះជាម្ចាស់មិនចង់ឲ្យធ្វើ។
អ្នកអាចបញ្ចាក់បន្ថែមអត្ថន័យនៅទីនេះ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកមានបាប ប្រសិនបើអ្នកធ្វើអ្វីដែលអ្នកមិនជឿថា ព្រះចង់ឲ្យអ្នកធ្វើ»។

---

15 [1]ឥឡូវនេះ យើងមានកម្លាំងគួរតែទ្រាំទ្រសេចក្តីកម្សោយរបស់អ្នកខ្សោយ ហើយមិនគួរធ្វើតាមតែចិត្តរបស់ខ្លួនឯងឡើយ។[2]ចូរឲ្យយើងម្នាក់ៗផ្គាប់ចិត្តអ្នកជិតខាង
ព្រោះការនោះគឺជាការល្អ ដើម្បីឲ្យយើងអាចស្អាងពួកគេឡើង។
[3]ដ្បិត សូម្បីតែព្រះគ្រិស្ត មិនបានធ្វើតាមព្រះទ័យរបស់ព្រះអង្គដែរ។ ផ្ទុយទៅវិញ ព្រះអង្គបានធ្វើដូចជាសេចក្តីដែលបានចែងទុកមកថា
«ពាក្យប្រមាថរបស់អស់អ្នកដែលប្រមាថព្រះអង្គ បានធ្លាក់មកលើទូលបង្គំ»។[4]ដ្បិត អ្វីក្តីដែលបានចែងពីមុន គឺបានចែងឡើង ដើម្បីណែនាំយើង តាមរយៈភាពអត់ធ្មត់
និងតាមរយៈការលើកទឹកចិត្តរបស់បទគម្ពីរ ធ្វើឲ្យយើងមានទំនុកចិត្ត។
[5]ឥឡូវនេះ សូមព្រះនៃេសចក្តីអត់ធ្មត់ និងការលើកទឹកចិត្តប្រទានដល់អ្នក ឲ្យមានចិត្តគំនិតតែមួយជាមួយគ្នាទៅវិញទៅមក ស្របតាមព្រះគ្រិស្តយេស៊ូ។
[6]សូមឲ្យព្រះអង្គធ្វើការនេះ ដើម្បីការមានចិត្តគំនិតតែមួយ អ្នកអាចសរសើរចេញពីសម្លេងតែមួយដល់ព្រះជាម្ចាស់ និងព្រះបិតានៃព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង។
[7]ដូច្នេះហើយ ចូរទទួលគ្នាទៅវិញទៅមក ដូចព្រះគ្រិស្តបានទទួលអ្នកដែរ ដើម្បីសរសើរតម្កើងដល់ព្រះជាម្ចាស់។
[8]ខ្ញុំសូមជម្រាប់ថា ព្រះគ្រិស្តបានត្រឡប់ទៅជាអ្នកបម្រើនៃពួកអ្នកកាត់ស្បែកជាតំណាងឲ្យសេចក្តីពិតរបស់ព្រះជាម្ចាស់
ដើម្បីបញ្ជាក់ពីសេចក្តីសន្យាដែលបានប្រទានដល់ដូនតារបស់ពួកគេ[9]ហើយដើម្បីឲ្យសាសន៍ដទៃបានថ្វាយសិរីល្អដល់ព្រះសម្រាប់សេចក្តីមេត្តារបស់ព្រះអង្គ។
ដូចមានសេចក្តីចែងទុកមកថា «ដូច្នេះ ទូលបង្គំនឹងថ្វាយការសរសើរដល់ព្រះអង្គនៅក្នុងចំណោមសាសន៍ដទៃ ហើយច្រៀងសរសើរដល់ព្រះនាមរបស់ព្រះអង្គ»។
[10]ហើយក៏មានសេចក្តីចែងទុកទៀតថា «ឱសាសន៍ដទៃអើយ ចូរមានអំណរជាមួយនឹងរាស្ត្ររបស់ព្រះអង្គចុះ!»។[11]ហើយចែងទៀតថា «ចូរសរសើរដល់ព្រះអម្ចាស់
ឱសាសន៍ដទៃអើយ ចូរឲ្យមនុស្សគ្រប់គ្នាសរសើរព្រះអង្គ!»។

generated on Wed Sep 10 16:16:32 2025

[12]លោកអេសាយមានប្រសាសន៍ម្តងទៀតថា «នឹងមានឫសរបស់លោកអ៊ីសាយ ហើយនឹងមានម្នាក់ងើបឡើងដើម្បីគ្រប់គ្រងលើសាសន៍ដទៃ។
សាសន៍ដទៃនឹងមានទំនុកចិត្តលើព្រះអង្គ»។
[13]ឥឡូវនេះ សូមឲ្យព្រះជាម្ចាស់នៃទំនុកចិត្ត បំពេញអ្នកជាមួយនឹងអំណរ និងសេចក្តីសុខសាន្តសម្រាប់ការជឿ ដើម្បីឲ្យអ្នកអាចមានទំនុកចិត្តជាបរិបូរណ៌
ដោយអំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
[14]បងប្អូនអើយ ខ្លួនខ្ញុំផ្ទាល់ក៏មានទំនុកចិត្តលើបងប្អូនដែរ។ ខ្ញុំបានជឿជាក់លើបងប្អូន ថាបងប្អូនបានពេញដោយសេចក្តីល្អ បានពេញដោយចំណេះដឹងគ្រប់យ៉ាង។
ខ្ញុំជឿជាក់ថា អ្នកក៏អាចដាស់តឿនដល់អ្នកទៅវិញទៅមកផងដែរ។
[15]ប៉ុន្តែ ខ្ញុំសរសេរមកកាន់បងប្អូនដោយសេចក្តីក្លាហានអំពីការមួយចំនួន ដើម្បីរំលឹកបងប្អូនម្តងទៀត ដោយសារតែអំណោយទានដែលព្រះជាម្ចាស់បានប្រទានដល់ខ្ញុំ។
[16]អំណោយនោះគឺថា ខ្ញុំអាចធ្វើជាអ្នកបម្រើរបស់ព្រះគ្រិស្តយេស៊ូ ដែលបានចាត់ទៅកាន់សាសន៍ដទៃ ដើម្បីធ្វើជាបូជាចារ្យនៃដំណឹងល្អរបស់ព្រះជាម្ចាស់។ ខ្ញុំអាចធ្វើការនេះ
ដើម្បីឲ្យការថ្វាយយញ្ញបូជារបស់សាសន៍ដទៃអាចទទួលយកបាន បានបរិសុទ្ធដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។
[17]ដូច្នេះ សេចក្តីអំណាររបស់ខ្ញុំគឺនៅក្នុងព្រះគ្រិស្តយេស៊ូ ហើយនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់។[18]ដ្បិត ខ្ញុំនឹងមិនហ៊ាននិយាយពីអ្វីទាំងអស់
លើកលែងតែអ្វីដែលព្រះគ្រិស្តបានធ្វើតាមរយៈខ្ញុំ ដោយព្រោះការស្តាប់បង្គាប់របស់សាសន៍ដទៃ។ មានការជាច្រើនបានសម្រេច ដោយសារសំដៅ និងការប្រព្រឹត្ត។
[19]ដោយសារអំណាចនៃទីសម្គាល់ និងការអស្ចារ្យ ព្រមទាំងដោយសារអំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ការនេះអាចកើតឡើងដូច្នេះ
ដើម្បីឲ្យខ្ញុំអាចនាំដំណឹងល្អរបស់ព្រះគ្រិស្តពីក្រុងយេរ៉ូសាឡិមរហូតដល់ក្រុងអ៊ីលីរីកុន។
[20]បំណងចិត្តរបស់ខ្ញុំ គឺចង់ប្រកាសដំណឹងល្អបែបនេះឯង ប៉ុន្តែ មិនមែនកន្លែងដែលគេស្គាល់ព្រះនាមព្រះគ្រិស្តរួចហើយនោះទេ
ដើម្បីកុំឲ្យខ្ញុំបានសង់នៅលើគ្រឹះរបស់អ្នកផ្សេងឡើយ។[21]ដូចមានសេចក្តីចែងទុកមកថា «អស់អ្នកដែលមិនបានឮពីព្រះអង្គនឹងបានឃើញព្រះអង្គ
ហើយអស់អ្នកណាដែលមិនធ្លាប់បានឮ នឹងបានយល់»។
[22]ដូច្នេះហើយ បានជាមានការរារាំងខ្ញុំជាច្រើនដង ក្នុងការមកឯបងប្អូន។[23]ប៉ុន្តែ ឥឡូវនេះ ខ្ញុំលែងមានកន្លែងនៅក្នុងតំបន់ទាំងនោះទៀតទេ
ហើយខ្ញុំក៏ប្រាថ្នាជាច្រើនឆ្នាំហើយ ក្នុងការទៅរកអ្នករាល់គ្នា។
[24]ដូច្នេះ នៅពេលណា ខ្ញុំបានទៅអេស្ប៉ាញ ខ្ញុំសង្ឃឹមថាបានទៅជួបអ្នករាល់គ្នាតាមផ្លូវដែលខ្ញុំឆ្លងកាត់នោះ ហើយបងប្អូនក៏មានចំណែកក្នុងការចាត់ខ្ញុំឲ្យទៅដែរ
បន្ទាប់ពីខ្ញុំបាននៅជាមួយបងប្អូនមួយរយៈ។[25]ប៉ុន្តែ ឥឡូវនេះ ខ្ញុំនឹងទៅក្រុងយេរ៉ូសាឡិម ដើម្បីបម្រើបងប្អូននៅទីនោះ។
[26]ដ្បិត សេចក្តីអំណាររបស់បងប្អូននៅស្រុកម៉ាសេដូន និងស្រុកអាខៃបានរួមចំណែកជួយដល់អ្នកក្រនៅក្នុងចំណោមអ្នកជឿដែលនៅក្នុងក្រុងយេរ៉ូសាឡិម។[27]មែនហើយ
ការរួមចំណែកជួយនេះពិតជាមានអំណរមែន ហើយពិតណាស់ ពួកគេគឺជាអ្នកជំពាក់អ្នកទាំងនោះ។ ដ្បិត ប្រសិនបើ
សាសន៍ដទៃមានចំណែកនៅក្នុងកិច្ចការខាងវិញ្ញាណជាមួយពួកគេ ពួកគេជំពាក់ដល់ពួកគេមែន ថែមទាំងត្រូវបម្រើពួកគេដោយសម្ភារៈផ្សេងៗផងដែរ។
[28]ដូច្នេះ នៅពេលខ្ញុំបានបំពេញភារកិច្ចនេះ ហើយប្រាកដថាពួកគេបានទទួលអ្វីដែលបានប្រមូលហើយ ខ្ញុំនឹងទៅអេស្ប៉ាញ ហើយនិងទៅជួបបងប្អូននៅតាមផ្លូវ។[29]ខ្ញុំដឹងថា
នៅពេលដែលខ្ញុំទៅជួបបងប្អូន ខ្ញុំនឹងទៅក្នុងព្រះពរដ៏បរិបូរថណ៌នៅក្នុងព្រះគ្រិស្ត។
[30]ឥឡូវនេះ បងប្អូនអើយ ខ្ញុំដាស់តឿនដល់អ្នករាល់គ្នា នៅក្នុងព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង និងដោយសេចក្តីស្រឡាញ់របស់ព្រះវិញ្ញាណថា
ចូរខំព្យាយាមអធិស្ឋានជាមួយខ្ញុំនៅក្នុងសេចក្តីអធិស្ឋានបស់អ្នករាល់គ្នាដល់ព្រះសម្រាប់ខ្ញុំ។[31]សូមអធិស្ឋាន ឲ្យខ្ញុំបានសង្គ្រោះពីអស់អ្នកដែលមិនស្តាប់បង្គាប់នៅក្នុងយូដា
និងកិច្ចការបម្រើរបស់ខ្ញុំសម្រាប់បងប្អូននៅក្នុងក្រុងយេរ៉ូសាឡិម ឲ្យអាចទទួលយកបាននៅក្នុងចំណោមបងប្អូនអ្នកជឿនៅទីនោះ។
[32]សូមអធិស្ឋានឲ្យខ្ញុំអាចមកជួបបងប្អូនដោយអំណរ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយអធិស្ឋានសូមឲ្យខ្ញុំអាចមកជួប ហើយសម្រាកជាមួយបងប្អូន។
[33]សូមព្រះនៃសេចក្តីសុខសាន្តគង់នៅជាមួយអ្នករាល់គ្នា។ អាមែន។

Romans 15:1

ប្រយោគភ្ជាប់

លោកប៉ូលបញ្ចប់វគ្គនេះ អំពីការរស់នៅរបស់អ្នកជឿសម្រាប់អ្នកដទៃ
ជាមួយការរំលឹកពួកគេពីរបៀបដែលព្រះគ្រិស្តធ្លាប់គង់នៅ។

ឥឡូវនេះ

ចូរបកប្រែពាក្យនេះ ដោយប្រើភាសារបស់អ្នក
ដើម្បីណែនាំគំនិតថ្មីទៅក្នុងការវែកញែក។

យើងមានកម្លាំង

ពាក្យ «កម្លាំង» នៅទីនេះ
សំដៅដល់មនុស្សដែលរឹងមាំក្នុងសេចក្តីជំនឿរបស់ពួកគេ។
ពួកគេជឿថាព្រះជាម្ចាស់អនុញ្ញាតឲ្យពួកគេបរិភោគគ្រប់ប្រភេទអាហារទាំងអស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «យើងដែលមានកម្លាំងក្នុងសេចក្តីជំនឿ»។

យើង

ពាក្យនេះសំដៅដល់លោកប៉ូល អ្នកអានរបស់លោក និងអ្នកជឿដទៃទៀត។

អ្នកខ្សោយ

ពាក្យ «អ្នកខ្សោយ» នៅទីនេះ
សំដៅដល់មនុស្សដែលខ្សោយក្នុងសេចក្តីជំនឿរបស់ពួកគេ។
ពួកគេជឿថាព្រះជាម្ចាស់មិនអនុញ្ញាតឲ្យគេបរិភោគអាហារមួយចំនួន។
ការបកប្រែតាមរបៀបផ្សេងទៀត: «អស់អ្នកដែលខ្សោយក្នុងសេចក្តីជំនឿ»។

ស្អាងពួកគេឡើង

ដោយប្រយោគនេះ លោកប៉ូលមានន័យ ដើម្បីពង្រឹងជំនឿរបស់អ្នកណាម្នាក់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដើម្បីពង្រឹងសេចក្តីជំនឿរបស់គេ»។

Romans 15:3

ព្រះអង្គបានធ្វើដូចជាសេចក្តីដែលបានចែងទុកមក

ឃ្លានេះលោកប៉ូលសំដៅដល់បទគម្ពីរ កន្លែងដែលព្រះគ្រិស្ត

ពាក្យប្រមាថរបស់អស់អ្នកដែលប្រមាថព្រះអង្គ បានធ្លាក់មកលើទូលបង្គំ

ពាក្យប្រមាថរបស់អស់អ្នកដែលបានប្រមាថព្រះជាម្ចាស់បានធ្លាក់ទៅលើព្រះគ្រិស្ត។

ដ្បិត អ្វីក្តីដែលបានចែងពីមុន គឺបានចែងឡើង ដើម្បីណែនាំយើង

អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «ដ្បិត
គ្រប់យ៉ាងដែលពួកព្យាការីបានសរសេរក្នុងបទគម្ពីរ ដើម្បីបង្រៀនយើង
ក្នុងអតីតកាល»។ របស់យើង...យើង -

លោកប៉ូលរាប់បញ្ចូលទាំងអ្នកអានរបស់លោក និងអ្នកជឿដទៃទៀត។

តាមរយៈភាពអត់ធ្មត់ និងតាមរយៈការលើកទឹកចិត្តរបស់បទគម្ពីរ ធ្វើឲ្យយើងមានទំនុកចិត្ត

ឃ្លា «ធ្វើឲ្យយើងមានទំនុកចិត្ត» នៅទីនេះ មានន័យថា អ្នកជឿនឹងដឹងថា
ព្រះជាម្ចាស់ នឹងសម្រេចព្រះបន្ទូលសន្យារបស់ទ្រង់។
អ្នកអាចធ្វើការបំពេញអត្ថន័យក្នុងការបកប្រែរបស់អ្នក។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដោយរបៀបនេះ បទគម្ពីរនឹងលើកទឹកចិត្តយើង
ឲ្យជឿជាក់ថា
ព្រះជាម្ចាស់នឹងធ្វើគ្រប់យ៉ាងសម្រាប់យើងតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ»។

Romans 15:5

ប្រយោគភ្ជាប់

លោកប៉ូលលើកទឹកចិត្តអ្នកជឿទាំងអស់ឲ្យចងចាំថា ទាំងអ្នកជឿសាសន៍ដទៃ
ទាំងជាសាសន៍យូដាដែលជឿ គឺបានរួមគ្នាមកតែមួយក្នុងព្រះគ្រិស្ត។

សូម...ព្រះ...ប្រទាន

«ខ្ញុំអធិស្ឋានថា...ព្រះជាម្ចាស់...នឹងប្រទាន»

ចិត្តគំនិតតែមួយជាមួយគ្នាទៅវិញទៅមក

ប្រយោគ «គំនិតដូចគ្នា» នៅទីនេះ ជាការប្រៀបធៀបដែលបញ្ជាក់ថា
ឲ្យមានកិច្ចព្រមព្រៀងគ្នាទៅវិញទៅមក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដើម្បីឲ្យមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក» ឬ «ដើម្បីឲ្យមានសាមគ្គី»។

សរសើរចេញពីសម្លេងតែមួយ

ឃ្លានេះមានន័យថា ដើម្បីឲ្យមានសាមគ្គីក្នុងការសរសើរព្រះជាម្ចាស់។
ការបកប្រែតាមរបៀបដទៃទៀត: «ចូរសរសើរព្រះជាម្ចាស់ដោយការសាមគ្គី
ដូចជាមនុស្សតែម្នាក់ដែលនិយាយពីមាត់តែមួយ»។

ចូរទទួលគ្នាទៅវិញទៅមក

generated on Wed Sep 10 16:16:32 2025

«ទទួលគ្នាទៅវិញទៅមក»។
Romans 15:8
ខ្ញុំសូមជម្រាប់ថា
«ខ្ញុំ» សំដៅដល់លោកប៉ូល។
ព្រះគ្រិស្តបានត្រឡប់ទៅជាអ្នកបម្រើនៃពួកអ្នកកាត់ស្បែក
នៅទីនេះ «ពួកអ្នកកាត់ស្បែក» សំដៅដល់សាសន៍យូដា។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបដទៃទៀត:
«ព្រះយេស៊ូគ្រិស្តបានមក ដើម្បីជួយសាសន៍យូដា»។
ដូច្នេះ ព្រះអង្គនឹងបញ្ជាក់ពីសេចក្តីសន្យាដែលបានប្រទានដល់ដូនតារបស់ពួកគេ
ពាក្យ «ដូនតា» នៅទីនេះ សំដៅដល់ដូនតារបស់សាសន៍យូដា។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបដទៃទៀត
«នោះព្រះជាម្ចាស់នឹងបញ្ជាក់សេចក្តីសន្យា
ដែលព្រះអង្គបានប្រទានឲ្យដូនតារបស់សាសន៍យូដា»។
ហើយដើម្បីឲ្យសាសន៍ដទៃ
នេះជាប្រយោគបិត។ អ្នកអាចរួមបញ្ចូលពាក្យដែលបាត់។
ការបកប្រែតាមរបៀបដទៃទៀត:
«ហើយព្រះគ្រិស្តបានមកដើម្បីជួយពួកសាសន៍ដទៃ»។
ដូចមានសេចក្តីចែងទុកមកថា
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដូចដែលអ្នកណាម្នាក់បានសរសេរក្នុងបទគម្ពីរ»។
ហើយច្រៀងសរសើរដល់ព្រះនាមរបស់ព្រះអង្គ
ឃ្លា «ព្រះនាមរបស់ព្រះអង្គ» ជាន័យធេៀបដែលសំដៅដល់ ព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «ហើយច្រៀងសរសើរព្រះអង្គ»។
Romans 15:10
ហើយក៏មានសេចក្តីចែងទុកទៀតថា
«បទគម្ពីរចែងទុកទៀតថា»។
ជាមួយនឹងរាស្ត្ររបស់ព្រះអង្គចុះ
ឃ្លានេះសំដៅដល់រាស្ត្ររបស់ព្រះជាម្ចាស់។
អ្នកអាចបន្ថែមអត្ថន័យក្នុងការបកប្រែរបស់អ្នក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ជាមួយនឹងរាស្ត្ររបស់ព្រះជាម្ចាស់»។
សរសើរព្រះអង្គ
«សរសើរព្រះអម្ចាស់»។
Romans 15:12
ឫសរបស់លោកអ៊ីសាយ
លោកអ៊ីសាយ ជាឪពុកខាងសាច់ឈាមរបស់ស្តេចដាវីឌ។
ការបកប្រែតាមរបៀបដទៃទៀត: «ពូជពង្សរបស់លោកអ៊ីសាយ»។
សាសន៍ដទៃនឹងមានទំនុកចិត្តលើព្រះអង្គ
«ព្រះអង្គ» សំដៅដល់ ព្រះមេស្ស៊ី ជាពូជពង្សរបស់លោកអ៊ីសាយ។
អស់អ្នកដែលមិនមែនជាសាសន៍យូដា ក៏នឹងទុកចិត្តថា
ទ្រង់នឹងសម្រេចព្រះបន្ទូលសន្យារបស់ទ្រង់។ ការបកប្រែតាមរបៀបដទៃទៀត:
«មនុស្សដែលមិនមែនជាសាសន៍យូដា អាចទុកចិត្តព្រះអង្គ
ថាទ្រង់ធ្វើអ្វីដែលទ្រង់បានសន្យា»។
Romans 15:13
ព្រះជាម្ចាស់នៃទំនុកចិត្ត
ពាក្យ «ទំនុកចិត្ត» នៅទីនេះសំដៅដល់សមត្ថភាពរបស់អ្នកណាម្នាក់
ក្នុងការទុកចិត្តព្រះជាម្ចាស់ ធ្វើអ្វីដែលព្រះអង្គបានសន្យាថានឹងធ្វើ។
ការបកប្រែតាមរបៀបដទៃទៀត: «ព្រះអម្ចាស់អើយ!
អស់អ្នកដែលព្រះអម្ចាស់ទុកចិត្ត ដើម្បីសម្រេចពាក្យសន្យារបស់ទ្រង់»។
បំពេញអ្នកជាមួយនឹងអំណរ និងសេចក្តីសុខសាន្ត
លោកប៉ូលបន្ថែមន័យនៅទីនេះ ដើម្បីបញ្ជាក់គោលបំណងរបស់គាត់។
ការបកប្រែតាមរបៀបដទៃទៀត: «បំពេញអ្នកជាមួយនឹងអំណរ
និងសេចក្តីសុខសាន្តដ៏បរិបូរ»។
អ្នកអាចមានទំនុកចិត្តជាបរិបូរ
«អ្នកអាចមានទំនុកចិត្តទាំងស្រុង»។
Romans 15:14
ប្រយោគភ្ជាប់
លោកប៉ូលរំលឹកអ្នកជឿនៅក្រុងរ៉ូមថា
ព្រះជាម្ចាស់បានជ្រើសគាត់ដើម្បីនាំដំណឹងល្អដល់សាសន៍ដទៃ។
បងប្អូនអើយ ខ្លួនខ្ញុំផ្ទាល់ក៏មានទំនុកចិត្តលើបងប្អូនដែរ
លោកប៉ូលប្រាកដចិត្តភ្លាមថា ក្នុងអាកប្បកិរិយារបស់អ្នកជឿនៅក្រុងរ៉ូម
គឺពួកគេមានការគោរពគ្នាទៅវិញទៅមក។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ខ្លួនខ្ញុំផ្ទាល់ប្រាកដណាស់ថាបងប្អូនមានពេញដោយក្តីស្រលាញ់
ក្នុងការប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក»
បងប្អូន
សំដៅដល់អ្នកជឿ ដែលរួមទាំងបុរស និងស្ត្រី។
ពេញដោយចំណេះដឹងគ្រប់យ៉ាង
លោកប៉ូលបន្ថែមអត្ថន័យដើម្បីបញ្ជាក់គោលបំណងរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត: «បានបំពេញដោយចំណេះដឹងគ្រប់គ្រាន់
ដើម្បីដើរតាមព្រះជាម្ចាស់»។
ក៏អាចដាស់តឿនដល់អ្នកទៅវិញទៅមកផងដែរ
ពាក្យ «ដាស់តឿន» នៅទីនេះមានន័យថា បង្រៀន។
ការបកប្រែតាមរបៀបផ្សេងទៀត: «ក៏អាចបង្រៀនគ្នាទៅវិញទៅមក»។
Romans 15:15
អំណោយទានដែលព្រះជាម្ចាស់បានប្រទានដល់ខ្ញុំ
អំណោយទាននេះជាការតែងតាំងលោកប៉ូលជាសាវកម្នាក់
ថ្វីបើលោកធ្លាប់ធ្វើទុក្ខបុកម្នេញអ្នកជឿ ក្នុងពេលលោកមិនទាន់ប្រែចិត្តក៏ដោយ។
លោកប៉ូលនិយាយអំពីការជ្រើសរើសរបស់គាត់ជាសាវក
ដែលជាអំណោយទានដែលព្រះបានប្រទានដល់លោក។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អំណោយទានដែលព្រះបានប្រទានដល់ខ្ញុំ»។
ការថ្វាយយញ្ញបូជារបស់សាសន៍ដទៃអាចទទួលយកបាន
លោកប៉ូលនិយាយអំពីការចែកចាយដំណឹងល្អរបស់ ដែលលោកដូចជាបូជាចារ្យ
ដែលធ្វើការថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់។ ការបកប្រែតាមរបៀបផ្សេងទៀត:
«សាសន៍ដទៃអាចសព្វព្រះទ័យព្រះជាម្ចាស់
នៅពេលដែលពួកគេស្តាប់បង្គាប់ព្រះអង្គ»។
Romans 15:17
សេចក្តីអំណររបស់ខ្ញុំគឺនៅក្នុងព្រះគ្រិស្តយេស៊ូ ហើយនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់
ឃ្លា «កិច្ចការរបស់ព្រះជាម្ចាស់» នៅទីនេះ
អាចសំដៅដល់កិច្ចការដែលព្រះជាម្ចាស់បានជ្រើសរើសលោកប៉ូលដើម្បីធ្វើវា។
ការបកប្រែតាមរបៀបផ្សេងទៀត: «ទោះបីយ៉ាងណាក៏ដោយ
ខ្ញុំមានហេតុផលដើម្បីមានអំណរក្នុងព្រះគ្រិស្តយេស៊ូ
និងក្នុងកិច្ចការរបស់ព្រះជាម្ចាស់ដែលប្រទានអោយខ្ញុំធ្វើ»។
ដ្បិត ខ្ញុំនឹងមិនហ៊ាននិយាយពីអ្វីទាំងអស់... មានការជាច្រើនបានសម្រេច ដោយសារសំដី
និងការប្រព្រឹត្ត ដោយសារអំណាចនៃទីសម្គាល់ និងការអស្ចារ្យ ព្រមទាំងដោយសារអំណាចរ
បស់ព្រះវិញ្ញាណដ៏វិសុទ្ធ
អ្នកអាចបកប្រែឃ្លាអវិជ្ជមានស្នួននេះ ទៅជាទម្រង់វិជ្ជមានវិញ។ ឃ្លា
«មានការជាច្រើន» នៅទីនេះ
សំដៅដល់អ្វីដែលព្រះគ្រិស្តបានសម្រេចតាមរយៈលោកប៉ូល។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដោយសារការស្តាប់បង្គាប់របស់សាសន៍ដទៃ
ខ្ញុំនឹងនិយាយតែអ្វីដែលព្រះគ្រិស្តសម្រេចតាមរយៈខ្ញុំ ដោយសារសម្តី និង
ការប្រព្រឹត្តរបស់ខ្ញុំ ដោយសារអំណាចនៃទីសម្គាល់ និងការអស្ចារ្យ
ព្រមទាំងដោយសារអំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ»។
ទីសម្គាល់ និងការអស្ចារ្យ
ពាក្យទាំងពីរនេះ មានអត្ថន័យជាគោលដូចគ្នា
ហើយសំដៅដល់ប្រភេទផ្សេងៗគ្នានៃការអស្ចារ្យ។
នាំដំណឹងល្អរបស់ព្រះគ្រិស្តពីក្រុងយេរូសាឡិមរហូតដល់ក្រុងអ៊ីលីរីកុន
គឺមកពីក្រុងយេរូ៉សាឡិមដែលនៅឆ្ងាយពីក្រុងអ៊ីលីរីកុន ជាតំបន់មួយក្បែរអ៊ីតាលី។
Romans 15:20
បំណងចិត្តរបស់ខ្ញុំ គឺចង់ប្រកាសដំណឹងល្អបែបនេះឯង ប៉ុន្តែ
មិនមែនកន្លែងដែលគេស្គាល់ព្រះនាមព្រះគ្រិស្តរួចហើយនោះទេ
លោកប៉ូលគ្រាន់តែចង់ផ្សាយដំណឹងល្អ
ទៅដល់មនុស្សដែលមិនទាន់បានឮអំពីព្រះគ្រិស្ត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយហេតុនេះ ខ្ញុំចង់ប្រកាសដំណឹងល្អនៅទីកន្លែងណា
ដែលមនុស្សមិនធ្លាប់បានឮអំពីព្រះគ្រិស្ត»។
ដើម្បីកុំឲ្យខ្ញុំបានសង់នៅលើគ្រឹះរបស់អ្នកផ្សេងឡើយ
លោកប៉ូលមានប្រសាសន៍ពីបេសកកម្មការងាររបស់លោក
ដែលដូចជាការសាងសង់ផ្ទះនៅលើគ្រឹះ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដើម្បីកុំឲ្យខ្ញុំបន្តការងារដែលអ្នកផ្សេងបានចាប់ផ្តើមរួចទៅហើយនោះ។

generated on Wed Sep 10 16:16:32 2025

ខ្ញុំមិនចង់ធ្វើជាមនុស្សដែលសាងសង់ផ្ទះលើគ្រឹះរបស់អ្នកណាម្នាក់ផ្សេងនោះទេ»
ដូចមានសេចក្តីចែងទុកមកថា
នៅទីនេះលោកប៉ូលសំដៅដល់អ្វីដែលលោកអេសាយបានសរសេរនៅក្នុងបទគម្ពីរ។
អ្នកអាចបកប្រែក្នុងទម្រង់សកម្ម និងធ្វើឲ្យមានន័យអត្ថន័យ។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្វីដែលកំពុងកើតឡើង
គឺដូចជាអ្វីដែលលោកអេសាយបានសរសេរក្នុងបទគម្ពីរ»។
អស់អ្នកដែលមិនបានឮពីព្រះអង្គ
លោកប៉ូលនិយាយពី «ដំណឹង» ឬសារអំពីព្រះគ្រិស្តមានដែលហាក់មានជីវិត
និងមានសកម្មភាពដោយខ្លួនឯង។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អស់អ្នកដែលមិនមានអ្នកណាប្រាប់ដំណឹងអំពីព្រះគ្រិស្ត»។
Romans 15:22
ប្រយោគភ្ជាប់
លោកប៉ូលប្រាប់អ្នកជឿនៅក្រុងរ៉ូមអំពីផែនការណ៍ផ្ទាល់ខ្លួនរបស់លោកដើម្បីមកជួបសួរសុខទុក្ខនិងសូមឲ្យអ្នកជឿអធិស្ឋានសម្រាប់លោក។
បានជាមានការរារាំងខ្ញុំ
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្មមួយ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ពួកគេបានរារាំងខ្ញុំ» ឬ «មនុស្សទាំងអស់ក៏បានរារាំងខ្ញុំ»។
ខ្ញុំលែងមានកន្លែងនៅក្នុងតំបន់ទាំងនោះទៀតទេ
លោកប៉ូលបញ្ជាក់ថាមិនមានកន្លែងច្រើនទេក្នុងតំបន់ទាំងនេះ
ដែលអ្នករស់នៅទីនោះមិនបានដឹងពីព្រះគ្រិស្តនោះទេ។
ការបកប្រែតាមរបៀបផ្សេងទៀត: «នៅតំបន់នេះមានកន្លែងច្រើន
ដែលមនុស្សមិនបានឮអំពីព្រះគ្រិស្ត»
Romans 15:24
អេស្ប៉ាញ
នេះជាអាណាខេត្តរ៉ូមខាងកើតនៃអាណាចក្ររ៉ូម ដែលលោកប៉ូលប្រាថ្នាទៅលេង។
ឆ្លងកាត់
«ដែលខ្ញុំឆ្លងកាត់ក្រុងរ៉ូម» ឬ «ពេលដែលខ្ញុំនៅតាមផ្លូវ»។
បងប្អូនក៏មានចំណែកក្នុងការចាត់ខ្ញុំឲ្យទៅដែរ
លោកប៉ូលបញ្ជាក់ថា
លោកចង់ឲ្យអ្នកជឿនៅក្រុងរ៉ូមផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុខ្លះដល់លោកសម្រាប់ការធ្វើដំណើរ
ការបកប្រែតាមរបៀបផ្សេងទៀត: «ដែលអ្នកនឹងជួយខ្ញុំក្នុងការធ្វើដំណើរ»
បន្ទាប់ពីខ្ញុំបាននៅជាមួយបងប្អូន
«ចំណាយពេលខ្លះជាមួយបងប្អូន» ឬ «រីករាយជួបជាមួយអ្នករាល់គ្នា»។
Romans 15:26
សេចក្តីអំណររបស់បងប្អូននៅស្រុកម៉ាសេដូន និងស្រុកអាខៃ
ពាក្យ «ម៉ាសេដូន» និង «អាខៃ» នៅទីនេះ
សំដៅដល់មនុស្សដែលរស់នៅក្នុងតំបន់ទាំងនោះ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«សេចក្តីអំណររបស់អ្នកជឿនៅក្នុងស្រុកម៉ាសេដូន និង ស្រុកអាខៃ»
មែនហើយ ការរួមចំណែកជួយនេះពិតជាមានអំណរមែន
«អ្នកជឿនៅក្នុងស្រុកម៉ាសេដូន និង ស្រុកអាខៃមានអំណរដែលបានរួមចំណែក»។
ពិតណាស់ ពួកគេគឺជាអ្នកជំពាក់អ្នកទាំងនោះ
«ពិតណាស់ អ្នកជឿនៅក្នុងស្រុកម៉ាសេដូន និង ស្រុកអាខៃ
ជាប់ជំពាក់អ្នកជឿក្នុងក្រុងយេរូសាឡិម»។
ប្រសិនបើ សាសន៍ដទៃមានចំណែកនៅក្នុងកិច្ចការខាងវិញ្ញាណរបស់ពួកគេ
ពួកគេជំពាក់ដល់ពួកគេមែន ថែមទាំងត្រូវបម្រើពួកគេ
«ប្រសិនបើ
សាសន៍ដទៃមានចំណែកនៅក្នុងកិច្ចការខាងវិញ្ញាណរបស់អ្នកជឿក្រុងយេរូសាឡិមទៅហើយ
នោះសាសន៍ដទៃក៏ជំពាក់ការបម្រើអ្នកជឿក្រុងយេរូសាឡិមដែរ»។
Romans 15:28
ហើយមានបញ្ជាក់ផលនេះដល់ពួកគេ
លោកប៉ូលមានប្រសាសន៍អំពីប្រាក់ដែលលោកនាំយកទៅក្រុងយេរូសាឡិមនោះជាផលផ្លែ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយមានការនាំយកដង្វាយនេះទៅដល់ពួកគេដោយសុវត្ថិភាព»។
ខ្ញុំដឹងថា នៅពេលដែលខ្ញុំទៅជួបបងប្អូន ខ្ញុំនឹងទៅក្នុងព្រះពរដ៏បរិបូរណ៌នៅក្នុងព្រះគ្រិស្ត
ឃ្លានេះមានន័យថា ព្រះគ្រិស្តនឹងប្រទានពរលោកប៉ូលនិងអ្នកជឿនៅក្រុងរ៉ូម។
ការបកប្រែតាមរបៀបផ្សេងទៀត: «ហើយខ្ញុំដឹងថា
នៅពេលដែលខ្ញុំមកលេងអ្នករាល់គ្នា
ព្រះគ្រិស្តនឹងប្រទានពរយ៉ាងលើសលប់ដល់យើង»
Romans 15:30
ឥឡូវនេះ
ចូរប្រើវានៅទីនេះ! ប្រសិនបើនៅក្នុងភាសារបស់អ្នកមានរបៀបដែលបង្ហាញថា
លោកប៉ូលបានឈប់និយាយអំពីកិច្ចការល្អ ដែលគាត់មានទំនុកចិត្ត ក្នុង (១៥:២៨)
ហើយឥឡូវនេះ គឺការចាប់ផ្តើមនិយាយអំពីមហន្តរាយ ដែលជួបនៅចំពោះមុខវិញ។
ខ្ញុំដាស់តឿនដល់អ្នករាល់គ្នា
«ខ្ញុំលើកទឹកចិត្តអ្នករាល់គ្នា»។
បងប្អូនអើយ
សំដៅដល់គ្រិស្តបរិស័ទ រួមបញ្ចូលទាំងបុរស ទាំងស្ត្រី។
ខំព្យាយាម
«ប្រឹងប្រែង» ឬ «ព្យាយាម»។
បានសង្គ្រោះ
«បានសង្គ្រោះ» ឬ «បានការពារ»។
ការនាំយកដង្វាយទៅឲ្យ
ឲ្យអាចទទួលយកបាននៅក្នុងចំណោមបងប្អូនអ្នកជឿនៅទីនោះ
លោកប៉ូលបញ្ជាក់បំណងប្រាថ្នារបស់លោក ថាអ្នកជឿក្នុងក្រុងយេរូសាឡិម
នឹងរីករាយយ៉ាងខ្លាំងក្នុងការទទួលប្រាក់ពីអ្នកជឿក្នុងស្រុកម៉ាសេដូន
និងស្រុកអាខៃ។ ការបកប្រែតាមរបៀបផ្សេងទៀត: «ហើយសូមអធិស្ឋាន
ដែលបងប្អូនអ្នកជឿក្នុងក្រុងយេរូសាឡិម
នឹងមានក្តីរីករាយទទួលប្រាក់ដែលខ្ញុំនាំយកទីអោយពួកគេ»។
Romans 15:33
សូមព្រះនៃសេចក្តីសុខសាន្ត
«ព្រះនៃសេចក្តីសុខសាន្ត» មានន័យថាព្រះ
ដែលធ្វើឲ្យអ្នកជឿមានក្តីសុខសាន្តពីខាងក្នុងមក។
ការបកប្រែតាមរបៀបផ្សេងទៀត: «ខ្ញុំអធិស្ឋាន សូមឲ្យព្រះជាម្ចាស់
ដែលធ្វើឲ្យយើងមានសេចក្តីសុខសាន្តពីខាងក្នុង»។

---

16 [1]ខ្ញុំសូមសរសើរដល់អ្នករាល់គ្នា និងបួនស្រីភីបេ ដែលជាអ្នកបម្រើម្នាក់នៃក្រុមជំនុំនៅក្រុងកេងគ្រា[2]ដើម្បីឲ្យបងប្អូនបានទទួលនាងនៅក្នុងព្រះអម្ចាស់។
សូមធ្វើការនេះ ដើម្បីឲ្យស័ក្តិសមជាអ្នកជឿ ហើយសូមជួយនាងនូវអ្វីដែលនាងត្រូវការជំនួយពីអ្នក។ ព្រោះនាងខ្លួនឯងបានជាជួយដល់កិច្ចការជាច្រើន
ហើយបានជួយដល់ខ្ញុំផងដែរ។
[3]សូមសួរសុខទុក្ខទៅនាងព្រីស៊ីល និងលោកអគីឡាផង ពួកគាត់គឺជាបងប្អូនរួមការងារជាមួយខ្ញុំនៅក្នុងព្រះគ្រិស្តយេស៊ូ[4]ពួកគេបានប្រថុយជីវិតរបស់ពួកគេសម្រាប់ជីវិតខ្ញុំ។
ខ្ញុំអរគុណដល់ពួកគេ ហើយមិនគ្រាន់តែខ្ញុំទេ ប៉ុន្តែ រួមទាំងក្រុមជំនុំរបស់សាសន៍ដទៃទាំងអស់ផងដែរ។[5]សូមសួរសុខទុក្ខដល់ក្រុមជំនុំដែលនៅផ្ទះរបស់ពួកគេដែរ។
សូមសួរសុខទុក្ខដល់លោកអេប៉ែណែតជាទីស្រឡាញ់របស់ខ្ញុំផង គាត់គឺជាផលដំបូងរបស់អាស៊ីថ្វាយដល់ព្រះគ្រិស្ត។
[6]សូមសួរសុខទុក្ខដល់នាងម៉ារី ដែលខំប្រឹងធ្វើការយ៉ាងខ្លាំងសម្រាប់អ្នករាល់គ្នា។[7]សូមសួរសុខទុក្ខដល់រលោកអាន់ត្រូនីក និងនាងយូនាស ជាញាតិសណ្តានរបស់ខ្ញុំ
និងជាអ្នកជាប់គុកជាមួយខ្ញុំដែរ។ ពួកគេមានកេរ្តិ៍ឈ្មោះល្អនៅក្នុងចំណោមពួកសាវក ដែលបាននៅក្នុងព្រះគ្រិស្តមុនខ្ញុំ។[8]សូមសួរសុខទុក្ខដល់លោក
អាំភ្លាសជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះអម្ចាស់ផង។
[9]សូមសួរសុខទុក្ខដល់លោកអ៊ើបាន ជាអ្នករួមការងារជាមួយយើងនៅក្នុងព្រះគ្រិស្ត និងលោកស័តាឃីសជាទីស្រឡាញ់ផង។[10]សូមសួរសុខទុក្ខដល់លោកអពេលេស
ដែលបានជឿជាក់នៅក្នុងព្រះគ្រិស្ត។ សូមសួរសុខទុក្ខដល់បងប្អូនដែលនៅក្នុងក្រុមគ្រួសាររបស់លោកអើរីស្តូប៊ូលផង។[11]សូមសួរសុខទុក្ខដល់លោកហេរ៉ូឌានជាញាតិ
សណ្តានរបស់ខ្ញុំ។ សូមសួរសុខទុក្ខដល់បងប្អូនដែលនៅក្នុងគ្រួសារលោកណើគីស ដែលនៅក្នុងព្រះអម្ចាស់។
[12]សូមសួរសុខទុក្ខដល់នាងទ្រីភែន និងនាងទ្រីផូស ដែលធ្វើការយ៉ាងខ្លាំងនៅក្នុងព្រះអម្ចាស់។ សូមសួរសុខទុកដល់នាងពើស៊ីសជាទីស្រឡាញ់ផង
នាងខំប្រឹងធ្វើការយ៉ាងខ្លាំងនៅក្នុងព្រះអម្ចាស់។[13]សូមសួរសុខទុក្ខដល់លោករូភូស ដែលបានជ្រើសរើសនៅក្នុងព្រះអម្ចាស់ និងដល់ម្តាយរបស់គាត់ និងម្តាយរបស់ខ្ញុំដែរ។
[14]សូមសួរសុខទុក្ខដល់លោកអស៊ុងគ្រីត លោកផ្លេគូន លោកហ៊ើម៉ាស លោកប៉ាត្រូបាស លោកហ៊ើមេស និងបងប្អូនដែលនៅជាមួយគេ។

generated on Wed Sep 10 16:16:32 2025

[15]សូមសួរសុខទុក្ខដល់លោកភីឡូឡុក នាងយូលាស លោកនេរើស និងប្អូនស្រីរបស់គាត់ ព្រមទាំងលោកអូលីមប៉ាស បុងបងប្អូនអ្នកជឿទាំងអស់ដែលនៅជាមួយពួកគេ។
[16]សូមបងប្អូនជំរាបសួរគ្នាទៅវិញទៅមកដោយស្និទ្ធស្នាលផង។ ក្រុមជំនុំទាំងអស់របស់ព្រះគ្រិស្ត សូមជំរាបសួរមកបងប្អូន។
[17]ឥឡូវនេះ ខ្ញុំសូមដាស់តឿនដល់អ្នករាល់គ្នា បងប្អូនអើយ សូមគិតពីអ្នកដែលធ្វើឲ្យបងប្អូនបាក់បែក និងមានការរវាតចិត្ត។
ពួកគេបានធ្វើហួសពីសេចក្តីបង្រៀនដែលបងប្អូនបានរៀនហើយ។ ចូរបែរចេញឲ្យឆ្ងាយពីពួកគេ។[18]ព្រោះមនុស្សបែបនេះ
ពួកគេមិនបានបម្រើព្រះអម្ចាស់នៃយើងគឺព្រះគ្រិស្តទេ ប៉ុន្តែ សម្រាប់ក្រពះរបស់ពួកគេវិញ។ ពួកគេបោកប្រាសដួងចិត្តរបស់មនុស្សទៀងត្រង់ តាមរយៈសំដីស្រទន់
និងពាក្យបញ្ជាររបស់ពួកគេ។
[19]ដ្បិត គំរូនៃការស្តាប់បង្គាប់របស់បងប្អូនបានទៅលើមនុស្សគ្រប់គ្នាហើយ។ ដូច្នេះហើយបានជាខ្ញុំមានអំណរចំពោះបងប្អូន ប៉ុន្តែ ខ្ញុំចង់ឲ្យបងប្អូនមានប្រាជ្ញា
ចំពោះអ្វីដែលល្អ និងល្ងង់ចំពោះអ្វីដែលអាក្រក់វិញ។[20]ព្រះនៃសេចក្តីសុខសាន្តនឹងជាន់ក្បាលសាតាំងនៅក្រោមជើងរបស់អ្នក។
សូមឲ្យព្រះគុណរបស់ព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើងនៅជាមួយអ្នករាល់គ្នា។
[21]លោកធីម៉ូថេ អ្នករួមការងារជាមួយខ្ញុំ ផ្តាំសួរសុខទុក្ខដល់បងប្អូន និងលោកលូគាស លោកយ៉ាសូន និងលោកសូសិប៉ាត្រុស ដែលជាញាតិសណ្តានរបស់ខ្ញុំផងដែរ។[22]ខ្ញុំ
ទើទាស ជាអ្នកសរសេរសំបុត្រនេះ សូមផ្តាំសួរសុខទុក្ខដល់បងប្អូននៅក្នុងព្រះអម្ចាស់ផងដែរ។
[23]លោកកៃយុស បានទទួលខ្ញុំ និងក្រុមជំនុំទាំងមូលផ្តាំសួរសុខទុក្ខបងប្អូន។ លោកអេរ៉ាស្ទុស ជាហិរញ្ញិករបស់ក្រុង
សូមផ្តាំសួរសុខទុក្ខមកបងប្អូនជាមួយនឹងបងប្រុសរបស់លោកក្លើតុសដែរ។[24]សូមឲ្យបងប្អូនបានប្រកបដោយព្រះគុណរបស់ព្រះយេស៊ូ ជាព្រះអម្ចាស់របស់យើង អាម៉ែន។
[25]ឥឡូវនេះ សូមថ្វាយសិរីល្អដល់ព្រះដែលធ្វើឲ្យអ្នកអាចឈរស្របតាមដំណឹងល្អរបស់ខ្ញុំ និងការប្រកាសរបស់ខ្ញុំអំពីព្រះយេស៊ូគ្រិស្តស្របតាម
ការបើកសម្តែងនៃអាថ៌កំបាំងដែលបានលាក់តាំងពីយូរយារណាស់មកហើយ[26]ប៉ុន្តែ ឥឡូវនេះ បានបើកសម្តែងហើយ
ដោយតាមរយៈសេចក្តីទំនាយដែលបានសរសេរបានធ្វើឲ្យប្រជាជាតិទាំងអស់បានដឹង ស្របតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ដ៏នូវអស់កល្ប
ដើម្បីឲ្យពួកគេបានស្តាប់បង្គាប់ដោយជំនឿ។
[27]សូមថ្វាយព្រះជាម្ចាស់ដែលមានប្រាជ្ញាតែមួយអង្គគត់ បានប្រកបដោយសិរីល្អ តាមរយៈព្រះយេស៊ូគ្រិស្ត អស់កល្បជានិច្ច។ អាមែន។

Romans 16:1
ប្រយោគភ្ជាប់
បន្ទាប់មក
លោកប៉ូលបានលើកសរសើរបងប្អូនអ្នកជឿក្នុងក្រុងរ៉ូមដោយចំៗឈ្មោះជាច្រើននាក់។
ខ្ញុំសូមសរសើរដល់អ្នករាល់គ្នា និងប្អូនស្រីភីបេ
«ខ្ញុំចង់ឲ្យបងប្អូន គោរពប្អូនស្រីភីបេ»។
ភីបេ
នេះជាឈ្មោះរបស់ស្ត្រីម្នាក់។
ប្អូនស្រីរបស់យើង
ពាក្យ «របស់យើង» សំដៅដល់ លោកប៉ូល និងអ្នកជឿទាំងអស់។
ការបកប្រែតាមរបៀបផ្សេងទៀត: «បងប្អូនស្រីរបស់យើងនៅក្នុងព្រះគ្រិស្ត»។
ក្រុងកេងគ្រា
ក្រុងនេះធ្លាប់ជាក្រុងកំពង់ផែសមុទ្រ ក្នុងប្រទេស ក្រិក។
ទទួលនាងនៅក្នុងព្រះអម្ចាស់
លោកប៉ូលលើកទឹកចិត្តអ្នកជឿនៅក្រុងរ៉ូម ឲ្យទទួលស្វាគមន៍នាងភីបេ
ជាអ្នកជឿម្នាក់។ ការបកប្រែផ្សេងទៀត: «ចូលទទួលស្វាគមន៍នាង
ព្រោះយើងទាំងអស់គ្នាជារបស់ព្រះជាម្ចាស់»។
ដើម្បីឲ្យស័ក្តិសមជាអ្នកជឿ
«អ្នកជឿគួរតែទទួលស្វាគមន៍អ្នកជឿដទៃទៀត»។
ហើយសូមជួយនាង
លោកប៉ូលលើកទឹកចិត្តអ្នកជឿសាសន៍រ៉ូម ឲ្យផ្តល់នូវអ្វីដែលនាងត្រូវការ។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ហើយជួយនាងដោយផ្តល់អោយនាងគ្រប់យ៉ាងដែលនាងត្រូវការ»
នាងខ្លួនឯងបានជាជួយដល់កិច្ចការជាច្រើន ហើយបានជួយដល់ខ្ញុំផងដែរ
«បានជួយមនុស្សជាច្រើន ហើយនាងក៏បានជួយខ្ញុំផងដែរ»។
Romans 16:3
នាងព្រីស៊ីល និងលោកអគីឡា
នាងព្រីស៊ីល គឺជាប្រពន្ធរបស់លោកអគីឡា។
ជាបងប្អូនរួមការងារជាមួយខ្ញុំនៅក្នុងព្រះគ្រិស្តយេស៊ូ
ពាក្យ «រួមការងារ» របស់លោកប៉ូល ជាមនុស្សដែលប្រាប់អ្នកដទៃអំពីព្រះយេស៊ូ។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកដែលធ្វើការជាមួយខ្ញុំ
ដើម្បីប្រាប់មនុស្សអំពីព្រះគ្រិស្តយេស៊ូ»។
សូមសួរសុខទុក្ខដល់ក្រុមជំនុំដែលនៅផ្ទះរបស់ពួកគេដែរ
«សូមសួរសុខទុក្ខដល់អ្នកជឿទាំងអស់ដែលជួបជុំគ្នានៅផ្ទះរបស់ពួកគេដើម្បីថ្វាយបង្គំ»។
លោកអេប៉ៃណែត
នេះជាឈ្មោះរបស់បុរសម្នាក់។
ផលដំបូងរបស់អាស៊ីថ្វាយដល់ព្រះគ្រិស្ត
លោកប៉ូលមានប្រសាសន៍អំពីលោក អេប៉ៃណែត
ដែលជាផលដំបូងដែលលោកបានច្រូតកាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សដំបូង ក្នុងអាស៊ី ដែលជឿលើព្រះយេស៊ូ»។

Romans 16:6
នាងម៉ារី
ជាឈ្មោះរបស់ស្ត្រីម្នាក់។
អាន់ត្រូនីក...លោកអាំភ្លាស
ជាឈ្មោះរបស់មនុស្សប្រុស។
យូនាស
ជាឈ្មោះរបស់ស្ត្រីម្នាក់។
ពួកគេមានកេរ្តិ៍ឈ្មោះល្អនៅក្នុងចំណោមពួកសាវក
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ របៀបលផ្សេងទៀតនៃការបកប្រែ:
«ពួកសាវក ស្គាល់ពួកគេយ៉ាងច្បាស់»។
ជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះអម្ចាស់ផង
«មិត្តសម្លាញ់របស់ខ្ញុំ និង បងប្អូនរួមជំនឿ»។
Romans 16:9
អ៊ើបាន់...ស័តាយីស...អពេលេស ..អើរិស្តូប៊ូល...ហេរ៉ូឌាន...ណើគីស
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
ដែលបានជឿជាក់នៅក្នុងព្រះគ្រិស្ត
ពាក្យ «បានជឿជាក់»
សំដៅដល់នរណាម្នាក់ដែលបានសាកល្បងនិងបានបង្ហាញថាពិតប្រាកដមែន។
ការបកប្រែតាមរបៀបផ្សេងទៀត: «អ្នកណាដែលព្រះគ្រិស្តបានជឿជាក់»។
ដែលនៅក្នុងព្រះអម្ចាស់
សំដៅដល់អស់អ្នកដែលទុកចិត្តលើព្រះយេស៊ូ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ដែលជាអ្នកជឿ» ឬ «អ្នកដែលជារបស់ព្រះជាម្ចាស់»។
Romans 16:12
ទ្រីភែន...ទ្រីផូស...ពើស៊ីស
ទាំងនេះគឺជាឈ្មោះរបស់មនុស្សស្រី។
រូភូស...អស៊ីងគ្រីត...ផ្លេគូន...ហ៊ើម៉ាស....ប៉ាត្រូបាស...ហ៊ើមេស
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
បានជ្រើសរើសនៅក្នុងព្រះអម្ចាស់
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកដែលត្រូវបានព្រះអម្ចាស់ជ្រើសរើស» ព្រោះគុណសម្បត្តិដ៏ពិសេស។
ម្តាយរបស់គាត់ និងម្តាយរបស់ខ្ញុំ
លោកប៉ូលនិយាយពីម្តាយរបស់លោករូភូស ដែលទុកដូចជាម្តាយរបស់លោក។
ការបកប្រែតាមរបៀបផ្សេងទៀត: «ម្តាយរបស់គាត់
ដែលខ្ញុំគិតថាដូចជាម្តាយរបស់ខ្ញុំ»។
បងប្អូន
នៅទីនេះសំដៅដល់គ្រិស្តបរិស័ទ ដែលរួមបញ្ចូលទាំងបុរស ទាំងស្ត្រី
Romans 16:15
ភីឡូឡូក...នេរើស ...អូលីមប៉ាស
ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។
យូលាស

generated on Wed Sep 10 16:16:32 2025

ជាឈ្មោះរបស់ស្ត្រីម្នាក់។ យូលាស ប្រហែលជាភរិយារបស់លោកភីឡូឡូគូស។
ដោយស្និទ្ធស្នាល
គឺជាការបង្ហាញក្តីស្រលាញ់សម្រាប់អ្នកជឿ។
ក្រុមជំនុំទាំងអស់របស់ព្រះគ្រិស្ត សូមជម្រាបសួរមកបងប្អូន
លោកប៉ូលមានប្រសាសន៍ក្នុងលក្ខណទូទៅទាក់ទងនឹងក្រុមជំនុំរបស់ព្រះគ្រិស្ត។
ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកជឿក្នុងក្រុមជំនុំទាំងអស់ក្នុងតំបន់នេះធ្វើការជម្រាបសួររបស់ពួកគេមកកាន់បងប្អូន»។
Romans 16:17
ប្រយោគភ្ជាប់
លោកប៉ូលផ្តល់ការដាស់តឿនចុងក្រោយដល់អ្នកជឿអំពី ភាពសាមគ្គី
និងការរស់នៅសម្រាប់ព្រះជាម្ចាស់។
បងប្អូន
នៅទីនេះសំដៅដល់គ្រិស្តបរិស័ទ ដែលរួមបញ្ចូលទាំងបុរស និងស្ត្រី។
គិតពីអ្នក
«មើលសម្រាប់»។
ដែលធ្វើឲ្យបងប្អូនបាក់បែក និងមានការរារាតចិត្ត
ឃ្លានេះសំដៅដល់អស់អ្នកដែលឈ្លោះប្រកែក
និងធ្វើឲ្យពួកគេឈប់ទុកចិត្តលើព្រះយេស៊ូ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«អ្នកណាដែលធ្វើឲ្យអ្នកជឿទាស់ទែងជាមួយអ្នកដទៃ
និងឈប់មានជំនឿលើព្រះជាម្ចាស់»។
ពួកគេបានធ្វើហួសពីសេចក្តីបង្រៀនដែលបងប្អូនបានរៀនហើយ
«ពួកគេបង្រៀន ការដែលមិនយល់ព្រមជាមួយសេចក្តីពិត
ដែលអ្នកបានរៀនរួចហើយ»។
ចូរបែរចេញឲ្យឆ្ងាយពីពួកគេ
«ចូរនៅឲ្យឆ្ងាយពីពួកគេ»។
ប៉ុន្តែ សម្រាប់ក្រពះរបស់ពួកគេវិញ
ពាក្យ «ក្រពះ» នៅទីនេះ ជានិយមធៀបដែលសំដៅដល់បំណងប្រាថ្នាសាច់ឈាម។
ការបម្រើក្រពះ តំណាងឲ្យការបំពេញបំណងប្រាថ្នារបស់ពួកគេ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ
ពួកគេចង់ត្រឹមតែបំពេញបំណងប្រាថ្នាខាងសាច់ឈាមរបស់ពួកគេ»។ (សូមមើល: និង)
តាមរយៈសំដីស្រទន់ និងពាក្យបញ្ជោររបស់ពួកគេ
ពាក្យ «សម្តីស្រទន់» និង «ពាក្យបញ្ជោរ» មានន័យជាគោលដូចគ្នា។
លោកប៉ូលបញ្ជាក់ពីរបៀបដែលមនុស្សទាំងនេះ ទទួលអ្នកជឿ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដោយនិយាយការដែលហាក់ដូចជាល្អ និងពិត»
។
ទៀងត្រង់
ពាក្យនេះសំដៅដល់អស់អ្នកដែលធម្មតា គ្មានបទពិសោធន៍ ហើយ គ្មានកិច្ចកល្។
ការបកប្រែតាមរបៀបផ្សេងទៀត:
«អស់អ្នកដែលទុកចិត្តពួកគេដោយចិត្តទៀងត្រង់» ឬ «អស់អ្នកដែលមិនដឹង
ថាគ្រូទាំងនេះ ដែលបំភាន់ពួកគេ»។
Romans 16:19
គំរូនៃការស្តាប់បង្គាប់របស់បងប្អូនបានទៅលើមនុស្សគ្រប់គ្នាហើយ
នៅទីនេះលោកប៉ូលមានប្រសាសន៍អំពីការស្តាប់បង្គាប់របស់អ្នកជឿសាសន៍រ៉ូម
ដែលដូចជាមនុស្សដែលអាចទៅដល់មនុស្សគ្រប់គ្នា។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ដ្បិតមនុស្សគ្រប់គ្នាបានឮពីរបៀបដែលអ្នកស្តាប់បង្គាប់ព្រះជាម្ចាស់»។
ព្រះនៃសេចក្តីសុខសាន្តនឹងជាន់ក្បាលសាតាំងនៅក្រោមជើងរបស់អ្នក
ឃ្លា «កម្ទេចនៅក្រោមជើងរបស់អ្នក» សំដៅដល់ជោគជ័យពេញលេញលើសត្រូវ។
នៅទីនេះលោកប៉ូលនិយាយពីជ័យជម្នះរបស់អ្នកជឿក្រុងរ៉ូមលើសាតាំង
ដោយជាន់នៅក្រោមជើងរបស់ពួកគេ។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ក្នុងពេលដ៏ខ្លី
ព្រះជាម្ចាស់នឹងប្រទានសេចក្តីសុខសាន្តនិងភាពជោគជ័យទាំងស្រុងលើសាតាំង»។
លូង់ចំពោះអ្វីដែលអាក្រក់វិញ
«មិនជាប់ពាក់ព័ន្ធនឹងការធ្វើអាក្រក់»។
Romans 16:21
ប្រយោគភ្ជាប់
លោកប៉ូលផ្តាំផ្ញើការសួរសុខទុក្ខពីអ្នកជឿដែលនៅជាមួយលោក។
លូគាស...លោកយ៉ាសូន...លោកសូសិប៉ាត្រុស...ទើទាស
ទាំងនេះជាឈ្មោះរបស់ប្រុស។
ទើទាស ជាអ្នកដែលសំបុត្រនេះឡើង
លោកទើទាស
គឺជាមនុស្សម្នាក់ដែលបានសរសេរនូវអ្វីដែលលោកប៉ូលបាននិយាយ។
សូមផ្តាំសួរសុខទុក្ខដល់បងប្អូននៅក្នុងព្រះអម្ចាស់ផងដែរ
«សូមផ្តាំសួរសុខទុក្ខដល់បងប្អូនជាអ្នកជឿ»។
Romans 16:23
កៃយុស...អេរ៉ាស្ទុស...ក្លើតុស
ទាំងនេះជាឈ្មោះមនុស្សប្រុស។
បានទទួល
សំដៅដល់លោកកៃយ៉ុស ជាម្ចាស់ផ្ទះដែលលោកប៉ូល
និងអ្នកជឿប្រមូលផ្តុំដើម្បីថ្វាយបង្គំព្រះជាម្ចាស់នៅផ្ទះរបស់លោក។
ហិរញ្ញិក
ជាមនុស្សម្នាក់ដែលថែរក្សាលុយរបស់ក្រុម។
សូមឲ្យបងប្អូនបានប្រកបដោយព្រះគុណរបស់ព្រះយេស៊ូ ជាព្រះអម្ចាស់របស់យើង
ពាក្យ «ព្រះគុណ» នៅទីនេះ
សំដៅដល់ការប្រទានពររបស់ព្រះជាម្ចាស់មកដល់រាស្ត្ររបស់ទ្រង់។
ការបកប្រែតាមរបៀបផ្សេងទៀត:
«សូមព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តបន្តប្រព្រឹត្តដោយសប្បុរសចំពោះអ្នករាល់គ្នា»។
Romans 16:25
ប្រយោគភ្ជាប់
លោកប៉ូលបញ្ចប់ជាមួយការអធិស្ឋានដោយការឲ្យពរ។
ឥឡូវនេះ
ពាក្យ «ឥឡូវនេះ» សម្គាល់ការបិតនៃសំបុត្រ។ អ្នកអាចប្រើវានៅ
ប្រសិនបើអ្នកមានរបៀបនៃការធ្វើបែបនេះក្នុងភាសារបស់អ្នក។
ធ្វើឲ្យអ្នកអាចឈរ
លោកកប៉ូលនិយាយនៅទីនេះដោយមានជំនឿយ៉ាងខ្លាំង
ដូចជាមនុស្សដែលកំពុងឈរ ជំនួសឲ្យការដួលចុះ។
ការបកប្រែតាមរបៀបផ្សេងទៀត: «ដើម្បីធ្វើឲ្យជំនឿរបស់អ្នករឹងមាំឡើង»។
ស្របតាមដំណឹងល្អរបស់ខ្ញុំ និងការប្រកាសរបស់ខ្ញុំអំពីព្រះយេស៊ូគ្រិស្ត
«ដោយសារដំណឹងល្អ ដែលខ្ញុំបានប្រកាសអំពីព្រះយេស៊ូគ្រីស្ត»។
ស្របតាម ការបើកសម្តែងនៃអាថ៌កំបាំងដែលបានលាក់តាំងពីយូរយារណាស់មកហើយ
លោកប៉ូលបាននិយាយថា
ព្រះជាម្ចាស់បានបើកសម្តែងអំពីការលាក់កំបាំងសេចក្តីពិត ដល់អ្នកជឿ។
លោកនិយាយពីសេចក្តីពិតទាំងនេះដូចជាការអាថ៌កំបាំង។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត:
«ព្រោះព្រះជាម្ចាស់មានបើកសម្តែងឲ្យយើងជាអ្នកជឿ
នូវការអាថ៌កំបាំងដែលទ្រង់បានរក្សាទុកអស់រយៈពេលជាយូមកហើយ»។
ប៉ុន្តែ ឥឡូវនេះ បានបើកសម្តែងហើយ
ដោយតាមរយៈសេចក្តីទំនាយដែលបានសរសេរបានធ្វើឲ្យប្រជាជាតិទាំងអស់បានដឹង
ស្របតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ដ៏នូវអស់កល្ប
កិរិយាសព្ទ «បើកសម្តែង» និង «បានធ្វើឲ្យដឹង» មានន័យជាគោលដូចគ្នា។
លោកប៉ូលប្រើប្រយោគទាំងពីរនេះដើម្បីបញ្ជាក់គោលបំណងរបស់លោក។
អ្នកអាចសរុបប្រយោគទាំងពីរនេះ ហើយបកប្រែក្នុងទម្រង់សកម្ម។
ការបកប្រែតាមរបៀបផ្សេងទៀត: «ប៉ុន្តែ ឥឡូវនេះ ព្រះដ៏អស់កល្ប
បានបើកឲ្យដឹងតាមរយៈបទគម្ពីរ»។
ដើម្បីឲ្យពួកគេបានស្តាប់បង្គាប់ដោយជំនឿ
ពាក្យ «ស្តាប់បង្គាប់» និង «ជំនឿ» នៅទីនេះជានាមអរូប។
អ្នកអាចបកប្រែឃ្លានេះក្នុងទម្រង់សកម្ម។ ការបកប្រែតាមរបៀបផ្សេងទៀត: «ដូច្នេះ
គ្រប់ជាតិសាសន៍ទាំងអស់ នឹងស្តាប់បង្គាប់ព្រះជាម្ចាស់ ព្រោះពួកគេទុកចិត្តទ្រង់»។
Romans 16:27
សូមថ្វាយព្រះជាម្ចាស់ដែលមានប្រាជ្ញាតែមួយអង្គគត់ បានប្រកបដោយសិរីល្អ
តាមរយៈព្រះយេស៊ូគ្រិស្ត អស់កល្បជានិច្ច។ អាម៉ែន
ឃ្លា «តាមរយៈព្រះយេស៊ូគ្រិស្ត» សំដៅដល់អ្វី ដែលព្រះយេស៊ូបានធ្វើ។
ប្រកបដោយ «សិរីរុងរឿង» មានន័យថា សរសេីរព្រះជាម្ចាស់។
ការបកប្រែតាមរបៀបផ្សេងទៀត:
«ដោយសារអ្វីៗដែលព្រះយេស៊ូគ្រិស្តបានធ្វើសម្រាប់យើង
យើងនឹងសសើរតម្កើងព្រះអង្គតែមួយគត់
និងជាព្រះអម្ចាស់ដែលមានប្រាជ្ញាតែមួយអង្គគត់ អស់កល្បជានិច្ច អាម៉ែន។

generated on Wed Sep 10 16:16:32 2025

១ កូរិនថូស

1 [1]ខ្ញុំ ប៉ូលជាអ្នកដែលព្រះយេស៊ូបានត្រាស់ហៅឲ្យធ្វើជាសាវ័ក តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងលោកសូស្ថែន
ជាបងប្អូនរបស់យើង[2]ជូនចំពោះក្រុមជំនុំនៅទីក្រុងកូរិនថូស និងអស់អ្នកដែលបានប្រោសជាវិសុទ្ធនៅក្នុងព្រះគ្រិស្តយេស៊ូ
ជាអ្នកដែលបានទទួលការត្រាស់ហៅឲ្យក្លាយជាប្រជាជនដ៏វិសុទ្ធ។ ពួកយើងក៏សូមធ្វើសំបុត្រនេះទៅកាន់អស់អ្នក
ដែលទូលអង្វររកព្រះនាមនៃព្រះអម្ចាស់យេស៊ូគ្រិស្តនៅគ្រប់ទីកន្លែង ព្រះអង្គជាព្រះអម្ចាស់របស់បងប្អូនទាំងនោះ ហើយក៏ជាព្រះអម្ចាស់របស់យើងដែរ។[3]សូមឲ្យព្រះគុណ
និងសេចក្តីសុខសាន្តបានដល់បងប្អូន ពីព្រះជាម្ចាស់បិតារបស់យើង និងព្រះអម្ចាស់យេស៊ូគ្រិស្ត។
[4]ខ្ញុំតែងតែអរព្រះគុណដល់ព្រះជាម្ចាស់របស់ខ្ញុំដើម្បីបងប្អូនជានិច្ច ដោយព្រោះតែព្រះគុណនៃព្រះជាម្ចាស់ ដែលព្រះគ្រិស្តយេស៊ូបានផ្តល់ឲ្យបងប្អូន។
[5]ព្រះអង្គបានធ្វើឲ្យបងប្អូនចម្រើនឡើងគ្រប់ទាំងផ្លូវ ទាំងពាក្យសម្តី និងការចេះដឹង[6]ដូចជាទីបន្ទាល់អំពីព្រះគ្រិស្តដែលបានបញ្ជាក់ពីសេចក្តីពិត នៅក្នុងចំណោមបងប្អូនដែរ។
[7]ដូច្នេះហើយ បងប្អូនមិនខ្វះអំណោយទានខាងឯវិញ្ញាណណាមួយឡើយ ដូចជាអ្វីដែលបងប្អូនចង់បាន
និងរង់ចាំការបើកសម្តែងរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើងឡើយ។[8]ព្រះអង្គនឹងចម្រើនកម្លាំងដល់បងប្អូនដើម្បីឲ្យដល់ទីបំផុត ដូច្នេះ បងប្អូននឹងរកកន្លែងបន្ទោសគ្មាន
នៅថ្ងៃនៃព្រះអម្ចាស់យេស៊ូគ្រិស្ត។[9]ព្រះជាម្ចាស់ស្មោះត្រង់ ដែលបានត្រាស់ហៅបងប្អូនចូលមកប្រកបរួមជាមួយព្រះបុត្រារបស់ព្រះអង្គ
ព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង។
[10]ឥឡូវនេះ បងប្អូនអើយខ្ញុំសូមទូន្មានអ្នករាល់គ្នា តាមរយៈព្រះនាមនៃព្រះអម្ចាស់យេស៊ូគ្រិស្ត ចូលឲ្យអ្នកព្រមព្រៀងគ្នា
ហើយក៏កុំឲ្យមានការបាក់បែកនៅក្នុងចំណោមបងប្អូនដែរ។ ត្រូវរួបរួមគ្នានិងមានគំនិតតែមួយ ព្រមទាំងមានគោលដៅតែមួយផង។[11]បងប្អូនអើយ តាមរយៈក្រុមគ្រួសារ
របស់នាងក្លូអេ ខ្ញុំបានឮដំណឹងថាមានកើតការទាស់ទែងគ្នាក្នុងចំណោមបងប្អូន។
[12]ខ្ញុំនិយាយដូច្នេះ ដោយព្រោះ បងប្អូនម្នាក់ៗបាននិយាយថា៖ «ខ្ញុំនៅខាងលោកប៉ូល» ឬ «ខ្ញុំនៅជាមួយលោកអប៉ូឡូស» ឬ «ខ្ញុំនៅជាមួយលោកកេផាស» ឬ
«ខ្ញុំនៅជាមួយព្រះគ្រិស្ត»។[13]តើព្រះគ្រិស្តបានបែងចែកទេ? តើប៉ូលបានជាប់ឆ្កាងសម្រាប់អ្នកមែនទេ? តើអ្នករាល់គ្នាទទួលពិធីជ្រមុជទឹកនៅក្នុងឈ្មោះរបស់ប៉ូលមែនទេ?
[14]ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលខ្ញុំមិនបានធ្វើពិធីជ្រមុជទឹកឲ្យអ្នកម្នាក់នៅក្នុងចំណោមបងប្អូនឡើយ លើកលែងតែលោកគ្រីសប៉ុស និងលោកកៃយុសប៉ុណ្ណោះ។
[15]បើដូច្នេះ គឺគ្មានអ្នកណាអាចនិយាយថា អ្នកត្រូវបានជ្រមុជទឹកដោយឈ្មោះខ្ញុំឡើយ។[16](ខ្ញុំក៏បានធ្វើពិធីជ្រមុជទឹកជូនក្រុមគ្រួសាររបស់លោកស្ទេផាណាសដែរ។
ក្រៅពីនេះ ខ្ញុំមិនដឹងថា តើខ្ញុំបានជ្រមុជទឹកឲ្យអ្នកណាទៀតទេ)។
[17]ដ្បិត ព្រះគ្រិស្តមិនបានចាត់ខ្ញុំមក ដើម្បីធ្វើពិធីជ្រមុជទឹកនោះទេ ប៉ុន្តែ ចាត់ខ្ញុំមកប្រកាសដំណឹងល្អវិញ។ ព្រះអង្គមិនបានចាត់ខ្ញុំឲ្យមកដើម្បីប្រកាសដោយប្រើពាក្យ
និងប្រាជ្ញារបស់មនុស្សឡើយ បើដូច្នេះមែន ឈើឆ្កាងនៃព្រះគ្រិស្តនឹងទៅជាអស់ន័យហើយ។
[18]ដ្បិត ព្រះបន្ទូលអំពីឈើឆ្កាងគឺលីលា សម្រាប់អ្នកដែលកំពុងតែស្លាប់។ ប៉ុន្តែ ក្នុងចំណោមអ្នកដែលបានសង្គ្រោះ គឺជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់វិញ។
[19]ដ្បិតមានសេចក្តីចែងទុកមកថា៖ «យើងនឹងបំផ្លាញប្រាជ្ញារបស់អ្នកប្រាជ្ញ។ ខ្ញុំក៏នឹងធ្វើឲ្យតម្រិះរបស់ពួកអ្នកចេះដឹងរលាយសាបសូន្យទៅដែរ»។
[20]តើអ្នកប្រាជ្ញនៅឯណា? តើអ្នកមានវិជ្ជាជ្រៅជ្រះនៅឯណា? តើអ្នកតទល់សម្តីក្នុងលោកនេះនៅឯណា? តើព្រះជាម្ចាស់មិនបានធ្វើឲ្យប្រាជ្ញានៃលោកីយ៍នេះទៅជាលីលា
វិញទេឬអី?[21]តាមរយៈប្រាជ្ញារបស់លោកីយ៍ មិនអាចស្គាល់ព្រះជាម្ចាស់បានទេ ប៉ុន្តែ ព្រះអង្គសព្វព្រះហឫទ័យជាពាក្យលីលានៃការប្រកាសដំណឹងល្អនេះវិញ
ដើម្បីសង្គ្រោះដល់អ្នកណាដែលជឿវិញ។
[22]ដ្បិត សាសន៍យូដា ចង់តែឃើញទីសម្គាល់ និងការអស្ចារ្យទេ ហើយសាសន៍ក្រិកចង់ស្វែងរកប្រាជ្ញា។[23]ប៉ុន្តែ ពួកយើងវិញ ប្រកាសអំពីព្រះគ្រិស្តសុគតនៅលើឈើឆ្កាង
ធ្វើឲ្យសាសន៍យូដារវាតចិត្ត ហើយសាសន៍ក្រិកថាជាភាពលីលាទៅវិញ។
[24]ប៉ុន្តែ សម្រាប់អស់អ្នកដែលព្រះជាម្ចាស់បានត្រាស់ហៅ ទោះជាសាសន៍យូដា ឬក្រិកក្តី គឺយើងប្រកាសពីព្រះគ្រិស្តជាឫទ្ធានុភាព និងប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។
[25]ដ្បិត ភាពលីលារបស់ព្រះគឺជាប្រាជ្ញារបស់មនុស្ស ហើយភាពខ្សោយនៃព្រះជាម្ចាស់ ខ្លាំងជាងកម្លាំងមនុស្សទៅទៀត។
[26]បងប្អូនអើយ សូមមើលពីការត្រាស់ហៅរបស់អ្នក។ ក្នុងចំណោមបងប្អូន មិនសូវមានអ្នកមានប្រាជ្ញាកម្រិតខ្ពង់ខ្ពស់ក្នុងលោកនេះទេ។
ក៏មិនសូវមានបងប្អូនមានតួនាទីធំដែរ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាមានត្រកូលខ្ពស់ផង។[27]ប៉ុន្តែ ព្រះអង្គជ្រើសរើសការលីលានៅក្នុងលោក
សម្រាប់ឲ្យអ្នកប្រាជ្ញខ្មាស។ ព្រះជាម្ចាស់ជ្រើសរើសអ្វីដែលខ្សោយក្នុងលោក ដើម្បីឲ្យអ្នកខ្លាំងពូកែត្រូវខ្មាសដែរ។
[28]ព្រះជាម្ចាស់បានជ្រើសរើសអ្វីដែលតូចតាច និងអ្វីដែលគេស្អប់ខ្ពើមនៅក្នុងលោកីយ៍នេះ។ ព្រះអង្គក៏ជ្រើសរើស សូម្បីរបស់ដែលគេគិតថាគ្មានតម្លៃ
ដើម្បីនាំការនោះឲ្យរាប់ជាមានតម្លៃបំផុតវិញ។[29]ព្រះជាម្ចាស់ធ្វើដូច្នេះ ដើម្បីកុំឲ្យអ្នកណាមានអំនួតនៅចំពោះព្រះអង្គឡើយ។
[30]ដោយសារអ្វីៗដែលព្រះអង្គបានធ្វើ ពេលនេះអ្នករាល់គ្នាបាននៅក្នុងព្រះគ្រិស្តយេស៊ូ ជាអ្នកដែលនាំប្រាជ្ញាមកដល់យើងពីព្រះជាម្ចាស់។
ព្រះយេស៊ូបានត្រឡប់ទៅជាសេចក្តីសុចរិត និងបានវិសុទ្ធ ព្រមទាំងការលោះបាបរបស់យើងផងដែរ។[31]ជាលទ្ធផល ដូចដែលបទគម្ពីរបានចែងថា៖
«សូមឲ្យអ្នកដែលមានអំនួត ចូរអួតតែពីព្រះអម្ចាស់បានហើយ»។

---

1 Corinthians 1:1

លោកប៉ូល
ក្នុងភាសារបស់អ្នកប្រហែលជាមានរបៀបជាក់លាក់ក្នុងការណែនាំឈ្មោះនៃអ្នកនិពន្ធ។
ការបកប្រែផ្សេងទៀត: «ខ្ញុំ ប៉ូល»។

លោកសូស្ថែន ជាបងប្អូនរបស់យើង
នេះបង្ហាញថាទាំងលោកប៉ូល និងក្រុមជំនុំកូរិនថូសបានស្គាល់លោកសូស្ថែន។
ការបកប្រែផ្សេងទៀត: «លោកសូស្ថែនជាបងប្អូនដែលអ្នក ហើយនឹងខ្ញុំស្គាល់»។

ជូនចំពោះក្រុមជំនុំនៅទីក្រុងកូរិនថូស
ក្នុងភាសារបស់អ្នកប្រហែលជាមានរបៀបជាក់លាក់ក្នុងការណែនាំអំពីសមាជិកនៃក្រុមជំនុំ។
ការបកប្រែផ្សេងទៀត:
«បានសរសេរសំបុត្រនេះទៅបងប្អូនក្នុងក្រុមជំនុំកូរិនថូសអ្នកដែលជឿលើព្រះអម្ចាស់»។

អស់អ្នកដែលបានប្រោសជាវិសុទ្ធនៅក្នុងព្រះគ្រិស្តយេស៊ូ
ពាក្យ «ប្រោសជាវិសុទ្ធ» សំដៅលើមនុស្សដែលព្រះជាម្ចាស់រៀបចំ
និងផ្តល់កិត្តិយសឲ្យ។ ការបកប្រែផ្សេងទៀត:
«អស់អ្នកណាដែលព្រះគ្រិស្តបានញែកទុកសម្រាប់ព្រះជាម្ចាស់» ឬ
«អស់អ្នកណាដែលព្រះជាម្ចាស់បានញែកទុកសម្រាប់អង្គទ្រង់ដោយសារពួកគេជាកម្មសិទ្ធិរបស់ព្រះគ្រិស្ត»។

អ្នកដែលបានទទួលការត្រាស់ហៅឲ្យក្លាយជាប្រជាជនដ៏វិសុទ្ធ
នេះអាចត្រូវបាននិយាយបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«អស់អ្នកដែលព្រះត្រូវបានហៅជាប្រជាជនដ៏វិសុទ្ធ»។

អស់អ្នកដែលទូលអង្វររកព្រះនាមនៃព្រះអម្ចាស់យេស៊ូគ្រិស្ត
ពាក្យ «ព្រះនាម» នៅទីនេះចង់បង្ហាញពីមនុស្សម្នាក់ ជាអង្គព្រះយេស៊ូគ្រិស្ត។
ការបកប្រែផ្សេងទៀត: «អ្នកហៅរកព្រះនាមព្រះយេស៊ូគ្រិស្ត»។

ជាព្រះអម្ចាស់របស់បងប្អូនហើយក៏ជាព្រះអម្ចាស់របស់យើង
ពាក្យថា: «របស់យើង» រួមបញ្ចូលទាំងសមាជិកក្រុមជំនុំរបស់លោកប៉ូលដែរ។
ព្រះយេស៊ូជាព្រះអម្ចាស់របស់លោកប៉ូល ក្រុមជំនុំកូរិនថូស
និងក្រុមជំនុំទាំងអស់ផងដែរ

ព័ត៌មានទូទៅ

លោកប៉ូល
និងលោកសូស្ថែនបានសរសេរសំបុត្រនេះទៅគ្រិស្តបរិស័ទដែលនៅក្នុងក្រុមជំនុំកូរិនថូស។

ព័ត៌មានទូទៅ

ទាល់តែ ត្រូវបានកត់ចំណាំលើពាក្យដូចជា «អ្នក» និង «របស់អ្នក»
សំដៅលើសមាជិកក្រុមជំនុំរបស់លោកប៉ូល ដែលសុទ្ធតែជាពហុវចនៈ។
[illegible]

ប្រយោគភ្ជាប់

generated on Wed Sep 10 16:16:32 2025

លោកប៉ូលពណ៌នាពីតួនាទីរបស់អ្នកជឿ
និងការប្រកបក្នុងព្រះគ្រិស្តនៅពេលពួកគេរង់ចាំការវិលត្រឡប់មកវិញរបស់ទ្រង់។
ដោយព្រោះតែព្រះគុណនៃព្រះជាម្ចាស់ ដែលព្រះគ្រិស្តយេស៊ូបានផ្តល់ឲ្យបងប្អូន
លោកប៉ូលនិយាយពីព្រះគុណ បីដូចជាអ្វីមួយខាងរូបកាយដែល
ព្រះគ្រិស្តឲ្យទៅគ្រិស្តបរិស័ទទាំងអស់ជាអំណោយ។ ការបកប្រែផ្សេងទៀត:
«ដោយសារព្រះេយស៊ូគ្រិស្តដែលអាចបានធ្វើឲ្យព្រះអម្ចាស់មានចិត្តសប្បុរសចំពោះអ្នកមិន
ព្រះអង្គបានធ្វើឲ្យបងប្អូនចម្រើនឡើង
អាចមានន័យដូចជាទី១ «ព្រះគ្រិស្តធ្វើឲ្យបងប្អូនចម្រើន» ទី២
«ព្រះអម្ចាស់ធ្វើឲ្យបងប្អូនចម្រើន»។
ព្រះអង្គបានធ្វើឲ្យបងប្អូនចម្រើនឡើងគ្រប់ទាំងផ្លូវ
លោកប៉ូលកំពុងនិយាយដាទូទៅ។ ការបកប្រែផ្សេងទៀត:
«ធ្វើអោយអ្នកចម្រើនឡើងគ្រប់ព្រះពរខាងវិញ្ញាណ»។
ទាំងពាក្យសំដី
ព្រះអង្គបានអនុញ្ញាតឲ្យអ្នកអាចប្រាប់មនុស្សដទៃៗទៀតពីព្រះបន្ទូលរបស់ព្រះអម្ចាស់តាមរយៈការ
ទាំងការចេះដឹង
ព្រះអង្គបានឲ្យអ្នកអាចយល់ពីព្រះបន្ទូលរបស់ព្រះអម្ចាស់តាមរបៀបផ្សេងៗជាច្រើន។
ទីបន្ទាល់អំពីព្រះគ្រិស្តដែលបានបញ្ជាក់ពីសេចក្តីពិត នៅក្នុងចំណោមបងប្អូន
អាចមានន័យដូចជាទី១
«អ្នកបានឃើញពីខ្លួនរបស់អ្នកផ្ទាស់ពីសេចក្តីពិតដែលយើងបានិយាយអំពីព្រះយេស៊ូ
ទី២ «មនុស្សដទៃទៀតរៀនដោយការមើលពីរបៀបរស់នៅបច្ចុបន្នរបស់បងប្អូន
ដែលពួកយើង និងបងប្អូននិយាយថាព្រះគ្រិស្តជាសេចក្តីពិត»។
1 Corinthians 1:7
ដូច្នេះហើយ
ដោយសារអ្វីដែលខ្ញុំបាននិយាយជាសេចក្តីពិត
បងប្អូនមិនខ្វះអំណោយទានខាងឯវិញ្ញាណទេ
នេះត្រូវបាននិយាយបញ្ជាក់ជាទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត:
«អ្នកមានគ្រប់ទាំងអំណោយទានខាងវិញ្ញាណ»។
ការបើកសម្តែងរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើង
អាចមានន័យដូចជាទី១
«ពេលវេលាដែលព្រះនិងបើកបង្ហាញពីព្រះអម្ចាស់យេស៊ូគ្រិស្ត» ឬ ទី២
«ពេលវេលាដែលព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើងនិងបង្ហាញអង្គទ្រង់»។
នឹងរកកន្លែងបន្ទោសគ្មាន
នឹងមិនមានហេតុផលណាមួយដែលព្រះដាក់ទោសអ្នកឡើយ។
ព្រះជាម្ចាស់ស្មោះត្រង់
ព្រះជាម្ចាស់នឹងធ្វើអ្វីៗដែលទ្រង់បានមានបន្ទូល ហើយទ្រង់នឹងធ្វើ
ព្រះបុត្រារបស់ព្រះអង្គ
នេះជាងាដ៏សំខាន់មួយសម្រាប់ព្រះយេស៊ូ ជាបុត្រារបស់ព្រះ។
1 Corinthians 1:10
ប្រយោគភ្ជាប់
លោកប៉ូលទូន្មានអ្នកជឿនៅក្នុងទីក្រុងកូរិនថូសថា
ពួកគេត្រូវរស់នៅដោយការរួបរួមគ្នាទៅវិញទៅមក
ហើយការសង្គ្រោះបានមកពីការឆ្កាងព្រះយេស៊ូមិនមែនដោយការជ្រមុជទឹកដោយមនុស្ស
បងប្អូនអើយ
នេះមានន័យថាគ្រិស្តបរិស័ទរួមជំនឿ ទាំង បុរស និងស្ត្រី។
តាមរយៈព្រះនាមនៃព្រះអម្ចាស់យេស៊ូគ្រិស្ត
ឈ្មោះនៅទីនេះចង់ផ្តោតលើមនុស្សម្នាក់ជាអង្គព្រះយេស៊ូគ្រិស្ត។
ការបកប្រែផ្សេងទៀត: «ដោយមានន័យថា ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង»។
ចូលឲ្យអ្នកព្រមព្រៀងគ្នា
ដែលអ្នកនិងរស់នៅដោយសុខដុមជាមួយនឹងគ្នា។
ហើយក៏កុំឲ្យមានការបាក់បែកនៅក្នុងចំណោមបងប្អូន
ដោយអ្នកមិនបានបែងចែងជាក្រុមដាច់ដោយឡែកក្នុងចំណោមអ្នករាល់គ្នាឡើយ។
ត្រូវរួបរួមគ្នា និងមានគំនិតតែមួយ ព្រមទាំងមានគោលដៅតែមួយផង
រស់នៅដោយរួបរួមគ្នា។
ក្រុមគ្រួសាររបស់នាងក្លូអេ
នេះសំដៅលើសមាជិកគ្រួសារ អ្នកបម្រើ និង
មនុស្សផ្សេងទៀតដែលជាផ្នែកមួយនៃក្រុមគ្រួសារនាងក្លូអេ
ដែលមានស្ត្រីជាមេគ្រួសារ។
មានកើតការទាស់ទែងគ្នាក្នុងចំណោមបងប្អូន
អ្នកស្ថិតក្នុងក្រុមដែលមានការឈ្លោះប្រកែកគ្នាទៅវិញទៅមក។

1 Corinthians 1:12
បងប្អូនម្នាក់ៗបាននិយាយថា
លោកប៉ូលកំពុងបង្ហាញពីឥរិយាបថទូទៅមួយនៃការបាក់បែក។
តើព្រះគ្រិស្តបានបែងចែកទេ?
លោកប៉ូលចង់បញ្ជាក់ពីសេចក្តីពិតថាព្រះគ្រិស្តមិនបានបែងចែកទេ គឺតែមួយ។
«ដោយសារព្រះេយស៊ូគ្រិស្តដែលអាចបានធ្វើឲ្យព្រះអម្ចាស់មានចិត្តសប្បុរសចំពោះអ្នកមិន អាចបែងចែកព្រះគ្រិស្ត នូវទង្វើរដែលអ្នកធ្វើនោះទេ!»
តើលោកប៉ូលត្រូវបានឆ្កាងសម្រាប់អ្នកមែនទេ?
លោកប៉ូលចង់បញ្ជាក់ថាព្រះគ្រិស្តទេតើ មិនមែនលោកប៉ូល
ឬលោកអប៉ូឡូសដែលត្រូវឆ្កាងនោះទេ។ នេះអាចបកប្រែក្នុងទម្រង់សកម្ម។
ការបកប្រែផ្សេងទៀត:
«វាពិតប្រាកដមិនមែនជាលោកប៉ូលដែលនិងត្រូវពួកគេទុកឲ្យស្លាប់នៅលើឈើឆ្កាងសំរាប់ការសង្គ្រោះនេ
តើអ្នករាល់គ្នាទទួលពិធីជ្រមុជទឹកនៅក្នុងឈ្មោះរបស់លោកប៉ូលមែនទេ?
លោកប៉ូលចង់បញ្ជាក់ថាយើងទាំងអស់ទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។
ការបកប្រែផ្សេងទៀត:
«មិនមែនក្នុងឈ្មោះរបស់លោកប៉ូលទេដែលមនុស្សធ្វើពិធីជ្រមុជទឹកឲ្យអ្នក!»
នៅក្នុងឈ្មោះរបស់ប៉ូល
ពាក្យឈ្មោះនេះចង់ផ្តោតលើ «ដោយសិទ្ធអំណាច» ការបកប្រែផ្សេងទៀត
«ដោយសិទ្ធអំណាចរបស់លោកប៉ូល»។
1 Corinthians 1:14
មិនមែនអ្នក លើកលែងតែ
តែប៉ុណ្ណោះ
លោកគ្រីសប៉ុស
លោកធ្លាប់ជាអ្នកគ្រប់គ្រងសាលាប្រជុំម្នាក់ដែលបានក្លាយជាគ្រិស្តបរិស័ទ។
លោកកៃយុស
លោកធ្លាប់បានធ្វើដំណើរជាមួយសាវ័កប៉ូល។
បើដូច្នេះ គឺគ្មានអ្នកណាអាចនិយាយថា អ្នកត្រូវបានជ្រមុជទឹកដោយឈ្មោះខ្ញុំឡើយ
ទីនេះ «ឈ្មោះ» តំណាងឲ្យ «សិទ្ធិអំណាច»។
នេះមានន័យថាលោកប៉ូលមិនបានធ្វើពិធីជ្រមុជទឹកសម្រាប់អ្នកដទៃដើម្បីឲ្យគេប្រកាសថាពួកគេបានក្លាយ
នេះអាចនិយាយបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«អ្នកខ្លះប្រហែលប្រកាសថាខ្ញុំបានធ្វើពិធីជ្រមុជទឹកអ្នកដើម្បីឲ្យគេក្លាយជាសិស្សរបស់ខ្ញុំ»។
ក្រុមគ្រួសាររបស់លោកស្ទេផាណាស
នេះសំដៅលើសមាជិកក្រុមគ្រួសារ និងអ្នកទាសករនៅក្នុងផ្ទះលោកស្ទេផាណាស
ជាមេគ្រួសារ។
1 Corinthians 1:17
ព្រះគ្រិស្តមិនបានចាត់ខ្ញុំមក ដើម្បីធ្វើពិធីជ្រមុជទឹកនោះទេ
នេះមានន័យថា
ការធ្វើពិធីជ្រមុជទឹកមិនមែនជាគោលដៅអាទិភាពក្នុងព័ន្ធកិច្ចរបស់លោកប៉ូលទេ។
ដោយប្រាជ្ញា... បើដូច្នេះមែន ឈើឆ្កាងនៃព្រះគ្រិស្តនឹងទៅជាអស់ន័យហើយ។
លោកប៉ូលនិយាយថា «ពាក្យ និងប្រាជ្ញារបស់មនុស្ស»
ហាក់បីដូចជាពាក្យទាំងនោះជាពាក្យរបស់មនុស្ស
ហើយឈើឆ្កាងជាកន្លែងដែលផ្ទុកមួយ
និងឃ្នឹងឆ្នាងភាពជាវត្ថុអ្វីមួយដែលព្រះគ្រិស្តបានដាក់ក្នុងកន្លែងដែលបានផ្ទុកនោះ។
នេះត្រូវបាននិយាយបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ពាក្យ
និងប្រាជ្ញារបស់មនុស្ស...ការប្រើពាក្យ
និងប្រាជ្ញារបស់មនុស្សនិងធ្វើឲ្យឈើឆ្កាងនៃព្រះគ្រិស្តនឹងទៅជាអស់ន័យហើយ» ឬ
«ការប្រើ ពាក្យ
និងប្រាជ្ញារបស់មនុស្ស...និងធ្វើឲ្យព្រះបន្ទូលរបស់ព្រះគ្រិស្តលែងមានអ្នកជឿ
និងចាប់ផ្តើមគិតថា ខ្ញុំមានសារសំខាន់ជាងព្រះគ្រិស្ត»។
1 Corinthians 1:18
ប្រយោគភ្ជាប់
លោកប៉ូលបញ្ជាក់ ប្រាជ្ញារបស់ព្រះជាម្ចាស់ ប្រសើរជាងប្រាជ្ញារបស់មនុស្ស។
ព្រះបន្ទូលអំពីឈើឆ្កាង
ជាការអធិប្បាយអំពីការឆ្កាង ឬ
«ព្រះបន្ទូលដែលនិយាយពីការសុគតរបស់ព្រះគ្រិស្តលើឈើឆ្កាង»។
ជាភាពលីលា
មិនដឹងខ្យល់ ឬ «ឆ្កួតលីលា»។
សម្រាប់អ្នកដែលកំពុងតែស្លាប់
ទីនេះ «កំពុងតែស្លាប់» សំដៅលើដំណើរការនៃការស្លាប់ខាងវិញ្ញាណ។
ជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់

generated on Wed Sep 10 16:16:32 2025

ជាឫទ្ធានុភាពដែលព្រះកំពុងធ្វើការក្នុងយើង
យើងនឹងបំផ្លាញប្រាជ្ញារបស់អ្នកប្រាជ្ញ។
យើងនឹងបំផ្លាញប្រាជ្ញារបស់មនុស្សឆ្លាត ឬ
«យើងនឹងធ្វើឲ្យគម្រោងការរបស់មនុស្សឆ្លាតទៅជាបរាជ័យទាំងស្រុង»។
1 Corinthians 1:20
តើអ្នកប្រាជ្ញនៅឯណា? តើអ្នកមានវិជ្ជាជ្រៅជ្រះនៅឯណា?
តើអ្នកតទល់សម្តីក្នុងលោកនេះនៅឯណា?
លោកប៉ូលបញ្ជាក់ថាមនុស្សអ្នកប្រាជ្ញពិតប្រាកដមិនអាចរកឃើញនៅក្នុងកន្លែងណាមួយនៅលើផែនដីទេ។
ការបកប្រែផ្សេងទៀត: «បើប្រៀបធៀបជាមួយប្រាជ្ញានៃដំណឹងល្អ គឺគ្មានអ្នកប្រាជ្ញ
គ្មានអ្នកមានវិជ្ជាជ្រៅជ្រះ គ្មានអ្នកតទល់សម្តីនោះទេ!»
អ្នកមានវិជ្ជាជ្រៅជ្រះ
ជាមនុស្សម្នាក់ដែលត្រូវគេទទួលស្គាល់ថាជាអ្នកបានរៀនសូត្រជ្រៅជ្រះ។
អ្នកតទល់សម្តី
ជាមនុស្សម្នាក់ដែលប្រកែកតវ៉ាពាក្យសម្តី ពីអ្វីដែលខ្លួនបានដឹង ឬ
អ្នកដែលមានជំនាញខាងប្រកែកពាក្យសម្តី។
តើព្រះជាម្ចាស់មិនបានធ្វើឲ្យប្រាជ្ញានៃលោកីយ៍នេះទៅជាលីលាវិញទេឬអី?
លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ពីអ្វីដែលព្រះបានធ្វើចំពោះប្រាជ្ញានៃលោកីយ៍នេះ។
ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានបង្ហាញថាគ្រប់អ្វីៗដែលគេហៅថាប្រាជ្ញានោះពិតជាឆ្កួតលីលាណាស់»។
អ្នកណាដែលជឿ
អាចមានន័យថាទី១ «គ្រប់អ្នកជឿលើព្រះបន្ទូល» ឬ ទី២
«គ្រប់អ្នកជឿក្នុងអង្គព្រះគ្រិស្ត»។
1 Corinthians 1:22
ព័ត៌មានទូទៅ
ពាក្យថា «ពួកយើង» សំដៅលើលោកប៉ូល និងគ្រូបង្រៀនព្រះគម្ពីរដទៃៗទៀត។
ព្រះគ្រិស្តសុគតនៅលើឈើឆ្កាង
អំពីព្រះគ្រិស្តដែលសុគតនៅលើឈើឆ្កាង។
ការជាន់លើរបា
ដូចជាមនុស្សម្នាក់ដែលអាចជាន់លើរបាកាត់ផ្លូវមួយ
ដូច្នេះព្រះបន្ទូលនៃសេចក្តីសង្គ្រោះតាមរយៈការឆ្កាងព្រះយេស៊ូបានធ្វើឲ្យសាសន៍យូដារាប់ឆ្នាំ
ការបកប្រែផ្សេងទៀត: «មិនអាចទទួលយកបាន» ឬ «ពិតជាប្រមាថណាស់»។
1 Corinthians 1:24
សម្រាប់អស់អ្នកដែលព្រះជាម្ចាស់បានត្រាស់ហៅ
ទៅកាន់មនុស្សដែលព្រះបានត្រាស់ហៅ
ព្រះគ្រិស្តជាឫទ្ធានុភាព និងប្រាជ្ញាញាណរបស់ព្រះជាម្ចាស់
អាចមានន័យថាទី១ «ព្រះជាម្ចាស់បញ្ចេញឫទ្ធានុភាព
និងប្រាជ្ញាញាណដោយបញ្ជូនព្រះគ្រិស្តមកសុគតជំនួសយើង» ឬ ទី២
«តាមរយៈព្រះគ្រិស្ត ព្រះជាម្ចាស់បានបង្ហាញភាពខ្លាំង
និងប្រាជ្ញាញាណរបស់ទ្រង់»។
ឫទ្ធានុភាព...នៃព្រះ
អាចមានន័យផ្សេងទៀតថា ព្រះគ្រិស្តមានឫទ្ធានុភាព និងតាមរយៈព្រះគ្រិស្ត
ទើបព្រះជាម្ចាស់សង្គ្រោះយើង។
ប្រាជ្ញានៃព្រះ
អាចមានន័យផ្សេងទៀតថាព្រះអង្គបង្ហាញប្រាជ្ញាញាណរបស់ទ្រង់តាមរយៈព្រះគ្រិស្ត។
ភាពលីលារបស់ព្រះជាម្ចាស់គឺជាប្រាជ្ញារបស់មនុស្ស ហើយភាពខ្សោយនៃព្រះជាម្ចាស់
ខ្លាំងជាងកម្លាំងមនុស្សទៅទៀត។
អាចមានន័យថាទី១ លោកប៉ូលកំពុងនិយាយយ៉ាងហួសចិត្តពីភាពលីលា
និងភាពខ្សោយរបស់ព្រះ។ លោកប៉ូលដឹងថាព្រះជាម្ចាស់មិនលីលា
ឬខ្សោយឡើយ។ ការបកប្រែផ្សេងទៀត:
«អ្វីដែលទំនងជាភាពលីលារបស់ព្រះគឺជាប្រាជ្ញារបស់មនុស្សឆ្លាត
ហើយអ្វីដែលទំនងជាភាពខ្សោយរបស់ព្រះគឺខ្លាំងជាងមនុស្សមានកម្លាំងទៅទៀត»
ឬ ទី២ លោកប៉ូលកំពុងនិយាយរំលឹកពីចំណុចនៃជនជាតិក្រិក
ដែលប្រហែលគិតថាព្រះជាម្ចាស់លីលា ហើយខ្សោយ។ ការបកប្រែផ្សេងទៀត:
«អ្វីដែលមនុស្សនិយាយថាព្រះអង្គលីលានោះមានប្រាជ្ញាជាងមនុស្សដែលប្រាជ្ញាទៅទៀត
ហើយអ្វីដែលមនុស្សនិយាយថាព្រះអង្គខ្សោយ
នោះខ្លាំងជាងមនុស្សដែលមានកម្លាំងទៅទៀត»។
1 Corinthians 1:26
ប្រយោគភ្ជាប់
បានត្រូវបញ្ជាក់ពីតួនាទីរបស់អ្នកជឿនៅចំពោះមុខព្រះ។
មិនសូវមានអ្នក
នេះអាចនិយាយបញ្ជាក់នៅក្នុងទំរង់សកម្ម។ ការបកប្រែផ្សេងទៀត: «តែពីរ
បីនាក់»។
មានប្រាជ្ញាកម្រិតខ្ពង់ខ្ពស់ក្នុងលោកនេះ
អ្វីដែលមនុស្សជាច្រើនហៅថាអ្នកប្រាជ្ញ
ត្រកូលខ្ពស់
ជាពិសេស ដោយសារតែគ្រួសារអ្នក ជាគ្រួសារសំខាន់
ព្រះអង្គជ្រើសរើស....អ្នកប្រាជ្ញ។ ព្រះអង្គជ្រើសរើស...អ្នកខ្លាំង
លោកប៉ូលនិយាយពាក្យដដែលៗនេះនៅក្នុងប្រយោគពីរ
មានន័យថាស្មើរតែដូចគ្នាដើម្បីបញ្ជាក់ពីភាពខុសគ្នារវាងរបៀបរបស់ព្រះក្នុងការធ្វើអ្វីមួយ
និងរបៀបរបស់មនុស្សដែលគិតថាព្រះគួរធ្វើអ្វីមួយ។
ព្រះអង្គជ្រើសរើសការលីលានៅក្នុងលោក សម្រាប់ឲ្យអ្នកប្រាជ្ញខ្មាស់
ព្រះជាម្ចាស់ជ្រើសរើសប្រើមនុស្សដែលលោកីយ៍ថាលីលា
ដើម្បីផ្ចាញ់អស់អ្នកណាដែលលោកីយ៍ថាជាអ្នកប្រាជ្ញ។
ព្រះជាម្ចាស់បានជ្រើសរើសអ្វីដែលខ្សោយក្នុងលោក ដើម្បីឲ្យអ្នកខ្លាំងពូកែត្រូវខ្មាស់
ព្រះជ្រើសរើសប្រើមនុស្សដែលលោកីយ៍គិតថាខ្សោយ
ដើម្បីផ្ចាញ់អស់អ្នកណាដែលលោកីយ៍ថាជាអ្នកខ្លាំង។
1 Corinthians 1:28
អ្វីដែលតូចតាច និងអ្វីដែលគេស្អប់ខ្ពើម
មនុស្សដែលគេបដិសេធ។ ការបកប្រែផ្សេងទៀត: «មនុស្សដែលសុភាព
ហើយត្រូវគេបដិសេធ»។
[illegible]
នេះអាចនិយាយបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ជាមនុស្សដែលគេមិនឲ្យតម្លៃជាញឹកញាប់»។
របស់ដែលគ្មានតម្លៃ ដើម្បីឲ្យក្លាយជារបស់ដែលមានតម្លៃ
របស់គ្មានតម្លៃ ទ្រង់ធ្វើការនេះដើម្បីឲ្យក្លាយជារបស់ដែលមានតម្លៃបំផុតវិញ។
របស់ដែលរាប់ជាមានតម្លៃ
នេះអាចនិយាយបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«របស់ដែលមនុស្សគិតថាមានតម្លៃជា លុយ» ឬ
«របស់ដែលមនុស្សគិតថាមានតម្លៃជា ការគោរព»។
1 Corinthians 1:30
ដោយសារអ្វីៗដែលព្រះអង្គបានធ្វើ
នេះសំដៅលើអ្វីៗដែលព្រះគ្រិស្តបានធ្វើលើឈើឆ្កាង
អ្នករាល់គ្នា
ពាក្យទាំងនេះសំដៅលើលោកប៉ូល អស់អ្នកដែលនៅជាមួយលោក
និងក្រុមជំនុំកូរិចូស។
ព្រះគ្រិស្តយេស៊ូ ជាអ្នកដែលនាំប្រាជ្ញាមកដល់យើងពីព្រះជាម្ចាស់
អាចមានន័យថាទី១ «ព្រះគ្រិស្តយេស៊ូបានប្រាប់យើងយ៉ាងប្រាកដថា
ព្រះទ្រង់សព្វប្រាជ្ញាញាណ» ឬ ទី២
«ព្រះគ្រិស្តយេស៊ូជាអ្នកដែលនាំប្រាជ្ញាញាណរបស់ព្រះអង្គម្ចាស់មកដល់យើង»។
សូមឲ្យអ្នកដែលមានអំនួត ចូរអួតតែពីព្រះអម្ចាស់បានហើយ
ប្រសិនបើ មនុ្សណាម្នាក់មានអំនួត
ចូរអួតតែពីសេចក្តីអស្ចារ្យរបស់ព្រះជាម្ចាស់ចុះ។

---

2 [1]បងប្អូនអើយ ពេលដែលខ្ញុំមកជួបបងប្អូន ខ្ញុំមិនបានមកជាមួយ និងពាក្យដែលពេញដោយវោហារ ឬប្រាជ្ញាខ្ពង់ខ្ពស់ ដើម្បីប្រកាសពីសេចក្តីដ៏លាក់កំបាំងរបស់
ព្រះជាម្ចាស់ឡើយ។[2]ដ្បិត ខ្ញុំបានកំណត់ថាមិនចេះអ្វីទេ ក្នុងពេលនៅជាមួយបងប្អូន គឺនិយាយតែពីព្រះយេស៊ូគ្រិស្ត និងការសុគតនៅលើឈើឆ្កាងរបស់ព្រះអង្គ។
[3]ហើយខ្ញុំធ្លាប់នៅជាមួយបងប្អូនក្នុងការខ្សោយ ហើយក្នុងការភ័យខ្លាច និងញាប់ញ័រយ៉ាងខ្លាំងផង។[4]ហើយសារនិងការប្រកាសរបស់ខ្ញុំ
មិនមែនដោយបញ្ចុះបញ្ចូលពេញដោយប្រាជ្ញានោះទេ។ ប៉ុន្តែ បានមកពីការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ និងអំណាចរបស់ព្រះអង្គវិញ។[5]ដូច្នេះហើយ
ជំនឿរបស់បងប្អូនគឺមិនមែនបានពីប្រាជ្ញារបស់មនុស្សទេ ប៉ុន្តែ កើតមកពីអំណាចរបស់ព្រះជាម្ចាស់វិញ។

generated on Wed Sep 10 16:16:32 2025

[6]ឥឡូវ យើងក៏និយាយពាក្យពេញដោយប្រាជ្ញាទៅចំពោះអ្នកពេញវ័យ ប៉ុន្តែ មិនមែនជាប្រាជ្ញារបស់លោកីយ៍ ឬ ប្រាជ្ញាអ្នកគ្រប់គ្រងនៃជំនាន់
និងប្រាជ្ញាអ្នកលាចាកលោកនេះទៅហើយនោះទេ។[7]ផ្ទុយទៅវិញ យើងនិយាយពីប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ក្នុងសេចក្តីអាថ៌កំបាំងនៃក្តីពិត ការអាថ៌កំបាំងនៃប្រាជ្ញា
ដែលត្រៀមទុកតាំងតែពីមុនរហូតដល់ជំនាន់នេះ សម្រាប់ប្រទានសិរីរុងរឿងដល់យើង។
[8]គ្មានអ្នកគ្រប់គ្រងនៅជំនាន់នេះណាម្នាក់ អាចស្គាល់ពីប្រាជ្ញានេះឡើយ ដ្បិត បើពួកគេបានយល់នៅក្នុងពេលនោះ គេនឹងមិនឆ្កាងព្រះអម្ចាស់នៃសិរីល្អទេ។[9]ប៉ុន្តែ
ឲ្យដូចសេចក្តីបានចែងទុកមកថា៖ «ការដែលភ្នែកមិនអាចមើលឃើញ ត្រចៀកមិនអាចស្តាប់ឮ គ្មានគំនិតដែលគិតយល់
គឺជាការដែលព្រះជាម្ចាស់បានរៀបចំសម្រាប់អ្នកដែលស្រឡាញ់ព្រះអង្គ»។
[10]ការទាំងនេះគឺជាអ្វីដែលព្រះជាម្ចាស់បានបើកសម្តែងដល់យើង តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ ដ្បិត ព្រះវិញ្ញាណដ៏វិសុទ្ធ ស្វែងរកគ្រប់អ្វីៗ
ទោះបីជាការសឹុជម្រៅរបស់ព្រះជាម្ចាស់ក្តី។[11]ដ្បិត តើអ្នកដែលដឹងពីការគិតរបស់មនុស្សបាន? លើកលែងតែព្រះវិញ្ញាណនៅក្នុងអ្នកនោះប៉ុណ្ណោះ ដូច្នេះ
គ្មានអ្នកណាអាចដឹងពីការសឹុជម្រៅរបស់ព្រជាម្ចាស់ឡើយ លើកលែងតែព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។
[12]ប៉ុន្តែ ពួកយើងមិនបានទទួលវិញ្ញាណរបស់លោកីយ៍នេះទេ ប៉ុន្តែ យើងបានទទួលព្រះវិញ្ញាណដែលមកអំពីព្រះជាម្ចាស់វិញ។ ដូច្នេះហើយ
បានជាយើងអាចទទួលដឹងគ្រប់ការទាំងអស់ ដែលបើកសម្តែងតាមរយៈព្រះជាម្ចាស់។[13]ពួកយើងនិយាយអំពីការនេះ ជាពាក្យដែលមិនមែនមកពីប្រាជ្ញារបស់មនុស្ស
ដែលបង្រៀនទេ ប៉ុន្តែ ព្រះវិញ្ញាណវិញទេតើ ដែលជាអ្នកបង្រៀនយើងវិញ។ ព្រះវិញ្ញាណបានបកបស្រាយសេចក្តីពាក្យខាងវិញ្ញាណជាមួយប្រាជ្ញាខាងឯវិញ្ញាណដែរ។
[14]អ្នកដែលមិនមែនជាមនុស្សខាងវិញ្ញាណមិនអាចទទួលការអ្វី ដែលជាកម្មសិទ្ធិរបស់ព្រះវិញ្ញាណនៃព្រះជាម្ចាស់ឡើយ ដ្បិត ពួកគេពិតជាលីលាចំពោះព្រះអង្គ
ដ្បិតគេមិនអាចយល់ការទាំងនោះទេ ពីព្រោះគ្រប់ការទាំងអស់គឺព្រះវិញ្ញាណជាអ្នកបើកឲ្យយល់។[15]ម្នាក់ដែលមានការវិនិច្ឆ័យដោយខាងឯព្រះវិញ្ញាណគ្រប់ការទាំងអស់
ប៉ុន្តែ គេមិនមានអំណាចដើម្បីវិនិច្ឆ័យអ្នកដទៃឡើយ។[16]ដ្បិត តើអ្នកណាអាចយល់ពីព្រះតម្រិះរបស់ព្រះអម្ចាស់ ដែលគេអាចណែនាំព្រះអង្គបាន?» ប៉ុន្តែ យើងវិញ
យើងមានគំនិតរបស់ព្រះគ្រិស្ត។

---

1 Corinthians 2:1

ប្រយោគភ្ជាប់

លោកប៉ូលនិយាយពីភាពផ្ទុយគ្នារវាងប្រាជ្ញារបស់មនុស្ស និងប្រាជ្ញារបស់ព្រះ។
លោកបញ្ជាក់ថាប្រាជ្ញាញាណខាងវិញ្ញាណដែលមកពីព្រះ។

បងប្អូនអើយ

នេះមានន័យថា គ្រិស្តបរិស័ទដែលរួមជំនឿ រួមមានទាំងបុរស និងស្ត្រី។

ខ្ញុំបានកំណត់ថាមិនចេះអ្វីទេ...លើកលែងតែព្រះគ្រិស្តយេស៊ូ

នៅពេលលោកប៉ូលនិយាយថា លោក «បានកំណត់ថាមិនចេះអ្វីទេ»
លោកចង់បញ្ជាក់ជាប្រាកដថាលោកបានសម្រេចចិត្ត
និងមិនផ្តោតលើការបង្រៀនណាមួយក្រៅពីព្រះយេស៊ូគ្រិស្តឡើយ។
ការបកប្រែផ្សេងទៀត:
«ខ្ញុំបានប្តេជ្ញាថាមិនចេះបង្រៀនអ្វីទាំងអស់...លើកលែងតែព្រះយេស៊ូគ្រិស្ត» ឬ
«ខ្ញុំសម្រេចចិត្តមិនបង្រៀនអ្វីទាំងអស់...លើកលែងតែព្រះយេស៊ូគ្រិស្ត»។

1 Corinthians 2:3

ខ្ញុំធ្លាប់នៅជាមួយអ្នក

ខ្ញុំធ្លាប់បានទៅសួរសុខទុក្ខបងប្អូន។

ក្នុងការខ្សោយ

អាចមានន័យថាទី១ «ការខ្សោយនៃរូបរាងកាយ» ឬ ទី២
«មានអារម្មណ៍ថាខ្ញុំមិនអាចអ្វីដែលខ្ញុំត្រូវតែធ្វើនោះទេ»។

ពាក្យបញ្ចុះបញ្ចូលពេញដោយប្រាជ្ញា

ពាក្យដែលស្តាប់ទៅពេញដោយប្រាជ្ញា
ហើយដែលអ្នកនិយាយសង្ឃឹមថាមនុស្សធ្វើតាម ឬជឿលើអ្វីមួយ។

1 Corinthians 2:6

ព័ត៌មានទូទៅ

លោកប៉ូលផ្អាកការប្រកែករបស់លោកដើម្បីពន្យល់ពីអត្ថន័យនៃពាក្យ «ប្រាជ្ញា»
ទៅកាន់អ្នកដែលលោកមានបំណងក្នុុងការនិយាយជាមួយ។

ឥឡូវ យើងក៏និយាយ

ពាក្យថា «ឥឡូវ»
ត្រូវបានប្រើសម្រាប់សញ្ញាសម្គាល់ក្នុងការសម្រាកក្នុងការបង្រៀនសំខាន់ៗ។
លោកប៉ូលចាប់ផ្តើមពន្យល់ថាប្រាជ្ញាពិតប្រាកដជាប្រាជ្ញាដែលមកពីព្រះ។

និយាយដោយប្រាជ្ញា

នាមអរូប «ពេញដោយប្រាជ្ញា» អាចនិយាយជាគុណនាមថា «ចេះដឹង»។
ការបកប្រែផ្សេងទៀត «និយាយដោយពាក្យចេះដឹង» ឬ
«និយាយទៅតាមប្រាជ្ញានៃព្រះបន្ទូល»។

គ្រប់លក្ខណ៍

អ្នកជឿដែលពេញវ័យ

តាំងតែពីមុន

មុនពេលព្រះបានបង្កើតអ្វីៗទាំងអស់។

សម្រាប់ប្រទានសិរីរុងរឿងដល់យើង

ដើម្បីធានាថាជាសិរីរុងរឿងនៃអនាគតយើង។

1 Corinthians 2:8

ព្រះអម្ចាស់នៃសិរីល្អ

ព្រះគ្រិស្ត ជាព្រះពេញដោយសិរីរុងរឿង។

ការដែលភ្នែកមិនអាច...មើលឃើញ ជាការដែល...សម្រាប់អ្នកដែលស្រឡាញ់ព្រះអង្គ

នេះជាប្រយោគដែលមិនពេញលេញមួយ។
ការបកប្រែមួយចំនួនបានបកប្រែជាប្រយោគពេញលេញ
«ការដែលភ្នែកមិនអាច...ស្រមៃឃើញ
ជាការដែល...សម្រាប់អ្នកស្រឡាញ់ព្រះអង្គ»។
ការបកប្រែខ្លះទៀតមិនបានបកប្រែជាប្រយោគពេញលេញទេ ប៉ុន្តែ
បង្ហាញថាវាមិនពេញលេញដោយមិនបានបញ្ចប់ដោយសញ្ញាវណ្ណយុត្តនៅទីនេះទេ
ហើយការចាប់ផ្តើមខគម្ពីរបន្ទាប់ដូចជាការបន្តនៃខគម្ពីរនេះទៀតអ៊ីចឹង
«ជាការដែលភ្នែកមិនអាច...ស្រមៃឃើញ
ជាការដែល...សម្រាប់អ្នកស្រឡាញ់ព្រះអង្គ«-»

ការដែលភ្នែកមិនអាចមើលឃើញ ត្រចៀកមិនអាចស្តាប់ឮ គ្មានគំនិតដែលគិតយល់

នេះជាឯកសារយោងទាំងបីដែលសំដៅទៅគ្រប់ផ្នែកនៃមនុស្សដើម្បីបញ្ជាក់ថា
គ្មានមនុស្សណាម្នាក់ធ្លាប់បានដឹងពីអ្វីដែលព្រះបានរៀបចំនោះទេ។

ជាការដែលព្រះជាម្ចាស់បានរៀបចំសម្រាប់អ្នកដែលស្រឡាញ់ព្រះអង្គ

ព្រះជាម្ចាស់បានបង្កើតអ្វីដែលរំភើបអស្ចារ្យក្នុងស្ថានសួគ៌សម្រាប់អ្នកដែលស្រឡាញ់ទ្រង់។

ដ្បិត មិនមែនជាវិញ្ញាណដែលនៅក្នុងខ្លួនមនុស្សទេដែលស្គាល់ពីសណ្ឋានរបស់មនុស្ស?

លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ថាគ្មាននរណាម្នាក់ដឹកថានរណាមួយគិតពីអ្វីនោះទេ
លើកលែងតែខ្លួនគេផ្ទាល់។ ការបកប្រែផ្សេងទៀត:
«គ្មាននរណាម្នាក់ដឹកពីអ្វីដែលមនុស្សកំពុងគិតនោះទេ
លើកលែងតែវិញ្ញាណរបស់គេផ្ទាល់»។

វិញ្ញាណនៃមនុស្ស

នេះសំដៅលើសណ្ឋានខាងក្នុងរបស់មនុស្ស ជាវិញ្ញាណដែលមកពីព្រះវិញ។

បើមិនមែនជាវិញ្ញាណនៃព្រះ នោះក៏គ្មាននរណាស្គាល់សណ្ឋាននៃព្រះដែរ

នេះអាចនិយាយបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«មានតែព្រះវិញ្ញាណនៃព្រះតែមួយប៉ុណ្ណោះដែលដឹងពីសណ្ឋានរបស់ព្រះ»។

1 Corinthians 2:10

ការទាំងនេះគឺជាអ្វី

លោកប៉ូលមានប្រសាសន៍ពីសេចក្តីពិតអំពីព្រះយេស៊ូ និងឈើឆ្កាង។ ប្រសិនបើ
២:៨ និយាយហាក់បីដូចជាប្រយោគមិនទាន់ពេញលេញ។ «នេះគឺជាអ្វីៗ»។

ដ្បិត តើអ្នកណាស្គាល់គំនិតរបស់មនុស្សបាន លើកលែងតែ

វិញ្ញាណរបស់មនុស្សដែលនៅក្នុងគាត់ទេ?

លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ថា
គ្មាននរណាស្គាល់អ្វីដែលមនុស្សម្នាក់គិតឡើយ
លើកលែងតែអ្នកនោះផ្ទាល់ទើបដឹង។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាដឹងអ្វីដែលមនុស្សគិតឡើយ លើកលែងតែវិញ្ញាណរបស់អ្នកនោះ»

ព្រះវិញ្ញាណនៅក្នុងអ្នកនោះ

ឃ្លានេះ សំដៅលើមនុស្សខាងក្នុងអ្នកនោះ ជីវិតខាងវិញ្ញាណរបស់អ្នកនោះផ្ទាល់។

គ្មានអ្នកណាអាចដឹងពីការសឹុជម្រៅរបស់ព្រជាម្ចាស់ឡើយ
លើកលែងតែព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ

generated on Wed Sep 10 16:16:32 2025

«មានតែវិញ្ញាណរបស់ព្រះជាម្ចាស់ទេ ដែលដឹងពីការស៊ីជម្រៅរបស់ព្រះជាម្ចាស់»
1 Corinthians 2:12
ព័ត៌មានទូទៅ
ពាក្យ «ពួកយើង» រួមបញ្ចូលទាំងលោកប៉ូល និងសមាជិកក្រុមជំនុំរបស់លោក។
ព្រះបានផ្តល់ឲ្យពួកយើងដោយឥតគិតថ្លៃ
នេះអាចនិយាយបញ្ជាក់ជាទម្រង់សកម្ម ការបកប្រែផ្សេងទៀត
«ថាព្រះទ្រង់ផ្តល់ឲ្យយើងដោយមិនគិតថ្លៃ» ឬ «ថា
ព្រះមានចិត្តសប្បុរសផ្តល់ឲ្យយើង»។
ព្រះវិញ្ញាណបានបកប្រែយ៉ាងសេចក្តីពាក្យខាងវិញ្ញាណជាមួយប្រាជ្ញាខាងឯវិញ្ញាណ
ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រាប់ឲ្យដឹងពីសេចក្តីពិតរបស់ព្រះដល់អ្នកជឿលើពាក្យរបស់ព្រះ
និងផ្តល់ឲ្យពួកគេនូវប្រាជ្ញាផ្ទាល់របស់ទ្រង់។
ព្រះវិញ្ញាណបានបកប្រែយ៉ាងសេចក្តីពាក្យខាងវិញ្ញាណជាមួយប្រាជ្ញាខាងឯវិញ្ញាណ
ព្រះវិញ្ញាណពន្យល់ដោយប្រើប្រាជ្ញាខាងឯវិញ្ញាណដើម្បីពន្យល់ពាក្យខាងវិញ្ញាណ។
1 Corinthians 2:14
ព័ត៌មានទូទៅ
ពាក្យ «ពួកយើង» រួមបញ្ចូលទាំងលោកប៉ូល និងសមាជិកក្រុមជំនុំរបស់លោក។
មិនមែនជាមនុស្សខាងវិញ្ញាណ
អ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ជាអ្នកមិនបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។
ពីព្រោះពួកគេមានការវិនិច្ឆ័យដោយខាងឯព្រះវិញ្ញាណ
ដោយព្រោះការយល់ពាក្យទាំងអស់នោះតម្រូវឲ្យមានជំនួយពីព្រះវិញ្ញាណ។
ជាម្ចាស់ដែលជាវិញ្ញាណ
ជាអ្នកជឿដែលបានទទួលព្រះវិញ្ញាណ។
តើអ្នកណាអាចយល់ពីព្រះតម្រិះរបស់ព្រះអម្ចាស់ ដែលគេអាចណែនាំព្រះអង្គបាន?
ឃ្លានេះជាសំណួរដើម្បីបញ្ជាក់ថាគ្មានរណាម្នាក់អាចយល់ដឹងពីព្រះតម្រិះរបស់ព្រះអម្ចាស់បានឡើយ។
គ្មាននរណាម្នាក់មានប្រាជ្ញាដូចទ្រង់ឡើយ។ ការបកប្រែផ្សេងទៀត:
«គ្មាននរណាម្នាក់អាចដឹងពីព្រះតម្រិះរបស់ព្រះអម្ចាស់ឡើយ ដូច្នេះ
ក៏គ្មាននរណាម្នាក់អាចបង្រៀនទ្រង់នូវអ្វីៗដែលទ្រង់មិនធ្លាប់ដឹងពីមុននោះឡើយ»។

---

3 [1]បងប្អូនអើយ ចំណែកខ្ញុំវិញ ខ្ញុំមិនអាចនិយាយទៅបងប្អូនដូចមនុស្សខាងឯវិញ្ញាណបានទេ ផ្ទុយទៅវិញខ្ញុំនិយាយមកកាន់បងប្អូនដូចជាមនុស្សធម្មតា
ហើយដូចជាកូនក្មេងនៅក្នុងព្រះគ្រិស្តវិញ។[2]ខ្ញុំបានឲ្យទឹកដោះដល់បងប្អូន មិនមែនអាហាររឹងទេ ដ្បិត អ្នករាល់គ្នាមិនទាន់រួចរាល់សម្រាប់អាហាររឹងនៅឡើយ
ទោះបីជាមកដល់ពេលនេះក៏នៅតែមិនអាចទទួលបានដែរ។
[3]ដ្បិត បងប្អូននៅក្នុងសាច់ឈាមលោកីយ៍។ កាលណានៅតែមានការច្រណែនទាស់ទែងគ្នាកើតឡើងក្នុងចំណោមបងប្អូន
តើបងប្អូនមិនបានរស់នៅអាស្រ័យខាងឯសាច់ឈាម ហើយតើអ្នកមិនបានដើរតាមរបៀបរបស់មនុស្សលោកទេឬអី?[4]ពេលមានម្នាក់និយាយថា៖ «ខ្ញុំដើរតាមប៉ូល»
ហើយអ្នកផ្សេងទៀតនិយាយថា៖ «ខ្ញុំដើរតាមលោកអប៉ូឡុស» តើនេះមិនមែនរស់នៅបែបមនុស្សលោកទេឬអី?[5]តើលោកអប៉ូឡុសជាអ្នកណា? តើប៉ូលជានរណា?
ជាអ្នកបម្រើព្រះជាម្ចាស់ដែលអ្នករាល់គ្នាបានជឿ ម្នាក់ៗធ្វើការតាមដែលព្រះអម្ចាស់ប្រគល់ភារកិច្ចឲ្យប៉ុណ្ណោះ។
[6]ខ្ញុំជាអ្នកដាំ ហើយលោកអាប៉ូឡូជាអ្នកស្រោចទឹក ប៉ុន្តែ ព្រះជាម្ចាស់ជាអ្នកធ្វើឲ្យលូតលាស់វិញ។[7]ដូច្នេះហើយ មិនថានរណាជាអ្នកដាំ ឬអ្នកណាជាអ្នកស្រោចទឹកនោះទេ។
ប៉ុន្តែ គឺជាព្រះជាម្ចាស់ទេ ដែលផ្តល់ការលូតលាស់វិញ។
[8]ពេលនេះ អ្នកដែលជាអ្នកដាំ និងអ្នកស្រោចទឹកគឺតែមួយ ហើយម្នាក់ៗនឹងបានទទួលបានកម្រៃតាមអ្វីដែលខ្លួនបានធ្វើ។[9]ដ្បិត ពួកយើងជាអ្នកដើរតាម
និងធ្វើការថ្វាយព្រះអង្គ។ បងប្អូនគឺជាសួនដំណាំរបស់ព្រះជាម្ចាស់ ហើយក៏ជាដំណាក់ដែលព្រះអង្គបានសង់ដែរ។
[10]ស្របតាមព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានប្រទានដល់ខ្ញុំក្នុងការមានជំនាញមេជាង ខ្ញុំបានសាងសង់គ្រឹះ ហើយអ្នកផ្សេងទៀតអាចសង់ពីលើវាបាន។
ប៉ុន្តែសូមឲ្យជាងទាំងអស់ប្រយ័ត្នក្នុងការដែលអ្នកសង់លើវា។[11]ដ្បិត គ្មានអ្នកណាអាចសង់គ្រឹះផ្សេងទៀតលួជាងគ្រឹះដែលបានសង់ឡើង ដោយព្រះយេស៊ូគ្រិស្តនោះទេ។
[12]ឥឡូវនេះ ប្រសិនបើ មានអ្នកណាសង់លើគ្រឹះនេះជាមួយមាស ប្រាក់ ពេជ្រ ឈើ ចំបើង ឬស្សូរ[13]កិច្ចការរបស់ពួកគេនឹងបង្ហាញឲ្យឃើញ សម្រាប់ពន្លឺថ្ងៃនឹងបង្ហាញពីវា។
ដ្បិត វានឹងត្រូវបង្ហាញនៅក្នុងភ្លើងដែរ។ ភ្លើងនឹងសាកល្បងពីគុណភាពរបស់អ្វីៗដែលម្នាក់បានធ្វើ។
[14]ប្រសិនបើ កិច្ចការអ្នកណាម្នាក់នៅតែអាចទ្រាំបាន អ្នកនោះនឹងទទួលបាននូវរង្វាន់[15]ប៉ុន្តែប្រសិនបើ កិច្ចការអ្នកណាត្រូវឆេះអស់ អ្នកនោះនឹងបាត់រង្វាន់
ប៉ុន្តែគាត់ខ្លួនឯងនឹងបានសង្គ្រោះ ដូចជាការដើរចេញពីភ្លើងដូច្នោះដែរ។
[16]តើបងប្អូន មិនដឹងទេឬអីថា បងប្អូនជាព្រះវិហាររបស់ព្រះជាម្ចាស់ និងជាកន្លែងដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គង់នៅក្នុងបងប្អូន?[17]ប្រសិនបើ
អ្នកណាបំផ្លាញព្រះវិហាររបស់ព្រះជាម្ចាស់ នោះព្រះជាម្ចាស់នឹងបំផ្លាញអ្នកនោះវិញ។ ដ្បិតព្រះវិហាររបស់ព្រះជាម្ចាស់វិសុទ្ធ ដូច្នេះអ្នកត្រូវតែវិសុទ្ធដែរ។
[18]សូមកុំបញ្ឆោតខ្លួនឯងឲ្យសោះ។ ប្រសិនបើ មាននរណានៅក្នុងចំណោមបងប្អូនគិតថាខ្លួនមានប្រាជ្ញាក្នុងជំនាន់នេះ សូមឲ្យគាត់ត្រឡប់ទៅជាអ្នក «លីលា»វិញចុះ
ដើម្បីឲ្យគាត់អាចនឹងទៅជាប្រាជ្ញវិញ។[19]ដ្បិត ប្រាជ្ញារបស់លោកីយ៍គឺលីលាសម្រាប់ព្រះជាម្ចាស់។ ដ្បិត មានសេចក្តីចែងទុកមកថា៖ «ព្រះអង្គយកកលល្បិចរបស់ពួកអ្នក
ប្រាជ្ញមកផ្ចាញ់ពួកគេផ្ទាល់»។[20]ម្តងទៀត «ព្រះអម្ចាស់ជ្រាបថាគំនិតរបស់ពួកអ្នកប្រាជ្ញគ្មានខ្លឹមសារអ្វីទេ»។
[21]ដូច្នេះមិនត្រូវអួតអាងអំពីមនុស្សណាឡើយ! ដ្បិតការទាំងអស់គឺជារបស់អ្នក[22]ទោះជាប៉ូល ឬអាប៉ូឡូស ឬកេផាស ឬពិភពលោកនេះ ឬជីវិត ឬការស្លាប់
ឬរបស់ក្នុងពេលបច្ចុប្បន្ននេះ ឬអ្វីដែលនឹងមកដល់។ គឺគ្រប់ទាំងអស់ជារបស់អ្នក[23]ហើយបងប្អូនជារបស់ព្រះគ្រិស្ត ហើយព្រះគ្រិស្តជារបស់ព្រះជាម្ចាស់។

---

1 Corinthians 3:1
ប្រយោគភ្ជាប់
ឥឡូវលោកប៉ូលរំលឹកដល់អ្នកជឿក្នុងពួកជំនុំកូរិនថូសអំពីរបៀបដែលពួកគេគួរតែរស់នៅ
ជាជាងការដែលធ្វើតែតាមតួនាទីរបស់ពួកគេនៅចំពោះមុខព្រះ។
លោកក៏បានរំលឹកពួកគេទៀតថា អ្នកដែលបង្រៀនពួកគេ
មិនមានសារសំខាន់ដូចជាព្រះទេ ដែលទ្រង់ជាអ្នកធ្វើឲ្យមានការលូតលាស់វិញ។
បងប្អូនអើយ
នេះមានន័យថា គ្រិស្តបរិស័ទដែលរួមជំនឿ រួមមានទាំងបុរស និងស្ត្រី។
មនុស្សខាងឯវិញ្ញាណ
មនុស្សដែលស្តាប់តាមព្រះវិញ្ញាណ
មនុស្សខាងសាច់ឈាម
មនុស្សដែលធ្វើតាមតែបំណងចិត្តរបស់ពួកគេ
ដូចជាកូនក្មេងនៅក្នុងព្រះគ្រិស្ត
ក្រុមជំនុំកូរិនថូសត្រូវបានប្រៀបធៀបដូចជាកូនក្មេងតូចខាងឯអាយុ
និងការយល់ដឹង។ ការបកប្រែផ្សេងទៀត: «ដូចជាអ្នកជឿព្រះគ្រិស្តលើកដំបូង»។
ខ្ញុំបានឲ្យទឹកដោះដល់បងប្អូន មិនមែនអាហាររឹងទេ
ក្រុមជំនុំកូរិនថូសអាចងាយស្រួលយល់តែសេចក្តីពិតប៉ុណ្ណោះប្រៀបដូចជាកូនក្មេងដែលអាចនឹងទទួលបានតែទឹកដោះប៉ុណ្ណោះ
ពួកគេមិនទាន់ពេញវ័យគ្រប់គ្រាន់ដើម្បីអាចយល់ពីសេចក្តីអស្ចារ្យដូចក្មេងធំដែលអាចបរិភោគអាហារដែលរឹងបានដែរ។
នៅតែមិនអាចទទួលបាន
ចង់បញ្ជាក់ថាពួកគេមិនទាន់រួចរាល់ដើម្បីអាចយល់ពីការបង្រៀនពិបាកៗនោះទេ។
ការបកប្រែផ្សេងទៀត:
«អ្នកនៅមិនទាន់រួចរាល់ដើម្បីអាចយល់ពីការបង្រៀនជ្រៅៗក្នុងការដើរតាមព្រះគ្រិស្តនៅឡើយទេ»។
1 Corinthians 3:3
នៅក្នុងសាច់ឈាម
នៅតែប្រព្រឹត្តទង្វើរទៅតាមអំពើបាប ឬ បំណងរបស់លោកីយ៍។
តើបងប្អូនមិនបានរស់នៅអាស្រ័យខាងឯសាច់ឈាម
ហើយតើអ្នកមិនបានដើរតាមរបៀបរបស់មនុស្សលោកទេឬអី?
លោកប៉ូលកំពុងតែស្តីបន្ទោសពួកជំនុំកូរិនថូសចំពោះការប្រព្រឹត្តអំពើបាបរបស់ពួកគេ។
«ការដើរ» នេះជាការប្រៀបធៀបមួយចំពោះ «ការថ្លឹងថ្លែងអាកប្បកិរិយាបងប្អូន»
ជាការសម្រេចថាអ្វីល្អ ហើយអ្វីអាក្រក់។ ការបកប្រែផ្សេងទៀត:
«បងប្អូនគួរតែត្រូវរៀនខ្មាស
ដោយសារបងប្អូនកំពុងតែប្រព្រឹត្តអំពើបាបទៅតាមបំណងចិត្តរបស់បងប្អូន
ហើយកំពុងប្រើរបៀបលោកីយ៍ក្នុងការសំរេចថាតើអាកប្បកិរិយារបស់បងប្អូនល្អ
ឬអាក្រក់!»
ដោយសារតែនៅមានការច្រណែនក្នុងចំណោមបងប្អូន
ចោទសួរដោយលោកប៉ូលអំពីរបៀបរស់នៅរបស់ក្រុមជំនុំកូរិនថូស។ ការបកប្រែផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«បងប្អូនគួរតែត្រូវខ្មាស់អៀនដោយសារបងប្អូនរស់នៅតាមរបៀបមនុស្សដដែល ដែលជាមនុស្សមិនមានព្រះវិញ្ញាណគង់នៅ»។

តើលោកអប៉ូឡូសជាអ្នកណា? តើប៉ូលជានរណា?

លោកប៉ូលកំពុងនិយាយធ្ងន់ៗថា លោក និងអប៉ូឡូសមិនមែនជាអ្នកផ្សាយដំណឹងល្អចេញពីប្រភពដើមនោះទេ ដូច្នេះហើយក្រុមជំនុំកូរិនថូសមិនគួរដើរតាមពួកលោកទេ។ ការបកប្រែផ្សេងទៀត: «ជាការមិនត្រឹមត្រូវក្នុងការប្រមូលផ្តុំក្រុមមនុស្សដើម្បីដើរតាមលោកអប៉ូឡូស ឬ លោកប៉ូល!» ឬ

ហើយតើប៉ូលជានរណា?

លោកប៉ូលកំពុងនិយាយពីខ្លួនលោកផ្ទាល់ ក៏ដូចជាកំពុងនិយាយចំពោះអ្នកដទៃដែរ។ ការបកប្រែផ្សេងទៀត: «ខ្ញុំមិនសំខាន់ទេ» ឬ «ខ្ញុំជានរណា?»

ជាអ្នកបម្រើព្រះជាម្ចាស់ដែលអ្នករាល់គ្នាបានជឿ

លោកប៉ូលបានឆ្លើយសំណួរខ្លួនឯងដោយនិយាយថា លោក និងលោកអប៉ូឡូសជាអ្នកបម្រើព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត: «លោកប៉ូល និងលោកអប៉ូឡូសជាអ្នកបម្រើព្រះគ្រិស្ត ហើយជាអ្នកជឿលើព្រះគ្រិស្តដោយព្រោះពួកយើងជាអ្នកបម្រើទ្រង់»។

ជាអ្នកបម្រើព្រះជាម្ចាស់ដែលអ្នករាល់គ្នាបានជឿ

ម្នាក់ៗធ្វើការតាមដែលព្រះអម្ចាស់ប្រគល់ភារកិច្ចឲ្យប៉ុណ្ណោះ

នេះអាចត្រូវបានបញ្ជាក់ជាមួយព័ត៌មានដែលបានយល់។ ការបកប្រែផ្សេងទៀត: «យើងជាអ្នកបម្រើព្រះជាម្ចាស់ដែលអ្នករាល់គ្នាបានជឿ។ មានតែពួកយើងប៉ុណ្ណោះដែលជាមនុស្សដែលព្រះអម្ចាស់ប្រគល់ភារកិច្ចឲ្យ»។

1 Corinthians 3:6

ខ្ញុំជាអ្នកដាំ

ការយល់ដឹងពីព្រះប្រៀបដូចជាគ្រាប់ពូជមួយដែលត្រូវបានដាំដើម្បីលូតលាស់។ ការបកប្រែផ្សេងទៀត: «នៅពេលខ្ញុំអធិប្បាយព្រះបន្ទូលរបស់ព្រះទៅបងប្អូន ខ្ញុំហាក់ដូចជាម្នាក់ដែលដាំគ្រាប់ពូជនៅក្នុងសួនច្បារ»។

លោកអាប៉ូឡូជាអ្នកស្រោចទឹក

ដូចគ្រាប់ពូជត្រូវការទឹក សេចក្តីជំនឿត្រូវការសេចក្តីបង្រៀនយូរដើម្បីឲ្យមានការលូតលាស់។ ការបកប្រែផ្សេងទៀត: «ហើយនៅពេលលោកអាប៉ូឡូសបន្តបង្រៀនបងប្អូនអំពីព្រះបន្ទូលរបស់ព្រះ លោកបានប្រៀបដូចជា អ្នកស្រោចទឹកក្នុងសួនច្បារនោះ»។

ប៉ុន្តែ ព្រះជាម្ចាស់ជាអ្នកធ្វើឲ្យលូតលាស់វិញ

នៅពេលដំណាំលូតលាស់ និងរីកចម្រើន ដូច្នេះសេចក្តីជំនឿ និងការយល់ដឹងពីព្រះក៏មានការលូតលាស់ និងរឹតតែមាំនិងជ្រៅទៅៗដែរ។ ការបកប្រែផ្សេងទៀត «ប៉ុន្តែ ព្រះជាអ្នកធ្វើឲ្យបងប្អូនលូតលាស់» ឬ «ប៉ុន្តែ បើព្រះធ្វើឲ្យដំណាំលូតលាស់ ទ្រង់ក៏និងធ្វើឲ្យបងប្អូនលូតលាស់ខាងវិញ្ញាណដូចគ្នាដែរ»។

មិនថានរណាជាអ្នកដាំ ឬជាអ្នក...ប៉ុន្តែ គឺជាព្រះជាម្ចាស់ទេ ដែលផ្តល់ការលូតលាស់វិញ។

លោកប៉ូលសង្កត់ធ្ងន់ៗទៀតថា មិនមែនជាលោក ឬ លោកអាប៉ូឡូសដែលមានកាតព្វកិច្ចធ្វើឲ្យអ្នកជឿទាំងអស់មានការលូតលាស់ខាងវិញ្ញាណ ប៉ុន្តែ ជាព្រះជាម្ចាស់ទេ។

ប៉ុន្តែ គឺជាព្រះជាម្ចាស់ទេ ដែលផ្តល់ការលូតលាស់វិញ

ឲ្យលូតលាស់មានន័យថា ធ្វើឲ្យលូតលាស់។ នាមអរូប «ការលូតលាស់» អាចត្រូវបានបកប្រែក្នុងប្រយោគនិយាយ។ ការបកប្រែផ្សេងទៀត «ជាព្រះដែលធ្វើឲ្យបងប្អូនលូតលាស់»។

1 Corinthians 3:8

អ្នកដែលជាអ្នកដាំ និងអ្នកស្រោចទឹកគឺតែមួយ

លោកប៉ូលនិយាយប្រាប់មនុស្សពីដំណឹងល្អ និងបង្រៀនដល់អ្នកដែលបានទទួលយកពាក្យទាំងនោះ បើទោះបីជាពួកគេជាអ្នកដាំ និងជាអ្នកស្រោចទឹកក៏ដោយ។

តែមួយ

អាចមានន័យថា «មួយ» ទី១ «រូបរួមក្នុងគោលបំណង» ឬ ទី២ «មានសារសំខាន់ស្មើភាពគ្នា»។

កម្រៃ

ចំនួនលុយដែលអ្នកធ្វើការណាម្នាក់ទទួលបានពីការងាររបស់ខ្លួន។

យើងត្រូវគេវាយធ្វើបាបយ៉ាងឃោរឃៅ

នេះសំដៅលើលោកប៉ូល និងលោកអាប៉ូឡូស ប៉ុន្តែ មិនមែនជាក្រុមជំនុំកូរិនថូសទេ។

ពួកយើងជាអ្នកដើរតាមព្រះ

លោកប៉ូលចាត់ទុកខ្លួនលោក និងលោកអប៉ូឡូសជាអ្នកធ្វើការរួមគ្នា។

ជាសួនដំណាំរបស់ព្រះជាម្ចាស់

អាចមានន័យថាទី១ ការផ្តើមធ្វើសួនដំណាំរបស់ព្រះជាម្ចាស់ តំណាងឲ្យជាកម្មសិទ្ធិព្រះ។ ការបកប្រែផ្សេងទៀត: «អ្នកដូចជាសួនដំណាំដែលជាកម្មសិទ្ធិរបស់ព្រះ» ឬ ទី២ ផ្តើមជាសួនដំណាំរបស់ព្រះជាម្ចាស់ តំណាងឲ្យការដែលព្រះបានធ្វើឲ្យយើងលូតលាស់។ ការបកប្រែផ្សេងទៀត: «អ្នកដូចជាសួនដំណាំមួយដែលព្រះធ្វើឲ្យលូតលាស់»។

ជាដំណាក់ដែលព្រះអង្គ

អាចមានន័យថាទី១ ចាប់ផ្តើមជាដំណាក់របស់ព្រះ ដែលតំណាងឲ្យកម្មសិទ្ធិនៃព្រះ។ ការបកប្រែផ្សេងទៀត: «ហើយអ្នកដូចជាដំណាក់ដែលជាកម្មសិទ្ធិរបស់ព្រះ» ឬ ចាប់ផ្តើមជាដំណាក់របស់ព្រះ តំណាងឲ្យព្រះដែលធ្វើឲ្យយើងក្លាយជាអ្វីដែលទ្រង់ចង់បាន។ ការបកប្រែផ្សេងទៀត: «ហើយអ្នកដូចជាដំណាក់ដែលព្រះបានកំពុងសាងសង់»។

1 Corinthians 3:10

ស្របតាមព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានប្រទានដល់ខ្ញុំ

នេះត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «យោងទៅតាមភារកិច្ចដែលព្រះបានឲ្យខ្ញុំធ្វើដោយសេរី»។

ខ្ញុំបានសាងសង់គ្រឹះ

លោកប៉ូលប្រៀបធ្មឹមការបង្រៀននៃជំនឿ និងសេចក្តីសង្គ្រោះរបស់លោកក្នុងព្រះយេស៊ូគ្រិស្ត ទៅជាការសាងសង់គ្រឹះសម្រាប់អគារមួយកន្លែង។

ហើយអ្នកផ្សេងទៀតអាចសង់ពីលើវាបាន

លោកប៉ូលសំដៅលើបុគ្គល ឬមនុស្សដែលបង្រៀនក្នុងក្រុមជំនុំកូរិនថូសនៅក្នុងពេលនោះ បើទោះបីជាពួកគេជាជាងឈើដែលសាងសង់អាគារពីលើគ្រឹះក៏ដោយ។

អ្នកផ្សេងទៀត

នេះសំដៅលើអ្នកដែលបម្រើព្រះជាទូទៅ ការបកប្រែផ្សេងទៀត: «ចូរឲ្យម្នាក់ៗបម្រើព្រះជាម្ចាស់»។

គ្មានអ្នកណាអាចសង់គ្រឹះផ្សេងទៀតល្អជាងគ្រឹះដែលបានសង់ឡើង

នេះអាចបញ្ជាក់ជាសកម្ម ការបកប្រែផ្សេងទៀត: «គ្មានអ្នកណាអាចសង់គ្រឹះផ្សេងទៀត ដែលជាគ្រឹះ ខ្ញុំប៉ូលបានសង់នោះឡើង» ឬ «ខ្ញុំបានសង់គ្រឹះរួចហើយ ជាគ្រឹះដែលអ្នកអាចសង់លើបាន»។

1 Corinthians 3:12

ព័ត៌មានទូទៅ៖

លោកប៉ូលនិយាយពីអ្វីដែលអ្នកសាងសង់ជាធម្មតាធ្វើនៅពេលសាងសង់អគារណាមួយដើម្បីពណ៌នាពីគ្រូ អ្នកសាងសង់ជាធម្មតាតែងតែប្រើមាស ប្រាក់ ឬពេជ្រ ជាការតុបតែងលើអគារ។

ឥឡូវនេះ ប្រសិនបើ មានអ្នកណាសង់លើគ្រឹះនេះជាមួយមាស ប្រាក់ ពេជ្រ ឈើ ចំបើង ឬស្មៅរ

សម្ភារអគារដែលត្រូវបានប្រើក្នុងការចាប់ផ្តើមសង់អគារថ្មីត្រូវបានប្រៀបធៀបទៅលើតម្លៃនៃព្រះវិញ្ញាណដែ និងសេចក្តីពិតនៃសេចក្តីជំនឿ។ ភាពណាមួយអំឡុងពេលគាត់នៅមានជីវិតនៅឡើយ។

ការបកប្រែផ្សេងទៀត:

«មិនមែនអ្នកដែលសាងសង់ដោយសម្ភារដែលមានតម្លៃនឹងនៅស្ថិតថេរជាង អ្នកដែលសាងសង់ដោយសម្ភារដែលថោកនិងងាយឆេះជាងនោះទេ»។

ពេជ្រ

ថ្មដែលថ្លៃ

កិច្ចការរបស់ពួកគេនឹងបង្ហាញឲ្យឃើញ

នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់នឹងបង្ហាញគ្រប់គ្នាពីអ្វីដែលអ្នកសាងសង់ត្រូវធ្វើ»។

សម្រាប់ពន្លឺថ្ងៃនឹងបង្ហាញពីវា

«ពន្លឺថ្ងៃ» ជាការប្រៀបធៀបពីពេលវេលាដែលព្រះជាម្ចាស់នឹងកាត់ទោសមនុស្សគ្រប់គ្នា។ នៅពេលព្រះជាម្ចាស់បង្ហាញមនុស្សគ្រប់គ្នាពីអ្វីដែលគ្រូម្នាក់នោះបានធ្វើហើយ វាហាក់បើដូចជាព្រះអាទិត្យដែលរះឡើងដើម្បីបង្ហាញពីអ្វីដែលបានកើតឡើងអំឡុងពេលយប់អ៊ីចឹង។

ដ្បិត វានឹងត្រូវបង្ហាញនៅក្នុងភ្លើងដែរ។ ភ្លើងនឹងសាកល្បងពីគុណភាពរបស់អ្វីៗដែលម្នាក់បានធ្វើ។

ដូចជាភ្លើងដែលនិងបង្ហាញពីកម្លាំង ឬបំផ្លាញភាពកម្សោយនៃអគារណាមួយ ភ្លើងរបស់ព្រះនិងវិនិច្ឆ័យពីសេចក្តីប្រឹងប្រែង និងសកម្មភាពរបស់មនុស្ស។

ការបកប្រែផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ព្រះជាម្ចាស់នឹងប្រើភ្លើងក្នុងការបង្ហាញពីគុណភាពនៃកិច្ចការងាររបស់ទ្រង់»។
1 Corinthians 3:14
ព័ត៌មានទូទៅ៖
ពាក្យ «អ្នកណាម្នាក់» និង «នរណាមួយ» និង «គាត់» និង «គាត់ផ្ទាល់» សំដៅលើអ្នកជឿ។
អាចទ្រាំបាន
កិច្ចការនៅចុងក្រោយ ឬ «កិច្ចការនៅមានជីវិត»។
ប្រសិនបើ កិច្ចការអ្នកណាត្រូវឆេះអស់
នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត: «ប្រសិនបើភ្លើងបំផ្លាញកិច្ចការនរណាម្នាក់» ឬ «ប្រសិនបើភ្លើងដុតកម្ទេចកិច្ចការនរណាម្នាក់»។
អ្នកនោះនឹងឈឺចាប់ចំពោះការបាត់បង់
នាមអរូប «ការបាត់បង់» អាចត្រូវបង្ហាញជាមួយកិរិយាសព្ទ «បាត់»។ ការបកប្រែផ្សេងទៀត: «អ្នកនោះនិងបាត់រង្វាន់»។
ប៉ុន្តែ គាត់ខ្លួនឯងនឹងបានសង្គ្រោះ
នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត: «ប៉ុន្តែព្រះនឹងសង្គ្រោះគាត់វិញ»។
1 Corinthians 3:16
តើបងប្អូន មិនដឹងទេឬអីថា បងប្អូនជាព្រះវិហាររបស់ព្រះជាម្ចាស់
និងជាកន្លែងដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គង់នៅក្នុងបងប្អូន?
លោកប៉ូលកំពុងស្តីបន្ទោសដល់ក្រុមជំនុំកូរិនថូស។ ការបកប្រែផ្សេងទៀត: «បងប្អូនធ្វើហាក់បីដូចជាមិនដឹងថាអ្នកជាព្រះវិហាររបស់ព្រះជាម្ចាស់
និងជាកន្លែងដែលព្រះវិញ្ញាណគង់នៅក្នុងបងប្អូនអ៊ីចឹង!»
1 Corinthians 3:18
សូមកុំបញ្ឆោតខ្លួនឯងឲ្យសោះ
គ្មាននរណាគួរជឿការពាក្យកុហកដែលបានកុហកខ្លួនឯងថាមានប្រាជ្ញាក្នុងលោកីយ៍នេះទេ។
ក្នុងជំនាន់នេះ
អាស្រ័យទៅលើរបៀបរបស់មនុស្ស អ្នកដែលមិនជឿសម្រេចចិត្តថា អ្វីជាប្រាជ្ញា។
សូមឲ្យគាត់ត្រឡប់ទៅជាអ្នក «លីលា» វិញចុះ
មនុស្សម្នាក់នោះគួរមានឆន្ទៈក្នុងការទទួលពាក្យពីអ្នកមិនជឿហៅគាត់ថាជាអ្នកលីលា។
ព្រះអង្គយកកលល្បិចរបស់ពួកអ្នកប្រាជ្ញមកផ្ចាញ់ពួកគេផ្ទាល់
ព្រះអង្គដាក់អន្ទាក់មនុស្សដែលគិតថាពួកគេឆ្លាតហើយប្រើប្រាស់គម្រោងការរបស់គេផ្ទាល់ដើម្បីចាប់ពួកគេវិញ។
ព្រះអម្ចាស់ជ្រាបថាគំនិតរបស់ពួកអ្នកប្រាជ្ញគ្មានខ្លឹមសារអ្វីទេ
ព្រះអម្ចាស់ជ្រាបថា អ្វីដែលមនុស្សគិតថាគម្រោងការពួកគេឆ្លាតវៃនឹងត្រលប់ទៅជាគ្មានខ្លឹមសារវិញ។
គ្មានខ្លឹមសារ
គ្មានប្រយោជន៍
ទ្រង់ជាព្រះគ្រិស្ត ហើយព្រះគ្រិស្តជាព្រះ
អ្នកជាកម្មសិទ្ធិព្រះគ្រិស្ត ហើយព្រះគ្រិស្តជាកម្មសិទ្ធិព្រះ។
1 Corinthians 3:21
បងប្អូនជារបស់ព្រះគ្រិស្ត ហើយព្រះគ្រិស្តជារបស់ព្រះជាម្ចាស់
«បងប្អូនជាកម្មសិទ្ធិរបស់ព្រះគ្រិស្ត ហើយព្រះគ្រិស្តជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់»

---

4 [1]នេះគឺជាអ្វីដែលមនុស្សគួរឲ្យតម្លៃដល់យើង ក្នុងនាមជាអ្នកបម្រើរបស់ព្រះគ្រិស្ត និងអ្នកមើលខុសត្រូវក្នុងការដ៏អាថ៌កំបាំងនៃសេចក្តីពិតរបស់ព្រះជាម្ចាស់។
[2]តាមរបៀបនេះ នេះគឺជាគុណសម្បត្តិសម្រាប់អ្នកមើលខុសត្រូវ គឺពួកគេត្រូវមានចិត្តស្មោះត្រង់។
[3]ប៉ុន្តែ សម្រាប់ខ្ញុំវិញ វាជារឿងតូចតាចទេដែលខ្ញុំនឹងបារម្ភពីការវិនិច្ឆ័យពីបងប្អូន ឬពីមនុស្សឯទៀត។ ដ្បិត ខ្ញុំក៏មិនដែលវិនិច្ឆ័យខ្លួនឯងនោះទេ។
[4]ខ្ញុំក៏អត់ដឹងពីការចោទប្រកាន់ដែលធ្វើទាស់នឹងខ្ញុំ ប៉ុន្តែ ការនេះមិនមែនមានន័យថា ខ្ញុំគ្មានទោសនោះទេ។ គឺព្រះអម្ចាស់ទេដែលជាអ្នកវិនិច្ឆ័យខ្ញុំវិញ។
[5]ដូច្នេះ ចូរកុំថ្លែងពាក្យវិច្ឆ័យពីអ្វីមួយមុនពេលមកដល់ ហើយមុនពេលព្រះអម្ចាស់យាងត្រឡប់មកវិញ។ ព្រះអង្គនឹងនាំពន្លឺមកទីដែលលាក់កំបាំង ក្នុងភាពងងឹត ហើយបើកបង្ហាញគោលបំណងនៃដួងចិត្តដែរ។ គ្រប់គ្នានឹងទទួលការសរសើរមកពីព្រះជាម្ចាស់។
[6]បងប្អូនអើយ ឥឡូវនេះខ្ញុំបានអនុវត្តគោលការណ៍នេះជាមួយខ្លួនខ្ញុំ និងជាមួយលោកអាប៉ូឡូស មកនិយាយជាឧទាហរណ៍ សម្រាប់ជាប្រយោជន៍ដល់បងប្អូន ដូច្នេះតាមរយៈពួកយើងបងប្អូននឹងរៀនពីអត្ថន័យនៃពាក្យដែលនិយាយថា៖ «មិនត្រូវឲ្យមាននរណាអួតខ្លួនដោយកាន់ជើងម្នាក់ ហើយប្រឆាំងនឹងម្នាក់ទៀតដែរ។[7]ដ្បិត តើអ្នកណានឹងឃើញភាពខុសគ្នារវាងខ្លួនអ្នក និងអ្នកដទៃ? អ្វីៗដែលអ្នកបានទទួល តើការទាំងនោះមិនមែនបានមកដោយឥតបង់ថ្លៃទេឬអី? ប្រសិនបើបងប្អូនបានទទួលដោយមិនបង់ថ្លៃ ហេតុអ្វីបានជាអ្នកបែរជាមានអំនួត ទាំងខ្លួនមិនបានធ្វើអ្វីសោះដូច្នេះ?
[8]បងប្អូនបានអ្វីៗទាំងអស់ដែលបងប្អូនប្រាថ្នាហើយ! ហើយបងប្អូនបានក្លាយជាអ្នកមានដែរហើយ! បងប្អូនក៏បានសោយរាជ្យលើអ្វីៗទាំងនោះ និងឃ្លាតឆ្ងាយពីយើងដែរ! ពិតណាស់ ខ្ញុំក៏ប្រាថ្នាឲ្យអ្នកបានសោយរាជ្យ ដើម្បីឲ្យពួកយើងអាចសោយរាជ្យជាមួយបងប្អូនដែរ។[9]ដ្បិត ខ្ញុំគិតថា ព្រះជាម្ចាស់ប្រទានឲ្យយើងមានតួនាទីជាសាវ័ក ដើម្បីដើរតួចុងក្រោយ គឺទុកដូចជាអ្នកដែលត្រូវគេកាត់ទោសប្រហារជីវិត។ យើងប្រៀបដូចជាទស្សនីយភាពដល់មនុស្សក្នុងលោកីយ៍នេះ និងពួកទេវតាផង។
[10]ពួកយើងលីលា ដោយព្រោះព្រះគ្រិស្ត ប៉ុន្តែ បងប្អូនវិញមានប្រាជ្ញាក្នុងព្រះគ្រិស្តវិញ។ ពួកយើងខ្សោយ ប៉ុន្តែ បងប្អូនមានកម្លាំង បងប្អូនបានទទួលសិរីរុងរឿង ប៉ុន្តែ ពួកយើងបានទទួលឈ្មោះមិនល្អវិញ។[11]មកដល់នៅពេល និងម៉ោងនេះ ពួកយើងឃ្លាន ហើយស្រេក ខ្វះសម្លៀកបំពាក់ មានគេវាយដំយើង ហើយរស់នៅអនាថាផងដែរ។
[12]ពួកយើងធ្វើការដោយនឿយហត់ តាមរយៈដៃរបស់យើង។ ពេលគេជេរយើង យើងបានពរវិញ។ ពេលគេបៀតបៀន យើងស៊ូទ្រាំ។[13]ពេលគេនិយាយបង្ខូចយើង យើងនិយាយដោយសប្បុរសវិញ។ យើងបានត្រឡប់ទៅជា ដូចអ្វីដែលគេបានគិតថា ជាសំរាមរបស់លោកីយ៍ និងជាមនុស្សគ្មានគេរាប់រក។
[14]ខ្ញុំមិនបានសរសេរការទាំងនេះ ដើម្បីឲ្យបងប្អូនបាក់មុខនោះទេ ប៉ុន្តែ ដើម្បីកែតម្រូវបងប្អូន ដែលដូចជាកូនជាទីស្រឡាញ់របស់ខ្ញុំ។[15]ទោះបីជាបងប្អូនមានអ្នកណែនាំមួយម៉ឺននាក់ក្នុងព្រះគ្រិស្តក៏ដោយ ក៏បងប្អូនគ្មានឪពុកច្រើនដែរ។ ដ្បិតខ្ញុំបានក្លាយជាឪពុកបងប្អូនក្នុងព្រះគ្រិស្តយេស៊ូ តាមរយៈការនាំដំណឹងល្អ។[16]ដូច្នេះ ខ្ញុំសុំទូន្មានបងប្អូនថា សូមយកតម្រាប់តាមខ្ញុំ។
[17]នេះហើយជាមូលហេតុ ដែលខ្ញុំចាត់លោកធីម៉ូថេដែលជាកូនដ៏ជាទីស្រឡាញ់និងស្មោះត្រង់របស់ខ្ញុំក្នុងព្រះអម្ចាស់។ គាត់នឹងរំលឹកបងប្អូនអំពីរបៀបក្នុងព្រះគ្រិស្ត ដូចជាអ្វីដែលខ្ញុំបានបង្រៀនដល់ពួកគេនៅគ្រប់ទីកន្លែង និងគ្រប់ក្រុមជំនុំផង។[18]ឥឡូវនេះ មានបងប្អូនខ្លះបានក្លាយទៅជាក្រអឺតក្រទម ដោយគិតថាខ្ញុំនឹងមិនត្រឡប់មករកបងប្អូនវិញទេ។
[19]ប៉ុន្តែ ខ្ញុំនឹងមករកបងប្អូនឆាប់ៗខាងមុខនេះ ប្រសិនបើ ព្រះអម្ចាស់សព្វព្រះហឫទ័យ។ ដូច្នេះ ខ្ញុំនឹងបានដឹង គឺមិនត្រឹមតែបានឮពាក្យសម្តីរបស់ពួកអ្នកដែលក្រអឺតក្រទមប៉ុណ្ណោះទេ ប៉ុន្តែ ខ្ញុំក៏ឃើញទាំងអំណាចរបស់គេផង។[20]ដ្បិតព្រះរាជ្យរបស់ព្រះជាម្ចាស់មិនស្ថិតលើពាក្យសម្តីនោះទេ ប៉ុន្តែ នៅលើអំណាចវិញ។[21]តើបងប្អូនចង់បានអ្វី? តើគួរឲ្យខ្ញុំមករកបងប្អូនដោយរំពាត់ ឬមកជាមួយដោយសេចក្តីស្រឡាញ់ និងចិត្តស្លូតបូត?។

---

1 Corinthians 4:1
ប្រយោគភ្ជាប់
ដើម្បីគ្រាន់តែជាការរំលឹកមនុស្សដើម្បីកុំឲ្យមានសេចក្តីអំនួតចំពោះអ្នកដែលបានបង្រៀន
និងអ្នកដែលបានធ្វើពិធីជ្រមុជទឹកសម្រាប់ពួកគេ។
លោកប៉ូលរំលឹកដល់ក្រុមជំនុំកូរិនថូសទាំងអស់ថា
អ្នកជឿទាំងអស់ជាអ្នកបម្រើដែលដាក់ខ្លួន។
អ្វីជាតម្រូវការនៃអ្នកបម្រើ
លោកប៉ូលកំពុងនិយាយពីខ្លួនលោកក៏ដូចជាលោកកំពុងនិយាយពីអ្នកដទៃផ្សេងទៀត
ការបកប្រែផ្សេងទៀត: «ពួកយើងត្រូវបានតំរូវឲ្យមាន»។
1 Corinthians 4:3
ពាក្យសំដីរបស់ខ្ញុំ
ខ្ញុំនឹងបារម្ភពីការវិនិច្ឆ័យពីបងប្អូន
លោកប៉ូលកំពុងប្រៀបធៀបពីភាពខុសគ្នារវាងការវិនិច្ឆ័យរបស់មនុស្ស
និងការវិនិច្ឆ័យរបស់ព្រះ។
ការវិនិច្ឆ័យរបស់មនុស្សមិនមានសារៈសំខាន់ទេបើប្រៀបផ្ទឹមពីការវិនិច្ឆ័យដ៏ពិតរបស់ព្រះចំពោះមនុស្ស។
ខ្ញុំក៏អត់ដឹងពីការចោទប្រកាន់ដែលធ្វើទាស់នឹងខ្ញុំ
ខ្ញុំមិនដែលធ្លាប់ឮនរណាម្នាក់ចោទប្រកាន់ខ្ញុំពីការធ្វើអ្វីខុសនោះទេ។

generated on Wed Sep 10 16:16:32 2025

ការនេះមិនមែនមានន័យថា ខ្ញុំគ្មានទោសនោះទេគឺព្រះអម្ចាស់ទេដែលជាអ្នកវិនិច្ឆ័យខ្ញុំវិញ
ការខ្វះនៃការចោទប្រកាន់មិនបានបញ្ជាក់ថាខ្ញុំគ្មានកំហុសនោះទេ។
ព្រះអម្ចាស់ជ្រាបថា ខ្ញុំមានទោស ឬមិនមានទោស។
1 Corinthians 4:5
ដូច្នេះ
ដោយសារអ្វីដែលខ្ញុំទើបបាននិយាយនោះជាសេចក្ដីពិត
ព្រះអង្គនឹងនាំពន្លឺមកទីដែលលាក់កំបាំង ក្នុងភាពងងឹត
ហើយបើកបង្ហាញគោលបំណងនៃដួងចិត្តដែរ
ពាក្យ «នាំពន្លឺមកទីដែលលាក់កំបាំង ក្នុងភាពងងឹត»
ជាការប្រៀបធៀបមួយដើម្បីធ្វើឲ្យមនុស្សគ្រប់គ្នាបានដឹងពីអ្វីដែលជាការលាក់កំបាំង។
ពាក្យ «ដួងចិត្ត» ជាការប្រៀបធៀបនៃចិត្តគំនិត និងចេតនារបស់មនុស្ស។
ការបកប្រែផ្សេងទៀត: «ដូចជាពន្លឺដែលចែងចាំងលើអ្វីមួយក្នុងភាពងងឹត
ព្រះទ្រង់និងបង្ហាញពីសេចក្ដីលាក់កំបាំងដែលមនុស្សបានធ្វើ
ក៏នឹងបង្ហាញពីគម្រោងការដ៏លាក់កំបាំងដែលមនុស្សបានមានផងដែរ»។
1 Corinthians 4:6
បងប្អូនអើយ
នេះមានន័យថាជាគ្រិស្តបរិស័ទដែលរួមជំនឿ រួមមានទាំងបុរស និងស្ត្រី។
សម្រាប់ជា
ជាប្រយោជន៍របស់អ្នក
ដ្បិតអ្នក...មាននូវអ្វីដែលអ្នកមិនមាន...អ្នកទទួលដោយមិនបង់ថ្លៃ...បែរជាមានអំនួត...ខ្លួនមិនបានធ្វើអ្វីសោះដូច្នេះ
លោកប៉ូលកំពុងនិយាយទៅក្រុមជំនុំកូរិនថូសដូចជានិយាយទៅកាន់មនុស្សតែម្នាក់
ជាឧទាហរណ៍ «អ្នក» ជាឯកវចនៈ។
ដ្បិត នរណាធ្វើឲ្យអ្នកបានខ្ពង់ខ្ពស់?
លោកប៉ូលស្ដីបន្ទោសដល់ក្រុមជំនុំកូរិនថូសដែលបានគិតថាពួកគេល្អប្រសើរជាងអស់អ្នកដែលបានបង្រៀនពួកគេ
ការបកប្រែផ្សេងទៀត: «ដ្បិត គ្មានអ្វីខុសប្លែកគ្នារវាងអ្នក និងអ្នកដទៃឡើយ» ឬ
«ដ្បិត អ្នកក៏មិនខ្ពង់ខ្ពស់ ជាជាងអ្នកដទៃដែរ»។
តើការទាំងនោះមិនមែនបានមកដោយឥតបង់ថ្លៃទេឬអី?
លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ថា
ពួកគេមិនបានបង់ថ្លៃនូវអ្វីដែលពួកគេមាននោះទេ។ ការបកប្រែផ្សេងទៀត:
«គ្រប់អ្វីៗដែលអ្នកមាន ជាអ្វីៗដែលអ្នកបានទទួលដោយឥតបង់ថ្លៃ» ឬ
«ព្រះបានផ្ដល់ឲ្យអ្នកនូវអ្វីៗដែលមានដោយឥតបង់ថ្លៃ!»។
ហេតុអ្វីបានជាអ្នកបែរជាមានអំនួត ទាំងខ្លួនមិនបានធ្វើអ្វីសោះដូច្នេះ?
លោកប៉ូលស្ដីបន្ទោសពួកគេចំពោះសេចក្ដីអំនួតនូវអ្វីដែលពួកគេមាន។
ការបកប្រែផ្សេងទៀត: «អ្នកមិនគួរមានអំនួតចំពោះអ្វីដែលអ្នកមិនបានធ្វើសោះ» ឬ
«អ្នកគ្មានសិទ្ធិមានអំនួតទេ!»
ចំពោះអ្នកមិនបានទទួលទេឬអី
ឃ្លាថា «បានធ្វើដូច្នេះ»
សំដៅលើការទទួលដោយឥតបង់ថ្លៃចំពោះអ្វីដែលពួកគេមាន។
ការបកប្រែផ្សេងទៀត: «ចំពោះអ្នកមិនបានទទួលដោយឥតបង់ថ្លៃទេឬអី» ឬ
«ទាំងខ្លួនមិនបានបង់ថ្លៃផង»។
1 Corinthians 4:8
ព័ត៌មានទូទៅ៖
លោកប៉ូលប្រើការមិនសមហេតុនេះដើម្បីធ្វើឲ្យក្រុមជំនុំកូរិនថូសមានការអៀសខ្លួន
និងដើម្បីឲ្យពួកគេដឹងថាពួកគេកំពុងធ្វើបាបនៅពេលពួកគេមានអំនួតលើខ្លួនឯង
និងការបង្រៀនរបស់ពួកគេផងដែរ។
ព្រះដាក់ពួកយើងជាសាវកជាទស្សនីយភាព
លោកប៉ូលបង្ហាញពីរបៀបពីរយ៉ាងដែលព្រះឲ្យពួកសាវករបស់ទ្រង់ធ្វើជាទស្សនីភាពសំរាប់ពិភពលោក
ដាក់ពួកយើងជាសាវកជាទស្សនីភាព
ព្រះបានបង្ហាញដល់សាវកគឺដូចជាអ្នកជាប់ទោសដែលត្រូវបណ្ដើរជាចុងក្រោយក្នុងក្បួនដង្ហែរជ័យជំនះ
ដែលត្រូវបានធ្វើឲ្យអាម៉ាស់មុខ មុនពេលកាត់ទោសប្រហារជីវិត។
ទុកដូចជាអ្នកដែលត្រូវគេកាត់ទោសប្រហារជីវិត
ព្រះដាក់សាវកជាទស្សនីភាពទុកដូចជាអ្នកដែលនឹងត្រូវកាត់ទោសប្រហារជីវិត។
ដល់លោកីយ៍ ដល់ទេវតា និងដល់មនុស្សសញ្ញាតិ
អាចមានន័យថាទី១ «លោកីយ៍» ទាំងពីរមានឫទ្ធិបដិហារលើពីធម្មជាតិ «ទេវតា»
នឹង ធម្មជាតិ «មនុស្សសញ្ញាតិ» ឬ ទី២ ជាតារាងសមាសធាតុទាំងបីយ៉ាង
«ដល់លោកីយ៍ ដល់ទេវតា និងដល់មនុស្សសញ្ញាតិ»។
1 Corinthians 4:10
ពួកយើងលីលា...មានឈ្មោះមិនល្អ
លោកប៉ូលប្រើការមិនសមហេតុផលទៅកាន់ក្រុមជំនុំកូរិនថូសដើម្បីឲ្យពួកយកគេបាក់មុខ

ដូច្នេះ ពួកគេនិងអាចគិតពីអ្វីដែលលោកកំពុងនិយាយ។
អ្នកបានទទួលសិរីរុងរឿង
មនុស្សចាត់ទុកអ្នកក្នុងក្រុមជំនុំកូរិនថូសជាមនុស្សសំខាន់
ពួកយើងបានទទួលឈ្មោះមិនល្អ
មនុស្សបំបាក់មុខយើងជាសាវក។
មកដល់នៅពេល និងម៉ោងនេះ
រហូតមកដល់ឥឡូវ ឬ «ដល់ឥឡូវ»។
ពួកយើងត្រូវគេវាយដំ
នេះសំដៅទៅលើការវាយដោយដៃ មិនប្រើរំពាត់ ឬ ព្រនង់។
នេះអាចបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«មនុស្សវាយពួកយើង»។
ពួកយើងក៏អនាថាដែរ
លោកប៉ូលមានន័យថា ពួកគេមានកន្លែងស្នាក់នៅ ប៉ុន្តែ
ពួកគេត្រូវរើពីកន្លែងមួយទៅកន្លែងមួយទៀត។ ពួកគេមិនមានផ្ទះស្ថិតស្ថេរនោះទេ។
1 Corinthians 4:12
ពេលគេជេរយើង យើងបានពរ
នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត «ពេលមនុស្សជេរពួកយើង
យើងប្រទានពរពួកគេវិញ» ឬ «ពេលមនុស្សមិនរាប់រកពួកយើង
យើងប្រទានពរពួកគេវិញ»។
ពួកយើងត្រូវបានគេបៀតបៀន
នេះអានបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត:
«ពេលមនុស្សបៀតបៀនយើង»។
ពេលគេនិយាយបង្ខូចយើង
«ពេលមនុស្សនិយាយបង្ខូចយើង»។
យើងបានត្រឡប់ទៅជា ដូចអ្វីដែលគេបានគិតថា ជាសំរាមរបស់លោកីយ៍ និងជាមនុស្សគ្មានគេរាប់
រក រហូតមកដល់ឥឡូវនេះ
មនុស្សបានពិចារណាពីយើង ហើយពួកគេនៅតែពិចារណាលើយើងទៀត
ក៏ជាសំរាមរបស់លោកីយ៍នេះ។
1 Corinthians 4:14
ខ្ញុំមិនបានសរសេរការទាំងនេះ ដើម្បីឲ្យបងប្អូនបាក់មុខនោះទេ ប៉ុន្តែ ដើម្បីកែតម្រូវបងប្អូន
ខ្ញុំគ្មានចេតនាឲ្យអ្នកបាក់មុខនោះទេ ប៉ុន្តែ ដើម្បីឲ្យអ្នកមានការរីកចម្រើនវិញ ឬ
«ខ្ញុំមិនបានព្យាយាមបំបាក់មុខអ្នកនោះទេ ប៉ុន្តែ ខ្ញុំចង់កែតម្រូវអ្នកវិញ» ។
កែតម្រូវ
«ដាស់តឿន»
មានអ្នកណែនាំមួយម៉ឺននាក់
នេះជាការនិយាយបំប៉ោងតួលេខនៃចំនួនមនុស្សដែលណែនាំពួកគេ
ដើម្បីបញ្ជាក់ពីសារសំខាន់នៃឪពុកខាងវិញ្ញាណតែមួយ។ ការបកប្រែផ្សេងទៀត:
«មានអ្នកណែនាំជាច្រើន» ឬ «ហ្វូងមនុស្សដ៏ធំមួយនៃអ្នកណែនាំ» «»
កូន...ឪពុក
ដោយសារលោកប៉ូលបាននាំអ្នកក្រុងកូរិនថូសថ្វាយព្រះគ្រិស្ត
ពួកគេហាក់បីដូចជាកូនខាងវិញ្ញាណរបស់លោកដូច្នោះដែរ។
ខ្ញុំបានក្លាយជាឪពុកបងប្អូនក្នុងព្រះគ្រិស្តយេស៊ូ តាមរយៈការនាំដំណឹងល្អ
លោកប៉ូលកំពុងបញ្ជាក់ថាទីមួយ
ទំនាក់ទំនងរបស់លោកជាមួយក្រុមជំនុំកូរិនថូសជាអ្វីដែលសំខាន់បំផុត
«ក្នុងព្រះគ្រិស្ត» ទីពីរ វាបានកើតឡើងដោយសារគាត់បាននាំដំណឹងល្អដល់ពួកគេ
ការបកប្រែផ្សេងទៀត:
ការបកប្រែផ្សេងទៀត:
ខ្ញុំបានភ្ជាប់អ្នកមកជាមួយព្រះគ្រិស្តនៅពេលខ្ញុំបានណែនាំអ្នកពីដំណឹងល្អគឺថាខ្ញុំជាម្នាក់
1 Corinthians 4:17
ជាកូនដ៏ជាទីស្រឡាញ់និងស្មោះត្រង់របស់ខ្ញុំក្នុងព្រះអម្ចាស់
ជាអ្នកដែលខ្ញុំស្រឡាញ់ និងជាអ្នកដែលខ្ញុំបង្រៀនអំពីព្រះអម្ចាស់
ក៏ជាកូនផ្ទាល់របស់ខ្ញុំផងដែរ។
ឥឡូវនេះ
ពាក្យនេះបង្ហាញថាលោកប៉ូលកំពុងបូរប្រធានបទរបស់លោកដើម្បីស្ដីបន្ទោសនូវឥរិយាបថក្រអឺតក្រទមរប
1 Corinthians 4:19
ខ្ញុំនឹងមករកបងប្អូន
ខ្ញុំនឹងសួរសុខទុក្ខបងប្អូន។
បងប្អូនចង់បានអ្វី?

generated on Wed Sep 10 16:16:32 2025

លោកប៉ូលបានធ្វើការអំពាវនាវចុងក្រោយមួយទៅកាន់ក្រុមជំនុំកូរិនថូស
ដូចតែលោកធ្លាប់បានស្តីបន្ទោសពួកគេចំពោះកំហុសដែលពួកគេបានធ្វើកាលពីមុន។
ការបកប្រែផ្សេងទៀត: «ប្រាប់ខ្ញុំតើបងប្អូនចង់ឃើញអ្វីកើតឡើងឥឡូវនេះ»។
តើគួរឲ្យខ្ញុំមករកបងប្អូនដោយរំពាត់ ឬមកជាមួយដោយសេចក្តីស្រឡាញ់ និងចិត្តស្លូតបូត?
លោកប៉ូលកំពុងផ្តល់ឲ្យពួកក្រុមជំនុំកូរិនថូសនូវឥរិយាបទផ្ទុយគ្នាពីរយ៉ាងដែលលោកអាចប្រើពេលលោកនៅក្បែរពួកគេនៅឡើយ។

---

5 [1]យើងបានឮដំណឹងថា ក្នុងចំណោមបងប្អូន កើតមានរឿងអសីលធម៌ខាងផ្លូវភេទ ជាអំពើកាមគុណ ទោះបីជាក្នុងសាសន៍ដទៃក៏មិនដែលមានបែបនេះដែរ។
ដំណឹងនោះគឺថា មានម្នាក់ក្នុងចំណោមបងប្អូន បានរួមរ័ក្សជាមួយប្រពន្ធរបស់ឪពុកខ្លួន។[2]បងប្អូនក៏ក្រអឺក្រទមខ្លាំងទៀត! តើបងប្អូនមិនគួរតែកាន់ទុក្ខជំនួសវិញទេឬអី?
ម្នាក់ដែលបានប្រព្រឹត្តអំពើថោកទាបនេះ ត្រូវដេញចេញពីចំណោមបងប្អូន។
[3]ទោះបីជា ខ្ញុំមិនបាននៅជាបងប្អូនខាងឯរូបកាយ ប៉ុន្តែខ្ញុំនៅជាមួយបងប្អូនខាងវិញ្ញាណខ្ញុំវិញ ហើយខ្ញុំក៏បានដាក់ទោសដល់ម្នាក់ដែលប្រព្រឹត្តអំពើបែបនោះ គឺដូចជាខ្ញុំ
បាននៅជាមួយបងប្អូនដែរ។[4]ពេលបងប្អូនជួបជុំគ្នា ក្នុងនាមរបស់ព្រះអម្ចាស់យេស៊ូ វិញ្ញាណខ្ញុំក៏នៅទីនោះផងដែរ គឺក្នុងអំណាចរបស់ព្រះអម្ចាស់យេស៊ូរបស់យើង
ក៏ដូចជាការដាក់ទោសដល់អ្នកនោះដែរ។[5]ខ្ញុំត្រូវតែបញ្ជូនម្នាក់នេះទៅសាតាំង ដើម្បីឲ្យរូបកាយរបស់គាត់វិនាស តែវិញ្ញាណរបស់គាត់នឹងទទួលការសង្គ្រោះនៅថ្ងៃ
ព្រះអម្ចាស់។
[6]អំនួតរបស់បងប្អូនមិនល្អទេ។ តើបងប្អូនមិនដឹងទេឬអីថាមេតែបន្តិចអាចធ្វើឲ្យម្សៅទាំងមូលដោរឡើងបាន?[7]ចូរជម្រះខ្លួនឲ្យស្អាតជាចេញពីមេចាស់នេះ ដើម្បីឲ្យបងប្អូន
បានទៅជានំប័ុងដែលគ្មានមេ។ ដ្បិត ព្រះគ្រិស្តបានធ្វើជាយញ្ញបូជារបស់យើងក្នុងពិធីបុណ្យចម្លង។[8]ដូច្នេះ ចូលយើងសាទរពិធីបុណ្យរំលង ដោយមិនមែនជាមួយម្សៅចាស់
ឬមេនៃអំពើអាក្រក់ និងអំពើថោកទាបនោះទេ។ ផ្ទុយទៅវិញ ចូរយើងប្រើនំប័ុងឥតមេជាសញ្ញានៃចិត្តស្មោះត្រង់វិញ។
[9]ក្នុងសំបុត្ររបស់ខ្ញុំ មិនបានសរសេរថា កុំទាក់ទងនឹងមនុស្សដែលប្រព្រឹត្តកាមគុណឲ្យសោះនោះទេ។[10]មិនមានន័យសំដៅទៅលើមនុស្សដែលប្រព្រឹត្ត កាមគុណទូទៅក្នុង
លោកីយ៍នេះទេ ឬអ្នកលោភលន់ ឬអ្នកប្លន់ទ្រព្យ ឬអ្នកថ្វាយបង្គំព្រះក្លែងក្លាយ បើបងប្អូនត្រូវតែនៅឲ្យឆ្ងាយពីមនុស្សទាំងនោះ មានន័យថាបងប្អូន ត្រូវចាកចេញពីពិភព
លោកនេះហើយ។
[11]ប៉ុន្តែ ពេលនេះ ខ្ញុំសរសេរមកកាន់បងប្អូន មិនឲ្យទាក់ទងជាមួយអ្នកណាដែលបានហៅថាបងប្អូន ប៉ុន្តែ អ្នកនោះរស់នៅក្នុងជីវិតកាមគុណ ឬមានចិត្តលោភលន់
ឬថ្វាយបង្គំព្រះក្លែងក្លាយ ឬជេរប្រមាថគេ ឬប្រមឹក ឬប្លន់យកទ្រព្យគេ។ សូមកុំហូបអាហាររួមជាមួយជនប្រភេទនេះឲ្យសោះ។[12]ដ្បិត
តើខ្ញុំរួមជាមួយក្នុងការដាក់ទោសដល់អ្នកដែលនៅក្រៅក្រុមជុំនំទេ? ផ្ទុយទៅវិញ តើបងប្អូនមិនត្រូវដាក់ទោសដល់អ្នកដែលនៅខាងក្រៅនោះទេ?[13]ប៉ុន្តែ ព្រះជាម្ចាស់នឹង
វិនិច្ឆ័យទោសពួកខាងក្រៅ។ «ចូរបណ្តេញមនុស្សអាក្រក់ចេញពីចំណោមអ្នករាល់គ្នាវិញ»។

---

1 Corinthians 5:1
ប្រយោគភ្ជាប់
ឥឡូវលោកប៉ូលបញ្ជាក់យ៉ាងច្បាស់លាស់ពីអំពើបាបរបស់ពួកគេដែលលោកបានឮ
និងពីការដែលអ្នកជឿក្នុងក្រុមជំនុំកូរិនថូសក្រអឺតក្រទមលើការទទួលយកបុរសម្នាក់នោះ
និងអំពើបាបរបស់គាត់។
ទោះបីជាក្នុងសាសន៍ដទៃក៏មិនដែលមានបែបនេះដែរ
នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត:
«បើទោះជាសាសន៍ដទៃក៏មិនអនុញ្ញាតឲ្យធ្វើដែរ»។
ជាបុរសម្នាក់ដែលបានរួមរ័ក្សជាមួយប្រពន្ធរបស់ឪពុកខ្លួន
បុរសម្នាក់ក្នុងចំណោមអ្នករាល់គ្នាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយប្រពន្ធរបស់ឪពុកខ្លួន។
ប្រពន្ធរបស់ឪពុកខ្លួន
ជាប្រពន្ធរបស់ឪពុកខ្លួន ប៉ុន្តែ ប្រហែលមិនមែនជាម្តាយបង្កើតរបស់ខ្លួនទេ។
តើបងប្អូនមិនគួរតែកាន់ទុក្ខជំនួសវិញទេឬអី?
ការប្រើសំណួរឥតបម្រុងទុកនេះត្រូវបានប្រើជាការស្តីបន្ទោសដល់ក្រុមជំនុំកូរិនថូស។
ការបកប្រែផ្សេងទៀត: «បងប្អូនគួរតែកាន់ទុក្ខជំនួសការនេះវិញ!
ម្នាក់ដែលបានប្រព្រឹត្តអំពើថោកទាបនេះ ត្រូវដេញចេញពីចំណោមបងប្អូន
នេះត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត
«បងប្អូនត្រូវដេញចេញចំពោះអ្នកណាម្នាក់ដែលបានប្រព្រឹត្តអំពើថោកទាបនេះក្នុងចំណោមបងប្អូន»។
1 Corinthians 5:3
ខ្ញុំនៅជាមួយបងប្អូនខាងវិញ្ញាណ
ខ្ញុំនៅជាមួយអ្នកខាងឯវិញ្ញាណ
ការនៅជាមួយពួកគេខាងឯវិញ្ញាណតំណាងឲ្យការយកចិត្តទុកដាក់
ឬការចង់នៅជាមួយពួកគេ។ ការបកប្រែផ្សេងទៀត:
«ខ្ញុំយកចិត្តទុកដាក់ចំពោះអ្នក» ឬ «ខ្ញុំចង់នៅជាមួយអ្នក»។
ហើយខ្ញុំក៏បានដាក់ទោសដល់ម្នាក់ដែលប្រព្រឹត្តអំពើបែបនោះដែរ
អាចមានអត្ថន័យថា ទី១
«ខ្ញុំបានសម្រេចចិត្តចំពោះអ្វីដែលគួរតែធ្វើលើអ្នកដែលបានប្រព្រឹត្តអំពើបែបនេះហើយ»
ឬ «ខ្ញុំបានរកឃើញអ្នកដែលបានប្រព្រឹត្តអំពើថោកទាបនេះហើយ»។
ពេលបងប្អូនជួបជុំគ្នា
នៅពេលអ្នកនៅជុំគ្នា ឬ «នៅពេលអ្នកជួបជុំគ្នា»។
ក្នុងនាមរបស់ព្រះអម្ចាស់យេស៊ូ
អាចមានអត្ថន័យថា ទី១
ក្នុងនាមរបស់ព្រះអម្ចាស់យេស៊ូជាការប្រៀបធៀបយ៉ាងច្បាស់លាស់មួយថា
ជាតំណាងសិទ្ធិអំណាចរបស់ទ្រង់។ ការបកប្រែផ្សេងទៀត
ការបកប្រែផ្សេងទៀត: «ប្រសិនបើអ្នកចង់ ខ្ញុំអាចមកដាក់ទណ្ឌកម្មអ្នក ឬ
ខ្ញុំអាចមកដើម្បីបង្ហាញអ្នកពីសេចក្តីស្រឡាញ់យ៉ាងខ្លាំងចំពោះអ្នកដោយចិត្តស្លូតបូតជាមួយអ្នក»។
ចិត្តស្លូតបូត
ចិត្តសប្បុរស ឬ «ចិត្តទន់ភ្លន់»។
លោកប៉ូលកំពុងផ្តល់ឲ្យពួកក្រុមជំនុំកូរិនថូសនូវឥរិយាបទផ្ទុយគ្នាពីរយ៉ាងដែលលោកអាចប្រើពេលលោកនៅក្បែរពួកគេនៅឡើយ។

«ជាមួយអំណាចនៃព្រះអម្ចាស់យេស៊ូ» ឬ ទី២
«ការជួបជុំគ្នាក្នុងនាមព្រះអម្ចាស់រួមបញ្ចូលទាំងការជួបជុំក្នុងការថ្វាយបង្គំទ្រង់ផងដែរ»។
ការបកប្រែផ្សេងទៀត: «ដើម្បីថ្វាយបង្គំព្រះអម្ចាស់យេស៊ូនៃយើង»។
បញ្ជូនម្នាក់នេះទៅសាតាំង
ការបញ្ជូនម្នាក់នេះទៅសាតាំង
ជាការតំណាងឲ្យការមិនអនុញ្ញាតឲ្យបុរសម្នាក់នេះអាចរួមចំណែកជាមួយក្រុមរបស់ពួកគេ
ដើម្បីឲ្យសាតាំងអាចធ្វើបាបគាត់បាន។ ការបកប្រែផ្សេងទៀត:
«ឲ្យបុរសម្នាក់នេះចេញពីក្រុមរបស់អ្នកដើម្បីឲ្យសាតាំងអាចធ្វើបាបគាត់បាន»។
ដើម្បីឲ្យរូបកាយរបស់គាត់វិនាស
អាចមានអត្ថន័យថា ទី១ «សាច់ឈាម» សំដៅទៅលើរូបរាងកាយរបស់គាត់
ការបកប្រែផ្សេងទៀត «ដើម្បីឲ្យសាតាំងធ្វើបាបរូបរាយកាយរបស់គាត់» ទី២
«សាច់ឈាម» ជាការប្រៀបធៀបពីអំពើបាបតាំងពីកំណើតមកម្លេ៉ះ។
ការបកប្រែផ្សេងទៀត: «ដើម្បីឲ្យអំពើបាបដែលមានតាំងពីកំណើតត្រូវបានបំផ្លាញ»
ឬ «តែកុំឲ្យគាត់អាចបន្តរស់នៅក្នុងជីវិតដែលមានអំពើបាបតាំងពីកំណើតមក»។
តែវិញ្ញាណរបស់គាត់នឹងទទួលការសង្គ្រោះនៅថ្ងៃព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត
«តែព្រះនឹងសង្គ្រោះវិញ្ញាណរបស់គាត់នៅថ្ងៃព្រះអម្ចាស់»។
1 Corinthians 5:6
អំនួតរបស់បងប្អូនមិនល្អទេ
អំនួតរបស់អ្នកអាក្រក់
តើបងប្អូនមិនដឹងទេឬអីថាមេតែបន្តិចអាចធ្វើឲ្យម្សៅទាំងមូលដោរឡើងបាន?
គ្រាន់តែការសាយភាយមេតែបន្តិចធ្វើអោយម្សៅទាំងមូលដោរជានំប័ុងបាន
ដូច្នេះអំពើបាបតូចមួយអាចប៉ះទង្គិចដល់ការប្រកបជាមួយអ្នកជឿទាំងមូលបាន។
ព្រះគ្រិស្តបានធ្វើជាយញ្ញបូជារបស់យើងក្នុងពិធីបុណ្យចម្លង
តែចៀមនៃពិធីបុណ្យចម្លងបានគ្របបាំងអំពើបាបនៃសាសអ៊ីុស្រាអែលដោយជំនឿជារាងរាល់ឆ្នាំ
ដូច្នេះ
ការសុគតរបស់ព្រះគ្រិស្តបានគ្របបាំងគ្រប់ទាំងអំពើបាបអ្នកដែលបានទុកចិត្តលើព្រះគ្រិស្តដោយជំនឿអ
នេះអាចបញ្ជាក់ក្នុងទំរង់សកម្ម ការបកប្រែផ្សេងទៀត
«ព្រះអម្ចាស់បានលះបង់ព្រះគ្រិស្ត ជាចៀមនៃពិធីបុណ្យចម្លងយើង»។
1 Corinthians 5:9
មនុស្សដែលប្រព្រឹត្តកាមគុណ
នេះសំដៅលើមនុស្សដែលប្រកាសថាជឿលើព្រះគ្រិស្ត
ប៉ុន្តែបែបជាមានឥរិយាបទបែបនេះវិញ។
មនុស្សដែលប្រព្រឹត្ត កាមគុណក្នុងលោកីយ៍នេះ

generated on Wed Sep 10 16:16:32 2025

មនុស្សដែលបានជ្រើសរើសក្នុងការរស់នៅដោយកាមគុណ ជាអ្នកដែលមិនជឿ។
អ្នកលោភលន់
អស់អ្នកដែលលោភលន់ ឬ
«អស់អ្នកដែលមានឆន្ទៈមិនស្មោះត្រង់ក្នុងការចង់បានរបស់អ្នកដទៃ»។
អ្នកប្លន់ទ្រព្យ
នេះមានន័យថា មនុស្សដែលបោកប្រាស់ចង់បានទ្រព្យអ្នកដទៃ។
បងប្អូន ត្រូវចាកចេញពីពិភពលោកនេះហើយ
អ្នកត្រូវតែចៀសឲ្យផុតពីមនុស្សទាំងអស់។
1 Corinthians 5:11
ប្រយោគភ្ជាប់
លោកប៉ូលប្រាប់ពួកគេពីរបៀបស្តីប្រដៅអ្នកជឿដែលបដិសេធការកែតម្រូវចំពោះការពាក់ព័ន្ធ
និងអំពើបាបពីមុនៗដែលបានធ្វើចំពោះអ្នកដទៃ។
អ្នកណាដែលបានហៅ
អ្នកណាដែលបានហៅខ្លួនឯង។
បងប្អូន
នេះមានន័យថា ការរួមប្រកបជាមួយគ្រិស្តបរិស័ទ មិនថាបុរស ឬស្ត្រី។
ដ្បិត តើខ្ញុំរួមជាមួយក្នុងការដាក់ទោសដល់អ្នកដែលនៅក្រៅក្រុមជំនុំទេ?
លោកប៉ូលចង់បញ្ជាក់ថា
លោកមិនមែនជាអ្នកដែលដាក់ទោសអ្នកដែលនៅខាងក្រៅក្រុមជំនុំនោះទេ។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ខ្ញុំមិនមែនជាអ្នកដែលគួរតែដាក់ទោសមនុស្សដែលមិនមែនជាកម្មសិទ្ធិរបស់ក្រុមជំនុំនោះទេ»។
តើបងប្អូនមិនត្រូវដាក់ទោសដល់អ្នកដែលនៅខាងក្នុងនោះទេឬអី?
ដោយសារប៉ូលកាំមុងស្រួចស្រាវ
«អ្នករាល់គ្នាគួរតែដឹងថាជាអ្នកទេតើដែលនឹងដាក់ទោសដល់អ្នកដែលនៅខាងក្នុងក្រុមជំនុំ»។

---

6 [1]នៅពេលអ្នកម្នាក់នៅក្នុងចំណោមបងប្អូន មានទំនាស់ជាមួយអ្នកដទៃ ហេតុអ្វីបានជាអ្នករាល់គ្នាទៅរកចៅក្រម ដែលនៅខាងក្រៅដែលមិនមែនជាអ្នកជឿឲ្យកាត់ក្តី
ជាជាងនាំមកឯអ្នកជឿកាត់ក្តីវិញ?[2]តើបងប្អូនមិនដឹងទេឬអីថា ពួកអ្នកជឿនឹងមានចំណែកកាត់ក្តីពិភពលោកនេះ? ប្រសិនបើ ដូច្នេះ បងប្អូនអាចវិនិច្ឆ័យលោកីយ៍មែន
តើបងប្អូនគ្មានលទ្ធិភាពសូម្បីដោះស្រាយបញ្ហាតូចតាចបែបនេះទេឬអី?[3]តើបងប្អូនមិនដែលដឹងទេថា យើងក៏មានវិនិច្ឆ័យទេវតាដែរ? តើចង់បានប៉ុណ្ណាទៀត
ទើបយើងមានសិទ្ធិដើម្បីវិនិច្ឆ័យរឿងតូចៗនៃជីវិតមែនទេ?
[4]បើដូច្នេះមែន បងប្អូនត្រូវការអ្វីដើម្បីកាត់ក្តីដែលទាក់ទងទៅនឹងជីវិតប្រចាំថ្ងៃ ប៉ុន្តែហេតុអ្វីបានជាបងប្អូននាំរឿងរ៉ាវទាំងនោះ ទៅឯអ្នកដែលមិ
នបានឈរនៅក្នុងក្រុមជំនុំទៅវិញ?[5]ខ្ញុំនិយាយការទាំងនេះ ដើម្បីឲ្យអ្នកមានការខ្មាស។ តើគ្មាននរណានៅក្នុងចំណោមអ្នករាល់គ្នាមានប្រាជ្ញាគ្រប់គ្រាន់
ដើម្បីដោះស្រាយរឿងបងប្អូនឯងដែលទាស់គ្នាទេឬអី?[6]ប៉ុន្តែ បងប្អូនបែរជាប្តឹងផ្តល់អ្នកជឿម្នាក់ ហើយទៅរកអ្នកជឿឲ្យកាត់ក្តីទៀត!
[7]ពិតណាស់ ប្រសិនបើមានការទាស់ទែងគ្នារវាងបងប្អូន ដែលជាគ្រិស្តបរិស័ទ នោះបងប្អូនបានបរាជ័យរួចស្រេចបាត់ទៅហើយ។ ហេតុអ្វីមិនទទួលយកការឈឺចាប់
និងកំហុសខ្លួនវិញ? ហើយហេតុអ្វីបានជាអនុញ្ញាតឲ្យខ្លួនឯង ស្ថិតនៅក្រោមការបោកប្រាស់បែបនេះ?[8]ប៉ុន្តែ បងប្អូនបានធ្វើខុស ហើយបានបោកប្រាស់អ្នកដទៃ
ហើយពួកគេគឺជាបងប្អូនរបស់ខ្លួនឯងផងដូច្នេះ!
[9]តើបងប្អូនមិនដឹងទេឬអីថា ពួកអ្នកមិនសុចរិតនឹងមិនអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមរតកបានទេ? មិនត្រូវជឿលើពាក្យកុហកឡើយ។ អស់អ្នក
ដែលប្រព្រឹត្តអំពើអសីលធម៌ខាងផ្លូវភេទ ពួកថ្វាយបង្គំព្រះក្លែងក្លាយ ពួកសហាយស្មន់ ពួកជនពាល ពួកអ្នករួមសង្វាសនឹងភេទដូចគ្នា[10]ពួកចោរប្លន់ ពួកលោភលន់ ពួក
ប្រមឹក ពួកជេរប្រមាថ ពួកប្លន់យកទ្រព្យគេ ពុំអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ទុកជាមរតកឡើយ។[11]បងប្អូនខ្លះក៏ជាមនុស្សប្រភេទនោះដែរ។ ប៉ុន្តែ
បងប្អូនត្រូវបានសម្អាត់ឲ្យស្អាត់ហើយ អ្នករាល់គ្នាបានបរិសុទ្ធ គឺបងប្អូនបានត្រឹមត្រូវជាមួយព្រះជាម្ចាស់ ក្នុងព្រះនាមរបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត
ហើយតាមរយៈព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។
[12]«ដ្បិត ខ្ញុំមានសិទ្ធិក្នុងការធ្វើគ្រប់ការទាំងអស់» ប៉ុន្តែ មិនមែនគ្រប់យ៉ាងសុទ្ធតែអត់ប្រយោជន៍នោះទេ។ «ដ្បិត ខ្ញុំមានសិទ្ធិក្នុងការធ្វើការទាំងអស់» ប៉ុន្តែ
ខ្ញុំមិនឲ្យសិទ្ធិទាំងនោះ ក្លាយទៅជាមេត្រួតត្រាលើខ្ញុំឡើយ។[13]«អាហារគឺសម្រាប់ក្រពះ ហើយក្រពះវិញក៏សម្រាប់ដាក់អាហារដែរ» ប៉ុន្តែ
ព្រះជាម្ចាស់នឹងធ្វើការផ្សេងពីរបៀបទាំងពីរនោះ។ ឯរូបកាយវិញ មិនមែនសម្រាប់ប្រព្រឹត្តអំពើអសីលធម៌ខាងផ្លូវភេទទេ។ ផ្ទុយទៅវិញ រូបកាយគឺសម្រាប់ព្រះអម្ចាស់
ហើយព្រះអម្ចាស់នឹងផ្គត់ផ្គង់ដល់រូបកាយផងដែរ។
[14]ព្រះជាម្ចាស់ដែលបានប្រោសព្រះអម្ចាស់ ហើយព្រះអង្គប្រោសយើងឲ្យរស់ឡើងវិញដោយសារអំណាចរបស់ព្រះអង្គដែរ។[15]តើបងប្អូនមិនដឹងទេឬអីថា រូបកាយរបស់
បងប្អូនជារបស់ព្រះគ្រិស្ត? តើគប្បីឲ្យខ្ញុំយករូបកាយរបស់ព្រះគ្រិស្តទៅរកស្ត្រីពេស្យាឬទេ? សូមកុំឲ្យការនេះកើតឡើង!
[16]តើអ្នកមិនដឹងទេឬអីថា អ្នកដែលបានរួមដំណេកជាមួយស្ត្រីពេស្យានឹងបានត្រឡប់ទៅជាសាច់តែមួយជានាង? ដូចដែលបទគម្ពីរបានចែងថា៖
«អ្នកទាំងពីរបានត្រឡប់ទៅជាសាច់តែមួយ»។[17]ប៉ុន្តែ អ្នកណារួមរស់ជាមួយព្រះអម្ចាស់នឹងត្រឡប់ទៅជាវិញ្ញាណតែមួយជាមួយព្រះអង្គ។
[18]ចូររត់ចេញពីអំពើប្រាសចាកសីលធម៌! គ្រប់អំពើបាបផ្សេងទៀត ដែលមនុស្សប្រព្រឹត្តជាអំពើបាបក្រៅរូបកាយ។ ប៉ុន្តែ អ្នកណាប្រព្រឹត្តអំពើប្រាសចាកសីលធម៌ អ្នកនោះ
ប្រព្រឹត្តអំពើបាប ដែលនាំឲ្យវិនាសដល់រូបកាយរបស់ខ្លួន។
[19]តើបងប្អូនមិនដឹងទេឬអីថា រូបកាយរបស់អ្នករាល់គ្នាគឺជាព្រះវិហាររបស់ព្រះវិញ្ញាណបរិសុទ្ធ ព្រះអង្គរស់នៅក្នុងអ្នក ហើយបងប្អូនក៏បានទទួលព្រះជាម្ចាស់ដែរ?
តើបងប្អូនមិនដឹងទេឬអីថា បងប្អូនមិនមែនជារបស់ខ្លួនឯងទេ?[20]ដ្បិត បងប្អូនត្រូវបានទិញជាមួយនឹងតម្លៃមួយដ៏ថ្លៃ។ ដូច្នេះ
ហើយសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយរូបកាយរបស់បងប្អូន។

---

1 Corinthians 6:1
ប្រយោគភ្ជាប់
លោកប៉ូលបន្ទាប់មកពន្យល់ពីរបៀបដែលអ្នកជឿត្រូវដោះស្រាយបញ្ហាជាមួយអ្នកជឿដទៃ
ទំនាស់
ការមិនយល់ព្រម ឬ ការឈ្លោះប្រកែក
ហេតុអ្វីបានជាអ្នករាល់គ្នាទៅរក...អ្នកជឿកាត់ក្តីវិញ?
លោកប៉ូលបានបញ្ជាក់ថាគ្រិស្តបរិស័ទត្រូវតែដោះស្រាយបញ្ហាក្នុងចំណោមពួកគេ។
ការបកប្រែផ្សេងទៀត: «គាត់មិនគួរទៅរក...អ្នកជឿកាត់ក្តីវិញ!» ឬ
«គាត់គួរតែកោតខ្លាចដល់ព្រះ និងមិនទៅរក...អ្នកជឿកាត់ក្តីវិញ!»
បងប្អូនមិនដឹងទេឬអីថា ពួកអ្នកជឿនឹងមានចំណែកកាត់ក្តីពិភពលោកនេះ?
លោកប៉ូលកំពុងធ្វើឲ្យក្រុមជំនុំកូរិនថូសត្រូវខ្មាស់ចំពោះទង្វើដែលពួកគេធ្វើដូចជាមិនដឹងអីសោះ
ប្រសិនបើ ដូច្នេះ បងប្អូនអាចវិនិច្ឆ័យលោកីយ៍មែន
តើបងប្អូនគ្មានលទ្ធិភាពសូម្បីដោះស្រាយបញ្ហាតូចតាចបែបនេះទេឬអី?
ដោយសារពួកគេនិងត្រូវបានផ្តល់អោយនូវទំនួលខុសត្រូវដ៏ធំសម្បើមនៅពេលក្រោយ
ឥឡូវនេះពួកគេត្រូវមានទំនួលខុសត្រូវលើការតូចតាចនេះសិន។
ការបកប្រែផ្សេងទៀត: «អ្នកនិងវិនិច្ឆ័យលោកីយ៍នៅពេលអនាគត
ដូច្នេះអ្នកអាចមានលទ្ធភាពក្នុងការដោះស្រាយបញ្ហាឥឡូវនេះ»។
រឿងតូចៗនៃជីវិត
ចម្លើយការឈ្លោះប្រកែកអំពីអ្វីដែលអ្នកត្រូវធ្វើក្នុងជីវិតនេះទៅ
តើបងប្អូនមិនដែលដឹងទេឬថា យើងក៏មានវិនិច្ឆ័យទេវតាដែរ?
លោកប៉ូលមានការភ្ញាក់ផ្អើលថា ពួកគេទំនងជាមិនដឹងទេថា ការបកប្រែផ្សេងទៀត:
«អ្នកដឹងហើយថា យើងនិងវិនិច្ឆ័យពួកទេវតា»។
យើងនឹងវិនិច្ឆ័យ
លោកប៉ូលនិយាយរួមទាំងខ្លួនលោក និងក្រុមជំនុំកូរិនថូសដែរ
តើចង់បានប៉ុណ្ណាទៀត ទើបយើងមានសិទ្ធិដើម្បីវិនិច្ឆ័យរឿងតូចៗនៃជីវិតមែនទេ?
ដោយសារពួកគេនិងត្រូវបានផ្តល់ឲ្យនូវទំនួលខុសត្រូវដ៏ធំសម្បើមនៅពេលក្រោយ
ឥឡូវនេះ ពួកគេត្រូវមានទំនួលខុសត្រូវលើការតូចតាចនេះសិន។
ការបកប្រែផ្សេងទៀត «ដោយសារយើងដឹងថាយើងនិងវិនិច្ឆ័យលើទេវតា
យើងក៏អាចដឹងយ៉ាងប្រាកដថាព្រះក៏និងឲ្យយើងវិនិច្ឆ័យលើរឿងតូចៗនៃជីវិតនេះដែរ»។
1 Corinthians 6:4
បើដូច្នេះមែន បងប្អូនត្រូវការអ្វីដើម្បីកាត់ក្តីដែលទាក់ទងទៅនឹងជីវិតប្រចាំថ្ងៃ ប៉ុន្តែ
ហេតុអ្វីបានជាបងប្អូននាំរឿងរ៉ាវទាំងនោះ ទៅឯអ្នកដែលមិនបានឈរនៅក្នុងក្រុមជំនុំទៅវិញ?

generated on Wed Sep 10 16:16:32 2025

អាចមានអត្ថន័យថា ទី១ «នេះជាសំនួរឥតបានព្រៀងទុក» ឬ ទី២
នេះជាការថ្លែងការមួយ
«ពីអតីតកាលបងប្អូនធ្លាប់បានដោះស្រាយបញ្ហាតូចតាចនេះនៅក្នុងជីវិត
បងប្អូនមិនបានដោះដៃចេញក្នុងការដោះស្រាយទំនាស់រវាងគ្រិស្តបរិស័ទទៅឲ្យអ្នកមិនជឿដោះស្រាយនោះទេ»
ឬ ទី៣ នេះជាបញ្ញត្តិ «នៅពេលបងប្អូនដោះស្រាយបញ្ហាតូចតាចនេះនៅក្នុងជីវិត
វាក៏ដូចជាការបានដោះស្រាយបញ្ហាចំពោះអ្នកដែលមិនបានឈរនៅក្នុងក្រុមជំនុំដែរ
គឺថាអ្នកបានដោះស្រាយទំនាស់ទាំងនោះ»។
បើដូច្នេះមែន បងប្អូនត្រូវការអ្វីដើម្បីកាត់ក្តីដែលទាក់ទងទៅនឹងជីវិតប្រចាំថ្ងៃ
ប្រសិនបើ អ្នកត្រូវបានហៅដើម្បីធ្វើការសម្រេចចិត្តអំពីជីវិតប្រចាំថ្ងៃ ឬ
«អ្នកត្រូវតែដោះស្រាយបញ្ហាតូចតាចនៅក្នុងជីវិតនេះ»។
ហេតុអ្វីបានជាបងប្អូននាំរឿងរ៉ាវទាំងនោះ ទៅឯអ្នកដែលមិនបានឈរនៅក្នុងក្រុមជំនុំទៅវិញ?
លោកប៉ូលកំពុងស្តីបន្ទោសក្រុមជំនុំកូរិនថូសចំពោះអ្នកបៀបដែលពួកគេដោះស្រាយបញ្ហានេះ។
អាចមានអត្ថន័យថា ទី១
«បងប្អូនគួរតែបញ្ឈប់ការយករឿងរ៉ាវទាំងនេះទៅឲ្យអ្នកដែលនៅខាងក្រៅក្រុមជំនុំទៅ»
ឬ ទី២
«បងប្អូនគួរតែយករឿងរ៉ាវទាំងនេះទៅកាន់សមាជិកនៃក្រុមជំនុំបើទោះជាអ្នកនោះមិនមែនជាអ្នកជឿក៏ដោយ»
ឲ្យអ្នកខ្មាស
ឲ្យអ្នកគ្មានកិត្តិយស ឬ «ដើម្បីបង្ហាញពីការបរាជ័យក្នុងបញ្ហានេះ»។
តើគ្មាននរណានៅក្នុងចំណោមអ្នករាល់គ្នាមានប្រាជ្ញាគ្រប់គ្រាន់
ដើម្បីដោះស្រាយរឿងបងប្អូនឯងដែលទាស់គ្នាទេឬអី?
លោកប៉ូលធ្វើឲ្យក្រុមជំនុំកូរិនថូសខ្មាស។ ការបកប្រែផ្សេងទៀត:
«អ្នកគួរតែខ្មាសដែលមិនអាចរកអ្នកជឿដែលមានប្រាជ្ញាដើម្បីដោះស្រាយជម្លោះរវាងអ្នកជឿបាន»
បងប្អូន
នេះមានន័យថាគ្រិស្តបរិស័ទទាំងអស់ ទាំងបុរស នឹងស្ត្រី។
ដើម្បីដោះស្រាយរឿង
ការឈ្លោះប្រកែក ឬ ការមិនយល់ព្រម។
បងប្អូនបែរជាប្តឹងផ្តល់អ្នកជឿម្នាក់ ហើយទៅរកអ្នកមិនជឿឲ្យកាត់ក្តីទៀត!
អ្នកជឿដែលមានទំនាស់ចំពោះគ្នាទៅវិញទៅមកហើយសូមឲ្យអ្នកមិនជឿវិនិច្ឆ័យដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវ
1 Corinthians 6:7
បានបរាជ័យរួចស្រេចបាត់ទៅហើយ
បានចាញ់បាត់ទៅហើយ
ហេតុអ្វីមិនទទួលយកការឈឺចាប់ និងកំហុសខ្លួនវិញ? ហើយហេតុអ្វីបានជាអនុញ្ញាតឲ្យខ្លួនឯង
ស្ថិតនៅក្រោមការបោកប្រាស់បែបនេះ?
លោកប៉ូលបន្តការធ្វើអោយក្រុមជំនុំកូរិនថូសនៅតែខ្មាស ការបកប្រែផ្សេងទៀត
«វាគួរតែប្រសើរជាងក្នុងការឲ្យអ្នកដ៏ទៃធ្វើកំហុសចំពោះអ្នក
និងបោកប្រាស់អ្នកជាជាងយកពួកគេទៅវិនិច្ឆ័យ»
ជាបងប្អូនរបស់ខ្លួនឯង
គ្រប់អ្នកជឿលើព្រះគ្រិស្តសុទ្ធតែជាបងប្អូនប្រុសស្រីចំពោះគ្នាទៅវិញទៅមក
«គឺជាបងប្អូនអ្នកជឿខ្លួនឯង»។
1 Corinthians 6:9
តើបងប្អូនមិនដឹងទេឬអីថា
លោកប៉ូលបញ្ជាក់ថាពួកគេគួរតែត្រូវបានដឹងពីសេចក្តីពិតនេះ
ការបកប្រែផ្សេងទៀត: «អ្នកបានដឹងសេចក្តីពិតហើយថា»។
នឹងជាមរតក
ការទទួលបាននូវអ្វីដែលព្រះបានសន្យាចំពោះអ្នកជឿដែលត្រូវបាននិយាយពីមរតកខាងលោកិយ
និងភាពស្និទ្ធស្នាលពីក្រុមគ្រួសារណាមួយ។
នឹងមិនអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមរតកបានទេ
ព្រះមិនវិនិច្ឆ័យពួកគេថាជាអ្នកសុចរិតក្នុងពេលជំនំជម្រះនោះទេ
ហើយពួកគេនឹងមិនអាចទទួលបានជីវិតអស់កល្បនោះដែរ។
បុរសពេស្យាចា ពួកអ្នករួមសង្វាសនឹងភេទដូចគ្នា
អាចមានអត្ថន័យថា ទី១
នេះជាការឲ្យនិមន័យមួយសម្រាប់គ្រប់សកម្មភាពរួមសង្វាស
និងភេទដូចគ្នាទាំងអស់ ឬ ទី២ លោកប៉ូលបានឲ្យឈ្មោះសកម្មភាពពីរខុសគ្នា។
បុរសពេស្យាចា
អាចមានន័យថា ទី១ ជាបុរសដែលអនុញ្ញាតឲ្យបុរសដទៃទៀតដេកជាមួយពួកគេ ឬ
ទី២ ជាបុរសដែលអនុញ្ញាតឲ្យបុរសដ៏ទៃទៀតបង់លុយក្នុងការដេកជាមួយពួកគេ ឬ
ទី៣
ជាបុរសដែលអនុញ្ញាតឲ្យបុរសដទៃទៀតដេកជាមួយពួកគេដែលជាផ្នែកនៃសកម្មភាពពេស្យាចារ
ពួកអ្នករួមសង្វាសនឹងភេទដូចគ្នា
បុរសដែលដេកជាមួយបុរសដទៃទៀត។
ពួកចោរ
មនុស្សដែលលួចពីអ្នកដទៃ
ជាមនុស្សដែលមានបំណងចិត្តក្នុងការធ្វើអំពើអាក្រក់ក្នុងគោលបំណងយករបស់ទ្រព្យអ្នកដទៃ។
បងប្អូនត្រូវបានសម្អាតឲ្យស្អាតហើយ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះបានសម្អាតអ្នកហើយ»។
អ្នករាល់គ្នាបានបរិសុទ្ធ
នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះបានញែកបងប្អូនសំរាប់អង្គទ្រង់»។
ពាក្យដែលបកប្រែថា «សមាជិក» សំដៅលើអវៈជីវៈនៃរូបកាយ។
ការបដិសេធមិនឲ្យមានទំនាក់ទំនងផ្លូវភេទ

លោកប៉ូលប្រើសំនួរនេះដើម្បីរំលឹកដល់មនុស្សពីអ្វីមួយដែលពួកគេធ្លាប់បានដឹងហើយ។
ការបកប្រែផ្សេងទៀត: «បងប្អូនគួរតែដឹងថា
រូបកាយរបស់បងប្អូនជាកម្មសិទ្ធរបស់ព្រះគ្រិស្ត»។
តើគប្បីឲ្យខ្ញុំយករូបកាយរបស់ព្រះគ្រិស្តទៅរកស្ត្រីពេស្យាឬទេ? សូមកុំឲ្យការនេះកើតឡើង!
លោកប៉ូលប្រើសំនួរនេះដើម្បីបញ្ជាក់ពីការមិនត្រឹមត្រូវចំពោះនរណាមួយដែលខ្លួនជាកម្មសិទ្ធរបស់ព្រះគ្រិស្ត។
ការបកប្រែផ្សេងទៀត: «ខ្ញុំជាផ្នែកមួយនៃព្រះគ្រិស្ត ខ្ញុំនិងមិនយករូបកាយរបស់ខ្ញុំ
ឬខ្លួនរបស់ខ្ញុំឲ្យទៅពាក់ព័ន្ធជាមួយស្ត្រីពេស្យាឡើយ!» ឬ
«យើងជាផ្នែកនៃរូបកាយព្រះគ្រិស្ត យើងមិនត្រូវយករូបកាយរបស់យើង
ទៅពាក់ព័ន្ធជាមួយស្ត្រីពេស្យាឡើយ!»
សូមកុំឲ្យការនេះកើតឡើង!
ដែរគួរមិនឲ្យមានឡើយ! ឬ «យើងមិនត្រូវធ្វើយ៉ាងដូច្នេះឡើយ!»។
1 Corinthians 6:16
តើអ្នកមិនដឹងទេឬអីថា...មួយជានាង?
លោកប៉ូលផ្តើមបង្រៀនដល់ក្រុមជំនុំកូរិនថូសដោយការបញ្ជាក់ពីសេចក្តីពិតមួយ
ដែលពួកគេបានដឹងរួច។ «ខ្ញុំចង់រំលឹកដល់បងប្អូនថា...ជាមួយនាង»។
អ្នកដែលបានរួមដំណេកជាមួយស្ត្រីពេស្យានឹងបានត្រឡប់ទៅជាសាច់តែមួយជានាង
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទំរង់សកម្ម ការបកប្រែផ្សេងទៀត
«នៅពេលរូបកាយរបស់អ្នកបានរួមដំណេកជាមួយនិងរូបរាងកាយរបស់ស្ត្រីពេស្យាណាម្នាក់
នោះរូបកាយអ្នកទាំងពីរនឹងត្រលប់ទៅជារូបកាយតែមួយវិញ»។
អ្នកណារួមរស់ជាមួយព្រះអម្ចាស់នឹងត្រឡប់ទៅជាវិញ្ញាណតែមួយជាមួយព្រះអង្គ
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«នៅពេលព្រះអម្ចាស់ភ្ជាប់ព្រះវិញ្ញាណទ្រង់នៅក្នុងវិញ្ញាណមនុស្សណាម្នាក់
នោះវិញ្ញាណទាំងពីរនោះនឹងត្រលប់ទៅជាមួយវិញ»។
1 Corinthians 6:18
រត់ចេញពី
លោកប៉ូលនិយាយនរណាម្នាក់ដែលបដិសេធអំពើប្រាសចាកសីលធម៌ ដ្បិត
អ្នកនោះរត់ចេញយ៉ាងឆ្ងាយពីការគ្រោះថ្នាក់នេះ។ ការបកប្រែផ្សេងទៀត:
«ជៀសឲ្យឆ្ងាយពី»។
អំពើប្រាសចាកសីលធម៌! គ្រប់អំពើបាបផ្សេងទៀត ដែលមនុស្សប្រព្រឹត្តជាអំពើបាបក្រៅរូបកាយ
ប៉ុន្តែ
អាចមានន័យថា ទី១
លោកប៉ូលបង្ហាញថាអំពើប្រាសចាកសីលធម៌ពិតជាអាក្រក់ណាស់
[illegible] ប៉ុន្តែខ្លួនឯងក៏ត្រូវវិនាសដែរ ឬ ទី១
លោកប៉ូលកំពុងដកស្រង់ពាក្យសំដីពីអ្វីដែលក្រុមជំនុំបានគិត។
ការបកប្រែផ្សេងទៀត: «អំពើប្រាសចាកសីលធម៌! មានអ្នកខ្លះនិយាយថា
ជាអំពើបាបទាំងឡាយណាដែលនរណាម្នាក់ប្រព្រឹត្តខាងក្រៅរូបកាយ ប៉ុន្តែ
ខ្ញុំនិយាយថា»។
ជាអំពើបាបដែលនរណាម្នាក់ប្រព្រឹត្ត
ជាអំពើអាក្រក់ដែលនរណាម្នាក់ធ្វើ។
1 Corinthians 6:19
តើបងប្អូនមិនដឹងទេឬអីថា...ព្រះអង្គដែរ?...បងប្អូនមិនមែនជារបស់ខ្លួនឯងទេ?
លោកប៉ូលបន្តបង្រៀនដល់ក្រុមជំនុំកូរិនថូសដោយបញ្ជាក់ពីអ្វីដែលពួកគេបានដឹងហើយ។
ការបកប្រែផ្សេងទៀត: «ខ្ញុំចង់រំលឹកដល់បងប្អូន...ព្រះជាម្ចាស់ដែរ
ហើយអ្នកមិនមែនជារបស់ខ្លួនឯងទេ»។
រូបកាយរបស់បងប្អូន
[illegible]
ព្រះវិហារនៃព្រះវិញ្ញាណដ៏វិសុទ្ធ
ព្រះវិហារបង្ហាញពីភាពដ៏វិសុទ្ធនៃព្រះ ហើយជាកន្លែងដែលទ្រង់គង់នៅដែរ។
ដូចគ្នាដែរ រូបកាយអ្នកជឿនីមួយៗជាព្រះវិហាររបស់ព្រះ
ដោយសារព្រះវិញ្ញាណបរិសុទ្ធនៅក្នុងពួកគេ។
ដ្បិត បងប្អូនត្រូវបានទិញជាមួយនឹងតម្លៃមួយដ៏ថ្លៃ
ព្រះបានបង់ថ្លៃសំរាប់សិរីភាពដល់អ្នកជឿនៅក្នុងក្រុមជំនុំកូរិនថូសពីភាពជាទេសករនៃអំពើបាប។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត:
«ព្រះបានបង់ថ្លៃសំរាប់សិរីភាពអ្នក»។
ដូច្នេះ
ពីព្រោះអ្វីដែលខ្ញុំបាននិយាយជាសេចក្តីពិត។

---

7 [1]ទាក់ទងនឹងរឿងដែលអ្នកបានសរសេរមកខ្ញុំអំពី «គឺជាការល្អដែលបុរសមិនត្រូវពាល់មនុស្សស្ត្រី»។[2]ប៉ុន្តែ ដោយព្រោះមានការល្បួងជាច្រើនទៅលើការប្រាសចាក
សីលធម៌ បុរសម្នាក់ៗត្រូវមានប្រពន្ធផ្ទាល់ខ្លួន ហើយស្ត្រីម្នាក់ៗក៏ត្រូវមានប្តីផ្ទាល់ខ្លួនដែរ។
[3]ប្តីត្រូវបំពេញករណីយកិច្ចជាប្តីចំពោះប្រពន្ធរបស់ខ្លួន រីឯប្រពន្ធក៏ត្រូវធ្វើដូច្នោះចំពោះប្តីវិញដែរ។[4]ប្រពន្ធមិនមានសិទ្ធិអំណាចលើរូបកាយរបស់ខ្លួននោះទេ ប៉ុន្តែ
ប្តីមានសិទ្ធិលើរូបកាយនោះ ហើយប្តីក៏គ្មានសិទ្ធិអំណាចទៅលើរូបកាយរបស់ខ្លួនដែរ ប៉ុន្តែ ប្រពន្ធមានសិទ្ធិអំណាចលើរូបការរបស់ប្តីនោះដូចគ្នា។
[5]មិនត្រូវបង្អត់គ្នាទៅវិញទៅមកឡើយ លើកលែងតែព្រមព្រៀងគ្នានៅក្នុងកំឡុងពេលពិសេសណាមួយ។ សូមធ្វើការដូច្នេះចុះ ដើម្បីញែកខ្លួនរបស់អ្នកសម្រាប់អធិស្ឋាន។
បន្ទាប់មក អ្នកទាំងពីរចូលទៅរកគ្នាម្តងទៀត ធ្វើដូច្នេះសាតាំងនឹងមិនអាចល្បួងអ្នក ដោយព្រោះអ្នកខ្វះការគ្រប់គ្រងខ្លួនឯងឡើយ។[6]ប៉ុន្តែ ខ្ញុំនិយាយពីការទាំងនេះ ដោយ
បើកសិទ្ធិឲ្យបងប្អូន មិនមែនបង្គាប់បងប្អូនទេ។[7]ខ្ញុំធ្លាប់ប្រាថ្នាសូមឲ្យគ្រប់គ្នាបានដូចខ្ញុំដែរ។ ប៉ុន្តែ គ្រប់គ្នាមានអំណោយទានផ្សេងៗគ្នា មកពីព្រះជាម្ចាស់។ ម្នាក់ទទួលយ៉ាង
នេះ ម្នាក់ទៀតក៏ទទួលយ៉ាងនោះ។
[8]សម្រាប់អ្នកដែលនៅលីវ និងស្ត្រីមេម៉ាយ ខ្ញុំចង់និយាយថាល្អហើយដែលពួកគេអាចនៅលីវបាន គឺនៅលីវដូចខ្ញុំដែរ។[9]ប៉ុន្តែ បើគេមិនអាចគ្រប់គ្រងខ្លួនឯងបានទេ
ពួកគេគួររៀបការទៅ។ ព្រោះបើរៀបការប្រសើរជាងទុកឲ្យចិត្តនៅពុះកញ្ជ្រោលដដែរ។
[10]ឥឡូវ សម្រាប់អ្នកដែលរៀបការខ្ញុំសូមណែនាំយ៉ាងដូច្នេះវិញ មិនមែនមកពីខ្ញុំទេ តែមកពីព្រះអម្ចាស់វិញ ប្រពន្ធមិនត្រូវនៅបែកពីប្តីនោះទេ[11](ប៉ុន្តែ
ប្រសិនបើនាងនៅបែកពីប្តីមែន មិនត្រូវយកប្តីទៀតទេ នាងគួរតែកុំរៀបការម្តងទៀតធ្វើអ្វី ឬគួរតែទៅជានានិងប្តីវិញ) ហើយប្តីមិនត្រូវលែងលះប្រពន្ធដែរ។
[12]ប៉ុន្តែ ចំពោះអ្នកផ្សេងទៀត ខ្ញុំនិយាយ មិនមែនព្រះអម្ចាស់ទេ ប្រសិនបើ បងប្អូនណាម្នាក់មានប្រពន្ធដែលជាអ្នកមិនជឿ ហើយបើនាងពេញចិត្តរស់នៅជាមួយគាត់ ដូច្នេះ
បុរសនោះមិនគួរលែងលះនាងឡើយ។[13]ប្រសិនបើ ស្ត្រីណាម្នាក់មានប្តីដែលជាអ្នកមិនជឿ ហើយបើគាត់ពេញចិត្តនឹងរស់ជាមួយនាង ដូច្នេះ
ស្ត្រីនោះមិនគួរលែងលះប្តីឡើយ។[14]ដ្បិត ប្តីដែលមិនជឿត្រូវបានញែកដោយឡែក ដោយព្រោះប្រពន្ធរបស់គាត់ ហើយប្រពន្ធដែលមិនជឿត្រូវបានញែកដោយឡែក
ដោយព្រោះបងប្អូនប្រុសជាអ្នកជឿដែរ។ បើមិនដូច្នោះទេ កូនៗរបស់អ្នករាល់គ្នាមុខជាមិនបានស្អាតឡើង ប៉ុន្តែ ពួកគេត្រូវបានញែកដោយឡែកហើយ។
[15]ប៉ុន្តែ ប្រសិនបើប្តី ឬប្រពន្ធមិនជឿចង់បែក ចូរឲ្យពួកគាត់ទៅចុះ។ ក្នុងករណីនេះ បងប្អូនប្រុសស្រីមិនបានជាប់ចំណងសន្យាអ្វីឡើយ។
ព្រះជាម្ចាស់បានត្រាស់ហៅយើងដើម្បីរស់ក្នុងសេចក្តីសុខសាន្ត។[16]ដ្បិត តើបងប្អូនអាចដឹងបានយ៉ាងដូចម្តេចថា ប្រពន្ធអាចនឹងសង្គ្រោះប្តីរបស់ខ្លួនបាប? ឬ
តើបងប្អូនអាចដឹងបានយ៉ាងដូចម្តេចថា ប្តីអាចនឹងសង្គ្រោះប្រពន្ធរបស់ខ្លួន?
[17]ក្រៅពីនេះ ម្នាក់ៗត្រូវតែរស់នៅឲ្យបានស្របតាមព្រះអម្ចាស់បានប្រទានឲ្យម្នាក់ៗ ព្រះជាម្ចាស់បានត្រាស់ហៅ។ នេះគឺជាតួនាទីរបស់ខ្ញុំនៅក្រុមជំនុំទាំងអស់។
[18]តើមាននរណាបានកាត់ស្បែកពេលគាត់ទទួលជឿព្រះអង្គទេ? គាត់មិនគួរបង្ហាញថាគាត់មិនបានកាត់ស្បែកនោះទេ។ តើមាននរណាមិនបានកាត់ស្បែក
ពេលគាត់ទទួលជឿព្រះអង្គទេ? បើដូច្នេះ គាត់មិនបាច់កាត់ស្បែកទេ។[19]ដ្បិត ការកាត់ស្បែក ឬមិនបានកាត់ស្បែកមិនមែនជាបញ្ហាទេ។
អ្វីដែលជាបញ្ហានោះគឺការស្តាប់បង្គាប់តាមបទបញ្ជារបស់ព្រះជាម្ចាស់វិញទេ។
[20]ម្នាក់ៗគួរប្រកាន់ខ្ជាប់ក្នុងការត្រាស់ហៅ តាំងពីពេលព្រះជាម្ចាស់បានហៅអ្នកនោះមកក្នុងជំនឿ។
[21]តើព្រះជាម្ចាស់បានហៅអ្នកក្នុងកាលដែលអ្នកនៅជាទាសករនៅឡើយមែនទេ? កុំបារម្ភអំពីការនោះពេក។ ប៉ុន្តែ ប្រសិនបើអ្នកមិនមែនជាទាសករ
វាជាការល្អសម្រាប់ហើយ[22]ដ្បិត នរណាម្នាក់ដែលបានត្រាស់ហៅតាមរយៈព្រះអម្ចាស់ក្នុងភាពជាទាសករ នោះមានសេរីភាពក្នុងព្រះអម្ចាស់វិញ។ ដូចគ្នាផងដែរ
អ្នកដែលបានទទួលសេរីភាពដោយការជឿ អ្នកនោះបានក្លាយជាទាសកររបស់ព្រះគ្រិស្តវិញ។[23]អ្នកទាំងអស់គ្នាបានបង់ថ្លៃលោះរួចហើយ ដូច្នេះ
កុំឲ្យខ្លួនអ្នកក្លាយជាទាសកររបស់មនុស្សឡើយ។[24]បងប្អូនអើយ មិនថាបងប្អូនរស់នៅក្នុងភាពយ៉ាងណា នៅពេលព្រះជាម្ចាស់ត្រាស់ហៅបងប្អូននោះទេ បើបងប្អូនមាន
ភាពយ៉ាងណា ចូរម្នាក់ៗស្ថិតក្នុងភាពនោះ នៅចំពោះព្រះអង្គបែបនោះទៅ។

generated on Wed Sep 10 16:16:32 2025

[25]ឥឡូវនេះទាក់ទងនឹងអ្នកដែលមិនទាន់រៀបការ ខ្ញុំមិនបានទទួលបញ្ជាអ្វីពីព្រះអម្ចាស់ទេ។ ក៏ប៉ុន្តែ ខ្ញុំសូមជូនយោបល់ ក្នុងនាមម្នាក់ដែលព្រះអង្គមានព្រះហឫទ័យ
មេត្តាដល់ខ្ញុំ ដែលបងប្អូនអាចទុកចិត្តបាន។[26]ដូច្នេះ ខ្ញុំគិតថា ក្នុងពេលដែលមានវិបត្តិដែលកើតឡើងនៅពេលនេះ គឺជាការល្អសម្រាប់ឲ្យមនុស្សប្រុសនៅទំនេរល្អជាង។
[27]តើអ្នកមានចំណងទំនាក់ទំនងជាមួយមនុស្សស្រីមែនទេ? កុំរកដោះដៃពីនាងឡើយ។ តើអ្នកបានលែងប្រពន្ធមែនទេ? ដូច្នេះ កុំយកប្រពន្ធទៀតឡើយ។[28]ប៉ុន្តែ
ប្រសិនបើអ្នកបានរៀបការ អ្នកមិនបានធ្វើបាបអ្វីទេ។ ប្រសិនបើ មនុស្សស្រីនៅលីវមិនទាន់រៀបការ នោះនាងមិនបានធ្វើបាបទេ។ មែនហើយ ពួកអ្នករៀបការហើយ
មានបញ្ហាច្រើនណាស់ក្នុងជីវិត ខ្ញុំចង់ឲ្យអ្នកនៅឲ្យឆ្ងាយពីពួកគេ។
[29]បងប្អូនអើយ ខ្ញុំប្រាប់អ្នករាល់គ្នាថា ពេលវេលាកាន់តែខ្លីណាស់ហើយ។ អស់អ្នកដែលមានប្រពន្ធហើយ ត្រូវកាន់ចិត្តដូចជាគ្មានប្រពន្ធ។[30]អស់អ្នកដែលយំសោក ដូចជា
មិនយំសោក ហើយអស់អ្នកដែលអរសប្បាយ ដូចជាមិនអរសប្បាយ អស់អ្នកដែលទិញអ្វីមួយ ធ្វើដូចជាមិនមែនម្ចាស់ទ្រព្យឡើយ[31]ហើយអស់អ្នកដែលប្រើប្រាស់សម្បត្តិ
លោកីយ៍ ក៏ត្រូវកាន់ចិត្តដូចជាមិនបានប្រើប្រាស់ដែរ។ ដ្បិតពិភពលោកនេះប្រែប្រួល ហើយទីបញ្ចប់នឹងមកដល់ដែរ។
[32]ខ្ញុំចង់ឲ្យបងប្អូនមានសេរីភាពពីការខ្វល់ខ្វាយ។ អ្នកដែលមិនរៀបការត្រូវខ្វល់ខ្វាយជាមួយអ្វីនៅក្នុងព្រះអម្ចាស់ និងធ្វើយ៉ាងណាឲ្យព្រះអង្គសព្វព្រះហឫទ័យវិញ។[33]ប៉ុន្តែ
អ្នកដែលបានរៀបការហើយ ត្រូវខ្វល់ខ្វាយជាមួយអ្វីដែលនៅក្នុងលោកីយ៍វិញ គឺត្រូវធ្វើយ៉ាងណាឲ្យប្រពន្ធពេញចិត្ត[34]គាត់មានចិត្តបែងចែក។ មនុស្សស្រីដែលមិនរៀបការ
ឬស្ត្រីព្រហ្មចារី ត្រូវខ្វល់ខ្វាយពីអ្វីដែលនៅក្នុងព្រះអម្ចាស់ ដោយញែករូបកាយ ហើយវិញ្ញាណសម្រាប់ព្រះអង្គ។ ប៉ុន្តែ ស្ត្រីដែលរៀបការវិញ
គឺត្រូវខ្វល់ខ្វាយពីអ្វីដែលនៅក្នុងលោកីយ៍វិញ ធ្វើយ៉ាងណាដើម្បីឲ្យប្តីពេញចិត្ត។
[35]ខ្ញុំនិយាយការនេះ ដើម្បីជាប្រយោជន៍ដល់បងប្អូន ហើយវាមិនជាការដាក់កំហិត បង្ខិតបង្ខំលើបងប្អូនទេ។ តែខ្ញុំនិយាយអ្វីដែលត្រឹមត្រូវ
ដើម្បីឲ្យបងប្អូនបានថ្វាយខ្លួនដល់ព្រះអម្ចាស់ ដោយមិនមានការបង្ខិតបង្ខំ។
[36]ប៉ុន្តែ ប្រសិនបើនរណាម្នាក់គិតថា គាត់មិនបានប្រព្រឹត្ត និងគោរព គូដណ្តឹងរបស់ខ្លួនទេ ហើយបើនាងហួសអាយុនៃការរៀបការនោះ ដូច្នេះ កុំចាំទៀត
បុរសនោះគួរធ្វើតាមអ្វីដែលគាត់ចង់។ បែបនេះគាត់មិនបានធ្វើបាបទេ។ អ្នកទាំងពីរគួររៀបការ។[37]ប្រសិនបើ អ្នកនោះបានប្តេជ្ញាចិត្តយ៉ាងមុឺងម៉ាត់ ដោយគ្មាននរណាបង្ខំ គឺ
យល់ឃើញថា អាចទប់ចិត្តបាន ហើយសម្រេចចិត្តថានឹងមិនប៉ះពាល់គូដណ្តឹងរបស់ខ្លួនទេនោះ គាត់ធ្វើត្រឹមត្រូវហើយ។[38]ដូច្នេះ បើមានអ្នកផ្សេងណាមករៀបការ
ជាមួយគូដណ្តឹង គឺជាការប្រសើរ ហើយសម្រាប់អ្នកដែលជ្រើសរើសមិនរៀបការ រឹតតែប្រសើរជាងទៀត។
[39]ប្រពន្ធត្រូវនៅជាប់នឹងប្តីជានិច្ច ដរាបណាប្តីនៅរស់។ តែបើប្តីស្លាប់ នាងមានសេរីភាពរៀបការជាមួយនរណាក៏បាន ស្រេចតែចិត្តនាង ឲ្យតែរៀបការជាមួយអ្នកជឿ
ព្រះអម្ចាស់ដូចគ្នា។[40]ប៉ុន្តែ តាមការគិតរបស់ខ្ញុំ ប្រសិនបើ នាងមិនយកប្តីទៀតទេនោះ នាងនឹងបានសប្បាយជាង។ ខ្ញុំនិយាយដូច្នេះ ព្រោះខ្ញុំយល់ថា ខ្ញុំក៏មានព្រះវិញ្ញាណ
របស់ព្រះជាម្ចាស់គង់ជាមួយដែរ។

---

1 Corinthians 7:1

ប្រយោគភ្ជាប់

លោកប៉ូលផ្តល់ឲ្យអ្នកជឿពីការបង្រៀនពីអាពាហ៍ពិពាហ៍យ៉ាងច្បាស់លាស់មួយចំនួន
ឥឡូវ

លោកប៉ូលផ្តើមការណែនាំពីប្រធានបទថ្មីក្នុងការបង្រៀនរបស់លោក។

ទាក់ទងនឹងរឿងដែលអ្នកបានសរសេរមកខ្ញុំអំពី

ក្រុមជំនុំកូរិនថូសបានសរសេរសំបុត្រទៅលោកប៉ូល

ដើម្បីសូមចម្លើយពីសំណួរជាក់លាក់មួយចំនួន។

គឺជាការល្អដែលបុរសមិនត្រូវពាល់មនុស្សស្រី

អាចមានន័យថា ទី១

លោកប៉ូលកំពុងសម្រង់រកអត្ថន័យពីសំបុត្ររបស់ក្រុមជំនុំកូរិនថូស។

ការបកប្រែផ្សេងទៀត: «អ្នកបានសរសេរ

ជាការល្អដែលបុរសមិនត្រូវពាល់មនុស្សស្រី» ឬ ទី២

លោកប៉ូលកំពុងនិយាយពីការគិតរបស់លោក។ ការបកប្រែផ្សេងទៀត:
«ចម្លើយរបស់ខ្ញុំគឺថា ពិតណាស់ បុរសមិនត្រូវពាល់មនុស្សស្រីឡើយ»។

ជាការល្អ

ពិតជាមានប្រយោជន៍ណាស់

ដែលបុរស

អាចមានន័យថា ទី១ «បុរស» សំដៅលើបុរសដែលរៀនការហើយ

ការបកប្រែផ្សេងទៀត: «ជាប្តី» ឬ ទី២ «បុរស» សំដៅលើគ្រប់បុរសទាំងអស់។

មិនត្រូវពាល់មនុស្សស្រី

អាចមានន័ថា ទី១ «ពាល់មនុស្សស្រី» ជាការនិយាយឲ្យសមរម្យងាយស្រួលស្តាប់
ជាជាងការនិយាយទំនាក់ទំនងផ្លូវភេទ។ ការបកប្រែផ្សេងទៀត:
«គួរផ្អាកមានទំនាក់ទំនងផ្លូវភេទជាមួយប្រពន្ធរបស់គាត់មួយរយៈសិន» ឬ ទី២
«ពាល់មនុស្សស្រី» ជាការប្រៀបធៀបចំពោះការរៀបការ។ ការបកប្រែផ្សេងទៀត:
«មិនត្រូវរៀបការ»។

ប៉ុន្តែដោយព្រោះ

អាចមានន័យថា ទី១ លោកប៉ូលឆ្លើយតបពីអ្វីដែលក្រុមជំនុំកូរិនថូសបានសរសេរ
ការបកប្រែផ្សេងទៀត: «ជាការពិត ប៉ុន្តែ ដោយព្រោះ» ឬ ទី២
«លោកប៉ូលកំពុងនិយាយពីអ្វីដែលជាការគិតរបស់លោក»។

ប៉ុន្តែ ដោយព្រោះមានការល្បួងជាច្រើនទៅលើការប្រាសចាកសីលធម៌ បុរសម្នាក់ៗ

ប៉ុន្តែ ដោយព្រោះ សាតាំងល្បួងមនុស្សឲ្យប្រព្រឹត្តអំពើប្រាសចាកសីលធម៌
បុរសម្នាក់ៗ ឬ «ប៉ុន្តែ យើងមានបំណងក្នុងការប្រព្រឹត្តអំពើប្រាកចាក់សីលធម៌
ពីព្រោះអំពើបាបយើងតាំងពីដើមមក ដូច្នេះបុរសម្នាក់ៗ»។

1 Corinthians 7:3

ករណីយកិច្ច

ទាំងប្តី

នឹងទាំងប្រពន្ធតម្រូវឲ្យរួមដំណេកជាមួយគ្នាជាប្រចាំជាមួយប្តីប្រពន្ធរបស់ខ្លួន។

ប្រពន្ធក៏ត្រូវធ្វើដូច្នោះចំពោះប្តីវិញដែរ

ពាក្យ «ត្រូវបំពេញ» និង «ករណីយកិច្ច» ត្រូវយល់ពីប្រយោគដើម។

ការបកប្រែផ្សេងទៀត:

«ដូច្នោះប្រពន្ធគួរបំពេញករណីកិច្ចរបស់ខ្លួនចំពោះប្តីផងដែរ»។

1 Corinthians 7:5

មិនត្រូវបង្អត់គ្នាទៅវិញទៅមកឡើយ

ពាក្យ «បង្អត់»

មានន័យថាការរក្សាទុកអ្វីមួយពីនរណាម្នាក់ដែលអ្នកនោះមានសិទ្ធិក្នុងការទទួលបាន។

«មិនត្រូវបដិសេធក្នុងការទំនាក់ទំនងជាមួយប្តីប្រពន្ធរបស់ខ្លួនឡើយ»។

ដើម្បីញែកខ្លួនរបស់អ្នកសម្រាប់អធិស្ឋាន

ដើម្បីមានពេលពិសេសក្នុងការអធិស្ឋានឲ្យស៊ីុជម្រៅ។

ញែកខ្លួន

ប្តេជ្ញាចំពោះខ្លួនឯង។

ចូលទៅរកគ្នាម្តងទៀត

ដេកជាមួយគ្នាសារជាថ្មី។

ដោយព្រោះអ្នកខ្វះការគ្រប់គ្រងខ្លួនឯង

បន្ទាប់ពីប៉ុន្មានថ្ងៃកន្លងមក

នោះចំណង់ផ្លូវភេទរបស់អ្នកនិងពិបាកក្នុងការគ្រប់គ្រង់។

ខ្ញុំនិយាយពីការទាំងនេះ ដោយបើកសិទ្ធិឲ្យបងប្អូន មិនមែនបង្គាប់បងប្អូនទេ

អាចមានន័យថា លោកប៉ូលបានប្រាប់ដល់ក្រុមជំនុំកូរិនថូសថា
លោកបានអនុញ្ញាតឲ្យពួកបងប្អូន មិនមែនបង្គាប់បញ្ជាបងប្អូននោះទេ។ ទី១
រៀបការ និងរួមដំណេកជាមួយគ្នា ឬ ទី២
បញ្ឈប់ការរួមដំណេកជាមួយគ្នាមួយរយៈសិន។

បានដូចខ្ញុំដែរ

បើទោះជាលោកប៉ូលមិនធ្លាប់រៀបការ
ឬក៏ប្រពន្ធរបស់លោកបានស្លាប់យ៉ាងណាក៏ដោយ
ក៏លោកប្រហែលជាមិនមានការលែងលះដែរ ទេមើលទៅ។

ប៉ុន្តែ គ្រប់គ្នាមានអំណោយទានផ្សេងៗគ្នា មកពីព្រះជាម្ចាស់។ ម្នាក់ទទួលយ៉ាងនេះ ម្នាក់ទៀត
ក៏ទទួលយ៉ាងនោះ

ព្រះអាចឲ្យមនុស្សធ្វើអ្វីបានខុសៗគ្នា ទ្រង់អាចនរណាម្នាក់ធ្វើអ្វីមួយ
ហើយមនុស្សដទៃធ្វើអ្វីផ្សេងៗទៀតបាន។

1 Corinthians 7:8

សម្រាប់អ្នកដែលនៅលីវ

ចំពោះអ្នកមិនទាន់រៀបការ។

generated on Wed Sep 10 16:16:32 2025

សម្រាប់ស្ត្រីមេម៉ាយ
ចំពោះស្ត្រីដែលប្តីស្លាប់ចោល។
ជាការល្អ
សូមមើលការបកប្រែនេះនៅក្នុង ១កូរិនថូស ៧:១ (.../0៧/0១.md)
ចិត្តនៅពុះកញ្ជ្រោល
ជាការរស់នៅដោយមានបំណងចិត្តក្នុងការរួមដំណេកជាមួយនរណាម្នាក់។
1 Corinthians 7:10
មិនត្រូវនៅបែកពី
លោកប៉ូលបានដឹងថាគ្មានភាពខុសគ្នានោះទេរវាងការនៅបែកពីគ្នា
និងការលែងលះគ្នា។
ការបញ្ឈប់ការរស់នៅជាមួយនរណាម្នាក់ជាការបញ្ចប់អាពាហ៍ពិពាហ៍។
ការបកប្រែផ្សេងទៀត: «មិនគួរលែងលះ»។
គួរតែទៅជានានិងប្តីវិញ
នេះអាចនិយាយក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត:
«នាងគួរតែត្រូវរ៉ូវជាមួយនិងប្តី និងត្រលប់មករកប្តីរបស់ខ្លួនវិញ»។
មិនត្រូវលែងលះ
លោកប៉ូលបានដឹងថាគ្មានភាពខុសគ្នារវាងការលែងលះ និង ការបាក់បែកនោះទេ។
ទាំងពីរនេះសុទ្ធតែជាការបែកបាក់អាពាហ៍ពិពាហ៍។ ការបកប្រែផ្សេងទៀត:
«មិនត្រូវបែកពី»។
1 Corinthians 7:12
យល់ព្រម
សុខចិត្ត ឬស្កប់ចិត្ត
ប្តី
ពាក្យនេះដូចជាពាក្យរបស់ភាសាក្រិក មានន័យថា «បុរស»។
ដ្បិត ប្តីដែលមិនជឿត្រូវបានញែកដោយឡែក ដោយព្រោះប្រពន្ធរបស់គាត់
អាចមានន័យថា ទី១ «ដ្បិត
ព្រះបានញែកប្តីដែលមិនជឿជាដោយឡែកសម្រាប់អង្គទ្រង់» ឬ ទី២
«ព្រះជាម្ចាស់ប្រព្រឹត្តដាក់ចំពោះប្តីដែលមិនជឿ
ដូចជាទ្រង់បានប្រព្រឹត្តដាក់ព្រះបុត្រាទ្រង់ដែលជាប្រយោជន៍សម្រាប់ប្រពន្ធដែលមានជំនឿ»។
ប្តី...ប្រពន្ធ
ពាក្យទាំងនេះដូចជាពាក្យរបស់ភាសាក្រិក មានន័យថា «បុរស» និង «ស្ត្រី»។
ប្រពន្ធដែលមិនជឿត្រូវបានញែកដោយឡែក ដោយព្រោះបងប្អូនដែរ
អាចមានន័យថា ទី១ «ព្រះបានញែកប្រពន្ធដែលមិនជឿជាដោយឡែកសម្រាប់ទ្រង់
ដោយសារប្តីរបស់នាងដែលជាអ្នកជឿ» ឬ ទី២
«ព្រះប្រព្រឹត្តចំពោះប្រពន្ធដែលមិនជឿដូចជាទ្រង់ប្រព្រឹត្តជាមួយកូនស្រីដោយជាប្រយោជន៍សម្រាប់ប្តីដែលជាអ្នកជឿ»។
បងប្អូន
បុរស ឬ ប្តីដែលជឿ។
ពួកគេត្រូវបានញែកដោយឡែក
អាចមានន័យថា ទី១ «ព្រះបានពួកគេជាដោយឡែកសំរាប់ទ្រង់» ឬ ទី២
«ព្រះប្រព្រឹត្តចំពោះពួកគេដូចជាទ្រង់ប្រព្រឹត្តចំពោះកូនផ្ទាស់របស់ទ្រង់»។
1 Corinthians 7:15
ក្នុងករណីនេះ បងប្អូនប្រុសស្រីមិនបានជាប់ចំណងសន្យាអ្វីឡើយ
ពាក្យ «បងប្អូនប្រុស» នឹង «បងប្អូនស្រី» សំដៅលើប្តី
ឬប្រពន្ធដែលជាគ្រិស្តបរិស័ទ។ ពាក្យ «មិនបានជាប់ចំណងសន្យា»
ជាការប្រៀបធៀបមួយមានន័យថា
អ្នកនោះមិនមានកាតព្វកិច្ចក្នុងការធ្វើអ្វីដែលពួកគេបានសន្យានោះឡើយ។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ក្នុងករណីនេះ
ព្រះមិនតម្រូវឲ្យប្រពន្ធ ឬប្តីដែលជាអ្នកជឿបន្តការគោរពនូវពាក្យសន្យាដែរ»។
ដឹងបានយ៉ាងដូចម្តេចថា ប្រពន្ធ... អ្នកនឹងសង្គ្រោះប្តីរបស់ខ្លួន...ដឹងបានយ៉ាងដូចម្តេចថា
ប្តី...អ្នកនឹងសង្គ្រោះប្រពន្ធរបស់ខ្លួន
លោកប៉ូលកំពុងនិយាយទៅក្រុមជំនុំកូរិនថូស ដែលពួកគេជាមនុស្សតែមួយ
តួយ៉ាងដូចជាពាក្យ «អ្នក» នឹង «របស់អ្នក» ពាក្យទាំងនេះជាឯកវចន:។
តើបងប្អូនដឹងបានយ៉ាងដូចម្តេចថាស្ត្រី ឬខ្លួនអ្នក
តើនិងអាចសង្គ្រោះប្តីរបស់ខ្លួនបានយ៉ាងដូចម្តេចទៅ?
លោកប៉ូលប្រើសំណួរនេះជាហេតុដើម្បីឲ្យស្ត្រីគិតឲ្យបានជ្រៅអំពីអ្វីដែលលោកកំពុងនិយាយ។
ការបកប្រែផ្សេងទៀត:
«អ្នកមិនអាចដឹងបានទេថាតើអ្នកនិងអាចសង្គ្រោះប្តីដែលមិនជឿរបស់អ្នកបានដោយរបៀបណា
តើអ្នកនិងអាចសង្គ្រោះប្តីដែលមិនជឿរបស់អ្នកបានដោយរបៀបណា»។
តើបងប្អូនដឹងបានយ៉ាងដូចម្តេចថាបុរស ឬខ្លួនអ្នក
តើនឹងអាចសង្គ្រោះប្រពន្ធរបស់ខ្លួនបានយ៉ាងដូចម្តេចទៅ?
លោកប៉ូលប្រើសំណួរនេះជាហេតុដើម្បីឲ្យបុរសគិតឲ្យបានជ្រៅអំពីអ្វីដែលលោកកំពុងនិយាយ។
ការបកប្រែផ្សេងទៀត:
«អ្នកមិនអាចដឹងបានទេថាតើអ្នកនិងអាចសង្គ្រោះប្រពន្ធដែលមិនជឿរបស់អ្នកបានដោយរបៀបណានោះ
តើអ្នកនិងអាចសង្គ្រោះប្តីដែលមិនជឿរបស់អ្នកបានដោយរបៀបណា»។
1 Corinthians 7:17
ម្នាក់ៗ
អ្នកជឿម្នាក់ៗ
ខ្ញុំណែនាំរបៀបនេះក្នុងក្រុមជំនុំទាំងអស់
លោកប៉ូលបានបង្រៀនអ្នកជឿនៅក្នុងក្រុមជំនុំទាំងអស់ឲ្យប្រព្រឹត្តក្នុងឥរិយាបថបែបនេះ។
តើមាននរណាបានកាត់ស្បែកពេលទទួលជឿព្រះអង្គទេ?
លោកប៉ូលបានបង្ហាញពីការកាត់ស្បែកតែមួយលើកទេ
តើមាននរណាម្នាក់ដែលត្រូវបានត្រាស់ហៅ ទាំងមិនទាន់បានកាត់ស្បែក?
ឥឡូវនេះ លោកប៉ូលកំពុងបង្ហាញអំពីការកាត់ស្បែកតែមួយលើ
ការបកប្រែផ្សេងទៀត: «ចំពោះអ្នកដែលមិនទាន់បានកាត់ស្បែកតែមួយលើក
គឺនៅពេលព្រះបានត្រាស់ហៅអ្នកដើម្បីអោយជឿ អ្នកមិនបានកាត់ស្បែកទេ»។
1 Corinthians 7:20
ព័ត៌មានទូទៅ
ពាក្យថា «ពួកយើង» នឹង «យើង» សំដៅលើគ្រប់គ្រិស្តបរិស័ទទាំងអស់
និងរួមទាំងសមាជិកក្រុមជំនុំរបស់លោកប៉ូលផងដែរ។
ក្នុងការត្រាស់ហៅ...គាត់គួរប្រកាន់ខ្ជាប់
ពាក្យ «ការត្រាស់ហៅ» សំដៅលើកិច្ចការ ឬ
មុខតំណែងក្នុងសង្គមដែលអ្នកបានពាក់ព័ន្ធ ការបកប្រែផ្សេងទៀត «រស់នៅ
និងធ្វើការដូចជាអ្វីដែលអ្នកធ្វើ»។
តើអ្នក...ត្រាស់ហៅអ្នកឬ? កុំបារម្ភ...អ្នកអាចក្លាយជា
លោកប៉ូលកំពុងនិយាយទៅកាន់ក្រុមជំនុំកូរិនថូស ពួកគេជាមនុស្សតែមួយ
ដូចជាតួយ៉ាងនៃពាក្យ «អ្នក» និងការបញ្ជា «ជា» ទាំងនេះជាឯកវចន:។
តើព្រះជាម្ចាស់បានហៅអ្នកក្នុងកាលដែលអ្នកនៅជាទាសករនៅឡើយមែនទេ ?
កុំបារម្ភអំពីការនោះពេក
នេះអាចត្រូវបានបញ្ជាក់ជារបាយការណ៍មួយ។ ការបកប្រែផ្សេងទៀត:
«ទោះបើអ្នកត្រូវបានត្រាស់ហៅដែលជាទាសករព្រះបានត្រាស់ហៅអ្នកឲ្យជឿ ខ្ញុំនិយាយយ៉ាងដូច្នេះ
ដើម្បីកុំឲ្យអ្នកបារម្ភ»។
មានសេរីភាពក្នុងព្រះអម្ចាស់វិញ
សេរីភាពនេះបានមកពីការលើកលែងទោសដែលមកពីព្រះ
ហើយជាការមានសេរីភាពពីសាតាំង និងអំពើបាប។
អ្នកទាំងអស់គ្នាបានបង់ថ្លៃលោះរួចហើយ
នេះអាចត្រូវបានបញ្ជាក់ក្នុងទំរង់សកម្ម ការបកប្រែផ្សេងទៀត:
«ព្រះគ្រិស្តបានបង់ថ្លៃជួសអ្នកដោយការសុគតសម្រាប់អ្នក»។
បងប្អូនអើយ
ពាក្យនេះមានន័យថាគ្រិស្តបរិស័ទរួមជំនឿ ទាំងបុរស និងស្ត្រី
បានត្រាស់ហៅ
នេះអាចត្រូវបានបញ្ជាក់ក្នុងទំរង់សកម្ម ការបកប្រែផ្សេងទៀត
«ពេលព្រះបានត្រាស់ហៅយើងឲ្យជឿលើទ្រង់»។
1 Corinthians 7:25
ឥឡូវនេះ ទាក់ទងនឹងអ្នកដែលមិនទាន់រៀបការ ខ្ញុំមិនបានទទួលបញ្ជាអ្វីពីព្រះអម្ចាស់ទេ
លោកប៉ូលដឹងថា
គ្មានការណាមួយពីព្រះយេស៊ូដែលនិយាយពីស្ថានភាពបែបនេះទេ។
ការបកប្រែផ្សេងទៀត:
«ព្រះអម្ចាស់មិនបានបញ្ជាឲ្យខ្ញុំនិយាយពីអ្វីទៅកាន់អ្នកដែលមិនធ្លាប់បានរៀនការនោះទេ»។
ខ្ញុំសូមជូនយោបល់
ខ្ញុំប្រាប់អ្នកនូវអ្វីដែលខ្ញុំគិត
ក្នុងនាមម្នាក់ដែលព្រះអង្គមានព្រះហឫទ័យមេត្តាដល់ខ្ញុំ ដែលបងប្អូនអាចទុកចិត្តបាន
ដោយសារព្រះអង្គមានព្រះហឫទ័យមេត្តា ខ្ញុំអាចទុកចិត្តបាន
1 Corinthians 7:27
ព័ត៌មានទូទៅ
លោកប៉ូលនិយាយទៅកាន់ក្រុមជំនុំកូរិនថូស
ដែលលោកបាននិយាយទៅមនុស្សម្នាក់ៗដែរ ទាំងអស់នេះជំនួសដោយពាក្យ
«អ្នក» និង ការបង្គាប់បញ្ជា «មិនត្រូវដោះដៃ» ជាឯកវចន:។
តើអ្នកមានការទាក់ទងជាមួយមនុស្សស្រីមែនទេ? កុំរក...
លោកប៉ូលប្រើសំនួរនេះក្នុងការណែនាំនូវលក្ខខណ្ឌមួយដែលអាចកើតឡើងបាន។
សំណួរនេះអាចត្រូវបានបកប្រែទៅជាឃ្លាភ្ជាប់ «ប្រសិនបើ»។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត: «ប្រសិនបើ អ្នកមានចំណងទំនាក់ទំនងជាមួយមនុស្សស្រី កុំរក»។

កុំរកដោះដៃ

កុំព្យាយាមដោះដៃពីនាង ឬ «កុំព្យាយាមបែកបាក់ចេញពីនាងឡើយ»។

កុំយកប្រពន្ធ

កុំព្យាយាមមានចំណងទំនាក់ទំនងជាមួយមនុស្សស្រី។

ខ្ញុំចង់ឲ្យអ្នកនៅឲ្យឆ្ងាយពីពួកគេ

ពាក្យ «នេះ»
សំដៅទៅលើប្រភេទនៃបញ្ហាលោកីយ៍ដែលមនុស្សដែលរៀបការជួបប្រទះ។

ការបកប្រែផ្សេងទៀត: «ខ្ញុំចង់ជួយអ្នកកុំឲ្យអ្នកមានបញ្ហាលោកីយ៍នេះឡើយ»។

1 Corinthians 7:29

ពេលវេលាកាន់តែខ្លីណាស់ហើយ

មានពេលវេលាតិចតួច ឬ «ពេលវេលាជិតអស់ហើយ»។

អស់អ្នកដែលយំសោក

ការយំ ឬសោកសៅលាយឡំដោយទឹកភ្នែក។

អស់អ្នកដែលប្រើប្រាស់សម្បត្តិលោកីយ៍

អស់អ្នកដែលទាក់ទងជាមួយអ្នកមិនជឿជារាងរាល់ថ្ងៃ។

ក៏ត្រូវកាន់ចិត្តដូចជាមិនបានប្រើប្រាស់ដែរ

គួរបង្ហាញពីទង្វើលរបស់ខ្លួនថា សេចក្តីសង្ឃឹមរបស់ពួកគេគឺនៅក្នុងព្រះ។

1 Corinthians 7:32

មានសេរីភាពពីការខ្វល់ខ្វាយ

«ស្ងប់ស្ងាត់» ឬ «មិនមានការខ្វល់ខ្វាយ»

ខ្វល់ខ្វាយជាមួយ

ផ្តោតលើ

គាត់មានចិត្តបែងចែក

«គាត់ព្យាយាមធ្វើឲ្យព្រះសព្វហឫទ័យ
ហើយក្នុងពេលតែមួយក៏ឲ្យប្រពន្ធរបស់គាត់ពេញចិត្តដែរ»។

1 Corinthians 7:35

បង្ខិតបង្ខំ

ការរឹតបន្តឹង

ថ្វាយខ្លួន

អាចផ្តង់ចិត្តលើ

1 Corinthians 7:36

គាត់ប្រព្រឹត្តមិនត្រឹមត្រូវចំពោះ

មិនមានសេចក្តីសប្បុរស ឬ «មិនគួរអោយគោរព» ។

នៅកំលោះ

អាចមានន័យថា ទី១ «ស្ត្រីដែលគាត់សន្យានិងរៀបការជាមួយ» ឬ ទី២ «កូនស្រីក្រមុំរបស់គាត់»។

ចូរឲ្យពួកគេរៀបការទៅ

អាចមានន័យថា ទី១ «គាត់គួរតែរៀបការជាមួយគូដណ្តឹងរបស់គាត់» ឬ ទី២ «គាត់គួរតែឲ្យកូនស្រីរបស់គាត់រៀបការ»។

ប្រសិនបើ អ្នកនោះបានប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់

ពាក្យ «យ៉ាងម៉ឺងម៉ាត់»
ជាការប្រៀបធៀបក្នុងការសម្រេចចិត្តយ៉ាងច្បាស់លាស់ក្នុងការធ្វើអ្វីមួយ។ ពាក្យ «ប្តេជ្ញាចិត្ត» គឺជាចិត្តគំនិតរបស់បុគ្គលណាម្នាក់។ ការបកប្រែផ្សេងទៀត:
«ប្រសិនបើ អ្នកនោះបានសម្រេចចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងគំនិតរបស់គាត់ផ្ទាល់»។

1 Corinthians 7:39

ដរាបណា...នៅរស់

រហូតគាត់ស្លាប់

ជាមួយនរណាក៏បាន ស្រេចតែចិត្តនាង

នរណាក៏បាន ឲ្យតែនាងចង់បាន។

ក្នុងព្រះអម្ចាស់

ប្តីថ្មីដែលជាអ្នកជឿ

តាមការគិតរបស់ខ្ញុំ

ការយល់របស់ខ្ញុំអំពីព្រះបន្ទូលរបស់ព្រះ។

សប្បាយជាង

ពេញចិត្តជាង រីករាយជាង។

រស់នៅមិនយកប្តីទៀត

«មិនបាច់រៀបការទេ»

---

8 [1]ឥឡូវនេះ ទាក់ទងនឹងអាហារដែលបានសែនដល់ព្រះក្លែងក្លាយ ពួកយើងដឹងហើយថា «យើងទាំងអស់គ្នាបានចេះដឹង»។ ការចេះដឹងតែងធ្វើឲ្យចិត្តប៉ោងឡើង
តែក្តីស្រឡាញ់ស្អាងចិត្តឡើងវិញ។[2]ប្រសិនបើ អ្នកណាគិតថាខ្លួនចេះដឹងអ្វីមួយ ម្នាក់នោះមិនទាន់ចេះដឹងដូចអ្វីដែលគាត់គួរដឹងនោះទេ។[3]ប៉ុន្តែបើ
អ្នកណាស្រឡាញ់ព្រះជាម្ចាស់ អ្នកនោះនឹងទទួលការចេះដឹងតាមរយៈព្រះអង្គ។
[4]ដូច្នេះ និយាយអំពីការបរិភោគអាហារដែលសែនដល់ព្រះក្លែងក្លាយ ពួកយើងដឹងពីការនេះ «ព្រះក្លែងក្លាយនៅក្នុងលោកីយ៍នេះគ្មានន័យអ្វីទេ» ហើយ
«គឺគ្មានព្រះណាផ្សេងឡើយ ក្រៅពីព្រះជាម្ចាស់តែមួយគត់»។[5]ទោះបីមានអ្វីៗដែលមនុស្សលោកចាត់ទុកជាព្រះនៅលើមេឃ ឬនៅលើផែនដីក៏ដោយ ដ្បិត
ពួកនោះគឺមានច្រើនណាស់ «ព្រះផ្សេងៗ» ហើយ «ម្ចាស់ផ្សេងៗ»។[6]ប៉ុន្តែ យើងវិញ «គឺយើងមានព្រះបិតាតែមួយប៉ុណ្ណោះ ព្រះអង្គគឺជាអ្វីទាំងអស់
ហើយជាព្រះផ្តល់ជីវិតឲ្យយើងរស់ និងព្រះអម្ចាស់យេស៊ូគ្រិស្តតែមួយ តាមរយៈព្រះអង្គគ្រប់យ៉ាងបានកើតឡើង និងយើងបានកើតមកតាមតរយៈព្រះអង្គ»។
[7]ទោះជាយ៉ាងក៏ដោយ មិនមែនគ្រប់គ្នាមានចំណេះដឹងនេះទេ។ អ្នកខ្លះនៅតែជំពាក់ចិត្តនឹងព្រះក្លែងក្លាយនៅឡើយ គេហូបសាច់ទាំងនោះទុកដូចជាសំណែន។ ហើយដោយ
គេរិះគិតមិនបានដិតដល់ ក៏នឹកស្មានថា ខ្លួនត្រូវសៅហ្មង ហើយទៅជាខ្សោយ។
[8]ប៉ុន្តែ អាហារមិនអាចនាំយើងចូលជិតព្រះជាម្ចាស់បានឡើយ។ បើយើងមិនអាក្រក់អ្វីទេ ប្រសិនបើយើងហូបអាហារទាំងនោះ ហើយវាក៏មិនចម្រើនអ្វីដែល ប្រសិនបើ
យើងទទួលវានោះ។[9]ហេតុនេះហើយ សូមបងប្អូនប្រុងប្រយ័ត្នខ្លួន កុំឲ្យសិទ្ធិសេរីភាពរបស់បងប្អូននាំឲ្យអ្នកដែលមានជំនឿទន់ខ្សោយធ្លាក់ក្នុងអំពើបាបនោះឡើយ។[10]ដ្បិត
ឧបមាថា មានអ្នកណាម្នាក់បានឃើញអ្នក គឺជាអ្នកដឹងអំពីការហូបអាហារ ទៅហូបរបស់សែនក្នុងព្រះវិហារនៃព្រះក្លែងក្លាយ។
តើនេះមិនមែនជាមនសិការទន់ខ្សោយរបស់គាត់ ដែលជំរុញគាត់ឲ្យហូបអ្វីដែលបានសែនដល់រូបព្រះទេឬអី?
[11]ដូច្នេះ ដោយព្រោះការយល់ដឹងអំពីសេចក្តីពិតនៃធម្មជាតិនៃព្រះរូបចម្លាក់ ធ្វើឲ្យអ្នកទន់ខ្សោយជាង គឺបងប្អូនដែលព្រះគ្រិស្តបានសុគតរបស់ព្រះគ្រិស្ត គឺត្រូវបំផ្លាញវិញ។
[12]ដោយបងប្អូនប្រព្រឹត្តអំពើបាបបែបនេះចំពោះបងប្អូនឯទៀតៗ និងធ្វើឲ្យមនសិការរបស់គេកាន់តែអាប់ឱនថែមទៀត នោះបងប្អូនក៏ដូចជាបានប្រព្រឹត្តអំពើបាបចំពោះ
ព្រះគ្រិស្តដែរ។[13]ហេតុនេះ ប្រសិនបើ ចំណីអាហារណាមួយធ្វើឲ្យបងប្អូនរបស់ខ្ញុំធ្លាក់ក្នុងអំពើបាប ខ្ញុំនឹងមិនហូបទៀតជាដាច់ខាត ដើម្បីកុំឲ្យបងប្អូនខ្ញុំរវាតចិត្តបាត់ជំនឿ។

---

1 Corinthians 8:1

ព័ត៌មានទូទៅ

យើងមានន័យថាលោកប៉ូល
និងការសរសេរសំបុត្រជាក់លាក់ទៅកាន់អ្នកជឿនៅក្រុមជំនុំកូរិនថូស
រួមទាំងអ្នកជឿទាំងអស់ផងដែរ។

ប្រយោគភ្ជាប់

លោកប៉ូលរំលឹកអ្នកជឿថា បើទោះព្រះក្លែងក្លាយពុំមានអំណាច
ប៉ុន្តែអ្នកជឿត្រូវតែប្រុងប្រយ័ត្នមិនត្រូវធ្វើឲ្យប៉ះពាល់ដល់អ្នកមានជំនឿទន់ខ្សោយឡើយ [illegible] ចិត្តទុកដាក់ជាមួយព្រះក្លែងក្លាយនោះ។
លោកប្រាប់អ្នកជឿត្រូវប្រុងប្រយ័ត្នជាមួយនឹងសេរីភាពដែលជឿមាននៅក្នុងព្រះគ្រិស្ត។ការចេះដឹងតែងធ្វើឲ្យមនុស្សមានចិត្តប៉ោងឡើង ពាក្យ «ចិត្តប៉ោងឡើង»
ឥឡូវនេះ

លោកប៉ូលប្រើឃ្លានេះដើម្បីបន្តសំណួរបន្ទាប់ទៀតដែលក្រុមជំនុំកូរិនថូសសួរលោក។

អាហារដែលបានសែនដល់ព្រះក្លែងក្លាយ

អ្នកថ្វាយបង្គំសាសន៍ដទៃនិងថ្វាយគ្រាប់ធញ្ញជាតិ ត្រី សត្វស្លាប
ឬសាច់ដល់ព្រះរបស់ពួកគេ។ លោកបូជាចារ្យ
និងដុតចំណែកមួយភាគនៅលើអាសនា។
លោកប៉ូលកំពុងនិយាយពីចំណែកមួយភាគដែលពួកបូជាចារ្យឲ្យទៅអ្នកថ្វាយបង្គំដើម្បីទទួលទាន
ឬ យកទៅលក់ក្នុងទីផ្សារ។
[illegible] ការប្រៀបធៀបមួយ ការធ្វើឲ្យនរណាម្នាក់មានអំនួត។ មានអរូប «ការចេះដឹង»

generated on Wed Sep 10 16:16:32 2025

អាចត្រូវបានប្រើជាកិរិយាសព្ទ «ចេះ» ការបកប្រែផ្សេងទៀត:
«ការចេះដឹងធ្វើឲ្យមនុស្សមានអំនួត» ឬ
«មនុស្សដែលគិតថាខ្លួនចេះដឹងច្រើនការជាមានអំនួតវិញ»។
តែក្តីស្រឡាញ់ស្អាងចិត្តឡើងវិញ
នាមអរូប «សេចក្តីស្រឡាញ់» អាចត្រូវបានប្រើជាកិរិយាសព្ទ។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែ ពេលយើងស្រឡាញ់មនុស្សដទៃទៀត
យើងបានស្អាងចិត្តពួកគេឡើងវិញ»។
ក្តីស្រឡាញ់ស្អាងចិត្ត
ការស្អាងចិត្តមនុស្សឡើងជាការតំណាងឲ្យការជួយពួកគេឲ្យក្លាយទៅជាពេញវ័យ
និងជំនឿរឹងមាំក្នុងជំនឿរបស់ពួកគេ។ ការបកប្រែផ្សេងទៀត:
«សេចក្តីស្រឡាញ់ធ្វើមនុស្សមានកម្លាំង» ឬ «ពេលយើងស្រឡាញ់មនុស្សម្នាក់
យើងធ្វើឲ្យពួកគេមានកម្លាំង» ។
គិតថាខ្លួនចេះដឹងអ្វីមួយ
ជឿថាខ្លួនដឹងគ្រប់អ្វីៗទាំងអស់។
អ្នកនោះនឹងទទួលការចេះដឹងតាមរយៈព្រះអង្គ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះទ្រង់ស្គាល់មនុស្សម្នាក់នោះ»។
1 Corinthians 8:4
ព័ត៌មានទូទៅ
យើងនិង «ពួកយើង» នៅទីនេះសំដៅលើគ្រប់អ្នកជឿ
និងសមាជិកក្រុមជំនុំរបស់លោកប៉ូលផងដែរ។
យើងដឹងពីការនេះព្រះក្លែងក្លាយនៅក្នុងលោកីយ៍នេះគ្មានន័យអ្វីទេហើយ គឺគ្មានព្រះណាផ្សេងឡើយ
ក្រៅពីព្រះជាម្ចាស់តែមួយគត់
លោកប៉ូលប្រហែលជាស្រង់នូវឃ្លាមួយចំនួនដែលក្រុមជំនុំកូរិនថូសបានប្រើ។
ដោយការផ្តើមនូវឃ្លា «គ្មានន័យ» តំណាងឲ្យការគ្មានអំណាច។
ការបកប្រែផ្សេងទៀត: «យើងទាំងអស់គ្នាដឹងហើយ
ដូចជាខ្លួនរបស់អ្នកដែលចូលចិត្តនិយាយថាព្រះក្លែងក្លាយនៅក្នុងលោកីយ៍នេះគ្មានអំណាចទេ
ហើយគ្មានព្រះណាផ្សេងឡើយ គឺមានតែព្រះជាម្ចាស់តែមួយគត់»។
ចាត់ទុកហៅថាជាព្រះ
ជាអ្វីៗដែលមនុស្សហៅថាព្រះ។
មានច្រើនណាស់ «ព្រះផ្សេងៗ» ហើយ «ម្ចាស់ផ្សេងៗ»
លោកប៉ូលជឿថាមិនមានព្រះណាផ្សេងៗ និងម្ចាស់ផ្សេងនោះទេ
ប៉ុន្តែលោកស្គាល់ថាមនុស្សដែលឥតសាសនាជឿលើអ្វីដែលពួកគេធ្វើ។
ប៉ុន្តែ យើងវិញគឺយើងមានព្រះបិតាតែមួយប៉ុណ្ណោះ
ប៉ុន្តែ យើងដឹងយ៉ាងច្បាស់ថា មានព្រះបិតាតែមួយប៉ុនណ្ណោះ។
1 Corinthians 8:7
ព័ត៌មានទូទៅ
លោកប៉ូលនិយាយពាក្យថា បងប្អូន «ទន់ខ្សោយ»
ជាមនុស្សដែលមិនបានបែងចែកអាហារដែលត្រូវសែនទៅព្រះក្លែងក្លាយដែលបានមកពីអាហារដែលមិនត្រូវបានសែនទៅព្រះក្លែងក្លាយ។
ប្រសិនបើ គ្រិស្តបរិស័ទណាមួយទទួលទានអាហារដែលបានសែនទៅព្រះក្លែងក្លាយ
នោះបងប្អូនដែលមានជំនឿទន់ខ្សោយនឹងគិតថាព្រះក៏អនុញ្ញាតឲ្យពួកគេថ្វាយបង្គំព្រះក្លែងក្លាយដែរ
ដោយការទទួលទានអាហារទាំងនោះ។
បើទោះជាអ្នកទទួលទានមិនគោរពថ្វាយបង្គំព្រះក្លែងក្លាយ
ឬគ្រាន់តែទទួលទានយ៉ាងណាក៏ដោយ
ក៏គាត់បានធ្វើឲ្យបងប្អូនដែលមានជំនឿទន់ខ្សោយនោះប្រែខ្លួនទៅជាសៅហ្មង។
គ្រប់គ្នា...អ្នកខ្លះ
មនុស្សគ្រប់គ្នា...មនុស្សខ្លះៗដែលឥឡូវ ជាគ្រិស្តបរិស័ទ។
ស្មោគគ្រោក
សេចក្តីវិនាស ឬ សេចក្តីអន្តរាយ។
1 Corinthians 8:8
អាហារមិនអាចនាំយើងចូលជិតព្រះជាម្ចាស់បានឡើយ
លោកប៉ូលនិយាយពីអាហារមិនអាចធ្វើឲ្យព្រះស្វាគមន៍ដល់ពួកយើង។
ការបកប្រែផ្សេងទៀត:
«អាហារមិនបានផ្តល់ឲ្យពួកយើងនូវសេចក្តីពេញចិត្តរបស់ព្រះនោះទេ» ឬ
«អាហារដែលយើងទទួលទានមិនបានធ្វើឲ្យព្រះសព្វព្រះហឫទ័យលើយើងឡើយ»។
យើងមិនអាក្រក់អ្វីទេ ប្រសិនបើយើងហូបអាហារទាំងនោះ ហើយវាក៏មិនចម្រើនអ្វីដែល ប្រសិនបើ
យើងទទួលទានវានោះ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«មនុស្សខ្លះប្រហែលគិតថា ប្រសិនបើយើងមិនទទួលទានអាហារនោះទេ
នោះព្រះនឹងមិនស្រឡាញ់ច្រើនដែរ ប៉ុន្តែ ពួកគេគិតខុសហើយ
ចំពោះអ្នកណាដែលគិតថាព្រះ និងស្រឡាញ់ពួកគេច្រើនជាង ប្រសិនបើ
ពួកគេទទួលទានអាហារទាំងនោះ ពួកនោះក៏គិតខុសដែរ»។
អ្នកដែលមានជំនឿទន់ខ្សោយ
អ្នកជឿដែលមិនរឹងមាំលើសេចក្តីជំនឿរបស់ខ្លួន។
បានឃើញអ្នក
លោកប៉ូលនិយាយទៅកាន់ក្រុមជំនុំកូរិនថូសហាក់ដូចជាពួកគេជាមនុស្សតែម្នាក់
ដូច្នេះពាក្យទាំងនេះជាឯកវចនៈ។
មនសិការ...របស់គាត់
ការយល់ដឹងរបស់គាត់
ធ្វើឡើងដើម្បីទទួលទាន
លើកទឹកចិត្តឲ្យបរិភោគ
1 Corinthians 8:11
ការយល់ដឹងរបស់អ្នក
លោកប៉ូលនិយាយទៅកាន់ក្រុមជំនុំកូរិនថូសហាក់ដូចពួកគេជាមនុស្សម្នាក់
ដូច្នេះពាក្យ «របស់អ្នក» នៅទីនេះជាឯកវចនៈ។
អ្នកដែលទន់ខ្សោយ...ត្រូវបំផ្លាញ
បងប្អូនប្រុស ស្រីដែលមានមិនរឹងមាំលើសេចក្តីជំនឿរបស់ខ្លួន និងធ្លាក់ក្នុងអំពើបាប
ឬ បាត់បង់សេចក្តីជំនឿរបស់ខ្លួន។
ហេតុនេះ
ដោយសារអ្វីដែលខ្ញុំបាននិយាយជាសេចក្តីពិត
[illegible]
ធ្លាក់ក្នុងអំពើបាប
អាហារ នៅទីនេះសំដៅលើបុគ្គលណាម្នាក់ដែលបរិភោគអាហារនោះ។
ក្លែងក្លាយ
ការបកប្រែផ្សេងទៀត: «ប្រសិនបើខ្ញុំធ្វើឲ្យអ្នកធ្លាក់ផុងដោយការបរិភោគ» ឬ
«ប្រសិនបើខ្ញុំ ដោយសារអ្វីដែលខ្ញុំបរិភោគ ធ្វើឲ្យ»។

9

[1]តើខ្ញុំគ្មានមានសេរីភាពមែនទេ? តើខ្ញុំមិនមែនជាសាវកទេឬអី? តើខ្ញុំមិនបានឃើញព្រះយេស៊ូជាព្រះអម្ចាស់ទេឬ? តើបងប្អូនមិនមែនជាស្នាដៃរបស់ខ្ញុំ ក្នុងការបម្រើ
ព្រះអម្ចាស់ទេឬអី?[2]ប្រសិនបើ ខ្ញុំមិនមែនជាសាវ័កសម្រាប់អ្នកដទៃផ្សេងទៀត យ៉ាងហោចណាស់ក៏សម្រាប់បងប្អូនដែរ។ បងប្អូនជាភស្តុតាងបញ្ជាក់ថា ខ្ញុំពិតជាមាន
មុខងារជាសាវ័កនៅក្នុងព្រះអម្ចាស់។[3]ខ្ញុំសូមឆ្លើយចំពោះអស់អ្នកដែលចោទប្រកាន់ខ្ញុំដូចតទៅនេះ:[4]នេះគឺជាការពាររបស់ខ្ញុំ ចំពោះ អស់អ្នកដែលចោទប្រកាន់ខ្ញុំ
តើយើងគ្មានសិទ្ធិ នឹងហូប ហើយផឹកទេឬ?[5]តើយើងគ្មានសិទ្ធិក្នុងការនាំប្រពន្ធ ដែលជាអ្នកជឿ ដូចជាសាវ័កឯទៀតៗ ក៏ដូចបងប្អូនដែលនៅក្នុងព្រះអម្ចាស់ និងដូច
ជាលោកកេផាសទេឬអី?[6]ឬមួយមានតែលោកបារណាបាស និងខ្ញុំទេ ដែលត្រូវធ្វើការនោះ?
[7]ដែលមានអ្នកណាចូលបម្រើជាកងទ័ព ហើយបើកប្រាក់ខែពីខ្លួនឯងទេ? តើមានអ្នកដាំដើមទំពាំងបាយជូរ ហើយមិនហូបផ្លែរបស់វាដែរឬទេ? ឬដែលមាននរណាចិញ្ចឹម
ហ្វូងសត្វ ហើយមិនពិសាទឹកដោះរបស់សត្វនោះដែរឬទេ?[8]តើខ្ញុំនិយាយការទាំងនេះផ្អែកទៅលើសិទ្ធិជាមនុស្សជាតិមែនទេ? តើក្រឹត្យវិន័យមិនបានចែងបែបនេះដែរទេឬអី?
[9]ដ្បិត ក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេមានចែងទុកថា៖ «កុំឃ្លុំមាត់គោ នៅពេលបញ្ជាន់ស្រូវនោះឡើយ»។
តើព្រះជាម្ចាស់មិនបានយកព្រះហឫទ័យទុកដាក់ដល់គោទេឬអី?[10]តើព្រះអង្គមិនបានមានបន្ទូលពីយើងទេមែនឬ? ក៏មានសេចក្តីចែងទុកអំពីយើងដែរ ពីព្រោះអ្នកដែលភ្ជួរ
រាស់ ត្រូវសង្ឃឹមថានឹងបានផល ហើយអ្នកបោកបែនក៏ត្រូវសង្ឃឹមថានឹងបានផលក្នុងរដូវចម្រូតដែរ។[11]ប្រសិនបើ
យើងបានសាបព្រោះអ្វីខាងឯព្រះវិញ្ញាណនៅក្នុងចំណោមអ្នករាល់គ្នា តើយើងច្រូតយកផលអ្វីដែលជាទ្រព្យសម្បត្តិ ក្នុងលោកីយ៍ពីបងប្អូនទេឬអី?
[12]ប្រសិនបើ អ្នកផ្សេងមានសិទ្ធិទទួលប្រយោជន៍ពីបងប្អូន តើយើងគ្មានសិទ្ធិដើម្បីទទួលពីបងប្អូនជាងអ្នកទាំងនោះទេឬអី? យ៉ាងណាក៏ដោយ
យើងមិនបានយកសិទ្ធិនេះមកប្រើឡើយ។ ផ្ទុយទៅវិញ យើងសុខចិត្តស៊ូទ្រាំគ្រប់បែបយ៉ាង កុំឲ្យវាក្លាយជាឧបសគ្គដល់ដំណឹងល្អរបស់ព្រះគ្រិស្តឡើយ។
[13]តើបងប្អូនមិនដឹងទេឬអីថា អស់អ្នកដែលបម្រើនៅព្រះវិហារ នឹងទទួលផលពីព្រះវិហារវិញនោះ? តើបងប្អូនមិនដឹងទេឬអីថា អស់អ្នកដែលបម្រើនៅលើអាសនៈ

generated on Wed Sep 10 16:16:32 2025

នឹងទទួលបានចំណែកដែលបានថ្វាយលើអាសនៈនោះ?[14]ដូចគ្នាដែរ ព្រះអម្ចាស់បានមានព្រះបន្ទូលបង្គាប់ថា អស់អ្នកដែលប្រកាសដំណឹងល្អ
គួរតែរស់នៅពីផលពីដំណឹងល្អនោះដែរ។
[15]ប៉ុន្តែ ខ្ញុំមិនបានយកសិទ្ធិទាំងនោះទេ។ ហើយខ្ញុំក៏មិនបានធ្វើសំបុត្រនេះមកដល់បងប្អូន ដើម្បីជាប្រយោជន៍ដល់ខ្ញុំដែរ។ ខ្ញុំសុខចិត្តស្លាប់ល្អជាង គ្មាននរណាអាចដកយក
កិត្តិយសនេះចេញពីខ្ញុំបានឡើយ។[16]ដ្បិត ប្រសិនបើ ខ្ញុំប្រកាសដំណឹងល្អ នោះខ្ញុំគ្មានហេតុនឹងមានអំនួតទេ ដោយព្រោះតែខ្ញុំត្រូវតែធ្វើការនោះ។ ហើយប្រសិនបើ ខ្ញុំមិន
ផ្សាយដំណឹងល្អទេ នោះវេទនាដល់ខ្ញុំហើយ!
[17]ដ្បិត ប្រសិនបើ ខ្ញុំធ្វើការដោយការពេញចិត្ត ខ្ញុំនឹងមានរង្វាន់។ ប៉ុន្តែ ប្រសិនបើមិនដោយការពេញចិត្តទេ ខ្ញុំនៅតែមានភាពទទួលខុសត្រូវ
ទៅលើអ្វីដែលជាចំណែករបស់ខ្ញុំ។[18]តើអ្វីទៅដែលជារង្វាន់របស់ខ្ញុំ? ពេលខ្ញុំបានផ្សាយដំណឹងល្អ ដោយឥតគិតថ្លៃ ហើយមិនបានប្រើសិទ្ធិជាអ្នកផ្សាយដំណឹងល្អឡើយ។
[19]ដ្បិត ខ្ញុំមានសេរីភាពពីអ្វីៗទាំងអស់ ខ្ញុំបានក្លាយទៅជាអ្នកបម្រើដល់គ្រប់គ្នា ដើម្បីឲ្យខ្ញុំអាននាំមនុស្សជាច្រើនថែមទៀត។[20]ក្នុងចំណោមសាសន៍យូដានោះខ្ញុំក៏ដូចយូដា
គឺដើម្បីឈោងចាប់សាសន៍យូដាផងដែរ។ សម្រាប់អ្នកដែលស្ថិតនៅក្រោមក្រឹត្យវិន័យ ខ្ញុំក៏ដូចជាអ្នកស្ថិតនៅក្រោមក្រឹត្យវិន័យ គឺដើម្បីឈោងចាប់អ្នកទាំងនោះផងដែរ។
ខ្ញុំបានធ្វើការទាំងនោះ បើទោះបីជាខ្លួនខ្ញុំមិនបាននៅក្រោមក្រឹត្យវិន័យទេ។
[21]សម្រាប់អស់អ្នកដែលគ្មានក្រឹត្យវិន័យ ខ្ញុំក៏ដូចជាអ្នកដែលគ្មានក្រឹត្យវិន័យដែរ ទោះបើខ្ញុំមិនមែននៅក្រោមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ក្តី តែខ្ញុំគឺនៅក្រោម
ក្រឹត្យវិន័យនៃព្រះគ្រិស្តវិញ។ ខ្ញុំធ្វើការនេះដោយចង់ឈោងចាប់ អ្នកដែលគ្មានក្រឹត្យវិន័យដែរ។[22]សម្រាប់អ្នកដែលខ្សោយ ខ្ញុំក៏ដូចអ្នកទាំងនោះដែរ ដូច្នេះ
ខ្ញុំអាចឈោងចាប់អ្នកទាំងនោះ។ ខ្ញុំអាចធ្វើគ្រប់ការទាំងអស់សម្រាប់មនុស្សទាំងអស់ ដូច្នេះ អ្វីដែលខ្ញុំបានធ្វើអាចនឹងឈោងចាប់អ្នកខ្លះថ្វាយព្រះអង្គ។
[23]ខ្ញុំធ្វើការទាំងអស់ដើម្បីប្រយោជន៍នៃដំណឹងល្អ ដើម្បីឲ្យបានចូលរួមទទួលព្រះពរពីដំណឹងល្អនោះ។
[24]តើបងប្អូនមិនដឹងទេឬអីថា អ្នករត់ប្រណាំងទាំងអស់ត្រូវរត់ដល់ទីប្រកួត ប៉ុន្តែមានតែម្នាក់ទេដែលនឹងទទួលភួងជ័យ? ដូច្នេះ ចូលរត់ឲ្យបានភួងជ័យ។[25]អ្នករត់ប្រណាំង
ខំហឹកហាត់គ្រប់គ្រងខ្លួនឯងក្នុងការហាត់សម។ ពួកគេធ្វើយ៉ាងនេះដើម្បីឲ្យបានទទួលភួងជ័យដែលខូចរលួយ រីឯយើងវិញ យើងនឹងទទួលភួងជ័យដែលមិនចេះរលាយ
សាបសូន្យឡើយ។[26]ដូច្នេះ ខ្ញុំមិនបានរត់ដោយគ្មានគោលដៅ ហើយមិនដាល់ដូចដាលើខ្យាល់នោះដែរ។[27]ប៉ុន្តែ ខ្ញុំលត់ដំរូបកាយខ្ញុំយ៉ាងតឹងរ៉ឹង ហើយខ្ញុំធ្វើម្ចាស់លើរូបកាយ
ខ្លួនឯង ក្រោយពីបានប្រកាសដំណឹងល្អដល់អ្នកឯទៀតៗហើយ ខ្លួនខ្ញុំផ្ទាល់បែរជាត្រូវមិនទទួលស្គាល់វិញ។

---

1 Corinthians 9:1

ប្រយោគភ្ជាប់

លោកប៉ូលពន្យល់ពីរបៀបដែលលោកប្រើសេរីភាពដែលលោកមាននៅក្នុងព្រះគ្រិស្ត។

តើខ្ញុំមិនមែនជាសាវកទេឬអី?

លោកប៉ូលប្រើសំណួរឥតព្រៀងទុកនេះដើម្បីរំលឹកដល់ក្រុមជំនុំកូរិនថូសអោយស្គាល់ពីលោក
នឹងសិទ្ធិដែលលោកមាន។ ការបកប្រែផ្សេងទៀត: «ខ្ញុំជាសាវកម្នាក់»។

តើខ្ញុំគ្មានមានសេរីភាពមែនទេ?

លោកប៉ូលប្រើសំណួរឥតព្រៀងទុកនេះដើម្បីរំលឹកដល់ក្រុមជំនុំកូរិនថូសអំពីសិទ្ធិដែលលោកមាន
ការបកប្រែផ្សេងទៀត: «ខ្ញុំជាមនុស្សម្នាក់ដែលមានសេរីភាព»។

តើខ្ញុំមិនបានឃើញព្រះយេស៊ូជាព្រះអម្ចាស់ទេឬ?

លោកប៉ូលប្រើសំណួរឥតព្រៀងទុកដើម្បីរំលឹកដល់ក្រុមជំនុំកូរិនថូសឲ្យស្គាល់ពីលោក។
ការបកប្រែផ្សេងទៀត: «ខ្ញុំបានឃើញព្រះយេស៊ូជាព្រះអម្ចាស់នៃយើង»។

តើបងប្អូនមិនមែនជាស្នាដៃរបស់ខ្ញុំ ក្នុងការបម្រើព្រះអម្ចាស់ទេឬអី?

លោកប៉ូលប្រើសំណួរឥតព្រៀងទុកដើម្បីរំលឹកដល់ក្រុមជំនុំកូរិនថូសពីទំនាក់ទំនងរបស់លោក
ការបកប្រែផ្សេងទៀត:
«អ្នកជឿព្រះគ្រិស្តដោយសារខ្ញុំបានធ្វើអ្វីដែលព្រះចង់ឲ្យខ្ញុំធ្វើ»។

បងប្អូនជាភ័ស្តុតាងបញ្ជាក់ថា ខ្ញុំពិតជាមានមុខងារជាសាវកនៅក្នុងព្រះអម្ចាស់។

ពាក្យ ភ័ស្តុតាង ជាការបញ្ជាក់អះអាងអ្វីមួយ។ ការបកប្រែផ្សេងទៀត:
«អ្នកជាសំអាងដែលខ្ញុំអាចប្រើដើម្បីបញ្ជាក់ថាព្រះបានជ្រើសរើសខ្ញុំឲ្យធ្វើជាសាវក»។

1 Corinthians 9:3

តើយើងគ្មានសិទ្ធិ នឹងហូប ហើយផឹកទេឬ?

លោកប៉ូលប្រើសំនួរនេះដើម្បីបញ្ជាក់ថា
លោកដឹងថាក្រុមជំនុំកូរិនថូសយល់ព្រមជាមួយអ្វីដែលលោកកំពុងនិយាយ។
ការបកប្រែផ្សេងទៀត: «យើងពិតជាមានសិទ្ធិក្នុងការហូប ហើយផឹកពីក្រុមជំនុំ»។

នេះគឺជាការពាររបស់ខ្ញុំ...ខ្ញុំ

អាចមានន័យថា ទី១ ពាក្យថា ដើរតាម ជាការការពាររបស់លោកប៉ូល ឬ ទី២
ពាក្យនៅក្នុង ១ កូរិនថូស ៩:១-២ ជាការការពារខ្លួនរបស់លោកប៉ូល។
ការបកប្រែផ្សេងទៀត: «នេះជាការការពារខ្លួនរបស់ខ្ញុំ...ខ្ញុំ»។

យើង...មាន

ពាក្យ «យើង» សំដៅលើលោកប៉ូល និងលោកបារណាបាស។

តើយើងគ្មានសិទ្ធិក្នុងការនាំប្រពន្ធ ដែលជាអ្នកជឿ ដូចជាសាវកឯទៀតៗ
ក៏ដូចបងប្អូនដែលនៅក្នុងព្រះអម្ចាស់ និងដូចជាលោកកេផាសទេឬអី?

លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ថា
លោកដឹងថាក្រុមជំនុំកូរិនថូសយល់ព្រមជាមួយអ្វីដែលលោកកំពុងនិយាយ។
ការបកប្រែផ្សេងទៀត: «ប្រសិនបើ យើងមានប្រពន្ធដែលជឿ
យើងមានសិទ្ធិក្នុងការនាំពួកគេមកជាមួយយើងដូចជាសាវកផ្សេងៗទៀត
និងបងប្អូនដែលនៅក្នុងព្រះអម្ចាស់ និងដូចជាលោកកេផាសដែរ»។

ឬមួយមានតែលោកបារណាបាស និងខ្ញុំទេ ដែលត្រូវធ្វើការនោះ?

លោកប៉ូលធ្វើឲ្យក្រុមជំនុំកូរិនថូសខ្មាសអៀន។ ការបកប្រែផ្សេងទៀត:
«អ្នកទំនងជាគិតថា
មនុស្សដែលត្រូវការធ្វើការដើម្បីរកប្រាក់ចំណូលមានតែលោកបារណាបាស
និងរូបខ្ញុំតែប៉ុណ្ណោះទេអី»។

1 Corinthians 9:7

លោកមានអ្នកណាចូលបម្រើជាកងទ័ព ហើយបើកប្រាក់ខែពីខ្លួនឯងទេ?

លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ថា
លោកដឹងថាក្រុមជំនុំកូរិនថូសយល់ព្រមជាមួយអ្វីដែលលោកកំពុងនិយាយ។

លោកចង់ថែរក្សាផ្សេងទៀត:
«យើងទាំងអស់គ្នាដឹងហើយថាគ្មានទាហានឯណាត្រូវទិញគ្រឿងសឹកដោយខ្លួនឯងនោះទេ»
ឬ «យើងទាំងអស់គ្នាហើយថា
គ្រប់ទាហានទាំងអស់ទទួលគ្រឿងសឹកពីរាជរដ្ឋាភិបាល»។

តើមានអ្នកដាំដើមទំពាំងបាយជូរ ហើយមិនហូបផ្លែរបស់វាដែរឬទេ?

លោកប៉ូលប្រើសំណួរនេះដើម្បីបញ្ជាក់ថា
លោកដឹងថាក្រុមជំនុំកូរិនថូសយល់ព្រមជាមួយអ្វីដែលលោកកំពុងនិយាយ។
ការបកប្រែផ្សេងទៀត: «យើងទាំងអស់គ្នាដឹងហើយថា
អ្នកដែលដាំដើមទំពាំងបាយជូរ តែងតែទទួលទានផ្លែរបស់វា» ឬ
«យើងទាំងអស់គ្នាដឹងហើយថា
គ្មានរណាម្នាក់រំពឹងថាអ្នកដែលដាំដើមទំពាំងបាយជូរមិនទទួលផ្លែរបស់វានោះទេ»។

ឬដែលមាននរណាចិញ្ចឹមហ្វូងសត្វ ហើយមិនពិសាទឹកដោះរបស់សត្វនោះដែរឬទេ?

លោកប៉ូលប្រើសំនួរនេះដើម្បីបញ្ជាក់ថា
លោកដឹងថាក្រុមជំនុំកូរិនថូសយល់ព្រមជាមួយអ្វីដែលលោកកំពុងនិយាយ។
ការបកប្រែផ្សេងទៀត: «យើងទាំងអស់គ្នាដឹងហើយថាអ្នកចិញ្ចឹមហ្វូងសត្វ
និងពិសាទឹកដោះដែលបានមកពីសត្វនោះ»។

តើខ្ញុំនិយាយការទាំងនេះផ្អែកទៅលើសិទ្ធិជាមនុស្សជាតិមែនទេ?

លោកប៉ូលកំពុងធ្វើឲ្យក្រុមជំនុំកូរិនថូសត្រូវខ្មាស។ ការបកប្រែផ្សេងទៀត:
«អ្នកទំនងជាគិតថា
ខ្ញុំនិយាយការទាំងនេះគ្រាន់តែអាស្រ័យលើសិទ្ធិជាមនុស្សជាតិតែប៉ុណ្ណោះឬ»។

តើក្រឹត្យវិន័យមិនបានចែងបែបនេះដែរទេឬអី?

លោកប៉ូលកំពុងធ្វើអោយក្រុមជំនុំកូរិនថូសត្រូវខ្មាស។ ការបកប្រែផ្សេងទៀត:
«អ្នកធ្វើហាក់បើដូចជាអ្នកមិនដឹងថា នេះត្រូវបានសរសេរនៅក្នុងច្បាប់»។

1 Corinthians 9:9

កុំឃ្លុំមាត់គោ

លោកម៉ូសេនិយាយទៅកាន់ជនជាតិអ៊ីស្រាអែល
ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់ ដូច្នេះ បទបញ្ជានេះជាឯកវចនៈ។

តើព្រះជាម្ចាស់មិនបានយកព្រះហឫទ័យទុកដាក់ដល់គោទេឬអី?

លោកប៉ូលសួរសំណួរនេះដើម្បីឲ្យក្រុមជំនុំកូរិនថូសគិតពីអ្វីដែលលោកនិយាយដោយលោកមិនចាំបាច់និ
ការបកប្រែផ្សេងទៀត: «អ្នកគួរតែដឹងមិនចំបាច់ខ្ញុំប្រាប់នោះទេដែលថា
មិនមែនជាសត្វគោទេដែលព្រះទ្រង់យកព្រះហឫទ័យទុកដាក់ដល់»។

តើព្រះអង្គមិនបានមានបន្ទូលពីពួកយើងទេមែនឬ?

generated on Wed Sep 10 16:16:32 2025

លោកប៉ូលសួរសំណួរនេះដើម្បីបញ្ជាក់សេចក្តីថ្លែងការដែលលោកកំពុងធ្វើ។
ការបកប្រែផ្សេងទៀត: «តែផ្ទុយទៅវិញ
ព្រះពិតប្រាកដជាមានព្រះបន្ទូលអំពីយើង»។
ពីពួកយើង
ពាក្យ «ពួកយើង» សំដៅលើលោកប៉ូល និងបារណាបាស។
តើវាច្រើនពេកឬអីសម្រាប់យើងច្រូតយកផលដែលជាទ្រព្យសម្បត្តិ ក្នុងលោកីយ៍ពីបងប្អូនមែនអត់?
លោកប៉ូលសួរសំណួរនេះដើម្បីឲ្យក្រុមជំនុំកូរិនថូសគិតពីអ្វីដែលលោកកំពុងនិយាយ
ដោយមិនចាំបាច់លោកនិយាយពីវា។ ការបកប្រែផ្សេងទៀត:
«អ្នកគួរតែដឹងដោយមិនចាំបាច់ខ្ញុំនិយាយទេថា
វាមិនច្រើនពេកទេសម្រាប់ពួកយើងក្នុងការទទួលទ្រព្យសម្បត្តិដែលជាការគាំទ្រពីអ្នករាល់គ្នា»។
1 Corinthians 9:12
ប្រសិនបើ អ្នកផ្សេងមានសិទ្ធិទទួលប្រយោជន៍ពីបងប្អូន
តើយើងគ្មានសិទ្ធិដើម្បីទទួលពីបងប្អូនជាងអ្នកទាំងនោះទេឬអី?
លោកប៉ូលសួរសំណួរនេះដើម្បីឲ្យក្រុមជំនុំកូរិនថូសគិតពីអ្វីដែលលោកកំពុងនិយាយ
ដោយមិនចាំបាច់លោកនិយាយពីវា។ ពាក្យ «ពួកយើង» សំដៅដល់លោកប៉ូល
និងលោកបារណាបាស។ ការបកប្រែផ្សេងទៀត: « អ្នកផ្សេងមានសិទ្ធិទទួល...អ្នក
ដូច្នេះ អ្នកដឹងដោយមិនចាំបាច់ខ្ញុំនិយាយនោះទេថា
យើងមានសិទ្ធិក្នុងការទទួលបានច្រើនជាងនេះទៅទៀត»។
ប្រសិនបើ អ្នកផ្សេងមានសិទ្ធិទទួលប្រយោជន៍ពីបងប្អូន
លោកប៉ូល និងក្រុមជំនុំកូរិថូសទាំងពីរនាក់ដឹងថា អ្នកផ្សេងមានសិទ្ធិ
«តាំងតែអ្នកផ្សេងមានសិទ្ធិទទួលប្រយោជន៍នេះ»។
អ្នកផ្សេង
អ្នកផ្សេងទៀតដែលមប្រើដំណឹងល្អ។
មានសិទ្ធិ
ជាសិទ្ធិដែលអ្នកជឿនៅក្នុងក្រុមជំនុំកូរិនថូសផ្តល់ចំពោះការចំណាយក្នុងការរស់នៅដល់
ក្លាយជាឧបសគ្គ
ក្លាយជាបន្ទុក ឬ «ឈប់រាលដាល» ។
តើបងប្អូនមិនដឹងទេឬអីថា អស់អ្នកដែលបម្រើនៅព្រះវិហារ នឹងទទួលផលពីព្រះវិហារវិញ
លោកប៉ូលរំលឹកដល់ក្រុមជំនុំកូរិនថូសពីអ្វីដែលពួកគេដឹង
ដើម្បីលោកអាចបន្ថែមព័ត៌មានថ្មីផ្សេងទៀត។ ការបកប្រែផ្សេងទៀត:
«ខ្ញុំចង់រំលឹកអ្នកថា អស់អ្នកដែលបម្រើនៅព្រះវិហារ
នឹងទទួលអាហាររបស់ពួកគេពីព្រះវិហារវិញដែរ»។
អស់អ្នកដែលបម្រើនៅលើអាសន: នឹងទទួលបានចំណែកពីអាសន:នោះផងដែរ?
លោកប៉ូលរំលឹកដល់ក្រុមជំនុំកូរិនថូសពីអ្វីដែលពួកគេដឹង
ដើម្បីលោកអាចបន្ថែមព័ត៌មានថ្មីផ្សេងទៀត។ ការបកប្រែផ្សេងទៀត:
«ខ្ញុំចង់រំលឹកអ្នកថា អស់អ្នកដែលបម្រើនៅលើអាសន: នឹងទទួលបានអាហារ
ហើយនឹងសាច់ដែលមនុស្សបានថ្វាយនៅលើអាសន:ផងដែរ»។
រស់នៅពីផលនៃដំណឹងល្អ
ពាក្យ «ដំណឹងល្អ» ជាពាក្យប្រៀបធៀបចំពោះ ទី១
ជាពួកមនុស្សដែលពួកគេប្រាប់ពីដំណឹងល្អ «ទទួលបានអាហាររបស់ពួកគេ
ហើយរបស់ផ្សេងៗទៀតដែលពួកគេត្រូវការពីអ្នកទាំងនោះដើម្បីបង្រៀនពីដំណឹងល្អ»
ឬ ទី២ លទ្ធផលនៃការបម្រើដំណឹងល្អ «ទទួលបានអាហាររបស់ពួកគេ
ហើយរបស់ផ្សេងៗទៀតដែលពួកគេត្រូវការដោយព្រោះពួកគេជាអ្នកធ្វើការជាអ្នកផ្សព្វផ្សាយដំណឹងល្អ»។
1 Corinthians 9:15
សិទ្ធិទាំងនោះ
ខ្ញុំសាកសមសំរាប់របស់ទាំងអស់នោះ
ដូច្នេះនេះមិនមែនដើម្បីជាប្រយោជន៍ដល់ខ្ញុំទេ
នេះអាចត្រូវបានបញ្ជាក់ក្នុងទំរង់សកម្ម ការបកប្រែផ្សេងទៀត
«ដូច្នេះអ្នកនឹងធ្វើអ្វីមួយសំរាប់ខ្ញុំ»។
ដកយកកិត្តិយសនេះចេញពីខ្ញុំ
យកឱកាសដែលខ្ញុំអួតនេះចេញទៅ។
ភាពចំបាច់នេះត្រូវបានដាក់លើខ្ញុំ
ខ្ញុំត្រូវតែប្រកាសដំណឹងល្អ។
នោះវេទនាដល់ខ្ញុំហើយ ប្រសិនបើ
នោះខ្ញុំឈឺចាប់ដោយសារគ្រោះកាចហើយ ប្រសិនបើ។
1 Corinthians 9:17
ដ្បិត ប្រសិនបើ ខ្ញុំធ្វើការដោយការពេញចិត្ត
ប្រសិនបើខ្ញុំប្រកាសដោយការពេញចិត្ត ឬ «ប្រសិនបើខ្ញុំប្រកាសដោយសារខ្ញុំចង់»។
ប៉ុន្តែ ប្រសិនបើមិនដោយការពេញចិត្តទេ
ពាក្យថា «ខ្ញុំធ្វើនេះ» ត្រូវបានយល់តាំងពីឃ្លាពីមុនមកម្ល៉េះ។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែ ប្រសិនបើខ្ញុំធ្វើ ទាំងខ្ញុំមិនចង់ធ្វើ» ឬ «ប៉ុន្តែ
ប្រសិនបើខ្ញុំធ្វើ ដោយត្រូវបានបង្ខំឲ្យធ្វើ»។
ខ្ញុំត្រូវបានទទួលភារកិច្ចរួមជាមួយអ្នកបម្រើដែរ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត:
«ខ្ញុំត្រូវធ្វើកិច្ចការនេះដោយថាព្រះទុកចិត្តខ្ញុំក្នុងការបំពេញកិច្ចការនេះ»
តើអ្វីទៅដែលជារង្វាន់របស់ខ្ញុំ?
លោកប៉ូលបានកំពុងរៀបចំពួកគេឲ្យបានដឹងពីព័ត៌មានថ្មីដែលលោកនឹងប្រាប់ដល់ពួកគេ។
ការបកប្រែផ្សេងទៀត: «នេះជារង្វាន់របស់ខ្ញុំ»។
ដោយឥតគិតថ្លៃ ដោយមិនយកប្រាក់ឈ្នួលពីដំណឹងល្អ
រង្វាន់របស់ខ្ញុំក្នុងការផ្សាយដំណឹងនោះ
គឺខ្ញុំអាចផ្សាយដំណឹងល្អដោយមិនទទួលបានការបង់ថ្លៃអ្វីឡើយ។
ផ្តល់នូវដំណឹងល្អ
ការប្រកាសដំណឹងល្អ
មិនបានប្រើសិទ្ធិជាអ្នកផ្សាយដំណឹងល្អឡើយ។
មិនបានសូមឲ្យមនុស្សគាំទ្រខ្ញុំនៅពេលខ្ញុំធ្វើដំណើរ
ហើយប្រកាសដំណឹងល្អនោះទេ។
1 Corinthians 9:19
ខ្ញុំអាចនាំមនុស្សរឹតតែច្រើនថែមទៀត
បញ្ចុះបញ្ចូលអ្នកដទៃឲ្យជឿ ឬ «ជួយអ្នកដទៃឲ្យទុកចិត្តដល់ព្រះ»។
ខ្ញុំក៏ដូចយូដាដែរ
ខ្ញុំធ្វើដូចជាសាសន៍យូដា ឬ «ខ្ញុំធ្វើតាមទំលៀមទំលាបជនជាតិជ្វីហ្វ»។
ខ្ញុំក៏ដូចជាអ្នកស្ថិតនៅក្រោមក្រឹត្យវិន័យ
ខ្ញុំក្លាយជាម្នាក់ដែលបានប្តេជ្ញាក្នុងការដើរតាមការដឹកនាំរបស់ជនជាតិជ្វីហ្វ
អ្នកដែលមិនស្ថិតនៅក្រោមក្រឹត្យវិន័យ ដូចជនជាតិជ្វីហ្វនោះផងដែរ។
1 Corinthians 9:21
សម្រាប់អស់អ្នកដែលគ្មានក្រឹត្យវិន័យ
អ្នកដែលមិនគោរពតាមក្រឹត្យវិន័យរបស់លោកម៉ូសេ។
1 Corinthians 9:24
ប្រយោគភ្ជាប់
លោកប៉ូលពន្យល់ថា
លោកប្រើសេរីភាពដែលលោកមានក្នុងព្រះគ្រិស្តក្នុងការកែតម្រង់ខ្លួនឯង។
តើបងប្អូនមិនដឹងទេឬអីថា អ្នករត់ប្រណាំងទាំងអស់ត្រូវរត់ដល់ទីប្រកួត ប៉ុន្តែ
មានតែម្នាក់ទេដែលនឹងទទួលភួងជ័យ?
លោកប៉ូលរំលឹកដល់ក្រុមជំនុំកូរិនថូសពីអ្វីដែលពួកគេដឹង
ដើម្បីលោកអាចបន្ថែមព័ត៌មានថ្មីបាន។ ការបកប្រែផ្សេងទៀត: «ចូរឲ្យខ្ញុំរំលឹកអ្នកថា
បើទោះជាអ្នករត់ប្រណាំងទាំងអស់ត្រូវរត់ ប៉ុន្តែ
មានតែអ្នករត់តែម្នាក់ទេដែលនឹងទទួលភួងជ័យ»។
រត់
លោកប៉ូលប្រៀបធ្មឹមការរស់នៅជាជីវិតគ្រិស្តបរិស័ទ
និងការធ្វើការថ្វាយព្រះជាការរត់ប្រណាំង និងជាការក្លាយជាអត្តពលិក។
ក្នុងការប្រណាំង ជីវិតជាគ្រិស្តបរិស័ទ
ត្រូវការការតស៊ូ ការប្តេជ្ញាចិត្ត ការលះបង់ និងការតាំងចិត្តយ៉ាងខ្លាំង
ហើយក្នុងការប្រណាំង គ្រិស្តបរិស័ទមានគោលដៅយ៉ាងជាក់លាក់។
ដូច្នេះ ចូលរត់ក្នុងរបៀបដែលអ្នកនឹងទទួលយកបានភួងជ័យ
លោកប៉ូលនិយាយពីរង្វាន់របស់ព្រះដែលនឹងផ្តល់ឲ្យប្រជារាស្ត្រដ៏ស្មោះត្រង់របស់ទ្រង់
ក៏ដូចជារង្វាន់ដែលនឹងផ្តល់ឲ្យចំពោះអ្នកប្រកួតអត្តពលិកផងដែរ។
ភួងជ័យដែលខូចរលួយ...រីឯយើងវិញ យើងនឹងទទួលភួងជ័យដែលមិនចេះរលាយសាបសូន្យវិញ
ភួងជ័យជាការមួរបញ្ចូលគ្នានៃស្លឹកមួយបាច់។
ភួងជ័យត្រូវបានផ្តល់ឲ្យទៅជារង្វាន់សម្រាប់អត្តពលិកដែលបានឈ្នះការប្រកួត។
លោកប៉ូលនិយាយពីជីវិតអស់កល្បដែលជាភួងជ័យដែលមិនចេះរីងស្ងួតឡើយ។
ខ្ញុំមិនបានរត់ដោយគ្មានគោលដៅ ហើយមិនដាល់ខ្យល់ដែរ
ពាក្យ «ការរត់» និង «ការប្រដាល់»
ទាំងពីរនេះជាការប្រៀបធៀបពីការរស់នៅក្នុងជីវិតជាគ្រិស្តបរិស័ទ
និងការបម្រើព្រះ។ នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់វិជ្ជមាន។
ការបកប្រែផ្សេងទៀត: «ខ្ញុំដឹងយ៉ាងច្បាស់ពីហេតុដែលខ្ញុំរត់
និងខ្ញុំដឹងពីអ្វីដែលខ្ញុំនឹងធ្វើពេលខ្ញុំឡើងប្រដាល់»។
ខ្លួនខ្ញុំផ្ទាល់ និងត្រូវទទួលស្គាល់យ៉ាងពេញលេញវិញ
នេះជាប្រយោគអសកម្មអាចដាក់ជាឃ្លាថ្មីក្នុងទម្រង់សកម្ម។

generated on Wed Sep 10 16:16:32 2025

ការវិនិច្ឆ័យនៃការប្រកួត ឬ ការប្រជែងជាការប្រៀបធៀបពីព្រះ។
ការបកប្រែផ្សេងទៀត: «ចៅក្រមនិងទទួលស្គាល់ខ្ញុំយ៉ាងពេញលេញ» ឬ «ព្រះនឹងមិននិយាយថា ខ្ញុំបានបរាជ័យក្នុងការស្តាប់បង្គាប់នូវក្រឹត្យវិន័យរបស់ព្រះអង្គទេ»។

---

10 [1]បងប្អូនអើយ ខ្ញុំចង់ឲ្យបងប្អូនដឹងថា បុព្វបុរស របស់យើងសុទ្ធតែបានដើរក្រោមពពក និងបានដើរឆ្លងសមុទ្រទាំងអស់គ្នា។[2]ពួកលោកបានទទួលពិធីជ្រមុជជាមួយ
លោកម៉ូសេក្នុងពពក និងក្នុងសមុទ្រ។[3]ហើយពួកគាត់ហូបអាហារខាងវិញ្ញាណដូចគ្នា។[4]គ្រប់គ្នាពិសាទឹកខាងឯវិញ្ញាណដូចគ្នា។ ដ្បិត
ពួកលោកបានពិសាទឹកខាងឯវិញ្ញាណពីថ្ម ដែលដើរតាមគេ និងថ្មនោះគឺជាព្រះគ្រិស្ត។
[5]ប៉ុន្តែ ព្រះជាម្ចាស់មិនបានសព្វព្រះហឫទ័យនឹងពួកគេភាគច្រើន ហើយសាកសពរបស់ពួកគេជាច្រើនបានស្លាប់នៅទីរហោស្ថាន។[6]ឥឡូវ ការទាំងនោះគឺជាគំរូសម្រាប់យើង
ដើម្បីកុំឲ្យយើងប្រាថ្នាចង់ធ្វើការអាក្រក់ដូចបុព្វបុរសយើងបានធ្វើឡើយ។
[7]កុំថ្វាយបង្គំព្រះក្លែងក្លាយ ដូចពួកបុព្វបុរសយើងខ្លះបានធ្វើនោះឡើយ ដ្បិតមានសេចក្តីចែងថា៖ «បណ្តាលជនបានអង្គុយសីុផឹក ហើយក្រោកលេងសប្បាយ»។
[8]សូមកុំឲ្យយើងប្រព្រឹត្តអំពើផិតក្បត់ដូចពួកគេភាគច្រើនបានធ្វើឡើយ។ ដែលជាហេតុនាំឲ្យពួកគេស្លាប់អស់ពីរម៉ឺនបីពាន់នាក់ក្នុងរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ។
[9]ហើយយើងមិនត្រូវល្បងលជាមួយនឹងព្រះគ្រិស្ត ដូចពួកគេជាច្រើនបានល្បងល ហើយក៏បានវិនាសទៅដោយពស់ចឹកឡើយ។[10]ក៏កុំឲ្យតួញត្អែរ
ដូចពួកគេភាគច្រើនបានធ្វើ ហើយក៏បានវិនាស ដោយទេវតានៃសេចក្តីស្លាប់។
[11]ដូច្នេះ ការទាំងនេះបានកើតឡើងដល់ពួកគេ គឺជាគំរូសម្រាប់យើង។ ហើយមានសេចក្តីចែងទុក ដើម្បីទូន្មានពួកយើងដែលរស់នៅជំនាន់ចុងក្រោយបង្អស់នេះ។[12]ដូច្នេះ
ចូរឲ្យគ្រប់គ្នាដែលគិតថា គាត់នឹងឈរ ត្រូវប្រយ័ត្នប្រយែងឡើង ដើម្បីកុំឲ្យគាត់ត្រូវដួលចុះវិញ។[13]គ្មានការល្បួងលណាមួយកើតមានដល់បងប្អូន ក្រៅពីការល្បួងដែល
មនុស្សលោកតែងជួបប្រទះនោះឡើយ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ ព្រះអង្គមិនបណ្តោយឲ្យសាតាំងល្បួងបងប្អូនហួសពីកម្លាំងរបស់បងប្អូនទេ។ ប៉ុន្តែ នៅ
ពេលបងប្អូនជួបការល្បួង ព្រះអង្គនឹងប្រទានមធ្យោបាយឲ្យបងប្អូនចេញរួច និងឲ្យបងប្អូនអាចទ្រាំទ្របាន។
[14]ដូច្នេះ បងប្អូនជាទីស្រឡាញ់អើយ ចូររត់ចេញពីព្រះក្លែងក្លាយចុះ។[15]ខ្ញុំនិយាយការទាំងនេះទៅបងប្អូនដោយគិតដល់បងប្អូនទេ ដូច្នេះហើយ
បងប្អូនអាចធ្វើការវិនិច្ឆ័យនូវពាក្យដែលខ្ញុំនិយាយនេះ។[16]ពេលយើងលើកពែងនៃព្រះពរឡើង តើមិនមានន័យថា យើងចូលរួមជាមួយព្រះលោហិតរបស់ព្រះគ្រិស្តទេឬអី?
នំប៉័ងដែលយើងកាច់ តើយើងមិនបានចូលរួមជាមួយព្រះកាយរបស់ព្រះគ្រិស្តដែរទេឬអី។[17]ព្រោះយើងទាំងអស់គ្នាបានទទួលចំណែកពីនំប៉័ងតែមួយ ទោះបីយើងមានគ្នា
ច្រើនក្តី តែរូបកាយតែមួយទេ។ យើងទាំងអស់គ្នារួមគ្នាមកជារូបកាយតែមួយ ក្នុងការកាច់នំប៉័ង។
[18]ចូរមើលអំពីសាសន៍អ៊ីស្រាអែល តើអស់អ្នកដែលហូបតង្វាយដែលថ្វាយជាយញ្ញបូជា មានចំណែកនៅក្នុងអាសន:?[19]តើខ្ញុំកំពុងនិយាយអំពីអ្វី?
តើព្រះក្លែងក្លាយមានប្រយោជន៍ទេ? ឬតើអាហារដែលបានសែនដល់ព្រះក្លែងក្លាយគ្មានប្រយោជន៍ទេឬអី?
[20]ប៉ុន្តែ ខ្ញុំនិយាយអំពីការអ្វីដែលសាសន៍ដទៃថ្វាយយញ្ញបូជា ពួកគេថ្វាយការទាំងនោះទៅដល់អារក្ស មិនមែនថ្វាយទៅព្រះម្ចាស់ទេ។
ខ្ញុំមិនចង់ឲ្យបងប្អូនមានចំណែកអ្វីជាមួយអារក្សឡើយ![21]បងប្អូនមិនអាចផឹកពីពែងរបស់ព្រះជាម្ចាស់ ហើយនិងពីពែងរបស់អារក្សផងបាននោះទេ។
បងប្អូនមិនអាចប្រកបរួមតុរបស់ព្រះជាម្ចាស់ផង ហើយរួមតុរបស់អារក្សផងនោះទេ។[22]ឬមួយក៏យើងចង់ឲ្យព្រះអម្ចាស់មានព្រះហឫទ័យប្រចណ្ឌ? តើយើងខ្លាំងពូកែជាង
ព្រះអង្គឬ?
[23]«យើងមានសិទ្ធិនឹងធ្វើអ្វីៗទាំងអស់បានមែន» ប៉ុន្តែ ការទាំងនោះមិនមែនសុទ្ធតែមានប្រយោជន៍នោះទេ។ «យើងមានសិទ្ធិនឹងធ្វើអ្វីៗទាំងអស់បានមែន» ប៉ុន្តែ ការទាំង
នោះមិនមែនសុទ្ធតែធ្វើឲ្យមនុស្សចម្រើនឡើងទេ។[24]ចូរកុំឲ្យមាននរណាស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ ផ្ទុយទៅវិញ
ចូរឲ្យម្នាក់ៗស្វែរប្រយោជន៍សម្រាប់អ្នកជិតខាងរបស់ខ្លួនវិញ។
[25]បងប្អូនអាចហូបអ្វីៗដែលគេលក់នៅតាមផ្សារតាមចិត្តបាន ដោយមិនបាច់សួរទេ ព្រោះខ្លាចធ្វើខុសនឹងមនសិការ។[26]ដ្បិត «ផែនដី និងអ្វីៗដែលស្ថិតនៅលើផែនដី សុទ្ធតែ
ជាកម្មសិទ្ធិរបស់ព្រះអម្ចាស់ទាំងអស់»។[27]ប្រសិនបើ មានអ្នកមិនជឿអញ្ជើញបងប្អូនទៅបរិភោគអាហារ ហើយបងប្អូនយល់ព្រមទៅ សូមបរិភោគអាហារទាំងប៉ុន្មាន ដែល
គេលើកមកជូនបងប្អូន មិនបាច់សួរទេ ព្រោះខ្លាចធ្វើខុសនឹងមនសិការ។
[28]ប៉ុន្តែ ប្រសិនបើ មានគេប្រាប់ថា៖ «អាហារនេះបានសែនដល់ព្រះដទៃហើយ» កុំហូបធ្វើអ្វី។ ធ្វើបែបនេះគឺដើម្បីជាប្រយោជន៍សម្រាប់អ្នកដែលបានប្រាប់
ហើយក៏កុំឲ្យខុសនឹងមនសិការដែរ។[29]ខ្ញុំមិនបាននិយាយថាវាខុសនឹងមនសិការ របស់បងប្អូននោះទេ តែបារម្ភពីមនសិការអ្នកដទៃវិញ។ ដ្បិត
ហេតុអ្វីបានជាសេរីភាពរបស់ខ្ញុំ ត្រូវបានជំនុំជម្រះដោយសារមនសិការរបស់អ្នកដទៃទៅវិញ?[30]ប្រសិនបើខ្ញុំទទួលទានអាហារទាំងមានឥរិយាបទល្អ ហេតុអ្វីបានជាគេរិះគន់
ខ្ញុំអំពីអាហារ ដែលខ្ញុំបានអរព្រះគុណព្រះអង្គរួចហើយនោះទៅវិញ?
[31]ដូច្នេះ ទោះបីបងប្អូនហូបឬផឹកអ្វី ឬទោះបីបងប្អូនធ្វើការអ្វីក៏ដោយ ត្រូវធ្វើទាំងអស់ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់វិញ។[32]សូមបងប្អូនកុំធ្វើឲ្យសាសន៍យូដា
សាសន៍ក្រិក ឬក្រុមជំនុំរបស់ព្រះជាម្ចាស់រវាតចិត្តឡើយ។[33]ខ្ញុំបានព្យាយាមផ្គាប់ចិត្តមនុស្សទាំងអស់ ក្នុងគ្រប់កិច្ចការ។ ខ្ញុំមិនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនទេ គឺស្វែងរក
ប្រយោជន៍សម្រាប់មនុស្សជាច្រើនវិញ។ ខ្ញុំធ្វើការនេះដើម្បីឲ្យពួកគេទទួលការសង្គ្រោះ។

---

1 Corinthians 10:1

ប្រយោគភ្ជាប់

លោកប៉ូលរំលឹកប្រាប់ពួកគេជាឧទាហរណ៍នៃបទពិសោធន៍របស់ឪពុកនៃជនជាតិយូដា ដែលបានប្រឈមនឹងការល្បួង ការមិនស្តាប់បង្គាប់ និងការថ្វាយបង្គំព្រះក្លែងក្លាយ។

បុព្វបុរស របស់យើង

លោកប៉ូលសំដៅលើសម័យកាលនៃលោកម៉ូសេនៅក្នុងព្រះគម្ពីរនិក្ខមនំនៅពេលរាស្ត្រអ៊ីស្រាអែលបានចាកចេញពីប្រទេសអេស៊ីប ដោយប្រើពាក្យ «របស់យើង» សំដៅលើលោកផ្ទាល់ និងក្រុមជំនុំកូរិនថូសរួមបញ្ចូលដែរ។

បានដើរឆ្លងសមុទ្រទាំងអស់គ្នា

សមុទ្រនេះហៅដោយឈ្មោះពីរ គឺសមុទ្រក្រហម និងសមុទ្រត្រែង។

ពួកលោកបានទទួលពិធីជ្រមុជជាមួយលោកម៉ូសេ

គ្រប់អ្នកដើរតាមបានប្តេជ្ញាជាមួយលោកម៉ូសេ។

ក្នុងពពក

ក្នុងពពកតំណាងពីព្រះវត្តមាននៃព្រះ
និងការដឹកនាំរាស្ត្រអ៊ីស្រាអែលអំឡុងពេលថ្ងៃ។

ពិសាទឹកខាងឯវិញ្ញាណដូចគ្នា... ខាងឯវិញ្ញាណពីថ្ម

ពិសាទឹកដូចគ្នាដែលព្រះបានធ្វើការអស្ចារ្យលើសពីធម្មតាក្នុងការយកទឹកចេញពីថ្ម...
ថ្មនៃការអស្ចារ្យលើសពីធម្មតា។

ថ្មនោះគឺជាព្រះគ្រិស្ត

«ថ្ម» គឺជាន័យត្រង់ ជារូបរាងថ្មមួយ ដូច្នេះ
ជាការល្អគួរតែបកប្រែទៅតាមន័យត្រង់របស់វា។

ប្រសិនបើបុព្វបុរសរបស់អ្នកមិនអាចមានអំពើអ៊ីចឹងបានទេ

ថ្មមួយនោះជាឈ្មោះរបស់នរណាម្នាក់នោះទេ សុំចាត់ទុកពាក្យ «ថ្ម»
ជាការប្រៀបធៀបពីអំណាចរបស់ព្រះគ្រិស្តដែលបានបង្ហាញថាតាមរយៈថ្ម។

អ្នកគ្រាន់តែត្រូវដឹងថាខ្ញុំ[illegible]

1 Corinthians 10:5

មិនបានសព្វព្រះហឫទ័យ

មិនពេញចិត្ត ឬ «ខឹងក្រោធ»។

ពួកគេភាគច្រើន

ជាបុព្វបុរសនៃរាស្ត្រអ៊ីស្រាអែល

សាកសពរបស់ពួកគេជាច្រើនបានស្លាប់រាយប៉ាយនៅទីរហោស្ថាន

ព្រះអម្ចាស់បានធ្វើឲ្យរូបកាយដែលស្លាប់របស់ពួកគេនៅរាយប៉ាយ ឬ
«ព្រះអម្ចាស់បានប្រហារ និងឲ្យរូបកាយរបស់ពួកគេនៅរាយប៉ាយ»។

នៅទីរហោស្ថាន

ជាវាលខ្សាច់រវាងប្រទេសអេស៊ីប
និងអ៊ីស្រាអែលដែលរាស្ត្រអ៊ីស្រាអែលបានវង្វេងនៅទីនោះអស់រយៈពេល៤០ឆ្នាំ។

1 Corinthians 10:7

generated on Wed Sep 10 16:16:32 2025

ព្រះក្លែងក្លាយ
មនុស្សដែលថ្វាយបង្គំរូបសំណាក់
បណ្តាលជនបានអង្គុយសឹុផឹក
ជាការអង្គុយបរិភោគអាហារមួយពេល។
លេងសប្បាយ
លោកប៉ូលដកស្រង់អត្ថបទគម្ពីរនេះពីជនជាតិយូដា។
អ្នកដែលបានអានអត្ថបទនេះគួរតែយល់ពីពាក្យមួយនេះគឺថា
បណ្តាលជនដែលថ្វាយបង្គំព្រះក្លែងក្លាយដោយការច្រៀង និងរាំ
ហើយការពាក់ព័ន្ធពីសកម្មភាពផ្លូវភេទផងដែរ
មិនមែនគ្រាន់តែជាការសប្បាយរីករាយបែបធម្មតានោះទេ។
ក្នុងរយៈពេលតែមួយថ្ងៃប៉ុណ្ណោះស្លាប់អស់ពីរម៉ឺនបីពាន់នាក់
ព្រះអម្ចាស់ប្រហារមនុស្សចំនួន២៣,០០០នាក់ក្នុងមួយថ្ងៃ។
1 Corinthians 10:9
បានវិនាសទៅដោយពស់ចឹក
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ដោយជាលទ្ធផល សត្វពស់បានធ្វើឲ្យពួកគេវិនាស»។
តួញញែរ
ការរអ៊ូរទាំ។
ត្រូវបានវិនាស ពីអ្នកបំផ្លាញ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ជាលទ្ធផល
ទេវតានៃសេចក្តីស្លាប់បានធ្វើឲ្យពួកគេវិនាសអស់»។
1 Corinthians 10:11
ការទាំងនេះបានកើតឡើងដល់ពួកគេ
ព្រះអម្ចាស់បានដាក់ទោសដល់បុព្វបុរសយើង។
ជាគំរូ
ពាក្យ «យើង» សំដៅដល់គ្រប់អ្នកជឿ។
នៅជំនាន់ចុងក្រោយបង្អស់នេះ
នៅថ្ងៃចុងក្រោយ
ដើម្បីកុំឲ្យត្រូវដួលចុះវិញ
កុំឲ្យប្រព្រឹត្តអំពើបាប ឬ បដិសេធព្រះ។
គ្មានការល្បួងណាមួយកើតមានដល់បងប្អូន ក្រៅពីការល្បួងដែលមនុស្សលោកតែងជួបប្រទះនោះ
ទេ
នេះអាចត្រូវបានបញ្ជាក់ជាវិជ្ជាមាន ការបកប្រែផ្សេងទៀត:
«សេចក្តីល្បួងដែលល្បួងអ្នកក៏ជាសេចក្តីល្បួងដែលមនុស្សលោកផ្សេងទៀតធ្លាប់មានបទពិសោធន៍ផងដែរ»។
ព្រះអង្គមិនបណ្តោយឲ្យសាតាំងល្បួងបងប្អូនហួសពីកម្លាំងរបស់បងប្អូនឡើយ
ទ្រង់និងអនុញ្ញាតឲ្យកើតមានតែសេចក្តីល្បួងណា
ដែលអ្នកអាចមានកម្លាំងគ្រប់គ្រាន់ក្នុងការប្រឆាំងទាស់បាន។
មិនបណ្តោយឲ្យសាតាំងល្បួងបងប្អូនបានឡើយ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«មិនបណ្តោយឲ្យនរណាម្នាក់ល្បួងអ្នកបានឡើយ»។
1 Corinthians 10:14
ប្រយោគភ្ជាប់
លោកប៉ូលបន្តការរំលឹកពួកគេឲ្យនូវតែបរិសុទ្ធ
និងនូវឲ្យឆ្ងាយពីការថ្វាយបង្គំព្រះក្លែងក្លាយ
និងអំពើប្រាសចាកសីលធម៌ខណៈលោកនិយាយពីពិធីលៀងព្រះអម្ចាស់
ដែលជាការតំណាងឲ្យព្រះលោហិត និងរូបកាយរបស់ព្រះគ្រិស្ត។
ចូររត់ចេញពីព្រះក្លែងក្លាយចុះ
លោកប៉ូលនិយាយពីមនុស្សដែលកំពុងថ្វាយបង្គំព្រះក្លែងក្លាយ
វាហាក់បីដូចជាមនុស្សដែលបានជូបសត្វសាហាវ។ ការបកប្រែផ្សេងទៀត:
«ធ្វើអ្វីតាមតែអ្នកធ្វើទៅបានដើម្បីគេចឲ្យឆ្ងាយពីការថ្វាយបង្គំព្រះក្លែងក្លាយ»។
ពែងនៃព្រះពរ
លោកប៉ូលនិយាយពីការប្រទានពររបស់ព្រះតាមរយៈស្រាទំពាំងបាយជូរ
នៅក្នុងពែងដែលជាក្បួនខ្នាតនៃពិធីលាងព្រះអម្ចាស់។
យើងមានពរ
សម្រាប់យើងក្នុងការអរគុណព្រះ។
តើមិនមានន័យថា យើងចូលរួមជាមួយព្រះលោហិតរបស់ព្រះគ្រិស្តទេឬអី?
លោកប៉ូលរំលឹកដល់ក្រុមជំនុំកូរិនថូសពីអ្វីដែលពួកគេបានដឹងហើយថា
ពែងនៃស្រាទំពាំងបាយជូរចែករំលែក
ជាតំណាងនៃការចូលរួមជាមួយព្រះលោកហិតរបស់ព្រះគ្រិស្ត។
ការបកប្រែផ្សេងទៀត: «យើងរួមជាមួយព្រះលោហិតរបស់ព្រះគ្រិស្ត»។
នំបុ័ងដែលយើងកាច់ តើយើងមិនបានចូលរួមជាមួយព្រះកាយរបស់ព្រះគ្រិស្តដែរទេឬអី
លោកប៉ូលរំលឹកដល់ក្រុមជំនុំកូរិនថូសពីអ្វីដែលពួកគេបានដឹងហើយ។
ការបកប្រែផ្សេងទៀត
«យើងចូលរួមក្នុងរូបកាយព្រះគ្រិស្តនៅពេលយើងចែកនំបុ័ង»។
ការចូលរួមចំណែក
ជាការរួមចំណែកក្នុង ឬ «ការចូលរួមស្មើគ្នាជាមួយអ្នកដទៃ»។
កាច់នំបុ័ង
ជាផ្នែកនៃនំបុ័ងមួយដែលជាចំណិត ឬ
ការកាច់ឲ្យទៅជាចំណិតមុនពេលត្រូវបានបរិភោគ។
1 Corinthians 10:18
តើអស់អ្នកដែលហូបតង្វាយដែលថ្វាយជាយញ្ញបូជា មានចំណែកនៅក្នុងអាសនៈទេ?
លោកប៉ូលរំលឹកក្រុមជំនុំកូរិនថូសពីអ្វីដែលពួកគេធ្លាប់បានដឹងហើយ
ដើម្បីលោកអាចឲ្យព័ត៌មានថ្មីទៅពួកគេបាន។ ការបកប្រែផ្សេងទៀត:
«អស់អ្នកដែលហូបតង្វាយដែលបានថ្វាយជាយញ្ញបូជា
មានចំណែកក្នុងការផ្តល់ពរពីអាសនៈ»។
តើខ្ញុំកំពុងនិយាយអំពីអ្វី?
លោកប៉ូលរំលឹកក្រុមជំនុំកូរិនថូសពីអ្វីដែលពួកគេធ្លាប់បានដឹងហើយ
ដើម្បីលោកអាចឲ្យព័ត៌មានថ្មីទៅពួកគេបាន។ ការបកប្រែផ្សេងទៀត:
«សូមឲ្យខ្ញុំនិយាយសារជាថ្មីម្តងទៀតពីអ្វីដែលខ្ញុំកំពុងនិយាយ» ឬ
«ខ្ញុំមានន័យយ៉ាងនេះ»។
តើព្រះក្លែងក្លាយមានប្រយោជន៍ទេ?
លោកប៉ូលចង់ឲ្យក្រុមជំនុំកូរិនថូសឆ្លើយសំណួរនៅក្នុងចិត្តរបស់ពួកគេដូច្នេះ
លោកមិនចាំបាច់និងនិយាយប្រាប់ពួកគេទេ។ ការបកប្រែផ្សេងទៀត:
«អ្នកបានដឹងហើយ
ខ្ញុំមិនបាននិយាយថាព្រះក្លែងក្លាយជាអ្វីមួយពិតប្រាកដនោះទេ»។
ឬតើអាហារដែលបានសែនដល់ព្រះក្លែងក្លាយគ្មានប្រយោជន៍ទេឬអី?
លោកប៉ូលចង់ឲ្យក្រុមជំនុំកូរិនថូសឆ្លើយសំណួរនៅក្នុងចិត្តរបស់ពួកគេដូច្នេះ
លោកមិនចាំបាច់និងនិយាយប្រាប់ពួកគេទេ។ ការបកប្រែផ្សេងទៀត:
«អ្នកបានដឹងហើយ ខ្ញុំមិនបាននិយាយថា
អាហារដែលបានសែនដល់ព្រះក្លែងក្លាយនោះមិនមានសារសំខាន់នោះទេ»។ « »
បងប្អូនមិនអាចផឹកពីពែងរបស់ព្រះជាម្ចាស់ ហើយនិងពីពែងរបស់អារក្សផងបាននោះទេ
លោកប៉ូលនិយាយពីអ្នកផឹកពែងរួមគ្នាជាមួយសាតាំងដែលជាភស្តុតាងបញ្ជាក់ថាអ្នកនោះជាមិត្តរបស់អារ
ការបកប្រែផ្សេងទៀត:
«មិនអាចទៅរួចទេសម្រាប់អ្នកក្នុងការធ្វើជាមិត្តសំឡាញ់របស់ព្រះអម្ចាស់ផង
និងអារក្សនោះទេ»។
បងប្អូនមិនអាចរួមតុជាមួយព្រះអម្ចាស់ផង ហើយរួមតុជាមួយអារក្សផងនោះទេ
មិនអាចទៅរួមទេសំរាប់បងប្អូនក្នុងការធ្វើជារាស្ត្រដ៏ពិតប្រាកដរបស់ព្រះអម្ចាស់ផង
ហើយជារាស្ត្ររបស់អារក្សផងនោះទេ។
ឬមួយក៏យើងចង់ឲ្យព្រះអម្ចាស់មានព្រះហឫទ័យប្រចណ្ឌ?
លោកប៉ូលចង់ឲ្យក្រុមជំនុំកូរិនថូសឆ្លើយសំណួរនេះក្នុងចិត្តរបស់ពួកគេ។
ការបកប្រែផ្សេងទៀត: «បងប្អូនគួរតែដឹងដោយមិនចាំបាច់ខ្ញុំប្រាប់ទេថា
មិនត្រឹមត្រូវទេដែលធ្វើឲ្យព្រះអម្ចាស់មានព្រះហឫទ័យប្រចណ្ឌ»។
ញុះញ៉ង់
ធ្វើឲ្យមានកំហឹង ឬ ខឹង។
យើងមិនខ្លាំងពូកែជាងព្រះអង្គទេ មែនទេ?
លោកប៉ូលចង់ឲ្យក្រុមជំនុំកូរិនថូសឆ្លើយសំណួរនេះក្នុងចិត្តរបស់ពួកគេ។
ការបកប្រែផ្សេងទៀត: «បងប្អូនគួរតែដឹងដោយមិនចាំបាច់ខ្ញុំប្រាប់ទេថា
យើងមិនខ្លាំងពូកែជាងព្រះអង្គទេ»។
1 Corinthians 10:20
បងប្អូនមិនអាចផឹកពីពែងរបស់ព្រះជាម្ចាស់ ហើយនិងពីពែងរបស់អារក្សផងបាននោះទេ។
លោកប៉ូលមានប្រសាសន៍ពីអ្នកដែលផឹកពែងរបស់អារក្ស
របៀបដូចជាមិត្តសម្លាញ់របស់អារក្ស។ ការបកប្រែផ្សេងទៀត:
«អ្នកមិនអាចធ្វើជាមិត្តសម្លាញ់ជាមួយព្រះជាអម្ចាស់ផង និងអារក្សផងបានទេ»
បងប្អូនមិនអាចប្រកបរួមតុរបស់ព្រះជាម្ចាស់ផង ហើយរួមតុរបស់អារក្សផងនោះទេ
«បងប្អូនមិនអាចរួមតែមួយជាមួយប្រជារាស្ត្ររបស់ព្រះអម្ចាស់
និងជាមួយអារក្សផងបានទេ»។
ឬមួយក៏យើងចង់ឲ្យព្រះអម្ចាស់មានព្រះហឫទ័យប្រចណ្ឌ?
លោកប៉ូលចង់ឲ្យអ្នកក្រុងកូរិនថូសឆ្លើយសំនួរនៅក្នុងគំនិតរបស់ពួកគេ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត: «អ្នកគួរដឹងថាបើគ្មានខ្ញុំប្រាប់អ្នកថា
ការធ្វើឲ្យព្រះអម្ចាស់ប្រចណ្ឌ មិនត្រឹមត្រូវទេ»
ខឹង
ខឹង ឬ ក្តៅក្រហាយ
តើយើងខ្លាំងពូកែជាងព្រះអង្គឬ?
លោកប៉ូលចង់ឲ្យអ្នកក្រុងកូរិនថូសឆ្លើយសំណួរនៅក្នុងគំនិតរបស់ពួកគេ។
ការបកប្រែផ្សេងទៀត: «អ្នកគួរដឹងថាបើគ្មានខ្ញុំប្រាប់អ្នករាល់គ្នាថា
យើងមិនខ្លាំងជាព្រះជាម្ចាស់ទេ»
1 Corinthians 10:23
ប្រយោគភ្ជាប់
ជាថ្មីម្តងទៀតលោកប៉ូលរំលឹកពួកគេពីបញ្ហាត្តិនៃសេរីភាព
និងការធ្វើអ្វីៗគ្រប់យ៉ាងដើម្បីជាប្រយោជន៍សម្រាប់អ្នកដទៃ។
យើងមានសិទ្ធិនឹងធ្វើអ្វីៗទាំងអស់បានមែន
អាចមានន័យថាទី១
លោកប៉ូលកំពុងឆ្លើយពីអ្វីដែលក្រុមជំនុំកូរិនថូសមួយចំនួនកំពុងគិត
«អ្នកខ្លះនិយាយថា ខ្ញុំអាចធ្វើគ្រប់អ្វីៗបានទាំងអស់» ឬ ទី២
លោកប៉ូលជាការពិតកំពុងនិយាយអ្វីដែលលោកគិតថាជាសេចក្តីពិត «
ព្រះអម្ចាស់អនុញ្ញាតឲ្យខ្ញុំធ្វើអ្វីៗគ្រប់យ៉ាងបាន»។
ឃ្លានេះអាចត្រូវបានបកប្រែនៅក្នុង ១ កូរិនថូស ៦:១២ (../06/12.md)
ប៉ុន្តែ ការទាំងនោះមិនមែនសុទ្ធតែមានប្រយោជន៍នោះទេ
អ្វីមួយចំនួនមិនមែនសុទ្ធតែមានប្រយោជន៍នោះទេ។
ប៉ុន្តែ ការទាំងនោះមិនមែនសុទ្ធតែធ្វើឲ្យមនុស្សចម្រើនឡើងទេ
ការធ្វើឲ្យមនុស្សចម្រើនជាតំណាងចំពោះការជួយពួកគេឲ្យមានជំនឿពេញវ័យ
និងរឹងមាំ។ សូមមើលការបកប្រែ: «ធ្វើឲ្យចម្រើនឡើង» ក្នុង ១កូរិនថូស ៨:១
មិនបាច់សួរទេ ព្រោះខ្លាចធ្វើខុសនឹងមនសិការ
បងប្អូន ព្រះអង្គចង់ឲ្យបងប្អូនបរិភោគអាហារដោយមានមនសិការច្បាស់លាស់។
1 Corinthians 10:25
ដោយមិនបាច់សួរទេ ព្រោះខ្លាចធ្វើខុសនឹងមនសិការ។
«បងប្អូនអើយ ព្រះជាម្ចាស់ចង់ឲ្យបងប្អូនទទួលទានអាហារដោយមនសិការស្អាត»
1 Corinthians 10:28
ប៉ុន្តែ ប្រសិនបើ មានគេប្រាប់ថា...កុំហូបធ្វើអ្វី...សម្រាប់អ្នកដែលបានប្រាប់បងប្អូន
ការបកប្រែខ្លះទៀតដាក់ខគម្ពីរនេះបន្តទៀត «ហើយមិនមែនជារបស់អ្នក»
នៅក្នុងខគម្ពីរបន្ទាប់ នៅក្នុងវង់ក្រចក ពីព្រោះ ទី១ ទម្រង់នៃពាក្យ «អ្នក» និង
«បរិភោគ» ទាំងនេះជាឯកវចន: ប៉ុន្តែ លោកប៉ូលប្រើពហុវចន:ភ្លាមៗពីមុន
និងបន្ទាប់ពី នៅក្នុងប្រយោគនេះ ទី២ ពាក្យ «ដ្បិត ហេតុអ្វីបានជាសេរីភាពរបស់ខ្ញុំ
ត្រូវបានជំនុំជម្រះដោយសារមនសិការរបស់អ្នកដទៃទៅវិញ?»
នៅក្នុងខគម្ពីរបន្ទាប់ហាក់បីដូចជំរុញឲ្យធ្វើ
«បរិភោគពីអ្វីដែលបានដាក់នៅខាងមុខបងប្អូនដោយមិនចាំបាច់សួរពីមនសិការរបស់ខ្លួនទេ»
១កូរិនថូស ១០:២៧
មានគេប្រាប់ថា...កុំហូបធ្វើអ្វី...បានប្រាប់បងប្អូន
លោកប៉ូលនិយាយពីក្រុមជំនុំកូរិនថូសដែលពួកគេជាមនុស្សតែមួយដូច្នេះពាក្យ
«បងប្អូន» និងបទបញ្ញាត្តិ «កុំបរិភោគ» ទាំងនេះជាឯកវចន:។
ខ្ញុំមិនបាននិយាយថាវាខុសនឹងមនសិការ របស់បងប្អូននោះទេ តែបារម្ភពីមនសិការអ្នកដទៃវិញ
ការបកប្រែមួយចំនួនបានដាក់ពាក្យទាំងនេះរួមជាមួយពាក្យនៅក្នុងខគម្ពីរពីខាងមុខពាក្យ
ក្នុងវង់ក្រចក ពីព្រោះ ទី១ ទម្រង់នៃពាក្យ «របស់អ្នក» ពាក្យនេះជាឯកវចន: ប៉ុន្តែ
លោកប៉ូលប៉ុន្តែលោកប៉ូលប្រើពហុវចន:ភ្លាមៗពីមុន និងបន្ទាប់ពី
នៅក្នុងប្រយោគនេះ ទី២ ពាក្យ «ដ្បិត ហេតុអ្វីបានជាសេរីភាពរបស់ខ្ញុំ
ត្រូវបានជំនុំជម្រះដោយសារមនសិការរបស់អ្នកដទៃទៅវិញ?»
នៅក្នុងខគម្ពីរបន្ទាប់ហាកបីដូចជំរុញឲ្យធ្វើ
«បរិភោគពីអ្វីដែលបានដាក់នៅខាងមុខបងប្អូនដោយមិនចាំបាច់សួរពីមនសិការរបស់ខ្លួនទេ»
១កូរិនថូស ១០:២៧
របស់បងប្អូននោះទេ
លោកប៉ូលនិយាយពីក្រុមជំនុំកូរិនថូសដែលពួកគេជាមនុស្សតែមួយដូច្នេះពាក្យ
«របស់បងប្អូន» ពាក្យនេះជាឯកវចន:។
ដ្បិតហេតុអ្វី...មនសិការ?
សំណួរនេះអាចមានន័យទៅតាមសំណួរនៅក្នុងខគម្ពីរបន្តបន្ទាប់ ដូចជាទី១ ពាក្យ
«ដ្បិត» សំដៅទៅលើ ១ កូរិនថូស ១០:២៧ (../10/27.md)។
ការបកប្រែផ្សេងទៀត: «ខ្ញុំមិនបានសួរសំណួរអំពីមនសិការនោះទេ
ដូច្នេះហេតុអ្វី...មនសិការ?» ឬ ទី២
លោកប៉ូលដកស្រង់ពីអ្វីដែលក្រុមជំនុំកូរិនថូសកំពុងគិត។ ការបកប្រែផ្សេងទៀត:
«ប្រហែលអ្នកមួយចំនួនគិតថា ដ្បិត ហេតុអ្វី...មនសិការ?»
ហេតុអ្វីបានជាសេរីភាពរបស់ខ្ញុំ ត្រូវបានជំនុំជម្រះដោយសារមនសិការរបស់អ្នកដទៃទៅវិញ?
អ្នកនិយាយចង់ឲ្យអ្នកដែលបានលឺឆ្លើយសំណួរនៅក្នុងចិត្តរបស់គាត់។
ការបកប្រែផ្សេងទៀត: «បងប្អូនគួរតែដឹងដោយមិនចាំបាច់ខ្ញុំនិយាយប្រាប់អ្នកទេថា
គ្មាននរណាម្នាក់អាចនិយាយថាខ្ញុំធ្វើខុសនោះទេដោយគ្រាន់តែអ្នកនោះមានគំនិតត្រូវ
ឬខុសដែលការគិតទាំងអស់នោះខុសពីគំនិតរបស់ខ្ញុំឡើយ»។
ប្រសិនបើ ខ្ញុំទទួលទានអាហារទាំងមានឥរិយាបទល្អ ហេតុអ្វីបានជាគេរិះគន់ខ្ញុំអំពីអាហារ ដែលខ្ញុំ
បានអរព្រះគុណព្រះអង្គរួចហើយនោះទៅវិញ?
អ្នកនិយាយចង់ឲ្យអ្នកដែលបានលឺឆ្លើយសំណួរនៅក្នុងចិត្តរបស់គាត់។
ការបកប្រែផ្សេងទៀត: «ខ្ញុំបរិភោគអាហារទាំងការដឹងគុណ ដូច្នេះ
មិនគួរឲ្យនរណាម្នាក់ប្រមាថចំពោះសេចក្តីដែលខ្ញុំអរគុណនោះទៅវិញ?»
ប្រសិនបើខ្ញុំទទួលទាន
ប្រសិនបើ លោកប៉ូលមិនបានដកស្រង់ពីការគិតរបស់ក្រុមជំនុំកូរិនថូសនោះទេ
ពាក្យ «ខ្ញុំ» តំណាងឲ្យអស់អ្នកដែលបរិភោគអាហារទាំងការអរព្រះគុណ។ «ដ្បិត
អ្នកដែលបានទទួលទាន» ឬ «នៅពេលអ្នកបរិភោគ» ។
ទាំងមានឥរិយាបទល្អ
ហើយអរព្រះគុណសំរាប់ការនេះ ឬ
«អរគុណដល់អ្នកដែលបានឲ្យមកខ្ញុំចំពោះការនេះ»។
កុំធ្វើឲ្យសាសន៍យូដា សាសន៍ក្រិក ឬក្រុមជំនុំរបស់ព្រះជាម្ចាស់រវាតចិត្តឡើយ
កុំធ្វើឲ្យសាសន៍យូដា សាសន៍ក្រិកមិនពេញចិត្តឡើយ ឬ «កុំធ្វើឲ្យសាសន៍យូដា ឬ
សាសន៍ក្រិកខឹងឡើយ»។
ខ្ញុំបានព្យាយាមផ្គាប់ចិត្តមនុស្សទាំងអស់
ធ្វើឲ្យមនុស្សទាំងអស់សប្បាយចិត្ត។
ខ្ញុំមិនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនទេ
ខ្ញុំមិនបានធ្វើអ្វីតាមតែបំណងចិត្តរបស់ខ្ញុំនោះទេ។
សម្រាប់មនុស្សជាច្រើនវិញ
សម្រាប់មនុស្សរឹតតែច្រើនតាមតែអាចធ្វើទៅបាន។
1 Corinthians 10:31
សូមបងប្អូនកុំធ្វើឲ្យសាសន៍យូដា សាសន៍ក្រិក ឬក្រុមជំនុំរបស់ព្រះជាម្ចាស់រវាតចិត្តឡើយ
«កុំធ្វើឲ្យជនជាតិយូដា ឬជនជាតិក្រិករវាតចិត្តឡើយ» ឬ «កុំធ្វើឲ្យជនជាតិយូដា ឬ
ជនជាតិក្រិកខឹងឡើយ»
ខ្ញុំបានព្យាយាមផ្គាប់ចិត្តមនុស្សទាំងអស់
ធ្វើឲ្យមនុស្សគ្រប់គ្នាអរសប្បាយ»
ខ្ញុំមិនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនទេ
«ខ្ញុំមិនធ្វើអ្វីៗ សម្រាប់ខ្លួនខ្ញុំទេ»
សម្រាប់មនុស្សជាច្រើនវិញ
ធ្វើសម្រាប់មនុស្សជាច្រើនតាមដែលអាចធ្វើបាន។

---

11 [1]ចូរយកតម្រាប់តាមខ្ញុំ ដូចខ្ញុំផ្ទាល់បានយកតម្រាប់តាមព្រះគ្រិស្តដែរ។[2]ឥឡូវ ខ្ញុំសូមសរសើរបងប្អូន ដោយបងប្អូននឹកដល់ខ្ញុំក្នុងគ្រប់ការទាំងអស់។ ខ្ញុំសូមសរសើរ
បងប្អូន ដោយព្រោះបងប្អូនបានធ្វើតាមរបៀបដែលខ្ញុំបាននាំមកដល់បងប្អូន។[3]ឥឡូវ ខ្ញុំចង់ប្រាប់បងប្អូនឲ្យដឹងថាព្រះគ្រិស្តគឺជាក្បាលរបស់មនុស្សគ្រប់រូប
ហើយមនុស្សប្រុសគឺជាក្បាលរបស់មនុស្សស្រី និងព្រះជាម្ចាស់គឺជាក្បាលរបស់ព្រះគ្រិស្តដែរ។[4]បុរសណាដែលអធិស្ឋាន ឬថ្លែងព្រះបន្ទូល ដោយបិតបាំងក្បាល បុរសនោះ
មិនឲ្យតម្លៃក្បាលខ្លួនឯងហើយ។
[5]ប៉ុន្តែ ស្ត្រីណាម្នាក់ដែលអធិស្ឋាន ឬថ្លែងព្រះបន្ទូលដោយគ្មានអ្វីគ្របលើក្បាលទេ នាងមិនឲ្យតម្លៃក្បាលរបស់នាងឡើយ។
ដ្បិតធ្វើបែបនេះគឺជាអ្វីមួយដែលប្រៀបដូចជានាងបានកោរក្បាលរបស់នាងដែរ។[6]បើស្ត្រីណាមិនទទូរស្បៃនៅលើក្បាលទេ ឲ្យនាងកោរសក់តែម្តងទៅ ប៉ុន្តែ បើការកាត់សក់
ឬកោរសក់ នាំឲ្យស្ត្រីៗអាម៉ាស់មុខដូច្នេះ នាងត្រូវតែទទូរស្បៃនៅលើក្បាលរបស់នាង។
[7]ដ្បិត បុរសមិនគួរទទូរស្បៃពីលើក្បាលឡើយ ព្រោះគេគឺជារូបភាព និងជាសិរីរុងរឿងរបស់ព្រះជាម្ចាស់។ រីឯស្ត្រី នាងគឺជាសិរីរុងរឿងរបស់ប្តីវិញ។[8]ដ្បិត
បុរសមិនបានកើតពីស្ត្រីទេ។ ផ្ទុយទៅវិញ ស្ត្រីបានកើតពីបុរសវិញ។

generated on Wed Sep 10 16:16:32 2025

[9]ដ្បិត បុរសមិនបានបង្កើតសម្រាប់ស្ត្រីទេ។ ផ្ទុយទៅវិញ ស្ត្រីគឺបានបង្កើតសម្រាប់បុរសវិញ។[10]នេះជាមូលហេតុ ស្ត្រីៗត្រូវតែទទួរស្បៃជាសញ្ញា
នៃសិទ្ធិអំណាចលើក្បាលរបស់នាង ពីព្រោះតែយល់ដល់ពួកទេវតា។
[11]ប៉ុន្តែ ក្នុងព្រះជាម្ចាស់ មនុស្សស្រីមិនមានភាពឯករាជ្យពីបុរសឡើយ ហើយបុរសក៏មិនមានភាពឯករាជ្យពីមនុស្សស្ត្រីដែរ។[12]ដ្បិត ស្ត្រីយកចេញពីបុរសមក បុរសក៏កើត
ចេញមកពីស្ត្រីយ៉ាងនោះដែរ។ ហើយអ្វីៗទាំងអស់សុទ្ធតែកើតមកពីព្រះជាម្ចាស់។
[13]ចូរវិនិច្ឆ័យពីខ្លួនអ្នកចុះ តើវាពិតជាមិនសមរម្យដែលស្ត្រីអធិស្ឋានទៅព្រះជាម្ចាស់ដោយគ្មានស្បៃគ្របក្បាលនោះ?[14]សូម្បីតែ ធម្មជាតិក៏បានបង្ហាញឲ្យយើងដឹងដែរថា បើ
ប្រុសៗទុកសក់វែង តើវាជាការអាម៉ាស់មុខគាត់ណាស់ឬ?[15]តើធម្មជាតិមិនបង្រៀនអ្នកទេឬអីថា បើស្រីសក់វែងជាសិរីរុងរឿងរបស់នាងនោះ? តាមពិត ព្រះជាម្ចាស់ប្រទាន
ឲ្យស្ត្រីៗមានសក់វែង ទុកដូចជាស្បៃនៅលើក្បាលរបស់នាង។[16]ប្រសិនបើ នរណាម្នាក់ចង់រករឿងពីការនេះ យើងមិនមានសេចក្តីណាផ្សេងទៀតដែរ ហើយក្រុមជំនុំរបស់
ព្រះជាម្ចាស់ក៏មិនមានដែរ។
[17]ប៉ុន្តែ តាមសេចក្តីណែនាំខាងក្រោមនេះ ខ្ញុំមិនសរសើរបងប្អូនឡើយ។ ដ្បិត ពេលបងប្អូនមកជួបប្រជុំគ្នា វាមិនបានធ្វើឲ្យប្រសើជាងមុននោះទេ ប៉ុន្តែ
បានធ្វើឲ្យអាក្រក់ជាងមុនទៅទៀត។[18]ដ្បិត ពីដំបូង ខ្ញុំបានឮថា ពេលដែលបងប្អូនបានមកជួបប្រជុំនៅព្រះវិហារ ហើយមានការបែកបាក់ក្នុងចំណោមបងប្អូន
ទៅជាបក្សពួកខ្ញុំជឿថាបែបនោះ។[19]ដ្បិត គឺមានការទាស់ប្រឆាំងគ្នា ក្នុងចំណោមបងប្អូន ដូច្នេះ អ្នកណាដែលធ្វើការនេះនឹងត្រូវបានស្គាល់នៅក្នុចំណោមបងប្អូន។
[20]ដូច្នេះ ពេលបងប្អូនមកប្រជុំគ្នា នោះមិនមែនយើងហូបដូចជាពិធីជប់លៀងរបស់ព្រះអម្ចាស់ទេ។[21]ពេលណាដែលអ្នកហូប នោះគ្រប់គ្នាខំហូបអាហារ របស់ខ្លួនឲ្យតែឆ្អែត
មុនអាហារអ្នកផ្សេងមកដល់។ បានជាមានមួយនៅឃ្លាន ហើយមួយទៀតស្រវឹង។[22]តើអ្នករាល់គ្នាគ្មានផ្ទះ សម្រាប់ដើម្បីហូបអាហារទេឬអី? តើអ្នកមើលងាយដល់ក្រុមជំនុំ
របស់ព្រះជាម្ចាស់ ហើយចង់ធ្វើឲ្យពួកអ្នកដែលគ្មានអ្វីនោះ មានសេចក្តីខ្មាសឬអី? តើគួរឲ្យខ្ញុំនិយាយនឹងបងប្អូនថាដូចម្តេច? គួរឲ្យសរសើរបងប្អូនឬអី? ខ្ញុំនឹងមិនសរសើរ
បងប្អូនសម្រាប់ការនេះទេ!។
[23]ដ្បិត ខ្ញុំបានទទួលអ្វីដែលមកពីព្រះអម្ចាស់ ហើយក៏ផ្តល់ដល់អ្នករាល់គ្នា គឺថានៅពេលយប់ដែលព្រះអម្ចាស់យេស៊ូត្រូវគេបញ្ជូន នោះទ្រង់បានកាច់នំបុ័ង។
[24]ក្រោយពីព្រះជាម្ចាស់អរព្រះគុណរួចហើយ ក៏កាច់នំបុ័ងដោយមានព្រះបន្ទូលថា៖ «នេះជារូបកាយខ្ញុំ ដែលត្រូវកាច់សម្រាប់អ្នករាល់គ្នា ចូរធ្វើកិច្ចនេះ ទុកជាសេចក្តីរំឭកពី
ខ្ញុំចុះ»
[25]ក្នុងរបៀបដដែល ព្រះជាម្ចាស់ក៏យកពែងបន្ទាប់ពីបានបរិភោគហើយ ដោយព្រះបន្ទូលថា៖ «ពែងនេះជាសម្ពន្ធមេត្រីថ្មី ដោយនូវឈាមខ្ញុំ។ ចូរធ្វើដូច្នេះរាល់វេលាណាដែល
ផឹក ទុកជាសេចក្តីរំឭកដល់ខ្ញុំ»។[26]ដ្បិត ពេលណាដែលបងប្អូនហូបនំបុ័ង ហើយផឹកពីពែងនេះ បងប្អូនបានប្រកាសពីការសុគតរបស់ព្រះអម្ចាស់ ដរាបដល់ព្រះអង្គយាង
មកវិញ។
[27]ដូច្នេះ អ្នកណាដែលបរិភោគនំបុ័ង ឬផឹកពីពែងនៃព្រះអម្ចាស់បែបមិនគួរសម នឹងមានទោសចំពោះព្រះកាយ ហើយនិងព្រះលោហិតរបស់ព្រះអម្ចាស់។[28]ត្រូវឲ្យមនុស្ស
ពិនិត្យខ្លួនឯងមើលហើយរួចសូមហូបនំបុ័ង ហើយផឹកពីពែងនោះចុះ។[29]ដ្បិត អ្នកណាដែលហូប និងផឹកបែបមិនគួរសមចំពោះព្រះកាយ អ្នកនោះ
ហូបហើយផឹកដោយជាប់ក្នុងការជំនុំជម្រះដល់ខ្លួនវិញ។[30]ដោយហេតុនេះហើយបានជាមានមនុស្សច្រើននៅក្នុងបងប្អូន ទៅជាខ្សោយ ហើយឈឺ ក៏មានអ្នកខ្លះបានដេក
លក់ទៅហើយដែរ។
[31]ប៉ុន្តែ ប្រសិនបើយើងបានពិចារណាអំពីខ្លួនយើងសិន យើងមិនត្រូវជាប់ជំនុំជម្រះឡើយ។[32]ប៉ុន្តែ ពេលយើងជាប់ជំនុំជម្រះដោយព្រះអម្ចាស់
ពួកយើងបានទទួលការកែតម្រង់ទេ ដូច្នេះ យើងមិនជាប់ក្នុងទោសជាមួយលោកីយ៍ឡើយ។
[33]ដូច្នេះ បងប្អូនអើយ កាលណាបងប្អូនប្រជុំគ្នា ដើម្បីនឹងបរិភោគគួររង់ចាំឲ្យបានរួចរាល់ទាំងអស់គ្នា។[34]បើសិនជាអ្នកណាឃ្លាន សូមឲ្យអ្នកនោះហូបនៅផ្ទះចុះ ដើម្បីកុំឲ្យ
អ្នករាល់គ្នាប្រជុំទៅ នាំឲ្យជាប់មានទោសឡើយ ឯការឯទៀត ដល់កាលណាខ្ញុំមក នោះខ្ញុំនឹងសម្រេចគ្រប់ទាំងអស់។

---

1 Corinthians 11:1

ប្រយោគភ្ជាប់

បន្ទាប់ពីរំលឹកពួកគេឲ្យតាមលោក ក្នុងរបៀបដែលលោកដើរតាមព្រះគ្រិស្ត
លោកប៉ូលក៏ផ្តល់នូវការបង្រៀនជាក់លាក់មួយចំនួនដល់ស្ត្រី
និងបុរសក្នុងការរស់នៅក្នុងភាពជាអ្នកជឿ។

បងប្អូននឹកដល់ខ្ញុំក្នុងគ្រប់ការទាំងអស់

បងប្អូនគិតពីខ្ញុំគ្រប់ពេលវេលា ឬ «បងប្អូនតែងតែព្យាយាមធ្វើតាមអ្វី
ដែលខ្ញុំចង់ឲ្យបងប្អូនធ្វើ» ក្រុមជំនុំកូរិនថូសបានភ្លេចថាលោកប៉ូលជានរណា ឬ
ពីអ្វីដែលលោកបានបង្រៀនពួកគេ។

ឥឡូវ ខ្ញុំចង់ប្រាប់

អាចមានន័យថា ទី១ «ដោយសាររឿងនេះ ខ្ញុំចង់ប្រាប់» ឬ ទី២
«ទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់ប្រាប់»។

គឺជាក្បាល

មានសិទ្ធិអំណាចលើ

មនុស្សប្រុសគឺជាក្បាលរបស់មនុស្សស្រី

អាចមានន័យថា ទី១ «បុរសមានសិទ្ធិអំណាចលើស្ត្រី» ឬ ទី២
«ប្តីមានសិទ្ធិអំណាចលើប្រពន្ធ»។

ដោយបិតបាំងក្បាលរបស់គាត់

ដោយធ្វើយ៉ាងដូច្នេះ បន្ទាប់ពីពាក់ក្រណាត់ ឬ ពាក់ស្បៃនៅលើក្បាលរបស់លោក

មិនឲ្យតម្លៃក្បាលខ្លួនឯង

អាចមានន័យថា ទី១ «ធ្វើឲ្យខូចកិត្តិយសខ្លួនឯង» ឬ ទី២
«ធ្វើឲ្យខូចកិត្តិនាមចំពោះព្រះគ្រិស្តដែលទ្រង់ជាសិរសា»។

1 Corinthians 11:5

ស្ត្រីណាម្នាក់ដែលអធិស្ឋាន...មិនឲ្យតម្លៃក្បាលរបស់នាងឡើយ

អាចមានន័យថា ទី១ «ស្ត្រីណាដែលអធិស្ឋាន...ធ្វើឲ្យខូចកិត្តិយសខ្លួនឯង» ឬ ទី២
«ប្រពន្ធណាដែលអធិស្ឋាន...ធ្វើឲ្យខូចកិត្តិនាមប្តីរបស់ខ្លួន»។

ដោយគ្មានអ្វីគ្របលើក្បាលទេ

ដោយមិនមានទទួរស្បៃនៅលើក្បាល និងមិនបានគ្រប់ទាំងសក់ និងស្មាផង។

ជាអ្វីមួយដែលប្រៀបដូចជានាងបានកោរក្បាលរបស់នាងដែរ

ដែលដូចជានាងកោរសក់ទាំងអស់របស់នាងជាមួយនឹងកាំបិតកោរ។

នាំឲ្យស្ត្រីៗអាម៉ាស់មុខដូច្នេះ

ជាសញ្ញាណនៃភាពអាម៉ាស់សម្រាប់ស្ត្រីដែលត្រូវបានកោរសក់ ឬកាត់សក់ខ្លី។

ទទួរស្បៃនៅលើក្បាលរបស់នាង

ដោយបានទទួរស្បៃនៅលើក្បាល និងបានគ្រប់ទាំងសក់ និងស្មារបស់នាងផងដែរ។

1 Corinthians 11:7

បុរសមិនគួរទទួរស្បៃពីលើក្បាលឡើយ

នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត: អាចមានន័យថា
ទី១ «មិនត្រូវទទួរស្បៃពីលើក្បាលឡើយ» ឬ ទី២
«មិនត្រូវការទទួរស្បៃពីលើក្បាលទេ»។

ជាសិរីរុងរឿងរបស់ប្តីវិញ

ជាប្តីឆ្លុះបញ្ចាំងពីភាពអស្ចារ្យរបស់ព្រះ ហើយស្ត្រីក៏ឆ្លុះបញ្ចាំងពីអត្តចរិករបស់ប្តីដែរ។

ដ្បិត បុរសមិនបានកើតពីស្ត្រីទេ។ ផ្ទុយទៅវិញ ស្ត្រីបានកើតពីបុរសវិញទេ

ព្រះបានបង្កើតស្ត្រីដោយការដកយកឆ្អឹងជំនីពីបុរស ហើយក៏បង្កើតស្ត្រីពីឆ្អឹងនោះ។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះមិនបានបង្កើតបុរសចេញពីស្ត្រីទេ។ តែផ្ទុយទៅវិញ
ទ្រង់បានបង្កើតស្ត្រីចេញពីបុរសវិញទេ»។

1 Corinthians 11:9

ដ្បិត បើមិន... បុរសវិញ

ពាក្យទាំងអស់នេះនៅ ១ កូរិនថូស ១១:៨(../11/07.md)
ដែលបានដាក់ក្នុងវង់ក្រចកដើម្បីឲ្យអ្នកអានមើលឃើញពាក្យ «នេះ» នៅក្នុង
«នេះជាមូលហេតុ...ទេវតា» ត្រូវបានសំដៅយ៉ាងច្បាស់លាស់ទៅលើពាក្យ
«ស្ត្រីជាសិរីរុងរឿងនៃបុរស» នៅក្នុង ១ កូរិនថូស ១១:៧ ។(../11/07.md).

ជាសញ្ញានៃសិទ្ធិអំណាចលើក្បាលរបស់នាង

អាចមានន័យថា ទី១ «ជាសញ្ញាដែលនាងមានបុរសក្បារបស់នាង» ឬ ទី២
«ជាសញ្ញាដែលនាងមានសិទ្ធិអំណាចក្នុងការអធិស្ឋានឬ ការថ្លែងទំនាយ»។

1 Corinthians 11:11

generated on Wed Sep 10 16:16:32 2025

ប៉ុន្តែ ក្នុងព្រះជាម្ចាស់
ខណៈអ្វីដែលខ្ញុំបាននិយាយសុទ្ធតែជាការពិត អ្វីដែលសំខាន់បំផុតនោះគឺ
ក្នុងព្រះជាម្ចាស់។
ក្នុងព្រះជាម្ចាស់
អាចមានន័យថា ទី១
«ក្នុងចំណោមគ្រិស្តបរិស័ទដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់» ឬ ទី ២
«ក្នុងពិភពលោកដែលព្រះបានបង្កើត»។
មនុស្សស្រីមិនមានភាពឯករាជ្យពីបុរសឡើយ ហើយបុរសក៏មិនមានភាពឯករាជ្យពីមនុស្សស្ត្រីដែរ
នេះអាចត្រូវបានបញ្ជាក់ជាវិជ្ជមាន ការបកប្រែផ្សេងទៀត:
«ស្ត្រីពឹងអាស្រ័យលើបុរស ហើយបុរសពឹងអាស្រ័យលើស្ត្រីដែរ»
អ្វីៗទាំងអស់សុទ្ធតែកើតមកពីព្រះជាម្ចាស់។
ព្រះជាម្ចាស់បង្កើតគ្រប់អ្វីៗទាំងអស់។
1 Corinthians 11:13
ចូរវិនិច្ឆ័យពីខ្លួនអ្នកចុះ
វិនិច្ឆ័យបញ្ហានេះយោងទៅតាមទំលៀមទំលាប់តាមតំបន់
និងការអនុវត្តក្នុងក្រុមជំនុំដែលអ្នកដឹង។
តើវាពិតជាមិនសមរម្យដែលស្ត្រីអធិស្ឋានទៅព្រះជាម្ចាស់ដោយគ្មានស្បៃគ្របក្បាលនោះ?
លោកប៉ូលរំពឹងក្រុមជំនុំកូរិនថូសយល់ព្រមជាមួយអ្វីដែលលោកនិយាយ។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម «ដើម្បីថ្វាយកិត្តិយសដល់ព្រះ
ស្ត្រីគួរអធិស្ឋានទៅព្រះដោយទទួរស្បៃពីលើក្បាលរបស់នាង»។
សូម្បីតែ ធម្មជាតិក៏បានបង្ហាញឲ្យយើងដឹងដែរថា...មុខគាត់ណាស់ឬ?
លោកប៉ូលរំពឹងក្រុមជំនុំកូរិនថូសយល់ព្រមជាមួយអ្វីដែលលោកនិយាយ។
ការបកប្រែផ្សេងទៀត:
«សូម្បីតែធម្មជាតិផ្ទាល់ក៏បង្រៀនអ្នក...សម្រាប់គាត់ផ្ទាល់»។
សូម្បីតែ ធម្មជាតិក៏បានបង្ហាញឲ្យយើងដឹងដែរថា...មុខគាត់ណាស់ឬ?
លោកកំពុងនិយាយពីរបៀបដែលមនុស្សក្នុងសង្គម
ដែលជាធម្មតាតែងតែធ្វើខ្លួនដូចជាអ្នកបង្រៀន។ ការបកប្រែផ្សេងទៀត:
«អ្នកដឹងដោយគ្រាន់តែមើលពីរបៀបធម្មតាដែលគេធ្វើ...សម្រាប់គាត់»។
ប្រទានឲ្យស្ត្រីៗមានសក់វែង
នេះអាចបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត: «ដ្បិត
ព្រះបង្កើតស្ត្រីរួមនិងសក់»។
1 Corinthians 11:17
ប្រយោគភ្ជាប់
ខណៈលោកប៉ូលនិយាយពីពិធីលៀងព្រះអម្ចាស់
ក្នុងពិធីនោះលោករំលឹកពួកគេឲ្យមានឥរិយាបថត្រឹមត្រូវ និងការរួបរួមផងដែរ។
លោករំលឹកពួកគេថា
ប្រសិនបើពួកគេធ្លាក់ខុសក្នុងចំណុចទាំងនោះខណៈកំពុងធ្វើពិធីលៀងព្រះអម្ចាស់
នោះពួកគេនឹងក្លាយជាមានជំងឺ ហើយស្លាប់
ដែលកាលទាំងនោះធ្លាប់កើតឡើញលើពួកគេមួយចំនួនហើយ។
តាមសេចក្តីណែនាំខាងក្រោមនេះ ខ្ញុំមិនសរសើរបងប្អូនឡើយ
ន័យផ្សេងទៀតដែលអាចមានគឺ «ខណៈខ្ញុំឲ្យសេចក្តីណែនាំទាំងនេះ
ដែលមានអ្វីមួយជាហេតុខ្ញុំមិនអាចសរសើរអ្នកបាន នៅពេល»។
តាមសេចក្តីណែនាំ
សេចក្តីណែនាំដែលខ្ញុំបម្រុងនិងនិយាយ។
ពេលបងប្អូនមកជួបប្រជុំគ្នា
ប្រមូលជុំគ្នា ឬ «ជួប»។
វាមិនបានធ្វើឲ្យប្រសើរជាងមុននោះទេ ប៉ុន្តែ បានធ្វើឲ្យអាក្រក់ជាងមុនទៅទៀត
បងប្អូនមិនបានជួយគ្នាទៅវិញទៅមកនោះទេ ផ្ទុយទៅវិញបងប្អូនធ្វើបាបគ្នាវិញ។
នៅព្រះវិហារ
សម្រាប់អ្នកជឿ។ លោកប៉ូលមិននិយាយពីការនៅខាងក្នុងអគារនោះទេ។
មានការបែកបាក់ក្នុងចំណោមបងប្អូន
បងប្អូនបំបែកខ្លួនឯងទៅជាក្រុមប្រឆាំង។
ដ្បិត គឺមានការទាស់ប្រឆាំងគ្នា ក្នុងចំណោមបងប្អូន
អាចមានន័យថា ទី១ ពាក្យ «ត្រូវតែ» បង្ហាញថា ស្ថានភាពនេះហាក់និងកើតឡើង។
ការបកប្រែផ្សេងទៀត: «ដ្បិត
ប្រហែលនិងមានការទាស់ប្រឆាំងក្នុងចំណោមបងប្អូន» ឬ ទី២
លោកប៉ូលប្រើសើចចំអកដើម្បីឲ្យពួកគេខ្មាសដោយពួកគេមានការទាស់ប្រឆាំងគ្នា។
ការបកប្រែផ្សេងទៀត: «ដ្បិត បងប្អូនទំនងជាគិតថា
ប្រាកដជាមានការទាស់ប្រឆាំងក្នុងចំណោមបងប្អូន» ឬ «ដ្បិត
បងប្អូនទំនងជាគិតថា ប្រាកដជាមានការបំបែកខ្លួនក្នុងចំណោមបងប្អូន»។
បក្សពួក
ក្រុមនៃមនុស្សប្រឆាំង។
ដូច្នេះ អ្នកណាដែលធ្វើការនេះនឹងត្រូវបានស្គាល់នៅក្នុងចំណោមបងប្អូន
អាចមានន័យថា ទី១ «ដូច្នេះមនុស្សបានស្គាល់
និងស្រឡាញ់រាប់អានយ៉ាងខ្លាំងចំពោះអ្នកជឿក្នុងចំណោមអ្នករាល់គ្នា» ឬ ទី២
«ដូច្នេះមនុស្សអាចបង្ហាញសេចក្តីយល់ព្រមនេះដល់អ្នកដទៃក្នុងចំណោមអ្នករាល់គ្នា»។
លោកប៉ូលក៏ប្រហែលជាប្រើពាក្យចំអកខ្លះៗដោយការនិយាយផ្ទុយពីអ្វីដែលលោកចង់ឲ្យក្រុមជំនុំកូរិនថូសបា
ដើម្បីឲ្យពួកគេខ្មាស។
អ្នកណាដែលធ្វើការនេះ
អាចមានន័យថា ទី១ «អ្នកដែលព្រះពេញចិត្ត» ឬ ទី២
«អ្នកដែលក្រុមជំនុំពេញចិត្ត»។
1 Corinthians 11:20
ពេលបងប្អូនមកប្រជុំគ្នា
ប្រមូលជុំជុំគ្នា
នោះមិនមែនយើងហូបដូចជាពិធីលាងព្រះអម្ចាស់ទេ
បងប្អូនប្រហែលជាជឿថា បងប្អូនកំពុងតែទទួលទានពិធីលៀងព្រះអម្ចាស់ ប៉ុន្តែ
បងប្អូនមិនបានធ្វើដោយការគោរពនោះទេ។
ដើម្បីហូបអាហារទេឬអី
ការជុំគ្នាទទួលទានអាហារ។
មើលងាយ
ការស្អប់ ឬ ការប្រព្រឹត្តដោយមិនផ្តល់កិត្តិយស និងការគោរព។
សេចក្តីខ្មាស
ភាពអាម៉ាស់ ឬ ធ្វើឲ្យមានអារម្មណ៍ខ្មាសអៀន។
តើគួរឲ្យខ្ញុំនិយាយនឹងបងប្អូនថាដូចម្តេច? គួរឲ្យសរសើរបងប្អូនឬអី?
លោកប៉ូលកំពុងស្តីបន្ទោសដល់ក្រុមជំនុំកូរិនថូស។ ការបកប្រែផ្សេងទៀត:
«ខ្ញុំអាចនិយាយថាគ្មានអ្វីល្អសោះសំរាប់ការនេះ ខ្ញុំមិនអាចសរសើរអ្នកបានទេ»។
1 Corinthians 11:23
ដ្បិត ខ្ញុំបានទទួលអ្វីដែលមកពីព្រះអម្ចាស់ ហើយក៏ផ្តល់ដល់អ្នករាល់គ្នា គឺថាព្រះអម្ចាស់
«ដ្បិត ជាអ្វីដែលមកពីព្រះអម្ចាស់ដែលខ្ញុំបានឮអ្វីដែលខ្ញុំបានប្រាប់អ្នក
ហើយនេះជា: ព្រះអម្ចាស់»
នៅពេលយប់ដែលព្រះអម្ចាស់ត្រូវគេបានក្បត់
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ជាយប់ដែលលោកយូដាស អ៊ីស្ការីយុតក្បត់ព្រះអង្គ»។
ទ្រង់បានកាច់នំប៉័ង
ទ្រង់ទាញចេញជាចំណែក។
នេះជារូបកាយខ្ញុំ
នំប៉័ងដែលខ្ញុំកំពុងកាន់ជារូបកាយរបស់ខ្ញុំ។
1 Corinthians 11:25
ពែង
ជាការល្អបំផុតក្នុងការបកប្រែពាក្យនេះជាន័យត្រង់។
ក្រុមជំនុំកូរិនថូសបានដឹងថាពែងណាដែលទ្រង់នឹងទទួល ដូច្នេះ មិនមែនគ្រាន់តែជា
«ពែងមួយ» ឬ «ពែងមួយចំនួន» «ពែងណាក៏ដោយ» នោះទេ។
អាចមានន័យផ្សេងទៀត ទី១
ជាពែងស្រាទំពាំងបាយជូរដាពែងដែលប្រើបានតែម្នាក់ដោយរំពឹងថាជាទ្រង់ ឬ ទី២
ជាទី៣ ឬទី៤
នៃចំនួនស្រាទំពាំងបាយជូរទាំងបួនដែលសាសន៍យូដាពិសារអាហារនៅថ្ងៃបុណ្យរំលង។
ចូរធ្វើដូច្នេះរាល់វេលាណាដែលផឹក
ផឹកពីពែងនេះ រាល់វេលាណាដែលអ្នកផឹក។
ប្រកាសពីការសុគតរបស់ព្រះអម្ចាស់
បង្រៀនពីការឈើឆ្កាង និងការរស់ឡើងវិញ។
ដរាបដល់ព្រះអង្គយាងមកវិញ
ឯកន្លែងដែលព្រះយេស៊ូមកនិងអាចកើតមានជាក់ស្តែង។ ការបកប្រែផ្សេងទៀត:
«រហូតដល់ព្រះយេស៊ូយាងមកផែនដីវិញ»។
1 Corinthians 11:27
បរិភោគនំប៉័ង ឬផឹកពីពែងនៃព្រះអម្ចាស់
បរិភោគនំប៉័ងនៃព្រះអម្ចាស់ ឬផឹកពីពែងនៃព្រះអម្ចាស់
ពិនិត្យ
លោកប៉ូលនិយាយពីមនុស្សណាមួយដែលសម្លឹងមើលទំនាក់ទំនងរបស់ខ្លួនជាមួយនិងព្រះ

generated on Wed Sep 10 16:16:32 2025

និងពីរបៀបដែលគាត់បានរស់នៅក្នុងជីវិតរបស់គាត់ដូចជាមនុស្សដែលស្វែងរកអ្វីមួយ**សូមមើលឈើឯកសារយោង**ក្នុង ១ កូរិនថូស ១១:២៨

សូមមើលពីរបៀប «សាកល្បងគុណភាព» ត្រូវបានបកប្រែក្នុង ១ កូរិនថូស ៣:១៣

បែបមិនគួរសមចំពោះព្រះកាយ

អាចមានន័យថា ទី១ «មិនបានទទួលស្គាល់ថា ក្រុមជំនុំជារូបកាយនៃព្រះអម្ចាស់» ឬ ទី២ «មិនបានពិចារណាថា គាត់កំពុងតែប្រើប្រាស់រូបកាយរបស់ព្រះអម្ចាស់»។

ខ្សោយ ហើយឈឺ

ពាក្យទាំងនេះមានន័យថាស្ទើរតែដូចគ្នា និងអាចបញ្ចូលគ្នាបាននៅក្នុងUDB។

ក៏មានអ្នកខ្លះបានដេកលក់ទៅហើយដែរ

ការសម្រាន់នៅទីនេះជាពាក្យសមរម្យនៃសេចក្តីស្លាប់ ការបកប្រែផ្សេងទៀត «ក៏មានអ្នកខ្លះទៀតបានត្រូវបានស្លាប់»។ .

មនុស្សច្រើននៅក្នុងបងប្អូន

ស្តាប់មើលទៅហាក់ដូចលោកប៉ូលកំពុងនិយាយពីអស់អ្នកដែលបានស្លាប់ អ្នកត្រូវធ្វើការបញ្ជាឲ្យច្បាស់លាស់ថាមិនមែនជាលោកទេ។ ការបកប្រែផ្សេងទៀត: «អ្នកខ្លះនៃសមាជិកក្រុមរបស់អ្នក»។

1 Corinthians 11:31

ពិនិត្យ

យើងមិនត្រូវជាប់ជំនុំជម្រះឡើយ

នេះត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ការកបប្រែផ្សេងទៀត: «ព្រះអង្គមិនជំនុំជម្រះយើងទេ»។

ពេលយើងជាប់ជំនុំជម្រះដោយព្រះអម្ចាស់ ពួកយើងបានទទួលការកែតម្រង់ទេ ដូច្នេះយើងមិនជាប់ក្នុងទោសឡើយ

នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ព្រះអង្គជំនុំជម្រះយើង ទ្រង់កែតម្រង់យើងដើម្បីយើងមិនត្រូវបានជាប់ទោសឡើយ»។

1 Corinthians 11:33

មកជុំគ្នាដើម្បីនឹងបរិភោគ

ប្រមូលមកឲ្យជុំគ្នាដើម្បីបរិភោគអាហារ មុនពេលប្រារព្ធពិធីលៀងព្រះអម្ចាស់។

គួររង់ចាំឲ្យបានរួចរាល់ទាំងអស់គ្នា

រង់ចាំអនុញ្ញាតឲ្យអ្នកដទៃបានមកដល់មុនពេលចាប់ផ្តើមបរិភោគអាហារ។

ឲ្យអ្នកនោះហូបនៅផ្ទះចុះ

សូមឲ្យគាត់ហូបឲ្យរួច មុនពេលមកជួបជុំគ្នាយ៉ាងដូច្នេះ។

នាំឲ្យជាប់មានទោសឡើយ

លោកប៉ូលនិយាយពីមនុស្សណាមួយដែលសម្លឹងមើលទំនាក់ទំនងរបស់ខ្លួនជាមួយនិង**មិន**មែនជាឱកាសសម្រាប់ព្រះក្នុងការស្តីប្រដៅអ្នកឡើយ។
និងពីរបៀបដែលគាត់បានរស់នៅក្នុងជីវិតរបស់គាត់ដូចជាមនុស្សដែលស្វែងរកអ្វីមួយដែលគាត់ចង់ទិញ។

---

12 [1]បងប្អូនអើយ អំពីអំណោយទានខាងវិញ្ញាណ ខ្ញុំមិនចង់ឲ្យបងប្អូនទៅជាល្ងង់ទេ។[2]បងប្អូនដឹងហើយថា ពីដើមបងប្អូនជាសាសន៍ដទៃ ដែលត្រូវបង្វែរទៅឯរូបព្រះគេតាមរបៀបអ្វីដែលបងប្អូនបានដឹកនាំដោយពួកគេ។[3]ដូច្នេះ បានជាខ្ញុំប្រាប់ឲ្យអ្នករាល់គ្នាដឹងថា មិនដែលមានអ្នកណានិយាយដោយនូវព្រះវិញ្ញាណនៃព្រះជាម្ចាស់ប្រាប់ថា៖ «ព្រះយេស៊ូត្រូវបណ្តាសា» ក៏គ្មានអ្នកណាអាចនិយាយថា៖ «ព្រះយេស៊ូគឺជាព្រះអម្ចាស់» បានទេ លើកតែដោយតែព្រះវិញ្ញាណដ៏វិសុទ្ធបើកបង្ហាញ។
[4]តទ្បូវ អំណោយទាន នោះមានផ្សេងៗពីគ្នា ប៉ុន្តែ ព្រះវិញ្ញាណដដែល។[5]ហើយក៏មានមុខងារផ្សេងៗពីគ្នា ប៉ុន្តែ គឺជាព្រះអម្ចាស់តែមួយ[6]ហើយក៏មានមុខងារផ្សេងៗពីគ្នាដែរ ប៉ុន្តែ ព្រះជាម្ចាស់តែមួយដែលធ្វើឲ្យមុខងារទាំងនោះដល់មនុស្សគ្រប់គ្នា។
[7]តទ្បូវ ព្រះអង្គប្រទានឲ្យព្រះវិញ្ញាណសម្តែងមកក្នុងគ្រប់គ្នា ដើម្បីឲ្យបានប្រយោជន៍សម្រាប់គ្រប់ការទាំងអស់។[8]ដ្បិត ព្រះអង្គប្រទានឲ្យម្នាក់មានពាក្យសម្តីនៃប្រាជ្ញាវាងវៃដោយសារព្រះវិញ្ញាណ ហើយឲ្យម្នាក់ទៀតមានពាក្យសម្តីនៃចំណេះដឹង តាមព្រះវិញ្ញាណដដែល។
[9]ដើម្បី ឲ្យម្នាក់ផ្សេងទៀតមានជំនឿ ដោយនូវព្រះវិញ្ញាណដដែល ហើយឲ្យមួយទៀតបានអស់ទាំងអំណោយទាននៃការប្រោសឲ្យជា ដោយព្រះវិញ្ញាណតែមួយ។[10]ដើម្បីឲ្យម្នាក់ទៀតបានសម្តែងឫទ្ធិបារមី និងឲ្យម្នាក់ទៀតចេះថ្លែងព្រះបន្ទូល។ ហើយប្រទានឲ្យម្នាក់ទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ ឲ្យម្នាក់ទៀតចេះនិយាយភាសាដទៃ ហើយឲ្យម្នាក់ទៀតចេះបកប្រែភាសាដទៃ។[11]ប៉ុន្តែ គឺជាព្រះវិញ្ញាណតែមួយដដែលនោះឯង ដែលធ្វើគ្រប់ការទាំងនោះ ទាំងផ្តល់អំណោយទានឲ្យគ្រប់គ្នារៀងៗខ្លួន តាមដែលព្រះជាម្ចាស់ជ្រើសរើស។
[12]ដ្បិត ដូចជារូបកាយមួយមានអវយវៈច្រើន ហើយអវយវៈទាំងនោះ ទោះមានច្រើនក៏ពិត តែមកពីរូបកាយតែមួយ ដូច្នេះក៏ដូចជាព្រះកាយនៃព្រះគ្រិស្តដែរ។[13]ដ្បិត យើងបានទទួលពិធីជ្រមុជចូលក្នុងរូបកាយតែមួយ ដោយសារព្រះវិញ្ញាណតែមួយ ទោះបើជាសាសន៍យូដា ឬសាសន៍ក្រិក អ្នកបម្រើ ឬអ្នកជាក្តី ហើយគ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែមួយដែរ។
[14]ដ្បិត រូបកាយមិនមែនមានអវយវៈតែមួយនោះទេ តែមានច្រើន។[15]ប្រសិនបើ ជើងនិយាយថា៖ «ខ្ញុំមិនមែនជាដៃទេ ខ្ញុំក៏មិនមែនជាចំណែកនៃរូបកាយដែរ» ក៏គ្មានចំណែកណាដែលតូចជាងគេនៃរូបកាយនោះទេ។[16]ហើយប្រសិនបើ ត្រចៀកនិយាយថា៖ «ពីព្រោះខ្ញុំមិនមែនជាភ្នែក ខ្ញុំមិនមែនជាផ្នែកនៃរូបកាយនោះទេ» គ្មានចំណែកណាដែលតូចជាងគេនៃរូបកាយនោះទេ។[17]បើរូបកាយទាំងមូលសុទ្ធតែជាភ្នែក តើនឹងស្តាប់តាមណាដែរ? បើរូបកាយទាំងមូល សុទ្ធតែជាត្រចៀក តើនឹងដឹងក្លិនតាមណាទៅ?
[18]ប៉ុន្តែ ព្រះជាម្ចាស់បានរៀបចំឲ្យអវយវៈនីមួយៗ ក្នុងរូបកាយតាមព្រះជាម្ចាស់ចែ្នា។[19]បើគ្រប់ទាំងអស់សុទ្ធតែជាអវយវៈតែមួយ តើរូបកាយនឹងនៅឯណា?[20]ដូច្នេះ ពេលនេះមានអវយវៈជាច្រើនក៏ពិតមែន ប៉ុន្តែ រូបកាយតែមួយទេ។
[21]ដូច្នេះ ភ្នែកពុំអាចនិយាយទៅដៃថា៖ «ខ្ញុំមិនត្រូវការឯងទេ»។ ឬក្បាលនិយាយទៅជើងថា៖ «ខ្ញុំមិនត្រូវការឯងទៀតឡើយ»។[22]ប៉ុន្តែ អស់ទាំងអវយវៈក្នុងរូបកាយ ដែលមើលទៅដូចជាខ្សោយជាងគេ នោះមានប្រយោជន៍ជាជាងវិញ ហើយអវយវៈណាក្នុងរូបកាយ ដែលយើងស្មានថា មិនឲ្យតម្លៃប៉ុន្មាននោះ គឺយើងបានឲ្យតម្លៃលើសទៅទៀត[23]ហើយអវយវៈណារបស់យើង ដែលមិនល្អមើល នោះបានល្អមើលកាន់តែខ្លាំងឡើងទៅទៀត។[24]ពេលនេះ អវយវៈណារបស់យើងដែលល្អមើល នោះមិនត្រូវការអ្វីទេ ដូច្នេះ ព្រះជាម្ចាស់បានផ្សំរូបកាយ ព្រមទាំងប្រទានឲ្យអវយវៈណាដែលខ្វះ បានប្រសើរលើសជាងទៅទៀត។
[25]ព្រះជាម្ចាស់ធ្វើបែបនេះ ដើម្បីកុំឲ្យមានសេចក្តីបែកខ្ញែកគ្នាក្នុងរូបកាយឡើយ តែឲ្យអវយវៈទាំងប៉ុន្មាន គួរជួយការពារគ្នាទៅវិញទៅមក
និងជួយដោះស្រាយបញ្ហាជាមួយគ្នាដែរ។[26]ដូច្នេះ ពេលអវយវៈណាឈឺ អវយវៈទាំងអស់ត្រូវឈឺទាំងអស់ដែរ ពេលអវយវៈមួយត្រូវបានសរសើរ
នោះទាំងអស់គ្នាត្រូវចូលរួមរីករាយដែរ។[27]ពេលនេះ អ្នករាល់គ្នាជារូបកាយនៃព្រះគ្រិស្ត ហើយជាអវយវៈរៀងខ្លួនវិញ។
[28]ហើយ ព្រះជាម្ចាស់បានរើសតាំង ក្នុងពួកជំនុំមុនដំបូង គឺពួកសាវក ទីពីរ ពួកព្យាការី ទីបី ពួកគ្រូបង្រៀន ក្រោយមក ពួកអ្នកដែលធ្វើការអស្ចារ្យ និងពួកអ្នកមានអំណោយទានជាការប្រោសឲ្យជា ពួកអ្នកផ្តល់ការជួយ និងពួកអ្នកធ្វើការគ្រប់គ្រង ព្រមទាំងអស់អ្នកដែលនិយាយភាសាផ្សេងៗផង។[29]តើពួកគេសុទ្ធជាសាវកឬអី?
តើពួកគេទាំងនោះសុទ្ធជាព្យាការីឬអី? តើអ្នកទាំងនោះសុទ្ធតែជាគ្រូបង្រៀនមែនទេ? តើពួកគាត់សុទ្ធតែជាធ្វើការឫទ្ធិបារមីឬអី?
[30]តើពួកគេមានអំណោយទានប្រោសឲ្យជាទាំងអស់គ្នាឬអី? តើពួកគេចេះនិយាយភាសារដទៃទាំងគ្នាឬអី?
តើពួកគាត់ទាំងអស់គ្នាចេះបកស្រាយភាសាដទៃទាំងអស់គ្នាឬអី? ចូរសង្វាតរកឲ្យបានអំណោយទានទាំងនោះ។[31]ប៉ុន្តែ ខ្ញុំនឹងបង្ហាញការដ៏ប្រសើរលើសជាងនេះទៅទៀត។

---

1 Corinthians 12:1

ប្រយោគភ្ជាប់

លោកប៉ូលឲ្យពួកគេដឹងថាព្រះបានផ្តល់ឲ្យអំណោយទានពិសេសសម្រាប់អ្នកជឿ។ អំណោយទានទាំងនោះដើម្បីជួយដល់រូបរាងកាយនៃអ្នកជឿ។

ខ្ញុំមិនចង់ឲ្យបងប្អូនទៅជាល្ងង់ទេ

នេះអាចត្រូវបានបញ្ជាក់ជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត: «ខ្ញុំចង់ឲ្យអ្នកដឹង»។

ដែលត្រូវបង្វែរទៅឯរូបព្រះគេ តាមរបៀបអ្វីដែលបងប្អូនបានដឹកនាំដោយពួកគេ

ពាក្យ «ត្រូវបង្វែរ» ជាការប្រៀបធៀបមួយ ដែលត្រូវបានបញ្ចុះបញ្ចូលឲ្យធ្វើអ្វីមួយដែលមិនត្រឹមត្រូវ។ ការត្រូវបានបង្វែរទៅព្រះក្លែងក្លាយជាតំណាងនៃការបញ្ចុះបញ្ចូលទាំងខុសដើម្បីឲ្យទៅថ្វាយបង្គំព្រះក្លែងក្ល

generated on Wed Sep 10 16:16:32 2025

ឃ្លា «ដែលត្រូវបានបង្វែរ» និង «បងប្អូនបានដឹងនាំដោយពួកគេ» អាចត្រូវបានបញ្ជាក់ក្នុងទម្រង់ជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត: «បងប្អូនត្រូវបានបញ្ឆោះបញ្ឆូលក្នុងរបៀបផ្សេងៗដើម្បីថ្វាយបង្គំព្រះក្លែងក្លាយ ជាព្រះដែលមិនចេះនិយាយ» ឬ «បងប្អូនជឿលើពាក្យកុហក មិនដឹងថាយ៉ាងម៉េច ហើយបងប្អូនក៏ថ្វាយបង្គំព្រះក្លែងក្លាយដែលមិនចេះនិយាយទៀត»។

មិនដែលមានអ្នកណានិយាយដោយនូវព្រះវិញ្ញាណនៃព្រះជាម្ចាស់ អាចមានន័យថា ទី១ «គ្មានគ្រិស្តបរិស័ទណាដែលមានព្រះវិញ្ញាណនៃព្រះក្នុងគាត់អាចនិយាយពាក្យនោះទេ» ឬ ទី២ «គ្មាននរណាដែលថ្លែងទំនាយដោយអំណាចនៃព្រះវិញ្ញាណរបស់ព្រះអាចនិយាយពាក្យបន្ទោសព្រះយេស៊ូថាត្រូវបណ្តាសា

ព្រះនិងដាក់ទណ្ឌកម្មព្រះគ្រិស្ត ឬ «ព្រះនិងធ្វើឲ្យព្រះគ្រិស្តរងទុក្ខ»

ជាអ្នកដែលកំពុងធ្វើការគ្រប់យ៉ាងក្នុងអ្នករាល់គ្នា ជាហេតុដែលអ្នករាល់គ្នាមានពួកគេ។

1 Corinthians 12:4

ព្រះជាម្ចាស់តែមួយដែលធ្វើឲ្យមុខងារទាំងនោះដល់មនុស្សគ្រប់គ្នា «ធ្វើឲ្យមនុស្សគ្រប់គ្នាបានទទួលអំណោយទាននោះ»

1 Corinthians 12:7

ប្រទានឲ្យព្រះវិញ្ញាណសម្តែងមកក្នុងគ្រប់គ្នា នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ព្រះអង្គជាម្ចាក់ដែលប្រទានឲ្យ ១ កូរិនថូស ១២:៦ (../12/06.md))។ ការបកប្រែផ្សេងទៀត: «ព្រះអង្គប្រទានឲ្យគ្រប់ៗគ្នា»។

ព្រះអង្គប្រទានឲ្យម្នាក់មានពាក្យសម្តីនៃប្រាជ្ញាវាងវៃ ដោយសារព្រះវិញ្ញាណ នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ដោយមានន័យថា ព្រះវិញ្ញាណនៃព្រះប្រទានឲ្យមនុស្សណាម្នាក់មានពាក្យនៃប្រាជ្ញា»។

ពាក្យសម្តី

ព្រះបន្ទូល

ដោយព្រះវិញ្ញាណ

ព្រះអង្គប្រទានអំណោយទានតាមរយៈកិច្ចការការងារព្រះវិញ្ញាណ។

ប្រាជ្ញា...ចំណេះដឹង

ភាពខុសគ្នារវាងពាក្យទាំងពីរនេះមិនសំខាន់ជាងសេចក្តីពិតដែលព្រះអង្គប្រទានពាក្យទាំងនេះ

ពាក្យសម្តីនៃប្រាជ្ញា

លោកប៉ូលចែករំលែកគំនិតតែមួយតាមរយៈពាក្យពីរម៉ាត់។ ការបកប្រែផ្សេងទៀត: «ពាក្យនៃប្រាជ្ញា»។ «»«»

ពាក្យសម្តីនៃចំណេះដឹង

លោកប៉ូលចែករំលែកគំនិតតែមួយតាមរយៈពាក្យពីរម៉ាត់។ ការបកប្រែផ្សេងទៀត: «ជាពាក្យដែលបង្ហាញពីចំណេះដឹង»។

បានប្រទានឲ្យ

នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ សូមមើលការបកប្រែនេះក្នុង ១ កូរិនថូស ១២:៨ (../12/07.md)។ ការបកប្រែផ្សេងទៀត: «ព្រអង្គប្រទាន»។

1 Corinthians 12:9

ហើយឲ្យមួយទៀតបានអស់ទាំងអំណោយទាននៃការប្រោសឲ្យជា ដោយព្រះវិញ្ញាណតែមួយ

ពាក្យ «បានប្រទានឲ្យ» ត្រូវបានយល់តាំងពីឃ្លាពីមុន។ ការបកប្រែផ្សេងទៀត: «អំណោយទានផ្សេងទៀតជាអំណោយទាននៃការព្យាបាលគឺបានយកដោយព្រះវិញ្ញាណតែមួយដដែលបានប្រទានឲ្យ»។

ឲ្យម្នាក់ទៀតចេះថ្លែងព្រះបន្ទូល

ឃ្លា «ប្រទានឲ្យដោយព្រះវិញ្ញាណដដែល» ត្រូវបានយល់តាំងពីឃ្លាពីមុន។ ការបកប្រែផ្សេងទៀត: «អំណោយទានចេះថ្លែងព្រះបន្ទូលក៏ត្រូវបានប្រទានដោយព្រះវិញ្ញាណដដែលដែរ»។

ឲ្យម្នាក់ទៀតចេះនិយាយភាសាដទៃ

ឃ្លា «ប្រទានឲ្យដោយព្រះវិញ្ញាណដដែល» ត្រូវបានយល់តាំងពីឃ្លាពីមុន។ ការបកប្រែផ្សេងទៀត: «អំណោយទានចេះនិយាយភាសាដទៃក៏ត្រូវបានប្រទានដោយព្រះវិញ្ញាណដដែលដែរ»។

ឲ្យម្នាក់ទៀតចេះបកប្រែភាសាដទៃ

ឃ្លា «ប្រទានឲ្យដោយព្រះវិញ្ញាណដដែល» ត្រូវបានយល់តាំងពីឃ្លាពីមុន។ ការបកប្រែផ្សេងទៀត: «អំណោយទានចេះបកប្រែភាសាដទៃក៏ត្រូវបានប្រទានដោយព្រះវិញ្ញាណដដែលដែរ»។

ការបកប្រែភាសាដទៃ

នេះជាសមត្ថភាពក្នុងការស្តាប់នរណាម្នាក់និយាយភាសាណាមួយ ហើយប្រើភាសាផ្សេងទៀតក្នុងការនិយាយប្រាប់អ្នកដទៃពីអ្វីដែលអ្នកនោះបាននិយាយ។ ការបកប្រែផ្សេងទៀត: «ជាសមត្ថភាពក្នុងការបកប្រែពីអ្វីដែលបាននិយាយទៅភាសាដទៃទៀត»។

គឺជាព្រះវិញ្ញាណតែមួយដដែលនោះឯង ព្រះអង្គប្រទានអំណោយទានតាមរយៈព្រះវិញ្ញាណតែមួយដដែលនោះឯង។ សូមមើលការបកប្រែនេះក្នុង ១ កូរិនថូស ១២:៨ (../12/07.md)។

1 Corinthians 12:12

ប្រយោគភ្ជាប់ លោកប៉ូលបន្តនិយាយពីអំណោយទានផ្សេងៗទៀតដែលព្រះប្រទានឲ្យអ្នកជឿ

ប៉ុន្តែលោកប៉ូលចង់ឲ្យពួកគេដឹងថាគ្រប់អ្នកជឿទាំងអស់ត្រូវរួមគ្នាជារូបកាយតែមួយ ដែលត្រូវបានហៅថាជា រូបកាយនៃព្រះគ្រិស្ត។ ដ្បិត នេះជាហេតុដែលអ្នកជឿគួរមានការរួបរួម។

ដ្បិត យើងបានទទួលពិធីជ្រមុជចូលក្នុងរូបកាយតែមួយ អាចមានន័យថា ទី១ ជាព្រះវិញ្ញាណដ៏វិសុទ្ធតែមួយដែលជ្រមុជយើង «ដ្បិត ព្រះវិញ្ញាណតែមួយដែលជ្រមុជយើង» ឬ ទី២ ព្រះវិញ្ញាណនោះ ដូចជាការជ្រមុជទឹក ដែលជារបៀបដែលយើងជ្រមុជចូលក្នុងរូបកាយ «ដ្បិត យើង បានទទួលពិធីជ្រមុជដោយព្រះវិញ្ញាណតែមួយ»។

បើទោះជា អ្នកបម្រើ ឬអ្នកជា ក្តី អ្នកបម្រើជាការតំណាងឲ្យនៃពាក្យ «ទាសករ»។ ការបកប្រែផ្សេងទៀត: «បើទោះជាមនុស្សជាទាសករ ឬមិនទាសករក្តី»។

ហើយគ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែមួយដែរ នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត៖ «ព្រះអង្គប្រទានឲ្យយើងទាំងអស់គ្នានូវព្រះវិញ្ញាណដដែល ហើយយើងចែករំលែកព្រះវិញ្ញាណតែមួយនោះ ដូចជាមនុស្សចែករំលែកពែងតែមួយដែរ»។

តើនឹងស្តាប់តាមណាដែរ?... តើនឹងដឹងក្លិនតាមណាទៅ? នេះអាចត្រូវធ្វើជាសេចក្តីថ្លែងការបាន ។ ការបកប្រែផ្សេងទៀត: «បងប្អូនមិនអាចស្តាប់ទាំងអស់គ្នាបានទេ...បងប្អូនមិនអាចដឹងក្លិនទាំងអស់គ្នាបានដែរ»។ «»

សុទ្ធតែជាអវយវៈតែមួយ

ពាក្យ «អវយវៈ» ត្រូវបានប្រើជាឧបមាសម្រាប់ផ្នែកនៃរូបរាងកាយ ដូចជា ក្បាល ដៃ ឬជង្គង់។ ការបកប្រែផ្សេងទៀត: «ផ្នែកដូចគ្នានៃរូបរាងកាយ»។

តើរូបកាយនឹងនៅឯណា? នេះអាចត្រូវធ្វើជាសេចក្តីថ្លែងការបាន ការបកប្រែផ្សេងទៀត: «នោះនឹងគ្មានរូបកាយទេ»។

1 Corinthians 12:14

តើនឹងស្តាប់តាមណាដែរ?...តើនឹងដឹងក្លិនតាមណាទៅ? ឃ្លានេះអាចធ្វើជាប្រយោគមួយ។ ការបកប្រែផ្សេងទៀត: «អ្នកមិនអាចឮអ្វីឡើយ...អ្នកក៏មិនអាចដឹងក្លិនបានដែរ»

1 Corinthians 12:18

ជាអវយវៈតែមួយ ពាក្យ អវយវៈ» គឺជាពាក្យទូទៅសម្រាប់ផ្នែកផ្សេងៗនៃរាងកាយ ដូចជាក្បាល ដៃ ឬជង្គង់ជាដើម។ ការបកប្រែផ្សេងទៀត: «ជាសរីរាង្គតែមួយ»

ឃ្លានេះអាចធ្វើជាប្រយោគមួយ។ ការបកប្រែផ្សេងទៀត: «អាចមិនមែនជារូបកាយទេ»

1 Corinthians 12:21

ខ្ញុំមិនត្រូវការឯងទេ ខ្ញុំអត់ត្រូវការអ្នកទេ។

ដែលមិនល្អមើល ដែលមិនមានសារសំខាន់។

អវយវៈណារបស់យើង ដែលមិនល្អមើល នេះប្រហែលសំដៅលើផ្នែកណាមួយនៃរូបកាយដែលមនុស្សរក្សាការបិទបាំង។

1 Corinthians 12:25

ដើម្បីកុំឲ្យមានសេចក្តីបែកខ្ញែកគ្នាក្នុងរូបកាយឡើយ រូបកាយប្រហែលត្រូវបានបង្រួបបង្រួមនិង»។

ពេលអវយវៈមួយត្រូវបានសរសើរ នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«នរណាម្នាក់ឲ្យការសរសើរដល់អវយវៈណាមួយ»។
ពេលនេះ អ្នករាល់គ្នា
ពាក្យ «ពេលនេះ»
ត្រូវប្រើក្នុងការទាញការចាប់អារម្មណ៍ចំពោះចំនុចសំខាន់ដែលត្រូវធ្វើតាម។
1 Corinthians 12:28
ពួកជំនុំមុនដំបូង
អាចមានន័យថា ទី១ «អំណោយដំបូងខ្ញុំផ្តោតលើគឺពួកសាវក» ឬ ទី២
«អំណោយដែលមានសារសំខាន់បំផុតគឺជាសាវក»។
ពួកអ្នកផ្តល់ការជួយ
អស់អ្នកដែលផ្តល់ការជួយដល់អ្នកជឿដទៃទៀត។
ពួកអ្នកធ្វើការគ្រប់គ្រង
អស់អ្នកគ្រប់គ្រង់ក្នុងក្រុមជំនុំ។
ព្រមទាំងអស់អ្នកដែលនិយាយភាសាផ្សេងៗផង
ជាបុគ្គលអ្នកដែលអាចនិយាយភាសាបរទេសបានមួយ
ឬច្រើនជាងមួយដោយមិនបានរៀនភាសាទាំងនោះទេ។
តើពួកគេសុទ្ធជាសាវកឬអី? តើពួកគេទាំងនោះសុទ្ធជាព្យាការីឬអី?
តើអ្នកទាំងនោះសុទ្ធតែជាគ្រូបង្រៀនមែនទេ? តើពួកគាត់សុទ្ធតែមានឬទ្ធិបារមីឬអី?
លោកប៉ូលរំលឹកអ្នកអានពីអ្វីដែលពួកគេបានដឹងហើយ។ ការបកប្រែផ្សេងទៀត៖
«មានតែមួយចំនួនពួកគេទេជាសាវក មានតែមួយចំនួនពួកគេទេជាព្យាការី។
មានតែមួយចំនួនពួកគេទេជាគ្រូបង្រៀន។
មានតែមួយចំនួនពួកគេដែលពិតជាមានឫទ្ធិបារមី»។
1 Corinthians 12:30
តើពួកគេមានអំណោយទានប្រោសឲ្យជាទាំងអស់គ្នាឬអី?
នេះអាចជាសេចក្តីថ្លែងការមួយ ការបកប្រែផ្សេងទៀត:
«មិនមែនពួកគេទាំងអស់គ្នាសុទ្ធតែមានអំណោយទានខាងប្រោសឲ្យជានោះទេ»។
តើពួកគេចេះនិយាយភាសារដទៃទាំងអស់គ្នាឬអី?
នេះអាចជាសេចក្តីថ្លែងការមួយ។ ការបកប្រែផ្សេងទៀត:
«មិនមែនពួកគេទាំងអស់គ្នាសុទ្ធចេះនិយាយភាសាដទៃនោះទេ»។
តើពួកគាត់ទាំងអស់គ្នាចេះបកស្រាយភាសាដទៃទាំងអស់គ្នាឬអី?
នេះអាចជាសេចក្តីថ្លែងការមួយ។ ការបកប្រែផ្សេងទៀត:
«មិនមែនពួកគេទាំងអស់គ្នាសុទ្ធចេះបកស្រាយភាសាដទៃនោះទេ»។
បកស្រាយ
នេះមានន័យថា
ជាការប្រាប់នរណាម្នាក់ដែលបាននិយាយកភាសាណាមួយទៅកាន់អ្នកដទៃដែលមិនយល់ភាសានោះ។
សូមមើលការបកប្រែក្នុង ១ កូរិនថូស ២:១៣ (../02/12.md)។
សេចក្តីសង្ខាតរកឲ្យបានអំណោយទានទាំងនោះ
អាចមានន័យថា ទី១
«បងប្អូនត្រូវតែខ្នះខ្នែងស្វែងរកពីព្រះអង្គនូវអំណោយទានដែលជួយក្រុមជំនុំ» ឬ
ទី២
«បងប្អូនខ្នះខ្នែងស្វែងរកអំណោយទានដែលបងប្អូនគិតថាអស្ចារ្យដោយបងប្អូនគិតថាអំណោយទានទាំង

---

13 [1]ទោះបើខ្ញុំចេះនិយាយភាសារបស់មនុស្សជាតិ និងភាសារបស់ពួកទេវតាក្តី។ ប៉ុន្តែ បើគ្មានសេចក្តីស្រឡាញ់ ខ្ញុំបានត្រឡប់ដូចជាលង្ហិនដែលឮខ្ទរ ឬដូចជាឈឹងដែលឮទ្រហឹងប៉ុណ្ណោះ។[2]បើខ្ញុំមានអំណោយទានចេះអធិប្បាយព្រះបន្ទូល ហើយស្គាល់អស់ទាំងសេចក្តីអាថ៌កំបាំង និងគ្រប់ទាំងការចេះដឹង ហើយបើខ្ញុំមានគ្រប់ទាំងជំនឿល្មមអាចនឹងភ្នំរើចេញបាន។ ប៉ុន្តែប្រសិនបើ ខ្ញុំគ្មានសេចក្តីស្រឡាញ់ នោះគ្មានន័យអ្វីឡើយ។[3]ប្រសិនបើ ខ្ញុំឲ្យអស់ទាំងទ្រព្យសម្បត្តិខ្ញុំជាអាហារដល់អ្នកក្រ ហើយប្រសិនបើខ្ញុំប្រគល់រូបកាយខ្ញុំទៅឲ្យគេដុត។ ប៉ុន្តែ គ្មានសេចក្តីស្រឡាញ់ នោះគ្មានប្រយោជន៍ដល់ខ្ញុំដែរ។
[4]សេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយសប្បុរស។ សេចក្តីស្រឡាញ់មិនចេះឈ្នានីស និងមិនចេះអួតខ្លួនឡើយ។ ក៏មិនក្រអឺតក្រទមដែរ។
[5]ឬមិនធ្វើអំពើដែលមិនគួរសមឡើយ។ សេចក្តីស្រឡាញ់មិនដែលរកប្រយោជន៍សម្រាប់ខ្លួនឯង។ មិនរហ័សខឹង និងមិនប្រកាន់ទោសឡើយ។
[6]និងមិនរីករាយនឹងនៅក្នុងសេចក្តីទុច្ចរិតឡើយ។ ផ្ទុយទៅវិញ ត្រូវរីករាយនៅក្នុងសេចក្តីពិតវិញ។[7]សេចក្តីស្រឡាញ់គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ និងទ្រាំទ្រទាំងអស់។
[8]សេចក្តីស្រឡាញ់មិនដែលផុតឡើយ។ ប៉ុន្តែ ប្រសិនបើសេចក្តីអធិប្បាយព្រះបន្ទូលវិញ នោះនឹងកន្លងផុតទៅ។
ហើយប្រសិនបើជាការនិយាយភាសារដទៃក៏នឹងត្រូវឈប់ដែរ។ ប្រសិនបើជាការចេះដឹង និងត្រូវកន្លងផុតទៅដែរ។[9]ដ្បិត អ្វីដែលយើងដឹងគ្រាន់ជាផ្នែកមួយ
ហើយការថ្លែងព្រះបន្ទូលក៏មិនទាន់បានពេញលេញដែរ។[10]ប៉ុន្តែ ពេលសេចក្តីគ្រប់លក្ខណ៍មកដល់ នោះសេចក្តីដែលមិនពេញខ្នាត នឹងកន្លងផុតទៅ។
[11]ពេលខ្ញុំនៅក្មេង ខ្ញុំនិយាយដូចជាកូនក្មេង ហើយការគិតដូចជាកូនក្មេងដែរ និងក្នុងការពិចារណាក៏ដូចកូនក្មេងដែរ។ តែពេលខ្ញុំធំឡើង
ខ្ញុំបានជម្រុះចោលការអ្វីដែលជាក្មេងចេញ។[12]ដ្បិត ឥឡូវនេះ យើងឃើញបែបមិនផ្ចាល់ ដូចជានៅក្នុងកញ្ចាក់ ប៉ុន្តែ ពេលខាងមុខ យើងនឹងឃើញមុខទល់នឹងមុខវិញ។
ឥឡូវនេះ ខ្ញុំចេះដឹងជាផ្នែកមួយតូច ប៉ុន្តែ ពេលខាងមុខខ្ញុំនឹងទទួលចេះដឹង ក៏ពេញលេញដូចជាព្រះជាម្ចាស់ស្គាល់ខ្ញុំដែរ។[13]ឥឡូវនេះ មានការបីដែលនៅគង់វង្សគឺ
សេចក្តីជំនឿ ទំនុកចិត្តនាពេលអនាគត និងសេចក្តីស្រឡាញ់។ ប៉ុន្តែ ការដែលអស្ចារ្យជាងគេនោះ គឺសេចក្តីស្រឡាញ់។

---

1 Corinthians 13:1
ប្រយោគភ្ជាប់
ជាការនិយាយអំពីអំណោយទានដែលព្រះបានប្រទានឲ្យអ្នកជឿ
លោកប៉ូលបញ្ជាក់ពីអ្វីដែលរឹតតែសំខាន់។
ភាសា...ទេវតាក្តី
អាចមានន័យថា ទី១ «លោកប៉ូលកំពុងនិយាយពន្លើសដោយដឹងពីផលប៉ះពាល់
និងមិនជឿថាមនុស្សអាចនិយាយភាសាដែលទេវតាប្រើបាននោះទេ ឬ ទី២
លោកប៉ូលគិតថា
មានអ្នកខ្លះដែលនិយាយភាសាដទៃពិតជាអាចនិយាយភាសាដែលទេវតាប្រើបាន។
ខ្ញុំបានត្រឡប់ដូចជាលង្ហិនដែលឮខ្ទរ ឬដូចជាឈឹងដែលឮទ្រហឹងប៉ុណ្ណោះ
ខ្ញុំបានត្រឡប់ដូចជាឧបករណ៍ភ្លេងដែលឮ មានសំលេងរំខានខ្លាំងប៉ុណ្ណោះ។
លង្ហិន
ជាបន្ទះដែកសំប៉ែតមូលស្តើងធំមួយ
ដែលគោះទ្រនាប់កំណាត់ឈើដើម្បីបង្កើតបានជាសំលេងឮមួយ
ឈឹងដែលឮទ្រហឹង
ជាបន្ទះពីរស្តើង ជាបន្ទះដែកសំប៉ែតមូល
ដែលគោះចូលគ្នាដើម្បីបង្កើតជាសំលេងឮទ្រហឹងបាន។
ខ្ញុំប្រគល់រូបកាយខ្ញុំ
ឃ្លា «ទៅឲ្យគេដុត» អាចក្លាយជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ខ្ញុំអនុញ្ញាតឲ្យអ្នកណាដែលបៀតបៀនខ្ញុំអាចយកខ្ញុំទៅដុតឲ្យស្លាប់បាន»។
1 Corinthians 13:4
សេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយសប្បុរស...ក៏មិនក្រអឺតក្រទមដែរ
នៅទីនេះលោកប៉ូលនិយាយពីសេចក្តីស្រឡាញ់ប្រៀបដូចជាមនុស្សណាម្នាក់។
មិនរហ័សខឹង
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«គ្មាននរណាម្នាក់អាចធ្វើឲ្យគាត់រហ័សខឹងបាននោះទេ»។
មិនរីករាយនឹងនៅក្នុងសេចក្តីទុច្ចរិតឡើយ។ ផ្ទុយទៅវិញ ត្រូវរីករាយនៅក្នុងសេចក្តីពិតវិញ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«រីករាយនៅក្នុងតែសេចក្តីសុច្ចរិត និងសេចក្តីពិតប៉ុណ្ណោះ»។
1 Corinthians 13:11
ដ្បិត ឥឡូវនេះ យើងឃើញបែបមិនផ្ចាល់ ដូចជានៅក្នុងកញ្ចាក់
នៅក្នុងសម័យកាលលោកប៉ូល
កញ្ចក់ត្រូវបានបង្កើតឡើងដោយការខាត់ឲ្យរលោងនៃលោហៈធាតុណាមួយជាជាងការធ្វើដោយកញ្ចក់ដែ
ចំណាំងមិនច្បាស់លាស់។
ដ្បិត ឥឡូវនេះ យើងឃើញ
អាចមានន័យថា ទី១ «ដ្បិត ឥឡូវនេះយើងឃើញព្រះគ្រិស្ត» ឬ ទី២
«ឥឡូវនេះយើងឃើញព្រះអង្គ»។
ប៉ុន្តែ ពេលខាងមុខខ្ញុំនឹងទទួលចេះដឹង
ពាក្យ «ព្រះគ្រិស្ត» បានយល់ហើយ។ ការបកប្រែផ្សេងទៀត:
«ខ្ញុំនឹងស្គាល់ព្រះគ្រិស្តពេញលេញ»។
ខ្ញុំនឹងទទួលចេះដឹង ក៏ពេញលេញ
«ខ្ញុំនឹងស្គាល់ព្រះគ្រិស្តពេញលេញ»

generated on Wed Sep 10 16:16:32 2025

ដូចជាព្រះជាម្ចាស់ស្គាល់ខ្ញុំដែរ
នេះអាចត្រូវបានបញ្ជាក់ថាជាសកម្ម។ ការបកប្រែផ្សេងទៀត:
«ដូចព្រះគ្រិស្តបានស្គាល់ខ្ញុំពេញលេញដែរ»
ឥឡូវនេះ មានការបីដែលនៅគង់វង្ស
«វាសំខាន់ណាស់...ឥឡូវនេះ។ វាសំខាន់ណាស់...ហើយវាសំខាន់ណាស់» (UDB)

សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់
នាមអរូបទាំងនេះត្រូវបានបង្ហាញនៅក្នុងឃ្លាដែលមានកិរិយាសព្ទ។
ការបកប្រែផ្សេងទៀត: «យើងត្រូវតែទុកចិត្តព្រះអម្ចាស់
ត្រូវតែជឿជាក់ថាទ្រង់នឹងធ្វើអ្វីដែលទ្រង់បានសន្យា និងត្រូវស្រឡាញ់ទ្រង់
និងអ្នកដទៃ»។

---

14 [1]ចូលតាមសេចក្តីស្រឡាញ់ ហើយសង្វាតឲ្យបានគ្រប់ទាំងអំណោយទានខាងឯវិញ្ញាណចុះ ជាពិសេសនោះគឺអំណោយទាននៃការថ្លែងព្រះបន្ទូល។[2]ដ្បិត
អ្នកដែលនិយាយភាសាដទៃ មិនមែននិយាយទៅកាន់មនុស្សទេ ប៉ុន្តែ និយាយទៅកាន់ព្រះជាម្ចាស់វិញ។ ពីព្រោះគ្មាននរណាអាចយល់ភាសាគាត់ឡើយ
ដោយសារគាត់បានថ្លែងពីសេចក្តីអាថ៌កំបាំងខាងឯវិញ្ញាណ។[3]ប៉ុន្តែ អ្នកដែលថ្លែងព្រះបន្ទូលជាពាក្យទៅកាន់មនុស្ស ដើម្បីស្អាងចិត្ត
និងលើកទឹកចិត្តព្រមទាំងកម្សាន្តចិត្តដល់ពួកគេដែរ។[4]អ្នកដែលនិយាយភាសាដទៃ គឺដើម្បីស្អាងចិត្តខ្លួនឯងឡើង ប៉ុន្តែ
អ្នកដែលថ្លែងព្រះបន្ទូលជាពាក្យគឺដើម្បីស្អាងចិត្តក្រុមជំនុំវិញ។
[5]ពេលនេះ ខ្ញុំចង់ឲ្យបងប្អូនទាំងអស់គ្នា និយាយភាសាដទៃដែរ។ ប៉ុន្តែ អ្វីដែលខ្ញុំចង់គឺច្រើនជាងនោះ ក៏ចង់ឃើញបងប្អូនអាចថ្លែងព្រះបន្ទូលផងដែរ។
អ្នកដែលថ្លែងព្រះបន្ទូលប្រសើរជាង អ្នកដែលនិយាយភាសាដទៃ (លើកតែអ្នកនោះចេះបកស្រាយ ទើបអាចស្អាងចិត្តក្រុមជំនុំ)។[6]ប៉ុន្តែពេលនេះ បងប្អូនអើយ
ប្រសិនបើខ្ញុំមករកបងប្អូន ហើយនិយាយតែភាសាដទៃ តើបងប្អូនអាចយល់បានទេ? ខ្ញុំមិនអាចឡើយ លើកលែងតែខ្ញុំបានទទួលការបើកសម្តែងសម្រាប់បងប្អូន
ឬការចេះដឹង ឬការថ្លែងព្រះបន្ទូល ឬសេចក្តីបង្រៀនវិញ។
[7]ប្រសិនបើ អ្វីដែលគ្មានជីវិតដូចជា ឧបករណ៍តន្ត្រីគឺធ្វើឲ្យឮសម្លេង ដូចជាខ្លុយ ឬពិណ ប្រសិនបើ មិនមានឮខ្ពស់ទាប តើធ្វើដូចម្តេចឲ្យដឹងថា ផ្លុំ ឬចាប់លេងបទណាទៅ
បាន?[8]ដ្បិត ប្រសិនបើ ត្រែ លេងឮសូរសម្លេងមិនច្បាស់ តើនឹងមានអ្នកណាដឹង ហើយប្រុងប្រៀបខ្លួនសម្រាប់ច្បាំងទៅ?[9]ដូច្នេះ អ្នករាល់គ្នាក៏យ៉ាងដូច្នោះដែរ។ ប្រសិនបើ
ជាអណ្តាតមិនបញ្ចេញចំពោះពាក្យដែលស្តាប់បាន តើធ្វើដូចម្តេចឲ្យគេដឹងថា អ្វីដែលអ្នកចង់និយាយបាន? បងប្អូននឹងនិយាយ ប៉ុន្តែ គ្មានអ្នកណាអាចយល់ឡើយ។
[10]មានភាសាជាច្រើនយ៉ាងណាស់ ហើយខុសៗពីគ្នានៅក្នុងពិភពលោកនេះ ហើយគ្មានភាសារណាមួយដែលមិនមានន័យនោះឡើយ។[11]ប៉ុន្តែ ប្រសិនបើ
ខ្ញុំមិនដឹងអំពីន័យរបស់ភាសានោះ ខ្ញុំនឹងក្លាយជាសាសន៍ដទៃសម្រាប់អ្នកនិយាយ ហើយអ្នកនិយាយភាសានោះ នឹងក្លាយជាសាសន៍ដទៃសម្រាប់ខ្ញុំវិញដែរ។
[12]ដូចគ្នានេះដែរ ជាមួយបងប្អូន ចាប់តាំងពីបងប្អូនសង្វាតចង់បានការបើកសម្តែងពីព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវស្វែងរក ឲ្យបានកាន់ច្រើនឡើង ដើម្បីស្អាងក្រុមជំនុំឡើង។
[13]ដូច្នេះ អ្នកដែលនិយាយភាសារដទៃ សូមអធិស្ឋានដើម្បីឲ្យចេះបកស្រាយផង។[14]ដ្បិត ប្រសិនបើខ្ញុំអធិស្ឋានជាភាសសារដទៃ វិញ្ញាណរបស់ខ្ញុំក៏ធិស្ឋានដែរ
ប៉ុន្តែនៅក្នុងគំនិតខ្ញុំវិញគឺមិនមានលទ្ធផលអ្វីទេ។
[15]តើគួរឲ្យធ្វើដូចម្តេច? ខ្ញុំនឹងអធិស្ឋានដោយវិញ្ញាណរបស់ខ្ញុំ ប៉ុន្តែ ខ្ញុំក៏អធិស្ឋានក្នុនៅក្នុងគំនិតរបស់ខ្ញុំដែរ។ ខ្ញុំនឹងច្រៀងដោយវិញ្ញាណរបស់ខ្ញុំ
ហើយខ្ញុំក៏នឹងច្រៀងនៅក្នុងគំនិតរបស់ខ្ញុំដែរ។[16]ម៉្យាងវិញទៀត ប្រសិនបើ បងប្អូនសរសើរតម្កើងព្រះជាម្ចាស់ដោយវិញ្ញាណ
តើធ្វើដូចម្តេចដើម្បីឲ្យអ្នកដែលអត់ចេះនឹងនិយាយថា៖ «អាម៉ែន» នៅពេលអ្នកអរព្រះគុណដល់ព្រះជាម្ចាស់ បើអ្នកផ្សេងឯទៀតមិនដឹងពីអ្វីដែលអ្នកកំពុងនិយាយទេ?
[17]ដ្បិត បងប្អូនអរព្រះគុណយ៉ាងល្អហើយ ប៉ុន្តែ អ្នកផ្សេងមិនបានទទួលការស្អាងចិត្តឡើយ។
[18]ខ្ញុំអរគុណដល់ព្រះជាម្ចាស់ដែលខ្ញុំនិយាយភាសាដទៃច្រើនជាងបងប្អូនរាល់គ្នា។[19]ប៉ុន្តែ ក្នុងក្រុមជំនុំ ខ្ញុំជ្រើសរើសនិយាយតែប្រាំពាក្យ ដែលខ្ញុំអាចយល់ ដូច្នេះ
ខ្ញុំអាចបង្រៀនដល់មនុស្សឯទៀតបាន ប្រសើជាងខ្ញុំនិយាយមួយពាន់ពាក្យជាភាសាដទៃវិញ។
[20]បងប្អូនអើយ សូមកុំនៅតែក្មេងខ្ចីខាងឯការគិតរបស់អ្នកឡើយ។ ផ្ទុញទៅវិញ នៅក្នុងការអាក្រក់ នោះចូលឲ្យនៅជាកូនង៉ែតចុះ។ ប៉ុន្តែ
នៅក្នុងការគិតរបស់បងប្អូនត្រូវតែចាស់ទុំ។[21]មានសេចក្តីចែងទុកនៅក្នុងក្រឹត្យវិន័យថា៖ «តាមរយៈ ភាសានៃអណ្តាតដ៏ចម្លែករបស់មនុស្ស
ហើយតាមបបូរមាត់សាសន៍ដទៃ ខ្ញុំនឹងថ្លែងព្រះបន្ទូលទៅមនុស្សទាំងនោះ។ ទោះបីពួកគេមិនស្តាប់ខ្ញុំក៏ដោយ» នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់។
[22]ដូច្នេះ ភាសាដទៃមិនមែនជាទីសម្គាល់សម្រាប់ពួកអ្នកជឿទេ ប៉ុន្តែ ជាទីសម្គាល់សម្រាប់ពួកអ្នកមិនជឿវិញ។ ប៉ុន្តែ ការថ្លែងព្រះបន្ទូលវិញ មិនមែនជាទីសម្គាល់សម្រាប់
ពួកអ្នកមិនជឿទេ ប៉ុន្តែជាទីសម្គាល់សម្រាប់ពួកអ្នកដែលជឿវិញ។[23]ប្រសិនបើដូច្នេះ ក្រុមជំនុំទាំងមូលដែលប្រជុំគ្នា ហើយគ្រប់គ្នានិយាយភាសាដទៃ រួចមានមនុស្សដែល
មិនចេះ ឬមនុស្សមិនជឿគេចូលមក តើគេមិនថាអ្នករាល់គ្នាឆ្កួតទេឬអី?
[24]ប៉ុន្តែ ប្រសិនបើបងប្អូន កំពុងថ្លែងព្រះបន្ទូល ហើយពួកអ្នកដែលមិនជឿ ឬពួកអ្នកដែលនៅខាងក្រៅចូលមកដល់ គេនិងបានដឹងខ្លួន តាមរយៈអ្វីដែលពួកគេបានឮ។
គេក៏នឹងពិចារណាតាមរយៈពាក្យដែលបានថ្លែងដែរ។[25]អស់ទាំង ការលាក់កំបាំងក្នុងចិត្តគេនឹងបានសម្តែងចេញមក។ ជាលទ្ធផល គេអាចក្រាបផ្កាប់មុខ ហើយថ្វាយបង្គំ
ដល់ព្រះជាម្ចាស់។ គេប្រហែលជាប្រកាសថា ព្រះជាម្ចាស់គង់នៅក្នុងចំណោមបងប្អូន។
[26]បងប្អូនអើយ តើយើងគួរធ្វើអ្វីបន្ទាប់? ពេលបងប្អូនប្រជុំគ្នា គ្រប់គ្នាមានទំនុកតម្កើង មានសេចក្តីបង្រៀន មានការបើកសម្តែង មាននិយាយភាសាដទៃ និងមានការបកប្រែ
ដែរ។ ចូរធ្វើការទាំងអស់ ដើម្បីនឹងស្អាងចិត្តដល់ក្រុមជំនុំចុះ។[27]ប្រសិនបើ មានអ្នកណានិយាយភាសាដទៃ សូមឲ្យមានតែពីរ ឬបីនាក់ ហើយនិយាយម្នាក់ម្តងៗផង
ហើយគួរមានអ្នកបកស្រាយពីអ្វីដែលគាត់បាននិយាយ។[28]ប៉ុន្តែប្រសិនបើគ្មានអ្នកបកស្រាយទេ សូមឲ្យគេនៅស្ងៀមក្នុងក្រុមជំនុំ។ សូមឲ្យគ្រប់គ្នា ទូលដល់ព្រះជាម្ចាស់
ដោយខ្លួនឯងវិញ។
[29]សូមឲ្យពីរ ឬបីនាក់ថ្លែងព្រះបន្ទូលទៅបានហើយ និងសូមឲ្យអ្នកផ្សេងទៀតស្តាប់ជាមួយការពិចារណា ពីអ្វីដែលគាត់បានថ្លែងនោះ។[30]ប៉ុន្តែ បើមានការបើកសម្តែង
បានផ្តល់ដល់អ្នកកំពុងអង្គុយ ក្នុងការថ្វាយបង្គំនោះ សូមឲ្យអ្នកដែលកំពុងថ្លែងព្រះបន្ទូលនៅស្ងៀមវិញ។
[31]ដ្បិត គ្រប់គ្នាម្នាក់ៗអាចថ្លែងព្រះបន្ទូលម្នាក់ម្តងៗ ដូច្នេះ គ្រប់គ្នានឹងរៀនព្រមទាំងបានទទួលការលើកទឹកចិត្តផង។[32]ដ្បិត
វិញ្ញាណរបស់អ្នកថ្លែងព្រះបន្ទូលគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកដែលថ្លែងព្រះបន្ទូលនោះឯង។[33]ដ្បិត ព្រះជាម្ចាស់មិនមែនជាព្រះនៃការវឹកវរទេ ប៉ុន្តែ ព្រះអង្គគឺជា
ព្រះជាម្ចាស់នៃសេចក្តីសុខសាន្តវិញ។ នេះគឺជាច្បាប់នៅក្នុងគ្រប់ក្រុមជំនុំរបស់អ្នកជឿទាំងអស់។
[34]មនុស្សស្រីគួរនៅស្ងៀមនៅក្នុងក្រុមជំនុំនាៗ។ ដ្បិត ពួកគេមិនអាចអនុញ្ញាតឲ្យថ្លែងព្រះបន្ទូលឡើយ។ ផ្ទុយទៅវិញ ស្ត្រីគួរប្រតិបត្តិតាមវិញ
ដូចជាអ្វីដែលក្រឹត្យវិន័យបានចែង។[35]បើពួកគេមានបំណងចិត្តចង់រៀនអ្វីមួយ សូមឲ្យគេសួរប្តីរបស់គេនៅឯផ្ទះចុះ។ ដ្បិត ស្ត្រីដែលថ្លែងព្រះបន្ទូលនៅក្នុងក្រុមជំនុំ
មិនសមរម្យទេ។[36]តើព្រះបន្ទូលរបស់ព្រះជាម្ចាស់មកពីបងប្អូនទេ? ឬមានតែបងប្អូនទេ ដែលបានទទួលព្រះបន្ទូល?
[37]ប្រសិនបើ មាននរណាគិតថា ខ្លួនឯងជាអ្នកថ្លែងព្រះបន្ទូល ឬជាមនុស្សខាងឯវិញ្ញាណ
គេត្រូវទទួលស្គាល់អ្វីដែលខ្ញុំសរសេរមកកាន់បងប្អូនគឺជាការបញ្ជារបស់ព្រះជាម្ចាស់។[38]ប៉ុន្តែ បើមានអ្នកណាដែលមិនយល់ នោះមិនចាំបាច់ឲ្យគាត់យល់ទេ។
[39]ដូច្នេះ បងប្អូនអើយ ចូរសង្វាតឲ្យបានចេះថ្លែងព្រះបន្ទូល ហើយកុំឲ្យឃាត់អ្នកណាម្នាក់ពីការនិយាយភាសាដទៃនោះឡើយ។[40]ប៉ុន្តែ
សូមឲ្យការទាំងអស់សម្រេចដូចអ្វីដែលបានថ្លែង និងតាមលំដាប់លំដោយផង។

---

1 Corinthians 14:1
ប្រយោគភ្ជាប់
លោកប៉ូលចង់ឲ្យពួកគេដឹងថា

បើទោះជាការបង្រៀនគឺជាការណែនាំមនុស្សមានសារសំខាន់យ៉ាងណាក៏ដោយ
ក៏ត្រូវធ្វើចេញពីសេចក្តីស្រឡាញ់ដែរ។
ចូលដេញតាមសេចក្តីស្រឡាញ់

generated on Wed Sep 10 16:16:32 2025

លោកប៉ូលនិយាយពីសេចក្តីស្រឡាញ់ប្រៀបដូចជាមនុស្សម្នាក់។
«ត្រូវដេញតាមស្រឡាញ់» ឬ «ខំប្រឹងប្រែងស្រឡាញ់មនុស្ស»។
ជាពិសេសនោះគឺអំណោយទាននៃការថ្លែងព្រះបន្ទូល
និងធ្វើការឲ្យរឹតតែខ្លាំងដើម្បីអាចថ្លែងព្រះបន្ទូលបាន។
ដើម្បីស្អាងចិត្តពួកគេ
ការស្អាងចិត្តមនុស្សគឺជាការតំណាងឲ្យការជួយពួកគេឲ្យក្លាយជាពេញវ័យ
និងរឹងមាំក្នុងសេចក្តីជំនឿរបស់ពួកគេ។ សូមមើលពីរបៀបអ្នកបកប្រែ
«ការស្អាងចិត្ត» នៅក្នុង ១កូរិនថូស ៨:១
ស្អាងចិត្ត
ការស្អាងចិត្តមនុស្សគឺជាការតំណាងឲ្យការជួយពួកគេឲ្យក្លាយជាពេញវ័យ
និងរឹងមាំក្នុងសេចក្តីជំនឿរបស់ពួកគេ។ សូមមើលពីរបៀបអ្នកបកប្រែ
«ការស្អាងចិត្ត» នៅក្នុង ១កូរិនថូស ៨:១
1 Corinthians 14:5
ឥឡូវអ្នកដែលថ្លែងព្រះបន្ទូលប្រសើរជាង
លោកប៉ូលបញ្ជាក់ថា
អំណោយទានថ្លែងព្រះបន្ទូលប្រសើរជាងអំណោយទាននៃការនិយាយភាសាដទៃ។
ការបកប្រែផ្សេងទៀត: «អ្នកដែលថ្លែងព្រះបន្ទូលមានអំណោយទានអស្ចារ្យជាង»។
អ្នកនោះចេះបកស្រាយ
អត្ថន័យនេះចង់ប្រាប់ពីអ្វីដែលនរណាម្នាក់បាននិយាយនៅក្នុងភាសាណាមួយទៅអ្នកដទៃដែលមិនចេះភាសានោះ។
សូមមើលពីការបកប្រែនេះក្នុង ១ កូរិនថូស ២:១៣ (../02/12.md)។
តើបងប្អូនអាចយល់បានទេ?
នេះអាចជាសេចក្តីថ្លែងការមួយ ការបកប្រែផ្សេងទៀត
«ខ្ញុំមិនមានប្រយោជន៍ចំពោះបងប្អូននោះទេ» ឬ
«ខ្ញុំមិនបានធ្វើអ្វីមួយដែលជួយអ្នកនោះទេ»។
1 Corinthians 14:7
ប្រសិនបើ មិនមានសំលេងខុសគ្នា
នេះសំដៅលើការលើកដាក់សំលេងផ្សេងៗគ្នាដែលបង្កើតបានជាសាច់ភ្លេង
ដោយមិនខុសគ្នារវាងសំលេងខ្លុយ និងសំលេងពិណ។
តើធ្វើដូចម្តេចឲ្យដឹងថា ខ្លុយត្រូវចាប់ផ្តើមលេង?
លោកប៉ូលចង់ឲ្យក្រុមជំនុំកូរិនថូសឆ្លើយសំណួរនេះដោយខ្លួនពួកគេផ្ទាល់។
ការបកប្រែផ្សេងទៀត: «គ្មានណាម្នាក់ដឹងថា ខ្លុយ ឬ
ពិណលេងបទណានោះទេ»។
តើនឹងមានអ្នកណារៀបចំសម្រាប់ច្បាំងទៅ?
លោកប៉ូលចង់ឲ្យក្រុមជំនុំកូរិនថូសឆ្លើយសំណួរនេះដោយខ្លួនពួកគេផ្ទាល់។
ការបកប្រែផ្សេងទៀត:
«គ្មាននរណាម្នាក់ដឹងថាពេលណាត្រូវរៀបចំសម្រាប់ច្បាំងនោះទេ»។
1 Corinthians 14:10
ហើយគ្មានភាសារណាមួយដែលមិនមានន័យនោះឡើយ
នេះអាចត្រូវបានបញ្ជាក់ជាវិជ្ជមាន។ ការបកប្រែផ្សេងទៀត:
«សុទ្ធតែមានន័យទាំងអស់»។
1 Corinthians 14:12
អំណោយទានខាងវិញ្ញាណ
អាចធ្វើអ្វីៗដោយការបង្ហាញថាព្រះវិញ្ញាណគ្រប់គ្រងអ្នក។
ត្រូវស្វែងរកឲ្យបានកាន់ច្រើនឡើង ដើម្បីស្អាងក្រុមជំនុំឡើង
លោកប៉ូលនិយាយពីក្រុមជំនុំប្រៀបដូចជាផ្ទះមួយដែលមាននរណាម្នាក់អាចសាងសង់ឡើង
និងការងារនៃការសាងសង់ក្រុមជំនុំប្រៀបដូចជាអ្វីមួយ ជាអ្នកដែលប្រមូលផល។
ការបកប្រែផ្សេងទៀត:
«ការជោគជ័យដ៏អស្ចារ្យជាការដែលធ្វើឲ្យប្រជារាស្ត្ររបស់ព្រះអាចបម្រើព្រះរឹតតែច្រើនឡើងៗ»
បកស្រាយ
អត្ថន័យនេះចង់ប្រាប់ពីអ្វីដែលនរណាម្នាក់បាននិយាយនៅក្នុងភាសាណាមួយទៅអ្នកដទៃដែលមិនចេះភាសានោះ។
សូមមើលពីការបកប្រែនេះក្នុង ១ កូរិនថូស ២:១៣ (../02/12.md)។
ប៉ុន្តែ នៅក្នុងគំនិតខ្ញុំវិញគឺមិនមានលទ្ធផលអ្វីទេ
ជាគំនិតដែលមិនបានយល់ពីអ្វីដែលកំពុងត្រូវបានអធិស្ឋាន
ដែរជាហេតុមិនបានទទួលប្រយោជន៍ពីសេចក្តីអធិស្ឋានដែលបាននិយាយនោះទេ
ប្រៀបដូចជា «គំនិតដែលមិនមានលទ្ធផល»។ ការបកប្រែផ្សេងទៀត:
«ខ្ញុំមិនយល់នៅក្នុងគំនិតខ្ញុំទេ» ឬ
«គំនិតរបស់ខ្ញុំមិនទទួលបានប្រយោជន៍ណាមួយពីសេចក្តីអធិស្ឋាននោះទេ
ដោយសារតែខ្ញុំមិនយល់ពាក្យដែលខ្ញុំកំពុងនិយាយនោះផង»។
1 Corinthians 14:15
តើខ្ញុំគួរធ្វើដូចម្តេច?
លោកប៉ូលកំពុងណែនាំការសរុបសេចក្តីរបស់លោក ការបកប្រែផ្សេងទៀត:
«នេះជាអ្វីដែលខ្ញុំនិងធ្វើ»។
អធិស្ឋានដោយវិញ្ញាណរបស់ខ្ញុំ...អធិស្ឋានក្នុនៅក្នុងគំនិតរបស់ខ្ញុំ...ច្រៀងដោយវិញ្ញាណរបស់ខ្ញុំ...ច្រៀងនៅក្នុងគំនិតរបស់ខ្ញុំ
សេចក្តីអធិស្ឋាន
និងបទចម្រៀងត្រូវតែជាភាសាមួយដែលមនុស្សក្នុងសម័យនោះអាចយល់បាន។
នៅក្នុងគំនិតរបស់ខ្ញុំ
ជាពាក្យដែលខ្ញុំអាចយល់បាន។
បងប្អូនសរសើរតម្កើងព្រះជាម្ចាស់...អ្នកអរព្រះគុណដល់ព្រះជាម្ចាស់...អ្នកកំពុងនិយាយ
ថ្វីបើ «អ្នក»
ជាឯកវចនៈនៅទីេនះលោកប៉ូលកំពុងសម្គាល់អ្នកគ្រប់គ្នាដែលអធិស្ឋានជាមួយតែវិញ្ញាណប៉ុណ្ណោះ
មិនមែនជាមួយគំនិតនោះទេ។
តើធ្វើដូចម្តេចដើម្បីឲ្យអ្នកដែលអត់ចេះនឹងនិយាយថា «អាម៉ែន»...កំពុងនិយាយទេ?
នេះអាចជាសេចក្តីថ្លែងការណ៍មួយ ការបកប្រែផ្សេងទៀត:
«អ្នកដែលអត់ចេះនិងមិនអាចនិយាយថា «អាម៉ែន» នោះទេ...កំពុងនិយាយទេ»។
អ្នកដែលអត់ចេះ
អានមានន័យថា ទី១ «អ្នកដទៃផ្សេងទៀត» ឬ ទី២
«មនុស្សថ្មីនៅក្នុងក្រុមរបស់អ្នក»។
ដែលមិនចេះភាសានោះ។
អាចយល់ព្រមបាន
1 Corinthians 14:17
បងប្អូនអរព្រះគុណយ៉ាងល្អហើយ
លោកប៉ូលកំពុងនិយាយចំពោះក្រុមជំនុំកូរិនថូស
ហាក់ដូចជាពួកគេជាមនុស្សតែមួយ ដូច្នេះពាក្យ «បងប្អូន» នៅទីនេះជាឯកវចនៈ។
ប៉ុន្តែ អ្នកផ្សេងមិនបានទទួលការស្អាងចិត្តឡើយ
ការស្អាងចិត្តមនុស្សជាតំណាងឲ្យការជួយពួកគេឲ្យក្លាយជាពេញវ័យ
និងរឹងមាំក្នុងសេចក្តីជំនឿរបស់ពួកគេ។ នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។
សូមមើលការបកប្រែ: «ស្អាងចិត្ត» នៅក្នុង ១ កូរិនថូស ៨:១
ប្រសើរជាងខ្ញុំនិយាយមួយពាន់ពាក្យជាភាសាដទៃវិញ
លោកប៉ូលមិនបានរាប់ពាក្យរបស់លោកនោះទេ ប៉ុន្តែ
លោកប្រើការបញ្ជាក់ថាពីរបីពាក្យដែលអាចស្តាប់យល់បានមានតម្លៃច្រើនប្រសើរជាងការនិយាយពាក្យជា
ការបកប្រែផ្សេងទៀត: «១០,០០០ពាក្យ» ឬ «ពាក្យជាច្រើនសន្ធឹកសន្ធាប់ទៀត»។
1 Corinthians 14:20
ព័ត៌មានទូទៅ
លោកប៉ូលប្រាប់ពួកគេថា
ការនិយាយភាសាដទៃត្រូវបានប្រាប់តាំងពីសម័យកាលមុនដោយព្យាការីអេសាយ
ជាច្រើនឆ្នាំមុនការនិយាយភាសាដទៃនេះបានកើតឡើងក្នុងក្រុមជំនុំដំបូងរបស់ព្រះគ្រិស្ត។
សូមកុំនៅតែក្មេងខ្ចីខាងឯការគិតរបស់អ្នកឡើយ
ពាក្យ «ក្មេងខ្ចី» ជាការប្រៀបធៀបពីការមិនពេញវ័យខាងឯវិញ្ញាណ។
ការបកប្រែផ្សេងទៀត: «កុំគិតដូចជាកូនក្មេង»។
មានសេចក្តីចែងទុកនៅក្នុងក្រឹត្យវិន័យថា
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្យាការីបានសរសេរចែងទុកពាក្យទាំងនេះក្នុងក្រឹត្យវិន័យថា»
តាមរយៈ ភាសានៃអណ្តាតដ៏ចម្លែករបស់មនុស្ស ហើយតាមបបូរមាត់សាសន៍ដទៃ
ឃ្លាទាំងពីរនេះមានន័យជាគោលដូចគ្នា
ហើយត្រូវបានប្រើរួមគ្នាដើម្បីបញ្ជាក់អ្វីមួយ។
1 Corinthians 14:22
ជាសញ្ញាប់
លោកប៉ូលបង្រៀនយ៉ាងជាក់លាក់ពីរបៀបប្រើប្រាស់អំណោយទានឲ្យបានត្រឹមត្រូវក្នុងក្រុមជំនុំ។
ទំនៃមិនសម្គាល់ពួកអ្នកជឿទេ ប៉ុន្តែជាទីសម្គាល់សម្រាប់ពួកអ្នកដែលជឿវិញ
នេះអាចត្រូវបង្ហាញជាវិជ្ជមាន
និងរួមបញ្ចូលជាមួយសេចក្តីថ្លែងការវិជ្ជមានផ្សេងទៀត។ ការបកប្រែផ្សេងទៀត:
«ជាទីសម្គាល់សម្រាប់ពួកអ្នកដែលជឿតែប៉ុណ្ណោះ»។ (សូមមើល:
តើគេមិនថាអ្នករាល់គ្នាឆ្កួតទេឬអី?
នេះអាចជាសេចក្តីថ្លែងការណ៍មួួយ ការបកប្រែផ្សេងទៀត:
«ពួកគេគួរតែនិយាយថាអ្នករាល់គ្នាឆ្កួតលីលា»។
1 Corinthians 14:24
គេនឹងបានដឹងខ្លួន ដោយគ្រប់អ្វីៗ និងបានពិនិត្យដោយគ្រប់អ្វីៗ
លោកប៉ូលនិយាយជាគោលដូចគ្នាពីរដងដើម្បីបញ្ជាក់អ្វីមួយ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត:
«គេគួរតែដឹងថាខ្លួនមានកំហុសធ្វើបាបដោយសារគេបានឮពីអ្វីដែលបងប្អូនបានកំពុងនិយាយ
អស់ទាំង ការលាក់កំបាំងក្នុងចិត្តគេនឹងបានសម្តែងចេញមក
ពាក្យ «ដួងចិត្ត» សំដៅលើគំនិតបុគ្គលណាម្នាក់។
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះអង្គនិងសម្តែងឲ្យគេឃើញពីសេចក្តីលាក់កំបាំងក្នុងដួងចិត្តរបស់គេ» ឬ
«គេគួរតែទទួលស្គាល់គំនិតខាងក្នុងខ្លួនរបស់គេផ្ទាល់»។
គេអាចក្រាបផ្កាប់មុខ ហើយថ្វាយបង្គំដល់ព្រះជាម្ចាស់
ក្រាបផ្កាប់មុខនៅទីនេះជាគ្រាមភាសា មានន័យថា ក្រាបចុះ។
ការបកប្រែផ្សេងទៀត: «គេនិងក្រាបចុះ ហើយថ្វាយបង្គំព្រះអម្ចាស់»។
1 Corinthians 14:26
បងប្អូនអើយ តើយើងគួរធ្វើអ្វីបន្ទាប់?
លោកប៉ូលប្រើសំណួរមួយដើម្បីបង្ហាញពីផ្នែកបន្ទាប់ពីការលិខិតរបស់លោក។
ការបកប្រែផ្សេងទៀត: «ដោយសារគ្រប់អ្វីៗដែលខ្ញុំបាននិយាយជាសេចក្តីពិត
នេះជាអ្វីដែលអ្នករាល់គ្នាត្រូវធ្វើ បងប្អូនរួមជំនឿខ្ញុំអើយ»។
ការបកប្រែ
នេះមានន័យថា ជាការប្រាប់នរណាម្នាក់ដែលបាននិយាយក្នុងភាសាណាមួយ
ទៅកាន់អ្នកដទៃដែលមិនបានយល់ភាសានោះ។ សូមមើល:ពាក្យ «ការស្រាយ»
បកប្រែយ៉ាងម៉េចក្នុង ១ កូរិនថូស ២:១៣ (../02/12.md)។
ហើយនិយាយម្នាក់ម្តងៗផង
ហើយពួកគេគួរនិយាយម្តងម្នាក់ៗ ឬ «ពួកគេគួរនិយាយម្តងមួយៗ»។
ត្រូវតែបកស្រាយ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«បកស្រាយពីអ្វីដែលអ្នកបាននិយាយ»។
1 Corinthians 14:29
សូមឲ្យពីរ ឬបីនាក់ថ្លែងព្រះបន្ទូលទៅបានហើយ
អាចមានន័យថា ទី១ សូមឲ្យតែព្យាការីតែពីរ
ឬបីនាក់ថ្លែងព្រះបន្ទូលទេក្នុងការប្រជុំណាមួយ ឬ ទី២ សូមឲ្យតែព្យាការីតែពីរ
ឬបីនាក់ដាក់វេនក្នុងការថ្លែងព្រះបន្ទូលក្នុងការប្រជុំណាមួយ។
ពីអ្វីដែលគាត់បានថ្លែងនោះ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ពីអ្វីដែលពួកគេនិយាយ»។
បើជាការបើកសម្តែង ដែលបានផ្តល់ឲ្យអ្នកដទៃទៀត
នេះអាចត្រូវបាននិយាយជាទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត: «ដ្បិត
ព្រះជាម្ចាស់បានប្រទានការបើកសម្តែងដល់នរណាម្នាក់»។
1 Corinthians 14:31
ថ្លែងព្រះបន្ទូលម្នាក់ម្តងៗ
ក្នុងពេលតែមួយគួរតែមានអ្នកដែលថ្លែងព្រះបន្ទូលតែម្នាក់ប៉ុណ្ណោះ។
គ្រប់ៗគ្នានិងបានទទួលការលើកទឹកចិត្ត
នេះអាចនិយាយជាទម្រង់វិជ្ជមាន។ ការបកប្រែផ្សេងទៀត:
«អ្នករាល់គ្នានិងលើកទឹកចិត្តគ្រប់គ្នាទាំងអស់»។
ព្រះជាម្ចាស់មិនមែនជាព្រះនៃការរឹករវេរ
ព្រះជាម្ចាស់មិនបានបង្កើតស្ថានភាពវឹកវរដែលធ្វើឲ្យមនុស្សគ្រប់គ្នានិយាយក្នុងពេលតែមួយនោះទេ។
1 Corinthians 14:34
សូមនៅស្ងៀម
អាចមានន័យថា ទី១ ឈប់និយាយ ទី២
ឈប់និយាយពេលព្យាការីកំពុងថ្លែងព្រះបន្ទូល ឬ ទី៣
សូមឲ្យស្ងៀមឈឹងខណៈពេលថ្វាយបង្គំក្នុងក្រុមជំនុំ។
តើព្រះបន្ទូលរបស់ព្រះជាម្ចាស់មកពីបងប្អូនទេ? ឬមានតែបងប្អូនទេ ដែលបានទទួលព្រះបន្ទូល?
លោកប៉ូលបញ្ជាក់ថា
ក្រុមជំនុំកូរិនថូសមិនមែនគ្រាន់តែជាម្នាក់ដែលយល់ពីអ្វីដែលព្រះអម្ចាស់ចង់ឲ្យគ្រិស្តបរិស័ទធ្វើនោះទេ។
ការបកប្រែផ្សេងទៀត:
«ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនមែនមកតែពីបងប្អូននៅក្នុងក្រុមជំនុំកូរិនថូសនោះទេ
បងប្អូនមិនមែនជាមនុស្សតែម្នាក់តែប៉ុណ្ណោះដែលយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ»។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅទីនេះជាការតំណាងឲ្យសារដែលមកពីព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត: «ព្រះបន្ទូលរបស់ព្រះជាម្ចាស់»។
1 Corinthians 14:37
គេត្រូវទទួលស្គាល់
ជាព្យាការីពិតម្នាក់ ឬ
ជាមនុស្សពិតខាងវិញ្ញាណម្នាក់ដែលនិងទទួលស្គាល់សំបុត្ររបស់លោកប៉ូលពិតជាមកពីព្រះជាម្ចាស់ពិត
មិនចាំបាច់ឲ្យគាត់យល់ទេ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«បងប្អូនមិនគួរមិនយល់ពីគាត់ទេ»។
1 Corinthians 14:39
កុំឲ្យឃាត់អ្នកណាម្នាក់ពីការនិយាយភាសាដទៃនោះឡើយ
លោកប៉ូលបញ្ជាក់យ៉ាងច្បាស់ថា
ការនិយាយភាសាដទៃនៅក្នុងការជួបជុំនៅក្នុងក្រុមជំនុំត្រូវបានអនុញ្ញាត
ហើយទទួលយកបាន។
ប៉ុន្តែ សូមឲ្យការទាំងអស់សម្រេចដូចអ្វីដែលបានថ្លែង និងតាមលំដាប់លំដោយផង
លោកប៉ូលសង្កត់ថា
ការជួបជុំនៅក្នុងក្រុមជំនុំគួរត្រូវធ្វើឡើយដោយមានឥរិយាបថត្រឹមត្រូវ។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែ សូមធ្វើអ្វីៗឲ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់» ឬ
«ប៉ុន្តែសូមធ្វើគ្រប់អ្វីៗទាំងអស់ឲ្យមានលំដាប់លំដោយ
ហើយក្នុងរបៀបដែលអាចទទួលយកបាន»។

---

15 [1]ពេលនេះ ខ្ញុំសូមរំលឹកដល់បងប្អូន ពីដំណឹងល្អដែលខ្ញុំប្រកាសជាមួយបងប្អូន ដែលបងប្អូនបានទទួល ហើយសូមឈរជាមួយការនោះផងដែរ។
[2]តាមរយៈដំណឹងល្អនេះហើយដែលបងប្អូនបានទទួលសេចក្តីសង្គ្រោះ ប្រសិនបើ អ្នកកាន់ខ្ជាប់តាមសេចក្តីដែលខ្ញុំបានប្រកាសដល់បងប្អូន
នោះសេចក្តីជំនឿរបស់បងប្អូននឹងមិនឥតប្រយោជន៍ឡើយ។
[3]ដ្បិត ខ្ញុំបាននាំមកឲ្យបងប្អូន ដូចជារបស់សំខាន់ដំបូងគេនូវអ្វីដែលខ្ញុំបានទទួលរួចហើយ: គឺព្រះគ្រិស្តបានសុគតសម្រាប់បាបរបស់យើង
តាមព្រះគម្ពីរបានចែង [4]គឺព្រះជាម្ចាស់ត្រូវបញ្ចុះក្នុងផ្នូរ ហើយព្រះអង្គមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ស្របតាមព្រះគម្ពីរដែរ។
[5]ព្រះគ្រិស្ត បានបង្ហាញអង្គទ្រង់ឲ្យលោកកេផាស និងពួកសិស្សទាំងដប់ពីរបានឃើញ [6]ក្រោយមកព្រះអង្គក៏បង្ហាញអង្គទ្រង់ឲ្យមនុស្សជាងប្រាំរយនាក់បានឃើញ។
អ្នកខ្លះក៏នៅមានជីវិត ប៉ុន្តែអ្នកផ្សេងទៀតក៏បានដេកលក់ទៅហើយដែរ។ [7]បន្ទាប់មក ព្រះជាម្ចាស់ក៏បានបង្ហាញអង្គទ្រង់ឲ្យលោកយ៉ាកុបឃើញ
ហើយក្រោយមកទៀតព្រះអង្គបង្ហាញឲ្យសាវកទាំងអស់បានឃើញដែរ។
[8]ចុងក្រោយគេបង្អស់ ព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ឲ្យខ្ញុំឃើញ ដូចជាកូនបានកើតមកខុសពេលដែរ។ [9]ដ្បិត ខ្ញុំនេះតូចជាងគេក្នុងចំណោមពួកសាវក។
រូបខ្ញុំមិនស័ក្តិសមឲ្យហៅជាសាវកនោះទេ ពីព្រោះខ្ញុំធ្លាប់បានបៀតបៀនដល់ក្រុមជំនុំរបស់ព្រះជាម្ចាស់។
[10]ប៉ុន្តែ តាមរយៈព្រះគុណរបស់ព្រះជាម្ចាស់ នោះខ្ញុំបានក្លាយជាខ្ញុំ ហើយព្រះគុណរបស់ព្រះជាម្ចាស់ដែលក្នុងខ្ញុំ គឺមិនមែនគ្មានប្រយោជន៍ឡើយ។ ផ្ទុយទៅវិញ
គឺខ្ញុំបានធ្វើការងារច្រើនជាងពួកសាវកផ្សេងទៀតផង។ ពិតណាស់ មិនមែនខ្ញុំទេ ប៉ុន្តែ ដោយសារព្រះគុណរបស់ព្រះជាម្ចាស់ដែលនៅជាមួយខ្ញុំវិញ។ [11]ដូច្នេះ ទោះបីជាខ្ញុំ
ឬពួកគេក្តី ដែលយើងបានប្រកាសនោះគឺធ្វើឲ្យបងប្អូនបានទទួលជឿវិញ។
[12]ពេលនេះ ប្រសិនបើព្រះគ្រិស្តបានប្រកាសថា មានព្រះជន្មរស់ឡើងពីសុគតវិញនោះ ហេតុអ្វីបានជាបងប្អូននិយាយថា គឺមិនមានការរស់ពីសេចក្តីស្លាប់ឡើងវិញ ដូច្នេះ?
[13]ប៉ុន្តែ ប្រសិនបើ គ្មានការរស់ពីស្លាប់ឡើងវិញមែន ដូច្នេះ
សូម្បីតែព្រះគ្រិស្តក៏មិនបានមានព្រះជន្មរស់ឡើងវិញដែរ [14]ហើយប្រសិនបើព្រះគ្រិស្តមិនបានមានព្រះជន្មរស់ឡើងវិញមែន ដូច្នេះ ការប្រកាសដំណឹងល្អរបស់យើង
គឺរាប់ថាជាឥតប្រយោជន៍ហើយ ហើយសេចក្តីជំនឿរបស់បងប្អូនរាប់ថាគ្មានប្រយោជន៍ដែរ។
[15]ដូចគ្នាដែរ ពួកយើងរកឃើញថា គឺជាការធ្វើបន្ទាល់ក្លែងក្លាយអំពីព្រះជាម្ចាស់ ពីព្រោះមកពីយើងបានទាស់ប្រឆាំងជាមួយព្រះជាម្ចាស់
ដោយនិយាយថាព្រះជាម្ចាស់ក៏មិនបានប្រោសព្រះគ្រិស្តឲ្យរស់ឡើងវិញដែរ។ [16]ដ្បិត បើពួកអ្នកដែលស្លាប់មិនអាចរស់ឡើង ដូច្នេះ
ព្រះគ្រិស្តក៏មិនបានមានព្រះជន្មរស់ឡើងវិញដែរ [17]ហើយជំនឿរបស់បងប្អូនគឺឥតប្រយោជន៍ នោះបងប្អូននៅក្នុងបាបរបស់បងប្អូនដដែល។

generated on Wed Sep 10 16:16:32 2025

[18]ដូច្នេះ អ្នកដែលបានស្លាប់នៅក្នុងព្រះគ្រិស្តនឹងត្រូវវិនាសដែរ។[19]ប្រសិនបើយើងមានទីសង្ឃឹមក្នុងព្រះគ្រិស្ត នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនាលើសជាងមនុស្ស
ទាំងអស់ទៅទៀត។
[20]ប៉ុន្តែ ពេលនេះ ព្រះគ្រិស្តពីជាមានព្រះជន្មរស់ពីស្លាប់ឡើងវិញមែន ក៏ជាផលដំបូងនៃពួកអ្នកដែលបានស្លាប់ទៅដែរ។[21]ដ្បិត
ដែលសេចក្តីស្លាប់បានចូលមកតាមរយៈមនុស្សតែម្នាក់ ហើយតាមរយៈមនុស្សក៏នាំសេចក្តីរស់ឡើង ពីការសេចក្តីស្លាប់ដែរ។
[22]ដ្បិត ដោយសារអដាំ គ្រប់គ្នាបានស្លាប់ ដូចគ្នាដែរ នៅក្នុងព្រះគ្រិស្តគ្រប់គ្នានឹងរស់ឡើងវិញដូច្នោះដែរ។[23]ប៉ុន្តែ គ្រប់គ្នាតាមលំដាប់រៀងខ្លួន ព្រះគ្រិស្តជាផលដំបូង
ហើយពួកអ្នកដែលជាកម្មសិទ្ធិរបស់ព្រះគ្រិស្ត នឹងធ្វើឲ្យរស់ឡើងវិញ នៅពេលដែលព្រះអង្គយាងត្រឡប់មកវិញ។
[24]នោះនឹងដល់ទីបញ្ចប់ហើយ នៅពេលដែលព្រះគ្រិស្តប្រគល់ព្រះរាជ្យដល់ព្រះជាម្ចាស់ជាព្រះបិតា។ ក្រោយព្រះអង្គនឹងទំលាក់រាជ្យទាំងអស់ និងអំណាច ព្រមទាំងឥទ្ធិឫទ្ធិ
ទាំងប៉ុន្មានចេញដែរ។[25]ដ្បិត ព្រះជាម្ចាស់នឹងសោយរាជ្យរហូតដល់ពេលដែលព្រះអង្គបានដាក់ពួកខ្មាំងសត្រូវនៅក្រោមព្រះបាទារបស់ព្រះអង្គ។[26]ពួកខ្មាំងសត្រូវ
ដែលនៅក្រោយគេ នឹងត្រូវបំផ្លាញគឺជាសេចក្តីស្លាប់។
[27]ដ្បិត «ព្រះជាម្ចាស់បានបង្ក្រាបគ្រប់យ៉ាងនៅក្រោមព្រះបាទារបស់ព្រះអង្គ» ប៉ុន្តែ នៅពេលនិយាយថា៖ «ព្រះជាម្ចាស់បង្ក្រាបអ្វីគ្រប់យ៉ាង» គឺច្បាស់ជា
មិនបានរាប់បញ្ចូលព្រះជាម្ចាស់ ដែលជាអ្នកបង្ក្រាបគ្រប់យ៉ាងនោះ ដើម្បីនៅក្រោមព្រះអង្គនោះទេ។[28]ពេលគ្រប់របស់ទាំងអស់ បានចុះចូលចំពោះព្រះអង្គ បន្ទាប់មក
ព្រះរាជ្យបុត្រាផ្ទាល់នឹងត្រូវចុះចូលចំពោះព្រះជាម្ចាស់ដែលបានបង្ក្រាបគ្រប់យ៉ាងឲ្យនៅក្រោមព្រះអង្គ។ ការនេះកើតឡើង ដើម្បីឲ្យព្រះជាម្ចាស់ដែលជាព្រះបិតាបានគ្រប់
ទាំងអស់នៅក្នុងគ្រប់ទាំងអស់។
[29]បើមនុស្សស្លាប់មិនរស់ឡើងវិញមែន ហេតុអ្វីបានជាគេធ្វើពិធីជ្រមុជសម្រាប់មនុស្សស្លាប់? ប្រសិនបើ សេចក្តីស្លាប់មិនរស់ឡើងវិញ ហេតុអ្វីបានជាពួកគេទទួល
ពិធីជ្រមុជចូលក្នុងសេចក្តីស្លាប់ធ្វើអ្វី?[30]ហេតុអ្វីបានជាយើងស្ថិតនៅក្នុងគ្រោះថ្នាក់គ្រប់ពេលវេសាដូច្នេះ?
[31]ខ្ញុំប្រឈមជាមួយសេចក្តីស្លាប់ជារៀងរាល់ថ្ងៃ! ការនេះច្បាស់ណាស់ ដូចជាខ្ញុំដែលមានអំនួតនៅក្នុងបងប្អូនដែរ
ក៏ដូចជាអំនួតដែលខ្ញុំមាននៅក្នុងព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើងដែរ។[32]តើខ្ញុំបានចំណេញអ្វី ចេញពីការយល់ឃើញរបស់មនុស្ស ប្រសិនបើ
ខ្ញុំបានប្រយុទ្ធនឹងសត្វព្រៃនៅឯអេភេសូរ ប្រសិនបើ សេចក្តីស្លាប់មិនរស់ឡើងវិញមែន? «ដូច្នេះសូមសី ឹផឹកទៅ ដ្បិតថ្ងៃស្អែកយើងស្លាប់ហើយ»។
[33]កុំឲ្យច្រឡំឡើយ «មានមិត្តអាក្រក់តែងនឹងបង្ខូចកិរិយាល្អ»។[34]ចូរដឹងខ្លួនឡើង! សូមរស់ក្នុងសេចក្តីសុចរិតវិញ! កុំធ្វើបាបតទៅទៀត។ ដ្បិត
មានបងប្អូនខ្លះអត់បានបង្ហាញពីការយល់ដឹងរបស់ព្រះជាម្ចាស់។ ខ្ញុំនិយាយពាក្យទាំងនេះដើម្បីឲ្យបងប្អូនខ្មាស។
[35]ប៉ុន្តែ អ្នកខ្លះនឹងនិយាយថា៖ «តើមនុស្សស្លាប់រស់ឡើងយ៉ាងដូចម្តេច ហើយតើរូបកាយបែបយ៉ាងណា ពេលដែលពួកគេរស់ឡើងវិញនោះ?»[36]បងប្អូនល្ងង់ណាស់!
អ្វីដែលបងប្អូនបានព្រោះទៅនឹងដីគឺវាមិនដុះភ្លាមទេ លើកតែវាបានស្លាប់ជាមុនសិន។
[37]អ្វីដែលបងប្អូនបានព្រោះ គឺមិនមែនជារូបកាយនោះទេ ប៉ុន្តែគឺជាគ្រាប់ពូជសុទ្ធ។ វាអាចជាពូជស្រូវ ឬជាអ្វីផ្សេងទៀត។[38]ប៉ុន្តែ ព្រះជាម្ចាស់នឹងផ្តល់ឲ្យនូវរូបកាយ
ដែលព្រះអង្គបានជ្រើសរើស ហើយគ្រប់គ្រាប់ពូជគឺមានសំបករបស់វា។[39]គ្រប់ទាំងសាច់ក៏មិនដូចគ្នាដែរ។ ផ្ទុយទៅវិញ ត្រូវមានសាច់តែមួយ
ហើយសាច់ផ្សេងទៀតសម្រាប់សត្វពាហនៈ ហើយសាច់ផ្សេងទៀតសម្រាប់សត្វស្លាប ហើយមួយទៀតសម្រាប់ត្រី។
[40]ក៏មានរូបកាយស្ថានបរមសុខ និងរូបកាយលោកីយ៍ដែរ។ ប៉ុន្តែ សិរីរុងរឿងនៃរូបកាយស្ថានសួគ៌មានលក្ខណៈផ្សេង
ហើយសិរីរុងរឿងនៃរូបកាយរបស់លោកីយ៍ក៏មានលក្ខណៈផ្សេងដែរ។[41]ក៏មានពន្លឺរបស់ព្រះអាទិត្យ និងពន្លឺរបស់ព្រះចន្ទដែរ ហើយនិងពន្លឺនៃផ្កាយដែរ។ ដ្បិត
ផ្កាយនីមួយៗមានពន្លឺខុសៗពីគ្នា។
[42]ដូចគ្នានឹងការរស់ពីស្លាប់ឡើងវិញដែរ។ អ្វីដែលគេបានកប់ទៅនឹងត្រូវពុករលួយ ហើយពេលរស់ឡើងវិញ ក្លាយជារូបកាយដែលមិនចេះពុករលួយ។[43]នៅពេលកប់ទៅ
កប់ជាមួយនឹងភាពអាប់ឱន ពេលរស់ឡើងវិញពេញដោយសិរីរុងរឿង ពេលកប់ទៅជាមួយនឹងភាពកម្សោយ ពេលរស់ឡើងវិញ គឺពេញដោយអំណាច។
[44]ពេលកប់ទៅជារូបកាយធម្មជាតិ ហើយពេលរស់ឡើងវិញជារូបកាយខាងឯវិញ្ញាណ។ ប្រសិនបើ មានរូបកាយធម្មជាតិ ដូច្នេះក៏មានរូបកាយខាងឯវិញ្ញាណដែរ។
[45]មានសេចក្តីចែងទុកមកថា៖ «លោកអដាំទីមួយបានត្រឡប់ទៅជាមានព្រលឹងរស់ឡើង»។ លោកអដាមចុងក្រោយបង្អស់បានត្រឡប់ជីវិតខាងឯវិញ្ញាណ។[46]ប៉ុន្តែ
អ្វីដែលខាងឯព្រះវិញ្ញាណមិនបានមកមុនទេ ប៉ុន្តែ អ្វីដែលខាងឯធម្មជាតិវិញ ហើយក្រោយមកខាងឯព្រះវិញ្ញាណ។
[47]បុរសទីមួយគឺកើតពីដី បង្កើតចេញពីធូលីដី។ ឯបុរសទីពីរគឺមកពីស្ថានសួគ៌។[48]ឯមនុស្សដែលកើតពីធូលីដីមកជាយ៉ាងណា នោះមនុស្សទាំងអស់ទាំងអស់ដែលកើតពី
ធូលីដី ក៏យ៉ាងនោះដែរ ហើយព្រះអម្ចាស់ដែលយាងមកពីស្ថានសួគ៌ជាយ៉ាងណា ពួកស្ថានសួគ៌ក៏យ៉ាងនោះដែរ។[49]ដូចដែលយើងបានកើតក្នុងរូបភាព
ជាមនុស្សដែលកើតពីដី យើងក៏មានលក្ខណមនុស្សខាងឯស្ថានបរមសុខដែរ។
[50]បងប្អូនអើយ ខ្ញុំចង់និយាយដូច្នេះថាសាច់និងឈាមមិនអាចគ្រងព្រះរាជ្យរបស់ព្រះជាម្ចាស់បានឡើយ។ ព្រោះ អ្វីដែលមិនចេះពុករលួយ
ក៏មិនអាចគ្រងអ្វីដែលពុករលួយបានឡើយ។[51]មើល! ខ្ញុំប្រាប់បងប្អូនពីការលាក់កំបាំងនៃសេចក្តីពិត ពួកយើងទាំងអស់គ្នានឹងមិនស្លាប់ទេ ប៉ុន្តែ
យើងទាំងអស់គ្នានឹងទទួលការផ្លាស់ប្តូរ។
[52]ពួកយើងនឹងផ្លាស់ប្តូរ ក្នុងពេលមួយ ក្នុងមួយពព្រិចភ្នែក ក្នុងកាលដែលឮសូរត្រែបន្លឺឡើង។ ដ្បិត ត្រែនឹងឮឡើង ហើយពួកដែលស្លាប់នឹងរស់ឡើង
លែងមានភាពពុករលួយទៀតឡើយ ហើយយើងនឹងផ្លាស់ប្តូរ។[53]ដ្បិត រូបកាយដែលពុករលួយនេះ នឹងជំនួសវិញនូវរូបកាយដែលមិនចេះពុករលួយ
ហើយរូបកាយដែលតែងតែស្លាប់នេះ នឹងទៅជារូបកាយដែលមិនចេះស្លាប់វិញ។
[54]ប៉ុន្តែ ពេលដែលរូបកាយដែលពុករលួយ បានជំនួសរូបកាយដែលមិនចេះពុករលួយ ហើយរូបកាយដែលតែងតែស្លាប់បានជំនួសរូបកាយដែលមិនចេះស្លាប់នោះ
ដូច្នេះគឺស្របទៅនឹងសេចក្តីដែលបានចែងថា៖ «ជ័យជម្នះបានលេបសេចក្តីស្លាប់បាត់ហើយ»[55]«សេចក្តីស្លាប់អើយ តើជោគជ័យឯងនៅណា? សេចក្តីស្លាប់អើយ
តើទ្រនិចឯងនៅណា?»
[56]ទ្រនិចនៃសេចក្តីស្លាប់គឺជាបាប ហើយអំណាចរបស់បាបគឺជាក្រឹត្យវិន័យ។[57]ប៉ុន្តែ អរគុណដល់ព្រះជាម្ចាស់
ដែលឲ្យយើងបានជ័យជម្នះតាមរយៈព្រះអម្ចាស់យេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង!
[58]បងប្អូនជាទីស្រឡាញ់អើយ ចូរកាន់យ៉ាងខ្ជាប់ខ្ជួន ដោយឥតរង្គើ ទាំងធ្វើការព្រះអម្ចាស់ ឲ្យបរិបូរជាដរាបចុះ ដោយដឹងថា ការដែលបងប្អូនខំប្រឹងធ្វើក្នុងព្រះអម្ចាស់ នោះ
មិនមែនឥតប្រយោជន៍ទេ។

---

1 Corinthians 15:1

ប្រយោគភ្ជាប់

លោកប៉ូលរំលឹកដល់ពួកគេថា ជាដំណឹងល្អទេដែលសង្គ្រោះពួកគេ
ហើយលោកបានប្រាប់ពួកគេម្តងទៀតថា អ្វីទៅជាដំណឹងល្អ។
ហើយបន្ទាប់មកលោកក៏បានឲ្យមេរៀនប្រវត្តិស្រាស្តខ្លីមួយទៅពួកគេ
ដែលនិងបញ្ចប់ជាមួយអ្វីដែលនិងមិនទាន់កើតនៅឡើយ។

ធ្វើឲ្យអ្នកបានដឹង

ជួយឲ្យអ្នកចង់ចាំបាន

សូមឈរជាមួួយ

លោកប៉ូលកំពុងនិយាយពីក្រុមជំនុំកូរិនថូសដែលពួកគេហាក់ដូចជាផ្ទះមួយ
ហើយដំណឹងល្អហាក់ដូចជាគ្រឹះដែលផ្ទះនោះអាចឈរបាន។

បងប្អូនបានទទួលសេចក្តីសង្គ្រោះ

នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ «ព្រះអម្ចាស់និងសង្គ្រោះអ្នក»។

តាមសេចក្តីដែលខ្ញុំបានប្រកាសដល់បងប្អូន

ជាព្រះបន្ទូលដែលខ្ញុំបានប្រកាសដល់បងប្អូន។

1 Corinthians 15:3

generated on Wed Sep 10 16:16:32 2025

ដូចជារបស់សំខាន់ដំបូង
អាចមានន័យថា ទី១ ជាអ្វីដែលមានសារសំខាន់បំផុតលើសអ្វីៗផ្សេងទៀត ឬ ទី២ ជាពេលដំបូងបង្អស់។
សម្រាប់បាបរបស់យើង
បង់ថ្លៃសម្រាប់បាបយើង ឬ
«ដើម្បីព្រះអម្ចាស់អាចលើកលែងទោសចំពោះបាបរបស់យើង»។
តាមព្រះគម្ពីរបានចែង
លោកប៉ូលសំដៅលើសេចក្តីចែងទុកក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់។
ព្រះជាម្ចាស់ត្រូវបញ្ចុះក្នុងផ្នូរ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ពួកគេបញ្ចុះទ្រង់»។
ព្រះអង្គមានព្រះជន្មរស់ឡើងវិញ
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់ប្រោសទ្រង់ឲ្យរស់ឡើងវិញ»។
មានព្រះជន្ម
បណ្តាលឲ្យរស់ឡើងវិញម្តងទៀត។
1 Corinthians 15:5
ប្រយោគភ្ជាប់
ប្រសិនបើ បងប្អូនចង់តម្រូវឲ្យខ៥ក្លាយជាប្រយោគពេញលេញមួយ បញ្ចប់ ១ កូរិនថូស ១៥:៤(../15/03.md) ជាមួយក្បៀសមួយដើម្បីឲ្យខ៥ អាចចាប់ផ្តើមមានប្រយោគពេញលេញវិញនៅក្នុង ១ កូរិនថូស ១៥:៣ (../15/03.md)។
ព្រះអង្គក៏បង្ហាញអង្គទ្រង់
បង្ហាញខ្លួន។
ប្រាំរយនាក់
៥០០
អ្នកផ្សេងទៀតក៏បានដេកលក់ទៅហើយដែរ
ដេកលក់ នៅទីនេះគឺជាពាក្យនិយាយធម្មតាសំរាប់ការស្លាប់ ការបកប្រែផ្សេងទៀត «មានអ្នកខ្លះទៀតត្រូវបានស្លាប់»។
1 Corinthians 15:8
ចុងក្រោយគេបង្អស់
ជាចុងបញ្ចប់ បន្ទាប់ពីទ្រង់បានបង្ហាញអង្គទ្រង់ដល់អ្នកដទៃ
កូនបានកើតមកខុសពេល
នេះជាគ្រាមភាសា ដែលលោកប៉ូលមានន័យថា
លោកបានក្លាយជាគ្រិស្តបរិស័ទម្នាក់ដែលយឺតជាងគេក្នុងចំណោមសាវកដទៃៗទៀត ឬ ប្រហែលជាលោកមានន័យថា មិនដូចជាសាវកដទៃទៀត
ដែលលោកមិនបានធ្វើជាសាក្សីសំរាប់ព្រះយេស៊ូដែលទ្រង់បានធ្វើព័ន្ធកិច្ចរយៈពេល៣ឆ្នាំ
ការបកប្រែផ្សេងទៀត: «ជានរណាម្នាក់ដែលខ្វះបទពិសោធន៍ពីអ្នកដទៃ»។
1 Corinthians 15:10
តាមរយៈព្រះគុណរបស់ព្រះជាម្ចាស់ នោះខ្ញុំបានក្លាយជាខ្ញុំ
ព្រះគុណរបស់ព្រះ
ឬសេចក្តីសប្បុរសរបស់ព្រះបានធ្វើឲ្យលោកប៉ូលក្លាយជាលោកប៉ូលមកដល់ឥឡូវនេះ។
ព្រះគុណរបស់ព្រះជាម្ចាស់ដែលក្នុងខ្ញុំ គឺមិនមែនគ្មានប្រយោជន៍ឡើយ
លោកប៉ូលកំពុងបញ្ជាក់ថាតាមរយៈការបំភ្លឺដែលព្រះធ្វើការតាមរយៈលោកប៉ូល។ ការបកប្រែផ្សេងទៀត: «ដោយសារទ្រង់មានចិត្តសប្បុរសដល់ខ្ញុំ ខ្ញុំអាចធ្វើការល្អៗបានជាច្រើនទៀត»។
ព្រះគុណរបស់ព្រះជាម្ចាស់ដែលនៅជាមួយខ្ញុំវិញ
លោកប៉ូលនិយាយពីកិច្ចការដែលលោកអាចធ្វើបានដោយសារព្រះមានចិត្តសប្បុរសដល់លោក ប្រៀបដូចជាព្រះគុណទេដែលបានធ្វើការទាំងនោះ។ ការបកប្រែផ្សេងទៀត: អាចមានន័យថា ទី១ នេះជាការនិយាយពិត ដែលព្រះអង្គទ្រង់ជាអ្នកធ្វើការ និងមានចិត្តសប្បុរសប្រើលោកប៉ូលដូចជាឧបករណ៍ ឬ ទី២ លោកប៉ូលកំពុងប្រើការប្រៀបធៀប ហើយនិយាយថា ព្រះមានចិត្តសប្បុរសឲ្យលោកប៉ូលធ្វើការ និងជួយឲ្យការងារលោកប៉ូលសម្រេចបានលទ្ធផលល្អ។
1 Corinthians 15:12
ហេតុអ្វីបានជាបងប្អូននិយាយថា គឺមិនមានការរស់ពីសេចក្តីស្លាប់ឡើងវិញ ដូច្នេះ?
លោកប៉ូលកំពុងប្រើសំណួរនេះក្នុងការចាប់ផ្តើមប្រធានបទថ្មីមួយ។ ការបកប្រែផ្សេងទៀត: «បងប្អូនមិនគួរនិយាយថា មិនមានការរស់ពីសេចក្តីស្លាប់ឡើយវិញនោះទេ!»
មានព្រះជន្ម
ធ្វើឲ្យមានជីវិតម្តងទៀត
ប្រសិនបើ គ្មានការរស់ពីស្លាប់ឡើងវិញមែន ដូច្នេះ
សូម្បីតែព្រះគ្រិស្តក៏មិនបានមានព្រះជន្មរស់ឡើងវិញដែរ
លោកប៉ូលកំពុងប្រើករណីដើម្បីអះអាងថា មានសេចក្តីរស់ឡើងវិញពីសេចក្តីស្លាប់។ លោកដឹងថា ព្រះគ្រិស្តត្រូវបានមានព្រះជន្មរស់ឡើងវិញ ដែលនេះជាហេតុដែលមានការរស់ឡើងវិញ។
ដែលនិយាយថាគ្មានការរស់ពីស្លាប់ឡើងវិញ
នោះជាការនិយាយថាព្រះគ្រិស្តក៏មិនបានមានព្រះជន្មរស់ឡើងវិញដែរ
ហើយនេះជាការមិនត្រឹមត្រូវទេដោយសារលោកប៉ូលបានឃើញការរស់ពីស្លាប់របស់ព្រះគ្រិស្ត ១ កូរិនថូស ១៥:៨
សូម្បីតែព្រះគ្រិស្តក៏មិនបានមានព្រះជន្មរស់ឡើងវិញដែរ
នេះអាចត្រូវបានបកប្រែក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់មិនទាំងបានប្រោសព្រះគ្រិស្តឲ្យមានព្រះជន្មរស់ឡើងវិញទេ»។
1 Corinthians 15:15
ប្រយោគភ្ជាប់
លោកប៉ូលចង់ឲ្យពួកគេអះអាងថា ព្រះគ្រិស្តបានរស់ពីសេចក្តីស្លាប់។
ពួកយើងរកឃើញថា គឺជាការធ្វើបន្ទាល់ក្លែងក្លាយអំពីព្រះជាម្ចាស់
លោកប៉ូលកំពុងជជែកវែកញែកថា
ប្រសិនបើព្រះគ្រិស្តមិនបានរស់ឡើងវិញពីសេចក្តីស្លាប់ទេនោះ
ពួកគេកំពុងធ្វើជាសាក្សីក្លែងក្លាយ ឬ
កំពុងនិយាយកុហកពីការរស់ឡើងវិញរបស់ព្រះគ្រិស្តហើយ។
ពួកយើងរកឃើញថា
នេះអាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «គ្រប់គ្នានិងដឹងប្រាកដថា យើងជា»។
ជំនឿរបស់បងប្អូនគឺឥតប្រយោជន៍ នោះបងប្អូននៅក្នុងបាបរបស់បងប្អូនដដែរ
ជំនឿរបស់ពួកគេគឺអាស្រ័យលើការរស់ឡើងវិញពីសេចក្តីស្លាប់របស់ព្រះគ្រិស្ត ដូច្នេះ ប្រសិនបើមិនមានការរស់ឡើងវិញទេនោះ ជំនឿរបស់ពួកគេនិងមិនល្អឡើយ។
មនុស្សទាំងអស់
មនុស្សគ្រប់គ្នា ទាំងអស់ជឿ និងអ្នកមិនជឿ
នោះយើងវេទនាលើសជាងមនុស្សទាំងអស់ទៅទៀត
មនុស្សគួរមានអារម្មណ៍សោកស្តាយចំពោះយើងច្រើនជាងមនុស្សដទៃផ្សេងទៀត។
1 Corinthians 15:18
មនុស្សទាំងអស់
«មនុស្សទាំងអស់ រួមបញ្ចូលទាំងអ្នកជឿ និងមិនជឿ»
នោះយើងវេទនាលើសជាងមនុស្សទាំងអស់ទៅទៀត។
មនុស្សនឹងមានអារម្មណ៍ថាអាណិតយើង ច្រើនជាងពួកគេអាណិតអ្នកដទៃទៀត»
1 Corinthians 15:20
ពេលនេះ ព្រះគ្រិស្ត
ជាព្រះគ្រិស្ត ឬ «នេះជាសេចក្តីពិត ព្រះគ្រិស្ត» ។
ផលដំបូង
ពាក្យ «ផលដំបូង» ជាការប្រៀបធៀប
ព្រះគ្រិស្តទៅជាផលដំបូងនៃអ្នកចម្រូតដែលនិងត្រូវឲ្យអ្នកច្រូតដទៃទៀតធ្វើតាម។
ព្រះគ្រិស្តជាម្នាក់ដំបូងដែលបានត្រូវបានរស់ពីសេចក្តីស្លាប់។
ការបកប្រែផ្សេងទៀត: «នរណាដែលជាផ្នែកដំបូងនៃការប្រមូលផល»
1 Corinthians 15:24
ព័ត៌មានទូទៅ
ពាក្យ «ទ្រង់» និង «របស់ទ្រង់» សំដៅដល់ព្រះគ្រិស្ត។
ព្រះអង្គនឹងទំលាក់រាជ្យទាំងអស់ និងអំណាច ព្រមទាំងឥទ្ធិឫទ្ធិទាំងប៉ុន្មានចេញដែរ
ទ្រង់និងបញ្ចប់ការគ្រប់គ្រង់របស់មនុស្សដែលមានអំណាច និងមនុស្សដែលមានឥទ្ធិពលក្នុងការធ្វើអ្វីដែលពួកគេកំពុងធ្វើ។
រហូតដល់ពេលដែលព្រះអង្គបានដាក់ពួកខ្មាំងសត្រូវនៅក្រោមព្រះបាទារបស់ព្រះអង្គ
ស្តេចដែលទទួលជ័យជម្នះក្នុងសង្គ្រាមដាក់ព្រះបាទារបស់ទ្រង់លើករបស់ខ្មាំងដែលបរាជ័យ។
ការបកប្រែផ្សេងទៀត:
«រហូតដល់ព្រះបានបញ្ចប់យ៉ាងបរិបូរក្នុងការបំផ្លាញខ្មាំងសត្រូវរបស់ព្រះគ្រិស្ត»។
ពួកខ្មាំងសត្រូវដែលនៅក្រោយគេ នឹងត្រូវបំផ្លាញគឺជាសេចក្តីស្លាប់
លោកប៉ូលនិយាយពីសេចក្តីស្លាប់នៅទីនេះហាក់ដូចជាមនុស្សណាម្នាក់ដែលព្រះទ្រង់និងសម្លាប់។ ការបកប្រែផ្សេងទៀត: «សត្រូវចុងក្រោយបង្អស់ដែលព្រះទ្រង់និងសម្លាប់ បានស្លាប់ដោយខ្លួនឯងផ្ទាល់»។

generated on Wed Sep 10 16:16:32 2025

1 Corinthians 15:27

ព្រះជាម្ចាស់បានបង្ក្រាបគ្រប់យ៉ាងនៅក្រោមព្រះបាទារបស់ព្រះអង្គ

ស្តេចដែលទទួលជ័យជម្នះក្នុងសង្គ្រាមដាក់ព្រះបាទារបស់ទ្រង់លើករបស់ខ្មាំងដែលបរាជ័យ
សូមមើលការបកប្រែពាក្យ «ដាក់...ក្រោមព្រះបាទាទ្រង់» នៅក្នុង ១ កូរិនថូស ១៥:២៥

គ្រប់របស់ទាំងអស់ បានចុះចូលចំពោះព្រះអង្គ

នេះអាចត្រូវបញ្ជាក់ជាសកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះបានធ្វើអ្វីៗគ្រប់ទាំងអស់ឲ្យចុះចូលចំពោះព្រះគ្រិស្ត»។

ព្រះរាជ្យបុត្រាផ្ទាល់នឹងត្រូវចុះចូល

នេះអាចត្រូវបញ្ជាក់ជាសកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះរាជ្យបុត្រាផ្ទាល់នឹងត្រលប់មកចុះចូល»។

បុត្រាផ្ទាល់

នៅក្នុងខគម្ពីរពីមុនៗទ្រង់សំដៅលើ «ព្រះគ្រិស្ត»។ ការបកប្រែផ្សេងទៀត:
«ព្រះគ្រិស្ត ជាព្រះរាជបុត្រាផ្ទាល់»។

បុត្រា

នេះជានាមមួយយ៉ាងសំខាន់ដែលពិពណ៌នាពីទំនាក់ទំនងរវាងព្រះគ្រិស្ត
និងព្រះជាម្ចាស់។

1 Corinthians 15:29

បើមនុស្សស្លាប់មិនរស់ឡើងវិញមែន ហេតុអ្វីបានជាគេធ្វើពិធីជ្រមុជសម្រាប់មនុស្សស្លាប់?

លោកប៉ូលប្រើសំនួរនេះដើម្បីបង្រៀនដល់ពួកជំនុំកូរិនថូស។
អាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «បើមិនដូច្នេះទេ
នោះនឹងមិនមានប្រយោជន៍សំរាប់គ្រិស្តបរិស័ទក្នុងការទទួលពិធីជ្រមុជសម្រាប់មនុស្សស្លាប់
ប្រសិនបើ សេចក្តីស្លាប់មិនរស់ឡើងវិញ ហេតុអ្វីបានជាពួកគេទទួលពិធីជ្រមុជចូលក្នុងសេចក្តីស្លាប់
ធ្វើអ្វី?

លោកប៉ូលប្រើការស្មានលើស្ថានភាពនេះដើម្បីវែកញែកថា
សេចក្តីស្លាប់ត្រូវបានប្រោសរស់ឡើងវិញ។ ការដែលនិយាយថា
សេចក្តីស្លាប់មិនត្រូវបានប្រោសរស់ឡើងវិញនោះជាការដែលនិយាយថាមនុស្សមិនគួរត្រូវ
ប៉ុន្តែ
មនុស្សខ្លះប្រហែលជាសមាជិកក្រុមជំនុំកូរិនថូសមួយចំនួនបានទទួលពិធីជ្រមុជចូលក្នុង
ដូច្នេះលោកយល់ព្រមឲ្យសមាជិកទាំងមនុស្សទាំងនោះទទួលពិធីជ្រមុជចូលក្នុងសេចក្តី
ពីព្រោះពួកគេជឿថា សេចក្តីស្លាប់ត្រូវបានប្រោសរស់ឡើងវិញ។

សេចក្តីស្លាប់មិនរស់ឡើងវិញ

នេះអាចត្រូវបានបកប្រែជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះអង្គមិនបានរស់ឡើងវិញពីសេចក្តីស្លាប់ទេ»។

មិនរស់ឡើងវិញ

ដែលមិនបង្កឲ្យរស់ឡើងវិញម្តងទៀតទេ។

ហេតុអ្វីបានជាពួកគេទទួលពិធីជ្រមុជចូលក្នុងសេចក្តីស្លាប់ធ្វើអ្វី?

លោកប៉ូលប្រើសំនួរនេះដើម្បីបង្រៀនដល់ពួកជំនុំកូរិនថូស។
អាចត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«មិនមានហេតុផលណាមួយសំរាប់ពួកគេក្នុងការឲ្យមនុស្សធ្វើពិធីជ្រមុជសំរាប់ពួកគេដើម្បី

ហេតុអ្វីបានជាយើងស្ថិតនៅក្នុងគ្រោះថ្នាក់គ្រប់ពេលវេលាដូច្នេះ?

លោកប៉ូលប្រើសំណួរនេះ ដើម្បីបង្រៀនដល់ក្រុមជំនុំកូរិនថូស។
ហេតុផលដែលលោក
និងអ្នកដទៃផ្សេងទៀតស្ថិតនៅក្នុងគ្រោះថ្នាក់ដោយព្រោះមានមនុស្សខ្លះបានខឹងពីការបង្រៀន
ថា ព្រះយេស៊ូនិងប្រោសមនុស្សឲ្យរស់ពីសេចក្តីស្លាប់ឡើងវិញ។
ការបកប្រែផ្សេងទៀត: «ប្រសិនបើមនុស្សមិនរស់ពីសេចក្តីស្លាប់ឡើងវិញនោះទេ
យើងមិនទទួលបានអ្វីសោះឡើយ
តែនឹងមានគ្រោះថ្នាក់គ្រប់ពេលសំរាប់ការបង្រៀនថាមនុស្សនិងរស់ឡើងវិញ»។

1 Corinthians 15:31

ខ្ញុំស្លាប់ជារៀងរាល់ថ្ងៃ!

ការនិយាយបន្ថែមនេះមានន័យថា លោកស្ថិតនៅក្នុងការគ្រោះថ្នាក់ដល់ស្លាប់។
លោកដឹងថា
មនុស្សមួយចំនួនចង់សម្លាប់លោកពីព្រោះពួកគេមិនចូលចិត្តពីការបង្រៀនរបស់លោក
ការបកប្រែផ្សេងទៀត: «ជារៀងរាល់ថ្ងៃ ខ្ញុំស្ថិតក្នុងភាពគ្រោះថ្នាក់ដល់ស្លាប់» ឬ
«ជារៀងរាល់ថ្ងៃខ្ញុំប្រថុយជីវិតរបស់ខ្ញុំ!»

ការនេះច្បាស់ណាស់ ដោយខ្ញុំដែលមានអំនួតនៅក្នុងបងប្អូនដែរ

លោកប៉ូលប្រើការនិយាយនេះដូចជាភ័ស្តុតាងថា
លោកប្រឈមសេចក្តីស្លាប់ជារៀងរាល់ថ្ងៃ។ ការបកប្រែផ្សេងទៀត:
«បងប្អូនអាចដឹងថានេះជាសេចក្តីពិត
ដោយសារបងប្អូនដឹងពីសេចក្តីអំនួតដែលខ្ញុំមានក្នុងបងប្អូន» ឬ
«បងប្អូនអាចដឹងថា នេះជាសេចក្តីពិត ដោយសារបងប្អូនដឹងថា
ខ្ញុំមានអំនួតយ៉ាងធំប៉ុណ្ណាក្នុងបងប្អូនទាំងអស់គ្នា»។

ខ្ញុំដែលមានអំនួតនៅក្នុងបងប្អូនដែរ

ក៏ដូចជាអំនួតដែលខ្ញុំមាននៅក្នុងព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើងដែរ

លោកប៉ូលមានអំនួតក្នុងពួកគេដោយព្រោះព្រះគ្រិស្តយេស៊ូបានធ្វើសំរាប់ពួកគេហើយ។
កាបកប្រែផ្សេងទៀត: «ខ្ញុំដែលមានអំនួតក្នុងបងប្អូន
ក៏ដូចជាអំនួតដែលខ្ញុំមាននៅក្នុងព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើងដែលបានធ្វើសំរាប់បងប្អូន»។

ខ្ញុំដែលមានអំនួតនៅក្នុងបងប្អូនដែរ

ពីរបៀបដែលខ្ញុំប្រាប់អ្នកដទៃពីសេចក្តីល្អរបស់បងប្អូន។

តើខ្ញុំបានចំណេញអ្វី...ប្រសិនបើ

ខ្ញុំបានប្រយុទ្ធនឹងសត្វព្រៃនៅឯអេភេសូរ...សេចក្តីស្លាប់មិនរស់ឡើងវិញ

លោកប៉ូលចង់ឲ្យក្រុមជំនុំកូរិនថូសបានយល់ដោយមិនចំបាច់លោកត្រូវប្រាប់ពួកប្រាប់ពួកគេឡើយ។
នេះអាចជាសេចក្តីថ្លែងការមួយ។ ការបកប្រែផ្សេងទៀត:
«ខ្ញុំមិនបានចំណេញអ្វីនោះទេ...ដោយការប្រយុទ្ធនឹងសត្វព្រៃនៅឯអេភេសូរ...សេចក្តីស្លាប់មិនបានរស់ឡើ

ខ្ញុំបានប្រយុទ្ធនឹងសត្វព្រៃនៅឯអេភេសូរ

លោកប៉ូលសំដៅលើអ្វីមួយដែលលោកប្រាកដបានធ្វើ។ អាចមានន័យថា ទី១
លោកបាននិយាយដោយប្រៀបធៀបពីការជជែកវែកញែករបស់លោក
ជាមួយការវៀនពីសាសន៍ដទៃ
ឬជម្លោះផ្សេងទៀតជាមួយមនុស្សដែលចង់សម្លាប់លោក ឬទី២
លោកប្រាកដជាដាក់នៅក្នុងទីលាន
ដើម្បីឈ្នះប្រឆាំងជាមួយសត្វដែលគ្រោះថ្នាក់។

ដូច្នេះសូមសីុធឹកទៅ ដ្បិតថ្ងៃស្អែកយើងស្លាប់ហើយ

លោកប៉ូលបង្រួមសេចក្តីថា គ្មានជីវិតណាវែងឆ្ងាយទៀតទេបន្ទាប់ពីសេចក្តីស្លាប់
ដូច្នេះ
ជាការល្អសំរាប់ពួកយើងក្នុងការសប្បាយនៅក្នុងជីវិតនេះតាមតែយើងអាចធ្វើបាន
ដោយគ្មានសេចក្តីសង្ឃឹមនៅខាងមុខនោះទេ។

1 Corinthians 15:33

ការសើចចំអកនឹងបង្ហូចកិរិយាល្អ

ប្រសិនបើបងប្អូនរស់នៅជាមួយមនុស្សអាក្រក់ បងប្អូននិងធ្វើដូចជាពួកគេ។
លោកប៉ូលកំពុងដកស្រង់ពីការនិយាយធម្មតាមួយ។

ចូរដឹងខ្លួនឡើង

បងប្អូនត្រូវតែគិតឲ្យបានម៉ត់ចត់ពីការនេះ។

1 Corinthians 15:35

ប្រយោគភ្ជាប់

លោកប៉ូលបានឲ្យការជាក់លាក់មួយចំនួនពីរការរស់ឡើងវិញនៃរូបរាងកាយអ្នកជឿ។
លោកបានឲ្យរូបភាពនៃធម្មជាតិ និងវិញ្ញាណខាងរូបរាងកាយ
និងការប្រៀបធៀបមនុស្សដំបូងអាដាមជាមួយមនុស្សចុងក្រោយអាដាម
ព្រះគ្រិស្ត។

ប៉ុន្តែអ្នកខ្លះនឹងនិយាយថា មនុស្សស្លាប់រស់ឡើងយ៉ាងដូចម្តេច ហើយតើរូបកាយបែបយ៉ាងណា
ពេលដែលពួកគេរស់ឡើងវិញនោះ?

អាចមានន័យថា ទី១ ជាបុគ្គលដែលសួរសំនួរនេះដោយភាពស្មោះត្រង់ ឬ ទី២
ជាបុគ្គលដែលកំពុងប្រើសំនួរនេះដើម្បីចំអកដល់គំនិតនៃការរស់ឡើងវិញ។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែអ្នកខ្លះនឹងនិយាយថា
ពួកគេមិនអាចស្រមៃឃើញពីរបៀបដែលព្រះប្រោសរស់អ្នកដែលស្លាប់នោះទេ
និងរូបកាយប្រភេទណាដែលព្រះនឹងផ្តល់ឲ្យពួកគេក្នុងថ្ងៃរស់ឡើងវិញនោះទេ»។

អ្នកខ្លះនឹងនិយាយថា

អ្នកខ្លះនឹងសួរថា។

រូបកាយបែបយ៉ាងណា ពេលដែលពួកគេរស់ឡើងវិញនោះ

នោះ តើនឹងជារូបរាងកាយខាងសាច់ឈាម ឬ ជារូបរាងកាយខាងវិញ្ញាណ?
តើរូបរាងកាយនិងមានទម្រង់ជាយ៉ាងម៉េច? តើរូបរាងកាយនិងត្រូវធ្វើពីអ្វី?
ការបកប្រែបានប្រើសំនួរទូទៅជាច្រើន
ដែលមនុស្សទូទៅចង់ដឹងពីចម្លើយនូវសំនួរទាំងឡាយណាដែលពួកគេសួរ។

បងប្អូនល្ងង់ណាស់! អ្វីដែលបងប្អូនបានព្រោះទៅ

លោកប៉ូលកំពុងនិយាយទៅដល់ពួកជំនុំកូរិនថូស
ហាក់ដូចជាពួកគេជាមនុស្សតែមួយ ដូច្នេះ ទាំងពីរជំនួសឲ្យពាក្យថា «បងប្អូន»
ជាឯកវចន:។

បងប្អូនល្ងង់ណាស់! អ្វីដែលបងប្អូនបានព្រោះទៅ

បងប្អូនមិនដឹងពីអ្វីទាល់តែសោះ

generated on Wed Sep 10 16:16:32 2025

អ្វីដែលបងប្អូនបានព្រោះទៅនឹងដីគឺវាមិនដុះភ្លាមទេ លើកតែវាបានស្លាប់ជាមុនសិន
គ្រាប់ពូជនឹងមិនលូតលាស់ទេ ទាល់តែកប់ក្រោមដីជាដំបូងសិន។
ក្នុងរបៀបដូចគ្នានោះដែរ
បុគ្គលនោះត្រូវស្លាប់សិនមុនពេលដែលព្រះជាម្ចាស់អាចប្រោសរស់គេ។
1 Corinthians 15:37
អ្វីដែលបងប្អូនបានព្រោះ គឺមិនមែនជារូបកាយនោះទេ
លោកប៉ូលប្រើការប្រៀបធៀបពីគ្រាប់ពូជម្តងទៀតដើម្បីនិយាយថា
ព្រះនិងប្រោសរូបកាយអ្នកជឿដែលស្លាប់ឲ្យរស់ឡើងវិញ ប៉ុន្តែ
រូបកាយនោះនឹងមិនលេចឡើងជារូបកាយដោយខ្លួនឯងនោះទេ។
អ្វីដែលបងប្អូនបានព្រោះ
លោកប៉ូលកំពុងនិយាយទៅក្រុមជំនុំកូរិនថូស
ហាក់បីដូចជាពួកគេជាមនុស្សតែមួយ ដូច្នេះពាក្យ «បងប្អូន»
នៅទីនេះជាឯកវចនៈ។
ប៉ុន្តែ ព្រះជាម្ចាស់នឹងផ្តល់ឲ្យនូវរូបកាយ ដែលព្រះអង្គបានជ្រើសរើស
ព្រះជាម្ចាស់នឹងសម្រេចចិត្តក្នុងការជ្រើសរើសប្រភេទរូបកាយដែលនិងត្រូវមាន។
សាច់
ក្នុងបរិបទនៃសត្វពាហនៈ: «សាច់» ប្រហែលជាត្រូវបកប្រែថា «រាងកាយ»
«ស្បែក» ឬ «សាច់»។
1 Corinthians 15:40
រូបកាយស្ថានបរមសុខ
អាចមានន័យថា ទី១ ព្រះអាទិត្យ ព្រះចន្ទ តារា
និងពន្លឺផ្សេងៗទៀតដែលមើលឃើញនៅលើមេឃ ឬ ទី២
នៅស្ថាបរមសុខមានហាក់ដូចជា ទេវតា
និងការអស្ចារ្យលើសពីធម្មតាជាច្រើនទៀត។
រូបកាយលោកីយ៍
នេះសំដៅលើមនុស្សលោក។
សិរីរុងរឿងនៃរូបកាយស្ថានសួគ៌មានលក្ខណៈផ្សេង
ហើយសិរីរុងរឿងនៃរូបកាយរបស់លោកីយ៍ក៏មានលក្ខណៈផ្សេងដែរ
សិរីរុងរឿងដែលរូបកាយស្ថាបរមសុខមានគឺមានភាពខុសគ្នាពីសិរីរុងរឿងនៃរូបកាយលោកីយ៍
សិរីរុងរឿង
ពាក្យ «សិរីរុងរឿង»
សំដៅលើពន្លឺដែលទាក់ទងនិងវត្ថុអ្វីមួយដែលភ្នែកមនុស្សលោកមើលឃើញនៅលើមេឃ
1 Corinthians 15:42
អ្វីដែលគេបានកប់...ពេលរស់ឡើងវិញ
អ្នកសរសេរនិយាយពីរូបកាយរបស់នរណាម្នាក់ដែលបានកប់
ហាក់ដូចជាគ្រាប់ពូជមួយដែលត្រូវបានដាក់ដាំក្រោមដី។
ហើយលោកនិយាយពីរូបកាយរបស់នរណាម្នាក់ដែលរស់ឡើងវិញពីសេចក្តីស្លាប់
ហាក់ដូចជាគ្រាប់ពូជដែលត្រូវបានដុះឡើង។
កិរិយាសព្ទអកម្មត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«អ្វីដែលបានកប់ក្នុងដី...អ្វីដែលដុះចេញពីដី» ឬ
«អ្វីដែលមនុស្សកប់...អ្វីដែលព្រះជាម្ចាស់ឲ្យរស់ឡើងវិញ»។
ពេលរស់ឡើងវិញ
បណ្តាលឲ្យមានជីវិតម្តងទៀត។
ក្នុងការរលួយ...ក្នុងភាពអសកល្បជានិច្ច
អាចពុករលួយ...មិនអាចពុករលួយ។
នៅពេលកប់ទៅ...ពេលរស់ឡើងវិញ
អ្នកសរសេរនិយាយពីរូបកាយរបស់នរណាម្នាក់ដែលបានកប់
ហាក់ដូចជាគ្រាប់ពូជមួយដែលត្រូវបានដាក់ដាំក្រោមដី។
ហើយលោកនិយាយពីរូបកាយរបស់នរណាម្នាក់ដែលរស់ឡើងវិញពីសេចក្តីស្លាប់
ហាក់ដូចជាគ្រាប់ពូជដែលត្រូវបានដុះឡើង។
កិរិយាសព្ទអកម្មត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«អ្វីដែលបានកប់ក្នុងដី...អ្វីដែលដុះចេញពីដី» ឬ
«មនុស្សអ្នកកប់...ព្រះជាម្ចាស់អ្នកធ្វើឲ្យរស់ឡើងវិញ»។
នៅពេលកប់ទៅ...ពេលរស់ឡើងវិញ
អ្នកសរសេរនិយាយពីរូបកាយរបស់នរណាម្នាក់ដែលបានកប់
ហាក់ដូចជាគ្រាប់ពូជមួយដែលត្រូវបានដាក់ដាំក្រោមដី។
ហើយលោកនិយាយពីរូបកាយរបស់នរណាម្នាក់ដែលរស់ឡើងវិញពីសេចក្តីស្លាប់
ហាក់ដូចជាគ្រាប់ពូជដែលត្រូវបានដុះឡើង។
កិរិយាសព្ទអកម្មត្រូវបានបញ្ជាក់ក្នុងទម្រង់សកម្ម ការបកប្រែផ្សេងទៀត:
«អ្វីដែលបានកប់ក្នុងដី...អ្វីដែលដុះចេញពីដី» ឬ
«មនុស្សអ្នកកប់...ព្រះជាម្ចាស់អ្នកធ្វើឲ្យរស់ឡើងវិញ»។
ប៉ុន្តែ អ្វីដែលខាងឯព្រះវិញ្ញាណមិនបានមកមុនទេ ប៉ុន្តែ អ្វីដែលខាងឯធម្មជាតិវិញ
ហើយក្រោយមកខាងឯព្រះវិញ្ញាណ
ជាធម្មជាតិដែលបានមកមុន។
វិញ្ញាណបានមកពីព្រះជាម្ចាស់ហើយបានមកក្រោយ។
ជាធម្មជាតិ
ត្រូវបានបង្កើតដោយរបៀបនៃផែនដី មិនទាន់មានទំនាក់ទំនងជាមួយព្រះទេ
1 Corinthians 15:45
ប៉ុន្តែ អ្វីដែលខាងឯព្រះវិញ្ញាណមិនបានមកមុនទេ ប៉ុន្តែ អ្វីដែលខាងឯធម្មជាតិវិញ
ហើយក្រោយមកខាងឯព្រះវិញ្ញាណ។
«អ្វីដែលជាធម្មជាតិមកមុន។
ហើយអ្វីដែលខាងវិញ្ញាណដែលមកពីព្រះជាម្ចាស់មកតាមក្រោយ»។
ធម្មជាតិ
បានកើតឡើយដោយសារលោកីយ៍ មិនទាក់ទងជាមួយព្រះជាម្ចាស់ទេ។
1 Corinthians 15:47
បុរសទីមួយគឺកើតពីដី បង្កើតចេញពីធូលីដី
ព្រះជាម្ចាស់បង្កើតបុរសជាទីដំបូង លោកអាដាមកើតចេញពីធូលីដីនៃផែនដី។
ធូលីដី
ក្អែល
មនុស្សខាងឯស្ថានបរមសុខ
ព្រះយេស៊ូគ្រិស្ត
ពួកស្ថានសួគ៌ក៏យ៉ាងនោះដែរ
អស់អ្នកដែលជាកម្មសិទ្ធិរបស់ព្រះ។
បានកើតក្នុងរូបភាព...មានលក្ខណៈមនុស្ស
ត្រូវបានដូចជា...និងត្រូវក្លាយដូចជា។
1 Corinthians 15:50
ប្រយោគភ្ជាប
ពីមុនចង់ឲ្យពួកគេដឹងថាមានអ្នកជឿខ្លះមិនបានស្លាប់ខាងរូបកាយនោះទេ
ប៉ុន្តែ នៅមានរូបកាយរស់ឡើងវិញតាមរយៈជ័យជម្នះរបស់ព្រះគ្រិស្ត។
សាច់និងឈាមមិនអាចគ្រងព្រះរាជ្យរបស់ព្រះជាម្ចាស់បានឡើយ។ ព្រោះ អ្វីដែលមិនចេះពុករលួយ
ក៏មិនអាចគ្រងអ្វីដែលពុករលួយបានឡើយ
អាចមានន័យថា ទី១ ប្រយោគទាំងពីរមានអត្ថន័យដូចគ្នា។ ការបកប្រែផ្សេងទៀត
«មនុស្សសញ្ជាតិដែលពិតប្រាកដជាស្លាប់មិនអាចគ្រងព្រះរាជ្យដ៏អស់កល្បរបស់ព្រះបានទេ»
ឬ ប្រយោគទីពីរបញ្ចប់ការការគិតដោយបានចាប់ផ្តើមដោយប្រើពាក្យដំបូង។
ការបកប្រែផ្សេងទៀត:
«មនុស្សទន់ខ្សោយមិនអាចគ្រងព្រះរាជ្យរបស់ព្រះជាម្ចាស់បានឡើយ។
ហើយអស់អ្នកដែលពិតជានិងស្លាប់ក៏មិនអាចគ្រង់ព្រះរាជដែលនិងអស់កល្បជានិច្ចរបស់ព្រះបានដែរ»។
សាច់និងឈាម
អស់អ្នកដែលរស់នៅក្នុងរូបកាយនិងត្រូវវិនាសដល់ស្លាប់។
គ្រងព្រះរាជ្យ
ជាការទទួលអ្វីដែលព្រះបានសន្យាដល់អ្នកជឿដែលត្រូវបាននិយាយដូចជាការទទួលទ្រព្យមរតក
និងការទទួលទ្រព្យសម្បត្តិពីសមាជិកគ្រួសារណាម្នាក់។
ពុករលួយ...មិនចេះពុករលួយវិញ
អាចពុក...មិនអាចពុក។ សូមមើលការបកប្រែពាក្យនេះនៅក្នុង ១ កូរិនថូស
១៥:៤២ (../15/42.md)។
យើងទាំងអស់គ្នានឹងទទួលការផ្លាស់ប្តូរ
នេះអាចត្រូវបានបញ្ជាក់ជាសកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់និងផ្លាស់ប្តូរយើងគ្រប់គ្នា»។
1 Corinthians 15:52
ពួកយើងនឹងផ្លាស់ប្តូរ
នេះអាចត្រូវបានបញ្ជាក់ជាសកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់និងផ្លាស់ប្តូរយើង»។
ក្នុងមួយពព្រិចភ្នែក
ជាការកើតឡើងយ៉ាងរហ័សហាក់បីដូចជាមនុស្សព្រិចភ្នែកមួយពព្រិច។
ក្នុងកាលដែលឮសូរត្រែបន្លឺ
នៅពេលដែលឮសូរត្រែបន្លឺជាចុងក្រោយ។
ពួកដែលស្លាប់នឹងរស់ឡើង
នេះអាចត្រូវបានបកប្រែក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ព្រះអង្គនិងប្រោសមនុស្សឲ្យរស់ឡើងវិញពីសេចក្ដីស្លាប់»។
បានរស់
បណ្ដាលឲ្យរស់ឡើងវិញម្ដងទៀត។
លែងមានភាពពុករលួយ
នៅក្នុងទម្រង់មួយដែលមិនពុករលួយ។
សូមមើលឃ្លាស្រដៀងគ្នាក្នុងការបកប្រែនៅក្នុង ១ កូរិនថូស ១៥:៤២(../15/42.md)។
រូបកាយដែលពុករលួយនេះ...ដែលមិនចេះពុករលួយ
រូបកាយនេះអាចរលួយ...មិនអាចពុករលួយ។
សូមមើលឃ្លាស្រដៀងគ្នាក្នុងការបកប្រែនៅក្នុង ១ កូរិនថូស ១៥:៤២(../15/42.md)។
នឹងទៅជា
លោកប៉ូលកំពុងនិយាយពីព្រះដែលបង្កើតរូបកាយរបស់យើងដូច្នេះពួកយើងនិងមិនត្រូវ
1 Corinthians 15:54
ប៉ុន្តែ ពេលដែលរូបកាយដែលពុករលួយ បានជំនួសរូបកាយដែលមិនចេះពុករលួយ
នៅទីនេះ រូបកាយត្រូវបាននិយាយហាក់បីដូចជាមនុស្សណាម្នាក់
និងការក្លាយជាមិនពុករលួយត្រូវបាននិយាយហាក់ដូចជាស្លៀកសំលៀកបំពាក់ដែលមិន
ការបកប្រែផ្សេងទៀត:
«នៅពេលដែលរូបកាយដែលពុករលួយនេះក្លាយជាមិនពុករលួយវិញ» ឬ
«នៅពេលដែលរូបកាយដែលអាចរលួយនេះ ទៅជាឈប់រលួយវិញ»។
រូបកាយដែលតែងតែស្លាប់បានជំនួសរូបកាយដែលមិនចេះស្លាប់
នៅទីនេះ រូបកាយត្រូវបាននិយាយហាក់បីដូចជាមនុស្សណាម្នាក់
និងការក្លាយជាមិនចេះស្លាប់ត្រូវបាននិយាយហាក់ដូចជាស្លៀកសំលៀកបំពាក់ដែលមិន
ការបកប្រែផ្សេងទៀត:
«នៅពេលដែលរូបកាយដែលពុករលួយនេះក្លាយជាមិនពុករលួយវិញ» ឬ
«នៅពេលដែលរូបកាយដែលអាចរលួយនេះ ទៅជាឈប់រលួយវិញ»។
សេចក្ដីស្លាប់អើយ តើជោគជ័យឯងនៅណា? សេចក្ដីស្លាប់អើយ តើទ្រនិចឯងនៅណា?

លោកប៉ូលនិយាយប្រៀបធៀបការស្លាប់ជាមនុស្សណាម្នាក់
ហើយលោកប្រើសំនួរនេះដើម្បីចំអកដល់អំណាចនៃសេចក្ដីស្លាប់ដែលព្រះគ្រិស្តបានយកជ័យ។
ការបកប្រែផ្សេងទៀត «សេចក្ដីស្លាប់បានបរាជ័យ។
សេចក្ដីស្លាប់ជ័យជម្នះឯងនៅឯណា»។
របស់អ្នក...របស់អ្នក
ពាក្យទាំងនេះជាឯកវចនៈ។
1 Corinthians 15:56
ទ្រនិចនៃសេចក្ដីស្លាប់គឺជាបាប
ដោយអំពើបាបដែលដឹកនាំយើងទៅប្រឈមនឹងសេចក្ដីស្លាប់ ជាការស្លាប់។
អំណាចរបស់បាបគឺជាក្រឹត្យវិន័យ
ក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ដែលបានប្រគល់ឲ្យលោកម៉ូសេបានបញ្ជាក់ពីអំពើបាប
និងបង្ហាញអំពើបាបពួកយើងចំពោះមុខព្រះ។
ស្លាប់ផ្លែដំណើរ
បានឈ្នះសេចក្ដីស្លាប់សម្រាប់យើង។
1 Corinthians 15:58
ប្រយោគភ្ជាប់
ការបកប្រែផ្សេងទៀត: «ត្រូវបានតាំងចិត្ត»។
ការបកប្រែផ្សេងទៀត:
លោកប៉ូលនិយាយពីការព្យាយាមក្នុងការធ្វើការសម្រាប់ព្រះអម្ចាស់
ហាក់ដូចជាគោលដៅដែលបុគ្គលម្នាក់នោះអាចទទួលបានកាន់តែច្រើន។
ការបកប្រែផ្សេងទៀត: «ជានិច្ចកាលធ្វើការឲ្យព្រះអម្ចាស់ដោយស្មោះត្រង់» ។

---

16 [1]ឥឡូវនេះ ទាក់ទងនឹងការប្រមូលប្រាក់ សម្រាប់ពួកអ្នកជឿ ដូចដែលខ្ញុំបានណែនាំក្រុមជំនុំនៅកាឡាទី ដូច្នេះបងប្អូន ក៏ដូចគ្នាដែរ។[2]គឺថ្ងៃទីមួយនៃអាទិត្យ
បងប្អូនត្រូវញែកប្រាក់ខ្លះទុកដោយឡែក ទុកតាមដែលបងប្អូនអាចធ្វើបាន។ ចូរធ្វើដូច្នេះ ដើម្បីកុំឲ្យមានការប្រមូលប្រាក់នៅពេលខ្ញុំទៅរកបងប្អូន។
[3]ពេលខ្ញុំមកដល់ អ្នកណាក៏ដោយដែលបងប្អូន ដែលយល់ព្រម ខ្ញុំនឹងផ្ញើសំបុត្រ និងនាំតង្វាយដែលបងប្អូនបានថ្វាយទៅក្រុងយេរូសាឡិម។[4]ប្រសិនបើ
ពេលវេលាស័ក្តិសមសម្រាប់ខ្ញុំ នោះខ្ញុំនឹងនាំយកតង្វាយទៅជាមួយខ្ញុំតែម្តង។
[5]ប៉ុន្តែ ខ្ញុំនឹងទៅជួបបងប្អូននៅពេលដែលខ្ញុំឆ្លងកាត់ស្រុកម៉ាសេដូន។ ដ្បិត ខ្ញុំនឹងឆ្លងកាត់ស្រុកម៉ាសេដូន។[6]ប្រហែល ខ្ញុំនៅជាមួយបងប្អូន
ហើយចំណាយពេលក្នុងរដូវរងាជាមួយបងប្អូនផង ដូច្នេះ បងប្អូនអាចនឹងជួយខ្ញុំក្នុងដំណើរ នៅពេលដែលខ្ញុំទៅរកបងប្អូន។
[7]ដ្បិត ខ្ញុំមិនចង់ជួបបងប្អូន សម្រាប់តែពេលខ្លីនោះទេ ព្រោះខ្ញុំចង់ចំណាយពេលយូរនៅជាបងប្អូន ប្រសិនបើ ព្រះជាម្ចាស់អនុញ្ញាត។[8]ប៉ុន្តែ ខ្ញុំនឹងនៅក្រុងអេភេសូរទាល់តែ
ដល់បុណ្យថ្ងៃទី៥០[9]ដ្បិត គឺមានទ្វារដ៏ធំមួយបើកសម្រាប់ខ្ញុំ ហើយក៏មានខ្មាំងសត្រូវជាច្រើនដែរ។
[10]ឥឡូវ ពេលលោកធីម៉ូថេបានមកដល់ សូមរាប់អានគាត់ និងកុំឲ្យគាត់មានការព្រួយបារម្ភអ្វីឡើយ។ ដ្បិត គាត់កំពុងធ្វើការថ្វាយព្រះជាម្ចាស់ ដូចជាខ្ញុំបានធ្វើដែរ។
សូមកុំមើលងាយគាត់ឡើយ។[11]ត្រូវជួយគាត់ក្នុងការធ្វើដំណើររបស់គាត់ដោយសុខសាន្ត ដើម្បីឲ្យគាត់អាចត្រឡប់មករកខ្ញុំវិញ។
ខ្ញុំសង្ឃឹមថាគាត់នឹងមកដល់ជាមួយបងប្អូនផ្សេងៗទៀតដែរ។[12]ចំណែកឯលោកអប៉ុឡូសជាបងប្អូនរបស់យើងវិញ ខ្ញុំបានលើកទឹកចិត្តដល់គាត់
ឲ្យទៅសួរសុខទុក្ខបងប្អូនជាមួយបងប្អូនផ្សេងទៀត។ ប៉ុន្តែ មិនទាន់ត្រូវពេលដែលគាត់ត្រូវមកទេ។ ប៉ុន្តែគាត់នឹងមកនៅពេលដែលមានឱកាសវិញ។
[13]ចូលចាំយាម និងឈរឲ្យមាំមួនក្នុងសេចក្ដីជំនឿ ចូរស្តែងចេញដូចជាមនុស្សក្លាហាន និងមានកម្លាំង។[14]សូមឲ្យគ្រប់ការទាំងអស់ដែលបងបងប្អូនធ្វើ
ចូរធ្វើដោយសេចក្ដីស្រឡាញ់។
[15]បងប្អូនអើយ គឺបងប្អូនស្គាល់ក្រុមគ្រួសាររបស់លោកស្ទេផានា ហើយពួកគេជាផលដំបូងនៃការប្រែចិត្តនៅក្នុងស្រុកអាខៃ
និងពួកគេបានញែកខ្លួនសម្រាប់ការបម្រើដល់ពួកអ្នកជឿផង។ ឥឡូវ បងប្អូនអើយ ខ្ញុំសូមលើកទឹកចិត្តបងប្អូនថា[16]ចូរចុះចូលទៅនឹងមនុស្សបែបនេះ
និងអស់អ្នកដែលបានជួយក្នុងការងារ ព្រមទាំងបានធ្វើជាអ្នកបម្រើជាមួយខ្ញុំដែរ។
[17]ខ្ញុំរីករាយជាមួយនឹងការមកដល់របស់លោកស្ទេផានា លោកភ័រទីណាទូស និងលោកអខៃគូស។ ពួកគេបានបំពេញឲ្យបងប្អូន ក្នុងការដែលអ្នកមិនមកបាន។[18]ដ្បិត
ពួកគេបានធ្វើឲ្យវិញ្ញាណរបស់ខ្ញុំស្រស់ថ្លា ហើយបងប្អូនក៏ដូចគ្នាដែរ។ ដូច្នេះ សូមរាប់អាន និងទទួលមនុស្សដូចជាពួកគេផង។
[19]ក្រុមជំនុំនៅអាសុី សូមផ្ញើពាក្យជម្រាបសួរមកដល់បងប្អូន។ លោកអគីឡា និងនាងព្រីសីុលក៏បានផ្ញើពាក្យសួរដល់បងប្អូននៅក្នុងព្រះអម្ចាស់
ជាមួយក្រុមជំនុំដែលនៅក្នុងផ្ទះរបស់ពួកគេដែរ។[20]ហើយបងប្អូនទាំងអស់ក៏បានជម្រាបសួរមកដល់បងប្អូនអ្នកដែរ។ ចូរជម្រាបសួរគ្នាទៅវិញទៅមក
ដោយការថើបបរិសុទ្ធផង។
[21]ខ្ញុំ ប៉ូល សរសេរសំបុត្រនេះជាមួយដៃរបស់ខ្ញុំផ្ទាល់។[22]ប្រសិនបើអ្នកណាមិនស្រឡាញ់ដល់ព្រះអម្ចាស់ សូមឲ្យអ្នកនោះត្រូវបណ្ដាសាចុះ។
ព្រះអម្ចាស់របស់យើងយាងមកវិញ![23]សូមព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគង់នៅជាមួយបងប្អូន។
[24]សូមឲ្យសេចក្ដីស្រឡាញ់របស់ខ្ញុំបាននៅជាមួយបងប្អូនទាំងអស់គ្នាក្នុងព្រះគ្រិស្តយេស៊ូ។

---

1 Corinthians 16:1
សម្រាប់ពួកអ្នកជឿ
លោកប៉ូលបានប្រមូលលុយពីក្រុមជំនុំរបស់លោកសម្រាប់គ្រិស្តបរិស័ទសាសន៍យូដាដែ
និងស្រុកយូដា។
ដូចដែលខ្ញុំបានណែនាំ

ដូចដែលខ្ញុំបានបង្រៀនយ៉ាងជាក់លាក់។
ទុកតាមដែលបងប្អូន
នៅផ្ទះ» ឬ «ទុកនៅជាមួយក្រុមជំនុំ» ។
ចូរធ្វើដូច្នេះ ដើម្បីកុំឲ្យមានការប្រមូលប្រាក់នៅពេលខ្ញុំទៅរកបងប្អូន
ដូច្នេះ បងប្អូននិងមិនត្រូវបានមូលលុយទៀតឡើយ ខណៈខ្ញុំនៅជាមួយបងប្អូន។

generated on Wed Sep 10 16:16:32 2025

1 Corinthians 16:3
អ្នកណាក៏ដោយដែលបងប្អូន ដែលយល់ព្រម
លោកប៉ូលកំពុងប្រាប់ដល់ក្រុមជំនុំឲ្យជ្រើសរើសមនុស្សមួយចំនួនក្នុងចំណោមពួកគេដើម្បីផ្តល់ជូនអំណោយរបស់ពួកគេសម្រាប់ក្រុមជំនុំក្នុងក្រុងយេរូសាឡិម។
«អ្នកណាក៏ដោយដែលបងប្អូនជ្រើសរើស» ឬ
«មនុស្សដែលបងប្អូនជ្រើសតាំងឡើង» ។
ខ្ញុំនឹងធ្វើសំបុត្រ
អាចមានន័យថា ទី១ «ខ្ញុំនិងធ្វើសំបុត្រដែលខ្ញុំនិងសរសេរ» ឬ ទី២
«ខ្ញុំនិងធ្វើសំបុត្រដែលបងប្អូននិងសរសេរ»។
បងប្អូនអាចនឹងជួយខ្ញុំក្នុងដំណើរ នៅពេលដែលខ្ញុំទៅរកបងប្អូន
នេះមានន័យថា ពួកគេប្រហែលនិងឲ្យលុយទៅលោកប៉ូល ឬ
របស់ផ្សេងៗដែលលោកត្រូវការដើម្បីលោក
និងក្រុមរបស់លោកអាចបន្តដំណើររបស់លោកទៀត។
1 Corinthians 16:5
បងប្អូនអាចនឹងជួយខ្ញុំក្នុងដំណើរ
ឃ្លានេះមានន័យថា ពួកគេអាចជួយលោកប៉ូលជាប្រាក់
ឬរបស់ផ្សេងទៀតដែលលោកត្រូវការ ដើម្បីលោក
និងក្រុមបម្រើព័ន្ធកិច្ចរបស់លោកអាចបន្តដំណើរទៅមុខទៀត។
1 Corinthians 16:7
ខ្ញុំមិនចង់ជួបបងប្អូន សម្រាប់តែពេលខ្លីនោះទេ
លោកប៉ូលកំពុងបញ្ជាក់ថា
លោកចង់មកសួរសុខទុកខក្នុងរយៈពេលវែងនៅលើកក្រោយ
មិនមែនពេលខ្លីនេះទេ។
បុណ្យថ្ងៃទី ៥០
លោកប៉ូលនឹងនៅក្រុងអេភេសូរយូរហួតដក់ពិធីបុណ្យនេះ
ដែលនឹងមកដល់ក្នុងខែឧសភា ឬ ខែមិថុនា ៥០ថ្ងៃបន្ទាប់ពី
ពិធីបុណ្យរំលងហើយ។ លោកនឹងធ្វើដំណើរឆ្លងកាត់ស្រុកម៉ាសេដូន
និងបន្ទាប់ទៀតព្យាយាមឲ្យទៅដល់ក្រុងកូរិនថូសមុនពេលរដូវរងាដែលនឹងចាប់ផ្តើមក្នុងខែវិច្ឆិកា។
មានទ្វារដ៏ធំមួយបើកសម្រាប់ខ្ញុំ
លោកប៉ូលនិយាយឱកាសដែលព្រះបានប្រទានឲ្យលោកបានឈ្នះមនុស្សក្នុងការប្រកាសដំណឹងល្អ
ហាក់បីដូចជាទ្វារដែលព្រះអម្ចាស់បានបើកចំហដើម្បីលោកអាចដើរឆ្លងកាត់បាន។
1 Corinthians 16:10
សូមរាប់អានគាត់ និងកុំឲ្យគាត់មានការព្រួយបារម្ភអ្វីឡើយ
សូមមើលទៅ
លោកមិនមានការភ័យខ្លាចអ្វីសោះក្នុងការនៅជាមួយបងប្អូនទាំងអស់គ្នា។
សូមកុំមើលងាយគាត់ឡើយ
ដោយសារលោកធីម៉ូថេមានវ័យក្មេងច្រើនជាងលោកប៉ូល ដូច្នេះ
ពេលខ្លះលោកមិនត្រូវបានទទួលលការគោរព
ដែលលោកស័ក្តិសមនឹងទទួលបានដែលលោកជាអ្នកបំរើព័ន្ធកិច្ចនៃដំណឹងល្អមួយរូប។
លោកអប៉ុឡូសជាបងប្អូនរបស់យើង
នៅទីនេះពាក្យថា «របស់យើង» សំដៅទៅលោកប៉ូល នឹងពួកជំនុំរបស់លោក
ត្រូវបានបញ្ចូលដែរ។
1 Corinthians 16:13
ចូលចាំយាម និងឈរឲ្យមាំមួនក្នុងសេចក្តីជំនឿ ចូរស្ទែងចេញដូចជាមនុស្សក្លាហាន និងមានកម្លាំង
លោកប៉ូលកំពុងពណ៌នាពីអ្វីដែលលោកចង់ឲ្យក្រុមជំនុំកូរិនថូសធ្វើប្រៀបដូចជាលោកចង់ឲ្យពួកគេ
បទបញ្ជាទាំងបួនយ៉ាងនោះមានន័យស្មើរដូចគ្នា
ហើយត្រូវបានប្រើសំរាប់ការបញ្ជាក់។
ចូលចាំយាម
លោកប៉ូលនិយាយពីមនុស្សដែលប្រុងប្រយ័ត្នពីអ្វីដែលនឹងកើតឡើងដូចជាពួកគេកំពុងយាមការពារទីក្រុង
ឈរឲ្យមាំមួនក្នុងសេចក្តីជំនឿ
លោកប៉ូលនិយាយពីមនុស្សដែលបន្តសេចក្តីជំនឿក្នុងព្រះគ្រិស្តតាមរយៈសេចក្តីបង្រៀនរបស់លោកប្រៀប
អាចមានន័យថា ទី១
«សូមរក្សាជំនឿឲ្យបានរឹងមាំពីអ្វីដែលយើងបានបង្រៀនបងប្អូន» ឬ ទី២
«សូមរក្សាទំនុកចិត្តនឹងព្រះគ្រិស្តឲ្យបានរឹងមុឺង»។
ចូរស្ទែងចេញដូចជាមនុស្សក្លាហាន
នៅក្នុងសង្គមដែលលោកប៉ូល និងពួកជំនុំរបស់លោករស់នៅ
មនុស្សតែងតែធ្វើការយ៉ាងលំបាកសម្រាប់ផ្គត់ផ្គង់គ្រួសារ
ហើយវៃប្រឆាំងតវ៉ាចំពោះជនឈ្លានពាន។
នេះអាចត្រូវបានបញ្ជាក់ឲ្យកាន់តែច្បាស់។ សូមមើលការបកប្រែផ្សេងទៀត:
«មានទំនុលខុសត្រូវ»។
សូមឲ្យគ្រប់ការទាំងអស់ដែលបងប្អូនធ្វើ ចូរធ្វើដោយសេចក្តីស្រឡាញ់
គ្រប់អ្វីដែលបងប្អូនធ្វើគួរតែបង្ហាញដល់មនុស្សថាបងប្អូនស្រឡាញ់ពួកគេ។
1 Corinthians 16:15
ប្រយោគភ្ជាប់
លោកប៉ូលចាប់ផ្តើមបញ្ចប់សេចក្តីក្នុងសំបុត្ររបស់លោក
ហើយធ្វើការសួរសុខទុក្ខដល់ក្រុមជំនុំផ្សេងៗទៀត ដូចជាលោកអគីឡា និងនាង
ព្រីស៊ីល និងក្រុមជំនុំរបស់លោកប៉ូលខ្លួនឯងផ្ទាស់។
ក្រុមគ្រួសាររបស់លោកស្ទេផានា
លោកស្ទេផានាជាអ្នកជឿដំបូងម្នាក់ក្នុងក្រុមជំនុំកូរិនថូស។
ស្រុកអាខៃ
នេះជាឈ្មោះនៃខេត្តមួយក្នុងប្រទេសក្រិក។
1 Corinthians 16:17
លោកស្ទេផានា លោកភ័រទីណាទូស និងលោកអខៃគូស
សំណើរបស់ពួកគេនេះបើមិនមានអ្នកខ្លះជាអ្នកជឿដំបូងក្នុងក្រុមជំនុំកូរិនថូសទេ
ក៏ជាចាស់ទុំក្នុងក្រុមជំនុំដែលជាក្រុមការងាររបស់លោកប៉ូលដែរ។
លោកស្ទេផានា លោកភ័រទីណាទូស និងលោកអខៃគូស
ទាំងនេះសុទ្ធតែជាឈ្មោះមនុស្ស។
ពួកគេបានបំពេញឲ្យបងប្អូន ក្នុងការដែលអ្នកមិនមកបាន
ពួកគេបំពេញពីសេចក្តីពិតដែលថាបងប្អូនមិននៅទីនេះ
ដ្បិត ពួកគេបានធ្វើឲ្យវិញ្ញាណរបស់ខ្ញុំស្រស់ថ្លា
លោកប៉ូលកំពុងនិយាយថា
លោកទទួលបានការលើកទឹកចិត្តពីការសម្របសួររបស់ពួកគេ។
1 Corinthians 16:21
ខ្ញុំ ប៉ូល សរសេរសំបុត្រនេះជាមួយដៃរបស់ខ្ញុំផ្ទាល់
លោកប៉ូលបានបញ្ជាក់យ៉ាងច្បាស់ថា
សេចក្តីណែនាំទាំងឡាយនៅក្នុងសំបុត្រនេះគឺលោកជាអ្នកសរសេរ
បើទោះជាមានអ្នករួមការងាររបស់លោកម្នាក់បានសរសេរពីអ្វីដែលលោកប៉ូលបាននិយាយនៅក្នុងសំបុត្រនេ
លោកប៉ូលបានសរសេរផ្នែកចុងក្រោយនៃសំបុត្រនេះដោយដៃរបស់លោកផ្ទាល់។
សូមឲ្យព្រះដាក់បណ្តាសាគាត់ចុះ។ សូមមើលការបកប្រែ: «ត្រូវបណ្តាសា» នៅក្នុង
១ កូរិនថូស ១២:៣(../12/03.md)។

---

២ កូរិនថូស

1 [1]ខ្ញុំប៉ូល ជាសាវ័ករបស់ព្រះគ្រិស្តយេស៊ូ ស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងលោកធីម៉ូថេជាបងប្អូនរបស់យើង
សូមជម្រាបសួរដល់ក្រុមជំនុំរបស់ព្រះជាម្ចាស់ដែលនៅក្រុងកូរិនថូស និងបងប្អូនដែលរួមជំនឿទាំងអស់គ្នា ដែលនៅក្នុងស្រុកអាខៃទាំងមូល។
[2]សូមឲ្យបងប្អូនប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្តមកពីព្រះដ៏ជាព្រះបិតា និងព្រះអម្ចាស់យេស៊ូគ្រិស្ត។
[3]សូមលើកតម្កើងព្រះជាម្ចាស់ និងជាព្រះបិតារបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង។ ព្រះជាម្ចាស់កម្សាន្តចិត្តយើង គ្រប់ទាំងសេចក្តីលំបាករបស់យើង។
[4]យើងកម្សាន្តចិត្តអ្នកដទៃដោយសេចក្តីកម្សាន្តចិត្តដដែល ដែលព្រះជាម្ចាស់បានកម្សាន្តចិត្តយើង។
[5]ដ្បិត ព្រះគ្រិស្តបានរងទុក្ខលំបាកដោយព្រោះយើងច្រើនយ៉ាងណា ដូច្នេះសេចក្តីកម្សាន្តចិត្តរបស់យើងក៏បានច្រើនឡើងតាមរយៈព្រះគ្រិស្តដែរ។[6]ប៉ុន្តែប្រសិនបើ
យើងមានទុក្ខលំបាក វាជាសេចក្តីកម្សាន្តចិត្ត និងជាសេចក្តីសង្គ្រោះដល់បងប្អូន។
សេចក្តីកម្សាន្តចិត្តរបស់បងប្អូនបានធ្វើការយ៉ាងមានប្រសិទ្ធភាពនៅពេលដែលបងប្អូនអត់ធ្មត់ក្នុងការរួមចំណែកក្នុងទុក្ខលំបាក ដូចយើងមានទុក្ខលំបាកដែរ។
[7]យើងមានការជឿជាក់លើបងប្អូនច្បាស់ណាស់ ដ្បិត យើងដឹងថា នៅពេលបងប្អូនរួមចំណែកក្នុងទុក្ខលំបាកយ៉ាងណា
បងប្អូនក៏មានចំណែកនៅក្នុងការកម្សាន្តចិត្តដូចគ្នាដែរ។

generated on Wed Sep 10 16:16:32 2025

[8]ដ្បិត យើងមិនចង់ឲ្យបងប្អូនដឹងពីបញ្ហាដែលយើងមាននៅស្រុកអាស៊ីនោះទេ។ ពួកយើងមានបន្ទុកយ៉ាងខ្លាំងដែលយើងមិនអាចទ្រាំទ្របាន
ហើយយើងក៏អស់សង្ឃឹមក្នុងនៅរស់ផងដែរ។[9]ពិតណាស់ ពួកយើងមានទោសស្លាប់នៅជាប់ជាមួយយើង។ ប៉ុន្តែ
ការនេះធ្វើឲ្យយើងមិនដាក់សេចក្តីជំនឿលើខ្លួនរបស់យើងឡើយ ផ្ទុយទៅវិញ យើងបានសេចក្តីជំនឿលើព្រះជាម្ចាស់ ដែលប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ។
[10]ព្រះអង្គបានសង្គ្រោះយើងឲ្យចេញពីសេចក្តីស្លាប់ដ៏គ្រោះថ្នាក់ ហើយទ្រង់នឹងសង្គ្រោះយើងម្តងទៀត។ យើងបានដាក់សេចក្តីទុកចិត្តរបស់យើងលើព្រះអង្គ
ហើយទ្រង់នឹងសង្គ្រោះយើងម្តងទៀត។
[11]ព្រះអង្គនឹងធ្វើការនេះដូចដែលបងប្អូនបានជួយពួកយើងតាមរយៈការអធិស្ឋានរបស់បងប្អូនដែរ។ ហេតុនេះហើយ មនុស្សជាច្រើននឹងអរព្រះគុណព្រះអង្គ
ដែលសណ្តោសប្រណីអត់ទោសដល់យើងតាមរយៈសេចក្តីទូលអង្វររបស់បងប្អូនជាច្រើន។
[12]យើងមានអំនួតដោយព្រោះ សេចក្តីបន្ទាល់នៃមនសិការរបស់យើង។ ដ្បិត នេះជាសេចក្តីបរិសុទ្ធ និងស្មោះត្រង់មកពីព្រះជាម្ចាស់
ដែលយើងបានប្រព្រឹត្តដោយខ្លួនយើងនៅក្នុងលោកីយ៍នេះ។ យើងបានធ្វើការទាំងអស់នេះជាច្រើនជាមួយបងប្អូន មិនមែនដោយពឹងអាងលើប្រាជ្ញារបស់យើង ប៉ុន្តែ
ដោយពឹងអាងលើព្រះគុណរបស់ព្រះជាម្ចាស់វិញ។[13]យើងមិនបានសរសេរអ្វីផ្សេងផ្ញើមកបងប្អូន ដែលបងប្អូនអានមិនបាន ឬមិនយល់នោះទេ។
ខ្ញុំសង្ឃឹមថា[14]បងប្អូនបានយល់ពីពួកយើងខ្លះហើយថា បងប្អូនជាហេតុដែលយើងនឹងមានអំនួតនៅក្នុងថ្ងៃរបស់ព្រះអម្ចាស់យេស៊ូ
ហើយយើងក៏ជាហេតុដែលធ្វើឲ្យបងប្អូនមានអំនួតដូចគ្នាដែរ។
[15]ដោយសារខ្ញុំមានទំនុកចិត្តអំពីការនេះ បានជាខ្ញុំចង់មករកបងប្អូនមុន ដើម្បីឲ្យអ្នករាល់គ្នាបានទទួលអត្ថប្រយោជន៍ពីរដងនៃការមកសួរសុខទុក្ខរបស់ខ្ញុំ។
[16]ខ្ញុំមានគម្រោងមកសួរសុខទុក្ខបងប្អូននៅក្នុងដំណើរដែលខ្ញុំទៅស្រុកម៉ាសេដូន។ បន្ទាប់មកគឺខ្ញុំចង់សួរសុខទុក្ខបងប្អូនម្តងទៀតក្នុងដំណើរដែលខ្ញុំចេញពីស្រុកម៉ាសេដូន
និងដើម្បីឲ្យបងប្អូនជូនដំណើរខ្ញុំទៅស្រុកយូដាផងដែរ។
[17]នៅពេលដែលខ្ញុំគិតពីការនេះ តើខ្ញុំស្មាក់ស្មើរមែនទេ? ឬមួយអ្វីដែលខ្ញុំសម្រេចចិត្ត ខ្ញុំសម្រេចចិត្តតាមខ្នាតតម្រារបស់មនុស្ស ដូច្នេះហើយបានជាខ្ញុំនិយាយថា «បាទ» ផង
«ទេ» ផង ដូច្នេះ?[18]ក៏ប៉ុន្តែ ដោយព្រះជាម្ចាស់ស្មោះត្រង់ ទើបយើងមិនអាចនិយាយ «បាទ» ផង «ទេ» ផងបានទេ។
[19]ដ្បិត ព្រះយេស៊ូគ្រិស្តគឺជាបុត្រានៃព្រះជាម្ចាស់ ដែលលោកស៊ីលវ៉ាន និងលោកធីម៉ូថេ ព្រមទាំងខ្ញុំបានប្រកាសនៅក្នុងចំណោមបងប្អូននោះ ព្រះអង្គមិនបានមានបន្ទូល
«បាទ» ផង «ទេ» ផងនោះទេ។ តែផ្ទុយទៅវិញព្រះអង្គមានតែ «បាទ» ប៉ុណ្ណោះ។[20]គ្រប់ទាំងព្រះបន្ទូលសន្យារបស់ព្រះអង្គគឺមានតែ «បាទ» នៅក្នុងព្រះអង្គ។ ដូច្នេះ
ដោយព្រោះព្រះអង្គយើងនិយាយថា «អាម៉ែន» ដើម្បីថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់។
[21]ឥឡូវនេះ ព្រះជាម្ចាស់ហើយដែលបានទទួលយកយើងជាមួយនឹងបងប្អូននៅក្នុងព្រះគ្រិស្ត ហើយព្រះអង្គបានចាក់ប្រេងតាំងយើង។
[22]ទ្រង់បានប្រថាប់ត្រារបស់ព្រះអង្គនៅលើយើង ហើយប្រទានព្រះវិញ្ញាណឲ្យគង់នៅក្នុងដួងចិត្តរបស់យើង
ដើម្បីជាការធានានូវអ្វីដែលព្រះអង្គនឹងប្រទានពរដល់យើងនៅពេលក្រោយ។
[23]ផ្ទុយទៅវិញ ខ្ញុំសូមព្រះជាម្ចាស់ឲ្យធ្វើជាសាក្សីសម្រាប់ខ្ញុំ ហេតុដែលខ្ញុំមិនបានមកក្រុងកូរិនថូសនោះ មកពីខ្ញុំយោកយល់ដល់បងប្អូន។
[24]នេះមិនមែនដោយសារពួកយើងចង់ព្យាយាមគ្រប់គ្រងលើជំនឿរបស់បងប្អូនទេ។ ផ្ទុយទៅវិញ ពួកយើងរួមគ្នាធ្វើជាមួយបងប្អូន
ដើម្បីឲ្យបងប្អូនមានអំណរដោយសារបងប្អូនឈរនៅក្នុងជំនឿរបស់បងប្អូន។

---

2 Corinthians 1:1

ប្រយោគភ្ជាប់

បន្ទាប់ពីសាវ័កប៉ូល ជម្រាបសួរដល់ក្រុមជំនុំក្នុងក្រុងកូរិនថូស
គាត់ក៏សរសេរពីការឈឺចាប់ និងការជួយសម្រួលពីព្រះយេស៊ូគ្រិស្ត។
លោកធីម៉ូថេក៏នៅជាមួយគាត់ដែរ។

ព័ត៌មានទូទៅ:

ពាក្យថា «បងប្អូន» សំដៅទៅលើប្រជារាស្ត្រនៃក្រុមជំនុំ ក្នុងក្រុងកូរិនថូស
និងបងប្អូនគ្រីស្ទបរិស័ទនៅតំបន់នោះ។ ហើយប្រហែលលោកធីម៉ូថេ
សរសេរលើស្បែកសត្វ តាមពាក្យដែលលោកសាវ័កបានថ្លែង។

សាវ័កប៉ូល.....ទៅកាន់ក្រុមជំនុំព្រះក្នុងក្រុងកូរិនថូស

ភាសារបស់អ្នកអាចមានលក្ខណៈពិសេសសម្រាប់
ការចង្អុលបង្ហាញពីអ្នកសរសេរសំបុត្រ និងអ្នកស្តាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំសាវ័កប៉ូក.....បានសរសេរសំបុត្រនេះទៅកាន់បងប្អូន
ក្រុមជំនុំព្រះក្នុងក្រុងកូរិនថូស»

លោកធីម៉ូថេ បងប្អូនរបស់យើង

នេះបង្ហាញថាទាំងសាវ័កប៉ូល និងជនជាតិកូរិនថូស បានត្រូវថា
និងចាត់ទុកលោកធីម៉ូថេ ជាបងប្អូនខាងព្រលឹងវិញ្ញាណរបស់ពួកគេ។

ស្រុកអាខៃ

នេះជាឈ្មោះនៃអាណាខេត្តរបស់ជនជាតិរ៉ូម៉ាំង
ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសក្រិចសព្វថ្ងៃ។

សូមឲ្យបងប្អូនប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្ត

នេះជាពាក្យជម្រាបសួរទូទៅ
ដែលសាវ័កប៉ូលប្រើក្នុងការសរសេរសំបុត្ររបស់លោក។

2 Corinthians 1:3

សូមលើកតម្កើងព្រះជាម្ចាស់ និងជាព្រះបិតារបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សូមឲ្យយើងខ្ញុំតែងតែឡើងតម្កើងព្រះជាម្ចាស់
និងជាព្រះបិតារបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង»

ព្រះជាម្ចាស់ និងជាព្រះបិតា

«ព្រះជាម្ចាស់ ជាព្រះបិតា»

ព្រះបិតានៃក្តីមេត្តាករុណា និងព្រះនៃការកំសាន្តចិត្ត

ឃ្លាទាំងពីរនេះ បង្ហាញពីគំនិតដូចគ្នា តែមានលក្ខណៈប្លែកពីគ្នា។
ឃ្លាទាំងពីរសំដៅទៅលើព្រះជាម្ចាស់។

ព្រះបិតានៃក្តីមេត្តាករុណា និងព្រះនៃការកំសាន្តចិត្ត

អាចមានន័យថា ១) ពាក្យថា «ក្តីមេត្តាករុណា» និង «កំសាន្តចិត្ត»
បង្ហាញពីលក្ខណៈពី «ព្រះបិតា» និង «ព្រះអម្ចាស់» ឬ ២) មានថា «ព្រះបិតា»
និង«ព្រះជាម្ចាស់» សំដៅលើ ទ្រង់តែមួយគត់ ដែលជាប្រភពនៃ «ក្តីមេត្តាករុណា»
និង «ចិត្តកំសាន្ត»។

កម្សាន្តចិត្តយើង គ្រប់ទាំងសេចក្តីលំបាករបស់យើង

ពាក្យថា «យើង» និង «របស់យើង» រួមជាមួយជនជាតិកូរិនថូស។

2 Corinthians 1:5

ព្រះគ្រិស្តបានរងទុក្ខលំបាកដោយព្រោះយើងច្រើនយ៉ាងណា

សាវ័កប៉ូលបានថ្លែងពីការរងទុក្ខលំបាករបស់ព្រះគ្រិស្ត ដូចជា
ការនោះធ្វើឲ្យចម្រើនឡើង។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះគ្រិស្តរងទុក្ខលំបាកខ្លាំង ដោយព្រោះតែយើង»។

ការរងទុក្ខលំបាករបស់ព្រះគ្រីស្ត

អាចមានន័យថា ១) សំដៅលើបទពិសោធន៍របស់ សាវ័កប៉ូល និងលោកធីម៉ូថេ
ពីការរងទុក្ខលំបាក ដោយព្រោះពួកគេអធិប្បាយពីព្រះគ្រិស្ត។ ឬ ២) សំដៅលើ
ការរងទុក្ខលំបាកជំនួសយើង ដែលព្រះគ្រិស្តធ្លាប់មានបទពិសោធន៍។

ការកំសាន្តចិត្តរបស់យើងច្រើនឡើង

សាវ័កប៉ូលថ្លែងពីការកំសាន្តចិត្ត ដែលជាការនោះបានកើនឡើង។

ប៉ុន្តែប្រសិនបើ យើងមានទុក្ខលំបាក

ពាក្យថា «យើង» សំដៅលើសាវ័កប៉ូល និងលោកធីម៉ូថេ
តែមិនមែនអ្នកនៅក្រុងកូរិនថូសឡើយ។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែប្រសិនបើ ពួកគេធ្វើឲ្យយើងមានទុក»

ប្រសិនបើយើងបានការកំសាន្តចិត្ត

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើព្រះអម្ចាស់កំសាន្តចិត្តយើង»

សេចក្តីកម្សាន្តចិត្តរបស់បងប្អូនបានធ្វើការយ៉ាងមានប្រសិទ្ធភាព

«អ្នកមានបទពិសោធន៍ការកម្សាន្តចិត្តយ៉ាងមានប្រសិទ្ធភាព»

2 Corinthians 1:8

យើងមិនចង់ឲ្យអ្នកល្ងង់ខ្លៅ

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងចង់ឲ្យបងប្អូនបានដឹង»
ពួកយើងមានបន្ទុកយ៉ាងខ្លាំងដែលយើងមិនអាចទ្រាំទ្របាន
សាវ័កប៉ូល និងលោកធីម៉ូថេ
ពួកគាត់សំដៅលើអារម្មណ៍របស់ពួកគាត់ដែលអស់សង្ឃឹម
ដោយមានបន្ទុកយ៉ាងធ្ងន់ដែលត្រូវទទួល។
ពួកយើងមានបន្ទុកយ៉ាងខ្លាំង
ពាក្យថា «បន្ទុក» សំដៅលើអារម្មណ៍ដែលអស់សង្ឃឹម។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកយើងមានបទពិសោធន៍ពីបញ្ហាដែលជាបន្ទុកយ៉ាងខ្លាំងសម្រាប់យើង»
ឬ«យើងពិតជាអស់សង្ឃឹមយ៉ាងខ្លាំង»
ពួកយើងមានទោសស្លាប់នៅជាប់ជាមួយយើង
សាវ័កប៉ូល និងលោកធីម៉ូថេ បានប្រៀបធៀបពីអារម្មណ៍នៃការអស់សង្ឃឹម
ដូចជានរណាម្នាក់ដែលត្រូវបានកាត់ទោសឲ្យស្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកយើងអស់សង្ឃឹមដូចនរណាម្នាក់ត្រូវបានកាត់ទោសឲ្យស្លាប់។
ផ្ទុយទៅវិញ យើងបានសេចក្តីជំនឿលើព្រះជាម្ចាស់
ពាក្យថា «ដាក់សេចក្តីជំនឿលើខ្លួនរបស់យើង» ត្រូវបានលុបចេញពីឃ្លានេះ។
ការបកប្រែរបៀបផ្សេងទៀត: «ផ្ទុយទៅវិញ ចូរដាក់សេចក្តីជំនឿលើព្រះអម្ចាស់»។
ដែលប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ
«ដែលប្រោសមនុស្សស្លាប់ឲ្យមានជីវិតឡើងវិញ»
សេចក្តីស្លាប់ដ៏គ្រោះថ្នាក់
សាវ័កប៉ូលបានប្រៀបធៀបពីអារម្មណ៍របស់គាត់
ដូចជាលទ្ធផលបញ្ហាដែលពួកគាត់មានបទពិសោធន៍ ពីសេចក្តីស្លាប់ដ៏គ្រោះថ្នាក់ ឬ
សេចក្តីគ្រោះថ្នាក់ដ៏កាចសាហាវ។ «ការអស់សង្ឃឹម»
2 Corinthians 1:11
ព្រះអង្គនឹងធ្វើការនេះដូចដែលបងប្អូនបានជួយពួកយើង
«ព្រះអម្ចាស់នឹងជួយសង្គ្រោះយើងដូចជាបងប្អូន
ដែលជាក្រុមជំនុំនៃទីក្រុងកូរិនថូស ដែលបានជួយពួកយើងដែរ»
ការសណ្តោសប្រណីអត់ទោសដល់យើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានផ្តល់ឲ្យយើង ការសណ្តោសប្រណីអត់ទោស»
2 Corinthians 1:12
យើងមានអំនួតដោយព្រោះ...មូលហេតុដែលមានអួតអាង
ពាក្យថា «អំនួត» និង «អួតអាង»
ត្រូវបានប្រើក្នុងន័យវិជ្ជមាននៃដែលមានអារម្មណ៍ពេញចិត្តយ៉ាងខ្លាំង
និងអំណរលើអ្វីមួយ។
សេចក្តីបន្ទាល់នៃមនសិការរបស់យើង
គំនិតរបស់សាវ័កប៉ូល និងលោកធីម៉ូថេ អំពីសកម្មភាពផ្ទាល់របស់ពួកគេ
សម្រាប់ជាទីបន្ទាល់ពីការប្រព្រឹត្តដើម្បីធ្វើឲ្យព្រះអង្គសព្វប្រទ័យ។
មិនមែនដោយពឹងអាងលើប្រាជ្ញាលោកីយ៍
ពាក្យថា «លោកីយ៍» សំដៅលើលក្ខណៈសង្គមមនុស្ស
ដែលមិនទុកចិត្តដល់ព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលមិនរួមជាមួយប្រាជ្ញារបស់មនុស្សឡើយ»។
យើងមិនបានសរសេរអ្វីផ្សេងផ្ញើមកបងប្អូន ដែលបងប្អូនអានមិនបាន ឬមិនយល់នោះទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់ស្រប។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនអាចអានបាន និងយល់អ្វីៗទាំងអស់ដែលយើងបានសរសេរមកបងប្អូន»
ក៏ជាហេតុដែលធ្វើឲ្យបងប្អូនមានអំនួតដូចគ្នាដែរ
បងប្អូនអាចប្រើពាក្យ «ហេតុផលរបស់យើង គឺជាអំនួត»។
ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនជាហេតុដែលយើងនឹងមានអំនួត»
2 Corinthians 1:15
ប្រយោគភ្ជាប់៖
សាវ័កប៉ូលពន្យល់ការរំពឹងទុកដោយឥតកំបាំងជាមួយចិត្តជំរុញដែលបរិសុទ្ធដើម្បីឃើញ[illegible]
បន្ទាប់ពីសំបុត្រទី១របស់គាត់។
ពត៌មានទូទៅ៖
សាវ័កប៉ូលបានសរសេរសំបុត្រ៣យ៉ាងតិចទៅកាន់អ្នកទីក្រុងកូរិនថូស។
តែមានតែពីរសំបុត្រប៉ុណ្ណោះ ដែលបានកត់ទុកក្នុងគម្ពីរ ទៅកាន់ទីក្រុងកូរិនថូស។
ដោយសារខ្ញុំមានទំនុកចិត្តអំពីការនេះ
ពាក្យថា «ការនេះ» សំដៅទៅលើពាក្យពេចន៍អំពីជនជាតិកូរិនថូស។
អ្នករាល់គ្នាបានទទួលអត្ថប្រយោជន៍ពីរដង
«អ្នកនឹងទទួលបានពីការសួរសុខទុកពីខ្ញុំពីរដង»
ជូនដំណើរខ្ញុំទៅស្រុកយូដា
«ជួយជូនដំណើរខ្ញុំទៅស្រុកយូដា»
2 Corinthians 1:17
តើខ្ញុំស្មាក់ស្មើរមែនទេ?
សាវ័កប៉ូលបានប្រើសំនួរនេះ
ដើម្បីបញ្ជាក់ពីភាពច្បាស់លាស់របស់គាត់ក្នុងការសម្រេចចិត្តទៅសួរសុខទុកអ្នករស់នៅទីក្រុងកូរិនថូស។
ចំលើយដែលបានគិតទុកសម្រាប់សំណួរនេះគឺថា ទេ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំគ្មានស្មាក់ស្មើរ» ឬ
«ខ្ញុំមានទំនុកចិត្តក្នុងការសម្រេចចិត្តរបស់ខ្ញុំ»
ឬមួយអ្វីដែលខ្ញុំសម្រេចចិត្តតាមរបៀបសាច់ឈាមរបស់មនុស្ស ....ក្នុងពេលតែមួយដូច្នេះ?
សាវ័កប៉ូលប្រើប្រាស់សំណួរនេះដើម្បីបញ្ជាក់ពីផែនការរបស់គាត់ដើម្បីសួរសុខទុកជនជាតិកូរិនថូសដោយ
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំមិនបានសម្រេចចិត្ត
តាមរបៀបសាច់ឈាមរបស់មនុស្ស .....ក្នុងពេលតែមួយដូច្នេះ?
ដូច្នេះហើយបានជាខ្ញុំនិយាយថា «បាទៗ» និង «ទេៗ» ក្នុងពេលតែមួយដូច្នេះ?
នោះមានន័យថា សាវ័កប៉ូលមិនបាននិយាយថា គាត់សួរសុខទុក ឬមិនសួរសុខទុក
ក្នុងពេលតែមួយដូច្នេះ? ហើយពាក្យថា «បាទ» និង «ទេ»
ត្រូវបាននិយាយដដែលដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះខ្ញុំនិយាយ «បាទ» ខ្ញុំច្បាស់ជាទៅ ហើយ «ទេ»
ខ្ញុំនឹងមិនទៅសួរសុខទុក្ខក្នុងពេលតែមួយ»
2 Corinthians 1:19
ដ្បិត ព្រះយេស៊ូគ្រិស្តគឺជាបុត្រានៃព្រះជាម្ចាស់ .....ព្រះអង្គមិនបានមានបន្ទូល «បាទ» ផង «ទេ»
ផងនោះទេ។ តែផ្ទុយទៅវិញព្រះអង្គមានតែ «បាទ» ប៉ុណ្ណោះ។
ព្រះយេស៊ូគ្រិស្តមានបន្ទូល «បាទ» សំដៅលើការសន្យារបស់ព្រះអង្គ
ដែលមានន័យថា ទ្រង់ធានាការនោះគឺជាការពិត។ ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិត» ព្រះយេស៊ូគ្រិស្តគឺជាបុត្រានៃព្រះជាម្ចាស់.....មិនបានមានបន្ទូល «បាទ»
ផង «ទេ» ផងនោះទេ សំដៅលើការសន្យារបស់ព្រះជាម្ចាស់។
តែផ្ទុយទៅវិញព្រះអង្គមានតែ «បាទ» ប៉ុណ្ណោះ។
បុត្រានៃព្រះជាម្ចាស់
នេះជាចំណងជើងដែលសំខាន់សម្រាប់ព្រះយេស៊ូដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ទ្រង់ជាមួយព្រះជាម្
គ្រប់ទាំងព្រះបន្ទូលសន្យារបស់ព្រះអង្គគឺមានតែ «បាទ» នៅក្នុងព្រះអង្គ។
មានន័យថាព្រះយេស៊ូធានារាល់ព្រះបន្ទូលសន្យា។ ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់ទាំងព្រះបន្ទូលសន្យារបស់ព្រះអម្ចាស់ត្រូវបានធានាក្នុងព្រះយេស៊ូគ្រិស្ត»
ដោយព្រោះព្រះអង្គយើងនិយាយថា «អាម៉ែន»
ពាក្យថា «ព្រះអង្គ» សំដៅលើ ព្រះយេស៊ូគ្រិស្ត។
2 Corinthians 1:21
ព្រះជាម្ចាស់ហើយដែលបានទទួលយកយើងជាមួយនឹងបងប្អូន
អាចមានន័យថា ១)
«ព្រះជាម្ចាស់ទទួលយកទំនាក់ទំនងរបស់យើងជាមួយគ្នាដោយសារតែយើងស្ថិតនៅក្នុងព្រះគ្រិស្ត»
ឬ ២) «ព្រះជាម្ចាស់ទទួលយកទាំងទំនាក់ទំនងជាមួយព្រះគ្រិស្តរបស់យើង
និងបងប្អូន»។
ព្រះអង្គបានចាក់ប្រេងតាំងយើង
អាចមានន័យថា ១)
«ទ្រង់ចាក់ប្រេងតាំងយើងដើម្បីចែកចាយពីដំណឹងល្អ» (UDB) ឬ២)«
ទ្រង់ចាក់ប្រេងតាំងយើងដើម្បីប្រែក្លាយជាប្រជារាស្ត្ររបស់ទ្រង់។»
ទ្រង់បានប្រថាប់ត្រារបស់ព្រះអង្គនៅលើយើង
មានន័យថា ព្រះអង្គធ្វើទីសំគាល់ដល់អ្នកជឿទាំងអស់ជាកម្មសិទ្ធរបស់ទ្រង់។
ការបកប្រែរបៀបផ្សេងទៀត: «ទ្រង់ធ្វើទីសំគាល់យើងជាកម្មសិទ្ធរបស់ទ្រង់»។
ប្រទានព្រះវិញ្ញាណឲ្យគង់នៅក្នុងដួងចិត្តរបស់យើង
ពាក្យថា «ដួងចិត្ត» សំដៅលើផ្នែកខាងក្នុងនៃមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:
[illegible]ព្រះវិញ្ញាណឲ្យគង់ក្នុងយើងម្នាក់ៗ»។
ព្រះវិញ្ញាណ.....ដើម្បីជាការធានានូវ
ព្រះវិញ្ញាណត្រូវបានថ្លែងថាព្រះបានបង់លះដើម្បីបានជីវិតអស់កល្បជានិច្ច។
2 Corinthians 1:23
ខ្ញុំសូមព្រះជាម្ចាស់ឲ្យធ្វើជាសាក្សីសម្រាប់ខ្ញុំ
ឃ្លា «ជាសាក្សី» សំដៅលើមនុស្សដែលនិយាយនូវអ្វីដែលគេបានឃើញ
ឬបានលឺដើម្បីដោះស្រាយបញ្ហា។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំសុំព្រះអង្គបង្ហាញអ្វីដែលខ្ញុំនិយាយគឺឲ្យបានត្រឹមត្រូវ»

generated on Wed Sep 10 16:16:32 2025

មកពីខ្ញុំយោកយល់ដល់បងប្អូន
«ដូច្នេះខ្ញុំនឹងមិនបង្ករបញ្ហាឲ្យអ្នករងទុក្ខទៀត»
ពួកយើងរួមគ្នាធ្វើជាមួយបងប្អូន ដើម្បីឲ្យបងប្អូនមានអំណរ
«ពួកយើងរួមគ្នាធ្វើជាមួយបងប្អូនដូច្នេះបងប្អូនមានអំណរ»
ឈរនៅក្នុងជំនឿរបស់បងប្អូន
ពាក្យថា «ឈរ» សំដៅលើអ្វីមួយដែលមិនផ្លាស់ប្រែ។ ការបកប្រែរបៀបផ្សេងទៀត:
«នៅតែរឹងមាំក្នុងជំនឿរបស់បងប្អូន»

---

2 [1]ដូច្នេះ ខ្ញុំបានសម្រេចចិត្តដោយខ្លួនឯងហើយថា ខ្ញុំនឹងមិនមកនៅក្នុងស្ថានភាពដែលពេញដោយការឈឺចាប់ម្តងទៀតនោះទេ។[2]ប្រសិនបើ ខ្ញុំធ្វើឲ្យអ្នកឈឺចាប់
តើអ្នកណាអាចលើកទឹកចិត្តខ្ញុំបាន ក្រៅពីពួកអ្នកឈឺចាប់ដោយសារខ្ញុំនោះ?
[3]ខ្ញុំបានសរសេរ ដូចអ្វីដែលខ្ញុំបានធ្វើ ដើម្បីនៅពេលដែលខ្ញុំមកឯអ្នករាល់គ្នា ខ្ញុំអាចនឹងមិនឈឺចាប់ ដោយសារអស់អ្នកដែលធ្វើឲ្យខ្ញុំមានអំណរនោះទេ។
ខ្ញុំមានជំនឿយ៉ាងមុតមាំចំពោះអ្នកទាំងអស់គ្នាថា អ្នករាល់គ្នាមានអំណរដូចអំណរដែលខ្ញុំមានដែរ។[4]ដ្បិត ខ្ញុំបានសរសេរមកអ្នករាល់គ្នាចេញពីទុក្ខលំបាក
និងសេចក្តីទុក្ខព្រួយនៅក្នុងចិត្ត ព្រមទាំងទឹកភ្នែកជាច្រើនផង។ ខ្ញុំមិនចង់ធ្វើឲ្យអ្នករាល់គ្នាឈឺចាប់នោះទេ ផ្ទុយទៅវិញ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងពីជម្រៅនៃក្តីស្រឡាញ់
ដែលខ្ញុំមានសម្រាប់បងប្អូន។
[5]ប្រសិនបើ នរណាម្នាក់ធ្វើឲ្យមានការឈឺចាប់ អ្នកនោះមិនគ្រាន់តែធ្វើឲ្យខ្ញុំឈឺចាប់នោះទេ គឺបងប្អូនទាំងអស់គ្នាមានការឈឺចាប់ដូចគ្នាដែរ
តែមិនត្រូវដាក់ទោសអ្នកទាំងនោះខ្លាំងពេកទេ។[6]ការដាក់អ្នកនោះគឺទុកឲ្យមនុស្សភាគច្រើនជាអ្នកដាក់ទោសគេវិញគឺគ្រប់គ្រាន់ហើយ។[7]ដូច្នេះ
ជំនួសឲ្យការដាក់ទោសអ្នកនោះ បងប្អូនគួរតែអត់ទោស ហើយលើកទឹកចិត្តគាត់វិញ។ ធ្វើដូច្នេះ ដើម្បីកុំឲ្យគាត់មានទុក្ខព្រួយខ្លាំងពេក។
[8]ដូច្នេះ ខ្ញុំលើកទឹកចិត្តឲ្យបងប្អូនបង្ហាញសេចក្តីស្រឡាញ់របស់បងប្អូនចំពោះគាត់នៅទីសាធារណៈ។[9]នេះគឺជាហេតុផលដែលខ្ញុំសរសេរមក ដូច្នេះ ខ្ញុំអាចនឹងល្បងលបងប្អូន
ហើយដឹងថាបងប្អូនស្តាប់បង្គាប់ខ្ញុំគ្រប់ការទាំងអស់។
[10]ប្រសិនបើ បងប្អូនអត់ទោសឲ្យអ្នកណាម្នាក់ ខ្ញុំក៏អត់ទោសឲ្យអ្នកនោះដូចគ្នាដែរ។ អ្វីដែលខ្ញុំបានអត់ទោស ប្រសិនបើខ្ញុំបានអត់ទោសរឿងអ្វីមួយ
គឺខ្ញុំបានអត់ទោសដោយយល់ដល់អ្នករាល់គ្នានៅក្នុងព្រះវត្តមានរបស់ព្រះគ្រិស្ត។[11]ដូច្នេះទើបសាតាំងមិនអាចបោកប្រាស់យើងបាន។ ដ្បិត
យើងយល់មិនដល់គម្រោងការរបស់វាឡើយ។
[12]ព្រះអម្ចាស់បានបើកទ្វារក្រុងចំហរឲ្យខ្ញុំ នៅពេលដែលខ្ញុំបានទៅទីក្រុងទ្រអាស ដើម្បីប្រកាស់ដំណឹងល្អអំពីព្រះគ្រិស្តនៅទីនោះ។[13]ទោះជាយ៉ាងនេះក៏ដោយ
នៅក្នុងចិត្តរបស់ខ្ញុំគ្មានសន្តិភាពទេ ព្រោះនៅទីនោះ ខ្ញុំរកលោកទីតុសជាបងប្អូនរបស់ខ្ញុំមិនឃើញទេ។ ដូច្នេះ ទើបខ្ញុំចាកចេញពីពួកគេ
ហើយត្រឡប់ទៅស្រុកម៉ាសេដូនវិញ។
[14]ប៉ុន្តែ សូមអរព្រះគុណដល់ព្រះជាម្ចាស់ ដែលតែងតែដឹកនាំយើងចូលក្នុងជ័យជម្នះរបស់ព្រះគ្រិស្តជានិច្ច។ តាមរយៈយើង
ព្រះអង្គបានសាយភាយក្លិនក្រអូបដែលនាំឲ្យស្គាល់ព្រះអង្គគ្រប់ទីកន្លែង។[15]ដ្បិត យើងជាក្លិនក្រអូបរបស់ព្រះគ្រិស្តចំពោះព្រះអង្គ ក្នុងចំណោមអ្នកដែលបានសង្គ្រោះ
និងអ្នកដែលកំពុងវិនាស។
[16]ចំពោះមនុស្សដែលកំពុងវិនាស វាជាក្លិននៃសេចក្តីស្លាប់ដែលនាំឲ្យស្លាប់។ ចំពោះអ្នកដែលបានសង្គ្រោះ វាជាក្លិននៃជីវិតដែលនាំឲ្យមានជីវិត។
តើអ្នកណាដែលស័ក្តិសមសម្រាប់ការទាំងនេះ?[17]ដ្បិតយើងមិនដូចជាក្រុមមនុស្សដែលលក់ព្រះបន្ទូលព្រះជាម្ចាស់ដើម្បីបានផលប្រយោជន៍នោះទេ។ ផ្ទុយទៅវិញ
យើងនិយាយលើកទឹកចិត្តចេញពីភាពបរិសុទ្ធនៅក្នុងព្រះគ្រិស្ត ដោយព្រះជាម្ចាស់បានចាត់យើងមក នៅចំពោះព្រះភក្ររបស់ព្រះជាម្ចាស់។

---

2 Corinthians 2:1
ប្រយោគភ្ជាប់:
ដោយសារតែក្តីស្រលាញ់យ៉ាងខ្លាំងរបស់លោកចំពោះពួកគេ
សាវ័កប៉ូលបានថ្លែងយ៉ាងច្បាស់ ការកែតម្រូវរបស់លោក ក្នុងសំបុត្រទី១ទៅពួកគេ
(ការកែតម្រូវដែលពួកគេទទួលពីអំពើបាបដែលអសីលធម៌)
ដែលធ្វើឲ្យលោកមានការឈឺចាប់ និងក្រុមជំនុំក្នុងទីក្រុងកូរិនថូសឈឺចាប់
និងមនុស្សអសីលធម៌។
ខ្ញុំបានសម្រេចចិត្តដោយខ្លួនឯង
«ខ្ញុំបានធ្វើការសម្រេចចិត្ត»
ក្នុងស្ថានភាពដែលពេញដោយការឈឺចាប់
«ក្នុងស្ថានភាពដែលអាចឲ្យអ្នកមានការឈឺចាប់»
ប្រសិនបើ ខ្ញុំធ្វើឲ្យអ្នកឈឺចាប់ តើអ្នកណាអាចលើកទឹកចិត្តខ្ញុំបាន
ក្រៅពីពួកអ្នកឈឺចាប់ដោយសារខ្ញុំនោះ?
សាវ័កប៉ូលបានប្រើនេះជាសំណួរវោហារស័ព្ទដើម្បីបញ្ជាក់ឲ្យច្បាស់ថា រូបលោក
និងពួកគេនឹងទទួលបានផលប្រយោជន៍តាមរយៈការអញ្ជើញទៅរបស់លោក
ដែលធ្វើឲ្យពួកគេមានការឈឺចាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើខ្ញុំធ្វើឲ្យអ្នកឈឺចាប់ អ្នកនោះហើយដែលជាអ្នកលើកទឹកចិត្តខ្ញុំ»
អ្នកដែលត្រូវបានខ្ញុំធ្វើឲ្យឈឺចាប់កាន់តែខ្លាំង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គឺជាអ្នកដែលខ្ញុំធ្វើឲ្យកាន់តែឈឺចាប់»
2 Corinthians 2:3
ខ្ញុំបានសរសេរ ដូចអ្វីដែលខ្ញុំបានធ្វើ
នេះសំដៅទៅសំបុត្រមួយទៀត
ដែលសាវ័កប៉ូលបានសរសេរគ្រីស្តបរិស័ទនៅក្នុងក្រុងកូរិនថូស
ដែលលែងមានតទៅទៀត។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំសរសេរនៅអ្វីដែលខ្ញុំបានធ្វើក្នុងសំបុត្រមុន»។
ខ្ញុំអាចនឹងមិនឈឺចាប់ ដោយសារអស់អ្នកដែលធ្វើឲ្យខ្ញុំមានអំណរនោះទេ
សាវ័កប៉ូលថ្លែងទៅអ្នកជឿក្នុងក្រុងកូរិនថូសដែលមានអាកប្បកិរិយាច្បាស់លាស់
ដែលធ្វើឲ្យមានមានអារម្មណ៍ឈឺចាប់។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលធ្វើឲ្យខ្ញុំមានអំណរ
នឹងមិនធ្វើឲ្យខ្ញុំឈឺចាប់ឡើយ»
អ្នករាល់គ្នាមានអំណរដូចអំណរដែលខ្ញុំមានដែរ
«អ្វីដែលធ្វើឲ្យខ្ញុំមានអំណរ និងធ្វើឲ្យអ្នកមានអំណរដែរ។»
ពីទុក្ខលំបាក
ពាក្យថា «ទុកលំបាក» សំដៅលើអារម្មណ៍ឈឺចាប់។
សេចក្តីទុក្ខព្រួយនៅក្នុងចិត្ត
ពាក្យថា «ក្នុងចិត្ត»សំដៅលើការមានអារម្មណ៍។ ការបកប្រែរបៀបផ្សេងទៀត:
«ជាមួយទុក្ខព្រួយយ៉ាងខ្លាំង»។
ព្រមទាំងទឹកភ្នែកជាច្រើន
«ជាមួយការយំស្រែកយ៉ាងខ្លាំង»
2 Corinthians 2:5
នោះមិនគ្រាន់តែធ្វើឲ្យខ្ញុំ
មានទំហំខ្លះៗ
មិនត្រូវដាក់ទោសអ្នកទាំងនោះខ្លាំងពេកទេ
អាចមានន័យថា ១) «ខ្ញុំមិនចង់និយាយវាធ្ងន់ធ្ងរពេកទេ» ឬ ២)
«ខ្ញុំមិនចង់និយាយបំផ្លើសទេ»។
ការដាក់អ្នកនោះគឺទុកឲ្យមនុស្សភាគច្រើនជាអ្នកដាក់ទោសគេវិញគឺគ្រប់គ្រាន់ហើយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ពាក្យ «ការដាក់ទោស»
គឺអាចបកប្រែដោយប្រើកិរិយាសព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«វិធីដែលមនុស្សភាគច្រើនជាអ្នកដាក់ទោសគេវិញគឺគ្រប់គ្រាន់ហើយ»
គឺគ្រប់គ្រាន់ហើយ
«សមគួរហើយ»
កុំឲ្យគាត់មានទុក្ខព្រួយខ្លាំងពេក
មានន័យថា ការឆ្លើយតបដោយអារម្មណ៍ខ្លាំងពីទុកព្រួយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ទុកព្រួយមិនមែនឈ្នះគាត់ទេ»
2 Corinthians 2:8
ប្រយោគភ្ជាប់៖

generated on Wed Sep 10 16:16:32 2025

សារ័កប៉ូលលើកទឹកចិត្តឲ្យក្រុមជំនុំនៃទីក្រុងកូរិនថូសបង្ហាញពីសេចក្តីស្រលាញ់
និងចេះអត់ទោសដល់មនុស្សមានទោស។ ហើយលោកបានសរសេរថា
រូបលោកក៏ត្រូវបានអត់ទោសដែរ។
បង្ហាញសេចក្តីស្រឡាញ់របស់បងប្អូនចំពោះគាត់នៅទីសាធារណៈ
មានន័យថា ពួកគេត្រូវបញ្ជាក់ពីសេចក្តីស្រលាញ់របស់ពួកគេចំពោះគាត់
ក្នុងវត្តមានរបស់អ្នកមានជំនឿ។
បងប្អូនស្តាប់បង្គាប់ខ្ញុំគ្រប់ការទាំងអស់
អាចមានន័យថា ១) «អ្នករាល់គ្នាបានស្តាប់បង្គាប់ព្រះជាម្ចាស់គ្រប់ការទាំងអស់» ឬ
អ្នកទាំងអស់គ្នាបានស្តាប់បង្គាប់គ្រប់ទាំងអ្វីដែលខ្ញុំបានបង្រៀន»
2 Corinthians 2:10
អត់ទោសដោយយល់ដល់អ្នករាល់គ្នា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំអត់ទោសដោយយល់ដល់អ្នក»
អត់ទោសដោយយល់ដល់អ្នករាល់គ្នា
អាចមានន័យថា ១)
«អត់ទោសដោយចេញពីសេចក្តីស្រលាញ់សម្រាប់អ្នក» (UBS) ឬ ២)
«អត់ទោសសម្រាប់ជាប្រយោជន៍របស់អ្នក។»
យើងយល់មិនដល់គម្រោងការរបស់វាឡើយ
សារ័កប៉ូលបានប្រើប្រាស់ន័យផ្ទុយដើម្បីសង្កត់ពីភាពផ្ទុយគ្នា។
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតយើងបានដឹងច្បាស់ពីគម្រោងផែនការនេះ»
2 Corinthians 2:12
ប្រយោគភ្ជាប់៖
សារ័កប៉ូល លើកទឹកចិត្តដល់អ្នកមានជំនឿក្នុងក្រុងកូរិនថូស
ដោយប្រាប់ពីឱកាសដែលគាត់អាចអធិប្បាយពីដំណឹងល្អ ក្នុងក្រុងទ្រអាស
និងស្រុកម៉ាសេដូន។
ព្រះអម្ចាស់បានបើកទ្វារក្រុងចំហរឲ្យខ្ញុំ.....ដើម្បីប្រកាសដំណឹងល្អ
សារ័កប៉ូលបាននិយាយពីឱកាសដែលគាត់អាចប្រកាសពីដំណឹងល្អតាមរយៈទ្វារក្រុងដែលត្រូវបានបើកចំហសម្រាប់គាត់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានបើកទ្វារក្រុងមកខ្ញុំ ....ដើម្បីប្រកាសដំណឹងល្អ»
ឬព្រះអម្ចាស់បានផ្តល់ឱកាសឲ្យខ្ញុំ....ដើម្បីប្រកាសដំណឹងល្អ»
ខ្ញុំគ្មានសន្តិភាពទេ
«ចិត្តរបស់ខ្ញុំមានបញ្ហា» ឬ «ខ្ញុំមានក្តីបារម្ភណ៍»
លោកទីតុសជាបងប្អូនរបស់ខ្ញុំ
សារ័កប៉ូលបានហៅលោកទីតុសជាបងប្អូនខាងវិញ្ញាណ។
ទើបខ្ញុំចាកចេញពីពួកគេ
«ដូច្នេះខ្ញុំចាកចេញពីប្រជាជនទីក្រុងទ្រអាស»
2 Corinthians 2:14
ព្រះជាម្ចាស់ ដែលតែងតែដឹកនាំយើងចូលក្នុងជ័យជម្នះ
សារ័កប៉ូលបានថ្លែងពីព្រះអម្ចាស់
គឺនៅពេលដែលលោកដឹកនាំក្បួនដង្ហែជ័យជំនះដោយទទួលបានជោគជ័យ
ហើយដោយរូបគាត់ផ្ទាល់
និងសហការីរបស់លោកដែលពួកគេបានចូលរួមក្បួនដង្ហែនោះ។ អាចមានន័យថា
១) «ព្រះជាម្ចាស់តែងតែធ្វើឲ្យយើងរាល់គ្នាអាចទទួលជ័យជម្នះរួមគ្នា» ឬ ២)
«ព្រះជាម្ចាស់តែងតែដឹកនាំយើងឲ្យទទួលបានជ័យជម្នះលើមនុស្សទាំងនោះដែលទទួលបានជ័យជម្នះ
តាមរយៈយើង ព្រះអង្គបានសាយភាយក្លិនក្រអូបដែលនាំឲ្យស្គាល់ព្រះអង្គគ្រប់ទីកន្លែង
សារ័កប៉ូលបានថ្លែងពីការស្គាល់ពីព្រះគ្រិស្ត ដូចជាគ្រឿងក្រអូបដែលមានក្លិនល្អ។
ការបកប្រែរបៀបផ្សេងទៀត: «គាត់បានបណ្តាលឲ្យការស្គាល់ពីព្រះអង្គ
បានចែកចាយដល់អ្នករាល់គ្នាបានស្តាប់លឺពីយើង
ដូចជាគ្រឿងក្រអូបដែលត្រូវបានដុតហើយសាយភាយដល់អ្នករាល់គ្នាដែលនៅជិតនោះ»
គ្រប់ទីកន្លែង
«គ្រប់ទីកន្លែងដែលយើងទៅ»
យើងជាក្លិនក្រអូបរបស់ព្រះគ្រិស្តចំពោះព្រះអង្គ
សារ័កប៉ូលថ្លែងពីព័ន្ធកិច្ចរបស់ល្អ ដូចជាដង្វាយដែលដុតថ្វាយសម្រាប់ព្រះអង្គ។
ក្លិនក្រអូបរបស់ព្រះគ្រិស្ត
អាចមានន័យថា ១) «ក្លិនក្រអូបដែលជាការបង្ហាញពីការស្គាល់ព្រះគ្រិស្ត» ឬ ២)
ព្រះគ្រិស្តបានប្រទានក្លិនក្រអូប។»
ក្នុងចំណោមអ្នកដែលបានសង្គ្រោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះគ្រិស្តបានសង្គ្រោះអ្នកទាំងនោះ»
2 Corinthians 2:16
វាជាក្លិន
«ការស្គាល់ព្រះគ្រីស្តគឺជាក្លិន»។ នេះសំដៅទៅ ជំពូក២៖១៤
ដែលសារ័កប៉ូលថ្លែងពីការស្គាល់ព្រះគ្រិស្ត
ដូចជាគ្រឿងក្រអូបដែលមានក្លិនឈ្ងុយ។
ក្លិននៃសេចក្តីស្លាប់ដែលនាំឲ្យស្លាប់
អាចមានន័យថា ១) ពាក្យថា «សេចក្តីស្លាប់»
ដែលត្រូវបានរំលឹកសារឡើងវិញដើម្បីបញ្ជាក់ឃ្លាដែលមាន
«ក្លិនដែលនាំឲ្យសេចក្តីស្លាប់» ឬ ២) ក្លិននៃសេចក្តីស្លាប់ដែលនាំឲ្យមនុស្សស្លាប់»
ចំពោះអ្នកដែលបានសង្គ្រោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលត្រូវបានព្រះសង្គ្រោះ»
ក្លិននៃជីវិតដែលនាំឲ្យមានជីវិត
ដែលត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ក្លិនដែលនាំឲ្យមានជីវិត
គឺត្រូវរំលឹកសារឡើងវិញដើម្បីបញ្ជាក់ឃ្លាដែលមានន័យថា «ក្លិនដែលនាំឲ្យជីវិត»
ឬ ២) ក្លិននៃជីវិត ដែលនាំឲ្យមនុស្សមានជីវិត»
តើអ្នកណាដែលស័ក្តិសមសម្រាប់ការទាំងនេះ?
សារ័កប៉ូលប្រើប្រាស់សំនួរនេះ
ដើម្បីបញ្ជាក់ថាគ្មាននរណាម្នាក់សាកសមបំរើព័ន្ធកិច្ចដែលព្រះបានត្រាស់ហៅពួកគេមកបំរើនោះទេ។
ការបកប្រែរបៀបផ្សេងទៀត: «គ្មាននរណាម្នាក់សាកសម្រាប់ការទាំងនេះ»
លើកទឹកចិត្តចេញពីភាពបរិសុទ្ធ
«លើកទឹកចិត្តដោយភាពបរិសុទ្ធ»
យើងនិយាយក្នុងព្រះគ្រិស្ត
«យើងនិយាយជាប្រជារាស្ត្រដែលចូលទៅព្រះគ្រិស្ត»
ឬ«យើងនិយាយដោយសិទ្ធអំណាចនៃព្រះគ្រិស្ត»
ដោយព្រះជាម្ចាស់បានចាត់យើងមក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ជាប្រជារាស្ត្រដែលទ្រង់ចាត់ឲ្យចេញទៅ»
នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់
សារ័កប៉ូល
និងសហការីរបស់លោកថ្លែងពីដំណឹងល្អដោយដឹងថាព្រះជាម្ចាស់កំពុងទតមើលពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «យើងថ្លែងពីព្រះវត្តមានរបស់ព្រះជាម្ចាស់»

---

3 [1]តើយើងចាប់ផ្តើមសរសើរតម្កើងខ្លួនយើងទៀតហើយឬ? យើងមិនត្រូវការយកលិខិតណែនាំខ្លួនបង្ហាញទៅអ្នក ឬយកពីអ្នកដូចមនុស្សមួយចំនួនទេ តើមែនទេ?
[2]បងប្អូនអើយ បងប្អូនរាល់គ្នាហើយជាលិខិតណែនាំខ្លួនរបស់យើង ដែលបានសរសេរនៅក្នុងដួងចិត្តយើង បានទទួលស្គាល់ និងបានអានដោយមនុស្សគ្រប់គ្នា។
[3]បងប្អូនបានបង្ហាញថា បងប្អូនគឺជាសំបុត្រលិខិតរបស់ព្រះគ្រិស្ត ដែលយើងបានរៀបចំ។ លិខិតនេះមិនបានសរសេរដោយទឹកខ្មៅនោះទេ
តែបានសរសេរឡើងដោយព្រះវិញ្ញាណដ៏រស់របស់ព្រះជាម្ចាស់វិញ។ លិខិតនោះមិនបានសរសេរនៅលើបន្ទះថ្មនោះទេ តែបានសរសេរឡើងនៅក្នុងដួងចិត្តនៃមនុស្សវិញ។
[4]នេះហើយជាទំនុកចិត្តដែលយើងមានតាមរយៈព្រះគ្រិស្តនៅចំពោះព្រះជាម្ចាស់។[5]យើងមិនមានសមត្ថភាពនៅក្នុងយើងដើម្បីប្រកាសអ្វីមួយ ដែលមកពីយើងនោះទេ។
ផ្ទុយទៅវិញ សមត្ថភាពគឺមកពីព្រះជាម្ចាស់។[6]គឺព្រះជាម្ចាស់ទេដែលធ្វើឲ្យយើងអាចក្លាយជាអ្នកបម្រើនៃសម្ពន្ធមេត្រីថ្មី។ សម្ពន្ធមេត្រីនេះមិនមែនគ្រាន់តែជាអក្សរទេ ប៉ុន្តែ
គឺជាព្រះវិញ្ញាណវិញ។ ដ្បិត អក្សរគឺជាការសម្លាប់ ចំណែកឯព្រះវិញ្ញាណវិញគឺប្រទានជីវិត។
[7]ឥឡូវនេះ ការបម្រើដែលនាំឲ្យស្លាប់ ដែលបានចារឹកទុកជាអក្សរថ្ម មានសិរីល្អដែលធ្វើឲ្យជនជាតិអ៊ីស្រាអែលមិនអាចមើលមុខលោកម៉ូសេដោយផ្ទាល់បាន។
នោះគឺដោយសារតែសិរីល្អនៃមុខរបស់លោកម៉ូសេ គឺជាសេចក្តីដែលកំពុងសាបសូន្យបាត់ទៅ។[8]តើមានសិរីរុងរឿងច្រើនប៉ុណ្ណាទៅនៃការបម្រើដែលព្រះវិញ្ញាណធ្វើ?
[9]ដ្បិត ប្រសិនបើ កិច្ចការបម្រើនៃការកាត់ទោសមានសិរីរុងរឿងប៉ុណ្ណឹងទៅហើយ ចុះបើកិច្ចការបម្រើខាងឯសេចក្តីសុចរិតនឹងមានសិរីរុងរឿងប៉ុណ្ណាទៅ![10]ពិតណាស់
សិរីរុងរឿងខាងឯសេចក្តីសុចរិតធ្វើឲ្យសិរីរុងរឿងខាងឯការកាត់ទោសលែងមានតម្លៃ ដោយសារតែសិរីរុងរឿងនេះប្រសើរជាងសិរីរុងរឿងនោះ។[11]ដ្បិត អ្វីដែលកន្លងផុតទៅ
មានសិរីល្អប៉ុណ្ណឹងទៅហើយ ចុះបើអ្វីដែលស្ថិតស្ថេរមានសិរីរុងរឿងប៉ុណ្ណាទៅ។

generated on Wed Sep 10 16:16:32 2025

[12]ចាប់តាំងពីពេលដែលយើងមានសង្ឃឹម យើងពិតជាក្លាហានណាស់។[13]យើងមិនដូចជាលោកម៉ូសេទេ ដែលពាក់ស្បៃនៅលើមុខរបស់គាត់ ដូច្នេះ
ជនជាតិអ៊ីស្រាអែលនឹងមិនអាចឃើញផ្នាល់ពីទីបញ្ចប់នៃសិរីរុងរឿងដែលនឹងសាបសូន្យនោះទេ។
[14]ប៉ុន្តែ គំនិតរបស់ពួកគេត្រូវបានបិទ។ សូម្បីតែរហូតដល់សព្វថ្ងៃនេះ ស្បៃនៅតែបាំងភ្នែកពួកគេដដែល ក្នុងការដែលគេអានគម្ពីរសម្ពន្ធមេត្រីចាស់។
វាមិនបានដោះចេញទេ ដោយសារតែព្រះគ្រិស្តទើបអាចដោះចេញបាន។[15]ទោះបីសព្វថ្ងៃនេះក៏ដោយ នៅពេលដែលនរណាអានក្រឹត្យវិន័យរបស់លោកម៉ូសេ
ស្បៃនោះនៅតែបាំងដួងចិត្តរបស់គេដដែល។[16]ប៉ុន្តែ នៅពេលដែលមនុស្សបែរទៅរកព្រះអម្ចាស់ ស្បៃនោះនឹងត្រូវដកចេញ។
[17]ឥឡូវនេះ ព្រះអម្ចាស់គឺជាព្រះវិញ្ញាណ។ កន្លែងណាដែលព្រះវិញ្ញាណនៃព្រះជាម្ចាស់គង់នៅ កន្លែងនោះនឹងមានសេរីភាព។[18]ឥឡូវនេះ ពួកយើង
យើញសិរីល្អរបស់ព្រះជាម្ចាស់ដោយ មិនបាំងមុខទេ។ យើងកំពុងតែផ្លាស់ប្រែទៅរកសិរីល្អមួយដែលដូចជាព្រះអម្ចាស់ ពីសិរីល្អមួយទៅសិរីល្អមួយ
ដែលព្រះអង្គជាព្រះវិញ្ញាណ។

---

2 Corinthians 3:1

ប្រយោគភ្ជាប់៖

សាវ័កប៉ូលរំលឹកពួកគេថាលោកមិនបានអួត
ដោយលោកប្រាប់ពួកគេថាអ្វីដែលលោកបានធ្វើតាមរយៈព្រះគ្រិស្ត។

តើយើងចាប់ផ្តើមសរសើរតម្កើងខ្លួនយើងទៀតហើយឬ?

សាវ័កប៉ូលសួរសំណួរនេះ ដើម្បីបញ្ជាក់ថាពួកគេមិនបានអួតពីពួកគេឡើយ។
ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនបានចាប់ផ្តើមសរសើរតម្កើងខ្លួនយើងឡើយ»

យើងមិនត្រូវការយកលិខិតណែនាំខ្លួនបង្ហាញទៅអ្នក ឬយកពីអ្នកដូចមនុស្សមួយចំនួនទេ

តើមែនទេ?

សាវ័កប៉ូលបានថ្លែងពីការដើម្បីបង្ហាញថាជនជាតិកូរិនថូសបានដឹងច្បាស់ពីកេរ្តិ៍ឈ្មោះរបស់គាត់ និងលោកធីម៉ូថេ។ សំណួរនេះបង្ហាញពីចំលើយផ្ទុយ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនត្រូវការលិខិតណែនាំខ្លួនបង្ហាញអ្នក
ឬយកពីអ្នកដូចមនុស្សមួយចំនួនទេ»

លិខិតណែនាំខ្លួន

លិខិតនេះដែលមនុស្សសរសេរដើម្បីណែនាំពី
ឬផ្តល់ការឯកភាពរបស់ពួកគេពីនរណាម្នាក់។

បងប្អូនអើយ បងប្អូនរាល់គ្នាហើយជាលិខិតណែនាំខ្លួនរបស់យើង

សាវ័កប៉ូលបានថ្លែងពីជនជាតិកូរិនថូស ព្រោះពួកគេជាលិខិតណែនាំខ្លួន។
ដែលពួកគាត់បានប្រែមកជាអ្នកមានជំនឿដែលឲ្យព័ន្ធកិច្ចរបស់លោកទៅកាន់អ្នកដទៃ ដូចជាលិខិតណែនាំ។
ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនអើយ បងប្អូនរាល់គ្នា
គឺដូចជាលិខិតណែនាំខ្លួនរបស់យើង»

ដែលបានសរសេរនៅក្នុងដួងចិត្តយើង

ពាក្យថា «ដួងចិត្ត» ទីនេះសំដៅលើគំនិត និងអារម្មណ៍។ អាចមានន័យថា ១) សាវ័កប៉ូល
និងសហការីរបស់លោកបានដឹងច្បាស់ពីជនជាតិកូរិនថូសដែលជាលិខិតណែនាំខ្លួនរបស់ពួកគេ
ឬ ២) សាវ័កប៉ូល
និងសហការីរបស់លោកយកចិត្តទុកដាំងសម្រាប់ជនជាតិកូរិនថូស។

ដែលបានសរសេរនៅក្នុងដួងចិត្តយើង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្មជាមួយ
«ព្រះគ្រិស្ត»ដែលដាក់ជាប្រធានបទ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះគ្រិស្តបានសរសេរនៅក្នុងដួងចិត្តយើង»

បានទទួលស្គាល់ និងបានអានដោយមនុស្សគ្រប់គ្នា

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សគ្រប់គ្នាអាចស្គាល់ និងអានបាន»

បងប្អូនគឺជាសំបុត្រលិខិតរបស់ព្រះគ្រិស្ត

សាវ័កប៉ូលបានបញ្ជាក់ថាព្រះគ្រិស្ត ដែលជាអ្នកសរសេរសំបុត្រនេះ។
ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនជាសំបុត្រដែលព្រះគ្រិស្តបានសរសេរ»

ដែលយើងបានរៀបចំ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបានរៀបចំ»

លិខិតនេះមិនបានសរសេរដោយទឹកខ្មៅនោះទេ.....ឡើងនៅក្នុងដួងចិត្តនៃមនុស្សវិញ

សាវ័កប៉ូលបានបញ្ជាក់ថាជនជាតិកូរិនថូសគឺជាលិខិតខាងវិញ្ញាណ
មិនមែនជាលិខិតដែលមនុស្សសរសេរដោយផ្នែកនៃរាងកាយឡើយ។

លិខិតនេះមិនបានសរសេរដោយទឹកខ្មៅនោះទេ
តែបានសរសេរឡើងដោយព្រះវិញ្ញាណដ៏រស់របស់ព្រះជាម្ចាស់វិញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«លិខិតនោះមិនមែនជាសំបុត្រដែលមនុស្សសរសេរដោយទឹកខ្មៅ
តែជាលិខិតដែលព្រះវិញ្ញាណដ៏រស់បានសរសេរ»

លិខិតនោះមិនបានសរសេរនៅលើបន្ទះថ្មនោះទេ តែបានសរសេរឡើងនៅក្នុងដួងចិត្តនៃមនុស្សវិញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«លិខិតនោះមិនបានសរសេរនៅលើបន្ទះថ្មនោះទេ
តែជាលិខិតដែលបានសរសេរឡើងនៅក្នុងដួងចិត្តនៃមនុស្សវិញ»

លិខិតនៃដួងចិត្តមនុស្ស

សាវ័កប៉ូលបានថ្លែងពីដួងចិត្តរបស់ពួកគេ ប្រៀបដូចជាបន្ទះថ្ម
ឬដីឥដ្ឋដែលរាបស្មើដែលមនុស្សត្រូវបានសរសេរចារលើលិខិត។

2 Corinthians 3:4

នេះហើយជាទំនុកចិត្ត

នេះសំដៅលើអ្វីដែលសាវ័កប៉ូលបានថ្លែងប្រាប់។
សាវ័កប៉ូលបានថ្លែងពីការដើម្បីបង្ហាញថាជនជាតិកូរិនថូសបានដឹងច្បាស់ពីកេរ្តិ៍ឈ្មោះរបស់គាត់ និងលោកធីម៉ូថេ។ សំណួរនេះបង្ហាញពីចំលើយផ្ទុយ។ ការបកប្រែរបៀបផ្សេងទៀត:

សមត្ថភាពនៅក្នុងយើង

«ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងយើង» ឬ «មានភាពគ្រប់គ្រាន់ក្នុងយើង»

ដើម្បីប្រកាសអ្វីមួយ ដែលមកពីយើង

ពាក្យថា «អ្វីមួយ» សំដៅលើអ្វីមួយដែលយោងទៅតាមការបំរើព័ន្ធកិច្ចនៃសាវ័ក។
ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីប្រកាសពីអ្វីមួយដែលយើងបម្រើព័ន្ធកិច្ចដែលចេញពីសមត្ថភាពរបស់យើងផ្ទាល់»

សមត្ថភាពគឺមកពីព្រះជាម្ចាស់

«ព្រះអង្គប្រទានឲ្យយើងមានភាពគ្រប់គ្រាន់របស់យើង»

ពាក្យថា «សំបុត្រ» មានន័យថាអក្សរនៃអក្ខក្រម
សំដៅទៅលើពាក្យដែលមនុស្សសរសេរចូល។
ដែលជាឃ្លាដែលយោងតាមច្បាប់គម្ពីរសញ្ញាចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«សម្ពន្ធមេត្រីមិនអាស្រ័យលើការបង្គាប់បញ្ជាដែលមនុស្សបានចែងទុកនោះទេ»
ប៉ុន្តែ គឺជាព្រះវិញ្ញាណវិញ
ព្រះវិញ្ញាណបរិសុទ្ធគឺព្រះដែលបង្កើតសម្ពន្ធមេត្រីព្រះជាម្ចាស់ជាមួយនឹងមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:
«ដោយព្រោះតែសម្ពន្ធមេត្រីដែលយោងតាមអ្វីដែលព្រះវិញ្ញាណបានបង្កើត»

អក្សរគឺជាការសម្លាប់

សាវ័កប៉ូលបានថ្លែងពីច្បាប់នៃសម្ពន្ធមេត្រីចាស់ ដូចជាមនុស្សដែលសម្លាប់គេ។
យោងតាមច្បាប់នោះ នឹងនាំឲ្យព្រះវិញ្ញាណស្លាប់។ ការបកប្រែរបៀបផ្សេងទៀត:
«ច្បាប់ដែលចែងហើយនាំឲ្យមានសម្លាប់»

2 Corinthians 3:7

ប្រយោគភ្ជាប់៖

សាវ័កប៉ូលប្រៀបធៀបពីការបាត់បង់សិរីល្អនៃសម្ពន្ធមេត្រីចាស់
ជាមួយនឹងភាពប្រសើរឡើង និងសេរីភាពនៃសម្ពន្ធមេត្រីថ្មី។
គាត់ប្រៀបធៀបរំនាំងនៃលោកម៉ូសេជាមួយនឹងសេចក្តីបើកបង្ហាញបច្ចុប្បន្ន។
សម័យកាលលោកម៉ូសេគឺជារូបភាពដែលមិនមានភាពច្បាស់លាស់នឹងអ្វីដែលត្រូវបានបើកបង្ហាញនាបច្ចុ

ឥឡូវនេះ ការបម្រើដែលនាំឲ្យស្លាប់.....មានសិរីល្អ

សាវ័កប៉ូលបានថ្លែងទោះបីជាច្បាប់នាំមកសេចក្តីស្លាប់ តែវានៅតែមានសិរីល្អ។

ការបម្រើដែលនាំឲ្យ

«ព័ន្ធកិច្ចនៃសេចក្តីស្លាប់»

សំដៅទៅលើច្បាប់គម្ពីរសញ្ញាចាស់ដែលព្រះអង្គបានប្រទានឲ្យលោកម៉ូសេ។
ការបកប្រែរបៀបផ្សេងទៀត:
«ព័ន្ធកិច្ចដែលនាំឲ្យស្លាប់ដោយព្រោះតែអាស្រ័យទៅលើច្បាប់»

ដែលបានចារឹកទុកជាអក្សរថ្ម

«ចារឹកទុកលើថ្មដោយការសរសេរ»។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះបានចារឹកនៅលើថ្មដោយការសរសេរ»

មានសិរីល្អ

generated on Wed Sep 10 16:16:32 2025

«ដែលមានសិរីល្អបរបូរណ៍»
នោះគឺដោយសារតែ
«ដោយព្រោះពួកគេមិនអាចមើល»
តើមានសិរីរុងរឿងច្រើនប៉ុណ្ណាទៅនៃការបម្រើដែលព្រះវិញ្ញាណធ្វើ?
សាវ័កប៉ូលសួរសំនួរនេះដើម្បីបញ្ជាក់ថា «ការបំរើខាងវិញ្ញាណ»
ដែលមានសិរីល្អច្រើនជាង «ការបំរើខាងបង្កើត» ដោយថាការបំរើនាំឲ្យមានជីវិត។
ការបកប្រែរបៀបផ្សេងទៀត: «ការបំរើខាងវិញ្ញាណ នឹងបានសិរីល្អច្រើនជាង»
ការបំរើខាងវិញ្ញាណ
«ការបំរើព័ន្ធកិច្ចខាងវិញ្ញាណ»។ សំដៅលើបញ្ញាតិថ្មី
ដែលសាវ័កប៉ូលជាអ្នកបំរើព័ន្ធកិច្ច។ ការបកប្រែរបៀបផ្សេងទៀត:
«ការបំរើព័ន្ធកិច្ចនាំឲ្យមានជីវិតដោយព្រោះតែពឹងលើខាងវិញ្ញាណ»
2 Corinthians 3:9
ការបម្រើដោយនៃការកាត់ទោស
«ជាការបម្រើព័ន្ធកិច្ចនៃការផ្តោលទោស» នេះសំដៅលើច្បាប់បញ្ញាតិចាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ការបម្រើព័ន្ធកិច្ចដែលផ្តោលទោសមនុស្សដោយព្រោះតែពឹងផ្អែកលើច្បាប់»
ចុះបើកិច្ចការបម្រើខាងឯសេចក្តីសុចរិតនឹងមានសិរីរុងរឿងប៉ុណ្ណាទៅ!
ពាក្យថា «ប៉ុណ្ណាទៅ» ជាការគូសបញ្ជាក់ថាឃ្លានេះគឺជាបង្ហាញ
មិនមែនជាសំណួរឡើយ។ ការបកប្រែរបៀបផ្សេងទៀត:
«នោះការបម្រើខាងសេចក្តីសុចរិត នឹងទទួលបានសិរីរុងរឿងច្រើនឡើង»។
ការបម្រើខាងឯសេចក្តីសុចរិតនឹងមានសិរីរុងរឿង
សាវ័កប៉ូលបានថ្លែងពី «ការបម្រើខាងឯសេចក្តីសុចរិត»
ដូចជាគោលបំណងមួយដែលបង្កើតបាន
ឬពហុគុណគោលបំណងផ្សេងជាច្រើនទៀត។ គាត់មានន័យថា
«ការបម្រើខាងឯសេចក្តីសុចរិត»
នឹងទទួលបានសិរីរុងរឿងច្រើនជាងដោយការប្រើច្បាប់
ដែលនឹងទទួលបានសិរីរុងរឿងផងដែរ។
ការបម្រើខាងឯសេចក្តីសុចរិត
«ការបម្រើខាងសេចក្តីសុចរិត» នេះសំដៅទៅលើបទបញ្ញាតិថ្មី
ដែលសាវ័កប៉ូលជាអ្នកបម្រើម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«ព័ន្ធកិច្ចដែលធ្វើឲ្យមនុស្សបានសុចរិតដោយព្រោះខាងវិញ្ញាណ»
អ្វីដែលធ្លាប់មានសិរីរុងរឿងពីដើម ទៅជាលែងមានសិរីរុងរឿង..... ដោយព្រោះសិរីរុងរឿងដែល
ប្រសើរជាងគឺនៅពេលនេះ
ក្នុងច្បាប់នៃគម្ពីរសញ្ញាចាស់
គឺលែងមានសិរីរុងរឿងប្រសិនបើប្រៀបធៀបជាមួយគម្ពីរសញ្ញាថ្មី
ដែលមានសិរីរុងរឿងច្រើនជាង។
អ្វីដែលធ្លាប់មានសិរីរុងរឿងពីដើម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ច្បាប់ដែលព្រះអម្ចាស់បានបង្កើតសិរីរុងរឿងពីដើមមក»
ក្នុងរបៀបនេះ
«នៅក្នុងវិធីនេះ»
អ្វីដែលកន្លងផុតទៅ
នេះសំដៅលើ «ការបម្រើដែលនាំឲ្យមានទោស» ដែលសាវ័កប៉ូលថ្លែង
ប្រៀបដូចជាការដែលអាចនឹងសាបសូន្យបាត់ទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលប្រែក្លាយជាគ្មានប្រយោជន៍»
2 Corinthians 3:12
ចាប់តាំងពីពេលដែលយើងមានសង្ឃឹម
នេះសំដៅលើអ្វីដែលសាវ័កប៉ូលបានថ្លែង។ សេចក្តីសង្ឃឹមរបស់លោក
ដោយដឹងថាបញ្ញាតិថ្មី នឹងនាំឲ្យមានសិរីរុងរឿងអស់កល្បជានិច្ច។
ទីបញ្ចប់នៃសិរីរុងរឿងដែលនឹងសាបសូន្យ
នេះសំដៅលើសិរីរុងរឿងដែលចាំងចែងលើផ្ទៃមុខលោកម៉ូសេ។
ការបកប្រែរបៀបផ្សេងទៀត: «សិរីរុងរឿងលើផ្ទៃមុខលោកម៉ូសេ
ដែលបានរលត់ចេញទៅទាំងស្រុង»
2 Corinthians 3:14
ប៉ុន្តែ គំនិតរបស់ពួកគេត្រូវបានបិទ
«ចិត្តរបស់ពួកគេរឹងរួស»។
ដែលសាវ័កប៉ូលបានថ្លែងពីចិត្តរបស់ជនជាតិអ៊ីស្រាអែលជាអ្វីដែលត្រូវបានបិទ
ឬធ្វើឲ្យរឹងរួស។
ការបង្ហាញនេះមានន័យថាពួកគេមិនអាចយល់នូវអ្វីដែលពួកគេបានឃើញ។
ការបកប្រែរបៀបផ្សេងទៀត: «ជនជាតិអ៊ីស្រាអែលមិនអាចយល់សព្វបាន
នៅអ្វីដែលពួកគេបានឃើញឡើយ»។
សូម្បីតែរហូតដល់សព្វថ្ងៃនេះ.....ទោះបីសព្វថ្ងៃនេះ
ឃ្លានេះសំដៅលើកាលដែលសាវ័កប៉ូលបានសរសេរសំបុត្រទៅអ្នកទីក្រុងកូរិនថូស។
ស្បៃនៅតែបាំងភ្នែកពួកគេដដែល ក្នុងការដែលគេអានគម្ពីរសម្ពន្ធមេត្រីចាស់
ដូចជាជនជាតិអ៊ីស្រាអែលដែលមិនអាចមើលឃើញពីសិរីរុងរឿងលើព្រះមុខលោកម៉ូសេ
ដោយព្រោះមុខរបស់គាត់ត្រូវបានគ្របបាំងដោយស្បៃ
ដែលជាស្បៃខាងវិញ្ញាណដែលការពារមនុស្សពីការយល់ដឹងនៅពេលដែលពួកគេអានគម្ពីរសម្ពន្ធមេត្រីចាស
ការអានគម្ពីរសម្ពន្ធមេត្រីចាស់
«នៅពេលដែលមាននរណាម្នាក់បានអានពីគម្ពីរសម្ពន្ធមេត្រីចាស់»
ឬនៅពេលដែលពួកគេបានលឺពីនរណាម្នាក់បានអានពីគម្ពីរសម្ពន្ធមេត្រីចាស់»។
វាមិនបានដោះចេញទេ ដោយសារតែព្រះគ្រិស្តទើបអាចដោះវាចេញបាន
ការប្រើ២ដងនៃពាក្យថា «វា» សំដៅទៅ «ស្បៃនៅតែបាំងភ្នែកពួកគេដដែល»។
ន័យម្យ៉ាងទៀត
នៅពេលដែលនរណាអានក្រឹត្យវិន័យរបស់លោកម៉ូសេ
ពាក្យថា «ម៉ូសេ» សំដៅលើច្បាប់ក្នុងគម្ពីរសញ្ញាចាស់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលនរណាម្នាក់បានអានក្រឹត្យវិន័យម៉ូសេ»
ស្បៃនោះនៅតែបាំងដួងចិត្តរបស់គេ
ពាក្យថា «ដួងចិត្ត» សំដៅលើចិត្ត និងគំនិត។ ស្បៃខាងវិញ្ញាណនឹងគ្របបាំងដួងចិត្ត
ដោយការពារពួកគេពីការយល់ដឹងពីគម្ពីរសម្ពន្ធមេត្រីចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ស្បៃដែលបាំងចិត្តរបស់គេ»
ស្បៃនោះនឹងត្រូវដកចេញ
មានន័យថា ពួកគេមានលទ្ធភាពក្នុងការយល់ដឹងបាន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានលើកស្បៃនោះចេញ»
2 Corinthians 3:17
ឥឡូវនេះ ពួកយើង
ពាក្យថា «ពួកយើង» សំដៅលើពួកអ្នកមានជំនឿ ទាំងសាវ័កប៉ូល
និងអ្នកទីក្រុងកូរិនថូស។
ឃើញសិរីល្អរបស់ព្រះជាម្ចាស់ ដោយមិនបាំងមុខទេ
មិនមែនតែជនជាតិអ៊ីស្រាអែល
ដែលមិនអាចឃើញពីសិរីល្អរបស់ព្រះដែលបានចែងចាំងលើផ្ទៃមុខលោកម៉ូសេ
ដោយព្រោះតែគាត់ត្រូវបានគ្របដោយស្បៃបាំងមុខ
តែគ្មានអ្វីមួយដែលអាចបិទបាំងពីអ្នកជឿពីការឃើញ
និងការយល់ដឹងពីសិរីល្អរបស់ព្រះជាម្ចាស់។
យើងកំពុងតែផ្លាស់ប្រែទៅរកសិរីល្អមួយដែលដូចជាព្រះអម្ចាស់
ព្រះវិញ្ញាណអាចផ្លាស់ប្តូរអ្នកជឿឲ្យមានសិរីល្អដូចព្រះអម្ចាស់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ផ្លាស់ប្តូរយើងទៅរកសិរីល្អមួយដែលដូចជាព្រះអម្ចាស់»
ពីសិរីល្អមួយទៅសិរីល្អមួយ
«ពីចំនួនសិរីល្អមួយ ទៅចំនួនសិរីល្អផ្សេងទៀត»។
មានន័យថាព្រះវិញ្ញាណបង្កើតសិរីល្អរបស់អ្នកជឿច្រើនឡើងជាលំដាប់។
ដ្បិតនេះមកពីព្រះអម្ចាស់
«ដ្បិតនេះដែលបានមកពីព្រះអម្ចាស់»

---

4 [1]ដូច្នេះ ដោយព្រោះតែយើងមានការងារនេះ ហើយយើងក៏បានទទួលនូវព្រះគុណផង នោះពួកយើងមិនដែលបាក់ទឹកចិត្តឡើយ។[2]ផ្ទុយទៅវិញ
យើងបានលះចោលផ្លូវដែលគួរឲ្យខ្មាស និងអំពើលាក់បាំងផ្សេងទៀត។ ពួកយើងមិនបានរស់នៅដោយល្បិចកល
ហើយយើងមិនភ្លេចក្នុងការហុចព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ ដោយបង្ហាញសេចក្តីពិត យើងបង្ហាញខ្លួនឯងទៅដល់មនសិការរបស់មនុស្សគ្រប់គ្នា
នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

[3]ប៉ុន្តែ ប្រសិនបើ ដំណឹងល្អរបស់ត្រូវបានបិទបាំងមែន គឺគ្របបាំងតែពួកអ្នកដែលនឹងត្រូវវិនាសវិញ។[4]នេះជាបញ្ហារបស់ពួកគេ
ព្រះនៃលោកីយ៍នេះបានធ្វើទៅជាមើលមិនឃើញ និងមានគំនិតមិនជឿផងដែរ។ ជាហេតុធ្វើឲ្យពួកគេមិនអាចឃើញពន្លឺនៃដំណឹងល្អ
និងសិរីរុងរឿងរបស់ព្រះគ្រិស្តដែលជារូបភាពនៃព្រះជាម្ចាស់បាន។
[5]ដ្បិត យើងមិនខំប្រកាសពីខ្លួនយើងនោះទេ ប៉ុន្តែ យើងប្រកាសពីព្រះគ្រិស្តយេស៊ូគឺជាព្រះអម្ចាស់វិញ ហើយពួកយើងគឺជាអ្នកបម្រើដល់បងប្អូន
ដោយយល់ដល់ព្រះយេស៊ូ។[6]ដ្បិត ព្រះជាម្ចាស់ព្រះអង្គមានបន្ទូលថា៖ «ពន្លឺនឹងភ្លឺចេញពីសេចក្តីងងឹត»។ ព្រះអង្គបានបំភ្លឺនៅក្នុងចិត្តរបស់យើង ដើ
ម្បីឲ្យពន្លឺរបស់ការចេះដឹងនៃសិរីល្អរបស់ព្រះជាម្ចាស់ នៅក្នុងវត្តមាននៃព្រះយេស៊ូគ្រិស្ត។
[7]ប៉ុន្តែ ពួកយើងមានសម្បត្តិ ដែលនៅក្នុងឆ្នាំងដី ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា ឫទ្ធានុភាពដ៏ធំគឺជារបស់ព្រះជាម្ចាស់ មិនមែនជារបស់យើងទេ។
[8]ពួកយើងត្រូវគេសង្កត់សង្កិនក្នុងគ្រប់ផ្លូវទាំងអស់ ប៉ុន្តែ យើងមិនបារម្ភអ្វីទេ។ យើងមានការទើសទាល់ ប៉ុន្តែ មិនការអស់សង្ឃឹមឡើយ។[9]ពួកយើងត្រូវបានគេបៀតបៀន
តែមិនត្រូវបានបោះបង់ចោលទេ។ យើងត្រូវដួលចុះ ប៉ុន្តែ មិនបានវិនាសនោះទេ។[10]ពួកយើងតែងតែនាំយកសេចក្តីស្លាប់របស់ព្រះយេស៊ូនៅជាមួយនឹងរូបកាយជានិច្ច
ដើម្បីឲ្យជីវិតរបស់ព្រះយេស៊ូបានស្តែងចេញនៅក្នុងរូបកាយរបស់យើងដែរ។
[11]ពួកយើងដែលរស់នៅ គឺតែងតែនាំការសុគតរបស់ព្រះយេស៊ូទៅជាមួយក្នុង នៅក្នុងរូបកាយយើង
ដូច្នេះជីវិតរបស់ព្រះយេស៊ូនឹងបានសម្តែងនៅក្នុងរូបកាយរបស់យើងដែរ។[12]ដូច្នេះ សេចក្តីស្លាប់គឺធ្វើការនៅក្នុងយើង ប៉ុន្តែ ជីវិតគឺបានធ្វើការបងប្អូនវិញដែរ។
[13]ប៉ុន្តែ ពួកយើងមានវិញ្ញាណនៃជំនឿដូចគ្នា ស្របតាមសេចក្តីដែលបានចែងទុកមកថា៖ «ខ្ញុំបានជឿ ដូច្នេះ ខ្ញុំក៏និយាយ»។ ពួកយើងក៏ជឿ ដូច្នេះ ពួកយើងក៏និយាយ។
[14]ពួកយើងដឹងថាព្រះអង្គដែលប្រោស ព្រះអម្ចាស់យេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញ ព្រះអង្គក៏នឹងប្រោសយើងឲ្យរស់ឡើងវិញរួមជាមួយព្រះយេស៊ូដែរ។
ហើយពួកយើងដឹងទៀតថា ព្រះជាម្ចាស់នឹងនាំពួកយើងជាមួយបងប្អូនទៅក្នុងព្រះវត្តមានរបស់ព្រះអង្គ។[15]គ្រប់យ៉ាងសម្រាប់ជាប្រយោជន៍ដល់បងប្អូន ដើម្បីឲ្យព្រះគុណ
បានចម្រើនឡើង ដល់មនុស្សជាច្រើន ការអរព្រះគុណក៏បានចម្រើនឡើងដល់សិរីល្អនៃព្រះជាម្ចាស់។
[16]ដូច្នេះ យើងមិនបាក់ទឹកចិត្តឡើយ។ ទោះបើយ៉ាងណាក្តី ខាងក្រៅរបស់យើង កំពុងតែខូចបង់ទៅ តែនៅខាងក្នុងយើងវិញគឺបានថ្មីឡើងរាល់ថ្ងៃជានិច្ច។[17]ដ្បិត សេចក្តីទុក្ខ
លំបាកបន្តិចបន្តួច គឺឲ្យយើងបានត្រៀមខ្លួន សម្រាប់ទុក្ខលំបាកយ៉ាងធ្ងន់ហួសដែលមិនអាចវាស់បាន ដ៏ឃ្លរអង្វែងជាមួយសិរីល្អផង។[18]ដ្បិត យើងមិនបានសម្លឹងរកមើល
សម្រាប់អ្វីដែលយើងមើលឃើញនោះទេ ប៉ុន្តែ គឺរបស់ដែលមើលមិនឃើញវិញ។ ដ្បិតអ្វីដែលយើងមើលឃើញគឺបានតែមួយគ្រាទេ
ប៉ុន្តែរបស់អ្វីដែលមើលមិនឃើញគឺស្ថិតនៅអស់កល្បជានិច្ចវិញ។

---

2 Corinthians 4:1

ប្រយោគភ្ជាប់៖

សាវ័កប៉ូលសរសេរពី

ភាពស្មោះត្រង់របស់លោកក្នុងព័ន្ធកិច្ចរបស់លោកដែលបានអធិប្បាយពីព្រះគ្រីស្ត
ដោយមិនលើកដង្គើងខ្លួនឯង។ លោកបង្ហាញពីការសុគត
និងការរស់នៅរបស់ព្រះយេស៊ូក្នុងរបៀបដែលទ្រង់រស់នៅដូច្នេះជីវិតដែលធ្វើការដល់អ្នក

យើងមានការងារនេះ

ពាក្យថា «យើង» សំដៅលើ សាវ័កប៉ូល និងសហការីរបស់លោក
តែមិនមែនអ្នកទីក្រុងកូរិនថូស។

ហើយយើងក៏បានទទួលនូវព្រះគុណផង

ឃ្លានេះបង្ហាញពីសាវ័កប៉ូល
និងសហការីរបស់លោក«ដែលបំរើការងារព័ន្ធកិច្ចនេះ»។
ដែលជាអំណោយទានដែលព្រះបានប្រទានឲ្យពួកគេតាមរយៈព្រះគុណ។
ការបកប្រែរបៀបផ្សេងទៀត: «ដោយព្រោះព្រះអង្គបានបង្ហាញពីព្រះគុណ»

យើងបានលះចោលផ្លូវដែលគួរឲ្យខ្មាស និងអំពើលាក់បាំងផ្សេងទៀត

មានន័យថាសាវ័កប៉ូល និងសហការីរបស់លោកបដិសេធរាល់អំពើលាក់បាំង
និងខ្មាសអៀននានា។
នោះមិនមានន័យថាពួកគាត់មិនបានធ្វើរឿងទាំងនេះពេលអតីតកាលឡើយ។

ផ្លូវដែលគួរឲ្យខ្មាស និងអំពើលាក់បាំង

ពាក្យថា «លាក់បាំង» ពិព័ណនាពីអំពើដែល «ដែលគួរឲ្យខ្មាស»។
ការបកប្រែរបៀបផ្សេងទៀត:
«ផ្លូវដែលគួរឲ្យខ្មាសដែលមនុស្សព្យាយាមលាក់បាំងពីពួកគេ»

រស់នៅដោយល្បិចកល

«រស់នៅដោយការបោកប្រាស់»

យើងមិនបានមិនភ្លេចក្នុងការហុចព្រះបន្ទូលរបស់ព្រះជាម្ចាស់

ឃ្លានេះប្រើគំនិតផ្ទុយពីរដង ដើម្បីបង្ហាញពីគំនិតស្របមួយ។
ការបកប្រែរបៀបផ្សេងទៀត: «យើងប្រើពាក្យរបស់ព្រះឲ្យបានត្រឹមត្រូវ»

យើងបង្ហាញខ្លួនឯងទៅដល់មនសិការរបស់មនុស្សគ្រប់គ្នា

មានន័យថាពួកគេផ្តល់ឲ្យសាក្ខីភាពគ្រប់គ្រាន់សម្រាប់មនុស្សម្នាក់ៗដែលបានលឺ
សម្រេចចិត្តថាតើពួកគេធ្វើបានត្រឹមត្រូវ ឬខុស។

នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់

នេះសំដៅលើព្រះវត្តមានរបស់ព្រះជាម្ចាស់។ ការស្គាល់
និងយល់ស្របនៃភាពត្រឹមត្រូវរបស់សាវ័ក
ប្រៀបដូចជាព្រះអង្គកំពុងទតមើលពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«នៅចំពោះព្រះភក្ត្រ» ឬជាសាក្សីភាពរបស់ព្រះ»

2 Corinthians 4:3

ដំណឹងល្អរបស់ត្រូវបានបិទបាំងមែន គឺគ្របបាំងតែពួកអ្នកដែលនឹងត្រូវវិនាសវិញ

នេះសំដៅទៅដំពូក៣:១៤ ដែលសាវ័កប៉ូលពន្យល់
ការគ្របបាំងនៃខាងវិញ្ញាណដែលការពារមនុស្សពីការយល់ដឹងនៅពេលពួកគេអានគម្ពីរសម្ពន្ធមេត្រីចាស់។
ក្នុងន័យដូចគ្នាថា មនុស្សទាំងនោះនឹងមិនអាចយល់ដឹងពីដំណឹងល្អឡើយ។

ដំណឹងល្អរបស់ត្រូវបានបិទបាំងមែន គឺគ្របបាំង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
ប្រសិនបើយើងរាល់គ្នាបាំងដំណឹងល្អរបស់យើង
នោះការគ្របបាំងនឹងគ្របបាំងហើយ»

ដំណឹងល្អរបស់យើង

«ដំណឹងល្អដែលយើងអធិប្បាយ»

ព្រះនៃលោកីយ៍នេះបានធ្វើទៅជាមើលមិនឃើញ និងមានគំនិតមិនជឿ

សាវ័កប៉ូលបានថ្លែងពីគំនិតរបស់ពួកគេ ដូចជាពួកគេមានភ្នែក
តែពួកគេមិនអាចយល់ដឹងបាន ដោយព្រោះចិត្តរបស់ពួកគេមិនអាចមើលឃើញ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះនៃលោកីយ៍រារាំងអ្នកមិនជឿពីការយល់ដឹង»

ព្រះនៃលោកីយ៍នេះ

«ព្រះដែលគ្រប់គ្រងលើលោកីយ៍នេះ»។ ឃ្លានេះសំដៅលើពួកសាតាំង។

ពួកគេមិនអាចឃើញពន្លឺនៃដំណឹងល្អ និងសិរីរុងរឿងរបស់ព្រះគ្រិស្ត

ជាតិសាសន៍អ៊ីស្រាអែលនឹងមិនអាចឃើញពីសិរីល្អនៃព្រះអម្ចាស់ដែលបានចែងចាំងលើផ្ទៃមុខលោកម៉ូសេ
(មើលជំពូក៣:១២)

អ្នកមិនជឿមិនអាចមើលឃើញសិរីល្អនៃព្រះគ្រិស្តដែលបានចែងចាំងក្នុងដំណឹងល្អ។

នេះមានន័យថាពួកគេមិនអាចយល់ដឹងពី «ដំណឹងល្អនៃសិរីល្អរបស់ព្រះគ្រិស្ត»

ពន្លឺនៃដំណឹងល្អ

«ពន្លឺដែលមកពីដំណឹងល្អ»

ដំណឹងល្អ និងសិរីរុងរឿងរបស់ព្រះគ្រិស្ត

«ដំណឹងល្អពីសិរីល្អរបស់ព្រះគ្រិស្ត»

2 Corinthians 4:5

ប៉ុន្តែ យើងប្រកាសពីព្រះគ្រិស្តយេស៊ូគឺជាព្រះអម្ចាស់វិញ ហើយពួកយើងគឺជាអ្នកបម្រើដល់បងប្អូន។

អ្នកបានដាក់កិរិយាសព្ទក្នុងឃ្លានេះ។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែយើងប្រកាសពីព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់
ហើយយើងប្រកាសខ្លួនយើងជាអ្នកបម្រើ»

ដោយយល់ដល់ព្រះយេស៊ូ

«ដោយសារតែព្រះយេស៊ូ»

ពន្លឺនឹងភ្លឺចេញពីសេចក្តីងងឹត

ក្នុងឃ្លានេះ សាវ័កប៉ូលសំដៅទៅព្រះបានបង្កើតពន្លឺ
ដែលបានសរសេរក្នុងគម្ពីរលោកុប្បត្តិ។

ព្រះអង្គបានបំភ្លឺ..... ដើម្បីឲ្យពន្លឺរបស់ការចេះដឹងនៃសិរីល្អរបស់ព្រះជាម្ចាស់

ពាក្យថា «ពន្លឺ» សំដៅលើសមត្ថភាពនៃការចេះដឹង។
ដូចជាពេលដែលព្រះបានបង្កើតពន្លឺ ហើយទ្រង់ក៏បង្កើតឲ្យអ្នកជឿចេះដឹងផងដែរ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត: « ព្រះបានបំភ្លឺ....
ធ្វើឲ្យយើងអាចចេះដឹងនៃសិរីល្អរបស់ព្រះ»
នៅក្នុងចិត្តរបស់យើង
ពាក្យថា «ចិត្ត» សំដៅលើសតិ និងគំនិត។ ការបកប្រែរបៀបផ្សេងទៀត:
«នៅក្នុងសតិរបស់យើង»
ពន្លឺរបស់ការចេះដឹងនៃសិរីល្អរបស់ព្រះជាម្ចាស់
«ពន្លឺដែលជាការចេះដឹងនៃសិរីល្អរបស់ព្រះជាម្ចាស់»
សិរីល្អរបស់ព្រះជាម្ចាស់ នៅក្នុងវត្តមាននៃព្រះយេស៊ូគ្រិស្ត
«សិរីល្អរបស់ព្រះជាម្ចាស់នៅក្នុងព្រះភក្ត្ររបស់ព្រះយេស៊ូគ្រិស្ត»។
ដូចជាសិរីល្អព្រះជាម្ចាស់ដែលបានភ្លឺលើផ្ទៃមុខរបស់លោកម៉ូសេ
(មើលក្នុងជំពូក៣៖៧)
មានន័យថានៅពេលសាវ័កប៉ូលអធិប្បាយពីដំណឹងល្អដែលមនុស្សអាចមើលឃើញនិងយល់បាន[illegible]
2 Corinthians 4:7
ប៉ុន្តែ ពួកយើងមាន
ពាក្យថា «យើង» សំដៅលើសាវ័កប៉ូល និងសហការីរបស់លោក
ប៉ុន្តែមិនមែនអ្នកនៅក្រុងកូរិនថូសទេ។
ពួកយើងមានសម្បត្តិ ដែលនៅក្នុងឆ្នាំងដី
សាវ័កថ្លែងពីដំណឹងល្អដែលប្រៀបដូចជាសម្បត្តិ
និងសាកសពរបស់ពួកគេប្រៀបដូចជាឆ្នាំងបែកបាក់ដែលធ្វើចេញពីដី។
ចង់បញ្ជាក់ឲ្យច្បាស់ថាពួកគេមានតម្លៃតូចបើប្រៀបធៀបជាមួយនឹងតម្លៃនៃដំណឹងល្អដែលពួកគេ[illegible]
ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា
«ដូច្នេះប្រជាជនបានដឹងច្បាស់» ឬ «ដូចនោះពួកគេបានដឹងយ៉ាងច្បាស់»
ពួកយើងត្រូវគេសង្កត់សង្កិនក្នុងគ្រប់ផ្លូវទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជាជនធ្វើការសង្កត់សង្កិនពួកយើងគ្រប់វិធីទាំងអស់»
ពួកយើងត្រូវបានគេបៀតបៀន តែមិនត្រូវបានបោះបង់ចោលទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបានបៀតបៀនយើង តែព្រះមិនបោះបង់យើងចោលទេ»
យើងត្រូវដួលចុះ ប៉ុន្តែ មិនបានវិនាសនោះទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សបានធ្វើឲ្យយើងដួលចុះ តែមិនបានធ្វើឲ្យយើងវិនាសទេ»
យើងត្រូវដួលចុះ
«ពួកយើងបានរងទុក្ខយ៉ាងវេទនា»
ពួកយើងតែងតែនាំយកសេចក្តីស្លាប់របស់ព្រះយេស៊ូនៅជាមួយនឹងរូបកាយជានិច្ច
សាវ័កប៉ូលបានថ្លែងពីការរងទុករបស់លោកប្រៀបដូចជាបទពិសោធន៍នៃការសុគតរបស់ព្រះយេស៊ូ។
ការបកប្រែរបៀបផ្សេងទៀត: «ពួកយើងតែងតែ
ស្ថិតនៅក្នុងការលំបាកនៃសេចក្តីស្លាប់ ដូចព្រះយេស៊ូសុគតដែរ» (UDB) ឬ
«យើងតែងតែរងទុកវេទនាក្នុងរបៀបដែលយើងមានបទពិសោធន៍នៃការសុគតរបស់ព្រះយេស៊ូ»
ជីវិតរបស់ព្រះយេស៊ូបានស្តែងចេញនៅក្នុងរូបកាយរបស់យើងដែរ
អាចមានន័យថា ១) «រូបកាយរបស់យើងនឹងរស់ឡើងវិញ
ដោយព្រោះតែព្រះយេស៊ូមានព្រះជន្មរស់» (UDB) ឬ ២)
«ជីវិតខាងវិញ្ញាណដែលព្រះយេស៊ូបានប្រទាន
នឹងបង្ហាញនៅក្នុងរូបកាយរបស់យើងផងដែរ»។
ជីវិតរបស់ព្រះយេស៊ូបានស្តែងចេញនៅក្នុងរូបកាយរបស់យើងដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សដទៃទៀតអាចឃើញជីវិតរបស់ព្រះយេស៊ូនៅក្នុងរូបកាយរបស់យើង»
2 Corinthians 4:11
ពួកយើងដែលរស់នៅ គឺតែងតែនាំការសុគតរបស់ព្រះយេស៊ូទៅជាមួយក្នុង នៅក្នុងរូបកាយយើង
នាំការសុគតរបស់ព្រះយេស៊ូ
បង្ហាញពីការស្ថិតនៅភាពគ្រោះថ្នាក់នៃការស្លាប់ដោយព្រោះតែមានភាពស្មោះត្រង់នឹងព្រះយេស៊ូ
ការបកប្រែរបៀបផ្សេងទៀត: «សម្រាប់ពួកយើងដែលមានជីវិត
ព្រះជាម្ចាស់តែងតែនាំយើងឲ្យប្រឈមនឹងសេចក្តីស្លាប់
ដោយព្រោះតែយើងត្រូវបានចូលរួមជាមួយព្រះយេស៊ូ»
ដូច្នេះជីវិតរបស់ព្រះយេស៊ូនឹងបានសម្តែងនៅក្នុងរូបកាយរបស់យើងដែរ
ព្រះជាម្ចាស់ចង់ឲ្យជីវិតរប់សព្រះយេស៊ូត្រូវបានបង្ហាញក្នុងជីវិតរបស់យើង។
អាចមានន័យថា ១) «រូបកាយរបស់យើងនឹងរស់សាជាថ្មី
ដោយព្រោះព្រះយេស៊ូមានព្រះជន្មរស់» (UDB) ឬ ២)
ជីវិតបែបខាងវិញ្ញាណដែលព្រះយេស៊ូបានប្រទានឲ្យអាចនឹងត្រូវបានបង្ហាញក្នុងជីវិតរបស់[illegible]
សូមមើលពីរបៀបអ្នកបានបកប្រែក្នុងឃ្លានៃជំពូក៤៖៧។
ដូច្នេះជីវិតរបស់ព្រះយេស៊ូនឹងបានសម្តែងនៅក្នុងរូបកាយរបស់យើងដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះមនុស្សដទៃអាចឃើញពីជីវិតរបស់ព្រះយេស៊ូក្នុងរូបកាយរបស់យើង»។
សូមមើលពីរបៀបអ្នកបានបកប្រែក្នុងឃ្លានៃជំពូក៤៖៧។
សេចក្តីស្លាប់គឺធ្វើការនៅក្នុងយើង ប៉ុន្តែ ជីវិតគឺបានធ្វើការបងប្អូនវិញដែរ
សាវ័កប៉ូលថ្លែងពីសេចក្តីស្លាប់ និងជីវិតប្រៀបដូចពួកគាត់ជាមនុស្សដែលធ្វើការ។
មានន័យថាពួកគេស្ថិតនៅស្ថានភាពគ្រោះថ្នាក់នៃសេចក្តីស្លាប់រូបកាយ
ដូច្នេះបានជាអ្នករស់នៅទីក្រុងកូរិនថូសមានជីវិតបែបខាងវិញ្ញាណ។
2 Corinthians 4:13
វិញ្ញាណនៃជំនឿដូចគ្នា
«ដែលមានឥរិយាបទនៃជំនឿដូចគ្នា» ពាក្យថា «វិញ្ញាណ» សំដៅលើឥរិយាបទ
[illegible]
ស្របតាមសេចក្តីដែលបានចែងទុកមកថា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូចជាពាក្យដែលគេបានសរសេរ»
ខ្ញុំបានជឿ ដូច្នេះ ខ្ញុំក៏និយាយ
នេះដកស្រង់ពីគម្ពីរទំនុបតម្កើង។
ព្រះអង្គដែលប្រោស ព្រះអម្ចាស់យេស៊ូ
ពាក្យថា «ព្រះអង្គ»សំដៅលើព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
[illegible]
ពីការសុគតឲ្យមានព្រះជន្មរស់ឡើងវិញ»
នាំពួកយើងជាមួយបងប្អូន
ពាក្យថា «ពួកយើង» មិនរាប់បញ្ចូល អ្នកនៅទីក្រុងកូរិនថូសឡើយ។
គ្រប់យ៉ាងសម្រាប់ជាប្រយោជន៍ដល់បងប្អូន
ពាក្យថា «គ្រប់យ៉ាង» សំដៅលើរាល់ទុកលំបាក
ដែលសាវ័កប៉ូលបានថ្លែងពីខគម្ពីរមុន។
ព្រះគុណ បានចម្រើនឡើង ដល់មនុស្សជាច្រើន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូចព្រះជាម្ចាស់នាំព្រះគុណទៅកាន់មនុស្សជាច្រើន»
ការអរព្រះគុណក៏បានចម្រើនឡើង
សាវ័កប៉ូលបានថ្លែងពីការអរព្រះគុណ
ប្រៀបបានដូចជាការដែលធ្វើឲ្យរីកចំរើនឡើងដោយខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សកាន់តែច្រើនឡើងនឹងអរព្រះគុណព្រះ»
2 Corinthians 4:16
សាវ័កប៉ូលបានសរសេរពីទុកលំបាករបស់អ្នករស់នៅក្រុងកូរិនថូស
ដែលមានបន្តិចបន្តួច ហើយមិនស្ថិតនៅយូរឡើយ
ប្រៀបជាមួយនឹងការដែលអស់កល្បដែលមើលមិនឃើញ។
ដូច្នេះ យើងមិនបាក់ទឹកចិត្តឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះយើងត្រូវតែមានជំនឿទុកចិត្ត»
ខាងក្រៅរបស់យើង កំពុងតែខូចបង់ទៅ
នេះសំដៅលើ រូបកាយខាងសាច់ឈាមរបស់គេនឹងពុកផុយ ហើយស្លាប់ទៅ។
ការបកប្រែរបៀបផ្សេងទៀត:
«រូបកាយខាងសាច់ឈាមរបស់យើងនឹងចុះខ្សោយទៅ ហើយនឹងស្លាប់ទៅ»
នៅខាងក្នុងយើងវិញគឺបានថ្មីឡើងរាល់ថ្ងៃជានិច្ច
នេះសំដៅលើ ជីវិតខាងវិញ្ញាណ និងផ្នែកខាងក្នុងដែលចេះតែរឹងមាំឡើង។
ការបកប្រែរបៀបផ្សេងទៀត: ជីវិតខាងវិញ្ញាណនឹងបានមាំមួនឡើងរាល់ថ្ងៃជានិច្ច»
នៅខាងក្នុងយើងវិញគឺបានថ្មីឡើងរាល់ថ្ងៃជានិច្ច
[illegible]
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់តែងតែធ្វើជីវិតរបស់យើងបានថ្មីឡើងរៀងរាល់ថ្ងៃ»
ដ្បិត សេចក្តីទុក្ខលំបាកបន្តិចបន្តួច គឺឲ្យយើងបានត្រៀមខ្លួន
សម្រាប់ទុក្ខលំបាកយ៉ាងធ្ងន់ហួសដែលមិនអាចវាស់បាន ដ៏ឃុវអង្វែងជាមួយសិរីល្អ។
សាវ័កប៉ូលថ្លែងពីទុកលំបាក និងសិរីល្អរបស់លោក ដែលព្រះបានប្រទានមកលោក
ប្រៀបដូចជាការនេះជាទុក្ខលំបាក។
តែសិរីល្អបានដកទុក្ខលំបាកចេញពីការរងទុកនោះ។
ដែលមិនអាចវាស់បាន
[illegible]
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ដែលគ្មាននរណាម្នាក់អាចវាស់បានឡើយ»
អ្វីដែលយើងមើលឃើញនោះទេ ប៉ុន្តែ គឺរបស់ដែលមើលមិនឃើញវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្វីដែលយើងអាចមើលឃើញបាន និងអ្វីដែលយើងមិនអាចមើលឃើញបាន»
របស់ដែលមើលមិនឃើញវិញ
អ្នកប្រើកិរិយាសព្ទក្នុងឃ្លានេះបាន។ ការបកប្រែរបៀបផ្សេងទៀត:
«តែពួកយើងកំពុងរកមើលរបស់ដែលមើលមិនឃើញ»

---

5 [1]ពួកយើងដឹងថា បើសិនជាទីលំនៅដែលយើងរស់នៅ របស់យើងនៅលើផែនដីនេះ កំពុងត្រូវខូចបង់ទៅ តែយើងនឹងបានអាគារមកពីព្រះជាម្ចាស់វិញ។
គឺជាផ្ទះដែលមិនបានធ្វើដោយដៃមនុស្ស ប៉ុន្តែគឺជាផ្ទះដ៏អស់កល្បជានិច្ចពីស្ថានសួគ៌។[2]ដ្បិត នៅក្នុងជម្រកនេះ យើងតែងតែថ្ងូរហើយរង់ចាំ
ដើម្បីឲ្យបានទៅនៅនិងផ្ទះដែលនៅស្ថានសួគ៌ដែរ។[3]យើងរង់ចាំសម្រាប់ការនេះ ពីព្រោះតាមរយៈក្តីរំពឹងនេះ យើងនឹងមិនខ្វះខាត់និងអាក្រាតឡើយ។
[4]ដ្បិត ក្នុងពេលដែលពួកយើងនៅក្នុងទីជម្រកនេះ គឺតែងតែតួញតែ្ពរ និងមានបន្ទុកយ៉ាងធ្ងន់ផង។ យើងមិនចង់ដោះរូបកាយនេះចេញឡើយ។ ផ្ទុយទៅវិញ
យើងចង់ឲ្យបានពាក់វិញ ដើម្បីឲ្យអ្វីដែលជាសេចក្តីស្លាប់ បានលេបបំបាត់តាមរយៈជីវិតនេះ។[3]អ្នកដែលបានរៀបចំយើងសម្រាប់ការនេះ គឺជាព្រះជាម្ចាស់ដែល
បានប្រទានដល់យើង ព្រះវិញ្ញាណ មកបញ្ចាំចិត្តទុកនូវអ្វីដែលនឹងកើតឡើង។
[6]ដូច្នេះ ចូលទុកចិត្តជាដរាបចុះ។ ដោយដឹងថាក្នុងពេលយើងនៅក្នុងផ្ទះនៃរូបកាយនេះ គឺយើងពិតជានៅឆ្ងាយពីព្រះអម្ចាស់ដែរ។[7]ដ្បិត យើងគឺដើរដោយជំនឿ
មិនមែនដោយការមើលឃើញនោះទេ។ ដូច្នេះ យើងមានទំនុកចិត្តជាខ្លាំង។[8]ពួកយើងគឺរួចរាល់ដើម្បីនឹងចាកចេញ ពីរូបកាយនេះហើយទៅផ្ទះថ្មីជាមួយព្រះអម្ចាស់។
[9]ដូច្នេះ យើងបានតាំងគោលដៅរបស់យើងហើយ ទោះបីជាយើងនៅក្នុងផ្ទះនេះឬនៅកន្លែងផ្សេងក៏យើងនៅតែ សរសើរព្រះអង្គជានិច្ច។[10]ដ្បិតយើងនឹងត្រូវទៅនៅមុខទី
ជំនុំជំរះនៃព្រះគ្រិស្ត ដើម្បីឲ្យគ្រប់គ្នាបានទទួលតាមការដែលបានធ្វើ នៅក្នុងរូបកាយរៀងខ្លួន ទោះល្អឬអាក្រក់ក្តី។
[11]ដូច្នេះ ដែលស្គាល់សេចក្តីស្ញែងខ្លាចនៃព្រះអម្ចាស់ យើងក៏ខំនាំមនុស្សឲ្យជឿដែរ។ ពួកយើងជាអ្នកដែលច្បាស់លាស់ដល់ព្រះជាម្ចាស់។ ខ្ញុំក៏សង្ឃឹមថា
វាក៏ស្របតាមមនសិកា របស់បងប្អូនដែរ។[12]ពួកយើងមិនព្យាយាមជំរុញបងប្អូនម្តងទៀត ក្នុងនាមយើងជាអ្នកមានបាបនោះទេ។ ផ្ទុយទៅវិញ
ពួកយើងនឹងផ្តល់នូវហេតុមួយ ដែលធ្វើឲ្យបងប្អូនមានទំនុកចិត្តលើយើងខ្ញុំវិញ ដូច្នេះ បងប្អូនអាចនិងមានចំលើយ សម្រាប់អស់អ្នកដែលមានអំនួត ពីចរិតខាងក្រៅ
តែមិនមែនអ្វីដែលនៅក្នុងចិត្តនោះទេ។
[13]ដ្បិត ប្រសិនបើយើងវង្វេងស្មារតីក៏ដោយ គឺសម្រាប់ព្រះជាម្ចាស់ ហើយបើទោះជាយើងមានស្មារតីល្អក្តី គឺសម្រាប់ជាប្រយោជន៍ដល់បងប្អូនវិញ។[14]ដ្បិត
សេចក្តីស្រឡាញ់នៃព្រះគ្រិស្ត បានពេញលេញនៅក្នុងយើង ដោយសារយើងបានពិចារណាឃើញថា គឺម្នាក់បានស្លាប់ជំនួសអ្នកទាំងអស់គ្នា ហើយទាំងអស់គ្នាឈ្មោះថា
បានស្លាប់ហើយដែរ។[15]ព្រះជាម្ចាស់បានសុគតជំនួសមនុស្សទាំងអស់ ដើម្បីឲ្យពួកអ្នកដែលបានរស់នៅ មិនគួររស់សំរាប់តែខ្លួនឯងទៀតទេ គឺរស់សម្រាប់ព្រះអង្គ ដែល
សុគតជំនួសពួកគេ ហើយបានរស់ឡើងវិញដែរ។
[16]ដោយហេតុផលនេះ គឺយើងមិនត្រូវវិនិច្ឆ័យ អ្នកណាតាមលក្ខណៈកំរិតមនុស្សឡើយ ទោះបីជាយើង ធ្លាប់ស្គាល់ព្រះគ្រិស្តក្នុងសណ្ឋានជាមនុស្សដែរក៏ដោយ។
អញ្ចឹងយើងវិនិច្ឆ័យនរណាតាមរបៀបនេះទៀតដែរ។[17]ដូច្នេះហើយ ប្រសិនបើ អ្នកណានៅក្នុងព្រះគ្រិស្ត គឺអ្នកនោះបានកើតជាថ្មីដែរ។ ការចាស់បានកន្លងផុតទៅ។ មើល
គ្រប់ការទាំងនោះបានត្រឡប់ទៅជាថ្មី។
[18]គ្រប់ការទាំងនេះគឺមកពីព្រះជាម្ចាស់។ ព្រះអង្គបានផ្សះផ្សាយើងជាមួយព្រះជាម្ចាស់តាមរយៈព្រះគ្រិស្ត ហើយព្រះអង្គក៏បានឲ្យសិទ្ធយើងក្នុងការធ្វើការនោះដែរ។
[19]គឺថាតាមរយៈក្នុងព្រះគ្រិស្ត ព្រះជាម្ចាស់បានផ្សះផ្សាលោកីយ៍នេះ ឲ្យត្រូវជាមួយព្រះអង្គដែរ ដោយមិនរាប់សេចក្តី ដែលលោកិយទាស់ប្រឆាំងពីមុនឡើយ។
ព្រះជាម្ចាស់ទុកព្រះទ័យនិងផ្តល់ព្រះបន្ទូលនៃការផ្សះផ្សាដល់យើងដែរ។
[20]ដូច្នេះ យើងបានតាំងឡើងជាអ្នកតំណាងនៃព្រះគ្រិស្ត ក៏ដូចជាព្រះជាម្ចាស់បានលេចមកនៅក្នុងយើងដែរ។ យើងសូមអង្វរជាមួយបងប្អូន ដើម្បីប្រយោជន៍នៃព្រះគ្រិស្ត:
«សូមឲ្យបានផ្សះផ្សាជាមួយព្រះជាម្ចាស់ចុះ!»[21]ព្រះជាម្ចាស់បានថ្វាយព្រះគ្រិស្ត ឲ្យក្លាយជាដង្វាយសម្រាប់បាបរបស់យើង។ ព្រះជាម្ចាស់បានធ្វើការនេះ
ដើម្បីឲ្យយើងបានក្លាយទៅជាសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ ក្នុងព្រះអង្គ។

---

2 Corinthians 5:1
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបានលើកឡើងពីភាពផ្ទុយគ្នារវាង រូបកាយលោកិយ៍
និងរូបកាយពីស្ថានសួគ៌ដែលព្រះបានប្រទានពរដល់អ្នកជឿ។
បើសិនជាទីលំនៅដែលយើងរស់នៅ របស់យើងនៅលើផែនដីនេះ កំពុងត្រូវខូចបង់ទៅ
តែយើងនឹងបានអាគារមកពីព្រះជាម្ចាស់វិញ
សាវ័កប៉ូលបានថ្លែងពីរូបកាយសាច់ឈាមរបស់លោក
ប្រៀបដូចជា«ការរស់នៅលើផែនដី» បណ្តោះអាសន្ន
ហើយរូបកាយដែលរស់ឡើងវិញដែលព្រះប្រទានប្រៀបដូចជា«អគារ»អចិន្ត្រៃយ៍
បើសិនជាទីលំនៅដែលយើងរស់នៅ របស់យើងនៅលើផែនដីនេះ កំពុងត្រូវខូចបង់ទៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើមនុស្សបំផ្លាញឲ្យខូចផែនដីនេះដែលយើងកំពុងរស់នៅ» ឬ
«ប្រិសិនបើ ើមនុស្សសម្លាប់រូបកាយរបស់យើង»
គឺជាផ្ទះដែលមិនបានធ្វើដោយដៃមនុស្ស
នេះសំដៅលើ «អាគារមកពីព្រះជាម្ចាស់» នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «នេះគឺផ្ទះដែលមនុស្សមិនអាចបង្កើតបានឡើយ»
នៅក្នុងជម្រកនេះ យើងតែងតែថ្ងូរ
ពាក្យថា «ជម្រក» សំដៅលើ «ការរស់នៅលើផែនដីដែលយើងរស់នៅ។» ពាក្យថា
ថ្ងូរ គឺជាសំលេងរបស់មនុស្សបញ្ចេញនៅពេលមានបំណងចង់បានអ្វីមួយល្អ។
រង់ចាំ ដើម្បីឲ្យបានទៅនៅនិងផ្ទះដែលនៅស្ថានសួគ៌
ឃ្លាថា «ផ្ទះដែលនៅស្ថានសួគ៌» សំដៅលើ«អាគារដែលបានមកពីព្រះជាម្ចាស់»។
សាវ័កប៉ូលបានថ្លែងពីរូបកាយដែលរស់ឡើងវិញ ប្រៀបដូចជាអាគារ
និងក្រណាត់ដែលមនុស្សអាចប្រាស្រ័យបាន។
តាមរយៈក្តីរំពឹងនេះ
«គឺដោយក្តីរំពឹងរស់នៅលើស្ថានសួគ៌របស់យើង»
យើងនឹងមិនខ្វះខាត់និងអាក្រាតឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងមិនអាក្រាតឡើយ» ឬ
«ព្រះជាម្ចាស់នឹងមិនស្វែងរកយើងដោយអាក្រាតកាយឡើយ»
2 Corinthians 5:4
ក្នុងពេលដែលពួកយើងនៅក្នុងទីជម្រកនេះ
សាវ័កប៉ូលថ្លែងពីរូបកាយសាច់ឈាមរបស់យើងប្រៀបដូចជា «ជម្រក»។
ក្នុងទីជម្រកនេះ គឺតែងតែតួញតែ្ពរ
ពាក្យថា «ជម្រក» សំដៅលើ «ការនៅលើផែនដី ដែលយើងកំពុងរស់នៅ»។
ពាក្យថាតួញតែ្ពរ
គឺជាសំលេងដែលមនុស្សបន្លឺសំលេងឡើងនៅពេលចង់បានអ្វីមួយដែលប្រសើរជាង។
សូមមើលការបកប្រែនេះក្នុងជំពូក ៥:១។
មានបន្ទុកយ៉ាងធ្ងន់
សាវ័កប៉ូលសំដៅលើទុក្ខលំបាកនៃរូបកាយសាច់ឈាមដែលមានបទពិសោធន៍ប្រៀបដូចជា
ការទាំងនោះជាបន្ទុកយ៉ាងធ្ងន់ដែលពិបាកទ្រាំបាន។
យើងមិនចង់ដោះរូបកាយនេះចេញឡើយ.....យើងចង់ឲ្យបានពាក់វិញ
សាវ័កប៉ូលថ្លែងពីរូបកាយប្រៀបដូចជាការស្លៀកពាក់។ ពាក្យថា
«ដោះរូបកាយនេះចេញ» សំដៅលើ ការស្លាប់នៃរូបកាយសាច់ឈាម ចំណែក
«ចង់ឲ្យបានពាក់វិញ»
សំដៅលើការមានរូបកាយនៃការរស់ឡើងវិញដែលព្រះបានប្រទានឲ្យ។
ដោះរូបកាយនេះចេញ
«រូបកាយដែលគ្មានសម្លៀកបំពាក់» ឬ «ដោយអាក្រាតកាយ»
ដើម្បីឲ្យអ្វីដែលជាសេចក្តីស្លាប់ បានលេបបំបាត់តាមរយៈជីវិតនេះ
សាវ័កប៉ូលថ្លែងពីជីវិតប្រៀបដូចជាសត្វដែលស៊ី «សាកសព»។
រូបកាយសាច់ឈាមនឹងស្លាប់បាត់ដោយជំនួសដោយរូបកាយនៃការរស់ឡើងវិញដែលអាចរស់នៅអស់កល

generated on Wed Sep 10 16:16:32 2025

ដើម្បីឲ្យអ្វីដែលជាសេចក្តីស្លាប់ បានលេបបំបាត់តាមរយៈជីវិតនេះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះជីវិតនេះលេបតែអ្វីដែលជាសេចក្តីស្លាប់»
ដែលបានប្រទានដល់យើង ព្រះវិញ្ញាណ មកបញ្ចាំចិត្តទុកនូវអ្វីដែលនឹងកើតឡើង
ព្រះវិញ្ញាណត្រូវបានថ្លែងប្រៀបដូចជាប្រាក់លោះសម្រាប់ជីវិតអស់កល្ប។
សូមមើលការបកប្រែដូចគ្នាក្នុងជំពូក១៖២១។
2 Corinthians 5:6
ប្រយោគភ្ជាប់៖
ដោយព្រោះអ្នកជឿមានរូបកាយថ្មី ហើយមានព្រះវិញ្ញាណដ៏វិសុទ្ធជារបស់បញ្ចាំចិត្ត
សាវ័កប៉ូលបានរំលឹកដល់ពួកគេឲ្យរស់នៅដោយមានជំនឿ
ដែលពួកគេអាចឲ្យព្រះគាប់ព្រះហឫទ័យ។
លោកបានបន្តដោយរំលឹកពួកគេឲ្យចេះនាំអ្នកដទៃដោយព្រោះ ១)
អ្នកជឿបង្ហាញខ្លួននៅចំពោះបល្ល័ង្ករបស់ព្រះគ្រិស្ត ហើយនឹង ២)
ដោយព្រោះសេចក្តីស្រលាញ់នៃព្រះគ្រិស្តដែលទ្រង់បានសុគតដើម្បីអ្នកមានជំនឿផងដែរ
ក្នុងពេលយើងនៅក្នុងផ្ទះនៃរូបកាយនេះ
សាវ័កប៉ូលថ្លែងពីរូបកាយសាច់ឈាមប្រៀបដូចជាទីកន្លែងដែលមនុស្សរស់នៅ។
ការបកប្រែរបៀបផ្សេងទៀត:
«ក្នុងពេលដែលយើងរស់នៅក្នុងរូបកាយលោកិយ៍នេះ»
យើងពិតជានៅឆ្ងាយពីព្រះអម្ចាស់
«យើងមិនបាននៅផ្ទះជាមួយព្រះអម្ចាស់ទេ» ឬ
«យើងមិនបាននៅស្ថានសួគ៌ជាមួយព្រះអម្ចាស់»
យើងគឺដើរដោយជំនឿ មិនមែនដោយការមើលឃើញនោះទេ
«យើងរស់នៅដោយសារជំនឿ មិនមែនដោយសារអ្វីដែលយើងមើលឃើញទេ»
ពួកយើងគឺរួចរាល់ដើម្បីនឹងចាកចេញ ពីរូបកាយនេះ
ពាក្យថា «រូបកាយ» សំដៅលើរូបកាយខាងសាច់ឈាម។
ទៅផ្ទះថ្មីជាមួយព្រះអម្ចាស់
«ទៅផ្ទះជាមួយព្រះអម្ចាស់នៅឯស្ថានសួគ៌»
2 Corinthians 5:9
ទោះបីជាយើងនៅក្នុងផ្ទះនេះឬនៅកន្លែងផ្សេង
ពាក្យថា «ព្រះអម្ចាស់» អាចប្រើក្នុងខគម្ពីរមុន។ ការបកប្រែរបៀបផ្សេងទៀត:
«ទោះបីយើងនៅក្នុងផ្ទះជាមួយព្រះអម្ចាស់ ឬនៅកន្លែងផ្សេងពីព្រះអម្ចាស់»
សរសើរព្រះអង្គជានិច្ច
«សរសើរព្រះអម្ចាស់ជានិច្ច»
នៅមុខទីជំនុំជំរះនៃព្រះគ្រិស្ត
«នៅមុខព្រះគ្រិស្តដើម្បីជំនុំជំរះ»
គ្រប់គ្នាបានទទួល
«គ្រប់គ្នាបានទទួលនៅអ្វីដែលសមនឹងទទួល»
តាមការដែលបានធ្វើ នៅក្នុងរូបកាយរៀងខ្លួន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ការដែលទ្រង់បានធ្វើនៅក្នុងរូបកាយសាច់ឈាម»
ទោះល្អឬអាក្រក់ក្តី
«ទោះការទាំងនោះល្អឬអាក្រក់ក្តី»
2 Corinthians 5:11
ស្គាល់សេចក្តីស្ញែងខ្លាចនៃព្រះអម្ចាស់
«ស្គាល់ពីអ្វីដែលមានន័យចំពោះសេចក្តីស្ញែងខ្លាចនៃព្រះអម្ចាស់»
យើងក៏ខំនាំមនុស្ស
អាចមានន័យថា ១) «យើងខំនាំមនុស្សដោយសេចក្តីពិតនៃដំណឹងល្អ» ឬ ២)
«យើងខំនាំមនុស្សព្រោះតែយើងជាក្រុមសាវ័កពេញសិទ្ធ»។
ពួកយើងជាអ្នកដែលច្បាស់លាស់ដល់ព្រះជាម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ដឹងយើងច្បាស់ថាជាមនុស្សប្រភេទណា»
វាក៏ស្របតាមមនសិកា របស់បងប្អូនដែរ
«ដែលបងប្អូនបានជឿលើការនោះ»
ដូច្នេះ បងប្អូនអាចនិងមានចំលើយ
«ដូច្នេះបងប្អូនប្រហែលមានអ្វីមកនិយាយ»
សម្រាប់អស់អ្នកដែលមានអំនួត ពីចរិតខាងក្រៅ តែមិនមែនអ្វីដែលនៅក្នុងចិត្តនោះទេ
ពាក្យថា «ចរិតខាងក្រៅ» សំដៅទៅ
ការបង្ហាញពីខាងក្រៅខ្លួនឯងពីអ្វីៗដូចជាសមត្ថភាព និងលក្ខណៈរបស់ខ្លួន។
ពាក្យថា «ក្នុងចិត្ត» សំដៅទៅ អត្តចរិតខាងក្នុងរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត:
«អស់អ្នកដែលមានអំនួតពីចរិតខាងក្រៅ....តែមិនមែនដែលមនុស្សមានពីខាងក្នុង»
2 Corinthians 5:13
ប្រសិនបើយើងវង្វេងស្មារតីក៏ដោយ ..... ហើយបើទោះជាយើងមានស្មារតីល្អក្តី
សាវ័កប៉ូលបានថ្លែងពីផ្លូវដែលមនុស្សគិតពីលោក និងសហការីរបស់លោក។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើមនុស្សគិតថាយើងឆ្កួត.....ទោះបីមនុស្សគិតថាយើងមិនឆ្កួតក៏ដោយ»
សេចក្តីស្រឡាញ់នៃព្រះគ្រិស្ត
អាចមានន័យថា ១) «សេចក្តីស្រលាញ់របស់យើងសម្រាប់ព្រះគ្រិស្ត» (UDB) ២)
«សេចក្តីស្រលាញ់របស់ព្រះគ្រិស្តសម្រាប់យើង។»
ស្លាប់ជំនួសអ្នកទាំងអស់គ្នា
«ស្លាប់ជំនួសមនុស្សទាំងអស់គ្នា»
ព្រះអង្គ ដែលសុគតជំនួសពួកគេ ហើយបានរស់ឡើងវិញដែរ
ពាក្យថា «ព្រះអង្គ» សំដៅលើព្រះគ្រីស្ត។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះគ្រីស្ត បានសុគត
ហើយជាអ្នកដែលព្រះជាម្ចាស់បានឲ្យរស់ឡើងវិញ»
2 Corinthians 5:16
ប្រយោគភ្ជាប់៖
ដោយព្រោះតែសេចក្តីស្រលាញ់ និងការសុគតរបស់ព្រះគ្រិស្ត
យើងត្រូវបានជំនុំជំនះបែបមនុស្សឡើយ។
យើងត្រូវបានចាត់តាំងឲ្យបង្រៀនដល់អ្នកដទៃ
របៀបរួបរួមគ្នាដោយសន្តិភាពជាមួយនិងព្រះជាម្ចាស់តាមរយៈការសុគតរបស់ព្រះគ្រិស្ត
ហើយទទួលបានសេចក្តីសុចរិតរបស់ព្រះតាមរយៈព្រះគ្រិស្ត។
ដោយហេតុផលនេះ
នេះសំដៅលើអ្វីដែលសាវ័កប៉ូលបានថ្លែងពីការរស់នៅដើម្បីព្រះគ្រិស្តជំនួសឲ្យការរស់នៅដោយខ្លួនឯង»។
អ្នកនោះបានកើតជាថ្មី
សាវ័កប៉ូលបានថ្លែងពីអ្នកដែលជឿលើព្រះគ្រិស្ត
ប្រៀបដូចជាព្រះបានបង្កើតសាជាថ្មី។ ការបកប្រែរបៀបផ្សេងទៀត:
«គេជាមនុស្សថ្មី»
ការចាស់បានកន្លងផុតទៅ
ពាក្យថា «ការចាស់»
សំដៅលើការដែលមនុស្សមានអត្តចរិតមុនពេលដែលពួកគេជឿលើព្រះគ្រិស្ត។
មើល
ពាក្យថា «មើល» រំលឹកយើងឲ្យយកចិត្តទុកដាក់លើការដែលកើតឡើងភ្លាមៗនោះ។
2 Corinthians 5:18
គ្រប់ការទាំងនេះ
«ព្រះជាម្ចាស់បានធ្វើគ្រប់ការទាំងនេះ»។
នេះសំដៅលើអ្វីដែលសាវ័កប៉ូលបានថ្លែងការពីខគម្ពីរមុនអំពីគ្រប់ការចាស់ត្រូវបានជំនួសដោយគ្រប់ការថ្មី
ព័ន្ធកិច្ចនៃការផ្សះផ្សា
នេះអាចបកប្រែបានជាមួយជាមួយឃ្លាកិរិយាសព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ព័ន្ធកិច្ចនៃការផ្សះផ្សាមនុស្សជាមួយទ្រង់»
គឺថា
«នេះមានន័យថា»
ក្នុងព្រះគ្រិស្ត ព្រះជាម្ចាស់បានផ្សះផ្សាលោកីយ៍នេះ ឲ្យត្រូវជាមួយព្រះអង្គដែរ
ពាក្យថា «លោកិយ៍» សំដៅលើមនុស្សនៅលើពិភពលោក។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះជាម្ចាស់កំពុងផ្សះផ្សាមនុស្សជាមួយទ្រង់
ក្នុងព្រះគ្រិស្ត»
ព្រះជាម្ចាស់ទុកព្រះទ័យនិងផ្តល់ព្រះបន្ទូលនៃការផ្សះផ្សាដល់យើងដែរ
ព្រះជាម្ចាស់បានប្រទានឲ្យសាវ័កប៉ូលការទទួលខុសត្រូវដើម្បីចែកចាយព្រះបន្ទូលដែលព្រះជាម្ចាស់កំពុងផ
ព្រះបន្ទូលនៃការផ្សះផ្សា
«ព្រះបន្ទូលអំពីការផ្សះផ្សា»
2 Corinthians 5:20
យើងបានតាំងឡើងជាអ្នកតំណាងនៃព្រះគ្រិស្ត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានតាំងឡើងពួកយើងជាអ្នកតំណាងនៃព្រះគ្រិស្ត»
អ្នកតំណាងនៃព្រះគ្រិស្ត
«អស់អ្នកដែលថ្លែងពីព្រះគ្រិស្ត»
សូមឲ្យបានផ្សះផ្សាជាមួយព្រះជាម្ចាស់ចុះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«សូមទុកឲ្យព្រះជាម្ចាស់ផ្សះផ្សាអ្នកជាមួយនឹងទ្រង់»
ព្រះជាម្ចាស់បានថ្វាយព្រះគ្រិស្ត ឲ្យក្លាយជាដង្វាយសម្រាប់បាបរបស់យើង
«ព្រះជាម្ចាស់បានធ្វើឲ្យព្រះគ្រិស្តជាដង្វាយសម្រាប់អំពើបាបរបស់យើង»
សម្រាប់បាបរបស់យើងព្រះជាម្ចាស់បានធ្វើការនេះ ដើម្បីឲ្យយើងបានក្លាយទៅជា
ពាក្យថា «របស់យើង» និង «យើង» គឺតែមួយ ដោយសំដៅលើអ្នកជឿទាំងអស់។
ព្រះជាម្ចាស់បានធ្វើការនេះ ដើម្បីឲ្យយើងបានក្លាយទៅជាសេចក្តីសុចរិតរបស់ព្រះជាម្ចាស់
ក្នុងព្រះអង្គ

«ព្រះជាម្ចាស់បានធ្វើការនេះ.....ជាសេចក្តីសុចរិតនៃព្រះជាម្ចាស់ក្នុងព្រះគ្រិស្ត»
ដើម្បីឲ្យយើងបានក្លាយទៅជាសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ ក្នុងព្រះអង្គ
ឃ្លាថា «សេចក្តីសុចរិតរបស់ព្រះជាម្ចាស់»
សំដៅលើសេចក្តីសុចរិតដែលព្រះទាមទារ ហើយដោយចេញមកពីព្រះ។
ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីឲ្យយើងបានសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ក្នុងយើងតាមរយៈព្រះគ្រិស្ត»

---

6 [1]ធ្វើការជាមួយព្រះអង្គ យើងក៏សូមប្រាប់បងប្អូនកុំឲ្យទទួលព្រះគុណរបស់ព្រះជាម្ចាស់ ដោយគ្មានន័យឡើយ។[2]ដ្បិត ព្រះជាម្ចាស់មានបន្ទូលថា៖
«ក្នុងពេលដែលអំណោយផល នោះយើងបានស្តាប់អ្នករាល់គ្នា ហើយនៅក្នុងថ្ងៃនៃក្តីសង្គ្រោះគឺយើងជួយអ្នក»។ មើល៍
ឥឡូវនេះពេលវេលាអំណោយផងនោះបានមកដល់ហើយ។ ហើយពេលនេះ ក៏ជាថ្ងៃនៃការសង្គ្រោះដែរ។[3]យើងមិនបានដាក់ភាពភ័យខ្លាចបាំងពីមុខរបស់អ្នករាល់គ្នាឡើយ
ដ្បិត យើងមិនបានប្រាថ្នាឲ្យការងាររបស់យើង ត្រូវខូចឈ្មោះឡើយ។
[4]ផ្ទុយទៅវិញ យើងបង្ហាញខ្លួនយើង ថាជាអ្នកបម្រើរបស់ព្រះជាម្ចាស់តាមរយៈទង្វើរបស់យើង។ យើងជាអ្នកបម្រើក្នុងការទាំងនេះ គឺក្នុងការទ្រាំទ្រ ការឈឺចាប់ ទុក្ខព្រួយ
និងទុក្ខលំបាក[5]ការត្រូវគេវាយ ការគេដាក់គុក ការវឹកវរ ការធ្វើការហួសកម្លាំង មិនបានដេកនៅពេលយប់ ខ្វះអាហារ[6]ដោយចិត្តស្អាត ដោយចេះដឹង ដោយអត់ធ្មត់ ដោយ
សប្បុរស ដោយព្រះវិញ្ញាណបរិសុទ្ធ ដោយសេចក្តីស្រឡាញ់ស្មោះត្រង់។[7]យើងគឺជាអ្នកបម្រើព្រះបន្ទូលនៃសេចក្តីពិតរបស់ព្រះអង្គ នៅក្នុងព្រះចេស្តានៃព្រះជាម្ចាស់។
យើងពាក់គ្រឿងសឹកនៃសេចក្តីសុចរិត កាន់នៅដៃទាំងស្តាំទាំងឆ្វេងរបស់យើងផង។
[8]យើងធ្វើការ ទាំងការឲ្យតម្លៃក្តី និងមិនឲ្យតម្លៃក្តី ទាំងការបន្ទោសក្តី និងការសរសើរក្តី។ យើងត្រូវបានការចោទប្រកាន់ថាជាមនុស្សបោកប្រាស់ផងដែរ ប៉ុន្តែ
យើងនៅតែប្រកាន់ជាប់ភាពស្មោះត្រង់ជានិច្ច។[9]យើងធ្វើការដូចជាគ្មានការទទួលស្គាល់ ប៉ុន្តែ យើងនៅតែមានការទទួលស្គាល់ដដែល។ យើងធ្វើការជាកំពុងស្លាប់
ហើយមើល៍ យើងនៅតែរស់ដដែល។ យើងធ្វើការដូចជាអ្នកជាប់ជំនុំជម្រះសម្រាប់ទង្វើរបស់យើង ប៉ុន្តែ មិនដូចជាប់ជំនុំជម្រះដល់ស្លាប់ឡើយ។
[10]យើងធ្វើការជាមួយនិងការឈឺចាប់ ប៉ុន្តែ យើងតែងតែរីករាយវិញ។ យើងធ្វើការដូចអ្នកក្រ ប៉ុន្តែយើងបានធ្វើឲ្យមនុស្សជាច្រើនទៅជាអ្នកមានដែរ។
យើងធ្វើការដូចជាមិនបានកម្រៃ ប៉ុន្តែ យើងមានគ្រប់របស់ទាំងអស់ដែរ។
[11]យើងបានថ្លែងពីសេចក្តីពិតទាំងស្រុងទៅកាន់បងប្អូន អ្នកនៅទីក្រុងកូរិនថូស ហើយដួងចិត្តរបស់បានបើក ជាមួយនឹងទុក្ខសោកផង។[12]ដួងចិត្តអ្នកមិនបានចង្អៀតចង្អល់
ជាមួយយើងឡើយ ប៉ុន្តែ ការនោះកើតឡើងដោយអារម្មណ៍បងប្អូនវិញ។[13]ឥឡូវនេះ ដើម្បីមានភាពស្មើភាព ហើយងាយទទួលនោះ គឺខ្ញុំនិយាយទៅកាន់បងប្អូន
ដូចជាកូនរបស់ខ្ញុំដែរ ចូរបើកចិត្តចំហឲ្យទូលាយចុះ។
[14]សូមកុំទឹមនឹមស្រែកជាមួយពួកអ្នកមិនជឿឡើយ។ ដ្បិត តើសេចក្តីសុចរិត និងការទទឹងច្បាប់ អាចចូលគ្នាបានទេ? ដូច្នេះ តើអាចចូលគ្នាបានទេរវាង ពន្លឺ
និងសេចក្តីងងឹតនោះ?[15]តើមានការព្រមព្រៀងគ្នារវាង អារក្សបេលាល និងព្រះគ្រិស្តទេ? ឬតើអ្នកជឿមានចំណែកជាមួយអ្នកមិនជឿបានទេ?[16]តើព្រះវិហារនៃព្រះជាម្ចាស់
និងវិហាររបស់ព្រះក្លែងក្លាយអាចចុះចូលជាមួយគ្នាបានទេ? ដ្បិត យើងទាំងអស់គ្នាគឺជាព្រះវិហាររបស់ព្រះដែលមានព្រះជន្មគង់នៅ ដូចព្រះអង្គមានបន្ទូលថា៖
«យើងនឹងគង់ ហើយយាងនៅក្នុងចំណោមពួកគេ។ យើងនឹងធ្វើជាព្រះជាម្ចាស់របស់គេ ហើយពួកគេនឹងធ្វើជាប្រជារាស្ត្ររបស់យើងដែរ»។
[17]ដូច្នេះ «ចូលចេញពីពួកអ្នកមិនជឿ ហើយញែកដោយឡែក» នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ «សូមកុំប៉ះរបស់មិនស្អាត នោះយើងនឹងស្វាគមន៍អ្នក។
[18]យើងគឺជាព្រះបិតាដល់អ្នក ហើយអ្នកនឹងក្លាយជាកូនប្រុសស្រីរបស់យើង» នេះគឺជាបន្ទូលរបស់ព្រះអម្ចាស់ដ៏មានព្រះចេស្តា។

---

2 Corinthians 6:1
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបានសង្ខេបពីរបៀបនៃការធ្វើការងារជាមួយគ្នាសម្រាប់ព្រះជាម្ចាស់ដែលត្រូវបានបង្ហាញ
ព័ត៌មានទូទៅ:
ក្នុងខ២ សាវ័កប៉ូលបានដកស្រង់ចំណុចពីព្យាការីអេសាយ។
ធ្វើការជាមួយ
សាវ័កប៉ូលបានបញ្ជាក់ថា រូបលោក និងលោកធីម៉ូថេគឺធ្វើការជាមួយព្រះអង្គ។
ការបកប្រែរបៀបផ្សេងទៀត: «ធ្វើការជាមួយនឹងព្រះជាម្ចាស់»
យើងក៏សូមប្រាប់បងប្អូនកុំឲ្យទទួលព្រះគុណរបស់ព្រះជាម្ចាស់ ដោយគ្មានន័យឡើយ
សាវ័កប៉ូលបានសន្យាជាមួយនឹងពួកគេថានឹងឲ្យព្រះគុណដែលមានន័យសម្រាប់ជីវិតរបស់អ្នកស្តាប់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់ស្រប។ ការបកប្រែរបៀបផ្សេងទៀត:
«យើងក៏សូមបងប្អូនប្រើប្រាស់ព្រះគុណដែលបានទទួលពីព្រះជាម្ចាស់»
ដ្បិត ព្រះជាម្ចាស់មានបន្ទូលថា
«ដ្បិតព្រះអង្គមានបន្ទូលថា»។
នេះជាការណែនាំពីការដកស្រង់ចេញពីព្យាការីអេសាយ។
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតព្រះជាម្ចាស់បានថ្លែងក្នុងខព្រះគម្ពីរ»
មើល៍
ពាក្យថា «មើល៍» ចង់រំលឹកយើងឲ្យយកចិត្តទុកដាក់
ព័ត៌មានដែលអាចនឹងកើតឡើងភ្លាមៗ។
យើងមិនបានដាក់ភាពភ័យខ្លាចបាំងពីមុខរបស់អ្នករាល់គ្នាឡើយ
សាវ័កប៉ូលបានថ្លែងពី ការអ្វីមួយដែលរារាំងឲ្យមនុស្សពីការទុកចិត្តព្រះគ្រិស្ត
ប្រៀបដូចជាផ្នែកមួយខាងសាច់ឈាមដែលមនុស្សបរាជ័យ និងដួលចុះ។
ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនចង់ធ្វើអ្វីមួយដែលរារាំងមនុស្សពីការជឿលើព្រះបន្ទូលរបស់យើង»
យើងមិនបានប្រាថ្នាឲ្យការងាររបស់យើង ត្រូវខូចឈ្មោះឡើយ
ពាក្យថា «ខូចឈ្មោះ»
សំដៅលើប្រជាជនដែលនិយាយអាក្រក់ពីការងាររបស់សាវ័កប៉ូល។

2 Corinthians 6:3
ព័ត៌មានទូទៅ:
នៅពេលសាវ័កប៉ូលប្រើប្រាស់ពាក្យថា «យើង» នៅនេះ លោកសំដៅលើខ្លួនគាត់
និងលោកធីម៉ូថេ
យើងបង្ហាញខ្លួនយើង ថាជាអ្នកបម្រើរបស់ព្រះជាម្ចាស់តាមរយៈទង្វើរបស់យើង
«យើងបង្ហាញថាយើងជាអ្នកបម្រើរបស់ព្រះជាម្ចាស់
តាមរយៈគ្រប់ការដែលយើងបានធ្វើ»
ការបម្រើក្នុងការទាំងនេះ គឺក្នុងការទ្រាំទ្រ ការឈឺចាប់ ទុក្ខព្រួយ និងទុក្ខលំបាក
5ការត្រូវគេវាយ ការគេដាក់គុក ការវឹកវរ ការធ្វើការហួសកម្លាំង មិនបានដេកនៅពេលយប់
ខ្វះអាហារ
សាវ័កប៉ូលបានលើកឡើងពីស្ថានភាពលំបាកផ្សេងៗគ្នានៅពេលដែលពួកគេបង្ហាញថាពួកគេជាអ្នកបម្រើរ
ដោយចិត្តស្អាត ដោយចេះដឹង ដោយអត់ធ្មត់ ដោយសប្បុរស ដោយព្រះវិញ្ញាណបរិសុទ្ធ ដោយ
សេចក្តីស្រឡាញ់ស្មោះត្រង់
សាវ័កប៉ូលចុះបញ្ជីតម្លៃសីលធម៌ដែលពួកគេបានប្រកាន់ភ្ជាប់ក្នុងស្ថានភាពលំបាកដែលបង្ហាញថាពួកគេជ
យើងគឺជាអ្នកបម្រើព្រះបន្ទូលនៃសេចក្តីពិតរបស់ព្រះអង្គ នៅក្នុងព្រះចេស្តានៃព្រះជាម្ចាស់
ការលះបង់របស់ពួកគេដើម្បីអធិប្បាយពីដំណឹងល្អនៅក្នុងព្រះចេស្តានៃព្រះជាម្ចាស់ដែលបង្ហាញថាពួកគេជ
ព្រះបន្ទូលនៃសេចក្តីពិត
«នៅក្នុងការអធិប្បាយពីពាក្យពេជន៍ដែលពិតនៃព្រះជាម្ចាស់»
យើងពាក់គ្រឿងសឹកនៃសេចក្តីសុចរិត កាន់នៅដៃទាំងស្តាំទាំងឆ្វេងរបស់យើងផង
សាវ័កប៉ូលថ្លែងពីសេចក្តីសុចរិតប្រៀបបានដូចជាអាវុធដែលពួកគេប្រើប្រាស់ដើម្បីប្រយុទ្ធក្នុងសមរភូមិខាង
គ្រឿងសឹកនៃសេចក្តីសុចរិត
សេចក្តីសុចរិតជាគ្រឿងសឹករបស់យើង» ឬ
«សេចក្តីសុចរិតប្រៀបដូចជាអាវុធរបស់យើង»
កាន់នៅដៃទាំងស្តាំទាំងឆ្វេង
អត្ថន័យដូចជា ១) មានអាវុធក្នុងដៃម្ខាង និងមានខែលក្នុងដៃម្ខាងទៀត ឬ២)

generated on Wed Sep 10 16:16:32 2025

ពួកគេត្រូវបានបំពាក់ពេញលេញសម្រាប់សមរភូមិដើម្បីការងារខ្លួនឯងពីការវាយប្រហារ

2 Corinthians 6:8

ព័ត៌មានទូទៅ:

សាវ័កប៉ូលបានធ្វើតារាងពីការជាច្រើនដែលមនុស្សគិតពីលោក
និងការងារបម្រើរបស់លោក។

យើងត្រូវបានការចោទប្រកាន់ថាជាមនុស្សបោកប្រាស់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សចោទប្រកាន់ថាពួកយើងជាមនុស្សបោកប្រាស់»

ដូចជាគ្មានការទទួលស្គាល់ ប៉ុន្តែ យើងនៅតែមានការទទួលស្គាល់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បៀបដូចជាមនុស្សមិនបានទទួលស្គាល់ពីពួកយើង
ប៉ុន្តែក៏មានមនុស្សនៅតែស្គាល់យើងច្បាស់ដែរ»

យើងធ្វើការដូចជាអ្នកជាប់ជំនុំជម្រះសម្រាប់ទង្វើរបស់យើង ប៉ុន្តែ
មិនដូចជាប់ជំនុំជម្រះដល់ស្លាប់ឡើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកយើងធ្វើការប្រៀបដូចជាមនុស្សកំពុងដាក់ទោសយើងពីសកម្មភាព
ប៉ុន្តែមិនមែនមានន័យថាពួកគេបានជំនុំជម្រះយើងរហូតដល់ស្លាប់ឡើយ»

2 Corinthians 6:11

ប្រយោគភ្ជាប់៖

សាវ័កប៉ូលបានលើកទឹកចិត្តអ្នកជឿក្នុងទីក្រុងកូរិនថូសឲ្យរស់នៅដាច់ដោយឡែកពីព្រះ
ហើយរស់នៅដោយជីវិតបរិសុទ្ធសម្រាប់ព្រះជាម្ចាស់។

ថ្លែងពីសេចក្តីពិតទាំងស្រុងទៅកាន់បងប្អូន

«ថ្លែងដោយភាពស្មោះត្រង់ទៅកាន់បងប្អូន»

ហើយដួងចិត្តរបស់យើងបានបើក

សាវ័កប៉ូលថ្លែងពីសេចក្តីស្រលាញ់ដ៏ធំក្រៃលែងសម្រាប់អ្នកនៅទីក្រុងកូរិនថូស
ដែលមានដួងចិត្តបើកចំហរ។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកយើងស្រលាញ់អ្នកយ៉ាងខ្លាំង»

ដួងចិត្តអ្នកមិនបានចង្អៀតចង្អល់ ជាមួយយើងឡើយ ប៉ុន្តែ
ការនោះកើតឡើងដោយអារម្មណ៍បងប្អូនវិញ

សាវ័កប៉ូលថ្លែងពីអ្នកនៅក្រុងកូរិនថូសដែលខ្វះសេចក្តីស្រលាញ់សម្រាប់លោក
ប្រៀបដូចជាដួងចិត្តរបស់គេចង្អៀតចង្អល់។

ដួងចិត្តអ្នកមិនបានចង្អៀតចង្អល់ ជាមួយយើង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនបានចង្អៀតចង្អល់ទៅដួងចិត្តរបស់បងប្អូនឡើយ» ឬ
«យើងបានឲ្យអ្នកគ្មានហេតុផលណាដើម្បីបញ្ឈប់សេចក្តីស្រលាញ់មកយើងឡើយ»

ការនោះកើតឡើងដោយអារម្មណ៍បងប្អូនវិញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អារម្មណ៍ផ្ទាល់របស់បងប្អូនកំពុងចង្អៀតចង្អល់ខ្លួនឯង» ឬ
«បងប្អូនបានឈប់ស្រលាញ់យើងដោយមូលហេតុផ្ទាល់ខ្លួន»

ដើម្បីមានភាពស្មើភាព

«ជាការឆ្លើយតបសមស្រប»

ខ្ញុំនិយាយទៅកាន់បងប្អូន ដូចជាកូនរបស់ខ្ញុំដែរ

សាវ័កប៉ូលបានថ្លែងពីអ្នកនៅទីក្រុងកូរិនថូសប្រៀបដូចជាកូនខាងវិញ្ញាណរបស់លោក។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំថ្លែងប្រៀបដូចជាខ្ញុំជាឪពុករបស់បងប្អូន»

ចូរបើកចិត្តចំហឲ្យទូលាយចុះ

សាវ័កប៉ូលជំរុញឲ្យអ្នកនៅទីក្រុងកូរិនថូសឲ្យស្រលាញ់លោក
ដូចលោកបានស្រលាញ់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ស្រលាញ់ពួកយើងច្រើនដូចពួកយើងស្រលាញ់បងប្អូនចឹង»

2 Corinthians 6:14

ព័ត៌មានទូទៅ៖

ក្នុងខគម្ពីរ១៦

សាវ័កប៉ូលបកស្រាយចំណុចខ្លះពីពួកព្យាការីក្នុងគម្ពីសញ្ញាចាស់ជាច្រើនរូបដូចជា៖
លោកម៉ូសេ លោកសាការី លោកអេម៉ុស និងពួកព្យាការីផ្សេងៗទៀត។

សូមកុំទឹមនឹមស្រៀកជាមួយពួកអ្នកមិនជឿឡើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ចូរមានចំណងដៃគូរជាមួយអ្នកជឿ»

នឹមស្រៀកជាមួយ

សាវ័កប៉ូលថ្លែងពីការធ្វើការងារជាមួយដើម្បីសម្រេចគោលដៅតែមួយប្រៀបដូចជាសត្វពីរក្បាលដែលនឹមនឹ
ឬដឹងរទេះ។ ការបកប្រែរបៀបផ្សេងទៀត: «រួមជាក្រុមជមួយ» ឬ
«មានទំនាក់ទំនងជិតស្និតជាមួយ»

តើសេចក្តីសុចរិត និងការទទឹងច្បាប់ អាចចូលគ្នាបានទេ?

នេះជាសំនួរដែលឥតមានចំលើយដែល ដែលដឹងជាមុនថាជាចំលើយផ្ទុយ។
ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតសេចក្តីសុចរិតមិនអាចចូលគ្នានិងបានជាមួយការទទឹងច្បាប់»

តើអាចចូលគ្នាបានទេរវាង ពន្លឺ និងសេចក្តីងងឹតនោះ?

សាវ័កប៉ូលបានសួរសំណួរនេះដើម្បីបញ្ជាក់ថា ពន្លឺ
និងសេចក្តីងងឹងមិនអាចចូរគ្នាឡើយ នៅពេលពន្លឺលេបបំបាត់សេចក្តីងងឹត។
ពាក្យ «ពន្លឺ» និង «សេចក្តីងងឹត» សំដៅលើគុណភាពខាងវិញ្ញាណ
និងសីលធម៌របស់អ្នកជឿ និងអ្នកមិនជឿ។ ការបកប្រែរបៀបផ្សេងទៀត:
«ពន្លឺមិនអាចចូលគ្នាបានជាមួយសេចក្តីងងឹត»

តើមានការព្រមព្រៀងគ្នារវាង អារក្សបេលាល និងព្រះគ្រិស្តទេ?

នេះជាសំនួរដែលឥតមានចំលើយដែល ដែលដឹងជាមុនថាជាចំលើយផ្ទុយ។
ការបកប្រែរបៀបផ្សេងទៀត: «គ្មានការព្រមព្រៀងណារវាង អារក្សបេលា
និងព្រះគ្រិស្តទេ»

ឬតើអ្នកជឿមានចំណែកជាមួយអ្នកមិនជឿបានទេ?

នេះជាសំនួរដែលឥតមានចំលើយដែល ដែលដឹងជាមុនថាជាចំលើយផ្ទុយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកជឿមិនមានអ្វីដែលដូចគ្នាជាមួយអ្នកមិនជឿ»

តើព្រះវិហារនៃព្រះជាម្ចាស់ និងវិហាររបស់ព្រះក្លែងក្លាយអាចចុះចូលជាមួយគ្នាបានទេ?

នេះជាសំនួរដែលឥតមានចំលើយដែល ដែលដឹងជាមុនថាជាចំលើយផ្ទុយ។
ការបកប្រែរបៀបផ្សេងទៀត: «គ្មានកិច្ចព្រមព្រៀងណារវាងព្រះវិហារនៃព្រះជាម្ចាស់
និងវិហាររបស់ព្រះក្លែងក្លាយ»

យើងទាំងអស់គ្នាគឺជាព្រះវិហាររបស់ព្រះដែលមានព្រះជន្មគង់នៅ

សាវ័កប៉ូលសំដៅលើគ្រិស្តបរិស័ទ ដូចជាការបង្កើត
ព្រះវិហារមួយសម្រាប់ព្រះជាម្ចាស់គង់នៅ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងប្រៀបបានដូចជាព្រះវិហារដែលព្រះដែលមានព្រះជន្មរស់គង់នៅ»

2 Corinthians 6:17

ព័ត៌មានទូទៅ៖

សាវ័កប៉ូលដកស្រង់ចំណុចខ្លះពីពួកព្យាការីនៃគម្ពីសញ្ញាចាស់ លោកអេសាយ
និងលោកអេសេគាល។

ញែកដោយឡែក

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ញែកខ្លួនឯងឲ្យនៅដោយឡែក» ឬ«អនុញ្ញាតឲ្យខ្ញុំញែកអ្នកនៅដោយឡែក»

សូមកុំប៉ះរបស់មិនស្អាត

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់ស្រប។ ការបកប្រែរបៀបផ្សេងទៀត:
«សូមប៉ះតែរបស់ដែលស្អាត»

---

7 [1]បងប្អូនជាទីស្រឡាញ់អើយ ដោយសារយើងមានសេចក្តីសន្យាទាំងនេះ ដូច្នេះ សូមឲ្យយើងជម្រះខ្លួនយើងឲ្យបានស្អាត ពីអ្វីដែលធ្វើឲ្យមិនស្អាតចេញពី ទាំងរូបកាយ
និងវិញ្ញាណរបស់យើងផងដែរ។ ចូរឲ្យយើង ដេញតាមសេចក្តីបរិសុទ្ធ ក្នុងការកោតខ្លាចដល់ព្រះជាម្ចាស់។
[2]សូមរៀបចំកន្លែងឲ្យយើងខ្ញុំផង! យើងមិនបានធ្វើអ្វីខុសជាមួយអ្នកណាឡើយ។ យើងក៏មិនបានធ្វើឲ្យអ្នកណាខ្មាស ឬកេញចំណេញពីអ្នកណាដែរ។[3]ខ្ញុំនិយាយដូច្នេះ
មិនមែនផ្តោលទោសដល់បងប្អូនទេ។ ដ្បិត ខ្ញុំបាននិយាយហើយថាបងប្អូនស្ថិតនៅក្នុងដួងចិត្តយើង គឺយើងនឹងស្លាប់រស់ជាមួយគ្នា។
[4]ខ្ញុំមានទំនុកចិត្តយ៉ាងមុតមាំជាមួយបងប្អូន ហើយក៏មានមោទនភាពចំពោះបងប្អូនដែរ។ ខ្ញុំបានទទួលការកម្សាន្តចិត្ត។ ខ្ញុំបានពោរពេញដោយអំណរ
ទោះបីជាយើងមានការខ្វះខាតក៏ដោយ។
[5]ពេលយើងមកដល់ស្រុកម៉ាសេដូន រូបកាយរបស់យើងមិនបានសម្រាកឡើយ។ ផ្ទុយទៅវិញ គឺយើងបានជួបបញ្ហាគ្រប់ផ្លូវទាំងអស់ តាមរយៈការប៉ះទង្គិចផ្នែករូបកាយ
ហើយធ្វើឲ្យមានការភ័យខ្លាចនៅខាងក្នុងយើងដែរ។[6]ប៉ុន្តែ ព្រះជាម្ចាស់ ព្រះអង្គកម្សាន្តចិត្តដល់ការបាក់ទឹកចិត្ត
ដោយស្អាងចិត្តយើងជាមួយវត្តមានរបស់លោកទីតុសមកដល់។[7]វាមិនគ្រាន់តែការមកលេងមួយមុខរបស់លោកទីតុសនោះទេ ដែលព្រះជាម្ចាស់កម្សាន្តចិត្តយើងនោះ។

ប៉ុន្តែ ក៏ឃើញថាបងប្អូនបានទទួលលោកទីតុសយ៉ាងល្អដែរ ធ្វើឲ្យមានរីករាយដោយសារការនេះ។ លោកទីតុសបានប្រាប់ខ្ញុំអំពីបងប្អូន នូវអ្វីដែលបងប្អូនមានចិត្ត
និងទុក្ខព្រួយរបស់បងប្អូន និងការដែលបងប្អូនព្រួយបារម្ភពីខ្ញុំ។ ការទាំងនោះធ្វើឲ្យខ្ញុំរីករាយណាស់។
[8]ទោះបីសំបុត្រខ្ញុំបានធ្វើឲ្យបងប្អូនមិនសប្បាយចិត្តក្តី តែខ្ញុំមិនសោកស្តាយទេ។ ប៉ុន្តែ អ្វីដែលធ្វើឲ្យខ្ញុំសោកស្តាយនោះគឺសំបុត្ររបស់ខ្ញុំបានធ្វើឲ្យបងប្អូនព្រួយវិញ។ ប៉ុន្តែ
បងប្អូននឹងមិនកើតទុក្ខព្រួយយូរនោះទេ។[9]ឥឡូវ ខ្ញុំសប្បាយចិត្ត តែមិនមែនដោយសារ បងប្អូនកើតទុក្ខនោះទេ ប៉ុន្តែ
ការទុក្ខព្រួយរបស់បងប្អូនបាននាំបងប្អូនឲ្យបានប្រែចិត្តវិញ។ បងប្អូនមានបទពិសោធន៍នៃនៅក្នុងការទុកព្រួយរបស់ព្រះ ដូច្នេះ
ការទុក្ខសោកនេះនឹងមិនធ្វើឲ្យបងប្អូនបាត់បង់ដោយសារយើងឡើយ។[10]ដ្បិត ការទុក្ខព្រួយនៅក្នុងព្រះអង្គនឹងនាំឲ្យមានការប្រែចិត្ត ហើយបានទទួលសេចក្តីសង្គ្រោះ
ដោយគ្មានការសោកស្តាយ។ ប៉ុន្តែ ទុក្ខព្រួយរបស់លោកីយ៍វិញ នឹងនាំឲ្យស្លាប់។
[11]មើល ទុក្ខព្រួយនៅក្នុងព្រះជាម្ចាស់បានកើតផលនៅក្នុងបងប្អូនយ៉ាងណា។ ផលដ៏ធំនៅក្នុងបងប្អូននោះគឺជាការបង្ហាញថាបងប្អូនមិនជាប់ទោស។
តើការទាំងនោះអស្ចារ្យយ៉ាងណា អំពីការឈឺចិត្ត ការភ័យព្រួយ ការរង់ចាំ ចិត្តខ្នះខ្នែង និងបំណងចិត្តរបស់បងប្អូន ចង់ឃើញសេចក្តីយុត្តិធម៌បានកើតឡើង!
ក្នុងការទាំងនោះបងប្អូនបានបង្ហាញឲ្យឃើញថា បងប្អូនគ្មានទោសក្នុងរឿងទាំងនោះទេ។[12]ទោះបើខ្ញុំសរសេរមកកាន់បងប្អូន គឺខ្ញុំមិនបានធ្វើមកដល់អ្នកដែលធ្វើខុសនោះទេ
ក៏មិនបានសម្រាប់អ្នកដែលឈឺចាប់ក្នុងការខុសនោះទេ។ ខ្ញុំសរសេរដើម្បីឲ្យបងប្អូន ប្រឹងអស់ពីចិត្តជាមួយយើង និងដើម្បីឲ្យគេបានស្គាល់បងប្អូន
នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់។
[13]តាមរយៈការទាំងនេះ យើងបានទទួលការលើកទឹកចិត្ត។ ក្នុងការបន្ថែមពីការកម្សាន្តចិត្តរបស់យើង គឺកាន់តែរីករាយថែមទៀតដោយសារ អំណររបស់លោកទីតុស
គឺវិញ្ញាណរបស់គាត់បានស្រស់ថ្លាដោយសារបងប្អូនទាំងអស់គ្នា។[14]ដ្បិត ខ្ញុំមានអំនួតអំពីគាត់ដោយសារបងប្អូន ហើយខ្ញុំក៏គ្មានសេចក្តីខ្មាសឡើយ។ ផ្ទុយទៅវិញ
អ្វីដែលយើងបាននិយាយទៅបងប្អូនសុទ្ធតែពិតទាំងអស់ អំនួតរបស់យើងអំពីបងប្អូនជាមួយនឹងលោកទីតុស បានបង្ហាញថាជាការពិត។
[15]គាត់បានទទួលការប៉ះពាល់យ៉ាងខ្លាំងពីបងប្អូន គាត់បានចាំពីការស្តាប់បង្គាប់ របស់បងប្អូនទាំងអស់គ្នា។ អំពីការស្វាគមន៍ដល់រូបគាត់
ជាមួយការបារម្ភហើយនិងខ្លាចផង។[16]ខ្ញុំរីករាយដោយសារខ្ញុំបានទុកចិត្តលើបងប្អូនទាំងស្រុង។

---

2 Corinthians 7:1
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបន្តរំលឹកដល់ពួកគេឲ្យនៅដាច់ពីអំពើបាបហើយស្វែងរកសេចក្តីបរិសុទ្ធដោយការចុះចូលចិត្ត។
បងប្អូនជាទីស្រឡាញ់អើយ
«អ្នកជាមនុស្សដែលខ្ញុំស្រលាញ់» ឬ«ឱមិត្តសំលាញ់អើយ»
សូមឲ្យយើងជម្រះខ្លួនយើង
ចំណុចនេះសាវ័កប៉ូលពោលពីការនៅឲ្យឆ្ងាយពីទម្រង់ណាមួយនៃអំពើបាបដែលអាចនឹងបង្ខូចទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
ចូរឲ្យយើង ដេញតាមសេចក្តីបរិសុទ្ធ
«ចូរឲ្យយើងព្យាយាមបានបរិសុទ្ធ»
ក្នុងការកោតខ្លាចដល់ព្រះជាម្ចាស់
«ដោយការគោរពដ៏ជ្រាលជ្រៅសម្រាប់ព្រះជាម្ចាស់»
2 Corinthians 7:2
ប្រយោគភ្ជាប់៖
អ្នករស់នៅទីក្រុងកូរិនថូសត្រូវបានដាស់តឿនអំពីអ្នកដឹកនាំផ្សេងទៀតដែលបានព្យាយាមធ្វើឲ្យពួកគេបែរចេញពីសាវ័កប៉ូលដែលបានបង្កើតក្រុមជំនុំនៅទីក្រុងកូរិនថូសដោយសារតាមពួកអ្នកដឹកនាំនោះ
ដោយសាវ័កប៉ូលបានរំលឹកពួកគេ ពីរបៀបដែលលោកមានអារម្មណ៍ចំពោះពួកគេ។
សូមរៀបចំកន្លែងឲ្យយើងខ្ញុំផង!
នេះសំដៅថយក្រោយពីអ្វីដែលសាវ័កប៉ូលបានថ្លែងក្នុងជំពូក៦:១១
អំពីពួកគេបើកដួងចិត្តចំពោះលោក។ ការបកប្រែរបៀបផ្សេងទៀត:
«សូមរៀបចំកន្លែងឲ្យយើងខ្ញុំផងនៅក្នុងដួងចិត្តរបស់អ្នក» ឬ«ស្រលាញ់យើងខ្ញុំ
និងទទួលយកយើងខ្ញុំ»
ខ្ញុំនិយាយដូច្នេះ មិនមែនផ្តោលទោសដល់បងប្អូនទេ
«ខ្ញុំមិនបាននិយាយចោទប្រកាន់បងប្អូនបានធ្វើខុសទេ» ពាក្យថា
«ដូច្នេះ»សំដៅលើពាក្យដែលសាវ័កប៉ូលគ្រាន់តែនិយាយដែលមិនប៉ះពាល់ដល់អ្នកដទៃ
បងប្អូនស្ថិតនៅក្នុងដួងចិត្តយើង
សាវ័កប៉ូលថ្លែងពីសេចក្តីស្រលាញ់យ៉ាងខ្លាំងពីលោក
និងសហការីរបស់លោកចំពោះអ្នករស់នៅទីក្រុងកូរិនថូសប្រៀបបានដូចជាពួកលោកបានរស់នៅជាមួយពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកជាមនុស្សសំណព្វរបស់ពួកយើង»
យើងនឹងស្លាប់រស់ជាមួយគ្នា
នេះមានន័យថា
សាវ័កប៉ូលនិងសហការីរបស់លោកនៅតែបន្តស្រលាញ់អ្នករស់នៅទីក្រុងកូរិនថូសទោះបីមានអ្វីក៏ដោយ។
ការបកប្រែរបៀបផ្សេងទៀត: «ទោះបីយើងរស់ ឬក៏យើងស្លាប់»
យើងនឹងស្លាប់
«យើង» រួមជាមួយនឹងអ្នកជឿនៅក្រុងកូរិនថូសទាំងអស់។
ខ្ញុំបានទទួលការកម្សាន្តចិត្ត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកបំពេញខ្ញុំឲ្យមានមានការកំសាន្តចិត្ត»
ខ្ញុំបានពោរពេញដោយអំណរ
សាវ័កប៉ូលថ្លែងពីសេចក្តីអំណរប្រៀបដូចជាទឹកដែលចាក់បំពេញរូបលោកឲ្យបានហូរហៀរ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំពិតជាមានអំណរក្រៃលែង»
ទោះបីជាយើងមានការខ្វះខាតក៏ដោយ
«ទោះបីការទាំងនោះជាការលំបាករបស់យើងក៏ដោយ»
2 Corinthians 7:5
ប្រយោគភ្ជាប់៖
ពាក្យថា «យើង» សំដៅលើសាវ័កប៉ូល និងលោកធីម៉ូថេ
មិនមែនអ្នករស់នៅទីក្រុងកូរិនថូស ឬលោកទីតុសឡើយ។
រូបកាយរបស់យើងមិនបានសម្រាកឡើយ
ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនបានសម្រាកឡើយ» ឬ «យើងនឿយហត់ខ្លាំងណាស់»
យើងបានជួបបញ្ហាគ្រប់ផ្លូវទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមានបទពិសោធន៍លើបញ្ហាគ្រប់ផ្លូវទាំងងស់»
តាមរយៈការប៉ះទង្គិចផ្នែករូបកាយ ហើយធ្វើឲ្យមានការភ័យខ្លាចនៅខាងក្នុងយើង
ពាក្យថា «ផ្នែករូបកាយ» អាចមានន័យថា គឺ ១) «ផ្នែកខាងក្រៅនៃរូបកាយ» ឬ ២)
សំដៅលើអារម្មណ៍ពីខាងក្នុងរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«តាមរយៈការប៉ះទង្គិចជាមួយមនុស្សដទៃទៀត
ហើយដោយតាមរយៈសេចក្តីភ័យខ្លាចនៅខាងក្នុងយើង»
ក៏ឃើញថាបងប្អូនបានទទួលលោកទីតុសយ៉ាងល្អដែរ
សាវ័កប៉ូលបានទទួលការកំសាន្តចិត្តពីការស្គាល់អ្នកទីក្រុងកូរិនថូស។
ការបកប្រែរបៀបផ្សេងទៀត:
«តាមរយៈការសិក្សាអីការកំសាន្តចិត្តដែលលោកទីតុសបានទទួលពីបងប្អូន»
2 Corinthians 7:8
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបានសរសើរពួកគេពីទុក្ខព្រួយចំពោះព្រះជាម្ចាស់
និងការខ្នះខ្នែងដើម្បីធ្វើការត្រឹមត្រូវ ហើយរូបលោក
និងសហការីរបស់លោកនៅក្នុងដួងចិត្តអំណរតាមកិច្ចការទាំងនោះ។
ព័ត៌មានទូទៅ៖
នេះសំដៅលើសំបុត្ររបស់សាវ័កប៉ូលពីមុនដល់អ្នកជឿនៅទីក្រុងកូរិនថូស
ដែលលោកបានស្តីបន្ទោសដល់ពួកគេពីទទួលយកអ្នកជឿដែលប្រព្រឹត្តអំពើអសីលធម៌ខាងកាម
សំបុត្ររបស់ខ្ញុំ
«ខ្ញុំបានយល់ដឹងពីសំបុត្ររបស់ខ្ញុំ»
តែមិនមែនដោយសារ បងប្អូនកើតទុក្ខនោះទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«តែមិនមែនដោយសារអ្វីដែលខ្ញុំបានពោលក្នុងសំបុត្រ
បានធ្វើឲ្យបងប្អូនកើតទុក្ខនោះទេ»
ការទុក្ខសោកនេះនឹងមិនធ្វើឲ្យបងប្អូនបាត់បង់ដោយសារយើងឡើយ
បងប្អូនបានរងទុកតែមិនធ្វើឲ្យបាត់បង់ឡើយ
ដោយព្រោះតែពួកយើងបានតាស់តឿនដល់បងប្អូន»។
នេះមានន័យថាទោះបីជាសំបុត្រនេះបានធ្វើឲ្យបងប្អូនមានទុក្ខព្រួយ

generated on Wed Sep 10 16:16:32 2025

តែបានប្រយោជន៍ពីសំបុត្រនេះដោយតែសំបុត្រនេះបានធ្វើឲ្យពួកគេបានប្រែចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះពួកយើងមិនបានធ្វើទុក្ខដល់បងប្អូនឡើយ»
ការទុក្ខព្រួយនៅក្នុងព្រះអង្គនឹងនាំឲ្យមានការប្រែចិត្ត ហើយបានទទួលសេចក្តីសង្គ្រោះ
ពាក្យថា «ការប្រែចិត្ត»
អាចនឹងប្រើច្រើនដងដើម្បីបញ្ជាក់ពីទំនាក់ទំនងរវាងអ្វីនៅខាងមុខ
និងអ្វីដែលខាងក្រោយ។ ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតការទុកព្រួយនៅក្នុងព្រះអង្គនាំឲ្យមានការប្រែចិត្ត
ហើយការប្រែចិត្តនាំឲ្យមានការសង្គ្រោះ»
ដោយគ្មានការសោកស្តាយ
អាចមានន័យថា ១)
សាវ័កប៉ូលមិនបានសោកស្តាយដែលធ្វើឲ្យពួកគេមានទុក្ខព្រួយដោយព្រោះតែទុក្ខព្រួយ
និងការសង្គ្រោះ ឬ ២)
អ្នករស់នៅទីក្រុងកូរិនថូសនឹងមិនសោកស្តាយដែលមានបទពិសោធន៍ទុក្ខព្រួយដោយ
ហើយការសង្គ្រោះ។
ប៉ុន្តែ ទុក្ខព្រួយរបស់លោកីយ៍វិញ នឹងនាំឲ្យស្លាប់
ទុក្ខព្រួយបែបនេះបាននាំឲ្យស្លាប់ ដោយព្រោះតែមិនបាននាំឲ្យមានការប្រែចិត្ត។
ការបកប្រែរបៀបផ្សេងទៀត: «ប៉ុន្តែទុក្ខព្រួយរបស់លោកីយ៍វិញ
នឹងនាំឲ្យស្លាប់ខាងវិញ្ញាណ»
2 Corinthians 7:11
មើល
ពាក្យនេះបញ្ជាក់ន័យថា អ្វីដែលនឹងកើតឡើងបន្ទាប់នេះ។
ផលដ៏ធំនៅក្នុងបងប្អូននោះគឺជាការបង្ហាញថាបងប្អូនមិនជាប់ទោស
ឃ្លាថា «នោះ» នៅទីនេះបង្កើតអត្ថន័យជាលាន់មាត់។ ការបកប្រែរបៀបផ្សេងទៀត:
ផលក្នុងបងប្អូន
ការឈឺចិត្តរបស់បងប្អូន
«កំហឹងរបស់បងប្អូន»
សេចក្តីយុត្តិធម៌បានកើតឡើង!
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នករាល់គ្នាគួរប្រកាន់ភ្ជាប់សេចក្តីយុត្តិធម៌»
អ្នកដែលធ្វើខុស
«អ្នកដែលប្រព្រឹត្តការខុស»
ដើម្បីឲ្យបងប្អូន ប្រឹងអស់ពីចិត្តជាមួយយើង និងដើម្បីឲ្យគេបានស្គាល់បងប្អូន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីឲ្យបងប្អូនបានស្គាល់ពី
ការខំប្រឹងអស់ពីចិត្តសម្រាប់ពួកយើងដែលជាអ្នកស្មោះត្រង់»
នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់
នេះសំដៅលើព្រះវត្តមានរបស់ព្រះអង្គ។ ការជ្រាបដឹង
និងការយល់ស្របរបស់ព្រះជាម្ចាស់ពីភាពស្មោះត្រង់របស់សាវ័កប៉ូល
ដែលសំដៅលើព្រះជាម្ចាស់អាចជ្រាបដឹងពីពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«នៅចំពោះព្រះជាម្ចាស់» ឬ«ជាសាក្សីដោយមានព្រះជាម្ចាស់»។
សូមមើលពីរបៀបបកប្រែក្នុងជំពូក ៤:១។
2 Corinthians 7:13
តាមរយៈការទាំងនេះ យើងបានទទួលការលើកទឹកចិត្ត
ឃ្លាថា «នេះ»
នៅទីនេះសំដៅទៅលើរបៀបដែលអ្នករស់នៅទីក្រុងកូរិនថូសឆ្លើយតបទៅសំបុត្រពីមុនរបស់សាវ័កប៉ូល
ដែលធ្វើឲ្យសាវ័កប៉ូលបានទទួលការលើកទឹកចិត្ត។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «នេះជាអ្វីដែលលើកទឹកចិត្តយើង»
ការនេះបានធ្វើឲ្យពួកគេទាំងអស់គ្នាបានប្រែចិត្ត
ឃ្លាថា «វិញ្ញាណ» នៅទីនេះសំដៅទៅលើអារម្មណ៍ពីខាងក្នុង និងចិត្តគំនិត។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នករាល់គ្នាបានធ្វើឲ្យវិញ្ញាណរបស់គាត់បានស្រស់ថ្លា»
ឬអ្នករាល់គ្នាបានធ្វើឲ្យគាត់ឈប់បារម្មណ៍»
ដ្បិត ខ្ញុំមានអំនួតអំពីគាត់ដោយសារបងប្អូន
«ដ្បិតទោះបីខ្ញុំបានអួតទៅគាត់ដោយសារបងប្អូន»
ខ្ញុំក៏គ្មានសេចក្តីខ្មាសឡើយ
«បងប្អូនបានធ្វើឲ្យខ្ញុំខកបំណងឡើយ»
អំនួតរបស់យើងអំពីបងប្អូនជាមួយនឹងលោកទីតុស បានបង្ហាញថាជាការពិត
«បងប្អូនបង្ហាញថាអំនួតរបស់យើងចំពោះលោកទីតុសគឺជាការពិតដោយសារបងប្អូន។
2 Corinthians 7:15
ការស្តាប់បង្គាប់ របស់បងប្អូនទាំងអស់គ្នា
នាម «ការស្តាប់បង្គាប់» អាចប្រើជាមួយកិរិយាសព្ទ «ស្តាប់បង្គាប់។»
ការបកប្រែរបៀបផ្សេងទៀត: «តើបងប្អូនរាល់គ្នាស្តាប់បង្គាប់យ៉ាងដូចម្តេច»
អំពីការស្វាគមន៍ដល់រូបគាត់ ជាមួយការបារម្ភហើយនិងខ្លាចផង
ពាក្យថា «បារម្ភ» និង «ខ្លាច» មានអត្ថន័យស្រដៀងគ្នា
និងបញ្ជាក់ពីការបង្កើនភាពភ័យខ្លាច។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនបានស្វាគមន៍គាត់ជាមួយនឹងការយកចិត្តទុកដាក់ខ្លាំង»
ជាមួយការបារម្ភហើយនិងខ្លាចផង
អាចមានន័យថា ១) «ជាមួយនឹងការយកចិត្តទុកដាក់ខ្លាំងចំពោះព្រះ» ឬ ២)
ជាមួយនឹងការយកចិត្តទុកដាក់ខ្លាំងចំពោះលោកទីតុស»។

---

8 [1]បងប្អូនអើយ យើងចង់ឲ្យបងប្អូនដឹងអំពី ព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានប្រទានឲ្យដល់ពួកជំនុំនៅស្រុកម៉ាសេដូន។[2]កំឡុងពេលជួបនឹងការល្បងលដោយសារទុក្ខវេទនាជាមួយនឹងភាពក្រីក្រយ៉ាងខ្លាំងយ៉ាងក៏ដោយ ពួកគេនៅតែមានអំណរជាបរិបូរ ហើយក៏នៅតែមានភាពសប្បុរសដដែល។
[3]ដ្បិត ខ្ញុំអាចធ្វើជាសាក្សីថា ពួកគេពិតជាបានផ្តល់ប្រាក់ទៅតាមសមត្ថភាពដែលពួកគេអាចធ្វើបាន ហើយពេលខ្លះពួកគេបានថ្វាយច្រើនជាងអ្វីដែលគេមានផង។
ហើយពួកគេធ្វើការទាំងនេះដោយការពេញចិត្តផងដែរ[4]ពួកគេសូមអង្វរ
ហើយទទូចដើម្បីឲ្យយើងអនុញ្ញាតឲ្យពួកគេអាចមានចំណែកបម្រើការងារជាមួយបងប្អូនអ្នកជឿដែរ។[5]ការនេះមិនបានកើតឡើងតាមអ្វីដែលបានរំពឹងទុកឡើយ។
ផ្ទុយទៅវិញ ពួកគេបានថ្វាយជីវិតរបស់ពួកគេទៅព្រះអម្ចាស់ជាដំបូង។ បន្ទាប់មក ពួកគេក៏បានថ្វាយខ្លួនគេដល់យើងដែរ ដោយស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។
[6]ដូច្នេះ យើងបានដាស់តឿនដល់ទីតុស ដែលជាអ្នកបានចាប់ផ្តើមការងារនេះ ដើម្បីធ្វើឲ្យសម្រេចការនេះស្របតាមភាពសប្បុរសនិងចំណែករបស់បងប្អូនដែរ។[7]ប៉ុន្តែ
បងប្អូននឹងចម្រើនឡើងក្នុងគ្រប់ការទាំងអស់ ក្នុងជំនឿ ក្នុងការនិយាយ ក្នុងសេចក្តីចេះដឹង ក្នុងសេចក្តីព្យាយាម ហើយនៅក្នុងសេចក្តីស្រឡាញ់ដល់ពួកយើង។ ដូច្នេះ
សូមឲ្យប្រកដថាបងប្អូនបានចម្រើន ក្នុងកិច្ចការសប្បុរសទាំងនេះដែរ។
[8]ខ្ញុំនិយាយការទាំងនេះមិនមែនដោយបង្គាប់បញ្ជានោះទេ។ ផ្ទុយទៅវិញ ខ្ញុំនិយាយការទាំងនេះតាមលំដាប់លំដោយ
ដើម្បីល្បងលពីភាពស្មោះត្រង់នៃសេចក្តីស្រឡាញ់របស់បងប្អូន ដោយប្រៀបធៀបវាជាមួយទឹកចិត្តរបស់មនុស្សផ្សេងទៀត។[9]ដ្បិត
បងប្អូនបានស្គាល់ពីព្រះគុណនៃព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើងហើយ។ ទោះបីជា ព្រះជាម្ចាស់មានសម្បត្តិយ៉ាងណាក្តី តែដោយសារបងប្អូនព្រះអង្គត្រឡប់ជាក្រវិញ
ហើយដោយសារភាពក្រីក្ររបស់ព្រះជាម្ចាស់នោះ បងប្អូននឹងត្រឡប់ទៅជាអ្នកមានទ្រព្យសម្បត្តិវិញ។
[10]នៅក្នុងរឿងនេះ ខ្ញុំនឹងផ្តល់នូវគំនិតជាជំនួយដល់បងប្អូន។ កាលពីឆ្នាំមុន បងប្អូនមិនទាន់ទាំងចាប់ផ្តើមធ្វើអ្វីផង ប៉ុន្តែ បងប្អូនមានចិត្តក្នុងការធ្វើវារួចទៅហើយ។[11]ដូច្នេះ
ចូរបង្ហើយវាចុះ។ ដូចអ្វីដែលបងប្អូនមានដួងចិត្តចង់ធ្វើយ៉ាងណា ដូច្នេះ ចូរធ្វើវាចុះ ហើយបងប្អូននឹងបង្ហើយវា តាមអ្វីដែលបងប្អូនអាចធ្វើទៅបាន។[12]ដ្បិត ប្រសិនបើ
បងប្អូនមានចិត្តស្មោះក្នុងការធ្វើការនេះ វាគឺជាការល្អ ហើយអាចទទួលយកបានផង។ ហើយវាអាស្រ័យទៅលើអ្វីដែលអ្នកនោះមាន
មិនមែនផ្អែកទៅលើអ្វីដែលពួកគេគ្មាននោះទេ។
[13]ដ្បិត កាតព្វកិច្ចទាំងនេះមិនមែនដើម្បីឲ្យអ្នកណាម្នាក់បានធូស្រាល ហើយឲ្យនរណាម្នាក់ទៀតមានបន្ទុកវិញនោះទេ។ ផ្ទុយទៅវិញ គួរតែធ្វើដោយស្មើរភាពគ្នា។
[14]តែបន្ទុករបស់បងប្អូនក្នុងពេលឥឡូវនេះ គឺត្រូវផ្គត់ផ្គង់អ្វីដែលពួកគេត្រូវការ។ ដូចដែលពួកគេមានបន្ទុកក្នុងការផ្គត់ផ្គង់ដល់តម្រូវការរបស់បងប្អូនដែរ
ដើម្បីឲ្យមានភាពស្មើរគ្នា។[15]ដ្បិត មានសេចក្តីចែងទុកមកថា៖ «អ្នកណាដែលរើសបានច្រើន នោះគ្មានសល់អ្វីឡើយ រីឯអ្នកដែលរើសបានតិច ក៏មិនខ្វះទេ»។
[16]ប៉ុន្តែ សូមអរព្រះគុណដល់ព្រះជាម្ចាស់ ដែលបានដាក់នៅក្នុងដួងចិត្តរបស់លោកទីតុសឲ្យមានដួងចិត្តដូចជាខ្ញុំដែរ ក្នុងការមើលថែបងប្អូន។[17]ដ្បិត
គាត់មិនមែនគ្រាន់តែទទួលការស្នើសុំរបស់យើងនោះទេ ប៉ុន្តែ គាត់ពិតជាមានចិត្តស្មោះជាមួយនឹងការនោះដែរ។
លោកទីតុសបានមករកបងប្អូនដោយស្ម័គ្រពីចិត្តរបស់គាត់វិញ។

generated on Wed Sep 10 16:16:32 2025

[18]ពួកយើងបានចាត់បងប្អូនផ្សេងទៀត មកជាមួយគាត់គឺជាអ្នកដែលមានការសរសើរនៅតាមក្រុមជំនុំផ្សេងៗ ដើម្បីជួយការងារគាត់ក្នុងការប្រកាសដំណឹងល្អ។
[19]មិនតែប៉ុណ្ណោះ គាត់ត្រូវបានជ្រើសរើសតាមរយៈក្រុមជំនុំ ដើម្បីឲ្យធ្វើដំណើរជាមួយយើងក្នុងការនាំយកកិច្ចការ និងទង្វើសប្បុរសរបស់យើងផង។
ការទាំងនេះសម្រាប់ជាសិរីល្អនៃព្រះអម្ចាស់ដោយខ្លួនគាត់ផ្ទាល់ និងដើម្បីបង្ហាញពីចិត្តឆេះឆួលចង់ជួយយើងដែរ។
[20]ពួកយើង ខំចៀសវាងពីការអ្វីដែលអាចកើតឡើង ពីនរណាម្នាក់ដែលមិនពេញចិត្តហើយបារម្ភពីដំណើរសប្បុរសនេះ ដែលយើងខ្ញុំកំពុងតែនាំចេញទៅផងដែរ។
[21]ពួកយើងយកចិត្តទុកដាក់ក្នុងការធ្វើការនេះដោយស្មោះត្រង់ មិនមែនតែនៅចំពោះព្រះអម្ចាស់ឡើយ ប៉ុន្តែ នៅចំពោះមនុស្សដែរ។
[22]ពួកយើងបានចាត់បងប្អូនផ្សេងទៀតទៅជាមួយពួកគេដែរ។ ពួកយើងបានល្បងលគាត់ជាញឹកញាប់ ហើយយើងបានរកឃើញថាគាត់ពិតជាមានចិត្តក្លៀវក្លា
សម្រាប់ការងារជាច្រើនដែរ។ គាត់ពេលនេះកាន់តែព្យាយាមទៀត ពីព្រោះតែគាត់មានទំនុកចិត្តជាខ្លាំងនៅក្នុងបងប្អូន។[23]ដ្បិត លោកទីតុស គាត់គឺជាគូកនរបស់ខ្ញុំ
ហើយក៏ជាអ្នករួមការងារសម្រាប់បងប្អូនដែរ។ ដ្បិត បងប្អូនទាំងនោះ ក្រុមជំនុំជាអ្នកចាត់ឲ្យពួកគេទៅ។ ពួកគេទាំងនោះគោរពកោតខ្លាចព្រះគ្រិស្ត។[24]ដូច្នេះ
សូមបង្ហាញដល់ពួកគេនូវសេចក្តីស្រឡាញ់របស់បងប្អូន ហើយបង្ហាញដល់ក្រុមជំនុំ ពីមូលហេតុដែលមានអំនួតរបស់យើងអំពីបងប្អូនដែរ។

---

2 Corinthians 8:1

ប្រយោគភ្ជាប់៖

សាវ័កប៉ូលបានថ្លែងពីការថ្វាយ ដែលគាត់ពន្យល់ពីការផ្លាស់ប្តូរផែនការថ្មី
ហើយនឹងការដឹកនាំព័ន្ធកិច្ចរបស់លោក។

ព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានប្រទានឲ្យដល់ពួកជំនុំនៅស្រុកម៉ាសេដូន

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានប្រទានឲ្យដល់ក្រុមជំនុំនៃស្រុកម៉ាសេដូន»

ទុក្ខវេទនាជាមួយនឹងភាពក្រីក្រយ៉ាងខ្លាំងយ៉ាងក៏ដោយ ពួកគេនៅតែមានអំណរជាបរិបូរ
ហើយក៏នៅតែមានភាពសប្បុរស

សាវ័កប៉ូលបានថ្លែងពី «អំណរ» និង «ភាពក្រីក្រ»
ប្រៀបដូចជាពាក្យទាំងពីរនេះដែលមានជីវិត ដែលអាចបង្កើតភាពសប្បុរស។
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារអំណរបរិបូរ និងភាពក្រីក្រយ៉ាងខ្លាំង
ដូច្នេះពួកគេប្រែទៅជាសប្បុរសវិញ»

ពួកគេនៅតែមានអំណរជាបរិបូរ

សាវ័កប៉ូលថ្លែងពីអំណរប្រៀបដូចជាខាងសាច់ឈាម
ដែលមានការរីកចំរើនទាំងទំហំ ឬបរិមាណ។

ភាពក្រីក្រយ៉ាងខ្លាំងយ៉ាងក៏ដោយ ពួកគេនៅតែមានអំណរជាបរិបូរ ហើយក៏នៅតែមានភាពសប្បុរស

តាមរយៈក្រុមជំនុំនៃស្រុកម៉ាសេដូន ដែលបានរងទុក្ខការល្បងនៃការឈឺចាប់
និងភាពក្រីក្រ ដោយព្រះគុណព្រះជាម្ចាស់
ពួកគេអាចប្រមូលដង្វាយពីអ្នកជឿក្នុងទីក្រុង យេរូសាឡិម។

នៅតែមានភាពសប្បុរសដដែល

«ភាពសប្បុរសដែលធំអស្ចារ្យ»។ ពាក្យថា «នៅតែមាន»
បញ្ជាក់ថាភាពធំអស្ចារ្យនៃភាពសប្បុរសរបស់ពួកគេ។

2 Corinthians 8:3

ពួកគេពិតជាបានផ្តល់

នេះសំដៅលើពួកជំនុំនៅស្រុកម៉ាសេដូន។

ពួកគេធ្វើការទាំងនេះដោយការពេញចិត្ត

«ដោយស្ម័គ្រចិត្ត»

ពួកគេសូមអង្វរ ហើយទទូចដើម្បីឲ្យយើង

ឃ្លាថា «សូមអង្វរ» និង «ទទូច» មានអត្ថន័យស្រដៀងគ្នា ហើយបញ្ជាក់
ការប្រឹងអស់ពីចិត្តជាមួយនឹងមនុស្សទទុ្ចចង់បាន។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេទទួចដោយអស់ពីចិត្តជាមួយនឹងពួកយើង»

បម្រើការងារជាមួយបងប្អូនអ្នកជឿ

សាវ័កប៉ូលសំដៅលើការថ្វាយដង្វាយឲ្យអ្នកជឿក្នុងក្រុងយេរូសាឡិម។
ការបកប្រែរបៀបផ្សេងទៀត:
«ការបម្រើការងារពីការថ្វាយសម្រាប់អ្នកជឿក្នុងក្រុងយេរូសាឡិម»

2 Corinthians 8:6

ដែលជាអ្នកបានចាប់ផ្តើមការងារនេះ

សាវ័កប៉ូលសំដៅលើការប្រមូលប្រាក់ពីអ្នករស់នៅទីក្រុងកូរិនថូសសម្រាប់អ្នកជឿនៅទីក្រុងយេរូសាឡិម។
ការបកប្រែរបៀបផ្សេងទៀត:
«ជាអ្នកដែលលើកទឹកចិត្តការថ្វាយរបស់បងប្អូននៅក្រុមជំនុំដំបូង»

ដើម្បីធ្វើឲ្យសម្រេចការនេះស្របតាមភាពសប្បុរសនិងចំណែករបស់បងប្អូនដែរ

លោកទីតុសបានជួយដល់អ្នករស់នៅទីក្រុងកូរិនថូសដើម្បីសម្រេចការប្រមូលប្រាក់។
ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីលើកទឹកចិត្តឲ្យបងប្អូនសម្រេចអំណោយទាននៃសប្បុរសរបស់បងប្អូន»

ប៉ុន្តែ បងប្អូននឹងចម្រើនឡើងក្នុងគ្រប់ការទាំងអស់

សាវ័កប៉ូលថ្លែងពីអ្នកជឿនៅទីក្រុងកូរិនថូសប្រៀបបានដូចជាពួកគេបានបង្កើតការល្អខាងសាច់ឈាម
ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនធ្វើល្អក្នុងគ្រប់ការទាំងអស់»

សូមឲ្យប្រកដថាបងប្អូនបានចម្រើន ក្នុងកិច្ចការសប្បុរសទាំងនេះដែរ

សាវ័កប៉ូលថ្លែងពីអ្នកជឿក្នុងទីក្រុងកូរិនថូសប្រៀបដូចជាពួកគេគួរតែបង្កើតការល្អខាងសាច់ឈាម។
ការបកប្រែរបៀបផ្សេងទៀត:
«ដោយប្រាកដថាបងប្អូនបានធ្វើការល្អក្នុងការថ្វាយសម្រាប់អ្នកជឿក្នុងទីក្រុងយេរូសាឡិម»

2 Corinthians 8:8

ដោយប្រៀបធៀបវាជាមួយទឹកចិត្តរបស់មនុស្សផ្សេងទៀត

សាវ័កប៉ូលលើកទឹកចិត្តអ្នករស់នៅទីក្រុងកូរិនថូសឲ្យចេះថ្វាយដោយភាពសប្បុរសដោយប្រៀបធៀបពួកគេ

ព្រះគុណនៃព្រះអម្ចាស់យេស៊ូគ្រិស្តរបស់យើង

ក្នុងបរិបទនេះ ពាក្យថា «ព្រះគុណ»
បញ្ជាក់ពីភាពសប្បុរសដែលមានព្រះយេស៊ូទ្រង់ប្រទានដល់អ្នករស់នៅទីក្រុងកូរិនថូស។

ទោះបីជា ព្រះជាម្ចាស់មានសម្បត្តិយ៉ាងណាក្តី តែដោយសារបងប្អូនព្រះអង្គត្រឡប់ជាក្រវិញ

សាវ័កប៉ូលថ្លែងពីព្រះយេស៊ូមុនពេលទ្រង់យាងមកចាប់កំណើតជាមនុស្ស
ព្រះជាម្ចាស់មានសម្បត្តិជាច្រើន ហើយការប្រែទៅជាមនុស្សរបស់ទ្រង់
បានត្រឡប់ជាក្រវិញ។

ដោយសារភាពក្រីក្ររបស់ព្រះជាម្ចាស់នោះ បងប្អូននឹងត្រឡប់ទៅជាអ្នកមានទ្រព្យសម្បត្តិវិញ

សាវ័កប៉ូលថ្លែងពីអ្នករស់នៅទីក្រុងកូរិនថូសបានប្រែក្លាយជាអ្នកមានខាងវិញ្ញាណដោយព្រោះតែព្រះយេស៊ូ

2 Corinthians 8:10

នៅក្នុងរឿងនេះ

នេះសំដៅលើការប្រមូលដង្វាយដើម្បីឲ្យអ្នកជឿនៅក្នុងក្រុងយេរូសាឡឹម។
ការបកប្រែរបៀបផ្សេងទៀត: «ដោយយោងតាមការប្រមូលដង្វាយ»

មានដួងចិត្តចង់ធ្វើយ៉ាងណា ដូច្នេះ ចូរធ្វើវាចុះ

អ្នកអាចបកប្រែដោយប្រើកិរិយាសព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនមានដួងចិត្ត និងមានបំណងចង់ធ្វើវា»

បង្ហើយវា

«បំពេញវា» ឬ «បញ្ចប់វា»

គឺជាការល្អ ហើយអាចទទួលយកបាន

ពាក្យថា «ល្អ» និង«អាចទទួលយកបាន» នៅទីនេះមានអត្ថន័យស្រដៀងគ្នា
ហើយបញ្ជាក់ពីសេចក្តីល្អនៃការទាំងនោះ។ ការបកប្រែរបៀបផ្សេងទៀត:
«គឺជាការដែលល្អបំផុត»

អាស្រ័យទៅលើអ្វីដែលអ្នកនោះមាន

«ការថ្វាយផ្អែកលើអ្វីដែលមនុស្សមាន»

2 Corinthians 8:13

ដ្បិតកាតព្វកិច្ចទាំងនេះ

នេះសំដៅលើការប្រមូលដង្វាយសម្រាប់អ្នកជឿក្នុងក្រុងយេរូសាឡិម។
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតការងារនៃការប្រមូលដង្វាយនេះ»

អ្នកណាម្នាក់បានធូស្រាល ហើយឲ្យនរណាម្នាក់ទៀតមានបន្ទុកវិញនោះទេ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូននឹងធ្វើឲ្យនរណាម្នាក់បានធូស្រាល តែបងប្អូននឹងទទួលបន្ទុកនោះវិញ»

[illegible]

«គួរតែមានភាពស្មើគ្នា»

ដូចដែលពួកគេមានបន្ទុកក្នុងការផ្គត់ផ្គង់ដល់តម្រូវការរបស់បងប្អូនដែរ

បន្ទាប់ពីអ្នករស់នៅទីក្រុងកូរិនថូសបានធ្វើសកម្មភាពនៅពេលនេះ
នោះបញ្ជាក់ថាអ្នកជឿនៅក្រុងយេរូសាឡឹមក៏បានជួយពួកគេ
ក្នុងពេលណាមួយក្នុងពេលអនាគត។ ការបកប្រែរបៀបផ្សេងទៀត:
«នេះដូចដែលក្នុងពេលអនគតពួកគេមានបន្ទុកក្នុងការផ្គត់ផ្គង់ដល់តម្រូវការរបស់បងប្អូនដែរ។

ដ្បិត មានសេចក្តីចែងទុក

សាវ័កបានយោងទៅគម្ពីរនិក្ខមនំ។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «ដូចអ្វីដែលលោកម៉ូសេបានចែងទុក»

generated on Wed Sep 10 16:16:32 2025

ក៏មិនខ្វះទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលមានអ្វីគ្រប់យ៉ាងដែលលោកមានតម្រូវការ»
2 Corinthians 8:16
ដែលបានដាក់នៅក្នុងដួងចិត្តរបស់លោកទីតុសឲ្យមានដួងចិត្តដូចជាខ្ញុំដែរ ក្នុងការមើលថែបងប្អូន
ឃ្លាថា «ដួងចិត្ត» នៅទីនេះសំដៅទៅលើអារម្មណ៍។
មានន័យថាព្រះជាម្ចាស់ធ្វើឲ្យលោកទីតុសស្រលាញ់ដល់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត:
«ជាអ្នកដែលធ្វើឲ្យលោកទីតុសយកចិត្តទុកដាក់បងប្អូនដូចដែលខ្ញុំបានធ្វើ»
ក្នុងការមើលថែ
«មានចិត្តសាទរដូចគ្នា» ឬ«មានការព្រួយបារម្ភណ៍ខ្លាំងដូចគ្នា»
ដ្បិត គាត់មិនមែនគ្រាន់តែទទួលការស្នើសុំរបស់យើងនោះទេ
សាវ័កប៉ូលបានថ្លែងពីសំនួររបស់លោកទៅ
លោកទីតុសដើម្បីត្រលប់មកពីក្រុងកូរិនថូស ហើយបង្ហើយការប្រមូលដង្វាយ»
ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតលោកមិនគ្រាន់តែមិនយល់ស្រប
ទៅកាន់សំណើររបស់យើងទេ តែថែមទាំងលោកជួយបងប្អូនពីការប្រមូលដង្វាយ»
2 Corinthians 8:18
ជាមួយគាត់
«ជាមួយលោកទីតុស»
បងប្អូនផ្សេងទៀត មកជាមួយគាត់គឺជាអ្នកដែលមានការសរសើរនៅតាមក្រុមជំនុំផ្សេងៗ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនដែលជាអ្នកជឿក្នុងចំពោះការសរសើរដម្កើងតាមពួកជំនុំ»
មិនតែប៉ុណ្ណោះ
«មិនតែប៉ុណ្ណោះ អ្នកជឿនានាក្នុងចំណោមពួកជំនុំបានសរសើរគាត់»
គាត់ត្រូវបានជ្រើសរើសតាមរយៈក្រុមជំនុំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកជំនុំក៏បានជ្រើសរើសគាត់ដែរ»
ក្នុងការនាំយកកិច្ចការ និងទង្វើសប្បុរសរបស់យើង
«ក្នុងការនាំយកកិច្ចការ និងទង្វើសប្បុរសរបស់យើង»។
នេះសំដៅលើការប្រមូលដង្វាយយកដាក់នៅក្រុងយេរូសាឡិម។
ដើម្បីបង្ហាញពីចិត្តឆេះឆួលចង់ជួយយើងដែរ
«បង្ហាញពីចិត្តឆេះឆួលចង់ជួយ»
2 Corinthians 8:20
ដែលមិនពេញចិត្តហើយបារម្ភពីដំណើរសប្បុរសនេះ ដែលយើងខ្ញុំកំពុងតែនាំចេញទៅផងដែរ
«ដែលបារម្ភពីវិធីដែលយើងគ្រប់គ្រងអំណោយសប្បុរសនេះ»។
នេះសំដៅលើការប្រមូលដង្វាយទៅឲ្យក្រុងយេរូសាឡិម។
ពួកយើងយកចិត្តទុកដាក់ក្នុងការធ្វើការនេះដោយស្មោះត្រង់
«យើងយកចិត្តទុកដាក់គ្រប់គ្រងដង្វាយនេះដោយភាពស្មោះត្រង់»
ចំពោះព្រះអម្ចាស់ឡើយ ប៉ុន្តែ នៅចំពោះមនុស្សដែរ
«នៅក្នុងគំនិតរបស់ព្រះអម្ចាស់.....នៅក្នុងគំនិតរបស់មនុស្ស»
2 Corinthians 8:22
ជាមួយពួកគេ
ឃ្លាថា «ពួកគេ» នៅទីនេះសំដៅទៅលើលោកទីតុស
និងបងប្អូនដែលបានរៀបរាប់ពីមុន។
គាត់គឺជាគូកនរបស់ខ្ញុំ ហើយក៏ជាអ្នករួមការងារសម្រាប់បងប្អូន
«គាត់គឺជាគូកនរបស់ខ្ញុំដែលធ្វើការជាមួយខ្ញុំដើម្បីជួយបងប្អូន»
ដ្បិត បងប្អូនទាំងនោះ
នេះសំដៅលើមនុស្ស២នាក់ក្នុងចំណោមអ្នកដទៃដែលបានរួមដំណើរជាមួយនឹងលោកទីតុស។
ក្រុមជំនុំជាអ្នកចាត់ឲ្យពួកគេទៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកជំនុំជាច្រើនបានចាត់ឲ្យពួកគេទៅ»
ពួកគេទាំងនោះគោរពកោតខ្លាចព្រះគ្រិស្ត
អ្នកអាចបកប្រែដោយប្រើផ្នាល់មាត់បាន។ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេនឹងនាំអ្នកទាំងនោះគោរពកោតខ្លាចព្រះគ្រីស្ត»

---

9 [1]ទាក់ទងនឹងព័ន្ធកិច្ចសម្រាប់បងប្អូនអ្នកជឿ មិនចាំបាច់ឲ្យខ្ញុំសរសេរសំបុត្រមកកាន់បងប្អូននោះ។[2]ខ្ញុំស្គាល់ពីបំណងចិត្តរបស់បងប្អូន
ហើយខ្ញុំក៏មានអំនួតដោយសារបងប្អូនដែលនៅស្រុកម៉ាសេដូនដែរ។ ខ្ញុំបានប្រាប់ពួកគេថា អ្នកស្រុកអាខៃបានរៀបចំខ្ញុំជាស្រេច តាំងពីឆ្នាំមុនមកម្ល៉េះ។
ទឹកចិត្តរបស់បងប្អូនបានធ្វើឲ្យពួកគេភាគច្រើនទទួលការលើកទឹកចិត្ត ហើយមានសកម្មភាពផងដែរ។
[3]ឥឡូវ ខ្ញុំបានចាត់បងប្អូនច្រើនទៀត ដើម្បីកុំឲ្យការដែលយើងមានអំនួតលើបងប្អូនទៅជាឥតប្រយោជន៍ និងដើម្បីឲ្យបងប្អូនបានរួចរាល់ដែរ
ដូចជាពាក្យដែលខ្ញុំបាននិយាយរួចមកហើយពីបងប្អូននោះ។[4]ម៉្យាងវិញទៀត ប្រសិនបើ មានអ្នកស្រុកម៉ាសេដូនទៅជាមួយខ្ញុំដែរនោះហើយឃើញថា
បងប្អូនបានត្រៀមខ្លួននោះ ពួកយើងនឹងទទួលការអាម៉ាសវិញមិនខាន ពួកគេអាចគិតថា ខ្ញុំមិនបាននិយាយអ្វីមកបងប្អូន តែមានទំនុកចិត្តលើបងប្អូនពេក។[5]ដូច្នេះ
ខ្ញុំគិតថាវាគឺជាការសំខាន់ ក្នុងការជំរុញឲ្យបងប្អូនទាំងនោះ មករកបងប្អូនហើយដើម្បីឲ្យបងប្អូន បានត្រៀមរៀបចំទុកជាមុន
នូវអំណោយទានដែលបងប្អូនបានសន្យានោះ។ ធ្វើដូច្នេះ បងប្អូននឹងអាចរួចរាល់សម្រាប់ជាព្រះពរ ហើយវាក៏មិនមែនជាការបន្ទាន់ពេកដែរ។
[6]ចំណុចសំខាន់គឺនៅត្រង់នេះ អ្នកណាព្រោះតិច នឹងច្រូតបានតិច ហើយអ្នកដែលព្រោះសម្រាប់គោលបំណងនៃព្រះពរ នោះនឹងច្រូតមកវិញជាមួយព្រះពរដែរ។
[7]សូមឲ្យគ្រប់គ្នាថ្វាយតាមការសម្រេចនៅក្នុងចិត្តរបស់គេចុះ។ សូមកុំឲ្យការថ្វាយនោះចេញពីការឈឺចាប់ ឬដោយការបង្ខិតបង្ខំឡើយ។ ដ្បិត
ព្រះជាម្ចាស់សព្វព្រះហឫទ័យជាមួយអ្នកថ្វាយដោយអំណរ។
[8]ហើយ ព្រះជាម្ចាស់នឹងប្រទានគ្រប់ទាំងព្រះពរ ឲ្យចម្រើនឡើង សម្រាប់បងប្អូន ដូច្នេះ ក្នុងគ្រប់ការទាំងអស់ នោះបងប្អូននឹងបានទទួលអ្វីដែលតាមតម្រូវការជានិច្ច។
ការនេះនឹងកើតឡើង ដើម្បីឲ្យបងប្អូនចម្រើនឡើងនៅក្នុងការដ៏ល្អ។[9]ដ្បិត មានសេចក្តីចែងទុកមកថា៖ «ព្រះជាម្ចាស់ចែកទ្រព្យរបស់ព្រះអង្គ ហើយប្រទានឲ្យអ្នកក្រ។
សេចក្តីសុចរិតរបស់ព្រះអង្គនៅស្ថិតស្ថេរ រហូតតរៀងទៅ»។
[10]ព្រះជាម្ចាស់ដែលប្រទានគ្រាប់ពូជដល់អ្នកដែលសាបព្រោះ និងនំបុ័ងសម្រាប់ជាអាហារដែរ ហើយព្រះអង្គនឹងផ្គត់ផ្គង់ឲ្យមានចម្រើនដល់គ្រាប់ពូជរបស់បងប្អូន
សម្រាប់សាបព្រោះផង។ ព្រះជាម្ចាស់នឹងធ្វើឲ្យរីកចម្រើន ក្នុងរដូវច្រូតកាត់នៃសេចក្តីសុចរិតរបស់បងប្អូន។[11]បងប្អូននឹងទៅអ្នកមានគ្រប់របស់ទាំងអស់ ដើម្បី
បងប្អូនអាចធ្វើការសប្បុរសបាន។ ការនេះនឹងនាំឲ្យមានការអរព្រះគុណដល់ព្រះជាម្ចាស់តាមរយៈយើងដែរ។
[12]ដ្បិត ការបន្តធ្វើការនេះ វាមិនគ្រាន់តែបានជួយបំពេញសេចក្តីខ្វះខាតរបស់បងប្អូនដែលជាអ្នកជឿប៉ុណ្ណោះទេ។
តែវាក៏ធ្វើឲ្យមានការអរព្រះគុណដល់ព្រះជាម្ចាស់ជាច្រើនថែមទៀតដែរ។[13]ដោយសារបងប្អូនត្រូវបានសាកល្បង ហើយទទួលស្គាល់តាមរយៈការបម្រើនេះ
បងប្អូននឹងថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់តាមរយៈការស្តាប់បង្គាប់ និងការទទួលពីដំណឹងល្អនៃព្រះគ្រិស្ត។ បងប្អូនក៏នឹងថ្វាយសិរីល្អដល់ព្រះជាម្ចាស់
តាមរយៈសេចក្តីសប្បុរសនៃអំណោយរបស់បងប្អូនឲ្យទៅពួកគេ និងអ្នកដដែលទៀតដែរ។[14]ពួកគេរង់ចាំដើម្បីជួបបងប្អូន ហើយពួកគេក៏អធិស្ឋានសម្រាប់បងប្អូនដែរ។
ពួកគេធ្វើការនេះ ដោយសារព្រះគុណដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ដែលនៅក្នុងបងប្អូន។[15]សូមអរព្រះគុណទៅដល់ព្រះជាម្ចាស់
សម្រាប់ព្រះអំណោយទានដែលមិនអាចរៀបរាប់អស់។

---

2 Corinthians 9:1
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបន្តអំពីការថ្វាយ។
លោកចង់ប្រាកដថាការប្រមូលដង្វាយរបស់ពួកគេសម្រាប់តំរូវការរបស់អ្នកជឿក្នុងក្រុងយេរូសាឡិម
ដែលបានកើតឡើងនៅមុនពេលដែលគាត់មកដល់ ដូច្នេះហាក់មិនដូចជា
គាត់ទទួលប្រយោជន៍នៃពួកគេ។ គាត់និយាយអំពីការឲ្យពរអ្នកថ្វាយ
ហើយនឹងលើកដម្កើងព្រះជាម្ចាស់។
ព័ត៌មានទូទៅ៖
នៅពេលសាវ័កប៉ូលសំដៅលើអ្នកស្រុកអាខៃ
គាត់ក៏និយាយអំពីស្រុករូម៉ាំងមួយដែលស្ថិតនៅភាពខាងត្បូងនៃប្រទេសក្រិចដែលក្រុងកូរិនថូសនៅទីនោះ។
ព័ន្ធកិច្ចសម្រាប់បងប្អូនអ្នកជឿ
នេះសំដៅលើការប្រមូលដង្វាយដើម្បីឲ្យទៅអ្នកជឿក្នុងក្រុងយេរូសាឡិម។

generated on Wed Sep 10 16:16:32 2025

អត្ថន័យពេញលេញនៃសេចក្តីថ្លែងនេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ព័ន្ធកិច្ចសម្រាប់អ្នកជឿក្នុងក្រុងយេរូសាឡឹម»
អ្នកស្រុកអាខៃបានរៀបចំខ្ញុំជាស្រេច
ពាក្យថា «អ្នកស្រុកអាខៃ» នៅទីនេះសំដៅទៅលើមនុស្សដែលរស់នៅក្នុងខេត្តនេះ
ជាងនេះទៅទៀតទៅលើសមាជិកពួកជំនុំក្នុងក្រុងកូរិនថូស។
ការបកប្រែរបៀបផ្សេងទៀត: «ប្រជាជននៃស្រុកអាខៃដែលបានរៀបចំរួចរាល់»
2 Corinthians 9:3
បងប្អូនច្រើនទៀត
នេះសំដៅលើលោកទីតុស
ហើយនឹងមនុស្ស២នាក់ទៀតដែលរួមដំណើរជាមួយគាត់។
យើងមានអំនួតលើបងប្អូនទៅជាឥតប្រយោជន៍
សាវ័កប៉ូលមិនចង់ឲ្យអ្នកដទៃគិតពីការដែលលោកមានអំនួតពីអ្នករស់នៅក្រុងកូរិនថូសនោះ
បងប្អូនបានមិនត្រៀមខ្លួននោះ
«ដឹងថាបងប្អូនមិនបានរៀបចំទុកជាមុនសម្រាប់ការថ្វាយ»
ខ្ញុំមិនបាននិយាយអ្វីមកបងប្អូន
សាវ័កប៉ូលបានប្រើពាក្យផ្ទួយដើម្បីបញ្ជាក់ពីការដូចគ្នាអំពីអ្នករស់នៅក្រុងកូរិនថូស។
ការបកប្រែរបៀបផ្សេងទៀត: «ហើយបងប្អូននឹងរឹតតែអៀនខ្មាសថែមទៀត»
បងប្អូនទាំងនោះ មករកបងប្អូន
ពីទស្សនៈរបស់សាវ័កប៉ូល បងប្អូនទាំងនោះនឹងទៅ។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនទាំងនោះនឹងទៅរកបងប្អូន»
វាក៏មិនមែនជាការបន្ទាន់ពេកដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«មិនមែនជាអ្វីដែលយើងបានបង្ខំឱ្យបងប្អូនថ្វាយទេ»
2 Corinthians 9:6
អ្នកណាព្រោះតិច នឹងច្រូតបានតិច ហើយអ្នកដែលព្រោះសម្រាប់គោលបំណងនៃព្រះពរ
នោះនឹងច្រូតមកវិញជាមួយព្រះពរដែរ
សាវ័កប៉ូលបានប្រើប្រាស់រូបភាពពីកសិករម្នាក់ដែលកំពុងសាបព្រួសគ្រាប់ពូជ
ដើម្បីបញ្ជាក់ពីលទ្ធផលនៃការថ្វាយ។
ការប្រមូលផលរបស់កសិករអាស្រ័យលើការសាបព្រោះប៉ុណ្ណា
ដូចជាព្រះពររបស់ព្រះជាម្ចាស់ច្រើន
ឬតិចអាស្រ័យលើអ្នករស់នៅទីក្រុងកូរិនថូសថ្វាយដោយចិត្តសប្បុរស។
ថ្វាយតាមការសម្រេចនៅក្នុងចិត្តរបស់គេចុះ
ឃ្លាថា «ដួងចិត្ត» នៅទីនេះសំដៅទៅលើគិនិត និងអារម្មណ៍។
ការបកប្រែរបៀបផ្សេងទៀត: «ថ្វាយតាមការសម្រេចចិត្ត»
ពីការឈឺចាប់ ឬដោយការបង្ខិតបង្ខំឡើយ
អ្នកអាចបកប្រែដោយផ្ទាល់មាត់បាន។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយព្រោះតែគេមានអារម្មណ៍ថាខុសឆ្គង ឬនរណាម្នាក់បង្ខិតបង្ខំគេ»
ព្រះជាម្ចាស់សព្វព្រះហឫទ័យជាមួយអ្នកថ្វាយដោយអំណរ
ព្រះជាម្ចាស់ចង់ឲ្យមនុស្សថ្វាយដោយក្តីរីករាយដើម្បីជួយផ្គត់ផ្គង់ដល់អ្នកជឿដទៃទៀត។
2 Corinthians 9:8
ព្រះជាម្ចាស់នឹងប្រទានគ្រប់ទាំងព្រះពរ ឲ្យចម្រើនឡើង សម្រាប់បងប្អូន
«ព្រះជាម្ចាស់នឹងចម្រើនគ្រប់ទាំងព្រះពរដល់បងប្អូន។»
ដូចអ្នកដែលបានផ្តល់ផ្នែកហរិញ្ញវត្ថុសម្រាប់អ្នកជឿផ្សេងទៀត
ហើយព្រះជាម្ចាស់ក៏ប្រទានពរថែមទៀតដល់អ្នកថ្វាយដើម្បីឲ្យថ្វាយទទួលបានអ្វីដែលនៅសល់ដែលត្រូវចែកចាយ
ដើម្បីឲ្យបងប្អូនចម្រើនឡើងនៅក្នុងការដ៏ល្អ
«ដើម្បីអោយបងប្អូនមានលទ្ធភាពធ្វើអំពើល្អកាន់តែច្រើនឡើងៗ»
ដ្បិត មានសេចក្តីចែងទុកថា
«នេះមានសេចក្តីចែងទុកថា។» នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត: «នេះជាអ្វីដែលអ្នកនិពន្ធ»
2 Corinthians 9:10
ព្រះជាម្ចាស់ដែលប្រទាន
«ទ្រង់ដែលអ្នកប្រទាន»
នំប៉័ងសម្រាប់ជាអាហារ
ឃ្លាថា «នំប៉័ង» នៅទីនេះសំដៅទៅលើជាទូទៅជាអាហារ។
ការបកប្រែរបៀបផ្សេងទៀត: «អាហារសម្រាប់ញ៉ាំ»
នឹងផ្គត់ផ្គង់ឲ្យមានចម្រើនដល់គ្រាប់ពូជរបស់បងប្អូន សម្រាប់សាបព្រោះផង
សាវ័កប៉ូលថ្លែងពីទ្រព្យរបស់អ្នករស់នៅក្រុងកូរិនថូសប្រៀបដូចជាគ្រាប់ពូជ
ហើយការផ្តល់ឲ្យអ្នកដទៃប្រៀបដូចជាការសាបព្រោះ។ ការបកប្រែរបៀបផ្សេងទៀត:
«នឹងផ្តត់ផ្គង់ឲ្យបានចម្រើនដល់ទ្រព្យសម្បត្តិរបស់បងប្អូនដែលបងប្អូនអាចសាបព្រោះវាដោយការផ្តល់ឲ្យដ
ព្រះជាម្ចាស់នឹងធ្វើឲ្យភែកចម្រើន ក្នុងរដូវច្រូតកាត់នៃសេចក្តីសុចរិតរបស់បងប្អូន
សាវ័កប៉ូលប្រៀបធៀបអត្ថប្រយោជន៍ដែលអ្នករស់នៅទីក្រុងកូរិនថូសនឹងទទួលបានចិត្តសប្បុរសរបស់ពួក
ការបកប្រែរបៀបផ្សេងទៀត:
«ដោយសារការថ្វាយទានបងប្អូនបន្ថែមទៀតចំពោះសេចក្តីសុចរិតរបស់បងប្អូន»
ក្នុងរដូវច្រូតកាត់នៃសេចក្តីសុចរិតរបស់បងប្អូន
«រដូវច្រូតកាត់ដែលបានមកពីសកម្មភាពសុចរិតរបស់បងប្អូន។» ពាក្យថា
«សេចក្តីសុចរិត» នៅទីនេះសំដៅទៅលើសកម្មភាពសុចរិតនៃអ្នករស់នៅទីក្រុងកូរិន
ថូសក្នុងការផ្តល់ធនធានរបស់ពួកគេទៅអ្នកជឿក្នុងទីក្រុងយេរូសាឡិម។
បងប្អូននឹងទៅអ្នកមានគ្រប់របស់ទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងប្រទានពរឲ្យបងប្អូនមានគ្រប់របស់ទាំងអស»
ការនេះនឹងនាំឲ្យមានការអរព្រះគុណដល់ព្រះជាម្ចាស់តាមរយៈយើងដែរ
ពាក្យនេះសំដៅលើសេចក្តីសប្បុរសរបស់អ្នករស់នៅទីក្រុងកូរិនថូស។
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារភាពសប្បុរសរបស់បងប្អូន
អ្នកណាដែលទទួលអំណោយទានដែលពួកយើងនាំយកទៅ
នោះពួកគេនឹងថ្លែងអំណរគុណដល់ព្រះ» ឬ
«និងនៅពេលយើងផ្តល់អំណោយរបស់អ្នកណាដែលត្រូវការអំណោយទានទាំងនោះ
នោះពួកគេនឹងថ្លែងអំណរគុណដល់ព្រះ»
2 Corinthians 9:12
ដ្បិត ការបន្តធ្វើការនេះ
ពាក្យថា «ធ្វើការ» នៅទីនេះសំដៅទៅលើ សាវ័កប៉ូល
ហើយនឹងសហការីរបស់លោកនាំយកវិភាគទានទៅអ្នកជឿនៅក្រុងយេរូសាឡិម។
ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតការបន្តធ្វើការរបស់យើងសម្រាប់អ្នកជឿនៅក្រុងយេរូសាឡិម»
តែវាក៏ធ្វើឲ្យមានការអរព្រះគុណដល់ព្រះជាម្ចាស់ជាច្រើនថែមទៀតដែរ
សាវ័កប៉ូលបានថ្លែងពីអំពីសកម្មភាពនៃការបម្រើរបស់អ្នកជឿនៅក្រុងកូរិនថូសរបៀបដូចជាអ្វីមួយដែលធ្វើ
ការបកប្រែរបៀបផ្សេងទៀត:
«វាក៏ធ្វើឱ្យការប្រព្រឹត្តរបស់មនុស្សមាននឹងអរគុណព្រះជាម្ចាស់កាន់តែច្រើនឡើង»
ដោយសារបងប្អូនត្រូវបានសាកល្បង ហើយទទួលស្គាល់តាមរយៈការបម្រើនេះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយសារបងប្អូនត្រូវបានសាកល្បង និងបើកបង្ហាញ តាមរយៈការបម្រើនេះ»
បងប្អូនក៏នឹងថ្វាយសិរីល្អដល់ព្រះជាម្ចាស់
តាមរយៈសេចក្តីសប្បុរសនៃអំណោយរបស់បងប្អូនឲ្យទៅពួកគេ និងអ្នកដដែលទៀតដែរ
សាវ័កប៉ូលថ្លែងពីអ្នកនៅក្រុងកូរិនថូសលើកដម្កើងព្រះជាម្ចាស់
ទាំងមានភាពស្មោះត្រង់ជាមួយព្រះយេស៊ូ
និងថ្វាយដោយចិត្តសប្បុរសទៅកាន់អ្នកជឿផ្សេងទៀតមានតម្រូវការ។
សម្រាប់ព្រះអំណោយទានដែលមិនអាចរៀបរាប់អស់
«មិនមានពាក្យណាដែលសាកសមជាមួយនឹងព្រះអំណោយទានរបស់ព្រះបានឡើយ»។
អាចមានន័យថា ១) អំណោយទាននេះសំដៅលើ «ព្រះគុណដ៏ធំមហិមា»
ដែលព្រះជាម្ចាស់បានប្រទានឲ្យអ្នកនៅក្រុងកូរិនថូស
ដែលនាំឲ្យពួកគេមានចិត្តសប្បុរស ឬ ២)
អំណោយទាននេះសំដៅលើព្រះយេស៊ូគ្រិស្ត
ដែលព្រះជាម្ចាស់បានប្រទានឲ្យអ្នកជឿទាំងអស់

---

10 [1]ខ្ញុំ ប៉ូល សូមបង្ហាញខ្លួនខ្ញុំដល់បងប្អូន ដោយបន្ទាបខ្លួន និងសុភាពនៅក្នុងព្រះគ្រិស្ត។ ខ្ញុំស្លូតបូតនៅពេលដែលខ្ញុំរស់នៅជាបងប្អូន ប៉ុន្តែ
ខ្ញុំបែរជាក្លាហានចំពោះបងប្អូននៅពេលខ្ញុំនៅឆ្ងាយពីបងប្អូនវិញ។ [2]ខ្ញុំសុំដល់បងប្អូនថា នៅពេលដែលខ្ញុំនៅជាមួយបងប្អូន ខ្ញុំមិនបាច់ត្រូវការសេចក្តីក្លាហាន
និងទំនុកចិត្តនោះទេ។ ប៉ុន្តែ ខ្ញុំគិតថា ខ្ញុំនឹងត្រូវការសេចក្តីក្លាហាន នៅពេលដែលខ្ញុំទាស់ជាមួយអ្នកដែលគិតថា ពួកយើងរស់ដោយខាងឯសាច់ឈាមវិញ។
[3]ដ្បិត ពួកយើងរស់នៅក្នុងសាច់ឈាមក៏ដោយ ប៉ុន្តែ យើងមិនបានតយុទ្ធតាមរយៈសាច់ឈាមនេះទេ។ [4]ដ្បិត អាវុធរបស់យើងប្រើ មិនមែនជាអាវុធខាងឯសាច់ឈាមទេ។
ផ្ទុយទៅវិញ អាវុធទាំងនោះគឺមកពីព្រះចេស្តា ដើម្បីបំផ្លាញទីរឹងមាំរបស់សត្រូវ។ គ្រប់ការនោះនឹងរំលំចុះ ហើយគេរកយល់មិនឃើញឡើយ។

generated on Wed Sep 10 16:16:32 2025

[5]យើងក៏នឹងវាយរំលំការដែលនៅទីខ្ពស់ ដែលទាស់ប្រឆាំងជាមួយចំណេះដឹងរបស់ព្រះជាម្ចាស់។ យើងនឹងដោះគ្រប់ទាំងគំនិតដែលជាប់ចំណង
ឲ្យបានស្ដាប់បង្គាប់ព្រះគ្រិស្តវិញ។[6]ហើយយើងរៀបចំរួចរាល់ដើម្បីជំនុំជម្រះ ដល់អស់ទាំងទង្វើនៃការមិនស្ដាប់បង្គាប់
គឺនៅណាដែលបងប្អូនបានស្ដាប់បង្គាប់ទាំងស្រុងហើយ។
[7]ចូរមើលទៅអ្វីដែលមាននៅចំពោះបងប្អូន។ ប្រសិនបើ នរណាបានជឿថាព្រះអង្គគឺជាព្រះគ្រិស្ត សូមអ្នកនោះរំលឹកខ្លួនឯងថា គឺគាត់ដូចជាព្រះគ្រិស្ត
ហើយពួកយើងក៏ដូចដែរ។[8]ដ្បិត ទោះបើជាខ្ញុំអួតបន្តិចបន្តួចអំពីសិទ្ធិអំណាចក្តី ដែលព្រះអម្ចាស់បានប្រទានដល់យើង គឺដើម្បីស្អាងបងប្អូនឡើង
មិនមែនឲ្យបងប្អូនបាក់ទឹកចិត្តឡើយ ហើយខ្ញុំក៏មិនបានធ្វើឲ្យបងប្អូនទទួលការអាម៉ាស់ដែរ។
[9]ខ្ញុំមិនចង់ឲ្យបងប្អូនយល់ឃើញថា ខ្ញុំមិនបានធ្វើឲ្យបងប្អូនភ័យខ្លាចដោយសារសំបុត្ររបស់ខ្ញុំនោះទេ។[10]ដ្បិត មានអ្នកខ្លះនិយាយថា៖ «ពាក្យក្នុងសំបុត្ររបស់ប៉ូលធ្ងន់ៗ
ណាស់ ហើយក៏តឹងរ៉ឹងផង តែពេលគាត់នៅទីនេះ គាត់មិនហ៊ានធ្វើអ្វីនរណាទេ ហើយក៏គ្មានវោហារអ្វីដែរ»។
[11]សូមឲ្យមនុស្សបែបនេះបានដឹងថា ពាក្យដែលនៅក្នុងសំបុត្ររបស់យើងយ៉ាងណា ទោះបីជាយើងមិននៅក្តី តែទង្វើរបស់យើងក៏ដូចជាអ្វីដែរ ពេលយើងនៅជាមួយ។
[12]យើងមិនបាននិយាយឲ្យអ្នកណាផ្សេងនោះទេ គឺនិយាយតែក្នុងក្រុមយើងតែប៉ុណ្ណោះ ក៏មិនបានប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកចេះតែសរសើរខ្លួនឯងនោះដែរ។ ប៉ុន្តែ
ពេលគេពិចារណាខ្លួនពួកគេ ដោយម្នាក់ៗនោះ ក៏ប្រៀបធៀបខ្លួនពួកគេជាមួយម្នាក់ នោះពួកគេគ្មានប្រាជ្ញាទេ។
[13]ទោះជាយ៉ាងណាក្តី យើងមិនបានអួតហួសកម្រិតឡើយ។ ផ្ទុយទៅវិញ យើងមានអំនួតជាមួយអ្វីដែលព្រះជាម្ចាស់បានប្រទានដល់ពួកយើង
ក្នុងកម្រិតមួយអាចធ្វើទៅបាន។[14]ដ្បិត យើងមិនបានធ្វើហួសព្រំដែនរបស់ខ្លួនយើងនោះទេ នៅពេលដែលយើងធ្វើមកកាន់បងប្អូន។ ពួកយើងគឺជាអ្នកដំបូងគេដែលត្រូវ
ឈោងចាប់ដរាបណាយើងនៅជាមួយដំណឹងល្អនៃព្រះគ្រិស្ត។
[15]ពួកយើងមិនបានមានអំនួត ឲ្យលើសពីកម្រិតអំពីការងាររបស់អ្នកផ្សេងនោះទេ។ ផ្ទុយទៅវិញ យើងសង្ឃឹមថាសេចក្តីជំនឿរបស់បងប្អូនបានលូតលាស់
នៅទីកន្លែងដែលយើងបម្រើ ហើយកិច្ចការនឹងចម្រើនឡើងកាន់តែធំ ការនេះនៅតែក្នុងកម្រិតមួយដែលទទួលយកបាន។[16]ពួកយើងសង្ឃឹមពីការនេះ ដូច្នេះ
ពួកយើងនឹងអាចប្រកាសដំណឹងល្អ ទៅស្រុកជិតខាងបងប្អូនដែរ។ យើងមិនបានអួតពីការងាររបស់អ្នកដទៃបានធ្វើនោះទេ។
[17]«ប៉ុន្តែ សូមឲ្យអ្នកដែលអួតនោះ គួរអួតតែពីព្រះជាម្ចាស់បានហើយ»។[18]ដ្បិត គឺមិនមែនអ្នកដែលតាំងខ្លួនឯង ហើយចេះតែមានអំនួតនោះទេ។ ផ្ទុយទៅវិញ
គឺជាម្នាក់ដែលព្រះអម្ចាស់តែងតាំងវិញ ទើបគួរអួតនោះ។

---

2 Corinthians 10:1

ប្រយោគភ្ជាប់៖

សាវ័កប៉ូលផ្លាស់ប្តូរប្រធានបទពីការថ្វាយទៅជាបញ្ជាក់ពីសិទ្ធិអំណាចរបស់គាត់ក្នុងការ

ដោយបន្ទាបខ្លួន និងសុភាពនៅក្នុងព្រះគ្រិស្ត

ពាក្យថា «បន្ទាបខ្លួន» និង «សុភាព» គឺជានាមអរូបី
ហើយអាចបង្ហាញតាមរបៀបផ្សេងទៀត។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំបន្ទាបខ្លួន
និងសុភាពដោយព្រោះតែព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំមានដោយរបៀបនេះ»

ដែលគិតថា

«ដែលយល់ថា»

ពួកយើងរស់ដោយខាងឯសាច់ឈាមវិញ

ពាក្យថា «សាច់ឈាម»
គឺជាពាក្យបៀបធៀបទៅនឹងធម្មជាតិរបស់មនុស្សមានបាប។
«យើងកំពុងប្រព្រឹត្តពីទង្វើរបស់មនុស្ស»

2 Corinthians 10:3

ពួកយើងរស់នៅក្នុងសាច់ឈាម

ពាក្យថា «សាច់ឈាម» គឺជាពាក្យបៀបធៀបទៅនឹងជីវិតខាងសាច់ឈាម។
ការបកប្រែរបៀបផ្សេងទៀត:
«យើងមានជីវិតក្នុងរាងកាយនៃសាច់ឈាមរបស់យើង»

យើងមិនបានតយុទ្ធតាមរយៈសាច់ឈាមនេះទេ។ 4ដ្បិត អាវុធរបស់យើង

សាវ័កប៉ូលថ្លែងពីការសាកល្បងរបស់លោក
ក្នុងការនិយាយដើម្បីឲ្យអ្នកនៅក្រុងកូរិនថូសជឿជាក់លើលោក
ដែលមិនជាគ្រូក្លែងក្លាយ ប្រៀបដូចជាការតយុទ្ធជាមួយនឹងសង្គ្រាមសាច់ឈាម។
ឃ្លានេះគួរតែបកប្រែឲ្យចំៗ។

តយុទ្ធតាមរយៈសាច់ឈាមនេះ

អាចមានន័យថា ១) ពាក្យថា «សាច់ឈាម»
គឺជាពាក្យបៀបធៀបទៅនឹងជីវិតសាច់ឈាម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រយុទ្ធនឹងសត្រូវយើងដោយអាវុធសាច់ឈាម» ឬ ២) ពាក្យថា «សាច់ឈាម»
គឺជាពាក្យបៀបធៀបទៅនឹងធម្មជាតិរបស់មនុស្សមានបាប។
ការបកប្រែរបៀបផ្សេងទៀត: «តយុទ្ធផ្លូវ នៃអំពើបាប»

ដ្បិតអាវុធរបស់យើងប្រើ មិនមែនជាអាវុធខាងឯសាច់ឈាមទេ។ ផ្ទុយទៅវិញ

អាវុធទាំងនោះគឺមកពីព្រះចេស្តា ដើម្បីបំផ្លាញទីរឹងមាំរបស់សត្រូវ។ គ្រប់ការនោះនឹងរំលំចុះ

ហើយគេរកយល់មិនឃើញឡើយ

សាវ័កប៉ូលថ្លែងពីប្រាជ្ញាដែលមកពីព្រះ ដែលបង្ហាញថា
ប្រាជ្ញារបស់មនុស្សគឺខុសឆ្គង
ប្រៀបដូចជាអាវុធដែលគាត់បំផ្លាញដល់បន្ទាយរបស់ខ្មាំងសត្រូវ។
ការបកប្រែរបៀបផ្សេងទៀត:
«អាវុធដែលយើងប្រើជាមួយ.....ដើម្បីបង្ហាញមនុស្សឃើញថាអ្វីដែលសត្រូវយើងនិយាយ

មិនមែនជាអាវុធខាងឯសាច់ឈាមទេ

អាចមានន័យថា ១) ពាក្យថា
[illegible]ប្រៀបធៀបទៅនឹងគ្រាន់តែជារូបកាយ។
ការបកប្រែរបៀបផ្សេងទៀត: «មិនមែនជារូបកាយឡើយ» ឬ២) ពាក្យថា
«សាច់ឈាម» គឺជាពាក្យបៀបធៀបទៅនឹងធម្មជាតិរបស់មនុស្សមានបាប។
ការបកប្រែរបៀបផ្សេងទៀត: «មិនមែនជាអំពើបាបឡើយ» ឬ
«មិនត្រូវអនុញ្ញាតឲ្យខ្លួនឯងធ្វើខុសឡើយ»

2 Corinthians 10:5

ការដែលនៅទីខ្ពស់ ដែលទាស់ប្រឆាំង

សាវ័កប៉ូលថ្លែងពីពាក្យប្រៀបធៀបនេះទៅនឹងសង្គ្រាម ប្រៀបដូចជា
«ចំណេះដឹងរបស់ព្រះជាម្ចាស់» ដែលជាទាហាន ហើយនឹង «ការដែលនៅទីខ្ពស់»
ដែលជាជញ្ជាំងរបងដែលមនុស្សធ្វើឡើងដើម្បីឲ្យទាហាននៅខាងក្រៅ។
ការបកប្រែរបៀបផ្សេងទៀត:
«រាល់ជម្លោះខុសឆ្គងដែលមនុស្សមានអំណួតគិតថាជាដើម្បីជាការពារខ្លួនឯង»

ការដែលនៅទីខ្ពស់

«គ្រប់យ៉ាងដែលមនុស្សមានអំនួតតែងតែធ្វើ»

ដែលទាស់ប្រឆាំងជាមួយចំណេះដឹងរបស់ព្រះជាម្ចាស់

សាវ័កប៉ូលថ្លែងពីជម្លោះប្រៀបដូចជាជញ្ជាំងក្រុងដែលឈរនៅទីខ្ពស់តទាល់នឹងទាហាន។
ឃ្លាថា «ទាស់ប្រឆាំង» មានន័យថា «ឈរនៅទីខ្ពស់» មិនមែន
«អ្វីដែលខ្ពស់ឡើយ» ដែលអណ្តែតឡើងលើអាកាស។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សធ្វើដូច្នេះពួកគេនឹងមិនដឹងថាព្រះជាម្ចាស់ជាអ្នកណាឡើយ»

យើងនឹងដោះគ្រប់ទាំងគំនិតដែលជាប់ចំណង ឲ្យបានស្ដាប់បង្គាប់ព្រះគ្រិស្តវិញ

សាវ័កប៉ូលថ្លែងគំនិតរបស់មនុស្សប្រៀបដូចជាទាហានសត្រូវដែលលោកចាប់បានក្នុងចម្បាំង។
ការបកប្រែរបៀបផ្សេងទៀត: «ពួកយើងបង្ហាញពីរបៀបដែលគំនិតខុសឆ្គង
ដែលមនុស្សទាំងនោះមានគឺខុស ហើយបង្រៀនមនុស្សឱ្យគោរពតាមព្រះគ្រិស្ត»

ជំនុំជម្រះ ដល់អស់ទាំងទង្វើនៃការមិនស្ដាប់បង្គាប់

ឃ្លាថា «ទង្វើនៃការមិនស្ដាប់បង្គាប់»
គឺជាពាក្យបៀបធៀបទៅនឹងមនុស្សដែលបានប្រពឹត្តទង្វើទាំងនោះ។
ការបកប្រែរបៀបផ្សេងទៀត: «ជំនុំជម្រះអ្នករាល់គ្នាដែលមិនស្ដាប់បង្គាប់យើង»

2 Corinthians 10:7

ចូរមើលទៅអ្វីដែលមាននៅចំពោះបងប្អូន

អាចមានន័យថា ១) នេះជាបទបញ្ញត្តិ ឬនេះគឺជាការថ្លែង
"បងប្អូនមើលឃើញតែអ្វីដែលអ្នកអាចមើលឃើញដោយភ្នែករបស់អ្នកតែប៉ុណ្ណោះ»។
អ្នកខ្លះគិតថានេះជាសំណួរវោហារសាស្ត្រដែលអាចត្រូវបានសរសេរជាការថ្លែងមួយ។
ការបកប្រែរបៀបផ្សេងទៀត:
«តើបងប្អូនកំពុងមើលអ្វីដែលច្បាស់នៅចំពោះមុខបងប្អូន?»
ឬ«បងប្អូនហាក់ដូចជាមិនអាចមើលឃើញអ្វីដែលច្បាស់នៅចំពោះមុខបងប្អូនឡើយ»

[illegible]

generated on Wed Sep 10 16:16:32 2025

«អ្នកនោះត្រូវតែចងចាំ»
គឺគាត់ដូចជាព្រះគ្រិស្ត ហើយពួកយើងក៏ដូចដែរ
«គឺយើងជាកម្មសិទ្ធរបស់ព្រះគ្រិស្ត ដោយពួកយើងដូចគ្នានឹងទ្រង់ដែរ»
ដើម្បីស្អាងបងប្អូនឡើង មិនមែនឲ្យបងប្អូនបាក់ទឹកចិត្តឡើយ
សាវ័កប៉ូលថ្លែងពីការជួយសង្គ្រោះអ្នកនៅក្រុងកូរិនថូសដើម្បីឲ្យបានស្គាល់ព្រះគ្រិស្តកាន់តែច្បាស់
ប្រៀបដូចជា«អ្នកទាំងនោះកំពុងកសាងអាគារមួយ» ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីជួយឲ្យបងប្អូនក្លាយជា អ្នកដើរតាមព្រះគ្រិស្តប្រសើរឡើង
មិនមែនឲ្យបងប្អូនបាក់ទឹកចិត្តឡើយដើម្បីបងប្អូនអាចនឹងឈប់ដើរតាមទ្រង់»
2 Corinthians 10:9
ខ្ញុំធ្វើឲ្យបងប្អូនភ័យខ្លាច
«ខ្ញុំព្យាយាមធ្វើឲ្យបងប្អូនតក់ស្លុត»
ធ្ងន់ៗណាស់ ហើយក៏តឹងរ៉ឹងផង
«ដែលមានការទាមទារនិងបង្ខំ»
2 Corinthians 10:11
សូមឲ្យមនុស្សបែបនេះបានដឹងថា
«ខ្ញុំចង់ឲ្យមនុស្សបែបនេះបានដឹងថា»
ពាក្យដែលនៅក្នុងសំបុត្ររបស់យើងយ៉ាងណា ទោះបីជាយើងមិននៅក្តី
តែទង្វើរបស់យើងក៏ដូចជាអ្វីដែរ ពេលយើងនៅជាមួយ។
«យើងនឹងធ្វើការដូចគ្នា
នៅពេលដែលយើងនៅទីនោះជាមួយបងប្អូនដូចអ្វីដែលបានយើងបានសរសេរក្នុងសំបុត្រមកកាន់បងប្អូន
យើង.....របស់យើង
ពាក្យទាំងនេះសំដៅទៅលើក្រុមការងាររបស់សាវ័កប៉ូលតែមិនមែនអ្នកនៅក្រុងកូរិនថូសនោះ
ក្នុងក្រុមយើងតែប៉ុណ្ណោះ ក៏មិនបានប្រៀបធៀប
«ចូរថ្លែងថាយើងបានល្អដូច»
ពេលគេពិចារណាខ្លួនពួកគេ ដោយម្នាក់ៗនោះ ក៏ប្រៀបធៀបខ្លួនពួកគេជាមួយម្នាក់ នោះ
សាវ័កប៉ូលថ្លែងដូចគ្នាពីរដង។
ប្រៀបធៀបខ្លួនពួកគេជាមួយម្នាក់ នោះ
សាវ័កប៉ូលថ្លែងពីសេចក្តីល្អដូចជាអ្វីដែលមនុស្សអាចវាស់បាន។
ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេមើលគ្នាហើយព្យាយាមមើលថាអ្នកណាល្អជាងខ្លួនឯង»
គ្មានប្រាជ្ញាទេ
«បង្ហាញអ្នករាល់គ្នាថាពួកគេមិនដឹងអ្វីទាំងអស់»
2 Corinthians 10:13
ព័ត៌មានទូទៅ៖
សាវ័កប៉ូលថ្លែងពីសិទ្ធិអំណាចដែលលោកមានប្រៀបដូចជាដែនដីដែលគាត់គ្រប់គ្រង
ការទាំងនោះដែលគាត់មានសិទ្ធិអំណាចស្ថិតតាមព្រំដែនឬ «កម្រិត»
នៃទឹកដីរបស់គាត់
និងការផ្សេងទៀតដែលមិនស្ថិតនៅក្រោមសិទ្ធអំណាចរបស់គាត់ដែលហួសពីការ
«កម្រិត»។
យើងមិនបានអួតហួសកម្រិតឡើយ
នេះជាសំនួនវោហារ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងនឹងមិនអួតពីអ្វីដែលយើងគ្មានសិទ្ធអំណាចឡើយ» ឬ
«នឹងអួតតែពីអ្វីដែលយើងមានសិទ្ធិអំណាច»
ជាមួយអ្វីដែលព្រះជាម្ចាស់បានប្រទានដល់
«ជាមួយអ្វីដែលនៅក្រោមសិទ្ធអំណាចដែលព្រះជាម្ចាស់»
ក្នុងកម្រិតមួយអាចធ្វើទៅបាន
សាវ័កប៉ូលថ្លែងពីសិទ្ធិអំណាចដែលលោកមានដូចជាដែនដីដែលគាត់គ្រប់គ្រង។
ការបកប្រែរបៀបផ្សេងទៀត:
«ហើយបងប្អូនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់យើង»
មិនបានធ្វើហួសព្រំដែនរបស់ខ្លួនយើងនោះទេ
«មិនបានធ្វើហួសព្រំដែនរបស់យើងទេ»
2 Corinthians 10:15
មិនបានមានអំនួត ឲ្យលើសពីកម្រិត
នេះជាសំនួនវោហារ។ ការបកប្រែរបៀបផ្សេងទៀត:
«មិនមានអំណួតពីអ្វីដែលយើងគ្មានសិទ្ធិអំណាចឡើយ»
ឬ«ក៏មិនមានអំណួតពីអ្វីដែលយើងមានសិទ្ធិអំណាចឡើយ។»
ការបកប្រែរបៀបផ្សេងទៀត: ឃ្លានេះ
នៅទីកន្លែងដែលយើងបម្រើ ហើយកិច្ចការនឹងចម្រើនឡើងកាន់តែធំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ពង្រីកទីកន្លែងការងាររបស់យើងឲ្យចម្រើនឡើងកាន់តែធំ»
ពីការងាររបស់អ្នកដទៃ
«ព្រះជាម្ចាស់បានប្រគល់ការងារផ្សេងទៀត ដល់អ្នកផ្សេង»
2 Corinthians 10:17
គួរអួតតែពីព្រះជាម្ចាស់បានហើយ
«អួតអំពីអ្វីដែលព្រះអម្ចាស់បានធ្វើ»
តាំងខ្លួនឯង
នេះមានន័យថាគាត់ផ្តល់ឱ្យមនុស្សម្នាក់ៗបានសួរសម្រាប់អ្នកដែលបានស្តាប់គាត់សម្រេចចិត្តថាតើគាត់ត្រូ
សូមមើលពីរបៀប «តាំងខ្លួនឯង» បកប្រែក្នុងជំពូក ៤:១។
ដែលត្រូវយល់ស្រប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលត្រូវបានព្រះជាម្ចាស់ពេញចិត្ត»
គឺជាម្នាក់ដែលព្រះអម្ចាស់តែងតាំងវិញ ទើបគួរអួតនោះ
បងប្អូនអាចធ្វើឱ្យច្បាស់នូវព័ត៌មានដែលបានយល់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលព្រះជាម្ចាស់បានតែងតាំង គឺជាអ្នកដែលព្រះជាម្ចាស់ពេញចិត្ត»

---

11 [1]ខ្ញុំសូមឲ្យបងប្អូនអត់ឱនដល់ភាពល្ងីល្ងើរបស់ខ្ញុំ។ ប៉ុន្តែ បងប្អូនបានអត់ឱនឲ្យខ្ញុំមែន![2]ដ្បិត ខ្ញុំបានប្រច័ណ្ឌជាមួយនឹងបងប្អូន។
ខ្ញុំមានចិត្តប្រច័ណ្ឌរបស់ព្រះជាម្ចាស់ជាមួយនឹងបងប្អូនដែរ ចាប់តាំងពីខ្ញុំបានសន្យាដល់បងប្អូន ចូររៀបការជាមួយប្តីតែមួយ។ ខ្ញុំបានសន្យាថានឹងនាំបងប្អូនមក
ដូចជាស្ត្រីព្រហ្មចារីបរិសុទ្ធទៅចំពោះព្រះគ្រិស្ត។
[3]ប៉ុន្តែ ពេលខ្លះខ្ញុំបារម្ភថា ដូចជាសត្វពស់ដែលល្បួងនាងអេវ៉ាជាមួយភាពវៃឆ្លាតរបស់វា ដូច្នេះ
គំនិតរបស់អ្នករាល់គ្នាអាចនឹងវង្វេងចេញឆ្ងាយពីពួកអ្នកដែលញែកខ្លួនជាបរិសុទ្ធចំពោះព្រះគ្រិស្ត។[4]ដ្បិត ឧបមាថា មានអ្នកផ្សេងមកហើយប្រកាស
អំពីយេស៊ូផ្សេងមួយទៀត ដែលមិនមែនជាព្រះជាម្ចាស់យេស៊ូដែលយើងបានប្រកាសវិញ។ ឬឧបមាថាបងប្អូនទទួលវិញ្ញាណផ្សេងទៀត
ដែលមិនមែនជាព្រះវិញ្ញាណដែលបងប្អូនបានទទួល។ ឬឧបមាថា បងប្អូនទទួលដំណឹងល្អផ្សេងទៀត ដែលមិនមែនដំណឹងល្អដែលបងប្អូនធ្លាប់ទទួលតាមរយៈយើង។
បងប្អូនបានជ្រើសរើសធ្វើការនេះ បានយ៉ាងល្អហើយ!
[5]ដ្បិត ខ្ញុំគិតថាខ្ញុំមិនមែនតូចជាងគេ នៅក្នុងចំណោមអ្នកដែលត្រូវបានហៅថា ពួកសាវ័កខ្ពង់ខ្ពស់នោះទេ។[6]ប៉ុន្តែ បើទោះបីជាខ្ញុំមិនបានទទួលការបង្វឹកបង្វឺន
ដើម្បីប្រកាសព្រះបន្ទូលក្តី និងមិនបានទទួលការបង្វឹកបង្វឺន ក្នុងការចេះដឹងក៏ដោយ។ ក្នុងគ្រប់ទាំងផ្លូវ និងក្នុងគ្រប់ការទាំងអស់ យើងបានធ្វើឲ្យបងប្អូនបានដឹងការពិត។
[7]តើខ្ញុំបានធ្វើបានឬអី ដែលបន្ទាបខ្លួនដើម្បីឲ្យបងប្អូនត្រូវបានលើកតម្កើងឡើងនោះ? ដ្បិត ខ្ញុំបានប្រកាសដំណឹងល្អដល់បងប្អូនដោយការពេញចិត្ត។
[8]ខ្ញុំបានជំពាក់ដល់ក្រុមជំនុំឯទៀត តាមរយៈទទួលការជួយឧបត្ថម្ភគាំទ្រពីពួកគេ ដូច្នេះហើយបានជាខ្ញុំបម្រើបងប្អូនវិញ។[9]ពេលខ្ញុំនៅជាមួយបងប្អូននោះ
ខ្ញុំពិតជាមានការខ្វះខាត ប៉ុន្តែ ខ្ញុំមិនបានប្រាប់ឲ្យបងប្អូនបារម្ភឡើយ។ ដោយសារតែខ្ញុំបានទទួលជំនួយពីបងប្អូននៅស្រុកម៉ាសេដូនវិញ។
ខ្ញុំបានការពារខ្លួនឯងពីការដែលធ្វើឲ្យខ្លួនខ្ញុំក្លាយជាបន្ទុកដល់បងប្អូនឡើយ ហើយខ្ញុំនឹងបន្តធ្វើការនេះទៅមុខទៀតដែរ។
[10]ក្នុងនាមខ្ញុំដែលមានសេចក្តីពិតរបស់ព្រះគ្រិស្តនៅជាមួយ អំនួតរបស់ខ្ញុំនឹងមិនអាចក្លាយជាស្ងៀមស្ងាត់នៅក្នុងស្រុកអាខៃឡើយ។[11]ហេតុអ្វី?
ដោយសារខ្ញុំមិនស្រឡាញ់បងប្អូនទេឬ? មានតែព្រះជាម្ចាស់ទេ ជ្រាប់ពីចិត្តខ្ញុំ។
[12]ហើយអ្វីដែលខ្ញុំធ្វើនោះខ្ញុំនឹងបន្តធ្វើទៀត ក្នុងរបៀបដែលខ្ញុំនឹងដកចេញ អំពីការរិះគន់ដល់ខ្ញុំ ហើយដកអំនួតចេញពីពួកអ្នក ដែលយើងរកឃើញថា
គេមានលេសក្នុងការនិយាយថា បានធ្វើការដូចជាយើងកំពុងធ្វើដែរ។[13]ដ្បិតមានមនុស្សជាច្រើនគឺជាសាវកក្លែងក្លាយ ហើយជាអ្នកបម្រើបោកប្រាស់។
ពួកគេបានក្លែងខ្លួនពួកគេថាជាសាវ័កនៃព្រះគ្រិស្ត។
[14]ហើយការនេះមិនភ្ញាក់ផ្អើលទេ ដ្បិតសាតាំងក៏បានក្លែងថាខ្លួនជាទេវតានៃពន្លឺដែរ។[15]បែបនេះគ្មានអីគួរឲ្យភ្ញាក់ផ្អើលនោះទេ បើពួកបរិវាររបស់វាក្លែងខ្លួនរបស់ពួកគេនោះ
ដោយថាវាគឺជាអ្នកបម្រើដ៏សុចរិត។ ហើយជោគវាសនារបស់ពួកវានឹងទទួលអ្វីដែលវាសមនិងទទួលជាពិត។

generated on Wed Sep 10 16:16:32 2025

[16]ខ្ញុំនិយាយម្តងទៀត សូមកុំឲ្យអ្នកគិតថាខ្ញុំជាមនុស្សល្ងង់ឡើយ។ តែបើបងប្អូនគិតបែបនេះ ហើយទទួលខ្ញុំដូចជាមនុស្សល្ងង់ នោះខ្ញុំប្រហែលអំនួតបន្តិចបន្តួចដែរ។
[17]អ្វីដែលខ្ញុំកំពុងនិយាយអំពីការសេចក្តីអំនួត គឺមិនមែនមិនគាំទ្រដោយព្រះអម្ចាស់នោះទេ តែខ្ញុំនិយាយបែបដូចជាមនុស្សលេលាវិញ។
[18]មនុស្សឯទៀតគេអួតពីអ្វីដែលខាងសាច់ឈាម ឯខ្ញុំក៏មានអំនួតនៅក្នុងព្រះជាម្ចាស់ដែរ។
[19]ដ្បិត បងប្អូនរីករាយហើយអាចទ្រាំ ជាមួយនឹងសេចក្តីល្ងង់ខ្លៅបាន។ បងប្អូនមានភាពវ័យឆ្លាតណាស់![20]ដ្បិត បងប្អូនអាចទ្រាំទ្រជាមួយនឹងអ្នក ដែលត្រួតត្រាលើបងប្អូន អ្នកដែលចង់ប្រើបងប្អូន ហើយប្រសិនបើ គេរកប្រយោជន៍ពីបងប្អូន អ្នកដែលគិតថាគេប្រសើរជាងបងប្អូន ឬអ្នកដែលទះកំផ្លៀងបងប្អូន។
[21]ខ្ញុំនឹងនិយាយទៅកាន់ភាពអាម៉ាស់របស់យើងថា យើងពិតជាគ្មានកម្លាំងគ្រប់គ្រាន់ក្នុងការធ្វើការនោះទេ។ ដូច្នេះហើយ បើមាននរណាម្នាក់មានអំនួត
ខ្ញុំនិយាយបែបល្ងង់ខ្លៅថា អ្នកដែលមានអំនួតនោះគួរតែខ្ញុំទេ។
[22]តើពួកគេជាជនជាតិហេព្រើរឬ? ខ្ញុំក៏ជាជនជាតិហេព្រើរដែរ។ តើពួកគេជាជនជាតិអ៊ីស្រាអែលឬ? ខ្ញុំក៏ជាជនជាតិអ៊ីស្រាអែលដែរ។ តើពួកគេជាពូជពង្សរបស់លោក
អប្រាហាំឬ? ខ្ញុំក៏ជាពូជពង្សរបស់លោកអប្រាហាំម្នាក់ដែរ។[23]តើពួកគេគឺជាអ្នកបម្រើរបស់ព្រះគ្រិស្តឬ? (ខ្ញុំនិយាយការនេះទាំងគិតថាខ្លួនជាមនុស្សគ្មានស្មារតី)
ខ្ញុំបម្រើច្រើនជាងផង។ ខ្ញុំបានធ្វើការខ្លាំងជាងផង ខ្ញុំត្រូវជាប់ឃុំឃាំងជាយូរ ខ្ញុំត្រូវរងការវាយដំលើសកម្រិត ហើយប្រឈមមុខជានឹងគ្រោះថ្នាក់ដល់ស្លាប់ជាច្រើនដងផង។
[24]ខ្ញុំត្រូវបានគេវាយសែបសិបរំពាត់ ខ្វះមួយ ចំនួនប្រាំដងពីជនជាតិយូដា។[25]បីដងដែលខ្ញុំត្រូវបានគេវាយនឹងដំបង។ ម្តងនោះខ្ញុំត្រូវបានគប់ដោយដុំថ្ម។ ខ្ញុំត្រូវលិចសំពៅបីដង។ ពេញមួយថ្ងៃនិងមួយយប់ ដែលខ្ញុំបានអណ្តែតនៅលើសមុទ្រ។[26]ពេលខ្ញុំធ្វើដំណើរជាញឹកញាប់ ជួបគ្រោះថ្នាក់តាមទន្លេ និងគ្រោះថ្នាក់ដោយសារចោរប្លន់ និងគ្រោះ
ថ្នាក់មកពីជនជាតិរបស់ខ្ញុំ និងគ្រោះថ្នាក់មកពីសាសន៍ដទៃផង គ្រោះថ្នាក់ក្នុងទីក្រុង គ្រោះថ្នាក់នៅទីរហោស្ថាន គ្រោះថ្នាក់នៅក្នុងសមុទ្រ គ្រោះថ្នាក់ព្រោះតែពួកបងប្អូន
ក្លែងក្លាយ។
[27]ខ្ញុំបានធ្វើការយ៉ាងនឿយហត់ ហើយក្នុងពេលដ៏លំបាក មិនបានដេកពេលយប់ អត់អាហារ និងស្រេកទឹកជាច្រើនដង ហើយជារឿយៗតែងតែតមអត់ ត្រូវរងា និង
អាក្រាតផង។[28]ការផ្សេងពីនេះទៀតនោះ គឺខ្ញុំខ្វល់ខ្វាយរៀងរាល់ថ្ងៃ ដោយគិតដល់ក្រុមជំនុំទាំងអស់ដែរ។[29]តើនរណាខ្សោយ តើខ្ញុំមែនទេឬ?
តើមានអ្នកណាត្រូវគេធ្វើឲ្យជំពប់ដួល នោះខ្ញុំមិនឈឺចាប់ទេឬអី?
[30]ប្រសិនបើ ខ្ញុំត្រូវអួតខ្លួន នោះខ្ញុំនឹងអួតតែអំពីភាពកម្សោយរបស់ខ្ញុំប៉ុណ្ណោះ។[31]ព្រះជាម្ចាស់ និងព្រះបិតារបស់ព្រះអម្ចាស់យេស៊ូ ព្រះអង្គនឹងទទួលការសរសើរជារៀងរហូត
ហើយព្រះអង្គជ្រាបថាខ្ញុំមិនបានកុហកនោះទេ!។
[32]នៅក្រុងដាម៉ាស លោកអភិបាលក្រោមស្តេចអើរេតាសបានដាក់ទាហានឲ្យយាមទ្វារក្រុងរបស់ដាម៉ាស ដើម្បីចាំចាប់ខ្ញុំ។[33]ប៉ុន្តែ គេបានដាក់ខ្ញុំក្នុងជាលមួយសម្រួតចុះតាម
បង្អួចកំពែង ហើយខ្ញុំបានគេចផុតពីដៃរបស់គាត់។

---

2 Corinthians 11:1
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបន្តអះអាងពីភាពជាសាវ័ករបស់លោក។
អត់ឱនដល់ភាពល្ងីល្ងើរបស់ខ្ញុំ
«អនុញ្ញាតឱ្យខ្ញុំធ្វើដូចជាមនុស្សល្ងីល្ងើ»
ប្រច័ណ្ឌ.....ចិត្តប្រច័ណ្ឌ
ពាក្យទាំងនេះថ្លែងពីការល្អ
មានបំណងខ្លាំងចង់អោយអ្នកនៅក្រុងកូរិនថូសមានភាពស្មោះត្រង់នឹងព្រះគ្រិស្ត
ហើយកុំអោយនរណាម្នាក់បញ្ចុះបញ្ចូលគាត់អោយចាកចេញពីព្រះអង្គឡើយ។
ខ្ញុំបានសន្យាដល់បងប្អូន ចូររៀបការជាមួយប្តីតែមួយ។ ខ្ញុំបានសន្យាថានឹងនាំបងប្អូនមក
ដូចជាស្ត្រីព្រហ្មចារីបរិសុទ្ធទៅចំពោះព្រះគ្រិស្ត
សាវ័កប៉ូលថ្លែងពីការយកចិត្តទុកដាក់របស់គាត់ចំពោះអ្នកជឿនៅក្រុងកូរិនថូស
ដូចជាលោកបានសន្យាជាមួយបុរសម្នាក់ផ្សេងទៀតថា
គាត់នឹងរៀបចំកូនស្រីរបស់គាត់ឱ្យរៀបការជាមួយគេ
ហើយគាត់មានការព្រួយបារម្ភបំផុត
ដែលគាត់អាចរក្សាការសន្យារបស់គាត់ចំពោះបុរសនោះ។
2 Corinthians 11:3
ប៉ុន្តែ ពេលខ្លះខ្ញុំបារម្ភថា ដូចជាសត្វពស់ដែលល្បួងនាងអេវ៉ាជាមួយភាពវៃឆ្លាតរបស់វា ដូច្នេះ
គំនិតរបស់អ្នករាល់គ្នាអាចនឹងវង្វេងចេញឆ្ងាយពីពួកអ្នកដែលញែកខ្លួនជាបរិសុទ្ធចំពោះព្រះគ្រិស្ត
ប៉ុន្តែខ្ញុំខ្លាចថាគំនិតខ្លះរបស់បងប្អូនអាចត្រូវបានដឹកនាំខុសពីភក្តីភាពដ៏ស្មោះត្រង់ចំពោះ
គំនិតរបស់អ្នករាល់គ្នាអាចនឹងវង្វេងចេញឆ្ងាយ
សាវ័កប៉ូលថ្លែងពីគំនិតដូចជាពួកគេជាសត្វដែលមនុស្សអាចនាំផ្លូវខុសបាន។
ការបកប្រែរបៀបផ្សេងទៀត: «នរណាម្នាក់អាចធ្វើឱ្យអ្នកជឿការកុហក»
ដ្បិត ឧបមាថា មានអ្នកផ្សេងមក
«នៅពេលដែលនរណាម្នាក់មក»
វិញ្ញាណផ្សេងទៀត ដែលមិនមែនជាព្រះវិញ្ញាណដែលបងប្អូនបានទទួល។ ឬឧបមាថា
បងប្អូនទទួលដំណឹងល្អផ្សេងទៀត ដែលមិនមែនដំណឹងល្អដែលបងប្អូនធ្លាប់ទទួល
«ជាវិញ្ញាណខុសពីព្រះវិញ្ញាណបរិសុទ្ធ ឬដំណឹងល្អដែលផ្សេងៗទៀត
ដែលអ្នកបានទទួលពីពួកយើង»
បានជ្រើសរើសធ្វើការនេះ
«ដោះស្រាយជាមួយរឿងទាំងនេះ» សូមមើលពីរបៀបបកប្រែក្នុងជំពូក ១១:១។
2 Corinthians 11:5
នៅក្នុងចំណោមអ្នកដែលត្រូវបានហៅថា ពួកសាវ័កខ្ពង់ខ្ពស់
ត្រូវបានហៅថា ពួកសាវ័កខ្ពង់ខ្ពស់-
សាវ័កប៉ូលប្រើពាក្យមិនសមរម្យនៅទីនេះដើម្បីបង្ហាញថាពួកគេមិនសូវសំខាន់ទេ
បន្ទាប់ពីពួកគេអះអាងនោះ។ ការបកប្រែរបៀបផ្សេងទៀត: «ត្រូវទាំងនោះ
ដែលអ្នកខ្លះគិតថាប្រសើរជាងគ្រូដទៃទៀត»
2 Corinthians 11:7
តើខ្ញុំបានធ្វើបានឬអី ដែលបន្ទាបខ្លួនដើម្បីឲ្យបងប្អូនត្រូវបានលើកតម្កើងឡើងនោះ?
សាវ័កប៉ូលចាប់ផ្តើមអះអាងថាគាត់បានប្រព្រឹត្តល្អចំពោះអ្នកនៅក្រុងកូរិនថូស។
សំនួរដែលមិនទាមទារចម្លើយនេះអាចបកប្រែជាការថ្លែង បើចាំបាច់។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំគិតថាយើងយល់ស្របថាខ្ញុំមិនបានធ្វើបាបឡើយ
ដោយបន្ទាបខ្លួនដើម្បីឲ្យបងប្អូនត្រូវបានលើកតម្កើង»
ដោយការពេញចិត្ត
«ដោយមិនរំពឹងការតបស្នង ពីបងប្អូនឡើយ»
ខ្ញុំបានជំពាក់ដល់ក្រុមជំនុំឯទៀត
នេះជាការបំផ្លើសមួយដើម្បីបញ្ជាក់ថាសាវ័កប៉ូលបានយកដង្វាយពីព្រះវិហារផ្សេងទៀត។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានយកដង្វាយពីព្រះវិហារឯទៀត»
ខ្ញុំបម្រើបងប្អូនវិញ
អត្ថន័យពេញលេញនៃការនេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំអាចបម្រើបងប្អូនបានដោយមិនគិតថ្លៃ»
ខ្ញុំបានការពារខ្លួនឯងពីការដែលធ្វើឲ្យខ្លួនខ្ញុំក្លាយជាបន្ទុកដល់បងប្អូនឡើយ
«ខ្ញុំមិនបានធ្វើជាបន្ទុកផ្នែកហិរញ្ញវត្ថុដល់បងប្អូនទេ។
"សាវ័កប៉ូលថ្លែងពីជនណាម្នាក់ដែលត្រូវបានគេបង់ថ្លៃជំនួស ដូចជាវត្ថុដ៏ធ្ងន់
ដែលអ្នកនោះត្រូវលីសែង។
អត្ថន័យដែលជាប្រយោគនៃការអះអាងរបស់គាត់ដែលថាគាត់ជាសាវ័ក
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបានធ្វើអស់ពីសមត្ថភាពដើម្បីធ្វើឱ្យប្រាកដថា
បងប្អូនមិនចាំបាច់បង់ថ្លៃដើម្បីឱ្យខ្ញុំអាចនៅជាមួយបងប្អូនបានឡើយ»
ពីបងប្អូននៅ
«បងប្អូន» ទាំងនេះប្រហែលជាប្រុសទាំងអស់.
ខ្ញុំនឹងបន្តធ្វើការនេះទៅមុខទៀតដែរ
«ខ្ញុំមិនដែលធ្វើជាបន្ទុកដល់បងប្អូនទេ»
2 Corinthians 11:10
ក្នុងនាមខ្ញុំដែលមានសេចក្តីពិតរបស់ព្រះគ្រិស្ត
«សាវ័កប៉ូលបញ្ជាក់ថាដោយសារតែអ្នកអានរបស់គាត់ដឹងថាគាត់បានថ្លែងពីសេចក្តីពិតរបស់ព្រះគ្រីស្តពួក
«ដូចបងប្អូនបានដឹងថា ខ្ញុំពិតជាដឹងហើយប្រកាសសេចក្តីពិតរបស់ព្រះគ្រិស្ត
ដែលបងប្អូនអាចដឹងថាអ្វីដែលខ្ញុំកំពុងនិយាយគឺជាសេចក្តីពិតនេះ»។
អំនួតរបស់ខ្ញុំនឹងមិនអាចក្លាយជាស្នៀមស្ងាត់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មាននរណាម្នាក់អាចធ្វើឱ្យខ្ញុំឈប់មានអំណួតខ្លួនហើយនៅស្ងៀមបានឡើយ»។
សាវ័កប៉ូលកំពុង «អួតខ្លួន» ថាគាត់ «បានប្រកាសដំណឹងល្អដោយសេរី»
នៅក្នុងស្រុកអាខៃ

generated on Wed Sep 10 16:16:32 2025

«តំបន់ នៃស្រុកអាខៃ»។ ពាក្យថា «ស្រុក» និយាយពីទីតាំងដី
មិនមែនជាការបែងចែកផ្នែកនយោបាយទេ។
ហេតុអ្វី? ដោយសារខ្ញុំមិនស្រឡាញ់បងប្អូនទេឬ?
សាវ័កប៉ូលប្រើសំណួរវោហារសាស្ត្រដើម្បីបញ្ជាក់អំពីសេចក្តីស្រឡាញ់ចំពោះអ្នកនៅក្រុងកូរិនថូស
សំណួរទាំងនេះអាចត្រូវបានបញ្ចូលគ្នាឬបង្កើតជាខ្លឹមសារមួយ។
ការបកប្រែរបៀបផ្សេងទៀត: «តើមកពីខ្ញុំមិនស្រឡាញ់បងប្អូន
ដែលខ្ញុំមិនចង់ធ្វើជាបន្ទុកដល់បងប្អូនទេ?» ឬ
«ខ្ញុំនឹងបន្តរក្សាអ្នកពីការចំណាយសម្រាប់តម្រូវការរបស់ខ្ញុំពីព្រោះនេះបង្ហាញអ្នកផ្សេងទៀតថាខ្ញុំ
ព្រះជាម្ចាស់ទេ ជ្រាប
អ្នកអាចធ្វើឱ្យច្បាស់នូវព័ត៌មានដែលបានយល់។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់ជ្រាបថាខ្ញុំស្រលាញ់បងប្អូន»
2 Corinthians 11:12
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបន្តអះអាងពីភាពជាសាវ័ករបស់លោក
ដែលលោកថ្លែងពីសាវ័កក្លែងក្លាយ។
ក្នុងរបៀបដែលខ្ញុំនឹងដកចេញ
សាវ័កប៉ូលថ្លែងពីការអះអាងមិនពិតដែលខ្មាំងសត្រូវរបស់លោកនិយាយដូចជាអ្វីដែលពួកគេធ្វើ
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះខ្ញុំអាចធ្វើឱ្យវាមិនអាចទៅរួច»
អំនួតចេញពីពួកអ្នក
ក្នុងពេលដែលសាវ័កប៉ូលបានអួតពី«ការប្រកាសដំណឹងល្អដោយសេរី» (ជំពូក១១៖
៧) តែសត្រូវរបស់លោកថា ពួកគេអាចប្រកាសប្រសើរជាង (ជំពូក១១៖៥)។
ដែលយើងរកឃើញថា គេមានលេសក្នុងការនិយាយថា បានធ្វើការដូចជាយើងកំពុងធ្វើដែរ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេទាំងនោះគិតថាពួកគេគឺដូចយើង»
ដ្បិតមានមនុស្សជាច្រើន
«ខ្ញុំនឹងធ្វើអ្វីដែលខ្ញុំអាចធ្វើបាន ព្រោះមនុស្សចូលចិត្តពួកគេ»
អ្នកបម្រើបោកប្រាស់
«អ្នកបម្រើដែលមិនស្មោះត្រង់»
ក្លែងខ្លួនពួកគេថាជាសាវ័ក
«ពួកគេព្យាយាមធ្វើខ្លួនឲ្យដូចជាសាវ័ក ទោះបីពួកគេមិនមែនជាសាវ័កក៏ដោយ»
2 Corinthians 11:14
ហើយការនេះមិនភ្ញាក់ផ្អើលទេ ដ្បិតសាតាំងក៏បានក្លែងថាខ្លួនជាទេវតានៃពន្លឺដែរ។
បែបនេះគ្មានអីគួរឲ្យភ្ញាក់ផ្អើលនោះទេ បើ
តាមរយៈការលើកឡើងនេះក្នុងទម្រង់អវិជ្ជមាន
សាវ័កប៉ូលបានសង្កត់ធ្ងន់ថាអ្នកនៅក្រុងកូរិនថូសគួរតែរំពឹងថានឹងជួប
«ពួកសាវកក្លែងក្លាយ»ជាច្រើន
ដ្បិតសាតាំងក៏បានក្លែងថាខ្លួនជាទេវតានៃពន្លឺដែរ
«សាតាំងមិនមែនជាទេវតានៃពន្លឺទេ
ប៉ុន្តែវាព្យាយាមធ្វើឱ្យខ្លួនវាមើលទៅដូចជាទេវតានៃពន្លឺ»
ពួកបរិវារបស់វាក្លែងខ្លួនរបស់ពួកគេនោះ ដោយថាវាគឺជាអ្នកបម្រើដ៏សុចរិត
«ពួកបរិវារបស់វា មិនមែនជាអ្នកបំរើនៃសេចក្តីសុចរិតនោះទេ
ប៉ុន្តែពួកវាព្យាយាមធ្វើឱ្យខ្លួនពួកវាមើលទៅដូចជាអ្នកបំរើនៃសេចក្តីសុចរិត»
2 Corinthians 11:16
ទទួលខ្ញុំដូចជាមនុស្សល្ងង់ នោះខ្ញុំប្រហែលអំនួតបន្តិចបន្តួច
«ទទួលខ្ញុំដូចដែលបងប្អូននឹងទទួលមនុស្សល្ងង់ម្នាក់៖
សូមទុកឲ្យខ្ញុំនិយាយហើយពិចារណាពីអំនួតរបស់ខ្ញុំ ដែលជាមនុស្សល្ងង់»
អ្វីដែលខ្ញុំកំពុងនិយាយអំពីការសេចក្តីអំនួត គឺមិនមែនមិនគាំទ្រដោយព្រះអម្ចាស់នោះទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់មិនប្រណីនឹងអ្វីដែលខ្ញុំបាននិយាយពីសេចក្តីអំនួតនេះទេ» ឬ
«ព្រះអម្ចាស់មិនដែលមានបន្ទូលមកខ្ញុំថា
ទ្រង់គាំទ្រនឹងអ្វីដែលខ្ញុំបាននិយាយពីសេចក្តីអំនួតរបស់នេះទេ»។
ពីអ្វីដែលខាងសាច់ឈាម
ពាក្យប្រៀបធៀបនឹង «សាច់ឈាម»
នេះសំដៅទៅលើមនុស្សដែលមាននិស្ស័យបាប និងអ្វីដែលគេបានធ្វើ។
ការបកប្រែរបៀបផ្សេងទៀត: «ពីអ្វីសមិទ្ធិផលរបស់ពួកគេ»
2 Corinthians 11:19
អាចទ្រាំ ជាមួយនឹងសេចក្តីល្ងង់ខ្លៅបាន
«ទទួលយកខ្ញុំនៅពេលដែលខ្ញុំធ្វើដូចជាល្ងង់ខ្លៅ»។
សូមមើលឃ្លាដូចគ្នាពីរបៀបបកប្រែក្នុងជំពូក ១១:១។
បងប្អូនមានភាពវ័យឆ្លាតណាស់!
សាវ័កប៉ូលធ្វើឱ្យអ្នកនៅទីក្រុងកូរិនថូសអាម៉ាស់មុខដោយប្រើពាក្យមិនសមរម្យ។
ការបកប្រែរបៀបផ្សេងទៀត: « បងប្អូនគិតថាបងប្អូនឆ្លាត
ប៉ុន្តែបងប្អូនមិនបានឆ្លាតទេ!»
បងប្អូនអាចទ្រាំទ្រ
សាវ័កប៉ូលថ្លែងពីបញ្ញាតិដែលព្រះមិនបានដាក់ ប៉ុន្តែមនុស្សខ្លះបង្ខំបងប្អូនឯទៀត
ឲ្យធ្វើតាមដូចជាទាសករ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកបង្ខំឲ្យអ្នកដទៃ
ត្រួតត្រាលើបងប្អូន
សាវ័កប៉ូលថ្លែងពីពួកសាវ័កខ្ពង់ខ្ពស់ ដែលយកធនធានសម្ភារៈពីអ្នកដទៃ
ដូចជាពួកគេកំពុងបឺតជញ្ជក់មនុស្សចឹង។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេប្លន់យកទ្រព្យសម្បត្តិទាំងអស់របស់បងប្អូន»
គេរកប្រយោជន៍ពីបងប្អូន
មនុស្សម្នាក់ឆ្លៀតយកប្រយោជន៍អ្នកដទៃ ដោយដឹងរឿងរ៉ាវដែលអ្នកដទៃមិនដឹង
ហើយប្រើចំណេះដឹងនោះដើម្បីជួយខ្លួនឯង និងធ្វើបាបអ្នកដទៃ។
ខ្ញុំនឹងនិយាយទៅកាន់ភាពអាម៉ាស់របស់យើងថា
យើងមានភាពខ្សោយ
«ខ្ញុំសូមសារភាពដោយអៀនខ្មាស់ថា
យើងមិនមានភាពក្លាហានក្នុងការប្រព្រឹត្តចំពោះបងប្អូនដូចនោះទេ»។
សាវ័កប៉ូលកំពុងប្រើពាក្យមិនសមហេតុផលដើម្បីប្រាប់អ្នកនៅក្រុងកូរិនថូសថា
វាមិនមែនដោយសារតែគាត់ខ្សោយទេ ដែលគាត់បានធ្វើល្អចំពោះពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: « ខ្ញុំមិនខ្មាសអៀនឡើយដោយនិយាយថា
ពួកយើងមានអំណាចដើម្បីធ្វើបាបបងប្អូន
ផ្ទុយទៅវិញយើងបានប្រព្រឹត្តចំពោះបងប្អូនឱ្យបានល្អ»
ដូច្នេះហើយ បើមាននរណាម្នាក់មានអំនួត ខ្ញុំនិយាយបែបលេងសើចថា
អ្នកដែលមានអំនួតនោះគួរតែខ្ញុំទេ
«ប្រសិនបើមាននរណាម្នាក់អួតពីអ្វីមួយ.....ខ្ញុំនឹងអួតពីការនោះផងដែរ»
2 Corinthians 11:22
ប្រយោគភ្ជាប់៖
នៅពេលដែលសាវ័កប៉ូលបន្តបញ្ជាក់ពីភាពជាសាវ័ករបស់លោក
លោកបានថ្លែងពីរឿងពិតដែលបានកើតឡើងចំពោះគាត់ចាប់តាំងពីគាត់បានក្លាយជាអ្នកជឿ។
តើពួកគេជាជនជាតិហេព្រើរឬ? ខ្ញុំក៏ជាជនជាតិហេព្រើរដែរ។ តើពួកគេជាជនជាតិអ៊ីស្រាអែលឬ?
ខ្ញុំក៏ជាពូជពង្សរបស់លោកអប្រាហាំឬ?
ខ្ញុំក៏ជាពូជពង្សរបស់លោកអប្រាហាំម្នាក់ដែរ។ 23តើពួកគេគឺជាអ្នកបម្រើរបស់ព្រះគ្រិស្តឬ?
(ខ្ញុំនិយាយការនេះទាំងគិតថាខ្លួនជាមនុស្សគ្មានស្មារតី) ខ្ញុំបម្រើច្រើនជាងផង
សាវ័កប៉ូលបានសួរសំណួរដែលបងប្អូននៅក្រុងកូរិនថូសអាចសួរហើយបន្ទាប់មកឆ្លើយទៅពួកគេដើម្បីបព្
បងប្អូនអាចប្រើប្រាស់ទម្រង់សំណួរនិងចម្លើយទាំងនេះ ប្រសិនបើអាច។
ការបកប្រែរបៀបផ្សេងទៀត: «ពួកគេចង់អោយបងប្អូនគិតថាពួកគេសំខាន់
ហើយជឿអ្វីដែលពួកគេនិយាយពីព្រោះពួកគេជាជនជាតិហេព្រើរ
និងអ៊ីស្រាអែលនិងជាកូនចៅរបស់លោកអប្រាហាំ។ មែនតើ ខ្ញុំអញ្ចឹងមែន។
ពួកគេនិយាយថាពួកគេជាអ្នកបំរើរបស់ព្រះគ្រិស្ត
ខ្ញុំនិយាយការនេះទាំងគិតថាខ្លួនជាមនុស្សគ្មានស្មារតី)
ប៉ុន្តែខ្ញុំបម្រើច្រើនជាងនេះផង។
ខ្លួនជាមនុស្សគ្មានស្មារតី
«ខ្លួនខ្ញុំមិនអាចគិតអ្វីឲ្យបានល្អឡើយ»
ខ្ញុំបម្រើច្រើនជាងផង
បងប្អូនអាចឲ្យយល់ច្បាស់ពីព័ត៌មានដែលបានដឹងថា។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំបំរើរបស់ព្រះគ្រិស្តច្រើនជាងពួកគេ»
ធ្វើការខ្លាំងជាងផង
«ខ្ញុំបានធ្វើការកាន់តែខ្លាំងឡើង»
ជាប់ឃុំឃាំងជាយូរ
«ខ្ញុំបានជាប់ឃុំឃាំងជាញឹកញាប់»
ត្រូវរងការវាយដំលើសកម្រិត
នេះគឺជាសំនួនវោហារ
ហើយត្រូវបានបំផ្លើសដើម្បីបញ្ជាក់ពីចំនួនដងដែលលោកត្រូវបានគេវាយដំ។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំត្រូវបានគេវាយដំជាច្រើនដង»
ប្រឈមមុខជានឹងគ្រោះថ្នាក់ដល់ស្លាប់ជាច្រើនដង
«ហើយខ្ញុំស្ទើរតែស្លាប់ជាច្រើនដង»
2 Corinthians 11:24

generated on Wed Sep 10 16:16:32 2025

សែបសិបរំពាត់ ខ្វះមួយ
នេះគឺជាការបញ្ជាទូទៅមួយ ដែលមនុស្សត្រូវបានវាយដំចំនួន ៣៩ដង។
វាយសែសិប (៤០) រំពាត់ត្រូវបានគេសន្មត់ថាអាចនឹងសម្លាប់មនុស្សបាន។
ខ្ញុំត្រូវបានគេវាយនឹងដំបង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានវាយដំខ្ញុំដោយដំបងឈើ»
ខ្ញុំត្រូវបានគប់ដោយដុំថ្ម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានគប់ដុំថ្មដាក់ខ្ញុំរហូតដល់គេគិតថាខ្ញុំបានស្លាប់ហើយ»
ពេញមួយថ្ងៃនិងមួយយប់ ដែលខ្ញុំបានអណ្តែតនៅលើសមុទ្រ
សាវ័កប៉ូលបានសំដៅលើការអណ្តែតនៅលើផ្នែសមុទ្របន្ទាប់សំពៅរបស់លោកបានលិចហើយ។
គ្រោះថ្នាក់ព្រោះតែពួកបងប្អូនក្លែងក្លាយ
អត្ថន័យទាំងមូលនៃថ្លែងការណ៍នេះអាចត្រូវបានធ្វើឱ្យច្បាស់។
ការបកប្រែរបៀបផ្សេងទៀត:
«និងគ្រោះថ្នាក់ពីមនុស្សដែលអះអាងថាជាបងប្អូនក្នុងព្រះគ្រិស្ត
ប៉ុន្តែពួកគេបានក្បត់យើង»
2 Corinthians 11:27
និងអាក្រាតផង
នៅទីនេះសាវ័កប៉ូលនិយាយបំផ្លើសដើម្បីបង្ហាញពីតម្រូវការសម្លៀកបំពាក់របស់គាត់។
ការបកប្រែរបៀបផ្សេងទៀត:
«ហើយដោយគ្មានសម្លៀកបំពាក់គ្រប់គ្រាន់ដើម្បីធ្វើឱ្យខ្ញុំកក់ក្តៅ»
តើនរណាខ្សោយ តើខ្ញុំមែនទេឬ?
នេះជាសំណួរវោហារស័ព្ទ អាចត្រូវបានបកប្រែមានន័យថា។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលណាដែលនរណាម្នាក់ខ្សោយ
ខ្ញុំមានអារម្មណ៍ថាខ្សោយដែរ»។
គឺខ្ញុំខ្វល់ខ្វាយរៀងរាល់ថ្ងៃ ដោយគិតដល់ក្រុមជំនុំទាំងអស់ដែរ
សាវ័កប៉ូលដឹងថាព្រះជាម្ចាស់នឹងចាត់លោក
ឲ្យទទួលខុសត្រូវចំពោះរបៀបដែលក្រុមជំនុំស្តាប់បង្គាប់ព្រះជាម្ចាស់
ហើយដែលថ្លែងពីការមានចំណេះដឹងនោះហាក់ដូចជាបន្ទុកដ៏ធ្ងន់ដែលរុញលោកឲ្យធ្លាក់ចុះ។
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំដឹងថាព្រះនឹងធ្វើឱ្យខ្ញុំទទួលខុសត្រូវចំពោះការរីកចម្រើនខាងវិញ្ញាណរបស់ក្រុមជំនុំទាំងអស់
ហើយដូច្នេះខ្ញុំតែងតែមានអារម្មណ៍ដូចជាវត្ថុធ្ងន់កំពុងរុញខ្ញុំធ្លាក់ចុះ»
តើនរណាខ្សោយ តើខ្ញុំមែនទេឬ?
ឃ្លាថា «ខ្សោយ» គឺប្រហែលជាពាក្យប្រៀបប្រដូចទៅនឹង ស្ថានភាពខាងវិញ្ញាណ
ប៉ុន្តែគ្មាននរណាម្នាក់ប្រាកដថាសាវ័កប៉ូលបានថ្លែងអំពីអ្វីទេ
ដូច្នេះយកល្អគួរតែប្រើពាក្យដដែលនៅទីនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំចុះខ្សោយនៅពេលណាដែលនរណាម្នាក់ទៀតបានចុះខ្សោយ»។
តើមានអ្នកណាត្រូវគេធ្វើឲ្យជំពប់ដួល នោះខ្ញុំមិនឈឺចាប់ទេឬអី?
សាវ័កប៉ូលប្រើសំណួរនេះដើម្បីបង្ហាញកំហឹងរបស់លោក
នៅពេលបងប្អូនរួមជំនឿម្នាក់ធ្វើអំពើបាប។ នៅទីនេះកំហឹងរបស់គាត់
សំដៅលើការឈឺចាប់ខាងក្នុងរបស់លោក។ នេះជាសំណួរវោហារស័ព្ទ
អាចត្រូវបានបកប្រែមានន័យថា។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលណានរណាម្នាក់ធ្វើឱ្យបងប្អូនប្រព្រឹត្តអំពើបាប នោះខ្ញុំនឹងខឹង»។
ត្រូវគេធ្វើឲ្យជំពប់ដួល
សាវ័កប៉ូលបានថ្លែងពីអំពើបាប ប្រៀបដូចជាដំណើរទៅកាន់អ្វីមួយ
ហើយបន្ទាប់មកក៏ដួលធ្លាក់។ ការបកប្រែរបៀបផ្សេងទៀត:
«ត្រូវបានគេនាំឱ្យប្រព្រឹត្តអំពើបាប» ឬ
«គិតថាព្រះជាម្ចាស់បានអនុញ្ញាតឱ្យគេប្រព្រឹត្តអំពើបាបបាន
ដោយព្រោះមាននរណាម្នាក់ផ្សេងទៀតបានធ្វើការនោះ»
នោះខ្ញុំមិនឈឺចាប់
សាវ័កប៉ូលថ្លែងពីការខឹងអំពីអំពើបាប
ប្រៀបដូចជាគាត់មានដុំភ្លើងនៅខាងក្នុងខ្លួនលោក។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំមិនខឹង» ក្នុងកាល:ទេស:នោះទេ។
2 Corinthians 11:30
អំពីភាពកម្សោយរបស់ខ្ញុំប៉ុណ្ណោះ
«បង្ហាញអ្វីដែលជាភាពកម្សោយរបស់ខ្ញុំតែប៉ុណ្ណោះ»
ខ្ញុំមិនបានកុហកនោះទេ
សាវ័កប៉ូលបានប្រើភាពស្មោះត្រង់ដើម្បីបញ្ជាក់ថាគាត់កំពុងនិយាយការពិត។
ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំកំពុងប្រាប់ការពិតទាំងស្រុង»
2 Corinthians 11:32
លោកអភិបាលក្រោមស្តេចអើរេតាសបានដាក់ទាហានឲ្យយាមទ្វារក្រុង
«លោកអភិបាលដែលស្តេចអ័រប៉ាសបានតែងតាំងបានបញ្ជាអោយទាហានយាមទីក្រុង»
ដើម្បីចាំចាប់ខ្ញុំ
ដើម្បីចាប់ខ្ញុំ
គេបានដាក់ខ្ញុំក្នុងជាល
ត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គេបានដាក់ក្នុងជាល ហើយសម្រូតខ្ញុំចុះដល់ដី»
ពីដៃរបស់គាត់
សាវ័កប៉ូលបានប្រើពាក្យថា ដៃរបស់អភិបាល ប្រៀបដូចជា ពួកអភិបាល។
ការបកប្រែរបៀបផ្សេងទៀត: «ពីពួកអភិបាល»

---

12 [1]ខ្ញុំត្រូវមានអំនួត តែគ្មានចំណេញអ្វីមកពីការនេះទេ។ ប៉ុន្តែ ខ្ញុំនឹងទៅតាមនិមិត្ត និងការបើកសម្តែងដែលមកពីព្រះអម្ចាស់វិញ។
[2]ខ្ញុំស្គាល់បុរសម្នាក់ដែលជាអ្នកជឿលើព្រះគ្រិស្ត កាលពីដប់បួនឆ្នាំមុន គឺត្រូវបានលើកឡើងទៅស្ថានសួគ៌ជាន់ទីបី ខ្ញុំក៏មិនដឹងច្បាស់ដែរថា
គាត់បានឡើងទៅតាំងរូបកាយ ឬព្រមទាំងវិញ្ញាណផងនោះ មានតែព្រះជាម្ចាស់ទេទើបជ្រាប។
[3]ហើយខ្ញុំស្គាល់បុរសនោះ ថាតើគាត់ត្រូវបានលើកឡើង នៅក្នុងរូបកាយ ឬក្រៅរូបកាយ ខ្ញុំមិនដឹងទេ តែព្រះជាម្ចាស់ជ្រាប[4]គាត់ត្រូវបានលើកឡើងទៅស្ថានសួគ៌
ហើយបានឮអ្វីដែលគួរឲ្យខ្លាច សម្រាប់មនុស្សក្នុងការនិយាយ។[5]ក្នុងនាមបុរសនេះ ខ្ញុំមានអំនួត។ ប៉ុន្តែ ក្នុងនាមខ្ញុំវិញគឺខ្ញុំនឹងមិនអួតទេ
តែបើខ្ញុំអួតគឺតែពីភាពទន់ខ្សោយរបស់ខ្ញុំវិញ។
[6]ប្រសិនបើ ជាខ្ញុំចង់អួត នោះខ្ញុំមិនមែនជាមនុស្សល្ងង់ខ្លៅទេ ដ្បិតខ្ញុំនិយាយតែការពិតវិញ។ ប៉ុន្តែ ខ្ញុំនឹងរក្សាខ្លួនមិនឲ្យមានអំនួតទេ
ដូច្នេះនឹងមិនមានអ្នកណាគិតពីខ្ញុំលើសពីអ្វីដែលពួកគេបានឃើញ និងឮពីខ្ញុំច្រើនជាងនេះ។[7]ខ្ញុំនឹងការពារខ្លួនខ្ញុំពីអំនួត ដោយព្រោះតែការបើកសម្តែងដ៏អស្ចារ្យ។ ដូច្នេះ
នោះខ្ញុំនឹងមិនអួតខ្លួនជាមួយនឹងភាពឆ្មើងឆ្មៃឡើយ បន្លាដែលនៅក្នុងសាច់ខ្ញុំគឺបានចាក់ខ្ញុំ ហើយអ្នកនាំសាររបស់សាតាំងក៏បានធ្វើទុក្ខបុកម្នេញដល់ខ្ញុំដែរ ដូច្នេះ
ខ្ញុំមិនអាចមានអំនួតបានឡើយ។
[8]បីដងដែលខ្ញុំបានទូលសូមព្រះអម្ចាស់អំពីការនេះ គឺសូមឲ្យព្រះអង្គយកការនោះចេញពីខ្ញុំ។[9]ប៉ុន្តែព្រះជាម្ចាស់មានបន្ទូលថា៖ «ព្រះគុណរបស់យើងល្មមដល់អ្នកហើយ
ដ្បិត ព្រះចេស្តារបស់ព្រះអង្គឥតខ្ចោះជាមួយនឹងភាពទន់ខ្សោយរបស់ខ្ញុំ»។ ដូច្នេះខ្ញុំអួតតែអំពីភាពទន់ខ្សោយរបស់ខ្ញុំវិញ ដើម្បីឲ្យព្រះចេស្តានៃព្រះគ្រិស្តបាននៅក្នុងខ្ញុំ។
[10]ដូច្នេះ ខ្ញុំស្កប់ចិត្តនឹងសេចក្តីកម្សោយដោយព្រោះព្រះគ្រិស្ត ទោះបីជាក្នុង គេជេរប្រមាថ មានបញ្ហាច្រើន ក្នុងការបៀតបៀន ហើយនៅក្នុងស្ថានភាពតប់ប្រមល់ក្តី។ ដ្បិត
ពេលណាដែលខ្ញុំទន់ខ្សោយ គឺពេលនោះហើយដែលខ្ញុំមានកម្លាំង។
[11]ខ្ញុំបានក្លាយទៅជាមនុស្សល្ងីល្ងើ! គឺបងប្អូនបានជំរុញខ្ញុំឲ្យធ្វើការងារនេះ ដ្បិត ខ្ញុំគួរតែបានលើកសរសើរតាមរយៈបងប្អូន។ ដ្បិត ខ្ញុំមិនអន់ជាងពួកអ្នកដែលហៅថា
មហាសាវក ទោះបីជាខ្ញុំគ្មានអ្វីទាំងអស់នោះ។[12]ទីសម្គាល់ដ៏ពិតរបស់ងារជាសាវកគឺបម្រើនៅក្នុងចំណោមបងប្អូនជាមួយនឹងការអត់ធ្មត់ ហើយជាមួយទីសម្គាល់
និងការអស្ចារ្យ ហើយនឹងឥទ្ធិឫទ្ធិផងដែរ។[13]បើដូច្នេះ តើបងប្អូនមិនសំខាន់ជាងអ្នកឯទៀតនៃក្រុមជំនុំទេឬអី លើកលែងតែខ្ញុំមិនបានរំខានដល់បងប្អូន?
សូមអត់ទោសឲ្យខ្ញុំផងអំពីការនេះ!
[14]មើល៍! ខ្ញុំបានរួចរាល់ក្នុងការទៅរកបងប្អូនជាលើកទីបី។ ខ្ញុំនឹងមិនធ្វើជាបន្ទុកដល់បងប្អូនទេ ហើយក៏មិនចង់បានអ្វីពីបងប្អូនដែរ។ ខ្ញុំចង់បានតែបងប្អូនទេ។ ដ្បិត
កូនៗមិនគួរសន្សំទ្រព្យសម្បត្តិទុកឲ្យឪពុកម្តាយទេ។ ប៉ុន្តែ ឪពុកម្តាយទេ ដែលត្រូវសន្សំទ្រព្យសម្បត្តិទុកឲ្យកូនចៅវិញ។[15]ខ្ញុំនឹងរីករាយក្នុងការចំណាយ
និងប្រើពេលទាំងអស់សម្រាប់ព្រលឹងរបស់បងប្អូន។ ប្រសិនបើ ខ្ញុំស្រឡាញ់បងប្អូនខ្លាំងយ៉ាងនេះទៅហើយ តើខ្ញុំនឹងទទួលការស្រឡាញ់តិចជាងឬអី?

generated on Wed Sep 10 16:16:32 2025

[16]ប៉ុន្តែ ដូចខ្ញុំបាននិយាយហើយ ខ្ញុំនឹងមិនធ្វើជាបន្ទុកដល់បងប្អូនទេ។ ប៉ុន្តែ នៅតែមានគេនិយាយថា ខ្ញុំមានល្បិចហើយជាអ្នកបោកប្រាស់ពីបងប្អូនដែរ។
[17]តើខ្ញុំដែលបានកេងចំណេញពីបងប្អូន ដែលខ្ញុំបានចាត់មករកបងប្អូនទេ?[18]ខ្ញុំបានអង្វរឲ្យលោកទីតុសទៅរកបងប្អូន និងអ្នកដទៃទៀតទៅជាមួយគាត់ដែរ។
តើលោកទីតុសកេងចំណេញពីបងប្អូនទេ? តើពួកយើងមិនបានដើរលើផ្លូវក្នុងតែមួយទេឬអី? តើពួកយើងមិនបានបោះជំហានតែមួយទេឬអី?
[19]តើបងប្អូនគិតថា ពួកយើងដោះសារការពារខ្លួនយើងនៅចំពោះបងប្អូនដែរមែនទេឬ? នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ យើងបាននិយាយសេចក្តីទាំងនេះ
ដើម្បីចម្រើនកម្លាំងដល់បងប្អូននៅក្នុងព្រះគ្រិស្តតែប៉ុណ្ណោះ។
[20]ដ្បិត ខ្ញុំបារម្ភថា ពេលដែលខ្ញុំមកដល់ ខ្ញុំមិនបានឃើញបងប្អូនដូចជាអ្វីដែលខ្ញុំចង់ឃើញ។ ខ្ញុំបារម្ភថា បងប្អូនមិនបានឃើញខ្ញុំ ដូចអ្វីដែលបងប្អូនចង់ឃើញដែរ។ ខ្ញុំបារម្ភ
ក្រែងលោមានការឈ្លោះប្រកែក ការឈ្នានីស កំហឹង ការប្រជែង ការនិយាយបង្កួច ការបរិហារកេរ្តិ៍ ការក្រអឺតក្រទម និងសេចក្តីវឹកវរកើតឡើង។[21]ខ្ញុំបារម្ភថា ក្រែងលោពេល
ខ្ញុំមកម្តងទៀត នោះព្រះជាម្ចាស់នៃខ្ញុំនឹងបន្ទាបខ្ញុំនៅចំពោះមុខអ្នករាល់គ្នា ហើយខ្ញុំត្រូវកើតទុក្ខចំពោះមនុស្សជាច្រើនដែលបានប្រព្រឹត្តបាបពីមុន ប៉ុន្តែ មិនប្រែចិត្តពីសេចក្តី
ស្មោកគ្រោក អំពើអសីលធម៌ខាងផ្លូវភេទ និងអំពើល្មោភកាមដែលគេបានប្រព្រឹត្ត។

---

2 Corinthians 12:1
ប្រយោគភ្ជាប់៖
ក្នុងការការពារភាពជាសាវករបស់លោកពីព្រះជាម្ចាស់
សាវ័កប៉ូលបន្តថ្លែងពីអ្វីជាក់លាក់
ហើយបានកើតឡើងចំពោះលោកចាប់តាំងពីលោកបានក្លាយជាអ្នកជឿ។
ខ្ញុំនឹងទៅតាម
«ខ្ញុំនឹងបន្តថ្លែង ប៉ុន្តែឥឡូវនេះអំពី»
និមិត្ត និងការបើកសម្តែងដែលមកពីព្រះអម្ចាស់
អាចមានន័យថា ១) សាវ័កប៉ូលបានប្រើពាក្យ «និមិត្ត» និង«ការបើកសំដែង»
ដែលមានន័យដូចគ្នា ហើយនឹងស្របគ្នាសម្រាប់ជាការបញ្ជាក់។
ការបកប្រែរបៀបផ្សេងទៀត:
«ការដែលព្រះជាម្ចាស់បានបើកសំដែងឲ្យខ្ញុំបានឃើញ» ឬ ២)
សាវ័កប៉ូលបានថ្លែងការពីរផ្សេងគ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«ការឥតកំបាំងដែលព្រះអម្ចាស់បានបើកសំដែងជាមួយភ្នែករបស់ខ្ញុំ
ហើយនឹងការឥតកំបាំងដែលព្រះអម្ចាស់មានបន្ទូលមក»
ខ្ញុំស្គាល់បុរសម្នាក់ដែលជាអ្នកជឿលើព្រះគ្រិស្ត
តាមពិតសាវ័កប៉ូលកំពុងថ្លែងពីខ្លួនគាត់
ប្រៀបដូចជាគាត់កំពុងនិយាយអំពីអ្នកផ្សេងទៀត
ប៉ុន្តែនេះគួរតែត្រូវបានបកប្រែឲ្យច្បាស់លាស់ ប្រសិនបើអាច។
ខ្ញុំក៏មិនដឹងច្បាស់ដែរថា គាត់បានឡើងទៅតាំងរូបកាយ ឬព្រមទាំងវិញ្ញាណផងនោះ
សាវ័កប៉ូលបន្តរៀបរាប់អំពីខ្លួនលោក
ដូចជាការនេះបានកើតឡើងចំពោះអ្នកដទៃទៀត។ «ខ្ញុំមិនដឹងច្បាស់ថា
តើបុរសនេះស្ថិតនៅក្នុងរូបកាយរបស់គាត់ឬរូបកាយខាងវិញ្ញាណរបស់គាត់ទេ»
មានតែព្រះជាម្ចាស់ទេទើបជ្រាប
«ព្រះជាម្ចាស់តែម្នាក់គត់ ដែលទើបជ្រាបដឹង»
ស្ថានសួគ៌ជាន់ទីបី
នេះសំដៅទៅលើកន្លែងព្រះជាម្ចាស់គង់នៅ មិនមែនលើមេឃឬលំហរខាងក្រៅ
(ភពផ្កាយនិងសកលលោក) ឡើយ។
2 Corinthians 12:3
ព័ត៌មានទូទៅ៖
សាវ័កប៉ូលបន្តថ្លែងពីខ្លួនគាត់ ដូចជាគាត់កំពុងថ្លែងពីអ្នកដទៃ។
បុរសនោះ ថាតើគាត់ត្រូវបានលើកឡើង នៅក្នុងរូបកាយ ឬក្រៅរូបកាយ ខ្ញុំមិនដឹងទេ
តែព្រះជាម្ចាស់ជ្រាប 4គាត់ត្រូវបានលើកឡើងទៅច
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
អាចមានន័យថា ១) ព្រះជាម្ចាស់បានយកបុរសនេះ.....ឡើងលើស្ថានសួគ៌»។ ២)
វេទតាបានយកបុរសនេះ...ឡើងលើស្ថានសួគ៌»។ បើអាចធ្វើបាន
វាជាការប្រសើរមិនត្រូវដាក់ឈ្មោះអ្នកដែលយកបុរសនោះទៅ:
«នរណាម្នាក់យក ... ស្ថានសួគ៌» ឬ «ពួកគេយក ... ស្ថានសួគ៌»។
ត្រូវបានលើកឡើង
ភ្លាមៗចាប់ទៅនិងចាប់ដោយបង្ខំ
ស្ថានសួគ៌
អាចមានន័យថា ១) ស្ថានបរមសុខ ឬ ២) ស្ថានសួគ៌ជាន់ទីបី ឬ
៣)កន្លែងពិសេសមួយនៅស្ថានបរមសុខ។
បុរសនេះ
«នៃបុរសនោះ»
ខ្ញុំនឹងមិនអួតទេ តែបើខ្ញុំអួតគឺតែពីភាពទន់ខ្សោយរបស់ខ្ញុំវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំនឹងអួត
តែភាពទន់ខ្សោយរបស់ខ្ញុំ»

2 Corinthians 12:6
ប្រយោគភ្ជាប់៖
សាវ័កប៉ូលការពារភាពជាសាវ័ករបស់គាត់ពីព្រះជាម្ចាស់ ដែលថ្លែងពីភាពទន់ខ្សោយ
ដែលព្រះបានប្រទានឱ្យលោក ដើម្បីឱ្យលោកចេះបន្ទាបខ្លួន។
ព័ត៌មានទូទៅ៖
សាវ័កប៉ូលថ្លែងពី «បន្លាដែលនៅក្នុងសាច់» ដែលលោកបង្ហាញថា លោកជា
«បុរស» នោះ ដែលលោកបានថ្លែងក្នុងជំពូក ១២៖០១។
ឮពីខ្ញុំច្រើនជាងនេះ។ ខ្ញុំនឹងការពារខ្លួនខ្ញុំពីអំនួត ដោយព្រោះតែការបើកសម្តែងដ៏អស្ចារ្យ។ ដូច្នេះ
នោះខ្ញុំនឹងមិនអួតខ្លួនជាមួយនឹងភាពឆ្មើងឆ្មៃឡើយ បន្លា
អត្ថន័យម៉្យាងទៀត «លើពីខ្ញុំ។ ដូច្នេះនោះខ្ញុំនឹងមិនអួតខ្លួនជាមួយនិងភាពឆ្មើងឆ្មៃ
ដោយព្រោះតែការបើកសម្តែងដ៏អស្ចារ្យ ដែលជាបន្លានោះ»។
គិតពីខ្ញុំលើសពីអ្វីដែលពួកគេបានឃើញ
«ផ្តល់ឱ្យខ្ញុំនូវកិត្តិយសច្រើនជាងអ្វីដែលពួកគេបានឃើញ»
ដោយព្រោះតែការបើកសម្តែងដ៏អស្ចារ្យ
«ដោយព្រោះតែ
ការបើកសម្តែងទាំងនោះគឺខុសពីអ្វីដែលនរណាម្នាក់ធ្លាប់បានឃើញ»
នោះខ្ញុំនឹងមិនអួតខ្លួនជាមួយនឹងភាពឆ្មើងឆ្មៃឡើយ
«ដើម្បីកុំអោយខ្ញុំមានអំនួត»
មិនអួតខ្លួន
ដោយពោលពេញទៅដោយខ្យល់ ហើយធំជាងពីធម្មតា
បន្លាដែលនៅក្នុងសាច់
បញ្ហាខាងសាច់ឈាមរបស់សាវ័កប៉ូលនៅទីនេះ ត្រូវបានប្រៀបធៀបទៅនឹង
«បន្លាមួយ» ដែលចាក់ទម្លុះ «សាច់ឈាម» របស់លោក។
ការបកប្រែរបៀបផ្សេងទៀត: «ទុក្ខវេទនា» ឬ «បញ្ហាខាងសាច់ឈាម»
អ្នកនាំសាររបស់សាតាំង
«អ្នកបម្រើរបស់សាតាំង»
ធ្វើទុក្ខបុកម្នេញដល់ខ្ញុំ
«ធ្វើទារុណកម្មដល់ខ្ញុំ»
2 Corinthians 12:8
បីដង
សាវ័កប៉ូលបានដាក់ពាក្យទាំងនេះនៅដើមនៃប្រយោគ
ដើម្បីបញ្ជាក់ថាលោកបានអធិស្ឋានជាច្រើនដងអំពី«បន្លា»របស់គាត់ (ជំពូក ១២៖
៦)។
ព្រះអម្ចាស់អំពីការនេះ
«ព្រះអម្ចាស់បានជ្រាបពីបន្លានៅក្នុងសាច់ឈាម» ឬ
«ព្រះអម្ចាស់បានជ្រាបពីទុក្ខវេទនានេះ»
ព្រះគុណរបស់យើងល្មមដល់អ្នកហើយ
ខ្ញុំនឹងមានចិត្តសប្បុរសល្អចំពោះអ្នក ហើយនោះគឺជាអ្វីដែលអ្នកត្រូវការ
ព្រះចេស្តារបស់ព្រះអង្គឥតខ្ចោះជាមួយនឹងភាពទន់ខ្សោយរបស់ខ្ញុំ
«ដ្បិតព្រះចេស្តារបស់ទ្រង់នឹងប្រសើរបំផុតនៅពេលដែលបងប្អូនទន់ខ្សោយ»
ព្រះចេស្តានៃព្រះគ្រិស្តបាននៅក្នុងខ្ញុំ
សាវ័កប៉ូលថ្លែងពីព្រះចេស្តានៃព្រះគ្រិស្តរៀបដូចជា
ក្រណាត់សំពត់ដែលគ្របបាំងលោក។ អាចមានន័យថា ១)
«មនុស្សប្រហែលជាឃើញថាខ្ញុំមានព្រះចេស្តានៃព្រះគ្រិស្ត» ឬ២)
«ខ្ញុំប្រហែលពិតជាមានព្រះចេស្តានៃព្រះគ្រិស្ត។»
ខ្ញុំស្កប់ចិត្តនឹងសេចក្តីកម្សាយដោយព្រោះព្រះគ្រិស្ត ទោះបីជាក្នុង គេជេរប្រមាថ មានបញ្ហាច្រើន
ក្នុងការបៀតបៀន ហើយនៅក្នុងស្ថានភាពតប់ប្រមល់ក្តី
អាចមានន័យថា ១) «ខ្ញុំស្កប់ចិត្តនឹងសេចក្តីកម្សាយ ការជេរប្រមាថ មានបញ្ហា

generated on Wed Sep 10 16:16:32 2025

ការបៀតបៀន និងក្នុងស្ថានភាពតប់ប្រមល់ក្តី បើការទាំងនោះបានកើតឡើង
ដោយព្រោះតែខ្ញុំជាកម្មសិទ្ធិរបស់ព្រះគ្រិស្តនោះ» ឬ ២)
ខ្ញុំស្កប់ចិត្តនឹងសេចក្តីកម្សោយ.....បើការទាំងនោះបាននាំមនុស្សជាច្រើនបានស្គាល់ព្រះអម្ចាស់
សេចក្តីកម្សោយ
«នៅពេលដែលខ្ញុំទន់ខ្សោយ»
គេជេរប្រមាថ
«នៅពេលដែលមនុស្សបានធ្វើឲ្យខ្ញុំខឹង ដោយថាខ្ញុំជាមនុស្សអាក្រក់»
មានបញ្ហាច្រើន
«នៅពេលដែលខ្ញុំរងទុក្ខវេទនា»
ស្ថានភាពតប់ប្រមល់
«នៅពេលដែលមានបញ្ហា»
ដ្បិត ពេលណាដែលខ្ញុំទន់ខ្សោយ គឺពេលនោះហើយដែលខ្ញុំមានកម្លាំង
សាវ័កប៉ូលថ្លែងពី នៅពេលដែលគាត់លែងមានកម្លាំងគ្រប់គ្រាន់
ក្នុងការធ្វើកិច្ចការអ្វីឲ្យបានសម្រេច
ព្រះគ្រិស្តដែលមានព្រះចេស្តាជាងសាវ័កប៉ូលអាចនឹងធ្វើការតាមរយៈសាវ័កប៉ូលដើម្បីឲ្យ
តែវាជាការល្អសម្រាប់ការបកប្រែពាក្យទាំងនេះឲ្យបានច្បាស់លាស់
ប្រសិនបើភាសារបស់បងប្អូនអាចប្រែបាន។
2 Corinthians 12:11
ប្រយោគភ្ជាប់៖
សាវ័កប៉ុលរំលឹកអ្នកជឿនៅទីក្រុងកូរិនថូសពីទីសំគាល់ពិតរបស់សាវ័ក
និងអំពីភាពរាបសាររបស់លោកនៅចំពោះមុខពួកគេដើម្បីធ្វើឲ្យពួកគេរីកចម្រើន។
ខ្ញុំបានក្លាយទៅជាមនុស្សល្ងីល្ងើ
«ខ្ញុំធ្វើខ្លួនដូចជាមនុស្សល្ងីល្ងើ»
បងប្អូនបានជំរុញខ្ញុំឲ្យធ្វើការងារនេះ
«បងប្អូនបានជំរុញខ្ញុំនិយាយពីរបៀបនេះ»
ខ្ញុំគួរតែបានលើកសរសើរតាមរយៈបងប្អូន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ការលើកសរសើរដែលបងប្អូន គួរផ្តល់មកខ្ញុំ»
បានលើកសរសើរ
អាចមានន័យថា ១) «លើកសរសើរ» (ជំពូក៣៖១) និង«បង្ហាញពី» (ជំពូក៤៖១)
ដ្បិត ខ្ញុំមិនអន់ជាង
ដោយប្រើន័យផ្ទុយ
សាវ័កប៉ូលបានថ្លែងខ្លាំងចំពោះអ្នកនៅក្រុងកូរិនថូសដែលគិតថាលោកអន់ជាង
គឺជាការខុសឆ្គង។ ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតខ្ញុំល្អដូចជា»
មហាសាវក
សាវ័ក -
សាវ័កប៉ូលប្រើពាក្យមិនសមរម្យនៅទីនេះដើម្បីបង្ហាញថាពួកគេមិនសូវសំខាន់ទេ
បន្ទាប់មកពួកគេអះអាងថាដូច្នេះ។ ការបកប្រែរបៀបផ្សេងទៀត: «គ្រូទាំងនោះ
ខ្លះគិតថាពូកែជាងអ្នកដទៃ។» សូមមើលពីរបៀបបកប្រែក្នុងជំពូក ១១:៥។
ទីសម្គាល់ដ៏ពិតរបស់ងារជាសាវកគឺបម្រើ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ដោយការបញ្ជាក់ពី «ទីសម្គាល់»។
ការបកប្រែរបៀបផ្សេងទៀត: «នេះជាទីសម្គាល់ពិតរបស់ងារជាសាវ័ក
ដែលខ្ញុំជាអ្នកបម្រើ»
ទីសម្គាល់.....ទីសម្គាល់
ជាការប្រើពាក្យដូចគ្នាពីរដង។
ទីសម្គាល់ និងការអស្ចារ្យ ហើយនិងឥទ្ធិឫទ្ធិផងដែរ
ទាំងអស់នេះគឺជា «ទីសម្គាល់ដ៏ពិតប្រាកដរបស់សាវ័ក»
ដែលសាវ័កប៉ូលបានសំដែង ជាមួយនឹងការអត់ធ្មត់ខ្លាំង។»
តើបងប្អូនមិនសំខាន់ជាងអ្នកឯទៀតនៃក្រុមជំនុំទេឬអី លើកលែងតែខ្ញុំមិនបានរំខានដល់បងប្អូន?
សាវ័កប៉ូលបានបញ្ជាក់ទៅអ្នកនៅក្រុងកូរិនថូសថាការចោទប្រកាន់ខុសដែលថាលោក
នេះជាសំណួរវោហារស័ព្ទ អាចត្រូវបានបកប្រែមានន័យថា។
ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំបានប្រព្រឹត្តចំពោះបងប្អូនដូចនឹងរបៀបដែលខ្ញុំបានប្រព្រឹត្តទៅលើក្រុមជំនុំឯទៀតលើកលែងតែ
ខ្ញុំមិនបានរំខានដល់បងប្អូន
ខ្ញុំមិនបានសុំថវិកា និងរបស់ផ្សេងទៀតដែលខ្ញុំត្រូវការឡើយ»
សូមអត់ទោសឲ្យខ្ញុំផងអំពីការនេះ!
សាវ័កប៉ូលបានលេងសើចដោយដើម្បីធ្វើឱ្យអ្នកនៅក្រុងកូរិនថូសអាម៉ាស់មុខ។
ទាំងគាត់និងពួកគេដឹងថាគាត់មិនបានធ្វើអ្វីខុសចំពោះពួកគេទេ
ប៉ុន្តែពួកគេបានចាត់ទុកគាត់ដូចជាគាត់បានធ្វើបាបពួកគេ។

2 Corinthians 12:14
ខ្ញុំចង់បានតែបងប្អូនទេ
អ្នកប្រែអាចប្រើរចនាប្រយោគណាមួយដែលធ្វើឲ្យ
«អ្វីដែលខ្ញុំចង់បាននោះបងប្អូនស្រលាញ់ និងទទួលយកខ្ញុំ»
កូនៗមិនគួរសន្សំទ្រព្យសម្បត្តិទុកឲ្យឪពុកម្តាយ
ក្មេងតូចៗមិនទទួលខុសត្រូវក្នុងការសន្សំប្រាក់ឬរបស់របរផ្សេងទៀត
ដើម្បីឱ្យឪពុកម្តាយរបស់គេកាន់តែមាននោះទេ។
ខ្ញុំនឹងរីករាយក្នុងការចំណាយ និងប្រើពេល
សាវ័កប៉ូលបានថ្លែងពីកិច្ចការ និងជីវិតសាច់ឈាមរបស់លោកប្រៀបដូចជាប្រាក់
ដែលលោក ឬព្រះជាម្ចាស់អាចយកចំណាយ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំនឹងរីករាយក្នុងការធ្វើកិច្ចការណាមួយ
ហើយអនុញ្ញាតឲ្យព្រះជាម្ចាស់អាចឲ្យនរណាម្នាក់មកសម្រាប់ខ្ញុំបាន»
សម្រាប់ព្រលឹងរបស់បងប្អូន
ពាក្យថា «ព្រលឹង» គឺជាពាក្យប្រៀបធៀបសំដៅទៅលើមនុស្សខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត: «សម្រាប់បងប្អូន» ឬ
«ដូច្នេះបងប្អូនអាចរស់នៅដោយមានក្តីសុខ»
ប្រសិនបើ ខ្ញុំស្រឡាញ់បងប្អូនខ្លាំងយ៉ាងនេះទៅហើយ តើខ្ញុំនឹងទទួលការស្រឡាញ់តិចជាងឬអី
នេះជាសំណួរវោហារស័ព្ទ អាចត្រូវបានបកប្រែមានន័យថា។
ការបកប្រែរបៀបផ្សេងទៀត: «ប្រសិនបើខ្ញុំស្រលាញ់បងប្អូនខ្លាំង
បងប្អូនមិនគួរស្រលាញ់ខ្ញុំតិចតួចឡើយ»។ ឬ «ប្រសិន.....ខ្លាំង
បងប្អូនគួរតែស្រលាញ់ខ្លាំងជាងនេះ។»
ច្រើន
ឃ្លានេះមិនច្បាស់លាស់ទេ ថាសេចក្តីស្រឡាញ់របស់សាវ័កប៉ូលគឺ «ច្រើនជាង»។
វាប្រហែលជាល្អបំផុតក្នុងការប្រើ «ច្រើនណាស់» ឬ «យ៉ាងច្រើន»
ដែលអាចត្រូវបានប្រៀបធៀបទៅនឹង «តិចតួច»
នៅពេលក្រោយក្នុងប្រយោគនោះ។
2 Corinthians 12:16
ប៉ុន្តែ នៅតែមានគេនិយាយថា ខ្ញុំមានល្បិចហើយជាអ្នកបោកប្រាស់ពីបងបប្អូនដែរ
សាវ័កប៉ូលប្រើពាក្យចំអកដើម្បីឱ្យអ្នកនៅក្រុងកូរិនថូសអាម៉ាស់
ដែលគិតថាលោកបានកុហកពួកគេ ទោះបីគាត់មិនបានសុំប្រាក់ពីពួកគេក៏ដោយ។
ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែអ្នកផ្សេងទៀតគិតថាខ្ញុំជាមនុស្សឆបោកនិងប្រើល្បិច»
តើខ្ញុំដែលបានកេងចំណេញពីបងប្អូន ដែលខ្ញុំបានចាត់មករកបងប្អូនទេ?
ទាំងសាវ័កប៉ូល និងអ្នកនៅក្រុងកូរិនថូសបានដឹងចម្លើយគឺទេ។
នេះជាសំណួរវោហារស័ព្ទ អាចត្រូវបានបកប្រែមានន័យថា។
ការបកប្រែរបៀបផ្សេងទៀត:
«គ្មាននរណាម្នាក់ដែលខ្ញុំបានចាត់ទៅបងប្អូនបានទាញយកផលប្រយោជន៍ពីបងប្អូនទេ!»
តើលោកទីតុសកេងចំណេញពីបងប្អូនទេ?
ទាំងសាវ័កប៉ូល និងអ្នកនៅក្រុងកូរិនថូសបានដឹងចម្លើយគឺទេ។
នេះជាសំណួរវោហារស័ព្ទ អាចត្រូវបានបកប្រែមានន័យថា។
ការបកប្រែរបៀបផ្សេងទៀត: «លោកទីតុសមិនបានកេងចំណេញពីបងប្អូនទេ»។
តើពួកយើងមិនបានដើរលើផ្លូវក្នុងតែមួយទេឬអី?
សាវ័កប៉ូលថ្លែងពីការរស់នៅដូចជាកំពុងដើរលើផ្លូវ។ ទាំងសាវ័កប៉ូល
និងអ្នកនៅក្រុងកូរិនថូសដឹងចម្លើយចំពោះសំណួរគឺថាពិតប្រាកដ។
នេះជាសំណួរវោហារស័ព្ទ អាចត្រូវបានបកប្រែមានន័យថា។
ការបកប្រែរបៀបផ្សេងទៀត:
«យើងទាំងអស់គ្នាមានអាកប្បកិរិយាដូចគ្នានិងរបៀបរស់នៅដូចគ្នា»។
តើពួកយើងមិនបានបោះជំហានតែមួយទេឬអី?
សាវ័កប៉ូលថ្លែងពីការរស់នៅដូចជាកំពុងដើរលើផ្លូវ។ ទាំងសាវ័កប៉ូល
និងអ្នកនៅក្រុងកូរិនថូសដឹងចម្លើយចំពោះសំណួរគឺថាពិតប្រាកដ។
នេះជាសំណួរវោហារស័ព្ទ អាចត្រូវបានបកប្រែមានន័យថា។
ការបកប្រែរបៀបផ្សេងទៀត: «ពួកយើងបានធ្វើកិច្ចការក្នុងរបៀបដូចគ្នា»។
2 Corinthians 12:19
តើបងប្អូនគិតថា ពួកយើងដោះសារការពារខ្លួនយើងនៅចំពោះបងប្អូនដែរមែនទេឬ?
សាវ័កប៉ូលសំណួរវោហារស័ព្ទ ការបកប្រែរបៀបផ្សេងទៀត:
«វាជាការកំហុសសម្រាប់បងប្អូនដែលគិតថាគ្រប់ពេលវេលា
យើងបានដោះសារការពារខ្លួនឯង នៅចំពោះបងប្អូន» ។
អ្នកខ្លះបកប្រែសេចក្តីនេះជាខ្លឹមសារទៀតថា។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនបានគិតគ្រប់ពេលវេលាថាយើងបានកំពុងតែ

generated on Wed Sep 10 16:16:32 2025

ដោះសារការពារខ្លួនឯងនៅចំពោះបងប្អូន»។
នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់
សាវ័កប៉ូលបានថ្លែងពីព្រះជាម្ចាស់
ដែលបានជ្រាបដឹងអ្វីៗទាំងអស់ដែលសាវ័កប៉ូលបានធ្វើ ប្រៀបដូចជា
ព្រះជាម្ចាស់មានវត្តមានសាច់ឈាមហើយឆ្វេងយល់អ្វីៗទាំងអស់ដែលសាវ័កប៉ូលបានធ្វើ។ ការបកប្រែរបៀបផ្សេងទៀត:
ការបកប្រែរបៀបផ្សេងទៀត: «នៅចំពោះព្រះជាម្ចាស់» ឬ
«ជាមួយព្រះជាម្ចាស់ជាសាក្សី» ឬ «នៅក្នុងវត្តមានរបស់ព្រះ»
ដើម្បីចម្រើនកម្លាំងដល់បងប្អូន
«ដើម្បីចម្រើនកម្លាំងដល់បងប្អូន» សាវ័កប៉ូលថ្លែងពីការចេះស្តាប់បង្គាប់ព្រះជាម្ចាស់
ហើយចង់ស្តាប់បង្គាប់លោក ប្រៀបដូចជាការលូតលាស់ខាងរូបកាយ។
ការបកប្រែរបៀបផ្សេងទៀត: «ដើម្បីឱ្យបងប្អូនបានស្គាល់ព្រះជាម្ចាស់
និងគោរពទ្រង់កាន់តែប្រសើរ»
2 Corinthians 12:20
ខ្ញុំមិនបានឃើញបងប្អូនដូចជាអ្វីដែលខ្ញុំចង់ឃើញ
«ខ្ញុំប្រហែលជាមិនចូលចិត្តអ្វីដែលខ្ញុំឃើញឡើយ» ឬ
«ខ្ញុំប្រហែលជាមិនចូលចិត្តអ្វីដែលខ្ញុំឃើញអ្នកធ្វើឡើយ»
បងប្អូនមិនបានឃើញខ្ញុំ ដូចអ្វីដែលបងប្អូនចង់ឃើញដែរ
«បងប្អូនប្រហែលមិនចង់ឃើញអ្វីដែលមាននៅក្នុងខ្ញុំ»
មានការឈ្លោះប្រកែក ការឈ្នានីស កំហឹង ការប្រជែង ការនិយាយបង្ខូច ការបរិហារកេរ្តិ៍
ការក្រអឺតក្រទម និងសេចក្តីវឹកវរកើតឡើង
នាមអរូបីដូចជា ការឈ្លោះប្រកែក ការឈ្នានីស កំហឹង មហិច្ឆតាអាត្មានិយម ការ
និយាយបង្ខូច ការបរិហារកេរ្តិ៍ ការក្រអឺតក្រទម និងសេចក្តីវឹកវរកើតឡើង»
អាចត្រូវបានបកប្រែដោយប្រើកិរិយាស័ព្ទ។ អាចមានន័យថា ១)
«បងប្អូនខ្លះនឹងឈ្លោះប្រកែកជាមួយពួកយើង ឈ្នានីសយើង
ភ្លាមៗខឹងយ៉ាងខ្លាំងជាមួយពួកយើង
និយាយអំពីជីវិតឯកជនរបស់យើងមានភាពក្រអឺតក្រទម
និងប្រឆាំងនិងយើងនៅពេលយើងព្យាយាមដឹកនាំបងប្អូន» ឬ ២)
«បងប្អូនខ្លះនឹងឈ្លោះប្រកែកគ្នា ឈ្នានីសនឹងគ្នាទៅវិញទៅមក
ភ្លាមៗខឹងយ៉ាងខ្លាំង និយាយគ្នាអំពីជីវិតឯកជនរបស់គ្នាទៅវិញទៅមក
មានភាពក្រអឺតក្រទម និងប្រឆាំងនឹងអ្នកដែលព្រះបានជ្រើសរើសដើម្បីដឹកនាំ»
ខ្ញុំបានធ្វើបាបច្រើនដងរួចមកហើយ ហើយសូមនិយាយម្តងទៀតដល់អ្នកដែលបានធ្វើបាបពីមុនទាំងអស់ និងដល់មនុស្សជាច្រើនដែលបានប្រព្រឹត្តបាបពីមុន
«ខ្ញុំត្រូវកើតទុកដោយព្រោះពួកគេជាច្រើន
មិនលះបង់ការប្រព្រឹត្តអំពើបាបចាស់របស់ពួកគេឡើយ»
មិនប្រែចិត្តពីសេចក្តីស្មោកគ្រោក អំពើអសីលធម៌ខាងផ្លូវភេទ និងអំពើល្មោភកាម
អាចមានន័យថា ១)
«សាវ័កប៉ូលបានថ្លែងពីស្ទើរតែនិយាយដូចគ្នាបីដងសម្រាប់ការបញ្ជាក់មួយនេះ។
ការបកប្រែរបៀបផ្សេងទៀត:
«មិនបានបញ្ឈប់ការប្រព្រឹត្តអំពើបាបខាងផ្លូវភេទដែលពួកគេបានប្រព្រឹត្តឡើយ»
ឬ២)សាវ័កប៉ូលបានថ្លែងពីអំពើបាបបីផ្សេងៗគ្នា។
ពីសេចក្តីស្មោកគ្រោក
នាមអរូបី នៃពាក្យសេចក្តីស្មោកគ្រោក
អាចត្រូវបានបកប្រែដោយប្រើឃ្លាជានាមដែលបានកែប្រែ។
ការបកប្រែរបៀបផ្សេងទៀត: «គិតដោយសម្ងាត់
និងចង់បានអ្វីដែលមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់»
ពីសេចក្តីស្មោកគ្រោក អំពើអសីលធម៌ខាងផ្លូវភេទ
នាមអរូបី នៃពាក្យ «អសីលធម៌»
អាចត្រូវបានបកប្រែដោយប្រើឃ្លាជានាមដែលបានកែប្រែ។
ការបកប្រែរបៀបផ្សេងទៀត: «ដែលបានប្រព្រឹត្តអំពើអសីលធម៌ខាងផ្លូវភេទ»
អំពើល្មោភកាម
នាមអរូបី នៃពាក្យ «អំពើ» អាចត្រូវបានបកប្រែដោយប្រើឃ្លាកិរិយាស័ព្ទ។
ការបកប្រែរបៀបផ្សេងទៀត:
«ដោយការប្រព្រឹត្តការដែលបំពេញចំណង់ផ្លូវភេទអសីលធម៌»

---

13 [1]នេះគឺជាដំណើរលើទីបីហើយដែលមករកបងប្អូន។ «គ្រប់ទាំងការចោតប្រកាន់ត្រូវធ្វើឡើង តាមរយៈសាក្សីពីរទៅបីនាក់»។
[2]ខ្ញុំបាននិយាយរួចហើយទៅអ្នកទាំងនោះដែលបានធ្វើបាបពីមុន ហើនិងអ្នកផ្សេងទៀតនៅក្នុងដំណើរលើកទីពីររបស់ខ្ញុំ ហើយលើកនេះ ខ្ញុំសូមនិយាយម្តងទៀត
ពេលខ្ញុំមកម្តងទៀតនោះខ្ញុំនឹងមិនអត់ឱនពួកគេទេ។
[3]ខ្ញុំប្រាប់ការទាំងនេះដល់បងប្អូនដោយសារតែបងប្អូនស្វែងរកភស្តុតាងដែលថា ព្រះគ្រិស្តមានបន្ទូលតាមខ្ញុំ។ ព្រះអង្គមិនខ្សោយនៅចំពោះបងប្អូនទេ។ ផ្ទុយទៅវិញ
ព្រះអង្គពេញដោយព្រះចេស្តានៅក្នុងបងប្អូន។[4]ដ្បិត ព្រះអង្គត្រូវគេឆ្កាងដោយសារភាពកម្សោយ ប៉ុន្តែ ព្រះអង្គមានព្រះជន្មរស់ដោយព្រះចេស្តារបស់ព្រះជាម្ចាស់។ ដ្បិត
ពួកយើងក៏ខ្សោយនៅក្នុងព្រះអង្គដែរ ប៉ុន្តែ យើងនឹងរស់ជាមួយព្រះអង្គ តាមរយៈព្រះចេស្តារបស់ព្រះជាម្ចាស់ក្នុងចំណោមយើងដែរ។
[5]ចូរពិនិត្យខ្លួនរបស់បងប្អូនឡើងវិញ ដើម្បីឲ្យដឹងថាបងប្អូននៅក្នុងជំនឿ។ ចូរល្បងលមើលខ្លួនឯងចុះ។ តើបងប្អូនមិនដឹងទេថា ព្រះយេស៊ូគ្រិស្តគង់នៅក្នុង
បងប្អូនទាំងអស់គ្នា? លើកលែងតែបងប្អូនមិនបានជាប់ក្នុងការល្បងលរបស់ព្រះអង្គ។[6]ហើយខ្ញុំជឿជាក់ថា
បងប្អូនដឹងហើយថាគឺពួកយើងមិនបានធ្លាក់ពីការល្បងលនោះទេ។
[7]ពេលយើងបានអធិស្ឋានទៅព្រះជាម្ចាស់ សូមកុំឲ្យបងប្អូនធ្វើអ្វីដែលខុសឡើយ។ ខ្ញុំមិនបានអធិស្ឋាន សូមឲ្យជាប់ការល្បងលឡើយ។ ផ្ទុយទៅវិញ
ខ្ញុំអធិស្ឋានសូមឲ្យបងប្អូនធ្វើអ្វីដែលត្រឹមត្រូវ ទោះបីជាយើងមើលទៅឃើញថាដូចជាធ្លាក់ការល្បងលក៏ដោយ។[8]ដ្បិត យើងមិនអាចធ្វើទាស់ទៅនឹងសេចក្តីពិតនោះទេ
តែត្រូវធ្វើអ្វីដែលជាសេចក្តីពិតវិញ។
[9]ដ្បិត យើងរីករាយពេលដែលពួកយើងខ្សោយ ហើយបងប្អូនខ្លាំងវិញ។ ពួកយើងក៏អធិស្ឋានឲ្យបងប្អូនបានជោគជ័យដែរ។[10]ខ្ញុំសរសេរសំបុត្រនេះ
គឺនៅពេលដែលខ្ញុំនៅឆ្ងាយពីបងប្អូន ដើម្បីពេលមកដល់បងប្អូន កុំឲ្យខ្ញុំប្រព្រឹត្តចំពោះបងប្អូន ដោយតឹងរ៉ឹងទៅតាមសិទ្ធិអំណាចដែលព្រះអម្ចាស់បានប្រទានឲ្យខ្ញុំសម្រាប់
ការស្អាងចិត្ត គឺមិនមែនបំផ្លាញបងប្អូនទេ។
[11]ជាទីបញ្ចប់ បងប្អូនអើយ! ចូរធ្វើការស្តារឡើងវិញ ចូរទទួលការលើកទឹកចិត្ត ចូរមានគំនិតតែមួយ ចូររស់នៅដោយសុខសាន្តចុះ។ ហើយព្រះជាម្ចាស់នៃសេចក្តីស្រឡាញ់
និងសេចក្តីសុខសាន្ត នឹងគង់នៅជាមួយបងប្អូនទាំងអស់គ្នា។[12]ចូរជម្រាបសួរគ្នាទៅវិញទៅមកដោយការថើបបរិសុទ្ធចុះ។
[13]ពួកបងប្អូនអ្នកជឿទាំងអស់ ក៏ជម្រាបសួរមកបងប្អូនដែរ។[14]សូមឲ្យព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត និងសេចក្តីស្រឡាញ់នៃព្រះជាម្ចាស់ និងព្រមទាំងសេចក្តីប្រកប
ក្នុងព្រះវិញ្ញាណបរិសុទ្ធ គង់នៅជាមួយបងប្អូនទាំងអស់គ្នា។

---

2 Corinthians 13:1
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបានថ្លែងថាព្រះគ្រិស្តកំពុងតែមានបន្ទូលតាមរយៈលោក
ដោយសាវ័កប៉ូលចង់ផ្តល់ស្តារជីវិតពួកគេឡើងវិញ លើកទឹកចិត្ត
និងបង្រួបបង្រួមពួកគេ។
គ្រប់ទាំងការចោតប្រកាន់ត្រូវធ្វើឡើង តាមរយៈសាក្សីពីរទៅបីនាក់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយជឿថាពេលនរណាម្នាក់ធ្វើខុសហើយ
បន្ទាប់មកមានមនុស្សពីរឬបីនាក់បាននិយាយបញ្ហានោះដូចគ្នា»
អ្នកផ្សេងទៀត
អ្នកទាំងអស់ផ្សេងទៀត
2 Corinthians 13:3
ព្រះអង្គត្រូវគេឆ្កាង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេបានឆ្កាងទ្រង់»
ប៉ុន្តែ យើងនឹងរស់ជាមួយព្រះអង្គ តាមរយៈព្រះចេស្តារបស់ព្រះជាម្ចាស់
ព្រះជាម្ចាស់ប្រទានសិទ្ធអំណាច និងសមត្ថភាពក្នុងការរស់នៅខាងក្នុង
និងនៅជាមួយព្រះអង្គ
2 Corinthians 13:5
ចូរល្បងលមើលខ្លួនឯងចុះ .....មិនត្រូវបានយល់ព្រម.....មិនយល់ព្រម
ឃ្លាថា «យល់ព្រម» និង «មិនយល់ព្រម» នៅទីនេះគឺត្រូវបានធ្វើ និងមិនបានធ្វើ
«ការល្បង»
តើបងប្អូនមិនដឹងទេថា ព្រះយេស៊ូគ្រិស្តគង់នៅក្នុងបងប្អូនទាំងអស់គ្នា?
សាវ័កប៉ូលសួរសំណួរដើម្បីបញ្ជាក់ពីចំណុចរបស់លោក។

generated on Wed Sep 10 16:16:32 2025

ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនគួរដឹងថាព្រះយេស៊ូគ្រិស្តគង់នៅជាមួួយបងប្អូន» ឬ
«ព្រះយេស៊ូគ្រិស្តគង់នៅក្នុងបងប្អូន»។ បងប្អូនគួរដឹងពីការនេះហើយ»
យើងមិនត្រូវបានយល់ព្រម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់ស្របៃ។ ការបកប្រែរបៀបផ្សេងទៀត:
«យើងប្រាកដជាត្រូវបានយល់ព្រម»
2 Corinthians 13:7
សូមកុំឲ្យបងប្អូនធ្វើអ្វីដែលខុសឡើយ
«ដែលបងប្អូននឹងមិនបានប្រព្រឹត្តអំពើបាបទាល់តែសោះ» ឬ
«បងប្អូននឹងមិនបដិសេធមិនស្តាប់បង្គាប់នៅពេលយើងកែតម្រូវបងប្អូនទេ»។
សាវ័កប៉ូលសង្កត់ធ្ងន់ភាពផ្ទុយពីការថ្លែងរបស់គាត់។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូននឹងធ្វើអ្វីដែលត្រឹមត្រូវ»
សូមឲ្យជាប់ការល្បងលឡើយ
«ធ្វើជាគ្រូដ៏ឆ្នើមនិងរស់ក្នុងសេចក្តីពិត»
ដ្បិត យើងមិនអាចធ្វើទាស់ទៅនឹងសេចក្តីពិតនោះទេ តែត្រូវធ្វើអ្វីដែលជាសេចក្តីពិតវិញ
«យើងមិនអាចរារាំងមនុស្សពីការរៀនសេចក្តីពិតទេ»
2 Corinthians 13:9
បានជោគជ័យដែរ
«ដែលប្រែក្លាយជាចាស់ទុំខាងវិញ្ញាណ»
ទៅតាមសិទ្ធិអំណាច
«នៅពេលដែលខ្ញុំមានសិទ្ធអំណាច»
សម្រាប់ការស្អាងចិត្ត គឺមិនមែនបំផ្លាញបងប្អូនទេ
សាវ័កប៉ូលថ្លែងពីការជួយអ្នកនៅក្រុងកូរិនថូសឱ្យស្គាល់ព្រះគ្រីស្ទកាន់តែច្បាស់
ប្រៀបដូចជាលោកកំពុងសាងសង់អាគារមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីជួយបងប្អូនឱ្យក្លាយជាអ្នកកាន់តាមព្រះគ្រិស្តកាន់តែប្រសើរហើយមិនធ្វើឱ្យអ្នកធ្លាក់ទឹកចិត្តដូច្នេះប
សូមមើលពីរបៀបដែលពាក្យទាំងនេះត្រូវបានបកប្រែនៅក្នុង ជំពូក១០: ៧។
2 Corinthians 13:11
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបានបិទសំបុត្ររបស់លោក ទៅបងប្អូនមានជំនឿនៅក្រុងកូរិនថូស។
ចូរធ្វើការស្អាងឡើងវិញ
«ធ្វើការដើម្បីរកភាពចាស់ទុំ»
ចូរមានគំនិតតែមួយ
«រស់នៅដោយសុខដុមជាមួយគ្នា»
ដោយការថើបបរិសុទ្ធ
«ដោយសេចក្តីស្រលាញ់បែបគ្រីស្ទាន»
2 Corinthians 13:13
អ្នកជឿទាំងអស់
«អស់អ្នកដែលព្រះបានញែកចេញសម្រាប់ទ្រង់» (UDB)

កាឡាទី

1 [1]ខ្ញុំ ប៉ូល ជាសាវក ដែលពុំមែនតែងតាំងដោយមនុស្សលោក ឬជនណាមួយឡើយ ប៉ុន្តែ តែងតាំងដោយព្រះយេស៊ូគ្រិស្ត និងព្រះជាម្ចាស់ជាព្រះបិតា
ដែលបានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញ[2]និងបងប្អូនទាំងអស់គ្នាដែលនៅជាមួយខ្ញុំ សូមជម្រាបមកក្រុមជំនុំទាំងឡាយនៅស្រុកកាឡាទី។
[3]សូមព្រះជាម្ចាស់ជាព្រះបិតានៃយើង និងព្រះអម្ចាស់យេស៊ូគ្រិស្តបានប្រទានព្រះគុណ និងសេចក្តីសុខសាន្តដល់បងប្អូនទាំងអស់គ្នា។[4]ព្រះអម្ចាស់បានលះបង់
ព្រះជន្មជំនួសបាបយើង ដើម្បីរំដោះយើងចេញពីសម័យអាក្រក់ នាពេលបច្ចុប្បន្ននេះ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងព្រះបិតានៃយើង។
[5]សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ នៅអស់កល្បតរៀងទៅ។ អាម៉ែន។
[6]ខ្ញុំឆ្ងល់ណាស់ ដោយបានឃើញបងប្អូនឆាប់បែរចេញពីព្រះជាម្ចាស់ ដែលបានត្រាស់ហៅបងប្អូនដោយសារព្រះគុណព្រះគ្រិស្ត។ ខ្ញុំឆ្ងល់ណាស់
ដោយបានឃើញបងប្អូនបែរទៅរកដំណឹងល្អផ្សេងមួយទៀត។[7]មិនគួរយើងនិយាយថា មានដំណឹងល្អមួយផ្សេងទៀតឡើយ គឺមានតែអ្នកខ្លះនាំបងប្អូនឲ្យវឹកវរ
និងចង់ផ្លាស់ប្តូរដំណឹងល្អរបស់ព្រះគ្រិស្តប៉ុណ្ណោះ។
[8]ប៉ុន្តែ ទោះបីជាយើង ឬទេវតាណាមួយមកពីស្ថានបរមសុខប្រកាសដំណឹងល្អផ្សេង ក្រៅពីដំណឹងល្អដែលខ្ញុំបានប្រកាសប្រាប់បងប្អូន សូមឲ្យអ្នកនោះត្រូវបណ្តាសាចុះ។
[9]ដូចខ្ញុំបានជម្រាបប្រាប់បងប្អូនរួចមកហើយ ឥឡូវនេះខ្ញុំសុំប្រាប់បងប្អូនម្តងទៀតថា ៖ «ប្រសិនបើ មាននរណាម្នាក់ប្រកាសដំណឹងល្អផ្សេង ក្រៅពីដំណឹងល្អ
ដែលខ្ញុំបានប្រកាសប្រាប់បងប្អូន សូមឲ្យអ្នកនោះត្រូវបណ្តាសាចុះ»។[10]តើឥឡូវនេះខ្ញុំចង់ផ្គាប់ចិត្តមនុស្ស ឬធ្វើឲ្យគាប់ព្រះហឫទ័យព្រះជាម្ចាស់? តើខ្ញុំចង់ផ្គាប់ចិត្តមនុស្ស?
បើខ្ញុំចង់ផ្គាប់ចិត្តមនុស្ស នោះខ្ញុំលែងជាអ្នកបម្រើព្រះគ្រិស្តហើយ។
[11]បងប្អូនអើយ ខ្ញុំចង់ជម្រាបបងប្អូនថា ដំណឹងល្អដែលខ្ញុំបានប្រកាសប្រាប់នោះ ពុំមែនចេញមកពីមនុស្សទេ។[12]ដ្បិត ខ្ញុំពុំបានទទួលមកពីមនុស្ស
ឬនរណាម្នាក់បង្រៀនខ្ញុំឡើយ។ ផ្ទុយទៅវិញ គឺព្រះយេស៊ូគ្រិស្តបើកសម្តែងប្រាប់ខ្ញុំដោយផ្ទាល់។
[13]អ្នករាល់គ្នាបានឮគេនិយាយគ្នាអំពីជីវិតខ្ញុំពីដើម ដែលជាអ្នកកាន់សាសនាយូដា និងរបៀបខ្ញុំបៀតបៀនក្រុមជំនុំរបស់ព្រះជាម្ចាស់យ៉ាងសាហាវ
និងរបៀបខ្ញុំព្យាយាមបំផ្លាញក្រុមជំនុំទៀតផង។[14]ខ្ញុំទទួលការអប់រំជ្រៅជ្រះខាងសាសនាយូដា លើសជាងអ្នកឯទៀតៗនៅអាយុស្រករខ្ញុំ និងជាជនរួមជាតិខ្ញុំដែរ។
ខ្ញុំមានចិត្តឧស្សាហ៍ខ្នះខ្នែងកាន់តាមប្រពៃណីរបស់បុព្វបុរសខ្ញុំ។
[15]ប៉ុន្តែ ពេលព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ តាំងពីផ្ទៃម្តាយមកម៉្លេះ
និងបានត្រាស់ហៅខ្ញុំដោយសារព្រះគុណព្រះអង្គ[16]នោះទ្រង់គាប់ព្រះហឫទ័យបើកសម្តែងព្រះបុត្រាឲ្យខ្ញុំស្គាល់ ដូច្នេះ ខ្ញុំបានប្រកាសដំណឹងល្អពីព្រះបុត្រានោះ
ក្នុងចំណោមសាសន៍ដទៃ ដោយខ្ញុំពុំបានទៅប្រឹក្សាយោបល់ពីនរណាម្នាក់[17]ហើយខ្ញុំក៏ពុំបានឡើងទៅក្រុងយេរូសាឡិម ទៅជួបពួកសាវកមុនៗខ្ញុំនោះដែរ។ ផ្ទុយទៅវិញ
ខ្ញុំបានឡើងទៅស្រុកអារ៉ាប់ រួចត្រឡប់មកក្រុងដាម៉ាសវិញ។
[18]បីឆ្នាំក្រោយមក ខ្ញុំបានឡើងទៅក្រុងយេរូសាឡិមទៅជួបលោកកេផាស រួចស្នាក់នៅជាមួយលោកអស់ដប់ប្រាំថ្ងៃ។[19]ប៉ុន្តែ ខ្ញុំពុំបានជួបសាវកណាម្នាក់ក្រៅពីលោកយ៉ាកុប
ដែលជាប្អូនប្រុសរបស់ព្រះអម្ចាស់ឡើយ។[20]សេចក្តីដែលខ្ញុំបានសរសេរប្រាប់បងប្អូន ឥតកុហកឡើយ ព្រោះមានព្រះជាម្ចាស់ជាសាក្សីស្រាប់។
[21]បន្ទាប់មក ខ្ញុំបានឡើងទៅស្រុកស៊ីរី និងគីលីគា។[22]ក្រុមជំនុំនានាជឿព្រះគ្រិស្តនៅស្រុកយូដា នៅតែពុំបានស្គាល់ខ្ញុំនៅឡើយ។[23]ពួកគេគ្រាន់តែបានឮថា៖
«មានបុរសម្នាក់ដែលធ្លាប់បៀតបៀនពួកយើង ឥឡូវនេះកំពុងប្រកាសជំនឿ ដែលគាត់ព្យាយាមបំផ្លាញកាលពីមុនទៅវិញ»។[24]ដូច្នេះ
ពួកគេលើកតម្កើងសិរីរុងរឿងដល់ព្រះជាម្ចាស់ ដោយសារតែខ្ញុំ។

Galatians 1:1
ប្រយោគភ្ជាប់:
លោកប៉ូល ដែលសរសេរសំបុត្រនេះទៅកាន់ក្រុមជំនុំនៅក្នុងតំបន់កាឡាទី។
ពត៌មានទូទៅ:
ទាល់តែមានការកត់ចំណាំ ដូច្នេះ រាល់ពាក្យទាំងអស់ថា «អ្នក» និង «របស់អ្នក»
នៅក្នុងសំបុត្រនេះសំដៅទៅលើក្រុមជំនុំកាឡាទី ហើយគឺពហុវចន: ។
ដែលបានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញ
«អ្នកដែលបានប្រោសព្រះយេស៊ូគ្រិស្ត»
មានព្រះជន្មរស់ឡើងវិញ
នៅទីនេះមានន័យថាបណ្តាលឲ្យមនុស្សមនុស្សស្លាប់ត្រឡប់ជាជីវិតម្តងទៀត។
បងប្អូន
នៅទីនេះមានន័យថាអ្នកដើរតាមព្រះយេស៊ូគ្រិស្ត រួមបញ្ចូលទាំងពីរ
គឺទាំងមនុស្សប្រុសនិងមនុស្សស្រីចាប់តាំងពីអ្នកជឿទាំងអស់នៅក្នុងព្រះគ្រិស្ត
គឺជាសមាជិកនៃគ្រួសារខាងវិញ្ញាណ
ជាមួយព្រះជាម្ចាស់ជាព្រះបិតារបស់ពួកគេនៅស្ថានបរមសុខ ។
ការបកប្រែផ្សេងទៀត:«បងប្អូនប្រុសស្រី»
Galatians 1:3
ជំនួសបាបយើង

generated on Wed Sep 10 16:16:32 2025

«អំពីបាប» «តំណាងឲ្យការដាក់ទណ្ឌចំពោះអំពើបាប។ការបកប្រែផ្សេងទៀត:
«ទទួលទាន់កម្មដែលយើងសាកសមទទួលដោយសារអំពើបាបរបស់យើង»
ដើម្បីរំដោះយើងចេញពីសម័យអាក្រក់ នាពេលបច្ចុប្បន្ននេះ
កន្លែងនេះ «បច្ចុប្បន្ន ... នេះ «តំណាងឲ្យអំណាចដែលធ្វើការនៅក្នុងបច្ចុប្បន្ន ។
ការបកប្រែផ្សេងទៀត:
«ដែលព្រះអង្គអាចរំដោះយើងឲ្យមានសេរីភាពពីអំណាចអាក្រក់ដែលធ្វើការនៅក្នុងពិភពលោកបច្ចុប្បន្ន»
Galatians 1:6
ប្រយោគភ្ជាប់:
លោកប៉ូលផ្តល់ហេតុផលរបស់គាត់សម្រាប់ចំពោះការសរសេរសំបុត្រ៖
គាត់រម្លឹកពួកគេដើម្បីបន្តឲ្យយល់ដំណឹងល្អ។
ខ្ញុំឆ្ងល់ណាស់
«ខ្ញុំមានការភ្ញាក់ផ្អើល» ឬ «ខ្ញុំមានការតក់ស្លុត»
លោកប៉ូលមានការអាក់អន់ចិត្តដែលេពួកគេបានកំពុងធ្វើដូចនេះ»
ដោយបានឃើញបងប្អូនឆាប់បែរចេញពីព្រះជាម្ចាស់ ... ទៅរកដំណឹងល្អផ្សេងមួយទៀត។
ទី១ ប្រហែលជាអាចមានន័យថា) «អ្នកបានឈប់ទុកចិត្ត ខ្ញុំទៀតហើយ» ឬ ទី ២)
«អ្នកបានឈប់ស្មោះត្រង់និងព្រះជាម្ចាស់ទៀតហើយ»
ព្រះជាម្ចាស់ ដែលបានត្រាស់ហៅបងប្អូន
«ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូន»
បានត្រាស់ហៅ
នៅទីនេះមានន័យថាព្រះជាម្ចាស់បានតែងតាំង ឬ
បានជ្រើសរើសធ្វើជាកូនរបស់ព្រះអង្គ ដើម្បីបម្រើព្រះអង្គ និង
ប្រកាសព្រះរាជសាររបស់ទ្រង់នៃការសង្គ្រោះតាមរយៈព្រះយេស៊ូ។
ដោយសារព្រះគុណព្រះគ្រិស្ត
«ដោយសារព្រះគុណរបស់ព្រះគ្រិស្ត» ឬ
«ពីព្រោះដោយសារព្រះគុណនៃការលះបង់»
ដោយបានឃើញបងប្អូនបែរទៅរកដំណឹងល្អផ្សេងមួយទៀត
អ្នកកំពុងជឿដំណឹងល្អផ្សេងមួយទៀត
Galatians 1:8
ប្រកាសដំណឹងល្អ
នេះគឺកំពុងពណ៌នាអ្វីម៉្យាងដែលមិនបានកើតឡើងនិង មិនគួរកើតឡើង។
ការបកប្រែផ្សេងទៀត: «នឹងប្រកាស» ឬ «បានប្រកាស»
ក្រៅពីដំណឹងល្អ
«ខុសពីដំណឹងល្អ» ឬ «ខុសពីសារាជសារ"
សូមឲ្យអ្នកនោះត្រូវបណ្តាសាចុះ
«ព្រះជាម្ចាស់គួរតែដាក់ទណ្ឌកម្មមនុស្សនោះជារៀងរហូត»
ប្រសិនបើភាសារបស់អ្នកមានរបៀបជាទូទៅនៃការដាក់បណ្តាសារនណាម្នាក់
អ្នកគួរប្រើរបៀបដូចច្នេះដែរ។
តើឥឡូវនេះខ្ញុំចង់ផ្គាប់ចិត្តមនុស្ស ឬធ្វើឲ្យគាប់ព្រះហឫទ័យព្រះជាម្ចាស់? តើខ្ញុំចង់ផ្គាប់ចិត្តមនុស្ស?
សំណួរទាំងនេះរំពឹងទុកចម្លើយ «ទេ» ការបកប្រែផ្សេងទៀត:
«ខ្ញុំមិនស្វែងរកការយល់ព្រះពីមនុស្ស
តែខ្ញុំស្វែងរកការយល់ព្រមពីព្រះជាម្ចាស់ជំនួសវិញ»
បើខ្ញុំចង់ផ្គាប់ចិត្តមនុស្ស នោះខ្ញុំលែងជាអ្នកបម្រើព្រះគ្រិស្តហើយ។
ទាំងពីរ «ប្រសិនបើ» ឃ្លាហ្នឹង «ហើយបន្ទាប់មកទៀត» ជាឃ្លាពិតដែលផ្ទុយគ្នា»
ខ្ញុំមិនកំពុងតែព្យាយាមផ្គាប់ចិត្តមនុស្សទេ ខ្ញុំគឺជាអ្នកបម្រើព្រះគ្រិស្ត» ឬ
«ប្រសិនបើខ្ញុំបានកំពុងព្យាយាមផ្គាប់ចិត្តមនុស្ស
ខ្ញុំមិនគួរនឹងធ្វើជាអ្នកបម្រើព្រះគ្រិស្តទៀតទេ»។
Galatians 1:11
ប្រយោគភ្ជាប់:
លោកប៉ូលពន្យល់ថាគាត់មិនបានរៀនពីដំណឹងល្អផ្សេងទៀតទេ
គាត់បានរៀនដំណឹងល្អពីព្រះគ្រិស្ត។
បងប្អូន
បកប្រែដូចនៅក្នុង ១:១
ពុំមែនចេញមកពីមនុស្សទេ
តាមរយៈការប្រើឃ្លានេះ លោកប៉ូល មិនមែនព្យាយាមនិយាយថាព្រះយេស៊ូគ្រិស្ត
អង្គទ្រង់ផ្ទាល់ជាមនុស្សជាតិទេ ពីព្រោះព្រះគ្រិស្តគឺទាំងពីរ គឺជាមនុស្សផង និង
ជាព្រះផង។ ទោះជាយ៉ាងណា ព្រះអង្គគឺមិនមែនជាមនុស្សដែលប្រព្រឹត្តអំពើបាប
លោកប៉ូលកំពុងសរសេរអំពីកន្លែងដែលដំណឹងល្អបានចេញមក
ដែលវាមិនមកពីមនុស្សមានបាបទេ ប៉ុន្តែវាមកពីព្រះយេស៊ូគ្រិស្ត។
គឺព្រះយេស៊ូគ្រិស្តបើកសម្តែងប្រាប់ខ្ញុំដោយផ្ទាល់
ទី១អាចមានន័យថា «ព្រះយេស៊ូគ្រិស្តបានបង្ហាញអង្គទ្រង់ផ្ទាល់តាមដំណូដល់ខ្ញុំ» ឬ
២)
«ព្រះជាម្ចាស់បានបង្កើតខ្ញុំដើម្បីស្គាល់ដំណឹងល្អពេលដែលព្រះអង្គបានបង្ហាញខ្ញុំព្រះយេស៊ូគ្រិស្តគឺជានរណ
ជាមួយការសរសេរទី ១:១៣» (សូមមើល:
ជីវិតខ្ញុំពីដើម
«អាកប្បកិរិយា នៅពេលមួយ» ឬ «ជីវិតពីមុន» ឬ «កាលពីមុន»
ខ្ញុំទទួលការអប់រំជ្រៅជ្រះ
នេះជារូបភាពនៃការប្រៀបធៀបលោកប៉ូលកំពុងទៅមុនជនជាតិយូដាដទៃនៅក្នុងសម័យរបស់គាត់នៅក្នុង
លើសជាងអ្នកឯទៀតៗនៅអាយុស្រករខ្ញុំ
«ជនជាតិយូដាដែលមានអាយុដូចខ្ញុំ»
បុព្វបុរស
«ដូនតា»
Galatians 1:15
បានត្រាស់ហៅខ្ញុំដោយសារព្រះគុណព្រះអង្គ
ទី១ប្រហែលជាមានន័យ)
«ព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំដើម្បីបម្រើព្រះអង្គពីព្រោះព្រះអង្គមានព្រះគុណ»
ទី២) «ព្រះអង្គបានត្រាស់ហៅខ្ញុំតាមរយៈរបស់ទ្រង់»។
បើកសម្តែងព្រះបុត្រាឲ្យខ្ញុំស្គាល់
ទី១ប្រហែលជាមានន័យ) «ដើម្បីអនុញ្ញាតិឲ្យខ្ញុំដើម្បីស្គាល់ព្រះបុត្រារបស់ទ្រង់»
ឬទី២)
«ដើម្បីបង្ហាញពិភពលោកតាមរយៈខ្ញុំថាព្រះយេស៊ូគឺបុត្រារបស់ព្រះជាម្ចាស់»។
ព្រះបុត្រា
នេះជាជីវិតដ៏សំខាន់របស់ព្រះយេស៊ូគ្រិស្ត ព្រះបុត្រារបស់ព្រះជាម្ចាស់។
ប្រកាសដំណឹងល្អពីព្រះបុត្រា
«ប្រកាសថាព្រះអង្គគឺជាព្រះបុត្រារបស់ព្រះជាម្ចាស់» ឬ
«ប្រកាសដំណឹងល្អអំពីព្រះបុត្រារបស់ព្រះជាម្ចាស់»
ទៅប្រឹក្សាយោបល់ពីនរណាម្នាក់
នេះគឺបង្ហាញន័យថានិយាយជាមនុស្សដទៃ ការបកប្រែផ្សេងទៀត:
«សូមគេឲ្យជួយដើម្បីឲ្យយល់ព្រះបន្ទូល»
ទៅក្រុងយេរូសាឡិម
«ទៅក្រុងយេរូសាឡិម» យេរូសាឡិម គឺនៅតំបន់ដីទួល
ចំចាប់ត្រូវឡើងទួលជាច្រើនដើម្បីទៅដល់ទីនោះ
ដូចច្នេះជាទូទៅគេនិយាយធ្វើដំណើរទៅទីក្រុងយេរូសាឡឹមជា
«ឡើងទីក្រុងយេរូសាឡឹម»។
Galatians 1:18
ខ្ញុំពុំបានជួបសាវកណាម្នាក់ក្រៅពីលោកយ៉ាកុប
នេះអធិប្បាយមានចម្ងល់ថា យ៉ាកុបជាសាវកម្នាក់ដែលលោកប៉ូលបានជួប
ការបកប្រែផ្សេងទៀត: «ខ្ញុំមិនឃើញសាវកដទៃទេ
បានឃើញតែលោកយ៉ាកុបប៉ុណ្ណោះទេ»
ព្រោះមានព្រះជាម្ចាស់
លោកប៉ូលចង់ឲ្យក្រុមជំនុំកាឡាទីយល់ទាំងស្រុងថាលោកប៉ូលបានទាំងស្រុងយ៉ាងច្បាស់
និង គាត់ស្គាល់ថាព្រះជាម្ចាស់ឮអ្វីដែលគាត់និយាយ ហើយនឹង
កាត់ទោសគាត់ប្រសិនបើគាត់មិនប្រាប់ការពិត។
សេចក្តីដែលខ្ញុំបានសរសេរប្រាប់បងប្អូន ឥតកុហកឡើយ ព្រោះមានព្រះជាម្ចាស់ជាសាក្សីស្រាប់។
លោកប៉ូលបានប្រើដើម្បីបញ្ជាក់ថា គាត់កំពុងប្រាប់ការពិត ការបកប្រែផ្សេងទៀត:
«ខ្ញុំមិនមែនកំពុងកុហកអ្នកទេនៅក្នុងព្រះបន្ទូលទេ ខ្ញុំសរសេរទៅកាន់បងប្អូន» ឬ
«នៅក្នុងអ្វីៗដែលខ្ញុំសរសេរទៅកាន់បងប្អូនខ្ញុំកំពុងបងប្អូនអំពីសេចក្តីពិត»
Galatians 1:21
ស្រុក
«ផ្នែកមួយនៃការហៅពិភពលោក»
ពួកគេគ្រាន់តែបានឮថា
«ប៉ុន្តែពួកគេបានដឹងនូវអ្វីដែលពួកគេបានឮអ្នកដទៃកំពុងនិយាយអំពីខ្ញុំ»
ក្រុមជំនុំនានាជឿព្រះគ្រិស្តនៅស្រុកយូដា នៅតែពុំបានស្គាល់ខ្ញុំនៅឡើយ។
ខ្ញុំនៅតែមិនស្គាល់ក្រុមជំនុំរបស់ជនជាតិយូដាដែលនៅក្នុងព្រះគ្រិស្តផ្ទាល់ខ្លួននៅឡើយ។

generated on Wed Sep 10 16:16:32 2025

2 [1]ដប់បួនឆ្នាំក្រោយមក ខ្ញុំបានឡើងទៅក្រុងយេរូសាឡិមម្តងទៀត ជាមួយលោកបារណាបាស ទាំងនាំយកលោកទីតុសទៅជាមួយខ្ញុំដែរ។[2]ខ្ញុំឡើងទៅ
ព្រោះខ្ញុំបានទទួលការបើកសម្តែងឲ្យទៅ និងមានបំណងចង់ជម្រាប់ប្រាប់បងប្អូននៅទីនោះ អំពីដំណឹងល្អដែលខ្ញុំបានប្រកាសជាមួយសាសន៍ដទៃ។
ហើយខ្ញុំក៏បានរៀបរាប់ប្រាប់បងប្អូនជាអ្នកដឹកនាំ ដាច់ដោយឡែកពីគេដែរ ដើម្បីឲ្យប្រាកដថា កិច្ចការដែលខ្ញុំកំពុងធ្វើ ឬបានធ្វើរួចហើយ ត្រឡប់ទៅជាអសារឥតការឡើយ។
[3]លោកទីតុសដែលទៅជាមួយខ្ញុំ ទោះបីគាត់ជាសាសន៍ក្រិកក្តី ក៏គេមិនបង្ខំគាត់ ឲ្យទទួលការកាត់ស្បែកឡើយ។[4]មានពួកបងប្អូនក្លែងក្លាយខ្លះ បានបន្លំខ្លួនជ្រៀតចូលមក
ដើម្បីឈ្លបមើលសេរីភាព ដែលយើងមាននៅក្នុងព្រះគ្រិស្តយេស៊ូ។ ពួកគេមានបំណងចង់ឲ្យយើងក្លាយជាទាសករ[5]ប៉ុន្តែយើងមិនព្រមធ្វើតាមពួកគេឡើយ
សូម្បីតែមួយភ្លែត ដូច្នេះសេចក្តីពិតនៃដំណឹងល្អនឹងស្ថិតនៅជាប់ជាមួយអ្នករាល់គ្នារហូត។
[6]ប៉ុន្តែ ចំពោះបងប្អូនដែលគេចាត់ទុកជាអ្នកដឹកនាំវិញ (ទោះបីជាមានឋានៈអ្វីក៏ដោយ ក៏ខ្ញុំមិនខ្វល់ដែរ ព្រោះព្រះជាម្ចាស់ពុំបានរើសនរណាឡើយ)
អស់អ្នកដែលគេចាត់ទុកជាអ្នកដឹកនាំ គ្មានអ្វីសំខាន់ចំពោះរូបខ្ញុំឡើយ)។[7]ផ្ទុយទៅវិញគេឃើញថា ព្រះជាម្ចាស់បានប្រគល់មុខងារប្រកាសដំណឹងល្អ ទៅពួកមិនកាត់ស្បែក
ដូចជាព្រះជាម្ចាស់ប្រទានមុខងារប្រកាសដំណឹងល្អ ទៅពួកកាត់ស្បែកឲ្យលោកពេត្រុសផងដែរ។[8]ដ្បិតព្រះជាម្ចាស់ដែលបានប្រទានឲ្យលោកពេត្រុសមាន
មុខងារជាសាវកប្រកាសដំណឹងល្អ ទៅពួកកាត់ពួកកាត់ស្បែកយ៉ាងណា នោះក៏ព្រះជាម្ចាស់បានប្រគល់មុខងារជាសាវកឲ្យខ្ញុំ
ទៅប្រកាសដំណឹងល្អដល់សាសន៍ដទៃយ៉ាងនោះដែរ។
[9]កាលលោកយ៉ាកុប លោកកេផាស និងលោកយ៉ូហានដែលត្រូវគេទទួលស្គាល់ថា ជាសរសរទ្រូងរបស់ក្រុមជំនុំ ហើយទទួលស្គាល់ព្រះគុណ
ដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ ដូច្នេះ ពួកគេបានប្រគល់ដៃស្តាំនៃសម្ពន្ធភាពជាមួយលោកបារណាបាស មកឲ្យខ្ញុំ។ ពួកគេធ្វើដូច្នេះ ទុកជាសញ្ញាថា
យើងរួមគ្នាប្រកាសដំណឹងល្អទៅសាសន៍ដទៃ ហើយពួកលោករួមគ្នាប្រកាសដំណឹងល្អទៅពួកកាត់ស្បែក។[10]ពួកគេគ្រាន់តែស្នើសុំឲ្យយើងចេះគិតគូរដល់ជនក្រីក្រ
ជាកិច្ចការដែលខ្ញុំខ្នះខ្នែងធ្វើរួចទៅហើយ។
[11]ប៉ុន្តែ ពេលលោកកេផាសទៅដល់ក្រុងអន់ទីយ៉ូក ខ្ញុំបានជំទាស់លោកនៅមុខគេឯង ព្រោះតែលោកបានប្រព្រឹត្តខុស។
[12]មុនពេលមានមនុស្សខ្លះដែលលោកយ៉ាកុបបានចាត់បញ្ជូនមកដល់ លោកកេផាសបរិភោគជាមួយសាសន៍ដទៃ។ ប៉ុន្តែស្រាប់តែ ពេលអ្នកទាំងនោះមកដល់
លោកបែរជាឈប់បរិភោគ និងដកខ្លួនថយចេញពីសាសន៍ដទៃ។ គាត់ខ្លាចពួកកាត់ស្បែក។
[13]មានបងប្អូនយូដាឯទៀតៗក៏លាក់ពុតដូចជាលោកដែរ។ សូម្បីតែលោកបារណាបាស ត្រូវគេអូសទាញឲ្យចេះលាក់ពុតដែរ។[14]ប៉ុន្តែពេលឃើញថា
ពួកគេលែងប្រព្រឹត្តតាមសេចក្តីពិតនៃដំណឹងល្អ នោះខ្ញុំក៏និយាយទៅកាន់លោកកេផាសនៅមុខគេឯងទាំងអស់គ្នាថា៖ «បើសិនជាលោកជាសាសន៍យូដា
លែងរស់នៅតាមរបៀបសាសន៍យូដាទៅហើយ ធ្វើម៉េចលោកអាចបង្ខំសាសន៍ដទៃ ឲ្យប្រព្រឹត្តតាមសាសន៍យូដាម្តេចកើត?»
[15]រីឯយើងរាល់គ្នាវិញ ជាសាសន៍យូដាតាំងពីកំណើត ពុំមែនជាមនុស្សមានបាបដូចសាសន៍ដទៃឡើយ[16]ប៉ុន្តែ យើងដឹងហើយថា ព្រះជាម្ចាស់ពុំបានប្រោស
នរណាម្នាក់ឲ្យបានសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ ផ្ទុយទៅវិញព្រះជាម្ចាស់បានប្រោសមនុស្សឲ្យបានសុចរិត ដោយសារជំនឿលើព្រះយេស៊ូគ្រិស្ត។
យើងជឿព្រះគ្រិស្តយេស៊ូ ដើម្បីឲ្យព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិត ដោយសារជំនឿ ពុំមែនដោយសារប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ។ ដ្បិត
គ្មាននរណាម្នាក់បានសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យទេ។
[17]ប៉ុន្តែ ប្រសិនបើយើងចង់បានសុចរិតតាមរយៈព្រះគ្រិស្ត តែមើលឃើញខ្លួនឯងជាមនុស្សជាប់បាបទៅវិញ តើព្រះគ្រិស្តនាំឲ្យយើងមានបាប?[18]ទេ ពុំមែនទេ!
បើសិនជាខ្ញុំសង់អ្វីដែលខ្ញុំបំផ្លាញកាលពីមុនឡើងវិញ បានសេចក្តីថាខ្ញុំល្មើសក្រឹត្យវិន័យហើយ។[19]ដោយសារក្រឹត្យវិន័យ ខ្ញុំបានរួចពីអំណាចក្រឹត្យវិន័យ
ដើម្បីឲ្យខ្ញុំបានរស់នៅសម្រាប់ព្រះជាម្ចាស់វិញ។
[20]ខ្ញុំបានជាប់ឆ្កាងជាមួយព្រះគ្រិស្ត។ ខ្ញុំរស់នៅ ពុំមែនជាខ្ញុំទៀតទេ ប៉ុន្តែ ព្រះគ្រិស្តមានព្រះជន្មរស់ក្នុងរូបកាយខ្ញុំវិញ។ ខ្ញុំរស់នៅសព្វថ្ងៃនេះ
ខ្ញុំរស់នៅដោយជំនឿលើព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលស្រឡាញ់ខ្ញុំ និងបូជាព្រះជន្មសម្រាប់ខ្ញុំ។[21]ខ្ញុំមិនលុបបំបាត់ព្រះគុណរបស់ព្រះជាម្ចាស់ឡើយ ប៉ុន្តែ
បើសិនមាននរណាម្នាក់បានសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យ នោះបានសេចក្តីថា ព្រះគ្រិស្តសោយទិវង្គតជាអសារឥតការ។

Galatians 2:1

ប្រយោគភ្ជាប់:

លោកប៉ូលបន្តផ្តល់ឲ្យប្រវត្តិនៃរបៀបដែលគាត់បានរៀនពីដំណឹងល្អពីព្រះជាម្ចាស់
មិនមែនពីសាវក។

ខ្ញុំឡើងទៅ

«ការធ្វើដំណើរ» ទីក្រុងយេរូសាឡឹមគឺជាតំបន់ទីទួលនៅក្នុងប្រទេស។
ជនជាតិយូដាបានបង្ហាញថាក្រុងយេរូសាឡឹមជាកន្លែងនៅលើផែនដីនោះគឺនៅជិតស្ថានសួគ៌បំផុត។

ដូចច្នេះលោកប៉ូលប្រហែលជាបានកំពុងនិយាយក្នុងន័យធៀបឬ
ប្រហែលបានកំពុងឆ្លុះបញ្ចាំងការលំបាកក្នុងការឡើងទួល
ដើម្បីធ្វើដំណើរទៅកាន់ក្រុងយេរូសាឡឹម។

បងប្អូនជាអ្នកដឹកនាំ ដាច់ដោយឡែកពីគេដែរ

«អ្នកដឹកនាំសំខាន់បំផុតក្នុងចំណោមអ្នកជឿ»

ខ្ញុំកំពុងធ្វើ ឬបានធ្វើរួចហើយ ត្រឡប់ទៅជាអសារឥតការឡើយ។

លោកប៉ូលកំពុងប្រៀបធៀបចំពោះកិច្ចការនិងផ្តោតទៅលើចំនុចសំខានពីរគឺ
កិច្ចការដែលគាត់បានធ្វើគឺមានប្រយោជន៍។ ការបកប្រែផ្សេងទៀត:
«ខ្ញុំបានកំពុងធ្វើ ឬ បានធ្វើ មានប្រយោេជន៍»

Galatians 2:3

ឲ្យទទួលការកាត់ស្បែកឡើយ

នេះអាចត្រូវថ្លែងជារម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«មាននរណាម្នាក់កាត់ស្បែកឲ្យគាត់»

មានពួកបងប្អូនក្លែងក្លាយខ្លះ បានបន្លំខ្លួនជ្រៀតចូលមក

«មនុស្សដែលធ្វើពុតជាគ្រិស្ទានបានមកនៅក្នុងក្រុមជំនុំ» ឬ
«មនុស្សដែលធ្វើពុតជាគ្រិស្ទានបានមកនៅក្នុងចំណោមយើង»

ដើម្បីឈ្លបមើលសេរីភាព

មើលមនុស្សយ៉ាងសម្ងាត់ដើម្បីឃើញគេរស់នៅក្នុងសេរីភាព

សេរីភាព

មានសេរីភាព

ពួកគេមានបំណង

«អ្នកឈ្លបមើលទាំងនេះមានបំណង» ឬ «បងប្អូនក្លែងដែលចង់បាន»

Galatians 2:6

គ្មានអ្វីសំខាន់ចំពោះរូបខ្ញុំឡើយ

ពាក្យ «ខ្ញុំ» នៅទីនេះតំណាងឲ្យអ្វីដែលលោកប៉ូលបានកំពុងបង្រៀន។
ការមស៊ើងផ្សេងទៀត: «បន្ថែមនូវអ្វីដែលខ្ញុំបង្រៀនឡើយ» ឬ
«កុំប្រាប់ខ្ញុំដើម្បីបន្ថែមនូវអ្វីដែលខ្ញុំបង្រៀន»

ផ្ទុយទៅវិញ

«ជំនួស» ឬ «ជាជាង»

ព្រះជាម្ចាស់បានប្រគល់មុខងារ

នេះអាចត្រូវថ្លែងជារម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់ទុកចិត្តខ្ញុំ»

Galatians 2:9

ជាសរសរទ្រូងរបស់ក្រុមជំនុំ

ពួកគេគឺជាមនុស្សដែលបានបង្រៀនមនុស្សអំពីព្រះយេស៊ូនិងបញ្ចុះបញ្ចូលដើម្បីឲ្យជឿលើព្រះយេស៊ូ។

ព្រះគុណ ដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ

«ដែលព្រះជាម្ចាស់មានក្តីសប្បុរសចំពោះខ្ញុំ»

ប្រគល់ដៃស្តាំនៃសម្ពន្ធភាព

«សូមស្វាគមន៍... ក្នុងនាមជាអ្នកធ្វើការជាមួយគ្នា» ឬ
«សូមស្វាគមន៍...ដោយការគោរព»

ដៃស្តាំ

«ដៃស្តាំរបស់ពួកគេ»

ចេះគិតគូរដល់ជនក្រីក្រ

«ថែរក្សាអ្នកក្រដែលមានសេចក្តីត្រូវការ»

Galatians 2:11

ខ្ញុំបានជំទាស់លោកនៅមុខគេឯង

generated on Wed Sep 10 16:16:32 2025

ពាក្យថា «មុខរបស់គាត់» គឺជានៃធៀបចំពោះ «កន្លែងដែលគាត់អាចជួបខ្ញុំនិងឮខ្ញុំ»
ការបកប្រែផ្សេងទៀត: «ខ្ញុំពេញចិត្តគាត់នៅនាមជាមនុស្ស» ឬ
«ខ្ញុំបានជម្រុញនៅក្នុងសកម្មភាពរបស់គាត់នៅក្នុងនាមជាមនុស្ស»
មុនពេល
នៅក្នុងពេលទំនាក់ទំនង
លោកបែរជាឈប់
«គាត់បានឈប់ញុាំជាមួយពួកគេ»
ដកខ្លួនថយចេញពីសាសន៍ដទៃ
«គាត់ខ្លាចថាបុរសដែលបានកាត់ស្បែកទាំងនោះនឹងកាត់ទោសគាត់ដែលគាត់កំពុងធ្វើ
ឬ»
គាត់ភ័យខ្លាចបុរសដែលបានកាត់ស្បែកនោះនឹងបន្ទោសគាត់សម្រាប់ការធ្វើខុស។
ខ្លាចពួកកាត់ស្បែក
យូដាដែលបានត្រឡប់ជាគ្រិស្តបរិស័ទ
តែទាមទារថាអ្នកដែលជឿនៅក្នុងព្រះគ្រិស្តរស់នៅទៅតាមប្រពៃណីទំនៀមទម្លាប់យូដា។
ដកខ្លួនថយចេញពី
«ឈរពីចម្ងាយ» ឬ «ជៀសចេញ»
Galatians 2:13
លែងប្រព្រឹត្តតាមសេចក្តីពិតនៃដំណឹងល្អ
«ពួកគេមិនកំពុងរស់នៅដូចមនុស្សដែលជឿដំណឹងល្អ» ឬ
«ពួកគេបានកំពុងរស់នៅដូចជាអ្នកមិនជឿលើដំណឹងល្អ»។
ធ្វើម៉េចលោកអាចបង្ខំសាសន៍ដទៃ ឲ្យប្រព្រឹត្តតាមសាសន៍យូដាម្តេចកើត?
សំនួរដ៏ល្អនេះគឺស្តីបន្ទោសហើយអាចបកប្រែបានថាជាសេចក្តីថ្លែង។
ការបកប្រែផ្សេងទៀត:
«អ្នកកំពុងធ្វើខុសដោយបង្ខំសាសន៍ដទៃឲ្យរស់នៅដូចជាសាសន៍យូដា» ពាក្យ
«អ្នក» សំដៅទៅលើលោកពេត្រុស ហើយគឺឯកវចន:
បង្ខំ
ទី១មួយប្រហែលជាមានន័យថា) បង្ខំដោយប្រើពាក្យ ឬ ទី២) បញ្ចុះបញ្ចូល។
Galatians 2:15
ប្រយោគភ្ជាប់:
លោកប៉ូលប្រាប់អ្នកជឿថាយនជាតិដែលស្គាល់ក្រឹត្យវិន័យដូចជាសាសន៍ដទៃដែលមិន
គឺបានសង្គ្រោះតាមរយៈជំនឿនៅក្នុងព្រះគ្រិស្តតែមួយគត់ហើយមិនមែនតាមរយៈការ
ពុំមែនជាមនុស្សមានបាបដូចសាសន៍ដទៃឡើយ
«មិនអស់អ្នកដែលជាជាតិយូដាហៅសាសន៍ដទៃជាមនុស្សមានបាបទេ»

យើងជឿព្រះគ្រិស្តយេស៊ូ ដើម្បីឲ្យព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិត ដោយសារជំនឿ
«យើងបានជឿដល់ព្រះយេស៊ូគ្រិស្ត»
យើង
នេះប្រហែលជាលោកប៉ូលចង់សំដៅលើអ្នកដទៃនិងមិនមែនជាសាសន៍ដទៃ។
គ្មាននរណាម្នាក់បានសុចរិត
ពាក្យថា «សាច់ឈាម» គឺបញ្ជាក់សម្រាប់ខ្លួនមនុស្សទាំងមូល។
ការបកប្រែផ្សេងទៀត: «គឺមិនមែនមនុស្ស»
Galatians 2:17
ប្រសិនបើយើងចង់បានសុចរិតតាមរយៈព្រះគ្រិស្ត
ឃ្លាថា «បានសុចរិតតាមរយៈព្រះគ្រិស្ត» មានន័យថាសុចរិតពីព្រោះ
យើងរួមជាមួយព្រះគ្រិស្តហើយសុចរិតដោយសារព្រះគ្រិស្ត។
តែមើលឃើញខ្លួនឯងជាមនុស្សជាប់បាបទៅវិញ
ដែលបញ្ជាក់ថា «យើងគឺជាមនុស្ស» មានបាបពិតប្រាកដ។ ការបកប្រែផ្សេងទៀត:
«យើងឃើញដែលថា យើងពិតជាមនុស្សមានបាបដែរ«។
ទេ ពុំមែនទេ!
«ពិតហើយ នោះគឺពិត!»
នេះបង្ហាញឲ្យយើងនូវចម្លើយបដិសេធយ៉ាងខ្លាំងមុននឹងសំនួរដ៏មានវោរហាសាស្ត្រ។
តើព្រះគ្រិស្តត្រឡប់ជាអ្នកបម្រើអំពើបាប?»
អ្នកអាចបង្ហាញនៅក្នុងភាសារបស់អ្នកដែលស្រដៀងគ្នាដែលអ្នកអាចប្រើនៅទីនេះ។
Galatians 2:20
ព្រះបុត្រារបស់ព្រះជាម្ចាស់
នេះគឺជាតួនាទីដ៏សំខាន់មួយសម្រាប់ព្រះយេស៊ូ។
ខ្ញុំមិនលុបបំបាត់
លោកប៉ូលបានថ្លែងសង្កត់ធ្ងន់ទៅអវិជ្ជាមានទៅជាវិជ្ជាមាន។ ការបកប្រែផ្សេងទៀត:
«ខ្ញុំបញ្ជាក់ពីគុណតម្លៃនៃ» សូមមើល:
បើសិនមាននរណាម្នាក់បានសុចរិតដោយ ... ព្រះគ្រិស្តសោយទិវង្គតជាអសារឥតការ។
លោកប៉ូលគឺកំពុងពិព៌នានៅកាលៈទេសដែលមិនអាចកើតមានបាន។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែសេចក្តីសុរិតមិនមាន... ដូចច្នេះព្រះគ្រិស្តមិនសុគត"
បើសិនមាននរណាម្នាក់បានសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យ
ឃ្លាសិក្សាពីវិន័យ អាចបានសុរិតតាមរយៈការរក្សាក្រឹត្យវិន័យ»
ក្រឹត្យវិន័យ អសារឥតការ
«នឹងមិនបានសម្រេចអ្វីទាំងអស់តាមរយៈការសុគត»

---

3 [1]ឱបងប្អូនអ្នកស្រុកកាឡាទីអើយ ហេតុអ្វីបានបងប្អូនល្ងីល្ងើដូច្នេះ? តើបងប្អូនត្រូវអំពើរបស់នរណា? ពីមុនមក បងប្អូនបានដឹងច្បាស់ថា ព្រះយេស៊ូគ្រិស្តបានជាប់ឆ្កាង។
[2]ខ្ញុំចង់ដឹងតែការមួយពីបងប្អូនប៉ុណ្ណោះ តើបងប្អូនបានទទួលព្រះវិញ្ញាណ ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យ ឬដោយជឿលើដំណឹងល្អដែលបងប្អូនបានស្តាប់?
[3]តើបងប្អូនល្ងីល្ងើដល់កាលណាទៀត? បងប្អូនចាប់ផ្តើមជីវិតថ្មីដោយព្រះវិញ្ញាណ តើឥឡូវនេះបងប្អូនចង់បញ្ចប់ដោយតាមរបៀបលោកីយ៍ឬ?
[4]តើបងប្អូនរងទុក្ខលំបាកជាច្រើនជាអសារឥតការឬ? ទេ ពុំមែនអសារឥតការទេ។[5]តើព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបងប្អូន និងធ្វើការអស្ចារ្យក្នុងចំណោមបងប្អូន
ដោយប្រព្រឹត្តតាមក្រឹត្យវិន័យ ឬជឿលើដំណឹងល្អបងប្អូនបានស្តាប់?
[6]ដូចលោកអប្រាហាំ «ជឿព្រះជាម្ចាស់ ហើយព្រះអង្គបានប្រោសលោកឲ្យបានសុចរិត ដោយយល់ជំនឿនេះ»[7]ដូចគ្នានេះដែរ សូមបងប្អូនយល់ថា អ្នកណាមានជំនឿ
អ្នកនោះជាកូនចៅលោកអប្រាហាំហើយ។[8]ព្រះគម្ពីរប្រាប់យើងទុកជាមុនថា ព្រះជាម្ចាស់នឹងប្រោសសាសន៍ដទៃឲ្យបានសុចរិត ដោយសារជំនឿ
ហើយដំបូងលោកអប្រាហាំបានទទួលដំណឹងល្អថា៖ «ជាតិសាសន៍ទាំងអស់នឹងបានទទួលពរដោយសារអ្នក»[9]ដូច្នេះ
អស់អ្នកដែលមានជំនឿនឹងបានទទួលព្រះពររួមជាមួយលោកអប្រាហាំ ដែលជាបិតានៃជំនឿ។
[10]អស់អ្នកដែលពឹងផ្អែកលើការប្រព្រឹត្តតាមក្រឹត្យវិន័យ អ្នកនោះត្រូវបណ្តាសាហើយ ដូច្នេះមានសេចក្តីចែងទុកមកថា៖ «អ្នកណាមិនប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែល
មានចែងទុកក្នុងគម្ពីរវិន័យយ៉ាងខ្ជាប់ខ្ជួនទេនោះ អ្នកនោះត្រូវបណ្តាសាហើយ»។[11]ឥឡូវនេះ យើងដឹងច្បាស់ថា គ្មាននរណាម្នាក់បានសុចរិតនៅចំពោះព្រះជាម្ចាស់
ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ ព្រោះមនុស្សសុចរិតរស់នៅដោយពឹងលើជំនឿ។[12]ប៉ុន្តែ ក្រឹត្យវិន័យខុសប្លែកពីជំនឿ ដ្បិតមានចែងទុកថា៖
«មនុស្សពឹងផ្អែកលើការប្រព្រឹត្តតាមក្រឹត្យវិន័យ នឹងត្រូវរស់នៅតាមក្រឹត្យវិន័យ»។
[13]ព្រះគ្រិស្តបានប្រោសលោះយើងរាល់គ្នា ឲ្យរួចពីបណ្តាសារបស់ក្រឹត្យវិន័យ គឺទ្រង់ទទួលបណ្តាសាជំនួសយើង ដ្បិតមានចែងទុកមកថា៖ «អ្នកណាដែលត្រូវគេព្យួរជាប់
នឹងឈើ អ្នកនោះត្រូវបណ្តាសាហើយ»[14]ដើម្បីឲ្យព្រះពររបស់លោកអប្រាហាំហូរទៅដល់សាសន៍ដទៃ ក្នុងព្រះគ្រិស្តយេស៊ូ ដូច្នេះ យើងទទួលព្រះវិញ្ញាណតាមសេចក្តីសន្យា
ដោយសារជំនឿ។
[15]បងប្អូនអើយ ខ្ញុំសុំនិយាយតាមពាក្យមនុស្សប្រើប្រាស់។ កិច្ចសន្យាដែលមនុស្សបានតាក់តែងឡើងត្រឹមត្រូវហើយ គ្មាននរណាម្នាក់អាចលុបបំបាត់ ឬបន្ថែមអ្វីបានឡើយ។
[16]ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាជាមួយលោកអប្រាហាំ ព្រមទាំងពូជពង្សរបស់លោក។ ក្នុងគម្ពីរពុំបានចែងទុកមកថា៖ «ពូជពង្សទាំងឡាយ»
ដែលសំដៅទៅលើពូជពង្សជាច្រើន ផ្ទុយទៅវិញ សំដៅទៅលើពូជពង្សតែមួយប៉ុណ្ណោះ «ពូជពង្សរបស់អ្នក» គឺព្រះគ្រិស្ត។
[17]ឥឡូវនេះ ខ្ញុំចង់ពន្យល់ថា៖ «ក្រឹត្យវិន័យកើតមានបួនរយសាមសិបឆ្នាំក្រោយមក ពុំបានលុបបំបាត់សម្ពន្ធមេត្រី ដែលព្រះជាម្ចាស់បានចងនោះឡើយ។[18]ប្រសិនបើ
ព្រះជាម្ចាស់ប្រទានមរតកមកមនុស្ស ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យ នោះបានសេចក្តីថា គេលែងទទួលមរតកតាមព្រះបន្ទូលសន្យាទៀតហើយ។ ប៉ុន្តែ
ព្រះជាម្ចាស់ប្រទានមរតកមកលោកអប្រាហាំ តាមព្រះបន្ទូលសន្យា។
[19]ដូច្នេះ តើក្រឹត្យវិន័យមានគោលបំណងអ្វី? ក្រឹត្យវិន័យកើតមានតាមក្រោយ ដើម្បីបង្ហាញបទល្មើសរបស់មនុស្ស រហូតដល់ពូជពង្សរបស់លោកអប្រាហាំ
ដែលត្រូវទទួលមត៌ក តាមព្រះបន្ទូលសន្យាមកដល់។ ពួកទេវតាបាននាំយកក្រឹត្យវិន័យមក ដោយមានមនុស្សម្នាក់ជួយអន្តរាគមន៍។[20]ឥឡូវនេះ
អ្នកជួយអន្តរាគមន៍ពុំមែនមានតែម្នាក់ទេ ប៉ុន្តែព្រះជាម្ចាស់មានតែមួយព្រះអង្គប៉ុណ្ណោះ។

generated on Wed Sep 10 16:16:32 2025

[21]ដូច្នេះ តើក្រឹត្យវិន័យទាស់នឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ឬ? ទេ ពុំមែនទេ! ប្រសិនបើ ក្រឹត្យវិន័យដែលមនុស្សទទួលមក អាចប្រទានជីវិតបាន
នោះមនុស្សបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យទៅហើយ។[22]ប៉ុន្តែ ព្រះគម្ពីរចែងថា អ្វីៗទាំងអស់ស្ថិតនៅក្រោមអំណាចបាប។ ព្រះជាម្ចាស់ធ្វើដូច្នេះ
ដើម្បីសង្គ្រោះយើងរាល់គ្នាតាមព្រះបន្ទូលសន្យា ដោយសារជំនឿលើព្រះយេស៊ូគ្រិស្ត បានប្រទានមកចំពោះអស់អ្នកណាដែលជឿព្រះអង្គ។
[23]មុនពេលមានជំនឿមកដល់ យើងនៅជាប់ឃុំក្រោមអំណាចរបស់ក្រឹត្យវិន័យ រហូតទាល់តែជំនឿបានបើកសម្តែងឡើង។[24]ដូច្នេះ ក្រឹត្យវិន័យក្លាយជាអ្នកមើលថែយើង
រហូតទាល់តែព្រះគ្រិស្តយាងមក ដើម្បីឲ្យយើងបានរាប់ជាសុចរិតដោយសារជំនឿ។[25]ឥឡូវនេះ ជំនឿបានមកដល់ហើយ
យើងលែងស្ថិតនៅក្រោមការមើលថែរបស់ក្រឹត្យវិន័យទៀតឡើយ។[26]ដ្បិត បងប្អូនរាល់គ្នាជាបុត្ររបស់ព្រះជាម្ចាស់ ដោយសារជំនឿលើព្រះគ្រិស្តយេស៊ូ។
[27]ដ្បិត មានបងប្អូនជាច្រើនបានទទួលពិធីជ្រមុជទឹក ដើម្បីចូលរួមជាមួយព្រះគ្រិស្ត នោះបងប្អូនមានព្រះគ្រិស្តហើយ។[28]គ្មានសាសន៍យូដា គ្មានសាសន៍ក្រិក គ្មានអ្នកជា
គ្មានអ្នកងារ គ្មានស្រី គ្មានប្រុសទៀតឡើយ ព្រោះបងប្អូនទាំងអស់គ្នារួមគ្នាមកតែមួយក្នុងអង្គព្រះគ្រិស្តយេស៊ូ។[29]បើបងប្អូនជារបស់ព្រះគ្រិស្ត
នោះបងប្អូនរាល់គ្នាជាពូជពង្សរបស់លោកអប្រាហាំ ហើយនឹងទទួលមរតកតាមព្រះបន្ទូលជាក់ជាមិនខាន។

Galatians 3:1

ប្រយោគភ្ជាប់:

លោកប៉ូលរម្លឹកអ្នកជឿនៅកាឡាទីថាព្រះជាម្ចាស់ផ្តល់ឲ្យពួកយើងនូវវិញ្ញាណរបស់ព្រះ
មិនមែនតាមរយៈការធ្វើរបស់ពួកគេតាមក្រឹត្យវិន័យរបស់ព្រះ។

ពត៌មានទូទៅ:

លោកប៉ូលគឺកំពុងបន្ទោសតាមរយៈការសួរសំនួរដ៏បិុនប្រសប់។

ហេតុអ្វីបានបងប្អូនល្ងីល្ងើដូច្នេះ?

លោកប៉ូលកំពុងប្រើសំនួរដ៏ល្អ និង បិុនប្រសប់
ដោយនិយាយថាកាឡាទីកំពុងប្រព្រឹត្តដូចជានរណាម្នាក់ដែលពួកគេត្រូវអំពើគេ។
គាត់ពិតជាមិនថាមាននរណាបានដាក់អំពើលើពួកគេទេ។ ការបកប្រែផ្សេងទៀត:
«អ្នកមានអាកប្បកិរិយាដូចត្រូវអំពើគេ!»

ខ្ញុំចង់ដឹងតែការមួយពីបងប្អូនប៉ុណ្ណោះ
ការនេះបន្តនិយាយខ្លាំងដូចខ១។
លោកប៉ូលដឹងចម្លើយដើម្បីឆ្លើយនឹងសំនួរដ៏បិុនប្រសប់ដែលគាត់សួរ។

តើបងប្អូនបានទទួលព្រះវិញ្ញាណ ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យ
ឬដោយជឿលើដំណឹងល្អដែលបងប្អូនបានស្តាប់?

បកប្រែសំនួរដ៏ល្អនេះជាសំនួរប្រសិនបើ អ្នកអាច
ពីព្រោះអ្នកអាននឹងរំពឹងទុកសំនួរនេះទៅទីនេះ។
ប្រាកដថាអ្នកអានដឹងចម្លើយនៅសំនួរនេះផងដែរគឺ
«តាមរយៈការជឿនូវអ្វីដែលអ្នកបាន» មិនមែន
តាមរយៈធ្វើតាមអ្វីដែលក្រឹត្យវិន័យចែងទេការបកប្រែផ្សេងទៀត:
«អ្នកបានទទួលព្រះវិញ្ញាណ មិនមែនតាមរយៈក្រឹត្យវិន័យចែងទេ
ប៉ុន្តែតាមរយៈការជឿនូវអ្វីដែលអ្នកបានឮ»

តើបងប្អូនល្ងីល្ងើដល់កាលណាទៀត?

នេះគឺសំនួរដ៏បិុនប្រសប់ដែលបង្ហាញថាលោកប៉ូល
មានការភ្ញាក់ផ្អើលហើយសូម្បីតែខឹងថា កាឡាទីអើយម្តេចល្ងីល្ងើម្លេះ។
ការបកប្រែផ្សេងទៀត: «អ្នកគឺល្ងីល្ងើណាស់!» (UDB)

ដោយតាមរបៀបលោកីយ៍ឬ?

ពាក្យថា «សាច់ឈាម» គឺមានចំថាការខិតខំប្រឹងប្រែង។ ការបកប្រែផ្សេងទៀត:
«តាមកម្លាំងផ្ទាល់ខ្លួន» ឬ «តាមរយៈការប្រព្រឹត្ត»

Galatians 3:4

តើបងប្អូនរងទុក្ខលំបាកជាច្រើនជាអសារឥតការ... ?

លោកប៉ូលប្រើសំនួរដើម្បីរម្លឹកក្រុមជំនុំនៅកាឡាទីថាពេលបានកំពុងរងទុក្ខលំបាក
ពួកគេបានជឿថា ពួកគេនឹងទទួលប្រយោជន៍ការបកប្រែផ្សេងទៀត:
«ប្រាកដណាស់
អ្នកមិនគិតថាអ្នកបានកំពុងរងទុកវេទនាជាច្រើនសម្រាប់ការឥតប្រយោជន៍ទេ ... !»
ឬ«ប្រាកដណាស់
អ្នកបានដឹងថាមានគោលបំណងល្អខ្លះសម្រាប់ការទុក្ខវេទនាជាច្រើន ... !»

តើបងប្អូនរងទុក្ខលំបាកជាច្រើនជាអសារឥតការ

វាអាចបានចាប់ផ្តើមយ៉ាងច្បាស់ថា
ពួកគេបានរងទុក្ខក្នុងការទាំងនេះដោយសារមនុស្សដែលប្រឆាំងពួកគេសម្រាប់ជំនឿរបស់ពួកគេ
ការបកប្រែផ្សេងទៀត:«តើបងប្អូនរងទុក្ខលំបាកជាច្រើនដោយសារអ្នកប្រឆាំងបងប្អូនចំពោះជំនឿ
ឬ «អ្នកបានជឿនៅក្នុងព្រះគ្រិស្ត
ហើយរងទុក្ខលំបាកដោយសារអ្នកដែលប្រឆាំងព្រះគ្រិស្ត។»ជំនឿរបស់អ្នកនិងការរងទុក្ខ

សម្រាប់ការឥតប្រយោជន៍

«ជាការគ្មានប្រយោជន៍» ឬ «គ្មានសង្ឃឹមទទួលបានអ្វីដែលល្អ»

ពុំមែនអសារឥតការទេ?

ទី១ប្រហែលជាមានន័យថា) លោកប៉ូលប្រើសំនួរដ៏បិុនប្រសប់ដើម្បីព្រមានពួកគេ
ដោយមិនអនុញ្ញាតិឲ្យឆ្លងការទុក្ខលំបាកដោយឥតប្រយោជន៍ទេ។
លការបកប្រែផ្សេងទៀត: «កុំឲ្យវាទៅជាឥតប្រយោជន៍!» ឬ
ហើយអនុញ្ញាតិឲ្យការរងទុក្ខលំបាកទៅជាអសារឥតការ» ឬ
២)លោកប៉ូលប្រើសំនួរនេះដើម្បីធានាដល់ពួកគេថា
ទុក្ខលំបាករបស់ពួកគេគឺមិនឥតប្រយោជន៍ទេ។ការបកប្រែផ្សេងទៀត:
«វាគឺប្រាកដណាស់មិនមែនឥតប្រយោជន៍ទេ!»

តើព្រះជាម្ចាស់...ដោយប្រព្រឹត្តតាមក្រឹត្យវិន័យ ឬជឿលើដំណឹងល្អបងប្អូនបានស្តាប់?

លោកប៉ូលសួរសំនួរដ៏បិុនប្រសប់ផ្សេងទៀតដើម្បីរម្លឹកក្រុមជំនុំកាឡាទីអំពីរបៀបដែលពួកគេទទួលព្រះវិ
ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់ ...
មិនធ្វើវាតាមរយៈការប្រព្រឹត្តតាមក្រឹត្យវិន័យ
ព្រះជាម្ចាស់ធ្វើតាមតាមរយៈការស្តាប់ឮដោយជំនឿ»

ដោយប្រព្រឹត្តតាមក្រឹត្យវិន័យ

នេះគឺតំណាងឲ្យមនុស្សដែលតម្រូវធ្វើតាមក្រឹត្យវិន័យ។ការបកប្រែផ្សេងទៀត:
«ពីព្រោះអ្នកធ្វើនូវអ្វីដែលក្រឹត្យវិន័យប្រាប់អ្នក»

ជឿលើដំណឹងល្អបងប្អូនបានស្តាប់

ភាសារបស់អ្នកអាចតម្រូវឲ្យមនុស្សបានស្តាប់ឮហើយនិងពួកគេបានទុកចិត្តយ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត:
«ពីព្រោះអ្នកបានឮព្រះបន្ទូលហើយមានជំនឿនៅក្នុងព្រះយេស៊ូ» ឬ
«ពីព្រោះអ្នកបានស្តាប់ព្រះបន្ទូលហើយទុកចិត្តដល់ព្រះយេស៊ូ»

Galatians 3:6

ប្រយោគភ្ជាប់:

លោកប៉ូលរម្លឹកក្រុមជំនុំអ្នកជឿនៅកាឡាទីថាសូម្បីតែលោកអប្រាហាំក៏ទទួលបានសុចរិតតាមរយៈជំនឿមិ
យៈក្រឹត្យវិន័យ។

ហើយព្រះអង្គបានប្រោសលោកឲ្យបានសុចរិត

ព្រះជាម្ចាស់បានទតឃើញជំនឿរបស់លោកអប្រាហាំនៅក្នុងព្រះជាម្ចាស់
ដូចច្នេះបន្ទាប់មកព្រះជាម្ចាស់បានទុកលោកអប្រាហាំជាមនុស្សសុចរិត។

អ្នកណាមានជំនឿ

«ដល់អស់អ្នកណាដែលមានជំនឿ» អត្ថន័យនៃមានជំនឿគឺជា «នាម»
អាចបង្ហាញជាកិរិយាសព្ទ «ជឿ» ការបកប្រែផ្សេងទៀត:
«ដល់អស់អ្នកណាដែលមានជំនឿ»

ជាកូនចៅលោកអប្រាហាំហើយ។

នេះគឺតំណាងឲ្យមនុស្សដែលព្រះជាម្ចាស់មានទស្សនៈដូចព្រះអង្គបានមានទស្សនៈចំពោះលោកអប្រាហាំ។
ការបកប្រែផ្សេងទៀត: «សេចក្តីសុរិតនៅក្នុងរបៀបដូចគ្នា»

ទុកជាមុន

ពីព្រោះព្រះជាម្ចាស់បានសន្យាចំពោះអប្រាហាំហើយពួកគេបានសរសេរចុះមុនពេលការសន្យាតាម
រយៈព្រះគ្រិស្ត ព្រះបន្ទូលគឺដូចនរណាម្នាក់ដែលដឹងអនាគតមុនវាកើតឡើង។
ការបកប្រែផ្សេងទៀត: «ព្យាករណ៍ទុកមុន» ឬ «ឃើញមុនវាកើតឡើង»

ដោយសារអ្នក

«ដោយសារនូវអ្វីដែលអ្នកបានធ្វើ»
[illegible]
«ព្រះអង្គបានសន្យាទុកមុនចំពោះ
ព្រះជាម្ចាស់បានផ្តោតថាព្រះអង្គគឺមិនមែនសព្វព្រះហឫទ័យតែជនជាតិយូដាទេ
គម្រោងការសង្គ្រោះរបស់ព្រះអង្គគឺទាំងពីរសម្រាប់យូដា និង
មិនមែនយូដាផងដែរ។

Galatians 3:10

អស់អ្នកដែលពឹងផ្អែក ...ការប្រព្រឹត្តតាមក្រឹត្យវិន័យត្រូវបណ្តាសាហើយ

generated on Wed Sep 10 16:16:32 2025

ត្រូវនៅក្រោមបណ្តាសាគឺណាំងឲ្យត្រូវបណ្តាសា
នៅទីនេះគឺសំដៅលើការទទួលទណ្ឌកម្មអស់កល្បជានិច្ច។
«អស់អ្នកដែលពឹងផ្អែក ...ការប្រព្រឹត្តតាមក្រឹត្យវិន័យត្រូវបណ្តាសាហើយ» ឬ
«ព្រះជាម្ចាស់នឹងដាក់ទោសដល់អស់អ្នកដែលពឹងផ្អែក ... តាមក្រឹត្យវិន័យ»
ឥឡូវនេះ យើងដឹងច្បាស់ថា
អ្វីដែលច្បាស់អាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ការបកប្រែផ្សេងទៀត:
«ព្រះបន្ទូលគឺច្បាស់» ឬ «ព្រះបន្ទូលបង្រៀនយ៉ាងច្បាស់»
គ្មាននរណាម្នាក់បានសុចរិតនៅចំពោះព្រះជាម្ចាស់ ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ
នេះអាចត្រូវបញ្ជាក់ដោយការិយាសព្ទសកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់រាប់ជាសុចរិត មិនមែនតាមរយៈក្រឹត្យវិន័យទេ»
គ្មាននរណាម្នាក់បានសុចរិតនៅចំពោះព្រះជាម្ចាស់
លោកប៉ូលគឺកំពុងកែតម្រូវការជឿរបស់ពួកគេប្រសិនបើពួកគេស្តាប់បង្គាប់តាមក្រឹត្យវិន័យ
ព្រះជាម្ចាស់នឹងបញ្ជាក់ដល់ពួកគេឲ្យបានត្រូវត្រូវ។ ការបកប្រែផ្សេងទៀត:
«គ្មាននរណាម្នាក់បានសុចរិតនៅចំពោះព្រះជាម្ចាស់
ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ» ឬ
«ព្រះជាម្ចាស់មិនបានរាប់ថានរណាម្នាក់សុរិតតាមរយៈស្តាប់តាមក្រឹត្យវិន័យនោះទេ»
មនុស្សសុចរិត
នេះសំដៅទៅមនុស្សសុរិត។ ការបកប្រែផ្សេងទៀត: «មនុស្សសុរិត» ឬ
«មនុស្សដែលចាត់ទុកជាសុចរិត »
ពឹងផ្អែកលើការប្រព្រឹត្តតាមក្រឹត្យវិន័យ
«អ្វីៗដែលក្រឹត្យវិន័យចែងយើងត្រូវតែធ្វើតាម»
ត្រូវរស់នៅតាមក្រឹត្យវិន័យ
ទី១ប្រហែលជាមានន័យថា) «ត្រូវស្តាប់បង្គាប់តាមក្រឹត្យវិន័យទាំងអស់» (UDB)
ឬទី២)
«នឹងត្រូវទទួលទោសតាមរយៈសមត្ថភាពរបស់គេដើម្បីធ្វើនូវអ្វីៗដែលក្រឹត្យវិន័យទាមទារ»
Galatians 3:13
ប្រយោគភ្ជាប់:
លោកប៉ូលរម្លឹកដល់អ្នកជឿទាំងនោះម្តងទៀតថាការរក្សាក្រឹត្យវិន័យមិនអាចសង្គ្រោះមនុស្សបានទេ
ពីបណ្តាសារបស់ក្រឹត្យវិន័យ
ពាក្យថា «បណ្តាសា» គឺជានាម «អាចបង្ហាញជាមួយ»ការិយាសព្ទ»
«ដាក់បណ្តាសា» ការបកប្រែផ្សេងទៀត: «អ្នកទទួលបណ្តាសានៃក្រឹត្យវិន័យ» ឬ
«អ្នកទទួលបណ្តាសាចំពោះអ្នកមិនស្តាប់ក្រឹត្យវិន័យ»។
ទទួលបណ្តាសាជំនួសយើង
«បណ្តាសា» ជានាម អាចបង្ហាញជាមួយកិរិយា «ទទួលបណ្តាសា»
ការបកប្រែផ្សេងទៀត: «ទទួលបណ្តាសាជំនួសយើង» ឬ
«ពេលព្រះជាម្ចាស់ទទួលបណ្តាសាជំនួសយើង «
ពីបណ្តាសារបស់ក្រឹត្យវិន័យ ...ទទួលបណ្តាសាជំនួសយើង ... អ្នកនោះត្រូវបណ្តាសាហើយ
បណ្តាសានៅទីនេះតំណាងឲ្យការទទួលការកាត់ទោស។ ការបកប្រែផ្សេងទៀត:
«ពីការទទួលការកាត់ទោសតាមរយៈក្រឹត្យវិន័យជំនួសយើង ...
គ្រប់ៗគ្នាទទួលការកាត់ទោស»
ព្យួរជាប់នឹងឈើ
លោកប៉ូលសង្ឃឹមថាអ្នកស្តាប់របស់គាត់យល់ថាគាត់បានកំពុងនិយាយទៅកាន់ព្រះយេស៊ូវ
ហូរ
«នឹង»
យើង
ពាក្យថា «យើង» រួមបញ្ចូលទាំងអ្នកអាចសំបុត្រនេះដែរ។
Galatians 3:15
បងប្អូនអើយ
សូមមើលការបកប្រែនៅក្នុង១:១
តាមពាក្យមនុស្សប្រើប្រាស់
«ជាមនុស្ស» ឬ «របស់អ្វីដែលមនុស្សយល់បំផុត»។
ឥឡូវនេះ
ពាក្យនេះបង្ហាញថាលោកប៉ូលបាននិយាយគោលការណ៍ជាទូទៅហើយឥឡូវគឺកំពុងចាប់ផ្តើមពន្យល់ពីការអនុវត្តជាក់លាក់
ដែលសំដៅទៅលើពូជពង្សជាច្រើន
«សំដៅទៅលើពូជពង្សជាច្រើន»
ពូជពង្សរបស់អ្នក
ពាក្យ «របស់អ្នក» គឺឯកវចន:, ហើយសំដៅទៅលើមនុស្សជាក់ច្បាស់
ដែលគឺជាពូជពង្សរបស់លោកអប្រាហាំ។
Galatians 3:17
ប្រសិនបើ ព្រះជាម្ចាស់ប្រទានមរតកមកមនុស្ស ប្រសិនបើ ព្រះជាម្ចាស់ប្រទានមរតកមកមនុស្ស
ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យ នោះបានសេចក្តីថា
គេលែងទទួលមរតកតាមព្រះបន្ទូលសន្យាទៀតហើយ។
លោកប៉ូលគឺកំពុងនិយាយក្នុងកាលៈទេសដែលមិនអាចកើតមានដើម្បីបញ្ជាក់ថាមរតកមកតាមរយៈព្រះប
ការបកប្រែផ្សេងទៀត: «មរតកមកដល់យើងតាមរយៈព្រះបន្ទូលសន្យា
ពីព្រោះយើងមិនអាចរក្សាការទាមទារតាមរយៈក្រឹត្យវិន័យបាន»។
មរតក
ទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យាដល់អ្នកជឿត្រូវបានគេនិយាយប្រសិនបើវាជាមរតកនៃទ្រព្យសម្ប
ហើយព្រះពរអស់កល្បជានិច្ច និងការសង្គ្រោះ។
Galatians 3:19
ប្រយោគភ្ជាប់:
លោកប៉ូលប្រាប់អ្នកជឿនៅកាឡាទីដែលបានឲ្យក្រឹត្យវិន័យ។
ដូច្នេះ តើក្រឹត្យវិន័យមានគោលបំណងអ្វី?
លោកប៉ូលប្រើដ៏ប៉ិនប្រសប់ដើម្បីណែនាំនៅប្រធានបទបន្ទាប់ដែលគាត់ចង់ពិភាក្សា។
វាក៏អាចបកប្រែបានថាជាសេចក្តីថ្លែងបានដែរ។ការបកប្រែផ្សេងទៀត:
«ខ្ញុំនឹងប្រាប់បងប្អូននៅគោលបំណងនៃក្រឹត្យវិន័យគឺ» ឬ
«អនុញ្ញាតិឲ្យខ្ញុំប្រាប់បងប្អូនហេតុដែលព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យ»
ក្រឹត្យវិន័យកើតមានតាមក្រោយ
នេះអាចបកប្រែជាសេចក្តីថ្លែងនៃទម្រង់សកម្ម។ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បន្ថែមវា» ឬ «ព្រះជាម្ចាស់បន្ថែមក្រឹត្យវិន័យ»
ពួកទេវតាបាននាំយកក្រឹត្យវិន័យមក ដោយមានមនុស្សម្នាក់ជួយអន្តរាគមន៍។
នេះអាចបកប្រែជាសេចក្តីថ្លែងនៃទម្រង់សកម្ម។ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានចេញក្រឹត្យវិន័យដោយទេវតាជួយ និង
អ្នកសម្រុះសម្រួលដាក់វាទៅដោយបង្ខំ»។
ជួយអន្តរាគមន៍
«អ្នកតំណាង»
ឥឡូវនេះ អ្នកជួយអន្តរាគមន៍ពុំមែនមានតែម្នាក់ទេ ប៉ុន្តែព្រះជាម្ចាស់មានតែមួយព្រះអង្គប៉ុណ្ណោះ។
[illegible]
ប៉ុន្តែព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យដល់លោកម៉ូសេដោយមានអ្នកសម្រុះសម្រួល
ជាលទ្ធិផលអ្នកអានរបស់លោកប៉ូលអាចមានគំនិតថាក្រឹត្យវិន័យបានបង្កើតការសន្យាដែលគ្មានផលប៉ះពា
លោកប៉ូលគឺថ្លែងនូវអ្វីដែលអ្នកអានរបស់គាត់អាចមានគំនិតនៅទីនេះ
ហើយនឹងឆ្លើយតបទៅកាន់ពួកគេនៅក្នុងខបន្ទាប់ទៀត។
Galatians 3:21
ពត៌មានទូទៅ:
ពាក្យ «យើង» នៅក្នុងផ្នែកនេះសំដៅទៅលើគ្រិស្ទានទាំងអស់។
ទាស់
«ប្រឆាំងនឹង» ឬ «មានជម្លោះជាមួយ»
ប្រសិនបើ ក្រឹត្យវិន័យដែលមនុស្សទទួលមក អាចប្រទានជីវិតបាន
នេះអាចបកប្រែជាសេចក្តីថ្លែងនៃទម្រង់សកម្ម ហើយជានាមអរូបី «ជីវិត»
អាចត្រូវបកប្រែជាកិយាសព្ទដែរ «រស់នៅ» ការបកប្រែផ្សេងទៀត:
«ប្រសិនបើព្រះជាម្ចាស់បានប្រទានក្រឹត្យវិនយឲ្យដល់អស់អ្នកណាដែលអាចរក្សាវាដើម្បីរស់នៅ»។
[illegible]
«យើងអាចបានត្រឡប់ជាសុចរិតតាមរយៈការស្តាប់បង្គាប់តាមក្រឹត្យវិន័យ»
ប៉ុន្តែ ព្រះគម្ពីរចែងថា អ្វីៗទាំងអស់ស្ថិតនៅក្រោមអំណាចបាប។ ព្រះជាម្ចាស់ធ្វើដូច្នេះ
ដើម្បីសង្គ្រោះយើងរាល់គ្នាតាមព្រះបន្ទូលសន្យា ដោយសារជំនឿលើព្រះយេស៊ូគ្រិស្ត
បានប្រទានមកចំពោះអស់អ្នកណាដែលជឿព្រះអង្គ។
ទី១ប្រហែលអាចមានន័យផ្សេងទៀត «ពីព្រោះយើងទាំងអស់មានបាប
ព្រះជាម្ចាស់ដាក់អ្វីទាំងអស់ឲ្យនៅក្រោមការគ្រប់គ្រងរបស់ក្រឹត្យវិន័យ
ដូចដាក់ពួកគេនៅក្នុងគុគ
ដូចច្នេះហើយព្រះជាម្ចាស់បានសន្យាដល់អស់អ្នកណាដែលមានជំនឿនៅក្នុងព្រះគ្រិស្ត
ដែលបានផ្តល់ឲ្យដល់អស់អ្នកណាដែលជឿ» ឬទី២) «ពីព្រោះយើងមានបាប
ព្រះជាម្ចាស់ដាក់អ្វីៗទាំងអស់ឲ្យនៅក្រោមការគ្រប់គ្រងនៃក្រឹត្យវិន័យ
[illegible]
ពីព្រោះនេះជាអ្វីដែលព្រះអង្គបានសន្យាដល់អស់អ្នកណាដែលជឿនៅក្នុងព្រះគ្រិស្តយេស៊ូ
ព្រះអង្គចង់ប្រទានឲ្យដល់អស់អ្នកណាដែលជឿ»។
ព្រះគម្ពីរ
លោកប៉ូលគឺកំពុងចាត់ទុកបទគម្ពីរដូចជាគាត់ជាមនុស្សម្នាក់
ហើយដែលកំពុងនិយាយជំនួយឲ្យព្រះជាម្ចាស់ ដែលបានសរសេរព្រះគម្ពីរឡើង
ការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់»

generated on Wed Sep 10 16:16:32 2025

Galatians 3:23

ប្រយោគភ្ជាប់:

លោកប៉ូលរម្លឹកដល់អស់អ្នកដែលនៅក្រុមជំនុំកាឡាទីថា
អ្នកជឿគឺមានសេរីភាពនៅក្នុងគ្រួសារព្រះជាម្ចាស់
មិនមែនជាទេសករនៅក្រោមក្រឹត្យវិន័យ។

យើងនៅជាប់ឃុំក្រោមអំណាចរបស់ក្រឹត្យវិន័យ

នេះអាចបកប្រែជាសេចក្តីថ្លែងនៃទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ក្រឹត្យវិន័យនៅឃុំជាប់យើងហើយយើងត្រូវនៅក្នុងគុក» ឬ
«ក្រឹត្យវិន័យឃុំយើងនៅក្នុងគុក»

យើងនៅជាប់ឃុំក្រោមអំណាចរបស់ក្រឹត្យវិន័យ

របៀបនៃក្រឹត្យវិន័យគ្រប់គ្រងយើងគឺត្រូវបាននិយាយថា
ប្រសិនបើក្រឹត្យវិន័យជាអ្នកយាមគុកឃុំយើងជាប់ជាអ្នកទោស។
ការបកប្រែផ្សេងទៀត: «ក្រឹត្យវិន័យគ្រប់គ្រងយើងដូចជាអ្នកយាមគុក»

រហូតទាល់តែជំនឿបានបើកសម្តែងឡើង

នេះអាចបកប្រែជាសេចក្តីថ្លែងនៃទម្រង់សកម្ម
ហើយអ្នកដែលមានជំនឿបែបនេះអាចបកប្រែថាសេចក្តីថ្លែងដ៏ច្បាស់។
ការបកប្រែផ្សេងទៀត:
«រហូតទាល់តែព្រះជាម្ចាស់នឹងបើកសម្តែងដែលព្រះអង្គធ្វើឲ្យសុរិតដល់អស់អ្នកណាដែលជឿ»
ឬ
«រហូតទាល់តែព្រះជាម្ចាស់នឹងបង្ហាញថាព្រះអង្គធ្វើឲ្យសុរិតដល់អ្នកណាដែលទុកចិត្តដល់ព្រះអង្គ»

អ្នកមើលថែ

សាមញ្ញជាងនេះគឺ «អ្នកដែលផ្តល់ឲ្យនូវការមើលថែរក្សាដល់កូន»

នេះគឺរឿងធម្មតាចំពោះទេសករដែលជាអ្នកទទួលខុសត្រូវសម្រាប់ការត្រួតពិនិត្យ
ហើយឥរិយាបថដែលបានផ្តល់ឲ្យតាមរយៈមាតាបិតាហើយនឹងរាយការណ៍ទៅលើសកម្មភាពរបស់កុមារ។

រហូតទាល់តែព្រះគ្រិស្តយាងមក

«រហូតទាល់ពេលព្រះគ្រិស្តបានយាងមក»

ដើម្បីឲ្យយើងបានរាប់ជាសុចរិត

មុនពេលព្រះគ្រិស្តបានយាងមក
ព្រះជាម្ចាស់មានផែនការធ្វើឲ្យយើងបានរាប់ជាសុចរិត។
ពេលព្រះគ្រិស្តបានយាងមក
ព្រះអង្គអនុវត្តន៍ផែនការរបស់ទ្រង់ដើម្បីរាប់យើងជាសុចរិត។

នេះអាចបកប្រែជាសេចក្តីថ្លែងនៃទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ដូចច្នេះព្រះជាម្ចាស់នឹងប្រកាសប្រកាសថាយើងគឺជាអ្នកសុរិត»

Galatians 3:27

បងប្អូន... បានបំពាក់ខ្លួនរបស់បងប្អូនជាមួយព្រះគ្រិស្ត

ទី១ប្រហែលអាចមានន័យ) «បងប្អូន...
បានត្រឡប់ជាមនុស្សតែមួយដូចព្រះគ្រិស្តគឺ»

គ្មានសាសន៍យូដា គ្មានសាសន៍ក្រិក គ្មានអ្នកជា គ្មានអ្នកងារ គ្មានស្រី គ្មានប្រុសទៀតឡើយ

«ព្រះជាម្ចាស់មិនទតឃើញរវាងយូដានិងក្រិកខុសគ្នាទេ ទេសករ និង សេរីភាព
ឬ
«ព្រះជាម្ចាស់មិនទតឃើញរវាងយូដានិងក្រិកខុសគ្នាទេ ទេសករ និង សេរីភាព

ទទួលមរតក

«ព្រះជាម្ចាស់បានសន្យាគឺត្រូវបាននិយាយ
ថាប្រសិនបើពួកគេទទួលមរតក និងទ្រព្យសម្បត្តិជាកម្មសិទ្ធពីសមាជិកគ្រួសារ។

---

4 [1]ខ្ញុំចង់ជម្រាបបងប្អូនថា ដរាបណាកូនដែលត្រូវទទួលមរតកនៅក្មេងនៅឡើយ នោះគ្មានអ្វីខុសពីអ្នកបម្រើទេ ទោះបីជាគាត់ជាម្ចាស់ទ្រព្យសម្បត្តិទាំងអស់ក៏ដោយ។
[2]ប៉ុន្តែ គាត់ត្រូវនៅក្រោមការមើលថែ និងការទទួលខុសត្រូវ រហូតដល់ពេលឪពុកកំណត់ឲ្យ។
[3]ដូចគ្នានេះដែរ ពេលណាយើងនៅក្មេងនៅឡើយ យើងជាអ្នកបម្រើរបស់មេគ្រប់គ្រងនៃលោកីយ៍នេះ។[4]ប៉ុន្តែ ដល់ពេលពេញវ័យមកដល់
ព្រះជាម្ចាស់បានចាត់បញ្ជូនព្រះបុត្រាព្រះអង្គ ឲ្យមកប្រសូតចេញពីស្ត្រីនៅក្រោមអំណាចរបស់ក្រឹត្យវិន័យ។[5]ទ្រង់បានប្រោសលោះ
អស់អ្នកណាដែលស្ថិតនៅក្រោមក្រឹត្យវិន័យ ដើម្បីទទួលបានឋានៈជាបុត្រព្រះអង្គ។
[6]ព្រោះបងប្អូនជាបុត្ររបស់ព្រះជាម្ចាស់ នោះព្រះអង្គបានចាត់បញ្ជូនព្រះវិញ្ញាណរបស់ព្រះបុត្រា មកគង់ក្នុងចិត្តយើង ហើយយើងបន្លឺសំឡេងថា៖ «អប្បា ព្រះបិតា!»។
[7]ដូច្នេះ ឥឡូវនេះបងប្អូនលែងជាអ្នកបម្រើទៀតហើយ ប៉ុន្តែជាបុត្ររបស់ព្រះជាម្ចាស់វិញ ហើយប្រសិនបើបងប្អូនជាបុត្ររបស់ព្រះជាម្ចាស់មែន
នោះបងប្អូននឹងទទួលមត៌កមកពីព្រះជាម្ចាស់ជាមិនខាន។
[8]កាលពីដើម បងប្អូនពុំទាន់បានស្គាល់ព្រះជាម្ចាស់នៅឡើយ បងប្អូនជាអ្នកបម្រើរបស់ព្រះនានា ដែលពុំមែនជាព្រះពិតប្រាកដទាល់តែសោះ។[9]ប៉ុន្តែ ឥឡូវនេះ
បងប្អូនបានស្គាល់ព្រះជាម្ចាស់ហើយ ឬគួរនិយាយថា ព្រះជាម្ចាស់បានស្គាល់បងប្អូន ហេតុអ្វីបានជាបងប្អូនវិលត្រឡប់ទៅរកមេគ្រប់គ្រងលោកីយ៍ ដែលទន់ខ្សោយ
និងគ្មានបារមីដូច្នេះ? តើបងប្អូនរាល់គ្នាចង់ត្រឡប់ទៅធ្វើជាអ្នកបម្រើម្តងទៀតឬ?
[10]អ្នករាល់គ្នាគោរពថ្ងៃ ខែ រដូវ និងឆ្នាំនានា![11]ខ្ញុំបារម្ភថា កិច្ចការដែលខ្ញុំបំពេញជាមួយបងប្អូន ត្រឡប់ជាឥតបានការ។
[12]បងប្អូនអើយ ខ្ញុំសុំអង្វរបងប្អូនថា ចូរកាន់ចិត្តដូចខ្ញុំ ដ្បិតខ្ញុំបានកាន់ចិត្តដូចបងប្អូនដែរ។ បងប្អូនគ្មានបានធ្វើអ្វីខុសចំពោះខ្ញុំទេ។[13]បងប្អូនបានជ្រាបស្រាប់ហើយថា
ព្រោះខ្ញុំមានសុខភាពទន់ខ្សោយ ខ្ញុំបានប្រកាសដំណឹងល្អជាមួយបងប្អូនលើកទីមួយ។[14]ទោះបីជំងឺខ្ញុំបណ្តាលឲ្យបងប្អូនលំបាកក៏ដោយ ក៏បងប្អូនពុំបានមើលងាយ
ឬស្អប់ខ្ពើមខ្ញុំឡើយ។ ផ្ទុយទៅវិញ បងប្អូនបានស្វាគមន៍ខ្ញុំយ៉ាងកក់ក្តៅ ទុកដូចជាទេវតារបស់ព្រះជាម្ចាស់ ឬទទួលខ្ញុំដូចព្រះគ្រិស្តយេស៊ូដែរ។
[15]ឥឡូវនេះ តើបងប្អូនរាល់គ្នាបានទទួលព្រះពរមកពីខាងណា? ដ្បិត ខ្ញុំធ្វើសក្ខីភាពចំពោះមុខបងប្អូន ប្រសិនបើ បងប្អូនហ៊ានខ្វេះភ្នែកទាំងពីរ និងប្រគល់មកឲ្យខ្ញុំ។
[16]តើខ្ញុំក្លាយជាសត្រូវរបស់បងប្អូន ព្រោះតែខ្ញុំនិយាយសេចក្តីពិតប្រាប់បងប្អូនឬ?
[17]ពួកគេឧស្សាហ៍ខ្នះខ្នែងចង់បានបងប្អូន ប៉ុន្តែ គ្មានបំណងល្អទេ។ ពួកគេចង់បំបែកបងប្អូនពីយើង ដូច្នេះ បងប្អូននឹងឧស្សាហ៍ខ្នះខ្នែងចំពោះពួកគេវិញ។
[18]ជាការប្រពៃណាស់ ដែលបងប្អូនមានចិត្តឧស្សាហ៍ក្នុងគោលបំណងល្អ មិនត្រឹមតែពេលដែលខ្ញុំនៅជាមួយបងប្អូនឡើយ។
[19]កូនចៅរាល់គ្នាអើយ ខ្ញុំឈឺចាប់ក្នុងការបង្កើតអ្នករាល់គ្នាសារជាថ្មី រហូតទាល់តែព្រះគ្រិស្តកើតជារូបរាងក្នុងអ្នករាល់គ្នា។[20]ពេលនេះ ខ្ញុំប្រាថ្នាចង់នៅជាមួយអ្នករាល់គ្នា
និងនិយាយជាមួយបងប្អូនផ្ទាល់ ព្រោះខ្ញុំទ័លគំនិតមិនដឹងត្រូវសរសេរអ្វីទៅកាន់បងប្អូន។
[21]សូមប្រាប់ខ្ញុំមើល៍ មានបងប្អូនណាខ្លះប្រាថ្នាចង់ចុះចូលនឹងក្រឹត្យវិន័យ តើបងប្អូនយល់អំពីក្រឹត្យវិន័យដែរទេ?[22]ដ្បិត មានសេចក្តីចែងទុកថា
លោកអប្រាហាំមានកូនប្រុសពីរនាក់ កូនមួយជាកូនរបស់ស្ត្រីអ្នកងារ និងម្នាក់ទៀតជាកូនរបស់ស្ត្រីអ្នកជា។[23]ប៉ុន្តែ កូនរបស់ស្ត្រីអ្នកងារកើតតាមរបៀបលោកីយ៍
ចំណែកឯកូនរបស់ស្ត្រីអ្នកជាកើតតាមព្រះបន្ទូលសន្យា។
[24]សេចក្តីទាំងនេះអាចជានិមិត្តរូបមួយដែរ ដ្បិត ស្ត្រីទាំងពីរនេះតំណាងឲ្យសម្ពន្ធមេត្រីពីរ។ មួយតំណាងសម្ពន្ធមេត្រីចងនៅភ្នំស៊ីណៃ ហើយនាងបង្កើតកូនជាអ្នកបម្រើ
គឺនាងហាការ។[25]ឥឡូវនេះ នាងហាការតំណាងភ្នំស៊ីណៃនៅស្រុកអារ៉ាប់ ជានិមិត្តរូបនៃក្រុងយេរូសាឡិមសព្វថ្ងៃ ហើយកូនរបស់នាងសុទ្ធតែជាកូនអ្នកងារ។
[26]តែក្រុងយេរូសាឡិមនៅស្ថានលើវិញ ជាកូនអ្នកជាដែលជាម្តាយរបស់យើង។[27]ដ្បិត មានសេចក្តីចែងទុកមកថា៖ «នាងជាស្ត្រីអារ នាងជាស្ត្រីមិនបានបង្កើតកូនអើយ ចូរ
អរសប្បាយឡើង! នាងពុំធ្លាប់ឈឺផ្ទៃអើយ ចូរបន្លឺសំឡេងស្រែកដោយអំណរឡើង! ដ្បិត កូនរបស់ស្ត្រីដែលប្តីបោះបង់ចោលនោះ នឹងមានចំនួនច្រើនជាងកូនរបស់ស្ត្រី
ដែលមានប្តីទៅទៀត»។
[28]ប៉ុន្តែ បងប្អូនរាល់គ្នាអើយ បងប្អូនដូចជាលោកអ៊ីសាក ជាកូនកើតតាមព្រះបន្ទូលសន្យា។[29]នៅពេលនោះ កូនកើតតាមរបៀបលោកីយ៍បៀតបៀន
កូនកើតតាមព្រះវិញ្ញាណ។ ឥឡូវនេះក៏ដូចគ្នាដែរ។
[30]តើព្រះគម្ពីរមានចែងថាដូចម្តេច? គឺចែងថា ៖«ចូរបណ្តេញស្ត្រីអ្នកងារ និងកូនរបស់នាងចេញទៅ។ ដ្បិត កូនរបស់ស្ត្រីអ្នកងារនឹងមិនត្រូវទទួលមរតក
រួមជាមួយកូនប្រុសរបស់ស្ត្រីអ្នកជាឡើយ»។[31]ដូច្នេះ បងប្អូនអើយ យើងរាល់គ្នាពុំមែនជាកូនរបស់ស្ត្រីអ្នកងារទេ តែជាកូនរបស់ស្ត្រីអ្នកជាវិញ។

---

generated on Wed Sep 10 16:16:32 2025

Galatians 4:1

ប្រយោគភ្ជាប់:

លោកប៉ូលបន្តដើម្បីរម្លឹកអ្នកជឿនៅកាឡាទីថា
ព្រះគ្រិស្តបានយាងមកដើម្បីរំដោះដល់អស់អ្នកណាដែលក្រោមក្រឹត្យវិន័យ
ហើយថាព្រះអង្គបានបង្កើតពួកគេមកមិនមែនជាទេសករទៀតទេ តែកូនវិញ។

នោះគ្មានអ្វីខុសពី

«ដូចគ្នា»

ការមើលថែ

មនុស្សដែលទទួលខុសត្រូវស្របច្បាប់សម្រាប់កុមារ

ការទទួលខុសត្រូវ

មនុស្សដែលអ្នកផ្សេងជឿទុកចិត្តដើម្បីឲ្យរក្សារបស់ដែលតម្លៃឲ្យមានសុវត្ថភាព។

Galatians 4:3

ពត៌មានទូទៅ:

ពាក្យថា «យើង»
នៅទីនេះសំដៅទៅលើគ្រិស្តបរិស័ទទាំងអស់រួមបញ្ចូលទាំងអ្នកអានរបស់លោកប៉ូលផងដែរ។

មេគ្រប់គ្រងនៃលោកីយ៍នេះ
ទី១ប្រហែលអាចមានន័យ)
នេះគឺសំដៅទៅលើក្រឹត្យឬគោលការណ៍សីលធម៌នៃលោកីយ៍ឬ
ឬទី២)នេះសំដៅទៅលើអំណាចខាងឯវិញ្ញាណដែលអ្នកខ្លះគិតគ្រប់គ្រងនូវអ្វីដែលកើតឡើងនៅលើផែនដី។

ប្រោសលោះ

លោកប៉ូលប្រើការប្រៀបធៀបនៃមនុស្សទិញទ្រព្យសម្បត្តិដែលបាត់មកវិញឬទិញសេរីភាពឲ្យទាសករ។

បុត្រ

នេះគឺជាតួនាទីដ៏សំខាន់របស់ព្រះយេស៊ូ បុត្ររបស់ព្រះជាម្ចាស់។

Galatians 4:6

បងប្អូនជាបុត្ររបស់ព្រះជាម្ចាស់... បងប្អូនលែងជាអ្នកបម្រើទៀតហើយ

ប៉ុន្តែជាបុត្ររបស់ព្រះជាម្ចាស់វិញ

លោកប៉ូលប្រើពាក្យក្មេងប្រុសនៅទីនេះពីព្រោះប្រធានបទគឺការទទួលមរតក។
នៅក្នុងវប្បធម៌របស់គាត់ហើយនឹងអ្នកអានរបស់គាត់
ការទទួលមរតកជាទូទៅគឺឲ្យបន្ត ប៉ុន្តែមិនមែនជានិច្ចទៅកាន់កូនប្រុសទេ។
គាត់មិនបានបញ្ជាក់ហើយក៏មិនបានរាប់បញ្ចូលក្មេងស្រីនៅទីនេះផងដែរ។

ព្រះអង្គបានចាត់បញ្ជូនព្រះវិញ្ញាណរបស់ព្រះបុត្រា មកគង់ក្នុងចិត្តយើង ហើយយើងបន្លឺសំឡេងថា៖
«អប្បា ព្រះបិតា!»

ព្រះជាម្ចាស់ជាព្រះបិតាបានបញ្ជូនព្រះវិញ្ញាណរបស់ព្រះបុត្រាទៅក្នុងចិត្តរបស់អ្នកជឿ
ឥឡូវពួកគេដឹងថាព្រះជាម្ចាស់ស្រឡាញ់ពួកគេពួកគេជានិច្ចដូចឪពុកស្រឡាញ់កូន។

បានចាត់បញ្ជូនព្រះវិញ្ញាណរបស់ព្រះបុត្រា មកគង់ក្នុងចិត្តយើង

បេះដូងគឺជាពាក្យទាក់ទងគ្នាសម្រាប់ផ្នែកនៃមនុស្សដែលគិតនិងមានអារម្មណ៍។
ការបកប្រែផ្សេងទៀត:
«ចាត់បញ្ជូនវិញ្ញាណព្រះបុត្រារបស់ទ្រង់ដើម្បីបង្ហាញដល់យើងរបៀបដែលយើងគិតនិងធ្វើ»

ព្រះវិញ្ញាណរបស់ព្រះបុត្រា

នេះគឺជាតួនាទីដ៏សំខាន់សម្រាប់ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់។

បន្លឺសំឡេង

ព្រះវិញ្ញាណគឺជាអ្នកតាស់ហៅ។

អប្បា ព្រះបិតា!

នេះគឺជារបៀបដែលក្មេងជំទង់នឹងនិយាយទៅកាន់ឪពុករបស់គេនៅក្នុងភាសាកំណើតរបស់ពួកគេ
ប៉ុន្តែមិនមែនជាភាសាអ្នកអាននៅកាឡាទីទេ
ដើម្បីរក្សាឲ្យងាយយល់ជាភាសាបរទេស សូមបកប្រែពាក្យនេះជាសម្លេងដូចជា
«អប្បា» ជាភាសារបស់អ្នកដែលអនុញ្ញាតិឲ្យប្រើ។

ដូច្នេះ ឥឡូវនេះបងប្អូនលែងជាអ្នកបម្រើទៀតហើយ... បងប្អូននឹងទទួលមត៌ក

លោកប៉ូលនិយាយទៅកាន់អ្នកស្តាប់របស់គាត់ហាក់ដូចជាពួកគេជាមនុស្សតែម្នាក់
ដូចច្នេះនៅទីនេះ «អ្នក» គឺឯកវចន:។

មត៌ក

មនុស្សដែលព្រះជាម្ចាស់បានមានព្រះបន្ទូលសន្យាគឺត្រូវបានគេនិយាយថាប្រសិនបើពួកគេ
និង ទ្រព្យសម្បត្តិជាកម្មសិទ្ធពីសមាិកគ្រួសារ។

Galatians 4:8

ប្រយោគភ្ជាប់:

លោកប៉ូលរម្លឹកអ្នកជឿនៅកាឡាទីដែលពួកគេកំពុងព្យាយាមដើម្បីរស់នៅក្រោមក្រឹត្យវិន័យ

ពត៌មានទូទៅ:

គាត់បន្តដើម្បីស្តីបន្ទោសតាមរយៈការសួរសំនួរដ៏បិុនប្រសប់។

បងប្អូនជាអ្នកបម្រើរបស់ព្រះនានា

«រឿងទាំងនោះគឺ» ឬ «វិញ្ញាណទាំងនោះគឺ»

បងប្អូនបានស្គាល់ព្រះជាម្ចាស់ហើយ

នេះអាចបកប្រែជាសេចក្តីថ្លែងនៃទម្រង់សកម្ម។ការបកប្រែផ្សេងទៀត: «
ព្រះជាម្ចាស់ស្គាល់បងប្អូន»

ហេតុអ្វីបានជាបងប្អូនវិលត្រឡប់ទៅរក ... មេគ្រប់គ្រងលោកីយ៍?

នេះគឺជាសំនួរទី១នៃសំនួរទី២ដ៏ប៊ិនប្រសប់។ ការបកប្រែផ្សេងទៀត:
«បងប្អូនមិនគួរត្រឡប់ទៅរ ... មេគ្រប់គ្រងលោកីយ៍»។

មេគ្រប់គ្រងលោកីយ៍

ការបកប្រែឃ្លានេះដូចរបៀបដែលអ្នកបកប្រែនៅក្នុង ៤:៣។

តើបងប្អូនរាល់គ្នាចង់ត្រឡប់ទៅធ្វើជាអ្នកបម្រើម្តងទៀតឬ?

សំនួរនេះអាចបកប្រែទៅជាសេចក្តីថ្លែងមួយ។ ការបកប្រែផ្សេងទៀត:
«អ្នកមិនគួរទៅធ្វើជាទេសករជាថ្មីម្តងទៀតទេ!» ឬ
«អ្វីៗហាក់ដូចជាអ្នកចង់ទៅធ្វើជាទេសករម្តងទៀត»។

Galatians 4:10

រាល់គ្នាគោរពថ្ងៃ ខែ រដូវ និងឆ្នាំនានា!

លោកប៉ូលគឺកំពុងនិយាយអំពីការប្រុងប្រយ័ត្នរបស់ពួកគេដើម្បីប្រារព្ធពីធីជាក់លាក់
ដោយគិតថាធ្វើបែបហ្នឹង នឹងធ្វើឲ្យពួកគេត្រឹមត្រូវចំពោះព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត: «បងប្អូនយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នដើម្បីប្រារព្ធថ្ងៃ
ត្រឡប់ជាឥតបានការ

លោកតាមរយៈការសុគតនៅលើឈើឆ្កាង។

Galatians 4:12

ប្រយោគភ្ជាប់:

លោកប៉ូលរម្លឹកអ្នកជឿនៅកាឡាទីរបៀបដែលពួកគេប្រព្រឹត្តយ៉ាងសម្បុរសចំពោះគាត់
នៅពេលគាត់បាននៅជាមួយពួកគេ
ហើយគាត់លើកទឹកចិត្តពួកគេដើម្បីបន្តទុកចិត្តគាត់ពេលដែលគាត់មិននៅទីនោះជាមួយពួកគេ។

សុំអង្វរ

នៅទីនេះមានន័យថាសួរ ឬ ជម្រុញឲ្យខ្លាំង
នេះមិនមែនជាពាក្យប្រើដើម្បីសូមលុយឬម្ហូបអាហារឬគោលបំណងខាងផ្នែករាងកាយទេ។

បងប្អូន

បកប្រែដូចនៅក្នុង ១:១

បងប្អូនគ្មានបានធ្វើអ្វីខុសចំពោះខ្ញុំទេ។

ការបកប្រែផ្សេងទៀត:
«បងប្អូនបានប្រព្រឹត្តចំពោះខ្ញុំបានល្អហើយ» ឬ
«បងប្អូនបានប្រព្រឹត្តចំពោះខ្ញុំដូជាបងប្អូនគួរធ្វើហើយ»

ទោះបីជំងឺខ្ញុំបណ្តាលឲ្យបងប្អូនលំបាកក៏ដោយ
«ទោះបីវាលំបាកសម្រាប់បងប្អូនដើម្បីថែរក្សាខ្ញុំចំពោះរាងកាយរបស់ខ្ញុំឈឺខ្លាំង»។

ដោយ

«ស្អប់ខ្លាំងបំផុត»

Galatians 4:17

ចង់បានបងប្អូន

«បញ្ចុះបញ្ចូលបងប្អូនដើម្បីចូលរួមជាមួយពួកគេ»

បំបែកបងប្អូន

ឧស្សាហ៍ខ្នះខ្នែងចំពោះពួកគេវិញ

«ឧស្សាហ៍ខ្នះខ្នែងធ្វើអ្វីដែលពួកគេប្រាប់បងប្អូនឲ្យធ្វើ»

Galatians 4:19

ប្រយោគភ្ជាប់:

លោកប៉ូលប្រាប់អ្នកជឿថាព្រះគុណនិងក្រឹត្យវិន័យមិនអាចធ្វើការជាមួយគ្នាបានទេ។

កូនចៅរាល់គ្នាអើយ

នេះគឺជាការប្រៀបធៀបចំពោះសិស្សឬអ្នកដើរតាម។ ការបកប្រែផ្សេងទៀត:

ខ្ញុំឈឺចាប់ក្នុងការបង្កើតអ្នករាល់គ្នារហូតទាល់តែព្រះគ្រិស្តកើតជារូបរាងក្នុងអ្នករាល់គ្នា។

លោកប៉ូលប្រើពាក្យសម្រាលកូនជាការប្រៀបធៀបចំពោះការព្រួយបារម្ភរបស់គាត់អំពីក្រុមជំនុំកាឡាទី។
ការបកប្រែផ្សេងទៀត: «ខ្ញុំឈឺចុកចាប់ដូចជាខ្ញុំជាស្ត្រីបានផ្តល់កំណើតដល់បងប្អូន

Galatians 4:21

សូមប្រាប់ខ្ញុំមើល៍

«ខ្ញុំចង់សួរសំនួរមួយ» ឬ «ខ្ញុំចង់ប្រាប់អ្នករឿងខ្លះ»

generated on Wed Sep 10 16:16:32 2025

តើបងប្អូនយល់អំពីក្រឹត្យវិន័យដែរទេ?
លោកប៉ូលគឺកំពុងតែណែនាំនូវអ្វីដែលគាត់នឹងនិយាយបន្ទាប់។
ការបកប្រែផ្សេងទៀត: «អ្នកត្រូវរៀននូវអ្វីដែលក្រឹត្យវិន័យចែង» ឬ
«អនុញ្ញាតិឲ្យខ្ញុំប្រាប់អ្នកនូវអ្វីដែលក្រឹត្យវិន័យចែង»
Galatians 4:24
ប្រយោគភ្ជាប់:
លោកប៉ូលចាប់ផ្តើមយករឿងមួយដើម្បីបង្ហាញថាសេចក្តីពិតដែលក្រឹវិន័យនិងព្រះគុណ[illegible]
សេចក្តីទាំងនេះអាចជានិមិត្តរូបមួយដែរ
«នេះគឺរឿងនៃកូនប្រុសពីរនាក់ដូចជារូបភាពនៃអ្វីដែលខ្ញុំនឹងប្រាប់អ្នក»
ជានិមិត្តរូបមួយ
ជា «ការប្រៀបធៀប» គឺជារឿងដែលជាប់ទាក់ទងជាមួយមនុស្ស
និងវត្ថុនៅក្នុងរវាដែលតំណាងឲ្យវត្ថុផ្សេងទៀតនៅក្នុងការប្រៀបធ្រៀបរបស់លោកប៉ូល
ស្ត្រីពីរនាក់ដែលបានលើកឡើងនៅក្នុង៤:២១តំណាងឲ្យសម្ជមេត្រីពីរ។
នៅភ្នំស៊ីណៃ
«នៅភ្នំស៊ីណៃ»
គឺជានិមិត្តរូបចំពោះក្រឹត្យវិន័យដែលលោកម៉ូសេបានផ្តល់ឲ្យអ៊ីស្រាអែលនៅទីនោះ។
ការបកប្រែផ្សេងទៀត: «ភ្នំស៊ីណៃ
ជាកន្លែងដែលម៉ូសេបានផ្តល់ក្រឹត្យវិន័យដល់អ៊ីស្រាអែល»
នាងបង្កើតកូនជាអ្នកបម្រើ
លោកប៉ូលប្រព្រឹត្តចំពោះក្រឹត្យវិន័យប្រសិនបើវាដូចជាមនុស្សម្នាក់។
ការបកប្រែផ្សេងទៀត:
«មនុស្សដែលនៅក្រោមសម្ជមេត្រីនេះដូចជាទេសករដែលស្តាប់បង្គាប់តាមក្រឹត្យវិន័យ»
តំណាង
«គឺរូបភាពនៃ»
ហើយកូនរបស់នាងសុទ្ធតែជាកូនអ្នកងារ។
ហាការគឺជាទេសករហើយកូនរបស់នាងគឺជាទេសករនៅជាមួយនាងការបកប្រែផ្សេងទៀត
«យេរូសាឡឹម ដូចជាហាការ គឺជាទេសករ
និងកូនរបស់នាងគឺជាទេសករជាមួយនាង»
Galatians 4:26
សេរីភាព
នៅទីនេះ «សេរីភាព»មានន័យថាមិនចងមិនមែនជាទេសករ។
ចូរអរសប្បាយឡើង
«សូមរីករាយ»
នាងជាស្ត្រីមិនបានបង្កើតកូនអើយ ... នាងពុំធ្លាប់ឈឺផ្ទៃអើយ
[illegible]
Galatians 4:28
បងប្អូន
នេះបកប្រែដូចនៅក្នុង១:១
ជាកូនកើតតាមព្រះបន្ទូលសន្យា
ប្រហែលជាអាចមានអត្ថន័យគឺបែបដូចច្នេះ
គឺកាឡាទីបានត្រឡប់ជាកូនរបស់ព្រះទី១)តាមរយៈការជឿលើព្រះបន្ទូលសន្យា(UDB)
ឬទី២)
ពីព្រោះព្រះជាម្ចាស់បានធ្វើការអស្ចារ្យដើម្បីបំពេញព្រះបន្ទូលសន្យារបស់ទ្រង់ចំពោះអប្រាហាំជាដំបូងតាម
កូនកើតតាមរបៀបលោកីយ៍
នេះគឺសំដៅទៅលើលោកអប្រាហាំក្លាយទៅជាឪពុករបស់អ៊ីស្មាអែលតាមរយៈការយកនាងហាការជាប្រព
ការបកប្រែផ្សេងទៀត: «មានន័យថាតាមរយៈសកម្មភាពរបស់មនុស្ស» ឬ
«ដោយសារតែមនុស្សបានធ្វើ»
កូនកើតតាមព្រះវិញ្ញាណ
«រឿងនេះបានកើតឡើងដោយសារព្រះវិញ្ញាបានធ្វើ»
Galatians 4:30
បងប្អូន
នេះបកប្រែដូចនៅក្នុង១:១។
តែជាកូនរបស់ស្ត្រីអ្នកជាវិញ។
[illegible]ក្យដែលមិនបានបំពេញអាចបំពេញនៅទីនេះ «ប៉ុន្តែផ្ទុយទៅវិញ
យើងជាកូនរបស់ស្ត្រីអ្នកជាវិញ»។

---

5 [1]ព្រះគ្រិស្តបានរំដោះយើងរាល់គ្នាឲ្យមានសេរីភាពហើយ។ ដូច្នេះ ចូរឈរមាំមួន ហើយកុំបណ្តោយខ្លួន ឲ្យស្ថិតក្រោមការត្រួតត្រារបស់នឹមទាសកររទៀត។[2]មើល៍ ខ្ញុំ
ប៉ូលជម្រាបប្រាប់បងប្អូនថា បើបងប្អូននៅតែទទួលពិធីកាត់ស្បែក នោះព្រះគ្រិស្តគ្មានប្រយោជន៍អ្វីចំពោះបងប្អូនឡើយ។
[3]ខ្ញុំធ្វើសក្ខីភាពម្តងទៀតប្រាប់បុរសគ្រប់រូប ដែលចង់ទទួលពិធីកាត់ស្បែក អ្នកនោះត្រូវគោរពតាមក្រឹត្យវិន័យទាំងស្រុងផង។
[4]បងប្អូនណាដែលចង់បានសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យ អ្នកនោះបានដាច់ចេញពីព្រះគ្រិស្ត និងដាច់ចេញពីព្រះគុណព្រះជាម្ចាស់ហើយ។
[5]តាមរយៈព្រះវិញ្ញាណ យើងទន្ទឹងរង់ចាំសេចក្តីសង្ឃឹមពិតប្រាកដថា ព្រះជាម្ចាស់នឹងប្រោសយើងឲ្យបានសុចរិត ដោយសារជំនឿ។[6]នៅក្នុងព្រះគ្រិស្តយេស៊ូ ការកាត់ស្បែក
ឬមិនកាត់ស្បែកគ្មានន័យអ្វីសោះឡើយ មានតែជំនឿនាំយើងឲ្យធ្វើការល្អផ្សេងៗ ដោយក្តីស្រឡាញ់ប៉ុណ្ណោះទើបសំខាន់។[7]បងប្អូនចាប់ផ្តើមជំនឿបានល្អណាស់។
តើនរណារារាំងបងប្អូនមិនឲ្យស្តាប់បង្គាប់សេចក្តីពិតនោះ?[8]ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូនមក ពុំបានបញ្ជះបញ្ជូលបងប្អូនឡើយ!
[9]មេម្សៅតែបន្តិច អាចធ្វើឲ្យម្សៅទាំងមូលដោរឡើងបាន។[10]ខ្ញុំមានជំនឿចិត្តលើព្រះអម្ចាស់ថា បងប្អូននឹងមិនបែកគំនិតទៅតាមអ្នកផ្សេងឡើយ។
អ្នកណាដែលនាំរឿងដល់បងប្អូន ទោះជានរណាក៏ដោយ មុខជាទទួលទោស។
[11]បងប្អូនអើយ ប្រសិនបើ ខ្ញុំនៅតែប្រកាសអំពីការកាត់ស្បែក ចុះហេតុអ្វីបានជាខ្ញុំ ត្រូវគេបៀតបៀនដដែល? នៅត្រង់ចំណុចនេះ ពួកគេលែងរវាតចិត្តទៀតឡើយ។
[12]អ្នកណាដែលធ្វើឲ្យបងប្អូនវឹកវរ ខ្ញុំចង់ឲ្យអ្នកនោះក្រៀវខ្លួនឯងទៅ!
[13]ដ្បិត ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ឲ្យមានសេរីភាព។ ប៉ុន្តែ កុំយកសេរីភាពនេះ ទៅធ្វើជាលេសដើម្បីរកឱកាស ប្រព្រឹត្តតាមនិស្ស័យលោកីយ៍ ផ្ទុយទៅវិញ
ចូរបម្រើគ្នាទៅវិញទៅមក ដោយចិត្តស្រឡាញ់។[14]ដ្បិត ក្រឹត្យវិន័យទាំងមូលបានសម្រេចឡើងដោយពាក្យមួយឃ្លាថា ៖ «បងប្អូនត្រូវស្រឡាញ់អ្នកជិតខាង
ដូចជាខ្លួនឯងដែរ»។[15]ក៏ប៉ុន្តែ បើបងប្អូននៅតែប្រខាំគ្នា និងហែកហួរគ្នាដូច្នេះ ចូរប្រយ័ត្នក្រែងលោបងប្អូនត្រូវវិនាសដោយសារគ្នាឯង។
[16]ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាថា ចូរដើរដោយវិញ្ញាណ នោះបងប្អូននឹងមិនបំពេញចិត្តលោភលន់ខាងនិស្ស័យលោកីយ៍ឡើយ។[17]ដ្បិត
ការបំពេញចិត្តលោភលន់ខាងនិស្ស័យលោកីយ៍ ទាស់ទទឹងនឹងព្រះវិញ្ញាណ ហើយការបំពេញចិត្តខាងព្រះវិញ្ញាណ ទាស់ទទឹងនឹងនិស្ស័យលោកីយ៍។ ដ្បិត ព្រះវិញ្ញាណ
និងនិស្ស័យលោកីយតែងទាស់ទទឹងគ្នា ដូច្នេះ បងប្អូនមិនអាចធ្វើអ្វី ដែលបងប្អូនចង់ធ្វើបានឡើយ។[18]ប៉ុន្តែ ប្រសិនបើព្រះវិញ្ញាណដឹកនាំបងប្អូន
នោះបងប្អូនមិនស្ថិតនៅក្រោមអំណាចក្រឹត្យវិន័យទៀតទេ។
[19]យើងដឹងច្បាស់ណាស់ថា កិច្ចការខាងនិស្ស័យលោកីយ៍មានដូចជា អំពើប្រាសចាកសីលធម៌ អំពើសៅហ្មង កាមគុណថោកទាប[20]ការថ្វាយបង្គំព្រះក្លែងក្លាយ វិជ្ជាធ្មប់
ឈ្លោះប្រកែកគ្នា បាក់បែកគ្នា ច្រណែនគ្នា កំហឹងឃោរឃៅ ប្រកួតប្រជែងគ្នាប្រឆាំងគ្នា ប្រកាន់បក្សពួក[21]ឈ្នានីសគ្នា ប្រមឹកស៊ីផឹកជ្រុល និងអំពើផ្សេងៗ
ទៀតស្រដៀងការទាំងនេះដែរ។ ខ្ញុំព្រមានបងប្អូនថា មនុស្សដែលប្រព្រឹត្តអំពើទាំងនោះ ពួកគេនឹងមិនអាចទទួលព្រះរាជ្យព្រះជាម្ចាស់ទុកជាមរតកឡើយ។
[22]ប៉ុន្តែ ផលផ្លែនៃព្រះវិញ្ញាណវិញគឺ សេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្តោស មេត្តា ជំនឿ[23]ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង។
គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីទាំងនេះទេ ។[24]អស់អ្នកណាដែលជាកម្មសិទ្ធិរបស់ព្រះគ្រិស្តយេស៊ូ បានឆ្កាងនិស្ស័យលោកីយ៍ រួមជាមួយតណ្ហា
និងចិត្តលោភលន់រួចហើយ។
[25]ប្រសិនបើ យើងរស់នៅដោយព្រះវិញ្ញាណ ចូរយើងដើរដោយព្រះវិញ្ញាណដែរ។[26]ចូរកុំឲ្យយើងអួតបំប៉ោង ការបង្កររឿងគ្នា និងឈ្នានីសគ្នាទៅវិញទៅមក។

Galatians 5:1
ប្រយោគភ្ជាប់:
លោកប៉ូលឆ្លើយតបតាមរយៈការប្រៀបធៀបដើម្បីរម្លឹកអ្នកជឿ
ដែលប្រើប្រាស់សេរីភាពរបស់ពួកគេនៅក្នុងព្រះគ្រិស្តពីព្រោះសេរីភាពក្រឹត្យវិន័យទាំងអស់គឺត្រូវបានបំពេ
មានសេរីភាព
ការបកប្រែនេះត្រូវផ្តោតទៅលើ «សេរីភាព»

generated on Wed Sep 10 16:16:32 2025

ផ្ទុយពីទេសករដែលបាននិយាយនៅក្នុងខមុនៗ។
ព្រះគ្រិស្តបានរំដោះយើងរាល់គ្នាឲ្យមានសេរីភាពហើយ
«អ្វីៗគឺដូចច្នេះយើងអាចមានសេរីភាពដែលព្រះគ្រិស្តបានរំដោះយើងទាំងអស់គ្នាឲ្យមាន»។ ឃ្លានេះ
ចូរឈរមាំមួន
ការឈរមាំមួននៅទីនេះ គឺតំណាងឲ្យការតាំងចិត្តមិនផ្លាស់ប្រែ។
ទោះបីជាពួកគេមិនផ្លាស់ប្រែអាចនៅតែថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត:»
កុំចុះចាញ់នៅក្នុងការឈ្លោះគ្នារបស់មនុស្សដែលបង្រៀនអ្វីផ្សេងទៀតឡើយ។ «ឬ»
ចូរតាំងចិត្តដើម្បីនៅជាមួយសេរីភាព»
បើបងប្អូននៅតែទទួលពិធីកាត់ស្បែក
លោកប៉ូលគឺកំពុងប្រើប្រាស់ការកាត់ស្បែកជាទាក់ទងគ្នាសម្រាប់សាសន៍យូដា។
ការបកប្រែផ្សេងទៀត: «បើអ្នកត្រឡប់ទៅកាន់សាសនាយូដាវិញ»។
Galatians 5:3
ធ្វើសក្ខីភាព
«ប្រកាស» ឬ «បម្រើក្នុងនាមជាសាក្សី»
បុរសគ្រប់រូប ដែលចង់ទទួលពិធីកាត់ស្បែក
លោកប៉ូលគឺកំពុងប្រើការស្បែកជាការប្រៀបធៀបសម្រាប់ជនជាតិយូដា។
ការបកប្រែផ្សេងទៀត: «មនុស្សគ្រប់គ្នាដែលបានក្លាយជាសាសន៍យូដា»
ត្រូវគោរពតាម
«មានព្រំដែន» ឬ «ជាប់ឃុំឃាំង» ឬ «ជាទេសករ»
អ្នកនោះបានដាច់ចេញពីព្រះគ្រិស្ត
«អ្នកបានបញ្ចប់ទំនាក់ទំនងជាមួយព្រះគ្រិស្តហើយ»
បងប្អូនណាដែលចង់បានសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យ
លោកបប៉ូលគឺកំពុងនិយាយនៅត្រង់នេះ។
តាមពិតគាត់បង្រៀនថាគ្មានជនជាតិយូដាអាចរាប់ជាសុចរិតតាមរយៈការព្យាយាមធ្វើតាមក្រឹត្យវិន័យ។
ការបកប្រែផ្សេងទៀត:
«បងប្អូនទាំងអស់គ្នាគិតថាបងប្អូនអាចរាប់ជាសុចរិតតាមរយៈការធ្វើតាមតម្រូវត្រូវការរបស់ក្រឹត្យវិន័យ»
ឬ «បងប្អូនដែលចង់ធ្វើអ្នកសុចរិតតាមរយៈក្រឹត្យវិន័យ»
ដាច់ចេញពីព្រះគុណព្រះជាម្ចាស់ហើយ។
ដែលព្រះគុណបានមកពីណាត្រូវបានត្រូវថ្លែងយ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់នឹងមិនផ្តល់ព្រះគុណទៅដល់អ្នកទេ»
Galatians 5:5
ពត៌មានទូទៅ:
ពាក្យនៅទីនេះ «យើង»
គឺសំដៅទៅលើលោកប៉ូលនិងអស់អ្នកដែលប្រឆាំងការកាត់ស្បែករបស់គ្រិស្តបរិសទ។
គាត់ប្រហែលជារួមបញ្ចូលទាំងក្រុមជំនុំកាឡាទីផងដែរ។
តាមរយៈ:
«នេះគឺពីព្រោះ»
យើងទន្ទឹងរង់ចាំសេចក្តីសង្ឃឹមពិតប្រាកដថា ព្រះជាម្ចាស់នឹងប្រោសយើងឲ្យបានសុចរិត
ដោយសារជំនឿ។
ទី១ប្រហែលអាចមានន័យថា
«យើងគឺកំពុងរងចាំតាមរយៈជំនឿងសម្រាប់សេចក្តីសង្ឃឹមដ៏ពិតប្រាកដនៃសេចក្តីសុរិតភាព»
ឬទី២)
«យើងគឺកំពុងរងចាំតាមរយៈជំនឿងសម្រាប់សេចក្តីសង្ឃឹមដ៏ពិតប្រាកដនៃសេចក្តីសុរិតភាព» (ប្រហែលជាមានន័យថា)
យើងទន្ទឹងរង់ចាំសេចក្តីសង្ឃឹមពិតប្រាកដថាព្រះជាម្ចាស់នឹងប្រោសយើងឲ្យបានសុចរិត
«យើងគឺកំពុងរងចាំយ៉ាងអត់អ្មត់បំផុតហើយនឹងជាមួយការរំភើបចំពោះព្រះជាម្ចាស់ដែលនឹងធ្វើឲ្យយើងសុចរិត
ហើយយើងរំពឹងទុកថាព្រះធ្វើវា»។
គ្មានន័យអ្វីសោះឡើយ
គឺគ្មានតម្លៃ
បងប្អូនចាប់ផ្តើមជំនឿបានល្អណាស់។
«អ្នកបានកំពុងអនុវត្តន៍នូវអ្វីដែលព្រះយេស៊ូបានបង្រៀន»។
ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូនមក ពុំបានបញ្ចុះបញ្ចូលបងប្អូនឡើយ!
«អ្នកដែលបានបញ្ចុះបញ្ចូលបងប្អូនដើម្បីធ្វើបែបនេះគឺមិនមែនព្រះជាម្ចាស់ទេ
គឺជាម្នាក់ដែលត្រាស់ហៅបងប្អូនវិញ»។
ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូន
អ្វីដែលព្រះអង្គត្រាស់ហៅពួកគេអាចត្រូវបានថ្លែងយ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត:
«អ្នកដែលត្រាស់ហៅបងប្អូនឲ្យធ្វើជាប្រជារាស្ត្ររបស់ទ្រង់»។
បញ្ចុះបញ្ចូល
ដើម្បីបញ្ចុះបញ្ចូលនរណាម្នាក់គឺត្រូវធ្វើឲ្យមនុស្សនោះផ្លាស់ប្តូរនូវអ្វីដែលគាត់និងការប្រព្រឹត្តរបស់គាត់។
Galatians 5:9
បងប្អូននឹងមិនបែកគំនិតទៅតាមអ្នកផ្សេងឡើយ។
«យើងក្នុងនាមជាគ្រិស្តបរិសទ» មិនជឿអ្វីផ្សេងទៀតខុសពីអ្វីដែលខ្ញុំដែលខ្ញុំកំពុងប្រាប់បងប្អូនឡើយ»។
អ្នកណាដែលនាំរឿងដល់បងប្អូន មុខជាទទួលទោស។
«ព្រះជាម្ចាស់នឹងដាក់ទោសអ្នកដែលកំពុងបង្ករឿងដល់បងប្អូន»។
នាំរឿងដល់បងប្អូន
«គឺបង្កហេតុឲ្យបងប្អូនក្លាយជាអ្នកមិនច្បាស់អំពីអ្វីដែលជាសេចក្តីពិត» ឬ
«គឺបង្កបញ្ហានៅក្នុងចំណោមបងប្អូន»។
ទោះជានរណាក៏ដោយ
ទី១ប្រហែលអាចមានន័យថា)
លោកប៉ូលគឺស្គាល់ឈ្មោះមនុស្សដែលកំពុងប្រាប់ក្រុមជំនុំកាឡាទីថា
ពួកគេត្រូវគោរពតាមក្រឹត្យវិន័យរបស់លោកម៉ូសេឬទី២)
លោកប៉ូលមិនចង់ឲ្យក្រុមជំនុំខ្វាល់ខ្វាយអំពីថាតើអ្នកដែល «បំភាន់»
ពួកគេគឺជាអ្នកមានឬជាអ្នកក្រឬជាអ្នកធំឬជាអ្នកតូចឬជាអ្នកកាន់សាសនាឬមិនមែនឡើយ»។
Galatians 5:11
បងប្អូនអើយ ប្រសិនបើ ខ្ញុំនៅតែប្រកាសអំពីការកាត់ស្បែក ចុះហេតុអ្វីបានជាខ្ញុំ
ត្រូវគេបៀតបៀនដដែល?
លោកប៉ូលគឺកំពុងពិពំណនាកាល:ទេសដែលមិនអាចកើតមានដើម្បីផ្តោតទៅលើថាមនុស្សគឺកំពុងបៀតប
នេះអាចថ្លែងទៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «បងប្អូន
អ្នកអាចឃើញថាខ្ញុំមិនមែនកំពុងប្រកាសការកាត់ស្បែក ពីព្រោះសាសន៍យូដា គឺ
កំពុងបៀតបៀនខ្ញុំ»។
បងប្អូន
បកប្រែដូចនៅក្នុង ១:១
«បើសិនខ្ញុំនៅតែនិយាយថាមនុស្សត្រូវតែក្លាយជាសាសន៍យូដា»។
ពួកគេលែងរវាតចិត្តទៀតឡើយ។
នេះអាចថ្លែងនៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ការបង្រៀនអំពីឈើឆ្កាងមិននាំឲ្យជំពប់ដួលទេ» ឬ
«គ្មានអ្វីនៅក្នុងការបង្រៀននៃឈើឆ្កាងដែលនឹងបណ្តាលឲ្យមនុស្សជំពប់ឡើយ»។
ក្រៀវខ្លួនឯងទៅ!
ទី១ប្រហែលអាចមានន័យថា)តាមន័យត្រង់
ដើម្បីកាត់សេរីភាពរបស់ពួកគេដើម្បីក្លាយជាអាមាត្យឬទី២)
ជាការប្រៀបធៀបនៃការដកចេញពីសហគមន៍របស់គ្រិស្តបរិស័ទ។
Galatians 5:13
ដ្បិត
លោកប៉ូលគឺកំពុងផ្តល់ហេតុផលសម្រាប់ពាក្យនៅក្នុង៥:១១
ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ឲ្យមានសេរីភាព។
នេះអាចបង្ហាញនៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនដើម្បីឲ្យមានសេរីភាព»
ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ឲ្យមានសេរីភាព។
ទី១ប្រហែលអាចមានន័យថា)
«ព្រះជាម្ចាស់បានជ្រើរើសបងប្អូនដើម្បីធ្វើជាប្រជារាស្ត្ររបស់ទ្រង់
ដើម្បីឲ្យយើងអាចរស់នៅជាមួយព្រះអង្គទ្រង់ផ្ទាល់ជារៀងរហូត
«ព្រះជាម្ចាស់បានបង្គាប់បញ្ជាឲ្យបងប្អូនមានសេរីភាព»។
បងប្អូន
បកប្រែនេះដូចនៅក្នុង១:១
ទៅធ្វើជាលេសដើម្បីរកឱកាស ប្រព្រឹត្តតាមនិស្ស័យលោកីយ៍
ការមានទំនាក់ទំនងរវាង ឱកាស និង
ការប្រព្រឹត្តតាមនិស្ស័យលោកីយ៍អាចត្រូវថ្លែងច្បាស់ជាង។ ការបកប្រែផ្សេងទៀត:
«បងប្អូនមានឱកាសដើម្បីប្រព្រឹត្តតាមនិស្ស័យលោកីយ៍របស់បងប្អូន»។
ក្រឹត្យវិន័យទាំងមូលបានសម្រេចឡើងដោយពាក្យមួយឃ្លាថា
ទី១ប្រហែលអាចមានន័យថា) «អ្នកអាចថ្លែងបទបញ្ញាតិទាំងមូលនៅក្នុងឃ្លាមួយ
គឺថា»។ ឬទី២) «តាមរយៈការស្តាប់តាមបទបញ្ញាតិមួយ
អ្នកស្តាប់តាមបទបញ្ញាតិទាំងអស់ ហើយបទបញ្ញាតិមួយនោះគឺថា»
បងប្អូនត្រូវស្រឡាញ់អ្នកជិតខាង ដូចជាខ្លួនឯងដែរ
ពាក្យថា «អ្នក» «របស់អ្នក» និង «ខ្លួនឯង» ទាំងគឺជាឯកវចនៈ។
Galatians 5:16

generated on Wed Sep 10 16:16:32 2025

ប្រយោគភ្ជាប់:

លោកប៉ូលពន្យល់របៀបដែលព្រះវិញ្ញាណអាចគ្រប់គ្រងលើអំពើបាប។

ចូរដើរដោយវិញ្ញាណ

ការដើរគឺជាការប្រៀបធៀបសម្រាប់ការរស់នៅ។ ការបកប្រែផ្សេងទៀត:
«ចូរឲ្យការប្រព្រឹត្តនៅក្នុងជីវិតរបស់បងប្អូននៅក្នុងអំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ»
ឬ «ចូររស់នៅដោយជីវិតរបស់បងប្អូនពឹងផ្អែកលើព្រះវិញ្ញាណ»។

បងប្អូននឹងមិនបំពេញចិត្តលោភលន់ខាងនិស្ស័យលោកីយ៍ឡើយ។

ឃ្លានេះ «អនុវត្តន៍សេចក្តីប៉ងប្រាថ្នារបស់នរណាម្នាក់»
គឺជាពាក្យសម្តីមានន័យថា«ធ្វើនូវអ្វីដែលជាសេចក្តីប៉ងប្រាថ្នានរណាម្នាក់»។
ការបកប្រែផ្សេងទៀត:
«អ្នកនឹងមិនធ្វើនូវអ្វីដែលជាសេចក្តីប៉ងប្រាថ្នាខាងនិស្ស័យលោកីយ៍ឡើយ»។

បំពេញចិត្តលោភលន់ខាងនិស្ស័យលោកីយ៍ឡើយ។

និស្ស័យលោកីយ៍គឺនិយាយដូចជា មនុស្សម្នាក់ហើយចង់ប្រព្រឹត្តអំបាប។
ការបកប្រែផ្សេងទៀត: «បស់អ្នក» ឬ
«រឿងខ្លះដែលអ្នកចង់ធ្វើពីព្រោះអ្នកគឺមានបាប»

មិនស្ថិតនៅក្រោមអំណាចក្រឹត្យវិន័យទៀតទេ

«មិនចាំបាច់គោរពតាមក្រឹត្យវិន័យរបស់លោកម៉ូសេទេ»

Galatians 5:19

កិច្ចការខាងនិស្ស័យលោកីយ៍

នាមអរូបិយ «ធ្វើការ» អាចបកប្រែជាកិរិយាសព្ទ ការបកប្រែផ្សេងទៀត:
អ្វីដែលមនុស្សមានបាបធ្វើ។

កិច្ចការខាងនិស្ស័យលោកីយ៍

និស្ស័យរបស់មនុស្សមានបាបបាននិយាយថា មនុស្សដែលធ្វើរឿងអ្វីម៉្យាង។
ការបកប្រែផ្សេងទៀត: «អ្វីដែលមនុស្សធ្វើដោយសារនិស្ស័យរបស់មនុស្សបាប» ឬ
«អ្វីដែលមនុស្សធ្វើពីព្រោះពួកគេមានបាប»។

មរតក

ការទទួលនៅអ្វីដែលព្រះជាម្ចាស់បានសន្យាអ្នកជឿគឺត្រូវបាននិយាយថាបានទទួលមរតក
និង ទ្រព្យសម្បត្តិពីមាជិកគ្រួសារ។

Galatians 5:22

ផលផ្លែនៃព្រះវិញ្ញាណវិញគឺ សេចក្តីស្រឡាញ់ ...ចេះទប់ចិត្តខ្លួនឯង។

ចេះទប់ចិត្តខ្លួនឯង។ -

លោកប៉ូលប្រើផលផ្លែជាការប្រៀបធៀបចំពោះអ្វីដែលមនុស្សអាចមើលឃើញនៅក្នុងអ្នកដទៃទៀត។
ការបកប្រែផ្សេងទៀត:
«មនុស្សដែលព្រះវិញ្ញាណដ៏វិសុទ្ធគ្រប់គ្រងនឹងបង្ហាញសេចក្តីស្រឡាញ់ ... ចេះទប់
ចិត្តខ្លួនឯងដូចជាដើមឈើបង្កើតផល»។

ផលផ្លែនៃព្រះវិញ្ញាណ

«អ្វីដែលជាផលផ្លែរបស់ព្រះវិញ្ញាណ»

បានឆ្កាងនិស្ស័យលោកីយ៍ រួមជាមួយតណ្ហា និងចិត្តលោភលន់រួចហើយ។

លោកប៉ូលនិយាយអំពីគ្រិស្ទានដែលបដិសេធរស់នៅទៅតាមនិស្ស័យមានបាបរបស់ពួកគេ
ប្រសិនបើគេគឺជាមនុស្សហើយពួកគេបានសុគតនៅលើឈើឆ្កាង។
ការបកប្រែផ្សេងទៀត:«បដិសេធដើម្បីរស់នៅតាមនិស្ស័យលោកិយ៍ជាមួយតណ្ហានិងបំណងប្រាថ្នារបស់វ

និស្ស័យលោកីយ៍ រួមជាមួយតណ្ហា និងចិត្តលោភលន់រួចហើយ។

មនុស្សមានបាបគឺត្រូវបាននិយាយថាគឺជា
មនុស្សដែលមានតណ្ហានិងសេចក្តីប៉ងប្រាថ្នា ការបកប្រែផ្សេងទៀត:
«និស្ស័យរបស់មនុស្សមានបាបរបស់ពួកគេ និង
អ្វីៗដែលពួកគេចង់ធ្វើខ្លាំងដោយសារវា»។

Galatians 5:25

ប្រសិនបើ យើងរស់នៅដោយព្រះវិញ្ញាណ

«ចាប់តាំងពីព្រះវិញ្ញាណរបស់ព្រះបណ្តាលមកដល់យើងធ្វើឲ្យយើងមានជីវិត»។

ចូរយើងដើរដោយព្រះវិញ្ញាណ

«ដើរ» គឺជាការប្រៀបធៀបសម្រាប់ការរស់នៅរៀងរាល់ថ្ងៃ។ ការបកប្រែផ្សេងទៀត:
«អនុញ្ញាតិឲ្យព្រះវិញ្ញាណដឹកនាំយើងដូចច្នេះយើងធ្វើអ្វីទាំងអស់ដែលគាប់ព្រះហឫទ័យនិង
ផ្តល់កិត្តិយសដល់ព្រះជាម្ចាស់»

ចូរកុំឲ្យយើង

យើងគួរតែ»

6 [1]បងប្អូនអើយ បើគេតាមទាន់មនុស្សម្នាក់កំពុងតែប្រព្រឹត្តអំពើបាប បងប្អូនដែលមានព្រះវិញ្ញាណគួរកែតម្រង់អ្នកនោះឡើងវិញ ដោយចិត្តស្លូតបូត។ ចូរប្រយ័ត្នខ្លួនឯង
ក្រែងលោបងប្អូនត្រូវរងការល្បួងដែរ។[2]ចូរចែករំលែកទុក្ខធុរៈគ្នាទៅវិញទៅមក ធ្វើដូច្នេះ បងប្អូនបានបំពេញតាមក្រឹត្យវិន័យរបស់ព្រះគ្រិស្តហើយ។
[3]ដ្បិត បើមាននរណាម្នាក់គិតថា ខ្លួនឯងសំខាន់ជាងគេ តែឥតបានការសោះ អ្នកនោះបញ្ឆោតខ្លួនឯង។[4]ម្នាក់ៗគួរពិចារណាមើលកិច្ចការខ្លួនឯងបានប្រព្រឹត្ត
អ្នកនោះមានហេតុផលនឹងអួតពីខ្លួនឯង កុំទៅប្រៀបធៀបជាមួយអ្នកដទៃឲ្យសោះ។[5]ដ្បិត គ្រប់គ្នានឹងទទួលខុសត្រូវកិច្ចការ ដែលខ្លួនបានប្រព្រឹត្តរួចមកហើយ។
[6]ម្នាក់ដែលទទួលការបង្រៀនខាងព្រះបន្ទូល ត្រូវយករបស់ល្អទាំងឡាយមួយចំណែក ចែកអ្នកដែលបង្រៀនខ្លួន។[7]កុំបញ្ឆោតខ្លួនឯងឲ្យសោះ។
គ្មាននរណាម្នាក់បោកបញ្ឆោតព្រះជាម្ចាស់បានទេ ដ្បិតមនុស្សសាបព្រោះពូជណា គេនឹងប្រមូលផលពូជនោះឯង។[8]ដ្បិតអ្នកណាសាបព្រោះពូជនិស្ស័យលោកីយ៍
នោះគេនឹងច្រូតបានផលជានិស្ស័យលោកីយ៍ ដែលតែងតែពុករលួយ។ ចំណែកឯ អ្នកណាដែលសាបព្រោះពូជព្រះវិញ្ញាណវិញ អ្នកនោះនឹងច្រូតបានជីវិតអស់កល្បជានិច្ច
តាមរយៈព្រះវិញ្ញាណ។
[9]កុំឲ្យយើងរសាយចិត្តក្នុងការប្រព្រឹត្តអំពើល្អឡើយ ដ្បិត ដល់ពេលកំណត់ យើងនឹងបានប្រមូលផល ប្រសិនបើ យើងពុំបោះបង់ចោលទេ។[10]ដូច្នេះ
ប្រសិនបើយើងមានឱកាស ចូរប្រព្រឹត្តអំពើល្អដល់មនុស្សទាំងអស់ ជាពិសេសដល់បងប្អូនរួមជំនឿយើង។
[11]ខ្ញុំបានសរសេរដោយផ្ទាល់ដៃមកកាន់បងប្អូន ជាអក្សរធំៗ។[12]អស់អ្នកដែលចង់បានចំណាប់អារម្មណ៍ ខាងនិស្ស័យលោកីយ៍
ពួកគេព្យាយាមបង្ខំបងប្អូនឲ្យទទួលពិធីកាត់ស្បែក។ ពួកគេធ្វើដូច្នេះ ដើម្បីជៀសវាងការបៀតបៀនព្រោះតែឈើឆ្កាងព្រះគ្រិស្ត។[13]ដ្បិត
អ្នកទាំងដែលបានទទួលពិធីកាត់ស្បែក ក៏មិនបានប្រព្រឹត្តតាមក្រឹត្យវិន័យដែរ ប៉ុន្តែ ពួកគេចង់ឲ្យបងប្អូនកាត់ស្បែក ដូច្នេះ ពួកគេនឹងអួតថា
ពួកគេបានកាត់ស្បែកឲ្យបងប្អូនតែប៉ុណ្ណោះ។
[14]ប៉ុន្តែ ខ្ញុំមិនអួតអ្វី ក្រៅពីឈើឆ្កាងរបស់ព្រះយេស៊ូគ្រិស្ត ជាព្រះអម្ចាស់នៃយើងឡើយ ដោយសារឈើឆ្កាងនេះអ្វីៗក្នុងពិភពលោកលែងទាក់ទាមនឹងខ្ញុំ ហើយខ្ញុំក៏លែងមាន
ទាក់ទាមអ្វីនឹងពិភពលោកទៀតដែរ។[15]ទោះកាត់ស្បែកក្តី មិនកាត់ស្បែកក្តី គ្មានអ្វីសំខាន់ទេ មានតែការកើតជាថ្មីប៉ុណ្ណោះទើបសំខាន់។[16]អស់អ្នកដែលរស់ក្នុងជីវិតថ្មីនេះ
សេចក្តីសុខសាន្ត និងសេចក្តីមេត្តារបស់ព្រះជាម្ចាស់ស្ថិតនៅជាមួយពួកគេ និងប្រជារាស្ត្រអ៊ីស្រាអែលផងដែរ។
[17]ចាប់ពីពេលនេះតទៅ សូមកុំឲ្យនរណាម្នាក់ធ្វើឲ្យខ្ញុំពិបាកចិត្តទៀត ដ្បិតខ្ញុំមានស្លាកស្នាមរបស់ព្រះយេស៊ូ នៅក្នុងរូបកាយខ្ញុំស្រាប់ហើយ។[18]សូមព្រះគុណរបស់ព្រះអម្ចាស់
យេស៊ូគ្រិស្តនៃយើង ស្ថិតនៅជាមួយវិញ្ញាណរបស់បងប្អូន។ អាម៉ែន។

Galatians 6:1

ប្រយោគភ្ជាប់:

លោកប៉ូលបង្រៀនអ្នកជឿរបៀបដែលពួកគេគួរតែប្រព្រឹត្តចំពោះអ្នកជឿដទៃទៀត
និងរបៀបដែលព្រះជាម្ចាស់ផ្តល់រង្វាន់។

បងប្អូន

បកប្រែដូចនៅក្នុង ១:១

បើគេ

«បើនរណា» ឬ «បើនរណាម្នាក់ក្នុងចំណោមបងប្អូន»

តាមទាន់មនុស្សម្នាក់កំពុងតែប្រព្រឹត្តអំពើបាប

ទី១ប្រហែលអាចមានន័យថា) នរណាម្នាក់រកឃើញថា
មនុស្សនៅក្នុងសក្ខភាព«គឺត្រូវបានរកឃើញនៅសកម្មភាពនៃអំពោះបាប» ឬទី២)
មនុស្សដែលប្រព្រឹត្តអំពើបាបដោយគ្មានបំណងដើម្បីធ្វើការអាក្រក់ទេ
«ចុះចាញ់ហើយប្រព្រឹត្តអំពើបាប»

បងប្អូនដែលមានព្រះវិញ្ញាណ

«ដល់អស់អ្នកណាក្នុងចំណោមបងប្អូនដែលបានដឹកនាំតាមរយៈព្រះវិញ្ញាណ» ឬ
«បងប្អូនដែលរស់នៅនៅក្នុងការដឹកនាំតាមរយៈណែនាំរបស់ព្រះវិញ្ញាណ»

កែតម្រង់អ្នកនោះឡើងវិញ

«ណែនាំមនុស្សដែលដែលប្រព្រឹត្តអំពើបាប» ឬ
«ដាស់តឿនមនុស្សដែលប្រព្រឹត្តអំពើបាបដើម្បីវិញត្រឡប់ទៅកាន់ការទំនាក់ទំនងការត្រឹមត្រូវជាមួយព្រះជ

ដោយចិត្តស្លូតបូត

generated on Wed Sep 10 16:16:32 2025

ទី១ប្រហែលអាចមានន័យថា)ដែលព្រះវិញ្ញាណគឺកំពុងដឹកនាំដល់អស់អ្នកដែលកំពុងផ្លាស់ប្តូរ
ឬទី២) «ជាមួយឥរិយាបទស្លូតបូត» ឬ «ដោយរបៀបសប្បុរស»
ចូរប្រយ័ត្នខ្លួនឯង
ពាក្យទាំងនេះដោះស្រាយជាអ្នកស្រុកកាឡាទីទោះបីជាពួកគេទាំងអស់ជាមនុស្សតែមួយ
គាត់កំពុងនិយាយទៅកាន់ពួកគេម្នាក់ៗ។ ការបកប្រែផ្សេងទៀត:
«ចូរប្រយ័ត្នខ្លួនឯង» ឬ «ខ្ញុំនិយាយទៅកាន់បងប្អូនម្នាក់ៗ ចូរប្រយ័ត្នខ្លួនឯង»
សូមមើល:
ក្រែងលោបងប្អូនត្រូវរងការល្បួងដែរ
នេះអាចបង្ហាញនៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ដូចច្នេះគ្មានអ្វីនឹងល្បួងបងប្អូនដើម្បីប្រព្រឹត្តអំពើបាបផងដែរ»
Galatians 6:3
ដ្បិត
«ពីព្រោះ»
នេះជាការគឺងុលបង្ហាញថាពាក្យធ្វើតាមគឺជាអ្វីដែលក្រុមជំនុំមកាឡាទីគួរតែធ្វើទី១)
«ជួយយកអាសារគ្នាទៅវិញទៅមក» (៦:១) ឬ ២) ចូរប្រយ័ត្នថា
ពួកគេខ្លួនឯងមិនត្រូវសេក្តីល្បួង។ (៦:១) ឬទី៣)
«មិនមែនអួតបំប៉ោងទេ» (៥:១)។
ខ្លួនឯងសំខាន់ជាងគេ
«គាត់គឺជាអ្នកសំខាន់» ឬ «គាត់គឺប្រសើរជាងអ្នកទៃ»
តែឥតបានការសោះ
«គាត់គឺមិនសំខាន់» ឬ «គាត់គឺមិនប្រសើរជាងគេ»
ម្នាក់ៗគួរ
«ម្នាក់ៗត្រូវតែ»
គ្រប់គ្នានឹងទទួលខុសត្រូវកិច្ចការ ដែលខ្លួនបានប្រព្រឹត្តរួចមកហើយ។
«មនុស្សម្នាក់ៗនឹងទទួលការកាត់ទោសតាមរយៈការប្រព្រឹត្តរបស់ពួកគេ» ឬ
«មនុស្សម្នាក់ៗនឹងទទួលខុសត្រូវសម្រាប់ការប្រព្រឹត្តរបស់ពួកគេប៉ុណ្ណោះ»
គ្រប់គ្នានឹង
«មនុស្សម្នាក់ៗនឹង»
Galatians 6:6
ម្នាក់
«មនុស្សម្នាក់»
ព្រះបន្ទូល
នៅទីនេះគឺមានន័យថាព្រះជាម្ចាស់បានមានព្រះបន្ទូលឬ បង្គាប់បញ្ជារ ដូចនៅក្នុង
«ព្រះបន្ទូលរបស់ព្រះជាម្ចាស់» ឬ «ព្រះបន្ទូលនៃសេចក្តីពិត»
ដ្បិតមនុស្សសាបព្រោះពូជណា គេនឹងប្រមូលផលពូជនោះឯង។
ការសាបព្រោះតំណាងឲ្យការធ្វើអ្វីម៉្យាងដែលបញ្ចប់ដោយមានលទ្ធផលខ្លះ និង
ការប្រមូលផ្តុំ តំណាងឲ្យបទពិសោធន៍ជាលទ្ធផលនៃអ្វីដែលអ្នកបានធ្វើ។
ការបកប្រែផ្សេងទៀត: «ដូចជាកសិករប្រមូលផលនូវអ្វីដែលពួកគេសាបព្រោះ
គេដាំ ដូចច្នេះគ្រប់គ្នាមានបទពិសោធន៍នៅលទ្ធផលដែលគេធ្វើ»
មុស្ស ... របស់គេ
លោកប៉ូលមិនបានបញ្ជាក់ច្បាស់ទៅទីនេះថាប្រុស។ «មនុស្ស ... ដែលមនុស្ស»
សាបព្រោះពូជនិស្ស័យលោកីយ៍
«សាបព្រោះគ្រប់ពូជតាមរយៈនិស្ស័យលោកីយ៍របស់គេ»នេះតំណាងឲ្យការធ្វើនូវអ្វីដែលគ
ការបកប្រែផ្សេងទៀត:
«សាបព្រោះគ្រប់ពូជតាមរយៈនូវអ្វីដែលគាត់ចង់ធ្វើដោយសារនិស្ស័យលោកីយ៍របស់គេ
ឬ «ធ្វើអ្វីដែលគាត់ចង់ធ្វើដោយសារនិស្ស័យលោកីយ៍របស់គេ»
ដែលតែងតែពុករលួយ
«នឹងទទួលទណ្ឌកម្មចំពោះអ្វីដែលគាត់បានធ្វើ»
សាបព្រោះពូជព្រះវិញ្ញាណ
«ធ្វើអ្វីម៉្យាងតាមព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដោយស្រឡាញ់»
នឹងច្រូតបានជីវិតអស់កល្បជានិច្ច តាមរយៈព្រះវិញ្ញាណ។
«នឹងទទួលជីវិតអស់កល្បជានិច្ចជារង្វាន់ពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់»
Galatians 6:9
កុំឲ្យយើងរសាយចិត្តក្នុងការប្រព្រឹត្តអំពើល្អឡើយ
«យើងគួរតែបន្តដើម្បីធ្វើការល្អ»
អំពើល្អ
ការប្រព្រឹត្តអំពើល្អ ដល់អ្នកដទៃដើម្បីសុខុមាលភាពរបស់ពួកគេ។
ដ្បិត ដល់ពេលកំណត់
«សម្រាប់ពេលកំណត់» ឬ «ពីព្រោះនៅពេលកំណត់ព្រះជាម្ចាស់បានជ្រើរើស»
ផ្លូវនៃការកែតម្រូវ
«នេះជាលទ្ធផល» ឬ «ដោយសារការនេះ»
ជាពិសេស ... ដល់
«នៅក្នុងលក្ខណៈពិសេស ...ដល់អស់អ្នកណា» ឬ
«នៅក្នុងលក្ខណៈពិសេស ...ដល់អស់អ្នកណា»
ដល់បងប្អូនរួមជំនឿ
«ដល់អស់អ្នកដែលជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់តាមរយៈជំនឿនៅក្នុងព្រះគ្រិស្ត»
Galatians 6:11
ប្រយោគភ្ជាប់:
ពេលលោកប៉ូលបញ្ចប់សំបុត្រនេះ
គាត់ផ្តល់ឲ្យនៅការរម្លឹកដែលក្រឹត្យវិន័យមិនអាចសង្គ្រោះហើយថាពួកគេគួរតែចងចាំឈើឆ្កាងរបស់ព្រះគ្រិ
ជាអក្សរធំៗ
នេះអាចមានន័យថាលោកប៉ូលចង់បញ្ជាក់១) សេចក្តីថ្លែងដែលធ្វើតាម ឬទី២)
ដែលសំបុត្រនេះបានមកពីគាត់
ដោយផ្ទាល់ដៃ
ទី១ប្រហែលអាចមានន័យថា)
លោកប៉ូលប្រហែលជាមានជំនួយការម្នាក់ដែលសរសេរសំបុត្រនេះភាគច្រើនដូចដែលលោកប៉ូលបានប្រាប់
២)លោកប៉ូលបានសរសេរសំបុត្រទាំងមូលដោយខ្លួនឯង។
ចំណាប់អារម្មណ៍
«ហេតុដែលបណ្តាលឲ្យអ្នកដៃគិតល្អពីពួកគេ» ឬ
«ហេតុដែលបណ្តាលឲ្យគិតថាអ្នកដទៃពួកគេគឺជាមនុស្សល្អ»
ខាងនិស្ស័យលោកីយ៍
«ជាមួយភស្តុតាងដែលមើលឃើញ» ឬ «តាមរយៈការខិតខំរបស់ពួកគេ»
បង្ខំ
«បង្ខំ» ឬ «លទ្ធិពលខ្លាំង»
ដើម្បីជៀសវាងការបៀតបៀនព្រោះតែឈើឆ្កាងព្រះគ្រិស្ត។
«ដូចច្នេះជនជាតិយូដានឹងមិនបៀតបៀនពួកគេសម្រាប់ការអះអាងថាឈើឆ្កាងនៃព្រះគ្រិស្តតែមួយគត់គឺជ
ឈើឆ្កាង
ឈើឆ្កាងនៅទីនេះតំណាងឲ្យនូវអ្វីដែលព្រះគ្រិស្តបានធ្វើសម្រាប់យើងពេលព្រះអង្គបានសុគតនៅលើឈើ
ការបកប្រែផ្សេងទៀត: «កិច្ចការព្រះយេស៊ូបានធ្វើនៅលើឈើឆ្កាង» ឬ
«ការសុគតនិងរស់ឡើងនៃព្រះយេស៊ូ»
ពួកគេចង់
«ដល់មនុស្សដែលជម្រុញបងប្អូនឲ្យចង់ធ្វើការកាត់ស្បែក»
ដូច្នេះ ពួកគេនឹងអួតថា ពួកគេបានកាត់ស្បែកឲ្យបងប្អូនតែប៉ុណ្ណោះ។
«ដូចច្នេះពួកគេអាចមានមោទនភាពដែលបានបន្ថែមបងប្អូនទៅកាន់មនុស្សដែលព្យាយាមរក្សាក្រឹត្យវិន័យ
Galatians 6:14
ប៉ុន្តែ ខ្ញុំមិនអួតអ្វី ក្រៅពីឈើឆ្កាង
«ខ្ញុំមិនចង់អួតពីអ្វីផ្សេងទៀតជាងឈើឆ្កាង» ឬ «ខ្ញុំអាចអួតតែពីឈើឆ្កាងប៉ុណ្ណោះ»
ក្នុងពិភពលោកលែងទាក់ទាមនឹងខ្ញុំ
នេះអាចបង្ហាញនៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ខ្ញុំគិតអំពីលោកីយ៍ដូចជាស្លាប់រួចហើយ» ឬ
«ខ្ញុំប្រព្រឹត្តចំពោះលោកីយ៍ដូចឧក្រិដ្ឋជនដែលព្រះជាម្ចាស់បានសម្លាប់នៅលើឈើឆ្កាង»
ខ្ញុំគិតចង់ធ្វើតាមនិស្ស័យលោកីយ៍របស់គាត់។
ពាក្យថា «ត្រូវបានឆ្កាង» គឺជាពាក្យ «ត្រូវបានឆ្កាង» ត្រូវបានយកពីឃ្លាមុននេះ។
ការបកប្រែផ្សេងទៀត: «ហើយខ្ញុំត្រូវបានឆ្កាងដល់ពិភពលោក»
គ្មានអ្វីសំខាន់ទេ
«គឺសំខាន់ចំពោះព្រះជាម្ចាស់»
ការកើកជាថ្មី
ទី១ប្រហែលអាចមានន័យថា) អ្នកជឿថ្មីនៅក្នុងព្រះគ្រិស្ត ឬ២)ជីវិតថ្មីនៃអ្នកជឿ។
សន្តិភាពនិងក្តីមេត្តាករុណាទៅលើពួកគេ ហើយ ទៅលើជនជាតិអ៊ីស្រាអែលរបស់ព្រះជាម្ចាស់។
ទី១ប្រហែលអាចមានន័យថា) អ្នកជឿទូទៅគឺជាអ៊ីស្រាអែលរបស់ព្រះជាម្ចាស់ឬ២)
«សូមឲ្យសន្តិភាពនិងក្តីមេត្តាករុណានៅលើអ្នកជឿជាសាសន៍ដទៃនិងនៅលើអ៊ីស្រាអែលរបស់ព្រះជាម្ចាស់
ឬទី3)
«សូមឲ្យសន្តិភាពនិងក្តីមេត្តាករុណានៅលើអស់អ្នកណាដែលតាមក្រឹត្យវិន័យ និង
សូមឲ្យសន្តិភាពនិងក្តីមេត្តាករុណានៅលើអ៊ីស្រាអែលរបស់ព្រះជាម្ចាស់»។
Galatians 6:17
ចាប់ពីពេលនេះតទៅ
នេះអាចមានន័យ «ចុងក្រោយ» ផងដែរ ឬ «ពេលខ្ញុំបញ្ចប់សំបុត្រនេះ»។
សូមកុំឲ្យនរណាម្នាក់ធ្វើឲ្យខ្ញុំពិបាកចិត្តទៀត

generated on Wed Sep 10 16:16:32 2025

ទី១ប្រហែលអាចមានន័យថា)
លោកប៉ូលកំពុងបញ្ជារក្រុមជំនុំកាឡាទីកុំធ្វើឲ្យគាត់ពិបាកចិត្ត
«ខ្ញុំកំពុងបញ្ជារបងប្អូន: កុំធ្វើឲ្យខ្ញុំពិបាកចិត្ត» ឬ ទី២)
លោកប៉ូលគឺកំពុងប្រាប់ក្រុមជំនុំកាឡាទីដែលគាត់គឺកំពុងបញ្ជារដល់មនុស្សទាំងអស់កុំធ្វើឲ្យគាត់ពិបាកចិត្ត
«ខ្ញុំគឺកំពុងបញ្ជារគ្រប់ៗគ្នា : កុំធ្វើឲ្យខ្ញុំពិបាក» ឬទី៣)
លោកប៉ូលគឺកំពុងបង្ហាញបំណងប្រាថ្នា
«ខ្ញុំមិនចង់ឲ្យអ្នកណាធ្វើឲ្យខ្ញុំពិបាកចិត្តទេ»។
ខ្ញុំពិបាកចិត្ត
ទី១ប្រហែលអាចមានន័យថា) «និយាយអំពីបញ្ហាទាំងនេះដល់ខ្ញុំ» (UDB) ឬទី២)
«បណ្តាលឲ្យខ្ញុំលំបាក» ឬ"ឲ្យខ្ញុំលំបាក»។
ដ្បិតខ្ញុំមានស្លាកស្នាមរបស់ព្រះយេស៊ូ នៅក្នុងរូបកាយខ្ញុំស្រាប់ហើយ។
«ខ្ញុំបានជានៅក្នុងរូបកាយរបស់ខ្ញុំដោយសារការបម្រើដល់ព្រះយេស៊ូ» ឬ
«ខ្ញុំនៅតែមានស្លាកស្នាមនៃរបួសនៅក្នុងរាងកាយពីព្រោះខ្ញុំជាកម្មសិទ្ធរបស់ព្រះយេស៊ូ»
ស្លាកស្នាម
ធ្វើឲ្យគាត់ពិបាកចិត្ត
ទី១ប្រហែលអាចមានន័យថា)
ស្នាមពីរបួសដែលទាហានរងទុក្ខវេទនានៅក្នុងសមរភូមិឬតាមរយៈគ្រោះថ្នាក់នៅក្នុងការងារឬ២)
ត្រាដែលសំគាល់ទេសករ។
សូមព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង ស្ថិតនៅជាមួយវិញ្ញាណ
«ខ្ញុំអធិស្ឋានឲ្យថាព្រះអម្ចាស់យេស៊ូនឹងមានព្រះហឫទ័យសប្បុរសចំពោះវិញ្ញាណរបស់បងប្អូន»។
បងប្អូន
នេះបកប្រែដូច១:១

អេភេសូរ

1 [1]ខ្ញុំ ប៉ូល ជាសាវករបស់ព្រះគ្រិស្តយេស៊ូ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យតែងតាំង សូមជម្រាបសួរប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ នៅក្រុងអេភេសូរ
ដែលនៅតែស្មោះត្រង់ចំពោះព្រះគ្រិស្តយេស៊ូ។[2]សូមព្រះជាម្ចាស់ជាព្រះបិតានៃយើង និងព្រះអម្ចាស់យេស៊ូគ្រិស្តបានប្រទានព្រះគុណ និងសេចក្តីសុខសាន្ត
ដល់បងប្អូនទាំងអស់គ្នា។
[3]សូមលើកតម្កើងព្រះជាម្ចាស់ និងព្រះបិតានៃព្រះអម្ចាស់យេស៊ូគ្រិស្ត ដែលព្រះអង្គបានប្រទានព្រះពរគ្រប់យ៉ាងខាងវិញ្ញាណ ពីស្ថានបរមសុខមកយើងរាល់គ្នា
ក្នុងអង្គព្រះគ្រិស្ត។[4]ព្រះជាម្ចាស់បានជ្រើសរើសយើង តាំងពីមុនកំណើតលោកីយ៍មកម្ល៉េះ ដើម្បីឲ្យយើងបានវិសុទ្ធ និងឥតសៅហ្មងនៅចំពោះព្រះភក្ត្រព្រះអង្គ។
[5]ព្រះជាម្ចាស់បានជ្រើសរើសយើងជាមុន ឲ្យធ្វើជាបុត្រព្រះអង្គ តាមរយៈព្រះយេស៊ូគ្រិស្ត ស្របតាមព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ។[6]ទ្រង់បានជ្រើសរើសយើង
ដើម្បីលើកតម្កើងព្រះគុណដ៏រុងរឿងរបស់ព្រះអង្គ ដែលបានប្រទានមកយើងរាល់គ្នាដោយឥតគិតថ្លៃ ក្នុងអង្គព្រះបុត្រាដ៏ជាទីស្រឡាញ់។
[7]យើងបានទទួលការប្រោសលោះក្នុងអង្គព្រះយេស៊ូគ្រិស្ត តាមរយៈព្រះលោហិត និងការអត់ទោសបាប ស្របតាមព្រះគុណដ៏លើសលប់របស់ព្រះអង្គ។
[8]ព្រះអង្គបានប្រទានព្រះគុណដ៏លើសលប់មកយើងរាល់គ្នា ដើម្បីឲ្យយើងទាំងអស់គ្នាមានតម្រិះ និងប្រាជ្ញាវាងវៃគ្រប់យ៉ាង។
[9]ព្រះជាម្ចាស់បានប្រទានឲ្យយើងស្គាល់គម្រោងការលាក់កំបាំង ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ
ដែលសម្តែងចេញមកក្នុងអង្គព្រះគ្រិស្ត[10]ព្រះអង្គកំណត់ពេលវេលាសម្រេចផែនការនេះ ដើម្បីនាំយកអ្វីៗទាំងអស់ គឺអ្វីៗនៅស្ថានបរមសុខ និងនៅផែនដីរួមគ្នាតែមួយ
ដែលមានព្រះគ្រិស្តជាម្ចាស់។
[11]ព្រះជាម្ចាស់បានតម្រូវយើងទុកជាមុន ដើម្បីទទួលមរតកក្នុងព្រះគ្រិស្ត។ ព្រះជាម្ចាស់បានជ្រើសរើសយើងទុកជាមុន ស្របតាមផែនការព្រះអង្គ
ដែលសម្រេចគ្រប់កិច្ចការទាំងអស់ តាមបំណងព្រះហឫទ័យព្រះអង្គ។[12]ព្រះជាម្ចាស់បានតម្រូវយើងទុកជាមុន
ដើម្បីទទួលមរតកនោះយើងនឹងមានសង្ឃឹមលើព្រះគ្រិស្តមុនដំបូងបង្អស់ ហេតុដូចនេះ យើងនឹងលើកតម្កើងសិរីរុងរឿងព្រះអង្គ។
[13]នៅក្នុងព្រះគ្រិស្ត បងប្អូនបានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អនាំឲ្យបងប្អូនបានសង្គ្រោះ បងប្អូនជឿព្រះអង្គ
នោះបងប្អូនបានទទួលសញ្ញាសម្គាល់ពីព្រះវិញ្ញាណដ៏វិសុទ្ធតាមព្រះបន្ទូលសន្យា[14]ព្រះអង្គប្រទានព្រះវិញ្ញាណមកបញ្ចាំចិត្តយើង
រហូតដល់ពេលយើងទទួលមរតកពេញលេញ ដើម្បីលើកតម្កើងសិរីរុងរឿងដល់ព្រះអង្គ។
[15]ដោយហេតុនេះហើយ ចាប់តាំងពីខ្ញុំបានឮគេតំណាលអំពីជំនឿបងប្អូន នៅក្នុងព្រះអម្ចាស់យេស៊ូ
និងសេចក្តីស្រឡាញ់បងប្អូនចំពោះប្រជារាស្ត្រដ៏វិសុទ្ធទាំងអស់របស់ព្រះជាម្ចាស់[16]នោះខ្ញុំអរព្រះគុណព្រះជាម្ចាស់ឥតឈប់ឈរសម្រាប់បងប្អូន
ដូចខ្ញុំបាននឹកចាំបងប្អូនក្នុងសេចក្តីអធិស្ឋានខ្ញុំដែរ។
[17]ខ្ញុំអធិស្ឋាន សូមព្រះជាម្ចាស់នៃព្រះយេស៊ូគ្រិស្តជាអម្ចាស់របស់យើងរាល់គ្នា គឺព្រះបិតាប្រកបដោយសិរីរុងរឿង ប្រទានវិញ្ញាណនៃព្រះប្រាជ្ញា
និងការបើកសម្តែងឲ្យយើងបានស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់។[18]សូមព្រះបិតាបំភ្លឺចិត្តគំនិតបងប្អូន និងធ្វើឲ្យបងប្អូនមានសង្ឃឹមជឿជាក់ក្នុងចិត្តថា
ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូន និងប្រទានមរតកដ៏រុងរឿងលើសលប់ រួមជាមួយប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។
[19]ខ្ញុំអធិស្ឋានសុំឲ្យបងប្អូនយល់ដឹង អំពីឫទ្ធានុភាពដ៏អស្ចារ្យ ដែលបានប្រទានមកយើងជាអ្នកជឿព្រះអង្គ ស្របតាមមហិទ្ធិឫទ្ធិនៃព្រះចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ។
[20]នេះជាមហិទ្ធិឫទ្ធិដែលព្រះជាម្ចាស់ធ្វើការក្នុងព្រះគ្រិស្ត ពេលព្រះអង្គប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញ ហើយគង់នៅខាងស្តាំព្រះបិតានៅស្ថានបរមសុខ។
[21]ព្រះជាម្ចាស់ឲ្យព្រះគ្រិស្តគង់នៅខ្ពស់ជាងអ្វីៗដែលមានអំណាច មានឫទ្ធិ មានបារមីគ្រប់គ្រង និងខ្ពស់លើសនាមទាំងអស់។ ព្រះគ្រិស្តមិនត្រឹមតែគ្រប់គ្រងនៅលោកនេះទេ
គឺនៅលោកខាងមុខទៀតផង។
[22]ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឲ្យនៅក្រោមព្រះបាទារបស់ព្រះគ្រិស្ត ព្រមទាំងគង់នៅលើអ្វីៗទាំងអស់ និងធ្វើជាសិរសារបស់ក្រុមជំនុំ។
[23]ក្រុមជំនុំជាព្រះកាយព្រះគ្រិស្ត ហើយពេញដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះគ្រិស្ត ហើយព្រះគ្រិស្តផ្ទាល់បានពេញដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែរ។

Ephesians 1:1
ប្រយោគភ្ជាប់:
លោកប៉ូលដាក់ឈ្មោះខ្លួនឯងជាអ្នកសរសេរសំបុត្រនេះទៅកាន់អ្នកជឿនៅក្រុមជំនុំអេភេសូរ
ពត៌មានទូទៅ:
លើកលេងតែកន្លែងបានកត់សម្គាល់ រាល់ករណីទាំងអស់នៃពាក្យ «អ្នក» និង
«របស់អ្នមក» សំដៅទៅលើអ្នកជឿនៅអេភេសូរក៏ដូចជាអ្នកជឿដទៃទៀតដែរ
ហើយ ជា ពហុវចនៈ។ (សូមមើល:
ដែលនៅតែស្មោះត្រង់ចំពោះព្រះគ្រិស្តយេស៊ូ។
«នៅក្នុងព្រះគ្រិស្ត» ហើយនឹងការបង្ហាញស្រដៀងគ្នា
គឺជាការប្រៀបធៀបដែលញឹកញាប់កើតឡើងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។
ពួកគេបង្ហាញទំនាក់ទំនងដ៏ល្អរវាងព្រះគ្រិស្តហើយនឹងដល់អស់អ្នកដែលជឿនៅក្នុងព្រះអង្គ។
ប្រទានព្រះគុណ និងសេចក្តីសុខសាន្ត
នេះជាការស្វាគមន៍ជាទូទៅនិងការប្រទានពរដែលលោកប៉ូលជាញឹកញាប់ប្រើនៅក្នុងសំបុត្ររបស់គាត់។

Ephesians 1:3
ប្រយោគភ្ជាប់:
ស្នាមប៉ូលចាប់ផ្តើមសំបុត្ររបស់គាត់តាមរយៈការនិយាយអំពីតួនាទីរបស់អ្នកជឿ
និងសុវត្ថាភាពរបស់ពួកគេនៅពីមុខព្រះភក្ត្រព្រះជាម្ចាស់។
ព័ត៌មានទូទៅ៖
នៅក្នុងសៀវភៅនេះទាល់តែមានការថ្លែងផ្សេង ពីពាក្យថា «របស់យើង» និង
«យើង» សំដៅទៅលើលោកប៉ូល អ្នកជឿនៅអេភេសូរ ក៏ដូចជាអ្នកជឿទាំងអស់។
សូមលើកតម្កើងព្រះជាម្ចាស់ និងព្រះបិតានៃព្រះអម្ចាស់យេស៊ូគ្រិស្ត
នេះអាចថ្លែងនៅក្នុងទម្រង់សកម្ម។សូមមើលការបកប្រែផ្សេងទៀត:
«ចូរយើងសរសើរតម្កើងព្រះជាម្ចាស់ជានិងព្រះបិតាជាព្រះអម្ចាស់របស់ព្រះយេស៊ូគ្រិស្ត»
ព្រះអង្គបានប្រទាន
ដែលបានប្រទានពរដល់យើង
ក្នុងស្ថានសួគ៌ខាងវិញ្ញាណ

generated on Wed Sep 10 16:16:32 2025

«គ្រប់ព្រះពរទាំងអស់មកពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់»
«ពីស្ថានបរមសុខ»
«នៅក្នុងពិភពអបីយ៍ជំនឿ» លោកីយ៍ «ស្ថានបរមសុខ»
សំដៅទៅកន្លែងដែលព្រះជាម្ចាស់គង់នៅ។
ក្នុងអង្គព្រះគ្រិស្ត។
«នៅក្នុងព្រះគ្រិស្ត»
និងការបង្ហាញស្រដៀងគ្នាគឺជាការប្រៀបធៀបដែលញឹកញាប់នៅព្រះគម្ពីរសញ្ញាថ្មី
ពួកគេបង្ហាញទំនាក់ទំនងដ៏ល្អរឹងមាំដែលអាចកើតមានឡើងរវាងព្រះគ្រិស្តនិងដល់អស់
ដើម្បីឲ្យយើងបានវិសុទ្ធ និងឥតសៅហ្មង
លោកប៉ូលប្រើពាក្យស្រដៀងគ្នាពីរដើម្បីបញ្ជាក់ពីក្រមសីលធម៌ល្អ។
Ephesians 1:5
ពត៌មានទូទៅ:
ពាក្យថា «របស់ទ្រង់» «ព្រះអង្គ» និង «គាត់» សំដៅទៅព្រះជាម្ចាស់ ។
ព្រះជាម្ចាស់បានជ្រើសរើសយើងជាមុន
ពាក្យថា «យើង» សំដៅទៅលើលោកប៉ូល ក្រុមជំនុំអេភេសូរ និង
អស់ទាំងអ្នកជឿនៅក្នុងព្រះគ្រិស្ត»។ សូមមើលការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានរៀបចំគម្រោងទុកជាយូរមកហើយដើម្បីទទួលយើងមកធ្វើជាកូន»
ឲ្យធ្វើជាបុត្រព្រះអង្គ
នៅទីនេះ «កូនចិញ្ចឹម» សំដៅទៅលើការដាក់នៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់។
តាមរយៈព្រះយេស៊ូគ្រិស្ត
ព្រះជាម្ចាស់បាននាំអ្នកជឿទាំងអស់ទៅកាន់គ្រួសាររបស់ទ្រង់
តាមរយៈកិច្ចការរបស់ព្រះយេស៊ូគ្រិស្ត។
ក្នុងអង្គព្រះបុត្រាដ៏ជាទីស្រឡាញ់។
«ព្រះបុត្រាម្នាក់ដែលព្រះអង្គស្រឡាញ់ គឺយេស៊ូគ្រិស្ត» ឬ
«ព្រះបុត្រារបស់ទ្រង់ដែលព្រះអង្គស្រឡាញ់»
Ephesians 1:7
ស្របតាមព្រះគុណដ៏លើសលប់របស់ព្រះអង្គ។
លោកប៉ូលនិយាយអំពីព្រះគុណរបស់ព្រះជាម្ចាស់ដូចជាទ្រព្យសម្បត្តិ។
សូមមើលការបកប្រែផ្សេងទៀត: «ព្រះគុណដ៏លើសលប់របស់ព្រះជាម្ចាស់» ឬ
«ព្រះគុណដ៏ពេញបរិបូណ៌របស់ព្រះជាម្ចាស់»
ព្រះអង្គបានប្រទានព្រះគុណដ៏លើសលប់មកយើងរាល់គ្នា
«ព្រះអង្គបានប្រទានព្រះគុណដ៏ច្រើនលើសលប់»ឬ
«ព្រះអង្គមានចិត្តសប្បុរសបំផុតដល់យើង»
មានតម្រិះ និងប្រាជ្ញាវាងវៃគ្រប់យ៉ាង។
ទី១ប្រហែលជាមានន័យ)
«ពីព្រោះព្រះអង្គមានគ្រប់ប្រាជ្ញានិងការយល់ដឹងទាំងអស់» ទី២)
«ដូចច្នេះយើងអាចមានប្រាជ្ញានិងការយល់ដឹងដ៏អស្ចារ្យ»
Ephesians 1:9
ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ
ទី១ប្រហែលជាមានន័យ) «ពីព្រោះព្រះអង្គចង់បង្កើតវាដើម្បីឲ្យស្គាល់យើង »
ឬទី២) «ដែលជាអ្វីដែលព្រះអង្គចង់បាន»
ដែលសម្តែងចេញមកក្នុងអង្គព្រះគ្រិស្ត
«ហើយព្រះអង្គបានបង្ហាញគោលបំណងនេះនៅក្នុងព្រះគ្រិស្ត»
ក្នុងអង្គព្រះគ្រិស្ត
«តាមរយៈព្រះគ្រិស្ត»
សម្រេចផែនការ
ប្រយោគថ្មីអាចត្រូវបានចាប់ផ្តើមនៅទីនេះ។ សូមមើលការបកប្រែផ្សេងទៀត:
«ព្រះអង្គបានធ្វើការនេះដោយមានទស្សនចំពោះផែនការនេះ» ឬ
«ព្រះអង្គបានធ្វើការនេះ ដោយគិតអំពីគម្រោងផែនការ»
កំណត់ពេលវេលា
«សម្រាប់ពេលវេលាត្រឹមត្រូវ» ឬ «សម្រាប់ពេលវេលាដែលបានចាត់ចែង»
Ephesians 1:11
ព្រះជាម្ចាស់បានតម្រូវយើងទុកជាមុន ដើម្បីទទួលមរតក
នេះអាចថ្លែងនៅក្នុងទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានជ្រើរើសយើងដើម្បីទទួលមរតក»
ព្រះជាម្ចាស់បានជ្រើសរើសយើងទុកជាមុន
«ព្រះជាម្ចាស់ជ្រើសរើសមុន»
យើងនឹងមានសង្ឃឹមលើព្រះគ្រិស្តមុនដំបូងបង្អស់
ពាក្យនៅទីនេះ «យើង»
សំដៅទៅលើអ្នកជឿជនជាតិយូដាដែលបានឧឮដំណឹងល្អមុន
មិនមែនអ្នកជឿនៅអេភេសូរទេ។
យើងនឹងមានសង្ឃឹមលើព្រះគ្រិស្តមុនដំបូងបង្អស់
«ដូចច្នេះយើងនឹងរស់នៅដើម្បីសរសើរតម្កើងព្រះអង្គសម្រាប់សិរីរុងរឿងរបស់ទ្រង់»
Ephesians 1:13
បានទទួលសញ្ញាសម្គាល់ពីព្រះវិញ្ញាណដ៏វិសុទ្ធតាមព្រះបន្ទូលសន្យា
ក្រមុនគឺត្រូវបាននៅលើសំបុត្រហើយបិទតែមជាមួយនិមិត្តសញ្ញា
ភ្នំតែងឲ្យមានភ្នែកមើលឃើញ
លោកប៉ូលប្រពៃណីនេះជារូបភាពដើម្បីបង្ហាញរបៀបដែលព្រះជាម្ចាស់បានប្រើព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីធា
យើងជាកម្មសិទ្ធរបស់ព្រះអង្គ។ សូមមើលការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានបោះត្រាបងប្អូនជាមួយព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះអង្គបានសន្យា»
រហូតដល់ពេលយើងទទួលមរតកពេញលេញ
ទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យាគឺត្រូវបាននិយាយថាមនុស្សទទួលមរតឬទ្រព្យសម្បត្តិពីសមាជិក
សូមមើលការបកប្រែផ្សេងទៀត:
«ការធានាអះអាងដែលយើងនឹងទទួលនូវអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូលសន្យា»
Ephesians 1:15
ប្រយោគភ្ជាប់:
លោកប៉ូលអធិស្ឋានសម្រាប់អ្នកជឿនៅអេភេសូរនិងសរសើរតម្កើងព្រះជាម្ចាស់សម្រាប់អំណាចដែលអ្នក
នោះខ្ញុំអរព្រះគុណព្រះជាម្ចាស់ឥតឈប់ឈរ
លោកប៉ូលប្រើ «មិនឈប់» ដើម្បីបញ្ជាក់ថាគាត់បន្តដើម្បីអរគុណព្រះជាម្ចាស់។
សូមមើលការបកប្រែផ្សេងទៀត: «ខ្ញុំនៅតែបន្តអរគុណព្រះជាម្ចាស់»
Ephesians 1:17
ប្រទានវិញ្ញាណនៃព្រះប្រាជ្ញា និងការបើកសម្តែងឲ្យយើងបានស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់។
«ព្រះវិញ្ញាណនៃប្រាជ្ញាដើម្បីយល់ការបើកសម្តែងរបស់ទ្រង់»
បំភ្លឺចិត្តគំនិតបងប្អូន
ឃ្លា«ភ្នែកនៃដួងចិត្ត» បង្ហាញសមត្ថភាពរបស់មនុស្សម្នាក់ក្នុងការយល់ដឹង។
សូមមើលការបកប្រែផ្សេងទៀត: «ដែលអ្នកអាចទទួលការយល់ដឹងនិងបំភ្លឺ»
បំភ្លឺ
«ធ្វើដើម្បីឲ្យមើលឃើញ»
មរតក
ទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យាគឺត្រូវបាននិយាយថាមនុស្សទទួលមរតឬទ្រព្យសម្បត្តិពីសមាជិក
សូមមើលការបកប្រែផ្សេងទៀត:
រួមជាមួយប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។
នេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់កាលសកម្ម។ សូមមើលការបកប្រែផ្សេងទៀត:
«ដល់អ្នកណាទាំងអស់ដែលព្រះអង្គបានញែកសម្រាប់អង្គទ្រង់ផ្ទាល់» ឬ
«ដល់អស់អ្នកណាដែលជាកម្មសិទ្ធទាំងស្រុងដល់ទ្រង់»
Ephesians 1:19
អំពីឫទ្ធានុភាពដ៏អស្ចារ្យ ដែលបានប្រទានមកយើងជាអ្នកជឿព្រះអង្គ
អំណាចដ៏អស្ចារ្យរបស់ព្រះអង្គគឺហួសឆ្ងាយពីអំណាចដ៏ទៃទៀតទាំងអស់
មកយើង
«សម្រាប់ផលប្រយោជន៍របស់យើង» ឬ «ទាក់ទងដល់ពួកយើង»
មហិទ្ធិឫទ្ធិនៃព្រះចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ
«អំណាចចេស្តាដ៏អស្ចារ្យរបស់ព្រះអង្គដែលធ្វើការសម្រាប់»
ពេលព្រះអង្គប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញ
«បានប្រោសព្រះអង្គឲ្យរស់ឡើងវិញ» ឬ «ធ្វើឲ្យព្រះអង្គមានជីវិតជាថ្មីម្តងទៀត»
ហើយគង់នៅខាងស្តាំព្រះបិតានៅស្ថានបរមសុខ។
«បានអង្គុយជាមួយព្រះគ្រិស្តនៅខាងស្តាំព្រះបិតា» ឬ
បានអង្គុយជាមួយព្រះគ្រិស្តនៅកន្លែងកិក្តិយស»
នៅស្ថានបរមសុខ
«នៅក្នុងពិភពលោកការលើពីវិស័យធម្មជាតិនៃ» ពាក្យថា «ស្ថានបរមសុខ»
គឺសំដៅទៅលើទីកន្លែងដែលព្រះជាម្ចាស់គង់។
សូមមើលរបៀបដែលបានមកប្រែនៅក្នុង ១:៣
នៅខ្ពស់ជាងអ្វីៗដែលមានអំណាច មានឫទ្ធិ មានបារមីគ្រប់គ្រង និងខ្ពស់លើសនាមទាំងអស់។
ពាក្យទាំងនេះគឺខុសគ្នាសម្រាប់ការបែកចែកការលើសពីធម្មជាតិទាំងពីរ
ទាំងពួកទេវតា និងពូកបិសា។ សូមមើលការបកប្រែផ្សេងទៀត:
«លើសឆ្ងាយពីប្រភេទនៃការលើសពីធម្មជាតិ»
ខ្ពស់លើសនាមទាំងអស់
នេះអាចថ្លែងនៅក្នុងទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត:
ទី១ប្រហែលជាមានន័យ) «គ្រប់មនុស្សទាំងអស់ដែលមនុស្សដាក់ឲ្យ» ឬទី២)

generated on Wed Sep 10 16:16:32 2025

«គ្រប់ឈ្មោះទាំងអស់ដែលព្រះជាម្ចាស់ប្រទាន»
នាម
ទី១ប្រហែលជាមានន័យ) ឋាន: ឬទី២) តួនាទីនៃសិទ្ធអំណាច។
លោក
«នៅពេលនេះ»
គឺនៅលោកខាងមុខទៀតផង។
«នៅអនាគត»
Ephesians 1:22
ព្រះជាម្ចាស់បាន
«ព្រះជាម្ចាស់បានដាក់នៅកន្លែង»ឬ«ព្រះជាម្ចាស់បានដាក់» (UDB)
អ្វីៗទាំងអស់ ឲ្យនៅក្រោមព្រះបាទារបស់ព្រះគ្រិស្ត
នៅទីនេះ «ជើង» តំណាងឲ្យភាពជាព្រះរបស់ព្រះគ្រិស្ត សិទ្ធអំណាច ។
សូមមើលការបកប្រែផ្សេងទៀត:

«គ្រប់ៗអ្វីទាំងអស់នៅក្រោមអំណាចរបស់ព្រះគ្រិស្ត»
ធ្វើជាសិរសារបស់ក្រុមជំនុំ ...ព្រះកាយព្រះគ្រិស្ត
ដូចគ្នាជាមួយរូបកាយមនុស្ស
ក្បាលគ្រប់គ្រងអ្វីទាំងអស់ដែលជាប់ទាក់ទងជាមួយរាងកាយ
ដូចច្នេះព្រះគ្រិស្តគឺជាប្រមុខនៃក្រុមជំនុំ។
ធ្វើជាសិរសារបស់ក្រុមជំនុំ ក្រុមជំនុំជាព្រះកាយព្រះគ្រិស្ត
នៅទីនេះ «ក្បាល» គឺនិយាយសំដៅទៅអ្នកដឹកនាំ ឬ
«ម្នាក់ដែលគ្រប់គ្រងអ្វីៗទាំងអស់នៅក្នុងក្រុមជំនុំ»
ព្រះកាយព្រះគ្រិស្ត
ក្រុមជំនុំគឺជាទូទៅសំដៅទៅលើព្រះកាយរបស់ព្រះគ្រិស្ត។
ព្រះគ្រិស្តផ្ទាល់បានពេញដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែរ
«ព្រះគ្រិស្តបំពេញក្រុមជំនុំជាមួយព្រះជន្មរបស់ទ្រង់ និង
អំណាចដូចជាព្រះអង្គប្រទានព្រះជន្មទ្រង់សម្រាប់អ្វីៗទាំងអស់»

---

2 [1]ចំពោះបងប្អូនវិញ បងប្អូនបានស្លាប់នៅក្នុងអំពើរំលង និងអំពើបាបរួចទៅហើយ។[2]កាលនោះអំពើរំលង និងអំពើបាបនេះហើយ
ដែលនាំឲ្យបងប្អូនរស់នៅតាមរបៀបលោកីយ៍។ បងប្អូនរស់នៅតាមមេគ្រប់គ្រងអំណាចលើអាកាស គឺជាវិញ្ញាណដែលមានឥទ្ធិពលនៅក្នុងអស់អ្នក
ដែលមិនស្តាប់បង្គាប់។[3]កាលពីដើម យើងរស់នៅក្នុងចំណោមអ្នកទាំងនោះដែរ បណ្តោយខ្លួនតាមតណ្ហាលោភលន់នៃនិស្ស័យលោកីយ៍
និងប្រព្រឹត្តអំពើផ្សេងៗតាមចិត្តគំនិតលោកីយ៍។ ពីកំណើតមក យើងជាមនុស្សត្រូវបណ្តាសា ដូចមនុស្សឯទៀតៗដែរ។
[4]ប៉ុន្តែ ព្រះជាម្ចាស់ពេញដោយព្រះទ័យមេត្តាច្រើនពន់ប្រមាណ ព្រោះព្រះអង្គស្រឡាញ់យើងយ៉ាងខ្លាំងបំផុត។[5]កាលយើងស្លាប់ក្នុងអំពើរំលងនៅឡើយ
ព្រះអង្គប្រោសយើងឲ្យរស់រួមជាមួយព្រះគ្រិស្ត ព្រះជាម្ចាស់បានសង្គ្រោះបងប្អូនដោយសារព្រះគុ ុណ។[6]ព្រះជាម្ចាស់ប្រោសឲ្យបងប្អូនរស់ឡើងវិញ
រួមជាមួយព្រះគ្រិស្តយេស៊ូ ព្រមទាំងឲ្យយើងអង្គុយនៅស្ថានបរមសុខ រួមជាមួយព្រះអង្គដែរ។[7]ហេតុដូច្នេះ នៅជាន់ក្រោយនេះ ព្រះជាម្ចាស់នឹងបង្ហាញឲ្យយើងស្គាល់
ព្រះគុណ ដ៏ប្រសើរលើសលប់បំផុតរបស់ព្រះអង្គចំពោះយើង ក្នុងព្រះគ្រិស្តយេស៊ូ។
[8]ព្រះជាម្ចាស់បានសង្គ្រោះបងប្អូនដោយសារព្រះគុណ តាមរយៈជំនឿ ហើយការសង្គ្រោះពុំមែនមកពីបងប្អូនទេ ជាអំណោយទានរបស់ព្រះជាម្ចាស់។
[9]ព្រះគុណពុំមែនមកពីមនុស្សខំប្រព្រឹត្តទេ ដើម្បីកុំឲ្យនរណាម្នាក់អួតខ្លួនឡើយ។[10]ដ្បិតយើងជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលបង្កើតមកក្នុងព្រះគ្រិស្តយេស៊ូ
ដើម្បីឲ្យយើងប្រព្រឹត្តអំពើល្អ ដែលព្រះជាម្ចាស់បានបម្រុងទុកតាំងពីមុនសម្រាប់យើង ដូច្នេះ យើងនឹងប្រព្រឹត្តតាម។
[11]ដូច្នេះ ចូរចាំថា កាលពីដើមបងប្អូននៅជាសាសន៍ដទៃក្នុងលោកីយ៍នៅឡើយ គេហៅបងប្អូនថា «ពួកមិនកាត់ស្បែក» ហើយពួកសាសន៍យូដាហៅខ្លួនថា
«ពួកកាត់ស្បែក» គ្រាន់តែជាសញ្ញាសម្គាល់មួយ ធ្វើដោយដៃមនុស្សប៉ុណ្ណោះ។[12]កាលនោះ បងប្អូននៅដាច់ឆ្ងាយពីព្រះគ្រិស្ត។
ប្រជារាស្ត្រអ៊ីស្រាអែលចាត់ទុកបងប្អូនជាជនបរទេស។ បងប្អូនជាសាសន៍ដទៃគ្មានទំនាក់ទំនងអ្វីនឹងសម្ពន្ធមេត្រី តាមព្រះបន្ទូលសន្យាឡើយ។
បងប្អូនគ្មានសង្ឃឹមចំពោះអនាគតខ្លួនឯង។ បងប្អូនរស់នៅក្នុងពិភពលោកនេះ ដោយគ្មានព្រះជាម្ចាស់។
[13]ប៉ុន្តែ ឥឡូវនេះដោយសារព្រះគ្រិស្តយេស៊ូ បងប្អូនដែលធ្លាប់នៅឆ្ងាយពីព្រះជាម្ចាស់ បានចូលមកជិតព្រះជាម្ចាស់ហើយ តាមរយៈព្រះលោហិតរបស់ព្រះគ្រិស្ត។[14]ដ្បិត
ព្រះអង្គជាសេចក្តីសុខសាន្តរបស់យើង។ ព្រះអង្គបានបង្រួបបង្រួមសាសន៍ទាំងពីរ ឲ្យរួមគ្នាមកតែមួយ។ ដោយសារព្រះកាយព្រះគ្រិស្ត ព្រះអង្គបានរំលំជញ្ជាំងដែលបំបាក់
បំបែកយើង ជាសត្រូវនឹងគ្នា។[15]ដូច្នេះ ព្រះអង្គបានលុបបំបាត់ក្រឹត្យវិន័យដែលមានបទបញ្ជា និងក្បួនតម្រាផ្សេងៗចោល ដើម្បីបង្រួបបង្រួមសាសន៍ទាំងពីរ
ជាមនុស្សថ្មីមួយក្នុងព្រះអង្គ ព្រមទាំងនាំសន្តិភាពមកផងដែរ។[16]ព្រះគ្រិស្តបានផ្សះផ្សាសាសន៍ទាំងពីរ ទៅក្នុងរូបកាយតែមួយរបស់ព្រះជាម្ចាស់ តាមរយៈឈើឆ្កាង
និងកំចាត់ការស្អប់គ្នាចោល។
[17]ព្រះយេស៊ូបានយាងមកប្រកាសសន្តិភាពជាមួយបងប្អូន ដែលធ្លាប់នៅឆ្ងាយ ព្រមទាំងប្រកាសសន្តិភាពជាមួយអ្នកដែលនៅជិត។[18]តាមរយៈព្រះយេស៊ូនេះហើយ យើង
ជាសាសន៍ទាំងពីរអាចចូលទៅរកព្រះបិតា ដោយរួមក្នុងព្រះវិញ្ញាណតែមួយ។
[19]ដូច្នេះ ឥឡូវនេះ បងប្អូនដែលជាសាសន៍ដទៃ លែងជាជនបរទេសទៀតហើយ។ ផ្ទុយទៅវិញ បងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធរបស់ព្រះជាម្ចាស់
និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់ផងដែរ។[20]បងប្អូនបានសង់សំណង់លើគ្រឹះយ៉ាងរឹងមាំរបស់ពួកសាវក និងព្យាការី ព្រមទាំងព្រះគ្រិស្តយេស៊ូផ្ទាល់ ដែលជាថ្មដ៏រឹងមាំ។
[21]ដោយសារព្រះអង្គ សំណង់ទាំងមូលបានសង់យ៉ាងរឹងមាំភ្ជាប់គ្នា និងចម្រើនឡើងទៅជាព្រះវិហារថ្វាយព្រះអម្ចាស់។[22]ដោយសារព្រះអង្គហើយ
ដែលបងប្អូនបានផ្គុំគ្នាឡើងជាព្រះដំណាក់ថ្វាយព្រះជាម្ចាស់ ក្នុងវិញ្ញាណ។

Ephesians 2:1
ប្រយោគភ្ជាប់:
លោកប៉ូលរម្លឹកអ្នកជឿពីអតីតកាលនៃអ្នកជឿ និង
របៀបដែលពួកគេនៅពីមុខព្រះភក្ត្រព្រះជាម្ចាស់។
បងប្អូនបានស្លាប់នៅក្នុងអំពើរំលង
ពាក្យថា «រំលង» និង «អំពើបាប» បានអត្ថន័យស្រដៀងគ្នា។
លោកប៉ូលប្រើពួកគេជាមួយគ្នាដើម្បីផ្តោតទៅលើអំពើបាបដ៏ធំរបស់មនុស្ស ។
បងប្អូនបានស្លាប់នៅក្នុងអំពើរំលង និងអំពើបាបរួចទៅហើយ។
នេះគឺបង្ហាញរបៀបមនុស្សមានបាបគឺមិនអាចគោរពព្រះជាម្ចាស់នៅក្នុងរបៀបដូចគ្នាមនុស្សម្នាក់គឺមិនអាចស្តាប់បង្គាប់ ឬ
នៅតាមរបៀបលោកីយ៍
សាវកបានប្រើ «លោកីយ៍» ដើម្បីសំដៅទៅលើអាកប្បកិរិយា និង
គុណតម្លៃពុករលួយនៃការរស់នៅតាមលោកីយ៍ ។ សូមមើលការបកប្រែផ្សេងទៀត:
«ទៅតាមគុណតម្លៃរបស់មនុស្សនៅក្នុងលោកីយ៍» ឬ
«តាមគោលការណ៍នៃលោកកីយ៍បច្ចុប្បន្ន»
បងប្អូនរស់នៅតាមមេគ្រប់គ្រងអំណាចលើអាកាស
នេះសំដៅទៅលើវិញ្ញាណអាក្រក់ឬសាតាំង។
គឺជាវិញ្ញាណដែលមានឥទ្ធិពល

«គឺវិញ្ញាណរបស់សាតាំង ដែលកំពុងធ្វើការ»
បណ្តោយខ្លួនតាមតណ្ហាលោភលន់នៃនិស្ស័យបណ្តោយខ្លួនតាមតណ្ហាលោភលន់នៃនិស្ស័យលោកីយ៍
និងប្រព្រឹត្តអំពើផ្សេងៗតាមចិត្តគំនិតលោកីយ៍
ពាក្យថា «រាងកាយ» និង «គំនិត» តំណាងឲ្យមនុស្សទាំងមូល។
មនុស្សត្រូវបណ្តាសា
មនុស្សដែលព្រះជាម្ចាស់ក្រោធ
Ephesians 2:4
ព្រះជាម្ចាស់ពេញដោយព្រះទ័យមេត្តាច្រើនពន់ប្រមាណ
[illegible]
«ព្រះជាម្ចាស់សប្បុរសខ្លាំងណាស់ចំពោះយើង»
ព្រោះព្រះអង្គស្រឡាញ់យើងយ៉ាងខ្លាំងបំផុត។
«ដោយសារសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់ចំពោះយើង» ឬ
«ពីព្រោះព្រះអង្គស្រឡាញ់យើងខ្លាំងណាស់»
កាលយើងស្លាប់ក្នុងអំពើរំលងនៅឡើយ ព្រះអង្គប្រោសយើងឲ្យរស់រួមជាមួយព្រះគ្រិស្ត
នេះជាការបង្ហាញរបៀបដែលមនុស្សមានបាបគឺមិនអាចស្តាប់បង្គាប់ព្រះជាម្ចាស់
រហូត
ព្រះអង្គបានផ្តល់ជីវិតថ្មីខាងវិញ្ញាណដូចជាមនុស្សស្លាប់គឺមិនអាចឆ្លើយតមខាងរាងកាយបានទេរហូតទាល់

generated on Wed Sep 10 16:16:32 2025

ព្រះអង្គប្រោសយើងឲ្យរស់រួមជាមួយព្រះគ្រិស្ត
«នៅក្នុងព្រះគ្រិស្ត»
និងការបង្ហាញដូចគ្នាគឺជាការប្រៀបធៀបដែលញឹកញាប់កើតឡើងនៅក្នុងសំបុត្រសញ្ញាថ្មី
ពួកគេបង្ហាញទំនាក់ទំនងដ៏រឹងមាំដែលកើតមានរវាងព្រះគ្រិស្តនិងដល់អស់អ្នកណាដែលជឿលើទ្រង់
ព្រះជាម្ចាស់ប្រោសឲ្យបងប្អូនរស់ឡើងវិញ រួមជាមួយព្រះគ្រិស្តយេស៊ូ
ព្រមទាំងឲ្យយើងអង្គុយនៅស្ថានបរមសុខ រួមជាមួយព្រះអង្គដែរ។
ដូចជាព្រះអង្គបានប្រោសព្រះយេស៊ូគ្រិស្តឲ្យរស់ឡើងវិញ
ហើយព្រះអង្គនឹងប្រោសយើងឲ្យរស់ឡើងវិញដែរ
ហើយយើងនឹងនៅជាមួយព្រះគ្រិស្តនៅនគរស្ថានសួគ៌។
ព្រះជាម្ចាស់បានសង្គ្រោះបងប្អូនដោយសារព្រះគុ ុណ។
នេះអាចថ្លែងនៅក្នុងទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់
បានសង្គ្រោះយើងដោយសារព្រះហឫទ័យដ៏អស្ចារ្យចំពោះយើង»
អង្គុយនៅស្ថានបរមសុខ
«ការលើសពីធម្មជាតិនៅក្នុងពិភពលោក» ពាក្យថា «ស្ថានបរមសុខ»
គឺសំដៅទៅលើកន្លែងដែលព្រះជាម្ចាស់គង់នៅសូមមើលរបៀបបកប្រែនៅក្នុង១:៣។
នៅជាន់ក្រោយនេះ
«នៅក្នុងអនាគត»
Ephesians 2:8
ព្រះជាម្ចាស់បានសង្គ្រោះបងប្អូនដោយសារព្រះគុណ តាមរយៈជំនឿ
សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ដល់យើងគឺជាហេតុផលព្រះអង្គបានបង្កើតវាអាចកត
ប្រសិនបើយើង ប្រសិនបើយើងគ្រាន់តែជឿតែទុកចិត្តព្រះយេស៊ូ។
សូមមើលការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់បានសង្គ្រោះបងប្អូនតាមរយៈព្រះគុណដោយសារជំនឿនៅក្នុងព្រះអង្គ»
ហើយការសង្គ្រោះពុំមែន
ពាក្យថា «នេះ» គឺសំដៅទៅលើ
«តាមរយៈព្រះគុណដែលបងប្អូនបានសង្គ្រោះតាមរយៈជំនឿ»។
ពុំមែនមកពីមនុស្សខំប្រព្រឹត្តទេ
«នេះគឺការសង្គ្រោះមិនមែនបានមកដោយសារការល្អដែលបងប្អូនបានធ្វើ»
ក្នុងព្រះគ្រិស្តយេស៊ូ
«ក្នុងព្រះគ្រិស្តយេស៊ូ»
ហើយការបង្ហាញដូចគ្នាគឺជាការប្រៀបធៀបដែលញឹកញាប់កើតឡើងនៅក្នុងព្រះសញ្ញាថ្មី
ពួកគេបង្ហាញទំនាក់ទំនងដ៏រឹងមាំរវាងព្រះគ្រិស្ត និង
ដល់អស់អ្នកដែលជឿនៅក្នុងព្រះអង្គ។
ប្រព្រឹត្តតាម
«ដើរតាម» ឬ «ធ្វើ» (UDB)
Ephesians 2:11
ប្រយោគភ្ជាប់:
លោកប៉ូលរម្លឹកដល់អ្នកជឿទាំងអស់ថាឥឡូវព្រះជាម្ចាស់បានធ្វើឲ្យសាសន៍យូដានិង
សាសន៍ដទៃទៅជារូបកាយតែមួយតាមរយៈព្រះគ្រិស្តនិងឈើឆ្កាងរបស់ទ្រង់។
សាសន៍ដទៃក្នុងលោកីយ៍
នេះគឺសំដៅទៅលើមនុស្សដែលដែលមិនបានកើតនៅក្នុងសាសន៍យូដា។
ពួកមិនកាត់ស្បែក
អ្នកដែលមិនមែនជាសាសន៍យូដាគឺមិនបានកាត់ស្បែកពីតូចមកទេ
ហេតុដូចច្នេះហើយជនជាតិយូដាចាត់ទុកពួកគេជាមនុស្សដែលមិនដើរតាមក្រឹត្យវិន័យ
ការបកប្រែផ្សេងទៀត: «សាសន៍ដទៃដែលមិនកាត់ស្បែក»
ពួកកាត់ស្បែក
នេះគឺជាពាក្យផ្សេងទៀតសម្រាប់សាសន៍យូដាពីព្រោះក្មេងប្រុសទាំងអស់គឺត្រូវបានកាត
ការបកប្រែផ្សេងទៀត: «មនុស្សបានកាត់ស្បែក»
បងប្អូននៅដាច់ឆ្ងាយពីព្រះគ្រិស្ត
«អ្នកមិនជឿ»
ដែលត្រូវបានហៅថា «ការកាត់ស្បែក» នៅក្នុងសាច់ឈាមដែលធ្វើដោយដៃមនុស្ស ។
ទី១ប្រហែលជាមានន័យ) «ជនជាតិយូដាដែលបានកាត់ស្បែកតាមរយៈមនុស្ស»
ឬទី២) «ជនជាតិយូដា ដែលកាត់ស្បែកផ្នែករាងកាយ»
ហើយពួកសាសន៍យូដាហៅខ្លួនថា
នេះអាចថ្លែងនៅក្នុងទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត:
«តាមរយៈអ្វីដែលមនុស្សហៅ" ឬ «តាមរយៈអស់អ្នកណាដែលបានហៅ»
ជាសាសន៍ដទៃគ្មានទំនាក់ទំនងអ្វីនឹងសម្ពន្ធមេត្រី តាមព្រះបន្ទូលសន្យាឡើយ។
លោកប៉ូលនិយាយទៅកាន់អ្នកជឿសាសន៍ដទៃ ដូចជាពួកគេជាបរទេស
មិនបានរក្សាការតាំងសញ្ញារបស់ព្រះជាម្ចាស់ និង ព្រះបន្ទូលសន្យា។

Ephesians 2:13
ប៉ុន្តែ ឥឡូវនេះដោយសារព្រះគ្រិស្តយេស៊ូ
លោកប៉ូលកំពុងសម្គាល់ភាពផ្ទុយគ្នារវាងពួកអេភេសូរមុនពេលពួកគេជឿលើព្រះគ្រិស្តនិងបន្ទាប់ពីពួកគេ
ឆ្ងាយនៅឆ្ងាយពីព្រះជាម្ចាស់ បានចូលមកជិតព្រះជាម្ចាស់ហើយ
តាមរយៈព្រះលោហិតរបស់ព្រះគ្រិស្ត។
ដោយសារតែអំពើបាបរបស់អ្នកជឿពួកគេបានបែកចេញពីព្រះជាម្ចាស់។
ប៉ុន្តែឥឡូវនេះព្រះយេស៊ូបាននាំពួកគេចូលទៅជិតព្រះជាម្ចាស់ដោយសារព្រះលោហិតរបស់ទ្រង់។
សូមមើលការបកប្រែផ្សេងទៀត:
តាមរយៈព្រះលោហិតរបស់ព្រះគ្រិស្ត
ព្រះលោហិតរបស់ព្រះគ្រិស្តគឺជាពាក្យប្រៀបធៀបសម្រាប់ការសុគតរបស់ទ្រង់។
សូមមើលការបកប្រែផ្សេងទៀត: «ដោយការសុគតរបស់ព្រះគ្រិស្ត» ឬ
«នៅពេលដែលព្រះគ្រិស្តបានសុគតជំនួសយើង»
ព្រះអង្គជាសេចក្តីសុខសាន្តរបស់យើង
«ព្រះយេស៊ូផ្តល់ឱ្យយើងនូវសន្តិភាពរបស់ទ្រង់»
ព្រះអង្គបានបង្រួបបង្រួមសាសន៍ទាំងពីរ ឲ្យរួមគ្នាមកតែមួយ។
«ព្រះអង្គបានធ្វើអោយជនជាតិយូដានិងសាសន៍ដទៃក្លាយជាតែមួយ»
ដោយសារព្រះកាយព្រះគ្រិស្ត
«ដោយសារការសោយទិវង្គតនៃព្រះកាយរបស់ព្រះអង្គនៅលើឈើឆ្កាង»
ជញ្ជាំងដែលបំបាក់បំបែក
«ច្បាប់នៃបទបញ្ជាដែលមានក្នុងក្រឹត្យវិន័យ
ជាសត្រូវនឹងគ្នា
ពាក្យថា «យើង» សំដៅទៅលើលោកប៉ូលនិងអេភេសូរ។
សាសន៍ដទៃត្រូវបានបំបែកចេញពីសាសន៍យូដា។ សូមមើលការបកប្រែផ្សេងទៀត:
«ដែលបំបែកយើងពួកយូដានិងពួកសាសន៍ដទៃចេញពីគ្នា»
ព្រះអង្គបានលុបបំបាត់ក្រឹត្យវិន័យដែលមានបទបញ្ជា និងក្បួនតម្រាផ្សេងៗចោល
ព្រះលោហិតរបស់ព្រះយេស៊ូបានបំពេញតាមក្រឹត្យវិន័យរបស់លោកម៉ូសេដើម្បីអោយជនជាតិយូដានិងស
មនុស្សថ្មីមួយ
ជាមនុស្សថ្មីតែមួយ ប្រជាជនដែលបានប្រោសលោះ
ក្នុងព្រះអង្គ
វាគឺជាការរួបរួមគ្នាជាមួយព្រះគ្រិស្តដែលធ្វើឱ្យមានការផ្សះផ្សាគ្នារវាងជនជាតិយូដានិងសាសន៍ដទៃ។
ព្រះគ្រិស្តបានផ្សះផ្សាសាសន៍ទាំងពីរ
«ព្រះគ្រិស្តនាំជនជាតិយូដានិងសាសន៍ដទៃមកជុំគ្នាដោយសុខសាន្ត»
តាមរយៈឈើឆ្កាង
ឈើឆ្កាងនៅទីនេះតំណាងឱ្យការសុគតរបស់ព្រះគ្រិស្តនៅលើឈើឆ្កាង។
សូមមើលការបកប្រែផ្សេងទៀត:
«តាមរយៈការសុគតរបស់ព្រះគ្រិស្តនៅលើឈើឆ្កាង»
កំចាត់ការស្អប់គ្នាចោល
ការបញ្ឈប់ភាពជាសត្រូវរបស់ពួកគេត្រូវបានគេនិយាយដូចជាគាត់បានសម្លាប់ភាពជាសត្រូវរបស់ពួកគេ។
តាមរយៈការសុគតនៅលើឈើឆ្កាងព្រះយេស៊ូបានលុបបំបាត់ហេតុផលដែលជនជាតិយូដានិងសាសន៍ដទៃ
ឥឡូវក៏មិនចាំបាច់រស់នៅស្របតាមច្បាប់របស់លោកម៉ូសេដែរ។
សូមមើលការបកប្រែផ្សេងទៀត: «បញ្ឈប់ពួកគេពីការស្អប់គ្នាទៅវិញទៅមក»
Ephesians 2:17
ប្រយោគភ្ជាប់:
ពាក្យថា «ទាំងពីរ» សំដៅទៅលើជនជាតិយូដាដែលជឿហើយនិងអ្នកដែលមិនមែនជាជនជាតិយូដា។
ដោយរួមក្នុងព្រះវិញ្ញាណតែមួយ
អ្នកជឿទាំងអស់ទាំងសាសន៍យូដានិងសាសន៍ដទៃត្រូវបានផ្តល់សិទ្ធិឱ្យចូលទៅក្នុងវត្តមានរបស់ព្រះបិតា
Ephesians 2:19
បងប្អូនដែលជាសាសន៍ដទៃ... ក្រុមគ្រួសាររបស់ព្រះជាម្ចាស់
លោកប៉ូលកំពុងនិយាយម្តងទៀតអំពីស្ថានភាពខាងវិញ្ញាណរបស់សាសន៍ដទៃបន្ទាប់ពីពួកគេបានក្លាយជា

generated on Wed Sep 10 16:16:32 2025

បងប្អូនបានសង់សំណង់លើគ្រឹះយ៉ាងរឹងមាំរបស់ពួកសាវក
លោកប៉ូលនិយាយអំពីប្រភាស្ត្ររបស់ព្រះជាម្ចាស់ដូចជាពួកគេកំពុងសាងសង់។
ព្រះគ្រិស្តគឺជាថ្មដ៏រឹងមាំ សាវកគឺជាគ្រឹះហើយអ្នកជឿគឺជារចនាសម្ព័ន្ធ។
បងប្អូនបានសង់សំណង់
នេះអាចត្រូវបានបញ្ជាក់នៅក្នុងសកម្មភាពតានតឹង។
សូមមើលការបកប្រែផ្សេងទៀត: «ព្រះជាម្ចាស់បានកសាងអបងប្អូន»
សំណង់ទាំងមូលបានសង់យ៉ាងរឹងមាំភ្ជាប់គ្នា និងចម្រើនឡើងទៅជាព្រះវិហារ
លោកប៉ូលបន្តនិយាយអំពីក្រុមគ្រួសាររបស់ព្រះគ្រិស្តដូចជាអាគារ។
តាមរបៀបដែលអ្នកសាងសង់ត្រូវដាក់ថ្មជាមួយគ្នាឲ្យត្រូវពេលកំពុងសាងស
ដូច្នេះព្រះគ្រិស្តសមជាមួយយើងទាំងអស់គ្នា។
ដោយសារព្រះអង្គ..ថ្វាយព្រះអម្ចាស់... ដោយសារព្រះអង្គហើយ
«នៅក្នុងព្រះគ្រិស្ត ... នៅក្នុងព្រះអម្ចាស់យេស៊ូ ... នៅក្នុងព្រះគ្រិស្ត»
ការប្រៀបធៀបទាំងនេះបង្ហាញពីទំនាក់ទំនងរឹងមាំបំផុតដែលអាចកើតមានរវាងព្រះគ្រិស្តនិងអ្នកដែលជឿ
ដែលបងប្អូនបានផ្គុំគ្នាឡើងជាព្រះដំណាក់ថ្វាយព្រះជាម្ចាស់ ក្នុងវិញ្ញាណ។
នេះពិពណ៌នាអំពីរបៀបដែលអ្នកជឿត្រូវបានដាក់បញ្ចូលគ្នាឱ្យក្លាយជាកន្លែងដែលព្រះជាម្ចាស់នឹងរស់នៅ
ដែលបងប្អូនបានផ្គុំគ្នាឡើងជាព្រះដំណាក់
នេះអាចថ្លែងជាទម្រង់សកម្ម។សូមមើលការបកប្រែផ្សេងទៀត:
«ព្រះជាម្ចាស់ក៏កំពុងកសាងបងប្អូនជាមួយគ្នាទាំងអស់»

---

3 [1]ដោយហេតុនេះ បានជាប៉ូលខ្ញុំជាប់ឃុំឃាំង ព្រោះតែព្រះគ្រិស្តយេស៊ូ សម្រាប់សាសន៍ដទៃ។
[2]បងប្អូនប្រហែលជាបានឮគេនិយាយពីការកាន់កាប់ធនធាននៃព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានប្រទានមកឲ្យខ្ញុំដោយផ្ទាល់។
[3]ខ្ញុំកំពុងតែសរសេរអំពីការបើកសម្តែង ដែលព្រះអង្គប្រទានឲ្យខ្ញុំ។ នេះជាសេចក្តីពិតដ៏លាក់កំបាំងរបស់ព្រះគ្រិស្ត ដែលខ្ញុំចង់ជម្រាបប្រាប់បងប្អូនទាំងអស់គ្នា ឲ្យបានដឹង។
[4]កាលណាបងប្អូនបានអានសំបុត្រនេះ បងប្អូនមុខជាអាចស្វែងយល់អំពីគម្រោងការលាក់កំបាំងនៃេសេចក្តីពិតស្តីអំពីព្រះគ្រិស្ត។[5]កាលពីដើម
ព្រះជាម្ចាស់ពុំបានបើកសម្តែងសេចក្តីពិតនេះ ឲ្យកូនមនុស្សបានយល់ឡើយ។ ក៏ប៉ុន្តែនៅបច្ចុប្បន្ននេះ ព្រះជាម្ចាស់បានបើកសម្តែងឲ្យក្រុមសាវក និងព្យាការី
ដែលព្រះអង្គត្រាស់ហៅឲ្យបំពេញមុខងារនេះ តាមរយៈព្រះវិញ្ញាណព្រះអង្គ។
[6]សេចក្តីពិតដែលលាក់កំបាំងនេះគឺថា សាសន៍ដទៃក៏ត្រូវទទួលមរតករួមជាមួយសាសន៍អ៊ីស្រាអែល និងជាសមាជិកក្នុងព្រះកាយតែមួយ
ព្រមទាំងទទួលព្រះបន្ទូលសន្យាក្នុងព្រះគ្រិស្តយេស៊ូ តាមរយៈដំណឹងល្អ។[7]ដ្បិត ខ្ញុំទទួលមុខងារបម្រើដំណឹងល្អនេះ តាមអំណោយទាននៃព្រះគុណរបស់ព្រះជាម្ចាស់
ដែលបានប្រទានមកខ្ញុំ តាមរយៈឫទ្ធានុភាពដ៏ខ្លាំងក្លារបស់ព្រះអង្គ។
[8]ព្រះជាម្ចាស់ប្រទានអំណោយទាននេះមកឲ្យខ្ញុំ ទោះបីខ្ញុំមានឋានៈតូចជាងគេក្នុងចំណោមប្រជាជនដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ក៏ដោយ។ អំណោយទាននេះ
នាំខ្ញុំឲ្យប្រកាសដំណឹងល្អ នៃភាពសំបូរបែបរបស់ព្រះគ្រិស្ត ដែលមនុស្សទូទៅមិននឹកស្មានដល់ ទៅកាន់សាសន៍ដទៃ។[9]ព្រះជាម្ចាស់ប្រទានអំណោយទានឲ្យខ្ញុំ
បំភ្លឺដល់មនុស្សគ្រប់គ្នា ស្គាល់គម្រោងការរបស់ព្រះជាម្ចាស់។ គម្រោងការនេះបានលាក់ទុកតាំងពីដើមរៀងមក ពេលព្រះជាម្ចាស់បង្កើតរបស់សព្វសារពើ។
[10]ព្រះជាម្ចាស់បើកសម្តែងគម្រោងការនេះតាមរយៈក្រុមជំនុំព្រះអង្គ ដូច្នេះ ពួកមេគ្រប់គ្រង និងត្រួតត្រានៅស្ថានលើ នឹងស្គាល់ព្រះប្រាជ្ញាញាណគ្រប់វិស័យរបស់
ព្រះជាម្ចាស់។[11]ហេតុការណ៍នេះកើតមានឡើង ស្របតាមគម្រោងការដ៏នៅអស់កល្បជានិច្ច ដែលបានសម្រេចក្នុងព្រះគ្រិស្តយេស៊ូ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។
[12]ដ្បិត នៅក្នុងព្រះគ្រិស្ត យើងមានចិត្តរឹងប៉ឹង និងមានផ្លូវចូលទៅកាន់ព្រះជាម្ចាស់ទាំងទុកចិត្ត តាមរយៈជំនឿលើព្រះអង្គ។[13]ហេតុដូច្នេះហើយ សូមបងប្អូនកុំបាក់ទឹកចិត្ត
ព្រោះខ្ញុំបានរងទុក្ខវេទនា ជាប្រយោជន៍ដល់បងប្អូន ហើយទុក្ខវេទនានោះជាសិរីរុងរឿងរបស់បងប្អូនវិញទេតើ។
[14]ហេតុដូច្នេះហើយបានខ្ញុំក្រាបថ្វាយបង្គំព្រះបិតា[15]ដ្បិត ទ្រង់ជាប្រភពនៃក្រុមគ្រួសារទាំងអស់ ទាំងនៅស្ថានបរមសុខ និងផែនដី។[16]ខ្ញុំអធិស្ឋាន
សូមព្រះអង្គប្រទានឲ្យបងប្អូនមានកម្លាំងមាំមួន តាមរយៈព្រះវិញ្ញាណគង់នៅក្នុងបងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ។
[17]ខ្ញុំអធិស្ឋាន សូមឲ្យព្រះគ្រិស្តគង់នៅក្នុងចិត្តបងប្អូនតាមរយៈជំនឿ និងឲ្យបងប្អូនបានចាក់ឫសយ៉ាងមាំមួនក្នុងក្តីស្រឡាញ់ព្រះអង្គ។
[18]សូមបងប្អូនមានសមត្ថភាពអាចស្វែងយល់ រួមជាមួយអ្នកជឿទាំងអស់ នូវទទឹង បណ្តោយ ជម្រៅ និងកម្ពស់[19]និងឲ្យបងប្អូនស្គាល់ក្តីស្រឡាញ់របស់ព្រះគ្រិស្ត ដែល
ប្រសើរហួសពីការយល់ដឹងរបស់មនុស្ស ដើម្បីឲ្យបងប្អូនពេញដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។
[20]ឥឡូវនេះ ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់ ហួសពីការសុំ និងនឹកស្មានដល់ ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ដែលបំពេញសកម្មភាពនៅក្នុងយើង។[21]សូមលើកតម្កើង
សិរីរុងរឿងព្រះអង្គក្នុងក្រុមជំនុំ និងក្នុងព្រះគ្រិស្តយេស៊ូ នៅគ្រប់ជំនាន់អស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន។

Ephesians 3:1
ប្រយោគភ្ជាប់:
ដើម្បីធ្វើឱ្យសេចក្តីពិតលាក់កំបាំងអំពីក្រុមជំនុំដល់ពួកអ្នកជឿលោកប៉ូលនិយាយសំដៅទៅលើ
ដោយហេតុនេះ
«ដោយសារព្រះគុណរបស់ព្រះជាម្ចាស់ចំពោះអ្នក»
បជាប់ឃុំឃាំង ព្រោះតែព្រះគ្រិស្តយេស៊ូ
«អ្នកដែលព្រះយេស៊ូគ្រិស្តបានដាក់គុក»
ការកាន់កាប់ធនធាននៃព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានប្រទានមកឲ្យខ្ញុំដោយផ្ទាល់
«ទំនួលខុសត្រូវដែលព្រះជាម្ចាស់បានប្រគល់ខ្ញុំឱ្យនាំព្រះគុណរបស់ព្រះអង្គមកអ្នក»
Ephesians 3:3
អំពីការបើកសម្តែង ដែលព្រះអង្គប្រទានឲ្យខ្ញុំ។
នេះអាចថ្លែងជាទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត:
«នេះបើយោងតាមអ្វីដែលព្រះជាម្ចាស់បានបង្ហាញដល់ខ្ញុំ»
ដែលខ្ញុំចង់ជម្រាបប្រាប់បងប្អូនទាំងអស់គ្នា ឲ្យបានដឹង។
លោកប៉ូលសំដៅទៅលើសំបុត្រមួយទៀតដែលគាត់បានសរសេរទៅកាន់ប្រជាជនទាំងនេះ
កាលពីដើម ព្រះជាម្ចាស់ពុំបានបើកសម្តែងសេចក្តីពិតនេះ ឲ្យកូនមនុស្សបានយល់ឡើយ
នេះអាចថ្លែងជាទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត:
«កាលពីមុនព្រះជាម្ចាស់មិនបានធ្វើឱ្យមនុស្សដឹងរឿងទាំងនេះទេ»
ក៏ប៉ុន្តែនៅបច្ចុប្បន្ននេះ ព្រះជាម្ចាស់បានបើកសម្តែង
នេះអាចថ្លែងជាទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត:
«ប៉ុន្តែឥឡូវនេះព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហាញ» ឬ
«ប៉ុន្តែឥឡូវនេះព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើឱ្យដឹង»
ឲ្យក្រុមសាវក និងព្យាការី ដែលព្រះអង្គត្រាស់ហៅឲ្យបំពេញមុខងារនេះ
តាមរយៈព្រះវិញ្ញាណព្រះអង្គ។
«ពួកសាវកនិងពួកព្យាការីដែលព្រះជាម្ចាស់បានញែកចេញដើម្បីធ្វើកិច្ចការនេះ»
Ephesians 3:6
នេះគឺជាសេចក្តីលាក់កំបាំងដែលលោកប៉ូលបានចាប់ផ្តើមពន្យល់នៅក្នុងខមុន។
សាសន៍ដទៃដែលបានទទួលព្រះគ្រិស្តក៏ទទួលបានដូចគ្នានឹងអ្នកជឿជនជាតិយូដាដែរ។
រួមជាមួយសាសន៍អ៊ីស្រាអែល និងជាសមាជិកក្នុងព្រះកាយតែមួយ
ក្រុមជំនុំជារឿយៗត្រូវបានគេហៅថារូបកាយរបស់ព្រះគ្រិស្ត។
ក្នុងព្រះគ្រិស្តយេស៊ូ
«នៅក្នុងព្រះគ្រិស្តយេស៊ូ»
និងការបង្ហាញដូចគ្នាគឺជាពាក្យប្រៀបធៀបដែលកើតឡើងជាញឹកញាប់នៅក្នុងសញ្ញាថ្មី។
ពួកគេបង្ហាញពីទំនាក់ទំនងរឹងមាំបំផុតដែលអាចកើតមានរវាងព្រះគ្រិស្តនិងអ្នកដែលជឿលើព្រះអង្គ។
តាមរយៈដំណឹងល្អ
ទី១អត្ថន័យប្រហែលជា)
ដោយសារដំណឹងល្អពួកសាសន៍ដទៃគឺជាអ្នករួមចំណែកក្នុងព្រះបន្ទូលសន្យាឬ
នេះ)
ដោយសារដំណឹងល្អពួកសាសន៍ដទៃជាអ្នករួមបំណែកទទួលមរតកនិងជាសមាជិកនៃរូបកាយនិងជាអ្នករួ
Ephesians 3:8
ប្រជាជនដ៏វិសុទ្ធរបស់ព្រះជាម្ចាស់
«អ្នកដែលព្រះជាម្ចាស់បានញែកចេញសម្រាប់អង្គទ្រង់ផ្ទាល់»
ដែលមនុស្សទូទៅមិននឹកស្មានដល់
មិនអាចត្រូវបានស្គាល់ទាំងស្រុង
ភាពសំបូរបែបរបស់ព្រះគ្រិស្ត
លោកប៉ូលនិយាយសេចក្តីពិតអំពីព្រះគ្រិស្តនិងព្រះពរដែលគាត់នាំមកដូចពួកគេជាទ្រព្យសម្បត្តិ។
បំភ្លឺដល់មនុស្សគ្រប់គ្នា ស្គាល់គម្រោងការរបស់ព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

ការផ្តល់ពន្លឺដល់មនុស្សតំណាងឱ្យការបង្រៀនពួកគេ។
សូមមើលការបកប្រែផ្សេងទៀត:
«ចាំងពន្លឺលើផែនការអាថ៌កំបាំងរបស់ព្រះជាម្ចាស់ដើម្បីឱ្យមនុស្សទាំងអស់ដឹងថាវាជាអ្វី» ឬ
ឬ «បង្រៀនមនុស្សទាំងអស់នូវផែនការអាថ៌កំបាំងរបស់ព្រះជាម្ចាស់»
គម្រោងការនេះបានលាក់ទុកតាំងពីដើមរៀងមក ពេលព្រះជាម្ចាស់បង្កើតរបស់សព្វសារពើ។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។
«ព្រះជាម្ចាស់ដែលបានបង្កើតអ្វីៗទាំងអស់បានរក្សាផែនការនេះឱ្យអាថ៌កំបាំងអស់រយៈពេលជាច្រើនសតវត្សរ៍»
Ephesians 3:10
ពួកមេគ្រប់គ្រង និងត្រួតត្រានៅស្ថានលើ នឹងស្គាល់ព្រះប្រាជ្ញាញាណគ្រប់វិស័យរបស់ព្រះជាម្ចាស់។
ផ្នែកធម្មជាតិនៃប្រាជ្ញារបស់ព្រះជាម្ចាស់ -
«ព្រះជាម្ចាស់នឹងធ្វើឱ្យមានប្រាជ្ញាដ៏អស្ចារ្យរបស់ទ្រង់តដើម្បីឲ្យគេបានស្គាល់ដល់មេគ្រប់គ្រងនិងអ្នកត្រួតត្រានៅស្ថានបរមសុខ»
ពួកមេគ្រប់គ្រង និងត្រួតត្រានៅស្ថានលើ
ពាក្យទាំងនេះមានអត្ថន័យស្រដៀងគ្នា។
លោកប៉ូលប្រើពួកគេរួមគ្នាដើម្បីបញ្ជាក់ថារាល់មនុស្សខាងវិញ្ញាណនឹងស្គាល់ប្រាជ្ញារបស់ព្រះជាម្ចាស់
នៅស្ថានលើ
«ការលើសពីធម្មជាតិនៅក្នុងពិភពលោក ពាក្យ «ស្ថានបរមសុខ»
សំដៅទៅលើកន្លែងដែលព្រះជាម្ចាស់គង់នៅ។
សូមមើលពីរបៀបដែលការបកប្រែនេះត្រូវបានបកប្រែនៅក្នុង ១: ៣ ។
នឹងស្គាល់ព្រះប្រាជ្ញាញាណគ្រប់វិស័យរបស់ព្រះជាម្ចាស់។
ផ្នែកធម្មជាតិនៃប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ -
ប្រាជ្ញាដ៏ស្មុគស្មាញរបស់ព្រះជាម្ចាស់
ស្របតាមគម្រោងការដ៏នៅអស់កល្បជានិច្ច
«នៅក្នុងការរក្សាផែនការអស់កល្បជានិច្ច» ឬ
«ស្របទៅនឹងផែនការអស់កល្បជានិច្ច»
Ephesians 3:12
ប្រយោគភ្ជាប់:
លោកប៉ូលសរសើរព្រះជាម្ចាស់នៅក្នុងការរងទុក្ខហើយអធិស្ឋានសម្រាប់អ្នកជឿនៅអេភេសូរ
យើងមានចិត្តរឹងប៉ឹង
«យើងគ្មានការភ័យខ្លាច» ឬ «យើងមានភាពក្លាហាន»
មានផ្លូវចូលទៅកាន់ព្រះជាម្ចាស់ទាំងទុកចិត្ត
« អាចចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ដោយការទុកចិត្ត» ឬ
«សេរីភាពក្នុងការចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ដោយមានទំនុកចិត្ត»
ទុកចិត្ត
« ភាពប្រាកដ» ឬ « ការធានា»
ជាសិរីរុងរឿងរបស់បងប្អូនវិញទេតើ
នៅទីនេះ
«សិរីរុងរឿងរបស់បងប្អូន»គឺជាពាក្យប្រើសម្រាប់មោទនភាពដែលពួកគេគួរតែមាន
គ្រិស្តបរិស័ទនៅក្រុងអេភេសូរគួរមានមោទនភាពចំពោះអ្វីដែលលោកប៉ូលកំពុងរងទុក្ខ
សូមមើលការបកប្រែផ្សេងទៀត: «នេះគឺដើម្បីផលប្រយោជន៍របស់បងប្អូន» ឬ
«អ្នកគួរតែមានមោទនភាពចំពោះរឿងនេះ»
Ephesians 3:14
ហេតុដូច្នេះហើយ
«ពីព្រោះព្រះជាម្ចាស់បានធ្វើអ្វីទាំងអស់សម្រាប់បងប្អូន»
ខ្ញុំក្រាបថ្វាយបង្គំព្រះបិតា
លុតជង្គង់គឺជារូបភាពរបស់មនុស្សទាំងមូលនៅក្នុងឥរិយាបថនៃការអធិស្ឋាន។
សូមមើលការបកប្រែផ្សេងទៀត:«ខ្ញុំក្រាបបង្គំអធិស្ឋានដល់ព្រះបិតា» ឬ
ខ្ញុំអធិស្ឋានដោយរាបសារដល់ព្រះបិតា
ដ្បិត ទ្រង់ជាប្រភពនៃក្រុមគ្រួសារទាំងអស់ ទាំងនៅស្ថានបរមសុខ និងផែនដី។
សកម្មភាពនៃការដាក់ឈ្មោះនៅទីនេះប្រហែលជាតំណាងឱ្យសកម្មភាពនៃការបង្កើតផងដែរ
សូមមើលការបកប្រែផ្សេងទៀត:
«ដែលបានបង្កើតនិងដាក់ឈ្មោះគ្រួសារទាំងអស់នៅស្ថានបរមសុខនិងនៅលើផែនដី»
សូមព្រះអង្គប្រទានឲ្យបងប្អូនមានកម្លាំងមាំមួន តាមរយៈព្រះវិញ្ញាណគង់នៅក្នុងបងប្អូន
ស្របតាមសិរីរុងរឿង
«ព្រះជាម្ចាស់ពីព្រោះព្រះអង្គអស្ចារ្យណាស់និងពេញដោយអំណាចចេស្តានឹងអនុញ្ញាតឱ្យបងប្អូនក្លាយជាអ្នកខ្លាំងដោយអំណាចចេស្តារបស់ទ្រង់»

---

4 [1]ហេតុដូចនេះ ខ្ញុំជាអ្នកជាប់ឃុំឃាំងព្រោះតែព្រះអម្ចាស់ សូមដាស់តឿនបងប្អូន ឲ្យចេះដើរបែបគួរសមនឹងការត្រាស់ហៅ ដែលព្រះអង្គបានត្រាស់ហៅបងប្អូនមក។
[2]ខ្ញុំដាស់តឿនបងប្អូនឲ្យចេះរស់នៅ ដោយការបន្ទាបខ្លួន ស្លូតបូត និងអត់ធ្មត់ ព្រមទាំងចេះទ្រាំទ្រគ្នាទៅវិញទៅមក ដោយក្តីស្រឡាញ់។
[3]ចូរយកចិត្តទុកដាក់រក្សាឯកភាពមកពីព្រះវិញ្ញាណ ដោយរក្សាចំណងនៃសេចក្តីសុខសាន្ត។

សូមព្រះអង្គប្រទានឲ្យ
«នឹងឲ្យ»
Ephesians 3:17
ប្រយោគភ្ជាប់:
លោកប៉ូលបន្តការអធិស្ឋានពេលគាត់បានចាប់ផ្តើមនៅ ៣:១៤ ។
សូមឲ្យព្រះគ្រិស្តគង់នៅក្នុងចិត្តបងប្អូនតាមរយៈជំនឿ
ដែលជាប្រយោជន៍ដល់យើង
នេះជាប្រធានទីពីរដែលលោកប៉ូលអធិស្ឋានថាព្រះជាម្ចាស់នឹង
«ប្រទានដល់ក្រុមជំនុំអេភេសូរ» ស្របតាមសិរីល្អដ៏លើសលប់បរិបូររបស់ទ្រង់»។
ទីមួយគឺពួកគេនឹងត្រូវបានសម្ថភាព (៣:១៤) ។
ដែលគ្រិស្តនឹងសង់ជាប់
នៅទីនេះ «ចិត្ត»តំណាងអោយផ្នែកខាងក្នុងរបស់មនុស្សម្នាក់ហើយ «តាមរយៈ»
ការបង្ហាញមានន័យថាព្រះគ្រិស្តរស់នៅនៅក្នុងអ្នកជឿ។
ព្រះគ្រិស្តរស់នៅក្នុងដួងចិត្តរបស់អ្នកជឿពីព្រោះព្រះជាម្ចាស់ផ្តល់ព្រះគុណដល់ពួកគេដើម្បីឲ្យមានជំនឿ
ជំនឿ និងឲ្យបងប្អូនបានចាក់ឫសយ៉ាងមាំមួនក្នុងក្តីស្រឡាញ់ព្រះអង្គ។
សូមបងប្អូនមានសមត្ថភាពអាចស្វែងយល់
ទី១អត្ថន័យប្រហែលជា) «ជំនឿ។ ខ្ញុំអធិស្ឋានថា
បងប្អូននឹងចាក់ឫសក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ដើម្បីបងប្អូនអាចយល់បាន» ឬ
២) «ជំនឿដូច្នេះអ្នកនឹងចាក់ឫសនៅក្នុងសេចក្តីស្រឡាញ់របស់ទ្រង់។
ខ្ញុំក៏អធិស្ឋានថាបងប្អូនអាចយល់បាន»
អាចស្វែងយល់
នេះជាប្រធានបទទីពីរដែលប៉ូលលត់ជង្គង់របស់គាត់ហើយអធិស្ឋាន។
ទីមួយគឺថាព្រះជាម្ចាស់នឹងផ្តល់ឱ្យពួកគេនូវសមត្ថភាព (៣:១៤)
ហើយថាព្រះគ្រិស្តអាចរស់នៅក្នុងចិត្តរបស់ពួកគេតាមរយៈជំនឿ (៣:១៤)។ ហើយ
«យល់»
គឺជារឿងដំបូងដែលប៉ូលអធិស្ឋានថាអេភេសូរនឹងមានសមត្ថភាពអាចធ្វើបាន។
ទាំងអស់
«អ្នកជឿទាំងអស់លើព្រះគ្រិស្ត» ឬ «ពួកបរិសុទ្ធទាំងអស់»
នូវទទឹង បណ្តោយ ជម្រៅ និងកម្ពស់
ទី១អត្ថន័យប្រហែលជា)
ពាក្យទាំងនេះពិពណ៌នាអំពីភាពអស្ចារ្យនៃប្រាជ្ញាញាណរបស់ព្រះជាម្ចាស់
សូមមើលការបកប្រែផ្សេងទៀត
«ប្រាជ្ញាញាណរបស់ព្រះជាម្ចាស់អស្ចារ្យខ្លាំងណាស់» ឬ ២)
ពាក្យទាំងនេះពិពណ៌នាអំពីសេចក្តីស្រឡាញ់ដ៏ខ្លាំងរបស់ព្រះគ្រិស្តចំពោះយើង។
សូមមើលការបកប្រែផ្សេងទៀត «តើព្រះគ្រិស្តស្រឡាញ់យើងខ្លាំងប៉ុណ្ណា»
ឲ្យបងប្អូនស្គាល់ក្តីស្រឡាញ់របស់ព្រះគ្រិស្ត
ដើម្បីឲ្យបងប្អូនពេញដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់
នេះជាប្រធានបទទីបីដែលប៉ូលលត់ជង្គង់របស់គាត់ហើយអធិស្ឋាន (៣:១៤)
ទីមួយគឺថាពួកគេនឹងត្រូវមានសមត្ថភាព (៣:១៤)
ហើយទីពីរគឺពួកគេអាចយល់បាន (៣:១៨) ។
Ephesians 3:20
ប្រយោគភ្ជាប់:
លោកប៉ូលបញ្ចប់សេចក្តីអធិដ្ឋានរបស់គាត់ជាមួយការប្រទានលពរ។
ពត៌មានទូទៅ:
ពាក្យ «យើង» និង «របស់យើង»
សំដៅលើបងប្អូនគ្រីស្ទានក្នុងតំណនេះបន្តរួមបញ្ចូលទាំងលោកប៉ូលនិងអ្នកជឿទាំងអស់។
ឥឡូវនេះ ព្រះជាម្ចាស់
«ឥឡូវដល់ព្រះជាម្ចាស់ដែល»
ធ្វើអ្វីៗទាំងអស់ ហួសពីការសុំ
ព្រះជាម្ចាស់អាចធ្វើអ្វីច្រើនជាងអ្វីដែលយើងធ្លាប់សុំឬមានក្តីស្រមៃ។

generated on Wed Sep 10 16:16:32 2025

[4]មានព្រះកាយតែមួយ និងមានព្រះវិញ្ញាណតែមួយ ដូចជាព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ឲ្យមានសេចក្តីសង្ឃឹមតែមួយដូច្នោះដែរ។[5]មានព្រះអម្ចាស់តែមួយ
មានជំនឿតែមួយ មានពិធីជ្រមុជទឹកតែមួយ[6]និងមានព្រះជាម្ចាស់តែមួយ ជាព្រះបិតាលើអ្វីៗទាំងអស់ តាមរយៈមនុស្សទាំងអស់ និងក្នុងមនុស្សទាំងអស់។
[7]ព្រះជាម្ចាស់បានប្រទានព្រះគុណមកយើងម្នាក់ៗ ស្របតាមកម្រិតនៃអំណោយទានរបស់ព្រះគ្រិស្ត។[8]បទគម្ពីរបានចែងទុកមកថា៖ «ពេលព្រះអង្គបានយាងឡើងទៅស្ថាន
ខ្ពស់ ព្រះអង្គបាននាំពួកជាប់ជាឈ្លើយទៅឃុំឃាំង ហើយព្រះអង្គប្រទានព្រះអំណោយទានផ្សេងៗដល់មនុស្សលោក»។
[9]តើពាក្យថា «យាងឡើងទៅ» មានន័យដូចម្តេច? លើកលែងតែព្រះអង្គយាងចុះមកផែនដីដ៏ទាបនេះជាមុនសិន។[10]ព្រះអង្គដែលបានយាងចុះមកយ៉ាងណា
គឺព្រះអង្គដដែលនោះទ្រង់នឹងយាងឡើងទៅខ្ពស់បំផុតនៃស្ថានបរមសុខយ៉ាងនោះដែរ ដើម្បីសម្រេចគ្រប់កិច្ចការទាំងអស់។
[11]ព្រះគ្រិស្តបានប្រទានឲ្យអ្នកខ្លះ បំពេញមុខងារជាសាវក ខ្លះជាព្យាការី ខ្លះជាអ្នកប្រកាសដំណឹងល្អ ខ្លះជាគ្រូគង្វាល និងខ្លះទៀតជាគ្រូបង្រៀន។
[12]ព្រះអង្គប្រទានមុខងារឲ្យប្រជាជនដ៏វិសុទ្ធបម្រើ និងកសាងព្រះកាយព្រះគ្រិស្តឡើង។[13]ព្រះអង្គនៅតែបន្តកសាងព្រះកាយព្រះអង្គ រហូតដល់យើងមានជំនឿរួបរួមគ្នា
ក្នុងការស្គាល់ព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយយើងពេញវ័យ ព្រមទាំងបានពេញដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះគ្រិស្ត។
[14]ព្រះគ្រិស្តបានកសាងយើងឡើង ដើម្បីកុំឲ្យយើងតែជាកូនក្មេង ដែលត្រូវរេរា និងត្រូវខ្យល់គោលលទ្ធិនានាបោកបក់
និងលែងចាញ់បោកឧបាយកលមនុស្សបោកបញ្ឆោតទៀតហើយ។[15]ផ្ទុយទៅវិញ ការប្រព្រឹត្តសេចក្តីពិតដោយក្តីស្រឡាញ់ នាំយើងឲ្យរីកចម្រើនឡើងគ្រប់វិស័យ
ឆ្ពោះទៅរកព្រះគ្រិស្តជាសិរសា។[16]ព្រះគ្រិស្តបានកសាងព្រះកាយទាំងមូល ឲ្យបានផ្គុំគ្នា និងភ្ជាប់គ្នាឡើងយ៉ាងមាំ ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មាន ដោយគាំទ្រសរីរាង្គ
នីមួយៗ ហើយពេលសរីរាង្គនីមួយៗផ្គុំគ្នាឡើង ធ្វើឲ្យព្រះកាយនោះរីកចម្រើនឡើងក្នុងសេចក្តីស្រឡាញ់។
[17]ដូច្នេះ ខ្ញុំចង់ជម្រាប និងបញ្ជាក់ប្រាប់បងប្អូនក្នុងព្រះអម្ចាស់ថា បងប្អូនមិនត្រូវរស់នៅដូចសាសន៍ដទៃ ដែលតែងធ្វើតាមចិត្តប្រាថ្នាឥតប្រយោជន៍ឡើយ។
[18]គំនិតពួកគេងងឹតសូន្យសុង នៅឆ្ងាយពីព្រះជាម្ចាស់ ព្រោះតែពួកគេមិនស្គាល់ព្រះជាម្ចាស់គង់នៅក្នុងពួកគេ និងព្រោះពួកគេមានចិត្តរឹងរូស។[19]ពួកគេមិនចេះខ្មាស
និងបណ្តោយខ្លួនប្រព្រឹត្តអំពើអបាយមុខ ហើយនៅតែបន្តប្រព្រឹត្តអំពើប្រាកចាកសីលធម៌គ្រប់យ៉ាង។
[20]ប៉ុន្តែ នេះមិនមែនជារបៀបបងប្អូនរៀនអំពីព្រះគ្រិស្តឡើយ។[21]បងប្អូនបានឮគេនិយាយអំពីគាត់ ហើយបងប្អូនក៏បានរៀនអំពីគាត់ដែរ ដូចជាសេចក្តីពិតក្នុងព្រះយេស៊ូ។
[22]បងប្អូនត្រូវលះបង់កិរិយាមាយាទចាស់ គឺត្រូវដោះជីវិតចាស់ចោល។ ជីវិតចាស់តែងតែពុកផុយ តាមការលោភលន់បញ្ឆោតចិត្តនេះចោលទៅ។
[23]បងប្អូនទទួលការបង្រៀន ដើម្បីកែប្រែចិត្តគំនិតខាងវិញ្ញាណ ជាថ្មីឡើងវិញ[24]និងត្រូវបំពាក់មនុស្សថ្មីដោយសេចក្តីសុចរិត
ដែលព្រះអង្គបានបង្កើតបងប្អូនឲ្យមានលក្ខណៈដូចព្រះជាម្ចាស់ គឺមានសេចក្តីសុចរិត និងវិសុទ្ធភាពពិតប្រាកដ។
[25]ហេតុដូច្នេះហើយ ចូរបងប្អូនម្នាក់ៗឈប់និយាយកុហក និងនិយាយសេចក្តីពិតទៅកាន់អ្នកជិតខាងរបស់ខ្លួន ព្រោះយើងជាសមាជិកនៃសរីរាង្គរបស់គ្នាទៅវិញទៅមក។
[26]ចូរខឹងចុះ តែកុំប្រព្រឹត្តអំពើបាបសោះឡើយ។ កុំឲ្យខឹងរហូតទាល់តែថ្ងៃលិចនោះឡើយ។[27]កុំឲ្យអារក្សមានឱកាសសោះ។
[28]បងប្អូនដែលធ្លាប់លួចយករបស់គេពីមុនមក ចូរឈប់លួចទៀត។ អ្នកនោះត្រូវចេះបំពេញការងារចិញ្ចឹមជីវិត ដោយដៃរបស់ខ្លួន ដូច្នេះហើយអ្នកនឹងមានរបស់
ចែកដល់អ្នកមានតម្រូវការចាំបាច់។[29]កុំឲ្យមានពាក្យសម្តីអាក្រក់ណា ចេញពីមាត់អ្នករាល់គ្នាឡើយ។ ចូរប្រើពាក្យសម្តីណា ដែលមានប្រយោជន៍ជួយកសាង
អ្នកដែលស្តាប់តាមបងប្អូន។[30]ហើយសូមកុំធ្វើឲ្យព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យ ព្រោះដោយសារព្រះអង្គហើយ ដែលបងប្អូនទទួលសញ្ញាសម្គាល់
ទុកសម្រាប់ថ្ងៃព្រះអង្គយាងមកលោះបងប្អូន។
[31]ចូរកំចាត់ចោលភាពល្វីងជូរចត់ ក្តៅក្រហាយ កំហឹង ស្រែកឡូឡា និងការប្រមាថ ព្រមទាំងសេចក្តីអាក្រក់គ្រប់យ៉ាងចេញពីបងប្អូន។[32]ចូរប្រព្រឹត្តដោយចិត្តសប្បុរស
មានចិត្តអាណិតអាសូរ និងអត់ទោសគ្នាទៅវិញទៅមក ដូចព្រះជាម្ចាស់តាមរយៈព្រះគ្រិស្តបានអត់ទោសបាបបងប្អូនរាល់គ្នាដែរ។

Ephesians 4:1

ប្រយោគភ្ជាប់:

ដោយសារអ្វីដែលលោកប៉ូលបានកំពុងសរសេរទៅអេភេសូរគាត់ប្រាប់ពួកគេពីរបៀបដែលពួកគេគួរតែរស់នៅដើម្បីបម្រើព្រះអម្ចាស់ដ៏ពិសិដ្ឋ។

ខ្ញុំជាអ្នកជាប់ឃុំឃាំងព្រោះតែព្រះអម្ចាស់

"ដូចជាមនុស្សម្នាក់ដែលនៅក្នុងគុកដោយសារតែជំរើសរបស់គាត់ដើម្បីបម្រើព្រះអម្ចាស់។

សូមដាស់តឿនបងប្អូន ឲ្យចេះដើរបែបគួរសមនឹងការត្រាស់ហៅ

ការដើរគឺជាមធ្យោបាយទូទៅមួយដើម្បីបង្ហាញពីគំនិតនៃការរស់នៅរបស់មនុស្សម្នាក់។

ឲ្យចេះរស់នៅ ដោយការបន្ទាបខ្លួន ស្លូតបូត និងអត់ធ្មត់ ព្រមទាំងចេះទ្រាំទ្រគ្នាទៅវិញទៅមក

«រៀនបន្ទាបខ្លួន ស្លូតបូតនិងអត់ធ្មត់»

រក្សាឯកភាពមកពីព្រះវិញ្ញាណ ដោយរក្សាចំណងនៃសេចក្តីសុខសាន្ត។

«ស្វែងរកការរស់នៅជាមួយគ្នាដោយសុខសាន្តដើម្បីរក្សាការរួបរួមនៃព្រះវិញ្ញាណដ៏វិសុទ្ធ

Ephesians 4:4

ព្រះកាយតែមួយ

ក្រុមជំនុំជាជាញឹកញាប់និយាយសំដៅជាព្រះកាយរបស់ព្រះគ្រិស្ត។

ព្រះវិញ្ញាណតែមួយ

«មានតែព្រះវិញ្ញាណដ៏វិសុទ្ធតែមួយប៉ុណ្ណោះ។»(UDB)

បានត្រាស់ហៅបងប្អូន ឲ្យមានសេចក្តីសង្ឃឹមតែមួយដូច្នោះដែរ។

«ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនឱ្យមានក្តីសង្ឃឹមប្រកបដោយទំនុកចិត្តមួយនៅក្នុងព្រះអង្គ

ឬ

«មានរឿងមួយដែលព្រះជាម្ចាស់បានជ្រើសរើសបងប្អូនឱ្យមានទំនុកចិត្តហើយរំពឹងថាព្រះអង្គនឹង

ព្រះបិតាលើអ្វីៗទាំងអស់... លើអ្វីៗទាំងអស់ ... តាមរយៈមនុស្សទាំងអស់ ... ក្នុងមនុស្សទាំងអស់។

ពាក្យថា «ទាំងអស់» នៅទីនេះមានន័យថា «អ្វីៗទាំងអស់»។

Ephesians 4:7

ប្រយោគភ្ជាប់:

ប៉ូលរម្លឹកអ្នកជឿអំពីអំណោយដែលព្រះគ្រិស្តប្រទានឱ្យអ្នកជឿប្រើប្រាស់នៅក្នុងក្រុមជំនុំ

ពត៌មានទូទៅ

ការដកស្រង់នៅទីនេះគឺមកពីបទចំរៀងដែលស្តេចដាវីឌបានសរសេរ។

ព្រះជាម្ចាស់បានប្រទានព្រះគុណមកយើងម្នាក់ៗ

នេះអាចត្រូវបានថ្លែងដោយប្រើទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត:

«ព្រះជាម្ចាស់បានប្រទានព្រះគុណដល់យើងម្នាក់ៗ» ឬ
«ព្រះជាម្ចាស់បានផ្តល់អំណោយដល់អ្នកជឿម្នាក់ៗ»

«នៅពេលដែលព្រះគ្រិស្តបានយាងឡើងទៅស្ថានបរមសុខ»

Ephesians 4:9

យាងឡើងទៅ

«ព្រះគ្រិស្តបានយាងឡើងទៅ»

ព្រះអង្គយាងចុះមកផែនដី

«ព្រះគ្រិស្តក៏បានយាងចុះផែនដី»

ផែនដីដ៏ទាបនេះជាមុនសិន។

ដែនអត្ថន័យប្រហែលជា) តំបន់ទាបកគឺជាផ្នែកមួយនៃផែនដីឬ ២)« តំបន់ទាប»

គឺជារបៀបមួយផ្សេងទៀតដើម្បីសំដៅទៅលើផែនដី។

សូមមើលការបកប្រែផ្សេងទៀត:«ចូលទៅក្នុងតំបន់ទាបនៃផែនដី។»

ដើម្បីសម្រេចគ្រប់កិច្ចការទាំងអស់។

«ដូច្នេះព្រះអង្គអាចមានវត្តមាននៅគ្រប់ទីកន្លែងក្នុងអំណាចរបស់ទ្រង់»

សម្រេច

«ពេញលេញទាំងស្រុង» ឬ «ស្កប់ចិត្ត»

ព្រះអង្គប្រទានមុខងារ

ការអធិប្បាយរបស់ព្រះគ្រិស្តបានប្រទានអំណោយទានអាចត្រូវបានថ្លែងយ៉ាងច្បាស់។

សូមមើលការបកប្រែផ្សេងទៀត::«ព្រះគ្រិស្តបានប្រគល់មុខទាំងនេះដល់ក្រុមជំនុំ»

ឬ «ព្រះអង្គបានផ្តល់ឱ្យមនុស្សនូវការទទួលខុសត្រូវទាំងនេះដល់ក្រុម» ជំនុំ

ប្រទានមុខងារឲ្យប្រជាជនដ៏វិសុទ្ធ

«ដើម្បីរៀបចំប្រជាជនដែលគាត់បានញែកចេញ» ឬ «ដើម្បីផ្គត់ផ្គង់អ្នកជឿ»

«ដូច្នេះពួកគេអាចបម្រើអ្នកដទៃ »

កសាងព្រះកាយព្រះគ្រិស្តឡើង។

លោកប៉ូលកំពុងនិយាយអំពីមនុស្សដែលរីកចម្រើនខាងវិញ្ញាណដូចជាពួកគេកំពុងធ្វើលំហាត់ប្រាណដើម្បី

សាងព្រះកាយព្រះអង្គ

generated on Wed Sep 10 16:16:32 2025

«ភាពប្រសើរឡើង»
ព្រះកាយព្រះគ្រិស្ត
« រូបកាយរបស់ព្រះគ្រិស្ត»
សំដៅទៅលើសមាជិកម្នាក់ៗនៃក្រុមជំនុះរបស់ព្រះគ្រិស្ត។
រហូតដល់យើងមានជំនឿរួបរួមគ្នា ក្នុងការស្គាល់ព្រះបុត្រារបស់ព្រះជាម្ចាស់
អ្នកជឿត្រូវស្គាល់ព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះប្រសិនបើពួកគេរួបរួមគ្នាក្នុងជំនឿនិងមានការយល់ដឹងដូចគ្នា។
មានជំនឿរួបរួមគ្នា
«មានភាពរឹងមាំស្មើគ្នានៅក្នុងជំនឿ» ឬ «ប្រែជារួបរួមជាមួយគ្នាដោយជំនឿ»
បុត្រារបស់ព្រះជាម្ចាស់
នេះគឺជាឈ្មោះដ៏សំខាន់សម្រាប់ព្រះយេស៊ូ។
ហើយយើងពេញវ័យ
«ក្លាយជាអ្នកជឿដែលមានភាពវ័យខាងជំនឿ»
ពេញវ័យ
«អភិវឌ្ឍពេញលេញ» «ធំឡើង» ឬ «ពេញលក្ខណៈ»
Ephesians 4:14
ជាកូនក្មេង
លោកប៉ូលសំដៅទៅលើអ្នកជឿដែលមិនបានរីកចម្រើនខាងវិញ្ញាណដូចជាពួកគេជាកុមារ។
សូមមើលការបកប្រែផ្សេងទៀត: «ធ្វើដូចកូនក្មេង»
ត្រូវរេរា ... និងត្រូវខ្យល់គោលលទ្ធិនានាបោកបក់
នេះនិយាយអំពីអ្នកជឿម្នាក់ដែលមិនមានទាន់ពេញវ័យហើយធ្វើតាមការបង្រៀនខុសដូចទូកតូចមួយ។
និងលែងចាញ់បោកឧបាយកលមនុស្សបោកបញ្ឆោតទៀតហើយ។
«តាមរយៈមនុស្សពូកែប្រើល្បិចឆបោកបញ្ឆោតអ្នកជឿដោយបិុនប្រសប់ភូតភរ»
រីកចម្រើនឡើងគ្រប់វិស័យ ឆ្ពោះទៅរកព្រះគ្រិស្តជាសិរសា ... ធ្វើឲ្យព្រះកាយនោះរីកចម្រើនឡើងក្នុង
សេចក្តីស្រឡាញ់។
លោកប៉ូលប្រើរាងកាយមនុស្សដើម្បីពិពណ៌នាអំពីរបៀបដែលព្រះគ្រិស្តបណ្តាលឱ្យអ្នកជឿរួបរួមគ្នា
ដូចជាក្បាលនៃរាងកាយបណ្តាលឱ្យផ្នែកនៃរាងកាយធ្វើការរួមគ្នាដើម្បីឱ្យមានសុខភាពល្អ។
ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មាន ដោយគាំទ្រសរីរាង្គនីមួយៗ
«សរសៃ»
គឺចងយ៉ាងរឹងមាំដែលភ្ជាប់ឆ្អឹងឬសរីរាង្គនៅកន្លែងដែលមាននៅក្នុងរាងកាយ។
ក្នុងសេចក្តីស្រឡាញ់។
«ដូចជាសមាជិកស្រឡាញ់គ្នាទៅវិញទៅមក»
Ephesians 4:17
ប្រយោគភ្ជាប់:
លោកប៉ូលប្រាប់ពួកគេពីអ្វីដែលពួកគេមិនគួរនៅធ្វើពេលនេះពួកគេជាអ្នកជឿត្រូវបានបង្រៀនឱ្យធ្វើ
ដូច្នេះ ខ្ញុំចង់ជម្រាប និងបញ្ជាក់ប្រាប់បងប្អូនក្នុងព្រះអម្ចាស់ថា
«ព្រោះអ្វីដែលខ្ញុំទើបតែនិយាយខ្ញុំនឹងនិយាយបន្ថែមទៀតដើម្បីលើកទឹកចិត្តបងប្អូនថែមទៀត»
បងប្អូនមិនត្រូវរស់នៅដូចសាសន៍ដទៃ ដែលតែងធ្វើតាមចិត្តប្រាថ្នាឥតប្រយោជន៍ឡើយ។
ការដើរគឺជាពាក្យប្រៀបធៀបមួយសម្រាប់របៀបរស់នៅរបស់មនុស្ស។
ការបកប្រែផ្សេងទៀត:«
ឈប់រស់នៅដូចពួកសាសន៍ដទៃដោយគំនិតឥតប្រយោជន៍របស់ពួកគេ»
គំនិតពួកគេងងឹតសូន្យសុង
ពួកគេលែងគិតឬរកហេតុផលឱ្យបានច្បាស់។ ការបកប្រែផ្សេងទៀត:
«ពួកគេបានធ្វើឱ្យគំនិតរបស់ពួកគេងងឹត» ឬ «ពួកគេមិនអាចយល់បានទេ»
នៅឆ្ងាយពីព្រះជាម្ចាស់ ព្រោះតែពួកគេមិនស្គាល់ព្រះជាម្ចាស់គង់នៅក្នុងពួកគេ
និងព្រោះពួកគេមានចិត្តរឹងរូស។
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ សូមមើលការបកប្រែផ្សេងទៀត: «
ពីព្រោះពួកគេមិនស្គាល់ព្រះពួកគេមិនអាចរស់នៅតាមរបៀបដែលព្រះចង់អោយប្រជាជនរស់នៅ»
ឬ
«ពួកគេបានផ្តាច់ខ្លួនចេញពីជីវិតរបស់ព្រះជាម្ចាស់ដោយភាពល្ងង់ខ្លៅរបស់ពួកគេ»
នៅឆ្ងាយ
«កាត់ផ្តាច់» ឬ «បំបែក»
មិនស្គាល់
«ខ្វះចំណេះដឹង» ឬ «ខ្វះព័ត៌មាន»
ព្រោះពួកគេមានចិត្តរឹងរូស
ពួកគេបដិសេធមិនស្តាប់ព្រះជាម្ចាស់និងធ្វើតាមការបង្រៀនរបស់ទ្រង់។
បណ្តោយខ្លួនប្រព្រឹត្តអំពើអបាយមុខ ហើយនៅតែបន្តប្រព្រឹត្តអំពើប្រាកចាកសីលធម៌គ្រប់យ៉ាង
លោកប៉ូលនិយាយអំពីមនុស្សទាំងនេះដូចជាពួកគេជាវត្ថុដែលពួកគេខ្លួនឯងបានប្រគល់ទៅឱ្យ
«ការបកប្រែផ្សេងទៀត:គ្រាន់តែចង់បំពេញបំណងប្រាថ្នាខាងរាងកាយរបស់ពួកគេ»
Ephesians 4:20
ប៉ុន្តែ នេះមិនមែនជារបៀបបងប្អូនរៀនអំពីព្រះគ្រិស្តឡើយ
ពាក្យថា «ដែល»
សំដៅទៅលើរបៀបរស់នៅរបស់សាសន៍ដទៃដូចដែលបានពិពណ៌នានៅក្នុង ៤:១៧
។ នេះសង្កត់ធ្ងន់ថាអ្វីដែលអ្នកជឿបានរៀនអំពីព្រះគ្រិស្តគឺផ្ទុយពីនោះ។
ការបកប្រែផ្សេងទៀត «ប៉ុន្តែអ្វីដែលអ្នកបានរៀនអំពីព្រះគ្រិស្តគឺមិនបែបហ្នឹងទេ"
ហើយបងប្អូនក៏បានរៀនអំពីគាត់ដែ
ប៉ូលដឹងថាអេភេសូរបានឮ និងបានបង្រៀន។
បងប្អូនក៏បានរៀនអំពីគាត់ដែរ
ទី១អត្ថន័យប្រហែលជា) «មនុស្សរបស់ព្រះយេស៊ូបានបង្រៀនបងប្អូន» ឬ ២)
«មាននរណាម្នាក់បានបង្រៀនអ្នកពីព្រោះបងប្អូនគឺជាមនុស្សរបស់ព្រះយេស៊ូ»។
ដូចជាសេចក្តីពិតក្នុងព្រះយេស៊ូ
«ដូចជាអ្វីៗទាំងអស់អំពីព្រះយេស៊ូគឺជាសេចក្តីពិត»
ត្រូវដោះជីវិតចាស់ចោល
លោកប៉ូលកំពុងនិយាយអំពីគុណសម្បត្តិខាងសីលធម៌ដូចជាចំណែកនៃសម្លៀកបំពាក់។
ការបកប្រែផ្សេងទៀត: «ឈប់រស់នៅដូចជាបងប្អូនបានធ្វើកាលពីអតីត»
ជីវិតចាស់
«ដោយសារតែអ្នកបានដោះចោលជីវិតចាស់» ឬ «អតីតខ្លួនឯង»។
ជីវិតចាស់តែងតែពុករលួយ តាមការលោភលន់បញ្ឆោតចិត្តនេះចោលទៅ
លោកប៉ូលនិយាយអំពីនិស្ស័យរបស់មនុស្សមានបាបដូចជារូបកាយដែលស្លាប់នៅក្នុងផ្នូរហើយចំណែកឆ្ល
Ephesians 4:23
ដើម្បីកែប្រែចិត្តគំនិតខាងវិញ្ញាណ ជាថ្មីឡើងវិញ
នេះអាចត្រូវបានបកប្រែជាមួយទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
ដើម្បីអនុញ្ញាតឱ្យព្រះជាម្ចាស់ផ្លាស់ប្តូរឥរិយាបថនិងគំនិតរបស់បងប្អូន» ឬ
«ដើម្បីអនុញ្ញាតឱ្យព្រះជាម្ចាស់ផ្តល់ឱ្យបងប្អូននូវឥរិយាបថថ្មីនិងគំនិតថ្មី»
ដោយព្រះអង្គបានបង្កើតបងប្អូនឲ្យមានលក្ខណៈដូចព្រះជាម្ចាស់
លោកប៉ូលកំពុងនិយាយអំពីគុណសម្បត្តិខាងសីលធម៌ដូចជាចំណែកនៃសម្លៀកបំពាក់។
ការបកប្រែផ្សេងទៀត:
«ដើម្បីរស់នៅក្នុងជីវិតថ្មីដែលត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះជាម្ចាស់» ឬ
«ដើម្បីចាប់ផ្តើមរស់នៅតាមរបៀបថ្មីពីព្រោះបងប្អូនត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះជាម្ចាស់»
គឺមានសេចក្តីសុចរិត និងវិសុទ្ធភាពពិតប្រាកដ
«ពិតជាសុចរិតនិងវិសុទ្ធ»
Ephesians 4:25
ការបកប្រែផ្សេងទៀត:
«ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។
«ឈប់និយាយកុហក»
«យើងជាកម្មសិទ្ធិរបស់ព្រះអម្ចាស់»
«យើងជាកម្មសិទ្ធិរបស់គ្នាទៅវិញទៅមក» ឬ
«យើងជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់»
ចូរខឹងចុះ តែកុំប្រព្រឹត្តអំពើបាបសោះឡើយ
«បងប្អូនអាចខឹងតែកុំធ្វើបាប» ឬ «បើបងប្អូនខឹងកុំធ្វើបាប»
កុំឲ្យខឹងរហូតទាល់តែថ្ងៃលិចនោះឡើយ។
«បងប្អូនត្រូវតែឈប់ខឹងមុនពេលថ្ងៃលិចមកដល់» ឬ
«សូមឲ្យបងប្អូនខឹងចុះមុនពេលថ្ងៃលិច»
កុំឲ្យអារក្សមានឱកាសសោះ។
កុំផ្តល់ឱ្យអារក្សមានឱកាសដើម្បីនាំអ្នកចូលទៅក្នុងអំពើបាប
Ephesians 4:28
នេះសំដៅទៅលើការនិយាយដែលព្រហើនឬឈ្លើយ។
ប្រយោជន៍ជួយកសាង
«សម្រាប់ការលើកទឹកចិត្តអ្នកដទៃ» ឬ «សម្រាប់ពង្រឹងអ្នកដទៃ»
ចូរប្រើពាក្យសម្តីណា ដែលមានប្រយោជន៍ជួយកសាង អ្នកដែលស្តាប់តាមបងប្អូន។
«តាមសេចក្តីត្រូវការរបស់ពួកគេ។
តាមរបៀបនេះបងប្អូននឹងជួយដល់អស់អ្នកណាដែលស្តាប់បងប្អូន»
សូមកុំធ្វើឲ្យព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យ
«កុំឈឺចិត្ត» ឬ «កុំតូចចិត្ត»
ព្រោះដោយសារព្រះអង្គហើយ ដែលបងប្អូនទទួលសញ្ញាសម្គាល់
លោកប៉ូលនិយាយអំពីរបៀបដែលពួកគេចង់បំពេញសេចក្តីប៉ងប្រាថ្នាខាងរាងកាយ
ព្រះវិញ្ញាណដ៏វិសុទ្ធធានាដល់អ្នកជឿថាព្រះជាម្ចាស់នឹងប្រោសលោះពួកគេ។
លោកប៉ូលនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធដូចជាគាត់ជាសំគាល់ថាព្រះជាម្ចាស់ដាក់លើអ្នកជឿដើម្បីបង្ហា

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត:
«ត្បិតព្រះអង្គគឺជាអ្នកដែលធានាដល់បងប្អូនថាព្រះជាម្ចាស់នឹងប្រោសលោះបងប្អូននៅថ្ងៃចុងក្រោយ»
ឬ « ដ្បិតគាត់គឺជាអ្នកដែលធានាថាព្រះជាម្ចាស់នឹងលោះអ្នកនៅថ្ងៃប្រោសលោះ»។
ឬ
Ephesians 4:31
ប្រយោគភ្ជាប់:
លោកប៉ូលបញ្ចប់ការបង្រៀនរបស់គាត់អំពីអ្វីដែលអ្នកជឿមិនគួរធ្វើហើយនិងបញ្ចប់នៅ
ចូរកំចាត់ចោល
ទី១អត្ថន័យប្រហែលជា) អ្នកត្រូវតែធ្វើវាដោយខ្លួនឯងឬ
២)»អ្នកត្រូវតែអនុញ្ញាតឱ្យព្រះជាម្ចាស់ដកយកចេញទៅ" ។

ចូរកំចាត់ចោលភាពល្ងីល្ងើ
[illegible]
ក្តៅក្រហាយ
ពេលមានកំហឹងខ្លាំង
កំហឹង
ពាក្យទូទៅសម្រាប់កំហឹង
[illegible]
«ផ្ទុយទៅវិញបងប្អូនត្រូវតែមានចិត្តល្អ»
មានចិត្តអាណិតអាសូរ
«ស្លូតបូត»ឬ «ពេញដោយក្តីមេត្តាករុណា»

---

5 [1]ដូច្នេះ សូមយកតម្រាប់តាមព្រះជាម្ចាស់ ក្នុងនាមបុត្រដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។[2]ចូរដើរក្នុងក្តីស្រឡាញ់ ដូចព្រះគ្រិស្តស្រឡាញ់យើង
និងប្រទានព្រះជន្មព្រះអង្គផ្ទាល់ទុកជាតង្វាយ និងយញ្ញបូជាថ្វាយព្រះជាម្ចាស់។
[3]បងប្អូនអើយ កុំឲ្យមានឮគេនិយាយអំពីអំពើប្រាសចាកសីលធ៌ម ឬអំពើអបាយមុខ ឬសេចក្តីលោភលន់ណាកើតមានក្នុងចំណោមបងប្អូនរាល់គ្នាឡើយ ដ្បិត
ពាក្យមិនសមរម្យទាំងនេះ គ្មានអ្វីគាប់ប្រសើរចំពោះប្រជាជនដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ទេ។[4]កុំឲ្យមានពាក្យទ្រគោះបោះបោក ពាក្យឡេះឡោះ
និងពាក្យលេងសើចអាសអាភាស ព្រោះពាក្យទាំងអស់នេះមិនសមរម្យទាល់តែសោះ។ ផ្ទុយទៅវិញត្រូវចេះអរព្រះគុណព្រះជាម្ចាស់។
[5]បងប្អូនត្រូវដឹងប្រាកដថា ពួកអ្នកប្រាសចាកសីលធ៌ម ពួកអ្នកប្រព្រឹត្តអំពើអបាយមុខ ឬពួកអ្នកលោភលន់ គឺជាមនុស្សថ្វាយបង្គំព្រះក្លែងក្លាយ
ពុំបានទទួលមរតកក្នុងព្រះរាជ្យរបស់ព្រះគ្រិស្ត និងព្រះជាម្ចាស់ឡើយ។[6]កុំឲ្យមាននរណាម្នាក់មកបោកបញ្ឆោត ដោយពាក្យសម្តីឥតខ្លឹមសារ
ដ្បិតអំពើទាំងអស់នេះជាព្រះពិរោធរបស់ព្រះជាម្ចាស់ និងនាំឲ្យមានកូនមិនស្តាប់បង្គាប់កើតមក។[7]ដូច្នេះ កុំសេពគប់ជាមួយពួកគេជាដាច់ខាត។
[8]កាលពីដើម បងប្អូនងងឹតមែន តែឥឡូវនេះ បងប្អូនជាពន្លឺក្នុងព្រះអម្ចាស់ហើយ។ ចូរដើរដូចកូនក្នុងពន្លឺ[9](ដ្បិតផលផ្លែនៃពន្លឺរួមមានសេចក្តីសប្បុរស សេចក្តីសុចរិត
និងសេចក្តីពិតគ្រប់យ៉ាង)[10]និងស្វែងរកអ្វីគាប់ព្រះហឫទ័យរបស់ព្រះអម្ចាស់។[11]ចូរកុំសេពគប់នឹងកិច្ចការខាងសេចក្តីងងឹត គ្មានផលផ្លែនោះឡើយ
ផ្ទុយទៅវិញត្រូវបង្ហាញឲ្យគេឃើញអំពើនោះផង។[12]ដ្បិត វាជារឿងអាម៉ាសទៅហើយ សូម្បីតែលើកយកមកនិយាយពីអំពើ ពួកគេប្រព្រឹត្តដោយលួចលាក់។
[13]ប៉ុន្តែ កាលណាអំពើទាំងនេះបើកបង្ហាញហើយ គេនឹងឃើញវាច្បាស់នៅក្នុងពន្លឺ។ ដ្បិតអ្វីៗដែលមើលឃើញ គឺជាពន្លឺ។[14]ដូច្នេះ ដ្បិតមានសេចក្តីចែងទុកមកថា៖ «ចូរភ្ញាក់
ឡើង អ្នកដេកលក់អើយ ចូរក្រោកឡើងចេញពីចំណោមមនុស្សស្លាប់ ព្រះគ្រិស្តនឹងជះពន្លឺមកលើអ្នករាល់គ្នា»។
[15]ចូររស់នៅដោយប្រុងប្រយ័ត្ន កុំឲ្យដូចមនុស្សឥតប្រាជ្ញាឡើយ តែត្រូវរស់ដូចមនុស្សមានប្រាជ្ញាវិញ។[16]ត្រូវចេះប្រើប្រាស់ពេលវេលា ដ្បិត សម័យនេះអាក្រក់ណាស់។
[17]ដូច្នេះ កុំប្រព្រឹត្តដូចមនុស្សល្ងីល្ងើ តែត្រូវស្វែងយល់អំពីអ្វី ដែលជាបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់វិញ។
[18]កុំឲ្យស្រវឹងស្រា ដែលនាំខ្លួនឲ្យព្រើលចិត្តឡើយ។ ផ្ទុយទៅវិញ ចូរឲ្យបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ[19]ចូរនិយាយគ្នាទៅវិញទៅមក ដោយទំនុកតម្កើង
ទំនុកសរសើរព្រះជាម្ចាស់ និងចម្រៀងមកពីព្រះវិញ្ញាណ ចូរច្រៀង និងលើកតម្កើងព្រះអម្ចាស់ឲ្យអស់ពីចិត្ត[20]ត្រូវចេះអរព្រះគុណព្រះជាម្ចាស់គ្រប់រឿងរ៉ាំងទាំងអស់
ក្នុងព្រះនាមព្រះយេស៊ូគ្រិស្តថ្វាយព្រះជាម្ចាស់ជាព្រះបិតានៃយើង[21]ចុះចូលគ្នាទៅវិញទៅមក ដោយគោរពដល់ព្រះគ្រិស្ត។
[22]ភរិយារាល់គ្នាអើយ ចូរចុះចូលនឹងស្វាមីរបស់ខ្លួន ដូចព្រះអម្ចាស់ដែរ។[23]ដ្បិត ស្វាមីនាំមុខភរិយាយ៉ាងណា ដូចជាព្រះគ្រិស្តនាំមុខក្រុមជំនុំយ៉ាងនោះដែរ
ហើយព្រះគ្រិស្តជាព្រះសង្គ្រោះរបស់ក្រុមជំនុំ។[24]ប៉ុន្តែ កាលណាក្រុមជំនុំចុះចូលនឹងព្រះគ្រិស្តយ៉ាងណា ដូច្នេះ ភរិយាក៏ត្រូវចុះនឹងស្វាមីរបស់ខ្លួន
ក្នុងគ្រប់កិច្ចការទាំងអស់យ៉ាងនោះដែរ។
[25]ស្វាមីរាល់គ្នាអើយ ចូរស្រឡាញ់ភរិយារបស់ខ្លួន ដូចព្រះគ្រិស្តស្រឡាញ់ក្រុមជំនុំ និងបូជាព្រះជន្មសម្រាប់ក្រុមជំនុំយ៉ាងនោះដែរ។
[26]ព្រះគ្រិស្តបានបូជាព្រះជន្មសម្រាប់ក្រុមជំនុំ ដើម្បីឲ្យក្រុមជំនុំបានទៅជាវិសុទ្ធ និងសម្អាតដោយការលាងនឹងទឹក[27]និងដោយសារព្រះបន្ទូលព្រះអង្គ ដូច្នេះ ព្រះអង្គសព្វ
ព្រះហឫទ័យនាំក្រុមជំនុំនេះមកថ្វាយព្រះអង្គផ្ទាល់ ជាក្រុមជំនុំដ៏រុងរឿង ឥតស្លាកស្នាម ឥតជ្រីវជ្រួញ និងឥតខ្ចោះត្រង់ណាឡើយ គឺឲ្យបានទៅជាវិសុទ្ធ ឥតសៅហ្មង។
[28]ដូចគ្នានេះដែរ ស្វាមីគួរតបស្នេហ៍ភរិយា ដូចជាស្រឡាញ់រូបកាយរបស់ខ្លួន។ ស្វាមីណាស្រឡាញ់ភរិយា ស្វាមីនោះស្រឡាញ់រូបកាយខ្លួនឯង។[29]ដ្បិត
គ្មាននរណាស្អប់រូបកាយរបស់ខ្លួនសោះឡើយ ផ្ទុយទៅវិញ អ្នកនោះតែងចិញ្ចឹមបីបាច់ថែរក្សារូបកាយនោះ ដូចព្រះគ្រិស្តចិញ្ចឹមបីបាច់ថែរក្សា
ក្រុមជំនុំផងដែរ[30]ព្រោះយើងទាំងអស់គ្នាជាសរីរាង្គនៃរូបកាយនោះ។
[31]ដោយហេតុនេះហើយបានជាបុរសត្រូវចាកចេញពីឪពុកម្តាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរនឹងត្រឡប់ទៅជារូបកាយតែមួយ។[32]គម្រោងការដ៏លាក់
កំបាំងនេះមានអត្ថន័យជ្រៅណាស់ ខ្ញុំនិយាយសំដៅលើព្រះគ្រិស្ត និងក្រុមជំនុំតែប៉ុណ្ណោះ។[33]ទោះជាយ៉ាងណាក៏ដោយ បងប្អូនម្នាក់ៗត្រូវស្រឡាញ់ភរិយារៀងៗខ្លួន ដូច
ស្រឡាញ់ខ្លួនឯង ហើយភរិយាក៏ត្រូវគោរពស្វាមីរបស់ខ្លួនដែរ។

Ephesians 5:1
ប្រយោគភ្ជាប់:
លោកប៉ូលបន្តប្រាប់អ្នកជឿអំពីរបៀបដែលពួកគេគួរនិងមិនគួររស់នៅក្នុងនាមជាកូនរបស់
ដូច្នេះ សូមយកតម្រាប់តាមព្រះជាម្ចាស់
«ដូច្នេះបងប្អូនគួរតែធ្វើអ្វីដែលព្រះជាម្ចាស់ធ្វើ»។ ដូច្នេះយោងទៅតាម ៤:៣១
ដែលប្រាប់ពីមូលហេតុដែលអ្នកជឿគួរតែយកតម្រាប់តាមព្រះជាម្ចាស់ពីព្រោះព្រះគ្រិស្ត
ក្នុងនាមបុត្រដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។
ព្រះជាម្ចាស់សព្វព្រះទ័យឲ្យយើងគ្រាប់តាមឬធ្វើតាមទ្រង់ចាប់តាំងពីយើងជាកូនរបស់ទ្រង់
ការបកប្រែផ្សេងទៀត: «ដូចជាកូនៗ
ដែលស្រឡាញ់ចូលចិត្តធ្វើគ្រាប់តាមឪពុករបស់ពួកគេ» ឬ
«ពីព្រោះបងប្អូនជាកូនរបស់ទ្រង់ហើយគាព្រះអង្គស្រឡាញ់បងប្អូនខ្លាំងណាស់»
ចូរដើរក្នុងក្តីស្រឡាញ់
ការដើរគឺជាមធ្យោបាយទូទៅមួយដើម្បីបង្ហាញពីគំនិតនៃការរស់នៅរបស់នរណាម្នាក់។
ការបកប្រែផ្សេងទៀត: «ចូររស់នៅក្នុងជីវិតនៃស្នេហា»
ទុកជាតង្វាយ និងយញ្ញបូជាថ្វាយព្រះជាម្ចាស់។
«ដូចជាតង្វាយដែលមានក្លិន» ឈ្មុយនិងថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់

Ephesians 5:3
បងប្អូនអើយ កុំឲ្យមានឮគេនិយាយអំពីអំពើប្រាសចាកសីលធ៌ម ឬអំពើអបាយមុខ
ឬសេចក្តីលោភលន់ណាកើតមានក្នុងចំណោមបងប្អូនរាល់គ្នាឡើយ
«កុំធ្វើអ្វីដែលនឹងអនុញ្ញាតិអោយអ្នកណាម្នាក់គិតថាអ្នកមានកំហុសខាងផ្លូវភេទឬភាពមិនស្អាតស្អំរឺការលេ
អំពើអបាយមុខ
[illegible]
ផ្ទុយទៅវិញត្រូវចេះអរព្រះគុណព្រះជាម្ចាស់។
ផ្ទុយទៅវិញអ្នកគួរតែអរគុណដល់ព្រះជាម្ចាស់»
Ephesians 5:5
ទទួលមរតក
ការទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យាដល់អ្នកជឿត្រូវបានគេនិយាយដូចជាទទួលមរតការកាន់កាប់និ
ពាក្យសម្តីឥតខ្លឹមសារ
ពាក្យដែលមិនពិតសម្រាប់ពួកគេ
Ephesians 5:8
កាលពីដើម បងប្អូនងងឹតមែន
ដូចជាមនុស្សម្នាក់មិនអាចមើលឃើញនៅក្នុងទីងងឹតបានទេដូច្នេះមនុស្សដែលស្រឡាញ់បាបខ្វះការយល់ដឹ

generated on Wed Sep 10 16:16:32 2025

តែឥឡូវនេះ បងប្អូនជាពន្លឺក្នុងព្រះអម្ចាស់ហើយ។
ដូចជាមនុស្សម្នាក់អាចមើលឃើញនៅក្នុងពន្លឺដូច្នេះមនុស្សដែលព្រះជាម្ចាស់បានសង្គ្រោះ
ចូរដើរដូចកូនក្នុងពន្លឺ
«រស់នៅដូចមនុស្សដែលយល់ពីអ្វីដែលព្រះអម្ចាស់ចង់អោយពួកគេធ្វើ»
ដ្បិតផលផ្លែនៃពន្លឺរួមមានសេចក្តីសប្បុរស សេចក្តីសុចរិត និងសេចក្តីពិតគ្រប់យ៉ាង)
ដូចជាដើមឈើដែលមានសុខភាពល្អបង្កើតបានផលល្អដែរអ្នកជឿនឹងធ្វើអ្វីដែលល្អ
ធ្វើអ្វីដែលសុចរិតព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យ គាត់ធ្វើនឹងនិយាយពាក្យពិត។
នឹង
ចូរកុំសេពគប់នឹងកិច្ចការខាងសេចក្តីងងឹត
លោកប៉ូលនិយាយអំពីដែលឥតប្រយោជន៍ដែលអ្នកមិនជឿធ្វើដូចជាអំពើអាក្រក់ដែលមនុស្សធ្វើនៅក្នុងទីងងឹត
ការបកប្រែផ្សេងទៀត:
«កុំធ្វើអ្វីដែលឥតប្រយោជន៍និងអំពើបាបជាមួយអ្នកមិនជឿ»
គ្មានផលផ្លែនោះឡើយ
សកម្មភាពដែលមិនធ្វើអ្វីល្អគឺគ្មានមានប្រយោជន៍ឬចំណេញទេ
បង្ហាញឲ្យគេឃើញអំពើនោះផង
«ចូរនាំពួកគេចូលទៅក្នុងពន្លឺ» ឬ «បង្ហាញពួកគេ» ឬ
«បង្ហាញនិងប្រាប់ប្រជាជនថារបៀបដែលប្រព្រឹត្តទាំងអស់នេះខុសយ៉ាងណា»
Ephesians 5:13
ប្រយោគភ្ជាប់:
គេមិនដឹងថាតើការដកស្រង់នេះជាការដកស្រង់ចេញពីព្យាការីអេសាយឬដកស្រង់ចេញពីទំនុកតម្កើង
កាលណាអំពើទាំងនេះបើកបង្ហាញហើយ គេនឹងឃើញវាច្បាស់នៅក្នុងពន្លឺ
«មនុស្សអាចមើលឃើញអ្វីៗយ៉ាងច្បាស់ដែលចូលមកក្នុងពន្លឺ»។
ពេលនេះគឺជាពាក្យប្រៀបធៀបមួយអំពីរបៀបដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់បង្ហាញ
ចូរភ្ញាក់ឡើង អ្នកដេកលក់អើយ ចូរក្រោកឡើងចេញពីចំណោមមនុស្សស្លាប់
ទី១អត្ថន័យប្រហែលជា)
លោកប៉ូលកំពុងនិយាយទៅកាន់អ្នកមិនជឿដែលត្រូវការភ្ញាក់ពីការស្លាប់ខាងវិញ្ញាណដូចជាមនុស្សម្នាក់
២)
លោកប៉ូលកំពុងនិយាយទៅកាន់អ្នកជឿអេភេសូរហើយប្រើសេចក្តីស្លាប់ជាពាក្យប្រៀប
«អ្នកដេកលក់អើយ... ជះពន្លឺមកលើអ្នករាល់គ្នា»។
ឧទាហរណ៍នៃ «បងប្អូន» សំដៅទៅលើ «បងប្អូនដេកលក់»
និងមានលក្ខណៈឯកវចនៈ។
«ព្រះគ្រិស្តនឹងជះពន្លឺមកលើអ្នករាល់គ្នា»។
ព្រះគ្រិស្តនឹងជួយអ្នកមិនជឿឱ្យយល់របៀបណាដែលពីអំពើអាក្រក់របស់គាត់និងរបៀប
Ephesians 5:15
ចូររស់នៅដោយប្រុងប្រយ័ត្ន កុំឲ្យដូចមនុស្សឥតប្រាជ្ញាឡើយ តែត្រូវរស់ដូចមនុស្សមានប្រាជ្ញាវិញ។
មនុស្សល្ងីល្ងើមិនការពារខ្លួនឯងប្រឆាំងអំពើបាបទេ។
ទោះយ៉ាងណាក៏ដោយមនុស្សដែលមានប្រាជ្ញាអាចស្គាល់អំពើបាបហើយរត់ចេញពីវា។
ការបកប្រែផ្សេងទៀត:«ដូច្នេះបងប្អូនត្រូវប្រយ័ត្នក្នុងការរស់នៅជាមនុស្សមានប្រាជ្ញា
ត្រូវចេះប្រើប្រាស់ពេលវេលា
«ធ្វើអ្វីដែលល្អបំផុតដែលបងប្អូនអាចធ្វើបានជាមួយពេលវេលារបស់បងប្អូន»
«ប្រើពេលវេលាប្រកបដោយភាពវៃឆ្លាត» ឬ «ដាក់ពេលវេលាឱ្យបានល្អបំផុត»
ដ្បិត សម័យនេះអាក្រក់ណាស់។
ពាក្យថា «ថ្ងៃ» គឺជាពាក្យប្រៀបធៀបសម្រាប់អ្វីដែលមនុស្សធ្វើក្នុងពេលថ្ងៃនោះ។
ការបកប្រែផ្សេងទៀត:
«ពីព្រោះមនុស្សនៅជុំវិញបងប្អូនកំពុងធ្វើរឿងអាក្រក់គ្រប់យ៉ាង»
Ephesians 5:18
ប្រយោគភ្ជាប់:
លោកប៉ូលបញ្ចប់ការបង្រៀនរបស់គាត់ទៅលើរបៀបដែលអ្នកជឿទាំងអស់គួររស់នៅ។
កុំឲ្យស្រវឹងស្រា
«ហើយបងប្អូនមិនគួរស្រវឹងពីការផឹកស្រាទេ »
ផ្ទុយទៅវិញ ចូរឲ្យបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ
«ផ្ទុយទៅវិញបងប្អូនគួរតែត្រូវបានគ្រប់គ្រងដោយព្រះវិញ្ញាណដ៏វិសុទ្ធ»
ដោយទំនុកតម្កើង ទំនុកសរសើរព្រះជាម្ចាស់ និងចម្រៀងមកពីព្រះវិញ្ញាណ
ទី១អត្ថន័យដែលអាចទៅរួចគឺថា)
លោកប៉ូលកំពុងប្រើពាក្យទាំងនេះជាការរួមបញ្ចូលគ្នាសម្រាប់
«ចម្រៀងសរសើរតម្កើងព្រះជាម្ចាស់គ្រប់ប្រភេទ» ឬ ២)

លោកប៉ូលកំពុងរាយបញ្ជីប្រភេទតន្ត្រីជាក់លាក់។
ទំនុកសរសើរ
ទី១អត្ថន័យប្រហែលជា) ដកស្រង់ចេញពីកណ្ឌទំនុកតម្កើងឬ ២)
ចម្រៀងថ្វាយបង្គំណាមួយ។
ទំនុកសរសើរព្រះជាម្ចាស់
ចម្រៀងដែលសរសើរព្រះបិតាឬព្រះរាជបុត្រា
ចម្រៀងមកពីព្រះវិញ្ញាណ
ទី១អត្ថន័យប្រហែល) ទាំងនេះគឺជាចម្រៀងអំពីព្រះជាម្ចាស់ឬ ២)
ទាំងនេះគឺជាចម្រៀងដែលផ្តល់ដោយព្រះវិញ្ញាណដ៏វិសុទ្ធឬ ៣)
មនុស្សធ្វើនៅក្នុងទីងងឹត
ហើយមិនត្រូវការពាក្យដាច់ដោយឡែកពីគ្នាឡើយ។
Ephesians 5:22
ប្រយោគភ្ជាប់:
លោកប៉ូលចាប់ផ្តើមដើម្បីពន្យល់ពីរបៀបដែលពួកគ្រិសបរិស័ទត្រូវចុះចូលចំពោះគ្នាទៅវិញទៅមក
(៥:១៨) ។
គាត់ចាប់ផ្តើមជាមួយនឹងការបង្រៀនដល់ប្រពន្ធនិងស្វាមីអំពីរបៀបដែលពួកគេគួរប្រព្រឹត្តចំពោះគ្នាទៅវិញ
ស្វាមីនាំមុខភរិយាយ៉ាងណា .. ដូចជាព្រះគ្រិស្តនាំមុខក្រុមជំនុំយ៉ាងនោះដែរ
ពាក្យថា «ក្បាល» តំណាងឱ្យអ្នកដឹកនាំ។
Ephesians 5:25
ប្រយោគភ្ជាប់:
នៅទីនេះពាក្យ «ខ្លួនគាត់» និង «គាត់» សំដៅទៅលើព្រះគ្រិស្ត។ ពាក្យថា «នាង»
សំដៅទៅក្រុមជំនុំ។
ដោយសារតែមនុស្សមានទំនោរធ្វើបាបនិងធ្វើអ្វីៗដែលបង្កគ្រោះថ្នាក់ឬអាក្រក់បងប្អូនគួរតែបកប្រែការនេះតាមន័យត្រង់។
នៅទីនេះ «សេចក្តីស្រឡាញ់»
សំដៅទៅលើការបម្រើដោយមិនគិតពីខ្លួនឯងឬផ្តល់សេចក្តីស្រឡាញ់ដល់ភរិយា។
ដូចជាមនុស្សម្នាក់ដែលបានស្លាប់ត្រូវតែរស់ឡើងវិញដើម្បីឆ្លើយតបឬ
«បានអនុញ្ញាតឱ្យមនុស្សសម្លាប់ទ្រង់»
ដើម្បីត្រូវបានបរិសុទ្ធដោយការលាងនឹងទឹក
ទី១អត្ថន័យប្រហែលជា) លោកប៉ូលចង់សំដៅទៅលើការ
ធ្វើរបស់ព្រះជាម្ចាស់ឲ្យមនុស្សរបស់ព្រះគ្រិស្តស្អាតតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់និងតាមរយៈពិធីបុ
ទី២) លោកប៉ូលកំពុងនិយាយថាព្រះជាម្ចាស់បាន ធ្វើឲ្យ
យើងស្អាតខាងវិញ្ញាណពីអំពើបាបរបស់យើងតាមរយៈព្រះបន្ទូលរបស់ព្រះនៅពេលដែលយើងសម្អាតរូបក
ដើម្បីឲ្យព្រះគ្រិស្តនឹងអត់ទោសឱ្យគាត់ហើយផ្តល់ឱ្យគាត់នូវជីវិតថ្មីដូចជាពន្លឺបង្ហាញពីអ្វីដែលពិតជាមាននៅ
បូជាព្រះជន្មសម្រាប់ក្រុមជំនុំ ... ឲ្យក្រុមជំនុំបានទៅជាវិសុទ្ធ ... សម្អាតដោយការលាងនឹងទឹក
លោកប៉ូលនិយាយអំពីការជួបជុំគ្នារបស់អ្នកជឿដូចជាស្ត្រីដែលព្រះយេស៊ូនឹងរៀបការជាមួយ។
ការបកប្រែផ្សេងទៀត: «សម្រាប់យើង ... ធ្វើឱ្យយើងវិសុទ្ធ ... សំអាតយើង»
ឥតស្លាកស្នាម ឥតជ្រីវជ្រួញ
ការបកប្រែផ្សេងទៀតអំពីក្រុមជំនុំហាក់ដូចជាសម្លៀកបំពាក់ដែលស្អាតហើយនៅល្អស្អាត។
ព្រះអង្គប្រើគំនិតដូចគ្នានឹងវិធីពីរយ៉ាងដើម្បីបញ្ជាក់ភាពវិសុទ្ធរបស់ក្រុមជំនុំ។
ឥតខ្ចោះត្រង់ណាឡើយ គឺឲ្យបានទៅជាវិសុទ្ធ ឥតសៅហ្មង។
ឃ្លា «ដោយគ្មានកំហុស» មានន័យជារួមដូចគ្នានឹង «វិសុទ្ធ» ។
លោកប៉ូលប្រើទាំងពីររួមគ្នាដើម្បីបញ្ជាក់ភាពវិសុទ្ធរបស់ក្រុមជំនុំ។
Ephesians 5:28
ស្រឡាញ់រូបកាយខ្លួនឯង
ថាមនុស្សស្រឡាញ់រាងកាយខ្លួនឯងអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
ការបកប្រែផ្សេងទៀត: «ដូចជាស្វាមីស្រឡាញ់រាងកាយរបស់ខ្លួនឯង»
ផ្ទុយទៅវិញ អ្នកនោះតែងចិញ្ចឹមបីបាច់ថែរក្សារូបកាយនោះ
«ប៉ុន្តែចិញ្ចឹម»
យើងទាំងអស់គ្នាជាសរីរាង្គនៃរូបកាយនោះ។
ទី១អត្ថន័យប្រហែលជា) «យើងជាសមាជិកនៃរូបកាយអ្នកជឿរបស់ទ្រង់ឬ ទី២)
អ្នកជឿសមនឹងនៅជាមួយគ្នាដើម្បីបង្កើតជារូបកាយរបស់ព្រះគ្រិស្តដូចជាចំណែកនៃរូបកាយមនុស្សសម
Ephesians 5:31
ប្រយោគភ្ជាប់:
ការដកស្រង់ចេញពីអត្ថបទសរសេររបស់លោកម៉ូសេនៅក្នុងសញ្ញាចាស់។
ពត៌មានទូទៅ
ពាក្យ «របស់គាត់» និង «ខ្លួនគាត់» សំដៅទៅលើអ្នកជឿបុរសដែលរៀបការ។

[1]កូនរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតារបស់ខ្លួន ដោយយល់ដល់ព្រះអម្ចាស់ ធ្វើដូច្នេះទើបត្រឹមត្រូវ។[2]«ចូរលើកកិត្តិយសមាតាបិតារបស់ខ្លួន» (នេះជាបទបញ្ជាទីមួយ
មានជាប់ទាំងព្រះបន្ទូលសន្យាមកជាមួយផង)[3]«ដូច្នេះ អ្នករាល់គ្នានឹងបានសេចក្ដីសុខ និងរស់នៅលើផែនដីបានអាយុវែង»។
[4]រីឯបងប្អូនជាឪពុកវិញ កុំនាំឲ្យកូនខ្លួនមួម៉ៅឡើយ។ ផ្ទុយទៅវិញ ត្រូវចេះប្រៀនប្រដៅកូន និងផ្ដល់ដំបូន្មានកូនស្របតាមព្រះអម្ចាស់។
[5]រីឯបងប្អូនជាអ្នកបម្រើអើយ ចូរស្ដាប់បង្គាប់ម្ចាស់របស់ខ្លួននៅលើផែនដីនេះ ដោយគោរព និងញាប់ញ័រ ដោយស្មោះអស់ពីចិត្ត។[6]ចូរស្ដាប់បង្គាប់អ្នកទាំងនោះ
ដូចស្ដាប់បង្គាប់ព្រះគ្រិស្ដដែរ។ កុំស្ដាប់បង្គាប់គ្រាន់តែចង់ឲ្យម្ចាស់ឃើញ និងផ្គាប់ចិត្តពួកគេឡើយ។ ផ្ទុយទៅវិញ ចូរស្ដាប់បង្គាប់ម្ចាស់ ដូចជាអ្នកបម្រើព្រះគ្រិស្ដ
ដែលធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់។[7]ចូរបម្រើម្ចាស់ឲ្យអស់ពីចិត្ត ទុកដូចជាបងប្អូនរាល់គ្នាបម្រើព្រះអម្ចាស់ ពុំមែនបម្រើមនុស្សទេ[8]ព្រោះយើងដឹងថា
ទង្វើល្អដែលមនុស្សម្នាក់ប្រព្រឹត្ត នឹងទទួលរង្វាន់ពីព្រះអម្ចាស់ មិនថាអ្នកនោះជាអ្នកងារ ឬអ្នកជាក្ដី។
[9]រីឯបងប្អូនជាម្ចាស់វិញ ចូរប្រព្រឹត្តចំពោះអ្នកបម្រើខ្លួនបែបនោះដែរ។ កុំគំរាមកំហែងពួកគេ។ បងប្អូនដឹងស្រាប់ហើយថា ម្ចាស់ពួកគេ និងម្ចាស់បងប្អូនគង់នៅស្ថានបរមសុខ
ហើយព្រះអង្គពុំរើសមុខនរណាម្នាក់ឡើយ។
[10]ចុងក្រោយបង្អស់ ចូររឹងមាំឡើងក្នុងព្រះអម្ចាស់ ដោយសារព្រះចេស្ដាដ៏ខ្លាំងពូកែរបស់ព្រះអង្គ។[11]ចូរបងប្អូនពាក់គ្រប់គ្រឿងសស្ត្រាវុធរបស់ព្រះជាម្ចាស់
ដើម្បីឲ្យបងប្អូនអាចឈរមាំមួនតទល់នឹងផែនការរបស់មារកំណាចៗ
[12]ដ្បិត យើងពុំមែនតយុទ្ធទល់នឹងមនុស្សទេ ផ្ទុយទៅវិញ យើងតយុទ្ធទល់នឹងមេត្រួតត្រាក្នុងលោកីយ៍ដ៏ងងឹតនេះ ហើយតយុទ្ធទល់នឹងវិញ្ញាណអាក្រក់ទាំងឡាយដែលនៅ
ស្ថានលើដែរ។[13]ហេតុនេះ ចូរបងប្អូនពាក់គ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ដើម្បីឲ្យបងប្អូនអាចតទល់នៅថ្ងៃអពមង្គល ហើយមានជំហររឹងប៉ឹងដដែល ដោយ
បានប្រើគ្រប់មធ្យោបាយទាំងអស់។
[14]ដូច្នេះ ចូរមានជំហររឹងប៉ឹងឡើង ដោយបងប្អូនបានពាក់សេចក្ដីពិតក្រវាត់ចង្កេះ និងយកសេចក្ដីសុចរិតធ្វើជាអាវក្រោះ។[15]បន្ទាប់មក យកចិត្តប្រុងប្រៀបផ្សាយ
ដំណឹងល្អអំពីសេចក្ដីសុខសាន្ត មកពាក់ជាស្បែកជើង។[16]នៅគ្រប់កាលៈទេសៈទាំងអស់ ចូរយកជំនឿធ្វើជាខែល ដើម្បីឲ្យបងប្អូនអាចពន្លត់ព្រួញភ្លើងទាំងប៉ុន្មានរបស់
មារកំណាចបាន។
[17]ចូរទទួលការសង្គ្រោះធ្វើជាមួកដែក និងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ធ្វើជាដាវរបស់ព្រះវិញ្ញាណ។[18]ចូរអធិស្ឋានគ្រប់ពេលវេលា តាមការណែនាំរបស់ព្រះវិញ្ញាណ
ដោយប្រើទាំងពាក្យអធិស្ឋាន ទាំងពាក្យអង្វរគ្រប់យ៉ាង ហើយប្រុងស្មារតីទូលអង្វរព្រះជាម្ចាស់ ដោយចិត្តព្យាយាមបំផុតសម្រាប់ប្រជាជនដ៏វិសុទ្ធទាំង
អស់របស់ព្រះជាម្ចាស់។
[19]ចូរអធិស្ឋានសម្រាប់ខ្ញុំផង សូមព្រះអង្គប្រទានឲ្យខ្ញុំរកបានពាក្យត្រឹមត្រូវ ពេលណាខ្ញុំហាមាត់និយាយ។ សូមព្រះអង្គប្រទានឲ្យខ្ញុំមានចិត្តអង់អាច នាំគេឲ្យស្គាល់
គម្រោងការលាក់កំបាំងនៃដំណឹងល្អ។[20]គឺដំណឹងល្អនេះហើយ បានធ្វើឲ្យខ្ញុំក្លាយជាទូតរបស់ព្រះអង្គ ដែលជាប់ឃុំឃាំង ដូច្នេះ ខ្ញុំសូមប្រកាសទាំងមានចិត្តអង់អាច និយាយ
តាមពាក្យដែលខ្ញុំត្រូវនិយាយ។
[21]លោកទីឃីកុស ជាបងប្អូនដ៏ជាទីស្រឡាញ់ និងជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះអម្ចាស់ នឹងជម្រាបប្រាប់បងប្អូនអំពីអ្វីៗគ្រប់យ៉ាងដល់បងប្អូន
ដើម្បីឲ្យបងប្អូនបានដឹងអំពីកិច្ចការដែលខ្ញុំធ្វើនោះដែរ។[22]ខ្ញុំចាត់គាត់ឲ្យមករកបងប្អូន ក្នុងគោលបំណងឲ្យបងប្អូនបានឮដំណឹងពីយើង និងឲ្យគាត់លើកទឹកចិត្តបងប្អូន
ដោយផ្ទាល់។
[23]សូមព្រះជាម្ចាស់ជាព្រះបិតា និងព្រះយេស៊ូគ្រិស្ដជាព្រះអម្ចាស់ ប្រទានសេចក្ដីសុខសាន្ត និងសេចក្ដីស្រឡាញ់ ព្រមទាំងជំនឿមកបងប្អូន។[24]សូមព្រះគុណរបស់
ព្រះជាម្ចាស់ស្ថិតនៅជាមួយ អស់អ្នកដែលស្រឡាញ់ព្រះអម្ចាស់យេស៊ូគ្រិស្ដនៃយើង ដោយចិត្តស្រឡាញ់ឥតប្រែប្រួលសោះឡើយ។

Ephesians 6:1

ប្រយោគភ្ជាប់:

លោកប៉ូលបន្តដើម្បីពន្យល់អំពីរបៀបដែលគ្រិស្តបរិស័ទគឺត្រូវចុះចូលចំពោះគ្នាទៅវិញទៅមក។

គាត់ផ្តល់ការបង្រៀនដល់កុមារ មាតាបិតា កម្មករ និងចៅហ្វាយ។

ពតិមានទូទៅ:

ពាក្យដំបូង «របស់អ្នក» គឺពហុវចនៈ។ បន្ទាប់មកប៉ូលដកស្រង់ពីលោកម៉ូសេ។

លោកម៉ូសេបានកំពុងនិយាយទៅកាន់ប្រជាជនអ៊ីស្រាអែលដូចជាពួកគេជាមនុស្សតែមួយ

«របស់អ្នក» និង «អ្នក» គឺមានលក្ខណៈតែមួយ។

អ្នកប្រហែលជាត្រូវការបកប្រែវាជាពហុវចនៈ។

កូនរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតារបស់ខ្លួន ដោយយល់ដល់ព្រះអម្ចាស់

លោកប៉ូលរម្លឹកកូនៗឱ្យស្តាប់បង្គាប់មាតាបិតាខាងរូបកាយ។

Ephesians 6:4

កុំនាំឲ្យកូនខ្លួនមួម៉ៅឡើយ

«កុំធ្វើឱ្យកូនរបស់អ្នកខឹង» ឬ «កុំបង្កឱ្យកូនរបស់អ្នកខឹង»

ត្រូវចេះប្រៀនប្រដៅកូន និងផ្ដល់ដំបូន្មានកូនស្របតាមព្រះអម្ចាស់។

«ជួយពួកគេឱ្យរីកចម្រើនក្នុងការបណ្តុះបណ្តាលនិងការបង្រៀនរបស់ព្រះអម្ចាស់»

Ephesians 6:5

ចូរស្ដាប់បង្គាប់

«គោរពតាម» នេះគឺជាបទបញ្ជា។

ដោយគោរព និងញាប់ញ័រ

ឃ្លាពាក្យ «ការគោរពនិងញាប់ញ័រ»

ប្រើពាក្យស្រដៀងគ្នាពីរដើម្បីសង្កត់ធ្ងន់លើគំនិតនៃកិត្តិយសនិងអាកប្បកិរិយារបស់ពួកគេ

ញាប់ញ័រ

«ដូចជាបងប្អូនបានកំពុងញ័រជាមួយការភ័យខ្លាច»

ដោយស្មោះអស់ពីចិត្ត

«ស្មោះត្រង់ទាំងស្រុង»

ដូចជាអ្នកបម្រើព្រះគ្រិស្ដ

បម្រើម្ចាស់លើផែនដីរបស់បងប្អូនដូចជាម្ចាស់លើផែនដីរបស់បងប្អូនគឺព្រះគ្រិស្តផ្ទាល់។

ចូរបម្រើម្ចាស់ឲ្យអស់ពីចិត្ត ទុកដូចជាបងប្អូនរាល់គ្នាបម្រើព្រះអម្ចាស់ ពុំមែនបម្រើមនុស្សទេ

«ចូរធ្វើការដោយអំណរព្រោះបងប្អូនកំពុងធ្វើការសម្រាប់ព្រះអម្ចាស់ហើយមិនមែនផ្តាប់ចិត្តមនុស្ស

Ephesians 6:9

ចូរប្រព្រឹត្តចំពោះអ្នកបម្រើខ្លួនបែបនោះដែរ

«ដូចជាអ្នកបម្រើត្រូវធ្វើល្អដល់ចៅហ្វាយរបស់ខ្លួនបងប្អូនក៏ត្រូវតែធ្វើល្អចំពោះអ្នកបម្រើរបស់បងប្អូនដែរ» ឬ «ដូចជាអ្នកបម្រើត្រូវធ្វើល្អដល់ចៅហ្វាយរបស់ខ្លួនបងប្អូនក៏ត្រូវតែធ្វើល្អចំពោះអ្នកបម្រើរបស់បងប្អូនដែរ» (

៦: ៥)

បងប្អូនដឹងស្រាប់ហើយថា ម្ចាស់ពួកគេ និងម្ចាស់បងប្អូនគង់នៅស្ថានបរមសុខ

ដែលបងប្អូនដឹងថាព្រះគ្រិស្តជាម្ចាស់លើទាំងពីរទាំងអ្នកបម្រើនិងចៅហ្វាយហើយដែលព្រះអង្គគង់នៅស្ថានមរ

ហើយព្រះអង្គពុំរើសមុខនរណាម្នាក់ឡើយ

«ព្រះអង្គវិនិច្ឆ័យគ្រប់ៗរគ្នាតាមរបៀបដូចគ្នា»

Ephesians 6:10

ប្រយោគភ្ជាប់:

លោកប៉ូលផ្តល់ការបង្រៀនដែលធ្វើឲ្យអ្នកជឿរឹងមាំនៅក្នុងសមរភូមិដែលយើងរស់នៅសម្រាប់ព្រះជាម្ចាស់

ដោយសារព្រះចេស្តាដ៏ខ្លាំងពូកែរបស់ព្រះអង្គ

«អំណាចដ៏អស្ចារ្យរបស់ទ្រង់»។ សូមមើលពីរបៀបដែល

«អំណាចដ៏អស្ចារ្យរបស់ទ្រង់» ត្រូវបានបកប្រែនៅជិតចុងបញ្ចប់នៃ ១:១៩ ។

ចូរបងប្អូនពាក់គ្រប់គ្រឿងសស្ត្រាវុធរបស់ព្រះជាម្ចាស់

ដើម្បីឲ្យបងប្អូនអាចឈរមាំមួនតទល់នឹងផែនការរបស់មារកំណាចៗ

គ្រិស្តបរិស័ទគួរតែប្រើប្រាស់ធនធានទាំងអស់ដែលព្រះជាម្ចាស់ប្រទានអោយដើម្បីឈរប្រឆាំងនឹងអារក្សដូ

ផែនការរបស់មារកំណាចៗ

ផែនការបោកបញ្ឆោត

Ephesians 6:12

ការបង្ហាញនេះសំដៅទៅលើមនុស្សមិនមែនវិញ្ញាណដែលមិនមានរាងកាយមនុស្សទេ។

ហេតុនេះ ចូរបងប្អូនពាក់គ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់

គ្រិស្តបរិស័ទគួរតែប្រើការពារធនធានដែលព្រះជាម្ចាស់ប្រទានដល់ពួកគេក្នុងការតយុទ្ធនឹងអារក្សតាមរបៀ

ដើម្បីឲ្យបងប្អូនអាចតទល់នៅថ្ងៃអពមង្គល

ពាក្យថា "ឈររឹងមាំ" តំណាងឱ្យការតស៊ូឬតយុទ្ធអ្វីមួយដោយជោគជ័យ។

ការបកប្រែផ្សេងទៀត: «ដូច្នេះអ្នកអាចទប់ទល់នឹងអំពើអាក្រក់បាន

Ephesians 6:14

ចិត្តមនុស្ស

ការរឹងប៉ឹងឡើង

generated on Wed Sep 10 16:16:32 2025

ពាក្យថា «ឈរ» តំណាងឱ្យការតស៊ូឬតយុទ្ធអ្វីមួយដោយជោគជ័យ។
សូមមើលពីរបៀបដែលអ្នកបកប្រែ «ឈររឹងមាំ» នៅក្នុង ៦:១២។
«ដូច្នេះត្រូវតស៊ូនឹងវិញ្ញាណអាក្រក់»
ពាក់សេចក្ដីពិតក្រវាត់ចង្កេះ
ប្រកាន់សេចក្ដីពិតគ្រប់អ្វីៗទាំងអស់ជាមួយគ្នាសម្រាប់អ្នកជឿដូចជាខ្សែក្រវ៉ាត់ទប់សម្លៀកបំពាក់ជាដើម។
សេចក្ដីពិត... សេចក្ដីសុចរិត
យើងត្រូវដឹងការពិតហើយប្រព្រឹត្តតាមរបៀបដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់។
ជាអាវក្រោះ
ជាអាវក្រោះនៃសេចក្ដីសុចរិត
ទី១អត្ថន័យប្រហែលជា)
អំណោយទាននៃសេចក្ដីសុចរិតគ្របបាំងបេះដូងរបស់អ្នកជឿដូចគ្នានឹងអាវក្រោះការពារដូច្នេះ
ទី២)
ការរស់នៅរបស់យើងដូចជាព្រះជាម្ចាស់ចង់ឲ្យយើងប្រទានឲ្យយើងនូវមនសិការច្បាស់
បន្ទាប់មក យកចិត្តប្រុងប្រៀបផ្សាយដំណឹងល្អអំពីសេចក្ដីសុខសាន្ត មកពាក់ជាស្បែកជើង។
ដូចជាទាហានពាក់ស្បែកជើងដើម្បីផ្តល់ឱ្យគាត់ឈរជើងរឹងមាំអ្នកជឿត្រូវតែមានចំណេះ
អ្នកជឿត្រូវតែប្រើជំនឿដែលព្រះជាម្ចាស់ប្រទានដើម្បីការពារនៅពេលអារក្សវាយប្រហារគឺដូចជាទាហាន
នៅគ្រប់កាល:ទេស:ទាំងអស់ ចូរយកជំនឿធ្វើជាខែល
ពន្លត់ព្រួញភ្លើងទាំងប៉ុន្មានរបស់មារកំណាចបាន។
ការវាយប្រហាររបស់អារក្សប្រឆាំងនឹងអ្នកជឿគឺដូចជាព្រួញដែលកំពុងបាញ់ទៅលើទាហាន
Ephesians 6:17
ចូរទទួលការសង្គ្រោះធ្វើជាមួកដែក
សេចក្ដីសង្គ្រោះដែលបានផ្តល់មកតាមរយៈព្រះជាម្ចាស់ការពារចិត្តគំនិតរបស់អ្នកជឿដូច
យកព្រះបន្ទូលរបស់ព្រះជាម្ចាស់ធ្វើជាដាវរបស់ព្រះវិញ្ញាចូរអធិស្ឋានគ្រប់ពេលវេលា តាមការណែនាំ
របស់ព្រះវិញ្ញាណ
ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលត្រូវបានបណ្តាលដោយព្រះវិញ្ញាណដ៏វិសុទ្ធគឺត្រូវបាន
ចូរអធិស្ឋានគ្រប់ពេលវេលា តាមការណែនាំរបស់ព្រះវិញ្ញាណ
«ចូរអធិស្ឋានគ្រប់ពេលដោយព្រះវិញ្ញាណដ៏វិសុទ្ធពេលបងប្អូនអធិស្ឋានហើយធ្វើការទូលសុំអ្វីក៏ត្រូវ»
ដោយចិត្តព្យាយាម
«ដូច្នេះបងប្អូនអាចអធិស្ឋានតាមវិធីនេះ»។
នេះសំដៅទៅលើអាកប្បកិរិយានៃការយកគ្រឿងសឹករបស់ព្រះជាម្ចាស់។
ប្រុងស្មារតីទូលអង្វរព្រះជាម្ចាស់ ដោយចិត្តព្យាយាមបំផុតសម្រាប់ប្រជាជនដ៏វិសុទ្ធទាំង
អស់របស់ព្រះជាម្ចាស់។
«តស៊ូក្នុងការប្រុងប្រយ័ត្នហើយអធិស្ឋានសម្រាប់ប្រជាជនដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ទាំងអស់»
ឬ «ចូរអធិស្ឋានដោយប្រុងស្មារតីជានិច្ចសំរាប់អ្នកជឿទាំងអស់»
[illegible]
ប្រយោគភ្ជាប់:
នៅក្នុងការបិទរបស់គាត់ប៉ូលបានសុំឱ្យពួកគេអធិស្ឋានសម្រាប់ភាពក្លាហានរបស់គាត់ក្នុងការប្រាប់ដំណឹង
សូមព្រះអង្គប្រទានឲ្យខ្ញុំរក
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត
«ដែលព្រះជាម្ចាស់អាចប្រទានឱ្យខ្ញុំនូវពាក្យ» ឬ
[illegible]
ពេលណាខ្ញុំហាមាត់និយាយ។ សូមព្រះអង្គប្រទានឲ្យខ្ញុំមានចិត្តអង់អាច
[illegible]
ពេលណាខ្ញុំហាមាត់និយាយ
[illegible]
ឱ្យខ្ញុំមានភាពក្លាហានក្នុងការប្រកាសអំពីដំណឹងល្អនៃសេចក្ដីសុខសាន្តដើម្បីត្រៀមខ្លួនដើម្បីប្រកាស។
[illegible]
ឥឡូវខ្ញុំកំពុងជាប់ពន្ធនាគារព្រោះខ្ញុំជាអ្នកតំណាងរបស់ដំណឹងល្អ។
ខ្ញុំសូមប្រកាសទាំងមានចិត្តអង់អាច និយាយតាមពាក្យដែលខ្ញុំត្រូវនិយាយ។
[illegible] ការបកប្រែផ្សេងទៀត:
«ដូច្នេះសូមអធិស្ឋានថាពេលណាក៏ដោយខ្ញុំបង្រៀនដំណឹងល្អខ្ញុំនឹងនិយាយវាដោយក្លាហានពេលដែលខ្ញុំគ
ឬ «អធិស្ឋានថាខ្ញុំអាចនិយាយដំណឹងល្អដោយក្លាហានដូចដែលខ្ញុំគួរតែ»
[illegible]
លោកទីយីកុស
លោកទីយីកុស
[illegible]
Ephesians 6:23
លោកប៉ូលបានបញ្ចប់សំបុត្ររបស់គាត់ទៅកាន់អ្នកជឿនៅទីក្រុងអេភេសូរជាមួយការប្រទានពរនិងព្រះគុណ
។

ភីលីព

1 [1]ខ្ញុំ ប៉ូល និងធីម៉ូថេ គឺជាអ្នកបម្រើរបស់ព្រះគ្រិស្តយេស៊ូ សូមជម្រាបមកដល់អស់អ្នកដែលបានញែកសម្រាប់ព្រះគ្រិស្តយេស៊ូនៅក្រុងភីលីព ព្រមទាំងអ្នកដឹកនាំ និង
អ្នកបម្រើទាំងអស់។[2]សូមព្រះគុណ និងសេចក្ដីសុខសាន្តបានផ្តល់ដល់បងប្អូន មកពីព្រះជាម្ចាស់ជាព្រះបិតារបស់យើង និងព្រះអម្ចាស់យេស៊ូគ្រិស្ត។
[3]ខ្ញុំតែងតែអរព្រះគុណព្រះជាម្ចាស់របស់ខ្ញុំជានិច្ច នៅពេលខ្ញុំនឹកគិតដល់បងប្អូន[4]ខ្ញុំតែងតែអធិស្ឋានសម្រាប់បងប្អូនដោយចិត្តរីករាយ ដែលខ្ញុំបានទូលអង្វរ។
[5]ខ្ញុំអរគុណដល់ព្រះជាម្ចាស់ សម្រាប់បងប្អូនដែលបានរួមចំណែកក្នុងការផ្សាយដំណឹងល្អ តាំងពីថ្ងៃដំបូងរហូតមកដល់សព្វថ្ងៃ។[6]ខ្ញុំជឿជាក់ថា ក្នុងគ្រប់ការទាំងអស់
ដែលព្រះជាម្ចាស់បានធ្វើមការល្អនៅក្នុងបងប្អូន នោះព្រះអង្គនឹងបង្ហើយ រហូតដល់ថ្ងៃព្រះយេស៊ូគ្រិស្តយាងមក។
[7]ជាការត្រឹមត្រូវណាស់ ដែលខ្ញុំមានអារម្មណ៍បែបនេះជាមួយបងប្អូនទាំងអស់គ្នា ដោយសារតែបងប្អូនស្ថិតនៅក្នុងដួងចិត្តរបស់ខ្ញុំ។
បងប្អូនទាំងអស់គ្នាក្លាយជាគូកនរបស់ខ្ញុំ ដោយព្រះគុណរួមទាំងពេលដែលខ្ញុំនៅជាប់ឃុំឃាំង ហើយដើម្បីការពារ និងប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់។[8]ព្រះជាម្ចាស់ជា
សាក្សីស្រាប់ហើយថា ខ្ញុំស្រឡាញ់បងប្អូនទាំងអស់គ្នាយ៉ាងខ្លាំង ដោយចិត្តអាណិតមេត្តាមកពីព្រះគ្រិស្តយេស៊ូ។
[9]នេះជាពាក្យអធិស្ឋានរបស់ខ្ញុំ សូមឲ្យបងប្អូនមានសេចក្ដីស្រឡាញ់កាន់តែខ្លាំងឡើងៗ ធ្វើឲ្យបងប្អូនចេះដឹងច្បាស់ និងយល់សព្វគ្រប់ទាំងអស់។[10]និងសូមឲ្យបងប្អូនចេះ
ពិចារណាមើលថា ការអ្វីប្រសើរជាងគេ ដូច្នេះ នៅថ្ងៃព្រះគ្រិស្តយាងមក បងប្អូននឹងបានវិសុទ្ធ គ្មានកំហុសអ្វីឡើយ។[11]ហើយសូមឲ្យបងប្អូនបានពោរពេញដោយផលនៃ
សេចក្ដីសុចរិត ដែលមកពីព្រះយេស៊ូគ្រិស្ត ដើម្បីលើកតម្កើងសិរីរុងរឿង និងសរសើរតម្កើងព្រះជាម្ចាស់។
[12]បងប្អូនអើយ ឥឡូវខ្ញុំចង់ប្រាប់ឲ្យបានដឹងថា អ្វីដែលបានកើតឡើងដល់រូបខ្ញុំក្នុងការបម្រើនោះ ដើម្បីចំណេញសម្រាប់ដំណឹងល្អវិញ។[13]ការនេះបានឃើញយ៉ាងច្បាស់
នៅពេលដែលខ្ញុំជាប់ឃុំឃាំងព្រោះព្រះគ្រិស្តដូចជាពន្លឺដែលភ្លឺឲ្យទាំងអ្នកយាមព្រះរាជវាំង និងមនុស្សគ្រប់គ្នាបានឃើញផងដែរ។[14]ដោយសារតែខ្ញុំជាប់ឃុំឃាំងនេះហើយ
បងប្អូនភាគច្រើនបានទុកចិត្តលើព្រះអម្ចាស់ ហើយពួកគេក៏បានការលើកទឹកចិត្តក្លាហាន ក្នុងការប្រកាសព្រះបន្ទូលរបស់ព្រះ ដោយឥតខ្លាចឡើយ។
[15]មានបងប្អូនខ្លះប្រកាសដំណឹងល្អអំពីព្រះគ្រិស្ត ដោយចិត្តច្រណែនឈ្នានីស ចង់ប្រណាំងប្រជែង តែបងប្អូនខ្លះទៀតថ្លែងព្រះបន្ទូលដោយមានបំណងល្អ។[16]ក្រោយមក
ពួកគេធ្វើដោយចេញពីក្ដីស្រឡាញ់ និងដឹងថាព្រះអម្ចាស់បានដាក់ខ្ញុំកន្លែងនេះ ដើម្បីការពារដំណឹងល្អ។[17]ប៉ុន្តែ អ្នកដែលផ្សាយដំណឹងពីមុនអំពីព្រះគ្រិស្ត
ដើម្បីធ្វើដោយគំនិតប្រកួតចង់ឈ្នះនោះវិញ គេមានគោលបំណងមិនល្អ។គេស្មានថានឹងធ្វើឲ្យខ្ញុំរឹងរឹតតែវេទនា ក្នុងពេលដែលខ្ញុំជាប់ឃុំឃាំង។
[18]តើហេតុអ្វីទៅ? ទោះជាវិធីណាក៏ដោយ បើទោះជាគេសម្តែងក្តី ឬស្មោះសរក្តី ក៏គេផ្សាយដំណឹងអំពីព្រះគ្រិស្តដែរ ហើយខ្ញុំនឹងសប្បាយចិត្តអំពីការនេះ[19]ដ្បិត ខ្ញុំដឹងថា ការ
នេះនឹងធ្វើឲ្យខ្ញុំទទួលការសង្គ្រោះទៅវិញទេ ដោយបងប្អូនអធិស្ឋានទៅសម្រាប់ខ្ញុំ ហើយពីព្រះវិញ្ញាណរបស់ព្រះយេស៊ូគ្រិស្តដល់ខ្ញុំផងដែរ។
[20]វាអាស្រ័យលើការទន្ទឹងរង់ចាំ និងយកចិត្តទុកដាក់របស់ខ្ញុំ ដោយសង្ឃឹមថា ខ្ញុំនឹងមិនត្រូវអាម៉ាស់មុខឡើយ។ ហើយនេះគឺជាមូលហេតុ ដែលខ្ញុំនៅតែមានចិត្តអង់អាច
ឥតរង្គើ ទោះបីជាខ្ញុំត្រូវរស់ ឬស្លាប់ក្តី ខ្ញុំនឹងលើកតម្កើងព្រះគ្រិស្តក្នុងរូបកាយខ្ញុំ។[21]សម្រាប់ខ្ញុំ បើរស់ ខ្ញុំរស់រួមជាមួយព្រះគ្រិស្ត ហើយបើស្លាប់ នោះបានជាកម្រៃវិញ។
[22]ប៉ុន្តែ បើខ្ញុំរស់ខាងឯសាច់ឈាមទៀតនោះ ដូច្នេះ មានន័យថា អ្វីដែលខ្ញុំធ្វើនឹងបានផល។ ខ្ញុំមិនដឹងជាជ្រើសរើសយកផ្លូវណាឡើយទេ? ខ្ញុំពិតជាមិនដឹងមែន។
[23]សម្រាប់ខ្ញុំពិតជារារែករវាងការទាំងពីរនោះ។ ខ្ញុំប៉ងប្រាថ្នាចង់លាចាកលោកនេះទៅនៅជាមួយព្រះគ្រិស្ត នោះគឺជាការប្រសើរជាង[24]ហើយបើខ្ញុំនៅរស់ក្នុង
សាច់ឈាមនេះទៀតនោះជាប្រយោជន៍សម្រាប់បងប្អូនវិញ។
[25]ខ្ញុំជឿជាក់ដូច្នេះ ដោយដឹងថា ខ្ញុំនឹងបន្តរស់នៅ ហើយស្នាក់នៅជាមួយបងប្អូនទាំងអស់គ្នា ដើម្បីឲ្យបងប្អូនបានលូតលាស់ឡើង ហើយមានអំណរនៅក្នុងជំនឿ។[26]ដ្បិត
នៅក្នុងខ្ញុំបងប្អូនរីកចម្រើនថែមទៀត រួមជាមួយព្រះគ្រិស្តយេស៊ូ ក្នុងពេលដែលខ្ញុំត្រឡប់មកវិញជួបបងប្អូនម្តងទៀត។[27]សូមបងប្អូនកាន់កិរិយាមារយាទឲ្យបានសមរម្យ

generated on Wed Sep 10 16:16:32 2025

សម្រាប់ដំណឹងល្អរបស់ព្រះគ្រិស្ត ដូច្នេះ ទោះបីជាខ្ញុំមកវិញ ឬមិនបានមកជួបបងប្អូនវិញក្តី នោះខ្ញុំតែងតែឮដំណឹង ពីការដែលបងប្អូនមានជំហរមាំមួនដោយមានចិត្តគំនិតតែមួយ ព្រមទាំងរួមចិត្តថ្លើមគ្នាតយុទ្ធ ដើម្បីជំនឿលើដំណឹងល្អ ផងដែរ។
[28]សូមបងប្អូនកុំភ័យខ្លាយ នឹងពួកដែលជាសត្រូវ ហើយទាស់នឹងប្រការណាមួយឡើយ។ នេះជាសញ្ញាបញ្ជាក់ឲ្យឃើញថា ពួកគេនឹងត្រូវវិនាសអន្តរាយ រីឯបងប្អូនវិញ នឹងទទួលការសង្គ្រោះ ហើយការនេះកើតពីព្រះជាម្ចាស់មក។[29]ដ្បិត ព្រះអង្គប្រណីសន្តោសបងប្អូនឲ្យបម្រើព្រះគ្រិស្ត ដោយមិនគ្រាន់តែជឿលើព្រះអង្គប៉ុណ្ណោះទេ ប៉ុន្តែ រួមទាំងរងទុក្ខលំបាករួមជាមួយព្រះអង្គទៀតដែរ[30]បងប្អូនបានតយុទ្ធរួមជាមួយខ្ញុំ ដូចបងប្អូនធ្លាប់បានឃើញខ្ញុំតយុទ្ធស្រាប់ហើយ ហើយដូចបងប្អូនឮថាខ្ញុំកំពុងតែតយុទ្ធនៅឡើយ។

Philippians 1:1

ប្រយោគភ្ជាប់:

អ្នកនិពន្ធផ្តល់ការសួរសុខទុក្ខដល់ក្រុមជំនុំនៅភីលីព។

ព័ត៌មានទូទៅ:

ពីព្រោះលោកប៉ូលសរសេរនៅក្នុងសំបុត្រក្រោយមកនិយាយថា «ខ្ញុំ» វាគឺជាទៅដែលសន្មតថាគាត់និពន្ធហើយថាលោកធីម៉ូថេដែលនៅជាមួយគាត់សរសេរ ទាំងអស់ជំនួយដោយពាក្យ «អ្នក» និង «របស់អ្នក» នៅក្នុងសំបុត្រនិយាយសំដៅទៅលើអ្នកនៅក្នុងក្រុមភីលីពហើយគឺជាពហុវចៈ។ ពាក្យថា «របស់យើង» ប្រហែលជានិយាយសំដៅទៅលើអ្នកជឿទាំងអស់នៅក្នុងព្រះគ្រិស្តរួមបញ្ចូលទាំងលោកប៉ូល ទីម៉ូថេ និង អ្នកជឿនៅភីលីព។

លោកប៉ូល និងទីម៉ូថេ

ប្រសិនបើភាសារបស់អ្នកមានរបៀបពិសេសនៃការណែនាំអ្នកនិពន្ធសំបុត្រ សូមប្រើវានៅទីនេះ។

ខ្ញុំ ប៉ូល និងធីម៉ូថេ គឺជាអ្នកបម្រើរបស់ព្រះគ្រិស្តយេស៊ូ

«ទីម៉ូថេ.យើងគឺជាអ្នកបម្រើរបស់ព្រះគ្រិស្តយេស៊ូ »

ដល់អស់អ្នកដែលបានញែកសម្រាប់ព្រះគ្រិស្តយេស៊ូ

«ដល់អស់អ្នកជឿនៅក្នុងព្រះគ្រិស្តយេស៊ូ»

អ្នកដឹកនាំ និងអ្នកបម្រើទាំងអស់។

«អ្នកដឹកនាំនៃក្រុមជំនុំ»

Philippians 1:3

ខ្ញុំអរគុណដល់ព្រះជាម្ចាស់ សម្រាប់បងប្អូនដែលបានរួមចំណែកក្នុងការផ្សាយដំណឹងល្អ

លោកប៉ូលគឺបង្ហាញការអរគុណទៅដល់ព្រះជាម្ចាស់ដែលក្រុមជំនុំនៅភីលីពគឺកំពុងផ្សាយដំណឹងល្អ(ដូចដែលគាត់បាននិយាយថា)

ការបកប្រែផ្សេងទៀត:

«ខ្ញុំថ្វាយការអរព្រះគុណទៅដល់ព្រះជាម្ចាស់ដែលបងប្អូនប្រកាសដំណឹងល្អ»

ខ្ញុំជឿជាក់ថា

«ខ្ញុំប្រាកដថា»

ដែលព្រះជាម្ចាស់បានផ្តើមការល្អ

«ព្រះជាម្ចាស់ ដែលបានចាប់ផ្តើម»

Philippians 1:7

ជាការត្រឹមត្រូវណាស់ ដែលខ្ញុំ

«វាគឺជាការត្រឹមត្រូវសម្រាប់ខ្ញុំ» ឬ «វាគឺល្អសម្រាប់ខ្ញុំ»

បងប្អូនស្ថិតនៅក្នុងដួងចិត្តរបស់ខ្ញុំ

«ខ្ញុំស្រឡាញ់អ្នកខ្លាំងណាស់»

បងប្អូនទាំងអស់គ្នាក្លាយជាគូកនរបស់ខ្ញុំ ដោយព្រះគុណ

«បានរួមចំណែកដោយសារព្រះគុណជាមួយខ្ញុំ» ឬ «បានចែកចាយព្រះគុណជាមួយខ្ញុំ»

ព្រះជាម្ចាស់ជាសាក្សី

«ព្រះជាម្ចាស់ជ្រាបដឹង» ឬ «ព្រះជាម្ចាស់យល់ដឹងទាំងអស់»

ដោយចិត្តអាណិតមេត្តាមកពីព្រះគ្រិស្តយេស៊ូ។

នាមអរូបអរូបី «មេក្តាករុណា» អាចបកប្រែជាមួយកិរិយា «ស្រឡាញ់»

ការបកប្រែផ្សេងទៀត:

«ហើយខ្ញុំស្រឡាញ់អ្នកដូចព្រះគ្រិស្តស្រឡាញ់យើងទាំងអស់គ្នា»

Philippians 1:9

ប្រយោគភ្ជាប់៖

លោកប៉ូអធិស្ឋានសម្រាប់អ្នកជឿនៅភីលីពនិងនិយាយអំពីអំណរដែលមាននៅក្នុងទុក្ខលំបាករបស់ពួកគេ

សូមឲ្យបងប្អូនមានសេចក្តីស្រឡាញ់កាន់តែខ្លាំង

លោកប៉ូលនិយាយអំពីសេចក្តីស្រឡាញ់ដូចជាវាជាកម្មបទដែលមនុស្សអាចថែរក្សាច្រើនជាងនេះទៅទៀត

ការបកប្រែផ្សេងទៀត: «អាចកើនឡើងថែមទៀត»

ចេះដឹងច្បាស់ និងយល់សព្វគ្រប់ទាំងអស់។

នៅទីនេះ «ការយល់ដឹង» មានន័យថាដឹងអំពីព្រះជាម្ចាស់ហើយអាចត្រូវបង្ហាញយ៉ាងច្បាស់។

ការបកប្រែផ្សេងទៀត:

«ពេលអ្នករៀនហើយយល់ថែមទៀតអំពីការគាប់ព្រះហឫទ័យព្រះជាម្ចាស់»

ចេះពិចារណាមើលថា

នេះគឺនិយាយសំដៅទៅលើការត្រួតពិនិត្យរឿងនិងយកតែអ្វីដែលល្អប៉ុណ្ណោះ។

[illegible] «ការសាកល្បងនិងជ្រើសរើស»

ការអ្វីប្រសើរជាងគេ

«ការអ្វីដែលល្អបំផុតគាប់ព្រះហឫទ័យព្រះជាម្ចាស់»

បានវិសុទ្ធ គ្មានកំហុសអ្វីឡើយ

[illegible] ថា «ស្មោះអស់ពីិចិត្ត» និង «គ្មានការវាយប្រហារ"

មានន័យថាជាមូលដ្ឋានដូចគ្នា។

លោកប៉ូលរួមបញ្ចូលពួកគេដើម្បីផ្តោតទៅលើភាពស្អាតខាងសីលធម៌។

ការបកប្រែផ្សេងទៀត: «គ្មានកំហុសទាំងស្រុង»

បងប្អូនបានពោរពេញ

លោកប៉ូលគឺកំពុងនិយាយអំពីអ្នកជឿហាក់ដូចជាពួកគេជាអ្នកផ្ទុកដែលអាចពោរពេញដោយផលផ្លែ។

ការបកប្រែផ្សេងទៀត:

«នេះក៏ដើម្បីឲ្យព្រះយេស៊ូគ្រិស្តអាចបណ្តាលឲ្យបងប្អូនស្តាប់បង្គាប់ព្រះជាម្ចាស់ថែមទៀត»

បានពោរពេញដោយផលនៃសេចក្តីសុចរិត ដែលមកពី

ការប្រព្រឹត្តល្អនៃអ្នកជឿដែលព្រះជាម្ចាស់បានប្រកាសថាល្អដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ដូចជារបៀ

ការបកប្រែផ្សេងទៀត:

«អាចគាប់ព្រះហឫទ័យព្រះជាម្ចាស់និងអ្នកដទៃទៀតតាមរយៈរបៀបបងប្អូនរស់នៅឥឡូវដែលព្រះជាម្ចាស់

ដើម្បីលើកតម្កើងសិរីរុងរឿង និងសរសើរតម្កើងព្រះជាម្ចាស់។

[illegible] ថា)

«បន្ទាប់មកអ្នកផ្សេងទៀតនឹងឃើញរបៀបដែលបងប្អូនថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់»

ឬទី២)

«បន្ទាប់មកមនុស្សនឹងសរសើរហើយថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ដោយសារការល្អដែលពួកគេឃើញ

ការបកប្រែទាំងនេះនឹងតម្រូវការប្រយោគថ្មី។

Philippians 1:12

ប្រយោគភ្ជាប់:

លោកប៉ូលមានប្រសាសន៍ថាមានរឿងពីរយ៉ាងបានកើតឡើងដោយសារ

«ដំណើរការនៃដំណឹងល្អ»

មនុស្សជាច្រើននៅខាងក្នុងនិងខាងក្រៅព្រះរមរាជវាំងបានរកឃើញមូលហេតុដែលគាត់នៅក្នុងគុក

និង គ្រិស្តានផ្សេងៗទៀតគឺមិនខ្លាចរប្រកាសដំណឹងល្អទៀតទេ។

ឥឡូវខ្ញុំចង់

នៅទីនេះពាក្យថា «ឥឡូវ» គឺត្រូវបានប្រើដើម្បីចាំណាំផ្នែកនៃសំបុត្រថ្មី។

បងប្អូន

នៅទីនេះមានន័យថាគ្រិស្តបរិស័ទរួមបញ្ចូលទាំងប្រុសនិងស្រីពីព្រះអ្នកជឿទាំងអស់នៅក្នុងព្រះគ្រិស្តគឺជា

ជាមួយព្រះជាម្ចាស់ជាព្រះបិតារបស់ពួកគេនៅស្ថានបរមសុខ។

អ្វីដែលបានកើតឡើងដល់រូបខ្ញុំ

លោកប៉ូលគឺកំពុងនិយាយអំពីពេលវេលារបស់គាត់នៅក្នុងគុក។

ការបកប្រែផ្សេងទៀត:

«ដែលទាំងនោះខ្ញុំរងទុក្ខវេទនាពីព្រោះខ្ញុំត្រូវបានគេដាក់ក្នុងគុកចំពោះការប្រកាសដំណឹងអំពីព្រះយេស៊ូ»។

ក្នុងការបម្រើនោះ ដើម្បីចំណេញសម្រាប់ដំណឹងល្អវិញ

«បានបណ្តាលឲ្យមនុស្សជាច្រើនដើម្បីឲ្យបានឮដំណឹងល្អ»

នៅពេលដែលខ្ញុំជាប់ឃុំឃាំងព្រោះព្រះគ្រិស្តដូចជាពន្លឺ

[illegible] «ជាប់ឃុំឃាំងដោយសារតែព្រះគ្រិស្ត»

គឺជាពាក្យប្រៀបធៀបសម្រាប់ការជាប់ពន្ធនាគារដើម្បីជាប្រយោជន៍ដល់ព្រះគ្រិស្ត។

[illegible] ពន្លឺ» គឺជាពាក្យប្រៀបធៀបសម្រាប់ «បានស្គាល់»។

ការបកប្រែផ្សេងទៀត: «គេបានដឹងថាខ្ញុំជាប់គុកដោយសារតែព្រះគ្រិស្ត»។

នៅពេលដែលខ្ញុំជាប់ឃុំឃាំងព្រោះព្រះគ្រិស្តដូចជាពន្លឺដែលភ្លឺ ... អ្នកយាម ... និងមនុស្សគ្រប់គ្នា

នេះអាចត្រូវបានថ្លែងនៅក្នុងទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

«ឆ្មាំយាមព្រះបរមរាជវាំងនិងប្រជាជនជាច្រើនទៀតនៅទីក្រុងរ៉ូមដឹងថាខ្ញុំជាប់ច្រវាក់ដោយសារតែព្រះគ្រីស្ទ»
ខ្ញុំជាប់ឃុំឃាំងព្រោះព្រះគ្រិស្ត
នៅទីនេះលោកប៉ូលប្រើឋានាក់ «នៅក្នុង» មានន័យថា «សម្រាប់ជាប្រយោជន៍នៃ»។
ការបកប្រែផ្សេងទៀត: «ច្រវាក់ខ្ញុំពីព្រោះខ្ញុំបង្រៀនមនុស្សអំពីព្រះគ្រិស្ត»
អ្នកយាមព្រះរាជវាំង
នេះគឺជាក្រុមទាហានដែលបានជួយការពារអធិរាជរ៉ូមុាំង។
Philippians 1:15
មានបងប្អូនខ្លះប្រកាសដំណឹងល្អអំពីព្រះគ្រិស្ត
«មនុស្សខ្លះប្រកាសដំណឹងល្អអំពីគ្រិស្ត»
ដោយចិត្តច្រណែនឈ្នានីស ចង់ប្រណាំងប្រជែង
«ពីព្រោះពួកគេមិនចង់អោយមនុស្សស្តាប់ខ្ញុំហើយពួកគេចង់បង្កបញ្ហា»
តែបងប្អូនខ្លះទៀតថ្លែងព្រះបន្ទូលដោយមានបំណងល្អ
«ប៉ុន្តែមនុស្សផ្សេងទៀតធ្វើវាពីព្រោះពួកគេមានចិត្តល្អហើយពួកគេចង់ជួយ»
ក្រោយមក
«អ្នកដែលប្រកាសពីព្រះគ្រិស្តចេញពីសុឆន្ទ»
ខ្ញុំនៅកន្លែងនេះ ដើម្បីការពារដំណឹងល្អ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
អត្ថន័យដែលអាចមានគឺការបកប្រែផ្សេងទៀត: ១) «ព្រះបានជ្រើសរើសខ្ញុំ ឲ្យ
ការពារដំណឹងល្អ»ឬ ២) «ខ្ញុំនៅក្នុងគុកពីព្រោះខ្ញុំការពារដំណឹងល្អ»។
ដើម្បីការពារដំណឹងល្អ
«ដើម្បីបង្រៀនមនុស្សគ្រប់គ្នាថាសាររបស់ព្រះយេស៊ូគឺសេចក្តីជាការពិត»
ប៉ុន្តែ អ្នកដែលផ្សាយដំណឹងពីមុន
«ប៉ុន្តែអ្នកផ្សេងទៀត» ឬ
«ប៉ុន្តែអ្នកដែលប្រកាសពីព្រះគ្រិស្តពីការច្រណែននិងការឈ្លោះប្រកែកគ្នា»
ក្នុងពេលដែលខ្ញុំជាប់ឃុំឃាំង
នៅទីនេះឃ្លាថា «នៅក្នុងច្រវាក់» ជាពាក្យទាក់ទងសម្រាប់ការដាក់ពន្ធនាគារ។
ការបកប្រែផ្សេងទៀត: «ពេលខ្ញុំជាប់គុក» ឬ «ពេលខ្ញុំកំពុងជាប់ពន្ធនាគារ»
Philippians 1:18
តើហេតុអ្វីទៅ?
លោកប៉ូលប្រើសំណួរនេះដើម្បីប្រាប់ពីអារម្មណ៍របស់គាត់ចំពោះស្ថានភាពដែលគាត់បានរៀបរាប់នៅក្នុងខ
១:១៥ ។ អត្ថន័យដែលអាចមានគឺ ១) នេះគឺជាលេខសម្គាល់ដែលមានន័យថា
«វាគ្មានបញ្ហាទេ»។ ឬ ២) ពាក្យថា «ខ្ញុំនឹងគិតអំពីរឿងនេះ»
ត្រូវបានយល់ជាផ្នែកនៃសំណួរ។ ការបកប្រែផ្សេងទៀត:
«តើខ្ញុំនឹងគិតយ៉ាងម៉េចអំពីរឿងនេះ?» ឬ «នេះជាអ្វីដែលខ្ញុំគិតអំពីវា»
ទោះជាវិធីណាក៏ដោយ បើទោះជាគេសម្តែងក្តី ឬស្មោះសរក្តី ក៏គេផ្សាយដំណឹងអំពីព្រះគ្រិស្តដែរ
«ដរាបណាមនុស្សប្រកាសអំពីព្រះគ្រិស្តវាមិនមានបញ្ហាទេប្រសិនបើពួកគេធ្វើវាសម្រាប់ហេតុផលត្រឹមត្រូវ»
ខ្ញុំសប្បាយចិត្តអំពីការនេះ
«ខ្ញុំសប្បាយចិត្តណាស់ពីព្រោះមនុស្សកំពុងប្រកាសអំពីព្រះយេស៊ូ»
ខ្ញុំនឹងសប្បាយចិត្ត
«ខ្ញុំនឹងអបអរ» ឬ «ខ្ញុំនឹងរីករាយ»
ការនេះនឹងធ្វើឲ្យខ្ញុំទទួលការសង្គ្រោះទៅវិញទេ
«ពីព្រោះមនុស្សប្រកាសពីព្រះគ្រិស្តនោះព្រះជាម្ចាស់នឹងរំដោះខ្ញុំ»
ខ្ញុំទទួលការសង្គ្រោះ
អត្ថន័យពិតប្រាកដនៃ «ការរំដោះ»
គឺៗអ្វីដែលព្រះជាម្ចាស់នឹងរំដោះលោកប៉ូលចេញពី គឺមិនច្បាស់ទេ។
ទី១អត្ថន័យប្រហែលជា)
លោកប៉ូលចង់សំដៅទៅលើការជួយឱ្យរួចផុតពីស្ថានភាពអាក្រក់ ឬទី២)លោក
ប៉ូលសំដៅទៅលើការដោះលែងពីពន្ធនាគារ។
ដោយបងប្អូនអធិស្ឋានទៅសម្រាប់ខ្ញុំ ហើយពីព្រះវិញ្ញាណរបស់ព្រះយេស៊ូគ្រិស្តដល់ខ្ញុំផងដែរ
«ពីព្រោះបងប្អូនកំពុងអធិស្ឋានហើយព្រះវិញ្ញាណនៃព្រះយេស៊ូគ្រិស្តកំពុងតែជួយខ្ញុំ»
វិញ្ញាណរបស់ព្រះយេស៊ូគ្រិស្ត
«ព្រះវិញ្ញាណដ៏វិសុទ្ធ»
Philippians 1:20
វាអាស្រ័យលើការទន្ទឹងរង់ចាំ និងយកចិត្តទុកដាក់របស់ខ្ញុំ ដោយសង្ឃឹម
នៅទីនេះឃ្លាថា «ការរំពឹងទុកយ៉ាងអន្ទះអន្ទែង» និង «ក្តីសង្ឃឹមជាក់លាក់»
មានន័យជារួមដូចគ្នា។
លោកប៉ូលប្រើពួកគេរួមគ្នាដើម្បីបញ្ជាក់ពីការរំពឹងទុករបស់គាត់យ៉ាងខ្លាំង។
ការបកប្រែផ្សេងទៀត: «ខ្ញុំជឿជាក់ទាំងស្រុង»
ខ្ញុំនៅតែមានចិត្តអង់អាច ឥតរង្គើ ទោះបីជាខ្ញុំត្រូវរស់ ឬស្លាប់ក្តី ខ្ញុំនឹងលើកតម្កើងព្រះគ្រិស្ត
ការរំពឹងនិងក្តីសង្ឃឹមរបស់លោកប៉ូល។ ការបកប្រែផ្សេងទៀត:
«ប៉ុន្តែខ្ញុំរំពឹងនិងសង្ឃឹមថាដោយភាពក្លាហានទាំងអស់ដូចពេលបច្ចុប្បន្ននេះព្រះគ្រិស្តនឹងត្រូវបានលើកត
មានចិត្តអង់អាច ឥតរង្គើ
«ខ្ញុំនឹងមានភាពក្លាហានឥឡូវនេះដូចដែលខ្ញុំបានមានជានិច្ចហើយនិង»
លើកតម្កើងព្រះគ្រិស្តក្នុងរូបកាយខ្ញុំ
ឃ្លាថា «រាងកាយរបស់ខ្ញុំ»
គឺជាពាក្យទាក់ទងសម្រាប់អ្វីដែលលោកប៉ូលធ្វើជាមួយរាងកាយរបស់គាត់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ អត្ថន័យដែលអាចមានគឺ ១)
«ខ្ញុំនឹងលើកកិត្តិយសព្រះគ្រិស្តតាមអ្វីដែលខ្ញុំធ្វើ» ឬ ទី២)
«មនុស្សនឹងសរសើរព្រះគ្រិស្តដោយសារអ្វីដែលខ្ញុំធ្វើ»
ទោះបីជាខ្ញុំត្រូវរស់ ឬស្លាប់ក្តី
«ប្រសិនបើខ្ញុំបន្តរស់នៅឬស្លាប់»
សម្រាប់ខ្ញុំ បើរស់ ខ្ញុំរស់រួមជាមួយព្រះគ្រិស្ត ហើយបើស្លាប់ នោះបានជាកម្រៃវិញ។
«ពីព្រោះប្រសិនបើខ្ញុំបន្តរស់នៅខ្ញុំនឹងរស់នៅដើម្បីផ្គាប់ព្រះហឫទ័យព្រះគ្រិស្តហើយប្រសិនបើខ្ញុំស្លាប់នោះ
Philippians 1:22
ប៉ុន្តែ បើខ្ញុំរស់ខាងឯសាច់ឈាម
ពាក្យថា «សាច់ឈាម» នៅទីនេះគឺជាពាក្យដែលទាក់ទងខាងរាងកាយហើយ
«ការរស់នៅក្នុងសាច់ឈាម» គឺជាពាក្យទាក់ទងម្រាប់ការរស់នៅ។
ការបកប្រែផ្សេងទៀត: «ប៉ុន្តែប្រសិនបើខ្ញុំនឹងនៅតែមានជីវិតនៅក្នុងខ្លួនខ្ញុំ» ឬ
«ប៉ុន្តែប្រសិនបើខ្ញុំនៅតែបន្តរស់នៅ»
ដូច្នេះ មានន័យថា អ្វីដែលខ្ញុំធ្វើនឹងបានផល
ពាក្យថា «ផលផ្លែ» នៅទីនេះសំដៅទៅលើលទ្ធផលល្អនៃការងាររបស់លោកប៉ូល។
ការបកប្រែផ្សេងទៀត:
«មានន័យថាខ្ញុំនឹងអាចធ្វើការបានហើយការងាររបស់ខ្ញុំនឹងទទួលបានលទ្ធផលល្អ»
ឬ
«បន្ទាប់មកខ្ញុំនឹងមានឱកាសច្រើនដើម្បីលើកទឹកចិត្តឱ្យមនុស្សជឿលើព្រះគ្រិស្ត» (សូមមើល:
និង
សម្រាប់ខ្ញុំពិតជារវែករវាងការទាំងពីរនោះ
ប៉ូលនិយាយអំពីការលំបាកសម្រាប់គាត់ក្នុងការជ្រើសរើសរវាងការរស់នៅនិងការស្លាប់ដូចជាវត្ថុធ្ងន់ពីរ
ដែលត្រូវបានថ្លឹងដោយមើលមុខ។ គាត់ហេតុកំពុងរុញច្រានគាត់ពីភាគីផ្ទុយគ្នាក្នុងពេលតែមួយ។
ភាសារបស់អ្នកអាចចូលចិត្តវត្ថុដើម្បីទាញជាជាងការរុញ។ ការបកប្រែផ្សេងទៀត:
«ខ្ញុំស្ថិតក្នុងភាពតានតឹងខ្ញុំមិនដឹងថាតើខ្ញុំគួរជ្រើសរើសការរស់នៅឬស្លាប់ទេ» (សូមមើល:
ខ្ញុំប៉ងប្រាថ្នាចង់លាចាកលោកនេះទៅនៅជាមួយព្រះគ្រិស្ត
លោកប៉ូលប្រើពាក្យពេចន៍នៅទីនេះដើម្បីបង្ហាញថាគាត់មិនខ្លាចស្លាប់ទេ។
ការបកប្រែផ្សេងទៀត: «ខ្ញុំចង់ស្លាប់ព្រោះខ្ញុំនឹងទៅនៅជាមួយព្រះគ្រីស្ត»
Philippians 1:25 ដោយសារតែហេតុផលអាក្រក់»
ខ្ញុំជឿជាក់ដូច្នេះ
«ពីព្រោះខ្ញុំដឹងច្បាស់ថាវាប្រសើរសម្រាប់អ្នកដែលខ្ញុំនៅរស់»
ដោយដឹងថា ខ្ញុំនឹងបន្តរស់នៅ
«ខ្ញុំដឹងថាខ្ញុំនឹងបន្តរស់នៅ» ឬ «ខ្ញុំដឹងថាខ្ញុំនឹងបន្តរស់នៅ»។
ជ្រិត នៅក្នុងខ្ញុំ
«អញ្ចឹងដោយសារខ្ញុំ» ឬ «អញ្ចឹងដោយសារអ្វីដែលខ្ញុំធ្វើ»
ដែលបងប្អូនមានជំហរមាំមួនដោយមានចិត្តគំនិតតែមួយ ព្រមទាំងរួមចិត្តថ្លើមគ្នាតយុទ្ធ ដើម្បីជំនឿ
លើដំណឹងល្អ ផងដែរ
ឃ្លាទាំងពីរនេះមានអត្ថន័យប្រហាក់ប្រហែលគ្នានិងបញ្ជាក់ពីសារៈសំខាន់នៃការរួបរួមគ្នា។
មានចិត្តគំនិតតែមួយ ព្រមទាំងរួមចិត្តថ្លើមគ្នា
«ការតស៊ូរួមគ្នាដោយគំនិតតែមួយ»។
យល់ស្របនឹងគ្នាទៅវិញទៅមកត្រូវបានគេនិយាយថាមានចិត្តគំនិតតែមួយ។
ការបកប្រែផ្សេងទៀត: «ព្រមព្រៀងគ្នានិងតស៊ូជាមួយគ្នា»
ព្រមទាំងរួមចិត្តថ្លើមគ្នាតយុទ្ធ
«ព្រមទាំងរួមចិត្តថ្លើមគ្នាតយុទ្ធ»
សម្រាប់ជំនឿនៃដំណឹងល្
ទី១អត្ថន័យប្រហែលជា) «ដើម្បីរីករាលដាលជំនឿដែលផ្អែកលើដំណឹងល្អ» ឬ
ទី២) «ដើម្បីជឿនិងរស់នៅជាដំណឹងល្អបង្រៀនយើង»
Philippians 1:28
សូមបងប្អូនកុំភ័យខ្លាច
នេះគឺជាបទបញ្ជាដល់ពួកអ្នកជឿនៅភីលីព។
ប្រសិនបើភាសារបស់អ្នកមានទម្រង់ពាក្យបញ្ជាពហុវចន:សូមប្រើវានៅទីនេះ។
នេះជាសញ្ញាបញ្ជាក់ឲ្យឃើញថា ពួកគេនឹងត្រូវវិនាសអន្តរាយ រីឯបងប្អូនវិញ នឹងទទួលការសង្គ្រោះ

generated on Wed Sep 10 16:16:32 2025

ហើយការនេះកើតពីព្រះជាម្ចាស់មក
«ភាពក្លាហានរបស់បងប្អូននឹងបង្ហាញពួកគេថាព្រះជាម្ចាស់នឹងបំផ្លាញពួកគេ។
វាក៏នឹងបង្ហាញបងប្អូនផងដែរថាព្រះនឹងសង្គ្រោះបងប្អូន»
បងប្អូនបានតយុទ្ធរួមជាមួយខ្ញុំ ដូចបងប្អូនធ្លាប់បានឃើញខ្ញុំតយុទ្ធស្រាប់ហើយ ហើយដូចបងប្អូនឮ
ថាខ្ញុំកំពុងតែតយុទ្ធនៅឡើយ។
«នោះហើយជាមូលហេតុដែលអ្នកកំពុងរងទុក្ខវេទនាដូចគ្នាតាមរបៀបដែលបងប្អូនបានឃើញខ្ញុំរងទុក្ខហើ
ខ្ញុំនៅតែរងទុក្ខ»

---

2 [1]ប្រសិនណាបើ មានការលើកទឹកចិត្តនៅក្នុងព្រះគ្រិស្ដ ហើយប្រសិនណាមានការកម្សាន្តចិត្តមកពីក្ដីស្រឡាញ់របស់ព្រះជាម្ចាស់
ហើយប្រសិនណាមានការប្រកបជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយប្រសិនណា បងប្អូនពិតជាមានចិត្តមេត្តាករុណា និងចិត្តអាណិតអាសូរ[2]ដូច្នេះ
ចូរធ្វើឲ្យខ្ញុំពេញដោយអំណរ ដោយបងប្អូនមានការគិតតែមួយ មានសេចក្ដីស្រឡាញ់តែមួយ មានការរួបរួមក្នុងឆន្ទៈតែមួយ ព្រមទាំងមានគោលបំណងតែមួយ។
[3]សូមកុំឲ្យមានភាពអាត្មានិយម ឬដោយអំនួតឥតប្រយោជន៍។ ផ្ទុយទៅវិញ ត្រូវបន្ទាបខ្លួន ហើយគិតថាអ្នកដទៃប្រសើរជាងខ្លួនជានិច្ច។[4]បងប្អូនអើយ
សូមកុំគិតតែពីតម្រូវការផ្ទាល់ខ្លួនឡើយ ប៉ុន្តែ ត្រូវគិតអំពីតម្រូវការរបស់អ្នកដទៃវិញ។
[5]បងប្អូន សូមគិតដូចជាព្រះគ្រិស្ដយេស៊ូគិតដែរ។[6]ព្រះអង្គមានឋានៈជាព្រះជាម្ចាស់ ប៉ុន្តែ ព្រះអង្គមិនបានគិតឲ្យស្មើនឹងព្រះជាម្ចាស់ឡើយ
ដូចជាអ្វីដែលជាកម្មសិទ្ធរបស់ព្រះអង្គនោះទេ។[7]ផ្ទុយទៅវិញ ព្រះអង្គបានលះបង់ទាំងអស់។ ព្រះជាម្ចាស់បានយកឋានៈជាអ្នកបម្រើ។
ព្រះអង្គបានបង្ហាញអំពីភាពជាមនុស្សដូចមនុស្សឯទៀតៗដែរ។ ព្រះអង្គត្រូវបានឃើញភាពជាមនុស្សដ៏សាមញ្ញរបស់ព្រះអង្គ។[8]ព្រះជាម្ចាស់បានបន្ទាបខ្លួន
និងស្ដាប់បង្គាប់រហូតដល់ទីមរណា ដោយសុគតនៅលើឈើឆ្កាង។
[9]ដូច្នេះហើយបានជាព្រះជាម្ចាស់លើកតម្កើងព្រះយេស៊ូឡើងខ្ពង់ខ្ពស់បំផុត។ ព្រះជាម្ចាស់ក៏ប្រទាន ព្រះនាមដ៏ប្រសើរដល់ព្រះយេស៊ូ លើសពីនាមណាៗទាំងអស់។
[10]ព្រះជាម្ចាស់ធ្វើដូច្នេះ ដើម្បីអោយក្នុងនាមព្រះយេស៊ូ គ្រប់ទាំងជង្គង់នឹងលុតចុះ រួមទាំងជង្គង់អ្នកនៅស្ថានបរមសុខ ទាំងនៅលើផែនដី ហើយទាំងនៅក្រោមដីផងដែរ។
[11]ព្រះជាម្ចាស់ធ្វើដូច្នេះ ដើម្បីឲ្យគ្រប់ទាំងអណ្ដាតបានប្រកាសថា ព្រះយេស៊ូគ្រិស្ដជាព្រះអម្ចាស់ ដើម្បីលើកតម្កើងសិរីរុងរឿងដល់ព្រះបិតា។
[12]ហេតុនេះ បងប្អូនជាទីស្រឡាញ់អើយ ដូចបងប្អូនតែងតែស្ដាប់បង្គាប់ជារៀងដរាបមក គឺមិនត្រឹមតែពេលដែលខ្ញុំនៅជាមួយបងប្អូននោះទេ
ប៉ុន្តែឥឡូវនេះទាំងគ្មានរូបខ្ញុំអ្នកបានធ្វើច្រើនជាងនោះផង សូមបងប្អូនខំប្រឹងធ្វើការ ទាំងគោរពកោតខ្លាច និងញាប់ញ័រ ស្របតាមការសង្គ្រោះដែលបងប្អូនបាន
ទទួល[13]ដ្បិត ព្រះជាម្ចាស់ទេតើ ដែលបានធ្វើការក្នុងបងប្អូន ទាំងឆន្ទៈហើយនិងការប្រព្រឹត្តដ៏សប្បុរសរបស់ព្រះអង្គ។
[14]ចូរធ្វើការទាំងអស់ដោយគ្មានការរអ៊ូរទាំ ឬដោយតវ៉ាឡើយ។[15]ចូរប្រព្រឹត្តបែបនេះ នោះបងប្អូនបានល្អឥតខ្ចោះ ឥតសៅហ្មងជាបុត្ររបស់ព្រះជាម្ចាស់ ដែលឥតមាន
កំហុស។ ចូរប្រព្រឹត្តក្នុងបែបនេះ បងប្អូនបានជះពន្លឺក្នុងចំណោមពួកគេ ដូចពន្លឺដែលបំភ្លឺពិភពលោកក្នុងចំណោមមនុស្សអាក្រក់ និងខិលខូចនៅជំនាន់នេះ។
[16]ចូរតោងព្រះបន្ទូលនៃជីវិត ធ្វើដូច្នេះហើយ ខ្ញុំមានហេតុនឹងថ្វាយសិរីល្អនៅថ្ងៃព្រះគ្រិស្ដយាងមក។ ដ្បិត ខ្ញុំនឹងបានដឹងថា ខ្ញុំមិនបានរត់ និងខំធ្វើការដោយនឿយហត់នោះ
មិនឥតប្រយោជន៍ឡើយ។
[17]ទោះបីខ្ញុំត្រូវបង្ហូរឈាមទុកជាតង្វាយ ដាក់លើយញ្ញបូជា និងពីលើការបម្រើនៃជំនឿរបស់បងប្អូន ខ្ញុំមានអំណរណាស់ ហើយខ្ញុំក៏សប្បាយចិត្តរួមជាមួយបងប្អូនទាំងអស់
គ្នាដែរ។[18]រីឯបងប្អូនវិញ ចូរឲ្យបងប្អូនមានអំណរ ហើយសប្បាយចិត្តរួមជាមួយខ្ញុំផង។
[19]ខ្ញុំសង្ឃឹមក្នុងព្រះអម្ចាស់យេស៊ូ នឹងចាត់លោកធីម៉ូថេមករកបងប្អូន ក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីឲ្យខ្ញុំបានទទួលការលើកទឹកចិត្ត ដោយទទួលដំណឹង និងឮដំណឹងពី
បងប្អូន[20]ដ្បិត ខ្ញុំមិនមានអ្នកណាផ្សេងទៀត ដែលមានឥរិយាបថដូចជាគាត់ ហើយជាអ្នកដែលយកចិត្តទុកដាក់សម្រាប់បងប្អូន។[21]ដ្បិត អ្នកផ្សេងវិញ ពួកគេគិតតែពី
ប្រយោជន៍ផ្ទាល់ខ្លួនឯង គេមិនគិតពីប្រយោជន៍របស់ព្រះយេស៊ូគ្រិស្ដទេ។
[22]បងប្អូនដឹងអំពីទឹកចិត្តរបស់គាត់ហើយ ព្រោះគាត់ដូចកូនដែលមប្រើឪពុក ហើយគាត់បានបម្រើរួមជាមួយខ្ញុំ ក្នុងដំណឹងល្អ។[23]ដូច្នេះ ខ្ញុំសង្ឃឹមថានឹងចាត់គាត់មករក
បងប្អូនក្នុងពេលឆាប់ៗ នៅពេលខ្ញុំបានដឹងថារឿងរបស់ខ្ញុំរៀបរយហើយ។[24]ប៉ុន្តែ ខ្ញុំជឿជាក់ក្នុងព្រះអង្គម្ចាស់ ថារូបខ្ញុំផ្ទាល់នឹងបានទៅរកបងប្អូនក្នុងពេលឆាប់ៗនេះ។
[25]ប៉ុន្តែ ខ្ញុំគិតថា ត្រូវតែចាត់លោកអេប៉ាប្រូឌីត ដើម្បីត្រឡប់ទៅបងប្អូនវិញជាចាំបាច់។ គាត់គឺជាបងប្អូនរបស់ខ្ញុំ ហើយក៏ជាសហការី និងជាទាហានរបស់ព្រះជាម្ចាស់
ហើយក៏ជាអ្នកនាំសំបុត្ររបស់អ្នករាល់គ្នា គាត់ជាម្ចាក់ដែលបម្រើសេចក្ដីត្រូវការរបស់ខ្ញុំ។[26]ដ្បិត គាត់មានទុក្ខព្រួយជាខ្លាំង
ហើយគាត់ទទឹងរង់ចាំឲ្យតែដល់ពេលត្រឡប់ទៅបងប្អូនទាំងអស់គ្នា ហើយបងប្អូនក៏ធ្លាប់ឮថាគាត់បានឈឺដែរ។ ជាការពិតនោះគាត់បានឈឺធ្ងន់មែន
រហូតក្បែរនឹងស្លាប់ផង។[27]ក៏ប៉ុន្តែ ព្រះជាម្ចាស់អាណិតគាត់ ព្រះអង្គមិនត្រឹមតែអាណិតគាត់ទេ ព្រះអង្គក៏អាណិតខ្ញុំដែរ ដើម្បីកុំឲ្យខ្ញុំមានទុក្ខត្រួតពីលើទុក្ខ។
[28]ដូច្នេះហើយ បានជាខ្ញុំខំខ្នះខ្នែងចាត់គាត់ឲ្យមកជួបបងប្អូន ដើម្បីឲ្យបងប្អូនមានអំណរសប្បាយ ដោយឃើញគាត់សារជាថ្មី ហើយឲ្យខ្ញុំផ្ទាល់ឈប់ព្រួយចិត្ត។[29]សូមទទួល
គាត់នៅក្នុងព្រះអង្គម្ចាស់ និងការអរសប្បាយបំផុត។ សូមគោរពមនុស្សដូចជាគាត់នេះផង។[30]ដ្បិត គាត់ជិតបាត់បង់ជីវិត ព្រោះតែកិច្ចការរបស់ព្រះគ្រិស្ដ។ គឺគាត់បានស៊ូប្តូរ
ជីវិតដើម្បីបម្រើខ្ញុំ ហើយបំពេញអ្វីដែលបងប្អូនមិនអាចធ្វើក្នុងការបម្រើដល់ខ្ញុំ។

Philippians 2:1
ប្រយោគភ្ជាប់:
លោកប៉ូលណែនាំអ្នកជឿឱ្យមានការរួបរួមគ្នា និងបន្ទាបខ្លួន
ហើយរម្លឹកពួកគេពីគំរូរបស់ព្រះគ្រិស្ដ។
ប្រសិនណាបើ មានការលើកទឹកចិត្តនៅក្នុងព្រះគ្រិស្
«ប្រសិនបើព្រះគ្រិស្ដបានលើទឹកចិត្តបងប្អូន»
ហើយប្រសិនណាមានការកម្សាន្តចិត្តមកពីក្ដីស្រឡាញ់របស់ព្រះជាម្ចាស់
«ប្រសិនបើសេចក្ដីស្រឡាញ់របស់ទ្រង់បានផ្ដល់ការលួងលោមបងប្អូន»
ហើយប្រសិនណាមានការប្រកបជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ
«ប្រសិនបើបងប្អូនមានការប្រកបគ្នាជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ»
ហើយប្រសិនណា បងប្អូនពិតជាមានចិត្តមេត្តាករុណា និងចិត្តអាណិតអាសូរ
«ប្រសិនបើបងប្អូនមានបទពិសោធន៍ជាច្រើននៃសកម្មភាពរបស់ព្រះជាម្ចាស់ដែលមានចិត្តមេត្តាករុណា និងចិត្តអាណិតអាសូរ»
ចូរធ្វើឲ្យខ្ញុំពេញដោយអំណរ
លោកប៉ូលនិយាយនៅទីនេះដោយអំណរដូចជាវត្ថុរាវមួយដែលបំពេញធុង។
ការបកប្រែផ្សេងទៀត: «ធ្វើឱ្យខ្ញុំរីករាយយ៉ាងខ្លាំង»
Philippians 2:3
សូមកុំឲ្យមានភាពអាត្មានិយម ឬដោយអំនួតឥតប្រយោជន៍។
«កុំបម្រើខ្លួនឯងឬគិតថាខ្លួនឯងប្រសើរជាងអ្នកដទៃ»
បងប្អូនអើយ សូមកុំគិតតែពីតម្រូវការផ្ទាល់ខ្លួនឡើយ ប៉ុន្តែ ត្រូវគិតអំពីតម្រូវការរបស់អ្នកដទៃវិញ។
«កុំយកចិត្តទុកដាក់តែលើអ្វីដែលបងប្អូនត្រូវការប៉ុន្តែក៏គិតពីអ្វីដែលបងប្អូនដទៃត្រូវការដែរ»។
Philippians 2:5
បងប្អូន សូមគិតដូចជាព្រះគ្រិស្ដយេស៊ូគិតដែរ។
«មានអាកប្បកិរិយាដូចព្រះគ្រិស្ដយេស៊ូ» ឬ
«គិតអំពីអ្វីៗតាមវិធីដែលព្រះគ្រិស្ដយេស៊ូបានធ្វើ
ព្រះអង្គមិនបានគិតឲ្យស្មើនឹងព្រះជាម្ចាស់ឡើយ ដូចជាអ្វីដែលជាកម្មសិទ្ធរបស់ព្រះអង្គនោះទេ។
លោកប៉ូលកំពុងនិយាយនៅទីនេះអំពីភាពស្មើគ្នានៃព្រះជាម្ចាស់ជាព្រះបិតាដូចជាវាជាអ្វីមួយដែលព្រះគ្រិស
ដូចដែលUDB
បានបញ្ជាក់យ៉ាងច្បាស់ក្នុងអំឡុងពេលនៃព្រះគ្រិស្ដនៅលើផែនដីព្រះអង្គមិនបានឈប់ធ្វើជាព្រះជាម្ចាស់
ផ្ទុយទៅវិញព្រះអង្គធ្វើសកម្មភាពដូចជាព្រះជាម្ចាស់។
ព្រះអង្គបានលះបង់ទាំងអស់។
ដូចជាព្រះអង្គជាអ្នកផ្ទុកតាមលំដាប់ដើម្បីនិយាយថាព្រះគ្រិស្ដបានបដិសេធមិនធ្វើសកម្មភាពជាមួយអំព
ព្រះអង្គត្រូវបានឃើញភាពជាមនុស្សដ៏សាមញ្ញរបស់ព្រះអង្គ។ ព្រះជាម្ចាស់បានបន្ទាបខ្លួន
ពាក្យ «ត្រូវបានគេរកឃើញ...ដូចជា» គឺជាពាក្យសំដីសម្រាប់«គឺ» ឬ «ក្លាយជា» ។
«ដោយបានក្លាយជាមនុស្សព្រះអង្គបានបន្ទាបខ្លួន» ។
ភាសារបស់អ្នកអាចមានសញ្ញាណស្រដៀងគ្នាដូចជា
«មនុស្សគ្រប់គ្នាអាចឃើញថាព្រះអង្គជាមនុស្ស។ ព្រះអង្គបន្ទាបខ្លួន» ។
ស្ដាប់បង្គាប់រហូតដល់ទីមរណា

generated on Wed Sep 10 16:16:32 2025

លោកប៉ូលនិយាយពីសេចក្តីស្លាប់នៅទីនេះតាមន័យធៀប។
អ្នកបកប្រែអាចយល់បានថារាជាពាក្យប្រៀបធៀបនៃទីតាំង
(ព្រះគ្រិស្តបានឆ្លងកាត់គ្រប់វិធីទាំងអស់រហូតដល់ស្លាប់)
ឬជាពាក្យប្រៀបធៀបនៃពេលវេលា
(ព្រះគ្រិស្តបានស្លាប់បង្គាប់រហូតដល់ពេលដែលព្រះអង្គបានស្លាប់។
ដោយសុគតនៅលើឈើឆ្កាង។
«សូម្បីតែការសុគតនៅលើឈើឆ្កាង»
Philippians 2:9
ព្រះនាមដ៏ប្រសើរដល់ព្រះយេស៊ូ លើសពីនាមណាៗទាំងអស់។
នៅទីនេះ «ឈ្មោះ»
គឺជាពាក្យសំដៅទៅលើឹលំដាប់ថ្នាក់ដែលមានទៅតាមឋានៈឬកិត្តិយស។
ការបកប្រែផ្សេងទៀត: «ឋានៈដែលខ្ពស់ជាងឋានៈផ្សេងទៀត» ឬ
«កិត្តិយសដែលខ្ពស់ជាងកិត្តិយសផ្សេងទៀត» (សូមមើល:
លើសពីនាមណាៗទាំងអស់
ឈ្មោះគឺសំខាន់ជាងត្រូវបានគេសរសើរច្រើនជាងឈ្មោះផ្សេងទៀត។
ក្នុងនាមព្រះយេស៊ូ
ទី១អត្ថន័យប្រហែលជា) «នៅពេលមនុស្សគ្រប់គ្នាឮព្រះនាមព្រះយេស៊ូ» (UDB)ឬ
២) «នៅក្នុងកិត្តិយសនៃព្រះយេស៊ូ»
គ្រប់ទាំងជង្គង់នឹងលុតចុះ
ត្រង់នេះ «ជង្គង់»
សំដៅទៅលើមនុស្សទាំងមូលហើយការពត់ជង្គង់ដើម្បីលុតជង្គង់ចុះនៅលើដីគឺជានិមិត្តរូបនៃការថ្វាយបង្គំ
ការបកប្រែផ្សេងទៀត: «មនុស្សគ្រប់គ្នានឹងថ្វាយបង្គំព្រះជាម្ចាស់»
នៅក្រោមដី
ទី១អត្ថន័យប្រហែលជា) កន្លែងដែលមនុស្សទៅនៅពេលពួកគេស្លាប់ឬទី ២)
កន្លែងដែលអារក្សរស់នៅ
គ្រប់ទាំងអណ្តាត
នៅទីនេះ «អណ្តាត» សំដៅទៅលើមនុស្សទាំងមូល។ ការបកប្រែផ្សេងទៀត:
«គ្រប់មនុស្សទាំងអស់» ឬ «មនុស្សគ្រប់រូប»
ដើម្បីលើកតម្កើងសិរីរុងរឿងដល់ព្រះបិតា។
នៅទីនេះពាក្យ «ដើម្បី» បង្ហាញពីលទ្ធផល:
«ជាមួយនឹងលទ្ធផលដែលពួកគេនឹងសរសើរដល់ព្រះបិតា»
Philippians 2:12
ប្រយោគភ្ជាប់:
លោកប៉ូលលើកទឹកចិត្តអ្នកជឿនៅភីលីពហើយបង្ហាញពួកគេពីរបៀបដែលគ្រិបរស័ទរស់នៅ
បងប្អូនជាទីស្រឡាញ់អើយ
«អ្នករួមជំនឿជាទីស្រឡាញ់របស់ខ្ញុំ»
ដែលខ្ញុំនៅជាមួយបងប្អូននោះ
«ពេលខ្ញុំនៅជាមួយបងប្អូន»
ទាំងគ្មានរូបខ្ញុំ
«ពេលខ្ញុំមិននៅជាមួយបងប្អូន»
សូមបងប្អូនខំប្រឹងធ្វើការ ទាំងគោរពកោតខ្លាច
«បន្តគោរពតាមព្រះជាម្ចាស់»
ទាំងគោរពកោតខ្លាច និងញាប់ញ័រ
ពាក្យ «ការភ័យខ្លាច» និង «ការញ័រ» មានន័យជារួមដូចគ្នា។
លោកប៉ូលប្រើពួកគេដើម្បីបញ្ជាក់ការគោរពចំពោះព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត: «ញាប់ញ័រដោយការភ័យខ្លាច» ឬ
«ដោយការគោរពយ៉ាងជ្រាលជ្រៅ»
ទាំងឆន្ទៈហើយនិងការប្រព្រឹត្ត
«ព្រះជាម្ចាស់ប្រព្រឹត្តដូចច្នេះបងប្អូននឹងមានបំណងប្រាថ្នាស្តាប់បង្គាប់ទ្រង់ហើយបន្ទាប់
Philippians 2:14
ល្អឥតខ្ចោះ ឥតសៅហ្មង
លោកប៉ូលបង្ហាញគំនិតដូចគ្នាដោយប្រើពាក្យវិជ្ជមាននិងអវិជ្ជមាន។
សូមការបកប្រែផ្សេងទៀត: «គ្មានកំហុសទាំងស្រុង»
ជាបុត្ររបស់ព្រះជាម្ចាស់ ដែលឥតមានកំហុស
«បុត្ររបស់ព្រះជាម្ចាស់ដោយគ្មានកំហុស» ឬ «បុត្រល្អឥតខ្ចោះរបស់ព្រះជាម្ចាស់»
ជះពន្លឺ
នៅទីនេះលោកប៉ូលនិយាយអំពីអ្នកជឿដូចជាពួកគេមានពន្លឺភ្លឺក្នុងទីងងឹតជួយអ្នកដទៃ
ការបកប្រែផ្សេងទៀត: «រស់នៅតាមរបៀបដែលគោរពដល់ព្រះជាម្ចាស់»
ដែលបំភ្លឺពិភពលោក
នៅទីនេះ «លោកីយ»
សំដៅទៅលើគុណតម្លៃនិងអាកប្បកិរិយាទាំងអស់ដែលមិនគោរពព្រះជាម្ចាស់
ចំណោមមនុស្សអាក្រក់ និងខិលខូចនៅជំនាន់នេះ
ពាក្យទាំងពីរនេះមានន័យជារួមដូចគ្នា។
លោកប៉ូលប្រើពួកគេដើម្បីបញ្ជាក់ពីជំនាន់អាក្រក់។ ការបកប្រែផ្សេងទៀត:
«អាក្រក់ទាំងស្រុង»
ចូរតោងព្រះបន្ទូលនៃជីវិត
លោកប៉ូលនិយាយនៅត្រង់នេះអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចជាអ្វីដែលអាចត្រូវបានធ្វើឡើងខាងរាង
ថ្វាយសិរីល្អ
«ដើម្បីមានអំណរ» ឬ «ធ្វើឲ្យសប្បាយរីករាយ»
នៅថ្ងៃព្រះគ្រិស្ត
នេះសំដៅទៅលើពេលដែលព្រះយេស៊ូត្រឡប់មកវិញដើម្បីរៀបចំរាជាណាចក្ររបស់ព្រះអង្គនិងគ្រប់គ្រង
ការបកប្រែផ្សេងទៀត: «នៅពេលដែលព្រះគ្រិស្តយាងត្រឡប់មកវិញ»
ខ្ញុំមិនបានរត់ និងខំធ្វើការដោយនឿយហត់នោះ មិនឥតប្រយោជន៍ឡើយ
ឃ្លាថា «ដំណើរការដោយឥតប្រយោជន៍» និង «ពលកម្មឥតប្រយោជន៍»
នៅទីនេះមានន័យដូចគ្នា។
លោកប៉ូលប្រើពួកគេរួមគ្នាដើម្បីបញ្ជាក់ពីការខិតខំរបស់គាត់ដើម្បីជួយមនុស្សឱ្យជឿលើព្រះគ្រិស្ត។
ការបកប្រែផ្សេងទៀត: «ខ្ញុំមិនបានធ្វើការយ៉ាងលំបាកដើម្បីគ្មានអ្វីទេ»
រត់
បទគម្ពីរច្រើនតែនិយាយអំពីការដើរជាអត្ថន័យនៃជីវិតរបស់មនុស្សម្នាក់។
បានត្រឹមត្រូវ ការថ្វាយបង្គំ
Philippians 2:17
ទោះបីខ្ញុំត្រូវបង្ហូរឈាមទុកជាតង្វាយ ដាក់លើយញ្ញបូជា និងពីលើការបម្រើនៃជំនឿរបស់បងប្អូន ខ្ញុំ
មានអំណរណាស់ ហើយខ្ញុំក៏សប្បាយចិត្តរួមជាមួយបងប្អូនទាំងអស់គ្នាដែរ។
លោកប៉ូលនិយាយអំពីមរណភាពរបស់គាត់ដូចជាការថ្វាយសត្វជាយញ្ញបូជាដែលបានចាក់ស្រាឬប្រេងអូ
អ្វីដែលលោកប៉ូលចង់និយាយគឺថាគាត់នឹងស្លាប់ដោយរីករាយសម្រាប់ភីលីពប្រសិនបើការនេះនឹងធ្វើឱ្យពួ
ដូចគ្នានេះផងដែរនេះអាចត្រូវបានបង្ហាញជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត:
«ប៉ុន្តែទោះបីជាជនជាតិរ៉ូមសំរេចចិត្តប្រហារជីវិតខ្ញុំក៏ដោយខ្ញុំនឹងរីករាយខ្លាំងណាស់ប្រសិនបើការស្លាប់រប
ចូរឲ្យបងប្អូនមានអំណរ ហើយសប្បាយចិត្តរួមជាមួយខ្ញុំផង។
ពាក្យទាំងពីរនេះរួមគ្នាបង្ហាញពីភាពរីករាយយ៉ាងខ្លាំង។ «ខ្ញុំចង់ឲ្យ
អ្នករីករាយជាមួយខ្ញុំយ៉ាងខ្លាំង»
Philippians 2:19
ប្រយោគភ្ជាប់:
លោកប៉ូលបានរៀបចំផែនការ
បងប្អូនជាទីស្រឡាញ់អើយ
ខ្ញុំសង្ឃឹមក្នុងព្រះអម្ចាស់យេស៊ូ
«ប៉ុន្តែប្រសិនបើព្រះអម្ចាស់យេស៊ូមានឆន្ទៈខ្ញុំសង្ឃឹមថា»
ដ្បិត ខ្ញុំមិនមានអ្នកណាផ្សេងទៀត ដែលមានឥរិយាបថដូចជាគាត់
«គ្មាននរណាម្នាក់នៅទីនេះស្រឡាញ់បងប្អូនដូចព្រះអង្គទេ»
ដ្បិត អ្នកផ្សេងវិញ
នៅទីនេះពាក្យ «ពួកគេ»
សំដៅទៅលើមនុស្សមួយក្រុមដែលប៉ូលមិនមានអារម្មណ៍ថាគាត់អាចទុកចិត្តដើម្បីបញ្ជូនទៅភីលីព។
លោកប៉ូលក៏បង្ហាញការមិនសប្បាយចិត្តរបស់គាត់ជាមួយក្រុមមនុស្សដែលគួរតែអាចទៅបានប៉ុន្តែលោកប៉ូ
Philippians 2:22
ដូចកូនដែលមប្រើឪពុក ហើយគាត់បានបម្រើរួមជាមួយខ្ញុំ ក្នុងដំណឹងល្អ។
លោកប៉ូលនិយាយអំពីធីម៉ូថេដែលបានបម្រើ ព្រះគ្រិស្តជាមួយនឹងប៉ូលដូចជាគាត់នៅក្មេងកំពុងបម្រើឪ
លោកប៉ូលកំពុងសង្កត់ធ្ងន់លើទំនាក់ទំនងរវាងឪពុកនិងកូនយ៉ាងជិតស្និទ្ធដែលគាត់មានជាមួយធីម៉ូថេក្នុង
ក្នុងដំណឹងល្អ
នៅទីនេះ «ដំណឹងល្អ» តំណាងឱ្យសកម្មភាពនៃការប្រាប់មនុស្សអំពីព្រះយេស៊ូ។
ការបង្ហាញនៅក្នុងព្រះអម្ចាស់ ប្រាប់
ខ្ញុំជឿជាក់ក្នុងព្រះអង្គម្ចាស់ ថារូបខ្ញុំផ្ទាល់នឹងបានទៅរកបងប្អូនក្នុងពេលឆាប់ៗនេះ។
«ខ្ញុំប្រាកដថាប្រសិនបើវាជាឆន្ទៈរបស់ព្រះអម្ចាស់ដែលខ្ញុំនឹងមកឆាប់ៗនេះ»
Philippians 2:25
លោកអេប៉ាប្រូឌីត
នេះជាឈ្មោះបុរសម្នាក់ដែលត្រូវបានចាត់ ឲ្យ
មកដោយក្រុមជំនុំនៅក្រុងភីលីពដើម្បីបម្រើដល់លោកប៉ូលក្នុងគុក។
ជាសហការី និងជាទាហាន
ទៅទីនេះ ឲ្យ
គាត់មានន័យថាអេប៉ាប្រូឌីតត្រូវបានបណ្តុះបណ្តាលហើយត្រូវបានថ្វាយដល់ការបម្រើព្រះជាម្ចាស់មិនថា
ការបកប្រែផ្សេងទៀត:«អ្នកជឿដែលធ្វើការនិងតស៊ូជាមួយយើង»

generated on Wed Sep 10 16:16:32 2025

ជាអ្នកនាំសំបុត្ររបស់អ្នករាល់គ្នា គាត់ជាម្នាក់ដែលបម្រើសេចក្តីត្រូវការរបស់ខ្ញុំ
«ហើយអ្នកណានាំសាររបស់បងប្អូនមកខ្ញុំហើយជួយខ្ញុំពេលខ្ញុំត្រូវការ»
គាត់មានទុក្ខព្រួយជាខ្លាំង ហើយគាត់ទទឹងរង់ចាំឲ្យតែដល់ពេលត្រឡប់ទៅបងប្អូនទាំងអស់គ្នា
«គាត់មានការព្រួយបារម្ភយ៉ាងខ្លាំងហើយចង់នៅជាមួយបងប្អូនទាំងអស់គ្នា»
ដើម្បីកុំឲ្យខ្ញុំមានទុក្ខត្រួតពីលើទុក្ខ
មូលហេតុនៃភាពទុក្ខព្រួយអាចត្រូវបានបង្ហាញឱ្យឃើញច្បាស់។
ការបកប្រែផ្សេងទៀត:
«ភាពសោកសៅនៃការបាត់បង់គាត់បានបន្ថែមទៅភាពទុក្ខព្រួយដែលខ្ញុំមានរួចទៅហើយ» ឬ «ខ្ញុំមានទុក្ខព្រួយជាខ្លាំងណាស់ព្រោះ
Philippians 2:28
ហើយឲ្យខ្ញុំផ្ទាល់ឈប់ព្រួយចិត្ត
«ខ្ញុំនឹងមិនសូវខ្វល់ខ្វាយ» ឬ «ខ្ញុំនឹងមិនបារម្ភដូចខ្ញុំបានបារម្ភទេ»
សូមទទួលគាត់
ទទួលយកអេប៉ាប្រូឌីតដោយអំណរ
ក្នុងព្រះអង្គម្ចាស់ និងការអរសប្បាយបំផុត
«ក្នុងនាមជាអ្នកជឿដូចគ្នាលើព្រះអម្ចាស់ដោយអំណរគ្រប់បែបយ៉ាង» ឬ
«ដោយសេចក្តីអំណរដ៏អស្ចារ្យដែលយើងមានពីព្រោះព្រះអម្ចាស់យេស៊ូស្រឡាញ់យើង» (UDB)
គាត់ជិតបាត់បង់ជីវិត
លោកប៉ូលនៅទីនេះនិយាយពីសេចក្តីស្លាប់ហាក់ដូចជាកន្លែងដែលមនុស្សម្នាក់អាចទៅបាន។
ហើយជាអ្នកដែលបានបម្រើ
មិនអាចធ្វើក្នុងការបម្រើដល់ខ្ញុំ។
លោកប៉ូលនិយាយអំពីតំរូវការរបស់គាត់ហាក់ដូចជាពួកគេជាអ្នកទទួលបន្ទុកដែលអេប៉ាប្រូឌីតបំពេញជាជ
ៗ សម្រាប់ប៉ូល។

---

3 [1]ជាចុងក្រោយ បងប្អូនអើយ ចូរអរសប្បាយនៅក្នុងព្រះអង្គម្ចាស់ចុះ។ ដ្បិត ខ្ញុំមិនធុញទ្រាន់ក្នុងការសរសេរសេចក្តីទាំងនេះមកបងប្អូនម្តងទៀតទេ។
[2]ពីព្រោះសេចក្តីទាំងនេះនឹងការពារបងប្អូនឲ្យមានសុវត្ថិភាព។ ចូរប្រយ័ត្ននឹងពួកឆ្កែ ចូរប្រយ័ត្ននឹងពួកអ្នកដែលធ្វើការអាក្រក់ ចូរប្រយ័ត្ននឹងពួកអ្នកកាត់ស្បែក។
[3]សម្រាប់ពួកយើង យើងគឺជាអ្នកដែលកាត់ស្បែកពិត។ គឺជាអ្នកដែលថ្វាយបង្គំដោយព្រះវិញ្ញាណនៃព្រះជាម្ចាស់។ ពួកយើងគឺជាអ្នកពឹងអាងនៅលើព្រះគ្រិស្តយេស៊ូ
ហើយយើងមិនពឹងអាងខាងឯសាច់ឈាមទេ។
[4]ទោះបីយ៉ាងនេះក្តី ខ្ញុំផ្ទាល់ក៏ហេតុនឹងពឹងអាងខាងឯសាច់ឈាមដែរ។ បើមាននរណាគិតថាគេបានពឹងអាងលើសាច់ឈាមនោះ
ហើយខ្ញុំនេះអាចនឹងពឹងអាងច្រើនជាងគេផង។[5]ពេលខ្ញុំកើតបានប្រាំបីថ្ងៃ ខ្ញុំបានទទួលពិធីកាត់ស្បែក ខ្ញុំជាសាសន៍អ៊ីស្រាអែលក្នុងកុលសម្ពន្ធបេនយ៉ាមីន ខ្ញុំជា
ជនជាតិហេប្រឺ កើតពីសាសន៍ហេប្រឺ ហើយបើពឹងអាចខាងក្រឹត្យវិន័យវិញ ខ្ញុំក៏នៅខាងពួកផារីស៊ីដែរ។
[6]ខាងឯសេចក្តីឧស្សាហ៍ គឺខ្ញុំបានបៀតបៀនដល់ក្រុមជំនុំ ចំពោះសេចក្តីសុចរិតវិញ ខ្ញុំបាននៅក្រោមក្រឹត្យវិន័យ ហើយក៏គ្មានកន្លែងបន្ទោសបានផង។[7]ប៉ុន្តែ អ្វីៗដែលខ្ញុំធ្លាប់
គិតថាមានតម្លៃចំពោះខ្ញុំនោះ ខ្ញុំចាត់ទុកទាំងអស់ថាឥតបានការទៅវិញ ព្រោះតែព្រះគ្រិស្ត។
[8]ចំពោះមុខ ខ្ញុំបានចាត់ទុកគ្រប់របស់ទាំងអស់ជាឥតប្រយោជន៍ ដោយព្រោះតែខ្ញុំបានស្គាល់ព្រះគ្រិស្តយេស៊ូជាអម្ចាស់របស់ខ្ញុំ ជាអ្វីដែលមានតម្លៃវិសេសវិសាលណាស់។
ដ្បិត ដោយសារតែព្រះអង្គ ខ្ញុំសុខចិត្តបោះបង់ចោលអ្វីៗទាំងអស់។ ខ្ញុំចាត់ទុកអ្វីៗទាំងអស់ដូចជាសំរាម ឲ្យតែខ្ញុំបានព្រះគ្រិស្ត[9]គេនឹងឃើញខ្ញុំនៅក្នុងព្រះអង្គ។
ខ្ញុំមិនបានទៅជាសុចរិតដោយខ្ញុំខំប្រព្រឹត្តតាមក្រឹត្យវិន័យនោះទេ។ ផ្ទុយទៅវិញ ដែលខ្ញុំបានរាប់ជាសុចរិតដោយសារជំនឿក្នុងព្រះគ្រិស្ត
និងសេចក្តីសុចរិតបានមកពីព្រះជាម្ចាស់ តាមរយៈជំនឿ។[10]ឥឡូវនេះ ខ្ញុំគឺចង់ស្គាល់ព្រះគ្រិស្ត និងស្គាល់ឫទ្ធានុភាពដែលបានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញ
ហើយចូលរួមជាមួយព្រះអង្គក្នុងទុក្ខលំបាកដែរ។ ហើយឲ្យបានដូចព្រះអង្គដែលសុគត[11]ដើម្បីឲ្យខ្ញុំមានជីវិតរស់ឡើងវិញ ប្រសិនបើអាចរស់ឡើងវិញបាន។
[12]វាមិនមែនជាការពិតទេ ដែលថាខ្ញុំបានទទួលការទាំងនេះរួច ឬបានគ្រប់លក្ខណៈហើយ។ ខ្ញុំកំពុងតែបន្តទៅមុខ ដើម្បីចាប់សេចក្តីនោះឲ្យបាន ដ្បិត ខ្លួនខ្ញុំផ្ទាល់ក៏ត្រូវ
ព្រះគ្រិស្តយេស៊ូចាប់ខ្ញុំដើម្បីសេចក្តីនោះដែរ។[13]បងប្អូនអើយ ខ្លួនខ្ញុំផ្ទាល់ ក៏យល់ឃើញថា ខ្ញុំបានទៅដល់គោលដៅនៅឡើយទេ។ ប៉ុន្តែ មានការមួយ ដែលខ្ញុំបំភ្លេចអ្វីៗទាំង
អស់ដែលកន្លងទៅ ដើម្បីផ្ចង់ចិត្តឆ្ពោះទៅខាងមុខវិញ។[14]ខ្ញុំរត់តម្រង់ទៅរកគោលដៅ ដើម្បីឲ្យបានទទួលរង្វាន់ពីព្រះជាម្ចាស់ដែលបានត្រាស់ហៅពីស្ថានបរមសុខនៅក្នុង
អង្គព្រះគ្រិស្តយេស៊ូ។
[15]យើងទាំងអស់គ្នាដែលជាមនុស្សគ្រប់ពេញវ័យ សូមឲ្យយើងគិតបែបនេះ ប្រសិនបើ បងប្អូនមានការគិតអំពីអ្វីមួយផ្សេង ព្រះជាម្ចាស់នឹងបង្ហាញបងប្អូន ឲ្យដឹង
ពីការនោះដែរ។[16]ទោះបីជាយ៉ាងណាក៏ដោយ ឬមានអ្វីកើតឡើងក៏ដោយ យើងត្រូវតែទៅមុខជានិច្ច ហើយសូមឲ្យតោងជាប់នឹងសេចក្តីទាំងនោះផង។
[17]បងប្អូនអើយ ចូរយកតម្រាប់តាមខ្ញុំ។ ចូរសម្លឹងមើលអស់អ្នកដែលដើរជាគំរូ ដែលបានដាក់ឲ្យបងប្អូនឃើញនៅក្នុងយើង។[18]ដ្បិត មានមនុស្សជាច្រើន ដែលខ្ញុំ
តែងតែប្រាប់ដល់បងប្អូនជាញយដង ហើយឥឡូវខ្ញុំកំពុងប្រាប់បងប្អូន ទាំងទឹកភ្នែកដូចជាសត្រូវនៃឈើឆ្កាងរបស់ព្រះគ្រិស្ត។[19]ដល់ទីបំផុត អ្នកទាំងនោះត្រូវវិនាស
អន្តរាយ។ គេយកក្រពះធ្វើជាព្រះ យកកេរ្តិ៍ខ្មាសធ្វើជាកិត្តិយស។ ពួកគេគិតតែពីអ្វីៗដែល នៅលើផែនដីនេះតែប៉ុណ្ណោះ។
[20]ប៉ុន្តែ សញ្ជាតិរបស់យើងគឺនៅក្នុងស្ថានបរមសុខ ហើយយើងនៅទន្ទឹងរង់ចាំព្រះសង្គ្រោះ គឺព្រះអម្ចាស់យេស៊ូគ្រិស្ត។[21]ព្រះអង្គនឹងបំផ្លាស់បំប្រែរូបកាយដ៏ថោកទាបរបស់
យើងនេះ ឲ្យបានដូចព្រះកាយប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ ដោយមហិទ្ធិឫទ្ធិ ដែលធ្វើឲ្យព្រះអង្គបង្ក្រាបអ្វីទាំងអស់នៅក្រោមអំណាចរបស់ព្រះអង្គ។

Philippians 3:1
ប្រយោគភ្ជាប់:
ដើម្បីដាស់តឿនបងប្អូនរួមជំនឿរបស់គាត់អំពីជនជាតិយូដាដែលព្យាយាមធ្វើឲ្យពួកគេ
លោកប៉ូលផ្តល់ឲ្យទីបន្ទាល់ផ្ទាល់ខ្លួនរបស់គាត់អំពីពេលគាត់បៀតបៀនអ្នកជឿ។
ជាចុងក្រោយ បងប្អូនអើយ
«ឥឡូវនេះកំពុងផ្លាស់ប្តូរបងប្អូនខ្ញុំ» ឬ
«ទាក់ទងនឹងបញ្ហាផ្សេងទៀតបងប្អូនរបស់ខ្ញុំ»
បងប្អូន
បកប្រែដូចនៅក្នុង១:១២
ចូរអរសប្បាយនៅក្នុងព្រះអង្គម្ចាស់ចុះ
«សប្បាយចិត្តដោយសារអ្វីៗដែលព្រះអម្ចាស់បានធ្វើ»
ធុញទ្រាន់
រំខាន
សេចក្តីទាំងនេះមកបងប្អូនម្តងទៀតទេ
នៅទីនេះ «របស់ទាំងនេះ» សំដៅទៅលើការបង្រៀនរបស់លោកប៉ូល។
អ្នកអាចបន្ថែមការបកប្រែជំនួសនេះនៅចុងបញ្ចប់នៃប្រយោគមុន។
ការបកប្រែផ្សេងទៀត:
«ពីព្រោះការបង្រៀនទាំងនេះនឹងការពារអ្នកពីអ្នកដែលបង្រៀនអ្វីដែលមិនពិត»
ចូរប្រយ័ត្ន
«ប្រយ័ត្ន» ឬ «ប្រយ័ត្នប្រយែង»
ចូរប្រយ័ត្ននឹងពួកឆ្កែ ...ពួកអ្នកដែលធ្វើការអាក្រក់ ... អ្នកកាត់ស្បែក
ទាំងនេះគឺជាវិធីបីយ៉ាងផ្សេងគ្នានៃការពិពណ៌នាអំពីក្រុមគ្រូក្លែងក្លាយ។
ធ្វើតាមក្រឹត្យវិន័យ
ដើម្បីបង្ហាញអារម្មណ៍របស់គាត់ចំពោះគ្រូគ្រិសបរិស័ទជនជាតិយូដាទាំងនេះ។
ឆ្កែ
ពាក្យ «ឆ្កែ»
ត្រូវបានប្រើដោយជនជាតិយូដាសំដៅទៅលើអ្នកដែលមិនមែនជាជនជាតិយូដា។
ពួកគេត្រូវបានគេចាត់ទុកថាមិនស្អាត។
លោកប៉ូលនិយាយអំពីគ្រូក្លែងក្លាយដូចជាពួកគេជាឆ្កែដើម្បីប្រមាថមើលងាយពួកគេ។
ប្រសិនបើអ្នកមានសត្វផ្សេងនៅក្នុងវប្បធម៌របស់អ្នកដែលត្រូវបានគេចាត់ទុកថាមិនស្អាតឬឈ្មោះរបស់វា
កាត់ស្បែក
លោកប៉ូលកំពុងនិយាយបំផ្លើសអំពីទង្វើនៃការកាត់ស្បែកដើម្បីប្រមាថគ្រូក្លែងក្លាយ។
គ្រូក្លែងក្លាយបាននិយាយថាព្រះជាម្ចាស់នឹងជួយសង្គ្រោះតែមនុស្សដែលកាត់ស្បែកប៉ុណ្ណោះដែលកាត់ស្
ជនជាតិអ៊ីស្រាអែលប្រុសៗទាំងអស់ត្រូវបានតម្រូវដោយច្បាប់របស់លោកម៉ូសេ។
សម្រាប់ពួកយើង
លោកប៉ូលប្រើ «យើង»
ដើម្បីសំដៅទៅលើខ្លួនគាត់និងអ្នកជឿពិតទាំងអស់នៅក្នុងព្រះគ្រិស្តរួមទាំងអ្នកជឿនៅភីលីពផង។
យើងគឺជាអ្នកដែលកាត់ស្បែកពិត
លោកប៉ូលប្រើឃ្លានេះដើម្បីសំដៅទៅលើអ្នកជឿលើព្រះគ្រិស្តដែលមិនមែនជាអ្នកកាត់ស្បែកទេតែត្រូវបាន
«ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ពិត»

generated on Wed Sep 10 16:16:32 2025

មិនពឹងអាងខាងឯសាច់ឈាមទេ
«កុំជឿថាមានតែកាត់ស្បែកប៉ុណ្ណោះដែលយើងនឹងផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់»
Philippians 3:4
ទោះបីយ៉ាងនេះក្តី
«នៅឡើយ» ឬ «ទោះយ៉ាងណា»
ខ្ញុំផ្ទាល់ក៏ហេតុនឹងពឹងអាងខាងឯសាច់ឈាមដែរ។
បើមាននរណាគិតថាគេបានពឹងអាងលើសាច់ឈាមនោះ
ហើយខ្ញុំនេះអាចនឹងពឹងអាងច្រើនជាងគេផង។
ស្ថានភាពនេះសន្មត់ថាលោកប៉ូលមិនជឿថាអាចធ្វើទៅបានទេ។
លោកប៉ូលមានប្រសាសន៍ថាប្រសិនបើអាចធ្វើបានដែលព្រះជាម្ចាស់នឹងជួយសង្គ្រោះមនុស្សដោយសារតែការកាត់ស្បែក
ការបកប្រែផ្សេងទៀត:
«គ្មានអ្នកណាម្នាក់អាចធ្វើអំពើល្អដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់បានទេប្រសិនបើនៅក្នុងជីវិតរបស់គាត់
ខ្ញុំអាចនឹងធ្វើអំពើល្អច្រើនថែមទៀតហើយគាប់ព្រះហឫទ័យព្រះជាម្ចាស់ច្រើនជាងអ្នកណាទាំងអស់។
ខ្ញុំផ្ទាល់
លោកប៉ូលប្រើ «ខ្លួនខ្ញុំ» សម្រាប់ជាការសង្កត់ធ្ងន់ «ខ្ញុំពិតជា»
ខ្ញុំបានទទួលពិធីកាត់ស្បែក
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម ។ការបកប្រែផ្សេងទៀត:
«បូជាចារ្យម្នាក់បានធ្វើពិធីកាត់ស្បែកអោយខ្ញុំ»
ប្រាំបីថ្ងៃ
«ប្រាំពីរថ្ងៃបន្ទាប់ពីខ្ញុំកើត» (UDB)
ខ្ញុំជាជនជាតិហេប្រឺ កើតពីសាសន៍ហេប្រឺ
ទី១អត្ថន័យប្រហែលជា) កូនប្រុសជនជាតិហេប្រឺដែលមានឪពុកម្តាយហេប្រឺ» ឬ
២) «ភាសាហេប្រឺបរិសុទ្ធបំផុត» ។
ហើយបើពឹងអាចខាងក្រឹត្យវិន័យវិញ ខ្ញុំក៏នៅខាងពួកផារីស៊ីដែរ។
វិធីតែមួយគត់ដែលជនជាតិយូដាអាចក្លាយជាផារិស៊ីបានកើតមកពីឪពុកដែលជាផារិស៊ីប៉ូលដាស់តឿនអ្នកជឿនៅភីលីព ឲ្យ
ប៉ុន្តែនេះបានដាក់កាតព្វកិច្ចដល់មនុស្សឲ្យរស់នៅក្នុងនាមជាផារីស៊ីដោយមានភក្តីភាព
«ក្នុងនាមជាផារិស៊ីម្នាក់ ត្រូវស្មោះត្រង់ដល់ក្រឹត្យវិន័យ»
Philippians 3:6
ខាងឯសេចក្តីឧស្សាហ៍ គឺខ្ញុំបានបៀតបៀនដល់ក្រុមជំនុំ
លោកប៉ូលនិយាយនៅទីនេះថាគាត់ចង់ដាក់ទណ្ឌកម្មខ្លាំងណាស់ចំពោះអ្នកដើរតាមព្រះគ្រីស្ទ។
«ខ្ញុំបានតាំងចិត្តធ្វើបាបគ្រិស្តបរិស័ទ»
ចំពោះសេចក្តីសុចរិតវិញ ខ្ញុំបាននៅក្រោមក្រឹត្យវិន័យ ហើយក៏គ្មានកន្លែងបន្ទោសបានផង
«ខ្ញុំបានគោរពតាមក្រឹត្យវិន័យទាំងស្រុង»
អ្វីៗដែលខ្ញុំធ្លាប់គិតថាមានតម្លៃចំពោះខ្ញុំនោះ
លោកប៉ូលកំពុងសំដៅទៅលើការសរសើរដែលគាត់បានទទួលដោយសារគាត់ជាផារិស៊ី
។ការបកប្រែផ្សេងទៀត:«អ្វីដែលជនជាតិយូដាផ្សេងទៀតបានសរសើរចំពោះខ្ញុំ»
ខ្ញុំចាត់ទុកទាំងអស់ថាឥតបានការទៅវិញ
លោកប៉ូលនិយាយអំពីការសរសើរនោះដូចជាឥឡូវគាត់កំពុងមើលឃើញថាវាជាការរក
ម្យ៉ាងវិញទៀតលោកប៉ូលនិយាយថាសកម្មភាពសាសនាទាំងអស់នៃភាពសុចរិតរបស់គាត់
Philippians 3:8
ចំពោះមុខ
«ជាក់ស្តែង» ឬ «ពិតប្រាកដ»
ខ្ញុំបានចាត់ទុក
ពាក្យ «ឥឡូវនេះ»
បញ្ជាក់ពីរបៀបដែលលោកប៉ូលបានផ្លាស់ប្តូរចាប់តាំងពីគាត់ឈប់ធ្វើជាផារិស៊ីហើយក្លាយ
ការបកប្រែផ្សេងទៀត: «ឥឡូវនេះខ្ញុំបានជឿទុកចិត្តលើព្រះគ្រិស្តខ្ញុំរាប់ទុកជា»
ខ្ញុំបានចាត់ទុកគ្រប់របស់ទាំងអស់ជាឥតប្រយោជន៍
លោកប៉ូលកំពុងបន្តការប្រៀបធៀបអាជីវកម្មពី ៣: ៦
ដោយនិយាយថាវាគ្មានប្រយោជន៍ទេក្នុងការទុកចិត្តលើអ្វីក្រៅពីព្រះគ្រិស្ត។
ដោយព្រោះតែខ្ញុំបានស្គាល់ព្រះគ្រិស្តយេស៊ូជាអម្ចាស់របស់ខ្ញុំ
ជាអ្វីដែលមានតម្លៃវិសេសវិសាលណាស់
«ពីព្រោះការស្គាល់ព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់របស់ខ្ញុំគឺមានតម្លៃជាង»
ដោយសារតែព្រះអង្គ ខ្ញុំសុខចិត្តបោះបង់ចោលអ្វីៗទាំងអស់។
«ដោយសារទ្រង់ខ្ញុំបានបោះចោលអ្វីៗផ្សេងទៀតដោយស្ម័គ្រចិត្ត»
បោះបង់ចោល
ប្រើពាក្យធម្មតារបស់អ្នកសម្រាប់ការដាក់បញ្ចូលរបស់អ្វីដែលមិនចង់ឲ្យយកចេញពីអ្នក
ខ្ញុំចាត់ទុកអ្វីៗទាំងអស់ដូចជាសំរាម
លោកប៉ូលនិយាយអំពីរឿងដែលមនុស្សម្នាក់អាចទុកចិត្តដូចជាសំរាមដែលត្រូវបានគេ
គាត់កំពុងសង្កត់ធ្ងន់ថាវាពិតជាគ្មានតម្លៃមែន។ការបកប្រែផ្សេងទៀត:

«ខ្ញុំគិតថាពួកគេដូចជាសម្រាម»
ឲ្យតែខ្ញុំបានព្រះគ្រិស្ត
«ដូច្នេះខ្ញុំអាចមានព្រះគ្រិស្តតែមួយ»
គេនឹងឃើញខ្ញុំនៅក្នុងព្រះអង្គ
ឃ្លា «ត្រូវបានរកឃើញ» គឺជាពាក្យដែលសង្កត់ធ្ងន់លើគំនិតនៃ «ដើម្បីក្លាយជា»
ការបកប្រែផ្សេងទៀត: «នឹងត្រូវបានរួបរួមជាមួយព្រះគ្រិស្តយ៉ាងពិតប្រាកដ»
ខ្ញុំមិនបានទៅជាសុចរិតដោយខ្ញុំខំប្រព្រឹត្តតាមក្រឹត្យវិន័យនោះទេ។
«ខ្ញុំមិនព្យាយាមផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ដោយខ្លួនខ្ញុំផ្ទាល់ដោយធ្វើតាមក្រឹត្យវិន័យនោះទេ»
ឫទ្ធានុភាពដែលបានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញ
[illegible]
ហើយចូលរួមជាមួយព្រះអង្គក្នុងទុក្ខលំបាកដែរ។
[illegible]
ព្រះអង្គដែលសុគត
ទី១អត្ថន័យប្រហែលជា)
លោកប៉ូលចង់អោយព្រះគ្រិស្តផ្លាស់ប្តូរគាត់ដូច្នេះគាត់អាចស្លាប់ដូចព្រះគ្រិស្តបានសុគតឬ
២)
គាត់ចង់ប្រាថ្នាអោយបាបរបស់គាត់ប្រែជាស្លាប់ដូចព្រះយេស៊ូមុនពេលព្រះអង្គត្រូវបានលើកឡើង។
ដើម្បីឲ្យខ្ញុំមានជីវិតរស់ឡើងវិញ ប្រសិនបើអាចរស់ឡើងវិញបាន។
ពាក្យថា «ដូចម្តេច»
មានន័យថាលោកប៉ូលមិនដឹងថានឹងមានអ្វីកើតឡើងចំពោះគាត់ក្នុងជីវិតនេះទេប៉ុន្តែទោះបីជាមានអ្វីកើតឡ
«ដូច្នេះគ្មានបញ្ហាមិនថាមានអ្វីកើតឡើងចំពោះខ្ញុំពេលនេះខ្ញុំនឹងរស់ឡើងវិញ
បន្ទាប់ពីខ្ញុំស្លាប់»
Philippians 3:12
ប្រយោគភ្ជាប់:
ទាំងនេះរួមមានការស្គាល់ព្រះគ្រិស្តការស្គាល់ពីអំណាចនៃការរស់ឡើងវិញរបស់ទ្រង់ការចូលរួមក្នុងការរងទ
ឬបានគ្រប់លក្ខណៈហើយ
«ដូច្នេះខ្ញុំមិនទាន់ល្អឥតខ្ចោះ» ឬ «ដូច្នេះខ្ញុំមិនទាន់ពេញវ័យ»
ខ្ញុំកំពុងតែបន្តទៅមុខ
«ប៉ុន្តែខ្ញុំនៅតែព្យាយាម»
[illegible]
«ខ្ញុំអាចនឹងទទួលបានរបស់ទាំងនេះ»
ដ្បិត ខ្លួនខ្ញុំផ្ទាល់ក៏ត្រូវព្រះគ្រិស្តយេស៊ូចាប់ខ្ញុំដើម្បីសេចក្តីនោះដែរ។
[illegible]
ការបកប្រែផ្សេងទៀត:
[illegible]
Active or Passive)
បងប្អូនអើយ
បកប្រែដូចនៅក្នុង១:១២
ខ្លួនខ្ញុំផ្ទាល់ ក៏យល់ឃើញថា
«របស់ទាំងអស់នេះមិនទាន់ជាកម្មសិទ្ធរបស់ខ្ញុំនៅឡើយទេ
[illegible]
ដូចជាអ្នករត់ប្រណាំងអ្នកប្រណាំងលែងព្រួយបារម្ភអំពីផ្នែកនៃការប្រណាំងដែលបានបញ្ចប់ប៉ុន្តែផ្តោតតែទ
ការបកប្រែផ្សេងទៀត:
ខ្ញុំមិនខ្វល់ពីអ្វីដែលខ្ញុំបានធ្វើកាលពីអតីតកាលទេខ្ញុំខំប្រឹងធ្វើការខ្លាំងណាស់តាមដែលខ្ញុំអាចធ្វើទៅបាន(ស
Metaphor)
ខ្ញុំរត់តម្រង់ទៅរកគោលដៅ ដើម្បីឲ្យបានទទួលរង្វាន់ពីព្រះជាម្ចាស់ដែលបានត្រាស់ហៅពីស្ថាន
បរមសុខនៅក្នុងអង្គព្រះគ្រិស្តយេស៊ូ។
ក្នុងនាមជាអ្នករត់ប្រណាំងរត់ទៅមុខដើម្បីឈ្នះការប្រកួតលោកប៉ូលខំប្រឹងបម្រើនិងរស់នៅដោយគោរពតា
ការបកប្រែផ្សេងទៀត:ខ្ញុំធ្វើអ្វីៗទាំងអស់ដែលខ្ញុំអាចធ្វើបានដូចជាព្រះគ្រិស្ត
ដូចជាអ្នករត់ប្រណាំងរត់ដល់ទីផ្តាច់ព្រ័ត្រដូច្នេះខ្ញុំអាចជាកម្មសិទ្ធិរបស់ទ្រង់ហើយព្រះជាម្ចាស់អាចហៅខ្ញុំដេ
Metaphor)
[illegible]
អត្ថន័យដែលអាចទៅរួចគឺថាលោកប៉ូលនិយាយអំពីការរស់នៅជារៀងរហូតជាមួយព្រះជាម្ចាស់ដូចជាព្រះ
[illegible]
ជំហានទៅវេទិកាដែលអ្នកឈ្នះនៃការប្រណាំងបានទទួលរង្វាន់ជាការប្រៀបធៀបសម្រាប់ការជួបជាមួយព្រ

generated on Wed Sep 10 16:16:32 2025

ហើយទទួលជីវិតអស់កល្បជានិច្ច។ (សូមមើល:|Metaphor)
Philippians 3:15
យើងទាំងអស់គ្នាដែលជាមនុស្សគ្រប់ពេញវ័យ សូមឲ្យយើងគិតបែបនេះ
លោកប៉ូលចង់ ឲ្យ
បងប្អូនរួមជំនឿរបស់គាត់មានសេចក្តីប៉ងប្រាថ្នាដូចគាត់បានរៀបរាប់ក្នុង ៣: ៨។
ការបកប្រែផ្សេងទៀត:
«ខ្ញុំលើកទឹកចិត្តឱ្យយើងទាំងអស់គ្នាដែលជាអ្នកជឿរឹងមាំក្នុងការគិតតាមរបៀបដូចគ្នា»
ព្រះជាម្ចាស់នឹងបង្ហាញបងប្អូន ឲ្យដឹងពីការនោះដែរ។
ព្រះជាម្ចាស់ក៏នឹងធ្វើវាឲ្យច្បាស់ដល់បងប្អូន ឬ
«ព្រះជាម្ចាស់នឹងធ្វើអោយអ្នកដឹងប្រាកដ
មានអ្វីកើតឡើងក៏ដោយ យើងត្រូវតែទៅមុខជានិច្ច ហើយសូមឲ្យតោងជាប់នឹងសេចក្តីទាំងនោះផង។
«ចូរយើងទាំងអស់គ្នាបន្តគោរពតាមសេចក្តីពិតដែលយើងបានទទួល»
Philippians 3:17
បងប្អូនអើយ ចូរយកតម្រាប់តាមខ្ញុំ
ធ្វើអ្វីដែលខ្ញុំធ្វើ» ឬ «រស់ដូចខ្ញុំរស់នៅ
បងប្អូន
បកប្រែដូចនៅក្នុង ១:១២
មើលអស់អ្នកដែលដើរជាគំរូ ដែលបានដាក់ឲ្យបងប្អូនឃើញនៅក្នុងយើង។
«អ្នកដែលកំពុងរស់នៅដូចខ្ញុំរស់នៅ» ឬ «អ្នកដែលកំពុងធ្វើអ្វីដែលខ្ញុំកំពុងធ្វើរួច»
ដ្បិត មានមនុស្សជាច្រើន...ជាសត្រូវនៃឈើឆ្កាងរបស់ព្រះគ្រិស្ត
ពាក្យទាំងនេះគឺជាគំនិតសំខាន់របស់លោកប៉ូលសម្រាប់ខនេះ។
ដ្បិត មានមនុស្សជាច្រើន
«មនុស្សជាច្រើនកំពុងរស់នៅ» ឬ «មនុស្សជាច្រើនកំពុងដឹកនាំជីវិតរបស់ពួកគេ»
សូមមើល:
ដែលខ្ញុំតែងតែប្រាប់ដល់បងប្អូនជាញយដង ហើយឥឡូវខ្ញុំកំពុងប្រាប់បងប្អូន ទាំងទឹកភ្នែក
លោកប៉ូលបណ្ឍប់គំនិតសំខាន់របស់គាត់ជាមួយនឹងពាក្យទាំងនេះដែលពិពណ៌នាអំពី
«មនុស្សជាច្រើន»។
អ្នកអាចប្តូរពួកវាទៅខាងដើមឬខាងចុងខប្រសិនបើអ្នកត្រូវការ។
ដែលខ្ញុំតែងតែប្រាប់ដល់បងប្អូនជាញយដង
«ខ្ញុំបានប្រាប់បងប្អូនច្រើនដងហើយ»
កំពុងប្រាប់បងប្អូន ទាំងទឹកភ្នែក
«ខ្ញុំកំពុងប្រាប់បងប្អូនដោយមានទុក្ខព្រួយយ៉ាងខ្លាំង»
ជាសត្រូវនៃឈើឆ្កាងរបស់ព្រះគ្រិស្ត។
នៅទីនេះ «ឈើឆ្កាងរបស់ព្រះគ្រិស្ត»
សំដៅទៅលើការរងទុក្ខនិងការសុគតរបស់ព្រះគ្រិស្ត។
ខ្មាំងសត្រូវគឺជាអ្នកដែលនិយាយថាពួកគេជឿលើព្រះយេស៊ូប៉ុន្តែមិនសុខចិត្តរងទុក្ខឬស្លាប់ដូចព្រះយេស៊ូ
ការបកប្រែផ្សេងទៀត:
«តាមរបៀបមួយដែលបង្ហាញថាពួកគេពិតជាប្រឆាំងនឹងព្រះយេស៊ូដែលសុខចិត្តរងទុក្ខនិងសុគតនៅលើ
ដល់ទីបំផុត អ្នកទាំងនោះត្រូវវិនាសអន្តរាយ។
«ថ្ងៃណាមួយព្រះជាម្ចាស់នឹងបំផ្លាញពួកគេ»
គេយកក្រពះធ្វើជាព្រះ
នៅទីនេះ «ក្រពះ»
សំដៅទៅលើបំណងប្រាថ្នារបស់មនុស្សម្នាក់សម្រាប់ការសប្បាយខាងរាងកាយ។
ការហៅវាថាព្រះរបស់ពួកគេមានន័យថាពួកគេចង់បានការសប្បាយទាំងនេះច្រើនជាងពួកគេចង់ស្តាប់បង
ការបកប្រែផ្សេងទៀត:
«ពួកគេចង់បានអាហារនិងការសប្បាយខាងរាងកាយច្រើនជាងពួកគេចង់គោរពតាមព្រះជាម្ចាស់»
គេយកក្រពះធ្វើជាព្រះ
ត្រង់នេះ «ភាពអៀនខ្មាស់»
តំណាងអោយសកម្មភាពដែលប្រជាជនគួរតែខ្មាស់អៀនប៉ុន្តែមិនមែនទេ។
ការបកប្រែផ្សេងទៀត:«ពួកគេមានមោទនភាពចំពោះអ្វីដែលបណ្តាលឱ្យពួកគេខ្មាស់អៀន»
ពួកគេគិតតែពីអ្វីៗដែល នៅលើផែនដីនេះតែប៉ុណ្ណោះ
នៅទីនេះ «ផែនដី»
សំដៅទៅលើអ្វីគ្រប់យ៉ាងដែលផ្តល់នូវការសប្បាយខាងរាងកាយនិងមិនគោរពព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត:
«អ្វីដែលពួកគេគិតគឺអ្វីដែលនឹងផ្គាប់ចិត្តខ្លួនឯងជាជាងអ្វីដែលគាប់ព្រះហឫទ័យព្រះ»
Philippians 3:20
ប្រយោគភ្ជាប់:
តាមរយៈការប្រើពាក្យ «របស់យើង» និង «យើង»
របស់ប៉ូលនៅទីនេះគាត់រួមបញ្ចូលទាំងខ្លួនគាត់និងអ្នកជឿនៅភីលីព។
សញ្ជាតិរបស់យើងគឺនៅក្នុងស្ថានបរមសុខ
ទី១អត្ថន័យប្រហែលជា) យើងជាពលរដ្ឋនៃស្ថានបរមសុខ» (UDB) ឬ ២)
«មាតុភូមិយើងគឺស្ថានបរមសុខ» ឬ ៣) «ផ្ទះពិតរបស់យើងគឺស្ថានបរមសុខ» ។
ព្រះអង្គនឹងបំផ្លាស់បំប្រែរូបកាយដ៏ថោកទាបរបស់យើងនេះ
«ព្រះអង្គនឹងផ្លាស់ប្តូររាងកាយទន់ខ្សោយនិងផែនដីរបស់យើង»
ឲ្យបានដូចព្រះកាយប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ
«ទៅជារូបរាងដូចជារូបកាយដ៏រុងរឿងរបស់ទ្រង់»
ដោយមហិទ្ធិឫទ្ធិ ដែលធ្វើឲ្យព្រះអង្គបង្ក្រាបអ្វីទាំងអស់នៅក្រោមអំណាចរបស់ព្រះអង្គ
នេះអាចត្រូវបានថ្លែងជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត: «រាងកាយ។
ព្រះអង្គនឹងផ្លាស់ប្តូររូបរាងកាយរបស់យើងដោយអំណាចតែមួយដែលព្រះអង្គប្រើដើម្បីគ្រប់គ្រងអ្វីៗទាំងអ

---

4 [1]បងប្អូនជាទីស្រឡាញ់ ខ្ញុំពិតជាចង់ជួបអ្នករាល់គ្នាខ្លាំងណាស់ បងប្អូនជាអំណរសប្បាយ និងជាមកុដរបស់ខ្ញុំ សំឡាញ់ខ្ញុំអើយ
សូមឈរឲ្យបានរឹងពឹងនៅក្នុងព្រះអម្ចាស់។[2]ខ្ញុំសូមទូន្មាននាងអ៊ើរ៉ូឌា និងនាងស៊ុនទីចថា ចូរមានចិត្តគំនិតតែមួយ ក្នុងព្រះអម្ចាស់។[3]ហើយខ្ញុំក៏សូម បងប្អូនដែលជាមិត្តដ៏
ស្មោះត្រង់ សូមជួយនាងទាំងពីរនាក់នេះផង។ ដ្បិត នាងធ្លាប់បានធ្វើការរួមជាមួយខ្ញុំ ដើម្បីផ្សាយដំណឹងល្អ ជាមួយលោកក្លេមេន ព្រមទាំងអ្នកផ្សេងទៀត ដែលពួកគេមាន
ឈ្មោះនៅក្នុងបញ្ជីជីវិតផងដែរ។
[4]ចូរអរសប្បាយក្នុងព្រះអម្ចាស់ចុះ។ ម្តងទៀតនិយាយថា ចូរអរសប្បាយឡើង។[5]ចូរបង្ហាញឲ្យមនុស្សទាំងអស់ស្គាល់ចិត្តសប្បុរសរបស់បងប្អូន។ ព្រះអម្ចាស់ជិតយាងមក
ដល់ហើយ។[6]សូមកុំខ្វល់ខ្វាយនឹងអ្វីឡើយ។ ផ្ទុយទៅវិញ ក្នុងគ្រប់ការទាំងអស់ គឺតាមរយៈពាក្យអធិស្ឋាន និងទូលអង្វរ ទាំងការអរព្រះគុណព្រះអង្គផង[7]ហើយ សេចក្តី
សុខសាន្តរបស់ព្រះជាម្ចាស់ ដែលហួសពីការយល់របស់មនុស្សនឹងស្ថិតជាប់ក្នុងចិត្តគំនិតបងប្អូន ដែលក្នុងអង្គព្រះគ្រិស្តយេស៊ូ។
[8]ជាទីបញ្ចប់ បងប្អូនអើយ សូមបងប្អូនគិតតែអំពីអ្វីៗដែលពិត ហើយអ្វីដែលថ្លៃថ្នូរ និងអ្វីដែលសុចរិត រួមទាំងអ្វីដែលបរិសុទ្ធ ហើយអ្វីដែលគួរឲ្យស្រឡាញ់ ហើយអ្វីដែលគួរ
ឲ្យគោរព ហើយប្រសិនបើ មានអ្វីដែលល្អឥតខ្ចោះ គួរឲ្យកោតសរសើរ សូមបងប្អូនគិតអំពីការទាំងនេះ។[9]សេចក្តីដែលបងប្អូនបានរៀន បានទទួល និងបានឮ
ហើយឃើញនៅក្នុងខ្ញុំ សូមប្រព្រឹត្តតាមការទាំងនោះចុះ ហើយព្រះជាម្ចាស់នៃសេចក្តីសុខសាន្តនឹងគង់ជាមួយអ្នករាល់គ្នា។
[10]ខ្ញុំមានអំណរក្នុងព្រះអម្ចាស់យ៉ាងខ្លាំង ដោយដឹងថា បងប្អូនបានបារម្ភដល់ខ្ញុំជាថ្មីម្តងទៀត។ មែនហើយ បងប្អូនក៏បានធ្លាប់នឹកគិតដល់ខ្ញុំដែរ តែបងប្អូនគ្មានឱកាសនឹង
សម្តែងទឹកចិត្តរបស់បងប្អូនដើម្បីជួយដល់ខ្ញុំទេ។[11]ខ្ញុំនិយាយដូច្នេះ មិនមែនមកពីខ្ញុំខ្វះខាតនោះទេ។ ដ្បិត ខ្ញុំបានរៀនឲ្យចេះស្កប់ចិត្ត ក្នុងគ្រប់កាលៈទេសៈទាំងអស់។
[12]ខ្ញុំស្គាល់អ្វីទៅដែលជាភាពទ័លក្រ ហើយខ្ញុំក៏ស្គាល់ពីការដែលមានបរិបូរដែរ។ ខ្ញុំបានអប់រំចិត្តក្នុងគ្រប់របៀបទាំងអស់ និងគ្រប់ទីកន្លែង គឺថា ទោះបីហូបឆ្អែត ឬអត់ឃ្លាន
ក្តី មានបរិបូរ ឬខ្វះខាតក្តី ខ្ញុំស្កប់ចិត្តជានិច្ច។[13]ខ្ញុំអាចធ្វើគ្រប់ការទាំងអស់បាន ដោយព្រះអង្គដែលប្រទានកម្លាំងឲ្យខ្ញុំ។
[14]ទោះជាយ៉ាងណាក៏ដោយ បងប្អូនបានធ្វើប្រសើរហើយដែលបានរួមជាមួយខ្ញុំក្នុងពេលដែលខ្ញុំជួបទុក្ខលំបាក។[15]ឱបងប្អូននៅក្រុងភីលីពអើយ បងប្អូនដឹងហើយថា តាំងពី
ខ្ញុំបានចាប់ផ្តើមផ្សាយដំណឹងល្អ នៅពេលខ្ញុំបានចាកចេញពីស្រុកម៉ាសេដូនមកនោះ ក្រៅពីបងប្អូន គ្មានក្រុមជំនុំណាជួយផ្គត់ផ្គងខ្ញុំនោះទេក្រៅពីបងប្អូន។[16]កាលខ្ញុំនៅ
ក្រុងថេស្សាឡូនិក បងប្អូនបានផ្ញើជំនួយ តាមសេចក្តីត្រូវការរបស់ខ្ញុំជាច្រើនលើក។ មិនមែនមានន័យថា ខ្ញុំឃើញតែពីជំនួយរបស់បងប្អូននោះទេ។[17]តែខ្ញុំឃើញអំពីផលផ្លែ
ការរីកចម្រើន និងភាពច្បាស់លាស់របស់បងប្អូនវិញ។
[18]ខ្ញុំបានទទួលគ្រប់ទាំងអស់ ហើយខ្ញុំមានបរិបូរផងដែរ។ ឥឡូវនេះ ខ្ញុំមានរឹតតែច្រើន ដោយបានទទួលអំណោយពីបងប្អូន តាមរយៈលោកអេប៉ាប្រូឌីត។ អំណោយទាំងនេះ
ប្រៀបបីដូចជាក្លិនក្រអូបឈ្ងុយឈ្ងប់ ជាយញ្ញបូជាដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ។[19]ព្រះជាម្ចាស់របស់ខ្ញុំនឹងបំពេញសេចក្តីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាម
សិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះគ្រិស្តយេស៊ូ។[20]ឥឡូវនេះ សូមលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ និងព្រះបិតារបស់យើងដ៏អស់កល្បជារៀងរហូតតទៅ។ អាម៉ែន!

generated on Wed Sep 10 16:16:32 2025

[21]សូមជម្រាបសួរបងប្អូនរួមជំនឿនៅក្នុងអង្គព្រះគ្រិស្តយេស៊ូទាំងអស់។ បងប្អូនដែលនៅជាមួយខ្ញុំ សូមជម្រាបសួរមកដល់បងប្អូនទាំងអស់គ្នាដែរ។
[22]ហើយអ្នកជឿទាំងអស់ក៏ជម្រាបសួរបងប្អូន ជាពិសេស បងប្អូនដែលជាអ្នករាជការរបស់ព្រះចៅអធិរាជ ក៏សូមជម្រាបសួរមកបងប្អូនដែរ។[23]សូមព្រះគុណរបស់
ព្រះអម្ចាស់យេស៊ូគ្រិស្តគង់នៅជាមួយវិញ្ញាណរបស់បងប្អូន។

Philippians 4:1
ប្រយោគភ្ជាប់:
លោកប៉ូលបន្តដោយមានការណែនាំជាក់លាក់មួយចំនួនដល់អ្នកជឿនៅភីលីពអំពីការរួបរួមនៅក្នុងសេចក្តីជំនឿ
ពត៌មានទូទៅ:
នៅពេលលោកប៉ូលនិយាយថា «នឹមរបស់ខ្ញុំពិតប្រាកដ» ពាក្យថា «អ្នក»
គឺឯកវចនៈ។ លោកប៉ូលមិនបានប្រាប់ឈ្មោះរបស់មន្ស្សនោះទេ។
គាត់ហៅគាត់ដើម្បីបង្ហាញថាគាត់បានធ្វើការជាមួយលោកប៉ូលដើម្បីផ្សព្វផ្សាយដំណឹងល្អ
បងប្អូនអើយ
បកប្រែដូចនៅក្នុង១:១២
បងប្អូនជាទីស្រឡាញ់ ខ្ញុំពិតជាចង់ជួបអ្នករាល់គ្នាខ្លាំងណាស់
«បងប្អូនរួមជំនឿខ្ញុំស្រឡាញ់បងប្អូនហើយខ្ញុំពិតជាចង់ជួបបងប្អូន»
បងប្អូនជាអំណរសប្បាយ និងជាមកុដរបស់ខ្ញុំ
លោកប៉ូលប្រើពាក្យ «អំណរ»
មានន័យថាក្រុមជំនុំភីលីពគឺជាដើមហេតុនៃការសប្បាយរបស់គាត់។
«មកុដ»ត្រូវបានធ្វើពីស្លឹកហើយបុរសម្នាក់ពាក់វានៅលើក្បាលរបស់គាត់ជាសញ្ញានៃកិត្តិយសឬជ័យជម្នះ
នៅទីនេះពាក្យថា «មកុដ»
មានន័យថាពួកជំនុំភីលីពបាននាំកិត្តិយសដល់លោកប៉ូលនៅចំពោះព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត:
«អ្នកផ្តល់ឱ្យខ្ញុំនូវអំណរព្រោះអ្នកបានជឿលើព្រះយេស៊ូហើយអ្នកគឺជារង្វាន់និងកិត្តិយសរបស់ខ្ញុំ»
សំឡាញ់ខ្ញុំអើយ សូមឈរឲ្យបានរឹងពឹងនៅក្នុងព្រះអម្ចាស់
«ដូច្នេះបន្តរស់នៅសម្រាប់ព្រះអម្ចាស់តាមរបៀបដែលខ្ញុំបានបង្រៀនបងប្អូនជាទីស្រឡាញ់ខ្ញុំ»
ខ្ញុំសូមទូន្មាននាងអ៊ើរ៉ូឌា និងនាងស៊ុនទីចថា
ទាំងនេះគឺជាស្ត្រីដែលជាអ្នកជឿហើយបានជួយលោកប៉ូលនៅក្នុងព្រះវិហារនៅភីលីព
«ខ្ញុំសូមអង្វរអ៊ើរ៉ូឌាហើយខ្ញុំសូមអង្វរនាងស៊ុនទីច» (សូមមើល: ការបកប្រែ-ឈ្មោះ)
ចូរមានចិត្តគំនិតតែមួយ ក្នុងព្រះអម្ចាស់
ឃ្លាថា «មានចិត្តគំនិតតែមួយ» មានន័យថាមានអាកប្បកិរិយាវឹមតិដូចគ្នា។
ការបកប្រែផ្សេងទៀត:
«ព្រមព្រៀងជាមួយគ្នាព្រោះអ្នកទាំងពីរជឿលើព្រះអម្ចាស់តែមួយ»
ហើយខ្ញុំក៏សូម បងប្អូន
នៅទីនេះ « អ្នក» សំដៅទៅលើ «មិត្តដ៏ស្មោះត្រង់» និងមានលក្ខណៈឯកវចនៈ។
ជាមិត្តដ៏ស្មោះត្រង់
នេះជាការប្រៀបធៀបរបស់គាត់គឺមកពីការធ្វើស្រែដែលមានសត្វពីរត្រូវបានចងភ្ជាប់នឹងគ្នា
ការបកប្រែផ្សេងទៀត: «មិត្តរួមការងារ»
ជាមួយលោកក្លេមេន
លោកក្លេមេន
គឺជាបុរសម្នាក់ដែលជាអ្នកជឿនិងជាអ្នកធ្វើការនៅក្នុងព្រះវិហារនៅភីលីព។
(សូមមើល: ការបកប្រែ-ឈ្មោះ)
ដែលពួកគេមានឈ្មោះនៅក្នុងបញ្ជីជីវិតផងដែរ។
ឈ្មោះរបស់ព្រះជាម្ចស់ដែលមានសរសេរនៅក្នុងសៀវភៅជីវិត
Philippians 4:4
ចូរអរសប្បាយក្នុងព្រះអម្ចាស់ចុះ
ការបកប្រែនេះដូចអ្នកបានធ្វើនៅក្នុង៣:១
ព្រះអម្ចាស់ជិតយាងមកដល់ហើយ។
ទី១អត្ថន័យប្រហែលជា) ព្រះអម្ចាស់យេស៊ូនៅជិតអ្នកជឿដោយវិញ្ញាណឬ ២)
ជាថ្ងៃដែលព្រះអម្ចាស់យេស៊ូនឹងយាងមកផែនដីវិញ។
ក្នុងគ្រប់ការទាំងអស់ គឺតាមរយៈពាក្យអធិស្ឋាន និងទូលអង្វរ ទាំងការអរព្រះគុណព្រះអង្គផង
«មានអ្វីកើតឡើងចំពោះបងប្អូនចូរទូលអង្វរព្រះជាម្ចាស់សម្រាប់អ្វីគ្រប់យ៉ាងដែលបងប្អូនត្រូវការ
ដែលហួសពីការយល់របស់មនុស្ស
«ដែលច្រើនជាងអ្វីដែលយើងអាចយល់បាន»
ដែលហួសពីការយល់របស់មនុស្សនឹងស្ថិតជាប់ក្នុងចិត្តគំនិតបងប្អូន ដែលក្នុងអង្គព្រះគ្រិស្តយេស៊ូ។
នេះបង្ហាញពីសេចក្តីសុខរបស់ព្រះជាម្ចាស់ជាទាហានដែលការពារអារម្មណ៍និងគំនិតរបស់អ្នកជឿ
ការបកប្រែផ្សេងទៀត:
«នឹងដូចជាទាហាននិងការពារអារម្មណ៍និងគំនិតរបស់អ្នកពីការព្រួយបារម្ភអំពីបញ្ហានៃជីវិតនេះ»
Philippians 4:8
ជាទីបញ្ចប់

នៅពេលប៉ូលបញ្ចប់សំបុត្ររបស់គាត់គាត់បានសង្ខេបពីរបៀបដែលអ្នកជឿគួររស់នៅដើម្បីមានសន្តិភាពជ
បងប្អូន
បងប្អូនដែលខ្ញុំស្រឡាញ់ និងចង់ឃើញ ជាអំណរ និងមកុដរបស់ខ្ញុំ
ហើយអ្វីដែលគួរឲ្យស្រឡាញ់
អ្វីៗដែលគាប់ចិត្ត
ហើយអ្វីដែលគួរឲ្យគោរព
អ្វីក៏ដោយដែលមនុស្សកោតសរសើរ» ឬ «អ្វីក៏ដោយដែលមនុស្សគោរព »
ហើយប្រសិនបើ មានអ្វីដែលល្អឥតខ្ចោះ
«ប្រសិនបើពួកគេមានសីលធម៌ល្អ»
ហើយប្រសិនបើ មានអ្វីដែលល្អឥតខ្ចោះ គួរឲ្យកោតសរសើរ
«ហើយប្រសិនបើវាជារបស់ដែលមនុស្សសរសើរ»
សេចក្តីដែលបងប្អូនបានរៀន បានទទួល និងបានឮហើយឃើញនៅក្នុងខ្ញុំ
«ដែលខ្ញុំបានបង្រៀននិងបង្ហាញបងប្អូន»
Philippians 4:10
លោកប៉ូលបានឈប់ពីគាត់បានឈ្នះការប្រកួតដ៏សំខាន់មួយ។
លោកប៉ូលនិយាយអំពីពួកអ្នកជឿនៅក្រុងភីលីពដែលបានគាំទ្រគាត់ផ្នែកហិរញ្ញវត្ថុហើយបញ្ចប់ដោយការ
បានរៀនឲ្យចេះស្កប់ចិត្ត
«ត្រូវបានពេញចិត្ត» ឬ «មានភាពសប្បាយរីករាយ»
ការផ្គត់ផ្គង់របស់ខ្ញុំ
«ទោះជាស្ថានភាពរបស់ខ្ញុំយ៉ាងណាក៏ដោយ»
ដែលអ្វីទៅដែលជាភាពទ័លក្រ... ដែលមានបរិបូរដែរ
លោកប៉ូលដឹងពីរបៀបរស់នៅប្រកបដោយសុភមង្គលដោយមិនមានទ្រព្យសម្បត្តិឬទ្រព្យសម្បត្តិជាច្រើន។
ទោះបីហូបឆ្អែត ឬអត់ឃ្លានក្តី មានបរិបូរ ឬខ្វះខាតក្តី ខ្ញុំស្កប់ចិត្តជានិច្ច។
ឆ្អែតឬឃ្លាននិងរបៀបមានភាពបរិបូណ៌ឬខ្វះខាត -
ឃ្លាទាំងពីរនេះមានន័យថាដូចគ្នា។
លោកប៉ូលប្រើពួកគេដើម្បីបញ្ជាក់ថាគាត់បានរៀនចេះស្កប់ស្កល់ក្នុងគ្រប់ស្ថានភាពណាទាំងអស់។
ខ្ញុំអាចធ្វើគ្រប់ការទាំងអស់បាន ដោយព្រះអង្គដែលប្រទានកម្លាំងឲ្យខ្ញុំ។
«ខ្ញុំអាចធ្វើបានគ្រប់យ៉ាងពីព្រោះព្រះគ្រិស្តផ្តល់កម្លាំងដល់ខ្ញុំ»
Philippians 4:14
ក្នុងពេលដែលខ្ញុំជួបទុក្ខលំបាក
លោកប៉ូលនិយាយអំពីការលំបាករបស់គាត់ហាក់ដូចជាពួកគេជាកន្លែងដែលគាត់បានស្ថិតនៅ។
ការបកប្រែផ្សេងទៀត: «នៅពេលដែលមានការលំបាក»
តាំងពីខ្ញុំបានចាប់ផ្តើមផ្សាយដំណឹងល្អ
លោកប៉ូលសំដៅទៅលើដំណឹងល្អនៅទីនេះមានន័យថាការផ្សព្វផ្សាយដំណឹងល្អរបស់គាត់។
ក្រៅពីបងប្អូន គ្មានក្រុមជំនុំណាជួយផ្គត់ផ្គងខ្ញុំនោះទេក្រៅពីបងប្អូន
នេះអាចត្រូវបានថ្លែងនៅក្នុងភាពវិជ្ជមាន។ការបកប្រែផ្សេងទៀត:
«បងប្អូនគឺជាក្រុមជំនុំតែមួយគត់ដែលបានផ្ញើប្រាក់មកខ្ញុំឬជួយខ្ញុំ»
Philippians 4:18
ខ្ញុំបានទទួលគ្រប់ទាំងអស់
ទី១អត្ថន័យប្រហែលជា)
លោកប៉ូលបានទទួលអ្វីៗទាំងអស់ដែលក្រុមជំនុំភីលីពបានផ្ញើឬ ២)
ប៉ូលកំពុងប្រើការនិយាយលេងដើម្បីនិយាយប្រៀបធៀបអាជីវកម្មពី ៣: ៨
ហើយនិយាយថាផ្នែកនៃលិខិតនេះគឺជាបង្កាន់ដៃសម្រាប់ទំនិញពាណិជ្ជកម្មដែលអេប៉ាប្រូឌីតបានចែកចា
ហើយខ្ញុំមានបរិបូរ
លោកប៉ូលមានន័យថាមានអ្វីៗជាច្រើនដែលគាត់ត្រូវការសម្រាប់ខ្លួនគាត់ផ្ទាល់។
អំណោយទាំងនេះប្រៀបបីដូចជាក្លិនក្រអូបឈ្ងុយឈ្ងល់ ជាយញ្ញបូជាដែលព្រះជាម្ចាស់គាប់
ត្រូវបានធ្វើឡើងដោយការអធិស្ឋាននិងអរព្រះគុណ»
ក្លិនក្រអូបជាតង្វាយអាចទទួលយកដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ -
លោកប៉ូលនិយាយអំពីអំណោយពីក្រុមជំនុំភីលីស្ទីនដូចជាតង្វាយដែលថ្វាយដល់ព្រះជាម្ចាស់នៅលើអាស
លោកប៉ូលបញ្ជាក់ថាអំណោយរបស់ក្រុមជំនុំគឺ
ធ្វើឲ្យ ព្រះគាប់ព្រះហឫទ័យ។ ការបកប្រែផ្សេងទៀត:
បំពេញសេចក្តីត្រូវការគ្រប់យ៉ាងរបស់បងប្អូន
នេះគឺជាពាក្យដែលបានបកប្រែថា «ត្រូវបានបំពេញ» នៅក្នុងខទី ១៨។

generated on Wed Sep 10 16:16:32 2025

វាគឺជាអត្ថន័យពិសេសមួយដែលថា «នឹងផ្តល់នូវអ្វីគ្រប់យ៉ាងដែលអ្នកត្រូវការ»
ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះគ្រិស្តយេស៊ូ
«ពីទ្រព្យសម្បត្តិដ៏រុងរឿងរបស់ព្រះអង្គដែលព្រះអង្គប្រទានអោយតាមរយៈព្រះគ្រិស្តយេស៊ូ»។
ឥឡូវនេះ សូមលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់
ពាក្យថា «ឥឡូវនេះ»
គឺសំគាល់ការអធិស្ឋានបិទនិងចុងបញ្ចប់នៃផ្នែករបស់លិខិតនេះ។
Philippians 4:21
បងប្អូន
នេះសំដៅទៅលើមនុស្សដែលកំពុងបម្រើព័ន្ធកិច្ចជាមួយឬលោកប៉ូល។
បងប្អូន
បកប្រែដូចនៅក្នុង១:១២

បងប្អូនរួមជំនឿ...ហើយអ្នកជឿទាំងអស់
ការបកប្រែខ្លះបកប្រែពាក្យនេះដោយប្រើ «មនុស្សដ៏វិសុទ្ធ» និង
«ជាជនដ៏វិសុទ្ធ»។
ជាពិសេស បងប្អូនដែលជាអ្នករាជការរបស់ព្រះចៅអធិរាជ
នេះសំដៅទៅលើអ្នកបម្រើដែលធ្វើការនៅក្នុងព្រះបរមរាជវាំងរបស់សេសារ។
«ជាពិសេសបងប្អូនរួមជំនឿដែលធ្វើការនៅព្រះបរមរាជវាំងសេសារ» (UDB)
ជាមួយវិញ្ញាណរបស់បងប្អូន
លោកប៉ូលសំដៅទៅលើអ្នកជឿដោយប្រើពាក្យ «វិញ្ញាណ»
ដែលជាអ្វីដែលអាចឱ្យមនុស្សទាក់ទងនឹងព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត:
«ជាមួយអ្នក»

កូឡូស

1 [1]ខ្ញុំ ប៉ូល ជាសាវ័ករបស់ព្រះយេស៊ូគ្រិស្ត ដែលព្រះជាម្ចាស់បានចាក់ប្រេងតាំង និងលោកធីម៉ូថេដែលជាបងប្អូនរបស់យើង[2]ទៅដល់អ្នកដែលមានជំនឿ
ហើយបងប្អូនដ៏ស្មោះត្រង់នៅក្នុងព្រះគ្រិស្ត ដែលនៅក្រុងកូឡូស។ សូមព្រះគុណ និងសេចក្តីសុខសាន្ត ដែលមកពីព្រះបិតានៃយើង កើតមានដល់អ្នករាល់គ្នា។
[3]សូមអរព្រះគុណដល់ព្រះជាម្ចាស់ និងព្រះបិតានៃព្រះយេស៊ូគ្រិស្ត ហើយយើងតែងតែអធិស្ឋានសម្រាប់បងប្អូនជានិច្ច។
[4]យើងបានឮពីជំនឿរបស់អ្នកនៅក្នុងព្រះគ្រិស្តយេស៊ូ និងសេចក្តីស្រឡាញ់របស់បងប្អូន ចំពោះប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។[5]អ្នកមានសេចក្តីស្រឡាញ់នេះ
ដោយសារតែសេចក្តីសង្ឃឹមជឿជាក់ ដែលបានបម្រុងទុកសម្រាប់អ្នកនៅស្ថានបរមសុខ។ អ្នកបានឮពីសេចក្តីសង្ឃឹមនេះពីមុន តាមរយៈព្រះបន្ទូលនៃសេចក្តីពិត
គឺដំណឹងល្អ[6]ដែលបានមកដល់អ្នក។ ដំណឹងល្អនេះកំពុងតែបង្កើតផលផ្លែ និងរីកចម្រើននៅក្នុងពិភពលោកទាំងមូល។
ដំណឹងល្អនេះស្ថិតនៅក្នុងអ្នកចាប់តាំងពីថ្ងៃអ្នកបានឮ ហើយបានស្វែងយល់អំពីព្រះគុណរបស់ព្រះជាម្ចាស់តាមរយៈសេចក្តីពិត។
[7]នេះគឺជាដំណឹងល្អដែលអ្នកបានរៀនពីលោកអេប៉ាប្រាស ជាអ្នកបម្រើដ៏ជាទីស្រឡាញ់របស់យើង ដែលបានបម្រើព្រះគ្រិស្តយ៉ាងស្មោះត្រង់សម្រាប់បងប្អូន។
[8]លោកអេប៉ាប្រាសបានធ្វើឲ្យយើងស្គាល់ពីសេចក្តីស្រឡាញ់ ដែលមាននៅក្នុងព្រះវិញ្ញាណ។
[9]ព្រោះតែសេចក្តីស្រឡាញ់នេះ ចាប់តាំងពីថ្ងៃដែលយើងបានដឹងពីដំណឹងនេះ យើងមិនដែលឈប់ក្នុងការអធិស្ឋានសម្រាប់បងប្អូនទេ។ យើងបានទូលសុំឲ្យអ្នកមានប្រាជ្ញា
និងចំណេះដឹង ព្រមទាំងតម្រិះដែលមកពីព្រះវិញ្ញាណ។[10]យើងបានអធិស្ឋានឲ្យអ្នកដើរដោយបែបសមគួរ ដែលគាប់ព្រះហឫទ័យរបស់ព្រះអម្ចាស់ គ្រប់វិស័យ។
យើងបានអធិស្ឋានឲ្យអ្នកបានបង្កើតផលផ្លែ គ្រប់ការល្អទាំងអស់ ដែលបងប្អូនធ្វើ ហើយរីកចម្រើនឡើងក្នុងការស្គាល់ព្រះជាម្ចាស់។
[11]យើងបានអធិស្ឋានឲ្យបងប្អូនមានកម្លាំង និងសមត្ថភាពគ្រប់យ៉ាង ស្របតាមឫទ្ធានុភាពនៃសិរីរុងរឿង ដើម្បីឲ្យបងប្អូនអាចស៊ូទ្រាំ និងអត់ធ្មត់បាន។
[12]យើងអធិស្ឋានឲ្យបងប្អូនមានអំណរក្នុងការអរព្រះគុណដល់ព្រះបិតា ដែលបានធ្វើឲ្យអ្នកអាចចូលរួមទទួលមរតកជាមួយអ្នករួមជំនឿនៅក្នុងពន្លឺ។
[13]ព្រះអង្គបានរំដោះយើងឲ្យរួចពីអំណាចនៃសេចក្តីងងឹត ហើយបាននាំយើងចូលទៅក្នុងព្រះរាជ្យនៃព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។[14]នៅក្នុងព្រះបុត្រា
យើងបានទទួលការប្រោសលោះ និងបានរួចពីបាប។
[15]ព្រះបុត្រាជាតំណាងរបស់ព្រះជាម្ចាស់ ដែលយើងមើលមិនឃើញ។ ព្រះអង្គជាកូនច្បង ដែលកើតមុនកំណើតផែនដី។[16]ដោយសារព្រះអង្គ
អ្វីៗទាំងអស់ត្រូវបានបង្កើតឡើងគ្រប់ទាំងអស់ ដែលមាននៅស្ថានសួគ៌ និងនៅលើផែនដី ទាំងអ្វីៗដែលមើលមិនឃើញ និងមើលឃើញ។ គ្រប់ទាំងអំណាច ឬការគ្រប់គ្រង
ឬសិទ្ធិអំណាចនានា អ្វីៗទាំងអស់បង្កើតឡើងដោយសារព្រះអង្គ និងសម្រាប់ព្រះអង្គ។[17]ព្រះជាម្ចាស់មានមុនអ្វីៗទាំងអស់ ហើយក្នុងព្រះអង្គអ្វីៗទាំងអស់ទ្រទ្រង់ជាមួយគ្នា។
[18]ព្រះអង្គជាព្រះសិរសានៃព្រះកាយ គឺក្រុមជំនុំ។ ព្រះអង្គជាទីចាប់ផ្តើម និងជាកូនច្បងពីចំណោមមនុស្សស្លាប់ ដូចនេះហើយបានជាព្រះអង្គជាទីមួយ
ក្នុងចំណោមរបស់ទាំងអស់។[19]ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫទ័យ ឲ្យគ្រប់លក្ខណៈសម្បត្តិព្រះអង្គ ស្ថិតនៅក្នុងព្រះគ្រិស្ត។[20]ព្រះអង្គបានផ្សះផ្សាតាមរយៈព្រះបុត្រា ហើយ
អ្វីៗទាំងអស់សម្រាប់ព្រះអង្គ។ ព្រះជាម្ចាស់បានបង្កើតសន្តិភាពតាមរយៈការសុគតនៅលើឈើឆ្កាង។ ព្រះជាម្ចាស់បានផ្សះផ្សាការទាំងអស់ ដើម្បីព្រះអង្គ
មិនថាអ្វីៗដែលនៅលើផែនដី ឬក៏អ្វីដែលនៅលើស្ថានបរមសុខទេ។
[21]កាលពីដើម បងប្អូនរាល់គ្នាជាមនុស្សបរទេស នៅចំពោះព្រះជាម្ចាស់ ហើយក៏ជាសត្រូវរបស់ព្រះអង្គ ដោយសារតែគំនិត និងអំពើអាក្រក់ដែលយើងបានធ្វើ។
[22]តែឥឡូវនេះ ព្រះជាម្ចាស់បានផ្សះផ្សាបងប្អូន ដោយបូជាព្រះកាយព្រះអង្គ រហូតដល់សុគត។ ព្រះអង្គធ្វើការនេះ ដើម្បីឲ្យអ្នកបានបរិសុទ្ធ គ្មានកន្លែងបន្ទោស
និងឥតសៅហ្មង ហើយអាចឈរនៅចំពោះព្រះភ័ក្ត្រព្រះអង្គបាន។[23]បើសិនអ្នកនៅតែបន្តជំនឿដែលរឹងប៉ឹងហើយខ្ជាប់ខ្ជួន ដែលមិនឃ្លាតឆ្ងាយពីសេចក្តីសង្ឃឹមនៃដំណឹងល្អ
ដែលអ្នកធ្លាប់បានឮពីមុនមក។ នេះជាដំណឹងល្អដែលបានប្រកាសប្រាប់ មនុស្សទាំងអស់នៅក្រោមមេឃ។ នេះជាដំណឹងល្អដែលនាំឲ្យខ្ញុំ ប៉ូល ក្លាយជាអ្នកបម្រើ។
[24]ឥឡូវនេះ ខ្ញុំមានអំណរនៅក្នុងទុក្ខលំបាករបស់ខ្ញុំសម្រាប់បងប្អូន ហើយខ្ញុំបំពេញរូបកាយខ្ញុំ ដែលគ្មានសេចក្តីទុក្ខលំបាកនៃព្រះគ្រិស្ត
ទុកជាប្រយោជន៍ដល់រូបកាយព្រះអង្គ គឺក្រុមជំនុំ។[25]នេះជាក្រុមជំនុំដែលខ្ញុំបានបម្រើ ស្របតាមទំនួលខុសត្រូវ ដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ
សម្រាប់បងប្អូនជាប្រយោជន៍សម្រេចតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។[26]នេះជាសេចក្តីពិតដែលលាក់កំបាំងអស់រយៈពេលជាច្រើនជំនាន់មកហើយ
ក៏ប៉ុន្តែនៅពេលនេះព្រះអង្គបានបើកសម្តែងឲ្យយើងឃើញអ្នកជឿព្រះអង្គ បានឃើញ។[27]អ្នកទាំងនោះហើយ
ដែលព្រះជាម្ចាស់សព្វព្រហឫទ័យឲ្យពួកគេបានទទួលសិរីរុងរឿងនៃសេចក្តីពិត ដែលលាក់កំបាំងក្នុងចំណោមសាសន៍ដទៃ។ ព្រះគ្រិស្តគង់នៅក្នុងអ្នករាល់គ្នា
ធ្វើឲ្យអ្នករាល់គ្នាមានសង្ឃឹមថា នឹងសិរីរុងរឿងនាពេលអនាគត។
[28]គឺព្រះអង្គនេះហើយដែលនាំឲ្យយើងប្រកាស។ យើងបានដាស់តឿនគ្រប់គ្នា ហើយយើងបានបង្រៀនពួកគេអស់ពីប្រាជ្ញា ដូច្នេះ
យើងបានពេញលក្ខណៈសម្បត្តិនៅក្នុងព្រះគ្រិស្ត។[29]ដោយហេតុនេះហើយបានខ្ញុំខិតខំតស៊ូធ្វើ ដោយពឹងអាងលើកម្លាំងរបស់ព្រះអង្គ ដែលមាននៅក្នុងខ្ញុំ
និងពេញដោយឫទ្ធានុភាព។

Colossians 1:1
ប្រយោគភ្ជាប់៖
តាមរយៈសំបុត្រនេះសាវ័កប៉ូល និងលោកធីម៉ូថេ
បានដែលផ្ញើដល់អ្នកជឿនៅក្រុងកូឡូស នៅក្នុងសំបុត្រសាវ័កប៉ូល
បានសរសេរយ៉ាងច្បាស់លាស់។
ដោយភាគច្រើនលោកធីម៉ូថេជាអ្នកដែលសរសេរទៅតាមអ្វីដែលសាវ័កប៉ូលបានថ្លែង
ដោយព្រោះតែគាត់នៅជាប់ជាមួយនៅសាវ័កប៉ូល។

ព័ត៌មានទូទៅ៖
ក្នុងសំបុត្រនេះពាក្យថា «យើង» «របស់យើង» និង «របស់ពួកយើង»
ដែលរួមទាំងអ្នកនៅក្រុងកូឡូស លើកលែងតែមិនមានការកត់ទុក។ ពាក្យថា
«បងប្អូន» «របស់បងប្អូន» ហើយនិង «របស់ពួកបងប្អូន»
សំដៅលើអ្នកជឿនៅក្រុងកូឡូស ហើយដែលជាចំនួនច្រើន
លើកលែងតែមិនមានការកត់ទុក។
ជាសាវ័ករបស់ព្រះយេស៊ូគ្រិស្ត ដែលព្រះជាម្ចាស់បានចាក់ប្រេងតាំង

generated on Wed Sep 10 16:16:32 2025

«អ្នកដែលព្រះបានជ្រើសរើស ដើម្បីឲ្យធ្វើជាសាវ័ករបស់ព្រះយេស៊ូគ្រិស្ត»
សូមអរព្រះគុណដល់ព្រះជាម្ចាស់ និងព្រះបិតានៃព្រះយេស៊ូគ្រិស្ត
ហើយយើងតែងតែអធិស្ឋានសម្រាប់បងប្អូនជានិច្ច
ឃ្លាទាំងនេះមិនបានរាប់បញ្ចូលទាំងអ្នកនៅកូឡូសទេ។
Colossians 1:4
យើងបានឮ
សាវ័កប៉ូលមិនបានរាប់បញ្ចូលអ្នកស្តាប់របស់លោកឡើយ។
ជំនឿរបស់អ្នកនៅក្នុងព្រះគ្រិស្តយេស៊ូ
«សេចក្តីជំនឿរបស់អ្នកនៅក្នុងព្រះគ្រិស្តយេស៊ូ»
ដោយសារតែសេចក្តីសង្ឃឹមជឿជាក់ ដែលបានបម្រុងទុកសម្រាប់អ្នកនៅស្ថានបរមសុខ
ឃ្លា «សេចក្តីសង្ឃឹមជឿជាក់»
នេះតំណាងឲ្យអ្វីដែលអ្នកជឿថាអាចមានសង្ឃឹមជឿជាក់បាន
នោះគឺជាអ្វីដែលព្រះបានសន្យាថានិងធ្វើដល់អ្នកជឿទាំងអស់។
ការទាំងនេះត្រូវបានគេថ្លែងថា ប្រៀបដូចជាពួកគេគឺជាផ្នែករូបកាយ
ដែលព្រះជាម្ចាស់បានរក្សាទុកនៅឯស្ថានសួគ៌សម្រាប់អ្នកជឿអាចយកមកប្រើប្រាស់នៅលើផែនដីនេះ
ការបកប្រែរបៀបផ្សេងទៀត: «ដោយព្រោះយើងបានដឹងច្បាស់ថា
ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងធ្វើកិច្ចការជាច្រើន
ដែលទ្រង់បានសន្យាដល់យើង»
បង្កើតផលផ្លែ និងរីកចម្រើន
សាវ័កប៉ូលបានថ្លែងពីដំណឹងល្អនៅទីនេះ ប្រៀបដូចជាដើមឈើ
ឬរុក្ខជាតិដែលដុះលូតលាស់ហើយបង្កើតផលផ្លែ។
នៅក្នុងពិភពលោកទាំងមូល
ដំណឹងល្អបានរីកលូតលាស់ហើយនិងរីកចម្រើននៅក្នុងពិភពលោកទាំងមូល។
ព្រះគុណរបស់ព្រះជាម្ចាស់តាមរយៈសេចក្តីពិត
«ព្រះគុណពិតរបស់ព្រះជាម្ចាស់»
Colossians 1:7
ជាអ្នកបម្រើដ៏ជាទីស្រឡាញ់របស់យើង ដែលបានបម្រើព្រះគ្រិស្តយ៉ាងស្មោះត្រង់សម្រាប់បងប្អូន
ឃ្លា «របស់យើង» និង «ពួកយើង» មិនរាប់បញ្ចូលអ្នកនៅក្រុងកូឡូស។
ដំណឹងល្អដែលអ្នកបានរៀនពីលោកអេប៉ាប្រាស ជាអ្នកបម្រើដ៏ជាទីស្រឡាញ់របស់យើង
«ដំណឹងល្អ។ វាគឺជាអ្វីដែលបងប្អូនពិតជាបានរៀនពីលោកអេប៉ាប្រាស់
ជាអ្នកបម្រើដ៏ជាទីស្រឡាញ់របស់យើងហើយដែលជាអ្នក» ឬ «ដំណឹងល្អ។
ដែលជាការលោកអេប៉ាប្រាសពិតជាអ្នកដែលបង្រៀនបងប្អូន
ជាអ្នកបម្រើដ៏ជាទីស្រឡាញ់របស់យើង។នោះជាគាត់»
លោកអេប៉ាប្រាស់ ជាអ្នកបម្រើដ៏ជាទីស្រឡាញ់របស់យើង
ដែលបានបម្រើព្រះគ្រិស្តយ៉ាងស្មោះត្រង់សម្រាប់បងប្អូន
ឃ្លាថា «សម្រាប់បងប្អូន» មានន័យថាលោកអេប៉ាប្រាសបានបម្រើព្រះគ្រិស្ត
ដែលសាវ័កប៉ូលខ្លួនឯងទទួលបានការបង្រៀននេះ
ប្រសិនបើលោកមិនជាប់ក្នុងគុកឡើយ។
លោកអេប៉ាប្រាស
ជាបុរសម្នាក់ដែលបានផ្សាយដំណឹងល្អដល់អ្នកនៅក្នុងកូឡូស
សេចក្តីស្រឡាញ់ ដែលមាននៅក្នុងព្រះវិញ្ញាណ
សាវ័កប៉ូលថ្លែងពីព្រះវិញ្ញាណបរិសុទ្ធ
ប្រៀបដូចជាលោកជាទីកន្លែងដែលអ្នកជឿស្ថិតនៅ។ ការបកប្រែរបៀបផ្សេងទៀត:
«របៀបដែលព្រះវិញ្ញាណបរិសុទ្ធជួយបងប្អូនអាចស្រលាញ់ដល់អ្នកជឿផ្សេងទៀត»
Colossians 1:9
ប្រយោគភ្ជាប់៖
ដោយព្រោះតែព្រះវិញ្ញាណបានជួយពួកគេស្រឡាញ់អ្នកដទៃ
ហើយសាវ័កប៉ូលបានអធិស្ឋានសម្រាប់ពួកគេហើយប្រាប់ពួកគេពីរបៀបដែលលោកអធិស្ឋានសម្រាប់ពួកគេ
ព្រោះតែសេចក្តីស្រឡាញ់នេះ
«ដោយព្រោះតែព្រះវិញ្ញាណបរិសុទ្ធបានជួយឱ្យបងប្អូនស្រឡាញ់អ្នកជឿផ្សេងទៀត»
យើងបានដឹងពីដំណឹងនេះ យើងមិនដែលឈប់ក្នុងការអធិស្ឋានសម្រាប់បងប្អូនទេ។
យើងបានទូលសុំឲ្យអ្នកមានប្រាជ្ញា និងចំណេះដឹង ព្រមទាំងតម្រិះដែលមកពីព្រះវិញ្ញាណ។
10យើងបានអធិស្ឋានឲ្យ
ឃ្លាទាំងនោះមិនបានរួមបញ្ចូលនឹង អ្នកនៅក្រុងកូឡូសឡើយ។
ចាប់តាំងពីថ្ងៃដែលយើងបានដឹងពីដំណឹងនេះ
«តាំងពីលោកអេប៉ាប៉ាសបានប្រាប់យើងពីការទាំងនេះ»
សុំឲ្យអ្នកមានប្រាជ្ញា
សាវ័កប៉ូលថ្លែងពីអ្នកជឿនៅក្រុងកូឡូសដូចជា ពួកគេជាដបទឹក។
ការបកប្រែរបៀបផ្សេងទៀត: «
ដែលព្រះជាម្ចាស់បានបំពេញឱ្យបងប្អូននូវអ្វីដែលបងប្អូនត្រូវដឹង
ដើម្បីបងប្អូនអាចធ្វើតាមបំណងព្រះ»
មានប្រាជ្ញា និងចំណេះដឹង ព្រមទាំងតម្រិះដែលមកពីព្រះវិញ្ញាណ
«ដូច្នេះព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើអោយបងប្អូនមានប្រាជ្ញា
ហើយអាចយល់ពីអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យបងប្អូនធ្វើការនោះ»
អ្នកដើរដោយបែបសមគួរ ដែលគាប់ព្រះហឫទ័យរបស់ព្រះអម្ចាស់
ការដើរនៅទីនេះបង្ហាញពីឥរិយាបថក្នុងជីវិត។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូននឹងរស់នៅតាមរបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យអោយបងប្អូន»
គ្រប់វិស័យ
ក្នុងរបៀបដែលសព្វព្រះហឫទ័យព្រះអម្ចាស់»
បង្កើតផលផ្លែ
សាវ័កប៉ូលថ្លែងពីអ្នកជឿកូឡូស ប្រៀបដូចជាពួកគេជាដើមឈើ ឬរុក្ខជាតិ។
ជាដើមដែលដុះហើយបង្កើតផលផ្លែ
ដូច្នេះអ្នកជឿក៏ត្រូវស្គាល់ព្រះជាម្ចាស់កាន់តែច្បាស់និងធ្វើការដែលល្អ។ (សូមមើល៖ fruit, spiritual)
ចម្រើនក្នុងការស្គាល់ព្រះ (to grow in the knowledge of God; to grow as an author)
Colossians 1:11
យើងបានអធិស្ឋាន
ពាក្យថា «យើង» សំដៅលើសាវ័កប៉ូល និងលោកធីម៉ូថេ
ប៉ុន្តែមិនមែនអ្នកនៅក្រុងកូឡូសឡើយ។
អាចស៊ូទ្រាំ និងអត់ធ្មត់បាន
សាវ័កប៉ូលថ្លែងពីអ្នកជឿនៅក្រុងកូឡូស
ប្រៀបដូចជាព្រះជាម្ចាស់នឹងនាំពួកគេទៅទីតាំងនៃការស៊ូទ្រាំនិងការអត់ធ្មត់។
ជាក់ស្តែង លោកអធិស្ឋានឲ្យពួកគេនឹងមិនឈប់ជឿលើព្រះជាម្ចាស់
ហើយពួកគេចេះអត់ធ្មត់ដូចពួកគេផ្តល់កិត្តិយសទ្រង់។
ធ្វើឲ្យអ្នកអាចចូលរួម
«អនុញ្ញាតឱ្យអ្នកចូលរួម»
ធ្វើឲ្យអ្នកអាច
នេះសាវ័កប៉ូលបានផ្តោតលើអ្នកអានរបស់លោក
ដូចជាអ្នកទទួលពរពីព្រះជាម្ចាស់។ ប៉ុន្តែលោកមិនបានមានន័យថាខ្លួនលោក
មិនទទួលព្រះពរទាំងនោះទេ។
មរតក
ការធ្វើតាមអ្វីដែលព្រះជាម្ចាស់បានសន្យាដល់អ្នកជឿដែលត្រូវបានថ្លែង
ប្រៀបដូចជាទទួលមរតកសម្បត្តិនិងទ្រព្យពីសមាជិកគ្រួសារ។
នៅក្នុងពន្លឺ
គំនិតនេះគឺផ្ទុយពីគំនិតពីអំណាចនៃសេចក្តីងងឹតនៅក្នុងខបន្ទាប់។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងសិរីល្អនៃវត្តមានរបស់ទ្រង់»
Colossians 1:13
ប្រយោគភ្ជាប់៖
សាវ័កប៉ូលថ្លែងពីរបៀបដែលព្រះគ្រិស្តល្អឥតខ្ចោះ។
ព្រះអង្គបានរំដោះ
«ព្រះជាម្ចាស់ជាព្រះបិតាដែលបានរំដោះ»
អំណាចនៃសេចក្តីងងឹត
សេចក្តីងងឹតគឺជារូបភាពទូទៅមួយនៅក្នុងបទគម្ពីរអំពើការអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត: «អំណាចនៃអំពើអាក្រក់»
ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ
ព្រះជាម្ចាស់ដែលជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះបិតា គឺព្រះយេស៊ូគ្រិស្ត»
នៅក្នុងព្រះបុត្រា យើងបានទទួលការប្រោសលោះ
ដូចជាអ្នកជឿបាន «នៅក្នុង» ព្រះយេស៊ូវគ្រិស្ត ឬ «នៅក្នុង»
ព្រះជាម្ចាស់។ ការបញ្ជានៅនេះក៏អាចបកប្រែជា "តាមរយៈព្រះរាជបុត្រារបស់ទ្រង់
ទើបយើងបានទទួលការប្រោសលោះ»។
បានរួចពីបាប
«ព្រះរាជបុត្រាទ្រង់អត់ទោសរាល់អំពើបាបរបស់យើង» ឬ
«ព្រះបិតានឹងអត់ទោសយើងតាមរយៈព្រះរាជបុត្រទ្រង់»
Colossians 1:15
ព្រះបុត្រាជាតំណាងរបស់ព្រះជាម្ចាស់ ដែលយើងមើលមិនឃើញ
ពាក្យថា «ជាតំណាង» មិនមានន័យថាតំណាងឱ្យអ្វីមួយដែលអាចមើលឃើញទេ។
ផ្ទុយទៅវិញ «ជាតំណាង» នៅទីនេះមានន័យថាដោយស្គាល់ព្រះបុត្រា
ដែលយើងបានរៀនថាព្រះជាម្ចាស់ជាព្រះវរបិតាមានលក្ខណៈយ៉ាងណា។
ព្រះបុត្រា

generated on Wed Sep 10 16:16:32 2025

នេះជាចំណងជើងសំខាន់នៃព្រះយេស៊ូ ដែលជាព្របុត្រានៃព្រះជាម្ចាស់។
ព្រះអង្គជាកូនច្បង
«ព្រះបុត្រាជាកូនច្បង។» ឃ្លាដែលថា «បុត្រច្បង»
មិនសំដៅលើកំណើតរបស់ព្រះយេស៊ូនៅភូមិបេថ្លេហិមទេ។ ផ្ទុយទៅវិញ
សំដៅលើឋានៈរបស់ព្រះបុត្រាជាព្រះបុត្រាដ៏អស់កល្បរបស់ព្រះវរបិតា។
ក្នុងន័យនេះ «កូនច្បង» គឺជាពាក្យប្រៀបធៀបដែលមានន័យថា «សំខាន់បំផុត»។
ព្រះយេស៊ូវគឺ «ព្រះបុត្រា» សំខាន់បំផុត និងតែមួយគត់របស់ព្រះជាម្ចាស់។
ទ្រង់គឺជាព្រះម្ចាស់។ ពាក្យថា
«ព្រះបុត្រា»បង្ហាញពីទំនាក់ទំនងជិតស្និទ្ធរបស់ព្រះយេស៊ូជាមួយព្រះវរបិតា។
ទំនាក់ទំនងនោះមិនអាចនិងយល់បានទេ លុះត្រាតែបងប្អូន ប្រើពាក្យជា
«ព្រះបុត្រា» និង «ព្រះវរបិតា»។
ដោយសារព្រះអង្គ អ្វីៗទាំងអស់ត្រូវបានបង្កើតឡើងគ្រប់ទាំងអស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយសារព្រះបុត្រាអ្វីៗទាំងអស់ត្រូវបានបង្កើតឡើង»
គ្រប់ទាំងអំណាច ឬការគ្រប់គ្រង ឬសិទ្ធិអំណាចនានា អ្វីៗទាំងអស់បង្កើតឡើងដោយសារព្រះអង្គ និងសម្រាប់ព្រះអង្គ
ព្រះបុត្រាបង្កើតអ្វីៗទាំងអស់សម្រាប់អង្គទ្រង់ រួមមានអំណាច ឬការគ្រប់គ្រង
ឬសិទ្ធិអំណាចនានា។
ព្រះជាម្ចាស់មានមុនអ្វីៗទាំងអស់
«ទ្រង់គង់នៅមុនអ្វីៗទាំងអស់»
ក្នុងព្រះអង្គអ្វីៗទាំងអស់ទ្រទ្រង់ជាមួយគ្នា
សាវ័កប៉ូលថ្លែងពី
ព្រះបុត្រាដែលត្រួតត្រាអ្វីៗទាំងអស់ដូចជាទ្រង់បានកាន់ជាប់គ្នាក្នុងផ្នែកសាច់ឈាម។
«ទ្រង់កាន់ជាប់អ្វីៗទាំងអស់ជាមួយគ្នា»
Colossians 1:18
ព្រះអង្គជាព្រះសិរសា
«ព្រះយេស៊ូគ្រិស្ត ដែលជាព្រះបុត្រានៃព្រះជាម្ចាស់ ហើយដែលជាព្រះសិរសា»
ព្រះអង្គជាព្រះសិរសានៃព្រះកាយ គឺក្រុមជំនុំ
សាវ័កប៉ូលថ្លែងពីតួនាទីរបស់ព្រះយេស៊ូនៅក្រុមជំនុំប្រៀបដូចជាទ្រង់ជាក្បាលលើរូបកាយមនុស្ស។
ជាក្បាលគ្រប់គ្រងរាងកាយ ដូច្នេះព្រះយេស៊ូវគ្រប់គ្រងក្រុមជំនុំ។
ទីចាប់ផ្តើម
«ជាប្រភពនៃស្វិទអំណាច»។ ទ្រង់ជាប្រធានទីមួយឬជាស្ថាបនិក។
ជាកូនច្បងពីចំណោមមនុស្សស្លាប់
ព្រះយេស៊ូវគឺជាកូនច្បង ដែលបានសុគតហើយបានរស់ឡើងវិញ
ហើយទ្រង់នឹងមិនសុគតម្តងទៀតឡើយ។
ព្រះបុត្រា
នេះជាចំណងជើងសំខាន់នៃព្រះយេស៊ូ ដែលជាព្របុត្រានៃព្រះជាម្ចាស់។
តាមរយៈការសុគតនៅលើឈើឆ្កាង
«មានន័យថាព្រះលោហិតរបស់ព្រះយេស៊ូបានហូរនៅលើឈើឆ្កាង»
ការសុគតនៅលើឈើឆ្កាង
ពាក្យថា «ការសុគត» នេះតំណាងការសុគតរបស់ព្រះគ្រិស្តនៅលើឈើឆ្កាង។
Colossians 1:21
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបានបញ្ជាក់យ៉ាងច្បាស់ថា
ឥឡូវនេះព្រះជាម្ចាស់បានបង្ហាញថាព្រះគ្រិស្តបានផ្លាស់ប្តូរអំពើបាបរបស់សាសន៍ដទៃ
ពីភាពបរិសុទ្ធរបស់ទ្រង់។
បងប្អូនរាល់គ្នា
«បងប្អូនដែលជាអ្នកជឿនៅក្នុងក្រុងកូឡូស»
ជាមនុស្សបរទេស នៅចំពោះព្រះជាម្ចាស់
«ជាអ្នកដែលព្រះជាម្ចាស់មិនបានស្គាល់» ឬ
«ជាអ្នកដែលរុញច្រាលព្រះជាម្ចាស់ចេញ»
ដើម្បីឲ្យអ្នកបានបរិសុទ្ធ គ្មានកន្លែងបន្ទោស និងឥតសៅហ្មង
ហើយអាចឈរនៅចំពោះព្រះភ័ក្ត្រព្រះអង្គបាន
សាវ័កប៉ូលពិពណ៌នាអំពីពួកអ្នកនៅក្រុងកូឡូស
ដូចព្រះយេស៊ូបានសំអាតរូបកាយរបស់ពួកគេ ស្មៀកពាក់សម្លៀកបំពាក់ស្អាត
ហើយនាំពួកគេឲ្យឈរនៅចំពោះព្រះវរបិតា។
គ្មានកន្លែងបន្ទោស និងឥតសៅហ្មង
សាវ័កប៉ូលប្រើពាក្យពីរដែលមានន័យថាស្ទើរតែដូចគ្នាដើម្បីបញ្ជាក់ពីគំនិតនៃភាពល្អឥតខ្ចោះ។
ការបកប្រែរបៀបផ្សេងទៀត: «ដែលល្អឥតខ្ចោះ»
នៅចំពោះព្រះភ័ក្ត្រព្រះអង្គ
ការចង្អុលបង្ហាញទីតាំងនេះ ដើម្បីបញ្ជាក់ពី «ការទតឃើញរបស់ព្រះជាម្ចាស់» ឬ
«នៅក្នុងព្រះទ័យរបស់ព្រះជាម្ចាស់»
ដែលបានប្រកាស
ដែលអស់អ្នកជឿប្រកាស
មនុស្សទាំងអស់នៅក្រោមមេឃ
«គ្រប់មនុស្សដែលនៅលើផែនដីនេះ»
នេះជាដំណឹងល្អដែលនាំឲ្យខ្ញុំ ប៉ូល ក្លាយជាអ្នកបម្រើ
សាវ័កប៉ូលពិតជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ដំណឹងល្អដែលនាំឲ្យខ្ញុំ ប៉ូលដែលបានបម្រើព្រះជាម្ចាស់ដោយការប្រកាស»
Colossians 1:24
ខ្ញុំបំពេញរូបកាយខ្ញុំ ដែលគ្មានសេចក្តីទុក្ខលំបាកនៃព្រះគ្រិស្ត
សាវ័កប៉ូលថ្លែងពីសេចក្តីទុក្ខលំបាកដែលលោកបានជួបប្រទះ។
លោកប្រហែលទទួលស្គាល់ថា
រូបគាត់និងគ្រិស្តបរិស័ទដទៃទៀតជួបប្រទះសេចក្តីទុក្ខលំបាកជាច្រើន
ដែលត្រូវតែស៊ូទ្រាំមុនពេលដែលព្រះគ្រិស្តយាងមកម្តងទៀត
ហើយព្រះវិញ្ញាណនៅជាមួយពួកគេនៅពេលដែលគេជួបប្រទះនូវសេចក្តីទុកលំបាកទាំងនេះ។
សាវ័កប៉ូលពិតជាមិនមានន័យថាការរងទុក្ខរបស់ព្រះគ្រិស្តតែអង្គទ្រង់
នោះមិនគ្រប់គ្រាន់ទេ ដើម្បីផ្តល់ការសង្គ្រោះដល់អ្នកជឿទេ។
ខ្ញុំបំពេញរូបកាយខ្ញុំ
សាវ័កប៉ូលថ្លែងពីរូបកាយរបស់គាត់
ប្រៀបដូចជាដបទឹកមួយដែលរងសេចក្តីទុកលំបាក។
ទុកជាប្រយោជន៍ដល់រូបកាយព្រះអង្គ គឺក្រុមជំនុំ
ភាគច្រើន សាវ័កប៉ូលតែងតែថ្លែងពីក្រុមជំនុំ ដែលជាបណ្តុំអ្នកជឿគ្រីស្ទបរិស័ទ
ប្រៀបដូចជារូបកាយរបស់ព្រះគ្រិស្ត។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
នេះមានន័យថា ការនាំពីវត្ថុបំណងនៃព្រះបន្ទូលពីដំណឹងល្អរបស់ព្រះជាម្ចាស់
ដែលត្រូវបានផ្សព្វផ្សាយ និងមានអ្នកជឿ។
នេះជាសេចក្តីពិតដែលលាក់កំបាំង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នេះជាសេចក្តីពិត ដែលព្រះជាម្ចាស់បានលាក់កំបាំង»
អស់រយៈពេលជាច្រើនជំនាន់មកហើយ
ពាក្យថា «អស់រយៈពេល» និង «ច្រើនជំនាន់»
សំដៅលើរយៈពេលពីការបង្កើតពិភពលោករហូតដល់ពេលដែលដំណឹងល្អត្រូវបានផ្សព្វផ្សាយ។
នៅពេលនេះព្រះអង្គបានបើកសម្តែងឲ្យឃើញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលនេះព្រះជាម្ចាស់បានបើកសម្តែងឲ្យឃើញការនេះ»
សិរីរុងរឿងនៃសេចក្តីពិត
សាវ័កប៉ូលថ្លែងពីគុណតម្លៃនៃសេចក្តីពិតដ៏លាក់កំបាំងនេះអំពីព្រះជាម្ចាស់
ប្រៀបដូចជាភោគទ្រព្យ។ «ទ្រព្យសម្បត្តិ»
មានសង្ឃឹមថា នឹងសិរីរុងរឿងនាពេលអនាគត
«ដូច្នេះបងប្អូនអាចសង្ឃឹមដោយជឿជាក់
ដែលចែករំលែកសិរីរុងរឿងរបស់ព្រះជាម្ចាស់» (សូមមើល UDB)
Colossians 1:28
យើងប្រកាស។ យើងបានដាស់តឿនគ្រប់គ្នា ហើយយើងបានបង្រៀនពួកគេអស់ពីប្រាជ្ញា ដូច្នេះ
យើងបាន
ឃ្លាទាំងនេះមិនបានរួមបញ្ចូលអ្នកនៅក្រុងកូឡូសឡើយ។
យើងបានដាស់តឿនគ្រប់គ្នា
«យើងប្រៀបប្រដៅគ្រប់គ្នា»
យើងបានពេញលក្ខណៈសម្បត្តិ
«ដូច្នេះយើងអាចបំពេញលក្ខណៈសម្បត្តិដូចព្រះជាម្ចាស់ឲ្យអ្នករាល់គ្នា»
បានពេញ
«ដែលមានភាពចាស់ទុំខាងវិញ្ញាណ» (សូមមើល៖figs-metaphor)

[1]ខ្ញុំចង់ឲ្យបងប្អូនដឹងពីឧបសគ្គ ដែលខ្ញុំបានប្រឈមមុខសម្រាប់បងប្អូន និងសម្រាប់អ្នកស្រុកឡៅឌីសេ ព្រមទាំងសម្រាប់បងប្អូនដែលមិនទាន់បានជួបមុខខ្ញុំផ្ទាល់។
[2]ខ្ញុំធ្វើដូច្នេះ ដើម្បីលើកទឹកចិត្តពួកគេដោយឲ្យពួកគេរួបរួមគ្នា ក្នុងសេចក្តីស្រឡាញ់ ហើយឲ្យពួកគេមានប្រាជ្ញាវាងវៃបំផុត និងស្គាល់ពីគម្រោងការដែលលាក់កំបាំងនោះ
គឺព្រះគ្រិស្ត។[3]នៅក្នុងព្រះអង្គមានលាក់ទុកគ្រប់ទាំងតម្រិះ និងប្រាជ្ញា។
[4]ខ្ញុំនិយាយដូច្នេះ ដើម្បីកុំឲ្យមាននរណាម្នាក់មកបោកបញ្ឆោតអ្នកដោយពាក្យសម្តីលួងលោមឡើយ។[5]ទោះបីរូបកាយខ្ញុំមិនបាននៅជាមួយបងប្អូន
តែចិត្តរបស់ខ្ញុំនៅជាមួយបងប្អូនជានិច្ច។ ខ្ញុំមានអំណរដោយឃើញបងប្អូនមានសណ្តាប់ធ្នាប់ល្អ និងមានជំនឿរឹងមាំនៅក្នុងព្រះគ្រិស្ត។
[6]បើបងប្អូនបានទទួលព្រះគ្រិស្តជាព្រះអម្ចាស់ ចូរដើរក្នុងព្រះអង្គ។[7]ត្រូវចាក់ឫសឲ្យរឹងមាំនៅក្នុងព្រះអង្គ ត្រូវសាងសង់ជីវិតនៅលើព្រះអង្គ
ត្រូវមានជំនឿរឹងមាំដូចអ្វីដែលអ្នកបានរៀន ហើយត្រូវអរព្រះគុណព្រះឲ្យបានច្រើន។
[8]សូមប្រយ័ត្នកុំឲ្យមាននរណាម្នាក់បញ្ឆោតអ្នកដោយប្រើទស្សនវិជ្ជា ឬដោយអរូបី ដោយពឹងផ្អែកលើទម្លាប់ពីបុរាណ
ការទាំងអស់នោះមិនមែនមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ។[9]ដ្បិតគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ស្ថិតនៅយ៉ាងពោរពេញក្នុងរូបកាយព្រះគ្រិស្ត។
[10]បងប្អូនក៏បានពោរពេញនៅក្នុងព្រះអង្គដែរ។ ព្រះអង្គជាប្រមុខដែលគ្រប់គ្រងលើគ្រប់ទាំងសិទ្ធិអំណាច។[11]នៅក្នុងព្រះអង្គ បងប្អូនក៏បានធ្វើវិធីកាត់ស្បែកដែរ
តែពុំមែនជាពិធីកាត់ស្បែកដោយដៃមនុស្សទេ គឺជាកាត់ស្បែកតាមរបៀបព្រះគ្រិស្តវិញ។[12]ពេលបងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនបានកប់រួមជាមួយព្រះអង្គ
ហើយបងប្អូនបានរស់ឡើងវិញ ដោយសារជឿលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលបានប្រោសព្រះគ្រិស្តឲ្យរស់ឡើងវិញពីស្លាប់។
[13]ពីដើម បងប្អូនបានស្លាប់នៅក្នុងនិស្ស័យចាស់ និងមិនបានធ្វើពិធីកាត់ស្បែកខាងរូបកាយឡើយ តែព្រះអង្គបានប្រទានឲ្យបងប្អូនមានជីវិតរួមជាមួយព្រះអង្គ
ហើយអត់ទោសរាល់អំពើរំលងរបស់បងប្អូន។[14]ព្រះអង្គបានលុបបញ្ជីបំណុល និងវិន័យដែលបានចោទប្រកាន់យើង។ ព្រះអង្គបានលុបចេញ
ហើយឆ្កាងអំពើទាំងនោះនៅលើឈើឆ្កាង។[15]ព្រះអង្គបានដកហូតអំណាច និងដកសិទ្ធិអំណាច ហើយព្រះអង្គបានបំបាក់មុខវាជាសាធារណៈ ដោយមានជ័យជម្នះលើវា
ដោយសុគតនៅលើឈើឆ្កាង។
[16]បន្ទាប់មក កុំឲ្យនរណាម្នាក់កាត់ទោសអ្នកអំពីការហូបអាហារ ផឹកភេសជ្ជៈ អំពីរឿងបុណ្យទាន បុណ្យចូលខែ ឬថ្ងៃសប្ប័ទនោះទេ។
[17]ទាំងនេះគ្រាន់តែជាស្រមោលដែលនឹងមកប៉ុណ្ណោះ តែសេចក្តីពិតនោះជាព្រះគ្រិស្ត។
[18]កុំឲ្យមាននរណាម្នាក់លួចយកការបន្ទាបខ្លួន និងការថ្វាយបង្គំ ដែលធ្វើឲ្យអ្នកបាត់បងរង្វាន់ដែលទេវតារបស់ព្រះរៀបចំសម្រាប់បងប្អូន។
ដូចជាមនុស្សម្នាក់ដែលបានឃើញអ្វីមួយ ហើយអួតបំបោងច់តាមគំនិតលោកីយ៍។[19]គេមិនបាននៅជាប់ជាមួយព្រះគ្រិស្តជាព្រះសិរសាទេ។
ព្រះសិរសាបានតភ្ជាប់ខ្លួនទាំងមូលតាមរយៈសន្លាក់ឆ្អឹង និងសរសៃ ហើយចម្រើនឡើងជាមួយគ្នាតាមរយៈព្រះជាម្ចាស់ប្រទានឲ្យ។
[20]ប្រសិនបើបងប្អូនស្លាប់រួមជាមួយព្រះគ្រិស្តមែន ហេតុអ្វីបានជាបងប្អូនរស់នៅដូចជានៅជាប់ជាមួយលោកីយ៍ទៀត។[21]«កុំយក! កុំភ្លក់!
កុំប៉ះ!»[22]ការទាំងអស់នោះជាផ្លូវដែលនាំឆ្ងាក់ចូលក្នុងអំពើពុករលួយ អាស្រ័យលើការណែនាំ និងសេចក្តីបង្រៀនរបស់មនុស្ស។
[23]ច្បាប់ទាំងនេះបង្កើតឡើងដោយប្រាជ្ញានៃសាសនា ហើយមានការបន្ទាបខ្លួន និងលត់ដំខ្លួន។ ប៉ុន្តែ
វាគ្មានតម្លៃអ្វីសោះក្នុងការប្រឆាំងនឹងសេចក្តីប៉ងប្រាថ្នាខាងនិស្ស័យលោកីយ៍។

Colossians 2:1

ប្រយោគភ្ជាប់៖

សាវ័កប៉ូលបន្តលើកទឹកចិត្តដល់អ្នកជឿនៅក្រុងកូឡូស
និងស្រុកឡៅឌីសេឲ្យស្គាល់ពីព្រះគ្រិស្តជាព្រះជាម្ចាស់ ហើយទ្រង់គង់នៅក្នុងអ្នកជឿ
ដូច្នេះពួកគេគួរតែរស់នៅតាមរបៀបដូចគ្នា ដែលពួកគេបានទទួលទ្រង់។

ពីឧបសគ្គ ដែលខ្ញុំបានប្រឈមមុខសម្រាប់បងប្អូន

សាវ័កប៉ូលបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធ្វើឲ្យពួកគេចម្រើនឡើងនៃភាពបរិសុទ្ធ
និងការយល់ដឹងពីដំណឹងល្អ។

សម្រាប់អ្នកស្រុកឡៅឌីសេ

នេះជាទីក្រុងមួយដែលនៅជិតក្រុងកូឡូស និងមានព្រះវិហារមួយ
ដែលសាវ័កប៉ូលធ្លាប់បានអធិស្ឋាន។

ព្រមទាំងសម្រាប់បងប្អូនដែលមិនទាន់បានជួបមុខខ្ញុំផ្ទាល់

ពាក្យថា «ជួបមុខខ្ញុំផ្ទាល់» តំណាងឱ្យបែបជាមនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «អស់អ្នកដែលខ្ញុំមិនដែលបានឃើញផ្ទាល់» ឬ
«អស់ដែលអ្នកខ្ញុំមិនដែលបានជួបផ្ទាល់»

ដើម្បីលើកទឹកចិត្តពួកគេ

សាវ័កប៉ូលបានបូករួមជាមួយអ្នកនៅស្រុកកាឡាទីផង
ទោះបីលោកប្រើសព្វនាមផ្សេងគ្នាក៏ដោយ។ ការបកប្រែរបៀបផ្សេងទៀត:
«ដើម្បីលើកទឹកចិត្តពួកគេ និងបងប្អូន»

ឲ្យពួកគេរួបរួមគ្នា

នេះមានន័យថា នាំមករួបរួមគ្នាដោយទំនាក់ទំនងជិតស្និត។

ឲ្យពួកគេមានប្រាជ្ញាវាងវៃបំផុត

សាវ័កប៉ូលថ្លែងពីមនុស្សម្នាក់ ដែលគាត់បានដឹងច្បាស់ពីដំណឹងល្អគឺជាការពិត
ទោះបីមនុស្សម្នាក់នោះជាអ្នកមានទ្រព្យខាងសាច់ឈាម។

គម្រោងការដែលលាក់កំបាំងនោះ គឺព្រះគ្រិស្ត

នេះជាការដែលត្រូវបានបើកសំដែងដោយព្រះជាម្ចាស់។

នោះ គឺព្រះគ្រិស្ត

ព្រះយេស៊ូជាគម្រោងការដែលលាក់កំបាំង
ដែលត្រូវបានបើកសំដែងដោយព្រះជាម្ចាស់។

នៅក្នុងព្រះអង្គមានលាក់ទុកគ្រប់ទាំងតម្រិះ និងប្រាជ្ញា

មានតែព្រះគ្រិស្តទេដែលអាចបើកសំដែងពីប្រាជ្ញានិងតម្រិះពិតរបស់ព្រះជាម្ចាស់។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជម្ចាស់បានលាក់ទុក ប្រាជ្ញានិងតម្រិះដែលនៅក្នុងព្រះគ្រិស្ត» ។

ប្រាជ្ញានិងតម្រិះ

សាវ័កប៉ូលថ្លែងពីព្រះប្រាជ្ញា
និងព្រះតម្រិះរបស់ព្រះជាម្ចាស់ប្រៀបដូចជាវត្ថុដែលមានតម្លៃ។
ការបកប្រែរបៀបផ្សេងទៀត: «ដែលជាប្រាជ្ញា និងតម្រិះដែលមានតម្លៃថ្លៃពិសេស»

ប្រាជ្ញានិងតម្រិះ

ពាក្យទាំងនេះមានន័យខ្លឹមសារដូចគ្នា។ សាវ័កប៉ូលប្រើពាក្យទាំង២នេះ
ដើម្បីបញ្ជាក់ថាការជ្រាបដឹងពីខាងព្រលឹងវិញ្ញាណដែលមកពីព្រះគ្រិស្ត។

Colossians 2:4

បោកបញ្ឆោត

មានន័យថា ជាការធ្វើឲ្យនរណាម្នាក់ជឿទុកចិត្តលើអ្វីដែលមិនពិត
ដូច្នេះគេប្រព្រឹត្តលើទង្វើនោះ បាននាំឲ្យគេទទួលរងឈឺចាប់វិញ។

ពាក្យសម្តីលួងលោម

ពាក្យសម្តីដែលធ្វើឲ្យគេគិតបែបផ្សេងៗ

រូបកាយខ្ញុំមិនបាននៅជាមួយបងប្អូន

«រូបកាយមិនបាននៅជាមួយបងប្អូនឡើយ»

ចិត្តរបស់ខ្ញុំនៅជាមួយបងប្អូន

«ខ្ញុំតែងតែគិតពីបងប្អូន»

មានសណ្តាប់ធ្នាប់ល្អ

ធ្វើកិច្ចការដែលត្រឹមត្រូវ

មានជំនឿរឹងមាំនៅក្នុងព្រះគ្រិស្ត

«គ្មានអ្វី ឬនរណាម្នាក់ដែលអាចបញ្ឈប់សេចក្តីជំនឿរបស់បងប្អូនឡើយ»

Colossians 2:6

ត្រូវចាក់ឫសឲ្យរឹងមាំនៅក្នុងព្រះអង្គ ត្រូវសាងសង់ជីវិតនៅលើព្រះអង្គ

ត្រូវមានជំនឿរឹងមាំដូចអ្វីដែលអ្នកបានរៀន ហើយត្រូវអរព្រះគុណព្រះឲ្យបានច្រើន

ឃ្លាទាំងនេះបង្ហាញពីអ្វីដែលមានន័យថា «ចូរដើរក្នុងព្រះអង្គ»។

ត្រូវចាក់ឫសឲ្យរឹងមាំនៅក្នុងព្រះអង្គ

សាវ័កថ្លែងពីមនុស្សដែលមានជំនឿពិតប្រាកដក្នុងព្រះគ្រិស្ត
ប្រៀបដូចជាមនុស្សដែលដូចដើមឈើដែលដុះក្នុងដីល្អហើយមានឫសចាក់បានជ្រៅ។

ត្រូវសាងសង់ជីវិតនៅលើព្រះអង្គ

សាវ័កថ្លែងពីមនុស្សដែលមានជំនឿពិតប្រាកដក្នុងព្រះគ្រិស្ត
ប្រៀបដូចជាមនុស្សដែលដូចអាគារដែលមានគ្រឹះមាំ។

generated on Wed Sep 10 16:16:32 2025

ត្រូវមានជំនឿរឹងមាំ
«ជឿលើព្រះយេស៊ូគ្រប់ការទាំងអស់»
ដូចអ្វីដែលអ្នកបានរៀន
នេះបង្ហាញដែលល្អបំផុត ដែលមិនដាក់ឈ្មោះបុគ្គល ឬបើដាក់ឈ្មោះ
នោះសំដៅលើលោកអេប៉ាប្រាស ដែលជាគ្រូ (ជំពូក១: ៧)។
ការបកប្រែរបៀបផ្សេងទៀត: «ដូចដែលអ្នកបានរៀន» ឬ
«ដូចដែលពួកគេបានបង្រៀនអ្នក» ឬ «ដូចដែលលោកបានបង្រៀនអ្នក»
អរព្រះគុណព្រះឲ្យបានច្រើន
សាវ័កប៉ូលថ្លែងពីការអរព្រះគុណប្រៀបដូចជាការដែលមនុស្សដែលនឹងទទួលថែមទៀត
ការបកប្រែរបៀបផ្សេងទៀត: «ចូរអរព្រះគុណដល់ព្រះជាម្ចាស់»
Colossians 2:8
ប្រយោគភ្ជាប់៖
សាវ័កប៉ូលជំរុញអ្នកជឿឲ្យមានការប្រុងប្រយ័ត្នដែលត្រលប់ជឿលើពាក្យ
និងបញ្ញាតិរបស់អ្នកដទៃដោយព្រោះតែគ្មានអ្វីមួយឡើយដែលអាចបំពេញភាពពេញលេញ
ដែលអ្នកជឿមានព្រះគ្រិស្ត។
សូមប្រយ័ត្ន
«សូមប្រាកដថា»
បញ្ឆោតអ្នក
សាវ័កប៉ូលថ្លែងពីរបៀបដែលមនុស្សជឿលើការបង្រៀនខុសឆ្គង
ទស្សនវិជ្ជា
គោលលទ្ធិ និងជំនឿសាសនាដែលមិនមែនមកពីព្រះបន្ទូលរបស់ព្រះ
ប៉ុន្តែផ្អែកលើគំនិតរបស់មនុស្សពីព្រះជាម្ចាស់និងជីវិតប្រចាំថ្ងៃ
ដោយអរូបី
សាវ័កប៉ូលថ្លែងពីគំនិតខុសឆ្គង ដែលមិនបង្កើតអ្វីសោះ
ដូច្នេះវាគ្មានតម្លៃទេដូចជាដបទឹកដែលគ្មានអ្វីទាល់តែសោះ។
ទម្លាប់ពីបុរាណ ការទាំងអស់នោះ
ទាំងទម្លាប់ជនជាតិជ្វីហ្វ និងអ្នកកាន់សាសនាច្រើន (សាសន៍ដទៃ)
ដែលជាជំនឿគឺគ្មានតម្លៃទេ។ «ការទាំងអស់»
ត្រូវបានសំដៅលើវិញ្ញាណអាក្រក់ដែលអះអាងថាគ្រប់គ្រងលោកិយ
ហើយដែលត្រូវបានមនុស្សគោរព។ ប៉ុន្តែអ្នកបកប្រែខ្លះចាត់ទុក «ការទាំងអស់»
នោះជាការបង្រៀនជាមូលដ្ឋានរបស់មនុស្សពីលោកិយនេះ។
គ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ស្ថិតនៅយ៉ាងពោរពេញក្នុងរូបកាយព្រះគ្រិស្ត
«ជាទូទៅព្រះជាម្ចាស់រស់នៅបែបសាច់ឈាមក្នុងព្រះគ្រីស្ត»
Colossians 2:10
នៅក្នុងព្រះអង្គ បងប្អូនក៏បានធ្វើវិធីកាត់ស្បែកដែរ
សាវ័កប៉ូលថ្លែងពីបងប្អូនដែលជាកម្មសិទ្ធិរបស់ព្រះគ្រីស្ត
ប្រៀបដូចជាបងប្អូនស្ថិតនៅក្នុងរូបកាយរបស់ព្រះគ្រិស្ត។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលបងប្អូនចូលរួមព្រះវិហារក្នុងពិធីបុណ្យជ្រមុជទឹក
នោះព្រះជាម្ចាស់បានធ្វើវិធីកាត់ស្បែកបងប្អូន»
បងប្អូនក៏បានពោរពេញនៅក្នុងព្រះអង្គដែរ
សាវ័កប៉ូលថ្លែងពីមនុស្ស
ដោយប្រដូចពួកគេជាដបទឹកមួយដែលព្រះជាម្ចាស់បានដាក់ព្រះគ្រិស្តចូលទៅ។
ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនត្រូវបានបំពេញខាងក្នុងដោយព្រះគ្រិស្ត»
ព្រះអង្គជាប្រមុខ
ព្រះគ្រិស្តជាអ្នកដឹកនាំ
តែពុំមែនជាពិធីកាត់ស្បែកដោយដៃមនុស្សទេ
ជាមួយការប្រៀបធៀបនេះ សាវ័កប៉ូលថ្លែងពី
គ្រីស្ទបរិស័ទដែលព្រះបាននាំពួកគេឲ្យទទួលយកទ្រង់ដោយរំលឹកទ្រង់ពីពិធីកាត់ស្បែក
ដែលពិធីកាត់ស្បែកនេះ ទារកភេទប្រុសជនជាតិហេប្រឺត្រូវបានធ្វើ
មុនពេលដែលបញ្ចូលក្នុងសហគមន៍អ៊ីស្រាអែល។
ពេលបងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនបានកប់រួមជាមួយព្រះអង្គ
សាវ័កប៉ូលថ្លែងពិធីជ្រមុជទឹក និងចូលរួមក្នុងក្រុមជំនុំរបស់អ្នកជឿ
ដូចត្រូវបានកប់រួមជាមួយព្រះគ្រិស្ត។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់បានកប់បងប្អូនជាមួយព្រះគ្រិស្តនៅពេលអ្នកចូលរួមក្នុងព្រះវិហារក្នុងពិធីជ្រមុជទឹក
ហើយបងប្អូនបានរស់ឡើងវិញ
ជាមួយការប្រៀបធៀបនេះ សាវ័កប៉ូលថ្លែងពីជីវិតខាងវិញ្ញាណរបស់អ្នកជឿ
ដោយព្រោះតែព្រះអង្គបាននាំព្រះគ្រិស្តរស់ឡើងវិញ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយព្រោះតែបងប្អូនបានចូលទៅព្រះគ្រិស្តដោយខ្លួនឯង
ព្រះជាម្ចាស់បានប្រទានឲ្យបងប្អូនរស់ឡើងវិញ»
Colossians 2:13
ពីដើម បងប្អូនបានស្លាប់
សាវ័កប៉ូលថ្លែងពីការមិនឆ្លើយតបទៅព្រះជាម្ចាស់ ប្រៀបដូចជាការស្លាប់។
ការបកប្រែរបៀបផ្សេងទៀត: «ពីដើម
អ្នកជឿនៅក្រុងកូឡូសមិនបានឆ្លើយតបទៅព្រះជាម្ចាស់»
ពីដើម បងប្អូនបានស្លាប់នៅក្នុងនិស្ស័យចាស់ និងមិនបានធ្វើពិធីកាត់ស្បែកខាងរូបកាយឡើយ
តែព្រះអង្គបានប្រទានឲ្យបងប្អូនមានជីវិត
ជាមួយការប្រៀបធៀបនេះ សាវ័កប៉ូលថ្លែងពីការមានជីវិតថ្មីខាងវិញ្ញាណ
ប្រៀបដូចជាការមានជីវិតថ្មីខាងសាច់ឈាមដែរ។
បានស្លាប់នៅក្នុងនិស្ស័យចាស់ និងមិនបានធ្វើពិធីកាត់ស្បែកខាងរូបកាយឡើយ
ការបកប្រែរបៀបផ្សេងទៀត: ១) បងប្អូនស្លាប់ខាងវិញ្ញាណ
តែរស់នៅដោយអំពើបាបដែលប្រឆាំងនឹងព្រះគ្រិស្ត ហើយ ២)
ដោយសារបងប្អូនមិនបានធ្វើពិធីកាត់ស្បែកតាមបញ្ញាតិលោកម៉ូសេ។
អត់ទោសរាល់អំពើរំលងរបស់បងប្អូន
«ទ្រង់អត់ទោសពួកយើង ទាំងយើង និងសាសន៍ យូដា ហើយបងប្អូនសាសន៍ដទៃ
រាល់អំពើរំលងរបស់យើង»
ព្រះអង្គបានលុបបញ្ជីបំណុល និងវិន័យដែលបានចោទប្រកាន់យើង
សាវ័កប៉ូលថ្លែងពីរបៀបដែលព្រះជាម្ចាស់បានអត់ទោសយើងប្រៀបដូចជា
មនុស្សដែលបានលុបបំណុល ដែលអ្នកដទៃជំពាក់លុយ របស់របរ
ដូច្នេះពួកគេមិនចាំបាច់សងគេវិញឡើយ។
ព្រះអង្គបានបំបាក់មុខវាជាសាធារណៈ:
នៅសម័យរ៉ូម៉ាំង
វាជាទម្លាប់ធម្មតាសម្រាប់កងទ័ពរ៉ូម៉ាំងដែលមានក្បួនដង្ហែរជ័យជំនះ
នៅពេលពួកគេត្រឡប់ទៅស្រុកកំណើតវិញ
ដោយដាក់បង្ហាញពួកឈ្លើយសឹកដែលពួកគេបានចាប់បាន និងរបស់របរទាំងអស់
ដែលពួកគេប្រមូលបាន។ ព្រះបានទទួលជ័យជំនះលើអំណាចនិងឥទ្ធិពលអាក្រក់។
សុគតនៅលើឈើឆ្កាង
ពាក្យថា «ឈើឆ្កាង» តំណាងឲ្យ ការសុគតរបស់ព្រះគ្រិស្តនៅលើឈើឆ្កាង។
Colossians 2:16
អំពីការហូបអាហារ ផឹកភេសជ្ជៈ
បញ្ញាតិលោកម៉ូសេ រួមមានអ្វីដែលគេអាចហូបអាហារនិងផឹកភេសជ្ជៈបាន។
«សម្រាប់អ្វីដែលបងប្អូនអាចហូបបាន ឬអ្វីដែលបងប្អូនអាចផឹកបាន»
អំពីរឿងបុណ្យទាន បុណ្យចូលខែ ឬថ្ងៃសប្ប័ទនោះទេ
បញ្ញាតិលោកម៉ូសេ កំណត់ថ្ងៃធ្វើពិធីបុណ្យ ថ្វាយបង្គំ និងដាក់ដង្វាយ។
«សម្រាប់វិធីដែលបងប្អូនធ្វើពិធីបុណ្យទាន បុណ្យចូលខែ ឬថ្ងៃសប្ប័ទនោះ»
ជាស្រមោលដែលនឹងមកប៉ុណ្ណោះ
ស្រមោលផ្តល់នូវគំនិតមិនច្បាស់លាស់ នៃរូបរាងនិងលក្ខណៈ។
តាមរបៀបស្រដៀងគ្នានេះ ដែលដូចទម្លាប់សាសនា ដូចជាបញ្ញាតិលោកម៉ូសេ
ដែលបង្ហាញតែផ្នែកខ្លះនៃភាពពិតរបស់ព្រះយេស៊ូវគ្រិស្តប៉ុណ្ណោះ។
សេចក្តីពិត
នេះមានន័យថា «ជាការពិត» ដែលការនោះអាចលុប «ស្រមោល» ចេញបាន។
Colossians 2:18
កុំឲ្យមាននរណាម្នាក់លួចយកការបន្ទាបខ្លួន និងការថ្វាយបង្គំ ដែលធ្វើឲ្យអ្នកបាត់បង់រង្វាន់
សាវ័កប៉ូលសំដៅលើគ្រូក្លែងក្លាយ ប្រៀបដូចជាពួកគេជាចៅក្រមពុករលួយ
ដែលនៅទីលានប្រកួត ដែលដកសិទ្ធិអ្នកជឿដោយអយុត្តិធម៌
ហើយលោកថ្លែងពីព្រះគ្រិស្តជួយសង្គ្រោះពួកគេ
ដូចជាព្រះគ្រិស្តបានប្រទានរង្វាន់ដល់អ្នកជ័យលាភីនៅក្នុងប្រកួតដែរ។
ការបកប្រែរបៀបផ្សេងទៀត: «កុំអោយអ្នកណា... ដកអ្នកពីការឈ្នះរង្វាន់នេះ»
លួចយកការបន្ទាបខ្លួន
ពាក្យថា «ការបន្ទាបខ្លួន»
គឺជាពាក្យប្រៀបធៀបសកម ភាពដែលនរណាម្នាក់ធ្វើអោយអ្នកដទៃគិតថាអ្នកដទៃបន្ទាបខ្លួន។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកណាចង់អោយបងប្អូនធ្វើការអ្វី
ដើម្បីបង្ហាញថាបងប្អូនអាចបន្ទាបខ្លួនបាន»
មនុស្សម្នាក់ដែលបានឃើញអ្វីមួយ
សាវ័កប៉ូលថ្លែងពីមនុស្សដែលអះអាងថាពួកគេឃើញសុបិន្ត និងនិមិត្តពីព្រះ

generated on Wed Sep 10 16:16:32 2025

ហើយតែងតែអួតពីមោទនភាពអំពីពួកគេ។
ហើយអួតបំប៉ោងចំតាមគំនិតលោកីយ៍
សាវ័កប៉ូលថ្លែងពីផ្លូវនៃអំពើបាបដែលដូចមនុស្សម្នាក់ក្រអឺតក្រទម។
ការបកប្រែរបៀបផ្សេងទៀត: «អួតបំប៉ោងតាមគំនិតលោកីយ៍»
អួតបំប៉ោង
មនុស្សដែលអួតបំប៉ោងពីអ្វីដែលពួកគេពោល
ប្រៀបដូចជាពួកគេផ្លុំខ្យល់ឲ្យរីកមាឌធំជាងធម្មតា។
តាមគំនិតលោកីយ៍
គំនិតលោកិយ៍ បង្ហាញពីលក្ខណៈមនុស្សដែលមានអំពើបាប។
«គំនិតបែបអំពើបាបដែលគេតែងតែគិត»
គេមិនបាននៅជាប់ជាមួយ
សាវ័កប៉ូលថ្លែងពីការជឿទុកចិត្តលើព្រះគ្រិស្តដូចជាមនុស្សម្នាក់
ដែលឈោងចាប់ព្រះគ្រិស្តដោយដៃរបស់ខ្លួនគេ។ ការបកប្រែរបៀបផ្សេងទៀត:
«គេមិនឈោងចាប់ដោយខ្លាំងក្លាឡើយ» ឬ «គេមិនប្រកាន់ខ្ជាប់ឡើយ»
ដូចកូនក្មេងនៅជាប់ជាមួយនឹងឪពុកម្តាយរបស់គាត់។
ព្រះសិរសាបានតភ្ជាប់ខ្លួនទាំងមូលតាមរយៈសន្លាក់ឆ្អឹង និងសរសៃ
ហើយចម្រើនឡើងជាមួយគ្នាតាមរយៈព្រះជាម្ចាស់ប្រទានឲ្យ
សាវ័កប៉ូលថ្លែងពីព្រះវិហារ
ដែលត្រូវបានគ្រប់គ្រងនិងផ្តល់សិទ្ធិអំណាចដោយព្រះគ្រិស្ត
ហាក់ដូចជារូបកាយរបស់មនុស្ស។ «ការនេះមកព្រះសិរសាដែលព្រះជាម្ចាស់
ដែលប្រទានឲ្យរូបកាយទាំងមូល តាមរយៈសន្លាក់ឆ្អឹង និងសរសៃតភ្ជាប់ជាមួយគ្នា»
Colossians 2:20
ប្រសិនបើបងប្អូនស្លាប់រួមជាមួយព្រះគ្រិស្តមែន ហេតុអ្វីបានជាបងប្អូនរស់នៅ
ដោយការប្រៀបធៀបនេះ សាវ័កប៉ូលថ្លែងពីអ្នកជឿ
ដូចជាមនុស្សម្នាក់ដែលមានរួមបញ្ចូលគ្នាខាងវិញ្ញាណជាមួយព្រះគ្រិស្ត៖
ដូចព្រះគ្រិស្តបានសុគត ដូច្នេះអ្នកជឿបានស្លាប់ខាងវិញ្ញាណ។
ព្រះគ្រិស្តមានព្រះជន្មរស់ឡើងវិញ ដូច្នេះអ្នកជឿមានជីវិតខាងវិញ្ញាណវិញ
ជាការឆ្លើយតបចំពោះព្រះជាម្ចាស់។ (សូមមើល៖figs-metaphor)
ហេតុអ្វីបានជាបងប្អូនរស់នៅដូចជានៅជាប់ជាមួយលោកីយ៍ទៀត។ 21 «កុំយក! កុំភ្លក់! កុំប៉ះ!»
សាវ័កប៉ូលបានប្រើសំនួរនេះដើម្បីស្តីបន្ទោសដល់អ្នកនៅក្រុងកូឡូសចំពោះការដើរតាមជំនឿក្លែងក្លាយរប
ការបកប្រែរបៀបផ្សេងទៀត: «ឈប់ចុះចូលនឹងជំនឿរបស់លោកីយ៍!
ឈប់ជឿលើពាក្យរបស់គេនិយាយ» «កុំ ... ប៉ះ!» (សូមមើល៖figs-rquestion)
រស់នៅដូចជានៅជាប់ជាមួយលោកីយ៍
«គិតថាបងប្អូនត្រូវគោរពតាមបំណងប្រាថ្នារបស់លោកីយ៍»
លោកីយ៍
គំនិត បំណង និងការសន្និដ្ឋាន
របស់មនុស្សភាគច្រើនដែលមានបាបនៅលើលោកីយ៍នេះ (សូមមើល៖figs-metonymy)
ដែលនាំធ្លាក់ចូលក្នុងអំពើពុករលួយ
«វិនាស» សាវ័កប៉ូលប្រើពាក្យប្រៀបធៀបនៅទីនេះនៃដូចជារូបកាយរលួយ
«ពុករលួយ» នៅក្នុងផ្នូរ។
ច្បាប់ទាំងនេះបង្កើតឡើងដោយប្រាជ្ញានៃសាសនា ហើយមានការបន្ទាបខ្លួន និងលត់ដំខ្លួន
សាសនា និងការបន្ទាបខ្លួន និងលត់ដំខ្លួននៃរាងកាយដែលបានបង្កើតឡើង -
«ច្បាប់ទាំងនេះប្រៀបដូចជាមានប្រាជ្ញាចំពោះអ្នកមិនជឿ
ដោយព្រោះពួកគេអនុញ្ញាតឱ្យខ្លួនឯងដែលធ្វើតាមដោយភាពបន្ទាបខ្លួន
ព្រោះពួកគេធ្វើឱ្យប៉ះពាល់ដល់រាងកាយរបស់ពួកគេ»
គ្មានតម្លៃអ្វីសោះក្នុងការប្រឆាំងនឹងសេចក្តីប៉ងប្រាថ្នាខាងនិស្ស័យលោកីយ៍
«កុំឲ្យបងប្អូនឈប់ធ្វើតាមបំណងប្រាថ្នារបស់បែបលោកិយ៍របស់បងប្អូនឡើយ»

3 [1]ប្រសិនបើព្រះជាម្ចាស់បានប្រោសបងប្អូនឲ្យរស់ឡើងវិញរួមជាមួយព្រះគ្រិស្ត ចូរស្វែងរកអ្វីៗនៅស្ថានលើ ជាស្ថានដែលព្រះគ្រិស្តគង់នៅខាស្តាំព្រះជាម្ចាស់។
[2]ចូរគិតពីអ្វីៗដែលនៅស្ថានលើ មិនមែនអ្វីៗដែលនៅផែនដីឡើយ។[3]ដ្បិតបងប្អូនបានស្លាប់ ហើយជីវិតរបស់អ្នកក៏បានលាក់ទុកជាមួយព្រះគ្រិស្ត នៅក្នុងព្រះជាម្ចាស់។
[4]នៅពេលព្រះគ្រិស្ត ដែលជាជីវិតរបស់បងប្អូន បានលេចមកនោះបងប្អូនក៏លេចមកជាមួយព្រះអង្គ ប្រកបដោយសិរីរុងរឿងដែរ។
[5]ចូរសម្លាប់អ្វីៗដែលនៅលើផែនដីនេះដូចជា អំពើប្រាសចាកសីលធម៌ អំពើសៅហ្មង ចិត្តស្រើបស្រាល បំណងប្រាថ្នាអាក្រក់ និងចិត្តលោភលន់ គឺយកទ្រព្យសម្បត្តិធ្វើជា
ព្រះ[6]ព្រោះតែសេចក្តីទាំងនេះហើយដែលធ្វើឲ្យសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ធ្លាក់ទៅលើកូនអស់អ្នកដែលមិនស្តាប់បង្គាប់។[7]អ្នកក៏ធ្លាប់ធ្វើការទាំងអស់នេះ
នៅពេលដែលអ្នករស់នៅក្នុងចំណោមមនុស្សទាំងនោះ។[8]ប៉ុន្តែ ឥឡូវនេះ បងប្អូនគួរតែលះចោលសេចក្តីទាំងនេះដូចជា សេចក្តីក្រោធ កំហឹង ចិត្តអាក្រក់ ប្រមាថ
និងពាក្យទ្រគោះបោះបោកចេញពីមាត់បងប្អូន។
[9]កុំកុហកអ្នកដទៃ ចាប់តាំងពីពេលបងប្អូនបានបោះបង់ជីវិតចាស់ និងទម្លាប់ចាស់ចោល[10]ហើយអ្នកបានបំពាក់មនុស្សថ្មី ដែលព្រះជាម្ចាស់បានបង្កើតមនុស្សថ្មី
ដើម្បីឲ្យស្គាល់លក្ខណៈដែលព្រះជាម្ចាស់បានបង្កើតមក។[11]ដូច្នេះទើបបានជាគ្មានសាសន៍ក្រិក និងសាសន៍យូដា ការកាត់ស្បែក និងការមិនកាត់ស្បែក មនុស្សព្រៃ
ពួកទមិឡ ទាសករ អ្នកងារ ប៉ុន្តែព្រះគ្រិស្តជាអ្វីទាំងអស់ នៅគ្រប់ទាំងអស់។
[12]ចូលបំពាក់នូវអ្វីដែលព្រះជាម្ចាស់បានជ្រើសរើសបងប្អូន ជារាស្ត្រដ៏វិសុទ្ធ និងជាទីស្រឡាញ់ មានចិត្តមេត្តា សប្បុរស បន្ទាបខ្លួន ស្លូតបូត និងអត់ធ្មត់។
[13]ទ្រាំទ្រគ្នាទៅវិញទៅមក សប្បុរសរវាងគ្នាទៅវិញទៅមក។ ប្រសិនបើមាននរណាម្នាក់រអ៊ូរទាំចំពោះនរណាម្នាក់ទៀត សូមអត់ទោសអ្នកដទៃ
តាមរបៀបព្រះអម្ចាស់បានអត់ទោសដល់អ្នកដែរ។[14]លើសពីការទាំងអស់នេះ ត្រូវមានសេចក្តីស្រឡាញ់ ដែលជាចំណងនៃភាពឥតខ្ចោះ។
[15]ចូរឲ្យសេចក្តីសុខសាន្តរបស់ព្រះគ្រិស្តសោយរាជ្យនៅក្នុងចិត្តរបស់បងប្អូន។ ចូរអរព្រះគុណព្រះជាម្ចាស់
ដោយសារតែសេចក្តីសុខសាន្តនេះហើយទើបបងប្អូនបានរួបរួមគ្នាក្នុងព្រះកាយតែមួយ។[16]ចូលឲ្យព្រះបន្ទូលរបស់ព្រះគ្រិស្តរស់នៅក្នុងបងប្អូនជាបរិបូរ។ ចូលបង្រៀន
និងទូន្មានគ្នាទៅវិញទៅដោយប្រើប្រាជ្ញា ទំនុកតម្កើង ចម្រៀងសរសើរ និងបទចម្រៀងដែលមកពីព្រះវិញ្ញាណ។ ចូរច្រៀងអរព្រះគុណថ្វាយព្រះជាម្ចាស់ដោយចេញពីចិត្ត។
[17]អ្វីដែលបងប្អូនធ្វើគ្រប់ទាំងពាក្យសម្តី និងកាយវិការ ចូរធ្វើគ្រប់ការទាំងអស់ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ។ ចូរអរព្រះគុណព្រះបិតាតាមរយៈព្រះយេស៊ូ។
[18]ប្រពន្ធគ្រប់គ្នាអើយ ចូរចុះចូលនឹងប្តី ដើម្បីឲ្យបានសមរម្យនៅក្នុងព្រះអម្ចាស់។[19]ប្តីគ្រប់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធរបស់ខ្លួន ហើយមិនត្រូវមួម៉ៅដាក់នាងឡើយ។
[20]កុមារគ្រប់គ្នាអើយចូលស្តាប់បង្គាប់ឪពុកម្តាយគ្រប់ការទាំងអស់ ដោយសារតែការទាំងអស់នេះជាទីគាប់ព្រះហឫទ័យក្នុងព្រះអម្ចាស់។[21]ឪពុកគ្រប់គ្នាអើយ
ចូរកុំខឹងកូនរបស់អ្នកឡើយ ដូច្នេះទើបគេមិនបាក់ទឹកចិត្ត។
[22]អ្នកបម្រើគ្រប់គ្នាអើយ ចូរគោរពម្ចាស់របស់ខ្លួនក្នុងលោកនេះ មិនត្រូវធ្វើព្រោះផ្គាប់ភ្នែកម្ចាស់ ក៏ដូចជាសម្រាប់ផ្គាប់មនុស្សដទៃទៀតឡើយ
ប៉ុន្តែត្រូវបម្រើដោយចិត្តស្មោះសរ និងដោយការកោតខ្លាចព្រះអម្ចាស់។[23]ចូរធ្វើឲ្យអស់ពីចិត្ត ដូចជាធ្វើថ្វាយព្រះអម្ចាស់ដែរ មិនមែនធ្វើសម្រាប់មនុស្សលោកទេ។[24]ដ្បិត
បងប្អូនបានដឹងថាបងប្អូននឹងទទួលរង្វាន់ពីព្រះអម្ចាស់ជាកេរមរតក។ អស់អ្នកដែលព្រះអម្ចាស់យេស៊ូគ្រិស្តបានអ្នកបម្រើ។[25]ដ្បិតអស់អ្នកណាដែលប្រព្រឹត្តអំពើទុច្ចរិត
អ្នកនោះនឹងទទួលពិន័យ ដូចជាអំពើទុច្ចរិតដែលគេបានប្រព្រឹត្ត ដោយមិនរើសមុខឡើយ។

Colossians 3:1
ប្រយោគភ្ជាប់៖
សាវ័កប៉ូលព្រមានដល់ពួកអ្នកជឿថា ដោយព្រោះពួកគេតែមួយជាមួយនឹងព្រះគ្រិស្ត
ពួកគេមិនគួរធ្វើការមួយឡើយ។
ព្រះជាម្ចាស់បានប្រោសបងប្អូនឲ្យរស់ឡើងវិញរួមជាមួយព្រះគ្រិស្ត
ព្រះជាម្ចាស់បានលើកព្រះគ្រិស្តឡើងទៅស្ថានបរមសុខដូច្នោះព្រះជាម្ចាស់ចាត់ទុកអ្នកជឿ
ដូចជាព្រះអង្គបានលើកពួកគេឡើងទៅស្ថានបរមសុខដែរ។
អ្វីៗនៅស្ថានលើ
«អ្វីដែលនៅស្ថានសួគ៌»
ដ្បិតបងប្អូនបានស្លាប់
ដូចព្រះគ្រិស្តបានសោយទិវង្គត
ដូច្នេះព្រះជាម្ចាស់ចាត់ទុកពួកអ្នកនៅក្រុងកូឡូសថាបានស្លាប់ជាមួយព្រះគ្រិស្ត។
ជីវិតរបស់អ្នកក៏បានលាក់ទុកជាមួយព្រះគ្រិស្ត នៅក្នុងព្រះជាម្ចាស់
ជីវិតរបស់អ្នក
ជីវិតរបស់មនុស្ស
ប្រៀបដូចជាការដែលត្រូវបានលាក់បាំងនៅក្នុងដប
ហើយបានថ្លែងពីព្រះជាម្ចាស់ដូចជាទ្រង់ជាដប។ ការបកប្រែរបៀបផ្សេងទៀត:

generated on Wed Sep 10 16:16:32 2025

អាចមានន័យថា ១) «រាល់ដង់ដូចជាព្រះជាម្ចាស់បានដកយកជីវិតរបស់អ្នក
ហើយបានលាក់បាំង ជាមួយព្រះគ្រិស្តនៅក្នុងវត្តមានរបស់ព្រះជាម្ចាស់» ឬ ២)
«មានតែព្រះជាម្ចាស់ទេ ដែលដឹងថាជីវិតពិតរបស់អ្នកយ៉ាងណា
ហើយទ្រង់នឹងបើកបង្ហាញនៅពេលទ្រង់បង្ហាញពីព្រះគ្រិស្ត»
ដែលជាជីវិតរបស់បងប្អូន
ព្រះគ្រិស្តគឺមានតែទ្រង់តែមួយគត់ដែលប្រទានជីវិតខាងវិញ្ញាណដល់អ្នកជឿ។
Colossians 3:5
ចូរសម្លាប់អ្វីៗដែលនៅលើផែនដីនេះ
សាវ័កប៉ូលថ្លែងពីសេចក្តីប៉ងប្រាថ្នាខុសឆ្គងប្រៀបដូចជាអវយវៈដែលពួកគេប្រើប្រាស់ដើម្បីបំពេញចិត្តខ្លួនឯង
(សូមមើល៖ និងfigs-metonymy)
អំពើសៅហ្មង
«អំពើមិនបរិសុទ្ធ»
ចិត្តស្រើបស្រាល
«ចិត្តពេញដោយតណ្ហា និងខ្លាំងក្លា»
និងចិត្តលោភលន់ គឺយកទ្រព្យសម្បត្តិធ្វើជាព្រះ
«និងចិត្តលោភលន់ គឺដូចគ្នានឹងការយកទ្រព្យសម្បត្តិធ្វើជាព្រះ» ឬ
«និងមិនត្រូវមានចិត្តលោភលន់
ដោយព្រោះនោះវាដូចគ្នានឹងការគោរពបូជារូបព្រះក្លែងក្លាយ» (UDB)
សេចក្តីក្រោធរបស់ព្រះជាម្ចាស់
ព្រះជាម្ចាស់ទ្រង់ព្រះពិរោធនឹងអស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់
ដូចអ្វីដែលព្រះអង្គបានដាក់ទណ្ឌកម្មពួកគេ។
កូនអស់អ្នកដែលមិនស្តាប់បង្គាប់
«មនុស្សជាតិដែលមិនស្តាប់បង្គាប់» ឬ «មនុស្សដែលមិនស្តាប់បង្គាប់ដល់ព្រះអង្គ»
អ្នកក៏ធ្លាប់ធ្វើការទាំងអស់នេះ
សាវ័កប៉ូលថ្លែងពីរបៀបដែលមនុស្សប្រព្រឹត្តដូចជាផ្លូវឬគន្លងផ្លូវដែលមនុស្សបានដើរ។
ការបកប្រែរបៀបផ្សេងទៀត: «ការទាំងនេះគឺជារឿងដែលអ្នកធ្លាប់ធ្វើគន្លងមក»
សេចក្តីក្រោធ កំហឹង
ពាក្យថា «សេចក្តីក្រោធ»
នៅទីនេះសំដៅទៅលើពេលដែលមានអ្នកដែលខឹងនឹងអ្នកដែលមិនពេញចិត្តគេ
ដូចដែលបានបង្ហាញដោយសកម្មភាពរបស់គេ ដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។
កំហឹង
កំហឹងយ៉ាងខ្លាំង
ចិត្តអាក្រក់
«ចូលចិត្តធ្វើអំពើអាក្រក់»
ប្រមាថ
ពាក្យសំដីដែលធ្វើឲ្យអ្នកដទៃឈឺចាប់
ពាក្យទ្រគោះបោះបោក
ពាក្យដែលមិនសមគួរក្នុងការសន្ទនា
ចេញពីមាត់បងប្អូន
ពាក្យថា «មាត់» គឺជាការប៉ៅបធៀបសម្រាប់ការនិយាយ។
«ក្នុងការនិយាយរបស់បងប្អូន»
Colossians 3:9
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបន្តថ្លែងប្រាប់អ្នកជឿពីរបៀបរស់នៅនិងរំលឹកពួកគេថាគ្រិស្តបរិស័ទគួរតែប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក
បងប្អូនបានបោះបង់ជីវិតចាស់ និងទម្លាប់ចាស់ចោល ហើយអ្នកបានបំពាក់មនុស្សថ្មី
សាវ័កប៉ូលនៅទីនេះថ្លែងពីការបដិសេធរបស់គ្រិស្តបរិស័ទពីជីវិតចាស់ដែលមានតែអំពើបាប
ជារឿងធម្មតាដែលជនជាតិអ៊ីស្រាអែលដែលសាវ័កប៉ូលបានថ្លែងពីខាងសីលធម៌ដូចជាចំណែកនៃសម្លៀកបំពាក់
លក្ខណៈ
នេះសំដៅលើព្រះយេស៊ូគ្រិស្ត។
ដូច្នេះទើបបានជាគ្មានសាសន៍ក្រិក និងសាសន៍យូដា ការកាត់ស្បែក និងការមិនកាត់ស្បែក
មនុស្សព្រៃ ពួកទមិឡ ទាសករ អ្នកងារ
ពាក្យទាំងនេះគឺជាឧទាហរណ៍នៃប្រភេទមនុស្សដែលសាវ័កប៉ូលបានថ្លែងពីដែលជាការមិនសំខាន់ក្នុងការរួមរស់ជាមួយគ្នា
ព្រះទតឃើញមនុស្សគ្រប់រូប ដោយមិនប្រកាន់ពូជសាសន៍ សាសនា សញ្ជាតិ
ឬឋានៈក្នុងសង្គមឡើយ។ ការបកប្រែរបៀបផ្សេងទៀត: «ពូជសាសន៍ សាសនា
វប្បធម៌ និងឋានៈក្នុងសង្គម ដែលជាការមិនសំខាន់ទេ»
មនុស្សព្រៃ
ប្រភេទមនុស្សមកពីខាងក្រៅដែលមិនស្គាល់ពីទំនៀមទំលាប់អ្នកនៅក្នុងស្រុក
ពួកទមិឡ
នេះគឺជាក្រុមមនុស្សដែលមកពីទឹកដីស៊ីសៀដែលនៅខាងក្រៅចក្រភពរ៉ូម។

ជនជាតិក្រិកនិងជនជាតិរ៉ូមបានប្រើពាក្យនេះសម្រាប់សំគាល់មនុស្សម្នាក់ដែលធំឡើងនៅកន្លែងដែលមនុ
ព្រះគ្រិស្តជាអ្វីទាំងអស់ នៅគ្រប់ទាំងអស់
គ្មានអ្វីដែលត្រូវបានដកចេញឬចាកចេញពីការគ្រប់គ្រងរបស់ព្រះគ្រិស្តទេ។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះគ្រិស្តគឺសំខាន់ជាងអ្វីទាំងអស់
ហើយគង់នៅក្នុងប្រជាជាតិរបស់ទ្រង់ទាំងអស់»
Colossians 3:12
ចូលបំពាក់នូវអ្វីដែលព្រះជាម្ចាស់បានជ្រើសរើសបងប្អូន ជារាស្ត្រដ៏វិសុទ្ធ និងជាទីស្រឡាញ់
មានចិត្តមេត្តា
ដើម្បីបំពេញចិត្តខ្លួនឯង
(សូមមើល៖ និងfigs-metonymy)
និងគុណធម៌ខាងសីលធម៌ដទៃទៀតនៅក្នុងអាកប្បកិរិយារបស់ពួកគេចំពោះគ្នាទៅវិញទៅមក។
ការមានចិត្តតជារឿយៗត្រូវបានគេគិតថាជាចំណុចកណ្តាលនៃចិត្តមេត្តានិងអាណិតអាសូរ។
អ្នកបកប្រែអាចផ្លាស់ប្តូរផ្នែកនៃការពាក្យពេជន៍នេះនៅក្នុងធ្វើកំណែថ្មីរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «មានចិត្តមេត្តាគ្រប់ពេលវេលា»
នូវអ្វីដែល
«ព្រោះអ្វីដែលខ្ញុំទើបតែនិយាយគឺជាការពិត»
ព្រះជាម្ចាស់បានជ្រើសរើសបងប្អូន ជារាស្ត្រដ៏វិសុទ្ធ និងជាទីស្រឡាញ់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដូចអ្នកដែលព្រះជាម្ចាស់បានជ្រើសរើសសម្រាប់ទ្រង់ផ្ទាល់
ដែលព្រះអង្គចង់ឃើញរស់នៅសម្រាប់ទ្រង់តែមួយ និងអ្នកដែលទ្រង់ស្រលាញ់»
សប្បុរស
«សេចក្តីល្អ» ឬ «ចិត្តសុភាពរាបសា»
បន្ទាបខ្លួន
«ចិត្តរាបទាប» ឬ «ចិត្តទន់ទាប»
ស្លូតបូត
«ចិត្តសុភាពរាបសា»
ទ្រាំទ្រគ្នាទៅវិញទៅមក
«កុំបណ្តោយឱ្យខ្លួនឯងឆាប់ខឹងនឹងគ្នា» ឬ
«ព្រមទទួលយកគ្នាទៅវិញទៅមកសូម្បីតែពេលអ្នកខកចិត្តក៏ដោយ»
សប្បុរសរវាងគ្នាទៅវិញទៅមក
«ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកប្រសើរជាងអ្វីដែលពួកគេទទួលបានពីបងប្អូនធ្វើចំពោះពួកគេ»
អ៊ូរទាំចំពោះ
«អ៊ូរទាំចំពោះ»
ដែលជាចំណងនៃភាពឥតខ្ចោះ
«ដែលចងយើងជាមួយគ្នាយ៉ាងល្អឥតខ្ចោះ»
Colossians 3:15
ចូរឲ្យសេចក្តីសុខសាន្តរបស់ព្រះគ្រិស្តសោយរាជ្យនៅក្នុងចិត្តរបស់បងប្អូន
សាវ័កប៉ូលថ្លែងពីសេចក្តីសុខសាន្តដែលព្រះគ្រិស្តបានប្រទានឲ្យ
ដូចជាអ្នកគ្រប់គ្រង។ អាចមានន័យថា ១)
«ធ្វើអ្វីគ្រប់យ៉ាងដើម្បីឱ្យបងប្អូនមានទំនាក់ទំនងប្រកបដោយសន្តិភាពជាមួយគ្នា»
ឬ ២)
«អនុញ្ញាតឱ្យព្រះជាម្ចាស់ផ្តល់ឱ្យបងប្អូននូវសេចក្តីសុខសាន្តនៅក្នុងចិត្តបងប្អូន»
ក្នុងចិត្តរបស់បងប្អូន
ជាធម្មតាសាវ័កប៉ូលថ្លែងពីក្នុងចិត្ត
ត្រូវតែជាលក្ខណៈដែលបង្ហាញថាមានលក្ខខណ្ឌជាក់លាក់ដូចជាសន្តិភាព។
បងប្អូនគួរតែប្រើការបញ្ចេញមតិបែបជាទូទៅបំផុតនៅក្នុងភាសារបស់បងប្អូនសម្រាប់អារម្មណ៍សុខសាន្ត។
(សូមមើលពីរបៀបដែលយើងបានបកប្រែឃ្លានេះនៅក្នុង Colossians 3:12 ដែលជាបំពាក់ចាស់ដែលគេដោះចេញដើម្បីស្លៀកសម្លៀកបំពាក់ដែលថ្មីវិញ។
ការបង្រៀនរបស់ព្រះគ្រិស្តរស់នៅក្នុងបងប្អូន
សាវ័កប៉ូលថ្លែងពីព្រះបន្ទូលរបស់ព្រះគ្រិស្ត
ប្រៀបដូចជាមនុស្សមានសមត្ថភាពអាចរស់នៅខាងក្នុងមនុស្សឯទៀត។
«ជឿទុកចិត្តលើការសន្យារបស់ព្រះគ្រិស្តជានិច្ច»
ទូន្មានគ្នាទៅវិញទៅមក
ទំនុកតម្កើង ចម្រៀងសរសើរ និងបទចម្រៀងដែលមកពីព្រះវិញ្ញាណ
«ជាមួយនឹងចំរៀងគ្រប់ប្រភេទ ដើម្បីសរសើរតម្កើងព្រះជាម្ចាស់»
អរព្រះគុណថ្វាយព្រះជាម្ចាស់ដោយចេញពីចិត្ត
«ដួងចិត្តដោយអរព្រះគុណ»
ទាំងពាក្យសម្តី និងកាយវិការ
ការថ្លែង ឬការប្រព្រឹត្ត
ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ

generated on Wed Sep 10 16:16:32 2025

«លើកកិត្តិយសព្រះអម្ចាស់យេស៊ូ» ឬ «ដោយអំណាចរបស់ព្រះអម្ចាស់យេស៊ូ»

តាមរយៈព្រះយេស៊ូ

អាចមានន័យថា ១) ដោយព្រោះទ្រង់បានធ្វើការល្អឬ ២) ដោយព្រោះទ្រង់បានធ្វើឲ្យមនុស្សអាចនិយាយទៅកាន់ព្រះអង្គបានហើយអរព្រះគុណទ្រង់។ (សូមមើល៖ Colossians 3:18

ប្រយោគភ្ជាប់៖

បន្ទាប់មកសាវ័កប៉ូលបានផ្តល់ការណែនាំពិសេសដល់ប្រពន្ធ ប្តី កូនៗ ឪពុក ទាសករ និងចៅហ្វាយ។

ប្រពន្ធគ្រប់គ្នាអើយ ចូរចុះចូល

«ប្រពន្ធគ្រប់គ្នាអើយ ចូរគោរព»

ដើម្បីឲ្យបានសមរម្យ

«ឲ្យបានសមស្រប» ឬ «ឲ្យបានត្រឹមត្រូវ»

មិនត្រូវមូម៉ៅដាក់

«កុំធ្វើបាបជាមួយ» ឬ «កុំខឹងនឹង»

ចូរកុំខឹងកូនរបស់អ្នកឡើយ

«ចូរកុំធ្វើឱ្យកូនរបស់បងប្អូនខឹងឡើយ»

Colossians 3:22

ចូរគោរពម្ចាស់របស់ខ្លួនក្នុងលោកនេះ

«ចូរគោរពម្ចាស់របស់ខ្លួនជាមនុស្ស»

មិនត្រូវធ្វើព្រោះផ្គាប់ភ្នែកម្ចាស់

«កុំគោរពម្ចាស់របស់បងប្អូន នៅពេលដែលគាត់កំពុងសង្កេតមើលបងប្អូនឡើយ ទោះបីបងប្អូនត្រូវការផ្គាប់ចិត្តមនុស្ស»។

ថ្វាយព្រះអម្ចាស់

«ដូចជាបងប្អូនធ្វើការថ្វាយព្រះអម្ចាស់»

រង្វាន់ពីព្រះអម្ចាស់ជាកេរមរតក

«កេរមរតកដែលជារង្វាន់របស់បងប្អូន»

កេរមរតក

ការទទួលនូវអ្វីដែលព្រះបានសន្យាដល់អ្នកជឿ ប្រៀបបានដូចជាទទួលមរតក និងទ្រព្យសម្បត្តិពីក្រុមគ្រួសារ។

ដ្បិតអស់អ្នកណាដែលប្រព្រឹត្តអំពើទុច្ចរិត អ្នកនោះនឹងទទួលពិន័យ

«ព្រះជាម្ចាស់នឹងដាក់ទោសអ្នកដែលប្រព្រឹត្តអំពើទុច្ចរិត»

អស់អ្នកណាដែលប្រព្រឹត្តអំពើទុច្ចរិត

អស់អ្នកណាដែលប្រព្រឹត្រអំពើទុច្ចរិតយ៉ាងសកម្មនិងគ្រប់បែបយ៉ាង

ដោយមិនរើសមុខឡើយ

«ព្រះជាម្ចាស់វិនិច្ឆ័យមនុស្សគ្រប់គ្នាដោយរបៀបដូចគ្នា»

---

4 [1]ចៅហ្វាយគ្រប់គ្នាអើយ ចូរប្រព្រឹត្តជាមួយអ្នកបម្រើរបស់ខ្លួន ឲ្យបានត្រឹមត្រូវនិងយុត្តិធម៌។ អ្នកដឹងហើយថា អ្នកក៏មានចៅហ្វាយមួយនៅស្ថានបរមសុខដែរ។
[2]ចូរបន្តព្យាយាមអធិស្ឋាន។ ចូរប្រុងស្មារតីនៅក្នុងការអធិស្ឋាន ដោយអរព្រះគុណ។[3]សូមរួមគ្នាអធិស្ឋានសម្រាប់យើង ដើម្បីឲ្យព្រះអង្គបើកទ្វារសម្រាប់ព្រះបន្ទូល
ដើម្បីឲ្យយើងបានប្រកាសពីសេចក្តីពិតដែលលាក់កំបាំងរបស់ព្រះគ្រិស្ត។ ហើយខ្ញុំបានជាប់ឃុំឃាំងដោយព្រោះការនេះ។
[4]សូមអធិស្ឋានឲ្យខ្ញុំយល់ច្បាស់ពីអ្វីដែលខ្ញុំត្រូវនិយាយ។
[5]ចូរដើរដោយប្រាជ្ញាជាមួយអ្នកដែលមិនទាន់ជឿ និងចេះរៀបចំពេលវេលាផង។[6]សូមឲ្យសម្តីរបស់បងប្អូនបានប្រកបដោយព្រះគុណជានិច្ច។
ឲ្យពួកគេទទួលបានពាក្យដែលមានខ្លឹមសារ ដើម្បីឲ្យបងប្អូនអាចដឹងពីរបៀបដែលបងប្អូនឆ្លើយតបទៅមនុស្សម្នាក់ៗ។
[7]រឿងអ្វីដែលទាក់ទងជាមួយខ្ញុំ លោកទីឃីកុសជម្រាបដល់បងប្អូនឲ្យបានដឹង។ លោកទីឃីកុសជាបងប្អូនជាទីស្រឡាញ់ ក៏ជាអ្នកបម្រើដ៏ស្មោះត្រង់
និងជាអ្នកបម្រើក្នុងព្រះអម្ចាស់។[8]ខ្ញុំបានបញ្ជូនគាត់សម្រាប់ការនេះ ដើម្បីប្រាប់ពីដំណឹងរបស់យើង ហើយគាត់ក៏អាចលើកទឹកចិត្តដល់បងប្អូនដែរ។
[9]ខ្ញុំបានបញ្ជូនគាត់ទៅជាមួយលោកអូនេស៊ីម ជាបងប្អូនដែលស្មោះត្រង់ និងជាទីស្រឡាញ់ ហើយជាម្នាក់ក្នុងចំណោមបងប្អូន។
ពួកគេនឹងជម្រាបដល់បងប្អូនពីអ្វីដែលបានកើតឡើងនៅទីនេះ។
[10]លោកអើរីស្តាក ជាបងប្អូនដែលជាប់ឃុំឃាំងជាមួយខ្ញុំ សូមជម្រាបសួរមកបងប្អូន ហើយលោកម៉ាកុស
ដែលត្រូវជាសាច់ញាតិរបស់លោកបារណាបាសក៏សូមជម្រាបសួរដល់បងប្អូនដែរ (ប្រសិនបើ គាត់មកសុខទុក្ខបងប្អូន
សូមទទួលគាត់ដូចអ្វីដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា)[11]ហើយលោកយេស៊ូ ហៅលោកយូស្ទុសក៏បានជម្រាបសួរដល់បងប្អូនដែរ។ មានតែអ្នកកាត់ស្បែកអ្នកនេះឯង
សម្រាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយក៏ជាអ្នកដែលកម្សាន្តចិត្តខ្ញុំដែរ។
[12]លោកអេប៉ាប្រាសសូមជម្រាបសួរដល់បងប្អូន។ គាត់គឺជាម្នាក់ក្នុងចំណោមបងប្អូន ហើយក៏ជាអ្នកបម្រើរបស់ព្រះយេស៊ូដែរ។ គាត់តែងតែអធិស្ឋានសម្រាប់បងប្អូន
ដើម្បីឲ្យបងប្អូនអាចឈរឆ្ងាំងមាំ និងពេញលក្ខណៈនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់។[13]ខ្ញុំអាចធ្វើជាសាក្សីសម្រាប់គាត់បាន ថាគាត់ពិតជាប្រឹងប្រែងសម្រាប់បងប្អូន
និងសម្រាប់អ្នកស្រុកឡៅឌីសេ ព្រមទាំងអ្នកស្រុកហេរ៉ាប៉ូល។[14]លោកគ្រូពេទ្យលូកាជាទីស្រឡាញ់របស់យើង និងលោកដេម៉ាសសូមជម្រាបសួរដល់បងប្អូនដែរ។
[15]សូមជម្រាបសួរដល់បងប្អូនដែលរស់នៅស្រុកឡៅឌីសេ និងនាងនឹមផាស ព្រមទាំងក្រុមជំនុំដែលប្រជុំគ្នានៅក្នុងផ្ទះរបស់នាងដែរ។
[16]នៅពេលដែលបងប្អូនបានអានសំបុត្រនេះរួចហើយ សូមអានសំបុត្រនេះសម្រាប់ក្រុមជំនុំឡៅឌីសេ ហើយសូមអានសំបុត្រដែលមកពីស្រុកឡៅឌីសេផង។
[17]សូមជម្រាបលោកអើឃីព ត្រូវយកចិត្តទុកដាក់ចំពោះព័ន្ធកិច្ចដែលអ្នកទទួលបាននៅក្នុងព្រះអម្ចាស់ ដែលអ្នកគួរតែធ្វើការនេះ។
[18]ពាក្យជម្រាបសួរនេះ ខ្ញុំប៉ូល ជាអ្នកសរសេរដោយដៃខ្ញុំផ្ទាល់។ សូមចាំថាខ្ញុំនៅជាប់ឃុំឃាំង។ សូមឲ្យព្រះគុណរបស់ព្រះជាម្ចាស់នៅជាប់ជាមួយបងប្អូន។

Colossians 4:1

ប្រយោគភ្ជាប់៖

បន្ទាប់ពីបានថ្លែងទៅកាន់ចៅហ្វាយ
សាវ័កប៉ូលបានបញ្ចប់ការណែនាំពិសេសរបស់លោក
ដល់អ្នកជឿដទៃទៀតនានានៅក្នុងក្រុមជំនុំក្រុងកូឡូស។

ត្រឹមត្រូវនិងយុត្តិធម៌

ពាក្យទាំងនេះមានន័យថាស្មើរតែដូចគ្នាហើយត្រូវបានប្រើដើម្បីបញ្ជាក់ពីអ្វីដែលត្រឹមត្រូវ[illegible]

អ្នកក៏មានចៅហ្វាយមួយនៅស្ថានបរមសុខដែរ

ព្រះជាម្ចាស់មានបំណង ឲ្យទំនាក់ទំនងរវាងម្ចាស់លើលោកិយ៍
និងខ្ញុំបម្រើរបស់គេបង្ហាញសេចក្តីស្រឡាញ់ដូចព្រះជាម្ចាស់
ដែលជាម្ចាស់នៅស្ថានបរមសុខស្រឡាញ់អ្នកបម្រើរបស់ព្រះអង្គនៅផែនដី
រួមទាំងចៅហ្វាយរបស់អ្នកបម្រើនៅលើផែនដី។

Colossians 4:2

ប្រយោគភ្ជាប់៖

សាវ័កប៉ូលបន្តផ្តល់ការណែនាំដល់អ្នកជឿអំពីរបៀបរស់នៅនិងនិយាយ។

ព័ត៌មានទូទៅ៖

ពាក្យថា «យើង» សំដៅលើ សាវ័កប៉ូល និងលោកធីម៉ូថេ
តែមិនមែនអ្នកនៅក្រុងកូឡូសទេ។

ចូរបន្តព្យាយាមអធិស្ឋាន

«បន្តអធិស្ឋានដោយស្មោះត្រង់» ឬ «បន្តអធិស្ឋានជានិច្ច»

ព្រះអង្គបើកទ្វារ

«ព្រះជាម្ចាស់ប្រទានឲ្យមានឱកាស» (សូមមើល៖figs-metaphor)

សេចក្តីពិតដែលលាក់កំបាំងរបស់ព្រះគ្រិស្ត

នេះសំដៅទៅលើដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្តដែលមិនទាន់ត្រូវបានគេយល់ [illegible]

ហើយខ្ញុំបានជាប់ឃុំឃាំងដោយព្រោះការនេះ

ពាក្យថា «ជាប់ឃុំឃាំង»
នៅទីនេះជាការប្រៀបប្រដូចដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ។
ការបកប្រែរបៀបផ្សេងទៀត «គឺការប្រកាសព្រះបន្ទូលព្រះយេស៊ូគ្រិស្ត
ថាពេលនេះខ្ញុំកំពុងជាប់ឃុំក្នុងពន្ធនាគារ»

សូមអធិស្ឋានឲ្យខ្ញុំយល់ច្បាស់

«សូមអធិស្ឋានឲ្យខ្ញុំអាចថ្លែងពីព្រះបន្ទូលព្រះយេស៊ូវគ្រិស្តយ៉ាងច្បាស់»

Colossians 4:5

ចូរដើរដោយប្រាជ្ញាជាមួយអ្នកដែលមិនទាន់ជឿ

គំនិតនៃការដើរត្រូវបានគេប្រើជាញឹកញាប់សម្រាប់គំនិតនៃរៀបចំជីវិតរបស់ខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត: «រស់នៅតាមរបៀបមួយដែលអ្នកមិនជឿ

generated on Wed Sep 10 16:16:32 2025

នឹងឃើញថាអ្នកមានប្រាជ្ញា»
ចេះរៀបចំពេលវេលា
«ចូររៀបចំអ្វីដែលល្អបំផុតដែល
បងប្អូនអាចធ្វើបានជាមួយពេលវេលារបស់បងប្អូន» ឬ
«ចូរដាក់ពេលវេលាដើម្បីប្រើប្រាស់បានល្អបំផុត»
សូមឲ្យសម្ដីរបស់បងប្អូនបានប្រកបដោយព្រះគុណជានិច្ច។
ឲ្យពួកគេទទួលបានពាក្យដែលមានខ្លឹមសារ
អាហារជាមួយអំបិល គឺជាពាក្យប្រៀបធៀបសម្រាប់ពាក្យដែលបង្រៀនអ្នកដទៃ
ហើយអ្នកទាំងនោះចូលចិត្តស្ដាប់។
«សូមឱ្យការសន្ទនារបស់បងប្អូនតែងតែមានភាពទន់ភ្លន់និងទាក់ទាញ»
ដើម្បីឲ្យបងប្អូនអាចដឹងពីរបៀបដែលបងប្អូនឆ្លើយតបទៅមនុស្សម្នាក់ៗ
«ដូច្នេះបងប្អូនអាចដឹងពីរបៀបឆ្លើយសំណួរ ពីនរណាម្នាក់អំពីព្រះយេស៊ូវគ្រិស្ត» ឬ
«ដូច្នេះបងប្អូនអាចប្រព្រឹត្តចំពោះមនុស្សគ្រប់គ្នាបានយ៉ាងល្អ»
Colossians 4:7
ប្រយោគភ្ជាប់៖
សាវ័កប៉ូលបានបញ្ចប់ជាមួយនឹងការណែនាំពិសេសអំពីមនុស្សយ៉ាងច្បាស់លាស់
ប្រៀបដូចជាការសួរសុខទុក្ខនិងពីអ្នកជឿម្នាក់ៗ។
ព័ត៌មានទូទៅ៖
លោកអូនេស៊ីមជាខ្ញុំបម្រើរបស់លោកភីលេម៉ូននៅទីក្រុងកូឡូស។
គាត់បានលួចលុយពីលោកភីលេម៉ូនហើយរត់ទៅទីក្រុងរ៉ូមជាកន្លែងដែលគាត់បានក្លាយ
ឥឡូវនេះ លោកទីឃីកុស
និងលោកអូនេស៊ីមជាអ្នកនាំសំបុត្ររបស់សាវ័កប៉ូលទៅក្រុងកូឡុស។
រឿងអ្វីដែលទាក់ទងជាមួយខ្ញុំ
«គ្រប់បញ្ហាដែលបានកើតឡើងចំពោះខ្ញុំ» (UDB)
ជាអ្នកបម្រើ
«ជាអ្នកបំរើ» ទោះបីសាវ័កប៉ូលជាមនុស្សមានសេរីភាពក៏ដោយ
ក៏លោកចាត់ទុកខ្លួនលោកជាអ្នកបំរើរបស់ព្រះគ្រិស្ត
ហើយឃើញថាលោកទីឃីកុសជាអ្នកបម្រើផងដែរ។
របស់យើង
ពាក្យនេះមិនបានរាប់បញ្ចូលជាមួយអ្នកនៅក្រុងកូឡូសឡើយ។
ក៏អាចលើកទឹកចិត្តដល់បងប្អូនដែរ
ដួងចិត្តត្រូវបានគេគិតថាជាចំណុចកណ្ដាលនៃអារម្មណ៍ជាច្រើន។
ការបកប្រែរបៀបផ្សេងទៀត: «អាចលើកទឹកចិត្តដល់បងប្អូន»
ជាបងប្អូនដែលស្មោះត្រង់
សាវ័កប៉ូលបានហៅលោកអូនេស៊ីម ជាគ្រីស្ដបរិស័ទ និងអ្នកបម្រើរបស់ព្រះគ្រិស្ត
ពួកគេនឹងជម្រាប
«លោកអូនេស៊ីម និងលោកទីឃីកុសនឹងជម្រាប»
ពីអ្វីដែលបានកើតឡើងនៅទីនេះ
ពួកគេនឹងប្រាប់អ្នកជឿនៅក្រុងកូឡូសទាំងអស់នូវអ្វីដែលបានកើតឡើងដែលសាវ័កប៉ូល
កាលនោះបានថ្លែងថាសាវ័កប៉ូលស្ថិតនៅក្នុងទីក្រុងរ៉ូមនៅក្រោមការឃុំឃាំងក្នុងផ្ទះ
ឬនៅក្នុងគុកនៅពេលនេះ។
Colossians 4:10
លោកអើរីស្ដាក
គាត់ត្រូវបាននៅក្នុងគុកជាមួយសាវ័កប៉ូលនៅក្រុងអេភេសូរ
នៅពេលដែលសាវ័កប៉ូលបានសរសេរសំបុត្រទៅកាន់ក្រុងកូឡូស។
ប្រសិនបើ គាត់មកសុខទុក្ខ
«ប្រសិនបើលោកម៉ាកុសមកសួរសុខទុក»
ហើយលោកយេស៊ូ ហៅលោកយូស្ទូស
នេះជាមនុស្សដែលបំពេញព័ន្ធកិច្ចជាមួយនឹងសាវ័កប៉ូល។
មានតែអ្នកកាត់ស្បែកអ្នកនេះឯង សម្រាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់
សាវ័កប៉ូលប្រើពាក្យ «ការធ្វើពិធីកាត់ស្បែក» ត្រង់នេះសំដៅលើជនជាតិយូដា
ដោយព្រោះតែយោងទៅតាមបទគម្ពីរសញ្ញាចាស់
ដែលប្រុសៗជនជាតិយូដាទាំងអស់ត្រូវកាត់ស្បែក។ ការបកប្រែរបៀបផ្សេងទៀត:
«បុរសទាំងបីនាក់នេះ គឺជាអ្នកជឿលើជនជាតិយូដាតែមួយគត់
ដែលធ្វើការជាមួយខ្ញុំដើម្បីប្រកាសព្រះជាម្ចាស់ជាស្ដេចតាមរយៈព្រះគ្រិស្តយេស៊ូ»
មានតែអ្នកកាត់ស្បែកអ្នកនេះឯង
បុរសទាំងនេះ គឺលោកអើរីស្ដាក លោកម៉ាកុស និងលោកយូសស
តែម្នាក់គត់ដែលបានកាត់ស្បែក»
Colossians 4:12
ព័ត៌មានទូទៅ៖
ស្រុកឡៅឌីសេ ព្រមទាំងស្រុកហេរ៉ាប៉ូល គឺជាក្រុងដែលនៅជិតនឹងក្រុងកូឡូស។
លោកអេប៉ាប្រាស
លោកអេប៉ាប្រាសគឺជាបុរសដែលបានអធិប្បាយពីដំណឹងល្អដល់ប្រជាជននៅទីក្រុងកូឡូស។
(សូមមើលនៅជំពូក ១៖៧)
ម្នាក់ក្នុងចំណោមបងប្អូន
«ពីទីក្រុងរបស់បងប្អូន» ឬ «អ្នកនៅក្នុងក្រុងជាមួយបងប្អូន» (UDB)
ជាអ្នកបម្រើរបស់ព្រះយេស៊ូដែរ
«ជាសិស្សប្ដេជ្ញាចិត្តរបស់ព្រះយេស៊ូគ្រិស្ត»
គាត់តែងតែអធិស្ឋានសម្រាប់បងប្អូន
«អធិស្ឋានយ៉ាងស្មោះអស់ពីចិត្តសំរាប់បងប្អូន»
បងប្អូនអាចឈេរឆីងមាំ និងពេញលក្ខណៈ
ខ្ញុំអាចធ្វើជាសាក្សីសម្រាប់គាត់បាន ថាគាត់ពិតជាប្រឹងប្រែងសម្រាប់បងប្អូន
«ខ្ញុំបានសង្កេតឃើញថាគាត់ពិតជាប្រឹងប្រែងយ៉ាងខ្លាំងសម្រាប់បងប្អូន» (UDB)
លោកដេម៉ាស
នេះជាសហការីមួយផ្សេងទៀតរបស់សាវ័កប៉ូល។
Colossians 4:15
បងប្អូន
នេះមានន័យថាបងប្អូនគ្រីស្ទានទាំងបុរសនិងស្ត្រី។
ស្រុកឡៅឌីសេ
ជាស្រុកមួយដែលនៅជាប់នឹងក្រុងកូឡូស ដែលមានក្រុមជំនុំមួយផងដែរ។
នាងនីមផាស ព្រមទាំងក្រុមជំនុំដែលប្រជុំគ្នានៅក្នុងផ្ទះរបស់នាងដែរ
ស្ត្រីម្នាក់ឈ្មោះនីមផាស បានរៀបចំក្រុមជំនុំតាមផ្ទះ។ ការបកប្រែរបៀបផ្សេងទៀត:
«នាងនីមផាស និងអ្នកជឿដទៃទៀតបានជួបជុំគ្នានៅក្នុងផ្ទះរបស់នាង» (UDB)
សូមជម្រាបលោកអើឃីព ត្រូវយកចិត្តទុកដាក់ចំពោះព័ន្ធកិច្ចដែលអ្នកទទួលបាននៅក្នុងព្រះអម្ចាស់
ដែលអ្នកគួរតែធ្វើការនេះ។
សាវ័កប៉ូលរំលឹកលោកអើឃីព ពីកិច្ចការដែលព្រះជាម្ចាស់បានប្រទានដល់គាត់
លោកអើឃីព ដែលមានកាតព្វកិច្ចចំពោះព្រះជាម្ចាស់ ដែលគាត់គួរតែធ្វើការនេះ។
ពាក្យថា «ត្រូវយកចិត្តទុកដាក់» «អ្នកទទួលបាន» និង «អ្នកគួរតែធ្វើការនេះ»
ទាំងអស់នេះសំដៅលើ លោកអើឃីព ហើយគួរតែមានតែមួយគត់។
ប្រយោគភ្ជាប់:
សាវ័កប៉ូលបានបញ្ចប់ការសរសេរសំបុត្ររបស់លោកជាមួយនឹងពាក្យសួរសុខទុក្ខ
ដែលសរសេរដោយដៃរបស់លោកផ្ទាល់។
សូមចាំថាខ្ញុំនៅជាប់ឃុំឃាំង
សាវ័កប៉ូលថ្លែងពីជាប់ឃុំឃាំងនៅពេលលោកមានន័យថាការជាប់ឃុំឃាំងរបស់លោក។
ការបកប្រែរបៀបផ្សេងទៀត:
«សូមនឹកចាំខ្ញុំហើយអធិស្ឋានអោយខ្ញុំនៅពេលដែលខ្ញុំនៅជាប់ឃុំឃាំង»
សូមឲ្យព្រះគុណរបស់ព្រះជាម្ចាស់នៅជាប់ជាមួយបងប្អូន
ពាក្យថា «ព្រះគុណ» តំណាងឲ្យព្រះជាម្ចាស់ ដែលព្រះអង្គបង្ហាញព្រះគុណ
ឬធ្វើការល្អដល់អ្នកជឿ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំសូមអង្វរព្រះជាម្ចាស់យេស៊ូគ្រិស្តរបស់យើង
បន្តធ្វើការល្អចំពោះបងប្អូនទាំងអស់គ្នា» (UDB)

១ ថេស្សាឡូនិក

1 [1]ខ្ញុំប៉ូល និងស៊ីលវ៉ាន ហើយនិងធីម៉ូថេ ជូនចំពោះក្រុមជំនុំនៃថេស្សាឡូនិកនៅក្នុងព្រះដ៏ជាព្រះបិតា និងព្រះអម្ចាស់យេស៊ូគ្រិស្ត។ សូមព្រះគុណ
និងសេចក្ដីសុខសាន្តកើតមានដល់អ្នករាល់គ្នា។

generated on Wed Sep 10 16:16:32 2025

[2]ពួកយើងអរគុណដល់ព្រះអង្គជានិច្ចសម្រាប់បងប្អូនទាំងអស់គ្នា យើងតែងតែនឹកគិតពីអ្នករាល់គ្នានៅក្នុងសេចក្តីអធិស្ឋានរបស់យើងជានិច្ច។
[3]យើងនឹកចាំបងប្អូននៅចំពោះព្រះជាម្ចាស់ ចំពោះកិច្ចការនៃជំនឿ និងកិច្ចការនៃសេចក្តីស្រឡាញ់
ព្រមទាំងមានការអត់ធ្មត់ជឿជាក់សម្រាប់អនាគតនៅក្នុងព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង។
[4]ព្រះជាម្ចាស់ស្រឡាញ់បងប្អូន យើងដឹងថា ព្រះអង្គបានជ្រើសរើសអ្នករាល់គ្នា[5]ដោយសារដំណឹងល្អរបស់យើងដែលមកដល់បងប្អូនមិនមែនគ្រាន់តែសំដីប៉ុណ្ណោះទេ
តែជាមួយនឹងអំណាច នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងដែលមានចិត្តជឿជាក់យ៉ាងខ្លាំងថែមទៀតផង។ ដូចគ្នានេះដែរ អ្នកក៏បានដឹងថា យើងជាមនុស្សបែបណា
ដែលនៅក្នុងចំណោមបងប្អូន គឺសម្រាប់បងប្អូន។
[6]អ្នករាល់គ្នាបានយកតម្រាប់តាមយើង និងតាមព្រះអម្ចាស់
ក្នុងការដែលអ្នករាល់គ្នាបានទទួលព្រះបន្ទូលនៅក្នុងគ្រាទុក្ខលំបាកយ៉ាងខ្លាំងដោយអំណរចេញពីព្រះវិញ្ញាណដ៏វិសុទ្ធ។[7]ជាលទ្ធផល
អ្នកបានក្លាយជាគំរូដល់បងប្អូនអ្នកជឿដែលនៅស្រុកម៉ាសេដូន និងស្រុកអាខៃផងដែរ។
[8]ដ្បិត ព្រះបន្ទូលរបស់ព្រះអម្ចាស់បានចេញពីអ្នករាល់គ្នា ហើយមិនគ្រាន់តែនៅក្នុងនៅស្រុកម៉ាសេដូន និងស្រុកអាខៃប៉ុណ្ណោះទេ ប៉ុន្តែ
ជំនឿរបស់អ្នករាល់គ្នានៅក្នុងព្រះជាម្ចាស់បានចេញទៅគ្រប់ទីកន្លែង។ ហេតុដូច្នេះហើយ យើងមិនចាំបាច់និយាយអ្វីទាំងអស់។[9]ដ្បិត
ពួកគេខ្លួនឯងបានរាយការណ៍ពីហេតុដែលយើងមកក្នុងចំណោមអ្នករាល់គ្នា។ ពួកគេបានប្រាប់ពីការដែលអ្នករាល់គ្នាបែរពីរូបព្រះ ទៅបម្រើព្រះដ៏មានព្រះជនរស់
និងសេចក្តីពិតវិញ។[10]ពួកគេបានរាយការណ៍ថា អ្នករាល់គ្នាបានរង់ចាំព្រះបុត្រារបស់ព្រះអង្គយាងមកពីស្ថានសួគ៌ ជាព្រះដែលព្រះអង្គបានប្រោសពីសេចក្តីស្លាប់ឡើងវិញ។
នេះគឺព្រះយេស៊ូ ដែលបានរំដោះយើងពីសេចក្តីក្រោធដែលមកដល់។

---

1 Thessalonians 1:1
ព័ត៌មានទូទៅ៖
ប៉ូលបញ្ជាក់ខ្លួនគាត់ជាអ្នកសរសេរសំបុត្រ
និងសួរសុខទុក្ខក្រុមជំនុំនៅថេស្សាឡូនិក។
ខ្ញុំប៉ូល និងស៊ីលវ៉ាន ហើយធីម៉ូថេ ជូនចំពោះក្រុមជំនុំ
វាបញ្ជាក់យ៉ាងច្បាស់ថាលោក គឺជាប៉ូលដែលបានសរសេរលិខិតនេះ។
សូមព្រះគុណ និងសេចក្តីសុខសាន្តកើតមានដល់អ្នករាល់គ្នា
ពាក្យ «ព្រះគុណ» និង «ក្តីសុខសាន្ត»
គឺជានិមិត្តរូបសម្រាប់មនុស្សដែលប្រព្រឹត្តចំពោះមនុស្សដោយសប្បុរស
និងដោយសន្តិភាព។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមឲ្យព្រះមានព្រះហឫទ័យសប្បុរសចំពោះអ្នក ហើយផ្តល់ឲ្យអ្នកនូវសន្តិភាព»
សេចក្តីសុខសាន្តកើតមានដល់អ្នករាល់គ្នា។
ពាក្យថា «អ្នក» សំដៅទៅលើអ្នកជឿថេស្សាឡូនិក។
1 Thessalonians 1:2
ព័ត៌មានទូទៅ៖
នៅក្នុងលិខិតនេះពាក្យ «យើង» និង «ពួកយើង» យោងទៅប៉ូល ស៊ីលវ៉ាន
និងធីម៉ូថេលើកលែងតែមានការកត់សម្គាល់ផ្សេង។ ដូចជាពាក្យ «អ្នក»
គឺពហុវចន:ហើយសំដៅទៅលើអ្នកជឿនៅឯក្រុមជំនុំថេស្សាឡូនិក។
ពួកយើងអរគុណដល់ព្រះអង្គជានិច្ច
ត្រង់ថា «ជានិច្ច»
បង្ហាញថាពេលប៉ូលអធិដ្ឋានទៅព្រះលោកបង្ហាញយ៉ាងទៀងទាត់នូវថេស្សាឡូនិកដល់ព្រះ
យើងតែងតែនឹកគិតពីអ្នករាល់គ្នានៅក្នុងសេចក្តីអធិស្ឋានរបស់យើងជានិច្ច
«យើងអធិដ្ឋានសម្រាប់អ្នក»
កិច្ចការនៃជំនឿ
ការប្រព្រឹត្តដែលបានធ្វើដោយសារតែការទុកចិត្តលើព្រះ
1 Thessalonians 1:4
ប្រយោគភ្ជាប់៖
ប៉ូល នៅតែបន្តថ្លែងអំណរគុណចំពោះអ្នកជឿនៅថេស្សាឡូនិក
ហើយសរសើរពួកគេ ចំពោះជំនឿរបស់ពួកគេលើព្រះ។
បងប្អូន
នេះមានន័យថាគ្រីស្ទានរួមទាំងបុរស និងស្ត្រី។
យើងដឹងថា
ពាក្យថា «យើង« សំដៅទៅលើប៉ូល ស៊ីលវ៉ាស និងធីម៉ូថេ
តែមិនមែនជាអ្នកជឿនៅក្រុងថេស្សាឡូនិកទេ។
មិនមែនគ្រាន់តែសំដីប៉ុណ្ណោះទេ
មិនត្រឹមតែតាមរយៈសកម្មភាពផ្សព្វផ្សាយសាររបស់ព្រះប៉ុណ្ណោះទេ។
តែជាមួយនឹងអំណាច នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ
អាចមានន័យថាទី ១) ព្រះវិញ្ញាណបរិសុទ្ធបានប្រទានដល់ប៉ុល
និងគូកនរបស់គាត់នូវសមត្ថភាពក្នុងការផ្សាយដំណឹងល្អប្រកបដោយអានុភាព ឬទី
២)
ព្រះវិញ្ញាណបរិសុទ្ធបានធ្វើឲ្យការផ្សាយដំណឹងល្អមានឥទ្ធិពលយ៉ាងខ្លាំងក្នុងចំណោមអ្នកស្តាប់
ឬទី ៣)
ព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញពីការពិតនៃការផ្សាយដំណឹងល្អតាមរយៈអព្ភូតហេតុសញ្ញា
និងអព្ភូតហេតុ។
ជាមនុស្សបែបណា
«របៀបដែលយើងបានធ្វើដោយខ្លួនយើងនៅពេលដែល» (UDB)
1 Thessalonians 1:6
អ្នករាល់គ្នាបានយកតម្រាប់តាម
ដើម្បី «ធ្វើត្រាប់តាម» មានន័យថាធ្វើដូច ឬ ចម្លងអាកប្បកិរិយារបស់អ្នកដទៃ។
ទទួលព្រះបន្ទូល
«ស្វាគមន៍ការបង្រៀន» ឬ «ទទួលការបង្រៀន»
ក្នុងគ្រាទុក្ខលំបាកយ៉ាងខ្លាំង
«ក្នុងអំឡុងពេលនៃការរងទុក្ខវេទនាជាខ្លាំង» ឬ
«នៅក្នុងការធ្វើទុក្ខបុកម្នេញជាច្រើន»
ស្រុកអាខៃ
នេះគឺជាស្រុកបុរាណមួយ អ្វីដែលនៅសព្វថ្ងៃក្នុងប្រទេសក្រិក។
1 Thessalonians 1:8
បានចេញពីអ្នករាល់គ្នា
នៅទីនេះប៉ូលនិយាយអំពីសាក្សីគ្រីស្ទានដែលបានមកដោយអ្នកជឿថេស្សាឡូនិក
ដូចលោកជាកណ្តឹងដែលរោទ៍ ឬឧ បករណ៍ភ្លេងដែលត្រូវបានចាក់។
ស្រុកអាខៃ
នេះគឺជាស្រុកបុរាណមួយ អ្វីដែលនៅសព្វថ្ងៃក្នុងប្រទេសក្រិក។
ដ្បិត ពួកគេខ្លួនឯង...ពួកគេប្រាប់...ពួកគេរាយការណ៍
ប៉ូលកំពុងសំដៅទៅលើព្រះវិហារដែលមានរួចហើយនៅតំបន់ជុំវិញដែលបានឮ
អំពីអ្នកជឿនៅក្រុងថេស្សាឡូនិក។
ដ្បិត ពួកគេខ្លួនឯង
ត្រង់ថា «ខ្លួនឯង»
ត្រូវបានប្រើដើម្បីបញ្ជាក់មនុស្សទាំងនោះដែលបានឮអ្នកជឿនៅក្រុងថេស្សាឡូនិកនេះ។
ដែលយើងមកក្នុងចំណោមអ្នករាល់គ្នា
ត្រង់ថា «មក»
តំណាងឲ្យការស្វាគមន៍ដែលមានបទពិសោធន៍ពីប៉ូលនិងគូកនរបស់លោក។
របៀបផ្សេងទៀតនៃការបកប្រែ: «តើអ្នកបានស្វាគមន៍ពួកយើងយ៉ាងកក់ក្តៅ»
ព្រះបុត្រារបស់ព្រះអង្គ
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូ
ដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ទ្រង់ជាមួយព្រះជាម្ចាស់។
ជាព្រះដែលព្រះអង្គបានលើកឡើង
«ជាអ្នកដែលព្រះអង្គបានលើកឡើង»
ប្រោសពីសេចក្តីស្លាប់ឡើងវិញ
ពីក្នុងចំណោមអ្នកដែលបានស្លាប់។
ការបញ្ចេញមតិនេះរៀបរាប់អំពីមនុស្សស្លាប់ទាំងអស់រួមគ្នានៅក្នុងនរក។
ដែលបានរំដោះយើង
ការធ្វើឲ្យបរិសុទ្ធ
ដែលនឹងមកដល់ពួកអ្នកជឿថេស្សាឡូនិក។

2

generated on Wed Sep 10 16:16:32 2025

[1]ដ្បិតបងប្អូនវិញ បងប្អូនបានដឹងហើយថា ការមកវិញរបស់ពួកយើងមិនឥតប្រយោជន៍ឡើយ។[2]អ្នករាល់គ្នាដឹងហើយថា យើងបានឈឺចាប់កាលពីមុន
ហើយយើងបានទទួលរងការប្រមាថនៅក្រុងភីលីព។
យើងមានសេចក្តីក្លាហាននៅក្នុងព្រះជាម្ចាស់នៃយើងក្នុងការនិយាយមកកាន់អ្នករាល់គ្នានូវដំណឹងល្អរបស់ព្រះជាម្ចាស់នៅក្នុងឧបសគ្គខ្លាំងយ៉ាងណាក្តី។
[3]ដ្បិត ការដាស់តឿនរបស់យើងមិនមែនមកពីកំហុស ឬមកពីភាពមិនបរិសុទ្ធ ឬមកពីការបោកប្រាស់ឡើយ។[4]ផ្ទុយទៅវិញ
ព្រះជាម្ចាស់បានអនុញ្ញាតនិងផ្ទុកផ្តាក់ឲ្យយើងនាំដំណឹងល្អ ដូច្នេះ យើងក៏ប្រកាស។ យើងប្រកាស មិនមែនដោយផ្គាប់ចិត្តមនុស្សទេ ប៉ុន្តែ
ផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់វិញ។ ព្រះអង្គគឺជាព្រះជាម្ចាស់ដែលពិនិត្យពិច័យដួងចិត្តរបស់យើង។
[5]ដ្បិត យើងមិនបានប្រើពាក្យបញ្ចើចបញ្ចើរណាមួយឡើយ ដូចបងប្អូនដឹងស្រាប់ហើយ ឬជាលេសសម្រាប់ការលោភលន់ឡើយ មានព្រះជាម្ចាស់ជាបន្ទាល់។[6]ឬ
យើងក៏មិនបានស្វែងរកសិរីល្អពីមនុស្សដែរ មិនថាពីបងប្អូន ឬអ្នកផ្សេងៗទៀត។ យើងមានឯកសិទ្ធិជាសាវករបស់ព្រះគ្រិស្ត។
[7]តែផ្ទុយទៅវិញ យើងដូចជាសាសន៍ដទៃនៅក្នុងចំណោមអ្នករាល់គ្នា ដូចជាម្តាយដែលលួងលោមកូនរបស់ខ្លួន។
[8]នេះគឺជារបៀបនៃសេចក្តីស្រឡាញ់ដែលយើងមានសម្រាប់បងប្អូន។ យើងមានអំណរក្នុងការចែកចាយជាមួយបងប្អូន មិនគ្រាន់តែដំណឹងល្អរបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ
ប៉ុន្តែ ថែមទាំងជីវិតរបស់យើងផងដែរ។ ដ្បិត អ្នករាល់គ្នាបានក្លាយជាទីស្រឡាញ់សម្រាប់យើងហើយ។[9]បងប្អូនចាំ ពីកិច្ចការ និងការងាររបស់យើងហើយ។
ទាំងយប់ទាំងថ្ងៃ យើងខំធ្វើការ ដើម្បីកុំឲ្យយើងបានក្លាយជាបន្ទុកដល់នរណាម្នាក់ឡើយ។ នៅក្នុងអំឡុងពេលនោះ
យើងបានប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ទៅកាន់បងប្អូន។
[10]អ្នករាល់គ្នាគឺជាបន្ទាល់ ហើយព្រះជាម្ចាស់ក៏ជាសាក្សីរបស់យើងផងដែរ ពីរបៀប ដ៏វិសុទ្ធ សុចរិត និងគ្មានកន្លែងបន្ទោសបាន
ដែលយើងបានប្រព្រឹត្តខ្លួនយើងនៅចំពោះបងប្អូនអ្នកជឿ។[11]ដូចគ្នានេះដែរ អ្នកបានដឹងពីរបៀបដែលយើងបានប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក
ប្រៀបដូចជាឪពុកប្រព្រឹត្តចំពោះកូនរបស់គាត់ផ្ទាល់[12]យើងអង្វរ និងលើកទឹកចិត្ត ព្រមទាំងដាស់តឿនដល់អ្នករាល់គ្នា ឲ្យដើរតាមបែបស័ក្តសមចំពោះព្រះជាម្ចាស់
ដែលបានត្រាស់ហៅអ្នកមកក្នុងព្រះរាជ្យ និងសិរីល្អរបស់ព្រះអង្គផ្ទាល់។
[13]ដោយហេតុផលនេះហើយ យើងក៏អរគុណដល់ព្រះជាម្ចាស់ជានិច្ច។ ដ្បិត នៅពេលអ្នករាល់គ្នាបានទទួលព្រះរាជសាររបស់ព្រះជាម្ចាស់ដែលអ្នករាល់គ្នាបានឮ
អ្នករាល់គ្នាបានទទួលពីយើង អ្នករាល់គ្នាប្រៀបដូចជាព្រះបន្ទូលរបស់ព្រះផ្ទាល់។ គឺព្រះបន្ទូលនេះហើយដែលធ្វើការនៅក្នុងចំណោមអ្នករាល់គ្នា
និងក្នុងចំណោមអ្នកជឿដែរ។
[14]ដ្បិត បងប្អូនអើយ អ្នករាល់គ្នាបានក្លាយជាគំរូរបស់ក្រុមជំនុំផ្សេងៗរបស់ព្រះជាម្ចាស់ ដែលនៅក្នុងយូដា នៅក្នុងព្រះគ្រិស្តយេស៊ូ។ ដ្បិត
អ្នករាល់គ្នាក៏បានរងទុក្ខដូចគ្នាពីបងប្អូនជនរួមជាតិរបស់អ្នករាល់គ្នា ដូចដែលពួកគេបានរងទុក្ខពីសាសន៍យូដាដែរ។
[15]គឺជាសាសន៍យូដាហើយដែលបានសម្លាប់ទាំងព្រះអម្ចាស់យេស៊ូ និងពួកព្យាការី។ គឺពួកយូដាហើយ ដែលបណ្តេញពួកយើងចេញ។
ពួកគេមិនបានធ្វើឲ្យព្រះជាម្ចាស់គាប់ព្រះហឫទ័យទេ។ ផ្ទុយទៅវិញ ពួកគេប្រឆាំងជាមួយមនុស្សគ្រប់គ្នា។[16]ពួកគេបានហាមប្រាមយើងមិនឲ្យប្រកាសទៅកាន់សាសន៍ដទៃ
ដើម្បីឲ្យពួកគេបានសង្គ្រោះឡើយ។ ជាលទ្ធផល ពួកគេបានធ្វើឲ្យបាប ធ្លាក់មកលើពួកគេកាន់តែច្រើន។ សេចក្តីក្រោធត្រូវតែធ្លាក់មកលើពួកគេនៅទីបញ្ចប់។
[17]បងប្អូនអើយ យើងត្រូវបានញែកដោយឡែកពីបងប្អូន តែមួយរយៈខ្លីតែប៉ុណ្ណោះ ខាងឯសាច់ឈាម ប៉ុន្តែមិនមែនខាងឯចិត្តគំនិតរបស់យើងទេ។
ជាពិសេសយើងមានចិត្តប្រាថ្នាចង់ឃើញមុខអ្នករាល់គ្នាយ៉ាងខ្លាំង។[18]ដ្បិត ខ្ញុំ ប៉ូល ម្តងហើយម្តងទៀត យើងចង់មកឯអ្នករាល់គ្នាណាស់ ប៉ុន្តែ សាតាំងបានរារាំងយើង។
[19]ដ្បិត តើអ្វីទៅជាសេចក្តីសង្ឃឹមនៃអនាគតរបស់យើង ឬអំណរ ឬជាភួងជ័យនៅចំពោះព្រះអម្ចាស់យេស៊ូនៅពេលដែលព្រះអង្គយាងត្រឡប់មកវិញ?
តើមិនមែនជាអ្នករាល់គ្នាទេឬអី?[20]ដ្បិតអ្នករាល់គ្នាគឺជាសិរីល្អ និងជាអំណររបស់យើង។

---

1 Thessalonians 2:1

ប្រយោគភ្ជាប់៖

ប៉ូលកំណត់ការបំរើសំរាប់អ្នកជឿនិងរង្វាន់។

អ្នក ខ្លួនឯង

ពាក្យថា «អ្នក» និង «ខ្លួនឯង» យោងទៅអ្នកជឿថេស្សាឡូនិក។

បងប្អូន

នេះមានន័យថាគ្រីស្ទានរួមទាំងបុរស និងស្ត្រី។

ការមកវិញរបស់ពួកយើង

ពាក្យថា «របស់យើង» សំដៅទៅលើប៉ូល ស៊ីលវ៉ានស
និងធីម៉ូថេតែមិនមែនជាអ្នកជឿនៅក្រុងថេស្សាឡូនិកទេ។

ឥតប្រយោជន៍

នេះអាចត្រូវបានបង្ហាញក្នុងលក្ខណៈវិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពិតជាមានប្រយោជន៍ណាស់»

យើងបានឈឺចាប់កាលពីមុន ហើយយើងបានទទួលរងការប្រមាថ

«ត្រូវបានគេធ្វើបាបនិងប្រមាថ»

ក្នុងឧបសគ្គខ្លាំងយ៉ាងណាក្តី

«ខណៈពេលកំពុងតស៊ូនៅក្រោមឧបសគ្គដ៏អស្ចារ្យ»

1 Thessalonians 2:3

មិនមែនមកពីកំហុស ឬមកពីភាពមិនបរិសុទ្ធ ឬមកពីការបោកប្រាស់ឡើយ

«ជាសេចក្តីពិតបរិសុទ្ធ និងស្មោះត្រង់»

ព្រះជាម្ចាស់បានអនុញ្ញាតនិងផ្ទុកផ្តាក់

ប៉ូលត្រូវបានសាកល្បង និងបង្ហាញថាគួរឲ្យទុកចិត្តដោយព្រះជាម្ចាស់។

យើងប្រកាស

ប៉ូលចង់សំដៅទៅលើការផ្សព្វផ្សាយសារដំណឹងល្អ។

ដែលពិនិត្យពិច័យដួងចិត្តរបស់យើង

ពាក្យ «ដួងចិត្ត» គឺជាពាក្យប្រៀបធៀបសម្រាប់បំណងប្រាថ្នា
និងគំនិតរបស់មនុស្សម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកណាដឹងពីបំណងប្រាថ្នា និងគំនិតរបស់យើង«

1 Thessalonians 2:5

ព័ត៌មានទូទៅ៖

ប៉ូលបានប្រាប់អ្នកជឿនៅក្រុងថេស្សាឡូនិកថាការប្រព្រឹត្តរបស់គាត់មិនមានមូលដ្ឋានលើភាពថ្លៃថ្នូរ
ការលោភលន់ ឬភាពអួតខ្លួនទេ។

ប្រើពាក្យបញ្ចើចបញ្ចើរ

«និយាយជាមួយអ្នកដោយការសរសើរមិនពិត»

ជាលេសសម្រាប់ការលោភលន់

«យើងក៏មិនបានប្រើពាក្យដើម្បីលាក់នូវសេចក្តីអាក្រក់ចំពោះលុយរបស់អ្នកដែរ»

អាចទាមទារសិទ្ធិ

«អាចទទួចឲ្យអ្នកផ្តល់ប្រាក់ដល់យើង»

1 Thessalonians 2:7

ដូចជាម្តាយដែលលួងលោមកូនរបស់ខ្លួន

ដូចជាម្តាយសម្រាលទុក្ខកូនៗរបស់ខ្លួនដែរ ដូច្នេះប៉ុលស៊ីលវ៉ាន
និងធីម៉ូថេបាននិយាយទៅកាន់អ្នកជឿថេស្សាឡូនិកយ៉ាងទន់ភ្លន់។

នេះគឺជារបៀបនៃសេចក្តីស្រឡាញ់ដែលយើងមានសម្រាប់បងប្អូន

«នេះជារបៀបដែលយើងបង្ហាញក្តីស្រឡាញ់របស់យើងចំពោះអ្នក»

យើងមានសេចក្តីស្រឡាញ់ចំពោះអ្នក

«យើងបានស្រឡាញ់អ្នក»

យើងមានអំណរក្នុងការចែកចាយជាមួយបងប្អូន មិនគ្រាន់តែដំណឹងល្អរបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ

ប៉ូលសំដៅទៅលើសារដំណឹងល្អហាក់ដូចជាវត្ថុរូបវន្តដែលមនុស្សម្នាក់អាចចែកចាយជាមួយអ្នកដទៃ។
តាមរយៈ: «ការចែករំលែក» គាត់មានន័យថា »ប្រាប់»

យើងមានអំណរក្នុងការចែកចាយជាមួយបងប្អូន...ថែមទាំងជីវិតរបស់យើងផងដែរ

ប៉ូលសំដៅទៅលើមិត្តរួមការងារ និងសហការីរបស់គាត់។
រស់នៅដូចជាពួកគេជាវត្ថុរូបវន្តដែលពួកគេអាចចែករំលែកជាមួយអ្នកដទៃ។
នៅទីនេះគាត់មានន័យថាចំណាយពេល និងការខំប្រឹងប្រែងជាមួយទស្សនិកជន។

អ្នករាល់គ្នាបានក្លាយជាទីស្រឡាញ់សម្រាប់យើងហើយ

«យើងបានយកចិត្តទុកដាក់ចំពោះអ្នកយ៉ាងខ្លាំង»

បងប្អូន

generated on Wed Sep 10 16:16:32 2025

នេះមានន័យថាគ្រីស្ទានរួមទាំងបុរស និងស្ត្រី។
ពីកិច្ចការ និងការងាររបស់យើង
ពាក្យថា «ពលកម្ម» និង «នឿយហត់» មានន័យថាជាមូលដ្ឋានដូចគ្នា។
ប៉ូលប្រើពួកគេដើម្បីបញ្ជាក់ពីការខិតខំរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «តើយើងខំធ្វើការនឿយហត់កំរិតណា?»
ទាំងយប់ទាំងថ្ងៃ យើងខំធ្វើការ ដើម្បីកុំឲ្យយើងបានក្លាយជាបន្ទុកដល់នរណាម្នាក់ឡើយ
«យើងខំធ្វើការចិញ្ចឹមជីវិតដោយខ្លួនឯងដូច្នេះអ្នកមិនចាំបាច់ជួយគាំទ្រយើងទេ»
1 Thessalonians 2:10
ដ៏វិសុទ្ធ សុចរិត និងគ្មានកន្លែងបន្ទោសបាន
លោកប៉ូលប្រើពាក្យបីដែលពិពណ៌នាអំពីអាកប្បកិរិយាល្អរបស់ពួកគេចំពោះអ្នកជឿថេស្សាឡូនិក
ប្រៀបដូចជាឪពុកប្រព្រឹត្តចំពោះកូនរបស់គាត់ផ្ទាល់
ប៉ូលប្រៀបធៀបរបៀបដែលគាត់លើកទឹកចិត្តបងប្អូននៅក្រុងថេស្សាឡូនិកទៅនឹងឪពុករបស់គាត់ថ្នមៗអំពីរបៀបប្រព្រឹត្ត។
យើងអង្វរ និងលើកទឹកចិត្ត ព្រមទាំងដាស់តឿនដល់អ្នករាល់គ្នា
ពាក្យថា «សុំទាន» «លើកទឹកចិត្ត» និង «ជម្រុញ»
ត្រូវបានប្រើជាមួយគ្នាដើម្បីបង្ហាញពីរបៀបដែលក្រុមរបស់ប៉ូលលើកទឹកចិត្តដល់ថែស្សាឡូនិក
របៀបផ្សេងទៀតនៃការបកប្រែ: «យើងកំពុងលើកទឹកចិត្តអ្នកយ៉ាងខ្លាំង»
ដែលបានត្រាស់ហៅអ្នកមកក្នុងព្រះរាជ្យ និងសិរីល្អរបស់ព្រះអង្គផ្ទាល់
ពាក្យ «សិរីរុងរឿង» ពិពណ៌នាអំពីពាក្យ «នគរ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូលទៅក្នុងនគរដ៏រុងរឿងរបស់ព្រះអង្គ»
1 Thessalonians 2:13
ព័ត៌មានទូទៅ៖
លោកប៉ូលបន្តប្រើ «យើង» ដើម្បីយោងទៅខ្លួនលោក
និងដៃគូធ្វើដំណើររបស់លោកនិង «អ្នក» ដល់អ្នកជឿនៅក្រុងថេស្សាឡូនិក។
យើងក៏អរគុណដល់ព្រះជាម្ចាស់ជានិច្ច
ជាញឹកញាប់លោកប៉ូលអរគុណព្រះចំពោះការទទួលយកសារលិខិតដែលលោកបានចែកចាយ
អ្នកបានទទួលវាជាព្រះបន្ទូលរបស់ព្រះយ៉ាងពិតប្រាកដ
ថេស្សាឡូនិកបានជឿថា
សាររបស់លោកប៉ូលគឺមកពីព្រះមិនមែនមកពីអំណាចផ្ទាល់ខ្លួនរបស់លោកប៉ូលទេ។
គឺព្រះបន្ទូលនេះហើយដែលធ្វើការនៅក្នុងចំណោមអ្នករាល់គ្នា និងក្នុងចំណោមអ្នកជឿដែរ
លោកប៉ូលនិយាយអំពីព្រះរាជសារដំណឹងល្អរបស់ព្រះដូចជាមនុស្សដែលកំពុងធ្វើការដែរ
1 Thessalonians 2:14
បងប្អូន
នេះមានន័យថាគ្រីស្ទានរួមទាំងបុរស និងស្ត្រី។
បានក្លាយជាគំរូរបស់ក្រុមជំនុំ
អ្នកជឿនៅថេស្សាឡូនិកបានស៊ូទ្រាំការបៀតបៀនស្រដៀងនឹងអ្នកជឿរបស់ជនជាតិយូដា
«បានក្លាយដូចជាក្រុមជំនុំ»
ពីបងប្អូនជនរួមជាតិរបស់អ្នករាល់គ្នា
«មកពីថេស្សាឡូនិកផ្សេងទៀត»
ពួកគេបានហាមប្រាមយើងមិនឲ្យប្រកាស
«ពួកគេព្យាយាមធ្វើឲ្យយើងឈប់និយាយ»
ពួកគេបានធ្វើឲ្យបាប ធ្លាក់មកលើពួកគេកាន់តែច្រើន
ប៉ូលនិយាយដូចជាមាននរណាម្នាក់អាចបំពេញធុងដោយអំពើបាបរបស់ពួកគេដូចជាវត្ថុរាវ។
សេចក្តីក្រោធត្រូវតែធ្លាក់មកលើពួកគេនៅទីបញ្ចប់។
នេះសំដៅទៅលើព្រះនៅទីបំផុតវិនិច្ឆ័យ
និងដាក់ទោសមនុស្សចំពោះអំពើបាបរបស់គេ។
1 Thessalonians 2:17
បងប្អូន
[illegible]
ខាងឯសាច់ឈាម ប៉ុន្តែមិនមែនខាងឯចិត្តគំនិតរបស់យើងទេ
[illegible]
គាត់មានអារម្មណ៍ជិតស្និទ្ធនឹងពួកគេ។
ចង់ឃើញមុខអ្នករាល់គ្នា
ទីនេះ «មុខអ្នក» មានន័យថាមនុស្សទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
[illegible]
ខ្ញុំ ប៉ូល ម្តងហើយម្តងទៀត
«ខ្ញុំប៉ូលបានសាកល្បងជាច្រើនដង»
តើអ្វីទៅជាសេចក្តីសង្ឃឹម...ពេលដែលព្រះអង្គយាងត្រឡប់មកវិញ?
ប៉ូលប្រើសំណួរនេះដើម្បីលើកទឹកចិត្តដល់អ្នកជឿ ហើយឆ្លើយវានៅក្នុងខបន្ទាប់។
សំណួរវោហារស័ព្ទនេះអាចត្រូវបានបញ្ជាក់ជាវិជ្ជមាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកគឺជាទំនុកចិត្តរបស់យើងចំពោះអនាគតសេចក្តីអំណរ
និងមកុដនៃសិរីល្អរបស់យើងនៅពេលព្រះអម្ចាស់យេស៊ូគ្រិស្តយាងមក»
សេចក្តីសង្ឃឹមនៃអនាគតរបស់យើង...តើមិនមែនជាអ្នករាល់គ្នាទេឬអី
[illegible] ប៉ូលមានន័យថាការធានាដែលលោកមាន
ថាព្រះនឹងប្រទានរង្វាន់ដល់គាត់សម្រាប់ការងាររបស់គាត់។
គ្រិស្ទានៅក្រុងថេស្សាឡូនិកជាមូលហេតុនៃទំនុកចិត្តរបស់លោក
ឬអំណរ
ថេស្សាឡូនិក គឺជាមូលហេតុនៃអំណររបស់គាត់។
[illegible]
ត្រង់ថា «មកុដ»
សំដៅទៅលើកម្រងផ្កាឡារ៉ាល់ដែលបានប្រគល់ជូនអត្តពលិកដែលឈ្នះ។
ការបង្ហាញអារម្មណ៍ «មកុដនៃមោទនភាព» មានន័យថាជារង្វាន់សំរាប់ជ័យជំនះ
ឬធ្វើបានល្អ។
[illegible]
សំណួរវោហារស័ព្ទនេះអាចត្រូវបានបកប្រែជាសេចក្តីថ្លែងការណ៍។
របៀបផ្សេងទៀតនៃការបកប្រែ: «គឺជាអ្នករាល់គ្នា និងអ្នកជឿផ្សេងទៀត»

---

3 [1]ដូច្នេះហើយ នៅពេលយើងទ្រាំលែងបានទៀត យើងគិតថា គឺជាការល្អ បើយើងចេញទៅក្រុងអាថែន។[2]យើងបានបញ្ជូនធីម៉ូថេ ជាបងប្អូន
និងជាអ្នករួមការងាររបស់យើងសម្រាប់ព្រះជាម្ចាស់ នៅក្នុងដំណឹងល្អរបស់ព្រះគ្រិស្ត ដើម្បីចម្រើនកម្លាំង និងកំសាន្តចិត្តអ្នករាល់គ្នាទាក់ទងនឹងជំនឿរបស់អ្នករាល់គ្នា។
[3]យើងធ្វើការដូច្នេះ ដើម្បីកុំឲ្យនរណាម្នាក់ត្រូវបានបោះបង់ចោលនៅពេលជួបទុក្ខលំបាក។ ដ្បិតបងប្អូនដឹងស្រាប់ហើយថា ព្រះអង្គបានជ្រើសរើសយើងសម្រាប់ការនេះ។
[4]ពិតណាស់ ពេលយើងនៅជាមួយនឹងបងប្អូន យើងបានប្រាប់បងប្អូនជាមុនហើយថា យើងបានរងទុក្ខដោយសេចក្តីស្រឡាញ់
ហើយការនោះបានកើតឡើងដូចអ្នកបានដឹងស្រាប់ហើយ។[5]ដោយហេតុនេះហើយ នៅពេលខ្ញុំឈរលែងបានទៀត ខ្ញុំបានចាត់គាត់មក
ដើម្បីខ្ញុំអាចដឹងពីជំនឿរបស់អ្នករាល់គ្នា។ ប្រហែលជាមេល្បួង ពេលខ្លះបានល្បួងអ្នករាល់គ្នា ហើយការងាររបស់យើងត្រូវបានក្លាយជាឥតប្រយោជន៍។
[6]ប៉ុន្តែ ធីម៉ូថេបានចេញពីអ្នករាល់គ្នា មកឯយើងវិញ ហើយបាននាំដំណឹងល្អនៃជំនឿ ហើយនិងសេចក្តីស្រឡាញ់របស់អ្នករាល់គ្នា។ គាត់បានប្រាប់យើងថា
អ្នករាល់គ្នាបាននឹកចាំពីយើងខ្ញុំជានិច្ច ហើយបងប្អូនលែងបានឃើញយើង ហើយយើងក៏លែងបានឃើញបងប្អូនផងដែរ។[7]បងប្អូនអើយ ដោយហេតុនេះហើយ
យើងបានកំសាន្តចិត្តដោយសារជំនឿរបស់បងប្អូន ពីគ្រប់ទាំងទុក្ខលំបាក និងការរងទុក្ខរបស់យើង។
[8]ដ្បិត យើងរស់នៅ ប្រសិនបើ អ្នកឈរមាំក្នុងព្រះអម្ចាស់។[9]ហើយ តើអ្វីទៅដែលយើងអាចនឹងអរគុណដល់ព្រះជាម្ចាស់សម្រាប់បងប្អូន
គឺគ្រប់ទាំងអំណរដែលយើងមាននៅចំពោះព្រះជាម្ចាស់ពីអ្នករាល់គ្នាវិញ?[10]ទាំងយប់ទាំងថ្ងៃ យើងអធិស្ឋានយ៉ាងខ្លាំងថា យើងអាចជួបមុខបងប្អូន
ហើយអាចផ្តល់អ្វីដែលជាជំនឿសម្រាប់បងប្អូនដែលខ្វះខាត។
[11]សូមព្រះជាម្ចាស់នៃយើង ព្រះបិតាផ្ទាល់ និងព្រះអម្ចាស់យេស៊ូនៃយើងបានដឹកនាំផ្លូវរបស់យើងទៅរកបងប្អូន។[12]សូមព្រះអម្ចាស់ធ្វើឲ្យបងប្អូនបានចម្រើនឡើង
និងមានសេចក្តីស្រឡាញ់ជាបរិបូរដល់គ្នាទៅវិញទៅមក ហើយដល់មនុស្សគ្រប់គ្នាផង ដូចដែលយើងបានធ្វើជាមួយបងប្អូនដែរ។
[13]សូមព្រះអង្គចម្រើនកម្លាំងចិត្តដល់បងប្អូន ដើម្បីឲ្យអ្នករាល់គ្នាក្លាយជាមនុស្សដែលគ្មានកន្លែងបន្ទោសបាន នៅក្នុងដ៏វិសុទ្ធក្នុងព្រះជាម្ចាស់ និងព្រះបិតានៃយើង
នៅពេលព្រះអម្ចាស់យេស៊ូគ្រិស្តយាងត្រឡប់មកវិញជាមួយនឹងពួកដ៏វិសុទ្ធរបស់ព្រះអង្គ។

generated on Wed Sep 10 16:16:32 2025

1 Thessalonians 3:1
ប្រយោគភ្ជាប់
ប៉ូលប្រាប់អ្នកជឿថា គាត់បានចាត់ធីម៉ូថេឲ្យពង្រឹងជំនឿរបស់ពួកគេ។
នៅពេលយើងទ្រាំលែងបានទៀត
«យើងមិនអាចស៊ូទ្រាំនឹងការព្រួយបារម្ភពីអ្នកទៀតទេ»
យើងគិតថា គឺជាការល្អ បើយើងចេញទៅក្រុងអាថែន
«ល្អសម្រាប់ស៊ីលវ៉ាន់ និងខ្ញុំនៅខាងក្រោយក្រុងអាថែន»
ល្អ
«ត្រឹមត្រូវ» ឬ «សមហេតុផល»
ក្រុងអាថែន
នេះគឺជាទីក្រុងមួយនៅខេត្តអាឆៃដែលសព្វថ្ងៃជាប្រទេសក្រិកសម័យទំនើប។
ជាបងប្អូន និងជាអ្នករួមការងាររបស់យើង
ឃ្លាទាំងពីរនេះពិពណ៌នាអំពីធីម៉ូថេ។
ដើម្បីកុំឲ្យនរណាម្នាក់ត្រូវបានបោះបង់ចោល
ដើម្បីត្រូវបាន «រង្គោះរង្គើ» គឺជាសតិអារម្មណ៍សម្រាប់ការភ័យខ្លាច។
របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាម្នាក់នឹងភ័យខ្លាចនៅឆ្ងាយពីការជឿទុកចិត្តលើព្រះគ្រិស្ត»
ព្រះអង្គបានជ្រើសរើសយើងសម្រាប់ការនេះ
ប៉ូលសន្និដ្ឋានមនុស្សគ្រប់គ្នាដឹងថា គឺជាព្រះដែលបានតែងតាំងពួកគេ។
នេះអាចត្រូវបានធ្វើឲ្យច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានតែងតាំងយើង»
1 Thessalonians 3:4
ពិតណាស់
«ច្បាស់ណាស់» ឬ «ប្រាកដណាស់»
រងទុក្ខដោយសេចក្តីស្រឡាញ់
«ត្រូវបានធ្វើបាបដោយអ្នកដទៃ»
ខ្ញុំឈរលែងបានទៀតហើយ
ប៉ូលកំពុងរៀបរាប់អំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ដោយប្រើលេខសម្គាល់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមិនអាចរង់ចាំដោយអត់ធ្មត់បានទេ»
ខ្ញុំបានចាត់
ពាក្យនេះបញ្ជាក់ថា ប៉ូលបានបញ្ជូនធីម៉ូថេ។ នេះអាចត្រូវបានធ្វើឲ្យច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានបញ្ជូនធីម៉ូថេ»
ការងាររបស់យើង
«ការខិតខំរបស់យើងក្នុងចំណោមអ្នក» ឬ
«ការបង្រៀនរបស់យើងក្នុងចំណោមអ្នក»
ឥតប្រយោជន៍
«គ្មានប្រយោជន៍»
1 Thessalonians 3:6
ប្រយោគភ្ជាប់៖
ប៉ូលប្រាប់អ្នកអានរបស់លោកអំពីរបាយការណ៍របស់ធីម៉ូថេបន្ទាប់ពីលោកត្រឡប់មកពី[illegible]
មកឯយើងវិញ
ពាក្យថា «យើង» សំដៅទៅលើប៉ូល និងស៊ីលវ៉ាន់។
ហើយបាននាំដំណឹងល្អនៃជំនឿ
គេយល់ថានេះសំដៅទៅលើជំនឿលើព្រះគ្រិស្ត។ នេះអាចត្រូវបានធ្វើឲ្យច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «របាយការណ៍ល្អនៃជំនឿរបស់អ្នក»
អ្នករាល់គ្នាបាននឹកចាំពីយើងខ្ញុំជានិច្ច
នៅពេលពួកគេគិតអំពីប៉ូលពួកគេតែងតែមានគំនិតល្អអំពីលោក។
បងប្អូនលែងបានឃើញយើង
«អ្នកមានបំណងចង់ឃើញយើង»
បងប្អូន
ត្រង់ថា «បងប្អូន» មានន័យថាគ្រីស្ទាន។
ដោយសារជំនឿរបស់បងប្អូន
នេះសំដៅទៅលើជំនឿលើព្រះគ្រិស្ត។ នេះអាចត្រូវបានធ្វើឲ្យច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយសារជំនឿរបស់អ្នកលើព្រះគ្រិស្ត"
ពីគ្រប់ទាំងទុក្ខលំបាក និងការរងទុក្ខរបស់យើង
ពាក្យថា «ទុក្ខវេទនា» ពន្យល់ពីមូលហេតុដែលពួកគេស្ថិតក្នុង «ទុក្ខព្រួយ» ។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅក្នុងទុក្ខព្រួយទាំងអស់ដែលបណ្តាលមកពីការរងទុក្ខរបស់យើង»
1 Thessalonians 3:8
យើងរស់នៅ
នេះគឺជាសំនួនវោហារស័ព្ទដែលបង្ហាញពីការរស់នៅដែលពេញចិត្ត។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងត្រូវ បានលើកទឹកចិត្តយ៉ាងខ្លាំង»
អ្នកឈរមាំក្នុងព្រះអម្ចាស់
ដើម្បី «ឈរឲ្យរឹងមាំ» គឺជាអត្ថន័យពិសេសដើម្បីបន្តស្មោះត្រង់។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិន បើអ្នកបន្តទុកចិត្តលើព្រះអម្ចាស់»
តើអ្វីទៅដែលយើងអាចនឹងអរគុណដល់ព្រះជាម្ចាស់សម្រាប់បងប្អូន
គឺគ្រប់ទាំងអំណរដែលយើងមាននៅចំពោះព្រះជាម្ចាស់ពីអ្នករាល់គ្នាវិញ?
សំណួរវោហាសាស្ត្រនេះអាចត្រូវបានបង្ហាញជាសេចក្តីថ្លែងការណ៍។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមិនអាចអរគុណដល់ព្រះបានគ្រប់គ្រាន់សម្រាប់អ្វីដែលព្រះអង្គបានធ្វើសម្រាប់អ្នក!
យើងរីករាយណាស់ចំពោះអ្នក នៅពេលដែលយើងអធិស្ឋានដល់ព្រះរបស់យើង!»
នៅចំពោះព្រះជាម្ចាស់
ប៉ូលនិយាយដូចជាលោក និងគូកនរបស់លោកនៅចំពោះមុខព្រះ។
លោកប្រហែលជាសំដៅទៅលើសកម្មភាពនៃការអធិស្ឋាន។
ទាំងយប់ទាំងថ្ងៃ
នៅទីនេះការនិយាយបំផ្លើសត្រូវបានប្រើដើម្បីបង្ហាញពីរបៀបដែលប៉ូលអធិស្ឋានជារឿយៗ។
របៀបផ្សេងទៀតនៃការបកប្រែ: «ញឹកញាប់»
យ៉ាងខ្លាំ
«យ៉ាងក្លៀវក្លា»
ជួបមុខបងប្អូន
ពាក្យថា «មុខ» សំដៅទៅលើមនុស្សទាំងមូលរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «សួរសុខទុក្ខអ្នក»
1 Thessalonians 3:11
ព័ត៌មានទូទៅ៖
នៅក្នុងខទាំងនេះពាក្យ «របស់យើង» មិនសំដៅទៅលើក្រុមមនុស្សតែមួយទេ។
សូមមើលកំណត់ចំណាំការបកប្រែសម្រាប់ព័ត៌មានលំអិត។
ព្រះជាម្ចាស់នៃយើង...ព្រះអម្ចាស់យេស៊ូនៃយើង
ប៉ូលរួមបញ្ចូលអ្នកជឿនៅក្រុងថេស្សាឡូនិក និងក្រុមការងាររបស់លោក។
សូមព្រះជាម្ចាស់នៃយើង
«យើងអធិស្ឋានថាព្រះរបស់យើង»
ដឹកនាំផ្លូវរបស់យើងទៅរកបងប្អូន
ប៉ូលនិយាយដូចជាគាត់ចង់ឲ្យ ព្រះបង្ហាញលោក និងគូកនរបស់លោកអំពីផ្លូវ
ដែលត្រូវធ្វើដំណើរទៅលេងគ្រិស្តបរិស័ទនៅក្រុងថែស្សាឡូនិច។
សូមធ្វើឲ្យយើងមានចិត្តស្រឡាញ់ ចង់អោយព្រះជាម្ចាស់ធ្វើឲ្យពួកគេអាចធ្វើបាន។
ដឹកនាំផ្លូវរបស់យើងទៅរកបងប្អូន
ពាក្យថា «យើង» សំដៅទៅលើប៉ូល ស៊ីលវ៉ាន និងធីម៉ូថេ
តែមិនមែនជាអ្នកជឿនៅក្រុងថេស្សាឡូនិកទេ។
ព្រះបិតាផ្ទាល់
ត្រង់ថា «ខ្លួនគាត់» សំដៅទៅលើ «ព្រះវរបិតា» សម្រាប់ការសង្កត់ធ្ងន់។
បានចម្រើនឡើង និងមានសេចក្តីស្រឡាញ់ជាបរិបូរ
ប៉ូលនិយាយអំពីសេចក្តីស្រឡាញ់ជាវត្ថុមួយដែលមនុស្សម្នាក់អាចទទួលបានច្រើនជាងនេះ។
ចម្រើនកម្លាំងចិត្តដល់បងប្អូន
ប៉ូលសំដៅទៅលើ «ចិត្ត» ជាមជ្ឈមណ្ឌលនៃជំនឿ និងជំនឿរបស់មនុស្សម្នាក់។
នៅពេលព្រះអម្ចាស់យេស៊ូគ្រិស្តយាងត្រឡប់មកវិញ
«នៅពេលដែលព្រះយេស៊ូបានយាងមកផែនដីវិញ»
នឹងពួកដ៏វិសុទ្ធរបស់ព្រះអង្គ
«ជាមួយអស់អ្នកដែលជាកម្មសិទ្ធិរបស់ព្រះអង្គ»

---

4 [1]ជាចុងក្រោយ បងប្អូនអើយ យើងលើកទឹកចិត្ត និងដាស់តឿនដល់បងប្អូននៅក្នុងព្រះអម្ចាស់យេស៊ូគ្រិស្ត។ ដូចដែលបងប្អូនបានទទួលសេចក្តីបង្គាប់ពីយើងរួចហើយ
អំពីរបៀបនៃការដើរយ៉ាងណាឲ្យគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ គឺដើរក្នុងរបៀបនេះឯង ដើម្បីឲ្យអ្នកបានធ្វើការច្រើនថែមទៀត។[2]ដ្បិត បងប្អូនបានដឹងស្រាប់ហើយ
ពីការណែនាំដែលយើងបានផ្តល់ដល់អ្នករាល់គ្នាតាមរយៈព្រះអម្ចាស់យេស៊ូ។

generated on Wed Sep 10 16:16:32 2025

[3]ដ្បិត នេះគឺជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺឲ្យបងប្អូនបានជ្រះស្អាត ដោយចៀសចេញពីការប្រព្រឹត្តខុសសីលធម៌ខាងផ្លូវភេទ[4]ដែលបងប្អូនម្នាក់ៗបានដឹងរួចមកហើយ
ពីរបៀបនៃការគ្រប់គ្រងរូបកាយរបស់ខ្លួន នៅក្នុងភាពដ៏វិសុទ្ធ និងថ្លៃថ្នូរ[5]មិនត្រូវនៅក្នុងតណ្ហាក្រាស់ (ដូចសាសន៍ដទៃដែលមិនស្គាល់ព្រះជាម្ចាស់ឡើយ)។
[6]កុំឲ្យនរណាម្នាក់ធ្វើរំលង និងខុសឆ្គងជាមួយបងប្អូនរបស់ខ្លួននៅក្នុងរឿងនេះឡើយ។ ដ្បិត ព្រះអម្ចាស់នឹងសងសឹកជាមួយនឹងការទាំងអស់នោះ
ដូចដែលយើងបានដាស់តឿនបងប្អូន និងថ្លែងជាមួយបងប្អូនពីមុនរួចហើយ។
[7]ដ្បិត ព្រះជាម្ចាស់មិនបានហៅយើងមកនៅក្នុងភាពមិនស្អាតឡើយ ប៉ុន្តែ នៅក្នុងភាពបរិសុទ្ធវិញ។[8]ដូច្នេះហើយ អ្នកណាដែលបដិសេធការនេះ គឺបដិសេធព្រះជាម្ចាស់
ដែលប្រទានភាពបរិសុទ្ធដល់អ្នក។
[9]ទាក់ទងនឹងសេចក្តីស្រឡាញ់បងប្អូនអើយ អ្នកបានធ្វើហើយ មិនចាំបាច់ឲ្យនរណាសរសេរសំបុត្រមកកាន់បងប្អូនឡើយ
ព្រោះព្រះជាម្ចាស់បានបង្រៀនដល់បងប្អូនដោយផ្ទាល់ឲ្យស្រឡាញ់គ្នាទៅវិញទៅមក។[10]ពិតណាស់ បងប្អូនបានធ្វើការនេះ ជាមួយបងប្អូនគ្រប់គ្នា
ដល់អស់អ្នកដែលនៅស្រុកម៉ាសេដូនទាំងអស់។[11]ប៉ុន្តែ យើងសូមដាស់តឿនដល់បងប្អូន ចង់ឲ្យបងប្អូនរស់នៅជាមួយគ្នាដោយស្ងៀមស្ងាត់ គិតពីការងារខ្លួនឯង
ហើយខំប្រឹងធ្វើការ ដូចដែលយើងបានបង្គាប់ដល់បងប្អូន។[12]ដើម្បីឲ្យបងប្អូនបានដើរត្រឹមត្រូវចំពោះអ្នកនៅខាងក្រៅ និងគ្មានអ្វីដែលខ្វះខាតឡើយ។
[13]បងប្អូនអើយ យើងមិនចង់ឲ្យបងប្អូនយល់ច្រឡំឡើយ អំពីអស់អ្នកដែលដេកលក់ទៅហើយ
ដើម្បីកុំឲ្យអ្នករាល់គ្នាយំសោកដូចមនុស្សដទៃទៀតដែលពួកគេមិនដឹងច្បាស់អំពីអនាគត។[14]ដ្បិត បើយើងជឿថា ព្រះយេស៊ូបានសុគត ហើយរស់ឡើងវិញ ហើយ
ព្រះជាម្ចាស់បាននាំអស់អ្នកដែលបានដេកលក់នៅក្នុងព្រះអង្គឡើងមកវិញដែរ។[15]ដោយហេតុនេះ យើងនិយាយមកកាន់បងប្អូន តាមរយៈព្រះបន្ទូលរបស់ព្រះអម្ចាស់ថា
យើងដែលនៅរស់នៅឡើយ យើងនឹងនៅរហូតទាល់តែព្រះអម្ចាស់យាងត្រឡប់មកវិញ យើងប្រាកដជាមិនឡើងទៅមុនអស់អ្នកដែលបានដេកលក់នោះទេ។
[16]ដ្បិត ព្រះអម្ចាស់ផ្ទាល់នឹងចុះពីស្ថានសួគ៌មក។ ព្រះអង្គនឹងយាងមកជាមួយនឹងសម្រែកមួយ ជាមួយនឹងសម្លេងរបស់មហាទេវតា
និងជាមួយនឹងសម្លេងត្រែរបស់ព្រះជាម្ចាស់ ហើយអ្នកដែលស្លាប់ក្នុងព្រះគ្រិស្ត នឹងរស់ឡើងវិញមុនគេ។[17]បន្ទាប់មកយើងគឺជាអ្នកដែលនៅសល់ ក៏រស់ឡើងវិញដែរ
យើងនឹងឡើងទៅជួបជាមួយគ្នានៅឯពពក។ តាមរបៀបនេះឯង យើងនឹងនៅជាមួយព្រះអម្ចាស់រហូតទៅ។[18]ដូច្នេះហើយ
ចូរកម្សាន្តចិត្តដល់គ្នាទៅវិញទៅមកជាមួយនឹងពាក្យទាំងនេះ។

---

1 Thessalonians 4:1

បងប្អូន

ត្រង់ថា «បងប្អូន» មានន័យថាគ្រីស្ទាន។

យើងលើកទឹកចិត្ត និងដាស់តឿនដល់បងប្អូន

ប៉ូលប្រើពាក្យ «លើកទឹកចិត្ត» និង «ដាស់តឿន»
ដើម្បីបញ្ជាក់ពីរបៀបដែលពួកគេលើកទឹកចិត្តដល់អ្នកជឿ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងលើកទឹកចិត្តអ្នកយ៉ាងខ្លាំង»

បងប្អូនបានទទួលសេចក្តីបង្គាប់ពីយើងរួចហើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបានបង្រៀនអ្នក»

អ្នកត្រូវតែដើរ

នៅទីនេះ «ដើរ» គឺជាការបង្ហាញផ្លូវសំរាប់ការរស់នៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកគួរតែរស់នៅ»

តាមរយៈព្រះអម្ចាស់យេស៊ូ

ប៉ូលនិយាយអំពីការណែនាំរបស់លោកហាក់ដូចជាពួកគេបានត្រូវឲ្យ
ដោយព្រះយេស៊ូផ្ទាល់។

1 Thessalonians 4:3

ដោយចៀសចេញពីការប្រព្រឹត្តខុសសីលធម៌ខាងផ្លូវភេទ

«អ្នកនៅឲ្យឆ្ងាយពីអំពើអសីលធម៌ខាងផ្លូវភេទ»

បានដឹងរួចមកហើយ ពីរបៀបនៃការគ្រប់គ្រង

អាចមានន័យថាទី ១) របៀបរស់នៅជាមួយប្រពន្ធ ឬទី ២)
របៀបរស់នៅដែលលត់ដំខ្លួន ឬទី ៣) របៀបរស់នៅជាមួយកូនស្រីព្រហ្មចារី។

នៅក្នុងតណ្ហាក្រាស់

«ជាមួយនឹងចំណង់ផ្លូវភេទខុស»

កុំឲ្យនរណាម្នាក់

ត្រង់ថា «បុរស» សំដៅទៅលើបុរស ឬស្ត្រី។ «គ្មាននរណាម្នាក់» ឬ
«គ្មាននរណាមនុស្សណា»

ធ្វើរំលង និងខុសឆ្គង

នេះគឺជាការបន្ថែមនូវគំនិតតែមួយតាមពីរវិធី ដើម្បីពង្រឹងគំនិតនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខុស»

ព្រះអម្ចាស់នឹងសងសឹក

នេះអាចត្រូវបានធ្វើឲ្យច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់នឹងដាក់ទោសអ្នកដែលបានធ្វើបាប
ហើយនឹងការពារអស់អ្នកដែលបានធ្វើខុស»

ដែលយើងបានដាស់តឿនបងប្អូន និងថ្លែងជាមួយបងប្អូន

«បានប្រាប់អ្នកជាមុន ហើយព្រមានប្រឆាំង»

1 Thessalonians 4:7

ព្រះជាម្ចាស់មិនបានហៅយើងមកនៅក្នុងភាពមិនស្អាតឡើយ ប៉ុន្តែ នៅក្នុងភាពបរិសុទ្ធវិញ

នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ត្រាស់ហៅយើងអោយមានភាពស្អាតស្អំ និងភាពបរិសុទ្ធ»

ព្រះជាម្ចាស់មិនបានហៅយើង

ពាក្យថា «យើង» សំដៅទៅលើអ្នកជឿទាំងអស់។

អ្នកណាដែលបដិសេធការនេះ

«អ្នកណាមិនគោរពការបង្រៀននេះ» ឬ
«អ្នកណាដែលមិនអើពើនឹងការបង្រៀននេះ»

មិនបដិសេធមនុស្សទេ តែព្រះជាម្ចាស់វិញ

ប៉ូលសង្កត់ធ្ងន់ថា ការបង្រៀននេះមិនមែនមកពីមនុស្សទេតែមកពីព្រះវិញ។

1 Thessalonians 4:9

សេចក្តីស្រឡាញ់បងប្អូន

«ស្រឡាញ់បងប្អូនរួមជំនឿ»

បងប្អូនបានធ្វើការនេះ ជាមួយបងប្អូនគ្រប់គ្នា ដល់អស់អ្នកដែលនៅស្រុកម៉ាសេដូនទាំងអស់

«អ្នកបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកជឿនៅទូទាំងស្រុកម៉ាសេដូន»

បងប្អូន

ត្រង់ថា «បងប្អូន» មានន័យថាគ្រីស្ទាន។

ដើម្បីសេចក្តីប្រាថ្នា

«ដើម្បីព្យាយាម»

រស់នៅដោយស្ងៀមស្ងាត់

ប៉ូលប្រើពាក្យ «ស្ងាត់ៗ»
ជាពាក្យប្រៀបធៀបដើម្បីពិពណ៌នាអំពីការរស់នៅប្រកបដោយសុខសន្តិភាពនៅក្នុងសហគមន៍របស់មនុស
និងមិនបង្កឲ្យមានជម្លោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«រស់នៅដោយស្ងប់ស្ងាត់ និងមានរបៀបរៀបរយ»

គិតពីការងារខ្លួនឯង

សម្គាល់នេះមានន័យថា
ត្រូវយកចិត្តទុកដាក់លើកង្វល់ផ្ទាល់ខ្លួនរបស់អ្នកមិនមែនរបស់អ្នកដទៃទេ។ នៅត្រង់
«បំពេញតាមតំរូវការផ្ទាល់ខ្លួនរបស់អ្នក»

ហើយខំប្រឹងធ្វើការ

នេះជាពាក្យប្រៀបធៀបសម្រាប់ការរស់នៅប្រកបដោយផលិតភាព។
របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើការងារផ្ទាល់ខ្លួន
ដើម្បីរកអ្វីដែលអ្នកត្រូវការដើម្បីរស់នៅ»

ដើរត្រឹមត្រូវ

ការប្រៀបធៀបនេះពិពណ៌នាអំពីវិធីដែលអ្នកជឿគួរទាក់ទងនឹងអ្នកនៅក្នុងសហគមន៍របស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «មានអាកប្បកិរិយាគោរព និងសក្តិសម»

អ្នកដែលនៅខាងក្រៅសេចក្តីជំនឿ

«អ្នកដែលមិនជឿលើព្រះគ្រិស្ត»។ ប៉ូលនិយាយអំពី «ជំនឿ»
ដូចជាប្រសិនបើជាកន្លែងមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ជំនឿ»
សំដៅទៅលើអ្នកដែលជឿជាក់លើព្រះគ្រិស្ត។

1 Thessalonians 4:13

ព័ត៌មានទូរទៅ៖

generated on Wed Sep 10 16:16:32 2025

ប៉ូលនិយាយអំពីអ្នកជឿដែលបានស្លាប់ទៅហើយ ដែលនៅរស់
និងអ្នកដែលនឹងរស់ឡើងវិញ នៅពេលដែលព្រះគ្រិស្តយាងត្រឡប់មកវិញ។
យើងមិនចង់ឲ្យបងប្អូនយល់ច្រឡំឡើយ
គាត់អាចត្រូវបានថ្លែងនៅក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងចង់អោយអ្នកយល់»
បងប្អូន
ត្រង់ថា «បងប្អូន» មានន័យថាគ្រីស្ទាន។
អស់អ្នកដែលដេកលក់
ពាក្យ «ដេក» គឺជា ជាពាក្យប្រើសម្រាប់អ្នកដែលបានស្លាប់។
កុំឲ្យអ្នករាល់គ្នាយំសោក
«អ្នកមិនយំសោក»
ដូចមនុស្សដទៃទៀតដែលពួកគេមិនដឹងច្បាស់អំពីអនាគត
«ដូចជាមនុស្សដែលមិនជឿ»
បើយើងជឿថា
ត្រង់ថា «យើង» សំដៅទៅលើប៉ូល និងអ្នកស្តាប់ របស់លោក។
រស់ឡើងវិញ
«បានរស់ឡើងវិញម្តងទៀត»
អស់អ្នកដែលបានដេកលក់នៅក្នុងព្រះអង្គ
ត្រង់ថា «ដេកលក់» គឺជាវិធីគួរសមដើម្បីយោងទៅលើការស្លាប់។
នៅរហូតទាល់តែព្រះអម្ចាស់យាងត្រឡប់មកវិញ
«នៅថ្ងៃនៃការយាងត្រឡប់មកវិញរបស់ព្រះគ្រិស្ត»
យើងប្រាកដជាមិនឡើងទៅមុន
«ច្បាស់ជាមិនទៅមុនទេ»
1 Thessalonians 4:16
ព្រះអម្ចាស់ផ្ទាល់នឹងចុះ
«ព្រះអម្ចាស់ផ្ទាល់នឹងយាងចុះមក»
មហាទេវតា
«មេទេវតា»
ហើយអ្នកដែលស្លាប់ក្នុងព្រះគ្រិស្ត នឹងរស់ឡើងវិញមុនគេ
«មនុស្សស្លាប់ក្នុងព្រះគ្រិស្ត» គឺជាអ្នកជឿទាំងនោះដែលបានចែកឋានទៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «អស់អ្នកដែលជឿលើព្រះយេស៊ូគ្រិស្ត
ប៉ុន្តែអ្នកដែលបានស្លាប់ទៅហើយនឹងរស់ឡើងវិញមុនគេ»
យើងគឺជាអ្នកដែលនៅសល់
ត្រង់ថា «យើង» សំដៅទៅលើអ្នកជឿទាំងអស់ដែលមិនបានស្លាប់។
ជាមួយគ្នា
ពាក្យ «ពួកគេ»
សំដៅទៅលើអ្នកជឿដែលបានស្លាប់ដែលនឹងរស់ឡើងវិញម្តងទៀត។
យើងនឹងឡើងទៅជួបព្រះអម្ចាស់នៅលើអាកាសនៅឯពពក
«ជួបជាមួយព្រះអម្ចាស់យេស៊ូនៅលើមេឃ»

---

5 [1]ឥឡូវនេះ ទាក់ទងនឹងពេលវេលា និងពេលកំណត់នោះ បងប្អូនអើយ អ្នកមិនចាំបាច់ត្រូវការសំបុត្រអ្វីពីនរណា មកអ្នករាល់គ្នាទៀតឡើយ។[2]ដ្បិត
អ្នករាល់គ្នាបានដឹងយ៉ាងច្បាស់ហើយថា ថ្ងៃរបស់ព្រះអម្ចាស់នឹងមកដល់ដូចជាចោរនៅពេលយប់។[3]នៅពេលដែលពួកគេនិយាយពី «សន្តិភាព និងសុវត្ថិភាព» ដូច្នេះ
មហន្តរាយនឹងធ្លាក់មកលើពួកគេដែរ។ វាប្រៀបដូចជាការឈឺពោះរបស់ស្រីមានផ្ទៃពោះនៅពេលសម្រាលកូន។ ពួកគេគ្មានផ្លូវអាចគេចវេសបានទេ។
[4]ប៉ុន្តែ ឯបងប្អូនវិញ គឺមិនស្ថិតនៅក្នុងទីងងឹតទេ ដូច្នេះ ថ្ងៃនោះមិនអាចយកឈ្នះអ្នករាល់គ្នាដូចជាចោរឡើយ។[5]ដ្បិតអ្នករាល់គ្នាគឺជាបុត្រនៃពន្លឺ
ហើយក៏ជាបុត្រនៃពេលថ្ងៃដែរ។ យើងមិនមែនជាបុត្រនៃពេលយប់ ឬងងឹតនោះទេ។[6]ដូច្នេះ យើងមិនត្រូវគេងលក់ដូចមនុស្សផ្សេងទៀតដែរ។ ផ្ទុយទៅវិញ ចូរយើងចាំយាម
ហើយមានចិត្តម៉ឺងម៉ាត់។[7]ដ្បិតអស់អ្នកដែលគេងលក់ គេគេងលក់នៅពេលយប់មែន ហើយអស់អ្នកដែលស្រវឹងក៏គេស្រវឹងនៅពេលយប់ដែរ។
[8]ប៉ុន្តែ ដោយព្រោះយើងជាកម្មសិទ្ធិនៃពន្លឺ យើងត្រូវតែរក្សាចិត្តម៉ឺងម៉ាត់ ហើយបំពាក់ជំនឿ និងសេចក្តីស្រឡាញ់ទុកដូចជាប្រដាប់បាំងដើមទ្រូង
ហើយពាក់មួកនៃសេចក្តីសង្គ្រោះសម្រាប់អនាគតរបស់យើង។[9]ដ្បិត ព្រះជាម្ចាស់មិនបានតម្រូវយើងសម្រាប់សេចក្តីក្រោធឡើយ ប៉ុន្តែ
ដើម្បីទទួលសេចក្តីសង្គ្រោះតាមរយៈព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើងវិញ។[10]គឺព្រះអង្គហើយដែលសុគតសម្រាប់យើង ទោះបើ យើងដេកលក់ ឬភ្ញាក់ឡើងក្តី
យើងអាចរស់នៅជាមួយព្រះអង្គ។[11]ដូច្នេះហើយ ចូរកម្លាចិត្តគ្នាទៅវិញទៅមក ហើយស្អាងគ្នាទៅវិញទៅមក ដូចដែលខ្ញុំធ្លាប់បានធ្វើរួចមកហើយ។
[12]បងប្អូនអើយ យើងសូមឲ្យអ្នករាល់គ្នា ទទួលស្គាល់ ថាតើអ្នកណាបានធ្វើការនៅក្នុងចំណោមបងប្អូន ហើយអ្នកណាដែលមើលថែបងប្អូននៅក្នុងព្រះអម្ចាស់
ហើយអ្នកណាគ្រប់គ្រងបងប្អូន។[13]យើងក៏សូមបងប្អូនផងដែរ ទាក់ទងនឹងពួកអ្នកដែលមានសេចក្តីស្រឡាញ់ដ៏លើសលប់ ដោយព្រោះការងាររបស់ពួកគេ។
ចូររស់នៅជាមួយគ្នាដោយសុខសាន្ត។[14]យើងដាស់តឿនអ្នករាល់គ្នា បងប្អូនអើយ ចូរដាស់តឿនពួកអ្នកដែលគ្មានរបៀបរៀបរយ លើកទឹកចិត្តដល់អ្នកដែលបាក់ទឹកចិត្ត
ជួយអ្នកដែលទន់ខ្សោយ ចូរអត់ធ្មត់ចំពោះមនុស្សគ្រប់គ្នា។
[15]ចូរប្រយ័ត្ន កុំឲ្យនរណាសងការអាក្រក់ចំពោះការអាក្រក់ដល់នរណាម្នាក់ឡើយ។ ផ្ទុយទៅវិញ ចូរដេញតាមអ្វីដែលល្អសម្រាប់គ្នាទៅវិញទៅមក
ហើយសម្រាប់មនុស្សគ្រប់គ្នាដែរ។[16]ចូរមានអំណរជានិច្ច។[17]ចូរអធិស្ឋានឥតឈប់ឈរ។[18]ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់។
ដ្បិតនេះគឺជាព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រិស្តយេស៊ូសម្រាប់អ្នក។
[19]កុំពន្លត់ព្រះវិញ្ញាណឡើយ។[20]កុំមើលងាយទំនាយឡើយ។[21]ចូរល្បងលគ្រប់ការទាំងអស់។ ចូរប្រកាន់ភ្ជាប់អ្វីដែលល្អ។[22]ចូរចៀសវាងការអាក្រក់គ្រប់យ៉ាង។
[23]សូមព្រះនៃសេចក្តីសុខសាន្ត បានធ្វើឲ្យអ្នករាល់គ្នាបានបរិសុទ្ធទាំងស្រុង។ សូមការពារវិញ្ញាណ ព្រលឹង និងរូបកាយរបស់អ្នករាល់គ្នាកុំឲ្យមានកន្លែងបន្ទោសបាន
សម្រាប់ការយាងមករបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង។[24]ចូរមានជំនឿទៅលើព្រះអង្គដែលបានត្រាស់ហៅយើង ព្រះអង្គនិងធ្វើកិច្ចការនេះ។
[25]បងប្អូនអើយ សូមអធិស្ឋានឲ្យយើងខ្ញុំផង។[26]សូមសួរសុខទុក្ខដល់បងប្អូនទាំងអស់ដែលនៅជាមួយបងប្អូនដោយការថើបដ៏វិសុទ្ធ។
[27]ខ្ញុំសូមបងប្អូនក្នុងព្រះនាមព្រះអម្ចាស់ថានេះគឺជាសំបុត្រដែលត្រូវអានទៅកាន់បងប្អូនទាំងអស់គ្នា។
[28]សូមព្រះគុណនៃព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើងគង់ជាមួយបងប្អូនទាំងអស់គ្នា។

---

1 Thessalonians 5:1
ប្រយោគភ្ជាប់៖
ប៉ូលបន្តនិយាយអំពីថ្ងៃដែលលោកយេស៊ូនឹងត្រឡប់មកវិញ។
ព័ត៌មានទូទៅ
ក្នុងជំពូកនេះពាក្យ «យើង» និង «ពួកយើង» យោងទៅប៉ូល ស៊ីលវ៉ាន និងធីម៉ូថេ
លើកលែងតែមានការកត់សម្គាល់ផ្សេង។ ដូចគ្នានេះផងដែរពាក្យ «អ្នក»
គឺពហុវចន: ហើយសំដៅទៅលើអ្នកជឿនៅឯក្រុមជំនុំនៃថេស្សាឡូនិក។
ទាក់ទងនឹងពេលវេលា និងពេលកំណត់នោះ
នេះសំដៅទៅលើព្រឹត្តិការណ៍ដែលកើតឡើងនៅមុនព្រះអម្ចាស់យេស៊ូត្រឡប់មកវិញ។
បងប្អូន
ត្រង់ថា «បងប្អូន» មានន័យថាគ្រីស្ទាន។
ដឹងយ៉ាងច្បាស់ហើយថា
«ល្អណាស់» ឬ «ត្រឹមត្រូវ» (UDB)
ដូចជាចោរនៅពេលយប់
ដូចជាមនុស្សម្នាក់មិនដឹងថាយប់ណាដែលចោរអាចនឹងមកយើងមិនដឹងថា
ថ្ងៃនៃព្រះអម្ចាស់នឹងមកដល់ទេ។ ការបកប្រែផ្សេងទៀត «មិនបានរំពឹងទុក»
នៅពេលដែលពួកគេនិយាយ
«នៅពេលដែលប្រជាជននិយាយ»
មហន្តរាយនឹងធ្លាក់មក
«បន្ទាប់មកការបំផ្លាញដែលមិនបានរំពឹងទុក»
ប្រៀបដូចជាការឈឺពោះរបស់ស្ត្រីដែលមានផ្ទៃពោះនៅពេលសម្រាលកូន
ដូចជាការឈឺពោះរបស់ស្ត្រីមានផ្ទៃពោះកើតឡើងភ្លាមៗហើយមិនឈប់រហូតដល់ពេលសំរាលកូនបានចប់
ហើយមនុស្សនឹងមិនរត់គេចខ្លួនឡើយ។
1 Thessalonians 5:4
ឯបងប្អូនវិញ
ត្រង់ថា «បងប្អូន» មានន័យថាគ្រីស្ទាន។
គឺមិនស្ថិតនៅក្នុងទីងងឹតទេ
ប៉ូលនិយាយអំពីការអាក្រក់

generated on Wed Sep 10 16:16:32 2025

និងភាពល្ងង់ខ្លៅដែលមិនស្គាល់អំពីព្រះដូចជាពួកគេងងឹត។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមិនដឹងទេដូចជាមនុស្សដែលរស់នៅក្នុងទីងងឹត»
ដូច្នេះ ថ្ងៃនោះមិនអាចយកឈ្នះអ្នករាល់គ្នាដូចជាចោរឡើយ
ថ្ងៃដែលព្រះអម្ចាស់យាងមកមិនគួរអោយភ្ញាក់ផ្អើលដល់អ្នកជឿទេ។
ដ្បិតអ្នករាល់គ្នាគឺជាបុត្រនៃពន្លឺ ហើយក៏ជាបុត្រនៃពេលថ្ងៃដែរ
ប៉ូលនិយាយអំពីការពិតដូចជាពន្លឺនិងថ្ងៃ។ របៀបផ្សេងទៀតនៃការបកប្រែ:
«សម្រាប់អ្នកដឹងពីការពិតដូចជាមនុស្សដែលរស់នៅក្នុងពន្លឺដូចជាមនុស្សពេលថ្ងៃ»
យើងមិនមែនជាបុត្រនៃពេលយប់ ឬងងឹតនោះទេ
ប៉ូលនិយាយអំពីប៉ូលនិយាយអំពីអំពើអាក្រក់
និងភាពល្ងង់ខ្លៅអំពីព្រះដូចជាពួកគេងងឹត។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងមិនដឹងទេដូចជាមនុស្សដែលរស់នៅក្នុងភាពងងឹតដូចជាមនុស្សនៅពេលយប់ដែរ»
យើងមិនត្រូវគេងលក់ដូចមនុស្ស
ប៉ូលនិយាយអំពីការមិនដឹងខ្លួនខាងវិញ្ញាណដូចជាកំពុងដេកលក់។
របៀបផ្សេងទៀតនៃការបកប្រែ:
«កុំអោយយើងធ្វើដូចអ្នកដទៃដែលមិនដឹងថាព្រះយេស៊ូនឹងយាងត្រឡប់មកវិញ»
ចូរយើង
ពាក្យថា «យើង» សំដៅទៅលើអ្នកជឿទាំងអស់។
ចាំយាម ហើយមានចិត្តម៉ឺងម៉ាត់
ប៉ូលពិពណ៌នាអំពីការយល់ដឹងខាងវិញ្ញាណថា ផ្ទុយពីការគេងនិងការស្រវឹង។
ដ្បិតអស់អ្នកដែលគេងលក់ គេគេងលក់នៅពេលយប់មែន
ដូចជានៅពេលដែលមនុស្សដេកលក់ ហើយមិនដឹងថាមានអ្វីកើតឡើង
ដូច្នេះប្រជាជននៅពិភពលោកនេះមិនដឹងថាព្រះគ្រិស្តនឹងយាងមកវិញទេ។
ហើយអស់អ្នកដែលស្រវឹងក៏គេស្រវឹងនៅពេលយប់ដែរ
ប៉ូលបានបញ្ជាក់ថានៅពេលយប់នៅពេលមនុស្សស្រវឹងដូច្នេះនៅពេលមនុស្សមិនដឹងពីអ្វីដែលកំពុងកើតឡើង
1 Thessalonians 5:8
ព័ត៌មានទូទៅ៖
នៅក្នុងខ ៨-១០ ពាក្យថា «យើង» សំដៅទៅលើអ្នកជឿទាំងអស់។
ដោយព្រោះយើងជាកម្មសិទ្ធិនៃពន្លឺ
ប៉ូលនិយាយអំពីការដឹងការពិតអំពីព្រះដែលជាកម្មសិទ្ធិនៃពន្លឺថ្ងៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងដឹងការពិត» ឬ
«យើងបានទទួលពន្លឺនៃសេចក្តីពិត»
យើងត្រូវតែរក្សាចិត្តម៉ឺងម៉ាត់
ប៉ូលប្រៀបធៀបការប្រៀបធៀបទៅនឹងការចេះទប់ចិត្ត។
របៀបផ្សេងទៀតនៃការបកប្រែ: «ចូរយើងចេះទប់ចិត្ត»
ហើយបំពាក់ជំនឿ និងសេចក្តីស្រឡាញ់ទុកដូចជាប្រដាប់បាំងដើមទ្រូង
ក្នុងនាមជាទាហានម្នាក់ដែលពាក់ក្រវិល ដើម្បីការពារខ្លួនរបស់គាត់អ្នកជឿ
ដែលរស់នៅដោយជំនឿនិងសេចក្តីស្រឡាញ់នឹងទទួលបានការការពារ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ការពារខ្លួនយើងដោយជំនឿនិងសេចក្តីស្រឡាញ់» ឬ
«ការពារខ្លួនយើងដោយការជឿទុកចិត្តលើព្រះគ្រិស្តនិងស្រឡាញ់គាត់»
ហើយពាក់មួកនៃសេចក្តីសង្គ្រោះសម្រាប់អនាគតរបស់យើង
ដូចជាមួកការពារក្បាលរបស់ទាហានការធានានៃការសង្គ្រោះការពារអ្នកជឿ។
នៅត្រង់ «ការពារខ្លួនយើងដោយដឹងថាព្រះគ្រិស្តនឹងសង្គ្រោះយើង»
ទោះបើ យើងដេកលក់ ឬភ្ញាក់ឡើងក្តី
ទាំងនេះជាវិធីគួរសមក្នុងការនិយាយទាំងរស់ ឬស្លាប់។ នៅត្រង់
«ទោះយើងរស់រឺក៏ស្លាប់»
ចូរកម្លាចិត្តគ្នាទៅវិញទៅមក
នៅទីនេះ «សាងសង់» គឺជាពាក្យប្រៀបធៀបដែលមានន័យថាលើកទឹកចិត្ត។
របៀបផ្សេងទៀតនៃការបកប្រែ: «លើកទឹកចិត្តគ្នាទៅវិញទៅមក»
1 Thessalonians 5:12
ព័ត៌មានទូទៅ៖
ប៉ូលចាប់ផ្តើមផ្តល់ការណែនាំចុងក្រោយដល់ក្រុមជំនុំនៅក្រុងថេស្សាឡូនិក។
បងប្អូន
ត្រង់ថា «បងប្អូន» មានន័យថាបងប្អូនរួមជំនឿ។
ទទួលស្គាល់ ថាតើអ្នកណាបានធ្វើការ
«គោរពនិងកោតសរសើរចំពោះអ្នកដែលចូលរួមក្នុងការដឹកនាំ»
ហើយអ្នកណាដែលមើលថែបងប្អូននៅក្នុងព្រះអម្ចាស់
នេះសំដៅទៅលើមនុស្សដែលព្រះបានតែងតាំងឲ្យធ្វើជាអ្នកដឹកនាំក្រុមអ្នកជឿក្នុងស្រុក។
អ្នកដែលមានសេចក្តីស្រឡាញ់ដ៏លើសលប់ ដោយព្រោះការងាររបស់ពួកគេ
ប៉ូលដាស់តឿនអ្នកជឿឲ្យស្រឡាញ់ និងគោរពអ្នកដឹកនាំសាសនារបស់ពួកគេ។
1 Thessalonians 5:15
ចូរមានអំណរជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់
ប៉ូលកំពុងដាស់តឿនពួកអ្នកជឿឲ្យ
រក្សាអាកប្បកិរិយាខាងវិញ្ញាណនៃការអរសប្បាយក្នុងគ្រប់ការទាំងអស់ត្រូវឧស្សាហ៍អធិស្ឋាន
និងបង្ហាញការដឹងគុណក្នុងគ្រប់ការទាំងអស់។
គ្រប់ការទាំងអស់
ក្នុងគ្រប់កាល:ទេស:
ដ្បិតនេះគឺជាព្រះហឫទ័យរបស់ព្រះជាម្ចាស់
ប៉ូលកំពុងសំដៅទៅលើអាកប្បកិរិយាដែលគាត់ទើបតែបានលើកឡើងថា
ជាឆន្ទៈរបស់ព្រះសម្រាប់អ្នកជឿ។
1 Thessalonians 5:19
កុំពន្លត់ព្រះវិញ្ញាណឡើយ
«កុំបញ្ឈប់ព្រះវិញ្ញាណបរិសុទ្ធពីការធ្វើការនៅក្នុងចំណោមអ្នក»
កុំមើលងាយទំនាយឡើយ
«កុំមើលងាយចំពោះការព្យាករណ៍» ឬ
«កុំ[illegible]
ចូរល្បងលគ្រប់ការទាំងអស់
«ត្រូវប្រាកដថាសារទាំងអស់ ហាក់ដូចជាមកពីព្រះពិតប្រាកដមែន»
ចូរប្រកាន់ភ្ជាប់អ្វីដែលល្អ
ប៉ូលនិយាយអំពីសារដែលមកពីព្រះវិញ្ញាណបរិសុទ្ធហាក់ដូចជាពួកគេជាវត្ថុដែលមនុស្សម្នាក់អាចចាប់បាន
1 Thessalonians 5:23
បានធ្វើឲ្យអ្នករាល់គ្នាបានបរិសុទ្ធទាំងស្រុង
នេះសំដៅទៅលើព្រះដែលធ្វើអោយមនុស្សម្នាក់គ្មានបាប
និងល្អឥតខ្ចោះនៅចំពោះមុខទ្រង់។
សូមការពារវិញ្ញាណ ព្រលឹង និងរូបកាយ
នេះគឺជាភាពស្របគ្នាដែលពាក្យ «ស្មារតី» «ព្រលឹង» និង «រាងកាយ»
មានអត្ថន័យស្រដៀងគ្នា និងត្រូវបានប្រើសម្រាប់ការសង្កត់ធ្ងន់។
កុំឲ្យមានកន្លែងបន្ទោស
«ត្រូវបានរក្សាទុកពីអំពើបាបរហូតដល់»
ចូរមានជំនឿទៅលើព្រះអង្គដែលបានត្រាស់ហៅយើង
«ព្រះអង្គស្មោះត្រង់ដែលហៅអ្នក»
ព្រះអង្គនឹងធ្វើកិច្ចការនេះ
«ព្រះអង្គនឹងជួយអ្នក»
1 Thessalonians 5:25
ព័ត៌មានទូទៅ៖
ប៉ូលថ្លែងសុន្ទរកថាបិទ។
បងប្អូន
ត្រង់ថា «បងប្អូន» មានន័យថាគ្រិស្តបរិស័ទ។
ខ្ញុំសូមបងប្អូនក្នុងព្រះនាមព្រះអម្ចាស់
«ខ្ញុំសួរអ្នក ប្រសិនបើព្រះអម្ចាស់កំពុងនិយាយជាមួយអ្នក»
នេះគឺជាសំបុត្រដែលត្រូវអាន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទាំងអស់នេះជាសំបុត្រដែលអ្នកត្រូវអាន»

---

២ ថេស្សាឡូនិក

1 [1]ខ្ញុំ ប៉ូល និងលោកស៊ីវ៉ាន ហើយនិងលោកធីម៉ូថេ ជូនចំពោះក្រុមជំនុំថេស្សាឡូនិក នៅក្នុងព្រះបិតា និងព្រះអម្ចាស់យេស៊ូគ្រិស្ត។
[2]សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ជាព្រះបិតានៃយើង និងព្រះអម្ចាស់យេស៊ូគ្រិស្ត។
[3]បងប្អូនអើយ យើងត្រូវអរព្រះគុណដល់ព្រះជាម្ចាស់ជានិច្ចសម្រាប់អ្នករាល់គ្នា។ ដ្បិត ការកោតសរសើរនេះ ដោយសារជំនឿរបស់អ្នកមានការរីកចម្រើនយ៉ាងខ្លាំង
ហើយការស្រឡាញ់គ្នាទៅវិញទៅមករបស់អ្នករាល់គ្នាបានចម្រើនជាបរិបូរដែរ។[4]ដូច្នេះ យើងខ្លួនឯងក៏និយាយដោយមោទនភាពអំពីការអត់ធ្មត់

generated on Wed Sep 10 16:16:32 2025

និងជំនឿនៅក្នុងគ្រប់ទាំងការរបៀតបៀនរបស់អ្នករាល់គ្នា។[5]យើងបាននិយាយអំពីទុក្ខលំបាកដែលអ្នកបានទ្រាំទ្រ។
នេះគឺជាសញ្ញានៃការវិនិច្ឆ័យដ៏សុចរិតរបស់ព្រះជាម្ចាស់។ ជាលទ្ធផលដែលរាប់ថាអ្នកស័ក្តសមនឹងព្រះរាជ្យរបស់ព្រះជាម្ចាស់ ដោយព្រះការណីចាប់របស់អ្នករាល់គ្នា។
[6]វាគឺជាសេចក្តីសុចរិតសម្រាប់ព្រះជាម្ចាស់ក្នុងការដែលព្រះអង្គបង្វែរទុក្ខវេទនាដល់អស់អ្នកដែលធ្វើទុក្ខដល់យើងវិញ[7]ហើយអ្នកបានសម្រាកជាមួយអស់អ្នកដែលរងទុក្ខជាមួយយើងដែរ។
ព្រះអង្គនឹងធ្វើការនេះ នៅពេលដែលព្រះអម្ចាស់យេស៊ូយាងត្រឡប់ពីស្ថានសួគ៌មកវិញ ជាមួយពួកទេវតាដែលមានអំណាចរបស់ព្រះអង្គ។[8]នៅក្នុងអណ្តាតភ្លើង
ព្រះអង្គសងសឹកលើអស់អ្នកដែលមិនស្គាល់ព្រះជាម្ចាស់ ហើយលើអស់អ្នកដែលមិនឆ្លើយតបចំពោះដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូនៃយើង។
[9]ពួកគេនឹងរងទុក្ខទោសនៃការបំផ្លាញដ៏នៅអស់កល្បជានិច្ច នៅឆ្ងាយពីព្រះវត្តមានរបស់ព្រះជាម្ចាស់ និងពីសិរីល្អដ៏មានចេស្តារបស់ព្រះអង្គ។[10]ព្រះអង្គនឹងធ្វើការនេះ
នៅពេលដែលព្រះអង្គយាងមកនៅថ្ងៃនោះ បានទទួលសិរីល្អដោយសារប្រជារាស្ត្ររបស់ព្រះអង្គ និងទទួលការស្ងើចសរសើរយ៉ាងខ្លាំងពីអ្នកដែលជឿព្រះអង្គទាំងអស់។
ដ្បិត អ្នករាល់គ្នាបានជឿពីបន្ទាល់របស់យើងរួចមកហើយ។
[11]ដោយហេតុនេះហើយ យើងក៏បន្តអធិស្ឋានឲ្យអ្នករាល់គ្នាផងដែរ។ យើងអធិស្ឋានថា ព្រះជាម្ចាស់របស់យើង រាប់អ្នកថា ស័ក្តសមនឹងការត្រាស់ហៅរបស់ព្រះអង្គ។
យើងអធិស្ឋានថា ព្រះអង្គនឹងបំពេញគ្រប់ទាំងចិត្តប៉ងប្រាថ្នានៃការធ្វើការល្អ និងគ្រប់ទាំងការល្អនៃជំនឿជាមួយនឹងអំណាចដែរ។[12]យើងអធិស្ឋានការទាំងនេះ
ដើម្បីឲ្យព្រះនាមរបស់ព្រះអម្ចាស់យេស៊ូនៃយើងបានទទួលសិរីល្អដោយសារអ្នករាល់គ្នា។ យើងអធិស្ឋានថា អ្នកនឹងថ្វាយសិរីល្អដល់ព្រះអង្គ
ដោយព្រោះព្រះគុណរបស់ព្រះជាម្ចាស់នៃយើង និងព្រះអម្ចាស់យេស៊ូគ្រិស្ត។

---

2 Thessalonians 1:1

ព័តមានទូទៅ:

សំបុត្រនេះត្រូវបានសរសេរឡើងដោយលោកប៉ូល ប៉ុន្តែលោកបានបញ្ជូន
លោកស៊ីលវ៉ាន និងលោក ធីម៉ូថេជាអ្នកនាំសារ។
គាត់ត្រូវបានចាប់ផ្តើមដោយការទទួលស្វាគមន៍នៅក្រុងថេស្សាឡូនិក ។

ព័តមានទូទៅ

ពាក្យថា «យើង» ហើយនឹង «ពួកយើង» គឺប្រើទៅកាន់លោកលោកប៉ូល ស៊ីលវ៉ាន
និងលោក ធីម៉ូថេ លុះត្រាតែតែមានការបញ្ជាក់ បើមិនដូចច្នេះពាក្យ «អ្នក»
ពហុវចន: គឺសំដៅទៅលើ ពួកអ្នកជឿក្នុងក្រុមជំនុំនៅក្រុងថេស្សឡូនិក

លោក ស៊ីលវ៉ាន

នេះគឺជាទម្រង់ឈ្មោះជាភាសាឡាតាំង នៃ «ស៊ីឡាស» គាត់គឺជាមនុស្សដដែល
ដែលមានឈ្មោះនៅក្នុងសៀវភៅ កិច្ចការ ក្នុងនាមជាអ្នក
ដែលដើតាមលោកប៉ូលនៅក្នុងដំណើររបស់គាត់។

សូមឱ្យព្រះគុណបានមានដល់អ្នក

ជាទូទៅលោកប៉ូលបានតែងតែប្រើការស្វាគមន៍បែបនេះនៅក្នុងសំបុត្ររបស់គាត់។

2 Thessalonians 1:3

ព័តមានទូទៅ៖

លោកប៉ូលបានធ្វើការថ្លែងអំណរគុណ ដល់ក្រុមអ្នកជឿនៅក្រុងថេស្សាឡូនិក។

ត្រូវតែអព្រះគុណដល់ព្រះជាម្ចាស់ជានិច្ច

លោកប៉ូលបាននិយាយដូច្នេះគាត់គួរតែធ្វើការអព្រះគុណដល់ព្រះជាម្ចាស់ជារឿយៗ។
ការបកប្រែរបៀបផ្សេងទៀត: ត្រូវតែអព្រះគុណដល់ព្រះជាម្ចាស់ជាញឹកញាប់(
សូមមើល:figs-hyperbole)

បងប្អូន

ត្រង់នេះពាក្យ «បងប្អូន» ដែលមានន័យថា បងប្អូនរួមជំនឿ
ដែលរួមបញ្ចូលទាំងបុរស និងស្ត្រី ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនប្រុស និង
បងប្អូនស្រី»

ដ្បិតនេះគឺការជាដែលសមរម្យ

«ដ្បិតវាគឺជារឿងត្រឹមត្រូវដែលត្រូវធ្វើ» ឬក៏ «ដ្បិតវាគឺជាការល្អ»

អ្នករាល់គ្នាមានសេចក្តីស្រលាញ់យ៉ាងច្រើនចំពោះគ្នាទៅវិញទៅមក

«អ្នកបានស្រលាញ់គ្នាយ៉ាងស្មោះទៅវិញទៅមក»

មួយផ្សេងទៀត

ត្រង់នេះពាក្យ «មួយផ្សេងទៀត» មានន័យថា បងប្អូនរួមជំនឿ។

ពួកយើង ខ្លួនយើង

ត្រង់នេះពាក្យ «ខ្លួនយើង» លោកប៉ូលបានប្រើដើម្បីសង្កត់បញ្ជាក់អំពីការអួតអាង។

ពិចារណាថាអ្នកនឹងក្លាយជាព្រះរាជាណាចក្សរបស់ព្រះជាម្ចាស់

វាអាចត្រូវបានថ្លែងនៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នោះព្រះជាម្ចាស់នឹងពិចារណាក្នុងការធ្វើឱ្យអ្នកជាផ្នែកមួយនៃព្រះរាជាណាចក្សរបស់ទ្រង់»

2 Thessalonians 1:6

ប្រយោគភ្ជាប់:

ដូចលោកប៉ូលតែងតែបន្តរ និយាយ ពីភាពសុចរិករបស់ព្រះជាម្ចាស់

វាគឺជាសេចក្តីសុចរិតសម្រាប់ព្រះជាម្ចាស់

«ព្រះជាម្ចាស់គឺត្រឹមត្រូវ» ឬក៏ «ព្រះជាម្ចាស់គឺសុចរិត»

ហើយកាសង្គ្រោះមានដល់អ្នក

អ្នកអាចកំណត់វាបានជាលាក់ថាគឺមានតែព្រះជាម្ចាស់តែមួយដែលបានត្រលប់វាឱ្យទៅជាធូស្បើយ។
ការបកប្រែរបៀបផ្សេងទៀត: «ហើយដ្បិតព្រះជាម្ចាស់ និងត្រលប់វាទៅជា
ភាពធូស្បើយដល់អ្នក»

ទេវតាដែលមានអំណាចរបស់ព្រះអង្គ

«ព្រះជាម្ចាស់គឺជាទេវតាដែលមានអំណាច»

នៅក្នុងអណ្តាតភ្លើង ព្រះអង្គសងសឹកលើអស់អ្នកដែលមិនស្គាល់ព្រះជាម្ចាស់

«ព្រះអង្គនិងវាយប្រដៅដោយអណ្តាតភ្លើងដល់អ្នកណាដែលមិនស្គាល់ព្រះជាម្ចាស់
ហើយដល់អ្នកណាដែល» ឬក៏ «បន្ទាប់មកជាមួយអណ្តាតភ្លើង
គឺព្រះអង្គនិងវាយប្រដៅដល់អ្នកណាដែលមិនស្គាល់ព្រះជាម្ចាស់
និងអ្នកណាដែល»

2 Thessalonians 1:9

ពួកគេនឹងរងទុក្ខទោស

ត្រង់នេះពាក្យ «ពួកគេ»
សំដៅទៅលើដល់អស់អ្នកណាដែលមិនស្តាប់បង្គាប់តាមព្រះបន្ទូល។

នៅពេលដែលព្រះអង្គយាងមកនៅថ្ងៃនោះ

ត្រង់នេះពាក្យ «ថ្ងៃនោះ» គឺជាថ្ងៃដែលព្រះយេស៊ូយាងត្រលប់មកផែនដីវិញ។

បានទទួលសិរីល្អដោយសារប្រជារាស្ត្ររបស់ព្រះអង្គ

គឺវាអាចថ្លែងបាននៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រជារាស្ត្ររបស់ព្រះអង្គនិងថ្វាយសិរីល្អដល់ទ្រង់»

ទទួលការស្ងើចសរសើរយ៉ាងខ្លាំងពីអ្នកដែលជឿព្រះអង្គទាំងអស់

គឺវាអាចចាប់ផ្តើមនៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អស់អ្នកណាដែលជឿនិងឈរទាំងស្ងប់ស្ងែងដល់ទ្រង់»

2 Thessalonians 1:11

យើងក៏បន្តអធិស្ឋានឲ្យអ្នករាល់គ្នាផងដែរ។

ជាញឹកញាប់សាវ័កប៉ូលបានអធិស្ឋានខ្លាំងៗសម្រាប់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: យើងកបានអធស្ឋានជយ៉ាងទៀងទាត់សម្រាប់អ្នក។

ត្រាស់ហៅ

ត្រង់នេះពាក្យ «ត្រាស់ហៅ»
សំដៅទៅលើអ្នកដែលព្រះជាម្ចាស់បានតែងតាំងឬក៏ត្រូវបានជ្រើសជាកូនរបស់ទ្រង់
ជាអ្នកបំរើរបស់ទ្រង់

ហើយប្រកាសព្រះបន្ទូលរបស់ទ្រង់អំពីការសង្គ្រោះតាមរយៈព្រះយេស៊ូ។

ព្រះអង្គនឹងបំពេញគ្រប់ទាំងចិត្តប៉ងប្រាថ្នានៃការធ្វើការល្អ

«ដើម្បីធ្វើឱ្យអ្នកអាច
គ្រប់ទាំងការល្អនៅក្នុងរបៀបដែលអ្នករាល់គ្នាចង់បាន» (UDB)

ព្រះនាមរបស់ព្រះអម្ចាស់យេស៊ូនៃយើងបានទទួលសិរីល្អដោយសារអ្នករាល់គ្នា។

គឺវាអាចថ្លែងបាននៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយសារអ្នកនឹងថ្វាយសិរីរុងរឿងដល់ព្រះនាមព្រះអម្ចាស់យេស៊ូជាព្រះរបស់យើងរាល់គ្នា»

អ្នកនឹងថ្វាយសិរីល្អដល់ព្រះអង្គ

គឺវាអាចថ្លែងនៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះយេស៊ូនិងប្រទានសិរីរុងរឿងដល់អ្នក»

ដោយព្រោះព្រះគុណរបស់ព្រះជាម្ចាស់នៃយើង

«ដោយសារព្រះគុណរបស់ព្រះជាម្ចាស់»

---

[1]ឥឡូវនេះ ទាក់ទងនឹងការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង និងការជួបជុំជាមួយគ្នា ដើម្បីនៅជាមួយព្រះអង្គ បងប្អូនអើយ
យើងអង្វរអ្នករាល់គ្នា[2]សូមកុំងាយនឹងរំខាន ឬខ្វល់ខ្វាយ មិនថាដោយវិញ្ញាណ ឬសារ ឬដោយសំបុត្រដែលហាក់បីដូចជាមកពីយើងក្តីថា
ថ្ងៃរបស់ព្រះជាម្ចាស់បានមកដល់រួចមកហើយ។
[3]សូមកុំឲ្យនរណាម្នាក់បោកប្រាស់អ្នករាល់គ្នាដោយរបៀបណាមួយបានឡើយ រហូតទាល់តែ បន្ទាប់ពីមនុស្សលះបង់ជំនឿ និងមនុស្សទទឹងច្បាប់លេចមកជាមុនសិន
គឺជាកូននៃការបំផ្លាញ។[4]គឺវាហើយដែលបះបោរ ហើយលើកខ្លួន ឬប្រឆាំងជាមួយអ្វីដែលហៅថា ព្រះជាម្ចាស់ ឬការថ្វាយបង្គំ។ ជាលទ្ធផល
វាបានអង្គុយនៅក្នុងព្រះវិហារនៃព្រះជាម្ចាស់ ហើយបង្ហាញខ្លួនឯងថាជាព្រះជាម្ចាស់។
[5]តើអ្នករាល់គ្នាមិនចាំទេឬអីថា នៅពេលខ្ញុំនៅជាមួយអ្នករាល់គ្នា ខ្ញុំបានប្រាប់ការទាំងអស់នេះដល់អ្នករាល់គ្នារួចហើយ?[6]ឥឡូវនេះ អ្នកដឹងថាអ្វីដែលអាចរារាំងវាបានហើយ
ដើម្បីឲ្យវាបានបង្ហាញខ្លួននៅពេលកំណត់។[7]ដ្បិត អាថ៌កំបាំងគឺបាន និងកំពុងធ្វើការហើយ មានតែម្នាក់ដែលរារាំងវា រហូតទាល់តែត្រូវដកវាចេញ។
[8]ដូច្នេះ ពួកទទឹងច្បាប់នឹងបង្ហាញខ្លួន គឺជាអ្នកដែលព្រះជាម្ចាស់យេស៊ូនឹងសម្លាប់ដោយដង្ហើមដែលចេញពីព្រះឱស្ឋព្រះអង្គមក។ ព្រះអម្ចាស់នឹងបំផ្លាញវា
ដោយការបើកសម្តែងនៃការយាងមកវិញរបស់ព្រះអង្គ។[9]ពួកទទឹងច្បាប់នឹងមក ហើយធ្វើការដោយពឹងផ្អែកលើអំណាចសាតាំងទាំងស្រុង រួមជាមួយ ការអស្ចារ្យ
និងទីសម្គាល់ក្លែងក្លាយ និងជាមួយបោកប្រាស់នៃអំពើទុច្ចរិតគ្រប់យ៉ាង។[10]ការទាំងនេះនឹងកើតឡើងសម្រាប់អស់អ្នកដែលត្រូវវិនាស
ព្រោះពួកគេមិនបានទទួលសេចក្តីស្រឡាញ់នៃសេចក្តីពិតសម្រាប់ពួកគេឲ្យបានសង្គ្រោះ។
[11]ដ្បិត ដោយហេតុនេះហើយ បានជាព្រះជាម្ចាស់ចាត់ពួកគេដើម្បីធ្វើការបោកប្រាស់ ដើម្បីឲ្យពួកគេបានជឿនៅក្នុងសេចក្តីកុហកនោះ។
[12]ជាលទ្ធផលពួកគេនឹងត្រូវវិនិច្ឆ័យគ្រប់គ្នា អស់អ្នកដែលមិនជឿលើសេចក្តីពិត ប៉ុន្តែ ផ្ទុយទៅវិញពួកគេរីករាយក្នុងអំពើទុច្ចរិតវិញ។
[13]ប៉ុន្តែ យើងត្រូវអរព្រះគុណដល់ព្រះជាម្ចាស់សម្រាប់បងប្អូនជានិច្ច បងប្អូនជាទីស្រឡាញ់របស់ព្រះអម្ចាស់អើយ។ ដ្បិត
ព្រះជាម្ចាស់បានជ្រើសរើសអ្នករាល់គ្នាជាផលដំបូងសម្រាប់សេចក្តីសង្គ្រោះនៅក្នុងភាពសុចរិតរបស់ព្រះវិញ្ញាណ និងជំនឿនៅក្នុងសេចក្តីពិត។
[14]នេះគឺជាអ្វីដែលព្រះជាម្ចាស់បានហៅអ្នករាល់គ្នាតាមរយៈដំណឹងល្អរបស់យើង ដើម្បីទទួលសិរីល្អរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង។[15]ដូច្នេះ បងប្អូនអើយ ចូរឈរមាំ។
ចូរកាន់ខ្ជាប់សន្តាប់ធ្នាប់ដែលយើងបានបង្រៀនដល់អ្នករាល់គ្នា មិនថាដោយសំដី ឬដោយសំបុត្ររបស់យើងទេ។
[16]ឥឡូវនេះ សូមព្រះអម្ចាស់យេស៊ូគ្រិស្តផ្ទាល់ និងព្រះបិតានៃយើង ដែលស្រឡាញ់យើង ហើយប្រទានដល់យើងនូវការកម្សាន្តចិត្តដ៏នូវអស់កល្ប
និងការមានទំនុកចិត្តមុតមាំសម្រាប់អនាគត តាមរយៈព្រះគុណ[17]ចូរកម្សាន្តចិត្ត ហើយពង្រឹងចិត្តរបស់អ្នករាល់គ្នាឲ្យរឹងមាំនៅក្នុងការល្អ និងសំដីគ្រប់យ៉ាង។

---

2 Thessalonians 2:1

ពត៌មានទូទៅ៖

លោកប៉ូលបានដាស់តឿនដល់ក្រុមអ្នកជឿអំពីការនិយាយភូតកុហកពីថ្ងៃដែលព្រះយេស៊ូវយាងមកវិញ

ឥឡូវនេះ

ពាក្យថា «ឥឡូវនេះ» សញ្ញាសម្គាល់ត្រូវបានផ្លាស់ប្តូរ
នៃប្រធានបទនៅក្នុងកាណែនាំរបស់សាវ័កប៉ូល។

បងប្អូន

ត្រង់នេះពាក្យ «បងប្អូន» ដែលមានន័យថា បងប្អូនរួមជំនឿ
ដែលរួមបញ្ចូលទាំងបុរស និងស្ត្រី។ ការបកប្រែរបៀបផ្សេងទៀត:
«បងប្អូនប្រុសនិងបងប្អូនស្រី»

សូមកុំងាយនឹងរំខាន ឬខ្វល់ខ្វាយ

«ដូចនេះអ្នកនឹងមិនងាយឱ្យបញ្ហាទាំអស់នេះងាយស្រួលចូលមកកាន់អ្នក»

មិនថាដោយសារ ឬដោយសំបុត្រដែលហាក់បីដូចជាមកពីយើងក្តី

«ដោយពាក្យដែលយើងនិយាយឬ ដោយសំបុត្រដែលយើងសរសេរ
នោះគឺជាការសម្តែងដែលចេញពីខ្លួនយើង»

ដែលហាក់បីដូចជា

«ដែលនិយាយថា»

ថ្ងៃរបស់ព្រះជាម្ចាស់

នេះសំដៅទៅលើពេលដែលព្រះយេស៊ូគ្រិស្តយាងត្រលប់មកផែនដីសម្រាប់អ្នកជឿទាំងអស់

2 Thessalonians 2:3

ព័ត៌មានទូទៅ៖

លោកប៉ូលបង្រៀនអំពីមនុស្សដែលទទឹងច្បាប់។

នោះនឹងមិនមកដ

ថ្ងៃរបស់ព្រះជាម្ចាស់និងមិនមកដល់

ការធ្លាក់ចុះ

នេះគឺសំដៅទៅលើពេលវេលានៅអនាគត
គឺនៅពេលដែលមនុស្សជាច្រើនបែរចេញពីព្រះជាម្ចាស់។

ហើយមនុស្សទទឹងច្បាប់លេចមក

គឺវាអាចថ្លែងនៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ហើយព្រះជាម្ចាស់បានបង្ហាញមនុស្សដែលទទឹងច្បាប់ចេញមក»

គឺជាកូននៃការបំផ្លិចបំផ្លាញ

លោកប៉ូលបាននិយាយអំពីការបំផ្លិចបំផ្លាញ
ជាមនុស្សម្នាក់ដែលបានបង្កើតកូនក្នុងគោលបំណងក្នុងការបំផ្លាញអ្វីៗទាំងអស់។
ការបកប្រែរបៀបផ្សេងទៀត:
«ជាមនុស្សម្នាក់ដែលបំផ្លាញអ្វីទាំងអស់ដែលគាត់អាចបំផ្លាញ»

ជាមួយអ្វីដែលហៅថា ព្រះជាម្ចាស់ ឬការថ្វាយបង្គំ។
គឺវាអាចថ្លែងនៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ជាអ្វីទាំងអស់ដែលមនុស្សពិចារណាថាតើព្រះឬអ្វីទាំងអស់ដែលមនុស្សថ្វាយបង្គំ» (UDB)
(សូមមើលៈfigs-activepassive)

ដែលអួតអាងខ្លួនជាព្រះជាម្ចាស់

«បង្ហាញថា ខ្លួនឯងជាព្រះជាម្ចាស់»

2 Thessalonians 2:5

តើអ្នកមិនចាំការទាំងអស់នេះទេឬអី?

លោកប៉ូលបានប្រើសំណួរដែលពេញដោយវោហាសព្ទ៍ដើម្បីរំលឹកពួកគេ
អំពីអ្វីដែលលោកបានបង្រៀនពួកគេ នៅគ្រាមុនដែលលោកបាននៅជាមួយពួកគេ។
នេះបានបង្ហាញជាប្រយោគ។ ការបកប្រែរបៀបផ្សេងទៀត:
«ខ្ញុំប្រាកដ៏ណាស់ថាអ្នកចាំការទាំងអស់នេះ»

ការទាំងអស់នេះ

នេះសំដៅទៅលើកាលដែលព្រះយេស៊ូយាងត្រលប់មកវិញ គឺថ្ងៃនៃព្រះអម្ចាស់
ហើយនឹងមនុស្សដែលទទឹងច្បាប់។

គាត់និងបង្ហាញខ្លួននៅពេលកំណត់

គឺវាអាចចាប់ផ្តើមនៅក្នុងទម្រង់បែបសកម្ម។ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងបង្ហាញមនុស្សដែលទទឹងច្បាប់ នៅពេលកំណត់បានមកដល់»

អាថ៌កំបាំងនៃការទទឹងច្បាប់

នេះគឺសំដៅទៅលើសេចក្តី អាថ៌កំបាំងដ៏ពិសិដ្ឋ
ដែលមានតែព្រះម្ចាស់មួយប៉ុណ្ណោះដែលបានដឹង។

អ្នកណាដែលរារាំងគាត់

ដើម្បីរារាំងនណារម្នាក់គឺ ចាប់ពួកគេទុក ឬក៏
បង្ខាំងពួកគេទុកចេញពីអ្វីដែលពួកគេចង់ធ្វើ។

2 Thessalonians 2:8

បន្ទាប់មកពួកទទឹងច្បាប់នឹងបង្ហាញខ្លួន

គឺវាអាចថ្លែងបាននៅក្នុងទម្រង់បែបសកម្ម។ការបកប្រែរបៀបផ្សេងទៀត:
«បន្ទាប់មកព្រះជាម្ចាស់នឹងអនុញ្ញាតិឱ្យអ្នកដែលទទឹងច្បាប់បង្ហាញខ្លួនគេ»

ជាមួយដង្ហើមដែលចេញពីព្រះឱស្ឋព្រះអង្គមក

ត្រង់នេះ «ដង្ហើម» តំណាងឱ្យឫទ្ធានុភាពនៃព្រះជាម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត: «ដោយឫទ្ធានុភាពនៃព្រះបន្ទូលរបស់ទ្រង់»

បំផ្លាញដោយការបើកសម្តែងនៃការយាងមកវិញរបស់ព្រះអង្គ។

នៅពេលដែលព្រះយេស៊ូយាងត្រលប់មកផែនដីហើយបង្ហាញព្រះកាយព្រះអង្គ
ព្រះអង្គនឹងបំផ្លាញអ្នកដែលទទឹងច្បាប់។

រួមជាមួយ ឫទ្ធានុភាព ការអស្ចារ្យ និងទីសម្គាល់ក្លែងក្លាយ

«រួមជាមួយគ្រប់កិច្ចការទាំងអស់នៃ ឫទ្ធានុភាព ការអស្ចារ្យ
និងទីសម្គាល់ក្លែងក្លាយ»

ជាមួយបោកប្រាស់នៃអំពើទុច្ចរិតគ្រប់យ៉ាង។

អ្នកនោះនិងប្រើគ្រប់របៀបនៃការអាក្រក់ ដើម្បីេាកបញ្ឆោមនុស្ស

generated on Wed Sep 10 16:16:32 2025

ជឿលើគេជំនួសឱ្យការជឿលើព្រះជាម្ចាស់
ការទាំងនេះនឹងកើតឡើងសម្រាប់អស់អ្នកដែលត្រូវវិនាស
បុរសនោះដែលត្រូវបានប្រគល់អំណាចដោយមាសាតាំង
ដើម្បីបំផ្លាញដល់អស់អ្នកដែលមិនជឿលើព្រះគ្រិស្តយេស៊ូ។
2 Thessalonians 2:11
ដ្បិត ដោយហេតុនេះហើយ
«ដោយព្រោះតែមនុស្សមិនបានស្រលាញ់សេចក្តីពិត»
ព្រះជាម្ចាស់ចាត់ពួកគេដើម្បីធ្វើការបោកប្រាស់ ដើម្បីឲ្យពួកគេបានជឿនៅក្នុងសេចក្តីកុហកនោះ។
លោកប៉ូលបាននិយាយអំពីអ្វីដែលព្រះជាម្ចាស់អនុញ្ញាតិឱ្យកើតឡើង ដល់មនុស្ស
ដូចជាប្រសិនបើគាត់បញ្ជូនពួកគេទៅជាអ្វីមួយ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់អនុញ្ញាតិ អ្នកដែលទទឹងច្បាប់ បោកបញ្ឆោតពួកគេ។
ពួកគេនឹងត្រូវវិនិច្ឆ័យគ្រប់គ្នា
នេះអាចថ្លែងបាននៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះជាម្ចាស់នឹងវិនិច្ឆ័យពួកគេ»
អស់អ្នកដែលមិនជឿលើសេចក្តីពិត ប៉ុន្តែ ផ្ទុយទៅវិញពួកគេរីករាយក្នុងអំពើទុច្ចរិតវិញ។
អស់អ្នកដែលរីករាយក្នុងអំពើទុច្ចរិត ដោយព្រោះពួកគេមិនបានជឿលើសេចក្តីពិត»
2 Thessalonians 2:13
ប្រយោគភ្ជាប់:
ឥឡូវលោកប៉ូលបាន ផ្លាស់ប្តូរប្រធានបទ។
ពំតមានទូទៅ:
លោកប៉ូលបានអព្រះគុណដល់ព្រះជាម្ចាស់សំរាប់ដល់អ្នកជឿនិងលើកទឹកចិត្តពួកគេ។
ប៉ុន្តែ
លោកប៉ូលបានប្រើពាក្យទីនេះដើម្បីសម្គាល់ការផ្លាស់ប្តូរនៅក្នុងប្រធានបទ។
យើងត្រូវតែអរព្រះគុណដល់ព្រះជាម្ចាស់ជានិច្ច
នេះគឺជាការនិយាយបំផ្លើស ជាការនិយាយផ្ទុយពីការពិត។
ការបកប្រែរបៀបផ្សេងទៀត: «យើងគួតែបន្តអព្រះគុណព្រះជាម្ចាស់»
យើងត្រូវតែ
ត្រង់នេះ «យើងគឺសំដៅទៅលើសាវ័កប៉ូល លោកស៊ីលវ៉ាន ហើយនិង
លោកធីម៉ូថេ។
បងប្អូនជាទីស្រឡាញ់របស់ព្រះអម្ចាស់
នេះអាចថ្លែងបាននៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដ្បិតព្រះអម្ចាស់ស្រលាញ់អ្នក បងប្អូនអើយ»
បងប្អូន
ត្រង់នេះ «បងប្អូន» មានន័យថាបងប្អូនរួមជំនឿ ដែលរួមបញ្ចូលទាំងបុរស
និងស្ត្រី។ ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនប្រុស និង បងប្អូនស្រី»
ជាផលដំបូងសម្រាប់សេចក្តីសង្គ្រោះ
«ស្ថិតក្នុងចំណោមអ្នកដែលជឿលើព្រះយេស៊ូដំបូងគេហើយទទួលបានការសង្គ្រោះ»
នៅក្នុងភាពសុចរិតរបស់ព្រះវិញ្ញាណ
«ហើយញែកអ្នករាល់គ្នាចេញ ដោយព្រះវិញ្ញាណរបស់ព្រះអង្គ»
មានជំនឿនៅក្នុងសេចក្តីពិត
«ជឿក្នុងសេក្តីពិត» ឬក៏ «មានទំនុកចិត្តនៅក្នុងសេចក្តីពិត»
ដូច្នេះ បងប្អូនអើយ ចូរឈរមាំ
លោកប៉ូលបានដាស់តឿនដល់ដល់អ្នកជឿឱ្យប្រកាន់ខ្ជាប់នូវសេចក្តីជំនឿនៅក្នុងព្រះគ្រិស្តយេស៊ូ។
កាន់ខ្ជាប់សន្តាប់ធ្នាប់
ត្រង់នេះ «សណ្តាប់ធ្នាប់» សំដៅទៅលើសេចក្តីពិតនៃព្រះគ្រិស្តយេស៊ូ
ដែលសាវ័កប៉ូលនិងសាវ័ងទៀតបានបង្រៀន។
លោកប៉ូលបានបាននិយាយទៅកាន់ពួគេដូចជាអ្នកអានរបស់គាត់
ដែលអាចកាន់ដោយដៃរបស់ពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«សូមចាំពីសេចក្តីពិត»
អ្នកត្រូវបានបង្រៀន
នេះអាចថ្លែងបាននៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«យើងបានបង្រៀនអ្នក» (UDB)
មិនថាដោយសំដី ឬដោយសំបុត្ររបស់យើងទេ
អ្នកអាចធ្វើឱ្យវាប្រាកដនូវព័តមានជាក់លាក់។ ការបកប្រែរបៀបផ្សេងទៀត:
«មិនថាដោយអ្វីដែលយើងបានបង្រៀនដល់អ្នកក្នុងនាមជាមនុស្ស ឬក៏
ដោយអ្វីដែលយើងបានសរសេរទៅកាន់អ្នកនូវក្នុងសំបុត្រ»
2 Thessalonians 2:16
ប្រយោគភ្ជាប់:
លោកប៉ូលបានបញ្ចប់ជាមួយនិងព្រះពរដែលមកពីព្រះជាម្ចាស់។
ឥឡូវនេះ
លោកប៉ូលបានប្រើពាក្យនៅត្រង់នេះដើម្បីផ្លាស់ប្តូរប្រធានបទមួយ។
សូមព្រះអម្ចាស់ដែលស្រឡាញ់យើង ហើយប្រទានដល់យើង
ពាក្យថា «របស់យើង» ហើយនិង «យើង» សំដៅទៅលើពួកអ្នកជឿទាំងអស់។
ព្រះអម្ចាស់យេស៊ូគ្រិស្តផ្ទាល់
ត្រង់នេះ «ព្រះអង្គផ្ទាល់» បានផ្តល់នូវការសង្កត់ធ្ងន់បន្ថែម ទៅកាន់ប្រយោគ
«ព្រះអម្ចាស់យេស៊ូគ្រិស្ត»។
ចូរកម្សាន្តចិត្ត ហើយពង្រឹងចិត្តរបស់អ្នក
«ចិត្ត» សំដៅទៅលើកៅអីនៃអារម្មណ៏។ ការបកប្រែរបៀបផ្សេងទៀត:
«កម្សាន្តចិត្តអ្នក ហើយនិង ពង្រឹងអ្នកសម្រាប់»

---

3 [1]ឥឡូវនេះ បងប្អូនអើយ សូមអធិស្ឋានឲ្យយើងខ្ញុំផង ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់បានផ្សាយលឿន
ហើយបានប្រកបដោយសិរីល្អនៅក្នុងចំណោមអ្នករាល់គ្នាដែរ។[2]សូមអធិស្ឋាន ឲ្យយើងបានរួចផុតពីមនុស្សទុច្ចរិត និងអាក្រក់
ព្រោះមិនមែនមនុស្សគ្រប់គ្នាមានជំនឿនោះទេ។[3]ប៉ុន្តែ ព្រះអម្ចាស់ស្មោះត្រង់ ដែលបានសាង ហើយការពារអ្នករាល់គ្នាពីមនុស្សអាក្រក់។
[4]យើងមានទំនុកចិត្តជាមួយបងប្អូននៅក្នុងព្រះអម្ចាស់ ថាបងប្អូននឹងធ្វើ ហើយបន្តក្នុងការធ្វើការនោះ ដូចដែលយើងបានបង្គាប់ដល់បងប្អូន។
[5]សូមព្រះអម្ចាស់ដឹកនាំចិត្តរបស់អ្នករាល់គ្នា ឲ្យស្រឡាញ់ព្រះជាម្ចាស់ និងឲ្យអត់ធ្មត់នៅក្នុងព្រះគ្រិស្ត។
[6]ឥឡូវនេះ បងប្អូនអើយ យើងបង្គាប់ដល់អ្នករាល់គ្នា នៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើងថា ចូរចៀសចេញពីបងប្អូនណាដែលរស់នៅគ្មានសណ្តាប់ធ្នាប់
ហើយមិនរស់តាមរបៀបដែលអ្នកបានទទួលពីយើង។[7]ដ្បិត អ្នករាល់គ្នាដឹងហើយថាអ្វីដែលត្រឹមត្រូវសម្រាប់អ្នករាល់គ្នាយកតម្រាបតាមយើង។
យើងមិនបានរស់នៅក្នុងចំណោមអ្នករាល់គ្នាដូចអស់អ្នកដែលគ្មានរបៀបវិន័យនោះទេ។[8]យើងមិនបានទទួលអាហាររបស់នរណាម្នាក់ ដោយមិនបានបង់លុយនោះទេ។
ផ្ទុយទៅវិញ យើងបានខំប្រឹងធ្វើការយ៉ាងនឿយហត់ទាំងយប់ទាំងថ្ងៃ ដើម្បីកុំឲ្យយើងបានក្លាយជាបន្ទុកដល់នរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាឡើយ។[9]យើងធ្វើបែបនេះ
មិនមែនដោយសារយើងគ្មានសិទ្ធិអំណាចនោះទេ ផ្ទុយទៅវិញ យើងធ្វើបែបនេះ ដើម្បីធ្វើជាគំរូដល់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាអាចយកតម្រាបតាមយើងវិញ។
[10]នៅពេលយើងនៅជាមួយអ្នករាល់គ្នា យើងបានបង្គាប់ដល់អ្នករាល់គ្នាថា «ប្រសិនបើ នរណាម្នាក់មិនចង់ធ្វើការ អ្នកនោះមិនគួរឲ្យហូបទេ»។[11]ដ្បិត យើងឮថា
មានអ្នកខ្លះរស់នៅដោយខ្ជិលច្រអូសនៅក្នុងចំណោមអ្នករាល់គ្នា។ ពួកគេមិនបានធ្វើការ ប៉ុន្តែ ផ្ទុយទៅវិញ ពួកគេចូលចិត្តច្រៀតជ្រែកកិច្ចការរបស់អ្នកដទៃ។[12]ដូច្នេះ
យើងបង្គាប់ ហើយដាស់តឿនបងប្អូននៅក្នុងព្រះអម្ចាស់យេស៊ូគ្រិស្តថា ចូរឲ្យពួកគេធ្វើការដោយឥតរអ៊ូរទាំឡើយ ហើយហូបអាហាររបស់ពួកគេផ្ទាល់។
[13]ប៉ុន្តែ ឯអ្នករាល់គ្នាវិញ បងប្អូនអើយ មិនត្រូវបាក់ទឹកចិត្តក្នុងការធ្វើអ្វីដែលត្រឹមត្រូវឡើយ។[14]ប្រសិនបើ នរណាម្នាក់មិនស្តាប់បង្គាប់តាមពាក្យរបស់យើង
ដែលនៅក្នុងសំបុត្រនេះទេ ចូរសម្គាល់អ្នកនោះ ហើយកុំទាក់ទងជាមួយគាត់ឡើយ ធ្វើដូច្នេះ គាត់អាចនឹងអាម៉ាស់។[15]សូមកុំរាប់គាត់ថាជាសត្រូវឡើយ ប៉ុន្តែ
ដាស់តឿនគាត់ដូចជាបងប្អូនវិញ។
[16]សូមព្រះអម្ចាស់នៃេចក្តីសុខសាន្ត ប្រទានសេចក្តីសុខសាន្តដល់អ្នករាល់គ្នាគ្រប់ពេលវេលាក្នុងគ្រប់ការទាំងអស់។ សូមព្រះអម្ចាស់គង់នៅជាមួយអ្នកទាំងអស់គ្នា។
[17]នេះគឺជាពាក្យជម្រាបសួររបស់ខ្ញុំ ប៉ូល សរសេរដោយដៃរបស់ខ្ញុំផ្ទាល់ ជាសញ្ញានៅក្នុងសំបុត្រទាំងអស់។ នេះគឺជារបៀបដែលខ្ញុំសរសេរ។
[18]សូមព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើងបាននៅជាមួយអ្នកទាំងអស់គ្នា។

---

2 Thessalonians 3:1
ពំតមានទូទៅ៖
លោកប៉ូលបានសូមឱ្យក្រុមអ្នកជឿអធិស្ឋានសម្រាប់គាត់និង ដៃគូររបស់គាត់។
ហើយំឡូវនេះ
លោកប៉ូលបានប្រើពាក្យ «ឥឡូវនេះ» ដើម្បីសម្គាល់ការផ្លាស់ប្តូរមួយនៅក្នុង
ប្រធាបបទ។

generated on Wed Sep 10 16:16:32 2025

បងប្អូន
ត្រង់នេះ«បងប្អូន»មានន័យថាបងប្អូនរួមជំនឿ ដែលរួមបញ្ចូលទាំងបុរស និងស្ត្រី។ ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនប្រុស និង បងប្អូនស្រី»
ព្រះបន្ទូលរបស់ព្រះអម្ចាស់បានផ្សាយលឿន ហើយបានប្រកបដោយសិរីល្អ
លោកប៉ូលបាននិយាយពីការរីករាលដាល នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលចេញពីកន្លែងមួយទៅកន្លែងមួយ។ ការបកប្រែរបៀបផ្សេងទៀត: «ឆាប់ៗនេះនិងមានមនុស្សកាន់តែច្រើនឡើងៗ ដែលនឹងបានលឺពីសាររបស់យើង ដែលនិយាយពី ព្រះអម្ចាស់យេស៊ូ ហើយថ្វាយព្រះកត្តិយស»
ឲ្យយើងបានរួចផុត
នេះអាចថ្លែងបាននៅក្នុងទម្រង់បែបសកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «នោះព្រះជាម្ចាស់នឹងសង្គ្រោះយើង» ឬក៏ «ព្រះជាម្ចាស់នឹងរំដោះយើង»
ព្រោះមិនមែនមនុស្សគ្រប់គ្នាមានជំនឿនោះទេ
«ដ្បិតមនុស្សជាច្រើននិងមិនជឿលើព្រះយេស៊ូគ្រិស្ត»
នណារដែលបានសាងអ្នក
«តើនណារដែលពង្រឹងកម្លាំងអ្នក»
មនុស្សអាក្រក់
«សាតាំង»
2 Thessalonians 3:4
យើងមានទំនុកចិត្ត
«យើងមានជំនឿ» ឬក៏ «យើងជឿ»
ដឹកនាំដួងចិត្តរបស់អ្នក
លោកប៉ូលបានបរិយាយ ពីព្រះអម្ចាស់ ដែលជំរុញទឹកចិត្តគ្រិស្តបរិស័ទឱ្យស្រលាញ់ព្រះជាម្ចាស់ ដូចដែលព្រះអម្ចាស់បាននាំពួកគេពួកគេឱ្យដើតាមផ្លូវ។ ការបកប្រែរបៀបផ្សេងទៀត: «ជួយអ្នកឱ្យបានស្គាល់»
ដួងចិត្ត
នេះគឺជាពាក្យប្រៀបធៀបសម្រាប់អារម្មណ៍ ឬក៏ ជាឆន្ទៈគ្រប់គ្រងរវាងក្តីស្រលាញ់និង ភាពស្មោះត្រង់។
ឲ្យស្រឡាញ់ព្រះជាម្ចាស់ និងឲ្យអត់ធ្មត់នៅក្នុងព្រះគ្រិស្ត។
លោកប៉ូលបាននិយាយពីក្តីស្រលាញ់របស់ព្រះជាម្ចាស់ និង ភាពអត់ធ្មត់បស់ព្រះគ្រិស្ត ដូចជាពួកគេដែលមានទិសដៅលើផ្លូវមួយ។ ការបកប្រែរបៀបផ្សេងទៀត: «តើព្រះជាម្ចាស់ស្រលាញ់អ្នកប៉ុណ្ណា ហើយ តើព្រះជាម្ចាស់ អត់ធ្មត់និងប៉ុណ្ណា សម្រាប់អ្នក»
2 Thessalonians 3:6
ព័តមានទូទៅ៖
លោកប៉ូលផ្តល់ការណែនាំចុងក្រោយខ្លះៗ ដល់ក្រុមអ្នកជឿ អំពីការធ្វើការ និងមិនត្រូវធ្វើការ។
ឥឡូវនេះ
លោកប៉ូលបានប្រពាក្យនេះសម្រាប់សម្គាល់ការផ្លាស់ប្តូរនៅក្នុងប្រធានបទមួយ។
នៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង
«ដោយសិទ្ធអំណាចព្រះយេស៊ូ»
បងប្អូន
បងប្អូន ត្រង់នេះ «បងប្អូន» មានន័យថាបងប្អូនរួមជំនឿ ដែលរួមបញ្ចូលទាំងបុរស និងស្ត្រី។ ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនប្រុស និង បងប្អូនស្រី»
ព្រះអម្ចាស់នៃយើង
«នៃយើង» សំដៅទៅលើក្រុមអ្នកជឿទាំងអស់។
រស់នៅដោយឥតបានការ
«គឺខ្ជិល ហើយនិង បដិសេដមិនធ្វើការ» (UDB)
យកតម្រាប់តាមយើង
«ធ្វើដូចជាលោកប៉ូល និងអ្នកដែលរួមការងារជាមួយគាត់» ឬក៏ «មានឥរិយាបថដូចជាលោកប៉ូល និងអ្នកដែលរួមការងារជាមួយគាត់»
យើងមិនបានរស់នៅក្នុងចំណោមអ្នករាល់គ្នាដូចអស់អ្នកដែលគ្មានរបៀបវិន័យនោះទេ
លោកប៉ូលបានប្រើភាពអវិជ្ជមានចំនួនពីរដងដើម្បីប្រៀបធៀបភាពវិជ្ជមាន។ នេះអាចថ្លែងបញ្ជាក់បានៅក្នុងភាពវិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត: «យើងបានរស់នៅក្នុងអ្នករាល់គ្នាដល់អ្នកណាដែលមានរបៀបវិន័យ»
យើងធ្វើការទាំយប់ទាំងថ្ងៃ
«យើងធ្វើការទាំងពេលយប់ ហើយនិងទាំងពេលថ្ងៃ» ឬក៏ «យើងធ្វើការគ្រប់ពេល»
នៅក្នុងការងារលំបាក ហើយនិងសេចក្តីលំបាកវេទនា
លោកប៉ូលបានប្រៀបធៀបកាលៈទសៈលំបាករបស់គាត់។
ការងារលំបាកបានបង្កប់ន័យ
ការងារដែលតម្រូវឱ្យមានកាខិតខំប្រឹងប្រែងយ៉ាងខ្លាំង។
សេចក្តីលំបាកបានបង្កប់ន័យថាពួកគេបានស៊ូទ្រាំនិងការឈឺចាប់។
ការបកប្រែរបៀបផ្សេងទៀត: «នៅក្នុងគ្រប់កាលៈទេសៈលំបាកទាំងអស់»
យើងធ្វើបែបនេះ មិនមែនដោយសារយើងគ្មានសិទ្ធិអំណាចនោះទេ
លោកប៉ូលបានប្រើភាពអវិជ្ជមានពីរដងដើម្បីប្រៀបធៀបភាពវិជ្ជមាន។ នេះអាចថ្លែងបញ្ជាក់បានជាភាពវិជ្ជមាន។ ការបកប្រែរបៀបផ្សេងទៀត: «យើងពិតជាមានសិទ្ធអំណាច»
2 Thessalonians 3:10
ខ្លះដើរយ៉ាងខ្ជីលច្រអូស
ត្រង់នេះ «ដើរ» ឈតំណាងឱ្យឥរយាបថនៅក្នុងជីវិត។ ការបកប្រែរបៀបផ្សេងទៀត: «អ្នកខ្លះរស់ក្នុងជីវិតដែលទំនេ» ឬក៏ «អ្នកខ្លះខ្ជីលច្រអូស»
ប៉ុន្តែផ្ទុយទៅវិញពួកគេចូលចិត្ត ការជ្រៀតជ្រែក
ការជ្រៀតជ្រែក
គឺជាមនុស្សដែលជ្រៀតជ្រែកកិច្ចការរបស់អ្នកដទៃដោយមិនត្រូវបានស្នើសុំឱ្យជួយ។
ដោយឥតរអ៊ូរទាំ
«ដោយស្ងៀមស្ងាត់ ប្រកបដោយសន្តិភាព សុភាពទន់ភ្លន់។»
លោកប៉ូលបានដាស់តឿនដល់មនុស្សដែលជ្រៀតជ្រៀក ឱ្យឈប់ចូលរួមចេះដឹងក្នុងកិច្ចការរបស់អ្នកដ៏ទៃ។
2 Thessalonians 3:13
ប៉ុន្តែ
លោកប៉ូលបានប្រពាក្យនេះដើម្បីប្រៀបធៀបអ្នកជឿដែលខ្ជីល និងអ្នកជឿដែលខិតខំធ្វើការ។
អ្នករាល់គ្នា បងប្អូនអើយ
ពាក្យ«អ្នករាល់»សំដៅទៅលើអ្នកជឿទាំងអស់ដែលនៅក្រុងថេស្សាឡូនិក។
បងប្អូន
ត្រង់នេះ«បងប្អូន»មានន័យថាបងប្អូនរួមជំនឿ ដែលរួមបញ្ចូលទាំងបុរស និងស្ត្រី។ ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនប្រុស និង បងប្អូនស្រី» (សូមមើល: ត្រង់នេះ «បងប្អូន» មានន័យថាបងប្អូនរួមជំនឿ ដែលរួមបញ្ចូលទាំងបុរស និងស្ត្រី។ ការបកប្រែរបៀបផ្សេងទៀត: «បងប្អូនប្រុស និង បងប្អូនស្រី»
មិនត្រូវបាក់ទឹក
«បាក់ទឹកចិត្ត» គឺជាពាក្យសំដីដែលមានន័យថា ចាប់ផ្តើមនឿយហត់ ធុញទ្រាន់ ឬក៏ «ធ្លាក់ទឹកចិត្ត»។ ការបកប្រែរបៀបផ្សេងទៀត: «មិនត្រូវបាក់ទឹកចិត្ត» ឬក៏ «មិនត្រូវនឿយណាយឡើយ»
ចូរសម្គាល់អ្នកនោះ
កត់សម្គាល់ថាគាត់ជានណារ។ ការបកប្រែរបៀបផ្សេងទៀត: «កត់សម្គាល់អត្តសញ្ញាណ អ្នកនោះជាសាធារណៈ» (UDB)
ដូច្នេះ គាត់អាចនឹងអាម៉ាស់
លោកប៉ូលបានណែនាំ ពួកអ្នកជឿ ឱ្យបដិសេដពួកអ្នកជឿដែលខ្ជីលច្រអូស ថាជាសកម្មភាពវិន័យមួយ។
2 Thessalonians 3:16
ព័តមានទូទៅ៖
លោកប៉ូលបានធ្វើការបញ្ចប់ការអធិប្បាយ ទៅកាន់ពួកអ្នកជឿនៅក្រុងថេស្សាឡូនិក។
សូមព្រះអម្ចាស់នៃេចក្តីសុខសាន្ត ប្រទានសេចក្តីសុខសាន្តដល់អ្នក
អ្នកអាចបញ្ជាក់យ៉ាងច្បាសថានេះគឺជាការអធិស្ឋាន របស់លោកប៉ូល សម្រាប់អ្នកក្រុងថេស្សាឡូនិក។ ការបកប្រែរបៀបផ្សេងទៀត: «ខ្ញុំអធិស្ឋានថា សូមព្រះអម្ចាស់នៃេចក្តីសុខសាន្ត ប្រទានសេចក្តីសុខសាន្តដល់អ្នក.....»
ព្រះអម្ចាស់នៃេចក្តីសុខសាន្ត
ត្រង់នេះ «អង្គទ្រង់ផ្ទាល់» បញ្ជាក់ថាព្រះអម្ចាស់ នឹងប្រទានសេចក្តីសុខសាន្តដល់អ្នកជឿដោយអង្គទ្រង់ផ្ទាល់។
នេះគឺជាពាក្យជម្រាបសួររបស់ខ្ញុំ ប៉ូល សរសេរដោយដៃរបស់ខ្ញុំផ្ទាល់
«ខ្ញុំប៉ូល បានសរសេរកិច្ចស្វាគមន៍នេះដោយដៃខ្ញុំផ្ទាល់»
នេះគឺជារបៀបដែលខ្ញុំសរសេរ
លោកប៉ូលបានបញ្ជាក់យ៉ាងច្បាស់ថានេះគឺសំបុត្រដែលមកពីគាត់ ហើយក៏មិនមែនជាការក្លែងបន្លំដែរ។

generated on Wed Sep 10 16:16:32 2025

១ ធីម៉ូថេ

1 [1]ខ្ញុំ ប៉ូលជាសាវ័ករបស់ព្រះគ្រិស្តយេស៊ូ ដែលធ្វើតាមបញ្ជារបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះនៃយើង និងព្រះយេស៊ូគ្រិស្តដែលជាទីសង្ឃឹមរបស់យើង[2]មកដល់
ធីម៉ូថេជាកូនដ៏ពិតប្រាកដក្នុងជំនឿ។ សូមព្រះជាម្ចាស់ដែលជាព្រះបិតា និងព្រះគ្រិស្តយេស៊ូជាព្រះជាម្ចាស់នៃយើង ប្រទានព្រះគុណ សេចក្តីមេត្តាករុណា
និងសេចក្តីសុខសាន្តមកដល់យើង។
[3]ខ្ញុំសូមផ្តែផ្តាំអ្នក ពេលខ្ញុំចាកចេញទៅស្រុកម៉ាសេដូន សូមអ្នកស្នាក់នៅក្រុងអេភេសូរនេះ ដូច្នេះ អ្នកអាចហាមប្រាមមនុស្សមួយចំនួនទៀត
កុំឲ្យបង្រៀនគោលលទ្ធិខុសឆ្គងណាផ្សេងទៀតឡើយ។[4]ហើយកុំឲ្យពួកគេជាប់ចិត្តនឹងរឿងព្រេង និងបញ្ជីវង្សត្រកូលដ៏វែងអន្លាយនោះដែរ។ រឿងទាំងនោះបង្កឲ្យមានជម្លោះ
ជាជាងការគិតអំពីគម្រោងការរបស់ព្រះជាម្ចាស់ ដោយជំនឿ។
[5]ឥឡូវនេះ គោលបំណងនៃការហាមប្រាមនោះ គឺជាសេចក្តីស្រឡាញ់ចេញពីដួងចិត្តដ៏បរិសុទ្ធ មនសិកាជ្រះថ្លា និងជំនឿដ៏ស្មោះត្រង់ដែ។
[6]មានអ្នកខ្លះបានធ្វើខុសពីគោលបំណង ហើយបានបែរចេញពីសេចក្តីអស់ទាំងនោះ ទៅរកការនិយាយសម្តីលើលើវិញ។[7]ពួកគេធ្វើជាអ្នកបង្រៀនខាងក្រឹត្យវិន័យ
ទាំងខ្លួនមិនទាន់យល់ពីអ្វី ដែលខ្លួនបាននិយាយ ឬអ្វីដែលខ្លួនអះអាងផង។[8]ពួកយើងដឹងហើយថាក្រឹត្យវិន័យល្អប្រសើរ លុះត្រាតែយើងប្រើត្រឹមត្រូវតាមក្បួនច្បាប់។
[9]យើងដឹងហើយថា ក្រឹត្យវិន័យមិនមែនបង្កើតមកសម្រាប់មនុស្សសុចរិតនោះទេ ប៉ុន្តែ បង្កើតឡើងសម្រាប់មនុស្សទុច្ចរិត មនុស្សមានចិត្តឃោរឃៅ មនុស្សមានបាប
និងអស់អ្នកដែលមិនស្គាល់ព្រះជាម្ចាស់ ព្រមទាំងអស់អ្នកប្រមាថទីសក្ការៈ។ ក្រឹត្យវិន័យនេះក៏សម្រាប់អ្នកសម្លាប់ឪពុកម្តាយរបស់ខ្លួន អ្នកសម្លាប់គេ[10]អ្នកល្មោភកាម
មនុស្សគ្មានសីលធម៌ មនុស្សរួមភេទជាមួយភេទដូចគ្នា អ្នកដែលចាប់មនុស្សធ្វើជាទាសករ មនុស្សកុហក និងពួកអ្នកធ្វើបន្ទាល់ក្លែងក្លាយ
ព្រមទាំងពួកអ្នកដែលទាស់ប្រឆាំងជាមួយនឹងសេចក្តីប្រៀនប្រដៅត្រឹមត្រូវ។[11]សេចក្តីប្រៀនប្រដៅនេះ ស្របទៅនឹងដំណឹងល្អប្រកបដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់
ដែលព្រះអង្គបានផ្ញើទុកនឹងខ្ញុំ។
[12]ខ្ញុំអរព្រះគុណដល់ព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើង ដែលបានប្រទានកម្លាំងដល់ខ្ញុំ រាប់ខ្ញុំជាមនុស្សស្មោះត្រង់ និងបានតែងតាំងឲ្យខ្ញុំបម្រើព្រះអង្គ។[13]ខ្ញុំធ្លាប់ប្រមាថ
ធ្លាប់បៀតបៀន និងជាមនុស្សឃោរឃៅ ប៉ុន្តែខ្ញុំបានទទួលសេចក្តីមេត្តាមកពីព្រះអង្គ ព្រោះខ្ញុំបានប្រព្រឹត្តដោយភាពល្ងង់ខ្លៅ កាលខ្ញុំមិនទាន់ជឿព្រះអង្គនៅឡើយ។[14]ប៉ុន្តែ
ព្រះគុណរបស់ព្រះជាម្ចាស់ ដែលហូរហៀមកលើខ្ញុំដោយជំនឿ ហើយនិងសេចក្តីស្រឡាញ់ក្នុងព្រះគ្រិស្តយេស៊ូ។
[15]ពាក្យទាំងនេះអាចជឿទុកចិត្តបាន ហើយស័ក្តិសមនឹងទទួលទាំងស្រុងថា ព្រះគ្រិស្តយេស៊ូបានយាងមកលើផែនដី ដើម្បីសង្គ្រោះមនុស្សមានបាប។
រូបខ្ញុំជាមនុស្សអាក្រក់ជាងគេ។[16]ប៉ុន្តែហេតុផលនេះ ព្រះគ្រិស្តយេស៊ូបានសម្តែងព្រះហឫទ័យអត់ធ្មត់គ្រប់ជំពូកដល់ខ្ញុំមុនគេ
ដើម្បីឲ្យខ្ញុំបានធ្វើជាគំរូដល់អស់អ្នកដែលជឿព្រះអង្គ ហើយទទួលបានជីវិតអស់កល្បជានិច្ច។[17]សូមឲ្យព្រះមហាក្សត្រដែលគង់នៅអស់កល្បជានិច្ច
មានព្រះជន្មមិនសាបសូន្យ មនុស្សមើលមិនឃើញ ព្រះជាម្ចាស់តែមួយ ប្រកបដោយកិត្តិនាម និងសិរីរុងរឿងគង់នៅអស់កល្បអង្វែងតទៅ! អាម៉ែន។
[18]ខ្ញុំសូមផ្តាំផ្ញើព្រះបន្ទូលដែលគេថ្លែងទុកមកនេះសម្រាប់ធីម៉ូថេ ជាកូនសម្លាញ់អើយ! ចូរពឹងផ្អែកលើព្រះបន្ទូលនេះ ដើម្បីឲ្យកូនបានជាអ្នកតយុទ្ធឲ្យបានល្អ
[19]ចូរកាន់ខ្ជាប់ជំនឿ និងមានមនសិការល្អចុះ។ ដោយសារមានអ្នកខ្លះបដិសេធការទាំងនេះ បានធ្វើឲ្យជំនឿរបស់គេមានការលិចលង់ដែរ។[20]មានដូចជា លោកហ៊ីមេនាស
និងលោកអលេក្សានត្រុសជាដើម ដែលខ្ញុំបានប្រគល់គេឲ្យទៅសាតាំង ដើម្បីឲ្យពួកគេរៀនឈប់ប្រមាថព្រះជាម្ចាស់តទៅទៀត។

---

1 Timothy 1:1

ព័ត៌មានទូទៅ៖

នៅក្នុងសៀវភៅនេះលើកលែងតែមានការកត់សំគាល់ក្រៅពីពាក្យ «របស់យើង» សំដៅទៅលើប៉ូល និងធីម៉ូថេ (អ្នកដែលត្រូវបានសរសេរសំបុត្រនេះ) ក៏ដូចជាអ្នកជឿទាំងអស់។ (សូមមើល:)

ប៉ូល

«ខ្ញុំប៉ូលបានសរសេរលិខិតនេះ» ។ ភាសារបស់អ្នកអាចមានវិធីជាក់លាក់មួយ ដើម្បីណែនាំអ្នកនិពន្ធនៃលិខិតមួយនេះ។

អ្នកប្រហែលជាចង់ប្រាប់នៅក្នុងខដដែលនេះទៅអ្នកណាម្នាក់ដែលលិខិតនោះត្រូវបានសរសេរ (UDB)។

ដែលធ្វើតាមបញ្ជា

«ដោយបញ្ជារបស់» ឬ «ដោយសិទ្ធិអំណាចនៃ»

ព្រះសង្គ្រោះនៃយើង

«ព្រះដែលជួយសង្គ្រោះយើង»

ព្រះយេស៊ូគ្រិស្តដែលជាទីសង្ឃឹមរបស់យើង

ត្រង់ថា «ទំនុកចិត្តរបស់យើង» សំដៅទៅលើបុគ្គលដែលយើងជឿជាក់។ របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះគ្រិស្តយេស៊ូដែលយើងមានជំនឿទុកចិត្ត» និង «ព្រះគ្រិស្តយេស៊ូដែលយើងទុកចិត្ត»

ជាកូនដ៏ពិតប្រាកដក្នុងជំនឿ

ប៉ូលនិយាយអំពីទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយធីម៉ូថេហាក់ដូចជាឪពុក និងកូនប្រុស។

ប៉ូលគិតអំពីធីម៉ូថេជាកូនប្រុសពីព្រោះប៉ូលបានបង្រៀនធីម៉ូថេឲ្យមានជំនឿលើព្រះយេស៊ូ។ របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកណាពិតជាដូចកូនប្រុសខ្ញុំ»

ព្រះគុណ មេត្តាករុណា និងសេចក្តីសុខសាន្ត

សូមឲ្យព្រះគុណមេត្តាករុណា និងសេចក្តីសុខសាន្តក្លាយជារបស់អ្នក ឬ «សូមឲ្យអ្នកទទួលបាននូវសេចក្តីមេត្តាករុណា និងសេចក្តីសុខសាន្ត» ។

ព្រះវរបិតា

«ព្រះអម្ចាស់ គឺជាព្រះវរបិតារបស់យើង» ។ ត្រង់ថា «ព្រះវរបិតា» គឺជាងារដ៏សំខាន់សម្រាប់ព្រះ។

ព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើង

«ព្រះគ្រិស្តយេស៊ូ គឺជាព្រះអម្ចាស់នៃយើង»

1 Timothy 1:3

ប្រយោគភ្ជាប់៖

ប៉ូលលើកទឹកចិត្តធីម៉ូថេឲ្យបដិសេធការប្រើច្បាប់ខុស ហើយប្រើការបង្រៀនល្អមកពីព្រះវិញ។

ព័ត៌មានទូទៅ៖

ពាក្យថា «អ្នក» នៅក្នុងលិខិតនេះគឺមានលក្ខណៈតែឯងហើយសំដៅទៅលើធីម៉ូថេ

ខ្ញុំសូមផ្តែផ្តាំអ្នក

«ដូចដែលខ្ញុំបានអង្វរអ្នក» ឬ «ដូចដែលខ្ញុំបានសុំអ្នកយ៉ាងខ្លាំង»

ស្នាក់នៅក្រុងអេភេសូរ

«ចាំខ្ញុំនៅទីនោះក្នុងក្រុងអេភេសូរ»

គោលលទ្ធិខុសឆ្គងណាផ្សេងទៀតឡើយ

ព័ត៌មានបង្កប់អត្ថន័យអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «គោលលទ្ធិខុសគ្នាពីអ្វីដែលយើងបង្រៀន»

ពួកគេមិនត្រូវយកចិត្តទុកដាក់ដែរ

ព័ត៌មានដែលអាចយល់បានអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ: «ហើយខ្ញុំក៏ចង់អោយអ្នកបញ្ជាពួកគេកុំអោយយកចិត្តទុកដាក់»

រឿង

ទាំងនេះប្រហែលជារឿងរ៉ាវអំពីជីដូនជីតារបស់ពួកគេ។

បញ្ជីវង្សត្រកូលដ៏វែងអន្លាយ

ប៉ូលប្រើពាក្យ «គ្មានទីបញ្ចប់» ដើម្បីបញ្ជាក់ថាពង្សាវតាមានរយៈពេលយូរណាស់។

បញ្ជីវង្សត្រកូល

«បញ្ជីដូនតា» ។ បញ្ជីវង្សត្រកូលគឺជាកំណត់ត្រាសរសេរ ឬសំដីរបស់ឪពុកម្តាយ និងជីដូនជីតារបស់មនុស្សម្នាក់។

ទាំងនេះមានសារៈសំខាន់ណាស់នៅអ៊ីស្រាអែលនៅពេលពួកគេបានបង្កើតកុលសម្ព័ន្ធមួយដែលត្រូវបានបញ្ចូលទៅក្នុងប្រជាជនអ៊ីស្រាអែល។

រឿងទាំងនោះបង្កឲ្យមានជម្លោះ

«ទាំងនេះធ្វើឲ្យមនុស្សមិនយល់ស្របដោយកំហឹង» ។

ប្រជាជនបានជជែកវែកញែកអំពីរឿង

និងពង្សាវតារដែលគ្មាននរណាម្នាក់អាចដឹងការពិតបានទេ។

ជាជាងការគិតអំពីគម្រោងការរបស់ព្រះជាម្ចាស់ ដោយជំនឿ

អត្ថន័យដែលអាចមានគឺ ១) «ជាជាងជួយយើងឲ្យយល់ពីផែនការរបស់ព្រះ

generated on Wed Sep 10 16:16:32 2025

ដើម្បីសង្គ្រោះយើងដែលយើងរៀនដោយជំនឿ» ឬ ២)
«ជាជាងជួយយើងឲ្យធ្វើកិច្ចការរបស់ព្រះដែលយើងធ្វើដោយជំនឿ»។
1 Timothy 1:5
ឥឡូវនេះ
ពាក្យនេះត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការសម្រាក់នៅក្នុងការបង្រៀននៅក្នុងចំណុចសំខាន់។
នៅទីនេះប៉ូលពន្យល់អំពីគោលបំណងដែលគាត់កំពុងបញ្ជាធីម៉ូថេ។
បទបញ្ជា
ត្រង់នេះមិនមែនមានន័យថាគម្ពីរសញ្ញាចាស់ ឬ បញ្ញត្តិទាំង ១០ ប្រការទេ
តែជាការណែនាំដែលប៉ូលបានប្រាប់នៅជំពូក ១:៣។
គឺជាសេចក្តីស្រឡាញ់
អត្ថន័យដែលអាចមានគឺ ១) «គឺត្រូវស្រឡាញ់ព្រះ» (UDB) ឬ២)
«គឺត្រូវស្រឡាញ់មនុស្ស» ។
ចេញពីដួងចិត្តដ៏បរិសុទ្ធ
ត្រង់ថា «បរិសុទ្ធ»
មានន័យថាបុគ្គលនោះមិនមានបំណងលាក់កំបាំងដើម្បីធ្វើខុស។ ត្រង់ថា
«បេះដូង» សំដៅទៅលើគំនិត និងការគិតរបស់មនុស្សម្នាក់ៗ។ របៀបផ្សេងទៀត
នៃការបកប្រែ: «ពីគំនិតដែលស្មោះត្រង់»
មនសិការជ្រះថ្លា
«មនសិការដែលជ្រើសរើសត្រូវជំនួសឲ្យការខុសវិញ»
ជំនឿដ៏ស្មោះត្រង់
«ជំនឿពិត» ឬ «ជំនឿដោយគ្មានការលាក់ពុត»
មានអ្នកខ្លះបានធ្វើខុសពីគោលបំណង
ប៉ូលនិយាយអំពីជំនឿលើព្រះគ្រិស្តដូចជាគោលដៅដែលត្រូវតម្រង់។
ប៉ូលមានន័យថាមនុស្សមួយចំនួនមិនបានបំពេញគោលបំណងនៃជំនឿរបស់ពួកគេដែលមានចែងនៅក្នុងជំពូក
១:៥។
ហើយបានបែរចេញពីសេចក្តីអស់ទាំងនោះ
ត្រង់ថា «បែរទៅឆ្ងាយ»
គឺជាសំនួរវោហារដែលមានន័យថាពួកគេឈប់ធ្វើអ្វីដែលព្រះបានបញ្ជា។
អ្នកបង្រៀនខាងក្រឹត្យវិន័យ
ត្រង់ថា «ច្បាប់» សំដៅលើច្បាប់របស់លោកម៉ូសេ។
ប៉ុន្តែពួកគេមិនយល់
«ទោះបីជាពួកគេមិនយល់» ឬ «ហើយពួកគេមិនទាន់យល់»
អ្វីដែលពួកគេទទូច
«អ្វីដែលពួកគេនិយាយដោយមានទំនុកចិត្តថាជាការពិត»
ពួកយើងដឹងហើយថាក្រឹត្យវិន័យល្អប្រសើរ
«យើងយល់ថាច្បាប់មានប្រយោជន៍» ឬ «យើងយល់ថាច្បាប់មានប្រយោជន៍»
លុះត្រាតែយើងប្រើត្រឹមត្រូវតាមក្បួនច្បាប់
«ប្រសិនបើយើងប្រើវាត្រឹមត្រូវ» ឬ
«ប្រសិនបើយើងប្រើវាតាមគោលបំណងរបស់ព្រះ»
1 Timothy 1:9
យើងដឹងហើយថា
«ពីព្រោះយើងដឹងរឿងនេះ» ឬ «យើងក៏ដឹងរឿងនេះ»
ក្រឹត្យវិន័យមិនមែនបង្កើតមកសម្រាប់មនុស្សសុចរិតនោះទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«លោកម៉ូសេមិនបានផ្តល់ច្បាប់សម្រាប់មនុស្សសុចរិតទេ»
មនុស្សសុចរិត
នៅត្រង់ថា «បុរស» រួមបញ្ចូលទាំងបុរស និងស្ត្រី។ របៀបផ្សេងទៀត នៃការបកប្រែ:
«មនុស្សសុចរិត» ឬ «មនុស្សល្អ»
បង្កើតឡើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«លោកម៉ូសេបានផ្តល់ច្បាប់»
មនុស្សល្មោភកាម
នេះសំដៅទៅលើអ្នកដែលដេកជាមួយនរណាម្នាក់ដែលពួកគេមិនបានរៀបការ។
ស្រឡាញ់ភេទដូចគ្នា
«បុរសដែលដេកជាមួយបុរសផ្សេង»
អ្នកដែលចាប់ជំរិតមនុស្សធ្វើជាទាសករ
«អ្នកដែលចាប់ជំរិតមនុស្សឲ្យលក់ជាទាសករ» ឬ
«អ្នកដែលយកមនុស្សទៅលក់ធ្វើជាទាសករ»
អ្នកដែលទាស់ប្រឆាំងជាមួយនឹងសេចក្តីប្រៀនប្រដៅត្រឹមត្រូវ
«សំរាប់អ្នកដែលធ្វើអ្វីផ្សេងទៀតដែលប្រឆាំងនឹងការបង្រៀនរបស់គ្រិស្តបរិស័ទ»
ដំណឹងល្អប្រកបដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់
«ដំណឹងល្អអំពីសិរីរុងរឿងដែលជាកម្មសិទ្ធិរបស់ព្រះដែលមានពរ» ឬ
«ដំណឹងល្អនៃព្រះដ៏រុងរឿង និងព្រះពរ»
ដែលព្រះអង្គបានផ្ញើទុកនឹងខ្ញុំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ដែលព្រះបានប្រទានដល់ខ្ញុំ ហើយធ្វើឲ្យខ្ញុំទទួលខុសត្រូវចំពោះ»
1 Timothy 1:12
ប្រយោគភ្ជាប់៖
ប៉ូលប្រាប់អំពីរបៀបដែលគាត់បានប្រព្រឹត្តនៅអតីតកាលហើយលើកទឹកចិត្តធីម៉ូថេឲ្យទុកចិត្តព្រះ។
ខ្ញុំអរព្រះគុណ
«ខ្ញុំមានអំណរចំពោះ» ឬ «ខ្ញុំអរគុណដល់»
រាប់ខ្ញុំជាមនុស្សស្មោះត្រង់
«ព្រះអង្គបានចាត់ទុកខ្ញុំជាមនុស្សគួរឲ្យទុកចិត្ត» ឬ «ព្រះអង្គបានចាត់ទុកខ្ញុំថា
គួរឲ្យទុកចិត្ត»
បានតែងតាំងឲ្យខ្ញុំបម្រើព្រះអង្គ
ប៉ូលនិយាយអំពីភារកិច្ចក្នុងការបម្រើព្រះដូចជាកន្លែងដែលគេអាចតែងតាំង។
របៀបផ្សេងទៀត នៃការបកប្រែ: «ព្រះអង្គបានចាត់ខ្ញុំឲ្យ បម្រើព្រះអង្គ» ឬ
«ព្រះអង្គបានតែងតាំងខ្ញុំឲ្យ ធ្វើជាអ្នកបម្រើរបស់ព្រះអង្គ»។
ខ្ញុំធ្លាប់ប្រមាថ
«ខ្ញុំបាននិយាយអាក្រក់ទាស់នឹងព្រះគ្រិស្ត»។ ប៉ូលកំពុងសំដៅទៅលើគ្រាមុន
មុនពេលដែលគាត់ជាគ្រិស្តបរិស័ទ។
ធ្លាប់បៀតបៀន
«ខ្ញុំបានធ្វើទុក្ខបុកម្នេញអ្នកដែលជឿលើព្រះគ្រិស្ត» ឬ
មនុស្សឃោរឃៅ
«ខ្ញុំបានធ្វើបាបមនុស្សដទៃទៀត»។
នេះគឺជាមនុស្សដែលជឿជាក់ថាគាត់មានសិទ្ធិធ្វើបាបអ្នកដទៃ។
ប៉ុន្តែខ្ញុំបានទទួលសេចក្តីមេត្តាមកពីព្រះអង្គ ព្រោះខ្ញុំបានប្រព្រឹត្តដោយភាពល្ងង់ខ្លៅ
កាលខ្ញុំមិនទាន់ជឿព្រះអង្គនៅឡើយ
«ប៉ុន្តែដោយសារតែខ្ញុំមិនជឿលើព្រះយេស៊ូ
ហើយខ្ញុំមិនដឹងថាខ្ញុំកំពុងធ្វើអ្វីទេខ្ញុំទទួលបានមេត្តាករុណាពីព្រះយេស៊ូ»
ខ្ញុំបានទទួលមេត្តាករុណា
«ព្រះយេស៊ូបានបង្ហាញសេចក្តីមេត្តាករុណាដល់ខ្ញុំ» ឬ
«ព្រះយេស៊ូមានព្រះហឫទ័យអាណិតអាសូរខ្ញុំ»
ប៉ុន្តែ ព្រះគុណ
«ហើយព្រះគុណ»
ព្រះគុណរបស់ព្រះជាម្ចាស់ ដែលហូរហៀមកលើខ្ញុំ
ប៉ូលនិយាយអំពីព្រះគុណរបស់ព្រះដូចជាអង្គធាតុរាវដែលអាចបំពេញកុងតឺន័រ
និងកំពប់ចេញពីកំពូលពេលធុងពេញ។ របៀបផ្សេងទៀត នៃការបកប្រែ:
«ព្រះបានបង្ហាញខ្ញុំនូវព្រះគុណជាច្រើន»
ដោយជំនឿ ហើយនិងសេចក្តីស្រឡាញ់
នេះជាលទ្ធផលនៃព្រះដែលបង្ហាញព្រះគុណដល់ប៉ូល។ របៀបផ្សេងទៀត
នៃការបកប្រែ: «ដែលបណ្តាលឲ្យខ្ញុំទុកចិត្តលើព្រះយេស៊ូ ហើយស្រឡាញ់ព្រះអង្គ»
ក្នុងព្រះគ្រិស្តយេស៊ូ
នេះនិយាយអំពីព្រះយេស៊ូដូចជាព្រះអង្គ ជាធុងមួយដែលផ្ទុកអង្គធាតុរាវ។ ត្រង់ថា
«នៅក្នុងព្រះគ្រិស្តយេស៊ូ» សំដៅទៅលើការមានទំនាក់ទំនងជាមួយព្រះយេស៊ូ។
របៀបផ្សេងទៀត នៃការបកប្រែ:
«ព្រះយេស៊ូគ្រិស្តអាចអោយខ្ញុំថ្វាយដល់ព្រះបានពីព្រោះខ្ញុំបានរួបរួមជាមួយព្រះអង្គ»
1 Timothy 1:15
ពាក្យទាំងនេះអាចជឿទុកចិត្តបាន
«សេចក្តីថ្លែងការណ៍នេះគឺពិត»
ហើយស័ក្តិសមនឹងទទួលទាំងស្រុង
«យើងគួរតែទទួលវាដោយគ្មានការសង្ស័យ» ឬ
«សមនឹងយើងទទួលយកដោយមានទំនុកចិត្តពេញលេញ»
ព្រះគ្រិស្តយេស៊ូបានសម្តែងព្រះហឫទ័យអត់ធ្មត់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ព្រះជាម្ចាស់បានបង្ហាញសេចក្តីមេត្តាករុណាដល់ខ្ញុំ» ឬ
«ខ្ញុំបានទទួលសេចក្តីមេត្តាករុណាពីព្រះ»

generated on Wed Sep 10 16:16:32 2025

ដើម្បីឲ្យខ្ញុំបានធ្វើជាគំរូ
«ដូច្នេះតាមរយៈខ្ញុំអ្នកមានបាបអាក្រក់បំផុត»
ឥឡូវនេះ អាម៉ែន
ពាក្យថា «ឥឡូវនេះ» ត្រូវបានប្រើនៅទីនេះ
ដើម្បីសម្គាល់ការឈប់សម្រាកក្នុងការបង្រៀននៅក្នុងចំណុចសំខាន់។
នៅទីនេះប៉ូលសរសើរព្រះ។
សូមឲ្យព្រះមហាក្សត្រដែលគង់នៅអស់កល្បជានិច្ច
«ស្តេចដែលនៅស្ថិតស្ថេរ» ឬ «មេដឹកនាំធំជារៀងរហូត»
ប្រកបដោយកិត្តិនាម និងសិរីរុងរឿង
«សូមអោយគាត់ទទួលកិត្តិយស ហើយលើកតម្កើងសិរីរុងរឿង» ឬ
«សូមឲ្យមនុស្សបានតម្កើងនិងថ្វាយសិរីល្អដល់ទ្រង់»។
1 Timothy 1:18
ខ្ញុំសូមផ្តាំផ្ញើព្រះបន្ទូលដែលគេថ្លែងទុកមកនេះសម្រាប់អ្នក
ប៉ូលនិយាយអំពីការណែនាំរបស់គាត់ហាក់ដូចជាគាត់អាចដាក់កាយវិការទាំងនោះនៅ
របៀបផ្សេងទៀត នៃការបកប្រែ: «ខ្ញុំប្រគល់អ្នកជាមួយបញ្ជានេះ» ឬ
«នេះជាអ្វីដែលខ្ញុំកំពុងបញ្ជាអ្នក»
ជាកូនសម្លាញ់
ប៉ូលនិយាយអំពីទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយធីម៉ូថេហាក់ដូចជាប៉ូលជាឪពុក
ហើយធីម៉ូថេជាកូន។ ប៉ូលគិតថាធីម៉ូថេនៅក្មេង ពីព្រោះប៉ូលបានបង្រៀនធីម៉ូថេ
ឲ្យមានជំនឿលើលោកយេស៊ូ។ របៀបផ្សេងទៀត នៃការបកប្រែ:
«អ្នកណាពិតជាដូចកូនខ្ញុំ»
ចូរពឹងផ្អែកលើព្រះបន្ទូលនេះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ព្រមព្រៀងជាមួយអ្វីដែលអ្នកជឿផ្សេងទៀតបានទាយអំពីអ្នក»
ចូលរួមក្នុងការតយុទ្ធឲ្យបានល្អ
ប៉ូលនិយាយអំពីធីម៉ូថេធ្វើការឲ្យព្រះអម្ចាស់ដូចជាគាត់ជាទាហានដែលកំពុងប្រយុទ្ធ។
របៀបផ្សេងទៀត នៃការបកប្រែ: «បន្តធ្វើការដើម្បីព្រះអម្ចាស់»
មានមនសិការល្អ
«មនសិការដែលជ្រើសរើសត្រូវជំនួសដោយខុស» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លានេះក្នុងជំពូក ១:៥។
បានធ្វើឲ្យជំនឿរបស់គេមានការលិចលង់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ពួកគេបានបំផ្លាញជំនឿរបស់ពួកគេ»
បានធ្វើឲ្យជំនឿរបស់គេមានការលិចលង់
ប៉ូលនិយាយអំពីជំនឿរបស់មនុស្សទាំងនេះហាក់ដូចជាកប៉ាល់ដែលអាចនឹងត្រូវលិចនៅឯសមុទ្រ។
គាត់មានន័យថាពួកគេបានបំផ្លាញជំនឿរបស់ពួកគេ
ហើយលែងជឿលើព្រះយេស៊ូទៀត។ អ្នកគួរតែប្រើពាក្យនេះ
ឬ
ទាំងនេះគឺជាឈ្មោះរបស់បុរស។
ដែលខ្ញុំបានប្រគល់គេឲ្យទៅសាតាំង
ប៉ូលនិយាយដូចជាគាត់បានប្រគល់បុរសទាំងនេះទៅសាតាំង។
នេះប្រហែលជាមានន័យថា ប៉ូលបានបដិសេធពួកគេពីសហគមន៍អ្នកជឿ។
ដោយសារពួកគេលែងជាសមាជិករបស់សហគមន៍សាតាំងអាចមានអំណាច
និងធ្វើបាបពួកគេ។
ដើម្បីឲ្យពួកគេរៀន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ដើម្បីឲ្យព្រះជាម្ចាស់អាចបង្រៀនពួកគេ»

---

2 [1]ជាដំបូងនេះ ខ្ញុំសូមផ្តែផ្តាំឲ្យអធិស្ឋានសូមព្រះជាម្ចាស់ ទូលអង្វរព្រះអង្គ ហើយអរព្រះគុណព្រះអង្គសម្រាប់មនុស្សទាំងអស់ផង[2]ចូរអធិស្ឋានសម្រាប់ស្តេច
និងអ្នកកាន់អំណាចគ្រប់រូប ដើម្បីឲ្យយើងរស់នៅបានសុខក្សេមក្សាន្ត និងមិនមានចលាចល ក្នុងការគោរពប្រតិបត្តិព្រះជាម្ចាស់ និងមានជីវិតថ្លៃថ្នូរ។[3]នេះគឺជាការល្អ
និងគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដែលជាព្រះសង្គ្រោះនៃយើងរាល់គ្នា។[4]ព្រះអង្គគាប់ព្រះហឫទ័យឲ្យមនុស្សទាំងអស់បានសង្គ្រោះ និងបានស្គាល់សេចក្តីពិតយ៉ាងច្បាស់។
[5]ដ្បិត មានព្រះជាម្ចាស់តែមួយ និងមានស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និងមនុស្ស គឺព្រះគ្រិស្តយេស៊ូ។[6]ព្រះអង្គបានបូជាព្រះកាយរបស់ព្រះអង្គ
ដើម្បីលោះមនុស្សទាំងអស់គ្នា ទុកជាស្មរបន្ទាល់នៅពេលកំណត់មកដល់។[7]ដោយសារមូលហេតុនេះ ព្រះអង្គតែងតាំងខ្ញុំផ្ទាល់ឲ្យធ្វើជាអ្នកប្រកាសសក្ខីភាព និងជាសាវ័ក។
ខ្ញុំនិយាយការពិត។ ខ្ញុំមិននិយាយកុហកទេ។ ខ្ញុំជាអ្នកបង្រៀនសាសន៍ដទៃអំពីជំនឿ និងសេចក្តីពិត។
[8]ហេតុដូចនេះហើយបានជា ខ្ញុំចង់ឲ្យបុរសទាំងអស់នៅគ្រប់ទីកន្លែង អធិស្ឋាន ហើយលើកដៃឡើងដោយចិត្តបរិសុទ្ធ ដោយមិនមានកំហឹង និងឈ្លោះប្រកែកគ្នាឡើយ។
[9]ដូចនេះដែរ ខ្ញុំក៏ចង់ឲ្យស្ត្រីទាំងអស់ស្លៀកសម្លៀកបំពាក់សមរម្យ មានភាពរម្យទម និងមានទំនួលខុសត្រូវ។ ពួកគេមិនគួរក្រងសក់ ពាក់មាស ឬគ្រឿងអលង្ការ
ឬសម្លៀកបំពាក់ថ្លៃៗទេ។[10]ខ្ញុំចង់ឲ្យពួកគេស្លៀកពាក់សមរម្យ ដែលជាស្ត្រីគោរពប្រតិបត្តិ កោតខ្លាចព្រះជាម្ចាស់ តាមរយៈការធ្វើកិច្ចការល្អវិញ។
[11]នៅពេលរៀនព្រះបន្ទូល ស្ត្រីត្រូវតែចេះរក្សាភាពស្ងៀមស្ងាត់ ហើយស្តាប់បង្គាប់ទាំងស្រុង។[12]ខ្ញុំមិនអនុញ្ញាតឲ្យស្ត្រីបង្រៀន ឬប្រើសិទ្ធិអំណាចត្រួតត្រាលើប្តីឡើយ ប៉ុន្តែ
ត្រូវរស់នៅដោយស្ងៀមស្ងាត់វិញ។
[13]ដ្បិត ព្រះជាម្ចាស់បានបង្កើតលោកអដាំជាមុន បន្ទាប់មកបង្កើតនាងអេវ៉ាតាមក្រោយ។[14]លោកអដាំមិនមែនជាអ្នកចាញ់បោកទេ ប៉ុន្តែ គឺស្ត្រីវិញទេតើដែលចាញ់បោក
ហើយរំលោភលើបញ្ញត្តិរបស់ព្រះជាម្ចាស់ថែមទៀតផង[15]ទោះបីជានាងត្រូវបានសង្គ្រោះតាមរយៈការបង្កើតកូនក្តី លុះត្រាតែពួកគេមានជំនឿ និងសេចក្តីស្រឡាញ់
សុភាពរាបសា ព្រមទាំងមានកិរិយាបរិសុទ្ធផង។

---

1 Timothy 2:1
ប្រយោគភ្ជាប់៖
ប៉ូលលើកទឹកចិត្តធីម៉ូថេឲ្យអធិស្ឋានសម្រាប់ប្រជាជនទាំងអស់។
ជាដំបូងនេះ
«សំខាន់បំផុត» ឬ «មុនអ្វីៗផ្សេងទៀត»
ខ្ញុំសូមផ្តែផ្តាំឲ្យអធិស្ឋានសូមព្រះជាម្ចាស់ ទូលអង្វរព្រះអង្គ ហើយអរព្រះគុណព្រះអង្គ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ខ្ញុំសូមជម្រុញអោយអ្នកជឿទាំងអស់ធ្វើការស្នើសុំការអធិស្ឋានការអង្វរ
និងការអរព្រះគុណដល់ព្រះ»
ខ្ញុំសូមផ្តែផ្តាំ
«ខ្ញុំសូមអង្វរ» ឬ «ខ្ញុំទូលសូម»
បានសុខក្សេមក្សាន្ត និងមិនមានចលាចល
ត្រង់ថា «សន្តិភាព» និង «ស្ងាត់» មានន័យថាដូចគ្នា។
ប៉ូលចង់ឲ្យអ្នកជឿទាំងអស់អាចរស់នៅដោយស្ងប់ស្ងាត់
ដោយគ្មានបញ្ហាពីអាជ្ញាធរ។
ក្នុងការគោរពប្រតិបត្តិព្រះជាម្ចាស់ និងមានជីវិតថ្លៃថ្នូរ
«ដែលគោរពដល់ព្រះហើយមានមនុស្សផ្សេងទៀតនឹងគោរព»
ព្រះអង្គគាប់ព្រះហឫទ័យឲ្យមនុស្សទាំងអស់បានសង្គ្រោះ និងបានស្គាល់សេចក្តីពិតយ៉ាងច្បាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ព្រះសព្វព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់
និងដើម្បីឲ្យពួកគេបានដឹងអំពីសេចក្តីពិត» ។
និងបានស្គាល់សេចក្តីពិតយ៉ាងច្បាស់
ប៉ូលនិយាយអំពីការរៀនសេចក្តីពិតអំពីព្រះដូចជាកន្លែងដែលមនុស្សអាចត្រូវបាននាំយកមក។
របៀបផ្សេងទៀត នៃការបកប្រែ: «ដើម្បីដឹង និងទទួលយកអ្វីដែលពិត»
1 Timothy 2:5
មានស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និងមនុស្ស
អ្នកសម្រុះសម្រួលគឺជាមនុស្សម្នាក់ដែលជួយចរចារកដំណោះស្រាយ
ដោយសន្តិវិធីរវាងគណបក្សពីរដែលមិនចុះសម្រុងនឹងគ្នា។ ត្រង់ថា
ព្រះយេស៊ូជួយមនុស្សមានបាបឲ្យមានទំនាក់ទំនងប្រកបដោយសន្តិភាពជាមួយព្រះ។
ព្រះអង្គបានបូជាព្រះកាយរបស់ព្រះអង្គ
«បានស្លាប់ដោយស្ម័គ្រចិត្ត»
ដើម្បីប្រោសលោះ
ជាតម្លៃសេរីភាព» ឬ «ជាការទូទាត់ដើម្បីទទួលបានសេរីភាព»
ទុកជាស្មរបន្ទាល់នៅពេលកំណត់មកដល់
ឃ្លានេះអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា
នេះគឺជាទីបន្ទាល់ដែលព្រះចង់ជួយសង្គ្រោះមនុស្សទាំងអស់។ របៀបផ្សេងទៀត

generated on Wed Sep 10 16:16:32 2025

នៃការបកប្រែ:
«ជាភស្តុតាងនៅពេលត្រឹមត្រូវដែលព្រះចង់ជួយសង្គ្រោះមនុស្សទាំងអស់»
នៅពេលកំណត់មកដល់
នេះមានន័យថានេះគឺជាពេលវេលាដែលព្រះបានជ្រើសរើស។
ដោយសារមូលហេតុនេះ
«សម្រាប់ការនេះ» ឬ «សម្រាប់ហេតុផលនេះ»
ព្រះអង្គតែងតាំងខ្ញុំផ្ទាល់ឲ្យធ្វើជាអ្នកប្រកាសសក្ខីភាព និងជាសាវ័ក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀត នៃការបកប្រែ:
«ព្រះគ្រិស្តបានធ្វើឲ្យខ្ញុំប៉ូលជាគ្រូគង្វាល និងជាសាវ័ក»
ខ្ញុំជាអ្នកបង្រៀនសាសន៍ដទៃអំពីជំនឿ និងសេចក្តីពិត
«ញុំបង្រៀនសាសន៍ដទៃនូវសារលិខិតនៃសេចក្តីជំនឿ និងសេចក្តីពិត»។
ត្រង់នេះលោកប៉ូលអាចនឹងប្រើ «ជំនឿ» និង «សេចក្តីពិត»
ដើម្បីបង្ហាញពីគំនិតមួយ។
1 Timothy 2:8
ប្រយោគភ្ជាប់៖
ប៉ូលបានបញ្ចប់ការណែនាំរបស់គាត់អំពីការអធិស្ឋានបន្ទាប់មកបានផ្តល់ការណែនាំពិសេសចំនួនបីសម្រាប់ប្រុសៗ។
ខ្ញុំចង់ឲ្យបុរសទាំងអស់នៅគ្រប់ទីកន្លែង អធិស្ឋាន ហើយលើកដៃឡើងដោយចិត្តបរិសុទ្ធ
ត្រង់ថា «ដៃស្អាត» មានន័យថាមនុស្សទាំងមូលគឺបរិសុទ្ធ។ របៀបផ្សេងទៀត
នៃការបកប្រែ:
«ខ្ញុំចង់អោយបុរសនៅគ្រប់ទីកន្លែងដែលបរិសុទ្ធលើកដៃហើយអធិស្ឋាន»
បុរសទាំងអស់នៅគ្រប់ទីកន្លែង
«បុរសនៅគ្រប់ទីកន្លែង» ឬ «បុរសគ្រប់ទីកន្លែង»។ នៅទីនេះពាក្យថា «បុរស»
សំដៅទៅលើបុរស។
លើកដៃឡើងដោយចិត្តបរិសុទ្ធ
ឃ្លានេះជាឥរិយាបថធម្មតាសម្រាប់មនុស្សក្នុងការលើកដៃពេលអធិស្ឋាន។
ដោយមិនមានកំហឹង និងឈ្លោះប្រកែកគ្នាឡើយ
ត្រួតពិនិត្យ ពាក្យទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា។ ប៉ូលកំពុងសង្កត់ធ្ងន់ថា
ស្ត្រីគួរតែស្លៀកសម្លៀកបំពាក់ដែលសមរម្យ
ហើយមិនទាក់ទាញការយកចិត្តទុកដាក់ពីបុរសឡើយ។
ពួកគេមិនគួរក្រងសក់
នៅសម័យប៉ូលស្ត្រីរ៉ូម៉ាំងជាច្រើនបានបោចសក់របស់ពួកគេ
ដើម្បីឲ្យពួកគេមានភាពទាក់ទាញ។ ការក្រងសក់គឺជាមធ្យោបាយតែមួយគត់
ដែលស្ត្រីអាចផ្តល់ការយកចិត្តទុកដាក់ហួសហេតុចំពោះសក់របស់នាង។
ប្រសិនបើសក់រុំមិនត្រូវបានគេដឹង នោះអាចត្រូវបាននិយាយតាមវិធីទូទៅ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេមិនគួរមានស្នាយម៉ូដសក់បែបពុម្ពអក្សរក្បួរក្បាច់» ឬ
«ពួកគេមិនគួរមានសស្នាយម៉ូដសក់ល្អិតល្អន់ ដែលទាក់ទាញចំណាប់អារម្មណ៍»
កោតខ្លាចព្រះជាម្ចាស់ តាមរយៈការធ្វើកិច្ចការល្អវិញ
«អ្នកណាចង់លើកកិត្តិយសព្រះដោយការល្អដែលពួកគេធ្វើ»

1 Timothy 2:11
នៅស្ងៀម
«នៅក្នុងភាពស្ងប់ស្ងាត់»
ហើយស្តាប់បង្គាប់ទាំងស្រុង
«និងមិនសួរសំណួរអំពីអ្វីដែលពួកគេបាន» (UDB) ឬ
«ត្រៀមខ្លួនដើម្បីគោរពតាមអ្វីគ្រប់យ៉ាងដែលព្រះបញ្ជា»
ខ្ញុំមិនអនុញ្ញាតឲ្យស្ត្រី
«ខ្ញុំមិនអនុញ្ញាតឲ្យស្ត្រីម្នាក់»
1 Timothy 2:13
ដ្បិត ព្រះជាម្ចាស់បានបង្កើតលោកអដាំជាមុន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អដាមគឺជាមនុស្សដែលព្រះបានបង្កើតមុន» ឬ «ព្រះបានបង្កើតអដាមជាមុន»
បន្ទាប់មកបង្កើតនាងអេវ៉ា
ព័ត៌មានដែលអាចយល់បានអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មកព្រះបានបង្កើតអេវ៉ា» ឬ
«ចំនួនបីសម្រាប់ស្ត្រីគឺ: «បន្ទាប់មកទៀតទ្រង់បានបង្កើតអេវ៉ា»
លោកអដាំមិនមែនជាអ្នកចាញ់បោកទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយអដាមមិនមែនជាអ្នកដែលពស់បានបំភាន់ទេ»
ប៉ុន្តែ គឺស្ត្រីវិញទេតើដែលចាញ់បោក ហើយរំលោភលើបញ្ញត្តិរបស់ព្រះជាម្ចាស់ថែមទៀតផង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែគឺជាស្ត្រីដែលមិនស្តាប់បង្គាប់ពីព្រោះសត្វពស់បានបំភាន់នាងទាំងស្រុង»
នាងត្រូវបានសង្គ្រោះតាមរយៈការបង្កើតកូនក្តី
នៅត្រង់ថា «នាង» សំដៅទៅលើស្ត្រីជាទូទៅ។ អត្ថន័យដែលអាចមានគឺ ១)
«ពេលខ្ញុំចាំអ្នកជានិច្ច» ឬ «ខណៈពេលដែលខ្ញុំចាំអ្នកគ្រប់ពេល»
ទាំងយប់ទាំងថ្ងៃ
ត្រង់ពាក្យថា «ទាំងយប់ទាំងថ្ងៃ» ប្រើដូចគ្នាទាំងពីរមានន័យថា «តែងតែ»។
របៀបផ្សេងទៀតនៃការបកប្រែ: «តែងតែ» ឬ «ជានិច្ច»
បានជាខ្ញុំមានចិត្តចង់ឃើញអ្នក
«ខ្ញុំចង់ឃើញអ្នកខ្លាំងណាស់»
ដើម្បីឲ្យខ្ញុំបានពេញដោយអំណរ
ប៉ូលនិយាយអំពីខ្លួនគាត់ដូចជាគាត់ជាធុងមួយដែលមនុស្សផ្សេងទៀតអាចបំពេញបាន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំអាចនឹងមានអំណរ» ឬ «ខ្ញុំអាចមានអំណរពេញលេញ»
ខ្ញុំនឹកចាំពីទឹកភ្នែករបស់អ្នក
ប៉ូលប្រើពាក្យ «ទឹកភ្នែក» គឺមានន័យថាការឈឺចាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំចាំបានទាំងអស់នូវអ្វីដែលអ្នកបានឈឺចាប់»
ខ្ញុំបានចងចាំពី
ពាក្យនេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំក៏ចងចាំពីអ្នក» ឬ «ខ្ញុំក៏បានរំលឹកពីអ្នក»
ជំនឿស្មោះត្រង់របស់អ្នក
«ជំនឿរបស់អ្នកគឺពិត» ឬ «ជំនឿរបស់អ្នកគឺស្មោះត្រង់»
ដែលដំបូងជាមួយលោកយាយឡូអ៊ីស ហើយម្តាយរបស់អ្នក គឺនាងអ៊ើនីស
ហើយខ្ញុំជឿយ៉ាងច្បាស់ថា ជំនឿនោះនៅក្នុងអ្នកផងដែរ
ប៉ូលកំពុងនិយាយអំពីជំនឿរបស់ពួកគេហាក់ដូចជាអ្វីដែលមានជីវិត
ហើយរស់នៅក្នុងពួកគេ។ ប៉ូលចង់មានន័យថាពួកគេមានជំនឿដូចគ្នា។
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាប្រយោគថ្មី។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឡូអ៊ីស យាយរបស់អ្នក
និងអ៊ើនីសដែលជាម្តាយរបស់អ្នកមានជំនឿពិតប្រាកដដំបូងគេ
ហើយខ្ញុំជឿជាក់ថាអ្នកក៏មានជំនឿពិតប្រាកដផងដែរ»
លោកយាយឡូអ៊ីស...នាងអ៊ើនីស
ពាក្យនេះជាឈ្មោះរបស់ស្ត្រី។
2 Timothy 1:6
ប្រយោគភ្ជាប់:
ប៉ូលលើកទឹកចិត្តធីម៉ូថេឲ្យរស់នៅដោយថាមពលសេចក្តីស្រឡាញ់
និងការប្រៀនប្រដៅ ហើយមិនត្រូវខ្មាស់អៀន
ដោយសារការរងទុក្ខវេទនារបស់ប៉ូលនៅក្នុងគុកដោយសារជំនឿ (របស់ប៉ូល)
របស់គាត់ទៅលើគ្រិស្ត។
នេះជាហេតុផល
«សម្រាប់ហេតុផលនេះ» ឬ «ដោយសារជំនឿដ៏ស្មោះរបស់អ្នកលើព្រះយេស៊ូ»
ចូរធ្វើឲ្យអំណោយទាន
ប៉ូលនិយាយអំពីតម្រូវការរបស់ធីម៉ូថេ
ដើម្បីចាប់ផ្តើមប្រើអំណោយទានរបស់គាត់ម្តងទៀត ដូចជាគាត់កំពុងឆេះឡើងវិញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ចាប់ផ្តើមប្រើអំណោយទានម្តងទៀត»
អំណោយទានរបស់ព្រះជាម្ចាស់ ដែលស្ថិតនៅក្នុងអ្នកតាមរយៈការដាក់ដៃលើអ្នក
«អំណោយទាននៃព្រះដែលអ្នកបានទទួលតាមរយៈការដាក់ដៃលើខ្ញុំ»។
ឃ្លានេះសំដៅទៅលើវិធីមួយដែលប៉ូលបានដាក់ដៃលើធីម៉ូថេ
ហើយបានអធិស្ឋានសុំព្រះជួយគាត់ឲ្យធ្វើកិច្ចការដែលព្រះអង្គបានបញ្ជាឲ្យលោកធ្វើ។
ដ្បិត ព្រះជាម្ចាស់
«ពីព្រោះព្រះជាម្ចាស់»
ព្រះជាម្ចាស់មិនបានប្រទានឲ្យយើងមានវិញ្ញាណ ដែលភ័យខ្លាចឡើយ ប៉ុន្តែវិញ្ញាណមានអំណាច
សេចក្តីស្រឡាញ់ និងមានវិន័យវិញ
អាចមានន័យថាទី ១) «វិញ្ញាណ» សំដៅទៅលើ «ព្រះវិញ្ញាណបរិសុទ្ធ»។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះមិនធ្វើឲ្យយើងភ័យខ្លាចទេ។
ព្រះអង្គបណ្តាលឲ្យយើងមានអំណាច និងសេចក្តីស្រឡាញ់ និងវិន័យ» ឬ ទី២)
«ស្មារតី» សំដៅទៅលើចរិតលក្ខណៈ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះមិនបណ្តាលឲ្យយើងភ័យខ្លាចទេ ប៉ុន្តែមានអំណាច និងសេចក្តីស្រឡាញ់
និងវិន័យវិញ»
មានវិន័យ
អាចមានន័យថាទី ១) អំណាចគ្រប់គ្រងខ្លួនយើង (UDB) ឬ ទី២)
អំណាចដើម្បីកែមនុស្សផ្សេងទៀតដែលកំពុងធ្វើខុស។
2 Timothy 1:8
ធ្វើបន្ទាល់
«នៃការផ្តល់សក្ខីកម្ម» ឬ «នៃការប្រាប់អ្នកដទៃ»
ជាអ្នកជាប់ឃុំឃាំងឡើយ
«អ្នកទោសសម្រាប់ជាប្រយោជន៍របស់ព្រះអង្គ» ឬ
«អ្នកទោសដោយសារតែខ្ញុំធ្វើជាសាក្សីអំពីព្រះអម្ចាស់»
ត្រូវរួមចំណែកក្នុងទុក្ខលំបាកសម្រាប់ដំណឹងល្អ
ប៉ូលនិយាយអំពីទុក្ខវេទនាដូចជាវត្ថុដែលអាចចែករំលែក
ចែកចាយក្នុងចំណោមមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«រងទុក្ខជាមួយខ្ញុំចំពោះដំណឹងល្អ»
តាមរយៈឫទ្ធានុភាពរបស់ព្រះជាម្ចាស់
«អនុញ្ញាតឲ្យព្រះប្រទានឲ្យអ្នករឹងមាំ»
ស្របតាមការត្រាស់ហៅដ៏វិសុទ្ធ
«ជាមួយនឹងការត្រាស់ហៅដែលញែកយើងជាប្រជារាស្ត្ររបស់ព្រះអង្គ» ឬ
«ធ្វើជាប្រជាជនដ៏វិសុទ្ធរបស់ព្រះអង្គ»
ព្រះអង្គធ្វើបែបនេះ
«ព្រះអង្គបានរក្សាទុក ហើយត្រាស់ហៅយើង»
មិនមែនដោយសារការប្រព្រឹត្តរបស់យើងទេ
«មិនមែនដោយសារតែយើងបានធ្វើអ្វីដែលសមនឹងទទួលបានទេ»
ប៉ុន្តែតាមរយៈគម្រោងការ និងព្រះគុណរបស់ព្រះអង្គវិញ
«ប៉ុន្តែដោយសារតែព្រះអង្គមានគម្រោង ដើម្បីបង្ហាញយើងនូវសេចក្តីសប្បុរសវិញ»
ក្នុងព្រះគ្រិស្តយេស៊ូ
«តាមរយៈទំនាក់ទំនងរបស់យើងជាមួយព្រះគ្រិស្តយេស៊ូ»
មុនសម័យកាលទាំងអស់
«មុនពេលពិភពលោកចាប់ផ្តើម» ឬ «មុនពេលចាប់ផ្តើម»
សេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់បានបើកសម្តែងហើយ
ប៉ូលនិយាយអំពីសេចក្តីសង្គ្រោះហាក់ដូចជាវត្ថុដែលអាចបើកចំហរ
និងអាចបើកសម្តែងដល់មនុស្ស។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានបង្ហាញពីរបៀបដែលព្រះអង្គនឹងជួយសង្គ្រោះយើង»
ដោយការលេចមករបស់ព្រះគ្រិស្តយេស៊ូ
«តាមរយៈការបញ្ជូនព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់យើង»
បាននាំយកជីវិតដែលគ្មានទីបញ្ចប់
ប៉ូលនិយាយអំពីសេចក្តីស្លាប់ហាក់ដូចជាដំណើរការឯករាជ្យជំនួសឲ្យព្រឹត្តិការណ៍ដែលមនុស្សស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលបំផ្លាញសេចក្តីស្លាប់» ឬ

generated on Wed Sep 10 16:16:32 2025

«អ្នកដែលធ្វើឲ្យមនុស្សមានលទ្ធភាពមិនស្លាប់ជារៀងរហូត»
បាននាំយកជីវិតដែលគ្មានទីបញ្ចប់ មកក្នុងពន្លឺនៃដំណឹងល្អវិញ
ប៉ូលនិយាយអំពីការបង្រៀនអំពីជីវិតអស់កល្បជានិច្ចដូចជាវត្ថុ
ដែលអាចនាំចេញពីភាពងងឹតទៅក្នុងពន្លឺ ដើម្បីឲ្យមនុស្សអាចមើលឃើញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«បង្រៀនពីជីវិតដែលមិនចេះស្លាប់គឺដោយការផ្សាយដំណឹងល្អ»
ព្រះជាម្ចាស់តែងតាំងខ្ញុំជាអ្នកប្រកាសដំណឹងល្អ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំឲ្យធ្វើជាអ្នកប្រកាសដំណឹងល្អ»
2 Timothy 1:12
ដោយសារបុព្វហេតុនេះ
«ដោយព្រោះខ្ញុំជាសាវ័ក»
ខ្ញុំត្រូវរងទុក្ខលំបាកការទាំងនេះ
ប៉ូលកំពុងសំដៅទៅលើការធ្វើជាអ្នកទោស។
ខ្ញុំជឿជាក់ច្បាស់
«ខ្ញុំជឿជាក់»
ព្រះអង្គនឹងរក្សាអ្វីដែលបានផ្ញើទុកនឹងខ្ញុំ
ប៉ូលកំពុងប្រើការប្រៀបធៀបរបស់មនុស្សម្នាក់ដែលធ្វើមួយជាមួយមនុស្សម្នាក់ទៀត
ដែលត្រូវបានសន្មត់ថាការពារអ្វីដែលគាត់ប្រគល់ឲ្យមនុស្សទីមួយវិញ។
អាចមានន័យថាទី ១)
ប៉ូលជឿជាក់លើព្រះយេស៊ូក្នុងការជួយគាត់ឲ្យរក្សាភាពស្មោះត្រង់ ឬ ទី២)
ប៉ូលកំពុងជឿជាក់ថាព្រះយេស៊ូនឹងធានាថាមនុស្សនឹងបន្តប្រកាស់ដំណឹងល្អ។
ថ្ងៃនោះឯង
ឃ្លានេះសំដៅទៅលើថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សទាំងអស់។
ចូរនឹកចាំពីព្រះបន្ទូលដ៏ស្មោះត្រង់ ដែលអ្នកបានឮពីខ្ញុំ
«បន្តបង្រៀនគំនិតត្រឹមត្រូវដែលខ្ញុំបានបង្រៀនអ្នក» ឬ
«ប្រើវិធីដែលខ្ញុំបានបង្រៀនអ្នកជាគំរូសម្រាប់អ្វីមួយ និងវិធីដែលអ្នកគួរបង្រៀន»
ទាំងមានជំនឿ និងសេចក្តីស្រឡាញ់ក្នុងព្រះគ្រិស្តយេស៊ូ
«ដូចដែលអ្នកទុកចិត្តលើព្រះយេស៊ូគ្រីស្ទ ហើយស្រឡាញ់ព្រះអង្គ» (UDB)
ការល្អ
ឃ្លានេះសំដៅទៅលើការងារនៃការប្រកាសដំណឹងល្អដែលត្រឹមត្រូវ។
ចូរថែរក្សា
ធីម៉ូថេត្រូវប្រុងប្រយ័ត្ន ពីព្រោះមនុស្សនឹងប្រឆាំងនឹងការងាររបស់គាត់
ដែលព្យាយាមបញ្ឈប់លោក ហើយបង្ខូចនូវអ្វីដែលគាត់និយាយផង។
តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ
«ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ»
2 Timothy 1:15
បានបែរចេញពីខ្ញុំហើយ
ប៉ូលនិយាយអំពីការឈប់ជួយពួកគេហាក់ដូចជាពួកគេបានឃ្លាតឆ្ងាយពីលោក។
ពួកគេបានបោះបង់ចោលប៉ូលដោយសារអាជ្ញាធរបានចាប់គាត់ដាក់គុក។
របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់ជួយខ្ញុំ»
ភីកេឡុស និងហ៊ើម៉ូគេន
ទាំងនេះគឺជាឈ្មោះរបស់បុរស។
ដល់អ្នកផ្ទះ
«ដល់គ្រួសារ»
ហើយមិនបានខ្មាសគេដោយសារច្រវាក់របស់ខ្ញុំទេ
ត្រង់ពាក្យថា «ច្រវាក់» គឺជាពាក្យប្រៀបធៀបដែលកំពុងជាប់ពន្ធនាគារ។
អូនេសិភ័រមិនអៀនខ្មាស់ទេ ដែលប៉ូលជាប់គុក ប៉ុន្តែគាត់មកលេងលោកញឹកញាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនខ្មាស់អៀនដែលខ្ញុំជាប់គុក»
សូមព្រះជាម្ចាស់ប្រទានសេចក្តីមេត្តាករុណា
«សូមឲ្យអូនេសិភ័រទទួលសេចក្តីមេត្តាករុណាពីព្រះអម្ចាស់» ឬ
«សូមព្រះអម្ចាស់សំដែងព្រះហឫទ័យមេត្តាករុណាដល់លោក»។
អាចស្វែងរកសេចក្តីមេត្តាករុណាពីព្រះជាម្ចាស់
ប៉ូលនិយាយអំពីសេចក្តីមេត្តាករុណាហាក់ដូចជាវត្ថុដែលអាចរកឃើញ។
នៅថ្ងៃនោះផង
ឃ្លានេះសំដៅទៅលើថ្ងៃដែលព្រះនឹងជំនុំជម្រះមនុស្សទាំងអស់។

---

2 [1]ហេតុដូច្នេះ កូនអើយ ចូរមានកម្លាំងនៅក្នុងព្រះគុណរបស់ព្រះគ្រិស្តយេស៊ូ។[2]ការអ្វីដែលអ្នកបានឮពីខ្ញុំនៅមុខស្មរបន្ទាល់ជាច្រើន ចូរធ្វើទុកនឹងមនុស្សស្មោះត្រង់
ដែលអាចនឹងបង្រៀនបន្តទៅអ្នកផ្សេងៗទៀតបាន។
[3]ចូររួមទុក្ខលំបាកជាមួយខ្ញុំ ប្រៀបដូចជាទាហានយ៉ាងល្អរបស់ព្រះគ្រិស្តយេស៊ូចុះ។[4]គ្មានទាហានណាដែលបម្រើហើយ
មានជាប់ពាក់ព័ន្ធនឹងការខ្វល់ខ្វាយពីជីវិតទៀតនោះទេ ដូច្នេះ គាត់គួរតែធ្វើឲ្យគាប់ចិត្តដល់អ្នកដែលកេណ្ឌខ្លួននោះវិញ។[5]ប្រសិនបើនរណាម្នាក់ប្រកួតជាកីឡាករ
អ្នកនោះនឹងមិនអាចទទួលភួងជ័យបានទេ លើកលែងតែប្រកួតគ្នាត្រឹមត្រូវតាមក្បួនច្បាប់វិញ។
[6]វាគឺជាការចាំបាច់ណាស់សម្រាប់កសិករ ដែលខំប្រឹងធ្វើការយ៉ាងលំបាក គាត់នឹងទទួលបានផលមុនគេ។[7]សូមពិចារណាអំពីអ្វីដែលខ្ញុំនិយាយចុះ
ដ្បិតព្រះជាម្ចាស់នឹងប្រទានឲ្យអ្នកយល់ដឹងក្នុងគ្រប់ការទាំងអស់។
[8]សូមនឹកចាំពី ព្រះយេស៊ូគ្រិស្តជាព្រះញាតិវង្សរបស់ព្រះបាទដាវីឌ ដែលបានរស់ពីសុគតឡើងវិញ តាមរយៈដំណឹងល្អដែលខ្ញុំបានប្រាប់[9]ដ្បិតអ្វីដែលខ្ញុំរងទុក្ខ
ទាំងជាប់ចំណងប្រៀបដូចជាឧក្រិដ្ឋជន។ ប៉ុន្តែ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនបានជាប់ច្រវាក់ទេ។[10]ហេតុនេះហើយបានជាខ្ញុំស៊ូទ្រាំគ្រប់ការទាំងអស់
សម្រាប់ពួកអ្នកដែលបានរើសតាំង ដើម្បីឲ្យពួកគេទទួលការសង្គ្រោះ ដែលមាននៅក្នុងព្រះគ្រិស្តយេស៊ូ ស្របតាមសិរីរុងរឿងនៅអស់កល្បជានិច្ចវិញ។
[11]ពាក្យទាំងនេះអាចទុកចិត្តបានថា «ប្រសិនបើយើងស្លាប់ជាមួយព្រះអង្គ នោះយើងនឹងរស់នៅជាមួយព្រះអង្គ។[12]ប្រសិនបើយើងស៊ូទ្រាំ
នោះពួកយើងនឹងសោយរាជ្យរួមជាមួយព្រះអង្គដែរ។ ប៉ុន្តែ ប្រសិនបើយើងបដិសេធព្រះអង្គវិញ នោះព្រះអង្គនឹងបដិសេធយើងដូចគ្នាដែរ។
[13]ប្រសិនបើយើងមិនស្មោះត្រង់ក៏ដោយ ក៏ព្រះអង្គនៅតែស្មោះត្រង់ដដែល ព្រោះព្រះអង្គមិនអាចបដិសេធព្រះអង្គផ្ទាល់បានឡើយ។
[14]សូមរំលឹកពួកគេអំពីការអស់ទាំងនេះ។ ចូរហាមប្រាមពួកគេនៅចំពោះមុខព្រះជាម្ចាស់ កុំឲ្យឈ្លោះប្រកែកគ្នាពីអត្ថន័យរបស់ពាក្យឡើយ។
ព្រោះពាក្យទាំងនេះឥតប្រយោជន៍ទេ។ ពាក្យទាំងនេះនាំឲ្យអន្តរាយដល់អស់អ្នកស្តាប់។[15]ចូរខំប្រឹងប្រែងបង្ហាញខ្លួនអ្នក នៅចំពោះព្រះជាម្ចាស់ដែលបានទទួលអ្នក
ជាអ្នកបំពេញការងារ ដោយគ្មានហេតុផលណាត្រូវអៀនខ្មាស ដែលបានបង្រៀនព្រះបន្ទូលនៃសេចក្តីពិត យ៉ាងត្រឹមត្រូវ។
[16]ត្រូវចៀសវាងការនិយាយឥតប្រយោជន៍ ដែលនាំយើងកាន់តែលែងគោរពប្រតិបត្តិព្រះជាម្ចាស់។[17]ការនិយាយរបស់ពួកគេនឹងប្រៀបបីដូចជាដំបៅរលួយ។
ក្នុងចំណោមអ្នកទាំងនោះរួមមាន ហ៊ីមេនាស និងភីលេតជាដើម។[18]អ្នកទាំងនោះបានភ្លេចសេចក្តីពិត។ ពួកគេនិយាយថា ការរស់ឡើងវិញបានកើតឡើងរួចមកហើយ។
ពួកគេក៏បានបង្វែរជំនឿអ្នកខ្លះដែរ។
[19]ទោះជាយ៉ាងណាក្តី ចូរចាក់ឫសរឹងមាំលើព្រះជាម្ចាស់ ដែលបានបោះត្រាថា៖ «ព្រះជាម្ចាស់ស្គាល់អស់អ្នកណា ដែលជារបស់ព្រះអង្គ» ហើយ
«អស់អ្នកដែលអំពាវនាវរកព្រះនាមព្រះជាម្ចាស់ ត្រូវញែកខ្លួនចេញអំពើទុច្ចរិត។[20]នៅក្នុងផ្ទះស្តុកស្តម្ភ ពុំមែនមានត្រឹមតែមាស និងប្រាក់ប៉ុណ្ណោះទេ។
គឺមានប្រដាប់ធ្វើពីឈើ និងពីដីដែរ។ ខ្លះប្រើសម្រាប់ការល្អប្រសើរ ហើយខ្លះប្រើសម្រាប់ការអាប់ឱនវិញ។[21]ប្រសិនបើនរណាម្នាក់សម្អាតខ្លួនឯងពីការអាប់ឱន
គាត់នឹងបានប្រដាប់ល្អប្រសើរ។ គាត់បានញែកខ្លួនដោយឡែក ក៏មានប្រយោជន៍ដល់ចៅហ្វាយ ហើយបានរៀបចំសម្រាប់គ្រប់ការល្អទាំងអស់ផងដែរ។
[22]ចូរចៀសចេញពីសេចក្តីស្រើបស្រាលរបស់ក្មេងៗ។ ត្រូវប្រកាន់ខ្ជាប់សេចក្តីសុចរិត ជំនឿ សេចក្តីស្រឡាញ់ និងសេចក្តីមេត្រីជាមួយអ្នក
ដែលស្រែករកព្រះជាម្ចាស់អស់អំពីចិត្តបរិសុទ្ធវិញ។[23]ប៉ុន្តែ ត្រូវបដិសេធសេចក្តីចោលម្សៀត និងសំណួរល្ងង់ខ្លៅវិញ។ អ្នកដឹងហើយថា
សេចក្តីទាំងនេះនាំមកនូវការឈ្លោះប្រកែកគ្នា។
[24]អ្នកបម្រើរបស់ព្រះជាម្ចាស់មិនត្រូវឈ្លោះប្រកែកគ្នាឡើយ។ ពិតណាស់គាត់គួរតែមានចិត្តសុភាពដល់មនុស្សទាំងអស់ ត្រូវចេះបង្រៀន ហើយមានចិត្តអំណត់ផង។
[25]គាត់ត្រូវតែប្រដៅអប់រំអ្នក ដែលឈ្លោះជាមួយគាត់។ ព្រះជាម្ចាស់នឹងធ្វើឲ្យពួកគេប្រែចិត្ត ដើម្បីឲ្យបានដឹងពីសេចក្តីពិតវិញ។[26]ពួកគេនឹងភ្ញាក់ខ្លួនឡើងវិញ
ហើយចាកចេញពីអន្ទាក់របស់អារក្ស ដែលបានទាក់ពួកគេជាប់ដើម្បីបម្រើគោលបំណងរបស់វា។

generated on Wed Sep 10 16:16:32 2025

2 Timothy 2:1

ប្រយោគភ្ជាប់៖

ប៉ូលរៀបរាប់អំពីជីវិតជាគ្រិស្តសាសនរបស់ធីម៉ូថេ ដូចជាជីវិតទាហាន និងជីវិតកសិករ និងជាជីវិតរបស់កីឡាករម្នាក់។

កូនអើយ

ប៉ូលបានចាត់ទុកធីម៉ូថេជាកូនប្រុសរបស់គាត់តាំងពីគាត់បង្រៀនធីម៉ូថេឲ្យទុកចិត្តលើគ្រិស្តរបៀបរបៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលជាដូចកូនរបស់ខ្ញុំ»

ចូរមានកម្លាំងនៅក្នុងព្រះគុណរបស់ព្រះគ្រិស្តយេស៊ូ

ប៉ូលនិយាយអំពីការជំរុញទឹកចិត្ត
និងការប្តេជ្ញាចិត្តថាព្រះគុណរបស់ព្រះអនុញ្ញាតឲ្យអ្នកជឿមាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមឲ្យព្រះជាម្ចាស់ប្រើព្រះគុណដែលព្រះអង្គបានផ្តល់ឲ្យអ្នកតាមរយៈទំនាក់ទំនងរបស់
ដើម្បីធ្វើឲ្យអ្នករឹងមាំ»

ខ្ញុំនៅមុខស្មរបន្ទាល់ជាច្រើន

«ដោយមានសាក្សីជាច្រើននៅទីនោះយល់ព្រមថាអ្វីដែលខ្ញុំបាននិយាយគឺជាការពិត»

ចូរធ្វើទុកនឹងមនុស្សស្មោះត្រង់

ប៉ូលនិយាយអំពីការណែនាំរបស់គាត់ទៅកាន់ធីម៉ូថេដូចជាភាជន:ទាំងនោះដែលធីម៉ូថេ
ហើយទុកចិត្តពួកគេឲ្យប្រើត្រឹមត្រូវ។ របៀបផ្សេងទៀតនៃការបកប្រែ: «ធ្វើពួកគេ»
ឬ «បង្រៀនពួកគេ»

មនុស្សស្មោះត្រង់

«ដែលគួរឲ្យទុកចិត្ត»

2 Timothy 2:3

ចូររួមទុក្ខលំបាកជាមួយខ្ញុំ

អាចមានន័យថាទី ១) ស៊ូទ្រាំនឹងទុក្ខវេទនាដូចខ្ញុំដែរ» (UDB) ឬ ២)
«ចូលរួមរំលែករំទុក្ខជាមួយខ្ញុំ»

ប្រៀបដូចជាទាហានយ៉ាងល្អរបស់ព្រះគ្រិស្តយេស៊ូចុះ

ប៉ូលប្រៀបធៀបការរងទុក្ខសម្រាប់ព្រះគ្រីស្ទយេស៊ូ
ទៅនឹងទុក្ខលំបាករបស់ទាហានល្អម្នាក់។

គ្មានទាហានណាដែលបម្រើហើយ មានជាប់ពាក់ព័ន្ធនឹងការខ្វល់ខ្វាយពីជីវិតទៀតនោះទេ

«គ្មានទាហានណាបំរើនៅពេលគាត់ចូលរួមក្នុងអាជីវកម្មប្រចាំថ្ងៃនៃជីវិតនេះទេ» ឬ
«នៅពេលទាហានកំពុងបម្រើពួកគេមិនត្រូវបានរំខានដោយរឿងសាមញ្ញ
ដែលប្រជាជនធ្វើនោះទេ»។

អ្នកបំរើរបស់ព្រះគ្រីស្ទមិនគួរអនុញ្ញាតឲ្យជីវិតប្រចាំថ្ងៃរារាំងពួកគេពីការធ្វើការសម្រាប់ព្រះ

មានជាប់ពាក់ព័ន្ធ

ប៉ូលនិយាយអំពីការបែរអារម្មណ៍នេះហាក់ដូចជាសំណាញ់ដែលបានទាក់មនុស្សនៅពេលពួកគេ

គាត់គួរតែធ្វើឲ្យគាប់ចិត្តដល់អ្នកដែលកេណ្ឌខ្លួននោះវិញ

«អ្នកដែលបានជ្រើសរើសគាត់ជាទាហាន» ឬ «អ្នកដែលបញ្ជាគាត់»

អ្នកនោះនឹងមិនអាចទទួលភួងជ័យបានទេ លើកលែងតែប្រកួតគ្នាត្រឹមត្រូវតាមក្បួនច្បាប់វិញ

ប៉ូលកំពុងនិយាយយ៉ាងចំៗអំពីអ្នកបំរើរបស់ព្រះគ្រិស្តដូចជាពួកគេជាអ្នកលេងកីឡា។

អ្នកនោះនឹងមិនអាចទទួលភួងជ័យបានទេ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងពាក់មកុដឲ្យលោកជាភួងជ័យ
ប្រសិនបើលោកប្រកួតប្រជែងដោយច្បាប់»

អ្នកនោះនឹងមិនអាចទទួលភួងជ័យបានទេ

«គេមិនអាចឈ្នះរង្វាន់ទេ»។

កីឡាករនៅសម័យប៉ូលត្រូវបានគេពាក់មកុដជាមួយកម្រងផ្កាធ្វើពីស្លឹករុក្ខជាតិនៅពេលនិងគោរពតាមប្រកួតផ្កា។

លើកលែងតែប្រកួតគ្នាត្រឹមត្រូវតាមក្បួនច្បាប់វិញ

«ប្រកួតប្រជែងតាមច្បាប់» ឬ «គោរពច្បាប់យ៉ាងតឹងរឹង»

2 Timothy 2:6

វាគឺជាការចាំបាច់ណាស់សម្រាប់កសិករ ដែលខំប្រឹងធ្វើការយ៉ាងលំបាក
គាត់នឹងទទួលបានផលមុនគេ

ឃ្លានេះគឺជាការប្រៀបធៀបទីបីដែលប៉ូលបានប្រាប់ធីម៉ូថេអំពីការងារ។
អ្នកអានគួរយល់ថាអ្នកបំរើរបស់ព្រះគ្រីស្ទត្រូវតែខិតខំធ្វើការ។

សូមពិចារណាអំពីអ្វីដែលខ្ញុំនិយាយចុះ

ប៉ូលបានឲ្យរូបភាពទៅធីម៉ូថេ
តែប៉ូលមិនបានពន្យល់អត្ថន័យរបស់រូបភាពទាំងស្រុងនោះទេ។
គាត់រំពឹងលើធីម៉ូថេនឹងរកឃើញអ្វីដែលគាត់កំពុងនិយាយអំពីអ្នកបំរើរបស់ព្រះគ្រីស្ទ។

ដ្បិតព្រះជាម្ចាស់

«ដោយព្រោះព្រះជាម្ចាស់»

ក្នុងគ្រប់ការទាំងអស់

«ពីអ្វីទាំងអស់»

2 Timothy 2:8

ប្រយោគភ្ជាប់៖

ប៉ូលបានណែនាំធីម៉ូថេអំពីរបៀបរស់នៅរបស់ព្រះគ្រិស្តរបៀបរងទុក្ខសម្រាប់ព្រះគ្រិស្ត
និងរបៀបបង្រៀនអ្នកឯទៀតឲ្យរស់នៅសម្រាប់ព្រះគ្រិស្ត។

ព្រះញាតិវង្សរបស់ព្រះបាទដាវីឌ

ត្រង់ពាក្យថា «ព្រះញាតិវង្ស» មានន័យថាកូនចៅ» របៀបផ្សេងទៀតនៃការបកប្រែ:
«ជាកូនចៅរបស់ព្រះបាទដាវីឌ»

ដែលបានរស់ពីសុគតឡើងវិញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស»

តាមរយៈដំណឹងល្អដែលខ្ញុំបានប្រាប់

ប៉ូលនិយាយអំពីដំណឹងល្អប្រសិនបើដំណឹងនេះពិសេសសម្រាប់លោក។
ប៉ូលមានន័យថា នេះគឺជាដំណឹងល្អដែលគាត់ប្រកាសចេញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលខ្ញុំ
ដ្បិតអ្វីដែលខ្ញុំរងទុក្ខ

«ដែលខ្ញុំរងទុក្ខ»

ទាំងជាប់ចំណងប្រៀបដូចជាឧក្រិដ្ឋជន

ត្រង់ពាក្យថា «ទាំងជាប់ចំណង» មានន័យថាជាប់នៅក្នុងគុក។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រមទាំងជាប់នៅក្នុងគុកផង»

ប៉ុន្តែ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនបានជាប់ច្រវាក់ទេ

ត្រង់ពាក្យថា «ជាប់ច្រវាក់» សំដៅទៅលើគុក។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានអ្នកណាអាចដាក់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងគុកបានទេ» ឬ
«គ្មានអ្នកណាអាចបញ្ឈប់ព្រះបន្ទូលរបស់ព្រះបានឡើយ»

សម្រាប់ពួកអ្នកដែលបានរើសតាំង

ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«សម្រាប់មនុស្សដែលព្រះជាម្ចាស់បានជ្រើសរើស»

ដើម្បីឲ្យពួកគេទទួលការសង្គ្រោះ ដែលមាននៅក្នុងព្រះគ្រិស្តយេស៊ូ

ប៉ូលនិយាយអំពីសេចក្តីសង្គ្រោះ ប្រសិនបើមាននរណាម្នាក់ត្រូវគេវាយរូបកាយ។
ប្រើឃ្លាផ្សេងទៀតនៃការបកប្រែ: «នឹងទទួលបានការសង្គ្រោះពីព្រះគ្រិស្តយេស៊ូ»

ស្របតាមសិរីរុងរឿងនៅអស់កល្បជានិច្ចវិញ

ប៉ូលនិយាយអំពីការបែរអារម្មណ៍នេះហាក់ដូចជាសំណាញ់ដែលបានទាក់មនុស្សនៅពេលពួកគេ
ជាមួយព្រះអង្គជារៀងរហូតនៅកន្លែងដ៏រុងរឿងដែលព្រះអង្គគង់នៅ» (ULB)

2 Timothy 2:11

ពាក្យទាំងនេះអាចទុកចិត្តបានថា

«ពាក្យទាំងនេះ»

ប្រសិនបើយើងស្លាប់ជាមួយព្រះអង្គ...ព្រោះព្រះអង្គមិនអាចបដិសេធព្រះអង្គផ្ទាល់បានឡើយ

ឃ្លានេះទំនងជាបទចម្រៀង ឬកំណាព្យដែលប៉ូលកំពុងដកស្រង់។
ប្រសិនបើភាសារបស់អ្នកមានវិធីបង្ហាញថានេះជាកំណាព្យអ្នកអាចប្រើឃ្លានេះបាន។
បើមិនដូច្នោះទេអ្នកអាចបកប្រែឃ្លាជាសំដីធម្មតាជាជាងកំណាព្យ។

ស្លាប់ជាមួយព្រះអង្គ

ប៉ូលប្រើឃ្លានេះមានន័យថា មនុស្សចូលរួមក្នុងការសុគតរបស់ព្រះគ្រិស្ត
នៅពេលពួកគេទុកចិត្តលើទ្រង់ ហើយបដិសេធសេចក្តីប៉ងប្រាថ្នារបស់ខ្លួន

ប្រសិនបើយើងមិនស្មោះត្រង់ក៏ដោយ

«ទោះបីយើងភ្លេចព្រះក៏ដោយ» ឬ
«ទោះបីជាយើងមិនបានធ្វើតាមអ្វីដែលយើងជឿថាព្រះចង់អោយយើងធ្វើក៏ដោយ»

ព្រះអង្គមិនអាចបដិសេធព្រះអង្គផ្ទាល់បានឡើយ

«ព្រះអង្គត្រូវតែសម្តែងសកម្មភាពតាមរយៈបុគ្គលិកលក្ខណៈរបស់ព្រះអង្គ» ឬ
«ព្រះអង្គមិនអាចសម្តែងសកម្មភាពតាមរបៀបដែលផ្ទុយពីបុគ្គលិកលក្ខណៈពិតរបស់ព្រះអង្គទេ»

2 Timothy 2:14

ព័ត៌មានទូទៅ៖

ពាក្យថា «ពួកគេ» សំដៅទៅលើ «គ្រូបង្រៀន» ឬ «មនុស្សក្នុងក្រុមជំនុំ»

នៅចំពោះមុខព្រះជាម្ចាស់

ប៉ូលនិយាយអំពីការជ្រាប់ច្បាស់របស់ព្រះជាម្ចាស់ចំពោះប៉ូលដូចជាប៉ូលស្ថិតនៅក្នុងវត្តមានរបស់ព្រះ។
ឃ្លានេះបញ្ជាក់អំពីព្រះនឹងធ្វើជាសាក្សីរបស់ធីម៉ូថេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅក្នុងវត្តមានរបស់ព្រះ» ឬ «ដោយព្រះជាសាក្សីរបស់អ្នក»

generated on Wed Sep 10 16:16:32 2025

កុំឲ្យឈ្លោះប្រកែកគ្នាពីអត្ថន័យរបស់ពាក្យឡើយ
«មិនត្រូវជជែកវែកញែកលើពាក្យអ្វីដែលមានន័យទេ» ឬ
«កុំជជែកតវ៉ាអំពីរឿងល្ងីល្ងើដែលមនុស្សនិយាយ»
ព្រោះពាក្យទាំងនេះឥតប្រយោជន៍ទេ
«ពាក្យនេះគ្មានប្រយោជន៍ដល់អ្នកណាម្នាក់ទេ»
ពាក្យទាំងនេះនាំឲ្យអន្តរាយដល់អស់អ្នកស្តាប់
រូបភាពនេះគឺជាការបំផ្លិចបំផ្លាញការសាងសង់។
អស់អ្នកដែលបានស្តាប់ការឈ្លោះប្រកែក បានឈប់គោរពសាររបស់គ្រីស្ទាន។
ជំនឿរបស់ពួកគេត្រូវបានបំផ្លាញ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះគ្រាន់តែបំផ្លាញជំនឿរបស់អ្នកដែលស្តាប់»
នៅចំពោះព្រះជាម្ចាស់ដែលបានទទួលអ្នក ជាអ្នកបំពេញការងារ
ដោយគ្មានហេតុផលណាត្រូវអៀនខ្មាស
«ដើម្បីបង្ហាញខ្លួនអ្នកចំពោះព្រះក្នុងនាមជាមនុស្សម្នាក់ដែលព្រះអង្គបានបង្ហាញថាសមនឹងទទួលបាន
ហើយគ្មានមូលហេតុដែលត្រូវអាម៉ាស់មុខនោះទេ»
ជាអ្នកបំពេញការងារ
«ដូចជាកម្មករ» ឬ «ដូចជាអ្នកធ្វើការ»។
ប៉ូលបង្ហាញគំនិតរបស់ធីម៉ូថេពន្យល់យ៉ាងត្រឹមត្រូវនូវព្រះបន្ទូលរបស់ព្រះដូចជាគាត់ជាអ្នកធ្វើការដ៏ប៉ិនប្រសប់
ដែលបានបង្រៀនព្រះបន្ទូលនៃសេចក្តីពិត យ៉ាងត្រឹមត្រូវ
ត្រង់ពាក្យថា «ព្រះបន្ទូល» មានន័យថាជាសារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការពន្យល់ពីសារដែលពិតត្រឹមត្រូវ»
2 Timothy 2:16
ដែលនាំយើងកាន់តែលែងគោរពប្រតិបត្តិព្រះជាម្ចាស់
ប៉ូលនិយាយអំពីការនិយាយបែបនេះហាក់ដូចជាអ្វីមួយដែលអាចផ្លាស់ទីនៅទៅទីតាំងផ្សេងទៀត
ហើយលោកនិយាយអំពីភាពគ្មានព្រះហាក់ដូចជាកន្លែងថ្មីនោះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបណ្តាលឲ្យមនុស្សក្លាយជាមនុស្សដែលមិនគោរពព្រះ»
ការនិយាយរបស់ពួកគេនឹងប្រៀបបីដូចជាដំបៅរលួយ
ដូចជាដំបៅរលួយដែលរាលដាលពាសពេញរាងកាយរបស់មនុស្សយ៉ាងលឿន
ហើយបំផ្លាញវា
អ្វីដែលមនុស្សទាំងនោះកំពុងនិយាយនឹងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត
ហើយធ្វើឲ្យអន្តរាយដល់ជំនឿរបស់អ្នកដែលបានឮផង
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលពួកគេនិយាយនឹងរាលដាលដូចជាជំងឺឆ្លង» ឬ
«ការនិយាយរបស់ពួកគេនឹងរីករាលដាលយ៉ាងឆាប់រហ័ស
និងបណ្តាលឲ្យមានការបំផ្លាញដូចជាដំបៅរលួយ»
ដំបៅរលួយ
«ស្លាប់ សាច់រលួយ»។ មានវិធីតែមួយគត់ ដើម្បីកុំអោយដំបៅរលួយឆ្លងរាលដាល
និងសម្លាប់អ្នកជម្ងឺគឺកាត់កន្លែងដែលឈឺនោះចេញ។
ហ៊ីមេនាស និងភីលេតជាដើម
ទាំងនេះជាឈ្មោះរបស់បុរស។
បានភ្លេចសេចក្តីពិត
ប៉ូលនិយាយអំពីការពិតហាក់ ដូចជាគោលដៅដែលត្រូវតម្រង់ទិសដៅ។
ប៉ូលមានន័យថាបុរសទាំងនេះមិនបានយល់ពីសេចក្តីពិត
ហើយកំពុងបង្រៀនអ្វីដែលមិនពិត។
ការរស់ឡើងវិញបានកើតឡើងរួចមកហើយ
«ព្រះជាម្ចាស់បានប្រោសអ្នកជឿដែលបានស្លាប់ទៅហើយឲ្យមានជីវិតអស់កល្បជានិច្ច
ពួកគេក៏បានបង្វែរជំនឿអ្នកខ្លះដែរ
ប៉ូលនិយាយអំពីការបំផ្លាញជំនឿរបស់មនុស្សហាក់ដូចជាជំនឿរបស់ពួកគេត្រូវបានបំផ្លាញ
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេបំផ្លាញជំនឿរបស់មនុស្សមួយចំនួន» ឬ
«ពួកគេបណ្តាលឲ្យមនុស្សមួយចំនួនបញ្ឈប់ការជឿ»
2 Timothy 2:19
ព័ត៌មានទូទៅ៖
ដូចជាប្រអប់ដ៏មានតម្លៃ
និងសាមញ្ញអាចត្រូវបានប្រើសម្រាប់ការគោរពក្នុងផ្ទះអ្នកមាន
អ្នកដែលត្រលប់ទៅរកព្រះ អាចត្រូវបានប្រើដោយព្រះជាម្ចាស់
តាមរបៀបកិត្តិយសក្នុងការធ្វើអំពើល្អ។
ចូរចាក់ឫសរឹងមាំលើព្រះជាម្ចាស់
អត្ថន័យដែលអាចមានគឺ ១) «សេចក្តីពិតរបស់ព្រះគឺដូចជាគ្រឹះរឹងមាំ» ឬ ២)
«ព្រះបានតាំងរាស្ត្ររបស់ព្រះអង្គដូចការសាងសង់នៅលើដ៏គ្រឹះរឹងមាំ» ឬ ៣)
«ភាពស្មោះត្រង់របស់ព្រះប្រៀបដូចជាគ្រឹះដ៏រឹងមាំ។
ក្នុងករណីណាក៏ដោយប៉ូលនិយាយអំពីគំនិតនេះហាក់ដូចជាគ្រឹះនៃអាគារមួយត្រូវបានសង់នៅលើដី។
អស់អ្នកដែលអំពាវនាវរកព្រះនាមព្រះជាម្ចាស់
«អស់អ្នកដែលអំពាវនាវរកព្រះនាមព្រះជាម្ចាស់» ត្រង់ឃ្លាថា
«ព្រះនាមព្រះជាម្ចាស់» សំដៅទៅលើព្រះជាម្ចាស់ដោយផ្ទាល់។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលស្រែករកព្រះជាម្ចាស់» ឬ
«អ្នកដែលនិយាយថា គេជាអ្នកដែលជឿលើព្រះជាម្ចាស់»
ត្រូវញែកខ្លួនចេញអំពើទុច្ចរិត
ប៉ូលនិយាយអំពីភាពទុច្ចរិតហាក់ដូចជាកន្លែងដែលមនុស្សអាចចាកចេញពីទីនោះបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ឈប់ធ្វើអំពើអាក្រក់» ឬ «ឈប់ធ្វើខុស»
ពុំមែនមានត្រឹមតែមាស និងប្រាក់ប៉ុណ្ណោះទេ...ឧធ្វើពីឈើ និងពីដីដែរ
ត្រង់ពាក្យថា «ប្រដាប់» គឺជាពាក្យទូទៅសម្រាប់ ចានគោម ចាន និងឆ្នាំង
ដែលមនុស្សដាក់អាហារ ឬទឹក ខាងក្នុង ឬ ពីលើ។
ប្រសិនបើភាសារបស់អ្នកមិនមានពាក្យទូទៅ សូមប្រើពាក្យ «ចាន» ឬ «ឆ្នាំង»។
ប៉ូលកំពុងប្រើរបស់នេះជាពាក្យប្រៀបធៀប
ដើម្បីពិពណ៌នាអំពីប្រភេទមនុស្សផ្សេងៗគ្នា។
ប្រើសម្រាប់ការអាប់ឱន
អត្ថន័យដែលអាចមានគឺ ១) «ជាឱកាសពិសេស ... ពេលវេលាធម្មតា» (UDB) ឬ
២) «ប្រភេទសកម្មភាពដែលមនុស្សធ្វើនៅទីសាធារណៈ ...
ប្រភេទសកម្មភាពដែលមនុស្សធ្វើជាឯកជនភាព»។
សម្អាតខ្លួនឯងពីការអាប់ឱន
អត្ថន័យដែលអាចមានគឺ ១) «បំបែកខ្លួនពីមនុស្សទុច្ចរិត» ឬ ២)
«ធ្វើឲ្យខ្លួនគាត់បរិសុទ្ធ»។
ក្នុងករណីណាក៏ដោយប៉ូលនិយាយអំពីដំណើរការនេះប្រសិនបើមនុស្សម្នាក់លាងសម្អាតខ្លួន។
គាត់នឹងបានប្រដាប់ល្អប្រសើរ
ប៉ូលនិយាយអំពីមនុស្សនេះហាក់ដូចជាគេជាប្រដាប់ដែលល្អប្រសើរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គេដូចជាប្រអប់ដែលមានប្រយោជន៍សម្រាប់ឱកាសពិសេស» ឬ
«គេដូចជាប្រដាប់ដែលមានប្រយោជន៍សម្រាប់សកម្មភាពដែលមនុស្សល្អធ្វើនៅទីសាធារណៈ»
គាត់បានញែកខ្លួនដោយឡែក ក៏មានប្រយោជន៍ដល់ចៅហ្វាយ
ហើយបានរៀបចំសម្រាប់គ្រប់ការល្អទាំងអស់ផងដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចៅហ្វាយ បានចែកគាត់ដាច់ពីគ្នា
ហើយគាត់បានត្រៀមខ្លួនជាស្រេចសម្រាប់ចៅហ្វាយដើម្បីប្រើគាត់ឲ្យធ្វើការងារល្អៗ»
គាត់បានញែកខ្លួនដោយឡែក
គាត់មិនត្រូវបានញែកដាច់ពីគ្នាខាងរាងកាយ ឬក្នុងន័យនៃទីតាំងនោះទេ
ប៉ុន្តែផ្ទុយទៅវិញដើម្បីបំពេញគោលបំណង។ ការបកប្រែខ្លះបកប្រែពាក្យនេះថា
«បរិសុទ្ធ» ប៉ុន្តែអត្ថបទបង្ហាញពីគំនិតសំខាន់នៃការញែកចេញពីគ្នា។
2 Timothy 2:22
ចូរចៀសចេញពីសេចក្តីស្រើបស្រាលរបស់ក្មេងៗ
ប៉ូលនិយាយអំពីចំណង់តណ្ហារបស់យុវវ័យប្រសិនបើពួកគេជាមនុស្សគ្រោះថ្នាក់
ឬសត្វដែលធីម៉ូថេគួររត់គេច។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចៀសវាងទាំងស្រុងនូវតណ្ហាយុវវ័យ» ឬ
«បដិសេធដាច់ខាតមិនធ្វើអ្វីដែលយុវជនចង់ធ្វើខ្លាំង»
ត្រូវប្រកាន់ខ្ជាប់សេចក្តីសុចរិត
ត្រង់ពាក្យថា «ត្រូវប្រកាន់ខ្ជាប់» មានន័យផ្ទុយពីពាក្យ «រត់គេចខ្លួន»។
ប៉ូលនិយាយអំពីសេចក្តីសុចរិតហាក់ដូចការនេះនឹងធ្វើឲ្យធីម៉ូថេល្អ
ដែលគាត់គួរតែរត់ឆ្ពោះទៅរកសេចក្តីសុចរិត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរព្យាយាមអស់ពីសមត្ថភាពដើម្បីទទួលបានសេចក្តីសុចរិត» ឬ
«ស្វែងរកសេចក្តីសុចរិត»
មួយអ្នក
អត្ថន័យដែលអាចមានគឺ ១)
ប៉ូលចង់ឲ្យធីម៉ូថេចូលរួមជាមួយអ្នកជឿផ្សេងទៀតក្នុងការស្វែងរកសេចក្តីសុចរិត
ជំនឿ សេចក្តីស្រឡាញ់ និងសន្តិភាព ឬទី ២) ប៉ូលចង់ឲ្យធីម៉ូថេមានសន្តិភាព
ហើយមិនប្រកែកជាមួយអ្នកជឿផ្សេងទៀត។
មួយអ្នក ដែលស្រែករកព្រះជាម្ចាស់
ត្រង់ពាក្យ «ស្រែករកព្រះជាម្ចាស់» គឺជាពាក្យប្រៀបធៀបដែលមានន័យថាទុកចិត្ត
និងថ្វាយបង្គំព្រះជាម្ចាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកណាដែលថ្វាយបង្គំព្រះជាម្ចាស់»

generated on Wed Sep 10 16:16:32 2025

អស់អំពីចិត្តបរិសុទ្ធវិញ
ប៉ូលនិយាយអំពីហេតុផលរបស់នរណាម្នាក់ដែលអំពាវនាវដូចជាព្រះមានចលនាដែលជួយសង្គ្រោះ
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយមានបំណងចិត្តស្មោះត្រង់» ឬ
«សម្រាប់ហេតុផលល្អ»
អំពីចិត្តបរិសុទ្ធវិញ
ប៉ូលនិយាយអំពីហេតុផលដែលល្អសម្រាប់ធ្វើអ្វីៗដូចជាសេចក្តីនេះចេញមកចិត្តដែលស្អាតជ
ត្រូវបដិសេធសេចក្តីចោលម្សៀត និងសំណួរល្ងង់ខ្លៅវិញ
«បដិសេធមិនឆ្លើយសំណួរល្ងីល្ងើ និងល្ងង់ខ្លៅ»។
ប៉ូលមានន័យថាមនុស្សដែលសួរសំណួរបែបនេះគឺល្ងីល្ងើ ហើយល្ងង់ខ្លៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «បដិសេធមិនឆ្លើយសំណួរដែលមនុស្សល្ងីល្ងើ
ជាអ្នកដែលមិនចង់ដឹងសំនួរពិត»
សេចក្តីទាំងនេះនាំមកនូវការឈ្លោះប្រកែកគ្នា
ប៉ូលនិយាយអំពីសំណួរល្ងង់ខ្លៅដូចសេចក្តីទាំងនេះជាស្ត្រីផ្តល់កំណើតឲ្យកូន។
របៀបផ្សេងទៀតនៃការបកប្រែ: «សំណួរល្ងង់ខ្លៅបង្កឲ្យមានការឈ្លោះប្រកែកគ្នា»
2 Timothy 2:24
អប់រំ
«ដោយសុភាពរាបសា» ឬ «ថ្នមៗ»
ប្រដៅអប់រំអ្នក
«បង្រៀនអស់អ្នក» ឬ «កែតម្រូវអស់អ្នក»
ព្រះជាម្ចាស់នឹងធ្វើឲ្យពួកគេប្រែចិត្ត
ដែលមានន័យថាការនេះជាអ្វីមួយដែលព្រះអាចផ្តល់ឲ្យមនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់អាចនឹងផ្តល់ឲ្យពួកគេនូវឱកាសដើម្បីប្រែចិត្ត»
ដើម្បីឲ្យបានដឹងពីសេចក្តីពិតវិញ
«ដើម្បីពួកគេនឹងដឹងការពិត»
ពួកគេនឹងភ្ញាក់ខ្លួនឡើងវិញ
ប៉ូលនិយាយអំពីមនុស្សមានបាបរៀនគិតឲ្យបានត្រឹមត្រូវអំពីព្រះដូចជាពួកគេស្រវឹងហើយចាប់ផ្តើមភ្ញាក់ដឹ
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេប្រហែលជាគិតត្រឹមត្រូវម្តងទៀត» (UDB)
ហើយចាកចេញពីអន្ទាក់របស់អារក្ស
ប៉ូលនិយាយអំពីសមត្ថភាពរបស់អារក្ស
ដើម្បីបញ្ចុះបញ្ចូលគ្រីស្ទបរិស័ទឲ្យធ្វើបាបដូចអារក្សជាអន្ទាក់។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយឈប់ធ្វើអ្វីដែលអារក្សចង់បាន»
ដែលបានទាក់ពួកគេជាប់ដើម្បីបម្រើគោលបំណងរបស់វា
ប៉ូលនិយាយអំពីអំពើនៅពេលសាតាំង
បញ្ចុះបញ្ចូលគ្រិស្តបរិស័ទឲ្យប្រព្រឹត្តអំពើបាប ហាក់ដូចជាអារក្សបានចាប់ពួកគេ
ហើយធ្វើឲ្យពួកគេក្លាយជាទាសកររបស់វា។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់ពីវាបានបោកបញ្ឆោតពួកគេឲ្យស្តាប់បង្គាប់វា»

---

3 [1]សូមដឹងថា នៅថ្ងៃចុងក្រោយនឹងមានទុក្ខលំបាកខ្លាំង។[2]ដ្បិត មនុស្សនឹងស្រឡាញ់តែខ្លួនឯង ជាអ្នកស្រឡាញ់ប្រាក់ មានអំនួត ក្រអឺតក្រទម ប្រមាថមើលងាយ
មិនស្តាប់បង្គាប់ឪពុកម្តាយ មិនដឹងគុណ ហើយមានចិត្តមិនបរិសុទ្ធ។[3]ពួកគេមិនស្រឡាញ់តាមរបៀបធម្មជាតិរបស់មនុស្ស មានចិត្តឃោរឃៅ និយាយមួលបង្កាច់គេ
មិនចេះទប់ចិត្ត ប្រើអំពើហឹង្សា មិនចូលចិត្តការល្អ។[4]ពួកគេមានចិត្តក្បត់ មានចិត្តធំ ចូលចិត្តនឹងការសប្បាយ ជាជាងស្រឡាញ់ព្រះជាម្ចាស់។
[5]ពួកគេមានលក្ខណៈជាអ្នកគោរពប្រតិបត្តិដល់ព្រះជាម្ចាស់ ប៉ុន្តែ ពួកគេបដិសេធព្រះចេស្តារបស់ព្រះអង្គ។ ចូរបែរចេញពីមនុស្សអស់ទាំងនោះ។[6]ដ្បិត
ក្នុងចំណោមពួកទាំងនោះ ជាមនុស្សចូលចិត្តចូលទៅផ្ទះរបស់គេ ហើយធ្វើឲ្យស្រីៗដែលល្ងង់ចាប់អារម្មណ៍។ ស្ត្រីទាំងនោះពោរពេញដោយអំពើបាប
ហើយបណ្តាយតាមសេចក្តីប៉ងប្រាថ្នាផ្សេងៗ។[7]ស្ត្រីទាំងនោះតែងតែរៀនជានិច្ច ប៉ុន្តែពួកគេមិនអាចយល់ដល់សេចក្តីពិតឡើយ។
[8]ដូចគ្នានេះដែរ យ៉ានេស និងយ៉ាមប្រេសបានទាស់ទទឹងនឹងលោកម៉ូសេ។ ហើយគ្រូបង្រៀនខុសឆ្គងតែងតែឈរទាស់ប្រឆាំងនឹងសេចក្តីពិត។
ពួកគេជាមនុស្សដែលមានគំនិតខូច ហើយជំនឿរបស់ពួកគេក៏ឥតប្រយោជន៍ដែរ។[9]ប៉ុន្តែ ពួកគេមិនមានការចម្រើនឡើងទៅមុខទៀតបានឡើយ។
ដ្បិតភាពល្ងង់ខ្លៅរបស់ពួកគេនឹងបើកបង្ហាញឲ្យមនុស្សទាំងអស់បានដឹងច្បាស់ ដូចជាភាពល្ងង់ខ្លៅរបស់បុរសទាំងនោះដែរ។
[10]ប៉ុន្តែ សម្រាប់អ្នកវិញ អ្នកបានដើរតាមសេចក្តីដែលខ្ញុំបង្រៀន កិរិយាប្រព្រឹត្ត បំណងចិត្ត ជំនឿ សេចក្តីស្រឡាញ់ ការអំណត់អត់ទ្រាំ។[11]ការបៀតបៀន ទុក្ខលំបាក
និងអ្វីដែលបានកើតឡើងមកលើខ្ញុំ នៅក្រុងអាន់ទីយ៉ូក ក្រុងអ៊ីកូនាម និងក្រុងលីស្ត្រា។ ខ្ញុំបានស៊ូទ្រាំនឹងសេចក្តីបៀតបៀន។ មិនដូចជាពួកគេទាំងនោះទេ
ព្រះអម្ចាស់បានប្រោសខ្ញុំវិញ។[12]អស់អ្នកដែលចង់រស់ក្នុងការគោរពប្រតិបត្តិព្រះគ្រិស្តយេស៊ូ នោះនឹងទទួលការបៀតបៀនផងដែរ។[13]មនុស្សអាក្រក់ និងពួកឆបោក
ព្រមទាំងមានសេចក្តីអាក្រក់កាន់តែខ្លាំងឡើងៗ។ ពួកគេនឹងនាំអ្នកផ្សេងទៀតឲ្យវង្វេង ដូចជាពួកគេនាំខ្លួនឯងឲ្យវង្វេងដែរ។
[14]ប៉ុន្តែ សម្រាប់អ្នក ចូរនៅជាប់អ្វីដែលអ្នកបានរៀន ហើយត្រូវជឿយ៉ាងប្រាកដវិញ។ អ្នកត្រូវដឹងថាសេចក្តីបង្រៀននេះបានមកពីអ្នកណា។[15]អ្នកដឹងហើយថា
តាំងពីក្មេងមក អ្នកបានស្គាល់បទគម្ពីរដ៏វិសុទ្ធ។ សេចក្តីទាំងនេះអាចធ្វើឲ្យអ្នកមានប្រាជ្ញា រហូតទទួលការសង្គ្រោះ ដោយសារជំនឿក្នុងព្រះគ្រិស្តយេស៊ូ។
[16]គ្រប់បទគម្ពីរទាំងអស់ សុទ្ធតែព្រះជាម្ចាស់បណ្តាលឲ្យតាក់តែងឡើង។ មានប្រយោជន៍សម្រាប់បង្រៀន កែតម្រង់ និងបណ្តុះបណ្តាលតាមសេចក្តីសុចរិត។[17]ដូច្នេះ
អ្នកសំណព្វរបស់ព្រះជាម្ចាស់មានសមត្ថភាព និងទទួលការបំប៉ន ដើម្បីបំពេញការល្អគ្រប់យ៉ាង។

---

2 Timothy 3:1
ប្រយោគភ្ជាប់៖
ប៉ូលប្រាប់ធីម៉ូថេថានៅពេលអនាគតមនុស្សនឹងងាកចេញពីសេចក្តីពិត។
ហើយទោះបីការបៀតបៀននឹងមកដល់គាត់អាចពឹងផ្អែកលើបទគម្ពីររបស់ព្រះ។
នៅថ្ងៃចុងក្រោយ
អត្ថន័យដែលអាចមានគឺ ១) នេះគឺជាពេលក្រោយជាងពេលរបស់ប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលអនាគត
មុនពេលព្រះយេស៊ូយាងត្រឡប់មកវិញ» ឬ ២)
ឃ្លានេះសំដៅទៅលើសម័យកាលរបស់គ្រិស្ត រួមទាំងពេលរបស់ប៉ូលផង។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្នុងអំឡុងពេលនេះមុនពេលថ្ងៃចុងបញ្ចប់»
មានទុក្ខលំបាកខ្លាំង
ទាំងនេះនឹងជាថ្ងៃ ខែ ឬសូម្បីតែឆ្នាំដែលគ្រិស្តបរិស័ទនឹងស៊ូទ្រាំទុក្ខវេទនា
និងរងគ្រោះថ្នាក់។
ស្រឡាញ់តែខ្លួនឯង
ត្រង់ពាក្យថា «ស្រឡាញ់» សំដៅទៅលើសេចក្តីស្រឡាញ់សម្រាប់បងប្អូន
ឬសេចក្តីស្រឡាញ់ចំពោះមិត្តភក្តិ ឬសមាជិកគ្រួសារ
ដែលជាសេចក្តីស្រឡាញ់របស់មនុស្សពីធម្មជាតិរវាងមិត្តភក្តិ ឬសាច់ញាតិ។
នេះមិនមែនជាសេចក្តីស្រឡាញ់ដែលមកពីព្រះទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គិតតែពីខ្លួនឯង»
អំនួត
និយាយអំពីខ្លួនឯងដោយមោទនភាព
មិនស្រឡាញ់តាមរបៀបធម្មជាតិរបស់មនុស្ស
«មិនការស្រឡាញ់គ្រួសារខ្លួនឯងទេ»
មានចិត្តឃោរឃៅ
«មិនយល់ព្រមជាមួយផ្សេង» ឬ «មិនរស់នៅក្នុងសន្តិភាពជាមួយផ្សេង»
និយាយមួលបង្កាច់គេ
«អ្នកចោទប្រកាន់មិនពិត»
ប្រើអំពើហឹង្សា
«កាចសាហាវ» ឬ «ពួកគេនឹងប្រព្រឹត្តអំពើផ្សេងៗដែលធ្វើឲ្យអ្នកឈឺចាប់ជារឿយៗ»
មិនចូលចិត្តការល្អ
«ស្អប់ការល្អ»
មានចិត្តធំ
«មិនចេះពិចារណា» ឬ «ឆោតល្ងង់»។
នេះមានន័យថាធ្វើអ្វីៗដោយមិនគិតពីផលវិបាក។
អំនួត
«ពួកគេគិតថាពួកគេប្រសើរជាងមនុស្សដទៃទៀត»
2 Timothy 3:5
មានលក្ខណៈជាអ្នកគោរពប្រតិបត្តិដល់ព្រះជាម្ចាស់
ប៉ូលនិយាយអំពីការគោរពប្រតិបត្តិព្រះជាម្ចាស់
ទម្លាប់គោរពប្រតិបត្តិដល់ព្រះជាម្ចាស់ ដូចជារបស់មួយដែលមានរូបរាង។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «លេចមុខជាព្រះ» ឬ
«បង្ហាញខ្លួនដើម្បីគោរពដល់ព្រះជាម្ចាស់»
ពួកគេបដិសេធព្រះចេស្តារបស់ព្រះអង្គ
ប៉ូលនិយាយអំពីភាពជាព្រះហាក់ដូចជាការដែលមានអំណាចខាងសាច់ឈាម។
អត្ថន័យដែលអាចមានគឺ ១)
«ពួកគេនឹងបដិសេធមិនទទួលយកអំណាចដែលព្រះពិតជាចង់ប្រទានដល់ពួកគេ» (UDB)
ឬ ២)
«ជីវិតរបស់ពួកគេនឹងមិនបង្ហាញភស្តុតាងណាមួយអំពីភាពជាព្រះដែលពួកគេនិយាយថាពួកគេមាន»
ចូរបែរចេញ
ប៉ូលប្រហែលជាកំពុងនិយាយអំពីការងាកចេញពីមនុស្សទាំងនេះ
ប៉ុន្តែគាត់ចង់អោយអ្នកអានធ្វើអ្វីៗដែលពួកគេអាចធ្វើបាន
ដើម្បីចៀសចេញពីពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចៀសចេញពីមនុស្សទាំងនេះ»
មនុស្សចូលចិត្តចូលទៅផ្ទះរបស់គេ
«ចូលទៅក្នុងផ្ទះ និងមានឥទ្ធិពលយ៉ាងខ្លាំង»
ធ្វើឲ្យស្រីៗដែលល្ងង់ចាប់អារម្មណ៍
«ស្ត្រីដែលខ្សោយខាងវិញ្ញាណ»។
នេះអាចមកពីពួកគេមិនបានធ្វើការដើម្បីក្លាយជាមនុស្សដែលគោរពព្រះជាម្ចាស់
ឬដោយសារតែពួកគេខ្ជិល និងមានបាបជាច្រើន។
ស្ត្រីទាំងនោះពោរពេញដោយអំពើបាប
ប៉ូលនិយាយអំពីភាពទាក់ទាញនៃអំពើបាបដូចជាអំពើបាបត្រូវបានប្រមូលផ្តុំនៅលើខ្នងស្ត្រីទាំងនេះ។
អត្ថន័យដែលអាចមានគឺ ១) «អ្នកដែលធ្វើបាបញឹកញាប់» ឬ ២)
«អ្នកដែលមានអារម្មណ៍ថាខ្លួនមានកំហុសគួរឲ្យខ្លាច ព្រោះពួកគេបន្តធ្វើបាប»។
យោបល់នេះគឺថាបុរសទាំងនេះអាចមានឥទ្ធិពលលើស្ត្រីទាំងនេះយ៉ាងងាយស្រួល
ព្រោះស្ត្រីមិនអាចបញ្ឈប់អំពើបាបបានទេ។
ហើយបណ្តាយតាមសេចក្តីប៉ងប្រាថ្នាផ្សេងៗ
ប៉ូលនិយាយអំពីបំណងប្រាថ្នាផ្សេងៗដូចជាសេចក្តីប៉ងប្រាថ្នានេះអាចនាំមនុស្សម្នាក់ទៀតឆ្ងាយ
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយពួកគេចង់ធ្វើបាបតាមវិធីផ្សេងៗជាជាងស្តាប់តាមព្រះគ្រីស្ទ»
2 Timothy 3:8
ប្រយោគភ្ជាប់៖
ប៉ូលបានលើកឧទាហរណ៍អំពីគ្រូក្លែងក្លាយពីរនាក់តាំងពីជំនាន់លោកម៉ូសេ
ហើយអនុវត្តវាតាមរបៀបដែលមនុស្សនឹងធ្វើ។ គាត់លើកទឹកចិត្តធីម៉ូថេឲ្យ
ធ្វើតាមគំរូរបស់ប៉ូល ហើយនៅជាប់នឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។
យ៉ាន៊េស និងយ៉ាមប្រេស
ឈ្មោះទាំងពីរនេះមានតែនៅក្នុងព្រះគម្ពីរទេ។
ប្រពៃណីបុរាណមួយដាក់ឈ្មោះពួកគេថា
ជាគ្រូមន្តអាគមអេហ្ស៊ីបដែលប្រឆាំងនឹងម៉ូសេក្នុងគម្ពីរនិក្ខមនំ។
បានទាស់ទទឹងនឹង
ប៉ូលនិយាយអំពីអ្នកដែលប្រកែកនឹងនរណាម្នាក់ដូចជាពួកគេកំពុងប្រឆាំងនឹងលោក។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រឆាំង»
ឈរទាស់ប្រឆាំងនឹងសេចក្តីពិត
«ប្រឆាំងនឹងដំណឹងល្អរបស់ព្រះយេស៊ូ»
ពួកគេជាមនុស្សដែលមានគំនិតខូច
«ពួកគេលែងចេះគិតត្រឹមត្រូវទៀតហើយ»
ហើយជំនឿរបស់ពួកគេក៏ឥតប្រយោជន៍ដែរ
ពួកគេត្រូវបានសាកល្បងថាតើពួកគេជឿជាក់លើព្រះគ្រីស្ទ
និងស្តាប់បង្គាប់ព្រះអង្គយ៉ាងដូចម្តេច ហើយពួកគេបានបរាជ័យក្នុងការសាកល្បង។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយគ្មានជំនឿស្មោះត្រង់» ឬ
«ហើយពួកគេបានបង្ហាញថាជំនឿរបស់ពួកគេគឺមិនពិត»
ភាពល្ងង់ខ្លៅរបស់ពួកគេនឹងបើកបង្ហាញឲ្យមនុស្សទាំងអស់បានដឹងច្បាស់
ប៉ូលប្រើការបញ្ចេញមតិអំពីចលនារាងកាយ
ដើម្បីមានន័យថាគ្រូក្លែងក្លាយនឹងមិនទទួលបានជោគជ័យច្រើនក្នុងចំណោមអ្នកជឿទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងមិនទទួលបានជោគជ័យច្រើនទេ»
ភាពល្ងង់ខ្លៅ
«ខ្វះការយល់ដឹង» ឬ «ល្ងីល្ងើ»
ដឹងច្បាស់
«ងាយស្រួលយល់»
របស់បុរសទាំងនោះដែរ

«របស់យ៉ាន៊េស និងយ៉ាមប្រេស»
2 Timothy 3:10
អ្នកបានដើរតាមសេចក្តីដែលខ្ញុំបង្រៀន
ប៉ូលនិយាយអំពីការយកចិត្តទុកដាក់យ៉ាងខ្លាំង
ចំពោះរឿងទាំងនេះដូចជាមនុស្សម្នាក់កំពុងដើរតាមសេចក្តីនេះនៅពេលពួកគេដើរ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកបានសង្កេត» ឬ
«អ្នកបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការបង្រៀនរបស់ខ្ញុំ»
ឃ្លានេះមាននោះទេ»។
«កែណែនាំ»
កិរិយាប្រព្រឹត្ត
«របៀបនៃជីវិត»
ការអំណត់អត់ទ្រាំ
«អត់ធ្មត់ជាមួយមនុស្ស»
អំណត់
«ការស៊ូទ្រាំក្នុងស្ថានភាពពិបាក»
មិនដូចជាពួកគេទាំងនោះទេ ព្រះអម្ចាស់បានប្រោសខ្ញុំវិញ
ប៉ូលនិយាយអំពីព្រះជាម្ចាស់ដែលបានរារាំងគាត់មិនឲ្យ រងទុក្ខលំបាក
និងជួបគ្រោះថ្នាក់ទាំងនេះហាក់ដូចជាព្រះជាម្ចាស់បានយកគាត់ចេញពីកន្លែងមួយ។
ចង់រស់ក្នុងការគោរពប្រតិបត្តិព្រះគ្រិស្តយេស៊ូ
«ដើម្បីរស់នៅក្នុងជីវិតដែលគោរពព្រះជាអ្នកដើរតាមព្រះយេស៊ូ»
ស្ត្រីទាំងនេះ។
ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រាកដជាត្រូវស៊ូទ្រាំការបៀតបៀន»
ពួកឆបោក
«អ្នកបោកប្រាស់» ឬ «មនុស្សដែលធ្វើពុតខុសពីការពិតរបស់ពួកគេ»
អាក្រក់កាន់តែខ្លាំងឡើងៗ
«នឹងកាន់តែអាក្រក់ទៅៗ»
ពួកគេនឹងនាំអ្នកផ្សេងទៀតឲ្យវង្វេង
«ពួកគេនឹងធ្វើឲ្យមនុស្សមិនគោរពតាមព្រះគ្រិស្ត»
ដូចជាពួកគេនាំខ្លួនឯងឲ្យវង្វេងដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយមនុស្សផ្សេងទៀតនឹងបណ្តាលឲ្យពួកគេមិនគោរពតាមព្រះគ្រិស្ត»
2 Timothy 3:14
ចូរនៅជាប់អ្វីដែលអ្នកបានរៀន
ប៉ូលនិយាយអំពីការណែនាំក្នុងគម្ពីរដូចជាកន្លែងដែលធីម៉ូថេអាចស្នាក់នៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំភ្លេចអ្វីដែលអ្នកបានរៀន» ឬ
«បន្តធ្វើអ្វីដែលអ្នកបានរៀន»
បានស្គាល់បទគម្ពីរដ៏វិសុទ្ធ។ សេចក្តីទាំងនេះអាចធ្វើឲ្យអ្នកមានប្រាជ្ញា រហូតទទួលការសង្គ្រោះ
ដោយសារជំនឿក្នុងព្រះគ្រិស្តយេស៊ូ
ប៉ូលនិយាយអំពីបទគម្ពីរដ៏វិសុទ្ធដូចជាបទគម្ពីរដ៏វិសុទ្ធជាមនុស្សម្នាក់ដែលអាចធ្វើឲ្យអ្នកដទៃមានប្រាជ្ញា។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលអ្នកអានព្រះបន្ទូលរបស់ព្រះអ្នកអាចមានប្រាជ្ញា
ដើម្បីទទួលការសង្គ្រោះពីព្រះគ្រីស្ទយេស៊ូតាមរយៈសេចក្តីជំនឿ»
2 Timothy 3:16
គ្រប់បទគម្ពីរទាំងអស់ សុទ្ធតែព្រះជាម្ចាស់បណ្តាលឲ្យតាក់តែងឡើង
«គ្រប់ទាំងបទគម្ពីរគឺជាដកដង្ហើមរបស់ព្រះជាម្ចាស់»។
នេះមានន័យថាព្រះបានតាក់តែងបទគម្ពីរតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ដោយប្រាប់មនុស្សអំពីអ្វីដែលត្រូ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានមានបន្ទូលបទគម្ពីរទាំងអស់តាមរយៈព្រះវិញ្ញាណរបស់ព្រះអង្គ»
មានប្រយោជន៍
«មានប្រយោជន៍» ឬ «មានអត្ថប្រយោជន៍»
កែតម្រង់
«សម្រាប់ចង្អុលបង្ហាញកំហុស»
កែតម្រង់
«សម្រាប់ការជួសជុលកំហុស»
បណ្តុះបណ្តាលតាមសេចក្តីសុចរិត
«សម្រាប់ការបណ្តុះបណ្តាលមនុស្សឲ្យក្លាយជាមនុស្សសុចរិត»
អ្នកសំណព្វរបស់ព្រះជាម្ចាស់
ឃ្លានេះមានន័យថាអ្នកជឿលើព្រះជាម្ចាស់មិនថាប្រុស ឬស្រី។

generated on Wed Sep 10 16:16:32 2025

4 [1]ខ្ញុំសូមផ្តាំយ៉ាងអស់ពីចិត្តនៅចំពោះព្រះជាម្ចាស់ និងព្រះគ្រិស្តយេស៊ូ ដែលព្រះអង្គនឹងជំនុំជម្រះអស់ទាំងមនុស្សរស់ និងមនុស្សស្លាប់
គឺដោយសារតែដំណើរយាងមករបស់ព្រះអង្គ ព្រមទាំងព្រះរាជ្យរបស់ព្រះអង្គផងដែរ[2]ចូរប្រកាសព្រះបន្ទូលចុះ។ ចូរឲ្យត្រៀមខ្លួនទទួលភាពស្រណុកសុខស្រួល
និងភាពលំបាកផងដែរ។ ត្រូវដាស់តឿនគេ និងស្តីបន្ទោល ហើយកម្លាចិត្តរបស់គេ ដោយការអត់ធ្មត់ និងការបង្រៀនគ្រប់បែបយ៉ាង។
[3]ដ្បិតនឹងមានពេលវេលាមួយមកដល់ គឺនៅពេលមនុស្សមិនទ្រាំទ្រនឹងសេចក្តីបង្រៀនត្រឹមត្រូវទៀតបាន។ ផ្ទុយទៅវិញ ពួកគេនឹងប្រមូលគ្រូបង្រៀនជាច្រើន
យល់ស្របតាមបំណងប្រាថ្នារបស់ពួកគេ។ សេចក្តីបង្រៀនទាំងនោះគ្រាន់តែពិរោះដល់ត្រចៀកប៉ុណ្ណោះ។[4]ពួកគេនឹងបែរត្រចៀកឆ្ងាយពីសេចក្តីពិត
ទៅស្តាប់រឿងព្រេងវិញ។[5]ចំពោះអ្នកវិញ ចូរមានចិត្តនឹងធឹងគ្រប់ការទាំងអស់។ ចូរស៊ូទ្រាំនឹងទុក្ខលំបាក និងខំប្រឹងផ្សាយដំណឹងល្អ
ព្រមទាំងបំពេញកិច្ចការបម្រើឲ្យបានល្អផងដែរ។
[6]ដ្បិត ខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីបូជាជីវិត។ ពេលវេលាដែលខ្ញុំត្រូវចាកចេញក៏បានមកដល់ហើយដែរ។[7]ខ្ញុំបានប្រណាំងយ៉ាងល្អ រហូតដល់ទីផ្តាច់ព្រ័ត្រ
ព្រមទាំងបានរក្សាជំនឿយ៉ាងមាំមួន។[8]មកុដនៃសេចក្តីសុចរិតបានរៀបចំជាស្រេចទុកសម្រាប់ខ្ញុំ ដែលព្រះអម្ចាស់ជាចៅក្រមដ៏សុចរិត នឹងប្រទានមកខ្ញុំនៅថ្ងៃនោះ
ហើយពុំមែនសម្រាប់ខ្ញុំតែម្នាក់ទេ ប៉ុន្តែសម្រាប់អស់អ្នកដែលស្រឡាញ់ការយាងមកវិញរបស់ព្រះអង្គ។
[9]ត្រូវខិតខំមកឯខ្ញុំជាប្រញាប់។[10]ដ្បិត លោកដេម៉ាសបានចាកចេញពីខ្ញុំហើយ។ គាត់ស្រឡាញ់លោកីយ៍នេះ ហើយគាត់បានទៅក្រុងថែស្សាឡូនិកហើយ។
លោកក្រេសេនបានទៅស្រុកកាឡាទី ហើយលោកទីតុសបានទៅស្រុកដាល់ម៉ាទា។
[11]មានតែលោកលូកាទេ ដែលនៅជាមួយខ្ញុំ។ ចូរនាំលោកម៉ាកុស ហើយនាំគាត់ទៅជាមួយអ្នកផង ព្រោះគាត់អាចជួយបំពេញកិច្ចការរបស់ខ្ញុំ។
[12]ខ្ញុំបានចាត់លោកទីឃីកុសទៅក្រុងអេភេសូហើយ។[13]អាវធំដែលខ្ញុំធ្វើនៅក្រុងការពួសជាមួយលោកទ្រអាស សូមយកវាពេលដែលអ្នកមកទីនេះ ហើយនិងសៀវភៅ
ជាពិសេសសៀវភៅធ្វើពីស្បែក។
[14]លោកអ័លេក្សានត្រុស ដែលជាជាងស្ពាន់បានប្រព្រឹត្តសេចក្តីអាក្រក់គ្រប់យ៉ាងមកលើខ្ញុំ។ ព្រះអម្ចាស់នឹងតបស្នងដល់គាត់វិញ
ទៅតាមទង្វើដែលគាត់បានប្រព្រឹត្តជាមិនខាន។[15]អ្នកគួរតែប្រយ័ត្នខ្លួនឯងចំពោះការប្រឆាំងទាស់នឹងគាត់ ព្រោះគាត់ប្រឆាំងយ៉ាងខ្លាំងនឹងពាក្យរបស់ពួកយើង។
[16]នៅពេលខ្ញុំការពារខ្លួនដំបូងឡើយ គ្មានអ្នកណាឈរជាមួយខ្ញុំទេ។ ផ្ទុយទៅវិញ គ្រប់គ្នាបោះបង់ខ្ញុំចោល។ សូមកុំឲ្យព្រះជាម្ចាស់ប្រកាន់ទោសគេឡើយ។
[17]ប៉ុន្តែ ព្រះអម្ចាស់បានគង់នៅខាងខ្ញុំ ហើយបានចម្រើនកម្លាំងដល់ខ្ញុំ ដូច្នេះហើយតាមរយៈខ្ញុំ ដំណឹងល្អបានប្រកាសគ្រប់ទីកន្លែង
និងសម្រាប់ឲ្យសាសន៍ដទៃទាំងអស់ដែលបានឮផងដែរ។ ព្រះជាម្ចាស់បានសង្គ្រោះខ្ញុំចេញពីមាត់តោ។[18]ព្រះអម្ចាស់នឹងសង្គ្រោះរូបខ្ញុំ ឲ្យចេញពីការអាក្រក់ទាំងអស់
និងសង្គ្រោះខ្ញុំសម្រាប់ព្រះរាជ្យនៃស្ថានបរមសុខ។ សូមថ្វាយសិរីរុងរឿងដល់ព្រះអម្ចាស់ដ៏នៅអស់កល្បជាអង្វែងតរៀងទៅ! អាម៉ែន។
[19]សូមជម្រាបសួរនាងព្រីសីល លោកអ័គីឡា ហើយទាំងក្រុមគ្រួសាររបស់លោកអូនេស៊ិភ័រផងដែរ។[20]លោកអេរ៉ាស្ទុសដែលស្ថិតនៅក្រុងកូរិនថូស ប៉ុន្តែ លោកទ្រភីម
ខ្ញុំបានទុកគាត់នៅក្រុងមីលេត ព្រោះគាត់មានជំងឺ។[21]សូមមកជាប្រញាប់ មុនរដូវរងាមកដល់។ សូមជម្រាបសួរមក លោកអ៊ើប៊ូឡុស លោកពូដេន លោកលីណុស
និងនាងក្លូឌា ព្រមទាំងបងប្អូនទាំងអស់ដែរ។[22]សូមព្រះអម្ចាស់គង់នៅជាមួយវិញ្ញាណរបស់អ្នក។ សូមព្រះគុណបានស្ថិតនៅជាមួយអ្នកទាំងអស់គ្នា។

2 Timothy 4:1
ប្រយោគភ្ជាប់៖
ប៉ូលនៅតែបន្តរំលឹកធីម៉ូថេឲ្យមានចិត្តស្មោះត្រ
ហើយពេលនោះប៉ូលត្រៀមខ្លួនជាស្រេចក្នុងការស្លាប់។
ផ្តាំយ៉ាងអស់ពីចិត្ត
«សេចក្តីបង្គាប់ដ៏ជាក់លាក់»
ចំពោះព្រះជាម្ចាស់ និងព្រះគ្រិស្តយេស៊ូ
«នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់និងព្រះគ្រិស្តយេស៊ូ»។
ឃ្លានេះបញ្ជាក់ថាព្រះជាម្ចាស់ និងព្រះគ្រិស្តយេស៊ូនឹងធ្វើជាសាក្សីរបស់ប៉ូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាមួយព្រះជាម្ចាស់
និងព្រះគ្រិស្តយេស៊ូជាសាក្សីរបស់ខ្ញុំ»
ទាំងមនុស្សរស់ និងមនុស្សស្លាប់
ត្រង់ពាក្យថា «ទាំងមនុស្សរស់» និង «មនុស្សស្លាប់»
ត្រូវបានប្រើរួមគ្នាដើម្បីមានន័យថាគ្រប់មនុស្សទាំងអស់។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សទាំងអស់ដែលធ្លាប់រស់នៅ»
គឺដោយសារតែដំណើរយាងមករបស់ព្រះអង្គ ព្រមទាំងព្រះរាជ្យរបស់ព្រះអង្គផងដែរ
ត្រង់ពាក្យថា «ព្រះរាជ្យ» តំណាងឲ្យការគ្រប់គ្រងរបស់ព្រះគ្រិស្តជាស្តេច។
របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលព្រះអង្គវិលត្រឡប់មកសោយរាជ្យជាស្តេច»
ព្រះបន្ទូល
ត្រង់ពាក្យថា «ព្រះបន្ទូល» សំដៅទៅលើសារ» របៀបផ្សេងទៀតនៃការបកប្រែ:
«សារអំពីព្រះគ្រិស្ត»
ទទួលភាពស្រណុកសុខស្រួល
ត្រង់ពាក្យថា «ស្រណុកសុខស្រួល» គឺបានយល់ដឹង។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលដែលមិនស្រួល»
ត្រូវដាស់តឿន
«ប្រាប់មនុស្សនៅពេលពួកគេមានកំហុស» ឬ
«ប្រាប់មនុស្សពីអ្វីដែលពួកគេបានធ្វើខុស»
ដោយការអត់ធ្មត់ និងការបង្រៀនគ្រប់បែបយ៉ាង
«ដាស់តឿន និងបង្រៀនមនុស្ស ហើយអត់ធ្មត់នឹងពួកគេ»
2 Timothy 4:3
ដ្បិតនឹងមានពេលវេលាមួយមកដល់
«ពីព្រោះនៅពេលណាមួយនាពេលអនាគត»
មនុស្ស
បរិបទបង្ហាញបញ្ជាក់ថាមនុស្សទាំងនេះគឺជាមនុស្សដែលជាផ្នែកនៃសហគមន៍អ្នកជឿ។
មិនទ្រាំទ្រនឹងសេចក្តីបង្រៀនត្រឹមត្រូវទៀតបាន
«នឹងលែងចង់ស្តាប់ការបង្រៀនល្អទៀតហើយ»
សេចក្តីបង្រៀនល្អ
ពាក្យនេះមានន័យថាការបង្រៀនដែលពិត
និងត្រឹមត្រូវយោងទៅតាមព្រះបន្ទូលរបស់ព្រះ។
ពួកគេនឹងប្រមូលគ្រូបង្រៀនជាច្រើន យល់ស្របតាមបំណងប្រាថ្នារបស់ពួកគេ
ប៉ូលនិយាយអំពីមនុស្សដែលទទួលបានគ្រូជាច្រើនដូចជាកំពុងដាក់ពួកគេចូលទៅក្នុងពំនូក
ឬគំនរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងស្តាប់គ្រូជាច្រើនដែលធានាពួកគេថាមិនមានអ្វីខុសជាមួយបំណងប្រាថ្នាខុសឆ្គងរបស់ពួកគេ»
ពួកគេនឹងបែរត្រចៀកឆ្ងាយពីសេចក្តីពិត ទៅស្តាប់រឿងព្រេងវិញ
ឃ្លានេះគឺជាសតិអារម្មណ៍ដែលមានន័យថាមនុស្សនឹងចូលចិត្តស្តាប់នូវគោលលទ្ធិថ្មីៗ
និងប្លែកៗ។ របៀបផ្សេងទៀតនៃការបកប្រែ:
«តាមរបៀបនេះពួកគេតែងតែស្វែងរកអ្វីដែលថ្មី និងប្លែកដើម្បីរៀន»
ពួកគេនឹងបែរត្រចៀកឆ្ងាយពីសេចក្តីពិត
ប៉ូលនិយាយអំពីមនុស្សលែងយកចិត្តទុកដាក់ដូចជាពួកគេងាកចេញ
ដូច្នេះពួកគេមិនអាចស្តាប់បានទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងលែងយកចិត្តទុកដាក់លើការពិត»
ទៅស្តាប់រឿងព្រេងវិញ
ប៉ូលនិយាយអំពីមនុស្សដែលចាប់ផ្តើមយកចិត្តទុកដាក់លើរឿងព្រេង
ដូចជាពួកគេកំពុងងាកទៅរករឿងព្រេងនោះវិញ។របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេនឹងយកចិត្តទុកដាក់ចំពោះការបង្រៀនដែលមិនពិត»
ចូរមានចិត្តនឹងធឹង
ចិតធឹង - ប៉ូលចង់អោយអ្នកអានគិតឲ្យបានត្រឹមត្រូវអំពីអ្វីៗគ្រប់យ៉ាង
ហើយគាត់និយាយអំពីពួកគេដូចជាគាត់ចង់អោយគេដឹងខ្លួនថាមិនស្រវឹងជាមួយស្រាទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «គិតអោយច្បាស់»
ព្រមទាំងបំពេញកិច្ចការបម្រើឲ្យបានល្អផងដែរ
ឃ្លានេះមានន័យថាដើម្បីប្រាប់មនុស្សអំពីថាតើព្រះយេស៊ូជាព្រះដែលបានធ្វើសម្រាប់ពួកគេ

និងរបៀបដែលពួកគេត្រូវរស់នៅសម្រាប់ព្រះអង្គ។

2 Timothy 4:6

ខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីបូជាជីវិត

ប៉ូលនិយាយអំពីការត្រៀមខ្លួនដើម្បីស្លាប់ដូចជាគាត់ត្រៀមស្រាមួយពែងដើម្បីត្រៀមបូជា

ពេលវេលាដែលខ្ញុំត្រូវចាកចេញក៏បានមកដល់ហើយដែរ

ត្រង់ពាក្យថា «ត្រូវចាកចេញ» គឺជាវិធីគួរសមក្នុងការសំដៅទៅលើការស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ឆាប់ៗនេះខ្ញុំនឹងស្លាប់
ហើយចាកចេញពីពិភពលោកនេះ»

ខ្ញុំបានប្រណាំងយ៉ាងល្អ

ប៉ូលនិយាយអំពីការខិតខំរបស់គាត់ដូចជាគាត់ធ្លាប់ជាអ្នកប្រកួតប្រជែងដណ្តើមយករង្វាន់
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានប្រឹងប្រែងអស់ពីសមត្ថភាព»

រហូតដល់ទីផ្តាច់ព្រ័ត្រ

ប៉ូលនិយាយអំពីជីវិតរបស់គាត់ក្នុងការបម្រើព្រះជាម្ចាស់ដូចជាគាត់កំពុងរត់ប្រណាំង។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំបានបំពេញអ្វីដែលខ្ញុំត្រូវធ្វើ»

ព្រមទាំងបានរក្សាជំនឿយ៉ាងមាំមួន

ប៉ូលនិយាយអំពីការទុកចិត្តរបស់គាត់ទៅលើព្រះគ្រិស្ត
និងការស្តាប់បង្គាប់ព្រះជាម្ចាស់ដូចជារបស់ទាំងនោះជារបស់មានតម្លៃដែលគាត់បានរក្សា
អត្ថន័យដែលអាចមានគឺ ១)
«ខ្ញុំបានស្មោះត្រង់ក្នុងការបំពេញព័ន្ធកិច្ចរបស់ខ្ញុំ» (UDB) ឬទី ២)
«ខ្ញុំបានរក្សាការបង្រៀនអំពីអ្វីដែលយើងជឿគ្រប់កំហុកទាំងអស់»

មកុដនៃសេចក្តីសុចរិតបានរៀបចំជាស្រេចទុកសម្រាប់ខ្ញុំ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានរក្សាមកុដនៃសេចក្តីសុចរិតសម្រាប់ខ្ញុំ»

មកុដនៃសេចក្តីសុចរិត

អត្ថន័យដែលអាចមានគឺ ១) មកុដគឺជារង្វាន់ដែលព្រះប្រទានដល់មនុស្ស
ដែលបានរស់នៅតាមរបៀបត្រឹមត្រូវ (UDB) ឬ ២)
មកុដគឺជានិមិត្តរូបនៃសេចក្តីសុចរិត។
ដូចជាចៅក្រមនៃការប្រណាំងមួយផ្តល់មកុដដល់អ្នកឈ្នះនៅពេល
ដែលប៉ូលបញ្ចប់ជីវិតរបស់គាត់ ព្រះជាម្ចាស់នឹងប្រកាសថាប៉ូលគឺសុចរិត។

មកុដ

កម្រងផ្កាធ្វើពីស្លឹកឈើផ្កាយជ័យព្រឹក្សដែលត្រូវបានផ្តល់ឲ្យអ្នកឈ្នះនៃការប្រកួតប្រជែង

នៅថ្ងៃនោះ

«នៅថ្ងៃដែលព្រះអម្ចាស់យាងមកម្តងទៀត» ឬ
«នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្ស»

ប៉ុន្តែសម្រាប់អស់អ្នកដែលស្រឡាញ់ការយាងមកវិញរបស់ព្រះអង្គ

ប៉ូលនិយាយអំពីព្រឹត្តិការណ៍នេះដូចជាការនេះបានកើតឡើងរួចហើយ។
ឃ្លាអាចត្រូវបានបញ្ជាក់ថាជាព្រឹត្តិការណ៍នាពេលអនាគត។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែព្រះអង្គក៏នឹងផ្តល់ឲ្យអ្នកដែលរង់ចាំយ៉ាងអន្ទះសាដើម្បីឲ្យព្រះអង្គយាងត្រឡប់មកវិញ»

2 Timothy 4:9

ប្រយោគភ្ជាប់៖

ប៉ូលនិយាយអំពីមនុស្សជាក់លាក់
និងរបៀបដែលពួកគេប្រព្រឹត្តអំពីការងាររបស់ព្រះសម្រាប់គាត់
ហើយបន្ទាប់មកគាត់បានបញ្ចប់ដោយការស្វាគមន៍ និងពីមនុស្សជាក់លាក់។

ជាប្រញាប់

«ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន»

លោកដេម៉ាស...ក្រេសេន...ទីតុស

ទាំងនេះគឺជាឈ្មោះរបស់បុរស។

លោកីយ៍នេះ

ត្រង់ពាក្យថា «លោកីយ៍»
សំដៅទៅលើអ្វីៗខាងលោកិយដែលផ្ទុយពីរឿងរបស់ព្រះជាម្ចាស់។
អត្ថន័យដែលអាចមានគឺ ១)
គាត់ពេញចិត្តភាពសុខស្រួលបណ្តោះអាសន្ននៃពិភពលោកនេះ ឬ ២)
គាត់ខ្លាចថាគាត់នឹងស្លាប់ប្រសិនបើគាត់នៅជាមួយប៉ូល។

ក្រេសេនបានទៅ...ហើយលោកទីតុសបានទៅ

បុរសទាំងពីរនាក់នេះបានចាកចេញពីប៉ូល តែប៉ូលមិននិយាយ ដែលពួកគេក៏
«ស្រឡាញ់លោកីយ៍នេះដែរ» ដូចនឹងដេម៉ាសដែរ។

ស្រុកដាល់ម៉ាទា

នេះគឺជាឈ្មោះនៃតំបន់មួយ។

2 Timothy 4:11

គាត់អាចជួយបំពេញកិច្ចការរបស់ខ្ញុំ

អត្ថន័យដែលអាចមានគឺ ១) «គាត់អាចជួយខ្ញុំក្នុងព័ន្ធកិច្ច» ឬ ២)
«គាត់អាចជួយខ្ញុំដោយការបម្រើខ្ញុំ»។

អាវធំ

សម្លៀកបំពាក់ដែលធ្ងន់ពាក់លើសម្លៀកបំពាក់ផ្សេងៗ

ការពូស

នេះជាឈ្មោះបុរសម្នាក់។

សៀវភៅ

នេះសំដៅទៅលើក្រាំង។ ក្រាំងគឺជាសៀវភៅមួយប្រភេទដែលធ្វើពីក្រដាស
ឬស្បែកវែងមួយសន្លឹក។ បន្ទាប់ពីសរសេរនៅលើក្រាំង
ឬអានក្រាំងនេះមនុស្សបានបង្វិលវាដោយប្រើឈើខាងនៅចុង

ស្បែក

ឃ្លានេះអាចយោងទៅលើប្រភេទជាក់លាក់នៃក្រាំង។
របៀបផ្សេងទៀតនៃការបកប្រែ:
«ជាពិសេសជាក្រាំងដែលធ្វើពីស្បែកសត្វ» (UDB)

[illegible]

លោកអ័លេក្សានត្រុស

នេះជាឈ្មោះរបស់បុរសម្នាក់។

ដែលជាជាងស្ពាន់

«ជាអ្នកដែលធ្វើជាមួយលោហធាតុ»

បានប្រព្រឹត្តសេចក្តីអាក្រក់គ្រប់យ៉ាងមកលើខ្ញុំ

ប៉ូលនិយាយអំពីការប្រព្រឹត្តអំពើអាក្រក់ហាក់ដូចជាពួកគេត្រូវបានបង្ហាញ។
របៀបផ្សេងទៀតនៃការបកប្រែ: «បានធ្វើអ្វីអាក្រក់ជាច្រើនចំពោះខ្ញុំ»

ព្រះអម្ចាស់នឹងតបស្នងដល់គាត់វិញ

«ព្រះអម្ចាស់នឹងដាក់ទោសគាត់ចំពោះអ្វីដែលគាត់បានធ្វើ» (UDB)

គាត់...គាត់...គាត់...គាត់

ពាក្យទាំងនេះគឺសំដៅទៅលើលោកអ័លេក្សានត្រុស។

ប្រឆាំងយ៉ាងខ្លាំងនឹងពាក្យរបស់ពួកយើង

ត្រង់ពាក្យថា «ពាក្យ» សំដៅទៅលើសារ ឬ ការបង្រៀន។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រឆាំងនឹងសារដែលពួកយើងបង្រៀន»។

នៅពេលខ្ញុំការពារខ្លួនដំបូងឡើយ

«នៅពេលដែលខ្ញុំបានបង្ហាញខ្លួនជាលើកដំបូងនៅក្នុងតុលាការ
ហើយបានពន្យល់ពីការប្រព្រឹត្តរបស់ខ្ញុំ»

គ្មានអ្នកណាឈរជាមួយខ្ញុំទេ

«គ្មាននរណាម្នាក់នៅខាងមួយខ្ញុំ និងជួយខ្ញុំទេ»

សូមកុំឲ្យព្រះជាម្ចាស់ប្រកាន់ទោសគេឡើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«សូមព្រះជាម្ចាស់កុំរាប់ពួកគេប្រឆាំងនឹងពួកគេឡើយ» ឬ «ខ្ញុំអធិស្ឋាន
សូមព្រះមិនដាក់ទោសអ្នកជឿទាំងនោះដែលបានចាកចេញពីខ្ញុំទេ»

2 Timothy 4:17

ព្រះអម្ចាស់បានគង់នៅខាងខ្ញុំ

ប៉ូលកំពុងនិយាយដូចជាព្រះអម្ចាស់បានឈរនៅក្បែរគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអម្ចាស់បានជួយខ្ញុំ»

ដូច្នេះហើយតាមរយៈខ្ញុំ ដំណឹងល្អបានប្រកាសគ្រប់ទីកន្លែង

ឃ្លានេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះខ្ញុំមានលទ្ធភាពនិយាយពីព្រះបន្ទូលរបស់ព្រះអម្ចាស់ទាំងអស់»

ព្រះជាម្ចាស់បានសង្គ្រោះខ្ញុំចេញពីមាត់តោ

ប៉ូលកំពុងនិយាយអំពីគ្រោះថ្នាក់ដូចជាគាត់ត្រូវបានគំរាមកំហែងដោយសត្វតោ។
គ្រោះថ្នាក់នេះអាចជាសាច់ឈាម ខាងវិញ្ញាណ ឬទាំងពីរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំត្រូវបានជួយសង្គ្រោះពីគ្រោះថ្នាក់ដ៏ធំ»

2 Timothy 4:19

ក្រុមគ្រួសាររបស់លោកអូនេស៊ីភ័រផងដែរ

ត្រង់ពាក្យថា «ក្រុមគ្រួសារ» សំដៅទៅលើមនុស្សដែលរស់នៅទីនោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្រួសាររបស់លោកអូនេស៊ីភ័រ»

អូនេស៊ីភ័រ

នេះជាឈ្មោះរបស់មនុស្សប្រុស។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឈ្មោះនេះក្នុងជំពូក ១:១៥។

លោកអេរ៉ាស្ទុស...លោកទ្រភីម...អុើប៊ូឡុស...ពូដេន...លីណុស

generated on Wed Sep 10 16:16:32 2025

ទាំងនេះជាឈ្មោះរបស់មនុស្សប្រុស។
មីលេត
នេះគឺជាឈ្មោះទីក្រុងមួយនៅខាងត្បូងក្រុងអេភេសូ។
សូមមកជាប្រញាប់
«រកវិធីមក»
មុនរដូវរងារមកដល់
«មុនពេលរដូវត្រជាក់មកដល់»
លោកពូដេន លោកលីណុស និងនាងក្លូឌា ព្រមទាំងបងប្អូនទាំងអស់ដែរ
ឃ្លានេះអាចត្រូវបានបកប្រែជាប្រយោគថ្មី។ របៀបផ្សេងទៀតនៃការបកប្រែ:
«លោកពូដេន លោកលីណុស និងនាងក្លូឌា
ព្រមទាំងបងប្អូនទាំងអស់ក៏ស្វាគមន៍អ្នកផងដែរ»
ក្លូឌា
នេះជាឈ្មោះរបស់មនុស្សស្រី។
ព្រមទាំងបងប្អូនទាំងអស់ដែរ
ត្រង់ពាក្យថា «បងប្អូន» មានន័យថាអ្នកជឿទាំងអស់មិនថាប្រុស ឬស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកជឿទាំងអស់នៅទីនេះ»
សូមព្រះអម្ចាស់គង់នៅជាមួយវិញ្ញាណរបស់អ្នក
«ខ្ញុំអធិស្ឋានសូមព្រះអម្ចាស់ប្រទានឲ្យអ្នកមានស្មារតីរឹងមាំ»។ ត្រង់ពាក្យថា «អ្នក»
គឺមានតែមួយ និងសំដៅទៅលើធីម៉ូថេ។
សូមព្រះគុណបានស្ថិតនៅជាមួយអ្នកទាំងអស់គ្នា
«ខ្ញុំអធិស្ឋានសូមព្រះអម្ចាស់បង្ហាញព្រះគុណរបស់ព្រះអង្គដល់អ្នកទាំងអស់គ្នាដែលនៅទីនោះ»។
ត្រង់ពាក្យថា «អ្នក» គឺពហុវចនៈ
ហើយសំដៅទៅលើអ្នកជឿទាំងអស់នៅទីនោះជាមួយធីម៉ូថេ។
ព្រះគុណបាន
«សេចក្តីសប្បុរសរបស់ព្រះអង្គ» ឬ «ការសព្វព្រះទ័យរបស់ព្រះអង្គ»

ទីតុស

1 [1]ខ្ញុំ ប៉ូលជាអ្នកបម្រើរបស់ព្រះជាម្ចាស់ និងជាសាវ័ករបស់ព្រះយេស៊ូគ្រិស្ត ដោយសារជំនឿបានក្លាយជាប្រជារាស្ត្រ ដែលព្រះជាម្ចាស់បានជ្រើសរើស និងស្គាល់សេចក្តីពិត និងជាអ្នកដែលព្រមទទួលការគោរពប្រតិបត្តិដល់ព្រះអង្គ[2]ដោយជឿជាក់ថា នឹងទទួលជីវិតអស់កល្បជានិច្ច ហើយព្រះអង្គមិនកុហកសោះឡើយ និងបានសន្យាតាំងពីមុនកាលសម័យទាំងអស់។[3]នៅពេលកំណត់ ព្រះអង្គបានបើកសម្តែងព្រះបន្ទូលរបស់ព្រះអង្គ គឺថាព្រះអង្គបានទុកព្រះហឫទ័យលើខ្ញុំ
ដើម្បីក្លាយជាអ្នកប្រកាសដំណឹងល្អ។ ខ្ញុំបានធ្វើការនេះតាមបញ្ជារបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះរបស់យើង។
[4]ជូនចំពោះលោកទីតុសជាកូនដ៏ពិតនៅក្នុងជំនឿរួមគ្នា។ សូមព្រះជាម្ចាស់ជាព្រះបិតា និងព្រះគ្រិស្តយេស៊ូជាព្រះសង្គ្រោះរបស់យើងប្រទានព្រះគុណ និងសេចក្តីសុខសាន្ត។
[5]តាមរយៈគោលបំណងនេះ ខ្ញុំបានទុកអ្នករាល់គ្នាឲ្យនៅលើកោះក្រែត ដើម្បីឲ្យអ្នកបានរៀបចំសណ្តាប់ធ្នាប់ ដែលមិនទាន់បានរៀបរយនៅឡើយ
និងតែងតាំងពួកចាស់ទុំនៅតាមក្រុងទាំងអស់ ដូចដែលខ្ញុំបានបង្គាប់អ្នករួចហើយ។
[6]ចាស់ទុំត្រូវតែជាអ្នកដែលគ្មានកំហុស មានភរិយាតែមួយ មានកូនចៅជាអ្នកដែលមានជំនឿ ហើយគ្មាននរណាចោទប្រកាន់ថាជាមនុស្សទុច្ចរិត និងគ្មានសីលធម៌នោះទេ។
[7]ជាការចាំបាច់ណាស់សម្រាប់អ្នកមើលការខុសត្រូវ ក្នុងនាមអ្នកគ្រប់គ្រងដំណាក់របស់ព្រះជាម្ចាស់ ត្រូវតែជាមនុស្សដែលគ្មានកំហុស។ គាត់មិនត្រូវវាយឫកក្រអឺតក្រទម
មិនឆាប់ខឹង មិនចំណូលស្រា មិនចេះឈ្លោះប្រកែក ឬជាមនុស្សលោភលន់ឡើយ។
[8]ផ្ទុយទៅវិញ គាត់គួរតែជាមនុស្សចៅរ៉ៅរាក់ទាក់ ស្រឡាញ់ការល្អ។ គាត់ជាមនុស្សដឹងខុសត្រូវ សុចរិត បរិសុទ្ធ និងចេះគ្រប់គ្រងខ្លួនឯង។
[9]គាត់គួរតែប្រកាន់ភ្ជាប់តាមព្រះបន្ទូលដ៏ពិត ដែលបានបង្រៀនរួចហើយ ដូច្នេះហើយ គាត់អាចមានសមត្ថភាពលើកទឹកចិត្តអ្នកដ៏ទៃ តាមសេចក្តីបង្រៀនត្រឹមត្រូវ
និងអាចកែតម្រង់អ្នកដែលជំទាស់នឹងគាត់វិញ។
[10]ដ្បិត មនុស្សជាច្រើនជាអ្នកបះបោរ ជាពិសេសគឺអ្នកដែលបានកាត់ស្បែក រីឯពាក្យរបស់ពួកគេគឺឥតប្រយោជន៏ ពួកគេបោកបញ្ឆោតហើយដឹកនាំមនុស្សឲ្យដើរផ្លូវខុស។
[11]យើងចាំបាច់ត្រូវបញ្ឈប់ពួកគេ។ ពួកគេបង្រៀននូវអ្វីដែលមិនគប្បីបង្រៀន ដើម្បីយកកម្រៃដោយគ្មានភាពអៀនខ្មាស់ និងធ្វើឲ្យមានការបែកបាក់ក្នុងគ្រួសារជាច្រើន ។
[12]មានម្នាក់នៅក្នុងចំណោមមពួកគេ ដែលជាព្យាការីបានពោលថា៖ «អ្នកស្រុកក្រែតសុទ្ធតែជាអ្នកកុហក ហើយជាមនុស្សអាក្រក់ជាសត្វតិរច្ឆាន
និងជាមនុស្សកម្លិចដែលលោភស៊ី។[13]ពាក្យនេះពិតណាស់ ដូច្នេះហើយ ត្រូវកែតម្រូវពួកគេយ៉ាងតឹងរឹង ដើម្បីឲ្យពួកគេមានជំនឿកាន់តែរឹងមាំឡើង។
[14]កុំឲ្យជាប់ចិត្តនឹងរឿងព្រេងរបស់សាសន៍យូដា ឬបទបញ្ជារបស់ពួកអ្នកដែលបោកបញ្ឆោតពីសេចក្តីពិត។
[15]ចំពោះអ្នកដែលបរិសុទ្ធ នោះអ្វីៗសុទ្ធតែបរិសុទ្ធ រីឯអ្នកដែលមានចិត្តសៅហ្មងនិងមិនជឿ នោះអ្វីៗទាំងអស់សុទ្ធតែមិនបរិសុទ្ធ ព្រោះប្រាជ្ញា
និងមនសិការរបស់ពួកគេសុទ្ធតែសៅហ្មង។[16]ពួកគេអះអាងថា គេស្គាល់ព្រះជាម្ចាស់ហើយ ប៉ុន្តែ ពួកគេបែរជាបដិសេធព្រះអង្គតាមរយៈការប្រព្រឹត្តរបស់ពួកគេទៅវិញ។
ពួកគេសុទ្ធតែជាមនុស្សគួរឲ្យស្អប់ខ្ពើម ហើយជាមនុស្សដែលមិនស្តាប់បង្គាប់ និងមិនអាចប្រព្រឹត្តអំពើល្អបានឡើយ។

Titus 1:1
ដ្បិត សេចក្តីជំនឿ
ដើម្បីពង្រឹងនូវសេចក្តីជំនឿ
ដែលត្រូវនឹងគោរពប្រតិបត្តិដល់ព្រះជាម្ចាស់
«ដែលព្រមទទួលការគោរពដល់ព្រះជាម្ចាស់»
តាំងពីមុនសម័យកាលទាំងអស់
«មុនពេលចាប់ផ្តើម»
ដល់ពេលកំណត់
«នៅពេលវេលាសមរម្យ»
ព្រះអង្គបានបើកសម្តែងព្រះបន្ទូលរបស់ព្រះជាម្ចាស់
លោកប៉ុល បាននិយាយអំពីសាររបស់ព្រះជាម្ចាស់
ដូចជាអត្ថបទមួយដែលអាចបង្ហាញដល់ប្រជារាស្ត្រ។ ការបកប្រែរបៀបផ្សេងទៀត:
«គាត់បានប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់»
ព្រះអង្គបានទុកព្រះហឫទ័យលើខ្ញុំ ដើម្បីឱ្យក្លាយជាអ្នកប្រកាសដំណឹងល្អ
«ព្រះអម្ចាស់ត្រូវបានប្រគល់សិទ្ធិដើម្បីឱ្យប្រកាសដំណឹងល្អ» ឬ «ព្រះអម្ចាស់
បានផ្តល់អោយយើងទំនួលខុសត្រូវ ក្នុងការប្រកាសដំណឹងល្អ»។
ព្រះជាម្ចាស់ ជាព្រះសង្គ្រោះនៃយើង
«ព្រះអម្ចាស់ ជាព្រះសង្គ្រោះនៃយើងរាល់គ្នា»
Titus 1:4
ជាកូនដ៏ពិត
ទោះបីជាទីតុសមិនមែនជាកូនប្រុសបង្កើតរបស់លោកប៉ុលក៏ដោយ
ពួកគេមានសេចក្តីជំនឿរួមគ្នាលើព្រះអង្គ។ ដូច្នេះក្នុងព្រះជាម្ចាស់
លោកប៉ុលចាត់ទុកទីតុសជាកូនរបស់គាត់។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដូចជាកូនប្រុសរបស់យើង»
សេចក្តីជំនឿរួមគ្នា
លោកប៉ុលបង្ហាញជំនឿលើព្រះជាម្ចាស់ដូចគ្នា
ដែលពួកគេទាំងពីរនាក់មានចំណែកដូចគ្នា។ ការបកប្រែរបៀបផ្សេងទៀត:
«សេចក្តីបង្រៀនតែមួយ ដែលពួកយើងទាំងពីរជឿ»។
ព្រះគុណ និង សេចក្តីសុខសាន្ត
នេះជាការស្វាគមន៍ ដែលជាទូទៅលោកប៉ុលប្រើ។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកអាចជួបប្រទះនឹងសេចក្តីសប្បុរស និងសន្តិភាពនៅក្នុងព្រះអម្ចាស់»
ព្រះជាម្ចាស់ជាព្រះសង្គ្រោះនៃយើង
«ព្រះអម្ចាស់ដែលជាព្រះអង្គសង្គ្រោះនៃយើង»
ដ្បិត គោលបំណង
«នេះគឺជាហេតុផល»
យើងបានទុកឲ្យអ្នករាល់គ្នានៅលើកោះក្រែត
«យើងបានប្រាប់អ្នកឱ្យនៅលើកោះក្រែត»
ដើម្បីនឹងអ្នកបានរៀបចំសណ្តាប់ធ្នាប់ ដែលមិនទាន់បានរៀបចំនៅឡើយ
«ដូច្នេះអ្នកនឹងបញ្ចប់ការរៀបចំអ្វីៗដែលត្រូវធ្វើ»
តែងតាំងអ្នកចាស់ទុំ

generated on Wed Sep 10 16:16:32 2025

«តែងតាំងអ្នកចាស់ទុំ» ឬ «បង្ហាញខ្លួនអ្នកចាស់ទុំ»
អ្នកចាស់ទុំ
នៅព្រះវិហារគ្រីស្តសាសនិកដំបូង
អ្នកចាស់ទុំរបស់ព្រះអម្ចាស់បានផ្តល់ការដឹកនាំខាងព្រះវិញ្ញាណដល់ក្រុមជំនុំរបស់អ្នកជឿ
Titus 1:6
ប្រយោគភ្ជាប់
ដោយបានប្រាប់ទីតុស
ឲ្យតែងតាំងអ្នកចាស់ទុំនៅគ្រប់ទីក្រុងទាំងអស់នៅកោះក្រែតនោះ
លោកប៉ុលបានតម្រូវឲ្យមានអ្នកចាស់ទុំ។
អ្នកចាស់ទុំត្រូវតែជាអ្នកដែលគ្មានកំហុស
ត្រូវ «គ្មានការស្តីបន្ទោស» គឺត្រូវគេស្គាល់ថាជាមនុស្សដែលមិនធ្វើអំពើអាក្រក់។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកចាស់ទុំមិនត្រូវមានកេរ្តិ៍ឈ្មោះអាក្រក់នោះទេ»
ដែលប្តីមានប្រពន្ធតែមួយ
ធ្វើជាប្តីស្មោះត្រង់។ អត្ថន័យដែលអាចមានគឺ ១)
មិនបន្តទំនាក់ទំនងជាមួយនារីផ្សេងទៀតឬ ២) មិនមានប្រពន្ធទី ២ ឬប្រពន្ធចុង។
កូនចៅជាអ្នកដែលជឿ
អាចមានន័យថា ១) កូនចៅដែលជឿលើព្រះអម្ចាស់ឬ ២)
ជាកូនចៅដែលគួរឱ្យទុកចិត្ត។
គ្មានសីលធម៌
«បះបោរ» ឬ «ដែលមិនអនុវត្តតាមច្បាប់»
អ្នកគ្រប់គ្រងដំណាក់របស់ព្រះជាម្ចាស់
លោកប៉ុលនិយាយអំពីអ្នកចាស់ទុំ ដូចជាពួកគេជាមេគ្រួសារ
ដែលទទួលបន្ទុកនៅក្នុងក្រុមគ្រួសារ។
មិនចំណូលស្រា
«មិនមែនជាគ្រឿងស្រវឹង» ឬ «មិនផឹកស្រា»
មិនមែនជាអ្នកឈ្លោះប្រកែក
«មិនមែនម្នាក់ដែលប្រើអំពើហឹង្សា» ឬ
«មិនមែនម្នាក់ដែលចូលចិត្តប្រយុទ្ធ» (UDB)
Titus 1:8
ផ្ទុយទៅវិញ
លោកប៉ុលគឺកំពុងផ្លាស់ប្តូរការឈ្លោះប្រកែករបស់គាត់ពីអ្វីដែលអ្នកចាស់ទុំមិនត្រូវធ្វើទៅនឹងអ្វីដែលពួកគេត្រូវធ្វើ។
មនុស្សចៅរ៉ៅរាក់ទាក់ ស្រឡាញ់ការល្អ
ដើម្បីចាប់យកនូវរឿងល្អៗ និងអាកប្បកិរិយាល្អ។
ប្រកាន់ភ្ជាប់តាម
លោកប៉ុលនិយាយអំពីភក្តីភាពចំពោះសេចក្តីជំនឿរបស់ព្រះអម្ចាស់
ដូចជាកំពុងកាន់ខ្ជាប់នូវជំនឿដោយដៃរបស់នរណាម្នាក់។
ការបកប្រែរបៀបផ្សេងទៀត: «ដែលត្រូវបានភក្តីភាពដល់» ឬ «កាន់តែដឹងច្បាស់»
សេចក្តីបង្រៀនដ៏ត្រឹមត្រូវ
គាត់ត្រូវតែបង្រៀនអ្វីដែលពិតអំពីព្រះអម្ចាស់
និងបញ្ហាខាងព្រះវិញ្ញាណផ្សេងទៀត។
Titus 1:10
ប្រយោគភ្ជាប់
ដោយសារអ្នកដែលប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះអម្ចាស់
លោកប៉ុលបានប្រាប់ហេតុផលដល់ទីតុស
ដើម្បីប្រកាសពីព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយព្រមានពួកគាត់អំពីគ្រូក្លែងក្លាយ។
មនុស្សបះបោរ
ទាំងនេះគឺជាមនុស្សបះបោរប្រឆាំងនឹងសារលិខិតដំណឹងល្អរបស់លោកប៉ុល។
អ្នកដែលបានកាត់ស្បែក
នេះសំដៅទៅលើជនជាតិយូដាជាព្រះគ្រីស្ត ដែលបានបង្រៀនថា
ត្រូវតែកាត់ស្បែកដើម្បីកាន់តាមព្រះអម្ចាស់។
ពាក្យរបស់ពួកគេគឺឥតប្រយោជន៍
«ពាក្យរបស់ពួកគេមិនផ្តល់ផលប្រយោជន៍ដល់អ្នកណាម្នាក់ទេ»
យើងចាំបាច់ត្រូវបញ្ឈប់ពួកគេ
«ពួកគេត្រូវតែរារាំងពីការរីករាលដាលនៃការបង្រៀនរបស់ពួកគេ» ឬ
«ពួកគេត្រូវតែបញ្ឈប់ពីការជះឥទ្ធិពលពីអ្នកដទៃតាមរយៈពាក្យរបស់ពួកគេ»
ដែលពួកគេមិនគួរបង្រៀន
អ្វីដែលមិនត្រឹមត្រូវក្នុងការបង្រៀនទាក់ទងនឹងព្រះអម្ចាស់ និងក្រិត្យវិន័យ។
ដើម្បីប្រាក់កម្រៃដោយគ្មានភាពអៀនខ្មាស់
នេះសំដៅទៅលើតែផលចំណេញ
ដែលមនុស្សរកបានដោយធ្វើអ្វីដែលមិនគួរឱ្យគោរព។
មានការបែកបាក់ក្នុងគ្រួសារជាច្រើន
«បំផ្លាញនូវសេចក្តីជំនឿរបស់ក្រុមគ្រួសារទាំងមូល»
Titus 1:12
ម្នាក់នៅក្នុងចំណោមពួកគេ
«មួយក្នុងចំណោមជនជាតិក្រេនដាន» ឬ «នរណាម្នាក់មកពីជនជាតិក្រែត»
ដែលជាព្យាការី
អាចមានន័យថា ១) ព្យាការីឬ ២) កំណាព្យឬទស្សនវិទូឬ ៣) គ្រូបង្រៀន។
អ្នកស្រុកក្រែតសុទ្ធតែជាអ្នកកុហក
«ពួកជនជាតិក្រែតកុហកគ្រប់ពេល»។
នេះគឺជាការបំផ្លើសមួយសម្រាប់ពួកជនជាតិក្រែតជាច្រើនដែលនិយាយកុហកជាទម្លាប់។
ជាមនុស្សអាក្រក់ និងជាសត្វតិរច្ឆាន
ការប្រៀបធៀបនេះ ប្រៀបធៀបនឹងជនជាតិក្រែតទៅនឹងសត្វសាហាវ។
កម្ចិលដែលល្មោភស៊ី
សម្រាប់មនុស្សដែលមិនធ្វើអ្វីសោះ ប៉ុន្តែបរិភោគអាហារច្រើន។
ដូច្នេះហើយ ត្រូវកែតម្រូវពួកគេយ៉ាងតឹងរឹង
«ដូច្នេះសូមប្រាប់ពួកគេយ៉ាងខ្លាំងថា ពួកគេគឺធ្វើខុសហើយ»
ដើម្បីឲ្យពួកគេមានជំនឿកាន់តែរឹងមាំឡើង
«ដូច្នេះ ពួកគេនឹងមានជំនឿដ៏ល្អ» ឬ
«ដូច្នេះជំនឿរបស់ពួកគេអាចនឹងក្លាយជាការពិត»
Titus 1:14
សេចក្តីថ្លែងការណ៍
លោកប៉ុលបន្តការណែនាំរបស់គាត់សម្រាប់អ្វីដែលទីតុសគឺកំពុងតែបង្រៀនដល់ជនជាតិក្រែត។
នេះសំដៅទៅលើការបង្រៀនមិនពិតរបស់ជនជាតិយូដា។
ការបោកបញ្ឆោតពីសេចក្តីពិត
លោកប៉ុលនិយាយអំពីសេចក្តីពិត ដូចជាពួកគេមានការជំទាស់មួយ
ដែលអាចនឹងត្រឡប់ទៅរកទិសដៅពីកន្លែងដែលពួកគេបានមក។
ការបកប្រែរបៀបផ្សេងទៀត: «បដិសេធការពិត»
Titus 1:15
ចំពោះអ្នកបរិសុទ្ធ នោះអ្វីៗសុទ្ធតែបរិសុទ្ធ
«ប្រសិនបើអ្នកណាម្នាក់គឺខាងក្នុងបរិសុទ្ធ អ្វីៗពួកគេធ្វើនឹងបានបរិសុទ្ធ»
ចំពោះអ្នកបរិសុទ្ធ
ចំពោះអ្នកដែលបរិសុទ្ធព្រមនឹងទទួលពីព្រះអម្ចាស់
អ្នកដែលមានចិត្តសៅហ្មងនិងមិនជឿ នោះអ្វីៗទាំងអស់សុទ្ធតែមិនបរិសុទ្ធ
លោកប៉ុលបាននិយាយអំពីមនុស្សមានបាបដូចជាពួកគេមានភាពមិនស្អាតខាងរាងកាយ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកដែលស្មោកគ្រោកខាងសីលធម៌
ហើយអ្នកដែលមិនជឿមិនអាចធ្វើជាមនុស្សបរិសុទ្ធបាននោះទេ»
ពួកគេបែរជាបដិសេធព្រះជាម្ចាស់តាមរយៈការប្រព្រឹត្តរបស់ពួកគេទៅវិញ
«សកម្មភាពរបស់ពួកគេធ្វើបានបញ្ជាក់ថា ពួកគេអត់ស្គាល់ព្រះអម្ចាស់ទេ»
គួរស្អប់ខ្ពើម
«គួរអោយស្អប់ខ្ពើម»
មនុស្សដែលមិនស្តាប់បង្គាប់ និងមិនអាចប្រព្រឹត្តអំពើល្អបានឡើយ
«គ្មានអ្នកណាម្នាក់រំពឹងថាពួកគេនឹងធ្វើអ្វីដែលល្អនោះទេ»

---

2 [1]ប៉ុន្តែចំពោះអ្នកវិញ ត្រូវនិយាយតែណាដែលស្របតាមសេចក្តីបង្រៀនដ៏ស្មោះត្រង់។[2]ពួកបុរសវ័យចំណាស់ ត្រូវតែជាមនុស្សស្លូតបូត មានភាពថ្លៃថ្នូរ មានសុភវិនិច្ឆ័យ
មានជំនឿស្អាតស្អំ មានសេចក្តីស្រឡាញ់ និងចេះស៊ូទ្រាំ។
[3]ពួកស្ត្រីវ័យចំណាស់ក៏ដូច្នេះដែរ ត្រូវតែមានកិរិយាមារយាទសម ជាអ្នកដែលគេគោរព មិននិយាយដើមគេ មិនចំណូលស្រា និងគួរតែបង្រៀននូវសេចក្តីល្អៗវិញ។
[4]ដើម្បីជួយអប់រំស្ត្រីៗដែលនៅក្មេង ឲ្យចេះស្រឡាញ់ស្វាមី និងកូនៗរបស់ខ្លួន។[5]ពួកគេគួរតែអប់រំស្ត្រីទាំងនោះឲ្យមានចិត្តបរិសុទ្ធ ជាស្ត្រីមេផ្ទះដ៏ល្អ
និងគោរពចុះចូលនឹងស្វាមីរបស់ពួកគេរៀងៗខ្លួន។ ធ្វើដូច្នេះ ដើម្បីកុំឲ្យនរណាម្នាក់ ប្រមាថព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។

generated on Wed Sep 10 16:16:32 2025

[6]រីឯពួកយុវជនវិញ ចូលលើកទឹកចិត្តពួកគេឲ្យមានសុភវិនិច្ឆ័យគ្រប់កិច្ចការទាំងអស់។[7]ចូរបង្ហាញ និងបង្រៀនអំពើល្អរបស់អ្នក ជាគំរូដល់គេ ដោយបង្ហាញពីភាពស្អាតស្អំ
និងសេចក្តីថ្លៃថ្នូររបស់អ្នក។[8]និយាយពាក្យសម្តីដែលល្អៗ ដោយមិនឲ្យគេរិះគន់បាន ដូច្នេះ អស់អ្នកដែលជំនាស់នឹងត្រូវអៀនខ្មាស់
ពីព្រោះគេគ្មានអ្វីនិយាយអាក្រក់ពីយើងបានឡើយ។
[9]ពួកអ្នកខ្ញុំបម្រើត្រូវស្តាប់បង្គាប់ម្ចាស់របស់ខ្លួន ក្នុងគ្រប់កិច្ចការទាំងអស់។ ពួកគេត្រូវផ្គាប់ចិត្ត និងមិនត្រូវប្រកែកជាមួយម្ចាស់ឡើយ។[10]ពួកគេមិនគួរលួចបន្លំម្ចាស់ឡើយ។
ផ្ទុយទៅវិញ ពួកគេត្រូវបង្ហាញនូវជំនឿដ៏ល្អ ដើម្បីលើកកម្ពស់សេចក្តីបង្រៀន អំពីព្រះជាម្ចាស់ជាព្រះអង្គសង្គ្រោះរបស់យើងក្នុងគ្រប់ការទាំងអស់។
[11]ព្រះគុណរបស់ព្រះជាម្ចាស់បានបើកសម្តែងទៅកាន់មនុស្សទាំងអស់។[12]ហើយអប់រំយើងឲ្យលះចោលការមិនគោរពកោតខ្លាចព្រះជាម្ចាស់
ហើយបដិសេធសេចក្តីបងប្រាថ្នាខាងសាច់ឈាម ដើម្បីអប់រំយើងឲ្យរស់នៅដោយសេចក្តីសុចរិត និងត្រឹមត្រូវដោយការគោរពកោតខ្លាចព្រះជាម្ចាស់ នៅក្នុងសម័យនេះ។
[13]ខណៈពេលដែលយើងរង់ចាំទទួលសេចក្តីសង្ឃឹមរបស់ពួកយើង ព្រះយេស៊ូគ្រិស្តជាព្រះដ៏ប្រសើរឧត្តមបំផុត និងជាព្រះសង្គ្រោះរបស់ពួកយើង
ព្រះអង្គនឹងបើកសម្តែងសិរីរុងរឿងរបស់ព្រះអង្គ។
[14]ព្រះយេស៊ូបានលះបង់ព្រះជន្មព្រះអង្គជំនួសយើង ដើម្បីដោះយើងឲ្យរួចពីការរំលងច្បាប់ទាំងអស់ និងជម្រះយើងឲ្យបានវិសុទ្ធថ្វាយព្រះអង្គផ្ទាល់
និងជាប្រជារាស្ត្រដ៏វិសេស ដែលយកចិត្តទុកដាក់ប្រព្រឹត្តអំពើល្អគ្រប់យ៉ាង។
[15]ចូរនិយាយ និងលើកទឹកចិត្តគ្នាទៅវិញទៅមក។ ចូរកែតម្រូវដោយប្រើសិទ្ធិអំណាចពេញទី។ កុំឲ្យនរណាម្នាក់មើលងាយអ្នកឡើយ។

Titus 2:1
ប្រយោគភ្ជាប់
លោកប៉ុល បន្តផ្តល់ហេតុផលដល់ទីតុស
ក្នុងការប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់ពីរបៀប ដែលពួកបុរសចំណាស់
ពួកស្ត្រីចំណាស់ យុវជន និងពួកអ្នកបំរើ ឬពួកអ្នកបំរើគួរតែរស់នៅជាអ្នកជឿ។
ប៉ុន្តែចំពោះអ្នកវិញ
លោកប៉ុលបញ្ជាក់អំពីអ្វីដែលផ្ទុយពីនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែអ្នកវិញ ទីតុសផ្ទុយពីគ្រូក្លែងក្លាយ»
ជាមួយនឹងសេចក្តីបង្រៀនដ៏ស្មោះត្រង់
«ជាមួយគោលលទ្ធិត្រឹមត្រូវ» ឬ «ជាមួយការបង្រៀនដ៏ត្រឹមត្រូវ»
មនុស្សស្លូតបូត
«ចេះដឹងខ្លួន» ឬ «ចេះគ្រប់គ្រងខ្លួនឯង»
សុភវិនិច្ឆ័យ
«នៅក្នុងការគ្រប់គ្រងនៃបំណងប្រាថ្នារបស់ពួកគេ»
ល្អ
ល្អប្រសើរ
សមស្របនឹងសេចក្តីជំនឿ
«ដោយជំនឿល្អ» ឬ «ត្រឹមត្រូវតាមជំនឿរបស់ពួកគេ»
សមស្រប...ក្នុងសេចក្តីស្រឡាញ់
«ជាមួយនឹងសេចក្តីស្រឡាញ់ដ៏ល្អ»
សមស្រប...ក្នុងការស៊ូទ្រាំ
«សេចក្តីខ្ជាប់ខ្ជួន» ឬ «ឥតឈប់ឈរ»
Titus 2:3
ស្រដៀងគ្នា
«នៅផ្លូវតែមួយ» ដូចទីតុសបានណែនាំដល់ពួកបុរសវ័យចំណាស់
គាត់ក៏ត្រូវណែនាំដល់ពួកស្ត្រីវ័យចំណាស់ដែរ។
គួរតែមានកិរិយាមារយាទសម
«គួរតែបង្ហាញខ្លួនឯងថាជា» ឬ «គួរតែរស់នៅដូចជា»
និយាយដើមគេ
ពាក្យនេះសំដៅទៅលើមនុស្សដែលនិយាយរឿងអាក្រក់ពីអ្នកដទៃ
ថាតើពួកគេជាការពិតរឺអត់។
ធ្វើជាខ្ញុំបម្រើស្រា
មនុស្សម្នាក់ដែលមានអារម្មណ៍ថាត្រូវការភេសជ្ជៈដែលមានជាតិអាល់កុលច្រើនតែផឹក
លោកប៉ុលនិយាយអំពីមនុស្សញៀន ដូចជាពួកគេជាទាសករ។
ការបកប្រែរបៀបផ្សេងទៀត: «អ្នកញៀនស្រា»
ដែលមានសុភវិនិច្ឆ័យ មានចិត្តបរិសុទ្ធ
ដោយគិតឱ្យបានត្រឹមត្រូវ
Titus 2:6
រីឯពួកយុវជនវិញ
ទីតុសគឺបង្ហាត់បង្រៀនដ៏យុវជនក្មេងៗ
ដូចជាគាត់បានបង្ហាត់បង្រៀនដល់មនុស្សវ័យចំណាស់។
បង្រៀនអំពើល្អរបស់អ្នក
«បង្ហាញខ្លួនអ្នកឱ្យក្លាយជា»
ជាគំរូដល់គេ
«ឧទាហរណ៍ អ្នកដែលធ្វើអ្វីដែលត្រឹមត្រូវ និងរឿងត្រឹមត្រូវ»
ពាក្យសម្តីដែលល្អៗ
លោកប៉ុលនិយាយអំពីការប្រកាសនិងការបង្រៀនទីតុស ពួកគេជាមនុស្ស
ដែលមានសុខភាពល្អនៅក្នុងខ្លួន។
ដូច្នេះ អស់អ្នកណាដែលជំនាស់នឹងត្រូវអៀនខ្មាស់
នេះបង្ហាញពីស្ថានភាពស្រមើលស្រមៃ ដែលមនុស្សម្នាក់ប្រឆាំងនឹងទីតុស
ហើយបន្ទាប់មកខ្មាស់អៀនដោយសារបានធ្វើដូច្នេះ។
វាមិនត្រូវបានបង្ហាញពីអ្វីដែលបានកើតឡើងទេ។
ភាសារបស់អ្នកអាចមានវិធីនៃការបញ្ចេញមតិនេះ។
Titus 2:9
ចៅហ្វាយនាយរបស់ខ្លួន
«ចៅហ្វាយនាយផ្ទាល់ខ្លួនរបស់ពួកគេ»
ក្នុងគ្រប់ការទាំងអស់
«ក្នុងគ្រប់ស្ថានភាព» ឬ «ជានិច្ចកាល»
ពួកគេត្រូវផ្គាប់ចិត្ត
«ធ្វើឱ្យចៅហ្វាយនាយរីករាយ» ឬ «បំពេញចិត្តម្ចាស់របស់ពួកគេ»
លួចបន្លំ
លួចរបស់តូចៗពីចៅហ្វាយខ្លួន
បង្ហាញនូវសេចក្តីជំនឿដ៏ល្អ
«បង្ហាញថាពួកគេសមនឹងទទួលបានការទុកចិត្តពីចៅហ្វាយនាយរបស់ពួកគេ»
ក្នុងគ្រប់វិធី
«នៅក្នុងអ្វីៗគ្រប់យ៉ាងដែលពួកគេបានធ្វើ»
លើកកម្ពស់សេចក្តីបង្រៀន
លោកប៉ុល បាននិយាយអំពីការបង្រៀនរបស់ព្រះអម្ចាស់ដូចជាមេរៀនមួយ
ដែលអាចផ្តល់ជារង្វាន់។ ការបកប្រែរបៀបផ្សេងទៀត:
«ធ្វើឱ្យការបង្រៀនរបស់យើងមានភាពទាក់ទាញ ដល់មនុស្សផ្សេងទៀត»
ព្រះអង្គសង្គ្រោះនៃយើង
«ព្រះអម្ចាស់នៃយើងដែលជាព្រះអង្គសង្គ្រោះ»
Titus 2:11
ប្រយោគភ្ជាប់
លោកប៉ុលលើកទឹកចិត្តទីតុស ឲ្យរកមើលការយាងមករបស់ព្រះអម្ចាស់
ហើយចងចាំពីសិទ្ធិអំណាចរបស់ព្រះអម្ចាស់ តាមរយៈព្រះអម្ចាស់ផងដែរ។
ព្រះគុណរបស់ព្រះជាម្ចាស់បានបើកសម្តែងមក...ការបង្ហាត់បង្រៀនដល់ពួកយើង
ដើម្បីឱ្យយើងរស់នៅ
លោកប៉ុលនិយាយអំពីព្រះគុណរបស់ព្រះអម្ចាស់ដូចជា
មនុស្សដែលទៅរកមនុស្សផ្សេងទៀត
ហើយបង្ហាត់ពួកគេឱ្យចេះរស់នៅក្នុងជីវិតដ៏បរិសុទ្ធ។
បង្រៀនយើងឲ្យលះបង់ចោលការមិនគោរពកោតខ្លាចព្រះជាម្ចាស់
«បង្រៀនយើងកុំអោយប្រមាថដល់ព្រះអម្ចាស់»
បដិសេធសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម
«សេចក្តីប៉ងប្រាថ្នាយ៉ាងខ្លាំងចំពោះរបស់នៅលើលោកីយនេះ» ឬ
«សេចក្តីប៉ងប្រាថ្នាយ៉ាងខ្លាំងចំពោះការសប្បាយដែលពេញដោយអំពើបាប»
នៅក្នុងសម័យនេះ
«ខណៈពេលដែលយើងរស់នៅក្នុងពិភពលោកនេះ» ឬ «អំឡុងពេលនេះ»
យើងទន្ទឹងរង់ចាំទទួល
«យើងរង់ចាំស្វាគមន៍»
សេចក្តីសង្ឃឹមរបស់យើង

generated on Wed Sep 10 16:16:32 2025

លោកប៉ុលមានន័យថាព្រះអម្ចាស់ ដែលយើងជឿជាក់ថា គាត់នឹងមករកយើងវិញ។
ការបើកសម្តែងសិរីរុងរឿងរបស់ព្រះអង្គ
លោកប៉ុល
បាននិយាយអំពីសិរីរុងរឿងរបស់ព្រះអម្ចាស់ដើម្បីបញ្ជាក់ថាព្រះអម្ចាស់នឹងយាងមក។
Titus 2:14
ព្រះជាម្ចាស់បានលះបង់ព្រះជន្មព្រះអង្គជំនួសយើងរាល់គ្នា
«ព្រះអម្ចាស់បានលះបង់ព្រះជន្ម ដើម្បីស្លាប់ជំនួសយើងរាល់គ្នា»
ដើម្បីដោះយើងឲ្យរួចផុតពីការរំលងច្បាប់ទាំងអស់
លោកប៉ុល បាននិយាយអំពីព្រះអម្ចាស់
ដូចជាលោកបានដោះលែងទាសកររបស់ពួកគេ។
ប្រជារាស្ត្រដ៏វិសុទ្ធ
មនុស្សមួយក្រុមដែលព្រះអម្ចាស់ឱ្យតម្លៃ។
យកចិត្តទុកដាក់
«មានបំណងប្រាថ្នាយ៉ាងខ្លាំង»
Titus 2:15
និយាយ និងលើកទឹកចិត្តគ្នាទៅវិញទៅមក
«ការបង្រៀនរឿងទាំងនេះហើយ លើកទឹកចិត្តអ្នកស្តាប់អោយធ្វើរឿងទាំងនេះ»
ចូរកែតម្រូវដោយប្រើសិទ្ធិអំណាចពេញទី
ខ្លឹមសារភ្ជាប់នេះអាចត្រូវបានធ្វើឱ្យជាក់ច្បាស់។ ការបកប្រែរបៀបផ្សេងទៀត
«ត្រូវនឹងសិទ្ធិអំណាចពេញទីរបស់មនុស្សទាំងនោះ ដែលមិនធ្វើអ្វីទាំងនេះ»
កុំឲ្យនរណាម្នាក់
«មិនអនុញ្ញាតឱ្យនរណាម្នាក់ឡើយ»
មិនគោរពអ្នកឡើយ
ខ្លឹមសារភ្ជាប់នេះអាចត្រូវបានធ្វើឱ្យយ៉ាងជាក់ច្បាស់។ ការបកប្រែរបៀបផ្សេងទៀត
«បដិសេធមិនស្តាប់ពាក្យរបស់អ្នករាល់គ្នា» ឬ «បដិសេធមិនគោរពអ្នករាល់គ្នា»

---

3 [1]ចូរដាស់តឿនដល់បងប្អូនឲ្យគោរពចុះចូលនឹងអាជ្ញាធរ រដ្ឋអំណាច ព្រមទាំងស្តាប់បង្គាប់ ដើម្បីប្រព្រឹត្តអំពើល្អគ្រប់យ៉ាង។
[2]ចូរដាស់តឿនពួកគេកុំឲ្យមើលងាយនរណាម្នាក់ ហើយក៏កុំឲ្យពួកគេទាស់ប្រឆាំង
តែចូរឲ្យគេមានចិត្តសប្បុរសនិងបង្ហាញពីចិត្តសុភាពរាបសាចំពោះមនុស្សទាំងអស់វិញ។
[3]កាលពីដើម ពួកយើងក៏ជាមនុស្សគិតខ្លី និងមិនស្តាប់បង្គាប់ដែរ។ យើងបានវង្វេង និងជាទាសករខាងឯសេចក្តីប៉ងប្រាថ្នា ព្រមទាំងភាពស្រើបស្រាលគ្រប់បែបយ៉ាងដែរ។
យើងបានរស់នៅក្នុងការអាក្រក់ និងច្រណែនឈ្នានីស។ យើងជាមនុស្សដែលគួរឲ្យស្អប់ខ្ពើម ព្រមទាំងស្អប់គ្នាទៅវិញទៅមកផង។
[4]ប៉ុន្តែ នៅពេលសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះរបស់យើង និងសេចក្តីស្រឡាញ់របស់ព្រះអង្គ
ចំពោះមនុស្សបានបើកសម្តែង[5]ពុំមែនមកពីយើងបានប្រព្រឹត្តសេចក្តីសុចរិតនោះទេ គឺដោយសារព្រះហឫទ័យមេត្តាករុណា របស់ព្រះអង្គបានសង្គ្រោះយើង។
ព្រះអង្គបានសង្គ្រោះយើងតាមរយៈការលាងជម្រះឲ្យកើតជាថ្មី និងប្រទានជីវិតថ្មីតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។
[6]ព្រះអង្គបានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងបរិបូរ មកលើយើងតាមរយៈព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់យើង។[7]ព្រះអង្គសង្គ្រោះយើង ដោយរាប់យើងជាសុចរិត
តាមរយៈព្រះគុណរបស់ព្រះអង្គ ដូច្នេះយើងបានទទួលជីវិតអស់កល្បជានិច្ចទុកជាមរតក ដោយសេចក្តីសង្ឃឹមរបស់យើង។
[8]ព្រះបន្ទូលនេះគួរឲ្យជឿទុកចិត្តបាន។ ខ្ញុំចង់ឲ្យអ្នកនិយាយពាក្យនេះ ដោយជឿជាក់ក្នុងចិត្តថា អស់អ្នកណាដែលទុកចិត្តលើព្រះជាម្ចាស់
នឹងមានចិត្តស្មោះសរប្រព្រឹត្តអំពើល្អដែលព្រះអង្គបានបង្គាប់។ សេចក្តីទាំងនេះជាការល្អប្រសើរ និងមានប្រយោជន៍ដល់មនុស្សលោក។
[9]ចូរចៀសចេញពីការសួរដេញដោលដ៏ល្ងង់ខ្លៅ និងពីបញ្ជីវង្សត្រកូល ការឈ្លោះប្រកែក និងជម្លោះអំពីគម្ពីរវិន័យ ដ្បិតការទាំងអស់នេះជាការឥតប្រយោជន៍ និងឥតបានការ
អ្វីទាំងអស់។[10]ចូរបដិសេធអ្នកណាដែលបង្ករការបែកបាក់គ្នា ក្នុងចំណោមអ្នករាល់គ្នា បន្ទាប់ពីការដាស់តឿនមួយម្តងពីរម្តងរួចហើយ
បណ្តេញគេឲ្យចេញទៅ[11]ដោយដឹងថាជនប្រភេទនេះបានផ្លាស់ប្តូរពីការល្អ ហើយមកប្រព្រឹត្តអំពើបាបហើយគេនឹងដាក់ទោសខ្លួនឯង។
[12]ពេលខ្ញុំបានចាត់លោកអើតេម៉ាស ឬលោកទីឃីកុសឲ្យទៅរកអ្នក ចូរប្រញាប់មករកខ្ញុំនៅទីក្រុងនីកូប៉ូល ជាកន្លែងខ្ញុំត្រូវស្នាក់នៅរដូវរងារ។[13]ចូរខិតខំជួយលោកសេណាស
ជាមេធាវី និងលោកអ័ប៉ុឡូសឲ្យបន្តដំណើរទៅមុខទៀត កុំឲ្យពួកគេខ្វះអ្វីឡើយ។
[14]ត្រូវឲ្យបងប្អូនយើងខិតខំធ្វើការល្អផង សម្រាប់បំពេញសេចក្តីត្រូវការចាំបាច់ទាំងឡាយ ដើម្បីកុំឲ្យត្រឡប់ជាមនុស្សមិនបង្កើតផលឡើយ។
[15]បងប្អូនទាំងអស់ដែលនៅជាមួយខ្ញុំក៏ជម្រាបសួរមកអ្នកដែរ។ ចូរជម្រាបសួរដល់ពួកអ្នករួមជំនឿ ដែលស្រឡាញ់យើងផង។ សូមឲ្យអ្នកទាំងអស់គ្នាបានប្រកបដោយ
ព្រះគុណ។

Titus 3:1
ប្រយោគភ្ជាប់៖
លោកប៉ុល បានបន្តផ្តល់ការណែនាំដល់ទីតុស អំពីរបៀបបង្រៀនពួកវ័យចំណាស់
និងមនុស្ស ដែលនៅក្រោមការថែទាំរបស់លោកនៅក្រែត។
ដាស់តឿនដល់បងប្អូន
«ប្រាប់បងប្អូនរបស់យើងម្តងទៀត នូវអ្វីដែលពួកគេបានដឹងរួចហើយ» ឬ
«បន្តរំលឹកដល់ពួកគេ»
ឲ្យគោរពចុះចូលនឹងអាជ្ញាធរ រដ្ឋអំណាច ព្រមទាំងស្តាប់បង្គាប់
«ធ្វើដូចជាមេដឹកនាំនយោបាយ
និងអាជ្ញាធររដ្ឋាភិបាលនិយាយដោយការស្តាប់បង្គាប់ពួកគេ»
អ្នកគ្រប់គ្រង និង អាជ្ញាធរ
ពាក្យទាំងនេះមានន័យប្រហាក់ប្រហែលគ្នា
និងត្រូវបានប្រើរួមគ្នាដើម្បីរាប់បញ្ចូលមនុស្សគ្រប់គ្នា
ដែលមានសិទ្ធិអំណាចនៅក្នុងរដ្ឋាភិបាល។
ដើម្បីប្រព្រឹត្តអំពើល្អគ្រប់យ៉ាង
«ត្រៀមខ្លួនធ្វើអោយបានល្អ ពេលណាដែលមានឱកាស»
ជេរប្រមាថ
«និយាយដោយគ្មានសីលធម៌»
តែចូរឲ្យពួកគេមានចិត្តសប្បុរស
នៅពេលដែលចំណង់ចំណូលចិត្តផ្ទាល់ខ្លួន មិនមានភាពខុសឆ្គង
លោកប៉ុលបានដាស់តឿនទៅអ្នកជឿឱ្យធ្វើអ្វី ដែលអ្នកដទៃចូលចិត្តធ្វើ។
Titus 3:3
កាលពីដើមឡើយ
ដោយសារតែ
ម្តងនោះ
«ពីមុន» ឬ «នៅពេលខ្លះ» ឬ «កាលពីមុន»
គិតខ្លី
«ល្ងង់» ឬ «ឥតប្រាជ្ញា»
បានវង្វេង ខាងឯសេចក្តីប៉ងប្រាថ្នា ព្រមទាំងភាពស្រើបស្រាលគ្រប់បែបយ៉ាង
លោកប៉ុល បាននិយាយអំពីសេចក្តីប៉ងប្រាថ្នាខុសឆ្គងរបស់យើង
ដូចជាពួកគេជាមនុស្សដែលនាំយើងអោយចេញពីផ្លូវត្រឹមត្រូវ។
ការបកប្រែរបៀបផ្សេងទៀត: «យើងត្រូវបានគេបោកបញ្ឆោត»
ជាទាសករ ខាងឯសេចក្តីប៉ងប្រាថ្នា ព្រមទាំងភាពស្រើបស្រាលគ្រប់បែបយ៉ាង
លោកប៉ុល បាននិយាយអំពីបំណងប្រាថ្នាដ៏ខ្លាំងពីមុនរបស់យើងក្នុងការធ្វើខុស
ដូចជាពួកគេជាម្ចាស់របស់យើង
ស្រើបស្រាល
«ស្រើបស្រាល» ឬ «សេចក្តីប្រាថ្នាចង់បាន»
រស់នៅក្នុងការអាក្រក់ និងការច្រណែនឈ្នានីស
«អាក្រក់» និង «ការច្រណែន» គឺជាពាក្យស្រដៀងគ្នាសម្រាប់អំពើបាប។
ការបកប្រែរបៀបផ្សេងទៀត: «ពួកយើងតែងតែធ្វើរឿងអាក្រក់
ហើយចង់បានអ្វីដែលអ្នកដទៃមាន»
យើងជាមនុស្សដែលគួរឲ្យស្អប់ខ្ពើម
«យើងជាអ្នកនាំឱ្យអ្នកដទៃស្អប់ខ្ពើមយើង»
Titus 3:4
នៅពេលសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះរបស់យើង
និងសេចក្តីស្រឡាញ់របស់ព្រះអង្គ ចំពោះមនុស្សបានបើកសម្តែង
លោកប៉ុល បាននិយាយអំពីសេចក្តីសប្បុរស និងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់
ដូចជាពួកគេជាមនុស្សដែលមើលឃើញ។

generated on Wed Sep 10 16:16:32 2025

ដោយសារព្រះហឫទ័យមេត្តាករុណា
«ពីព្រោះព្រះអម្ចាស់បានអាណិតអាសូរដល់យើងរាល់គ្នា»
ការលាងជម្រះឲ្យកើតសារជាថ្មី
លោកប៉ុល
ប្រហែលជាកំពុងនិយាយអំពីការអភ័យទោសរបស់ព្រះអម្ចាស់ចំពោះអ្នករាល់គ្នា
ដែលប្រព្រឹត្តអំពើខុសឆ្គង ដូចជាកំពុងតែលាងសម្អាតខ្លួនប្រាណ។
លោកប៉ុលក៏កំពុងតែនិយាយអំពីមនុស្សមានបាប
ដែលប្រែខ្លួនឆ្លើយតបនឹងព្រះអម្ចាស់ ដូចជាពួកគេបានកើតសារជាថ្មី។
Titus 3:6
ការចាក់បង្ហូរ
«បរិបូរ» ឬ «តំណ»
ព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងបរិបូរ មកលើយើង
វាជារឿងធម្មតាសម្រាប់អ្នកសរសេរគម្ពីរសញ្ញាថ្មីនិយាយអំពីព្រះវិញ្ញាណបរិសុទ្ធ
ដូចជាវត្ថុរាវដែលអាចចាក់បាន។ ការបកប្រែរបៀបផ្សេងទៀត
«បានប្រទានព្រះវិញ្ញាណបរិសុទ្ធដល់យើងរាល់គ្នាដោយចិត្តសប្បុរស»
តាមរយៈព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់យើង។
«នៅពេលដែលព្រះអម្ចាស់បានសង្គ្រោះយើងរាល់គ្នា»
តាមរយៈព្រះគុណរបស់ព្រះអង្គ
«ព្រះអម្ចាស់បានប្រកាសថា យើងរាល់គ្នាជាមនុស្សដែលគ្មានបាបទៀតទេ»
យើងបានទទួលជីវិតអស់កល្បជានិច្ច
មនុស្សដែលព្រះអម្ចាស់បានសន្យាចំពោះពួកគេត្រូវបានគេនិយាយថា
ពួកគេនឹងទទួលមរតកទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។
Titus 3:8
នេះជាព្រះបន្ទូល
នេះសំដៅទៅលើព្រះអម្ចាស់
ដែលប្រទានអោយអ្នកជឿនូវព្រះវិញ្ញាណបរិសុទ្ធតាមរយៈព្រះអម្ចាស់នៅក្នុងជំពូក ៣:៦ ។
នឹងមានចិត្តស្មោះសរប្រព្រឹត្តអំពើល្អ ដែលព្រះអង្គបានបង្គាប់
«នឹងមានការប្រព្រឹត្តអំពើល្អ»
សេចក្តីទាំងនេះជាការល្អប្រសើរ
លោកប៉ុល បាននិយាយអំពីអំពើល្អដូចជាហេតុផលមួយ ដែលព្រះអម្ចាស់អាចដាក់
នៅចំពោះមុខមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលព្រះអម្ចាស់បានរៀបចំសម្រាប់ពួកគេដើម្បីធ្វើវា»
Titus 3:9
ប្រយោគផ្ចាប់
លោកប៉ុល បានពន្យល់អំពីអ្វីដែលទីតុសគួរជៀសវាង និងរបៀបប្រព្រឹត្តចំពោះអ្នក
ដែលបង្កជម្លោះក្នុងចំណោមអ្នកជឿ។
ប៉ុន្តែ
«ប៉ុន្តែអ្នករាល់គ្នា ទីតុស»
ការសួរដេញដោលដ៏លំបាក់ខ្លៅ
«ឈ្លោះប្រកែកគ្នាអំពីរឿងមិនសំខាន់»
បញ្ជីវង្សត្រកូល
នេះគឺជាការសិក្សាអំពីទំនាក់ទំនងគ្រួសារញាតិមិត្ត។
ការឈ្លោះប្រកែក
«ឈ្លោះប្រកែកគ្នា»
គម្ពីរវិន័យ
«ច្បាប់របស់លោកម៉ូសេ»
ចូរបដិសេធអ្នកណា
«ទៅអោយឆ្ងាយពីទីនេះ»
បន្ទាប់ពីការដាស់តឿនមួយម្តងពីរម្តងរួចហើយ បណ្តេញគេឲ្យចេញទៅ
«បន្ទាប់ពីអ្នកបានព្រមានបុគ្គលនោះម្តងឬពីរដង»
ជនប្រភេទនេះ
«មនុស្សដូចនេះ»
ផ្លាស់ប្តូរពីការល្អ
លោកប៉ុល បាននិយាយអំពីអ្នករាល់គ្នា ដែលធ្វើខុសដូចជាលោកកំពុងដើរតាមផ្លូវ
ដែលលោកកំពុងដើរ។
ដាក់ទោសខ្លួនឯង
«នាំមកនូវការវិនិច្ឆ័យដោយខ្លួនឯង»
Titus 3:12
ប្រយោគផ្ចាប់៖
លោកប៉ុល បានបិទសំបុត្រដោយប្រាប់ទីតុសនូវអ្វីដែលត្រូវធ្វើ
បន្ទាប់ពីគាត់តែងតាំងពួកអ្នកចាស់ទុំនៅកោះក្រែតនិងដោយការសួរសុខទុក្ខពីអ្នកដែលនៅជាមួយគាត់ផង
ពេលណាខ្ញុំបានចាត់អោយ
«បន្ទាប់ពីខ្ញុំចាត់អោយ»
លោកអើតេម៉ាស ... លោកទីឃីកុស ... លោកសេណាស
ទាំងនេះគឺជាឈ្មោះបុរស។
ចូរប្រញាប់ ហើយមករក
«អ្នករាល់គ្នាត្រូវតែប្រញាប់ ហើយមក» ឬ «មកអោយលឿន»
ត្រូវនៅក្នុងរដូវរងារ
«នៅក្នុងរដូវរងារ»
ចូរខិតខំជួយលោក
«អ្នករាល់គ្នាត្រូវតែប្រញាប់» ឬ «កុំពន្យារពេលក្នុងការជួយ»
និងលោកអ័ប៉ុឡូស
និងជួយដំណើរលោកអាប៉ូឡូស
Titus 3:14
ប្រយោគផ្ចាប់៖
លោកប៉ុលពន្យល់អំពីមូលហេតុ
ដែលមានសារៈសំខាន់ក្នុងការផ្គត់ផ្គង់លោកសេណាស និងអាប៉ូឡូ។
បងប្អូនយើង
លោកប៉ុល កំពុងសំដៅទៅលើអ្នកជឿនៅកោះក្រែត។
ខិតខំធ្វើ
«រវល់ក្នុងការធ្វើ»
ត្រូវការចាំបាច់ទាំងឡាយ
ទាំងនេះគឺជាតម្រូវការចាំបាច់ ដែលមិនបានគ្រោងទុក ឬបន្ទាន់
ដែលមិនត្រូវបានគេដឹងពីមុន។
ដើម្បីកុំឲ្យត្រឡប់ជាមនុស្សមិនបង្កើតផលឡើយ
លោកប៉ុល បាននិយាយអំពីលទ្ធផលល្អ ដូចជាពួកគេមានផ្លែផ្កា។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះពួកគេនឹងផ្តល់លទ្ធផលល្អ»
Titus 3:15
ព័ត៌មានទូទៅ៖
លោកប៉ុល បានបញ្ចប់សំបុត្ររបស់លោក ទៅកាន់ទីតុស។
បងប្អូនទាំងអស់
ប្រជាជនទាំងអស់
ចូរជម្រាបសួរដល់ពួកអ្នករួមជំនឿ ដែលស្រឡាញ់យើងផង
អាចមានន័យថា១) «អ្នកជឿ ដែលស្រឡាញ់យើង» ឬ ២)
«អ្នកជឿដែលស្រឡាញ់យើង ពីព្រោះយើងមានជំនឿដូចគ្នា»។
សូមឲ្យអ្នកទាំងអស់គ្នាបានប្រកបដោយព្រះគុណ
នេះគឺជាលក្ខណៈការសួរសុខទុក្ខរបស់គ្រីស្ទបរិស័ទ។ ការបកប្រែរបៀបផ្សេងទៀត:
«សូមអោយព្រះគុណរបស់ព្រះអម្ចាស់គង់នៅជាមួយអ្នករាល់គ្នា» ឬ
«យើងសូមអោយព្រះអម្ចាស់ប្រណីសន្តោសដល់អ្នកទាំងអស់គ្នា»

ភីលេម៉ូន

1 [1]ខ្ញុំ ប៉ូល នៅជាប់ឃុំឃាំងរបស់ព្រះគ្រិស្តយេស៊ូ និងលោកធីម៉ូថេជាបងប្អូន សូមជម្រាបមកលោកភីលេម៉ូនជាទីស្រឡាញ់ ដែលចូលរួមការងារជាមួយយើង[2]សូមជម្រាបមកប្អូនស្រីអាប់ភា ហើយជម្រាបមកលោកអើឃីពដែលតយុទ្ធរួមជាមួយយើង ព្រមទាំងសូមជម្រាបមកក្រុមជំនុំដែលប្រជុំគ្នាក្នុងផ្ទះរបស់លោកប្អូន។[3]សូមព្រះព្រះគុណ និងសេចក្តីសុខសាន្តដល់បងប្អូនពីព្រះជាម្ចាស់ជាព្រះបិតា និងព្រះយេស៊ូគ្រិស្តជាអម្ចាស់របស់យើង។
[4]ពេលខ្ញុំអធិស្ឋាន ខ្ញុំតែងតែដំណាលពីលោកប្អូន។ ខ្ញុំតែងតែអរព្រះគុណដ៏ព្រះជាម្ចាស់របស់ខ្ញុំជានិច្ច។[5]ដ្បិត ខ្ញុំបានឮអំពីសេចក្តីស្រឡាញ់ និងជំនឿរបស់លោកប្អូន នៅចំពោះព្រះអម្ចាស់យេស៊ូ និងចំពោះអ្នករួមជំនឿទាំងអស់។[6]ខ្ញុំអធិស្ឋានសូមឲ្យមានការរួមរស់ក្នុងជំនឿ ជំរុញចិត្តលោកប្អូនឲ្យស្គាល់ច្បាស់ នូវការល្អគ្រប់យ៉ាង ដែលយើង

generated on Wed Sep 10 16:16:32 2025

ត្រូវធ្វើថ្វាយព្រះគ្រិស្ត។[7]ខ្ញុំពិតជាមានអំណរ និងការលើកទឹកចិត្តយ៉ាងខ្លាំង ដោយសារឃើញសេចក្តីស្រឡាញ់របស់លោកប្អូន
ព្រោះចិត្តរបស់ប្រជាជនដ៏វិសុទ្ធបានធូរស្បើយដោយសារលោកប្អូន។
[8]ទោះបីខ្ញុំមានសិទ្ធិគ្រប់ទាំងអស់នឹងបង្គាប់លោកប្អូន ក្នុងនាមព្រះគ្រិស្ត ឲ្យធ្វើអ្វីដែលលោកប្អូនត្រូវធ្វើក៏ដោយ[9]ក៏ព្រោះតែសេចក្តីស្រលាញ់ទើបខ្ញុំមកអង្វរលោកប្អូន។ ខ្ញុំ
ប៉ូល ដែលមានវ័យកាន់តែចាស់ហើយ ឥឡូវនេះក៏ជាប់ឃុំឃាំង ព្រោះតែព្រះគ្រិស្តយេស៊ូថែមទៀតផង។
[10]ខ្ញុំសូមអង្វរលោកប្អូនអំពីកូនរបស់ខ្ញុំ គឺអូនេស៊ីម ដែលខ្ញុំបានបង្កើតនៅពេលជាប់ឃុំឃាំង។[11]ពីដើម គាត់គ្មានប្រយោជន៍អ្វីដល់លោកប្អូនមែន ប៉ុន្តែ ឥឡូវនេះគាត់ពិតជា
មានប្រយោជន៍ដល់លោកប្អូន ក៏ដូចជាមានប្រយោជន៍ដល់ខ្ញុំដែរ។[12]ខ្ញុំសូមចាត់គាត់ ឲ្យវិលមករកលោកប្អូនវិញ ដែលគាត់ប្រៀបបីដូចជាដួងចិត្តរបស់ខ្ញុំ។[13]ខ្ញុំក៏មានបំណង
ចង់ទុកគាត់ឲ្យនៅជាមួយខ្ញុំដែរ ដើម្បីឲ្យនៅបម្រើខ្ញុំជំនួសលោកប្អូន ក្នុងពេលខ្ញុំជាប់ឃុំឃាំង ព្រោះតែដំណឹងល្អនេះ។
[14]ប៉ុន្តែ ខ្ញុំមិនចង់ធ្វើអ្វីដោយមិនមានការយល់ព្រមពីលោកប្អូនឡើយ។ ខ្ញុំមិនចង់ឱ្យការប្រព្រឹត្តល្អរបស់ប្អូន ធ្វើទាំងទើសទាល់នោះទេ គឺធ្វើដោយស្ម័គ្រចេញពីចិត្តវិញ។
[15]ប្រហែលជាគាត់ត្រូវតែឃ្លាតឆ្ងាយពីលោកប្អូនមួយរយៈ ដើម្បីឲ្យលោកប្អូនបានទទួលគាត់វិញជាដរាបតទៅ[16]មិនមែនក្នុងឋានៈជាខ្ញុំបម្រើទៀតនោះទេ គឺក្នុងឋានៈជា
បងប្អូនដ៏ជាទីស្រឡាញ់ ជាមនុស្សពិសេសបំផុតសម្រាប់ខ្ញុំ។ គាត់ជាបងប្អូនដ៏ជាទីស្រឡាញ់យ៉ាងខ្លាំងរបស់ខ្ញុំ ហើយចំពោះលោកប្អូន គាត់ក៏រឹតតែជាទីស្រឡាញ់ថែមទៀត
ទាំងខាងលោកីយ៍ ទាំងខាងព្រះអម្ចាស់។
[17]ដូច្នេះ ប្រសិនបើលោកប្អូនចាត់ទុកខ្ញុំជាបងប្អូនរួមជំនឿមែន សូមទទួលយកគាត់ឲ្យបានដូចជាទទួលយកខ្ញុំដែរ។[18]ប្រសិនបើ គាត់ធ្វើអ្វីខុសចំពោះលោកប្អូន ឬប្រសិនបើ
គាត់ជំពាក់អ្វីលោកប្អូន សូមគិតលើខ្ញុំចុះ។[19]ខ្ញុំ ប៉ូល ខ្ញុំសរសេរពាក្យទាំងនេះដោយដៃខ្ញុំផ្ទាល់ថា ខ្ញុំនឹងសងលោកប្អូនវិញ (តែខ្ញុំមិនចាំបាច់រំឭកទេថា លោកប្អូនក៏នៅជំពាក់
ខ្ញុំដែរនោះទេ)។[20]លោកប្អូនអើយ សូមលោកប្អូនមេត្តាជួយខ្ញុំ ដោយយល់ដល់ព្រះនាមព្រះអម្ចាស់ ហើយសូមធ្វើឲ្យចិត្តខ្ញុំបានធូរស្បើយក្នុងអង្គព្រះគ្រិស្តផង។
[21]ខ្ញុំសូមសរសេរមកលោកប្អូន ដោយភាពជឿជាក់ថា លោកប្អូនមុខជាស្តាប់តាមសំណូមពររបស់ខ្ញុំ។ ខ្ញុំក៏ដឹងថា លោកប្អូននឹងធ្វើលើសពីពាក្យដែលខ្ញុំសុំនេះទៅទៀត។
[22]ក្នុងពេលជាមួយគ្នានេះ សូមលោកប្អូនរៀបចំកន្លែងមួយសម្រាប់ឲ្យខ្ញុំស្នាក់នៅផង ដ្បិតខ្ញុំសង្ឃឹមថា ដោយសារបងប្អូនបានទូលអង្វរព្រះជាម្ចាស់ឲ្យខ្ញុំ នោះខ្ញុំនឹងបានមក
ជួបបងប្អូនជាក់ជាមិនខាន។
[23]លោកអេប៉ាប្រាសដែលបានជាប់ឃុំឃាំងជាមួយនឹងខ្ញុំ ព្រោះតែព្រះគ្រិស្តយេស៊ូ សូមជម្រាបសួរមកលោកប្អូន[24]ហើយព្រមទាំងលោកម៉ាកុស លោកអើរីស្តាក លោក
ដេម៉ាស និងលោកលូកា ដែលរួមការងាររបស់ខ្ញុំដែរ។[25]សូមព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង ស្ថិតនៅជាប់ជាមួយវិញ្ញាណរបស់លោកប្អូន។ អាម៉ែន។

Philemon 1:1

ប្រយោគភ្ជាប់

លោកប៉ូលបានបញ្ជាក់ខ្លួនគាត់បីដងថា គឺជាអ្នកនិពន្ធសំបុត្រនេះ។
ជាក់ស្តែងលោកធីម៉ូថេនៅជាមួយលោកហើយប្រហែលជាសរសេរពាក្យនេះចូលដូចដែលគាត់ធ្លាប់ធ្វើ
លោកប៉ូលបានស្វាគមន៍អ្នកដទៃទៀតដែលជួបនៅឯព្រះវិហារនៅផ្ទះរបស់លោកភីលេម៉ូន។

ព័ត៌មានទូទៅ

ឧទាហរណ៍ថា «ខ្ញុំ» «ខ្ញុំ» និង «របស់ខ្ញុំ» សំដៅទៅលើលោកប៉ូល។
លោកភីលេម៉ូនជាមនុស្សសំខាន់ដែលបានសរសេរសំបុត្រនេះ។ ឧទាហរណ៍ថា
«អ្នក» និង «របស់អ្នក» ដែលសំដៅទៅលើគាត់
ហើយមានលក្ខណៈតែម្នាក់ឯងលុះត្រាតែមានការកត់សម្គាល់ផ្សេង។

ព័ត៌មានទូទៅ

ពាក្យថា «យើង» នៅទីនេះរាប់បញ្ចូលទាំងប៉ូល និងភីលេម៉ូន
ហើយអាចមានអ្នកជឿនៅព្រះវិហារដែលជួបជុំគ្នានៅផ្ទះភីលេម៉ូន។

លោកប៉ូលជាអ្នកទោសរបស់ព្រះគ្រិស្តយេស៊ូនិងប្អូនប្រុសលោកធីម៉ូថេនៅក្រុងភីលេម៉ូន

ភាសារបស់អ្នកអាចមានវិធីជាក់លាក់ណាមួយដើម្បីណែនាំអ្នកនិពន្ធនៃសំបុត្រ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំ ប៉ូលដែលជាប់ឃុំឃាំងក្នុងព្រះគ្រិស្តយេស៊ូ
និងលោកធីម៉ូថេដែលជាបងប្អូនយើងកំពុងតែសរសេរសំបុត្រនេះជូនលោកភីលេម៉ូន»
។ (សូមមើល:)

អ្នកទោសរបស់ព្រះគ្រិស្តយេស៊ូ

«អ្នកទោសគឺសម្រាប់ជាប្រយោជន៍របស់ព្រះគ្រិស្តយេស៊ូ» ។
មនុស្សដែលប្រឆាំងនឹងការផ្សព្វផ្សាយរបស់លោកប៉ូលបានដាក់ទណ្ឌកម្មលោកដោយដាក់គុក

បងប្អូន

នេះមានន័យថាបងប្អូនគ្រីស្ទានម្នាក់

និងមិត្តរួមការងារ

«អ្នកខ្លះទៀត ក៏ដូចជាពួកយើងដែរធ្វើការដើម្បីផ្សាយដំណឹងល្អ»

អាប់ភា ជាប្អូនស្រីរបស់យើង

«អាប់ភា ជាអ្នកចូលរួមជឿរបស់យើង» ឬ «អាប់ភា
ជាប្អូនស្រីខាងវិញ្ញាណរបស់យើង» (សូមមើល:)

អើឃីព

នេះគឺជាឈ្មោះបុរសម្នាក់នៅក្នុងព្រះវិហារជាមួយភីលេម៉ូន។ (សូមមើល:)

ទាហានដែលតយុទ្ធរួមជាមួយយើង

លោកប៉ូលនិយាយនៅទីនេះអំពីអើឃីព ហាក់ដូចជា
ពួកគេទាំងពីរនាក់ជាទាហាននៅក្នុងជួរកងទ័ព។ លោកមានន័យថា
អើឃីពខំធ្វើការដូចលោកប៉ូលខ្លួនឯងខំប្រឹងផ្សព្វផ្សាយដំណឹងល្អ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកចម្បាំងខាងវិញ្ញាណរបស់យើង» ឬ
«អ្នកដែលប្រឆាំងខាងវិញ្ញាណជាមួយយើងផងដែរ»

សូមព្រះជាម្ចាស់ជាព្រះបិតារបស់យើងនិងព្រះអម្ចាស់យេស៊ូគ្រិស្តប្រទានព្រះគុណនិងសេចក្តីសុខសាន្តដល់អ្នក

«សូមព្រះគុណ និងសេចក្តីសុខសាន្តដល់បងប្អូន ពីព្រះជាម្ចាស់ជាព្រះបិតា
និងព្រះយេស៊ូគ្រិស្តជាអម្ចាស់របស់យើង»។ នេះគឺជាព្រះពរ។

ព្រះវរបិតារបស់យើង

នេះគឺជាងារដ៏សំខាន់សំរាប់ព្រះ។

Philemon 1:4

ការអធិស្ឋាន

លោកប៉ូលបានសរសេរពាក្យទាំងនេះដោយដៃខ្ញុំផ្ទាល់ថា «យើង» គឺពហុវចនៈ ហើយសំដៅទៅលើលោកប៉ូល លោកធីម៉ូថេ
និងភីលេម៉ូន។ (សូមមើល:)

ការរួមរស់ក្នុងជំនឿ

«ដែលអ្នកធ្វើការជាមួយយើង»

ជំរុញចិត្តបងប្អូនឲ្យស្គាល់ច្បាស់ នូវការល្អគ្រប់យ៉ាង

«លទ្ធផលនៃការដឹងថាអ្វីដែលល្អ»

ព្រះគ្រិស្ត

«ពីព្រោះតែព្រះគ្រិស្ត»

ចិត្តរបស់អ្នកជឿដ៏វិសុទ្ធបានធូរស្បើយដោយសារអ្នក។

«អ្នកបានលើកទឹកចិត្តអ្នកជឿ» ឬ «អ្នកបានជួយដល់អ្នកជឿ»

បងប្អូន

«បងប្រុសជាទីស្រឡាញ់» ឬ «មិត្តជាទីស្រឡាញ់» ។
លោកប៉ូលបានហៅភីលេម៉ូនថា «ប្អូនប្រុស» ពីព្រោះពួកគេទាំងពីរជាអ្នកជឿ
និងសង្កត់ធ្ងន់ទៅលើមិត្តភាពរបស់ពួកគេ។

Philemon 1:8

ប្រយោគភ្ជាប់

លោកប៉ូលបានចាប់ផ្តើមអង្វរ និងមូលហេតុពីសំបុត្ររបស់លោក។

ទាំងអស់នឹងបង្គាប់លោកប្អូន ក្នុងនាមព្រះគ្រិស្ត

អត្ថន័យដែលអាចមានគឺ ១) «សិទ្ធិអំណាចដោយសារព្រះគ្រិស្ត» ឬ ២)
«ភាពក្លាហានដោយសារព្រះគ្រិស្ត ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ភាពក្លាហានពីព្រោះព្រះគ្រិស្តបានផ្តល់សិទ្ធិអំណាចដល់ខ្ញុំ»

ក៏ព្រោះតែក្តីស្រឡាញ់

អាចមានន័យថាទី ១) «ពីព្រោះខ្ញុំដឹងថាអ្នកស្រឡាញ់ប្រជារាស្ត្ររបស់ព្រះ» ទី ២)
«ពីព្រោះអ្នកស្រឡាញ់ខ្ញុំ» ឬ ទី ៣) «ព្រោះខ្ញុំស្រឡាញ់អ្នក»

Philemon 1:10

ព័ត៌មានទូទៅ

អូនេស៊ីមជាឈ្មោះរបស់បុរសម្នាក់

ដែលតាមមើលទៅជាទាសកររបស់លោកភីលេម៉ូន ដែលបានលួចរបស់មួយចំនួន
ហើយរត់គេចខ្លួន។

កូនរបស់ខ្ញុំគឺអូនេស៊ីម

«កូនប្រុសរបស់ខ្ញុំអូនេស៊ីម»។
លោកប៉ូលនិយាយអំពីរបៀបដែលលោកជាមិត្តភក្តិនឹងអូនេស៊ីមហាក់ដូចជាឪពុក
និងកូនប្រុសរបស់លោកស្រឡាញ់គ្នា។
អូនេស៊ីមមិនមែនជាកូនប្រុសពិតរបស់លោកប៉ូលទេ
ប៉ុន្តែលោកបានទទួលជីវិតខាងវិញ្ញាណនៅពេលដែលលោកប៉ូលបានបង្រៀនគាត់អំពីព្រះយេស៊ូ

generated on Wed Sep 10 16:16:32 2025

ហើយលោកប៉ូលស្រឡាញ់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«កូនប្រុសខាងវិញ្ញាណរបស់ខ្ញុំគឺអូនេស៊ីម» (សូមមើល:)
អូនេស៊ីម
ឈ្មោះ «អូណេស៊ីម» មានន័យថា «ផលចំណេញ» ឬ «មានផលប្រយោជន៍» ។
(សូមមើល:translate-names)
ដែលខ្ញុំបានបង្កើតមក
របៀបដែលអូនេស៊ីមបានក្លាយជាកូនប្រុសរបស់លោកប៉ូលអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបានក្លាយជាកូនប្រុសខាងវិញ្ញាណរបស់ខ្ញុំនៅពេលខ្ញុំបង្រៀនលោកអំពីព្រះគ្រីស្ទ» ឬ «ដែលបានក្លាយជាកូនប្រុសខ្ញុំ»
នៅពេលជាប់ឃុំឃាំង
អ្នកទោសត្រូវបានគេដាក់ច្រវាក់ជាញឹកញាប់។
នៅពេលដែលលោកប៉ូលសរសេរសំបុត្រនេះគឺនៅពេលដែលលោកបានជាប់គុក។
របៀបផ្សេងទៀតនៃការបកប្រែ: «ពេលខ្ញុំនៅក្នុងគុក»
ខ្ញុំសូមចាត់គាត់... ឲ្យវិលមករកអ្នកវិញ
លោកប៉ូលប្រហែលជាបានចាត់អូនេស៊ីមជាមួយអ្នកជឿម្នាក់ទៀតដែលកាន់សំបុត្រនេះ។
ប្រៀបបីដូចជាដួងចិត្តរបស់ខ្ញុំ
ត្រង់ពាក្យថា «បេះដូង» ត្រូវបានប្រើសម្រាប់មនុស្សដែលជាទីស្រឡាញ់។
លោកប៉ូលបាននិយាយអំពីអូនេស៊ីម។របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលខ្ញុំស្រឡាញ់ខ្លាំង» (សូមមើល)
ដើម្បីឲ្យនៅបម្រើខ្ញុំជំនួសអ្នក
«ដោយសារអ្នកមិនអាចនៅទីនេះ គាត់អាចជួយខ្ញុំ» ឬ
«ដូច្នេះគាត់អាចជួយខ្ញុំជំនួសអ្នក»
ពេលខ្ញុំនៅជាប់ឃុំឃាំង
«ពេលខ្ញុំនៅគុក» (សូមមើល:)
ព្រោះតែដំណឹងល្អនេះ
«ពីព្រោះខ្ញុំផ្សាយដំណឹងល្អ»
Philemon 1:14
ប៉ុន្តែខ្ញុំមិនចង់ធ្វើអ្វីដោយគ្មានការយល់ព្រមពីអ្នកឡើយ
លោកប៉ូលនិយាយបដិសេធពីរដង ដើម្បីមានន័យផ្ទុយពីនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប៉ុន្តែខ្ញុំចង់រក្សាគាលោកនៅជាមួយខ្ញុំ
លុះត្រាតែលោកយល់ព្រម»
ខ្ញុំមិនចង់ឱ្យការប្រព្រឹត្តល្អរបស់ប្អូន ធ្វើទាំងទើសទាល់នោះទេ គឺធ្វើដោយស្ម័គ្រចេញពីចិត្តវិញ
«ដូច្នេះអ្នកនឹងធ្វើអ្វីដែលត្រឹមត្រូវមិនមែនដោយសារខ្ញុំកំពុងបង្ខំអ្នកឡើយ»
ប៉ុន្តែធ្វើដោយស្ម័គ្រចេញពីចិត្តវិញ
«ប៉ុន្តែដោយសារតែអ្នកបានជ្រើសរើសធ្វើអ្វីដែលត្រឹមត្រូវ»
ប្រហែលជាគាត់ត្រូវតែឃ្លាតឆ្ងាយពីអ្នក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រហែលជាហេតុផលដែលព្រះបានយកអូនេស៊ីមចេញពីអ្នក» (សូមមើល:)
មួយរយៈ
«ក្នុងកំឡុងពេលនេះ»
ប្រសើរជាងទាសករ
«មានតម្លៃជាងទាសករ»
ជាបងប្អូនដ៏ជាទីស្រឡាញ់
«បងប្អូនជាទីស្រឡាញ់» ឬ «បងប្រុសជាទីស្រឡាញ់នៅក្នុងព្រះគ្រិស្ត»
រឹតតែជាទីស្រឡាញ់ថែមទៀត
«គាត់មានន័យថាកាន់តែមានច្រើនចំពោះអ្នក»
ទាំងខាងលោកីយ៍
«ទាំងពីរគឺដូចជាបុរស»។ លោកប៉ូលកំពុងសំដៅទៅលើអូនេស៊ីមដែលជាអ្នកបម្រើដែលគួរឲ្យ ទុកចិត្ត។ (សូមមើល:)
ទាំងខាងព្រះអម្ចាស់
«និងជាបងប្អូននៅក្នុងព្រះអម្ចាស់» ឬ
«ហើយដោយសារតែគាត់ជាកម្មសិទ្ធិរបស់ព្រះអម្ចាស់»
Philemon 1:17
ប្រសិនបើអ្នកចាត់ទុកខ្ញុំជាបងប្អូនរួមជំនឿមែន
«ប្រសិនបើអ្នកគិតថាខ្ញុំជាអ្នករួមការងារដើម្បីព្រះគ្រិស្ត»
សូមគិតលើខ្ញុំចុះ
«និយាយថា ខ្ញុំគឺជាអ្នកដែលជំពាក់លោក»
ខ្ញុំ ប៉ូល សរសេរពាក្យទាំងនេះដោយដៃខ្ញុំផ្ទាល់
ខ្ញុំ ប៉ូលសរសេរពាក្យទាំងនេះដោយខ្លួនឯង។
ប៉ូលសរសេរផ្នែកនេះដោយដៃរបស់គាត់ផ្ទាល់ដើម្បីឲ្យភីលេម៉ូនដឹងថា
ពាក្យទាំងនេះគឺមកពីប៉ូល ហើយប៉ូលប្រាកដជាបង់ប្រាក់អោយភីលេម៉ូន។
ខ្ញុំមិនចាំបាច់រំឭកទេ
«ខ្ញុំមិនចាំបាច់រំលឹកអ្នក» ឬ «អ្នកដឹងរួចហើយ» (សូមមើល:)
អ្នកជំពាក់ខ្ញុំនូវជីវិតថ្មី
«អ្នកជំពាក់ខ្ញុំគឺជាជីវិតផ្ទាល់ខ្លួនរបស់អ្នក» ។
លោកប៉ូលបានបញ្ជាក់ថាភីលេម៉ូនមិនគួរនិយាយថាអូនេស៊ីម ឬ
ប៉ូលជំពាក់អ្វីទាំងអស់ ពីព្រោះភីលេម៉ូនជំពាក់ប៉ូលច្រើនជាង។
មូលហេតុដែលភីលេម៉ូនជំពាក់ប៉ុលជីវិតរបស់លោកអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកជំពាក់ខ្ញុំច្រើនព្រោះខ្ញុំបានជួយសង្គ្រោះជីវិតរបស់អ្នក» ឬ
«អ្នកជំពាក់ជីវិតខ្លួនឯងព្រោះអ្វីដែលខ្ញុំបានប្រាប់អ្នកគឺដើម្បីជួយជីវិតរបស់អ្នក» (សូមមើល:)
សូមធ្វើឲ្យចិត្តខ្ញុំបានធូរស្បើយ
«ធ្វើឲ្យខ្ញុំរីករាយ» ឬ «លួងលោមខ្ញុំ» ។ របៀបដែលប៉ូលចង់ឲ្យ
អូនេស៊ីមធ្វើកិច្ចការនេះអាចបញ្ជាក់យ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ធ្វើអោយបេះដូងខ្ញុំស្រស់ស្រាយដោយទទួលយកអូនេស៊ីមដោយចិត្តល្អ» (សូមមើល:
និង)
Philemon 1:21
ប្រយោគភ្ជាប់
លោកប៉ូលបានបិទសំបុត្ររបស់គាត់ហើយជូនពរដល់ភីលេម៉ូននិងអ្នកជឿដែលបានជួបជុំគ្នានៅព្រះវិហារ
ព័ត៌មានទូទៅ
ពាក្យ «របស់អ្នក» និង «អ្នក»
នៅទីនេះសំដៅទៅលើភីលេម៉ូននិងអ្នកជឿដែលបានជួបគ្នានៅផ្ទះរបស់គាត់ហើយមានគ្នាច្រើននាក់។
ដោយភាពជឿជាក់ថា លោកប្អូនមុខជាស្តាប់តាមសំណូមពររបស់ខ្ញុំ
«ពីព្រោះខ្ញុំដឹងច្បាស់ថាអ្នកនឹងធ្វើអ្វីដែលខ្ញុំស្នើសុំ»
ក្នុងពេលជាមួយគ្នានេះ
«ផងដែរ»
សូមអ្នករៀបចំកន្លែងមួយសម្រាប់ឲ្យខ្ញុំស្នាក់នៅផង
«រៀបចំបន្ទប់នៅក្នុងផ្ទះរបស់អ្នកឲ្យរួចរាល់សម្រាប់ខ្ញុំ» ។ លោកប៉ូលបានសុំឲ្យ
ភីលេម៉ូនធ្វើការនេះសម្រាប់គាត់។
ខ្ញុំនឹងប្រគល់ជូនអ្នកវិញ
«អ្នកដែលកំពុងឃុំឃាំងខ្ញុំ និងដោះលែងខ្ញុំដើម្បីឲ្យខ្ញុំអាចទៅជួបអ្នកបាន»។
Philemon 1:23
អេប៉ាប្រាស
នេះគឺជាអ្នកជឿ និងជាអ្នកទោសជាមួយប៉ូល។
ដែលបានជាប់ឃុំឃាំងជាមួយនឹងខ្ញុំ ព្រោះតែព្រះគ្រិស្តយេស៊ូ
«ជាអ្នកជាប់ក្នុងគុកជាមួយខ្ញុំពីព្រោះគាត់បំរើព្រះគ្រិស្តយេស៊ូ»
ព្រមទាំងលោកម៉ាកុស លោកអើរីស្ទាក លោកដេម៉ាស និងលោកលូកា ដែលរួមការងាររបស់ខ្ញុំដែរ
«លោកម៉ាកុស លោកអើរីស្ទាក លោកដេម៉ាសនិងលោកលូកា ដែលរួមការងាររបស់
ខ្ញុំក៏សូមជំរាបសួរមកអ្នកដែរ»។
លោកម៉ាកុស... លោកអើរីស្ទាក... លោកដេម៉ាស... និងលោកលូកា
ទាំងនេះគឺជាឈ្មោះរបស់មនុស្សប្រុស។
ដែលរួមការងាររបស់ខ្ញុំ
«បុរសដែលធ្វើការជាមួយខ្ញុំ» ឬ «អ្នកដែលធ្វើការជាមួយខ្ញុំ» ។
សូមព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង ស្ថិតនៅជាប់ជាមួយវិញ្ញាណរបស់លោកប្អូន។
ពាក្យថា «របស់អ្នក»
នៅទីនេះគឺសំដៅទៅលើភីលេម៉ូននិងអ្នកដែលបានជួបគ្នានៅក្នុងផ្ទះរបស់លោក។
ពាក្យថា «វិញ្ញាណរបស់អ្នក» គឺជានិមិត្តរូបមួយហើយតំណាងឱ្យប្រជាជនខ្លួនឯង។
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមអោយព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើងមានព្រះហឫទ័យសប្បុរសចំពោះអ្នក»
។

ហេព្រើរ

generated on Wed Sep 10 16:16:32 2025

1 [1]កាលពីដើម ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបុរសយើងតាមរយៈពួកព្យាការី ច្រើនលើកច្រើនសារ និងប្រើរបៀបផ្សេងៗជាច្រើន។[2]ប៉ុន្តែ
នៅសម័យចុងក្រោយបង្អស់ ព្រះអង្គមានព្រះបន្ទូលមកកាន់យើងរាល់គ្នា តាមរយៈព្រះបុត្រាវិញ ព្រះអង្គបានប្រគល់អ្វីៗទាំងអស់ឲ្យព្រះបុត្រាគ្រប់គ្រងជាមរតក។
ព្រះជាម្ចាស់បានបង្កើតពិភពទាំងមូល ដោយសារព្រះបុត្រា។[3]ព្រះបុត្រាជាពន្លឺនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈដូចព្រះអង្គបេះបិទ។ ព្រះបុត្រាទ្រទ្រង់អ្វីៗ
ទាំងអស់ដោយសារព្រះបន្ទូលពេញឫទ្ធានុភាព។ លុះព្រះអង្គប្រោសមនុស្សឲ្យបានវិសុទ្ធរួចផុតពីបាបរួចហើយ ទ្រង់ក៏គង់នៅខាងស្ដាំព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត។
[4]ព្រះបុត្រាបានទទួលព្រះនាមប្រសើរលើសពួកទេវតាយ៉ាងណា ទ្រង់ក៏ទទួលឋានៈប្រសើរជាងពួកទេវតាយ៉ាងនោះដែរ។[5]តើព្រះជាម្ចាស់ធ្លាប់មានព្រះបន្ទូលទៅកាន់ទេវតា
ណាថា៖ «ព្រះអង្គជាបុត្ររបស់យើង នៅថ្ងៃនេះ យើងបានទទួលព្រះអង្គធ្វើជាបុត្រ» ឬមានព្រះបន្ទូលថា៖ «តើយើងនឹងធ្វើជាបិតារបស់ព្រះអង្គ ហើយព្រះអង្គនឹងទៅជា
បុត្ររបស់យើងដែរឬទេ?»
[6]មួយវិញទៀត ពេលព្រះជាម្ចាស់ចាត់បញ្ជូនបុត្រច្បងមកផែនដីនេះ ព្រះអង្គមានព្រះបន្ទូលថា៖ «ទេវតាទាំងអស់របស់ព្រះជាម្ចាស់ត្រូវថ្វាយបង្គំព្រះបុត្រា»។
[7]ចំពោះពលទេវតាវិញ ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «ព្រះអង្គជាព្រះជាម្ចាស់ ដែលបានបង្កើតទេវតាជាវិញ្ញាណ ហើយអ្នកបម្រើព្រះអង្គជាអណ្ដាតភ្លើង»។
[8]ចំពោះព្រះបុត្រាវិញ ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «បពិត្រ ព្រះជាម្ចាស់ បល្ល័ង្ករបស់ព្រះអង្គនៅស្ថិតស្ថេរអស់កល្បជានិច្ច។
ហើយព្រះរាជ្យរបស់ព្រះអង្គជារាជ្យប្រកបដោយយុត្តិធម៌។[9]ព្រះអង្គសព្វព្រះហឫទ័យសេចក្ដីសុចរិត និងមិនសព្វព្រះហឫទ័យនឹងអំពើទុច្ចរិត។ ហេតុដូចនេះ
ព្រះជាម្ចាស់ជាព្រះរបស់ព្រះអង្គបានចាក់ប្រេងអភិសេកព្រះអង្គ ដោយប្រេងនៃអំណរលើសលប់ ជាងមិត្តភក្តិរបស់ព្រះអង្គទៅទៀត»។
[10]កាលដើមដំបូងបង្អស់ ព្រះអម្ចាស់បានបង្កើតគ្រឹះផែនដី ហើយផ្ទៃមេឃក៏ជាស្នាព្រះហស្តរបស់ព្រះអង្គដែរ។[11]ផែនដី និងផ្ទៃមេឃមុខជារលាយបាត់ទៅអស់ តែព្រះអង្គនៅ
ស្ថិតស្ថេររហូត។ ផែនដី និងផ្ទៃមេឃមុខជាចាស់ទៅៗ ដូចសម្លៀកបំពាក់។[12]ព្រះអង្គនឹងបត់ទាំងផែនដី និងទាំងផ្ទៃមេឃទុក ដូចគេបត់អាវធំ ។ ផែនដី និងផ្ទៃមេឃនឹង
ត្រូវរេចរឹលទៅដូចសម្លៀកបំពាក់។ ចំពោះព្រះអង្គវិញ ព្រះអង្គមិនចេះប្រែព្រះទ័យឡើយ ហើយព្រះជន្មាយុរបស់ព្រះអង្គក៏មិនចេះអស់ដែរ។
[13]ចុះតើទេវតាមួយណា ដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់គ្រប់ពេលថា៖ «ចូរអង្គុយនៅខាងស្ដាំយើង
រហូតយើងបង្ក្រាបខ្មាំងសត្រូវព្រះអង្គដាក់ក្រោមព្រះបាទាព្រះអង្គ?»[14]តើទេវតាទាំងអស់មិនមែនជាវិញ្ញាណ ដែលបម្រើព្រះជាម្ចាស់
ហើយត្រូវព្រះអង្គបញ្ជូនឲ្យមកមើលថែអ្នក ដែលត្រូវទទួលការសង្គ្រោះជាមរតកដែរឬទេ?

Hebrews 1:1

ប្រយោគភ្ជាប់៖

បុរេកថានេះទាញទៅរកជីវប្រវត្តិសម្រាប់ព្រះគម្ពីរ
ព្រះរាជបុត្រាមានឋានៈធំលើសគេទាំងអស់។
ព្រះគម្ពីរបានចាប់ផ្តើមជាមួយនឹងការបញ្ជាក់ថា
ព្រះបុត្រាគឺល្អប្រសើរជាងពួកព្យាការី និងពួកទេវតា។

ព័ត៌មានទូទៅ៖

ទោះបីជាមិនបានប្រាប់នៅក្នុងពិធីបើកសំបុត្រនេះ
ត្រូវបានសរសេរជាពិសេសដើម្បីជនជាតិហេព្រើរ (ជនជាតិយូដា)
ដែលនឹងបានយល់សេចក្តីយោងតាមរយៈគម្ពីរសញ្ញាចាស់ជាច្រើន។

នៅសម័យចុងក្រោយបង្អស់

«នៅសម័យចុងក្រោយបង្អស់»។ ក្នុងឃ្លានេះសំដៅទៅលើពេលវេលា
ដែលលោកយេស៊ូបានផ្សព្វផ្សាយព្រះរាជកិច្ចរបស់ព្រះអង្គ
ដោយបន្តរហូតដល់ព្រះជាម្ចាស់បានបង្កើតច្បាប់ពេញលេញរបស់ព្រះអង្គនៅក្នុងការបង្កើតថ្មី

តាមរយៈព្រះបុត្រា

«ព្រះបុត្រា»
គឺជាការសំខាន់សម្រាប់ព្រះយេស៊ូមាននាមជាព្រះបុត្រារបស់ព្រះជាម្ចាស់។

ប្រគល់អ្វីៗទាំងអស់ឲ្យព្រះបុត្រាគ្រប់គ្រងជាមរតក

អ្នកនិពន្ធនិយាយអំពី ព្រះបុត្រា ប្រសិនបើលោកនឹងគ្រងទ្រព្យសម្បត្តិ
និងទ្រព្យសម្បត្តិពីព្រះបិតារបស់ព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីគ្រប់គ្រងលើរបស់ទាំងអស់»

ព្រះជាម្ចាស់បានបង្កើតពិភពទាំងមូល ដោយសារព្រះបុត្រា

«គឺតាមរយៈព្រះរាជបុត្រា ដែលព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់»

ពន្លឺនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់

«ពន្លឺនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់»។ សិរីរុងរឿងរបស់ព្រះជាម្ចាស់
ត្រូវបានផ្សារភ្ជាប់ជាមួយនឹងពន្លឺភ្លឺខ្លាំង។ អ្នកនិពន្ធកំពុងនិយាយថា
ព្រះរាជបុត្រាតំណាងឲ្យពន្លឺនោះហើយតំណាងឲ្យសិរីល្អរបស់ព្រះជាម្ចាស់យ៉ាងពេញលេញ

មានលក្ខណៈដូចព្រះអង្គបេះបិទ

«រូបភាពនៃការចាប់ផ្តើមរបស់ព្រះជាម្ចាស់»។ នេះគឺស្រដៀងនឹងអត្ថន័យទៅនឹង
«គឺជារស្មីនៃសិរីល្អរបស់ព្រះអង្គ»។ ព្រះបុត្រាតំណាងបុគ្គលិកលក្ខណៈ:
និងខ្លឹមសារនៃព្រះជាម្ចាស់
និងតំណាងឲ្យអ្វីគ្រប់យ៉ាងដែលជាព្រះជាម្ចាស់យ៉ាងពេញលេញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះបុត្រាគឺដូចព្រះ» ឬ
«អ្វីដែលពិតអំពីព្រះគឺជាការពិត អំពីព្រះរាជបុត្រាដែរ»

ព្រះបន្ទូលពេញឫទ្ធានុភាព

«ព្រះបន្ទូលពេញឫទ្ធានុភាពរបស់ព្រះអង្គ»។ ត្រង់ថា «ព្រះបន្ទូល»
សំដៅទៅលើសារ ឬការបង្គាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អានុភាពនៃសេចក្តីបង្គាប់របស់ព្រះអង្គ»

លុះព្រះអង្គប្រោសមនុស្សឲ្យបានវិសុទ្ធរួចផុតពីបាបរួចហើយ

នាមអរូបី «ការលៀងសំអាត» អាចបញ្ជាក់ជាកិរិយាស័ព្ទ «ធ្វើឲ្យស្អាត»។
របៀបផ្សេងទៀតនៃការបកប្រែ: «បន្ទាប់មកព្រះអង្គបានបញ្ចប់ការធ្វើឲ្យយើងបាន
ជាស្អាតបរិសុទ្ធពីអំពើបាប» ឬ
«បន្ទាប់មកព្រះអង្គបានជំរះយើងអោយបានបរិសុទ្ធរួចពីបាបរបស់យើង»

ព្រះអង្គប្រោសមនុស្សឲ្យបានវិសុទ្ធរួចផុតពីបាប

អ្នកនិពន្ធបាននិយាយអំពី ដូចជាការអត់ទោសចំពោះកំហុសឆ្គង
ប្រសិនបើការនេះបានធ្វើឲ្យមនុស្សម្នាក់ស្អាត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គធ្វើឲ្យការនេះអាចធ្វើទៅបានចំពោះព្រះជាម្ចាស់នឹងអត់ទោសបាបរបស់យើង»

ព្រះអង្គគង់នៅខាងស្ដាំព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត

ត្រង់ថា «ខាងស្ដាំ» សំដៅទៅលើទីកន្លែងកិត្តិយស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គគង់នៅកន្លែងកិត្តិយសនៅក្បែរព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត»

ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត

«ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់» សំដៅទៅលើព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះដ៏ខ្ពង់ខ្ពស់បំផុត»

Hebrews 1:4

ព័ត៌មានទូទៅ៖

សម្រង់ទំនាយទីមួយ (ព្រះអង្គជាបុត្ររបស់យើង)
ដកស្រង់ចេញពីព្រះគម្ពីរទំនុកតម្កើង។
ព្យាការីសាំយូអែលបានសរសេរទម្រង់ទំនាយទីពីរ (យើងនឹងធ្វើជាបិតារបស់
ព្រះអង្គ)។ ការកើតឡើងទាំងអស់នៃ «ព្រះអង្គ» សំដៅទៅលើព្រះយេស៊ូ ព្រះបុត្រា។
ពាក្យថា «អ្នក» សំដៅទៅលើ ព្រះយេស៊ូ ហើយពាក្យថា «យើង» និង «យើង»
សំដៅទៅលើព្រះជាម្ចាស់ជាព្រះបិតា។

ព្រះអង្គនឹងក្លាយជា

«ព្រះបុត្រានឹងក្លាចជា»

ព្រះនាមប្រសើរលើសពួកទេវតាយ៉ាងណា ព្រះអង្គក៏ទទួលឋានៈប្រសើរជាងពួកទេវតាយ៉ាងនោះដែរ

ត្រង់ថា «ព្រះនាម» សំដៅទៅលើកិត្តិយស និងអំណាច។ «ជាកិត្តិយស
និងអំណាចដែលព្រះអង្គបានទទួលគឺប្រសើរជាងកិត្តិយស
និងអំណាចរបស់ពួកទេវតា»

ព្រះអង្គបានទទួលឋានៈ

អ្នកនិពន្ធនិយាយដូចការទទួលកិត្តិយស និងអំណាច ប្រសិនបើ
ព្រះអង្គត្រូវបានទទួលទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិពីព្រះបិតារបស់ព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គបានទទួល»

តើព្រះជាម្ចាស់ធ្លាប់មានព្រះបន្ទូលទៅកាន់ទេវតាណាថា៖ «ព្រះអង្គជាបុត្ររបស់យើង...ជាបុត្រា
របស់យើងដែរឬទេ?»

សំណួរនេះសង្កត់ធ្ងន់ថាព្រះជាម្ចាស់មិនហៅទេវតាណាមួយ
ជាបុត្ររបស់ព្រះអង្គទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដ្បិតព្រះជាម្ចាស់មិនដែលមានព្រះបន្ទូលហៅពួកទេវតាណាម្នាក់ថា
អ្នកជាបុត្ររបស់យើង...ជាបុត្ររបស់យើង»។

generated on Wed Sep 10 16:16:32 2025

យើងបានទទួលព្រះអង្គធ្វើជាបុត្រ...យើងនឹងធ្វើជាបិតារបស់ព្រះអង្គ
ឃ្លាទាំងពីរនេះមានន័យថាសំខាន់ដូចគ្នា។
ឬមានព្រះបន្ទូលថា
ពាក្យ «ម្តងទៀត» បង្ហាញថាសំនួរស្រដៀងគ្នា អនុវត្តទៅសម្រង់ទីពីរ។ ពាក្យថា
«ម្តងទៀត» អាចត្រូវបានលុបចោល ឬជំនួសដោយសំណួរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយ» ឬ
«អំពីពួកទេវតាដែលព្រះជាម្ចាស់មិនធ្លាប់មានព្រះបន្ទូល»
Hebrews 1:6
ព័ត៌មានទូទៅ៖
ការដកស្រង់ដំបូងនៅក្នុងផ្នែកនេះ (ទេវតាទាំងអស់របស់ព្រះជាម្ចាស់ ...)
ចេញពីសៀវភៅមួយដែលលោកម៉ូសេបានសរសេរ។ ទីពីរ
(ព្រះអង្គជាព្រះជាម្ចាស់ដែលបានបង្កើត ...)
គឺដកស្រង់មកពីព្រះគម្ពីរទំនុកតម្កើង។
បុត្រច្បង
នេះមានន័យថាព្រះយេស៊ូ។ អ្នកនិពន្ធសំដៅទៅលើព្រះអង្គថាជា «បុត្រច្បង»
ដើម្បីបញ្ជាក់ពីសារៈសំខាន់ និងសិទ្ធិអំណាចរបស់ព្រះរាជបុត្រាលើមនុស្សគ្រប់គ្នា។
គឺមិនបានមានន័យថា មានពេលវេលាមុនពេលដែលព្រះយេស៊ូបានប្រសូត្រមក
ឬថាព្រះជាម្ចាស់មានបុត្រា ឯទៀតដូចព្រះយេស៊ូនោះទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះរាជបុត្រាដែលមានកិត្តិយស
គឺជាព្រះរាជបុត្រាតែមួយគត់របស់ព្រះអង្គ»
ព្រះជាម្ចាស់មានព្រះបន្ទូល
«ព្រះជាម្ចាស់មានព្រះបន្ទូល»
ព្រះអង្គជាព្រះជាម្ចាស់ ដែលបានបង្កើតទេវតាជាវិញ្ញាណ ហើយអ្នកបម្រើព្រះអង្គជាអណ្តាតភ្លើង
អាចមានន័យថាទី ១)
«ព្រះជាម្ចាស់បានធ្វើអោយទេវតារបស់ព្រះអង្គក្លាយជាវិញ្ញាណដែលបំរើព្រះអង្គប្រកបដោយអំណាចដូចជាអណ្តាតភ្លើង(UDB)
ឬទី២) ព្រះជាម្ចាស់ធ្វើឲ្យមានខ្យល់ ហើយអណ្តាតភ្លើងនៃអ្នកនាំសារ
និងអ្នកបំរើរបស់ព្រះអង្គ។ នៅក្នុងភាសាដើមពាក្យសម្រាប់ «ទេវតា»គឺដូចគ្នានឹង
«អ្នកនាំសារ «ហើយពាក្យ «វិញ្ញាណ» គឺដូចគ្នានឹង «ខ្យល់»។
ដោយអាចមានន័យសំខាន់ថា
ទេវតាបម្រើព្រះបុត្រាព្រោះព្រះអង្គមានឋានៈខ្ពស់ជាង។
Hebrews 1:8
ព័ត៌មានទូទៅ៖
ការដកស្រង់បទគម្ពីរនេះចេញមកពីព្រះគម្ពីរទំនុកតម្កើង។
ចំពោះព្រះបុត្រាវិញ ព្រះជាម្ចាស់មានព្រះបន្ទូល
«ចំពោះព្រះជាម្ចាស់មានព្រះបន្ទូល គឺមានបន្ទូលអំពីព្រះបុត្រា»
ព្រះបុត្រា
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូជា ព្រះរាជបុត្រានៃព្រះជាម្ចាស់។
បពិត្រ ព្រះជាម្ចាស់ បល្ល័ង្កព្រះអង្គនៅស្ថិតស្ថេរអស់កល្បជានិច្ច
បល្ល័ង្ករបស់ព្រះបុត្រាតំណាងការគ្រប់គ្រងរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គគឺជាព្រះ
ហើយរជ្ជកាលរបស់ព្រះអង្គនឹងស្ថិតស្ថេរជារៀងរហូត»
ព្រះរាជ្យរបស់ព្រះអង្គជារាជ្យប្រកបដោយយុត្តិធម៌
ត្រង់ថា «ព្រះរាជ្យ» សំដៅទៅលើការគ្រប់គ្រងរបស់ព្រះរាជបុត្រា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយព្រះអង្គនឹងគ្រប់គ្រងលើប្រជាជននៃនគររបស់ព្រះអង្គដោយយុត្តិធម៌»
ព្រះអង្គបានចាក់ប្រេងអភិសេកព្រះអង្គ ដោយប្រេងនៃអំណរលើសលប់
ជាងមិត្តភក្តិរបស់ព្រះអង្គទៅទៀត
ត្រង់ថា «ប្រេងនៃសេចក្តីអំណរ»
សំដៅទៅលើអំណរដែលព្រះរាជបុត្រាមាននៅពេលព្រះជាម្ចាស់លើកកិត្តិយសព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានផ្តល់កិត្តិយសដល់ព្រះអង្គហើយធ្វើឲ្យព្រះអង្គរីករាយជាងអ្នកដទៃ»
Hebrews 1:10
ប្រយោគភ្ជាប់៖
អ្នកនិពន្ធបន្តពន្យល់ថាព្រះយេស៊ូ មានឋានៈខ្ពស់ជាងពួកទេវតា។
ព័ត៌មានទូទៅ
ការដកស្រង់នេះចេញមកពីទំនុកតម្កើងមួយទៀត។
កាលដើមដំបូងបង្អស់
«មុនពេលមានអ្វីៗកើតឡើង»
ព្រះអម្ចាស់បានបង្កើតគ្រឹះផែនដី
អ្នកនិពន្ធនិយាយអំពី ព្រះជាម្ចាស់បានបង្កើតផែនដី ដូចជាព្រះអង្គ
បានសាងសង់នៅលើគ្រឹះ។របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានបង្កើតផែនដី»
ផ្ទៃមេឃជាស្នាព្រះហស្តរបស់ព្រះអង្គ
ត្រង់ថា «ព្រះហស្ត» សំដៅទៅលើអំណាច និងសកម្មភាពរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គបានបង្កើតផ្ទៃមេឃ»
ផែនដី និងផ្ទៃមេឃមុខជារលាយបាត់ទៅអស់
«ផ្ទៃមេឃ និងផែនដីនឹងរលាយបាត់ទៅ» ឬ
«ផ្ទៃមេឃនិងផែនដីនឹងលែងមានទៀតហើយ»
ដូចសម្លៀកបំពាក់
អ្នកនិពន្ធនិយាយពីមេឃ និងផែនដីហាក់ដូចជា សម្លៀកបំពាក់
ដែលនឹងចាស់ហើយនៅទីបំផុតនឹងក្លាយទៅជាឥតប្រយោជន៍។
បត់ផែនដី និងផ្ទៃមេឃទុក ដូចគេបត់អាវធំ
អ្នកនិពន្ធនិយាយពីមេឃ និងផែនដី ដូចជាអាវផាយ
ឬសម្លៀកបំពាក់ខាងក្រៅផ្សេង។
ផែនដី និងផ្ទៃមេឃនឹងត្រូវរចរឹលទៅដូចសម្លៀកបំពាក់
អ្នកនិពន្ធនិយាយអំពីមេឃ
និងផែនដីដូចជាសម្លៀកបំពាក់ដែលអាចផ្លាស់ប្តូរសម្រាប់សម្លៀកបំពាក់ផ្សេងទៀត។
ផែនដី និងផ្ទៃមេឃនឹងត្រូវរចរឹលទៅ
[illegible] ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនឹងផ្លាស់ប្តូរពួកគេ»
ព្រះជន្មាយុរបស់ព្រះអង្គក៏មិនចេះអស់
ជារយៈពេលនៃពេលវេលាត្រូវបានប្រើ
ដើម្បីតំណាងឲ្យអត្ថិភាពដ៏អស់កល្បរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជន្មាយុរបស់ព្រះអង្គក៏មិនចេះអស់»
Hebrews 1:13
ព័ត៌មានទូទៅ៖
ការដកស្រង់នេះចេញមកពីទំនុកតម្កើងមួយទៀត។
ចុះតើទេវតាមួយណា ដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់គ្រប់ពេលថា...ព្រះបាទាព្រះអង្គ?»
អ្នកនិពន្ធប្រើសំនួរមួយដើម្បីបញ្ជាក់ថា
ព្រះជាម្ចាស់មិនដែលមានព្រះបន្ទូលពីរឿងនេះទៅកាន់ទេវតាទេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែព្រះជាម្ចាស់មិនដែលមានព្រះបន្ទូលទៅកាន់ទេវតាណាមួយឡើយ...ព្រះបាទាព្រះអង្គ»
ចូរអង្គុយនៅខាងស្តាំយើង
ត្រង់ថា «នៅខាងស្តាំ» សំដៅទៅលើកន្លែងកិត្តិយស។
របៀបផ្សេងទៀតនៃការបកប្រែ: «អង្គុយជិតខ្ញុំនៅកន្លែងកិត្តិយស»
រហូតយើងបង្ក្រាបខ្មាំងសត្រូវព្រះអង្គដាក់ក្រោមព្រះបាទាព្រះអង្គ
ខ្មាំងសត្រូវរបស់ព្រះគ្រីស្ទបាននិយាយដូចជា
ពួកគេនឹងក្លាយជាវត្ថុដែលដាក់ជើងរបស់ស្តេច។ រូបភាពនេះតំណាងឲ្យការបរាជ័យ
និងភាពអាម៉ាស់សម្រាប់សត្រូវរបស់ព្រះអង្គ។
តើទេវតាទាំងអស់មិនមែនជាវិញ្ញាណ...ទទួលការសង្គ្រោះជាមរតកដែរឬទេ?
អ្នកនិពន្ធប្រើសំណួរនេះដើម្បីរំលឹកអ្នកអានថាទេវតា
គឺមិនមានឥទ្ធិពលដូចព្រះគ្រិស្តនោះទេ ប៉ុន្តែពួកគេមានតួនាទីផ្សេងគ្នា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកទេវតាទាំងអស់ជាវិញ្ញាណ...ទទួលការសង្គ្រោះជាមរតក»។
ដែលត្រូវទទួលការសង្គ្រោះជាមរតក
ការទទួលនូវអ្វី ដែលព្រះជាម្ចាស់បានសន្យាដល់អ្នកជឿត្រូវបានគេនិយាយ
ដូចជាទទួលមរតកទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្រាប់អ្នកដែលព្រះជាម្ចាស់នឹងសង្គ្រោះ»

---

2 [1]ហេតុដូចនេះ យើងត្រូវយកចិត្តទុកដាក់ ចំពោះកិច្ចការដែលយើងបានឮ ដើម្បីកុំឲ្យយើងត្រូវរសាត់បាត់ឆ្ងាយ។
[2]ដ្បិតបើព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង តាមរយៈពួកទេវតា មានប្រសិទ្ធភាព ធ្វើឲ្យមនុស្សប្រព្រឹត្តល្មើស និងមិនស្តាប់បង្គាប់គ្រប់គ្នា
ទទួលទោសយ៉ាងនេះទៅហើយ[3]ចុះតើធ្វើដូចម្តេចឲ្យយើងរួចខ្លួនបាន បើយើងធ្វេសប្រហែសនឹងការសង្គ្រោះដូច្នេះ? គឺការសង្គ្រោះដែលព្រះអម្ចាស់បានប្រកាស

generated on Wed Sep 10 16:16:32 2025

និងបញ្ជាក់ប្រាប់យើង ដែលបានឮរួចមកហើយ។[4]ជាមួយគ្នានេះដែរ ព្រះជាម្ចាស់បានផ្តល់សក្ខីភាព តាមរយៈទីសម្គាល់ ឫទ្ធិបាដិហារិយ៍ និងការអស្ចារ្យទាំងឡាយ
ព្រមទាំងបានចែកអំណោយទានរបស់ព្រះវិញ្ញាណ ស្របតាមព្រះហឫទ័យព្រះអង្គ។
[5]ដ្បិត ពុំមែនជាពួកទេវតារបស់ព្រះជាម្ចាស់ទេ ដែលព្រះអង្គប្រគល់ឲ្យគ្រប់គ្រងពិភពលោក ដូចយើងធ្លាប់និយាយនោះទេ។[6]ផ្ទុយទៅវិញ
មានមនុស្សបានផ្តល់សក្ខីភាពនៅកន្លែងមួយថា៖ «តើបុត្រមនុស្សជាអ្វីបានជាព្រះជាម្ចាស់នឹកនាដល់គេម្លេ៎ះ? ឬក៏បុត្រមនុស្សដែលបងប្អូនគ្នាយកចិត្តទុកដាក់?»
[7]ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យមានឋានៈតូចជាងពួកទេវតាតែបន្តិចប៉ុណ្ណោះ តែបងប្អូនរាល់គ្នាទទួលបានមកុដ ប្រកបដោយសិរីរុងរឿង និងកិត្តិយស។
[8]ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឲ្យនៅក្រោមបាទជើងពួកគេ។ ដ្បិតព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ឲ្យចុះចូលនឹងព្រះអង្គ គឺគ្មានអ្វីមួយនៅសេសសល់
ពុំចុះចូលនឹងព្រះអង្គឡើយ។ ប៉ុន្តែ ឥឡូវនេះយើងឃើញថា អ្វីទាំងអស់ពុំទាន់ចុះចូលនឹងព្រះអង្គនៅឡើយទេ។
[9]ប៉ុន្តែ យើងឃើញថា ម្នាក់ដែលតូចជាងពួកទេវតា តែមួយរយៈខ្លីប៉ុណ្ណោះ គឺព្រះយេស៊ូដែលបានរងទុក្ខលំបាក និងសោយទិវង្គត
ហើយព្រះអង្គទទួលបានមកុដប្រកបដោយសិរីរុងរឿង និងកិត្តិយស។ ឥឡូវនេះ ដោយសារព្រះគុណ ព្រះអង្គបានភ្លក្សសេចក្តីស្លាប់ម្តង សម្រាប់មនុស្សគ្រប់គ្នា។[10]ដ្បិត
ពិតជាសក្តិសមណាស់ចំពោះព្រះជាម្ចាស់ ព្រោះអ្វីៗទាំងអស់កើតឡើងដើម្បីថ្វាយព្រះអង្គ តាមរយៈព្រះអង្គ និងនាំកូនៗជាច្រើន ឲ្យទទួលបានសិរីរុងរឿង។
ស័ក្តិសមណាស់ចំពោះព្រះអង្គ ធ្វើជាអ្នកដឹកនាំការសង្គ្រោះពេញលក្ខណៈ តាមរយៈការរងទុក្ខលំបាក។
[11]ទាំងព្រះយេស៊ូដែលប្រោសមនុស្សឲ្យបានវិសុទ្ធ និងអ្នកដែលព្រះយេស៊ូប្រោសឲ្យបានវិសុទ្ធ ចេញមកពីប្រភពតែមួយ។ ដូច្នេះ ព្រះអង្គមិនខ្មាសនឹងហៅពួកគេថា
បងប្អូនឡើយ។[12]ព្រះអង្គមានព្រះបន្ទូលថា៖ «ទូលបង្គំនឹងប្រកាសពីព្រះនាមព្រះអង្គប្រាប់បងប្អូនទូលបង្គំ ហើយយើងនឹងច្រៀងអំពីព្រះអង្គ នៅក្នុងអង្គប្រជុំ»។
[13]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ទូលបង្គំនឹងទុកចិត្តព្រះអង្គ»។ ព្រះអង្គមានព្រះបន្ទូលថា៖ «មើល៍ ទូលបង្គំនៅទីនេះ រួមជាមួយកូនចៅ
ដែលព្រះជាម្ចាស់ប្រទានមកទូលបង្គំ»។[14]ដោយសារ កូនចៅរបស់ព្រះជាម្ចាស់ជាប់សាច់ឈាមជាមួយគ្នា ព្រះយេស៊ូក៏ចែករំលែកអ្វីៗព្រះអង្គមាន ជាមួយពួកគេដែរ ដូច្នេះ
ព្រះយេស៊ូសុគតដើម្បីបំផ្លាញមារកំណាច ដែលមានអំណាចលើសេចក្តីស្លាប់។[15]ព្រះអង្គធ្វើដូច្នេះ ដើម្បីរំដោះពួកអ្នកខ្លាចសេចក្តីស្លាប់
ដែលកំពុងតែរស់នៅជាទាសកររួមជីវិត ឲ្យមានសេរីភាពឡើងវិញ។
[16]ពិតប្រាកដណាស់ ព្រះយេស៊ូពុំបានជួយពួកទេវតាទេ ផ្ទុយទៅវិញព្រះអង្គបានទៅជួយពូជរបស់លោកអប្រាហាំ។[17]ដូច្នេះ ព្រះអង្គត្រូវតែដូចបងប្អូនព្រះអង្គគ្រប់យ៉ាង
ដើម្បីធ្វើជាមហាបូជាចារ្យពេញដោយចិត្តមេត្តា និងស្មោះត្រង់ក្នុងការបំពេញកិច្ចការថ្វាយព្រះជាម្ចាស់ និងនាំការអត់ទោសបាបដល់មនុស្សទាំងអស់។
[18]ព្រះយេស៊ូអាចជួយអ្នកដែលត្រូវល្បួងបាន ព្រោះព្រះអង្គផ្ទាល់ក៏រងទុក្ខលំបាក និងរងការល្បួងដូចគ្នាដែរ។

Hebrews 2:1

ប្រយោគភ្ជាប់៖

នេះគឺជាការព្រមានដំបូងបង្អស់ក្នុងចំណោមការព្រមានជាបន្ទាន់ចំនួនប្រាំ
ដែលអ្នកនិពន្ធបានប្រាប់។

យើងត្រូវ

ត្រង់ថា «យើង» សំដៅទៅលើអ្នកនិពន្ធ ហើយរួមទាំងទស្សនិកជនរបស់គាត់។

ដើម្បីកុំឲ្យយើងត្រូវរសាត់បាត់ឆ្ងាយ

ការជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែតិចទៅៗ ត្រូវបានគេនិយាយដូចជា
ទូកកំពុងរសាត់នៅលើទឹកពីកន្លែងដែលគួរទៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះយើងមិនបញ្ឈប់ការជឿឡើយ» (UDB)

Hebrews 2:2

ដ្បិតបើព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង តាមរយៈពួកទេវតា

ជនជាតិយូដាជឿថាព្រះបានមានបន្ទូលទៅកាន់ម៉ូសេអំពីក្រឹត្យវិន័យរបស់ព្រះអង្គតាមរយៈពួកទេវតា។ ការបកប្រែ:
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រសិនបើព្រះបន្ទូលដែលព្រះបានមានបន្ទូលតាមរយៈពួកទេវតា»

ដ្បិតបើព្រះបន្ទូល

អ្នកនិពន្ធប្រាកដថា រឿងទាំងនេះគឺជាការពិត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពីព្រោះដោយសារតែព្រះបន្ទូល»

មានប្រសិទ្ធភាព

«គឺប្រាកដ» ឬ «គឺជាការពិត»

ធ្វើឲ្យមនុស្សប្រព្រឹត្តល្មើស និងមិនស្តាប់បង្គាប់គ្រប់គ្នា ទទួលទោសយ៉ាងនេះទៅហើយ

ត្រង់ថា «ល្មើស» និង «ស្តាប់បង្គាប់»
សម្រាប់ប្រជាជនដែលមានកំហុសនៃអំពើបាបទាំងនេះ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សគ្រប់គ្នាដែលមានអំពើបាប
និងមិនស្តាប់បង្គាប់នឹងត្រូវទទួលទោស»

ល្មើស និងមិនស្តាប់បង្គាប់

ពាក្យទាំងពីរនេះមានន័យថាជាមូលដ្ឋានដូចគ្នា។

ចុះតើធ្វើដូចម្តេចឲ្យយើងរួចខ្លួនបាន បើយើងធ្វេសប្រហែសនឹងការសង្គ្រោះដូច្នេះ?

អ្នកនិពន្ធប្រើសំណួរដើម្បីបញ្ជាក់ថា មនុស្សពិតជានឹងទទួលទណ្ឌកម្ម
ប្រសិនបើពួកគេបដិសេធសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពេលនោះព្រះជាម្ចាស់ប្រាកដជានឹងដាក់ទណ្ឌកម្មយើង
បើយើងមិនយកចិត្តទុកដាក់នឹងព្រះបន្ទូលរបស់ព្រះអង្គអំពីរបៀបដែលព្រះជាម្ចាស់នឹងសង្គ្រោះយើង»

បដិសេធ

«មិនខ្វល់» ឬ «យល់ថាមិនសំខាន់»

ការសង្គ្រោះដែលព្រះអម្ចាស់បានប្រកាស

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអម្ចាស់ផ្ទាល់បានប្រកាសសារអំពីរបៀបដែលព្រះជាម្ចាស់នឹងសង្គ្រោះយើង»

និងបញ្ជាក់ប្រាប់យើង ដែលបានឮរួចមកហើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយបន្ទាប់មកអស់អ្នកដែលឮព្រះបន្ទូលនោះ បានបញ្ជាក់ថា
ព្រះបន្ទូលដល់ពួកយើង»

បើយោងតាមព្រះហឫទ័យរបស់ព្រះអង្គ

«តាមរបៀបដែលព្រះអង្គគាប់ព្រះហឫទ័យ»

Hebrews 2:5

ប្រយោគភ្ជាប់៖

អ្នកនិពន្ធរំលឹកដល់អ្នកជឿជនជាតិហេព្រើរទាំងនេះថា
នៅថ្ងៃណាមួយផែនដីនឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់យេស៊ូវ។

ព័ត៌មានទូទៅ៖

ការដកស្រង់នៅតែបន្តតាមរយៈផ្នែកបន្ទាប់។

ដ្បិត ពុំមែនជាពួកទេវតារបស់ព្រះជាម្ចាស់ទេ

ដ្បិតព្រះជាម្ចាស់មិនបានប្រទានឲ្យពួកទេវតាធ្វើជាអ្នកដឹកនាំទេ»

ប្រគល់ឲ្យគ្រប់គ្រងពិភពលោក

ត្រង់ថា «ពិភពលោក» សំដៅទៅលើមនុស្សរស់នៅទីនោះ។ ហើយ
«ប្រគល់ឲ្យគ្រប់គ្រង»
មានន័យថានេះគឺជាពិភពលោកក្នុងយុគសម័យបន្ទាប់ពីព្រះគ្រិស្តយាងត្រឡប់មកវិញ។
របៀបផ្សេងទៀតនៃការបកប្រែ: «មនុស្សដែលនឹងរស់នៅក្នុងពិភពលោកថ្មី»

តើបុត្រមនុស្សជាអ្វីបានជាព្រះជាម្ចាស់នឹកនាដល់គេម្លេ៎ះ?

សំណួរនេះត្រូវបានប្រើដើម្បី បញ្ជាក់ថាមនុស្សមិនសំខាន់គ្រប់គ្រាន់ទេ
ដែលព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ពួកគេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានមនុស្សដែលសក្តិសមនឹងព្រះអង្គយកព្រះហឫទ័យទុកដាក់ទេ!»

ឬក៏បុត្រមនុស្សដែលបងប្អូនគ្នាយកចិត្តទុកដាក់?

នេះមានន័យថាជាមូលដ្ឋានដូចគ្នានឹងសំណួរទីមួយ។
សំណួរវោហារស័ព្ទនេះបង្ហាញពី ការភ្ញាក់ផ្អើលដែលថា
មនុស្សមិនសំខាន់គ្រប់គ្រាន់សម្រាប់ព្រះជាម្ចាស់ក្នុងការថែរក្សាពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានមនុស្សដែលសក្តិសមនឹងឲ្យព្រះអង្គថែរក្សាពួកគេទេ!»

Hebrews 2:7

តូចជាងពួកយើងតែបន្តិចប៉ុណ្ណោះ

អ្នកនិពន្ធនិយាយអំពីមនុស្សដែលមិនសូវសំខាន់ដូចពួកទេវតាដូចជា
មនុស្សកំពុងតែឈរក្នុងឋានៈទាបជាងពួកទេវតាតែបន្តិចប៉ុណ្ណោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «មិនសំខាន់ដូចពួកទេវតាតែបន្តិចប៉ុណ្ណោះទេ»

បង្កើតមនុស្ស...ទទួលបានមកុដ...នៅក្រោមបាទជើងពួកគេ...ចុះចូលនឹងព្រះអង្គនៅឡើយទេ

generated on Wed Sep 10 16:16:32 2025

ត្រង់នេះ ឃ្លាទាំងនេះមិនសំដៅទៅលើមនុស្សជាក់លាក់ទេ
ប៉ុន្តែសំដៅទៅលើមនុស្សទូទៅរួមទាំងបុរស និងស្ត្រី។
របៀបផ្សេងទៀតនៃការបកប្រែ:
«បង្កើតមនុស្សលោក...ពាក់មកុដឲ្យពួកគេ...ជើងរបស់ពួកគេ...ដល់ពួកគេ»
បងប្អូនរាល់គ្នាទទួលបានមកុដ ប្រកបដោយសិរីរុងរឿង និងកិត្តិយស
អំណោយនៃសិរីល្អ និងកិត្តិយសត្រូវបានគេនិយាយដូចជាកម្រងផ្កា
ដែលដាក់នៅលើក្បាលរបស់អត្តពលិកដែលទទួលបានជ័យជំនះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គបានប្រទានសិរីរុងរឿង
និងកិត្តិយសដល់ពួកគេ»
ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឲ្យនៅក្រោមបាទជើងពួកគេ
អ្នកនិពន្ធនិយាយអំពីមនុស្សគ្រប់គ្រងលើអ្វីៗគ្រប់យ៉ាងដូចជា
ពួកគេបានបោះជំហានទៅមុខលើអ្វីៗគ្រប់យ៉ាងដោយជើងរបស់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានផ្តល់ឲ្យពួកគេគ្រប់គ្រងលើអ្វីៗទាំងអស់»
ដ្បិតព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ឲ្យចុះចូលនឹងព្រះអង្គ
ភាពអវិជ្ជមានទ្វេដងនេះមានន័យថាអ្វីៗទាំងអស់នឹងត្រូវចុះចូលចំពោះព្រះគ្រិស្ត។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានដាក់អ្វីៗទាំងអស់នៅក្រោមអំណាចពួកគេ»
យើងឃើញថា អ្វីទាំងអស់ពុំទាន់ចុះចូលនឹងព្រះអង្គនៅឡើយទេ
«យើងដឹងថាមនុស្សមិនអាចគ្រប់គ្រងអ្វីៗទាំងអស់បានទេ»
Hebrews 2:9
ប្រយោគភ្ជាប់៖
អ្នកនិពន្ធរំឭកជឿថា
ព្រះគ្រិស្តជាភាសាហេព្រើរទាំងនេះបានក្លាយជាការទាបជាងពួកទេវតា
នៅពេលដែលព្រះអង្គបានយាងមកផែនដី
ដើម្បីរងទុក្ខសុគតដើម្បីអោយបានរួចពីបាបហើយថា
ព្រះអង្គបានក្លាយជាមហាបូជាចារ្យមេត្តាករុណាដល់អ្នកជឿ។
យើងឃើញម្នាក់
»យើងឃើញថា តែម្នាក់»
អ្នកដែលបានកើត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលព្រះជាម្ចាស់បានបង្កើត»
តូចជាងពួកទេវតា...មកុដប្រកបដោយសិរីរុងរឿង និងកិត្តិយស
បកប្រែពាក្យទាំងនេះដូចដែលអ្នកបានធ្វើនៅក្នុងជំពូក ២: ៧។
ទទួលបានមកុដប្រកប
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានទទួលបានមកុដ»
បានភ្លក្សសេចក្តីស្លាប់
បទពិសោធន៍នៃការស្លាប់ត្រូវបានគេនិយាយដូចជាអាហារដែលត្រូវបានភ្លក់។
របៀបផ្សេងទៀតនៃការបកប្រែ: «បានឆ្លងកាត់ការស្លាប់» ឬ «បានស្លាប់»
សម្រាប់មនុស្សគ្រប់គ្នា
ត្រង់ថា «មនុស្ស» មានន័យថាមនុស្សទូទៅទាំងប្រុសទាំងស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្រាប់មនុស្សគ្រប់គ្នា»
នាំកូនៗជាច្រើន ឲ្យទទួលបានសិរីរុងរឿង
អំណោយនៃសិរីល្អត្រូវបានគេនិយាយនៅទីនេះដូចជាកន្លែង
ដែលមនុស្សអាចត្រូវបានគេនាំយកមក។ របៀបផ្សេងទៀតនៃការបកប្រែ:
«សង្គ្រោះកូនៗជាច្រើន»
កូនៗជាច្រើន
ត្រង់នេះសំដៅទៅលើអ្នកជឿលើព្រះគ្រិស្តរួមទាំងបុរសនិងស្ត្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកជឿជាច្រើន»
អ្នកដឹកនាំការសង្គ្រោះ
អ្នកនិពន្ធនិយាយពីសេចក្តីសង្គ្រោះដូចជា កន្លែងដែលព្រះយេស៊ូបានដឹកនាំពួកគេ។
នេះមានន័យថាព្រះយេស៊ូគឺជាព្រះ
ដែលបានសម្តែងសកម្មភាពមុនដើម្បីជួយសង្គ្រោះអ្នកដទៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលជួយសង្គ្រោះអ្នកដទៃ»
ពេញលក្ខណៈ
ក្លាយជាមនុស្សពេញវ័យ និងទទួលការបណ្តុះបណ្តាលទាំងស្រុង
ដូចជាមនុស្សម្នាក់ត្រូវបានគេធ្វើឲ្យបានពេញលេញ
ប្រហែលជាពេញលេញនៅក្នុងផ្នែកទាំងអស់នៃរាងកាយរបស់គាត់។
Hebrews 2:11
ព័ត៌មានទូទៅ:
ការដកស្រង់ពាក្យទំនាយនេះ ពីទំនុកតម្កើងរបស់ស្តេចដាវីឌ។
អ្នកដែលប្រោសមនុស្សឲ្យបានវិសុទ្ធ
«អ្នកដែលប្រោសមនុស្សឲ្យបានវិសុទ្ធ» ឬ
«អ្នកដែលធ្វើអោយអ្នកដទៃបរិសុទ្ធពួចចេញពីអំពើបាប»
អ្នកដែលត្រូវបានរាប់ជាបរិសុទ្ធ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលព្រះអង្គបានធ្វើឲ្យបរិសុទ្ធ» ឬ
«អស់អ្នកដែលព្រះអង្គបានធ្វើឲ្យបរិសុទ្ធរួចពីអំពើបាប»
ចេញមកពីប្រភពតែមួយ
អ្នកដែលជាប្រភពនោះ គឺអាចបញ្ជាក់យ៉ាងច្បាស់។របៀបផ្សេងទៀតនៃការបកប្រែ:
«ចេញមកពីប្រភពតែមួយ គឺព្រះជាម្ចាស់» ឬ «មានព្រះវរបិតាតែមួយ»
ព្រះអង្គមិនខ្មាស
«ព្រះយេស៊ូមិនខ្មាសឡើយ»
មិនខ្មាសនឹងហៅពួកគេថា បងប្អូនឡើយ
នេះជាមធ្យោបាយអវិជ្ជមានពីរដងថាព្រះអង្គនឹងអះអាងថាពួកគេជាបងប្អូនរបស់ព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ:
«គឺរីករាយក្នុងការហៅពួកគេថាជាបងប្អូនរបស់ព្រះអង្គ»
បងប្អូន
នៅទីនេះនេះសំដៅទៅលើអស់អ្នកដែលបានជឿលើព្រះយេស៊ូ
រួមមានទាំងបុរសនិងស្ត្រី។
ទួលបង្គំនឹងប្រកាសពីព្រះនាមព្រះអង្គប្រាប់បងប្អូនទួលបង្គំ
ត្រង់ថា «ឈ្មោះ» សំដៅទៅលើលើកេរ្តិ៍ឈ្មោះរបស់បុគ្គល
និងអ្វីដែលពួកគេបានធ្វើ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំនឹងប្រកាសដល់បងប្អូនខ្ញុំនូវការអស្ចារ្យដែលព្រះអង្គបានធ្វើ»
នៅក្នុងអង្គប្រជុំ
«នៅពេលដែលអ្នកជឿមករួមគ្នាដើម្បីថ្វាយបង្គំព្រះជាម្ចាស់»
Hebrews 2:13
ព័ត៌មានទូទៅ៖
ព្យាការីអេសាយបានសរសេរសម្រង់ពាក្យទាំងនេះ។
ម្តងទៀត
«ហើយព្យាការីមួយរូបបានសរសេរក្នុងអត្ថបទគម្ពីរមួយទៀត
ពីអ្វីដែលព្រះគ្រិស្តបានមានព្រះបន្ទូលអំពីព្រះជាម្ចាស់»។ (UDB)
កូនចៅ...កូនចៅរបស់ព្រះជាម្ចាស់
នេះនិយាយអំពីអ្នកដែលជឿលើព្រះគ្រិស្ត ដូចជាពួកគេជាកូនក្មេង។
របៀបផ្សេងទៀតនៃការបកប្រែ: «អស់អ្នកណាដែលដូចជាកូនៗ របស់យើង ...
អស់អ្នកណាដែលដូចជាកូនៗរបស់ព្រះ»
ជាប់សាច់ឈាមជាមួយគ្នា
ឃ្លាថា "សាច់ និងឈាម" សំដៅទៅលើធម្មជាតិរបស់មនុស្ស។
របៀបផ្សេងទៀតនៃការបកប្រែ: «ជាមនុស្សទាំងអស់»
ព្រះយេស៊ូក៏ចែករំលែកអ្វីៗព្រះអង្គមាន ជាមួយពួកគេដែរ
«ព្រះយេស៊ូវបានក្លាយជាមនុស្សដូចគេដែរ»
តាមរយៈការសុគត
ត្រង់ថា «ការសុគត» អាចត្រូវបានថ្លែងជាកិរិយាស័ព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយការស្លាប់»
មានអំណាចលើសេចក្តីស្លាប់
ត្រង់ថា «ការសុគត» អាចត្រូវបានថ្លែងជាកិរិយាស័ព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «មានអំណាចធ្វើអោយមនុស្សស្លាប់»
ព្រះអង្គធ្វើដូច្នេះ ដើម្បីរំដោះពួកអ្នកខ្លាចសេចក្តីស្លាប់ ដែលកំពុងតែរស់នៅជាទាសករមួយជីវិត
ឲ្យមានសេរីភាពឡើងវិញ
ការភ័យខ្លាចនៃការស្លាប់ត្រូវបានគេនិយាយដូចជា ជាទាសករ។
ដកហូតការភ័យខ្លាចរបស់នរណាម្នាក់ត្រូវបានគេនិយាយថា
កំពុងដោះលែងមនុស្សនោះពីទាសករ។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះជាអ្វីដែលព្រះអង្គអាចដោះលែងមនុស្សទាំងអស់។
ព្រោះយើងបានរស់នៅដូចជាទាសករពីព្រោះយើងខ្លាចស្លាប់»
Hebrews 2:16
ពូជរបស់លោកអប្រាហាំ
កូនចៅរបស់លោកអប្រាហាំដូចជាកូនចៅរបស់ព្រះអង្គដែរ។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «កូនចៅរបស់អប្រាហាំ»
គឺជាការចាំបាច់សម្រាប់ព្រះអង្គ
«គឺជាការចាំបាច់សម្រាប់ព្រះយេស៊ូ»
បងប្អូនព្រះអង្គ
ត្រង់ថា «បងប្អូន» សំដៅទៅលើមនុស្សទូទៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«គឺដូចជាមនុស្ស»
ព្រះជាម្ចាស់នឹងនាំការអត់ទោសបាបដល់មនុស្សទាំងអស់
ការសុគតនៅលើឈើឆ្កាងរបស់ព្រះគ្រិស្តមានន័យថា
ព្រះអង្គអាចអត់ទោសបាបបាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គប្រហែលជាអាចធ្វើឲ្យព្រះជាម្ចាស់អាចអត់ទោសបាបរបស់មនុស្ស»
ត្រូវល្បួងបាន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«សាតាំងបានល្បួងព្រះអង្គ»
អ្នកដែលត្រូវល្បួងបាន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលសាតាំងកំពុងល្បួង»

---

3 [1]ដូច្នេះ បងប្អូនដ៏វិសុទ្ធអើយ បងប្អូនបានទទួលការត្រាស់ហៅមកស្ថានបរមសុខ។[2]ចូរគិតពិចារណាអំពីព្រះយេស៊ូ ដែលជាសាវក និងជាមហាបូជាចារ្យរបស់យើង
តាមការប្រកាសជំនឿ។ ព្រះអង្គស្មោះត្រង់ចំពោះព្រះជាម្ចាស់ ដែលបានតែងតាំងព្រះអង្គ
ដូចជាលោកម៉ូសេស្មោះត្រង់ចំពោះព្រះដំណាក់របស់ព្រះជាម្ចាស់យ៉ាងនោះដែរ។[3]ដ្បិត ព្រះយេស៊ូទទួលបានសិរីរុងរឿងដ៏ប្រសើរជាងលោកម៉ូសេយ៉ាងណា
នោះអ្នកសង់ផ្ទះក៏មានកិត្តិយសលើសជាងផ្ទះយ៉ាងនោះដែរ។[4]ដ្បិត គ្រប់ផ្ទះទាំងអស់មានជាងជាអ្នកសាងសង់ តែព្រះជាម្ចាស់ជាអ្នកសង់អ្វីៗទាំងអស់។
[5]ម៉្យាងវិញទៀត លោកម៉ូសេជាអ្នកបម្រើដ៏ស្មោះត្រង់ នៅក្នុងព្រះដំណាក់ទាំងមូលរបស់ព្រះជាម្ចាស់។ ព្រះអង្គផ្តល់សក្ខីភាពអំពីហេតុការណ៍ទាំងឡាយ
ដែលនឹងកើតមានឡើងនាពេលអនាគត។[6]ប៉ុន្តែ ព្រះគ្រិស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ទទួលបន្ទុកលើព្រះដំណាក់។ យើងជាព្រះដំណាក់របស់ព្រះជាម្ចាស់
បើយើងមានចិត្តរឹងប៉ឹង និងទំនុកចិត្តប្រកបដោយមោទនភាព។
[7]ដូច្នេះ ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលថា៖ «នៅថ្ងៃនេះ បើអ្នករាល់គ្នាឮព្រះសូរសៀងព្រះជាម្ចាស់ហើយ[8]មិនត្រូវមានចិត្តរឹងរូស និងបះបោរ កំឡុងពេលរងការល្បង
នៅទីរហោស្ថាន។
[9]ការនេះកើតឡើង ពេលបុព្វបុរសអ្នករាល់គ្នាបះបោរ ដោយការល្បងលយើង រួចហើយពួកគេបានឃើញកិច្ចការយើងធ្វើ កំឡុងពេលសែសិបឆ្នាំ។[10]ហេតុនេះ
យើងទើសចិត្តនឹងមនុស្សជំនាន់នោះខ្លាំងណាស់។ យើងថ្លែងថា៖ «ចិត្តពួកគេវង្វេងអស់ហើយ។ ពួកគេពុំស្គាល់មាគ៌ារបស់យើងទេ។[11]ពេលយើងខឹង យើងបានស្បថថា៖
«ពួកគេនឹងមិនអាចសម្រាកបានឡើយ»។
[12]បងប្អូនអើយ ចូរប្រយ័ត្នឲ្យមែនទែន ព្រោះនៅក្នុងចំណោមបងប្អូនមានមនុស្សមានចិត្តអាក្រក់មិនជឿ និងបែរចិត្តចេញពីព្រះជាម្ចាស់ដែលមានព្រះជន្មរស់។[13]ផ្ទុយទៅវិញ
ចូរលើកទឹកចិត្តគ្នាជាប្រចាំ កាលណាព្រះគម្ពីរចែងថា «ថ្ងៃនេះ» នៅឡើយ កុំឲ្យមានបងប្អូនណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា មានចិត្តរឹងរូស និងចាញ់បោកបាប់ឲ្យសោះ។
[14]ដ្បិត យើងបានក្លាយជាដៃគូរបស់ព្រះគ្រិស្តរួចហើយ ប្រសិនបើ យើងមានចិត្តរឹងប៉ឹងទាំងទុកចិត្តព្រះអង្គ តាំងពីដើមរហូតដល់ទីបញ្ចប់។[15]មានសេចក្តីចែងទុកមកថា៖
«នៅថ្ងៃនេះ បើអ្នករាល់គ្នាឮព្រះសូរសៀងព្រះជាម្ចាស់ហើយ មិនត្រូវមានចិត្តរឹងរូស និងបះបោរឡើយ។
[16]តើនរណាខ្លះបានឮព្រះជាម្ចាស់ និងមានចិត្តបះបោរ? តើអ្នកទាំងនោះ ជាអ្នកដែលពុំបានចេញពីប្រទេសអេស៊ីប ជាមួយលោកម៉ូសេទេឬ?[17]តើព្រះអង្គខឹងនឹងនរណាខ្លះ
រយៈពេលសែសិបឆ្នាំនេះ? តើព្រះជាម្ចាស់មិនខឹងមនុស្សប្រព្រឹត្តអំពើបាបទេឬ?[18]តើសាកសពនរណាខ្លះត្រូវបោះចោលទីរហោស្ថាន?
តើព្រះជាម្ចាស់បានស្បថពួកគេនឹងមិនអាចសម្រាកបានឡើយ ប្រសិនបើ គេមិនស្តាប់បង្គាប់ព្រះអង្គដូច្នេះ?[19]យើងដឹងថា ពួកគេនឹងមិនអាចសម្រាកបានឡើយ
ព្រោះគ្មានជំនឿ។

Hebrews 3:1
ប្រយោគភ្ជាប់៖
ការព្រមានលើកទីពីរនេះគឺវែងជាង និងលម្អិតជាងនេះទៅទៀត ហើយរួមទាំងជំពូក
៣ និង ៤។ អ្នកនិពន្ធចាប់ផ្តើមដោយបង្ហាញថា
ព្រះគ្រិស្តប្រសើរជាងលោកម៉ូសេជាអ្នកបម្រើរបស់ព្រះអង្គ។
បងប្អូនដ៏វិសុទ្ធ
ត្រង់ថា «បងប្អូន» សំដៅទៅលើពួកគ្រីស្ទានទាំងប្រុសទាំងស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនប្រុស និងស្រីដ៏វិសុទ្ធ» ឬ
«បងប្អូនរួមជំនឿរបស់យើង»
បងប្អូនបានទទួលការត្រាស់ហៅមកស្ថានបរមសុខ
ត្រង់ថា «ស្ថានបរមសុខ» តំណាងឲ្យព្រះជាម្ចាស់។របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានត្រាស់ហៅយើងទាំងអស់គ្នា»
សាវក
ត្រង់ពាក្យនេះមានន័យថាអ្នកដែលត្រូវបានបញ្ជូន។ នៅក្នុងអត្ថបទនេះគឺ
មិនសំដៅទៅលើសាវកណាម្នាក់ក្នុងចំណោមសាវកទាំងដប់ពីរនាក់ទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលត្រូវបានបញ្ជូន»
តាមការប្រកាសជំនឿ
នេះអាចត្រូវបានកែសម្រួល ដូច្នេះហើយនាមអរូបី «ការប្រកាស»
គឺបានបញ្ជាក់ថាជាកិរិយាស័ព្ទ «ប្រកាស»។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលប្រកាសប្រាប់» ឬ «អ្នកដែលយើងជឿ»
ក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់
ប្រជាជនហេព្រើរ
ជាអ្នកដែលព្រះជាម្ចាស់បានបើកសម្តែងព្រះអង្គផ្ទាល់អាចនិយាយបាន
បើពួកគេជាផ្ទះពិត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដល់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់»
ព្រះយេស៊ូទទួលបាន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានទទួលព្រះយេស៊ូ»
អ្នកដែលសាងសង់អ្វីៗទាំងអស់
សកម្មភាពដែលព្រះជាម្ចាស់ បង្កើតពិភពលោក ត្រូវបានគេនិយាយ
ដូចជាព្រះអង្គបានសាងសង់ផ្ទះ។
គ្រប់ផ្ទះទាំងអស់មានជាង ជាអ្នកសាងសង់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ផ្ទះនីមួយៗមានអ្នកសាងសង់»
Hebrews 3:5
ម៉្យាងវិញទៀត
ឃ្លានេះចាប់ផ្តើមការប្រៀបធៀបរវាងលោកម៉ូសេ និងព្រះគ្រិស្ត។
ឃ្លានេះអាចទុកចោលចេញពីការបកប្រែរបស់អ្នក បើចាំបាច់។
នៅក្នុងព្រះដំណាក់ទាំងមូលរបស់ព្រះជាម្ចាស់
ប្រជាជនហេព្រើរដែលព្រះជាម្ចាស់បានបើកសម្តែងព្រះអង្គផ្ទាល់
បើពួកគេជាផ្ទះពិត។ សូមមើលពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ៣: ១។
ព្រះអង្គផ្តល់សក្ខីភាពអំពីហេតុការណ៍ទាំងឡាយ
ឃ្លានេះប្រហែលជាសំដៅទៅលើកិច្ចការរបស់លោកម៉ូសេទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «ជីវិតរបស់លោកម៉ូសេ
និងកិច្ចការចង្អុលបង្ហាញអំពីហេតុការណ៍»
ដែលនឹងកើតមានឡើងនាពេលអនាគត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះយេស៊ូនឹងមានព្រះបន្ទូលនៅពេលអនាគត»
ព្រះបុត្រា
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូជា ព្រះរាជបុត្រានៃព្រះជាម្ចាស់។
ទទួលបន្ទុកលើព្រះដំណាក់
នេះនិយាយអំពីប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដូចជាពួកគេជា ផ្ទះពិត។
របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលគ្រប់គ្រងលើប្រជារាស្ត្ររបស់ព្រះជាម្ចាស់» (UDB)
យើងជាព្រះដំណាក់របស់ព្រះជាម្ចាស់
នេះនិយាយអំពីប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដូចជាពួកគេជា ផ្ទះពិត។

generated on Wed Sep 10 16:16:32 2025

របៀបផ្សេងទៀតនៃការបកប្រែ: «យើងជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់»
បើយើងមានចិត្តរឹងប៉ឹង និងទំនុកចិត្តប្រកបដោយមោទនភាព
ត្រង់ថា «មានចិត្តរឹងប៉ឹង» និង «ទំនុកចិត្តប្រកបដោយមោទនភាព»
គឺជាអរូបីហើយ អាចត្រូវបានបញ្ជាក់ជាកិរិយាស័ព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ: «បើយើងបន្តមានទំនុកចិត្ត
ហើយសង្ឃឹមថាព្រះជាម្ចាស់នឹងធ្វើអ្វីៗដែលព្រះអង្គបានសន្យា»
Hebrews 3:7
ប្រយោគភ្ជាប់៖
ការព្រមាននៅទីនេះគឺជាការរំលឹកពីការមិនជឿរបស់ជនជាតិអ៊ីស្រាអែល
ដែលបានរារាំងពួកគេស្ទើរតែទាំងអស់ពីការចូលទឹកដីដែលព្រះជាម្ចាស់បានសន្យាជាមួយបុព្វបុរសរបស់ពួកគេ។
ការមិនជឿរបស់ពួកគេត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរនិក្ខមនំជំពូក
១៧: ១ នៅពេលពួកគេតូញត្អែរនឹងលោកម៉ូសេ
ហើយសង្ស័យថាព្រះជាម្ចាស់គង់នៅជាមួយពួកគេ។
ព័ត៌មានទូទៅ:
ដកស្រង់ចេញមកពីព្រះគម្ពីរសញ្ញាចាស់ នៅក្នុងព្រះគម្ពីរទំនុកដំកើង។
បើអ្នករាល់គ្នាឮព្រះសូរសៀងព្រះជាម្ចាស់ហើយ
បញ្ញត្តិរបស់ព្រះជាម្ចាស់ចំពោះជនជាតិអ៊ីស្រាអែលគឺដូចជាព្រះអង្គបានឲ្យពួកគេស្តាប់សំឡេងរបស់ព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើអ្នកឮព្រះជាម្ចាស់មានព្រះបន្ទូល»
មិនត្រូវមានចិត្តរឹងរូស
ការរឹងចចេសត្រូវបានគេនិយាយថា ជាចិត្តដែលមានលក្ខណៈរឹងរូស។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំរឹងរូស»
បះបោរ កំឡុងពេលរងការល្បង នៅទីរហោស្ថាន
ត្រង់ថា «បះបោរ» និង «ការល្បង» អាចបញ្ជាក់ថា ជាកិរិយាស័ព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចបុព្វបុរសរបស់អ្នកបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់
ហើយល្បងលព្រះអង្គនៅទីរហោស្ថាន»
Hebrews 3:9
ព័ត៌មានទូទៅ៖
សម្រង់នេះដកស្រង់ចេញពីព្រះគម្ពីរទំនុកតម្កើង។
បុព្វបុរសអ្នករាល់គ្នា
ត្រង់ថា «របស់អ្នករាល់គ្នា» នេះគឺជាពហុវចន:
និងសំដៅទៅលើជនជាតិអ៊ីស្រាអែល។
ដោយការល្បងលយើង
ត្រង់ថា «យើង» សំដៅលើព្រះជាម្ចាស់។
សែសិបឆ្នាំ
« ៤០ ឆ្នាំ»
យើងទើសចិត្ត
«យើងទើសចិត្ត» ឬ «យើងពិតជាមិនសប្បាយចិត្តខ្លាំងណាស់»
ចិត្តពួកគេវង្វេងអស់ហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេតែងតែវង្វេងនៅក្នុងដួងចិត្តរបស់ពួកគេ» ឬ
«ដួងចិត្តរបស់ពួកគេតែងតែវង្វេងវង្វាន់»
ចិត្តពួកគេវង្វេងអស់ហើយ
មនុស្សដែលមិនស្មោះត្រង់នឹងព្រះជាម្ចាស់ ត្រូវបានគេនិយាយដូចជា
មនុស្សម្នាក់កំពុងដឹកនាំពួកគេចេញពីផ្លូវត្រឹមត្រូវ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេតែតែងបដិសេធក្នុងការដើរតាមយើង» ឬ
«ពួកគេនឹងមិនប្រព្រឹត្តតាមអ្វីដែលយើងបានបង្គាប់ឡើយ»
ក្នុងចិត្តរបស់ពួកគេ
ត្រង់ថា «ចិត្ត» សំដៅទៅលើគំនិត ឬការសម្រេចចិត្តរបស់ពួកគេ។
ពួកគេពុំស្គាល់មាគ៌ារបស់យើងទេ
ការនេះនិយាយអំពីលក្ខណៈ នៃការប្រព្រឹត្តជីវិតរបស់មនុស្សម្នាក់ ដូចជារបៀបមួយ
ឬផ្លូវមួយ។ របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេមិនយល់ពីរបៀប
ដែលយើងចង់ឲ្យពួកគេអនុវត្តជីវិតរបស់ពួកគេទេ»
ពួកគេនឹងមិនអាចសម្រាកបានឡើយ
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
បើសិនពួកគេអាចសម្រាក់ដោយព្រះអង្គប្រទានឲ្យ
និងហាក់ដូចជាពួកគេនៅទីកន្លែងដែលមនុស្សអាចទៅបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងមិនបានចូលទីកន្លែងសម្រាកឡើយ» ឬ
«យើងនឹងមិនអនុញ្ញាតឲ្យពួកគេជួបប្រទះនឹងពរជ័យនៃការសម្រាករបស់យើងទេ»
Hebrews 3:12
បងប្អូន
ត្រង់នេះគឺសំដៅទៅលើ គ្រីស្ទបរិស័ទរួមទាំងបុរស និងស្ត្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនប្រុស និងស្រី» ឬ «បងប្អូនរួមជំនឿ»
មានមនុស្សមានចិត្តអាក្រក់មិនជឿ
ចិត្តត្រូវបានគេនិយាយនៅទីនេះ ហាក់ដូចជាគំនិតរបស់មនុស្ស
ជាចំនុចកណ្តាលនៃឆន្ទៈរបស់មនុស្ស និងការលើកទឹកចិត្ត។
របៀបផ្សេងទៀតនៃការបកប្រែ:
«ក្នុងចំណោមអ្នករាល់គ្នាគ្មាននរណាម្នាក់ឈប់ជឿលើព្រះជាម្ចាស់បានទេ»
ចិត្តរឹងរូស
ចិត្តរបស់មនុស្សត្រូវបានគេនិយាយថា
ដូចជាមនុស្សទាំងអស់ដែលអាចបោះបង់ចោលផ្លូវត្រឹមត្រូវ ក្នុងការដើរតាម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយអ្នកឈប់គោរពព្រះជាម្ចាស់ដ៏មានព្រះជន្មរស់»
ព្រះជាម្ចាស់ដែលមានព្រះជន្មរស់
«ព្រះពិត ជាព្រះដែលពិតជាមានជីវិត»
ថ្ងៃនេះ
ពាក្យនេះសំដៅលើអ្វីដែលមានចែងក្នុងគម្ពីរចែងថា «ថ្ងៃនេះ»
«ខណៈពេលដែលនៅតែមានឱកាស»
កុំឲ្យមានបងប្អូនណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា មានចិត្តរឹងរូស និងចាញ់បោកបាបឲ្យសោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការបោកបញ្ឆោតនៃអំពើបាបមិនធ្វើអោយអ្នកណាម្នាក់រឹងរូសឡើយ»
កុំឲ្យមានបងប្អូនណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា មានចិត្តរឹងរូស និងចាញ់បោកបាបឲ្យសោះ
ការរឹងចចេសត្រូវបានគេនិយាយថា ជាមនុស្សរឹង ឬមានចិត្តរឹងរូស។
ភាពរឹងគឺជាលទ្ធផលនៃការបញ្ឆោតដោយអំពើបាប។ នេះអាចត្រូវបានប្រើឡើងវិញ
ដូច្នេះនាមអរូបី «បោកបញ្ឆោត» គឺជាត្រូវបានបង្ហាញជាកិរិយាស័ព្ទ «បញ្ឆោត»។
របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មាននរណាម្នាក់ក្នុងចំណោមអ្នកនឹងត្រូវបានបញ្ឆោត ដោយអំពើបាប
ហើយក្លាយជាមនុស្សរឹងចចេសទេ» ឬ «អ្នកមិនធ្វើបាបបោកបញ្ឆោតខ្លួនឯង
ដើម្បីឲ្យអ្នកក្លាយជាមនុស្សរឹងចចេសឡើយ»
Hebrews 3:14
ព័ត៌មានទូទៅ៖
ការបន្តដកស្រង់ចេញពីកាន់ទំនុកដំកើងដូចដែលត្រូវបានដកស្រង់នៅក្នុងជំពូក
៣: ៧។
ដ្បិត យើងបានក្លាយជា
ត្រង់ថា «យើង» សំដៅទៅលើទាំងអ្នកនិពន្ធ និងអ្នកអាន។
ប្រសិនបើ យើងមានចិត្តរឹងប៉ឹងទាំងទុកចិត្តព្រះអង្គ
«ប្រសិនបើ យើងនៅតែបន្តមានចិត្តរឹងប៉ឹងមានជំនឿលើព្រះអង្គ»
តាំងពីដើម
«តាំងពីយើងចាប់ផ្តើមជឿលើព្រះអង្គ«
រហូតដល់ទីបញ្ចប់
នេះជាវិធីគួរសមក្នុងការសំដៅលើនៅពេលមនុស្សស្លាប់។
របៀបផ្សេងទៀតនៃការបកប្រែ: «រហូតដល់យើងស្លាប់»
មានសេចក្តីចែងទុកមកថា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកនិពន្ធជាអ្នកសរសេរ»
នៅថ្ងៃនេះ បើអ្នករាល់គ្នាឮ
បញ្ញត្តិរបស់ព្រះជាម្ចាស់ចំពោះជនជាតិអ៊ីស្រាអែលគឺដូចជាព្រះអង្គ
បានឲ្យពួកគេស្តាប់ព្រះសូរសៀងដែរ។របៀបផ្សេងទៀតនៃការបកប្រែ: «ប្រសិនបើ
អ្នកឮព្រះជាម្ចាស់មានព្រះបន្ទូល»។ «សូមមើល
ពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ៣:៧»
និងបះបោរឡើយ
ត្រង់ថា «បះបោរ» អាចបញ្ជាក់ថា ជាកិរិយាស័ព្ទ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចនៅពេល ដែលបុព្វបុរសរបស់អ្នកបះបោរប្រឆាំងនឹងព្រះជាម្ចាស់»។ សូមមើល
ពីរបៀបដែលអ្នកបានបកប្រែនៅក្នុងជំពូក ៣:៧
Hebrews 3:16
ព័ត៌មានទូទៅ៖
ពាក្យថា «ពួកគេ» សំដៅទៅលើជនជាតិអ៊ីស្រាអែល ដែលមិនស្តាប់បង្គាប់ និង
«យើង» សំដៅទៅលើទាំងអ្នកនិពន្ធ និងអ្នកអាន។
តើនរណាខ្លះបានឮព្រះជាម្ចាស់ និងមានចិត្តបះបោរ? តើអ្នកទាំងនោះ

generated on Wed Sep 10 16:16:32 2025

ជាអ្នកដែលពុំបានចេញពីប្រទេសអេស៊ីប ជាមួយលោកម៉ូសេទេឬ?
អ្នកនិពន្ធប្រើសំណួរដើម្បីបង្រៀនអ្នកអានរបស់គាត់។
សំណួរទាំងពីរនេះអាចត្រូវបានដាក់បញ្ចូលជាប្រយោគមួយ ប្រសិនបើការចាំបាច់។
របៀបផ្សេងទៀតនៃការបកប្រែ: «អស់អ្នកដែលចេញពី
អេស៊ីបដោយលោកម៉ូសេបានឮព្រះសូរសៀងព្រះជាម្ចាស់
តែពួកគេនៅតែបះបោរ»។
តើព្រះអង្គខឹងនឹងនរណាខ្លះ រយៈពេលសែសិបឆ្នាំនេះ?
តើព្រះជាម្ចាស់មិនខឹងមនុស្សប្រព្រឹត្តអំពើបាបទេឬ?
អ្នកនិពន្ធប្រើសំណួរដើម្បីបង្រៀនអ្នកអានរបស់គាត់។
សំណួរទាំងពីរនេះអាចត្រូវបានដាក់បញ្ចូលជាប្រយោគមួយ ប្រសិនបើការចាំបាច់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ខ្ញាល់អស់រយៈពេលសែសិបឆ្នាំជាមួយនឹងអស់អ្នកដែលបានប្រព្រឹត្តអំពើបាប
និងអនុញ្ញាតឲ្យពួកគេស្លាប់នៅទីរហោស្ថាន»។
សែសិបឆ្នាំ
«៤០ ឆ្នាំ»
តើសាកសពនរណាខ្លះត្រូវបោះចោលទីរហោស្ថាន?
តើព្រះជាម្ចាស់បានស្បថពួកគេនឹងមិនអាចសម្រាកបានឡើយ ប្រសិនបើ
គេមិនស្តាប់បង្គាប់ព្រះអង្គដូច្នេះ?
អ្នកនិពន្ធប្រើសំណួរដើម្បីបង្រៀនអ្នកអានរបស់គាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ហើយចំពោះអ្នកណា
ដែលមិនគោរពព្រះជាម្ចាស់បានស្បថថា
ព្រះអង្គនឹងមិនអនុញ្ញាតឲ្យពួកគេចូលក្នុងការសម្រាករបស់ព្រះអង្គទេ»។
ពួកគេនឹងមិនអាចសម្រាកបានឡើយ
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
បើសិនពួកគេអាចសម្រាក់ដោយព្រះអង្គប្រទានឲ្យ
និងហាក់ដូចជាពួកគេនៅទីកន្លែងដែលមនុស្សអាចទៅបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងមិនចូលទីកន្លែងសម្រាកឡើយ» ឬ
«ពួកគេនឹងមិនបានភ្លក់ព្រះពរ នៃការសម្រាករបស់គាត់ទេ»
ព្រោះគ្មានជំនឿ
ត្រង់ថា «គ្មានជំនឿ» អាចបញ្ជាក់ជាពាក្យនៃកិរិយាស័ព្ទ «ជឿ»។
របៀបផ្សេងទៀតនៃការបកប្រែ: «ពីព្រោះពួកគេមិនបានជឿជាក់លើព្រះអង្គឡើយ»

---

4 [1]ដូច្នេះ ចូរយើងរាល់គ្នាប្រយ័ត្នឲ្យមែនទែន កុំឲ្យបងប្អូនណាម្នាក់ខកខានមិនបានទទួលព្រះបន្ទូលសន្យា
និងធ្វើឲ្យបងប្អូនមិនបានចូលទៅសម្រាករួមជាមួយព្រះជាម្ចាស់។[2]ដ្បិត យើងបានទទួលដំណឹងល្អជាមួយពួកគេដែរ ប៉ុន្តែ ព្រះបន្ទូលមិនបានផ្តល់ផលប្រយោជន៍
ដល់អស់អ្នកណាដែលមិនរួបរួមក្នុងជំនឿ ដែលពួកគេជឿឡើយ។
[3]ដ្បិត អស់អ្នកណាដែលជឿ អ្នកនោះនឹងបានចូលសម្រាក ដូចព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងស្បថដោយព្រះពិរោធថា
ពួកគេនឹងពុំបានចូលទៅសម្រាកសោះឡើយ»។ ទោះបីការបង្កើតរបស់សព្វសារពើបានសម្រេចតាំងពីកំណើតផែនដីមកម្ល៉ះ។[4]ដ្បិត
ព្រះអង្គមានព្រះបន្ទូលអំពីថ្ងៃទីប្រាំពីរ។ «ព្រះជាម្ចាស់សម្រាកពីគ្រប់កិច្ចការទាំងអស់ នៅថ្ងៃទីប្រាំពីរ។[5]ព្រះជាម្ចាស់គូសបញ្ជាក់សារជាថ្មីថា៖
«ពួកគេនឹងពុំបានចូលទៅសម្រាកសោះឡើយ»។
[6]ហេតុដូចនេះ ព្រះជាម្ចាស់បានតម្រូវឲ្យអ្នកខ្លះបានចូលទៅសម្រាក ហើយចាប់តាំងពីអ៊ីស្រាអែលជាច្រើនបានឮដំណឹងល្អហើយ តែពុំបានចូលទៅសម្រាក
ព្រោះតែពួកគេមិនស្តាប់បង្គាប់[7]ដូច្នេះ ព្រះជាម្ចាស់បានកំណត់យកថ្ងៃមួយ គឺ៖ «ថ្ងៃនេះ»។ បន្ទាប់ពីព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈព្រះបាទដេវីឌ ជាយូរអង្វែងមកថា៖
«ថ្ងៃនេះ បើអ្នករាល់គ្នាឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ហើយ កុំឲ្យមានចិត្តរឹងរូសឡើយ»។
[8]ប្រសិនបើ លោកយ៉ូស្វេនាំឲ្យពួកគេបានសម្រាកមែន[9]នោះព្រះជាម្ចាស់នឹងពុំមានព្រះបន្ទូលអំពីថ្ងៃមួយទៀតទេ។ ដូច្នេះ ព្រះជាម្ចាស់តម្រូវឲ្យមានថ្ងៃសប្ប័ទមួយទៀត
សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ។[10]ដ្បិត អស់អ្នកណាបានចូលទៅសម្រាកជាមួយព្រះជាម្ចាស់ អ្នកនោះក៏បានសម្រាកពីកិច្ចការរបស់ខ្លួន
ដូចជាព្រះជាម្ចាស់បានធ្វើរួចមកហើយ។[11]ដូច្នេះ ចូរឲ្យយើងបានសង្វាតចូលទៅសម្រាក ដើម្បីកុំឲ្យនរណាម្នាក់ធ្លាក់ខ្លួនជាមនុស្សមិនស្តាប់បង្គាប់ឡើយ។
[12]ដ្បិត ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានជីវិត ធ្វើចលនា និងមុតជាងដាវមុខពីរទៅទៀត។ ព្រះបន្ទូលចាក់ទម្លុះញែកព្រលឹងចេញពីវិញ្ញាណ និងញែកសន្លាក់ចេញពីខួរឆ្អឹង។
ព្រះបន្ទូលជ្រាបពីគំនិត និងបំណងដ៏ស៊ីជម្រៅរបស់មនុស្ស។[13]គ្មានអ្វីមួយដែលព្រះជាម្ចាស់បង្កើតមក អាចលាក់កំបាំងពីព្រះអង្គបានឡើយ។ ផ្ទុយទៅវិញ
អ្វីៗទាំងអស់នៅទទេ និងបើកចំហចំពោះព្រះនេត្រព្រះអង្គ ដែលយើងម្នាក់ៗត្រូវទូលថ្វាយគ្រប់កិច្ចការទាំងអស់។
[14]ដូច្នេះ ដោយសារយើងមានមហាបូជាចារ្យមួយរូបដ៏ប្រសើរ ដែលបានឆ្លងកាត់ស្ថានបរមសុខ គឺព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់
ចូរឲ្យយើងកាន់ជំនឿឲ្យបានរឹងមាំ។[15]ដ្បិត យើងពុំមែនមានមហាបូជាចារ្យ ដែលមិនចេះប្រណីសណ្តោស ចំពោះភាពទន់ខ្សោយរបស់យើងឯណា។ ផ្ទុយទៅវិញ
ព្រះអង្គរងការល្បួងគ្រប់ជំពូក ដូចជាយើងដែរ តែព្រះអង្គពុំបានធ្វើបាបសោះឡើយ។[16]ចូរយើងចូលទៅកាន់បល្ល័ង្កនៃព្រះគុណ ទាំងទុកចិត្តថាបានទទួលក្តីមេត្តា
និងស្វែងរកព្រះគុណ ទុកជាជំនួយ ពេលណាយើងត្រូវការ។

Hebrews 4:1
ប្រយោគភ្ជាប់៖
ជំពូក ៤ បន្តការព្រមានដល់អ្នកជឿដែលចាប់ផ្តើមពីជំពូក ៣: ៧។ ព្រះជាម្ចាស់
តាមរយៈអ្នកនិពន្ធផ្តល់ការសម្រាក់ដល់អ្នកជឿ ជាការសម្រាប់របស់ព្រះជាម្ចាស់
ក្នុងការបង្កើតពិភពលោកគឺជារូបភាព។
ដូច្នេះ
«ចាប់តាំងពីព្រះជាម្ចាស់នឹងដាក់ទោសអ្នកដែលមិនប្រតិបត្តិតាម» (៣:១៦)
កុំឲ្យបងប្អូនណាម្នាក់ខកខានមិនបានទទួលព្រះបន្ទូលសន្យា
និងធ្វើឲ្យបងប្អូនមិនបានចូលទៅសម្រាករួមជាមួយព្រះជាម្ចាស់
ការសន្យារបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា
ជាអំណោយដែលព្រះបានទុកចោលនៅពេលព្រះជាម្ចាស់យាងមកជួបប្រជាជន។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្នុងចំណោមអ្នករាល់គ្នា
គ្មាននរណាម្នាក់ខកខានមិនបានចូលទៅសំរាកជាមួយព្រះជាម្ចាស់
ដែលព្រះអង្គបានសន្យាជាមួយយើងនោះឡើយ»
ចូលទៅសម្រាករួមជាមួយព្រះជាម្ចាស់
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
បើសិនពួកគេអាចសម្រាក់ដោយព្រះអង្គប្រទានឲ្យ
និងហាក់ដូចជាពួកគេនៅទីកន្លែងដែលមនុស្សអាចទៅបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងមិនចូលទីកន្លែងសម្រាកឡើយ» ឬ
«ពួកគេនឹងមិនបានភ្លក់ព្រះពរ នៃការសម្រាករបស់គាត់ទេ»
ដ្បិត យើងបានទទួលដំណឹងល្អជាមួយពួកគេដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិត
យើងបានឮដំណឹងល្អដូចជាពួកគេដែរ»
ជាមួយពួកគេដែរ
ត្រង់ថា «ពួកគេ»
សំដៅទៅលើបុព្វបុរសរបស់ពួកហេព្រើរដែលបានរស់នៅសម័យលោកម៉ូសេ។
ប៉ុន្តែ ព្រះបន្ទូលមិនបានផ្តល់ផលប្រយោជន៍ ដល់អស់អ្នកណាដែលមិនរួបរួមក្នុងជំនឿ
ដែលពួកគេជឿឡើយ
«ប៉ុន្តែសារនោះមិនបានផ្តល់ផលប្រយោជន៍ដល់អ្នកដែលមិនចូលរួមជាមួយមនុស្សដែលជឿ
និងគោរពនោះទេ»។ អ្នកនិពន្ធកំពុងនិយាយអំពីមនុស្សពីរក្រុម
គឺអ្នកដែលបានទទួលសេចក្តីសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ ដោយសេចក្តីជំនឿ
និងអ្នកដែលបានឮហើយ តែមិនបានជឿ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែសារនោះបានផ្តល់ផលប្រយោជន៍ដល់អ្នកដែលជឿ
និងគោរពនោះតែប៉ុណ្ណោះ»
Hebrews 4:3
ព័ត៌មានទូទៅ៖
នេះជាសម្រង់ទីមួយ (យើងស្បថ...) គឺដកស្រង់ចេញពីកាន់គម្ពីរទំនុកតម្កើងមួយ
ហើយសម្រង់ទីពីរនេះ (ព្រះជាម្ចាស់សម្រាកពី...)
គឺដកស្រង់ចេញពីកាន់គម្ពីរលោកម៉ូសេ និងទីបី (ពួកគេនឹងពុំបានចូលទៅ...)

generated on Wed Sep 10 16:16:32 2025

គឺបានដកស្រង់ចេញពីកាន់គម្ពីរទំនុកតម្កើងដែរ។
អស់អ្នកណាដែលជឿ
«យើងជាអ្នកជឿ»
អ្នកនោះនឹងបានចូលសម្រាក
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
បើសិនពួកគេអាចសម្រាក់ដោយព្រះអង្គប្រទានឲ្យ
និងហាក់ដូចជាពួកគេនៅទីកន្លែងដែលមនុស្សអាចទៅបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងមិនចូលទីកន្លែងសម្រាកឡើយ» ឬ
«ពួកគេនឹងមិនបានភ្លក់ព្រះពរ នៃការសម្រាករបស់គាត់ទេ»
ដូចព្រះជាម្ចាស់មានព្រះបន្ទូល
«ដូចជាព្រះជាម្ចាស់មានព្រះបន្ទូល»
យើងស្បថដោយព្រះពិរោធ
«ដូចជាយើងបានស្បថនៅពេលដែលយើងខ្ញាល់យ៉ាងខ្លាំង»
ពួកគេនឹងពុំបានចូលទៅសម្រាកសោះឡើយ
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
បើសិនពួកគេអាចសម្រាក់ដោយព្រះអង្គប្រទានឲ្យ
និងហាក់ដូចជាពួកគេនៅទីកន្លែងដែលមនុស្សអាចទៅបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងមិនចូលទីកន្លែងសម្រាកឡើយ» ឬ
«ពួកគេនឹងមិនបានភ្លក់ព្រះពរ នៃការសម្រាករបស់គាត់ទេ»
ការបង្កើតរបស់សព្វសារពើបានសម្រេច
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គបានបញ្ចប់ការបង្កើត» ឬ
«ព្រះអង្គបានបញ្ចប់កិច្ចការនៃការបង្កើតរបស់ព្រះអង្គ»
តាំងពីកំណើតផែនដីមកម៉្លេះ
អ្នកនិពន្ធនិយាយពីពិភពលោកដូចជា អាគារដែលត្រូវបានដាក់នៅលើគ្រឹះ។
របៀបផ្សេងទៀតនៃការបកប្រែ: «តាំងពីដើមនៃពិភពលោកនេះ»
នៅថ្ងៃទីប្រាំពីរ
នេះគឺជាលេខលំដាប់សម្រាប់ «ប្រាំពីរ»។
Hebrews 4:6
ព័ត៌មានទូទៅ៖
នៅទីនេះយើងបានរកឃើញថា
ការដកស្រង់ចេញពីកាន់គម្ពីទំនុកតម្កើងត្រូវបានសរសេរដោយដាវីឌ។
(សូមមើលក្នុងជំពូក ៣:៧)
ព្រះជាម្ចាស់បានតម្រូវឲ្យអ្នកខ្លះបានចូលទៅសម្រាក
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
បើសិនពួកគេអាចសម្រាក់ដោយព្រះអង្គប្រទានឲ្យ
និងហាក់ដូចជាពួកគេនៅទីកន្លែងដែលមនុស្សអាចទៅបាន។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់នៅតែបន្តឲ្យមនុស្សមួយចំនួនអាចចូលទៅទីសម្រាករបស់ព្រះអង្គបាន» ឬ
«ព្រះជាម្ចាស់នៅតែបន្តឲ្យមនុស្សមួយចំនួនបានភ្លក់នូវព្រះពរនៃការសម្រាក់របស់ព្រះអង្គ»
បើសិនអ្នករាល់គ្នាឮព្រះសូរសៀងរបស់ព្រះជាម្ចាស់
បញ្ញត្តិរបស់ព្រះជាម្ចាស់ចំពោះជនជាតិអ៊ីស្រាអែលគឺ ហាក់ដូចជា
ព្រះអង្គបានឲ្យពួកគេស្តាប់សំឡេងដែរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រសិនបើអ្នករាល់គ្នាឮព្រះជាម្ចាស់មានព្រះបន្ទូល»។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះក្នុងជំពូក ៣:៧។
កុំឲ្យមានចិត្តរឹងរូសឡើយ
ការរឹងចចេសត្រូវបានគេនិយាយថា ហាក់ដូចជាចិត្តដែលមានលក្ខណៈរឹងរូស។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំរឹងរូស»
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះក្នុងជំពូក ៣:៧។
Hebrews 4:8
ប្រយោគភ្ជាប់៖
នៅទីនេះអ្នកនិពន្ធបានព្រមានអ្នកជឿស្តាប់បង្គាប់
ហើយត្រូវចូលទៅក្នុងការសម្រាករបស់ព្រះជាម្ចាស់ដែលប្រទានឲ្យ។
អ្នកនិពន្ធរំលឹកពួកគេថា ព្រះបន្ទូលរបស់ព្រះនឹងធ្វើឲ្យគេជឿជាក់
ហើយពួកគេអាចអធិស្ឋានដោយមានទំនុកចិត្តថាព្រះជាម្ចាស់នឹងជួយពួកគេ។
ប្រសិនបើ លោកយ៉ូស្វេនាំឲ្យពួកគេបានសម្រាកមែន
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
ពួកគេអាចសម្រាកដោយលោកយ៉ូស្វេអាចនឹងឲ្យ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បើសិនលោកយ៉ូស្វេបាននាំប្រជាជនអ៊ីស្រាអែលទៅកាន់ទីកន្លែងដែលព្រះជាម្ចាស់អាចនឹងឲ្យពួកគេសម្រ
ឬ
«បើសិនក្នុងសម័យលោកយ៉ូស្វេប្រជាជនអ៊ីស្រាអែលបានភ្លក់នូវព្រះពរនៃកាសម្រាករបស់ព្រះជាម្ចាស់»
តម្រូវឲ្យមានថ្ងៃសប្ប័ទមួយទៀត សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«នៅតែមានថ្ងៃសប្ប័ទមួយទៀត សម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់»
ថ្ងៃសប្ប័ទ
សន្តិភាព និងសេចក្តីសុខអស់កល្បជានិច្ចត្រូវបានគេនិយាយថា
ជាថ្ងៃឈប់សម្រាក ដែលជាថ្ងៃគោរពបូជារបស់ជនជាតិយូដា
ហើយឈប់សម្រាកពីការងារ។របៀបផ្សេងទៀតនៃការបកប្រែ:
«ឈប់សម្រាកអស់កល្បជានិច្ច»
អស់អ្នកណាបានចូលទៅសម្រាកជាមួយព្រះជាម្ចាស់
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
ជាកន្លែងដែលពួកគេត្រូវចូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សដែលចូលទៅកាន់ទីកន្លែងសម្រាករបស់ព្រះជាម្ចាស់» ឬ
«មនុស្សដែលភ្លក់នូវព្រះពរនៃការសម្រាករបស់ព្រះជាម្ចាស់»
ចូរឲ្យយើងបានសង្វាតចូលទៅសម្រាក
សន្តិភាព និងសេចក្តីសុខដែលព្រះជាម្ចាស់ប្រទានឲ្យ អាចនិយាយបានថា
ជាកន្លែងដែលពួកគេត្រូវចូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងក៏គួរតែធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបាន
ដើម្បីសម្រាកជាមួយព្រះជាម្ចាស់ជាកន្លែងដែលព្រះអង្គគង់នៅ»
កុំឲ្យនរណាម្នាក់ធ្លាក់ខ្លួនជាមនុស្សមិនស្តាប់បង្គាប់ឡើយ
ការមិនស្តាប់បង្គាប់ត្រូវបានគេនិយាយថា
ជាប្រហោងដែលអាចបណ្តោយឲ្យរាងកាយមនុស្សធ្លាក់ទៅក្នុងគ្រោះថ្នាក់។
អត្ថបទនេះអាចត្រូវកែសម្រួល ដូច្នេះនាមអរូបី «ការមិនស្តាប់បង្គាប់»
គឺបង្ហាញថាជាកិរិយាស័ព្ទ «មិនស្តាប់បង្គាប់» របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងមិនស្តាប់បង្គាប់តាមរបៀបដែលពួកគេបានធ្វើ»
Hebrews 4:12
ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានជីវិត
ត្រង់ថា «ព្រះបន្ទូលរបស់ព្រះជាម្ចាស់»
សំដៅទៅលើអ្វីដែលព្រះជាម្ចាស់បានប្រាស្រ័យទាក់ទងនឹងមនុស្សជាតិមិនថាតាមរយៈមានព្រះបន្ទូល
ឬតាមរយៈសារជាលាយលក្ខណ៍អក្សរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានជីវិត»
មានជីវិត និងធ្វើចលនា
នេះនិយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហាក់ដូចជានៅមានជីវិត។
គឺមានន័យថា នៅពេលដែលព្រះជាម្ចាស់មានព្រះបន្ទូល នោះពិតជាមានអានុភាព
និងប្រសិទ្ធភាព។
មុតជាងដាវមុខពីរទៅទៀត
មុខដាវ ដាវមុខពីរអាចងាយក្នុងការកាត់សាច់មនុស្ស។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានប្រសិទ្ធភាពណាស់ក្នុងការបង្ហាញពីអ្វី
ដែលមាននៅក្នុងចិត្តនិងគំនិតរបស់មនុស្ស។
ដាវមុខពីរ
មុខដាវ ដាវដែលមុតនៅលើគែមទាំងពីរ
ចាក់ទម្លុះញែកព្រលឹងចេញពីវិញ្ញាណ និងញែកសន្លាក់ចេញពីខួរឆ្អឹង
ត្រង់នេះគឺបន្តនិយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចជាដាវ។
នៅទីនេះដាវគឺមុតស្រួចណាស់ ដែលអាចកាត់ និងចែកផ្នែកខ្លះនៃមនុស្ស
ដែលពិបាកខ្លាំង ឬមិនអាចចែកបាន។
នេះមានន័យថាគ្មានអ្វីនៅក្នុងចិត្តរបស់យើងដែលអាចលាក់ពីព្រះជាម្ចាស់បានទេ។
ព្រលឹងចេញពីវិញ្ញាណ
ទាំងនេះគឺជាផ្នែកពីរផ្សេងគ្នា ប៉ុន្តែមិនទាក់ទងនឹងផ្នែករាងកាយរបស់មនុស្ស។
«ព្រលឹង» គឺជាអ្វីដែលបណ្តាលឲ្យមនុស្សមានជីវិត។ «វិញ្ញាណ»
គឺជាផ្នែកមួយនៃមនុស្ស ដែលធ្វើឲ្យគេអាចស្គាល់ និងជឿលើព្រះជាម្ចាស់។
សន្លាក់ចេញពីខួរឆ្អឹង
«សន្លាក់» គឺជាអ្វីដែលមានឆ្អឹងពីររួមគ្នា។ «ខួរឆ្អឹង» គឺជាផ្នែកនៅកណ្តាលឆ្អឹង។
ជ្រាបពីគំនិត
ត្រង់នេះនិយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់
ហាក់ដូចជាមនុស្សម្នាក់ដែលអាចដឹងអ្វីមួយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបន្ទូលរបស់ព្រះជាម្ចាស់លាតត្រដាងឡើង» (UDB)
បំណងដ៏ស៊ីជម្រៅ

generated on Wed Sep 10 16:16:32 2025

ត្រង់នេះនិយាយអំពីចិត្ត ហាក់ដូចជាចំណុចកណ្តាលនៃការគិត
និងអារម្មណ៍នៅក្នុងខ្លួនមនុស្សម្នាក់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលមនុស្សកំពុងគិត ហើយមានបំណងធ្វើ»
គ្មានអ្វីមួយដែលព្រះជាម្ចាស់បង្កើតមក អាចលាក់កំបាំងពីព្រះអង្គបានឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គ្មានអ្វីមួយដែលព្រះជាម្ចាស់បង្កើតមក អាចលាក់កំបាំងពីព្រះអង្គបានឡើយ»
ផ្ទុយទៅវិញ អ្វីៗទាំងអស់នៅទទេ និងបើកចំហ
នេះនិយាយអំពីអ្វីទាំងអស់ ដូចជាមនុស្សម្នាក់ដែលឈរនៅកណ្តាលវាល
ឬជាប្រអប់ដែលបើកចំហ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីគ្រប់យ៉ាងត្រូវបានលាតត្រដាងទាំងស្រុង» (UDB)
នៅទទេ និងបើកចំហ
ពាក្យទាំងពីរនេះជាទូទៅមានន័យដូចគ្នា
ហើយបញ្ជាក់ថាគ្មានអ្វីត្រូវបានលាក់ពីព្រះជាម្ចាស់ទេ។
ចំពោះព្រះនេត្រព្រះអង្គ ដែលយើងម្នាក់ៗត្រូវទូលថ្វាយគ្រប់កិច្ចការទាំងអស់
ព្រះជាម្ចាស់គឺត្រូវបានគេនិយាយ បើសិនព្រះអង្គមានព្រះនេត្រ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ចំពោះព្រះដែលនឹងវិនិច្ឆ័យអំពីរបៀបដែលយើងបានរស់នៅ» (សូមមើល [[c://*/ta/man/translate/figs-metaphor]])
Hebrews 4:14
ដែលបានឆ្លងកាត់ស្ថានបរមសុខ
«អ្នកដែលបានចូលទៅកាន់កន្លែងដែលព្រះជាម្ចាស់គង់នៅ»
ព្រះបុត្រារបស់ព្រះជាម្ចាស់
នេះគឺជាឋានៈដែលសំខាន់សម្រាប់ព្រះយេស៊ូ។
ចូរឲ្យយើងកាន់ជំនឿឲ្យបានរឹងមាំ
ជំនឿ និងការទុកចិត្តត្រូវបានគេនិយាយថា
ដូចជាវត្ថុដែលមនុស្សអាចយល់បានយ៉ាងរឹងមាំ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរឲ្យយើងនៅតែបន្តជឿដោយទុកចិត្តលើព្រះអង្គ»
យើងពុំមែនមានមហាបូជាចារ្យ ដែលមិនចេះប្រណីសណ្តោស ចំពោះភាពទន់ខ្សោយរបស់យើង
ភាពអវិជ្ជមានពីរដងនេះមានន័យថា
តាមពិតព្រះយេស៊ូពិតជាអាណិតអាសូរដល់មនុស្សខ្លាំងណាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងមានមហាបូជាចារ្យ
ដែលអាចប្រណីសណ្តោស...ជាការពិតយើងមាន»
ព្រះអង្គរងការល្បួងគ្រប់ជំពូក ដូចជាយើងដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលបានស៊ូទ្រាំនឹងការល្បួងតាមគ្រប់មធ្យោបាយដែលយើងមាន» ឬ
«អារក្សដែលបានល្បួងយើងតាមគ្រប់មធ្យោបាយដែលវាល្បួងយើង»
ព្រះអង្គពុំបានធ្វើបាបសោះឡើយ
«ព្រះអង្គមិនប្រព្រឹត្តអំពើបាបទេ»
បល្ល័ង្កនៃព្រះគុណ
«ចូលទៅកាន់បល្ល័ង្ករបស់ព្រះជាម្ចាស់ ជាកន្លែងដែលមានព្រះគុណ»។ នៅត្រង់
«បល្ល័ង្ក» សំដៅទៅលើព្រះជាម្ចាស់សោយរាជ្យជាស្តេច។
របៀបផ្សេងទៀតនៃការបកប្រែ:
«ជាកន្លែងដែលព្រះជាម្ចាស់ដ៏មានព្រះគុណរបស់យើងកំពុងគង់លើបល្ល័ង្ករបស់ទ្រង់»
យើងបានទទួលក្តីមេត្តា និងស្វែងរកព្រះគុណ ទុកជាជំនួយ ពេលណាយើងត្រូវការ។
ត្រង់ថា «ក្តីមេត្តា» និង «ព្រះគុណ» ត្រូវបានគេនិយាយថា ដូចជា
វត្ថុដែលអាចត្រូវបានផ្តល់ឱ្យឬអាចត្រូវបានរកឃើញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់អាចមានព្រះហឫទ័យមេត្តាករុណា
និងប្រណីសន្តោស ហើយជួយយើងនៅពេលមានតម្រូវការ»

---

5 [1]គេជ្រើសរើសមហាបូជាចារ្យគ្រប់រូបពីចំណោមមនុស្ស ដើម្បីតែងតាំងឲ្យបំពេញមុខងារតំណាងឲ្យមនុស្ស ទាក់ទងជាមួយព្រះជាម្ចាស់ ដូច្នេះ លោកនឹងថ្វាយតង្វាយ
និងថ្វាយយញ្ញបូជាលោះបាប។[2]លោកមានអធ្យាស្រ័យជាមួយមនុស្សល្ងង់ និងវង្វេង ព្រោះលោកផ្ទាល់ក៏នៅជាមួយមនុស្សទន់ខ្សោយដែរ។[3]ដោយហេតុនេះ
បានជាលោកត្រូវថ្វាយតង្វាយលោះបាបខ្លួនឯងមុនសិន ទើបថ្វាយតង្វាយលោះបាបឲ្យប្រជារាស្ត្រ។
[4]ពុំមែនសម្រាប់លោកទេ ដែលគ្រប់គ្នាបានទទួលកិត្តិយសនេះ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់ទេតើ ដែលបានត្រាស់ហៅលោកឲ្យបំពេញមុខងារនេះ ដូចជាលោកអ៊ីរ៉ុនជាដើម។
[5]ដូចគ្នានេះដែរ ព្រះគ្រិស្តពុំបានលើកកិត្តិយសខ្លួនឯងធ្វើជាមហាបូជាចារ្យឡើយ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ព្រះអង្គថា៖ «ថ្ងៃនេះ
យើងទទួលព្រះអង្គជាព្រះបុត្រាយើង យើងជាព្រះបិតាព្រះអង្គ»។
[6]ព្រះជាម្ចាស់មានបន្ទូលមួយវគ្គទៀតថា៖ «ព្រះអង្គជាបូជាចារ្យជារៀងរហូត តាមរបៀបព្រះបាទម៉ិលគីស្សាដែក»។
[7]កាលព្រះគ្រិស្តគង់នៅក្នុងលោកនេះនៅឡើយ ព្រះអង្គអធិស្ឋានទូលអង្វរដោយបន្លឺសំឡេងខ្លាំងៗ និងបង្ហូរទឹកភ្នែក សូមព្រះជាម្ចាស់សង្គ្រោះមនុស្សពីសេចក្តីស្លាប់។
ព្រះជាម្ចាស់ស្តាប់ឮការទូលអង្វរ ព្រោះអង្គរគោរពប្រណិបតន៍ព្រះជាម្ចាស់។[8]ទោះបីព្រះអង្គជាព្រះបុត្រាក៏ដោយ ក៏ព្រះអង្គរៀនស្តាប់បង្គាប់ពីការរងទុក្ខលំបាក។
[9]ព្រះអង្គបានគ្រប់លក្ខណ៍ និងក្លាយជាប្រភពនៃការសង្គ្រោះអស់កល្បជានិច្ចចំពោះអ្នកណាដែលស្តាប់បង្គាប់ព្រះជាម្ចាស់។[10]ព្រះជាម្ចាស់បានតម្រូវទុកជាមុន
ឲ្យព្រះអង្គបំពេញមុខងារជាមហាបូជាចារ្យតាមរបៀបព្រះបាទម៉ិលគីស្សាដែក។[11]យើងមានចំណុចច្រើនត្រូវនិយាយពីព្រះយេស៊ូ ប៉ុន្តែពិបាកពន្យល់ណាស់
ព្រោះបងប្អូនក្រនឹងយល់ណាស់។
[12]រហូតមកទល់នឹងពេលនេះ បងប្អូនគួរធ្វើជាគ្រូបង្រៀនគេបាន ប៉ុន្តែ បងប្អូននៅតែត្រូវការគេបង្រៀន អំពីគោលការណ៍គ្រឹះខ្លះនៃព្រះបន្ទូលព្រះជាម្ចាស់។
[13]បងប្អូនត្រូវការទឹកដោះគោ តែមិនទាន់ត្រូវការអាហាររឹងនៅឡើយ។ អស់អ្នកណាត្រូវការតែទឹកដោះគោ អ្នកនោះគ្មានបទពិសោធន៍ជាមួយព្រះបន្ទូលនៃសេចក្តីសុចរិត
ព្រោះខ្លួនគេនៅក្មេងខ្ចីនៅឡើយ។[14]ប៉ុន្តែ អាហាររឹងសម្រាប់មនុស្សពេញវ័យ។ អ្នកទាំងនោះជាមនុស្សពេញវ័យ មានការយល់ដឹងថាអ្វីមួយល្អ អ្វីមួយអាក្រក់។

Hebrews 5:1
ប្រយោគភ្ជាប់៖
អ្នកនិពន្ធពិពណ៌នាអំពី អំពើបាបរបស់បូជាចារ្យនៅក្នុងព្រះគម្ពីរសញ្ញាចាស់
បន្ទាប់មកអ្នកនិពន្ធបង្ហាញថា
ព្រះគ្រិស្តមានបព្វជិតភាពល្អប្រសើរជាងមុនមិនមែនផ្អែកលើបព្វជិតភាពរបស់អើរ៉ុនទេ
តែផ្អែកលើបព្វជិតភាពរបស់មិលគីស្សាដែក។
ជ្រើសរើសពីចំណោមមនុស្ស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកដែលព្រះជាម្ចាស់ជ្រើសរើសពីក្នុងចំណោមប្រជាជន»
ដើម្បីតែងតាំងឲ្យ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់តែងតាំង»
បំពេញមុខងារតំណាងឲ្យមនុស្ស
«ដើម្បីតំណាងឲ្យប្រជាជន»
មនុស្សល្ងង់ និងវង្វេង
គុណនាមបន្ទាប់បន្សំទាំងនេះអាចត្រូវបានបញ្ជាក់ជា គុណនាម។
របៀបផ្សេងទៀតនៃការបកប្រែ: «អស់អ្នកណាដែលជាមនុស្សល្ងង់ និងវង្វេង»
វង្វេង
ជាមនុស្សដែលប្រព្រឹត្តអំពើខុសក្នុងអំពើ
នៅជាមួយមនុស្សទន់ខ្សោយ
ភាពទន់ខ្សោយផ្ទាល់ខ្លួនរបស់សម្តេចសង្ឃគឺដូចជា កម្លាំងដែលព័ទ្ធជុំវិញគាត់។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្សោយខាងវិញ្ញាណ» ឬ
«ខ្សោយប្រឆាំងនឹងអំពើបាប»
មនុស្សទន់ខ្សោយ
ត្រង់នេះសំដៅទៅលើការមានប្រាថ្នាធ្វើបាប។
បានជាលោកត្រូវថ្វាយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ក៏ត្រូវការលោកដែរ»
Hebrews 5:4
ព័ត៌មានទូទៅ៖
ការដកស្រង់នេះ ចេញពីកាន់គម្ពីរទំនុកតម្កើងនៅក្នុងព្រះគម្ពីរសញ្ញាចាស់។
ទទួលកិត្តិយសនេះ
កិត្តិយសត្រូវបានគេនិយាយដូចជា
វត្ថុដែលមនុស្សអាចចាប់បាននៅក្នុងដៃរបស់គាត់។

generated on Wed Sep 10 16:16:32 2025

ទទួលកិត្តិយសនេះ
ពាក្យ «កិត្តិយស» ឬការសរសើរ និងការគោរពដែលមនុស្សបានផ្តល់ឲ្យ
បូជាចារ្យគឺសម្រាប់ភារកិច្ចរបស់គាត់។
ព្រះជាម្ចាស់ទេតើ ដែលបានត្រាស់ហៅលោកឲ្យបំពេញមុខងារនេះ ដូចជាលោកអ៊ីរ៉ុនជាដើម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានត្រាស់ហៅលោក ដូចជាព្រះអង្គបានត្រាស់ហៅលោកអ៊ីរ៉ុនដែរ»
ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់ព្រះអង្គ
«ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោក»
ជាព្រះបុត្រាយើង យើងជាព្រះបិតាព្រះអង្គ
ឃ្លាទាំងពីរនេះមានន័យសំខាន់ដូចគ្នា។
សូមមើលពីរបៀបដែលអ្នកបានបកប្រែឃ្លានេះនៅក្នុងជំពូក ១:៤។
ព្រះបុត្រា...ព្រះបិតា
ទាំងនេះគឺជាឋានៈសំខាន់ៗ ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះយេស៊ូ
និងព្រះវរបិតា។
Hebrews 5:6
ព័ត៌មានទូទៅ៖
ទំនាយនេះចេញមកពីកាន់គម្ពីរទំនុកតម្កើងរបស់ដាវីឌ។
ព្រះជាម្ចាស់មានបន្ទូលមួយវគ្គទៀត
ទៅកាន់អ្នកដែលព្រះជាម្ចាស់កំពុងមានព្រះបន្ទូល អាចបញ្ជាក់បានយ៉ាងច្បាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «គាត់ក៏និយាយទៅកាន់ព្រះគ្រីស្ទដែរ»
មួយវគ្គទៀត
«មួយវគ្គទៀតនៅក្នុងបទគម្ពីរ»
តាមរបៀបព្រះបាទម៉ិលគីស្សាដែក
នេះមានន័យថា ព្រះគ្រិស្តជាបូជាចារ្យមានរឿងរ៉ាវដូចគ្នានឹងម៉ិលគីស្សាដែក
ជាបូជាចារ្យដែរ។ របៀបផ្សេងទៀតនៃការបកប្រែ: «តាមរបៀបដែលម៉ិលគីស្សាដែក
ជាបូជាចារ្យ»
Hebrews 5:7
កាលព្រះគ្រិស្តគង់នៅក្នុងលោកនេះនៅឡើយ
ត្រង់ថា «ក្នុងលោកនេះ» តំណាងឲ្យរយៈពេលមួយនៃពេលវេលា។ ហើយ
«សាច់ឈាម» តំណាងឲ្យជីវិតនៅលើផែនដីរបស់ព្រះយេស៊ូ។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្នុងពេលដែលព្រះអង្គបានរស់នៅលើផែនដី»
អធិស្ឋាន និងទូលអង្វរ
ពាក្យទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា។
សង្គ្រោះមនុស្សពីសេចក្តីស្លាប់
សេចក្តីស្លាប់អាចហៅថាដូចជា កន្លែងដែលព្រះគ្រិស្តអាចត្រូវបានរារាំងមិនឲ្យចូល
ឬជាកន្លែងដែលព្រះអង្គអាចបានសង្គ្រោះ។ ត្រង់នេះសមនឹងអត្ថន័យទាំងពីរ។
UDB ជ្រើសរើសអត្ថន័យទីមួយ។ ប្រសិនបើអាច
សូមបកប្រែអនុញ្ញាតឲ្យមានការបកស្រាយទាំងពីរ។
ព្រះជាម្ចាស់ស្តាប់ឮ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានស្តាប់ឮគាត់»
ព្រះបុត្រា
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះ។
ការរងទុក្ខលំបាក
បទពិសោធន៍នៃទុក្ខវេទនាត្រូវបានគេនិយាយថា ដូចជាអ្វីដែលពួកគេធ្លាប់មាន។
Hebrews 5:9
ប្រយោគភ្ជាប់៖
នៅក្នុងខ១១ អ្នកនិពន្ធចាប់ផ្តើមការព្រមានលើកទីបីរបស់គាត់។
គាត់ព្រមានអ្នកជឿទាំងនេះថា ពួកគេនៅតែមិនទាន់ពេញវ័យ
ហើយលើកទឹកចិត្តពួកគេឲ្យរៀនព្រះបន្ទូលរបស់ព្រះ
ដើម្បីពួកគេអាចយល់ពីអ្វីដែលត្រឹមត្រូវ។
ព្រះអង្គបានគ្រប់លក្ខណ៍
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់ធ្វើឲ្យព្រះអង្គបានគ្រប់លក្ខណ៍»
បានគ្រប់លក្ខណ៍
ត្រង់នេះន័យថា ត្រូវធ្វើឲ្យមានភាពចាស់ទុំ
គឺអាចលើកកិត្តិយសព្រះជាម្ចាស់គ្រប់ផ្នែកទាំងអស់នៃជីវិត។
ក្លាយជាប្រភពនៃការសង្គ្រោះអស់កល្បជានិច្ចចំពោះអ្នកណាដែលស្តាប់បង្គាប់ព្រះជាម្ចាស់
ជានាមអរូបី «ការសង្គ្រោះ» អាចបញ្ជាក់ថាជាកិរិយាស័ព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ឡូវនេះព្រះអង្គជួយសង្គ្រោះអស់អ្នកដែលស្តាប់បង្គាប់ព្រះអង្គ
ហើយឲ្យពួកគេរស់នៅជារៀងរហូត»
ព្រះជាម្ចាស់បានតម្រូវទុកជាមុន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានតម្រូវព្រះអង្គ» ឬ «ព្រះជាម្ចាស់បានតែងតាំងព្រះអង្គ»
តាមរបៀបព្រះបាទម៉ិលគីស្សាដែក
នេះមានន័យថា ព្រះគ្រិស្តជាបូជាចារ្យមានរឿងរ៉ាវដូចគ្នានឹងម៉ិលគីស្សាដែក
ជាបូជាចារ្យដែរ។ របៀបផ្សេងទៀតនៃការបកប្រែ: «តាមរបៀបដែលម៉ិលគីស្សាដែក
ធ្វើជាបូជាចារ្យ»
យើងមានចំណុចច្រើនត្រូវនិយាយ
ទោះបីជាអ្នកនិពន្ធប្រើសព្វនាមពហុវចន: «យើង» ក៏ដោយ
គឺភាគច្រើនគាត់សំដៅទៅលើតែខ្លួនរបស់គាត់ប៉ុណ្ណោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមានរឿងជាច្រើនដែលត្រូវនិយាយ»
បងប្អូនក្រនឹងយល់ណាស់
សមត្ថភាពក្នុងការយល់ និងស្តាប់បង្គាប់ត្រូវបានគេនិយាយថា
ជាសមត្ថភាពក្នុងការស្តាប់។
ហើយសមត្ថភាពក្នុងការស្តាប់ត្រូវបានគេនិយាយដូចជាឧបករណ៍ដែក
ដែលក្លាយទៅជារឹលជាមួយនឹងការប្រើប្រាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកមានបញ្ហាក្នុងការស្វែងយល់»
Hebrews 5:12
អំពីគោលការណ៍គ្រឹះ
ត្រង់ថា «គោលការណ៍» មានន័យថា ជាគោលការណ៍ណែនាំ
ឬស្តង់ដារសំរាប់ធ្វើការសំរេចចិត្ត។ របៀបផ្សេងទៀតនៃការបកប្រែ:
«មូលដ្ឋានសេចក្តីពិត»
បងប្អូនត្រូវការទឹកដោះគោ
ការបង្រៀនអំពីព្រះជាម្ចាស់ ដែលងាយយល់គឺត្រូវនិយាយដូចជា
ទឹកដោះគោដែលជាអាហារតែមួយគត់ដែលទារកអាចទទួលយកបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកបានក្លាយជាទារក
ហើយអាចផឹកតែទឹកដោះគោ»
មិនទាន់ត្រូវការអាហាររឹងនៅឡើយ
ការបង្រៀនអំពី ព្រះជាម្ចាស់ដែលពិបាកយល់ត្រូវបាននិយាយដូចជា
អាហាររឹងសមស្របសម្រាប់មនុស្សពេញវ័យ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជំនួសឲ្យអាហាររឹង ដែលមនុស្សពេញវ័យអាចញ៉ាំបាន» (សូមមើល:
ត្រូវការទឹកដោះគោ
ត្រង់ថា «ត្រូវការ» តំណាឲ្យ «ផឹក» របៀបផ្សេងទៀតនៃការបកប្រែ:
«ផឹកទឹកដោះគោ»
ព្រោះខ្លួនគេនៅក្មេងខ្ចីនៅឡើយ
នេះនិយាយអំពី អ្នកជឿដែលអាចយល់បានតែការបង្រៀនដ៏សាមញ្ញនៃដំណឹងល្អ
ដូចជាគេជាទារកពិត។
ប៉ុន្តែ អាហាររឹងសម្រាប់មនុស្សពេញវ័យ អ្នកទាំងនោះជាមនុស្សពេញវ័យ
មានការយល់ដឹងថាអ្វីមួយល្អ អ្វីមួយអាក្រក់
មនុស្សដែលបានបណ្តុះបណ្តាលឲ្យយល់អ្វីមួយ អាចបាននិយាយថា
ដូចជាសមត្ថភាពក្នុងការយល់ដឹងត្រូវបានបណ្តុះបណ្តាល។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកណាដែលមានភាពចាស់ទុំ
ហើយអាចបែងចែករវាងភាពល្អ និងអាក្រក់»

---

6 [1]ដូច្នេះ ចូរយើងទុកសេចក្តីដំបូងនៃព្រះបន្ទូលរបស់ព្រះគ្រិស្តមួយឡែក រួចហើយបោះជំហានទៅមុខ ដើម្បីក្លាយខ្លួនជាមនុស្សពេញវ័យវិញ។
ចូរយើងកុំចាក់គ្រឹះនៃការកែប្រែចិត្ត ពីកិច្ចការណាឥតបានការ ហើយមានជំនឿលើព្រះជាម្ចាស់វិញ។[2]ចូរកុំចាក់គ្រឹះនៃពិធីជ្រមុជទឹក ការដាក់ដៃ
និងការរស់ឡើងវិញរបស់មនុស្សស្លាប់ និងការជំរំជម្រះអស់កល្បជានិច្ចវិញ។[3]យើងនឹងនិយាយសេចក្តីទាំងនេះ បើព្រះជាម្ចាស់គាប់ព្រះហឫទ័យ។
[4]វាមិនអាចទេ ដែលអ្នកខ្លះបានភ្លឺម្តងរួចហើយ ស្គាល់ឱជារសអំណោយទានស្ថានបរមសុខ
ចូលរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ[5]និងអស់អ្នកបានស្គាល់ឱជារសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រមទាំងស្គាល់ឫទ្ធានុភាពនៃលោកខាងមុខ[6]ប៉ុន្តែ

generated on Wed Sep 10 16:16:32 2025

បែរជាធ្លាក់ខ្លួនបាត់ជំនឿទៅវិញ គេមិនអាចនាំអ្នកនោះឲ្យកែប្រែចិត្តវិញបានទេ។ ព្រោះពួកគេបានឆ្កាងព្រះបុត្រារបស់ព្រះជាម្ចាស់ និងខ្លួនគេផ្ទាល់ម្តងទៀត
ព្រមទាំងធ្វើឲ្យព្រះអង្គអាម៉ាស់ជាសាធារណៈ។
[7]ដ្បិត ដីណាទទួលទឹកភ្លៀងញឹកញាប់ ដីនោះនឹងបង្កើតផលជារុក្ខជាតិមានប្រយោជន៍ ព្រោះដីនោះបង្កើតផល គឺជាដីទទួលព្រះពរមកពីព្រះជាម្ចាស់។[8]ប៉ុន្តែ បើវាដុះបន្លា
និងអញ្ចាញវិញ ជាដីគ្មានប្រយោជន៍ទាល់តែសោះ ហើយជិតត្រូវបណ្តាសាទៀត។ គេនឹងយកវាទៅដុតចោល។
[9]ប៉ុន្តែ បងប្អូនជាទីស្រឡាញ់អើយ យើងជឿជាក់លើអ្វីៗដែលនាំឲ្យបងប្អូនទទួលការសង្គ្រោះ ទោះបីយើងនិយាយបែបនេះក៏ដោយ។[10]ដ្បិត ព្រះជាម្ចាស់ពុំមែនអយុត្តិធ៌ម
ដោយបំភ្លេចកិច្ចការ និងសេចក្តីស្រឡាញ់របស់បងប្អូន ដែលបានលើកតម្កើងព្រះនាមព្រះអង្គ ពីព្រោះបងប្អូនបានបម្រើអ្នកជឿទាំងឡាយពីមុន
ហើយឥឡូវបងប្អូននៅតែបម្រើដដែល។
[11]យើងពិតជាមានបំណងចង់ឲ្យបងប្អូនម្នាក់ៗ បង្ហាញទឹកចិត្តខ្នះខ្នែងដូចគ្នា រហូតដល់ទីបញ្ចប់ ប្រយោជន៍ផ្តល់ទំនុកចិត្តធានារ៉ាប់រងពេញលក្ខណៈ។[12]ហេតុដូច្នេះ
បងប្អូនលែងខ្ជិលច្រអូស ប៉ុន្តែ យកតម្រាប់តាមមនុស្សទទួលមរតក តាមព្រះបន្ទូលសន្យា ដោយសារជំនឿ និងចិត្តអត់ធ្មត់។
[13]ដ្បិត ពេលព្រះជាម្ចាស់សន្យាជាមួយលោកអប្រាហាំ ព្រះអង្គស្បថចំពោះព្រះអង្គផ្ទាល់ ព្រោះគ្មាននរណាមានឋានៈធំជាងព្រះអង្គធ្វើជាទីសម្បថឡើយ។[14]ព្រះអង្គមាន
ព្រះបន្ទូលថា៖ «យើងពិតជាឲ្យពរអ្នក ហើយក៏នឹងធ្វើឲ្យពូជពង្សរបស់អ្នកកើនចំនួនច្រើនឡើងផងដែរ»។[15]លោកអប្រាហាំបានទទួលព្រះពរតាមព្រះបន្ទូលសន្យា
តាមរបៀបនេះឯង ក្រោយពេលលោករង់ចាំដោយចិត្តអត់ធ្មត់។
[16]ដ្បិត មនុស្សម្នាស្បថដោយយកអ្នកណាមានឋានៈធំជាងខ្លួនធ្វើជាទីសម្បថ។ នៅចុងបញ្ចប់នៃជម្លោះ គេតែងយកពាក្យសម្បថនោះជាការបញ្ជាក់អះអាង។
[17]ពេលព្រះជាម្ចាស់សម្រេចព្រះទ័យ ដើម្បីបង្ហាញឲ្យអ្នកទទួលមរតកតាមព្រះបន្ទូលសន្យាយ៉ាងច្បាស់ថា ព្រះអង្គសម្រេចយ៉ាងណា នោះព្រះអង្គពុំប្រែប្រួលឡើយ
ហើយព្រះអង្គធានាអះអាងដោយពាក្យសម្បថថែមទៀតផង។[18]ព្រះអង្គធ្វើដូច្នេះ ដើម្បីឲ្យរបស់ពីរយ៉ាងពុំប្រែប្រួល គឺព្រះជាម្ចាស់ពុំចេះកុហក់ឡើយ
និងអ្នកដែលរត់ទៅរកទីជម្រកនឹងទទួលបានការលើកទឹកចិត្ត ដើម្បីមានទំនុកចិត្តរឹងមាំនូវអ្វី ដែលព្រះអង្គបានដាក់នៅមុខយើង។
[19]យើងមានទំនុកចិត្តប្រកបដោយសុវត្ថិភាព និងប្រៀបបីដូចជាយុថ្កាខាងវិញ្ញាណដ៏រឹងមាំ ដែលធ្វើឲ្យយើងចូលទៅហួសវាំងននទីសក្ការៈ។
[20]ព្រះយេស៊ូបានចូលទៅទីសក្ការៈមុនយើង ទុកជាប្រយោជន៍ដល់យើង ហើយព្រះអង្គបានទទួលឋានៈជាមហាបូជាចារ្យ អស់កល្បជានិច្ចតាមរបៀបព្រះបាទ
មិលគីស្សាដែក។

Hebrews 6:1

ប្រយោគភ្ជាប់៖

អ្នកនិពន្ធបន្តជាមួយអ្វី ដែលអ្នកជឿជនជាតិហេព្រើរដែលមិនទាន់ពេញវ័យ
ត្រូវធ្វើដើម្បីក្លាយទៅជាគ្រីស្ទានដែលមានភាពចាស់ទុំ។

គាត់រំលឹកពួកគេអំពីគ្រឹះនៃការបង្រៀន។

ចូរយើងទុកសេចក្តីដំបូងនៃព្រះបន្ទូលរបស់ព្រះគ្រិស្តមួយឡែក រួចហើយបោះជំហានទៅមុខ
ដើម្បីក្លាយខ្លួនជាមនុស្សពេញវ័យវិញ

នេះនិយាយអំពី មូលដ្ឋាននៃការបង្រៀន ដូចជាពួកគេចាប់ផ្តើមនៃការធ្វើដំណើរ
និងការបង្រៀនដែលមានភាពចាស់ទុំ ជាចុងបញ្ចប់នៃដំណើរមួយ។

របៀបផ្សេងទៀតនៃការបកប្រែ: «សូមឲ្យយើងឈប់ពិភាក្សាតែអ្វី
ដែលយើងបានរៀនដំបូង
ហើយចាប់ផ្តើមយល់ពីការបង្រៀនដែលមានភាពចាស់ទុំជាងមុនផងដែរ»

ចូរយើងកុំចាក់គ្រឹះ...មានជំនឿលើព្រះជាម្ចាស់វិញ

មូលដ្ឋាននៃការបង្រៀនអាចហៅថា ដូចជាអាគារដែលការស្ថាបនា
គឺចាប់ផ្តើមដោយការចាក់គ្រឹះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«កុំអោយយើងរំលឹកឡើងវិញនូវការបង្រៀនជាមូលដ្ឋាន... អំពីជំនឿលើព្រះ»

កិច្ចការណាឥតបានការ

ការប្រព្រឹត្តអំពើបាបអាចហៅបានថា ពួកគេជាកម្មសិទ្ធិសេចក្តីស្លាប់នៃពិភពលោក។

ចូរកុំចាក់គ្រឹះនៃពិធីជ្រមុជទឹក...ការជំរិជម្រះអស់កល្បជានិច្ចវិញ

ការបង្រៀនជាមូលដ្ឋានអាចហៅថា ជាអាគារដែលការស្ថាបនាចាប់ផ្តើម
ដោយការចាក់គ្រឹះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការបង្រៀនជាមូលដ្ឋាន...ការជំរិជម្រះអស់កល្បជានិច្ច»

ការដាក់ដៃ

ការអនុវត្តនេះត្រូវបានធ្វើឡើង
ដើម្បីកំណត់នរណាម្នាក់ដាច់ដោយឡែកពីគ្នាសម្រាប់សេវាកម្ម
ឬមុខតំណែងពិសេស។

Hebrews 6:4

អ្នកខ្លះបានភ្លឺម្តងរួចហើយ

ការយល់ដឹងត្រូវបានគេនិយាយ ដូចជាការបំភ្លឺ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលធ្លាប់យល់អំពីព្រះបន្ទូលព្រះគ្រិស្ត»

ស្គាល់ឱជារសអំណោយទានស្ថានបរមសុខ

ការសង្គ្រោះដែលមានបទពិសោធន៍ត្រូវបានគេនិយាយ
ហាក់ដូចជាការកំពុងភ្លក់អាហារ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលមានបទពិសោធន៍សន្សំព្រះចេស្តារបស់ព្រះជាម្ចាស់»

ចូលរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះវិញ្ញាណបរិសុទ្ធ ដែលមករកអ្នកជឿត្រូវបានគេនិយាយថា
ព្រះវិញ្ញាណបរិសុទ្ធជាវត្ថុដែលមនុស្សអាចចែករំលែកបាន។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ»

អស់អ្នកបានស្គាល់ឱជារសព្រះបន្ទូលរបស់ព្រះជាម្ចាស់

ការសិក្សាព្រះបន្ទូលរបស់ព្រះ ត្រូវបានគេនិយាយដូចជាការភ្លក់អាហារ។
របៀបផ្សេងទៀតនៃការបកប្រែ: «អ្នកដែលរៀនពីព្រះបន្ទូលល្អៗរបស់ព្រះជាម្ចាស់»

ស្គាល់ឫទ្ធានុភាពនៃលោកខាងមុខ

នេះមានន័យថាអំណាចរបស់ព្រះជាម្ចាស់
នៅពេលដែលព្រះរាជរបស់ព្រះអង្គមានវត្តមាននៅលើពិភពលោកទាំងមូល។
ក្នុងន័យនេះ «ឫទ្ធានុភាព»
គឺសំដៅទៅលើព្រះជាម្ចាស់ដែលមានអំណាចលើទាំងអស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«បានរៀនពីរបៀបដែលព្រះជាម្ចាស់នឹងធ្វើការប្រកបដោយឫទ្ធានុភាពពេលអនាគត»

បែរជាធ្លាក់ខ្លួនបាត់ជំនឿទៅវិញ

ការបាត់បង់ភាពស្មោះត្រង់ចំពោះព្រះជាម្ចាស់ត្រូវបានគេនិយាយថា
ហាក់ដូចជាការធ្លាក់ចុះខាងរាងកាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់មកអ្នកដែលឈប់ជឿលើព្រះជាម្ចាស់»

គេមិនអាចនាំអ្នកនោះឲ្យកែប្រែចិត្តវិញបានទេ

«គឺមិនអាចទៅរួចទេក្នុងការនាំពួកគេត្រឡប់មកវិញដើម្បីប្រែចិត្តម្តងទៀត»

ពួកគេបានឆ្កាងព្រះបុត្រារបស់ព្រះជាម្ចាស់ និងខ្លួនគេផ្ទាល់ម្តងទៀត

នៅពេលមនុស្សងាកចេញពីព្រះជាម្ចាស់
គឺហាក់ដូចជាពួកគេឆ្កាងព្រះយេស៊ូម្តងទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាពួកគេបានឆ្កាងសំរាប់ព្រះរាជបុត្រានៃព្រះជាម្ចាស់ម្តងទៀត»

ព្រះបុត្រារបស់ព្រះជាម្ចាស់

នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូ
ដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះជាម្ចាស់។

Hebrews 6:7

ដីណាទទួលទឹកភ្លៀងញឹកញាប់

ដីស្រែដែលទទួលបានអត្ថប្រយោជន៍ពីទឹកភ្លៀងច្រើន ត្រូវបានគេនិយាយ
ដូចជាមនុស្សដែលផឹកទឹកភ្លៀង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដីដែលស្រូបយកទឹកភ្លៀង»

ដីនោះនឹងបង្កើតផលជារុក្ខជាតិ

ដីស្រែដែលផលិតដំណាំត្រូវបានគេនិយាយថា គឺការផ្តល់កំណើតដល់ពួកគេ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដែលផលិតរុក្ខជាតិ»

ដីនោះបង្កើតផល

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដល់អ្នកណាដែលបានរៀបចំដី»

គឺជាដីទទួលព្រះពរមកពីព្រះជាម្ចាស់

ទឹកភ្លៀង និងដំណាំត្រូវបានគេមើលឃើញថា ជាភស្តុតាងដែលបង្ហាញថា
ព្រះជាម្ចាស់បានជួយដល់ដីស្រែចំការ។ ដីចំការត្រូវបានគេនិយាយដូចជា
មនុស្សដែលអាចទទួលពរពីព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

ព្រះពរមកពីព្រះជាម្ចាស់
ត្រង់ថា «ព្រះពរ» មានន័យថា ការជួយពីព្រះជាម្ចាស់ មិនមែនដោយនិយាយទេ។
ហើយជិតត្រូវបណ្ដាសាទៀត
នេះនិយាយពី «បណ្ដាសា» ដូចជាកន្លែង ដែលមនុស្សអាចចូលទៅជិត។
របៀបផ្សេងទៀតនៃការបកប្រែ:
«នេះគឺជាគ្រោះថ្នាក់នៃបណ្ដាសារបស់ព្រះជាម្ចាស់»
គេនឹងយកវាទៅដុតចោល
ព្រះជាម្ចាស់នឹងធ្វើឲ្យអ្វីៗទាំងអស់ នៅចំការនោះឆេះ។
Hebrews 6:9
យើងជឿជាក់
ទោះបីជាអ្នកនិពន្ធប្រើសព្វនាមពហុវចន: «យើង» ក៏ដោយ
គឺភាគច្រើនគាត់សំដៅទៅលើតែខ្លួនគាត់ប៉ុណ្ណោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំជឿជាក់» ឬ «ខ្ញុំប្រាកដ»
លើអ្វីៗដែលនាំឲ្យបងប្អូន
នេះមានន័យថាពួកគេធ្វើបានល្អជាងអ្នកដែលបានបដិសេធព្រះជាម្ចាស់មិនស្ដាប់បង្គាប់ព្រះអង្គ
ហើយឥឡូវនេះមិនអាចប្រែចិត្តទៀតទេ ដូច្នេះព្រះជាម្ចាស់នឹងអត់ទោសឲ្យពួកគេ
(សូមមើល ៦:៤)។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកកំពុងធ្វើអ្វីៗប្រសើរជាងនោះ»
ទទួលការសង្គ្រោះ
នាមអរូបី «ការសង្គ្រោះ» អាចបញ្ជាក់ថាជាកិរិយាស័ព្ទ។
របៀបផ្សេងទៀតនៃការបកប្រែ:
«សំលេងដែលខ្ទរខ្ទាយពីព្រះជាម្ចាស់ជួយសង្គ្រោះអ្នក»
ដ្បិត ព្រះជាម្ចាស់ពុំមែនអយុត្តិធម៌ ដោយបំភ្លេចកិច្ចការ
ភាពអវិជ្ជមានពីរនេះអាចមានន័យថា
ព្រះជាម្ចាស់នៅក្នុងសេចក្ដីសុចរិតរបស់ព្រះអង្គនឹងចងចាំនូវអ្វីដែលល្អដែលប្រជាជនរបស់ព្រះអង្គបានធ្វើ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិតព្រះជាម្ចាស់យុត្តិធម៌
ដូច្នេះហើយព្រះអង្គនឹងនឹកចាំជានិច្ច»
ព្រះនាមព្រះអង្គ
«ព្រះនាម» របស់ព្រះជាម្ចាស់គឺជានាមដែលតំណាងឲ្យព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដ្បិតព្រះអង្គ»
Hebrews 6:11
យើងពិតជាមានបំណង
ទោះបីជាអ្នកនិពន្ធប្រើសព្វនាមពហុវចន: «យើង» ក៏ដោយ
គឺភាគច្រើនគាត់សំដៅទៅលើតែខ្លួនគាត់ប៉ុណ្ណោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំពិតជាមានបំណង»
ចិត្តខ្ជះខ្ជែង
ប្រុងប្រយ័ត្ន ការខិតខំធ្វើការងារ
រហូតដល់ទីបញ្ចប់
អត្ថន័យជាក់ស្ដែងបានបញ្ជាក់យ៉ាងច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដល់ទីបញ្ចប់នៃជីវិតរបស់អ្នក»
ប្រយោជន៍ផ្តល់ទំនុកចិត្តធានារ៉ាប់រងពេញលក្ខណៈ:
«ដើម្បីអោយប្រាកដថា ព្រះអង្គនឹងសំរេចតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ»
យកតម្រាប់តាម
ការ «យកតម្រាប់តាម» គឺអ្នកណាម្នាក់ដែលចំលងតាម
អាកប្បកិរិយារបស់អ្នកដទៃ។
ទទួលមរតក តាមព្រះបន្ទូលសន្យា
ការទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យាដល់អ្នកជឿត្រូវបានគេនិយាយ
ដូចជាការទទួលមរតកជាទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។
របៀបផ្សេងទៀតនៃការបកប្រែ: «ទទួលអ្វីដែលព្រះជាម្ចាស់បានសន្យា»
Hebrews 6:13
ព្រះអង្គមានព្រះបន្ទូល
ព្រះជាម្ចាស់មានព្រះបន្ទូល
ហើយក៏នឹងធ្វើឲ្យពូជពង្សរបស់អ្នកកើនចំនួនច្រើនឡើង
ត្រង់ថា «កើនចំនួនច្រើនឡើង» តំណាងឲ្យយកូនចៅ។
របៀបផ្សេងទៀតនៃការបកប្រែ: «យើងនឹងប្រទានឲ្យអ្នកមានកូនចៅជាច្រើន»
តាមព្រះបន្ទូលសន្យា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្វីដែលព្រះជាម្ចាស់បានសន្យាជាមួយគាត់»
Hebrews 6:16
ទទួលមរតកតាមព្រះបន្ទូលសន្យា
មនុស្សដែលព្រះជាម្ចាស់បានសន្យាចំពោះពួកគេ ត្រូវបានគេនិយាយថា
ពួកគេនឹងទទួលមរតកទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដល់អស់អ្នកណាដែលនឹងទទួលអ្វីដែលព្រះអង្គបានសន្យា»
ព្រះអង្គពុំប្រែប្រួលឡើយ ហើយព្រះអង្គធានាអះអាងដោយពាក្យសម្បថ
«ព្រះរាជបំណងរបស់ព្រះអង្គនឹងមិនផ្លាស់ប្តូរទេ» ឬ
«ព្រះអង្គតែងតែធ្វើតាមអ្វីដែលព្រះអង្គមានព្រះបន្ទូលជានិច្ច»
ដើម្បីឲ្យរបស់ពីរយ៉ាងពុំប្រែប្រួល
នេះគឺមានន័យថា ការសន្យារបស់ព្រះជាម្ចាស់ និងសម្បថរបស់ព្រះជាម្ចាស់។
ការទាំងពីរនេះមិនអាចផ្លាស់ប្តូរបានទេ។
គឺព្រះជាម្ចាស់ពុំចេះកុហក់ឡើយ
អវិជ្ជមានទ្វេដងនេះអាចមានន័យថា
ព្រះជាម្ចាស់នឹងប្រាប់ការពិតអំពីស្ថានភាពនេះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អំពីអ្នកដែលព្រះតែងតែមានព្រះបន្ទូលការពិត»
អ្នកដែលរត់ទៅរកទីជម្រក
អ្នកជឿដែលទុកចិត្តលើព្រះជាម្ចាស់ ដើម្បីការពារពួកគេអាចនិយាយ
ដូចជាពួកគេកំពុងរត់ទៅកន្លែងសុវត្ថិភាព។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងដែលបានជឿទុកចិត្តព្រះអង្គ»
នឹងទទួលបានការលើកទឹកចិត្ត ដើម្បីមានទំនុកចិត្តរឹងមាំនូវអ្វី ដែលព្រះអង្គបានដាក់នៅមុខយើង
ការជឿទុកចិត្តលើព្រះជាម្ចាស់អាចនិយាយបានថា ហាក់ដូចជា
ជំនឿជាវត្ថុមួយដែលអាចត្រូវបានបង្ហាញដល់មនុស្ស
ហើយមនុស្សនោះអាចកាន់ខ្ជាប់បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«នឹងបន្តទុកចិត្តលើព្រះជាម្ចាស់ដូចដែលព្រះអង្គបានលើកទឹកចិត្តឲ្យយើងធ្វើ»
ដែលបានដាក់នៅមុខយើង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលព្រះជាម្ចាស់បានដាក់នៅពីមុខយើង»
Hebrews 6:19
ប្រយោគភ្ជាប់៖
ដោយបានបញ្ចប់ការព្រមាន និងការលើកទឹកចិត្តលើកទីបីរបស់អ្នកនិព្វដល់អ្នកជឿ
អ្នកនិពន្ធកាន់គម្ពីរហេព្រើរនៅតែបន្តការប្រៀបធៀបរបស់គាត់អំពីព្រះយេស៊ូ
ជាបូជាចារ្យ ជាមួយមិលគីស្សាដែកជាបូជាចារ្យដែរ។
មានទំនុកចិត្តប្រកបដោយសុវត្ថិភាព និងប្រៀបបីដូចជាយុថ្កាខាងវិញ្ញាណ
ដូចយុថ្ការក្សាទូកមិនឲ្យរសាត់ក្នុងទឹក
នោះព្រះយេស៊ូការពារយើងឲ្យមានសុវត្ថិភាពនៅចំពោះព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «
ដែលបណ្ដាលឲ្យយើងរស់នៅដោយសុវត្ថិភាពនៅចំពោះព្រះជាម្ចាស់»
ទំនុកចិត្តប្រកបដោយសុវត្ថិភាព និងប្រៀបបីដូចជាយុថ្កា
ត្រង់ពាក្យថា «សុវត្ថិភាព» និង «ទំនុកចិត្ត» មានន័យថាជាមូលដ្ឋានដូចគ្នា
ហើយសង្កត់ធ្ងន់ទៅលើភាពជឿជាក់ពេញលេញនៃយុថ្កា។
របៀបផ្សេងទៀតនៃការបកប្រែ: «យុថ្កាដែលអាចទុកចិត្តបានទាំងស្រុង»
ដែលធ្វើឲ្យយើងចូលទៅហួសវាំងននទីសក្ការៈ
ភាពជឿជាក់ត្រូវបានគេនិយាយដូចជា
មនុស្សដែលអាចចូលទៅក្នុងទីបរិសុទ្ធបំផុតនៃព្រះវិហារ។
ចូលទៅហួស
នេះជាកន្លែងបរិសុទ្ធបំផុតនៅក្នុងព្រះវិហារ។ គឺត្រូវបានគេគិតថា
ជាកន្លែងដែលព្រះមានវត្តមានខ្លាំងជាងគេក្នុងចំណោមប្រជាជនរបស់ព្រះអង្គ។
នៅក្នុងអត្ថបទនេះកន្លែងនេះ តំណាងឲ្យឋានសួគ៌
និងបន្ទប់បល្ល័ង្ករបស់ព្រះជាម្ចាស់។
ទុកជាប្រយោជន៍ដល់យើង
ហេតុការណ៍ដែលថា ព្រះយេស៊ូបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ហើយឥឡូវនេះព្រះអង្គគង់នៅជាមួយព្រះជាម្ចាស់ ជាព្រះបិតាបង្ហាញថា
អ្នកដែលជឿលើព្រះអង្គនឹងជួបរឿងយ៉ាងនោះដែរ។
ព្រះយេស៊ូត្រូវបានគេនិយាយនៅទីនេះថា ដូចជាអ្នកដែលនាំមុខយើង
ដែលយើងកំពុងរត់តាមព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជាអ្នកដែលដើរនៅពីមុខយើង»
តាមរបៀបព្រះបាទម៉ិលគីស្សាដែក
នេះមានន័យថា
ព្រះគ្រិស្តជាបូជាចារ្យមានរឿងរ៉ាវដូចគ្នានឹងមិលគីស្សាដែកជាបូជាចារ្យដែរ។

generated on Wed Sep 10 16:16:32 2025

7 [1]ព្រះបាទម៉ិលគីស្សាដែក ជាមហាក្សត្រក្រុងសាឡិម ជាបូជាចារ្យរបស់ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ដែលបានជួបលោកអប្រាហាំ ក្រោយពេលលោកវាយឈ្នះស្តេចនានា
និងជូនពរលោក។[2]លោកអប្រាហាំបានថ្វាយមួយភាគដប់នៃអ្វីៗលោកមាន ដល់ព្រះបាទម៉ិលគីស្សាដែក។ ព្រះនាម «ម៉ិលគីស្សាដែក» មានន័យថា
«មហាក្សត្រនៃសេចក្តីសុចរិត»។ ព្រះអង្គមានគោរមងារ «មហាក្សត្រនៃក្រុងសាឡិម» គឺ «មហាក្សត្រនៃសេចក្តីសុខសាន្ត»។[3]ព្រះអង្គគ្មានព្រះមាតាបិតា គ្មានវង្សត្រកូល
គ្មានដើមកំណើត ក៏គ្មានចុងបញ្ចប់ដែរ។ ផ្ទុយទៅវិញ ព្រះអង្គដូចជាព្រះបុត្រាព្រះជាម្ចាស់ ព្រោះព្រះអង្គជាបូជាចារ្យជារៀងរហូត។
[4]ចូរពិចារណាមើលថាតើព្រះបាទម៉ិលគីស្សាដែកធំកម្រិតណា។ លោកអប្រាហាំជាបុព្វបុរសយើងថ្វាយតង្វាយមួយភាគដប់ ពីអ្វីៗដែលលោករឹបអូសបានពីសង្គ្រាម។
[5]ម្យ៉ាងវិញទៀត កូនៗរបស់លោកលេវី ដែលបានទទួលមុខងារជាបូជាចារ្យ ក៏បានទទួលបញ្ជាតាមក្រឹត្យវិន័យ ដើម្បីប្រមូលតង្វាយមួយភាគដប់ពីបណ្តាជន
គឺពីបងប្អូនពួកគេ ទោះបីជាពួកគេជាបងប្អូននឹងគ្នាកើតចេញពី ពូជពង្សលោកអប្រាហាំដូចគ្នា។[6]ប៉ុន្តែ ចំណែកឯព្រះបាទម៉ិលគីស្សាដែក
ដែលពុំជាប់សាច់ឈាមនឹងពួកគេ បានទទួលតង្វាយមួយភាគដប់ពីលោកអប្រាហាំ និងជូនពរលោក តាមព្រះបន្ទូលសន្យា។
[7]យើងពុំអាចប្រកែកបានទេថា អ្នកតូចទទួលពរពីអ្នកធំ។[8]នៅត្រង់ចំណុចនេះ មនុស្សដែលតែងតែស្លាប់ទទួលតង្វាយមួយភាគដប់ ប៉ុន្តែ
នៅត្រង់ចំណុចផ្សេងទៀតបញ្ជាក់ថា អ្នកនោះមានជីវិតរស់នៅ។[9]បើនិយាយពីរបៀបលោកលេវីវិញ លោកបានទទួលតង្វាយមួយភាគដប់
ហើយលោកក៏បានថ្វាយតង្វាយមួយភាគដប់តាមរយៈលោកអប្រាហាំវិញដែរ[10]ព្រោះលោកលេវីស្ថិតនៅក្នុងបុព្វបុរសលោក
ពេលព្រះបាទម៉ិលគីស្សាដែកជួបលោកអប្រាហាំ។
[11]ឥឡូវនេះ ប្រសិនបើមនុស្សបានគ្រប់លក្ខណ៍តាមរយៈមុខងារបូជាចារ្យរបស់លោកលេវីទៅហើយ (ដ្បិតមនុស្សបានទទួលក្រឹត្យវិន័យ
ពេលស្ថិតនៅក្រោមមុខងារបូជាចារ្យនេះ) តើគួរចាំបាច់ត្រូវមានមុខងារបូជាចារ្យណាមួយទៀត គឺរបៀបព្រះបាទម៉ិលគីស្សាដែកធ្វើអ្វី?
ហេតុអ្វីមិនគិតពីបូជាចារ្យតាមរបៀបលោកអើរ៉ុនទៅ?[12]ដ្បិតកាលណាមានការផ្លាស់ប្តូររបៀបបូជាចារ្យ នោះក៏ត្រូវមានការផ្លាស់ប្តូរក្រឹត្យវិន័យដែរ?
[13]ដ្បិតម្នាក់ដែលមានចែងក្នុងអត្ថបទនេះ ស្ថិតក្នុងកុលសម្ព័ន្ធមួយផ្សេងទៀត ពុំដែលមាននរណាម្នាក់ធ្លាប់បម្រើនៅលើអាសនៈឡើយ។[14]ឥឡូវនេះ មានចែងច្បាស់ថា
លោកកើតចេញពីកុលសម្ព័ន្ធយូដា ដែលព្រះអម្ចាស់បានប្រសូតមក គឺជាកុលសម្ព័ន្ធមួយ ដែលលោកម៉ូសេពុំដែលបាននឹកនាដល់ អំពីរបៀបបូជាចារ្យ។
[15]សេចក្តីដែលយើងបាននិយាយយ៉ាងច្បាស់ ប្រសិនបើ មានរបៀបបូជាចារ្យមួយផ្សេងទៀត តាមរបៀបព្រះបាទម៉ិលគីស្សាដែក។
[16]មុខងារបូជាចារ្យនេះមិនស្ថិតលើមូលដ្ឋានគ្រឹះក្រឹត្យវិន័យរបស់មនុស្ស ផ្ទុយទៅវិញមុខងារបូជាចារ្យនេះ ស្ថិតនៅលើឫទ្ធានុភាពនៃជីវិតមិនចេះសាបសូន្យឡើយ។[17]ដ្បិត
ព្រះគម្ពីរធ្វើបន្ទាល់អំពីព្រះអង្គ៖ «ព្រះអង្គជាបូជាចារ្យអស់កល្បជានិច្ច តាមរបៀបព្រះបាទម៉ិលគីស្សាដែក»។
[18]បទបញ្ជាពីមុនត្រូវបានលុបចោលហើយ ព្រោះវាទន់ខ្សោយ និងគ្មានប្រយោជន៍ទៀតទេ។[19]ដ្បិត ក្រឹត្យវិន័យពុំបានធ្វើឲ្យអ្វីៗបានគ្រប់លក្ខណៈឡើយ។ ផ្ទុយទៅវិញ
យើងមានទំនុកចិត្តប្រសើរជាងមុន នាពេលអនាគត ដែលនាំយើងឲ្យចូលជិតព្រះជាម្ចាស់។
[20]ព្រះអង្គពុំបានទទួលមុខងារជាបូជាចារ្យដោយគ្មានសម្បថឡើយ។ រីឯង អ្នកខ្លះបានទទួលមុខងារជាបូជាចារ្យដោយគ្មានសម្បថ។[21]លើសពីនេះ ព្រះយេស៊ូវិញ
បានទទួលមុខងារជាបូជាចារ្យ ដោយព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «ព្រះអម្ចាស់បានស្បថ ហើយព្រះអង្គពុំប្រែប្រួលសោះឡើយ។
ព្រះអង្គជាបូជាចារ្យនៅអស់កល្បជានិច្ច»។
[22]ដោយសារហេតុនេះហើយ បានជាព្រះយេស៊ូធានានូវសម្ពន្ធមេត្រីប្រសើរជាងមុន។[23]ម្យ៉ាងវិញទៀត មានមនុស្សជាច្រើនបំពេញមុខងារជាបូជាចារ្យ
តែពួកគេតែងតែស្លាប់ដោយពុំអាចបំពេញរហូតបានទេ។[24]លើសពីនេះទៅទៀត ដោយសារព្រះយេស៊ូគង់នៅអស់កល្បជានិច្ច
ព្រះអង្គបំពេញមុខជាបូជាចារ្យអស់កល្បជានិច្ច។
[25]ដូច្នេះ ព្រះអង្គអាចសង្គ្រោះពេញទីដល់អស់អ្នកណា ដែលចូលមករកព្រះជាម្ចាស់តាមរយៈព្រះអង្គ ព្រោះព្រះអង្គតែងទូលអង្វរព្រះជាម្ចាស់ជំនួសពួកគេ។
[26]យើងមានមហាបូជាចារ្យដ៏ប្រសើរមួយអង្គ។ ព្រះអង្គគ្មានបាប ឥតសៅហ្មង បរិសុទ្ធ ចេញឆ្ងាយពីអំពើបាប និងគង់នៅខ្ពស់ជាងស្ថានបរមសុខ។
[27]ពុំដូចជាបូជាចារ្យដទៃទៀតឡើយ ព្រះអង្គពុំចាំបាច់ត្រូវថ្វាយតង្វាយប្រចាំថ្ងៃ ដើម្បីលោះបាបផ្ទាល់ខ្លួន និងតង្វាយលោះបាបជំនួសប្រជាជនអ៊ីស្រាអែលទេ។
ព្រះអង្គថ្វាយអង្គទ្រង់ជាតង្វាយលោះបាប ម្តងជាសម្រេច។[28]ដ្បិតក្រឹត្យវិន័យតែងតាំងបូជាចារ្យជាមនុស្ស ដែលទន់ខ្សោយ។ ប៉ុន្តែ
ព្រះបន្ទូលសម្បថមកក្រោយក្រឹត្យវិន័យបានតែងតាំងព្រះបុត្រា ដែលគ្រប់លក្ខណ៍ជារៀងរហូត។

Hebrews 7:1

ប្រយោគភ្ជាប់៖

អ្នកនិពន្ធកាន់គម្ពីរហេព្រើរបន្តប្រៀបធៀបព្រះយេស៊ូជាបូជាចារ្យជាមួយបូជាចារ្យម៉ិលគីស្សាដែក

ក្រុងសាឡិម

នេះគឺជាឈ្មោះនៃទីក្រុងមួយ។

ដែលបានជួបលោកអប្រាហាំ ក្រោយពេលលោកវាយឈ្នះស្តេចនានា

នេះគឺសំដៅទៅលើពេល ដែលអប្រាហាំ
និងមនុស្សរបស់គាត់បានចេញទៅវាយយកកងទ័ពរបស់ស្តេចបួនអង្គ
ដើម្បីជួយសង្គ្រោះក្មួយប្រុសឡុត និងគ្រួសាររបស់គាត់។

សម្រាប់លោក

«សម្រាប់លោកម៉ិលគីស្សាដែក»

មហាក្សត្រនៃសេចក្តីសុចរិត...មហាក្សត្រនៃសេចក្តីសុខសាន្ត

«ស្តេចដ៏សុចរិត...ស្តេចប្រកបដោយសន្តិភាព»

ព្រះអង្គគ្មានព្រះមាតាបិតា គ្មានវង្សត្រកូល គ្មានដើមកំណើត ក៏គ្មានចុងបញ្ចប់ដែរ

យើងអាចគិតពីអត្ថបទនេះ យើងមិនបានដឹងថា ម៉ិលគីស្សាដែក កើតពេលណា
ឬស្លាប់ពេលណានោះទេ។ ទោះយ៉ាងណាគឺមើលទៅអ្នកនិពន្ធទាំងអស់មានន័យថា
បទគម្ពីរមិនមានព័ត៌មានអំពីកំណើតជីដូនជីតា ឬមរណភាពរបស់ម៉ិលគីស្សាដែក។

Hebrews 7:4

ប្រយោគភ្ជាប់៖

អ្នកនិពន្ធបាននិយាយថា
បព្វជិតភាពរបស់ម៉ិលគីស្សាដែកគឺប្រសើរជាងបព្វជិតភាពរបស់អើរ៉ុន
ហើយបន្ទាប់មករំលឹកពួកគេថា
បព្វជិតភាពរបស់អើរ៉ុនមិនបានធ្វើឲ្យអ្វីគ្រប់យ៉ាងល្អឥតខ្ចោះទេ។

ព្រះបាទម៉ិលគីស្សាដែកធំកម្រិតណា

ស្សាដែកម៉ិលគីស្សាដែកធំកម្រិតណា»

ម្យ៉ាងវិញទៀត...ប៉ុន្តែ ចំណែកឯ

ឃ្លាទាំងនេះត្រូវបានប្រើដើម្បីប្រៀបធៀបរឿងពីរ។
ភាសារបស់អ្នកអាចមានវិធីដើម្បីបញ្ជាក់ថា អ្នកនិពន្ធកំពុងធ្វើការប្រៀបធៀប។
ឬអ្នកអាចទុក «ម្យ៉ាងវិញទៀត» និងបកប្រែ «ប៉ុន្តែ ចំណែកឯ» គ្រាន់តែជា
«ប៉ុន្តែ»។

កូនៗរបស់លោកលេវី ដែលបានទទួលមុខងារជាបូជាចារ្យ

អ្នកនិពន្ធនិយាយបែបនេះពីព្រោះមិនមែនកូនប្រុសទាំងអស់របស់លេវីក្លាយជាបូជាចារ្យទេ។
របៀបផ្សេងទៀតនៃការបកប្រែ: «កូនចៅលេវីដែលបានក្លាយជាបូជាចារ្យ»

ពីបងប្អូន

«ពីប្រជាជនអ៊ីស្រាអែល»

ជាបងប្អូននឹងគ្នា

ត្រង់ថា «បងប្អូន»
មានន័យថាពួកគេទាំងអស់មានទំនាក់ទំនងជាមួយគ្នាតាមរយៈលោកអប្រាហាំ។
របៀបផ្សេងទៀតនៃការបកប្រែ: «មកពីសាច់ញាតិរបស់ពួកគេ»

ពួកគេជាបងប្អូននឹងគ្នាកើតចេញពី ពូជពង្សលោកអប្រាហាំ

នេះគឺជារបៀបនៃការនិយាយថា ពួកគេជាកូនចៅរបស់អប្រាហាំ។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេក៏ជាកូនចៅរបស់អ័ប្រាហាំដែរ»

ដែលពុំជាប់សាច់ឈាមនឹងពួកគេ

«ដែលមិនមែនជាកូនចៅលេវី»

generated on Wed Sep 10 16:16:32 2025

តាមព្រះបន្ទូលសន្យា
អ្វីដែលព្រះជាម្ចាស់បានសន្យាថានឹងធ្វើសម្រាប់អប្រាហាំត្រូវបានគេនិយាយ
ដូចជាវត្ថុដែលគាត់អាចមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលព្រះជាម្ចាស់បានសន្យានឹងគាត់»
Hebrews 7:7
អ្នកតូចទទួលពរពីអ្នកធំ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សសំខាន់ជាង អោយពរដល់មនុស្សដែលមិនសូវសំខាន់»
នៅត្រង់ចំណុចនេះ...នៅត្រង់ចំណុចផ្សេងទៀត
ឃ្លាទាំងនេះត្រូវបានប្រើដើម្បីប្រៀបធៀបពួកលេវីជាមួយនឹងម៉ិលគីស្សាដែក។
ក្នុងភាសារបស់អ្នកអាចមានវិធីដើម្បីបញ្ជាក់ថា អ្នកនិពន្ធកំពុងធ្វើការប្រៀបធៀប។
បញ្ជាក់ថា អ្នកនោះមានជីវិតរស់នៅ
គឺនៅក្នុងបទគម្ពីរ
មិនដែលបានសរសេរអំពីការស្លាប់របស់ម៉ិលគីស្សាដែកបានជាក់លាក់នោះទេ។
អ្នកនិពន្ធកាន់គម្ពីរហេព្រើរនិយាយ
ពីអវត្តមាននៃព័ត៌មានអំពីមរណភាពរបស់ម៉ិលគីស្សាដែក នៅក្នុងបទគម្ពីរ
ហាក់ដូចជាសេចក្តីថ្លែងការណ៍វិជ្ជមាន ដែលថាគាត់នៅរស់នៅឡើយ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បទគម្ពីរបង្ហាញថាគាត់រស់នៅ»
លោកលេវី...ស្ថិតនៅក្នុងបុព្វបុរសរបស់លោក
ចាប់តាំងពីលេវីមិនទាន់បានកើតមក អ្នកនិពន្ធនិយាយអំពីគាត់ថា
គាត់នៅតែមាននៅក្នុងខ្លួនរបស់អប្រាហាំ។ តាមរបៀបនេះអ្នកនិពន្ធអះអាងថា
លេវីបានបង់មួយភាគដប់ ដល់ម៉ិលគីស្សាដែកតាមរយៈអប្រាហាំ។
Hebrews 7:11
ឥឡូវនេះ
នេះមិនមានន័យថា «នៅពេលនេះ» ទេ
ប៉ុន្តែត្រូវបានប្រើដើម្បីយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ដែលនៅខាងក្រោម។
តើគួរចាំបាច់ត្រូវមានមុខងារបូជាចារ្យណាមួយទៀត គឺរបៀបព្រះបាទមិ្លគីស្សាដែកធ្វើអ្វី?
ហេតុអ្វីមិនគិតពីបូជាចារ្យតាមរបៀបលោកអើរ៉ុនទៅ?
សំណួរនេះសង្កត់ធ្ងន់ថា
មិននឹកស្មានដល់ទេដែលថាបូជាចារ្យមកបន្ទាប់ពីមិលគីស្សាដែក។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាម្នាក់ត្រូវការបូជាចារ្យផ្សេងទៀត
អ្នកដែលដូចជាម៉ិលគីស្សាដែក និងមិនដូចលោកអើរ៉ុន
ដើម្បីក្រោកឈរឡើងនោះទេ»
ដើម្បីក្រោកឡើង
«មក» ឬ «បង្ហាញខ្លួន»
គឺរបៀបព្រះបាទមិ្លគីស្សាដែក
នេះមានន័យថា
ព្រះគ្រិស្តជាបូជាចារ្យមានរឿងរ៉ាវដូចគ្នានឹងមិលគីស្សាដែកជាបូជាចារ្យដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «តាមរបៀបម៉ិលគីស្សាដែកជាបូជាចារ្យ»
មិនគិតពីបូជាចារ្យតាមរបៀបលោកអើរ៉ុន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«កុំធ្វើតាមគំរូរបស់អើរ៉ុន» ឬ «អ្នកដែលមិនមែនជាបូជាចារ្យដូចលោកអើរ៉ុន»
ដ្បិតកាលណាមានការផ្លាស់ប្តូររបៀបបូជាចារ្យ នោះក៏ត្រូវមានការផ្លាស់ប្តូរក្រឹត្យវិន័យដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រោះនៅពេលដែលព្រះជាម្ចាស់បានផ្លាស់ប្តូរបព្វជិតភាពព្រះអង្គក៏ត្រូវផ្លាស់ប្តូរច្បាប់ដែរ»
Hebrews 7:13
ដ្បិតម្នាក់ដែល
សំដៅទៅលើព្រះយេស៊ូ។
ដែលមានចែងក្នុងអត្ថបទនេះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អំពីនរណាដែលខ្ញុំកំពុងនិយាយ»
ឥឡូវនេះ
នេះមិនមានន័យថា «នៅពេលនេះ»ទេ
ប៉ុន្តែត្រូវបានប្រើដើម្បីយកចិត្តទុកដាក់ទៅចំណុចសំខាន់ដែលនៅខាងក្រោម។
លោកកើតចេញពីកុលសម្ព័ន្ធយូដា ដែលព្រះអម្ចាស់បានប្រសូតមក
ពាក្យថា «ព្រះអម្ចាស់» សំដៅទៅលើព្រះយេស៊ូ។
ចេញពីកុលសម្ព័ន្ធយូដា
«ពីកុលសម្ព័ន្ធយូដា»
Hebrews 7:15
ព័ត៌មានទូទៅ៖
ការដកស្រង់នេះចេញមកពីទំនុកតម្កើងរបស់ស្តេចដាវីឌ។
សេចក្តីដែលយើងបាននិយាយយ៉ាងច្បាស់
«យើងអាចយល់កាន់តែច្បាស់ថែមទៀត»។ ត្រង់ថា «យើង» សំដៅលើអ្នកនិពន្ធ
និងអ្នកស្តាប់របស់លោក។
ប្រសិនបើ មានរបៀបបូជាចារ្យមួយផ្សេងទៀត
«ប្រសិនបើបូជាចារ្យមួយទៀតមក»
តាមរបៀបព្រះបាទមិ្លគីស្សាដែក
នេះមានន័យថា ព្រះគ្រិស្តជាបូជាចារ្យមានរឿងរ៉ាវដូចគ្នានឹងមិលគីស្សាដែកដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «តាមរបៀបម៉ិលគីស្សាដែកជាបូជាចារ្យ»
ស្ថិតលើមូលដ្ឋានគ្រឹះក្រឹត្យវិន័យរបស់មនុស្ស
គំនិតនៃដើមកំណើតមនុស្សត្រូវបានគេនិយាយ
គឺគ្រាន់តែទាក់ទងនឹងសាច់ឈាមនៃរាងកាយរបស់មនុស្សម្នាក់ប៉ុណ្ណោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «ផ្អែកលើមូលដ្ឋាននៃច្បាប់អំពីថា
តើក្រុមគ្រួសាររបស់គាត់ជានរណា»
ផ្ទុយទៅវិញមុខងារបូជាចារ្យនេះ ស្ថិតនៅលើឫទ្ធានុភាពនៃជីវិតមិនចេះសាបសូន្យឡើយ
ឃ្លាថា «គាត់បានក្លាយជាបូជាចារ្យ» គឺយល់បាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប៉ុន្តែផ្ទុយទៅវិញគាត់បានក្លាយជាបូជាចារ្យផ្អែកលើអំណាចនៃជីវិតរបស់គាត់ដែលមិនចេះចប់»
ដ្បិត ព្រះគម្ពីរធ្វើបន្ទាល់អំពីព្រះអង្គ
នេះគឺនិយាយអំពីបទគម្ពីរហាក់ដូចជាមនុស្សម្នាក់ដែលអាចធ្វើជាសាក្សីអំពីអ្វីមួយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ចំពោះព្រះជាម្ចាស់ដែលធ្វើបន្ទាល់អំពីព្រះអង្គតាមរយៈបទគម្ពីរ»
តាមរបៀបព្រះបាទមិ្លគីស្សាដែក
នេះមានន័យថា ព្រះគ្រិស្តជាបូជាចារ្យមានរឿងរ៉ាវដូចគ្នានឹងមិលគីស្សាដែកដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «តាមរបៀបម៉ិលគីស្សាដែកជាបូជាចារ្យ»
Hebrews 7:18
បទបញ្ជាពីមុនត្រូវបានលុបចោលហើយ
«ព្រះជាម្ចាស់បានបង្កើតបញ្ញត្តិមិនត្រឹមត្រូវតាំងពីដើមមក»
ក្រឹត្យវិន័យពុំបានធ្វើឲ្យអ្វីៗបានគ្រប់លក្ខណៈឡើយ
ច្បាប់នេះត្រូវបានគេនិយាយថា ជាមនុស្សដែលអាចធ្វើ សកម្មភាពបាន។
មានទំនុកចិត្តប្រសើរជាងមុន
«ព្រះជាម្ចាស់បានផ្តល់ហេតុផលដ៏ប្រសើរសម្រាប់យើងក្នុងការមានទំនុកចិត្ត»
មានទំនុកចិត្តប្រសើរជាងមុន នាពេលអនាគត ដែលនាំយើងឲ្យចូលជិតព្រះជាម្ចាស់
មានទំនុកចិត្តចំពោះអនាគតត្រូវបានគេនិយាយដូចជា
វត្ថុដែលមនុស្សម្នាក់ត្រូវតែដើរ ដើម្បីចូលទៅជិតព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះជាម្ចាស់បានផ្តល់ហេតុផលល្អប្រសើរជាងមុន
ដើម្បីឲ្យយើងមានទំនុកចិត្តលើព្រះអង្គពីព្រោះព្រះអង្គធ្វើឲ្យយើងមានលទ្ធភាពចូលទៅជិតព្រះអង្គ» (UDB
យើងចូលជិតព្រះជាម្ចាស់
ការថ្វាយបង្គំព្រះជាម្ចាស់ និងទទួលការពេញចិត្តពីព្រះត្រូវបានគេនិយាយថា
ជាសកម្មភាពដែលត្រូវចូលទៅជិតព្រះអង្គ។
Hebrews 7:20
ព័ត៌មានទូទៅ៖
ការដកស្រង់នេះក៏ចេញមកពីទំនុកតម្កើងរបស់ដាវីឌដូច ក្នុងខ១៧ ដែរ។
(សូមមើល: ៧:១៥)
ព្រះអង្គពុំបានទទួលមុខងារជាបូជាចារ្យដោយគ្មានសម្បថឡើយ
សកម្មភាពការស្បថអាចនិយាយ ដោយមិននិយាយថានរណាបានស្បថឡើយ។
ទោះជាយ៉ាងណាក៏ដោយគឺជាព្រះជាម្ចាស់។
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«រឿងនេះបានកើតឡើងពីព្រោះព្រះជាម្ចាស់បានស្បថ»
ដោយព្រះជាម្ចាស់មានព្រះបន្ទូលថា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
ពីព្រោះព្រះជាម្ចាស់បានស្បថចំពោះគាត់ដោយមានព្រះបន្ទូលថា»
Hebrews 7:22
ប្រយោគភ្ជាប់៖
បន្ទាប់មកអ្នកនិពន្ធបានអះអាងដល់អ្នកជឿជនជាតិយូដាទាំងនេះថា
ព្រះគ្រិស្តមានបព្វជិតភាពប្រសើរជាងមុនពីព្រោះព្រះអង្គមានព្រះជន្មជារៀងរហូត
ហើយបូជាចារ្យដែលមកពីកូនចៅអើរ៉ុនបានស្លាប់។
ធានា

generated on Wed Sep 10 16:16:32 2025

«ការធានា» ឬ «ភាពប្រាកដប្រជា»
ម្យ៉ាងវិញទៀត...លើសពីនេះទៅទៀត
ឃ្លាទាំងនេះត្រូវបានប្រើដើម្បីប្រៀបធៀបរឿងពីរ។
ភាសារបស់អ្នកអាចមានវិធីដើម្បីបញ្ជាក់ថា អ្នកនិពន្ធកំពុងធ្វើការប្រៀបធៀប។
ឬអ្នកអាចទុកទីមួយ «ម្យ៉ាងវិញទៀត» និងបកប្រែទីពីរ «លើសពីនេះទៅទៀត»
គ្រាន់តែជា «ប៉ុន្តែ»។
តែពួកគេតែងតែស្លាប់ដោយពុំអាចបំពេញរហូតបានទេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ទីបំផុតពួកគេស្លាប់ហើយមិនអាចបន្តទៅមុខទៀតបានទេ»
ព្រះអង្គបំពេញមុខជាបូជាចារ្យអស់កល្បជានិច្ច
ការងាររបស់បូជាចារ្យត្រូវបានគេនិយាយដូចជា វត្ថុដែលព្រះយេស៊ូមាន។
នេះអាចត្រូវបានគេនិយាយដោយជឿសវាងគំនិតអរូបី។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គជាបូជាចារ្យជារៀងរហូត»
Hebrews 7:25
ដូច្នេះ
អ្នកអាចធ្វើឲ្យច្បាស់នូវអ្វីដែល «ដូច្នេះ» បង្កប់ន័យ។ ពីព្រោះព្រះគ្រិស្ត
គឺជាសម្តេចសង្ឃរបស់យើងដែលមានព្រះជន្មជារៀងរហូត»
ដែលចូលមករកព្រះជាម្ចាស់តាមរយៈព្រះអង្គ
«អ្នកដែលចូលមកឯព្រះជាម្ចាស់ ដោយសារអ្វីដែលព្រះយេស៊ូបានធ្វើ»
និងគង់នៅខ្ពស់ជាងស្ថានបរសមុខ
«ហើយព្រះជាម្ចាស់បានលើកគាត់ឡើងទៅស្ថានខ្ពស់បំផុត»។
អ្នកនិពន្ធនិយាយពីកិត្តិយស និងអំណាចច្រើនជាងអ្នកដទៃទៀត
ដូចជាឋានៈខ្ពស់ជាងអ្វីៗទាំងអស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយព្រះជាម្ចាស់បានផ្តល់ឲ្យគាត់នូវកិត្តិយស និងអំណាចច្រើនជាងអ្នកដទៃ»
Hebrews 7:27
ព័ត៌មានទូទៅ៖
ត្រង់ពាក្យថា «ព្រះអង្គ» និង «អង្គទ្រង់» សំដៅទៅលើព្រះយេស៊ូ។ ពាក្យ
«របស់ព្រះអង្គ» សំដៅទៅលើសម្តេចសង្ឃជាន់ខ្ពស់នៅលើផែនដី។
ក្រឹត្យវិន័យតែងតាំង
ត្រង់ថា «ក្រឹត្យវិន័យ»
គឺជាពាក្យប្រៀបធៀបដែលតំណាងព្រះដែលបានបង្កើតច្បាប់។
បើយោងតាមច្បាប់ដែលជនជាតិអ៊ីស្រាអែលបានតែងតាំងបូជាចារ្យរបស់ពួកគេ។
ជាមនុស្ស ដែលទន់ខ្សោយ
«បុរសដែលខ្សោយខាងវិញ្ញាណ» ឬ «បុរសដែលទន់ខ្សោយប្រឆាំងនឹងអំពើបាប»
ព្រះបន្ទូលសម្បថមកក្រោយក្រឹត្យវិន័យបានតែងតាំងព្រះបុត្រា
នេះអាចត្រូវបានប្រើឡើងវិញដូច្នេះនាមអរូបី «ព្រះបន្ទូល»
ត្រូវបានបង្ហាញជាកិរិយាស័ព្ទ «ស្បថ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់ពីគាត់បានផ្តល់ច្បាប់ព្រះជាម្ចាស់បានស្បថ
ហើយបានតែងតាំងព្រះបុត្រារបស់ព្រះអង្គ»
ព្រះបន្ទូលសម្បថ
ពាក្យ «សម្បថ» មានលក្ខណៈ
និងការបង្ហាញដូចជាមនុស្សម្នាក់ដែលបាននិយាយ។
ព្រះបុត្រា
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះជាម្ចាស់។
ដែលគ្រប់លក្ខណ៍ជារៀងរហូត
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបានស្តាប់បង្គាប់ព្រះជាម្ចាស់ទាំងស្រុង ហើយក្លាយជាមនុស្សចាស់ទុំ»

---

8 [1]ចំណុចសំខាន់ដែលយើងកំពុងតែបរិយាយនេះគឺថា យើងមានមហាបូជាចារ្យមួយរូប ដែលបានគង់នៅខាងស្តាំបល្ល័ង្កនៃព្រះដ៏ខ្ពង់ខ្ពស់បំផុតគង់នៅស្ថានបរមសុខ។
[2]ព្រះអង្គជាអ្នកបម្រើនៅក្នុងទីសក្ការៈ និងជាព្រះពន្លាដែលព្រះអម្ចាស់បានសាងសង់ឡើង ពុំមែនសង់ដោយដៃមនុស្សទេ។
[3]ដ្បិត មហាបូជាចារ្យគ្រប់រូបទទួលការតែងតាំងឲ្យបំពេញមុខងារថ្វាយតង្វាយ និងយញ្ញបូជាផ្សេងៗ។ ដូច្នេះ ពួកលោកត្រូវតែមានតង្វាយចាំបាច់ថ្វាយដល់ព្រះជាម្ចាស់។
[4]ឥឡូវនេះ បើព្រះគ្រិស្តគង់នៅលើផែនដី ព្រះអង្គពុំមែនជាបូជាចារ្យទេ ព្រោះមានអ្នកថ្វាយតង្វាយរួចហើយ ស្របតាមក្រឹត្យវិន័យ។[5]ពួកលោកបម្រើនៅក្នុងព្រះពន្លា
ដែលជាគំរូ និងស្រមោលនៃពិធីផ្សេងៗនៅស្ថានបរមសុខ។ ដូចជាព្រះជាម្ចាស់បានព្រមានដល់លោកម៉ូសេ ពេលលោករៀបនឹងសង់ព្រះពន្លាថា៖ «ចូរ
ប្រយ័ត្ននូវអ្វីដែលអ្នកត្រូវសង់ ដោយយកគម្រូតាមការបង្ហាញនៅលើភ្នំចុះ»។
[6]ប៉ុន្តែឥឡូវនេះ ព្រះគ្រិស្តបានទទួលព័ន្ធកិច្ចប្រសើរជាងមុន។ គឺព្រះអង្គជាស្ពាននៃសម្ពន្ធមេត្រីប្រសើរជាងមុន ដែលចងឡើងព្រះបន្ទូលសន្យាប្រសើរជាង។
[7]ដ្បិតប្រសិនបើសម្ពន្ធមេត្រីទីមួយគ្មានកំហុស នោះពុំចាំបាច់មានសម្ពន្ធមេត្រីទីពីរទេ។
[8]ដ្បិត ពេលព្រះជាម្ចាស់រកឃើញថាប្រជាជនមានកំហុស នោះព្រះអង្គមានព្រះបន្ទូលថា៖ «មើល ថ្ងៃជិតមកដល់ហើយ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
យើងនឹងចងសម្ពន្ធមេត្រីមួយថ្មី ជាមួយនឹងពូជពង្សអ៊ីស្រាអែល និងយូដា។[9]វាមិនដូចសម្ពន្ធមេត្រីមុន ដែលយើងបានចងឡើងជាមួយបុព្វបុរសរបស់ពួកគេ
គឺនៅថ្ងៃយើងដឹកដៃពួកគេចេញពីប្រទេសអេស៊ីប។ ដ្បិតពួកគេពុំបានរក្សាសម្ពន្ធមេត្រីរបស់យើងឡើយ ដូច្នេះ យើងក៏លែងរវីរវល់ជាមួយពួកគេដែរ
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
[10]ដ្បិត នេះជាសម្ពន្ធមេត្រី ដែលយើងនឹងចងជាមួយប្រជាជនអ៊ីស្រាអែល បន្ទាប់ពីថ្ងៃនោះកន្លងផុតទៅ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។
យើងនឹងចារក្រឹត្យវិន័យយើងក្នុងគំនិត ហើយយើងចារក្រឹត្យវិន័យទាំងនោះក្នុងដួងចិត្តពួកគេផងដែរ។ យើងធ្វើជាព្រះជាម្ចាស់ពួកគេ
ហើយពួកគេនឹងធ្វើជាប្រជារាស្ត្ររបស់យើង។
[11]ពួកគេលែងបង្រៀនអ្នកជិតខាង និងបង្រៀនបងប្អូនទៅវិញទៅមក ដោយនិយាយថា៖ «ចូរស្គាល់ព្រះអម្ចាស់ ដ្បិតមនុស្សគ្រប់គ្នានឹងស្គាល់យើង
ពីអ្នកតូចបំផុត[12]រហូតដល់អ្នកធំបំផុត។ ដ្បិត យើងនឹងផ្តល់ក្តីមេត្តា ចំពោះអំពើទុច្ចរិតដែលគេបានប្រព្រឹត្ត ហើយយើងនឹងមិននឹកចាំពីអំពើបាបពួកគេទៀតទេ»។
[13]ដោយព្រះអម្ចាស់មានព្រះបន្ទូលថា សម្ពន្ធមេត្រីនេះជាសម្ពន្ធមេត្រី «ថ្មី» ដូច្នេះសម្ពន្ធមេត្រីទីមួយជាសម្ពន្ធមេត្រីចាស់ ហើយអ្វីដែលកាន់តែចាស់ទៅៗនោះ នឹងត្រូវសាប
សូន្យមិនខាន។

Hebrews 8:1
ប្រយោគភ្ជាប់៖
អ្នកនិពន្ធបានបង្ហាញថាបព្វជិតភាពរបស់ព្រះគ្រិស្តប្រសើរជាងបព្វជិតភាពនៅលើផែនដី[1]
ហើយបព្វជិតភាពនៅលើផែនដី គឺជាគំរូនៃអ្វីៗនៅស្ថានសួគ៌។
ព្រះគ្រីស្ទមានកិច្ចបំរើដ៏ខ្ពង់ខ្ពស់ និងសេចក្តីសញ្ញាខ្ពង់ខ្ពស់។
បរិយាយនេះ
នេះមិនមានន័យថា «នៅពេលនេះ» ទេ
ប៉ុន្តែត្រូវបានប្រើដើម្បីយកចិត្តទុកដាក់ទៅចំណុចសំខាន់ដែលនៅខាងក្រោម។
យើងកំពុងតែនិយាយ
ទោះបីជាអ្នកនិពន្ធប្រើសព្វនាមពហុវចន: «យើង» ក៏ដោយ
ភាគច្រើនគឺគាត់សំដៅទៅលើតែខ្លួនគាត់ប៉ុណ្ណោះ។របៀបផ្សេងទៀតនៃការបកប្រែ:
«ខ្ញុំកំពុងនិយាយ» ឬ «ខ្ញុំកំពុងសរសេរ»
ដែលបានគង់នៅខាងស្តាំ
ត្រង់ថា «នៅខាងស្តាំ» សំដៅទៅលើទីកន្លែងកិត្តិយស។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រះអង្គគង់នៅទីកន្លែងកិត្តិយស»។
[1]សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះក្នុងជំពូក ១:១។
បល្ល័ង្កនៃព្រះដ៏ខ្ពង់ខ្ពស់
ត្រង់ថា «ព្រះដ៏ខ្ពង់ខ្ពស់» សំដៅទៅលើព្រះជាម្ចាស់ ហើយ «បល្ល័ង្ក»
សំដៅទៅលើការគ្រប់គ្រងរបស់ព្រះជាម្ចាស់ដូចជាស្តេច។
របៀបផ្សេងទៀតនៃការបកប្រែ: «នៃព្រះដែលជាស្តេចដ៏អស្ចារ្យរបស់យើង»
ជាព្រះពន្លាដែលព្រះអម្ចាស់បានសាងសង់ឡើង ពុំមែនសង់ដោយដៃមនុស្សទេ
មនុស្សបានសង់ត្រសាលនៅលើផែនដី ចេញពីស្បែកសត្វភ្ជាប់ទៅនឹងគ្រោងឈើ
ហើយពួកគេរៀបចំឡើងតាមរបៀបនៃតង់។ ត្រង់នេះ «ឧបោសថ»
មានន័យថារោងព្រះពន្លានៅស្ថានសួគ៌ដែលព្រះជាម្ចាស់បានបង្កើត។
Hebrews 8:3
ដ្បិត មហាបូជាចារ្យគ្រប់រូបទទួលការតែងតាំងឲ្យ

generated on Wed Sep 10 16:16:32 2025

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ត្បិតព្រះជាម្ចាស់តែងតាំងបូជាចារ្យគ្រប់ៗរូប»
ឥឡូវនេះ
នេះមិនមានន័យថា «នៅពេលនេះ» ទេ
ប៉ុន្តែត្រូវបានប្រើដើម្បីយកចិត្តទុកដាក់ទៅចំណុចសំខាន់ដែលនៅខាងក្រោម។
ស្របតាមក្រឹត្យវិន័យ
«ដូចជាព្រះជម្ចាស់តម្រូវក្នុងច្បាប់»
ជាគំរូ និងស្រមោល
ពាក្យទាំងនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា ដើម្បីបញ្ជាក់ថា
រោងឧបោសថគ្រាន់តែជារូបសំណាកនៃត្រសាលពិតប្រាកដនៅស្ថានសួគ៌ប៉ុណ្ណោះ។
របៀបផ្សេងទៀតនៃការបកប្រែ: «រូបភាពមិនច្បាស់»
ស្រមោលនៃពិធីផ្សេងៗនៅស្ថានបរមសុខ
អ្នកនិពន្ធនិយាយអំពី
ប្រាសាទនៅលើផែនដីដែលជាច្បាប់ចម្លងនៃប្រាសាទនៅស្ថានបរមសុខ
ហាក់ដូចជាស្រមោល។
ដូចជាព្រះជាម្ចាស់បានព្រមានដល់លោកម៉ូសេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គឺគ្រាន់តែជាការព្រមានម៉ូសេ នៅពេលដែលលោកម៉ូសេសង់ព្រះពន្លា»
ពេលលោករៀបនឹងសង់ព្រះពន្លា
លោកម៉ូសេមិនបានសង់ត្រសាលដោយខ្លួនឯងទេ។
គាត់បានបញ្ជាឲ្យប្រជាជនសាងសង់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហៀបនឹងបញ្ជាប្រជាជនអោយសាងសង់សង់ព្រះពន្លា»
ចូរប្រយ័ត្ននូវអ្វី
«ឲ្យប្រាកដថា»
ដោយយកគម្រូ
«ការរចនា»
តាមការបង្ហាញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលខ្ញុំបានបង្ហាញអ្នក»
នៅលើភ្នំ
អ្នកអាចបញ្ជាក់យ៉ាងច្បាស់ថា «ភ្នំ» សំដៅទៅលើភ្នំស៊ីណៃ។
របៀបផ្សេងទៀតនៃការបកប្រែ: «នៅលើភ្នំស៊ីណៃ»
Hebrews 8:6
ប្រយោគភ្ជាប់៖
ផ្នែកនេះចាប់ផ្តើមបង្ហាញថា
កិច្ចព្រមព្រៀងថ្មីប្រសើរជាងកិច្ចព្រមព្រៀងចាស់ជាមួយអ៊ីស្រាអែល និងយូដា។
ព្រះគ្រិស្តបានទទួល
«ព្រះជាម្ចាស់បានប្រទានព្រះគ្រិស្ត»
ព័ន្ធកិច្ចប្រសើរជាងមុន។ គឺព្រះអង្គជាស្ពាននៃសម្ពន្ធមេត្រីប្រសើរជាងមុន
«ជាកិច្ចបំរើដ៏ប្រសើរជាងនេះដូចជា
ព្រះគ្រិស្តគឺជាអ្នកសម្រុះសម្រួលនៃសម្ពន្ធមេត្រីដែលប្រសើរជាង»
ជាស្ពាននៃសម្ពន្ធមេត្រីប្រសើរជាងមុន
នេះមានន័យថាព្រះគ្រិស្តបណ្តាលឲ្យ មានកិច្ចព្រមព្រៀងល្អប្រសើររវាងព្រះជាម្ចាស់
និងមនុស្ស។
ដែលចងឡើងព្រះបន្ទូលសន្យាប្រសើរជាង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«គឺជាកិច្ចព្រមព្រៀងនេះដែលព្រះជាម្ចាស់បានធ្វើដោយផ្អែកលើការសន្យាប្រសើរជាងមុន»
ឬ
«ព្រះជាម្ចាស់បានសន្យាអ្វីដែលប្រសើរជាងមុននៅពេលដែលព្រះអង្គបានធ្វើកិច្ចព្រមព្រៀងនេះ»
សម្ពន្ធមេត្រីទីមួយ...សម្ពន្ធមេត្រីទីពីរ
ពាក្យថា «ទីមួយ» និង «ទីពីរ» ជាលេខធម្មតា។ របៀបផ្សេងទៀតនៃការបកប្រែ:
«កិច្ចព្រមព្រៀងចាស់...កិច្ចព្រមព្រៀងថ្មី»
គ្មានកំហុស
«បានល្អឥតខ្ចោះ»
Hebrews 8:8
ព័ត៌មានទូទៅ៖
នៅក្នុងសម្រង់នេះព្យាការីយេរេមាបានទាយអំពី សម្ពន្ធមេត្រីថ្មីដែលព្រះនឹងធ្វើ។
ប្រជាជន
«ជាមួយប្រជាជនអ៊ីស្រាអែល»
ឃើញ
«មើល» ឬ «ស្តាប់» ឬ «យកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំរៀបនឹងប្រាប់អ្នក»
ថ្ងៃជិតមកដល់ហើយ
នាពេលអនាគតត្រូវបានគេនិយាយ ហាក់ដូចជាកំពុងឆ្ពោះទៅរកអ្នកនិយាយ។
របៀបផ្សេងទៀតនៃការបកប្រែ: «នឹងមានពេលមួយ»
ពូជពង្សអ៊ីស្រាអែល និងពូជពង្សយូដា
ប្រជាជនអ៊ីស្រាអែល និងយូដាត្រូវបានគេនិយាយដូចជាផ្ទះដែរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជនអ៊ីស្រាអែល និងប្រជាជនយូដា»
យើងបានចងឡើងជាមួយបុព្វបុរសរបស់ពួកគេ គឺនៅថ្ងៃយើងដឹកដៃពួកគេចេញពីប្រទេសអេស៊ីប
ពាក្យប្រៀបធៀបនេះតំណាងឲ្យសេចក្តីស្រឡាញ់
និងការយកចិត្តទុកដាក់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងបាននាំពួកគេចេញពីប្រទេសអេហ្ស៊ីបដូចជាឪពុកដឹកនាំកូនតូចរបស់» (UDB)
លែងរវីរវល់ជាមួយពួកគេដែរ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់
ដើម្បីធ្វើតាមកិច្ចព្រមព្រៀងរបស់ព្រះជាម្ចាស់គឺហាក់ដូចជាមាននរណាម្នាក់បន្តធ្វើដូច្នោះដែរ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ពួកគេមិនបានគោរពតាមសម្ពន្ធមេត្រីរបស់យើងទេ»
Hebrews 8:10
ព័ត៌មានទូទៅ៖
នេះជាការដកស្រង់ចេញពីព្យាការីយេរេមា។
ប្រជាជនអ៊ីស្រាអែល
ប្រជាជនអ៊ីស្រាអែលត្រូវបានគេនិយាយដូចជាពួកគេជាផ្ទះមួយ។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជាជនអ៊ីស្រាអែល»
បន្ទាប់ពីថ្ងៃនោះកន្លងផុតទៅ
«បន្ទាប់ពីពេលនោះ»
យើងនឹងចារក្រឹត្យវិន័យយើងក្នុងគំនិត
តម្រូវការរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយ
ដូចជាវត្ថុដែលអាចដាក់នៅកន្លែងណាមួយ។
សមត្ថភាពរបស់មនុស្សក្នុងគំនិតត្រូវបានគេនិយាយ ដូចជាកន្លែងមួយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងអនុញ្ញាតឱ្យពួកគេយល់ពីច្បាប់របស់យើង» (UDB)
យើងចារក្រឹត្យវិន័យទាំងនោះក្នុងដួងចិត្តពួកគេផងដែរ
ដួងចិត្តរបស់មនុស្សដែលត្រូវបានគេគិតថា
ជាចំណុចកណ្តាលនៃភាពស្មោះត្រង់របស់ពួកគេចំពោះព្រះជាម្ចាស់ត្រូវបានគេនិយាយថា
ជាទំព័រដែលអាចត្រូវបានសរសេរ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងអនុញ្ញាតឲ្យពួកគេគោរពច្បាប់របស់យើងដោយស្មោះត្រង់»
យើងធ្វើជាព្រះជាម្ចាស់ពួកគេ
«យើងនឹងធ្វើជាព្រះដែលពួកគេថ្វាយបង្គំ»
ពួកគេនឹងធ្វើជាប្រជារាស្ត្ររបស់យើង
«ពួកគេនឹងធ្វើជាមនុស្សដែលយើងយកចិត្តទុកដាក់»
Hebrews 8:11
ព័ត៌មានទូទៅ៖
នេះនៅតែបន្តសម្រង់ពីព្យាការីយេរេមានេះ។
ពួកគេលែងបង្រៀនអ្នកជិតខាង និងបង្រៀនបងប្អូនទៅវិញទៅមក ដោយនិយាយថា
ចូរស្គាល់ព្រះអម្ចាស់
សម្រង់ផ្នែកនេះអាចត្រូវបានបញ្ជាក់ជាសម្រង់ដោយប្រយោល។
របៀបផ្សេងទៀតនៃការបកប្រែ: «ពួកគេនឹងមិនចាំបាច់បង្រៀនអ្នកជិតខាង
ឬបងប្អូនរបស់ពួកគេឲ្យស្គាល់យើងទេ»
អ្នកជិតខាង...បងប្អូន
ទាំងពីរនេះសំដៅទៅលើជនរួមជាតិអ៊ីស្រាអែល។
ស្គាល់ព្រះអម្ចាស់...មនុស្សគ្រប់គ្នានឹងស្គាល់យើង
«ស្គាល់» ត្រង់នេះតំណាងឲ្យការទទួលស្គាល់។
ចំពោះអំពើទុច្ចរិតដែលគេបានប្រព្រឹត្ត
នេះគឺតំណាងឲ្យមនុស្សដែលតាំងចិត្តប្រព្រឹត្តអំពើទុច្ចរិតទាំងនេះ»
របៀបផ្សេងទៀតនៃការបកប្រែ: «ចំពោះអ្នកដែលបានធ្វើអំពើទុច្ចរិត»
យើងនឹងមិននឹកចាំពីអំពើបាបពួកគេទៀតទេ
ត្រង់ថា «នឹកចាំ» តំណាងឲ្យ «ការពិត»។
Hebrews 8:13
នឹងត្រូវសាបសូន្យមិនខាន

generated on Wed Sep 10 16:16:32 2025

9 [1]ឥឡូវនេះ សូម្បីតែសម្ពន្ធមេត្រីទីមួយក៏មានក្បួនច្បាប់សម្រាប់ថ្វាយបង្គំ និងទីសក្ការៈនៅលើផែនដីដែរ។[2]គេសង់ព្រះពន្លាឡើង។ បន្ទប់ទីមួយមានដាក់ជើងចង្កៀង តុ
និងនំប៉័ងតំណាងវត្តមាន គេហៅថា ទីសក្ការៈ។
[3]នៅខាងក្រោយវាំងននទីពីរ មានបន្ទប់មួយគេថា ទីសក្ការៈបំផុត។ នៅទីនោះមានអាសនៈថ្វាយគ្រឿងក្រអូបធ្វើពីមាស។[4]មានហិបនៃសម្ពន្ធមេត្រីស្រោបពីមាស។
នៅខាងក្នុងហិបនោះ មានពានមាសមួយសម្រាប់ដាក់នំម៉ាណា មានដំបងរបស់លោកអើរ៉ុនមានដុះផ្ការចេញ និងបន្ទះថ្មនៃសម្ពន្ធមេត្រី។[5]នៅលើហិបនៃសម្ពន្ធមេត្រី មានរូប
ចេរូប៊ីនពេញដោយសិរីរុងរឿង ត្រដាងស្លាបបាំងពីលើកន្លែងថ្វាយឈាម ដែលយើងមិនអាចរៀបរាប់ឲ្យបានលម្អិតនៅពេលនេះទេ។
[6]បន្ទាប់ពីបានរៀបចំរបស់ទាំងនេះរួចហើយ បូជាចារ្យចេញទៅខាងក្រៅព្រះពន្លា ដើម្បីបំពេញមុខងារបម្រើ។[7]ប៉ុន្តែ មានតែមហាបូជាចារ្យប៉ុណ្ណោះ
មានសិទ្ធិចូលទៅទីសក្ការៈបំផុតមួយឆ្នាំម្តង ហើយលោកត្រូវយកឈាមទៅថ្វាយយញ្ញបូជាដាំដោះបាបខ្លួនលោកផ្ទាល់ និងរំដោះបាបប្រជាជនទាំងមូលផង។
[8]ព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហាញថា ផ្លូវចូលទៅកាន់ទីសក្ការៈបំផុតមិនទាន់បើកឲ្យមនុស្សទូទៅចូលបានឡើយ ដរាបណាព្រះពន្លានៅឈរឯមាំនៅឡើយ។
[9]នេះជានិមិត្តរូបបច្ចុប្បន្នកាលនេះ គឺទាំងតង្វាយ និងយញ្ញបូជាដែលមនុស្សបានថ្វាយ មិនអាចធ្វើឲ្យមនសិការអ្នកថ្វាយបង្គំបានគ្រប់លក្ខណ៍ទេ។
[10]ព្រោះពួកគេខ្វល់ខ្វាយរឿងអាហារ និងភេសជ្ជៈ ព្រមទាំងពិធីប្រោះទឹកផ្សេងៗ។ ទាំងនេះជាក្បួនតម្រាសម្រាប់មនុស្ស
ដែលបានប្រទានទំរាំដល់ពេលព្រះជាម្ចាស់ប្រទានបទបញ្ជាថ្មី។
[11]ព្រះគ្រិស្តបានយាងមកក្នុងឋានៈជាមហាបូជាចារ្យ ដើម្បីនាំសម្បត្តិដែលព្រះអង្គបានប្រទានមក។ ព្រះអង្គយាងកាត់ព្រះពន្លាមួយដ៏ប្រសើរ និងគ្រប់លក្ខណ៍
ពុំមែនសង់ឡើងដោយដៃមនុស្ស និងពុំមែនជារបស់លោកនេះឡើយ។[12]ព្រះអង្គពុំបានយកឈាមពពែ និងកូនគោទេ ប៉ុន្តែព្រះអង្គយកព្រះលោហិតរបស់ព្រះអង្គផ្ទាល់
ចូលទៅទីសក្ការៈបំផុតម្តងជាសម្រេច ដើម្បីប្រោសលោះយើងអស់កល្បជានិច្ច។
[13]ដ្បិតប្រសិនបើឈាមរបស់ពពែ និងឈាមគោបា ព្រមទាំងផេះគោញីស្ទាវដែលគេបាចលើមនុស្សសៅហ្មង ធ្វើឲ្យរូបកាយគេបានបរិសុទ្ធ និងជាវិសុទ្ធទៅហើយ[14]ចុះចំណង់
បើព្រះលោហិតព្រះគ្រិស្ត តាមរយៈព្រះវិញ្ញាណដ៏អស់កល្បជានិច្ច ថ្វាយព្រះអង្គផ្ទាល់ទុកជាយញ្ញបូជាឥតសៅហ្មងនៅចំពោះព្រះជាម្ចាស់
ទាំងសម្អាតមនសិការយើងកិច្ចការឥតបានការ ដើម្បីគោរពបម្រើព្រះជាម្ចាស់ដ៏មានព្រះជន្មរស់យ៉ាងណាទៅទៀត?
[15]ដោយហេតុនេះហើយបានជាព្រះអង្គជាស្ពាននៃសម្ពន្ធមេត្រីថ្មីមួយ។ ដូច្នេះ ព្រះអង្គបានរំដោះអស់អ្នកស្ថិតនៅក្រោមសម្ពន្ធមេត្រីទីមួយ ឲ្យមានសេរីភាពរួចពីបាប
គឺអស់អ្នកដែលព្រះអង្គបានត្រាស់ហៅមក ឲ្យទទួលព្រះបន្ទូលសន្យាទុកជាមរតកអស់កល្បជានិច្ច។
[16]ដ្បិត គេនឹងចែកបណ្តាំមរតក ដរាបណាមានភស្តុតាងបង្ហាញថា អ្នកសរសេរបណ្តាំមរតកស្លាប់ជាមុនសិន។[17]គេនឹងអនុវត្តតាមបណ្តាំមរតក
កាលណាអ្នកសរសេរបណ្តាំមរតកបានស្លាប់រួចហើយ ព្រោះគេនឹងមិនអនុវត្តតាមបណ្តាំមរតកទេ ខណៈពេលអ្នកសរសេរបណ្តាំមរតកនៅរស់នៅឡើយ។
[18]ដូច្នេះ សូម្បីតែសម្ពន្ធមេត្រីទីមួយក៏មិនបានចងឡើង ដោយគ្មានការបង្ហូរឈាមនោះឡើយ។[19]ដ្បិត ពេលលោកម៉ូសេប្រកាសបទបញ្ជាទាំងអស់
មានចែងក្នុងក្រឹត្យវិន័យដល់ប្រជាជន លោកបានយកឈាមកូនគោ និងឈាមពពែឈ្មោល ព្រមទាំងទឹកប្រោះ ដោយជ្រលក់នឹងរោមចៀមព៌ណក្រហម និងស្លឹកហ៊ីសុប
យកមកប្រោះលើគម្ពីរ និងប្រជាជនទាំងមូល។[20]បន្ទាប់មក លោកមានប្រសាសន៍ថា៖ «នេះជាឈាមនៃសម្ពន្ធមេត្រី ដែលព្រះជាម្ចាស់បានបង្គាប់អ្នកឲ្យប្រព្រឹត្តតាម»។
[21]ជាមួយគ្នានេះដែរ លោកបានប្រោះឈាមលើព្រះពន្លា និងប្រដាប់ប្រដាប្រើប្រាស់ទាំងអស់ សម្រាប់បម្រើព្រះជាម្ចាស់។[22]យោងតាមក្រឹត្យវិន័យ
ស្ទើរតែគ្រប់អ្វីៗទាំងអស់បានស្អាត ដោយសារឈាម។ បើគ្មានការបង្ហូរឈាមទេនោះ ក៏គ្មានការអត់ទោសបាបដែរ។
[23]ដូច្នេះ ចាំបាច់ណាស់ឲ្យយើងដឹងថា គ្រាន់តែអ្វីៗចម្លងពីស្ថានបរមសុខបានស្អាតបរិសុទ្ធដោយសារយញ្ញបូជារបស់សត្វទាំងនេះទៅហើយ
ចុះបើអ្វីៗនៅស្ថានបរមសុខនឹងបានស្អាតបរិសុទ្ធ ដោយត្រូវការយញ្ញបូជាប្រសើរជាងនេះទៅទៀត។[24]ដ្បិត ព្រះគ្រិស្តពុំបានយាងចូលទីសក្ការៈបំផុត
ដែលសង់ឡើងដោយដៃមនុស្ស ដែលគ្រាន់តែចម្លងពីរបស់ពិតប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ ព្រះអង្គយាងចូលស្ថានបរមសុខដោយព្រះអង្គផ្ទាល់
ឥឡូវនេះព្រះអង្គគង់នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់ ជាប្រយោជន៍សម្រាប់យើងរាល់គ្នា។
[25]ព្រះអង្គពុំបានយាងចូលទៅទីនោះ ដើម្បីថ្វាយព្រះអង្គផ្ទាល់ច្រើនលើកច្រើនសានោះទេ ដូចជាមហាបូជាចារ្យចូលទៅទីសក្ការៈបំផុត ដើម្បីថ្វាយយញ្ញបូជារៀងរាល់ឆ្នាំ
ដោយយកឈាមរបស់អ្នកដទៃនោះទេ។[26]ប្រសិនបើវាដូច្នោះមែន ព្រះអង្គត្រូវរងទុក្ខជាច្រើនលើកច្រើនសា តាំងពីកំណើតលោកីយ៍មកម្ល៉ៈ។
ប៉ុន្តែឥឡូវនៅគ្រាចុងក្រោយនេះ ព្រះជាម្ចាស់បានបើកសម្តែងថា ព្រះអង្គយាងមកតែម្តងគត់ ដើម្បីលុបបំបាត់បាបដោយព្រះអង្គត្រូវថ្វាយព្រះអង្គផ្ទាល់ជាយញ្ញបូជា។
[27]មនុស្សគ្រប់គ្នាត្រូវស្លាប់ម្តង បន្ទាប់មកត្រូវជំនុំជម្រះ។[28]ដូចគ្នានេះដែរ ព្រះគ្រិស្តត្រូវថ្វាយព្រះអង្គទ្រង់ម្តង ដើម្បីដកបាបពីមនុស្សទាំងអស់
នោះព្រះអង្គនឹងលេចមកម្តងទៀតពុំមែនដើម្បីរំដោះបាបមនុស្សលោកទេ ផ្ទុយទៅវិញព្រះអង្គនឹងសង្គ្រោះដល់អស់អ្នកណាដែលរង់ចាំព្រះអង្គ ដោយចិត្តអត់ធ្មត់។

Hebrews 9:1

ប្រយោគភ្ជាប់៖

អ្នកនិពន្ធបានបញ្ជាក់យ៉ាងច្បាស់ដល់អ្នកជឿជនជាតិយូដាទាំងនេះថា ច្បាប់
និងព្រះពន្លានៃសម្ព័ន្ធមេត្រីចាស់គ្រាន់តែជារូបភាពនៃកិច្ចព្រមព្រៀងថ្មីប្រសើរជាង។

ឥឡូវនេះ

ពាក្យនេះសម្គាល់ផ្នែកថ្មីនៃការបង្រៀន។

សម្ពន្ធមេត្រីទីមួយ

បកប្រែដូចដែលអ្នកបានបកប្រែនៅក្នុងជំពូក ៨: ៦។

មានក្បួនច្បាប់

«មានការណែនាំលំអិត» ឬ «មានច្បាប់»

សម្រាប់

អ្នកនិពន្ធកំពុងបន្តការពិភាក្សាចាប់ពីជំពូក ៨: ៦។

សង់ព្រះពន្លាឡើង

ព្រះពន្លាត្រូវបានសាងសង់ និងបានត្រៀមខ្លួនជាស្រេចសម្រាប់ការប្រើ។

គំនិតនេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ជនជាតិអ៊ីស្រាអែលបានរៀបចំរោងឧបោសថ»

ជើងចង្កៀង តុ និងនំប៉័ងតំណាងវត្តមាន

វត្ថុទាំងអស់នេះត្រូវបានចង្អុលបញ្ជាក់ដោយ «នេះ»
ពីព្រោះអ្នកនិពន្ធសន្មតថាអ្នកអានរបស់គាត់ដឹងអំពីរឿងទាំងនេះហើយ។

នំប៉័ងតំណាងវត្តមាន

នេះអាចត្រូវបានប្រើឡើងវិញដូច្នេះនាមអរូបី «វត្តមាន»
ត្រូវបានបង្ហាញជាកិរិយាស័ព្ទ «បង្ហាញ» ឬ «បច្ចុប្បន្ន»។
របៀបផ្សេងទៀតនៃការបកប្រែ: «នំប៉័ងដាក់បង្ហាញនៅចំពោះព្រះ» ឬ
«នំប៉័ងដែលពួកបូជាចារ្យថ្វាយដល់ព្រះ»

Hebrews 9:3

នៅខាងក្រោយវាំងននទីពីរ

វាំងននទីមួយគឺជញ្ជាំងខាងក្រៅនៃត្រសាលដូច្នេះ «វាំងននទីពីរ» គឺជាវាំងននរវាង
«ទីបរិសុទ្ធ» និង «ទីបរិសុទ្ធបំផុត»។

ទីពីរ

នេះគឺជាពាក្យលេខលំដាប់លេខពីរ។

នៅខាងក្នុងហិបនោះ

«នៅខាងក្នុងហិបនៃសម្ពន្ធមេត្រី»

ដំបងរបស់លោកអើរ៉ុនមានដុះផ្ការចេញ

នេះសំដៅទៅលើ ពេលដែលព្រះជាម្ចាស់បានបង្ហាញដល់ប្រជាជនអ៊ីស្រាអែលថា
ព្រះអង្គបានជ្រើសរើសអើរ៉ុនធ្វើជាបូជាចារ្យរបស់ព្រះអង្គ ដោយធ្វើដំបងរបស់អើរ៉ុន។

ដុះផ្ការចេញ

«ផ្ការ» ឬ «ពន្លក» ឬ «លូតលាស់ និងអភិវឌ្ឍ»

បន្ទះថ្មនៃសម្ពន្ធមេត្រី

ត្រង់ថា «បន្ទះថ្ម» គឺជាដុំថ្មរាបស្មើដែលបានសរសេរពីលើ។
នេះសំដៅទៅលើបន្ទះថ្មដែលសេចក្តីបង្គាប់ទាំងដប់បានសរសេរពីលើ។

generated on Wed Sep 10 16:16:32 2025

រូបចេរូប៊ីនពេញដោយសិរីរុងរឿង ត្រដាងស្លាបបាំងពីលើ
នៅពេលដែលជនជាតិអ៊ីស្រាអែលកំពុងធ្វើទុកធំនៃកិច្ចព្រមព្រៀងនោះ
ព្រះជាម្ចាស់បានបញ្ជាពួកគេឲ្យឆ្លាក់រូបចេរូប៊ីនពីរនៅទុលមុខគ្នា
ដោយស្លាបរបស់ពួកគេប៉ះលើគម្របដង្វាយលោះបាបរបស់ហិបនៃសម្ពន្ធមេត្រី។
រូបចេរូប៊ីន
ត្រង់ថា «ចេរូប៊ីន» មានន័យថាជារូបចេរូប៊ីនពីរ។
ដែលយើងមិនអាច
ទោះបីជាអ្នកនិពន្ធប្រើសព្វនាមពហុវចន: «យើង» ក៏ដោយ
គឺភាគច្រើនគាត់ជាសំដៅទៅលើតែខ្លួនគាត់ប៉ុណ្ណោះ។ «ដែលខ្ញុំមិនអាច»
Hebrews 9:6
បន្ទាប់ពីបានរៀបចំរបស់ទាំងនេះរួចហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់ពីក្រុមបូជាចារ្យបានរៀបចំរបស់ទាំងនេះ»
ហើយលោកត្រូវយកឈាមទៅថ្វាយយញ្ញបូជារំដោះបាបខ្លួនលោកផ្ទាល់
នេះអាចត្រូវបានបញ្ជាក់នៅក្នុងទម្រង់វិជ្ជមាន។ របៀបផ្សេងទៀតនៃការបកប្រែ:
«ហើយគាត់តែងតែនាំឈាម»
ឈាម
នេះជាឈាមគោបានិងឈាមពពែដែលលោកមហាបូជាចារ្យត្រូវថ្វាយនៅថ្ងៃធ្វើពិធីលោះបាប
Hebrews 9:8
ផ្លូវចូលទៅកាន់ទីសក្ការៈបំផុតមិនទាន់បើកឲ្យមនុស្សទូទៅចូលបានឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់មិនទាន់បានបង្ហាញផ្លូវទៅកាន់ទីបរិសុទ្ធបំផុតទេ»
ទីសក្ការៈបំផុតមិន
អត្ថន័យដែលអាចមានទី១គឺ បន្ទប់ខាងក្នុងនៃរោងឧបោសថនៅលើផែនដី ឬទីពីរគឺ
វត្តមានរបស់ព្រះនៅស្ថានសួគ៌។
ដរាបណាព្រះពន្លានៅឈរអីមាំនៅឡើយ
អាចមានន័យថាទី១) គឺ «បន្ទប់ខាងក្រៅនៃរោងឧបោសថនៅតែឈរដដែល» ឬ
ទី៣២) គឺ «រោងឧបោសថនៅលើផែនដី
និងប្រព័ន្ធថ្វាយយញ្ញបូជានៅតែមាននៅឡើយ។
នេះជានិមិត្តរូប
«នេះជារូបភាពមួយ» ឬ «នេះគឺជានិមិត្តរូប»
បច្ចុប្បន្នកាលនេះ
«ក្នុងពេលឥឡូវនេះ»
មិនអាចធ្វើឲ្យមនសិការអ្នកថ្វាយបង្គំបាន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបូជាចារ្យប្រគល់ឲ្យឥឡូវ»
មិនអាចធ្វើឲ្យមនសិការអ្នកថ្វាយបង្គំបានគ្រប់លក្ខណ៍ទេ
អ្នកនិពន្ធនិយាយពីមនសិការរបស់មនុស្សម្នាក់ដូចជា
វត្ថុមួយដែលអាចត្រូវបានធ្វើឲ្យប្រសើរឡើង
និងប្រសើរជាងមុនរហូតដល់វាគ្មានកំហុស។
មនសិការរបស់មនុស្សម្នាក់គឺចំណេះដឹងអំពីអ្វីដែលត្រូវ និងអ្វីដែលមិនត្រឹមត្រូវ។
ក៏ជាការយល់ដឹងរបស់គាត់ផងដែរថា តើគាត់បានធ្វើខុស ឬអត់។
ប្រសិនបើគាត់ដឹងថា គាត់បានធ្វើខុសយើងអាចថា
គាត់មានអារម្មណ៍ថាមានកំហុស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មិនអាចធ្វើឲ្យអ្នកថ្វាយបង្គំមិនមានកំហុកទេ»
អ្នកថ្វាយបង្គំបានគ្រប់លក្ខណ៍
អ្នកនិពន្ធហាក់ដូចជាសំដៅទៅលើ អ្នកថ្វាយបង្គំម្នាក់ប៉ុណ្ណោះ ប៉ុន្តែគាត់មានន័យថា
អ្នកដែលមកថ្វាយបង្គំព្រះជាម្ចាស់នៅត្រសាល។
តម្រាសម្រាប់មនុស្ស
ត្រង់ថា «សាច់ឈាម» សំដៅទៅលើរូបរាងកាយ។ «ច្បាប់សម្រាប់រាងកាយ»
ទាំងនេះជាក្បួនតម្រាសម្រាប់មនុស្ស ដែលបានប្រទាន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានផ្តល់បទបញ្ជាទាំងអស់នេះសម្រាប់សាច់ឈាម»
ដែលបានប្រទានទំរាំដល់ពេលព្រះជាម្ចាស់ប្រទានបទបញ្ជាថ្មី
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលព្រះបានផ្តល់រហូតដល់ព្រះអង្គបានបង្កើតបទបញ្ជាថ្មី»
បទបញ្ជាថ្មី
«សម្ព័ន្ធមេត្រីថ្មី» (UDB)
Hebrews 9:11
ប្រយោគភ្ជាប់៖
ដោយបានពិពណ៌នាអំពី សេវាកម្មនៃត្រសាលនៅក្រោមច្បាប់របស់ព្រះជាម្ចាស់
អ្នកនិពន្ធបានបញ្ជាក់យ៉ាងច្បាស់ថា
ការបម្រើរបស់ព្រះគ្រិស្តនៅក្រោមកិច្ចព្រមព្រៀងថ្មី
គឺប្រសើរជាងព្រោះត្រូវបានផ្សាភ្ជាប់ជាមួយនឹងព្រះលោហិតរបស់ព្រះអង្គ។
ក៏ប្រសើរដែរ ព្រោះព្រះគ្រិស្តបានចូលក្នុងរោងឧបោសថពិត។
នោះគឺវត្តមានរបស់ព្រះជាម្ចាស់ផ្ទាល់នៅស្ថានសួគ៌ជាជាងបូជាចារ្យឯទៀតចូលក្នុងត្រសាលនៅផែនដី
ដែលមានតែច្បាប់ចម្លងមិនល្អឥតខ្ចោះប៉ុណ្ណោះ។
សម្បត្តិ
នេះមិនសំដៅទៅលើទ្រព្យសម្បត្តិទេ។ គឺមានន័យថារបស់ល្អៗ
ដែលព្រះជាម្ចាស់បានសន្យានៅក្នុងកិច្ចព្រមព្រៀងថ្មីរបស់ព្រះអង្គ។
ពន្លាមួយដ៏ប្រសើរ និងគ្រប់លក្ខណ៍
នេះមានន័យថាត្រសាល ឬរោងឧបោសថនៅស្ថានសួគ៌គឺសំខាន់
និងល្អឥតខ្ចោះជាងត្រសាលនៅលើផែនដី។
ពុំមែនសង់ឡើងដោយដៃមនុស្ស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលមិនបានធ្វើដោយដៃមនុស្ស»
ដោយដៃមនុស្ស
ត្រង់ថា «ដៃ» សំដៅទៅលើមនុស្សទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្ស»
ទីសក្ការៈបំផុត
វត្តមានរបស់ព្រះជម្ចាស់នៅស្ថានសួគ៌ត្រូវបានគេនិយាយថា
ជាកន្លែងបរិសុទ្ធបំផុតជាបន្ទប់ខាងក្នុងបំផុតនៅក្នុងរោងឧបោសថ។
Hebrews 9:13
ផេះគោញីស្ទាវដែលគេបាចលើមនុស្សសៅហ្មង
បូជាចារ្យត្រូវទម្លាក់ផេះបន្តិចបន្តួចទៅលើមនុស្សមិនបរិសុទ្ធ។
ធ្វើឲ្យរូបកាយគេបានបរិសុទ្ធ
ត្រង់ថា «សាច់ឈាម» សំដៅទៅលើរាងកាយទាំងមូល។
របៀបផ្សេងទៀតនៃការបកប្រែ: «សម្រាប់ការសំអាតរាងកាយរបស់ពួកគេ»
ចុះចំណង់បើព្រះលោហិតព្រះគ្រិស្ត តាមរយៈព្រះវិញ្ញាណដ៏អស់កល្បជានិច្ច
ថ្វាយព្រះអង្គផ្ទាល់ទុកជាយញ្ញបូជាឥតសៅហ្មងនៅចំពោះព្រះជាម្ចាស់
ទាំងសម្អាតមនសិការយើងកិច្ចការឥតបានការ ដើម្បីគោរពបម្រើព្រះជាម្ចាស់ដ៏មានព្រះជន្ម
រស់យ៉ាងណាទៅទៀត?
អ្នកនិពន្ធប្រើសំណួរនេះដើម្បីបញ្ជាក់ថា
ការលះបង់របស់ព្រះគ្រិស្តគឺមានឥទ្ធិពលបំផុត។
ប្រោកដហើយព្រះលោហិតរបស់ព្រះគ្រិស្តនឹងសំអាតមនសិការរបស់យើងអោយបានកាន់តែច្រើនថែមទៀត
ពីការប្រព្រឹត្ត ដែលស្លាប់ដើម្បីបំរើព្រះដ៏មានព្រះជន្មរស់
ដោយសារតាមរយៈវិញ្ញាណដ៏នៅអស់កល្បជានិច្ចព្រះអង្គបានថ្វាយខ្លួនដោយគ្មានស្នាមជាព្រះ។
ព្រះលោហិតព្រះគ្រិស្ត
«ព្រះលោហិត» នៃព្រះគ្រិស្តតំណាងឲ្យការសុគត់របស់ព្រះអង្គ។
សម្អាតមនសិកា
ត្រង់ថា «មនសិកា» សំដៅទៅលើអារម្មណ៍នៃកំហុសរបស់មនុស្សម្នាក់។
ដោយសារព្រះយេស៊ូបានបូជាព្រះជន្មរបស់ព្រះអង្គ
នោះអ្នកជឿមិនចាំបាច់មានអារម្មណ៍ថាខ្លួនគេមានកំហុសចំពោះអំពើបាបដែលពួកគេបានធ្វើដោយសារព្រ
ស្នាមជាំ
នេះគឺជាអំពើបាបតូច ឬកំហុសខាងសីលធម៌ ដែលត្រូវបានគេនិយាយនៅទីនេះ
ដូចជាចំណុចតូចមិនធម្មតា ឬពិការភាពនៅលើព្រះកាយរបស់ព្រះគ្រិស្ត។
សម្អាត
ត្រង់ថា «សម្អាត» តំណាងឱ្យសកម្មភាពនៃការបំបាត់មនសិការរបស់យើងពី
កំហុសដែលយើងបានធ្វើ។
កិច្ចការឥតបានការ
ការប្រព្រឹត្តអំពើបាបត្រូវបានគេនិយាយដូចជា
ពួកគេជាកម្មសិទ្ធិរបស់ពិភពលោកនៃការស្លាប់នេះ។
ដោយហេតុនេះហើយ
«ជាលទ្ធផល» ឬ «ដោយសារតែរឿងនេះ»
ព្រះអង្គជាស្ពាននៃសម្ពន្ធមេត្រីថ្មីមួយ
នេះមានន័យថា ព្រះគ្រិស្តបណ្តាលឲ្យមានកិច្ចព្រមព្រៀងថ្មីរវាងព្រះជាម្ចាស់
និងមនុស្ស។
សម្ពន្ធមេត្រីទីមួយ

generated on Wed Sep 10 16:16:32 2025

បកប្រែពាក្យនេះដូចជាអ្នកបានបកប្រែនៅក្នុងជំពូក ៨:៦។
អស់អ្នកដែលព្រះអង្គបានត្រាស់ហៅមក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលព្រះជាម្ចាស់បានជ្រើសរើសធ្វើជាកូនរបស់ព្រះអង្គ»
មរតក
ការទទួលនូវអ្វី ដែលព្រះជាម្ចាស់បានសន្យាដល់អ្នកជឿត្រូវបានគេនិយាយដូចជា
ការទទួលមរតកទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារ។
Hebrews 9:16
នឹង
ឯកសារស្របច្បាប់ ដែលបុគ្គលម្នាក់បានចែងថា
គួរតែទទួលទ្រព្យសម្បត្តិរបស់គាត់នៅពេលគាត់ស្លាប់
ដរាបណាមានភស្តុតាងបង្ហាញថា អ្នកសរសេរបណ្តាំមរតកស្លាប់ជាមុនសិន
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។របៀបផ្សេងទៀតនៃការបកប្រែ:
«នរណាម្នាក់ត្រូវតែបង្ហាញថា អ្នកដែលបានធ្វើតាមឆន្ទៈនឹងបានស្លាប់»
Hebrews 9:18
ដូច្នេះ សូម្បីតែសម្ពន្ធមេត្រីទីមួយក៏មិនបានចងឡើង ដោយគ្មានការបង្ហូរឈាមនោះឡើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្មនិងវិជ្ជមាន។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដូច្នេះព្រះជាម្ចាស់បានបង្កើតសម្ពន្ធមេត្រីដំបូងជាមួយឈាម»
សម្ពន្ធមេត្រីទីមួយ
បកប្រែពាក្យនេះដូចជាអ្នកបានបកប្រែនៅក្នុងជំពូក ៨:៦។
ឈាម
ការស្លាប់របស់សត្វ ដែលបានថ្វាយដល់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា
មិនមែនជាឈាមទេ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ការស្លាប់របស់សត្វបានបូជាដល់ព្រះជាម្ចាស់»
យកឈាម...ព្រមទាំងទឹក...ប្រោះ...ដោយជ្រលក់...ប្រជាជនទាំងមូល
បូជាចារ្យជ្រលក់មែកហ៊ីសុបក្នុងឈាម និងទឹករួចរញ្ជួយមើមហុស ដូច្នេះឈាម
និងទឹកនឹងធ្លាក់ចុះនៅលើរមូរ លើប្រជាជន។
ការប្រោះទឹកគឺជាសកម្មភាពនិមិត្តរូបដែលធ្វើឡើងដោយពួកបូជាចារ្យ
ដែលពួកគេអនុវត្តអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងចំពោះមនុស្ស និងវត្ថុ។
នៅទីនេះរមូរ
និងភាពអាចទទួលយកបានរបស់ប្រជាជនចំពោះព្រះជាម្ចាស់ត្រូវបានបង្កើតជាថ្មី។
ស្លឹកហ៊ីសុប
ជាដើមឈើតូចមួយដែលមានផ្កានៅរដូវក្តៅប្រើក្នុងពិធីប្រោះទឹក
ជាឈាមនៃសម្ពន្ធមេត្រី
ត្រង់ថា «ឈាម» សំដៅទៅលើការស្លាប់របស់សត្វដែលបានបូជា
ដើម្បីបំពេញតាមតម្រូវការនៃកិច្ចព្រមព្រៀង។ របៀបផ្សេងទៀតនៃការបកប្រែ:
«ឈាមដែលនាំមកនូវសម្ពន្ធមេត្រីនេះ» (UDB)
Hebrews 9:21
លោកបានប្រោះ
«លោកម៉ូសេបានប្រោះ»
ប្រោះ
ការប្រោះទឹកគឺជាសកម្មភាពនិមិត្តរូបដែលធ្វើឡើងដោយពួកបូជាចារ្យ
ដែលពួកគេអនុវត្តអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងចំពោះមនុស្ស និងវត្ថុ។
សូមមើលរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុងជំពូក ៩:១៨។
ប្រដាប់ប្រដាប្រើប្រាស់ទាំងអស់ សម្រាប់បម្រើព្រះជាម្ចាស់
ប្រអប់គឺជា វត្ថុដែលអាចដាក់របស់របរបាន។
នៅទីនេះអាចសំដៅទៅលើប្រភេទនៃប្រដាប់ប្រដាប្រើប្រាស់ ឬឧបករណ៍ណាមួយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ឧបករណ៍ប្រើប្រាស់ទាំងអស់ដែលត្រូវបានប្រើក្នុងសេវាកម្ម»
ប្រើប្រាស់ទាំងអស់ សម្រាប់បម្រើ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បូជាចារ្យប្រើក្នុងការងាររបស់ពួកគេ»
ស្ទើរតែគ្រប់អ្វីៗទាំងអស់បានស្អាត ដោយសារឈាម
ការធ្វើអ្វីៗដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់គឺ ត្រូវបានគេនិយាយថា
គឺកំពុងតែសំអាតរឿងនោះហើយ។ គំនិតនេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
របៀបផ្សេងទៀតនៃការបកប្រែ: «ក្រុមបូជាចារ្យប្រើឈាម
ដើម្បីសំអាតអ្វីៗស្ទើរតែទាំងអស់»
បើគ្មានការបង្ហូរឈាមទេនោះ ក៏គ្មានការអត់ទោសបាបដែរ
ត្រង់ថា «ការបង្ហូរឈាម»
សំដៅទៅលើអ្វីមួយដែលស្លាប់ជាការបូជាដល់ព្រះជាម្ចាស់។
អវិជ្ជមានទ្វេដងនេះអាចមានន័យថា
ការអភ័យទោសទាំងអស់កើតឡើងតាមរយៈការបង្ហូរឈាម។
របៀបផ្សេងទៀតនៃការបកប្រែ:
«ការអភ័យទោសបានកើតឡើងនៅពេលមានអ្វីមួយស្លាប់ជាយញ្ញបូជា» ឬ
«ព្រះជាម្ចាស់លើកលែងទោសអោយ លុះត្រាតែមានអ្វីមួយស្លាប់ជាយញ្ញបូជា»
ការអត់ទោស
អ្នកអាចបញ្ជាក់យ៉ាងច្បាស់នូវអត្ថន័យដែលបានបង្កប់។
របៀបផ្សេងទៀតនៃការបកប្រែ: «ការអភ័យទោសពីអំពើបាបរបស់ប្រជាជន»
Hebrews 9:23
ប្រយោគភ្ជាប់៖
អ្នកនិពន្ធបានសង្កត់ធ្ងន់ថាព្រះគ្រិស្ត (ឥឡូវនេះនៅស្ថានបរមសុខអង្វរជំនួសយើង)
ត្រូវតែសុគត់តែម្តងគត់សម្រាប់អំពើបាប
ហើយព្រះអង្គនឹងត្រឡប់មកផែនដីជាលើកទីពីរ។
គ្រាន់តែអ្វីៗចម្លងពីស្ថានបរមសុខបានស្អាតបរិសុទ្ធដោយសារយញ្ញបូជារបស់សត្វទាំងនេះទៅហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បូជាចារ្យគួរតែប្រើការបូជាសត្វទាំងនេះ
ដើម្បីសំអាតនូវអ្វីដែលជាច្បាប់ចម្លងពីអ្វីៗដែលនៅស្ថានសួគ៌»
អ្វីៗនៅស្ថានបរមសុខនឹងបានស្អាតបរិសុទ្ធ ដោយត្រូវការយញ្ញបូជាប្រសើរជាងនេះទៅទៀត
នោះគឺជាការប្រសើរជាងការលះបង់
ដែលប្រើដើម្បីសំអាតច្បាប់ចម្លងនៅលើផែនដី។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ចំពោះរបស់នៅស្ថានសួគ៌វិញ ព្រះជាម្ចាស់ត្រូវតែសំអាតពួកគេ
ដោយការលះបង់ដ៏ប្រសើរ»
ដោយដៃមនុស្ស
ត្រង់ថា «ដៃ» សំដៅទៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលមនុស្សបានបង្កើត»
ពីរបស់ពិតប៉ុណ្ណោះទេ
«នៃទីបរិសុទ្ធបំផុតដ៏ពិត»
Hebrews 9:25
ព្រះអង្គពុំបានយាងចូលទៅទីនោះ
«ព្រះអង្គមិនបានចូលទៅស្ថានសួគ៌ទេ» (UDB)
រៀងរាល់ឆ្នាំ
«រៀងរាល់ឆ្នាំ» ឬ «ក្នុងមួយឆ្នាំៗ»
ដោយយកឈាមរបស់អ្នកដទៃ
នេះមានន័យថា ជាឈាមរបស់ជនរងគ្រោះមិនមែនដោយឈាមរបស់ព្រះអង្គទេ។
ប្រសិនបើវាដូច្នោះមែន
«ប្រសិនបើ ព្រះអង្គបានថ្វាយព្រះអង្គផ្ទាល់ជាញឹកញាប់»
តាំងពីកំណើតលោកីយ៍មកម្ល៉ះ
ការបង្កើតពិភពលោកត្រូវបានគេនិយាយថា ពិភពលោកគឺជាអាគារ
ហើយគ្រឹះគឺជាផ្នែកដំបូងដែលត្រូវបានសាងសង់។របៀបផ្សេងទៀតនៃការបកប្រែ:
«ចាប់តាំងពីព្រះបានចាប់ផ្តើមបង្កើតពិភពលោក»
ព្រះជាម្ចាស់បានបើកសម្តែង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះបានបង្ហាញគាត់»
ដើម្បីលុបបំបាត់បាបដោយព្រះអង្គត្រូវថ្វាយព្រះអង្គផ្ទាល់ជាយញ្ញបូជា
នេះនិយាយអំពីអំពើបាប ដូចជាវត្ថុដែលមនុស្សអាចបោះចោលបាន។
ធ្វើឲ្យព្រះជាម្ចាស់អត់ទោសបាបដោយលះបង់ព្រះអង្គផ្ទាល់»
Hebrews 9:27
ព្រះគ្រិស្តត្រូវថ្វាយព្រះអង្គទ្រង់ម្តង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះគ្រិស្តក៏បានថ្វាយព្រះអង្គផ្ទាល់ដែរ»
ដើម្បីដកបាប
ទង្វើនៃការធ្វើឲ្យយើងគ្មានទោសជាជាងមានទោសចំពោះអំពើបាបរបស់យើង
ត្រូវបានគេនិយាយថា អំពើបាបរបស់យើងគឺ
ជារបស់ខាងសាច់ឈាមដែលព្រះគ្រិស្តអាចយកចេញពីយើង។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូច្នេះព្រះជាម្ចាស់នឹងអត់ទោសបាប»
អំពើបាប

generated on Wed Sep 10 16:16:32 2025

ត្រង់ថា «បាប» មានន័យថា ជាកំហុសដែលមនុស្សមានចំពោះព្រះជាម្ចាស់
ដោយសារអំពើបាបដែលពួកគេបានប្រព្រឹត្ត។

---

10 [1]ដ្បិត ក្រឹត្យវិន័យគ្រាន់តែជាស្រមោលនៃអ្វីៗដែលនឹងត្រូវមកដល់ ពុំមែនជារបស់ប្រចក្សទេ។ អស់អ្នកណាដែលចូលមករកព្រះជាម្ចាស់
មិនអាចបានគ្រប់លក្ខណ៍ដោយយញ្ញបូជាដដែលៗ ដែលពួកបូជាចារ្យថ្វាយមួយឆ្នាំម្តងជាបន្តបន្ទាប់នោះទេ។[2]ឬបើពួកគេបានគ្រប់លក្ខណ៍មែន
ពួកគេលែងថ្វាយទៀតហើយ? ដូចគ្នានេះដែរ ប្រសិនបើ ពួកគេបានស្អាតបរិសុទ្ធម្តងរួចស្រេចហើយ ពួកអ្នកថ្វាយបង្គំនឹងលែងរំពឹកថា ពួកគេមានបាបទៀត។
[3]យញ្ញបូជាទាំងនោះរំឭកថា ពួកគេមានបាបពីមួយឆ្នាំទៅមួយឆ្នាំ។[4]ដ្បិត ឈាមគោឈ្មោល និងឈាមពពែពុំអាចដកបាបមនុស្សលោកបានទេ។
[5]ពេលព្រះគ្រិស្តយាងមកក្នុងលោកនេះ ព្រះអង្គមានព្រះបន្ទូលថា៖ «ព្រះអង្គមិនចង់បានយញ្ញបូជា ឬតង្វាយអ្វីនោះទេ ផ្ទុយទៅវិញ ព្រះអង្គបានធ្វើរូបកាយមួយឲ្យ
ទូលបង្គំរួចហើយ។[6]ព្រះអង្គមិនគាប់ព្រះទ័យនឹងតង្វាយដុត ឬយញ្ញបូជារំដោះបាបនោះទេ»។[7]រួចមក ទូលបង្គំពោលថា៖ «មើល ទូលបង្គំនៅទីនេះ
ដូចមានសេចក្តីចែងទុកពីទូលបង្គំនៅក្នុងគម្ពីរថា ទូលបង្គំត្រូវធ្វើតាមព្រះហឫទ័យព្រះអង្គ»។
[8]ជាបឋម ព្រះអង្គមានព្រះបន្ទូលថា៖ «ព្រះអង្គពុំចង់បានយញ្ញបូជា ជាតង្វាយតង្វាយដុតទាំងមូល ឬជាយញ្ញបូជារំដោះបាបទេ។
ព្រះអង្គមិនសព្វព្រះហឫទ័យនឹងតង្វាយទាំងនេះទេ»។ យញ្ញបូជាទាំងអស់នេះត្រូវថ្វាយស្របតាមក្រឹត្យវិន័យ។[9]រួចព្រះអង្គមានព្រះបន្ទូលថា៖ «មើល
ទូលបង្គំនៅទីនេះធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់»។ ដូច្នេះ ចូរដករបៀបគោរពបម្រើទីមួយចោល ដើម្បីបង្កើតរបៀបគោរពបម្រើទីពីរវិញ។
[10]ហេតុនេះហើយបានជាព្រះជាម្ចាស់ប្រោសយើងបានវិសុទ្ធ តាមរយៈព្រះយេស៊ូគ្រិស្តថ្វាយរូបកាយព្រះអង្គម្តងជាសម្រេច។
[11]ចំណែកឯ បូជាចារ្យគ្រប់រូបឈរបម្រើព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃ។ លោកថ្វាយយញ្ញបូជាដដែលៗ
ទោះបីជាយញ្ញបូជាទាំងនោះពុំអាចដកបាបមនុស្សលោកបានក៏ដោយ។[12]ម៉្យាងវិញទៀត ព្រះគ្រិស្តថ្វាយយញ្ញបូជារំដោះបាបម្តងជាសម្រេច
រួចព្រះអង្គគង់នៅខាងស្តាំព្រះជាម្ចាស់។[13]ព្រះអង្គកំពុងរង់ចាំរហូតទាល់តែសត្រូវរបស់ព្រះជាម្ចាស់ត្រូវបង្ក្រាបដាក់ក្រោមព្រះបាទាព្រះអង្គ។[14]ដ្បិត
ដោយសារតង្វាយមួយបានធ្វើឲ្យអស់អ្នក ដែលព្រះអង្គប្រោសឲ្យបានវិសុទ្ធ បានគ្រប់លក្ខណ៍ជារៀងរហូត។
[15]ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើបន្ទាល់ប្រាប់យើង។ ដ្បិត ព្រះអម្ចាស់មានព្រះបន្ទូលដំបូងថា៖[16]«យើងនឹងចងសម្ពន្ធមេត្រីជាមួយពួកគេ បន្ទាប់ពីពេលនោះកន្លងផុតទៅ
នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ យើងនឹងដាក់ក្រឹត្យវិន័យយើងនៅក្នុងចិត្តពួកគេ ហើយយើងនឹងចារក្រឹត្យវិន័យក្នុងគំនិតពួកគេផងដែរ។
[17]យើងនឹងលែងនឹកនាពីអំពើបាប និងអំពើទុច្ចរិតរបស់ពួកគេទៀតហើយ»។[18]កាលណាមានការអត់ទោសបាប ក៏លែងមានយញ្ញបូជារំដោះបាបទៀតដែរ។
[19]ដូច្នេះ បងប្អូនអើយ យើងមានចិត្តរឹងប៉ឹងចូលទៅទីសក្ការៈបំផុត ដោយពឹងលើព្រះលោហិតព្រះយេស៊ូ។[20]នេះជារបៀបរស់នៅថ្មីមួយ
ដែលព្រះជាម្ចាស់បានបើកសម្រាប់យើង ដោយព្រះអង្គបានឆ្លងកាត់វាំងនន គឺព្រះអង្គបានកើតមកជាមនុស្ស។[21]ដោយសារតែយើងមានមហាបូជាចារ្យដ៏ប្រសើរឧត្តម
គ្រប់គ្រងលើព្រះដំណាក់ព្រះជាម្ចាស់[22]ចូរយើងចូលទៅជិតព្រះអង្គ ដោយចិត្តទៀងត្រង់ ពេញដោយជំនឿ និងមានចិត្តបរិសុទ្ធ បានជម្រះគំនិតសៅហ្មង ព្រមទាំងលាងរូប
កាយដោយទឹកបរិសុទ្ធផង។
[23]ចូរយើងកាន់ចិត្តមាំមួនចំពោះជំនឿ ដែលយើងបានប្រកាសដោយគ្មានរង្គើ ព្រោះព្រះជាម្ចាស់បានសន្យាយ៉ាងណា ព្រះអង្គនឹងសម្រេចយ៉ាងនោះដែរ។
[24]ចូរយើងពិចារណាអំពីរបៀបជំរុញចិត្តគ្នាទៅវិញទៅមក ដោយក្តីស្រឡាញ់ និងអំពើល្អគ្រប់យ៉ាង។[25]ចូរយើងកុំឈប់ជួបជុំគ្នា ដូចដែលអ្នកខ្លះបានធ្វើឡើយ។ ផ្ទុយទៅវិញ
ចូរលើកទឹកចិត្តគ្នាទៅវិញទៅមក រឹតតែច្រើនឡើងៗ ដោយដឹងថាថ្ងៃរបស់ព្រះអម្ចាស់កាន់តែជិតមកដល់ហើយ។
[26]ដ្បិត ប្រសិនបើយើងប្រព្រឹត្តអំពើបាបដោយចេតនា ក្រោយពេលយើងបានទទួលសេចក្តីពិតហើយ នោះគ្មានយញ្ញបូជាណាអាចជួយរំដោះបាបអ្នកបានទេ។[27]ផ្ទុយទៅវិញ
មានតែការភ័យខ្លាចចំពោះការជំនុំជម្រះ និងភ្លើងសន្ធោសន្ធៅឆេះសត្រូវរបស់ព្រះជាម្ចាស់។
[28]បើមាននរណាម្នាក់បដិសេធក្រឹត្យវិន័យរបស់លោកម៉ូសេ នឹងត្រូវស្លាប់ដោយគ្មានត្រាប្រណីឡើយ នៅចំពោះមុខសាក្សីពីរ ឬបីនាក់។[29]តើបងប្អូនគិតថា
ម្នាក់ដែលបានមើលងាយព្រះបុត្រារបស់ព្រះជាម្ចាស់ និងមើលងាយព្រះលោហិតនៃសម្ពន្ធមេត្រី ជាព្រះលោហិតដែលបានប្រោសគេឲ្យវិសុទ្ធ
ព្រមទាំងធ្វើឲ្យព្រះវិញ្ញាណនៃព្រះគុណត្រូវអាម៉ាស់នឹងត្រូវទទួលទោសធ្ងន់យ៉ាងណាទៅទៀត?
[30]ដ្បិត យើងស្គាល់ព្រះជាម្ចាស់ដែលមានព្រះបន្ទូលថា៖ «ការសងសឹកស្រេចលើយើង យើងនឹងតបស្នងដល់គេវិញ»។ ជាថ្មីម្តងទៀត
«ព្រះអម្ចាស់នឹងវិនិច្ឆ័យទោសប្រជារាស្ត្រព្រះអង្គ»។ ហើយជាថ្មីម្តងទៀត «ព្រះអម្ចាស់នឹងវិនិច្ឆ័យទោសប្រជារាស្ត្ររបស់ព្រះអង្គ»។[31]ជាការគួរឲ្យខ្លាចណាស់
ដែលធ្លាក់ចូលក្នុងព្រះហស្តព្រះជាម្ចាស់ដ៏មានព្រះជន្មរស់!
[32]ប៉ុន្តែ ចូរនឹកចាំពីសម័យអតីតកាល បន្ទាប់ពីយើងភ្លឺហើយម្តង។ តើបងប្អូនត្រូវស៊ូទ្រាំនឹងការលំបាកកម្រិតណា។[33]បងប្អូនត្រូវគេប្រមាថមើលងាយ
ដោយទទួលរងការអាម៉ាស់ និងការបៀតបៀន បានសេចក្តីថា បងប្អូនកំពុងតែចូលរួមទុក្ខលំបាកជាមួយអស់អ្នកដែលរងការលំបាកធ្ងន់ធ្ងរ។[34]ដ្បិត
បងប្អូនមានចិត្តក្តួលអាណិតចំពោះជនជាប់ទោស និងទទួលពួកគេដោយអំណរ សុខចិត្តឲ្យគេរឹបអូស យកទ្រព្យសម្បត្តិ។ បងប្អូនដឹងច្បាស់ថា
បងប្អូនសមនឹងទទួលទ្រព្យសម្បត្តិដែលនៅស្ថិតស្ថេរជានិច្ចវិញ។
[35]ដូច្នេះ ចូរកុំបោះបង់ទំនុកចិត្តបងប្អូនឡើយ ព្រោះដល់ពេលកំណត់បងប្អូននឹងទទួលរង្វាន់មិនខាន។[36]បងប្អូនត្រូវចេះអត់ធ្មត់
ដើម្បីឲ្យបងប្អូនអាចទទួលនូវអ្វីដែលព្រះជាម្ចាស់សន្យា ក្រោយពេលបងប្អូនសម្រេចតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ។[37]ដ្បិតនៅពេលបន្តិចទៀត
ព្រះអង្គមួយដែលនឹងយាងមក ព្រះអង្គនឹងយាងមកមិនបង្អង់យូរឡើយ។
[38]បងប្អូនជាមនុស្សសុចរិតរបស់យើង នឹងរស់នៅដោយសារជំនឿ។ បើគេត្រឡប់ក្រោយវិញ យើងនឹងលែងពេញចិត្តគេហើយ។»[39]ប៉ុន្តែ
យើងពុំមែនជាប្រភេទមនុស្សដើរថយក្រោយឲ្យត្រូវវិនាសឡើយ។ ផ្ទុយទៅវិញ យើងជាអ្នកជឿរហូតទាល់តែព្រលឹងបានទទួលការសង្គ្រោះ។

Hebrews 10:1

ប្រយោគភ្ជាប់៖

អ្នកនិពន្ធបង្ហាញពីភាពទន់ខ្សោយនៃច្បាប់ និងយញ្ញបូជា
ហេតុអ្វីព្រះជាម្ចាស់ប្រទានច្បាប់ និងភាពល្អឥតខ្ចោះនៃបព្វជិតភាពថ្មី
និងការលះបង់របស់ព្រះគ្រិស្ត។

ក្រឹត្យវិន័យគ្រាន់តែជាស្រមោលនៃអ្វីៗដែលនឹងត្រូវមកដល់

នេះនិយាយអំពីច្បាប់ដូចជា ស្រមោល។ អ្នកនិពន្ធចង់មានន័យថា
ច្បាប់មិនមែនជារឿងល្អដែលព្រះជាម្ចាស់បានសន្យាទេ។
គឺគ្រាន់តែប្រាប់អំពីរឿងល្អៗ ដែលព្រះជម្ចាស់នឹងធ្វើ។

ពុំមែនជារបស់ប្រចក្សទេ

«មិនមែនជារបស់ពិតរបស់ពួកគេទេ»

មួយឆ្នាំម្តងជាបន្តបន្ទាប់

«ជារៀងរាល់ឆ្នាំ»

បើពួកគេបានគ្រប់លក្ខណ៍មែន ពួកគេលែងថ្វាយទៀតហើយ?

អ្នកនិពន្ធប្រើសំណួរមួយដើម្បីបញ្ជាក់ថា
ការលះបង់ត្រូវបានកំណត់ដោយអំណាចរបស់ពួកគេ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:

«ពួកគេនឹងឈប់ផ្តល់ការបូជា»

លែង

«បានបញ្ឈប់»

ដូចគ្នានេះដែរ

«ក្នុងស្ថានភាពនោះ»

ប្រសិនបើ ពួកគេបានស្អាតបរិសុទ្ធ

អំពើបាបរបស់មនុស្សអាចនិយាយបានថា

generated on Wed Sep 10 16:16:32 2025

ដូចជាពួកគេបានលាងសំអាតរាងកាយចេញ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ប្រសិនបើព្រះជាម្ចាស់បានអត់ទោសបាបរបស់ពួកគេរួចហើយ»
នឹងលែងរំឭកថា
«ដឹងថាពួកគេលែងមានទោសពីអំពើបាបទៀតហើយ»
ដ្បិត ឈាមគោឈ្មោល និងឈាមពពែពុំអាចដកបាបមនុស្សលោកបានទេ
អំពើបាបត្រូវបានគេនិយាយថា ជាវត្ថុដែលឈាមសត្វអាចហូរចេញនៅពេលហូរ។
របៀបផ្សេងទៀតនៃការបកប្រែ: «ព្រោះឈាមគោឈ្មោល
និងឈាមពពែមិនអាចធ្វើឲ្យព្រះជាម្ចាស់អត់ទោសបាបបានឡើយ»
ឈាមគោឈ្មោល និងឈាមពពែ
ត្រង់ថា «ឈាម» សំដៅទៅលើសត្វទាំងនេះស្លាប់ជាយញ្ញបូជាដល់ព្រះជាម្ចាស់។
Hebrews 10:5
ព័ត៌មានទូទៅ៖
ព្រះបន្ទូលរបស់ព្រះគ្រិស្ត
នៅពេលដែលព្រះអង្គនៅលើផែនដីត្រូវបានទាយទុកនៅក្នុងការដកស្រង់ចេញពីកាន់គម្ពីរ
ព្រះអង្គចង់បាន
ត្រង់ថា «ព្រះអង្គ» គឺជាឯកវចន: ហើយសំដៅទៅលើព្រះជាម្ចាស់។
បានធ្វើ
«បានធ្វើរួមហើយ»
រួចមក ទូលបង្គំពោលថា
ត្រង់ថា «ទូលបង្គំ» សំដៅទៅលើព្រះយេស៊ូគ្រិស្ត។
ដូចមានសេចក្ដីចែងទុកពីទូលបង្គំនៅក្នុងគម្ពីរថា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចពួកហោរាបានសរសេរអំពីទូលបង្គំនៅក្នុងក្រាំង»
ក្រាំង
នេះមានន័យថាបទគម្ពីរ ឬសំណេរបរិសុទ្ធ។
Hebrews 10:8
ព័ត៌មានទូទៅ៖
ទោះជាមានការផ្លាស់ប្តូរពាក្យបន្តិចបន្តួច
ក៏ដោយអ្នកនិពន្ធបានដកស្រង់ពាក្យទាំងនេះចេញពីកាន់គម្ពីរ
យញ្ញបូជា...តង្វាយ..តង្វាយដុតទាំងមូល...យញ្ញបូជារំដោះបាប
សូមបកប្រែពាក្យទាំងនេះដូចជាអ្នកបានបកប្រែនៅក្នុងជំពូក ១០:៥។
ទាំងអស់នេះត្រូវថ្វាយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលបូជាចារ្យថ្វាយ»
មើល
«មើល» ឬ «ស្តាប់»
ចូរដកពរបៀបគោរពបម្រើទីមួយចោល
នាមអរូបី «គោរព» នេះសំដៅទៅលើវិធីនៃការធ្វើដង្វាយលោះសម្រាប់អំពើបាប។
ការបញ្ឈប់ការធ្វើ ត្រូវបានគេនិយាយ ដូចជាវត្ថុដែលអាចត្រូវបានដកចេញ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ឈប់ថ្វាយដង្វាយលោះសំរាប់អំពើបាបទីមួយចោល»
គោរពបម្រើទីមួយ...គោរពបម្រើទីពីរ
ពាក្យថា «ទីមួយ» និង «ទីពីរ» គឺលេខលំដាប់។ របៀបផ្សេងទៀតនៃការបកប្រែ:
«គោរពបម្រើចាស់..គោរពបម្រើថ្មី»
យើងបានវិសុទ្ធ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បាបរាប់យើងជាបរិសុទ្ធ» ឬ
«ព្រះយាម្ចាស់បានប្រគល់យើងទៅកាន់ព្រះអង្គផ្ទាល់»
តាមរយៈព្រះយេស៊ូគ្រិស្តថ្វាយរូបកាយព្រះអង្គ
នាមអរូបី «ការថ្វាយ» អាចត្រូវបានបង្ហាញជាមួយកិរិយាស័ព្ទ «ថ្វាយ» ឬ
«ការលះបង់»។ របៀបផ្សេងទៀតនៃការបកប្រែ: «នៅពេលដែលព្រះយេស៊ូគ្រិស្ត
បានថ្វាយព្រះកាយរបស់ព្រះអង្គជាយញ្ញបូជា» ឬ
«ពីព្រោះព្រះយេស៊ូគ្រិស្តបានបូជាព្រះជន្មរបស់ព្រះអង្គ»
Hebrews 10:11
ចំណែកឯ...ម៉្យាងវិញទៀត
ឃ្លាទាំងនេះត្រូវបានប្រើដើម្បីប្រៀបធៀបរឿងពីរ។
ក្នុងភាសារបស់អ្នកអាចមានវិធីដើម្បីបញ្ជាក់ថា អ្នកនិពន្ធកំពុងធ្វើការប្រៀបធៀប។
ឬអ្នកអាចទុកពាក្យ «ចំណែកឯ» ចោល ហើយបកប្រែ «ម៉្យាងវិញទៀត»
គ្រាន់តែជាពាក្យ «ប៉ុន្តែ» បានហើយ។
ពីមួយថ្ងៃទៅមួយថ្ងៃ
«ពីមួយថ្ងៃទៅមួយថ្ងៃ» ឬ «ជារៀងរាល់ថ្ងៃ»
ពុំអាចដកបាបមនុស្សលោកបាន
នេះនិយាយអំពី «អំពើបាប» ប្រសិនបើ ជាវត្ថុដែលមនុស្សម្នាក់អាចយកទៅឆ្ងាយ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មិនអាចធ្វើអោយព្រះជាម្ចាស់អត់ទោសបាបបានឡើយ»
ព្រះអង្គគង់នៅខាងស្តាំព្រះជាម្ចាស់
ត្រង់ថា «ខាងស្តាំ» សំដៅទៅលើទីកន្លែងកិត្តិយស។
របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះអង្គគង់នៅកន្លែងកិត្តិយសនៅក្បែរព្រះជាម្ចាស់»។
សូមមើលរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុងជំពូក ១:១។
រហូតទាល់តែសត្រូវរបស់ព្រះជាម្ចាស់ត្រូវបង្ក្រាបដាក់ក្រោមព្រះបាទាព្រះអង្គ
ការខ្មាស់អៀនរបស់ខ្មាំងសត្រូវរបស់ព្រះគ្រិស្តត្រូវបានគេនិយាយ
ថាជាកម្រាលតម្កល់ព្រះបាទារបស់ព្រះអង្គ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«រហូតដល់ព្រះជាម្ចាស់ធ្វើឲ្យខ្មាំងសត្រូវរបស់ព្រះគ្រិស្តអាម៉ាស់
ហើយពួកគេបានក្លាយកំណល់កល់ព្រះបាទារបស់ព្រះអង្គ»
ប្រោសឲ្យបានវិសុទ្ធ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«អស់អ្នកណាដែលព្រះជាម្ចាស់កំពុងធ្វើឲ្យបរិសុទ្ធ» ឬ
«អ្នកដែលព្រះបានប្រគល់ព្រះអង្គផ្ទាល់»
Hebrews 10:15
ព័ត៌មានទូទៅ៖
នេះជាការដកស្រង់ចេញពីកាន់គម្ពីរហោរាយេរេមានៅក្នុងគម្ពីរសញ្ញាចាស់។
ជាមួយពួកគេ
«ជាមួយប្រជាជនរបស់យើង»
បន្ទាប់ពីពេលនោះកន្លងផុតទៅ
«ពេលកំណត់នៃសម្ពន្ធមេត្រីទីមួយជាមួយប្រជារាស្ត្ររបស់យើងបានចប់សព្វគ្រប់ហើយ» (UDB)
ដាក់ច្បាប់ទាំងនោះនៅក្នុងចិត្តពួកគេ
ហើយយើងនឹងចារក្រឹត្យវិន័យក្នុងគំនិតពួកគេផងដែរ
ដួងចិត្ត និងគំនិតរបស់មនុស្សត្រូវបានគេនិយាយដូចជាច្បាប់របស់ព្រះជាម្ចាស់
បានដាក់ ឬសរសេរនៅលើច្បាប់ទាំងនោះ។ របៀបផ្សេងទៀតនៃការបកប្រែ:
«យើងនឹងធ្វើឲ្យពួកគេយល់ពីច្បាប់របស់យើង
ហើយយើងនឹងធ្វើឲ្យពួកគេគោរពតាម» (UDB)
Hebrews 10:17
ព័ត៌មានទូទៅ៖
នេះជាការដកស្រង់ចេញពីកាន់គម្ពីរហោរាយេរេមានៅក្នុងគម្ពីរសញ្ញាចាស់។
នឹងលែងនឹកនាពីអំពើបាប និងអំពើទុច្ចរិតរបស់ពួកគេទៀតហើយ
នេះគឺជាផ្នែកទីពីរនៃទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធ
នឹងលែងនឹកនាពីអំពើបាប
«យើងនឹងមិនចាំពីអំពើបាបរបស់ពួកគេទៀតទេ» ឬ
«យើងនឹងមិនគិតអំពីអំពើបាបរបស់ពួកគេទៀតទេ»
អំពើបាប និងអំពើទុច្ចរិត
ពាក្យថា «អំពើបាប» និង «អំពើទុច្ចរិត» មានន័យជាមូលដ្ឋានរឿងដូចគ្នា។
ពាក្យទាំងពីរនេះរួមគ្នាសង្កត់ធ្ងន់ ថាតើអំពើបាបគឺអាក្រក់ប៉ុណ្ណា។
របៀបផ្សេងទៀតនៃការបកប្រែ: «បាបកម្ម អំពើអាក្រក់»
កាលណាមាន
នេះមិនមានន័យថា «នៅពេលនេះ» ទេ
ប៉ុន្តែត្រូវបានប្រើដើម្បីយកចិត្តទុកដាក់ទៅចំណុចសំខាន់ដែលនៅខាងក្រោម។
មានការអត់ទោសបាប
នេះអាចប្រើឡើងវិញ ដូច្នេះនាមអរូបី «ការអភ័យទោស»
គឺបានបង្ហាញជាកិរិយាស័ព្ទ «អត់ទោស»។ របៀបផ្សេងទៀតនៃការបកប្រែ:
«នៅពេលដែលព្រះជាម្ចាស់បានអត់ទោសគ្រប់រឿងទាំងនេះ»
លែងមានយញ្ញបូជារំដោះបាបទៀតដែរ
នេះអាចប្រើឡើងវិញ ដូច្នេះនាមអរូបី «ថ្វាយយញ្ញ បូជា»
គឺបានបង្ហាញជាកិរិយាស័ព្ទ «ធ្វើតង្វាយ»។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សលែងត្រូវការតង្វាយសម្រាប់អំពើបាបទៀតហើយ»
Hebrews 10:19

generated on Wed Sep 10 16:16:32 2025

ប្រយោគភ្ជាប់៖
ដោយបានបញ្ជាក់យ៉ាងច្បាស់ថា មានតែយញ្ញបូជាតែមួយសម្រាប់អំពើបាប
អ្នកនិពន្ធនៅតែបន្តរូបភាពនៃទីសក្ការៈបំផុតនៅក្នុងព្រះវិហារ
ដែលមានតែមហាបូជាចារ្យប៉ុណ្ណោះ ដែលអាចចូលក្នុងមួយឆ្នាំៗ
ដោយឈាមនៃយញ្ញបូជាសម្រាប់អំពើបាប។ លោកបានរំលឹកអ្នកជឿថា
ពួកគេឥឡូវថ្វាយបង្គំព្រះជាម្ចាស់នៅក្នុងវត្តមានរបស់ព្រះអង្គ
ប្រសិនបើពួកគេត្រូវបានគេឈរនៅក្នុងទីសក្ការៈបំផុត។
បងប្អូនអើយ
ត្រង់នេះមានន័យថា អ្នកជឿលើព្រះគ្រីស្ទមិនថាប្រុស ឬស្រី។
របៀបផ្សេងទៀតនៃការបកប្រែ: «បងប្អូនប្រុសស្រី» ឬ «គ្ឺគ្នាអ្នកជឿ»
ទីសក្ការៈបំផុត
នេះមានន័យថា
វត្តមានរបស់ព្រះជាម្ចាស់មិនមែននៅកន្លែងបរិសុទ្ធបំផុតនៅក្នុងត្រសាលចាស់ទេ។
ដោយពឹងលើព្រះលោហិតព្រះយេស៊ូ
ត្រង់ថា «ព្រះលោហិតព្រះយេស៊ូ» សំដៅទៅលើការសុគតរបស់ព្រះយេស៊ូ។
របៀបរស់នៅ
អាចមានន័យថាទី១) គឺ
វិធីថ្មីនេះចំពោះព្រះជាម្ចាស់ដែលព្រះយេស៊ូបានផ្តល់លទ្ធផលដល់អ្នកជឿដែលរស់នៅជាមួយនឹងព្រះអង្គ
ទី២) គឺ ព្រះយេស៊ូមានព្រះជន្មរស់ ហើយព្រះអង្គគឺជា
មាគ៌ាដែលអ្នកជឿចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់។
ឆ្លងកាត់វាំងនន
វាំងននៅក្នុងព្រះវិហារនៅលើផែនដី តំណាងឲ្យការបែកចែករវាងមនុស្ស
និងវត្តមានពិតរបស់ព្រះជាម្ចាស់។
គឺព្រះអង្គបានកើតមកជាមនុស្ស
ត្រង់ថា «ជាមនុស្ស» សំដៅទៅរូបរាងកាយរបស់ព្រះយេស៊ូ
ហើយព្រះកាយរបស់ព្រះអង្គ តំណាងឲ្យការលះបង់ព្រះជន្មរបស់ព្រះអង្គ។
របៀបផ្សេងទៀតនៃការបកប្រែ: «តាមរយៈការសុគតរបស់ព្រះអង្គ»
យើងមានមហាបូជាចារ្យដ៏ប្រសើរឧត្តម គ្រប់គ្រងលើព្រះដំណាក់ព្រះជាម្ចាស់
នេះត្រូវតែបកប្រែតាមរបៀប ដើម្បីឲ្យច្បាស់ថា ព្រះយេស៊ូជា «មហាបូជាចារ្យ»។
គ្រប់គ្រងលើព្រះដំណាក់
«ទទួលបន្ទុកលើព្រះដំណាក់»
ព្រះដំណាក់ព្រះជាម្ចាស់
នេះនិយាយអំពីរាស្ត្ររបស់ព្រះដូចជា ពួកគេជាព្រះដំណាក់ពិត។
របៀបផ្សេងទៀតនៃការបកប្រែ: «ប្រជារាស្ត្រទាំងអស់របស់ព្រះជាម្ចាស់»
ចូរយើងចូលទៅជិត
ត្រង់ថា «ចូលទៅជិត» តំណាងឲ្យការសំរាប់ថ្វាយបង្គំព្រះជាម្ចាស់
ដូចជាបូជាចារ្យដែលឡើងទៅលើអាសនៈរបស់ព្រះជាម្ចាស់ដើម្បីបូជាសត្វអោយគាត់។
ដោយចិត្តទៀងត្រង់
«ដួងចិត្តស្មោះត្រង់» ឬ «ចិត្តស្មោះត្រង់»។ ត្រង់ថា «ចិត្ត»
តំណាងឲ្យឆន្ទៈពិតប្រាកដ និងការលើកទឹកចិត្តរបស់អ្នកជឿ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដោយស្មោះ»
ពេញដោយជំនឿ
«ដោយជំនឿជឿជាក់» ឬ «ជឿទុកចិត្តលើព្រះយេស៊ូទាំងស្រុង»
មានចិត្តបរិសុទ្ធ បានជម្រះគំនិតសៅហ្មង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាព្រះអង្គបានធ្វើឲ្យចិត្តរបស់យើងស្អាតដោយព្រះលោហិតរបស់ព្រះអង្គ»
បានជម្រះគំនិតសៅហ្មង
ត្រង់ថា «គំនិត» តំណាងឱ្យមនសិការការយល់ដឹងអំពីអ្វីដែលត្រឹមត្រូវ និងខុស។
ត្រូវបានស្អាតស្អំ តំណាងឲ្យការអភ័យទោស និងបានផ្តល់ឋានៈនៃសេចក្តីសុចរិត។
ដួងចិត្តអាចនិយាយថា ពួកគេបានសំអាតដោយឈាម។
បានជម្រះ
ការប្រោះទឹកគឺជាសកម្មភាពនិមិត្តរូបដែលធ្វើឡើងដោយពួកបូជាចារ្យ
ដែលពួកគេអនុវត្តអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងចំពោះមនុស្ស និងវត្ថុ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែពាក្យនេះនៅក្នុងជំពូក ៨:១៨។
ព្រមទាំងលាងរូបកាយដោយទឹកបរិសុទ្ធផង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាគាព្រះអង្គបានលាងសំអាតរាងកាយរបស់យើងក្នុងទឹកបរិសុទ្ធ» (UDB)
លាងរូបកាយដោយទឹកបរិសុទ្ធផង
ប្រសិនបើអ្នកបកប្រែយល់ឃ្លានេះសំដៅទៅលើ
ពិធីបុណ្យជ្រមុជទឹករបស់គ្រិស្តបរិស័ទនោះ «ទឹក»
គឺន័យត្រង់មិនមែនជាន័យធៀបទេ។ ប៉ុន្តែប្រសិនបើទឹកត្រូវបានយកជាន័យត្រង់
បន្ទាប់មកពាក្យ «សុទ្ធ»
គឺជាន័យធៀបឈរសម្រាប់ភាពបរិសុទ្ធខាងវិញ្ញាណដែលពិធីបុណ្យជ្រមុជទឹកត្រូវបានគេនិយាយនៅទីនេះ
«ការលាងសំអាត» តំណាងឲ្យអ្នកជឿដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។
Hebrews 10:23
កាន់ចិត្តមាំមួនចំពោះជំនឿ ដែលយើងបានប្រកាស
នៅទីនេះផ្នែកនៃជំនឿ ដែលមនុស្សសារភាពត្រូវបានគេនិយាយ
ដូចជាវត្ថុដែលមនុស្សអាចកាន់នៅក្នុងដៃរបស់គេ។ ឃ្លាថា «កាន់ចិត្តមាំមួន»
មានន័យថា «បន្ត»។ របៀបផ្សេងទៀតនៃការបកប្រែ: «បន្តប្រាប់ប្រជាជនថា
យើងមានទំនុកចិត្តពីព្រោះយើងជឿជាក់ថាព្រះជាម្ចាស់នឹងធ្វើតាមអ្វីដែលព្រះអង្គបានសន្យា»
ដោយគ្មានរង្គើ
ការមិនប្រាកដប្រជាអំពីអ្វីមួយត្រូវបានគេនិយាយ ដូចជាគេវង្វេងស្មារតី
ឬងាកពីម្ខាងទៅម្ខាងទៀត។ របៀបផ្សេងទៀតនៃការបកប្រែ: «ដោយមិនប្រាកដ»
ឬ «ដោយគ្មានការសង្ស័យ»
ចូរយើងកុំឈប់ជួបជុំគ្នា
អ្នកអាចបញ្ជាក់យ៉ាងច្បាស់ថា ប្រជាជនបានជួបជុំគ្នាដើម្បីគោរពបូជា។
របៀបផ្សេងទៀតនៃការបកប្រែ: «កុំអោយយើងឈប់មករួមគ្នាដើម្បីគោរពបូជា»
ដោយដឹងថាថ្ងៃរបស់ព្រះអម្ចាស់កាន់តែជិតមកដល់ហើយ
ពេលអនាគតត្រូវបានគេនិយាយថា ជាវត្ថុដែលខិតជិតអ្នកនិយាយ។ ត្រង់ថា «ថ្ងៃ»
សំដៅទៅលើពេលដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញ។
របៀបផ្សេងទៀតនៃការបកប្រែ: «ដូចដែលអ្នកដឹងថា
ព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញឆាប់ៗ»
Hebrews 10:26
ប្រយោគភ្ជាប់៖
បន្ទាប់មកអ្នកនិពន្ធបានផ្តល់ការព្រមានលើកទីបួនរបស់គាត់។
ចេតនា
«ដោយចេតនា»
ក្រោយពេលយើងបានទទួលសេចក្តីពិតហើយ
ចំណេះដឹងអំពីសេចក្តីពិតត្រូវបាននិយាយដូចជា វត្ថុដែលអាចផ្តល់
ដោយមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ របៀបផ្សេងទៀតនៃការបកប្រែ:
«ក្រោយពេលយើងបានរៀនពីការពិត»
សេចក្តីពិត
សេចក្តីពិតអំពីព្រះ។
នោះគ្មានយញ្ញបូជាណាអាចជួយរំដោះបាបអ្នកបានទេ
គ្មាននរណាម្នាក់អាចថ្វាយយញ្ញបូជាថ្មីបានទេ
ពីព្រោះការលះបង់របស់ព្រះគ្រិស្តគឺជា អង្គតែមួយដែលធ្វើការ។
របៀបផ្សេងទៀតនៃការបកប្រែ: «គ្មាននរណាម្នាក់អាចផ្តល់ការលះបង់
ដែលព្រះជាម្ចាស់នឹងលើកលែងទោសបាបរបស់ឲ្យយើងទេ»
យញ្ញបូជាណាអាចជួយរំដោះបាប
ត្រង់ថា «យញ្ញបូជាណាអាចជួយរំដោះបាប» តំណាងឲ្យ
«មធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការលះបង់សត្វ ដើម្បីដកបាប»
ការជំនុំជម្រះ
អំពីការជំនុំជំរះរបស់ព្រះជាម្ចាស់នោះគឺថា ព្រះជាម្ចាស់នឹងជំនុំជម្រះ។
ភ្លើងសន្ធោសន្ធៅឆេះសត្រូវរបស់ព្រះជាម្ចាស់
សេចក្តីក្រោធរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយដូចជា
ភ្លើងដែលនឹងឆាបឆេះសត្រូវរបស់ព្រះអង្គ។
Hebrews 10:28
នៅចំពោះមុខសាក្សីពីរ ឬបីនាក់
ការបង្កប់ន័យនេះមានន័យថា «យ៉ាងហោចណាស់មានសាក្សីពីរ ឬបីនាក់»។
តើបងប្អូនគិតថា ម្នាក់ដែលបានមើលងាយព្រះបុត្រារបស់ព្រះជាម្ចាស់...នៃព្រះគុណ?
អ្នកនិពន្ធកំពុងសង្កត់ធ្ងន់លើភាពអស្ចារ្យនៃការដាក់ទណ្ឌកម្ម
ចំពោះអ្នកដែលបដិសេធព្រះគ្រិស្ត។ របៀបផ្សេងទៀតនៃការបកប្រែ:
«នេះជាទណ្ឌកម្មធ្ងន់ធ្ងរ»
ប៉ុន្តែការដាក់ទណ្ឌកម្មនឹងកាន់តែធំសម្រាប់អ្នកណានរម្នាក់...ព្រះគុណ!»
មើលងាយព្រះបុត្រារបស់ព្រះជាម្ចាស់
ការមិនគោរពព្រះគ្រិស្ត និងប្រមាថមើលងាយព្រះអង្គត្រូវបានគេនិយាយដូចជា
មាននរណាម្នាក់បានដើរលើព្រះអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានបដិសេធព្រះរាជបុត្រានៃព្រះជាម្ចាស់»

generated on Wed Sep 10 16:16:32 2025

ព្រះបុត្រារបស់ព្រះជាម្ចាស់
នេះគឺជា ឋានៈសំខាន់សម្រាប់ព្រះយេស៊ូ។
មើលងាយព្រះលោហិតនៃសម្ពន្ធមេត្រី ជាព្រះលោហិតដែលបានប្រោសគេឲ្យវិសុទ្ធ
ការបង្ហាញនេះអំពី មនុស្សដែលបានមើលងាយព្រះបុត្រារបស់ព្រះជាម្ចាស់។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដោយចាត់ទុកព្រះលោហិតនៃសម្ពន្ធមេត្រីថាមិនបរិសុទ្ធ»
ព្រះលោហិតនៃសម្ពន្ធមេត្រី
ត្រង់ថា «ព្រះលោហិត» តំណាងឲ្យការសុគតរបស់ព្រះជាម្ចាស់
ដែលព្រះជាម្ចាស់បានសម្ពន្ធមេត្រីថ្មី។
ជាព្រះលោហិតដែលបានប្រោសគេឲ្យវិសុទ្ធ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះលោកហិត ដែលព្រះជាម្ចាស់បានរាប់ជាបរិសុទ្ធ»
ព្រះវិញ្ញាណនៃព្រះគុណ
«ព្រះវិញ្ញាណនៃព្រះជម្ចាស់ដែលផ្តល់ព្រះគុណ»
Hebrews 10:30
ព័ត៌មានទូទៅ៖
ពាក្យថា «យើង» ត្រង់នេះសំដៅទៅលើអ្នកនិពន្ធ និងអ្នកជឿទាំងអស់។
ការដកស្រង់ទាំងពីរនេះចេញមកពីច្បាប់
ដែលលោកម៉ូសេបានអោយនៅក្នុងព្រះគម្ពីរសញ្ញាចាស់។
ការសងសឹកស្រេចលើយើង
ការសងសឹកត្រូវបានគេនិយាយដូចជា វត្ថុដែលជាកម្មសិទ្ធិរបស់ព្រះជម្ចាស់
ដែលមានសិទ្ធិធ្វើដូចដែលព្រះអង្គចង់បានជាមួយនឹងអ្វីដែលព្រះអង្គមាន។
ព្រះជាម្ចាស់មានសិទ្ធិសងសឹកសត្រូវរបស់ព្រះអង្គ។
យើងនឹងតបស្នងដល់គេវិញ
ព្រះជាម្ចាស់សងសឹក អាចយាយបានថា
ព្រះអង្គបានអោយប្រាក់ឈ្នួលដែលគេសមនឹងទទួល។
ធ្លាក់ចូលក្នុងព្រះហស្ត
ការទទួលទណ្ឌកម្មពីព្រះជាម្ចាស់ទាំងស្រុងអាចនិយាយថា
ដូចជាមនុស្សនោះធ្លាក់ចូលក្នុងព្រះហស្តរបស់ព្រះជាម្ចាស់។ ត្រង់ថា «ព្រះហស្ត»
សំដៅទៅលើអំណាចរបស់ព្រះជាម្ចាស់ ដើម្បីវិនិច្ឆ័យ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដើម្បីទទួលទណ្ឌកម្មពេញលេញរបស់ព្រះជាម្ចាស់»
Hebrews 10:32
សម័យអតីតកាល
«ពេលវេលាក្នុងអតីតកាល»
បន្ទាប់ពីយើងភ្លឺហើយម្តង
ការរៀនពីសេចក្តីពិតអាចនិយាយបានថា ព្រះជាម្ចាស់បានបំភ្លឺមកលើមនុស្ស។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«បន្ទាប់ពីអ្នកបានរៀនសេចក្តីពិតអំពីព្រះគ្រិស្ត»
តើបងប្អូនត្រូវស៊ូទ្រាំនឹងការលំបាកកម្រិតណា
«តើអ្នកត្រូវស៊ូទ្រាំនឹងទុក្ខលំបាកប៉ុន្មាន»
បងប្អូនត្រូវគេប្រមាថមើលងាយ ដោយទទួលរងការអាម៉ាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ មនុស្សចំអកអ្នកដោយការជេរប្រមាថ
និងធ្វើទុក្ខបុកម្នេញអ្នកនៅទីសាធារណៈ»
បងប្អូនកំពុងតែចូលរួមទុក្ខលំបាកជាមួយអស់អ្នកដែល
«អ្នកបានចូលរួមជាមួយអ្នកទាំងនោះ»
សមនឹងទទួលទ្រព្យសម្បត្តិដែលនៅស្ថិតស្ថេរជានិច្ចវិញ
ព្រះពរដ៏អស់កល្បរបស់ព្រះជាម្ចាស់ត្រូវបាននិយាយថាជា «កម្មសិទ្ធិ»។
Hebrews 10:35
ព័ត៌មានទូទៅ៖
នៅក្នុងជំពូក ១០:៣៧
គឺជាការដកស្រង់ចេញពីកាន់គម្ពីរហោរាអេសាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់។
ចូរកុំបោះបង់ទំនុកចិត្តបងប្អូនឡើយ ព្រោះដល់ពេលកំណត់បងប្អូននឹងទទួលរង្វាន់មិនខាន
ការបដិសេធការសន្យាត្រូវបានគេនិយាយថា
ដូចជាការបោះចោលអ្វីមួយដែលគ្មានតម្លៃ ឬគ្មានប្រយោជន៍។
របៀបផ្សេងទៀតនៃការបកប្រែ:
«ចូរកុំឈប់ជឿទុកចិត្តលើព្រះជាម្ចាស់ដែលនឹងផ្តល់រង្វាន់ដល់អ្នក» ឬ
«ទុកចិត្តទាំងស្រុងលើព្រះជាម្ចាស់ដែលនឹងឲ្យរង្វាន់ដល់អ្នក»
ដ្បិតនៅពេលបន្តិចទៀត
អ្នកអាចធ្វើឲ្យការនេះកាន់តែច្បាស់។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចព្រះបានមានព្រះបន្ទូលនៅក្នុងបទគម្ពីរថា ក្នុងពេលដ៏ខ្លីនេះ»
នៅពេលបន្តិចទៀត
«យ៉ាងឆាប់»
Hebrews 10:38
ព័ត៌មានទូទៅ៖
នៅក្នុងជំពូក ១០:៣៨ អ្នកនិពន្ធដកស្រង់ចេញពីកាន់គម្ពីរហោរាហាបាគុក
ដែលធ្វើតាមការដកស្រង់ពីកាន់គម្ពីរហោរាអេសាយនៅក្នុងជំពូក ១០:៣៧។
បងប្អូនជាមនុស្សសុចរិតរបស់យើង...បើគេត្រឡប់ក្រោយវិញ...គេហើយ
ទាំងនេះសំដៅទៅលើរាស្ត្រណាមួយរបស់ព្រះជាម្ចាស់ជាទូទៅ។
របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សសុចរិតរបស់យើង...ប្រសិនបើអ្នកណាម្នាក់ក្នុងចំណោមពួកគេប្រែ ...
ជាមួយមនុស្សនោះ» ឬ «មនុស្សសុចរិតយើង ... ប្រសិនបើពួកគេងាក ...
ជាមួយពួកគេ»
បងប្អូនជាមនុស្សសុចរិតរបស់យើង...យើងនឹង
ត្រង់ថា «របស់យើង» និង «យើង» សំដៅទៅព្រះជាម្ចាស់។
បើគេត្រឡប់ក្រោយវិញ
ការបាត់បង់ភាពក្លាហាន
និងជំនឿត្រូវបានគេនិយាយដូចជាកំពុងងាកចេញពីផ្លូវមួយ។
ជាប្រភេទមនុស្សដើរថយក្រោយឲ្យត្រូវវិនាសឡើយ
ការបាត់បង់ភាពក្លាហាន
និងជំនឿត្រូវបានគេនិយាយដូចជាកំពុងងាកចេញពីផ្លូវមួយ។ ហើយ «ការបំផ្លាញ»
ត្រូវបានគេនិយាយថា ជាទិសដៅ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកណាឈប់ទុកចិត្តលើព្រះជាម្ចាស់នឹងធ្វើឲ្យព្រះអង្គបំផ្លាញយើង»
ព្រលឹងបានទទួលការសង្គ្រោះ
ការរស់នៅជារៀងរហូតជាមួយព្រះជាម្ចាស់ត្រូវបានគេនិយាយដូចជា
កំពុងរក្សាព្រលឹងរបស់មនុស្សម្នាក់។ ត្រង់ថា «ព្រលឹង»
សំដៅទៅលើមនុស្សទាំងមូល។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលនឹងនាំឲ្យយើងរស់នៅជាមួយព្រះជាម្ចាស់ជារៀងរហូត»

---

11 [1]ឥឡូវនេះ ជំនឿគឺជាការសង្ឃឹមជាក់ ថានឹងបានដូចការរំពឹងទុក។ ជំនឿជាភស្តុតាងនូវព្រឹត្តការណ៍ទាំងឡាយណា ដែលយើងមើលពុំឃើញនៅឡើយ។
[2]ដោយហេតុនេះហើយបានជាបុព្វបុរស បានទទួលកេរ្តិ៍ឈ្មោះល្អដោយសារជំនឿ។[3]ដោយសារជំនឿ យើងយល់ថា ព្រះជាម្ចាស់បង្កើតពិភពលោកទាំងមូល
ដោយសារព្រះបន្ទូល ដូច្នេះ អ្វីៗដែលមើលឃើញនឹងភ្នែក ពុំមែនកើតឡើងដោយអ្វីៗមានរូបរាងឡើយ។
[4]ដោយសារជំនឿ លោកអេបិលបានថ្វាយយញ្ញបូជា ដ៏ប្រសើរជាងយញ្ញបូជាលោកកាអ៊ីនទៅព្រះជាម្ចាស់។ ដោយសារជំនឿ ព្រះជាម្ចាស់រាប់លោកជាមនុស្ស សុចរិត។
ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងតង្វាយរបស់លោក ហើយដោយសារជំនឿ លោកនៅតែមានប្រសាសន៍នៅឡើយ ទោះបីលោកបានស្លាប់ទៅហើយក៏ដោយ។
[5]ដោយសារជំនឿ ព្រះជាម្ចាស់បានលើកលោកហេណុកឡើងទៅ ទាំងលោកនៅមិនទាន់ស្លាប់ផង។ «គ្មាននរណារកលោកឃើញឡើយ
ព្រោះព្រះជាម្ចាស់បានលើកលោកឡើង»។ មុនពេលព្រះជាម្ចាស់លើកលោកឡើងទៅ លោកបានទទួលសក្ខីភាពថា ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងលោក។[6]ឥឡូវនេះ
បើគ្មានជំនឿទេ គ្មាននរណាគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ ដ្បិត អស់អ្នកណាដែលចូលទៅរកព្រះជាម្ចាស់ អ្នកនោះចាំបាច់ត្រូវជឿថា
មានព្រះជាម្ចាស់មែន ហើយថាព្រះអង្គនឹងប្រទានរង្វាន់ ដល់អស់អ្នកណាស្វែងរកព្រះអង្គ។
[7]ដោយសារជំនឿ លោកណូអេបានទទួលព្រះរាជសារពីស្ថានបរមសុខ នូវហេតុការណ៍ទាំងឡាយណា ដែលពុំទាន់មើលឃើញនៅឡើយ ដោយការស្តាប់បង្គាប់ព្រះជាម្ចាស់
លោកបានសង់ទូកដ៏ធំដើម្បីសង្គ្រោះក្រុមគ្រួសារលោក។ ដោយបានធ្វើដូច្នេះ លោកបានដាក់ទោសពិភពលោក និងក្លាយជាមនុស្សសុចរិតទុកជាមរតក ដោយសារជំនឿ។
[8]ដោយសារជំនឿ ពេលព្រះជាម្ចាស់បានត្រាស់ហៅលោកអប្រាហាំលោកស្តាប់បង្គាប់ព្រះអង្គ ដោយចាកចេញទៅកន្លែងមួយ ដែលលោកនឹងទទួលទុកជាមរតក។ លោក
ចេញទៅទាំងពុំដឹងថា ត្រូវទៅណាផង។[9]ដោយសារជំនឿ លោកបានមករស់នៅទឹកដីសន្យា ក្នុងនាមជាជនបរទេស។ លោកបានបោះជំរំនៅជាមួយលោកអ៊ីសាក និង

generated on Wed Sep 10 16:16:32 2025

លោកយ៉ាកុប ជាអ្នកត្រូវទទួលទឹកដីនោះជាមរតករួមជាមួយលោក តាមព្រះបន្ទូលសន្យាដដែល។[10]ដ្បិតលោកទន្ទឹងរង់ចាំទទួលក្រុងមួយ ដែលមានគ្រឹះរឹងមាំ គឺជាក្រុង
ដែលព្រះជាម្ចាស់ជាស្ថាបត្យករ និងសាងសង់។
[11]ដោយសារជំនឿ ទោះបីលោកស្រីសារ៉ាជាស្ត្រីអារក៏ដោយ ក៏លោកអប្រាហាំបានទទួលសមត្ថភាពធ្វើជាឪពុកដែរ។ ហេតុការណ៍នេះកើតឡើង
ទោះបីលោកមានវ័យចាស់ក៏ដោយ លោកយល់ថាព្រះជាម្ចាស់ស្មោះត្រង់ និងសម្រេចតាមព្រះបន្ទូលសន្យា។[12]ដូច្នេះ ដោយសារតែបុរសម្នាក់ដែលហៀបនឹងស្លាប់ទៅហើយ
ក៏កើតមានមនុស្សជាច្រើនរាប់មិនអស់ ដូចផ្កាយនៅលើមេឃ និងដូចគ្រាប់ខ្សាច់នៅមាត់សមុទ្រ។
[13]ដោយសារជំនឿ អស់លោកទាំងនោះបានស្លាប់ទៅ ដោយពុំបានទទួលអ្វីតាមព្រះបន្ទូលសន្យាឡើយ។ ផ្ទុយទៅវិញ លោកបានឃើញ និងទទួលពីចម្ងាយថា
លោកគ្រាន់តែជាជនបរទេស ធ្វើដំណើរនៅលើផែនដីតែប៉ុណ្ណោះ។[14]ដ្បិត អស់អ្នកដែលបាននិយាយដូច្នោះ បង្ហាញថាពួកលោកកំពុងតែស្វែងរកមាតុភូមិរបស់ខ្លួន។
[15]ប្រសិនបើ ពួកលោកគិតដល់ប្រទេសដែលពួកលោកបានចាកចេញ ពួកលោកប្រាកដជាមានឱកាសត្រឡប់មកវិញបាន។[16]ប៉ុន្តែ
ពួកលោកប្រាថ្នាទៅរស់នៅប្រទេសមួយប្រសើរជាងនេះ គឺស្ថានបរមសុខ។ ហេតុដូចនេះ បានជាព្រះជាម្ចាស់មិនអាម៉ាស់នឹងឲ្យគេហៅថា ព្រះជាម្ចាស់របស់ពួកគេឡើយ
ព្រោះព្រះអង្គបានរៀបចំទីក្រុងមួយសម្រាប់ពួកគេ។
[17]ដោយសារជំនឿ លោកអប្រាហាំថ្វាយអ៊ីសាកជាយញ្ញបូជា ពេលព្រះជាម្ចាស់សាកល្បងចិត្តលោក។ លោកថ្វាយអ៊ីសាកដែលជាកូនតែមួយគត់
ដែលលោកបានទទួលតាមព្រះបន្ទូលសន្យា។[18]ទោះបីជាព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «លោកអ៊ីសាកនឹងបន្តពូជពង្សជាច្រើនយ៉ាងក៏ដោយ»។[19]ក៏លោកអប្រាហាំជឿថា
ព្រះជាម្ចាស់អាចនឹងប្រោសអ៊ីសាកឲ្យរស់ពីស្លាប់វិញបាន ហើយដោយហេតុនេះ លោកបានទទួលកូនមកវិញ។
[20]ដោយសារជំនឿ លោកអ៊ីសាកបានឲ្យពរលោកយ៉ាកុបនិងអេសាវ ទុកសម្រាប់អនាគត។[21]ដោយសារជំនឿ លោកយ៉ាកុបហៀបនឹងស្លាប់ទៅហើយ
ក៏បានឲ្យពរកូនៗរបស់លោកយ៉ូសែប។ លោកយ៉ាកុបថ្វាយបង្គំព្រះជាម្ចាស់ ដោយផ្អែកលើឈើច្រត់របស់លោក។[22]ដោយសារជំនឿ
លោកយ៉ូសែបជិតនឹងលាលោកនេះទៅហើយ បានប្រកាសថា កូនចៅអ៊ីស្រាអែលនឹងត្រូវចាកចេញពីប្រទេសអេស៊ីប
ហើយប្រាប់ពួកគេពីរបៀបរៀបចំទុកដាក់ឆាតុរបស់លោក។
[23]ដោយសារជំនឿ ពេលលោកម៉ូសេកើតមក ឪពុកម្តាយលោកបានយកលោកទៅលាក់ទុកចំនួនបីខែ ព្រោះលោកឃើញថា កូននោះស្អាតខ្លាំងណាស់។
ពួកគេមិនខ្លាចបញ្ជារបស់ស្តេចឡើយ។[24]ដោយសារជំនឿ លោកម៉ូសេធំពេញវ័យឡើង ហ៊ានបដិសេធមិនឲ្យគេហៅលោកថា កូនរបស់បុត្រីព្រះចៅផារ៉ោនឡើយ។
[25]ផ្ទុយទៅវិញ លោកបានជ្រើសរើសរងទុក្ខលំបាករួមជាមួយប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជាជាងរស់នៅសប្បាយនឹងអំពើបាបតែមួយរយៈខ្លី។[26]លោកយល់ថា
រងការប្រមាថព្រោះតែដើរតាមព្រះគ្រិស្ត ប្រសើរជាងបានទ្រព្យសម្បត្តិនានានៅអេស៊ីបទៅទៀត។ ដ្បិត លោកសម្លឹងមើលរង្វាន់មកពីព្រះជាម្ចាស់វិញ។
[27]ដោយសារជំនឿ លោកម៉ូសេបានចាកចេញពីប្រទេសអេស៊ីប។ លោកមិនបានខ្លាចស្តេចខ្ញាល់ឡើយ លោកស៊ូទ្រាំនឹងទុក្ខលំបាក
ដោយលោកសម្លឹងមើលឃើញព្រះជាម្ចាស់ ដែលមនុស្សមើលពុំឃើញ។[28]ដោយសារជំនឿ លោករក្សាពិធីបុណ្យរំលង និងពិធីប្រោះឈាម
ដើម្បីកុំឲ្យមច្ចុរាជបំផ្លាញកូនច្បងរបស់អ៊ីស្រាអែល។
[29]ដោយសារជំនឿ ជនជាតិអ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម ដូចដើរលើគោក។ ពេលពួកអេស៊ីបខំឆ្លងមកដែរ តែត្រូវទឹកសមុទ្រគ្របពីលើស្លាប់អស់។[30]ដោយសារជំនឿ
ជញ្ជាំងក្រុងយេរីខូដួលរំលំចុះ បន្ទាប់ពីពួកអ៊ីស្រាអែលដើរជុំវិញប្រាំពីរថ្ងៃ។[31]ដោយសារជំនឿ នាងរ៉ាហាបជាស្ត្រីពេស្យាពុំបានស្លាប់ជាមួយពួកមិនស្តាប់បង្គាប់ឡើយ
ព្រោះនាងបានទទួលអ្នកស៊ើបការដោយមេត្រី។
[32]តើខ្ញុំអាចនិយាយអ្វីបានខ្លះទៀត? ខ្ញុំគ្មានពេលនិយាយអំពីរឿងលោកគេឌាន លោកបារ៉ាក់ លោកសាំសុន លោកយ៉ែបថា ព្រះបាទដាវីឌ លោកសាំយូអែល និងព្យាការី
នានាទៀតទេ។[33]ដោយសារជំនឿ លោកទាំងនោះបានច្បាំងឈ្នះនគរផ្សេងៗ ប្រព្រឹត្តអំពើសុចរិត និងទទួលអ្វីៗដែលព្រះជាម្ចាស់សន្យាប្រទានមក។ ពួកគេបានបិទមាត់
សឹង្ហ[34]ពន្លត់ភ្លើងឆេះសន្ធោសន្ធៅ និងគេចផុតពីមុខដាវ និងបានជាសះស្បើយពីជំងឺ មានកម្លាំងច្បាំងឈ្នះសង្គ្រាម ព្រមទាំងផ្តួលសត្រូវបរទេសឲ្យខ្លាចបាក់ទ័ព។
[35]ស្ត្រីៗបានឃើញគ្រួសារខ្លួន ដែលស្លាប់ទៅហើយនោះរស់ឡើងវិញ។ អ្នកខ្លះទទួលទារុណកម្ម មិនព្រមឲ្យគេដោះលែងឡើយ ដើម្បីទទួលបានជីវិតរស់ឡើងវិញប្រសើរ
ជាង។[36]អ្នកខ្លះទៀតសុខចិត្តឲ្យគេចំអកឡកឡឺយ គេវាយដំ ព្រមទាំងឲ្យគេដាក់ច្រវាក់ឃុំឃាំងថែមទៀតផង។[37]អ្នកខ្លះត្រូវគេគប់សម្លាប់នឹងដុំថ្ម។ អ្នកខ្លះត្រូវគេសម្លាប់
ដោយអារនឹងរណារ។ អ្នកខ្លះត្រូវគេសម្លាប់ដោយដាវ។ អ្នកខ្លះមានតែស្បែកចៀម និងស្បែកពពែបិទបាំងខ្លួន។ អ្នកខ្លះខ្វះខាតសព្វគ្រប់ទាំងអស់ ត្រូវគេជិះជាន់
សង្កត់សង្កិន និងធ្វើបាបថែមទៀតផង។[38]លោកីយ៍ពុំស័ក្តិសមនឹងឲ្យអ្នកនោះរស់នៅជាមួយឡើយ។ ដូច្នេះ ពួកគេត្រាច់ចរតាមទីរហោស្ថាន តាមភ្នំ តាមរូងភ្នំ និងតាមរអាង
ភ្នំជាដើម។
[39]ទោះបីព្រះជាម្ចាស់បានទទួលអ្នកទាំងនោះដោយសារជំនឿក្តី ក៏គេពុំទាន់បានទទួលអ្វីៗតាមព្រះបន្ទូលសន្យាដែរ។[40]ព្រះជាម្ចាស់គ្រោងទុកថា នឹងប្រទានអ្វីៗដ៏ល្អប្រសើរ
មកយើង ដូច្នេះ បើគ្មានយើងទេ អ្នកទាំងនោះពុំបានគ្រប់លក្ខណ៍ឡើយ។

Hebrews 11:1

ប្រយោគភ្ជាប់៖

អ្នកនិពន្ធប្រាប់រឿងបីយ៉ាងអំពីជំនឿលើសេចក្តីណែនាំខ្លីនេះ។

ឥឡូវនេះ

ពាក្យនេះត្រូវបានប្រើនៅទីនេះ ដើម្បីសម្គាល់ការសម្រាកនៅក្នុងការបង្រៀនគោល។
នៅទីនេះអ្នកនិពន្ធចាប់ផ្តើមពន្យល់ពីអត្ថន័យនៃ «ជំនឿ»។

ជំនឿគឺជាការសង្ឃឹមជាក់ ថានឹងបានដូចការរំពឹងទុក

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«សេចក្តីជំនឿគឺជា
អ្វីដែលអាចអោយមនុស្សម្នាក់ទទួលបាននូវការរំពឹងទុកលើអ្វីដែលជឿជាក់លាក់»

បានដូចការរំពឹងទុក

ត្រង់នេះបញ្ជាក់យ៉ាងច្បាស់អំពីការសន្យារបស់ព្រះជាម្ចាស់
ជាពិសេសការជឿជាក់ថា
អ្នកជឿលើព្រះយេស៊ូទាំងអស់នឹងរស់នៅជាមួយព្រះជាម្ចាស់ជារៀងរហូតនៅឯស្ថានសួគ៌

មើលពុំឃើញនៅឡើយ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ដែលយើងនៅតែមិនបានឃើញ» ឬ «ដែលនៅតែមិនទាន់កើតឡើង»

ដោយហេតុនេះហើយ

«ពីព្រោះពួកគេប្រាកដអំពីព្រឹត្តិការណ៍ដែលមិនបានកើតឡើង»

បានជាបុព្វបុរស បានទទួលកេរ្តិ៍ឈ្មោះល្អដោយសារជំនឿ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាម្ចាស់បានយល់ព្រមនឹងបុព្វបុរសរបស់យើងដោយសារពួកគេមានជំនឿ»

ជាបុព្វបុរស

អ្នកនិពន្ធកំពុងនិយាយទៅកាន់ប្រជាជនហេព្រើរអំពី បុព្វបុរសរបស់ហេព្រើរ។
នេះអាចត្រូវបានគេនិយាយថាយ៉ាងសកម្មថា
«ព្រះជាម្ចាស់មិនបានសម្រេចធ្វើការអាក្រក់អ្វីទាំងអស់»។
ហើយព្រះអង្គផ្ទាល់ក៏មិនល្បួងនរណាម្នាក់ដែរ
«ហើយព្រះអង្គផ្ទាល់ក៏មិនល្បួងនរណាម្នាក់ឲ្យធ្វើការអាក្រក់ដែរ»។
James 1:14
គ្រប់គ្នាទទួលការល្បួងដោយសារបំណងចិត្ត និងភាពលោភលន់របស់ខ្លួនវិញ
បំណងចិត្តរបស់មនុស្សម្នាក់ត្រូវបានគេនិយាយ
ហាក់ដូចជានរណាម្នាក់ផ្សេងទៀតដែលកំពុងអូសទាញគេឲ្យប្រព្រឹត្តបាប។
ដែលបានអូសទាញ និងលួងលោមបញ្ឆោតប៉ុណ្ណោះ
គេនៅតែបន្តនិយាយថាបំណងចិត្តរបស់ការអាក្រក់គឺហាក់ដូចជាមនុស្សទៀតដែលអាចអូសយកមនុស្សផ្សេងទៀតឲ្យធ្វើបាប។
ការបោកបញ្ឆោត
ការទាក់ទាញ ការបង្ខំឲ្យនរណាម្នាក់ធ្វើការអាក្រក់។
បន្ទាប់ពីបំណងចិត្តចាប់ទុំក្នុងផ្ទៃ វានឹងសម្រាលចេញមកជាអំពើបាប
ហើយក្រោយពីបាបនោះបានលូតលាស់ធំហើយ វានឹងប្រសូតជាសេចក្តីស្លាប់
គេនៅតែបន្តនិយាយថាបំណងចិត្តគឺជាមនុស្ស ពេលនេះប្រាកដណាស់
ដែលជាស្ត្រីម្នាក់ដែលមានផ្ទៃពោះជាមួយនឹងកូនតូចមួយ។
ក្មេងតូចនេះគឺត្រូវបានគេស្គាល់ថាជាអំពើបាប។
អំពើបាបគឺជាទារិការម្នាក់ទៀតដែលធំឡើង មានផ្ទៃពោះ
ហើយប្រសូតជាសេចក្តីស្លាប់។
ច្រវ៉ាក់នៃការប្រៀបធៀបនេះគឺជារូបភាពរបស់នរណាម្នាក់ដែលបញ្ចប់ដោយការស្លាប់ទាំងរូបកាយ
និងព្រលឹងវិញ្ញាណ ដោយសារតែការអាក្រក់ និងអំពើបាបរបស់គេ។
សូមកុំច្រឡំ
«សូមកុំឲ្យនរណាម្នាក់បោកបញ្ឆោតអ្នកឡើយ» ឬ
«កុំបោកបញ្ឆោតខ្លួនឯងឡើយ»។
James 1:17
អំណោយដ៏ល្អៗទាំងឡាយ និងអំណោយដ៏គ្រប់លក្ខណៈ
ឃ្លាទាំងពីរនេះមានន័យសំខាន់ដូចគ្នា។
លោកយ៉ាកុបប្រើឃ្លាទាំងពីរនេះដើម្បីបញ្ជាក់ថា
ការល្អគឺជាបុគ្គលម្នាក់ដែលមកពីព្រះជាម្ចាស់។
ព្រះបិតានៃពន្លឺ
ព្រះជាម្ចាស់ គឺជាសត្តនិករនៃពន្លឺទាំងអស់នៅលើមេឃ
ព្រះអង្គមិនប្រែប្រួលឡើយ សូម្បីតែស្រមោលនៃការប្រែប្រួលក៏គ្មានផង
រូបភាពនៃការបញ្ជាក់នេះ ព្រះជាម្ចាស់ គឺជាពន្លឺដែលមិនចេះប្រែប្រួល
ដែលខុសពីព្រះអាទិត្យ ព្រះចន្ទ ភព និងតារាផ្សេងៗទៀតដែលឆ្លងកាត់ផ្ទៃមេឃ
គឺតែងតែផ្លាស់ប្តូរពន្លឺរបស់ពួកគេ។ ព្រះជាម្ចាស់មិនដែលផ្លាស់ប្រែដូចជាព្រះអាទិត្យ
ព្រះចន្ទ និងហ្វូងតារាដែលតែងតែលិចឡើង លិចចុះ។
ព្រះអង្គប្រទានដល់យើង
ពាក្យថា "យើង" គឺសំដៅលើលោកយ៉ាកុប និង មនុស្សរបស់គាត់។
ព្រះអង្គបង្កើតយើងមក
ព្រះជាម្ចាស់បាននាំយកជីវិតដ៏អស់កល្បដល់យើង
គឺជាជីវិតដែលទ្រង់បានប្រទានដល់យើង។
ព្រះបន្ទូលនៃសេចក្តីពិត
ព្រះបន្ទូលនៃសេចក្តីពិតរបស់ជាម្ចាស់។ នេះគឺមានន័យថា
ជាព្រះបន្ទូលដែលបានបង្កើតយើងមក។
ជាផលដំបូង
លោកយ៉ាកុបកំពុងប្រើគំនិតបុរាណរបស់ជនជាតិហេព្រើរនៃផលផ្លែដំបូងជាវិធីដើម្បីពន្យល់ពីតម្លៃរបស់គ្រិ
លោកបានបញ្ជាក់ថា នឹងមានអ្នកជឿបន្ថែមទៀតនៅក្នុងថ្ងៃអនាគត។
James 1:19
បងប្អូនសុទ្ធតែដឹងហើយ
ន័យដែលអាចទៅរួចគឺ ១) «ដឹងស្រាប់ហើយ» ជាបញ្ញត្តិ
ដើម្បីឲ្យផ្តោតអារម្មណ៍ទៅលើអ្វីខ្ញុំបម្រុងនឹងសរសេរ ឬក៏ ២) «បងប្អូនសុទ្ធតែដឹង
ហើយ»
ជាឃ្លាមួយដែលខ្ញុំបម្រុងនឹងរំលឹកដល់អ្នកទាំងអស់គ្នាពីអ្វីដែលអ្នកដឹងរួចហើយ។
សូមឲ្យគ្រប់គ្នារហ័សនឹងស្តាប់ តែយឺតនឹងនិយាយ ហើយយឺតនឹងខឹងផងដែរ
មនុស្សគ្រប់គ្នាគួរតែស្តាប់ដោយយកចិត្តជាមុនសិន
រួចពិចារណាដោយប្រុងប្រយ័ត្នពីអ្វីដែលពួកគេបាននិយាយ «យឺតនឹងនិយាយ»
មិនមែនមានន័យថានិយាយយឺតៗទេ។
យឺតនឹងខឹង
«មិនងាយនឹងខឹងងាយៗ»
កំហឹងរបស់មនុស្សមិនអាចធ្វើតាមសេចក្តីសុចរិតនៃព្រះជាម្ចាស់ឡើយ
នៅបុគ្គលម្នាក់ខឹង គេមិនអាចធ្វើតាមសេចក្តីសុចរិតនៃព្រះឡើយ
ចូរដាក់អំពើបាបគ្រប់យ៉ាង និងចិត្តឃោរឃៅឲ្យនៅមួយឡែក
អំពើបាប និង
ចិត្តឃោរឃៅនៅទីនេះគឺហាក់ដូចជាកម្មបទមួយដែលអាចត្រូវបានដាក់នៅមួយឡែក
ឬចេញឆ្ងាយ។ (សូមមើលៈfigs-metaphor)
ចូរលះបង់នូវអំពើបាបគ្រប់យ៉ាង និងចិត្តឃោរឃៅទាំងនោះចោលចេញទៅ
កាបញ្ជាក់នៅទីនេះ «អំពើបាបគ្រប់យ៉ាង» និង «ចិត្តឃោរឃៅ»
គឺមានន័យស្រដៀងនឹងគ្នា។
ដើម្បីបញ្ជាក់ថាអំពើបាបវាអាក្រក់ប៉ុណ្ណោះ។
«សូមឈប់ប្រព្រឹត្តវិប្បាបថដែលជាអំពើបាបទៀត»។
អំពើបាបគ្រប់យ៉ាង
នៅទីនេះ «ការអាក្រក់» គឺជា «សេចក្តីស្មោកគ្រោក ដែលសំដៅទៅលើអំពើបាប
និងសេចក្តីអាក្រក់»។
ចូរបន្ទាបខ្លួន
«គ្មានមោទនភាព» ឬ «គ្មានការអួតអាង»។
ទទួលការបំប៉នពីព្រះបន្ទូល
ឃ្លានេះមានន័យថា «ការបំប៉ន» មានន័យថា
ដាក់អ្វីមួយនៅក្នុងរបស់អ្វីផ្សេងទៀត។

generated on Wed Sep 10 16:16:32 2025

ព្រះបន្ទូលព្រះជាម្ចាស់នៅក្នុងកន្លែងនេះគឺមានន័យថា
ជារុក្ខជាតិដែលដុះនៅក្នុងអ្នកដែលមានជំនឿ។
«សូមគោរពនៅអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលទៅកាន់អ្នកចុះ»។
ទទួលការបំប៉នពីព្រះបន្ទូល
នៅកន្លែងនេះ «ពាក្យ» គឺជា «ព្រះបន្ទូលរបស់ព្រះជាម្ចាស់
ដែលសំដៅទៅលើព្រះបន្ទូលនៃសេចក្តីសង្គ្រោះរបស់តាមរយៈព្រះយេស៊ូគ្រិស្តដែលព្រះជាម្ចាស់បានបន្ទូលទៅកាន់អស់អ្នកដែលជឿ។
នៅពេលដែលពួកគេជឿ ព្រះជាម្ចាស់នឹងសង្គ្រោះពួកគេ។
សង្គ្រោះព្រលឹងរបស់បងប្អូន
អ្វីដែលមនុស្សត្រូវបានសង្គ្រោះ អាចត្រូវបានគេបង្កើតយ៉ាងពិតប្រាកដមែន។
«ជួសសង្គ្រោះអ្នកពីការជំនុំជម្រះរបស់ព្រះជាម្ចាស់»។
ព្រលឹងវិញ្ញាណ
ពាក្យថា «ព្រលឹង» នៅកន្លែងនេះគឺសំដៅទៅបុគ្គលម្នាក់ៗ។
James 1:22
ចូរធ្វើតាមព្រះបន្ទូល
ពួកគេត្រូវធ្វើតាមអ្វីដែលជាបញ្ញត្តិរបស់ព្រះជាម្ចាស់។
បញ្ឆោតចិត្តខ្លួនឯង
«បោកបញ្ឆោតខ្លួនឯង»
អ្នកណាស្តាប់ព្រះបន្ទូលមិនប្រតិបត្តិតាម អ្នកនោះប្រៀបដូចជាមនុស្ស ដែលឆ្លុះកញ្ចក់មើលមុខខ្លួន
បុគ្គលដែលឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយ តែមិនបានគោរពតាមអ្នកនោះ
ប្រៀបដូចជាមនុស្ស ដែលឆ្លុះកញ្ចក់មើលមុខខ្លួន
ក្រោយមកក៏ភ្លេចថាខ្លួនឯងដូចអ្វីនោះទេ។ (សូមមើលfigs-simile)
មុខរបស់ខ្លួនឯង
មុខរបស់ខ្លួនឯងដូចអ្វីឲ្យប្រាកដ
ពិនិត្យមើលខ្លួនឯងរួចហើយ ស្រាប់តែភ្លេចទៅវិញភ្លាម
បុគ្គលដែលពិនិត្យមើលមុខខ្លួនឯងហើយ ស្រាប់តែភ្លេចទៅវិញ
នោះប្រៀបដូចជាមនុស្សដែលបានឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយ
ស្រាប់ភ្លេចពីអ្វីដែលគេបានឮ។
អ្នកដែលមើលដោយយកចិត្តទុកដាក់ ចំពោះក្រឹត្យវិន័យ
ឃ្លានេះបន្តថា រូបភាពនៃក្រឹតវិន័យប្រៀបដូចជាកញ្ចក់។
សេរីភាពដ៏គ្រប់លក្ខណៈ
«ក្រឹតវិន័យដ៏គ្រប់លក្ខណៈបានអនុញ្ញាតិឲ្យមនុស្សធ្វើអ្វីដេ ោយសេរី។»
អ្នកនោះនឹងបានពរក្នុងកិច្ចការដែលខ្លួនធ្វើ
នេះត្រូវបានគេនិយាយតាមបែបសកម្មថា
«ព្រះជាម្ចាស់នឹងប្រទានពរដល់អ្នកនោះដែលធ្វើតាមក្រឹតវិន័យរបស់ព្រះអង្គ»។
James 1:26
គិតថាខ្លួនជាអ្នកកាន់សាសនា
«គិតថាខ្លួនឯងជាអ្នកថ្វាយបង្គំព្រះយ៉ាងត្រឹមត្រូវ»។
អណ្តាតខ្លួនឯង
ការគ្រប់អណ្តាតខ្លួនឯង សំដៅលើការគ្រប់គ្រងលើសម្តីរបស់ខ្លួនឯង
«អ្វីដែលទ្រង់មានបន្ទូល»
ការបោកបញ្ឆោត
«ការបោកបញ្ឆោត» ឬ «ការយល់ខុស»។
ចិត្តរបស់ខ្លួនឯង
នៅទីនេះ «ចិត្ត» សំដៅទៅលើជំនឿ ឬ គំនិតរបស់គេ «ខ្លួនឯង»។
សាសនារបស់ខ្លួនឯងគឺគ្មានតម្លៃ
«គាត់ថ្វាយបង្គំព្រះដោយឥតប្រយោជន៍»។
វិសុទ្ធ និងគ្មានកន្លែងបន្ទោស
លោកយ៉ាកុបនិយាយពីសាសនា ដែលជាវិធីមួយសម្រាប់ថ្វាយបង្គំព្រះ
តាមរយៈរូបកាយដ៏វិសុទ្ធ ហើយគ្មានទាស់សោះឡើយ។
ទាំងនេះជាវិធីបុរាណសម្រាប់ជនជាតិយូដាដែលនិយាយពីអ្វីដែលអាចទៅរួចចំពោះព្រះជាម្ចាស់។
នៅចំពោះព្រះភក្ត្រព្រះបិតា
មានទំនាក់ទំនងផ្ទាល់ជាមួយព្រះជាម្ចាស់។
ក្មេងកំព្រា
«ក្មេងកំព្រា»
ស្ត្រីមេម៉ាយដែលមានទុក្ខលំបាក
ស្ត្រីដែលមានទុក្ខលំបាកដោយសារតែស្វាមីបានស្លាប់បង់ជីវិត។
រក្សាខ្លួនឲ្យល្អ ចៀសចេញពីអំពើសៅហ្មងរបស់លោកីយ៍នេះ
សូមកុំអនុញ្ញាតិឲ្យការអាក្រក់ក្នុងលោកីយធ្វើឲ្យអ្នកប្រព្រឹត្តិអំពើបាប។

---

2 [1]បងប្អូនអើយ សូមកុំឲ្យជំនឿលើព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តនៃយើង និងព្រះអម្ចាស់ប្រកបដោយសិរីរុងរឿង បែបលំអៀងទៅលើមនុស្សមួយចំនួននោះឡើយ។[2]ឧបមាថា នរណាម្នាក់ចូលរួមប្រជុំ មានពាក់ចិញ្ចៀនមាស និងមានសម្លៀកបំពាក់ស្អាត ហើយម្នាក់ទៀតជាអ្នកក្រ ស្លៀកពាក់មិនសមរម្យ។[3]ប្រសិនបើបងប្អូនរាក់ទាក់ទទួលអ្នកស្លៀកពាក់ស្អាតល្អ ទាំងនិយាយថា៖ «សូមលោកអញ្ជើញមកអង្គុយនៅកន្លែងកិត្តិយសនេះ» ប៉ុន្តែ និយាយទៅកាន់អ្នកក្រថា៖ «ចូលអ្នកឈរនៅទីនោះ» ឬថា៖ «មកអង្គុយនៅខាងក្រោមកន្លែងខ្ញុំដាក់ជើងវិញ»[4]តើធ្វើបែបនេះបងប្អូនមិនមែនលំអៀងទេឬអី? តើបងប្អូនមិនបានវិនិច្ឆ័យគេដោយគំនិតអាក្រក់ទេឬអី?។
[5]សូមស្តាប់! បងប្អូនជាទីស្រឡាញ់អើយ តើព្រះជាម្ចាស់មិនបានជ្រើសរើសអ្នកក្រក្នុងលោកនេះ ឲ្យទៅជាអ្នកមានក្នុងជំនឿ ហើយឲ្យទទួលមរតកនៃព្រះរាជ្យ ដែលព្រះអង្គបានសន្យា ដល់អស់អ្នកដែលស្រឡាញ់ព្រះអង្គទេឬ?[6]ប៉ុន្តែ បងប្អូនបែរជាមិនឲ្យតម្លៃអ្នកក្រទៅវិញ! តើមិនមែនពួកអ្នកមានទេឬ ដែលបានសង្កត់សង្កិនបងប្អូន? តើពួកគេមិនបានអូសបងប្អូនយកទៅឲ្យតុលាការទេ?[7]តើអ្នកទាំងនោះមិនបានប្រមាថព្រះនាមដ៏ប្រសើរ ដែលជារបស់បងប្អូនទេឬ?។
[8]ប្រសិនបើបងប្អូនប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ ព្រះគម្ពីរចែងថា៖ «អ្នកត្រូវស្រឡាញ់អ្នកជិតខាង ឲ្យដូចស្រឡាញ់ខ្លួនឯងដែរ» ទើបបានល្អ។[9]ប៉ុន្តែ ប្រសិនបើបងប្អូនឲ្យតម្លៃតែមនុស្សមួយចំនួន បងប្អូនបានប្រព្រឹត្តបាបហើយ ក្រឹត្យវិន័យរាប់ថាបងប្អូនជាអ្នកល្មើសច្បាប់។
[10]ដ្បិតនរណាដែលប្រព្រឹត្តតាមក្រឹត្យវិន័យទាំងអស់ ប៉ុន្តែ បើអ្នកនោះភ្លាំងភ្លាត់នៅក្នុងការតែមួយ
នោះគាត់នឹងត្រឡប់ទៅ ជាមានទោសក្នុងការប្រព្រឹត្តខុសក្រឹត្យវិន័យទាំងមូលដែរ។[11]ដ្បិតមានសេចក្តីចែងមកថា៖ «កុំប្រព្រឹត្តអំពើផិតក្បត់» ហើយថា៖ «កុំសម្លាប់មនុស្ស»។ បើសិនជា អ្នកមិនប្រព្រឹត្តអំពើផិតក្បត់ទេ ប៉ុន្តែបែរជាសម្លាប់គេ នោះបានសេចក្តីថា អ្នកប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យហើយ។
[12]ដូច្នេះ ចូរនិយាយ និងប្រព្រឹត្តដូចអ្នកទាំងនោះដែលនឹងទទួលការវិនិច្ឆ័យតាមន័យរបស់ក្រឹត្យវិន័យនៃសេរីភាព។
[13]ដ្បិតអ្នកកាត់ក្តីនឹងវិនិច្ឆ័យដោយពុំមានការយល់យោកចំពោះអ្នកធ្វើខុស ហើយគ្មានក្តីមេត្តាដល់អស់អ្នកដែលគ្មានមេត្តាឡើយ។
ដ្បិតសេចក្តីមេត្តាករុណានឹងយកជោគជ័យលើការវិនិច្ឆ័យ។
[14]ប្រសិនបើមាននរណាម្នាក់និយាយថា ខ្លួនមានជំនឿ ប៉ុន្តែ មិនបានធ្វើការល្អទេ នោះតើមានប្រយោជន៍អ្វី? តើជំនឿនោះអាចសង្គ្រោះគាត់បានឬ?[15]ឧបមាថា បងប្អូនប្រុសស្រីណាម្នាក់ គ្មានសម្លៀកបំពាក់ល្អ និងគ្មានម្ហូបអាហារហូបពេញមួយថ្ងៃ។[16]ឧបមាថា មានម្នាក់ក្នុងចំណោមអ្នករាល់គ្នា និយាយទៅកាន់ពួកគេថា «សូមអញ្ជើញទៅដោយសុខសាន្តចុះ ហើយភាពមានកក់ក្តៅ និងសូមឲ្យអ្នកបានឆ្អែតចុះ»។ ប្រសិនបើជាអ្នកមិនបានឲ្យអ្វី ដែលជាតម្រូវការពួកគេទេ តើពាក្យទាំងនោះមានប្រយោជន៍អ្វី?[17]បើគ្មានការប្រព្រឹត្តទេ ជំនឿនោះនឹងស្លាប់។
[18]ប៉ុន្តែ មានអ្នកខ្លះនិយាយថា៖ «អ្នកមានជំនឿ ឯខ្ញុំវិញមានការប្រព្រឹត្តវិញ»។ សូមបង្ហាញជំនឿគ្មានមានការប្រព្រឹត្តឲ្យខ្ញុំឃើញផង នោះខ្ញុំនឹងបង្ហាញឲ្យអ្នកឃើញជំនឿរបស់ខ្ញុំ ដោយការប្រព្រឹត្ត។[19]អ្នកពិតជាបានជឿថា មានព្រះជាម្ចាស់តែមួយ គឺត្រឹមត្រូវហើយ។ ប៉ុន្តែ ពួកអារក្សក៏ជឿដូច្នេះដែរ ហើយពួកវាភ័យញាប់ញ័រផងដែរ។
[20]តើបងប្អូនដឹងតែថា មនុស្សឥតប្រាជ្ញា និងជំនឿគ្មានការប្រព្រឹត្ត ជាជំនឿឥតបានការអ្វីទាំងអស់?
[21]តើមិនមែនលោកអប្រាហាំជាឪពុករបស់យើង បានរាប់ជាសុចរិតដោយការប្រព្រឹត្ត កាលលោកបានយកអ៊ីសាកជាកូនទៅថ្វាយជាយញ្ញបូជាលើអាសនៈទេឬអី?[22]ជំនឿរបស់លោកបានរួមផ្សំនឹងការប្រព្រឹត្ត ហើយតាមរយៈការប្រព្រឹត្តនោះ ធ្វើឲ្យជំនឿរបស់លោកបានពេញលក្ខណៈ។[23]«លោកអប្រាហាំជឿលើព្រះជាម្ចាស់ ហើយព្រះអង្គរាប់លោកជាសុចរិត» ហើយលោកក៏បានហៅថាជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ដែរ។[24]បងប្អូនឃើញទេ ព្រះជាម្ចាស់រាប់មនុស្សឲ្យសុចរិត ដោយសារប្រព្រឹត្តដែរ គឺមិនមែនដោយសារ តែជំនឿមួយមុខនោះទេ។
[25]ដូចគ្នានេះដែរ តើមិនមែននាងរ៉ាហាបជាស្ត្រីពេស្យាទេឬអី ដែលបានសុចរិត ដោយសារការប្រព្រឹត្តរបស់នាង ព្រោះនាងបានទទួលពួកអ្នកនាំសារ ឲ្យស្នាក់នៅ ហើយឲ្យគេចាកចេញទៅវិញ តាមផ្លូវមួយផ្សេងទៀត?[26]ដ្បិតបើរូបកាយដាច់ចេញពីវិញ្ញាណ រូបកាយនោះនឹងស្លាប់ ហើយជំនឿគ្មានការប្រព្រឹត្ត ក៏ជាជំនឿស្លាប់ដែរ។

generated on Wed Sep 10 16:16:32 2025

James 2:1

ប្រយោគភ្ជាប់

លោកយ៉ាកុបនៅតែបន្តប្រាប់ដល់អ្នកមានជំនឿជនជាតិយូដាដែលបានបែកខ្ញែកពីរបៀបនៅទីនោះដោយការប្រឡាយប្រឡែងដើម្បីកែតម្រូវអ្នកអានរបស់គាត់។ ហើយរំលឹកពួកគេកុំឲ្យយកចិត្តអ្នកមានជាងបងប្អូនជាទីទាល់ក្រ។

បងប្អូនរបស់ខ្ញុំអើយ

លោកយ៉ាកុបបានពិចារណាពីអ្នកដែលស្តាប់គាត់ដែលបានក្លាយជាអ្នកជឿជនជាតិយូដាថា «អស់អ្នកដែលមានជំនឿរបស់យើងអើយ» ឬ «បងប្អូននៅក្នុងព្រះគ្រិស្តរបស់ខ្ញុំអើយ»។

សូមមានជំនឿលើព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តនៃយើង

ការដែលមានជំនឿលើព្រះគ្រិស្តគឺហាក់ដូចជាកម្មបទមួយដែលយើងអាចកាន់បាន។

ព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តនៃយើង

ពាក្យថា «របស់យើង» រួមទាំង លោកយ៉ាកុបនិងអ្នកដែលស្តាប់លោកទាំងអស់។

ដោយក្តីអនុគ្រោះដល់មនុស្សមួយចំនួន

បំណងដែលជួយមនុស្សមួយចំនួនជាងអ្នកណាផ្សេងទៀត

ឧបមាថា នរណាម្នាក់

លោកយ៉ាកុបបានផ្តើមពន្យល់ពីស្ថានភាពនៃទីកន្លែងមួយដែលអ្នកដែលអ្នកមានជំនឿ[illegible]

ពាក់ចិញ្ចៀនមាស និងមានសម្លៀកបំពាក់ស្អាត

«ស្លៀកពាក់ដូចជាអ្នកមាន»

មកអង្គុយនៅទីនេះជាកន្លែងថ្លៃថ្នូរ

មកអង្គុយនៅកន្លែងកិត្តិយសនេះ

ចូលអ្នកឈរនៅទីនោះ

ចូលទៅទីកន្លែងដែលគ្មានកិត្តិយស

មកអង្គុយនៅខាងក្រោមកន្លែងខ្ញុំដាក់ជើងវិញ

ចូលទៅទីកន្លែងដែលបន្ទាបខ្លួន

តើធ្វើបែបនេះបងប្អូនមិនមែនលំអៀងទេឬអី? តើបងប្អូនមិនបានវិនិច្ឆ័យគេដោយគំនិតអាក្រក់ទេឬអី?

លោកយ៉ាកុបកំពុងប្រើសំណួរបំភ្លៃដើម្បីបង្រៀន ព្រមទាំងអាចស្តីបន្ទោសដល់អ្នកអានរបស់គាត់។ «អ្នកកំពុងវិនិច្ឆ័យក្នុងចំណោមអ្នករាល់គ្នា ហើយកំពុងតែវិនិច្ឆ័យគេដោយគំនិតអាក្រក់»

James 2:5

សូមស្តាប់! បងប្អូនជាទីស្រឡាញ់អើយ

លោកយ៉ាកុបកំពុងដាស់តឿនដល់អ្នកអានរបស់លោកក្នុងជាគ្រួសារថា «សូមស្តាប់» អ្នកដែលមានជំនឿរបស់ខ្ញុំអើយ។

តើព្រះជាម្ចាស់មិនបានជ្រើសរើសគាត់ទេឬអី?

នៅទីនេះ

លោកយ៉ាកុបប្រើសំណួរបំភ្លៃដើម្បីបង្រៀនដល់អ្នកអានទាំងអស់កុំឲ្យបង្ហាញក្តីអនុគ្រោះ[illegible] វាអាចត្រូវបានគេបង្កើតឃ្លាមួយថា «ព្រះជាម្ចាស់បានជ្រើសរើស ហើយស្រឡាញ់គាត់»។

អ្នកក្រីក្រ

«មនុស្សដែលក្រីក្រ»

សូមមានជំនឿរឹងមាំ

មានជំនឿដ៏រឹងមាំគឺហាក់ដូចជាអ្នកដែលទ្រព្យធន ឬជាមាន។

កម្មបទនៃសេចក្តីជំនឿអាចនឹងត្រូវបានគេកំណត់ជាក់លាក់ «មានជំនឿរឹងមាំនៅក្នុងអង្គព្រះគ្រិស្ត»។

ទាយាទ

ជាមនុស្សដែលព្រះបានមានបន្ទូលសន្យា ហើយហាក់ដូចជាពួកគេត្រូវបានទទួលមរតក និងទ្រព្យសម្បត្តិពីសមាជិកគ្រួសារណាមួយ។

ប៉ុន្តែ អ្នកមាន

លោកយ៉ាកុបកំពុងនិយាយពីអ្នកស្តាប់របស់គាត់ទាំងអស់។

បងប្អូនបែរជាមិនឲ្យតម្លៃអ្នកក្រទៅវិញ

«អ្នកមិនផ្តល់កិត្តិយសដល់អ្នកក្រីក្រ»។

តើមិនមែនពួកអ្នកមានទេឬ ដែលបានសង្កត់សង្កិនបងប្អូន?

នៅទីនេះ លោកយ៉ាកុបប្រើសំណួរបំភ្លៃដើម្បីកែតម្រូវអ្នកអានរបស់គាត់ទាំងអស់ «តើមិនមែនពួកអ្នកមានទេឬ ដែលបានសង្កត់សង្កិនបងប្អូន»?

អ្នកមាន

«មនុស្សដែលមានទ្រព្យសម្បត្តិ»។

អ្នកដែលបានសង្កត់សង្កិនបងប្អូន

«ជាមនុស្សដែលបានរាប់អ្នកដោយមិនល្អ»។

តើពួកគេមិនបានអូសបងប្អូនយកទៅឲ្យតុលាការទេ?

នៅទីនេះដោយការប្រឡាយប្រឡែងដើម្បីកែតម្រូវអ្នកអានរបស់គាត់។ វាត្រូវបានគេបង្កើតឃ្លាមួយថា: «ពួកអ្នកមានជាអ្នកបានអូសបងប្អូនយកទៅឲ្យតុលាការ»។

ដូចបងប្អូនយកទៅឲ្យតុលាការទេ

«ប្រើអំណាចអូសទាញបងប្អូនទៅតុលាការដើម្បីចោទប្រកាន់អ្នកនៅចំពោះមុខការជំនុំជម្រះ»។ (សូមមើលfigs-explicit)

តើអ្នកទាំងនោះមិនបានប្រមាថព្រះនាមដ៏ប្រសើរ ដែលជារបស់បងប្អូនទេឬ?

នៅទីនេះ លោកយ៉ាកុបប្រើសំណួរបំភ្លៃដើម្បីកែតម្រូវអ្នកអានរបស់គាត់។ វាត្រូវបានគេបង្កើតឃ្លាមួយថា «ពួកអ្នកមាន---------- ជាកម្មសិទ្ធិរបស់»។

ព្រះនាមដ៏ថ្លៃថ្លា

«ព្រះនាមព្រះគ្រិស្ត»។ នេះសំដៅទៅលើព្រះនាមព្រះយេស៊ូ។ «ព្រះគ្រិស្ត ដែលអ្នកជាកម្មសិទ្ធទ្រង់»។

អ្នកជាកម្មសិទ្ធិរបស់

[illegible] មានជាងអ្នកក្រ។

James 2:8

បើសិនជាអ្នកបំពេញ

ពាក្យថា «អ្នក» សំដៅទៅលើអ្នកជឿជនជាតិយូដា។

បំពេញដោយក្រឹត្យវិន័យរបស់ព្រះជាម្ចាស់

«គោរពក្រឹត្យវិន័យរបស់ព្រះជាម្ចាស់»

ព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យដល់លោកម៉ូសេដើម្បីកត់ត្រានៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់។

អ្នកត្រូវស្រឡាញ់អ្នកជិតខាង ឲ្យដូចស្រឡាញ់ខ្លួនឯងដែរ

លោកយ៉ូកុបកំពុងដកស្រង់ចេញពីគម្ពីរលេវីវិន័យ។

អ្នកជិតខាងរបស់អ្នក

«មនុស្សទាំងអស់» ឬ «គ្រប់គ្នា»។

អ្នកធ្វើបានល្អ

«អ្នកកំពុងធ្វើបានល្អ» ឬ «អ្នកកំពុងធ្វើដែលត្រឹមត្រូវ» ។

បើសិនជាអ្នកអនុគ្រោះ

«ផ្តល់ការព្យាបាលជាពិសេស» ឬ «ផ្តល់កិត្តិយសដល់» ប្រព្រឹត្តបាប។

«ការប្រព្រឹត្តបាប»

គឺខុសនឹងក្រឹត្យវិន័យ។

អ្នកល្មើសច្បាប់ត្រូវបានគេកាត់ទោស

ក្រឹត្យវិន័យនៅកន្លែងនេះហាក់បីដូចជាមនុស្សកាត់ទោស « មានកំហុសដោយការល្មើសនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់»។ (សូមមើល: figs-personification)

James 2:10

ដ្បិត នរណាដែលប្រព្រឹត្តតាមក្រឹត្យវិន័យ

«ដ្បិត នរណាដែលប្រព្រឹត្តតាមក្រឹត្យវិន័យ»។

លើកលែងតែគាត់ភ្លាំងភ្លាត់ នោះក្រឹត្យវិន័យទាំងមូល

ការដើរខ្ទើចៗនឹងដួលចុះខណៈពេលដែលអ្នកកំពុងព្យាយាមធ្វើដើរ។

ការមិនគោរពក្រឹត្យវិន័យណាមួយគឺហាក់ដូចជាវាកំពុងដើរខ្ទើចខណៈពេលកំពុងដើរ។

នៅក្នុងការតែមួយ

ដោយសារការមិនគោរពដោយគ្រាន់តែត្រឹតវិន័យតែមួយ។

ដ្បិត មានសេចក្តីចែងមកថា

ការនេះសំដៅលើព្រះជាម្ចាស់ដែលបានប្រទានក្រឹត្យវិន័យដល់លោកម[illegible]សេ។

មិនប្រព្រឹត្តអំពើផិតក្បត់

ប្រព្រឹត្ត «អំពើផិត» គឺជាការធ្វើសកម្មភាព។

ប្រសិនបើអ្នក...ប៉ុន្តែ ប្រសិនបើអ្នក...អ្នកនឹងមាន

នៅទីនេះ «អ្នក» មានន័យថា «ម្នាក់ៗ»

ទោះបីជាលោកយ៉ាកុបកំពុងនិយាយទៅកាន់អ្នកដែលមានជំនឿជនជាតិយូដាជាច្រើននៅក្នុងករណីនេះ គាត់បានប្រើទម្រង់តែមួយដូចគ្នានឹងការដែលគាត់កំពុងសរសេរទៅកាន់អ្នករាល់គ្នាម្នាក់។

James 2:12

ដូច្នេះ ចូរនិយាយ ហើយប្រព្រឹត្ត

«ដូច្នេះ អ្នកត្រូវតែនិយាយ ហើយគោរព»

លោកយ៉ាកុបបានបញ្ជាឲ្យប្រព្រឹត្តការនេះ។

អ្នកទាំងនោះដែលនឹងទទួលការវិនិច្ឆ័យតាមន័យរបស់ក្រឹត្យវិន័យនៃសេរីភាព

នេះត្រូវបាននិយាយជាទម្រង់យ៉ាងសកម្ម

generated on Wed Sep 10 16:16:32 2025

«អ្នកដែលដឹងថាព្រះជាម្ចាស់នឹងវិនិច្ឆ័យពួកគេដោយក្រឹត្យវិន័យនៃសេរីភាព»។
ដោយក្រឹត្យវិន័យ
ឃ្លានេះមានន័យថា
គឺជាព្រះជាម្ចាស់ដែលនឹងវិនិច្ឆ័យផ្អែកលើក្រឹត្យវិន័យរបស់ព្រះអង្គ។
ក្រឹត្យវិន័យនៃសេរីភាព
«ជាក្រឹត្យវិន័យដែលផ្តល់សេរីភាពពិតប្រាកដ»។
សេចក្តីមេត្តាករុណានឹងយកជោគជ័យលើការវិនិច្ឆ័យ
«សេចក្តីមេត្តាករុណានឹងប្រសើរជាង» ឬ « សេចក្តីមេត្តាករុណានឹងឈ្នះ»។
James 2:14
ប្រយោគភ្ជាប់
លោកយ៉ាកុបបានលើកទឹកចិត្តអ្នកមានជំនឿដែលបានបែកខ្ញែកឲ្យបង្ហាញពីសេចក្តីជំនឿ
ដូចដែលលោកអាប្រាហាំបានបង្ហាញអ្នកដទៃពីជំនឿរបស់លោកតាមរយៈកិច្ចការរបស់លោក
ប្រសិនបើ មាននរណាម្នាក់និយាយថា ខ្លួនមានជំនឿ ប៉ុន្តែ មិនបានធ្វើការល្អទេ នោះតើមាន
ប្រយោជន៍អ្វី?
លោកយ៉ាកុបកំពុងប្រើសំណួរបំភ្លៃដើម្បីបង្រៀនអ្នកស្តាប់របស់លោក:
«វាមិនមែនជាការល្អនោះទេ ចំពោះអ្នកដែលមានជំនឿ ប្រសិនបើ
នរណាម្នាក់និយាយថាគេមានជំនឿ ប៉ុន្តែ មិនបានធ្វើការល្អនោះ»។
មានសេចក្តីជំនឿ
លោកយ៉ាកុបបាននិយាយពីសេចក្តីជំនឿ ជាជំនឿនៅក្នុងព្រះជាម្ចាស់
គឺប្រៀបដូចជាកម្មបទនៃរូបកាយមួយ។
មិនបានធ្វើការល្អ
លោកយ៉ាកុបបាននិយាយពីការធ្វើការ ជាការធ្វើការល្អ
ហាក់ដូចជាកម្មបទនៃរូបកាយជាច្រើន។
តើជំនឿនោះអាចសង្គ្រោះគាត់បានឬ?
លោកយ៉ាកុបបានមានប្រសាសន៍ពីសេចក្តីជំនឿ ជាជំនឿនៅក្នុងព្រះជាម្ចាស់
វាហាក់ដូចជាថាមពលពិសេសដើម្បីសង្គ្រោះមនុស្សម្នាក់។ វាមានន័យថា
ជំនឿនេះមិនគ្រប់គ្រាន់ទេ នេះអាចជាឃ្លាមួយ
«ជំនឿនេះមិនអាចជួយសង្គ្រោះគាត់បានទេ»។
ជួយសង្គ្រោះគាត់
ជួយសង្គ្រោះគាត់ពីការជំនុំជម្រះរបស់ព្រះជាម្ចាស់។
រក្សាភាពកក់ក្តៅ
នេះក៏មានន័យថា «មានសម្លៀកបំពាក់គ្រប់គ្រាន់ដើម្បីស្លៀកពាក់» ឬ
«មានកន្លែងមួយដើម្បីដេក»។
សូមឲ្យបានឆ្អែត
«មានគ្រប់គ្រាន់ដើម្បីហូប»។
ដើម្បីរូបរាងកាយ
ដើម្បីហូប ដើម្បីស្លៀកពាក់ និងដើម្បីរស់នៅដោយមានផាសុខភាព។
តើពាក្យទាំងនោះមានប្រយោជន៍អ្វី?
លោកយ៉ាកុបបានប្រើសំណួរបំភ្លៃដើម្បីបង្រៀនអ្នកស្តាប់របស់គាត់។
នោះមិនមែនជាការល្អទេ។
បងប្អូនប្រុស ស្រី
អ្នកដែលមានជំនឿនៅក្នុងព្រះគ្រិស្ត អាចជាស្ត្រី ឬជាបុរស
សេចក្តីជំនឿ ...ជាសេចក្តីស្លាប់
លោកយ៉ាកុបមានប្រសាសន៍ពីសេចក្តីជំនឿដែលមានជីវិតគឺនៅពេលដែលធ្វើការល្អ
ហើយសេចក្តីជំនឿដែលស្លាប់ នៅពេលនរណាម្នាក់មិនធ្វើការល្អនោះ។
សេចក្តីជំនឿ ...ធ្វើការល្អ
សេចក្តីជំនឿគឺហាក់បីដូចជាបុគ្គលម្នាក់បានធ្វើការល្អ។
James 2:18
ប៉ុន្តែ មានអ្នកខ្លះនិយាយថា
លោកយ៉ាកុបពន្យល់ពីស្ថានភាពជាគ្រាមភាសា
ដែលនរណាម្នាក់ជំទាស់ទៅនឹងការបង្រៀនរបស់លោក។
លោកយ៉ាកុបស្វែងរកដើម្បីកែតម្រូវពីចំនេះដឹងនៃសេចក្តីជំនឿ
និងកិច្ចរបស់អ្នកដែលស្តាប់របស់លោក។ (សូមមើល: |Hypothetical Situations)
អ្នកមានជំនឿ ឯខ្ញុំវិញមានការប្រព្រឹត្តវិញ
«វាអាចទទួលយកបានបើសិនជានរណាម្នាក់មានជំនឿ អ្នកផ្សេងទៀតធ្វើការល្អ»
លោកយ៉ាកុបកំពុងពណ៌នាពីរបៀបដែលនរណាម្នាក់ដែលអាចនឹងជំទាស់នឹងការបង្រៀនរបស់លោក
អ្នកមានជំនឿ ឯខ្ញុំវិញមានការប្រព្រឹត្តវិញ ...សូមបង្ហាញជំនឿរបស់អ្នកមក
លោកយ៉ាកុបមានប្រសាសន៍ពីសេចក្តីជំនឿ និងការធ្វើកិច្ចការរបស់នរណាម្នាក់
ហើយបង្ហាញដល់អ្នកដទៃ។
នោះខ្ញុំនឹងបង្ហាញឲ្យអ្នកឃើញជំនឿរបស់ខ្ញុំ ដោយការប្រព្រឹត្ត
លោកយ៉ាកុបនិយាយពីសេចក្តីជំនឿហាក់បីដូចជាមួយរយៈដែលនរណាម្នាក់បានធ្វើការល្អ
« ខ្ញុំនឹងបង្ហាញពីជំនឿរបស់ខ្ញុំដោយការធ្វើកិច្ចការល្អ»។
ពួកអារក្សក៏ជឿដូច្នេះដែរ ហើយពួកវាភ័យញាប់ញ័រផងដែរ
«ពួកអារក្សក៏ជឿដូច្នេះដែរ ប៉ុន្តែ ពួកវាភ័យញាប់ញ័រផងដែរ»។
លោកយ៉ាកុបប្រឆាំងនឹងពួកអារក្សជាមួយនឹងពួកអ្នកដែលបានអះអាងថាជឿ
ហើយមិនបានធ្វើការល្អ។
លោកយ៉ាកុបបានមានប្រសាសន៍ថាពួកអារក្សគឺវាឆ្លាតជាង
ដោយសារតែពួកវាភ័យខ្លាចនឹងព្រះជាម្ចាស់ខណៈពេលដែលអ្នកខ្លះទៀតមិនបានប្រព្រឹត្ត។
[illegible] និងជំនឿគ្មានការប្រព្រឹត្ត ជាជំនឿឥតបានការអ្វីទាំងអស់?
ជាសំណួរបំភ្លៃដែលត្រូវបានប្រើដើម្បីបន្ទោសបុគ្គលដែលមិនបានស្តាប់លោកយ៉ាកុប។
«មនុស្សឥតប្រាជ្ញា!»
អ្នកមិនចង់ស្តាប់យើងបង្ហាញថាជំនឿដែលគ្មានការប្រព្រឹត្តគឺជាការឥតប្រយោជន៍។
(សូមមើល: |Rhetorical Question)
តើអ្នកដឹងទេ...ការឥតប្រយោជន៍?
លោកយ៉ាកុបបានសួរសំណួរនេះដើម្បីបង្កើតសេចក្តីបង្រៀននៅពេលក្រោយ។
«យើងនឹងបង្ហាញអ្នកពីរបៀប...ការឥតប្រយោជន៍»។
James 2:21
ព័ត៌មានទូទៅ
ដោយសារតែអ្នកដែលមានជំនឿជនជាតិយូដាទាំងនេះ
ពួកគេបានដឹងពីសាច់រឿងរបស់លោកអាប្រាហាំ
ដែលព្រះជាម្ចាស់បានមានបន្ទូលប្រាប់ដល់ពួកគេតាមរយៈព្រះបន្ទូលរបស់ទ្រង់ជាយូរណាស់មកហើយ។
តើមិនមែនលោកអប្រាហាំជាឪពុកដ៏សុចរិតរបស់យើង
សំណួរបំភ្លៃនេះត្រូវប្រើដើម្បីជំទាស់ប្រឆាំងនឹងការប្រឆាំងរបស់មនុស្សឥតប្រាជ្ញាពីជំពូក២
ខ១៨ ដែលបានបដិសេធពីសេចក្តីជំនឿ និងការប្រព្រឹត្តដែលវាដើរទន្ទឹមគ្នា។
«លោកអាប្រាហាំជាបិតានៃសេចក្តីសុចរិត»។
សុចរិតដោយការប្រព្រឹត្ត
លោកយ៉ាកុបនិយាយពីការប្រព្រឹត្តហាក់ដូចជាកាជំទាស់មួយដែលអ្នកមាន
«សុចរិតដោយការប្រព្រឹត្តល្អ»។
ព្រះបិតា
នៅទៅនេះ «ព្រះបិតា» គឺត្រូវបានប្រើជំនួសឲ្យពាក្យថា «បុព្វបុរស»។
អ្នកយល់ទេ
ពាក្យថា «អ្នក» គឺជាឯកវចនដែលសំដៅទៅលើមនុស្សប្រឌិត។
លោកយ៉ាកុបបានមានប្រសាសន៍ទៅអ្នកស្តាប់ទាំងអស់របស់លោកប្រៀបដូចជាមនុស្សតែម្នាក់។
អ្នកដឹងទេ
ពាក្យថា «ដឹង» គឺជាពាក្យប្រៀប «យល់»។
ជំនឿរួមផ្សំនឹងការប្រព្រឹត្ត ហើយតាមរយៈការប្រព្រឹត្តនោះ
លោកយ៉ាកុបនិយាយពីជំនឿគឺហាក់ដូចជាការធ្វើការល្អអញ្ចឹង។
ជំនឿរបស់លោកអាប្រាហាំនៅក្នុងព្រះជាម្ចាស់តាមរយៈលោកអ៊ីសាកដែលអាចឲ្យលោកអាប្រាហាំគោរពព្រ
ដោយការគោរពព្រះជាម្ចាស់ ជំនឿរបស់លោកអាប្រាហាំបានជារឹងមាំ។
តាមរយៈការប្រព្រឹត្តនោះ ធ្វើឲ្យជំនឿរបស់លោកបានពេញលក្ខណៈ
ការជឿជាក់របស់លោកអាប្រាហាំនៅក្នុងព្រះជាម្ចាស់គឺហាក់ដូចជាអ្វីមួយដែលអាចនាំមកវិញនូវភាពល្អឥ
ដូច្នេះហើយវាអាចបំពេញបំណងបានពេញលេញ។
«ដោយសារលោកអាប្រាហាំបានគោរពព្រះជាម្ចាស់
នោះលោកបានទុកចិត្តទាំងស្រុងលើព្រះជាម្ចាស់»។
បទគម្ពីរត្រូវបានបំពេញ
នេះត្រូវបានគេនិយាយជាច្រើនដង «ការនេះបានបំពេញបទគម្ពីរហើយ»។
លោកអាប្រាហាំត្រូវបានគេរាប់ថាជាមនុស្សសុចរិត។
«ព្រះជាម្ចាស់បានរាប់ថាជំនឿរបស់លោកថាជាសុចរិត»។ ជំនឿ
និងសេចក្តីសុចរិតរបស់លោកអាប្រាហាំ គឺត្រូវបានគេរាប់ថាជាការដែលមានតម្លៃ។
អ្នកដឹងទេ
លោកយ៉ាកុបបានហៅអ្នកស្តាប់របស់លោកម្តងទៀតដោយផ្ទាល់ដោយប្រើពាក្យទម្រង់ពហុវចននៃពាក្យ
«អ្នក»។
មនុស្សត្រូវបានរាប់ថាជាសុចរិត ដោយសារប្រព្រឹត្តដែរ គឺមិនមែនដោយសារ តែជំនឿមួយមុខនោះទេ
«ការប្រព្រឹត្ត និងសេចក្តីជំនឿគឺជាអ្វីដែលធ្វើឲ្យមនុស្សសុចរិត
[illegible]ដោយសារតែជំនឿនោះទេ»។ លោកយ៉ាកុបបានប្រព្រឹត្ត
ដែលហាក់ដូចជាការបដិសេធទទួលទទួលយក។
James 2:25

generated on Wed Sep 10 16:16:32 2025

ដូចគ្នានេះដែរ...បានសុចរិតដោយការប្រព្រឹត្ត
លោកយ៉ាកុបបាននិយាយអ្វីដែលជាការពិតពីលោកអាប្រាហាំគឺវាពិតដូចជានាងរ៉ាហាបដែរ។
អ្នកទាំងពីរនោះបានសុចរិតដោយសារការប្រព្រឹត្ត។
តើមិនមែននាងរ៉ាហាបជាស្ត្រីពេស្យាទេឬអី ដែលបានសុចរិត ដោយសារការប្រព្រឹត្ត
របស់នាង...តាមផ្លូវមួយផ្សេងទៀត?
លោកយ៉ាកុបកំពុងប្រើសំណួរបំភ្លៃដើម្បីណែនាំដល់អ្នកស្តាប់លោករបស់លោក។
«គឺជានាងរ៉ាហាបជាស្ត្រីពេស្យា ដែលបានសុចរិត ដោយសារការប្រព្រឹត្ត
របស់នាង...តាមផ្លូវមួយផ្សេងទៀត»។
នាងរ៉ាហាបជាស្ត្រីពេស្យា
ស្ត្រីឈ្មោះរាហាប់គឺមកពីគម្ពីរសម្ពន្ធមេត្រីចាស់ដែលលោកយ៉ាកុបបានរំពឹងថាអ្នកស្តាប់របស់លោកនឹងយល់។
បានសុចរិតដោយសារការប្រព្រឹត្ត
លោកយ៉ាកុបបាននិយាយពីការប្រព្រឹត្តដូចទៅនឹងអ្វីដែលមាន។
អ្នកនាំសារ
មនុស្សដែលនាំយកព័ត៌មានពីកន្លែងមួយផ្សេងទៀត
ហើយឲ្យគេចាកចេញទៅវិញ តាមផ្លូវមួយផ្សេងទៀត
«បន្ទាប់មកជួយពួកគេឲ្យគេចខ្លួនចេញពីទីក្រុង»។
ដ្បិត បើរូបកាយដាច់ចេញពីវិញ្ញាណ រូបកាយនោះនឹងស្លាប់ ហើយជំនឿគ្មានការប្រព្រឹត្ត ក៏ជាជំនឿ
ស្លាប់ដែរ
លោកយ៉ាកុបបានមានប្រសាសន៍ពីសេចក្តីជំនឿដោយគ្មានការប្រព្រឹត្តគឺហាក់ដូចជារូបកាយដែលស្លាប់ដេ

---

3 [1]បងប្អូនអើយ មិនមានមនុស្សច្រើនទេដែលបានធ្វើជាគ្រូបង្រៀន។ យើងដឹងថាយើងនឹងត្រូវទទួលការវិនិច្ឆ័យទោសធ្ងន់ធ្ងរដែរ។[2]ដ្បិត យើងតែងតែធ្វើខុសជាញយដង។ បើសិនជានរណាម្នាក់មិនបានធ្វើខុសដោយពាក្យសម្តី អ្នកនោះជាមនុស្សគ្រប់លក្ខណៈ ហើយអាចត្រួតលើខ្លួនឯងទាំងមូលបាន។
[3]ប្រសិនបើ យើងដាក់បង្ហៀរនៅមាត់របស់សេះ ដើម្បីឲ្យវាស្តាប់បង្គាប់យើង យើងអាចបញ្ជារូបកាយវាឲ្យទៅណាក៏បាន។[4]ចូរសង្កេតមើលសំពៅដូចគ្នាដែរ
ទោះបីជាវាធំយ៉ាងណា ហើយខ្យល់បក់ខ្លាំងក៏ដោយ អ្នកបើកសំពៅអាចបត់បែនទៅណាក៏បាន តាមចិត្តរបស់អ្នកបើកសំពៅចង់ទៅ ទោះបីវាមានចង្កូតតូចមួយក្តី។
[5]អណ្តាតក៏ដូចគ្នាដែរ វាជាផ្នែកមួយតូចមួយនៃរាងកាយ តែវាពូកែបង្កើតបញ្ហាណាស់។ មើលចុះ សូម្បីតែផ្កាភ្លើងតូចមួយវាអាចធ្វើឲ្យឆេះព្រៃធំមួយបាន។[6]អណ្តាតក៏ជាភ្លើង
ម្យ៉ាង ជាពិភពនៃអំពើទុច្ចរិត ដែលជាផ្នែកមួយនៅក្នុងរូបកាយរបស់យើង។ វាអាចធ្វើឲ្យរូបកាយទាំងមូលទៅជាសៅហ្មង និងធ្វើឲ្យដំណើរជីវិតរបស់យើងត្រូវខ្លោចផ្សា
ព្រោះមានភ្លើងនរកនៅក្នុងអណ្តាតនេះ។
[7]ដ្បិត សត្វព្រៃគ្រប់ប្រភេទ រួមមានសត្វស្លាប ហើយសត្វលូនវារ សត្វនៅក្នុងទឹក មនុស្សអាចផ្សាំងបានទាំងអស់។[8]ប៉ុន្តែ គ្មាននរណាម្នាក់អាចផ្សាំងអណ្តាតបានឡើយ
ព្រោះវាមិនអាចគ្រប់គ្រងបាន ហើយចង្រៃអាក្រក់បំផុត ពោរពេញទៅដោយពិសពុល បណ្តាលឲ្យស្លាប់បាន។
[9]ដោយសារអណ្តាត យើងអាចសរសើរព្រះជាម្ចាស់ និងព្រះបិតា ហើយដោយសារអណ្តាតដដែល យើងក៏ដាក់បណ្តាសាដល់មនុស្ស
ដែលព្រះជាម្ចាស់បានបង្កើតដូចជារូបអង្គទ្រង់ដែរ។[10]វាចេញពីមាត់តែមួយ ប៉ុន្តែ វាអាចជាព្រះពរហើយក៏បណ្តាសាដែរ។ បងប្អូនអើយ
ការនេះមិនគួរឲ្យកើតឡើងក្នុងចំណោមពួកយើងឡើយ។
[11]តើដែលមានប្រភពទឹកមួយអាចបញ្ចេញទឹកផ្អែម និងល្វីងផងបានទេ?[12]បងប្អូនអើយ តើដើមឧទុម្ពរអាចចេញផ្លែអូលីវបានទេ? ឬតើដើមទំពាំងបាយជូរ
អាចចេញផ្លែឧទុម្ពរបានទេ? រន្ធទឹកមួយមិនអាចចេញទឹកប្រៃ និងទឹកផ្អែមផងបានទេ។
[13]តើក្នុងចំណោមបងប្អូន មានអ្នកណាមានប្រាជ្ញាដែរឬទេ? សូមឲ្យអ្នកនោះបង្ហាញគំរូជីវិត ដោយការប្រព្រឹត្តល្អ ក៏ដូចជាការដាក់ខ្លួនពេញដោយប្រាជ្ញា។[14]ប៉ុន្តែ
ប្រសិនបើមានការច្រណែន ជូរល្វីង និងមហិច្ឆតានៅក្នុងចិត្តរបស់អ្នកនោះ សូមកុំអួតខ្លួន និងកុហកទាស់នឹងសេចក្តីពិតឲ្យសោះ។
[15]នេះមិនមែនជាប្រាជ្ញាដែលមកពីព្រះជាម្ចាស់ទេ។ ផ្ទុយទៅវិញ ប្រាជ្ញាទាំងនេះមកពីលោកីយ៍ ពីមនុស្ស និងអារក្សវិញ។[16]ដ្បិត ទីណាមានការច្រណែន ប្រណាំងប្រជែងគ្នា
ទីនោះតែងតែមានការខ្វះសណ្តាប់ធ្នាប់ និងមានរឿងអាស្រូវគ្រប់យ៉ាង។[17]ប៉ុន្តែ ប្រាជ្ញាដែលមកពីព្រះជាម្ចាស់គឺវិសុទ្ធ សន្តិភាព សុភាព ស្តាប់បង្គាប់
ហើយពេញដោយសេចក្តីមេត្តា និងបង្កើតផលល្អគ្រប់យ៉ាង ឥតមានសេចក្តីលំអៀងនិងពុតត្បុតឡើយ។
[18]ផលនៃសេចក្តីសុចរិតបានសាបព្រោះនៅក្នុងចំណោមអ្នកកសាងសន្តិភាព។

James 3:1
មិនមានមនុស្សច្រើនទេ
«មិនមានមនុស្សច្រើនទេក្នុងចំណោមអ្នករាល់គ្នា»
លោកយ៉ាកុបកំពុងនិយាយការនេះជាទូទៅ។
បងប្អូនអើយ
«អ្នកដែលមានជំនឿរបស់ខ្ញុំអើយ»។
យើងដឹងថាយើងនឹងត្រូវទទួលការវិនិច្ឆ័យទោសធ្ងន់ធ្ងរដែរ
នៅក្នុងឃ្លានេះនិយាយពីវាវិនិច្ឆ័យម៉ឺងម៉ាត់ដែលនឹងមកពីព្រះជាម្ចាស់ទៅលើអស់អ្នកដែលបង្រៀន
ព្រះជាម្ចាស់នឹងវិនិច្ឆ័យពួកយើងយ៉ាងតឹងតែងជាងហ្នឹងទៅទៀត
ដោយសារតែយើងដឹងពីព្រះបន្ទូលរបស់ព្រះជាងអ្នកទាំងនោះដែលយើងបានបង្រៀនទៅទៀត
យើងនឹងទទួល
លោកយ៉ាកុបកំពុងចាត់ចែងអ្នកទាំងនោះដែលបង្រៀនជាមួយគាត់។
បើទោះជាអ្នកខ្លះក្នុងចំណោមអ្នកដែលមានជំនឿដែលនឹងទទួលលិខិតនេះអាចជាគ្រូបង្រៀនទៅទៀតក៏
ហើយខ្លះទៀតក៏មិនមែនដែរ។
ដ្បិត យើងតែងតែធ្វើខុសជា
ពាក់ព័ន្ធនឹងពាក្យថា «យើង»
លោកយ៉ាកុបក៏ត្រលប់មកវិញដើម្បីបញ្ចូលពួកអ្នកស្តាប់គាត់ទាំងអស់។
ការធ្វើខុស
ការធ្វើបាបគឺត្រូវបានត្រូវគេនិយាយប្រដូចទៅនឹងការធ្វើខុសខណៈពេលកំពុងតែដើរ
«បរាជ័យ» ឬ «អំពើបាប»។
មិនមែនខុសដោយពាក្យសម្តី
«មិនមែនធ្វើបាបដោយការនិយាយស្តីអ្វីខុសនោះទេ»។
អ្នកនោះជាមនុស្សគ្រប់លក្ខណៈ
«គាត់ជាមនុស្សចាស់ទុំខាងព្រលឹងវិញ្ញាណ»។
ហើយអាចត្រួតលើខ្លួនឯងទាំងមូលបាន
លោកយ៉ាកុបកំពុងសំដៅទៅលើដួងចិត្ត អារម្មណ៍ ការប្រព្រឹត្តរបស់មនុស្សម្នាក់ៗ
«ត្រួតត្រាលើអាកប្បកិរិយារបស់គាត់» ឬ «គ្រប់គ្រងទៅលើការប្រព្រឹត្តរបស់គាត់»។
James 3:3
ព័ត៌មានទូទៅ
លោកយ៉ាកុបកំពុងសម្រួលជម្លោះសម្រាប់ការតូចឲ្យគ្រប់គ្រងលើការធំ។
ប្រសិនបើ យើងដាក់បង្ហៀរនៅមាត់របស់សេះ
លោកយ៉ាកុបនិយាយពីបង្ហៀរសត្វសេះ។
បង្ហៀរគឺជាចំណែកតូចនៃលោហៈធាតុដែលត្រូវបានគេដាក់នៅហ្នឹងមាត់សេះដើម្បីបញ្ជាវាឲ្យទៅកន្លែងណា
អ្នកដែលបង្រៀន
«ប្រសិនបើ» ឬ «នៅពេល»។
សេះគឺជាសត្វធំមួយក្បាលត្រូវបានប្រើដើម្បីដឹកវត្ថុ ឬក៏មនុស្ស។
ចូរសង្កេតមើលសំពៅដូចគ្នាដែរ ទោះបីជាវាធំយ៉ាងណា ...អ្នកបើកសំពៅអាចបត់បែនទៅណាក៏បាន
ប៉ុន្តែ គឺជារថយន្តដឹកទំនិញដែលអណ្តែតនៅលើទឹក។
អ្នកបើកសំពៅគឺជាទូកសំប៉ែតមួយ
ឬក៏ជាលោហធាតុនៅផ្នែកខាក្រោយនៃសំពៅដែលត្រូវបានគេប្រើដើម្បីវាដើម្បីគ្រប់គ្រងទិសដៅ។
ពាក្យថា «អ្នកបើកសំពៅ» អាចត្រូវបានគេបកប្រែថាជា «ឧបករណ៍» ផងដែរ។
ហើយត្រូវបានខ្យល់បក់ខ្លាំង
នេះត្រូវបានគេនិយាយជាច្រើនលើសារ។ ខ្យល់ខ្លាំងបានបក់បោកពួកគេទៅ។
អាចបត់បែនទៅណាក៏បាន តាមចិត្តរបស់អ្នកបើកសំពៅចង់ទៅ ទោះបីវាមានចង្កូតតូចមួយក្តី
«មានឧបករណ៍តូចមួយដែលមនុស្សម្នាក់អាចប្រើវាដើម្បីគ្រប់គ្រងទិសដៅដែលសំពៅចង់ទៅ»។
James 3:5
ក៏ដូចគ្នាដែរ
ន័យរបស់ពាក្យនេះមានន័យស្រដៀងនឹងអណ្តាតទៅនឹងបង្ហៀរបស់សេះ
និងអ្នកបើកសំពៅបាននិយាយនៅក្នុងខគម្ពីរមុន «នៅក្នុងស្ថានភាពដូចគ្នា»។
អួតអាងពីអ្វីៗអស្ចារ្យជាច្រើន
នៅទីនេះ «អ្វីៗ» គឺជាពាក្យទូទៅចំពោះអ្វីៗដែលមនុស្សទាំងនោះមានមោទនភាព។

generated on Wed Sep 10 16:16:32 2025

សូមកត់ចំណាំផង
«គិតអំពី»
សូម្បីតែផ្កាភ្លើងតូចមួយវាអាចធ្វើឲ្យឆេះព្រៃធំមួយបាន
ដើម្បីជួយមនុស្សទាំងនោះឲ្យយល់ពីគ្រោះថ្នាក់ដែលអណ្តាតអាចបង្ក
លោកយ៉ាកុបនិយាយពីគ្រោះថ្នាក់ដែលអណ្តាតភ្លើងដ៏តូចមួយអាចបង្កគ្រោះថ្នាក់បាន។
«សូម្បីតែផ្កាភ្លើងតូចមួយវាអាចធ្វើឲ្យឆេះដើមឈើជាច្រើនដើមបាន»។
អណ្តាតក៏ជាភ្លើងម្យ៉ាង
អណ្តាតគឺជាពាក្យប្រៀបធៀបចំពោះអ្វីដែលមនុស្សនិយាយ។
លោកយ៉ាកុបបានហៅថាវាថាជាភ្លើងដោយសារតែការខូចខាតខ្លាំងដែលវាអាចបង្កឡើង
«អណ្តាតក៏ដូចជាភ្លើងមួយផងដែរ» ឬជា
«អ្វីដែលមនុស្សនិយាយដែលអាចបង្កបញ្ហាធ្ងន់ធ្ងរដោយសារតែអណ្តាតភ្លើង»។
ជាពិភពនៃអំពើទុច្ចរិត ដែលជាផ្នែកមួយនៅក្នុងរូបកាយរបស់យើង
ផលប៉ះពាល់ដ៏ធំនៃអំពើបាបដោយពាក្យសម្តី
គឺវាហាក់បីដូចជាប្រភពមួយដែលបង្កើតឡើងដោយខ្លួនឯង។
វាអាចធ្វើឲ្យរូបកាយទាំងមូលទៅជាសៅហ្មង
អំពើបាបដោយពាក្យសម្តីគឺត្រូវបានគេនិយាយបែបប្រៀបធៀបហាក់ដូចជាវាធ្វើឲ្យរូបកាយ
ហើយក្លាយទៅជាការដែលមិនអាចទៅរួចនៅចំពោះមុខព្រះជាម្ចាស់
គឺហាក់ដូចជាភាពកខ្វក់នៅលើរាងកាយ។
និងធ្វើឲ្យដំណើរជីវិតរបស់យើងត្រូវខ្លោចផ្សា
ឃ្លាដែលថា «ដំណើរជីវិត» សំដៅទៅលើជីវិតរបស់មនុស្សម្នាក់ទាំងស្រុង
«ហើយវាអាចបំផ្លាញជីវិតរបស់មនុស្សម្នាក់ទាំងស្រុង»។
ជីវិត ព្រោះមានភ្លើងនរកនៅក្នុងអណ្តាតនេះ
ពាក្យថា «ខ្លួនឯង» សំដៅទៅលើអណ្តាត។ នៅទីនេះពាក្យថា«នរក»
សំដៅទៅលើអាវុធរបស់ការអាក្រក់ ឬអារក្ស។ នេះត្រូវបានគេនិយាយជាញឹកញាប់
«ជីវិតគឺដោយសារអារក្សប្រើវាដើម្បីការអាក្រក់»។
James 3:7
ដ្បិត សត្វព្រៃគ្រប់ប្រភេទ...និងមនុស្សជាតិផងដែរ
នៅឃ្លា «គ្រប់ប្រភេទ» គឺជាឃ្លាដែលសំដៅទៅលើសត្វព្រៃគ្រប់ប្រភេទទាំងអស់។
នេះត្រូវបានគេនិយាយជារឿយៗ។
«មនុស្សបានរៀនគ្រប់គ្រងលើសត្វព្រៃគ្រប់ប្រភេទ បក្សី និងសត្វលូនវា
និងសត្វនៅក្នុងទឹកផងដែរ»។
សត្វលូនវា
នេះគឺជាប្រភេទសត្វលូនវា នៅលើដី។
សត្វនៅក្នុងទឹក
នេះគឺជាសត្វដែលរស់នៅក្នុងទឹក។
ប៉ុន្តែ ដោយសារតែអណ្តាត គ្មាននរណាម្នាក់អាចផ្សាំងអណ្តាតបានឡើយ
លោកយ៉ាកុបបានចែកចាយពីអណ្តាត វាហាក់បីដូចជាសត្វព្រៃអញ្ចឹង។ នៅទីនេះ
«អណ្តាត»
តំណាងឲ្យគោលបំណងមួយរបស់មនុស្សដើម្បីនិយាយពីគំនិតដែលអាក្រក់។
ព្រោះវាមិនអាចគ្រប់គ្រងបាន
អណ្តាតគឺត្រូវបានគេប្រៀបប្រដូចទៅនឹងសេចក្តីអាក្រក់ដែលគ្មាននរណាម្នាក់អាចគ្រប់គ្រងបាន
លោកយ៉ាកុបកំពុងយោងទៅលើគោលបំណងរបស់មនុស្សដើម្បីនិយាយពីគំនិតដែលអាក្រក់
ពោរពេញទៅដោយពិសពុលរហូតដល់ស្លាប់
យ៉ាកុបសំដៅទៅលើសមត្ថភាពរបស់មនុស្សនរណាម្នាក់ដើម្បីនិយាយពីការអាក្រក់ដែលវាអាចធ្វើបាប
ឬក៏រក្ខជាតិដែលមានពិស។
ពិសគឺវាមានគ្រោះថ្នាក់ដល់ពាក្យសម្តីទាំងអស់នោះដែលអាចដាក់ទោសដល់អ្នកដទៃ
James 3:9
ដោយសារអណ្តាតយើងអាច
«ដោយសារអណ្តាតយើងអាចប្រើអណ្តាតដើម្បីនិយាយពាក្យជាច្រើន»។
យើងក៏ដាក់បណ្តាសាដល់មនុស្ស
ដើម្បីដាក់បណ្តាសាគឺជាការទូលសូមព្រះជាម្ចាស់ឲ្យធ្វើបាបដល់អ្នកដទៃ។
ជាអ្នកព្រះជាម្ចាស់បានបង្កើតដូចជារូបអង្គទ្រង់
នេះត្រូវបានគេនិយាយជារឿយៗ
«អស់អ្នកដែលព្រះជាម្ចាស់បានបង្កើតឲ្យដូចជារូបអង្គទ្រង់»។
វាចេញពីមាត់តែមួយ ប៉ុន្តែ វាអាចជាព្រះពរហើយក៏បណ្តាសាដែរ
ពាក្យដែលនាំមកនូវព្រះពរ ឬក៏
បណ្តាសាគឺជាត្រូវបានគេប្រៀបធៀបទៅហ្នឹងការបដិសេធដែលចេញពីមាត់របស់នរណាម្នាក់
បងប្អូនអើយ
«បងប្អូនគ្រិស្តបរិស័ទ»
ការនេះមិនគួរឲ្យកើតឡើងទេ
«នេះគឺជាការដែលខុស»
James 3:11
សេចក្តីថ្លែងការដែលជាប់ពាក់ព័ន្ធគ្នា
ក្រោយពេលដែលលោកយ៉ាកុបបញ្ជាក់ថាពាក្យសម្តីរបស់អ្នកដែលមានជំនឿមិនគួរជាព្រះពរ
ឬក៏ជាបណ្តាសាទេ
គាត់បានផ្តល់ជាគំរូតាមបែបធម្មជាតិដើម្បីបង្រៀនអ្នកអានរបស់លោកដែលពួកគេស្មោះត្រង់ចំពោះព្រះជា
តើដែលមានប្រភពទឹកមួយអាចបញ្ចេញទឹកផ្អែម និងល្វីងផងបានទេ?
លោកយ៉ាកុបប្រើសំណួរបំភ្លៃដើម្បីរំលឹកអ្នកជឿពីអ្វីដែលកើតឡើងតាមបែបធម្មជាតិ។
នេះត្រូវបានគេនិយាយជារឿយៗ។ «ប្រភពទឹកមួយមិនអាចបញ្ចេញទឹកផ្អែមផង
និងល្វីងផងបានទេ»។
បងប្អូនអើយ
«បងប្អូនរួមជំនឿជាស្រឡាញ់»។
បងប្អូនអើយ តើដើមឧទុម្ពរអាចចេញផ្លែអូលីវបានទេ? ឬតើដើមទំពាំងបាយជូរ
អាចចេញផ្លែឧទុម្ពរបានទេ?
លោកយ៉ាកុបប្រើសំណួរបំភ្លៃពីរយ៉ាងដើម្បីរំលឹកអ្នកដែលមានជំនឿពីអ្វីដែលកើតឡើងតាមបែបធម្មជាតិ។
«បងប្អូនអើយ ដើមឧទុម្ពរមិនអាចចេញជាផ្លែអូលីវបានទេ
ហើយដើមទំពាំងបាយជូរ ក៏មិនអាចចេញជាផ្លែឧទុម្ពរបានដែរ»។
James 3:13
តើក្នុងចំណោមបងប្អូន មានអ្នកណាមានប្រាជ្ញាដែរឬទេ?
លោកយ៉ាកុបប្រើសំណួរនេះដើម្បីបង្រៀនអ្នកស្តាប់របស់លោកពីឥរិយាបថសមរម្យ។
ពាក្យថា «មានប្រាជ្ញា» និង «ចំណេះដឹង» គឺមានន័យស្រដៀងគ្នា
«ខ្ញុំនឹងប្រាប់អ្នករាល់គ្នាពីរបៀបដែលបុគ្គលដែលមានប្រាជ្ញា
និងចំណេះដឹងបានប្រព្រឹត្ត»។
បង្ហាញពីគំរូជីវិតដ៏ល្អមួយ
ទិសដៅនៃសកម្មភាពគឺត្រូវបានប្រៀបធៀបទៅហ្នឹងកម្មបទមួយដែលនរណាម្នាក់បានបង្ហាញដល់អ្នកដទៃ
«ការបង្ហាញពីគំរូជីវិតរស់នៅមួយដ៏ល្អ»។
ដោយការប្រព្រឹត្តល្អ ក៏ដូចជាការដាក់ខ្លួនពេញដោយប្រាជ្ញា
«ដោយការប្រព្រឹត្តល្អ ក៏ដូចជាការដាក់ខ្លួនគឺមកពីការមានប្រាជ្ញាពិតៗ»។
មានការច្រណែន ជូរល្វីង និងមហិច្ឆតានៅក្នុងចិត្តរបស់អ្នកនោះ
ពាក្យថា «ចិត្ត» គឺសំដៅទៅលើអារម្មណ៍ ឬគំនិត។
«បំណងប្រាថ្នាដ៏រឹងមាំទៅលើអ្វីដែលអ្នកដទៃមាន ឬមានបទពិសោធន៍
ហើយអ្នកស្វែងបំណងចិត្តរបស់ខ្លួនដោយផ្អែកលើបំណងចិត្តរបស់អ្នកដទៃ»។
ការច្រណែន ជូរល្វីង និងមហិច្ឆតា
អារម្មណ៍ទាំងនេះគឺត្រូវបានគេដឹងវាជាវត្ថុបំណងដែលកើតមាននៅក្នុងចិត្តរបស់មនុស្សម្នាក់ៗ។
មហិច្ឆតានៅក្នុងបរិបទនេះគឺជាបំណងចិត្តដើម្បីទទួលជោគជ័យជាងអ្នកដទៃ។
សូមកុំអួតខ្លួន និងកុហកទាស់នឹងសេចក្តីពិតឲ្យសោះ
«សូមកុំបំពានសេចក្តីពិតដោយការកុហក
ហើយមានមោទនៈនឹងការកុហកនោះឲ្យសោះ»។
James 3:15
ត្រង់ចំណុចនេះ
«ការនេះ» សំដៅទៅលើ «ការច្រណែន ជូរល្វីង និងសេចក្តីវេទនា»
បានពណ៌នានៅក្នុងខគម្ពីរមុន។
គុណភាពនៃប្រាជ្ញាគឺត្រូវបានគេនិយាយវាគឺជាបំណងដែលព្រះជាម្ចាស់ប្រទានមកពីស្ថានសួគ៌។
នៅទីនេះ «ខាងលើ» គឺជាការប្រៀបធៀបមួយសម្រាប់ព្រះជាម្ចាស់។
លោកីយ៍
ពាក្យថា «លោកីយ៍» សំដៅទៅលើតម្លៃ
និងឥរិយាបថរបស់មនុស្សដែលមិនស្មោះត្រង់នឹងព្រះជាម្ចាស់
«មិនស្មោះត្រង់នឹងព្រះជាម្ចាស់»។
មនុស្ស
«មិនមែនមកពីព្រះវិញ្ញាណបរិសុទ្ធ» ឬ «មិនមែនមកពីវិញ្ញាណទេ»។
អារក្ស
«មកពីអារក្ស»
ដ្បិត ទីណាមានការច្រណែន ប្រណាំងប្រជែងគ្នា
នៅទីនេះ «ការច្រណែន» សំដៅទៅលើបំណងប្រាថ្នាមុតមាំដើម្បីឲ្យមាន
ឬមានបទពិសោធន៍ពីអ្វីដែលអ្នកដទៃមាន និងប្រព្រឹត្ត
ហើយមហិច្ឆតាសំដៅទៅលើការស្វែងរកចំណាប់អារម្មណ៍របស់ខ្លួនឯងដោយផ្អែកលើបំណងចិត្តរបស់អ្នក

generated on Wed Sep 10 16:16:32 2025

មានការយល់ច្រលំ

«មានការចលាចល» ឬ «មានការរឹកវរ»។

រឿងអាស្រូវគ្រប់យ៉ាង

«ឥរិយាបថនៃអំពើបាបគ្រប់បែបយ៉ាង» ឬ «រឿងកំណាចគ្រប់បែបយ៉ាង»។

គឺវិសុទ្ធ

«គឺជាព្រះវិញ្ញាណបរិសុទ្ធ»

ស្តាប់បង្គាប់

បារម្ភចំពោះអ្នកដទៃ។

ផលផ្លែល្អ

ការប្រព្រឹត្តល្អគឺត្រូវបានគេប្រៀបធៀបនឹងផ្លែឈើនៅលើដើមឈើ «ការប្រព្រឹត្តល្អ»។

ភាពស្មោះត្រង់

«ភាពស្មោះសរ» ឬ «ពេញដោយការទុកចិត្ត»។

ផលនៃសេចក្តីសុចរិតបានសាបព្រោះនៅក្នុងចំណោមអ្នកកសាងសន្តិភាព

លទ្ធផលនៃអំពើសុចរិតគឺត្រូវបានគេប្រៀបធៀបទៅនឹងគ្រាប់ពូជដែលត្រូវបានសាបព្រោះដោយកសិករ។

«គឺអស់អ្នកដែលរស់នៅក្នុងសន្តិភាពកំពុងធ្វើកិច្ចការអ្វីដែលព្រះមានបន្ទូលថាត្រឹមត្រូវ»។

បង្កើតសន្តិភាព

«រស់នៅក្នុងសន្តិភាព»

សន្តិភាពត្រូវបានគេចាត់ទុកជាគោលបំណងមួយដែលមនុស្សអាចបង្កើតបាន។

«ដោយសារតែមនុស្សរស់នៅពេញដោយសន្តិភាព» ។

---

4 [1]តើការទាស់ទែង និងការឈ្លោះប្រកែកគ្នាក្នុងចំណោមបងប្អូនកើតចេញមកពីណា? តើការនោះមិនមែនចេញពីបំណងចិត្ត
ដែលទាស់ប្រឆាំងគ្នាក្នុងចំណោមបងប្អូនអ្នករាល់គ្នាទេឬអី?[2]បងប្អូនចង់បាន តែមិនបានដូចចិត្តប៉ងទេ។ ទោះបងប្អូនសម្លាប់ និងឈ្នានីសគេ ក៏បងប្អូននៅតែមិនបាន
អ្វីដែរ។ បងប្អូនឈ្លោះប្រកែក និងទាស់ទែងគ្នា។ បងប្អូនមិនបានទទួល ព្រោះបងប្អូនមិនបានទូលសុំ។[3]ទោះបងប្អូនទូលសុំ ក៏នៅតែពុំបានទទួលអ្វីដែរ ព្រោះសំណូមរបស់
បងប្អូនមិនល្អ ដ្បិត បងប្អូនទូលសុំដើម្បីបំពេញចិត្តស្រើបស្រាលរបស់ខ្លួនឯង។
[4]ឱអ្នកដែលមានចិត្តក្បត់អើយ! តើបងប្អូនមិនដឹងទេឬអីថា ការធ្វើជាមិត្តសម្លាញ់របស់លោកីយ៍ ប្រឆាំងទាស់ជាមួយនឹងព្រះជាម្ចាស់ ដូច្នេះ
នរណាចង់ក្លាយជាមិត្តសម្លាញ់របស់លោកីយ៍ អ្នកនោះបានតាំងខ្លួនធ្វើជាសត្រូវរបស់ព្រះជាម្ចាស់ហើយ។[5]ឬតើអ្នកគិតថាព្រះបន្ទូល
ដែលបានចែងទាំងអស់នោះសុទ្ធតែឥតបានការឬអី? «ព្រះវិញ្ញាណព្រះអង្គដែលគង់ក្នុងយើង ពេញដោយសេចក្តីប្រច័ណ្ឌ»។
[6]ប៉ុន្តែ ព្រះជាម្ចាស់បានប្រទានព្រះគុណច្រើនថែមទៀត ដូចបទគម្ពីរបានចែងថា៖ «ព្រះជាម្ចាស់ប្រឆាំងនឹងមនុស្សមានអំនួត តែព្រះអង្គប្រណីសន្តោសដល់អស់អ្នកដែល
បន្ទាបខ្លួនវិញ»។[7]ដូច្នេះ សូមបងប្អូនគោរពចុះចូលព្រះជាម្ចាស់។ ហើយប្រឆាំងនឹងមារ នោះវាមុខជារត់ចេញឆ្ងាយពីបងប្អូនមិនខាន។
[8]សូមចូលមកជិតព្រះអង្គ នោះព្រះជាម្ចាស់នឹងយាងមកជិតបងប្អូនវិញ។ សូមលាងដៃបងប្អូនឲ្យបានស្អាត បងប្អូនជាមនុស្សមានបាប សូមជម្រះចិត្តឲ្យបានវិសុទ្ធ
ហើយសូមជម្រះគំនិតដែលតែងតែសង្ស័យឲ្យបានស្អាតផង។[9]ចូលកាន់ទុក្ខ និងសោកសង្រេង ព្រមទាំងធ្វើឲ្យសំណើចក្លាកក្លាយរបស់បងប្អូន ប្រែទៅជាទុក្ខសោក ហើយ
ឲ្យអំណរសប្បាយរបស់បងប្អូនប្រែទៅជាទុក្ខព្រួយវិញ។[10]ចូលបន្ទាបខ្លួនបងប្អូន នៅចំពោះព្រះជាម្ចាស់ នោះព្រះជាម្ចាស់នឹងលើកបងប្អូនឡើង។
[11]បងប្អូនអើយ មិនត្រូវនិយាយទាស់គ្នាទៅវិញទៅមកឡើយ។ អ្នកណានិយាយទាស់ ឬថ្កោលទោសបងប្អូនណាម្នាក់ អ្នកនោះក៏ដូចជានិយាយទាស់នឹងក្រឹត្យវិន័យ
ហើយក៏ថ្កោលទោសក្រឹត្យវិន័យដែរ។ ប្រសិនបើ អ្នកថ្កោលទោសក្រឹត្យវិន័យបានសេចក្តីថា អ្នកមិនបានកាន់ក្រឹត្យវិន័យទេ គឺអ្នកថ្កោលទោសក្រឹត្យវិន័យវិញ។
[12]ព្រះជាម្ចាស់តែមួយគត់ ដែលជាអ្នកផ្តល់ក្រឹត្យវិន័យ និងការវិនិច្ឆ័យ។ ព្រះអង្គតែមួយគត់ដែលអាចសង្គ្រោះ និងធ្វើឲ្យវិនាសបាន។
តើបងប្អូនជានរណាបានជាហ៊ានវិនិច្ឆ័យបងប្អូនរបស់អ្នកនោះ?
[13]ឥឡូវនេះ បងប្អូនដែលនិយាយថា៖ «ថ្ងៃនេះឬស្អែក យើងនឹងធ្វើដំណើរទៅក្រុងមួយ ហើយស្នាក់នៅក្រុងនោះមួយឆ្នាំ ដើម្បីរកស៊ី និងបានចំណេញ»។
[14]បងប្អូនមិនដឹងថា ថ្ងៃស្អែកជីវិតបងប្អូននឹងទៅជាយ៉ាងណាឡើយ? បងប្អូនប្រៀបបីដូចជាចំហាយទឹក ដែលមានតែមួយភ្លែត រួចក៏រសាត់បាត់ទៅ។
[15]ផ្ទុយទៅវិញ បងប្អូនគួរតែនិយាយថា៖ «បើព្រះអម្ចាស់គាប់ព្រះហឫទ័យ យើងនឹងមានជីវិតរស់ ហើយយើងធ្វើការនេះ ឬធ្វើការនោះ»។[16]តែឥឡូវនេះ បងប្អូនបែរជា
ក្អេងក្អាងអួតបំប៉ោងទៅវិញ។ ការអួតក្អេងក្អាងបែបនេះអាក្រក់ណាស់។[17]ដូច្នេះ ប្រសិនបើអ្នកណាដឹងថាត្រូវធ្វើអំពើល្អយ៉ាងណាហើយ តែមិនព្រមធ្វើ អ្នកនោះប្រព្រឹត្តអំពើ
បាបហើយ។

James 4:1

ប្រយោគភ្ជាប់

លោកយ៉ាកុបបានស្តីបន្ទោសដល់អ្នកជឿទាំងនេះចំពោះលោកីយ៍
និងខ្វះការគោរពរបស់ពួកគេ។

គាត់ជម្រុញពួកគេឲ្យមើលពីរបៀបដែលពួកគេនិយាយគ្នាទៅវិញទៅមកម្តងទៀត។

ព័ត៌មានទូទៅ

នៅក្នុងផ្នែកនេះ ពាក្យថា «របស់ខ្លួនអ្នក» «របស់អ្នក» និង «អ្នក» គឺជាពហុវចន
ហើយសំដៅទៅលើអស់អ្នកដែលជឿដែលលោកយ៉ាកុបបានសរសេរទៅកាន់។

តើការទាស់ទែង និងការឈ្លោះប្រកែកគ្នាកើតចេញមកពីណា?

ពាក្យថា «ការទាស់ទែង» និង «ការឈ្លោះប្រកែក» មានន័យថាដូចគ្នា។
លោកយ៉ាកុបប្រើពាក្យទាំងនេះដើម្បីបញ្ជាក់ថាគឺកំពុងចែកចាយពីប្រភេទជម្លោះរវាងមនុស្ស។

ការទាស់ទែង និងការឈ្លោះប្រកែក

ប្រភេទនៃឥរិយាបថទាំងនេះគឺត្រូវបានគេប្រៀបធៀបទៅនឹងការជំទាស់ដែលមកពីកន្លែងមួយ

តើការនោះមិនមែនចេញពីបំណងចិត្ត ដែលទាស់ប្រឆាំងគ្នាទេឬ

លោកយ៉ាកុបប្រើសំណួរដើម្បីបន្ទោសដល់អ្នកស្តាប់របស់លោក។
ការនេះត្រូវបានសម្រួលទៅជាឃ្លាមួយ។
«គឺដោយសារតែអ្នកមានគោលបំណងអាក្រក់» ឬ
«ដោយសារតែអ្នកមានអ្វីដែលជាគោលបំណងអាក្រក់»។

តើការនោះមិនមែនចេញពីបំណងចិត្ត ដែលទាស់ប្រឆាំងគ្នាក្នុងចំណោមបងប្អូនអ្នករាល់គ្នាទេឬអី?

លោកយ៉ាកុបនិយាយពីគោលបំណង
ដោយសារពួកគេជាសត្រូវដែលធ្វើសង្គ្រាមប្រឆាំងនឹងអ្នកដែលមានជំនឿទាំងអស់។

ជាក់ស្តែង

វាជាការពិតដែលមនុស្សមានគោលបំណងទៅលើអ្នកដែលជំទាស់ប្រឆាំងនឹងខ្លួនរបស់ពួកគេ។

«អ្នកមានគោលបំណងអាក្រក់ ហើយអ្នកបញ្ចប់ដោយការធ្វើបាបដល់អ្នកដទៃ»។

ក្នុងចំណោមបងប្អូនអ្នករាល់គ្នា

វាអាចមានន័យថា ១) មានជម្លោះក្នុងចំណោមអ្នកជឿ ឬ ២) មានការជំទាស់
ប្រឆាំងនៅក្នុងខ្លួនរបស់អ្នកជឿម្នាក់ៗ។

ទោះបងប្អូនសម្លាប់ និងឈ្នានីសគេ ក៏បងប្អូននៅតែមិនបានអ្វីដែរ

ពាក្យថា «បងប្អូនសម្លាប់»
បញ្ជាក់ពីវិធីដែលមនុស្សធ្វើអាក្រក់ដើម្បីឲ្យបាននូវអ្វីដែលពួកគេចង់បាន។

វាអាចត្រូវបានគេបកស្រាយថា
«អ្នកធ្វើការអាក្រក់ទាំងអស់ដើម្បីឲ្យបាននូវអ្វីដែលខ្លួនឯងមិនមាន»។
(សូមមើល: |Hyperbole)

អ្នកបានជំទាស់ ហើយប្រឆាំង

ពាក្យថា «ជំទាស់» និង «ប្រឆាំង» មានន័យស្រដៀងគ្នា។
លោកយ៉ាកុបបានប្រើពាក្យទាំងនេះដើម្បីបញ្ជាក់របៀបដែលមនុស្សមានជម្លោះនឹងខ្លួនឯងខ្លាំងប៉ុណ្ណា
«អ្នកជំទាស់យ៉ាងខ្លាប់ខ្លួន»។

ឬ «អ្នកសុំដោយមិនល្អ

ន័យដែលអាចទៅរួចគឺ ១)«អ្នកបានទូលសូមដោយគោលបំណងមិនត្រឹមត្រូវ» ឬ
«អ្នកទូលសូមដោយមានឥរិយាបថមិនត្រឹមត្រូវ» ២)
«អ្នកកំពុងទូលសូមនូវអ្វីដែលខុស» ឬ «អ្នកកំពុងទូលសូមនូវអ្វីដែលមិនល្អ» ។

James 4:4

ឱអ្នកដែលមានចិត្តក្បត់អើយ!

លោកយ៉ាកុបនិយាយពីអ្នកមានជំនឿគឺហាក់ដូចជាប្រពន្ធដែលដេកជាមួយនឹងបុរសៗជាស្វាមីខ្លួនឯង។
«អ្នកមិនបានស្មោះត្រង់នឹងព្រះជាម្ចាស់!»

តើបងប្អូនដឹងទេថា...ព្រះជាម្ចាស់?

លោកយ៉ាកុបបានប្រើសំណួរដើម្បីបង្រៀនដល់អ្នកស្តាប់របស់គាត់។
ពាក្យនេះអាចត្រូវបានគេសម្រួលទៅជាឃ្លាមួយ។ «អ្នកដឹងទេ ...ព្រះជាម្ចាស់!»

ការធ្វើជាមិត្តសម្លាញ់ជាមួយនឹងលោកីយ៍

ឃ្លានេះសំដៅទៅលើការកំណត់សម្គាល់ ឬការចូលរួមនៅក្នុងតម្លៃនៃប្រព័ន្ធ

generated on Wed Sep 10 16:16:32 2025

ឬឥរិយាបទរបស់លោកីយ៍។
ការធ្វើជាមិត្តសម្លាញ់ជាមួយនឹងលោកីយ៍
នៅទីនេះប្រព័ន្ធនៃតម្លៃរបស់លោកីយ៍គឺត្រូវបានគេប្រៀបធៀបទៅនឹងបុគ្គលម្នាក់ដែលអ្នកអាចធ្វើមិត្តភាពជាមួយបាន។
ការធ្វើជាមិត្តសម្លាញ់របស់លោកីយ៍ ប្រឆាំងទាស់ជាមួយនឹងព្រះជាម្ចាស់
ការធ្វើមិត្តជាមួយលោកីយ៍គឺមានន័យថាអ្នកនោះគឺជាសត្រូវនឹងព្រះជាម្ចាស់។
នៅទីនេះ «ការធ្វើមិត្តជាមួយលោកីយ៍»
គឺសំដៅទៅលើមនុស្សដែលមិត្តនឹងលោកីយ៍ ហើយ
«ប្រឆាំងទាស់ជាមួយនឹងព្រះជាម្ចាស់»
គឺសំដៅទៅលើមនុស្សដែលជំទាស់ប្រឆាំងនឹងព្រះជាម្ចាស់។
«មិត្តភាពជាមួយនឹងលោកីយ៍គឺជាសត្រូវនឹងព្រះជាម្ចាស់»។
ឬតើអ្នកគិតថាព្រះបន្ទូល ដែលបានចែងទាំងអស់នោះសុទ្ធតែឥតបានការឬអី
នេះគឺជាសំនួរបំភ្លៃដែលលោកយ៉ាកុបប្រើដើម្បីដាស់តឿនដល់អ្នកស្តាប់របស់លោក។
និយាយឥតបានការគឺមានន័យថានិយាយឥតប្រយោជន៍
«មានហេតុផលមួយដែលបទគម្ពីរថ្លែង»។
ព្រះវិញ្ញាណព្រះអង្គដែលគង់ក្នុងយើង
នៅក្នុងកំណែខ្លះៗដោយរួមទាំង ULB និង UDB
ក៏យល់ពីការនេះជាសេចក្តីយោងទៅលើព្រះវិញ្ញាណបរិសុទ្ធ។
កំណែផ្សេងៗទៀតៗបានបកស្រាយថា «ព្រះវិញ្ញាណ»។ នៅក្នុងន័យនេះ
វិញ្ញាណរបស់មនុស្ស ព្រះជាម្ចាស់បង្កើតមនុស្សម្នាក់ៗឲ្យមានវិញ្ញាណនោះ។
យើងសូមណែនាំថាអ្នកប្រើអត្ថន័យនោះគឺត្រូវបានគេបង្ហាញនៅក្នុងការសម្រួលផ្សេងទៀតដែលត្រូវបានផ្តល់ជូនអ្នក។
James 4:6
ប៉ុន្តែ ព្រះជាម្ចាស់បានប្រទានព្រះគុណច្រើនថែមទៀត
តើឃ្លានេះជាប់ពាក់ព័ន្ធទៅនឹងខគម្ពីរមុនដែលអាចត្រូវបានគេបង្កើតជាក់ស្តែងយ៉ាងម៉េចខ្លះ?
«ប៉ុន្តែ បើទោះជាវិញ្ញាណរបស់យើង អាចនឹងសម្រេចអ្វីដែលយើងមិនអាចមាន
នោះព្រះជាម្ចាស់នឹងប្រទានព្រះគុណច្រើនជាងហ្នឹងទៀត
បើសិនជាយើងបន្ទាបខ្លួនយើង»។
ប្រទានព្រះគុណច្រើនថែមទៀត
ព្រះគុណកំពុងត្រូវបានគេចាត់ទុកជាគោលបំណងមួយដែលអាចត្រូវបានប្រទានឲ្យ។
មោទនភាព
«មនុស្សដែលមានមោទនភាព»។
កាបន្ទាបខ្លួន
«មនុស្សដែលបន្ទាបខ្លួន»។
ដូច្នេះ
«ដោយសារការនេះ»
គោរពចុះចូលព្រះជាម្ចាស់
«គោរពតាមព្រះជាម្ចាស់»
ហើយប្រឆាំងនឹងមារ
«ប្រឆាំងនឹងបីសាច» ឬ «សូមកុំធ្វើអ្វីដែលបីសាចចង់ធ្វើ»។
នោះវាមុខជារត់ចេញឆ្ងាយពីបងប្អូនមិនខាន
«វានឹងរត់ចេញឆ្ងាយពីអ្នក» ។
James 4:8
ព័ត៌មានទូទៅ
ពាក្យអ្នក «អ្នក»
នៅទីនេះសំដៅទៅលើអ្នកជឿដែលបែកខ្ញែកដែលលោកយ៉ាកុបសរសេរទៅកាន់។
សូមចូលមកជិតព្រះអង្គ នោះព្រះជាម្ចាស់នឹងយាងមកជិតបងប្អូនវិញ
នៅទីនេះគំនិតដែលថាចូលមកជិតសំដៅទៅលើការស្មោះត្រង់
ហើយបើកចំហរនឹងព្រះជាម្ចាស់។
សូមលាងដៃបងប្អូនឲ្យបានស្អាត បងប្អូនជាមនុស្សមានបាប សូមជម្រះចិត្តឲ្យបានវិសុទ្ធ
ហើយសូមជម្រះគំនិតដែលតែងតែសង្ស័យឲ្យបានស្អាតផង។
គំនិតដែលតែងតែសង្ស័យ ឃ្លាទាំងពីរនេះគឺវាមានន័យស្របគ្នាទៅវិញទៅមក។
សូមលាងដៃបងប្អូនឲ្យបានស្អាត
ការពញ្ញាក់នេះគឺជាបញ្ញត្តិសម្រាប់មនុស្សទៅទូឲ្យប្រព្រឹត្តសុចរិតជំនួសឲ្យការប្រព្រឹត្តទុច្ចរិត
«សូមប្រព្រឹត្តទៅតាមផ្លូវដែលស្មោះត្រង់នឹងព្រះជាម្ចាស់»។
សូមជម្រះចិត្តឲ្យបានវិសុទ្ធ
នៅទីនេះ «ចិត្ត» សំដៅទៅលើគំនិត និងអារម្មណ៍របស់មនុស្ស
«សូមស្មោះត្រង់នឹងព្រះជាម្ចាស់ដោយចេញពីចិត្ត»។
គំនិតដែលតែងតែសង្ស័យ
គំនិត ពាក្យថា «ចិត្តដែលសង្ស័យ»
សំដៅទៅអ្នកដែលមិនអាចសម្រេចចិត្តច្បាស់លាស់ពីអ្វីមួយ។
«មនុស្សដែលតែងតែសង្ស័យ» ឬ
«មនុស្សដែលមិនអាចសម្រេចចិត្តថាតើគេចង់គោរពតាមព្រះជាម្ចាស់ឬក៍អត់នោះទេ»។
ការធ្វើមិត្តភាពជាមួយនឹងលោកីយ៍ គឺមានន័យថាធ្វើមិត្តភាពជាមួយបាន។
ពាក្យទាំងនេះមានន័យស្រដៀងគ្នា។
លោកយ៉ាកុបប្រើពាក្យទាំងពីរនេះដើម្បីបញ្ជាក់ថាមនុស្សគួរតែសុំទោសដោយស្មោះត្រង់ចំពោះការដែលមិ
លោកយ៉ាកុបនិយាយបែបនេះគឺវាជាបញ្ញត្តិមួយ។
ធ្វើឲ្យសំណើចក្អាកក្អាយរបស់បងប្អូន ប្រែទៅជាទុក្ខសោក ហើយឲ្យអំណរសប្បាយរបស់បងប្អូនប្រែ
ទៅជាទុក្ខព្រួយវិញ
ការនិយាយបែបនេះដូចគ្នា នៅក្នុងការបញ្ជាក់ខុសគ្នាផ្សេងៗ។ សំណើច
ក្អាកក្អាយគឺត្រូវបានគេប្រៀបប្រដូចនៅទៅហ្នឹងកម្មបទមួយដែលអាចត្រូវបានគេផ្លាស់ប្តូរទៅជាការសោក
វាដូចគ្នាទៅហ្នឹងរីករាយ និងទុក្ខព្រួយ «បញ្ឈប់សំណើចរបស់អ្នកភ្លាមៗ
ហើយចាប់ផ្តើមទូលព្រះជាម្ចាស់ថាអ្នកសូមទោស»។ (សូមមើល: និងfigs-
abstractnouns)
ចូរបន្ទាបខ្លួនបងប្អូន នៅចំពោះព្រះជាម្ចាស់
«ចូរបន្ទាបខ្លួនចំពោះព្រះជាម្ចាស់»
ការប្រព្រឹត្តត្រូវបានសម្រេចដោយមានវត្តមានព្រះជាម្ចាស់នៅក្នុងចិត្តគឺត្រូវបានគេប្រៀបប្រដូចទៅហ្នឹងការ
នោះព្រះជាម្ចាស់នឹងលើកបងប្អូនឡើង
លោកយ៉ាកុបនិយាយពីព្រះជាម្ចាស់ស្មោះត្រង់នឹងអ្នកដែលចេះបន្ទាបខ្លួន
ប្រៀបដូចជាទ្រង់នឹងលើកអ្នកនោះឡើងចេញពីផែនដីដែលជាទីដែលអ្នកនោះបានឱនលំទោនខ្លួនឯងដោ
ត្រូវបានផ្តល់ជូនអ្នក។
James 4:11
ព័ត៌មានទូទៅ
ពាក្យថា «អ្នក» និង «របស់អ្នក» នៅក្នុងផ្នែកនេះ
សំដៅទៅលើអ្នកដែលជឿដែលលោកយ៉ាកុបបានសរសេរទៅកាន់។
និយាយទាស់
«និយាយពីអ្វីដែលអាក្រក់» ឬ «ជំទាស់»។
បងប្អូនអើយ
លោកយ៉ាកុបនិយាយពីអ្នកជឿគឺត្រូវបានប្រៀបប្រដូចទៅនឹងបងប្អូនតាមបែបជីវសាស្ត្រ
«បងប្អូនជាទីស្រឡាញ់»។
ប៉ុន្តែការថ្កោលទោស
«ប៉ុន្តែ អ្នកកំពុងប្រព្រឹត្តដូចជាមនុស្សដែលផ្តល់ក្រឹត្យវិន័យអញ្ចឹង»។
ព្រះជាម្ចាស់តែមួយគត់ ដែលជាអ្នកផ្តល់ក្រឹត្យវិន័យ និងការវិនិច្ឆ័យ
ការនេះសំដៅលើព្រះជាម្ចាស់
«គឺមានតែព្រះជាម្ចាស់តែមួយអង្គគត់ដែលប្រទានក្រិត្យវិន័យ
និងការវិនិច្ឆ័យដល់មនុស្ស»។
តើបងប្អូនជានរណាបានជាហ៊ានវិនិច្ឆ័យបងប្អូនរបស់អ្នកនោះ?
នេះជាសំណួរបំភ្លៃដែលលោកយ៉ាកុបប្រើដើម្បីស្តីបន្ទោសដល់អ្នកស្តាប់របស់លោក។
នេះត្រូវបានគេបញ្ជាក់ជាឃ្លាមួយ។ «អ្នកជាមនុស្សម្នាក់
ហើយអ្នកមិនអាចវិនិច្ឆ័យទៅលើអ្នកណាផ្សេងបានទេ»។ (សូមមើល: |
Rhetorical Question)
James 4:13
ចំណាយពេលមួយឆ្នាំនៅទីនោះ
លោកយ៉ាកុបនិយាយពីការចំណាយពេល
ហាក់ដូចជាត្រូវបានគេប្រៀបប្រដូចទៅនឹងលុយ «ស្នាក់នៅទីនោះមួយឆ្នាំ»។
តើអ្នកណាដឹងថាថ្ងៃស្អែកមានរឿងកើតអីឡើង?
លោកយ៉ាកុបប្រើសំណួរនេះដើម្បីកែតម្រូវអ្នកស្តាប់របស់លោក។
ឃ្លានេះត្រូវបានគេបញ្ជាក់ជាឃ្លាមួយ
«គ្មាននរណាម្នាក់ដឹងថានឹងមានរឿងអ្វីកើតឡើងនៅថ្ងៃស្អែកទេ»។
ហើយតើជីវិតបងប្អូននឹងទៅជាយ៉ាងណា?
លោកយ៉ាកុបបានប្រើសំណួរនេះដើម្បីបង្រៀនអ្នកជឿទាំងនេះថា
ជីវិតខាងរូបកាយគឺមិនមានអ្វីសំខាន់ទេ។ ឃ្លានេះត្រូវបានគេបញ្ជាក់ជាឃ្លាមួយ
ហើយសូមគិតពីជីវិតខាងរូបកាយរបស់បងប្អូន»។
ដោយសារតែបងប្អូនប្រៀបបីដូចជាចំហាយទឹក ដែលមានតែមួយភ្លែត រួចក៏រសាត់បាត់ទៅ
លោកយ៉ាកុបនិយាយពីមនុស្សដែលប្រៀបដូចជាចំហាយទឹកដែលមានតែមួយភ្លែត
រួចក៏រសាត់បាត់ទៅ «អ្នករស់នៅតែមួយរយៈពេលខ្លី
ហើយក៏ស្លាប់បាត់បង់ជីវិតទៅ»។
James 4:15
ផ្ទុយទៅវិញ បងប្អូនគួរតែនិយាយថា
«ផ្ទុយទៅវិញ កិរិយាមាយាទរបស់អ្នកគួរតែជា»។

generated on Wed Sep 10 16:16:32 2025

យើងនឹងមានជីវិតរស់នៅ
ពាក្យថា «យើង» មិនបានសំដៅលោកយ៉ាកុប
ឬក៏អ្នកស្តាប់របស់លោកដោយផ្ទាល់ទេ ប៉ុន្តែ
វាជាគំរូដែលអ្នកស្តាប់របស់លោកយ៉ាកុបគួរតែប្រព្រឹត្ត។
ការនេះ ឬធ្វើការនោះ
«សូមធ្វើអ្វីដែលយើងបានត្រៀមធ្វើ»។
ប្រសិនបើអ្នកណាដឹងថាត្រូវធ្វើអំពើល្អយ៉ាងណាហើយ តែមិនព្រមធ្វើ អ្នកនោះប្រព្រឹត្តអំពើបាប
ហើយ។
អ្នកណាដែលបរាជ័យក្នុងការធ្វើការល្អ ដោយគេដឹងថាគេគួរតែធ្វើ
នោះរាប់ថាជាអំពើបាបហើយ។

---

5 [1]ឥឡូវនេះ សម្រាប់អ្នកមាន ចូរស្រែកទ្រហោយំវិញ ពីព្រោះទុក្ខលំបាកនឹងកើតមានដល់អ្នកជាមិនខាន។[2]ភាពមានបានរបស់បងប្អូននឹងរលួយអស់
ហើយសម្លៀកបំពាក់របស់អ្នកក៏ត្រូវរកណ្តៀរសីុដែរ។[3]មាស និងប្រាក់របស់បងប្អូនត្រូវច្រេះសីុបំផ្លាញ។
ការសីុបំផ្លាញទាំងនោះជាសក្ខីភាពអំពីការទាស់ប្រឆាំងជាមួយបងប្អូន។ វានឹងធ្វើឲ្យវិនាសដល់សរសៃឈាមរបស់អ្នកដូចជាភ្លើងឆេះ។
ហើយកន្លែងដែលបងប្អូនរក្សាទ្រព្យសម្បត្តិទុកគឺជាថ្ងៃចុងក្រោយ។
[4]មើល៍! ប្រាក់ឈ្នួលដែលត្រូវបើកឲ្យពួកកម្មករ នោះត្រូវបានទាមទារ ដោយព្រោះតែគ្មានប្រាក់បើកឲ្យដល់អ្នកច្រូត ដែលបានធ្វើការឲ្យអ្នក
នោះសម្រែកពួកគេក៏បានឮដល់ព្រះជាម្ចាស់នៃពិភពទាំងមូល។[5]អ្នករាល់គ្នាបានរស់នៅលើផែនដីយ៉ាងសម្បូរសប្បាយ ហើយរុងរឿង និងអាចបំពេញតាមបំណងចិត្ត
ដែលខ្លួនត្រូវការ ដូចនៅថ្ងៃដែលគេសម្លាប់សត្វ។[6]អ្នករាល់គ្នាបានដាក់ទោស និងសម្លាប់អ្នកសុចរិតផង។ ដោយសារពួកគេមិនបានចុះចូលនឹងអ្នក។
[7]ដូច្នេះ បងប្អូនអើយ ត្រូវមានចិត្តអត់ធ្មត់ រហូតដល់ព្រះជាម្ចាស់យាងត្រឡប់មកវិញ។ មើល! អ្នកចម្ការបានរង់ចាំផលផ្លែដ៏មានតម្លៃ ចេញពីការច្រូតកាត់ពីដីមក។
ពួកគេបានរងចាំដោយការអត់ធ្មត់សម្រាប់ផលទាំងនោះ រហូតដល់បានទទួលនៅដើមរដូវ និងចុងរដូវភ្លៀងផង។[8]បងប្អូនក៏ដូចគ្នា ត្រូវតែអត់ធ្មត់។
សូមធ្វើចិត្តឲ្យបានរឹងប៉ឹុង ដោយព្រោះការយាងត្រឡប់មកវិញរបស់ព្រះជាម្ចាស់ ជិតមកដល់ហើយ។
[9]បងប្អូនអើយ មិនត្រូវរអ៊ូរទាំ និងទាស់ប្រឆាំងគ្នាទៅវិញទៅមកទេ ដូច្នេះហើយ បងប្អូនមិនត្រូវវិនិច្ឆ័យឡើយ។ សូមមើលចុះ អ្នកកាត់ក្តី កំពុងតែឈរនៅនឹងមាត់ទ្វារ។
[10]បងប្អូន សូមយកគំរូតាមព្យាការី ដែលបានរងទុក្ខលំបាក និងមានការអត់ធ្មត់ គឺជាអ្នកដែលថ្លែងព្រះបន្ទូលក្នុងនាមរបស់ព្រះជាម្ចាស់។[11]មើលចុះ
យើងត្រូវបានរាប់ដូចជាព្យាការីដែលបានលើកសរសើរ និងបានព្រះពរដែរ។ អ្នករាល់គ្នាធ្លាប់ឮការសរសើររបស់លោកយ៉ូប
ហើយបងប្អូនក៏ដឹងពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ ដ្បិត ព្រះអង្គមានព្រះហឫទ័យ អាណិតអាសូរ និងសេចក្តីមេត្តាករុណាផង។
[12]លើសជាងនេះ បងប្អូនអើយ កុំស្បថឲ្យសោះ មិនត្រូវយកមេឃ ឬផែនដី ឬសេស្បថជាមួយអ្វីផ្សេងៗទៀតឡើយ។ តែផ្ទុយទៅវិញ សូមឲ្យបងប្អូនគ្រាន់តែនិយាយថា
«បាទ» គឺ «បាទ» ហើយថា «ទេ» គឺ «ទេ» ដូច្នេះ អ្នកនឹងមិននៅជាប់ក្រោមការកាត់ទោសឡើយ។
[13]តើមានអ្នកណានៅក្នុងចំណោមអ្នករាល់គ្នាជួបទុក្ខលំបាក និងការឈឺចាប់ឬទេ? សូមឲ្យអ្នកទាំងនោះអធិស្ឋានចុះ។ តើមានអ្នកណាអរសប្បាយដែលឬទេ?
សូមឲ្យអ្នកនោះច្រៀងសរសើរតម្កើងចុះ។[14]តើមានអ្នកណាឈឺក្នុងចំណោមអ្នកឬទេ? សូមឲ្យគេអញ្ជើញពួកចាស់ទុំរបស់ក្រុមជំនុំ
ហើយសូមឲ្យពួកគេអធិស្ឋានឲ្យអ្នកឈឺនោះចុះ។ ចូរយកប្រេងមកលាបឲ្យអ្នកឈឺក្នុងនាមព្រះអម្ចាស់ផង។[15]សេចក្តីអធិស្ឋានដោយជំនឿនឹងប្រោសអ្នកឈឺឲ្យបានជា
ហើយព្រះអម្ចាស់នឹងលើកគាត់ឡើងវិញ។ ហើយប្រសិនបើ គាត់បានធ្វើអំពើបាប ព្រះជាម្ចាស់នឹងលើកលែងទោសឲ្យអ្នកនោះផងដែរ។
[16]ដូច្នេះ សូមលន់តួបាបចំពោះគ្នាទៅវិញទៅមក ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមកដែរ ធ្វើដូចនេះអ្នកនឹងបានប្រោសឲ្យជា។
សេចក្តីអធិស្ឋានរបស់មនុស្សសុចរិតខ្លាំងពូកែណាស់។[17]ព្យាការីអេលីយ៉ាជាបុរសម្នាក់ដូចជាយើងរាល់គ្នាដែរ។ លោកបានអធិស្ឋានសូមកុំឲ្យមានភ្លៀង
ហើយមេឃក៏លែងភ្លៀងនៅលើផែនដីអស់រយៈបីឆ្នាំ និងប្រាំមួយខែ។[18]បន្ទាប់មកទៀត ព្យាការីអេលីយ៉ាបានទូលសុំម្តងទៀត។ ដើម្បីសុំភ្លៀងពីមេឃ
ហើយឲ្យផែនដីបានដុះភោគផលឡើងវិញ។
[19]បងប្អូនអើយ ប្រសិនបើ មានអ្នកណាក្នុងចំណោមបងប្អូន វង្វេងផ្លូវចេញពីសេចក្តីពិត ហើយមានម្នាក់ទៀតនាំគាត់ ត្រឡប់មកវិញ[20]អ្នកនោះត្រូវដឹងថា ម្នាក់
ដែលបាននាំមនុស្សមានបាបឲ្យចេញពីការវង្វេងផ្លូវនោះ នឹងសង្គ្រោះគាត់ឲ្យរួចពីសេចក្តីស្លាប់ ហើយជាងនេះទៅទៀត អំពើបាបដ៏ធំនឹងត្រូវគ្របបាំងដ៏លើសលប់ផងដែរ។

James 5:1
ប្រយោគភ្ជាប់
លោកយ៉ាកុបបានដាស់តឿនដល់ពួកអ្នកមានពីការផ្តោតរបស់គេទៅលើក្តីរីករាយ
និងទ្រព្យសម្បត្តិ។
សម្រាប់អ្នកមាន
វាអាចមានន័យថា
១)លោកយ៉ាកុបកំពុងដាស់តឿនយ៉ាងម៉ឺងម៉ាត់ដល់អ្នកជឿដែលមានទ្រព្យសម្បត្តិ
ពីព្រោះទុក្ខលំបាកនឹងកើតមានដល់អ្នកជាមិនខាន
លោកយ៉ាកុបបាននិយាយថាអ្នកទាំងនេះនឹងទទួលរងយ៉ាងធ្ងន់ធ្ងរនៅក្នុងថ្ងៃអនាគត
ហើយការទទួលរបស់គេប្រៀបដូចជាការជំទាស់ដែលនឹងចូលទៅក្នុងជីវិតរបស់គេ
«ដោយសារតែអ្នកនឹងទទួលរងយ៉ាងធ្ងន់ធ្ងរនៅក្នុងថ្ងៃអនាគត»។
ភាពមានបានរបស់បងប្អូននឹងរលួយអស់ ហើយសម្លៀកបំពាក់របស់អ្នកក៏ត្រូវរកណ្តៀរសីុដែរ។
មាស និងប្រាក់របស់បងប្អូនត្រូវច្រេះសីុបំផ្លាញបាន។
មាស និងប្រាក់របស់បងប្អូនត្រូវច្រេះសីុបំផ្លាញ។
លោកយ៉ាកុបនិយាយពីព្រឹត្តិការណ៍ទាំងនេះហាក់បីដូចជាពួកវាបានកើតឡើងរួចហើយ
លោកយ៉ាកុបបានបញ្ជាក់ថា អ្នកមាននៅក្នុងលោកីយ៍មិនអាចនៅបានយូរ
ឬក៏មានជីវិតដ៏នៅអស់កល្បទេ «ភាពមានបានក៏ដូចជាកាស្មុយរលួយ
សម្លៀកបំពាក់របស់អ្នកក៏ដូចជាកណ្តៀរសីុ មាស
និងប្រាក់របស់បងប្អូនក៏ដូចជាការសីុបំផ្លាញ»។
ភាពមានបាន...សម្លៀកបំពាក់...មាសប្រាក់
ទាំងអស់នេះគឺត្រូវបាននិយាយជាឧទាហរណ៍នៃរបស់ដែលមានតម្លៃចំពោះអ្នកមានទ្រព្យសម្បត្តិ
ការសីុបំផ្លាញទាំងនោះជាសក្ខីភាពអំពីការទាស់ប្រឆាំងជាមួយបងប្អូន
«ការស៊ីបំផ្លាញ»
គឺជាកំណត់នៃប្រភេទដែលពិពណ៌នាពីការបំបែកលោហៈធាតុតាមបែបធម្មជាតិ។
លោកយ៉ាកុបកំពុងនិយាយពីបន្ទប់តុលាការដែលចោទប្រកាន់ចំពោះអំពើអាក្រក់របស់អ្នកមាន
«ហើយនៅពេលដែលព្រះជាម្ចាស់វិនិច្ឆ័យអ្នក
ទ្រព្យសម្បត្តិបង្ហិនបង្ហោចរបស់អ្នកនឹងដូចជានរណាម្នាក់ដែលចោទប្រកាន់អ្នកនៅក្នុងតុលាការ។
នឹងបំផ្លាញអ្នក...ដូចជាភ្លើងអញ្ចឹង
ការបំផ្លាញនៅទីនេះត្រូវបានគេប្រៀបធៀបទៅនឹងភ្លើងដែលនឹងដុតបំផ្លាញម្ចាស់របស់វាអញ្ចឹង។
សរសៃឈាមរបស់អ្នក
នៅទីនេះ «សរសៃឈាម» សំដៅលើរាងកាយរបស់មនុស្ស។
ភ្លើង
គំនិតនៃភ្លើងនៅកន្លែងនេះគឺមានន័យថា នាំមនុស្សឲ្យចងចាំថា
ភ្លើងជារឿយៗគេសំដៅលើការដាក់ទោសរបស់ព្រះជាម្ចាស់ដែលនឹងកើតឡើងលើមនុស្សអាក្រក់។
នៅថ្ងៃចុងក្រោយ
នេះសំដៅទៅលើពេលវេលាដ៏សមស្របនៅចំពោះព្រះជាម្ចាស់ចូលមកជំនុំជម្រះមនុស្សទាំងអស់។
មនុស្សអាក្រក់គិតថាពួកគេអាចរក្សាទុកទ្រព្យសម្បត្តិរបស់ពួកគេបាននៅថ្ងៃអនាគត
ប៉ុន្តែ អ្វីដែលពួកគេកំពុងធ្វើគឺកំពុងប្រមូលទណ្ឌកម្មទុក។
«ដ្បិតដល់ពេលកំណត់ព្រះជាម្ចាស់នឹងជំនុំជម្រះអ្នក»។ (UDB)
James 5:4
ប្រយោគភ្ជាប់
លោកយ៉ាកុបបន្តដាស់តឿនដល់អ្នកមានពីភាពងប់ងុលលើក្តីរីករាយ
និងភាពមានរបស់គេ។
ប្រាក់ឈ្នួលដែលត្រូវបើកឲ្យពួកកម្មករ នោះត្រូវបានទាមទារ
ដោយព្រោះតែគ្មានប្រាក់បើកឲ្យដល់អ្នកច្រូត ដែលបានធ្វើការឲ្យអ្នក
លុយកាក់ដែលគួរតែត្រូវបានបង់គឺត្រូវបានគេបៀបប្រដូចនៅនឹងមនុស្សម្នាក់ដែលកំពុងស្រែក
ដោយសារតែភាពអយុត្តិធម៌ដែលកើតឡើងដល់គេ។
«ការពិតដែលថាអ្នកមិនបានបង់ថ្លៃដល់អ្នកទាំងនោះដែលអ្នកបានជួលឲ្យធ្វើការនៅក្នុងវាលស្រែ
បានបង្ហាញថាអ្នកបានធ្វើខុស»។
នោះសម្រែកពួកគេក៏បានឮដល់ព្រះជាម្ចាស់នៃពិភពទាំងមូល
ការស្រែករបស់អ្នកច្រូតកាត់
គឺត្រូវបានប្រៀបធៀបទៅនឹងអ្វីដែលគេបានឮនៅស្ថានសួគ៌

generated on Wed Sep 10 16:16:32 2025

«ព្រះអម្ចាស់នៃប្រភពទាំងមូលបានឮសម្រែកស្រែកយំរបស់អ្នកច្រូតកាត់»។
(សូមមើល: | Metaphor)
បានឮដល់ព្រះជាម្ចាស់នៃពិភពទាំងមូល
ព្រះជាម្ចាស់ត្រូវបានគេដឹងថា
ទ្រង់ហាក់មានព្រះកាណ៌ដូចដែលមនុស្សមានអញ្ចឹងដែរ
«ព្រះអម្ចាស់នៃប្រភពទាំងមូលបានឮ»។
ហើយអ្នកអាចបំពេញតាមបំណងចិត្ត ដែលខ្លួនត្រូវការ ដូចនៅថ្ងៃដែលគេសម្លាប់សត្វ
នៅទីនេះ មនុស្សទាំងអស់គឺត្រូវបានគេមើលឃើញថាហាក់ដូចជាគោក្របី
ដែលត្រូវបានផ្តល់អាហារល្អៗ ដូច្នេះ
ពួកគេក៏បានធំធាត់ឡើងដើម្បីឲ្យគេសម្លាប់ដើម្បីធ្វើបុណ្យ។ ទោះយ៉ាងនេះក្តី
ក៏គ្មាននរណាម្នាក់នឹងធ្វើបុណ្យនៅថ្ងៃជំនុំជម្រះដែរ
«ភាពលោភលន់របស់អ្នកបានធ្វើឲ្យអ្នកត្រៀមខ្លួនសម្រាប់តែការជំនុំជម្រះនៃអំពើដ៏អាក្រក់ប៉ុណ្ណោះ»។
ដួងចិត្តរបស់អ្នក
នៅទីនេះ «ចិត្ត»
គឺត្រូវបានគេប្រើជាចំនុចកណ្តាលចំពោះគោលបំណងរបស់មនុស្ស។
ពាក្យនេះសំដៅទៅលើមនុស្សទាំងស្រុង។
អ្នករាល់គ្នាបានដាក់ទោស និងសម្លាប់អ្នកសុចរិតផង
នេះប្រហែលជាមិនបាន «ដាក់ទោស» តាមអារម្មណ៍ដែលត្រឹមត្រូវ នៃការជំនុំជម្រះ
ដែលបានឈ្នះលើការកាត់ទោសប្រហារជីវិតលើបទឧក្រិដ្ឋ។ ផ្ទុយទៅវិញ
វាប្រហែលជាសំដៅទៅលើមនុស្សអាក្រក់
និងពួកមានអំណាចដែលបានសម្រេចចិត្តធ្វើបាបដល់អ្នកក្រហូតដល់ពួកគេស្លាប់។
មនុស្សសុចរិត
«មនុស្សដែលធ្វើអ្វីដែលត្រឹមត្រូវ»
ការបញ្ជាក់នេះសំដៅទៅលើមនុស្សសុចរិតជាទូទៅ
មិនមែនសំដៅលើបុគ្គលណាម្នាក់ទេ។
គេមិនបានចុះចូលនឹងអ្នក
«មិនបានជំទាស់នឹងអ្នក» ។
James 5:7
សេចក្តីថ្លែងការដែលជាប់ពាក់ព័ន្ធគ្នា
លោកយ៉ាកុបបានប្តូរប្រធានបទពីការបន្ទោសអ្នកមានទៅជាការដាស់តឿនដល់អ្នកជឿ។
ព័ត៌មានទូទៅ
ជាទីបញ្ចប់
លោកយ៉ាកុបបានរំលឹកដល់អ្នកជឿពីការយាងត្រលប់មកវិញរបស់ព្រះជាម្ចាស់
និងប្រទានមេរៀនខ្លីជាច្រើនពីរបៀបរស់នៅដើម្បីព្រះជាម្ចាស់។
ដូច្នេះ បងប្អូនអើយ ត្រូវមានចិត្តអត់ធ្មត់
«ដោយការនេះ សូមរង់ចាំ ហើយស្ងប់ចិត្តចុះ»។
រហូតដល់ព្រះជាម្ចាស់យាងត្រឡប់មកវិញ
ឃ្លានេះសំដៅទៅលើការយាងត្រលប់មកវិញរបស់ព្រះយេស៊ូគ្រិស្ត
នៅពេលនោះទ្រង់នឹងចាប់ផ្តើមអាណាចក្ររបស់ទ្រង់នៅលើផែនដី
ព្រមទាំងជំនុំជម្រះមនុស្សទាំងអស់
«រហូតដល់ការយាងត្រលប់វិញរបស់ព្រះយេស៊ូគ្រិស្ត»។
អ្នកចម្ការ
លោកយ៉ាកុបបានប្រៀបធៀបដោយប្រើឈ្មោះអ្នកចម្ការ
និងអ្នកជឿដើម្បីបង្រៀនពីអ្វីដែលមានន័យថាការអត់ធ្មត់។
សូមធ្វើចិត្តឲ្យបានរឹងប៉ឹង
លោកយ៉ាកុបកំពុងធ្វើឲ្យចិត្តរបស់អ្នកជឿមានភាពស្មើគ្នាទៅនឹងឆន្ទៈរបស់គេដើម្បីនៅ
«នៅតែប្តេជ្ញាចិត្ត» ឬ «សូមរក្សាសេចក្តីជំនឿនៅតែរឹងមាំ»។
ការយាងត្រឡប់មកវិញរបស់ព្រះជាម្ចាស់ ជិតមកដល់ហើយ
«ព្រះអម្ចាស់នឹងត្រលប់មកវិញឆាប់ៗនេះ»។
James 5:9
បងប្អូនអើយ មិនត្រូវរអ៊ូរទាំ និងទាស់ប្រឆាំងគ្នាទៅវិញទៅមកទេ...
លោកយ៉ាកុបកំពុងសរសេរទៅកាន់អ្នកជឿជនជាតិយូដាដែលបានបែកខ្ញែកគ្នា។
ទាស់ប្រឆាំងគ្នាទៅវិញទៅមកទេ
«ទៅវិញទៅមក»។
បងប្អូនមិនត្រូវបានវិនិច្ឆ័យឡើយ
ការនេះត្រូវបានគេនិយាយជារឿយៗ «ព្រះយេស៊ូគ្រិស្តនឹងមិនវិនិច្ឆ័យអ្នកឡើយ»។
អ្នកកាត់ក្តី កំពុងតែឈរនៅនឹងមាត់ទ្វារ
លោកយ៉ាកុបបានប្រៀបធៀប ព្រះយេស៊ូ ការវិនិច្ឆ័យ
ទៅនឹងមនុស្សម្នាក់ដែលបានឆ្លងកាត់ទ្វារដើម្បីបញ្ជាក់ពីរបៀបដែលព្រះយេស៊ូគ្រិស្តនឹង
ការវិនិច្ឆ័យនឹងចូលមកឆាប់ៗនេះ»។
ការរងទុក្ខ និងការអត់ធ្មត់របស់ព្យាការី
«របៀបដែលព្យាការីរងទុក្ខពីការធ្វើទុក្ខបុកម្នេញដោយការអត់ធ្មត់»។
ថ្លែងព្រះបន្ទូលក្នុងនាមរបស់ព្រះជាម្ចាស់
«ថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅកាន់មនុស្សទាំងអស់» ។
សូមមើលចុះ
នៅទីនេះ «សូមមើល» បានបញ្ជាក់ទៅលើអ្វីដែលត្រូវអនុវត្ត
«សូមស្តាប់ដោយប្រុងប្រយ័ត្ន» ឬ «សូមចងចាំ»។
ព្យាការីដែលបានលើកសរសើរ
អស់អ្នកដែលបន្តគោរពព្រះជាម្ចាស់សូម្បីតែស្ថិតនៅក្នុងស្ថានភាពលំបាកយ៉ាងណា។
James 5:12
ការសន្យាទេ
«នេះជាការដែលសំខាន់» ឬ «ជាពិសេស»។
បងប្អូនអើយ
«បងប្អូនជាទីស្រឡាញ់អើយ»។
កុំស្បថឲ្យសោះ
«ស្បថ» គឺត្រូវនិយាយអ្វីដែលអ្នកនឹងធ្វើអ្វីៗ ឬនោះជាអ្វីដែលពិត
ហើយដើម្បីឲ្យប្រកាន់ភ្ជាប់នូវទំនួលខុសត្រូវដោយអជ្ញាធរជាន់ខ្ពស់
«សូមកុំធ្វើការស្បថស្បែ» ឬ «សូមកុំធ្វើការសច្ចា»។
មិនថាស្ថានសួគ៌ ឬលោកីយ៍
ពាក្យថា «ស្ថានសួគ៌» និង «លោកីយ៍» សំដៅទៅលើសិទ្ធិអំណាចរបស់វិញ្ញាណ
ឬក៏មនុស្សដែលនៅក្នុងស្ថានសួគ៌ ឬផែនដី។
សូមឲ្យបងប្អូនគ្រាន់តែនិយាយថា «បាទ» គឺ «បាទ» ហើយថា «ទេ» គឺ «ទេ»
«សូមធ្វើអ្វីដែលអ្នកនិយាយថានឹងធ្វើដោយគ្មានការស្បថស្បែ»។
ដូច្នេះ អ្នកនឹងមិននៅជាប់ក្រោមការកាត់ទោសឡើយ
ការកាត់ទោសត្រូវបានគេប្រៀបប្រដូចទៅនឹងអ្វីមួយដែលបានធ្លាក់ចុះ
ប៉ះទង្គិចនឹងអ្វីមួយដែលមានទម្ងន់ធ្ងន់
«ដូច្នេះព្រះជាម្ចាស់នឹងដាក់ទោសដល់អ្នក»។
James 5:13
តើមានអ្នកណានៅក្នុងចំណោមអ្នករាល់គ្នាជួបទុក្ខលំបាក និងការឈឺចាប់ឬទេ?
សូមឲ្យអ្នកទាំងនោះអធិស្ឋានចុះ។
«បើសិនជានរណាម្នាក់កំពុងស្ថិតនៅក្នុងការលំបាក អ្នកនោះគួរតែអធិស្ឋាន»។
តើមានអ្នកណាអរសប្បាយដែលឬទេ? សូមឲ្យអ្នកនោះច្រៀងសរសើរតម្កើងចុះ។
«បើសិនជានរណាម្នាក់រីករាយ អ្នកនោះគួរតែច្រៀងចម្រៀងសរសើរតម្កើងវិញ»។
តើមានអ្នកណាឈឺក្នុងចំណោមអ្នកឬទេ? សូមឲ្យគេអញ្ជើញ
«បើសិនជានរណាម្នាក់ឈឺ គេគួរតែអញ្ជើញ»។
សេចក្តីអធិស្ឋានដោយជំនឿនឹងប្រោសអ្នកឈឺឲ្យបានជា ហើយព្រះអម្ចាស់នឹងលើកគាត់ឡើងវិញ
នៅពេលដែលអ្នកជឿអធិស្ឋានដល់អ្នកឈឺ
នោះព្រះអម្ចាស់នឹងឮពីសេចក្តីអធិស្ឋានរបស់ពួកគេ
រួចទ្រង់នឹងព្យាបាលអ្នកទាំងនោះ
«ព្រះអម្ចាស់នឹងឮពួកគេអ្នកជឿកំពុងអធិស្ឋានដោយសេចក្តីជំនឿ
នោះទ្រង់នឹងព្យាបាលអ្នកដែលឈឺនោះ»។
James 5:16
ព័ត៌មានទូទៅ
ដោយសារតែអ្នកទាំងនេះជាអ្នកជឿជនជាតិយូដា
លោកយ៉ាកុបលើកទឹកចិត្តពួកគេឲ្យអធិស្ឋានដោយការអញ្ជើញព្យាការីចាស់ទុំម្នាក់
ហើយនោះជាសំណូមអធិស្ឋានរួមទាំងការប្រព្រឹត្តរបស់ព្យាការី។
ដូច្នេះ សូមលន់តួបាប
នេះគឺជាការសារភាពដល់អ្នកជឿដទៃទៀត នូវអ្វីដែលអ្នកបានធ្វើខុស ដូច្នេះ
អ្នកអាចនឹងត្រូវបានគេអត់ទោសឲ្យ។
ចំពោះគ្នាទៅវិញទៅមក
«ទៅវិញទៅមក»។
ធ្វើដូចនេះអ្នកនឹងបានប្រោសឲ្យជា
«ដូច្នេះព្រះជាម្ចាស់នឹងប្រោសអ្នកឲ្យបានជា»។
សេចក្តីអធិស្ឋានរបស់មនុស្សសុចរិតខ្លាំងពូកែណាស់។
សំណូមអធិស្ឋានគឺត្រូវបានគេបង្ហាញហាក់ដូចជាគោលបំណងដែលរឹងមាំ
និងមានអំណាច។
«នៅពេលដែលមនុស្សគោរពប្រតិបត្តិតាមអ្វីដែលព្រះជាម្ចាស់អធិស្ឋាន
នោះទ្រង់នឹងធ្វើការសម្រេចវិនិច្ឆ័យពីភពលោក

generated on Wed Sep 10 16:16:32 2025

យ៉ាងស្មោះអស់ពីចិត្ត
«យ៉ាងស្រេកឃ្លាន» ឬក៏ «យ៉ាងក្លៀវក្លា»។
បីឆ្នាំ និងប្រាំមួយខែ
«៣...៦» (សូមមើល ːtranslate-numbers)
ស្ថានសួគ៌នឹងប្រទានភ្លៀងមក
«ស្ថានសួគ៌» ប្រហែលសំដៅទៅលើផ្ទៃមេឃ ដែលតំណាងឲ្យប្រភពនៃទឹកភ្លៀង។ «ភ្លៀងធ្លាក់បានមកពីលើមេឃ»។
ផែនដីបានដុះភោគផលឡើងវិញ
នៅទីនេះផែនដីគឺតំណាងឲ្យប្រភពនៃដំណាំ។
ផ្លែឈើ
នៅទីនេះ «ផ្លែឈើ» តំណាងឲ្យដំណាំទាំងអស់របស់កសិករ។
James 5:19
បងប្អូនអើយ
«បងប្អូនអើយជាទីស្រឡាញ់»
ប្រសិនបើ មានអ្នកណាក្នុងចំណោមបងប្អូន វង្វេងផ្លូវចេញពីសេចក្តីពិត ហើយមានម្នាក់ទៀតនាំគាត់ត្រឡប់មកវិញ
អ្នកជឿម្នាក់ដែលឈប់ជឿជាក់ លើព្រះជាម្ចាស់
ហើយមិនការគោរពប្រតិបត្តិតាមទ្រង់
គឺត្រូវបានប្រៀបប្រដូចទៅនឹងចៀមមួយក្បាលដែលវង្វេងចេញពីហ្វូង។
អ្នកដែលបានជម្រុញឲ្យអ្នកជឿលើព្រះជាម្ចាស់ម្តងទៀត
គឺត្រូវបានប្រៀបធៀបទៅនឹងអ្នកគង្វាលម្នាក់ដែលបានចេញទៅរកចៀមដែលវង្វេង។
«នៅពេលណាដែលនរណាម្នាក់ឈប់គោរពប្រតិបត្តិព្រះជាម្ចាស់
ហើយមានម្នាក់ទៀតនឹងជួយគាត់ឲ្យចាប់ផ្តើមគោរពព្រះជាម្ចាស់ម្តងទៀត»។
ម្នាក់
ដែលបាននាំមនុស្សមានបាបឲ្យចេញពីការវង្វេងផ្លូវនោះ...អំពើបាបដ៏ធំនឹងត្រូវគ្របបាំងដ៏លើសលប់ផងដែរ។
លោកយ៉ាកុបចង់មានន័យថា ព្រះជាម្ចាស់នឹងប្រើការប្រព្រឹត្តរបស់មនុស្សម្នាក់នេះ
ដើម្បីជម្រុញអ្នកមានបាបសារភាពកំហុស ហើយទទួលបានការសង្គ្រោះ។ ប៉ុន្តែ
លោកយ៉ាកុបថ្លែងបែបនេះ
ប្រៀបធៀបទៅនឹងអ្នកដទៃទៀតដែលបានសសង្គ្រោះអ្នកចេញពីព្រលឹងដែលមានបាប
ឲ្យចេញពីសេចក្តីស្លាប់។
នឹងសង្គ្រោះគាត់ឲ្យរួចពីសេចក្តីស្លាប់ ហើយជាងនេះទៅទៀត
អំពើបាបដ៏ធំនឹងត្រូវគ្របបាំងដ៏លើសលប់ផងដែរ
នៅទីនេះ «សេចក្តីស្លាប់» សំដៅទៅលើសេចក្តីស្លាប់ខាងវិញ្ញាណ
ការដាច់ចេញពីព្រះដ៏អស់កល្ប។
«នឹងសង្គ្រោះគាត់ឲ្យរួចពីសេចក្តីស្លាប់ខាងវិញ្ញាណ
ហើយទ្រង់នឹងអត់អោនទោសរាល់អំពើបាបរបស់គេទាំងអស់»។ (សូមមើល: igs-synecdoche)
អំពើបាបដ៏ធំនឹងត្រូវគ្របបាំងដ៏លើសលប់ផងដែរ
ន័យដែលអាចទៅរួចគឺ ១)
អ្នកដែលនាំបងប្អូនដែលមិនបានស្តាប់បង្គាប់ឲ្យត្រលប់មកវិញ
នឹងត្រូវបានអត់ទោសរាល់អំពើបាបរបស់គេ ឬក៏
២)បងប្អូនដែលមិនបានស្តាប់បង្គាប់ នៅពេលដែលគេត្រលប់មករកព្រះជាម្ចាស់វិញ
គេនឹងត្រូវបានលើកលែងទោសរាល់អំពើបាបរបស់គេ។
អំពើបាបត្រូវបានគេប្រៀបធៀបទៅនឹងការជំទាស់ដែលព្រះជាម្ចាស់អាចគ្រប់បាំង
ដូច្នេះ ទ្រង់នឹងមិនឃើញពួកគេ
ដែលជាហេតុដែលទ្រង់បានលើកលែងទោសដល់ពួកគេ។

១ ពេត្រុស

1 [1]ខ្ញុំ ពេត្រុស ជាសាវ័ករបស់ព្រះយេស៊ូគ្រិស្ត សូមជម្រាបសួរទៅដល់បងប្អូនដែលព្រះជាម្ចាស់បានជ្រើសរើស
ហើយបានបែកខ្ញែកគ្នាទៅរស់នៅតាមស្រុកផ្សេងៗពីគ្នាដូចជា ប៉ុនតុស ស្រុកកាឡាទី ស្រុកកាប៉ាដូគា ស្រុកអាស៊ី និងស្រុកប៊ីធូនា។[2]ព្រះជាម្ចាស់ ជាព្រះបិតា
បានជ្រើសរើសបងប្អូន តាមគម្រោងផែនការដែលព្រះអង្គគ្រោងទុកពីមុនមក ដោយព្រះវិញ្ញាណប្រោសបងប្អូនឲ្យបានវិសុទ្ធ ដើម្បីឲ្យបងប្អូនស្ងួនភ្ងាស្តាប់បង្គាប់
ព្រះយេស៊ូគ្រិស្ត និងឲ្យព្រះអង្គប្រោសព្រះលោហិតរបស់ព្រះអង្គលើបងប្អូន។ សូមឲ្យបងប្អូនបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្តកាន់តែច្រើនឡើងៗ។
[3]សូមសរសើរតម្កើងព្រះជាម្ចាស់ជាព្រះបិតារបស់ព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង។ ដោយសេចក្តីមេត្តាករុណាដ៏ធំធេងរបស់ព្រះជាម្ចាស់
ដែលព្រះអង្គបានផ្តល់ឱ្យយើងនូវកំណើតថ្មីសម្រាប់ទទួលមរតក។ មរតកនេះគឺតាមរយៈការរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្តពីសេចក្តីស្លាប់។[4]នេះជាមរតក
ដែលមិនចេះសាបសូន្យ មិនចេះរលួយ មិនចេះស្រពោន មិនចេះសៅហ្មង ហើយនិងមិនរលាយបាត់ឡើយ។
ព្រះជាម្ចាស់បានបម្រុងទុកមរតកនេះឲ្យបងប្អូនស្ងួនភ្ងានៅស្ថានបរមសុខ។[5]ដោយសារជំនឿ បងប្អូនត្រូវបានការពារថែរក្សាដោយព្រះចេស្តារបស់ព្រះជាម្ចាស់ ដើម្បីឲ្យ
បងប្អូនទទួលការសង្គ្រោះ ដែលព្រះអង្គបានរៀបចំទុកជាស្រេច ហើយដែលព្រះអង្គនឹងបើកសម្តែងនៅគ្រាចុងក្រោយបំផុត។
[6]បងប្អូនមានសេចក្តីអំណរជាខ្លាំង ក្នុងសេចក្តីសង្គ្រោះនោះ ទោះបើសព្វថ្ងៃនេះត្រូវរងទុក្ខព្រួយយូរបន្តិច និងកើតមានសេក្តីល្បងផ្សេងៗក៏ដោយ។
[7]ដើម្បីឲ្យការល្បងជំនឿនៃអ្នករាល់គ្នា គឺវិសេសជាងមាសដែលតែងតែខូច ទោះបើបានសាកល្បងនឹងភ្លើងក៏ដោយ។ ការនោះកើតឡើង
ដើម្បីឲ្យឃើញជំនឿជាផលនៃការសរសើរ ហើយនិងសិរីល្អ ក្នុងកាលព្រះយេស៊ូគ្រិស្តលេចមកវិញ។
[8]អ្នករាល់គ្នាមិនដែលបានឃើញព្រះអង្គទេ ប៉ុន្តែបានស្រឡាញ់ព្រះអង្គ ទោះបើពេលឥឡូវនេះក្តី ប៉ុន្តែអ្នករាល់គ្នានៅតែមានចិត្តជឿលើកព្រះអង្គដដែល
ហើយក៏មានអំណរក្នុងព្រះអង្គ ដោយអំណរដ៏ប្រសើរដែលរកអ្វីថ្លែងមិនបាន[9]ដោយឥឡូវនេះអ្នករាល់គ្នាបានទទួលផលនៃជំនឿរបស់អ្នករាល់
គឺជាសេចក្តីសង្គ្រោះដល់ព្រលឹងរបស់អ្នក[10]រីឯពួកព្យាការី ជាអ្នកបានទាយពីព្រះគុណ ដែលផ្តល់មកអ្នករាល់គ្នា គេបានសើុបសួរ
ហើយខំរកឲ្យដឹងពីសេចក្តីសង្គ្រោះនោះ។
[11]ពួកគេស្វែងរកឲ្យដឹងពីអ្នកណា ឬពេលណា ដែលព្រះវិញ្ញាណរបស់ព្រះគ្រិស្តសណ្ឋិតក្នុងពួកគេ ដែលទ្រង់មានព្រះបន្ទូលមកពួកគេ។
នេះគឺជាហេតុការណ៍នឹងកើតឡើងដូចដែលទ្រង់បានប្រាប់ជាមុន អំពីព្រះគ្រិស្តត្រូវរងទុក្ខលំបាក ហើយពីសិរីល្អទាំងប៉ុន្មាន ដែលត្រូវមកតាមក្រោយ។
[12]នេះជាការបើកសម្តែងឲ្យគេដឹងថា ពួកគេមិនបានបំរើខ្លួនឯង ដែលឥឡូវនេះពួកគេនិយាយអំពីសេចក្តីទាំងប៉ុន្មានដែលពួកគេបានដឹង
អ្នកខ្លះប្រកាសដំណឹងល្អទៅអ្នករាល់គ្នាដោយព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់បានចាត់ពីស្ថានសួគ៌មក ហើយគឺអ្វីដែលពួកទេវតាទទឹងរង់ចាំមើល។
[13]ដូច្នេះចូរយកគំនិតរបស់អ្នករាល់គ្នាមកក្រវ៉ាត់ចង្កេះអោយជាប់ចុះ ដោយដឹងខ្លួន។
ចូរទុកចិត្តនៅក្នុងព្រះគុណដែលផ្តល់មកដល់អ្នករាល់គ្នាក្នុងការដែលព្រះយេស៊ូបើកសម្តែងមក។ [14]ចូរធ្វើដូចជាកូនៗដែលស្តាប់បង្គាប់
មិនត្រូវធ្វើតាមតែចិត្តរបស់ខ្លួនឯងដែលអ្នកធ្លាប់ធ្វើពីមុន ក្នុងភាពល្ងីល្ងើនោះឡើយ។
[15]ប៉ុន្តែ ព្រះជាម្ចាស់បានត្រាស់ហៅអ្នករាល់គ្នាគឺព្រះអង្គវិសុទ្ធ អ្នករាល់គ្នាក៏វិសុទ្ធដូច្នេះដែរ ចូរឲ្យអ្នករាល់គ្នាបានវិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ចុះ។
[16]ដ្បិតមានសេចក្តីចែងទុកមកថា «អ្នករាល់គ្នាត្រូវវិសុទ្ធ ពីព្រោះយើងជាព្រះវិសុទ្ធ។»[17]ដូច្នេះ ប្រសិនបើអ្នករាល់គ្នាហៅយើងថា «ព្រះបិតា»
ជាអ្នកដែលជំនុំជម្រះដែលមិនលំអៀងទៅតាមអំពើដែលអ្នករាល់ប្រព្រឹត្តរៀងៗខ្លួន នោះត្រូវរស់នៅដោយកោតខ្លាចព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់។
[18]អ្នករាល់គ្នាបានដឹងហើយថាព្រះជាម្ចាស់បានលោះអ្នករាល់គ្នាចេញពីកិរិយាដែលឥតប្រយោជន៍ដែលអ្នករាល់គ្នាបានរៀនពីឪពុករបស់អ្នករាល់គ្នាមក។
[19]អ្នករាល់គ្នាត្រូវបានប្រោសលោះដោយព្រះលោហិតរបស់ព្រះគ្រិស្តយេស៊ូ ជាចៀមដែលល្អឥតខ្ចោះដែលឥតស្លាកស្នាម។
[20]ព្រះគ្រិស្តយេស៊ូ ត្រូវបានជ្រើសរើសតាំងពីមុនដើមកំណើតពិភពលោក ប៉ុន្តែទ្រង់ទើបតែបង្ហាញអង្គនៅគ្រាចុងក្រោយ។[21]ដោយសារព្រះអង្គ
អ្នករាល់គ្នាបានជឿដល់ព្រះជាម្ចាស់ដែលប្រោសឲ្យព្រះយេស៊ូឲ្យមានព្រះជន្មរស់ពីសុគតឡើងវិញ ព្រមទាំងប្រទានឲ្យព្រះអង្គឲ្យមានសិរីល្អ
ដោយអ្នករាល់គ្នាមានជំនឿនិងមានសង្ឃឹមនៅក្នុងព្រះជាម្ចាស់។
[22]ព្រលឹងអ្នករាល់គ្នាបានបរិសុទ្ធដោយការស្តាប់តាមសេចក្តីពិត។ ត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចជាបងប្អូន ចូរស្រលាញ់គ្នាឲ្យខ្លាំងដោយចេញពីចិត្ត។
[23]អ្នកបានកើតជាថ្មី ដែលមិនមកពីរូបកាយដែលពុករលួយទេ ប៉ុន្តែជារូបកាយដែលមិនចេះពុករលួយ ដោយការរស់នៅជាប់ជាមួយព្រះបន្ទូលនៃព្រះជាម្ចាស់។

generated on Wed Sep 10 16:16:32 2025

[24]«មនុស្សគ្រប់រូបដូចជាស្មៅ ហើយគ្រប់ទាំងសិរីល្អគឺដូចជាផ្កានៃស្មៅ។ ហើយដូចជាស្មៅក្រៀមស្វិតហើយផ្ការុះរោយ។[25]តែព្រះបន្ទូលនៃព្រះនៅជាប់ជាដរាប។»
ការនេះគឺជាដំណឹងល្អដែលបានផ្តល់មកអ្នក។

---

1 Peter 1:1
ព័ត៌មានទូទៅ
លោកពេត្រុសបានតាំងខ្លួនគាត់ជាអ្នកសរសេរ
ហើយបានកំណត់ខ្លួនគាត់ជាអ្នកនាំការសួរសុខទុក្ខទៅដល់បងប្អូនរួមជំនឿ
ដែលគាត់កំពុងសរសេរសំបុត្រនេះទៅ។
បានបែកខ្ញែកគ្នាទៅរស់នៅតាមស្រុកផ្សេងៗពីគ្នា
លោកពេត្រុសបាននិយាយទៅកាន់អ្នក
ដែលអានសំបុត្ររបស់គាត់ដែលរស់នៅឆ្ងាយពីផ្ទះ នៅក្នុងស្រុកផ្សេងៗពីគ្នា។
ស្រុកកាប៉ាដូគា...ស្រុកប៊ីធូនា
ជាមួយនឹងកន្លែងផ្សេងទៀតដែលលោកពេត្រុសបានលើកឡើង «ស្រុកកាប៉ាដូគា»
និង «ស្រុកប៊ីធូនា» ដែលជាខេត្តមួយនៃប្រទេសរ៉ូម
ដែលសព្វថ្ងៃស្ថិតនៅក្នុងប្រទេសទួរគី។
ព្រះជាម្ចាស់ ជាព្រះបិតា... បានជ្រើសរើសបងប្អូន តាមគម្រោងផែនការ
«បងប្អូនដែលព្រះអម្ចាស់ ជាព្រះបិតា
បានជ្រើសរើស...តាមផែនការដែលព្រះអង្គគ្រោងទុក» ព្រះអម្ចាស់
បានជ្រើសរើសពួកគេស្របតាមបុព្វញ្ញាណរបស់ព្រះអង្គ។
គម្រោងផែនការដែលបានគ្រោងទុកជាមុន របស់ព្រះជាម្ចាស់ ជាព្រះបិតា
អាចមានន័យថាទី១)
ព្រះអម្ចាស់បានកំណត់នូវអ្វីដែលនឹងកើតឡើងនៅពេលខាងមុខ។
របៀបមួយទៀតក្នុងការបកប្រែ «គឺអ្វីដែលព្រះអម្ចាស់
ជាព្រះបិតាបានគ្រោងទុកពីមុនមក» ឬ ២) ព្រះអម្ចាស់
បានដឹងពីអ្វីដែលនិងកើតឡើងនៅពេលខាងមុខ។ ការបកប្រែរបៀបផ្សេងទៀត
«គឺអ្វីដែលព្រះអម្ចាស់ ជាព្រះបិតាបានដឹងជាមុន»
ឲ្យព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្ទប្រោសលើបងប្អូន
«ព្រះលោហិត» នេះទីនេះគឺសំដៅដល់ការសុគតរបស់ព្រះយេស៊ូ។
ដូចដែលលោកម៉ូសេ បានប្រោសលោហិតទៅលើប្រជាជនអ៊ីស្រាអែល
ដើម្បីជានិមិត្តរូបបង្ហាញពីសម្ពន្ធមេត្រីរបស់ពួកគេជាមួយព្រះអម្ចាស់
ការសុគតរបស់ព្រះយេស៊ូគឺជាការផ្សារភ្ជាប់ទំនាក់ទំនងរវាងបងប្អូនអ្នកជឿ
និងព្រះអម្ចាស់។
សូមឲ្យបងប្អូនបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្តកាន់តែច្រើនឡើងៗ
បទគម្ពីរនេះនិយាយអំពីព្រះគុណ
ដែលប្រៀបបានដូចជាវត្ថុមួយដែលបងប្អូនអ្នកជឿអាចមាន ហើយសេចក្តី
សុខសាន្តនោះកាន់តែកើនឡើងៗ។ ជាការពិត ព្រះគុណ គឺជាការផ្តល់ឲ្យ
របស់ព្រះអម្ចាស់ទៅដល់បងប្អូនអ្នកជឿ ហើយសេចក្តីសុខសាន្តនោះ គឺធ្វើឲ្យ
បងប្អូនអ្នកជឿរស់នៅដោយសុខសាន្ត និងមានអំណរជាមួយព្រះអម្ចាស់។
1 Peter 1:3
ព័ត៌មានទូទៅ
លោកពេត្រុសបាននិយាយទៅកាន់អ្នកជឿ អំពីសេចក្តីសង្គ្រោះនិងសេចក្តីជំនឿ។
ត្រង់ចំនុចនេះលោកបានបរិយាយយ៉ាងលម្អិត
និងការប្រៀបធៀបនៅអ្វីដែលព្រះអម្ចាស់ធ្វើការសន្យា ចំពោះអ្នកជឿទាំងអស់ថា
និងឲ្យពួកគេនៅមរតក។
ព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង...បានផ្តល់ឲ្យយើងនូវកំណើតជាថ្មី
ពាក្យថា«ពួកយើង» និងពាក្យ «យើង» គឺសំដៅទៅលើលោកពេត្រុស
និងអស់អ្នកដែលលោកកំពុងសរសេរទៅ។
ព្រះអង្គបានផ្តល់ឱ្យយើងនូវកំណើតជាថ្មី
«ព្រះអង្គបានឲ្យពួកយើងបានកើតសារជាថ្មីម្តងទៀត»
សម្រាប់ការទទួលមរតក
អ្នកអាចបកប្រែដោយប្រើជាកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះយើងរំពឹងថានឹងទទួលបាននូវមរតក»
មរតក
ការទទួលនូវអ្វីដែលព្រះអម្ចាស់បានសន្យាចំពោះអ្នកជឿ
អាចនិយាយបានថាដូចជាការទទួលមរតកនិងទ្រព្យសម្បត្តិពីសមាជិកក្នុងគ្រួសារ។
មិនចេះសាបសូន្យ មិនចេះរលួយ មិនចេះស្រពោន មិនចេះសៅហ្មង ហើយនិងមិនរលាយបាត់ឡើយ
លោកពេត្រុស ប្រើឃ្លាទាំងបីនេះស្រដៀងគ្នា
ដើម្បីពិពណ៌នាពីមរតកដែលជាអ្វីដែលល្អឥតខ្ចោះ និងអស់កល្បជានិច្ច។
វាបានបម្រុងទុកនៅស្ថានបរមសុខ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ បានធ្វើការបម្រុងទុកនៅស្ថានបរមសុខសម្រាប់អ្នករាល់គ្នា»
បងប្អូនត្រូវបានការពារថែរក្សាដោយព្រះចេស្តារបស់ព្រះអម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ កំពុងការពារអ្នករាល់គ្នា»
ដោយព្រះចេស្តារបស់ព្រះអម្ចាស់
«ព្រះចេស្តា»
ត្រង់នេះគឺជារបៀបនៃការនិយាយពីភាពខ្លាំងក្លារបស់ព្រះអម្ចាស់ក្នុងការការពារដល់អ្នកជឿ។
ដោយសេចក្តីជំនឿ
«សេចក្តីជំនឿ» នៅទីនេះគឺសំដៅលើអ្នកជឿដែលមានជំនឿលើព្រះគ្រីស្ទ។
ការបកប្រែរបៀបផ្សេងទៀត: «ដោយសារសេចក្តីជំនឿរបស់អ្នករាល់គ្នា»
រៀបចំទុកជាស្រេច ដែលនឹងបើកត្រូវសម្តែង
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានត្រៀមរួចជាស្រេចដើម្បីបើកបង្ហាញ»
1 Peter 1:6
បងប្អូនមានសេចក្តីអំណរជាខ្លាំង ក្នុងសេចក្តីសង្គ្រោះនោះ
ពាក្យថា «នេះ» ត្រង់ចំនុចនេះគឺសំដៅលើព្រះពរ
ដែលលោកពេត្រុសបានលើកឡើងនៅក្នុងខមុន។
នេះគឺជាការល្បងជំនឿនៃអ្នករាល់គ្នា
ប្រៀបបានដូចជាការស្លរមាសសុទ្ធនៅក្នុងភ្លើង ការសាកល្បង និងសេចក្តីលំបាក
ថាតើអ្នកជឿទុកចិត្តលើព្រះគ្រីស្ទយ៉ាងដូចម្តេច។
ការល្បងជំនឿនៃអ្នករាល់គ្នា
ព្រះអម្ចាស់ និងល្បងថាតើអ្នកជឿទុកចិត្តលើព្រះគ្រីស្ទយ៉ាងដូចម្តេច។
សេចក្តីជំនឿ គឺវិសេសជាងមាសដែលតែងតែខូច ទោះបើបានសាកល្បងនឹងភ្លើងក៏ដោយ
ជំនឿពិតជាមានតម្លៃវិសេសជាងមាស ព្រោះមាសពិតជាមិនអាចស្ថិតស្ថេរជានិរន្តរ៍
បើទោះបីជាត្រូវសម្រិតសម្រាំងនៅក្នុងភ្លើង។
ដោយសេចក្តីជំនឿ អ្នកនឹងរកឃើញផលនៃការសរសើរ សិរីល្អ និងលើកតម្កើង
អាចមានន័យថាទី១) ដោយសេចក្តីជំនឿរបស់អ្នក
«ព្រះអម្ចាស់នឹងលើកតម្កើងអ្នកយ៉ាងខ្ពស់បំផុត» (UDB) ឬ អាចមានន័យទី២)
«ជំនឿរបស់អ្នកនាំមកនូវ ការសរសើរ សិរីល្អ និងលើកតម្កើង» ចំពោះព្រះអម្ចាស់។
ជំនឿរបស់អ្នកនឹងរកឃើញផល
«ជំនឿរបស់អ្នកនឹងបង្ហាញនូវផល ដែលនឹងកើតមានយ៉ាងពិតប្រាកដ»
ក្នុងកាលព្រះយេស៊ូគ្រិស្តយាងត្រលប់មកវិញ
ចំនុចនេះអាចសំដៅទៅលើការយាងត្រលប់របស់ព្រះគ្រិស្ត។
ការបកប្រែរបៀបផ្សេងទៀត: «នៅពេលដែលព្រះយេស៊ូគ្រិស្តបង្ហាញ
អោយមនុស្សទាំងអស់បានឃើញ។
1 Peter 1:8
អំណរដ៏ប្រសើរដែលរកអ្វីថ្លែងមិនបាន
«អំណរដ៏អស្ចារ្យ ដែលគ្មានពាក្យអ្វីមកពិពណ៌នាបាន»
សេចក្តីសង្គ្រោះដល់ព្រលឹងរបស់អ្នក
ឃ្លាថា «ព្រលឹង» នៅទីនេះសំដៅទៅលើ រូបរាងកាយរបស់មនុស្ស។
អ្នកអាចបកប្រែដោយប្រើកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ការសង្គ្រោះអ្នករាល់គ្នា» ឬ «ព្រះអម្ចាស់សង្គ្រោះអ្នករាល់គ្នា»
សេចក្តីសង្គ្រោះ...ព្រះគុណ
ពាក្យទាំងនេះបង្ហាញគំនិតពីរដូចជា វាជាអ្វី រឺជាវត្ថុ។ ជាការពិត «សេចក្តីសង្គ្រោះ»
គឺសំដៅទៅលើសកម្មភាពដែលព្រះអម្ចាស់សង្គ្រោះពួកយើង
ឬអ្វីដែលកើតឡើងជាលទ្ធផល។ ស្រដៀងទៅនិង «ព្រះគុណ»
សំដៅទៅលើរបៀបដែលព្រះអម្ចាស់មានទំនាក់ទំនងជាមួយអ្នកជឿ។
ស្វែងរក និងការសើុបសួរ ដោយយកចិត្តទុកដាក់
ឃ្លា «ការសើុបសួរ ដោយយកចិត្តទុកដាក់» មានន័យមូលដ្ឋានស្រដៀងគ្នាទៅនឹង
«ស្វែងរក» ។ ឃ្លាទាំងពីរនេះបញ្ចូលគ្នាបញ្ជាក់ ពីអត្ថន័យនៃការលំបាក
ដែលពួកព្យាការី ព្យាយាមដឹងពីសេចក្តីសង្គ្រោះនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«ការពិចារណា ដោយយកចិត្តទុកដាក់បំផុត»
1 Peter 1:11

generated on Wed Sep 10 16:16:32 2025

ប្រយោគភ្ជាប់
លោកពេត្រុស បន្តនិយាយអំពីការស្វែងរករបស់ពួកព្យាការី
ដើម្បីស្វែងរកសេចក្តីសង្គ្រោះ។
ពួកគេបានស្វែងរកឲ្យដឹង
«ពួកគេបានព្យាយាមកំណត់»
ព្រះវិញ្ញាណរបស់ព្រះគ្រិស្ត
នេះគឺជាការសំដៅទៅលើព្រះវិញ្ញាណបរិសុទ្ធ។
វាត្រូវបានបើកសម្តែងដល់ពួកគេ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានបើកសម្តែងដល់ពួកព្យាការី»
ពួកទេវតា ទទឹងរង់ចាំមើល
«ពួកទេវតា កំពុងតែចង់ដឹង»
1 Peter 1:13
ដូច្នេះ
«ព្រោះតែហេតុនេះ»។
លោកពេត្រុសប្រើឃ្លានេះគឺសំដៅទៅលើអ្វីដែលគាត់បាននិយាយពីសេចក្តីសង្គ្រោះ
សេចក្តីជំនឿរបស់ពួកគេ និងព្រះវិញ្ញាណនៃព្រះគ្រីស្ត
ផ្តល់ការបើកសម្តែងដល់ពួកព្យាការី។
យកគំនិតរបស់អ្នករាល់គ្នាមកក្រវ៉ាត់ចង្កេះ
ឃ្លានេះគឺសំដៅលើការរៀបចំដើម្បីខិតខំប្រឹងប្រែង។
វាកើតចេញពីការជីបចុងផាយអាវរបស់មនុស្សម្នាក់ទៅជាខ្សែក្រវ៉ាត់ជុំវិញចង្កេះ
ដើម្បីងាយស្រួលក្នុងការផ្លាស់ទី។ ការបកប្រែរបៀបផ្សេងទៀត:
«ការត្រៀមខ្លួនរួចរាល់»
ដោយការដឹងខ្លួន
ក្នុងឃ្លានេះ «ដោយការដឹងខ្លួន» សំដៅទៅលើភាពច្បាស់លាស់ផ្លូវចិត្ត
និងស្មារតីប្រុងប្រយ័ត្ន។ ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់គ្រងការគិតរបស់អ្នករាល់គ្នា» ឬ «ប្រយ័ត្នចំពោះនូវអ្វីដែលអ្នករាល់គ្នាគិត»
ព្រះគុណដែលនឹងផ្តល់មកដល់អ្នករាល់គ្នា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះគុណដែលព្រះអម្ចាស់នឹងនាំមកដល់អ្នករាល់គ្នា»។
សូមអោយបងប្អូនបានប្រកបដោយព្រះគុណ
នេះគឺជារបៀបដែលព្រះអម្ចាស់មានព្រះបន្ទូលជាមួយអ្នកជឿ
ដែលជាអ្វីដែលអាចត្រូវបានផ្តល់ឱ្យពួកគេ។
ការដែលព្រះយេស៊ូគ្រិស្តបើកសម្តែងមក
នេះគឺសំដៅលើការវិលត្រលប់របស់ព្រះគ្រិស្ត។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលព្រះយេស៊ូគ្រិស្តបង្ហាញអោយមនុស្សទាំងអស់បានឃើញ។»
សូមមើលពីរបៀបបកប្រែក្នុងជំពូក 1:6។
មិនត្រូវធ្វើតាមតែចិត្តរបស់ខ្លួនឯង
«កុំបំណងប្រាថ្នាចង់បានអ្វី» ការបកប្រែរបៀបផ្សេងទៀត:
«កុំរស់ដើម្បីបំពេញតែសេចក្តីប្រាថ្នា »
1 Peter 1:15
ដ្បិតមានសេចក្តីចែងទុកមកថា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត: «ដ្បិតតែ
លោកម៉ូសេបានសរសេរ»
អ្នករាល់គ្នាត្រូវវិសុទ្ធ ពីព្រោះយើងជាព្រះវិសុទ្ធ
ឃ្លានេះ «យើង» នៅទីនេះសំដៅទៅលើព្រះអម្ចាស់។
នោះត្រូវរស់នៅដោយកោតខ្លាចព្រះអម្ចាស់
លោកពេត្រុស និយាយពីអ្នកអានរបស់គាត់
ដែលពួកគេជាប្រជាជនរស់នៅឆ្ងាយពីផ្ទះរបស់ពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «គ្រប់ការទាំងអស់
ដែលអ្នករាល់គ្នាកំពុងរស់នៅឆ្ងាយពីផ្ទះពិតរបស់អ្នក។
1 Peter 1:18
អ្នករាល់គ្នាត្រូវបានប្រោសលោះ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានប្រោសលោះអ្នករាល់គ្នា»
ព្រះលោហិតរបស់ព្រះគ្រិស្ត
ឃ្លាថា «ព្រះលោហិត»
នៅទីនេះតំណាងឱ្យការសុគតរបស់ព្រះគ្រិស្តនៅលើឈើឆ្កាង។
ដូចជាចៀមដែលល្អឥតខ្ចោះដែលឥតស្លាកស្នាម
ព្រះយេស៊ូ បានសុគតជាយញ្ញបូជា ដើម្បីការអត់ទោសដល់អំពើបាបរបស់មនុស្ស។
ការបកប្រែរបៀបផ្សេងទៀត: «ដូចជាចៀមដែលល្អឥតខ្ចោះ ដែលឥតស្លាកស្នាម
ដែលជនជាតិយូដាបានបូជា។
ល្អឥតខ្ចោះដែលឥតស្លាកស្នាម
លោកពេត្រុសបង្ហាញពីគំនិតតែមួយតាមវិធីពីរយ៉ាង
ដើម្បីបញ្ជាក់ភាពបរិសុទ្ធរបស់ព្រះគ្រិស្ត។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយគ្មានភាពមិនល្អឥតខ្ចោះ»
1 Peter 1:20
ព្រះគ្រិស្ត ត្រូវបានជ្រើសរើស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានជ្រើសរើសព្រះគ្រិស្ត»
តាំងពីមុនដើមកំណើតពិភពលោក
អ្នកអាចបកប្រែដោយប្រើកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«មុនពេលដែលព្រះអម្ចាស់បង្កើតភពផែនដី»
ព្រះអម្ចាស់ទើបតែបង្ហាញអង្គទៅអ្នករាល់គ្នា
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានបើកបង្ហាញអង្គទ្រង់ទៅអ្នករាល់គ្នា»
ព្រះអម្ចាស់ទើបតែបង្ហាញអង្គទៅអ្នករាល់គ្នា
លោកពេត្រុសមិនបានមានន័យថាអ្នកអាន ពិតជាបានឃើញព្រះគ្រីស្តទេ
ប៉ុន្តែពួកគេបានរៀនពីសេចក្តីពិតអំពីព្រះអង្គ។
ព្រមទាំងប្រទានឲ្យព្រះអម្ចាស់ឲ្យមានសិរីល្អ
លោកពេត្រុសនិយាយពីការតម្កើងរបស់ព្រះអម្ចាស់ដល់ព្រះយេស៊ូ
ក៏ដូចជាព្រះអង្គប្រទានឲ្យទ្រង់នូវអ្វីមួយ។
1 Peter 1:22
ព្រលឹងអ្នករាល់គ្នាបានបរិសុទ្ធ
នៅទីនេះ លោកពេត្រុសនិយាយអំពីអ្នកជឿ
ដូចជាពួកគេបានធ្វើខ្លួនរអោយបរិសុទ្ធ។ ជាការពិត ពួកគេមិនបានធ្វើអ្វីទាំងអស់
ប៉ុន្តែពួកគេគឺទទួលយកការសង្គ្រោះពីព្រះគ្រីស្ត។
ព្រលឹងអ្នករាល់គ្នាបានបរិសុទ្ធ
ឃ្លានេះ «ព្រលឹង» នៅទីនេះសំដៅទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកបានធ្វើខ្លួនរបស់អ្នកបរិសុទ្ធ»
បរិសុទ្ធ
គំនិតនៅក្នុងចំនុចនេះគឺភាពស្អាតស្អំ
ដែលសំដៅទៅលើការទទួលយកពីព្រះអម្ចាស់។
ដោយការស្តាប់តាមសេចក្តីពិត
អ្នកអាចបកប្រែដោយប្រើកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
«ដោយការគោរពតាមសេចក្តីពិត»
ស្រលាញ់គ្នា ដូចជាបងប្អូន
នេះសំដៅទៅលើសេចក្តីស្រឡាញ់រវាងបងប្អូនរួមជំនឿ។
ស្រលាញ់គ្នាឲ្យខ្លាំងដោយចេញពីចិត្ត
ឃ្លានេះ «ចិត្ត» នៅទីនេះសំដៅទៅលើកការដាក់មនោសញ្ចេតនា
ហើយបង្ហាញថាពួកគេត្រូវបានស្រលាញ់គ្នាយ៉ាងពេញលេញ។
ការបកប្រែរបៀបផ្សេងទៀត: «ស្រឡាញ់គ្នាទៅវិញទៅមកដោយស្មោះត្រង់
និងយ៉ាងពេញលេញ» ឬ «ស្រឡាញ់គ្នាទៅវិញទៅមកដោយស្មោះត្រង់
និងយ៉ាងស្មោះអស់ពីចិត្ត»
ការកើតជាថ្មី ដែលមិនមកពីរូបកាយដែលពុករលួយទេ ប៉ុន្តែជារូបកាយដែលមិនចេះពុករលួយ
អាចមានន័យថា លោកពេត្រុសនិយាយពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ដូចជាគ្រាប់ពូជនៃរុក្ខជាតិដែលលូតលាស់ និងបង្កើតជីវិតថ្មីដល់អ្នកជឿ ឬ
ក៏ដូចជាកោសិកាតូចៗនៅខាងក្នុងបុរស
ឬស្ត្រីដែលរួមបញ្ចូលគ្នាធ្វើអោយទារកលូតលាស់នៅក្នុងស្ត្រី។
មិនពុករលួយ
«មិនចេះពុករលួយ» ឬ «មិនស្លិតស្ពេរ»
ដោយការរស់នៅជាប់ជាមួយព្រះបន្ទូលនៃព្រះអម្ចាស់
លោកពេត្រុស មានប្រសាសន៍ពីព្រះបន្ទូលរបស់ព្រះអម្ចាស់
ហាក់ដូចជាវាមានជីវិតជារៀងរហូត។ ជាការពិត
គឺជាព្រះអម្ចាស់ដែលមានជីវិតអស់កល្បជានិច្ច
ហើយអ្នកណាដែលធ្វើតាមបទបញ្ជា និងពាក្យសន្យា និងនៅអស់កល្បជានិច្ច។
1 Peter 1:24
ព័ត៌មានទូទៅ :

generated on Wed Sep 10 16:16:32 2025

នៅក្នុងខទាំងនេះ លោកពេត្រុសបានដកស្រង់ពីព្យាការីអេសាយនូវគម្ពីរមួយ
ដែលទាក់ទងទៅនឹងអ្វីដែលគាត់ទើបតែបាននិយាយអំពីពួកគេ
ដែលបានកើតមកពីរូបកាយដែលមិនចេះរលួយ។
មនុស្សគ្រប់រូបដូចជាស្មៅ
ព្យាការីអេសាយប្រៀបធៀបមនុស្សទៅនឹងស្មៅ ដែលដុះលូតលាស់
និងងាយស្លាប់យ៉ាងឆាប់រហ័ស។ ការបកប្រែរបៀបផ្សេងទៀត:
«មនុស្សនឹងស្លាប់ដូចជា ស្មៅងាប់»
មនុស្សគ្រប់រូប
ឃ្លាថា «សាច់ឈាម » គឺសំដៅទៅលើមនុស្សជាតិ។ ការបកប្រែរបៀបផ្សេងទៀត:
«គ្រប់ប្រជាជន»
គ្រប់ទាំងសិរីល្អគឺដូចជាផ្កានៃស្មៅ
ឃ្លាថា «សិរីល្អ» នៅទីនេះសំដៅទៅលើភាពស្រស់ស្អាត ឬដ៏ល្អ។
អេសាយប្រៀបធៀបអ្វីៗ ដែលមនុស្សចាត់ទុកថាល្អ
ឬស្រស់ស្អាតរបស់មនុស្សទៅនឹងផ្កា ដែលងាយនឹងងាប់យ៉ាងរហ័ស។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សជាតិទាំងអស់ឆាប់ឈប់ការល្អ
ប្រៀបដូចជាផ្កាឆាប់ងាប់»
នេះគឺជាដំណឹងល្អ
ឃ្លាថា «នេះ» នៅទីនេះសំដៅទៅលើ «ព្រះបន្ទូលរបស់ព្រះអម្ចាស់។»
ដំណឹងល្អដែលបានផ្តល់មក
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដំណឹងល្អដែលពួកយើងបានផ្តល់មក»

---

2 [1]ដូច្នេះ ដែលអ្នកបានបោះបង់ចោលអស់ទាំងសេចក្តីអាក្រក់ និងកិច្ចកលទាំងប៉ុន្មាន ព្រមទាំងពុតមាយា ចិត្តច្រណែន ហើយពាក្យនិយាយបង្ខូចគេ។
[2]ដូចជាទារកទើបនឹងកើត សង្វាតរកទឹកដោះ ដើម្បីឲ្យអ្នករាល់គ្នាបានធំធាត់ឡើង រហូតដល់បានសង្គ្រោះ។[3]ប្រសិនបើអ្នករាល់គ្នាបានភ្លក់ការនេះនឹងដឹងថា
ព្រះអម្ចាស់ល្អមែន។
[4]អ្នករាល់គ្នាដែលកំពុងមករកព្រះអង្គជាថ្មដ៏រស់ ដែលជាមនុស្សបានបោះបង់ចោល តែព្រះជាម្ចាស់បានជ្រើសរើសហើយរាប់ជាវិសេសសម្រាប់ព្រះអង្គវិញ។
[5]អ្នករាល់គ្នាក៏ដូចជាថ្មរស់ដែលបានស្អាងឡើងឲ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ ដូចជាពួកសង្ឃវិសុទ្ធសម្រាប់នឹងថ្វាយយញ្ញបូជាខាងព្រលឹងវិញ្ញាណដែលគាប់ព្រះហឫទ័យ
ដល់ព្រះតាមរយៈព្រះយេស៊ូគ្រិស្ត។
[6]ពីព្រោះមានសេចក្តីចែងទុកមកក្នុងបទគម្ពីរថា «មើល ខ្ញុំដាក់ថ្មជ្រុងមួយនៅក្រុងស៊ីយ៉ូន ជាថ្មដែលជ្រើសរើសហើយវិសេសវិសាល។
អស់អ្នកណាដែលជឿដល់ព្រះអង្គនោះនឹងគ្មានហេតុនាំឲ្យខ្មាសឡើយ»។
[7]កិត្តិយសគឺសម្រាប់អស់អ្នកដែលជឿ។ «ថ្មដែលជាងផ្ទះមិនត្រូវការហើយរើចេញ
ប៉ុន្តែថ្មនោះក៏បានត្រឡប់ទៅជាជ្រុងមួយដ៏វិសេស»[8]ពួកអស់អ្នកដែលជំពប់ដួលពីព្រោះពួកគេមិនបានស្តាប់បង្គាប់នូវអ្វីដែលពួកគេត្រូវធ្វើ
ហើយដូចជាថ្មដែលធ្វើឲ្យពួកគេជំពប់ហើយក៏ជាថ្មដែលធ្វើឲ្យពួកគេធ្លាក់ចុះដែរ។
[9]ពីព្រោះតែយើងជាមនុស្សដែលបានជ្រើសរើស ជាបូជាចារ្យ ជាពូជសាសន៍ដ៏វិសុទ្ធ ជាប្រជារាស្ត្រដែលព្រះអម្ចាស់បានជ្រើសតាំង
ដូច្នេះហើយយើងត្រូវតែបង្ហាញចេញនូវសកម្មភាពដំណឹងល្អ ពីព្រះអម្ចាស់ដែលបានហៅយើងឲ្យចេញពីទីងងឹតមករកពន្លឺដ៏អស្ចារ្យ។
[10]កាលពីដើមដំបូងយើងរាល់គ្នាមិនមែនជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទេ ប៉ុន្តែឥឡូវនេះអ្នករាល់គ្នាជាប្រជារាស្ត្រព្រះជាម្ចាស់វិញ។
អ្នករាល់គ្នាមិនដែលទទួលសេចក្តីមេត្តាករុណាទេ ប៉ុន្តែឥឡូវនេះអ្នករាល់គ្នាបានទទួលសេចក្តីមេត្តាករុណាវិញ។
[11]បងប្អូនជាទីស្រលាញ់អើយ ខ្ញុំសូមប្រាប់ទៅអ្នករាល់ក៏ដូចជាបងប្អូនសាសន៍ដទៃដែរ ដើម្បីឲ្យអ្នករាល់គ្នាជៀសចេញឆ្ងាយពីសេចក្តីប៉ងប្រាថ្នាខាងឯសាច់ឈាម
ដែលធ្វើឲ្យអ្នករាល់គ្នាមានការទាស់ប្រឆាំងជាមួយព្រលឹងរបស់អ្នករាល់គ្នា។[12]បងប្អូនគួរមានកិរិយាមាយាទល្អក្នុងចំណោមសាសន៍ដទៃ ដូច្នេះ
ប្រសិនបើពួកគេបាននិយាយពីការអាក្រក់របស់អ្នក ពួកគេនិងបានឃើញពីការល្អរបស់អ្នកវិញនៅថ្ងៃដែលព្រះជាអង្គយាងមក
ហើយពួកគេក៏សរសើរតម្កើងដល់ព្រះអម្ចាស់ទៀតផង។
[13]ដោយព្រោះព្រះអម្ចាស់ ចូរចុះចូលនឹងអំណាចទាំងអស់របស់មនុស្ស មិនថាចំពោះស្តេចដែលមានអំណាចឧត្តម។[14]ហើយក៏ត្រូវគោរពដល់លោកចៅហ្វាយខេត្ត
ដែលជាអ្នកដាក់ទោសដល់មនុស្សអាក្រក់ ហើយក៏ជាអ្នកដែលសរសើរដល់អស់អ្នកដែលធ្វើការល្អដែរ។
[15]ដ្បិតព្រះអម្ចាស់សព្វព្រះទ័យនឹងបំបិទមាត់របស់មនុស្សល្ងង់ខ្លៅដោយអំពើល្អវិញ។[16]អ្នករាល់គ្នាមានសេរីភាព
តែមិនត្រូវយកសេរីភាពមកបិទបាំងអំពើអាក្រក់របស់ខ្លួនឡើយ ប៉ុន្តែ ត្រូវយកសេរីភាពនេះមកប្រើឲ្យសមជាអ្នកបម្រើព្រះអម្ចាស់។[17]ចូរសម្តែងក្តីគោរពដល់មនុស្សទាំងអស់
និងស្រលាញ់រាប់អានបងប្អូនរួមជំនឿ គោរពកោតខ្លាចដល់ព្រះអម្ចាស់ និងគោរពដល់ស្តេចផង។
[18]ពួកអ្នកបម្រើអើយ ចូរចុះចូលនៅនឹងចៅហ្វាយ ដោយកោតខ្លាចគ្រប់យ៉ាង។ ចុះចូលមិនមែនត្រឹមតែចៅហ្វាយណាដែលស្លូតបូតល្អប៉ុណ្ណោះ
ប៉ុន្តែទោះបើចៅហ្វាយដែលមានចិត្តព្យាបាទក្តី។[19]បើសិនជាបងប្អូនណាដែលស៊ូទ្រាំអត់ធន់ក្នុងការឈឺចាប់នៅខណៈពេលដែលទទួលរងអយុត្តិធម៌[20]ព្រោះយល់ដល់ព្រះអង្គ
នោះគួរសរសើរហើយ។
[21]ដ្បិតព្រះអង្គបានត្រាស់ហៅអ្នករាល់គ្នាមកសម្រាប់ការនេះ ព្រោះព្រះគ្រិស្តក៏បានរងទុក្ខសម្រាប់អ្នករាល់គ្នាដែរ ដើម្បីទុកគំរូឲ្យអ្នករាល់គ្នាដើរតាមផ្លូវរបស់ព្រះអង្គ។
[22]ព្រះអង្គមិនដែលប្រព្រឹត្តបាប ហើយក៏មិនដែលឃើញមានសេចក្តីបោកប្រាស់ចេញពីព្រះឱស្ឋរបស់ព្រះអង្គដែរ។[23]ពេលគេប្រមាថព្រះអង្គ នោះព្រះអង្គមិនតបតទេ ពេល
ព្រះអង្គរងទុក្ខលំបាក ព្រះអង្គក៏មិនបានគំរាមកំហែងគេដែរ ផ្ទុយទៅវិញព្រះអង្គបានថ្វាយអង្គទ្រង់ដល់ព្រះជាម្ចាស់ដែលជំនុំជម្រះដោយសុច្ចរិត។
[24]ព្រះអង្គបានយកបាបរបស់យើងមកក្នុងរូបកាយរបស់ព្រះអង្គនៅលើឈើឆ្កាង ដើម្បីឲ្យយើងបានញែកចេញពីបាប ហើយរស់នៅខាងឯសេចក្តីសុចរិតវិញ
អ្នករាល់ក៏បានជាសះស្បើយដោយសារបួសរបស់ព្រះអង្គ។[25]កាលពីដើមអ្នករាល់គ្នាប្រៀបដូចជាចៀមវង្វេង ប៉ុន្តែឥឡូវនេះអ្នករាល់គ្នាបានត្រឡប់មកឯអ្នកគង្វាលវិញ
និងអ្នកមើលថែព្រលឹងអ្នករាល់គ្នាដែរ។

---

1 Peter 2:1
ប្រយោគភ្ជាប់
លោកពេត្រុសកំពុងបន្តបង្រៀនអ្នកអានរបស់លោកអំពីភាពបរិសុទ្ធ
និងការគោរពប្រតិបត្តិ។
ដូច្នេះ ដែលអ្នកបានបោះបង់ចោលអស់ទាំងសេចក្តីអាក្រក់ និងកិច្ចកលទាំងប៉ុន្មាន
ព្រមទាំងពុតមាយា ចិត្តច្រណែន ហើយពាក្យនិយាយបង្ខូចគេ
អំពើបាបទាំងនេះ
ត្រូវបានគេនិយាយឡើងដូចជាអ្វីដែលមនុស្សអាចបោះចោលបាន។ ពាក្យថា
«ដូច្នេះ» គឺសំដៅទៅលើអ្វីទាំងអស់
ដែលលោកពេត្រុសបានលើកឡើងពីភាពបរិសុទ្ធ និងការគោរពប្រតិបត្តិ។
ការបកប្រែរបៀបផ្សេងទៀត: «ដូច្នេះត្រូវបោះបង់ចោល» ឬ «ដូច្នេះ ត្រូវឈប់»
ដូចជាទារកទើបនឹងកើត សង្វាតរកទឹកដោះ
លោកពេត្រុស និយាយពីអ្នកអានរបស់គាត់ប្រសិនបើពួកគេគឺជាទារក។
ទារកគឺត្រូវការអាហារ ដែលល្អ ដែលពួកគេអាចរំលាយបានយ៉ាងងាយស្រួល។
ដូចដែលអ្នកជឿ ត្រូវការបង្រៀនពីព្រះបន្ទូលរបស់ព្រះអម្ចាស់។
ការបកប្រែរបៀបផ្សេងទៀត:
«ដូចទារកចង់បានបឺតជញ្ជាក់ទឹកដោះពីទ្រូងម្តាយរបស់ពួកគេដែរ ដូច្នេះ
អ្នកត្រូវតែប្រាថ្នាចង់បាននូវទឹកដោះខាងវិញ្ញាណបរិសុទ្ធ»
សង្វាតរក
«សេចក្តី ប៉ងប្រាថ្នា» ឬ «ចង់បាន»
ទឹកដោះខាងវិញ្ញាណបរិសុទ្ធ
លោកពេត្រុសកំពុងនិយាយពីព្រះបន្ទូលរបស់ព្រះអម្ចាស់ដូចជាទឹកដោះផ្នែកវិញ្ញាណ
ដែលចិញ្ចឹមអ្នករាល់គ្នា។
អ្នករាល់គ្នាបានធំធាត់ឡើង រហូតដល់បានសង្គ្រោះ

generated on Wed Sep 10 16:16:32 2025

ឃ្លាថា «សេចក្តីសង្គ្រោះ»
នៅទីនេះសំដៅទៅលើពេលដែលព្រះអម្ចាស់នាំសេចក្តីសង្គ្រោះដល់ប្រជាជនរបស់ព្រះអង្គ
នៅពេលដែលព្រះយេស៊ូយាងត្រឡប់មកវិញ។
អ្នកអាចបកប្រែដោយប្រើកិរិយាស័ព្ទ។ ការបកប្រែរបៀបផ្សេងទៀត:
អ្នកអាចធំធាត់ឡើងខាងវិញ្ញាណរហូតដល់ពេលចុងបញ្ចប់
ដែលព្រះអម្ចាស់ជួយសង្គ្រោះអ្នករាល់គ្នាយ៉ាងពេញលេញ»
ធំធាត់
លោកពេត្រុសនិយាយពីអ្នកជឿដែលកំពុងតែចម្រើនចំណេះដឹងពីព្រះអម្ចាស់
និងសេចក្តីជំនឿចំពោះព្រះអង្គ ដូចជាពួកគេជាក្មេងកំពុងតែធំធាត់ឡើង។
ប្រសិនបើអ្នករាល់គ្នាបានភ្លក់ការនេះនឹងដឹងថា ព្រះអម្ចាស់ល្អមែន
នៅទីនេះបានភ្លក់ មានន័យថាជួបប្រទះអ្វីមួយដោយខ្លួនឯង។
ការបកប្រែរបៀបផ្សេងទៀត:
«ប្រសិនបើអ្នកបានជួបប្រទះនូវសេចក្តីសប្បុរសរបស់ព្រះអម្ចាស់ចំពោះអ្នករាល់គ្នា»
1 Peter 2:4
ព័ត៌មានទូទៅ:
លោកពេត្រុសនិយាយពីការប្រៀបធៀបអំពីព្រះយេស៊ូ
និងអ្នកជឿដែលកំពុងរស់នៅដូចជាថ្ម។
កំពុងមករកព្រះអង្គជាថ្មដ៏រស់
លោកពេត្រុសនិយាយអំពីព្រះយេស៊ូ ដូចជាព្រះអម្ចាស់ជាថ្មមួយនៅក្នុងអាគារ។
ការបកប្រែរបៀបផ្សេងទៀត: «មករកព្រះអម្ចាស់ដែលដូចជាដុំថ្មនៅក្នុងអាគារ
ប៉ុន្តែមានជីវិត មិនមែនជាថ្មដែលងាប់ទេ»
ព្រះអង្គជាថ្មដ៏រស់
អាចមានន័យថាទី១) «ព្រះអម្ចាស់ជាថ្មមួយ ដែលមានជីវិត» ឬ ទី២)
ព្រះអម្ចាស់ជាថ្មដែលផ្តល់ជីវិត»
ដែលជាមនុស្សបានបោះបង់ចោល
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលត្រូវបានមនុស្សបដិសេធ»
តែព្រះអម្ចាស់បានជ្រើសរើសព្រះអង្គវិញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ប៉ុន្តែត្រូវបានព្រះអម្ចាស់ជ្រើសរើស»
អ្នករាល់គ្នាក៏ដូចជា...ស្អាងឡើងឲ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ
ដូចគ្នានឹងមនុស្សយកថ្មដើម្បីសង់ប្រាសាទដូចមាននៅក្នុងគម្ពីរសញ្ញាចាស់ដែរ
អ្នកជឿគឺដូចជាសំភារៈដែលព្រះអម្ចាស់កំពុងប្រើដើម្បីសាងសង់ជាដំណាក់
ដែលព្រះអម្ចាស់នឹងគង់នៅ។
អ្នករាល់គ្នាក៏ដូចជាថ្មដ៏រស់
លោកពេត្រុសប្រៀបធៀបអ្នកអានរបស់គាត់ទៅនឹងថ្ម ដែលមានជីវិត។
ដែលបានស្អាងឡើងឲ្យបានធ្វើជាផ្ទះខាងវិញ្ញាណ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់កំពុងសាងសង់ចូលទៅដំណាក់ខាងវិញ្ញាណ»
ដូចជាពួកសង្ឃវិសុទ្ធសម្រាប់នឹងថ្វាយយញ្ញាបូជាខាងព្រលឹងវិញ្ញាណ
តួនាទីនៃបព្វជិតភាព នៅទីនេះតំណាងអោយពួកសង្ឃ ដែលត្រូវបំពេញភារកិច្ច។
1 Peter 2:6
មានសេចក្តីចែងទុកមកក្នុងបទគម្ពីរថា
បទគម្ពីរបាននិយាយដូចជាមានអ្នកចែងទុក។ បទគម្ពីរនេះសំដៅទៅលើពាក្យ
ដែលមនុស្សម្នាក់បានអាននៅក្នុងបទគម្ពីរ។ ការបកប្រែរបៀបផ្សេងទៀត:
«នេះគឺជាអ្វីដែលពួកព្យាការីបានសរសេរនៅក្នុងបទគម្ពីរទុកជាយូរមកហើយ»
មើល
ឃ្លាថា «មើល»
នៅទីនេះដាស់តឿនយើងអោយយកចិត្តទុកដាក់លើព័ត៌មានគួរឱ្យភ្ញាក់ផ្អើល
ដែលកើតឡើងជាបន្តបន្ទាប់។
ថ្មជ្រុងមួយ ដែលជ្រើសរើសហើយវិសេសវិសាល
ព្រះអម្ចាស់គឺជាអ្នកដែលជ្រើសរើសយកថ្មនេះ។ ការបកប្រែរបៀបផ្សេងទៀត:
«ជាថ្មដ៏សំខាន់បំផុត ដែលព្រះអម្ចាស់បានជ្រើសរើស»
ថ្មជ្រុងមួយ
ព្យាការីបាននិយាយពីព្រះមែស៊ីដែលប្រៀបបានដូចជាដុំថ្មមួយ
ដែលសំខាន់បំផុតនៅក្នុងអគារ។
1 Peter 2:7
ប្រយោគភ្ជាប់
លោកពេត្រុសបន្តដកស្រង់ចេញពីបទគម្ពីរ។
ថ្មដែលត្រូវបានរើចេញ...ក៏បានត្រឡប់ទៅជាជ្រុងមួយដ៏វិសេស
អត្ថបទបកប្រែ: ប្រៀបធៀបដែលសំដៅទៅលើមនុស្ស ដូចជាពួកជាងផ្ទះ
ដែលបានបដិសេធព្រះយេស៊ូ ប៉ុន្តែព្រះអម្ចាស់បាន
ធ្វើឲ្យព្រះអង្គក្លាយជាថ្មដ៏សំខាន់បំផុតដែលមិនអាចខ្វះបាននៅក្នុងអគារ។
ថ្មដែលជាងផ្ទះមិនត្រូវការហើយរើចេញ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ថ្មដែលពួកជាងសង់ផ្ទះបានរើចេញ»
ជ្រុងមួយដ៏វិសេស
នេះគឺសំដៅទៅលើថ្មដែលសំខាន់បំផុតនៅក្នុងអគារហើយមានន័យថាជាមូលដ្ឋានគ្រឹះដូចគ្នានឹង
«ថ្មជ្រុង» នៅក្នុង ២:៦។
ថ្មមួយដែលធ្វើឲ្យពួកគេជំពប់ហើយក៏ជាថ្មដែលធ្វើឲ្យពួកគេធ្លាក់ចុះ
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា។
ឃ្លាទាំងនេះរួមគ្នាបញ្ជាក់ថាភាពសោកស្តាយនឹងអាក់អន់ចិត្តរបស់ពួកគេទាំងនោះចំពោះ
«ថ្ម» ដែលសំដៅទៅលើព្រះយេស៊ូ។ ការបកប្រែរបៀបផ្សេងទៀត: «ថ្មមួយ
ឬថ្មត្រួតគ្នាដែលមនុស្សនឹងជំពប់ដួល»
មិនបានស្តាប់បង្គាប់
ឃ្លាថា «បង្គាប់» នេះគឺសំដៅលើការចែកចាយដំណឹងល្អ។
ហើយការមិនស្តាប់បង្គាប់មានន័យថាពួកគេមិនជឿ។ ការបកប្រែរបៀបផ្សេងទៀត:
«ពីព្រោះពួកគេមិនជឿលើសារអំពីព្រះយេស៊ូ»
ពួកអស់អ្នកដែលត្រូវបានបង្គាប់អោយធ្វើ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«សម្រាប់អ្វីដែលព្រះអម្ចាស់បានកំណត់អោយពួកគេផងដែរ»
1 Peter 2:9
ព័ត៌មានទូទៅ:
នៅក្នុងខ ១០ លោកពេត្រុសបានដកស្រង់ខមួយពីព្យាការីហូសេ។
កំណែជំនាន់ថ្មីខ្លះមិនបានរដកស្រង់ទម្រង់នេះមកទេ
ប៉ុន្តែក៏អាចទទួលយកបានដែរ។
មនុស្សដែលបានជ្រើសរើស
លោកអ្នកអាចបញ្ជាក់ច្បាស់បានថាព្រះអម្ចាស់ជាអ្នកដែលបានជ្រើសរើសពួកគេ។
ការបកប្រែរបៀបផ្សេងទៀត: «មនុស្សដែលព្រះអម្ចាស់បានជ្រើសរើស»
ជាបូជាចារ្យ
អាចមានន័យថាទី១) «ក្រុមស្តេច និងក្រុមបូជាចារ្យមួយក្រុម» (UDB) ឬ ទី២
«ក្រុមបូជាចារ្យដែលបំរើស្តេច»។
រាស្ត្រដែលព្រះអម្ចាស់បានជ្រើសតាំង
«ក្រុមមនុស្សដែលព្រះអម្ចាស់បានជ្រើសយកជាកម្មសិទ្ធិរបស់ព្រះអង្គ»
ព្រះអម្ចាស់ដែលបានហៅយើងឲ្យចេញ
«ព្រះអម្ចាស់ដែលបានហៅយើងឲ្យចេញមក»
ពីទីងងឹតមករកពន្លឺដ៏អស្ចារ្យ
ឃ្លាថា «ទីងងឹត»
នៅទីនេះសំដៅទៅលើស្ថានភាពពួកគេដែលជាមនុស្សដែលមានបាប
ដែលមិនស្គាល់ព្រះអម្ចាស់ ឯឃ្លាថា «ពន្លឺ»
សំដៅលើស្ថានភាពពួកគេដែលជាមនុស្ស ដែលស្គាល់ព្រះអម្ចាស់
និងអនុវត្តសេចក្តីសុចរិត។ ការបកប្រែរបៀបផ្សេងទៀត: «ពីជីវិតនៃបាប
និងភាពល្ងង់ខ្លៅ ទៅជាជីវិតមួយដែលស្គាល់ពីព្រះអម្ចាស់
និងគាប់ព្រះហឫទ័យព្រះអង្គ»
អ្នករាល់គ្នានឹងមិនដែលទទួលសេចក្តីមេត្តាករុណា... អ្នករាល់គ្នាបានទទួលសេចក្តីមេត្តាករុណាវិញ
នេះជាសេចក្តីមេត្តាករុណា
ដែលរៀបព្រះអម្ចាស់មានព្រះហឫទ័យមេត្តាករុណាចំពោះអស់អ្នកដែលមិនសមនឹងទទួលយកសេចក្តីនេ
ដូចជាត្រូវបានគេនិយាយថា
វាប្រៀបបាននឹងអ្វីដែលមនុស្សម្នាក់អាចទទួលបាននៅក្នុងដៃរបស់គេ។
1 Peter 2:11
ព័ត៌មានទូទៅ:
លោកពេត្រុសចាប់ផ្តើមនិយាយអំពីរបៀបដែលគ្រីស្តបរិស័ទរស់នៅ។
បងប្អូនសាសន៍ដទៃ និងអ្នកដែលដើរសាត់ព្រាត់
ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា។
លោកពេត្រុសនិយាយពីអ្នកអានរបស់គាត់ថាជាមនុស្សដែលកំពុងរស់នៅក្នុងទឹកដីផ្សេងដែលឆ្ងាយពីផ្ទះរ
សូមមើលពីរបៀបបកប្រែ «សាសន៍ដទៃ» ក្នុងជំពូក ១:១
ជៀសចេញពីសេចក្តីប៉ងប្រាថ្នាខាងឯសាច់ឈាម
នៅទីនេះគំនិតឯខាងសាច់ឈាម គឺសំដៅទៅលើអំពើបាបរបស់មនុស្សបានប្រព្រឹត្ត

generated on Wed Sep 10 16:16:32 2025

ដែលនៅក្នុងលោកីយ៍នេះ។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលមិនអនុញ្ញាតមានសេចក្ដីប៉ងប្រាថ្នាទៅនឹងអំពើបាប»។
ការទាស់ប្រឆាំងជាមួយព្រលឹងរបស់អ្នករាល់គ្នា
ឃ្លាថា «ព្រលឹង» នៅទីនេះសំដៅទៅលើជីវិតឯខាងវិញ្ញាណរបស់មនុស្ស។
លោកពេត្រុសនិយាយអំពីសេចក្ដីប៉ងប្រាថ្នាដ៏អាក្រក់ប្រៀបដូចជាពួកទាហានដែលកំពុងវាយប្រហារ
ការបកប្រែរបៀបផ្សេងទៀត:
«ការស្វែងរកដើម្បីបំផ្លាញជីវិតឯខាងវិញ្ញាណរបស់អ្នក»
បងប្អូនគួរមានកិរិយាមាយាទល្អ
លោកពេត្រុសនិយាយអំពីពួកអ្នកជឿអោយមានកិរិយាមាយាទល្អ
ដែលជាអ្វីដែលពួកគេគួរមាន
ដែលអាចអោយពួកអ្នកមិនជឿបានមើលឃើញការល្អដែលពួកអ្នកជឿធ្វើ។
ប្រសិនបើពួកគេបាននិយាយពីអ្នក
«ប្រសិនបើពួកគេចោទប្រកាន់អ្នក»
ពួកគេនឹងបានឃើញពីការល្អរបស់អ្នកវិញ
លោកពេត្រុសនិយាយអំពីពួកអ្នកជឿដែលប្រព្រឹត្តល្អប្រសិនបើនោះជាអ្វីមួយដែលអ្នក
ដែលអោយពួកគេមើលឃើញតាមរយៈការប្រព្រឹត្តល្អរបស់គ្រីស្ទបរិស័ទ។
ថ្ងៃដែលព្រះអម្ចាស់យាងមក
នេះសំដៅទៅលើថ្ងៃដែលព្រះអម្ចាស់នឹងជំនុំជម្រះមនុស្សលោកទាំងអស់។
អ្នកអាចបកប្រែដោយផ្ទាល់មាត់បាន។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលដែលព្រះអម្ចាស់មកដើម្បីជំនុំជម្រះអ្នករាល់គ្នា»
1 Peter 2:13
ដើម្បីជាប្រយោជន៍ដល់ព្រះអម្ចាស់
អាចមានន័យថាទី១) ដោយការចុះចូលនឹងអំណាចទាំងអស់របស់មនុស្ស
ពួកគេបានគោរពប្រតិបត្តិ ព្រះអម្ចាស់ដែលជាអ្នកតាំងឡើងនៅអំណាចទាំងនោះ ឬ
ទី២) ដោយការចុះចូលនឹងអំណាចទាំងអស់របស់មនុស្ស
ពួកគេនឹងគោរពដល់ព្រះយេស៊ូ ដែលបានចុះចូលនឹងអំណាចរបស់មនុស្សផងដែរ។
ស្តេចដែលមានអំណាចឧត្តម
«ស្តេចដែលមានអំណាចខ្ពស់បំផុត»
ដែលជាអ្នកដាក់ទោស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកដែលស្តេចបានចាត់អោយមកដាក់ទោស»
បំបិទមាត់របស់មនុស្សល្ងង់ខ្លៅដោយអំពើល្អ
«ដោយការធ្វើការល្អ
យើងបញ្ឈប់មនុស្សល្ងង់ខ្លៅពីការនិយាយអំពីអ្វីដែលពួកគេមិនដឹង»
ជាការបិទបាំងអំពើអាក្រក់
លោកពេត្រុសនិយាយពីពួកមនុស្ស
ដែលមានសេរីភាពប្រៀបដូចជាអ្វីមួយដែលពួកគេប្រើដើម្បីលាក់កិរិយាមាយាទនៃអំពើ
ការបកប្រែរបៀបផ្សេងទៀត: «ដូចជាយកអ្វីមួយជាលេសដើម្បីធ្វើអំពើអាក្រក់»
បងប្អូនរួមជំនឿ
នេះសំដៅទៅលើបងប្អូនអ្នកជឿជាគ្រីស្ទបរិស័ទទាំងអស់។
1 Peter 2:18
ព័ត៌មានទូទៅ:
លោកពេត្រុសចាប់ផ្តើមនិយាយជាពិសេសទៅកាន់ពួកអ្នកបម្រើ
ដែលបម្រើនៅក្នុងផ្ទះរបស់គេ។
ចៅហ្វាយដែលល្អ និងស្លូតបូត
ឃ្លាថា «ល្អ» និង «ស្លូតបូត»
គឺមានន័យស្រដៀងគ្នាហើយសង្កត់ធ្ងន់ទៅលើចៅហ្វាយនាយ
ដែលធ្វើល្អដល់ពួកអ្នកបម្រើរបស់ពួកគេដោយសន្តានចិត្តល្អ។
ការបកប្រែរបៀបផ្សេងទៀត: «ចៅហ្វាយនាយដែលប្រកបដោយចិត្តសប្បុរស»
ដែលមានចិត្តព្យាបាទ
«មនុស្សកំណាច» ឬ «អ្នកដែលសាហាវ»
វាគួរឲ្យសរសើរ
«វាគឺសមនឹងទទួលបានការសរសើរ» ឬ «ជាទីសព្វព្រះហឫទ័យរបស់ព្រះអម្ចាស់»
ស៊ូទ្រាំអត់ធន់ក្នុងការឈឺចាប់...ព្រោះយល់ដល់ព្រះអម្ចាស់
អាចមានន័យនៅក្នុងបទគម្ពីរ ទី១)
ដែលអ្នកទាំងនេះគឺទទួលយកការរងភាពអយុត្តិធម៌
ដោយសារតែពួកគេដឹងថាពួកគេកំពុងគោរពប្រតិបត្តិព្រះអម្ចាស់ (UDB) ឬ ទី២)
ដែលមនុស្សនេះអាចស៊ូទ្រាំអត់ធន់នឹងការដាក់ទោសអយុត្តិធម៌
ពីព្រោះពួកគេដឹងថាព្រះអម្ចាស់ជ្រាបដឹងពីទុក្ខវេទនា ដែលពួកគេកំពុងជួប។
ថាតើវាមានទំហំប៉ុន្មា...នៅខណៈពេលដែលទទួលរងរងទុក្ខទណ្ឌកម្ម?
លោកពេត្រុសសួរសំណួរនេះដើម្បីបញ្ជាក់ថាគ្មានអ្វីគួរឲ្យសរសើរអំពីការរងទុក្ខទណ្ឌកម្មដោយសារការធ្វើខុ
ការបកប្រែរបៀបផ្សេងទៀត: «សម្រាប់អ្នកដែលមិនត្រូវបានសរសើរ...
នៅពេលដែលរងទុក្ខទណ្ឌកម្ម»
ដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិតឯខាងវិញ្ញាណរបស់អ្នកជឿ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពេលដែលនរណាម្នាក់ដាក់ទណ្ឌកម្មមកលើអ្នករាល់គ្នា»
អ្នករងនូវទុក្ខលំបាកនៅពេលទទួលទណ្ឌកម្ម
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«អ្នកទទួលរងនូវទុក្ខវេទនា
ខណៈនៅពេលដែលមាននរណាម្នាក់ដាក់ទណ្ឌកម្មមកលើអ្នករាល់គ្នា»
1 Peter 2:21
ប្រយោគភ្ជាប់
លោកពេត្រុសបន្តនិយាយទៅកាន់មនុស្ស ដែលជាអ្នកបម្រើក្នុងផ្ទះរបស់ប្រជាជន។
ឃ្លាថា «នេះ» នៅទីនេះសំដៅទៅលើអ្នកជឿ ដែលស៊ូទ្រាំពេលរងទុក្ខ
ដោយសារការធ្វើល្អដូចលោកពេត្រុសទើបតែបានពិពណ៌នា។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានហៅអ្នករាល់គ្នាពីរឿងនេះ»
ឲ្យអ្នករាល់គ្នាដើរតាមផ្លូវរបស់ព្រះអង្គ
«ដ្បិតអ្នកដើរតាមដានជើងរបស់ព្រះគ្រីស្ទ។»
លោកពេត្រុសនិយាយអំពីការធ្វើតាមគំរូរបស់ព្រះយេស៊ូតាមរបៀប
ដែលពួកគេរងទុក្ខដូចជាមនុស្សម្នាក់កំពុងតែដើរតាមផ្លូវ ដែលព្រះយេស៊ូបានធ្វើ។
ការបកប្រែរបៀបផ្សេងទៀត: «សម្រាប់អ្នកធ្វើត្រាប់តាមអាកប្បកិរិយារបស់ព្រះអង្គ»
ហើយក៏មិនដែលឃើញមានសេចក្ដីបោកប្រាស់ចេញពីព្រះឱស្ឋរបស់ព្រះអង្គដែរ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«គ្មាននរណាម្នាក់រកឃើញការបោកបញ្ឆោតនៅក្នុងព្រះឱស្ឋរបស់ព្រះអង្គទេ»
ហើយក៏មិនដែលឃើញមានសេចក្ដីបោកប្រាស់ចេញពីព្រះឱស្ឋរបស់ព្រះអង្គដែរ
ឃ្លាថា «ការបោកបញ្ឆោត» នៅទីនេះសំដៅទៅលើពាក្យ ដែលមនុស្សម្នាក់និយាយ
ដែលមានបំណងបញ្ឆោតមនុស្សផ្សេងទៀត។ ការបកប្រែរបៀបផ្សេងទៀត:
«យើងមិនបាននិយាយកុហកទេ»
ពេលគេប្រមាថព្រះអង្គ
ឃ្លាថា «ជេរប្រមាថ» មានន័យថានិយាយជេរប្រមាថដល់មនុស្សម្នាក់ទៀត។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«នៅពេលមនុស្សជេរប្រមាថព្រះអង្គ»
បានថ្វាយអង្គទ្រង់ដល់ព្រះអម្ចាស់ដែលជំនុំជម្រះដោយសុចរិត
ដែលជំនុំជម្រះដោយសុចរិតវិញ»។
នេះមានន័យថាព្រះអង្គទុកចិត្តដល់ព្រះអម្ចាស់ដើម្បីដកភាពអាម៉ាស់របស់ព្រះអង្គ
ដែលត្រូវបានគេដាក់លើព្រះអង្គដោយអ្នកដែលធ្វើបាបព្រះអង្គយ៉ាងឃោរឃៅ។
1 Peter 2:24
ប្រយោគភ្ជាប់
លោកពេត្រុសបន្តនិយាយអំពីព្រះយេស៊ូគ្រីស្ត។
គាត់នៅតែបន្តនិយាយទៅកាន់ពួកអ្នកបម្រើ។
ព្រះអង្គផ្ទាល់
នេះគឺសំដៅទៅលើព្រះយេស៊ូ ជាមួយនឹងការសង្កត់ន័យ។
បានយកបាបរបស់យើងមកក្នុងរូបកាយរបស់ព្រះអង្គនៅលើឈើឆ្កាង
ឃ្លាថា «យកបាបរបស់យើង»
មានន័យថាព្រះអម្ចាស់បានទទួលទណ្ឌកម្មសំរាប់អំពើបាប។
ការបកប្រែរបៀបផ្សេងទៀត: «ព្រះអម្ចាស់ទទួលរងនូវការធ្វើទណ្ឌកម្ម
លើរូបកាយរបស់ព្រះអង្គដោយអំពើបាបរបស់ពួកយើងនៅលើដើមឈើ»
ដើមឈើ
នេះគឺតំណាងឲ្យឈើឆ្កាងដែលព្រះយេស៊ូទ្រង់បានសោយទីវង្គត
ដែលត្រូវបានធ្វើឡើងពីឈើ។
ដោយសាររបួសរបស់ព្រះអង្គ អ្នករាល់គ្នាក៏បានជាសះស្បើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានធ្វើការព្យាបាលដល់អ្នករាល់គ្នា
ពីព្រោះការធ្វើទុករបស់មនុស្សលើព្រះកាយព្រះអង្គ»
កាលពីដើមអ្នករាល់គ្នាប្រៀបដូចជាចៀមវង្វេង
លោកពេត្រុសនិយាយទៅកាន់អ្នកអានរបស់គាត់មុនពេលដែលពួកគេជឿលើព្រះគ្រីស្ត

generated on Wed Sep 10 16:16:32 2025

ពួកគេប្រៀបដូចជាសត្វចៀមដែលវង្វេងបាត់វង្វេងបាត់។
អ្នកគង្វាល និងអ្នកមើលថែព្រលឹងអ្នករាល់គ្នា
លោកពេត្រុសនិយាយអំពីព្រះយេស៊ូ ដូចជាព្រះអង្គជាអ្នកគង្វាល។
ដូចជាអ្នកគង្វាលការពារចៀមរបស់គាត់ ព្រះយេស៊ូការពារអស់អ្នករាល់គ្នា
ដែលជឿទុកចិត្តលើព្រះអង្គ។

3 [1]ប្រពន្ធរាល់គ្នាអើយ ត្រូវគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន ដើម្បីឲ្យកិរិយាមារយាទរបស់បងប្អូនទាក់ទាញចិត្តស្វាមីខ្លះដែលមិនជឿព្រះបន្ទូល ឲ្យបានស្គាល់ព្រះអង្គ
ដោយមិនបាច់បញ្ចេញពាក្យសម្តីទេ។[2]គេបានសង្កេតឃើញពីអាកប្បកិរិយាជាមួយការគោរព។
[3]ចូរកុំតុបតែងខ្លួនតែសំបកខាងក្រៅដូចជាក្រងសក់ ពាក់មាស និងស្លៀកសម្លៀកបំពាក់ម៉ូតផ្សេងៗនោះឡើយ។[4]ផ្ទុយទៅវិញ ចូរតុបតែងមនុស្សខាងក្នុងនៃចិត្ត
ដោយគ្រឿងមិនចេះពុករលួយគឺដោយវិញ្ញាណស្លូតបូត និងស្រគត់ស្រគំ ដែលមានតម្លៃបំផុតនៅព្រះភក្ត្រព្រះជាម្ចាស់។
[5]កាលពីយូណាស់មកហើយពួកស្ត្រីវិសុទ្ធដែលមានសង្ឃឹមលើព្រះជាម្ចាស់ក៏បានតុបតែងខ្លួនរបៀបនេះ ទាំងចុះចូលនឹងប្តីរបស់ខ្លួនដែរ។
[6]ដូចជាសារ៉ាបានស្តាប់បង្គាប់អ័ប្រាហាំហើយហៅគាត់ថាលោកម្ចាស់ទៀតផង។
ឥឡូវអ្នករាល់គ្នាបានក្លាយជាកូនរបស់សារ៉ាបើសិនជាអ្នករាល់គ្នាប្រព្រឹត្តអំពើល្អដោយមិនភ័យខ្លាចចំពោះបញ្ហា។
[7]រីឯប្តីរាល់គ្នាក៏ដូច្នោះដែរ អ្នកជាប្តីត្រូវតែរស់នៅជាមួយប្រពន្ធរបស់ខ្លួនដោយមានការយោគយល់គ្នា ដោយយល់ដល់ស្ត្រីដែលទន់ខ្សោយ។
យើងគួរតែផ្តល់កិត្តិយសដល់នាងទុកជាអ្នកស្នងមរតកព្រះគុណនៃជីវិត។ ដូច្នេះនិងមិនមានអ្វីមកររាំងសេចក្តីអធិស្ឋានរបស់អ្នកឡើយ។
[8]នៅទីបញ្ចប់ អ្នកទាំងអស់គ្នាមានគំនិតតែមួយ ចិត្តអាណិតអាសូរ ស្រឡាញ់គ្នាដូចជាបងប្អូន ចិត្តសន្តោស និងចិត្តសុភាពចុះ។
[9]កុំឲ្យធ្វើការអាក្រក់ស្នងនិងការអាក្រក់ឬការប្រមាថស្នងនិងការប្រមាថឡើយ។ ផ្ទុយទៅវិញ ចូរបន្តប្រទានពរដល់គេ ពីព្រោះអ្នកត្រូវបានត្រាស់ហៅតាមរយៈកិច្ចការនេះ
ដោយអ្នករាល់គ្នាបានទទួលព្រះពរទុកជាមរតក។
[10]ដ្បិតអ្នកដែលស្រឡាញ់ជីវិតហើយចង់ឃើញថ្ងៃល្អត្រូវតែបញ្ឈប់អណ្តាតរបស់ខ្លួនពីការនិយាយអាក្រក់
ហើយនិងបបូរមាត់របស់ខ្លួនកុំឲ្យនិយាយពាក្យបោកបញ្ឆោតឡើយ។[11]ត្រូវឲ្យអ្នកនោះត្រឡប់ចេញពីការអាក្រក់ហើយធ្វើអ្វីដែលល្អវិញ។
ចូរឲ្យអ្នកនោះស្វែងរកនិងដេញតាមសន្តិភាពវិញ។[12]ដ្បិតព្រះនេត្ររបស់ព្រះជាម្ចាស់ទតឃើញសេចក្តីសុចរិត
ហើយព្រះកាណ៌របស់ព្រះអង្គក៏ស្តាប់សេចក្តីអធិស្ឋានរបស់គេដែរ។ ប៉ុន្តែព្រះភក្ត្ររបស់ព្រះជាម្ចាស់ទាស់ប្រឆាំងនិងពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់។"
[13]បើសិនអ្នករាល់គ្នាមានចិត្តបួងផ្តាច់ប្រព្រឹត្តល្អ តើអ្នកណានិងធ្វើបាបអ្នករាល់គ្នា?[14]ប៉ុន្តែបើសិនអ្នករាល់គ្នារងទុក្ខដោយព្រោះតែសេចក្តីសុចរិតមែន អ្នករាល់គ្នាមានពហើយ។
ចូរកុំភ័យខ្លាចនូវអ្វីដែលពួកគេភ័យខ្លាចឡើយ។ កុំជ្រួលច្របល់ឡើយ។
[15]ផ្ទុយទៅវិញ ចូរទុកព្រះគ្រិស្តជាព្រះអម្ចាស់នៅក្នុងដួងចិត្តរបស់អ្នករាល់គ្នាចុះ។ ត្រូវតែរួចរាល់ជានិច្ចក្នុងការឆ្លើយនិងសំនួរអស់អ្នកដែលសួរថា
ហេតុអ្វីបានជាអ្នកមានទំនុកចិត្តលើព្រះជាម្ចាស់។ ចូរធ្វើកិច្ចការនេះដោយគោរពនិងសុភាពរាបសារ។
[16]ត្រូវមានមនសិការល្អដើម្បីឲ្យពួកអ្នកដែលនិយាយមួលបង្កាច់អ្នករាល់គ្នាត្រង់ចំណុចណាមួយនោះត្រូវអាម៉ាសមុខ
គឺពួកអ្នកដែលនិយាយបង្ខូចពីអាកប្បកិរិយាល្អរបស់អ្នករាល់គ្នានៅក្នុងព្រះគ្រិស្ត។[17]វាគឺជាការល្អ បើជាបំណងរបស់ព្រះជាម្ចាស់មែន
នោះស៊ូរងទុក្ខដោយធ្វើការប្រសើជាងធ្វើការអាក្រក់។
[18]ព្រះគ្រិស្តត្រូវបានរងទុក្ខម្តងដោយព្រោះបាប។ គឺព្រះអង្គព្រះដ៏សុចរិតហើយបានរងទុក្ខជួសយើង អស់អ្នកដែលទុច្ចរិត ព្រះអង្គនាំអ្នករាល់គ្នាទៅឯព្រះជាម្ចាស់។
ព្រះអង្គត្រូវបានគេសម្លាប់ខាងឯសាច់ឈាម ប៉ុន្តែត្រូវបានប្រោសឲ្យរស់ឡើងវិញខាងឯព្រះវិញ្ញាណ។[19]ដោយសារព្រះវិញ្ញាណនោះ
ព្រះអង្គបានយាងទៅប្រកាសពីព្រះបន្ទូលប្រាប់វិញ្ញាណទាំងឡាយដែលបានជាប់ឃុំឃាំង។
[20]ពួកអ្នកដែលមិនស្តាប់បង្គាប់កាលពីដើមនៅពេលដែលព្រះអម្ចាស់បានរងចាំអត់ធ្មត់នៅជំនាន់លោកណូអេ នៅក្នុងថ្ងៃដែលសាងសង់ទូកធំ
ហើយនៅក្នុងទូកធំមានមនុស្សបន្តិចបន្តួច គឺមានមនុស្សប្រាំបីនាក់ដែលរួចជីវិតពីទឹកជំនន់។
[21]នេះគឺជាគំរូអំពីពិធីជ្រមុជទឹកដែលបានសង្គ្រោះអ្នករាល់គ្នាឥឡូវនេះដែរ មិនមែនជាការលាងសម្អាតភាពស្មោកគ្រោគរបស់រូបកាយនោះទេ
ផ្ទុយទៅវិញជាការឆ្លើយតបចេញពីមនសិការល្អចំពោះព្រះជាម្ចាស់ ដោយសារការរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្ត។[22]ព្រះយេស៊ូគ្រិស្តយាងទៅស្ថានសួគ៌។
ហើយព្រះអង្គគង់នៅខាងស្តាំនៃព្រះជាម្ចាស់។ ពួកទេវតា សិទ្ធអំណាច និងអំណាចទាំងឡាយត្រូវតែចុះចូលនឹងព្រះអង្គផងដែរ។

---

1 Peter 3:1
ព័ត៌មានទូទៅ:
លោកពេត្រុសចាប់ផ្តើមនិយាយជាពិសេសទៅដល់ស្ត្រីដែលជាប្រពន្ធ។
ប្រពន្ធរាល់គ្នាអើយ ត្រូវគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន
ដូចគ្នានឹងអ្នកជឿដែល «ចុះចូលនឹងអំណាចរបស់មនុស្ស» (២:១៣)
ហើយនិងពួកអ្នកបម្រើដែល
«ត្រូវបានចុះចូលនឹងចៅហ្វាយនាយរបស់ខ្លួន» (២:១៨) ប្រពន្ធរាល់គ្នាក៏ត្រូវគោរព
ប្រតិបត្តិចំពោះស្វាមីរបស់ពួកគេផងដែរ។ ឃ្លាថា «គោរពតាម » «ត្រូវចុះចូល» និង
«ចុះចូល» គឺបកប្រែជាពាក្យដូចគ្នា ។
ស្វាមីខ្លះដែលមិនជឿព្រះបន្ទូល
ឃ្លាថា «ព្រះបន្ទូល» នៅទីនេះសំដៅទៅលើសារនៃដំណឹងល្អ។
ការមិនស្តាប់បង្គាប់មានន័យថាពួកគេមិនជឿ។
សូមមើលរបៀបបកប្រែស្រដៀងគ្នាក្នុង ២:៧។ ការបកប្រែរបៀបផ្សេងទៀត:
«បុរសជាស្វាមីខ្លះមិនជឿលើសារអំពីព្រះយេស៊ូទេ»
ពួកគេបានស្គាល់ព្រះអង្គ
«ពួកគេអាចនឹងត្រូវបានទាក់ទាញចិត្តឲ្យទទួលជឿព្រះគ្រីស្ត»
នេះមានន័យថាស្វាមីដែលមិនទទួលជឿនឹងក្លាយជាអ្នកជឿ។
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកគេអាចប្រែក្លាយទៅជាអ្នកជឿ»
ដោយមិនបាច់បញ្ចេញពាក្យសម្តី
«ដោយប្រពន្ធមិនបានបញ្ចេញពាក្យសម្តីអ្វីទាំងអស់» ឃ្លាថា «ពាក្យសម្តី»
នៅទីនេះសំដៅទៅលើពាក្យដែលប្រពន្ធនិយាយ។
សង្កេតឃើញពួកគេមានអាកប្បកិរិយាជាមួយការគោរព
លោកត្រុសនិយាយពីអាកប្បកិរិយាដូចជាអ្វីដែលយើងអាចមើលឃើញ
ជាជាងអ្វីដែលពួកគេបង្ហាញចេញមកក្រៅ។
ដោយអាកប្បកិរិយានៃការគោរព
អាចមានន័យថា ១) «អាកប្បកិរិយារបស់អ្នករាល់គ្នាចំពោះពួកគេ
និងរបៀបដែលអ្នករាល់គ្នាគោរពពួកគេ» (UDB) ឬ ២)
«អាកប្បកិរិយាដ៏ពិតរបស់អ្នករាល់គ្នាទៅពួកគេ
និងរបៀបដែលអ្នករាល់គ្នាគោរពព្រះអម្ចាស់» ។
1 Peter 3:3
ប្រយោគភ្ជាប់:
លោកពេត្រុសបន្តនិយាយទៅកាន់ស្ត្រីដែលជាប្រពន្ធ។
ចូរធ្វើវាឲ្យរួចរាល់
ឃ្លាថា «វា» គឺសំដៅលើប្រពន្ធ ដែលបានចុះចូល
និងធ្វើអ្វីមួយសម្រាប់ប្តីរបស់ពួកគេ។
តុបតែងមនុស្សខាងក្នុងនៃចិត្ត
ឃ្លាថា «តុបតែងមនុស្ស» និង «ចិត្ត» គឺសំដៅទៅលើចរិតលក្ខណៈខាងក្នុង
និងបុគ្គលក្ខណៈខាងក្រៅរបស់មនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«លក្ខណៈពិតរបស់អ្នករាល់គ្នាគឺស្ថិតនៅខាងក្នុង»
ដោយវិញ្ញាណស្លូតបូត និងស្រគត់ស្រគំ
«ស្រគត់ស្រគំ ប្រកបដោយឥរិយាបថសុខសាន្ត» ឃ្លាថា «ស្រគត់ស្រគំ»
មានន័យថា «សន្តិភាព» ឬ «ស្ងប់ស្ងាត់» ។ ឃ្លាពាក្យ «ស្មារតី»
សំដៅទៅលើអាកប្បកិរិយាឬនិស្ស័យរបស់មនុស្សម្នាក់។

generated on Wed Sep 10 16:16:32 2025

ដែលមានតម្លៃបំផុតនៅមុខព្រះភក្ត្រព្រះអម្ចាស់
លោកពេត្រុសនិយាយអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់មនុស្សនោះ
ដូចជាមនុស្សនោះកំពុងឈរនៅពីមុខព្រះអម្ចាស់។ ការបកប្រែរបៀបផ្សេងទៀត:
«ដែលព្រះអម្ចាស់ឲ្យតម្លៃខ្ពស់បំផុត»
1 Peter 3:5
បានហៅគាត់ថាលោកម្ចាស់
ដែលបាននិយាយថាគាត់ជាម្ចាស់របស់នាង នោះគឺ ចៅហ្វាយរបស់នាង
អ្នករាល់គ្នាបានក្លាយជាកូនរបស់នាង
លោកពេត្រុសនិយាយពីស្ត្រី ដែលជាអ្នកជឿដែលដូចជាសារ៉ា
ហើយត្រូវបានគេគិតថាពួកគេរាល់គ្នាជាកូនពិតប្រាកដរបស់នាង។
1 Peter 3:7
ព័ត៌មានទូទៅ:
លោកពេត្រុសចាប់ផ្តើមនិយាយជាពិសេសទៅកាន់បុរសដែលជាស្វាមី។
រឹងប៉ឹងរាល់គ្នាក៏ដូច្នោះដែរ
នេះសំដៅទៅលើរបៀបដែលសារ៉ា
និងស្ត្រីដទៃទៀតគោរពប្រតិបត្តិដល់ស្វាមីរបស់ពួកគេ ក្នុង៣:៥
ដោយមានការយោគយល់គ្នា ដោយយល់ដល់ស្ត្រីដែលទន់ខ្សោយ
លោកពេត្រុសនិយាយអំពីស្ត្រី ដែលពួកគេជាស្ត្រីដែលទន់ខ្សោយ
ដូចជាពេលខ្លះត្រូវបានពួកបុរសៗចំអន់ផងដែរ។ ការបកប្រែរបៀបផ្សេងទៀត:
«ប្រពន្ធរាល់គ្នាតែងតែយល់ថាស្ត្រីគឺទន់ខ្សោយជាងបុរស»
ផ្តល់កិត្តិយសដល់នាងទុកជាអ្នកស្នងមរតកព្រះគុណនៃជីវិត
អ្នកអាចបកប្រែដោយផ្ទាល់មាត់បាន។ ការបកប្រែរបៀបផ្សេងទៀត:
«ផ្តល់កិត្តិយសដល់ពួកនាងព្រោះពួកនាងនឹងទទួលបានជីវិតអស់កល្បជានិច្ច
ដែលព្រះអម្ចាស់ទ្រង់ប្រទាន»
ស្នងមរតកព្រះគុណនៃជីវិត
ជីវិតអស់កល្បជានិច្ចជាញឹកញាប់ត្រូវបានគេនិយាយដូចជាវាជាអ្វីដែលមនុស្សទទួលបានឬស្នងមរតក
ធ្វើបែបនេះ
ឃ្លាថា «បែបនេះ» នៅទីនេះសំដៅទៅលើរបៀប ដែលស្វាមីគួរធ្វើចំពោះប្រពន្ធ។
ការបកប្រែរបៀបផ្សេងទៀត: «ស់នៅជាមួយប្រពន្ធរបស់ខ្លួនដោយរបៀបនេះ»
ដូច្នេះនិងមិនមានអ្វីមកររាំងសេចក្តីអធិស្ឋានរបស់អ្នកឡើយ
«ររាំង» គឺមិនឲ្យអ្វីមួយកើតឡើងបាន។ នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។
ការបកប្រែរបៀបផ្សេងទៀត:
«ដូច្នេះមិនមានអ្វីមកររាំងសេចក្តីអធិស្ឋានអ្នកឡើយ» ឬ
«ដូច្នេះគ្មានអ្វីអាចមកររាំងអ្នកពីការអធិស្ឋាននោះទេ»
1 Peter 3:8
ព័ត៌មានទូទៅ:
លោកពេត្រុសចាប់ផ្តើមនិយាយម្តងទៀតទៅកាន់អ្នកជឿទាំងអស់។
មានគំនិតតែមួយ
«មានយោបល់ដូចគ្នា» ឬ «មានចិត្តគំនិតដូចគ្នា»
ចិត្តសន្តោស
នេះសំដៅទៅលើក្តីស្រឡាញ់ចំពោះមនុស្សដទៃទៀត
កុំឲ្យធ្វើការអាក្រក់តបស្នងនិងការអាក្រក់ឬការប្រមាថស្នងនិងការប្រមាថឡើយ
លោកពេត្រុសនិយាយពីការធ្វើស្នងតបទៅវិញ
ចំពោះទង្វើដែលមនុស្សបានធ្វើជាការសងត្រលប់ទៅទង្វើនោះវិញ។
ការបកប្រែរបៀបផ្សេងទៀត:
«សូមកុំធ្វើអាក្រក់ទៅអ្នកណាម្នាក់ដែលធ្វើអាក្រក់មកលើអ្នក
ឬជេរប្រមាថទៅអ្នកណាម្នាក់ដែលជេរប្រមាថអ្នក»
ចូរបន្តប្រទានពរ
អ្នកឲ្យដឹងច្បាស់ថាអ្វីទៅជាព្រះពរ។ ការបកប្រែរបៀបផ្សេងទៀត:
«បន្តប្រទានពរដល់អ្នកដែលធ្វើអាក្រក់ចំពោះអ្នក ឬពួកអ្នកដែលជេរប្រមាថអ្នក »
ព្រោះអ្នកត្រូវបានត្រាស់ហៅ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់បានត្រាស់ហៅអ្នកសម្រាប់ការនេះ»
អ្នករាល់គ្នាបានទទួលព្រះពរទុកជាមរតក
លោកពេត្រុសនិយាយអំពីការទទួលព្រះពរពីព្រះអម្ចាស់ប្រៀបបានដូចជាការទទួលជាមរតក
ការបកប្រែរបៀបផ្សេងទៀត: «នោះអ្នកនឹងទទួលបានព្រះពរ
ដែលជាទ្រព្យសម្បត្តិដែលអស់កល្បជានិច្ច»
1 Peter 3:10
ព័ត៌មានទូទៅ:
នៅក្នុងខទាំងនេះ លោកពេត្រុសដកស្រង់ចេញពីគម្ពីរទំនុកតម្កើង
អ្នកដែលស្រឡាញ់ជីវិតហើយចង់ឃើញថ្ងៃល្អ
ឃ្លាទាំងពីរនេះមានន័យជាមូលដ្ឋានដូចគ្នា
និងបង្ហាញពីបំណងប្រាថ្នាចង់មានជីវិតមួយដ៏ល្អ។
ឃើញថ្ងៃល្អ
ការជួបរឿងល្អ នៅទីនេះត្រូវបានគេនិយាយថាបានមើលឃើញអ្វីដែលល្អ។ ឃ្លាថា
«ថ្ងៃ» គឺសំដៅទៅលើអាយុរបស់មនុស្សម្នាក់។ ការបកប្រែរបៀបផ្សេងទៀត:
«បានជួបរឿងល្អៗក្នុងជីវិត»
បញ្ឈប់អណ្តាតរបស់ខ្លួនពីការនិយាយអាក្រក់
ហើយនិងបបូរមាត់របស់ខ្លួនកុំឲ្យនិយាយពាក្យបោកបញ្ឆោត
ឃ្លាថា «អណ្តាត» និង «បបូរមាត់» សំដៅទៅលើអស់អ្នកដែលកំពុងនិយាយ។
ឃ្លាទាំងពីរនេះមានអត្ថន័យមូលដ្ឋានដូចគ្នា
និងសង្កត់ធ្ងន់លើការដាក់កំហិតមិនអោយនិយាយកុហក។
ការបកប្រែរបៀបផ្សេងទៀត: «បញ្ឈប់រាល់ការនិយាយអាក្រក់
និងពាក្យបោកបញ្ឆោត»
ព្រះនេត្ររបស់ព្រះជាម្ចាស់ទតឃើញសេចក្តីសុចរិត
ឃ្លាថា «ព្រះនេត្រ» សំដៅទៅលើសមត្ថភាពរបស់ព្រះអម្ចាស់ក្នុងការដឹងរឿង។
ការយល់ស្របរបស់ព្រះអម្ចាស់ចំពោះមនុស្សសុចរិត
ត្រូវបានគេនិយាយនៅពេលព្រះអង្គទតមើលពួកគេ។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់ទតឃើញសេចក្តីសុចរិត» ឬ
«ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងមនុស្សសុចរិត»
ព្រះកាណ៌របស់ព្រះអង្គក៏ស្តាប់សេចក្តីអធិស្ឋាន
ឃ្លាថា «ព្រះកាណ៌» សំដៅទៅលើព្រះអម្ចាស់ទ្រង់ជ្រាប ដឹង
ពីអ្វីដែលពួកគេនិយាយ» ឬ
«ព្រះអង្គប្រទានឲ្យពួកគេស្របតាមសេចក្តីអធិស្ឋានរបស់ពួកគេ»
ប្រឆាំងនឹងព្រះ
ឃ្លាថា «ព្រះភក្ត្រ» សំដៅទៅលើព្រះអម្ចាស់ដើម្បីតតាំប្រឆាំងនិងពួកសត្រូវ ។
ការប្រឆាំងនឹងនរណាម្នាក់ត្រូវបានគេប្រៀបប្រដូចថាជាការប្រឈមមុខដាក់គ្នានឹងមនុស្សម្នាក់នោះ»
1 Peter 3:13
ប្រយោគភ្ជាប់
លោកពេត្រុសបន្តបង្រៀនអ្នកជឿអំពីការប្រៀរបៀបរស់នៅជាគ្រិស្តបរិស័ទ។
បើសិនអ្នករាល់គ្នាមានចិត្តបូផ្តាច់ប្រព្រឹត្តល្អ តើអ្នកណានិងធ្វើបាបអ្នករាល់គ្នា?
លោកពេត្រុសសួរសំនួរនេះដើម្បីបញ្ជាក់ថា
មិនមាននរណាម្នាក់នឹងធ្វើបាបអ្នករាល់គ្នាទេ ប្រសិនបើអ្នករាល់គ្នាធ្វើអំពើល្អ។
ការបកប្រែរបៀបផ្សេងទៀត: «មិនមាននរណាម្នាក់នឹងធ្វើបាបអ្នកទេ
ប្រសិនបើអ្នកធ្វើតែអំពើល្អ»
រងទុក្ខដោយព្រោះតែសេចក្តីសុចរិតមែន
អ្នកអាចបកប្រែដោយផ្ទាល់មាត់បាន។ ការបកប្រែរបៀបផ្សេងទៀត:
«រងទុក្ខដោយព្រោះតែការធ្វើត្រឹមត្រូវ»
អ្នករាល់គ្នាមានពរហើយ
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះអម្ចាស់នឹងប្រទានពរដល់អ្នករាល់គ្នា»
ចូរកុំភ័យខ្លាចនូវអ្វីដែលពួកគេភ័យខ្លាចឡើយ។ កុំជ្រួលច្របល់ឡើយ។
ឃ្លាទាំងពីរនេះមានអត្ថន័យស្រដៀងគ្នា
និងសង្កត់ធ្ងន់ថាអ្នកជឿមិនគួរខ្លាចការបន្ទាចរបស់ពួកអ្នកដែលបៀតបៀនគេឡើយ។
ការបកប្រែរបៀបផ្សេងទៀត: «កុំភ័យខ្លាចនូវអ្វីដែលមនុស្សធ្វើមកលើអ្នករាល់គ្នា»
អ្វីដែលពួកគេភ័យ
ឃ្លាថា «ពួកគេ» គឺសំដៅទៅលើអ្នកណាដែលព្យាយាមធ្វើទុក្ខដល់អ្នក
ដែលលោកពេត្រុសកំពុងសរសេរ។
1 Peter 3:15
ផ្ទុយទៅវិញ
«ជំនួសឲ្យការរភ័យខ្លាចនិងបញ្ហា»
ចូរទុកព្រះគ្រិស្តជាព្រះអម្ចាស់នៅក្នុងដួងចិត្តដ៏បរិសុទ្ធរបស់អ្នករាល់គ្នា
ក្នុងឃ្លា «ចូរទុកព្រះគ្រិស្តជាព្រះអម្ចាស់...ដ៏បរិសុទ្ធ»
មានន័យថាទទួលស្គាល់ព្រះគ្រីស្តគឺជាព្រះដ៏វិសុទ្ធ។
ការនេះដែលត្រូវបាននញ្ជាក់ថានឹងដាក់អ្វីមួយនៅកន្លែងមួយដែលមានកិត្តិយស។
ក្នុងដួងចិត្ត
នៅទីនេះផ្នែកខាងក្នុង និងអារម្មណ៍របស់មនុស្សត្រូវបានគេហៅថា «ដួងចិត្ត»។
ការបកប្រែរបៀបផ្សេងទៀត: «ដោយឆន្ទៈរបស់អ្នករាល់គ្នា»

generated on Wed Sep 10 16:16:32 2025

1 Peter 3:18

ប្រយោគភ្ជាប់

លោកពេត្រុស

ពន្យល់អំពីអ្វីដែលព្រះគ្រីស្ទបានរងទុក្ខនិងអ្វីដែលព្រះគ្រីស្ទបានសម្រេចដោយការរងទុក្ខ
វេទនា។

រងទុក្ខជួសយើង

ឃ្លាថា «យើង» សំដៅទៅលើលោកពេត្រុសខ្លួនឯងនិងអ្នកដែលស្តាប់។

ព្រះអង្គនាំអ្នករាល់គ្នាទៅឯព្រះអម្ចាស់

លោកពេត្រុស

ប្រហែលជាមានន័យថានៅទីនេះថាព្រះគ្រីស្តបានសុគតដើម្បីបង្កើតទំនាក់ទំនងជិតស្និទ្ធ
និងព្រះអម្ចាស់។

ព្រះអង្គត្រូវបានគេសម្លាប់ខាងឯសាច់ឈាម

ឃ្លាថា «សាច់ឈាម» សំដៅទៅលើសំបករាងកាយរបស់ព្រះគ្រីស្ត

ព្រះគ្រីស្តទ្រង់បានសុគតឯខាងសាច់ឈាម។

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ពួកមនុស្សបានធ្វើគុតខាងឯសាច់ឈាមរបស់ព្រះគ្រិស្ត»

ព្រះអង្គត្រូវបានប្រោសឲ្យរស់ឡើងវិញខាងឯព្រះវិញ្ញាណ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ព្រះវិញ្ញាណបានធ្វើឲ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ»

ដោយព្រះវិញ្ញាណ

អាចមានន័យថាទី១) ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ (UDB) ឬ ទី២)
ជីវិតនៅឯខាងវិញ្ញាណ។

ដោយសារព្រះវិញ្ញាណនោះ ព្រះអង្គបានយាងទៅ

អាចមានន័យថាទី១) «ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ
ព្រះអង្គបានយាងទៅ» (UDB) ឬ ទី២) «ជីវិតនៅឯខាងវិញ្ញាណរបស់ព្រះអង្គ
ព្រះអង្គបានយាងទៅ»

វិញ្ញាណទាំងឡាយដែលបានជាប់ឃុំឃាំង

អាចមានន័យថាទី១នៃពាក្យ «វិញ្ញាណ»
គឺសំដៅទៅលើពួកវិញ្ញាណអាក្រក់» (UDB) ឬ ទី២
«វិញ្ញាណរបស់មនុស្សស្លាប់»។

នៅពេលដែលព្រះជាម្ចាស់ទ្រង់រងចាំដោយការអត់ធ្មត់

ឃ្លាថា «ការអត់ធ្មត់» គឺជាពាក្យប្រៀបធៀបសម្រាប់ព្រះអម្ចាស់ផ្ទាល់។

លោកពេត្រុសសរសេរអំពីការអត់ធ្មត់របស់ព្រះអម្ចាស់ ដូចជាវាជាមនុស្សម្នាក់។

ការបកប្រែរបៀបផ្សេងទៀត: «នៅពេលព្រះអម្ចាស់បានរង់ចាំដោយការអត់ធ្មត់»

នៅជំនាន់លោកណូអេ នៅក្នុងថ្ងៃដែលសាងសង់ទូកធំ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែរបៀបផ្សេងទៀត:
«ក្នុងអំឡុងសម័យកាលលោកណូអេ
នៅពេលដែលលោកបានសាងសង់ទូកដ៏ធំមួយ»

ព្រលឹងចំនួនប្រាំបី

ឃ្លាថា «ព្រលឹង» នៅទីនេះសំដៅទៅលើមនុស្ស។ ការបកប្រែរបៀបផ្សេងទៀត:
«មានមនុស្សប្រាំបីនាក់»

1 Peter 3:21

នេះគឺជាគំរូអំពីពិធីជ្រមុជទឹកដែលបានសង្គ្រោះអ្នករាល់គ្នាឥឡូវនេះដែរ

លោកពេត្រុសនិយាយថាពិធីបុណ្យជ្រមុជទឹក

ដែលទាក់ទងទៅនឹងរបៀបដែលព្រះអម្ចាស់បានសង្គ្រោះលោកណូអេ
និងក្រុមគ្រួសាររបស់លោកនៅក្នុងទូកធំអោយរួចផុតពីទឹកជំនន់។

ពិធីជ្រមុជទឹកដែលបានសង្គ្រោះអ្នករាល់គ្នា

ពិធីជ្រមុជទឹកគឺជារបៀបដែលព្រះអម្ចាស់ជួយសង្គ្រោះមនុស្សរាល់គ្នា។

ការបកប្រែរបៀបផ្សេងទៀត:
«ពិធីបុណ្យជ្រមុជទឹកដែលព្រះអម្ចាស់បានសង្គ្រោះអ្នករាល់គ្នាឥឡូវនេះដែរ»។

ការឆ្លើយតបចេញពីមនសិការល្អចំពោះព្រះជាម្ចាស់

អាចមានន័យថាទី១)
«ការអំពាវនាវទៅកាន់មនុស្សម្នាក់ដល់ព្រះអម្ចាស់អោយប្រទាននូវមនសិការល្អមួយ» (UDB)
ឬទី២)
«ដូចជាការសន្យារបស់មនុស្សម្នាក់ចំពោះព្រះអម្ចាស់ចេញពីមនសិការដ៏ល្អពោល
នោះគឺភាពស្មោះត្រង់»។

ដោយសារការរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្ត

«ដោយសារតែការរស់ឡើងវិញរបស់ព្រះយេស៊ូគ្រីស្ត» នេះគឺជាឃ្លាបញ្ចប់

«នេះគឺតំណាងឲ្យនិមិត្តរូបនៃពិធីបុណ្យជ្រមុជទឹក
ដែលជួយសង្គ្រោះអ្នករាល់គ្នាឥឡូវនេះ»

ចុះចូលនឹងព្រះអង្គផងដែរ

«ចុះចូលចំពោះព្រះយេស៊ូគ្រីស្ត»

---

4 [1]ដូចច្នេះ ដោយព្រះគ្រិស្តបានរងទុក្ខខាងសាច់ឈាមរួចហើយ នោះអ្នករាល់គ្នាក៏ត្រូវត្រៀមលក្ខណដូច្នោះដែរ។
សម្រាប់អ្នកដែលរងទុក្ខខាងឯសាច់ឈាមអ្នកនោះឈប់ប្រព្រឹត្តិអំពើបាបទៀតហើយ។[2]ជាលទ្ធផល ដូចជាមនុស្សដែលរស់នៅខាងឯសាច់ឈាម
ហើយសេចក្តីប៉ងប្រាថ្នារបស់គេនិងគ្មានទៀតឡើយ ប៉ុន្តែមានតែក្តីប៉ងប្រាថ្នារបស់ព្រះជាម្ចាស់វិញ។
[3]អ្នកបានចំណាយពេលគ្រប់គ្រាន់សម្រាប់មនុស្សដែលចង់ឲ្យអ្នកធ្វើ រស់នៅដោយត្រេកត្រអាល លោភកាម ស៊ីផឹកអ៊ូអែ ប្រមឹក និងថ្វាយបង្គំរូបព្រះដែលគួរឲ្យស្អប់
នោះល្មមហើយ។[4]ពួកគេងឿងឆ្ងល់ដែលអ្នលរាល់គ្នាប្រយ័ត្នជាមួយនិងឥរិយាបថខិលខូចហួសហេតុរបស់ពួកគេ ដូច្នេះពួកគេក៏និយាយអាក្រក់ពីអ្នក។
[5]ពួកគេនិងត្រូវរៀបរាប់ប្រាប់ព្រះអង្គដែលត្រូវជំនុំជំរះទាំងអ្នករស់និងអ្នកស្លាប់។[6]ហេតុនេះហើយបានជាដំណឹងល្អបានប្រកាសប្រាប់មនុស្សដែលស្លាប់
ដើម្បីឲ្យគេជាប់ក្នុងការជំនុំជំរះខាងឯសាច់ឈាមដូចជាមនុស្សដែរ ប៉ុន្តែឲ្យគេមានជីវិតខាងឯវិញ្ញាណដូចព្រះជាម្ចាស់វិញ។
[7]ទីបញ្ចប់នៃគ្រប់ទាំងអស់ជិតមកដល់ហើយ។ ចូរមានគំនិតត្រឹមត្រូវ កុំឲ្យកាត់បន្ថយក្នុងការអធិស្ឋានឡើយ។[8]គ្រប់ការទាំងអស់ អ្នកទាំងអស់គ្នាស្រឡាញ់គ្នាទៅវិញទៅមក
សេចក្តីស្រលាញ់គឺគ្របបាំងលើមនុស្សទាំងអស់ពីអំពើបាប។[9]គឺត្រូវទទួលរាក់ទាក់គ្នាទៅវិញទៅមកដោយមិនត្អូញត្អែ។
[10]ចូរបម្រើគ្នាទៅវិញទៅមក តាមអំណោយទានដែលម្នាក់ៗបានទទួល ស្មោះត្រង់ជួយគ្រប់កិច្ចការទាំងអស់ដោយព្រះគុណរបស់ព្រះអង្គ។[11]ប្រសិនបើនរណាម្នាក់និយាយ
ចូរនិយាយពីព្រះបន្ទូលរបស់ព្រះអង្គ។ ប្រសិនអ្នកបម្រើ ចូរបម្រើតាមកម្លាំងដែលព្រះជាម្ចាស់ផ្តល់ឲ្យ។
ដើម្បីឲ្យព្រះជាម្ចាស់បានតម្កើងឡើងក្នុងគ្រប់ការទាំងអស់តាមរយៈព្រះយេស៊ូគ្រិស្ត។ សូមឲ្យមានសិរីរុងរឿង និងព្រះចេស្តាអស់កល្បជានិច្ច។ អាម៉ែន។
[12]បងប្អូនជាទីស្រលាញ់ ចូរអ្នករាល់គ្នាកុំប្លែកចិត្តនឹងសេចក្តីល្បួងដ៏ឈឺចាប់ដែលកំពុងកើតមានក្នុងចំណោមអ្នករាល់គ្នាដើម្បីល្បងលនោះ
ប្រៀបដូចជារឿងចម្លែកមួយកើតឡើងចំពោះអ្នករាល់គ្នាឡើយ។[13]ផ្ទុយទៅវិញ យ៉ាងណាអ្នករាល់គ្នាបានចូលរួមចំណែករងទុក្ខជាមួយព្រះគ្រិស្ត ចូរមានអំណរ
ដូច្នេះហើយអ្នកត្រូវរីករាយជាមួយអំណរនៅពេលព្រះអង្គបង្ហាញសិរីរុងរឿងរបស់ព្រះអង្គ។[14]ប្រសិនបើអ្នករាល់គ្នាត្រូវគេដៀលត្មះដោយនូវនាមព្រះគ្រិស្ត
អ្នកនោះមានពរហើយ ដោយព្រោះព្រះវិញ្ញាណប្រកបដោយសិរីរុងរឿងដែលជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សណ្ឋិតលើអ្នករាល់គ្នា។
[15]កុំឲ្យមានអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាត្រូវរងទុក្ខដោយព្រោះតែឃាតករ ជាចោរ ឧក្រិដ្ឋជន ឬក៏ជាអ្នកជ្រៀតជ្រែកគេ។
[16]ប៉ុន្តែប្រសិនបើអ្នករងទុក្ខដោយព្រោះតែជាគ្រិស្តបរិស័ទ ចូរកុំឲ្យអ្នករាល់គ្នាអៀនខ្មាស់ឡើយ ផ្ទុយទៅវិញ
ចូរឲ្យអ្នករាល់គ្នាថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់ដោយព្រោះតែឈ្មោះនោះចុះ។
[17]ដ្បិតពេលវេលាជំនុំជម្រះត្រូវចាប់ផ្តើមពីដំណាក់របស់ព្រះជាម្ចាស់។ ហើយប្រសិនបើការជំនុំជម្រះចាប់ផ្តើមជាមួយយើងរាល់គ្នាមុននោះ
តើនឹងមានអ្វីកើតឡើងជាមួយអស់អ្នកដែលមិនស្តាប់តាមដំណឹងល្អរបស់ព្រះជាម្ចាស់?[18]ម្យ៉ាងទៀត
"ប្រសិនបើមនុស្សសុចរិតពិបាកក្នុងការទទួលបានសេចក្តីសង្គ្រោះទៅហើយ
តើពួកអស់អ្នកដែលមិនជឿហើយនិងអ្នកដែលមានបាបទៅជាយ៉ាងណាវិញ?"[19]ដូច្នេះអស់អ្នកដែលបានរងទុក្ខដោយព្រោះព្រះជាម្ចាស់
ត្រូវប្រគល់ព្រលឹងខ្លួនទុកនឹងព្រះដ៏ស្មោះត្រង់ដែលបង្កើតអ្វីៗទាំងអស់ហើយប្រព្រឹត្តការល្អចុះ។

---

generated on Wed Sep 10 16:16:32 2025

1 Peter 4:1
ប្រយោគភ្ជាប់
លោកពេត្រុស បន្តបង្រៀនអ្នកជឿអំពីការរស់នៅជាគ្រីស្តបរិស័ទ។
គាត់ចាប់ផ្តើមដោយការសន្មតទៅគំនិតរបស់គាត់ពីជំពូកមុន
អំពីការរងទុក្ខរបស់ព្រះគ្រីស្ត។
ខាងសាច់ឈាម
«ក្នុងរូបកាយរបស់ព្រះអង្គ»
នោះអ្នករាល់គ្នាក៏ត្រូវត្រៀមលក្ខណដូច្នោះដែរ
ឃ្លាថា «ត្រៀមខ្លួន» គឺធ្វើឲ្យអ្នកអានគិតទៅដល់ទាហាន
ដែលត្រៀមអាវុធរបស់ពួកគេសម្រាប់ប្រយុទ្ធ។ វាក៏បង្ហាញពី
«ត្រៀមលក្ខណដូចគ្នា» ដូចជាអាវុធ ឬអាចជាគ្រឿងសឹក។
ពាក្យនេះមានន័យថាអ្នកជឿត្រូវត្រៀមចិត្ត ប្រសិនបើត្រូវរងទុក្ខដូចព្រះយេស៊ូដែរ។
ការបកប្រែរបៀបផ្សេងទៀត: «ត្រៀមខ្លួនឲ្យរួចរាល់ក្នុងការទទួលរងទុក្ខ
ដែលព្រះគ្រីស្តធ្លាប់ទទួល»
រងទុក្ខខាងឯសាច់ឈាម
ឃ្លាថា «ខាងឯសាច់ឈាម»
គឺសំដៅដល់ពេលវេលានៃជីវិតរបស់យើងរាល់គ្នានៅលើផែនដី។
ការបកប្រែរបៀបផ្សេងទៀត: «ការរងទុក្ខឈឺចាប់ពេល
ដែលយើងរស់នៅលើផែនដី»
ឈប់ប្រព្រឹត្តិអំពើបាប
«បានឈប់ធ្វើអំពើបាប»
បំណងប្រាថ្នារបស់គេ
សម្រាប់អ្វីដែលមនុស្សមានបាបតែងតែប្រាថ្នាចង់បាន
1 Peter 4:3
ស៊ីផឹកអ៊ូអែ ប្រមឹក
ពាក្យទាំងនេះសំដៅទៅលើសកម្មភាពដែលមនុស្សប្រមូលផ្តុំផឹកស្រា
ហើយមានអាកប្បកិរិយាគួរឲ្យអាម៉ាស់។
ឥរិយាបថខិលខូចហួសហេតុ
ទាំងនេះជាឧទាហរណ៍នៃអំពើបាប
ដែលហួសហេតុដែលត្រូវបានគេប្រៀបធៀបដូចជាទឹកជំនន់ដ៏ធំដែលហូរគ្របមកលើមនុស្ស
ហួសហេតុ
ការលោភលន់ដោយឥតកំណត់តាមសេចក្តីប៉ង ប្រាថ្នានៃរូបកាយ
សូមមើលការបកប្រែឃ្លាស្រដៀងគ្នានៅក្នុងជំពូក១ ខ១ និងជំពូក១ ខ៨
និងជំពូក២ ខ២០ ។ «ទទួលបទពិសោធន៍កាន់តែច្រើនឡើងៗ
ពីព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង ដែលសម្តែងព្រះហឫទ័យសប្បុរសចំពោះអ្នក
ហើយអ្នកនឹងស្គាល់ព្រះអង្គកាន់តែច្បាស់ឡើងៗ »

១ យ៉ូហាន

1 [1]ពីអ្វីដែលយើងបានឮដំបូងគេបំផុត គឺអ្វីដែលយើងបានឃើញជាមួយភ្នែករបស់យើង ហើយអ្វីដែលយើងបានសម្លឹងមើល និងដៃរបស់យើងបានប៉ះ
គឺអំពីព្រះបន្ទូលនៃជីវិតដែលមានតាំងពីដំបូងមកម្ល៉េះ[2]ជាមួយនិងជីវិតដែលបានសម្តែងឲ្យស្គាល់ ហើយយើងបានឃើញជីវិតនោះ
យើងក៏បានធ្វើទីបន្ទាល់ពីជីវិតនោះដែរ។ យើងកំពុងតែប្រកាសពីជីវិតអស់កល្ប ដែលបានគង់នៅជាមួយព្រះវរបិតា ហើយបានសម្តែងឲ្យយើងបានស្គាល់ផង។
[3]គឺយើងបានឃើញ ហើយឮ យើងក៏ប្រកាសដល់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានរួមប្រកបជាមួយយើង។ ការរួមប្រកបរបស់យើងគឺរួមប្រកបជាមួយព្រះវរបិតា
និងជាមួយព្រះបុត្រារបស់ព្រះអង្គ ព្រះយេស៊ូគ្រិស្ត។[4]យើងសរសេរសេចក្តីទាំងនេះផ្ញើដល់អ្នករាល់គ្នា ដើម្បីឲ្យអំណររបស់យើងបានពេញបរិបូរឡើង។
[5]ការនេះគឺជាសារដែលយើងបានឮពីព្រះអង្គ និងកំពុងតែប្រកាសដល់អ្នក៖ ព្រះជាម្ចាស់ជាពន្លឺ ហើយនៅក្នុងព្រះអង្គ គ្មានសេចក្តីងងឹតទាល់តែសោះ។[6]ប្រសិនបើ
យើងនិយាយថា យើងបានរួមប្រកបជាមួយព្រះអង្គ ហើយនៅតែដើរក្នុងសេចក្តីងងឹត នោះយើងកំពុងតែកុហកហើយ ក៏មិនបានប្រព្រឹត្តតាមសេចក្តីពិតដែរ។[7]ប៉ុន្តែ
ប្រសិនបើ យើងដើរនៅក្នុងពន្លឺ ដូចជាព្រះអង្គដែលនៅក្នុងពន្លឺ គឺយើងបានប្រកបជាមួយគ្នាទៅវិញទៅមក នោះព្រះលោហិតរបស់ព្រះយេស៊ូ
ព្រះបុត្រារបស់ព្រះអង្គសម្អាតយើងពីបាបទាំងអស់។
[8]ប្រសិនបើ យើងនិយាយថា យើងគ្មានបាបសោះ នោះយើងកំពុងកុហកខ្លួនឯងហើយ គឺគ្មានសេចក្តីពិតនៅក្នុងយើងទេ។[9]ប៉ុន្តែ ប្រសិនបើយើងសារភាពបាបរបស់យើង
នោះទ្រង់ស្មោះត្រង់ ថែមទាំងអត់ទោសបាបរបស់យើង និងសម្អាតបាបយើងចេញពីអំពើទុច្ចរិតទាំងអស់ផង។[10]ប្រសិនបើយើងនិយាយថា យើងមិនបានធ្វើបាបទេ
យើងធ្វើឲ្យព្រះអង្គក្លាយជាអ្នកកុហក ហើយព្រះបន្ទូលរបស់ព្រះអង្គមិនបាននៅក្នុងយើងទេ។

1 John 1:1
ឃ្លាភ្ជាប់៖
កណ្ឌគម្ពីរនេះមានគោលបំណងពីរ គឺសម្ព័ន្ធភាពនិងអំណរ។
ព័ត៌មានទូទៅ:
សាវ័កយ៉ូហានបានសរសេរសំបុត្រនេះទៅកាន់អ្នកជឿ។ ឧទាហរណ៍ពាក្យ «អ្នក»
«របស់អ្នក» និង «របស់អ្នក» រួមបញ្ចូលអ្នកជឿទាំងអស់ និងជាពហុវចនៈ។
នៅទីនេះពាក្យ «យើង» និង «យើង»
សំដៅទៅលើលោកយ៉ូហាននិងអ្នកដែលបាននៅជាមួយព្រះយេស៊ូ។
ព័ត៌មានទូទៅ:
ខ១ ជាប្រយោគមួយផ្នែក។
ប្រសិនបើអ្នកត្រូវការប្រយោគពេញលេញអ្នកអាចចាប់ផ្តើមប្រយោគដោយខ១
ចាត់ទុកខ ២ ជាវង់ក្រចកដូចយូឌីប៊ី ហើយបំពេញប្រយោគ ជំពូក១ ខ៣ ។
ដំបូងគេបំផុត
ឃ្លាថា «អ្វីៗដែលមានដំបូងគេបំផុត»
សំដៅទៅលើព្រះយេស៊ូដែលមានមុនពេលអ្វីៗទាំងអស់ ដែលបានបង្កើតឡើង។
ការបកប្រែផ្សេងទៀត៖ «យើងសរសេរសេចក្តីទាំងនេះទៅប្រាប់អ្នករាល់គ្នា
ស្តីអំពីព្រះអង្គ ដែលមានមុនកំណើតពិភពលោក»។
ដំបូង
«ការចាប់ផ្តើមនៃអ្វីៗទាំងអស់» ឬ «ការបង្កើតពិភពលោក»
អ្វីដែលយើងបានឮ
«ដែលយើងបានឮទ្រង់បង្រៀន»
អ្វីដែលយើងបានឃើញជាមួយភ្នែករបស់យើង ហើយអ្វីដែលយើងបានសម្លឹងមើល
សង្កត់ន័យម្តងទៀត។ ការបកប្រែបន្ថែម៖ «ដែលខ្លួនយើងបានឃើញ»
ព្រះបន្ទូលនៃជីវិត
«ព្រះបន្ទូលនៃជីវិត» គឺព្រះយេស៊ូ។ ការបកប្រែបន្ថែម៖
«ព្រះយេស៊ូដែលជាអ្នកធ្វើឲ្យមនុស្សរស់ជារៀងរហូត»

generated on Wed Sep 10 16:16:32 2025

ជីវិត
ពាក្យ «ជីវិត» នៅក្នុងសំបុត្រនេះសំដៅទៅលើអ្វីច្រើនជាងជីវិតខាងរាងកាយ។
តំណាងឲ្យព្រះយេស៊ូដែលជាជីវិតអស់កល្បជានិច្ច។
ជីវិតដែលបានសម្តែងឲ្យស្គាល់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់បានធ្វើឱ្យយើងស្គាល់ជីវិតអស់កល្បជានិច្ច»ឬ«ព្រះជាម្ចាស់បានធ្វើឱ្យយើងមានជីវិតអស់កល្បជានិច្ច»
យើងបានឃើញជីវិតនោះ
«ហើយយើងបានឃើញព្រះអង្គ»
យើងក៏បានធ្វើទីបន្ទាល់ពីជីវិតនោះដែរ
«ហើយយើងប្រាប់អ្នកដទៃអំពីព្រះអង្គ»
ជីវិតអស់កល្ប
ត្រង់នេះ «ជីវិតអស់កល្បជានិច្ច» គឺសំដៅទៅលើអ្នកដែលបានផ្តល់ជីវិតឲ្យយើង គឺ
ព្រះយេស៊ូ។ ការបកប្រែផ្សេងទៀត៖ «អ្នកដែលអាចឲ្យយើងរស់នៅជារៀងរហូត»
គង់នៅជាមួយព្រះវរបិតា
«ដែលនៅជាមួយព្រះជាម្ចាស់ជាព្រះវរបិតា»
បានសម្តែងឲ្យយើងបានស្គាល់ផង
នេះជាពេលដែលទ្រង់រស់នៅលើផែនដី។ ការបកប្រែបន្ថែម៖
«ហើយទ្រង់បានមករស់នៅក្នុងចំណោមពួកយើង»
1 John 1:3
ព័ត៌មានទូទៅ:
នៅទីនេះពាក្យថា «យើង» «យើងទាំងអស់» និង «របស់យើង»
សំដៅទៅលើលោកយ៉ូហាននិងអ្នកដែលបាននៅជាមួយព្រះយេស៊ូ។
គឺយើងបានឃើញ ហើយឮ យើងក៏ប្រកាសដល់អ្នករាល់គ្នា
«យើងនិយាយទៅកាន់អ្នកនូវអ្វីដែលយើងបានឃើញនិង បានឮផង»
ការរួមប្រកបរបស់យើងគឺរួមប្រកបជាមួយព្រះវរបិតា
«ធ្វើជាមិត្តជិតស្និទ្ធរបស់យើង។ យើងជាមិត្តនឹងព្រះជាម្ចាស់ជាព្រះវរបិតា»
ការរួមប្រកបរបស់យើង
វាមិនច្បាស់ទេថាតើលោកយ៉ូហានកំពុងរាប់បញ្ចូលឬមិនរាប់បញ្ចូលអ្នកអានរបស់គាត់។
អ្នកអាចបកប្រែតាមវិធីនេះ។
ព្រះវរបិតា .....ព្រះបុត្រា
ទាំងនេះគឺមានសារសំខាន់ណាស់ដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់និងព្រះយេស៊ូ
ដើម្បីឲ្យអំណររបស់យើងបានពេញបរិបូរណ៌ឡើង
«ដើម្បីធ្វើឱ្យអំណររបស់យើងបានពេញលេញ» ឬ
«ធ្វើឱ្យខ្លួនយើងសប្បាយរីករាយក្រៃលែង»
1 John 1:5
ឃ្លាភ្ជាប់៖
ចាប់ពីជំពូកនេះទៅជំពូកបន្ទាប់លោកយ៉ូហានសរសេរអំពីការប្រកប -
ទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់និងអ្នកជឿផ្សេងទៀត។
ព័ត៌មានទូទៅ:
នៅទីនេះពាក្យថា «យើង» និង «យើងទាំងអស់»
សំដៅទៅលើអ្នកជឿទាំងអស់រួមទាំងមនុស្សដែលលោកយ៉ូហានកំពុងសរសេរ។
លើកលែងតែមានការបញ្ជាក់ផ្សេងនោះគឺជាអត្ថន័យសម្រាប់សៀវភៅដែលនៅសល់។
ព្រះជាម្ចាស់ជាពន្លឺ
នេះមានន័យថាព្រះជាម្ចាស់គឺព្រះដ៏វិសុទ្ធឥតខ្ចោះ។
វប្បធម៌ដែលភ្ជាប់ភាពល្អជាមួយពន្លឺអាចរក្សាគំនិតនៃពន្លឺដោយមិនពន្យល់ពាក្យប្រៀបធៀប។
ការបកប្រែបន្ថែម «ព្រះជាម្ចាស់សុចរិតដូចពន្លឺសុទ្ធឥតខ្ចោះ»
ក្នុងព្រះអង្គគ្មានសេចក្តីងងឹតសោះឡើយ
នេះមានន័យថាព្រះជាម្ចាស់មិនដែលធ្វើបាបហើយមិនដែលធ្វើការអាក្រក់ទាំងអស់។
វប្បធម៌ដែលភ្ជាប់អំពើអាក្រក់ជាមួយភាពងងឹតប្រហែលជាអាចរក្សាគំនិតនៃភាពងងឹតដោយមិនពន្យល់ពី
ការបកប្រែផ្សេងទៀត៖ «នៅក្នុងទ្រង់គ្មានភាពងងឹតនៃអំពើបាបទេ»
ដើរក្នុងសេចក្តីងងឹត
នេះមានន័យថា «ប្រព្រឹត្តអំពើអាក្រក់» ឬ «ធ្វើអំពើអាក្រក់»។
ដើរនៅក្នុងពន្លឺ
នេះមានន័យថា «អនុវត្តការល្អ» ឬ «ធ្វើអ្វីដែលល្អ»។
ព្រះលោហិតរបស់ព្រះយេស៊ូ
នេះសំដៅទៅលើការសុគតរបស់ព្រះយេស៊ូ
ព្រះបុត្រា
នេះគឺជាឋានៈសំខាន់របស់ព្រះយេស៊ូដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។
1 John 1:8
ព័ត៌មានទូទៅ:
ត្រង់នេះពាក្យ «ព្រះអង្គ» «របស់ព្រះអង្គ» និង «របស់ព្រះអង្គ»
សំដៅទៅលើព្រះជាម្ចាស់។ (សូមមើល៖ ជំពូក១ ខ ៥)
គ្មានបាបសោះ
«មិនដែលធ្វើបាប»
កំពុងកុហក
«កំពុងបញ្ឆោត» ឬ «និយាយពាក្យមិនពិតប្រាប់គេ»
គ្មានសេចក្តីពិតនៅក្នុងយើងទេ
សេចក្តីពិតត្រូវបានគេនិយាយដូចជាវត្ថុដែលអាចស្ថិតនៅខាងក្នុងអ្នកជឿ។
ការបកប្រែផ្សេងទៀត៖ «យើងមិនជឿថាអ្វីដែលជាសេចក្តីពិត»
ថែមទាំងអត់ទោសបាបរបស់យើង និងសម្អាតបាបយើងចេញពីអំពើទុច្ចរិតទាំងអស់ផង
ឃ្លាទាំងពីរនេះមានអត្ថន័យដូចគ្នា។
ការប្រើវាដើម្បីបញ្ជាក់ថាព្រះជាម្ចាស់ពិតជានឹងអត់ទោសបាបរបស់យើង។
ការបកប្រែផ្សេងទៀត៖
«ហើយនឹងអត់ទោសឱ្យយើងទាំងស្រុងនូវអ្វីដែលយើងបានធ្វើខុស»
យើងធ្វើឲ្យព្រះអង្គក្លាយជាអ្នកកុហក
យើងអះអាងថាទ្រង់ជាអ្នកកុហក។ ការបកប្រែផ្សេងទៀត៖
«វាដូចគ្នានឹងការហៅទ្រង់ថាជាអ្នកកុហកដែរពីព្រោះទ្រង់បាននិយាយថាយើងបានធ្វើបាបទាំងអស់»
ព្រះបន្ទូលរបស់ព្រះអង្គមិនបាននៅក្នុងយើងទេ
ការគោរពប្រតិបត្តិនិងលើកតម្កើងព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថា
ព្រះបន្ទូលរបស់ព្រះអង្គស្ថិតនៅខាងក្នុងអ្នកជឿ។ ការបកប្រែផ្សេងទៀត៖
«យើងមិនយល់ពីព្រះបន្ទូលរបស់ព្រះ
ហើយក៏មិនធ្វើតាមអ្វីដែលទ្រង់មានបន្ទូលដែរ»

---

2 [1]កូនរាល់គ្នាអើយ ខ្ញុំសរសេរសេចក្តីទាំងនេះផ្ញើដល់អ្នក ដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត។ ប៉ុន្តែ ប្រសិនបើ នរណាម្នាក់បានធ្វើបាប គឺយើងមានមេធាវី
ដែលនៅជាមួយព្រះវរបិតា គឺព្រះយេស៊ូគ្រិស្ត ព្រះអង្គជាព្រះដ៏សុចរិត។[2]ទ្រង់គឺជាតង្វាយធួននឹងបាបរបស់យើង
ហើយមិនគ្រាន់តែសម្រាប់បាបរបស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងសម្រាប់ពិភពលោកទាំងមូលផងដែរ។[3]តាមរយៈការនេះយើងប្រាកដថា យើងស្គាល់ព្រះអង្គ
ប្រសិនបើយើង កាន់តាមបបញ្ញារបស់ព្រះអង្គ។
[4]អ្នកណាដែលនិយាយថា «ខ្ញុំស្គាល់ព្រះជាម្ចាស់» ប៉ុន្តែ មិនកាន់តាមបញ្ញារបស់ព្រះអង្គទេ គឺជាមនុស្សកុហក ហើយសេចក្តីពិតមិននៅក្នុងគាត់។[5]ប៉ុន្តែ
អស់អ្នកណាដែលកាន់តាមព្រះបន្ទូល ពិតជាស្គាល់ព្រះជាម្ចាស់ ហើយសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍របស់ព្រះជាម្ចាស់នៅក្នុងអ្នកនោះ។[6]ហេតុដូច្នេះ
អ្នកណាដែលនិយាយថា គាត់នៅជាប់ក្នុងព្រះជាម្ចាស់ អ្នកនោះត្រូវដើរដូចជាព្រះយេស៊ូបានដើរដែរ។
[7]បងប្អូនស្ងួនភ្ងាអើយ ខ្ញុំមិនបានសរសេរបញ្ញាតិថ្មីមកកាន់អ្នករាល់គ្នាទេ ប៉ុន្តែ ជាបញ្ញាចាស់ ដែលអ្នកធ្លាប់មានតាំងពីដំបូងមក។
បញ្ញាចាស់គឺជាព្រះបន្ទូលដែលអ្នកបានឮ។[8]លើសពីនេះ ខ្ញុំសរសេរបញ្ញាថ្មីមកកាន់អ្នក ជាសេចក្តីពិតនៅក្នុងព្រះគ្រិស្ត និងក្នុងអ្នក
ដោយសារសេចក្តីងងឹតកំពុងតែកន្លងផុតទៅ ហើយពន្លឺនៃសេចក្តីពិតក៏កំពុងតែជះពន្លឺដែរ។
[9]អ្នកណាដែលនិយាយថា គាត់នៅក្នុងពន្លឺ ហើយស្អប់បងប្អូនរបស់គាត់ នោះកំពុងស្ថិតក្នុងភាពងងឹតហើយ។[10]អ្នកណាដែលស្រឡាញ់បងប្អូនខ្លួន គឺស្ថិតនៅក្នុងពន្លឺ
ហើយគ្មានឱកាសធ្វើឲ្យរវាតចិត្តនៅក្នុងគាត់បានឡើយ។[11]ប៉ុន្តែ អ្នកណាដែលស្អប់បងប្អូនរបស់ខ្លួនវិញ គឺកំពុងស្ថិតក្នុងភាពងងឹត ក៏ដើរក្នុងភាពងងឹតដែរ
គាត់មិនដឹងថាគាត់កំពុងទៅណានោះទេ ព្រោះភាពងងឹតបានធ្វើឲ្យភ្នែករបស់គាត់មើលមិនឃើញ។
[12]ខ្ញុំសរសេរមកអ្នក ជូនកូនជាទីស្រឡាញ់រាល់គ្នាអើយ ពីព្រោះបាបរបស់អ្នកបានអត់ទោស គឺដោយសារព្រះនាមរបស់ព្រះអង្គ។[13]ខ្ញុំសរសេរមកអ្នក ជូនឪពុករាល់គ្នាអើយ
ដោយអ្នកស្គាល់ព្រះអង្គតាំងពីដំបូង។ ខ្ញុំសរសេរមកអ្នក ជូនកំឡោះៗរាល់គ្នាអើយ ដោយសារអ្នកបានឈ្នះអារក្ស។ ខ្ញុំសរសេរមកអ្នករាល់គ្នា កូនតូចៗរាល់គ្នាអើយ
ដោយសារអ្នកស្គាល់ព្រះបិតា។[14]ខ្ញុំសរសេរមកអ្នករាល់គ្នា ឪពុករាល់គ្នាអើយ ដោយសារអ្នកបានស្គាល់ព្រះតាំងពីដំបូងមក។ ខ្ញុំសរសេរមកអ្នករាល់គ្នា កម្លោះរាល់គ្នាអើយ
ដោយសារអ្នកមានកម្លាំង ហើយព្រះបន្ទូលរបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងអ្នក ហើយអ្នកបានយកឈ្នះអារក្សហើយ។

generated on Wed Sep 10 16:16:32 2025

[15]កុំស្រឡាញ់លោកីយ៍ ឬអ្វីៗដែលនៅក្នុងលោកីយ៍ឡើយ។ ប្រសិនបើ នរណាម្នាក់ស្រឡាញ់លោកីយ៍ សេចក្តីស្រឡាញ់របស់ព្រះបិតាមិននៅក្នុងអ្នកនោះទេ។[16]ដ្បិត
អ្វីៗដែលនៅក្នុងលោកីយ៍ គឺជាសេចក្តីប៉ងប្រាថ្នាខាងឯសាច់ឈាម និងសេចក្តីប៉ងប្រាថ្នានៃភ្នែក ព្រមទាំងអំនួតនៃជីវិត មិនមែនមកពីព្រះបិតាទេ ប៉ុន្តែ មកពីលោកីយ៍វិញ។
[17]លោកីយ៍ និងសេចក្តីប៉ងប្រាថ្នារបស់លោកីយ៍នឹងកន្លងផុតទៅ។ ប៉ុន្តែ អស់អ្នកណាដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច។
[18]កូនតូចៗរាល់គ្នាអើយ នេះគឺជាពេលចុងក្រោយហើយ។ ដូចដែលអ្នករាល់គ្នាបានឮថាពួកប្រឆាំងនឹងព្រះគ្រិស្តកំពុងតែមកដែរ ឥឡូវនេះ
ពួកប្រឆាំងនឹងព្រះគ្រិស្តបានមកហើយ។ ដូច្នេះ យើងដឹងថា នេះគឺជាពេលចុងក្រោយហើយ។[19]ពួកគេបានចេញពីពួកយើង ប៉ុន្តែ ពួកគេមិនមែនជាគ្នាយើងទេ។ ប្រសិនបើ
ពួកគេជាគ្នារបស់យើងមែន ពួកគេនឹងនៅជាមួយយើងហើយ។ ប៉ុន្តែ ពួកគេបានចេញពីយើង នោះបង្ហាញថា ពួកគេមិនមែនជាគ្នាយើងទេ។
[20]ប៉ុន្តែ អ្នករាល់គ្នាមានប្រេងតាំងពីព្រះអង្គដ៏បរិសុទ្ធ ហើយអ្នកស្គាល់សេចក្តីពិតទាំងអស់ហើយ។[21]ខ្ញុំមិនបានសរសេរមកកាន់អ្នករាល់គ្នា
ដោយសារអ្នករាល់គ្នាមិនស្គាល់សេចក្តីពិតនោះទេ ប៉ុន្តែ ដោយសារអ្នកស្គាល់សេចក្តីពិត ក៏ដោយសារនៅក្នុងសេចក្តីពិតគ្មានការកុហកដែរ។
[22]តើអ្នកណាជាមនុស្សកុហក តើអ្នកណាដែលកុហកគឺជាអ្នកដែលបដិសេធព្រះយេស៊ូថាជាព្រះគ្រិស្ត? អ្នកនោះគឺជាអ្នកដែលប្រឆាំងនិងព្រះគ្រិស្ត
ដោយសារគាត់បដិសេធព្រះបិតា និងព្រះរាជបុត្រា។[23]គ្មាននរណាដែលបដិសេធព្រះបុត្រា មានព្រះបិតានោះទេ។ អ្នកណាដែលទទួលស្គាល់ព្រះបុត្រា
ក៏ទទួលស្គាល់ព្រះបិតាដែរ។
[24]អ្នកក៏ដូចគ្នាដែរ ចូរឲ្យអ្វីដែលអ្នកបានឮតាំងពីដំបូងបាននៅជាប់ក្នុងអ្នករាល់គ្នា។ ប្រសិនបើ អ្នកបានឮអ្វីតាំងពីដំបូងស្ថិតនៅជាប់ក្នុងអ្នក នោះអ្នកក៏នៅជាប់ក្នុងព្រះបុត្រា
និងក្នុងព្រះវរបិតាដែរ។[25]នេះគឺជាសេចក្តីសន្យាដែលព្រះអង្គបានប្រទានដល់យើង គឺជាជីវិតអស់កល្ប។[26]ខ្ញុំសរសេរការទាំងនេះមកអ្នករាល់គ្នា
ចំពោះអ្នកដែលនឹងនាំអ្នករាល់គ្នាឲ្យវង្វេង។
[27]អ្នករាល់គ្នាក៏ដូចគ្នាដែរ ប្រេងតាំងដែលអ្នករាល់គ្នាបានទទួលពីព្រះអង្គ ស្ថិតនៅក្នុងអ្នករាល់គ្នាហើយ ដូច្នេះ
អ្នករាល់គ្នាមិនចាំបាច់ត្រូវការនរណាម្នាក់បង្រៀនអ្នករាល់គ្នាទេ។ ប៉ុន្តែ ប្រេងតាំងរបស់ព្រះអង្គនឹងបង្រៀនអ្នកគ្រប់យ៉ាង ព្រមទាំងបង្រៀនសេចក្តីពិត មិនមែនការកុហកទេ
ហើយសេចក្តីពិតនោះបានបង្រៀនអ្នករាល់គ្នាឲ្យនៅជាប់ជាមួយព្រះអង្គ។[28]ឥឡូវនេះ កូនៗជាទីស្រឡាញ់អើយ ចូរនៅជាប់ក្នុងព្រះអង្គ ដើម្បីនៅពេលព្រះអង្គលេចមក
យើងនឹងមានសេចក្តីក្លាហាន ហើយនឹងមិនអាម៉ាស់នៅចំពោះព្រះអង្គនៅពេលដែលព្រះអង្គយាងមកនោះទេ។[29]ប្រសិនបើ អ្នកដឹងថាព្រះអង្គសុចរិត អ្នកក៏ដឹងដែរថា
មនុស្សគ្រប់គ្នាធ្វើអ្វីដែលត្រឹមត្រូវគឺបានកើតពីព្រះអង្គមក។

---

1 John 2:1

ឃ្លាភ្ជាប់៖

លោកយ៉ូហានបន្តសរសេរអំពីការប្រកបហើយបង្ហាញថាវាអាចទៅរួចពីព្រោះព្រះយេស៊ូវ

ព័ត៌មានទូទៅ:

នៅទីនេះពាក្យ «យើង» និង «យើងទាំងអស់»
សំដៅទៅលើលោកយ៉ូហាននិងអ្នកជឿទាំងអស់។ ពាក្យ «ទ្រង់» និង
«របស់ព្រះអង្គ» អាចសំដៅទៅលើព្រះវរបិតាឬព្រះយេស៊ូ។

កូនរាល់គ្នាអើយ

លោកយ៉ូហានជាបុរសវ័យចំណាស់និងជាអ្នកដឹកនាំពួកគេ។
គាត់បានប្រើពាក្យនេះដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះពួកគេ។
ការបកប្រែផ្សេងទៀត៖ «កូនជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះគ្រិស្ត» ឬ
«អ្នកដែលជាទីស្រឡាញ់ដល់ខ្ញុំដូចជាកូនរបស់ខ្ញុំ»

ខ្ញុំសរសេរសេចក្តីទាំងនេះ

«ខ្ញុំសរសេរលិខិតនេះ»

ប៉ុន្តែ ប្រសិនបើ នរណាម្នាក់បានធ្វើបាប

«ប៉ុន្តែនៅពេលនរណាម្នាក់ធ្វើបាប»។ នេះគឺជាអ្វីដែលទំនងជាកើតឡើង។

យើងមានមេធាវី ដែលនៅជាមួយព្រះវរបិតា

ពាក្យថា «មេធាវី» នៅទីនេះសំដៅលើព្រះយេស៊ូ។ ការបកប្រែផ្សេងទៀត៖
«អ្នកដែលនិយាយទៅកាន់ព្រះវរបិតាហើយសុំឱ្យទ្រង់អត់ទោសឱ្យយើង»

ទ្រង់គឺជាតង្វាយធួននឹងបាបរបស់យើង

«ព្រះយេស៊ូបានលះបង់ជីវិតរបស់ទ្រង់សម្រាប់យើង
ហើយដោយសារតែការនេះព្រះជាម្ចាស់អត់ទោសបាបឲ្យយើង»

តាមរយៈការនេះយើងប្រាកដថា យើងស្គាល់ព្រះអង្គ ប្រសិនបើយើង កាន់តាមបញ្ជារបស់ព្រះអង្គ

«ប្រសិនបើយើងធ្វើអ្វីដែលទ្រង់បានប្រាប់ឱ្យយើងធ្វើនោះយើងដឹងប្រាកដថាយើងមានទំនាក់ទំនងជាមួយព្រះអង្គ»

យើងស្គាល់ព្រះអង្គ

«យើងមានទំនាក់ទំនងជាមួយព្រះអង្គ»

1 John 2:4

អ្នកណាដែលនិយាយថា

«អ្នកណានិយាយ» ឬ «អ្នកដែលនិយាយ»

ខ្ញុំស្គាល់ព្រះជាម្ចាស់

«ខ្ញុំមានទំនាក់ទំនងល្អជាមួយព្រះជាម្ចាស់»

មិនកាន់តាម

«មិនធ្វើ» ឬ «មិនគោរពតាម»

បញ្ជារបស់ព្រះអង្គ

«អ្វីដែលព្រះជាម្ចាស់ប្រាប់គេឲ្យធ្វើ»

សេចក្តីពិតមិននៅក្នុងគាត់

សេចក្តីពិតត្រូវបានគេនិយាយដូចជាវត្ថុដែលអាចស្ថិតនៅខាងក្នុងអ្នកជឿ។
ការបកប្រែផ្សេងទៀត៖

«គាត់មិនជឿអ្វីដែលព្រះជាម្ចាស់មានបន្ទូលថាជាសេចក្តីពិតទេ»

កាន់តាម

«ធ្វើតាមនូវអ្វីដែលព្រះជាម្ចាស់បានបង្គាប់ឱ្យធ្វើ»

ព្រះបន្ទូល

«អ្វីដែលព្រះប្រាប់លោកឲ្យធ្វើ»

សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

អត្ថន័យមាន២ គឺ ១) «សេចក្តីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់» ឬ ២)
«សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង» ។

ពិតជាស្គាល់ព្រះជាម្ចាស់ ហើយសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍របស់ព្រះជាម្ចាស់

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖ «
ព្រះជាម្ចាស់បានធ្វើឲ្យសេចក្តីស្រឡាញ់របស់ទ្រង់បានគ្រប់លក្ខណៈនៅក្នុងមនុស្ស»«
ប្រាកដណាស់អ្នកដែលគោរពបទបញ្ជារបស់ព្រះជាម្ចាស់គឺជាមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់គ្រប់បែប
ឬ«
សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សបានសម្រេចគោលដៅនៅពេលពួកគេធ្វើអ្វីដែលទ្រង់
ប្រាប់ពួកគេឱ្យធ្វើ »

ព្រះជាម្ចាស់នៅក្នុងអ្នកនោះ

ឃ្លាដែលថា« យើងស្ថិតនៅក្នុងព្រះអង្គ»
មានន័យថាអ្នកជឿតែងតែរួមជាមួយព្រះជាម្ចាស់
ឬមានទំនាក់ទំនងប្រកបជាមួយព្រះជាម្ចាស់ជានិច្ច។
ជាញឹកញាប់នៅក្នុងយ៉ូហានទី១
ឃ្លាថា«នៅជាប់នឹងព្រះអង្គ»ត្រូវបានប្រើដើម្បីមានន័យដូចគ្នា។

ការបកប្រែផ្សេងទៀត៖

«នៅពេលយើងស្តាប់តាមអ្វីដែលព្រះជាម្ចាស់មានបន្ទូលយើងអាចប្រាកដថាយើងបានប្រកបជាមួយព្រះអ
«មានទំនាក់ទំនងជាមួយព្រះអង្គ»

«មានទំនាក់ទំនងជាមួយព្រះជាម្ចាស់»

អ្នកនោះត្រូវដើរដូចជាព្រះយេស៊ូបានដើរដែរ

ការប្រតិបត្តិជីវិតរបស់មនុស្សម្នាក់ត្រូវបានគេនិយាយដូចជាកំពុងធ្វើដំណើរ។
ការបកប្រែផ្សេងទៀត៖ «ត្រូវតែរស់នៅដូចព្រះយេស៊ូគ្រិស្តបានរស់នៅ» ឬ
«ក៏គួរតែគោរពតាមព្រះជាម្ចាស់ដូចព្រះយេស៊ូគ្រិស្តបានធ្វើដែរ»

1 John 2:7

ឃ្លាភ្ជាប់៖

លោកយ៉ូហានផ្តល់ឱ្យអ្នកជឿនូវគោលការណ៍គ្រឹះនៃការប្រកបគ្នា -
ការគោរពប្រតិបត្តិនិងសេចក្តីស្រឡាញ់។

បងប្អូនស្ងួនភ្ងាអើយ

«អ្នកជាមនុស្សដែលខ្ញុំស្រឡាញ់» ឬ «មិត្តជាទីស្រឡាញ់»

ខ្ញុំមិនបានសរសេរបញ្ជាថ្មីមកកាន់អ្នករាល់គ្នាទេ ប៉ុន្តែ ជាបញ្ជាចាស់

«ខ្ញុំសរសេរទៅអ្នកឱ្យស្រឡាញ់គ្នាទៅវិញទៅមកដែលនេះមិនមែនជារឿងថ្មីដែលត្រូវធ្វើទេប៉ុន្តែជាបទបញ្ជា
។

generated on Wed Sep 10 16:16:32 2025

លោកយ៉ូហានសំដៅទៅលើបទបញ្ជារបស់ព្រះយេស៊ូគឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ការបកប្រែផ្សេងទៀត៖ «ដោយសារតែអ្វីដែលព្រះគ្រិស្តបានធ្វើសម្រាប់អ្នក»។
តាំងពីដំបូងមក
នៅទីនេះ« ការចាប់ផ្តើម»
សំដៅទៅលើពេលដែលពួកគេសម្រេចចិត្តដើរតាមព្រះគ្រិស្ត។
ការបកប្រែផ្សេងទៀត៖ «ចាប់តាំងពីពេលដែលអ្នកជឿលើព្រះគ្រិស្ត»
លើសពីនេះ ខ្ញុំសរសេរបញ្ជាថ្មីមកកាន់អ្នក
"ប៉ុន្តែតាមរបៀបមួយពីបទបញ្ជាដែលខ្ញុំសរសេរទៅអ្នកគឺថ្មី"
ជាសេចក្តីពិតនៅក្នុងព្រះគ្រិស្ត និងក្នុងអ្នក
នៅទីនេះពាក្យ "នៅក្នុង" មានន័យថា "ដោយសារតែ" ។ ការបកប្រែផ្សេងទៀត៖
"ដែលជាសេចក្តីពិតពីព្រោះអ្វីដែលព្រះគ្រិស្តបានធ្វើនិងអ្វីដែលអ្នកកំពុងធ្វើ"
សេចក្តីងងឹតកំពុងតែកន្លងផុតទៅ ហើយពន្លឺនៃសេចក្តីពិតក៏កំពុងតែជះពន្លឺដែរ
ត្រង់នេះ « ភាពងងឹត» សំដៅទៅលើអំពើអាក្រក់ហើយ« ពន្លឺ»
សំដៅទៅលើអំពើល្អ។ ការបកប្រែផ្សេងទៀត៖
«ពីព្រោះអ្នកឈប់ធ្វើអំពើអាក្រក់ហើយអ្នករាល់គ្នាកំពុងធ្វើការល្អកាន់តែច្រើន»
1 John 2:9
ព័ត៌មានទូទៅ:
នៅទីនេះពាក្យថា« បងប្អូន» សំដៅទៅលើគ្រិស្តបរិស័ទដូចគ្នា។
អ្នកណាដែលនិយាយថា
«អ្នកណានិយាយ» ឬ «អ្នកដែលទាមទារ» ។
នេះមិនសំដៅទៅលើមនុស្សណាម្នាក់ទេ។
គាត់នៅក្នុងពន្លឺ
នេះគឺជារូបភាពនៃការរស់នៅត្រឹមត្រូវ។
នៅពេលមនុស្សធ្វើអ្វីដែលត្រឹមត្រូវពួកគេអាចធ្វើវានៅក្នុងពន្លឺ
មិនលាក់ខ្លួននៅក្នុងទីងងឹតទេ។ ការបកប្រែផ្សេងទៀត៖ «គាត់ធ្វើអ្វីដែលត្រឹមត្រូវ»
ស្ថិតក្នុងភាពងងឹត
នេះគឺជារូបភាពនៃការរស់នៅដោយប្រព្រឹត្តអំពើបាប។
នៅពេលមនុស្សធ្វើអ្វីខុសពួកគេចូលចិត្តលាក់ខ្លួននៅក្នុងទីងងឹត។
ការបកប្រែផ្សេងទៀត៖ «ស្ថិតនៅក្នុងភាពងងឹតគឺធ្វើអ្វីដែលអាក្រក់»
គ្មានឱកាសធ្វើឲ្យរវាតចិត្តនៅក្នុងគាត់បានឡើយ
«គ្មានអ្វីនឹងធ្វើឱ្យរវាតចិត្តឡើយ»។
«ពាក្យថារវាតចិត្តគឺជាពាក្យប្រៀបធៀបដែលមានន័យថាបរាជ័យខាងឯវិញ្ញាណ
ឬខាងសីលធម៌»។ ការបកប្រែផ្សេងទៀត៖ «គ្មានអ្វីនឹងនាំឱ្យគាត់ធ្វើបាបទេ» ឬ
«គាត់នឹងមិនបរាជ័យក្នុងការធ្វើអ្វីដែលព្រះសព្វព្រះហឫទ័យ»
ស្ថិតក្នុងភាពងងឹត ក៏ដើរក្នុងភាពងងឹត
គំនិតដូចគ្នានេះត្រូវបានគេនិយាយពីរដងដើម្បីយកចិត្តទុកដាក់
ថាតើវាអាក្រក់យ៉ាងណាការដែលស្អប់អ្នកជឿដូចគ្នា។ ការបកប្រែផ្សេងទៀត៖
«កំពុងរស់នៅក្នុងភាពងងឹត» ឬ «កំពុងរស់នៅក្នុងភាពងងឹតនៃអំពើបាប»
គាត់មិនដឹងថាគាត់កំពុងទៅណានោះទេ
នេះគឺជារូបភាពរបស់អ្នកជឿដែលមិនរស់នៅក្នុងភាពជាគ្រិស្តបរិស័ទដែលគួរតែរស់នៅ។
ការបកប្រែផ្សេងទៀត៖«គាត់មិនដឹងថាគាត់កំពុងធ្វើអ្វីដែលអាក្រក់»
ភាពងងឹងបានធ្វើឲ្យភ្នែករបស់គាត់មើលមិនឃើញ
«ភាពងងឹតបានធ្វើឱ្យគាត់មិនអាចមើលឃើញ» ។
ភាពងងឹតគឺជាឧទាហរណ៍មួយនៃអំពៅបាបឬអំពើអាក្រក់។
ការបកប្រែផ្សេងទៀត៖ «បាបបានធ្វើឱ្យគាត់មិនអាចយល់សេចក្តីពិត»
1 John 2:12
ព័ត៌មានទូទៅ:
លោកយ៉ូហានពន្យល់ពីមូលហេតុដែលគាត់សរសេរសំបុត្ររបស់គាត់ទៅក្រុមអាយុខុសគ្នា
ព្យាយាមប្រើពាក្យស្រដៀងគ្នាសម្រាប់ប្រយោគទាំងនេះដូចដែលពួកគេត្រូវបានសរសេរ
កូនជាទីស្រឡាញ់រាល់គ្នាអើយ
លោកយ៉ូហានជាបុរសវ័យចំណាស់និងជាអ្នកដឹកនាំពួកគេ។
គាត់បានប្រើពាក្យនេះដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះពួកគេ។
ការបកប្រែផ្សេងទៀត៖«កូនជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះគ្រិស្ត» ឬ
«អ្នកដែលជាទីស្រឡាញ់ដល់ខ្ញុំដូចជាកូន ៗ របស់ខ្ញុំ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ១ ។
បាបរបស់អ្នកបានអត់ទោស
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់អត់ទោសបាបឲ្យអ្នក»
ដោយសារព្រះនាមរបស់ព្រះអង្គ
«ឈ្មោះរបស់ព្រះអង្គ» សំដៅទៅលើព្រះគ្រិស្តហើយទ្រង់ជាអ្នកណា។
ខ្ញុំសរសេរមកអ្នក ជូនឪពុករាល់គ្នាអើយ
ពាក្យថា «ឪពុក»
នៅទីនេះអាចជាពាក្យប្រៀបធៀបសំដៅទៅលើអ្នកជឿដែលមានភាពចាស់ទុំ។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំកំពុងសរសេរទៅកាន់អ្នកជឿដែលមានភាពចាស់ទុំ»
អ្នកស្គាល់
«អ្នកមានទំនាក់ទំនងជាមួយ»
អ្នកស្គាល់ព្រះអង្គតាំងពីដំបូង
«អ្នកដែលតែងតែរស់នៅ» ឬ «អ្នកដែលមានវត្តមានជាដរាប» ។ គឺសំដៅទៅលើ
«ព្រះយេស៊ូ» ឬ «ព្រះជាម្ចាស់ជាព្រះវរបិតា»។
កំឡោះៗរាល់គ្នាអើយ
នេះសំដៅទៅលើអ្នកដែលមិនមែនជាអ្នកជឿថ្មី
ប៉ុន្តែកំពុងរីកចម្រើនក្នុងភាពចាស់ទុំខាងវិញ្ញាណ។ ការបកប្រែផ្សេងទៀត៖
«អ្នកជឿវ័យក្មេង»
ដោយសារអ្នកមានកម្លាំង
នៅទីនេះ «ខ្លាំង» មិនសំដៅទៅលើកម្លាំងរាងកាយរបស់អ្នកជឿទេ
ប៉ុន្តែសំដៅទៅលើភាពស្មោះត្រង់របស់ពួកគេចំពោះព្រះគ្រិស្ត។
ព្រះបន្ទូលរបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងអ្នក
អ្នកនិពន្ធនិយាយអំពីការរីកចម្រើននូវភាពស្មោះត្រង់របស់អ្នកជឿចំពោះព្រះគ្រិស្តនិងការយល់ដឹងពីព្រះអ
ដូចជាគាត់កំពុងនិយាយពីព្រះបន្ទូលរបស់ព្រះដែលមាននៅក្នុងពួកគេដូច្នោះដែរ ។
ការបកប្រែផ្សេងទៀត៖ «អ្នកស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់»
យកឈ្នះ
អ្នកនិពន្ធកំពុងនិយាយអំពីការបដិសេធរបស់អ្នកជឿដើម្បីធ្វើតាមសាតាំង
និងពីផែនការរបស់គេដែលធ្វើឲ្យពួកគេខកចិត្ត ដូចជាបញ្ហានៃការយកឈ្នះមេដែរ។
1 John 2:15
កុំស្រឡាញ់លោកីយ៍
ក្នុងជំពូក ២ ខ១៥-១៧
ពាក្យ«លោកីយ៍»សំដៅទៅលើអ្វីៗទាំងអស់ដែលមនុស្សចង់ធ្វើដែលមិនគោរពដល់ព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត៖
«កុំធ្វើដូចមនុស្សក្នុងលោកីយ៍នេះដែលមិនគោរពព្រះជាម្ចាស់»
ឬអ្វីៗដែលនៅក្នុងលោកីយ៍ឡើយ
«ហើយមិនចង់បានរបស់ដដែលទេអ្នកដែលប្រមាថព្រះជាម្ចាស់ចង់បាន»
ប្រសិនបើ នរណាម្នាក់ស្រឡាញ់លោកីយ៍ សេចក្តីស្រឡាញ់របស់ព្រះបិតាមិននៅក្នុងអ្នកនោះទេ
មនុស្សម្នាក់មិនអាចស្រឡាញ់លោកីយ៍នេះបានទេហើយអ្នកដែលប្រមាថព្រះជាម្ចាស់និងស្រឡាញ់ព្រះបិត
សេចក្តីស្រឡាញ់របស់ព្រះបិតាមិននៅក្នុងអ្នកនោះទេ
«គេមិនស្រឡាញ់ព្រះវរបិតា»
សេចក្តីប៉ងប្រាថ្នាខាងឯសាច់ឈាម និងសេចក្តីប៉ងប្រាថ្នានៃភ្នែក ព្រមទាំងអំនួតនៃជីវិត
នេះគឺជាបញ្ជីមួយចំនួននៅក្នុងលោកីយ៍នេះ។
ពន្យល់ពីអត្ថន័យអ្វីៗគ្រប់យ៉ាងនៅក្នុងពិភពលោក។
សេចក្តីប៉ងប្រាថ្នាខាងឯសាច់ឈាម
«បំណងប្រាថ្នាយ៉ាងខ្លាំងដើម្បីមានភាពរីករាយខាងរាងកាយដែលមានបាប»
សេចក្តីប៉ងប្រាថ្នានៃភ្នែក
«ជាបំណងប្រាថ្នាយ៉ាងខ្លាំងដើម្បីឲ្យមានអ្វីៗដែលយើងបានឃើញ»
អំនួតនៃជីវិត
«មោទនភាពនៃជីវិត» ។ នេះអាចបញ្ជាក់ទាំងទ្រព្យសម្បត្តិនិងឥរិយាបថ។
«អ្នកអំពីអ្វីដែលមនុស្សម្នាក់មានឬធ្វើ» ឬ
«ឬនៅអ្នកជឿដែលមានភាពរីករាយនឹងអ្វីដែលគាត់មាន» ឬ «ការបង្ហាញរបស់ពួកគេនិងអ្វីដែលគាត់ធ្វើ»
ជីវិតកំណាព្យ។
នេះអាចយោងទៅលើអ្វីដែលមនុស្សមានដើម្បីរស់នៅដូចជាការកាន់កាប់ទ្រព្យសម្បត្តិនិងទ្រព្យសម្បត្តិដែ
ក៏ដូចជាឥរិយាបថ។
មិនមែនមកពីព្រះបិតាទេ
«មិនមកពីព្រះវរបិតា» ឬ
«មិនមែនជារបៀបដែលព្រះវរបិតាបង្រៀនយើងឲ្យរស់នៅ»
កន្លងផុតទៅ
«ស្លាប់» ឬ «ថ្ងៃណាមួយនឹងមិននៅទីនេះទេ»
1 John 2:18
ឃ្លាភ្ជាប់៖
លោកយ៉ូហានព្រមានអំពីអ្នកដែលប្រឆាំងនឹងព្រះគ្រិស្ត។
កូនតូចៗរាល់គ្នាអើយ

generated on Wed Sep 10 16:16:32 2025

«ពួកគ្រិស្តបរិស័ទដែលមិនទាន់មានភាពចាស់ទុំ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ ១ ។
នេះគឺជាពេលចុងក្រោយហើយ
ឃ្លា«ម៉ោងចុងក្រោយ»នេះសំដៅទៅលើពេលវេលាមុនពេលព្រះយេស៊ូយាងត្រឡប់មកវិញ
ការបកប្រែផ្សេងទៀត៖ «ព្រះយេស៊ូនឹងយាងត្រឡប់មកវិញឆាប់ៗ»
ពួកប្រឆាំងនឹងព្រះគ្រិស្តកំពុងតែមក
«មានមនុស្សជាច្រើនដែលប្រឆាំងនឹងព្រះគ្រិស្ត»
ដូច្នេះ យើងដឹងថា
«ហើយដោយសារតែរឿងនេះយើងដឹង» ឬ
«ក៏ដោយសារតែអ្នកប្រឆាំងព្រះគ្រិស្តជាច្រើនបានមក ហើយយើងដឹង»
ពួកគេបានចេញពីពួកយើង
«ពួកគេបានចាកចេញពីយើង»
ប៉ុន្តែ ពួកគេមិនមែនជាគ្នាយើងទេ
«ប៉ុន្តែពួកគេពិតជាមិនមែនជាកម្មសិទ្ធិរបស់យើង» ឬ
«ពួកគេមិនមែនជាសមាជិកក្រុមរបស់យើងតាំងពីដំបូងមកម្ល៉េះ»។
មូលហេតុដែលពួកគេមិនមែនជាសមាជិកនៃក្រុមនេះគឺថាពួកគេមិនមែនជាអ្នកជឿលើព្រះយេស៊ូ
ប្រសិនបើ ពួកគេជាគ្នារបស់យើងមែន ពួកគេនឹងនៅជាមួយយើងហើយ
«យើងដឹងរឿងនេះពីព្រោះពួកគេនឹងមិនចាកចេញពីយើងទេប្រសិនបើពួកគេពិតជាអ្នកជឿមែន»
1 John 2:20
ព័ត៌មានទូទៅ:
នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ពាក្យថា«ចាក់ប្រេងតាំង»សំដៅទៅលើការចាក់ប្រេងលើ
ប៉ុន្តែ អ្នករាល់គ្នាមានប្រេងតាំងពីព្រះអង្គដ៏បរិសុទ្ធ
« ប៉ុន្តែព្រះដ៏បរិសុទ្ធបានចាក់ប្រេងតាំងអ្នក» ត្រង់នេះ« ការចាក់ប្រេងតាំង»
គឺសំដៅទៅលើការដែលព្រះយេស៊ូបានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់អ្នកជឿដើម្បីញែក
ការបកប្រែផ្សេងទៀត៖
"ប៉ុន្តែព្រះយេស៊ូគ្រិស្តជាព្រះដ៏វិសុទ្ធបានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកអ្នក"
សេចក្តីពិតគ្មានការកុហក
នៅទីនេះសកម្មភាពនៃការនិយាយកុហកត្រូវបានគេនិយាយដូចជាវត្ថុមួយ។
ការបកប្រែផ្សេងទៀត៖
«គ្មានការកុហកណាមួយមកពីព្រះដែលជាសេចក្តីពិតនោះឡើយ»
1 John 2:22
តើអ្នកណាជាមនុស្សកុហក តើអ្នកណាដែលកុហកគឺជាអ្នកដែលបដិសេធព្រះយេស៊ូថាជាព្រះគ្រិស្ត?
«តើអ្នកណាជាអ្នកកុហក?» គឺអ្នកណាបដិសេធថាព្រះយេស៊ូជាព្រះគ្រិស្ត។
»លោកយ៉ូហានបានប្រើមួយសំណួរដើម្បីបញ្ជាក់ថានរណាជាអ្នកកុហក។
បដិសេធព្រះយេស៊ូថាជាព្រះគ្រិស្ត
«បដិសេធថាព្រះយេស៊ូជាព្រះគ្រិស្ត» ឬ
«និយាយថាព្រះយេស៊ូមិនមែនជាព្រះសង្គ្រោះទេ»
បដិសេធព្រះបិតា និងព្រះរាជបុត្រា
«បដិសេធមិននិយាយការពិតអំពីព្រះវរបិតានិងព្រះរាជបុត្រា» ឬ
«បដិសេធព្រះវរបិតានិងព្រះរាជបុត្រា» ។
ព្រះបិតា និងព្រះរាជបុត្រា
ទាំងនេះគឺជាការសំខាន់ៗដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់និងព្រះយេស៊ូ
មានព្រះបិតា
«ជាកម្មសិទ្ធិរបស់ព្រះវរបិតា»
ទទួលស្គាល់ព្រះបុត្រា
«និយាយការពិតអំពីព្រះរាជបុត្រា»
ទទួលស្គាល់ព្រះបិតា
«ជាកម្មសិទ្ធិរបស់ព្រះវរបិតា»
1 John 2:24
ឃ្លាភ្ជាប់៖
លោកយ៉ូហានរំលឹកអ្នកជឿឲ្យបន្តនៅជាប់នឹងអ្វីដែលពួកគេបានស្តាប់ឮដំបូង។
ព័ត៌មានទូទៅ:
នៅទីនេះពាក្យថា «អ្នក»
គឺពហុវចន:ហើយសំដៅទៅលើមនុស្សដែលលោកយ៉ូហានបានសរសេរក៏ដូចជាអ្នកជឿទាំងអស់
ពាក្យថា« ទ្រង់» គឺជាការយល់ចិត្តនិងសំដៅទៅលើព្រះគ្រិស្ត។
អ្នកក៏ដូចគ្នាដែរ
នេះបង្ហាញថាលោកយ៉ូហានប្រាប់ពួកគេពីរបៀបដែលពួកគេគួរតែរស់នៅជាអ្នកដើរតាម
ជំនួសឱ្យរបៀបដែលអ្នកប្រឆាំងនឹងព្រះគ្រិស្តទរស់នៅ។
ចូរឲ្យអ្វីដែលអ្នកបានឮតាំងពីដំបូងបាននៅជាប់ក្នុងអ្នករាល់គ្នា
«ចងចាំនិងជឿនូវអ្វីដែលអ្នកបានឮ ពីដំបូងមក» ។ របៀបដែលពួកគេបានឮ
អ្វីដែលពួកគេបានឮ និងអ្វីដែល «ចាប់ផ្តើម»
មានន័យថាអាចត្រូវបានបង្ហាញឲ្យឃើញច្បាស់: ការបកប្រែផ្សេងទៀត៖
«ប្រសិនបើអ្នកបន្តទុកចិត្តលើអ្វីដែលយើងបានបង្រៀនអ្នកអំពីព្រះយេស៊ូដូចអ្នកបានជឿទុកចិត្តតាំងពីអ្នកបានក្លាយជា
អ្នកបានឮអ្វីតាំងពីដំបូងស្ថិតនៅជាប់ក្នុងអ្នក
«អ្វីដែលយើងបានបង្រៀនអ្នកអំពីព្រះយេស៊ូនៅពេលដែលអ្នកក្លាយជាអ្នកជឿដំបូង»
ប្រសិនបើ អ្នកបានឮអ្វីតាំងពីដំបូងស្ថិតនៅជាប់ក្នុងអ្នក
ពាក្យថា «នៅជាប់គឺនិយាយអំពីទំនាក់ទំនងមិនមែនការសង្គ្រោះទេ។
ប្រសិនបើអ្នកបន្តទុកចិត្តលើអ្វីដែលយើងបានបង្រៀនអ្នកដំបូង»
នោះអ្នកក៏នៅជាប់ក្នុងព្រះបុត្រា និងក្នុងព្រះវរបិតាដែរ
«ក៏មានទំនាក់ទំនងជាមួយព្រះរាជបុត្រានិងព្រះវរបិតាដែរ» ។
សូមមើលពីរបៀបដែលការបកប្រែនេះត្រូវបានបកប្រែនៅជំពូក ២ ខ ៤ ។
នេះគឺជាសេចក្តីសន្យាដែលព្រះអង្គបានប្រទានដល់យើង គឺជាជីវិតអស់កល្ប
«ហើយនេះគឺជាអ្វីដែលព្រះអង្គបានសន្យាថានឹងផ្តល់ឲ្យយើងនូវជីវិតអស់កល្បជានិច្ច»
ឬ «ហើយទ្រង់បានសន្យាថានឹងធ្វើឲ្យយើងមានជីវិតអស់កល្បជានិច្ច»
ពាក្យថា «ជីវិត» នៅក្នុងសំបុត្រនេះសំដៅទៅលើអ្វីច្រើនជាងជីវិតខាងរាងកាយ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១ ខ ១ ។
នឹងនាំអ្នករាល់គ្នាឲ្យរង្វេង
មានអ្នកដែលព្យាយាមទាញអ្នកជឿចេញពីព្រះជាម្ចាស់។ ការបកប្រែផ្សេងទៀត៖
«ចង់ទាញអ្នកចេញពីព្រះជាម្ចាស់ និងសេចក្តីពិតរបស់ព្រះអង្គ»
1 John 2:27
ឃ្លាភ្ជាប់៖
ចាប់ផ្តើមនៅក្នុងខ ២៩
លោកយ៉ូហានណែនាំគំនិតនៃការកើតនៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់។ ខមុនៗ
បង្ហាញថាអ្នកជឿនៅតែបន្តធ្វើបាប។ ផ្នែកនេះបង្ហាញអ្នកជឿក៏មានលក្ខណៈថ្មី
ដែលមិនអាចធ្វើបាបបាន។ វាបន្តបង្ហាញពីរបៀបដែលអ្នកជឿអាចស្គាល់គ្នា។
អ្នករាល់គ្នាក៏ដូចគ្នាដែរ
នេះបង្ហាញថាលោកយ៉ូហានប្រាប់ពួកគេនូវអ្វីផ្សេងទៀតអំពីរបៀបដែលពួកគេគួរតែរស់នៅជាអ្នកដើរតាម
ប្រេងតាំង
នេះសំដៅទៅលើ«ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់»។
សូមមើលកំណត់ចំណាំអំពីការចាក់ប្រេងតាំងនៅជំពូក ២ ខ២០ ។
ប្រេងតាំងរបស់ព្រះអង្គនឹងបង្រៀនអ្នក
«ពីព្រោះការចាក់ប្រេងតាំងរបស់ព្រះអង្គបង្រៀនអ្នក»
គ្រប់យ៉ាង
នៅទីនេះឃ្លានេះគឺជាចំណុចខ្ពស់។ ការបកប្រែផ្សេងទៀត៖
«អ្វីគ្រប់យ៉ាងដែលអ្នកត្រូវដឹង»
ជាប់ក្នុងព្រះអង្គ
«រស់នៅសម្រាប់ព្រះអង្គ» ។
សូមមើលពីរបៀបដែលឃ្លានេះត្រូវបានបកប្រែនៅជំពូក ២ ខ៤ ។
របៀបដែលមនុស្សម្នាក់នៅជាប់គឺ
សំដៅទៅលើការប្រកបឬទំនាក់ទំនងរបស់ព្រះអង្គ។
ឥឡូវនេះ
ឃ្លានេះត្រូវបានប្រើនៅទីនេះដើម្បីសម្គាល់ផ្នែកថ្មីនៃសំបុត្រ។
កូនៗជាទីស្រឡាញ់អើយ
លោកយ៉ូហានជាបុរសវ័យចំណាស់និងជាអ្នកដឹកនាំពួកគេ។
គាត់បានប្រើពាក្យនេះដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះពួកគេ។
ការបកប្រែផ្សេងទៀត៖ «កូនជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះគ្រិស្ត» ឬ
«អ្នកដែលជាទីស្រឡាញ់ដល់ខ្ញុំដូចជាកូនៗ របស់ខ្ញុំ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ១ ។
យើងឃើញព្រះអង្គ
សេចក្តីក្លាហាន
ព្រះអង្គយាងមក
ពេលព្រះអង្គយាងមកម្តងទៀត

generated on Wed Sep 10 16:16:32 2025

បានកើតពីព្រះអង្គមក
«បានកើតពីព្រះជាម្ចាស់» ឬ «ជាកូនរបស់ព្រះជាម្ចាស់»

---

3 [1]សូមមើល ថាតើសេចក្ដីស្រឡាញ់ដែលព្រះបិតាមានសម្រាប់យើងយ៉ាងណា នោះព្រះអង្គក៏ហៅយើងថាជាបុត្រធីតារបស់ព្រះអង្គដែរ នេះឯងជាអ្វីដែលយើងមាន។
ដោយហេតុនេះហើយ បានជាលោកីយ៍មិនស្គាល់យើងទេ ដោយសារលោកីយ៍មិនស្គាល់ព្រះអង្គ។[2]បងប្អូនជាទីស្រឡាញ់ ឥឡូវនេះ យើងគឺជាបុត្រធីតារបស់ព្រះអង្គ
ហើយមិនទាន់បានបើកសម្ដែងឲ្យយើងឃើញថានឹងទៅជាយ៉ាងណាទេ។ យើងដឹងថា នៅពេលដែលព្រះគ្រីស្ទលេចមក យើងនឹងបានដូចព្រះអង្គ
យើងនឹងបានឃើញព្រះអង្គ ថាព្រះអង្គជានរណា។[3]អ្នកណាដែលមានជំនឿអំពីអនាគត នឹងផ្តោតទៅលើព្រះអង្គ ហើយនឹងធ្វើឲ្យខ្លួនឯងបានបរិសុទ្ធ
ដូចជាព្រះអង្គបរិសុទ្ធដែរ។
[4]អ្នកណាដែលប្រព្រឹត្តបាបគឺកំពុងតែធ្វើអ្វីដែលខុសច្បាប់ ព្រោះបាបគឺជាភាពខុសច្បាប់។[5]អ្នកដឹងហើយថា ព្រះគ្រិស្តបានលេចមកដើម្បីដកយកអំពើបាបចេញ
ហើយក្នុងព្រះអង្គគ្មានបាបសោះឡើយ។ គ្មាននរណាម្នាក់ដែលនៅជាប់នឹងព្រះអង្គ ហើយបន្តធ្វើបាបទៀតនោះទេ។[6]ក៏គ្មាននរណាដែលបន្តធ្វើបាប បានឃើញព្រះអង្គ
ឬបានស្គាល់ព្រះអង្គនោះដែរ។
[7]កូនៗជាទីស្រឡាញ់ កុំអនុញ្ញាតឲ្យនរណាម្នាក់នាំអ្នកឲ្យវង្វេងឡើយ អ្នកណាដែលប្រព្រឹត្តអំពើសុចរិតនឹងបានសុចរិត ដូចជាព្រះគ្រិស្តសុចរិតដែរ។
[8]អ្នកណាដែលប្រព្រឹត្តអំពើបាបគឺមកពីសាតាំង ព្រោះសាតាំងបានធ្វើបាបតាំងពីដំបូង។ ដោយហេតុនេះហើយ បានជាព្រះបុត្រានៃព្រះបានលេចមក
ដើម្បីព្រះអង្គអាចបំផ្លាញកិច្ចការរបស់សាតាំងចោល។
[9]អស់អ្នកណាដែលបានកើតមកពីព្រះជាម្ចាស់មិនបន្តធ្វើបាបទៀតទេ ពីព្រោះគ្រាប់ពូជរបស់ព្រះជាម្ចាស់បានស្ថិតក្នុងអ្នកនោះ។ គាត់មិនអាចបន្តធ្វើបាបទៀតបានទេ
ដោយសារគាត់បានកើតចេញពីព្រះជាម្ចាស់មក។[10]ការនេះហើយ បានបើកសម្ដែងឲ្យឃើញពីកូនរបស់ព្រះជាម្ចាស់ និងកូនរបស់សាតាំង។
អស់អ្នកណាដែលមិនបានធ្វើអ្វីដែលសុចរិត មិនមែនមកពីព្រះជាម្ចាស់ទេ ហើយអ្នកដែលស្អប់បងប្អូនរបស់ខ្លួនក៏ដូច្នោះដែរ។
[11]នេះហើយគឺជាសារដែលអ្នកបានឮតាំងពីដំបូងថា៖ យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក[12]មិនដូចជាលោកកាអ៊ិនទេ គាត់កើតចេញពីសាតាំង
ហើយបានសម្លាប់ប្អូនប្រុសរបស់គាត់។ ហេតុអ្វីបានជាគាត់សម្លាប់លោកអេបិល? ដោយសារកិច្ចការរបស់គាត់មកពីសាតាំង ហើយប្អូនប្រុសរបស់គាត់សុចរិត។
[13]សូមកុំភ្ញាក់ផ្អើលឡើយ បងប្អូនអើយ ប្រសិនបើ លោកីយ៍ស្អប់អ្នករាល់គ្នា។[14]យើងដឹងថា យើងបានឆ្លងផុតពីសេចក្ដីស្លាប់មកកាន់ជីវិតហើយ
ដោយសារយើងស្រឡាញ់បងប្អូន។ អ្នកណាដែលមិនស្រឡាញ់បងប្អូន ស្ថិតក្នុងសេចក្ដីស្លាប់ហើយ។ អ្នកណាដែលស្អប់បងប្អូនរបស់ខ្លួន គឺជាឃាតករ។[15]អ្នកដឹងហើយថា
គ្មានឃាតករណាមានជីវិតអស់កល្បជានិច្ចស្ថិតនៅក្នុងគាត់ទេ។
[16]ដោយសារការនេះ យើងស្គាល់សេចក្ដីស្រឡាញ់ ដោយសារព្រះគ្រិស្តបានលះបង់ជីវិតរបស់ព្រះអង្គសម្រាប់យើង។
យើងក៏គួរតែលះបង់ជីវិតរបស់យើងសម្រាប់បងប្អូនរបស់យើងដែរ។[17]ប៉ុន្តែ អស់អ្នកណាមានរបស់ដែលនៅក្នុងលោកីយ៍នេះ ហើយឃើញបងប្អូនមានការខ្វះខាត
ហើយបិទចិត្តមេត្តាចំពោះអ្នកនោះ តើសេចក្ដីស្រឡាញ់ព្រះជាម្ចាស់ស្ថិតនៅក្នុងគាត់យ៉ាងដូចម្តេចទៅ?[18]កូនៗជាទីស្រឡាញ់អើយ ចូរឲ្យយើងស្រឡាញ់មិនគ្រាន់តែជាពាក្យ
ឬសំដីតែប៉ុណ្ណឹងទេ ប៉ុន្តែ ចូរស្រឡាញ់ដោយការប្រព្រឹត្ត និងសេចក្ដីពិតផង។
[19]ដោយសារការនេះ យើងដឹងថា យើងកើតមកពីសេចក្ដីពិត ហើយយើងក៏មានអំណះអំណាងនៅក្នុងចិត្តរបស់យើងនៅចំពោះព្រះអង្គដែរ។[20]ប្រសិនបើ
ចិត្តរបស់យើងកាត់ទោសយើង ព្រះជាម្ចាស់ធំជាងចិត្តរបស់យើង ហើយព្រះស្គាល់អ្វីៗទាំងអស់។[21]បងប្អូនជាទីស្រឡាញ់ ប្រសិនបើ ចិត្តរបស់យើងមិនកាត់ទោសយើងទេ
យើងមានទំនុកចិត្តនៅចំពោះព្រះជាម្ចាស់។[22]អ្វីក្តីដែលយើងសូម យើងនឹងបានទទួលពីព្រះអង្គ ដោយសារយើងបានកាន់តាមបញ្ជារបស់ព្រះអង្គ
ហើយធ្វើតាមអ្វីៗដែលគាប់ព្រះហឫទ័យនៅចំពោះព្រះអង្គ។
[23]នេះគឺជាបញ្ជារបស់ព្រះអង្គ៖ គឺថា យើងត្រូវជឿលើព្រះនាមព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រិស្ត ហើយត្រូវស្រឡាញ់គ្នាទៅវិញទៅមក
ដូចដែលព្រះអង្គប្រទានបញ្ជានេះមកដល់យើង។[24]អ្នកណាដែលកាន់តាមបញ្ជារបស់ព្រះអង្គ គឺស្ថិតនៅជាប់នឹងព្រះអង្គ ហើយព្រះអង្គក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ។
ដោយសារការនេះ យើងដឹងថា ព្រះអង្គនៅជាប់នឹងយើង ដោយព្រះវិញ្ញាណដែលព្រះអង្គប្រទានដល់យើង។

---

1 John 3:1

ឃ្លាភ្ជាប់៖

នៅក្នុងផ្នែកនេះលោកយ៉ូហានប្រាប់អ្នកជឿអំពីលក្ខណៈថ្មីរបស់ពួកគេដែលមិនអាចធ្វើបាន

សូមមើល ថាតើសេចក្ដីស្រឡាញ់ដែលព្រះបិតាមានសម្រាប់យើងយ៉ាងណា

«គិតអំពីតើព្រះបិតារបស់យើងស្រឡាញ់យើងខ្លាំងប៉ុណ្ណា»

ព្រះអង្គក៏ហៅយើងថាជាបុត្រធីតារបស់ព្រះអង្គ

«ព្រះវរបិតាបានហៅយើងថាបុត្រធីតារបស់ព្រះអង្គ»

បុត្រធីតា

នេះមានន័យថាមនុស្សដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់តាមរយៈជំនឿលើព្រះយេស៊ូ។

ដោយហេតុនេះហើយ បានជាលោកីយ៍មិនស្គាល់យើងទេ ដោយសារលោកីយ៍មិនស្គាល់ព្រះអង្គ

អាចមានន័យថា ១)«

ដោយសារយើងជាបុត្រធីតារបស់ព្រះជាម្ចាស់ហើយដោយសារពិភពលោកមិនបានស្គាល់ព្រះជាម្ចាស់

ឬ ២)«

ដោយសារតែពិភពលោកមិនបានស្គាល់ព្រះជាម្ចាស់ហើយក៏មិនស្គាល់យើងដែរ» ។

លោកីយ៍មិនស្គាល់យើងទេ ដោយសារលោកីយ៍មិនស្គាល់ព្រះអង្គ

នៅទីនេះ« លោកីយ» សំដៅទៅលើមនុស្សដែលមិនគោរពព្រះជាម្ចាស់។

អ្វីដែលពិភពលោកមិនដឹងអាចត្រូវបានបញ្ជាក់ឱ្យច្បាស់៖ ការបកប្រែផ្សេងទៀត៖

អ្នកដែលមិនគោរពព្រះជាម្ចាស់មិនដឹងថាយើងជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ទេពីព្រោះពួកគេមិនស្គាល់ព្រះអង្គ

បងប្អូនជាទីស្រឡាញ់

«អ្នកជាមនុស្សដែលខ្ញុំស្រឡាញ់» ឬ «មិត្តជាទីស្រឡាញ់» ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ជំពូក២ ខ៧ ។

មិនទាន់បានបើកសម្ដែងឲ្យយើងឃើញ

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម ការបកប្រែផ្សេងទៀត៖

«ព្រះជាម្ចាស់មិនទាន់បានបង្ហាញ»

បើកសម្ដែង

នេះមានន័យថា« ប្រាប់» ឬ« សម្ដែងចេញ» « បង្ហាញ» ។

អ្នកណាដែលមានជំនឿអំពីអនាគត នឹងផ្តោតទៅលើព្រះអង្គ ហើយនឹងធ្វើឲ្យខ្លួនឯងបានបរិសុទ្ធ
ដូចជាព្រះអង្គបរិសុទ្ធដែរ។

«មនុស្សគ្រប់គ្នាដែលមានជំនឿចិត្តរំពឹងថានឹងឃើញព្រះគ្រិស្តថាទ្រង់គឺជាព្រះពិត
គេនឹងរក្សាខ្លួនគេឲ្យបរិសុទ្ធព្រោះព្រះគ្រិស្តបរិសុទ្ធ»

1 John 3:4

កំពុងតែធ្វើអ្វីដែលខុសច្បាប់

«កំពុងបដិសេធមិនគោរពច្បាប់របស់ព្រះ»

ព្រះគ្រិស្តបានលេចមក

អាចប្រើជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត៖ «ព្រះគ្រិស្តបានលេចមក»

ជាប់នឹងព្រះអង្គ

«មានទំនាក់ទំនងជាមួយព្រះជាម្ចាស់» ។

សូមមើលពីរបៀបបកប្រែនេះដែលបានបកប្រែនៅជំពូក ២ ខ៤ ។

ក៏គ្មាននរណា បានឃើញព្រះអង្គ ឬបានស្គាល់ព្រះអង្គ

លោកយ៉ូហានប្រើពាក្យ« បានឃើញ» និង« ស្គាល់»

មនុស្សម្នាក់ប្រព្រឹត្តតាមនិស្ស័យអំពើបាបរបស់ខ្លួនមិនអាចស្គាល់ព្រះគ្រិស្តបានទេ។

ការបកប្រែផ្សេងទៀត៖ «គ្មាននរណាម្នាក់ ... មិនដែលជឿជាក់លើព្រះអង្គ»

1 John 3:7

កូនៗជាទីស្រឡាញ់

លោកយ៉ូហានជាបុរសវ័យចំណាស់និងជាអ្នកដឹកនាំពួកគេ។
គាត់បានប្រើពាក្យនេះដើម្បីបង្ហាញសេចក្ដីស្រឡាញ់របស់គាត់ចំពោះពួកគេ។

generated on Wed Sep 10 16:16:32 2025

ការបកប្រែផ្សេងទៀត៖ «កូនជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះគ្រិស្ត» ឬ «អ្នកដែលជាទីស្រឡាញ់ដល់ខ្ញុំដូចជាកូន ៗ របស់ខ្ញុំ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ១ ។
កុំអនុញ្ញាតឲ្យនរណាម្នាក់នាំអ្នកឲ្យវង្វេងឡើយ
ត្រូវបានគេបញ្ចុះបញ្ចូលឲ្យមិនស្តាប់បង្គាប់ព្រះគ្រិស្ត
គេនិយាយដូចជាមនុស្សម្នាក់ត្រូវបានដឹកនាំឲ្យដើរតាមផ្លូវមិនត្រឹមត្រូវ។
ការបកប្រែផ្សេងទៀត៖«កុំអោយនរណាម្នាក់បោកបញ្ឆោតអ្នក» ឬ «កុំអោយនរណាម្នាក់បោកបញ្ឆោតអ្នក»
អ្នកណាដែលប្រព្រឹត្តអំពើសុចរិតនឹងបានសុចរិត ដូចជាព្រះគ្រិស្តសុចរិតដែរ
«អ្នកណាដែលធ្វើអ្វីដែលត្រឹមត្រូវគាប់ព្រះទ័យដល់ព្រះជាម្ចាស់ដូចព្រះគ្រិស្តត្រូវបានព្រះបន្ទូលរបស់ព្រះអង្គ»
គឺមកពីសាតាំង
«ជាកម្មសិទ្ធិរបស់អារក្ស» ឬ «គឺដូចជាអារក្ស»
តាំងពីដំបូង
នេះសំដៅទៅលើពេលវេលាដំបូងបំផុតនៃការបង្កើតពិភពលោក
មុនពេលមនុស្សបានធ្វើបាបដំបូង។ ការបកប្រែផ្សេងទៀត៖
«ចាប់តាំងពីពេលដំបូងនៃការបង្កើតពិភពលោក»
ព្រះបុត្រានៃព្រះបានលេចមក
អាចប្រើ ជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត៖
«ព្រះជាម្ចាស់បានបង្ហាញព្រះបុត្រារបស់ព្រះអង្គ»
ព្រះបុត្រានៃព្រះ
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះបិតា
1 John 3:9
ឃ្លាភ្ជាប់៖
សម្រាប់ពេលនេះលោកយ៉ូហានបញ្ចប់ផ្នែកនេះអំពីការកើតជាថ្មីដែលមិនអាចធ្វើបាបបាន
អស់អ្នកណាដែលបានកើតមកពីព្រះជាម្ចាស់
នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖
«អ្នកណាដែលព្រះបានបង្កើតជាកូនរបស់ព្រះអង្គ»
គ្រាប់ពូជរបស់ព្រះជាម្ចាស់
នេះនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះប្រទានដល់អ្នកជឿហើយដែលធ្វើឱ្យពួកគេ
ពេលខ្លះនេះត្រូវបានគេហៅជាកំណើតថ្មី។ ការបកប្រែផ្សេងទៀត៖
«ព្រះវិញ្ញាណដ៏វិសុទ្ធ»
គាត់បានកើតចេញពីព្រះជាម្ចាស់មក
អាចប្រើជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត៖
«ព្រះបានប្រទានជីវិតខាងវិញ្ញាណថ្មីដល់គាត់» ឬ «គាត់ជាកូនរបស់ព្រះជាម្ចាស់»
ការនេះហើយ បានបើកសម្តែងឲ្យឃើញពីកូនរបស់ព្រះជាម្ចាស់ និងកូនរបស់សាតាំង
អាចប្រើជាទម្រង់កិរិយាសកម្ម។ ការបកប្រែផ្សេងទៀត៖
«នេះគឺជារបៀបដែលយើងស្គាល់កូនចៅរបស់ព្រះជាម្ចាស់និងកូនរបស់អារក្ស»
អស់អ្នកណាដែលមិនបានធ្វើអ្វីដែលសុចរិត មិនមែនមកពីព្រះជាម្ចាស់ទេ
ហើយអ្នកដែលស្អប់បងប្អូនរបស់ខ្លួនក៏ដូច្នោះដែរ
នៅទីនេះ « បងប្អូន» មានន័យថាជាគ្រិស្តបរិស័ទដូចគ្នា។
«មានតែអ្នកដែលប្រព្រឹត្តអំពើសុចរិតប៉ុណ្ណោះដែលមកពីព្រះជាម្ចាស់ហើយមានតែអ្នកដែលស្រឡាញ់បងប្អូនរបស់ខ្លួនប៉ុណ្ណោះ»
1 John 3:11
ឃ្លាភ្ជាប់៖
នៅទីនេះលោកយ៉ូហានបង្រៀនអ្នកជឿពីរបៀបដែលពួកគេអាចស្គាល់គ្នាបានតាមរយៈ
គាត់បង្រៀនមិត្តអ្នកអានអោយចេះស្រឡាញ់គ្នា។
ព័ត៌មានទូទៅ:
លោកកាអិននិងអេបិលជាកូនច្បងរបស់អាដាំនិងអេវ៉ាជាបុរសនិងស្ត្រីដំបូង។
មិនដូចជាលោកកាអិនទេ
យើងមិនគួរប្រព្រឹត្តដូចលោកកាអិនទេ។
ប្អូនប្រុស
ពាក្យនេះសំដៅលើប្អូនប្រុសរបស់លោកកាអិន គឺលោកអេបិល។
ហេតុអ្វីបានជាគាត់សម្លាប់លោកអេបិល?
លោកយ៉ូហានប្រើសំណួរដើម្បីបង្រៀនមនុស្ស។ នេះអាចត្រូវបានបកប្រែជាឃ្លា។
ការបកប្រែផ្សេងទៀត៖ «គាត់បានសម្លាប់ប្អូនព្រោះ»
កិច្ចការរបស់គាត់មកពីសាតាំង ហើយប្អូនប្រុសរបស់គាត់សុចរិត
កិច្ចការរបស់ប្អូនប្រុសគាត់គឺសុចរិត។ ការបកប្រែផ្សេងទៀត៖
«គាត់បានធ្វើអ្វីដែលអាក្រក់ហើយប្អូនប្រុសរបស់គាត់បានធ្វើអ្វីដែលត្រឹមត្រូវ»
1 John 3:13
បងប្អូន
«អ្នកជឿដូចគ្នា»
ប្រសិនបើ លោកីយ៍ស្អប់អ្នករាល់គ្នា
ត្រង់នេះពាក្យ«លោកីយ»សំដៅលើមនុស្សដែលមិនគោរពព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត៖
«ប្រសិនបើអ្នកដែលមិនគោរពព្រះជាម្ចាស់ស្អប់អ្នកដែលគោរពព្រះជាម្ចាស់»
យើងបានឆ្លងផុតពីសេចក្តីស្លាប់មកកាន់ជីវិតហើយ
លក្ខខណ្ឌនៃការរស់នៅ
និងការស្លាប់ត្រូវបានគេនិយាយថាជាទីតាំងដែលមនុស្សអាចចាកចេញនិងទៅកន្លែងណាមួយ។
ការបកប្រែផ្សេងទៀត៖
«យើងដែលស្អប់ខាងវិញ្ញាណ ដែលនៅជាប់ជាមួយនឹងព្រះយេស៊ូវគ្រីស្ទ យើងមានជីវិតខាងវិញ្ញាណវិញ»
ជីវិត
ពាក្យ «ជីវិត»
នៅក្នុងសំបុត្រទាំងអស់នេះសំដៅទៅលើអ្វីច្រើនជាងជីវិតខាងរាងកាយ។
ពាក្យជីវិតនៅទីនេះគឺសំដៅលើព្រះយេស៊ូដែលមានជីវិតអស់កល្បជានិច្ច។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១ ខ ១ ។
ស្ថិតក្នុងសេចក្តីស្លាប់
«គឺសេចក្តីស្លាប់ខាងឯវិញ្ញាណ»
អ្នកណាដែលស្អប់បងប្អូនរបស់ខ្លួន គឺជាឃាតករ
លោកយ៉ូហាននិយាយអំពីមនុស្សម្នាក់ដែលស្អប់អ្នកជឿផ្សេងទៀតគឺដូចជាគាត់ជាឃាតករ។
ចាប់តាំងពីមនុស្សប្រព្រឹត្តអំពើឃោរឃៅដោយសារតែពួកគេស្អប់មនុស្សផ្សេងទៀតព្រះជាម្ចាស់ចាត់ទុកមនុ
ការបកប្រែផ្សេងទៀត៖
«អ្នកណាស្អប់អ្នកជឿផ្សេងទៀតមានទោសដូចអ្នកដែលសម្លាប់មនុស្ស»
គ្មានឃាតករណាមានជីវិតអស់កល្បជានិច្ចស្ថិតនៅក្នុងគាត់ទេ
«ជីវិតអស់កល្បជានិច្ច»
គឺជាអ្វីមួយដែលព្រះជាម្ចាស់ប្រទានដល់អ្នកជឿបន្ទាប់ពីពួកគេបានស្លាប់
ប៉ុន្តែវាក៏ជាអំណាចដែលព្រះប្រទានដល់អ្នកជឿនៅក្នុងជីវិតនេះដែរ។
ដើម្បីជួយពួកគេឲ្យឈប់ធ្វើបាបនិងធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះអង្គវិញ។
នៅទីនេះជីវិតអស់កល្បត្រូវបានគេនិយាយដូចជាវត្ថុដែលអាចមាននៅក្នុងនរណាម្នាក់។
ការបកប្រែផ្សេងទៀត៖ «ប្រព្រឹត្តនិងធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ដូចជាគេជាគ្រាប់ពូជដែលត្រូវបានដ
«ឃាតករមិនមានអំណាចនៃជីវិតខាងវិញ្ញាណដែលធ្វើការនៅខាងក្នុងគេទេ»
1 John 3:16
ព្រះគ្រិស្តបានលះបង់ជីវិតរបស់ព្រះអង្គសម្រាប់យើង
ឃ្លានេះមានន័យថា « ព្រះគ្រិស្តសុខចិត្តលះបង់ព្រះជន្មរបស់ព្រះអង្គជំនួសយើង»
ឬ« ព្រះគ្រិស្តសុខចិត្តសុគតជំនួសយើង»
របស់ដែលនៅក្នុងលោកីយ៍នេះ
ទ្រព្យសម្បត្តិដូចជាលុយ ម្ហូបអាហារ ឬសម្លៀកបំពាក់។
ឃើញបងប្អូនមានការខ្វះខាត
«និងដឹងថាអ្នកជឿដូចគ្នាត្រូវការជំនួយ»
បិទចិត្តមេត្តាចំពោះអ្នកនោះ
«បិទចិត្តនៃការអាណិតអាសូរ» គឺជាពាក្យប្រៀបធៀប។ ការបកប្រែផ្សេងទៀត៖
«ប៉ុន្តែមិនឲ្យបងប្អូនរបស់ខ្លួនអាណិតអ៊ាណោតែមួយមុខ ប៉ុណ្ណឹងមិនសម្តែងចិត្តជួយគេ»
តើសេចក្តីស្រឡាញ់ព្រះជាម្ចាស់ស្ថិតនៅក្នុងគាត់យ៉ាងដូចម្តេចទៅ
លោកយ៉ូហានប្រើសំណួរដើម្បីបង្រៀនមនុស្ស។ ការបកប្រែផ្សេងទៀត៖
«បងប្អូនដឹងថាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មិននៅក្នុងខ្លួនគេទេ»
កូនៗជាទីស្រឡាញ់អើយ
លោកយ៉ូហានជាបុរសវ័យចំណាស់និងជាអ្នកដឹកនាំពួកគេ។
គាត់បានប្រើពាក្យនេះដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះពួកគេ។
ការបកប្រែផ្សេងទៀត៖ «កូនជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះគ្រិស្ត» ឬ «អ្នកដែលជាទីស្រឡាញ់របស់ខ្ញុំដូចជាកូនៗរបស់ខ្ញុំ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ១។
ចូរឲ្យយើងស្រឡាញ់មិនគ្រាន់តែជាពាក្យ ឬសំដីតែប៉ុណ្ណឹងទេ
ឃ្លា «ពាក្យ» និង «នៅក្នុងអណ្តាត»
ទាំងពីរសំដៅទៅលើអ្វីដែលមនុស្សម្នាក់និយាយ។ ការបកប្រែផ្សេងទៀត៖
«កុំគ្រាន់តែនិយាយថាអ្នកស្រឡាញ់មនុស្ស»
ចូរស្រឡាញ់ដោយការប្រព្រឹត្ត និងសេចក្តីពិតផង
កិរិយាស័ព្ទ «ស្រឡាញ់» ត្រូវបានសន្មតពីពាក់កណ្តាលដំបូងនៃប្រយោគនេះ។
ការបកប្រែផ្សេងទៀត៖
«ប៉ុន្តែបង្ហាញថាអ្នកពិតជាស្រឡាញ់មនុស្សដោយជួយពួកគេ»
1 John 3:19

generated on Wed Sep 10 16:16:32 2025

ឃ្លាភ្ជាប់៖
នៅទីនេះលោកយ៉ូហានប្រហែលជាមានន័យថាសមត្ថភាពរបស់អ្នកជឿដើម្បីស្រឡាញ់ព្រះនិងគ្នាទៅវិញទៅមក
(សូមមើលជំពូក ១៨)
គឺជាសញ្ញាមួយដែលបង្ហាញថាជីវិតថ្មីរបស់ពួកគេពិតជាមានប្រភពចេញពីសេចក្តីពិតអំពីព្រះយេស៊ូវ
យើងកើតមកពីសេចក្តីពិត
«យើងជាកម្មសិទ្ធិរបស់សេចក្តីពិត» ឬ
«យើងកំពុងរស់នៅតាមរបៀបដែលព្រះយេស៊ូបានបង្រៀនយើង»
យើងក៏មានអំណះអំណាងនៅក្នុងចិត្តរបស់យើង
ពាក្យថា« ចិត្ត» នៅទីនេះសំដៅទៅលើអារម្មណ៍។ ការបកប្រែផ្សេងទៀត៖
«យើងមិនមានអារម្មណ៍ថាមានកំហុស»
ប្រសិនបើ ចិត្តរបស់យើងកាត់ទោសយើង
នេះជាពាក្យប្រៀបធៀប។ ការបកប្រែផ្សេងទៀត៖
«ប្រសិនបើយើងដឹងថាយើងបានធ្វើបាបគឺយើងមានអារម្មណ៍ថាមានកំហុស»
ព្រះជាម្ចាស់ធំជាងចិត្តរបស់យើង
ព្រះជាម្ចាស់យល់ដឹងលើសយើង ហើយវិនិច្ឆ័យបានល្អជាងយើង។
ឥទ្ធិពលនៃសេចក្តីពិតនេះគឺប្រហែលជាព្រះជាម្ចាស់មានសេចក្តីមេត្តាករុណាច្រើនជាងមនុស្ស
គុណភាពនៃព្រះនេះត្រូវបានបង្ហាញដោយពាក្យថា« ធំជាង» ។
ការបកប្រែផ្សេងទៀត៖ «ព្រះជាម្ចាស់ជ្រាបអ្វីៗលើសយើងដឹងទៅទៀត»
ព្រះនិងគ្នាទៅវិញទៅមក
«អ្នកជាមនុស្សដែលខ្ញុំស្រឡាញ់» ឬ «មិត្តជាទីស្រឡាញ់» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ជំពូក២ ខ ៧ ។
ធ្វើតាមអ្វីៗដែលគាប់ព្រះហឫទ័យនៅចំពោះព្រះអង្
គំនិតរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយថាវាអាស្រ័យលើអ្វីដែលទ្រង់បានឃើញកើតឡើងនៅចំពោះមុខ
«ហើយយើងធ្វើអ្វីដែលគាប់ព្រះហឫទ័យព្រះអង្គ»
1 John 3:23
នេះគឺជាបទបញ្ជារបស់ព្រះអង្គ
«នេះជាអ្វីដែលព្រះជាម្ចាស់ចង់ឲ្យយើងធ្វើ»។
ព្រះបុត្រា
នេះជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះជាម្ចាស់។
ស្ថិតនៅជាប់នឹងព្រះអង្គ ហើយព្រះអង្គក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ
ភាពជិតស្និទ្ធនៃអ្នកជឿត្រូវបានបង្ហាញដោយពាក្យ «នៅជាប់នឹងព្រះអង្គ» ។
សូមមើលពីរបៀបដែល« នៅជាប់នឹងព្រះជាម្ចាស់» ត្រូវបានបកប្រែនៅជំពូក ២
ដែលការរបស់យើង។

---

4 [1]បងប្អូនជាទីស្រឡាញ់ សូមកុំជឿគ្រប់ទាំងវិញ្ញាណផ្សេងៗឡើយ។ ផ្ទុយទៅវិញ ចូរល្បងលវិញ្ញាណទាំងនោះ ដើម្បីឲ្យឃើញថា មកពីព្រះជាម្ចាស់ឬយ៉ាងណា
ដោយសារមានព្យាការីក្លែងក្លាយជាច្រើនបានចេញទៅក្នុងលោកីយ៍នេះ។[2]ដោយសារការនេះ អ្នកនឹងស្គាល់ព្រះវិញ្ញាណនៃព្រះជាម្ចាស់
គ្រប់ទាំងវិញ្ញាណដែលទទួលស្គាល់ថា ព្រះយេស៊ូគ្រិស្តបានត្រឡប់ទៅជាសាច់ឈាមគឺមកពីព្រះជាម្ចាស់[3]ហើយគ្រប់ទាំងវិញ្ញាណផ្សេងៗដែលមិនទទួលស្គាល់
ថាព្រះយេស៊ូមកពីព្រះជាម្ចាស់។ នេះគឺជាវិញ្ញាណនៃអ្នកដែលប្រឆាំងនឹងព្រះគ្រិស្ត ដែលអ្នកបានឮថា វានឹងមក ហើយឥឡូវនេះ វាបានមកក្នុងលោកីយ៍រួចរាល់ហើយ។
[4]កូនៗជាទីស្រឡាញ់អើយ អ្នករាល់គ្នាមកពីព្រះជាម្ចាស់ ហើយអ្នករាល់គ្នាបានឈ្នះពួកវាហើយ ដោយសារព្រះអង្គដែលនៅក្នុងអ្នក
គឺធំជាងម្នាក់ដែលនៅក្នុងលោកីយ៍នេះ។[5]ពួកគេមកពីលោកីយ៍ ហេតុដូច្នេះហើយ អ្វីដែលពួកគេនិយាយចេញពីលោកីយ៍មក ហើយពួកលោកីយ៍បានស្តាប់ពួកគេ។
[6]យើងមកពីព្រះជាម្ចាស់។ អ្នកណាដែលស្គាល់ព្រះជាម្ចាស់ នឹងស្តាប់យើង។ ដោយសារយើងស្គាល់វិញ្ញាណនៃសេចក្តីពិត និងវិញ្ញាណនៃខុសឆ្គង។
[7]បងប្អូនជាទីស្រឡាញ់ ចូរយើងស្រឡាញ់គ្នាទៅវិញទៅមក ព្រោះសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់
ហើយអស់អ្នកណាដែលមានសេចក្តីស្រឡាញ់គឺកើតចេញមកពីព្រះជាម្ចាស់ ហើយស្គាល់ព្រះជាម្ចាស់។[8]អ្នកណាដែលគ្មានសេចក្តីស្រឡាញ់មិនស្គាល់ព្រះជាម្ចាស់ទេ
ព្រោះព្រះជាម្ចាស់គឺជាសេចក្តីស្រឡាញ់។
[9]ដោយសារការនេះ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានសម្តែងឲ្យឃើញនៅក្នុងចំណោមយើង
ថាព្រះជាម្ចាស់បានចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គមកក្នុងលោកីយ៍នេះ ដើម្បីឲ្យយើងអាចរស់នៅដោយសារព្រះអង្គ។[10]នៅក្នុងសេចក្តីស្រឡាញ់នេះ
មិនមែនដោយសារយើងស្រឡាញ់ព្រះជាម្ចាស់ទេ ប៉ុន្តែ ដោយសារព្រះអង្គស្រឡាញ់យើង
ហើយព្រះអង្គបានចាត់ព្រះបុត្រារបស់ព្រះអង្គមកធ្វើជាយញ្ញបូជាធួននឹងបាបសម្រាប់លោះបាបរបស់យើង។
[11]បងប្អូនជាទីស្រឡាញ់ ប្រសិនបើ ព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងដល់ម្ល៉េះ ដូច្នេះ យើងត្រូវស្រឡាញ់ដល់គ្នាទៅវិញទៅមកដែរ។
[12]គ្មាននរណាម្នាក់ធ្លាប់បានឃើញព្រះជាម្ចាស់ទេ។ ប្រសិនបើ យើងស្រឡាញ់គ្នាទៅវិញទៅមក ព្រះជាម្ចាស់ស្ថិតនៅក្នុងយើង
ហើយសេចក្តីស្រឡាញ់របស់ព្រះអង្គក៏បានគ្រប់លក្ខណ៍នៅក្នុងយើងដែរ។[13]ដោយសារការនេះ យើងដឹងថា យើងស្ថិតនៅក្នុងព្រះអង្គ ហើយព្រះអង្គនៅក្នុងយើង
ដោយសារព្រះអង្គបានប្រទានដល់យើងនូវព្រះវិញ្ញាណរបស់ព្រះអង្គ។[14]ហើយយើងបានឃើញ ហើយបានធ្វើបន្ទាល់ថា
ព្រះបិតាបានចាត់ព្រះបុត្រាមកសង្គ្រោះលោកីយ៍ទាំងមូល។
[15]អស់អ្នកណាដែលទទួលស្គាល់ថា ព្រះយេស៊ូជាបុត្រានៃព្រះជាម្ចាស់ ព្រះអង្គនឹងស្ថិតនៅក្នុងអ្នកនោះ ហើយអ្នកនោះក៏នៅក្នុងព្រះជាម្ចាស់ដែរ។[16]យើងបានស្គាល់
ហើយបានជឿលើសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មានសម្រាប់យើង។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ហើយអ្នកណាដែលស្ថិតនៅក្នុងសេចក្តីស្រឡាញ់នេះ
ក៏ស្ថិតនៅក្នុងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏ស្ថិតនៅក្នុងអ្នកនោះដែរ។
[17]ដោយសារការនេះ បានធ្វើឲ្យសេចក្តីស្រឡាញ់នេះបានគ្រប់លក្ខណ៍នៅក្នុងចំណោមយើង ដូច្នេះ យើងនឹងមានទំនុកចិត្តនៅថ្ងៃជំនុំជម្រះ
ដោយសារព្រះអង្គជាសេចក្តីស្រឡាញ់ យើងដែលនៅក្នុងលោកីយ៍នេះក៏មានសេចក្តីស្រឡាញ់ដែរ។[18]ដូច្នេះហើយ គ្មានការភ័យខ្លាចនៅក្នុងសេចក្តីស្រឡាញ់ឡើយ។
ផ្ទុយទៅវិញ សេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍ បណ្តេញភាពភ័យខ្លាច ព្រោះភាពភ័យខ្លាចដោយសារមានការជំនុំជម្រះ។ ប៉ុន្តែ អ្នកណាដែលភ័យខ្លាច
មិនបានស្ថិតនៅក្នុងសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍នៅឡើយទេ។
[19]យើងស្រឡាញ់ ដោយសារព្រះអង្គស្រឡាញ់យើងជាមុន។[20]ប្រសិនបើ នរណាម្នាក់និយាយថា «ខ្ញុំស្រឡាញ់ព្រះជាម្ចាស់» ប៉ុន្តែ ស្អប់បងប្អូនរបស់ខ្លួន
គាត់ជាមនុស្សកុហក។ ព្រោះអស់អ្នកដែលមិនស្រឡាញ់បងប្អូនរបស់ខ្លួន ដែលមើលឃើញ មិនអាចស្រឡាញ់ព្រះជាម្ចាស់ ដែលគាត់មើលមិនឃើញបានទេ។
[21]នេះគឺជាបញ្ជាដែលយើងបានទទួលពីព្រះអង្គ៖ អស់អ្នកណាដែលស្រឡាញ់ព្រះជាម្ចាស់ ត្រូវស្រឡាញ់បងប្អូនរបស់ខ្លួនដែរ។

---

1 John 4:1
ព័ត៌មានទូទៅ:
លោកយ៉ូហានផ្តល់ការព្រមានប្រឆាំងនឹងគ្រូក្លែងក្លាយដែលបង្រៀនប្រឆាំងនឹងព្រះគ្រិស្ត
ដែលមានរូបកាយជាមនុស្ស
និងគ្រូដែលនិយាយតាមរបៀបអ្នកដែលស្រឡាញ់លោកីយនិយាយ។
បងប្អូនជាទីស្រឡាញ់
«អ្នកជាមនុស្សដែលខ្ញុំស្រឡាញ់» ឬ «មិត្តជាទីស្រឡាញ់» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ជំពូក២ ខ ៧ ។
សូមកុំជឿគ្រប់ទាំងវិញ្ញាណផ្សេងៗ
ត្រង់នេះពាក្យថា« វិញ្ញាណ» សំដៅទៅលើអំណាចខាងវិញ្ញាណ
ឬភាពខាងវិញ្ញាណដែលផ្តល់ឲ្យមនុស្សនូវសារ ឬ ទំនាយ។ ការបកប្រែផ្សេងទៀត៖
«កុំទុកចិត្តព្យាការីគ្រប់រូបដែលអះអាងថាមានព្រះរាជសារពីខាងឯវិញ្ញាណនោះឡើយ»
ល្បងលវិញ្ញាណទាំងនោះ
ត្រង់នេះពាក្យថា« វិញ្ញាណ» សំដៅទៅលើអំណាចខាងវិញ្ញាណ
ឬភាពខាងវិញ្ញាណដែលផ្តល់ឲ្យមនុស្សនូវសារឬទំនាយ។ ការបកប្រែផ្សេងទៀត៖ «
ត្រូវប្រាកដថាស្តាប់ដោយយកចិត្តទុកដាក់នូវអ្វីដែលព្យាការីនិយាយ»
ល្បង
«បង្ហាញ»
ត្រឡប់ទៅជាសាច់ឈាម
«បានយកទម្រង់បែបជាមនុស្ស» ឬ «បានមកទម្រង់ជារូបកាយ»

generated on Wed Sep 10 16:16:32 2025

នេះគឺជាវិញ្ញាណនៃអ្នកដែលប្រឆាំងនឹងព្រះគ្រិស្ត
«ពួកគេជាគ្រូដែលទាស់នឹងព្រះគ្រិស្ត»ឬ«ពួកគេជាគ្រូដែលប្រឆាំងនឹងព្រះគ្រិស្ត»
អ្នកដែលប្រឆាំងនឹងព្រះគ្រិស្ត ដែលអ្នកបានឮថា វានឹងមក ហើយ
«អ្នកប្រឆាំងនឹងព្រះគ្រិស្ត។
អ្នកបានឮថាមនុស្សនោះកំពុងតែមកក្នុងចំណោមយើង»
ឥឡូវនេះ វាបានមកក្នុងលោកីយ៍រួចរាល់ហើយ
វាកំពុងមក។ «មកសូម្បីតែឥឡូវនេះពួកគេនៅទីនេះរួចហើយ»
1 John 4:4
កូនៗជាទីស្រឡាញ់អើយ
លោកយ៉ូហានជាបុរសវ័យចំណាស់និងជាអ្នកដឹកនាំពួកគេ។
គាត់បានប្រើពាក្យនេះដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះពួកគេ។
«កូនជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះគ្រិស្ត» ឬ
«អ្នកដែលជាទីស្រឡាញ់ដល់ខ្ញុំដូចជាកូនៗរបស់ខ្ញុំ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ១ ។
បានឈ្នះពួកវាហើយ
«មិនជឿគ្រូក្លែងក្លាយ»
ព្រះអង្គដែលនៅក្នុងអ្នក
«ព្រះជាម្ចាស់ដែលគង់នៅក្នុងអ្នក»
ម្នាក់ដែលនៅក្នុងលោកីយ៍នេះ
អត្ថន័យពីរដែលអាចទៅរួចគឺ ១) "គ្រូក្នុងលោកីយ៍ទាំងនោះឬ ២)"
សាតាំងដែលនៅក្នុងលោកីយ៍នេះ។
លោកីយ៍
ពាក្យ«លោកីយ៍»សំដៅទៅលើមនុស្សទាំងអស់ដែលមិនគោរពតាមព្រះជាម្ចាស់
និងប្រព័ន្ធគ្រប់គ្រងមិនល្អដែលមាននៅក្នុងពិភពលោកមានបាបមួយនេះ។
ពួកគេមកពីលោកីយ៍
«គ្រូក្លែងក្លាយទាំងនោះគឺជាមនុស្សដែលមិនគោរពតាមព្រះជាម្ចាស់»
ហេតុដូច្នេះហើយ អ្វីដែលពួកគេនិយាយចេញពីលោកីយ៍មក
«ដូច្នេះពួកគេបង្រៀនគំនិតដែលប្រឆាំងនឹងព្រះជាម្ចាស់»
ហើយពួកលោកីយ៍បានស្តាប់ពួកគេ
«មនុស្សដែលមិនជឿព្រះជាម្ចាស់ស្តាប់ពួកគេ»
1 John 4:7
ព័ត៌មានទូទៅ:
លោកយ៉ូហានបន្តបង្រៀនអំពីមនុស្សថ្មី។
គាត់បង្រៀនអ្នកអានអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់និងចេះស្រឡាញ់គ្នាទៅវិញទៅមក។
បងប្អូនជាទីស្រឡាញ់
«អ្នកជាមនុស្សដែលខ្ញុំស្រឡាញ់» ឬ «មិត្តជាទីស្រឡាញ់» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ជំពូក២ ខ៧ ។
ចូរយើងស្រឡាញ់គ្នាទៅវិញទៅមក
«អ្នកជឿគឺត្រូវស្រឡាញ់អ្នកជឿផ្សេងទៀត»
អស់អ្នកណាដែលមានសេចក្តីស្រឡាញ់គឺកើតចេញមកពីព្រះជាម្ចាស់ ហើយស្គាល់ព្រះជាម្ចាស់
«ពីព្រោះអស់អ្នកដែលស្រឡាញ់អ្នកជឿដូចគ្នា
បានក្លាយជាកូនរបស់ព្រះជាម្ចាស់ហើយស្គាល់ព្រះអង្គ»
សេចក្តីស្រឡាញ់គឺកើតចេញមកពីព្រះជាម្ចាស់
«ពីព្រោះព្រះជាម្ចាស់បណ្តាលឲ្យយើងស្រឡាញ់គ្នា»
មកពីព្រះជាម្ចាស់
នេះគឺជាការប្រៀបធៀបដែលមានន័យថានរណាម្នាក់មានទំនាក់ទំនងជាមួយព្រះជាម្ចាស់
គឺដូចជាកូនមានទំនាក់ទំនងជាមួយនឹងឪពុករបស់ខ្លួនដែរ។
អ្នកណាដែលគ្មានសេចក្តីស្រឡាញ់មិនស្គាល់ព្រះជាម្ចាស់ទេ ព្រោះព្រះជាម្ចាស់គឺជាសេចក្តីស្រឡាញ់
«ធម្មជាតិរបស់ព្រះជាម្ចាស់គឺការស្រឡាញ់មនុស្ស។
អ្នកដែលមិនស្រឡាញ់អ្នកជឿដូចគ្នាមិនស្គាល់ព្រះជាម្ចាស់ទេពីព្រោះចរិតរបស់ព្រះជាម្ចាស់គឺជាសេចក្តីស្រឡាញ់»
ព្រះជាម្ចាស់គឺជាសេចក្តីស្រឡាញ់
នេះគឺការបញ្ជាក់មួយដែលមានន័យថា
បុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់គឺមានក្តីស្រឡាញ់។
1 John 4:9
ដោយសារការនេះ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានសម្តែងឲ្យឃើញនៅក្នុងចំណោមយើង
នេះអាចធ្វើឱ្យទៅជាសកម្ម។ ការបកប្រែផ្សេងទៀត៖
«តាមរយៈការនេះព្រះជាម្ចាស់បានបង្ហាញថាព្រះអង្គស្រឡាញ់យើង»
សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានសម្តែង
ការពិតដែលថាព្រះជាម្ចាស់ស្រឡាញ់មនុស្សគ្រប់គ្នាត្រូវបានគេនិយាយដូចជាវត្ថុដែលអាចមើលឃើញ

ដើម្បីឲ្យយើងអាចរស់នៅដោយសារព្រះអង្គ
«ដើម្បីឲ្យយើងអាចរស់នៅបានជារៀងរហូតដោយសារតែអ្វីដែលព្រះយេស៊ូបានធ្វើ»
នៅក្នុងសេចក្តីស្រឡាញ់នេះ
«ព្រះបានបង្ហាញយើងពីសេចក្តីស្រឡាញ់ពិត»។
សេចក្តីស្រឡាញ់នេះ មិនមែនដោយសារយើងស្រឡាញ់ព្រះជាម្ចាស់ទេ ប៉ុន្តែ
ដោយសារព្រះអង្គស្រឡាញ់យើង ហើយ
«សេចក្តីស្រឡាញ់៖
សេចក្តីស្រឡាញ់ពិតមិនមែនជារបៀបដែលយើងស្រឡាញ់ព្រះជាម្ចាស់ទេតែជារបៀបដែលព្រះអង្គបានស្រ
ព្រះអង្គបានចាត់ព្រះបុត្រារបស់ព្រះអង្គមកធ្វើជាយញ្ញបូជាជួនឹងបាបសម្រាប់លោះបាបរបស់យើង
ត្រង់នេះ« ការធ្វើយញ្ញបូជា»
សំដៅទៅលើការដែលព្រះរាជបុត្រាបានថ្វាយយញ្ញបូជាសំរាប់អំពើបាបរបស់មនុស្សលោកទាំងអស់។
«ហើយព្រះជាម្ចាស់បានចាត់ព្រះរាជបុត្រារបស់ព្រះអង្គឲ្យបូជាព្រះជន្មដើម្បីព្រះអង្គអាចអត់ទោសបាបរប
1 John 4:11
បងប្អូនជាទីស្រឡាញ់
«អ្នកជាមនុស្សដែលខ្ញុំស្រឡាញ់» ឬ «មិត្តជាទីស្រឡាញ់» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុង ជំពូក២ ខ ៧ ។
ប្រសិនបើ ព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងដល់ម្ល៉េះ
«ដោយសារព្រះជាម្ចាស់ស្រឡាញ់យើងតាមរបៀបនេះ»
ស្រឡាញ់ដល់គ្នាទៅវិញទៅមកដែរ
«អ្នកជឿគឺត្រូវស្រឡាញ់អ្នកជឿផ្សេងទៀត»
ព្រះជាម្ចាស់ស្ថិតនៅក្នុងយើង យើងស្ថិតនៅក្នុងព្រះអង្គ ហើយព្រះអង្គនៅក្នុងយើង
«ព្រះជាម្ចាស់មានទំនាក់ទំនងជាមួយយើង ...
យើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ហើយទ្រង់មានទំនាក់ទំនងជាមួយយើង»
។ សូមមើលពីរបៀបបកប្រែនេះត្រូវបានបកប្រែហើយនៅជំពូក ២ ខ៤ ។
សេចក្តីស្រឡាញ់របស់ព្រះអង្គក៏បានគ្រប់លក្ខណ៍នៅក្នុងយើង
«សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់គឺមាននៅក្នុងយើង»
ដោយសារការនេះ យើងដឹងថា យើង ដោយសារព្រះអង្គបានប្រទាន
ការបកប្រែរបស់អ្នកអាចកាន់តែច្បាស់ប្រសិនបើអ្នកលុបចោល «ដោយនេះ» ឬ
«ពីព្រោះ» ។ ការបកប្រែផ្សេងទៀត៖ «យើងដឹង ... ព្រោះព្រះអង្គបានផ្តល់ឲ្យ» ឬ
«តាមរយៈនេះយើងដឹង ... យើង: ទ្រង់បានផ្តល់ឲ្យ»
ដោយសារព្រះអង្គបានប្រទានដល់យើងនូវព្រះវិញ្ញាណរបស់ព្រះអង្គ
«ពីព្រោះព្រះអង្គបានប្រទានព្រះវិញ្ញាណរបស់ព្រះអង្គឲ្យមកយើង» ឬ
«ពីព្រោះព្រះអង្គបានដាក់ព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើយើង» ។
ទៅមុខទៀត ការយាងមកជាឃ្លានេះមិនបានន័យថាព្រះជាម្ចាស់មានព្រះវិញ្ញាណតិចជាងមុនទេបន្ទាប់ពីព្រះអង្គបានប្រទ
យើងបានឃើញ ហើយបានធ្វើបន្ទាល់ថា ព្រះបិតាបានចាត់ព្រះបុត្រាមកសង្គ្រោះលោកីយ៍ទាំងមូល
«យើងជាសាវ័កបានឃើញព្រះរាជបុត្រានៃព្រះជាម្ចាស់
ហើយប្រាប់អ្នករាល់គ្នាថាព្រះជាម្ចាស់ជាព្រះវរបិតាបានចាត់ព្រះរាជបុត្រារបស់ព្រះអង្គឲ្យមកសង្គ្រោះមនុស
ព្រះបិតា ព្រះបុត្រា
ទាំងនេះគឺជាឋានៈសំខាន់ៗដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់និងព្រះយេស៊ូ។
1 John 4:15
អស់អ្នកណាដែលទទួលស្គាល់ថា ព្រះយេស៊ូជាបុត្រានៃព្រះជាម្ចាស់
«អ្នកដែលនិយាយការពិតអំពីព្រះយេស៊ូថាព្រះអង្គជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់»
ព្រះរាជបុត្រារបស់ព្រះជាម្ចាស់
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះជាម្ចាស់។
ព្រះអង្គនឹងស្ថិតនៅក្នុងអ្នកនោះ ហើយអ្នកនោះក៏នៅក្នុងព្រះជាម្ចាស់ដែរ
ព្រះមានទំនាក់ទំនងជាមួយគេហើយគេក៏មានទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរ»
។ សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ៤ ។
ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់
នេះគឺជាពាក្យប្រៀបធៀបដែលមានន័យថា
«ការស្រឡាញ់អ្នកជឿគឺជាសេចក្តីស្រឡាញ់» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ៤ ខ៧ ។
អ្នកណាដែលស្ថិតនៅក្នុងសេចក្តីស្រឡាញ់នេះ ក៏ស្ថិតនៅក្នុងព្រះជាម្ចាស់
ហើយព្រះជាម្ចាស់ក៏ស្ថិតនៅក្នុងអ្នកនោះដែរ
«អ្នកដែលបន្តស្រឡាញ់អ្នកដទៃមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់ហើយព្រះជាម្ចាស់មានទំនាក់
1 John 4:17
ដោយសារការនេះ បានធ្វើឲ្យសេចក្តីស្រឡាញ់នេះបានគ្រប់លក្ខណ៍នៅក្នុងចំណោមយើង ដូច្នេះ
យើងនឹងមានទំនុកចិត្ត
អាចជាទម្រង់កិរិយាសកម្ម។ អាចមានន័យថា១) «ដោយសាររឿងនេះ» យោងទៅ
ជំពូក ៣ ខ ១៩-២៤ ដល់ពួកគេ។

generated on Wed Sep 10 16:16:32 2025

«ពីព្រោះអ្នកណាដែលរស់នៅក្នុងសេចក្ដីស្រឡាញ់គឺនៅក្នុងព្រះជាម្ចាស់ហើយព្រះជាម្ចាស់ក៏ស្ថិតនៅក្នុងអ្នកនោះដែរ»
ព្រះបានឲ្យសេចក្ដីស្រឡាញ់របស់ព្រះអង្គមកយើងពេញលេញហើយ
ដូច្នេះយើងអាចមានទំនុកចិត្តទាំងស្រុង» ឬទី 2) «ដោយសារតែរឿងនេះ»
សំដៅទៅលើ «យើងអាចមានទំនុកចិត្ត។ »
«យើងមានទំនុកចិត្តថាព្រះជាម្ចាស់នឹងទទួលយើងនៅថ្ងៃដែលទ្រង់វិនិច្ឆ័យទោសមនុស្សលោក
ដូច្នេះយើងដឹងថាទ្រង់បានធ្វើឲ្យសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះយើងពេញលេញ»
សេចក្ដីស្រឡាញ់នេះបានគ្រប់លក្ខណ៍នៅក្នុងចំណោមយើង
«នេះជារបៀបដែលព្រះជាម្ចាស់បានធ្វើឲ្យសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះយើងបានពេញលេញ
ដោយសារព្រះអង្គជាសេចក្ដីស្រឡាញ់ យើងដែលនៅក្នុងលោកីយ៍នេះក៏មានសេចក្ដីស្រឡាញ់ដែរ
«ពីព្រោះទំនាក់ទំនងដែលព្រះយេស៊ូមានជាមួយព្រះជាម្ចាស់ដូចជាទំនាក់ទំនងដែលយើងមានជាមួយព្រះជាម្ចាស់
សេចក្ដីស្រឡាញ់ដ៏គ្រប់លក្ខណ៍ បណ្តេញភាពភ័យខ្លាច
នៅទីនេះ «សេចក្ដីស្រឡាញ់» ត្រូវបានពិពណ៌នាថា
មនុស្សម្នាក់ដែលមានអំណាចបំបាត់ការភ័យខ្លាច។
សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់គឺល្អឥតខ្ចោះ។

«ដែលនៅក្នុងនេះ ក៏ដែលនៅក្នុងយើងដែរ ដែលនៅក្នុងយើងគ្រប់លក្ខណ៍ យើងលែងខ្លាចទៀតហើយ»
ព្រោះភាពភ័យខ្លាចដោយសារមានការជំនុំជម្រះ
«យើងនឹងភ័យខ្លាចប្រសិនបើយើងគិតថាព្រះជាម្ចាស់នឹងដាក់ទោសយើងនៅពេលដែលទ្រង់មកវិនិច្ឆ័យ
អ្នកណាដែលភ័យខ្លាច មិនបានស្ថិតនៅក្នុងសេចក្ដីស្រឡាញ់ដ៏គ្រប់លក្ខណ៍នៅឡើយទេ
ដូច្នេះមនុស្សម្នាក់ខ្លាចព្រះជាម្ចាស់នឹងដាក់ទោសគេនោះមានន័យថាសេចក្ដីស្រឡាញ់របស់គេមិនពេ
1 John 4:19
ស្អប់បងប្អូនរបស់ខ្លួន
«ប្រសិនបើអ្នកស្រឡាញ់
អ្នកដែលមិនស្រឡាញ់បងប្អូនរបស់ខ្លួន ដែលមើលឃើញ មិនអាចស្រឡាញ់ព្រះជាម្ចាស់
«ប្រសិនបើយើងមានអារម្មណ៍ថាមិនអាចស្រឡាញ់ព្រះជាម្ចាស់»
ប្រសិនបើឃ្លាអវិជ្ជមានពីរក្នុងមួយជួរមានភាពច្របូកច្របល់
នេះអាចត្រូវបានបកប្រែខុសគ្នា។ ការបកប្រែផ្សេងទៀត៖
«មានតែអ្នកដែលស្រឡាញ់បងប្អូនរបស់ខ្លួនដែលមើលឃើញប៉ុណ្ណោះ
ទើបស្រឡាញ់ព្រះដែលគាត់មើលមិនឃើញ»

---

5 [1]អស់អ្នកណាដែលជឿថា ព្រះយេស៊ូជាព្រះគ្រិស្ដ ដែលកើតមកពីព្រះជាម្ចាស់ ហើយអស់អ្នកណាដែលស្រឡាញ់ព្រះបិតា ក៏ស្រឡាញ់កូនដែលកើតចេញពីព្រះអង្គដែរ។
[2]ដោយសារការនេះ យើងដឹងថា យើងស្រឡាញ់បុត្រធីតារបស់ព្រះអង្គ៖ នៅពេលយើងស្រឡាញ់ព្រះជាម្ចាស់ ហើយប្រព្រឹត្តតាមបញ្ជារបស់ព្រះអង្គ។[3]ដ្បិត
ការនេះគឺជាសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់៖ គឺថា យើងកាន់តាមបញ្ជារបស់ព្រះអង្គ។ ហើយបញ្ជារបស់ព្រះអង្គមិនមែនជាបន្ទុកធ្ងន់ទេ។
[4]មនុស្សគ្រប់រូបដែលកើតមកពីព្រះជាម្ចាស់បានឈ្នះលោកីយ៍ហើយ។ ហើយនេះគឺជាជ័យជំនះដែលឈ្នះលោកីយ៍៖ គឺដោយជំនឿរបស់យើង។
[5]តើអ្នកណាជាអ្នកឈ្នះលោកីយ៍? គឺជាអ្នកដែលជឿលើព្រះយេស៊ូថាជាព្រះបុត្រានៃព្រះជាម្ចាស់។
[6]នេះគឺជាអ្នកដែលបានមកដោយទឹក និងលោហិត៖ គឺព្រះយេស៊ូគ្រិស្ដ។ ព្រះអង្គបានយាងមកមិនគ្រាន់តែដោយទឹក ប៉ុន្តែ ដោយទឹក និងព្រះលោហិត។
[7]ព្រោះមានការបីយ៉ាងដែលធ្វើបន្ទាល់ពីការនេះ៖ [8]ព្រះវិញ្ញាណ ទឹក និងព្រះលោហិត។ ទាំងបីនេះព្រមព្រៀងគ្នា។
[9]ប្រសិនបើ យើងទទួលទីបន្ទាល់ពីមនុស្ស ទីបន្ទាល់របស់ព្រះជាម្ចាស់ប្រសើរជាង។ ព្រោះទីបន្ទាល់របស់ព្រះជាម្ចាស់គឺបែបនេះ គឺថា
ព្រះបានធ្វើបន្ទាល់ទាក់ទងនឹងព្រះបុត្រារបស់ព្រះអង្គ។[10]អស់អ្នកណាដែលជឿលើព្រះបុត្រារបស់ព្រះជាម្ចាស់ គេមានទីបន្ទាល់នៅក្នុងខ្លួនគេ។
អស់អ្នកណាដែលមិនជឿថាព្រះជាម្ចាស់បានបង្កើតព្រះអង្គចេញមក គឺជាមនុស្សកុហក
ដោយសារគាត់មិនបានជឿទីបន្ទាល់ដែលព្រះជាម្ចាស់បានប្រទានមកទាក់ទងនឹងព្រះបុត្រារបស់ព្រះអង្គ។
[11]ហើយទីបន្ទាល់គឺយ៉ាងដូច្នេះ៖ ព្រះជាម្ចាស់ប្រទានជីវិតអស់កល្បជានិច្ចដល់យើង ហើយជីវិតនេះនៅក្នុងព្រះបុត្រារបស់ព្រះអង្គ។[12]អ្នកណាដែលមានព្រះបុត្រា
គឺមានជីវិត។ ហើយអ្នកណាដែលគ្មានព្រះបុត្រារបស់ព្រះជាម្ចាស់ក៏គ្មានជីវិតដែរ។
[13]ខ្ញុំសរសេរសេចក្ដីទាំងនេះ មកកាន់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ
ចំពោះអ្នកណាដែលជឿនៅក្នុងព្រះនាមព្រះបុត្រារបស់ព្រះជាម្ចាស់។[14]ហើយនេះក៏ជាទំនុកចិត្តដែលយើងមានចំពោះព្រះអង្គដែរ គឺថាប្រសិនបើយើង
សូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះព្រះអង្គនឹងស្ដាប់យើង។[15]ហើយប្រសិនបើយើងដឹងថា ព្រះអង្គស្ដាប់យើង អ្វីៗដែលយើងបានទូលសុំពីព្រះអង្គ យើងដឹងថា
យើងបានទទួលអ្វីៗដែលយើងបានសុំពីព្រះអង្គនោះហើយ។
[16]ប្រសិនបើ នរណាម្នាក់ឃើញបងប្អូនរបស់គាត់ធ្វើបាប ដែលមិនមានទោសដល់ស្លាប់ គាត់ត្រូវអធិស្ឋាន ហើយព្រះអង្គនឹងប្រទានជីវិតដល់គាត់។
ខ្ញុំសំដៅលើអស់អ្នកដែលធ្វើបាបដែលមិនមានទោសដល់ស្លាប់។ បើធ្វើបាបមានទោសដល់ស្លាប់ ខ្ញុំមិននិយាយថា គាត់គួរអធិស្ឋានសម្រាប់ការនោះទេ។
[17]អ្វីៗដែលមិនសុចរិតគឺជាបាប ប៉ុន្តែ ក៏មានបាបដែលមិនមានទោសដល់ស្លាប់ដែរ។
[18]យើងដឹងថា អស់អ្នកណាដែលកើតមកពីព្រះជាម្ចាស់មិនធ្វើបាបទេ។ ប៉ុន្តែ ព្រះអង្គដែលកើតមកពីព្រះជាម្ចាស់ នឹងការពារគាត់ឲ្យមានសុវត្ថិភាព
ហើយការអាក្រក់មិនអាចធ្វើទុក្ខគាត់បានទេ។[19]យើងដឹងថាយើងមកពីព្រះជាម្ចាស់ ហើយយើងដឹងថា លោកីយ៍ទាំងមូលកំពុងតែដេកនៅក្នុងមេកំណាច។
[20]ប៉ុន្តែ យើងដឹងថា ព្រះបុត្រារបស់ព្រះជាម្ចាស់បានយាងមក ហើយបានប្រទានមកយើងនូវការយល់ដឹង ដើម្បីឲ្យយើងបានដឹងថា ព្រះអង្គជាសេចក្ដីពិត។
ហើយយើងនៅក្នុងព្រះជាម្ចាស់នៃសេចក្ដីពិតដែរ ហើយនៅក្នុងព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រិស្ដ។ ព្រះជាម្ចាស់គឺជាព្រះដ៏ពិត និងជាជីវិតអស់កល្ប។[21]កូនៗរាល់គ្នាអើយ
ចូររក្សាខ្លួនចេញពីរូបព្រះផ្សេងៗ។

---

1 John 5:1
ព័ត៌មានទូទៅ:
លោកយ៉ូហានបន្តបង្រៀនអ្នកអានរបស់គាត់អំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់
ហើយនិងអ្នកជឿដែលមានក្ដីស្រឡាញ់
ព្រោះពួកគេមាននិស្ស័យថ្មីនេះមកពីព្រះជាម្ចាស់។
ដែលកើតមកពីព្រះជាម្ចាស់
«គឺជាបុត្រារបស់ព្រះជាម្ចាស់»
ដោយសារការនេះ យើងដឹងថា យើងស្រឡាញ់បុត្រធីតារបស់ព្រះអង្គ៖
នៅពេលយើងស្រឡាញ់ព្រះជាម្ចាស់ ហើយប្រព្រឹត្តតាមបញ្ជារបស់ព្រះអង្គ
«ពេលយើងស្រឡាញ់ព្រះជាម្ចាស់ហើយធ្វើតាមអ្វីដែលព្រះអង្គបង្គាប់យើង
នឹងដឹងថាយើងស្រឡាញ់បុត្រ របស់ព្រះអង្គ»
ដ្បិត ការនេះគឺជាសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់៖ គឺថា យើងកាន់តាមបញ្ជារបស់ព្រះអង្គ
«ពីព្រោះនៅពេលយើងធ្វើអ្វីដែលទ្រង់បញ្ជានោះគឺជាសេចក្ដីស្រឡាញ់ពិតចំពោះព្រះជាម្ចាស់
ហើយបញ្ជារបស់ព្រះអង្គមិនមែនជាបន្ទុកធ្ងន់ទេ
«ហើយអ្វីដែលទ្រង់បញ្ជាគឺមិនពិបាកទេនោះទេ»
បន្ទុកធ្ងន់
«ធ្ងន់» «កម្ទេច» ឬ «ពិបាក»
1 John 5:4
មនុស្សគ្រប់រូបដែលកើតមកពីព្រះជាម្ចាស់
«បុត្រារបស់ព្រះជាម្ចាស់ទាំងអស់»
បានឈ្នះលោកីយ៍ហើយ
«មានជ័យជម្នះលើលោកីយ៍» «ជោគជ័យលើលោកីយ៍» ឬ
«បដិសេធមិនធ្វើអំពើអាក្រក់ដែលអ្នកមិនជឿធ្វើ»
ហើយនេះគឺជាជ័យជំនះដែលឈ្នះលោកីយ៍៖ គឺដោយជំនឿរបស់យើង
«ជំនឿរបស់យើងជួយផ្តល់អំណាចដើម្បីទប់ទល់នឹងអ្វីដែលនឹងនាំយើងឱ្យធ្វើបាបប្រឆាំងនឹងព្រះជាម្ចាស់»
តើអ្នកណាជាអ្នកឈ្នះលោកីយ៍
លោកយ៉ូហានបានប្រើសំណួរនេះដើម្បីណែនាំអ្វីដែលគាត់ចង់បង្រៀន។
ការបកប្រែផ្សេងទៀត៖ «ខ្ញុំនឹងប្រាប់អ្នកថាអ្នកណាឈ្នះលោកីយ៍នេះ»
លោកីយ៍
អត្ថបទនេះប្រើពាក្យ «លោកីយ៍»
ដើម្បីសំដៅទៅលើមនុស្សមានបាបនិងប្រព័ន្ធអាក្រក់ទាំងអស់នៅក្នុងលោកីយ៍។
ការបកប្រែផ្សេងទៀត៖ «អ្វីៗនៅក្នុងលោកីយ៍ដែលប្រឆាំងនឹងព្រះជាម្ចាស់»
អ្នកដែលជឿលើព្រះយេស៊ូថាជាព្រះបុត្រានៃព្រះជាម្ចាស់
នេះមិនសំដៅទៅលើមនុស្សណាម្នាក់មួយទេ
តែសំដៅទៅលើអ្នកណាដែលជឿការនេះ។ ការបកប្រែផ្សេងទៀត៖
«អ្នកណាជឿថាព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះជាម្ចាស់»។

generated on Wed Sep 10 16:16:32 2025

បុត្រានៃព្រះជាម្ចាស់
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះជាម្ចាស់។
1 John 5:6
ឃ្លាភ្ជាប់៖
លោកយ៉ូហានបង្រៀនអំពីព្រះយេស៊ូគ្រិស្តនិងអ្វីដែលព្រះជាម្ចាស់មានបន្ទូលអំពីព្រះអង្គ។
នេះគឺជាអ្នកដែលបានមកដោយទឹក និងលោហិត៖ គឺព្រះយេស៊ូគ្រិស្ត
«ព្រះយេស៊ូគ្រិស្តគឺជាអ្នកដែលមកដោយទឹកនិងឈាម» ។ នៅទីនេះ «ទឹក»
គឺជាឈ្មោះហៅក្រៅប្រហែលជាសម្រាប់ពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូ ហើយ
«ឈាម» តំណាងឲ្យការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាង។
ការបកប្រែផ្សេងទៀត៖ «ព្រះបានបង្ហាញថាព្រះយេស៊ូគ្រិស្តគឺជាបុត្រារបស់ព្រះអង្គ
នៅឯពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូនិងការសុគតរបស់ព្រះអង្គនៅលើឈើឆ្កាង» នៅទីនេះ« ជីវិត»
មិនគ្រាន់តែដោយទឹក ប៉ុន្តែ ដោយទឹក និងព្រះលោហិត
ទឹកសំដៅទៅលើពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូនិងឈាមសំដៅទៅលើការសុគត
ការបកប្រែផ្សេងទៀត៖
«ព្រះមិនគ្រាន់តែបង្ហាញយើងថាព្រះយេស៊ូជាបុត្រារបស់ព្រះអង្គតាមរយៈពិធីបុណ្យជ្រមុជទឹក
ប៉ុន្តែតាមរយៈពិធីបុណ្យជ្រមុជទឹកនិងការសុគតរបស់ទ្រង់នៅលើឈើឆ្កាង»
1 John 5:9
ប្រសិនបើ យើងទទួលទីបន្ទាល់ពីមនុស្ស ទីបន្ទាល់របស់ព្រះជាម្ចាស់ប្រសើរជាង
អ្នកបកប្រែអាចបញ្ជាក់កាន់តែច្បាស់នូវហេតុផលបង្កប់ន័យថាហេតុអ្វីបានជាយើងគួរជឿ
ការបកប្រែផ្សេងទៀត៖ «
បើយើងជឿអ្វីដែលមនុស្សនិយាយអញ្ចឹងយើងគួរតែជឿអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល
ព្រោះទ្រង់តែងតែមានព្រះបន្ទូលការពិត»
ទទួលទីបន្ទាល់ពីមនុស្ស
ការពិតដែលមនុស្សធ្វើជាសាក្សីឬថ្លែងទីបន្ទាល់អំពីរឿងផ្សេងៗត្រូវបានគេនិយាយនៅទីនេះ
ទីបន្ទាល់របស់ព្រះជាម្ចាស់ប្រសើរជាង
សាក្សីរបស់ព្រះជាម្ចាស់គឺសំខាន់ជាងហើយអាចជឿទុកចិត្តបានជាង
ព្រះបុត្រា
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។
អស់អ្នកណាដែលជឿលើព្រះបុត្រារបស់ព្រះជាម្ចាស់ គេមានទីបន្ទាល់នៅក្នុងខ្លួនគេ
អ្នកណាជឿលើព្រះយេស៊ូដឹងច្បាស់ថាព្រះយេស៊ូពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ "
បានបង្កើតព្រះអង្គចេញមក គឺជាមនុស្សកុហក
«កំពុងហៅព្រះជាម្ចាស់ជាមនុស្សកុហក»
ដោយសារគាត់មិនបានជឿទីបន្ទាល់ដែលព្រះជាម្ចាស់បានប្រទានមកទាក់ទងនឹងព្រះបុត្រារបស់ព្រះអង្គ
«ពីព្រោះគាត់មិនជឿថាព្រះបានប្រាប់ការពិតអំពីព្រះរាជបុត្រារបស់ព្រះអង្គ»
1 John 5:11
ហើយទីបន្ទាល់គឺយ៉ាងដូច្នេះ
«នេះជាអ្វីដែលព្រះជាម្ចាស់មានបន្ទូល»
ជីវិត
នៅទីនេះ« ជីវិត»
តំណាងឲ្យសិទ្ធិរស់នៅជារៀងរហូតដោយព្រះគុណនិងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១ ខ១ ។
ជីវិតនេះនៅក្នុងព្រះបុត្រារបស់ព្រះអង្គ
ជីវិតនេះគឺតាមរយៈព្រះរាជបុត្រារបស់ព្រះអង្គ
«យើងនឹងរស់ជារៀងរហូតប្រសិនបើយើងចូលរួមជាមួយព្រះរាជបុត្រារបស់ព្រះអង្គ
» ឬ
«យើងនឹងរស់ជារៀងរហូតប្រសិនបើយើងរួបរួមជាមួយព្រះរាជបុត្រារបស់ព្រះអង្គ»
ព្រះរាជបុត្រា
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះជាម្ចាស់។
អ្នកណាដែលមានព្រះបុត្រា គឺមានជីវិត
ការមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះរាជបុត្រានោះមានន័យថាមាន
ព្រះរាជបុត្រា។ ការបកប្រែផ្សេងទៀត៖
«អ្នកណាជឿលើព្រះបុត្រារបស់ព្រះជាម្ចាស់មានជីវិតអស់កល្បជានិច្ច»
1 John 5:13
ព័ត៌មានទូទៅ:
ចុងបញ្ចប់នៃសំបុត្ររបស់លោកយ៉ូហាន។
គាត់ប្រាប់អ្នកអាននូវគោលបំណងចុងក្រោយរបស់គាត់
ដែលបានជ្រើសរើសក្នុងការសរសេរនូវការបង្រៀនចុងក្រោយមួយចំនួន។
សេចក្តីទាំងនេះ
«សំបុត្រនេះ»
ចំពោះអ្នកណាដែលជឿនៅក្នុងព្រះនាមព្រះបុត្រារបស់ព្រះជាម្ចាស់
នៅទីនេះ «ឈ្មោះ» គឺជាឈ្មោះហៅក្រៅសម្រាប់ព្រះរាជបុត្រានៃព្រះជាម្ចាស់។
ការបកប្រែផ្សេងទៀត៖ «ចំពោះអ្នកដែលជឿជាក់លើព្រះរាជបុត្រានៃព្រះជាម្ចាស់»
ព្រះរាជបុត្រានៃព្រះជាម្ចាស់
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះជាម្ចាស់។
ជីវិត
នៅទីនេះ« ជីវិត»
តំណាងឲ្យសិទ្ធិរស់នៅជារៀងរហូតដោយព្រះគុណនិងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១ ខ១ ។
នេះក៏ជាទំនុកចិត្តដែលយើងមានចំពោះព្រះអង្គដែរ គឺថា
ប្រសិនបើយើង សូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ
«ប្រសិនបើយើងសុំអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ»
យើងដឹងថា យើងបានទទួលអ្វីៗដែលយើងបានសុំពីព្រះអង្គនោះហើយ
1 John 5:16
ប្អូន
«អ្នកជឿដូចគ្នា»
ជីវិត
និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១ ខ១ ។
ស្លាប់
1 John 5:18
ឃ្លាភ្ជាប់៖
លោកយ៉ូហានបានបញ្ចប់លិខិតរបស់គាត់ដោយពិនិត្យមើលអ្វីដែលគាត់បាននិយាយអំពីលក្ខណៈថ្មីនៃអ្នក
លោកីយ៍ទាំងមូលកុហក
«លោកីយ៍»គឺជាវិធីមួយដែលអ្នកនិពន្ធគម្ពីរខ្លះនិយាយអំពីមនុស្សដែលរស់នៅក្នុងលោកីយ៍ដែលកំពុងប
ក្នុងមេកំណាច
នោះគឺនៅក្នុងអំណាចរបស់មារកំណាច។
1 John 5:20
ព័ត៌មានទូទៅ:
ពាក្យ «របស់ព្រះអង្គ» និង «ព្រះអង្គ» សំដៅទៅលើព្រះយេស៊ូគ្រិស្ត។
ព្រះបុត្រារបស់ព្រះជាម្ចាស់
នេះគឺជាឋានៈសំខាន់សម្រាប់ព្រះយេស៊ូដែលពិពណ៌នាអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះជាម្ចាស់។
បានប្រទានមកយើងនូវការយល់ដឹង
«បានជួយឲ្យយើងយល់ពីសេចក្តីពិត»
ជីវិត
នៅទីនេះ« ជីវិត»
តំណាងឲ្យសិទ្ធិរស់នៅជារៀងរហូតដោយព្រះគុណនិងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១ ខ ១ ។
ព្រះជាម្ចាស់គឺ ជាជីវិតអស់កល្ប
នេះតំណាងឱ្យគំនិតដែលថាព្រះគ្រិស្តផ្តល់ឱ្យយើងនូវជីវិតអស់កល្បជានិច្ច។
កូនៗរាល់គ្នាអើយ
លោកយ៉ូហានជាបុរសវ័យចំណាស់និងជាអ្នកដឹកនាំពួកគេ។
គាត់បានប្រើពាក្យនេះដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះពួកគេ។
ការបកប្រែផ្សេងទៀត៖ «កូនជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងព្រះគ្រិស្ត» ឬ
«អ្នកដែលជាទីស្រឡាញ់ដល់ខ្ញុំដូចជាកូនៗរបស់ខ្ញុំ» ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ២ ខ១ ។

២ យ៉ូហាន

generated on Wed Sep 10 16:16:32 2025

1 [1]ពីចាស់ទុំ ទៅកាន់ស្ត្រីដែលបានជ្រើសរើស និងកូនៗរបស់នាង ដែលខ្ញុំស្រឡាញ់នៅក្នុងសេចក្ដីពិត ហើយមិនគ្រាន់តែខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែ
ថែមទាំងអស់អ្នកដែលបានស្គាល់សេចក្ដីពិតផងដែរ[2]ដោយសារសេចក្ដីពិត នៅក្នុងយើង ហើយនឹងនៅជាមួយយើងរហូតអស់កល្ប។[3]សូមព្រះគុណ សេចក្ដីមេត្តា
និងសេចក្ដីសុខសាន្ត នៅជាមួយយើង ពីព្រះវរបិតា និងពីព្រះយេស៊ូវគ្រិស្ត ជាព្រះបុត្រារបស់ព្រះវរបិតា នៅក្នុងសេចក្ដីពិត និងសេចក្ដីស្រឡាញ់។
[4]ខ្ញុំមានអំណរជាខ្លាំង ដែលខ្ញុំបានដឹងថា មានកូនៗរបស់យើងមួយចំនួនកំពុងតែដើរក្នុងសេចក្ដីពិត ដូចដែលយើងបានទទួលបញ្ញត្តិនេះ មកពីព្រះវរបិតា។[5]ឥឡូវនេះ
ខ្ញុំសូមអង្វរអ្នកស្រី ខ្ញុំមិនគ្រាន់តែសរសេរបញ្ញត្តិថ្មីមកកាន់អ្នកស្រីតែប៉ុណ្ណឹងទេ ប៉ុន្តែ ព្រះដែលយើងមានតាំងពីដើមបំបូងមក ថា យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក។
[6]នេះគឺជាសេចក្ដីស្រឡាញ់ ដែលយើងត្រូវដើរតាមបញ្ញត្តិរបស់ព្រះអង្គ។ នេះគឺជាបញ្ញត្តិ ដូចដែលអ្នកធ្លាប់បានឮរួចមកហើយតាំងពីដំបូង ថាអ្នកត្រូវដើរតាមបញ្ញត្តិនេះ។
[7]ដោយសារមានអ្នកបោកប្រាស់ជាច្រើនបានចេញទៅក្នុងលោកីយ៍នេះ ហើយពួកគេមិនបានប្រកាសថា ព្រះយេស៊ូគ្រិស្តបានត្រឡប់ទៅជាសាច់ឈាមឡើយ។
នេះគឺជាអ្នកបោកប្រាស់ និងជាអ្នកដែលប្រឆាំងនឹងព្រះគ្រិស្តហើយ។[8]ចូរប្រ័យ្នខ្លួនរបស់អ្នក ថាអ្នកមិនបាត់បង់អ្វីៗដែលយើងបានធ្វើការ
ដើម្បីឲ្យអ្នកបានទទួលរង្វាន់យ៉ាងបរិបូរ។
[9]អស់អ្នកណាដែលមិននៅជាប់ក្នុងសេចក្ដីបង្រៀនរបស់ព្រះគ្រិស្តទេ អ្នកនោះគ្មានព្រះជាម្ចាស់ទេ។ អ្នកណាដែលនៅជាប់នឹងសេចក្ដីបង្រៀន អ្នកនោះមានទាំងព្រះវរបិតា
និងព្រះបុត្រា។[10]ប្រសិនបើ នរណាម្នាក់មករកអ្នក ហើយមិនបាននាំសេចក្ដីបង្រៀននេះមកកាន់អ្នកទេ សូមកុំទទួលពួកគេមកក្នុងផ្ទះរបស់អ្នកឡើយ
ហើយមិនត្រូវស្វាគមន៍គេដែរ។[11]ព្រោះអ្នកណាដែលស្វាគមន៍ពួកគេនឹងមានចំណែកក្នុងអំពើអាក្រក់របស់គេដែរ។
[12]ខ្ញុំមានកិច្ចការជាច្រើន ដើម្បីសរសេរមកកាន់អ្នក ប៉ុន្តែ ខ្ញុំមិនចង់សរសេរទៅកាន់ពួកគេដោយទឹកបិចលើក្រដាស់ឡើយ។ ប៉ុន្តែ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងទៅរកអ្នក
ហើយនិយាយជាមួយឯកមុខទល់នឹងមុខ ដើម្បីឲ្យអំណររបស់យើងបានគ្រប់លក្ខណ៍ឡើង។[13]កូនៗរបស់បងស្រីជ្រើសរើសរបស់អ្នក ជម្រាប់សួរអ្នក។

---

2 John 1:1

ឃ្លាភ្ជាប់៖

បន្ទាប់ពីការសួរសុខទុក្ខលោកយ៉ូហានបង្ហាញអ្នកជឿថាសេចក្ដីស្រឡាញ់
និងសេចក្ដីពិតនៅជាមួយគ្នា។

ព័ត៌មានទូទៅ:

ទំនៀមទម្លាប់សម្គាល់សាវ័កយ៉ូហានជាអ្នកសរសេរសំបុត្រនេះ។
ទោះបីជាអាចធ្វើទៅបានចំពោះស្ត្រីម្នាក់ៗក៏ដោយព្រោះគាត់សរសេរថាពួកគេគួរតែ
«ស្រឡាញ់គ្នាទៅវិញទៅមក» នេះប្រហែលជាសំដៅទៅក្រុមជំនុំ។

ព័ត៌មានទូទៅ:

ឧទាហរណ៍ពាក្យ «អ្នក» និង «របស់អ្នក»
នៅក្នុងលិខិតនេះគឺមានពហុវចន:លើកលែងតែមានការកត់សម្គាល់ផ្សេងក្រៅពីនេះ។

ព័ត៌មានទូទៅ:

នៅក្នុងសំបុត្រនេះលោកយ៉ូហានបានបញ្ចូលខ្លួនគាត់និងអ្នកអានរបស់គាត់ដោយប្រើពាក្យ
"យើង" និង «របស់យើង»

ពីចាស់ទុំ ទៅកាន់ស្ត្រីដែលបានជ្រើសរើស និងកូនៗរបស់នាង
នេះជារបៀបដែលសំបុត្រត្រូវបានចាប់ផ្តើម។
ឈ្មោះអ្នកនិពន្ធអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំយ៉ូហានជាចាស់ទុំកំពុងសរសេរសំបុត្រនេះទៅកាន់ស្ត្រីដែលបានជ្រើសរើសនិងកូនៗ
របស់នាង»

ចាស់ទុំ
នេះសំដៅទៅលើលោកយ៉ូហានដែលជាសាវ័កនិងជាសិស្សរបស់ព្រះយេស៊ូ។
គាត់សំដៅទៅលើខ្លួនគាត់ថាជា «ចាស់ទុំ»
ដោយសារគាត់មានអាយុចាស់ឬដោយសារគាត់ជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំ។

ទៅកាន់ស្ត្រីដែលបានជ្រើសរើស និងកូនៗរបស់នាង
នេះប្រហែលជាសំដៅទៅលើក្រុមជំនុំ និងអ្នកជឿដែលជាកម្មសិទ្ធិរបស់ក្រុមជំនុំ។

ដែលខ្ញុំស្រឡាញ់នៅក្នុងសេចក្ដីពិត
"អ្នកជាមនុស្សដែលខ្ញុំស្រឡាញ់ពិត"

អ្នកដែលបានស្គាល់សេចក្ដីពិត
អ្នកដែលស្គាល់សេចក្ដីពិតអំពីព្រះជាម្ចាស់និងព្រះយេស៊ូ។

ព្រះវរបិតា ព្រះបុត្រា
ទាំងនេះគឺជាឋានៈសំខាន់ៗដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់
និងព្រះយេស៊ូ។

នៅក្នុងសេចក្ដីពិត និងសេចក្ដីស្រឡាញ់
ពាក្យ «សេចក្ដីពិត» ពិពណ៌នាអំពី «សេចក្ដីស្រឡាញ់» ។
ប្រហែលជាវាមានន័យថា៖ ការបកប្រែផ្សេងទៀត៖ «នៅក្នុងស្នេហាពិត» ។

2 John 1:4

មានកូនៗរបស់យើង អ្នក អ្នកស្រី សរសេរមកអ្នក
ឧទាហរណ៍នៃ «របស់អ្នក» និង «អ្នក» របស់អ្នកគឺឯកវចន:។

ដូចដែលយើងបានទទួលបញ្ញត្តិនេះ មកពីព្រះវរបិតា
«ដូចព្រះជាព្រះវរបិតាបានបញ្ជាយើង»

ខ្ញុំមិនគ្រាន់តែសរសេរបញ្ញត្តិថ្មីមកកាន់អ្នកស្រីតែប៉ុណ្ណឹងទេ
“ មិនមែនដូចជាខ្ញុំបញ្ជាអោយអ្នកធ្វើអ្វីថ្មីទេ”

ប៉ុន្តែ ព្រះដែលយើងមានតាំងពីដើមដំបូងមក
ត្រង់នេះ «ការចាប់ផ្តើម» សំដៅទៅលើ «ពេលដែលយើងជឿមុនដំបូង» ។

ការបកប្រែផ្សេងទៀត៖
«ប៉ុន្តែខ្ញុំកំពុងសរសេរទៅអ្នកនូវអ្វីដែលព្រះគ្រិស្តបានបញ្ជាឲ្យយើងធ្វើនៅពេលយើងជឿដំបូង»។

យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក
នេះអាចត្រូវបានបកប្រែជាប្រយោគថ្មី:
«ហើយគាត់បានបញ្ជាថាយើងគួរតែស្រឡាញ់គ្នាទៅវិញទៅមក» ។

នេះគឺជាបញ្ញត្តិ ដូចដែលអ្នកធ្លាប់បានឮរួចមកហើយតាំងពីដំបូង ថាអ្នកត្រូវដើរតាមបញ្ញត្តិនេះ
ការប្រព្រឹត្តក្នុងជីវិតរបស់យើងស្របតាមបទបញ្ជារបស់ព្រះជាម្ចាស់ប្រៀបដូចជាយើងកំពុងដើរតាមគន្លងរ
ពាក្យថា «វា» គឺសំដៅទៅលើសេចក្ដីស្រឡាញ់។ «ហើយទ្រង់បានបញ្ជាអ្នក
ត្រូវស្រឡាញ់គ្នាទៅវិញទៅមក» តាំងពីអ្នកជឿដំបូងមកម្ល៉េះ។

2 John 1:7

ឃ្លាភ្ជាប់៖

លោកយ៉ូហានព្រមានពួកគេអំពីអ្នកបោកបញ្ឆោតរំលឹកពួកគេឲ្យនៅជាប់នឹងការបង្រៀនរបស់ព្រះគ្រិស្តហើ

ពាក្យសរសេរមានអ្នកបោកប្រាស់ជាច្រើនបានចេញទៅក្នុងលោកីយ៍នេះ
«មានគ្រូក្លែងក្លាយជាច្រើនបានចាកចេញពីក្រុមជំនុំ» ឬ
«មានអ្នកបោកបញ្ឆោតជាច្រើននាក់នៅក្នុងពិភពលោក»

អ្នកបោកប្រាស់ជាច្រើន
«គ្រូក្លែងក្លាយជាច្រើន» ឬ «អ្នកក្លែងបន្លំជាច្រើន»

លោកីយ៍នេះ
ជាការបញ្ជាក់សំដៅទៅលើមនុស្សគ្រប់គ្នាដែលរស់នៅក្នុងពិភពលោក។

ព្រះយេស៊ូគ្រិស្តបានត្រឡប់ទៅជាសាច់ឈាម
«ព្រះយេស៊ូគ្រិស្តបានយាងមកជាមនុស្សពិត»

នេះគឺជាអ្នកបោកប្រាស់ និងជាអ្នកដែលប្រឆាំងនឹងព្រះគ្រិស្ត
«ពួកគេគឺជាអ្នកដែលបញ្ឆោតអ្នកដទៃហើយប្រឆាំងនឹងព្រះគ្រិស្តខ្លួនឯង»

អ្នកដែលប្រឆាំងនឹងព្រះគ្រិស្ត
"ប្រឆាំងនឹងព្រះគ្រិស្ត"

ចូរប្រ័យ្នខ្លួនរបស់អ្នក
«ប្រយ័ត្ន» ឬ «យកចិត្តទុកដាក់»

មិនបាត់បង់អ្វីៗ
«បាត់បង់រង្វាន់នាពេលអនាគតនៅឋានសួគ៌»

រង្វាន់យ៉ាងបរិបូរ
«រង្វាន់នៅស្ថានសួគ៌»

2 John 1:9

អស់អ្នកណាដែលមិននៅជាប់
នេះសំដៅទៅលើមនុស្សម្នាក់ដែលអះអាងថាស្គាល់ព្រះនិងសេចក្ដីពិតច្រើនជាងអ្នកដទៃ។
ការបកប្រែផ្សេងទៀត៖ «អ្នកណាអះអាងថាស្គាល់ព្រះកាន់តែច្បាស់» ឬ
«អ្នកណាដែលមិនគោរពសេចក្ដីពិត» ។

គ្មានព្រះជាម្ចាស់ទេ
«មិនមែនជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់»

អ្នកណាដែលនៅជាប់នឹងសេចក្ដីបង្រៀន អ្នកនោះមានទាំងព្រះវរបិតា និងព្រះបុត្រា
«អ្នកដែលធ្វើតាមការបង្រៀនរបស់ព្រះគ្រិស្តជាកម្មសិទ្ធិរបស់ព្រះវរបិតានិងព្រះរាជបុត្រា»

ព្រះវរបិតា និងព្រះបុត្រា
ទាំងនេះគឺជាឋានៈសំខាន់ៗដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់និងព្រះយេស៊ូ។

ទទួលគេមកក្នុងផ្ទះរបស់អ្នក
នេះមានន័យថាស្វាគមន៍និងគោរពគាត់ដោយកិត្តិយសដើម្បីកសាងទំនាក់ទំនងជាមួយគាត់។

generated on Wed Sep 10 16:16:32 2025

មានចំណែកក្នុងអំពើអាក្រក់របស់គេដែរ
«ចែករំលែកជាមួយគាត់ក្នុងអំពើអាក្រក់របស់គាត់» ឬ
«ជួយគាត់ក្នុងអំពើអាក្រក់របស់គាត់»
2 John 1:12
ឃ្លាភ្ជាប់៖
សំបុត្ររបស់លោកយ៉ូហានបានបញ្ចប់ដោយបំណងប្រាថ្នាចង់មកលេងពួកគេហើយជំរាបសួរពីក្រុមជំនុំ
ព័ត៌មានទូទៅ:
ពាក្យថា «អ្នក» នៅក្នុងខ ១២ គឺជាឯកវចនៈ។ ពាក្យ «របស់អ្នក» នៅក្នុងខ ១៣
គឺពហុវចនៈ។

ខ្ញុំមិនចង់សរសេរទៅកាន់ពួកគេដោយទឹកបិចលើក្រដាស់ឡើយ
លោកយ៉ូហានមិនចង់សរសេរអ្វីផ្សេងទៀតទេតែចង់មកនិយាយពាក្យទាំងនោះ។
គាត់មិននិយាយថាគាត់នឹងសរសេរជាមួយអ្វីផ្សេងក្រៅពីក្រដាសនិងទឹកខ្មៅទេ។
កូនៗរបស់បងស្រីរបស់លោកស្រីដែលព្រះជាម្ចាស់បានជ្រើសរើស
លោកយ៉ូហានសំដៅទៅលើក្រុមជំនុំផ្សេងទៀត
របស់ពួកគេ
ដូចជាកូនរបស់ក្រុមជំនុំនោះដែរ។ បញ្ជាក់ន័យថា
អ្នកជឿទាំងអស់ជាក្រុមគ្រួសារខាងវិញ្ញាណ។

បី យ៉ូហាន

1 [1]ពីចាស់ទុំទៅកាន់លោកកៃយុសជាទីស្រឡាញ់ និងជាអ្នកដែលខ្ញុំស្រឡាញ់នៅក្នុងសេចក្តីពិត[2]បងប្អូនជាទីស្រឡាញ់ ខ្ញុំអធិស្ឋាន
សូមឲ្យអ្នករាល់គ្នាបានចម្រុងចម្រើនក្នុងកិច្ចការទាំងអស់ ហើយមានសុខភាពល្អផង ក៏ដូចជាព្រលឹងរបស់អ្នករាល់គ្នា។[3]ខ្ញុំមានអំណរជាខ្លាំង
នៅពេលដែលបងប្អូនមករកខ្ញុំ ហើយបានធ្វើបន្ទាល់ពីសេចក្តីពិតរបស់អ្នក ក្នុងការដែលអ្នករាល់គ្នាដើរនៅក្នុងសេចក្តីពិតនោះ។[4]ខ្ញុំគ្មានអ្វីមានអំណរលើសជាងនេះទៀតទេ
ក្នុងការឮថាកូនៗរបស់ខ្ញុំដើរក្នុងសេចក្តីពិតនោះ។
[5]បួនជាទីស្រឡាញ់ បួនបានប្រព្រឹត្តតាមសេចក្តីស្មោះត្រង់ ទោះបីជានៅពេលអ្នកបម្រើដល់បងប្អូន
ឬអ្នកដទៃក្តី[6]គេបានធ្វើបន្ទាល់ពីសេចក្តីស្រឡាញ់របស់បួននៅក្នុងចំណោមក្រុមជំនុំ។ ថាបួនបានធ្វើយ៉ាងល្អ ក្នុងការចាត់ពួកគេឲ្យធ្វើដំណើរចេញទៅ
ក្នុងលក្ខណៈជាមនុស្សដែលស័ក្តសមមកពីព្រះជាម្ចាស់ ដោយសារការធ្វើដំណើរចេញទៅនេះ ព្រោះតែព្រះនាមរបស់ព្រះជាម្ចាស់
ពួកគេមិនបានយកអ្វីពីសាសន៍ដទៃទៅជាមួយឡើយ។[8]ដូច្នេះហើយ យើងត្រូវស្វាគមន៍អ្នកទាំងនោះ
ដើម្បីឲ្យយើងអាចក្លាយជាអ្នកមានចំណែកធ្វើការរួមសម្រាប់សេចក្តីពិត។
[9]ខ្ញុំបានសរសេរការខ្លះទៅកាន់ក្រុមជំនុំ ប៉ុន្តែ លោកឌីអូត្រែប ជាអ្នកដែលចូលចិត្តចង់បានមុខមាត់នៅក្នុងចំណោមពួកគេ គាត់មិនបានទទួលយើងទេ។[10]ដូច្នេះហើយ
ប្រសិនបើ ខ្ញុំមក ខ្ញុំនឹងនឹកចាំពីអំពើដែលគាត់បានធ្វើ ពីការដែលគាត់បាននិយាយចំអកមើលងាយទាស់នឹងយើង ជាមួយនឹងពាក្យបង្កាច់បង្ខូចជាច្រើនផង។
មិនត្រឹមតែប៉ុណ្ណឹងទេ គាត់ខ្លួនឯងក៏មិនទទួលបងប្អូន គាត់ថែមទាំងហាមប្រាមបងប្អូនដែលចង់ទទួលយើង ហើយបានបណ្តេញពួកគេចេញពីក្រុមជំនុំថែមទៀតផង។
[11]បួនជាទីស្រឡាញ់ សូមកុំយកតម្រាប់តាមអ្វីដែលអាក្រក់ឡើយ ផ្ទុយទៅវិញ ចូរយកតម្រាប់តាមអ្វីដែលល្អវិញ។ អ្នកណាដែលធ្វើល្អគឺមកពីព្រះជាម្ចាស់ ប៉ុន្តែ
អ្នកណាដែលធ្វើអាក្រក់មិនបានឃើញព្រះជាម្ចាស់ទេ។[12]គេបានធ្វើបន្ទាល់ល្អពីលោកដេមទ្រាសគ្រប់យ៉ាង ថែមទាំងនិយាយការពិតពីគាត់ផង។ យើងក៏ធ្វើបន្ទាល់
ហើយអ្នកក៏ដឹងថាទីបន្ទាល់របស់យើងគឺជាការពិតដែរ។
[13]ខ្ញុំមានកិច្ចការជាច្រើនចង់សរសេរមកកាន់បួន ប៉ុន្តែ ខ្ញុំមិនចង់សរសេរវាមកកាន់បួនដោយបិច ឬទឹកខ្មៅឡើយ។[14]ប៉ុន្តែ ខ្ញុំសង្ឃឹមថានឹងបានជួបបួនឆាប់ៗ
ហើយនឹងនឹងនិយាយគ្នាមុខទល់នឹងមុខ។[15]សូមសេចក្តីសុខសាន្តនៅជាមួយបួន។ មិត្តសំឡាញ់សូមជម្រាប់សួរបួន។ សូមជម្រាប់សួរពួកគេតាមឈ្មោះផង។

3 John 1:1
ឃ្លាភ្ជាប់៖
យ៉ូហានជម្រាបសួរដល់កៃយុស។
ព័ត៌មានទូទៅ:
នេះជាសំបុត្រផ្ទាល់ខ្លួនរបស់យ៉ូហានទៅកៃយុស។ ឧទាពាក្យ «អ្នក» និង
«របស់អ្នក» សំដៅទៅលើកៃយុសហើយមានលក្ខណៈឯកវចនៈ។
ចាស់ទុំ
សំដៅទៅលើយ៉ូហានដែលជាសាវ័កនិងជាសិស្សរបស់ព្រះយេស៊ូ។
គាត់សំដៅទៅលើខ្លួនគាត់ថាជា «ចាស់ទុំ»
ទាដោយសារគាត់មានអាយុចាស់ឬដោយសារគាត់ជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំ។
ឈ្មោះរបស់អ្នកនិពន្ធអាចត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា:
«ខ្ញុំយ៉ូហានជាអ្នកចាស់ទុំកំពុងសរសេរ» ។
កៃយុស
គឺជាបងប្អូនរួមជំនឿរបស់លោកយ៉ូហានដែលកំពុងសរសេរសំបុត្រនេះ។
ជាអ្នកដែលខ្ញុំស្រឡាញ់នៅក្នុងសេចក្តីពិត
អ្នកដែលខ្ញុំស្រឡាញ់ពិតប្រាកដមែន
សូមឲ្យអ្នករាល់គ្នាបានចម្រុងចម្រើនក្នុងកិច្ចការទាំងអស់ ហើយមានសុខភាពល្អផង
«អ្នកអាចធ្វើបានល្អគ្រប់កិច្ចការនិងមានសុខភាពល្អ»
ក៏ដូចជាព្រលឹងរបស់អ្នករាល់គ្នាបានចម្រុងចម្រើនដែរ
«ដូចខាងឯវិញ្ញាណដែលអ្នកមានសុខភាពល្អ»
បងប្អូន
អ្នកដែលមានជំនឿហើយដើរតាម
ធ្វើបន្ទាល់ពីសេចក្តីពិតរបស់អ្នក ក្នុងការដែលអ្នករាល់គ្នាដើរនៅក្នុងសេចក្តីពិតនោះ
«នេះបានប្រាប់ខ្ញុំថាអ្នកកំពុងរស់នៅស្របតាមសេចក្តីពិតរបស់ព្រះ»
កូនរបស់ខ្ញុំ
យ៉ូហាននិយាយអំពីអ្នកដែលគាត់បានបង្រៀនឲ្យជឿលើព្រះយេស៊ូដូចជាពួកគេជាកូនរបស់គាត់
នេះសង្កត់ធ្ងន់លើសេចក្តីស្រឡាញ់និងការយកចិត្តទុកដាក់របស់គាត់ចំពោះពួកគេ។
គាត់ផ្ទាល់ជាអ្នកនាំពួកគេទៅរកព្រះអម្ចាស់។ ការបកប្រែផ្សេងទៀត៖
«កូនខាងឯវិញ្ញាណរបស់ខ្ញុំ»

3 John 1:5
ឃ្លាភ្ជាប់៖
គោលបំណងរបស់យ៉ូហានក្នុងការសរសេរសំបុត្រនេះគឺដើម្បីសរសើរដល់លោកកៃយុស
ដែលបានមើលថែគ្រូដែលជាអ្នកបង្រៀនព្រះគម្ពីរធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ។
បន្ទាប់មកគាត់និយាយអំពីមនុស្សពីរនាក់គឺមួយជាមនុស្សអាក្រក់និងមួយជាមនុស្សល្អ។
ព័ត៌មានទូទៅ:
នៅទីនេះពាក្យ «យើង»
សំដៅទៅលើយ៉ូហាននិងអ្នកដែលនៅជាមួយគាត់ហើយអាចរួមបញ្ចូលអ្នកជឿទាំងអស់។
បួនជាទីស្រឡាញ់
នេះត្រូវបានប្រើជាពាក្យនៃសេចក្តីស្រឡាញ់សម្រាប់អ្នកដែលមានជំនឿហើយដើរតាម។
បួនបានប្រព្រឹត្តតាមសេចក្តីស្មោះត្រង់
«អ្នកកំពុងធ្វើអ្វីដែលស្មោះត្រង់នឹងព្រះ» ឬ «អ្នកស្មោះត្រង់នឹងព្រះ»
បម្រើដល់បងប្អូន ឬអ្នកដទៃក្តី
«ជួយបងប្អូនរួមជំនឿនិងជួយដល់អ្នក ដែលអ្នកមិនស្គាល់»
អ្នកដទៃក្តី គេបានធ្វើបន្ទាល់ពីសេចក្តីស្រឡាញ់របស់បួននៅក្នុងចំណោមក្រុមជំនុំ
«ជនចម្លែកដែលបានប្រាប់អ្នកជឿនៅក្នុងក្រុមជំនុំអំពីរបៀបដែលអ្នកបានស្រឡាញ់ពួកគេ»
បួនបានធ្វើយ៉ាងល្អ ក្នុងការចាត់ពួកគេឲ្យធ្វើដំណើរចេញទៅ
«ខ្ញុំកំពុងស្នើសុំអ្នកឲ្យបញ្ជូនពួកគេ»
ដោយសារការធ្វើដំណើរចេញទៅនេះ ព្រោះតែព្រះនាមរបស់ព្រះជាម្ចាស់
នៅទីនេះ «ឈ្មោះ» សំដៅទៅលើព្រះយេស៊ូ។ ការបកប្រែផ្សេងទៀត៖
«ពីព្រោះពួកគេបានចេញទៅប្រាប់មនុស្សអំពីព្រះយេស៊ូ»
ពួកគេមិនបានយកអ្វី
មិនបានទទួលអំណោយឬជំនួយទេ
សាសន៍ដទៃ
«សាសន៍ដទៃ» មិនត្រឹមតែមានន័យថាមនុស្សដែលមិនមែនជាសាសន៍យូដាទេ។
ប៉ុន្តែក៏ជាការសំដៅអំពីមនុស្សដែលមិនទុកចិត្តលើព្រះយេស៊ូ។
ដើម្បីឲ្យយើងអាចក្លាយជាអ្នកមានចំណែកធ្វើការរួមសម្រាប់សេចក្តីពិត
«ដូច្នេះយើងនឹងសហការជាមួយពួកគេក្នុងការប្រកាសពីសេចក្តីពិតរបស់ព្រះដល់ប្រជាជន»
3 John 1:9

generated on Wed Sep 10 16:16:32 2025

ព័ត៌មានទូទៅ:

ពាក្យថា «យើង»

សំដៅទៅលើលោកយ៉ូហាននិងអ្នកដែលនៅជាមួយគាត់ហើយមិនរាប់បញ្ចូលលោកកៃយុស

ក្រុមជំនុំ

នេះសំដៅទៅលើកៃយុសនិងក្រុមអ្នកជឿដែលបានជួបជុំគ្នាដើម្បីថ្វាយបង្គំព្រះ។

លោកឌីអូត្រែប

គាត់ជាសមាជិកក្រុមជំនុំ។

អ្នកដែលចូលចិត្តចង់បានមុខមាត់នៅក្នុងចំណោមពួកគេ

«អ្នកណាចូលចិត្តធ្វើជាមនុស្សសំខាន់ជាងគេក្នុងចំណោមពួកគេ» ឬ «ចូលចិត្តធ្វើខ្លួនដូចជាគាត់ជាមេដឹកនាំរបស់ពួកគេ»។

ពីការដែលគាត់បាននិយាយចំអកមើលងាយទាស់នឹងយើង ជាមួយនឹងពាក្យបង្កាច់បង្ខូចជាច្រើនផង

«និងរបៀបដែលគាត់និយាយអាក្រក់អំពីយើងដែលមិនមែនជាការពិត»

គាត់ខ្លួនឯង

ពាក្យថា «ខ្លួនគាត់» សំដៅលើលោកឌីអូត្រែប ដែលធ្វើអ្វីទាំងនេះ។

មិនទទួលបងប្អូន

"មិនស្វាគមន៍បងប្អូនរួមជំនឿ"

ហាមប្រាមបងប្អូនដែលចង់ទទួលយើង

«គាត់បានបញ្ឈប់អ្នកដែលចង់ស្វាគមន៍អ្នកជឿ»

ហើយបានបណ្តេញពួកគេចេញពីក្រុមជំនុំថែមទៀតផង

«ហើយគាត់បានបង្ខំឲ្យពួកគេចាកចេញពីក្រុមជំនុំ»

3 John 1:11

ព័ត៌មានទូទៅ:

ពាក្យ «យើង»

សំដៅទៅលើលោកយ៉ូហាននិងអ្នកដែលនៅជាមួយគាត់ហើយមិនរាប់បញ្ចូលលោកកៃយុស

បងប្អូនជាទីស្រឡាញ់

ជាពាក្យនៃសេចក្តីស្រឡាញ់សម្រាប់បងប្អូនរួមជំនឿ។

សូមមើលពីរបៀបដែលអ្នកបានបកប្រែវានៅក្នុងជំពូក ១ ខ ៥ ។

កុំយកតម្រាប់តាមអ្វីដែលអាក្រក់ឡើយ

«កុំចម្លងអំពើអាក្រក់ដែលមនុស្សធ្វើ»

ចូរយកតម្រាប់តាមអ្វីដែលល្អវិញ

មានពាក្យដែលនៅសល់ប៉ុន្តែពួកគេត្រូវបានគេយល់ពាក្យនោះ។

ការបកប្រែផ្សេងទៀត៖ «តែធ្វើត្រាប់តាមអ្វីដែលល្អដែលមនុស្សធ្វើ»

មកពីព្រះជាម្ចាស់

«ជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់»

មិនបានឃើញព្រះជាម្ចាស់ទេ

មិនមែនជារបស់ព្រះ» ឬ «មិនជឿលើព្រះជាម្ចាស់ទេ»

គេបានធ្វើបន្ទាល់ល្អពីលោកដេមេទ្រាសគ្រប់យ៉ាង

នេះអាចត្រូវបានបញ្ជាក់ជាទម្រង់សកម្ម។ ការបកប្រែផ្សេងទៀត៖

«អស់អ្នកដែលស្គាល់ដេមេទ្រាសធ្វើបន្ទាល់អំពីគាត់» ឬ

«អ្នកជឿណាដែលស្គាល់ដេមេទ្រាសនិយាយល្អពីគាត់»

លោកដេមេទ្រាស

នេះប្រហែលជាបុរសម្នាក់ដែលលោកយ៉ូហានចង់អោយកៃយុសនិងក្រុមជំនុំស្វាគមន៍ពេលគាត់មកលេង។

ថែមទាំងនិយាយការពិតពីគាត់ផង

ហើយនិយាយការពិតពីគាត់យ៉ាងច្បាស់។ នៅទីនេះ «សេចក្តីពិត»

ត្រូវបានពិពណ៌នាថាជាមនុស្សម្នាក់ដែលកំពុងនិយាយ។ ការបកប្រែផ្សេងទៀត៖

«ហើយអ្នកដែលដឹងសេចក្តីពិតដឹងថាគាត់ជាមនុស្សល្អ»

យើងក៏ធ្វើបន្ទាល់

ចំពោះលោកយ៉ូហានដែលសំដៅទៅនរណាដែលអាចនិយាយបានហើយអាចបញ្ជាក់យ៉ាងច្បាស់នៅទីនេះ

ការបកប្រែផ្សេងទៀត៖ «យើងក៏និយាយបានល្អដែរពីដេមេទ្រាស»

3 John 1:13

ព័ត៌មានទូទៅ:

នេះជាចុងបញ្ចប់នៃសំបុត្ររបស់លោកយ៉ូហានទៅកៃយុស។

គាត់បានផ្តល់នូវការកត់សម្គាល់ចុងក្រោយនិងការបញ្ចប់ដោយការស្វាគមន៍។

ខ្ញុំមិនចង់សរសេរវាមកកាន់បួនដោយបិច ឬទឹកខ្មៅឡើយ

លោកយ៉ូហានមិនចង់សរសេររឿងផ្សេងទៀតទាល់តែសោះ។

គាត់មិននិយាយថាគាត់នឹងសរសេររវាជាមួយអ្វីផ្សេងក្រៅពីបិចនិងទឹកខ្មៅទេ។

មុខ

«រួមគ្នា» ឬ «ដោយផ្ទាល់»

សូមសេចក្តីសុខសាន្តនៅជាមួយបួន

«សូមព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដល់បងប្អូន»

មិត្តសំឡាញ់សូមជម្រាប់សួរបួន

«មិត្តភក្តិនៅទីនេះស្វាគមន៍ប្អូន»

សូមជម្រាប់សួរពួកគេតាមឈ្មោះផង

សូមជំរាបសួរអ្នកជឿម្នាក់ៗនៅទីនោះផ្ទាល់ជំនួសខ្ញុំផង។

មិត្តសំឡាញ់

«មិត្តភក្តិរបស់អ្នក» ឬ «អ្នកជឿនៅទីនោះ»

យូដាស

1 [1]ខ្ញុំ យូដាស ជាអ្នកបម្រើរបស់ព្រះយេស៊ូគ្រិស្ត និងជាប្អូនរបស់លោកយ៉ាកុប ដែលព្រះជាម្ចាស់ជាព្រះបិតាបានត្រាស់ហៅ និងស្រឡាញ់
ព្រមទាំងបម្រុងទុកសម្រាប់ព្រះយេស៊ូគ្រិស្ត សូមជ្រាប។[2]សូមសេចក្តីមេត្តាករុណា សេចក្តីសុខសាន្ត
និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានចម្រើនឡើងដល់បងប្អូនយ៉ាងបរិបូណ៌។
[3]បងប្អូនជាទីស្រឡាញ់ ខ្ញុំព្យាយាមសរសេរអំពីសេចក្តីសង្គ្រោះមកកាន់បងប្អូន ដើម្បីដាស់តឿនបងប្អូនឲ្យចេះពុះពារការពារជំនឿអស់ពីចិត្ត
ដែលព្រះជាម្ចាស់បានប្រទានមកអ្នកជឿទាំងអស់មួយដងជាសំរេច។[4]ចំពោះអ្នកខ្លះបានបន្លំខ្លួនចូលមកក្នុងចំណោមបងប្អូន។ ពួកគេស្វែងរកឱកាសថ្កោលទោស។
ពួកគេជាមនុស្សមិនគោរពប្រណិប័តន៍ព្រះជាម្ចាស់ ដែលបង្ខូចព្រះគុណព្រះអង្គជារឿងអាសអាភាស និងបដិសេធមិនទទួលស្គាល់ព្រះយេស៊ូគ្រិស្តជាចៅហ្វាយ
និងជាព្រះអម្ចាស់នៃយើង។
[5]ឥឡូវនេះខ្ញុំចង់រំឭកបងប្អូនជាថ្មីម្តងទៀត ទោះបីជាបងប្អូនបានដឹងច្បាស់ហើយក៏ដោយថា ព្រះអម្ចាស់បានសង្គ្រោះអ៊ីស្រាអែលចេញពីប្រទេសអេស៊ីប ប៉ុន្តែក្រោយ
មកទៀត ទ្រង់បានបំផ្លាញអស់ពួកអ្នកមិនព្រមជឿ។[6]ទេវតាពុំបានរក្សាមុខតំណែងរបស់ខ្លួនឡើយ តែបែរជាចាកចោលលំនៅដ្ឋានរបស់ខ្លួន
ព្រះជាម្ចាស់ឃុំពួកគេដាក់ច្រវាក់ជាប់រឿងរហូតនៅទីងងឹត រង់ចាំថ្ងៃព្រះជាម្ចាស់វិនិច្ឆ័យទោសដ៏អស្ចារ្យ។
[7]ដូចជាទីក្រុងសូដុម ក្រុងកូម៉ូរ៉ា និងក្រុងឯទៀតៗដែលនៅជុំវិញ ពួកអ្នកក្រុងបណ្តោយខ្លួនប្រព្រឹត្តអំពើប្រាសចាកសីលធម៌ និងរួមបវេណីខុសពីធម្មជាតិ។
ពួកគេទទួលទណ្ឌកម្មក្នុងបឹងភ្លើងឆេះអស់កល្ប ទុកជាការព្រមានដល់អ្នកឯទៀតៗ។[8]ដូចគ្នានេះដែរ ពួកអ្នករវើរវាយទាំងនេះធ្វើឲ្យរូបកាយពួកគេទៅជាសៅហ្មង។
ពួកគេបដិសេធសិទ្ធិអំណាច និងជេរប្រមាថពួកទេវតាប្រកបដោយសិរីរុងរឿងទៅវិញ។
[9]សូម្បីតែមហាទេវតាមីកែល ពេលឈ្លោះប្រកែកជាមួយមារសត្រូវអំពីសពរបស់លោកម៉ូសេ ក៏លោកពុំហ៊ានជេរប្រមាថដែរ។ លោកគ្រាន់តែពោលថា៖
«សូមព្រះជាម្ចាស់ដាក់ទោសឯង!»[10]ប៉ុន្តែ ពួកទាំងនេះជេរប្រមាថអ្វីៗ ដែលខ្លួនពុំស្គាល់។ ហើយពួកគេយល់ដឹងតាមតែសភាវគតិដូចសត្វតិរច្ឆាន
ដែលនាំឲ្យខ្លួនវិនាសតែប៉ុណ្ណោះ។[11]ពួកគេត្រូវវិនាសហើយ! ព្រោះតែបានដើរតាមផ្លូវរបស់លោកកាអ៊ីន និងបណ្តោយខ្លួនឲ្យវង្វេងតាមលោកបាឡាម។
ពួកគេត្រូវវិនាសដូចការបះបោររបស់លោកកូរេ។
[12]ពួកគេធ្វើឲ្យល្អក់កករ ពេលបរិភោគអាហាររួមគ្នាដោយក្តីស្រឡាញ់។ ពួកគេបរិភោគឥតអៀនខ្មាស ចម្អែតតែក្រពះខ្លួនឯង។ ប្រៀបបីដូចជាពពកគ្មានភ្លៀង
បោកបក់ផាត់តាមខ្យល់។ ជាដើមឈើឥតផ្លែតាមរដូវ រលើងដល់ឫសងាប់ពីរដង។[13]ពួកគេប្រៀបបីដូចជារលកសមុទ្របោកបក់ខ្លាំងៗ បែកពពុះគ្មានអៀនខ្មាសអ្វីឡើយ។
ប្រៀបបីដូចជាផ្កាយវង្វេងទិស ដែលព្រះជាម្ចាស់បម្រុងទុកនៅទីងងឹតសូន្យសុង។
[14]លោកហេណុកជាបុព្វបុរសតំណទីប្រាំពីរក្រោយពីលោកអដាំ បានថ្លែងទំនាយអំពីអ្នកទាំងនោះថា៖ «មើល!
ព្រះអម្ចាស់នឹងយាងមកជាមួយប្រជាជនដ៏វិសុទ្ធមានចំនួនអនេកអនន្ត។[15]ព្រះអង្គនឹងយាងមកវិនិច្ឆ័យទោសមនុស្សគ្រប់គ្នា។
ទ្រង់នឹងវិនិច្ឆ័យទោសមនុស្សដែលមិនគោរពប្រណិប័តន៍ព្រះជាម្ចាស់ ចំពោះទង្វើអាក្រក់ដែលពួកគេបានប្រព្រឹត្ត

generated on Wed Sep 10 16:16:32 2025

និងពាក្យសម្តីដែលមនុស្សបាបប្រឆាំងទាស់នឹងព្រះអង្គ»។[16]ពួកគេជាមនុស្សរអ៊ូរទាំ និងមិនសប្បាយចិត្ត ដែលប្រព្រឹត្តតាមចិត្តលោភលន់របស់ខ្លួន។
ពួកគេជាមនុស្សអួតបំប៉ោង រកប្រយោជន៍ផ្ទាល់ខ្លួន និងបញ្ចើចបញ្ចើអ្នកដទៃ។
[17]ចំពោះបងប្អូនជាទីស្រឡាញ់វិញ ចូរនឹកចាំពីពាក្យប្រៀនប្រដៅរបស់ពួកសាវករបស់ព្រះយេស៊ូគ្រិស្តកាលពីមុន។[18]អ្នកទាំងនោះប្រាប់អ្នករាល់គ្នាថា៖
«នៅគ្រាចុងក្រោយបំផុត នឹងមានពួកចំអកឡកឡឺយ ប្រព្រឹត្តតាមចិត្តលោភលន់របស់ខ្លួន»។[19]ពួកគេជាមេបង្កការបែកបាក់។ ពួកគេជាមនុស្សលោកីយ៍
និងគ្មានព្រះវិញ្ញាណគង់នៅជាមួយ។
[20]ចំពោះបងប្អូនវិញ បងប្អូនជាទីស្រឡាញ់អើយ ចូរកសាងខ្លួនលើជំនឿដ៏វិសុទ្ធបំផុត និងអធិស្ឋានតាមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
[21]ចូរស្ថិតនៅជាប់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ទាំងទន្ទឹងរង់ចាំព្រះហឫទ័យមេត្តាករុណារបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត
ដែលនាំយើងឲ្យទទួលបានជីវិតអស់កល្បជានិច្ចវិញ។
[22]ចូរមានចិត្តមេត្តាដល់បងប្អូនណា ដែលមានចិត្តសង្ស័យ។[23]ចូរសង្គ្រោះមនុស្សដទៃ ដោយអូសគេចេញពីភ្លើង។ ចូរមានចិត្តមេត្តាចំពោះមនុស្សដទៃ ដោយការភ័យខ្លាច។
សូម្បីតែប៉ះពាល់អាវពួកគេ ក៏នាំឲ្យយើងឥតសៅហ្មងដែរ។
[24]ឥឡូវនេះ ព្រះជាម្ចាស់អាចការពារបងប្អូនមិនឲ្យជំពប់ជើងដួល និងរក្សាបងប្អូនឲ្យមានជំហររឹងប៉ឹង នៅចំពោះវត្តមានពេញដោយសិរីរុងរឿង ឥតកន្លែងបន្តោស
និងអំណរពេញលេញ។[25]ព្រះជាម្ចាស់តែមួយអង្គគត់ ជាព្រះសង្គ្រោះនៃយើង តាមរយៈព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង សូមថ្វាយសិរីរុងរឿង បារមី និង ព្រះចេស្តា
មុនពេលមានអ្វីទាំងអស់ ពេលឥឡូវនេះ និងអស់កល្បតរៀងរហូត។ អាម៉ែន!

Jude 1:1
ព័ត៌មានទូទៅ
យូដាបានបញ្ជាក់ខ្លួនឯងថាជាអ្នកសរសេរសំបុត្រនេះហើយស្វាគមន៍អ្នកអាន។
គាត់ប្រហែលជាប្អូនប្រុសរបស់ព្រះយេស៊ូ។
មានចៅក្រមពីរនាក់ផ្សេងទៀតដែលបានរៀបរាប់នៅក្នុងសម្ពន្ធមេត្រីថ្មី។
ព័ត៌មានទូទៅ
ពាក្យ «អ្នក»
នៅក្នុងលិខិតនេះសំដៅទៅលើគ្រិស្តបរិស័ទដែលយូដាសកំពុងសរសេរហើយតែងតែប្រើពហុវចនៈ។
យូដាស ជាអ្នកបម្រើរបស់
យូដាសជាបងប្អូនរបស់យ៉ាកុប។ ការបកប្រែផ្សេងទៀត៖
«ខ្ញុំគឺជាយូដាសជាអ្នកបម្រើរបស់»
និងជាបងប្អូនរបស់លោកយ៉ាកុប
យ៉ាកុប និងយូដាសគឺជាបងប្អូនរបស់ព្រះយេស៊ូ។
សូមសេចក្តីមេត្តាករុណា សេចក្តីសុខសាន្ត
និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានចម្រើនឡើងដល់បងប្អូនយ៉ាងបរិបូណ៌
«សូមសេចក្តីមេត្តាករុណា សេចក្តីសុខសាន្ត និងសេចក្តីស្រឡាញ់
កើនច្រើនដងដល់អ្នក»
គំនិតទាំងនេះត្រូវបានគេនិយាយដូចជាវត្ថុដែលអាចជាទំហំ ឬលេខ។
Jude 1:3
ឃ្លាភ្ជាប់៖
យូដាសប្រាប់អ្នកជឿនូវមូលហេតុដែលគាត់សរសេរសំបុត្រនេះ។
ព័ត៌មានទូទៅ
ពាក្យ «យើង» នៅក្នុងសំបុត្រនេះសំដៅលើយូដាសនិងអ្នកជឿផ្សេងទៀត។
សេចក្តីសង្គ្រោះរបស់យើង
សេចក្តីសង្គ្រោះដែលយើងប្រាប់គេ។
ខ្ញុំត្រូវតែសរសេរ
«ខ្ញុំមានអារម្មណ៍ថាចាំបាច់ត្រូវតែសរសេរ» ឬ
«ខ្ញុំមានអារម្មណ៍ថាចាំបាច់បន្ទាន់ត្រូវតែសរសេរ»
ដើម្បីដាស់តឿនបងប្អូនឲ្យចេះពុះពារការពារជំនឿអស់ពីចិត្ត
«ដើម្បីលើកទឹកចិត្តអ្នកឲ្យការពារការបង្រៀនពិត»
អ្នកជឿ
«ពួកដ៏វិសុទ្ធ» ការបកប្រែខ្លះបកប្រែថា «អ្នកដ៏វិសុទ្ធ» ។
វាផ្តល់នូវគំនិតដល់គ្រិស្តបរិស័ទដែលជឿដោយមិនផ្តោតលើអារម្មណ៍
ជាពិសេសទៅលើសីលធម៌របស់ពួកគេ
ប៉ុន្តែផ្ទុយទៅវិញអ្នកជឿដែលត្រូវបានធ្វើឲ្យទៅជាពួកដ៏វិសុទ្ធដោយជំនឿលើការសុគតរបស់ព្រះយេស៊ូ
ចំពោះអ្នកខ្លះបានបន្លំខ្លួនចូលមកក្នុងចំណោមបងប្អូន
«អ្នកខ្លះបានចូលមកក្នុងចំណោមអ្នកជឿដោយមិនយកចិត្តទុកដាក់លើខ្លួនឯង»
ពួកគេស្វែងរកឱកាសថ្កោលទោស
នេះក៏អាចជាទំរង់សកម្មផងដែរ"មនុស្សដែលព្រះបានជ្រើសរើសដើម្បីថ្កោលទោស"
អ្នកដែលបង្ខូចព្រះគុណព្រះអង្គជារឿងអាសអាភាស
ព្រះគុណរបស់ព្រះជាម្ចាស់ត្រូវបានគេនិយាយដូចជារឿងដែលអាចត្រូវបានផ្លាស់ប្តូរទៅជា
ការបកប្រែផ្សេងទៀត៖
«អ្នកដែលប្តូរព្រះគុណរបស់ព្រះជាម្ចាស់របស់យើងឲ្យទៅជាតណ្ហាដ៏កខ្វក់” ឬ“
បង្រៀនគេថាព្រះគុណរបស់ព្រះអនុញ្ញាតឲ្យមនុស្សម្នាក់បន្តរស់នៅក្នុងអំពើបាបខាងផ្លូវភេទ»
បដិសេធមិនទទួលស្គាល់ព្រះយេស៊ូគ្រិស្តជាចៅហ្វាយ និងជាព្រះអម្ចាស់នៃយើង
អត្ថន័យដែលអាចមានគឺ ១) ពួកគេបង្រៀនថាទ្រង់មិនមែនជាព្រះឬ ២)
បុរសទាំងនេះមិនគោរពតាមព្រះយេស៊ូគ្រិស្តទេ។
Jude 1:5
ឃ្លាភ្ជាប់៖
យូដាសផ្តល់ឧទាហរណ៍កាលពីមុនពីអ្នកដែលមិនធ្វើតាមព្រះអម្ចាស់។
ខ្ញុំចង់រំឭកបងប្អូន
«ខ្ញុំចង់ឲ្យ អ្នកចងចាំ»
ដែលបានដឹងច្បាស់ហើយក៏ដោយ
អាចមានន័យៈ ១) ពាក្យ «ម្តង ... ពេញលេញ»
ប្រាប់ពីរបៀបដែលអ្នកអានបានដឹងឬ ២)
«ទោះបីនៅពេលមួយអ្នកដឹងរឿងនេះក៏ដោយ»
ព្រះអម្ចាស់បានសង្គ្រោះមនុស្សចេញពីប្រទេសអេស៊ីប
«ព្រះអម្ចាស់បានរំដោះជនជាតិអ៊ីស្រាអែលតាំងពីយូរយារណាស់មកហើយចេញពីស្រុកអេស៊ីប»
ព្រះអម្ចាស់
អត្ថបទខ្លះអាន «ព្រះយេស៊ូ»
រក្សាមុខតំណែងរបស់ខ្លួនឡើយ
«ទំនួលខុសត្រូវដែលព្រះបានប្រគល់ឲ្យពួកគេ»
ចាកចោលលំនៅដ្ឋានរបស់ខ្លួន
«បោះបង់កន្លែងដែលគេបានប្រគល់ឲ្យដោយខ្លួនឯង»
ព្រះជាម្ចាស់ឃុំពួកគេដាក់ច្រវាក់ជាប់រៀងរហូតនៅទីងងឹត
«ព្រះជាម្ចាស់បានដាក់ពួកទេវតាទាំងនេះនៅក្នុងគុកងងឹតដែលពួកគេមិនអាចគេចខ្លួនបាន»។
ថ្ងៃដ៏អស្ចារ្យ
ថ្ងៃចុងក្រោយដែលព្រះនឹងវិនិច្ឆ័យទោសមនុស្សទាំងអស់
Jude 1:7
ប្រព្រឹត្តអំពើប្រាសចាកសីលធម៌
អំពើបាបខាងផ្លូវភេទនៅសូដុមនិងកូម៉ូរ៉ាគឺជាលទ្ធផលនៃការបះបោរដូចគ្នានឹងផ្លូវអាក្រក់របស់ពួកទេវតា។
ប្រព្រឹត្តអំពើប្រាសចាកសីលធម៌
នៅទីនេះ «ទីក្រុង» តំណាងឲ្យប្រជាជនដែលរស់នៅក្នុងពួកគេ។
ព្រះបានបង្ហាញពួកគេ
វាបញ្ជាក់ថាព្រះបានបង្ហាញពួកគេជាគំរូ។ «ព្រះបានបង្ហាញពួកគេ»
ពួកគេទទួលទណ្ឌកម្មក្នុងបឹងភ្លើងឆេះអស់កល្ប ទុកជាការព្រមានដល់អ្នកឯទៀតៗ
ការបំផ្លាញប្រជាជននៅក្រុងសូដុមនិងកូម៉ូរ៉ាបានក្លាយជាគំរូសម្រាប់ជោគវាសនារបស់មនុស្សទាំងអស់ដែ
ពួកអ្នករវើរវាយ
មនុស្សដែលមិនគោរពព្រះដោយសារពួកគេអះអាងថាពួកគេបានឃើញនិមិត្ត
ដែលបានផ្តល់សិទ្ធិអំណាចដោយព្រះ
រូបកាយពួកគេទៅជាសៅហ្មង
ការប្រៀបធៀបនេះប្រាប់ថា អំពើបាបរបស់ពួកគេបង្កើតរូបកាយរបស់ពួកគេ -
ជាសកម្មភាពរបស់ពួកគេ - ប្រៀបដូចសម្រាមធ្វើឲ្យទឹកកខ្វក់មិនអាចផឹកបាន។
ជេរប្រមាថ
«និយាយប្រមាថ»
ដែលគួរតែមានសិទ្ធិអំណាច
នេះសំដៅទៅលើមនុស្សខាងវិញ្ញាណដូចជាទេវតា។
Jude 1:9
ព័ត៌មានទូទៅ:
បាឡាមគឺជាហោរាម្នាក់ដែលបដិសេធមិនដាក់បណ្តាសាអ៊ីស្រាអែលចំពោះខ្មាំងសត្រូវ

generated on Wed Sep 10 16:16:32 2025

ប៉ុន្តែក្រោយមកគាត់បានបង្រៀនខ្មាំងសត្រូវគឺ
ឲ្យប្រជាជនរៀបការជាមួយអ្នកមិនជឿហើយក្លាយជាអ្នកគោរពបូជារូបព្រះក្លែងក្លាយ។

ព័ត៌មានទូទៅ:

កូរេជាបុរសជនជាតិអ៊ីស្រាអែលដែលបានបះបោរប្រឆាំងនឹងការដឹកនាំរបស់ម៉ូសេ
និងអើរ៉ុន។

ប្រកែកជាមួយមារ

«ឈ្លោះជាមួយមារ»

មិនហ៊ាននាំ

«គ្រប់គ្រងខ្លួនឯង គាត់មិនបាននាំយក» ឬ «មិនមានឆន្ទៈក្នុងការនាំយកមក»

ពុំហ៊ានជេរប្រមាថ

«ការវិនិច្ឆ័យនិយាយអាក្រក់» ឬ «ការវិនិច្ឆ័យអាក្រក់»

ពួកទាំងនេះ

មនុស្សទុច្ចរិត

ពួកទាំងនេះជេរប្រមាថ

«មនុស្សទាំងនេះនិយាយអាក្រក់ពីរឿងមិនពិតអំពីពួកគេ»

អ្វីៗ ដែលខ្លួនពុំស្គាល់

អ្វីទាំងអស់ដែលពួកគេមិនដឹងអត្ថន័យ។ អត្ថន័យដែលអាចមានគឺ ១)
«អ្វីៗដែលល្អដែលពួកគេមិនយល់» ឬ ២) «សិរីរុងរឿងដែលពួកគេមិនយល់» (១:
៧) ។

ផ្លូវរបស់លោកកាអ៊ីន

កាអ៊ីនបានសម្លាប់ប្អូនប្រុសរបស់គាត់ ហើយមិនបានរស់នៅសម្រាប់ព្រះទេ។

Jude 1:12

ឃ្លាភ្ជាប់៖

យូដាសប្រើពាក្យប្រៀបធៀបជាច្រើនដើម្បីពិពណ៌នាអំពីបុរសទុច្ចរិត។
គាត់ប្រាប់អ្នកជឿអំពីរបៀបស្គាល់បុរសទុច្ចរិតទាំងនេះនៅពេលគេស្ថិតក្នុងចំណោមពួកគេ។

ពួកគេ

ពាក្យថា «ទាំងនេះ» សំដៅទៅលើ «មនុស្សដែលមិនគោរពព្រះ» នៃ ១: ៣ ។

ធ្វើឲ្យល្អក់កករ

ថ្មប៉ប្រះទឹកគឺជាថ្មធំ ៗ ដែលនៅជិតផ្ទៃទឹកនៅសមុទ្រ។

ដោយសារតែនាវិកមិនអាចមើលឃើញថ្មនោះពួកគេមានគ្រោះថ្នាក់ខ្លាំងណាស់។
កប៉ាល់អាចត្រូវបំផ្លាញយ៉ាងងាយស្រួលប្រសិនបើពួកគេបុកថ្មទាំងនេះ។

ដើមឈើឥតផ្លែ

អត្ថន័យដែលអាចទៅរួចគឺថាប្រជាជនទាំងនេះគឺដូចជា ១) ដើមឈើ
ដែលមនុស្សរំពឹងថានឹងប្រមូលផលប៉ុន្តែពួកគេគ្មាន ឬ ២)
ដើមឈើដែលមិនដែលបង្កើតផលផ្លែ។

ផ្លែ

នេះជាពាក្យប្រៀបធៀបមួយសម្រាប់ជីវិតដែលគាប់ព្រះហឫទ័យព្រះ
និងជួយអ្នកដទៃ។

រលើងដល់ឫសងាប់ពីរដង

ដើមឈើដែលមានគេដកឬគឺជាពាក្យប្រៀបធៀបសម្រាប់សេចក្តីស្លាប់។

រលើងដល់ឫស

ដូចជាដើមឈើដែលត្រូវបានទាញចេញពីដីដោយឫសរបស់វាមនុស្សដែល ។
ដូចមនុស្សមិនគោរពព្រះបានឃ្លាតឆ្ងាយពីព្រះដែលជាប្រភពនៃជីវិត។

ពួកគេប្រៀបបីដូចជារលកសមុទ្របោកបក់ខ្លាំង

នៅពេលរលកសមុទ្របក់បោកដោយខ្យល់បក់ខ្លាំងដូច្នេះមនុស្សទុច្ចរិតងាយនឹងផ្លាស់ទេ

គ្មានអៀនខ្មាសអ្វីឡើយ

ដូចជាខ្យល់បក់ធ្វើឲ្យដីហុយឡើងមក -
ដូច្នេះបុរសទាំងនេះតាមរយៈការបង្រៀននិងសកម្មភាពមិនពិតរបស់ពួកគេធ្វើឲ្យមួកគេ

ការបកប្រែផ្សេងទៀត៖

«ដូចជារលកនាំមកនូវស្មោនិងភាពកខ្វក់បុរសទាំងនេះបំពុលអ្នកដទៃដោយភាពអាម៉ាស

ផ្កាយវង្វេងទិស

អ្នកដែលសិក្សាអំពីផ្កាយនៅសម័យបុរាណបានកត់សម្គាល់ថាអ្វីដែលយើងហៅថាភព
ការបកប្រែផ្សេងទៀត៖ «ផ្កាយអសកម្ម» ឬ «ផ្កាយផ្លាស់ប្តូរ»

ប្រៀបបីដូចជាផ្កាយវង្វេងទិស ដែលព្រះជាម្ចាស់បម្រុងទុកនៅទីងងឹតសូន្យសុង។

«ផ្កាយ
ចំពោះពួកគេព្រះជាម្ចាស់បានដាក់កន្លែងនៃភាពងងឹតទាំងស្រុងជាកន្លែងដែលព្រះអង្គនឹង

Jude 1:14

បុព្វបុរសតំណទីប្រាំពីរក្រោយពីលោកអដាំ

ប្រសិនបើអាដាំត្រូវបានរាប់ជាមនុស្សជំនាន់ទី ១ អេណុកគឺជាមនុស្សទី ៧ ។

ប្រសិនបើកូនប្រុសរបស់អាដាំត្រូវបានរាប់ជាជំនាន់ទីមួយនោះអេណុកស្ថិតនៅលំដាប់ទីប្រាំមួយ។

ចែល

«ស្តាប់» ឬ «យកចិត្តទុកដាក់លើរឿងសំខាន់នេះដែលខ្ញុំនឹងនិយាយ»

វិនិច្ឆ័យទោស

«ដើម្បីធ្វើការវិនិច្ឆ័យលើ» ឬ «ដើម្បីវិនិច្ឆ័យ»

មនុស្សរអ៊ូរទាំ និងមិនសប្បាយចិត្ត

មនុស្សដែលមិនចង់ស្តាប់បង្គាប់ពួកគេនិយាយប្រឆាំងនឹងអំណាចគ្រប់គ្រងរបស់ព្រះ។

«អ្នករអ៊ូរទាំ» មានទំនោរនិយាយស្ងាត់ ៗ ខណៈពេលដែល «អ្នកតួញតែ្ពរ»
និយាយដោយបើកចំហ។

មនុស្សអួតបំប៉ោង

មនុស្សដែលសរសើរខ្លួនឯងដើម្បីឲ្យអ្នកដទៃស្តាប់។

បញ្ឆើចបញ្ឆើអ្នកដទៃ

«ផ្តល់ការសរសើរមិនពិតដល់អ្នកដទៃ»

Jude 1:17

ពួកគេ

«អ្នកចំអក»

ប្រព្រឹត្តតាមចិត្តលោភលន់របស់ខ្លួន

មនុស្សទាំងនេះនិយាយពីបំណងប្រាថ្នារបស់ពួកគេគឺជាស្តេចដែលគ្រប់គ្រងលើពួកគេ។

ការបកប្រែផ្សេងទៀត៖

«មិនអាចបញ្ឈប់ការប្រមាថព្រះជាម្ចាស់ដោយការធ្វើអំពើអាក្រក់ដែលពួកគេចង់ធ្វើ»។

ប្រព្រឹត្តតាមចិត្តរបស់ខ្លួន

សេចក្តីប៉ងប្រាថ្នាមិនគោរពព្រះគឺធ្វើដូចខ្លួនជាផ្លូវដែលមនុស្សម្នាក់ដើរតាម។

លោកីយ៍

គិតដូចមនុស្សទុច្ចរិតដទៃទៀតគិត។

ពាក្យ

ពួកគេឲ្យតម្លៃទៅលើអ្វីដែលអ្នកមិនជឿឲ្យតម្លៃ។

គ្មានព្រះវិញ្ញាណគង់នៅជាមួយ

ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវបានគេនិយាយដូចជាគាត់គឺជាអ្វីដែលមនុស្សអាចមាន។

Jude 1:20

ឃ្លាភ្ជាប់៖

យូដាសប្រាប់អ្នកជឿអំពីរបៀបដែលពួកគេគួររស់នៅនិងរបៀបដែលពួកគេគួរប្រព្រឹត្តចំពោះអ្នកដទៃ។

ចំពោះបងប្អូនវិញ បងប្អូនជាទីស្រឡាញ់អើយ ចូរកសាងខ្លួន

ការក្លាយជាមនុស្សដែលអាចជឿទុកចិត្តលើព្រះកាន់តែខ្លាំងឡើងហើយស្តាប់បង្គាប់ទ្រង់ត្រូវបានគេនិយាយ

«កុំធ្វើដូចពួកគេឡើយ បងប្អូនជាទីស្រឡាញ់ហើយ។
ផ្ទុយទៅវិញអ្នកត្រូវកសាងខ្លួនអ្នក»

ទន្ទឹងរង់ចាំ

«ទន្ទឹងរងចាំយ៉ាងអន្ទះសារ»

ចូរស្ថិតនៅជាប់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

នៅតែអាចទទួលសេចក្តីស្រឡាញ់របស់ព្រះគឺនិយាយអំពីមនុស្សម្នាក់បានរក្សាខ្លួនឯងនៅកន្លែងជាក់លាក់

ព្រះហឫទ័យមេត្តាករុណារបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត

ដែលនាំយើងឲ្យទទួលបានជីវិតអស់កល្បជានិច្ចវិញ។

ត្រង់នេះ «មេត្តាករុណា»

តំណាងឲ្យព្រះយេស៊ូគ្រិស្តផ្ទាល់ដែលនឹងបង្ហាញសេចក្តីមេត្តាករុណារបស់ទ្រង់ដល់អ្នកជឿដោយធ្វើឲ្យពួក

Jude 1:22

បងប្អូនណា ដែលមានចិត្តសង្ស័យ

ការបកប្រែផ្សេងទៀត៖

សង្គ្រោះមនុស្សដទៃ ដោយអូសគេចេញពីភ្លើង

នេះកំពុងធ្វើសម្រាប់អ្នកដទៃទៀតនូវអ្វីដែលត្រូវធ្វើដើម្បីការពារពួកគេពីការស្លាប់ដោយគ្មានព្រះគ្រិស្ត

ចូរមានចិត្តមេត្តាចំពោះមនុស្សដទៃ

សូម្បីតែប៉ះពាល់អាវពួកគេ ក៏នាំឲ្យយើងឥតសៅហ្មងដែរ

ដែលមនុស្សអាចមានជំងឺដោយប៉ះសម្លៀកបំពាក់របស់ពួកគេ។

ការបកប្រែផ្សេងទៀត“

ប្រព្រឹត្តលើពួកគេដូចជាអ្នកមានទោសពីអំពើបាបដោយគ្រាន់តែប៉ះសម្លៀកបំពាក់របស់ពួកគេ”

ឃ្លាភ្ជាប់៖

យូដាសបញ្ចប់ដោយពរ។

រក្សាបងប្អូនឲ្យមានជំហររឹងប៉ឹង នៅចំពោះវត្តមានពេញដោយសិរីរុងរឿង

generated on Wed Sep 10 16:16:32 2025

សិរីរុងរឿងរបស់ព្រះអង្គគឺជាពន្លឺដ៏អស្ចារ្យដែលតំណាងភាពអស្ចារ្យរបស់ព្រះអង្គ។
ការបកប្រែផ្សេងទៀត៖
«និងអនុញ្ញាតឲ្យយើងរីករាយនិងថ្វាយបង្គំសិរីរុងរឿងរបស់ព្រះអង្គ»។
ឥតកន្លែងបន្ទោស
នៅទីនេះអំពើបាបត្រូវបានគេនិយាយថា ៖
វាជាភាពកខ្វក់លើរាងកាយរបស់មនុស្សម្នាក់
ឬគុណវិបត្តិនៅលើរាងកាយរបស់មនុស្សម្នាក់។ ការបកប្រែផ្សេងទៀត៖
«កន្លែងដែលអ្នកនឹងគ្មានបាប»
ព្រះជាម្ចាស់តែមួយអង្គគត់ ជាព្រះសង្គ្រោះនៃយើង តាមរយៈព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង
«ព្រះតែមួយគត់ដែលបានសង្គ្រោះយើងដោយសារអ្វីដែលព្រះយេស៊ូគ្រិស្តបានធ្វើ»
។ នេះបញ្ជាក់ថាព្រះបិតាក៏ដូចជាព្រះរាជបុត្រាគឺជាព្រះអង្គសង្គ្រោះ។
សូមថ្វាយសិរីរុងរឿង បារមី និង ព្រះចេស្តា មុនពេលមានអ្វីទាំងអស់ ពេលឥឡូវនេះ
និងអស់កល្បតរៀងរហូត
ព្រះជាម្ចាស់តែងតែមាន ឥឡូវនេះហើយតែងតែមានសិរីរុងរឿង
ភាពជាអ្នកដឹកនាំដាច់ខាតនិងគ្រប់គ្រងលើអ្វីៗទាំងអស់។

វិវរណៈ

1 [1]នេះគឺជាការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត ដែលព្រះជាម្ចាស់បានប្រទានដល់ព្រះអង្គ ដើម្បីបង្ហាញដល់អ្នកបម្រើរបស់ព្រះអង្គ នូវអ្វីដែលនឹងត្រូវកើតឡើងជាឆាប់។
ព្រះអង្គធ្វើឲ្យពួកគេដឹងដោយសារព្រះអង្គចាត់ទេវតារបស់ព្រះអង្គដល់អ្នកបម្រើរបស់ព្រះអង្គគឺលោកយ៉ូហាន។
[2]លោកយ៉ូហានបានធ្វើបន្ទាល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងធ្វើបន្ទាល់អំពីព្រះយេស៊ូគ្រិស្ត ពីអ្វីគ្រប់យ៉ាងដែលគាត់បានឃើញ។
[3]មានពរហើយអស់អ្នកណាដែលបានអាន និងអស់អ្នកដែលស្តាប់ពាក្យទំនាយនេះ និងអស់អ្នកដែលស្តាប់បង្គាប់តាមអ្វីដែលបានសរសេរនៅក្នុងនេះ
ព្រោះពេលកំណត់ជិតមកដល់ហើយ។
[4]ខ្ញុំ យ៉ូហាន ជូនចំពោះក្រុមជំនុំទាំងប្រាំពីរនៅក្នុងអាស៊ី៖ សូមព្រះគុណនៅជាមួយអ្នករាល់គ្នា និងសេចក្តីសុខសាន្តពីព្រះអង្គដែលគង់នៅសព្វថ្ងៃ និងពីដើម
និងព្រះអង្គដែលនឹងយាងមក ព្រមទាំងពីវិញ្ញាណទាំងប្រាំពីរដែលគង់នៅមុខបល្ល័ង្ករបស់ព្រះអង្គ[5]និង ពីព្រះយេស៊ូគ្រិស្ត ដែលជាបន្ទាល់ដ៏ស្មោះត្រង់
និងជាព្រះដែលជាផលដំបូងនៃការកើតឡើងវិញពីពួកមនុស្សស្លាប់ និងជាស្តេចគ្រប់គ្រងនៅលើផែនដី។ ថ្វាយដល់ព្រះដែលស្រឡាញ់យើង
ហើយបានដោះយើងឲ្យរួចពីបាបដោយសារព្រះលោហិតរបស់ព្រះអង្គ[6]ទ្រង់បានធ្វើឲ្យយើងក្លាយជាអាណាចក្រ ធ្វើជាបូជាចារ្យសម្រាប់ព្រះរបស់ព្រះអង្គ និងព្រះបិតា
ថ្វាយសិរីរុងរឿងដល់ព្រះអង្គ និងចេស្តាជារៀងរហូតតទៅ! អាម៉ែន។
[7]មើល៍ ព្រះអង្គកំពុងតែយាងមកនៅលើពពក ភ្នែកទាំងអស់នឹងឃើញព្រះអង្គ បូករួមទាំងអ្នកដែលបានចាក់ព្រះអង្គដែរ។ គ្រប់ទាំងជាតិសាសន៍នៅលើផែនដីនឹងយំសោក
ដោយសារតែព្រះអង្គ។ មែន! អាម៉ែន។[8]ព្រះអម្ចាស់មានបន្ទូលថា៖ «ខ្ញុំជាអាល់ផា និងជាអូមេកា» (ព្រះដែលគង់នៅសព្វថ្ងៃ និងពីដើម និងព្រះដែលនឹងយាងមក
ពេញដោយព្រះចេស្តា)។
[9]ខ្ញុំ យ៉ូហាន ជាបងប្អូន និងជាម្នាក់ដែលរួមចំណែកជាមួយបងប្អូននៅក្នុងទុក្ខលំបាក និងព្រះរាជ្យ ព្រមទាំងអត់ធ្មត់ស៊ូទ្រាំនៅក្នុងព្រះយេស៊ូ
ដែលត្រូវនិរទេសទៅកោះមួយដែលហៅថា ប៉ាតម៉ុស ដោយសារតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងទីបន្ទាល់អំពីព្រះយេស៊ូ។
[10]ខ្ញុំបាននៅក្នុងថ្ងៃរបស់ព្រះអម្ចាស់នៅក្នុងវិញ្ញាណរបស់ខ្ញុំ។ ខ្ញុំបានឮសម្លេងយ៉ាងខ្លាំងនៅខាងក្រោយខ្ញុំ ដូចជាសម្លេងត្រែ។[11]សម្លេងនោះប្រាប់ថា
«ចូរកត់ត្រាអ្វីដែលអ្នកឃើញនៅក្នុងសៀវភៅ ហើយផ្ញើទៅកាន់ក្រុមជំនុំទាំងប្រាំពីរ ទៅកាន់ក្រុមជំនុំនៅក្រុងអេភេសូរ ក្រុងស្មៀរណា ក្រុងពើកាម៉ុស ក្រុងធាទេរ៉ា ក្រុង
សើដេស ក្រុងភីឡាដិលភា និងក្រុងឡៅឌីសេ»។
[12]ខ្ញុំបានបែរខ្លួនជុំវិញ ដើម្បីរកមើលសម្លេងដែលកំពុងនិយាយមកកាន់ខ្ញុំនោះ ហើយនៅពេលខ្ញុំបែរ ខ្ញុំបានឃើញជើងចង្កៀងមាសប្រាំពីរ។[13]នៅចំកណ្តាលនៃជើងចង្កៀង
មានម្នាក់ដូចជាកូនមនុស្ស ពាក់រ៉ូបវែងដល់ជើងរបស់គាត់ ហើយពាក្យខ្សែក្រវាត់មាននៅជុំវិញដើមទ្រូង។
[14]ក្បាល និងសក់របស់គាត់មានពណ៌សដូចជារោមសត្វ សដូចជាព្រិល ហើយភ្នែករបស់គាត់ដូចជាអណ្តាតភ្លើង។
[15]ជើងរបស់គាត់ដូចជាលង្ហិនដែលត្រូវបានដុតដោយសារឡភ្លើង ហើយសម្លេងរបស់គាត់ដូចជាសម្លេងនៃទឹកជាច្រើន។[16]គាត់មានផ្កាយប្រាំពីរនៅក្នុងដៃស្តាំរបស់គាត់
ហើយមានដាវមួយដែលមានមុខពីរយ៉ាងមុត ចេញពីមាត់របស់គាត់មក។ មុខរបស់គាត់ជះពន្លឺដូចជាពន្លឺព្រះអាទិត្យនៅពេលពេញកម្តៅ។
[17]ពេលខ្ញុំបានឃើញគាត់ ខ្ញុំដួលចុះនៅទាបជើងរបស់គាត់ដូចជាមនុស្សស្លាប់។ គាត់បានដាក់ដៃស្តាំរបស់គាត់លើខ្ញុំ ហើយប្រាប់ថា៖«កុំខ្លាចឡើយ។[18]ខ្ញុំជាមុន
និងជាក្រោយបង្អស់ ហើយជាម្នាក់ដែលរស់នៅ។ ខ្ញុំបានស្លាប់ ប៉ុន្តែ ខ្ញុំរស់នៅរហូតអស់កល្បជានិច្ច! ហើយខ្ញុំមានកូនសោរនៃសេចក្តីស្លាប់ និងស្ថាននរកដែរ។
[19]ដូច្នេះ ចូរកត់ត្រាចុះ អ្វីដែលអ្នកបានឃើញ អ្វីដែលបានកើតឡើងនៅពេលនេះ និងអ្វីដែលនឹងកើតឡើងបន្ទាប់ពីនេះ។
[20]ចំណែកឯអាថ៌កំបាំងអត្ថន័យពីផ្កាយទាំងប្រាំពីរដែលអ្នកឃើញនៅក្នុងដៃរបស់ខ្ញុំ និងជើងចង្កៀងមាសទាំងប្រាំពីរគឺ៖ ផ្កាយទាំងប្រាំពីរគឺជាទេវតានៃក្រុមជំនុំទាំងប្រាំពីរ
និងជើងចង្កៀងទាំងប្រាំពីរគឺជាក្រុមជំនុំទាំងប្រាំពីរ។

Revelation 1:1
ព័ត៌មានទូទៅ៖
នេះគឺជាការណែនាំអំពីកាន់គម្ពីរវិវរណៈ។
គម្ពីរវិវរណៈពន្យល់ថាគឺជាគម្ពីរវិវរណៈពីព្រះយេស៊ូគ្រិស្ត
ហើយព្រះគម្ពីរនេះផ្តល់នូវពរជ័យដល់អ្នកដែលអានគម្ពីរនេះ។
អ្នកបម្រើរបស់ព្រះអង្គ
ពាក្យនេះសំដៅទៅលើមនុស្សដែលជឿលើព្រះគ្រីស្ទ។
នូវអ្វីដែលនឹងត្រូវកើតឡើងជាឆាប់
«ព្រឹត្តិការណ៍ដែលត្រូវតែកើតឡើងឆាប់ៗនេះ»
ធ្វើឲ្យពួកគេដឹង
«ទំនាក់ទំនង»
ដល់អ្នកបម្រើរបស់ព្រះអង្គគឺលោកយ៉ូហាន
លោកយ៉ូហានបានកាន់ពម្ពីរនេះ ហើយគាត់សំដៅទៅលើខ្លួនគាត់នៅទីនេះ។
របៀបផ្សេងទៀតនៃការបកប្រែ:
«ចំពោះខ្ញុំយ៉ូហានជាអ្នកបំរើរបស់ព្រះអង្គ» (សូមមើល:figs-123person)
ព្រះបន្ទូលរបស់ព្រះជាម្ចាស់
ត្រង់ពាក្យនេះសំដៅទៅលើសារដែលព្រះបានប្រទានឲ្យទៅដល់លោកយ៉ូហាន។
អ្នកដែលអានលឺៗ
ពាក្យនេះមិនសំដៅទៅលើមនុស្សជាក់លាក់ទេ។
ពាក្យនេះសំដៅទៅលើអ្នកដែលអានខ្លាំងៗ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកដែលអានលឺៗ»
អស់អ្នកដែលស្តាប់បង្គាប់តាមអ្វីដែលបានសរសេរនៅក្នុងនេះ
«ជឿអ្វីដែលបានសរសេរនៅក្នុងកាន់គម្ពីរនេះ
ហើយគោរពបទបញ្ជាដែលមាននៅក្នុងនោះ»
ពេលកំណត់ជិតមកដល់ហើយ
«អ្វីៗដែលត្រូវតែកើតឡើងឆាប់ៗខាងមុខនេះ»
Revelation 1:4
ព័ត៌មានទូទៅ៖
នេះជាការចាប់ផ្តើមនៃសំបុត្ររបស់យ៉ូហាន។ នៅទីនេះគាត់ដាក់ឈ្មោះខ្លួនឯងថា
ជាអ្នកនិពន្ធ និងសួរសុខទុក្ខមនុស្សដែលគាត់កំពុងសរសេរទៅ។
សូមព្រះគុណនៅជាមួយអ្នករាល់គ្នា
និងសេចក្តីសុខសាន្តពីព្រះអង្គ...ព្រមទាំងពីវិញ្ញាណទាំងប្រាំពីរ...ពីព្រះយេស៊ូគ្រិស្ត
នេះគឺជាបំណងប្រាថ្នា ឬពរជ័យ។
លោកយ៉ូហាននិយាយដូចជារបស់ទាំងនេះដែលព្រះអាចផ្តល់ឲ្យទោះបីការពិតជាវិធីដែលគាត់សង្ឃឹមថាព្រ
របៀបផ្សេងទៀតនៃការបកប្រែ:
«សូមឲ្យអ្នកដែលជា...និងវិញ្ញាណទាំងប្រាំពីរ...ហើយព្រះយេស៊ូគ្រីស្ទប្រព្រឹត្តចំពោះអ្នក

generated on Wed Sep 10 16:16:32 2025

ដោយសប្បុរសនិងជួយឲ្យអ្នករស់នៅដោយសន្តិភាព និងសុវត្ថិភាព»
ពីនរណាម្នាក់គឺ
«មកពីព្រះ»
ដែលនឹងយាងមក
មានស្រាប់នាពេលអនាគតត្រូវបានគេនិយាយថានឹងមកដល់។
វិញ្ញាណទាំងប្រាំពីរ
លេខប្រាំពីរគឺជានិមិត្តរូបនៃភាពពេញលេញ និងឥតខ្ចោះ។ «វិញ្ញាណទាំងប្រាំពីរ»
សំដៅទៅលើវិញ្ញាណរបស់ព្រះ ឬវិញ្ញាណប្រាំពីរដែលបម្រើព្រះ។
ផលដំបូងនៃការកើតឡើងវិញពីពួកមនុស្សស្លាប់
«ជាមនុស្សទីមួយដែលត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ»
បានដោះយើង
«បានកំណត់ឲ្យយើងមានសេរីភាព»
បានធ្វើឲ្យយើងក្លាយជាអាណាចក្រ ធ្វើជាបូជាចារ្យ
«ព្រះអង្គបានញែកយើងចេញ ហើយចាប់ផ្តើមគ្រប់គ្រងលើយើង
ព្រះអង្គបានតែងតាំងយើងឲ្យធ្វើជាបូជាចារ្យ»
ព្រះរបស់ព្រះអង្គ និងព្រះបិតា
ឃ្លានេះគឺជាព្រះតែមួយអង្គ។ របៀបផ្សេងទៀតនៃការបកប្រែ:
«ព្រះជាព្រះបិតារបស់ព្រះអង្គ»
ព្រះបិតា
ពាក្យនេះគឺជាព្រះនាមដ៏សំខាន់សម្រាប់ព្រះដែលពិពណ៌នាអំពីទំនាក់ទំនងរវាងព្រះជាម្ចាស់
និងព្រះយេស៊ូ។
ថ្វាយសិរីរុងរឿងដល់ព្រះអង្គ និងចេស្តា
ឃ្លានេះគឺជាបំណងប្រាថ្នា ឬការអធិស្ឋាន។ អត្ថន័យដែលអាចមានគឺ ១)
«សូមអោយមនុស្សគោរពកិត្តិយស និងអំណាចរបស់ព្រះអង្គ» ឬ ២)
«សូមឲ្យលោកមានសិរីរុងរឿង និងអំណាច»។
លោកយ៉ូហានអធិស្ឋានថាព្រះយេស៊ូគ្រីស្ទនឹងត្រូវបានគោរព
ហើយនឹងអាចគ្រប់គ្រងទាំងស្រុងលើមនុស្សគ្រប់គ្នា និងអ្វីៗទាំងអស់។
ចេស្តា
ពាក្យនេះប្រហែលជាសំដៅទៅលើសិទ្ធិអំណាចរបស់ព្រះអង្គជាស្តេច។
Revelation 1:7
ព័ត៌មានទូទៅ
នៅក្នុងខ ៧ លោកយ៉ូហានកំពុងដកស្រង់ពីដានីយ៉ែលនិងសាការី។
ភ្នែកទាំងអស់
ចាប់តាំងពីមនុស្សមើលឃើញដោយភ្នែកពាក្យ «ភ្នែក»
ត្រូវបានប្រើដើម្បីសំដៅទៅលើមនុស្ស។ របៀបផ្សេងទៀតនៃការបកប្រែ:
«មនុស្សគ្រប់រូប» ឬ «អ្នករាល់គ្នា»
បូករួមទាំងអ្នកដែលបានចចែដែរ
«ហើយអ្នកដែលចាក់ទម្លុះព្រះអង្គក៏នឹងឃើញព្រះអង្គដែរ»
ចាក់ទម្លុះព្រះអង្គ
ដៃ និងជើងរបស់ព្រះយេស៊ូត្រូវបានគេចាក់ទម្លុះនៅពេលគេឆ្កាងព្រះយេស៊ូ។
ត្រង់នេះវាសំដៅទៅលើមនុស្សដែលសម្លាប់គាត់។ របៀបផ្សេងទៀតនៃការបកប្រែ:
«បានសម្លាប់គាត់»
ចាក់ទម្លុះ
ធ្វើប្រហោងក្នុង
ជាអាល់ផា និងជាអូមេកា
ទាំងនេះគឺជាអក្សរទីមួយនិងចុងក្រោយនៃអក្ខរក្រមក្រិក។ អត្ថន័យដែលអាចមានគឺ
១) «អ្នកដែលបានចាប់ផ្តើមអ្វីៗទាំងអស់ហើយជាអ្នកដែលបញ្ចប់អ្វីៗទាំងអស់» ឬ
២) «អ្នកដែលធ្លាប់រស់នៅហើយដែលតែងតែរស់នៅ»។
ប្រសិនបើមិនច្បាស់ដល់អ្នកអានអ្នកអាចពិចារណាប្រើអក្សរទីមួយនិងចុងក្រោយនៃអក្ខរក្រមរបស់អ្នក។
របៀបផ្សេងទៀតនៃការបកប្រែ: «A និង Z» ឬ «ទីមួយ និងក្រោយ»
ដែលនឹងយាងមក
មានស្រាប់នាពេលអនាគតត្រូវបានគេនិយាយថានឹងមកដល់។
ព្រះអម្ចាស់មានបន្ទូលថា
ភាសាខ្លះនឹងដាក់ថា «ព្រះជាអម្ចាស់មានព្រះបន្ទូល» នៅដើម
ឬចុងបញ្ចប់នៃប្រយោគទាំងមូល។
Revelation 1:9
ព័ត៌មានទូទៅ៖
លោកយ៉ូហានពន្យល់ពីចក្ខុវិស័យរបស់គាត់បានចាប់ផ្តើម
និងការណែនាំដែលព្រះវិញ្ញាណបានប្រាប់គាត់។
របស់អ្នក...អ្នក
ពាក្យទាំងនេះសំដៅទៅលើអ្នកជឿនៅក្នុងព្រះវិហារទាំងប្រាំពីរ។
ដែលរួមចំណែកជាមួយបងប្អូននៅក្នុងទុក្ខលំបាក និងព្រះរាជ្យ
ព្រមទាំងអត់ធ្មត់ស៊ូទ្រាំនៅក្នុងព្រះយេស៊ូ
«ដែលបានចូលរួមជាមួយអ្នកនៅក្នុងនគររបស់ព្រះ។ ខ្ញុំក៏រងទុក្ខ
និងស៊ូទ្រាំនឹងការសាកល្បងរួមជាមួយអ្នកដែរពីព្រោះយើងជាកម្មសិទ្ធិរបស់ព្រះយេស៊ូ»
ដោយសារតែព្រះបន្ទូលរបស់ព្រះជាម្ចាស់
«ព្រោះខ្ញុំបានប្រាប់អ្នកផ្សេងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់»
នៅក្នុងវិញ្ញាណ
លោកយ៉ូហាននិយាយអំពីការទទួលឥទ្ធិពលពីព្រះវិញ្ញាណរបស់ព្រះហាក់ដូចជាគាត់ស្ថិតនៅក្នុងព្រះវិញ្ញា
របៀបផ្សេងទៀតនៃការបកប្រែ: «ទទួលឥទ្ធិពលពីព្រះវិញ្ញាណ» ឬ
«ព្រះវិញ្ញាណមានឥទ្ធិពលលើខ្ញុំ»
នៅក្នុងថ្ងៃរបស់ព្រះអម្ចាស់
ថ្ងៃគោរពបូជាសម្រាប់អ្នកជឿលើព្រះគ្រីស្ទ
ដូចជាសម្លេងត្រែ
សំលេងលឺខ្លាំងណាស់វាស្តាប់ទៅដូចជាសំឡេងត្រែ។
ត្រែ
ពាក្យនេះសំដៅទៅលើឧបករណ៍សម្រាប់ផលិតតន្ត្រី
ឬសម្រាប់ការអំពាវនាវឲ្យមនុស្សប្រមូលផ្តុំគ្នាសម្រាប់ការប្រកាស ឬការប្រជុំ។
ភីឡាដិលភា ស្មៀរណា ក្រុងពើកាម៉ុស ក្រុងធាទេរ៉ា ក្រុងសើដេស ក្រុងភីឡាដិលភា និងក្រុងឡៅឌីសេ
ឃ្លានេះគឺជាឈ្មោះនៃទីក្រុងនានានៅអាស៊ីដែលជាសម័យប្រទេសទួរគី។
Revelation 1:12
ប្រយោគភ្ជាប់៖
លោកយ៉ូហានចាប់ផ្តើមពន្យល់ពីអ្វីដែលគាត់បានឃើញនៅក្នុងចក្ខុវិស័យរបស់គាត់។
សម្លេងដែល
ពាក្យនេះសំដៅទៅលើមនុស្សដែលនិយាយ។ របៀបផ្សេងទៀតនៃការបកប្រែ:
«អ្នកណា»
ជាកូនមនុស្ស
កន្សោមនេះពិពណ៌នាអំពីមនុស្សម្នាក់ដែលមើលទៅដូចជាមនុស្ស។
ពាក់ខ្សែក្រវាត់មាស
ក្រណាត់មួយដែលពាក់នៅជុំវិញទ្រូង។
វាប្រហែលជាមានខ្សែស្រឡាយមាសនៅក្នុងនោះ។
Revelation 1:14
ក្បាល និងសក់របស់គាត់មានពណ៌សដូចជារោមសត្វ សដូចជាព្រិល
រោមចៀម និងព្រិលគឺជាឧទាហរណ៍នៃអ្វីដែលមានពណ៌សខ្លាំង។ ពាក្យដដែលៗនៃ
«ពណ៌សដូច» បញ្ជាក់ថាពួកគេពណ៌សណាស់។ W
រោមសត្វ
ពាក្យនេះគឺជាសក់ចៀម ឬពពែ។ វាត្រូវបានគេដឹងថាមានពណ៌សខ្លាំង។
ភ្នែករបស់គាត់ដូចជាអណ្តាតភ្លើង
ភ្នែករបស់គាត់ត្រូវបានពណ៌នាថាមានពន្លឺដូចជាអណ្តាតភ្លើង។
របៀបផ្សេងទៀតនៃការបកប្រែ: «ភ្នែករបស់គាត់ភ្លឺដូចអណ្តាតភ្លើង»
ជើងរបស់គាត់ដូចជាលង្ហិន
សំរិទ្ធត្រូវបានប៉ូលាដើម្បីឲ្យវាភ្លឺ និងឆ្លុះបញ្ចាំងពន្លឺ។របៀបផ្សេងទៀតនៃការបកប្រែ:
«ជើងរបស់គាត់ភ្លឺថ្លាដូចលង្ហិន»
ដូចជាលង្ហិនដែលត្រូវបានដុតដោយសារឡភ្លើង
លង្ហិននឹងត្រូវបានចម្រាញ់ជាមុន ហើយបន្ទាប់មកត្រូវបានប៉ូលា។
របៀបផ្សេងទៀតនៃការបកប្រែ:
«ដូចជាសំរិទ្ធដែលត្រូវបានបន្សុតនៅក្នុងឡក្តៅនិងប៉ូលា»
ធុងដ៏រឹងមាំសម្រាប់កាន់ភ្លើងក្តៅខ្លាំងមួយ។ មនុស្សនឹងដាក់ដែកនៅក្នុងវា
ហើយភ្លើងក្តៅនឹងដុតបំផ្លាញរាល់ភាពមិនបរិសុទ្ធដែលមាននៅក្នុងលោហៈ។
សម្លេងនៃទឹកជាច្រើន
នេះលឺខ្លាំងដូចជាសំលេងទឹកហូរហែរលឿនទឹកទន្លេទឹកជ្រោះធំរឹតែរលកធំៗ
នៅសមុទ្រ។
ដាវមួយ... ចេញពីមាត់របស់គាត់មក
ដាវកំពុងជាប់នឹងមាត់របស់គាត់។ ដាវខ្លួនឯងមិនមានចលនាទេ។
ដាវដែលមានមុខពីរយ៉ាងមុត
ឃ្លានេះសំដៅទៅលើដាវមុខពីរដែលត្រូវបានធ្វើឲ្យមុតស្រួចទាំងសងខាងដើម្បីកាត់ទិសដៅទាំងពីរ។
Revelation 1:17

generated on Wed Sep 10 16:16:32 2025

ដួលចុះនៅទាបជើងរបស់គាត់
យ៉ូហានបានក្រាបចុះដល់ដី។
គាត់ប្រហែលជាភ័យខ្លាចខ្លាំងណាស់ហើយគាត់បានបង្ហាញការគោរពយ៉ាងខ្លាំងចំពោះ**ព្រះយេស៊ូវ**
គាត់បានដាក់ដៃស្តាំរបស់គាត់លើខ្ញុំ
«ព្រះអង្គបានពាល់ខ្ញុំដោយព្រះហស្តស្តាំរបស់ព្រះអង្គ»
ខ្ញុំជាមុន និងជាក្រោយបង្អស់
ឃ្លានេះសំដៅទៅលើលក្ខណៈដ៏អស់កល្បរបស់ព្រះយេស៊ូ។
ខ្ញុំមានកូនសោរនៃសេចក្តីស្លាប់ និងស្ថាននរកដែរ
ការមានអំណាចលើអ្វីមួយត្រូវបានគេនិយាយថាមានកូនសោសម្រាប់វា។
ព័ត៌មានបង្កប់ន័យគឺថាគាត់អាចផ្តល់ជីវិតដល់អ្នកដែលបានស្លាប់និងអនុញ្ញាតឱ្យពួកគេចេញពីស្ថាននរក
របៀបផ្សេងទៀតនៃការបកប្រែ: «ខ្ញុំមានអំណាចលើសេចក្តីស្លាប់និងស្ថាននរក» ឬ
«ខ្ញុំមានអំណាចដើម្បីផ្តល់ជីវិតដល់មនុស្សដែលបានស្លាប់
និងអនុញ្ញាតឲ្យពួកគេចេញពីស្ថាននរក»
Revelation 1:19
ប្រយោគភ្ជាប់៖
កូនមនុស្សនៅតែបន្តនិយាយ។
ផ្កាយ
ផ្កាយទាំងប្រាំពីរនេះគឺជានិមិត្តសញ្ញា។
ពួកគេលេចចេញជាតំណាងឱ្យទេវតាទាំងប្រាំពីរនៃក្រុមជំនុំទាំងប្រាំពីរ។
ជើងចង្កៀង
ជើងចង្កៀងគឺជានិមិត្តសញ្ញាដែលតំណាងឱ្យព្រះវិហារទាំងប្រាំពីរ។
សូមមើលពីរបៀបដែលអ្នកបានបកប្រែនេះ 1:12.
ទេវតានៃក្រុមជំនុំទាំងប្រាំពីរ
អត្ថន័យដែលអាចមានគឺ ១) **ទេវតាដែលតំណាងឱ្យ**ក្រុមជំនុំទាំងប្រាំពីរ ឬ ២)
អ្នកនាំសារមនុស្សមកក្រុមជំនុំទាំងប្រាំពីរ ។
ក្រុមជំនុំទាំងប្រាំពីរ
នេះសំដៅទៅលើព្រះវិហារចំនួន ៧ ដែលមានពិតនៅអាស៊ីនៅពេលនោះ។
មើលរបៀបដែលអ្នកបកប្រែនេះក្នុងជំពូក ១:៩។

---

2 [1]«ចូរសរសេរទៅកាន់ទេវតានៃក្រុមជំនុំនៅក្នុងក្រុងអេភេសូថា៖ «នេះគឺជាព្រះបន្ទូលព្រះអង្គ ដែលបានកាន់ផ្កាយទាំងប្រាំពីរនៅក្នុងព្រះហស្តស្តាំរបស់ព្រះអង្គ
និងជាព្រះដែលបានយាងនៅក្នុងចំណោមជើងចង្កៀងមាសទាំងប្រាំពីរថា៖[2]«យើងបានដឹងពីអ្វីដែលអ្នកបានធ្វើ និងដឹងពីការខំធ្វើការយ៉ាងនឿយហត់
និងអត់ធ្មត់ស៊ូទ្រាំរបស់អ្នក។ ខ្ញុំដឹងថាអ្នកមិនអាចទប់ទល់នឹងការអាក្រក់របស់មនុស្សបានទេ។ ខ្ញុំដឹងថា អ្នកបានទទួលការល្បងល ចំពោះអស់អ្នកដែលនិយាយថាខ្លួនជា
សាវ័ក ប៉ុន្តែ មិនមែនទេ ហើយអ្នកបានដឹងថាពួកគេជាមនុស្សកុហក។
[3]ខ្ញុំដឹងថាអ្នកបានស៊ូទ្រាំអត់ធ្មត់ ហើយអ្នកបានរងទុក្ខជាច្រើនដោយសារឈ្មោះខ្ញុំ ហើយថា អ្នកមិនមានការព្រួយបារម្ភឡើយ។[4]ប៉ុន្តែ
ខ្ញុំមានការមួយទាស់នឹងអ្នករាល់គ្នាពីការមួយដែលអ្នកបានបោះបង់ចោលសេចក្តីស្រឡាញ់ដើម។[5]សូមចាំ ថាអ្នកបានចេញឆ្ងាយពីសេចក្តីស្រឡាញ់ប៉ុណ្ណា។ ចូរប្រែចិត្ត
ហើយធ្វើការអ្វីដែលអ្នករាល់គ្នាបានធ្វើតាំងពីដំបូង។ បើអ្នករាល់គ្នាមិនប្រែចិត្តទេ ខ្ញុំនឹងមកឯអ្នករាល់គ្នា ហើយនឹងរើជើងចង្កៀងរបស់អ្នកចេញពីកន្លែងរបស់វា។
[6]ប៉ុន្តែ អ្នករាល់គ្នាមានការនេះ៖ គឺថាអ្នករាល់គ្នាបានស្អប់អ្វីដែលពួកនីកូឡាសបានធ្វើ ដែលខ្ញុំក៏ស្អប់ដែរ។[7]ចូរឲ្យអ្នកដែលមានត្រចៀកស្តាប់អ្វី
ដែលព្រះវិញ្ញាណមានបន្ទូលទៅកាន់ក្រុមជំនុំផ្សេងៗ។ ចំពោះអ្នកដែលមានជ័យជម្នះ ខ្ញុំនឹងឲ្យសិទ្ធិទទួលទានផ្លែពីដើមនៃជីវិត ដែលនៅស្ថានសួគ៌របស់ព្រះជាម្ចាស់។
[8]«ចូរសរសេរទៅកាន់ក្រុមជំនុំនៅក្រុងស្មៀរណាដូចតទៅនេះ៖ នេះជាព្រះបន្ទូលរបស់ព្រះដែលជាដើម និងជាចុង ជាព្រះដែលបានស្លាប់ និងបានរស់ឡើងវិញម្តងទៀតថា៖
[9]«ខ្ញុំស្គាល់ពីការឈឺចាប់ និងពីភាពក្រីក្ររបស់អ្នករាល់គ្នា ប៉ុន្តែ ជាអ្នករាល់គ្នាគឺជាអ្នកមាន។ ខ្ញុំស្គាល់ អ្នកជេរប្រមាថ ដែលនិយាយថាខ្លួនជាសាសន៍យូដា ប៉ុន្តែ
ពួកគេមិនមែនជាសាសន៍យូដាទេ។ ពួកគេជាក្រុមជំនុំរបស់សាតាំងវិញ។
[10]កុំភ័យខ្លាចជាមួយអ្វីដែលអ្នកនឹងត្រូវរងទុក្ខឡើយ។ មើល៍! មារកំពុងចាប់អ្នកខ្លះក្នុងចំណោមអ្នករាល់គ្នាទៅក្នុងគុក ដើម្បីធ្វើការល្បងលដល់អ្នករាល់គ្នា
ហើយអ្នកនឹងរងទុក្ខអស់រយៈពេលដប់ថ្ងៃ។ ចូរស្មោះត្រង់ដល់ស្លាប់ចុះ ហើយខ្ញុំនឹងផ្តល់មកុដនៃជីវិតដល់អ្នករាល់គ្នា។
[11]ចូរឲ្យអ្នកមានត្រចៀកស្តាប់អ្វីដែលព្រះវិញ្ញាណកំពុងមានបន្ទូលទៅកាន់ក្រុមជំនុំផ្សេងៗ។ អស់អ្នកណាដែលឈ្នះ
នឹងមិនរងទុក្ខដោយសារសេចក្តីស្លាប់លើកទីពីរឡើយ»។
[12]«ចូរសរសេរទៅកាន់ក្រុមជំនុំនៅក្រុងពើកាម៉ុស ដូចតទៅនេះ៖ មានព្រះបន្ទូលរបស់ព្រះអង្គ ដែលមានដាវដ៏មុតស្រួចមុខពីរ៖[13]«ខ្ញុំដឹងថាអ្នករាល់គ្នារស់នៅកន្លែងណា
គឺនៅចំបល្ល័ង្ករបស់សាតាំង។ លើសពីនេះ អ្នករាល់គ្នាមានចិត្តស្មោះត្រង់ចំពោះឈ្មោះខ្ញុំ។ ខ្ញុំដឹងថាអ្នករាល់គ្នាមិនបានបដិសេធជំនឿរបស់អ្នករាល់គ្នានៅក្នុងខ្ញុំទេ
ទោះបីជានៅក្នុងថ្ងៃរបស់អាន់ទីប៉ាសជាអ្នកធ្វើស្មរបន្ទាល់របស់ខ្ញុំ ជាអ្នកដែលស្មោះត្រង់នឹងខ្ញុំ ជាអ្នកដែលត្រូវគេសម្លាប់នៅក្នុងចំណោមអ្នករាល់គ្នា
ជាកន្លែងដែលសាតាំងនៅនោះ។
[14]ប៉ុន្តែ ខ្ញុំមានការមួយចំនួនទាស់នឹងអ្នករាល់គ្នា៖ មានអ្នកខ្លះកាន់ខ្ជាប់ជាមួយនឹងសេចក្តីបង្រៀនរបស់បាឡាម
ដែលបានបង្រៀនបាឡាក់ឲ្យដាក់អន្ទាក់នៅចំពោះមុខកូនចៅអ៊ីស្រាអែល ដើម្បីឲ្យពួកគេបរិភោគអាហារថ្វាយទៅរូបព្រះ និងប្រព្រឹត្តអំពើប្រាកចាសសីលធម៌ខាងផ្លូវភេទ។
[15]ក៏មានអ្នកខ្លះក្នុងចំណោមអ្នករាល់គ្នាបានកាន់ខ្ជាប់តាមសេចក្តីបង្រៀនរបស់ពួកនីកូឡាសដូចគ្នាដែរ។
[16]ដូច្នេះ ចូរប្រែចិត្ត! ប្រសិនបើ មិនប្រែចិត្ត ខ្ញុំនឹងមកឯអ្នករាល់គ្នាជាឆាប់ ហើយខ្ញុំនឹងច្បាំងជាមួយនឹងពួកគេដោយដាវនៅក្នុងមាត់របស់ខ្ញុំ។[17]អស់អ្នកដែលមានត្រចៀក
ចូរស្តាប់អ្វីដែលព្រះវិញ្ញាណមានបន្ទូលទៅកាន់ក្រុមជំនុំផ្សេងៗ។ អស់អ្នកដែលឈ្នះ ខ្ញុំនឹងឲ្យនំម៉ាណាដែលលាក់ទុកដល់អ្នកនោះ
ហើយខ្ញុំនឹងឲ្យគ្រួសពណ៌សដល់អ្នកនោះជាមួយនឹងឈ្មោះថ្មីសរសេរនៅលើថ្មនោះ ជាឈ្មោះដែលគ្មាននរណាស្គាល់ មានតែអ្នកទទួលវាទេទើបស្គាល់»។
[18]«ចូរសរសេរទៅកាន់ក្រុមជំនុំនៅក្រុងធាទេរ៉ាដូចតទៅនេះ៖ នេះគឺជាព្រះបន្ទូលរបស់បុត្រានៃព្រះជាម្ចាស់ ដែលព្រះនេត្រប្រៀបដូចជាអណ្តាតភ្លើង
និងព្រះបាទប្រៀបដូចជាលង្ហិនភ្លឺរលោង[19]«ខ្ញុំដឹងពីអ្វីដែលអ្នករាល់គ្នាបានធ្វើ គឺសេចក្តីស្រឡាញ់ និងជំនឿ ព្រមទាំងការបម្រើ និងការស៊ូទ្រាំអត់ធ្មត់របស់អ្នករាល់គ្នា។
ខ្ញុំដឹងថា អ្វីដែលអ្នកបានធ្វើថ្មីៗនេះច្រើនជាងអ្វីដែលអ្នកធ្វើពីដំបូងទៀត។
[20]ប៉ុន្តែ ខ្ញុំមានការនេះទាស់ជាមួយអ្នករាល់គ្នា អ្នកបានបណ្តោយខ្លួនទៅតាមនាងយេសិបិល ដែលហៅខ្លួនឯងថា ព្យាការានី។ ដោយសារការបង្រៀនរបស់នាង
នាងបានបោកប្រាស់អ្នកបម្រើរបស់យើងឲ្យប្រព្រឹត្តអំពើប្រាកចាកសីលធម៌ខាងផ្លូវភេទ ហើយបានបរិភោគយញ្ញបូជាដែលថ្វាយដល់រូបព្រះ។
[21]ខ្ញុំបានផ្តល់ពេលឲ្យនាងប្រែចិត្ត ប៉ុន្តែ នាងគ្មានបំណងចិត្តប្រែចិត្តចេញពីអំពើប្រាសចាកសីលធម៌ឡើយ។
[22]មើល៍! ខ្ញុំនឹងធ្វើឲ្យនាងឈឺនៅលើគ្រែ ហើយអស់អ្នកដែលប្រព្រឹត្តកំផិតជាមួយនាងនៅក្នុងការឈឺចាប់យ៉ាងខ្លាំងដែរ លុះត្រាតែ
ពួកគេប្រែចិត្តចេញពីការប្រព្រឹត្តរបស់នាង។[23]ខ្ញុំនឹងវាប្រហារជីវិតកូនៗរបស់នាង ហើយនិងក្រុមជំនុំទាំងអស់នឹងដឹងថា ខ្ញុំគឺជាព្រះដែលឈ្វេងយល់ពីគំនិត
និងដួងចិត្តរបស់មនុស្ស។ ខ្ញុំនឹងឲ្យអ្នករាល់គ្នាម្នាក់ៗទៅតាមការប្រព្រឹត្តរបស់អ្នករាល់គ្នា។
[24]ប៉ុន្តែ អ្នកទាំងអស់គ្នាដែលនៅក្នុងក្រុងធាទេរ៉ា អស់អ្នកណាដែលមិនកាន់តាមសេចក្តីបង្រៀននេះ ហើយមិនបានដឹងអ្វីដែលគេហៅថាការស៊ីជម្រៅរបស់សាតាំង
ខ្ញុំនិយាយទៅកាន់អ្នករាល់គ្នាថា «ខ្ញុំមិនដាក់បន្ទុកអ្វីផ្សេងទៀតមកលើអ្នករាល់គ្នាឡើយ។[25]នៅក្នុងករណីណាក្តី អ្នករាល់គ្នាត្រូវកាន់ខ្ជាប់រហូតទាល់តែខ្ញុំមកដល់។
[26]អស់អ្នកដែលមានជ័យជម្នះ និងអស់អ្នកដែលធ្វើអ្វីដែលខ្ញុំបានធ្វើរហូតដល់ទីបំផុត ខ្ញុំនឹងឲ្យសិទ្ធិអំណាចដល់អ្នកនោះឲ្យគ្រប់គ្រងប្រជាជាតិ។
[27]គាត់នឹងគ្រប់គ្រងពួកគេដោយដំបងដែក គាត់នឹងកម្ទេចពួកគេដូចកម្ទេចភាជនៈធ្វើពីដីឥដ្ឋដែរ។[28]ដូចដែលខ្ញុំបានទទួលពីព្រះបិតាខ្ញុំមក
ខ្ញុំនឹងផ្តល់ដល់គាត់នូវផ្កាយព្រឹក។[29]អស់អ្នកដែលមានត្រចៀក ចូរស្តាប់អ្វីដែលព្រះវិញ្ញាណកំពុងមានបន្ទូលទៅកាន់ក្រុមជំនុំផ្សេងៗចុះ។

---

generated on Wed Sep 10 16:16:32 2025

Revelation 2:1
ព័ត៌មានទូទៅ៖
នេះជាការចាប់ផ្តើមនៃសាររបស់កូនមនុស្សទៅកាន់ទេវតានៃក្រុមជំនុំនៅអេភេសូរ។
ទេវតា
